# ព្រះគម្ពីរមរមន

# គោលលទ្ធិ និង សេចក្ដីសញ្ញា

# មុក្ដាដ៏មានតម្លៃមហិមា

# ព្រះគម្ពីរមរមន

សក្ខីបទមួយទៀត អំពី ព្រះយេស៊ូវគ្រីស្ទ

# គោលលទ្ធិ និង សេចក្ដីសញ្ញា

របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# មុក្ដាដ៏មានតម្លៃមហិមា

បោះពុម្ពផ្សាយដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុងសលត៍លេក រដ្ឋយូថាហ៍ សហរដ្ឋអាមេរិក

© 2007 by Intellectual Reserve, Inc

រក្សាសិទ្ធិគ្រប់យ៉ាង

Printed in the United States of America 12/2007

19932006

Translation of the Book of Mormon, Doctrine and
Covenants, and Pearl of Great Price
Cambodian

## មាតិកា

ព្រះគម្ពីរមរមន

គោលលទ្ធិ និង សេចក្ដីសញ្ញា

មុក្ដាដ៏មានតម្លៃមហិមា

សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ

បុព្វកថា

តារាងប្រធានបទទាំងឡាយតាមលំដាប់អក្ខរក្រម

បទជំរើសនានាចេញពីការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស្ម៊ីធ

ប្រវត្តិសាសនាចក្រតាមលំដាប់ពេលកើតឡើង, ផែនទី, និងរូបថតទាំងឡាយ

ផែនទី និងរូបថតទាំងឡាយអំពីព្រះគម្ពីរប៊ីប

# ពាក្យសរសេរកាត់ និងនាមកត្តាទាំងឡាយនៅក្នុងន័យលក្ខណៈ និងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ

**ព្រះគម្ពីរសញ្ញាចាស់**

| | |
|---|---|
| លោកុ. | លោកុប្បត្តិ |
| និក្ខ. | និក្ខមនំ |
| លេវី. | លេវីវិន័យ |
| ជនគ. | ជនគណនា |
| ចោទិ. | ចោទិយកថា |
| យ៉ូស្វេ | យ៉ូស្វេ |
| ពួកចៅ. | ពួកចៅហ្វាយ |
| នាងរស់ | នាងរស់ |
| ១ សាំយូ. | សាំយូអែល ទី ១ |
| ២ សាំយូ. | សាំយូអែល ទី ២ |
| ១ ពង្សាវ. | ពង្សាវតារក្សត្រ ទី ១ |
| ២ ពង្សាវ. | ពង្សាវតារក្សត្រ ទី ២ |
| ១ របា. | របាក្សត្រ ទី ១ |
| ២ របា. | របាក្សត្រ ទី ២ |
| អែសរ៉ា | អែសរ៉ា |
| នេហេ. | នេហេមា |
| នាងអេស | នាងអេសធើរ |
| យ៉ូប | យ៉ូប |
| ទំនុក. | ទំនុកដំកើង |
| សុភា. | សុភាសិត |
| សាស្ដា | សាស្ដា |
| បទចំរៀង. | បទចំរៀងសាឡូម៉ូន |
| អេសាយ | អេសាយ |
| យេរេ. | យេរេមា |
| បរិទេវ | បរិទេវ |
| អេសេ. | អេសេគាល |
| ដានី. | ដានីយ៉ែល |
| ហូសេ | ហូសេ |
| យ៉ូអែល | យ៉ូអែល |
| អេម៉ុស | អេម៉ុស |
| អូបា. | អូបាឌា |
| យ៉ូណាស | យ៉ូណាស |
| មីកា | មីកា |
| ណាហ៊ុម | ណាហ៊ុម |
| ហាបា. | ហាបាគុក |
| សេផា. | សេផានា |
| ហាកាយ | ហាកាយ |
| សាការី | សាការី |
| ម៉ាឡាគី | ម៉ាឡាគី |

**ព្រះគម្ពីរសញ្ញាថ្មី (ព.ស.ថ.)**

| | |
|---|---|
| ម៉ាថាយ | ម៉ាថាយ |
| ម៉ាកុស | ម៉ាកុស |
| លូកា | លូកា |
| យ៉ូហាន | យ៉ូហាន |
| កិច្ចការ | កិច្ចការពួកសាវក |
| រ៉ូម | រ៉ូម |
| ១ កូរិន. | កូរិនថូស ទី ១ |
| ២ កូរិន. | កូរិនថូស ទី ២ |
| កាឡាទី | កាឡាទី |
| អេភេ. | អេភេសូ |
| ភីលីព | ភីលីព |
| កូល៉ុស | កូល៉ុស |
| ១ ថែស្សា. | ថែស្សាឡូនីច ទី ១ |
| ២ ថែស្សា. | ថែស្សាឡូនីច ទី ២ |
| ១ ធីម៉ូ. | ធីម៉ូថេ ទី ១ |
| ២ ធីម៉ូ. | ធីម៉ូថេ ទី ២ |
| ទីតុស | ទីតុស |
| ភីលេ. | ភីលេម៉ូន |
| ហេព្រើរ | ហេព្រើរ |
| យ៉ាកុប (ព.ស.ថ.) | យ៉ាកុប (ព្រះគម្ពីរសញ្ញាថ្មី) |
| ១ ពេត្រុស | ពេត្រុស ទី ១ |
| ២ ពេត្រុស | ពេត្រុស ទី ២ |
| ១ យ៉ូហាន | យ៉ូហាន ទី ១ |
| ២ យ៉ូហាន | យ៉ូហាន ទី ២ |
| ៣ យ៉ូហាន | យ៉ូហាន ទី ៣ |
| យូដាស | យូដាស |
| វិវរ. | វិវរណៈ |

**ព្រះគម្ពីរមរមន**

| | |
|---|---|
| ១ នីហ្វៃ | នីហ្វៃ ទី ១ |
| ២ នីហ្វៃ | នីហ្វៃ ទី ២ |
| យ៉ាកុប | យ៉ាកុប |
| អេណុស | អេណុស |
| យ៉ារ៉ុម | យ៉ារ៉ុម |
| អោមណៃ | អោមណៃ |
| ព. នៃ ម. | ពាក្យសំដីនៃមរមន |
| ម៉ូសាយ | ម៉ូសាយ |
| អាលម៉ា | អាលម៉ា |
| ហេលេ. | ហេលេមិន |
| ៣ នីហ្វៃ | នីហ្វៃ ទី ៣ |
| ៤ នីហ្វៃ | នីហ្វៃ ទី ៤ |
| មរមន | មរមន |
| អេធើរ | អេធើរ |
| ម៉ូរ៉ូណៃ | ម៉ូរ៉ូណៃ |

**គោលលទ្ធិ និងសេចក្ដីសញ្ញា**

| | |
|---|---|
| គ. និង ស. | គោលលទ្ធិ និងសេចក្ដីសញ្ញា |
| សេចក្ដីប្រកាស – ១ | សេចក្ដីប្រកាសជាផ្លូវការ ទី ១ |
| សេចក្ដីប្រកាស – ២ | សេចក្ដីប្រកាសជាផ្លូវការ ទី ២ |

**មុក្ដាដ៏មានតម្លៃមហិមា**

| | |
|---|---|
| ម៉ូសេ | ម៉ូសេ |
| អ័ប្រា. | អ័ប្រាហាំ |
| យ.ស.—ម៉ាថាយ | យ៉ូសែប ស្ម៊ីធ—ម៉ាថាយ |
| យ.ស.—ប្រវត្តិ | យ៉ូសែប ស្ម៊ីធ—ប្រវត្តិ |
| ម. នៃ ស. | មាត្រានៃសេចក្ដីជំនឿ |

| | |
|---|---|
| ក.យ.ស. | ការបកប្រែដោយយ៉ូសែប ស្ម៊ីធ |
| ស.ប. | សេចក្ដីណែនាំដល់បទគម្ពីរ |

| | |
|---|---|
| ហេ. | ការបកប្រែផ្សេងទៀតចេញពីភាសាហេព្រើរ |
| ក.ព. | ការពន្យល់ពាក្យ និងប្រយោគពិបាកៗ |
| ឬ | មានន័យថា មានពាក្យផ្សេងទៀតនៅតាមក្រោយដែលបញ្ជាក់ពាក្យផុតសម័យ |

# ព្រះគម្ពីរមរមន

សក្ខីបទមួយទៀត

អំពី

ព្រះយេស៊ូវគ្រីស្ទ

# ព្រះគម្ពីរមរមន

## ដំណើររឿងដែលបានសរសេរទុកដោយ
## ដៃរបស់មរមន
## លើផ្ទាំងទាំងឡាយ
## បានដកស្រង់ចេញពីផ្ទាំងទាំងឡាយនៃនីហ្វៃ

ហេតុដូច្នេះ គម្ពីរនេះគឺជាបញ្ជីសង្ខេបអំពីប្រជាជននីហ្វៃ និងអំពីពួកសាសន៍លេមិនផង — សរសេរដល់ពួកសាសន៍លេមិន ដែលជា សំណល់នៃវង្សអ៊ីស្រាអែល; និងដល់សាសន៍យូដា និងសាសន៍ដទៃផង — សរសេរតាមរយៈការបញ្ជា ហើយដោយវិញ្ញាណនៃការព្យាករណ៍ និងវិវរណៈផង — សរសេរ ហើយបិទត្រាជិត ហើយលាក់ទុកថ្វាយព្រះអម្ចាស់ ដើម្បីពុំអាចនឹងត្រូវបំផ្លាញបានឡើយ — សំរាប់នឹងនាំចេញមកឲ្យ ឃើញ ដោយព្រះអំណោយទាន និងដោយព្រះចេស្ដានៃព្រះ តាមការបកប្រែនេះ — បានបិទត្រាជិតទុកដោយដៃរបស់ម៉ូរ៉ូណៃ ហើយបានលាក់ទុក ថ្វាយព្រះអម្ចាស់ សំរាប់នឹងនាំចេញមកឲ្យឃើញ នៅវេលាកំណត់តាមរយៈសាសន៍ដទៃ — ការបកប្រែនេះធ្វើឡើង ដោយអំណោយទាននៃព្រះ ។

សេចក្ដីសង្ខេបដែលដកស្រង់ចេញពីគម្ពីរអេធើរមានផងដែរ គឺជាបញ្ជីអំពីប្រជាជនយ៉ារេឌ ដែលខ្ចាត់ខ្ចាយទៅ នៅវេលាដែល ព្រះអម្ចាស់ទ្រង់បំភាន់ភាសាមនុស្ស កាលមនុស្សទាំងនោះ កំពុងតែសាងប៉មទៅកាន់ស្ថានសួគ៌ — ដើម្បីបង្ហាញដល់សំណល់នៃវង្សអ៊ីស្រាអែល អំ ពីរឿងដ៏អស្ចារ្យទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើសំរាប់ពួកអយ្យកោគេ; ហើយដើម្បីឲ្យពួកគេយល់សេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ ថា គេនឹងមិនត្រូវបោះបង់ចោលរហូតឡើយ — ហើយក៏ដើម្បីជាការបរិវត្តន៍ដល់សាសន៍យូដា និងសាសន៍ដទៃថា **ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះដ៏នៅអស់កល្បជានិច្ច** ដែលបានសម្ដែងរូបអង្គទ្រង់ដល់គ្រប់ទាំងសាសន៍ — ហើយឥឡូវនេះ ប្រសិនបើមានកំហុសណាមួយ គឺជាសេចក្ដី ភាន់ច្រឡំរបស់មនុស្សទេ; ហេតុដូច្នេះហើយ សូមកុំថ្កោលទោសដល់វត្ថុ ដែលជារបស់ផងព្រះឡើយ ដើម្បីឲ្យអ្នករាល់អាចបានឃើញថាគ្មាន ទោស នៅចំពោះវេទិកាជំនុំជំរះនៃព្រះគ្រីស្ទ ៕

---


ការបកប្រែមុនដំបូងចេញពីផ្ទាំងទាំងឡាយ ទៅជាភាសាអង់គ្លេស

ដោយយ៉ូសែប ស្ម៊ីធ ជុញ៉័រ

បានបោះពុម្ពផ្សាយលើកទីមួយ ជាភាសាអង់គ្លេសនៅ

ទីក្រុងប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក សហរដ្ឋអាមេរិក ឆ្នាំ ១៨៣០

# បុព្វកថា

ព្រះគម្ពីរមរមនគឺជាភាគនៃគម្ពីរពិសិដ្ឋមួយ ប្រៀបបានទៅនឹងព្រះគម្ពីរប៊ីប ។ ព្រះគម្ពីរនេះគឺជាបញ្ជីប្រវត្តិ អំពីការទំនាក់ទំនងនៃព្រះចំពោះមនុស្សជំនាន់ដើមនៃទ្វីបអាមេរិក ហើយវាមាននូវភាពពោរពេញ នៃដំណឹងល្អដ៏អស់កល្បជានិច្ច ។

ព្រះគម្ពីរនេះបានសរសេរដោយពួកព្យាការីបុរាណជាច្រើន ដោយវិញ្ញាណនៃការព្យាករណ៍និងវិវរណៈ ។ ពាក្យពេចន៍របស់ពួកគេបាន ឆ្លាក់នៅលើផ្ទាំងមាសទាំងឡាយ ដែលបានដកស្រង់ ហើយសង្ខេប ដោយព្យាការី-ប្រវត្តិសាស្ត្រម្នាក់មាននាមថា មរមន ។ បញ្ជីប្រវត្តិនេះរៀប រាប់អំពីដំណើររឿងនៃអារ្យធម៌ដ៏ធំពីរ ។ អារ្យធម៌មួយបានចេញមកពីក្រុងយេរូសាឡិម នៅឆ្នាំ៦០០មុនគ.ស., ហើយក្រោយមកបានបំបែកចេញ ជាពីរសាសន៍ ហៅថាពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ។ អារ្យធម៌មួយទៀតបានចេញមកមុនជាយូរហើយ គឺនៅក្នុងជំនាន់ដែលព្រះ អម្ចាស់ទ្រង់បានបំភាន់ភាសាទាំងឡាយនៅឯប៉មនៃក្រុងបាបិល ។ ក្រុមនេះមានឈ្មោះថា ពួកសាសន៍យ៉ារេឌ ។ ច្រើនពាន់ឆ្នាំកន្លងមក សាសន៍ ទាំងអស់ត្រូវបានបំផ្លាញចោល លើកលែងតែពួកសាសន៍លេមិន ហើយពួកគេគឺជាពួកដូនតាសំខាន់របស់ពួកឥណ្ឌាសាសន៍អាមេរិកាំងដើម ។

ព្រឹត្តិការណ៍ដ៏សំខាន់បំផុត ដែលមានកត់ត្រាទុកក្នុងព្រះគម្ពីរមរមន គឺជាការងារបំរើនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទផ្ទាល់ នៅក្នុងចំណោម ពួកសាសន៍នីហ្វៃ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ។ ព្រះគម្ពីរនេះនាំមកនូវគោលលទ្ធិទាំងឡាយនៃដំណឹងល្អ, ផ្ដល់នូវចំណុចសំខាន់អំពី ផែនការនៃសេចក្ដីសង្គ្រោះ, ហើយប្រាប់ដល់មនុស្សទាំងឡាយ អំពីអ្វីដែលគេត្រូវធ្វើ ដើម្បីឲ្យបានទទួលសេចក្ដីសុខសាន្ត នៅក្នុងជីវិតនេះ និងសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច នៅក្នុងជីវិតខាងមុខ ។

ក្រោយពីមរមនបានសរសេរចប់ហើយ លោកក៏បានប្រគល់ដំណើររឿងនេះទៅកូនប្រុសលោកឈ្មោះ ម៉ូរ៉ូណៃ គឺជាអ្នកដែលបានបន្ថែមពាក្យផ្ទាល់របស់លោកខ្លះ ហើយបានលាក់ផ្ទាំងទាំងនេះ នៅក្នុងកូនភ្នំគូម៉ូរ៉ា នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៨២៣ គឺម៉ូរ៉ូណៃដដែលនេះដែល ជាអ្នកបានរស់ឡើងវិញ ព្រមទាំងបានទទួលសិរីល្អហើយនោះ បានលេចមកឲ្យព្យាការីយ៉ូសែប ស្ម៊ីធឃើញ ហើយបានបង្គាប់លោក អំពីបញ្ជីប្រវត្តិ បុរាណ ហើយនិងការបកប្រែ នៅពេលខាងមុខទៅជាភាសាអង់គ្លេស ។

លុះដល់ពេលកំណត់ហើយ ផ្ទាំងទាំងឡាយក៏ត្រូវបានប្រគល់ទៅយ៉ូសែប ស្ម៊ីធ ដែលជាអ្នកបកប្រែផ្ទាំងទាំងនេះ ដោយអំណោយទាន និងចេស្ដានៃព្រះ ។ ឥឡូវនេះ បញ្ជីប្រវត្តិត្រូវបានបោះពុម្ពទៅជាភាសាជាច្រើន ដែលជាសាក្សីបន្ថែមដ៏ថ្មីមួយទៀតថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះ រាជបុត្រានៃព្រះ ដ៏មានព្រះជន្មរស់នៅ ហើយអស់អ្នកណាដែលមករកព្រះអង្គ ហើយធ្វើតាមក្រិត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយ នៃដំណឹងល្អ របស់ទ្រង់ នោះនឹងបានសង្គ្រោះ ។

អំពីបញ្ជីនេះ ព្យាការីយ៉ូសែប ស្ម៊ីធមានប្រសាសន៍ថា « ខ្ញុំបានប្រាប់បងប្អូនទាំងឡាយថា ព្រះគម្ពីរមរមន គឺជាគម្ពីរដ៏ត្រឹមត្រូវបំផុតជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនារបស់យើង ហើយបុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយសារធ្វើ តាមសិក្ខាបទទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់ » ។

ក្រៅពីយ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់ទ្រង់ប្រទានដល់មនុស្ស១១នាក់ទៀត ឲ្យឃើញផ្ទាំងមាសទាំងនេះ ដោយខ្លួនគេផ្ទាល់ ហើយដើម្បីធ្វើ ជាសាក្សីដ៏ពិសេស អំពីសេចក្ដីពិត និងទេវភាពនៃព្រះគម្ពីរមរមន ។ សេចក្ដីបន្ទាល់របស់ពួកគេមានចុះក្នុងគម្ពីរនេះ ក្នុងចំណោមនៃ « ទីបន្ទាល់នៃពួកសាក្សីបីនាក់ » និង « ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់ » ។

យើងសូមអញ្ជើញមនុស្សទាំងអស់ នៅគ្រប់ទិសទី សូមឲ្យអានព្រះគម្ពីរមរមន, សូមឲ្យពិចារណាមើលនៅក្នុងចិត្ត នូវពាក្យពេចន៍នៅក្នុង គម្ពីរនេះ, ហើយបន្ទាប់មក សូមឲ្យសួរដល់ព្រះ ជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ដោយនូវព្រះនាមនៃព្រះគ្រីស្ទ ថាតើគម្ពីរនេះពិតឬទេ ។ អស់អ្នកណាដែលធ្វើតាមបែបបទនេះ ហើយសូមសួរដោយសេចក្ដីជំនឿ នោះនឹងបានទទួលសេចក្ដីបន្ទាល់អំពីសេចក្ដីពិត និងទេវភាពរបស់ គម្ពីរនេះ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើលគម្ពីរម៉ូរ៉ូណៃ ១០:៣–៥) ។

អស់អ្នកណាដែលបានទទួលទីបន្ទាល់ដ៏ប្រសើរ ពីព្រះវិញ្ញាណបរិសុទ្ធ ក៏នឹងបានដឹងដោយសារព្រះចេស្ដាដដែលថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក ថាយ៉ូសែប ស្ម៊ីធ គឺជាអ្នកទទួលវិវរណៈ និងជាព្យាការីរបស់ទ្រង់ នៅជាន់ចុងក្រោយបង្អស់ ហើយថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជានគរនៃព្រះអម្ចាស់ ដែលបានសាងឡើងវិញម្ដងទៀត នៅលើផែនដី ដើម្បីរៀបចំសំរាប់ការយាងមកលើកទីពីរនៃព្រះមែស៊ី ៕

# ទី បន្ទាល់នៃពួកសាក្សីបីនាក់

សូមឲ្យបានដឹងដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា ហើយនឹងគ្រប់ទាំងប្រជាជន ដែលកិច្ចការនេះមកដល់គេះ ថាយើង ដោយសារព្រះគុណនៃព្រះដ៏ជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់យើង បានឃើញផ្ទាំងទាំងឡាយ ដែលមានបញ្ជីនេះ គឺជា បញ្ជីអំពីប្រជាជននីហ្វៃ និងអំពីពួកសាសន៍លេមិន ជាបងប្អូនរបស់ពួកគេ ហើយព្រមទាំងអំពីប្រជាជនយ៉ារេឌ ដែលបានចេញមកពីប៉ម ដូចដែល បានពោលមកហើយនោះ ។ ហើយយើងដឹងផងដែរថា ផ្ទាំងទាំងឡាយនេះបានបកប្រែឡើង ដោយសារអំណោយទាន និងព្រះចេស្ដានៃព្រះ ត្បិត សម្លេងនៃព្រះបានថ្លែងប្រាប់យើងថាដូច្នោះ; ហេតុដូច្នេះហើយ យើងដឹងជាពិតប្រាកដថា ការបកប្រែនេះបានត្រឹមត្រូវពិតមែន ។ ហើយយើង សូមធ្វើបន្ទាល់ថា យើងបានឃើញឆ្លាក់ត្រាដែលនៅលើផ្ទាំងទាំងឡាយ; ហើយឆ្លាក់ត្រានោះបានបង្ហាញឲ្យយើងឃើញ ដោយព្រះចេស្ដានៃព្រះ ពុំមែន ដោយចេស្ដានៃមនុស្សទេ ។ ហើយយើងសូមថ្លែងដោយម៉ឺងម៉ាត់ថា មានទេវតានៃព្រះបានចុះមកពីស្ថានសួគ៌ ហើយនាំយកផ្ទាំងទាំងឡាយមកបង្ហាញ នៅចំពោះភ្នែកយើង ដែលយើងបានទាំងមើល ហើយឃើញផ្ទាំងទាំងឡាយ ព្រមទាំងឆ្លាក់ត្រានៅលើនោះផង; ហើយយើង ដឹងថា ដោយសារព្រះគុណនៃព្រះដ៏ជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់របស់យើង ដែលយើងបានមើលឃើញ ហើយបានធ្វើបន្ទាល់ ថា អ្វីៗទាំងអស់មានជាការពិតមែន ។ ហើយគឺជារឿងដ៏ចម្លែកអស្ចារ្យ ដែលភ្នែកយើងបានឃើញ ។ មិនតែប៉ុណ្ណោះសោត សម្លេងនៃព្រះ អម្ចាស់បានបញ្ជាយើងថា យើងគួរធ្វើបន្ទាល់អំពីរឿងនេះ; ហេតុដូច្នេះហើយ ទុកជាទីគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ យើងសូមថ្លែង សេចក្ដីបន្ទាល់អំពីរឿងទាំងអស់នេះ ។ ហើយយើងដឹងថា បើយើងស្មោះត្រង់នឹងព្រះគ្រីស្ទ នោះយើងនឹងអាចកំចាត់សំលៀកបំពាក់របស់យើង ពីលោហិតនៃមនុស្សទាំងអស់បាន ហើយឲ្យបានឃើញថាគ្មានទោស នៅចំពោះវេទិកានៃជំនុំជំរះនៃព្រះគ្រីស្ទ ព្រមទាំងបានស្នាក់នៅជាមួយ នឹងទ្រង់នៅលើស្ថានសួគ៌ដ៏នៅអស់កល្បជានិច្ច ។ ហើយយើងសូមថ្វាយកិត្តិយសនេះ ដល់ព្រះវរបិតា និងព្រះរាជបុត្រា ហើយនិងព្រះវិញ្ញាណបរិសុទ្ធ ដែលជាព្រះតែមួយ ។ អាម៉ែន ៕

អូលីវើរ ខៅឌើរី
ដាវីឌ វិតមើរ
ម៉ាទិន ហារីស

# ទី បន្ទាល់នៃពួកសាក្សីប្រាំបីនាក់

សូមឲ្យបានដឹងដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា ហើយនឹងគ្រប់ទាំងប្រជាជន ដែលកិច្ចការនេះមកដល់គេះ ថាយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបកប្រែរឿងនេះ បានបង្ហាញយើងនូវផ្ទាំងទាំងឡាយ ដូចដែលបានពោលមកហើយនោះ ដែលមានរូបរាងជាមាស; ហើយ នូវសន្លឹកទាំងប៉ុន្មាន ដែលលោកស្ម៊ីធបានបកប្រែមកនោះ យើងបានកាន់ដោយដៃយើងផ្ទាល់; យើងថែមទាំងបានឃើញឆ្លាក់ត្រានៅលើនោះផង របស់ទាំងអស់នោះមានរូបរាងដូចជាវត្ថុស្នាដៃបុរាណមួយយ៉ាងចំណាន ។ ហើយរឿងនេះ យើងសូមធ្វើបន្ទាល់ដោយម៉ឺងម៉ាត់ថា លោកស្ម៊ីធ បានបង្ហាញផ្ទាំងទាំងឡាយដល់យើង ត្បិតយើងបានទាំងឃើញ និងលើក ហើយដឹងជាប្រាកដថា លោកស្ម៊ីធមានផ្ទាំងទាំងឡាយ ដែលយើងបាន និយាយនោះពិត ។ ហើយយើងទាំងអស់គ្នាសូមប្រគល់នាមយើងដល់មនុស្សលោក ដើម្បីធ្វើជាសាក្សីដល់មនុស្សលោក ចំពោះអ្វីៗដែលយើង បានឃើញ ហើយយើងមិនបានពោលពាក្យកុហកសោះ ត្បិតព្រះទ្រង់ជាសាក្សីក្នុងរឿងនេះ ៕

| | |
|---|---|
| គ្រីស្ទាន វិតមើរ | ហៃរាំ ភេជ |
| យ៉ាកុប វិតមើរ | យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ |
| ពេត្រុស វិតមើរ | ជុញ្ញ័រហៃរុម ស្ម៊ីធ |
| យ៉ូហាន វិតមើរ | សាំយូអែល អេច ស្ម៊ីធ |

## ទីបន្ទាល់នៃព្យាការីយ៉ូសែបស៊្មីធ

ពាក្យផ្ទាល់របស់ព្យាការីយ៉ូសែបស៊្មីធ អំពីការបញ្ចេញលេចមកនៃព្រះគម្ពីរមរមន គឺដូចតទៅនេះ ៖

« នៅវេលារាត្រីនៃ . . . ថ្ងៃទី២១ ខែកញ្ញា (១៨២៣) . . . ខ្ញុំបានចាប់ផ្ដើមអធិស្ឋាន ហើយទូលអង្វរដល់ព្រះដ៏មានមហិទ្ធិឫទ្ធិ . . .។

« នៅពេលដែលខ្ញុំកំពុងតែអំពាវនាវដល់ព្រះ នោះស្រាប់តែខ្ញុំប្រទះឃើញមានពន្លឺមួយរះឡើងនៅក្នុងបន្ទប់ខ្ញុំ ឯពន្លឺនោះចេះតែភ្លឺខ្លាំងឡើងៗ រហូតដល់បន្ទប់ទាំងមូលភ្លឺជាងពន្លឺថ្ងៃត្រង់ទៅទៀត នៅមួយរំពេចនោះ មានរូបមនុស្សមួយ បានលេចមកនៅក្បែរគ្រែខ្ញុំ ឈរនៅ លើអាកាស ពីព្រោះជើងលោកពុំបានប៉ះក្ដារសោះ ។

« លោកពាក់អាវវល្លុង ដែលមានពណ៌ដ៏សអស្ចារ្យ ។ គឺជាភាពសជាងអ្វីៗនៅលើលោកិយ ដែលខ្ញុំធ្លាប់ប្រទះឃើញមក; ហើយខ្ញុំថែមទាំងមិនជឿថា មានអ្វីមួយនៅក្នុងលោកិយនេះ នឹងត្រូវធ្វើឲ្យឃើញសក្រៃលែង ហើយចែងចាំងដូច្នោះឡើយ ។ ដៃរបស់លោកនៅទទេត្រឹម ខាងលើកដៃបន្តិច; ក៏ដូចជាជើងលោកនៅទទេ ត្រឹមខាងលើកជើងបន្តិច ។ ឯក្បាលនិងកលោកក៏នៅទទេដែរ ។ ខ្ញុំបានឃើញថា លោកមិន បានស្លៀកពាក់អ្វី ក្រៅពីអាវនោះឡើយ នៅពេលអាវនោះចំហ ធ្វើឲ្យខ្ញុំឃើញទ្រូងលោក ។

« មិនត្រឹមតែអាវលោកដែលជាសក្រៃលែងប៉ុណ្ណោះឡើយ តែថែមទាំងរូបកាយលោក ក៏ឧត្តមរុងរឿងជាងដែលអាចអធិប្បាយបាន ឯមុខរបស់លោក នោះពិតជាដូចផ្លេកបន្ទោរ ។ បន្ទប់ខ្ញុំភ្លឺក្រៃលែង តែភ្លឺមិនជាប៉ុន្មាន ដូចជានៅជុំវិញរាងកាយលោកទេ ។ កាលខ្ញុំបានមើល ឃើញលោកមុនដំបូងបង្អស់នោះ ខ្ញុំខ្លាច ប៉ុន្តែមិនយូរប៉ុន្មាន សេចក្ដីខ្លាចក៏បាត់ពីខ្ញុំទៅ ។

« លោកបានហៅខ្ញុំដោយឈ្មោះ ហើយពោលមកកាន់ខ្ញុំថាលោកជាទូត ដែលបានចាត់មកពីវត្តមាននៃព្រះ ឲ្យមករកខ្ញុំ ហើយថាឈ្មោះលោក គឺម៉ូរ៉ូណៃ; ថាព្រះទ្រង់មានកិច្ចការឲ្យខ្ញុំធ្វើ; ហើយថាឈ្មោះរបស់ខ្ញុំ នឹងមានដើម្បីសេចក្ដីល្អ និងសេចក្ដីអាក្រក់ នៅក្នុងចំណោមគ្រប់ ទាំងសាសន៍ គ្រប់ពូជមនុស្ស ហើយគ្រប់ទាំងភាសា ឬថាឈ្មោះខ្ញុំនឹងត្រូវនិយាយដល់ទាំងសេចក្ដីល្អ និងសេចក្ដីអាក្រក់ នៅក្នុងចំណោមប្រជាជន ទាំងអស់ ។

« លោកមានប្រសាសន៍ថា មានគម្ពីរមួយកប់ទុក ដែលឆ្លាក់នៅលើផ្ទាំងមាស ដែលចែងអំពីប្រវត្តិរបស់ប្រជាជន ដែលបានរស់នៅលើ ទ្វីបនេះ កាលពីជំនាន់ដើម ហើយអំពីទីកំណើត ដែលពួកគេលេចមក ។ លោកមានប្រសាសន៍ទៀតថា ភាពពោរពេញនៃដំណឹងល្អដ៏អស់កល្ប ជានិច្ច មាននៅក្នុងគម្ពីរនេះ ដូចជាព្រះអង្គសង្គ្រោះទ្រង់បានប្រទានឲ្យប្រជាជនជំនាន់ដើម;

« ប្រាប់ទៀតថា មានត្បូងពីរដុំនៅក្នុងស៊ុមប្រាក់ — ហើយត្បូងទាំងពីរនេះភ្ជាប់ជាមួយនឹងប្រដាប់បាំងទ្រូង ជារបស់ដែលហៅថា យូរីម និងធូមីម — បានបង្កប់នៅជាមួយនឹងផ្ទាំងទាំងឡាយ; ហើយការធ្វើជាម្ចាស់ និងការប្រើត្បូងទាំងនេះ គឺការដែលធ្វើឲ្យអ្នកនោះជា*អ្នកមើលឆុត* នៅជំនាន់បុរាណ ឬជំនាន់ដើម ហើយថាព្រះទ្រង់បានរៀបត្បូងនោះទុក ដើម្បីជាប្រយោជន៍នៃការបកប្រែគម្ពីរនេះឯង ។

* * * * * * *

« ម្ដងទៀត លោកបានប្រាប់ខ្ញុំថា កាលណាខ្ញុំបានទទួលយកផ្ទាំងទាំងឡាយ ដែលលោកបានថ្លែងដល់នោះ — ត្បិតមិនទាន់ដល់ពេលដែលខ្ញុំត្រូវទទួលផ្ទាំងទាំងនោះទេ — នោះខ្ញុំមិនត្រូវបង្ហាញដល់អ្នកណាឲ្យសោះ; សូម្បីតែប្រដាប់បាំងទ្រូង ព្រមទាំងយូរីម និងធូមីមផង; ខ្ញុំអាចបង្ហាញតែត្រឹមជនណា ដែលព្រះទ្រង់បញ្ជាឲ្យបង្ហាញដល់ប៉ុណ្ណោះ; បើខ្ញុំបង្ហាញឲ្យអ្នកផ្សេងឃើញ នោះខ្ញុំនឹងត្រូវបំផ្លាញចោល ។ នៅពេល ដែលលោកកំពុងតែសន្ទនាជាមួយនឹងខ្ញុំអំពីផ្ទាំងចារិកនោះ ការនិមិត្តបានបើកសម្ដែងនៅក្នុងគំនិតខ្ញុំ លុះត្រាខ្ញុំបានមើលឃើញទីកន្លែង ដែលមាន ផ្ទាំងទាំងនោះកប់ទុក ហើយការនិមិត្តនោះច្បាស់លាស់ រហូតដល់ខ្ញុំស្គាល់កន្លែងនោះបាននៅពេលដែលខ្ញុំទៅកាន់កន្លែងនោះក្រោយមក ។

« ក្រោយពីការសន្ទនានេះហើយ ខ្ញុំឃើញថាពន្លឺនៅក្នុងបន្ទប់ចាប់ផ្ដើមប្រមូលរួមជុំវិញកាយ លោកដែលមានប្រសាសន៍មកកាន់ខ្ញុំ

ហើយនៅដូច្នោះតទៅ លុះគ្រាបន្ទប់ត្រឡប់ទៅជាងងឹតម្តងទៀត លើកលែងតែនៅជុំវិញលោកប៉ុណ្ណោះ; មួយរំពេចនោះ ខ្ញុំឃើញហាក់ដូចជា មានផ្លូវមួយចំហត្រង់ឡើងទៅដល់ស្ថានសួគ៌ ហើយលោកក៏ត្រឡប់ឡើងទៅ រហូតដល់មើលលែងឃើញ ក្រោយមក បន្ទប់ខ្ញុំក៏ត្រឡប់ទៅក្នុង សភាពដើមវិញ ដូចកាលមុនដែលពន្លឺនៃស្ថានសួគ៌នេះបានលេចមក ។

«ខ្ញុំដេកសញ្ជឹងគិតដល់សេចក្តីប្លែកនៃហេតុការណ៍ ហើយនឹកឆ្ងល់ជាខ្លាំង ដល់រឿងដែលទូតដ៏ពិសេសនេះបានប្រាប់ខ្ញុំ; នៅពេលដែលកំពុងតែគិតនោះ ខ្ញុំក៏ឃើញថាបន្ទប់ខ្ញុំ ចាប់ផ្តើមភ្លឺឡើងម្តងទៀត ហើយនៅមួយរំពេចនោះ ទូតស្ថានសួគ៌ដដែលនោះក៏មកឈរនៅក្បែរគ្រែខ្ញុំម្តងទៀត ។

«លោកក៏ចាប់ផ្តើម ហើយនិយាយពីរឿងដដែលនោះទៀត ដែលលោកបានធ្វើហើយកាលលោកបានមកមុនដំបូង ដោយមិនប្រែប្រួលឡើយ; នៅពេលចប់ហើយ នោះលោកបានប្រាប់ខ្ញុំ អំពីសេចក្តីជំនុំជំរះដ៏មហិមា ដែលនឹងកើតឡើងនៅលើផែនដីនេះ ព្រមទាំងសេចក្តីហិន វិនាសដ៏ខ្លាំង ដោយអំណត់អត់ ដាវ និងជម្ងឺអាសន្នរោគ; ហើយថាសេចក្តីជំនុំជំរះដ៏គួរធ្ងន់ធ្ងរទាំងឡាយនេះ នឹងកើតមាននៅលើផែនដីក្នុង ជំនាន់នេះឯង ។ កាលបានថ្លែងពីរឿងទាំងអស់នេះហើយ នោះលោកក៏ត្រឡប់ឡើងទៅវិញម្តងទៀត ដូចដែលលោកបានធ្វើពេលមុនដែរ ។

«នៅវេលានេះ ហេតុការណ៍ដែលបានយល់នៅក្នុងចិត្តរបស់ខ្ញុំ គឺជ្រាលជ្រៅណាស់ ដែលពុំអាចដេកបាន ហើយខ្ញុំដេកភ្លឹកភ្លាំងនៅក្នុងការណ៍អស្ចារ្យ ដែលខ្ញុំបានទាំងឃើញ ហើយបានឮមក ។ ប៉ុន្តែជាសេចក្តីប្លែកចិត្តរបស់ខ្ញុំអ្វីម្ល៉េះ កាលឃើញទូតដដែលនៅក្បែរគ្រែខ្ញុំម្តងទៀត ហើយបានឮទូតរៀបរាប់ ឬថ្លែងមកខ្ញុំម្តងទៀត ពីរឿងដដែលដូចពេលមុននោះ; ហើយព្រមទាំងឲ្យពាក្យដាស់តឿនដល់ខ្ញុំ ដោយប្រាប់ខ្ញុំថាអារក្ស សាតាំងនឹងព្យាយាមល្បួងខ្ញុំ (ពីព្រោះមកពីសភាពក្រខ្សត់របស់គ្រួសារឪពុកខ្ញុំ) ឲ្យទៅយកផ្ទាំងទាំងឡាយ ដើម្បីនឹងកសាងខ្លួនជាអ្នកមាន ។ រឿងនេះលោកឃាត់ខ្ញុំ ដោយមានប្រសាសន៍ថា ខ្ញុំមិនត្រូវមានគោលបំណងផ្សេងទៀតក្នុងសេចក្តីនឹកគិត ក្នុងការបានផ្ទាំងទាំងឡាយមក ក្រៅពីដើម្បីសរសើរដំកើងព្រះ ហើយមិនត្រូវធ្លាក់ទៅក្នុងឥទ្ធិពលនៃមូលហេតុអ្វីផ្សេងទៀតឡើយ ក្រៅពីការកសាងនគរនៃព្រះប៉ុណ្ណោះ; មិនដូច្នោះសោតទេ ខ្ញុំមិនអាចនឹងយកផ្ទាំងទាំងឡាយមកបានឡើយ ។

«ក្រោយពីបានមកជួបខ្ញុំជាលើកទីបី នោះលោកក៏ត្រឡប់ឡើងទៅស្ថានសួគ៌វិញ ដូចលើកមុន ហើយខ្ញុំត្រូវទុកឲ្យរំពឹងគិតទៀតចំពោះសេចក្តីប្លែកនៃហេតុការណ៍ ដែលខ្ញុំទើបតែបានជួបប្រទះមក; នៅមួយរំពេចក្រោយមក ដែលទូតស្ថានសួគ៌បានត្រឡប់ឡើងចេញពីខ្ញុំទៅ វិញជាលើកទីបី នោះមាន់ក៏រងាវ ហើយខ្ញុំក៏ដឹងថា ជិតភ្លឺហើយ ដូច្នោះការសន្ទនារបស់យើងច្បាស់ជាបានប្រព្រឹត្តទៅអស់ពេលពេញមួយយប់ តែម្តង ។

«មួយសន្ទុះក្រោយមក ខ្ញុំក្រោកពីដំណេក ហើយទៅធ្វើការដូចដែលត្រូវធ្វើតាមធម្មតារាល់ៗថ្ងៃ; ប៉ុន្តែក្នុងការព្យាយាមធ្វើការដូចពេលផ្សេងៗ ខ្ញុំហាក់បីដូចជាអស់កម្លាំងជាខ្លាំង រហូតដល់ធ្វើអ្វីលែងកើត ។ ឪពុកខ្ញុំដែលកំពុងតែធ្វើការនៅក្បែរខ្ញុំនោះ ឃើញថាមានអ្វីខុស ពីធម្មតាចំពោះខ្ញុំ ហើយបានប្រាប់ឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញ ។ ខ្ញុំចេញទៅដោយសេចក្តីតាំងចិត្តថានឹងត្រឡប់ទៅផ្ទះ; ប៉ុន្តែក្នុងការព្យាយាមឆ្លងរបង ចេញពីចំការ នោះខ្ញុំអស់កម្លាំងរលីងពីខ្លួន ហើយខ្ញុំដួលស្តូកស្តឹងនៅលើដី ហើយសន្លប់អស់មួយសន្ទុះទៅ ។

«រឿងដំបូងដែលខ្ញុំចាំបាន គឺសម្លេងមួយនិយាយមកកាន់ខ្ញុំ ហៅខ្ញុំដោយឈ្មោះ ។ ខ្ញុំមើលទៅលើ ហើយឃើញទូតដដែលឈរនៅលើក្បាលខ្ញុំ ហ៊ុំព័ទ្ធជុំវិញដោយរស្មីដូចពីលើកមុនដែរ ។ ខណៈនោះ លោកក៏ថ្លែងពីរឿងទាំងអស់មកខ្ញុំម្តងទៀត ដែលលោកបានប្រាប់ខ្ញុំកាល ពីយប់មិញ ហើយលោកបញ្ជាខ្ញុំឲ្យទៅរកឪពុកខ្ញុំ ហើយប្រាប់គាត់ពីការនិមិត្ត និងបញ្ញត្តិទាំងឡាយដែលខ្ញុំបានទទួល ។

«ខ្ញុំធ្វើតាម; ខ្ញុំត្រឡប់ទៅរកឪពុកខ្ញុំនៅក្នុងចំការ ហើយបានរៀបរាប់រឿងសព្វគ្រប់ជំរាបគាត់ ។ គាត់ឆ្លើយតបមកខ្ញុំថា ជារឿងរបស់ ព្រះ ហើយគាត់បានប្រាប់ឲ្យខ្ញុំទៅ ហើយធ្វើដូចដែលទូតបានបញ្ជាចុះ ។ ខ្ញុំបានចេញពីចំការ ហើយទៅកាន់ទីកន្លែង ដែលទូតបានប្រាប់ខ្ញុំថាមាន ផ្ទាំងទាំងឡាយកប់ទុក; ហើយមកពីសេចក្តីច្បាស់លាស់នៃការនិមិត្តដែលខ្ញុំបានឃើញមក នោះខ្ញុំស្គាល់កន្លែងនោះភ្លាមនៅពេលខ្ញុំទៅដល់ ទីនោះ ។

« នៅជិតភូមិម៉ែនឆេស្ទើរ ស្រុកអុនតារីយ៉ូ រដ្ឋនូវយ៉ោក មានភ្នំមួយធំ ហើយខ្ពស់បំផុតនៅក្នុងតំបន់ ។ នៅប៉ែកខាងលិចភ្នំនេះ មិនជាឆ្ងាយប៉ុន្មានពីកំពូល ហើយនៅក្រោមដុំថ្មមួយដ៏ធំ មានផ្ទាំងទាំងឡាយដាក់ទុកនៅក្នុងហិបថ្ម ។ ដុំថ្មនេះក្រាស់ ហើយនៅចំកណ្ដាលប៉ែកខាងលើមានរាងមូល ហើយស្ដើងបន្តិចខាងជ្រុងៗ ហើយនៅចំកណ្ដាលវាផុសពីដី ប៉ុន្តែជ្រុងជុំវិញត្រូវដីកប់ជិតអស់ ។

« កាលបានកាយដីចេញហើយ ខ្ញុំបានដងគំនាស់មួយ ដែលខ្ញុំបញ្ចូលក្រោមជ្រុងថ្ម ហើយដោយកម្លាំងបន្តិចបន្តួច ក៏គាស់ថ្មនោះរបើកឡើងបាន ។ ខ្ញុំមើលទៅខាងក្នុង ហើយពិតជាទីនោះមែន ខ្ញុំឃើញទាំងផ្ទាំងទាំងឡាយ យូរីម និងធូមីម ហើយព្រមទាំងប្រដាប់បាំងទ្រូង ដូចដែលទូតមានប្រសាសន៍មក ។ ហិបដែលដាក់របស់ទាំងនេះ បានធ្វើឡើងដោយការដាក់ថ្មភ្ជាប់គ្នាពីជាតិស៊ីម៉ង់ត៍ម្យ៉ាង ។ នៅបាតហិប មានថ្មពីរដុំ ដាក់ទុកទទឹងហិប ហើយនៅពីលើថ្មពីរដុំនេះ មានផ្ទាំងទាំងឡាយ ព្រមទាំងវត្ថុផ្សេងៗដាក់ទុកជាមួយគ្នាផង ។

« ខ្ញុំព្យាយាមយករបស់ទាំងនោះចេញមក ប៉ុន្តែត្រូវទូតហាមឃាត់ ហើយប្រាប់ម្ដងទៀតថា ពេលដែលត្រូវយករបស់ទាំងនោះចេញមក ពុំទាន់មកដល់នៅឡើយ គឺមិនទាន់ដល់វេលាទេ ។ លុះត្រាតែគម្រប់បួនឆ្នាំចាប់ពីឆ្នាំនេះទៅ; ប៉ុន្តែលោកមានប្រសាសន៍ប្រាប់ខ្ញុំថា ចាប់ពី ថ្ងៃនេះទៅរហូតដល់កំណត់មួយឆ្នាំ ខ្ញុំត្រូវត្រឡប់មកកាន់កន្លែងនេះវិញ ហើយលោកនឹងមកជួបខ្ញុំនៅទីនោះ ហើយថា ខ្ញុំត្រូវធ្វើដូច្នោះតទៅ លុះត្រាដល់ពេលដែលនឹងបានទទួលផ្ទាំងទាំងឡាយនោះមក ។

« ម្ល៉ោះហើយ ដូចដែលខ្ញុំត្រូវបានបញ្ជាមក ខ្ញុំក៏ទៅនៅពេលគ្រប់កំណត់មួយឆ្នាំម្ដងៗ ហើយជារៀងរាល់ដង ខ្ញុំបានជួបទូតដដែលនៅទីនោះ ហើយបានទទួលការបង្គាប់ និងប្រាជ្ញាពីលោក គ្រប់ពេលដែលយើងសន្ទនាគ្នា អំពីរឿងដែលព្រះអម្ចាស់ទ្រង់នឹងធ្វើ ហើយតើដោយរបៀបណា និងដោយនូវអ្វីដែលនគរព្រះ នឹងត្រូវចាត់ចែងនៅគ្រាក្រោយបង្អស់ ។

* * * * * * *

« នៅទីបញ្ចប់ ក៏ដល់ពេលដែលនឹងបានទទួលទាំងផ្ទាំងទាំងឡាយ យូរីម និងធូមីម ហើយព្រមទាំងប្រដាប់បាំងទ្រូងផង ។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៨២៧ ខ្ញុំបានត្រឡប់ទៅកាន់កន្លែង ដែលមានវត្ថុទាំងនេះ កប់ទុកតាមធម្មតា នៅពេលគ្រប់កំណត់មួយឆ្នាំទៀត ទូតស្ថានសួគ៌ ដដែលក៏បានប្រគល់វត្ថុទាំងនោះដល់ខ្ញុំ៖ ថាខ្ញុំត្រូវទទួលការខុសត្រូវចំពោះវត្ថុទាំងនោះ; ហើយថាបើខ្ញុំបណ្ដោយឲ្យរបស់ទាំងនោះខូចខាត ទៅ ដោយមិនយកចិត្តទុកដាក់ ឬក៏ដោយការធ្វេសប្រហែសណាមួយរបស់ខ្ញុំ នោះខ្ញុំនឹងត្រូវកាត់ចេញ; ប៉ុន្តែបើខ្ញុំខំប្រើសេចក្ដីព្យាយាមដ៏អស់ពីចិត្តខ្ញុំ ដែលនឹងរក្សាវត្ថុទាំងនោះទុក លុះត្រាដល់លោក ជាទូតនឹងហៅយករបស់ទាំងនោះវិញ នោះវត្ថុទាំងនោះនឹងបានទទួលការពារឲ្យគង់វង់នៅ ។

« នៅមិនយូរប៉ុន្មាន ខ្ញុំក៏ដឹងហេតុផលដែលខ្ញុំត្រូវបានទទួលបំរាមយ៉ាងតឹងរឹងដូច្នោះ ដើម្បីឲ្យថែរក្សារបស់ទាំងនោះទុកឲ្យផុតអន្តរាយ ហើយហេតុដែលទូតបានពោលទុកថា កាលណាខ្ញុំបានសំរេចនូវអ្វីដែលត្រូវការពីដៃរបស់ខ្ញុំហើយ នោះលោកនឹងហៅយករបស់ផងនោះវិញ ។ ត្បិតនៅមិនយូរប៉ុន្មាន ដែលអ្នកផ្សេងទាំងពួងដឹងថាខ្ញុំមានរបស់ទាំងនោះ នោះគេបានខិតខំព្យាយាមធ្វើអំពើអាស្រូវបំផុតដើម្បីនឹងដណ្ដើមយក របស់ទាំងនោះពីខ្ញុំទៅ ។ មធ្យោបាយគ្រប់បែប ដែលអាចគិតឃើញបានមក ក៏ធ្វើដើម្បីប្រយោជន៍នោះ ។ សេចក្ដីបៀតបៀនមកលើរូបខ្ញុំ មាន ទម្ងន់ធ្ងន់ល្វីងជូរចត់ជាងពេលណាៗទាំងអស់ ហើយមនុស្សទាំងហ្វូងឃាមចាំគ្រប់ពេលវេលា ដើម្បីនឹងដណ្ដើមយករបស់ទាំងនោះពីខ្ញុំទៅ ប្រសិនបើធ្វើបាន ។ ប៉ុន្តែដោយសារប្រាជ្ញារបស់ព្រះ របស់ទាំងនោះបាននៅក្នុងកណ្ដាប់ដៃរបស់ខ្ញុំដោយផុតអន្តរាយ លុះត្រាខ្ញុំបានសំរេច ភារកិច្ច ដោយវត្ថុនោះ ដែលត្រូវធ្វើតាមពីដៃរបស់ខ្ញុំ ។ នៅពេលដែលទូតតម្រូវយកវត្ថុទាំងនោះវិញ ដូចដែលបានគ្រោងទុក នោះខ្ញុំបានប្រគល់ វត្ថុទាំងនោះទៅលោកវិញ; ហើយលោកមានវត្ថុទាំងនោះ នៅក្នុងសេចក្ដីថែរក្សានៃលោករហូតដល់ថ្ងៃនេះ គឺថ្ងៃទី២ ខែឧសភា ឆ្នាំ១៨៣៨ » ។

សំរាប់រឿងទាំងមូល សូមមើល យ៉ូសែបស្ម៊ីធ — ប្រវត្តិ នៅក្នុងមុក្ដាដ៏មានតម្លៃមហិមា *History of the Church of Jesus Christ of Latter-day Saints* (ប្រវត្តិពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ) ភាគទី១ ជំពូកទី១ ដល់ជំពូកទី៦ ។

បញ្ជីប្រវត្តិបុរាណដែលបាននាំចេញមកពីដី ដូចជាសម្លេងរបស់ប្រជាជនមួយ ដែលនិយាយចេញពីធូលីដីមក ហើយបានបកប្រែចេញ ជាភាសាបច្ចុប្បន្ន ដោយសារអំណោយទាន និងព្រះចេស្ដានៃព្រះ ដែលពិសោធបានដោយសេចក្ដីបញ្ជាក់ពីព្រះ បានត្រូវបោះពុម្ពផ្សាយដល់ ពិភពលោក ជាលើកដំបូងបង្អស់ នៅក្នុងឆ្នាំ១៨៣០ ជា The Book of Mormon ។

## ការអធិប្បាយដ៏ខ្លីអំពី

# ព្រះគម្ពីរមរមន

ព្រះគម្ពីរមរមន គឺជាបញ្ជីដ៏ពិសិដ្ឋនៃជនសម័យបុរាណ នៅទ្វីបអាមេរិក ហើយបានឆ្លាក់នៅលើផ្ទាំងដែក ។ ផ្ទាំងដែកបួនយ៉ាងដែលបាន និយាយពោលដល់ នៅក្នុងគម្ពីរនេះ គឺ៖

១. *ផ្ទាំងនីហ្វៃ* ដែលមានពីរយ៉ាង គឺ៖ ផ្ទាំងតូចនិងផ្ទាំងធំ ។ ផ្ទាំងតូចកត់ត្រាជាពិសេសនូវរឿងរ៉ាវខាងវិញ្ញាណ និងការងារបំរើ និងការបង្រៀននៃពួកព្យាការី រីឯផ្ទាំងធំកត់ត្រាជាភាគច្រើននូវប្រវត្តិសាស្ត្រនៃប្រជាជន (នីហ្វៃ ទី១ ៩:២–៤) ។ ប៉ុន្តែចាប់តាំងពីសម័យម៉ូសាយមក ផ្ទាំងធំក៏កត់បញ្ចូលនូវប្រវត្តិផ្សេងៗ នៃការណ៍សំខាន់ខាងវិញ្ញាណដែរ ។

២. *ផ្ទាំងមរមន* ដែលមាននូវការសង្ខេបអំពីផ្ទាំងធំរបស់នីហ្វៃ ព្រមទាំងមាននូវសេចក្តីអត្ថាធិប្បាយទាំងឡាយ ។ ផ្ទាំងទាំងនេះក៏មានប្រវត្តិសាស្ត្រតរឿងមក ដែលសរសេរដោយមរមនផ្ទាល់ ព្រមទាំងសេចក្តីបន្ថែម ដែលសរសេរដោយម៉ូរ៉ូណៃ ដែលជាកូនប្រុសរបស់ មរមន ។

៣. *ផ្ទាំងអេធើរ* ដែលចែងអំពីប្រវត្តិសាស្ត្រនៃពួកសាសន៍យ៉ារេឌ ។ បញ្ជីនេះសង្ខេបដោយម៉ូរ៉ូណៃ ដែលបានបញ្ចូលនូវអត្ថាធិប្បាយផ្ទាល់របស់លោក ព្រមទាំងបានបញ្ចូលទៅក្នុងសាច់រឿង នូវប្រវត្តិសាស្ត្រទូទៅ ក្រោមចំណងជើងថា «គម្ពីរអេធើរ» ។

៤. *ផ្ទាំងលង្ហិន* ដែលប្រជាជនលីហៃបាននាំមកពីដែនដីយេរូសាឡិម ក្នុងកំឡុងឆ្នាំ៦០០មុន គ.ស. ។ ផ្ទាំងទាំងនេះមាននូវ «គម្ពីរម៉ូសេប្រាំច្បាប់, ... ហើយក៏មាននូវបញ្ជីប្រវត្តិនៃពួកសាសន៍យូដា ចាប់តាំងពីដើមដំបូងមក, ... រហូតមកដល់ការចាប់ផ្តើមរជ្ជកាលនៃ សេដេគាជាស្តេចស្រុកយូដា; ហើយព្រមទាំងមាននូវសេចក្តីព្យាករណ៍ទាំងឡាយនៃពួកព្យាការីបរិសុទ្ធ» (នីហ្វៃ ទី១ ៥:១១–១៣) ។ ពាក្យស្រង់ជាច្រើនចេញពីផ្ទាំងទាំងនេះ យោងតាមពាក្យព្យាករណ៍របស់អេសាយ និងតាមពាក្យព្យាករណ៍របស់ពួកព្យាការីផ្សេងៗ នៅក្នុងព្រះគម្ពីរប៊ីប និងនៅក្រៅព្រះគម្ពីរប៊ីប ដែលមាននៅក្នុងព្រះគម្ពីរមរមន ។

ព្រះគម្ពីរមរមនបែងចែកជា ១៥ ភាគ ឬបទ ដែលស្គាល់ថាជាគម្ពីរទាំងឡាយ ដាក់តាមឈ្មោះអ្នក និពន្ធឯក លើកលែងតែមួយគត់ ។ ផ្នែកទីមួយ (គម្ពីរប្រាំមួយច្បាប់មុនដំបូង ដែលបញ្ចប់នឹងគម្ពីរអោមណៃ) គឺបានបកប្រែចេញពីផ្ទាំងតូចរបស់នីហ្វៃ ។ នៅចន្លោះគម្ពីរអោមណៃ និងគម្ពីរម៉ូសាយ គឺជាពាក្យបញ្ចូលដែលហៅថា ពាក្យសំដីនៃមរមន ។ ពាក្យបញ្ចូលនេះភ្ជាប់បញ្ជីដែលឆ្លាក់នៅលើផ្ទាំងតូច ទៅនឹងសេចក្តី សង្ខេបរបស់មរមន ពីផ្ទាំងធំ ។

ផ្នែកវែងបង្អស់ ចាប់ពីម៉ូសាយទៅដល់មរមន ជំពូកទី៧ គឺជាសេចក្តីបកប្រែនៃការសង្ខេបរបស់មរមន ពីផ្ទាំងធំរបស់នីហ្វៃ ។ ផ្នែកខាង ចុងនៃព្រះគម្ពីរមរមន ចាប់ពីមរមន ជំពូកទី៨ រហូតដល់ចប់ ត្រូវបានឆ្លាក់ដោយកូនប្រុសរបស់មរមន គឺម៉ូរ៉ូណៃ បន្ទាប់ពីបានបញ្ចប់នូវបញ្ជីអំពីជីវិត របស់ឪពុកលោកហើយ នោះក៏បានសង្ខេបនូវបញ្ជីអំពីសាសន៍យ៉ារេឌ (ជាគម្ពីរអេធើរ) ហើយបន្ទាប់មកលោកក៏បានបន្ថែមនូវវគ្គទាំងឡាយ ដែលស្គាល់ថាជាគម្ពីរម៉ូរ៉ូណៃ ។

ក្នុងរយៈពេល ឬប្រមាណជាឆ្នាំ៤២១ គ.ស. ម៉ូរ៉ូណៃ ជាព្យាការី-ប្រវត្តិសាស្ត្រចុងក្រោយបំផុតនៃសាសន៍នីហ្វៃ បានផ្សារភ្ជាប់នូវបញ្ជី ដ៏ពិសិដ្ឋ ហើយលាក់ទុកថ្វាយព្រះអម្ចាស់ ដើម្បីនឹងនាំលេចមកវិញ នៅថ្ងៃចុងក្រោយ ដូចដែលបានព្យាករដោយសម្លេងនៃព្រះតាមរយៈពួក ព្យាការីបុរាណរបស់ទ្រង់ ។ នៅ គ.ស. ១៨២៣ ម៉ូរ៉ូណៃដដែល ជាអ្នកដែលបានរស់ឡើងវិញ បានមករកព្យាការីយ៉ូសែបស្ម៊ីធ ហើយនៅទីបញ្ចប់ ក៏បានប្រគល់ផ្ទាំងចារិកទាំងឡាយទៅលោក ។

## ឈ្មោះនិងលំដាប់នៃគម្ពីរទាំងឡាយក្នុង

# ព្រះគម្ពីរមរមន

*ឈ្មោះ* *ទំព័រ*


គម្ពីរទីមួយ នៃនីហ្វៃ . . . . . . . . . . . . . . . . . . . . ១
គម្ពីរទីពីរ នៃនីហ្វៃ . . . . . . . . . . . . . . . . . . . ៥៥
គម្ពីរយ៉ាកុប . . . . . . . . . . . . . . . . . . . . ១២២
គម្ពីរអេណុស . . . . . . . . . . . . . . . . . . . . ១៤០
គម្ពីរយ៉ារ៉ុម . . . . . . . . . . . . . . . . . . . . ១៤៣
គម្ពីរអោមណៃ . . . . . . . . . . . . . . . . . . . . ១៤៥
ពាក្យសំដីនៃមរមន . . . . . . . . . . . . . . . . . . . ១៤៧
គម្ពីរម៉ូសាយ . . . . . . . . . . . . . . . . . . . . ១៤៩
គម្ពីរអាលម៉ា . . . . . . . . . . . . . . . . . . . . ២១២
គម្ពីរហេលេមិន . . . . . . . . . . . . . . . . . . . . ៣៧៥
នីហ្វៃទីបី . . . . . . . . . . . . . . . . . . . . ៤១៤
នីហ្វៃទីបួន . . . . . . . . . . . . . . . . . . . . ៤៧៣
គម្ពីរមរមន . . . . . . . . . . . . . . . . . . . . ៤៧៧
គម្ពីរអេធើរ . . . . . . . . . . . . . . . . . . . . ៤៩៦
គម្ពីរមរ៉ូណៃ . . . . . . . . . . . . . . . . . . . . ៥២៧

# គម្ពីរទីមួយនៃនីហ្វៃ

រជ្ជកាល និងការងារបំរើរបស់លោក

ដំណើររឿងមួយអំពីលោកលីហៃ និងនាងសារ៉ាយ ជាប្រពន្ធរបស់លោក និងកូនប្រុសបួននាក់របស់លោក មានឈ្មោះថា (ចាប់ផ្ដើមពី កូនច្បង) លេមិន លេមយ្យួល សាំ និងនីហ្វៃ ។ ព្រះអម្ចាស់ទ្រង់ព្រមានលីហៃ ឲ្យចាកចេញពីដែនដីយេរូសាឡិម ពីព្រោះលោកបាន ព្យាករអំពីសេចក្ដីទុច្ចរិតនៃប្រជាជន ហើយគេព្យាយាមរកផ្ដាច់ជីវិតលោក ។ លោកធ្វើដំណើរចូលទីរហោស្ថានអស់រយៈពេលបីថ្ងៃ ជាមួយនឹងគ្រួសារលោក ។ នីហ្វៃនាំពួកបងប្រុសរបស់លោក ហើយត្រឡប់ទៅឯដែនដីយេរូសាឡិមវិញ ដើម្បីតាមយកបញ្ជីរបស់ពួក សាសន៍យូដា ។ ដំណើររឿងអំពីសេចក្ដីទុក្ខលំបាកទាំងឡាយរបស់ពួកគេ ។ ពួកគេយកពួកកូនស្រីរបស់អ៊ីសម៉ាអែលធ្វើជាប្រពន្ធ ។ ពួកគេនាំគ្រួសារគេទាំងឡាយ ហើយចាកចេញទៅក្នុងទីរហោស្ថាន ។ សេចក្ដីទុក្ខលំបាក និងសេចក្ដីទុក្ខវេទនាទាំងឡាយរបស់ពួក គេនៅទីរហោស្ថាន ។ ផ្លូវនៃដំណើរទាំងឡាយរបស់ពួកគេ ។ ពួកគេមកដល់ទឹកដ៏ធំធេង ។ ពួកបងប្រុសរបស់នីហ្វៃបះបោរទាស់នឹង លោក ។ លោកធ្វើឲ្យពួកគេជ្រប់មុខ ព្រមទាំងធ្វើសំពៅមួយផង ។ គេហៅកន្លែងនោះថា បរិបូរណ៍ ។ គេឆ្លងទឹកដ៏ធំធេងទៅដល់ ដែនដីសន្យា ។ល។ អត្ថបទនេះគឺស្របតាមដំណើររឿងរបស់នីហ្វៃ; ឬពាក្យម្យ៉ាងទៀតថា គឺខ្ញុំ នីហ្វៃ បានសរសេរបញ្ជីនេះ ។

## ជំពូកទី ១

*នីហ្វៃចាប់ផ្ដើមបញ្ជីអំពីប្រជាជនរបស់លោក — លីហៃឃើញនៅក្នុងការនិមិត្ត ជាបង្គោលភ្លើងមួយ ហើយអានគម្ពីរនៃការព្យាករណ៍ មួយ — លោកសរសើរដំកើងព្រះ ហើយព្យាករអំពីការយាងមកនៃព្រះមែស៊ី និងព្យាករអំពីសេចក្ដីបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម — លោកត្រូវពួកសាសន៍យូដាបៀតបៀន ។ ប្រមាណជាឆ្នាំ ៦០០ ម.គ.ស. (មុនគ្រីស្ទសករាជ) ។*

ខ្ញុំ [ក]នីហ្វៃ ដោយបានកើតមកពី[ខ]ឪពុកម្ដាយ[គ]ល្អ ហេតុដូច្នេះហើយ ខ្ញុំត្រូវបាន[ឃ]បង្រៀនខ្លះៗ នូវអស់ទាំងចំណេះវិជ្ជារបស់ឪពុកខ្ញុំ; ហើយដោយបាន ឃើញ[ង]សេចក្ដីទុក្ខវេទនាទាំងឡាយ នៅក្នុងដំណើរនៃជីវិតខ្ញុំ ទោះជាយ៉ាងណាក៏ដោយ គង់តែបានប្រោសប្រណីជាខ្លាំងពីព្រះអម្ចាស់ អស់មួយជីវិតខ្ញុំដែរ; មែនហើយ ដោយមានដំរិះដ៏ជ្រាលជ្រៅអំពីសេចក្ដីល្អសប្បុរស និង[ច]សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ ហេតុដូច្នេះ ហើយ ទើបខ្ញុំ[ឆ]ធ្វើបញ្ជីពីដំណើរការរបស់ខ្ញុំ នៅក្នុងជីវិតខ្ញុំ ។

២ មែនហើយ ខ្ញុំធ្វើបញ្ជីមួយនៅក្នុង[ក]ភាសារបស់ឪពុកខ្ញុំ ដែលមានរួមទាំងចំណេះវិជ្ជានៃពួកសាសន៍យូដា និងភាសារបស់ពួក សាសន៍អេស៊ីព្ទ ។

៣ ហើយខ្ញុំដឹងថា បញ្ជីដែលខ្ញុំធ្វើនេះ គឺជា[ក]ការពិត; ហើយខ្ញុំធ្វើដោយដៃរបស់ខ្ញុំផ្ទាល់ ហើយខ្ញុំធ្វើតាមការចេះដឹងរបស់ខ្ញុំ ។

៤ ត្បិតហេតុការណ៍បានកើតឡើង គឺនៅក្នុងរយៈពេលដើមឆ្នាំ[ក]ទីមួយ នៃរជ្ជកាលនៃ[ខ]សេដេគា ជាស្ដេចស្រុកយូដា (ឪពុកខ្ញុំគឺលីហៃ បានអាស្រ័យនៅ[គ]ក្រុងយេរូសាឡិម អស់មួយជីវិតលោក); ហើយនៅក្នុងឆ្នាំជាមួយគ្នានោះ មាន[ឃ]ពួកព្យាការីជាច្រើនព្យាករដល់ប្រជាជនថា ត្រូវតែប្រែចិត្ត បើពុំនោះសោតទេ [ង]ទីក្រុងយេរូសាឡិមដ៏ធំ នឹងត្រូវបំផ្លាញចោល ។

៥ ហេតុដូច្នេះហើយ ហេតុការណ៍បានកើតឡើងថា ឪពុកខ្ញុំ

[១ នីហ្វៃ]

១ ១*ក* ស.ប. នីហ្វៃ, កូនប្រុសរបស់លីហៃ.
*ខ* សុភា. ២២:១.
*គ* គ. និង ស. ៦៨:២៥, ២៨.
ស.ប. មាតាបិតា, ឪពុកម្ដាយ.
*ឃ* អេណុស ១:១; ម៉ូសាយ ១:២–៣.
ស.ប. បង្រៀន, គ្រូបង្រៀន.
*ង* ស.ប. សេចក្ដីទំនាស់.
*ច* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*ឆ* ស.ប. បទព្រះគម្ពីរ.
២ *ក* ម៉ូសាយ ១:២–៤;
មរមន ៩:៣២–៣៣.
៣ *ក* ១ នីហ្វៃ ១៤:៣០; ម៉ូសាយ ១:៦;
អេធើរ ៥:១–៣; គ. និង ស. ១៧:៦.
៤ *ក* ស.ប. លំដាប់ពេល–៥៩៨ ម.គ.ស.
*ខ* ២ របា. ៣៦:១០;
យេរេ. ៥២:៣–៥;
អោមណៃ ១:១៥.
*គ* ១ របា. ៩:៣.
*ឃ* ២ ពង្សាវ. ១៧:១៣–១៥;
២ របា. ៣៦:១៥–១៦;
យេរេ. ៧:២៥–២៦.
ស.ប. ព្យាការី.
*ង* យេរេ. ២៦:១៨; ២ នីហ្វៃ ១:៤;
ហេលេ. ៨:២០.

[ក]លីហៃ នៅពេលដែលលោកចេញទៅអធិស្ឋានដល់ព្រះអម្ចាស់ មែនហើយ គឺដោយអស់ពី[ខ]ដួងចិត្ត សំរាប់ប្រជាជនរបស់លោក ។

៦ ហើយហេតុការណ៍បានកើតឡើង គឺនៅពេលដែលលោកកំពុងតែអធិស្ឋានដល់ព្រះអម្ចាស់ នោះស្រាប់តែមាន[ក]បង្គោលភ្លើងមួយ ផុសចេញមក ហើយស្ថិតនៅលើថ្មមួយដុំចំពីមុខលោក; ហើយលោកបានឃើញ និងបានឮជាច្រើន; ហើយមកពីអ្វីៗដែលលោកបានឃើញ និងបានឮមក នោះលោកមានសេចក្ដីរន្ធត់ញាប់ញ័រជាខ្លាំង ។

៧ ហើយហេតុការណ៍បានកើតឡើងថា លោកវិលត្រឡប់ទៅផ្ទះលោក នៅក្រុងយេរូសាឡិមវិញ; ហើយផ្ដួលខ្លួនទៅលើគ្រែ ដោយ[ក]ស្លុងទៅក្នុងព្រះវិញ្ញាណ និងអ្វីៗដែលលោកបានឃើញ ។

៨ ហើយដោយស្លុងទៅក្នុងព្រះវិញ្ញាណ នោះលោកក៏បណ្ដែតអារម្មណ៍ ទៅក្នុង[ក]ការនិមិត្តមួយ ថែមទាំង[ខ]ឃើញផ្ទៃមេឃបើកចំហ ហើយលោកគិតថា លោកឃើញព្រះកំពុងតែគង់នៅលើបល្ល័ង្ករបស់ទ្រង់ ដោយមានពួកពលបរិវារទេវតាដ៏ឥតគណនា ហែរហមជុំវិញ នៅក្នុងអាកប្បកិរិយាកំពុងតែច្រៀង និងសរសើរដំកើងដល់ព្រះរបស់គេ ។

៩ ហើយហេតុការណ៍បានកើតឡើងថា លោកបានឃើញមួយអង្គយាងចុះមកពីកណ្ដាលផ្ទៃមេឃ ហើយលោកបានឃើញថា [ក]រស្មីទ្រង់ភ្លឺត្រចះត្រចង់ ជាងព្រះអាទិត្យនៅពេលថ្ងៃត្រង់ទៅទៀត ។

១០ ហើយលោកក៏បានឃើញមាន[ក]១២នាក់ទៀត ចុះមកតាមដែរ ហើយរស្មីពួកគេ ភ្លឺត្រចះជាងតារានៅលើផ្ទៃមេឃទៅទៀត ។

១១ ហើយពួកគេចុះមក ហើយចេញទៅលើផ្ទៃផែនដី; មួយអង្គដែលយាងចុះមកដំបូង បានឈរនៅចំពោះមុខឪពុកខ្ញុំ ហើយបាន ប្រទាន[ក]គម្ពីរមួយទៅឪពុកខ្ញុំ ហើយបញ្ជាឲ្យលោកអាន ។

១២ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលឪពុកខ្ញុំកំពុងតែអាននោះ លោកក៏បានពោរពេញទៅដោយ[ក]ព្រះវិញ្ញាណ នៃព្រះអម្ចាស់ ។

១៣ ហើយឪពុកខ្ញុំអានថា៖ វេទនា វេទនាដល់ក្រុងយេរូសាឡិម ត្បិតយើងបានឃើញ[ក]អំពើគួរខ្ពើមឆ្អើមរបស់ពួកអ្នកហើយ! មែនហើយ មានរឿងជាច្រើនទៀត ដែលឪពុកខ្ញុំបានអានអំពី[ខ]ក្រុងយេរូសាឡិម — ថាទីក្រុងនេះនឹងត្រូវបំផ្លាញចោល ព្រមទាំងបណ្ដាជន ដែលនៅទីនោះផង; មនុស្សជាច្រើននឹងត្រូវវិនាសដោយមុខដាវ ហើយមនុស្សជាច្រើនទៀតនឹងត្រូវ[គ]ចាប់ជាឈ្លើយ នាំយកទៅឯក្រុង បាប៊ីឡូន ។

១៤ ហើយហេតុការណ៍បានកើតឡើងថា កាលឪពុកខ្ញុំបានអានហើយឃើញនូវរឿងដ៏មហិមា និងដ៏គួរអស្ចារ្យជាច្រើន នោះលោក ក៏បានថ្លែងវាចាជាច្រើន ទៅកាន់ព្រះអម្ចាស់ដូច្នេះថា៖ ឱព្រះអម្ចាស់ជាព្រះ ដ៏មានមហិទ្ធិឫទ្ធិអើយ ប្រសើរមែនកិច្ចការទាំងឡាយរបស់ ព្រះអង្គនោះមហិមានិងគួរអស្ចារ្យណាស់! បល្ល័ង្កព្រះអង្គខ្ពស់នៅលើផ្ទៃមេឃ ហើយទាំងព្រះចេស្ដានិងសេចក្ដីសប្បុរស ហើយនិងសេចក្ដី មេត្តាករុណារបស់ព្រះអង្គ មានមកលើគ្រប់បណ្ដាជនទាំងអស់នៅលើផែនដី; ហើយដោយទ្រង់ប្រកបដោយសេចក្ដីមេត្តាករុណា នោះព្រះអង្គនឹងមិនទ្រាំឲ្យអស់អ្នកណា ដែល[ក]មករកព្រះអង្គត្រូវវិនាសឡើយ ។

១៥ ហើយតាមរបៀបនេះហើយ គឺជាភាសារបស់ឪពុកខ្ញុំក្នុងការសរសើរដំកើងដល់ព្រះរបស់លោក; ត្បិតព្រលឹងវិញ្ញាណលោកបាន អរសប្បាយ ហើយដួងចិត្តលោកបានពោរពេញ មកពីរឿងអ្វីៗដែលលោកបានឃើញ មែនហើយ គឺព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ លោក ។

១៦ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ មិនរៀបរាប់ឲ្យអស់នូវដំណើររឿង ដែលឪពុកខ្ញុំបានសរសេរទេ ត្បិតឪពុកខ្ញុំបានសរសេរនូវ

---

៥ *ក* ស.ប. លីហៃ, ឪពុករបស់នីហ្វៃ.
*ខ* យ៉ាកុប (ព.ស.ថ.) ៥:១៦.
៦ *ក* និក្ខ. ១៣:២១; ហេលេ. ៥:២៤, ៤៣; គ. និង ស. ២៩:១២; យ.ស.—ប្រវត្តិ ១:១៦.
៧ *ក* ដានី. ១០:៨; ១ នីហ្វៃ ១៧:៤៧; ម៉ូសេ ១:៩–១០; យ.ស.—ប្រវត្តិ ១:២០.
៨ *ក* ១ នីហ្វៃ ៥:៤. ស.ប. ការនិមិត្ត.
*ខ* អេសេ. ១:១; កិច្ចការ ៧:៥៥–៥៦; ១ នីហ្វៃ ១១:១៤; ហេលេ. ៥:៤៥–៤៩; គ. និង ស. ១៣៧:១.
៩ *ក* យ.ស.—ប្រវត្តិ ១:១៦–១៧.
១០ *ក* ស.ប. សាវក.
១១ *ក* អេសេ. ២:៩.
១២ *ក* គ. និង ស. ៦:១៥.
១៣ *ក* ២ ពង្សាវ. ២៤:១៨–២០; ២ របា. ៣៦:១៤.
*ខ* ២ ពង្សាវ. ២៣:២៧; ២៤:២; យេរេ. ១៣:១៣–១៤; ២ នីហ្វៃ ១:៤.
*គ* ២ ពង្សាវ. ២០:១៧–១៨; ២ នីហ្វៃ ២៥:១០; អោមណៃ ១:១៥.
១៤ *ក* អាលម៉ា ៥:៣៣–៣៦; ៣ នីហ្វៃ ៩:១៤.

រឿងជា ច្រើន ដែលលោកបានឃើញនៅក្នុងការនិមិត្ត និងក្នុងសុបិនទាំងឡាយ; ហើយលោកបានសរសេរនូវរឿងជាច្រើនផងដែរ ដែលលោកបាន[ក]ព្យាករ ហើយនិយាយប្រាប់កូនចៅរបស់លោក ដែលខ្ញុំនឹងពុំយកមករៀបរាប់ឲ្យអស់បានឡើយ ។

១៧ ប៉ុន្តែ ខ្ញុំនឹងរៀបរាប់នូវដំណើរការទាំងឡាយក្នុងជីវិតខ្ញុំ ។ មើលចុះ ខ្ញុំ[ក]សង្ខេបនូវ[ខ]បញ្ជីរបស់ឪពុកខ្ញុំ នៅលើផ្ទាំងទាំងឡាយ ដែលខ្ញុំ បានធ្វើឡើងដោយដៃខ្ញុំផ្ទាល់; ហេតុ ដូច្នេះហើយ បន្ទាប់ពីខ្ញុំបានសង្ខេបនូវបញ្ជីរបស់ឪពុកខ្ញុំរួចស្រេចបាច់ នោះខ្ញុំនឹងរៀបរាប់អំពី ជីវិតខ្ញុំផ្ទាល់ ។

១៨ ហេតុដូច្នេះហើយ ខ្ញុំមានបំណងចង់ឲ្យអ្នករាល់គ្នាដឹងថា បន្ទាប់ពីព្រះអម្ចាស់ ទ្រង់បានបង្ហាញដល់លីហៃ ជាឪពុកខ្ញុំ នូវរឿងដ៏គួរ អស្ចារ្យទាំងឡាយ មែនហើយ [ក]អំពីសេចក្តីបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម មើលចុះ លោកបានចេញទៅក្នុងចំណោមប្រជាជន ហើយបាន ចាប់ផ្តើម[ខ]ព្យាករ និងប្រកាសប្រាប់បណ្តាជនអំពីរឿងទាំងឡាយ ដែលលោកបានឃើញ ហើយបានឮ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍យូដាបាន[ក]ចំអកឡកឡឺយដល់លោក មកពីរឿងទាំងឡាយដែលលោកបានធ្វើ បន្ទាល់ពីពួកគេ; ត្បិតលោកបានធ្វើបន្ទាល់ដោយពិត អំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ; ហើយលោកបានធ្វើ បន្ទាល់ថា អ្វីៗដែលលោកបានឃើញ ហើយបានឮ ព្រមទាំងអ្វីៗដែលលោកបានអានក្នុងគម្ពីរផងនោះ បានសម្តែងយ៉ាងច្បាស់ប្រាប់ អំពីការយាងមកនៃ[ខ]ព្រះមែស៊ី ហើយព្រមទាំងអំពីសេចក្តីប្រោសលោះនៃពិភពលោកផង ។

២០ ហើយកាលពួកសាសន៍យូដា បានឮពីរឿងទាំងនេះ ពួកគេក៏ខឹងនឹងលោក; មែនហើយ គឺដូចជាគេធ្លាប់បានខឹងនឹងពួកព្យាការី ពីជំនាន់ដើមដែរ ដែលពួកគេ[ក]បានទាំងបណ្តេញចេញ ហើយចោលថ្ម ហើយសម្លាប់; ហើយពួកគេថែមទាំងព្យាយាមតាមយកជីវិតលោក ដើម្បីនឹងផ្តាច់ចោលដែរ ។ ប៉ុន្តែមើលចុះ ខ្ញុំ នីហ្វៃ នឹងបង្ហាញដល់អ្នករាល់គ្នាថា [ខ]សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ មានមកលើជនទាំងអស់ណាដែលព្រះទ្រង់បានរើស ដោយសារសេចក្តីជំនឿរបស់គេ ដើម្បីធ្វើឲ្យគេខ្លាំងពូកែ ស្មើនឹងអំណាចនៃសេចក្តី ដោះលែងឲ្យរួចផុត ៕

## ជំពូកទី ២

*លីហៃនាំគ្រួសារលោកចូលក្នុងទីរហោស្ថាន តាមមាត់សមុទ្រក្រហម — គេចាកចោលទ្រព្យសម្បត្តិ — លីហៃធ្វើយញ្ញបូជាថ្វាយព្រះអម្ចាស់ ហើយបង្រៀនកូនប្រុសទាំងឡាយរបស់លោក ឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយ — លេមិន និងលេមយួលរអ៊ូរទាំទាស់នឹងឪពុករបស់គេ — នីហ្វៃគោរពធ្វើតាម ហើយអធិស្ឋាននៅក្នុងសេចក្តីជំនឿ; ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅនីហ្វៃ ហើយនីហ្វៃត្រូវបានរើសឲ្យត្រួតត្រាលើ បងប្រុសទាំងឡាយរបស់លោក ។ ប្រមាណជាឆ្នាំ ៦០០ ម.គ.ស. ។*

ត្បិតមើលចុះ ហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅឪពុកខ្ញុំ មែនហើយ គឺនៅក្នុងសុបិន ដោយមានព្រះបន្ទូលថា៖ លីហៃអើយ អ្នកមានពរហើយ ដោយសារអំពើទាំងឡាយដែលអ្នកបានធ្វើ ហើយដោយសារអ្នកមានចិត្តស្មោះត្រង់ ព្រមទាំងបានថ្លែងប្រាប់ បណ្តាជន អំពីអ្វីៗដែលយើងបានបញ្ជាអ្នក មើលចុះ ពួកគេព្យាយាម[ក]រកផ្តាច់ជីវិតអ្នកទៅវិញ ។

២ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់[ក]បានបញ្ជាឪពុកខ្ញុំ គឺនៅក្នុង[ខ]សុបិន ឲ្យលោក[គ]នាំគ្រួសារ ហើយធ្វើដំណើរចេញ ទៅក្នុងទីរហោស្ថាន ។

៣ ហើយហេតុការណ៍បានកើតឡើងថា លោកបាន[ក]គោរពធ្វើតាមព្រះបន្ទូលនៃព្រះអម្ចាស់ ហេតុដូច្នោះហើយ លោកបានធ្វើដូច ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាលោក ។

---

១៦ *ក* ១ នីហ្វៃ ៧:១.
១៧ *ក* ១ នីហ្វៃ ៩:២—៥.
*ខ* ១ នីហ្វៃ ៦:១—៣; ១៩:១—៦; ២ នីហ្វៃ ៥:២៩—៣៣; គ. និង ស. ១០:៣៨—៤៦.
១៨ *ក* ២ នីហ្វៃ ២៥:៩—១០; គ. និង ស. ៥:២០.
*ខ* ស.ប. ការព្យាករណ៍, ព្យាករ.
១៩ *ក* ២ របា. ៣៦:១៥—១៦; យេរេ. ២៥:៤; ១ នីហ្វៃ ២:១៣; ៧:១៤.
*ខ* ស.ប. ព្រះមែស៊ី.
២០ *ក* ហេលេ. ១៣:២៤—២៦.
*ខ* អាលម៉ា ៣៤:៣៨; គ. និង ស. ៤៦:១៥. ស.ប. សេចក្តីមេត្តាករុណា, មេត្តាករុណា.
**២** ១ *ក* ១ នីហ្វៃ ៧:១៤.
២ *ក* ១ នីហ្វៃ ៥:៨; ១៧:៤៤.
*ខ* ស.ប. សប្តិ.
*គ* លោកុ. ១២:១; ២ នីហ្វៃ ១០:២០; អេធើរ ១:៤២; អ័ប្រា. ២:៣.
៣ *ក* ស.ប. ការគោរព, ដែលគោរព, គោរព.

៤ ហើយហេតុការណ៍បានកើតឡើងថា លោកបានចេញទៅ
ក្នុងទីរហោស្ថាន ។ ហើយលោកបានចាកចោលផ្ទះ
សំបែងរបស់លោក និងដែនដីនៃកេរ្ដិ៍អាកររបស់លោក និង
មាសរបស់លោក និងប្រាក់របស់លោក និងវត្ថុដ៏មាន
តម្លៃរបស់លោក ហើយមិនបានយកអ្វីទៅជាមួយ លោកឡើយ
ក្រៅពីគ្រួសារលោក និងស្បៀងអាហារ ហើយនិង
ត្រសាល ហើយបានចេញទៅក្នុងទីរហោស្ថាន ។
៥ ហើយលោកបានចុះមកដល់តំបន់ព្រំប្រទល់ ជិតឆ្នេរសមុទ្រ
ក្រហម; ហើយលោកបានធ្វើដំណើរនៅក្នុងទីរហោស្ថាន ក្នុង
តំបន់ព្រំ ប្រទល់ ដែលនៅជិតសមុទ្រក្រហម; ហើយលោកបាន
ធ្វើដំណើរក្នុងទីរហោស្ថាន ជាមួយគ្រួសាររបស់លោក ដែល
មានម្ដាយខ្ញុំឈ្មោះ សារ៉ាយ និងបងប្រុសខ្ញុំទាំងឡាយ
គឺលេមិន លេមយ្អួល និងសាំ ។
៦ ហើយហេតុការណ៍បានកើតឡើងថា កាលឪពុកខ្ញុំបានធ្វើ
ដំណើរ អស់រយៈពេលបីថ្ងៃ នៅក្នុងទីរហោស្ថាន
នោះលោកបានបោះ ត្រសាល នៅក្នុងច្រកភ្នំមួយ នៅក្បែរ
មាត់ទន្លេទឹក ។
៧ ហើយហេតុការណ៍បានកើតឡើងថា លោកបាន
សង់អាសនាមួយពីថ្ម ហើយបានថ្វាយដង្វាយដល់ព្រះអម្ចាស់
ហើយបានថ្លែង អំណរគុណដល់ព្រះអម្ចាស់ ជាព្រះ
របស់យើង ។
៨ ហើយហេតុការណ៍បានកើតឡើងថា លោកបាន
ហៅឈ្មោះទន្លេនោះថា លេមិន ហើយទន្លេនោះ ហូរចាក់ទៅ
ក្នុងសមុទ្រក្រហម ហើយច្រកភ្នំនោះ នៅត្រង់ព្រំប្រទល់
ជិតមាត់ទន្លេ ។
៩ ហើយនៅពេលដែលឪពុកខ្ញុំបានឃើញថា ទឹកក្នុងទន្លេ
ហូរចាក់ទៅក្នុងប្រភពនៃសមុទ្រក្រហម នោះលោកមានប្រសាសន៍
ទៅ លេមិនថា៖ ឱ សូមឲ្យកូនបានដូចជាទឹកទន្លេនេះចុះ ដែល
ហូរជានិច្ច ទៅក្នុងប្រភពនៃអស់ទាំងសេចក្ដីសុចរិត ។
១០ ហើយលោកក៏មានប្រសាសន៍ទៅលេមយ្អួលថា៖ ឱ
សូមឲ្យកូនបានដូចជាច្រកភ្នំនេះចុះ រឹងប៉ឹង និងខ្ជាប់ខ្ជួន
ហើយឥតបែរចេញ ក្នុងការកាន់តាមបញ្ញត្តិទាំងឡាយ នៃព្រះ
អម្ចាស់ឡើយ ។
១១ ឥឡូវនេះ លោកមានប្រសាសន៍យ៉ាងនេះ មកពីការ
រឹងទទឹងនៃលេមិន និងលេមយ្អួល; ត្បិតមើលចុះ គេបាន
រអ៊ូរទាំពីរឿងជាច្រើន ទាស់នឹងឪពុកគេ ពីព្រោះលោកជាអ្នក
ប្រកបដោយការនិមិត្ត ហើយបាននាំពួកគេចេញពីដែនដីយេរូសាឡិម
ដោយបានទាំងទុកចោល ដែនដីនៃកេរ្ដិ៍អាកររបស់គេ និងមាស
របស់គេ និងប្រាក់របស់គេ និងវត្ថុដ៏មានតម្លៃរបស់គេ
ឲ្យមកវិនាសបង់នៅក្នុងទីរហោស្ថាន ។ ហើយគេបាននិយាយ
ថា លោកធ្វើយ៉ាងនេះ ដោយមកពីគំនិតដ៏ឥតប្រយោជន៍នៃ
ចិត្តរបស់លោក ។
១២ ហើយលេមិន និងលេមយ្អួល ដែលជាបងបង្អស់ បាន
រអ៊ូរទាំទាស់នឹងឪពុកគេយ៉ាងដូច្នោះ ។ ហើយពួកគេបាន
រអ៊ូរទាំ ពីព្រោះ គេមិនបានដឹងអំពីព្រឹត្តិការណ៍នៃព្រះ ដែលបាន
បង្កើតពួកគេមក ។
១៣ គេព្រមទាំងមិនជឿថា ទីក្រុងយេរូសាឡិម គឺទីក្រុង
ដ៏ធំនោះ អាចត្រូវបំផ្លាញចោល តាមពាក្យសំដីរបស់ពួក
ព្យាការីបានឡើយ ។ ហើយគេក៏ដូចជាពួកសាសន៍យូដា
ដែលនៅឯទីក្រុងយេរូសាឡិមដែរ ដែលបានព្យាយាម
រកផ្ដាច់ជីវិតនៃឪពុកខ្ញុំ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ឪពុកខ្ញុំក៏បាន
និយាយទៅពួកគេ នៅក្នុងច្រកភ្នំលេមយ្អួល ដោយអំណាច
គឺបានពោរពេញ ទៅដោយព្រះវិញ្ញាណ រហូតដល់ខ្លួនប្រាណ
របស់គេញ័រចំប្រប់ នៅចំពោះមុខលោក ។ លោកបានធ្វើឲ្យ
គេជ្រប់មុខ ទាល់តែគេមិនអាចបន្លឺ សម្លេងប្រកែកនឹងលោកបាន
ហេតុដូច្នោះហើយ គេបានធ្វើតាមបង្គាប់លោក ។
១៥ ហើយឪពុកខ្ញុំបានអាស្រ័យនៅក្នុងត្រសាល ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ
ពេលនោះនៅក្មេងណាស់ ប៉ុន្តែមានមាឌធំមាំមួន ហើយមាន
ចិត្តមោះមុត ចង់ដឹង នូវសេចក្ដីអាថ៌កំបាំងទាំងឡាយនៃ
ព្រះ ហេតុដូច្នោះហើយ ខ្ញុំបានអំពាវនាវដល់ព្រះអម្ចាស់;

៤ *ក* ១ នីហ្វៃ ១០:៤; ១៩:៨.
៥ *ក* ១ នីហ្វៃ ១៦:១៤;
គ. និង ស. ១៧:១.
*ខ* ស.ប. លេមិន
៦ *ក* ១ នីហ្វៃ ៩:១.
៧ *ក* លោកុ. ១២:៧–៨; និក្ខ. ២៤:៤;
អ័ប្រា. ២:១៧.
*ខ* និក្ខ. ២០:២៥; ចោទិ. ២៧:៥–៦.
*គ* ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
១១ *ក* ១ នីហ្វៃ ១៧:១៧.
ស.ប. រអ៊ូរទាំ.
*ខ* សុភា. ២០:២០.
*គ* ១ នីហ្វៃ ៥:២–៤.
១២ *ក* ម៉ូសេ ៤:៦.
១៣ *ក* យេរេ. ១៣:១៤; ១ នីហ្វៃ ១:១៣.
១៤ *ក* ស.ប. អំណាច.
*ខ* ១ នីហ្វៃ ១៧:៤៥.
១៦ *ក* ស.ប. សេចក្ដីអាថ៌កំបាំងទាំង
ឡាយនៃព្រះ.

ហើយមើលចុះ ទ្រង់បាន[ខ]យាងមកជួបនឹងខ្ញុំ ហើយ[គ]បន្ទន់ចិត្តខ្ញុំ
[ឃ]បណ្ដាលឲ្យខ្ញុំជឿអស់ទាំងពាក្យ ដែលបានពោលមកដោយ
ឪពុកខ្ញុំ; ហេតុដូច្នោះហើយ ខ្ញុំមិនបានបះបោរទាស់នឹងលោក
ដូចជាបងៗខ្ញុំនោះ ទេ ។
១៧ ហើយខ្ញុំបាននិយាយទៅសាំ ធ្វើឲ្យសាំដឹងអំពីរឿងទាំង
ឡាយ ដែលព្រះអម្ចាស់ទ្រង់បានសម្ដែងដល់ខ្ញុំ ដោយព្រះវិញ្ញាណ
បរិសុទ្ធ របស់ទ្រង់ ។ ហើយហេតុការណ៍បានកើតឡើងថា
សាំបានជឿតាមពាក្យសំដីទាំងឡាយរបស់ខ្ញុំ ។
១៨ ប៉ុន្តែមើលចុះ លេមិន និងលេមយួលមិនព្រមស្ដាប់តាម
ពាក្យសំដីរបស់ខ្ញុំទេ; ហើយដោយ[ក]ព្រួយចិត្ត មកពីភាពរឹងរូស
នៃចិត្តរបស់ បងខ្ញុំទាំងពីរ នោះខ្ញុំបានអំពាវនាវដល់ព្រះ
អម្ចាស់សំរាប់គេ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
មានព្រះបន្ទូលមកខ្ញុំថា៖ ឱនីហ្វៃអើយ អ្នកមានពរហើយ
ដោយសារសេចក្ដី [ក]ជំនឿរបស់អ្នក ព្រោះអ្នកបានព្យាយាម
ស្វែងរកយើង ដោយមានចិត្តសុភាពរាបសា ។
២០ ហើយដរាបណាអ្នកកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង
នោះអ្នកនឹង[ក]ចំរើនឡើង ហើយនឹងបាននាំទៅកាន់[ខ]ដែនដីសន្យា;
មែនហើយ គឺជាដែនដីដែលយើងបានរៀបចំឡើងសំរាប់អ្នក;
មែនហើយ គឺជាដែនដីមួយ ដែលជាជំរើសលើដែនដីឯទៀត
ទាំងអស់ ។
២១ ហើយដរាបណាបងប្រុសទាំងឡាយរបស់អ្នក
នៅតែបះបោរទាស់នឹងអ្នក គេទាំងនោះនឹងត្រូវ[ក]កាត់ចេញពីវត្តមាន
នៃព្រះអម្ចាស់ ។
២២ ហើយដរាបណាអ្នកនៅតែកាន់តាមបញ្ញត្តិទាំងឡាយ
របស់យើង នោះអ្នកនឹងបានទៅជាអ្នក[ក]គ្រប់គ្រង និងជាគ្រូបង្រៀន
ទៅលើ បងប្រុសទាំងឡាយរបស់អ្នក ។
២៣ ត្បិតមើលចុះ នៅថ្ងៃណាមួយដែលពួកគេបះបោរទាស់
នឹងយើង នោះយើងនឹង[ក]ដាក់បណ្ដាសាពួកគេ ដោយពាក្យ
បណ្ដាសាដ៏ ធ្ងន់ធ្ងរ ហើយពួកគេនឹងមិនមានអំណាចអ្វី
ទៅលើពូជរបស់អ្នកឡើយ លើកលែងតែពូជអ្នកបះបោរទាស់
នឹងយើងដែរ ។
២៤ ហើយប្រសិនបើពួកគេបះបោរទាស់នឹងយើងមែន នោះ
ពួកគេនឹងក្លាយទៅជា[ក]រំពាត់ ចំពោះពូជអ្នក ដើម្បី
ដាស់[ខ]រំឮលពូជអ្នក អំពីផ្លូវនៃការចងចាំ ៕

---

ជំពូកទី ៣

*កូនប្រុសទាំងឡាយរបស់លីហៃ ត្រឡប់ទៅក្រុងយេរូសាឡិមវិញ ដើម្បីទៅយកផ្ទាំងលង្ហិន — ឡាបាន់មិនព្រមប្រគល់ផ្ទាំងទាំងនោះឲ្យគេទេ — នីហ្វៃទូន្មាន ហើយលើកទឹកចិត្តបងប្រុសទាំងឡាយរបស់លោក — ឡាបាន់លួចយកទ្រព្យសម្បត្តិរបស់ពួកគេ ហើយថែមទាំងរក ប្រហារពួកគេទៀត — លេមិន និងលេមយួលវាយនីហ្វៃ និងសាំ ហើយត្រូវទេវតាស្ដីបន្ទោស ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស.។*

ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បន្ទាប់ពីបាន
ទូលជាមួយនឹងព្រះអម្ចាស់ហើយ ក៏ត្រឡប់មកត្រសាលឪពុក
ខ្ញុំវិញ ។
២ ហើយហេតុការណ៍បានកើតឡើងថា ឪពុកខ្ញុំបាននិយាយ
មកខ្ញុំថា៖ មើលចុះ ឪពុកបានដេកយល់[ក]សប្ដិ ហើយក្នុង
សុបិននោះ ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យកូនឯង ជាមួយនឹង
បងប្រុសទាំងឡាយ ត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ។
៣ ត្បិតមើលចុះ ឡាបាន់មានបញ្ជីរបស់ពួកសាសន៍យូដា
ព្រមទាំង[ក]ពង្សាវតាររបស់ពួកអយ្យកោឪពុក ដែលឆ្លាក់នៅលើផ្ទាំ
ងលង្ហិន ទាំងឡាយ ។
៤ ហេតុដូច្នោះហើយ ព្រះអម្ចាស់ទ្រង់បានបញ្ជាដល់ឪពុកថា

---

១៦ *ខ* ទំនុក. ៨:៤; អាលម៉ា ១៧:១០;
គ. និង ស. ៥:១៦.
ស.ប. វិវរណៈ.
*គ* ១ ពង្សាវ. ១៨:៣៧;
អាលម៉ា ៥:៧.
*ឃ* ១ នីហ្វៃ ១១:៥.
*ង* ស.ប. ឪពុកខាងសាច់ឈាម;
ព្យាការី.
១៨ *ក* អាលម៉ា ៣១:២៤;
៣ នីហ្វៃ ៧:១៦.
១៩ *ក* ១ នីហ្វៃ ៧:១២; ១៥:១១.
២០ *ក* យ៉ូស្វេ ១:៧; ១ នីហ្វៃ ៤:១៤;
ម៉ូសាយ ១:៧.
*ខ* ចោទិ. ៣៣:១៣–១៦;
១ នីហ្វៃ ៥:៥; ៧:១៣;
ម៉ូសេ ៧:១៧–១៨.
ស.ប. ដែនដីសន្យា.
២១ *ក* ២ នីហ្វៃ ៥:២០–២៤;
អាលម៉ា ៩:១៣–១៥; ៣៨:១.
២២ *ក* លោកុ. ៣៧:៨–១១;
១ នីហ្វៃ ៣:២៩.
២៣ *ក* ចោទិ. ១១:២៨;
១ នីហ្វៃ ១២:២២–២៣;
គ. និង ស. ៤១:១.
២៤ *ក* យ៉ូស្វេ ២៣:១៣;
ពួកចៅ. ២:២២–២៣.
*ខ* ២ នីហ្វៃ ៥:២៥.
**៣** ២ *ក* ស.ប. សប្ដិ.
៣ *ក* ១ នីហ្វៃ ៥:១៤.

កូន និងបងៗឯង ត្រូវត្រឡប់ទៅផ្ទះឡាបាន់ ដើម្បីស្វែងរកបញ្ជី
ទាំងឡាយ ហើយនាំយកមកទីនេះ ក្នុងទីរហោស្ថានវិញ ។
៥ ហើយឥឡូវនេះ មើលចុះ បងៗរបស់កូនរអ៊ូរទាំថា ឪពុក
បានតម្រូវឲ្យគេធ្វើការដ៏លំបាក; ប៉ុន្តែមើលចុះ ឪពុកមិនបាន
តម្រូវគេទេ ប៉ុន្តែនេះជាព្រះបញ្ញត្តិនៃព្រះអម្ចាស់ទេតើ ។
៦ ហេតុដូច្នេះហើយ ទៅចុះកូនប្រុសឪពុក កូននឹងបាន
ប្រោសប្រណីពីព្រះអម្ចាស់ ពីព្រោះកូនមិនបានរអ៊ូរទាំ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាន
និយាយទៅឪពុកខ្ញុំថា៖ ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗ ដែលព្រះ
អម្ចាស់ទ្រង់បានបញ្ជា ត្បិតខ្ញុំដឹងថា ព្រះអម្ចាស់ទ្រង់មិនចេញ
បញ្ជា ដល់កូនចៅមនុស្សណាឡើយ លើកលែងតែទ្រង់នឹង
រៀបចំផ្លូវ ដើម្បីឲ្យគេអាចសំរេច នូវអ្វីៗ ដែលទ្រង់បានបញ្ជា
ដល់ពួកគេទុកជាមុនសិន ។
៨ ហើយហេតុការណ៍បានកើតឡើងថា នៅពេលឪពុកខ្ញុំបាន
ឮពាក្យទាំងនេះហើយ នោះលោកមានសេចក្ដីត្រេកអរជាអនេក
ត្បិតលោកបានដឹងថា ខ្ញុំបានទទួលព្រះពរពីព្រះអម្ចាស់ ។
៩ ហើយខ្ញុំ នីហ្វៃ និងបងប្រុសទាំងឡាយរបស់ខ្ញុំ បានចេញ
ដំណើរក្នុងទីរហោស្ថាន ព្រមទាំងមានត្រសាលយកទៅជាមួយផង
ដើម្បីឡើងទៅឯដែនដីយេរូសាឡិម ។
១០ ហើយហេតុការណ៍បានកើតឡើងថា កាលយើង
បានឡើងទៅដល់ដែនដីយេរូសាឡិមហើយ នោះខ្ញុំ និង
បងប្រុសទាំងឡាយ របស់ខ្ញុំ បានពិគ្រោះគ្នាទៅវិញទៅមក ។
១១ ហើយយើងបានចាប់ឆ្នោត រកនរណាម្នាក់ ក្នុងចំណោមពួ
កយើង ដែលត្រូវចូលទៅផ្ទះឡាបាន់ ។ ហើយហេតុការណ៍
បានកើត ឡើងថា ឆ្នោតនោះធ្លាក់ទៅលើលេមិន; ហើយលេមិនបា
នចូលទៅផ្ទះឡាបាន់ ហើយគាត់បាននិយាយជាមួយនឹងឡា
បាន់ នៅពេលគាត់ អង្គុយនៅក្នុងផ្ទះរបស់ឡាបាន់ ។
១២ ហើយលេមិនស្នើសុំយកបញ្ជីទាំងប៉ុន្មាន ដែលបាន
ឆ្លាក់នៅលើផ្ទាំងលង្ហិន ដែលមានពង្សាវតារនៃឪពុកខ្ញុំ ពីឡា
បាន់មក ។
១៣ ហើយមើលចុះ ហេតុការណ៍បានកើតឡើងថា ឡាបាន
កើតក្ដីខឹងខ្លាល់ ហើយបណ្ដេញលេមិនចេញពីវត្តមានរបស់
គាត់; ហើយ មិនព្រមឲ្យលេមិន យកបញ្ជីទាំងឡាយឡើយ ។
ហេតុដូច្នោះហើយ ឡាបាន់និយាយទៅកាន់លេមិនថា៖ មើលចុះ
ឯងនេះគឺជាចោរ អញនឹងសម្លាប់ឯងចោល ។
១៤ ប៉ុន្តែ លេមិនបានរត់គេចចេញពីវត្តមានរបស់គាត់
ហើយត្រឡប់មកប្រាប់យើង អំពីរឿងដែលឡាបាន់បានធ្វើ ។
ហើយពួកយើង ចាប់ផ្ដើមមានចិត្តទុក្ខព្រួយជាខ្លាំង ហើយបងប្រុ
សទាំងឡាយរបស់ខ្ញុំ ស្ទើរតែនឹងត្រឡប់ទៅរកឪពុកខ្ញុំ នៅក្នុង
ទីរហោស្ថានវិញ ។
១៥ ប៉ុន្តែមើលចុះ ខ្ញុំបាននិយាយទៅគេថា៖ ប្រាកដដូចជា
ព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ ហើយប្រាកដ
ដូចជាយើងនៅមាន ជីវិត នោះយើងនឹងមិនចុះទៅរកឪពុក
យើង នៅក្នុងទីរហោស្ថានឡើយ ទាល់តែយើងបានសំរេចនូវ
កិច្ចការ ដែលព្រះអម្ចាស់ទ្រង់បាន បញ្ជាយើងសិន ។
១៦ ហេតុដូច្នោះហើយ ចូរយើងមានចិត្តស្មោះត្រង់
ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់; ហេតុ
ដូច្នេះហើយ ចូរយើង ចុះទៅឯដែនដីនៃកេរ្ដិ៍អាកររបស់ឪពុកយើង
ត្បិតមើលចុះ លោកបានចោលមាសប្រាក់ ព្រមទាំង
ទ្រព្យសម្បត្តិគ្រប់មុខ ។ ហើយដែល លោកបានធ្វើការទាំង
អស់នេះ ក៏ដោយសារតែ ព្រះបញ្ញត្តិទាំងឡាយនៃព្រះ
អម្ចាស់ដែរ ។
១៧ ត្បិតលោកដឹងថា ក្រុងយេរូសាឡិម នឹងត្រូវ
បំផ្លាញចោល មកពីអំពើទុច្ចរិតរបស់មនុស្ស ។
១៨ ត្បិតមើលចុះ ពួកគេបានបដិសេធ នូវពាក្យទាំងឡាយ
នៃពួកព្យាការី ។ ហេតុដូច្នោះហើយ បើសិនជាឪពុកខ្ញុំ ស្នាក់
ចិត្តអាស្រ័យ នៅលើដែនដីនេះតទៅទៀត ក្រោយពីព្រះបាន
បញ្ជាឲ្យរត់ចេញនោះ មើលចុះ លោកក៏នឹងត្រូវវិនាសដែរ ។
ហេតុដូច្នោះហើយ ជាចាំបាច់ណាស់ ដែលលោកត្រូវតែ
រត់ចេញពីដែនដីនេះ ។
១៩ ហើយមើលចុះ នេះគឺជាប្រាជ្ញានៅក្នុងព្រះ ដែលយើង
ត្រូវតែយកបញ្ជីទាំងនេះមកឲ្យបាន ដើម្បីឲ្យយើងអាចថែរក្សា

៦ *ក* ស.ប. ការគាំទ្រពួកអ្នកដឹក
នាំសាសនាចក្រ.
៧ *ក* ១ សាំយូ. ១៧:៣២;
១ ពង្សាវ. ១៧:១១–១៥.
ស.ប. សេចក្ដីជំនឿ; ការគោរព,
ដែលគោរព, គោរព.
*ខ* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
*គ* លោកុ. ១៨:១៤; ភីលិព ៤:១៣;
១ នីហ្វៃ ១៧:៣, ៥០;
គ. និង ស. ៥:៣៤.
១១ *ក* នេហេ. ១០:៣៤; កិច្ចការ ១:២៦.
១២ *ក* ១ នីហ្វៃ ៣:៣; ៥:១៤.
១៦ *ក* ១ នីហ្វៃ ២:៤.
*ខ* ១ នីហ្វៃ ២:២; ៤:៣៤.
១៧ *ក* ២ របា. ៣៦:១៦–២០;
យេរេ. ៣៩:១–៩; ១ នីហ្វៃ ១:១៣.
១៨ *ក* ស.ប. ការបះបោរ.
*ខ* ១ នីហ្វៃ ១៦:៨.
១៩ *ក* អោមណៃ ១:១៧;
ម៉ូសាយ ១:២–៦.

នូវភាសារបស់ពួកអយ្យកោយើង ទុកដល់កូនចៅរបស់យើង
ទាំងឡាយ;
២០ ហើយក៏ដើម្បីឲ្យយើងអាចរក្សា នូវពាក្យពេចន៍ទាំងឡាយ
ដែលបានពោលដោយមាត់ នៃគ្រប់ទាំងពួកព្យាការីដ៏បរិសុទ្ធ
ដែលព្រះវិញ្ញាណ និងព្រះចេស្ដានៃព្រះ បានប្រគល់ឲ្យពួកព្យាការី
ចាប់តាំងពីកំណើតលោកិយ រហូតមកដល់បច្ចុប្បន្ននេះ ។
២១ ហើយហេតុការណ៍បានកើតឡើងថា តាមពាក្យ
បែបនេះហើយ ដែលខ្ញុំបានបញ្ចុះបញ្ចូលបងៗខ្ញុំ ដើម្បីឲ្យ
គេអាចមានចិត្តស្មោះ ត្រង់ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំង
ឡាយនៃព្រះ ។
២២ ហើយហេតុការណ៍បានកើតឡើងថា យើងក៏បាន
ចុះទៅឯដែនដីនៃកេរ្តិ៍អាកររបស់យើង ហើយយើងបានទាំង
ប្រមូលមាស របស់យើង និងប្រាក់របស់យើង ហើយនិងវ
ត្ថុដ៏មានតម្លៃរបស់យើង ។
២៣ ហើយបន្ទាប់ពីយើង បានប្រមូលវត្ថុទាំងនេះរួចស្រេចហើយ
នោះយើងក៏បានឡើងទៅឯផ្ទះឡាបាន់ម្ដងទៀត ។
២៤ ហើយហេតុការណ៍បានកើតឡើងថា យើងបាន
ចូលទៅជួ បនឹងឡាបាន់ ហើយស្នើសុំឲ្យលោក ឲ្យបញ្ជីទាំង
ឡាយ ដែលបាន ឆ្លាក់នៅលើផ្ទាំងលង្ហិនទាំងប៉ុន្មាននោះមកយើង
ត្បិតយើងនឹងប្រគល់ ឲ្យគាត់ទាំងមាសរបស់យើង និង
ប្រាក់របស់យើង ហើយព្រមទាំងវត្ថុដ៏មានតម្លៃៗទាំងអស់
របស់យើង ។
២៥ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែល
ឡាបាន់ឃើញទ្រព្យរបស់យើង គឺជាទ្រព្យវិសេសហួសប្រមាណ
ទើប លោកកើតក្ដីលោភលន់ចង់បាន រហូតដល់បណ្ដេញ
យើងទៅក្រៅ ហើយបានប្រើឲ្យពួកបាវបំរើរបស់
គាត់ដេញតាមសម្លាប់យើងចោល ដើម្បីគាត់អាចបានទ្រព្យ
របស់យើង ។
២៦ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបាន
រត់គៀសខ្លួនពីបាវបំរើឡាបាន់ ហើយពួកយើងត្រូវតែ
ទម្លាក់ចោលទ្រព្យសម្បត្តិ របស់យើង ហើយទ្រព្យនោះក៏ធ្លាក់ទេ
ៅក្នុងកណ្ដាប់ដៃឡាបាន់ ។
២៧ ហើយហេតុការណ៍បានកើតឡើងថា យើងបាន
រត់ចូលទៅក្នុងទីរហោស្ថាន ហើយពួកបាវបំរើរបស់ឡាបាន
ដេញយើងមិន ទាន់សោះ ហើយយើងបានពួននៅក្នុងរូងថ្មមួយ ។
២៨ ហើយហេតុការណ៍បានកើតឡើងថា លេមិនកើតក្ដីខឹង
នឹងខ្ញុំ ហើយនឹងឪពុកខ្ញុំផង; ឯលេមយួលក៏ដូច្នោះដែរ ត្បិត
គាត់ជឿតាមពាក្យ ទាំងឡាយនៃលេមិន ។ ហេតុដូច្នោះហើយ
លេមិន និងលេមយួលបានពោលពាក្យទ្រគោះជាច្រើន មក
លើយើងដែលជាប្អូន ហើយគេថែម ទាំងយករំពាត់វាយ
យើងទៀត ។
២៩ ហើយហេតុការណ៍បានកើតឡើងថា កាលពួក
គេកំពុងតែវាយយើងនឹងរំពាត់ មើលចុះ ស្រាប់តែទេវតានៃ
ព្រះអម្ចាស់បានមក ឈរនៅចំពោះមុខគេ ហើយលោកមាន
ប្រសាសន៍ទៅគេថាៈ ចុះហេតុអ្វីបានជាអ្នកវាយប្អូនអ្នកនឹង
រំពាត់ ? អ្នកមិនដឹងទេឬអីថា ព្រះអម្ចាស់ទ្រង់បានរើសប្អូនអ្នក
ឲ្យធ្វើជាអ្នកត្រួតត្រាលើរូបអ្នក ហើយការណ៍នេះ គឺមកពីអំពើ
ទុច្ចរិតទាំងឡាយរបស់អ្នក ? មើលចុះ ចូរអ្នករាល់
គ្នាឡើងទៅឯក្រុងយេរូសាឡិមម្ដងទៀតចុះ ហើយព្រះអម្ចាស់
ទ្រង់នឹងប្រគល់ឡាបាន់ មកក្នុងកណ្ដាប់ដៃអ្នក ។
៣០ ហើយបន្ទាប់ពីទេវតាមានប្រសាសន៍មកយើង
រួចស្រេចហើយ នោះលោកក៏បានយាងចេញទៅ ។
៣១ ហើយបន្ទាប់ពីទេវតាបានយាងចេញទៅហើយ នោះលេមិន
និងលេមយួលក៏ចាប់ផ្ដើមរអ៊ូរទាំទៀតថាៈ តើព្រះអម្ចាស់ទ្រង់
នឹង អាចប្រគល់ឡាបាន់ មកក្នុងកណ្ដាប់ដៃយើងយ៉ាងណាបាន ?
មើលចុះ គាត់នេះជាអ្នកខ្លាំងពូកែ គាត់អាចបញ្ជា
មនុស្ស៥០នាក់បាន មែនហើយ គាត់អាចទាំងសម្លាប់
មនុស្ស៥០នាក់បានទៀតផង ចុះហេតុអ្វីក៏នឹងសម្លាប់យើងមិនបាន ?

## ជំពូកទី ៤

*នីហ្វៃប្រហារឡាបាន់ តាមបញ្ជារបស់ព្រះអម្ចាស់ ហើយបន្ទាប់មក ក៏យកផ្ទាំងលង្ហិនបាន ដោយប្រើឧបាយកល — ស្សូរាំដាច់ចិត្តទៅតាម គ្រួសារលីហៃ ក្នុងទីរហោស្ថាន ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាននិយាយទៅកាន់

២០ *ក* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរ ដែលត្រូវរក្សាទុក.
២២ *ក* ១ នីហ្វៃ ២:៤.
២៤ *ក* ១ នីហ្វៃ ៣:៣.
២៥ *ក* ស.ប. លោភ.
២៨ *ក* ១ នីហ្វៃ ១៧:១៧–១៨.
២៩ *ក* ១ នីហ្វៃ ៤:៣; ៧:១០. ស.ប. ពួកទេវតា.
*ខ* ១ នីហ្វៃ ២:២២.
៣០ *ក* ១ នីហ្វៃ ១៦:៣៨.
៣១ *ក* ស.ប. រអ៊ូរទាំ.

បងៗខ្ញុំថា៖ ចូរយើងឡើងទៅឯក្រុងយេរូសាឡិម ជាថ្មីម្ដងទៀត
ហើយចូរយើង មានចិត្តស្មោះត្រង់ ក្នុងការកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះអម្ចាស់; ត្បិតមើលចុះ ទ្រង់មានអំណាចជាង
អ្វីៗ នៅលើផែនដីនេះ ទាំងអស់ ហើយចុះហេតុអ្វី ក៏មិនមាន
អំណាចជាងឡាបាន់និងមនុស្ស៥០នាក់របស់គាត់បាន មែនហើយ
ឬមានអំណាចលើសជាងទាំងមនុស្សរាប់ម៉ឺន នាក់ទៅទៀត ?
២ ហេតុដូច្នេះហើយ ចូរយើងឡើងទៅ; ចូរយើងមាន
កម្លាំងខ្លាំង ដូចលោកម៉ូសេ; ត្បិតលោកពិតជាបាននិយាយ
ទៅទឹកនៅក្នុងសមុទ្រ ក្រហម ហើយទឹកក៏បែកចេញជាពីរចំណែក
ដើម្បីឲ្យពួកអយ្យកោយើង ឆ្លងកាត់ទៅលើដីគោក
រួចផុតពីការជាប់ឃុំឃាំង ហើយពលទ័ព របស់ផារ៉ោនដែល
បានដេញតាម ក៏បានលិចលង់នៅក្នុងទឹកសមុទ្រក្រហមអស់ទៅ ។
៣ ឥឡូវនេះ មើលចុះ បងដឹងថានេះជាការពិត;
ហើយបងក៏ដឹងដែរថា មានទេវតាមួយ មានប្រសាសន៍មកបង;
ហេតុដូច្នោះហើយ តើបងនៅតែសង្ស័យទៀតឬ ?
ចូរយើងឡើងទៅ; ព្រះអម្ចាស់ទ្រង់នឹងរំដោះយើងឲ្យរួចផុត
ដូចជាទ្រង់បានរំដោះពួកអយ្យកោយើងឲ្យ រួចផុតដែរ ហើយ
នឹងបំផ្លាញឡាបាន់ចោល ក៏ដូចជាបានបំផ្លាញពួកសាសន៍
អេស៊ីព្ទដែរ ។
៤ ឥឡូវនេះ នៅពេលខ្ញុំបានពោលពាក្យទាំងនេះ
នោះបងៗខ្ញុំនៅតែក្រេវក្រោធ ហើយនៅតែរអ៊ូរទាំតទៅទៀត;
ក៏ប៉ុន្តែ គេបាន ឡើងតាមខ្ញុំ រហូតទៅដល់ខាងក្រៅ
កំផែងក្រុងយេរូសាឡិម ។
៥ ហើយពេលនោះជាវេលាយប់; ហើយខ្ញុំឲ្យបងៗខ្ញុំពួននៅ
ខាងក្រៅកំផែង ។ ហើយបន្ទាប់ពីគេបានពួនរួចហើយ នោះខ្ញុំ នីហ្វៃ
បានលួចចូលទៅក្នុងទីក្រុង ហើយដើរសំដៅទៅផ្ទះឡាបាន់ ។
៦ ហើយខ្ញុំត្រូវបាននាំទៅដោយព្រះវិញ្ញាណ ដោយមិនដឹង
ជាមុនសោះឡើយថា តើខ្ញុំនឹងត្រូវធ្វើអ្វីខ្លះ ។
៧ ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ
ហើយកាលខ្ញុំទៅជិតដល់ផ្ទះឡាបាន់ហើយ នោះខ្ញុំបានឃើញ
បុរសម្នាក់ ហើយលោកបានដួលនៅលើដីចំពោះមុខខ្ញុំ ត្បិត
គាត់ស្រវឹងស្រា ។
៨ ហើយនៅពេលខ្ញុំទៅដល់គាត់ ក៏ឃើញថាលោកគឺជា
ឡាបាន់ ។
៩ ហើយខ្ញុំបានឃើញដាវរបស់គាត់ ហើយខ្ញុំបាន
ហូតដាវនោះចេញពីស្រោម; ហើយដងដាវធ្វើពីមាសសុទ្ធ
ហើយក្បូរក្បាច់ដាវនោះ ល្អវិចិត្រ ហើយខ្ញុំឃើញផ្លែដាវ ធ្វើ
ពីដែកដ៏មានតម្លៃបំផុត ។
១០ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំត្រូវបាន
បង្ខំដោយព្រះវិញ្ញាណថា ខ្ញុំត្រូវតែសម្លាប់ឡាបាន់; ប៉ុន្តែ ខ្ញុំ
នឹកក្នុងចិត្តថា៖ ខ្ញុំមិន ដែលបានកំចាយឈាម
ជនណាម្នាក់សោះឡើយ ។ ហើយខ្ញុំក៏រុញរា មិនចង់សម្លាប់
គាត់ឡើយ ។
១១ ហើយព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលមកខ្ញុំទៀតថា៖
មើលចុះ ព្រះអម្ចាស់ ទ្រង់បានប្រគល់ឡាបាន់ មកក្នុង
កណ្ដាប់ដៃអ្នកហើយ ។ មែនហើយ ហើយខ្ញុំក៏បានដឹងថា
គាត់បានរកផ្ដាច់ជីវិតខ្ញុំដែរ; មែនហើយ គាត់មិនព្រម
ស្ដាប់តាមព្រះបញ្ញត្តិទាំងឡាយ នៃព្រះអម្ចាស់ទេ; ហើយគាត់
ថែមទាំងបានយកទ្រព្យសម្បត្តិរបស់យើងផង ។
១២ ហើយហេតុការណ៍បានកើតឡើងថា ព្រះវិញ្ញាណ
ទ្រង់ក៏មានព្រះបន្ទូលមកខ្ញុំទៀតថា៖ ចូរសម្លាប់គាត់ចុះ ត្បិត
ព្រះអម្ចាស់ទ្រង់ បានប្រគល់គាត់ មកក្នុងកណ្ដាប់ដៃអ្នក
ហើយ ។
១៣ មើលចុះ ព្រះអម្ចាស់ ទ្រង់បានសម្លាប់ពួកទុច្ចរិតចោល
ដើម្បីនាំមកនូវគោលបំណងដ៏សុចរិតទាំងឡាយរបស់ទ្រង់ ។
មនុស្ស ម្នាក់វិនាសទៅ គឺប្រសើរជាងសាសន៍ទាំងមូលត្រូវ
ចុះអន់ថយ ហើយវិនាសក្នុងការឥតជំនឿ ។
១៤ ហើយឥឡូវនេះ កាលខ្ញុំ នីហ្វៃ បានឮពាក្យ
ទាំងនេះហើយ នោះខ្ញុំនឹកឃើញដល់ព្រះបន្ទូលទាំងឡាយនៃ
ព្រះអម្ចាស់ ដែលមាន ព្រះបន្ទូលមកខ្ញុំ កាលនៅក្នុង

៤ ១*ក* ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន; សេចក្ដីជំនឿ.
*ខ* ១ នីហ្វៃ ៧:១១–១២.
២ *ក* ចោទិ. ១១:៨.
*ខ* ស.ប. ម៉ូសេ.
*គ* និក្ខ. ១៤:២១; ១ នីហ្វៃ ១៧:២៦; ម៉ូសាយ ៧:១៩.
៣ *ក* ១ នីហ្វៃ ៣:២៩–៣១; ៧:១០.
៦ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ; ការបំផុសគំនិត, បំផុសគំនិត.
*ខ* ហេព្រើរ ១១:៨.
៩ *ក* ២ នីហ្វៃ ៥:១៤; គ. និង ស. ១៧:១.
១០ *ក* អាលម៉ា ១៤:១១.
១១ *ក* ១ សាំយូ. ១៧:៤១–៤៩.
*ខ* ១ នីហ្វៃ ៣:២៦.
១៣ *ក* ១ នីហ្វៃ ១៧:៣៣–៣៨; គ. និង ស. ៩៨:៣១–៣២.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
*គ* អាលម៉ា ៣០:៤៧.

ទីរហោស្ថានថា៖ [ក]ដរាបណាពូជរបស់អ្នកនៅកាន់[ខ]តាមបញ្ញត្តិ
ទាំងឡាយរបស់យើង នោះគេនឹង[គ]បានចំរើនឡើង នៅលើ
[ឃ]ដែនដីសន្យា ។
១៥ មែនហើយ ខ្ញុំគិតដែរថា ពួកគេមិនអាចកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះអម្ចាស់ តាមក្រិត្យវិន័យលោកម៉ូសេបានទេ
លើក លែងតែគេមានក្រិត្យវិន័យនោះ ។
១៦ ហើយខ្ញុំក៏ដឹងដែរថា [ក]ក្រិត្យវិន័យនោះមានឆ្លាក់នៅលើផ្ទាំង
លង្ហិន ។
១៧ ហើយមួយទៀត ខ្ញុំក៏ដឹងថា ព្រះអម្ចាស់ទ្រង់បានប្រគល់
ឡាបាន់ មកក្នុងកណ្ដាប់ដៃខ្ញុំ ដោយព្រោះហេតុនេះ — ដើម្បីឲ្យ
ខ្ញុំអាចបាន បញ្ញើទាំងប៉ុន្មាន តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។
១៨ ហេតុដូច្នេះហើយ ខ្ញុំបានគោរពតាមសម្លេងនៃព្រះវិញ្ញាណ
ហើយបានចាប់ក្របួចសក់ក្បាលរបស់ឡាបាន់ ហើយខ្ញុំបាន
កាត់ក្បាល គាត់ ដោយ[ក]ដាវរបស់គាត់ផ្ទាល់ ។
១៩ ហើយក្រោយពីខ្ញុំបានកាត់ក្បាលឡាបាន់ ដោយដាវ
ផ្ទាល់របស់គាត់ហើយ នោះខ្ញុំយកសំលៀកបំពាក់ទាំងឡាយ
របស់ឡាបាន់ មកបំពាក់លើខ្លួនខ្ញុំ; មែនហើយ ដោយមិនមាន
ខ្វះមុខណាឡើយ ហើយខ្ញុំបានយកគ្រឿងការពារខ្លួនរបស់
គាត់មកក្រវ៉ាត់នៅចង្កេះខ្ញុំ ។
២០ ហើយបន្ទាប់ពីខ្ញុំបានធ្វើដូច្នេះហើយ នោះខ្ញុំបាន
ទៅកាន់ឃ្លាំងរបស់ឡាបាន់ ។ ហើយនៅពេលដែល
ខ្ញុំកំពុងតែដើរតម្រង់ទៅឯ ឃ្លាំងរបស់ឡាបាន់ មើលចុះ ខ្ញុំបាន
ឃើញ[ក]បាវបំរើរបស់ឡាបាន់ ជាអ្នកកាន់សោឃ្លាំង ។ ហើយខ្ញុំ
បានបញ្ជាបុរសនោះ ដោយប្រើសម្លេង របស់ឡាបាន់ ឲ្យទៅ
ក្នុងឃ្លាំងជាមួយខ្ញុំ ។
២១ ហើយគាត់បានគិតស្មានថា ខ្ញុំជាឡាបាន់ ជាចៅហ្វាយ
របស់ខ្លួន ព្រោះគាត់បានឃើញសំលៀកបំពាក់ទាំងឡាយ និង
ដាវផង ដែល ក្រវ៉ាត់នៅចង្កេះខ្ញុំ ។
២២ ហើយគាត់បាននិយាយមកកាន់ខ្ញុំ ពីពួកចាស់ទុំនៃពួក
សាសន៍យូដា គាត់ដឹងថា ឡាបាន់ ជាចៅហ្វាយរបស់ខ្លួន
បានចេញទៅក្នុង ចំណោមពួកនោះ នៅពេលយប់ ។
២៣ ហើយខ្ញុំបាននិយាយទៅគាត់ ហាក់ដូចជាខ្ញុំគឺឡាបាន់ ។
២៤ ហើយខ្ញុំបាននិយាយទៅគាត់ទៀតថា ខ្ញុំត្រូវតែយក
ឆ្លាក់ត្រាទាំងឡាយ ដែលឆ្លាក់នៅលើ[ក]ផ្ទាំងលង្ហិន ទៅរកបងៗខ្ញុំ
ដែលនៅ ខាងក្រៅកំផែង ។
២៥ ហើយខ្ញុំថែមទាំងបានបង្គាប់ ឲ្យគាត់មកតាមខ្ញុំ ។
២៦ ហើយគាត់គិតស្មានថា ខ្ញុំនិយាយអំពីពួកបងប្អូននៃសាសន
ាចក្រ ហើយស្មានថា ខ្ញុំនេះពិតជាឡាបាន់ ដែលខ្ញុំ
បានសម្លាប់ ទើបគាត់មកតាមខ្ញុំ ។
២៧ ហើយគាត់បាននិយាយមកកាន់ខ្ញុំជាច្រើនផង អំពីពួក
ចាស់ទុំនៃពួកសាសន៍យូដា នៅពេលខ្ញុំធ្វើដំណើរ
ត្រឡប់ទៅរកបងៗខ្ញុំ ដែលនៅខាងក្រៅកំផែង ។
២៨ ហើយហេតុការណ៍បានកើតឡើងថា កាលលេមិនបាន
ឃើញខ្ញុំ គាត់ក៏កើតសេចក្ដីភ័យស្លុតជាខ្លាំង ឯលេមយួល និង
សាំ ក៏ដូច្នោះដែរ ។ ហើយពួកគេបានរត់ចេញពីវត្តមានខ្ញុំ;
ត្បិតពួកគេបានគិតស្មានថា នេះជាឡាបាន់ ហើយគិតថា ឡាបាន់
បានសម្លាប់ខ្ញុំចោល ហើយបានមករកផ្ដាច់ជីវិតពួកគេដែរ ។
២៩ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាន
ស្រែកហៅបងៗខ្ញុំ ហើយគេបានឮខ្ញុំហៅ; ហេតុដូច្នោះហើយ
គេក៏ឈប់រត់ ចេញពីវត្តមានខ្ញុំទៀតទៅ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា កាលបាវបំរើរបស់ឡ
ាបាន់បានឃើញបងៗខ្ញុំ គាត់ក៏ញ័ររន្ធត់ ហើយស្ទើរតែនឹងរត់គេចស
ខ្លួនពីមុខខ្ញុំ ហើយត្រឡប់ទៅឯទីក្រុងយេរូសាឡិមវិញ ។
៣១ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ ដែលជាមនុស្សមាឌធំ ព្រម
ទាំងបានទទួល[ក]កម្លាំងជាច្រើន ពីព្រះអម្ចាស់ ហេតុដូច្នេះហើយ
ខ្ញុំបានចាប់ បាវបំរើរបស់ឡាបាន់ ហើយឱបគាត់ជាប់ ដើម្បី
មិនឲ្យរត់បាន ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាននិយាយ
ទៅគាត់ថា បើសិនជាគាត់ប្រុងស្ដាប់តាមពាក្យទាំងឡាយ
របស់ខ្ញុំ ប្រាកដ ដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ
ហើយប្រាកដដូចជាខ្ញុំនៅមានជីវិត ហើយដរាបណាគាត់ប្រុង
ស្ដាប់តាមពាក្យទាំងឡាយរបស់ យើង នោះយើងនឹងប្រណី
ជីវិតដល់គាត់ ។
៣៣ ហើយខ្ញុំបាននិយាយទៅគាត់ គឺដោយ[ក]ពាក្យសម្បថ

១៤ *ក* អោមណៃ ១:៦; ម៉ូសាយ ២:២២;
អេធើរ ២:៧–១២.
*ខ* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
*គ* ១ នីហ្វៃ ២:២០.
*ឃ* ១ នីហ្វៃ ១៧:១៣–១៤;
យ៉ាកុប ២:១២.
១៦ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
១៨ *ក* ១ សាំយូ. ១៧:៥១.
២០ *ក* ២ នីហ្វៃ ១:៣០.
២៤ *ក* ១ នីហ្វៃ ៣:១២, ១៩–២៤;
៥:១០–២២.
៣១ *ក* ម៉ូសាយ ៩:១៧; អាលម៉ា ៥៦:៥៦.
៣៣ *ក* ស.ប. សម្បថ.

ថាគាត់មិនត្រូវភ័យខ្លាចអ្វីឡើយ ថាគាត់នឹងបានរួចខ្លួនជាអ្នកសេរី ដូចយើង រាល់គ្នាដែរ បើគាត់ព្រមចុះទៅក្នុងទីរហោស្ថានជាមួយនឹងយើង ។

៣៤ ហើយខ្ញុំបាននិយាយទៅគាត់ទៀតថា៖ ជាប្រាកដមែន ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យយើងធ្វើកិច្ចការនេះ; ហើយតើយើងមិនខំព្យាយាមកាន់តាមព្រះបញ្ញត្តិទាំងឡាយ នៃព្រះអម្ចាស់ទេឬ ? ហេតុដូច្នេះហើយ បើសិនជាអ្នកព្រមចុះទៅក្នុងទីរហោស្ថាន ទៅឯឪពុកខ្ញុំ នោះអ្នក នឹងមានកន្លែងនៅជាមួយនឹងយើង ។

៣៥ ហើយហេតុការណ៍បានកើតឡើងថា សូរ៉ាំបានតាំងចិត្តក្លាហានឡើង ចំពោះពាក្យទាំងឡាយរបស់ខ្ញុំ ។ ឥឡូវនេះ សូរ៉ាំ គឺជា ឈ្មោះរបស់បាវបំរើនោះ ហើយគាត់បានសន្យាថានឹងចុះទៅក្នុងទីរហោស្ថាន ទៅឯឪពុកយើង ។ មែនហើយ គាត់ក៏បានស្បថស្បែជាមួយ នឹងយើង ថាគាត់នឹងនៅជាមួយនឹងយើង ចាប់ពីពេលនោះតទៅ ។

៣៦ ឥឡូវនេះ យើងមានបំណងចង់ឲ្យគាត់ នៅជាប់ជាមួយនឹងយើង ដើម្បីកុំឲ្យពួកសាសន៍យូដា ដឹងពីរឿងភៀសខ្លួនរបស់យើង ចូលក្នុងទីរហោស្ថាន ក្រែងគេនឹងលបតាមមកបំផ្លាញយើងចោល ។

៣៧ ហើយហេតុការណ៍បានកើតឡើងថា កាលសូរ៉ាំបានស្បថចំពោះយើងរួចស្រេចហើយ នោះសេចក្ដីខ្លាចទាំងប៉ុន្មានរបស់យើង ដែលមានចំពោះគាត់ ក៏បាត់អស់រលីងទៅ ។

៣៨ ហើយហេតុការណ៍បានកើតឡើងថា យើងបាននាំយកផ្ទាំងលង្ហិន និងបាវបំរើរបស់ឡាបាន់ ហើយចេញទៅក្នុងទីរហោស្ថាន ហើយបានធ្វើដំណើរទៅឯត្រសាលឪពុកយើង ៕

## ជំពូកទី ៥

*សារ៉ាយត្អូញត្អែរទាស់នឹងលីហៃ — អ្នកទាំងពីរត្រេកអរនៅពេលឃើញកូនៗទាំងអស់ត្រឡប់មកវិញ — ពួកគេថ្វាយយញ្ញបូជាទាំងឡាយ — ផ្ទាំងលង្ហិនមានពាក្យសរសេររបស់លោកម៉ូសេ និងពួកព្យាការី — ផ្ទាំងទាំងនោះបង្ហាញថាលីហៃជាពូជនៃយ៉ូសែប — លីហៃព្យាករអំពី ពូជលោក និងអំពីការរក្សានូវផ្ទាំងទាំងឡាយ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា កាលយើងបានចុះមកក្នុងទីរហោស្ថាន មកឯឪពុកយើងហើយ មើលចុះ លោកបានពោរពេញ ទៅដោយសេចក្ដីអំណរ ឯម្ដាយខ្ញុំ សារ៉ាយ ក៏មានសេចក្ដីរីករាយជាខ្លាំងដែរ ត្បិតនាងពិតជាមានទុក្ខសោកពីព្រោះតែពួកយើង ។

២ ត្បិតនាងបានគិតស្មានថា យើងបានវិនាសនៅក្នុងទីរហោស្ថានទៅហើយ ហើយនាងក៏បានពោលពាក្យត្អូញត្អែរទាស់ នឹងឪពុកខ្ញុំថា ឪពុកខ្ញុំ ជាអ្នកប្រកបដោយការនិមិត្តដោយថា៖ មើលចុះ លោកបាននាំយើងរាល់គ្នាចាកចេញចោលដែនដីនៃកេរ្តិ៍អាករ របស់យើង ហើយកូនប្រុសទាំងឡាយរបស់ខ្ញុំ ក៏ទៅបាត់អស់ទៀត ហើយយើងនឹងត្រូវវិនាសនៅក្នុងទីរហោស្ថាន ។

៣ ហើយតាមពាក្យបែបនេះហើយ ដែលម្ដាយខ្ញុំបានពោលពាក្យត្អូញត្អែរទាស់នឹងឪពុកខ្ញុំ ។

៤ ហើយហេតុការណ៍បានកើតឡើងថា ឪពុកខ្ញុំបាននិយាយទៅម្ដាយខ្ញុំថា៖ ខ្ញុំដឹងហើយថា ខ្ញុំជាមនុស្សប្រកបដោយការនិមិត្ត; ត្បិតបើខ្ញុំ មិនបានឃើញរឿងទាំងឡាយនៃព្រះ នៅក្នុងការនិមិត្តទេ នោះខ្ញុំក៏មិនអាចដឹងនូវសេចក្ដីល្អសប្បុរសនៃព្រះបានដែរ ប៉ុន្តែបើនៅក្នុងក្រុង យេរូសាឡិមតទៅទៀត ច្បាស់ជាត្រូវវិនាសទៅជាមួយនឹងបងប្អូនខ្ញុំហើយ ។

៥ ប៉ុន្តែមើលចុះ ខ្ញុំបានទទួលដែនដីសន្យាហើយ ការណ៍នេះធ្វើឲ្យខ្ញុំរីករាយណាស់; មែនហើយ ហើយខ្ញុំដឹងថា ព្រះអម្ចាស់ទ្រង់ នឹងរំដោះកូនប្រុសខ្ញុំទាំងឡាយ ឲ្យបានរួចផុតពីកណ្ដាប់ដៃឡាបាន់ ហើយនាំពួកគេចុះមកក្នុងទីរហោស្ថានវិញ ។

៦ ហើយដោយពោលពាក្យបែបនេះហើយ ដែលឪពុកខ្ញុំ លីហៃបានកំសាន្តចិត្តម្ដាយខ្ញុំ សារ៉ាយ ពីរឿងយើង កាលដែលយើងធ្វើ ដំណើរក្នុងទីរហោស្ថាន ឡើងទៅឯដែនដីយេរូសាឡិមដើម្បីទៅយកបញ្ជីនៃពួកសាសន៍យូដា ។

៧ ហើយកាលយើងបានត្រឡប់មកដល់ត្រសាលឪពុកខ្ញុំវិញ មើលចុះ ឪពុកម្ដាយខ្ញុំពោរពេញទៅដោយសេចក្ដីអំណរ ហើយម្ដាយ ខ្ញុំក៏បានកំសាន្តចិត្តដែរ ។

៣៤ *ក* ១ នីហ្វៃ ២:២; ៣:១៦.
៣៥ *ក* ១ នីហ្វៃ ១៦:៧; ២ នីហ្វៃ ៥:៥–៦.
ស.ប. សូរ៉ាំ, ពួកសាសន៍សូរ៉ាំ.
៣៧ *ក* យ៉ូស្វេ ៩:១–២១; សាស្ដា ៥:៤.
ស.ប. សម្បថ.
**៥** ១ *ក* ស.ប. សារ៉ាយ.
៤ *ក* ១ នីហ្វៃ ២:១១.
*ខ* ១ នីហ្វៃ ១:៨–១៣.
ស.ប. ការនិមិត្ត.
៥ *ក* ១ នីហ្វៃ ២:២០; ១៨:៨, ២២–២៣.
ស.ប. ដែនដីសន្យា.
*ខ* ស.ប. សេចក្ដីជំនឿ.

៨ ហើយម្ដាយខ្ញុំបានពោលថា៖ ឥឡូវនេះ ខ្ញុំដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់បានបញ្ជាប្ដីខ្ញុំ ឲ្យភៀសខ្លួនចូលក្នុងទីរហោស្ថាន; មែនហើយ ខ្ញុំក៏ដឹងដោយប្រាកដថា ព្រះអម្ចាស់ទ្រង់បានការពារកូនប្រុសទាំងឡាយរបស់ខ្ញុំដែរ ហើយបានរំដោះពួកគេឲ្យរួចផុតពីកណ្ដាប់ដៃ ឡាបាន់ ហើយបានប្រទានអំណាចដល់ពួកគេ ដើម្បីឲ្យពួកគេអាចសំរេចនូវកិច្ចការ ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាដល់ពួកគេ ។ ហើយតាមពាក្យបែបនេះហើយ ដែលម្ដាយខ្ញុំបាននិយាយ ។

៩ ហើយហេតុការណ៍បានកើតឡើងថា ឪពុកម្ដាយខ្ញុំសប្បាយរីករាយជាខ្លាំង ហើយបានថ្វាយយញ្ញបូជា ហើយថ្វាយដង្វាយដុតទាំង ឡាយដល់ព្រះអម្ចាស់ ហើយលោកទាំងពីរ បានថ្លែងអំណរគុណដល់ព្រះនៃអ៊ីស្រាអែល ។

១០ ហើយបន្ទាប់ពីលោកបានថ្លែងអំណរគុណ ដល់ព្រះនៃអ៊ីស្រាអែលហើយ នោះឪពុកខ្ញុំ លីហៃ បានយកបញ្ជីទាំងប៉ុន្មាន ដែលបានឆ្លាក់នៅលើផ្ទាំងលង្ហិន ហើយលោកបានពិចារណាមើលពីដើមឃ្លាមក ។

១១ ហើយលោកបានឃើញថា ផ្ទាំងទាំងនេះមានគម្ពីរនៃលោកម៉ូសេប្រាំច្បាប់ ដែលមានដំណើររឿង អំពីដើមកំណើតលោកិយ និងអំពីលោកអ័ដាម និងនាងអេវ៉ា ដែលជាឪពុកម្ដាយដើមបង្អស់របស់យើង ។

១២ ហើយមានបញ្ជីរបស់ពួកសាសន៍យូដាដែរ តាំងពីដើមរហូតមកដល់ការចាប់ផ្ដើមរជ្ជកាលនៃសេដេគា ជាស្ដេចស្រុកយូដា;

១៣ ហើយព្រមទាំងពាក្យព្យាករណ៍ទាំងឡាយរបស់ពួកព្យាការីដ៏បរិសុទ្ធ ចាប់ពីដើមរហូតមកដល់ការចាប់ផ្ដើមរជ្ជកាលនៃសេដេគា; ហើយព្រមទាំងពាក្យព្យាករណ៍ទាំងឡាយ ដែលបានពោលដោយមាត់លោកយេរេមា ។

១៤ ហើយហេតុការណ៍បានកើតឡើងថា ឪពុកខ្ញុំ លីហៃ បានរកឃើញនៅលើផ្ទាំងលង្ហិននេះ នូវពង្សាវតាររបស់ពួកអយ្យកោលោក; ហេតុដូច្នោះហើយ ទើបលោកដឹងថា លោកត្រូវជាពូជពង្សរបស់យ៉ូសែប មែនហើយ គឺយ៉ូសែប ត្រូវជាកូនប្រុសរបស់យ៉ាកុប ដែលបាន លក់ទៅដែនដីអេស៊ីព្ទ ហើយគឺជាអ្នកដែលត្រូវបានថែរក្សាទុក ដោយព្រះហស្តនៃព្រះអម្ចាស់ ដើម្បីឲ្យគាត់អាចថែរក្សាឪពុកគាត់ គឺយ៉ាកុប និងគ្រួសារលោកទាំងមូល កុំឲ្យវិនាសបង់ទៅដោយអំណត់អត់ ។

១៥ ហើយពួកគេបានត្រូវនាំចេញពីការជាប់ឃុំឃាំង ហើយចេញពីដែនដីអេស៊ីព្ទ ដោយព្រះដដែល ជាព្រះដែលបានថែរក្សាពួកគេ ទុក ។

១៦ ហើយដោយដូច្នេះហើយ ទើបឪពុកខ្ញុំ លីហៃ បានរកឃើញនូវពង្សាវតាររបស់ពួកអយ្យកោលោក ។ រីឯឡាបាន់ក៏ត្រូវជាពូជពង្ស របស់យ៉ូសែបដែរ ហេតុដូច្នោះហើយ គាត់និងពួកអយ្យកោគាត់ បានកត់បញ្ជីទាំងនេះ ។

១៧ ហើយឥឡូវនេះ កាលឪពុកខ្ញុំបានដឹងរឿងទាំងអស់នេះ លោកក៏ពោរពេញទៅដោយព្រះវិញ្ញាណ ហើយក៏ចាប់ផ្ដើមព្យាករ អំពីពូជលោក ។

១៨ ថាផ្ទាំងលង្ហិនទាំងនេះ នឹងបានចេញផ្សព្វផ្សាយដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ដែលជាពូជរបស់លោក ។

១៩ ហេតុដូច្នោះហើយ លោកមានប្រសាសន៍ថា ផ្ទាំងលង្ហិនទាំងនេះ មិនត្រូវវិនាសបង់ឡើយ; ហើយក៏មិនត្រូវស្រអាប់តទៅទៀត តាមពេលវេលាឡើយ ។ ហើយលោកបានព្យាកររឿងជាច្រើន ដែលទាក់ទងទៅនឹងពូជរបស់លោក ។

២០ ហើយហេតុការណ៍បានកើតឡើងថា រហូតមក

៨ *ក* ១ នីហ្វៃ ២:២.
*ខ* ១ នីហ្វៃ ៣:៧.
៩ *ក* ម៉ូសាយ ២:៣;
៣ នីហ្វៃ ៩:១៩–២០.
ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
១០ *ក* ១ នីហ្វៃ ៤:២៤, ៣៨; ១៣:២៣.
ស.ប. ផ្ទាំងលង្ហិន.
១១ *ក* ១ នីហ្វៃ ១៩:២៣.
ស.ប. គម្ពីរ៥ច្បាប់.
១២ *ក* ១ របា. ៩:១.
ស.ប. បទព្រះគម្ពីរ.
១៣ *ក* ២ ពង្សាវ. ២៤:១៨;
យេរេ. ៣៧:១.
*ខ* អែសរ៉ា ១:១;
យេរេ. ៣៦:១៧–៣២;
១ នីហ្វៃ ៧:១៤; ហេលេ. ៨:២០.
១៤ *ក* ១ នីហ្វៃ ៣:៣, ១២.
ស.ប. ផ្ទាំងលង្ហិន.
*ខ* ២ នីហ្វៃ ៣:៤; អាលម៉ា ១០:៣.
ស.ប. យ៉ូសែប, កូនប្រុសរបស់
យ៉ាកុប.
*គ* ស.ប. យ៉ាកុប, កូនប្រុសរបស់
អ៊ីសាក.
*ឃ* លោកុ. ៣៧:២៩–៣៦.
*ង* លោកុ. ៤៥:៤–៥.
១៥ *ក* និក្ខ. ១៣:១៧–១៨;
អេម៉ុស ៣:១–២;
១ នីហ្វៃ ១៧:២៣–៣១;
គ. និង ស. ១០៣:១៦–១៨;
១៣៦:២២.
១៦ *ក* ១ នីហ្វៃ ៦:២.
១៩ *ក* អាលម៉ា ៣៧:៤–៥.

ដល់ពេលនេះ ខ្ញុំ និងឪពុកខ្ញុំបានកាន់តាមព្រះបញ្ញត្តិទាំងឡាយ
ដូចដែលព្រះ អម្ចាស់ ទ្រង់បានបញ្ជាយើង ។
២១ ហើយយើងបានបញ្ជីទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់
បានបញ្ជាយើង ហើយបានពិចារណាមើល ហើយរកឃើញថា
បញ្ជីប្រវត្តិ ទាំងនេះគឺគួរឲ្យចង់បាន; មែនហើយ ព្រមទាំង
មានប្រយោជន៍ជាអតិបរមា ចំពោះយើង ដរាបដល់
យើងនឹងអាចថែរក្សានូវព្រះ បញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់
ទុកដល់កូនចៅយើង ។
២២ ហេតុដូច្នោះហើយ គឺជាប្រាជ្ញានៃព្រះអម្ចាស់
ថាយើងគប្បីយកបញ្ជីប្រវត្តិនេះទៅជាមួយនឹងយើង នៅពេល
ដែលយើងធ្វើ ដំណើរក្នុងទីរហោស្ថាន ទៅឯដែនដីសន្យា ៕

ជំពូកទី ៦

*នីហ្វៃសរសេរកិច្ចការទាំងឡាយនៃព្រះ — គោលបំណង របស់នីហ្វៃ គឺទៅបញ្ចុះបញ្ចូលមនុស្ស ឲ្យមករកព្រះនៃអ័ប្រាហាំ ហើយបាន សង្គ្រោះ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ មិនរៀបរាប់អំពីពង្សាវតាររបស់ពួក
អយ្យកោខ្ញុំ នៅក្នុង ផ្នែកនៃបញ្ជីរបស់ខ្ញុំទេ; ក៏ដូចជានៅក្នុងពេល
ក្រោយៗដែរ ដែលខ្ញុំនឹងមិនរៀបរាប់អំពីពង្សាវតារ
នៅលើផ្ទាំងទាំងឡាយ ដែលខ្ញុំកំពុងសរសេរនេះឡើយ; ត្បិត
ពង្សាវតារ នោះមាននៅក្នុងបញ្ជី ដែលបានកត់ដោយឪពុក
ខ្ញុំហើយ; ហេតុដូច្នោះហើយ ខ្ញុំមិនសរសេរពីពង្សាវតារ
នោះ ក្នុងបញ្ជីនេះឡើយ ។
២ ត្បិតល្មមហើយ ដែលខ្ញុំគ្រាន់តែនិយាយថា យើងជា
ពូជពង្សទាំងឡាយរបស់យ៉ូសែបប៉ុណ្ណោះ ។
៣ ហើយវាមិនជាសំខាន់អ្វីដល់ខ្ញុំទេ ដែលខ្ញុំត្រូវរៀបរាប់
ជាពិសេស អំពីដំណើររឿងទាំងអស់របស់ឪពុកខ្ញុំ ត្បិតរឿង
ទាំងនោះ មិនអាចយកមកសរសេរ នៅក្នុងផ្ទាំងទាំងនេះ
បានឡើយ ព្រោះខ្ញុំចង់ទុកចន្លោះ សំរាប់សរសេរនូវរឿងទាំង
ឡាយនៃព្រះវិញ ។
៤ ត្បិតភាពពោរពេញនៃចេតនារបស់ខ្ញុំ គឺដើម្បីឲ្យខ្ញុំអាច
បញ្ចុះបញ្ចូលមនុស្ស ឲ្យមករកព្រះនៃអ័ប្រាហាំ និងព្រះនៃអ៊ីសាក
និងព្រះនៃ យ៉ាកុប ហើយបានសង្គ្រោះ ។
៥ ហេតុដូច្នោះហើយ អ្វីៗដែលផ្គាប់ចិត្តដល់មនុស្សលោក
នោះខ្ញុំមិនសរសេរទេ ប៉ុន្តែខ្ញុំសរសេរអំពីអ្វីៗដែលសព្វព្រះហឫទ័យ
ដល់ព្រះ ហើយគាប់ចិត្តដល់អស់អ្នកណា ដែលមិនមែនជា
របស់ផងលោកិយនោះវិញ ។
៦ ហេតុដូច្នោះហើយ ខ្ញុំនឹងបញ្ជាដល់ពូជរបស់ខ្ញុំ ថាពួកគេ
មិនត្រូវឆ្លាក់នៅលើផ្ទាំងទាំងនេះ នូវអ្វីៗដែលគ្មានប្រយោជន៍
ដល់កូនចៅមនុស្សឡើយ ៕

ជំពូកទី ៧

*កូនប្រុសទាំងឡាយរបស់លីហៃ វិលត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ ហើយបបួលអ៊ីសម៉ាអែល ព្រមទាំងគ្រួសារលោក ឲ្យរួមដំណើរ ជាមួយនឹងពួកគេ — លេមិន និងអ្នកឯទៀតបះបោរ — នីហ្វៃទូន្មានដល់ បងៗរបស់លោក ឲ្យមានសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់ — ពួកគេយកខ្សែចងលោក ហើយធ្វើគំរោងការសំរាប់សេចក្ដីបំផ្លិចបំផ្លាញរូបលោកចោល — លោកត្រូវបានរួចពីចំណង ដោយអំណាចនៃសេចក្ដីជំនឿ — បងៗរបស់លោកសុំការអភ័យទោស — លីហៃ និងក្រុមលោកបានថ្វាយយញ្ញបូជា ហើយថ្វាយដង្វាយ ដុតទាំងឡាយដល់ព្រះ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា បន្ទាប់ពីឪពុកខ្ញុំ
លីហៃ បានបញ្ចប់ការព្យាករណ៍អំពីពូជលោកហើយ
នោះហេតុការណ៍បាន កើតឡើងថា ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលមកលោកទៀតថា ការណ៍ដែលលោក គឺលីហៃ ត្រូវនាំ
គ្រួសារចូលក្នុងទីរហោស្ថាន តែឯង យ៉ាងនេះ មិនសមរម្យទេ;
ប៉ុន្តែថាកូនប្រុសទាំងឡាយរបស់លោក ត្រូវយកប្រពន្ធ ដើម្បី
នឹងអាចបន្តពូជថ្វាយព្រះអម្ចាស់ នៅឯដែនដី សន្យា ។

២១ *ក* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ខ* ២ នីហ្វៃ ២៥:២៦.
៦ ១*ក* ២ នីហ្វៃ ៤:១៤–១៥.
*ខ* ១ នីហ្វៃ ៩:២.
*គ* ១ នីហ្វៃ ១:១៦–១៧; ១៩:១–៦.
២ *ក* ១ នីហ្វៃ ៥:១៤–១៦.
៣ *ក* យ៉ាកុប ៧:២៧; យ៉ារ៉ុម ១:២, ១៤; អោមណៃ ១:៣០.
៤ *ក* យ៉ូហាន ២០:៣០–៣១.
សូមមើលទំព័រចំណងជើងនៃព្រះគម្ពីរមរមន.
*ខ* ២ នីហ្វៃ ៩:៤១, ៤៥, ៥១.
៥ *ក* ១ ថែស្សា. ២:៤; ព. នៃ ម. ១:៤.
**៧** ១*ក* ១ នីហ្វៃ ៥:១៧–១៩.
*ខ* ១ នីហ្វៃ ១៦:៧.
*គ* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍.

២ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់[ក]បានបញ្ជាទៅឪពុកខ្ញុំថា ខ្ញុំ នីហ្វៃ និងបងប្រុសទាំងឡាយរបស់ខ្ញុំ ត្រូវត្រឡប់ ទៅឯដែនដីយេរូសាឡិមម្ដងទៀត ហើយនាំអ៊ីសម៉ាអែល និងគ្រួសារលោក ចុះមកក្នុងទីរហោស្ថាន ។

៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ និងបងប្រុសទាំងឡាយរបស់ខ្ញុំ បានធ្វើដំណើរកាត់ទីរហោស្ថានឡើងទៅឯក្រុង យេរូសាឡិម[ក]ម្ដងទៀត ។

៤ ហើយហេតុការណ៍បានកើតឡើងថា យើងបានឡើងទៅដល់ផ្ទះអ៊ីសម៉ាអែល ហើយយើងបានទទួលការប្រោសប្រណីនៅក្នុង ភ្នែកនៃអ៊ីសម៉ាអែល ដរាបដល់យើងបានជំរាបលោក នូវព្រះបន្ទូលទាំងឡាយនៃព្រះអម្ចាស់ ។

៥ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានបង្ទន់ចិត្តអ៊ីសម៉ាអែល ហើយព្រមទាំងគ្រួសារលោកផង ដរាបដល់គេ ព្រមធ្វើដំណើរជាមួយនឹងយើង ចុះមកក្នុងទីរហោស្ថានមកកាន់ត្រសាលរបស់ឪពុកខ្ញុំ ។

៦ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលយើងធ្វើដំណើរក្នុងទីរហោស្ថាន មើលចុះ លេមិន និងលេមយ៉ួលហើយព្រម ទាំងកូនស្រីអ៊ីសម៉ាអែលពីរនាក់ និង[ក]កូនប្រុសពីរនាក់របស់អ៊ីសម៉ាអែល ព្រមទាំងគ្រួសារគេទាំងឡាយ បានបះបោរទាស់នឹងយើង; មែនហើយ ទាស់នឹងខ្ញុំ នីហ្វៃ និងសាំនិងឪពុកគេ អ៊ីសម៉ាអែល ព្រមទាំងប្រពន្ធលោក ហើយនឹងកូនស្រីលោកបីនាក់ទៀតផង ។

៧ ហើយហេតុការណ៍បានកើតឡើងថា ក្នុងការបះបោរលើកនេះ គឺមកពីគេមានបំណងចង់ត្រឡប់ទៅឯដែនដីយេរូសាឡិមវិញ ។

៨ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ [ក]ព្រួយចិត្តចំពោះភាពរឹងរូសនៃចិត្តរបស់ពួកគេ ហេតុដូច្នេះហើយ ខ្ញុំបាននិយាយទៅពួកគេ មែនហើយ គឺទៅលេមិន និងលេមយ៉ួលថា៖ មើលចុះ បងទាំងពីរនាក់ គឺជាបងប្រុសរបស់ខ្ញុំ ហើយចុះហេតុអ្វីបានជាចិត្តបងៗមានចិត្តរឹងរូស ហើយមានគំនិតងងឹតងងល់ម្លេះ ចាំបាច់ឲ្យខ្ញុំដែលជាប្អូន ត្រូវនិយាយទៅកាន់បងៗ មែនហើយ ហើយធ្វើជាគំរូដល់ពួកបងទៅវិញ ?

៩ ចុះហេតុអ្វីបានជាបងៗ មិនប្រុងស្ដាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ ?

១០ ចុះហេតុអ្វីបានជាបងៗ[ក]ភ្លេចថា បងៗបានឃើញទេវតានៃព្រះអម្ចាស់ ?

១១ មែនហើយ ចុះហេតុអ្វីបានជាបងៗ ភ្លេចពីរឿងដ៏គួរអស្ចារ្យទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើដើម្បីយើង នៅក្នុងការ[ក]រំដោះយើងឲ្យរួចផុតពីកណ្ដាប់ដៃឡាបាន់ ហើយជួយយើងឲ្យយកបានបញ្ជីទៀតផង ?

១២ មែនហើយ ចុះហេតុអ្វីបានជាបងរាល់គ្នាភ្លេចថា ព្រះអម្ចាស់ទ្រង់អាចធ្វើ[ក]នូវអ្វីៗគ្រប់យ៉ាង ទៅតាម[ខ]ព្រះ ហឫទ័យទ្រង់ ដើម្បីកូន ចៅមនុស្ស ប្រសិនបើគេអនុវត្តសេចក្ដីជំនឿជឿដល់ព្រះអង្គ ? ហេតុដូច្នោះហើយ ចូរយើងមានចិត្តស្មោះត្រង់ចំពោះទ្រង់ចុះ ។

១៣ ហើយបើយើងមានចិត្តស្មោះត្រង់ចំពោះព្រះអង្គមែន នោះយើងនឹងបានទទួល[ក]ដែនដីសន្យា; ហើយបងរាល់គ្នានឹងដឹងថា នៅ ក្នុងរយៈពេលខាងមុខនេះ ព្រះបន្ទូលនៃព្រះអម្ចាស់នឹងបានសំរេច [ខ]អំពីសេចក្ដីបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម; ត្បិតរឿងទាំងអស់ ដែល ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល អំពីសេចក្ដីបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម នោះនឹងត្រូវបានសំរេច ។

១៤ ត្បិតមើលចុះ ព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់បានឈប់តស៊ូជាមួយនឹងពួកគេហើយ; ត្បិតមើលចុះ [ក]ពួកគេបាន[ខ]បោះបង់ចោល ពួកព្យាការី ព្រមទាំងលោកយេរេមា ក៏ត្រូវពួកគេចាប់ដាក់គុក ។ ហើយពួកគេបានព្យាយាម[គ]រកផ្ដាច់ជីវិតរបស់ឪពុកខ្ញុំទៀត រហូតដល់ គេបានបណ្ដេញលោកចេញពីដែនដី ។

១៥ ឥឡូវនេះ មើលចុះ ខ្ញុំប្រាប់បងរាល់គ្នាថា បើសិនជាបងរាល់គ្នាត្រឡប់ទៅឯក្រុងយេរូសាឡិមវិញ នោះបងរាល់គ្នានឹងត្រូវវិនាស ដូចពួកគេផងដែរ ។ ហើយឥឡូវនេះ បើសិនជាបងរាល់

២ *ក* ១ នីហ្វៃ ១៦:៧–៨.
៣ *ក* ១ នីហ្វៃ ៣:២–៣.
៦ *ក* ២ នីហ្វៃ ៤:១០.
៨ *ក* អាលម៉ា ៣១:២; ម៉ូសេ ៧:៤១.
១០ *ក* ចោទិ. ៤:៩; ១ នីហ្វៃ ៣:២៩; ៤:៣.
១១ *ក* ១ នីហ្វៃ ៤.
១២ *ក* ១ នីហ្វៃ ១៧:៥០; អាលម៉ា ២៦:១២.
*ខ* ១ នីហ្វៃ ៣:៧; ១៥:១១.
១៣ *ក* ១ នីហ្វៃ ២:២០. ស.ប. ដែនដីសន្យា.
*ខ* ២ ពង្សាវ. ២៥:១–២១; ២ នីហ្វៃ ៦:៨; ២៥:១០; អោមណៃ ១:១៥; ហេលេ. ៨:២០–២១.
១៤ *ក* អេសេ. ៥:៦; ១ នីហ្វៃ ១:១៨–២០; ២:១៣. ស.ប. ការបះបោរ.
*ខ* យេរេ. ៣៧:១៥–២១.
*គ* ១ នីហ្វៃ ២:១.

គ្នាដាច់ចិត្ត ចូរឡើងទៅឯដែនដីនោះ ហើយចូរចាំនូវពាក្យទាំង ឡាយ ដែលខ្ញុំបានពោលដល់បងរាល់គ្នានេះថា បើសិនជាបងទៅមែន នោះបងនឹងវិនាសបង់; ត្បិតព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់បានបង្គាប់ឲ្យខ្ញុំនិយាយបែបដូច្នេះ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា កាលខ្ញុំ នីហ្វៃ បានពោលពាក្យទាំងនេះ ទៅកាន់បងៗរបស់ ខ្ញុំហើយ នោះពួកគេក៏ខឹង នឹងខ្ញុំ ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានដាក់ដៃមកលើខ្ញុំ ត្បិតមើលចុះ ពួកគេខឹងជាខ្លាំង ហើយពួកគេបាន[ក]ចងខ្ញុំដោយ ខ្សែពួរ ព្រោះពួកគេបានព្យាយាមរកផ្ដាច់ជីវិតខ្ញុំ ដើម្បីពួកគេអាចទុកខ្ញុំចោលនៅក្នុងទីរហោស្ថានឲ្យសត្វសាហាវស៊ី ។

១៧ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា ខ្ញុំបានអធិស្ឋានដល់ព្រះអម្ចាស់ថា៖ ឱ ព្រះអម្ចាស់អើយ ស្របតាមសេចក្ដីជំនឿរបស់ទូលបង្គំ ដែលមានចំពោះទ្រង់ សូមព្រះអង្គរំដោះទូលបង្គំឲ្យរួចផុត ពីកណ្ដាប់ដៃបងៗទូលបង្គំផង; ព្រះ[ក]ពរ សូមប្រទានកម្លាំងដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចផ្ដាច់ខ្សែ ដែលចងទូលបង្គំនេះបាន ។

១៨ ហើយហេតុការណ៍បានកើតឡើងថា កាលខ្ញុំបានពោលនូវពាក្យទាំងនេះហើយ មើលចុះ ខ្សែទាំងនោះក៏របូតចេញពីដៃ និងពីជើងខ្ញុំទៅ ហើយខ្ញុំក៏ឈរនៅពីមុខបងៗខ្ញុំ ហើយខ្ញុំបានពោលទៅគេទៀត ។

១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេក៏ខឹងនឹងខ្ញុំទៀត ហើយព្យាយាមដាក់ដៃមកលើខ្ញុំ; ប៉ុន្តែមើលចុះ [ក]កូនស្រីអ៊ីសម៉ាអែល ម្នាក់ មែនហើយ និងម្ដាយនាងផង និងកូនប្រុសអ៊ីសម៉ាអែលម្នាក់ បានសូមអង្វរបងៗខ្ញុំ ដរាបដល់ពួកគេបានបង្អន់ចិត្តបងៗខ្ញុំ; ហើយពួក គេក៏ឈប់ខិតខំរកផ្ដាច់ជីវិតខ្ញុំទៅ ។

២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេមានចិត្តសោកស្ដាយ មកពីអំពើទុច្ចរិតរបស់គេ ដរាបដល់គេបានក្រាបចុះចំពោះ មុខខ្ញុំ ហើយអង្វរឲ្យខ្ញុំអភ័យទោសពួកគេចំពោះអំពើដែលគេបានប្រព្រឹត្តទាស់នឹងខ្ញុំ ។

២១ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាន[ក]អភ័យទោសដល់ពួកគេ ដោយស្មោះអស់ពីចិត្ត នូវអ្វីៗដែលពួកគេបានប្រព្រឹត្ត ហើយខ្ញុំបានទូន្មានពួកគេឲ្យអធិស្ឋានដល់ព្រះអម្ចាស់ ជាព្រះរបស់ពួកគេ សូមក្ដីអភ័យទោស ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើដូច្នោះ ។ ហើយបន្ទាប់ពីគេបានអធិស្ឋានដល់ព្រះអម្ចាស់ហើយ នោះយើងក៏បានបន្តដំណើរ សំដៅទៅត្រសាលរបស់ ឪពុកខ្ញុំវិញ ។

២២ ហើយហេតុការណ៍បានកើតឡើងថា យើងបានចុះមកដល់ត្រសាលឪពុកយើងវិញ ។ ហើយបន្ទាប់ពីខ្ញុំ និងបងៗខ្ញុំ ហើយនឹង គ្រួសារអ៊ីសម៉ាអែលទាំងមូល បានចុះមកដល់ត្រសាលឪពុកខ្ញុំហើយ នោះពួកគេបាន[ក]ថ្លែងអំណរគុណដល់ព្រះអម្ចាស់ជាព្រះរបស់ពួកគេ; ហើយពួកគេបាន[ខ]ថ្វាយយញ្ញបូជាហើយថ្វាយដង្វាយដុតទាំងឡាយ ដល់ព្រះអង្គផង ៕

## ជំពូកទី ៨

*លីហៃឃើញការនិមិត្តមួយអំពីដើមជីវិត — លោកទទួលទានផ្លែនៃដើមជីវិត ហើយមានបំណងចង់ឲ្យគ្រួសារលោកទទួលទានផ្លែឈើ នោះដែរ — លោកឃើញដំបងដែក និងផ្លូវតូចហើយចង្អៀត ហើយនឹងអ័ព្ទនៃសេចក្ដីងងឹតដែលបិទបាំងមនុស្សទាំងឡាយ — សារ៉ាយ នីហ្វៃ និងសាំ ទទួលទានផ្លែឈើនោះ ប៉ុន្តែលេមិន និងលេមយួល មិនព្រមឡើយ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា យើងបានប្រមូលគ្រាប់ពូជផ្សេងៗគ្រប់មុខ ព្រមទាំងគ្រាប់ធញ្ញជាតិគ្រប់មុខ និងគ្រាប់ផ្លែឈើ គ្រប់មុខដែរ ។

២ ហើយហេតុការណ៍បានកើតឡើងថា កាលឪពុកខ្ញុំនៅក្នុងទីរហោស្ថាន នោះលោកបាននិយាយមកយើងថា៖ មើលចុះ ឪពុកបាន[ក]យល់សប្ដិ ឬពាក្យម្យ៉ាងទៀតថា ឪពុកបានឃើញ[ខ]ការនិមិត្តមួយ ។

៣ ហើយមើលចុះ ដោយសារការណ៍ដែលឪពុកបានឃើញ គឺជាហេតុដែលនាំឲ្យឪពុកមានសេចក្ដីត្រេកអរីករាយក្នុងព្រះអម្ចាស់ ពីព្រោះតែ[ក]នីហ្វៃ ហើយព្រមទាំងសាំផង; ត្បិតឪពុកមានហេតុដល់សន្និដ្ឋានថា ពួកគេ ហើយព្រមទាំងពូជរបស់ពួកគេជាច្រើននឹងបាន សង្គ្រោះដែរ ។

---

១៦ *ក* ១ នីហ្វៃ ១៨:១១–១៥.
១៧ *ក* អាលម៉ា ១៤:២៦–២៨.
១៩ *ក* ១ នីហ្វៃ ១៦:៧.
២១ *ក* ស.ប. អត់ទោស, អភ័យទោស.
២២ *ក* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
*ខ* ១ នីហ្វៃ ៥:៩.
**៨** ២ *ក* ស.ប. សប្ដិ; វិវរណៈ.
*ខ* ១ នីហ្វៃ ១០:១៧. ស.ប. ការនិមិត្ត.
៣ *ក* ១ នីហ្វៃ ៨:១៤–១៨.

៤ ប៉ុន្តែមើលចុះ [ក]លេមិន និងលេមយ្យូល ឪពុកភ័យខ្លាចជាខ្លាំង ពីព្រោះតែកូន; ត្បិតមើលចុះ ឪពុកគិតថា ឪពុកបានដេកយល់សប្តិ ឃើញទីរហោស្ថានដ៏ងងឹត និងអាប់អួរមួយ នៅក្នុងសុបិនរបស់ឪពុក ។

៥ ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានឃើញបុរសម្នាក់ ហើយបុរសនោះ[ក]ស្លៀកពាក់អាវពណ៌ស ហើយបុរសនោះមក ឈរនៅចំពោះមុខឪពុក ។

៦ ហើយហេតុការណ៍បានកើតឡើងថា បុរសនោះមានប្រសាសន៍មកឪពុក ហើយប្រាប់ឲ្យឪពុកទៅតាមលោក ។

៧ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលឪពុកទៅតាមបុរសនោះ នោះឪពុកបានឃើញថា ខ្លួនឪពុកនៅក្នុងទីចោល ស្ងាត់មួយដ៏ងងឹត ហើយអាប់អួរ ។

៨ ហើយបន្ទាប់ពីឪពុកបានធ្វើដំណើរអស់រយៈពេលជាច្រើនម៉ោងនៅក្នុងសេចក្ដីងងឹត នោះឪពុកក៏ចាប់ផ្តើមអធិស្ឋានដល់ព្រះអម្ចាស់ សូមឲ្យទ្រង់មាន[ក]សេចក្ដីមេត្តាករុណាដល់ឪពុក តាមសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ឥតគណនារបស់ទ្រង់ ។

៩ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឪពុកបានអធិស្ឋានដល់ព្រះអម្ចាស់ហើយ នោះឪពុកក៏បានឃើញ[ក]ទីវាលដ៏ធំ ហើយ ទូលាយមួយ ។

១០ ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានឃើញ[ក]ដើមឈើមួយ ដែលមាន[ខ]ផ្លែដ៏គួរធ្វើឲ្យមនុស្សសប្បាយរីករាយ ។

១១ ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានដើរចូលទៅបេះ[ក]ផ្លែឈើនោះ ហើយទទួលទាន ហើយឪពុកឃើញថាវាមានរស់ ជាតិផ្អែមបំផុត គឺផ្អែមជាងអ្វីៗ ដែលឪពុកធ្លាប់បានភ្លក់ពីមុនមក ។ មែនហើយ ហើយឪពុកបានឃើញថា ផ្លែឈើនោះមានពណ៌[ខ]ស គឺស ជាងអ្វីទាំងអស់ ដែលឪពុកធ្លាប់បានឃើញមក ។

១២ ហើយកាលឪពុកបានទទួលទានផ្លែ[ក]ឈើនោះហើយ នោះព្រលឹងវិញ្ញាណឪពុកក៏ពោរពេញទៅដោយសេចក្ដីអំណរជាអតិបរមា; ហេតុដូច្នោះហើយ ឪពុកក៏ចាប់ផ្តើមមាន[ខ]បំណងចង់ឲ្យគ្រួសារឪពុក ទទួលទាន[គ]ផ្លែឈើនោះដែរ; ត្បិតឪពុកដឹងថា ផ្លែឈើនោះ គួរឲ្យមានប្រាថ្នាជាងផ្លែឈើណាៗទាំងអស់ ។

១៣ ហើយកាលឪពុកចោលភ្នែកមើលជុំវិញខ្លួន [ក]ក្រែងឪពុកអាចឃើញគ្រួសារឪពុកដែរ នោះឪពុកក៏ឃើញទន្លេទឹកមួយ ទន្លេនោះ ហូរតាមបណ្ដោយ ហើយវានៅជិតដើមឈើ ដែលឪពុកបានទទួលទានផ្លែ ។

១៤ ហើយឪពុកសម្លឹងរកមើលថា តើទន្លេនោះមានប្រភពមកពីណា; ហើយឪពុកបានឃើញក្បាលទន្លេ នៅមិនឆ្ងាយប៉ុន្មានទេ; ហើយនៅឯក្បាលទន្លេនោះ ឪពុកបានឃើញម្ដាយកូន គឺសារ៉ាយ និងសាំ ហើយនឹងនីហ្វៃ; ហើយពួកគេឈរ ហាក់បីដូចជាគេមិនដឹងជានឹងទៅផ្លូវណាឡើយ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានបោយហៅពួកគេ; ហើយឪពុកព្រមទាំងបានស្រែកហៅពួកគេយ៉ាងខ្លាំងឲ្យមករកឪពុក ហើយទទួលទានផ្លែឈើ គឺផ្លែឈើដ៏គួរឲ្យប្រាថ្នាជាងផ្លែឈើណាៗទាំងអស់ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានមករកឪពុក ហើយបានទទួលទានផ្លែឈើនោះដែរ ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ឪពុកចង់ឲ្យលេមិន និងលេមយ្យូល មកទទួលទានផ្លែឈើនោះផង; ហេតុដូច្នោះហើយ ឪពុកបានសម្លឹងទៅក្បាលទន្លេ ក្រែងឪពុកអាចឃើញពួកគេទាំងពីរ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានឃើញគេទាំងពីរនាក់ ប៉ុន្តែពួកគេ[ក]មិនព្រមមករកឪពុក ហើយទទួលផ្លែឈើ នោះឡើយ ។

១៩ ហើយឪពុកបានឃើញ[ក]ដំបងដែកមួយ ហើយដំបងដែកនោះផ្ដេកបណ្ដោយតាមមាត់ទន្លេ ហើយតម្រង់ទៅឯដើមឈើដែលឪពុកឈរជិត ។

២០ ហើយឪពុកក៏បានឃើញ[ក]ផ្លូវមួយតូច ហើយចង្អៀត

៤ *ក* ១ នីហ្វៃ ៨:៣៥–៣៦.
៥ *ក* យ.ស.––ប្រវត្តិ ១:៣០–៣២.
៨ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៩ *ក* ម៉ាថាយ ១៣:៣៨.
១០ *ក* លោកុ. ២:៩; វិវរ. ២:៧; ២២:២; ១ នីហ្វៃ ១១:៤, ៨–២៥. ស.ប. ដើមជីវិត.
*ខ* អាលម៉ា ៣២:៤១–៤៣.
១១ *ក* អាលម៉ា ៥:៣៤.
*ខ* ១ នីហ្វៃ ១១:៨.
១២ *ក* ស.ប. សេចក្ដីអំណរ.
*ខ* អាលម៉ា ៣៦:២៤.
*គ* ១ នីហ្វៃ ១៥:៣៦.
១៣ *ក* ១ នីហ្វៃ ១២:១៦–១៨; ១៥:២៦–២៩.
១៨ *ក* ២ នីហ្វៃ ៥:២០–២៥.
១៩ *ក* ទំនុក. ២:៩; វិវរ. ១២:៥; ក.យ.ស., វិវរ. ១៩:១៥; ១ នីហ្វៃ ៨:៣០; ១១:២៥; ១៥:២៣–២៤.
២០ *ក* ម៉ាថាយ ៧:១៤; ២ នីហ្វៃ ៣១:១៧–២០.

ដែលនៅបណ្តោយតាមដំបងដែក តម្រង់ទៅឯដើមឈើ
ដែលឪពុកឈរជិត; ហើយផ្លូវនោះរត់តាមក្បាលប្រភព ទៅ
ដល់ទីវាលដ៏ធំ ហើយទូលាយមួយ ប្រៀបដូចជាលោកិយ ។
២១ ហើយឪពុកបានឃើញក្រុមមនុស្សជាច្រើនឥតគណនា
ពួកគេជាច្រើននាក់ក្នុងចំណោមនោះ កំពុងតែប្រជ្រៀតទៅ
មុខ ដើម្បីពួក គេអាចទៅដល់ផ្លូវ ដែលនាំទៅដើមឈើដែល
ឪពុកឈរជិតនោះ ។
២២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានទៅមុខ
ហើយចាប់ផ្តើមដើរនៅលើផ្លូវ ដែលនាំទៅដល់ដើមឈើនោះ។
២៣ ហើយហេតុការណ៍បានកើតឡើងថា មានអ័ព្ទនៃសេច
ក្តីងងឹតបានផុសឡើង មែនហើយ គឺជាអ័ព្ទនៃសេចក្តីងងឹតដ៏ធំ
ដរាបដល់ ធ្វើឲ្យពួកគេ ដែលបានដើរនៅលើផ្លូវនោះត្រូវ
ធ្លាក់វង្វេងផ្លូវ ខ្វាត់ខ្វាយបាត់អស់ទៅ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ឪពុកបានឃើញ
មនុស្សជាច្រើនទៀតកំពុងតែប្រជ្រៀតទៅមុខ ហើយពួកគេ
បានចេញមក ចាប់ចុងដំបងដែក; ហើយពួកគេប្រជ្រៀត
ពុះពារអ័ព្ទនៃសេចក្តីងងឹតទៅមុខ ដោយដើរស្ទួតាមដំបងដែក
រហូតដល់ពួកគេទៅដល់ ហើយទទួលទានផ្លែឈើនោះ ។
២៥ ហើយបន្ទាប់ពីពួកគេបានទទួលទានផ្លែឈើនោះហើយ
នោះពួកគេក៏សម្លឹងមើលជុំវិញខ្លួន ហាក់បីដូចជាពួកគេមាន
ការខ្មាស់ អៀនចំពោះខ្លួន ។
២៦ ហើយឪពុកក៏សម្លឹងមើលជុំវិញដែរ ហើយបានឃើញថា
នៅឯត្រើយម្ខាងទន្លេនោះមានអាគារដ៏ធំ ហើយទូលាយមួយ
ហើយ អាគារនោះ ហាក់ដូចជាឈរនៅលើអាកាសខ្ពស់ពីដី ។
២៧ ហើយអាគារនោះពេញទៅដោយមនុស្ស ទាំង
ចាស់ទាំងក្មេង ទាំងប្រុសទាំងស្រី; ហើយរបៀបស្លៀកពាក់របស់
ពួកគេ សុទ្ធតែល្អប្រសើរ; ហើយពួកគេកំពុងតែនៅក្នុង
អាកប្បកិរិយាចំអកឡកឡឺយ ហើយចង្អុលដៃខ្លួន ទៅរកពួក
អ្នកដែលបានទៅដល់ ហើយកំពុងតែទទួលទានផ្លែឈើនោះ ។
២៨ ហើយបន្ទាប់ពីពួកគេបានភ្លក់ផ្លែឈើនោះហើយ នោះ
ពួកគេមានការខ្មាស់អៀន ពីព្រោះតែពួកអ្នកដែលចំអកដាក់គេ;
ហើយពួកគេក៏បានធ្លាក់តាមផ្លូវហាមឃាត់ទាំងឡាយ ហើយវ
ង្វេងបាត់អស់ទៅ ។
២៩ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ មិនរៀបរាប់ពាក្យទាំងឡាយ
របស់ឪពុកខ្ញុំឲ្យអស់បានឡើយ ។
៣០ ប៉ុន្តែរមសេចក្តីឲ្យខ្លីមក មើលចុះ ឪពុកខ្ញុំបានឃើញ
មនុស្សទាំងហ្វូងៗប្រជ្រៀតទៅមុខ; ហើយពួកគេបានមក
កាន់ចុងដំបងដែក; ហើយពួកគេបានប្រជ្រៀតគ្នាទៅមុខ
ដោយកាន់ដំបងដែកយ៉ាងខ្ជាប់ជានិច្ច រហូតដល់ពួកគេបានមក
ដល់ ហើយដួលចុះ ហើយបរិភោគ ផ្លែឈើនោះទៅ ។
៣១ ហើយលោកក៏បានឃើញមនុស្សទាំងហ្វូងៗទៀត
កំពុងតែស្ទាបរកផ្លូវឆ្ពោះទៅអាគារដ៏ធំ ហើយទូលាយនោះ ។
៣២ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្ស
ជាច្រើនលង់ទឹកស្លាប់ នៅក្នុងទីជំរៅនៃប្រភពទឹក; ហើយមាន
មនុស្សជាច្រើន វង្វេងបាត់ពីភ្នែកលោក ដោយដើររសាត់ទៅ
លើផ្លូវចម្លែកៗទាំងឡាយ ។
៣៣ ហើយមានមនុស្សទាំងហ្វូង បានចូលទៅក្នុងអាគារ
ចម្លែកនោះ ។ ហើយបន្ទាប់ពីគេបានចូល ទៅក្នុងអាគារ
នោះហើយ ពួកគេចង្អុលមើលងាយដល់ខ្ញុំ និងពួកអ្នកដែល
បរិភោគផ្លែឈើផងនោះ; ប៉ុន្តែពួកយើងឥតយកចិត្ត
ទុកដាក់ដល់គេឡើយ ។
៣៤ ទាំងនេះគឺជាពាក្យរបស់ឪពុកខ្ញុំ៖ ត្បិតមនុស្សជាច្រើន
ណាដែលយកចិត្តទុកដាក់ដល់គេ ក៏ត្រូវវង្វេងបាត់បង់អស់ទៅ ។
៣៥ ហើយឪពុកខ្ញុំបានមានប្រសាសន៍ថា លេមិន និងលេមយ្យួល
មិនទទួលទានផ្លែឈើនោះឡើយ ។
៣៦ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឪពុកខ្ញុំ
បាននិយាយអស់ទាំងពាក្យនៃសុបិន ឬនៃការនិមិត្តរបស់លោក
ដែលជា ពាក្យច្រើនហើយ នោះលោកក៏និយាយមកពួក
យើងថា ពីព្រោះមកពីរឿងទាំងឡាយ ដែលលោកបានឃើញ
នៅក្នុងការនិមិត្ត ធ្វើឲ្យ លោកភ័យខ្លាចជាខ្លាំងជំនួសលេមិន

២០ *ខ* ម៉ាថាយ ១៣:៣៨.
២១ *ក* ស.ប. ផ្លូវ.
២៣ *ក* ១ នីហ្វៃ ១២:១៧; ១៥:២៤.
២៤ *ក* ១ នីហ្វៃ ៨:១០–១២.
២៥ *ក* រ៉ូម ១:១៦; ២ ធីម៉ូ. ១:៨;
អាលម៉ា ៤៦:២១; មរមន ៨:៣៨.
២៦ *ក* ១ នីហ្វៃ ១១:៣៥–៣៦; ១២:១៨.
២៧ *ក* ស.ប. សេចក្តីឆ្មើងឆ្មៃ.
២៨ *ក* ២ ពេត្រុស ២:១៩–២២.
*ខ* ម៉ាកុស ៤:១៤–២០; ៨:៣៨;
លូកា ៨:១១–១៥;
យ៉ូហាន ១២:៤២–៤៣.
*គ* ស.ប. សេចក្តីក្បត់សាសនា.
២៩ *ក* ១ នីហ្វៃ ១:១៦–១៧.
៣០ *ក* ១ នីហ្វៃ ១៥:២៣–២៤.
៣១ *ក* ម៉ាថាយ ៧:១៣.
៣២ *ក* ១ នីហ្វៃ ១៥:២៦–២៩.
៣៣ *ក* ស.ប. បៀតបៀន, សេច
ក្តីបៀតបៀន.
៣៤ *ក* និក្ខ. ២៣:២.
៣៥ *ក* ១ នីហ្វៃ ៨:១៧–១៨;
២ នីហ្វៃ ៥:១៩–២៤.

និងលេមយ្យូល; មែនហើយ លោកខ្លាចក្រែងពួកគេនឹងត្រូវកាត់កាលចេញពីវត្តមាននៃព្រះអម្ចាស់ ។

៣៧ ហើយលោកបានទូន្មានដល់ពួកគេនៅពេលនោះ ដោយអស់ទាំងអារម្មណ៍របស់[ក]មេបាដ៏ទន់ភ្លន់ម្នាក់ ដើម្បីឲ្យពួកគេប្រុងស្ដាប់ តាមពាក្យទាំងឡាយរបស់លោក ក្រែងព្រះអម្ចាស់ ទ្រង់នឹងមេត្តាករុណាដល់ពួកគេ ហើយមិនកាត់កាលពួកគេចេញ; មែនហើយ ឪពុកខ្ញុំបាន ថ្លែងពន្យល់ប្រាប់ពួកគេ ។

៣៨ ហើយបន្ទាប់ពីលោកបានប្រកាសប្រាប់ពួកគេ ហើយបានព្យាករអំពីអ្វីៗជាច្រើនដល់ពួកគេផង លោកបានបង្គាប់ឲ្យពួកគេកាន់ តាមបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ហើយលោកក៏បញ្ចប់ការនិយាយប្រាប់ពួកគេទៅ ៕

## ជំពូកទី ៩

*នីហ្វៃធ្វើបញ្ជីប្រវត្តិពីរច្បាប់ — បញ្ជីនីមួយៗ ហៅថាផ្ទាំងនីហ្វៃ — ផ្ទាំងធំទាំងឡាយមានប្រវត្តិសាស្ត្រលោកិយ រីឯផ្ទាំងតូច ទាំងឡាយទាក់ទងតែខាងកិច្ចការដ៏ពិសិដ្ឋទាំងឡាយ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយរឿងអស់ទាំងនេះ ឪពុកខ្ញុំបានឃើញ ហើយបានឮ ហើយបាននិយាយ នៅពេលដែលលោកអាស្រ័យនៅក្នុងត្រសាល នៅ[ក]ក្នុងចន្លោះភ្នំលេមយ្យូល ហើយរឿងដ៏អស្ចារ្យជាច្រើនទៀតផងដែលមិនអាចយកមកសរសេរនៅលើផ្ទាំងទាំងនេះបានទេ ។

២ ហើយឥឡូវនេះ នៅពេលដែលខ្ញុំនិយាយអំពីផ្ទាំងទាំងនេះ មើលចុះ គឺពុំមែនលើផ្ទាំងទាំងឡាយ ដែលខ្ញុំកត់អំពីដំណើររឿងទាំងឡាយ នៃប្រវត្តិសាស្ត្ររបស់សាសន៍ខ្ញុំនោះទេ; ត្បិត[ក]ផ្ទាំងទាំងនោះ ដែលខ្ញុំកត់នូវដំណើររឿងទាំងឡាយ នៃប្រវត្តិសាស្ត្ររបស់សាសន៍ខ្ញុំ ខ្ញុំបានដាក់ឈ្មោះថា នីហ្វៃ; ហេតុដូច្នោះហើយ ផ្ទាំងទាំងនោះបានហៅថា ផ្ទាំងនីហ្វៃ តាមឈ្មោះខ្ញុំផ្ទាល់; ឯផ្ទាំងទាំងនេះ ក៏បានហៅថា ផ្ទាំងនីហ្វៃផងដែរ ។

៣ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំបានទទួលព្រះបញ្ញត្តិពីព្រះអម្ចាស់ថា ខ្ញុំត្រូវធ្វើផ្ទាំងទាំងនេះ ដោយ[ក]គោលបំណងពិសេសដើម្បីឲ្យមាន[ខ]ដំណើររឿងឆ្លាក់ទុក អំពីការងារបំរើនៃប្រជាជនខ្ញុំ ។

៤ នៅលើផ្ទាំងផ្សេងៗទៀត ត្រូវចារ ហើយឆ្លាក់អំពីដំណើររឿង នៃរជ្ជកាលនៃស្ដេចទាំងឡាយ និងសង្គ្រាមទាំងឡាយ ហើយនឹង ការទាស់ទែងទាំងឡាយនៃប្រជាជនខ្ញុំ; ហេតុដូច្នោះហើយ ផ្ទាំងទាំងនេះភាគច្រើន ទុកសំរាប់កត់អំពីការបំរើ; ឯ[ក]ផ្ទាំងផ្សេងៗទៀតភាគ ច្រើន ទុកសំរាប់កត់ត្រាអំពីរជ្ជកាលនៃស្ដេចទាំងឡាយ និងសង្គ្រាមទាំងឡាយ ហើយនឹងការទាស់ទែងទាំងឡាយនៃសាសន៍ខ្ញុំ ។

៥ ហេតុដូច្នោះហើយ ព្រះអម្ចាស់ទ្រង់បានបញ្ជាខ្ញុំ ឲ្យធ្វើផ្ទាំងទាំងនេះ សំរាប់[ក]គោលបំណងដ៏សំខាន់មួយចំពោះទ្រង់ ឯគោលបំណង នោះ ខ្ញុំមិនដឹងទេ ។

៦ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់[ក]ជ្រាបគ្រប់រឿងទាំងអស់ ចាប់តាំងពីដើមមក; ហេតុដូច្នោះហើយ ទ្រង់បានរៀបចំផ្លូវមួយ ដើម្បីសំរេចគ្រប់ កិច្ចការទាំងអស់របស់ព្រះអង្គ នៅក្នុងចំណោមកូនចៅមនុស្ស; ត្បិតមើលចុះ ទ្រង់មាន[ខ]ព្រះចេស្ដាគ្រប់យ៉ាង ដើម្បីបំពេញគ្រប់ព្រះបន្ទូល ទាំងអស់របស់ទ្រង់ ។ ហើយគឺយ៉ាងដូច្នោះមែន ។ អាម៉ែន ៕

## ជំពូកទី ១០

*លីហៃទាយថាពួកសាសន៍យូដា នឹងត្រូវចាប់យកទៅជាឈ្លើយដោយពួកសាសន៍បាប៊ីឡូន — លោកប្រាប់អំពីការយាងមកនៃព្រះមែស៊ី ជាព្រះអង្គសង្គ្រោះ ជាព្រះប្រោសលោះ នៅក្នុងចំណោមពួកសាសន៍យូដា — លោកប្រាប់អំពីការយាងមកនៃបុរសម្នាក់ ដែលនឹងធ្វើ បុណ្យជ្រមុជទឹកថ្វាយកូនចៀមនៃព្រះដែរ — លីហៃប្រាប់អំពីការសុគត និងដំណើររស់ឡើងវិញនៃព្រះមែស៊ី — លោកប្រៀបធៀបការ ខ្ចាត់ខ្ចាយ និងការប្រមូលនៃសាសន៍អ៊ីស្រាអែល ទៅនឹងដើមអូលីវ — នីហ្វៃនិយាយអំពីព្រះរាជបុត្រានៃព្រះ អំពីអំណោយទានជា ព្រះវិញ្ញាណ*

៣៧ *ក* ស.ប. គ្រួសារ; មាតាបិតា, ឪពុកម្ដាយ.
៩ ១*ក* ១ នីហ្វៃ ២:៤–៦, ៨, ១៤–១៥; ១៦:៦.
២ *ក* ១ នីហ្វៃ ១៩:២, ៤; យ៉ាកុប ៣:១៣–១៤; ព. នៃ ម. ១:២–១១; គ. និង ស. ១០:៣៨–៤០. ស.ប. ផ្ទាំងទាំងឡាយ.
៣ *ក* គ. និង ស. ៣:១៩.
*ខ* ១ នីហ្វៃ ៦:៣.
៤ *ក* យ៉ាកុប ១:២–៤; ព. នៃ ម. ១:១០.
៥ *ក* ១ នីហ្វៃ ១៩:៣; ព. នៃ ម. ១:៧; អាលម៉ា ៣៧:២, ១២, ១៤.
៦ *ក* ២ នីហ្វៃ ៩:២០; គ. និង ស. ៣៨:២; ម៉ូសេ ១:៦, ៣៥. ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
*ខ* ម៉ាថាយ ២៨:១៨.

*បរិសុទ្ធ ហើយនឹងអំពីសេចក្ដីត្រូវការ សំរាប់សេចក្ដីសុចរិត ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ នឹងចាប់ផ្ដើមឲ្យដំណើររឿងនៅលើ[ក]ផ្ទាំងទាំងនេះ នូវដំណើរការទាំងឡាយរបស់ខ្ញុំ និងរជ្ជកាល ហើយនឹង ការងារបំរើរបស់ខ្ញុំ; ហេតុដូច្នោះហើយ ដើម្បីនឹងចាប់ផ្ដើមប្រាប់ពីដំណើររឿងខ្ញុំ ខ្ញុំត្រូវនិយាយអំពីរឿងរបស់ឪពុកខ្ញុំខ្លះ ហើយនឹងរបស់ បងៗខ្ញុំដែរ ។

២ ត្បិតមើលចុះ ហេតុការណ៍បានកើតឡើង គឺបន្ទាប់ពីឪពុកខ្ញុំបានបញ្ចប់ការនិយាយនូវពាក្យទាំងឡាយ អំពី[ក]សុបិនរបស់លោក និងការទូន្មានឲ្យបងៗខ្ញុំ មានចិត្តឧស្សាហ៍គ្រប់យ៉ាងហើយ នោះលោកប្រាប់ពួកគេអំពីពួកសាសន៍យូដា —

៣ ថាបន្ទាប់ពីពួកគេនឹងត្រូវបំផ្លាញចោល សូម្បីតែ[ក]ក្រុងយេរូសាឡិមដ៏ធំ ហើយមនុស្សជាច្រើន នឹង[ខ]ត្រូវចាប់យកទៅជាឈ្លើយនៅ [គ]ក្រុងបាប៊ីឡូន តាមកំណត់នៃព្រះអម្ចាស់ នោះពួកគេនឹង[ឃ]ត្រឡប់មកវិញ មែនហើយ គឺនឹងត្រូវនាំចេញពីការជាប់ឃុំឃាំងមក; ហើយបន្ទាប់ ពីពួកគេត្រូវបាននាំចេញពីការជាប់ឃុំឃាំងមក នោះពួកគេនឹងបានដែនដីនៃកេរ្ដិ៍អាកររបស់គេវិញ ។

៤ មែនហើយ គឺ[ក]ប្រាំមួយរយឆ្នាំ ចាប់តាំងពីពេលដែលឪពុកខ្ញុំចាកចេញពីក្រុងយេរូសាឡិមមក នោះនឹងមាន[ខ]ព្យាការីម្នាក់ដែល ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងលើកឡើងនៅក្នុងចំណោមពួកសាសន៍យូដា — គឺ[គ]ព្រះមែស៊ី ឬពាក្យម្យ៉ាងទៀតថា ព្រះអង្គសង្គ្រោះនៃ ពិភពលោក ។

៥ ហើយលោកថែមទាំងបាននិយាយពីពួកព្យាការី ដោយថាមានចំនួនជាច្រើន បាន[ក]ធ្វើបន្ទាល់អំពីរឿងទាំងនេះ គឺអំពីព្រះមែស៊ីអង្គ នេះ ដែលលោកបាននិយាយដល់ ឬព្រះដ៏ប្រោសលោះនៃពិភពលោកអង្គនេះ ។

៦ ហេតុដូច្នោះហើយ មនុស្សលោកទាំងអស់ រស់នៅក្នុងស្ថានភាពវង្វេង និង[ក]ស្ថានភាពធ្លាក់ ហើយនឹងនៅជាដរាបតទៅ លើកលែងតែពួកគេនឹងពឹងពាក់ ទៅលើព្រះដ៏ប្រោសលោះអង្គនេះ ។

៧ ហើយលោកក៏បានស្ដីអំពី[ក]ព្យាការីម្នាក់ដែរ ដែលនឹងមកមុនព្រះមែស៊ី ដើម្បីរៀបចំផ្លូវថ្វាយព្រះអម្ចាស់—

៨ មែនហើយ គឺលោកនឹងចេញទៅ ហើយស្រែកប្រកាសនៅទីរហោស្ថានថា៖ ចូរអ្នករាល់គ្នា[ក]រៀបចំផ្លូវទទួលព្រះអម្ចាស់ ហើយ តម្រង់ផ្លូវថ្វាយទ្រង់ចុះ; ត្បិតនៅចំណោមពួកអ្នករាល់គ្នា មានព្រះមួយអង្គ ដែលអ្នករាល់គ្នាមិនស្គាល់ ហើយទ្រង់មានអំណាចលើស ជាងខ្ញុំ ខ្ញុំមិនគួរនឹងស្រាយខ្សែសុពណ៌បាទទ្រង់ទេ ។ ហើយឪពុកខ្ញុំបាននិយាយជាច្រើនអំពីរឿងនេះ ។

៩ ហើយឪពុកខ្ញុំបាននិយាយថា លោកនោះនឹងធ្វើបុណ្យជ្រមុជទឹកនៅ[ក]ភូមិបេថាបារ៉ា ខាងនាយទន្លេយ័រដាន់; ហើយឪពុកខ្ញុំក៏បាន និយាយដែរថា លោកនោះនឹង[ខ]ធ្វើបុណ្យជ្រមុជដោយទឹក; គឺលោកនេះឯង ដែលនឹងធ្វើបុណ្យជ្រមុជថ្វាយព្រះមែស៊ីដោយទឹក ។

១០ ហើយបន្ទាប់ពីលោក បានធ្វើបុណ្យជ្រមុជថ្វាយព្រះមែស៊ីដោយទឹកហើយ នោះលោកនឹងឃើញ ហើយនឹងធ្វើបន្ទាល់ថា លោកបានធ្វើបុណ្យជ្រមុជថ្វាយ[ក]កូនចៀមនៃព្រះ គឺជាព្រះដែលនឹងលោះអំពើបាបទាំងឡាយនៃមនុស្សលោក ។

១១ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឪពុកខ្ញុំបាននិយាយនូវពាក្យទាំងនេះរួចហើយ លោកបាននិយាយទៅបងៗខ្ញុំ អំពីដំណឹងល្អដែលនឹងត្រូវយកទៅផ្សព្វផ្សាយនៅក្នុងចំណោមពួកសាសន៍យូដា ហើយនឹងអំពី[ក]ការចុះអន់ថយក្នុងការ[ខ]ឥតជំនឿ នៃពួកសាសន៍យូដាផង ។ ហើយបន្ទាប់ពីពួកគេបាន[គ]ធ្វើគតព្រះមែស៊ី ដែលនឹងយាងមក ហើយបន្ទាប់ពីទ្រង់ត្រូវគេធ្វើគត នោះទ្រង់ នឹងមាន[ឃ]ព្រះជន្មរស់ពីស្លាប់ឡើងវិញ

**១០** ១*ក* ១ នីហ្វៃ ៩:១–៥; ១៩:១–៦; យ៉ាកុប ១:១–៤.
២ *ក* ១ នីហ្វៃ ៨.
៣ *ក* នាងអេស. ២:៦; ២ នីហ្វៃ ៦:៨; ហេលេ. ៨:២០–២១.
*ខ* ២ នីហ្វៃ ២៥:១០. ស.ប. លំដាប់ពេល — ៥៨៧ ម.គ.ស.
*គ* អេសេ. ២៤:២; ១ នីហ្វៃ ១:១៣; អោមណៃ ១:១៥.
*ឃ* យេរេ. ២៩:១០; ២ នីហ្វៃ ៦:៨–៩.
៤ *ក* ១ នីហ្វៃ ១៩:៨; ២ នីហ្វៃ ២៥:១៩; ៣ នីហ្វៃ ១:១.
*ខ* ១ នីហ្វៃ ២២:២០–២១.
*គ* ស.ប. ព្រះមែស៊ី.
៥ *ក* យ៉ាកុប ៧:១១; ម៉ូសាយ ១៣:៣៣; ហេលេ. ៨:១៩–២៤; ៣ នីហ្វៃ ២០:២៣–២៤.
៦ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
៧ *ក* ១ នីហ្វៃ ១១:២៧; ២ នីហ្វៃ ៣១:៤.
៨ *ក* អេសាយ ៤០:៣; ម៉ាថាយ ៣:១–៣.
៩ *ក* យ៉ូហាន ១:២៨.
*ខ* ស.ប. យ៉ូហាន–បាទីស្ទ.
១០ *ក* ស.ប. កូនចៀមនៃព្រះ.
១១ *ក* យ៉ាកុប ៤:១៤–១៨.
*ខ* មរមន ៥:១៤.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ; ការឆ្កាង.
*ឃ* ស.ប. ដំណើររស់ឡើងវិញ.

ហើយនឹងសម្ដែងរូបអង្គទ្រង់ ដល់ពួកសាសន៍ដទៃ ដោយព្រះវិញ្ញាណបរិសុទ្ធ ។

១២ មែនហើយ គឺឪពុកខ្ញុំបាននិយាយជាច្រើន អំពីពួកសាសន៍ដទៃ និងអំពីវង្សអ៊ីស្រាអែលផងថា ពួកគេនឹងត្រូវប្រៀបធៀបដូចជា ដើមអូលីវ ដែលមែកទាំងឡាយនឹងត្រូវកាត់ចេញ ហើយត្រូវខ្ចាត់ខ្ចាយពាសពេញនៅលើផ្ទៃផែនដី ។

១៣ ហេតុដូច្នោះហើយ លោកបាននិយាយថា ជាការចាំបាច់ ដែលយើងត្រូវនាំទៅឯដែនដីសន្យា ដើម្បីបំពេញនូវព្រះបន្ទូលនៃ ព្រះអម្ចាស់ថា យើងនឹងត្រូវខ្ចាត់ខ្ចាយពាសពេញនៅលើផ្ទៃផែនដី ។

១៤ ហើយបន្ទាប់ពីវង្សអ៊ីស្រាអែល ត្រូវខ្ចាត់ខ្ចាយទៅហើយ នោះពួកគេនឹងបានប្រមូលរួមគ្នាជាថ្មី; ឬសរុបសេចក្ដីថា បន្ទាប់ពីពួកសាសន៍ដទៃ បានទទួលនូវភាពពោរពេញនៃដំណឹងល្អហើយ នោះមែកកំណើតទាំងឡាយនៃដើមអូលីវ ឬក៏សំណល់ទាំងឡាយនៃ វង្សអ៊ីស្រាអែល នឹងបានបំបៅជាប់នឹងដើមវិញ ឬនឹងបានការចេះដឹងអំពីព្រះមែស៊ីដ៏ពិត គឺជាព្រះអម្ចាស់របស់ពួកគេ និងព្រះដ៏ប្រោស លោះរបស់ពួកគេ ។

១៥ ហើយដោយពាក្យបែបនេះហើយ ដែលឪពុកខ្ញុំបានព្យាករ ហើយនិយាយទៅបងៗខ្ញុំ ហើយព្រមទាំងរឿងជាច្រើនទៀត ដែលខ្ញុំពុំបានសរសេរទុកនៅក្នុងសៀវភៅនេះ; ត្បិតខ្ញុំបានសរសេរជាច្រើនរឿង ដែលគាប់ចិត្តខ្ញុំ ទុកនៅក្នុងសៀវភៅរបស់ខ្ញុំមួយទៀត ហើយ ។

១៦ ហើយគ្រប់រឿងទាំងអស់ ដែលខ្ញុំបាននិយាយនេះ គឺកើតឡើងក្នុងកាលដែលឪពុកខ្ញុំអាស្រ័យនៅក្នុងត្រសាល នៅក្នុងច្រកភ្នំ លេមយួល ។

១៧ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំ នីហ្វៃ បានឮពាក្យពេចន៍ទាំងអស់របស់ឪពុកខ្ញុំ អំពីរឿងទាំងឡាយ ដែលលោកបានឃើញនៅក្នុងការនិមិត្ត ហើយព្រមទាំងរឿងទាំងឡាយដែលលោកបាននិយាយ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ គឺជាអំណាចដែលលោកបានទទួល ដោយសារសេចក្ដីជំនឿជឿដល់ព្រះរាជបុត្រានៃព្រះ — ហើយឯព្រះរាជបុត្រានៃព្រះនោះ គឺជាព្រះមែស៊ី ដែលនឹងយាងមក — នោះខ្ញុំ នីហ្វៃ ក៏ប្រាថ្នាចង់ឃើញ និងឮ និងដឹងនូវរឿងទាំងនេះដែរ គឺដោយព្រះចេស្ដានៃព្រះ វិញ្ញាណបរិសុទ្ធ ដែលជាអំណោយទាននៃព្រះ ដល់អស់អ្នកណា ដែលព្យាយាមស្វែងរកទ្រង់ ទោះជានៅជំនាន់បុរាណក៏ដូចជានៅ ជំនាន់ដែលទ្រង់នឹងសម្ដែងរូបអង្គទ្រង់ដល់កូនចៅមនុស្សដែរ ។

១៨ ត្បិតទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ; ហើយផ្លូវត្រូវបានរៀបចំឡើង សំរាប់មនុស្ស ទាំងអស់ ចាប់តាំងពីកំណើតលោកិយមក ប្រសិនបើពួកគេប្រែចិត្ត ហើយមករកទ្រង់ ។

១៩ ត្បិតអ្នកណាដែលព្យាយាមរក នឹងឃើញ; ហើយការអាថ៌កំបាំងទាំងឡាយនៃព្រះ នឹងបានបើកបង្ហាញដល់គេ ដោយព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ ទោះនៅជំនាន់នេះក៏ដូចជានៅជំនាន់ដើមដែរ ហើយទោះជានៅជំនាន់ដើមក៏ដូចជានៅជំនាន់ខាងមុខដែរ; ហេតុដូច្នោះហើយ ដំណើរនៃព្រះអម្ចាស់ គឺជាវង់មួយដ៏នៅអស់កល្បជានិច្ច ។

២០ ហេតុដូច្នេះ ចូរចាំចុះ ឱអ្នកអើយ ត្បិតគ្រប់ការប្រព្រឹត្តទាំងអស់របស់អ្នក នោះនឹងត្រូវបញ្ជូនមកជំនុំជំរះវិញ ។

២១ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាព្យាយាមប្រព្រឹត្តអំពើអាក្រក់ នៅក្នុងថ្ងៃទាំងឡាយ នៃការសាកល្បងរបស់អ្នករាល់គ្នា នោះនឹងឃើញថា អ្នករាល់គ្នាមិនស្អាតនៅចំពោះវេទិកា

---

១១ *ង* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
១២ *ក* លោកុ. ៤៩:២២–២៦;
១ នីហ្វៃ ១៥:១២;
២ នីហ្វៃ ៣:៤–៥;
យ៉ាកុប ៥; ៦:១–៧.
ស.ប. ដើមអូលីវ; ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*ខ* ១ នីហ្វៃ ២២:៣–៨.
ស.ប. អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
១៣ *ក* ១ នីហ្វៃ ២:២០.
ស.ប. ដែនដីសន្យា.
១៤ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* ១ នីហ្វៃ ១៣:៤២;
គ. និង ស. ១៤:១០.
*គ* យ៉ាកុប ៥:៨, ៥២, ៥៤, ៦០, ៦៨.
១៥ *ក* ១ នីហ្វៃ ១:១៦–១៧.
១៧ *ក* អេណុស ១:៣; អាលម៉ា ៣៦:១៧.
*ខ* ១ នីហ្វៃ ៨:២.
*គ* ស.ប. ព្រះមែស៊ី.
*ឃ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ង* ម៉ូរ៉ូណៃ ១០:៤–៥, ៧, ១៩.
*ច* គ. និង ស. ២០:២៦.
១៨ *ក* ហេព្រើរ ១៣:៨; មរមន ៩:៩;
គ. និង ស. ២០:១២.
ស.ប. ព្រះ, ក្រុមព្រះ.
១៩ *ក* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* អាលម៉ា ៧:២០;
គ. និង ស. ៣:២; ៣៥:១.
២០ *ក* សាស្ដា ១២:១៤; ២ នីហ្វៃ ៩:៤៦.
ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
២១ *ក* អាលម៉ា ៣៤:៣២–៣៥.
*ខ* ១ កូរិន. ៦:៩–១០;
៣ នីហ្វៃ ២៧:១៩;
គ. និង ស. ៧៦:៥០–៦២;
ម៉ូសេ ៦:៥៧.

ជំនុំជំរះនៃព្រះទេ; ហើយគ្មានអ្វីដែលមិនស្អាត អាចអាស្រ័យនៅជាមួយនឹង ព្រះបានឡើយ; ហេតុដូច្នោះហើយ អ្នកនឹងត្រូវបោះបង់ចោល ជារៀងដរាបតទៅ ។

២២ ហើយព្រះវិញ្ញាណបរិសុទ្ធ ទ្រង់បានប្រទានអំណាចឲ្យខ្ញុំនិយាយរឿងទាំងនេះ ហើយមិនឲ្យខ្ញុំ បដិសេធរឿងទាំងនេះឡើយ ៕

## ជំពូកទី ១១

*នីហ្វៃឃើញព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយត្រូវបានបង្ហាញឲ្យឃើញដើមជីវិតនៅក្នុងការនិមិត្ត — លោកឃើញមាតារបស់ព្រះរាជបុត្រានៃព្រះ ហើយដឹងអំពីការយាងចុះមកនៃព្រះ — លោកឃើញបុណ្យជ្រមុជទឹក, ការងារបំរើ, និងការឆ្កាងកូនចៀមនៃព្រះ — លោកឃើញការរើស និងការងារបំរើនៃពួកសាវក១២នាក់របស់កូនចៀម ។ ប្រមាណជាឆ្នាំ ៦០០ — ៥៩២ ម.គ.ស. ។*

ត្បិតហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំបានប្រាថ្នាចង់ដឹងពីរឿងទាំងឡាយ ដែលឪពុកខ្ញុំបានឃើញមក ហើយដោយជឿថា ព្រះ អម្ចាស់ទ្រង់អាចធ្វើឲ្យខ្ញុំដឹងរឿងនេះបាន កាលខ្ញុំអង្គុយរំពឹងគិតនៅក្នុងចិត្តខ្ញុំ នោះខ្ញុំត្រូវបាននាំទៅដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ មែនហើយ នាំទៅឯភ្នំមួយដ៏ខ្ពស់អស្ចារ្យ ដែលខ្ញុំមិនដែលបានឃើញពីមុនមក ហើយដែលខ្ញុំមិនដែលបានដាក់ជើងលើភ្នំនោះពីមុនដែរ ។

២ ហើយព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ មើលចុះ តើអ្នកប្រាថ្នាអ្វី ?

៣ ហើយខ្ញុំបានទូលថា៖ ទូលបង្គំប្រាថ្នាចង់ឃើញអ្វីៗ ដែលឪពុកទូលបង្គំបានឃើញមក ។

៤ ហើយព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ តើអ្នកជឿៈទេថាឪពុកអ្នកបានឃើញដើមឈើ ដែលឪពុកអ្នកបាននិយាយនោះ ?

៥ ហើយខ្ញុំបានទូលថា៖ ព្រះពរ ព្រះអង្គជ្រាបហើយថាទូលបង្គំជឿនូវគ្រប់ពាក្យទាំងអស់របស់ឪពុកទូលបង្គំ ។

៦ ហើយនៅពេលដែលខ្ញុំបាននិយាយពាក្យទាំងនេះ នោះព្រះវិញ្ញាណ ទ្រង់ក៏បន្លឺសម្លេងជាខ្លាំងថា៖ ហូសាណាដល់ព្រះអម្ចាស់ព្រះ ដ៏ខ្ពស់បំផុតអើយ; ត្បិតទ្រង់ជាព្រះលើផែនដីទាំងមូល មែនហើយ គឺជាព្រះនៅលើ អ្វីៗទាំងអស់ ។ ឱនីហ្វៃអើយ អ្នកមានពរហើយ ព្រោះអ្នកជឿដល់ព្រះរាជបុត្រា នៃព្រះដ៏ខ្ពស់បំផុត; ហេតុដូច្នោះហើយ អ្នកនឹងបានឃើញនូវអ្វីៗ ដែលអ្នកប្រាថ្នា ។

៧ ហើយមើលចុះ ការណ៍នេះនឹងត្រូវបានប្រទានដល់អ្នកទុកជាទីសំគាល់មួយថា បន្ទាប់ពីអ្នកបានឃើញដើមឈើដែលផ្តល់ផ្លែ ដែលឪពុកអ្នកបានភ្លក់ហើយ នោះអ្នកក៏នឹងឃើញបុរសម្នាក់ ដែលកំពុងយាងចុះមកពីលើមេឃ បុរសនោះហើយដែលអ្នកនឹងឃើញ ហើយបន្ទាប់ពីអ្នកបានឃើញទ្រង់ហើយ អ្នកនឹងធ្វើបន្ទាល់ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ មើលន៏ ! ហើយខ្ញុំក៏សម្លឹងមើលហើយឃើញ ដើមឈើមួយ; ហើយដើមឈើនោះក៏ដូចជាដើមឈើដែលឪពុកខ្ញុំបានឃើញមក; ហើយសម្រស់នៃដើមឈើនោះល្អដ៏លើសលប់ មែនហើយ ល្អជាងសម្រស់អ្វីៗទាំងអស់; ហើយសេចក្តីសនៃដើមឈើនោះក៏សជាងហិមៈដែលរសាត់ទៅទៀត ។

៩ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំបានឃើញដើមឈើនោះហើយ ខ្ញុំក៏ទូលទៅព្រះវិញ្ញាណថា៖ ទូលបង្គំបានឃើញ ថា ព្រះអង្គបានបង្ហាញឲ្យទូលបង្គំឃើញដើមឈើ ដ៏មានតម្លៃលើសជាងអ្វីៗទាំងអស់ ។

១០ ហើយព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា៖ តើអ្នកប្រាថ្នាអ្វីទៀត ?

១១ ហើយខ្ញុំបានទូលទ្រង់ថា៖ ទូលបង្គំប្រាថ្នាចង់ដឹងពីការបកស្រាយនៃរឿងនេះ — ត្បិតខ្ញុំនិយាយជាមួយទ្រង់ដូចជាមនុស្សនិយាយ; ត្បិតខ្ញុំបានឃើញថា ទ្រង់នៅក្នុងរូបរាងមនុស្ស; ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំបានដឹងថា នេះគឺជា

---

១១ ១*ក* គ. និង ស. ៧៦:១៩.
ស.ប. រំពឹងគិត.
*ខ* ២ កូរិន. ១២:១–៤;
វិវ. ២១:១០; ២ នីហ្វៃ ៤:២៥;
ម៉ូសេ ១:១.
*គ* ចោទិ. ១០:១; អេធើរ ៣:១.
៣ *ក* ១ នីហ្វៃ ៨:២–៣៤.
៤ *ក* ១ នីហ្វៃ ៨:១០–១២;
១៥:២១–២២.
៥ *ក* ១ នីហ្វៃ ២:១៦.
៦ *ក* និក្ខ. ៩:២៩; ២ នីហ្វៃ ២៩:៧;
៣ នីហ្វៃ ១១:១៤; ម៉ូសេ ៦:៤៤.
*ខ* ស.ប. ជំនឿ, ជឿ.
៧ *ក* ស.ប. ទីសំគាល់.
*ខ* ស.ប. ទីបន្ទាល់.
៨ *ក* ១ នីហ្វៃ ៨:១០.
*ខ* ១ នីហ្វៃ ៨:១១.
៩ *ក* ១ នីហ្វៃ ១១:២២–២៥.
១១ *ក* លោកុ. ៤០:៨.
*ខ* អេធើរ ៣:១៥–១៦.

ព្រះវិញ្ញាណនៃព្រះអម្ចាស់; ហើយទ្រង់មានព្រះបន្ទូលមកខ្ញុំ ដូចជា
មនុស្សម្នាក់និយាយជាមួយនឹងមនុស្សម្នាក់ទៀត ។
១២ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់មានព្រះបន្ទូលមក
ខ្ញុំថា៖ មើលន៏ ! ហើយខ្ញុំក៏មើល ហាក់បីដូចជាមើលព្រះអង្គ
ទ្រង់ ហើយខ្ញុំមើលមិនឃើញទ្រង់សោះ; ត្បិតទ្រង់បាន
យាងចេញពីវត្តមានខ្ញុំបាត់ទៅ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានមើល
ហើយឃើញក្រុងយេរូសាឡិមដ៏ធំ និងព្រមទាំងក្រុងឯទៀតៗ
ទាំងឡាយផង ។ ហើយខ្ញុំបានឃើញភូមិណាសារ៉ែត;
ហើយនៅភូមិណាសារ៉ែត ខ្ញុំបានឃើញនាងព្រហ្មចារីម្នាក់
ហើយនាងស្រស់ល្អ ហើយស ដ៏លើសលប់ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញ
ផ្ទៃមេឃបើកចំហ; ហើយមានទេវតាមួយយាងចុះមក
ហើយឈរនៅចំពោះ មុខខ្ញុំ; ហើយទេវតានោះមានបន្ទូលមក
ខ្ញុំថា៖ ឱនីហ្វៃអើយ តើអ្នកឃើញអ្វី ?
១៥ ហើយខ្ញុំបានទូលទៅទេវតានោះថា៖ ខ្ញុំឃើញនាងព្រហ្មចារី
ម្នាក់ស្អាតបំផុត ហើយស្រស់ល្អជាងនាងព្រហ្មចារីនានាទាំង
អស់ ។
១៦ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ តើអ្នកយល់ពីការយាងចុះ
មកនៃព្រះឬទេ ?
១៧ ហើយខ្ញុំបានទូលទៅទេវតាថា៖ ខ្ញុំដឹងថាព្រះអង្គ
ទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់; ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ
គង់តែខ្ញុំមិនយល់ន័យនៃរឿងទាំងអស់នោះទេ ។
១៨ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលចុះ នាងព្រហ្មចារី
ដែលអ្នកឃើញនោះ គឺជាមាតារបស់ព្រះរាជបុត្រានៃព្រះ
ស្របតាមខាងឯសាច់ឈាម ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញថា
នាងត្រូវបាននាំទៅដោយព្រះវិញ្ញាណ; ហើយបន្ទាប់ពីនាងត្រូវ
បាននាំទៅ ដោយព្រះវិញ្ញាណ អស់មួយរយៈហើយ នោះទេវតា
ក៏មានបន្ទូលមកខ្ញុំថា៖ មើលន៏ !
២០ ហើយខ្ញុំក៏មើល ហើយបានឃើញនាងព្រហ្មចារីម្ដងទៀត
នាងកំពុងតែបីព្រះឱរសក្នុងដៃរបស់នាង ។
២១ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៏ កូនចៀម
នៃព្រះ មែនហើយ គឺជាព្រះរាជបុត្រានៃព្រះវរបិតា
ដ៏នៅអស់កល្បជានិច្ច! តើអ្នកយល់ន័យពីដើមឈើ ដែលឪពុក
អ្នកបានឃើញនោះទេ ?
២២ ហើយខ្ញុំបានឆ្លើយតបទៅទេវតាថា៖ ព្រះពរ នោះ
គឺជាសេចក្ដីស្រឡាញ់នៃព្រះ ដែលមានសាយសព្វនៅក្នុងចិត្ត
នៃកូនចៅ មនុស្ស; ហេតុដូច្នោះហើយ នោះគឺជាសេចក្ដីស្រឡាញ់
ដែលគួរឲ្យប្រាថ្នាដ៏លើសលប់ជាងអ្វីៗទាំងអស់ ។
២៣ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មែនហើយ គឺជាសេចក្ដី
រីករាយបំផុតដល់ព្រលឹង ។
២៤ ហើយបន្ទាប់ពីទេវតាមានបន្ទូលនូវពាក្យទាំងនេះហើយ
លោកមានបន្ទូលមកខ្ញុំថា៖ មើលន៏ ! ហើយខ្ញុំក៏មើល ហើយខ្ញុំ
បាន ឃើញព្រះរាជបុត្រានៃព្រះ កំពុងតែយាងចេញទៅក្នុង
ចំណោមកូនចៅមនុស្ស; ហើយខ្ញុំបានឃើញមនុស្សជាច្រើន
ក្រាបនៅជិតព្រះបាទ ទ្រង់ ហើយថ្វាយបង្គំទ្រង់ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាន
ឃើញថាដំបងដែក ដែលឪពុកខ្ញុំបានឃើញមកនោះ គឺជាព្រះ
បន្ទូលនៃព្រះ ដែលនាំ ទៅឯប្រភពនៃទឹករស់ ឬទៅឯដើមជីវិត;
ឯទឹកនោះគឺជាតួយ៉ាងអំពីសេចក្ដីស្រឡាញ់នៃព្រះ; ហើយខ្ញុំក៏បាន
ឃើញថា ដើមជីវិតនោះ គឺជាតួយ៉ាងអំពីសេចក្ដីស្រឡាញ់នៃ
ព្រះដែរ ។
២៦ ហើយទេវតាមានបន្ទូលមកខ្ញុំទៀតថា៖ នុ៎ះន៏ ចូរមើល
ការយាងចុះមកនៃព្រះ !
២៧ ហើយខ្ញុំក៏មើល ហើយបានឃើញព្រះដ៏ប្រោសលោះ

១៣ *ក* ម៉ាថាយ ២:២៣.
*ខ* លូកា ១:២៦–២៧;
អាលម៉ា ៧:១០.
ស.ប. នាងម៉ារា, មាតារបស់
ព្រះយេស៊ូវ.
១៤ *ក* អេសេ. ១:១; ១ នីហ្វៃ ១:៨.
១៨ *ក* អេសាយ ៧:១៤;
លូកា ១:៣៤–៣៥.
*ខ* ម៉ូសាយ ៣:៨.
១៩ *ក* ម៉ាថាយ ១:២០.
២០ *ក* លូកា ២:១៦.
២១ *ក* ស.ប. កូនចៀមនៃព្រះ.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*គ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏
ជាព្រះវរបិតា.
*ឃ* ១ នីហ្វៃ ៨:១០;
អាលម៉ា ៥:៦២.
ស.ប. ដើមជីវិត.
២២ *ក* ស.ប. សេចក្ដីស្រឡាញ់.
២៣ *ក* ស.ប. សេចក្ដីអំណរ.
២៤ *ក* លូកា ៤:១៤–២១.
២៥ *ក* ១ នីហ្វៃ ៨:១៩.
*ខ* ស.ប. ទឹករស់.
*គ* លោកុ. ២:៩;
អាលម៉ា ៣២:៤០–៤១;
ម៉ូសេ ៤:២៨, ៣១.
២៦ *ក* ១ នីហ្វៃ ១១:១៦–៣៣.
២៧ *ក* ២ នីហ្វៃ ២៥:១៣.

នៃពិភពលោក គឺជាទ្រង់នេះហើយដែលឪពុកខ្ញុំបានពោលមកនោះ;
ហើយខ្ញុំក៏បានឃើញព្យាការី ដែលនឹងរៀបចំផ្លូវថ្វាយទ្រង់ដែរ ។
ហើយកូនចៀមនៃព្រះ បានយាងទៅ ហើយបានទទួលបុណ្យ
ជ្រមុជទឹក ពីលោក; ហើយបន្ទាប់ពីទ្រង់បានទទួលបុណ្យ
ជ្រមុជទឹកហើយ ខ្ញុំបានឃើញផ្ទៃមេឃបើកចំហ ហើយព្រះវិញ្ញាណ
បរិសុទ្ធយាងចុះមកពី លើមេឃ ហើយសណ្ឋិតលើទ្រង់ មាន
រូបដូចជាព្រាប ។
២៨ ហើយខ្ញុំឃើញថា ទ្រង់បានយាងចេញទៅធ្វើការងារបំរើដល់
បណ្ដាជន ដោយនូវព្រះចេស្ដា និងសិរីល្អដ៏អស្ចារ្យ; ហើយ
មនុស្ស ទាំងហ្វូងបានប្រមូលគ្នា ដើម្បីមកស្ដាប់ទ្រង់; ហើយខ្ញុំ
បានឃើញថា ពួកគេបណ្ដេញទ្រង់ចេញពីចំណោមពួកគេ ។
២៩ ហើយខ្ញុំបានឃើញមនុស្ស១២នាក់ទៀតដើរតាមទ្រង់ដែរ ។
ហើយហេតុការណ៍បានកើតឡើងថា ពួកគេត្រូវបាននាំទៅ
ដោយព្រះវិញ្ញាណ ចេញពីមុខខ្ញុំបាត់ទៅ ហើយខ្ញុំមើលមិន
ឃើញពួកគេសោះ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូល
មកខ្ញុំទៀតថា៖ មើលន៏ ! ហើយខ្ញុំក៏មើល ហើយខ្ញុំបានឃើញ
ផ្ទៃមេឃ បើកចំហម្ដងទៀត ហើយខ្ញុំបានឃើញពួកទេវតាយាង
ចុះមកឯកូនចៅមនុស្ស; ហើយពួកទេវតាបានធ្វើការងារបំរើដល់
ពួកគេ ។
៣១ ហើយលោកមានបន្ទូលមកកាន់ខ្ញុំទៀតថា៖ មើលន៏ !
ហើយខ្ញុំក៏មើល ហើយខ្ញុំបានឃើញកូនចៀមនៃព្រះ កំពុងតែ
យាងចេញ ទៅក្នុងចំណោមកូនចៅមនុស្ស ។ ហើយខ្ញុំបាន
ឃើញមនុស្សទាំងហ្វូង គឺពួកអ្នកឈឺ និងពួកអ្នកដែលរងទុក្ខ
វេទនា ដោយជំងឺគ្រប់មុខ និងដោយពួកអារក្ស និងដោយ
អារក្សអសោចិ៍ចូល; ហើយទេវតានោះមានបន្ទូល ហើយបាន
បង្ហាញគ្រប់រឿងទាំងអស់នេះដល់ខ្ញុំ ។ ហើយពួកគេត្រូវបាន
ប្រោសឲ្យជា ដោយព្រះចេស្ដានៃកូនចៀមនៃព្រះ; ឯពួកអារក្ស
និងអារក្សអសោចិ៍ក៏ត្រូវបានបណ្ដេញចេញទៅ ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូល
មកខ្ញុំទៀតថា៖ មើលន៏ ហើយខ្ញុំក៏មើល ហើយបានឃើញ
កូនចៀមនៃ ព្រះថា ទ្រង់ត្រូវបណ្ដាជនចាប់យកទៅ; មែន
ហើយ ព្រះរាជបុត្រានៃព្រះដ៏គង់នៅអស់កល្បជានិច្ច ត្រូវមនុស្ស
លោកជំនុំជំរះ; នោះខ្ញុំបាន ឃើញ ហើយបានធ្វើបន្ទាល់ ។
៣៣ ហើយខ្ញុំ នីហ្វៃ បានឃើញទ្រង់ត្រូវ
គេលើកឡើងលើឈើឆ្កាង ហើយធ្វើគតជំនួសអំពើបាបទាំង
ឡាយនៃមនុស្សលោក ។
៣៤ ហើយបន្ទាប់ពីទ្រង់ត្រូវគេធ្វើគតហើយ នោះខ្ញុំបានឃើញ
ហ្វូងមនុស្សនៅលើផែនដី គឺពួកគេប្រមូលគ្នា ដើម្បីទៅច្បាំង
នឹង ពួកសាវកនៃកូនចៀម; ព្រោះពួក១២នាក់នោះត្រូវទេវតា
នៃព្រះអម្ចាស់បានហៅថាដូច្នោះហើយ ។
៣៥ ហើយពួកបណ្ដាជននៅលើផែនដីបានប្រមូលគ្នា; ហើយខ្ញុំ
បានឃើញថា ពួកគេនៅក្នុងអាគារដ៏ធំ ហើយទូលាយ
ដូចជាអាគារ ដែ ឪពុកខ្ញុំបានឃើញមកនោះ ។ ហើយទេវតា
នៃព្រះអម្ចាស់មានបន្ទូលមកខ្ញុំទៀតថា៖ មើលន៏ មនុស្សលោក
ហើយនឹងប្រាជ្ញារបស់គេ; មែនហើយ មើលន៏ វង្សអ៊ីស្រាអែល
បានប្រមូលគ្នាទៅច្បាំងនឹងពួកសាវក១២នាក់នៃកូនចៀម ។
៣៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញ ហើយ
បានធ្វើបន្ទាល់ថា អាគារដ៏ធំ ហើយទូលាយ គឺជាសេចក្ដីឆ្មើងឆ្មៃនៃ
មនុស្សលោក; ហើយអាគារនោះរលំ ឯការរលំរបស់វាធំ
ធ្ងន់ធ្ងរណាស់ ។ ហើយទេវតានៃព្រះអម្ចាស់មានបន្ទូលមក
ខ្ញុំទៀតថា៖ សេចក្ដីបំផ្លិចបំផ្លាញនៃគ្រប់ទាំងសាសន៍ គ្រប់ពូជ
មនុស្ស គ្រប់ភាសា ហើយគ្រប់ទាំងប្រជាជន ដែលនឹងច្បាំង
នឹងពួកសាវក១២នាក់នៃ កូនចៀម នឹងកើតទៅយ៉ាងដូច្នោះ ៕

## ជំពូកទី ១២

*នីហ្វៃបានឃើញនៅក្នុងការនិមិត្ត អំពីដែនដីសន្យា; អំពីសេចក្ដីសុចរិត, សេចក្ដីទុច្ចរិត, និងការរលំនៃបណ្ដាជននៅទីនោះ; អំពីការ យាងមកនៃកូនចៀមនៃព្រះ ក្នុងចំណោមពួកគេ; អំពី*

២៧ *ខ* ម៉ាថាយ ១១:១០; ១ នីហ្វៃ ១០:៧–១០; ២ នីហ្វៃ ៣១:៤.
*គ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ឃ* ស.ប. ព្រាប, ទីសំគាល់ជា.
២៨ *ក* គ. និង ស. ១៣៨:២៥–២៦.
២៩ *ក* ស.ប. សាវក.
៣០ *ក* ស.ប. ពួកទេវតា.
៣១ *ក* ម៉ាកុស ៥:១៥–២០; ម៉ូសាយ ៣:៥–៧. ស.ប. អារក្ស.
*ខ* ស.ប. វិញ្ញាណ — អារក្សអសោចិ៍.
*គ* ស.ប. ប្រោស, ការប្រោស.
៣២ *ក* ម៉ាកុស ១៥:១៧–២០.
៣៣ *ក* យ៉ូហាន ១៩:១៦–១៩; ម៉ូសាយ ៣:៩–១០; ៣ នីហ្វៃ ២៧:១៤. ស.ប. ឈើឆ្កាង.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
៣៥ *ក* ១ នីហ្វៃ ៨:២៦; ១២:១៨.
៣៦ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.

*ពួកសិស្ស១២នាក់ និងពួកសាវក១២នាក់ ដែលនឹងជំនុំជំរះនៃសាសន៍ អ៊ីស្រាអែល; អំពីភាពដ៏គួរឲ្យខ្ពើម និងប្រឡាក់កខ្វក់របស់អស់អ្នកណា ដែលចុះអន់ថយក្នុងការឥតជំនឿ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូលមកខ្ញុំ
ថា៖ មើលន៏ ហើយចូរមើលពូជអ្នក និងពូជបងៗរបស់
អ្នកដែរ ។ ហើយខ្ញុំក៏ មើល ហើយបានឃើញដែនដីសន្យា;
ហើយខ្ញុំឃើញហ្វូងមនុស្ស មែនហើយ គឺមានចំនួនជាច្រើន
ដូចខ្សាច់នៅមាត់សមុទ្រ ។
២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញមនុស្ស
ទាំងហ្វូងប្រមូលគ្នា មកធ្វើចម្បាំងរវាងគ្នានឹងគ្នា; ហើយខ្ញុំបាន
ទាំង ឃើញសង្គ្រាម និងពាក្យចចាមអារាមអំពីសង្គ្រាមទាំង
ឡាយ និងការកាប់សម្លាប់ដោយដាវយ៉ាងធ្ងន់ធ្ងរ ក្នុង
ចំណោមសាសន៍ខ្ញុំ ។
៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញតំណ
មនុស្សជាច្រើនបានស្លាប់ទៅ ដោយសារសង្គ្រាមទាំងឡាយ
និងការ ទាស់ទែងគ្នាទាំងឡាយនៅលើដែនដីនោះ; ហើយខ្ញុំ
បានឃើញក្រុងជាច្រើន មែនហើយ គឺច្រើនរហូតដល់ខ្ញុំមិនអាច
រាប់បាន ។
៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំឃើញអ័ព្ទនៃ
សេចក្ដីងងឹត នៅលើផ្ទៃដែនដីសន្យា; ហើយខ្ញុំឃើញផ្លេកបន្ទោរ
ហើយខ្ញុំ ឮផ្គរលាន់ និងផែនដីកក្រើក ហើយនឹង
សូរស័ព្ទអឺងកងគ្រប់បែបយ៉ាង; ហើយខ្ញុំបានឃើញផែនដី និងថ្ម
ទាំងឡាយប្រេះបែកចេញ; ហើយខ្ញុំបានឃើញភ្នំទាំងឡាយ
រលំបែកទៅជាដុំៗ; ហើយខ្ញុំបានឃើញផ្ទៃដីទំនាបបែកចេញពីគ្នា;
ហើយខ្ញុំឃើញទីក្រុងជាច្រើនលិចចុះ; ហើយខ្ញុំបានឃើញ
ទីក្រុងជាច្រើនដែលត្រូវភ្លើងឆេះ; ហើយខ្ញុំបានឃើញក្រុង
ជាច្រើនរលំខ្ទាត់ខ្ចាយទៅលើដី មកពីការកក្រើកផែនដី ។
៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំបានឃើញ
រឿងទាំងនេះហើយ នោះខ្ញុំបានឃើញចំហាយនៃសេចក្ដីងងឹត
គឺចំហាយនោះហុយចេញពីលើផ្ទៃផែនដី; ហើយមើលចុះ
ខ្ញុំបានឃើញមនុស្សទាំងហ្វូង ដែលមិនរលំដួលដោយសារ
ការជំនុំជំរះ ដ៏មហិមា និងគួរឲ្យស្ញែងខ្លាចរបស់ព្រះអម្ចាស់ ។
៦ ហើយខ្ញុំបានឃើញផ្ទៃមេឃបើកចំហ ហើយកូនចៀមនៃ
ព្រះ ទ្រង់យាងចុះមកពីលើមេឃ; ហើយទ្រង់បានយាងចុះមក
ហើយបង្ហាញរូបអង្គទ្រង់ដល់ពួកគេ ។
៧ ហើយខ្ញុំក៏បានឃើញ ហើយធ្វើបន្ទាល់ដែរថា ព្រះវិញ្ញាណ
បរិសុទ្ធបានយាងចុះមកសណ្ឋិតលើមនុស្ស១២នាក់ទៀត; ហើយ
ពួកគេ ត្រូវបានតែងតាំងដោយព្រះ ហើយត្រូវបានរើស ។
៨ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៏ សិស្ស១២នាក់នៃកូ
នចៀម ដែលត្រូវបានរើស ដើម្បីធ្វើការងារបំរើដល់ពូជអ្នក ។
៩ ហើយលោកមានបន្ទូលមកខ្ញុំថា៖ តើអ្នកចាំពួក
សាវក១២នាក់នៃកូនចៀមឬទេ ? មើលន៏ ពួកគេនោះហើយ
ដែលនឹងជំនុំជំរះ ពូជអំបូរអ៊ីស្រាអែលទាំង១២ពូជ; ហេតុ
ដូច្នោះហើយ ពួកអ្នកធ្វើការងារបំរើ១២នាក់ពីពូជអ្នក នឹងត្រូវ
បានទទួលការជំនុំជំរះពី ពួកគេ ត្បិតអ្នករាល់គ្នាជាវ
ង្សអ៊ីស្រាអែល ។
១០ ហើយពួកអ្នកធ្វើការងារបំរើ១២នាក់ដែលអ្នកបាន
ឃើញនោះ នឹងជំនុំជំរះពូជអ្នក ។ ហើយមើលចុះ ពួកគេជាអ្នក
សុចរិត រហូតតទៅ; ត្បិតដោយសារសេចក្ដីជំនឿរបស់ពួកគេ
ដែលជឿដល់កូនចៀមនៃព្រះ នោះសំលៀកបំពាក់របស់ពួកគេ
នឹងត្រូវលាងជំរះ ឲ្យបានស ដោយលោហិតរបស់ទ្រង់ ។
១១ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៏ ! ហើយ
ខ្ញុំក៏មើល ហើយបានឃើញមនុស្សបីតំណបានស្លាប់ទៅ នៅ
ក្នុងសេចក្ដី សុចរិត; ហើយសំលៀកបំពាក់របស់គេសោត
សដូចកូនចៀមនៃព្រះ ។ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖
សំលៀកបំពាក់ទាំងនេះបាន លាងជំរះឲ្យស ដោយលោហិត
នៃកូនចៀម ដោយសារសេចក្ដីជំនឿរបស់ពួកគេ ដែលជឿ
ដល់ទ្រង់ ។

**១២** ១*ក* ស.ប. ដែនដីសន្យា.
២ *ក* អេណុស ១:២៤; មរមន ៨:៧–៨.
ស.ប. សង្គ្រាម.
៤ *ក* ហេលេ. ១៤:២០–២៨.
*ខ* ១ នីហ្វៃ ១៩:១០.
*គ* ៣ នីហ្វៃ ៨:១៤.
៥ *ក* ៣ នីហ្វៃ ៨:២០; ១០:៩.
៦ *ក* ២ នីហ្វៃ ២៦:១, ៩;
៣ នីហ្វៃ ១១:៣–១៧.
៧ *ក* ៣ នីហ្វៃ ១២:១; ១៩:១២–១៣.
៩ *ក* លូកា ៦:១៣.
*ខ* ម៉ាថាយ ១៩:២៨;
គ. និង ស. ២៩:១២.
ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
១០ *ក* ៣ នីហ្វៃ ២៧:២៧;
មរមន ៣:១៨–១៩.
*ខ* វិវរ. ៧:១៤; អាលម៉ា ៥:២១–
២៧; ១៣:១១–១៣;
៣ នីហ្វៃ ២៧:១៩–២០.
១១ *ក* ២ នីហ្វៃ ២៦:៩–១០;
៣ នីហ្វៃ ២៧:៣០–៣២.

១២ ហើយខ្ញុំ នីហ្វៃ ក៏បានឃើញមនុស្សជាច្រើនក្នុងតំណទីបួនបានស្លាប់ទៅ នៅក្នុងសេចក្ដីសុចរិតដែរ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញពួកបណ្ដាជននៅលើផែនដីប្រមូលរួមគ្នា ។

១៤ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៏ ពូជអ្នក និងពូជបងៗរបស់អ្នកដែរ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំក៏មើល ហើយបានឃើញមនុស្សនៃពូជខ្ញុំ ប្រមូលគ្នាទាំងហ្វូង ទៅទាស់នឹងពូជបងៗ របស់ខ្ញុំ; ហើយពួកគេប្រមូលគ្នា ដើម្បីទៅធ្វើចម្បាំង ។

១៦ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៏ ប្រភពទឹកកខ្វក់ដែលឪពុកអ្នកបានឃើញមកនោះ; មែនហើយ គឺជាទន្លេដែលលោក បាននិយាយផងដែរ; ហើយជំរៅរបស់វាគឺជាជំរៅនៃស្ថាននរក ។

១៧ ហើយអ័ព្ទនៃសេចក្ដីងងឹត គឺជាការល្បួងរបស់អារក្សដែលធ្វើឲ្យភ្នែកទាំងឡាយខ្វាក់ ហើយធ្វើឲ្យចិត្តទាំងឡាយកូនចៅមនុស្ស រឹងរូស ហើយនាំពួកគេទៅតាមផ្លូវទូលាយទាំងឡាយដើម្បីឲ្យពួកគេវិនាស ហើយវង្វេងបាត់ទៅ ។

១៨ ហើយអាគារដ៏ធំ ហើយទូលាយ ដែលឪពុកអ្នកបានឃើញមកនោះ គឺជាគំនិតដ៏ឥតប្រយោជន៍ និងជាសេចក្ដីឆ្មើងឆ្មៃនៃកូនចៅ មនុស្ស ។ ហើយជង្ហុកមួយយ៉ាងធំ ហើយគួរឲ្យស្ញែងខ្លាចនោះបំបែកពួកគេ; មែនហើយ គឺជាព្រះបន្ទូលនៃសេចក្ដីយុត្តិធម៌របស់ព្រះ ដ៏នៅអស់កល្បជានិច្ច និងព្រះមែស៊ី ជាកូនចៀមនៃព្រះ ដែលព្រះជាព្រះវិញ្ញាណបរិសុទ្ធទ្រង់ធ្វើបន្ទាល់ តាំងពីកំណើតលោកិយមក រហូតដល់ពេលនេះ ហើយតាំងពីពេលនេះជារៀងដរាបតទៅ ។

១៩ ហើយខណៈដែលទេវតាមានបន្ទូលនូវពាក្យទាំងនេះនោះខ្ញុំក៏មើល ហើយបានឃើញពូជបងៗរបស់ខ្ញុំបានទាស់នឹងពូជខ្ញុំ ស្របតាមពាក្យរបស់ទេវតា; ហើយមកពីសេចក្ដីឆ្មើងឆ្មៃនៃពូជខ្ញុំ និងសេចក្ដីល្បួងទាំងឡាយរបស់អារក្ស នោះខ្ញុំបានឃើញថា ពូជបងៗរបស់ខ្ញុំ បានឈ្នះលើប្រជាជននៃពូជខ្ញុំ ។

២០ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានមើល ហើយបានឃើញថា ប្រជាជននៃពូជបងៗរបស់ខ្ញុំបានឈ្នះលើពូជខ្ញុំ; ហើយពួកគេដើរទាំងហ្វូងៗនៅលើផ្ទៃដែនដី ។

២១ ហើយខ្ញុំបានឃើញពួកគេប្រមូលគ្នាទាំងហ្វូង; ហើយខ្ញុំបានឃើញសង្គ្រាម និងពាក្យចចាមអារាម អំពីសង្គ្រាមទាំងឡាយ ក្នុងចំណោមពួកគេ; ហើយខ្ញុំបានឃើញតំណមនុស្សជាច្រើនបានស្លាប់ទៅ នៅក្នុងសង្គ្រាម និងពាក្យចចាមអារាមអំពីសង្គ្រាម ទាំងឡាយ ។

២២ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលចុះ ពួកមនុស្សទាំងនេះ នឹងចុះអន់ថយក្នុងការឥតជំនឿ ។

២៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញថាបន្ទាប់ពីពួកគេបានចុះអន់ថយ ក្នុងការឥតជំនឿ នោះពួកគេបានក្លាយ ទៅជាមនុស្សខ្មៅ ហើយគួរស្អប់ខ្ពើម និងកខ្វក់ពោរពេញទៅដោយការខ្ជិលច្រអូស និងការគួរខ្ពើមឆ្អើមគ្រប់បែបយ៉ាង ៕

## ជំពូកទី ១៣

*នីហ្វៃឃើញនៅក្នុងការនិមិត្ត អំពីសាសនាចក្រនៃអារក្សដែលកើតឡើង ក្នុងចំណោមពួកសាសន៍ដទៃ, អំពីការរកឃើញ និងការធ្វើ និគមកិច្ចនៃទ្វីបអាមេរិក, អំពីការបាត់បង់នៃផ្នែកច្បាស់ៗនិងពិសេសជាច្រើននៃព្រះគម្ពីរប៊ីប, អំពីផលវិបាកដោយសារសេចក្ដីក្បត់ សាសនានៃសាសន៍ដទៃ, អំពីការសាងឡើងវិញនៃដំណឹងល្អ, អំពីការនាំមកនូវព្រះគម្ពីរថ្ងៃចុងក្រោយ, និងអំពីការកសាងក្រុងស៊ីយ៉ូន ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូលមកខ្ញុំថា៖

១២ *ក* អាលម៉ា ៤៥:១០–១២; ហេលេ. ១៣:៥, ៩–១០; ៣ នីហ្វៃ ២៧:៣២; ៤ នីហ្វៃ ១:១៤–២៧.
១៥ *ក* មរមន ៦.
១៦ *ក* ស.ប. ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក.
*ខ* ១ នីហ្វៃ ៨:១៣; ១៥:២៦–២៩.
*គ* ស.ប. ស្ថាននរក.
១៧ *ក* ១ នីហ្វៃ ៨:២៣; ១៥:២៤; គ. និង ស. ១០:២០–៣២.
*ខ* ស.ប. សេចក្ដីក្បត់សាសនា.
*គ* ម៉ាថាយ ៧:១៣–១៤.
១៨ *ក* ១ នីហ្វៃ ៨:២៦; ១១:៣៥–៣៦.
*ខ* យេរេ. ៧:២៤.
*គ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ឃ* លូកា ១៦:២៦; ១ នីហ្វៃ ១៥:២៨–៣០.
*ង* ស.ប. សេចក្ដីយុត្តិធម៌.
១៩ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* យ៉ារ៉ុម ១:១០; ព. នៃ ម៉. ១:១–២.
២១ *ក* មរមន ៨:៨; មរ៉ូណៃ ១:២. ស.ប. សង្គ្រាម.
២២ *ក* ១ នីហ្វៃ ១៥:១៣; ២ នីហ្វៃ ២៦:១៥.
២៣ *ក* ២ នីហ្វៃ ២៦:៣៣.
*ខ* ២ នីហ្វៃ ៥:២០–២៥.
*គ* ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.

មើលន៍! ហើយខ្ញុំក៏មើល ហើយបានឃើញសាសន៍ និងនគរ
ជាច្រើន ។
២ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ តើអ្នកឃើញអ្វី? ហើយ
ខ្ញុំទូលថា៖ ខ្ញុំឃើញសាសន៍ និងនគរជាច្រើន ។
៣ ហើយលោកមានបន្ទូលមកខ្ញុំថា៖ នេះគឺជាសាសន៍ និង
នគរទាំងឡាយរបស់ពួកសាសន៍ដទៃ ។
៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញសាសនា
ចក្រ[ក]ធំមួយកើតឡើង ក្នុងចំណោមសាសន៍ទាំងឡាយ [ខ]នៃពួក
សាសន៍ ដទៃ ។
៥ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៍ ការ
បង្កើតឡើងនៃសាសនាចក្រ [ក]ដ៏គួរខ្ពើមឆ្អើមបំផុត ជាងសាសនា
ចក្រណាៗទាំងអស់ ដែលសម្លាប់ពួកបរិសុទ្ធនៃព្រះ មែន
ហើយ ហើយទាំងធ្វើទុក្ខពួកគេ និងចងពួកគេចុះ និងបំពាក់
[ខ]នឹមដែកលើពួកគេ ហើយនាំពួកគេចុះ ទៅក្នុងការជាប់ឃុំឃាំង ។
៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញសាសនា
ចក្រ[ក]ដ៏ធំ ហើយគួរខ្ពើមឆ្អើម; ហើយខ្ញុំបានឃើញ[ខ]ថា អារក្ស ជា
អ្នក បង្កើតសាសនាចក្រនេះ ។
៧ ហើយខ្ញុំបានឃើញ[ក]ទាំងមាស និងប្រាក់ និងសំពត់សូត្រ
ទាំងឡាយ និងសំពត់ពណ៌ក្រហមទាំងឡាយ និងសំពត់ត្បាញ
ដោយអំបោះ ខ្លូតទេសវេញយ៉ាងខ្មាញ់ ព្រមទាំង
សំលៀកបំពាក់ ដ៏មានតម្លៃៗគ្រប់បែបយ៉ាង; ហើយខ្ញុំឃើញ
ពួកស្រីពេស្យាជាច្រើន ។
៨ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលចុះ មាស និង
ប្រាក់ និងសំពត់សូត្រទាំងឡាយ និងសំពត់ពណ៌ក្រហមទាំង
ឡាយ និងសំពត់ ត្បាញដោយអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់
និងសំលៀកបំពាក់ដ៏មានតម្លៃ ហើយនឹងពួកស្រីពេស្យាទាំង
ឡាយនេះ គឺជា[ក]សេចក្ដីប្រាថ្នា នៃសាសនាចក្រដ៏ធំ ហើយ
គួរខ្ពើមឆ្អើមនោះ ។
៩ ហើយក៏ដើម្បីសេចក្ដីសរសើរដំកើងនៃមនុស្សលោកផងដែរ
នោះពួកគេ[ក]បំផ្លាញពួកបរិសុទ្ធនៃព្រះ ហើយចាប់ពួកគេចុះទៅ
ក្នុងការ ជាប់ឃុំឃាំង ។
១០ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានមើល
ហើយឃើញផ្ទៃទឹកដ៏ធំ ហើយផ្ទៃទឹកនោះ បំបែកពួកសាសន៍
ដទៃចេញពីពូជ បងៗរបស់ខ្ញុំ ។
១១ ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូល
មកខ្ញុំថា៖ មើលន៍ សេចក្ដីក្រោធនៃព្រះ កំពុងតែធ្លាក់មកលើ
ពូជបងៗ របស់អ្នក។
១២ ហើយខ្ញុំក៏មើល ហើយបានឃើញបុរសម្នាក់ ក្នុងចំណោម
ពួកសាសន៍ដទៃ ដែលត្រូវឃ្លាតចេញពីពូជបងៗរបស់ខ្ញុំ ដោយផ្ទៃ
ទឹកដ៏ធំ; ហើយខ្ញុំបានឃើញថា [ក]ព្រះវិញ្ញាណនៃព្រះយាងចុះមក
សណ្ឋិតលើបុរសនោះ; ហើយលោកចេញដំណើរឆ្លង
កាត់ផ្ទៃទឹកដ៏ធំនោះ គឺទៅឯពូជបងៗរបស់ខ្ញុំ ដែល
នៅលើដែនដីសន្យា ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញថា
ព្រះវិញ្ញាណនៃព្រះយាងមកសណ្ឋិតលើពួកសាសន៍ដទៃផ្សេងទៀត;
ហើយពួកគេបានរួចផុតពីការជាប់ឃុំឃាំង ដោយ
ឆ្លងកាត់លើផ្ទៃទឹកដ៏ធំនោះ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញពួក
សាសន៍ដទៃទាំង[ក]ហ្វូងៗ នៅលើដែនដីសន្យានោះ; ហើយខ្ញុំបាន
ឃើញថា សេចក្ដីក្រោធនៃព្រះ ធ្លាក់លើពូជបងៗរបស់ខ្ញុំ;
ហើយពួកគេត្រូវ[គ]បែកខ្ចាត់ខ្ចាយ នៅចំពោះពួកសាសន៍ដទៃ
ហើយត្រូវវាយដំកំទេច ។
១៥ ហើយខ្ញុំបានឃើញថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ យាង
មកសណ្ឋិតលើពួកសាសន៍ដទៃ ហើយពួកគេក៏បានចំរើនឡើង
ហើយ បានដែនដី[ក]ទុកជាកេរ្តិ៍អាករដល់ពួកគេ; ហើយខ្ញុំបាន
ឃើញថា ពួកគេមានសម្បុរស ហើយស្រស់ល្អ ហើយ
[ខ]ស្អាតដ៏លើសលប់ ដូចជា សាសន៍ខ្ញុំ មុនពេលដែលពួកគេត្រូវ
[គ]បានស្លាប់ទៅ ។

---

១៣ ៤ *ក* ស.ប. ពួកសាសន៍ដទៃ.
*ខ* ១ នីហ្វៃ ១៣:២៦, ៣៤; ១៤:៣, ៩–១៧.
៥ *ក* វិវរ. ១៧:៣–៦; ១ នីហ្វៃ ១៤:១៣.
*ខ* យេរេ. ២៨:១០–១៤.
៦ *ក* គ. និង ស. ៨៨:៩៤.
ស.ប. អារក្ស — សាសនាចក្រនៃអារក្ស.
*ខ* ១ នីហ្វៃ ២២:២២–២៣.
៧ *ក* មរមន ៨:៣៦–៣៨.
៨ *ក* វិវរ. ១៨:១០–២៤; មរមន ៨:៣៥–៣៨.
៩ *ក* វិវរ. ១៣:៤–៧.
១២ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
១៤ *ក* ២ នីហ្វៃ ១:១១; មរមន ៥:១៩–២០.
*ខ* ស.ប. ដែនដីសន្យា.
*គ* ១ នីហ្វៃ ២២:៧–៨.
ស.ប. អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
១៥ *ក* ២ នីហ្វៃ ១០:១៩.
*ខ* ២ នីហ្វៃ ៥:២១.
*គ* មរមន ៦:១៧–២២.

១៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានឃើញថា ពួកសាសន៍ដទៃដែលបានរួចផុតពីការជាប់ឃុំឃាំង បានបន្ទាបខ្លួន នៅចំពោះព្រះអម្ចាស់; ហើយព្រះចេស្ដានៃព្រះអម្ចាស់បានស្ថិតនៅជាមួយនឹងពួកគេ ។

១៧ ហើយខ្ញុំបានឃើញថា មាតានៃពួកសាសន៍ដទៃ បានប្រមូលគ្នានៅលើទឹក ហើយនៅលើដី ដើម្បីទៅច្បាំងនឹងពួកគេ ។

១៨ ហើយខ្ញុំបានឃើញថា ព្រះចេស្ដានៃព្រះបានស្ថិតនៅជាមួយនឹងពួកគេ ហើយក៏បានឃើញថា សេចក្ដីក្រោធនៃព្រះ បានធ្លាក់មក លើអស់អ្នកណា ដែលប្រមូលគ្នាមកច្បាំងនឹងពួកគេ ។

១៩ ហើយខ្ញុំ នីហ្វៃ បានឃើញថា ពួកសាសន៍ដទៃដែលបានរួចផុតពីការជាប់ឃុំឃាំង នោះត្រូវបានដោះលែង ដោយព្រះចេស្ដា នៃព្រះ ឲ្យរួចផុតពីកណ្ដាប់ដៃនៃគ្រប់អស់ទាំងសាសន៍ផ្សេងៗ ។

២០ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានឃើញថា ពួកគេបានចំរើនឡើងនៅលើដែនដី; ហើយខ្ញុំបានឃើញគម្ពីរមួយ ហើយគម្ពីរនោះត្រូវបាននាំចេញទៅក្នុងចំណោមពួកគេ ។

២១ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ តើអ្នកយល់ន័យពីគម្ពីរនោះឬទេ ?

២២ ហើយខ្ញុំបានទូលលោកថា៖ ខ្ញុំមិនយល់ទេ ។

២៣ ហើយលោកមានបន្ទូលថា៖ មើលចុះ គម្ពីរនេះចេញមកពីមាត់របស់សាសន៍យូដាម្នាក់ ។ ហើយខ្ញុំ នីហ្វៃ បានឃើញគម្ពីរនោះ; ហើយលោកមានបន្ទូលមកខ្ញុំថា៖ គម្ពីរដែលអ្នកឃើញនោះ គឺជាបញ្ជីមួយរបស់ពួកសាសន៍យូដា ដែលមានសេចក្ដីសញ្ញាទាំងឡាយ នៃព្រះអម្ចាស់ ដែលទ្រង់បានធ្វើជាមួយនឹងវង្សអ៊ីស្រាអែល; ហើយគម្ពីរនោះ ក៏មានពាក្យព្យាករណ៍ជាច្រើននៃពួកព្យាការីបរិសុទ្ធទាំង ឡាយ; ហើយគឺជាបញ្ជី ដូចគ្នានឹងឆ្លាក់ត្រា ដែលឆ្លាក់នៅលើផ្ទាំងលង្ហិន លើកលែងតែមិនសូវមានច្រើន ដូចនៅលើផ្ទាំងទាំងនោះ ទេ; ទោះជាយ៉ាងណាក៏ដោយ គង់តែគម្ពីរនេះមានសេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ ដែលទ្រង់បានធ្វើជាមួយនឹងវង្សអ៊ីស្រាអែល; ម្ល៉ោះហើយ គម្ពីរនេះមានប្រយោជន៍ដ៏ធំ ដល់ពួកសាសន៍ដទៃ ។

២៤ ហើយទេវតានៃព្រះអម្ចាស់មានបន្ទូលមកខ្ញុំថា៖ អ្នកបានឃើញហើយថា គម្ពីរនេះចេញមកពីមាត់របស់សាសន៍យូដាម្នាក់; ហើយកាលគម្ពីរនេះបានចេញមកពីមាត់សាសន៍យូដា គម្ពីរនេះមាននូវភាពពោរពេញនៃដំណឹងល្អរបស់ព្រះអម្ចាស់ ដែលពួកសាវក ១២នាក់ ធ្វើបន្ទាល់; ហើយពួកគេធ្វើបន្ទាល់ស្របតាមសេចក្ដីពិត ដែលនៅក្នុងកូនចៀមនៃព្រះ ។

២៥ ហេតុដូច្នោះហើយ ការណ៍ទាំងនេះចេញមកពីពួកសាសន៍យូដា ទៅឯពួកសាសន៍ដទៃ ក្នុងសេចក្ដីបរិសុទ្ធ ស្របតាមសេចក្ដីពិត ដែលនៅក្នុងព្រះ ។

២៦ ហើយបន្ទាប់ពីការណ៍ទាំងនេះ ចេញពីពួកសាសន៍យូដា ទៅឯពួកសាសន៍ដទៃ ដោយសារស្នាដៃរបស់ពួកសាវក១២នាក់នៃ កូនចៀមហើយ នោះអ្នកនឹងឃើញការបង្កើតឡើងនៃសាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើម គឺគួរខ្ពើមឆ្អើមជាងសាសនាចក្រឯណាៗ ទាំងអស់; ត្បិតមើលចុះ ពួកគេបានដកយកភាគដ៏ច្បាស់ និងពិសេសៗជាច្រើនចេញពីដំណឹងល្អនៃកូនចៀម; ហើយថែមទាំងដកយក សេចក្ដីសញ្ញាទាំងឡាយ នៃព្រះអម្ចាស់ជាច្រើនចេញដែរ ។

២៧ ហើយគ្រប់ការណ៍អស់ទាំងនេះហើយដែលពួកគេបានធ្វើ ដើម្បីពួកគេអាចបង្ខូចផ្លូវដ៏ត្រឹមត្រូវទាំងឡាយនៃព្រះអម្ចាស់ ដើម្បីពួក គេអាចធ្វើឲ្យភ្នែកទាំងឡាយខ្វាក់ ហើយធ្វើឲ្យចិត្តទាំងឡាយនៃកូនចៅមនុស្សរឹងរូស ។

២៨ ហេតុដូច្នោះហើយ អ្នកឃើញហើយថា បន្ទាប់ពីពេលដែលគម្ពីរនោះ ធ្លាក់ទៅដល់ដៃនៃសាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើម នោះហើយ នោះសេចក្ដីដ៏ច្បាស់ និងពិសេសៗជាច្រើន ត្រូវបានដកយកពីគម្ពីរនោះចេញ គឺជាគម្ពីររបស់កូនចៀមនៃព្រះ ។

២៩ ហើយបន្ទាប់ពីសេចក្ដីដ៏ច្បាស់ និងពិសេសៗទាំងប៉ុន្មានត្រូវបានដកយកចេញហើយនោះ គម្ពីរនេះនឹងត្រូវបានផ្សាយ

១៦ ក គ. និង ស. ១០១:៨០.
១៩ ក ២ នីហ្វៃ ១០:១០–១៤; ៣ នីហ្វៃ ២១:៤; អេធើរ ២:១២.
២០ ក ១ នីហ្វៃ ១៤:២៣.
២៣ ក ១ នីហ្វៃ ១៣:៣៨; ២ នីហ្វៃ ២៩:៤–១២.
ខ ស.ប. បទព្រះគម្ពីរ.
គ ២ នីហ្វៃ ៣:១២.
ឃ ១ នីហ្វៃ ៥:១០–១៣.
២៥ ក ២ នីហ្វៃ ២៩:៤–៦; គ. និង ស. ៣:១៦. ស.ប. ពួកសាសន៍យូដា.
ខ ស.ប. ពួកសាសន៍ដទៃ.
២៦ ក ម៉ាថាយ ២១:៤៣.
ខ ១ នីហ្វៃ ១៣:៤–៦; ១៤:៣, ៩–១៧.
គ ស.ប. សេចក្ដីក្បត់សាសនា — សេចក្ដីក្បត់សាសនានៃសាសនាចក្រគ្រិស្ទានដើម.
ឃ មរមន ៨:៣៣; ម៉ូសេ ១:៤១.
ង ១ នីហ្វៃ ១៤:២០–២៦; ម. នៃ ស. ១:៨.

ទៅគ្រប់ ទាំងសាសន៍នៃពួកសាសន៍ដទៃ; ហើយបន្ទាប់ពីគម្ពីរនេះ ត្រូវបានផ្សាយទៅគ្រប់ទាំងសាសន៍នៃពួកសាសន៍ដទៃហើយមែនហើយ គឺនឹងឆ្លងកាត់ផ្ទៃទឹកដ៏ធំ ដែលអ្នកបានឃើញទៅជាមួយនឹងពួកសាសន៍ដទៃ ដែលបានចេញរួចផុតពីការជាប់ឃុំឃាំងនោះហើយ នោះអ្នកបានឃើញ — ពីព្រោះមកពីសេចក្ដីដ៏ច្បាស់ និងពិសេសៗជាច្រើន ដែលបានដកយកពីគម្ពីរនេះចេញ គឺជាសេចក្ដីដ៏ច្បាស់ ចំពោះការយល់ដល់កូនចៅមនុស្ស តាមសេចក្ដីច្បាស់លាស់ ដែលនៅក្នុងកូនចៀមនៃព្រះ — ពីព្រោះមកពីសេចក្ដីទាំងនេះត្រូវបាន ដកយកចេញពីដំណឹងល្អនៃកូនចៀមបានជាមនុស្សជាច្រើនលើសលប់ ត្រូវជំពប់ដួល មែនហើយ រហូតដល់អារក្សសាតាំងមានអំណាច ដ៏ធំទៅលើពួកគេ ។

៣០ ទោះជាយ៉ាងណាក៏ដោយ គង់តែអ្នកបានឃើញថា ពួកសាសន៍ដទៃដែលបានរួចផុតពីការជាប់ឃុំឃាំងនោះ ត្រូវបានលើកឡើង ដោយព្រះចេស្ដានៃព្រះ ឲ្យខ្ពស់ជាងសាសន៍នានាទាំងអស់នៅលើដែនដី ដែលជាជំរើសលើដែនដីឯទៀតទាំងអស់ គឺជាដែនដីដែល ព្រះអម្ចាស់ទ្រង់បានធ្វើសេចក្ដីសញ្ញាជាមួយនឹងឪពុកអ្នកថា ពូជលោកនឹងបាន[ក]ដែនដីនៃកេរ្ដិ៍អាកររបស់គេ; ហេតុដូច្នោះហើយ អ្នកបានឃើញថា ព្រះអម្ចាស់ដ៏ជាព្រះទ្រង់មិនព្រមឲ្យពួកសាសន៍ដទៃ [ខ]បំផ្លាញពូជអ្នកដែលនៅក្នុងចំណោមពួកបងប្អូនរបស់អ្នកឲ្យសាប សូន្យអស់ឡើយ ។

៣១ ហើយទ្រង់ក៏មិនព្រមឲ្យពួកសាសន៍ដទៃ [ក]បំផ្លាញពូជបងៗរបស់អ្នកដែរ ។

៣២ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ក៏មិនព្រមឲ្យពួកសាសន៍ដទៃ ស្ថិតនៅក្នុងសភាពល្ងិតល្ងង់តទៅទៀតឡើយ ដែលអ្នកបាន ឃើញហើយថា ពួកគេកំពុងតែនៅក្នុងសភាពបែបនេះ ដោយមកពីភាគដ៏ច្បាស់ និងពិសេសៗទាំងប៉ុន្មាននៃដំណឹងល្អរបស់កូនចៀម ត្រូវបានយកចេញដោយសាសនាចក្រ[ក]ដ៏គួរខ្ពើមឆ្អើម ឯការបង្កើតសាសនាចក្រនោះអ្នកបានឃើញហើយ ។

៣៣ ហេតុដូច្នោះហើយ កូនចៀមនៃព្រះមានព្រះបន្ទូលថា៖ យើងនឹងមេត្តាដល់ពួកសាសន៍ដទៃ រហូតដល់មកធ្វើទោសដល់សំណល់នៃវង្សអ៊ីស្រាអែល ដោយការជំនុំជំរះដ៏ធំ ។

៣៤ ហើយហេតុការណ៍បានកើតឡើងថា ទេវតានៃព្រះអម្ចាស់មានបន្ទូលមកខ្ញុំថា៖ មើលចុះ កូនចៀមនៃព្រះមានព្រះបន្ទូលដូច្នេះថា បន្ទាប់ពីយើងមកពិនិត្យពិច័យ[ក]សំណល់នៃវង្សអ៊ីស្រាអែល — ហើយសំណល់ដែលយើងពោលដល់នេះ គឺជាពូជឪពុករបស់អ្នក — ហេតុដូច្នោះហើយ បន្ទាប់ពីយើងមកពិនិត្យពិច័យពួកគេដោយការជំនុំជំរះ ហើយវាយពួកគេដោយដៃរបស់ពួកសាសន៍ដទៃ ហើយបន្ទាប់ពីពួកសាសន៍ដទៃ[ខ]ជំពប់ដួលជាខ្លាំងដោយមកពីភាគដ៏ច្បាស់ និងពិសេសៗទាំងប៉ុន្មាននៃ[គ]ដំណឹងល្អរបស់កូនចៀមត្រូវបាន យកចេញ ដោយសាសនាចក្រដ៏គួរខ្ពើមឆ្អើមនោះ ដែលជាមាតានៃពួកស្រីពេស្យា នោះកូនចៀមមានព្រះបន្ទូលថាដូច្នោះ — យើងនឹង [ឃ]មេត្តាដល់ពួកសាសន៍ដទៃនៅថ្ងៃនោះ គឺដរាបដល់យើងនឹងនាំចេញមកដល់ពួកគេ ដោយអំណាចយើងផ្ទាល់ នូវភាគច្រើននៃដំណឹងល្អរបស់យើង ដែលនឹងទៅជាសេចក្ដីច្បាស់ និងពិសេសៗ កូនចៀមមានព្រះបន្ទូលថាដូច្នោះ ។

៣៥ ត្បិតមើលចុះ កូនចៀមមានព្រះបន្ទូលថា៖ យើងនឹងសម្ដែងខ្លួនឲ្យពូជអ្នកឃើញ ដើម្បីឲ្យពួកគេសរសេរអំពីអ្វីៗជាច្រើន ដែលយើងនឹងធ្វើការងារបំរើដល់ពួកគេ ដែលនឹងទៅជាសេចក្ដីច្បាស់ និងពិសេសៗ; ហើយបន្ទាប់ពីពូជអ្នកត្រូវបានបំផ្លាញចោល ហើយចុះអន់ថយ[ក]ក្នុងការឥតជំនឿហើយពូជបងៗរបស់អ្នកផងនោះ មើលចុះ សេចក្ដីទាំងនេះនឹងត្រូវបានលាក់ទុក ដើម្បីឲ្យបានចេញ មកដល់ពួកសាសន៍ដទៃដោយអំណោយទាន និងព្រះចេស្ដានៃកូនចៀម ។

៣៦ កូនចៀមមានព្រះបន្ទូលថា ទាំង[ក]ដំណឹងល្អ និង[ខ]ថ្ម ហើយនឹងសេចក្ដីសង្គ្រោះរបស់យើង នឹងត្រូវបានសរសេរទុកនៅក្នុងគម្ពីរទាំង នេះ ។

៣៧ នោះមាន[ក]ពរហើយ ដល់អស់អ្នកណា ដែលនឹងព្យាយាមខំនាំក្រុង[ខ]ស៊ីយ៉ូនរបស់យើងចេញមកនៅថ្ងៃនោះ ត្បិត

៣០ ក ស.ប. ដែនដីសន្យា.
ខ អាលម៉ា ៤៥:១០–១៤.
៣១ ក ២ នីហ្វៃ ៤:៧; ១០:១៨–១៩; យ៉ាកុប ៣:៥–៩; ហេលេ. ១៥:១២; ៣ នីហ្វៃ ១៦:៨–៩; មរមន ៥:២០–២១.
៣២ ក ស.ប. អារក្ស — សាសនាចក្រនៃអារក្ស.
៣៤ ក ស.ប. យ៉ូសែប, កូនប្រុសរបស់យ៉ាកុប.
ខ ១ នីហ្វៃ ១៤:១–៣; ២ នីហ្វៃ ២៦:២០.
គ ស.ប. ដំណឹងល្អ.
ឃ គ. និង ស. ១០:៦២. ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៣៥ ក ២ នីហ្វៃ ២៧:៦; ២៩:១–២. ស.ប. ព្រះគម្ពីរមរមន.
៣៦ ក ៣ នីហ្វៃ ២៧:១៣–២១.
ខ ហេលេ. ៥:១២; ៣ នីហ្វៃ ១១:៣៨–៣៩. ស.ប. ថ្ម.
៣៧ ក គ. និង ស. ២១:៩.
ខ ស.ប. ស៊ីយ៉ូន.

ពួកគេនឹងបាន ទទួល[គ]អំណោយទាន និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ; ហើយបើពួកគេ[ឃ]កាន់ខ្ជាប់ ដរាបដល់ចុងបំផុត នោះពួកគេនឹងត្រូវបានលើក [ង]ឡើង នៅថ្ងៃចុងក្រោយបង្អស់ ហើយនឹងបានសង្គ្រោះ [ច]នៅក្នុងនគរដ៏អស់កល្បជានិច្ចនៃកូនចៀម; ហើយអស់អ្នកណាប្រកាសប្រាប់ពី សេចក្ដីសុខសាន្ដ មែនហើយ គឺដំណឹងពីសេចក្ដីអំណរដ៏អស្ចារ្យ នោះល្អណាស់ហ្ន៎ គឺពួកអ្នកដែលដើរលើភ្នំ ។

៣៨ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញសំណល់នៃពូជបងៗរបស់ខ្ញុំ និងព្រមទាំង[ក]គម្ពីររបស់កូនចៀមនៃព្រះដែរ ដែលបានចេញមកពីមាត់របស់សាសន៍យូដា ថាគម្ពីរនោះបានចេញមកពីពួកសាសន៍ដទៃ [ខ]ដល់សំណល់នៃពូជបងៗរបស់ខ្ញុំ ។

៣៩ ហើយបន្ទាប់ពីគម្ពីរនោះបានមកដល់ពួកគេហើយ នោះខ្ញុំឃើញ[ក]គម្ពីរផ្សេងៗទៀត ដែលត្រូវបាននាំចេញមកដោយព្រះចេស្ដា នៃកូនចៀម គឺចេញមកពីពួកសាសន៍ដទៃដល់ពួកគេ ដើម្បី[ខ]ជាការបរិវត្តន៍ដល់ពួកសាសន៍ដទៃ និងសំណល់នៃពូជបងៗរបស់ខ្ញុំ និងពួក សាសន៍យូដា ដែលបានខ្ចាត់ខ្ចាយពាសពេញលើផ្ទៃផែនដីផងថា បញ្ជីទាំងឡាយនៃពួកព្យាការី និងនៃពួកសាវក១២នាក់នៃកូនចៀម គឺជា[គ]សេចក្ដីពិត ។

៤០ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ [ក]បញ្ជីចុងក្រោយទាំងឡាយនេះ ដែលអ្នកបានឃើញក្នុងចំណោមពួកសាសន៍ដទៃនោះ នឹង[ខ]តាំងនូវសេចក្ដីពិតអំពី[គ]បញ្ជីមុន ដែលជាបញ្ជីនៃពួកសាវក១២នាក់នៃកូនចៀម ហើយនឹងបង្ហាញឲ្យដឹងសេចក្ដីដ៏ច្បាស់ និងពិសេសៗ ដែលបានដកយកពីបញ្ជីទាំងនោះ; ហើយនឹងបង្ហាញដល់គ្រប់ទាំងពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជនឲ្យដឹងថា កូនចៀមនៃព្រះ គឺជា[ឃ]ព្រះរាជបុត្រានៃព្រះវរបិតា ដ៏នៅអស់កល្បជានិច្ច ហើយគឺជាព្រះអង្គសង្គ្រោះនៃពិភពលោក; ហើយថា មនុស្ស ទាំងអស់ត្រូវតែមករកព្រះអង្គ បើពុំនោះសោតទេ ពួកគេនឹងពុំបានសង្គ្រោះឡើយ ។

៤១ ហើយពួកគេត្រូវតែមក ស្របតាមព្រះបន្ទូលទាំងឡាយ ដែលនឹងត្រូវបានតាំងឡើងដោយព្រះឱស្ឋនៃកូនចៀម; ហើយព្រះបន្ទូល ទាំងឡាយនៃកូនចៀម នឹងត្រូវបានធ្វើឲ្យដឹងនៅក្នុងបញ្ជីនៃពូជអ្នក ក៏ដូចជានៅក្នុងបញ្ជីនៃពួកសាវក១២នាក់នៃកូនចៀមដែរ; ហេតុដូច្នោះហើយ បញ្ជីទាំងពីរនេះ នឹងត្រូវបានតាំងឡើងជារបស់[ក]តែមួយ ត្បិតមានព្រះ[ខ]តែមួយ និង[គ]អ្នកគង្វាលមួយប៉ុណ្ណោះ នៅលើផែនដីទាំងមូល ។

៤២ ហើយពេលនឹងមកដល់ ដែលទ្រង់នឹងសម្ដែងរូបអង្គទ្រង់ដល់គ្រប់ទាំងសាសន៍ ព្រមទាំងពួកសាសន៍យូដា និងពួកសាសន៍ដទៃ ផង; ហើយបន្ទាប់ពីទ្រង់បានសម្ដែងរូបអង្គទ្រង់ដល់[ក]ពួកសាសន៍យូដា និងព្រមទាំងដល់ពួកសាសន៍ដទៃផង ខណៈនោះទ្រង់នឹងសម្ដែង រូបអង្គទ្រង់ដល់ពួកសាសន៍ដទៃ និងព្រមទាំងដល់ពួកសាសន៍យូដាផង ហើយ[ខ]មនុស្សក្រោយទៅជាមុន រីឯ[គ]មនុស្សមុនទៅជាក្រោយវិញ ៕

## ជំពូកទី ១៤

*ទេវតាប្រាប់នីហ្វៃអំពីពរជ័យ និងពាក្យបណ្ដាសាទាំងឡាយដែលនឹងធ្លាក់មកលើពួកសាសន៍ដទៃ — មានសាសនាចក្រតែពីរគត់ គឺ៖ សាសនាចក្រនៃកូនចៀមនៃព្រះ និងសាសនាចក្រនៃអារក្ស — ពួកបរិសុទ្ធនៃព្រះនៅគ្រប់សាសន៍ ត្រូវបានបៀតបៀន ដោយ សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើមនោះ — សាវកយ៉ូហាននឹងសរសេរអំពីចុងបំផុតនៃលោកិយ ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

៣៧ *គ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
*ឃ* ៣ នីហ្វៃ ២៧:១៦.
ស.ប. កាន់ខ្ជាប់.
*ង* ស.ប. សិរីល្អនៃសេឡេស្ទាល.
*ច* អេសាយ ៥២:៧;
ម៉ូសាយ ១៥:១៤–១៨;
៣ នីហ្វៃ ២០:៤០.
៣៨ *ក* ១ នីហ្វៃ ១៣:២៣;
២ នីហ្វៃ ២៩:៤–៦.
*ខ* មរមន ៥:១៥.
៣៩ *ក* ស.ប. បទព្រះគម្ពីរ — គម្ពីរដែលបានព្យាករថានឹងចេញមក.
*ខ* អេសេ. ៣៧:១៥–២០;
២ នីហ្វៃ ៣:១១–១២.
*គ* ១ នីហ្វៃ ១៤:៣០.
៤០ *ក* ២ នីហ្វៃ ២៦:១៦–១៧; ២៩:១២.
ស.ប. ព្រះគម្ពីរមរមន.
*ខ* មរមន ៧:៨–៩.
*គ* ស.ប. ព្រះគម្ពីរប៊ីប.
*ឃ* សូមមើលទំព័រចំណងជើងនៃព្រះគម្ពីរមរមន. ម៉ូសេ ១:៦.
៤១ *ក* អេសេ. ៣៧:១៧.
*ខ* ចោទិ. ៦:៤; យ៉ូហាន ១៧:២១–២៣; ២ នីហ្វៃ ៣១:២១.
*គ* ស.ប. អ្នកគង្វាលល្អ.
៤២ *ក* គ. និង ស. ៩០:៨–៩;
១០៧:៣៣; ១១២:៤.
*ខ* យ៉ាកុប ៥:៦៣.
*គ* លូកា ១៣:៣០;
១ នីហ្វៃ ១៥:១៣–២០.

ហើយហេតុការណ៍នឹងកើតឡើងថា ប្រសិនបើពួកសាសន៍
ដទៃនឹងប្រុងស្ដាប់តាមកូនចៀមនៃព្រះ នៅថ្ងៃនោះដែលទ្រង់
នឹងសម្ដែង រូបអង្គទ្រង់ដល់ពួកគេ ដោយព្រះបន្ទូល និង
ព្រមទាំងដោយព្រះចេស្ដាដែរ ដោយការប្រព្រឹត្ត ដែលជាការ
យកថ្មជំពប់ចេញ —
២ ហើយបើមិនមានចិត្តរឹងរូសទាស់នឹងកូនចៀមនៃព្រះទេ នោះ
ពួកគេនឹងត្រូវបានរាប់ក្នុងចំណោមពូជឪពុករបស់អ្នក; មែនហើយ
ពួកគេនឹងត្រូវបានរាប់ក្នុងចំណោមវង្សអ៊ីស្រាអែល; ហើយពួក
គេនឹងត្រូវបានទៅជារាស្ត្រមួយ ដែលមានពរនៅលើដែនដីសន្យា
រហូតតទៅ; ពួកគេនឹងមិនត្រូវធ្លាក់ ទៅក្នុង
ការជាប់ឃុំឃាំងទៀតឡើយ; ហើយវង្សអ៊ីស្រាអែលក៏នឹងមិន
ត្រូវលាយឡំតទៅទៀតដែរ ។
៣ ហើយឯរណ្ដៅដ៏ជ្រៅ ដែលត្រូវបានជីកសំរាប់ពួកគេ ដោយ
សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើមនោះ គឺជាសាសនាចក្រ
ដែល ត្រូវបានបង្កើតឡើងដោយអារក្ស និងកូនចៅវា ដើម្បីឲ្យ
វាអាចនាំព្រលឹងមនុស្ស យកទៅស្ថាននរក — មែនហើយ
គឺរណ្ដៅ ដ៏ជ្រៅ ដែលត្រូវបានជីកសំរាប់សេចក្ដីបំផ្លិចបំផ្លាញ
នៃមនុស្ស នោះនឹងត្រូវបំពេញដោយពួកអ្នកដែលបានជីកវា
រហូតដល់សេចក្ដីបំផ្លិច បំផ្លាញទាំងស្រុងរបស់ពួកគេ កូនចៀមនៃ
ព្រះមានព្រះបន្ទូលថាដូច្នោះ; គឺមិនមែនជាសេចក្ដីបំផ្លិចបំផ្លាញ
នៃព្រលឹងទេ តែគឺជាការចោល ព្រលឹងទៅក្នុងស្ថាននរកនោះ
ដែលគ្មានចុងបំផុតវិញ ។
៤ ត្បិតមើលចុះ នេះគឺស្របតាមការជាប់ឃុំឃាំងនៃអារក្ស
និងព្រមទាំងស្របតាមសេចក្ដីយុត្តិធម៌នៃព្រះផង ដែលនឹងមាន
ដល់អស់ អ្នកណាដែលនឹងធ្វើនូវអំពើទុច្ចរិត និង
អំពើដ៏គួរខ្ពើមឆ្អើមនៅចំពោះមុខទ្រង់ ។
៥ ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូល
មកខ្ញុំ នីហ្វៃថា៖ អ្នកបានឃើញហើយថា បើសិនជាពួកសាសន៍
ដទៃព្រម ប្រែចិត្ត នោះនឹងបានស្រួលដល់ពួកគេហើយ; ហើយ
អ្នកក៏ស្គាល់នូវសេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ ដែលទ្រង់
មានដល់វង្សអ៊ីស្រា អែលហើយដែរ; ហើយអ្នកក៏បានឮហើយ
ថា អស់អ្នកណាដែលមិនព្រមប្រែចិត្តទេ នោះនឹងត្រូវវិនាស ។
៦ ហេតុដូច្នេះហើយ វេទនាដល់ពួកសាសន៍ដទៃ បើសិនជា
ពួកគេធ្វើចិត្តរឹងរូស ទាស់នឹងកូនចៀមនៃព្រះ ។
៧ កូនចៀមនៃព្រះមានព្រះបន្ទូលថា៖ ត្បិតពេលនឹងមកដល់
ដែលយើងនឹងធ្វើកិច្ចការដ៏ធំ ហើយអស្ចារ្យ នៅចំណោម
កូនចៅ មនុស្ស; ដែលជាកិច្ចការដ៏អស់កល្បជានិច្ច ទោះ
ជាតាមខាងនេះ ឬខាងនោះក៏ដោយ — ទោះជា
ទុកជាការបរិវត្តន៍ដល់ពួកគេ ចំពោះសេចក្ដីសុខ សាន្ត និង
ជីវិតដ៏នៅអស់កល្បជានិច្ច ឬទុកជាការបណ្ដោយឲ្យពួក
គេទៅតាមភាពរឹងរូសនៃចិត្តរបស់គេ និងភាពងងឹតងងល់នៃគំនិត
របស់គេ រហូតដល់ត្រូវធ្លាក់ទៅក្នុងការជាប់ឃុំឃាំង ហើយ
ធ្លាក់ទៅក្នុងសេចក្ដីបំផ្លិចបំផ្លាញ ទាំងខាងសាច់ឈាម និង
ខាងវិញ្ញាណ ស្របតាមការជាប់ឃុំឃាំងនៃអារក្ស ដែល
យើងមានបន្ទូលមកហើយនោះក្ដី ។
៨ ហើយហេតុការណ៍បានកើតឡើងថា នៅគ្រាដែលទេវតាមាន
បន្ទូលនូវពាក្យទាំងនេះ នោះលោកមានបន្ទូលមកខ្ញុំថា៖ តើអ្នក
ចាំនូវសេចក្ដីសញ្ញាទាំងឡាយនៃព្រះវរបិតា ដែលទ្រង់មាន
ដល់វង្សអ៊ីស្រាអែលឬទេ ? ខ្ញុំបានទូលលោកថា៖ ព្រះពរ ។
៩ ហើយហេតុការណ៍បានកើតឡើងថា លោកមានបន្ទូលមកខ្ញុំ
ថា៖ មើលន៏ ចូរមើលសាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើមនោះ
ដែលជាមាតានៃសេចក្ដីគួរខ្ពើមឆ្អើមទាំងឡាយ ឯអ្នកបង្កើត
សាសនាចក្រនោះ គឺអារក្ស ។
១០ ហើយលោកមានបន្ទូលមកខ្ញុំថា៖ មើលន៏ មានសាសនា

១៤ ១*ក* ៣ នីហ្វៃ ១៦:៦–១៣.
ស.ប. ពួកសាសន៍ដទៃ.
*ខ* ១ ថែស្សា. ១:៥;
១ នីហ្វៃ ១៤:១៤;
យ៉ាកុប ៦:២–៣.
*គ* អេសាយ ៥៧:១៤;
១ នីហ្វៃ ១៣:២៩, ៣៤;
២ នីហ្វៃ ២៦:២០.
២ *ក* កាឡាទី ៣:៧, ២៩;
២ នីហ្វៃ ១០:១៨–១៩;
៣ នីហ្វៃ ១៦:១៣;
២១:៦, ២២;
អេព្រ. ២:៩–១១.
*ខ* ២ នីហ្វៃ ៦:១២; ១០:៨–១៤;
៣ នីហ្វៃ ១៦:៦–៧; ២០:២៧.
៣ *ក* ១ នីហ្វៃ ២២:១៤;
គ. និង ស. ១០៩:២៥.
*ខ* ស.ប. សេចក្ដីជាប់ទោស;
ស្ថាននរក.
៥ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
៦ *ក* ២ នីហ្វៃ ២៨:៣២.
៧ *ក* អេសាយ ២៩:១៤;
១ នីហ្វៃ ២២:៨;
២ នីហ្វៃ ២៧:២៦; ២៩:១–២;
គ. និង ស. ៤:១.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
*គ* ២ នីហ្វៃ ២:២៦–២៩;
អាលម៉ា ១២:៩–១១.
៨ *ក* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
៩ *ក* ១ នីហ្វៃ ១៥:៣៥;
គ. និង ស. ១:៣៥.
ស.ប. អារក្ស.

ចក្រ[ក]តែពីរប៉ុណ្ណោះ; មួយគឺជាសាសនាចក្រនៃកូនចៀមនៃព្រះ
[ខ]រីឯមួយទៀត គឺជាសាសនាចក្រនៃអារក្ស; ហេតុដូច្នោះហើយ
អស់អ្នកណាដែលមិនជាពួកផងសាសនាចក្រនៃកូនចៀមនៃព្រះទេ
គឺជាពួកផងសាសនាចក្រដ៏ធំវិញ ដែលជាមាតានៃសេចក្ដី
គួរខ្ពើមឆ្អើមទាំងឡាយនោះ ហើយវាជា[គ]ពេស្យានៃអស់ទាំងផែនដី ។
១១ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានមើល ហើយបាន
ឃើញពេស្យានៃអស់ទាំងផែនដី ហើយវាអង្គុយនៅលើ[ក]ផ្ទៃទឹកដ៏ធំ;
ហើយ[ខ]វាមានអំណាចលើផែនដីទាំងមូល នៅគ្រប់ទាំងសាសន៍
គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ។
១២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញសាសនា
ចក្រនៃកូនចៀមនៃព្រះ ហើយសមាជិកនៃសាសនាចក្រមាន
[ក]ចំនួនតិចណាស់ ពីព្រោះមកពីសេចក្ដីទុច្ចរិត និងសេចក្ដី
គួរខ្ពើមឆ្អើមទាំងឡាយនៃពេស្យា ដែលអង្គុយនៅលើផ្ទៃទឹកដ៏ធំនោះ;
ទោះជា យ៉ាងណាក៏ដោយ គង់តែខ្ញុំបានឃើញថា សាសនា
ចក្រនៃកូនចៀម ដែលជាពួកបរិសុទ្ធរបស់ព្រះ ក៏មាននៅ
[ខ]ពាសពេញលើផ្ទៃផែនដីដែរ ហើយអំណាចរបស់ពួកគេ
នៅលើផ្ទៃផែនដីមានចំនួនតូច ពីព្រោះមកពីសេចក្ដីទុច្ចរិត
របស់ពេស្យាដ៏ធំ ដែលខ្ញុំបានឃើញនោះ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញថាមាតា
ដ៏ធំ នៃសេចក្ដីគួរខ្ពើមឆ្អើមទាំងឡាយ បានប្រមូលមនុស្សទាំង
ហ្វូង នៅពាសពេញលើផ្ទៃផែនដី នៅគ្រប់ទាំងសាសន៍នៃពួក
សាសន៍ដទៃ ដើម្បីទៅ[ក]ច្បាំងនឹងកូនចៀមនៃព្រះ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាន
ឃើញថាព្រះចេស្ដានៃកូនចៀមនៃព្រះ បានយាងចុះមកសណ្ឋិតលើ
ពួក បរិសុទ្ធក្នុងសាសនាចក្រនៃកូនចៀម ហើយលើរាស្ត្រដែល
នៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ ដែលបានខ្ចាត់ខ្ចាយពាសពេញ
លើ ផ្ទៃផែនដី; ហើយពួកគេប្រដាប់អាវុធដោយសេចក្ដីសុចរិត
និងដោយ[ក]ព្រះចេស្ដានៃព្រះ ដោយសិរីល្អដ៏អស្ចារ្យ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញថាសេចក្ដី
ក្រោធនៃព្រះ [ក]បានស្រោចមកលើសាសនាចក្រដ៏ធំ ហើយគួរខ្ពើម
ឆ្អើមនោះ ដរាបដល់មានសង្គ្រាម និងពាក្យចចាមអារាមអំពី
សង្គ្រាមទាំងឡាយ ក្នុង[ខ]ចំណោមសាសន៍ទាំងឡាយ និងពូជ
មនុស្សទាំង អស់នៅលើផែនដី ។
១៦ ហើយខណៈដែលចាប់ផ្ដើមមាន[ក]សង្គ្រាម និងពាក្យ
ចចាមអារាមអំពីសង្គ្រាមទាំងឡាយ នៅក្នុងចំណោមសាសន៍
ទាំងអស់ ដែល ជាពួកផងមាតានៃសេចក្ដីគួរខ្ពើមឆ្អើមទាំង
ឡាយ នោះទេវតាមានបន្ទូលមកខ្ញុំថា៖ មើលចុះ សេចក្ដី
ក្រោធនៃព្រះធ្លាក់មកលើមាតា នៃពួកពេស្យា; ហើយមើលចុះ
អ្នកឃើញរឿងទាំងអស់នេះហើយ —
១៧ ហើយ[ក]ថ្ងៃនោះនឹងមកដល់ កាល[ខ]សេចក្ដីក្រោធនៃព្រះ
នឹងស្រោចមកលើមាតានៃពួកស្រីពេស្យា គឺជាសាសនាចក្រ
ដ៏ធំ ហើយគួរខ្ពើមឆ្អើម នៅលើអស់ទាំងផែនដី ឯអ្នកបង្កើត
សាសនាចក្រនោះ គឺអារក្ស ហេតុដូច្នោះហើយ នៅថ្ងៃនោះ
[គ]កិច្ចការនៃ ព្រះវរបិតា នឹងចាប់ផ្ដើម ក្នុងការរៀបចំផ្លូវ ដើម្បី
បំពេញ[ឃ]សេចក្ដីសញ្ញាទាំងឡាយរបស់ទ្រង់ ដែលទ្រង់បានធ្វើដល់
ប្រជារាស្ត្ររបស់ទ្រង់ ដែលជាវង្សអ៊ីស្រាអែល ។
១៨ ហើយហេតុការណ៍បានកើតឡើងថា ទេវតាមានបន្ទូល
មកខ្ញុំថា៖ មើលន៏ !
១៩ ហើយខ្ញុំក៏មើល ហើយបានឃើញបុរសម្នាក់
ហើយបុរសនោះស្លៀកពាក់អាវពណ៌ស ។
២០ ហើយទេវតាមានបន្ទូលមកខ្ញុំថា៖ មើលន៏ សាវកម្នាក់[ក]ក្នុង
ចំណោមពួកសាវកទាំង១២នាក់នៃកូនចៀម ។
២១ មើលចុះ លោកនឹងឃើញ ហើយសរសេររឿងដែល
នៅសល់ទាំងប៉ុន្មាន; មែនហើយ និងព្រមទាំងរឿងជាច្រើន
ដែលបាន កន្លងមកហើយ ។
២២ ហើយលោកនឹងសរសេរអំពីចុងបំផុតផែនដីដែរ ។

១០ ក ១ នីហ្វៃ ២២:២៣.
ខ ១ នីហ្វៃ ១៣:៤–៦, ២៦.
គ វិវ. ១៧:៥, ១៥;
២ នីហ្វៃ ១០:១៦.
១១ ក យេរេ. ៥១:១៣;
វិវ. ១៧:១៥.
ខ គ. និង ស. ៣៥:១១.
១២ ក ម៉ាថាយ ៧:១៤;
៣ នីហ្វៃ ១៤:១៤;
គ. និង ស. ១៣៨:២៦.
ខ គ. និង ស. ៩០:១១.
១៣ ក វិវ. ១៧:១–៦; ១៨:២៤;
១ នីហ្វៃ ១៣:៥;
គ. និង ស. ១២៣:៧–៨.
១៤ ក យ៉ាកុប ៦:២;
គ. និង ស. ៣៨:៣២–៣៨.
១៥ ក គ. និង ស. ១:១៣–១៤.
ខ ម៉ាកុស ១៣:៨;
គ. និង ស. ៨៧:៦.
១៦ ក ១ នីហ្វៃ ២២:១៣–១៤;
មរមន ៨:៣០.
១៧ ក ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
ខ ១ នីហ្វៃ ២២:១៥–១៦.
គ ៣ នីហ្វៃ ២១:៧, ២០–២៩.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
ឃ មរមន ៨:២១, ៤១.
ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
២០ ក វិវ. ១:១–៣;
១ នីហ្វៃ ១៤:២៧.

២៣ ហេតុដូច្នោះហើយ រឿងទាំងឡាយដែលលោកនឹងសរសេរ គឺជារឿងពិត ហើយត្រឹមត្រូវ; ហើយមើលចុះ រឿងទាំងនោះបាន សរសេរនៅក្នុង[ក]គម្ពីរ ដែលអ្នកបានឃើញចេញមកពីមាត់នៃសាសន៍យូដា; ហើយនៅពេលដែលរឿងទាំងនោះចេញពីមាត់នៃសាសន៍ យូដា ឬនៅពេលដែលគម្ពីរនោះ ចេញមកពីមាត់នៃសាសន៍យូដា រឿងដែលបានសរសេរទុកនោះជារឿងដ៏ច្បាស់ ហើយ[ខ]បរិសុទ្ធ និងពិសេសបំផុត ហើយងាយយល់ដល់មនុស្សទាំងអស់ ។

២៤ ហើយមើលចុះ រឿងទាំងឡាយ ដែល[ក]សាវកនៃកូនចៀមនេះនឹងសរសេរ គឺជារឿងដ៏ច្រើន ដែលអ្នកបានឃើញមក; ហើយមើលចុះ អ្នកនឹងឃើញរឿងដែលនៅសល់ទាំងប៉ុន្មានដែរ ។

២៥ ប៉ុន្តែរឿងទាំងឡាយដែលអ្នកនឹងឃើញ ពីអំណឹះតទៅនោះអ្នកមិនត្រូវសរសេរឡើយ; ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បាន តែងតាំង[ក]សាវកនៃកូនចៀមនៃព្រះ ឲ្យសរសេររឿងទាំងនោះហើយ ។

២៦ ហើយព្រមទាំងអ្នកផ្សេងៗទៀតដែលបានឃើញ នោះទ្រង់បានបង្ហាញរឿងទាំងអស់ដល់ពួកគេដែរ ហើយពួកគេបានសរសេររឿងទាំងនោះ; ហើយរឿងទាំងនោះ[ក]បានផ្សារភ្ជិតទុក ដើម្បីឲ្យបានចេញមកក្នុងសេចក្ដីបរិសុទ្ធនៃរឿងនោះ ស្របតាមសេចក្ដីពិត ដែលមាននៅក្នុងកូនចៀម នៅក្នុងពេលកំណត់នៃព្រះអម្ចាស់ ដល់វង្សអ៊ីស្រាអែល ។

២៧ ហើយខ្ញុំ នីហ្វៃ បានឮ ហើយធ្វើបន្ទាល់ថា ឈ្មោះរបស់សាវកនៃកូនចៀមនោះ គឺ[ក]យ៉ូហាន ស្របតាមបន្ទូលរបស់ទេវតា ។

២៨ ហើយមើលចុះ ខ្ញុំ នីហ្វៃ ត្រូវបានហាមមិនឲ្យសរសេររឿងទាំងឡាយ ដែលនៅសល់ពីរឿង ដែលខ្ញុំបានឃើញ ហើយបានឮ នោះទេ; ហេតុដូច្នោះហើយ រឿងទាំងឡាយដែលខ្ញុំបានសរសេរ គឺល្មមសំរាប់ខ្ញុំហើយ ហើយខ្ញុំគ្រាន់តែសរសេរផ្នែកតូចមួយនៃរឿង ដែលខ្ញុំបានឃើញមកប៉ុណ្ណោះ ។

២៩ ហើយខ្ញុំធ្វើបន្ទាល់ថា ខ្ញុំបានឃើញរឿងទាំងឡាយ ដែល[ក]ឪពុកខ្ញុំបានឃើញ ហើយទេវតានៃព្រះ បានធ្វើឲ្យខ្ញុំដឹងរឿងទាំងនោះ ។

៣០ ហើយឥឡូវនេះ ខ្ញុំបញ្ចប់នូវការនិយាយអំពីរឿងទាំងឡាយ ដែលខ្ញុំបានឃើញ កាលដែលខ្ញុំត្រូវបាននាំទៅដោយព្រះវិញ្ញាណ; ហើយបើសិនជារឿងទាំងអស់ ដែលខ្ញុំបានឃើញនេះ មិនបានសរសេរទុកក៏ដោយ គង់តែរឿងទាំងឡាយដែលខ្ញុំបានសរសេរទុក គឺជារឿង[ក]ពិតដែរ ។ ហើយគឺយ៉ាងដូច្នោះមែន ។ អាម៉ែន ៕

---

## ជំពូកទី ១៥

*ពូជរបស់លោកលីហៃ នឹងទទួលដំណឹងល្អពីពួកសាសន៍ដទៃនៅគ្រាចុងក្រោយ — ការប្រមូលសាសន៍អ៊ីស្រាអែលប្រៀបដូច ជាដើមអូលីវ ឯមែកកំណើតទាំងឡាយ នឹងបានបំពោជាប់វិញ — នីហ្វៃបកស្រាយការនិមិត្តអំពីដើមជីវិត ហើយនិយាយអំពី សេចក្ដីយុត្តិធម៌នៃព្រះ នៅក្នុងការបំបែកពួកទុច្ចរិត ចេញពីពួកសុចរិត ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំ នីហ្វៃ ត្រូវបាននាំទៅដោយព្រះវិញ្ញាណ ហើយបានឃើញរឿងទាំងអស់នេះមក នោះខ្ញុំបានត្រឡប់មកត្រសាលរបស់ឪពុកខ្ញុំវិញ ។

២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញបងៗប្រុសខ្ញុំ ហើយពួកគេកំពុងតែប្រកែកគ្នា អំពីរឿងទាំងឡាយ ដែលឪពុក ខ្ញុំបាននិយាយប្រាប់គេ ។

៣ ត្បិតលោកពិតជាបាននិយាយប្រាប់ពួកគេ នូវរឿងដ៏អស្ចារ្យជាច្រើន ដែលជារឿង[ក]ពិបាកយល់ លើកលែងតែអ្នកនោះសូមដល់ ព្រះអម្ចាស់; ហើយមកពីពួកគេមានចិត្តរឹងរូស ហេតុដូច្នេះហើយ បានជាពួកគេ មិនបានពឹងដល់ព្រះអម្ចាស់ ដូចដែលគេគួរធ្វើនោះឡើយ ។

៤ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ កើតទុក្ខដោយសារតែភាពរឹងរូសនៃចិត្តរបស់ពួកគេ និងដោយសាររឿងទាំងឡាយ ដែលខ្ញុំបាន ឃើញមក ហើយបានដឹងថា រឿងទាំងនេះនឹងកើតឡើងដោយមិនអាចចៀសវាងបានឡើយ ពីព្រោះតែសេចក្ដីទុច្ចរិតដ៏ធំរបស់កូន ចៅមនុស្ស ។

៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំអស់កម្លាំង ពីព្រោះ

---

២៣ *ក* ១ នីហ្វៃ ១៣:២០–២៤;
មរមន ៨:៣៣.
*ខ* ១ នីហ្វៃ ១៣:២៨–៣២.
២៤ *ក* អេធើរ ៤:១៦.
២៥ *ក* យ៉ូហាន ២០:៣០–៣១;
វិវរ. ១:១៩.
២៦ *ក* ២ នីហ្វៃ ២៧:៦–២៣;
អេធើរ ៣:២១–២៧; ៤:៤–៧;
គ. និង ស. ៣៥:១៨;
យ.ស.—ប្រវត្តិ ១:៦៥.
២៧ *ក* វិវរ. ១:១–៣.
២៩ *ក* ១ នីហ្វៃ ៨.
៣០ *ក* ២ នីហ្វៃ ៣៣:១០–១៤.
**១៥** ៣ *ក* ១ កូរិន. ២:១០–១២;
អាលម៉ា ១២:៩–១១.

មកពីការឈឺចាប់របស់ខ្ញុំ ត្បិតខ្ញុំឃើញថា [ក]ការឈឺចាប់របស់ខ្ញុំ
ធ្ងន់ជាងអ្វីៗទាំងអស់ មកពី[ខ]សេចក្ដីបំផ្លិចបំផ្លាញនៃរាស្ត្រខ្ញុំ ត្បិត
ខ្ញុំបានឃើញការរលំរបស់ពួកគេ ។

៦ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំមាន
[ក]កម្លាំងឡើងវិញ នោះខ្ញុំបាននិយាយទៅបងៗរបស់ខ្ញុំ ដោយ
មានប្រាថ្នា ចង់ដឹងថាតើពួកគេប្រកែកគ្នាអំពីរឿងអ្វីដែរ ។

៧ ហើយពួកគេបានឆ្លើយថា៖ មើលចុះ យើងមិនអាចយល់នូវ
ពាក្យទាំងឡាយ ដែលឪពុកយើងបាននិយាយ អំពីមែកកំណើត
ទាំងឡាយនៃដើមអូលីវ និងព្រមទាំងអំពីពួកសាសន៍ដទៃផងនោះ
បានទេ ។

៨ ហើយខ្ញុំបាននិយាយទៅពួកគេថា៖ តើពួកបងៗបាន[ក]សូម
ដល់ព្រះអម្ចាស់ហើយឬនៅ ?

៩ ហើយពួកគេឆ្លើយមកខ្ញុំថា៖ យើងមិនទាន់បានសូមទេ;
ត្បិតព្រះអម្ចាស់ ទ្រង់មិនបានធ្វើឲ្យយើងដឹងរឿងបែបនេះទេ ។

១០ មើលចុះ ខ្ញុំនិយាយទៅគេថា៖ ចុះហេតុអ្វីបានជាបងៗ
មិនកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះចុះ? ហេតុអ្វីបានជាបងៗ
នឹងត្រូវវិនាស ពីព្រោះតែ[ក]ភាពរឹងរូសនៃចិត្តរបស់បងៗប៉ុណ្ណោះ ?

១១ តើបងៗមិនចាំរឿងទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់
មានព្រះបន្ទូលទេឬ ? បើសិនជាអ្នកណាមិនធ្វើចិត្តរឹងរូស ហើយ
[ក]សូម ដល់យើង ដោយសេចក្ដីជំនឿ ដោយជឿថា អ្នកនឹងបាន
ទទួល ដោយមានចិត្តឧស្សាហ៍កាន់តាមបញ្ញត្តិទាំងឡាយ
របស់យើង នោះរឿងទាំងនេះ នឹងត្រូវបានធ្វើឲ្យអ្នកដឹងជាប្រាកដ ។

១២ មើលចុះ ខ្ញុំប្រាប់បងរាល់គ្នាថា វង្សអ៊ីស្រាអែលត្រូវបាន
ប្រៀបដូចជាដើមអូលីវ ដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ ដែល
ស្ថិត ក្នុងឪពុកយើង; ហើយមើលចុះ តើយើងមិនបាន
បែកចេញមកពីវង្សអ៊ីស្រាអែលទេឬអី ហើយចុះតើយើងមិន
មែនជា[ក]មែក នៃវង្ស អ៊ីស្រាអែលទេឬ ?

១៣ ហើយឥឡូវនេះ រឿងដែលឪពុកយើងបាននិយាយ អំពីការ
បំបៅជាប់នៃមែក[ក]កំណើតទាំងឡាយ តាមរយៈភាពពោរពេញនៃ
ពួកសាសន៍ដទៃ គឺមានន័យថា នៅគ្រាចុងក្រោយ កាលពូជ
យើង នឹងចុះអន់ថយក្នុងការឥតជំនឿ មែនហើយ
អស់រយៈពេលជាច្រើនឆ្នាំ ហើយជាច្រើនតំណ បន្ទាប់ពី[ខ]ព្រះ
មែស៊ី ទ្រង់នឹងសម្ដែងរូបអង្គទ្រង់ឲ្យកូនចៅមនុស្សឃើញ ខណៈនោះ
ភាពពោរពេញនៃ[គ]ដំណឹងល្អ របស់ព្រះមែស៊ី នឹងត្រូវបានមក
ដល់[ឃ]ពួកសាសន៍ដទៃ ហើយពីពួកសាសន៍ដទៃនឹងត្រូវបានមក
ដល់សំណល់នៃពូជយើងវិញ —

១៤ ហើយនៅថ្ងៃនោះ សំណល់នៃ[ក]ពូជយើងនឹងបានដឹងថា
ពួកគេជាវង្សអ៊ីស្រាអែល ហើយថាពួកគេជារាស្ត្រដែលនៅ
ក្នុង[ខ]សេចក្ដី សញ្ញានៃ[គ]ព្រះអម្ចាស់; ហើយខណៈនោះ ពួកគេនឹង
បានដឹង ហើយនឹងបានការចេះដឹងអំពីពួកអយ្យកោរបស់ពួកគេ
ហើយនឹងបានការចេះ ដឹងអំពីដំណឹងល្អនៃព្រះដ៏ប្រោសលោះរបស់
ពួកគេ ជាដំណឹងល្អដែលទ្រង់បានផ្សាយដល់ពួកអយ្យកោគេដែរ;
ហេតុដូច្នោះហើយ ពួកគេនឹងបានការចេះដឹងអំពី
ព្រះដ៏ប្រោសលោះរបស់ពួកគេ និងគ្រប់ន័យទាំងឡាយ
នៃគោលលទ្ធិរបស់ទ្រង់ ដើម្បីឲ្យពួកគេអាចដឹងថា ត្រូវតែមក
រកទ្រង់ ទើបនឹងបានសង្គ្រោះ ។

១៥ ហើយខណៈនោះ តើពួកគេនឹងមិនរីករាយ ហើយ
សរសើរដំកើងដល់ព្រះ ដ៏គង់នៅអស់កល្បជានិច្ចរបស់ពួកគេ
គឺដែលជា[ក]ថ្ម ហើយជាសេចក្ដីសង្គ្រោះរបស់ពួកគេនៅក្នុង
ថ្ងៃនោះទេឬអី ? មែនហើយ តើពួកគេនឹងមិនបានទទួលកម្លាំង
និងអាហារពី[ខ]ដើមទំពាំង បាយជូរដ៏ពិត នៅថ្ងៃនោះទេឬ ? មែន
ហើយ តើពួកគេនឹងមិនមករកក្រោលដ៏ពិតនៃព្រះទេឬ ?

១៦ មើលចុះ ខ្ញុំប្រាប់បងរាល់គ្នាថា ពិតមែនហើយ; ពួកគេ
នឹងត្រូវបានចងចាំទៀត នៅក្នុងចំណោមវង្សអ៊ីស្រាអែល; ពួក

---

៥ *ក* ស.ប. សេចក្ដីទំនាស់.
*ខ* អេណុស ១:១៣; មរមន ៦:១.
៦ *ក* ម៉ូសេ ១:១០;
យ.ស.—ប្រវត្តិ ១:២០, ៤៨.
៨ *ក* ម៉ូសាយ ២៦:១៣;
អាលម៉ា ៤០:៣.
ស.ប. ការអធិស្ឋាន.
១០ *ក* ស.ប. សេចក្ដីក្បត់សាសនា.
១១ *ក* យ៉ាកុប (ព.ស.ថ.) ១:៥–៦;
អេណុស ១:១៥; មរ៉ូណៃ ៧:២៦;
គ. និង ស. ១៨:១៨.
ស.ប. សូម.
១២ *ក* លោកុ. ៤៩:២២–២៦;
១ នីហ្វៃ ១០:១២–១៤; ១៩:២៤.
ស.ប. លីហៃ, ឪពុករបស់នីហ្វៃ.
១៣ *ក* ១ នីហ្វៃ ១២:២២–២៣;
២ នីហ្វៃ ២៦:១៥.
*ខ* ស.ប. ព្រះមែស៊ី.
*គ* ស.ប. ដំណឹងល្អ.
*ឃ* ១ នីហ្វៃ ១៣:៤២; ២២:៥–១០;
គ. និង ស. ១៤:១០.
ស.ប. ពួកសាសន៍ដទៃ.
១៤ *ក* ២ នីហ្វៃ ១០:២;
៣ នីហ្វៃ ៥:២១–២៦; ២១:៤–៧.
*ខ* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*គ* ២ នីហ្វៃ ៣:១២; ៣០:៥;
មរមន ៧:១, ៩–១០;
គ. និង ស. ៣:១៦–២០.
សូមមើលផងដែរនូវ
ទំព័រចំណងជើងនៃព្រះគម្ពីរមរមន.
១៥ *ក* ស.ប. ថ្ម.
*ខ* លោកុ. ៤៩:១១; យ៉ូហាន ១៥:១.

គេនឹង ត្រូវបានបំបៅជាប់ទៅនឹងដើមអូលីវដ៏ពិត ព្រោះពួកគេ
ជាមែកកំណើតនៃដើមអូលីវនោះ ។
១៧ ហើយនេះគឺជារឿងដែលឪពុកយើងមានន័យដល់;
ហើយលោកមានន័យថា រឿងនោះនឹងមិនកើតឡើងឡើយ
ទាល់តែបន្ទាប់ ពីពួកគេត្រូវខ្ចាត់ខ្ចាយទៅដោយពួកសាសន៍
ដទៃ; ហើយលោកមានន័យថា រឿងនោះនឹងត្រូវបានមក
តាមរយៈពួកសាសន៍ដទៃ ដើម្បី ព្រះអម្ចាស់ទ្រង់អាចសម្ដែង
ព្រះចេស្ដារបស់ទ្រង់ ដល់ពួកសាសន៍ដទៃ ត្បិតហេតុនេះហើយ
បានជាទ្រង់នឹងត្រូវពួកសាសន៍យូដា ឬវង្ស អ៊ីស្រាអែល
បដិសេធ ។
១៨ ហេតុដូច្នោះហើយ ឪពុកយើងមិនបាននិយាយអំពី
ពូជយើងតែប៉ុណ្ណោះទេ តែលោកព្រមទាំងបាននិយាយ
អំពីវង្សអ៊ីស្រាអែល ទាំងអស់ដែរ ដោយចង្អុលដល់សេចក្ដីសញ្ញា
ដែលនឹងត្រូវបានបំពេញនៅគ្រាចុងក្រោយ គឺជាសេចក្ដីសញ្ញា
ដែលព្រះអម្ចាស់ ទ្រង់បានធ្វើជាមួយនឹងលោកអ័ប្រាហាំ ជា
អយ្យកោរបស់យើងថា៖ ដោយសារពូជអ្នក នោះគ្រប់ទាំង
ពូជមនុស្សនៅផែនដីនឹងបានពរ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាន
និយាយទៅពួកគេជាច្រើន អំពីរឿងទាំងនេះ; មែនហើយ
ខ្ញុំបាននិយាយ ទៅពួកគេពីការសាងឡើងវិញនៃពួកសាសន៍
យូដា នៅគ្រាចុងក្រោយ ។
២០ ហើយខ្ញុំបានរំឭកដល់ពួកគេ ពីពាក្យទាំងឡាយ
របស់លោកអេសាយ ដែលបាននិយាយអំពីការសាងឡើងវិញនៃ
ពួកសាសន៍ យូដា ឬវង្សអ៊ីស្រាអែល; ហើយបន្ទាប់ពីពួកគេ
បានសាងឡើងវិញ នោះពួកគេនឹងមិនត្រូវលាយឡំ ឬធ្វើឲ្យ
ខ្ចាត់ខ្ចាយទៀតឡើយ; ហើយហេតុការណ៍បានកើតឡើងថា
ខ្ញុំបាននិយាយពាក្យជាច្រើនជាមួយនឹងបងៗខ្ញុំ ដែលធ្វើឲ្យពួក
គេបានស្ងប់ស្ងាត់ ហើយបានបន្ទាប ខ្លួនចំពោះព្រះអម្ចាស់ ។
២១ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
និយាយជាមួយនឹងខ្ញុំទៀតថា៖ ចុះតើរឿងដែលឪពុកយើងបាន
ឃើញ នៅក្នុង សុបិន នោះមានន័យយ៉ាងណា ? ដើមឈើ
ដែលលោកបានឃើញ នោះមានន័យដូចម្ដេច ?
២២ ហើយខ្ញុំបាននិយាយជាមួយនឹងពួកគេថា៖ នោះគឺជាតួ
យ៉ាងនៃដើមជីវិត ។
២៣ ហើយពួកគេនិយាយមកខ្ញុំថា៖ ចុះតើដំបងដែកដែល
ឪពុកយើងបានឃើញ ដែលនាំទៅឯដើមឈើ នោះមានន័យ
ដូចម្ដេច ?
២៤ ហើយខ្ញុំបាននិយាយទៅពួកគេថា៖ នោះគឺជាព្រះបន្ទូល
នៃព្រះ; ហើយអស់អ្នកណាដែលប្រុងស្ដាប់តាមព្រះបន្ទូលនៃ
ព្រះ ហើយតោងជាប់តាមព្រះបន្ទូលនៃព្រះ នោះនឹងមិនត្រូវ
វិនាសឡើយ; សូម្បីតែការល្បួងទាំងឡាយ និងព្រួញភ្លើងទាំង
ឡាយរបស់ មារសត្រូវ ក៏មិនអាចឈ្នះលើគេ ដល់ទៅធ្វើឲ្យ
គេខ្វាក់ ដើម្បីនាំគេទៅឯសេចក្ដីបំផ្លិចបំផ្លាញបានដែរ ។
២៥ ហេតុដូច្នោះហើយ ខ្ញុំ នីហ្វៃ បានទូន្មានពួកគេឲ្យ
ស្ដាប់បង្គាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់; មែនហើយ ខ្ញុំបាន
ទូន្មានពួកគេ ដោយអស់ពីកម្លាំងនៃព្រលឹងខ្ញុំ ហើយ
អស់ពីសមត្ថភាពដែលខ្ញុំមាន ដើម្បីឲ្យពួកគេស្ដាប់បង្គាប់តាមព្រះ
បន្ទូលនៃព្រះ ហើយចងចាំ និងកាន់តាមព្រះបញ្ញត្តិទាំងឡាយ
របស់ទ្រង់ជានិច្ច នៅគ្រប់ការណ៍ទាំងអស់ ។
២៦ ហើយពួកគេបាននិយាយមកខ្ញុំថា៖ ចុះតើទន្លេទឹកដែល
ឪពុកយើងបានឃើញ នោះមានន័យដូចម្ដេច ?
២៧ ហើយខ្ញុំបាននិយាយទៅពួកគេថា ទឹកដែលឪពុកខ្ញុំ
ឃើញនោះ គឺជាភាពស្មោកគ្រោក; ហើយដោយចិត្តលោករវ
ល់តែគិត ដល់រឿងផ្សេងៗទៀត បានជាលោកមិនបានឃើញ
ភាពស្មោកគ្រោកនៃទឹកនោះ ។
២៨ ហើយខ្ញុំបាននិយាយទៅពួកគេថា នោះគឺជាជង្ហុកមួយ

១៦ *ក* យ៉ាកុប ៥:៦០–៦៨.
១៧ *ក* ស.ប. ការផ្ដាច់.
១៨ *ក* លោកុ. ១២:១–៣;
អេប្រា. ២:៦–១១.
១៩ *ក* ១ នីហ្វៃ ១៩:១៥.
ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
២០ *ក* ១ នីហ្វៃ ១៩:២៣.
*ខ* ១ នីហ្វៃ ១៦:៥, ២៤, ៣៩.
២១ *ក* ១ នីហ្វៃ ៨:១០–១២.
២២ *ក* ១ នីហ្វៃ ១១:៤, ២៥;
ម៉ូសេ ៣:៩.
២៣ *ក* ១ នីហ្វៃ ៨:១៩–២៤.
២៤ *ក* ស.ប. ព្រះបន្ទូលនៃព្រះ.
*ខ* ១ នីហ្វៃ ៨:៣០;
២ នីហ្វៃ ៣១:២០.
*គ* ១ នីហ្វៃ ៨:២៣.
ស.ប. ល្បួង, សេចក្ដីល្បួង.
*ឃ* អេភេ. ៦:១៦;
គ. និង ស. ៣:៨; ២៧:១៧.
*ង* ស.ប. អារក្ស.
២៥ *ក* គ. និង ស. ១១:២; ៣២:៤;
៨៤:៤៣–៤៤.
២៦ *ក* ១ នីហ្វៃ ៨:១៣.
២៧ *ក* ១ នីហ្វៃ ១២:១៦.
*ខ* ស.ប. ស្មោកគ្រោក, សេច
ក្ដីស្មោកគ្រោក.
២៨ *ក* លូកា ១៦:២៦;
១ នីហ្វៃ ១២:១៨;
២ នីហ្វៃ ១:១៣.

ដ៏គួរឲ្យស្លប់ស្លែង ដែលបំបែកពួកទុច្ចរិតចេញពីដើមជីវិត ហើយចេញពី ពួកបរិសុទ្ធនៃព្រះ ។

២៩ ហើយខ្ញុំបាននិយាយទៅពួកគេថា នោះគឺជាត្រូយ៉ាងនៃស្ថាននរកដ៏គួរឲ្យស្លប់ស្លែង ដែលទេវតាមានបន្ទូលប្រាប់ខ្ញុំថា បានរៀបចំសំរាប់ពួកទុច្ចរិត ។

៣០ ហើយខ្ញុំបាននិយាយទៅពួកគេថា ឪពុកយើងក៏បានឃើញថា សេចក្ដីយុត្តិធម៌នៃព្រះ បានបំបែកពួកទុច្ចរិតចេញពីពួកសុចរិត ដែរ; ហើយពន្លឺរបស់វា ដូចជាពន្លឺរបស់អណ្ដាតភ្លើង ដែលឡើងទៅឯព្រះជារៀងដរាបតទៅ ហើយគ្មានចុងបំផុតឡើយ ។

៣១ ហើយពួកគេបាននិយាយមកខ្ញុំថា៖ តើរឿងនេះមានន័យដល់ការរងទុក្ខវេទនានៃរូបកាយ នៅក្នុងថ្ងៃសាកល្បង ឬវាមានន័យដល់សភាពចុងក្រោយបង្អស់នៃព្រលឹង បន្ទាប់ពីការស្លាប់នៃរូបកាយខាងសាច់ឈាម ឬវានិយាយដល់រឿងទាំងឡាយដែលជា រឿងខាងសាច់ឈាមវិញ ?

៣២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាននិយាយទៅពួកគេថា នោះគឺជាត្រូយ៉ាងនៃអ្វីៗទាំងឡាយ ទាំងខាងសាច់ឈាម និងខាងវិញ្ញាណដែរ; ត្បិតថ្ងៃនោះនឹងត្រូវបានមកដល់ ដែលពួកគេនឹងត្រូវជំនុំជំរះ ចំពោះកិច្ចការទាំងឡាយរបស់ពួកគេ មែនហើយ គឺកិច្ចការទាំងឡាយ ដែលត្រូវបានប្រព្រឹត្តដោយរូបកាយខាងសាច់ឈាម នៅថ្ងៃសាកល្បងរបស់គេ ។

៣៣ ហេតុដូច្នោះហើយ បើសិនជាពួកគេស្លាប់នៅក្នុងអំពើទុច្ចរិតរបស់គេ នោះពួកគេនឹងត្រូវបោះបង់ចេញ ពីអ្វីៗខាងឯវិញ្ញាណ ដែលទាក់ទងទៅនឹងសេចក្ដីសុចរិតដែរ; ហេតុដូច្នោះហើយ ពួកគេនឹងត្រូវនាំយកទៅឈរនៅចំពោះព្រះ ដើម្បីទទួលការជំនុំជំរះអំពី កិច្ចការទាំងឡាយរបស់គេ; ហើយបើសិនជាកិច្ចការទាំងឡាយរបស់គេ ប្រកបដោយភាពស្មោកគ្រោក នោះពួកគេក៏ច្បាស់ជាស្មោក គ្រោកដែរ; ហើយបើសិនជាពួកគេស្មោកគ្រោក ក៏ច្បាស់ជាពួកគេមិនអាចអាស្រ័យនៅក្នុងនគរនៃព្រះបានឡើយ; បើពុំនោះសោតទេ នគរនៃព្រះក៏ច្បាស់ជាស្មោកគ្រោកដែរ ។

៣៤ ប៉ុន្តែមើលចុះ ខ្ញុំប្រាប់បងរាល់គ្នាថា នគរនៃព្រះពុំមែនស្មោកគ្រោកទេ ហើយគ្មានរបស់អ្វីដែលមិនស្អាត អាចចូលទៅក្នុងនគរ នៃព្រះបានឡើយ; ហេតុដូច្នោះហើយ ច្បាស់ជាមានកន្លែងស្មោកគ្រោកមួយ ដែលបានរៀបចំទុកសំរាប់អ្វីដែលស្មោកគ្រោកនោះ ។

៣៥ ហើយមានកន្លែងមួយដែលបានរៀបចំទុក មែនហើយ គឺជាស្ថាននរកដ៏គួរឲ្យស្លប់ស្លែង ដែលខ្ញុំបាននិយាយមកនោះ ហើយ អារក្សគឺជាអ្នករៀបចំវាទុក; ហេតុដូច្នោះហើយ សភាពចុងក្រោយបង្អស់នៃព្រលឹងទាំងឡាយរបស់មនុស្ស គឺត្រូវទៅអាស្រ័យនៅក្នុង នគរព្រះ ឬក៏ត្រូវបណ្ដេញចេញពីព្រោះមកពីសេចក្ដីយុត្តិធម៌ ដែលខ្ញុំបាននិយាយមកនោះ ។

៣៦ ហេតុដូច្នោះហើយ ពួកទុច្ចរិតនឹងត្រូវបោះបង់ចេញពីពួកសុចរិត និងក៏ចេញពីដើមជីវិតដែរ ដែលមានផ្លែដ៏ពិសេស ហើយគួរឲ្យ ប្រាថ្នាជាងផ្លែណាៗទាំងអស់; មែនហើយ គឺជាអំណោយទានដ៏មហិមាបំផុតនៃព្រះ ។ ហើយខ្ញុំបាននិយាយបែបដូច្នេះទៅបងៗខ្ញុំ ។ អាម៉ែន ៕

## ជំពូកទី ១៦

*ពួកទុច្ចរិតរាប់សេចក្ដីពិតទុកជាការពិបាក — កូនប្រុសទាំងឡាយរបស់លីហៃ រៀបអាពាហ៍ពិពាហ៍នឹងកូនស្រីទាំងឡាយរបស់ អ៊ីសម៉ាអែល— លីអាហូណានាំដំណើរគេនៅក្នុងទីរហោស្ថាន — ជួនកាល ព្រះបន្ទូលនៃព្រះអម្ចាស់ ត្រូវបានសរសេរនៅលើ លីអាហូណា — អ៊ីសម៉ាអែលស្លាប់;*

២៩ *ក* ស.ប. ស្ថាននរក.
៣០ *ក* ស.ប. សេចក្ដីយុត្តិធម៌.
៣១ *ក* អាលម៉ា ១២:២៤; ៤២:១០; ហេលេ. ១៣:៣៨.
*ខ* អាលម៉ា ៤០:៦, ១១–១៤.
៣២ *ក* ស.ប. កិច្ចការ.
៣៣ *ក* ម៉ូសាយ ១៥:២៦; មរ៉ូណៃ ១០:២៦.
*ខ* អាលម៉ា ១២:១២–១៦; ៤០:២៦.
*គ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*ឃ* ៣ នីហ្វៃ ២៧:២៣–២៧.
*ង* ២ នីហ្វៃ ៩:១៦; គ. និង ស. ៨៨:៣៥.
*ច* ទំនុក. ១៥:១–៥; ២៤:៣–៤; អាលម៉ា ១១:៣៧; គ. និង ស. ៧៦:៥០–៧០; ម៉ូសេ ៦:៥៧.
៣៤ *ក* ស.ប. ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក.
៣៥ *ក* ២ នីហ្វៃ ៩:១៩; ម៉ូសាយ ២៦:២៧. ស.ប. ស្ថាននរក.
*ខ* ១ នីហ្វៃ ១៤:៩; គ. និង ស. ១:៣៥.
*គ* ស.ប. សេចក្ដីយុត្តិធម៌.
៣៦ *ក* លោកុ. ២:៩; ២ នីហ្វៃ ២:១៥.
*ខ* ១ នីហ្វៃ ៨:១០–១២; អាលម៉ា ៣២:៤២.
*គ* គ. និង ស. ៦:១៣.
*ឃ* គ. និង ស. ១៤:៧. ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.

*គ្រួសាររបស់លោករអ៊ូរទាំអំពីសេចក្ដីវេទនា ។ ប្រមាណជាឆ្នាំ ៦០០–៥៩២ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំនីហ្វៃ បានបញ្ចប់នូវការនិយាយទៅបងៗខ្ញុំហើយ មើលចុះ ពួកគេទាំង អស់គ្នាបាននិយាយមកកាន់ខ្ញុំថា៖ ឯងបានថ្លែងរឿងដ៏ធ្ងន់ៗមកយើង ធ្ងន់ហួសកំណត់ ដែលយើងអាចទ្រាំបាន ។

២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាននិយាយទៅគេថា ខ្ញុំដឹងហើយថា ខ្ញុំបានស្ដីរឿងដ៏ធ្ងន់ៗ ទាស់នឹងពួកទុច្ចរិត ស្របតាម សេចក្ដីពិត; ហើយពួកសុចរិតខ្ញុំបានរាប់ថាសុចរិត ហើយបានធ្វើបន្ទាល់ថា ពួកគេនឹងត្រូវបានលើកឡើងនៅថ្ងៃចុងក្រោយបង្អស់; ហេតុដូច្នោះហើយ អ្នកណាដែល[ក]មានទោស [ខ]រាប់សេចក្ដីពិតទុកជាការពិបាក ព្រោះអីសេចក្ដីពិត [គ]កាត់ទំលុះគេរហូតដល់ដួងចិត្ត ។

៣ ហើយឥឡូវនេះ ឱបងទាំងអស់គ្នាអើយ បើបងជាមនុស្សសុចរិត ហើយយល់ព្រមស្ដាប់បង្គាប់តាមសេចក្ដីពិត ហើយគោរពសេច ក្ដីពិត ដើម្បីឲ្យបងរាល់គ្នានឹងអាច[ក]ដើរដោយទៀងត្រង់ នៅចំពោះព្រះ ខណៈនោះ បងរាល់គ្នានឹងមិនរអ៊ូរទាំ ពីព្រោះមកពីសេចក្ដីពិត នោះទេ ហើយនិយាយថា៖ ឯងស្ដីរឿងដ៏ធ្ងន់ៗមកដល់យើង ។

៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានទូន្មានបងៗខ្ញុំ ដោយគ្រប់សមត្ថភាព ឲ្យពួកគេកាន់តាមព្រះបញ្ញត្តិទាំងឡាយ នៃព្រះអម្ចាស់ ។

៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេក៏បាន[ក]បន្ទាបខ្លួននៅចំពោះព្រះអម្ចាស់; ដរាបដល់ខ្ញុំមានសេចក្ដីអំណរ និងសេចក្ដី សង្ឃឹមជាខ្លាំងដល់ពួកគេថា ពួកគេនឹងដើរតាមផ្លូវទាំងឡាយនៃសេចក្ដីសុចរិត ។

៦ ឥឡូវនេះ រឿងទាំងអស់នេះត្រូវបាននិយាយ ហើយបានធ្វើទៅ នៅពេលដែលឪពុកខ្ញុំស្ថិតនៅក្នុងត្រសាល ដែលនៅក្នុងច្រកភ្នំ ដែលលោកបានហៅថា លេមយួលនោះ ។

៧ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានយក[ក]កូនស្រីរបស់អ៊ីសម៉ាអែលម្នាក់ធ្វើជាប្រពន្ធ; ឯបងៗ[ខ]ខ្ញុំ ក៏បានយកកូនស្រីទាំង ឡាយរបស់អ៊ីសម៉ាអែល ធ្វើជាប្រពន្ធដែរ; រីឯ[គ]សូរ៉ាំក៏បានយកកូនស្រីច្បង របស់អ៊ីសម៉ាអែល ធ្វើជាប្រពន្ធដែរ ។

៨ ដូច្នេះហើយ ទើបឪពុកខ្ញុំបានបំពេញនូវគ្រប់ទាំងព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ដែលបានប្រទានឲ្យលោក ។ ហើយខ្ញុំនីហ្វៃ ក៏បានពរជាអតិបរមាពីព្រះអម្ចាស់ដែរ ។

៩ ហើយហេតុការណ៍បានកើតឡើងថា សម្លេងនៃព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលមកឪពុកខ្ញុំក្នុងកណ្ដាលរាត្រី ហើយបានបញ្ជាលោក ថា ស្អែកឡើងលោកត្រូវធ្វើដំណើរចូលទីរហោស្ថានទៀត ។

១០ ហើយហេតុការណ៍បានកើតឡើងថា នៅពេលឪពុកខ្ញុំបានក្រោកឡើងនៅពេលព្រឹក ហើយបានដើរចេញទៅឯមាត់ទ្វារត្រសាល នោះលោកប្លែកចិត្តជាខ្លាំង ដោយបានឃើញ[ក]ដុំមូលមួយនៅលើដី ដែលមានក្បូរក្បាច់ចម្លែក; ហើយធ្វើពីធាតុលង្ហិនដ៏ល្អ ។ ហើយនៅក្នុងដុំមូលនោះ មានទ្រនិចពីរ; ហើយទ្រនិចមួយនោះ ចង្អុលផ្លូវដែលយើងត្រូវធ្វើដំណើរក្នុងទីរហោស្ថាន ។

១១ ហើយហេតុការណ៍បានកើតឡើងថា យើងបានប្រមូលសម្ភារៈផ្សេងៗ ដែលយើងអាចនាំចូលក្នុងទីរហោស្ថានបាន និងស្បៀង អាហារ ដែលនៅសល់ទាំងប៉ុន្មាន ដែលព្រះអម្ចាស់ ទ្រង់បានប្រទានដល់យើង; ហើយយើងបានយកគ្រាប់ពូជដំណាំគ្រប់មុខ ដែល យើងអាចយកចូលក្នុងទីរហោស្ថានបាន ។

១២ ហើយហេតុការណ៍បានកើតឡើងថា យើងបានយកត្រសាលរបស់យើង ហើយចូលទៅក្នុងទីរហោស្ថាន ឆ្លងកាត់ទន្លេលេមិន ។

១៣ ហើយហេតុការណ៍បានកើតឡើងថា យើងបានធ្វើដំណើរអស់រយៈពេលបួនថ្ងៃ ជិតទៅទិសខាងត្បូង ឈៀងខាងកើត ហើយ យើងបានបោះត្រសាលជាថ្មី; ហើយយើងដាក់ឈ្មោះទីនោះថា សាសេរ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា យើងបានយកធ្នូរបស់យើង និងព្រួញរបស់យើង ហើយចូលក្នុងទីរហោស្ថាន

១៦ ២*ក* យ៉ូហាន ៣:២០; ២ នីហ្វៃ ៣៣:៥; អេណុស ១:២៣; ហេលេ. ១៤:១០. ស.ប. ទោស.
*ខ* សុភា. ១៥:១០; ២ នីហ្វៃ ១:២៦; ៩:៤០; ហេលេ. ១៣:២៤–២៦.
*គ* កិច្ចការ ៥:៣៣; ម៉ូសាយ ១៣:៧.
៣ *ក* គ. និង ស. ៥:២១. ស.ប. ដើរ, ដើរជាមួយព្រះ.
៥ *ក* ១ នីហ្វៃ ១៦:២៤, ៣៩; ១៨:៤.
៧ *ក* ១ នីហ្វៃ ៧:១.
*ខ* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍.
*គ* ១ នីហ្វៃ ៤:៣៥; ២ នីហ្វៃ ៥:៥–៦.
១០ *ក* អាលម៉ា ៣៧:៣៨–៤៦. ស.ប. លីអាហូណា.

ដើម្បីទៅ បរបាញ់រកអាហារសំរាប់គ្រួសារយើង; ហើយបន្ទាប់ពីយើងបានបរបាញ់រកអាហារសំរាប់គ្រួសាររួចហើយ នោះយើងបានត្រឡប់ទៅ ជួបគ្រួសារយើងវិញ ដែលនៅក្នុងទីរហោស្ថានឯកន្លែងសាសើរនោះ ។ ហើយយើងបានបន្តដំណើរទៅមុខទៀត នៅក្នុងទីរហោ ស្ថាន តាមទិសដដែល ទៅតាមតំបន់ដែលមានជីជាតិបំផុតនៅក្នុងទីរហោស្ថាន ដែលនៅព្រំប្រទល់ជិតសមុទ្រក្រហម ។

១៥ ហើយហេតុការណ៍បានកើតឡើងថា យើងបានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ បានបរបាញ់រកអាហារតាមផ្លូវដោយ ប្រើធ្នូរបស់យើង និងព្រួញរបស់យើង និងគ្រួសរបស់យើង និងខ្សែដង្ហក់របស់យើង ។

១៦ ហើយយើងបានទៅតាមទិសនៃដុំមូល ដែលនាំយើងទៅក្នុងតំបន់ដ៏មានជីជាតិច្រើននៃទីរហោស្ថាន ។

១៧ ហើយបន្ទាប់ពីយើងបានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ នោះយើងបានបោះត្រសាល មួយរយៈទៀត ដើម្បីយើងអាចសំរាក ហើយរកអាហារសំរាប់គ្រួសារយើងទៀត ។

១៨ ហើយហេតុការណ៍បានកើតឡើងថា នៅពេលខ្ញុំ នីហ្វៃចេញទៅបរបាញ់រកអាហារ មើលចុះ ខ្ញុំបានធ្វើធ្នូខ្ញុំបាក់ដែលធ្វើពីដែក ដ៏ល្អ; ហើយបន្ទាប់ពីខ្ញុំធ្វើធ្នូខ្ញុំបាក់ មើលចុះបងៗខ្ញុំខឹងនឹងខ្ញុំ ពីព្រោះមកពីការបាក់ធ្នូរបស់ខ្ញុំ ត្បិតយើងរកអាហារមិនបានសោះ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា យើងបានត្រឡប់មកវិញ ដោយគ្មានស្បៀងយកមកឲ្យគ្រួសារឡើយ ហើយដោយមានការ នឿយហត់ជាខ្លាំង ដោយពីដំណើររបស់ពួកគេ នោះពួកគេបានរងទុក្ខជាខ្លាំង ដោយការឃ្លានអាហារ ។

២០ ហើយហេតុការណ៍បានកើតឡើងថា លេមិន និងលេមយួល និងកូនប្រុសទាំងឡាយរបស់អ៊ីសម៉ាអែល បានចាប់ផ្ដើមរអ៊ូរទាំជាខ្លាំង ដោយមកពីសេចក្ដីទុក្ខលំបាក និងសេចក្ដីវេទនារបស់ពួកគេ នៅក្នុងទីរហោស្ថាន ហើយឪពុកខ្ញុំ ក៏បានចាប់ផ្ដើមរអ៊ូរទាំទាស់ នឹងព្រះអម្ចាស់របស់លោកដែរ; មែនហើយ ពួកគេទាំងអស់គ្នាមានការទុក្ខព្រួយជាខ្លាំង រហូតដល់ពួកគេបានរអ៊ូរទាំទាស់នឹងព្រះអម្ចាស់ ។

២១ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ ដោយកើតទុក្ខព្រួយនឹងបងៗខ្ញុំ ព្រោះតែការបាក់ធ្នូរបស់ខ្ញុំ ហើយដោយធ្នូ របស់ពួកគេឈប់យឺតអស់ទៅ នោះទើបវាចាប់ផ្ដើមពិបាកប្រើជាខ្លាំង មែនហើយ ដរាបដល់យើងមិនអាចរកអាហារបានសោះឡើយ ។

២២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាននិយាយទៅបងៗខ្ញុំជាច្រើន ពីព្រោះគេបានធ្វើចិត្តរឹងរូសជាថ្មីទៀត រហូតដល់បានត្អូញត្អែរទាស់នឹងព្រះអម្ចាស់ ជាព្រះរបស់ពួកគេ ។

២៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានធ្វើធ្នូពីឈើ ហើយធ្វើព្រួញពីឈើត្រង់; ហេតុដូច្នោះហើយ ខ្ញុំបានប្រដាប់ខ្លួន ដោយធ្នូ និងព្រួញ ដោយខ្សែដង្ហក់ និងគ្រួស ។ ហើយខ្ញុំជំរាបឪពុកខ្ញុំថា៖ តើខ្ញុំត្រូវទៅទីណា ដើម្បីរកអាហារបាន ?

២៤ ហើយហេតុការណ៍បានកើតឡើងថា ឪពុកខ្ញុំបានសូមដល់ព្រះអម្ចាស់ ព្រោះអ៊ីពួកគេបានបន្ទាបខ្លួនដោយសារសំដីរបស់ខ្ញុំ; ព្រោះខ្ញុំបាននិយាយជាច្រើនទៅកាន់ពួកគេ ដោយអស់ពីសមត្ថភាពនៃដួងចិត្តខ្ញុំ ។

២៥ ហើយហេតុការណ៍បានកើតឡើងថា សម្លេងនៃព្រះអម្ចាស់ បានបន្លឺមកឪពុកខ្ញុំ; ហើយឪពុកខ្ញុំបានត្រូវស្ដីប្រដៅជាទម្ងន់ដោយ មកពីលោកបានរអ៊ូរទាំទាស់នឹងព្រះអម្ចាស់ ដរាបដល់លោកធ្លាក់ទៅក្នុងជំរៅនៃការសោកសៅ ។

២៦ ហើយហេតុការណ៍បានកើតឡើងថា សម្លេងនៃព្រះអម្ចាស់ ក៏មានព្រះបន្ទូលមកលោកថា៖ ចូរមើលលើដុំមូលនោះនឹងឃើញអ្វី ដែលបានសរសេរទុក ។

២៧ ហើយហេតុការណ៍បានកើតឡើងថា កាលឪពុកខ្ញុំឃើញនូវអ្វីៗ ដែលបានសរសេរទុក នៅលើដុំមូលហើយនោះលោកក៏កើត ក្ដីភ័យខ្លាច ហើយញ័ររន្ធត់ ហើយព្រមទាំងបងៗខ្ញុំ កូនប្រុសទាំងឡាយរបស់អ៊ីសម៉ាអែល ហើយនឹងប្រពន្ធយើងក៏ដូច្នោះដែរ ។

២៨ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានឃើញថា ទ្រនិចនៅក្នុងដុំមូលនោះ ដើរតាមសេចក្ដីជំនឿ និងសេចក្ដី ព្យាយាម និងការគោរពដែលយើងមានចំពោះវា ។

២៩ ហើយមានការសរសេរថ្មី ទុកនៅក្នុងដុំមូលនោះផងដែរ

១៤ *ក* គ. និង ស. ១៧:១.
១៦ *ក* ១ នីហ្វៃ ១៦:១០, ១៦, ២៦; ១៨:១២; អាលម៉ា ៣៧:៣៨–៤៦.
១៨ *ក* ២ សាំយូ. ២២:៣៥.
២២ *ក* និក្ខ. ១៦:៨; ជនគ. ១១:១.
២៣ *ក* និក្ខ. ២០:១២; ម៉ូសាយ ១៣:២០.
២៤ *ក* ស.ប. ការអធិស្ឋាន.
២៥ *ក* អេធើរ ២:១៤. ស.ប. វាយផ្ចាល, ការវាយផ្ចាល.
២៨ *ក* អាលម៉ា ៣៧:៤០. ស.ប. សេចក្ដីជំនឿ.

គឺច្បាស់សំរាប់អាន ដែលបណ្ដាលឲ្យយើងយល់[ក]ផ្លូវទាំងឡាយនៃ
ព្រះអម្ចាស់បាន; ហើយសេចក្ដីទាំងនោះ បានត្រូវសរសេរ
ហើយផ្លាស់ប្ដូរតាមវេលា ស្របតាមសេចក្ដីជំនឿ និងសេច
ក្ដីព្យាយាម ដែល យើងមានចំពោះវា ។ ដោយហេតុនេះហើយ
ទើបយើងឃើញថា ដោយសារមធ្យោបាយដ៏[ខ]តូចតាច នោះព្រះ
អម្ចាស់ទ្រង់អាច សំរេចការណ៍យ៉ាងធំបាន ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាន
ដើរឡើងទៅដល់កំពូលភ្នំ តាមសេចក្ដីណែនាំ ដែលមាននៅ
ក្នុងដុំមូលនោះ ។
៣១ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានបរបាញ់
សត្វព្រៃជាច្រើន ដរាបដល់ខ្ញុំអាចរកអាហារបាន សំរាប់
គ្រួសារយើងទាំង អស់គ្នា ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានត្រឡប់មក
ត្រសាលយើងវិញ ដោយរែកសត្វព្រៃ ដែលខ្ញុំបាញ់បាន;
ហើយឥឡូវនេះ កាលពួកគេបានឃើញខ្ញុំរកអាហារមកបាន
នោះគេក៏មានសេចក្ដីអំណរជាខ្លាំង ! ហើយហេតុការណ៍
បានកើតឡើងថា ពួកគេក៏បន្ទាប ខ្លួននៅចំពោះព្រះអម្ចាស់
ហើយបានថ្លែងអំណរគុណដល់ទ្រង់ ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា យើងក៏បានបន្ត
ដំណើររបស់យើងទៀត ដោយទៅតាមក្បែរផ្លូវដដែល ដូច
ដែលយើង បានធ្វើមក; ហើយបន្ទាប់ពីយើងបានធ្វើដំណើរ
អស់ជាច្រើនថ្ងៃ យើងបានបោះត្រសាលម្ដងទៀត ដើម្បីឲ្យ
យើងអាចឈប់សំរាកមួយ រយៈសិន ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា [ក]អ៊ីសម៉ាអែល
ក៏ស្លាប់ទៅ ហើយបានត្រូវបញ្ចុះនៅកន្លែងមួយហៅថា ណាហុម ។
៣៥ ហើយហេតុការណ៍បានកើតឡើងថា កូនស្រីទាំងប៉ុន្មាន
របស់អ៊ីសម៉ាអែល បានយំទួញសោកជាខ្លាំង ពីព្រោះ[ក]មក
ពីការបាត់ បង់ឪពុករបស់ពួកគេ ហើយពីព្រោះមកពីសេចក្ដី
វេទនារបស់គេ នៅក្នុងទីរហោស្ថាន; ហើយគេបានរអ៊ូរទាំទាស់នឹង
ឪពុកខ្ញុំ ពីព្រោះ លោកបាននាំពួកគេចេញពីដែនដីយេរូសាឡិម
ថា៖ ឪពុកយើងស្លាប់ហើយ; មែនហើយ យើងបាន
ដើររសាត់ព្រាត់នៅក្នុងទីរហោស្ថាន ហើយយើងបានរងទុក្ខ
វេទនា នូវសេចក្ដីអត់ឃ្លាន សេចក្ដីស្រេក និងសេចក្ដីនឿយហត់ជា
ខ្លាំង; ហើយបន្ទាប់ពីសេចក្ដីទុក្ខលំបាកទាំង នេះ យើងនឹងត្រូវ
វិនាសនៅក្នុងទីរហោស្ថាន ដោយការអត់ឃ្លានទៀត ។
៣៦ ហើយពួកគេបានរអ៊ូរទាំទាស់នឹងឪពុកខ្ញុំ ហើយទាស់
នឹងខ្ញុំដូច្នេះដែរ; ហើយពួកគេមានប្រាថ្នាចង់ត្រឡប់ទៅឯក្រុង
យេរូសាឡិមវិញ ។
៣៧ ហើយលេមិនបាននិយាយទៅលេមយ្យូល និងកូនប្រុស
ទាំងឡាយរបស់អ៊ីសម៉ាអែលផងថា៖ មើលចុះ ចូរយើង
[ក]សម្លាប់ឪពុក យើង និងប្អូនប្រុសយើងផង គឺនីហ្វៃ ដែលជាអ្នក
បានលើកខ្លួន[ខ]ធ្វើជាអ្នកត្រួតត្រា និងជាគ្រូបង្រៀនយើង ដែល
ត្រូវជាបងៗរបស់វា ។
៣៨ ឥឡូវនេះ វានិយាយថា ព្រះអម្ចាស់ទ្រង់បានប្រាប់វា
ហើយថា [ក]ពួកទេវតាបានធ្វើការងារបំរើវាទៀត ។ ប៉ុន្តែមើលចុះ
យើងដឹងថា វាកុហកយើង; ហើយវាប្រាប់យើងពីរឿងទាំងនេះ
ហើយវាប្រឌិតរឿងជាច្រើន ដោយសារល្បិចភូតភររបស់វា
ដើម្បីវាអាចបន្លំភ្នែកយើង ដោយគិតថា ប្រហែលជាវាអាច
នាំយើង ទៅក្នុងទីរហោរស្ថានដ៏ចម្លែក; ហើយបន្ទាប់ពីវាបាន
នាំយើងទៅ ឆ្ងាយហើយ វាគិតថា នឹងលើកខ្លួនវាជាស្ដេច
និងជាអ្នកត្រួតត្រាលើយើង ដើម្បីវានឹងអាចធ្វើអ្វីៗដល់យើង
ស្របតាមចំណង់ និងការ គាប់ចិត្តវា ។ ហើយដោយពាក្យ
បែបនេះហើយ ដែលបងខ្ញុំ លេមិន បានចាក់រុកចិត្តពួកគេឲ្យ
កើតសេចក្ដីក្រេវក្រោធ ។
៣៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
បានគង់នៅជាមួយនឹងយើង មែនហើយ សូម្បីតែសម្លេងនៃព្រះ
អម្ចាស់ ក៏បានបន្ទឹ[ក]មកយើង ហើយមានព្រះបន្ទូលទៅពួកគេ
ជាច្រើន ហើយបានស្ដីប្រដៅពួកគេជាខ្លាំង; ហើយបន្ទាប់ពីពួកគេ
បានត្រូវស្ដីប្រដៅ ដោយសម្លេងនៃព្រះអម្ចាស់ហើយ គេក៏ឈប់
ខឹងទៅ ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេ ដរាប
ដល់ព្រះអម្ចាស់ទ្រង់បានប្រទាន ពរដល់យើង ដោយប្រទាន
អាហារទៀត ដែលយើងមិនបានវិនាសឡើយ ៕

## ជំពូកទី ១៧

*នីហ្វៃត្រូវបានបញ្ជាឲ្យសង់សំពៅមួយ — បងៗរបស់លោ*

២៩ *ក* ស.ប. យោបល់.
*ខ* ២ ពង្សាវ. ៥:១៣; យ៉ាកុប ៣:៤; អាលម៉ា ៣៧:៦–៧, ៤១; គ. និង ស. ១២៣:១៦.
៣៤ *ក* ១ នីហ្វៃ ៧:២–៦.
៣៥ *ក* ស.ប. សេចក្ដីទំនាស់.
៣៧ *ក* ១ នីហ្វៃ ១៧:៤៤. ស.ប. ឃាតកម្ម.
*ខ* លោកុ. ៣៧:៩–១១; ១ នីហ្វៃ ២:២២; ១៨:១០.
៣៨ *ក* ១ នីហ្វៃ ៣:៣០–៣១; ៤:៣.
៣៩ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.

*ករឹងទទឹងនឹងលោក — លោកទូន្មានពួកគេ ដោយប្រាប់អំពីប្រវត្តិនៃ ទំនាក់ទំនងនៃព្រះជាមួយនឹងសាសន៍អ៊ីស្រាអែល — លោកបានពោរពេញទៅដោយព្រះចេស្ដានៃព្រះ — បងៗរបស់លោកត្រូវបាន ហាមមិនឲ្យប៉ះពាល់លោក ក្រែងពួកគេត្រូវស្វិតដូចដើមត្រែងស្ងួត ។ ប្រមាណជាឆ្នាំ ៥៩២–៥៩១ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា យើងបានបន្តដំណើរក្នុងទីរហោស្ថានម្ដងទៀត; ហើយយើងបានធ្វើដំណើរបញ្ឆិតទៅទិសខាង កើត ចាប់ពីពេលនោះតទៅ ។ ហើយយើងបានធ្វើដំណើរលុយកាត់សេចក្ដីវេទនាជាច្រើន នៅក្នុងទីរហោស្ថាន; ហើយប្រពន្ធ យើងបានបង្កើតកូន នៅក្នុងទីរហោស្ថាន ។

២ ហើយព្រះពរនៃព្រះអម្ចាស់ ដែលទ្រង់បានប្រទានមកលើយើងនោះច្រើនណាស់ គឺនៅពេលដែលយើងបានចិញ្ចឹមជីវិតដោយ [ក]សាច់ឆៅ នៅក្នុងទីរហោស្ថាន នោះប្រពន្ធយើងមានទឹកដោះគ្រប់គ្រាន់ សំរាប់បំបៅកូនៗ ហើយមានកម្លាំងមាំមួន មែនហើយ ដូចជា ប្រុសៗដែរ; ហើយពួកគេបានចាប់ផ្ដើមទ្រាំទ្រនឹងការធ្វើដំណើរ ដោយពុំបានរអ៊ូរទាំឡើយ ។

៣ ដូច្នេះហើយ ទើបយើងឃើញថា ព្រះបញ្ញត្តិទាំងឡាយនៃព្រះត្រូវតែបានបំពេញ ។ ហើយបើសិនជាកូនចៅមនុស្ស [ក]កាន់តាម ព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះទ្រង់នឹងចិញ្ចឹមគេ ហើយផ្ដល់កម្លាំងដល់គេ ព្រមទាំងផ្ដល់ផ្លូវឲ្យ ដើម្បីគេអាច[ខ]សំរេចនូវអ្វីៗដែលទ្រង់ បានបញ្ជាពួកគេ; ហេតុដូច្នោះហើយ ទ្រង់បានផ្ដល់ផ្លូវសំរាប់ពួកយើង នៅពេលដែលយើងឈប់សំរាកក្នុងទីរហោស្ថាន ។

៤ ហើយយើងបានធ្វើដំណើរអស់រយៈពេលជាច្រើនឆ្នាំ មែនហើយ គឺអស់ដល់ទៅប្រាំបីឆ្នាំ នៅក្នុងទីរហោស្ថាន ។

៥ ហើយយើងបានមកដល់ដែនដីដែលយើងហៅថា បរិបូរណ៍ ពីព្រោះទីនោះបរិបូរទៅដោយផ្លែឈើ និងទឹកឃ្មុំព្រៃ; ហើយគ្រប់ ការណ៍ទាំងអស់នេះ ត្រូវបានរៀបចំទុកដោយព្រះអម្ចាស់ ដើម្បីកុំឲ្យយើងអាចត្រូវវិនាស ។ ហើយយើងបានឃើញសមុទ្រ ដែលយើង ហៅថា អេរេអានទុម ដែលប្រែថា ទឹកច្រើន ។

៦ ហើយហេតុការណ៍បានកើតឡើងថា យើងបានបោះត្រសាលនៅក្បែរឆ្នេរសមុទ្រ ហើយទោះបីយើងរងទុក្ខ[ក]សេចក្ដីវេទនា និង សេចក្ដីលំបាកមកជាច្រើនក៏ដោយ មែនហើយ គឺច្រើនណាស់ រហូតដល់យើងពុំអាចសរសេរឲ្យអស់ទេ គង់តែយើងមានសេចក្ដីត្រេកអរជាខ្លាំង កាលយើងមកដល់មាត់សមុទ្រ ហើយយើងហៅទីនោះថា បរិបូរណ៍ ពីព្រោះទីនោះមានផ្លែឈើច្រើន ។

៧ ហើយហេតុការណ៍បានកើតឡើងថា កាលខ្ញុំ នីហ្វៃ បាននៅក្នុងដែនដីបរិបូរណ៍ អស់រយៈពេលជាច្រើនថ្ងៃហើយ នោះសម្លេងនៃ ព្រះអម្ចាស់បានបន្លឺមកខ្ញុំថា៖ ចូរក្រោកឡើង ហើយដើរទៅលើភ្នំ ។ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំក៏ក្រោកឡើង ហើយដើរ ឡើងទៅលើភ្នំ ហើយអំពាវនាវដល់ព្រះអម្ចាស់ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ អ្នកត្រូវសង់[ក]សំពៅមួយ តាមរបៀបដែលយើងនឹង បង្ហាញអ្នក ដើម្បីយើងអាចនាំគ្រួសាររបស់អ្នកឆ្លងកាត់ទឹកទាំងនេះ ។

៩ ហើយខ្ញុំទូលថា៖ ឱព្រះអម្ចាស់អើយ តើទូលបង្គំនឹងទៅផ្លូវណា ដើម្បីរកលោហធាតុមករំលាយ ដើម្បីទូលបង្គំអាចធ្វើគ្រឿង ឧបករណ៍ សំរាប់សង់សំពៅទៅតាមរបៀបដែលព្រះអង្គទ្រង់បានបង្ហាញទូលបង្គំនោះ ?

១០ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានប្រាប់ខ្ញុំ នូវកន្លែងដែលខ្ញុំត្រូវទៅដើម្បីរកលោហធាតុ ដើម្បីខ្ញុំអាច ធ្វើគ្រឿងឧបករណ៍ ។

១១ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានធ្វើឧបករណ៍ផ្លុំខ្យល់ដោយស្បែកសត្វ សំរាប់ផ្លុំភ្លើង; ហើយបន្ទាប់ពីខ្ញុំធ្វើបំពង់ ដើម្បីយកទៅផ្លុំភ្លើងហើយ នោះខ្ញុំបានយកថ្មពីរដុំមកកួតនឹងគ្នា ដើម្បីបង្កាត់ភ្លើង ។

១២ ត្បិតព្រះអម្ចាស់ ទ្រង់មិនបានអនុញ្ញាតឲ្យយើងដុតភ្លើងឡើយ កាលយើងធ្វើដំណើរនៅក្នុងទីរហោស្ថាន; ត្បិតទ្រង់មានព្រះបន្ទូលថា៖ យើងនឹងធ្វើឲ្យអាហាររបស់អ្នកផ្អែមឆ្ងាញ់ ដោយអ្នកមិនបាច់[ក]ចំអិនទេ ។

១៣ ហើយយើងក៏នឹងទៅជា[ក]ពន្លឺរបស់អ្នករាល់គ្នា នៅក្នុងទីរហោស្ថានដែរ; ហើយយើងនឹងរៀបចំផ្លូវសំរាប់អ្នករាល់គ្នា បើសិនជា អ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង; ហេតុដូច្នោះហើយ ដរាបណាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំង

**១៧** ២*ក* ១ នីហ្វៃ ១៧:១២.
៣ *ក* ម៉ូសាយ ២:៤១; អាលម៉ា ២៦:១២.
ស.ប. ការគោរព, ដែលគោរព, គោរព.
*ខ* ១ នីហ្វៃ ៣:៧.
៦ *ក* ២ នីហ្វៃ ៤:២០.
៨ *ក* ១ នីហ្វៃ ១៨:២.
១២ *ក* ១ នីហ្វៃ ១៧:២.
១៣ *ក* អាលម៉ា ៣៧:៣៨–៣៩.

ឡាយរបស់យើង នោះអ្នករាល់គ្នានឹងត្រូវបាននាំទៅដែនដីសន្យា;
ហើយអ្នករាល់គ្នានឹងដឹងថា គឺយើងនេះហើយដែលបាននាំអ្នក
រាល់គ្នាទៅ ។
១៤ មែនហើយ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដែរថា៖
បន្ទាប់ពីអ្នករាល់គ្នាបានទៅដល់ដែនដីសន្យាហើយ នោះអ្នក
រាល់ គ្នានឹងដឹងថា យើងជាព្រះអម្ចាស់ គឺជាព្រះ; ហើយថា
យើងជាព្រះអម្ចាស់ បានរំដោះអ្នករាល់គ្នា ឲ្យរួចផុតពីសេច
ក្ដីបំផ្លិចបំផ្លាញ; មែនហើយ គឺថា យើងបាននាំអ្នករាល់
គ្នាចេញពីដែនដីយេរូសាឡិម ។
១៥ ហេតុដូច្នោះហើយ ខ្ញុំ នីហ្វៃ បានខំព្យាយាមកាន់
តាមបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ហើយខ្ញុំបានទូន្មានបងៗរបស់ខ្ញុំ
ឲ្យមានចិត្ត ស្មោះត្រង់ ហើយមានចិត្តឧស្សាហ៍ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានធ្វើគ្រឿង
ឧបករណ៍ផ្សេងៗ អំពីលោហធាតុ ដែលខ្ញុំចំរាញ់យកពីថ្មមក ។
១៧ ហើយកាលបងៗខ្ញុំ បានឃើញខ្ញុំកំពុងនឹងសង់សំពៅ
នោះពួកគេក៏ចាប់ផ្ដើមរអ៊ូរទាំទាស់នឹងខ្ញុំថា៖ ប្អូនយើងជាមនុស្សឆ្កួត
ព្រោះវាស្មានថា វាអាចសង់សំពៅបាន; មែនហើយ ហើយវា
ក៏គិតស្មានថា វាអាចឆ្លងកាត់ទឹកដ៏ធំនេះបាន ។
១៨ ដូច្នេះហើយ ទើបបងៗខ្ញុំបានពោលត្អូញត្អែរទាស់នឹងខ្ញុំ
ហើយដោយមានប្រាថ្នាថា ពួកគេមិនបាច់ធ្វើការទេ ត្បិតពួក
គេមិន ជឿថា ខ្ញុំអាចសង់សំពៅបានឡើយ; ហើយពួកគេក៏ព្រម
ទាំងមិនជឿថា ខ្ញុំត្រូវបានបង្គាប់ពីព្រះអម្ចាស់ឡើយ ។
១៩ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ
កើតសេចក្ដីព្រួយបារម្ភយ៉ាងខ្លាំង ព្រោះតែភាពរឹងរូសនៃចិត្ត
របស់ ពួកគេ; ហើយឥឡូវនេះ នៅពេលដែលគេបានឃើញខ្ញុំ
ចាប់ផ្ដើមកើតសេចក្ដីព្រួយបារម្ភ នោះពួកគេកើតសេចក្ដី
សប្បាយក្នុងចិត្ត ដរាបដល់បានរីករាយដាក់លើរូបខ្ញុំ ដោយ
និយាយថា៖ យើងបានដឹងហើយថា ឯងមិនអាចសង់សំពៅ
បានទេ ព្រោះយើងដឹងហើយថា ឯងខ្វះការវិនិច្ឆ័យ; ហេតុ
ដូច្នោះហើយ ឯងពុំអាចសំរេច នូវកិច្ចការដ៏ធំនេះបានឡើយ ។
២០ ហើយឯងនេះ ក៏ដូចជាឪពុកយើងដែរ ដោយបានត្រូវ
នាំដោយគំនិតដ៏ឥតប្រយោជន៍នៃចិត្តលោក; មែនហើយ
លោកបាន នាំយើង ចេញពីដែនដីយេរូសាឡិម ហើយយើង
បានដើររសាត់ព្រាត់នៅក្នុងទីរហោស្ថាន អស់ពេលជាច្រើន
ឆ្នាំ; ហើយប្រពន្ធយើង បានធ្វើការនឿយហត់ ដោយមាន
ផ្ទៃពោះផង; ហើយគេបានបង្កើតកូននៅក្នុងទីរហោស្ថាន ហើយរង
ទុក្ខគ្រប់យ៉ាង លើកលែងតែ សេចក្ដីស្លាប់; ហើយប្រសិន
បើគេបានស្លាប់ មុនពេលចាកចេញពីក្រុងយេរូសាឡិម នោះ
គឺជាការប្រសើរជាង ត្រូវរងទុក្ខសេចក្ដីវេទនា បែបនេះ ។
២១ មើលចុះ ប៉ុន្មានឆ្នាំមកហើយនេះ យើងបានរងទុក្ខនៅ
ក្នុងទីរហោស្ថាន គឺជារយៈពេលនោះ ដែលយើងអាចត្រេកអរ
នឹងទ្រព្យ សម្បត្តិរបស់យើង និងដែនដីនៃកេរ្ដិ៍អាកររបស់យើង;
មែនហើយ ហើយយើងអាចមានសេចក្ដីសុខសប្បាយ ។
២២ ហើយយើងដឹងថា មនុស្សដែលនៅឯដែនដីយេរូសាឡិម
គឺជាមនុស្សសុចរិត; ព្រោះពួកគេបានកាន់តាមក្រិត្យក្រម សេចក្ដី
យុត្តិធម៌នៃព្រះអម្ចាស់ និងគ្រប់ទាំងបញ្ញត្តិទាំងអស់របស់ទ្រង់
ស្របតាមក្រិត្យវិន័យលោកម៉ូសេ; ហេតុដូច្នោះហើយ យើងដឹងថា
ពួកគេជាមនុស្សសុចរិត; ហើយឪពុកយើងបានថ្កោលទោសគេ
ហើយបាននាំយើងចេញឆ្ងាយ ពីព្រោះយើងបានស្ដាប់តាមពាក្យ
សំដីលោក; មែនហើយ ហើយប្អូនយើងនេះ ក៏ដូចលោកដែរ ។
ហើយដោយពាក្យបែបនេះហើយ ដែលបងៗខ្ញុំបានរអ៊ូរទាំ
ហើយពោលទាស់ នឹងយើង ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាន
និយាយទៅពួកគេថា៖ តើបងរាល់គ្នាជឿទេថា ពួកអយ្យកោ
យើងជាកូន ចៅរបស់អ៊ីស្រាអែល បានត្រូវនាំចេញ
ពីកណ្ដាប់ដៃរបស់ពួកសាសន៍អេស៊ីព្ទរួចឬ ប្រសិនបើពួកគេមិន
បានប្រុងស្ដាប់តាមព្រះបន្ទូលនៃព្រះ អម្ចាស់នោះ ?
២៤ មែនហើយ តើបងរាល់គ្នាគិតស្មានថា ពួកគេនឹងត្រូវ
នាំចេញផុតពីសេវកភាពបានឬ ប្រសិនបើព្រះអម្ចាស់ ទ្រង់មិន
បានបញ្ជា លោកម៉ូសេ ឲ្យនាំពួកគេចេញពីសេវកភាពនោះ ?
២៥ ឥឡូវនេះ បងរាល់គ្នាដឹងថា កូនចៅអ៊ីស្រាអែលនៅ
ក្នុងសេវកភាព; ហើយបងរាល់គ្នាដឹងថា ពួកគេត្រូវបង្ខំឲ្យធ្វើ
ការជាទម្ងន់ ដែលពិបាកនឹងទ្រាំទ្របាន; ហេតុដូច្នោះហើយ
បងរាល់គ្នាដឹងថា ជាការល្អមួយសំរាប់ពួកគេ ដែលពួកគេនឹង
ត្រូវនាំចេញពីសេវកភាព នោះបាន ។
២៦ ឥឡូវនេះ បងរាល់គ្នាដឹងហើយថា លោកម៉ូសេត្រូវ

១៣ *ខ* ១ នីហ្វៃ ២:២០; យ៉ាកុប ២:១២.
*គ* និក្ខ. ៦:៧.
១៤ *ក* ២ នីហ្វៃ ១:៤.
ស.ប. ទីបន្ទាល់.
*ខ* គ. និង ស. ៥:២.
១៧ *ក* ១ នីហ្វៃ ១៨:១–៦.
១៩ *ក* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
២០ *ក* ១ នីហ្វៃ ២:១១.
២២ *ក* ១ នីហ្វៃ ១:១៣.
២៤ *ក* និក្ខ. ៣:២–១០; ១ នីហ្វៃ ១៩:១០;
២ នីហ្វៃ ៣:៩; ២៥:២០.
២៥ *ក* លោកុ. ១៥:១៣–១៤.
*ខ* និក្ខ. ១:១១; ២:១១.
២៦ *ក* កិច្ចការ ៧:២២–៣៩.

បានបញ្ជាដោយព្រះ[ខ]អម្ចាស់ ឲ្យធ្វើកិច្ចការដ៏ធំនោះ; ហើយបងរាល់គ្នាដឹងថា ដោយពាក្យរបស់លោក នោះទឹកសមុទ្រក្រហមត្រូវញែកជាពីរ ពីម្ខាងទៅម្ខាង ហើយពួកគេដើរឆ្លងកាត់លើដីគោក ។

២៧ ប៉ុន្តែបងរាល់គ្នាដឹងថា ពួកសាសន៍អេស៊ីព្ទ ដែលជាពលទ័ពរបស់ផារ៉ោន ត្រូវលិចលង់ទៅក្នុងទឹកសមុទ្រក្រហម ។

២៨ ហើយបងរាល់គ្នាក៏ដឹងដែរថា ពួកគេត្រូវបាន[ក]នំម៉ាណាមកបរិភោគ នៅក្នុងទីរហោស្ថាន ។

២៩ មែនហើយ បងរាល់គ្នាក៏ដឹងដែរថា លោកម៉ូសេដោយសារពាក្យរបស់លោក ដែលស្របតាមព្រះ[ក]ចេស្តានៃព្រះដែលមាននៅ ក្នុងខ្លួនលោក នោះលោកបានវាយថ្ម ហើយទឹកក៏ហូរចេញមក ដើម្បីឲ្យកូនចៅអ៊ីស្រាអែល ផឹកបំបាត់ស្រេក ។

៣០ ហើយទោះបីពួកគេត្រូវបាននាំទៅ ដោយមានព្រះអម្ចាស់ជាព្រះរបស់ពួកគេ ជាព្រះប្រោសលោះរបស់គេ យាងពីមុខគេ, នាំគេក្នុងពេលថ្ងៃ និងផ្ដល់[ក]ពន្លឺក្នុងពេលយប់, ហើយធ្វើអ្វីៗសព្វបែបយ៉ាងសំរាប់ពួកគេ ដែលសមនឹងមនុស្សបានទទួលក្ដី ក៏គង់តែពួកគេ នៅតែ[ខ]ធ្វើចិត្តរឹងរូស ហើយធ្វើគំនិតងងឹតងងល់ ហើយបានជេរប្រមាថទាស់នឹងលោកម៉ូសេ ហើយទាស់នឹងព្រះដ៏ពិត និងដ៏មានព្រះជន្ម រស់នៅដែរ ។

៣១ ហើយហេតុការណ៍បានកើតឡើងថា ស្របតាមព្រះបន្ទូលរបស់ព្រះអង្គ ទ្រង់បាន[ក]បំផ្លាញពួកគេ; ហើយស្របតាមព្រះបន្ទូលរបស់ ព្រះអង្គ ទ្រង់[ខ]បាននាំពួកគេ; ហើយស្របតាមព្រះបន្ទូលរបស់ព្រះអង្គ ទ្រង់បានធ្វើអ្វីៗសព្វបែបយ៉ាងសំរាប់គេ; ហើយគ្មានអ្វីមួយដែលត្រូវ បានប្រព្រឹត្តឡើយ លើកលែងតែដោយសារព្រះបន្ទូលព្រះអង្គប៉ុណ្ណោះ ។

៣២ ហើយបន្ទាប់ពីគេបានឆ្លងកាត់ទន្លេយ័រដាន់ នោះទ្រង់បានធ្វើឲ្យពួកគេខ្លាំងពូកែ រហូតដល់បាន[ក]ដេញពួកកូនចៅដែលនៅ លើដែនទីនោះចេញ មែនហើយ រហូតដល់ធ្វើឲ្យពួកនោះខ្ចាត់ខ្ចាយដល់សេចក្ដីបំផ្លិចបំផ្លាញ ។

៣៣ ហើយឥឡូវនេះ តើបងរាល់គ្នាគិតស្មានថា ពួកកូនចៅដែលនៅលើដែនដីនេះ ដែលនៅលើដែនដីសន្យា ដែលត្រូវបានដេញ ចេញដោយពួកអយ្យកោយើង តើបងរាល់គ្នាគិតស្មានថា ពួកគេជាមនុស្សសុចរិតឬ ? មើលចុះ ខ្ញុំសូមប្រាប់បងថា មិនមែនទេ ។

៣៤ តើបងរាល់គ្នាគិតស្មានថា ពួកអយ្យកោយើងគាប់ព្រះហឫទ័យព្រះជាងពួកនេះឬ ប្រសិនបើពួកនេះជាមនុស្សសុចរិត ? ខ្ញុំប្រាប់ បងរាល់គ្នាថា មិនមែនទេ ។

៣៥ មើលចុះ ព្រះ[ខ]អម្ចាស់ទ្រង់យោគយល់ថា[ក]សាច់ទាំងអស់ដូចគ្នា; អ្នកណាដែលសុចរិត នោះ[គ]ត្រូវបានប្រោសប្រណីពីព្រះ ។ ប៉ុន្តែមើលចុះ ប្រជាជននេះបានបដិសេធនូវគ្រប់ព្រះបន្ទូលនៃព្រះ ហើយពួកគេកំពុងតែទុំក្នុងអំពើទុច្ចរិត; ហើយភាពពោរពេញនៃ សេចក្ដីក្រោធរបស់ព្រះ បានធ្លាក់មកលើពួកគេ; ហើយព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដែនដីនេះទាស់នឹងពួកគេ ហើយបានប្រទាន ពរដែនដីនេះ ដល់ពួកអយ្យកោយើង; មែនហើយ ទ្រង់បានដាក់បណ្ដាសាដែនដីនេះទាស់នឹងពួកគេ រហូតដល់សេចក្ដីបំផ្លិចបំផ្លាញ ហើយបានប្រទានពរដែនដី ដល់ពួកអយ្យកោយើង ឲ្យពួកគេមានអំណាចនៅលើដីនេះវិញ ។

៣៦ មើលចុះ ទ្រង់បាន[ក]បង្កើត[ខ]ផែនដី ដើម្បីឲ្យ[គ]មនុស្សអាស្រ័យនៅ; ហើយទ្រង់បានបង្កើតកូនចៅរបស់ព្រះអង្គដើម្បីឲ្យគ្រប់គ្រងផែន ដីនេះ ។

៣៧ ហើយទ្រង់បាន[ក]លើកសាសន៍ដ៏សុចរិតមួយ ហើយបានបំផ្លាញសាសន៍ទាំងឡាយរបស់ពួកទុច្ចរិត ។

៣៨ ហើយទ្រង់បាននាំពួកសុចរិត ទៅឯ[ក]ដែនដីទាំងឡាយ

២៦ ខ និក្ខ. ១៤:២១–៣១;
១ នីហ្វៃ ៤:២; ម៉ូសាយ ៧:១៩;
ហេលេ. ៨:១១; គ. និង ស. ៨:៣;
ម៉ូសេ ១:២៥.
២៨ ក និក្ខ. ១៦:៤, ១៤–១៥, ៣៥;
ជនគ. ១១:៧–៨; ចោទិ. ៨:៣;
ម៉ូសាយ ៧:១៩.
២៩ ក និក្ខ. ១៧:៦; ជនគ. ២០:១១;
ចោទិ. ៨:១៥; ១ នីហ្វៃ ២០:២១.
៣០ ក គ. និង ស. ១៨:១៨;
៨៨:៦៤–៦៥.
ខ និក្ខ. ៣២:៨; ជនគ. ១៤:២–៣;
អេសេ. ២០:១៣–១៦;
គ. និង ស. ៨៤:២៣–២៥.
៣១ ក ជនគ. ២៦:៦៥.
ខ ១ នីហ្វៃ ៥:១៥;
គ. និង ស. ១០៣:១៦–១៨.
៣២ ក ជនគ. ៣៣:៥២–៥៣;
យ៉ូស្វេ ២៤:៨.
៣៥ ក កិច្ចការ ១០:១៥, ៣៤;
រ៉ូម ២:១១;
២ នីហ្វៃ ២៦:២៣–៣៣.
ខ ទំនុក. ៥៥:២២; ១ នីហ្វៃ ២២:១៧.
គ ១ សាំយូ. ២:៣០; ទំនុក. ៩៧:១០;
១៤៥:២០; អាលម៉ា ១៣:៤;
គ. និង ស. ៨២:១០.
៣៦ ក ស.ប. បង្កបង្កើត, ការបង្កបង្កើត.
ខ ស.ប. ផែនដី.
គ អេសាយ ៤៥:១៨;
អ័ប្រា. ៣:២៤–២៥.
៣៧ ក សុភា. ១៤:៣៤; ១ នីហ្វៃ ៤:១៣;
អេធើរ ២:១០; គ. និង ស. ១១៧:៦.
៣៨ ក ស.ប. ដែនដីសន្យា.

ដែលពិសេស ហើយទ្រង់[ខ]បំផ្លាញពួកទុច្ចរិត ហើយដាក់បណ្ដាសា
ដែនដីដល់ពួកនេះ ដោយយល់ដល់ពួកគេ ។
៣៩ ទ្រង់គ្រប់គ្រងនៅខ្ពស់លើមេឃ ត្បិតជាបល្ល័ង្ករបស់ទ្រង់
ហើយផែនដីនេះ គឺជា[ក]ទីកំណល់កល់ព្រះបាទរបស់ទ្រង់ ។
៤០ ហើយទ្រង់ស្រឡាញ់អស់អ្នកណា ដែលទទួលទ្រង់ជា
ព្រះរបស់គេ ។ មើលចុះ ទ្រង់បានស្រឡាញ់ពួកអយ្យកោយើង
ហើយទ្រង់ បាន[ក]ធ្វើសេចក្ដីសញ្ញាជាមួយនឹងពួកគេ មែនហើយ
គឺអ័ប្រាហាំ [ខ]អ៊ីសាក និង[គ]យ៉ាកុប; ហើយទ្រង់ចាំនូវសេចក្ដីសញ្ញា
ទាំងឡាយ ដែល[ឃ]ទ្រង់ បានធ្វើ; ហេតុដូច្នោះហើយ បានជាទ្រង់
នាំពួកគេចេញពីស្រុកអេស៊ីព្ទ ។
៤១ ហើយទ្រង់បានប្រដៅពួកគេ នៅក្នុងទីរហោស្ថាន ដោយ
រំពាត់របស់ព្រះអង្គ; ព្រោះពួកគេបានធ្វើ[ក]ចិត្តរឹងរូស ដូចជាបងរាល់
គ្នា ដែរ; ហើយទ្រង់បានប្រដៅពួកគេ ដោយព្រោះសេច
ក្ដីទុច្ចរិតរបស់ពួកគេ ។ ទ្រង់បានចាត់[ខ]ឲ្យពស់ភ្លើង ហោះចុះមក
ក្នុងចំណោមពួកគេ; ហើយបន្ទាប់ពីពួកគេត្រូវពស់ចឹក នោះទ្រង់
បានរៀបចំ[គ]ផ្លូវឡើង ដើម្បីឲ្យពួកគេបានជាវិញ; ហើយការដែល
គេត្រូវធ្វើនោះ គឺគេគ្រាន់ តែក្រលេកមើលប៉ុណ្ណោះ;
ហើយដោយវិធីនេះ[ឃ]ងាយពេក ឬស្រួលពេក ទើបមានមនុស្ស
ជាច្រើនត្រូវវិនាស ។
៤២ ហើយជួន[ក]កាល [ខ]ពួកគេបានធ្វើចិត្តរឹងរូស ហើយពួកគេ
បានជេរប្រមាថទាស់នឹងលោកម៉ូសេ ហើយព្រមទាំងទាស់នឹង
ព្រះផងដែរ; ទោះជាយ៉ាងណាក៏ដោយ គង់តែបងរាល់គ្នា
ដឹងហើយថា ពួកគេត្រូវបាននាំដោយព្រះចេស្ដាដ៏ឥតប្រៀបផ្ទឹមបាន
របស់ទ្រង់ ទៅឯដែនដីសន្យាដែរ ។
៤៣ ហើយឥឡូវនេះ បន្ទាប់ពីគ្រប់ការណ៍ទាំងអស់នេះ
នោះថ្ងៃក៏មកដល់ដែលពួកគេក្លាយទៅជាពួកទុច្ចរិត មែន
ហើយ គឺទុច្ចរិត ជិតទុំអស់ទៅហើយ; ហើយខ្ញុំមិនដឹងទេ ប៉ុន្តែ
ថ្ងៃនេះ ពួកគេជិតត្រូវបំផ្លាញអស់ទៅហើយ; ត្បិតខ្ញុំដឹងថា
ថ្ងៃនោះនឹងមកដល់ជាពិត ប្រាកដ ដែលគេត្រូវបំផ្លាញចោល
លើកលែងតែមនុស្សបន្តិចបន្តួចប៉ុណ្ណោះ ដែលនឹងត្រូវចាប់យក
ទៅក្នុងការជាប់ឃុំឃាំង ។
៤៤ ហេតុដូច្នោះហើយ ព្រះអម្ចាស់ ទ្រង់[ក]បានបញ្ជាឲ្យឪពុក
ខ្ញុំថា លោកត្រូវចេញទៅទីរហោស្ថាន; ហើយពួកសាសន៍
យូដា ក៏ព្យាយាមរកផ្ដាច់ជីវិតលោកផង; មែនហើយ ហើយ
[ខ]បងរាល់គ្នាក៏ព្យាយាមរកផ្ដាច់ជីវិតលោកដែរ; ហេតុដូច្នោះហើយ
បងរាល់គ្នា ក៏ជាពួកឃាតកនៅក្នុងចិត្តបង ហើយបងៗក៏ដូចពួក
គេនោះដែរ ។
៤៥ បងរាល់គ្នា[ក]រហ័សធ្វើអំពើទុច្ចរិតណាស់ ប៉ុន្តែកម្រនឹកចាំ
ដល់ព្រះអម្ចាស់ ជាព្រះរបស់បង ។ បងរាល់គ្នាបានឃើញ
[ខ]ទេវតា ហើយទេវតានោះបាននិយាយជាមួយនឹងបងរាល់គ្នា;
មែនហើយ បងរាល់គ្នាបានឮសម្លេងរបស់ព្រះអង្គជាញឹកញយ;
ហើយទ្រង់មាន ព្រះបន្ទូលជាមួយនឹងបងរាល់គ្នា ដោយ
សម្លេងតូចរហៀងៗ ប៉ុន្តែបងរាល់គ្នាមាន[គ]ចិត្តរក់រិញ ទើបមិន
អាចចាប់អារម្មណ៍ ពីព្រះបន្ទូល របស់ព្រះអង្គឡើយ; ហេតុ
ដូច្នោះហើយ បានជាទ្រង់មានព្រះបន្ទូលជាមួយនឹងបង ដូចជា
សូរផ្គរលាន់ ដែលធ្វើឲ្យផែនដីញ័រ ហាក់បីដូច ជា
ចង់ប្រេះចេញពីគ្នា ។
៤៦ ហើយបងរាល់គ្នាក៏ដឹងដែរថា ដោយ[ក]ព្រះចេស្ដានៃព្រះ
បន្ទូល ដ៏មានឫទ្ធិរបស់ព្រះអង្គ ទ្រង់អាចធ្វើឲ្យផែនដីវិនាស
បាត់បង់ទៅ បាន; មែនហើយ ហើយបងរាល់គ្នាដឹងថា ដោយ
ព្រះបន្ទូលរបស់ព្រះអង្គ ទ្រង់អាចធ្វើឲ្យដីគ្រោតគ្រាតរាបស្មើបាន
ហើយដីរាបបែក បាក់បាន; ឱ បើដូច្នោះមែន ហេតុអ្វីបានជាបង
រាល់គ្នា ធ្វើចិត្តរឹងរូសអ្វីម្ល៉េះ ?
៤៧ មើលចុះ ព្រលឹងខ្ញុំត្រូវទុក្ខព្រួយ ពីព្រោះតែបងរាល់
គ្នា ហើយដួងចិត្តខ្ញុំក៏ឈឺខ្លោចផ្សា; ខ្ញុំខ្លាចក្រែងតែបងរាល់គ្នា
នឹងត្រូវបោះ បង់ចោលជារៀងដរាបតទៅ ។ មើលចុះ
[ក]ខ្ញុំពោរពេញទៅដោយព្រះវិញ្ញាណនៃព្រះ ដរាបដល់រាងកាយខ្ញុំ
អស់កម្លាំង ។

៣៨ *ខ* លេវី. ២០:២២.
៣៩ *ក* អេសាយ ៦៦:១;
គ. និង ស. ៣៨:១៧; អ័ប្រា. ២:៧.
៤០ *ក* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*ខ* លោកុ. ២១:១២;
គ. និង ស. ២៧:១០.
*គ* លោកុ. ២៨:១–៥.
*ឃ* ចោទិ. ៤:៣៧.
៤១ *ក* ២ ពង្សាវ. ១៧:៧–២៣.
*ខ* ជនគ. ២១:៤–៩; ចោទិ. ៨:១៥;
អាលម៉ា ៣៣:១៨–២២.
*គ* យ៉ូហាន ៣:១៣–១៥;
២ នីហ្វៃ ២៥:២០.
*ឃ* អាលម៉ា ៣៧:៤៤–៤៧;
ហេលេ. ៨:១៥.
៤២ *ក* ជនគ. ១៤:១–១២.
ស.ប. ការបះបោរ.
*ខ* គ. និង ស. ៨៤:២៣–២៤.
៤៤ *ក* ១ នីហ្វៃ ២:១–២.
*ខ* ១ នីហ្វៃ ១៦:៣៧.
៤៥ *ក* ម៉ូសាយ ១៣:២៩.
*ខ* ១ នីហ្វៃ ៤:៣.
*គ* អេភេ. ៤:១៩.
៤៦ *ក* ហេលេ. ១២:៦–១៨.
៤៧ *ក* មីកា ៣:៨.
*ខ* ១ នីហ្វៃ ១៩:២០.

៤៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលខ្ញុំបាននិយាយនូវពាក្យទាំងនេះរួចហើយ ពួកគេក៏ខឹងនឹងខ្ញុំ ហើយមានប្រាថ្នាចង់បោះខ្ញុំទៅក្នុងជំរៅទឹកសមុទ្រ; ហើយនៅពេលគេស្ទុះមកចាប់ខ្ញុំ ខ្ញុំបាននិយាយទៅគេថា៖ ដោយនូវព្រះនាមនៃព្រះដ៏មាន មហិទ្ធិឫទ្ធិ ខ្ញុំបញ្ជាបងថា កុំពាល់ខ្ញុំឲ្យសោះព្រោះខ្ញុំពោរពេញទៅដោយព្រះចេស្ដានៃព្រះ គឺរហូតដល់ឆេះសាច់ខ្ញុំ; ហើយអស់អ្នកណា ដាក់ដៃមកលើខ្ញុំ នោះនឹងត្រូវស្វិតដូចដើមត្រែងស្ងួត; ហើយអ្នកនោះនឹងក្លាយជាសូន្យបាត់ទៅ នៅចំពោះព្រះចេស្ដានៃព្រះ ព្រោះព្រះ ទ្រង់នឹងវាយអ្នកនោះ ។

៤៩ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាននិយាយទៅពួកគេថា គេមិនត្រូវរអ៊ូរទាំទាស់នឹងឪពុកគេតទៅទៀតឡើយ ហើយក៏មិនត្រូវប្រកែកមិនព្រមធ្វើកិច្ចការ ដែលខ្ញុំបានពឹងនោះដែរ ព្រោះព្រះទ្រង់បានបញ្ជាខ្ញុំថា ខ្ញុំត្រូវសង់សំពៅមួយ ។

៥០ ហើយខ្ញុំបាននិយាយទៅពួកគេថា៖ បើព្រះទ្រង់បានបញ្ជាខ្ញុំឲ្យធ្វើនូវកិច្ចការគ្រប់យ៉ាង នោះខ្ញុំអាចធ្វើកិច្ចការទាំងនោះបាន បើព្រះទ្រង់បញ្ជាឲ្យខ្ញុំនិយាយទៅទឹកនេះថា ចូរក្លាយទៅជាដី នោះទឹកនឹងក្លាយទៅជាដីមែន; ហើយបើខ្ញុំនឹងនិយាយថាដូចម្ដេចក៏នឹងបានសំរេចយ៉ាងនោះឯង ។

៥១ ហើយឥឡូវនេះ បើព្រះអម្ចាស់ទ្រង់មានព្រះចេស្ដាដ៏មហិមាយ៉ាងនេះ ហើយបានបង្កើតឲ្យមានអព្ភូតហេតុជាច្រើន ក្នុងចំណោម កូនចៅមនុស្ស ថ្វីក៏ទ្រង់មិនអាចបង្គាប់ខ្ញុំឲ្យសង់សំពៅបាន ?

៥២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាននិយាយពីរឿងជាច្រើន ទៅបងៗរបស់ខ្ញុំ ដរាបដល់ពួកគេត្រូវបានជ្រប់មុខ ហើយមិនអាចរករឿងទាស់នឹងខ្ញុំទៀតឡើយ; ហើយពួកគេក៏មិនហ៊ានដាក់ដៃមកលើខ្ញុំ ឬប៉ះពាល់ខ្ញុំនឹងដៃពួកគេឡើយ គឺអស់រយៈពេល ជាច្រើនថ្ងៃ ។ ឥឡូវនេះ ពួកគេពុំហ៊ានធ្វើយ៉ាងនេះ ក្រែងពួកគេត្រូវស្វិតនៅចំពោះមុខខ្ញុំ ព្រះវិញ្ញាណនៃព្រះមានអំណាចដល់ម្ល៉េះ; ហើយទ្រង់ប្រព្រឹត្តទៅលើពួកគេដូច្នោះ ។

៥៣ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ចូរហុចដៃទៅឲ្យបងៗរបស់អ្នកទៀតចុះ ហើយ ពួកគេនឹងមិនត្រូវស្វិតនៅចំពោះអ្នកឡើយ ប៉ុន្តែព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា យើងនឹងធ្វើឲ្យគេភ្លឹកភ្លាំងស្មារតី ហើយយើងធ្វើ យ៉ាងនេះ ដើម្បីឲ្យពួកគេដឹងថា យើងជាព្រះអម្ចាស់ ដ៏ជាព្រះរបស់ពួកគេ ។

៥៤ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានហុចដៃទៅឲ្យបងៗខ្ញុំ ហើយពួកគេមិនបានស្វិតនៅ ចំពោះមុខខ្ញុំឡើយ; ប៉ុន្តែព្រះ អម្ចាស់ ទ្រង់បានកន្ត្រាក់ពួកគេ ដូចដែលព្រះអង្គមានព្រះបន្ទូលទុក ។

៥៥ ហើយឥឡូវនេះ ពួកគេបាននិយាយថា៖ យើងដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងឯង ព្រោះយើងដឹងថាព្រះ ចេស្ដានៃព្រះអម្ចាស់បានកន្ត្រាក់ពួកយើង ។ ហើយពួកគេបានលុតជង្គង់ចុះចំពោះមុខខ្ញុំ ហើយបំរុងនឹងថ្វាយបង្គំខ្ញុំ ប៉ុន្តែខ្ញុំបានឃាត់ ពួកគេថា៖ ខ្ញុំជាប្អូនរបស់បង មែនហើយ ដែលមានអាយុតិចជាងបង; ហេតុដូច្នោះហើយ សូមបងថ្វាយបង្គំព្រះអម្ចាស់ ដ៏ជាព្រះរបស់ បងវិញ ហើយសូមគោរពប្រតិបត្តិដល់ឪពុករបស់បង និងម្ដាយរបស់បងចុះ ដើម្បីឲ្យបងអាចមានអាយុយឺនយូរនៅលើដែនដី ដែលព្រះអម្ចាស់ ដ៏ជាព្រះរបស់បង ទ្រង់នឹងប្រទានឲ្យបង ៕

## ជំពូកទី ១៨

*សំពៅត្រូវបានធ្វើរួចហើយ — កំណើតរបស់យ៉ាកុប និងយ៉ូសែបត្រូវបានជំណាលប្រាប់ — ក្រុមគេចុះសំពៅទៅរកដែនដីសន្យា — កូនប្រុសៗរបស់អ៊ីសម៉ាអែល និងប្រពន្ធគេរួមក្នុងការសប្បាយអ៊ូអរ និងការបះបោរ — នីហ្វៃត្រូវគេចង ហើយសំពៅត្រូវខ្យល់ព្យុះ កំណាចរុញច្រានថយក្រោយ — នីហ្វៃបានរួចពីចំណង ហើយដោយការអធិស្ឋានរបស់លោក ខ្យល់ព្យុះក៏ស្ងប់ស្ងាត់ទៅ — ប្រជាជនទៅដល់ដែនដីសន្យា ។ ប្រមាណជាឆ្នាំ ៥៩១–៥៨៩ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានថ្វាយបង្គំព្រះអម្ចាស់ ហើយបានចេញទៅជាមួយខ្ញុំ; ហើយយើងយកឈើធ្វើរាងសំពៅ ដ៏វិចិត្រ ។ ហើយព្រះអម្ចាស់ទ្រង់បានបង្ហាញខ្ញុំជាញយៗពីរបៀបដែលខ្ញុំត្រូវធ្វើរាងសំពៅ ។

២ ឥឡូវនេះ ខ្ញុំ នីហ្វៃ មិនបានធ្វើរាងសំពៅតាមរបៀបដែលមនុស្សបានរៀនទេ ហើយខ្ញុំក៏ពុំបានសង់សំពៅ តាមក្បួនរបស់មនុស្ស ដែរ; ប៉ុន្តែខ្ញុំបានធ្វើសំពៅនេះ តាមរបៀបដែល

៤៨ *ក* ម៉ូសាយ ១៣:៣.
*ខ* ២ នីហ្វៃ ១:២៦–២៧.
ស.ប. អំណាច.
*គ* ១ ពង្សាវ. ១៣:៤–៧.
៥០ *ក* ភីលីព ៤:១៣; ១ នីហ្វៃ ៣:៧.
៥១ *ក* លោកុ. ៦:១៤–១៦; ១ នីហ្វៃ ១៨:១.
៥២ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៥៥ *ក* កិច្ចការ ១៤:១១–១៥.
*ខ* និក្ខ. ២០:១២; ម៉ូសាយ ១៣:២០.

ព្រះបានបង្ហាញខ្ញុំ; ហេតុដូច្នោះហើយ ពុំមែនជារបៀបរបស់
មនុស្សឡើយ ។
៣ ហើយខ្ញុំ នីហ្វៃ បានទៅលើភ្នំជាញឹកញាប់ ហើយខ្ញុំបាន
[ក]អធិស្ឋានដល់ព្រះអម្ចាស់ជាញយៗ; ហេតុដូច្នោះហើយ ទើបព្រះ
អម្ចាស់ [ខ]ទ្រង់បង្ហាញខ្ញុំ ពីការណ៍ដ៏ប្រសើរជាច្រើន ។
៤ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំបានធ្វើ
សំពៅ ស្របតាមព្រះបន្ទូលនៃព្រះអម្ចាស់រួចហើយ នោះបងៗខ្ញុំ
បានឃើញ ថា សំពៅនេះល្អ ឯក្បាច់ក្បូរសោតក៏ល្អវិចិត្រ; ហេតុ
ដូច្នោះហើយ ទើបពួកគេបាន[ក]បន្ទាបខ្លួនចំពោះព្រះអម្ចាស់ម្តងទៀត ។
៥ ហើយហេតុការណ៍បានកើតឡើងថា សម្លេងនៃព្រះ
អម្ចាស់បានបន្លឺមកឪពុកខ្ញុំថា ពួកយើងត្រូវក្រោកឡើង ហើយ
ចុះទៅក្នុងសំពៅ ។
៦ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង
បន្ទាប់ពីយើងបានរៀបចំវត្ថុគ្រប់យ៉ាង មានផ្លែឈើជាច្រើន និង
[ក]សាច់ ដែលបានមកពីទីរហោស្ថាន និងទឹកឃ្មុំដ៏បរិបូរ ហើយស្បៀង
ទាំងឡាយ ស្របតាមអ្វីដែលព្រះអម្ចាស់ទ្រង់បានបញ្ជាយើង
នោះយើង បានចុះទៅក្នុងសំពៅ ជាមួយនឹងផ្ទុកអីវ៉ាន់
របស់យើងគ្រប់យ៉ាង និងគ្រាប់ពូជរបស់យើង និងអ្វីៗដែល
យើងបានយកមក ស្របតាមអាយុ របស់ខ្លួនម្នាក់ៗ; ហេតុ
ដូច្នោះហើយ ទើបយើងទាំងអស់គ្នាបានចុះទៅក្នុងសំពៅ ជា
មួយនឹងប្រពន្ធយើង និងកូនចៅយើង ។
៧ ហើយឥឡូវនេះ ឪពុកខ្ញុំបង្កើតបានកូនប្រុសពីរនាក់ នៅក្នុង
ទីរហោស្ថាន; បងត្រូវហៅថា [ក]យ៉ាកុប រីឯប្អូន គឺ[ខ]យ៉ូសែប ។
៨ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីយើងទាំង
អស់គ្នាបានចុះទៅក្នុងសំពៅរួចហើយ ហើយបានយកមកជា
មួយយើង នូវស្បៀង និងវត្ថុទាំងឡាយ ដែលត្រូវបានបញ្ជាឲ្យ
យើងយក នោះយើងបានចេញដំណើរ ទៅតាម[ក]សមុទ្រ ហើយ
បានត្រូវខ្យល់បក់ សំពៅសំដៅទៅឯ[ខ]ដែនដីសន្យា ។
៩ ហើយបន្ទាប់ពីយើងបានត្រូវខ្យល់បក់ទៅមុខ អស់រយៈ
ពេលជាច្រើនថ្ងៃ នោះមើលចុះ បងៗខ្ញុំ និងកូនប្រុសៗរបស់
អ៊ីសម៉ាអែល ហើយព្រមទាំងប្រពន្ធរបស់ពួកគេផង បានចាប់ផ្តើម
មានការសប្បាយ ដរាបដល់គេចាប់ផ្តើមរាំ ហើយច្រៀង
ហើយនិយាយពាក្យ ទ្រគោះ មែនហើយ គឺរហូតដល់ពួក
គេភ្លេចអស់ថា តើដោយសារអំណាចអ្វី ដែលបាននាំពួកគេ
មកដល់ទីនេះ; មែនហើយ ពួកគេ បានដំកើងគ្នា ដល់ទៅមាន
ភាពទ្រគោះហួសវិស័យ ។
១០ ហើយខ្ញុំ នីហ្វៃ បានចាប់ផ្តើមភិតភ័យជាខ្លាំង ក្រែងព្រះ
អម្ចាស់ទ្រង់ខ្ញាល់នឹងយើង ហើយវាយយើង ដោយព្រោះសេច
ក្តីទុច្ចរិត របស់យើង ខ្លាចក្រែងយើងត្រូវលេបលិចទៅក្នុង
ទីជំរៅនៃសមុទ្រនេះ; ហេតុដូច្នោះហើយ ខ្ញុំ នីហ្វៃ បានចាប់ផ្តើម
និយាយទៅពួកគេ ដោយភាពម៉ឺងម៉ាត់; ប៉ុន្តែមើលចុះ ពួក
គេបែរជា[ក]ខឹងនឹងខ្ញុំវិញ ហើយនិយាយថា៖ យើងមិនព្រមឲ្យប្អូន
ប្រុសយើង [ខ]ធ្វើជាអ្នកត្រួតត្រា លើយើងទេ ។
១១ ហើយហេតុការណ៍បានកើតឡើងថា លេមិន និងលេមយ្អួល
បានចាប់ខ្ញុំ ហើយចងខ្ញុំដោយខ្សែព្រួរ ហើយបានធ្វើបាបខ្ញុំយ៉ាង
ព្រៃផ្សៃ; ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអម្ចាស់ទ្រង់
បាន[ក]អត់ទ្រាំឲ្យពួកគេធ្វើយ៉ាងនេះ ដើម្បីទ្រង់អាចបង្ហាញព្រះចេស្តា
របស់ព្រះអង្គ រហូតដល់បានបំពេញនូវព្រះបន្ទូលទ្រង់ ដែលទ្រង់
បានថែងទុក អំពីពួកទុច្ចរិត ។
១២ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេ
បានចងខ្ញុំយ៉ាងជាប់ ដែលខ្ញុំមិនអាចកំរើកបាន [ក]ត្រីវិស័យដែល
ព្រះ អម្ចាស់ ទ្រង់បានរៀបចំឡើងនោះ ក៏ឈប់ដើរទៅ ។
១៣ ហេតុដូច្នោះហើយ ពួកគេមិនដឹងថាត្រូវ
កាច់ចង្កូតសំពៅទៅខាងណាឡើយ ដរាបដល់មានព្យុះមួយធំ
បានកួចឡើង មែនហើយ គឺជាព្យុះសង្ឃរាមួយដ៏កំណាច ហើយ
គួរស្ញប់ស្ញែង ហើយពួកយើង[ក]ត្រូវរសាត់ថយក្រោយនៅលើទឹក
អស់រយៈពេលបីថ្ងៃ ហើយពួក គេបានចាប់ផ្តើមតក់ស្លុតជាខ្លាំង
ក្រែងគេត្រូវលិចទៅក្នុងសមុទ្រ ទោះជាយ៉ាងណាក៏ដោយ
គង់តែគេមិនបានដោះលែងខ្ញុំដែរ ។
១៤ ហើយនៅក្នុងថ្ងៃទី៤ ដែលយើងត្រូវរសាត់ថយក្រោយនោះ
ខ្យល់ព្យុះចាប់ផ្តើមកាចសាហាវជាខ្លាំង ។
១៥ ហើយហេតុការណ៍បានកើតឡើងថា យើងជិតតែ

**១៨** ៣ *ក* ស.ប. ការអធិស្ឋាន.
*ខ* ស.ប. វិវរណៈ.
៤ *ក* ១ នីហ្វៃ ១៦:៥.
៦ *ក* ១ នីហ្វៃ ១៧:២.
៧ *ក* ២ នីហ្វៃ ២:១.
*ខ* ២ នីហ្វៃ ៣:១.
៨ *ក* ២ នីហ្វៃ ១០:២០.
*ខ* ១ នីហ្វៃ ២:២០.
ស.ប. ដែនដីសន្យា.
១០ *ក* ១ នីហ្វៃ ១៧:១៧–៥៥.
*ខ* លោកុ. ៣៧:៩–១១;
១ នីហ្វៃ ១៦:៣៧–៣៨;
២ នីហ្វៃ ១:២៥–២៧.
១១ *ក* អាលម៉ា ១៤:១១.
១២ *ក* ១ នីហ្វៃ ១៦:១០, ១៦, ២៦;
២ នីហ្វៃ ៥:១២;
អាលម៉ា ៣៧:៣៨–៤៧;
គ. និង ស. ១៧:១.
១៣ *ក* ម៉ូសាយ ១:១៧.

នឹងលេបលិចចុះទៅក្នុងជំរៅ នៃទឹកសមុទ្រទៅហើយ ។
ហើយបន្ទាប់ពីយើង ត្រូវបានរសាត់ថយក្រោយ
នៅលើទឹកអស់រយៈបួនថ្ងៃ នោះបងៗខ្ញុំចាប់ផ្ដើមយល់ថា សេច
ក្ដីជំនុំជំរះទាំងឡាយនៃព្រះ កំពុងតែធ្លាក់មក លើពួកគេ ហើយ
ថា ពួកគេរាល់គ្នាមុខជានឹងវិនាសជាមិនខានឡើយ លើកលែងតែ
ពួកគេប្រែចិត្ត ចំពោះអំពើទុច្ចរិតរបស់ពួកគេ; ហេតុដូច្នោះហើយ
ពួកគេបានមករកខ្ញុំ ហើយស្រាយចំណងដែលចងកដៃខ្ញុំ
ហើយមើលចុះ កដៃខ្ញុំហើមឡើងខ្លាំង; ហើយកជើងខ្ញុំ ក៏ហើមជា
ខ្លាំងដែរ ហើយឈឺចុកចាប់ឥតឧបមា ។
១៦ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំបានសម្លឹងឆ្ពោះ
ទៅរកព្រះរបស់ខ្ញុំ ហើយខ្ញុំបានសរសើរដំកើងទ្រង់ពេញមួយថ្ងៃ
តែម្ដង; ហើយខ្ញុំមិនបានរអ៊ូរទាំទាស់នឹងព្រះអម្ចាស់ ពីព្រោះ
តែសេចក្ដីវេទនារបស់ខ្ញុំឡើយ ។
១៧ ឥឡូវនេះ ឪពុកខ្ញុំ លីហៃ បាននិយាយនូវរឿងជាច្រើន
ទៅកាន់ពួកគេ និងទៅកាន់កូនប្រុសៗរបស់អ៊ីសម៉ាអែលផង;
ប៉ុន្តែមើល ចុះ ពួកគេបានបញ្ចេញពាក្យគ្រហឹមគ្រហែងនឹងអ្នក
ណា ដែលនិយាយកាន់ជើងខ្ញុំ; ហើយឪពុកម្ដាយខ្ញុំ ដែល
ចាស់ជរាទៅហើយ ហើយបានទ្រាំទ្រនឹងការពិបាកចិត្តជាខ្លាំង
ពីព្រោះតែកូនៗរបស់លោក នោះលោកក៏ត្រឡប់ទៅជាឈឺ
មែនហើយ គឺធ្លាក់ខ្លួនឈឺនៅ លើគ្រែ ។
១៨ ដោយព្រោះសេចក្ដីទុក្ខសោក និងសេចក្ដីសោកសៅ
ដ៏ខ្លាំង និងសេចក្ដីទុច្ចរិតរបស់បងៗខ្ញុំ នោះឪពុកម្ដាយខ្ញុំជិតតែ
នឹងចាក លោកនេះ ទៅជួបនឹងព្រះរបស់គាត់; មែនហើយ
សក់ស្កូវរបស់លោកជិតត្រូវកប់នៅក្នុងដី; មែនហើយ
លោកជិតតែនឹងត្រូវបញ្ចុះ ទាំងសេចក្ដីសោកសៅនៅ
ក្នុងផ្នូរទឹក ។
១៩ ឯយ៉ាកុប និងយ៉ូសែបផងនៅក្មេងនៅឡើយ ដោយត្រូវ
ការសេចក្ដីទំនុកបំរុងបីបាច់ច្រើន ក៏ត្រូវកើតទុក្ខលំបាក ពីព្រោះតែ
សេចក្ដីវេទនារបស់ម្ដាយខ្លួន; ហើយប្រពន្ធខ្ញុំផង ទាំងទឹកភ្នែក
និងពាក្យអធិស្ឋាន ហើយកូនៗខ្ញុំផង ក៏មិនអាចធ្វើឲ្យបងៗខ្ញុំទន់
ចិត្ត ដើម្បីឲ្យពួកគេស្រាយខ្ញុំឡើយ ។
២០ ហើយមិនមានអ្វីអាចធ្វើឲ្យពួកគេទន់ចិត្តឡើយ
លើកលែងតែព្រះចេស្ដានៃព្រះ ដែលបានគំហកកំហែងពួក
គេដោយសេចក្ដីបំផ្លិច បំផ្លាញ; ហេតុដូច្នោះហើយ នៅពេល
ពួកគេបានឃើញថា ពួកគេជិតត្រូវលេបលិចទៅក្នុង
ជំរៅសមុទ្រហើយ នោះទើបពួកគេប្រែចិត្ត ចំពោះអំពើដែល
គេបានប្រព្រឹត្ត ដរាបដល់ពួកគេស្រាយខ្ញុំ ។
២១ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេ
បានស្រាយខ្ញុំហើយ មើលចុះ ខ្ញុំក៏យកត្រីវិស័យ ហើយវាក៏ដើរតាម
បំណងខ្ញុំ ។ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាន
អធិស្ឋានដល់ព្រះអម្ចាស់; ហើយបន្ទាប់ពីខ្ញុំបានអធិស្ឋាន នោះ
ខ្យល់ក៏ស្ងប់ស្ងាត់ ហើយព្យុះក៏ឈប់បក់ ហើយមានសភាព
ស្ងប់ឈឹងអស់ទៅ ។
២២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ
បាននាំសំពៅទៅ ដើម្បីយើងបានបើកក្ដោងម្ដងទៀត
សំដៅទៅឯដែនដីសន្យា ។
២៣ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីយើង
បានធ្វើដំណើរក្នុងសំពៅ អស់រយៈពេលជាច្រើនថ្ងៃហើយ
នោះយើងបាន ទៅដល់ដែនដីសន្យា; ហើយយើង
បានឡើងទៅលើដែនដីនោះ ហើយបានបោះត្រសាលរបស់យើង;
ហើយយើងបានហៅទីនោះថា ដែនដីសន្យា ។
២៤ ហើយហេតុការណ៍បានកើតឡើងថា យើងចាប់ផ្ដើម
ភ្ជួររាស់ដី ហើយយើងបានចាប់ផ្ដើមដាំគ្រាប់ពូជ; មែនហើយ
យើងបានដាំ គ្រាប់ពូជទាំងអស់របស់យើងទៅក្នុងដី ដែល
យើងបានយកមកពីដែនដីយេរូសាឡិម ។ ហើយហេតុការណ៍
បានកើតឡើងថា គ្រាប់ពូជ ទាំងនោះ បានដុះឡើងយ៉ាងល្អ;
ហេតុដូច្នោះហើយ យើងបានទទួលពរដ៏បរិបូរ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា នៅពេលយើងធ្វើ
ដំណើរនៅក្នុងទីរហោស្ថាន យើងបានប្រទះឃើញថា មាន
សត្វជើងបួន គ្រប់មុខ នៅក្នុងព្រៃលើដែនដីសន្យា មានទាំងគោញី
និងគោឈ្មោល លា សេះ ពពែ ពពែព្រៃ ហើយនឹងសត្វព្រៃ
គ្រប់ប្រភេទ ដែល សំរាប់ឲ្យមនុស្សប្រើប្រាស់ ។ ហើយយើង
បានប្រទះឃើញរ៉ែគ្រប់មុខ មានទាំងមាស និងប្រាក់ និងស្ពាន់ ។

## ជំពូកទី ១៩

*នីហ្វៃធ្វើផ្ទាំងទាំងឡាយអំពីលោហធាតុ ហើយកត់ត្រាប្រវត្តិនៃប្រជាជនលោក — ព្រះនៃសាសន៍អ៊ីស្រាអែលនឹងយាងមករវាង៦០០ ឆ្នាំពីពេលដែលលីហៃចាកចេញពីក្រុងយេរូសាឡិមមក — នីហ្វៃរៀបរាប់អំពីសេចក្ដីទុក្ខលំបាក និងការភ្លាំងរបស់*

១៥ *ក* ហោសេ. ១២:៣.
១៦ *ក* អាលម៉ា ៣៦:២៨.
១៧ *ក* ១ នីហ្វៃ ៧:៤–២០.
១៩ *ក* ១ នីហ្វៃ ៧:១៩; ១៦:៧.
២៣ *ក* ស.ប. ដែនដីសន្យា.

*ទ្រង់ — ពួកសាសន៍ យូដានឹងត្រូវគេមើលងាយ ហើយត្រូវខ្ចាត់ខ្ចាយ រហូតដល់គ្រាចុងក្រោយ ពេលនោះ ពួកគេនឹងត្រឡប់មករកព្រះអម្ចាស់វិញ ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានបញ្ជាខ្ញុំ
ហេតុដូច្នោះហើយ ខ្ញុំបានធ្វើផ្ទាំងទាំងឡាយពីលោហធាតុ ដើម្បីខ្ញុំ
អាចឆ្លាក់នៅលើនោះ នូវជីវនៃប្រជាជនខ្ញុំ ។ ហើយនៅលើ[ក]ផ្ទាំង
ទាំងឡាយដែលខ្ញុំបានធ្វើ នោះខ្ញុំបានឆ្លាក់នូវ[ខ]បញ្ជីរបស់ឪពុកខ្ញុំ និង
អំពីការធ្វើដំណើរនៅក្នុងទីរហោស្ថានរបស់យើងផង ព្រមទាំង
ពាក្យព្យាករណ៍ទាំងឡាយរបស់ឪពុកខ្ញុំដែរ; ហើយព្រម ទាំង
ពាក្យព្យាករណ៍ជាច្រើនរបស់ខ្ញុំផង ដែលខ្ញុំបានឆ្លាក់នៅលើផ្ទាំង
ទាំងនោះ ។

២ ហើយនៅពេលដែលខ្ញុំធ្វើផ្ទាំងនោះ ខ្ញុំមិនដឹងទេថា ខ្ញុំនឹង
ត្រូវព្រះអម្ចាស់បញ្ជាឲ្យ[ក]ធ្វើផ្ទាំងទាំងនេះ; ហេតុដូច្នោះហើយ បញ្ជី
របស់ឪពុកខ្ញុំ និងពង្សាវតាររបស់ពួកអយ្យកោរបស់លោក
ហើយនឹងភាគច្រើននៃអស់ទាំងដំណើរការរបស់យើង នៅក្នុង
ទីរហោស្ថាន នោះត្រូវបានឆ្លាក់ត្រាទុក នៅលើផ្ទាំងដំបូង
ទាំងនោះ ដែលខ្ញុំបានពោលដល់; ហេតុដូច្នោះហើយ រឿង
ទាំងឡាយ ដែលកើតឡើង [ខ]មុនពេលខ្ញុំធ្វើផ្ទាំងទាំងនេះ គឺតាមពិត
បានពោលដល់នៅលើផ្ទាំងដំបូងច្រើនជាង ។

៣ ហើយបន្ទាប់ពីខ្ញុំបានធ្វើផ្ទាំងទាំងនេះ តាមរយៈការបញ្ជាហើយ
នោះខ្ញុំ នីហ្វៃ បានទទួលបញ្ជាមួយថា ការងារបំរើ និងពាក្យ
ព្យាករណ៍ទាំងឡាយនៃភាគដ៏ច្បាស់ ហើយពិសេសៗ ត្រូវ
យកមកសរសេរនៅលើ[ក]ផ្ទាំងទាំងនេះ; ហើយរឿងទាំងឡាយ
ដែលបាន សរសេរទុក នោះត្រូវរក្សាទុកសំរាប់ការបង្រៀន
ដល់ប្រជាជនខ្ញុំ ដែលនឹងបានទទួលដែនដីនោះ ហើយសំរាប់
[ខ]ប្រយោជន៍ផ្សេងៗ ទៀតផង ជាប្រយោជន៍ទាំងឡាយដែល
ព្រះអម្ចាស់ទ្រង់ជ្រាប ។

៤ ហេតុដូច្នោះហើយ ខ្ញុំ នីហ្វៃ បានធ្វើបញ្ជីមួយ
នៅលើផ្ទាំងផ្សេងទៀត ដែលមានដំណើររឿង ឬមានដំណើរ
រឿងជាច្រើនអំពី សង្គ្រាមទាំងឡាយ និងការទាស់ទែងគ្នាទាំង
ឡាយ និងសេចក្ដីបំផ្លិចបំផ្លាញទាំងឡាយនៃប្រជាជនខ្ញុំ ។
ហើយការណ៍នេះហើយដែល ខ្ញុំបានធ្វើ ហើយបានបញ្ជា
ប្រជាជនខ្ញុំថា ពួកគេត្រូវធ្វើយ៉ាងណា បន្ទាប់ពីខ្ញុំស្លាប់ទៅ;
ហើយថា ផ្ទាំងទាំងនេះ ត្រូវប្រគល់តពីតំណមួយ ទៅតំណ
មួយទៀត ឬពីព្យាការីមួយទៅព្យាការីមួយទៀត រហូតដល់
បានទទួលបញ្ជាទាំងឡាយពីព្រះអម្ចាស់ថ្មីទៀត ។

៥ ហើយដំណើររឿងអំពីការដែលខ្ញុំ[ក]ធ្វើផ្ទាំងទាំងនេះ នឹងត្រូវ
បានប្រាប់ពីអំណើះតទៅ; ហើយខណៈនោះ មើលចុះ ខ្ញុំនិយាយតទៅ
ទៀត នូវអ្វីដែលខ្ញុំបាននិយាយមក; ហើយការណ៍នេះហើយដែល
ខ្ញុំធ្វើ ដើម្បីឲ្យ[ខ]ការណ៍ទាំងឡាយដែលពិសិដ្ឋលើសលែងទៅទៀត
នឹងត្រូវបានរក្សាទុក សំរាប់ជាដំណឹងអំពីប្រជាជនខ្ញុំ ។

៦ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំមិនសរសេរ
រឿងអ្វីនៅលើផ្ទាំងទាំងនេះទេ លើកលែងតែរឿងណាដែលខ្ញុំ
គិតថា[ក]ពិសិដ្ឋ ប៉ុណ្ណោះ ។ ហើយឥឡូវនេះ បើខ្ញុំធ្វើខុស គឺសូម្បីតែ
មនុស្សដើមក៏បានធ្វើខុសដែរ; ខ្ញុំនឹងមិន[ខ]ដោះសាខ្លួនឯង ដោយ
សារអ្នកដទៃ នោះទេ ប៉ុន្តែដោយសារភាពទន់ខ្សោយ ដែល
នៅក្នុងខ្លួនខ្ញុំ ស្របតាមសាច់ឈាម នោះទើបខ្ញុំដោះសាខ្លួន
ខ្ញុំវិញ ។

៧ ត្បិតរឿងទាំងឡាយដែលអ្នកខ្លះរាប់ថាតម្លៃដ៏មហិមា
គឺដល់ទាំងរូបកាយ និងដល់ព្រលឹងដែរ នោះមានអ្នក
ផ្សេងទៀតចាត់ទុកថា [ក]គ្មានតម្លៃអ្វីសោះ ហើយយកមកជាន់ឈ្លី
នៅក្រោមជើងរបស់ពួកគេ ។ មែនហើយ សូម្បីតែព្រះនៃសាសន៍
អ៊ីស្រាអែល ក៏មនុស្សយកមក [ខ]ជាន់ឈ្លីនៅក្រោមជើងរបស់ពួកគេ
ដែរ; ខ្ញុំថា ជាន់ឈ្លីនៅក្រោមជើងរបស់ពួកគេ ប៉ុន្តែខ្ញុំចង់និយាយ
ម្យ៉ាងទៀតថា — ពួកគេចាត់ទ្រង់ ទុកថាគ្មានតម្លៃអ្វី
សោះ ហើយមិនប្រុងស្ដាប់តាមពាក្យទូន្មានរបស់ព្រះអង្គ
ឡើយ ។

៨ ហើយមើលចុះ ទ្រង់នឹង[ក]យាងមក ស្របតាមពាក្យសំដី

១៩ ១*ក* ស.ប. ផ្ទាំងទាំងឡាយ.
*ខ* ១ នីហ្វៃ ១:១៦–១៧; ៦:១–៣.
២ *ក* ២ នីហ្វៃ ៥:៣០.
*ខ* ១ នីហ្វៃ ៩:១–៥.
៣ *ក* យ៉ាកុប ១:១–៤; ៣:១៣–១៤; ៤:១–៤.
*ខ* ១ នីហ្វៃ ៩:៤–៥; ព. នៃ ម. ១:៧; គ. និង ស. ៣:១៩–២០; ១០:១–៥១.
៥ *ក* ២ នីហ្វៃ ៥:២៨–៣៣.
*ខ* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរដែលត្រូវរក្សាទុក.
៦ *ក* សូមមើលទំព័រចំណងជើងនៃព្រះគម្ពីរមរមន. ស.ប. បរិសុទ្ធ.
*ខ* មរមន ៨:១៣–១៧; អេធើរ ១២:២៣–២៨.
៧ *ក* ២ នីហ្វៃ ៣៣:២; យ៉ាកុប ៤:១៤.
*ខ* ស.ប. ការបះបោរ.
៨ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើតនិងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.

របស់ទេវតា ក្នុង៦០០ឆ្នាំ ចាប់តាំងពីពេលដែលឪពុកខ្ញុំបាន
ចាកចេញពីក្រុង យេរូសាឡិមមក ។
៩ ហើយមនុស្សលោក ដោយព្រោះសេចក្ដីទុច្ចរិតរបស់ពួក
គេ នោះនឹងចាត់ទ្រង់ទុកជាគ្មានតម្លៃទៅវិញ; ហេតុដូច្នោះហើយ
ពួកគេ វាយទ្រង់ ក៏ទ្រង់អត់ធ្មត់; ពួកគេទះទ្រង់ ក៏ទ្រង់អត់ធ្មត់ ។
មែនហើយ ពួកគេស្ដោះដាក់ទ្រង់ ក៏ទ្រង់អត់ធ្មត់ ពីព្រោះមក
ពីសេចក្ដីមេត្តា ករុណា និងការអត់ធ្មត់ ដែលទ្រង់មាន
ចំពោះកូនចៅមនុស្ស ។
១០ ហើយព្រះនៃពួកអយ្យកោយើង ដែលត្រូវ
បាននាំចេញពីស្រុកអេស៊ីព្ទ ឲ្យរួចផុតពីសេវកភាព ហើយត្រូវ
បានថែរក្សាទុកនៅក្នុង ទីរហោស្ថានដោយសារទ្រង់ មែន
ហើយ ជាព្រះនៃអ័ប្រាហាំ និងអ៊ីសាក ហើយជាព្រះនៃយ៉ាកុប
ទ្រង់ប្រគល់រូបអង្គទ្រង់ដូចជាមនុស្ស ទៅក្នុងដៃពួកទុច្ចរិត ស្របតាម
ពាក្យសំដីរបស់ទេវតា, ដើម្បីឲ្យត្រូវបានលើកឡើង ស្របតាម
ពាក្យសំដីរបស់ស៊ីណុក, ហើយដើម្បីឲ្យ ត្រូវបានឆ្កាង ស្របតាម
ពាក្យសំដីរបស់នីអ៊ុម, ហើយដើម្បីឲ្យត្រូវបានបញ្ចុះទៅក្នុងផ្នូរ
ស្របតាមពាក្យសំដីរបស់ស៊ីណូស, ដែលលោក បាននិយាយ
អំពីភាពងងឹតបីថ្ងៃ ដែលជាទីសំគាល់ប្រាប់អំពីការសុគតរបស់
ព្រះអង្គ គឺប្រាប់ដល់ពួកអ្នកដែលនៅលើកោះទាំងឡាយ
ក្នុងសមុទ្រ ជាពិសេសទៅទៀត គឺប្រាប់ដល់ពួកអ្នកដែលជាវង្ស
អ៊ីស្រាអែល ។
១១ ត្បិតព្យាការីនោះបាននិយាយថា៖ ព្រះអម្ចាស់ដ៏ជាព្រះ
ទ្រង់ពិតជានឹងពិនិត្យពិច័យវង្សអ៊ីស្រាអែលទាំងអស់ នៅ
ថ្ងៃនោះ; វង្សខ្លះ ដោយព្រះបន្ទូលរបស់ទ្រង់ ពីព្រោះមក
ពីសេចក្ដីសុចរិតរបស់ពួកគេ ដើម្បីឲ្យពួកគេមានសេចក្ដីអំណរ
ដ៏ធំ និងសេចក្ដីសង្គ្រោះ, ឯខ្លះទៀត ដោយផ្គរ និងរន្ទះនៃ
ព្រះចេស្ដារបស់ទ្រង់ ដោយព្យុះសង្ឃរា ដោយភ្លើង និងដោយ
ផ្សែង និងចំហាយនៃសេចក្ដីងងឹត និង ដោយដីបែកក្រហែង
ហើយដោយភ្នំទាំងឡាយ ដែលនឹងផុសខ្ពស់ឡើងមក ។
១២ ហើយព្យាការី ស៊ីណូសនិយាយថា ការណ៍អស់
ទាំងនេះត្រូវតែមកដល់ជាពិតប្រាកដ ។ ហើយថ្មនៅលើដីត្រូវ
ប្រេះចេញពីគ្នា; ហើយដោយសារសម្លេងថ្ងូររបស់ផែនដី
នោះស្ដេចជាច្រើននៅលើកោះទាំងឡាយក្នុងសមុទ្រ នឹងត្រូវ
បានព្រះវិញ្ញាណនៃព្រះបណ្ដាល ឲ្យស្រែកថា៖ ព្រះនៃធម្មជាតិ
រងទុក្ខវេទនា ។
១៣ រីឯពួកអ្នកដែលនៅក្រុងយេរូសាឡិម នោះព្យាការីនិយាយ
ថា ពួកគេនឹងត្រូវមនុស្សទាំងពួងវាយ ពីព្រោះពួកគេឆ្កាងព្រះ
នៃ សាសន៍អ៊ីស្រាអែល ហើយបែរចិត្តចេញ ដោយបដិសេធនូវ
ទីសំគាល់ និងការណ៍អស្ចារ្យទាំងឡាយ ហើយនឹងព្រះចេស្ដា
និងសិរីល្អ របស់ព្រះនៃសាសន៍អ៊ីស្រាអែល ។
១៤ ហើយព្យាការីនិយាយថា ដោយមកពីពួកគេបែរចិត្តចេញ
ហើយមើលងាយដល់ព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែល
នោះពួក គេនឹងដើររសាត់ព្រាត់ក្នុងសាច់ឈាម ហើយវិនាស
ហើយក្លាយទៅជាទីដៀលត្មះ ជាទីដំណៀល ហើយ
ស្អប់នៅគ្រប់អស់ទាំងសាសន៍ ។
១៥ ទោះជាយ៉ាងណាក៏ដោយ គង់តែព្យាការីនិយាយថា

---

៨ *ខ* ១ នីហ្វៃ ១០:៤; ២ នីហ្វៃ ២៥:១៩.
៩ *ក* អេសាយ ៥០:៥–៦;
ម៉ាថាយ ២៧:៣០.
១០ *ក* ២ នីហ្វៃ ២៦:១២;
ម៉ូសាយ ៧:២៧; ២៧:៣០–៣១;
អាលម៉ា ១១:៣៨–៣៩;
៣ នីហ្វៃ ១១:១៤–១៥.
*ខ* និក្ខ. ៣:២–១០; ៦:៦;
១ នីហ្វៃ ៥:១៥;
គ. និង ស. ១៣៦:២២.
*គ* លោកុ. ៣២:៩; ម៉ូសាយ ៧:១៩;
គ. និង ស. ១៣៦:២១.
ស.ប. ព្រះយេហូវ៉ា.
*ឃ* ស.ប. ធ្វើឲ្យធ្ងន់, ដង្វាយធួន.
*ង* ៣ នីហ្វៃ ២៧:១៤.
*ច* អាលម៉ា ៣៣:១៥; ៣៤:៧;
ហេលេ. ៨:១៩–២០;
៣ នីហ្វៃ ១០:១៥–១៦.
ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរ
ដែលបាត់; ស៊ីណុក.
*ឆ* ២ នីហ្វៃ ៦:៩; ម៉ូសាយ ៣:៩.
ស.ប. ការឆ្កាង.
*ជ* ម៉ាថាយ ២៧:៦០; លូកា ២៣:៥៣;
២ នីហ្វៃ ២៥:១៣.
*ឈ* យ៉ាកុប ៦:១; ហេលេ. ១៥:១១.
ស.ប. ស៊ីណូស.
*ញ* ១ នីហ្វៃ ១២:៤–៥;
ហេលេ. ១៤:២០, ២៧;
៣ នីហ្វៃ ៨:៣, ១៩–២៣; ១០:៩.
*ដ* ៣ នីហ្វៃ ១៦:១–៤.
១១ *ក* ៣ នីហ្វៃ ៩:១–២២;
គ. និង ស. ៥:១៦.
*ខ* ហេលេ. ១៤:២០–២៧;
៣ នីហ្វៃ ៨:៥–២៣.
*គ* លូកា ២៣:៤៤–៤៥;
៣ នីហ្វៃ ៨:១៩–២០.
*ឃ* ២ នីហ្វៃ ២៦:៥.
*ង* ៣ នីហ្វៃ ៨:១០.
១២ *ក* ហេលេ. ១៤:២០–២៨.
*ខ* យ៉ាកុប ៥:១.
*គ* ម៉ាថាយ ២៧:៥១.
១៣ *ក* លូកា ២៣:២៧–៣០.
*ខ* ២ នីហ្វៃ ១០:៣.
១៤ *ក* អេសាយ ៥៣:៣–៦;
ម៉ូសាយ ១៤:៣–៦.
*ខ* ស.ប. ពួកសាសន៍យូដា.
*គ* ចោទិ. ២៨:៣៧; ១ពង្សាវ. ៩:៧;
៣ នីហ្វៃ ១៦:៩.

កាលណាថ្ងៃនោះមកដល់ ដែលពួកគេនឹងមិនបែរចិត្តចេញពី
ព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែលទៀតទេ នោះទ្រង់នឹងនឹក
ឃើញសេចក្ដីសញ្ញាទាំងឡាយ ដែលទ្រង់បានធ្វើជាមួយនឹងពួក
អយ្យកោរបស់ពួកគេ ។
១៦ មែនហើយ ខណៈនោះ ទ្រង់នឹងនឹកឃើញកោះទាំង
ឡាយក្នុងសមុទ្រ; មែនហើយ និងអស់ទាំងប្រជាជនដែលជាវ
ង្សអ៊ីស្រាអែល នោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ យើង
នឹងប្រមូលមកពីទិសទាំងបួននៃផែនដី ស្របតាមពាក្យរបស់
ព្យាការីស៊ីណូស ។
១៧ ព្យាការីនិយាយថា មែនហើយ ហើយអស់ទាំងផែនដី
នឹងឃើញសេចក្ដីសង្គ្រោះនៃព្រះអម្ចាស់ គឺគ្រប់ទាំងសាសន៍
គ្រប់ពូជ មនុស្ស គ្រប់ភាសា ហើយនឹងគ្រប់ទាំងប្រជាជននឹង
បានពរ ។
១៨ ហើយខ្ញុំ នីហ្វៃ បានសរសេររឿងទាំងនេះសំរាប់
ប្រជាជនខ្ញុំ ក្រែងខ្ញុំអាចបញ្ចុះបញ្ចូលពួកគេ ឲ្យចងចាំដល់ព្រះ
អម្ចាស់ ជាព្រះ ដ៏ប្រោសលោះរបស់គេ ។
១៩ ហេតុដូច្នោះហើយ ខ្ញុំនិយាយទៅវង្សអ៊ីស្រាអែលទាំង
អស់ថា បើសិនជាដូច្នេះមែន នោះពួកគេនឹងទទួលយកការណ៍
អស់ ទាំងនេះ ។
២០ ត្បិតមើលចុះ ខ្ញុំមានការហេវហត់ខាងវិញ្ញាណ ដើម្បី
ពួកអ្នកដែលនៅក្នុងក្រុងយេរូសាឡិម ដែលធ្វើឲ្យខ្ញុំខ្សោះល្ហើយ
សូម្បីតែ ឆ្អឹងខ្ញុំក៏ទន់ខ្សោយ; ព្រោះបើព្រះអម្ចាស់ទ្រង់មិន
មេត្តាបង្ហាញខ្ញុំអំពីរឿងពួកគេ ដូចជាទ្រង់បានបង្ហាញដល់ពួក
ព្យាការីដើម នោះខ្ញុំក៏នឹង ត្រូវវិនាសទៅហើយដែរ ។
២១ ហើយទ្រង់បានបង្ហាញយ៉ាងពិតប្រាកដដល់ពួក
ព្យាការីដើម នូវរឿងទាំងអស់អំពីពួកគេ; ហើយទ្រង់ក៏បាន
បង្ហាញដល់មនុស្ស ជាច្រើន អំពីរឿងយើងដែរ; ហេតុ
ដូច្នោះហើយ ជាការចាំបាច់ដែលយើងត្រូវតែដឹងពីរឿង
ទាំងនោះ ព្រោះរឿងទាំងនោះត្រូវបាន សរសេរនៅលើផ្ទាំង
លង្ហិនដែរ ។
២២ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ
បានបង្រៀនបងៗខ្ញុំអំពីរឿងទាំងនេះ; ហើយហេតុការណ៍
បានកើតឡើងថា ខ្ញុំបានអានរឿងជាច្រើនឲ្យពួកគេស្ដាប់ ដែល
បានឆ្លាក់នៅលើផ្ទាំងលង្ហិន ដើម្បីឲ្យពួកគេអាចដឹងអំពីកិច្ចការ
ទាំងឡាយនៃព្រះអម្ចាស់ នៅលើដែនដីផ្សេងៗ ក្នុង
ចំណោមប្រជាជនជាន់ដើម ។
២៣ ហើយខ្ញុំបានអានរឿងជាច្រើនទៅឲ្យបងៗខ្ញុំស្ដាប់ ដែល
មានសរសេរនៅក្នុងគម្ពីរទាំងឡាយនៃលោកម៉ូសេ; ប៉ុន្តែដើម្បី
បញ្ចុះ បញ្ចូលពួកគេឲ្យបានច្រើនថែមទៀត ឲ្យជឿដល់ព្រះអម្ចាស់
ជាព្រះដ៏ប្រោសលោះរបស់ពួកគេ នោះខ្ញុំបានអានឲ្យគេស្ដាប់
នូវរឿង ដែលបានសរសេរដោយព្យាការីអេសាយ; ត្បិតខ្ញុំ
ប្រៀបធៀបបទព្រះគម្ពីរទាំងអស់ ទៅនឹងខ្លួនយើង ដើម្បីទុកជា
ប្រយោជន៍ និងការចេះដឹងដល់យើង ។
២៤ ហេតុដូច្នោះហើយ ខ្ញុំបាននិយាយទៅពួកគេថា៖
ចូរបងរាល់គ្នាស្ដាប់ពាក្យសំដីរបស់ព្យាការីចុះ គឺបងរាល់គ្នា
ដែលជាសំណល់ នៃវង្សអ៊ីស្រាអែល ដែលជាមែកដែលបាន
កាត់ចេញ; ចូរបងរាល់គ្នាស្ដាប់ពាក្យសំដីរបស់ព្យាការី ដែល
បានសរសេរសំរាប់វង្សអ៊ីស្រា អែលទាំងអស់ ហើយប្រៀបធៀប
ពាក្យទាំងនោះ ទៅនឹងខ្លួនយើង ដើម្បីបងរាល់គ្នាអាចមាន
សេចក្ដីសង្ឃឹម ដូចជាបងប្អូនទាំងឡាយ របស់បង ដែល
បងរាល់គ្នាបានកាត់ចេញពីពួកគេមកនោះ ព្រោះព្យាការីបាន
សរសេរទុកយ៉ាងនេះ ៕

## ជំពូកទី ២០

*ព្រះអម្ចាស់ទ្រង់បើកសម្ដែងគោលបំណងទាំងឡាយរបស់ទ្រង់ដល់សាសន៍អ៊ីស្រាអែល — ពួកអ៊ីស្រាអែលត្រូវបានរើសនៅក្នុងឡ នៃសេចក្ដីវេទនា ហើយដើម្បីចេញពីក្រុងបាប៊ីឡូនទៅមុខទៀត — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៤៨ ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

១៥ *ក* ១ នីហ្វៃ ២២:១១–១២.
*ខ* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
១៦ *ក* ១ នីហ្វៃ ២២:៤; ២ នីហ្វៃ ១០:២១.
*ខ* អេសាយ ៤៩:២០–២២.
ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
១៧ *ក* អេសាយ ៤០:៤–៥.
១៩ *ក* អេណុស ១:១៦; មរមន ៥:១២; ៧:៩–១០.
២១ *ក* ២ ពង្សាវ. ១៧:១៣; អេម៉ុស ៣:៧.
ស.ប. ព្យាការី.
*ខ* ៣ នីហ្វៃ ១០:១៦–១៧.
២២ *ក* ១ នីហ្វៃ ២២:១.
២៣ *ក* និក្ខ. ១៧:១៤; ១ នីហ្វៃ ៥:១១; ម៉ូសេ ១:៤០–៤១.
*ខ* ១ នីហ្វៃ ១៥:២០; ២ នីហ្វៃ ២៥:៤–៦; ៣ នីហ្វៃ ២៣:១.
*គ* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ឃ* ២ នីហ្វៃ ៤:១៥.
២៤ *ក* លោកុ. ៤៩:២២–២៦; ១ នីហ្វៃ ១៥:១២; ២ នីហ្វៃ ៣:៤–៥.

ចូរស្ដាប់សេចក្ដីនេះ ឱពួកវង្សយ៉ាកុបអើយ ជាពួកអ្នកដែល
បានហៅតាមឈ្មោះអ៊ីស្រាអែល ហើយបានចេញពីទឹករបស់
យូដាមក ឬចេញពីទឹកនៃបុណ្យជ្រមុជទឹកមក ជាពួកអ្នកដែល
ស្បថដោយព្រះនាមនៃព្រះអម្ចាស់ ព្រមទាំងដំណាលពីព្រះ
នៃសាសន៍អ៊ីស្រាអែលផង តែមិនមែនដោយស្មោះចំពោះ
ឬដោយសុចរិតទេ ។
២ ទោះយ៉ាងនេះក្ដី ពួកគេហៅខ្លួនគេជាអ្នកក្រុងបរិសុទ្ធ ប៉ុន្តែពួក
គេមិនពឹងផ្អែកទៅលើព្រះនៃសាសន៍អ៊ីស្រាអែល ដែលជាព្រះ
អម្ចាស់នៃពួកពលបរិវារទេ; មែនហើយ ព្រះអម្ចាស់នៃពួក
ពលបរិវារ គឺជាព្រះនាមទ្រង់ ។
៣ មើលចុះ យើងបានថ្លែងប្រាប់នូវការណ៍ដែលកន្លងទៅហើយ
តាំងពីបុរាណមក; ហើយរឿងនោះបាន ចេញពីមាត់យើងទៅ
ហើយយើងបានបង្ហាញយ៉ាងច្បាស់ ឯការណ៍ទាំងនោះ យើង
បានបង្ហាញភ្លាមមួយរំពេច ។
៤ ហើយយើងបានធ្វើយ៉ាងនេះ ពីព្រោះយើងបានដឹងថា
អ្នកជាមនុស្សរឹងចចេស ហើយមានកដូចជា ចំរឹងដែក ឯថ្ងាស
អ្នកក៏ជា លង្ហិន;
៥ ហើយយើងបានទាំងថ្លែងប្រាប់សេចក្ដីនោះដល់អ្នកតាំង
ពីបុរាណមក; យើងបានបង្ហាញឲ្យអ្នកដឹងមុន ដែលការណ៍
នោះកើតមក ផង; ហើយយើងបានបង្ហាញសេចក្ដីនោះ ក្រែង
អ្នកនិយាយថា — រូបព្រះរបស់ខ្ញុំ ដែលបានធ្វើការនោះវិញ
ហើយរូបឆ្លាក់របស់ខ្ញុំ និងរូបសិតរបស់ខ្ញុំ ដែលបង្គាប់ការណ៍
នោះឡើង ។
៦ អ្នកបានឃើញ ហើយឮការណ៍គ្រប់ទាំងនេះ; តើអ្នកមិន
ព្រមថ្លែងប្រាប់ទេឬ ? ហើយពីពេលនេះទៅ យើងបាន
បង្ហាញឲ្យអ្នកឃើញ ការណ៍ថ្មីទៀត គឺជាការណ៍លាក់កំបាំង
ដែលអ្នកមិនបានស្គាល់ផង ។
៧ ការណ៍ទាំងនោះទើបនឹងកើតឡើង ឥឡូវនេះ មិនមែន
កាលពីបុរាណទេ គឺកាលមុនថ្ងៃនេះ អ្នកមិនដែលបាន
ឮពីការណ៍ទាំង នោះឡើយ តែការណ៍នេះបានថ្លែងប្រាប់អ្នក
ហើយ ក្រែងអ្នកនិយាយថា — មើលចុះ ខ្ញុំបានដឹងការណ៍
នោះហើយ ។
៨ មែនហើយ អ្នកមិនបានឮសោះ; មែនហើយ អ្នកមិនបាន
ដឹងផង; មែនហើយ តាំងពីបុរាណមក ត្រចៀកអ្នកមិនទាន់បាន
បើកឡើង នៅឡើយ; ត្បិតយើងបានដឹងថា អ្នកនឹងប្រព្រឹត្ត
ដោយចិត្តក្បត់ ហើយអ្នកមានឈ្មោះថា ជាអ្នកបះបោរ តាំង
ពីផ្ទៃម្ដាយមក ។
៩ ទោះជាយ៉ាងនេះក្ដី ដោយយល់ដល់នាមយើង នោះយើង
នឹងផ្អាកសេចក្ដីក្រេវក្រោធរបស់យើង ហើយដោយយល់ដល់
សេចក្ដីសរសើរដំកើងរបស់យើង នោះយើងនឹងឈប់លែង
ពីដំណើរអ្នក ដើម្បីកុំឲ្យយើងកាត់អ្នកចេញ ។
១០ ត្បិតមើលចុះ យើងបានសំរង់អ្នក គឺយើងបានរើសអ្នក
នៅក្នុងឡនៃសេចក្ដីវេទនាវិញ ។
១១ ដោយយល់ដល់ខ្លួនយើង មែនហើយ គឺដោយ
ខ្លួនយើងផ្ទាល់ យើងនឹងធ្វើការណ៍នោះ ត្បិតយើងមិនអនុញ្ញាតឲ្យ
នាមយើង ត្រូវបង្អាប់បាន ឯសិរីល្អរបស់យើង យើងមិនព្រម
លើកឲ្យអ្នកដទៃឡើយ ។
១២ ឱពួកយ៉ាកុប និងអ៊ីស្រាអែល ជាអ្នកដែលយើងបាន
ហៅអើយ ចូរប្រុងស្ដាប់តាមយើងចុះ ត្បិតយើងនេះហើយ
ជាដើម ហើយជាចុងដែរ ។
១៣ ដៃយើងក៏បានដាក់ឫសនៃផែនដី ហើយដៃស្ដាំរបស់យើង
បានលាតផ្ទៃមេឃ ។ យើងហៅភាគទាំងពីរភាគនោះក៏ឈរឡើង
ជាមួយគ្នា ។
១៤ ចូរឲ្យអ្នករាល់គ្នា ប្រជុំគ្នាទាំងអស់ ហើយស្ដាប់ចុះ; ក្នុង
ចំណោមពួកគេ តើមានអ្នកណាដែលថ្លែងប្រាប់ អំពីការណ៍
ទាំងនេះដល់ ពួកគេឬ ? អ្នកមួយនោះ ដែលព្រះអម្ចាស់
ទ្រង់ស្រឡាញ់; មែនហើយ គេនឹងធ្វើឲ្យព្រះបន្ទូលបានសំរេច
ដែលគេបានថ្លែងប្រាប់ពួកគេ; ហើយគេនឹងសំរេចដល់ក្រុងបាប៊ី
ឡូន តាមបំណងព្រះហឫទ័យទ្រង់ ហើយដៃរបស់គេនឹងសង្កត់លើ
ពួកខាល់ដេ ។

---

**២០** ១*ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យ ជ្រមុជទឹក.
២ *ក* អេសាយ ៥២:១. ស.ប. ក្រុងយេរូសាឡិម.
*ខ* ក.ន. ពឹងផ្អែក.
៣ *ក* អេសាយ ៤៦:៩–១០.
៤ *ក* ក.ន. អ៊ីស្រាអែល.
៥ *ក* ស.ប. ការថ្វាយបង្គំរូបព្រះ.
៨ *ក* ទំនុក. ៥៨:៣.
៩ *ក* ១ សាំយូ. ១២:២២; ទំនុក. ២៣:៣; ១ យ៉ូហាន ២:១២.
១០ *ក* ស.ប. សេចក្ដីទំនាស់.
១១ *ក* យេរេ. ៤៤:២៦.
*ខ* អេសាយ ៤២:៨; ម៉ូសេ ៤:១–៤.
១២ *ក* វិវ. ១:១៧; ២២:១៣. ស.ប. អាលផា និងអូមេកា; កូនច្បង.
១៣ *ក* ទំនុក. ១០២:២៥. ស.ប. បង្កបង្កើត, ការបង្កបង្កើត.
១៤ *ក* ១ ពង្សាវ. ៨:៥៦; គ. និង ស. ៦៤:៣១; ៧៦:៣.
*ខ* ស.ប. បាបិល, បាប៊ីឡូន.

១៥ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដែរថា យើងជាព្រះ
អម្ចាស់ មែនហើយ យើងបានពោល; មែនហើយ យើងបាន
ហៅគេឲ្យថ្លែង ប្រាប់ យើងបាននាំគេមក ហើយគេនឹងធ្វើការ
គេឲ្យចំរើនឡើង ។
១៦ ចូរឲ្យអ្នករាល់គ្នាចូលមកជិតយើង; យើងមិនបាននិយាយ
ដោយសម្ងាត់ទេ; តាំងពីដើមដំបូងមក គឺតាំងពីការណ៍
នោះចាប់ផ្ដើម កើតឡើង យើងបានពោល; ហើយព្រះអម្ចាស់ដ៏ជា
ព្រះ ទ្រង់បានចាត់ខ្ញុំ ជាមួយនឹងព្រះវិញ្ញាណទ្រង់ឲ្យមក ។
១៧ ព្រះអម្ចាស់ ជាព្រះដ៏ប្រោសលោះ គឺជាព្រះដ៏បរិសុទ្ធ
នៃសាសន៍អ៊ីស្រាអែល ទ្រង់មានព្រះបន្ទូលថាដូច្នោះ; យើងគឺជា
ព្រះអម្ចាស់ ជាព្រះនៃអ្នក បានចាត់លោកមក ជាព្រះដែល
បង្រៀនឲ្យអ្នកបានទទួលប្រយោជន៍ ហើយក៏នាំអ្នកទៅក្នុងផ្លូវ
ដែលអ្នកគួរដើរ គឺយើង នេះហើយបានធ្វើការណ៍ទាំងនោះ ។
១៨ ឱ បើអ្នកបានប្រុងស្ដាប់តាមបញ្ញត្តិទាំងប៉ុន្មានរបស់យើង —
នោះសេចក្ដីសុខសាន្តរបស់អ្នក នឹងបានដូចជាទន្លេ សេចក្ដី
សុចរិតរបស់អ្នក នឹងបានដូចជារលកនៃសមុទ្រហើយ ។
១៩ ឯពូជអ្នកក៏នឹងបានច្រើនដូចខ្សាច់; ហើយផលដែលកើតពីអ្នក
មក នោះនឹងបានដូចជាគ្រាប់ខ្សាច់ទាំងប៉ុន្មាន; ឯឈ្មោះគេក៏មិន
ត្រូវកាត់ចេញ ឬបំផ្លាញពីមុខយើងឡើយ ។
២០ ចូរចេញពីក្រុងបាប៊ីឡូនទៅ ហើយរត់គៀសខ្លួនពីពួក
ខាល់ដេ ចូរប្រកាសប្រាប់ ដោយសម្លេងច្រៀង ចូរថ្លែងពីរឿងនេះ
ហើយ បញ្ជូនរហូតដល់ចុងផែនដីផង ចូរប្រាប់ថា៖ ព្រះអម្ចាស់
ទ្រង់បានប្រោសលោះពួកយ៉ាកុប ជាអ្នកបំរើទ្រង់ហើយ ។
២១ ហើយពួកគេមិនបានស្រេកឡើយ; ទ្រង់នាំគេដើរកាត់
សមុទ្រខ្សាច់; ទ្រង់បានធ្វើឲ្យមានទឹកហូរចេញពីថ្មដាសំរាប់គេ;
ទ្រង់ក៏ បំប្រេះថ្មដា ហើយទឹកក៏ផុសចេញមក ។
២២ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ទោះបីទ្រង់
បានធ្វើការណ៍ទាំងនេះក្ដី និងការណ៍ធំជាងនេះទៀតក៏ដោយ
គង់តែគ្មាន សេចក្ដីសុខសាន្ត ដល់មនុស្សដែលប្រព្រឹត្តអំពើ
អាក្រក់ឡើយ ៕

## ជំពូកទី ២១

*ព្រះមែស៊ីនឹងទៅជាពន្លឺដល់ពួកសាសន៍ដទៃ ហើយនឹងដោះលែងពួកអ្នកជាប់គុកទាំងឡាយ — ពួកសាសន៍អ៊ីស្រាអែលនឹងត្រូវបានប្រមូលគ្នា ដោយមានព្រះចេស្ដា នៅគ្រាក្រោយបង្អស់ — ពួកមហាក្សត្រ ត្រូវជាឪពុកចិញ្ចឹមរបស់គេ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៤៩ ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយជាថ្មីម្ដងទៀត៖ ឱគំណរវង្សអ៊ីស្រាអែលអើយ ចូរស្ដាប់យើងចុះ
អស់អ្នកដែលបានកាត់ចេញ ហើយបានបណ្ដេញចេញ ដោយ
មក ពីសេចក្ដីអាក្រក់នៃអ្នកគង្វាលនៃរាស្ត្រយើង; មែនហើយ
អស់អ្នកដែលបានកាត់ចេញ ហើយបានខ្ចាត់ខ្ចាយទៅគ្រប់ទិសទី ឱវ
ង្សអ៊ីស្រា អែល ជារាស្ត្ររបស់យើង ម្នាលកោះទាំងឡាយ
អើយ ។ ចូរស្ដាប់យើងចុះ ឱប្រជាជាតិទាំងប៉ុន្មានដែលនៅ
ឆ្ងាយអើយ ហើយចូរប្រុង ស្ដាប់ចុះ; ព្រះអម្ចាស់ទ្រង់បាន
ហៅខ្ញុំ តាំងពីផ្ទៃម្ដាយមក; ទ្រង់បានដំណាលពីឈ្មោះខ្ញុំ តាំង
ពីនៅក្នុងពោះម្ដាយមកម្ល៉េះ ។
២ ហើយទ្រង់បានធ្វើឲ្យមាត់ខ្ញុំដូចជាដាវដ៏មុត; បានលាក់ខ្ញុំនៅ
ក្រោមម្លប់នៃព្រះហស្តទ្រង់ ហើយបានធ្វើឲ្យខ្ញុំដូចជាត្រួញ
ដែលខាត់ រំលីង; ព្រមទាំងដាក់ខ្ញុំទុកក្ជិតនៅក្នុងបំពង់ព្រួញ
របស់ទ្រង់ ។
៣ ហើយទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ អ្នកជាអ្នកបំរើរបស់យើង
គឺអ៊ីស្រាអែល ដែលយើងនឹងបានសិរីល្អ ដោយសារអ្នក ។
៤ ខណៈនោះខ្ញុំពោលថា៖ ខ្ញុំបានខំប្រឹងធ្វើការឥតប្រយោជន៍
ខ្ញុំបានបង់កម្លាំងខ្ញុំទៅទទេៗជាអសារឥតការ; ប៉ុន្តែសេចក្ដី
យុត្តិធម៌ដែលគួរដល់ខ្ញុំ នោះនៅនឹងព្រះអម្ចាស់ ហើយរង្វាន់
របស់ខ្ញុំក៏នៅនឹងព្រះនៃខ្ញុំដែរ ។
៥ ហើយឥឡូវនេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំ —
ជាព្រះដែលជប់បង្កើតខ្ញុំនៅក្នុងផ្ទៃម្ដាយ ដើម្បីឲ្យបានធ្វើជាអ្នក
បំរើទ្រង់ សំរាប់នឹងនាំពួកយ៉ាកុបមកឯទ្រង់វិញ — ថ្វីបើពួក

១៦ *ក* អេសាយ ៤៥:១៩.
១៧ *ក* ស.ប. ព្រះដ៏ប្រោសលោះ.
*ខ* ស.ប. ការបំផុសគំនិត, បំផុសគំនិត; វិវរណៈ.
១៨ *ក* សាស្ដា ៨:៥.
១៩ *ក* លោកុ. ២២:១៥–១៩; ហូសេ ១:១០.
២០ *ក* យេរេ. ៥១:៦; គ. និង ស. ១៣៣:៥–១៤.
*ខ* អេសាយ ៤៤:១–២, ២១.
២១ *ក* អេសាយ ៤១:១៧–២០.
*ខ* និក្ខ. ១៧:៦; ជនគ. ២០:១១; ១ នីហ្វៃ ១៧:២៩; ២ នីហ្វៃ ២៥:២០.
២២ *ក* ស.ប. សេចក្ដីសុខសាន្ត.
**២១** ១*ក* ១ នីហ្វៃ ២២:៤; ២ នីហ្វៃ ១០:២០–២២.
*ខ* គ. និង ស. ១:១.
៣ *ក* លេវី. ២៥:៥៥; អេសាយ ៤១:៨; គ. និង ស. ៩៣:៤៥–៤៦.
៥ *ក* អេសាយ ៤៤:២៤.

អ៊ីស្រាអែលមិនបានមូលមកឯទ្រង់ក្តី ត្បិតខ្ញុំជាទីរាប់អាននៅព្រះនេត្រព្រះអម្ចាស់ ហើយព្រះនៃខ្ញុំ ទ្រង់ជាកម្លាំងនៃខ្ញុំ ។

៦ ហើយទ្រង់មានព្រះបន្ទូលថា៖ ការដែលអ្នកធ្វើជាអ្នកបំរើរបស់យើង ដើម្បីលើកអស់ទាំងពូជអំបូរ នៃយ៉ាកុបឡើង ហើយនឹង នាំពួកបំរុងទុកក្នុងសាសន៍អ៊ីស្រាអែលឲ្យមកវិញ នោះជាការតិចតួចពេកដល់ឯង ។ យើងនឹងបន្ថែមការនោះឲ្យអ្នកបានធ្វើជាពន្លឺ ដល់សាសន៍ដទៃទាំងប៉ុន្មានទៀត ដើម្បីឲ្យអ្នកបានធ្វើ ជាអ្នកជួយសង្គ្រោះរបស់យើង រហូតដល់ចុងផែនដី ។

៧ ព្រះអម្ចាស់ ជាព្រះដ៏ប្រោសលោះនៃសាសន៍អ៊ីស្រាអែល ហើយជាព្រះបរិសុទ្ធនៃគេ ទ្រង់មានព្រះបន្ទូលដូច្នេះ ដល់អ្នកនោះ ដែល ជាមនុស្សទាំងឡាយមិនអើពើ ដែលជាទីស្អប់ខ្ពើមដល់សាសន៍នេះ គឺជាអ្នកបំរើរបស់ពួកអ្នកដែលគ្រប់គ្រងថា៖ បណ្តាក្សត្រនឹងឃើញ ហើយក្រោកឈរឡើង ព្រមទាំងពួកចៅហ្វាយដែរ គេនឹងក្រាបថ្វាយបង្គំ ដោយព្រោះព្រះអម្ចាស់ ទ្រង់ជាព្រះដ៏ស្មោះត្រង់ ។

៨ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ឱកោះទាំងឡាយនៅក្នុងសមុទ្រ ដល់វេលាដែលគាប់ចិត្តយើង នោះយើងនឹងឆ្លើយ ដល់អ្នក ហើយនៅថ្ងៃសំរាប់សង្គ្រោះ នោះយើងបានជួយអ្នក; យើងនឹងទំនុកបំរុងអ្នក ហើយតាំងអ្នកឡើង ទុកជាសេចក្តីសញ្ញាដល់ បណ្តាជន ប្រយោជន៍ដើម្បីនឹងរៀបចំផែនដីឡើង ឲ្យគេបានគ្រងទី ដែលចោលស្ងាត់ទុកជាកេរ្តិ៍មរតក;

៩ ព្រមទាំងប្រាប់ដល់ពួកអ្នកដែលជាប់ចំណងថា៖ ចូរចេញទៅ ហើយដល់ពួកអ្នក ដែលអង្គុយនៅក្នុងសេចក្តីងងឹតថា៖ ចូរសម្តែងខ្លួនចេញមកចុះ ។ គេនឹងមានអាហារស៊ីតាមផ្លូវ ហើយនៅលើកំពូលត្រងិលទាំងប៉ុន្មាន នឹងបានជាទីរកស៊ីដល់គេ ស្មៅរបស់គេនឹង នៅគ្រប់ទីខ្ពស់ ។

១០ គេនឹងមិនដែលស្រេកឃ្លានទៀត ឯចំហាយក្តៅ ឬព្រះអាទិត្យនឹងមិនធ្វើទុក្ខគេ; ត្បិតព្រះដែលផ្តល់សេចក្តីមេត្តាដល់គេ ទ្រង់នឹង ដឹកដៃគេ នាំទៅតាមទីមានក្បាលទឹក ។

១១ ហើយយើងនឹងធ្វើអស់ទាំងភ្នំរបស់យើង ឲ្យទៅជាផ្លូវ ឯអស់ទាំងថ្នល់របស់យើង នឹងបានដំកើងឡើង ។

១២ ហើយពេលនោះ ឱវង្សអ៊ីស្រាអែលអើយ មើលចុះ ពួកនេះនឹងមកពីចម្ងាយ ហើយមើលចុះ ពួកនោះនឹងមកពីទិសខាងជើង និងពីខាងលិច; ហើយពួកមួយនេះមកពីស្រុកស៊ីនីម ។

១៣ ឱផ្ទៃមេឃអើយ ចូរច្រៀងឡើង; ឱផែនដីអើយ ចូរឲ្យអរសប្បាយចុះ ត្បិតជើងនៃពួកជននៅទិស ខាងកើតនឹងបង្កើតឡើង; ឱភ្នំទាំងឡាយអើយ ចូរផ្លាយចេញជាបទចំរៀង; ពីព្រោះពួកគេមិនត្រូវបានធ្វើទុក្ខទៀតទេ; ពីព្រោះព្រះអម្ចាស់ទ្រង់បានកំសាន្តចិត្ត រាស្ត្រទ្រង់ហើយ ទ្រង់នឹងមានព្រះហឫទ័យអាណិតអាសូរដល់ពួករបស់ទ្រង់ ដែលត្រូវរងទុក្ខវេទនាផង ។

១៤ ប៉ុន្តែមើលចុះ ក្រុងស៊ីយ៉ូនបានថា៖ ព្រះអម្ចាស់ទ្រង់បានបោះបង់ខ្ញុំ គឺព្រះអម្ចាស់របស់ខ្ញុំ ទ្រង់ភ្លេចខ្ញុំហើយ– ប៉ុន្តែទ្រង់នឹងបង្ហាញ ថា ទ្រង់មិនបោះបង់ ឬភ្លេចពួកគេឡើយ ។

១៥ ត្បិតអឺ ស្ត្រីនឹងភ្លេចកូន ដែលកំពុងបៅដោះឬ ? ឥតមានអាណិតដល់កូនដែលចេញពីផ្ទៃខ្លួនមកបានដែរឬ ? មែនហើយ ឱវង្សអ៊ីស្រាអែលអើយ គេនឹងភ្លេចបាន ប៉ុន្តែយើងមិនដែលភ្លេចអ្នកឡើយ ។

១៦ មើលចុះ យើងបានចារិកអ្នកទុក នៅផ្ទៃបាតដៃរបស់យើងហើយ; អស់ទាំងកំផែងអ្នកនៅចំពោះ ភ្នែកយើងជានិច្ច ។

១៧ ពួកកូនចៅរបស់អ្នកនឹងប្រញាប់តទល់នឹងពួក ដែលបំផ្លាញអ្នក; ហើយពួកដែលរំលោងអ្នក គេនឹងចេញពីអ្នកទៅ ។

១៨ ចូរងើបភ្នែកឡើងមើលជុំវិញចុះ; ពួកទាំងនេះគេមូលចូលគ្នា ហើយពួកគេនឹងចូលមកឯអ្នក ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលដូច្នេះ យើងស្បថនឹងជីវិតយើងថា៖ ប្រាកដជាអ្នកនឹងបានប្រដាប់កាយដោយអ្នកទាំងនោះ ដូចជាពាក់គ្រឿងលំអ ហើយក្រវាត់ខ្លួន ដោយអ្នក ទាំងនោះ ដូចជាប្រពន្ធថ្មោងថ្មី ដែលតែងខ្លួនដែរ ។

១៩ ត្បិតឯទីកន្លែងដែលរំលោង ហើយចោលស្ងាត់ និងស្រុកអ្នកដែលត្រូវបំផ្លាញនោះ ឥឡូវនេះ នឹងបានជាទីចង្អៀតណែន

៦ *ក* ស.ប. អ៊ីស្រាអែល — ពូជអ៊ីស្រាអែលទាំង១២អំបូរ.
*ខ* គ. និង ស. ១០៣:៨–១០; អ័ប្រា. ២:១០–១១.
*គ* ៣ នីហ្វៃ ២១:១១.
៨ *ក* ២ នីហ្វៃ ៣:៦–១៥; ៣ នីហ្វៃ ២១:៨–១១; មរមន ៨:១៦, ២៥.
៩ *ក* ស.ប. សេចក្តីសង្គ្រោះ សំរាប់មនុស្សស្លាប់.
*ខ* ២ នីហ្វៃ ៣:៥.
*គ* អេសេ. ៣៤:១៤.
១១ *ក* អេសាយ ៦២:១០; គ. និង ស. ១៣៣:២៣–៣២.
១២ *ក* អេសាយ ៤៣:៥–៦.
១៣ *ក* អេសាយ ៤៤:២៣.
១៥ *ក* ស.ប. ស្ត្រី, ពួកស្ត្រី.
*ខ* អេសាយ ៤១:១៧; អាលម៉ា ៤៦:៨; គ. និង ស. ៦១:៣៦.
១៦ *ក* សាការី ១៣:៦.
១៧ *ក* ៣ នីហ្វៃ ២១:១២–២០.
១៨ *ក* មីកា ៤:១១–១៣.

ដល់ពួក ឲអ្នកដែលអាស្រ័យនៅវិញ; ហើយពួកអ្នកដែលបាន លេបអ្នក គេនឹងនៅឆ្ងាយពីអ្នកហើយ ។

២០ ពួកកូនចៅអ្នកដែលកើត បន្ទាប់ពីអ្នកបានបាត់ពួក កូនចៅដំបូង គេនឹងនិយាយដាក់ត្រចៀកអ្នក ថា៖ ទីនេះចង្អៀត ដល់យើង ខ្ញុំណាស់ សូមឲ្យមានទីអាស្រ័យនៅផង ។

២១ នោះអ្នកនឹងនឹកក្នុងចិត្តថា៖ តើអ្នកណាបង្កើតកូនទាំងនេះឲ្យ យើង ត្បិតយើងបានបាត់កូនចៅយើងអស់ទៅ ហើយយើង ក៏នៅឯកឯងដូច្នេះ គឺជាអ្នកដែលត្រូវបំបរបង់ ហើយដើររ សាត់ព្រាត់ទេតើ ? ហើយតើអ្នកណាបានចិញ្ចឹមកូនទាំងនេះ ? មើលចុះ យើងបានត្រូវចោលនៅតែឯង; ដូច្នេះ តើកូនទាំងនេះ បាននៅឯណា ?

២២ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ មើលចុះ យើងនឹងបោយដៃហៅពួកសាសន៍ដទៃ ហើយនឹងលើកទង់ ជ័យយើង ឡើងសំរាប់ប្រជាជាតិទាំងឡាយ; រួចគេនឹងបីយក កូនប្រុសទាំងឡាយរបស់អ្នកមក ហើយនឹងបញ្ជិះកូនស្រីទាំង ឡាយរបស់អ្នកនៅ លើស្មាគេ ។

២៣ ហើយពួកមហាក្សត្រនឹងធ្វើជាឪពុកចិញ្ចឹមអ្នក ហើយ ពួកអគ្គមហេសីនឹងធ្វើជាម្ដាយបំបៅអ្នក; ពួកគេនឹងក្រាបផ្កាប់ មុខដល់ដីនៅ មុខអ្នក ហើយនឹងលិតធូលីដីដែលជាប់ជើងអ្នក; នោះអ្នកនឹងដឹងថា យើងនេះជាព្រះអម្ចាស់; ហើយអស់អ្នក ដែលសង្ឃឹមដល់យើង នឹងមិនត្រូវខ្មាស់ឡើយ ។

២៤ ត្បិតតើរបឹបនឹងត្រូវឆក់យកពីអ្នកខ្លាំងពូកែ ឬពួក ឈ្លើយដែលចាប់តាមច្បាប់នឹងត្រូវដោះចេញបានឬទេ ?

២៥ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ទោះ ទាំងពួកឈ្លើយរបស់មនុស្សខ្លាំងពូកែ ក៏នឹងត្រូវឆក់យកទៅ ហើយរបឹប របស់ពួកគួរស្ញែងខ្លាច នឹងបានដោះចេញផង; ត្បិតយើងនឹងតតាំងចំពោះអ្នក ដែលតតាំងនឹងអ្នក ហើយយើងនឹង ជួយសង្គ្រោះកូន ចៅអ្នកដែរ ។

២៦ ហើយយើងនឹងធ្វើឲ្យពួកអ្នក ដែលសង្កត់សង្កិនអ្នក ត្រូវ ស៊ីសាច់របស់ខ្លួនគេវិញ; ពួកគេនឹងត្រូវស្រវឹង ដោយឈាម របស់ខ្លួន ដូចជាស្រវឹងដោយស្រាទំពាំងបាយជូរថ្មី; នោះគ្រប់ទាំង មនុស្សនឹងដឹងថា យើងនេះគឺជាព្រះអម្ចាស់ ជាព្រះអង្គសង្គ្រោះ នៃអ្នក ហើយជាព្រះដ៏ប្រោសលោះអ្នក គឺជាព្រះដ៏មាន ឥទ្ធិឫទ្ធិនៃយ៉ាកុប ៕

## ជំពូកទី ២២

*សាសន៍អ៊ីស្រាអែលនឹងត្រូវខ្ចាត់ខ្ចាយពាសពេញលើផ្ទៃផែនដី — ពួកសាសន៍ដទៃនឹងបំបៅ ហើយចិញ្ចឹមពួកសាសន៍ អ៊ីស្រាអែល តាម ដំណឹងល្អ នៅគ្រាក្រោយបង្អស់ — សាសន៍អ៊ីស្រាអែលនឹងត្រូវបានមូលគ្នា ហើយនឹងបានសង្គ្រោះ ឯពួកទុច្ចរិតនឹងត្រូវឆេះដូចជាចំបើង — នគរនៃអារក្សនឹង ត្រូវបំផ្លាញចោល ឯអារក្សសាតាំង នឹងត្រូវបានចង ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំ នីហ្វៃ បានអានរឿងទាំងនេះ ដែលបានចារិក នៅលើផ្ទាំងលង្ហិន រួចហើយ នោះបងៗខ្ញុំបានមករកខ្ញុំ ហើយនិយាយនឹងខ្ញុំថា៖ តើរឿងដែលឯងបានអានទាំងនេះ មានន័យថាដូចម្ដេចដែរ ? មើលចុះ តើរឿងទាំង នេះ ត្រូវឲ្យយើងបានយល់តាមផ្លូវខាង ឯវិញ្ញាណ ដែលនឹងកើតឡើងមកពីខាងវិញ្ញាណ តែមិនមែន មកពីខាងសាច់ឈាមឬអី ?

២ ហើយខ្ញុំ នីហ្វៃ បាននិយាយទៅពួកគេថា៖ មើលចុះ រឿង ទាំងនោះត្រូវបានថ្លែងប្រាប់ដល់ពួកព្យាការី ដោយសម្លេងនៃព្រះ វិញ្ញាណ; ត្បិតដោយសារព្រះវិញ្ញាណ ទើបគ្រប់រឿងទាំងអស់ ត្រូវបានធ្វើឲ្យដឹងដល់ពួកព្យាការី ដែលនឹងកើតមានឡើងដល់កូនចៅ មនុស្ស ស្របតាមសាច់ឈាម ។

៣ ហេតុដូច្នោះហើយ រឿងទាំងប៉ុន្មាន ដែលខ្ញុំបានអាននោះ គឺជារឿងដែលទាក់ទងទៅនឹងរឿងទាំងខាងសាច់ឈាម និងខាង វិញ្ញាណផង; ត្បិតហាក់បីដូចជាមិនយូរមិនឆាប់ វង្សអ៊ីស្រាអែល

២០ *ក* ឬ ចង្អៀត ឬតូច.
២១ *ក* ក.ន. ស៊ីយ៉ូន.
*ខ* អេសាយ ៥៤:១;
កាឡាទី ៤:២៧.
២២ *ក* អេសាយ ៦៦:១៨–២០.
*ខ* អេសាយ ១១:១២; ១៨:៣.
*គ* ១ នីហ្វៃ ២២:៨;
២ នីហ្វៃ ១០:៨–៩.
២៣ *ក* អេសាយ ៦០:១៦.
*ខ* ១ នីហ្វៃ ២២:៦.
*គ* ២ នីហ្វៃ ៦:១៣;
គ. និង ស. ៩៨:២;
១៣៣:១០–១១, ៤៥.
២៤ *ក* ១ នីហ្វៃ ២១:២៥.
២៦ *ក* ១ នីហ្វៃ ២២:១៣–១៤.
*ខ* ម៉ូសាយ ១១:២២.
*គ* ស.ប. ព្រះយេហូវ៉ា.
**២២** ១*ក* ១ នីហ្វៃ ១៩:២២;
២ នីហ្វៃ ៤:២.
២ *ក* ២ ពេត្រុស ១:១៩–២១.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* ស.ប. ការព្យាករណ៍, ព្យាករ.
៣ *ក* គ. និង ស. ២៩:៣១–៣៤.

នឹងត្រូវ[ខ]ខ្ចាត់ខ្ចាយ ពាសពេញលើផ្ទៃផែនដី និងគ្រប់ចំណោមសាសន៍ នានា ។

៤ ហើយមើលចុះ មានមនុស្សជាច្រើន ដែលអ្នកនៅឯក្រុងយេរូសាឡិមឈប់ស្គាល់ទៀត ។ មែនហើយ មនុស្សមួយភាគធំនៃ អស់ទាំង[ក]ពូជអំបូរ[ខ]ត្រូវបានដឹកនាំចេញទៅ; ហើយពួកគេត្រូវបានខ្ចាត់ខ្ចាយទៅវិញទៅមក ពាសពេញអស់ទាំង[គ]កោះនៅក្នុងសមុទ្រ; ហើយពួកគេនៅឯណា នោះគ្មានពួកយើងណាម្នាក់ដឹងទេ យើងគ្រាន់តែដឹងថា ពួកគេត្រូវបាននាំចេញទៅប៉ុណ្ណោះ ។

៥ ហើយតាំងពីពេលពួកគេត្រូវបាននាំចេញទៅ នោះរឿងទាំងនេះត្រូវបានព្យាករអំពីពួកគេ និងអំពីអស់ទាំងពួកអ្នកដែលនឹងត្រូវ ខ្ចាត់ខ្ចាយ ហើយលាយឡំពីអំណើះទៅ ពីព្រោះមកពីព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល; ត្បិតពួកគេនឹងធ្វើចិត្តរឹងរូសទាស់នឹងទ្រង់; ហេតុដូច្នោះហើយ ពួកគេនឹងត្រូវខ្ចាត់ខ្ចាយ ទៅលើគ្រប់ចំណោមសាសន៍នានា ហើយនឹងទៅជា[ក]ទីស្អប់ដល់គ្រប់មនុស្ស ។

៦ តែទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពី[ក]ពួកសាសន៍ដទៃ [ខ]បានបំបៅគេ ហើយព្រះអម្ចាស់ទ្រង់បានបោយ ដៃហោអស់ទាំងសាសន៍ដទៃ ហើយលើកពួកគេឡើងជាទង់ជ័យ ហើយ[គ]កូនចៅរបស់ពួកគេត្រូវបានបីមក ហើយបានបញ្ជិះកូនស្រីនៅលើស្មាគេ មើលចុះ រឿងទាំង នេះ ដែលបានពោលដល់ គឺជារឿងខាងសាច់ឈាម; ត្បិតនេះគឺជាសេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ ដល់ពួកអយ្យកោយើង; ហើយរឿងនេះ មានន័យដល់ពួកយើង នៅថ្ងៃខាងមុខនេះ និងដល់បងប្អូនយើងទាំងប៉ុន្មានដែលជាពួកអ្នកនៃវង្សអ៊ីស្រាអែលផង ។

៧ ហើយរឿងនេះមានន័យថា ពេលវេលានឹងមកដល់គឺបន្ទាប់ពីអស់ទាំងវង្សអ៊ីស្រាអែល ត្រូវបានខ្ចាត់ខ្ចាយ ហើយលាយឡំ នោះព្រះអម្ចាស់ទ្រង់នឹងលើកសាសន៍ដ៏ខ្លាំងពូកែមួយឡើង [ក]ក្នុងចំណោមពួកសាសន៍ដទៃ មែនហើយ គឺនៅលើដែនដីនេះផង; ហើយដោយសារពួកគេនេះហើយ ដែលពូជយើងនឹង[ខ]ត្រូវបានខ្ចាត់ខ្ចាយ ។

៨ ហើយបន្ទាប់ពីពូជយើងត្រូវខ្ចាត់ខ្ចាយ នោះព្រះអម្ចាស់ទ្រង់នឹងចាប់ផ្ដើមធ្វើកិច្ច[ក]ការដ៏អស្ចារ្យមួយ នៅក្នុងចំណោម[ខ]ពួកសាសន៍ដទៃ ជាការណ៍ដ៏មានប្រយោជន៍សំខាន់ដល់ពូជយើង; ហេតុដូច្នោះហើយ រឿងនេះប្រៀបដូចជាពួកសាសន៍ដទៃបានចញ្ចឹមពូជយើង ហើយបានទាំងបី ហើយបញ្ជិះលើស្មាគេ ។

៩ ហើយជាការណ៍ដ៏មាន[ក]ប្រយោជន៍ដល់ពួកសាសន៍ដទៃដែរ; ហើយមិនត្រឹមតែដល់ពួកសាសន៍ដទៃប៉ុណ្ណោះទេ ប៉ុន្តែការណ៍នេះ មានប្រយោជន៍[ខ]ដល់[គ]ពួកសាសន៍អ៊ីស្រាអែលថែមទៀតផង ដើម្បីធ្វើឲ្យដឹង[ឃ]ពីសេចក្ដីសញ្ញានៃព្រះវរបិតា ដែលគង់នៅស្ថានសួគ៌[ង] ដល់អ័ប្រាហាំថា៖ [ច]ដោយសារពូជអ្នក នោះគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងបានពរ ។

១០ ឱបងទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា អស់ទាំងពូជមនុស្ស[ក]នៅលើផែនដី មិនអាចបានទទួលពរទេ ប្រសិនបើ ទ្រង់មិនបានលាតព្រះពាហុ នៅភ្នែកនៃសាសន៍ទាំងឡាយ ។

១១ ហេតុដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងចាប់ផ្ដើមលាតព្រះពាហុ នៅភ្នែកនៃគ្រប់ទាំងសាសន៍ ដើម្បីនឹងនាំយកសេចក្ដី សញ្ញាទាំងឡាយរបស់ទ្រង់ និងដំណឹងល្អរបស់ទ្រង់ មកដល់អស់អ្នកណា ដែលជាវង្សអ៊ីស្រាអែល ។

១២ ហេតុដូច្នោះហើយ ទ្រង់នឹងនាំពួកគេចេញពីការជាប់ឃុំឃាំងទៀត ហើយពួកគេនឹង[ក]ប្រមូលគ្នាមកឯដែនដីកេរ្ដិ៍អាកររបស់គេវិញ; ហើយពួកគេនឹងត្រូវនាំចេញពីទីអាប់អួរ និងពីទីនៃ

៣ *ខ* ១ នីហ្វៃ ១០:១២–១៤;
២ នីហ្វៃ ២៥:១៤–១៦.
ស.ប. អ៊ីស្រាអែល —— ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
៤ *ក* ស.ប. អ៊ីស្រាអែល —— ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់.
*ខ* ២ នីហ្វៃ ១០:២២.
*គ* ១ នីហ្វៃ ២១:១;
២ នីហ្វៃ ១០:៨, ២០.
៥ *ក* ១ នីហ្វៃ ១៩:១៤.
៦ *ក* ១ នីហ្វៃ ២១:២៣.
*ខ* ស.ប. ពួកសាសន៍ដទៃ.
*គ* ១ នីហ្វៃ ១៥:១៣.
៧ *ក* ៣ នីហ្វៃ ២០:២៧.
*ខ* ១ នីហ្វៃ ១៣:១២–១៤;
២ នីហ្វៃ ១:១១.
៨ *ក* អេសាយ ២៩:១៤;
១ នីហ្វៃ ១៤:៧;
២ នីហ្វៃ ២៧:២៦.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ២ នីហ្វៃ ១០:១០–១១;
៣ នីហ្វៃ ១៦:៤–៧;
មរមន ៥:១៩.
*គ* ១ នីហ្វៃ ១៥:១៣–១៨;
៣ នីហ្វៃ ៥:២១–២៦; ២១:៧.
៩ *ក* ១ នីហ្វៃ ១៤:១–៥.
*ខ* ២ នីហ្វៃ ៣០:១–៧.
*គ* ២ នីហ្វៃ ២៩:១៣–១៤.
*ឃ* ចោទិ. ៤:៣១.
*ង* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*ច* លោកុ. ១២:២–៣;
៣ នីហ្វៃ ២០:២៧;
អ័ប្រា. ២:៩–១១.
១០ *ក* អេសាយ ៥២:១០.
១២ *ក* ស.ប. អ៊ីស្រាអែល —— ការប្រមូលនៃសាសន៍អ៊ីស្រាអែល.

[ខ]សេចក្ដីងងឹត; ហើយពួកគេនឹងដឹងថា [គ]ព្រះអម្ចាស់ គឺជា
ព្រះអង្គសង្គ្រោះរបស់គេ ហើយជា[ឃ]ព្រះដ៏ប្រោសលោះរបស់គេ
គឺជា[ង]ព្រះដ៏មានឥទ្ធិឫទ្ធិនៃសាសន៍អ៊ីស្រាអែល ។
១៣ ហើយឈាមនៃសាសនាចក្រដ៏ធំ ហើយ[ក]គួរខ្ពើមឆ្អើមនោះ
ដែលជាពេស្យានៃអស់ទាំងផែនដី នឹងត្រឡប់មកលើក្បាលពួក
គេ; ត្បិតពួកគេនឹង[ខ]ធ្វើសង្គ្រាម នៅក្នុងចំពោះគ្នាឯង ហើយ
ដាវទាំងឡាយនៅដៃរបស់ពួកគេនឹងធ្លាក់មកលើ[គ]ក្បាលពួកគេ
ហើយពួកគេនឹង ស្រវឹង ដោយឈាមរបស់ខ្លួនផ្ទាល់ ។
១៤ ឱវង្សអ៊ីស្រាអែលអើយ គ្រប់ទាំង[ក]សាសន៍ដែលធ្វើសង្គ្រាម
ទាស់នឹងអ្នក ពួកគេនឹងត្រឡប់ជាទាស់គ្នាឯងវិញ ហើយពួកគេ
នឹង[ខ]ធ្លាក់ ទៅក្នុងរណ្ដៅ ដែលខ្លួនបានជីក ធ្វើទុកដាក់រាស្ត្រ
របស់ព្រះអម្ចាស់ ។ ហើយជនទាំងអស់ណាដែល[គ]ច្បាំងនឹង
ក្រុងស៊ីយ៉ូន នឹងត្រូវបំផ្លាញ ចោល ហើយពេស្យាដ៏ធំនោះ
ដែលបានបង្ខូចផ្លូវដ៏ត្រឹមត្រូវទាំងឡាយនៃព្រះអម្ចាស់ មែន
ហើយ សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើម នោះ នឹងរលំចុះ
មកដល់[ឃ]ធូលីដី ហើយការរលំនោះគឺខ្លាំងណាស់ណា ។
១៥ ត្បិតមើលចុះ ព្យាការីបាននិយាយថា ថ្ងៃនោះនឹងមកដល់
យ៉ាងឆាប់រហ័ស ដែលអារក្សសាតាំងនឹងគ្មានអំណាចទៅលើដួង
ចិត្តនៃកូនចៅមនុស្សទៀតទេ; ព្រោះថ្ងៃជិតមកដល់ហើយ ដែល
អស់ពួកអ្នកឆ្មើងឆ្មៃ និងអស់ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់
គេនឹងដូចជា[ក]ជញ្ជ្រាំង; ហើយថ្ងៃនោះនឹងមកដល់ ដែលពួកគេ
ត្រូវតែ[ខ]បានឆេះសុះ ។
១៦ ត្បិតវេលាជិតមកដល់ហើយ ដែល[ក]សេចក្ដីក្រោធ
ដ៏ពេញទំហឹងនៃព្រះនឹងធ្លាក់មកលើកូនចៅ មនុស្សទាំងអស់;
ត្បិតទ្រង់នឹងមិន ទ្រាំឲ្យពួកទុច្ចរិតបំផ្លាញពួកសុចរិតឡើយ ។
១៧ ហេតុដូច្នោះហើយ ទ្រង់នឹង[ក]ទំនុកបំរុង[ខ]ពួកសុចរិតទុក
ដោយព្រះចេស្ដាទ្រង់ ទោះបីសេចក្ដីក្រោធ ដ៏ពេញទំហឹង
របស់ទ្រង់នឹងធ្លាក់ មកក៏ដោយ ហើយពួកអ្នកសុចរិតនឹងត្រូវ
បានទំនុកបំរុងទុក គឺរហូតដល់សេចក្ដីបំផ្លិចបំផ្លាញពួកខ្មាំង
សត្រូវគេដោយភ្លើង ។ ហេតុដូច្នោះហើយ ពួកសុចរិតមិនត្រូវ
ខ្លាចឡើយ; ត្បិតព្យាការីបាននិយាយដូច្នេះថា ពួកគេនឹងបាន
សង្គ្រោះ សូម្បីតែដោយភ្លើង ។
១៨ ឱបងទាំងឡាយរបស់ខ្ញុំអើយ មើលចុះ ខ្ញុំប្រាប់បងថា
ការណ៍ទាំងនេះត្រូវតែមកដល់នៅពេលឆាប់ៗ; មែនហើយ
គឺឈាម និងភ្លើង ហើយនឹងចំហាយផ្សែងត្រូវតែមកដែរ;
ហើយការណ៍នេះច្បាស់ជានឹងកើតឡើងនៅលើផែនដីនេះ;
ហើយការណ៍នេះនឹង កើតឡើងដល់មនុស្ស ស្របតាមសាច់ឈាម
ប្រសិនបើពួកគេធ្វើចិត្តរឹងរូសទាស់នឹងព្រះដ៏បរិសុទ្ធ នៃសាសន៍
អ៊ីស្រាអែល ។
១៩ ត្បិតមើលចុះ ពួកសុចរិតនឹងមិនត្រូវវិនាសឡើយ;
ត្បិតពេលនោះច្បាស់ជានឹងមកដល់ថា អស់អ្នកណាដែលច្បាំងនឹង
ក្រុងស៊ីយ៉ូន នោះនឹងត្រូវកាត់កាល់ចេញ ។
២០ ហើយព្រះអម្ចាស់ទ្រង់ច្បាស់ជានឹងរៀបចំផ្លូវសំរាប់
រាស្ត្រទ្រង់ ចំពោះការបំពេញតាមពាក្យសំដីរបស់លោកម៉ូសេ
ដែលលោក បាននិយាយថា៖ មាន[ក]ព្យាការីម្នាក់ដែលព្រះ
អម្ចាស់ជាព្រះនៃអ្នករាល់គ្នា ទ្រង់នឹងបង្កើតឡើងដល់អ្នករាល់
គ្នា ឲ្យដូចខ្ញុំ; លោកនោះ ហើយដែលអ្នករាល់គ្នាត្រូវ
ស្ដាប់តាមគ្រប់ការណ៍ទាំងអស់ ដែលលោកនឹងប្រាប់ដល់
អ្នក ។ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណា
ដែលមិនព្រមស្ដាប់តាមព្យាការីនោះទេ នោះនឹងត្រូវ
[ខ]កាត់កាល់ចេញពីចំណោមប្រជាជន ។
២១ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ សូមថ្លែងប្រាប់បងថា [ក]ព្យាការី
ដែលលោកម៉ូសេបាននិយាយមកនោះ គឺជាព្រះដ៏បរិសុទ្ធ
នៃសាសន៍ អ៊ីស្រាអែល; ហេតុដូច្នោះហើយ ទ្រង់នឹងអនុវត្ត
[ខ]សេចក្ដីជំនុំជំរះ ដោយនូវសេចក្ដីសុចរិត ។
២២ ហើយពួកសុចរិតមិនត្រូវខ្លាចឡើយ ត្បិតពួក

១២ *ខ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
*គ* ២ នីហ្វៃ ៦:១០–១១.
*ឃ* ស.ប. ព្រះអង្គសង្គ្រោះ.
*ង* ស.ប. ព្រះយេហូវ៉ា.
១៣ *ក* ស.ប. អារក្ស — សាសនាចក្រនៃអារក្ស.
*ខ* ១ នីហ្វៃ ១៤:៣, ១៥–១៧.
*គ* ១ នីហ្វៃ ២១:២៦.
១៤ *ក* លូកា ២១:១០.
*ខ* អេសាយ ៦០:១២; ១ នីហ្វៃ ១៤:៣; គ. និង ស. ១០៩:២៥.
*គ* ២ នីហ្វៃ ១០:១៣; ២៧:៣.
*ឃ* អេសាយ ២៥:១២.
១៥ *ក* អេសាយ ៥:២៣–២៤; ណាហ៊ុម ១:១០; ម៉ាឡាគី ៤:១; ២ នីហ្វៃ ១៥:២៤; ២៦:៤–៦; គ. និង ស. ៦៤:២៣–២៤; ១៣៣:៦៤.
*ខ* ទំនុក. ២១:៩; ៣ នីហ្វៃ ២៥:១; គ. និង ស. ២៩:៩. ស.ប. ផែនដី — ការសំអាតផែនដី.
១៦ *ក* ១ នីហ្វៃ ១៤:១៧.
១៧ *ក* ២ នីហ្វៃ ៣០:១០; ម៉ូសេ ៧:៦១.
*ខ* ១ នីហ្វៃ ១៧:៣៣–៤០.
២០ *ក* យ៉ូហាន ៤:១៩; ៧:៤០.
*ខ* គ. និង ស. ១៣៣:៦៣.
២១ *ក* ចោទិ. ១៨:១៥, ១៨; កិច្ចការ ៣:២០–២៣; ១ នីហ្វៃ ១០:៤; ៣ នីហ្វៃ ២០:២៣.
*ខ* ទំនុក. ៩៨:៩; ម៉ូសេ ៦:៥៧.

គេនេះហើយដែលនឹងមិនត្រូវបំផ្លាញចោលឡើយ ។ ប៉ុន្តែគឺជា
នគរនៃអារក្សទេតើ ដែលនឹងត្រូវបានតាំងឡើងក្នុងចំណោម
កូនចៅមនុស្ស ជានគរដែលបង្កើតឡើងក្នុងចំណោមពួកគេ
គឺខាងសាច់ឈាម—

២៣ ត្បិតពេលនោះនឹងមកដល់យ៉ាងឆាប់រហ័សថា អស់
ទាំងសាសនាចក្រ[ក]ណាដែលបានតាំងឡើង ដើម្បីរកកំរៃ ហើយ
អស់អ្នក ណាដែលបានតាំងឡើង ដើម្បីរកអំណាចលើខាង
សាច់ឈាម ហើយអស់អ្នកណាដែលបានតាំងឡើង ដើម្បីរក
[ខ]ប្រជាប្រិយភាពខាងឯ ភ្នែកមនុស្សលោក និងអស់អ្នកណា
ដែលស្វែងរកសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាម និងវត្ថុ
ខាងលោកិយ ហើយដើម្បីប្រព្រឹត្តនូវសេចក្ដី ទុច្ចរិតគ្រប់បែប
យ៉ាង; មែនហើយ សរុបសេចក្ដីថា អស់អ្នកណាដែលនៅក្នុង[គ]
នគររបស់អារក្ស គឺជាពួកអ្នកដែលត្រូវភិតភ័យ ហើយញ័រ រន្ធត់;
ពួកគេនេះហើយដែលជាពួកអ្នកដែលត្រូវរលំ[ឃ]មកដល់ធូលីដី;
ពួកគេនេះហើយដែលជាពួកអ្នកដែលត្រូវឆេះសុះដូចជាជញ្ជ្រាំង;
ហើយការណ៍នេះ គឺស្របតាមពាក្យសំដីរបស់ព្យាការីនោះ ។

២៤ ហើយពេលនោះនឹងមកដល់យ៉ាងឆាប់រហ័សថា ពួក
សុចរិតនឹងត្រូវបាននាំដូចជាកូន[ក]គោ នៅក្នុងក្រោល ហើយ
ព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែល ទ្រង់នឹងសោយរាជ្យដោយ
អំណាច ឥទ្ធិឫទ្ធិ ព្រះចេស្ដា និងសិរីល្អដ៏អស្ចារ្យរបស់ទ្រង់ ។

២៥ ហើយទ្រង់នឹងប្រមូល[ក]កូនចៅរបស់ទ្រង់ ពីគ្រប់ទិសទាំងបួន
នៃផែនដី; ហើយទ្រង់នឹងរាប់ចំនួនចៀមរបស់ទ្រង់ ឯពួកវាក៏ស្គាល់
ទ្រង់ដែរ; ហើយនឹងមានចៀមមួយហ្វូង និងអ្នក[ខ]គង្វាលមួយ;
ហើយទ្រង់នឹងចញ្ចឹមចៀមរបស់ទ្រង់ ហើយនៅក្នុងព្រះអង្គ នោះពួក
វានឹងរក ឃើញវាលស្មៅ[គ] ។

២៦ ហើយដោយសារអំពើសុចរិតរបស់រាស្ត្រទ្រង់ នោះ[ក]អារក្ស
សាតាំងគ្មានអំណាចសោះ; ហេតុដូច្នោះហើយ អារក្សមិនត្រូវ
អាច ដោះ ចេញមកបាន អស់រយៈពេលជាច្រើនឆ្នាំ; ត្បិតវា
គ្មានអំណាចទៅលើដួងចិត្តនៃមនុស្សទេ ព្រោះពួកគេស្ថិតនៅ
ក្នុងសេចក្ដីសុចរិត ហើយព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល
ទ្រង់សោយរាជ្យ ។

២៧ ហើយឥឡូវនេះ មើលចុះ ខ្ញុំ នីហ្វៃ ប្រាប់បងថា:
ការណ៍ទាំងអស់នេះនឹងកើតឡើង ស្របតាមសាច់ឈាម ។

២៨ ប៉ុន្តែមើលចុះ គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់
ភាសា ហើយនិងគ្រប់ទាំងប្រជាជននឹងរស់ នៅដោយសុខសាន្ត
ជាមួយនឹង ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ប្រសិនបើពួក
គេព្រម[ក]ប្រែចិត្ត ។

២៩ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ សូមបញ្ចប់តែប៉ុណ្ណេះ; ត្បិតខ្ញុំ
មិនហ៊ាននិយាយតទៅទៀត អំពីការណ៍ទាំងនេះឡើយ ។

៣០ ហេតុដូច្នេះហើយ ឱបងទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់ឲ្យ
បងចាត់ទុកថា សេចក្ដីដែលសរសេរនៅលើ [ក]ផ្ទាំងលង្ហិន
ទាំងនោះ គឺពិត; ហើយសេចក្ដីទាំងនោះធ្វើបន្ទាល់ថា មនុស្ស
ត្រូវតែគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។

៣១ ហេតុដូច្នេះហើយ បងរាល់គ្នាមិនត្រូវគិតស្មានថា មាន
តែខ្ញុំ និងឪពុកខ្ញុំទេ ដែលជាអ្នកបានធ្វើបន្ទាល់ ហើយក៏បាន
បង្រៀន ការណ៍ទាំងនេះ ។ ហេតុដូច្នោះហើយ បើ
សិនជាបងរាល់គ្នានឹងគោរពតាម[ក]ព្រះបញ្ញត្តិទាំងប៉ុន្មាន ហើយ
កាន់ខ្ជាប់ ដរាបដល់ចុងបំផុត នោះបងរាល់គ្នានឹងបានសង្គ្រោះ
នៅថ្ងៃចុងក្រោយបង្អស់ ។ ហើយគឺយ៉ាងដូច្នោះមែន ។
អាម៉ែន ។ :៙៚

២៣ *ក* ១ នីហ្វៃ ១៤:១០;
២ នីហ្វៃ ២៦:២០.
ស.ប. ឧបាយកលផ្ទែកសង្ឃ.
*ខ* លូកា ៦:២៦; អាលម៉ា ១:៣.
*គ* ២ នីហ្វៃ ២៨:១៩.
*ឃ* ២ នីហ្វៃ ២៦:៦.
២៤ *ក* អេម៉ុស ៦:៤; ម៉ាឡាគី ៤:២;
៣ នីហ្វៃ ២៥:២.
២៥ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
*ខ* ស.ប. អ្នកគង្វាលល្អ.
*គ* ទំនុក. ២៣.
២៦ *ក* វិវរ. ២០:២; អាលម៉ា ៤៨:១៧;
គ. និង ស. ៤៣:៣១; ៤៥:៥៥;
៨៨:១១០; ១០១:២៨.
ស.ប. អារក្ស.
*ខ* យ៉ាកុប ៥:៧៦.
*គ* ស.ប. សហស្សវត្សរ៍.
២៨ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត;
អត់ទោស, អភ័យទោស.
៣០ *ក* ២ នីហ្វៃ ៤:២.
៣១ *ក* ម៉ាថាយ ១៩:១៧.
ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.

# គម្ពីរទីពីរនៃនីហ្វៃ

ដំណើររឿងមួយអំពីមរណភាពរបស់លីហៃ ។ ពួកបងប្រុសរបស់នីហ្វៃបះបោរទាស់នឹងនីហ្វៃ ។ ព្រះអម្ចាស់ទ្រង់ព្រមាននីហ្វៃឲ្យចាកចេញទៅក្នុងទីរហោស្ថាន ។ ដំណើររបស់លោកនៅក្នុងទីរហោស្ថាន ។ល។

## ជំពូកទី ១

*លីហៃព្យាករអំពីដែនដីនៃឥស្សរភាពមួយ — កូនចៅរបស់លោកនឹងត្រូវខ្ចាត់ព្រាត់ ហើយបរាជ័យ ប្រសិនបើពួកគេបដិសេធព្រះ ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល — លោកទូន្មានកូនប្រុសទាំងឡាយរបស់លោក ឲ្យប្រដាប់នូវគ្រឿងការពារនៃសេចក្តីសុចរិត ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំ នីហ្វៃ បានបញ្ចប់នូវការប្រៀនប្រដៅបងៗខ្ញុំហើយ នោះ[ក]ឪពុករបស់យើង គឺលីហៃ ក៏មានប្រសាសន៍អំពីរឿងជាច្រើនដល់ពួកគេដែរ ហើយតំណាលប្រាប់ដល់គេ អំពីការណ៍ដ៏ធំក្រៃលែង ដែលព្រះអម្ចាស់ទ្រង់ បានមេត្តាប្រោសដល់ពួកគេ ដើម្បីជួយនាំពួកគេចេញពី ដែនដីយេរូសាឡិម ។

២ ហើយលោកបាននិយាយទៅកាន់ពួកគេ អំពី[ក]ការបះបោររបស់ពួកគេ កាលធ្វើដំណើរតាមទឹក និងអំពីសេចក្តីមេត្តាករុណានៃព្រះ ដោយទ្រង់បានប្រណីជីវិតដល់ពួកគេ ដើម្បីកុំឲ្យពួកគេត្រូវលេបលិចបាត់នៅក្នុងសមុទ្រ ។

៣ ហើយលោកក៏បាននិយាយទៅកាន់ពួកគេ អំពីដែនដីសន្យាដែលពួកគេបានទទួលយក — គឺព្រះអម្ចាស់ទ្រង់ប្រកបដោយសេចក្តីមេត្តា ដែលបានព្រមានដល់យើង ឲ្យយើងរត់គៀសខ្លួនចេញពីដែនដីយេរូសាឡិម ។

៤ ត្បិតមើលចុះ លោកបាននិយាយថា ឪពុកបានឃើញ[ក]ការនិមិត្តមួយ ហើយដោយការនិមិត្តនោះ ឪពុកដឹងថា [ខ]ក្រុងយេរូសាឡិមត្រូវ បានបំផ្លាញចោល; ហើយប្រសិនបើយើងរស់នៅក្រុងយេរូសាឡិមតទៅ នោះយើងក៏នឹងត្រូវ[គ]វិនាសទៅហើយដែរ ។

៥ ប៉ុន្តែលោកបាននិយាយថា ទោះបីបានឆ្លងកាត់ការវេទនារបស់យើងជាច្រើនក៏ដោយ គង់តែយើងបាន[ក]ទទួលដែនដីសន្យាដែរ គឺជាដែនដីមួយដែលជាទី[ខ]ជំរើសលើអស់ទាំងដែនដីឯទៀត; ជាដែនដីមួយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើសេចក្តីសញ្ញាជាមួយនឹងឪពុកថា ជាដែនដីទុកជាកេរ្តិ៍អាករសំរាប់ពូជឪពុក ។ មែនហើយ ព្រះអម្ចាស់ទ្រង់បាន[គ]ធ្វើសេចក្តីសញ្ញាថាឲ្យដែនដីនេះដល់ឪពុក ហើយដល់កូន ចៅឪពុករហូតតទៅ និងដល់អស់អ្នកផងទាំងឡាយណា ដែលត្រូវដឹកនាំចេញពីប្រទេសផ្សេងៗមកដោយព្រះហស្តនៃព្រះអម្ចាស់ ។

៦ ហេតុដូច្នោះហើយ ឪពុក គឺលីហៃ ព្យាករតាមកិច្ចការនៃព្រះវិញ្ញាណ ដែលនៅក្នុងខ្លួនឪពុក ថា[ក]គ្មានអ្នកណាមួយ នឹងអាចមកដល់ ដែនដីនេះបានឡើយ លើកលែងតែមកដោយព្រះហស្តនៃព្រះអម្ចាស់ប៉ុណ្ណោះ ។

៧ ហេតុដូច្នោះហើយ [ក]ដែនដីនេះញែកទុកសំរាប់តែអ្នកណាដែលទ្រង់នឹងនាំមកតែប៉ុណ្ណោះ ។ ហើយបើសិនជាពួកគេនឹងបំរើព្រះអង្គ ស្របតាមព្រះបញ្ញត្តិទាំងឡាយ ដែលព្រះអង្គបានប្រទានមកនោះ នោះដែនដីនេះនឹងទៅជាដែនដី [ខ]នៃឥស្សរភាពដល់ពួកគេ; ហេតុដូច្នោះ ហើយ ពួកគេនឹងមិនត្រូវនាំចុះទៅក្នុងការជាប់ឃុំឃាំងឡើយ; បើពុំនោះសោតទេ គឺការណ៍នោះកើតមកពីសេចក្តីទុច្ចរិត; ត្បិតបើសិនជាមានសេចក្តីទុច្ចរិតពាសពេញ នោះដែនដីនឹងត្រូវ[គ]បណ្តាសា ដោយព្រោះពួកគេ ប៉ុន្តែចំពោះពួកសុចរិតវិញ ដែនដីនេះ នឹងត្រូវបានពររហូតតទៅ ។

៨ ហើយមើលចុះ គឺដោយសារប្រាជ្ញារបស់ព្រះ ដែលដែនដីនេះត្រូវបានថែរក្សាទុក មិនឲ្យដឹងដល់សាសន៍ដទៃឡើយ; ត្បិតមើលចុះ សាសន៍ជាច្រើននឹងមកជិះជាន់ដែនដីនេះ ដើម្បីមិនឲ្យមានកន្លែងណាទុកជាកេរ្តិ៍អាករឡើយ ។

៩ ហេតុដូច្នោះហើយ ឪពុក គឺលីហៃ បានទទួលពាក្យសន្យាថា

[២ នីហ្វៃ]
១ ១*ក* ស.ប. អយ្យកោ, ខាងអយ្យកោ.
២ *ក* ១ នីហ្វៃ ១៨:៩–២០.
៤ *ក* ស.ប. ការនិមិត្ត.
*ខ* ២ ពង្សាវ. ២៤:១៤–១៥; យេរេ. ៤៤:២; ១ នីហ្វៃ ១:៤; ហេលេ. ៨:២០.
*គ* អាលម៉ា ៩:២២.
៥ *ក* ស.ប. ដែនដីសន្យា.
*ខ* អេធើរ ២:៩–១០.
*គ* ស.ប. សេចក្តីសញ្ញា.
៦ *ក* ២ នីហ្វៃ ១០:២២.
៧ *ក* ម៉ូសាយ ២៩:៣២; អាលម៉ា ៤៦:១០, ២០.
*ខ* ២ នីហ្វៃ ១០:១១. ស.ប. ឥស្សរភាព.
*គ* អាលម៉ា ៤៥:១០–១៤, ១៦; មរមន ១:១៧; អេធើរ ២:៨–១២.

ដរាបណាពួកអ្នកដែលព្រះអម្ចាស់ ទ្រង់បាននាំចេញពីដែនដី
យេរូសាឡិមមក កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអង្គ
នោះពួកគេនឹងបានចំរើនឡើង នៅលើផ្ទៃនៃដែនដីនេះ; ហើយ
ពួកគេ នឹងត្រូវបានរក្សាទុកពី អស់ទាំងសាសន៍ឯទៀត ដើម្បីឲ្យ
ពួកគេអាចគ្រងដែនដីនេះទុកដល់ខ្លួន ។ ហើយប្រសិនបើពួក
គេកាន់តាម ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអង្គ នោះពួកគេ
នឹងបានពរនៅលើផ្ទៃនៃដែនដីនេះ ហើយនឹងគ្មាននរណាមួយ
មកបៀតបៀនពួកគេ ឬក៏ដណ្ដើមយកដែនដីនៃកេរ្តិ៍ អាករ
របស់គេឡើយ; ហើយពួកគេនឹងរស់នៅ ដោយសុខសាន្ត
ជារៀងតទៅ ។
១០ ប៉ុន្តែមើលចុះ កាលពេលនោះមកដល់ ដែលពួកគេ
ចុះអន់ថយក្នុងការឥតជំនឿ បន្ទាប់ពីពួកគេបានពរជាច្រើន
ពីព្រះហស្តនៃព្រះ អម្ចាស់ — ដោយមានការចេះដឹងអំពីការ
បង្កើតផែនដី និងមនុស្សលោកទាំងអស់ ដោយដឹងអំពីកិច្ចការ
ទាំងឡាយរបស់ទ្រង់ដែលតែធំ ហើយអស្ចារ្យ ចាប់តាំងពីការ
បង្កើតលោកិយមក; ដោយមានអំណាចដែលបានប្រទានដល់
ពួកគេ សំរាប់ឲ្យធ្វើនូវអ្វីៗគ្រប់យ៉ាង ដោយសារសេចក្ដីជំនឿ;
ដោយមានព្រះបញ្ញត្តិទាំងអស់ ចាប់តាំងពីដំបូងមក ហើយដោយ
បាននាំមកដល់ដែនដីសន្យាដ៏ពិសេសនេះ ដោយសារសេច
ក្ដីល្អដ៏និរន្តរ៍របស់ទ្រង់ — មើលចុះ ឪពុកនិយាយថា បើ
សិនជាថ្ងៃនោះមកដល់ ដែលពួកគេមិនទទួលស្គាល់ព្រះដ៏ បរិសុទ្ធ
នៃពួកសាសន៍អ៊ីស្រាអែល ជាព្រះមែស៊ីដ៏ពិត ជា
ព្រះដ៏ប្រោសលោះរបស់គេ និងជាព្រះរបស់គេទេ មើលចុះ
សេចក្ដីជំនុំជំរះទាំង ឡាយរបស់ទ្រង់ដែលត្រឹមត្រូវ នឹងធ្លាក់មក
លើពួកគេ ។
១១ មែនហើយ ទ្រង់នឹងនាំពួកសាសន៍ឯទៀតមកទីនេះ ហើយ
ទ្រង់នឹងប្រទានអំណាចដល់ពួកសាសន៍ទាំងនេះ ហើយទ្រង់នឹង
ដក យកដែនដីជាកេរ្តិ៍អាកររបស់ពួកគេមកវិញ ហើយទ្រង់
នឹងធ្វើឲ្យពួកគេខ្ចាត់ខ្ចាយ ហើយរងទុក្ខ ។
១២ មែនហើយ ពីតំណមួយទៅតំណមួយ នឹងមានការ
ខ្ចាយឈាមទាំងឡាយ និងការពិនិត្យពិច័យដ៏ធំ ក្នុងចំណោម
ពួកគេ; ហេតុដូច្នោះហើយ ឱកូនប្រុសទាំងឡាយរបស់ឪពុក
អើយ ឪពុកចង់ឲ្យកូនចងចាំ; មែនហើយ ឪពុកចង់ឲ្យកូនប្រុង
ស្ដាប់តាមវាចារបស់ ឪពុកចុះ ។
១៣ ឱ ចូរឲ្យកូនរាល់គ្នាភ្ញាក់ឡើង; ចូរភ្ញាក់ពីដំណេកដ៏លង់លក់
មែនហើយ ព្រមទាំងពីដំណេកនរក ហើយរលាស់ចោលនូវ
ច្រវាក់ ដ៏អប្រិយ៍ ដែលចងកូនរាល់គ្នា ដែលជាច្រវាក់ចងកូនចៅ
មនុស្សលោក ដើម្បីនាំយកទៅជាជាប់ឃុំឃាំង ចុះទៅកាន់
ជង្ហុកនៃសេចក្ដី វេទនា និងទុក្ខលំបាក ។
១៤ ចូរភ្ញាក់ឡើង! ហើយងើបពីធូលីដី ហើយស្ដាប់នូវវាចា
របស់ឪពុកដែលញ័រ ហើយមិនយូរប៉ុន្មានទេ ខ្លួនប្រាណរបស់
ឪពុកនេះ នឹងត្រូវកូនរាល់គ្នាបញ្ចុះទៅក្នុងផ្នូរដ៏ត្រជាក់ ហើយ
ស្ងប់ស្ងាត់ ជាកន្លែងដែលពុំមានអ្នកធ្វើដំណើរណា អាចត្រឡប់
មកវិញបានឡើយ; នៅតែប៉ុន្មានថ្ងៃទៀត ឪពុកនឹងទៅតាម
ផ្លូវនៃអស់ទាំងផែនដីហើយ ។
១៥ ប៉ុន្តែមើលចុះ ព្រះអម្ចាស់ទ្រង់បានប្រោសលោះព្រលឹង
របស់ឪពុក ឲ្យរួចពីស្ថាននរកហើយ; ឪពុកបានឃើញសិរីល្អរបស់
ទ្រង់ ហើយឪពុកត្រូវបានឱបក្រសោបជាអង្វែងតទៅ ដោយ
ព្រះពាហុនៃសេចក្ដីស្រឡាញ់របស់ទ្រង់ ។
១៦ ហើយឪពុកចង់ឲ្យកូនរាល់គ្នាចងចាំថា ត្រូវប្រតិបត្តិតាមមា
ត្រា និងសេចក្ដីជំនុំជំរះទាំងឡាយនៃព្រះអម្ចាស់; មើលចុះ នេះគឺ
ជាសេចក្ដីបារម្ភនៅក្នុងដួងព្រលឹងឪពុក ចាប់ពីដំបូងមកម្ល៉េះ ។
១៧ ជួនពេលខ្លះ ចិត្តឪពុកធ្ងន់ជាប់ទៅដោយសេចក្ដីសោកសៅ
ព្រោះឪពុកខ្លាចក្រែងភាពរឹងរូសនៃចិត្តរបស់ពួកកូន នាំឲ្យព្រះ
អម្ចាស់ជាព្រះរបស់កូន ទ្រង់កើតសេចក្ដីខ្ញាល់មកលើកូន
ទាំងស្រុង ដែលនឹងធ្វើឲ្យកូនរាល់គ្នា ត្រូវកាត់ចេញ ហើយត្រូវ
បំផ្លាញចោល ជាដរាប ។
១៨ ឬក៏បណ្ដាសានឹងធ្លាក់មកលើពួកកូន អស់រយៈជាច្រើនតំណ;

---

៩ *ក* ២ នីហ្វៃ ៤:៤; អាលម៉ា ៩:១៣.
*ខ* ចោទិ. ២៩:៩.
*គ* ស.ប. ការគោរព, ដែលគោរព, គោរព.
១០ *ក* ស.ប. ព្រះមែស៊ី.
១១ *ក* ១ នីហ្វៃ ១៣:១២–២០; មរមន ៥:១៩–២០.
*ខ* ១ នីហ្វៃ ២២:៧.
១២ *ក* មរមន ១:១១–១៩; ៤:១១.
១៣ *ក* ស.ប. ស្ថាននរក.
*ខ* អាលម៉ា ១២:៩–១១.
*គ* ១ នីហ្វៃ ១៥:២៨–៣០; ហេលេ. ៣:២៩–៣០.
១៤ *ក* ស.ប. មាតាបិតា, ឪពុកម្ដាយ.
*ខ* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
*គ* យ៉ូស្វេ ២៣:១៤.
១៥ *ក* អាលម៉ា ៣៦:២៨. ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* យ៉ាកុប ៦:៥; អាលម៉ា ៥:៣៣; ៣ នីហ្វៃ ៩:១៤.
*គ* រ៉ូម ៨:៣៩. ស.ប. សេចក្ដីស្រឡាញ់.
១៦ *ក* ចោទិ. ៤:៥–៨; ២ នីហ្វៃ ៥:១០–១១.
១៧ *ក* ២ នីហ្វៃ ៥:២១–២៤; អាលម៉ា ៣:៦–១៩.
*ខ* ម៉ូសាយ ១២:៨.
១៨ *ក* ១ នីហ្វៃ ១២:២០–២៣.

ហើយកូនរាល់គ្នានឹងត្រូវពិនិត្យពិច័យ ដោយមុខដាវ និងដោយអំណត់អត់ ហើយនឹងត្រូវស្អប់ខ្ពើម ហើយនឹងត្រូវដឹកនាំទៅតាមចំណង់ និងការជាប់ឃុំឃាំងរបស់អារក្ស ។

១៩ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ សូមកុំឲ្យការណ៍ទាំងនេះធ្លាក់មកលើពួកកូនឡើយ ប៉ុន្តែសូមឲ្យកូនរាល់គ្នាក្លាយទៅជា ប្រជាជនជំរើស និងសំណប់នៃព្រះអម្ចាស់ចុះ ។ ប៉ុន្តែមើលចុះ ព្រះហឫទ័យទ្រង់នឹងបានសំរេច; ត្បិតផ្លូវទាំងឡាយរបស់ទ្រង់ គឺជា សេចក្ដីសុចរិតជារៀងដរាប ។

២០ ហើយទ្រង់មានព្រះបន្ទូលថា៖ ដរាបណាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹងបានចំរើន ឡើងនៅលើដែនដី; ប៉ុន្តែបើដរាបណាអ្នករាល់គ្នាមិនកាន់តាមបញ្ញត្តិទាំងឡាយរបស់យើងទេ នោះអ្នករាល់គ្នានឹងត្រូវកាត់ចេញ ពីវត្តមានរបស់យើង ។

២១ ហើយឥឡូវនេះ ដើម្បីឲ្យព្រលឹងឪពុកអាចមានសេចក្ដីអំណរទៅលើកូន ហើយដើម្បីឲ្យដួងចិត្តឪពុកអាចចាកចេញពីលោក នេះទៅទាំងត្រេកអរ ដោយសារកូន ដើម្បីកុំឲ្យឪពុកអាចត្រូវបាននាំចុះទៅក្នុងផ្នូរ ដោយសារសេចក្ដីទុក្ខសោក និងសេចក្ដីសោកសៅ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ចូរកូនទាំងអស់ក្រោកពីធូលីដីឡើង ហើយធ្វើជាមនុស្ស ហើយតាំងស្មារតី ក្នុងគំនិតតែមួយ និងក្នុងចិត្តតែមួយ គឺសាមគ្គីគ្នាក្នុងការណ៍គ្រប់មុខ ដើម្បីកុំឲ្យកូនរាល់គ្នាធ្លាក់អាចចុះទៅការជាប់ឃុំឃាំងឡើយ;

២២ ដើម្បីកុំឲ្យកូនត្រូវពាក្យបណ្ដាសាដ៏ធ្ងន់ធ្ងរ; ហើយព្រមទាំងកុំឲ្យកូនរាល់គ្នាបានការអព្រះហឫទ័យនៃព្រះដ៏យុត្តិធម៌ មកលើកូនដល់សេចក្ដីបំផ្លិចបំផ្លាញឡើយ មែនហើយ គឺជាសេចក្ដីបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច នៃព្រលឹង និងទាំងរូបកាយដែរ ។

២៣ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ចូរភ្ញាក់ឡើង; ហើយចូរប្រដាប់នូវគ្រឿងការពារនៃសេចក្ដីសុចរិតចុះ។ ចូររលាស់ចោលនូវច្រវាក់ដែលចងកូន ហើយចូរចេញពីទីអាប់អួរមក ហើយចូរក្រោកពីធូលីដីឡើង ។

២៤ ចូរកុំបះបោរទាស់នឹងប្អូនទៀតឡើយ វាធ្លាប់មានទស្សនៈដ៏រុងរឿង ហើយវាបានកាន់តាមព្រះបញ្ញត្តិទាំងឡាយចាប់តាំង ពីពេលដែលយើងចាកចេញពីក្រុងយេរូសាឡិមមកម្ល៉េះ; ហើយវាធ្លាប់ទៅជាគ្រឿងឧបករណ៍មួយ នៅក្នុងព្រះហស្តនៃព្រះ ក្នុងការ នាំយើងមកដល់ដែនដីសន្យា; ត្បិតបើសិនជាមិនមែនដោយសារវាទេ នោះយើងទាំងអស់គ្នាច្បាស់ជាត្រូវវិនាសដោយការអត់ឃ្លាន នៅក្នុងទីរហោស្ថានទៅហើយ; ទោះជាយ៉ាងនេះក៏ដោយ គង់តែកូនរាល់គ្នាបានព្យាយាមចង់យកជីវិតវាដែរ; មែនហើយ ហើយវា បានរងទុក្ខវេទនានូវការសោកសៅដ៏ច្រើន ពីព្រោះតែពួកកូន ។

២៥ ហើយឪពុកភិតភ័យ ហើយញ័ររន្ធត់ក្រៃលែង ពីព្រោះតែពួកកូន ក្រែងវានឹងរងទុក្ខទៀត; ត្បិតមើលចុះ កូនរាល់គ្នាបានចោទ ប្រកាន់ថាវាស្វែងរកអានុភាព និងសិទ្ធិអំណាចលើពួកកូន; ប៉ុន្តែឪពុកដឹងថា វាមិនបានស្វែងរកអានុភាព ឬសិទ្ធិអំណាចលើពួកកូនទេ ប៉ុន្តែវាបានស្វែងរកសិរីល្អនៃព្រះ និងសុខុមាលភាពដ៏អស់កល្បជានិច្ចដល់ពួកកូនវិញ ។

២៦ ហើយកូនរាល់គ្នាបានរអ៊ូរទាំ ពីព្រោះវាបាននិយាយដោយច្បាស់លាស់ដល់កូន ។ កូនរាល់គ្នាថា វាបានប្រើវាចាតឹងរឹង; កូនរាល់គ្នាថា វាបានខឹងនឹងពួកកូន; ប៉ុន្តែមើលចុះ ការតឹងរឹងរបស់វា គឺជាការតឹងរឹងរបស់ចេស្ដានៃព្រះបន្ទូលនៃព្រះ ដែលនៅក្នុង ខ្លួនវា; ហើយអ្វីដែលកូនរាល់គ្នាហៅថា កំហឹង នោះគឺជាសេចក្ដីពិត ស្របតាមសេចក្ដីពិត ដែលនៅក្នុងព្រះ ដែលវាពុំអាចទប់បាន ទើបសម្ដែងប្រាប់ដោយក្លាហានអំពីសេចក្ដីទុច្ចរិតទាំងឡាយរបស់ពួកកូន ។

២៧ ហើយជាប្រាកដថា ព្រះចេស្ដានៃព្រះច្បាស់ជាមាននៅក្នុងខ្លួនវា សូម្បីតែការបញ្ជារបស់វា កូនត្រូវធ្វើតាមដែរ ។ ប៉ុន្តែមើលចុះ គឺមិនមែនវាទេ តែជាព្រះវិញ្ញាណនៃព្រះអម្ចាស់ដែលនៅក្នុងខ្លួនវាទេតើ ដែលបើកមាត់វាឲ្យចេញសំដី ដែលវាមិនអាច បិទមាត់បាន ។

២៨ ហើយឥឡូវនេះ លេមិន ឱកូនប្រុសរបស់ឪពុកអើយ! ព្រម

១៨ *ខ* ស.ប. អារក្ស.
១៩ *ក* ស.ប. ជំរើស (គ. ឬ ន.).
*ខ* ហូសេ ១៤:៩.
២០ *ក* យ៉ារ៉ុម ១:៩;
ម៉ូសាយ ១:៦–៧;
អាលម៉ា ៩:១៣–១៤.
*ខ* លេវី. ២៦:៣–១៤;
យ៉ូអែល ២:២៣–២៦.
*គ* ទំនុក. ៦៧:៦;
ម៉ូសាយ ២:២១–២៥.
២១ *ក* ១ សាំយូ. ៤:៩; ១ពង្សាវ. ២:២.
*ខ* ម៉ូសេ ៧:១៨.
២២ *ក* គ. និង ស. ៣:៤.
២៣ *ក* អេភេ. ៦:១១–១៧.
២៤ *ក* ១ នីហ្វៃ ១៦:៣២.
*ខ* ១ នីហ្វៃ ១៦:៣៧.
២៥ *ក* លោកុ. ៣៧:៩–១១.
២៦ *ក* សុភា. ១៥:១០;
១ នីហ្វៃ ១៦:២;
ម៉ូរ៉ូណៃ ៩:៤;
គ. និង ស. ១២១:៤១–៤៣.
២៧ *ក* ១ នីហ្វៃ ១៧:៤៨.
*ខ* គ. និង ស. ១២១:៤៣.
*គ* គ. និង ស. ៣៣:៨.

ទាំងលេមយ្អួល និងសាំ ហើយនឹងកូនទាំងឡាយ ដែលជាកូនរបស់ អ៊ីសម៉ាអែលអើយ មើលចុះ បើសិនជាកូនរាល់គ្នាប្រុងស្ដាប់តាមសម្លេងរបស់នីហ្វៃ កូនរាល់គ្នានឹងមិនត្រូវវិនាសឡើយ ។ ហើយបើ សិនជាកូនរាល់គ្នាប្រុងស្ដាប់តាមវា នោះឪពុកនឹងប្រទានពរដល់កូន មែនហើយ គឺជាពរមុនដំបូងរបស់ឪពុក ។

២៩ ប៉ុន្តែបើសិនជាកូនរាល់គ្នាពុំស្ដាប់តាមវាទេ នោះឪពុកនឹងដកយកពរមុនដំបូងរបស់ឪពុកវិញ មែនហើយ គឺជាពរដំបូងរបស់ ឪពុក ហើយពរនោះនឹងបានស្ថិតទៅលើវា ។

៣០ ហើយឥឡូវនេះ សូរ៉ាំ យើងសូមនិយាយទៅកាន់អ្នកថា៖ មើលចុះ អ្នកគឺជាអ្នកបំរើរបស់ឡាបាន់; ទោះជាយ៉ាងណាក៏ដោយ គង់តែអ្នកត្រូវបាននាំចេញពីដែនដីយេរូសាឡិមដែរ ហើយយើងដឹងថា អ្នកគឺជាមិត្តដ៏ពិតដល់កូនយើង គឺនីហ្វៃ ជារៀងរហូតតទៅ ។

៣១ ហេតុដូច្នោះហើយ ដោយមកពីអ្នកមានចិត្តស្មោះត្រង់ នោះពូជអ្នកនឹងបានពរ ជាមួយនឹងពូជវា គឺពួកគេនឹងរស់នៅដ៏ចំរុង ចំរើនដ៏យូរលង់នៅលើដែនដីនេះ; ហើយគ្មានអ្វីក្រៅពីសេចក្ដីទុច្ចរិតរបស់ពួកគេ ដែលនឹងធ្វើឲ្យខូចខាត ឬរំខានដល់សេចក្ដីចំរុងចំរើន របស់ពួកគេ នៅលើដែនដីនេះ ជារៀងរហូតតទៅ ។

៣២ ហេតុដូច្នោះហើយ បើសិនជាអ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះព្រះអម្ចាស់ទ្រង់នឹងញែកដែនដីនេះទុកជាទីសន្តិសុខដល់ពូជអ្នក ជាមួយនឹងពូជកូនរបស់យើង ៕

## ជំពូកទី ២

*សេចក្ដីប្រោសលោះនឹងបានមកតាមរយៈព្រះមែស៊ីដ៏បរិសុទ្ធ — សេរីភាពខាងការជ្រើសរើស (សិទ្ធិជ្រើសរើស) មានសារៈសំខាន់ជា ចាំបាច់ដល់វត្តមាន និងការលូតលាស់ — លោកអ័ដាមធ្លាក់ដើម្បីឲ្យមានមនុស្សលោក — មនុស្សលោកមានសេរីដើម្បីរើសយក ឥស្សរភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយឥឡូវនេះ យ៉ាកុប ឪពុកនិយាយទៅកូនថា៖ កូនគឺជាកូនច្បងរបស់ឪពុក ដែលបានកើតនៅក្នុងថ្ងៃនៃសេចក្ដីវេទនារបស់ឪពុក នៅក្នុងទីរហោស្ថាន ។ ហើយមើលចុះ កាលពីវ័យក្មេង កូនបានរងទុក្ខវេទនា និងការសោកសៅដ៏ច្រើន ដោយព្រោះការទ្រគោះ របស់បងៗកូន ។

២ ទោះជាយ៉ាងនេះក៏ដោយ យ៉ាកុប ឱកូនច្បងរបស់ឪពុក ដែលបានកើតនៅក្នុងទីរហោស្ថានអើយ កូនបានស្គាល់ភាពខ្លាំងក្លា របស់ព្រះ; ហើយទ្រង់នឹងធ្វើឲ្យសេចក្ដីវេទនាទាំងឡាយរបស់កូន ក្លាយទៅជាផលប្រយោជន៍ដល់កូនវិញ ។

៣ ហេតុដូច្នោះហើយ ព្រលឹងកូននឹងបានពរ ហើយកូននឹងរស់នៅដោយសុខសាន្តជាមួយនឹងបងរបស់កូន គឺនីហ្វៃ; ហើយជីវិត របស់កូន នោះនឹងត្រូវបានចំណាយក្នុងការបំរើព្រះរបស់កូន ។ ហេតុដូច្នោះហើយ ឪពុកដឹងថា កូនត្រូវបានប្រោសលោះឲ្យរួច ពីព្រោះតែសេចក្ដីសុចរិត នៃព្រះដ៏ប្រោសលោះរបស់កូន; ត្បិតកូនបានឃើញថា ដល់កាលដ៏ពេញកំណត់ នោះទ្រង់នឹងយាងមកប្រទាន សេចក្ដីសង្គ្រោះដល់មនុស្ស លោក ។

៤ ហើយកូនបានឃើញសិរីល្អរបស់ទ្រង់ កាលកូននៅវ័យក្មេង; ហេតុដូច្នោះហើយ កូនមានពរ ដូចជាអ្នកឯទៀត ដែលទ្រង់នឹងធ្វើ ការងារបំរើ នៅក្នុងសាច់ឈាម; ត្បិតព្រះវិញ្ញាណនៅតែដដែល ទោះពីថ្ងៃម្សិល ថ្ងៃនេះ និងរហូតតទៅ ។ ហើយផ្លូវត្រូវបានរៀបចំ ជាស្រេចចាប់តាំងពីការធ្លាក់នៃមនុស្សមកម្ល៉េះ ឯសេចក្ដីសង្គ្រោះនឹងបានដោយឥតគិតថ្លៃ ។

៥ ហើយមនុស្សលោកបានប្រៀនប្រដៅគ្រប់គ្រាន់ ឲ្យដឹងខុស និងត្រូវ ។ ហើយក្រិត្យវិន័យត្រូវបានប្រទានដល់មនុស្ស ហើយតាមក្រិត្យវិន័យ នោះគ្មានសាច់ឈាមណាបានរាប់ជាសុចរិតឡើយ; ឬក៏តាមក្រិត្យវិន័យ នោះមនុស្សលោកត្រូវបានកាត់ចេញ ។ មែនហើយ តាមក្រិត្យវិន័យខាងសាច់ឈាម នោះពួកគេត្រូវបានកាត់ចេញ; ហើយតាមក្រិត្យវិន័យខាងវិញ្ញាណវិញ នោះពួកគេវិនាសពីអ្វីដែលល្អ ហើយក្លាយទៅជាវេទនា ជារៀងរហូតតទៅ ។

២៨ *ក* ស.ប. សិទ្ធិកូនច្បង.
២៩ *ក* អ័ប្រា. ១:៣.
៣០ *ក* ១ នីហ្វៃ ៤:២០, ៣៥.
៣១ *ក* ២ នីហ្វៃ ៥:៦.
**២** ១ *ក* ១ នីហ្វៃ ១៨:៧.
៤ *ក* ២ នីហ្វៃ ១១:៣; យ៉ាកុប ៧:៥.
*ខ* ស.ប. ព្រះគុណ.
៥ *ក* មរ៉ូណៃ ៧:១៦.
*ខ* រ៉ូម ៣:២០; ២ នីហ្វៃ ២៥:២៣; អាលម៉ា ៤២:១២–១៦. ស.ប. ការរាប់ជាសុចរិត, រាប់ជាសុចរិត.
*គ* ១ នីហ្វៃ ១០:៦; ២ នីហ្វៃ ៩:៦–៣៨; អាលម៉ា ១១:៤០–៤៥; ១២:១៦, ២៤; ៤២:៦–១១; ហេលេ. ១៤:១៥–១៨.

៦ ហេតុដូច្នោះហើយ [ក]សេចក្ដីប្រោសលោះនឹងមកដោយ និងតាមរយៈ[ខ]ព្រះមែស៊ីដ៏បរិសុទ្ធ; ត្បិតទ្រង់ពោរពេញទៅដោយ[គ]ព្រះគុណ និងសេចក្ដីពិត ។

៧ មើលចុះ ទ្រង់ថ្វាយរូបអង្គទ្រង់ជា[ក]យញ្ញបូជា ជំនួសអំពើបាប ដើម្បីតបស្នងការចុងបំផុតនៃក្រិត្យវិន័យ ដល់អស់អ្នកណាដែលមាន ចិត្តសង្រេង និងវិញ្ញាណទន់ទាប; ហើយគ្មានអ្នកណាទៀតសោះ ដែលអាចតបស្នង[ខ]ការចុងបំផុតនៃក្រិត្យវិន័យបាន។

៨ ហេតុដូច្នោះហើយ គឺជាការសំខាន់បំផុត ដើម្បីធ្វើឲ្យការណ៍ទាំងនេះបានដឹងដល់បណ្ដាជននៅលើផែនដី ដើម្បីឲ្យពួកគេអាច ដឹងថា គ្មានសាច់ឈាមណាអាចរស់នៅក្នុងវត្តមាននៃព្រះបានឡើយ [ក]លើកលែងតែដោយបុណ្យគុណ និងសេចក្ដីមេត្តាករុណា និងព្រះគុណនៃព្រះមែស៊ីដ៏បរិសុទ្ធ ទ្រង់បានប្ដូរជីវិតរបស់ទ្រង់ ស្របតាមសាច់ឈាម ហើយយកមកវិញ ដោយព្រះចេស្ដានៃព្រះវិញ្ញាណ ដើម្បីទ្រង់ អាចបណ្ដាលឲ្យមាន[ខ]ដំណើររស់ឡើងវិញដល់មនុស្សស្លាប់ ដោយទ្រង់ជាអ្នកទីមួយដែលត្រូវបានប្រោសរស់ឡើងវិញ ។

៩ ហេតុដូច្នោះហើយ ទ្រង់គឺជាផលដំបូងថ្វាយព្រះ ដរាបដល់ទ្រង់នឹង[ក]អង្វរជំនួសកូនចៅមនុស្សទាំងអស់; ហើយអ្នកណាដែលជឿ ដល់ទ្រង់ នោះនឹងបានសង្គ្រោះ ។

១០ ហើយដោយមកពីការអង្វរជំនួសមនុស្ស[ក]ទាំងអស់ ទើបមនុស្សលោកទាំងអស់មករកព្រះ; ហេតុដូច្នោះហើយ ពួកគេឈរនៅ វត្តមានទ្រង់ ដើម្បីឲ្យទ្រង់[ខ]ជំនុំជំរះ ស្របតាម[គ]សេចក្ដីពិត និងសេចក្ដីបរិសុទ្ធ ដែលនៅក្នុងទ្រង់ ។ ហេតុដូច្នោះហើយ ការចុងបំផុតនៃ ក្រិត្យវិន័យ ដែលព្រះដ៏បរិសុទ្ធទ្រង់បានប្រទានមក ចំពោះការធ្វើទុក្ខទោសដល់ទោសដែលភ្ជាប់ទៅនឹងក្រិត្យវិន័យ រីឯទោសដែល ភ្ជាប់ទៅនឹងក្រិត្យវិន័យនេះ ជាការផ្ទុយទៅនឹងសុភមង្គល ដែលភ្ជាប់ទៅនឹងក្រិត្យវិន័យទាំងអស់នេះ ដើម្បីតបស្នងការចុងបំផុតនៃ [ឃ]ដង្វាយធួន——

១១ ត្បិតជាការចាំបាច់ ត្រូវតែមាន[ក]ការផ្ទុយចំពោះរឿងសព្វសារពើ ។ បើពុំនោះសោតទេ ឱកូនច្បងរបស់ឪពុកដែលកើតនៅក្នុង ទីរហោស្ថានអើយ សេចក្ដីសុចរិតពុំអាចកើតឡើងបានទេ ឯសេចក្ដីទុច្ចរិតក៏ដូច្នោះដែរ ទាំងសេចក្ដីបរិសុទ្ធ និងសេចក្ដីទុក្ខវេទនា ទាំងសេចក្ដីល្អ ឬក៏សេចក្ដីអាក្រក់ក៏គ្មានដែរ; ហេតុដូច្នោះហើយ គ្រប់អ្វីៗទាំងអស់ ត្រូវតែប្រមូលគ្នាជាដុំមួយ; ហេតុដូច្នោះហើយ ប្រសិនបើអ្វីៗជារូបកាយតែមួយ នោះនៅដូចជាស្លាប់ ដោយពុំមានទាំងជីវិតឬក៏សេចក្ដីស្លាប់ដែរ គ្មានការពុករលួយ ឬការពុំពុក រលួយ គ្មានសុភមង្គល ឬសេចក្ដីវេទនា គ្មានការចាប់អារម្មណ៍ ឬពុំចាប់អារម្មណ៍ឡើយ ។

១២ ហេតុដូច្នោះហើយ ជាការណ៍ដែលត្រូវបានបង្កើតឡើងដោយឥតប្រយោជន៍; ម្ល៉ោះហើយ នឹងគ្មានប្រយោជន៍អ្វី នៅទីចុងបំផុតនៃការបង្កើតវត្ថុនោះឡើយ ។ ហេតុដូច្នោះហើយ [ក]ការណ៍នេះច្បាស់ជាត្រូវបំផ្លាញប្រាជ្ញានៃព្រះ និងគោលបំណងទាំងឡាយដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ ហើយព្រមទាំងព្រះចេស្ដា និងសេចក្ដីមេត្តាករុណា និង[ខ]សេចក្ដីយុត្តិធម៌របស់ព្រះដែរ ។

១៣ ហើយបើសិនជាកូនរាល់គ្នានឹងនិយាយថា គ្មានក្រិត្យវិន័យទេ កូនរាល់គ្នាក៏ត្រូវនិយាយថា គ្មានបាបដែរ ។ បើសិនជាកូន រាល់គ្នានឹងនិយាយថា គ្មានបាបទេ កូនរាល់គ្នាក៏ត្រូវនិយាយថា [ក]គ្មានសេចក្ដីសុចរិតដែរ ។ ហើយបើសិនជាគ្មានសេចក្ដីសុចរិតទេ នោះក៏គ្មានសុភមង្គលដែរ។ ហើយបើសិនជាគ្មានសេចក្ដីសុចរិតឬសុភមង្គលទេ នោះក៏គ្មានទោស និងសេចក្ដីទុក្ខវេទនាដែរ ។ ហើយបើសិនជាគ្មានអ្វីទាំងនេះទេ [ខ]នោះក៏គ្មានព្រះដែរ ។ ហើយបើសិនជាគ្មានព្រះទេ ក៏គ្មានពួកយើង ឬផែនដីដែរ; ត្បិតពុំអាចមាន នូវការបង្កើតអ្វីទាំងឡាយ ដែលនឹងធ្វើសកម្មភាព ឬទទួលសកម្មភាពដែរ; ហេតុដូច្នោះហើយ អ្វីៗសព្វសារពើត្រូវតែសាបសូន្យ បាត់អស់ ។

៦ ក ១ នីហ្វៃ ១០:៦; ២ នីហ្វៃ ២៥:២០; អាលម៉ា ១២:២២–២៥. ស.ប. ផែនការនៃសេចក្ដីប្រោសលោះ.
ខ ស.ប. ព្រះមែស៊ី.
គ យ៉ូហាន ១:១៤, ១៧; ម៉ូសេ ១:៦.
៧ ក ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
ខ រ៉ូម ១០:៤.
៨ ក ២ នីហ្វៃ ២៥:២០; ៣១:២១; ម៉ូសាយ ៤:៨; ៥:៨; អាលម៉ា ៣៨:៩.
ខ ១ កូរិន. ១៥:២០; អាលម៉ា ៧:១២; ១២:២៤–២៥; ៤២:២៣. ស.ប. ដំណើររស់ឡើងវិញ.
៩ ក អេសាយ ៥៣:១–១២; ម៉ូសាយ ១៤:១២; ១៥:៨–៩.
១០ ក ស.ប. ព្រះដ៏ប្រោសលោះ.
ខ ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
គ ស.ប. បរិសុទ្ធភាព.
ឃ ២ នីហ្វៃ ៩:៧, ២១–២២, ២៦; អាលម៉ា ២២:១៤; ៣៣:២២; ៣៤:៩.
១១ ក គ. និង ស. ២៩:៣៩; ១២២:៥–៩. ស.ប. សេចក្ដីទំនាស់.
១២ ក គ. និង ស. ៨៩:២៥–២៦. ស.ប. ផែនដី — បង្កើតសំរាប់មនុស្ស.
ខ ស.ប. សេចក្ដីយុត្តិធម៌.
១៣ ក ២ នីហ្វៃ ៩:២៥.
ខ អាលម៉ា ៤២:១៣.

១៤ ហើយឥឡូវនេះ ឱកូនទាំងឡាយរបស់ឪពុកអើយ ឪពុក
និយាយទៅកូនអំពីការណ៍ទាំងនេះ ដើម្បីជាប្រយោជន៍ និង
ជាតម្រិះ ដល់កូន; ត្បិតមានព្រះមួយអង្គ ហើយទ្រង់បានបង្កើត
អ្វីៗសព្វសារពើ ទាំងផ្ទៃមេឃ និងផែនដីដែរ ហើយនឹងគ្រប់ទាំង
អ្វីៗសព្វសារពើ ដែលនៅលើនោះ ដើម្បីធ្វើសកម្មភាព
និងទទួលសកម្មភាពផង ។
១៥ ហើយដើម្បីសំរេចនូវគោលបំណងទាំងឡាយរបស់
ទ្រង់ដ៏អស់កល្បជានិច្ច សំរាប់មនុស្សលោក បន្ទាប់ពីទ្រង់បាន
បង្កើត ឪពុកម្ដាយដើមរបស់យើង និងសត្វព្រៃ សត្វស្រុក និង
សត្វហើរលើអាកាស ហើយសរុបសេចក្ដីថា គ្រប់សព្វសារពើ
ដែលបានបង្កើតមក ត្រូវតែមានការផ្ទុយ; សូម្បីតែផ្លែដែល
ហាមឃាត់ ក៏ផ្ទុយទៅនឹងដើមជីវិតដែរ; មួយមានរស់ជាតិផ្អែម
ឯមួយទៀតល្វីងជូរចត់ ។
១៦ ហេតុដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ប្រទាន
ដល់មនុស្សថា គេត្រូវប្រព្រឹត្តអ្វីៗដោយខ្លួនឯង ។ ហេតុ
ដូច្នោះហើយ មនុស្សពុំអាចប្រព្រឹត្តអ្វីៗ ដោយខ្លួនឯងបានទេ
លើកលែងតែមានអ្វីមកល្បួងខាងនេះមួយ ឬខាងនោះមួយ ។
១៧ ហើយឪពុក លីហៃ ស្របតាមរឿងដែលឪពុកបានអាន
មក សន្និដ្ឋានជាចាំបាច់ថា មានទេវតាមួយនៃព្រះ ស្របតាម
ដែលបាន សរសេរទុក បានធ្លាក់មកពីលើមេឃ; ហេតុ
ដូច្នោះហើយ ទេវតានោះបានក្លាយទៅជាអារក្ស; ដោយបាន
ព្យាយាមស្វែងរកអ្វីមួយ ដែលអាក្រក់ចំពោះព្រះ ។
១៨ ហើយព្រោះទេវតានោះបានធ្លាក់មកពីលើមេឃ ហើយ
ក្លាយទៅជាមានទុក្ខវេទនា នៅអស់កល្បជានិច្ច នោះវាក៏បាន
ព្យាយាម ធ្វើឲ្យមនុស្សលោកទាំងអស់មានទុក្ខវេទនាដែរ; ហេតុ
ដូច្នោះហើយ ទើបវានិយាយទៅនាងអេវ៉ា មែនហើយ គឺជា
សត្វពស់ពីដើមនោះ ដែលជាអារក្ស ដែលជាបិតានៃសេចក្ដី
កុហក ហេតុដូច្នោះហើយ វានិយាយថា៖ ចូរទទួល
ទានផ្លែដែលហាមឃាត់ទៅ ហើយអ្នកនឹងពុំ ស្លាប់ទេ ប៉ុន្តែអ្នក
នឹងបានដូចជាព្រះ ដោយដឹងខុស និងត្រូវ ។
១៩ ហើយបន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ាបានទទួល
ទានផ្លែដែលហាមឃាត់ហើយ នោះពួកគេត្រូវបាន
ដេញចេញពីសួនច្បារ អេដែន ដើម្បីទៅភ្ជួររាស់នៅលើផែនដី ។
២០ ហើយពួកគេបង្កើតបានកូន មែនហើយ គឺគ្រួសារទាំង
ឡាយនៃអស់ទាំងផែនដី ។
២១ ហើយជីវិតរបស់កូនចៅមនុស្សត្រូវបានពន្យារវែង
ស្របតាមព្រះហឫទ័យនៃព្រះ ដើម្បីឲ្យពួកគេអាចប្រែចិត្ត កាលគេនៅ
ក្នុង សាច់ឈាមនៅឡើយ; ហេតុដូច្នោះហើយ ស្ថានភាពរបស់គេ
បានក្លាយទៅជាស្ថានភាពសាកល្បង ហើយពេលវេលារបស់
ពួកគេ ត្រូវបានពន្យារវែង ស្របតាមព្រះបញ្ញត្តិទាំងឡាយ ដែល
ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានប្រទានដល់កូនចៅមនុស្ស ។ ត្បិតទ្រង់
បាន បញ្ជាថា មនុស្សលោកទាំងអស់ត្រូវតែប្រែចិត្ត; ត្បិតទ្រង់
បានបង្ហាញដល់មនុស្សលោកទាំងអស់ថា ពួកគេវង្វេងបង់
ព្រោះតែអំពើរំលង ច្បាប់របស់ពួកឪពុកម្ដាយរបស់ពួកគេ ។
២២ ហើយឥឡូវនេះ មើលចុះ បើសិនជាលោកអ័ដាមពុំបាន
រំលងច្បាប់ទេ លោកក៏ពុំបានធ្លាក់ខ្លួនដែរ ប៉ុន្តែលោកច្បាស់ជានៅ
ក្នុង សួនច្បារអេដែននៅឡើយ ។ ហើយអ្វីៗសព្វសារពើដែលបាន
បង្កើតឡើង នឹងនៅក្នុងសណ្ឋានដើមដដែល បន្ទាប់ពីបាន
បង្កើតមក; ហើយនឹងស្ថិតនៅដូច្នោះរហូតតទៅ ហើយគ្មាន
ចុងបំផុតឡើយ ។

១៤ ក ស.ប. បង្កបង្កើត, ការបង្កបង្កើត.
ខ គ. និង ស. ៩៣:៣០.
១៥ ក អេសាយ ៤៥:១៨; អាលម៉ា ៤២:២៦; ម៉ូសេ ១:៣១, ៣៩.
ខ លោកុ. ២:១៦–១៧; ម៉ូសេ ៣:១៧.
គ លោកុ. ៣:៦; អាលម៉ា ១២:២១–២៣.
ឃ លោកុ. ២:៩; ១ នីហ្វៃ ១៥:២២, ៣៦; អាលម៉ា ៣២:៤០.
១៦ ក ២ នីហ្វៃ ១០:២៣; អាលម៉ា ១២:៣១. ស.ប. សិទ្ធិជ្រើសរើស.
ខ គ. និង ស. ២៩:៣៩–៤០.
១៧ ក ស.ប. អារក្ស.
ខ អេសាយ ១៤:១២; ២ នីហ្វៃ ៩:៨; ម៉ូសេ ៤:៣–៤; អ័ប្រា. ៣:២៧–២៨.
គ ស.ប. អារក្ស.
១៨ ក ២ នីហ្វៃ ២៨:១៩–២៣; ៣ នីហ្វៃ ១៨:១៨; គ. និង ស. ១០:២២–២៧.
ខ ស.ប. នាងអេវ៉ា.
គ ២ នីហ្វៃ ២៨:៨; ម៉ូសេ ៤:៤.
ឃ លោកុ. ៣:៥; អាលម៉ា ២៩:៥; ម៉ូរ៉ូណៃ ៧:១៥–១៩.
១៩ ក អាលម៉ា ១២:៣១. ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
ខ ស.ប. អេដែន.
២០ ក គ. និង ស. ១៣៨:៣៨–៣៩.
២១ ក អាលម៉ា ១២:២៤; ម៉ូសេ ៤:២៣–២៥.
ខ អាលម៉ា ៣៤:៣២. ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
គ ស.ប. ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់.
ឃ យ៉ាកុប ៧:១២.

២៣ ហើយពួកគេក៏ពុំមានកូនចៅដែរ; ហេតុដូច្នោះហើយ
ពួកគេនឹងនៅក្នុងភាពឆោតល្ងង់ ដោយគ្មានសេចក្ដីអំណរ ព្រោះ
ពួកគេ មិនស្គាល់សេចក្ដីទុក្ខវេទនា; ដោយមិនប្រព្រឹត្តអំពើល្អ
ត្បិតពួកគេមិនស្គាល់អំពើបាប ។
២៤ ប៉ុន្តែមើលចុះ អ្វីៗសព្វសារពើបានត្រូវធ្វើឡើង
ទៅតាមប្រាជ្ញារបស់ទ្រង់ ដែលជ្រាបគ្រប់ការណ៍ទាំងអស់ ។
២៥ លោកអ័ដាមបានធ្លាក់ខ្លួន ដើម្បីឲ្យមានមនុស្សលោក;
ហើយមានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្ដីអំណរ ។
២៦ ហើយព្រះមែស៊ីនឹងយាងមក នៅកាលដ៏ពេញកំណត់
ដើម្បីទ្រង់អាចប្រោសលោះកូនចៅមនុស្សឲ្យរួចពីការធ្លាក់ ។
ហើយពី ព្រោះពួកគេត្រូវបានប្រោសលោះឲ្យរួចពីការធ្លាក់ ទើប
ពួកគេមានឥស្សរភាពរហូតតទៅ ដោយដឹងខុស និងត្រូវ; ដើម្បីធ្វើ
សកម្មភាព ដោយខ្លួនឯង ហើយពុំមែនទទួលសកម្មភាពទេ
លើកលែងតែដោយការធ្វើទោសតាមក្រិត្យវិន័យ នៅក្នុងថ្ងៃ
ដ៏មហិមា ហើយចុង ក្រោយបង្អស់ ស្របតាមព្រះបញ្ញត្តិទាំង
ឡាយ ដែលព្រះទ្រង់បានប្រទានមក ។
២៧ ហេតុដូច្នោះហើយ មនុស្សលោកមានសេរីភាព ស្របតាម
សាច់ឈាម; ហើយអ្វីៗសព្វសារពើត្រូវបានផ្ដល់ដល់ពួកគេ ដែល
ជា ការចាំបាច់ដល់មនុស្ស ។ ហើយពួកគេមានសិទ្ធិនឹងរើសយក
ឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះជាអ្នកសង្រួប
សង្រួម ដ៏ធំរបស់មនុស្សលោកទាំងអស់ ឬក៏រើសយក
ការជាប់ឃុំឃាំង និងការស្លាប់ ស្របតាមការជាប់ឃុំឃាំង
និងអំណាចរបស់ អារក្ស; ត្បិតវាព្យាយាមធ្វើឲ្យមនុស្សលោកទាំង
អស់មានទុក្ខវេទនាដូចវាដែរ ។
២៨ ហើយឥឡូវនេះ ឱកូនទាំងឡាយរបស់ឪពុកអើយ ឪពុក
ចង់ឲ្យកូនរាល់គ្នាសម្លឹងទៅព្រះជាអ្នកសង្រួបសង្រួមដ៏ធំនោះ
ហើយប្រុងស្ដាប់តាមព្រះបញ្ញត្តិទាំងឡាយដ៏មហិមារបស់
ទ្រង់ចុះ; ហើយចូរមានចិត្តស្មោះត្រង់ចំពោះព្រះបន្ទូលទាំង
ឡាយរបស់ទ្រង់ ហើយរើសយកជីវិតដ៏នៅអស់កល្បជានិច្ច
ស្របតាមព្រះហឫទ័យ នៃព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ចុះ ។
២៩ ហើយចូរកុំរើសយកសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច
ស្របតាមចំណង់របស់សាច់ឈាម និងសេចក្ដីអាក្រក់ ដែល
នៅក្នុងនោះ ឡើយ ដែលផ្ដល់អំណាចដល់វិញ្ញាណអារក្ស
ឲ្យចាប់ឃុំឃាំង ដើម្បីនាំកូនចុះទៅស្ថាននរក ដើម្បីវា
អាចសោយរាជ្យលើកូននៅក្នុង នគរវា ។
៣០ ឪពុកបាននិយាយពាក្យបន្តិចបន្តួចទាំងនេះ ដល់កូនទាំង
អស់គ្នា ឱកូនទាំងឡាយរបស់ឪពុកអើយ គឺនៅគ្រាក្រោយបង្អស់
នៃការសាកល្បងរបស់ឪពុក; ហើយឪពុកបានរើសខាងផ្នែកល្អ
ស្របតាមពាក្យទាំងឡាយនៃព្យាការី ។ ហើយឪពុកពុំមានគិតអ្វី
ទៀតទេ ក្រៅពីសុខុមាលភាពដល់ព្រលឹងដ៏អស់កល្បជានិច្ច
របស់កូនទាំងឡាយប៉ុណ្ណោះ ។ អាម៉ែន ៕

## ជំពូកទី ៣

*យ៉ូសែបនៅស្រុកអេស៊ីព្ទបានឃើញពួកសាសន៍នីហ្វៃនៅក្នុងការនិមិត្ត — លោកបានព្យាករអំពីយ៉ូសែប ស្ម៊ីធ ជាអ្នកមើលឆុតនៃថ្ងៃចុង ក្រោយ; អំពីលោកម៉ូសេ ដែលនឹងរំដោះសាសន៍អ៊ីស្រាអែល; និងអំពីការលេចចេញមកនៃព្រះគម្ពីរមរមន ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយឥឡូវនេះ ឪពុកនិយាយទៅកូន គឺយ៉ូសែប ដែល
ជាកូនពៅរបស់ឪពុក ។ កូនបានកើតនៅក្នុងទីរហោស្ថាននៃ
សេចក្ដីទុក្ខវេទនា របស់ឪពុក មែនហើយ នៅក្នុងថ្ងៃដែលឪពុក
មានទុក្ខសោកយ៉ាងធំ ដែលម្ដាយកូនបានបង្កើតកូនមក ។
២ ហើយសូមព្រះទ្រង់ញែកដែនដីនេះទុកសំរាប់កូនផងចុះ
ដែលជាដែនដីដ៏ពិសេសបំផុត ដើម្បីទុកជាកេរ្ដិ៍អាករដល់កូន
ហើយជា កេរ្ដិ៍អាករដល់ពូជកូន ជាមួយនឹងពូជបងរបស់កូន

២៣ *ក* ម៉ូសេ ៥:១១.
២៤ *ក* ស.ប. ព្រះ, ក្រុមព្រះ.
២៥ *ក* ស.ប. អ័ដាម.
*ខ* ម៉ូសេ ៦:៤៨.
ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*គ* ស.ប. ដែលរមែងស្លាប់, ភាពដែល
រមែងស្លាប់.
*ឃ* ម៉ូសេ ៥:១០.
ស.ប. សេចក្ដីអំណរ; មនុស្ស,
មនុស្សលោក.
២៦ *ក* ស.ប. ព្រះមែស៊ី.
*ខ* ស.ប. ផែនការនៃសេចក្ដីប្រោសលោះ.
*គ* អាលម៉ា ៤២:២៧;
ហេលេ. ១៤:៣០.
*ឃ* ស.ប. ក្រិត្យវិន័យ.
២៧ *ក* កាឡាទី ៥:១;
ម៉ូសេ ៦:៥៦.
*ខ* ស.ប. សិទ្ធិជ្រើសរើស.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
២៨ *ក* ស.ប. អ្នកសង្រួបសង្រួម.
២៩ *ក* រ៉ូម ៦:១៦–១៨;
អាលម៉ា ១២:១១.
*ខ* ស.ប. ស្ថាននរក.
៣ ១ *ក* ១ នីហ្វៃ ១៨:៧.
២ *ក* ១ នីហ្វៃ ២:២០.
ស.ប. ដែនដីសន្យា.

ដើម្បីទុកជាទីសន្តិសុខជរាបតទៅ ប្រសិនបើកូនរាល់គ្នានឹងកាន់តាមព្រះបញ្ញត្តិទាំង ឡាយ នៃព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ។

៣ ហើយឥឡូវនេះ យ៉ូសែប កូនពៅរបស់ឪពុក ដែលឪពុកបាននាំកូនចេញពីទីរហោស្ថាន នៃសេចក្ដីទុក្ខវេទនារបស់ឪពុកអើយ សូមឲ្យព្រះអម្ចាស់ទ្រង់ប្រទានពរដល់កូនជរាបតទៅ ត្បិតពូជកូននឹងមិនត្រូវបំផ្លាញសូន្យបង់ឡើយ ។

៤ ត្បិតមើលចុះ កូនជាផលនៃពោះឪពុក; ហើយឪពុកគឺជាពូជពង្សនៃយ៉ូសែប ដែលត្រូវចាប់ជាឈ្លើយ ទៅស្រុកអេស៊ីព្ទ ។ ហើយ សេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ ដែលទ្រង់បានធ្វើដល់យ៉ូសែប នោះធំណាស់ហ្ន៎ ។

៥ ហេតុដូច្នោះហើយ យ៉ូសែបបានមើលឃើញជំនាន់យើងយ៉ាងពិតប្រាកដ ។ ហើយលោកបានទទួលសេចក្ដីសន្យាពីព្រះអម្ចាស់ថា ចេញពីផលនៃពោះលោក នោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងបង្កើតមែកមួយដ៏សុចរិត ដល់វង្សអ៊ីស្រាអែល; ពុំមែនជាព្រះមែស៊ីទេ ប៉ុន្តែជាមែកដែលនឹងត្រូវបានកាត់ចេញទោះជាយ៉ាងណាក៏ដោយ គង់តែនឹងត្រូវបាននឹកចាំនៅក្នុងសេចក្ដីសញ្ញាទាំងឡាយនៃ ព្រះអម្ចាស់ថា ព្រះមែស៊ីទ្រង់នឹងសម្ដែងរូបអង្គទ្រង់ដល់ពួកគេ នៅគ្រាចុងក្រោយ ដោយវិញ្ញាណនៃព្រះចេស្ដា ដើម្បីនាំពួកគេចេញ ពីទីងងឹតទៅឯពន្លឺ– មែនហើយ គឺចេញពីទីកំបាំងងងឹត ហើយចេញពីការជាប់ឃុំឃាំងទៅឯសេរីភាព ។

៦ ត្បិតយ៉ូសែបបានធ្វើបន្ទាល់ជាពិតប្រាកដថា៖ មានអ្នកមើលឆុតម្នាក់ដែលព្រះអម្ចាស់ដ៏ជាព្រះរបស់ខ្ញុំទ្រង់នឹងបង្កើតឡើង ដែលនឹងទៅជាអ្នកមើលឆុតដ៏ជំរើស ចំពោះផលនៃពោះរបស់ខ្ញុំ ។

៧ មែនហើយ យ៉ូសែបបាននិយាយជាពិតប្រាកដថា៖ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំដូច្នេះថា៖ មានអ្នកមើលឆុតម្នាក់ដ៏ជំរើស ដែលយើងនឹងបង្កើតឡើងពីផលនៃពោះអ្នក; ហើយអ្នកនោះនឹងបានដំកើងខ្ពស់ នៅក្នុងចំណោមផលនៃពោះអ្នក ។ ហើយចំពោះ អ្នកនោះ នោះយើងនឹងបញ្ជាថា គាត់ត្រូវធ្វើកិច្ចការមួយដើម្បីផលនៃពោះអ្នក ជាបងប្អូនរបស់គាត់ ដែលនឹងទៅជាប្រយោជន៍ដ៏ធំ ដល់ពួកគេ គឺដើម្បីនាំឲ្យពួកគេស្គាល់នូវសេចក្ដីសញ្ញាទាំងឡាយ ដែលយើងបានធ្វើជាមួយនឹងពួកអយ្យកោរបស់អ្នក ។

៨ ហើយយើងនឹងប្រទានដល់គាត់នូវបញ្ញត្តិមួយថា គាត់មិនត្រូវធ្វើកិច្ចការអ្វីផ្សេងទៀត ក្រៅអំពីការណ៍ដែលយើងនឹងបញ្ជាដល់ គាត់ប៉ុណ្ណោះ ។ ហើយយើងនឹងធ្វើឲ្យគាត់ទៅជាធំនៅចំពោះភ្នែកយើង; ត្បិតគាត់នឹងធ្វើកិច្ចការរបស់យើង ។

៩ ហើយគាត់នឹងបានជាធំដូចម៉ូសេ ជាអ្នកដែលយើងបានប្រាប់ថា យើងនឹងបង្កើតឡើងដល់អ្នក ដើម្បីដោះលែងរាស្ត្រយើង ឱវង្សអ៊ីស្រាអែលអើយ ។

១០ ហើយម៉ូសេ យើងនឹងបង្កើតឡើង ដើម្បីដោះលែងប្រជាជនរបស់អ្នកចេញពីស្រុកអេស៊ីព្ទ ។

១១ ប៉ុន្តែមានអ្នកមើលឆុតម្នាក់ ដែលយើងនឹងបង្កើតឡើងពីផលនៃពោះអ្នក; ហើយចំពោះអ្នកនោះ នោះយើងនឹងប្រទានអំណាចឲ្យនាំពាក្យរបស់យើង ដល់ពូជនៃពោះអ្នក — ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ប៉ុន្តែមិនគ្រាន់តែចំពោះការនាំពាក្យយើង ប៉ុណ្ណោះទេ តែចំពោះការបរិវត្តន៍ពួកគេអំពីពាក្យយើងផង ដែលនឹងត្រូវបានផ្សាយជាមុនក្នុងចំណោមពួកគេ ។

១២ ហេតុដូច្នោះហើយ ផលនៃពោះអ្នកនឹងសរសេរទុក; ហើយផលនៃពោះយូដានឹងសរសេរទុក; ហើយអ្វីដែលនឹងបានសរសេរទុក ដោយផលនៃពោះអ្នក ហើយព្រមទាំងអ្វីដែលនឹងបានសរសេរទុក ដោយផលនៃពោះយូដា នោះនឹងត្រូវបានរួមទៅជាមួយគ្នា ចំពោះ ការផ្ចាញ់ផ្ចាលនូវគោលលទ្ធិក្លែងក្លាយទាំងឡាយ ហើយបង្ក្រាបការទាស់ទែងគ្នាទាំងប៉ុន្មាន ហើយបង្កើតឲ្យមានសេចក្ដីសុខសាន្ត នៅ ក្នុងចំណោមផល

៣ *ក* ២ នីហ្វៃ ៩:៥៣.
៤ *ក* លោកុ. ៣៩:១–២; ៤៥:៤; ៤៩:២២–២៦; ១ នីហ្វៃ ៥:១៤–១៦.
*ខ* លោកុ. ៣៧:២៩–៣៦.
៥ *ក* ក.យ.ស. លោកុ. ៥០:២៤–៣៨; ២ នីហ្វៃ ៤:១–២.
*ខ* យ៉ាកុប ២:២៥.
*គ* លោកុ. ៤៩:២២–២៦; ១ នីហ្វៃ ១៥:១២; ១៩:២៤. ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*ឃ* ២ នីហ្វៃ ៦:១៤; គ. និង ស. ៣:១៦–២០.
*ង* អេសាយ ៤២:១៦.
៦ *ក* ៣ នីហ្វៃ ២១:៨–១១; មរមន ៨:១៦. ស.ប. អ្នកមើលឆុត.
*ខ* គ. និង ស. ១៣២:៣០.
៧ *ក* ស.ប. ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ
៨ *ក* គ. និង ស. ២៤:៧, ៩.
៩ *ក* ម៉ូសេ ១:៤១.
*ខ* និក្ខ. ៣:៧–១០; ១ នីហ្វៃ ១៧:២៤.
១១ *ក* គ. និង ស. ៥:៣–៤.
១២ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ១ នីហ្វៃ ១៣:២៣–២៩.
*គ* ស.ប. ព្រះគម្ពីរប៊ីប.
*ឃ* អេសេ. ៣៧:១៥–២០; ១ នីហ្វៃ ១៣:៣៨–៤១; ២ នីហ្វៃ ២៩:៨; ៣៣:១០–១១.

នៃពោះអ្នក ហើយនាំ[ង]ឲ្យពួកគេស្គាល់[ច]នូវពួកអយ្យកោរបស់គេ នៅ
ថ្ងៃចុងក្រោយ ហើយព្រមទាំងឲ្យស្គាល់នូវសេចក្ដី សញ្ញាទាំង
ឡាយរបស់យើងផង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៣ ហើយចេញពីភាពទន់ខ្សោយ អ្នកនោះនឹងត្រូវបានធ្វើឲ្យ
មាំមួន នៅថ្ងៃនោះ កាលកិច្ចការរបស់យើងនឹងចាប់ផ្ដើមនៅក្នុង
ចំណោមរាស្ត្ររបស់យើងទាំងអស់ ដើម្បីសាងអ្នកឡើងវិញ
ឱវង្សអ៊ីស្រាអែលអើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៤ ហើយយ៉ូសែបបានព្យាករដូច្នេះថា៖ មើលចុះ អ្នក
មើលឆុតនោះហើយដែលព្រះអម្ចាស់ទ្រង់នឹងប្រទានពរឲ្យ; ហើយ
អ្នកណា ដែលស្វែងរកបំផ្លាញលោក នោះនឹងត្រូវបំផ្លាញចោល;
ព្រោះដោយសារសេចក្ដីសន្យានេះ ដែលជាសេចក្ដីសន្យា
ដែលខ្ញុំបានទទួលពី ព្រះអម្ចាស់ អំពីផលនៃពោះខ្ញុំ នោះនឹងត្រូវ
បានបំពេញ ។ មើលចុះ ខ្ញុំដឹងយ៉ាងច្បាស់ នូវការបំពេញនៃ
សេចក្ដីសន្យានេះ;
១៥ ហើយឈ្មោះលោកនឹងត្រូវបានហៅតាម[ក]ឈ្មោះខ្ញុំ; ហើយ
[ខ]ឈ្មោះនោះដាក់តាមឈ្មោះឪពុកលោក ។ ហើយលោកនឹង
បាន ដូចជាខ្ញុំដែរ; ត្បិតការណ៍ដែលព្រះអម្ចាស់ ទ្រង់
នឹងធ្វើឡើងដោយស្នាដៃលោក ដោយព្រះចេស្ដានៃព្រះអម្ចាស់
នោះនឹងនាំប្រជាជន ខ្ញុំទៅកាន់សេចក្ដីសង្គ្រោះ ។
១៦ មែនហើយ យ៉ូសែបបានព្យាករដូច្នេះថា៖ ខ្ញុំដឹងយ៉ាងច្បាស់
នូវការណ៍នេះ ដូចជាខ្ញុំដឹងយ៉ាងច្បាស់នូវសេចក្ដីសន្យារបស់
លោកម៉ូសេ; ត្បិតព្រះអម្ចាស់ទ្រង់បានប្រាប់ខ្ញុំថា៖ យើងនឹង
[ក]ថែរក្សាពូជអ្នកទុករហូត ។
១៧ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ យើងនឹង
បង្កើតម៉ូសេម្នាក់; ហើយយើងនឹងប្រទានដល់អ្នកនោះនូវអំណាច
ក្នុងរំពាត់; ហើយយើងនឹងប្រទានសេចក្ដីជំនុំជំរះដល់គាត់ ក្នុង
ការសរសេរ ។ ក៏ប៉ុន្តែយើងមិនស្រាយអណ្ដាតគាត់ ដើម្បីឲ្យ
គាត់និយាយច្រើនទេ ត្បិតយើងមិនធ្វើឲ្យគាត់ខ្លាំងពូកែក្នុងការ
និយាយឡើយ ។ ប៉ុន្តែយើងនឹង[ក]សរសេរក្រិត្យវិន័យរបស់យើងដល់[ខ]
គាត់ ដោយម្រាមដៃយើង ផ្ទាល់; ហើយយើងនឹងបង្កើតអ្នក
និយាយជំនួសម្នាក់ដល់គាត់ ។
១៨ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំដែរថា៖ យើងនឹង
បង្កើតឡើងដល់ផលនៃពោះអ្នក; ហើយយើងបង្កើតអ្នកនិយាយ
ជំនួសម្នាក់ដល់គាត់ ។ ហើយយើង មើលចុះ យើងនឹងប្រទាន
ដល់គាត់ ដើម្បីឲ្យគាត់សរសេរពាក្យរបស់ផលនៃពោះអ្នក
សំរាប់ផលនៃ ពោះអ្នក; ហើយអ្នកនិយាយពីពោះអ្នក នឹង
ប្រកាសរឿងនោះ ។
១៩ ហើយពាក្យទាំងឡាយដែលអ្នកនោះនឹងសរសេរ គឺជា
ពាក្យទាំងឡាយដែលជាការចាំបាច់ នៅក្នុងប្រាជ្ញារបស់យើង
ដែលត្រូវ ផ្សាយ[ក]ដល់ផលនៃពោះអ្នក ។ ហើយការណ៍នេះ
ហាក់ដូចជាផលនៃពោះអ្នកបានស្រែកប្រកាសដល់ពួកគេ
[ខ]ចេញពីធូលីដី; ត្បិតយើង ស្គាល់សេចក្ដីជំនឿរបស់ពួកគេ ។
២០ ហើយពួកគេនឹង[ក]ស្រែកប្រកាសចេញពីធូលីដី; មែនហើយ
គឺពីការប្រកាសឲ្យប្រែចិត្តដល់បងប្អូនរបស់ពួកគេ គឺបន្ទាប់ពីតំណ
ជាច្រើនបានកន្លងផុតពួកគេទៅ ។ ហើយហេតុការណ៍នឹង
បានកើតឡើងថា សំរែករបស់គេនឹងប្រកាសចេញទៅ គឺស្របតាម
ពាក្យ សាមញ្ញរបស់គេ ។
២១ ពីព្រោះមកពីសេចក្ដីជំនឿរបស់ពួកគេ នោះពាក្យ[ក]ទាំង
ឡាយរបស់ពួកគេនឹងបានផ្សាយចេញពីមាត់របស់យើង ទៅដល់
បងប្អូន គេ ដែលជាផលនៃពោះអ្នក; ហើយឯភាពទន់ខ្សោយ
នៃពាក្យទាំងឡាយរបស់ពួកគេ នោះយើងនឹងឲ្យសេចក្ដីជំនឿ
របស់ពួកគេខ្លាំង ឡើង ដើម្បីឲ្យពួកគេនឹកចាំដល់សេចក្ដី
សញ្ញារបស់យើង ដែលយើងបានធ្វើជាមួយនឹងពួកអយ្យកោ
របស់ពួកគេ ។
២២ ហើយឥឡូវនេះ មើលចុះ ឱយ៉ូសែប កូនប្រុសរបស់
ឪពុកអើយ តាមពាក្យបែបនេះហើយដែលឪពុកដើមរបស់
[ក]ឪពុកបានព្យាករ ។
២៣ ហេតុដូច្នោះហើយ ដោយសារសេចក្ដីសញ្ញានេះ នោះកូន
មានពរហើយ; ត្បិតពូជកូននឹងមិនត្រូវបានបំផ្លាញចោលឡើយ
ពីព្រោះគេនឹងប្រុងស្ដាប់តាមពាក្យទាំងឡាយនៅក្នុងគម្ពីរ ។
២៤ ហើយនឹងមានអ្នកខ្លាំងពូកែម្នាក់កើតឡើងនៅក្នុងចំណោម
ពួកគេ ដែលនឹងធ្វើអំពើល្អជាច្រើន ទាំងពាក្យសំដី និងកិច្ចការ
ដែល ជាគ្រឿងឧបករណ៍មួយ នៅក្នុងព្រះហស្តនៃព្រះ ដោយ
មានសេចក្ដីជំនឿយ៉ាងខ្លាំង ដើម្បីធ្វើកិច្ចការដ៏អស្ចារ្យ ហើយ

១២ ង ម៉ូរ៉ូណៃ ១:៤.
ច ១ នីហ្វៃ ១៥:១៤;
២ នីហ្វៃ ៣០:៥;
មរមន ៧:១, ៥, ៩–១០.
១៥ ក គ. និង ស. ១៨:៨.
ខ យ.ស.—ប្រវត្តិ ១:៣.
១៦ ក លោកុ. ៤៥:១–៨.
១៧ ក ចោទិ. ១០:២, ៤; ម៉ូសេ ២:១.
ខ និក្ខ. ៤:១៦.
១៩ ក គ. និង ស. ២៨:៨.
ខ អេសាយ ២៩:៤;
២ នីហ្វៃ ២៧:១៣; ៣៣:១៣;
មរមន ៩:៣០; ម៉ូរ៉ូណៃ ១០:២៧.
២០ ក ២ នីហ្វៃ ២៦:១៦;
មរមន ៨:២៣.
២១ ក ២ នីហ្វៃ ២៩:២.
២២ ក ២ នីហ្វៃ ៣:៥.

ប្រព្រឹត្តនូវអ្វីដែល ធំនៅចំពោះព្រះនេត្រនៃព្រះ ដើម្បីសំរេចនូវ
ការកសាងឡើងវិញជាច្រើន ដល់វង្សអ៊ីស្រាអែល និងដល់ពូជ
បងប្អូនរបស់កូន ។
២៥ ហើយឥឡូវនេះ ឱយ៉ូសែបអើយ កូនមានពរហើយ ។
មើលចុះ កូននៅតូចនៅឡើយ; ហេតុដូច្នោះហើយ ចូរប្រុង
ស្តាប់តាម ពាក្យសំដីរបស់បងកូន គឺនីហ្វៃ ហើយការណ៍
ទាំងនោះ នឹងកើតឡើងដល់កូន គឺស្របតាមពាក្យទាំងឡាយដែល
ឪពុកបាននិយាយ ។ ចូរនឹកចាំពាក្យរបស់ឪពុកដ៏ជិតស្លាប់នេះចុះ ។
អាម៉ែន ៕

## ជំពូកទី ៤

*លីហៃទូន្មាន ហើយឲ្យពរដល់កូនចៅរបស់លោក — លោកស្លាប់ ហើយបានបញ្ចុះ — នីហ្វៃសរសើរដំកើងចំពោះសេចក្ដីល្អសប្បុរស នៃព្រះ ដែលប្រទានដល់លោក — នីហ្វៃទុកចិត្តលើព្រះអម្ចាស់ដរាបតទៅ ។ ប្រមាណជាឆ្នាំ ៥៨៨–៥៧០ ម.គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ និយាយពីពាក្យព្យាករណ៍ទាំងឡាយ
ដែលឪពុកខ្ញុំបាននិយាយអំពី[ក]យ៉ូសែប ដែលត្រូវចាប់យក
ទៅស្រុក អេស៊ីព្ទ ។
២ គ្បិតមើលចុះ លោកបានព្យាករយ៉ាងពិតប្រាកដ អំពីពូជ
របស់លោក។ ហើយ[ក]ពាក្យព្យាករណ៍ទាំងប៉ុន្មាន ដែលលោកបាន
សរសេរ នោះគ្មានអ្វីសំខាន់ជាងនេះទេ ។ ហើយលោកបាន
ព្យាករអំពីពួកយើង និងតំណរបស់យើងនៅអនាគត; ហើយ
ពាក្យ ព្យាករណ៍ទាំងនោះ ត្រូវបានសរសេរទុកនៅលើផ្ទាំងលង្ហិន។
៣ ហេតុដូច្នោះហើយ បន្ទាប់ពីឪពុកខ្ញុំបានបញ្ចប់នូវការ
និយាយអំពីពាក្យព្យាករណ៍ទាំងឡាយរបស់យ៉ូសែបហើយ
នោះលោកបាន ហៅកូនៗរបស់លេមិន គឺកូនប្រុសទាំងឡាយ
របស់គាត់ និងកូនស្រីទាំងឡាយរបស់គាត់ ហើយបាននិយាយ
ទៅពួកគេថា៖ មើលចុះ ចៅប្រុសទាំងឡាយរបស់តា
និងចៅស្រីទាំងឡាយរបស់តា ដែលជាកូនប្រុសទាំងឡាយ
និងកូនស្រីទាំងឡាយរបស់[ក]កូនច្បងរបស់តា អើយ តាចង់ឲ្យចៅ
រាល់គ្នាផ្ទៀងត្រចៀកស្តាប់ពាក្យសំដីរបស់តា ។
៤ គ្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ [ក]ដរាបណាអ្នក
រាល់គ្នា កាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់
គ្នានឹងបាន ចំរើនឡើងនៅលើដែនដី; ហើយបើដរាបណាអ្នក
រាល់គ្នា មិនកាន់តាមបញ្ញត្តិទាំងឡាយរបស់យើងទេ នោះអ្នក
រាល់គ្នានឹងត្រូវ កាត់ចេញពីវត្តមានរបស់យើង ។
៥ ប៉ុន្តែមើលចុះ ឱចៅប្រុសទាំងឡាយរបស់តា និងចៅស្រីទាំង
ឡាយរបស់តាអើយ តាពុំអាចចុះទៅក្នុងផ្នូររបស់តា
លើកលែងតែ តាបានទុក[ក]ពរឲ្យចៅទាំងឡាយសិន; គ្បិតមើលចុះ
តាបានដឹងថា បើសិនជាចៅរាល់គ្នាត្រូវបានដឹកនាំទៅតាម
[ខ]ផ្លូវដែលចៅរាល់គ្នា ត្រូវដើរ នោះចៅរាល់គ្នានឹងមិន
បែរចេញពីផ្លូវនោះឡើយ ។
៦ ហេតុដូច្នោះហើយ បើសិនជាចៅរាល់គ្នាត្រូវបណ្ដាសា
មើលចុះ តាទុកពរឲ្យចៅ ដើម្បីឲ្យពាក្យបណ្ដាសានោះ បាន
ដកចេញ ពីចៅទាំងឡាយ ហើយធ្លាក់ទៅលើ[ក]ក្បាលទាំង
ឡាយនៃឪពុកម្ដាយរបស់ចៅវិញ ។
៧ ហេតុដូច្នោះហើយ ពីព្រោះមកពីពររបស់តា នោះព្រះ
អម្ចាស់ទ្រង់នឹង[ក]មិនអនុញ្ញាតឲ្យចៅរាល់គ្នា ត្រូវវិនាសឡើយ;
ហេតុដូច្នោះ ហើយ [ខ]ទ្រង់នឹងមានសេចក្ដីមេត្តាករុណាដល់ចៅ
និងដល់ពូជពង្សរបស់ចៅរហូតតទៅ ។
៨ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឪពុកខ្ញុំបាន
បញ្ចប់នូវការនិយាយទៅកូនប្រុសទាំងឡាយ និងកូនស្រីទាំង
ឡាយ របស់លេមិនហើយ នោះលោកក៏ឲ្យនាំកូនប្រុសទាំង
ឡាយ និងកូនស្រីទាំងឡាយរបស់លេមយ្មួល មក
ចំពោះលោក ។
៩ ហើយលោកបាននិយាយទៅពួកគេថា៖ មើលចុះ
ឱចៅប្រុសទាំងឡាយរបស់តា និងចៅស្រីទាំងឡាយរបស់តា
ដែលជាកូនប្រុស ទាំងឡាយ និងកូនស្រីទាំងឡាយ
របស់កូនប្រុសទីពីររបស់តាអើយ; មើលចុះ តាទុកពរឲ្យចៅ
ដូចគ្នាដែលតាបានទុកឲ្យកូនប្រុសទាំង ឡាយ និងកូនស្រីទាំង
ឡាយរបស់លេមិនដែរ; ហេតុដូច្នោះហើយ ចៅនឹងមិនត្រូវ
បានបំផ្លាញសូន្យបង់ឡើយ; ប៉ុន្តែនៅទីបញ្ចប់ ពូជ របស់ចៅនឹង
បានពរវិញ ។
១០ ហើយហេតុការណ៍បានកើតឡើងថា កាលឪពុកខ្ញុំបាន

៤ ១*ក* លោកុ. ៣៩:១–២.
២ *ក* ២ នីហ្វៃ ៣:៥.
៣ *ក* ស.ប. កូនច្បង.
៤ *ក* ២ នីហ្វៃ ១:៩.
៥ *ក* ស.ប. ពរនៃអយ្យកោ.
*ខ* សុភា. ២២:៦.
៦ *ក* គ. និង ស. ៦៨:២៥–២៩.
៧ *ក* ២ នីហ្វៃ ៣០:៣–៦;
គ. និង ស. ៣:១៧–១៨.
*ខ* ១ នីហ្វៃ ១៣:៣១;
២ នីហ្វៃ ១០:១៨–១៩;
យ៉ាកុប ៣:៥–៩;
ហេលេ. ១៥:១២–១៣.

បញ្ចប់នូវការនិយាយទៅពួកគេហើយ មើលចុះ លោកក៏បាន
និយាយទៅ កូនប្រុសទាំងឡាយរបស់អ៊ីសម៉ាអែល មែន
ហើយ គឺអស់ទាំងគ្រួសាររបស់ពួកគេផង ។
១១ ហើយបន្ទាប់ពីលោកបានបញ្ចប់នូវការនិយាយទៅពួក
គេហើយ លោកបាននិយាយទៅសាំថា៖ កូនមានពរហើយ
ព្រមទាំង ពូជកូនផង; ព្រោះអីកូននឹងគ្រងដែនដីនេះទុកជាមរតកដូច
នីហ្វៃ ជាប្អូនប្រុសរបស់កូនដែរ ។ ហើយពូជកូននឹងត្រូវបាន
រាប់ជាមួយ នឹងពូជរបស់នីហ្វៃដែរ; ហើយកូននឹងបាន
ដូចជាប្អូនប្រុសកូនដែរ ឯពូជកូននឹងបានដូចជាពូជរបស់នីហ្វៃដែរ;
ហើយកូននឹងបានពរ អស់មួយជីវិតរបស់កូន ។
១២ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឪពុកខ្ញុំ
គឺលីហៃ បានផ្ដែផ្ដាំដល់គ្រួសារលោក ស្របតាមម
នោសញ្ចេតនារបស់ លោក និងតាមព្រះវិញ្ញាណនៃព្រះអម្ចាស់
ដែលមាននៅក្នុងលោកហើយ លោកចាស់ជរាណាស់ ។
ហើយហេតុការណ៍បានកើត ឡើងថា លោកក៏ស្លាប់ ហើយ
បានបញ្ចុះទៅ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា មិនយូរថ្ងៃប៉ុន្មាន
មក បន្ទាប់ពីលោកបានស្លាប់ទៅ លេមិន និងលេមយួល ហើយនឹង
កូន ប្រុសទាំងឡាយរបស់អ៊ីសម៉ាអែល ក៏ខឹងនឹងខ្ញុំ ពីព្រោះ
តែសេចក្ដីដាស់តឿនរបស់ព្រះអម្ចាស់ ។
១៤ ព្រោះខ្ញុំ នីហ្វៃ ត្រូវបានបង្ខំឲ្យនិយាយទៅពួកគេ ស្រប
តាមព្រះបន្ទូលរបស់ទ្រង់; ត្បិតខ្ញុំបាននិយាយនូវរឿងជាច្រើនទៅពួក
គេ ហើយឪពុកខ្ញុំក៏ដូច្នោះដែរ មុនពេលដែលលោកស្លាប់ទៅ;
ពាក្យជាច្រើនត្រូវបានសរសេរទុក នៅលើផ្ទាំងរបស់ខ្ញុំផ្សេងទៀត;
ឯភាគដែលច្រើនទៅដោយប្រវត្តិសាស្ត្រ នោះត្រូវបានសរ
សេរទុក នៅលើផ្ទាំងរបស់ខ្ញុំផ្សេងទៀត ។
១៥ ហើយនៅលើផ្ទាំងទាំងនេះ ខ្ញុំសរសេរអំពីរឿងទាំងឡាយនៃ
ព្រលឹងខ្ញុំ ហើយបទគម្ពីរភាគច្រើន ដែលមានឆ្លាក់នៅលើផ្ទាំង
លង្ហិន ។ ត្បិតព្រលឹងខ្ញុំត្រេកអរចំពោះបទគម្ពីរទាំងឡាយ ឯចិត្តខ្ញុំ
រំពឹងគិតពីបទគម្ពីរទាំងនោះ ហើយខ្ញុំក៏សរសេរទុក ដើម្បី
ជាការ ចេះដឹង និងជាប្រយោជន៍ដល់កូនចៅខ្ញុំ ។
១៦ មើលចុះ ព្រលឹងខ្ញុំត្រេកអរចំពោះការណ៍ទាំងឡាយនៃ
ព្រះអម្ចាស់; ឯចិត្តខ្ញុំរំពឹងគិតជារៀងរហូត អំពីការណ៍ទាំង
ឡាយ ដែលខ្ញុំបានឃើញ ហើយបានឮមក ។
១៧ តែទោះបីសេចក្ដីល្អដ៏ធំរបស់ព្រះអម្ចាស់ ដែលបាន
បង្ហាញដល់ខ្ញុំពីការណ៍ដ៏ធំ ហើយអស្ចារ្យក៏ដោយ គង់តែចិត្ត
ខ្ញុំស្រែកថា៖ ឱរូបខ្ញុំអើយវេទនាអ្វីម្ល៉េះ ! មែនហើយ ចិត្តខ្ញុំ
សោកសៅ ព្រោះតែសាច់ឈាមរបស់ខ្ញុំ; ឯព្រលឹងខ្ញុំព្រួយ
ដោយព្រោះសេចក្ដីទុច្ចរិតទាំងឡាយរបស់ខ្ញុំ ។
១៨ ខ្ញុំត្រូវបានហ៊ុំព័ទ្ធ ព្រោះតែការល្បួងទាំងឡាយ និងអំពើ
បាបទាំងឡាយដែលរំខានខ្ញុំដោយងាយ ។
១៩ ហើយពេលខ្ញុំចង់សប្បាយ ចិត្តខ្ញុំថ្ងូរទៅវិញ ព្រោះតែ
អំពើបាបទាំងឡាយរបស់ខ្ញុំ; ទោះជាយ៉ាងណាក៏ដោយ គង់
តែខ្ញុំស្គាល់អ្នក ដែលខ្ញុំទុកចិត្ត ។
២០ ព្រះរបស់ខ្ញុំ គឺជាទីផ្អែករបស់ខ្ញុំ; ទ្រង់បានដឹកនាំខ្ញុំឲ្យឆ្លង
កាត់សេចក្ដីទុក្ខវេទនាទាំងឡាយរបស់ខ្ញុំ នៅក្នុងទីរហោស្ថាន;
ហើយ ទ្រង់បានរក្សាខ្ញុំទុក នៅលើផ្ទៃទឹកនៃទីជំរៅដ៏ធំ ។
២១ ទ្រង់បានបំពេញចិត្តខ្ញុំ ដោយសេចក្ដីស្រឡាញ់របស់
ទ្រង់ គឺដល់ទៅឆេះឆាបទៅពេញសាច់ឈាមខ្ញុំ ។
២២ ទ្រង់បានធ្វើឲ្យពួកខ្មាំងសត្រូវរបស់ខ្ញុំជ្រប់មុខ រហូត
ដល់ធ្វើឲ្យពួកគេញ័ររន្ធត់នៅចំពោះមុខខ្ញុំ ។
២៣ មើលចុះ ទ្រង់បានឮសំរែកអំពាវនាវរបស់ខ្ញុំនៅពេលថ្ងៃ
ហើយទ្រង់បានប្រទានគំរិះដល់ខ្ញុំ ដោយការនិមិត្តនៅពេលយប់ ។
២៤ ហើយនៅពេលថ្ងៃ ខ្ញុំមានការក្លាហានឡើង ខាងការ
អធិស្ឋានដ៏អស់ពីចិត្តនៅចំពោះទ្រង់; មែនហើយ ខ្ញុំបានបង្ហើរ
សម្លេង ទៅស្ថានលើ; ហើយទេវតាបានចុះមក ហើយបាន
ធ្វើការងារបំរើដល់ខ្ញុំ ។
២៥ ហើយនៅលើស្លាបនៃព្រះវិញ្ញាណរបស់ទ្រង់ នោះ
រូបកាយខ្ញុំត្រូវបាននាំទៅលើភ្នំដ៏ខ្ពស់លើសលប់ ។ ហើយភ្នែកខ្ញុំ
បានឃើញ ការណ៍ដ៏អស្ចារ្យនានា មែនហើយ គឺជាការណ៍
ហួសវិស័យរបស់មនុស្ស; ហេតុដូច្នោះហើយ ខ្ញុំត្រូវបាន
ហាមឃាត់មិនឲ្យសរសេរពី ការណ៍ទាំងនោះឡើយ ។

---

១០ *ក* ១ នីហ្វៃ ៧:៦.
១៤ *ក* ១ នីហ្វៃ ១:១៦–១៧; ៩:៤.
១៥ *ក* ១ នីហ្វៃ ៦:៤–៦.
*ខ* ស.ប. រំពឹងគិត; បទព្រះគម្ពីរ.
*គ* ១ នីហ្វៃ ១៩:២៣.
១៦ *ក* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
*ខ* ស.ប. ចិត្ត.
១៧ *ក* ២ នីហ្វៃ ៩:១០; គ. និង ស. ៨៦:១១.
*ខ* រ៉ូម ៧:២៤.
១៨ *ក* រ៉ូម ៧:២១–២៣; ហេព្រើរ ១២:១; អាលម៉ា ៧:១៥.
២១ *ក* ស.ប. សេចក្ដីស្រឡាញ់.
២២ *ក* ១ នីហ្វៃ ១៧:៥២.
២៣ *ក* ស.ប. ការនិមិត្ត.
២៤ *ក* យ៉ាកុប (ព.ស.ថ.) ៥:១៦; ១ នីហ្វៃ ២:១៦.
២៥ *ក* ១ នីហ្វៃ ១១:១; ម៉ូសេ ១:១–២.

២៦ ឱបើដូច្នេះ បើសិនខ្ញុំបានឃើញការណ៍ដ៏អស្ចារ្យជាច្រើន បើសិនជាព្រះអម្ចាស់ទ្រង់បានយាងចុះមកឯកូនចៅមនុស្ស ហើយ បានមករកមនុស្សលោក ដោយសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ ហេតុអ្វីបានជាចិត្តខ្ញុំយំ ហើយព្រលឹងខ្ញុំរេរាំងនៅលើច្រកភ្នំនៃសេចក្ដី សោកសៅ ហើយសាច់ខ្ញុំរីងរៃទៅ ហើយកម្លាំងខ្ញុំត្រូវទន់ខ្សោយ ព្រោះតែទុក្ខវេទនាទាំងឡាយរបស់ខ្ញុំ ?

២៧ ហើយហេតុអ្វីបានជាខ្ញុំ បណ្ដោយទៅតាមអំពើបាប ព្រោះតែសាច់ឈាមខ្ញុំ? មែនហើយ ហេតុអ្វីបានជាខ្ញុំបណ្ដោយទៅតាម ការល្បួងទាំងឡាយ ដែលអ្នកអាក្រក់បានដាក់ក្នុងចិត្តរបស់ខ្ញុំ ដើម្បីបំផ្លាញសេចក្ដីសុខសាន្តរបស់ខ្ញុំ ហើយធ្វើទុក្ខដល់ព្រលឹងរបស់ខ្ញុំ ? ហេតុអ្វីបានជាខ្ញុំខឹង ព្រោះតែខ្មាំងសត្រូវរបស់ខ្ញុំ ?

២៨ ឱព្រលឹងខ្ញុំអើយ ចូរភ្ញាក់ឡើង កុំងប់ងល់ក្នុងអំពើបាបទៀតឡើយ ។ ឱចិត្តខ្ញុំអើយ ចូររីករាយឡើង ហើយកុំទុកកន្លែងសំរាប់ ខ្មាំងសត្រូវនៃព្រលឹងខ្ញុំទៀតឡើយ ។

២៩ ចូរកុំខឹងទៀតឡើយ ព្រោះតែខ្មាំងសត្រូវរបស់ខ្ញុំ ។ ចូរកុំធ្វើឲ្យកម្លាំងខ្ញុំទន់ខ្សោយ ព្រោះតែទុក្ខវេទនាទាំងឡាយរបស់ខ្ញុំ ឡើយ ។

៣០ ឱចិត្តខ្ញុំអើយ ចូររីករាយឡើង ហើយអំពាវនាវដល់ព្រះអម្ចាស់ចុះ ហើយចូរនិយាយថា៖ ឱព្រះអម្ចាស់អើយ ទូលបង្គំសរសើរដំកើងព្រះអង្គជានិច្ច; មែនហើយ ព្រលឹងទូលបង្គំរីករាយទៅលើទ្រង់ ឱព្រះរបស់ទូលបង្គំ ដែលជាថ្មនៃសេចក្ដីសង្គ្រោះរបស់ទូលបង្គំអើយ ។

៣១ ឱព្រះអម្ចាស់អើយ តើព្រះអង្គនឹងប្រោសលោះព្រលឹងទូលបង្គំឬទេ ? តើព្រះអង្គនឹងរំដោះទូលបង្គំ ឲ្យរួចពីកណ្ដាប់ដៃនៃពួកខ្មាំង សត្រូវទូលបង្គំឬទេ? តើព្រះអង្គនឹងធ្វើឲ្យទូលបង្គំញ័រនៅចំពោះអំពើបាបឬទេ?

៣២ សូមទ្វារនៃស្ថាននរក បិទជិតពីមុខទូលបង្គំជានិច្ច ពីព្រោះចិត្តទូលបង្គំសង្រេង ហើយវិញ្ញាណទូលបង្គំទន់ទាប! ឱព្រះអម្ចាស់អើយ សូមព្រះអង្គកុំបិទទ្វារទាំងឡាយនៃសេចក្ដីសុចរិតរបស់ទ្រង់ពីមុខទូលបង្គំឡើយ ដើម្បីឲ្យទូលបង្គំអាចដើរតាមផ្លូវនៃទីវាលទំនាប ដើម្បីឲ្យទូលបង្គំអាចដើរតាមផ្លូវទៀងត្រង់ ។

៣៣ ឱព្រះអម្ចាស់អើយ សូមព្រះអង្គរុំព័ទ្ធខ្លួនទូលបង្គំដោយសំលៀកបំពាក់ដ៏សុចរិតរបស់ទ្រង់! ឱព្រះអម្ចាស់អើយ សូមព្រះអង្គធ្វើ ផ្លូវសំរាប់ឲ្យទូលបង្គំគេចខ្លួន រួចផុតពីពួកខ្មាំងសត្រូវរបស់ទូលបង្គំផង! សូមព្រះអង្គធ្វើឲ្យផ្លូវខាងមុខទូលបង្គំត្រង់! សូមព្រះអង្គកុំ ដាក់ថ្មជំពប់តាមផ្លូវទូលបង្គំឡើយ — ប៉ុន្តែសូមព្រះអង្គឆ្កាផ្លូវខាងមុខទូលបង្គំផង ហើយសូមកុំស្រាស់លើផ្លូវទូលបង្គំឡើយ ប៉ុន្តែសូម ស្រាស់នៅលើផ្លូវទាំងឡាយ នៃខ្មាំងសត្រូវទូលបង្គំវិញ ។

៣៤ ឱព្រះអម្ចាស់អើយ ទូលបង្គំបានទុកចិត្តទៅលើព្រះអង្គ ហើយទូលបង្គំនឹងទុកចិត្តទៅលើព្រះអង្គជារៀងដរាប ។ ទូលបង្គំនឹងមិន ដាក់ទីទុកចិត្តរបស់ទូលបង្គំ ទៅលើដៃនៃមនុស្សឡើយ; ត្បិតទូលបង្គំដឹងថាត្រូវបណ្ដាសាហើយ ដល់អ្នកណាដែលដាក់ទីទុកចិត្តរបស់ខ្លួន ទៅលើដៃនៃមនុស្ស ។ មែនហើយ ត្រូវបណ្ដាសាហើយ ដល់អ្នកណាដែលដាក់ទីទុកចិត្តរបស់ខ្លួនទៅលើមនុស្ស ឬក៏យកសាច់ឈាម ធ្វើជាដៃរបស់ខ្លួន ។

៣៥ មែនហើយ ទូលបង្គំដឹងថា ព្រះទ្រង់នឹងប្រទានឲ្យអ្នកណា ដែលសូមដល់ទ្រង់ដោយសទ្ធា ។ មែនហើយ ព្រះរបស់ទូលបង្គំនឹង ប្រទានឲ្យទូលបង្គំ បើសិនជាទូលបង្គំមិនសូមនូវអ្វីដែលទុច្ចរិត; ហេតុដូច្នេះហើយ ទូលបង្គំនឹងបន្លឺសម្លេងឡើងដល់ព្រះអង្គ មែនហើយ ទូលបង្គំនឹងអំពាវនាវដល់ព្រះអង្គ ឱព្រះរបស់ទូលបង្គំ ដែលជាថ្មនៃសេចក្ដីសុចរិតរបស់ទូលបង្គំអើយ ។ មើលចុះ សម្លេងរបស់ទូលបង្គំ នឹងអណ្ដែតឡើងទៅដល់ព្រះអង្គជារៀងដរាប ដែលជាថ្មរបស់ទូលបង្គំ ហើយជាព្រះដ៏គង់នៅអស់កល្បជានិច្ចរបស់ទូលបង្គំ ។ អាម៉ែន ៕

## ជំពូកទី ៥

*ពួកសាសន៍នីហ្វៃបែកចេញពីពួកសាសន៍លេមិន, កាន់តាមក្រិត្យវិន័យលោកម៉ូសេ, ហើយសាងព្រះវិហារ — មកពីការឥតជំនឿ របស់ពួកគេ នោះពួកសាសន៍លេមិនបានត្រូវកាត់ចេញពីវត្តមាននៃព្រះអម្ចាស់, ត្រូវបណ្ដាសា, ហើយក្លាយទៅជារំពាត់ចំពោះ ពួកសាសន៍នីហ្វៃ ។ ប្រមាណជាឆ្នាំ ៥៨៨–៥៥៩ ម.គ.ស. ។*

២៦ *ក* ទំនុក. ៤៣:៥.
២៧ *ក* រ៉ូម ៦:១៣.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
*គ* ស.ប. សេចក្ដីសុខសាន្ត.
២៨ *ក* ស.ប. អារក្ស.
៣០ *ក* ១ កូរិន. ៣:១១.
ស.ប. ថ្ម.
៣១ *ក* រ៉ូម ១២:៩; អាលម៉ា ១៣:១២.
៣២ *ក* ស.ប. ចិត្តសង្រេង.
*ខ* ស.ប. ដើរ, ដើរជាមួយព្រះ.
៣៤ *ក* ស.ប. ទុកចិត្ត.
*ខ* ទំនុក. ៤៤:៦–៨.
*គ* យេរេ. ១៧:៥;
មរមន ៣:៩; ៤:៨.
៣៥ *ក* យ៉ាកុប (ព.ស.ថ.) ១:៥.
*ខ* ស.ប. ការអធិស្ឋាន.
*គ* ហេប្រេ. ១០:៥.
*ឃ* ចោទិ. ៣២:៤.

មើលចុះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាន
ស្រែកអំពាវនាវជាយូរដល់ព្រះអម្ចាស់ ដ៏ជាព្រះរបស់ខ្ញុំ ពីព្រោះ
តែកំហឹងរបស់ បងៗខ្ញុំ ។
២ ប៉ុន្តែមើលចុះ កំហឹងរបស់ពួកគេចេះតែមានខ្លាំងឡើងមក
លើខ្ញុំ ដរាបដល់ពួកគេបានព្យាយាមចង់យកជីវិតខ្ញុំទៅទៀត ។
៣ មែនហើយ ពួកគេបានរអ៊ូរទាំទាស់នឹងខ្ញុំ ដោយថាៈ
ប្អូនប្រុសរបស់យើងគិតថា វានឹងត្រួតត្រាលើយើង; ហើយយើង
បានទទួល ការលំបាកជាច្រើន ក៏ដោយសារតែវា; ហេតុ
ដូច្នោះហើយ ឥឡូវនេះ ចូរយើងសម្លាប់វាចោលទៅ ដើម្បីកុំឲ្យ
យើងអាចត្រូវរងទុក្ខ លំបាកថែមទៀត ដោយសារសំដីរបស់វា ។
ត្បិតមើលចុះ យើងមិនព្រមឲ្យវាធ្វើជាអ្នកត្រួតត្រាលើយើងឡើយ;
ត្បិតគឺយើងទេតើ ដែលជាបងប្រុស ត្រូវមាន
ភារៈត្រួតត្រាលើប្រជាជននេះ ។
៤ ឥឡូវនេះ ខ្ញុំមិនសរសេរនៅលើផ្ទាំងទាំងនេះ នូវពាក្យ
ទាំងអស់ដែលពួកគេរអ៊ូរទាំទាស់នឹងខ្ញុំទេ ។ ប៉ុន្តែល្មមឲ្យខ្ញុំគ្រាន់តែ
និយាយថា ពួកគេបានព្យាយាមចង់យកជីវិតខ្ញុំ ។
៥ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
បានព្រមានខ្ញុំថា ខ្ញុំ នីហ្វៃ ត្រូវតែចេញពីពួកគេ ហើយ
រត់ភៀសខ្លួនទៅ ក្នុងទីរហោស្ថាន ហើយនឹងអស់អ្នកណា ដែល
ចង់ទៅជាមួយនឹងខ្ញុំ ។
៦ ហេតុដូច្នោះហើយ ហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ
បាននាំយកគ្រួសារខ្ញុំ និងព្រមទាំងសូរ៉ាំ និងគ្រួសារលោក និង
សាំ ដែលជាបងប្រុសខ្ញុំ ព្រមទាំងគ្រួសារលោក និងយ៉ាកុប
និងយ៉ូសែបដែលជាប្អូនប្រុសខ្ញុំ ហើយព្រមទាំងបងស្រីទាំង
ឡាយរបស់ខ្ញុំផង និងអស់អ្នកណាដែលចង់ទៅជាមួយនឹងខ្ញុំ ។
ហើយអស់ទាំងអ្នកដែលចង់ទៅជាមួយនឹងខ្ញុំ សុទ្ធតែជាពួក
ដែលជឿនូវសេចក្ដីព្រមាន ទាំងឡាយ និងវិវរណៈទាំងឡាយ
របស់ព្រះ; ហេតុដូច្នោះហើយ ពួកគេបានប្រុងស្ដាប់តាមពាក្យ
សំដីរបស់ខ្ញុំ ។
៧ ហើយយើងបានយកត្រសាលទាំងឡាយរបស់យើង និង
របស់ណាដែលយើងអាចយកបាន ហើយបានធ្វើដំណើរចូល
ទីរហោស្ថាន អស់រយៈពេលជាច្រើនថ្ងៃ ។ ហើយបន្ទាប់ពីបាន
ធ្វើដំណើរអស់ជាច្រើនថ្ងៃ នោះយើងក៏បានបោះត្រសាលទាំង
ឡាយរបស់យើង ។
៨ ហើយប្រជាជនខ្ញុំ ចង់ឲ្យយើងហៅទីនោះថា នីហ្វៃ; ហេតុ
ដូច្នោះហើយ យើងហៅទីនោះថា នីហ្វៃ ។
៩ ហើយអស់អ្នកណាដែលមកជាមួយនឹងខ្ញុំ បានហៅខ្លួនថា
ប្រជាជននីហ្វៃ ។
១០ ហើយយើងប្រតិបត្តិតាមសេចក្ដីយុត្តិធម៌ទាំងឡាយ និង
ក្រឹត្យក្រមទាំងឡាយ និងព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់
ចំពោះការណ៍ទាំងអស់ ស្របតាមក្រឹត្យវិន័យលោកម៉ូសេ ។
១១ ហើយព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងយើង; ហើយយើង
បានចំរើនឡើងដ៏លើសលប់; ត្បិតយើងបានព្រោះគ្រាប់ពូជ
ហើយយើងច្រូតកាត់បានជាបរិបូរទៀត ។ ហើយយើងចា
ប់ផ្ដើមចិញ្ចឹមចៀមទាំងហ្វូង និងគោទាំងក្រោល ហើយនឹង
សត្វគ្រប់ប្រភេទ ។
១២ ហើយខ្ញុំ នីហ្វៃ ក៏បានយកបញ្ជីទាំងឡាយមកផងដែរ
ដែលបានឆ្លាក់នៅលើផ្ទាំងលង្ហិន; ហើយព្រមទាំងវត្ថុមូល ឬ
ត្រីវិស័យ ដែលត្រូវបានរៀបចំឡើងសំរាប់ឪពុកខ្ញុំ ដោយ
ព្រះហស្តនៃព្រះអម្ចាស់ ស្របតាមអ្វីដែលបានសរសេរទុក ។
១៣ ហើយហេតុការណ៍បានកើតឡើងថា យើង
ក៏ចាប់ផ្ដើមចំរើនឡើងដ៏លើសលប់ ហើយកើនចំនួនឡើង
នៅលើដែនដីនេះ ។
១៤ ហើយខ្ញុំ នីហ្វៃ បានយកដាវរបស់ឡាបាន់ ធ្វើជា
គំរូដើម្បីធ្វើដាវជាច្រើនទៀត ក្រែងតាមមធ្យោបាយណាមួយ
ប្រជាជន ដែលឥឡូវនេះហៅថា សាសន៍លេមិន នឹងសង្កត់មក
លើយើង ហើយបំផ្លាញពួកយើងចោល; ត្បិតខ្ញុំដឹងអំពីសំអប់
របស់គេ ដែលគេ មានចំពោះខ្ញុំ និងកូនចៅខ្ញុំ និងអស់អ្នកណា
ដែលហៅថា ប្រជាជនខ្ញុំ ។
១៥ ហើយខ្ញុំបានបង្រៀនប្រជាជនខ្ញុំឲ្យសាងអាគារទាំង

---

៥ ១*ក* ២ នីហ្វៃ ៤:១៣–១៤.
៣ *ក* ១ នីហ្វៃ ១៦:៣៧–៣៨;
ម៉ូសាយ ១០:១៤–១៥.
៥ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
*ខ* ម៉ូសាយ ១០:១៣.
៦ *ក* ១ នីហ្វៃ ៤:៣៥; ១៦:៧;
២ នីហ្វៃ ១:៣០–៣២.
*ខ* ស.ប. ព្រមាន, ពាក្យព្រមាន.
៨ *ក* អោមណៃ ១:១២, ២៧;
ម៉ូសាយ ៩:១–៤; ២៨:១.
៩ *ក* យ៉ាកុប ១:១៣–១៤.
១០ *ក* ២ នីហ្វៃ ១១:៤.
ស.ប. ក្រឹត្យវិន័យលោកម៉ូសេ.
១២ *ក* ម៉ូសាយ ១:៣–៤.
ស.ប. ផ្ទាំងទាំងឡាយ.
*ខ* ម៉ូសាយ ១:១៦.
*គ* ១ នីហ្វៃ ១៦:១០, ១៦, ២៦;
១៨:១២, ២១;
អាលម៉ា ៣៧:៣៨–៤៧;
គ. និង ស. ១៧:១.
១៤ *ក* ១ នីហ្វៃ ៤:៩; យ៉ាកុប ១:១០;
ព. នៃ ម. ១:១៣.
*ខ* ស.ប. ពួកសាសន៍លេមិន.

ឡាយ ហើយឲ្យធ្វើរបស់របរគ្រប់បែបយ៉ាងពីឈើ និងពីដែក និងពីស្ពាន់ និងពីលង្ហិន និងពីដែកថែប និងពីមាស និងពីប្រាក់ និងពីលោហធាតុដ៏មានតម្លៃឯទៀត ដែលមានដ៏បរិបូរ ។

១៦ ហើយខ្ញុំ នីហ្វៃ បានសាងព្រះវិហារបរិសុទ្ធមួយ; ហើយខ្ញុំបានសង់ព្រះវិហារបរិសុទ្ធនេះ តាមរបៀបព្រះវិហារបរិសុទ្ធរបស់ សាឡូម៉ូន លើកលែងតែព្រះវិហារបរិសុទ្ធនេះពុំបានសាងដោយសម្ភារៈដ៏មានតម្លៃជាច្រើនទេ; ត្បិតរបស់ទាំងនោះពុំអាចរកបាននៅ លើដីនេះឡើយ ហេតុដូច្នោះហើយ ព្រះវិហារបរិសុទ្ធនេះមិនអាចសង់ឲ្យដូចព្រះវិហារបរិសុទ្ធរបស់សាឡូម៉ូនបានទេ ។ ក៏ប៉ុន្តែឯរបៀប សង់វិញនោះដូចគ្នានឹងព្រះវិហារបរិសុទ្ធរបស់សាឡូម៉ូន; ឯក្បូរក្បាច់នៃព្រះវិហារបរិសុទ្ធនេះល្អវិចិត្រក្រៃលែង ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បាននាំប្រជាជនខ្ញុំឲ្យមានចិត្តឧស្សាហ៍ ហើយឲ្យធ្វើការដោយដៃរបស់ខ្លួន ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេចង់ឲ្យខ្ញុំធ្វើជាស្ដេចរបស់ពួកគេ ។ ប៉ុន្តែខ្ញុំ នីហ្វៃ មានប្រាថ្នាថា ពួកគេពុំគួរមាន ស្ដេចទេ; ទោះជាយ៉ាងនេះក៏ដោយ គង់តែខ្ញុំបានធ្វើអ្វីៗដើម្បីពួកគេ ស្របតាមអំណាចដែលខ្ញុំមាន ។

១៩ ហើយមើលចុះ ព្រះបន្ទូលទាំងឡាយនៃព្រះអម្ចាស់ត្រូវបានបំពេញចំពោះបងៗខ្ញុំ ដែលទ្រង់មានព្រះបន្ទូលអំពីពួកគេថា ខ្ញុំត្រូវធ្វើជាអ្នកត្រួតត្រារបស់ពួកគេ ហើយជាគ្រូបង្រៀនរបស់ពួកគេ ។ ម្ល៉ោះហើយ ខ្ញុំបានធ្វើជាអ្នកត្រួតត្រារបស់ពួកគេ ហើយជា គ្រូបង្រៀនរបស់គេ ស្របតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ រហូតដល់ពេលដែលពួកគេបានព្យាយាមចង់យកជីវិតខ្ញុំ ។

២០ ហេតុដូច្នោះហើយ ព្រះបន្ទូលនៃព្រះអម្ចាស់ក៏បានបំពេញដែលទ្រង់មានព្រះបន្ទូលមកខ្ញុំ ដោយមានព្រះបន្ទូលថា៖ ដរាបណា ពួកគេមិនប្រុងស្ដាប់តាមសំដីរបស់អ្នកទេ នោះពួកគេនឹងត្រូវបានកាត់ចេញពីវត្តមាននៃព្រះអម្ចាស់ ហើយមើលចុះ ពួកគេត្រូវបានកាត់ចេញ ពីវត្តមានរបស់ទ្រង់មែន ។

២១ ហើយទ្រង់បានធ្វើឲ្យបណ្ដាសា ធ្លាក់មកលើពួកគេ មែនហើយ គឺជាបណ្ដាសាដ៏ក្ដៅ ដោយព្រោះសេចក្ដីទុច្ចរិតរបស់គេ ។ ត្បិតមើលចុះ ពួកគេបានចិត្តរឹងរូសទាស់នឹងព្រះអង្គ ដែលពួកគេបានក្លាយទៅជារឹងដូចថ្មដែកភ្លើង; ហេតុដូច្នោះហើយ មកពីពួកគេមាន សម្បុរស ហើយស្រស់ល្អដ៏លើសលប់ ហើយដ៏គួរឲ្យចូលចិត្ត នោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានធ្វើឲ្យពួកគេមានស្បែកក្រមៅ ដើម្បីកុំឲ្យពួកគេអាចមក ល្បួងប្រជាជនខ្ញុំបានឡើយ ។

២២ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ យើងនឹងធ្វើឲ្យពួកគេក្លាយទៅជារាស្ត្រដ៏គួរឲ្យស្អប់ចំពោះរាស្ត្រអ្នក លើកលែងតែពួកគេប្រែចិត្តពីសេចក្ដីទុច្ចរិតទាំងឡាយរបស់គេ ។

២៣ ហើយត្រូវបណ្ដាសាហើយដល់ពូជណាដែលមកលាយឡំជាមួយនឹងពូជរបស់ពួកគេ; ត្បិតពួកគេនឹងត្រូវបណ្ដាសាដូចជាបណ្ដាសានោះដែរ ។ ហើយព្រះអម្ចាស់ទ្រង់មានបន្ទូលដូច្នោះ ហើយព្រះបន្ទូលនោះបានសំរេចមែន ។

២៤ ហើយដោយមកពីបណ្ដាសា ដែលដាក់លើពួកគេ នោះពួកគេបានក្លាយទៅជាប្រជាជនមួយដ៏ខ្ជិលច្រអូស ពោរពេញទៅដោយល្បិចកិច្ចកល ហើយបានស្វែងរកសត្វព្រៃធ្វើជាអាហារនៅក្នុងទីរហោស្ថាន ។

២៥ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ពួកគេនឹងទៅជារំពាត់មួយដល់ពូជអ្នក ដើម្បីដាស់រំជួលពូជអ្នកឲ្យនឹកចាំដល់យើង; ហើយដរាបណាគេមិននឹកចាំដល់យើង ហើយមិនប្រុងស្ដាប់តាមពាក្យទាំងឡាយរបស់យើងទេ នោះពួកគេនឹង វាយពូជអ្នក រហូតដល់សេចក្ដីបំផ្លិចបំផ្លាញចោល ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ នីហ្វៃ បានតែងតាំងយ៉ាកុប និងយ៉ូសែប ដើម្បីឲ្យពួកគេធ្វើជាពួកសង្ឃ ហើយជាពួក គ្រូបង្រៀន នៅលើដែនដីនៃប្រជាជនខ្ញុំ ។

១៥ *ក* អេធើរ ១០:២៣.
១៦ *ក* ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់.
*ខ* ១ ពង្សាវ. ៦; ២ របា. ៣.
*គ* គ. និង ស. ១២៤:២៦–២៧.
១៧ *ក* លោកុ. ៣:១៩; គ. និង ស. ៤២:៤២.
១៨ *ក* យ៉ាកុប ១:៩, ១១.
១៩ *ក* ១ នីហ្វៃ ២:២២.
*ខ* ស.ប. បង្រៀន, គ្រូបង្រៀន.
២០ *ក* ២ នីហ្វៃ ២:២១.
*ខ* អាលម៉ា ៩:១៤.
២១ *ក* ស.ប. បណ្ដាសា, បណ្ដាសាទាំងឡាយ.
*ខ* ៤ នីហ្វៃ ១:១០.
*គ* ២ នីហ្វៃ ២៦:៣៣; ៣ នីហ្វៃ ២:១៤–១៦.
២២ *ក* ១ នីហ្វៃ ១២:២៣.
២៣ *ក* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍រវាងសេចក្ដីជំនឿ.
២៤ *ក* ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
២៦ *ក* យ៉ាកុប ១:១៨–១៩; ម៉ូសាយ ២៣:១៧.

២៧ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបាន
រស់នៅតាមរបៀបនៃសុភមង្គល ។
២៨ ហើយរយៈពេលសាមសិបឆ្នាំបានកន្លងផុតទៅ
ចាប់តាំងពីពេលដែលយើងចាកចេញពីក្រុងយេរូសាឡិមមក ។
២៩ ហើយខ្ញុំ នីហ្វៃ បានកត់បញ្ជីទាំងឡាយនៅលើផ្ទាំងរបស់ខ្ញុំ
ដែលខ្ញុំបានធ្វើ គឺអំពីប្រជាជនខ្ញុំ រហូតមកដល់ពេលនេះ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា [ក]ព្រះអម្ចាស់ដ៏ជាព្រះ
ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ចូរធ្វើផ្ទាំងផ្សេងទៀត; ហើយអ្នក
ត្រូវ ឆ្លាក់ការណ៍ជាច្រើន នៅលើផ្ទាំងនោះ ដែល
ឃើញថាល្អនៅចំពោះភ្នែកយើង ដើម្បីជាប្រយោជន៍ដល់
រាស្ត្ររបស់អ្នក ។
៣១ ហេតុដូច្នោះហើយ ខ្ញុំ នីហ្វៃ ដោយ
ចង់គោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ក៏បាន
ទៅធ្វើ[ក]ផ្ទាំងទាំងនេះ ដែលខ្ញុំបាន ឆ្លាក់ការណ៍អស់ទាំងនេះ ។
៣២ ហើយខ្ញុំឆ្លាក់អ្វីដែលសព្វព្រះហឫទ័យព្រះ ។ ហើយបើ
សិនជាប្រជាជនខ្ញុំគាប់ចិត្តនឹងការណ៍ទាំងឡាយរបស់ព្រះ
នោះពួកគេ ក៏នឹងគាប់ចិត្តនឹងឆ្លាក់ត្រាទាំងឡាយរបស់ខ្ញុំ ដែល
ខ្ញុំបានឆ្លាក់នៅលើផ្ទាំងទាំងនេះដែរ ។
៣៣ ហើយបើសិនជាប្រជាជនរបស់ខ្ញុំប្រាថ្នាចង់ដឹងអំពី
ប្រវត្តិនៃប្រជាជនខ្ញុំឲ្យបានល្អិតល្អន់ជាងនេះ នោះពួកគេត្រូវ
ពិចារណាមើល ផ្ទាំងរបស់ខ្ញុំផ្សេងៗទៀត ។
៣៤ ហើយល្មមឲ្យខ្ញុំគ្រាន់តែនិយាយថា សែសិបឆ្នាំបាន
កន្លងផុតទៅ ហើយយើងមានសង្គ្រាមទាំងឡាយ និងការ
ទាស់ទែងគ្នា ទាំងឡាយជាមួយនឹងបងប្អូនយើងទៅហើយ ៕

## ជំពូកទី ៦

*យ៉ាកុបតំណាលប្រាប់អំពីប្រវត្តិនៃសាសន៍យូដា គឺ៖ ការដែលពួកគេជាប់ឃុំឃាំងនៅក្រុងបាប៊ីឡូន និងការវិលត្រឡប់វិញ; ការងារបំរើ និងការឆ្កាងព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល; ជំនួយដែលបានទទួលមកពីពួកសាសន៍ដទៃ; និងការសាងឡើងវិញនៅថ្ងៃចុងក្រោយ កាលពួកគេជឿដល់ព្រះមែស៊ី ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ពាក្យសំដីរបស់យ៉ាកុប ដែលជាប្អូនរបស់នីហ្វៃ ដែលបាន
និយាយទៅកាន់ប្រជាជននីហ្វៃថា៖
២ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំ យ៉ាកុប
ដោយត្រូវបានហៅពីព្រះ ហើយបានតែងតាំងឡើង តាម
របៀបដ៏បរិសុទ្ធ របស់ទ្រង់ ហើយដោយបាន
ញែកចេញដោយបងប្រុសខ្ញុំ គឺនីហ្វៃ ជាអ្នកដែលបងប្អូនរាល់
គ្នាចាត់ទុក[ក]ថាជាស្ដេច ឬជាអ្នកការពារម្នាក់ ហើយដែល
បងប្អូនរាល់គ្នាពឹងផ្អែកទៅលើ ដើម្បីសន្តិសុខ នោះមើលចុះ
បងប្អូនរាល់គ្នាដឹងថា ខ្ញុំបាននិយាយទៅបងប្អូន ពីសេចក្ដី
ដ៏ច្រើនហួសប្រមាណ ។
៣ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំនិយាយទៅបងប្អូន
ម្ដងទៀត; ត្បិតខ្ញុំប្រាថ្នានូវសុខុមាលភាពដល់ព្រលឹងទាំងឡាយ
នៃបងប្អូន។ មែនហើយ ខ្ញុំបារម្ភដ៏ខ្លាំងចំពោះបងប្អូន; ហើយបងប្អូន
រាល់គ្នាផ្ទាល់ក៏ដឹងថាការណ៍នោះពិតមែន ។ ព្រោះខ្ញុំបាន
ទូន្មានបងប្អូន ជាញយៗ ដោយអស់ពីសមត្ថភាព; ហើយខ្ញុំបាន
បង្រៀនបងប្អូនអំពីពាក្យសំដីរបស់ឪពុកខ្ញុំ; ហើយខ្ញុំបាននិយាយ
ប្រាប់បងប្អូន អំពីការណ៍ ទាំងអស់ ដែលបានកត់ត្រាទុក
ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ ។
៤ ហើយឥឡូវនេះ មើលចុះ ខ្ញុំចង់និយាយប្រាប់បងប្អូន
អំពីការណ៍ទាំងឡាយ ដែលកំពុងកើតឡើង និងអំពីការណ៍ទាំង
ឡាយ ដែល នឹងកើតឡើង; ហេតុដូច្នោះហើយ ខ្ញុំនឹងអានឲ្យ
បងប្អូនស្ដាប់នូវពាក្យពេចន៍របស់[ក]លោកអេសាយ ។ ហើយទាំងនេះ
គឺជាពាក្យដែលបង ប្រុសខ្ញុំ មានប្រាថ្នាចង់ឲ្យខ្ញុំនិយាយប្រាប់
បងប្អូន។ ហើយខ្ញុំនិយាយទៅបងប្អូននេះដោយយល់ដល់បងប្អូន
រាល់គ្នា ដើម្បីឲ្យបងប្អូន រាល់គ្នាអាចចេះដឹង ហើយសរសើរ
ដំកើងដល់ព្រះនាម នៃព្រះរបស់អ្នករាល់គ្នា ។
៥ ហើយឥឡូវនេះ ឯពាក្យពេចន៍ដែលខ្ញុំនឹងអាន គឺជាពាក្យ
ដែលលោកអេសាយបាននិយាយ អំពីវង្សអ៊ីស្រាអែលទាំងអស់;
ហេតុដូច្នោះហើយ ពួកគេក៏អាចប្រៀបដូចជាអ្នករាល់គ្នាដែរ
ព្រោះអ្នករាល់គ្នាគឺជាវង្ស អ៊ីស្រាអែល ហើយមានការណ៍ជាច្រើន
ដែលលោក អេសាយបាននិយាយ ដែលអាចប្រៀបដូចទៅ
នឹងអ្នករាល់គ្នា ពីព្រោះអ្នករាល់គ្នា ជាវង្សអ៊ីស្រាអែល ។
៦ ហើយឥឡូវនេះ ពាក្យទាំងនោះមានដូចតទៅគឺ៖ ព្រះអម្ចាស់
ទ្រង់មាន[ក]ព្រះបន្ទូលដូច្នេះថា៖ មើលចុះ យើងនឹងបោយដៃហោអស់
ទាំងពួកសាសន៍ដទៃ ហើយលើក[ខ]ទង់ជ័យយើងឡើងសំរាប់
ប្រជាជាតិទាំងឡាយ; រួចពួកគេនឹងបីយកកូនប្រុសអ្នកមក ហើយ
នឹងបញ្ជិះ កូនស្រីៗរបស់អ្នកនៅលើស្មាគេ ។

៣០ *ក* ១ នីហ្វៃ ១៩:១–៦.
៣១ *ក* ស.ប. ផ្ទាំងទាំងឡាយ.
៦ ២ *ក* យ៉ាកុប ១:៩, ១១.
៤ *ក* ៣ នីហ្វៃ ២៣:១.
៦ *ក* អេសាយ ៤៩:២២–២៣.
*ខ* ស.ប. ទង់.

៧ ហើយពួកមហាក្សត្រនឹងធ្វើជាឪពុកចិញ្ចឹមអ្នក ហើយពួក
អគ្គមហេសីនឹងធ្វើជាម្ដាយបំបៅអ្នក; ពួកគេនឹងក្រាបផ្កាប់មុខ
ដល់ដីនៅ ចំពោះមុខអ្នក ហើយនឹងលិតធូលីដីដែលជាប់ជើង
អ្នក; នោះ[ក]អ្នកនឹងដឹងថា យើងជាព្រះអម្ចាស់; ត្បិតអស់អ្នក
ណាដែលរង់ចាំយើង នឹងមិនត្រូវខ្មាស់ឡើយ ។
៨ ហើយឥឡូវនេះ ខ្ញុំ យ៉ាកុប ចង់និយាយអ្វីខ្លះពីពាក្យ
ទាំងនេះ ។ ត្បិតមើលចុះ [ក]ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ខ្ញុំថា
អស់អ្នកណា ដែលនៅឯក្រុងយេរូសាឡិម ពីកន្លែង[ខ]ដែលពួក
យើងចេញមក នោះត្រូវបានស្លាប់ ហើយត្រូវគេចាប់យក
ទៅជាឈ្លើយអស់ហើយ ។
៩ ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអម្ចាស់ទ្រង់បាន
បង្ហាញខ្ញុំថា ពួកគេនឹងបាន[ក]ត្រឡប់មកវិញម្ដងទៀត ។ ហើយ
ទ្រង់ក៏បាន បង្ហាញខ្ញុំដែរថា ព្រះអម្ចាស់ដ៏ជាព្រះ គឺជាព្រះដ៏បរិសុទ្ធ
នៃសាសន៍អ៊ីស្រាអែល នឹងសម្ដែងរូបអង្គទ្រង់ឲ្យពួកគេឃើញ
នៅក្នុងសាច់ ឈាម; ហើយ[ខ]បន្ទាប់ពីបានសម្ដែងរូបអង្គទ្រង់មក
នោះពួកគេនឹងវាយទ្រង់ ហើយឆ្កាងទ្រង់ ស្របតាមពាក្យសំដី
របស់ទេវតា ដែលបាន និយាយប្រាប់ខ្ញុំ ។
១០ ហើយបន្ទាប់ពីពួកគេធ្វើចិត្តរឹងរូស ហើយពង្រឹងករបស់
ពួកគេទាស់នឹងព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល មើលចុះ
[ក]សេចក្ដី ជំនុំជំរះនៃព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល នឹង
ធ្លាក់មកលើពួកគេ ។ ហើយថ្ងៃនោះនឹងមកដល់ ដែលពួកគេ
នឹងត្រូវវាយដំ ហើយមានទុក្ខវេទនា ។
១១ ហេតុដូច្នោះហើយ បន្ទាប់ពីពួកគេត្រូវបានដេញទៅមក
ត្បិតទេវតាមានបន្ទូលដូច្នេះថា នោះមនុស្សជាច្រើននឹងត្រូវឈឺ
ចាប់ខាងសាច់ឈាម តែមិនត្រូវរងទុក្ខដល់វិនាសឡើយ ដោយ
សារការអធិស្ឋានទាំងឡាយរបស់ពួកស្មោះត្រង់; ពួកគេនឹង
ត្រូវបាន ខ្ចាត់ខ្ចាយ ហើយត្រូវគេវាយដំ ហើយត្រូវគេស្អប់;
ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអម្ចាស់ ទ្រង់នឹងមាន
សេចក្ដីមេត្តាករុណា ដល់ពួកគេ [ក]គឺកាលណាពួកគេនឹងបាន
[ខ]ការចេះដឹងអំពីព្រះដ៏ប្រោសលោះរបស់ពួកគេ នោះពួកគេ
នឹង[គ]ប្រមូលរួមគ្នាម្ដងទៀត នៅលើ ដែនដីនៃកេរ្ដិ៍អាករ
របស់គេ ។
១២ នោះមានពរហើយ[ក]ពួកសាសន៍ដទៃ ជាពួកអ្នកដែលពួក
ព្យាការីបានសរសេរទុក; ត្បិតមើលចុះ ប្រសិនបើពួកគេប្រែចិត្ត
ហើយមិនច្បាំងនឹងក្រុងស៊ីយ៉ូនទេ ហើយមិនចូលរួមជាមួយនឹង
សាសនាចក្រដ៏ធំ ហើយ[ខ]គួរខ្ពើមឆ្អើមនោះទេ នោះពួកគេនឹង
បាន សង្គ្រោះ; ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងបំពេញ
[គ]សេចក្ដីសញ្ញាទាំងឡាយរបស់ទ្រង់ ដែលទ្រង់បានធ្វើជាមួយនឹង
កូនចៅព្រះអង្គ; ហើយដោយហេតុនេះ បានជាពួកព្យាការី
សរសេរការណ៍ទាំងនេះទុក ។
១៣ ហេតុដូច្នោះហើយ អ្នកណាដែលច្បាំងនឹងក្រុងស៊ីយ៉ូន
ហើយនឹងរាស្ត្រដែលនៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ នោះ
នឹង លិតធូលីដី ដែលជាប់ជើងពួកគេ; ហើយរាស្ត្ររបស់ព្រះ
អម្ចាស់នឹងមិន[ក]ត្រូវខ្មាស់ឡើយ ។ ព្រោះរាស្ត្រនៃព្រះអម្ចាស់
គឺជាពួកអ្នក ដែលនឹងនៅ[ខ]រង់ចាំទ្រង់; ត្បិតពួកគេនៅតែ
រង់ចាំការយាងមកនៃព្រះមែស៊ី ។
១៤ ហើយមើលចុះ ស្របតាមពាក្យសំដីរបស់ព្យាការី ព្រះ
មែស៊ីនឹងប្រុងចាំជួយពួកគេជាលើក[ក]ទីពីរ; ហេតុដូច្នោះហើយ
ទ្រង់នឹង [ខ]សម្ដែងរូបអង្គទ្រង់ឲ្យពួកគេឃើញ ដោយព្រះចេស្ដា
និងដោយសិរីល្អដ៏អស្ចារ្យ រហូត[គ]ដល់សេចក្ដីបំផ្លិចបំផ្លាញពួក
ខ្មាំងសត្រូវរបស់ពួកគេ កាលថ្ងៃមកដល់ នៅពេលពួកគេ
នឹងជឿដល់ទ្រង់; ហើយទ្រង់នឹងមិនបំផ្លាញអ្នកណា ដែលជឿ
ដល់ទ្រង់ឡើយ ។
១៥ ហើយអ្នកណាដែលមិនជឿដល់ទ្រង់ទេ នោះនឹងត្រូវ

៧ ក ម៉ូសេ ១:៦;
គ. និង ស. ១៣៣:៤៥.
៨ ក នាងអេស. ២:៦;
១ នីហ្វៃ ៧:១៣;
២ នីហ្វៃ ២៥:១០;
អោមណៃ ១:១៥;
ហេលេ. ៨:២០–២១.
ខ ២ ពង្សាវ. ២៤:១០–១៦;
២៥:១–១២.
ស.ប. អ៊ីស្រាអែល — ការ
ខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
៩ ក ១ នីហ្វៃ ១០:៣.
ខ ១ នីហ្វៃ ១៩:១០, ១៣;
ម៉ូសាយ ៣:៩;
៣ នីហ្វៃ ១១:១៤–១៥.
ស.ប. ការឆ្កាង.
១០ ក ម៉ាថាយ ២៧:២៤–២៥.
១១ ក ១ នីហ្វៃ ២២:១១–១២;
២ នីហ្វៃ ៩:២.
ខ ហូសេ ៣:៥.
គ ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
១២ ក ១ នីហ្វៃ ១៤:១–២;
២ នីហ្វៃ ១០:៩–១០.
ខ ស.ប. អារក្ស — សាសនាចក្រ
នៃអារក្ស.
គ ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
១៣ ក ៣ នីហ្វៃ ២២:៤.
ខ អេសាយ ៤០:៣១;
១ នីហ្វៃ ២១:២៣;
គ. និង ស. ១៣៣:៤៥.
១៤ ក អេសាយ ១១:១១;
២ នីហ្វៃ ២៥:១៧; ២៩:១.
ខ ២ នីហ្វៃ ៣:៥.
គ ១ នីហ្វៃ ២២:១៣–១៤.

បំផ្លាញចោល ទាំងដោយភ្លើង និងដោយព្យុះ និងដោយផែនដីរញ្ជួយ និងដោយការខ្ចាយឈាម និងដោយជម្ងឺអាសន្នរោគ និងដោយអំណត់អត់ ។ ហើយពួកគេនឹងដឹងថា ព្រះអម្ចាស់គឺជាព្រះ ជាព្រះ ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ។

១៦ ក្បិតតើរបឹបនឹងត្រូវឆក់យកពីអ្នកខ្លាំងពូកែ ឬពួកឈ្លើយដែលចាប់មកតាមច្បាប់នឹងត្រូវដោះចេញបានទេឬ ?

១៧ តែព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ សូម្បីតែពួកឈ្លើយរបស់មនុស្សខ្លាំងពូកែ ក៏នឹងត្រូវយកចេញទៅ ហើយរបឹបរបស់ ពួកអ្នកគួរស្ញែងខ្លាចនឹងបានរំដោះចេញផង; ក្បិតព្រះដ៏មានឥទ្ធិឫទ្ធិ នឹងដោះលែងពួករាស្ត្រនៃសេចក្ដីសញ្ញារបស់ទ្រង់ ។ ក្បិតព្រះ អម្ចាស់ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ យើងនឹងតតាំងចំពោះអ្នកដែលតតាំងនឹងអ្នក —

១៨ ហើយយើងនឹងធ្វើឲ្យពួកអ្នកដែលសង្កត់សង្កិនអ្នកត្រូវស៊ីសាច់របស់គេវិញ; ហើយពួកគេនឹងត្រូវស្រវឹងដោយឈាមរបស់ខ្លួន ដូចជាស្រវឹងដោយស្រាទំពាំងបាយជូរថ្មី; នោះគ្រប់ទាំងមនុស្សនឹងដឹងថា យើងគឺជាព្រះអម្ចាស់ គឺជាព្រះអង្គសង្គ្រោះនៃអ្នក ហើយ ជាព្រះដ៏ប្រោសលោះអ្នក គឺជាព្រះដ៏មានឥទ្ធិឫទ្ធិនៃយ៉ាកុប ៕

## ជំពូកទី ៧

*អេសាយនិយាយប្រៀបដូចជាព្រះមែស៊ី — ព្រះមែស៊ីនឹងមានវោហារនៃពួកអ្នករៀនសូត្រ — ទ្រង់នឹងប្រគល់ខ្នង ទៅឲ្យពួកអ្នកដែល វាយទ្រង់ — ទ្រង់នឹងមិនត្រូវផ្ចាញ់ផ្ចាលឡើយ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៥០ ។ ប្រមាណជាឆ្នាំ ៥៥៩—៥៤៥ ម.គ.ស. ។*

មែនហើយ ក្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ តើយើងបានបណ្ដេញអ្នកចេញ ឬក៏យើងបានបោះបង់អ្នកចោលរហូតទៅឬ? ក្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ សំបុត្រលះលែងដែលយើងឲ្យដល់ម្ដាយអ្នក នោះតើនៅឯណា? តើយើងបានបណ្ដេញ អ្នកចេញទៅឲ្យអ្នកណា ឬក៏តើយើងបានលក់អ្នកដល់ម្ចាស់បំណុលរបស់យើងណាមួយ ? មែនហើយ តើយើងបានលក់អ្នកឲ្យអ្នកណា ? មើលចុះ ដែលអ្នកត្រូវលក់នោះ ក៏ដោយព្រោះអំពើទុច្ចរិតរបស់អ្នកទេ ហើយដែលម្ដាយអ្នកត្រូវបណ្ដេញ នោះក៏ដោយព្រោះអំពើ រំលងរបស់អ្នករាល់គ្នាដែរ ។

២ ហេតុដូច្នោះហើយ កាលយើងបានមកដល់ នោះគ្មានអ្នកណាមួយសោះ; កាលយើងបានហៅ មែនហើយ នោះគ្មានអ្នកណា ឆ្លើយតប ។ ឱវង្សអ៊ីស្រាអែលអើយ តើដៃយើងបានរួញខ្លីនឹងជួយលោះអ្នកមិនបាន ឬតើយើងគ្មានអំណាចនឹងដោះឲ្យរួចទេឬអី ? មើលចុះ កាលណាយើងស្ដីឲ្យ នោះសមុទ្រក៏រីងស្ងួតទៅ ហើយទន្លេក៏ទៅជាទីហួតហែង ឯត្រីក៏ធុំស្អុយ ដោយគ្មានទឹក ហើយនឹង ស្លាប់ទៅ ដោយស្រេកដែរ ។

៣ យើងបំពាក់ផ្ទៃមេឃដោយពពកខ្មៅ ហើយយើងដណ្ដប់ទៅដោយសំពត់ធ្មៃផង ។

៤ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានប្រទានឲ្យខ្ញុំមានវោហារដូចជាអ្នកដែលបានរៀនសូត្រហើយ ដើម្បីឲ្យខ្ញុំបានចេះប្រើពាក្យសំដី ដល់អ្នក ឱវង្សអ៊ីស្រាអែលអើយ ។ កាលណាអ្នករាល់គ្នាហេវហត់ ទ្រង់ដាស់រាល់តែព្រឹក ។ ទ្រង់ដាស់ត្រចៀកខ្ញុំ ដើម្បីឲ្យខ្ញុំស្ដាប់ ដូចជាអ្នកដែលកំពុងតែរៀនសូត្រ ។

៥ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានបើកត្រចៀកខ្ញុំ ហើយខ្ញុំមិនបានរឹងចចេស ឬបែរក្រោយឡើយ ។

៦ ខ្ញុំបានប្រគល់ខ្នងទៅឲ្យអ្នកដែលវាយ ហើយថ្ពាល់ខ្ញុំទៅឲ្យពួកអ្នកដែលបោចពុកចង្កា ។ ខ្ញុំមិនបានគេចមុខពីសេចក្ដីអាម៉ាស់ខ្មាស ឬពីការស្ដោះទឹកមាត់ទេ ។

៧ ពីព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងជួយខ្ញុំ ហេតុនោះ

១៥ *ក* ២ នីហ្វៃ ១០:១៦; ២៨:១៥;
៣ នីហ្វៃ ១៦:៨.
ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
*ខ* យ៉ាកុប ៦:៣.
*គ* គ. និង ស. ៩៧:២២—២៦.
១៦ *ក* អេសាយ ៤៩:២៤—២៦.
*ខ* ក.ន.រាស្ត្រនៅក្នុងសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ដូចដែលបានថ្លែងប្រាប់នៅក្នុងខ១៧.
១៧ *ក* ១ នីហ្វៃ ២១:២៥.
*ខ* ស.ប. ព្រះយេហូវ៉ា.
*គ* ២ ពង្សាវ. ១៧:៣៩.
១៨ *ក* ស.ប. ព្រះដ៏ប្រោសលោះ.
*ខ* លោកុ. ៤៩:២៤;
អេសាយ ៦០:១៦.
៧ ១*ក* ស.ប. សេចក្ដីក្បត់សាសនា.
២ *ក* សុភា. ១:២៤—២៥;
អេសាយ ៦៥:១២;
អាលម៉ា ៥:៣៧.
*ខ* និក្ខ. ១៤:២១; ទំនុក. ១០៦:៩;
គ. និង ស. ១៣៣:៦៨—៦៩.
*គ* យ៉ូស្វេ ៣:១៥—១៦.
*ឃ* និក្ខ. ៧:២១.
៣ *ក* និក្ខ. ១០:២១.
*ខ* វិវរ. ៦:១២.
៤ *ក* លូកា ២:៤៦—៤៧.
៥ *ក* គ. និង ស. ៥៨:១.
៦ *ក* ម៉ាថាយ ២៧:២៦;
២ នីហ្វៃ ៩:៥.

បានជាខ្ញុំមិនត្រូវជ្រប់មុខ ។ ដូច្នេះហើយ ខ្ញុំបានកាត់ចិត្តឲ្យរឹងដូចថ្មដែកភ្លើង ហើយខ្ញុំដឹងថា ខ្ញុំមិនត្រូវខ្មាស់ឡើយ ។

៨ ហើយព្រះអម្ចាស់ទ្រង់គង់នៅជិតខ្ញុំ ហើយទ្រង់បានតាំងខ្ញុំជាសុចរិត ។ តើអ្នកណានឹងតវ៉ាចំពោះខ្ញុំទៀត ? ចូរយើងឈរឡើងជា មួយគ្នា ។ តើអ្នកណាដែលជាទំនាស់នឹងខ្ញុំ ? ចូរឲ្យអ្នកនោះចូលមកជិតខ្ញុំចុះ ខ្ញុំនឹងវាយអ្នកនោះនឹងអំណាចនៃមាត់ខ្ញុំ ។

៩ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងជួយខ្ញុំ ។ ហើយអស់អ្នកឯណាដែលនឹងកាត់ទោសខ្ញុំ មើលចុះ គេនឹងចាស់ទៅទាំងអស់គ្នា ដូចជាសំលៀកបំពាក់ ហើយកន្លាតនឹងកាត់គេអស់ទៅ ។

១០ ក្នុងពួកអ្នករាល់គ្នា តើមានអ្នកណា ដែលកោតខ្លាចដល់ព្រះអម្ចាស់ ដែលស្ដាប់តាមសម្លេង របស់អ្នកបំរើទ្រង់ឯអ្នកដែលដើរ ក្នុងសេចក្ដីងងឹត ឥតមានពន្លឺសោះ ?

១១ មើលចុះ អស់អ្នកដែលបង្កាត់ភ្លើង ជាអ្នកដែលក្រវាត់ខ្លួនដោយកន្ទុយឧសអើយ ចូរឲ្យអ្នករាល់គ្នា ដើរក្នុងអណ្ដាតភ្លើងរបស់អ្នក ហើយកណ្ដាលកន្ទុយឧសដែលអ្នកបានបង្កាត់នោះចុះ ។ អ្នកនឹងបានយល់តែប៉ុណ្ណោះពីដៃយើង— ហើយអ្នករាល់គ្នានឹងត្រូវដេក ទៅដោយការសោកសៅ ៕

## ជំពូកទី ៨

*នៅគ្រាក្រោយបង្អស់ នោះព្រះអម្ចាស់ទ្រង់កំសាន្ដចិត្តក្រុងស៊ីយ៉ូន ហើយប្រមូលសាសន៍អ៊ីស្រាអែល — ពួកអ្នកដែលបានប្រោសលោះ នឹងមកក្រុងស៊ីយ៉ូន ដោយសេចក្ដីអំណរដ៏ធំ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៥១ និង ៥២:១–២ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ឱអ្នករាល់គ្នាដែលខំដេញតាមសេចក្ដីសុចរិតអើយ ចូរប្រុងស្ដាប់តាមយើងចុះ ។ ចូរមើលចំទៅឯថ្មដា ជាទីដែលបានដាប់អ្នករាល់គ្នា ចេញមក ហើយទៅឯអន្លង់ គឺជារណ្ដៅដែលជាកន្លែងបានជីកយកអ្នកឡើងមកនោះ ។

២ ចូរមើលទៅឯអ័ប្រាហាំ ជាអយ្យកោអ្នក ហើយទៅឯសារ៉ាដែលបង្កើតអ្នកមក; ត្បិតយើងបានហៅលោកមកតែម្នាក់ឯង ហើយ បានឲ្យពរលោក ។

៣ ព្រោះព្រះអម្ចាស់ទ្រង់នឹងកំសាន្ដចិត្តក្រុងស៊ីយ៉ូន ទ្រង់នឹងដោះទុក្ខអស់ទាំងកន្លែងខូចបង់របស់គេ; ហើយទ្រង់ក៏នឹងធ្វើឲ្យទីស្ងាត់ ឈឹង បានដូចជាច្បារអេដែន ហើយឲ្យវាលខ្សាច់នោះត្រឡប់ដូចជាសួនរបស់ព្រះអម្ចាស់ដែរ ។ នឹងមានសេចក្ដីអំណរ និងសេចក្ដី រីករាយ នៅក្នុងទីក្រុងនោះ ព្រមទាំងការអរព្រះគុណ និងសម្លេងពីរោះពីរោះផង ។

៤ ឱរាស្ត្រយើងអើយ ចូរប្រុងស្ដាប់តាមយើង; ឱសាសន៍របស់យើងអើយ ចូរផ្ទៀងត្រចៀកចំពោះយើងចុះ; ត្បិតនឹងមានច្បាប់មួយ ចេញពីយើងទៅ ហើយយើងនឹងតាំងសេចក្ដីយុត្តិធម៌របស់យើង ទុកជាពន្លឺដល់អស់ទាំងសាសន៍ ។

៥ ឯសេចក្ដីសុចរិតរបស់យើងបានមកជិតបង្កើយ; សេចក្ដីសង្គ្រោះរបស់យើង បានផ្សាយចេញទៅ ហើយដើមដៃយើងនឹងជំនុំជំរះ អស់ទាំងសាសន៍ ។ ឯបណ្ដាកោះទាំងប៉ុន្មាន គេនឹងសង្ឃឹមដល់យើង ហើយដើមដៃរបស់យើង គេនឹងទុកចិត្តលើ ។

៦ ចូរងើបភ្នែកមើលទៅលើមេឃ ហើយមើលចុះមកផែនដីខាងក្រោមនេះទៀត; ត្បិតផ្ទៃមេឃនឹងសូន្យបាត់ទៅដូចជាផ្សែង ហើយផែនដីនឹងចាស់ទៅដូចជាសំលៀកបំពាក់; ឯពួកអ្នកដែលនៅស្ថាននេះ នឹងស្លាប់ទៅបែបដូច្នោះដែរ ។ តែសេចក្ដីសង្គ្រោះ របស់យើងនឹងនៅជាដរាប ហើយសេចក្ដីសុចរិតរបស់យើងនឹងមិនត្រូវលើកចោលឡើយ ។

៧ អ្នករាល់គ្នាដែលស្គាល់សេចក្ដីសុចរិត ជាជនជាតិដែលមានច្បាប់ ដែលយើងបានសរសេរនៅក្នុងចិត្តអើយ ចូរប្រុងស្ដាប់តាម យើងចុះ កុំឲ្យខ្លាចសេចក្ដីត្មះតិះដៀលរបស់មនុស្សឡើយ ក៏កុំឲ្យស្រយុតចិត្ត ដោយពាក្យបង្អាច់របស់គេដែរ ។

៨ ត្បិតកន្លាតនឹងកាត់ស៊ីគេ ដូចជាកាត់សំលៀកបំពាក់ ហើយដង្កូវនឹងចោះគេ ដូចជាសំពត់រោមចៀម ។ តែសេចក្ដីសុចរិតរបស់ យើងនឹងស្ថិតស្ថេរនៅជាដរាប ហើយសេចក្ដីសង្គ្រោះរបស់យើងផង ដរាបដល់អស់ទាំងតំណមនុស្សតទៅ ។

៩ ឱព្រះពាហុនៃព្រះអម្ចាស់អើយ សូមតើនឡើង សូមតើនឡើង!

៩ *ក* រ៉ូម ៨:៣១.
១០ *ក* គ. និង ស. ១:៣៨.
១១ *ក* ពួកចៅ. ១៧:៦.
៨ ១*ក* ស.ប. ថ្ម.
២ *ក* លោកុ. ១៧:១–៨; គ. និង ស. ១៣២:៤៩.
*ខ* លោកុ. ២៤:៣៦.
៣ *ក* ស.ប. ស៊ីយ៉ូន.
*ខ* អេសាយ ៣៥:១–២, ៦–៧.
៤ *ក* ឬ ការបង្រៀន, លទ្ធិ.
*ខ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៥ *ក* ស.ប. សេចក្ដីសង្គ្រោះ.
*ខ* ២ នីហ្វៃ ១០:២០.
៦ *ក* ២ ពេត្រុស ៣:១០.
*ខ* ហេ. ហុយបាត់.
*គ* ហេ. ពុក.
៧ *ក* ទំនុក. ៥៦:៤, ១១; គ. និង ស. ១២២:៩.

ហើយពាក់ជាឥទ្ធិឫទ្ធិ; សូមតើនឡើង ដូចជាកាលពីចាស់បុរាណ ។ តើមិនមែនទ្រង់ដែលកាត់រ៉ាហាបខ្ទេចខ្ទី ដែលចាក់ទម្លុះនាគនោះទេឬអី ?

១០ តើមិនមែនទ្រង់ទេឬអី ដែលពង្រីងទឹកសមុទ្រ គឺជាទឹកនៃទីជំរៅដ៏ធំ; ហើយបានធ្វើឲ្យបាតសមុទ្រ ត្រឡប់ជាផ្លូវសំរាប់ឲ្យពួក មនុស្សដែលទ្រង់ប្រោសលោះបានដើរឆ្លងទៅ ?

១១ ដូច្នេះហើយ ពួកអ្នកប្រោសលោះរបស់ព្រះអម្ចាស់ គេនឹងវិលមកវិញ ហើយមកដល់ក្រុងស៊ីយ៉ូន ដោយច្រៀងចំរៀង; គេនឹងមានសេចក្ដីអំណរដ៏អស់កល្បជានិច្ច និងបរិសុទ្ធភាពពាក់លើក្បាលរបស់គេ; ហើយគេនឹងទទួលសេចក្ដីរីករាយ និងសេច ក្ដីអំណរ; ឯសេចក្ដីសោកសៅ និងសេចក្ដីយំសោកនោះនឹងខ្ចាត់បាត់ទៅ ។

១២ យើងជាអ្នកនោះហើយ; មែនហើយ យើងជាអ្នកដែលកំសាន្តចិត្តអ្នករាល់គ្នា ។ មើលចុះ តើអ្នកជាអ្វី បានជាអ្នកខ្លាចចំពោះ មនុស្សដែលត្រូវតែស្លាប់ ហើយចំពោះពួកអ្នកដែលកើតពីមនុស្សមកដូច្នេះ ដែលគេនឹងត្រូវក្រៀមទៅដូចជាស្មៅនោះ ?

១៣ ហើយតើអ្នកបានទាំងភ្លេចព្រះអម្ចាស់ ជាព្រះដែលបានបង្កើតអ្នកមក ដែលទ្រង់បានលាតផ្ទៃមេឃ ក៏ដាក់ឫសផែនដីផង ហើយ រាល់តែថ្ងៃអ្នកមានសេចក្ដីភ័យមិនល្ហែដោយខ្លាចចំពោះសេចក្ដីក្រោធ របស់អ្នកដែលសង្កត់សង្កិនហាក់ដូចជាគេរៀបនឹងបំផ្លាញ អ្នកបង់ឬ? តែសេចក្ដីក្រោធរបស់គេ នោះនៅឯណា ?

១៤ បន្តិចទៀត ពួកអ្នកដែលជាប់ជាឈ្លើយ នឹងបានរួចចេញពីចំណងគេជាប្រាកដ គេនឹងមិនត្រូវស្លាប់ ចុះទៅក្នុងរណ្ដៅឡើយ ក៏មិនខ្វះខាតអាហារដែរ ។

១៥ ត្បិតយើងជាព្រះអម្ចាស់ ជាព្រះនៃអ្នក ដែលបានធ្វើឲ្យរលកលាន់រំពង; នាមយើងគឺជាព្រះអម្ចាស់ នៃពួកពលបរិវារ ។

១៦ ហើយយើងបានដាក់ពាក្យពេចន៍របស់យើងនៅក្នុងមាត់អ្នក ហើយបានគ្របបាំងអ្នកដោយ ស្រមោលនៃដៃយើង ដើម្បីយើងបាន រៀបចំផ្ទៃមេឃ ហើយដាក់ឫសផែនដី រួចនិយាយដល់ពួកក្រុងស៊ីយ៉ូនថាៈ មើលចុះ អ្នកជារាស្ត្ររបស់យើង ។

១៧ ឱក្រុងយេរូសាឡិម ដែលបានផឹកពីព្រះហស្តនៃព្រះអម្ចាស់ នូវពែងនៃសេចក្ដីក្រោធរបស់ទ្រង់អើយ ចូរភ្ញាក់ឡើង ចូរភ្ញាក់ឡើង ចូរក្រោកឈរឡើង — អ្នកបានផឹកស្រូបទាំងកាកក្នុងពែង ជាសេចក្ដីទ្រេតទ្រោតអស់រលីងហើយ —

១៨ ក្នុងពួកកូនប្រុសៗ ដែលកើតចេញពីទីក្រុងនោះមក គ្មានណាមួយសំរាប់ដឹកនាំមុខគេឡើយ; ហើយក្នុងពួកកូនប្រុសៗ ដែល ទីក្រុងនោះបានចិញ្ចឹម ក៏គ្មានណាមួយចាប់ដៃដឹកទៅដែរ ។

១៩ កូនប្រុសទាំងពីរនេះបានធ្លាក់មកលើអ្នកហើយ តើអ្នកឯណានឹងសោកស្ដាយដល់អ្នក — គឺសេចក្ដីរឹបជាន់ និងសេចក្ដីបំផ្លិច បំផ្លាញ និងសេចក្ដីអំណត់ និងដាវទាំងឡាយរបស់អ្នក — តើដោយអ្នកណាដែលយើងកំសាន្តចិត្តអ្នក ?

២០ ពួកកូនប្រុសបានសន្លប់ទៅហើយ លើកលែងតែពីរនាក់នេះ; ពួកគេដេកតាមក្បាលថ្នល់; ដូចជាគោព្រៃជាប់ក្នុងបង្កាត់ គេមាន ពេញដោយសេចក្ដីក្រោធរបស់ព្រះអម្ចាស់ គឺជាសេចក្ដីបន្ទោសរបស់ព្រះនៃអ្នក ។

២១ ដូច្នេះ អ្នកដែលត្រូវរងទុក្ខវេទនា ហើយក៏ស្រវឹង តែមិនមែនដោយស្រាទំពាំងបាយជូរទេ ចូរស្ដាប់សេចក្ដីនេះឥឡូវៈ

២២ ព្រះអម្ចាស់ ហើយជាព្រះនៃអ្នក ទ្រង់កាត់ក្ដីជំនួសរាស្ត្រទ្រង់ ព្រះអម្ចាស់នៃអ្នក ទ្រង់មានព្រះបន្ទូលដូច្នេះថា មើលចុះ យើងបាន ដកយកពែងដែលនាំឲ្យទ្រេតទ្រោត គឺជាកាកនៅក្នុងពែងនៃសេចក្ដីក្រោធរបស់យើង ចេញពីដៃអ្នកហើយ; អ្នកនឹងមិនត្រូវផឹកទៀត ឡើយ ។

២៣ តែយើងនឹងដាក់ពែងនោះ ទៅក្នុងដៃរបស់ពួកអ្នកដែលធ្វើទុក្ខអ្នកវិញ; ជាពួកអ្នកដែលបាននិយាយទៅព្រលឹងអ្នកថាៈ ចូរឱនចុះ ដើម្បីឲ្យយើងបានដើរលើ — ហើយអ្នកបានដេកទៅឲ្យខ្នងអ្នក បានរាបដូចជាដី សំរាប់ជាថ្នល់ឲ្យគេដើរលើ ។

២៤ ចូរភ្ញាក់ឡើង ចូរភ្ញាក់ឡើង ឱក្រុងស៊ីយ៉ូនអើយ ចូរពាក់កម្លាំងរបស់អ្នក; ឱយេរូសាឡិម ជាទីក្រុងបរិសុទ្ធអើយ

---

៩ *ក* គ. និង ស. ១១៣:៧–៨.
១០ *ក* អេសាយ ៣៥:៨.
១១ *ក* ស.ប. ប្រោសលោះ, បាន ប្រោសលោះ, សេចក្ដីប្រោសលោះ.
*ខ* អេសាយ ៣៥:១០.
*គ* វិវ. ២១:៤.
១២ *ក* គ. និង ស. ១៣៣:៤៧; ១៣៦:២២.
*ខ* យេរេ. ១:៨.
*គ* អេសាយ ៤០:៦–៨; ១ ពេត្រុស ១:២៤.
១៣ *ក* យេរេ. ២៣:២៧.
១៥ *ក* ១ នីហ្វៃ ៤:២.
១៦ *ក* ២ នីហ្វៃ ៣:៩; ២៩:១៤.
១៧ *ក* អេសាយ ២៩:៩; យេរេ. ២៥:១៥.
*ខ* លូកា ២១:២៤.
១៩ *ក* វិវ. ១១:៣.
២១ *ក* ២ នីហ្វៃ ២៧:៤.
២២ *ក* យេរេ. ៥០:៣៤.
២៣ *ក* សាការី ១២:៩.
២៤ *ក* អេសាយ ៥២:១–២.
*ខ* គ. និង ស. ១១៣:៧–៨.
*គ* ស.ប. ស៊ីយ៉ូន.

ចូរប្រដាប់ដោយ សំលៀកបំពាក់ដ៏រុងរឿងរបស់អ្នកចុះ; ត្បិត
ពីនេះទៅមុខ នឹងគ្មានពួកមិនកាត់ស្បែក ឬពួកស្មោកគ្រោកចូល
មកក្នុងអ្នកទៀតឡើយ ។
២៥ ឱក្រុងយេរូសាឡិមអើយ ចូររលាស់ធូលីដីពីអ្នកចេញ
ហើយក្រោកអង្គុយឡើង; ឱកូនស្រីនៃក្រុងស៊ីយ៉ូន ដែល
ជាឈ្លើយអើយ ចូរដោះចំណងពីកអ្នកចេញ ៕

## ជំពូកទី ៩

*ពួកសាសន៍យូដានឹងប្រមូលគ្នា នៅគ្រប់ដែនដីសន្យារបស់ពួកគេ — ដង្វាយធួនលោះមនុស្សលោកពីការធ្លាក់ — រូបកាយទាំងឡាយ នៃមនុស្សស្លាប់នឹងក្រោកឡើងពីផ្នូរ ឯវិញ្ញាណទាំងឡាយរបស់ពួកគេនឹងចេញមកពីស្ថាននរក និងពីស្ថានបរមសុខមក — ពួកគេនឹង ត្រូវបានជំនុំជំរះ — ដង្វាយធួនជួយសង្គ្រោះឲ្យរួចពីសេចក្ដីស្លាប់ ស្ថាននរក អារក្ស និងការទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ — ពួកសុចរិតនឹងត្រូវបានសង្គ្រោះ នៅក្នុងនគរនៃព្រះ — ទោសសំរាប់ អំពើបាបត្រូវបានចែងឡើង — ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលគឺជាអ្នកឆ្មាំទ្វារ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស.។*

ហើយឥឡូវនេះ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំបានអាន
ការណ៍ទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នា អាចដឹងអំពីសេចក្ដីសញ្ញា
ទាំង ឡាយនៃព្រះអម្ចាស់ ដែលទ្រង់បានធ្វើសេចក្ដីសញ្ញាជា
មួយនឹងអស់ទាំងវង្សអ៊ីស្រាអែល —
២ គឺទ្រង់មានព្រះបន្ទូលទៅពួកសាសន៍យូដា ដោយមាត់
របស់ពួកព្យាការីដ៏បរិសុទ្ធរបស់ទ្រង់ ចាប់តាំងពីដើមចុះមក
ពីតំណមួយ ទៅតំណមួយ រហូតដល់ពេលដែលពួកគេនឹង
បានសាងឡើងវិញ នៅក្នុងសាសនាចក្រដ៏ពិត និងក្នុងក្រោលនៃ
ព្រះ; កាលពួកគេនឹង ត្រូវបានប្រមូលគ្នាទៅដែនដីនៃកេរ្តិ៍អាករ
របស់ពួកគេទាំងឡាយ ហើយនឹងបានតាំងឲ្យមានឡើង នៅលើ
អស់ទាំងដែនដីសន្យារបស់ ពួកគេ ។
៣ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំពោល
ការណ៍ទាំងអស់ដល់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាអាចបាន
ត្រេកអរ ហើយងើយក្បាលអ្នកឡើងជាដរាប ដោយសារពរ
ទាំងឡាយ ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងប្រទានមកលើ
កូនចៅអ្នករាល់គ្នា ។
៤ ត្បិតខ្ញុំដឹងថា អ្នករាល់គ្នាភាគច្រើនបាន
ខំពិចារណាមើលណាស់ ដើម្បីឲ្យដឹងការណ៍ ដែលនឹងកើត
មក; ហេតុដូច្នោះហើយ ខ្ញុំដឹងថាអ្នករាល់គ្នាដឹងហើយថា
រូបកាយរបស់យើងរាល់គ្នា ត្រូវបាត់បង់ស្លាប់ទៅ ក៏ប៉ុន្តែនៅ
ក្នុងរូបកាយរបស់យើង យើងនឹងបាន ឃើញព្រះ ។
៥ មែនហើយ ខ្ញុំដឹងថា អ្នករាល់គ្នាដឹងហើយថានៅក្នុងរូបកាយ
ទ្រង់នឹងបង្ហាញរូបអង្គទ្រង់ដល់ពួកអ្នក នៅក្រុងយេរូសាឡិម គឺជា
កន្លែងដែលយើងបានចេញមក; ព្រោះជាការចាំបាច់ ដែលត្រូវ
តែនៅក្នុងចំណោមពួកគេ; ត្បិតជាព្រះហឫទ័យរបស់ព្រះបង្កបង្កើត
ដ៏ធំ ដែលទ្រង់ត្រូវបណ្ដោយឲ្យខ្លួននៅក្រោមអំណាចមនុស្ស
ក្នុងសាច់ឈាម ហើយសុគតជំនួសមនុស្សលោកទាំងអស់ ដើម្បីឲ្យ
មនុស្ស លោកទាំងអស់អាចបាននៅក្រោមអំណាចរបស់ព្រះអង្គ ។
៦ ត្បិតដូចជាសេចក្ដីស្លាប់បានមកដល់មនុស្សលោកគ្រប់រូប
ដើម្បីបំពេញផែនការនៃការប្រោសប្រណីរបស់ព្រះបង្កបង្កើត
ដ៏ធំយ៉ាង ណា នោះក៏ជាការចាំបាច់ដែលត្រូវតែមានអំណាច
នៃដំណើររស់ឡើងវិញយ៉ាងនោះដែរ ហើយដំណើររស់ឡើងវិញ
ក៏ត្រូវតែមានដល់ មនុស្សលោក ដោយព្រោះការធ្លាក់; ហើយការ
ធ្លាក់កើតឡើង ដោយព្រោះសេចក្ដីរំលង; ហើយដោយព្រោះ
មនុស្សបានក្លាយទៅជា មនុស្សដែលធ្លាក់ នោះពួកគេត្រូវបាន
កាត់ចេញពីវត្តមាននៃព្រះអម្ចាស់ ។
៧ ហេតុដូច្នោះហើយ ត្រូវតែមានដង្វាយធួនដ៏និរន្តរ៍មួយ —

២៤ *ឃ* យ៉ូអែល ៣:១៧.
២៥ *ក* ក.ន. ក្រោកឡើងពីដី ហើយអង្គុយដោយថ្កុំថ្កើង ព្រោះត្រូវបានប្រោសលោះហើយ.
*ខ* គ. និង ស. ១១៣:៩–១០.
៩ ១ *ក* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
២ *ក* ២ នីហ្វៃ ៦:១១.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*គ* ២ នីហ្វៃ ១០:៧–៨.
ស.ប. ដែនដីសន្យា.
៣ *ក* ក.យ.ស., ទំនុក. ២៤:៧–១០.
៤ *ក* យ៉ូប ១៩:២៦;
អាលម៉ា ១១:៤១–៤៥;
៤២:២៣;
ហេលេ. ១៤:១៥;
មរមន ៩:១៣.
៥ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* យ៉ូហាន ១២:៣២;
២ នីហ្វៃ ២៦:២៤;
៣ នីហ្វៃ ២៧:១៤–១៥.
៦ *ក* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
*ឃ* ២ នីហ្វៃ ២:៥.
៧ *ក* អាលម៉ា ៣៤:១០.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.

លើកលែងតែមានដង្វាយធួនដ៏និរន្ដរ៍ នោះការពុករលួយនេះ
ក៏មិនអាច ក្លាយទៅជាមិនពុករលួយវិញបានឡើយ ។ ហេតុ
ដូច្នោះហើយ សេចក្ដីជំនុំជំរះទីមួយ ដែលធ្លាក់មកលើមនុស្ស
ត្រូវស្ថិតនៅរហូតដោយ មិនចេះចប់មិនចេះហើយ ។ ហើយបើ
ជាយ៉ាងនេះមែន សាច់ឈាមនេះនឹងត្រូវបញ្ចុះឲ្យរលួយ
ហើយរលាយនៅក្នុងព្រះធរណី ដោយមិនអាចនឹង
ក្រោកឡើងបានទៀតឡើយ ។
៨ ឱប្រាជ្ញានៃព្រះ សេចក្ដីមេត្ដាករុណា និងព្រះគុណព្រះអើយ!
ត្បិតមើលចុះ បើសិនជាសាច់ឈាមមិនអាចក្រោកឡើងទៀតទេ
នោះវិញ្ញាណរបស់យើងនឹងនៅក្នុងអំណាចនៃទេវតា ដែល
ធ្លាក់ចុះពីវត្ដមាននៃព្រះដ៏នៅអស់កល្បជានិច្ច ហើយបានក្លាយ
ទៅជាអារក្ស ហើយមិនអាចក្រោកឡើងទៀតសោះ ។
៩ ហើយវិញ្ញាណទាំងឡាយរបស់យើងនឹងក្លាយ
ទៅដូចជាវាដែរ ហើយយើងនឹងក្លាយទៅជាពួកអារក្ស គឺជាពួក
ទេវតានៃអារក្ស ដែលនឹងត្រូវបិទចេញពីវត្ដមាននៃព្រះរបស់យើង
ហើយត្រូវនៅជាមួយនឹងបិតានៃសេចក្ដីកុហកទាំងឡាយ នៅ
ក្នុងសេចក្ដីទុក្ខវេទនា ដូចវាដែរ; មែនហើយ ទៅឯអ្នកដែល
បញ្ឆោតឪពុកម្ដាយដើមយើង ជាអ្នកដែលបានក្លែងខ្លួនជា
ទេវតានៃពន្លឺ ហើយចាក់រុកកូនចៅ មនុស្ស ឲ្យធ្វើបក្សព័ន្ធ
សម្ងាត់នៃអំពើឃាតកម្ម និងគ្រប់ទាំងកិច្ចការសម្ងាត់ទាំង
ឡាយនៃសេចក្ដីងងឹតទៀត ។
១០ ឱសេចក្ដីល្អសប្បុរសនៃព្រះរបស់យើងធំណាស់ហ្ន៎ ព្រះ
ទ្រង់បានរៀបចំផ្លូវសំរាប់ឲ្យយើងរំដោះខ្លួនចេញពីក្រញាំ
នៃវិរូបដ៏គួរស្ញែង ខ្លាចនេះ; មែនហើយ វិរូបនោះ គឺជាសេចក្ដី
ស្លាប់ និងស្ថាននរក ដែលខ្ញុំហៅថា សេចក្ដីស្លាប់នៃរូបកាយ
ហើយសេចក្ដីស្លាប់ នៃវិញ្ញាណផង ។
១១ ហើយដោយសារផ្លូវរំដោះនៃព្រះរបស់យើង គឺជា
ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល នោះសេចក្ដីស្លាប់នេះ ដែលខ្ញុំ
បាន និយាយមក ដែលជាសេចក្ដីស្លាប់ខាងសាច់ឈាម នឹង
ត្រូវប្រគល់ពួកអ្នកដែលស្លាប់; ឯសេចក្ដីស្លាប់នេះ គឺជាផ្នូរ ។
១២ ហើយសេចក្ដីស្លាប់នេះ ដែលខ្ញុំបាននិយាយមក
គឺជាសេចក្ដីស្លាប់ខាងវិញ្ញាណ នោះនឹងប្រគល់ពួកអ្នកដែល
ស្លាប់; សេចក្ដី ស្លាប់ខាងវិញ្ញាណនេះ គឺជាស្ថាននរក; ហេតុ
ដូច្នោះហើយ សេចក្ដីស្លាប់ និងស្ថាននរក ត្រូវប្រគល់ពួកអ្នក
ដែលស្លាប់ ហើយស្ថាននរក ត្រូវប្រគល់វិញ្ញាណទាំងឡាយ
ដែលជាប់ឃុំឃាំង ហើយផ្នូរត្រូវប្រគល់រូបកាយទាំងឡាយ
ដែលជាប់ឃុំឃាំង ហើយរូបកាយទាំងឡាយ និងវិញ្ញាណ
ទាំងឡាយនៃមនុស្សលោក នឹងបានចូលរួមគ្នាវិញ; ហើយនេះ
គឺដោយអំណាចនៃដំណើររស់ឡើងវិញ របស់ព្រះដ៏បរិសុទ្ធ
នៃសាសន៍អ៊ីស្រាអែល ។
១៣ ឱផែនការនៃព្រះរបស់យើងធំណាស់ហ្ន៎ ! ត្បិតម៉្យាងទៀត
ស្ថានបរមសុខនៃព្រះ ក៏ត្រូវប្រគល់វិញ្ញាណទាំងឡាយនៃពួក
សុចរិត ឯផ្នូរវិញក៏ត្រូវប្រគល់រូបកាយទាំងឡាយនៃពួកសុចរិត;
ហើយវិញ្ញាណ និងរូបកាយ ក៏បានចូលរួមគ្នាវិញ ហើយមនុស្ស
លោកទាំងអស់ នឹងក្លាយទៅជាមិនពុករលួយ ហើយក្លាយ
ទៅជាអមតៈ ហើយពួកគេជាព្រលឹងដែលមានជីវិត ដោយ
មានដំរិះដ៏ឥតខ្ចោះ ដូចកាល យើងនៅក្នុងសាច់ឈាម
លើកលែងតែដំរិះរបស់យើងនឹងបានឥតខ្ចោះ ។

៧ ក ម៉ូសាយ ១៦:៤–៥;
អាលម៉ា ៤២:៦, ៩, ១៤.
ឃ ម៉ូសាយ ១៥:១៩.
៨ ក យ៉ូប ១២:១៣; អ័ប្រា. ៣:២១.
ស.ប. ប្រាជ្ញា.
ខ ស.ប. សេចក្ដីមេត្ដាករុណា,
មេត្ដាករុណា.
គ ស.ប. ព្រះគុណ.
ឃ គ. និង ស. ៩៣:៣៣–៣៤.
ង អេសាយ ១៤:១២;
២ នីហ្វៃ ២:១៧–១៨;
ម៉ូសេ ៤:៣–៤;
អ័ប្រា. ៣:២៧–២៨.
ច ស.ប. អារក្ស.
៩ ក យ៉ាកុប ៣:១១;
អាលម៉ា ៥:២៥, ៣៩.
ខ វិវ. ១២:៧–៩.
គ ស.ប. សេចក្ដីកុហក.
ឃ លោកុ. ៣:១–១៣;
ម៉ូសាយ ១៦:៣;
ម៉ូសេ ៤:៥–១៩.
ង ២ កូរិន. ១១:១៤;
អាលម៉ា ៣០:៥៣.
ច គ. និង ស. ១២៩:៨.
ឆ ស.ប. បក្សព័ន្ធសម្ងាត់.
១០ ក ម៉ូសាយ ១៦:៧–៨;
អាលម៉ា ៤២:៦–១៥.
ខ ស.ប. ស្ថាននរក.
១១ ក ស.ប. ព្រះដ៏ប្រោសឲ្យរួច.
ខ ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
១២ ក ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
ខ គ. និង ស. ៧៦:៨១–៨៥.
គ ស.ប. វិញ្ញាណ.
ឃ ស.ប. ដំណើររស់ឡើងវិញ.
១៣ ក ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
ខ គ. និង ស. ១៣៨:១៤–១៩.
ស.ប. ស្ថានបរមសុខ.
គ អាលម៉ា ១១:៤៣.
ឃ ស.ប. អមតៈ, អមតភាព.
ង ស.ប. ល្អឥតខ្ចោះ.
ច គ. និង ស. ១៣០:១៨–១៩.

១៤ ហេតុដូច្នោះហើយ យើងនឹងមានដំរិះដ៏ឥតខ្ចោះពីអស់ទាំងកំហុសរបស់យើង និងភាពស្មោកគ្រោករបស់យើង និងភាពអាក្រាត របស់យើង; ហើយពួកសុចរិតនឹងមានដំរិះដ៏ឥតខ្ចោះពីការសប្បាយរបស់គេ និងពីសេចក្ដីសុចរិតរបស់គេ បំពាក់ដោយសេចក្ដីបរិសុទ្ធ មែនហើយ គឺដោយអាវនៃសេចក្ដីសុចរិត ។

១៥ ហើយហេតុការណ៍នឹងកើតឡើងថា កាលមនុស្សលោកទាំងអស់ ឆ្លងផុតពីសេចក្ដីស្លាប់ទីមួយនេះទៅរកជីវិតដរាបដល់ពួកគេ បានក្លាយទៅជាអមតៈ នោះពួកគេត្រូវបង្ហាញខ្លួនចំពោះវេទិកាជំនុំជំរះនៃព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែល; ហើយខណៈនោះ ទើបមានការជំនុំជំរះកើតឡើង ហើយខណៈនោះ ពួកគេនឹងត្រូវបានជំនុំជំរះ ស្របតាមសេចក្ដីជំនុំជំរះដ៏បរិសុទ្ធនៃព្រះ ។

១៦ ហើយប្រាកដមែន ដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយជា ព្រះបន្ទូលដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ ដែលមិនសាបសូន្យទៅឡើយ ថាពួកអ្នកដែលសុចរិត ក៏នឹងនៅតែសុចរិតដដែល ហើយ ពួកអ្នកដែលស្មោកគ្រោក ក៏នឹងនៅតែស្មោកគ្រោកដដែលដែរ; ហេតុដូច្នោះហើយ ពួកអ្នកដែលស្មោកគ្រោក គឺជាអារក្ស ហើយជា ពួកទេវតាវា; ហើយពួកគេនឹងរសាត់ទៅឆ្ងាយ ក្នុងភ្លើងដែលឆេះនៅអស់កល្បជានិច្ចដែលបានរៀបចំឡើងសំរាប់ពួកគេ; ឯការរងទុក្ខ វេទនារបស់ពួកគេ គឺដូចជាបឹងភ្លើង និងស្ពាន់ធ័រ ដែលមានអណ្ដាតភ្លើងឆេះឡើងខ្ពស់ជារៀងដរាបតទៅ ហើយគ្មានទីបំផុតសោះ ។

១៧ ឱភាពអស្ចារ្យ និងសេចក្ដីយុត្តិធម៌នៃព្រះរបស់យើង ធំណាស់ហ្ន៎ ! ត្បិតទ្រង់បានអនុវត្តព្រះបន្ទូលរបស់ទ្រង់ទាំងអស់ ហើយ ព្រះបន្ទូលទាំងនោះ បានចេញមកពីព្រះឱស្ឋរបស់ទ្រង់ ហើយក្រិត្យវិន័យរបស់ទ្រង់ ត្រូវតែបានបំពេញ ។

១៨ ប៉ុន្តែមើលចុះ ពួកសុចរិត ជាពួកបរិសុទ្ធនៃព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ពួកគេដែលជឿដល់ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ពួកគេដែលបានស៊ូទ្រាំនូវឈើឆ្កាងទាំងឡាយនៃពិភពលោក ហើយពុំញញើតដល់ការខ្មាស់អៀន ពួកគេនឹងគ្រងនគរព្រះ ទុកជាមរតក ដែលបានរៀបចំសំរាប់ពួកគេចាប់តាំងពីកំណើតលោកិយមកម្លេះ ហើយសេចក្ដីអំណររបស់គេ នឹងបានពោរពេញ រហូតតទៅ ។

១៩ ឱភាពអស្ចារ្យនៃសេចក្ដីមេត្តាករុណានៃព្រះរបស់យើងជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលអើយ ធំណាស់ហ្ន៎ ! ត្បិតទ្រង់ រំដោះពួកបរិសុទ្ធរបស់ទ្រង់ឲ្យរួចផុតពីរូបដ៏ស្លៀងខ្លាច គឺអារក្ស និងសេចក្ដីស្លាប់ និងស្ថាននរក ហើយនឹងបឹងភ្លើង និងស្ពាន់ធ័រ ដែលជាការរងទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ ។

២០ ឱសេចក្ដីបរិសុទ្ធនៃព្រះរបស់យើង ធំណាស់ហ្ន៎ ! ត្បិតទ្រង់ជ្រាបគ្រប់អស់ទាំងការណ៍ ហើយគ្មានការណ៍អ្វី ដែលទ្រង់មិនជ្រាប នោះឡើយ ។

២១ ហើយទ្រង់យាងមកឯលោកិយ ដើម្បីទ្រង់អាចសង្គ្រោះមនុស្សលោកទាំងអស់ បើសិនជាពួកគេព្រមស្ដាប់តាមព្រះបន្ទូលរបស់ទ្រង់; ត្បិតមើលចុះ ទ្រង់រងទុក្ខការឈឺចាប់នៃមនុស្សលោកទាំងអស់ មែនហើយ គឺការឈឺចាប់របស់សត្វលោកសព្វសារពើដែល រស់នៅ ទាំងប្រុស ទាំងស្រី និងក្មេងៗ ដែលជាគ្រួសារនៃលោកអ័ដាម ។

២២ ហើយទ្រង់រងទុក្ខបែបនេះ គឺដើម្បីឲ្យមានដំណើររស់ឡើងវិញដល់មនុស្សលោកទាំងអស់ ហើយដើម្បីឲ្យមនុស្សលោកទាំង អស់ អាចឈរចំពោះទ្រង់ នៅក្នុងថ្ងៃជំនុំជំរះដ៏ធំ ។

---

១៤ *ក* ម៉ូសាយ ៣:២៥; អាលម៉ា ៥:១៨.
*ខ* ស.ប. ទោស.
*គ* មរមន ៩:៥.
*ឃ* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ង* សុភា. ៣១:២៥.
*ច* ស.ប. សុទ្ធ, សុទ្ធសាធ.
*ឆ* គ. និង ស. ១០៩:៧៦.
១៥ *ក* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*ខ* ទំនុក. ១៩:៩; ២ នីហ្វៃ ៣០:៩.
១៦ *ក* ១ ពង្សាវ. ៨:៥៦; គ. និង ស. ១:៣៨; ម៉ូសេ ១:៤.
*ខ* គ. និង ស. ៥៦:១១.
*គ* ស.ប. ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក.
*ឃ* ១ នីហ្វៃ ១៥:៣៣–៣៥; អាលម៉ា ៧:២១; មរមន ៩:១៤; គ. និង ស. ៨៨:៣៥.
*ង* ស.ប. អារក្ស.
*ច* ម៉ូសាយ ២៧:២៨.
*ឆ* វិវ. ២១:៨; ២ នីហ្វៃ ២៨:២៣; គ. និង ស. ៦៣:១៧.
១៧ *ក* ស.ប. សេចក្ដីយុត្តិធម៌.
១៨ *ក* ស.ប. ជនបរិសុទ្ធ.
*ខ* លូកា ១៤:២៧.
*គ* គ. និង ស. ៤៥:៥៨; ៨៤:៣៨.
*ឃ* ស.ប. ភាពដំកើងឡើង.
*ង* អាលម៉ា ១៣:៣.
*ច* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
១៩ *ក* គ. និង ស. ១០៨:៨.
*ខ* ១ នីហ្វៃ ១៥:៣៥.
*គ* ស.ប. ស្ថាននរក.
២០ *ក* ស.ប. បរិសុទ្ធភាព.
*ខ* អាលម៉ា ២៦:៣៥; គ. និង ស. ៣៨:២.
២១ *ក* ស.ប. សេចក្ដីសង្គ្រោះ.
*ខ* គ. និង ស. ១៨:១១; ១៩:១៨.
*គ* ស.ប. អ័ដាម.

២៣ ហើយទ្រង់បញ្ជាមនុស្សលោកទាំងអស់ថា ពួកគេត្រូវតែប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមទ្រង់ ដោយ មានសេចក្ដីជំនឿដ៏ឥតខ្ចោះ ជឿដល់ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល បើពុំនោះសោតទេ ពួកគេមិនអាចបានសង្គ្រោះ នៅក្នុង នគរនៃព្រះបានឡើយ ។

២៤ ហើយបើសិនជាពួកគេមិនប្រែចិត្ត ហើយមិនជឿដល់ព្រះនាមទ្រង់ ហើយមិនទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមទ្រង់ ហើយមិនកាន់ខ្ជាប់ដរាបដល់ចុងបំផុតទេ នោះពួកគេនឹងត្រូវផាប់ទោស; ត្បិតព្រះអម្ចាស់ដ៏ជាព្រះ គឺព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

២៥ ហេតុដូច្នោះហើយ ទ្រង់បានប្រទានក្រិត្យវិន័យមួយ; ហើយទីណាដែលគ្មានក្រិត្យវិន័យ ទីនោះក៏គ្មានទោសដែរ; ហើយទីណាដែលគ្មានទោស ទីនោះក៏គ្មានការកាត់ទោសដែរ; ហើយទីណាដែលគ្មានការកាត់ទោស នោះសេចក្ដីមេត្តាករុណា នៃព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែល នឹងមានសិទ្ធិទៅលើពួកគេ ដោយសារដង្វាយធួន; ព្រោះពួកគេត្រូវបានរំដោះឲ្យរួចដោយព្រះចេស្ដារបស់ទ្រង់ ។

២៦ ត្បិតដង្វាយធួន នឹងបំពេញសេចក្ដីត្រូវការនៃសេចក្ដីយុត្តិធម៌របស់ទ្រង់ ទៅលើអស់អ្នកណា ដែលមិនបានទទួលក្រិត្យវិន័យ ដើម្បីឲ្យពួកគេអាចរួចផុតពីវិរូបដ៏ស្ញែងខ្លាចពីសេចក្ដីស្លាប់ និងពីស្ថាននរក និងអារក្ស ហើយនឹងបឹងភ្លើងនិងស្ពាន់ធ័រ ដែលជាការវេទនាដ៏មិនចេះចប់មិនចេះហើយ; ហើយពួកគេត្រូវបានជូនទៅឯព្រះអង្គនោះ ដែលបានប្រទានដង្ហើមដល់ពួកគេ គឺជាព្រះ ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ។

២៧ ប៉ុន្តែវេទនាដល់អ្នកណា ដែលបានទទួលក្រិត្យវិន័យ មែនហើយ ដែលមានគ្រប់ទាំងព្រះបញ្ញត្តិនៃព្រះ ដូចជាយើងរាល់គ្នា ហើយបានរំលងលើព្រះបញ្ញត្តិទាំងនោះ ហើយបានខាតពេលវេលានៃការសាកល្បងរបស់ខ្លួនបង់ ត្បិតស្ថានភាពនៃអ្នកនេះ គឺគួរឲ្យ ស្ញើបខ្លាច!

២៨ ឱផែនការដែលប្រកបដោយឧបាយកលរបស់អ្នកអាក្រក់នោះអើយ ! ឱអំពើមោឃៈ និងភាពទន់ខ្សោយ និងការឆ្កួតលីលានៃ មនុស្សលោកអើយ! កាលណាគេបានរៀនសូត្រ គេស្មានថាគេឆ្លាតវៃ ហើយគេមិនស្ដាប់តាមពាក្យដំបូន្មាននៃព្រះឡើយ ព្រោះគេបាន ទុកមួយអន្លើ ដោយគិតស្មានថាគេបានដឹងដោយខ្លួនគេសព្វគ្រប់ហើយ ហេតុដូច្នោះហើយប្រាជ្ញារបស់គេនោះ គឺជាសេចក្ដីឆ្កួតលីលា ហើយមិនផ្ដល់ប្រយោជន៍អ្វី ដល់ពួកគេឡើយ ហើយពួកគេនឹងត្រូវវិនាសទៅ ។

២៩ ប៉ុន្តែដែលបានរៀនសូត្រ គឺជាការល្អវិញ បើសិនជាគេស្ដាប់តាមពាក្យដំបូន្មាននៃព្រះ ។

៣០ ប៉ុន្តែវេទនាដល់អ្នកមាន ដែលជាអ្នកមានទ្រព្យសម្បត្តិនៃលោកិយ ។ ត្បិតមកពីគេមាន គេមើលងាយមនុស្សក្រីក្រ ហើយ បៀតបៀនមនុស្សស្លូតត្រង់ ឯចិត្តរបស់គេឆ្ពោះទៅរកតែទ្រព្យសម្បត្តិរបស់គេ; ហេតុដូច្នោះហើយ ទ្រព្យសម្បត្តិរបស់គេ គឺជាព្រះ របស់គេ ។ ហើយ មើលចុះ ទ្រព្យសម្បត្តិរបស់គេ នឹងវិនាសទៅជាមួយគេដែរ ។

៣១ ហើយវេទនាដល់ពួកថ្លង់ ដែលមិនព្រមស្ដាប់; ត្បិតពួកគេនឹងត្រូវវិនាសទៅ ។

២៣ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
២៤ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
*ខ* ស.ប. កាន់ខ្ជាប់.
*គ* ស.ប. សេចក្ដីផាប់ទោស.
២៥ *ក* យ៉ាកុប (ព.ស.ថ.) ៤:១៧.
ស.ប. ក្រិត្យវិន័យ.
*ខ* រ៉ូម ៤:១៥; ២ នីហ្វៃ ២:១៣;
អាលម៉ា ៤២:១២–២៤.
ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
២៦ *ក* ២ នីហ្វៃ ២:១០;
អាលម៉ា ៣៤:១៥–១៦.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
*គ* ម៉ូសាយ ៣:១១.
*ឃ* ម៉ូសាយ ១៥:២៤;
គ. និង ស. ១៣៧:៧.
*ង* លោកុ. ២:៧;
គ. និង ស. ៩៣:៣៣;
អ័ប្រា. ៥:៧.
២៧ *ក* លូកា ១២:៤៧–៤៨.
២៨ *ក* អាលម៉ា ២៨:១៣.
*ខ* ស.ប. ឥតប្រយោជន៍, ការឥតប្រយោជន៍.
*គ* លូកា ១៦:១៥;
២ នីហ្វៃ ២៦:២០; ២៨:៤, ១៥.
*ឃ* សុភា. ១៤:៦; យេរេ. ៨:៨–៩;
រ៉ូម ១:២២.
ស.ប. សេចក្ដីឆ្មើងឆ្មៃ; ប្រាជ្ញា.
*ង* អាលម៉ា ៣៧:១២.
ស.ប. ពាក្យទូន្មាន (ន.).
២៩ *ក* ២ នីហ្វៃ ២៨:២៦.
*ខ* យ៉ាកុប ៤:១០.
៣០ *ក* លូកា ១២:៣៤; ១ ធីម៉ូ. ៦:១០;
គ. និង ស. ៥៦:១៦.
*ខ* ស.ប. មនុស្សក្រីក្រ.
៣១ *ក* អេសេ. ៣៣:៣០–៣៣;
ម៉ាថាយ ១១:១៥;
ម៉ូសាយ ២៦:២៨;
គ. និង ស. ១:២, ១១, ១៤;
ម៉ូសេ ៦:២៧.

៣២ វេទនាដល់ពួកខ្វាក់ ដែលមិនព្រមមើល; ត្បិតពួកគេក៏ត្រូវវិនាសផងដែរ ។

៣៣ វេទនាដល់ពួកអ្នកដែលមានចិត្តមិនកាត់ស្បែក ត្បិតការដឹងពីអំពើទុច្ចរិតទាំងឡាយរបស់ពួកគេ នឹងវាយគេនៅថ្ងៃចុងក្រោយ បង្អស់ ។

៣៤ វេទនាដល់ពួកដែល[ក]កុំហាក ត្បិតអ្នកនោះនឹងត្រូវបោះចោលទៅក្នុង[ខ]ស្ថាននរក ។

៣៥ វេទនាដល់ឃាតក ដែល[ក]សម្លាប់មនុស្សដោយចេតនា ត្បិតគេនឹងត្រូវ[ខ]ស្លាប់ ។

៣៦ វេទនាដល់អ្នកណាដែលប្រព្រឹត្ត[ក]អំពើសហាយស្មន់ទាំងឡាយ ត្បិតគេនឹងត្រូវបោះចោលទៅក្នុងស្ថាននរក ។

៣៧ មែនហើយ វេទនាដល់ពួកអ្នក ដែល[ក]ថ្វាយបង្គំរូបព្រះ ត្បិតអារក្សលើអស់ទាំងពួកអារក្សត្រេកអរនឹងពួកនេះណាស់ ។

៣៨ ហើយសរុបសេចក្ដីមក វេទនាដល់អ្នកណាដែលស្លាប់ក្នុងអំពើបាបទាំងឡាយរបស់ខ្លួន; ត្បិតគេនឹងត្រ[ក]ឡប់ទៅជួបព្រះវិញ ហើយឃើញព្រះភ័ក្ត្រទ្រង់ ហើយស្ថិតនៅក្នុងអំពើបាបទាំងឡាយរបស់គេដដែល ។

៣៩ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ សូមនឹកចាំដល់ភាពដ៏ស្ញែងខ្លាច នៃការរំលងទាស់នឹងព្រះដ៏បរិសុទ្ធ និងភាពដ៏ស្ញែងខ្លាចនៃ ការបណ្ដោយខ្លួនទៅតាមការល្បួងទាក់ទាញទាំងឡាយរបស់[ក]មេឧបាយកលនោះ ។ សូមនឹកចាំចុះថា [ខ]គំនិតដែលជាប់ទៅខាងរូប កាយ គឺជា[គ]សេចក្ដីស្លាប់ រីឯគំនិតដែលជាប់ទៅខាងវិញ្ញាណ គឺជា[ឃ]ជីវិតដ៏នៅអស់កល្បជានិច្ចវិញ។

៤០ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ សូមផ្ទៀងត្រចៀកស្ដាប់ពាក្យទាំងឡាយរបស់ខ្ញុំចុះ ។ សូមនឹកចាំដល់ភាពធំអស្ចារ្យ នៃព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ។ សូមកុំនិយាយថា ខ្ញុំបាននិយាយពីរឿងធ្ងន់ៗទាស់នឹងអ្នកឡើយ; ត្បិតបើសិនជាអ្នក រាល់គ្នានិយាយថាដូច្នោះ នោះអ្នករាល់គ្នាជេរប្រមាថដល់[ក]សេចក្ដីពិត; ព្រោះខ្ញុំបានពោលព្រះបន្ទូលរបស់ព្រះដ៏បង្កបង្កើតបងប្អូន ។ ខ្ញុំដឹងថា ពាក្យទាំងឡាយនៃសេចក្ដីពិត គឺជាពាក្យដ៏[ខ]ធ្ងន់ទាស់នឹងការស្មោកគ្រោកទាំងអស់; ប៉ុន្តែពួកសុចរិតមិនខ្លាចដល់ពាក្យទាំង នោះទេ ព្រោះគេស្រឡាញ់សេចក្ដីពិត ហើយមិនរន្ធត់ឡើយ ។

៤១ ឱបើដូច្នោះ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរ[ក]មករកព្រះអម្ចាស់ គឺជាព្រះដ៏បរិសុទ្ធចុះ ។ សូមនឹកចាំថា [ខ]ផ្លូវទាំងឡាយ របស់ទ្រង់សុទ្ធតែសុចរិត ។ មើលចុះ ផ្លូវសំរាប់មនុស្ស[គ]គឺចង្អៀត ប៉ុន្តែសន្ទឹងត្រង់នៅចំពោះមុខគេ ហើយ[ឃ]អ្នកឆ្មាំទ្វារ គឺជាព្រះ ដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល; ហើយទ្រង់មិនជួលបាវបំរើនៅទីនោះឡើយ; ហើយគ្មានផ្លូវឯណាផ្សេងទៀតទេ ក្រៅពីតាមទ្វារនោះ; ត្បិតគ្មាននរណាអាចបន្លំបានឡើយ ព្រោះព្រះអម្ចាស់ដ៏ជាព្រះ គឺជាព្រះនាមទ្រង់ ។

៤២ ហើយអ្នកណាដែលគោះ ទ្រង់នឹងបើកឲ្យ; ហើយ[ក]អ្នក[ខ]ប្រាជ្ញ និងអ្នករៀនសូត្រ និងពួកអ្នកមានដែលជាពួកអ្នកមានចិត្តធំដោយមកពីការរៀនសូត្ររបស់គេ និងប្រាជ្ញារបស់គេ ហើយនឹងទ្រព្យសម្បត្តិរបស់គេ — មែនហើយ គឺពួកគេនេះហើយដែល ព្រះអង្គទ្រង់ស្អប់; ហើយលើកលែងពួកគេលះបង់ចរិតទាំងនេះចេញ ហើយព្រមទទួលខ្លួនថា [គ]ល្ងង់ល្ងើនៅចំពោះព្រះ ហើយ[ឃ]បន្ទាប ខ្លួនចុះដល់ជំរៅនៃភាពទន់ទាប នោះទ្រង់នឹងពុំបើកទ្វារឲ្យពួកគេឡើយ ។

៤៣ ប៉ុន្តែការណ៍ទាំងឡាយដែលជារបស់អ្នកប្រាជ្ញ និង

---

៣៤ *ក* សុភា. ១៩:៩.
ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់; សេចក្ដីកុហក.
*ខ* ស.ប. ស្ថាននរក.
៣៥ *ក* និក្ខ. ២០:១៣; ម៉ូសាយ ១៣:២១.
*ខ* ស.ប. ការដាក់ទោសដល់ជីវិត.
៣៦ *ក* ៣ នីហ្វៃ ១២:២៧–២៩.
ស.ប. ព្រហ្មចារីភាព.
៣៧ *ក* ស.ប. ការថ្វាយបង្គំរូបព្រះ.
៣៨ *ក* អាលម៉ា ៤០:១១, ១៣.
៣៩ *ក* ២ នីហ្វៃ ២៨:២០–២២; ៣២:៨; ម៉ូសាយ ២:៣២; ៤:១៤; អាលម៉ា ៣០:៥៣.
*ខ* រ៉ូម ៨:៦.
ស.ប. ខាងរូបកាយ.
*គ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
*ឃ* សុភា. ១១:១៩.
*ង* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៤០ *ក* ស.ប. សេចក្ដីពិត.
*ខ* ១ នីហ្វៃ ១៦:២; ២ នីហ្វៃ ២៨:២៨; ៣៣:៥.
៤១ *ក* ១ នីហ្វៃ ៦:៤; យ៉ាកុប ១:៧; អោមណៃ ១:២៦; មរ៉ូណៃ ១០:៣០–៣២.
*ខ* ២ នីហ្វៃ ៣១:១៧–២១; អាលម៉ា ៣៧:៤៦; គ. និង ស. ១៣២:២២, ២៥.
*គ* លូកា ១៣:២៤; ២ នីហ្វៃ ៣៣:៩; ហេលេ. ៣:២៩–៣០.
*ឃ* ២ នីហ្វៃ ៣១:៩, ១៧–១៨; ៣ នីហ្វៃ ១៤:១៣–១៤; គ. និង ស. ៤៣:៧; ១៣៧:២.
៤២ *ក* ម៉ាថាយ ១១:២៥.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*គ* ១ កូរិន. ៣:១៨–២១.
*ឃ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.

អ្នកឈ្លាសវៃ នឹងត្រូវលាក់ពីគេរហូត — មែនហើយ គឺសុភមង្គល ដែលបានរៀបចំឡើង សំរាប់ពួកបរិសុទ្ធ ។

៤៤ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ សូមចងចាំនូវពាក្យទាំងឡាយរបស់ខ្ញុំចុះ ។ មើលចុះ ខ្ញុំដោះសំលៀកបំពាក់របស់ខ្ញុំ ហើយខ្ញុំ រលាស់នៅពីមុខអ្នករាល់គ្នា; ខ្ញុំអធិស្ឋានដល់ព្រះនៃសេចក្ដីសង្គ្រោះដល់ខ្ញុំ សូមព្រះអង្គទតមើលខ្ញុំ ដោយព្រះនេត្រឈ្វេង យល់របស់ទ្រង់; ហេតុដូច្នោះហើយ អ្នករាល់គ្នានឹងបានដឹងនៅថ្ងៃចុងក្រោយបង្អស់ នៅពេលមនុស្សលោកទាំងអស់ នឹងត្រូវជំនុំជំរះ ចំពោះអំពើទាំងឡាយរបស់ខ្លួន គឺសូមព្រះនៃសាសន៍អ៊ីស្រាអែលបានធ្វើជាសាក្សី ថាខ្ញុំបានរលាស់អំពើទុច្ចរិតទាំងឡាយរបស់អ្នក រាល់គ្នា ចេញពីព្រលឹងខ្ញុំហើយ ហើយថាខ្ញុំឈរភ្លឺថ្លា នៅចំពោះព្រះអង្គ ហើយជ្រះស្រឡះពីលោហិតនៃអ្នករាល់គ្នា ។

៤៥ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរបែរចេញពីអំពើបាបទាំងឡាយរបស់អ្នករាល់គ្នាចុះ; ចូររលាស់ច្រវាក់នៃមេដែលចងក្រៀកបងប្អូនចោលទៅ; ចូរមករកព្រះដែលជាថ្មនៃសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នាវិញ ។

៤៦ ចូរប្រុងប្រៀបព្រលឹងទាំងឡាយរបស់អ្នករាល់គ្នា ចាំថ្ងៃដ៏រុងរឿងនោះ នៅពេលដែលសេចក្ដីយុត្តិធម៌ នឹងត្រូវប្រគល់ដល់ ពួកសុចរិត គឺនៅក្នុងថ្ងៃជំនុំជំរះ ដើម្បីកុំឲ្យបងប្អូនរាល់គ្នារួញដោយសេចក្ដីភិតភ័យ; ដើម្បីកុំឲ្យបងប្អូនរាល់គ្នាចាំនូវកំហុសដ៏អាស្រូវ របស់ខ្លួនដោយឥតខ្ចោះ ហើយត្រូវឲ្យស្រែកថា៖ បរិសុទ្ធ ! បរិសុទ្ធ ! គឺជាសេចក្ដីជំនុំជំរះរបស់ទ្រង់ ឱព្រះអម្ចាស់ជាព្រះដ៏មានមហិទ្ធិឫទ្ធិ អើយ — ប៉ុន្តែខ្ញុំដឹងកំហុសរបស់ខ្ញុំហើយ; ខ្ញុំបានរំលងក្រិត្យវិន័យរបស់ព្រះអង្គ ហើយការរំលងនេះជារបស់ខ្ញុំ; ហើយអារក្សបានយក ខ្លួនខ្ញុំ ហើយធ្វើឲ្យខ្ញុំទៅជាចំណីនៃសេចក្ដីទុក្ខវេទនាដ៏អាស្រូវរបស់វា ។

៤៧ ប៉ុន្តែមើលចុះ បងប្អូនទាំងឡាយរបស់ខ្ញុំអើយ តើជាការចាំបាច់ដែលខ្ញុំត្រូវដាស់បងប្អូន ឲ្យស្គាល់សេចក្ដីពិត ដ៏គួរឲ្យភ័យខ្លាច នៃរឿងទាំងនេះឬអី ? តើគួរឲ្យខ្ញុំធ្វើឲ្យចិត្តអ្នករាល់គ្នាកើតទុក្ខឬ បើសិនជាគំនិតរបស់អ្នករាល់គ្នាបរិសុទ្ធនោះ ? តើខ្ញុំគួរនិយាយត្រង់ៗ ទៅកាន់អ្នករាល់គ្នាតាមការពិត បើសិនជាអ្នករាល់គ្នាគ្មានបាបនោះឬ ?

៤៨ មើលចុះ បើសិនជាអ្នករាល់គ្នាបរិសុទ្ធ ខ្ញុំនឹងនិយាយទៅបងប្អូនអំពីបរិសុទ្ធភាព; ប៉ុន្តែមកពីអ្នករាល់គ្នាមិនបរិសុទ្ធ ហើយអ្នក រាល់គ្នាទុកខ្ញុំជាគ្រូបង្រៀន ហេតុដូច្នោះហើយ ជាការចាំបាច់ដែលខ្ញុំត្រូវបង្រៀនអ្នករាល់គ្នា អំពីផលរបស់អំពើបាប ។

៤៩ មើលចុះ ព្រលឹងខ្ញុំស្អប់ខ្ពើមអំពើបាប ហើយចិត្តខ្ញុំត្រេកអរនឹងអំពើសុចរិត; ហើយខ្ញុំនឹងសរសើរដំកើង ដល់ព្រះនាមដ៏បរិសុទ្ធនៃ ព្រះរបស់ខ្ញុំ ។

៥០ ចូរមក បងប្អូនទាំងឡាយរបស់ខ្ញុំអើយ អស់អ្នកណាដែលស្រេក ចូរមករកទឹកទាំងឡាយចុះ; ហើយអស់អ្នកណាដែលគ្មានប្រាក់ ចូរមកទិញ ហើយបរិភោគចុះ; មែនហើយ មកទិញស្រាទំពាំងបាយជូរ និងទឹកដោះ ដោយមិនបាច់ប្រាក់ ហើយមិនបាច់បង់ថ្លៃផង ។

៥១ ហេតុដូច្នោះហើយ សូមកុំចំណាយប្រាក់លើអ្វី ដែលឥតប្រយោជន៍ ឬក៏ធ្វើការសំរាប់អ្វីដែលពុំអាចធ្វើឲ្យបានស្កប់ស្កល់ឡើយ ។ សូមព្យាយាមស្ដាប់តាមខ្ញុំ ហើយចងចាំនូវពាក្យទាំងឡាយដែលខ្ញុំបាននិយាយចុះ; ហើយចូរមករកព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ហើយទទួលទាននូវអ្វីដែលមិនវិនាស និងអ្វីដែលមិនអាចពុករលួយផង ហើយចូរឲ្យព្រលឹងអ្នករាល់គ្នាបានត្រេកអរនៅក្នុងការធាត់ចុះ ។

៥២ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ សូមចងចាំនូវព្រះបន្ទូលទាំងឡាយរបស់ព្រះនៃអ្នករាល់គ្នាចុះ; សូមអធិស្ឋានដល់ ទ្រង់ជានិច្ចនៅពេលថ្ងៃ ហើយថ្លែងអំណរគុណដល់ព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់នៅពេលយប់ ។ សូមឲ្យចិត្តរបស់អ្នកបានសប្បាយ រីករាយ ។

៥៣ ហើយមើលចុះ សេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ធំណាស់ហ្ន៎ មែនហើយ ការយាងចុះរបស់ព្រះអង្គ មកកាន់កូនចៅ មនុស្ស ធំណាស់ហ្ន៎; ហើយដោយសារភាព

៤៣ *ក* ១ កូរិន. ២:៩–១៦.
៤៤ *ក* យ៉ាកុប ២:១០.
*ខ* យ៉ាកុប ១:១៩.
*គ* យ៉ាកុប ២:២; ម៉ូសាយ ២:២៨.
៤៥ *ក* ២ នីហ្វៃ ២៨:២២; អាលម៉ា ៣៦:១៨.
*ខ* ស.ប. ថ្ម.
៤៦ *ក* ស.ប. សេចក្ដីយុត្តិធម៌.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*គ* ម៉ូសាយ ៣:២៥.
*ឃ* ១ នីហ្វៃ ១:១៤; ម៉ូសេ ២:១.
៤៨ *ក* អាលម៉ា ៣៧:៣២.
*ខ* ស.ប. អំពើបាប.
៤៩ *ក* ១ នីហ្វៃ ១៨:១៦.
៥០ *ក* ស.ប. ទឹករស់.
*ខ* អាលម៉ា ៤២:២៧.
៥១ *ក* អេសាយ ៥៥:១–២.
*ខ* ២ នីហ្វៃ ៣១:២០; ៣២:៣; ៣ នីហ្វៃ ១២:៦.
៥២ *ក* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
៥៣ *ក* ស.ប. សេចក្ដីសញ្ញា.

អស្ចារ្យរបស់ទ្រង់ និងព្រះគុណ និង[ខ]សេចក្ដីមេត្តាករុណារបស់
ទ្រង់ ទើបទ្រង់បានសន្យានឹង យើងថា ពូជយើងនឹងមិនត្រូវបាន
បំផ្លាញចោល ស្របតាមសាច់ឈាមឡើយ ប៉ុន្តែទ្រង់នឹងរក្សាពូជ
យើងទុក ហើយនៅតំណខាងមុខ នោះពួកគេនឹងក្លាយទៅជា[គ]មែក
ដ៏សុចរិតមួយ ចំពោះវង្សអ៊ីស្រាអែល ។
៥៤ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់
និយាយទៅអ្នកថែមទៀត; ប៉ុន្តែទុកដល់ថ្ងៃស្អែកសិន ខ្ញុំនឹងប្រកាស
ប្រាប់នូវពាក្យទាំងឡាយ ដែលនៅសល់ទាំងប៉ុន្មាន ដល់អ្នក
រាល់គ្នាទៀត ។ អាម៉ែន ៕

## ជំពូកទី ១០

*ពួកសាសន៍យូដានឹងឆ្កាងព្រះរបស់គេ — ពួកគេនឹងត្រូវខ្ចាត់ខ្ចាយ ទាល់តែពួកគេចាប់ផ្ដើមជឿដល់ទ្រង់វិញ — ទ្វីបអាមេរិកនឹងបានទៅ ជាដែនដីនៃឥស្សរភាពមួយ ដែលគ្មានស្ដេចគ្រប់គ្រង — ចូរសម្រុះសម្រួលនឹងព្រះ ហើយទទួលសេចក្ដីសង្គ្រោះតាមរយៈព្រះគុណ របស់ទ្រង់ ។ ប្រមាណជាឆ្នាំ ៥៥៩—៥៤៥ ម.គ.ស.។*

ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់ទាំងឡាយអើយ ខ្ញុំ
យ៉ាកុប និយាយទៅអ្នករាល់គ្នាម្ដងទៀត ស្ដីអំពី[ក]មែកដ៏សុចរិតនេះ
ដែលខ្ញុំបាននិយាយមក ។
២ ត្បិតមើលចុះ [ក]សេចក្ដីសន្យាទាំងឡាយដែលពួកយើងបាន
ទទួលនោះ គឺជាសេចក្ដីសន្យាដល់យើង ស្របតាម
សាច់ឈាម; ហេតុដូច្នោះហើយ ដូចជាតាមការណ៍ដែលបាន
បង្ហាញដល់ខ្ញុំហើយថា កូនចៅរបស់យើងជាច្រើននឹងត្រូវ
វិនាសនៅក្នុងសាច់ឈាម ពីព្រោះតែការឥតជំនឿ ទោះជាយ៉ាង
ណាក៏ដោយ គង់តែព្រះទ្រង់នឹងមានសេចក្ដីមេត្តាករុណាដល់
មនុស្សជាច្រើន; ហើយកូនចៅ របស់យើងនឹងត្រូវ
បានសាងឡើងវិញ ដើម្បីឲ្យពួកគេអាចមកឯអ្វី ដែល
នឹងផ្ដល់ដល់ពួកគេនូវការចេះដឹងដ៏ពិត ពីព្រះដ៏ប្រោសលោះ
របស់ពួកគេ ។
៣ ហេតុដូច្នោះហើយ ដូចជាខ្ញុំបានប្រាប់អ្នករាល់គ្នាមក
ហើយនោះថា គឺជាការចាំបាច់ថាព្រះគ្រីស្ទ — ត្បិតកាលយប់
មិញ [ក]ទេវតាបាន និយាយមកខ្ញុំថា នោះគឺជាព្រះនាមរបស់
ទ្រង់ — ថាទ្រង់នឹង[ខ]យាងមកក្នុងចំណោមពួកសាសន៍យូដា
គឺនៅក្នុងចំណោមផ្នែកមនុស្ស លោកដែលទុច្ចរិតជាង; ហើយ
ពួកគេនឹង[គ]ឆ្កាងទ្រង់ — ត្បិតជាព្រះហឫទ័យរបស់ព្រះរបស់យើង
យ៉ាងដូច្នោះហើយ ហើយគ្មានសាសន៍ ណាទៀតនៅលើផែនដី
ដែលនឹង[ឃ]ឆ្កាង[ង]ព្រះរបស់គេឡើយ ។
៤ ព្រោះបើសិនជាមាន[ក]អព្ភូតហេតុដ៏អស្ចារ្យទាំងនេះកើតឡើង
ក្នុងចំណោមសាសន៍ផ្សេងៗទៀត នោះពួកគេនឹងប្រែចិត្ត
ហើយដឹង ថា ទ្រង់នឹងទៅជាព្រះរបស់ពួកគេ ។
៥ ប៉ុន្តែពីព្រោះមកពី[ក]ឧបាយកលផ្នែកសង្ឃ និងអំពើទុច្ចរិត
ទាំងឡាយ ទើបពួកអ្នកដែលនៅក្រុងយេរូសាឡិម នឹង
ពង្រឹងករបស់ពួកគេ ទាស់នឹងទ្រង់ រហូតដល់ព្រះអង្គត្រូវគេឆ្កាង ។
៦ ហេតុដូច្នោះហើយ ពីព្រោះមកពីអំពើទុច្ចរិតទាំងឡាយ
របស់គេ ទើបការបំផ្លិចបំផ្លាញ អំណត់អត់ ជម្ងឺអាសន្នរោគ
និងការខ្ចាយ ឈាម ត្រូវធ្លាក់មកលើគេ; ឯពួកអ្នកដែល
មិនត្រូវបានបំផ្លាញ នោះនឹងត្រូវ[ក]ខ្ចាត់ព្រាត់ទៅក្នុងចំណោម
អស់ទាំងសាសន៍ ។
៧ ប៉ុន្តែមើលចុះ [ក]ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូល
ដូច្នេះថា៖ [ខ]ដល់ថ្ងៃណាដែលគេនឹងជឿដល់យើងថា យើងជា
ព្រះគ្រីស្ទ ខណៈនោះ យើងបានធ្វើសេចក្ដីសញ្ញាជាមួយនឹងពួក
អយ្យកោរបស់គេថា ពួកគេនឹងបានសាងឡើងវិញ នៅក្នុង
សាច់ឈាម នៅលើ ផែនដី គឺត្រឡប់ទៅឯដែនដីទាំងឡាយ
នៃកេរ្តិ៍អាកររបស់គេវិញ ។

---

៥៣ *ខ* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
*គ* ស.ប. ចំការទំពាំងបាយជូរនៃព្រះ
អម្ចាស់.
**១០** ១*ក* ១ នីហ្វៃ ១៥:១២—១៦;
២ នីហ្វៃ ៣:៥;
យ៉ាកុប ៥:៤៣—៤៥.
២ *ក* ១ នីហ្វៃ ២២:៨;
៣ នីហ្វៃ ៥:២១—២៦; ២១:៤—៧.
៣ *ក* ២ នីហ្វៃ ២៥:១៩; យ៉ាកុប ៧:៥;
ម៉ូរ៉ូណៃ ៧:២២.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យ
ព្យាករណ៍ទាំងឡាយអំពីកំណើត
និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
*គ* ១ នីហ្វៃ ១១:៣៣;
ម៉ូសាយ ៣:៩;
គ. និង ស. ៤៥:៥២—៥៣.
*ឃ* លូកា ២៣:២០—២៤.
*ង* ១ នីហ្វៃ ១៩:១០.
៤ *ក* ស.ប. អព្ភូតហេតុ.
៥ *ក* លូកា ២២:២.
ស.ប. ឧបាយកលផ្នែកសង្ឃ.
៦ *ក* ១ នីហ្វៃ ១៩:១៣—១៤.
ស.ប. អ៊ីស្រាអែល — ការ
ខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
៧ *ក* ស.ប. ព្រះអម្ចាស់.
*ខ* ២ នីហ្វៃ ២៥:១៦—១៧.

៨ ហើយហេតុការណ៍នឹងកើតឡើងថា ពួកគេនឹងត្រូវ
បានប្រមូលមកពីការបែកខ្ញែកដ៏យូរ ពីពួកកោះក្នុងសមុទ្រ និង
ពីទិសទាំងបួននៃ ផែនដី; រីឯសាសន៍ទាំងឡាយនៃពួកសាសន៍
ដទៃ នឹងបានធំអស្ចារ្យ ចំពោះភ្នែកយើង ក្នុងការនាំពួកគេ
ត្រឡប់មកដែនដី ដែលជា កេរ្តិ៍អាកររបស់គេវិញ ព្រះទ្រង់មាន
ព្រះបន្ទូលថាដូច្នោះ ។
៩ មែនហើយ អស់ទាំងមហាក្សត្រនៃពួកសាសន៍ដទៃ
នឹងធ្វើជាឪពុកចិញ្ចឹមរបស់គេ ហើយអគ្គមហេសីនៃគេ នឹងធ្វើ
ជាម្ដាយបំបៅ របស់គេ; ហេតុដូច្នោះហើយ សេចក្ដីសន្យាទាំង
ឡាយរបស់ព្រះអម្ចាស់ ប្រសើរណាស់ ចំពោះពួកសាសន៍
ដទៃ ត្បិតទ្រង់មានព្រះ បន្ទូលថាដូច្នោះ ហើយតើអ្នកណាអាច
ប្រកែកបាន ?
១០ ប៉ុន្តែមើលចុះ ព្រះទ្រង់មានព្រះបន្ទូលថា ដែនដីនេះនឹង
ទុកជាដែនដីនៃកេរ្តិ៍អាកររបស់អ្នក ឯពួកសាសន៍ដទៃ គេនឹង
មានពរនៅ លើដែនដីនេះ ។
១១ ហើយដែនដីនេះនឹងត្រូវបានទៅជាដែនដីនៃសេរីភាព
មួយ សំរាប់ពួកសាសន៍ដទៃ ហើយនឹងពុំមានស្ដេចនៅលើដែនដី
ដែលនឹងលើកឡើងចំពោះពួកសាសន៍ដទៃឡើយ ។
១២ ហើយយើងនឹងពង្រឹងដែនដីនេះ ដើម្បីតទល់នឹងអស់
ទាំងសាសន៍ដទៃ ។
១៣ ហើយអ្នកណាដែលប្រឆាំងនឹងក្រុងស៊ីយ៉ូន នោះនឹង
ត្រូវវិនាស ព្រះទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៤ ត្បិតអ្នកណាដែលលើកស្ដេចឡើងឲ្យមកប្រឆាំង
នឹងយើង នោះនឹងត្រូវវិនាស ព្រោះយើងជាព្រះ អម្ចាស់
គឺជាស្ដេចលើមេឃ ហើយជាស្ដេចរបស់ពួកគេ; ហើយយើង
នឹងធ្វើជាពន្លឺដល់គេជាដរាប ដល់អស់អ្នកណាដែលស្ដាប់តាម
ពាក្យទាំងឡាយរបស់យើង ។
១៥ ហេតុដូច្នោះហើយ ដោយមកពីហេតុនេះ គឺដើម្បីឲ្យ
សេចក្ដីទាំងឡាយសញ្ញារបស់យើងអាចបានបំពេញ ដែល
យើងបានធ្វើជា មួយនឹងកូនចៅមនុស្សថា យើងត្រូវ
ធ្វើនៅពេលគេនៅក្នុងសាច់ឈាមនៅឡើយ នោះយើងត្រូវ
តែ បំផ្លាញទាំងកិច្ចការសម្ងាត់ទាំង ឡាយនៃសេចក្ដីងងឹត និង
ឃាតកម្ម ហើយនឹងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ។
១៦ ហេតុដូច្នោះហើយ អ្នកណាដែលប្រឆាំងនឹងក្រុងស៊ីយ៉ូន
ទាំងសាសន៍យូដា និងសាសន៍ដទៃ ទាំងបាវគេ និងអ្នកសេរី
ទាំងប្រុស និងស្រី នឹងត្រូវវិនាស; ព្រោះពួកគេនេះហើយដែល
ជាពេស្យានៃអស់ទាំងផែនដី; ព្រោះអ្នកណាដែលមិនតាមយើង
គឺខ្មាំងនឹងយើង ព្រះរបស់ យើងទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៧ ត្បិតយើងនឹងបំពេញពាក្យសន្យាទាំងឡាយរបស់យើង
ដែលយើងបានធ្វើជាមួយនឹងកូនចៅមនុស្សថា យើង
នឹងធ្វើនៅពេល ដែលពួកគេនៅក្នុងសាច់ឈាមនៅឡើយ —
១៨ ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ព្រះរបស់យើងទ្រង់មានព្រះបន្ទូលដូច្នេះថា៖ យើងនឹងធ្វើទុក្ខ
ដល់ពូជ របស់អ្នក ដោយដៃនៃពួកសាសន៍ដទៃ; ទោះជាយ៉ាង
ណាក៏ដោយ គង់តែយើងនឹងបន្ទន់ចិត្តពួកសាសន៍ដទៃ ដើម្បីឲ្យ
ពួកសាសន៍បាន ទៅដូចជាឪពុករបស់ពួកគេ; ហេតុដូច្នោះហើយ
ពួកសាសន៍ដទៃនឹងមានពរ ហើយនឹងត្រូវបានរាប់ក្នុងចំណោមវ
ង្សអ៊ីស្រាអែលដែរ ។
១៩ ហេតុដូច្នោះហើយ យើងនឹងញែកដីនេះទុកឲ្យពូជរបស់
អ្នក និងពួកអ្នកណាដែលនឹងត្រូវបានរាប់ក្នុងចំណោមពូជរបស់

៨ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* ១ នីហ្វៃ ២២:៤; ២ នីហ្វៃ ១០:២០–២២; គ. និង ស. ១៣៣:៨.
*គ* ១ នីហ្វៃ ២២:៨.
៩ *ក* អេសាយ ៤៩:២២–២៣.
*ខ* ១ នីហ្វៃ ២២:៨–៩; គ. និង ស. ៣:១៩–២០.
១០ *ក* ២ នីហ្វៃ ៦:១២.
១១ *ក* ស.ប. សេរី, សេរីភាព.
*ខ* ម៉ូសាយ ២៩:៣១–៣២.
១៣ *ក* ១ នីហ្វៃ ២២:១៤, ១៩.
*ខ* អេសាយ ៦០:១២.
១៤ *ក* អាលម៉ា ៥:៥០; គ. និង ស. ៣៨:២១–២២; ១២៨:២២–២៣; ម៉ូសេ ៧:៥៣.
*ខ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
១៥ *ក* ស.ប. សេចក្ដីសញ្ញា.
*ខ* ហេលេ. ៣:២៣. ស.ប. បក្សព័ន្ធសម្ងាត់.
*គ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
១៦ *ក* ស.ប. ស៊ីយ៉ូន.
*ខ* ១ នីហ្វៃ ១៣:៤–៥.
*គ* ១ នីហ្វៃ ១៤:១០.
*ឃ* ១ នីហ្វៃ ២២:១៣–២៣; ២ នីហ្វៃ ២៨:១៥–៣២; ៣ នីហ្វៃ ១៦:៨–១៥; អេធើរ ២:៩.
*ង* ម៉ាថាយ ១២:៣០.
១៧ *ក* គ. និង ស. ១:៣៨.
១៨ *ក* លូកា ១៣:២៨–៣០; គ. និង ស. ៤៥:៧–៣០.
*ខ* អេភេ. ៣:៦.
*គ* កាឡាទី ៣:៧, ២៩; ១ នីហ្វៃ ១៤:១–២; ៣ នីហ្វៃ ១៦:១៣; ២១:៦, ២២; ៣០:២; អ័ប្រា. ២:៩–១១.
១៩ *ក* ២ នីហ្វៃ ៣:២.

អ្នកជា ដរាប គឺទុកជាដែនដីនៃកេរ្តិ៍អាកររបស់ពួកគេ; ព្រោះព្រះទ្រង់មានព្រះបន្ទូលប្រាប់ខ្ញុំថា ដែនដីនេះគឺជាដែនដីដ៏ជំរើសមួយ គឺលើដែនដី ឯទៀតទាំងអស់ ហេតុដូច្នោះហើយ យើងនឹងឲ្យអស់ទាំងមនុស្សដែលនៅលើដែនដីនោះ ថ្វាយបង្គំដល់យើង ព្រះទ្រង់មាន ព្រះបន្ទូលថាដូច្នោះ ។

២០ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ដោយឃើញថា ព្រះរបស់យើងដែលប្រកបដោយសេចក្ដីមេត្តាករុណា ទ្រង់បានប្រទានការចេះដឹងដ៏ធំដល់យើងពីរឿងទាំងនេះ នោះចូរយើងនឹកចាំដល់ទ្រង់ ហើយទំលាក់អំពើបាបទាំងឡាយរបស់យើង មួយអន្លើសិន ហើយកុំជ្រប់មុខ ត្បិតយើងមិនត្រូវបានបោះបង់ចោលទេ; ទោះជាយ៉ាងណាក៏ដោយ គង់តែយើងត្រូវបានដេញចេញ ពីដែនដីនៃកេរ្តិ៍អាកររបស់យើងដែរ; ប៉ុន្តែយើងត្រូវបាននាំមកឯដែនដីមួយ ដែលប្រសើរលើសលែងទៅទៀត ព្រោះព្រះអម្ចាស់ទ្រង់ បានយកសមុទ្រធ្វើជាផ្លូវឲ្យយើង ហើយយើងនៅលើកោះក្នុងសមុទ្រ ។

២១ ប៉ុន្តែពាក្យសន្យាទាំងឡាយរបស់ព្រះធំណាស់ហ្ន៎ ចំពោះពួកអ្នកដែលនៅលើកោះទាំងឡាយក្នុងសមុទ្រ; ហេតុដូច្នោះហើយ ពាក្យថាកោះទាំងឡាយ នោះច្បាស់ជាមានកោះឯទៀតក្រៅពីនេះ ហើយកោះទាំងនោះ មានបងប្អូនរបស់យើងរស់នៅដែរ ។

២២ ត្បិតមើលចុះ មានពេលខ្លះដែលព្រះអម្ចាស់ដ៏ជាព្រះទ្រង់នាំចេញពីវង្សអ៊ីស្រាអែល ស្របតាមព្រះហឫទ័យ និងបំណងរបស់ ទ្រង់ ។ ហើយឥឡូវនេះ មើលចុះ ព្រះអម្ចាស់ទ្រង់នឹកចាំដល់ពួកគេទាំងអស់គ្នាដែលត្រូវបានកាត់ចេញ ហេតុដូច្នោះហើយទ្រង់ក៏នឹកចាំដល់ពួកយើងដែរ ។

២៣ ហេតុដូច្នោះហើយ ចូររីករាយក្នុងចិត្តឡើង ហើយចូរចងចាំថា អ្នករាល់គ្នាបានសេរីភាព ដើម្បីធ្វើអ្វីៗសំរាប់ខ្លួនឯង — គឺដើម្បីរើសយកផ្លូវទៅឯសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច ឬក៏ផ្លូវទៅឯជីវិតដ៏នៅអស់កល្បជានិច្ចវិញ ។

២៤ ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរសម្រុះសម្រួលខ្លួនទៅតាមបំណងនៃព្រះ ហើយមិនមែនតាមបំណង នៃអារក្ស និងរបស់ខាងសាច់ឈាមទេ; ហើយចូរចងចាំថា បន្ទាប់ពីបងប្អូនរាល់គ្នាបានស្រុះស្រួលជាមួយនឹងព្រះហើយនោះ គឺមានតែដោយសារ និងតាមរយៈព្រះគុណរបស់ព្រះប៉ុណ្ណោះ ដែលបងប្អូនរាល់គ្នាបានសង្គ្រោះ ។

២៥ ហេតុដូច្នោះហើយ សូមព្រះទ្រង់ប្រោសឲ្យអ្នករាល់គ្នារស់ពីសេចក្ដីស្លាប់ ដោយអំណាចនៃដំណើររស់ឡើងវិញ ហើយព្រម ទាំងពីសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ចដែរ ដោយអំណាចនៃដង្វាយធួន ដើម្បីឲ្យអ្នករាល់គ្នាអាចបានទទួលចូលក្នុងនគរដ៏អស់កល្ប ជានិច្ចនៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាអាចសរសើរដំកើងទ្រង់ តាមរយៈព្រះគុណដ៏ឧត្ដមរបស់ទ្រង់ ។ អាម៉ែន ៕

## ជំពូកទី ១១

*យ៉ាកុបបានឃើញព្រះដ៏ប្រោសលោះរបស់លោក — ក្រឹត្យវិន័យលោកម៉ូសេ ជាគំរូអំពីព្រះគ្រីស្ទ ហើយបញ្ជាក់ថាទ្រង់នឹងយាងមកមែន ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយឥឡូវនេះ យ៉ាកុបបាននិយាយជាច្រើនសេចក្ដីទៀតទៅប្រជាជនខ្ញុំ នៅពេលនោះ; ទោះជាយ៉ាងណាក៏ដោយ មានតែរឿង ប៉ុន្មាននេះទេដែលខ្ញុំបានឲ្យសរសេរទុក ព្រោះរឿងទាំងឡាយដែលខ្ញុំសរសេរទុក ខ្ញុំឃើញថាល្មមគ្រប់គ្រាន់ហើយ ។

២ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ សរសេរពាក្យពេចន៍របស់លោកអេសាយថែមទៀត ព្រោះព្រលឹងខ្ញុំត្រេកអរចំពោះពាក្យពេចន៍របស់ លោក ។ ត្បិតខ្ញុំនឹងប្រៀបពាក្យទាំងឡាយរបស់លោក ទៅលើប្រជាជនខ្ញុំ ហើយខ្ញុំនឹងផ្សាយពាក្យទាំងឡាយដល់កូនចៅខ្ញុំទាំងអស់ ត្បិតលោកពិតជាបានឃើញព្រះដ៏ប្រោសលោះរបស់ខ្ញុំ ដូចជាខ្ញុំបានឃើញទ្រង់ដែរ ។

៣ ហើយយ៉ាកុប ដែលជាប្អូនខ្ញុំ ក៏បានឃើញទ្រង់ដូចខ្ញុំបានឃើញដែរ; ហេតុដូច្នោះហើយ ខ្ញុំនឹងផ្សាយពាក្យទាំងឡាយរបស់ពួកគេ ដល់កូនចៅរបស់ខ្ញុំ ដើម្បីបញ្ជាក់ដល់កូនចៅខ្ញុំថា

២០ *ក* ១ នីហ្វៃ ២:១–៤.
*ខ* ១ នីហ្វៃ ២:២០.
ស.ប. ដែនដីសន្យា.
*គ* ១ នីហ្វៃ ១៨:៥–២៣.
*ឃ* អេសាយ ១១:១០–១២.
២១ *ក* ១ នីហ្វៃ ១៩:១៥–១៦; ២២:៤.
២២ *ក* ១ នីហ្វៃ ២២:៤.
២៣ *ក* ស.ប. សិទ្ធិជ្រើសរើស.
*ខ* ២ នីហ្វៃ ២:១៦.
*គ* ចោទិ. ៣០:១៩.
២៤ *ក* ស.ប. ព្រះគុណ.
*ខ* ស.ប. សេចក្ដីសង្គ្រោះ.
២៥ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
**១១** ១*ក* ២ នីហ្វៃ ៦:១–១០.
*ខ* ២ នីហ្វៃ ៣១:១.
២ *ក* ៣ នីហ្វៃ ២៣:១.
*ខ* ស.ប. ព្រះដ៏ប្រោសលោះ.
៣ *ក* ២ នីហ្វៃ ២:៣; យ៉ាកុប ៧:៥.

ពាក្យទាំងឡាយរបស់ខ្ញុំជាពាក្យពិត ។ ហេតុដូច្នោះហើយ ព្រះទ្រង់មានព្រះបន្ទូលថា ដោយពាក្យពេចន៍របស់អ្នកទាំងបី នោះយើងនឹងតាំងពាក្យរបស់យើងឡើង ។ ទោះជាយ៉ាងនេះក៏ដោយ គង់តែព្រះទ្រង់បានបញ្ជូន សាក្សីថែមទៀត ហើយព្រះអង្គបានបញ្ជាក់អស់ទាំងពាក្យរបស់ព្រះអង្គ ។

៤ មើលចុះ ព្រលឹងខ្ញុំត្រេកអរក្នុងការបញ្ជាក់ដល់ប្រជាជនខ្ញុំនូវការពិតអំពីការយាងមកនៃព្រះគ្រីស្ទ; ហើយដោយគោលបំណងនេះ ទើបក្រិត្យវិន័យលោកម៉ូសេត្រូវបានប្រទានមក; ហើយអស់ទាំងអ្វីដែលព្រះទ្រង់បានប្រទានដល់មនុស្ស ចាប់តាំងពីកំណើតលោកិយមក គឺជាគំរូអំពីព្រះអង្គ ។

៥ ហើយព្រលឹងខ្ញុំក៏ត្រេកអរចំពោះសេចក្ដីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ ដែលទ្រង់បានធ្វើជាមួយនឹងពួកអយ្យកោរបស់យើងដែរ; មែនហើយ ព្រលលឹងខ្ញុំត្រេកអរដល់ព្រះគុណរបស់ទ្រង់ ហើយដល់សេចក្ដីយុត្តិធម៌ និងព្រះចេស្ដា និងសេចក្ដីមេត្តាករុណារបស់ទ្រង់ ក្នុងផែនការដ៏ធំ ហើយអស់កល្បជានិច្ចនៃការរំដោះពីសេចក្ដីស្លាប់ ។

៦ ហើយព្រលឹងខ្ញុំត្រេកអរក្នុងការបញ្ជាក់ដល់ប្រជាជនខ្ញុំថា លើកលែងតែព្រះគ្រីស្ទនឹងយាងមក នោះមនុស្សលោកទាំងអស់នឹងត្រូវ វិនាស ។

៧ ត្បិតបើសិនជាគ្មានព្រះគ្រីស្ទទេ នោះក៏គ្មានព្រះដែរ; ហើយបើសិនជាគ្មានព្រះទេ នោះក៏គ្មានយើងរាល់គ្នាដែរ ព្រោះមិនអាច មានការបង្កបង្កើតបានឡើយ ។ ប៉ុន្តែមានព្រះមួយអង្គ ហើយទ្រង់ជាព្រះគ្រីស្ទ ហើយទ្រង់នឹងយាងមក ក្នុងពេលកំណត់របស់ទ្រង់ ។

៨ ហើយឥឡូវនេះ ខ្ញុំសរសេរពាក្យរបស់លោកអេសាយខ្លះថា បើសិនជាប្រជាជនខ្ញុំណាម្នាក់បានឃើញពាក្យទាំងនេះហើយ នោះគេអាចលើកចិត្តគេឡើង ហើយអរសប្បាយសំរាប់មនុស្សលោកទាំងអស់ ។ ឥឡូវនេះ នេះគឺជាពាក្យទាំងឡាយ ហើយអ្នក រាល់គ្នាអាចប្រៀបពាក្យទាំងឡាយនេះ ទៅលើខ្លួនអ្នក ហើយទៅលើមនុស្សលោកទាំងអស់ ៕

## ជំពូកទី ១២

*អេសាយឃើញព្រះវិហារនៃថ្ងៃក្រោយ, ការប្រមូលសាសន៍អ៊ីស្រាអែល, និងសេចក្ដីជំនុំជំរះ និងសេចក្ដីសុខសាន្តនៃរយៈពេលមួយ ពាន់ឆ្នាំ — ពួកឆ្មើងឆ្មៃ និងពួកទុច្ចរិតនឹងត្រូវបន្ទាបចុះ នៅពេលការយាងមកលើកទីពីរ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ២ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ពាក្យដែលអេសាយ ជាកូនអ័ម៉ូស បានឃើញអំពីដំណើរស្រុកយូដា និងក្រុងយេរូសាឡិម គឺៈ

២ ហើយហេតុការណ៍នឹងកើតឡើងថា នៅគ្រាចុងក្រោយបង្អស់ នោះភ្នំជាទីសាងព្រះវិហារនៃព្រះអម្ចាស់ នឹងបានតាំងឡើងខ្ពស់លើសអស់ទាំងភ្នំធំៗ ហើយនឹងបានដំកើងឡើង ប្រសើរជាងអស់ទាំងភ្នំតូចៗដែរ ហើយអស់ទាំងសាសន៍នឹងចូលហូរហែទៅក្នុងទីនោះ ។

៣ ឯប្រជាជាតិជាច្រើន គេនឹងទៅដោយពោលថា ចូរមក ហើយចូរយើងឡើងទៅឯភ្នំនៃព្រះអម្ចាស់ ដល់ព្រះវិហារនៃព្រះរបស់ពួក យ៉ាកុបចុះ; ហើយទ្រង់នឹងបង្រៀនយើងពីផ្លូវទាំងឡាយរបស់ទ្រង់ ហើយយើងនឹងដើរតាមផ្លូវទាំងឡាយរបស់ទ្រង់; ត្បិតក្រិត្យវិន័យនឹង ចេញពីក្រុងស៊ីយ៉ូនទៅ ហើយព្រះបន្ទូលនៃព្រះអម្ចាស់ពីក្រុងយេរូសាឡិមដែរ ។

៤ ហើយទ្រង់នឹងជំនុំជំរះនៅក្នុងចំណោមសាសន៍ទាំងឡាយ ហើយនឹងសំរេចរឿងដល់ប្រជាជនជាច្រើន ហើយពួកគេនឹង

៣ *ខ* ២ នីហ្វៃ ២៧:១២;
អេធើរ ៥:២–៤;
គ. និង ស. ៥:១១.
៤ *ក* ២ នីហ្វៃ ៣១:២.
*ខ* យ៉ាកុប (ពម) ៤:៥;
យ៉ារ៉ុម ១:១១;
អាលម៉ា ២៥:១៥–១៦;
អេធើរ ១២:១៩.
*គ* ២ នីហ្វៃ ៥:១០.
៥ *ក* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
៦ *ក* ម៉ូសាយ ៣:១៥.
៧ *ក* ២ នីហ្វៃ ២:១៣.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
**១២** ១*ក* គម្ពីរអេសាយ ជំពូកទី ២–១៤ គឺបានដកស្រង់ចេញមកពីផ្ទាំងលង្ហិន ដោយនីហ្វៃ នៅក្នុង ២ នីហ្វៃ ១២–២៤; មានពាក្យខុសពីគ្នាខ្លះៗដែលត្រូវឲ្យសំគាល់.
*ខ* ហេ. *ខាសា* មានន័យថា «និមិត្តឃើញ» ។ មានន័យថាលោកអេសាយបានទទួលសាររបស់លោក តាមរយៈការនិមិត្តពីព្រះអម្ចាស់ ។
២ *ក* យ៉ូអែល ៣:១៧.
ស.ប. ស៊ីយ៉ូន.
*ខ* ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់.
*គ* គ. និង ស. ៤៩:២៥.
៣ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* ហេ. ការបង្រៀន ឬ លទ្ធិ.
៤ *ក* ២ នីហ្វៃ ២១:២–៩.

យកដាវ របស់ខ្លួនដំធ្វើជាផាលនង្គ័ល ហើយលំពែងគេធ្វើជា
ដង្កាវវិញ — សាសន៍មួយនឹងមិនលើកដាវ ទាស់នឹងសាសន៍មួយ
ទៀតឡើយ ឬក៏មិនហាត់រៀនធ្វើសឹកសង្គ្រាមទៀតដែរ ។
៥ ឱពួកវង្សនៃយ៉ាកុបអើយ ចូរមក ចូរយើងដើរក្នុងពន្លឺនៃ
ព្រះអម្ចាស់ចុះ; មែនហើយ ចូរមក ត្បិតអស់អ្នករាល់គ្នាបានវ
ង្វេងទៅ តាមផ្លូវទុច្ចរិតរៀងខ្លួន ។
៦ ឱព្រះអម្ចាស់អើយ ហេតុនេះបានជាទ្រង់បោះ
បង់ចោលពួកវង្សយ៉ាកុប ជារាស្ត្រទ្រង់ចេញ ពីព្រោះមាន
ទំនៀមទំលាប់ពីស្រុកខាង កើតបានចូលមកពេញទី ហើយនឹង
ស្តាប់តាមពួកគ្រូទាយ ដូចជាសាសន៍ភីលីស្ទីន ហើយពួកគេ
ចងសម្ព័ន្ធមិត្រជាមួយនឹងកូនចៅ របស់ពួកសាសន៍ដទៃ ។
៧ ស្រុករបស់ពួកគេក៏ពោរពេញទៅដោយមាស និងប្រាក់
ឯទ្រព្យសម្បត្តិរបស់ពួកគេ នោះរាប់មិនអស់ឡើយ; ស្រុករបស់
ពួកគេក៏ ពោរពេញដោយសេះ ហើយរទេះចម្បាំងទាំងឡាយ
របស់ពួកគេ ក៏រាប់មិនអស់ដែរ ។
៨ ស្រុករបស់ពួកគេក៏ពោរពេញដោយរូបព្រះដែរ; ពួក
គេថ្វាយបង្គំចំពោះស្នាដៃរបស់ខ្លួន គឺជារបស់ដែលម្រាមដៃគេ
បានធ្វើឡើង ។
៩ ហើយមនុស្សធម្មតាមិនបានឱនចុះ ឯពួកអ្នកធំមិនបាន
បន្ទាបខ្លួនទេ ដូច្នេះ សូមកុំអត់ទោសដល់គេឡើយ ។
១០ ឱពួកទុច្ចរិតអើយ ចូរឲ្យចូលទៅក្នុងរូងថ្ម ហើយពួនខ្លួនទៅ
ក្នុងធូលីដីចុះ ព្រោះសេចក្តីកោតខ្លាច ដល់ព្រះអម្ចាស់ ហើយ
សិរីល្អ នៃឫទ្ធានុភាពរបស់ទ្រង់នឹងវាយអ្នក ។
១១ ហើយហេតុការណ៍នឹងកើតឡើងថា ឫកខ្ពស់របស់មនុស្ស
នឹងត្រូវបន្ទាបចុះ ហើយចិត្តឆ្មើងឆ្មៃរបស់មនុស្សនឹងត្រូវបង្អោន
ទាប វិញ នៅគ្រានោះមានតែព្រះអម្ចាស់មួយអង្គប៉ុណ្ណោះទេ
ដែលនឹងបានដំកើងឡើង ។
១២ ត្បិតថ្ងៃនៃព្រះអម្ចាស់នៃពួកពលបរិវារ នឹងមកលើគ្រប់ទាំង
សាសន៍ មែនហើយ មកលើគ្រប់រូប; មែនហើយ មក
លើគ្រប់ទាំងឫក ខ្ពស់ និងចិត្តឆ្មើងឆ្មៃ ព្រមទាំងលើគ្រប់អ្វីទាំង
អស់ ដែលបានលើកឡើងផង ហើយនោះ នឹងត្រូវទ្រង់
បន្ទាបចុះវិញ ។
១៣ មែនហើយ ហើយថ្ងៃនៃព្រះអម្ចាស់នឹងមកលើអស់
ទាំងដើមតាត្រៅ នៅភ្នំល្បាណូន ព្រោះជាភ្នំខ្ពស់
ហើយដំកើងឡើង និងលើ គ្រប់ទាំងដើមម៉ៃសាក់ នៅស្រុក
បាសានដែរ ។
១៤ ហើយមកលើអស់ទាំងភ្នំខ្ពស់ និងភ្នំតូចៗ និងលើគ្រប់
សាសន៍ដែលបានដំកើងឡើង និងលើគ្រប់ទាំងប្រជាជន;
១៥ ហើយមកលើអស់ទាំងប៉មយ៉ាងខ្ពស់ និងលើកំផែងមាន
គ្រឿងចម្បាំង;
១៦ ហើយមកលើអស់ទាំងនាវានៅក្នុងសមុទ្រ និងលើអស់
ទាំងនាវាស្រុកតើស៊ីស ហើយលើអ្វីៗទាំងអស់ដែល
គាប់ដល់ភ្នែកដែរ ។
១៧ ហើយសណ្ឋានខ្ពស់របស់មនុស្សនឹងត្រូវបង្អោនទាប
ឯសេចក្តីឆ្មើងឆ្មៃរបស់មនុស្ស ក៏នឹងត្រូវបន្ទាបចុះ; នៅគ្រានោះ
នឹងមានតែ ព្រះអម្ចាស់មួយអង្គប៉ុណ្ណោះទេ ដែលនឹងបាន
ដំកើងឡើង ។
១៨ ហើយរូបព្រះទាំងឡាយនឹងសាបសូន្យបាត់ទៅអស់រលីង ។
១៩ ឯមនុស្ស គេនឹងចូលទៅក្នុងរអាងថ្ម ហើយក្នុងរូងដី
ត្បិតសេចក្តីស្ញែងខ្លាចនៃព្រះអម្ចាស់នឹងមកលើគេ ហើយសិរីល្អនៃ
ឫទ្ធានុភាព របស់ទ្រង់នឹងវាយគេ ក្នុងកាលដែលទ្រង់ក្រោកឡើង
ដើម្បីនឹងអង្រួនផែនដី ដោយឫទ្ធិយ៉ាងអស្ចារ្យ ។
២០ នៅគ្រានោះ មនុស្សនឹងបោះចោលរូបព្រះទាំងឡាយ
របស់ខ្លួនដែលធ្វើពីមាស និងរូបព្រះទាំងឡាយដែលធ្វើពីប្រាក់
ជារបស់ ដែលគេបានធ្វើសំរាប់នឹងថ្វាយបង្គំ ទៅឲ្យកណ្តុរ
ហើយនឹងប្រចៀវ ។
២១ ដើម្បីនឹងចូលទៅក្នុងរអាងថ្ម ហើយក្នុងក្រហែងថ្មរ
ខិញរខុញ ឲ្យបានរួចពីសេចក្តីស្ញែងខ្លាចនៃព្រះអម្ចាស់ ដែល

៥ *ក* ២ នីហ្វៃ ២៨:១៤;
ម៉ូសាយ ១៤:៦; អាលម៉ា ៥:៣៧.
៦ *ក* ក.ន. បានពោរពេញ,
ទំនុកបំរុងដោយការបង្រៀនទាំង
ឡាយ, ការជឿទាំងឡាយ
នៃសាសន៍កើត.
*ខ* ស.ប. ពួកភីលីស្ទីន.
*គ* ហេ. រួមដៃ ឬធ្វើសេចក្តីសញ្ញាជា
មួយ.
៨ *ក* ស.ប. ការថ្វាយបង្គំរូបព្រះ.
៩ *ក* ក.ន. ចំពោះព្រះ; គេថ្វាយបង្គំរូបព្រះ
ទាំងឡាយទៅវិញ.
១០ *ក* អាលម៉ា ១២:១៤.
១២ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.
*ខ* ម៉ាឡាគី ៤:១;
២ នីហ្វៃ ២៣:១១;
គ. និង ស. ៦៤:២៤.
១៦ *ក* ច្បាប់ក្រេក (សេព្ទូជិនត៍) មានពាក្យ
មួយដែលពួកហេព្រើរពុំមាន ហើយ
ពួកហេព្រើរមានពាក្យមួយដែល ពួក
ក្រេកពុំមាន; ប៉ុន្តែ
២ នីហ្វៃ ១២:១៦ មានទាំងពីរ
១៧ *ក* ក.ន. នៅគ្រាដែលព្រះអម្ចាស់ទ្រង់
នឹងយាងមកក្នុងសិរីល្អ.
២០ *ក* ហេ. ក្រវែងចោល.

នឹងមកលើគេ ហើយឫទ្ធានុភាពនៃសិរីល្អរបស់ទ្រង់ដែលនឹងវាយគេ
ក្នុងកាលដែលទ្រង់ក្រោកឡើង ដើម្បីនឹងអង្រួនផែនដី ដោយ
ឫទ្ធិយ៉ាងអស្ចារ្យ ។
២២ ចូរលែងទុកចិត្តដល់[ក]មនុស្ស ដែលមានតែដង្ហើមចេញ
ចូលតាមរន្ធច្រមុះទៅ; ត្បិតតើនឹងពឹងដល់គេឯណាបាន ?

## ជំពូកទី ១៣

*ស្រុកយូដា និងក្រុងយេរូសាឡិមនឹងទទួលទោស ព្រោះការមិនស្ដាប់បង្គាប់របស់គេ — ព្រះអម្ចាស់ទ្រង់តវ៉ា ហើយជំនុំជំរះរាស្ត្រទ្រង់ — ពួកកូនស្រីនៃក្រុងស៊ីយ៉ូនត្រូវបណ្ដាសា ហើយមានទុក្ខដោយមកពីតណ្ហាខាងលោកិយរបស់គេ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៣ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស.។*

ត្បិតមើលចុះ ព្រះអម្ចាស់ គឺជាព្រះអម្ចាស់នៃពួកពលបរិវារ
ទ្រង់ដកយកទីពឹង ហើយនឹងបង្អែកចេញពីក្រុងយេរូសាឡិម
និងស្រុកយូដា ព្រមទាំងបង្អែកជាស្បៀងអាហារ និង
ទីពឹងនៃទឹកផឹកអស់រលីងទៅ —
២ ទាំងមនុស្សខ្លាំងពូកែ និងមនុស្សថ្មីកចម្បាំង ទាំងចៅក្រម
និងព្យាការី ទាំងគ្រូទាយ និងអ្នកចាស់ព្រឹទ្ធាចារ្យ;
៣ ទាំងមេត្រួតត្រាលើ៥០នាក់ និងមនុស្សដែលមាន
សក្ដិយស ទាំងអ្នកប្រឹក្សា និងជាងប៉ិនប្រសប់ ហើយនឹងអ្នក
មានវោហារ យ៉ាងចំណានផង ។
៤ នោះយើងនឹងតាំងពួកក្មេងៗ ឲ្យធ្វើជាចៅហ្វាយលើគេ
ហើយកូនតូចៗត្រួតត្រាលើគេវិញ ។
៥ ហើយបណ្ដាជនទាំងឡាយនឹងត្រូវសង្កត់សង្កិន គឺម្នាក់ទល់នឹង
ម្នាក់ទៀត ព្រមទាំងអ្នកជិតខាងខ្លួនផង; ពួកក្មេងៗនឹងប្រព្រឹត្ត
ព្រហើន ចំពោះចាស់ព្រឹទ្ធាចារ្យ ហើយមនុស្សជាន់ទាបចំពោះ
មនុស្សជាន់ខ្ពស់ដែរ ។
៦ កាលណាមនុស្សម្នាក់នឹងយកបងប្អូនពីក្នុងគ្រួសាររបស់
ឪពុកខ្លួនមក ហើយនិយាយថា៖ អ្នកឯងមានសំលៀកបំពាក់
សូមអ្នក ធ្វើជាអ្នកគ្រប់គ្រងទៅ សូមកុំឲ្យស្រុក[ក]ខ្ទេចខ្ទីនេះ
នៅក្រោមអំណាចអ្នកឡើយ —
៧ នៅគ្រានោះ គេនឹងប្រកែកថា៖ ខ្ញុំមិនចង់ធ្វើជាអ្នក[ក]មើលឲ្យ
ជាទេ; ព្រោះនៅផ្ទះខ្ញុំគ្មានអាហារ ឬសំលៀកបំពាក់អ្វីឡើយ;
អ្នករាល់ គ្នាមិនត្រូវតាំងខ្ញុំឡើង ឲ្យធ្វើជាអ្នកគ្រប់គ្រងលើ
បណ្ដាជនទេ ។
៨ ត្បិតក្រុងយេរូសាឡិម[ក]ខ្ទេចខ្ទី ហើយស្រុកយូដាក៏[ខ]បាន
ដួលដែរ ពីព្រោះអណ្ដាតគេ ហើយនឹងអំពើរបស់គេ ដែល
សុទ្ធតែបង្អុច បង្អាល ដល់ព្រះនេត្រដ៏មានសិរីនៃព្រះអម្ចាស់ ។
៩ ភាពនៃទឹកមុខគេតែងធ្វើបន្ទាល់ទាស់នឹងគេ ក៏បើកបង្ហាញ
អំពើបាបរបស់គេចេញ ដូចជា[ក]ក្រុងសូដុំម ហើយគេមិនអាចបិទ
បាំងបាន ឡើយ ។ វេទនាដល់ព្រលឹងគេ ព្រោះគេបានប្រព្រឹត្ត
អំពើអាក្រក់ ដល់ខ្លួនគេហើយ !
១០ ចូរថ្លែងប្រាប់ថា មនុស្សសុចរិតនឹង[ក]បានសេចក្ដីសុខវិញ;
ត្បិតគេនឹងទទួលផលនៃការដែលគេប្រព្រឹត្ត ។
១១ វេទនាដល់មនុស្សអាក្រក់ ព្រោះគេនឹងត្រូវវិនាស;
ត្បិតការដែលដៃគេបានធ្វើ នោះនឹងបានសងដល់គេវិញ !
១២ ឯរាស្ត្ររបស់យើង គឺជាកូនក្មេងដែលសង្កត់សង្កិនគេ
ហើយគឺពួកស្រីៗ ដែលមានអំណាចត្រួតត្រាលើគេដែរ ។
ឱរាស្ត្ររបស់ យើងអើយ ពួកអ្នកដែលនាំមុខអ្នក គេ[ក]នាំឲ្យ
អ្នកវង្វេង ក៏បំផ្លាញផ្លូវទាំងឡាយ ដែលអ្នកដើរដែរ ។
១៣ ព្រះអម្ចាស់ទ្រង់កំពុងឈរ ដើម្បី[ក]អង្វរ ទ្រង់ឈរ ដើម្បី
ជំនុំជំរះប្រជាជនទាំងឡាយ ។
១៤ ព្រះអម្ចាស់ទ្រង់នឹងកើតមានក្ដីនឹងពួកចាស់ព្រឹទ្ធាចារ្យ
នៃរាស្ត្រទ្រង់ ហើយនិង[ក]ពួកចៅហ្វាយ; ព្រោះអ្នករាល់គ្នាហើយ
ដែលបាន [ខ]ស៊ីបង្ហិន[គ]ចំការទំពាំងបាយជូរ ហើយ[ឃ]របឹបដែល
រឹបជាន់យក[ង]ពីអ្នកទាល់ក្រ នោះសុទ្ធតែនៅក្នុងផ្ទះអ្នកទាំងអស់ ។
១៥ ព្រះអម្ចាស់ដ៏ជាព្រះនៃពួកពលបរិវារ ទ្រង់មានព្រះ
បន្ទូលសួរថា៖ តើអ្នករាល់គ្នាមានច្បាប់អីនឹងញាំញីរាស្ត្រយើង
ហើយបត់បែន មុខរបស់មនុស្សទាល់ក្រដូច្នេះ ?
១៦ ម្យ៉ាងទៀត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ ដោយ

២២ *ក* ក.ន. ឈប់ពឹងមនុស្សលោក; គេគ្រាន់តែមាន អំណាចតិចតួចប៉ុណ្ណោះបើ សិនជាប្រៀបធៀបទៅនឹងព្រះ.
**១៣** ៦ *ក* អេសាយ ៣:៦.
៧ *ក* ហេ. អ្នករុំប៉ង់ (របួស); ឧទាហរណ៍ ខ្ញុំពុំអាចដោះស្រាយបញ្ហាទាំងឡាយរបស់អ្នកបានទេ.
៨ *ក* យេរ. ៩:១១.
*ខ* បរិទេវ ១:៣.
៩ *ក* លោកុ. ១៩:១, ៤–៧, ២៤–២៥. ស.ប. ការប្រតិព័ទ្ធភេទដូចគ្នា.
១០ *ក* ចោទិ. ១២:២៨.
១២ *ក* អេសាយ ៩:១៦.
១៣ *ក* ហេ. តវ៉ា. មីកា ៦:២; គ. និង ស. ៤៥:៣–៥.
១៤ *ក* ហេ. ពួកអ្នកត្រួតត្រា ឬពួកអ្នកដឹកនាំ.
*ខ* ហេ. បរិភោគ ឬដុត.
*គ* អេសាយ ៥:៧.
*ឃ* ក.ន. របស់ដែលរឹបអូសយកបាន.
*ង* ២ នីហ្វៃ ២៨:១២–១៣.

ព្រោះពួកកូនស្រីក្រុងស៊ីយ៉ូនមានឫកខ្ពស់ មានដំណើរ
ងើបងើយ ផាត់វង្វេង ភ្នែក ដើរយ៉ាងយារ ហើយបំភ្លៃជើងឲ្យ
មានសូររ៉ូងរ៉ុង ។
១៧ ហេតុនេះព្រះអម្ចាស់ ទ្រង់នឹងវាយក្រយៅក្បាលនៃពួក
កូនស្រីក្រុងស៊ីយ៉ូនឲ្យកើតមក ហើយព្រះអម្ចាស់ ទ្រង់នឹង
សំរាតកេរ្តិ៍ ខ្មាសគេ ។
១៨ នៅគ្រានោះ ព្រះអម្ចាស់ទ្រង់នឹងដកសេចក្ដីលំអនៃ
គ្រឿងអលង្ការ សំណាញ់សក់ កំឯក;
១៩ ខ្សែក កងដៃ កំស្បៃ;
២០ ក្បាំងសក់ ខ្សែចង្កេះជើង បូរក្បាល ក្លងហិត និងក្រវិល;
២១ ចិញ្ចៀន និងត្បូងតែងច្រមុះ;
២២ សំលៀកបំពាក់សំរាប់បុណ្យ កន្សែងទទូរ ផាហ៊ុម
កាបូបយួរ;
២៣ កញ្ចក់ អាវសារូ មួក និងក្រមារបស់គេចេញ ។
២៤ ហើយហេតុការណ៍នឹងកើតឡើងថា នឹងមានក្លិនស្អុយ
ជំនួសក្រអូប; ខ្សែចង ជំនួសខ្សែក្រវាត់; ក្បាលទំពែក ជំនួស
សក់សំអាង; សំពត់ធ្មៃ ជំនួសសំពត់ល្បើក; ស្នាមត្រា
ជំនួសលំអខ្លួន ។
២៥ ពួកប្រុសៗរបស់អ្នកនឹងដួលដោយមុខដាវ ហើយ
មនុស្សខ្លាំងពូកែរបស់អ្នកនឹងស្លាប់ក្នុងចម្បាំង ។
២៦ នោះអស់ទាំងទ្វារក្រុងនឹងមានការខ្សឹកខ្សួលហើយសោយ
សោក; ឯនាងនឹងត្រូវចោលនៅតែឯង ហើយអង្គុយនៅដី ៕

## ជំពូកទី ១៤

*ក្រុងស៊ីយ៉ូន និងពួកកូនស្រី នឹងត្រូវបានប្រោសលោះ ហើយ លាងជំរះនៅក្នុងសហស្សវត្សរ៍ — ចូរប្រៀបធៀបនឹងគម្ពីរ អេសាយ ៤ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស.។*

ហើយនៅគ្រានោះ ស្រីប្រាំពីរនាក់នឹងជាប់នៅជាមួយប្រុសម្នាក់
ដោយពោលថា៖ យើងនឹងបរិភោគអាហាររបស់ខ្លួនយើង ហើយ
នឹង រកប្រដាប់ស្លៀកពាក់ដោយខ្លួនយើងដែរ; សូមឲ្យតែយើង
បានឈ្មោះ ជាប្រពន្ធរបស់អ្នកចុះ ដើម្បីនឹងដោះសេចក្ដីដំណៀល
ពីយើងចេញ ។
២ នៅគ្រានោះ មែកខ្ទែងរបស់ព្រះអម្ចាស់ នឹងបានជាល្អប្រពៃ
ហើយរុងរឿង; ឯផលកើតពីដី នឹងបានជាប្រសើរ ហើយ
ជាលំអដល់ សំណល់ពួកសាសន៍អ៊ីស្រាអែល ដែលបានរួច ។
៣ ហើយហេតុការណ៍នឹងកើតឡើងថា ពួកអ្នកណាដែល
សល់នៅក្នុងក្រុងស៊ីយ៉ូន ជាអ្នកដែលនៅក្នុង
ក្រុងយេរូសាឡិមនៅឡើយ នោះនឹងបានហៅជាអ្នកបរិសុទ្ធ
គឺគ្រប់ទាំងមនុស្សក្នុងក្រុងយេរូសាឡិម —
៤ ក្នុងកាលដែលព្រះអម្ចាស់ទ្រង់បានលាងជំរះ គ្រឿងលាមក
របស់ពួកកូនស្រីនៃក្រុងស៊ីយ៉ូនចេញ ហើយបានចំរាញ់សំអាត
ឈាមនៃ ក្រុងយេរូសាឡិមពីកណ្ដាលទីក្រុងទៅ ដោយ
អំណាចនៃសេចក្ដីយុត្តិធម៌ និងអំណាចនៃភ្លើងឆេះបន្សុស ។
៥ ហើយព្រះអម្ចាស់ ទ្រង់នឹងបង្កើតឲ្យមានពពក និង
ផ្សែងនៅវេលាថ្ងៃ ហើយភ្លើងដ៏ឆេះបំភ្លឺនៅវេលាយប់
ពីលើទីលំនៅទាំងមូល នៅលើភ្នំស៊ីយ៉ូន ហើយ
ពីលើទីប្រជុំទាំងប៉ុន្មានរបស់គេ; ត្បិតគ្រប់ទាំងទីគួរគោរព
នៃក្រុងស៊ីយ៉ូន នឹងមានគំរបគ្របបាំងទាំងអស់ ។
៦ ហើយនឹងមានរោងបារាំ សំរាប់ជាម្លប់បាំងកំដៅនៅពេលថ្ងៃ
និងសំរាប់ជាទីជ្រក ហើយជាទីបាំងខ្លួន ឲ្យរួចពីព្យុះ និងភ្លៀងផង ។

## ជំពូកទី ១៥

*ចំការទំពាំងបាយជូរ (អ៊ីស្រាអែល) របស់ព្រះអម្ចាស់ នឹងត្រូវចោលទទេ ហើយរាស្ត្រទ្រង់នឹងត្រូវបែកខ្ចែក — វេទនា*

១៦ *ក* ក.ន. ការដើរឈានជើងជិតៗ
គ្នាតាមរបៀបណាម៉្យាង.
១៧ *ក* ហេ. បើកបង្ហាញ; មាន
ន័យវិសេសថា « ធ្វើឲ្យគេមានសេច
ក្ដីអាម៉ាស់ ».
១៨ *ក* ប្រហែលជាសំណាញ់សក់ ។ ពួក
អ្នកប្រាជ្ញពុំដែលស្រុះស្រួលគ្នា
អំពីគ្រឿងអលង្កាដែលពួកស្ត្រីប្រើ
នៅក្នុង *ខ* ១៨–២៣ ឡើយ.
*ខ* ក.ន. អលង្កាដែលមានរាងដូចជា
ចំណិតលោកខែ.
១៩ *ក* ហេ. ស្បៃ.
២២ *ក* ហេ. សំលៀកបំពាក់ដ៏គ្រចះគ្រចង់.
២៣ *ក* ឬ សំលៀកបំពាក់មើលធ្លុះ.
២៤ *ក* ហេ. កន្ទប.
*ខ* ឬ អាវវែង.
*គ* ឬ ស្នាមត្រា (សំគាល់ជាខ្ញុំកញ្ជះ).
**១៤** ១ *ក* ក.ន. ជាសេចក្ដីដំណៀលដែល
ពុំបានរៀបការ ហើយគ្មានកូន.
២ *ក* អេសាយ ៦០:២១;
២ នីហ្វៃ ៣:៥;
យ៉ាកុប ២:២៥.
៤ *ក* ក.ន. កាលព្រះអម្ចាស់ទ្រង់បាន
សំអាតផែនដី.
*ខ* ស.ប. លាង, បានលាង, ការលាង.
*គ* ម៉ាឡាគី ៣:២–៣; ៤:១.
៥ *ក* និក្ខ. ១៣:២១.
៦ *ក* អេសាយ ២៥:៤;
គ. និង ស. ១១៥:៦.

*នឹងកើតមាន ដល់គេ នៅគ្រាដែលគេក្បត់សាសនា និងគ្រាដែលបែកខ្ញែក — ព្រះអម្ចាស់ទ្រង់នឹងលើកទង់ជ័យ ហើយប្រមូលសាសន៍អ៊ីស្រាអែល — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៥ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស.។*

ហើយនៅពេលនោះ ខ្ញុំសូមច្រៀងបទថ្វាយស្ងួនសំឡាញ់របស់ខ្ញុំ គឺជាបទចំរៀង ច្រៀងពីស្ងួនសំឡាញ់ខ្ញុំ ខាងឯចំការទំពាំងបាយជូរ របស់ទ្រង់ថា ស្ងួនសំឡាញ់ខ្ញុំ ទ្រង់មានចំការទំពាំងបាយជូរនៅលើភ្នំ ដែលមានដីជាតិ ។

២ ហើយទ្រង់ក៏ធ្វើរបងហ៊ុំ ហើយរើសយកដុំថ្មចេញ រួចទ្រង់ដាំទំពាំងបាយជូរយ៉ាងល្អបំផុត ហើយសង់ប៉មមួយនៅចំកណ្ដាល ហើយធ្វើធុងឃ្នាបគាបផ្លែផង; ក្រោយនោះទ្រង់ប្រាថ្នាចង់ឲ្យទំពាំងបាយជូរនោះកើតផល តែបានកើតផលក្លាយជាទំពាំងបាយ ជូរព្រៃវិញ ។

៣ ហើយឥឡូវនេះ ឱពួកក្រុងយេរូសាឡិម និងជនជាតិយូដាអើយ សូមវិនិច្ឆ័យរឿងយើង ដែលកើតក្ដីនឹងចំការទំពាំងបាយជូរ របស់យើងនេះចុះ ។

៤ តើគួរឲ្យយើងធ្វើអ្វីទៀត ដល់ចំការទំពាំងបាយជូររបស់យើង ដែលយើងលះបង់មិនបានធ្វើនោះ ? ហេតុដូច្នោះហើយ កាលយើងប្រាថ្នាកើតមានផលល្អ ម្ដេចក៏ក្លាយទៅជាមានផ្លែទំពាំងបាយជូរព្រៃវិញ ?

៥ ហើយឥឡូវនេះ ទៅចុះ; យើងនឹងប្រាប់ឲ្យអ្នករាល់គ្នាដឹងថា យើងនឹងធ្វើអ្វីដល់ចំការទំពាំងបាយជូររបស់យើងនោះ — គឺយើងនឹងរើរបងចេញ នោះសត្វនឹងចូលស៊ីបំផ្លាញ; ហើយយើងនឹងរំលំកំផែងចេញ នោះចំការនឹងត្រូវជាន់ឈ្លីទៅ ។

៦ ហើយយើងនឹងបំផ្លាញអស់រលីង; ហើយគ្មានអ្នកណាកាត់លួស ឬជួយដីទៀតឡើយ; ប៉ុន្តែនឹងកើតមានអញ្ចាញ ហើយបន្លាដុះ ឡើងវិញ; យើងក៏នឹងបង្គាប់ដល់ពពក ហាមមិនឲ្យធ្លាក់ភ្លៀងមកលើចំការនោះតទៅ ។

៧ ក្បិតអើចំការទំពាំងបាយជូររបស់ព្រះអម្ចាស់នៃពួកពលបរិវារ នោះគឺជាវង្សអ៊ីស្រាអែល ហើយពួកយូដាជាដំណាំដែលគាប់ដល់ ព្រះនេត្រទ្រង់; ហើយទ្រង់បានទតរកការជំនុំជំរះ ហើយមើលចុះ បានការសង្កត់សង្កិនវិញ; រកសេចក្ដីសុចរិត ប៉ុន្តែមើលចុះ បានសំរែកគ្រ លួចវិញ ។

៨ វេទនាដល់ពួកអ្នកដែលសង់ផ្ទះភ្ជាប់គ្នា ឥតមានចន្លោះណាឡើយ បណ្ដាលឲ្យអ្នករាល់គ្នានៅតែឯង តាមញកស្រុកវិញ !

៩ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលដាក់ត្រចៀកខ្ញុំថា ពិតប្រាកដជាផ្ទះជាច្រើននោះ នឹងត្រូវចោលទទេ ព្រមទាំង ទីក្រុងធំៗ ហើយល្អៗផង ឥតមានអ្នកណានៅឡើយ ។

១០ មែនហើយ ចំការទំហំ១០រ៉ៃ នឹងបានទឹកទំពាំងបាយជូរតែ១ប៉ោត ហើយពូជពង្រោះ១០ថាំង នឹងច្រូតបានតែ១ថាំងទេ ។

១១ វេទនាដល់ពួកអ្នក ដែលក្រោកឡើងពីព្រលឹម ដើម្បីតែនឹងរកគ្រឿងស្រវឹង ហើយអត់ងងុយ ដរាបដល់យប់ជ្រៅ ទាល់តែឆេះ រោលរាល ដោយសារស្រាទំពាំងបាយជូរ !

១២ ជាពួកអ្នកដែលមានស៊ុង ពិណ ក្រាប់ ខ្លុយ និងស្រាទំពាំងបាយជូរក្នុងការស៊ីលៀងរបស់គេ; តែគេមិនយកចិត្តទុកដាក់ ចំពោះ ស្នាដៃរបស់ព្រះអម្ចាស់ទេ ក៏មិនពិចារណាពីការដែលព្រះហស្តទ្រង់ធ្វើដែរ ។

១៣ ហេតុនោះ បានជារាស្ត្ររបស់យើង ត្រូវបានចាប់យកទៅក្នុងការជាប់ឃុំឃាំង គឺដោយព្រោះគេខ្វះខាតដំរិះ; ពួកអ្នករុងរឿង ត្រូវអត់ឃ្លានរហិតរហៃទៅ ហើយពួកបណ្ដាជនណែនណាន់ ក៏ខះកដោយស្រេកទឹក ។

១៤ ដូច្នេះ ស្ថាននរកបានរីកធំឡើង ព្រមទាំងហាមាត់ធំហួសប្រមាណ; ឯពួករុងរឿងឧត្តម ពួកណែនណាន់តាន់តាប់ ពួកអ៊ឹកធឹក និងពួកអ្នកដែលរីករាយសប្បាយក្នុងពួកគេ ក៏ចុះទៅឯស្ថាននោះ ។

១៥ ហើយមនុស្សជាន់ទាបត្រូវឱនចុះ ហើយមនុស្សជាន់ខ្ពស់ក៏ត្រូវបន្ទាបដែរ ឯភ្នែករបស់អ្នកមានឫកខ្ពស់ នឹងត្រូវចុះសំយុងជ្រប់ ។

---

១៥ ១ក ក.ន. ព្យាការីចង់ក្រង់ចំរៀង ឬកំណាព្យជាពាក្យប្រៀបប្រដូចមួយ អំពីចំការទំពាំងបាយជូរ ដោយបង្ហាញ អំពីសេចក្ដីមេត្តាករុណារបស់ព្រះ និងការប្រងើយកន្តើយរបស់សាសន៍អ៊ីស្រាអែល.
២ ក យេរេ. ២:២១.
៥ ក ទំនុក. ៨០:១២.
៦ ក អេសាយ ៧:២៣; ៣២:១៣.
ខ យេរេ. ៣:៣.
៧ ក ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
ខ ឬ សេចក្ដីយុត្តិធម៌.
៨ ក មីកា ២:១–២.
ខ ក.ន. ទុកឲ្យនៅតែឯង ។ អ្នកមានដីដ៏ស្ដុកស្ដម្ភក៏រឹបយកដីស្រែតូចតាចរបស់អ្នកក្រីក្រ.
១០ ក អេសេ. ៤៥:១០–១១.
១១ ក សុភា. ២៣:៣០–៣២.
ខ ស.ប. ពាក្យសំដីនៃប្រាជ្ញាវាងវៃ.
១២ ក ទំនុក. ២៨:៥.
១៣ ក ហូសេ ៤:៦. ស.ប. ដំរិះ.

១៦ តែព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់បានដំកើងឡើងដោយ
សេចក្ដីយុត្តិធម៌ គឺព្រះដ៏បរិសុទ្ធ ទ្រង់បានញែកជាបរិសុទ្ធ
ក្នុងសេចក្ដី សុចរិតវិញ ។
១៧ នៅពេលនោះ កូនចៀមនឹងរកស៊ីនៅគ្រប់កន្លែង
ដូចជានៅវាលស្មៅរបស់វា ឯមនុស្សដទៃគេនឹង
ត្របាក់លេបទ្រព្យសម្បត្តិបាក់ បែក របស់ពួកអ្នកស្ដុកស្ដម្ភ ។
១៨ វេទនាដល់ពួកអ្នក ដែលអូសទាញសេចក្ដីទុច្ចរិត ដោយ
ខ្សែជាសេចក្ដីភូតភរ ហើយអំពើបាប ដោយខ្សែលាមរទេះ ។
១៩ ជាពួកអ្នកដែលថាៈ ចូរឲ្យទ្រង់ប្រញាប់ឡើង ឲ្យទ្រង់
បង្ហើយការឲ្យឆាប់ចុះ ដើម្បីឲ្យយើងបានឃើញនឹងភ្នែក; ហើយ
ចូរឲ្យគំនិត របស់ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលចូលមក
ជិត ហើយមកដល់ចុះ ដើម្បីឲ្យយើងបានស្គាល់ផង ។
២០ វេទនាដល់ពួកអ្នក ដែលរាប់សេចក្ដីអាក្រក់ថាជាល្អ
ហើយសេចក្ដីល្អថាជាអាក្រក់វិញ ជាពួកអ្នកដែលយកសេចក្ដី
ងងឹតថា ជាពន្លឺ ហើយយកពន្លឺជាងងឹត ក៏យកសេចក្ដី
ល្វីងជូរចត់ជាផ្អែម ហើយយកផ្អែមជាល្វីងជូរចត់វិញ !
២១ វេទនាដល់ពួកអ្នកដែលរាប់ខ្លួនថា ជាអ្នកមានប្រាជ្ញា
ហើយស្មានថាខ្លួនគេមានគំនិតស្រួច ។
២២ វេទនាដល់ពួកអ្នកដែលប៉ិនប្រសប់នឹងផឹកស្រាទំពាំងបាយជូរ
និងអ្នកដែលខ្លាំងពូកែក្នុងការលាយគ្រឿងស្រវឹង;
២៣ ជាពួកអ្នកដែលស៊ីសំណូក ដើម្បីរាប់មនុស្សអាក្រក់ថា
ជាសុចរិតវិញ ហើយដកសេចក្ដីសុចរិត របស់មនុស្សសុចរិតចេញ !
២៤ ហេតុនោះ ប្រៀបដូចជាអណ្ដាតភ្លើងឆេះបន្សុសជញ្ជ្រាំង
ហើយស្មៅក្រៀមស្រុតចុះក្នុងភ្លើងយ៉ាងណា នោះឫសរបស់
ពួកអ្នក ទាំងនោះនឹងបាន ដូចជាអ្វីដែលពុករលួយ ហើយផ្កា
របស់គេនឹងហុយ ឡើងដូចជាធូលីយ៉ាងនោះដែរ; ពីព្រោះគេ
បានលះចោល ក្រិត្យវិន័យ នៃព្រះអម្ចាស់នៃពួកពលបរិវារ
ព្រមទាំងមើលងាយចំពោះព្រះបន្ទូល របស់ព្រះដ៏បរិសុទ្ធ
នៃសាសន៍អ៊ីស្រាអែលផង ។
២៥ ហេតុនោះ សេចក្ដីខ្ញាល់នៃព្រះអម្ចាស់ បានឆួលឡើងទាស់
នឹងរាស្ត្រនៃទ្រង់ ហើយទ្រង់បានលូកព្រះហស្តទាស់នឹងគេ ហើយ
បានវាយគេ; ឯភ្នំទាំងប៉ុន្មានក៏ញ័រ ហើយខ្មោចគេបានត្រឡប់ដូចជា
សំរាម នៅកណ្ដាលផ្លូវទាំងឡាយ ។ ត្បិតទោះជាយ៉ាង
នោះក៏ដោយ គង់តែសេចក្ដីខ្ញាល់របស់ទ្រង់ មិនទាន់បែរចេញ
ទាំងអស់ទៅដែរ គឺព្រះហស្តទ្រង់ចេះតែលូកមកទៀត ។
២៦ ហើយទ្រង់នឹងលើកទង់ជ័យសំរាប់ពួកសាសន៍ដែល
នៅទីឆ្ងាយ ហើយនឹងហួចហៅឲ្យមកពីចុងផែនដី; ហើយមើលចុះ
ពួកខ្លាំង នឹងខំសង្វាតមកដោយប្រញាប់; ឥតមានអ្នកណា
មួយអស់កម្លាំង ឬជំពប់ដើងឡើយ ។
២៧ ឥតមានអ្នកណាមួយងុយងោក ឬដេកលក់ដែរ; ក៏ឥតមាន
អ្នកណាមួយបន្ធូរខ្សែក្រវាត់ ឬស្រាយខ្សែស្បែកជើងដែរ;
២៨ ជាពួកអ្នកដែលមានព្រួញមុតណាស់ ហើយធ្នូទាំង
អស់ក៏ដំឡើងជាស្រេច ឯក្រចកសេះ នោះនឹងបាន
រាប់ជាថ្មដែកភ្លើង ហើយកង់រទេះរបស់គេក៏ដូចជាខ្យល់កួច
សូរសន្ធឹករបស់ពួកនោះនឹងបានដូចជាសូរគ្រហឹមរបស់មេសិង្ហ។
២៩ គេនឹងគ្រហឹមដូចជាកូនសិង្ហ; មែនហើយ គេនឹងគ្រហឹម
ហើយចាប់រំពាយកទៅ ហើយឥតមានអ្នកណាជួយឲ្យរួច
បានឡើយ ។
៣០ ហើយនៅគ្រានោះ គេនឹងគ្រហឹមដាក់ពួកអ្នកទាំងនោះឲ្យឮ
ដូចជាសូរគ្រាំគ្រេងនៃសមុទ្រ; ហើយបើសិនជាអ្នកណាមើលទៅ
ក្នុងស្រុក នោះនឹងឃើញមានតែងងឹត និងសេចក្ដីសោកសៅទេ
ហើយពន្លឺដែលនៅលើមេឃ នឹងងងឹតសូន្យទៅដែរ ៕

១៦ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ចៅក្រម.
១៨ *ក* ស.ប. ឥតប្រយោជន៍,
ការឥតប្រយោជន៍.
*ខ* ក.ន. ពួកគេបានជាប់ទៅនឹងអំពើបាប
ទាំងឡាយរបស់ខ្លួន ហាក់ដូចជា
សត្វទៅនឹងបន្ទុក.
១៩ *ក* យេរេ. ១៧:១៥.
*ខ* ក.ន. ពួកគេនឹងមិនជឿដល់ព្រះ
មែស៊ីឡើយ រហូតដល់ពួកគេបាន
ឃើញទ្រង់.
២០ *ក* ម៉ូរ៉ូណៃ ៧:១៤, ១៨;
គ. និង ស. ៦៤:១៦; ១២១:១៦.
*ខ* ១ យ៉ូហាន ១:៦.
២១ *ក* សុភា. ៣:៥–៧;
២ នីហ្វៃ ២៨:១៥.
២៣ *ក* ក.ន. ដកហូតគាត់កុំឲ្យមានសិទ្ធិ
តាមច្បាប់.
២៤ *ក* អូបា. ១:១៨; ម៉ាឡាគី ៤:១–២;
២ នីហ្វៃ ២០:១៧.
*ខ* យ៉ូអែល ២:៥; ១ នីហ្វៃ ២២:១៥,
២៣; ២ នីហ្វៃ ២៦:៤, ៦;
គ. និង ស. ៦៤:២៣–២៤;
១៣៣:៦៤.
*គ* លូកា ៣:១៧;
ម៉ូសាយ ៧:២៩–៣១.
*ឃ* ២ សាំយូ. ១២:៧–៩.
២៥ *ក* គ. និង ស. ៦៣:៣២;
ម៉ូសេ ៦:២៧.
២៦ *ក* ស.ប. ទង់.
*ខ* ឬ ហួច; ឧទាហរណ៍ គឺជា
សំគាល់ហៅឲ្យជួបជុំគ្នា.
*គ* ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
២៩ *ក* ៣ នីហ្វៃ ២១:១២–១៣.

## ជំពូកទី ១៦

*អេសាយឃើញព្រះអម្ចាស់ — អំពើបាបទាំងឡាយរបស់អេសាយត្រូវបានអត់ទោសឲ្យ — លោកត្រូវបានហៅឲ្យព្យាករ — លោកព្យាករ អំពីការបង្រៀននៃព្រះគ្រីស្ទ ដែលពួកសាសន៍យូដាមិនទទួលស្គាល់ — សំណល់នៃពូជមួយនឹងវិលត្រឡប់ — ចូរប្រៀបធៀបនឹងគម្ពីរ អេសាយ ៦ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

នៅឆ្នាំដែលស្ដេចអ៊ូសៀសទ្រង់បានសុគត នោះខ្ញុំឃើញព្រះ
អម្ចាស់ទ្រង់គង់លើបល្ល័ង្កនៅទីខ្ពស់ ហើយបានដំកើងឡើង
ឯភាយ ព្រះពស្ត្រ ទ្រង់សាយមកពេញក្នុងព្រះវិហារបរិសុទ្ធ ។
២ នៅពីលើទ្រង់មានពួកសេរ៉ាភីម; ម្នាក់ៗមានស្លាបប្រាំមួយ;
ក៏បាំងមុខដោយស្លាបពីរ បាំងជើងដោយស្លាបពីរ ហើយប្រើពីរ
សំរាប់ហើរ ។
៣ ហើយមួយបន្លឺទៅកាន់មួយថា៖ បរិសុទ្ធ បរិសុទ្ធ គឺព្រះ
អម្ចាស់នៃពួកពលបរិវារ ទ្រង់បរិសុទ្ធ; ផែនដីទាំងមូល ពោរពេញ
ដោយ សិរីល្អនៃទ្រង់ ។
៤ ហើយក្រុបទ្វារក៏ញ័រ ដោយសូរសម្លេងនៃសេរ៉ាភីមដែល
បន្លឺនោះ ហើយព្រះវិហារបានពេញទៅដោយផ្សែង ។
៥ ខណៈនោះ ខ្ញុំពោលថា៖ វរហើយខ្ញុំ ! ត្បិតខ្ញុំត្រូវ
វិនាសជាពិត; ពីព្រោះខ្ញុំជាមនុស្សមានបបូរមាត់មិនស្អាត;
ហើយខ្ញុំនៅកណ្ដាល បណ្ដាមនុស្ស ដែលមានបបូរមាត់មិន
ស្អាតដែរ; ព្រោះភ្នែកខ្ញុំបានឃើញមហាក្សត្រ គឺជាព្រះអម្ចាស់នៃ
ពួកពលបរិវារ ។
៦ ខណៈនោះ សេរ៉ាភីមមួយបានហើរមកឯខ្ញុំ ដៃកាន់រងើកភ្លើង
ដែលបានយកពីអាសនាដោយដង្កៀប;
៧ ហើយក៏ឲ្យប៉ះនឹងមាត់ខ្ញុំ ដោយពោលថា៖ នែ រងើកនេះ
បានប៉ះនឹងបបូរមាត់អ្នកហើយ; ឯសេចក្ដីទុច្ចរិតរបស់អ្នក នោះ
បានដក ចេញ ហើយអំពើបាបរបស់អ្នកបានអត់ទោសឲ្យផង ។
៨ រួចខ្ញុំក៏ឮសូរសម្លេងនៃព្រះអម្ចាស់ មានព្រះបន្ទូលមកថា៖
តើយើងនឹងចាត់អ្នកណាឲ្យទៅ តើអ្នកណានឹងទៅឲ្យយើង?
ខណៈនោះ ខ្ញុំទូលឆ្លើយថា៖ ទូលបង្គំនៅឯណេះហើយ
សូមចាត់ទូលបង្គំចុះ ។
៩ រួចទ្រង់មានព្រះបន្ទូលតបថា៖ ចូរទៅប្រាប់ដល់ជន
ជាតិនេះថា — ចូរអ្នករាល់គ្នាស្ដាប់ចុះ តែឥតយល់;
ហើយមើលផង តែឥតដឹងឡើយ ។
១០ ត្រូវធ្វើឲ្យចិត្តនៃជនជាតិនេះទៅជាស្ពឹក ហើយឲ្យត្រចៀកគេ
ធ្ងន់ ចូរបាំងភ្នែកគេ — ក្រែងគេមើល ឃើញដោយភ្នែកគេ
ក៏ស្ដាប់ឮដោយត្រចៀកគេ ហើយយល់ដោយចិត្ត រួចប្រែចិត្ត
ដើម្បីឲ្យបានប្រោសឲ្យជា ។
១១ ខណៈនោះ ខ្ញុំទូលសួរថា៖ ឱព្រះអម្ចាស់អើយ តើដល់
យូរប៉ុន្មានទៅ ? រួចទ្រង់មានព្រះបន្ទូលតបថា៖ គឺដរាប
ដល់កាលណា ទីក្រុងទាំងប៉ុន្មានត្រូវចោលស្ងាត់ ឥតមានអ្នក
ណានៅសោះ ហើយផ្ទះទាំងប៉ុន្មានផង ឥតមានមនុស្ស ដរាប
ដល់ស្រុកនេះបានទៅ ជាទីស្ងាត់ឈឹងទាំងអស់ទៅ;
១២ ហើយដរាបដល់វេលាណាដែលព្រះអម្ចាស់បានរើយក
មនុស្សទាំងឡាយចេញទៅឯទីឆ្ងាយ ព្រោះមានកន្លែងច្រើន
ត្រូវចោល ស្ងាត់នៅកណ្ដាលស្រុក ។
១៣ នោះ ទោះបើមាន១ភាគ១០សល់នៅក្នុងស្រុក គង់តែ
ចំណែកនោះនឹងត្រឡប់មកវិញ ហើយនឹងត្រូវវិនាសបាត់
ដូចជាដើម ឈើទាល ហើយនិងដើមម៉ៃសាក់ដែលសល់
នៅតែគល់ក្រោយដែល គេកាប់រំលំហើយ គឺពូជបរិសុទ្ធជា
គល់ឈើនោះឯង ៕

## ជំពូកទី ១៧

*ពួកអេប្រាអិម និងសាសន៍ស៊ីរីធ្វើសង្គ្រាមនឹងស្រុកយូដា — ព្រះគ្រីស្ទនឹងបានប្រសូតមកពីនាងព្រហ្មចារីម្នាក់ — ចូរប្រៀបធៀបនឹង គម្ពីរអេសាយ ៧ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើង គឺនៅក្នុងរាជ្យស្ដេចអេហាស
បុត្រយ៉ូថាម ដែលជាបុត្រអ៊ូសៀស ស្ដេចស្រុកយូដា នោះរេស៊ីន

---

១៦ ១*ក* ក.ន. ប្រមាណជាឆ្នាំ ៧៥០ ម.គ.ស.
*ខ* ក.ន. ជាយព្រះពស្ត្ររបស់ទ្រង់ ឬរងជើងនៃព្រះពស្ត្រ.
២ *ក* ស.ប. ចេរ៉ូប៊ីន.
៤ *ក* ហេ. ក្របនៃធរណីទ្វារញ័រ.
៥ *ក* ហេ. កាត់ចេញ; ឧទាហរណ៍ លោកមានចិត្តតប់ប្រមល់ ដោយសាលោកមានអារម្មណ៍អំពីអំពើបាបទាំងឡាយរបស់ខ្លួន និងរបស់ប្រជាជនលោក.
៦ *ក* ក.ន. ជានិមិត្តរូបអំពីការសំអាត.
៧ *ក* ស.ប. ការផ្ដាច់បាប.
១០ *ក* ម៉ាថាយ ១៣:១៤–១៥.
១២ *ក* ២ ពង្សាវ. ១៧:១៨, ២០.
១៣ *ក* ក.ន. ដូចជាដើមឈើដែលស្លិករោយអស់ ប៉ុន្តែនៅមានជីវិត និងសមត្ថភាពដើម្បីផលិតពូជ.

ជាស្ដេចស្រុកស៊ីរី ហើយពេកា ជាបុត្ររេម៉ាលា ស្ដេចស្រុកអ៊ីស្រាអែល គេលើកទ័ពឡើង ទៅច្បាំងនឹងក្រុងយេរូសាឡិម តែយក ជ័យជំនះមិនបានទេ ។

២ គ្រានោះ មានដំណឹងមកដល់ពួកវង្សដាវីឌថា៖ សាសន៍ស៊ីរីបានចូលដៃនឹងពួកអេប្រាអិមហើយ ។ ហើយស្ដេចទ្រង់មានព្រះទ័យ ចំប្រប់ ព្រមទាំងចិត្តរបស់ពួករាស្ត្រទ្រង់ផង ប្រៀបដូចជាដើមឈើនៅព្រៃ ដែលត្រូវខ្យល់បក់ ។

៣ ខណៈនោះ ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅអេសាយថា៖ ឥឡូវនេះ ចូរអ្នក និងស្អាយ៉ាស៊ូប ជាកូនអ្នក ចេញទៅជួបនឹងអេហាស ឯចុងប្រឡាយទឹកហូរមកដល់ស្រះខាងលើ តាមផ្លូវទៅឯទីវាលជាងប្រមោក;

៤ ហើយទូលថា៖ ចូរប្រុងខ្លួន ហើយសង្រួមចិត្ត; កុំឲ្យភ័យឲ្យសោះ ក៏កុំឲ្យរាថយ ដោយព្រោះកន្ទុយឧសទាំងពីរ ដែលហុយផ្សែង នោះឡើយ ដោយព្រោះសេចក្ដីកំហឹងដ៏រហ័សរបស់រេស៊ីន និងសាសន៍ស៊ីរី ហើយរបស់កូនរេម៉ាលានោះដែរ ។

៥ ពីព្រោះសាសន៍ស៊ីរី និងពួកអេប្រាអិម ព្រមទាំងកូនរេម៉ាលាបានគិតសំរេចនឹងធ្វើអាក្រក់ដល់អ្នក ដោយពាក្យថា៖

៦ ចូរយើងឡើងទៅច្បាំងនឹងស្រុកយូដា យើងនឹងធ្វើឲ្យគេមានសេចក្ដីវេទនា ព្រមទាំងទំលាយឲ្យមានផ្លូវចូលបាន រួចយើងនឹងតាំងស្ដេចមួយឡើងនៅក្នុងស្រុកគេ មែនហើយ គឺជាកូនរបស់តាបៀល ។

៧ ឯព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ការនោះមិនបានទេ គេនឹងធ្វើមិនកើតឡើយ ។

៨ ត្បិតក្បាលរបស់ស្រុកស៊ីរី គឺក្រុងដាម៉ាស ហើយក្បាលរបស់ក្រុងដាម៉ាស គឺរេស៊ីននេះហើយ; ហើយនៅក្នុងរវាង៦៥ឆ្នាំ នោះពួកអេប្រាអិម នឹងត្រូវបែកខ្ញែក រតាត់រតាយអស់ទៅ លែងមានពូជពង្សតទៅទៀត ។

៩ ឯក្បាលរបស់ពួកអេប្រាអិម គឺក្រុងសាម៉ារី ហើយក្បាលរបស់ក្រុងសាម៉ារី គឺជាកូនរេម៉ាលានេះ ។ បើសិនជាអ្នកមិនព្រមជឿទេ នោះប្រាកដជាអ្នកមិនបានតាំងនៅជាប់ឡើយ ។

១០ ម្យ៉ាងទៀត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលនឹងអេហាសថា៖

១១ ចូរអ្នកសូមទីសំគាល់១ពីព្រះអម្ចាស់ដ៏ជាព្រះនៃអ្នកចុះ; ចូរសូមទោះបើនៅក្នុងទីជំរៅ ឬនៅទីខ្ពស់ខាងលើក្ដី ។

១២ តែអេហាសតបថា៖ យើងមិនព្រមសូមទេ ហើយមិនព្រមល្បួងលព្រះអម្ចាស់ដែរ ។

១៣ ហើយអេសាយពោលថា៖ ឱវង្សរបស់ដាវីឌអើយ ចូរស្ដាប់ឥឡូវចុះ; ការដែលអ្នករាល់គ្នាធ្វើ ឲ្យរំខានចិត្តមនុស្សនោះតើ ជាការតូចឬអី បានជាចង់រំខានដល់ព្រះហឫទ័យនៃព្រះរបស់ទូលបង្គំទៀតផង ?

១៤ ដូច្នេះ ព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់មួយមកអ្នករាល់គ្នា ដោយព្រះអង្គផ្ទាល់ថា — មើលចុះ នាងព្រហ្មចារីនឹងមានគភ៌ ហើយនឹងប្រសូតបានបុត្រាមួយ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល ។

១៥ បុត្រនោះនឹងបរិភោគខ្លាញ់ទឹកដោះ ហើយនឹងទឹកឃ្មុំ ដើម្បីឲ្យខ្លួនចេះបដិសេធចោលរបស់អាក្រក់ ហើយរើសយករបស់ល្អវិញ ។

១៦ ត្បិតមុនដែលបុត្រនោះចេះបដិសេធចោលរបស់អាក្រក់ ហើយរើសយករបស់ល្អ នោះស្រុករបស់ស្ដេចទាំងពីរ ដែលអ្នកខ្ពើម នោះ នឹងត្រូវចោលស្ងាត់ទៅ ។

១៧ ព្រះអម្ចាស់ទ្រង់នឹងនាំហេតុការណ៍មួយ មកលើអ្នក ហើយលើរាស្ត្រអ្នក ហើយលើពួកវង្សរបស់ឪពុកអ្នក គឺជាស្ដេចស្រុក អាសស៊ើរ ជាការណ៍ដែលមិនបានកើតមានចាប់តាំងពីគ្រាដែលអេប្រាអិម បែកចេញពីពួកយូដាមក ។

១៨ ហើយហេតុការណ៍នឹងកើតឡើងថា នៅគ្រានោះ ព្រះអម្ចាស់ទ្រង់នឹងហួចហៅរុយ ដែលនៅទីឆ្ងាយបំផុតនៃស្រុកអេស៊ីព្ទ ព្រមទាំងឃ្មុំដែលនៅស្រុកអាសស៊ើរផង ។

១៩ នោះវានឹងនាំគ្នាមកទំនៅក្នុងច្រកភ្នំដែលត្រូវចោលស្ងាត់ ហើយនៅក្នុងក្រហែងថ្ម ហើយនៅលើគ្រប់ទាំងរបងបន្លា ហើយនៅ អស់ទាំងវាលស្មៅផង ។

២០ នៅគ្រានោះ ព្រះអម្ចាស់ទ្រង់នឹងកោរសក់ក្បាល

១៧ ២ *ក* ក.ន. ពួកអ៊ីស្រាអែលទាំងអស់ ដែលនៅទិសខាងជើង ត្រូវបានហៅតាមឈ្មោះអេប្រាអិម ជាពូជអំបូរដឹកនាំគេនៅទិសខាងជើង.
៣ *ក* ហេ. សំណល់នឹងវិលមកវិញ.
៤ *ក* ក.ន. កុំភ័យឲ្យសោះ ដោយព្រោះការវាយ; ស្ដេចទាំងពីរនោះនៅសល់ភ្លើងតែបន្តិចទេ.
៦ *ក* ហេ. បំបែកចេញ.
៩ *ក* ២ របា. ២០:២០.
១១ *ក* ស.ប. ទីសំគាល់.
១២ *ក* ក.ន. ល្បួង, សាក, ឬពិសោធមើល.
១៤ *ក* ស.ប. ព្រហ្មចារី.
*ខ* ហេ. គង់នៅជាមួយយើង គឺជាព្រះ.
១៦ *ក* ២ នីហ្វៃ ១៨:៤.
*ខ* ២ពង្សាវ. ១៥:៣០; ១៦:៩.
១៧ *ក* ២ របា. ២៨:១៩–២១.
*ខ* ១ ពង្សាវ. ១២:១៦–១៩.
១៨ *ក* ឬ ហួច; ក.ន., ឲ្យសំគាល់, ហៅ.
២០ *ក* ក.ន. ដែនដីនឹងត្រូវពង្រាបទៅដោយសាសន៍ដទៃលុកលុយយក.

និងរោមជើងផង ដោយកាំបិតដែលបានជួល ពីទីនៅត្រើយខាងនាយ
ទន្លេ គឺដោយ[ខ]ស្ដេចនៃស្រុកអាសស៊ើរ; ហើយកាំបិតនោះនឹង
រំលាងទាំងពុកចង្កាផង ។
២១ ហើយហេតុការណ៍នឹងកើតឡើងថា នៅគ្រានោះ
មនុស្សម្នាក់នឹង[ក]ចិញ្ចឹមគោញីមួយ និងចៀមពីរ;
២២ ហើយហេតុការណ៍នឹងកើតឡើង សត្វទាំងនោះមាន
ទឹកដោះជាបរិបូរ បានជាអ្នកនោះនឹងបរិភោគខ្លាញ់ទឹកដោះ;
ត្បិតពួកអ្នក ដែលនៅសល់ក្នុងស្រុក គេនឹងបានខ្លាញ់ទឹកដោះ
និងទឹកឃ្មុំ បរិភោគគ្រប់គ្នា ។
២៣ ហើយហេតុការណ៍នឹងកើតឡើងថា នៅគ្រានោះ
គ្រប់ទីកន្លែងណា ដែលពីដើមមានចំការទំពាំងបាយជូរចំនួន
មួយពាន់ដើម មាន[ក]តម្លៃជាប្រាក់មួយពាន់រៀល នោះនឹងបាន
ជាទីសំរាប់អញ្ចាញនិងបន្លាវិញ ។
២៤ ឯអ្នកណាដែលចូលទៅក្នុងទីនោះ នឹងត្រូវកាន់ព្រួញ
និងធ្នូផង ពីព្រោះស្រុកទាំងមូលនឹងដុះសុទ្ធតែអញ្ចាញ និងបន្លា ។
២៥ ហើយអ្នកក៏នឹងមិនឡើងទៅលើទីទួល ដែលពីដើមមាន
គេកាប់គាស់ដោយចបដែរ ដោយខ្លាចអញ្ចាញ និងបន្លា; ប៉ុន្តែ
ទីនោះនឹងបានសំរាប់ជាទីលែងហ្វូងគោ ហើយសំរាប់ឲ្យ[ក]ហ្វូងចៀម
ញាំញីទៅប៉ុណ្ណោះ ៕

## ជំពូកទី ១៨

*ព្រះគ្រីស្ទនឹងបានទៅជាថ្មជំពប់ ហើយជាថ្មដាដែល
បង្អាក់បង្អន់ចិត្ត — ចូរស្វែងរកព្រះអម្ចាស់ មិនមែនពួក
គ្រូគាថាទេ — ចូរបែរទៅរក ក្រិត្យវិន័យ និងសេចក្ដីបន្ទាល់
ទុកជាការណែនាំ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ
៨ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ម្យ៉ាងទៀត ព្រះបន្ទូលនៃព្រះអម្ចាស់បន្លឺមកខ្ញុំថា៖ ចូរយក
ក្ដារឈ្នួនមួយធំ ហើយសរសេរជាអក្សររបស់មនុស្សថា [ក]ការ
រឹបជាន់ជិត ណាស់ហើយ គេរួតរះមកចាប់រំពា ។
២ ហើយខ្ញុំនឹងយក[ក]សាក្សីស្មោះត្រង់ គឺអ៊ូរី ជាសង្ឃ និង
សាការី ជាកូនយេបេរេគា ដើម្បីកត់សេចក្ដីទុក ។
៣ រួចមកខ្ញុំបានចូលទៅឯ[ក]ព្យាការីស្រី; ហើយនាងមានទំងន់
បង្កើតបានកូនប្រុសមួយ ។ ខណៈនោះ ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូល មកខ្ញុំថា៖ ចូរឲ្យឈ្មោះកូននេះថា ម៉ាហេ-សាឡាល-
ហាសបាស ។
៤ ត្បិតមើលចុះ [ក]កូននេះ[ខ]ពុំចេះហៅ ឪអើយ ម៉ែអើយនៅឡើយ
នោះគេនឹងដឹកយកទ្រព្យសម្បត្តិរបស់ក្រុងដាម៉ាស ហើយនឹង
[គ]រឹបយក នៅក្រុងសាម៉ារី នាំទៅនៅចំពោះស្ដេចស្រុក
អាសស៊ើរហើយ ។
៥ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំទៀតថា៖
៦ ដរាបណាសាសន៍នេះ គេមិនព្រមយកទឹក[ក]ស៊ីឡោមដែល
ហូរគ្រៀនៗ តែមានសេចក្ដីរីករាយ ចំពោះ[ខ]រេស៊ីន ហើយនិង
កូន របស់រេម៉ាលាវិញ;
៧ ឥឡូវនេះ ដោយហេតុនោះ មើលចុះ ព្រះអម្ចាស់ទ្រង់នាំទឹកទន្លេ
ដែលហូរខ្លាំង ហើយច្រើនមក[ក]លើគេ គឺជាស្ដេចស្រុក
អាសស៊ើរ និងឫទ្ធានុភាពទាំងប៉ុន្មានរបស់ទ្រង់; ទន្លេនោះនឹង
ហូរចេញតាមគ្រប់ទាំងព្រែក ហើយលិចច្រាំងទាំងអស់ ។
៨ [ក]ក៏នឹងសាយចូលទៅក្នុងស្រុកយូដាដែរ; ព្រមទាំង
លិចហូរកាត់ស្រុកឡើងត្រឹមក; ហើយនឹងជន់រាច ពេញស្រុក
របស់ឯង [ខ]ឱអេម៉ាញូអែលអើយ ។
៩ ឱជនជាតិទាំងឡាយអើយ ចូររួប[ក]រួមគ្នាចុះ គង់តែអ្នករាល់
គ្នានឹងត្រូវបាក់បែកខ្ទេចខ្ទីវិញ; នែ អស់ទាំងស្រុកដែល
នៅឆ្ងាយៗអើយ ចូរផ្ទៀងត្រចៀកស្ដាប់ចុះ; ចូរក្រវាត់ចង្កេះ
ខ្លួនដែរ នោះអ្នកនឹងត្រូវបាក់បែកខ្ទេចខ្ទី; ចូរក្រវាត់ចង្កេះចុះ
នោះអ្នកនឹងត្រូវបាក់បែកខ្ទេច ខ្ទីទៅ ។
១០ ចូរប្រឹក្សាគ្នា នោះការសំរេចរបស់អ្នកនឹងត្រូវ
សាបសូន្យទៅ; ចូរចេញវាចាចុះ តែពាក្យសំដីនោះ នឹងមិន
ស្ថិតស្ថេរនៅឡើយ; [ក]ត្បិតព្រះទ្រង់គង់នៅខាងយើងហើយ ។
១១ ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមក ដោយព្រះហស្ត

២០ *ខ* ២ ពង្សាវ. ១៦:៥–៩.
២១ *ក* ក.ន. មានអ្នកដែលចេះចិញ្ចឹម ខ្លួនតែបន្តិចបន្តួចប៉ុណ្ណោះទេដែលនៅសល់.
២៣ *ក* ឬ ប្រាក់កាក់.
២៥ *ក* ហេ. ហ្វូងចៀម ឬ ហ្វូងពពែ.
**១៨** ១*ក* ក.ន. សេចក្ដីបំផ្លិចបំផ្លាញគឺជិតណាស់.
២ *ក* ស.ប. សាក្សី.
៣ *ក* ក.ន. ប្រពន្ធលោក.
៤ *ក* ២ នីហ្វៃ ១៧:១៦.
*ខ* អេសាយ ៨:៤.
*គ* ២ ពង្សាវ. ១៥:២៩.
៦ *ក* លោកុ. ៤៩:១០; ក.យ.ស., លោកុ. ៥០:២៤.
*ខ* អេសាយ ៧:១.
៧ *ក* ក.ន. មកលើពួកអ៊ីស្រាអែល ខាងជើងមុនគេ.
៨ *ក* ក.ន. អាសស៊ើរក៏នឹងចូលទៅស្រុកយូដាដែរ.
*ខ* ស.ប. អេម៉ាញូអែល.
៩ *ក* ក.ន. ចូលរួមដៃគ្នា.
១០ *ក* ក.ន. ស្រុកយូដា (ដែនដីនៃអេម៉ាញូអែល) នឹងត្រូវបានស្ថិតស្ថេរនៅ. ទំនុក. ៤៦:៧.

សង្កត់លើខ្ញុំជាខ្លាំង ទ្រង់ដាស់តឿនខ្ញុំមិនឲ្យ ដើរតាមផ្លូវរបស់ជន
ជាតិ នេះ ដោយថា៖
១២ កុំឲ្យអ្នកថា មាន[ក]ការក្បត់ ក្នុងគ្រប់ទាំងការដែល
ជនជាតិនេះថា មានការក្បត់នោះឡើយ; ក៏កុំឲ្យភ័យខ្លាច
ចំពោះការដែលគេ ភ័យខ្លាចដែរ កុំឲ្យតក់ស្លុតឲ្យសោះ ។
១៣ ត្រូវឲ្យរាប់ព្រះអម្ចាស់នៃពួកពលបរិវារទុកជាបរិសុទ្ធ
ព្រមទាំងយកទ្រង់ជាទី[ក]ភ័យខ្លាច ហើយតក់ស្លុតវិញ ។
១៤ នោះទ្រង់នឹងបានសំរាប់ជាទី[ក]បរិសុទ្ធ; តែជា[ខ]ថ្មជំពប់ ហើយ
ជាថ្មដាដែលបង្អាក់បង្អន់ចិត្តដល់ពួកអ៊ីស្រាអែលទាំងពីរវង្ស គឺសំរាប់
ជាអន្ទាក់ និងជាជង់ ដល់ពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់ ។
១៥ ហើយមនុស្សជាច្រើននឹង[ក]ជំពប់នឹងថ្មនោះ ហើយដួលទៅ
ព្រមទាំងត្រូវបាក់បែក ជាប់អន្ទាក់ ហើយចាប់បានផង ។
១៦ ចូរចងសេចក្ដីបន្ទាល់ចុះ ហើយបិទត្រា[ក]ក្រិត្យវិន័យ នៅ
ក្នុងពួកសិស្សរបស់យើងចុះ ។
១៧ ឯខ្ញុំៗនឹងទន្ទឹងចាំព្រះអម្ចាស់ ដែលទ្រង់[ក]លាក់ព្រះភក្ត្រ
នឹងវង្សនៃយ៉ាកុប ហើយខ្ញុំនឹងរង់ចាំមើលតែទ្រង់ ។
១៨ មើលចុះ ខ្ញុំហើយនឹងកូនចៅដែលព្រះអម្ចាស់ទ្រង់បាន
ប្រទានមកខ្ញុំ សំរាប់ជាទី[ក]សំគាល់មកពីព្រះអម្ចាស់ នៃពួក
ពលបរិវារ ដែលទ្រង់គង់នៅភ្នំស៊ីយ៉ូន ហើយជាទីអស្ចារ្យ នៅ
ក្នុងពួកអ៊ីស្រាអែល ។
១៩ ហើយកាលបើអ្នកណាពោលដល់អ្នកថា៖ ចូររក[ក]ពួក
[ខ]គ្រូខាប និងគ្រូគាថា ដែលចេញសម្លេងអ៊ិអ៊ុ ហើយងុមៗ —
នោះត្រូវឆ្លើយ ថា៖ តើ[គ]គួរគប្បីឲ្យបណ្ដាជន ស្វែងរកព្រះ
របស់ខ្លួន ដើម្បីឲ្យមនុស្សរស់បាន[ឃ]ដំណឹងពីមនុស្សស្លាប់ឬអី ?
២០ ចូរទៅបើកគម្ពីរក្រិត្យវិន័យ និងសេចក្ដីបន្ទាល់មើល; បើ
សិនជា[ក]គេនិយាយមិនត្រូវនឹងព្រះបន្ទូលនេះ នោះពីព្រោះមក
ពីគេគ្មាន ពន្លឺរះឡើងនៅក្នុងខ្លួនទេ ។
២១ ហើយ[ក]គេនឹងដើរចុះឡើងក្នុងស្រុកមានទាំងទុក្ខវេទនា
ហើយស្រេកឃ្លាន; ហើយហេតុការណ៍នឹងកើតឡើងថា កាល
ណាគេ ស្រេកឃ្លាន នោះនឹងមានចិត្តក្ដៅក្រហាយ ហើយ
ប្រទេចផ្ដាសាដល់ស្ដេច និងព្រះរបស់ខ្លួន ដោយ
ងាកមើលទៅលើមេឃផង ។
២២ រួចគេងាកមើលទៅផែនដី ឃើញមានសុទ្ធតែសេចក្ដី
លំបាក និងសេចក្ដីងងឹត ឈ្លប់ស្លន្សស្លុង គ្របសង្កត់ដោយវេទនា
ចិត្ត ហើយនឹងត្រូវបណ្ដេញទៅក្នុងសេចក្ដីងងឹតយ៉ាងក្រាស់ ៕

## ជំពូកទី ១៩

*សាយនិយាយប្រៀបដូចជាព្រះមែស៊ី — ប្រជាជនដែលនៅក្នុងសេចក្ដីងងឹតនឹងឃើញពន្លឺដ៏ធំ — មានបុត្រមួយកើតដល់យើង — បុត្រនោះនឹងបានជាម្ចាស់នៃមេត្រីភាព ហើយសោយរាជ្យលើបល្ល័ង្ករបស់ដាវីឌ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៩ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

យ៉ាងណាក៏ដោយ គង់តែសេចក្ដីឈ្លប់ស្លន្សស្លុងនឹង
មិននៅលើស្រុក ដូចនៅគ្រាដែលមានសេចក្ដីវេទនាចិត្តនោះទេ
កាលពី ដើម ទ្រង់បានធ្វើទុក្ខបន្តិចបន្តួចដល់ស្រុកសាប់យូល៉ូន
និងស្រុកណែបថាលី ហើយនៅជាន់ក្រោយ ទ្រង់បានធ្វើទុក្ខ
កាន់តែធ្ងន់ធ្ងរឡើង តាមផ្លូវទៅឯសមុទ្រក្រហម ត្រើយខាងនា
យទន្លេយ័រដាន់ ជាដែនខេត្តកាលីឡេរបស់ពួកសាសន៍ដទៃ ។
២ ឯបណ្ដាជនដែលដើរ[ក]ក្នុងសេចក្ដីងងឹត គេបានឃើញពន្លឺយ៉ាង
ធំ; ពួកអ្នកដែលអាស្រ័យនៅក្នុងស្រុក នៃម្លប់សេចក្ដីស្លាប់
នោះមាន ពន្លឺភ្លឺមកលើគេ ។
៣ ទ្រង់បានប្រោសឲ្យសាសន៍[ក]ចំរើនឡើង ហើយបានធ្វើឲ្យ
គេមានសេចក្ដីអំណរជាច្រើនឡើងដែរ — គេមានសេចក្ដី
អំណរ នៅចំពោះទ្រង់ ដូចជាសេចក្ដីអំណរនៅរដូវចំរូត ហើយ
ដូចជាសេចក្ដីអំណរអរនៃមនុស្ស ដែលកំពុងតែចែករបឹបគ្នា ។

១២ *ក* ក.ន. ស្រុកយូដាមិនគួរពឹងទៅលើផែនការសម្ងាត់ជាមួយអ្នកដទៃ ដើម្បីឲ្យបានសុខឡើយ.
១៣ *ក* ក.ន. ចូរមានចិត្តគោរពហើយរាបសានៅចំពោះព្រះ.
១៤ *ក* អេសេ. ១១:១៥–២១.
*ខ* ១ ពេត្រុស ២:៤–៨; យ៉ាកុប ៤:១៤–១៥.
១៥ *ក* ម៉ាថាយ ២១:៤២–៤៤.
១៦ *ក* ហេ. ការបង្រៀន ឬលទ្ធិ .
១៧ *ក* អេសាយ ៥៤:៨.
១៨ *ក* ក.ន. ឈ្មោះរបស់លោកអេសាយ និងពួកកូនប្រុសលោក មានន័យដូចតទៅនេះ ៖ «ព្រះយេហូវ៉ាជួយសង្គ្រោះ», «ទ្រង់ឆាប់រឹបយក», និង «សំណល់មួយនឹងវិលមកវិញ» ២ នីហ្វៃ ១៧:៣; ១៨:៣.
១៩ *ក* លេវី. ២០:៦.
*ខ* ក.ន. គ្រូខាប, គ្រូគាថា.
*គ* ១ សាំយូ. ២៨:៦–២០.
*ឃ* ឬ ជំនួស
២០ *ក* ក.ន. ពួកគ្រូខាប និងគ្រូគាថា (ក៏នៅខ ២១–២២ ដែរ).
២១ *ក* ក.ន. ពួកអ៊ីស្រាអែលនឹងត្រូវគេចាប់ឃុំឃាំង ពីព្រោះពួកគេមិនព្រមស្ដាប់តាម.
១៩ ១*ក* ម៉ាថាយ ៤:១២–១៦.
២ *ក* «សេចក្ដីអ័ព្ទ» និង «សេចក្ដីងងឹត» គឺជាសេចក្ដីក្បត់សាសនា និងការឃុំឃាំង «ពន្លឺដ៏ធំ» គឺជាព្រះ គ្រីស្ទ .
៣ *ក* អេសាយ ៩:៣.

៤ ត្បិតទ្រង់បានបំបាក់នឹម ដែលសង្កត់លើគេ និង
ដងរែកនៅស្មាគេ ហើយដំបងរបស់ពួកអ្នកដែលសង្កត់សង្កិនគេផង។
៥ ព្រោះគ្រប់ទាំងចម្បាំងរបស់ពួកទាហាន គឺក្នុងចម្បាំង
យ៉ាងអឺកធឹក ហើយសំលៀកបំពាក់ប្រឡាក់ ដោកដោយឈាម;
ប៉ុន្តែនេះ នឹងបានសំរាប់ដុត ហើយជាចំណីដល់ភ្លើង ។
៦ ត្បិតមានបុត្រមួយកើតដល់យើង ព្រះទ្រង់ប្រទានបុត្រា
មួយមកយើងហើយ; ឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ;
ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ប្រសើរអស្ចារ្យ ព្រះដ៏
ជួយគំនិត ព្រះដ៏មានព្រះចេស្ដា ព្រះវរបិតាដ៏គង់នៅអស់កល្ប
និងជាម្ចាស់នៃមេត្រីភាព ។
៧ ឯសេចក្ដីចំរើននៃរដ្ឋបាលទ្រង់ និងសេចក្ដីសុខសាន្ដរបស់ទ្រង់
នោះនឹងមិនចេះផុតពីបល្ល័ង្ករបស់ដាវីឌ និងនគរនៃទ្រង់ឡើយ
ដើម្បីនឹងតាំងឡើង ហើយទប់ទល់ដោយសេចក្ដីយុត្តិធម៌
និងសេចក្ដីសុចរិត ចាប់តាំងពីឥឡូវនេះ ជារៀងដរាបតទៅ ។
សេចក្ដី ឧស្សាហ៍របស់ព្រះអម្ចាស់នៃពួកពលបរិវារ នឹងសំរេច
ការណ៍នេះ ។
៨ ព្រះអម្ចាស់ទ្រង់បានផ្ញើព្រះបន្ទូលមក ក្នុងពួកយ៉ាកុប
ហើយព្រះបន្ទូលនោះបានធ្លាក់មកត្រូវជនជាតិអ៊ីស្រាអែល ។
៩ នោះបណ្ដាជនទាំងអស់គ្នានឹងដឹងដែរ ព្រមទាំងពួក
អេប្រាអិម និងពួកអ្នកនៅស្រុកសាម៉ារីផង ជាពួកអ្នកដែល
និយាយ ដោយ សេចក្ដីឆ្មើងឆ្មៃ និងចិត្តធំរបស់គេថា៖
១០ ជញ្ជាំងឥដ្ឋបានរលំហើយ តែយើងនឹង
សង់ឡើងដោយថ្មដាប់វិញ; ដើមឧទុម្ពរបានត្រូវកាប់រលំ
អស់ទៅហើយ តែយើងនឹងយក ដើមតាត្រៅមកជំនួសវិញ ។
១១ ដូច្នេះ ព្រះអម្ចាស់ទ្រង់នឹងតាំងពួកខ្មាំងសត្រូវរបស់រេស៊ីនឲ្យ
ទាស់នឹងគេ ហើយនឹងញុះញង់ពួកសត្រូវរបស់គេឲ្យរួបរួមគ្នាដែរ;
១២ គឺពួកសាសន៍ស៊ីរីនៅខាងមុខ ហើយពួកសាសន៍
ភីលីស្ទីននៅខាងក្រោយ; ហើយពួកទាំងនោះនឹង
ហាមាត់ត្របាក់លេប សាសន៍អ៊ីស្រាអែលទៅ ។ ប៉ុន្តែទោះ
បើធ្វើទោសជាច្រើនដល់ម្ល៉េះក៏ដោយ គង់តែសេចក្ដីខ្ញាល់
របស់ទ្រង់មិនទាន់បែរចេញនៅឡើយ គឺព្រះហស្ដទ្រង់នៅតែ
លូកមកទៀត ។
១៣ រីឯបណ្ដាជនទាំងឡាយ គេមិនបានវិលមកឯព្រះដែល
ទ្រង់បានវាយផ្ចាលគេ ក៏មិនស្វែងរកព្រះអម្ចាស់ នៃពួក
ពលបរិវារឡើយ ។
១៤ ហេតុនោះ បានជាព្រះអម្ចាស់ទ្រង់នឹងកាត់ទាំងក្បាល
និងកន្ទុយ ទាំងមែក ហើយនិងធាងរបស់សាសន៍អ៊ីស្រាអែល
ចេញក្នុង ថ្ងៃតែមួយ ។
១៥ ឯក្បាល គឺជាពួកអ្នកចាស់ទុំ; ហើយកន្ទុយ គឺជា
ព្យាការីដែលបង្រៀនសេចក្ដីកុហក ។
១៦ ត្បិតពួកអ្នកដែលដឹកនាំសាសន៍នេះ គេនាំឲ្យវង្វេងទេ;
ហើយពួកអ្នកដែលគេនាំមុខ នោះក៏ត្រូវបំផ្លាញដែរ ។
១៧ ដូច្នេះ ព្រះអម្ចាស់ទ្រង់នឹងមិនមានសេចក្ដីអំណរចំពោះ
ពួកកំឡោះគេឡើយ ក៏មិនមានសេចក្ដីមេត្តាករុណាចំពោះពួក
កំព្រា និងពួកស្រីមេម៉ាយរបស់គេដែរ; ព្រោះគ្រប់គ្នាជាអ្នក
លាក់ពុត ហើយជាអ្នកប្រព្រឹត្តអំពើអាក្រក់ គ្រប់ទាំង
មាត់ក៏បញ្ចេញសុទ្ធតែ សេចក្ដីចំកួត ។ ប៉ុន្តែទោះបើធ្វើទោ
សជាច្រើនដល់ម្ល៉េះក៏ដោយ គង់តែសេចក្ដីខ្ញាល់របស់ទ្រង់ មិន
ទាន់បែរចេញនៅឡើយ គឺព្រះហស្ដទ្រង់ នៅតែលូកមកទៀត ។
១៨ ត្បិតអំពើអាក្រក់ឆេះដូចជាភ្លើង; ក៏ឆេះបន្ទ្រុសទាំងអញ្ចាញ
និងគុម្ពបន្លាអស់រលីងទៅ ហើយភ្លើងនោះក៏កាត់ឡើងក្នុង
ទីស្តុកនៅ ព្រៃ ហើយឆេះរាលឡើងហុយផ្សែងទ្រលោម ។
១៩ ដោយសេចក្ដីក្រោធរបស់ព្រះអម្ចាស់នៃពួកពលបរិវារ
នោះស្រុកត្រូវឆេះសូន្យទៅ ហើយបណ្ដាជនក៏ដូចជាចំណីភ្លើង;
គ្មានអ្នក ណាប្រណីដល់បងប្អូនខ្លួនឡើយ ។
២០ ហើយម្នាក់នឹងកញ្ឆក់យកពីខាងស្ដាំ នឹងនៅតែឃ្លានទៀត;
ហើយម្នាក់ខាងឆ្វេង នឹងស៊ីទៅឥតបានឆ្អែតឡើយ; គេនឹង
ស៊ីសាច់ ដើមដៃខ្លួនគ្រប់ៗគ្នា —
២១ គឺម៉ាន៉ាសេនឹងស៊ីសាច់អេប្រាអិម; ហើយអេប្រាអិមនឹង
ស៊ីសាច់ម៉ាន៉ាសេ; ហើយទាំងពីរពួកនោះ នឹងទាស់ទទឹងនឹង

៦ *ក* អេសាយ ៧:១៤; លូកា ២:១១.
*ខ* ម៉ាថាយ ២៨:១៨.
*គ* ទីតុស ២:១៣–១៤.
*ឃ* អាលម៉ា ១១:៣៨–៣៩, ៤៤.
*ង* យ៉ូហាន ១៤:២៧.
៧ *ក* ស.ប. រដ្ឋាភិបាល.
*ខ* ដានី. ២:៤៤.
៨ *ក* ក.ន. សាររបស់ព្យាការីដែល
មានតាមក្រោយ (ខ ៨–២១)
គឺជាពាក្យព្រមានដល់ពូជអំបូរទាំង
១០ ដែលនៅខាងជើង ហៅថា
អ៊ីស្រាអែល.
១១ *ក* ២ ពង្សាវ. ១៦:៥–៩.
១២ *ក* ២ ពង្សាវ. ១៧:៦, ១៨.
*ខ* អេសាយ ៥:២៥; ១០:៤.
១៣ *ក* អេម៉ុស ៤:៦–១២.
១៧ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
*ខ* ២ នីហ្វៃ ៩:២៨–២៩.
*គ* យ៉ាកុប ៥:៤៧; ៦:៤.
១៩ *ក* មីកា ៧:២–៦.
២០ *ក* ចោទិ. ២៨:៥៣–៥៧.
២១ *ក* ស.ប. ម៉ាន៉ាសេ.
*ខ* ស.ប. អេប្រាអិម.

[ឝ]ពួកយូដា ។ ប៉ុន្តែទោះបើធ្វើទោសជាច្រើនដល់ម្លេះក៏ដោយ
គង់តែសេចក្ដីខ្ញាល់របស់ទ្រង់ មិនទាន់បែរចេញនៅឡើយ
គឺព្រះហស្តទ្រង់នៅតែលូក មកទៀត ៕

## ជំពូកទី ២០

*ការបំផ្លិចបំផ្លាញស្រុកអាសស៊ើរគឺជាគំរូអំពីការបំផ្លិចបំផ្លាញពួកទុច្ចរិត នៅគ្រាដែលព្រះយាងមកលើកទីពីរ — មនុស្សចំនួនតិចនៅរស់ បន្ទាប់ពីព្រះអម្ចាស់ទ្រង់យាងមកម្ដងទៀត — សំណល់នៃពួកយ៉ាកុប នឹងត្រឡប់មកវិញ នៅគ្រានោះ — ចូរប្រៀបធៀបនឹងគម្ពីរ អេសាយ ១០ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

វេទនាដល់ពួកអ្នក ដែលចេញបញ្ញត្តិទុច្ចរិត និងពួកអ្នកដែល
តែងច្បាប់វៀចវេរ;
២ ដើម្បីនឹងបង្វែរពួកកំសត់ទុគ៌តចេញពី[ក]ការជំនុំជំរះ ហើយ
ដកយកសិទ្ធិចេញពីមនុស្សទាល់ក្រ ក្នុងពួករាស្ត្ររបស់យើង
ឲ្យតែបានពួក [ខ]ស្រីមេម៉ាយទុកជារបឹប ហើយធ្វើឲ្យពួកកំព្រាបាន
ជារំពាដល់ខ្លួន ។
៣ នោះតើអ្នករាល់គ្នានឹងធ្វើដូចម្ដេច ក្នុងថ្ងៃ[ក]ពិនិត្យពិច័យ
ហើយក្នុងការបំផ្លាញ ដែលនឹងមកពីទីឆ្ងាយ ? តើអ្នករាល់គ្នា
នឹងរកពឹង ពាក់ដល់អ្នកណា? ហើយតើនឹងផ្ញើសក្ដិយសរបស់
អ្នកទុកនៅឯណា ?
៤ ក្រៅពីយើង ពួកគេនឹងឱនចុះទៅក្រោមពួកឈ្លើយប៉ុណ្ណោះ
ហើយនឹងត្រូវដួលនៅក្រោមខ្មោច នៃពួកអ្នកដែលត្រូវ
គេសម្លាប់ ។ ទោះបើធ្វើទោសជាច្រើនដល់ម្លេះក៏ដោយ គង់
តែសេចក្ដីខ្ញាល់របស់ទ្រង់ មិនទាន់បែរចេញនៅឡើយ
គឺព្រះហស្តទ្រង់នៅតែលូក មកទៀត ។
៥ ឱពួកសាសន៍អាសស៊ើរអើយ ដែលជាដំបងនៃសេចក្ដី
កំហឹងរបស់យើង ហើយរំពាត់នៅដៃគេ គឺជាសេចក្ដីគ្នា
[ក]ន់ក្នាញ់របស់គេ ។
៦ យើងនឹងចាត់គេឲ្យទៅ[ក]ទាស់នឹងសាសន៍មួយ ដែល
លាក់ពុត ហើយនឹងបង្គាប់ការដល់គេឲ្យទាស់នឹងសាសន៍មួយ
ដែលត្រូវសេចក្ដីក្រោធរបស់យើង ឲ្យបានចាប់យករបឹប
ចាប់រំពា ហើយជាន់ឈ្លីសាសន៍ នោះដូចជាភក់នៅផ្លូវផង ។
៧ ប៉ុន្តែគេមិនយល់ដូច្នោះទេ ហើយចិត្តគេក៏មិនគិតឃើញ
ដល់ម្លេះដែរ; ប៉ុន្តែគេមានចិត្តចង់បំផ្លាញវិញ ក៏ចង់កាត់
សាសន៍ជាច្រើន ឲ្យសូន្យ ចេញមិនតិចឡើយ ។
៨ ត្បិតគេថា៖ ឯចៅហ្វាយរបស់ខ្ញុំទាំងប៉ុន្មាន មិនមែន
ជាស្ដេចគ្រប់គ្នាទេឬអី ?
៩ ឯក្រុងកាលនរ តើមិនមែនដូចជាក្រុងកើកេមីសទេឬអី ?
ឯក្រុងហាម៉ាត តើមិនមែនដូចជាក្រុងអើផាឌទេឬអី ? ហើយ
ក្រុងសាម៉ារី តើមិនមែនដូចជាក្រុងដាម៉ាសទេឬអី ?
១០ ត្បិតដៃ[ក]យើងបានលូកទៅចាប់យកអស់ទាំងនគរ ដែល
គោរពដល់រូបព្រះ ជាស្រុកដែលមានរូបឆ្លាក់ វិសេសជាងរូប
ឆ្លាក់នៅ ក្រុងយេរូសាឡិម និងក្រុងសាម៉ារីទៅហើយ;
១១ ចុះតើយើងនឹងមិនធ្វើដល់ក្រុងសាម៉ារី និងរូបព្រះ
របស់គេ ដូចជាបានធ្វើដល់ក្រុងយេរូសាឡិម និងរូបព្រះ
របស់គេដែរទេឬអី ?
១២ ដោយហេតុនោះ ហេតុការណ៍នឹងកើតឡើងថា
កាលណាយើង ជាព្រះអម្ចាស់បានសំរេចគ្រប់ទាំងការ
របស់យើងនៅលើភ្នំ ស៊ី[ខ]យ៉ូន និងក្រុងយេរូសាឡិម នោះយើង
នឹងធ្វើទោស[ក]ដល់ស្ដេចអាសស៊ើរ ដោយព្រោះការដែល
សេចក្ដីអំនួតរបស់គេបានធ្វើ ហើយ ដល់សេចក្ដីអង់អាចនៃឫក
ខ្ពស់របស់គេដែរ ។
១៣ ត្បិត[ក]គេបានថា៖ យើងបានធ្វើការទាំងនេះដោយកម្លាំង
នៃដៃយើង ហើយដោយប្រាជ្ញារបស់យើងដែរ; ដោយយើង
មាន យោបល់ពិត; ហើយយើងបានដកព្រំដែននៃសាសន៍
ទាំងប៉ុន្មានចោល ក៏បានរឹបយកទ្រព្យសម្បត្តិគេ ហើយយើងបាន
បង្ក្រាបបណ្ដាជន ទាំងឡាយ បីដូចជាមនុស្សមានចិត្តក្លាហាន ។
១៤ ឯដៃយើងយកបានទ្រព្យសម្បត្តិនៃអស់ទាំងសាសន៍;
ដូចជាយកបានសំបុកសត្វ ក៏ដូចជាប្រមូលពងសត្វ ដែល
មេចោលហើយ ជាយ៉ាងណា យើងក៏បានប្រមូលរួបរួម
លោកិយទាំងមូលយ៉ាងនោះដែរ; ហើយឥតមានអ្វីមួយកំរើកស្លាប
ឬហាមាត់ ឬស្រែក ចេចចាចឡើយ ។

២១ *ឝ* ស.ប. យូដា.
**២០** ២*ក* ឬ សេចក្ដីយុត្តិធម៌.
*ខ* ស.ប. ស្រីមេម៉ាយ.
៣ *ក* ក.ន. ការដាក់ទោស.
៥ *ក* អេសាយ ១០:៥.
៦ *ក* ក.ន. ទាស់នឹងសាសន៍អ៊ីស្រាអែល.
១០ *ក* ក.ន. ដីរបស់ស្ដេចស្រុកអាសស៊ើរ (*ខ* ១០–១១).
១២ *ក* ក.ន. សេចក្ដីអួតរបស់ពួកឆ្មើងឆ្មៃ.
*ខ* សេផា. ២:១៣.
១៣ *ក* ក.ន. ស្ដេចស្រុកអាសស៊ើរ (*ខ* ១៣–១៤).

១៥ [ក]ឯពូថៅ តើ[ខ]នឹងអួតខ្លួន ចំពោះអ្នកដែលប្រើវាឬអី ? តើរណារនឹងដំកើងខ្លួន ចំពោះអ្នកដែលអារដែរឬ? នេះឧបមាដូចជា រំពាត់ដែលនឹងយារអ្នកដែលលើកវាឡើង ឬដូចជាដំបងនឹងលើកមនុស្សឡើង ជាមនុស្សដែលមិនមែនធ្វើជាឈើផង !

១៦ ដោយហេតុនោះ ព្រះអម្ចាស់ គឺជាព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់នឹងចាត់សេចក្ដីស្គមស្គាំង ក្នុងចំណោមពួក[ក]ធាត់ៗរបស់គេ; ហើយនៅក្រោមសិរីល្អរបស់ទ្រង់ នោះទ្រង់នឹងឆួលឆេះឡើងដូចជាភ្លើងឆេះ ។

១៧ ឯពន្លឺនៃសាសន៍អ៊ីស្រាអែល នោះនឹងបានសំរាប់ជាភ្លើង ហើយព្រះដ៏បរិសុទ្ធរបស់គេ ជាអណ្ដាតភ្លើង ភ្លើងនោះនឹងឆេះឡើង ហើយបន្សុសពួកបន្លា និងអញ្ចាញរបស់គេ ក្នុងថ្ងៃតែមួយ;

១៨ ព្រមទាំងធ្វើឲ្យលំអនៃព្រៃ និងចំការដុះដាលរបស់គេសាបសូន្យទៅ ទាំង[ក]ព្រលឹង និងរូបកាយរបស់គេផង; នោះគេនឹងបានដូចជា មនុស្សកើតជម្ងឺ ដែលនាំឲ្យខ្លួនរីងរៃស្លាប់ទៅ ។

១៩ [ក]ឯសំណល់ដើមឈើ ដែលសល់នៅក្នុងព្រៃរបស់គេ នោះនឹងមានតិចណាស់ ដល់ម្ល៉េះបានជាកូនក្មេង នឹងអាចកត់ទុកបាន ។

២០ ហើយហេតុការណ៍នឹងកើតឡើងថា [ក]នៅថ្ងៃនោះ សំណល់នៃពួកអ៊ីស្រាអែល និង[ខ]វង្សនៃយ៉ាកុប ដែលបានរួចខ្លួនមក គេនឹងលែង [គ]ពឹងផ្អែកលើមនុស្ស ដែលបានវាយគេតទៅ ប៉ុន្តែនឹងផ្អែកលើព្រះ ជាព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែល ដោយពិតត្រង់វិញ ។

២១ ឯពួកដែល[ក]សល់ មែនហើយ គឺជាសំណល់នៃពួកយ៉ាកុប គេនឹងត្រឡប់មកឯព្រះដ៏មានព្រះចេស្ដាវិញ ។

២២ ឱអ៊ីស្រាអែលអើយ ទោះបើជនជាតិអ្នកបានដូចជាខ្សាច់នៅសមុទ្រក៏ដោយ គង់តែនឹងមានតែសំណល់ខ្លះដែលមកវិញ; ត្បិតបានសំរេចឲ្យមាន[ក]ការបំផ្លាញ ដោយសេចក្ដីសុចរិត[ខ]ដ៏លើសលន់ ។

២៣ ព្រោះព្រះអម្ចាស់ដ៏ជាព្រះនៃពួកពលបរិវារ ទ្រង់នឹង[ក]បង្ហើយការបំផ្លាញសព្វគ្រប់ នៅកណ្ដាលស្រុកទាំងមូល ដូចជាបានសំរេច ហើយ ។

២៤ ហេតុដូច្នេះ ព្រះអម្ចាស់ដ៏ជាព្រះនៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ឱរាស្ត្រយើង ដែលអាស្រ័យនៅក្រុងស៊ីយ៉ូនអើយ កុំឲ្យខ្លាចចំពោះសាសន៍អាសស៊ើរនោះឡើយ; ទោះបើគេវាយអ្នកដោយរំពាត់ ហើយលើកដំបងខ្លួនឡើងទាស់នឹងអ្នក [ក]ដូចយ៉ាង សាសន៍អេស៊ីព្ទក៏ដោយ ។

២៥ ត្បិតនៅតែបន្ដិចទៀត សេចក្ដីឈឺចាប់នឹងបានសំរេច ហើយសេចក្ដីកំហឹងរបស់យើង នឹងបែរទៅសេចក្ដីបំផ្លិចបំផ្លាញដល់ គេវិញ ។

២៦ នោះព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់នឹងពន្លះរំពាត់មួយមកទាស់នឹងគេ បែបដូចជាកាលប្រហារជីវិតសាសន៍[ក]ម៉ាឌាននៅត្រង់ថ្មអូរិប; ហើយទ្រង់នឹងយារដំបងពីលើទឹកសមុទ្រ ដូចយ៉ាងរបៀបនៅស្រុកអេស៊ីព្ទដែរ ។

២៧ ហើយហេតុការណ៍នឹងកើតឡើង គឺនៅថ្ងៃនោះ [ក]បន្ទុកដែលគេដាក់លើអ្នក នឹងបាត់ចេញពីស្មាអ្នកទៅ ហើយនឹមដែលគេដាក់លើអ្នក នឹងបាត់ចេញពីកអ្នកដែរ ឯនឹមនោះនឹងត្រូវបំផ្លាញដោយព្រោះពិធី [ខ]លាបប្រេង ។

២៨ [ក]គេបានឡើងមកដល់អៃយ៉ាត គេបានដើរកាត់ស្រុកមីក្រូន; គេបានដាក់អីវ៉ាន់របស់គេនៅត្រង់មីកម៉ាសហើយ ។

២៩ គេបានឆ្លងមកហួសផ្លូវកាត់ភ្នំ; គេបាន

---

១៥ *ក* ក.ន. គ្រប់ពាក្យប្រៀបប្រដូចទាំងអស់នៅក្នុងខនេះ ចេះតែសួរសំនួរដដែលថា៖ តើមនុស្ស (ឧទាហរណ៍ ស្ដេចអាសស៊ើរ) អាចលូតលាស់ទាស់នឹងព្រះបានឬ ?
*ខ* ក.ន. ព្យាការីប្រៀបធៀបស្ដេចទៅនឹងគ្រឿងឧបករណ៍.
១៦ *ក* ក.ន. ស្ដេចអាសស៊ើរ (ព្រមទាំងខ ១៧—១៩ ផងដែរ).
១៨ *ក* ក.ន. ស្រុកអាសស៊ើរនឹងសាបសូន្យបាត់អស់ទៅ.
១៩ *ក* ក.ន. ពួកសំណល់នៃពលទ័ពអាសស៊ើរ.
២០ *ក* ក.ន. ថ្ងៃចុងក្រោយ.
*ខ* អេម៉ុស ៩:៨—៩.
*គ* ក.ន. ពឹងទៅលើ.
២១ *ក* អេសាយ ១១:១១—១២.
២២ *ក* គ. និង ស. ៦៣:៣៤.
ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
*ខ* ក.ន. សូម្បីតែនៅពេលការកាត់ទោសមកដល់ ក៏គង់តែមានសេចក្ដីមេត្តាករុណាដែរ.
២៣ *ក* ក.ន. បណ្ដាលឲ្យមានសេចក្ដីបំផ្លិចបំផ្លាញដែលបានចែងទុក.
២៤ *ក* ក.ន. ដូចជាពួកសាសន៍អេស៊ីព្ទបានប្រព្រឹត្តនៅពេលមុនៗ.
និក្ខ. ១:១៣—១៤.
២៦ *ក* លោកុ. ២៥:១—២;
ពួកចៅ. ៧:២៥.
២៧ *ក* អេសាយ ១៤:២៥.
*ខ* ស.ប. ព្រះដែលបានចាក់ប្រេងតាំង.
២៨ *ក* ក.ន. ដំណើរនៃពលទ័ពអាសស៊ើរទៅកាន់ក្រុងយេរូសាឡិមត្រូវបានរៀបរាប់ប្រាប់; រួចហើយ (ខ ៣៣—៣៤) ទើបប្រាប់ពីការរបស់ព្រះអម្ចាស់ទាស់នឹងពួកគេស្របតាមនិមិត្តរូប.

ឈប់ស្នាក់នៅត្រង់កេបា; ក្រុងរ៉ាម៉ាតក៏ភ័យញ័រ; ហើយពួក
គីបៀរ ជាស្រុករបស់ សូលបានរត់អស់ហើយ ។
៣០ ឱកូនស្រីនៃក្រុងកាលីមអើយ ចូរបន្លឺសម្លេងឡើង; ឱពួក
ក្រុងឡាអ៊ីសអើយ ចូរស្តាប់ចុះ; ឱពួកក្រុងអាន៉ាថោតអើយ
គួរអាណិតអ្នកណាស់ហ្ន៎ ។
៣១ ពួកម៉ាតមេណាបានរត់រួចទៅហើយ; ឯពួកកេប៊ីមក៏កំពុងតែ
រកផ្លូវរត់ដែរ ។
៣២ នៅថ្ងៃនេះឯង ពួកខ្មាំងនឹងឈប់ស្នាក់នៅត្រង់ក្រុងណូប;
គេជន្លទៃដកំហែងភ្នំនៃកូនស្រីក្រុងស៊ីយ៉ូន គឺភ្នំនៃក្រុងយេរូសាឡិម ។
៣៣ មើលចុះ ព្រះអម្ចាស់ គឺជាព្រះអម្ចាស់នៃពួកពលបរិវារ
ទ្រង់នឹងផ្តាច់មែកឈើ ដោយសេចក្តីស្ញែងខ្លាច; នោះ[ក]ពួកដែល
មាន កំពស់នឹងត្រូវកាប់រំលំចុះ; ហើយពួកនៅទីខ្ពស់នឹងត្រូវ
បន្ទាបវិញ ។
៣៤ ហើយទ្រង់នឹងគ្រាយព្រៃស្តុកដោយគ្រឿងដែក ហើយ
ព្រៃល្បាណូននឹងត្រូវដួលទៅ ដោយ អំណាចនៃអ្នកមាន
អានុភាព ៕

## ជំពូកទី ២១

*គល់របស់អ៊ីសាយ (ព្រះគ្រីស្ទ) នឹងជំនុំជំរះដោយនូវសេចក្តីសុចរិត — សេចក្តីចេះដឹងអំពីព្រះនឹងគ្របដណ្តប់ផែនដីនៅក្នុងសហស្សវត្សរ៍ — ព្រះអម្ចាស់ទ្រង់នឹងលើកទង់ ហើយប្រមូលពួកសាសន៍ អ៊ីស្រាអែល — ចូរប្រៀបធៀបនឹងគម្ពីរ អេសាយ ១១ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

មាន[ក]លំពង់១នឹងដុះចេញពីគល់របស់[ខ]អ៊ីសាយ ហើយ[គ]មែក១
ដែលចេញពីឫសលោកនឹងកើតមានផលផ្លែ ។
២ ហើយ[ក]ព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងសណ្ឋិតនៅលើលោក
គឺជាវិញ្ញាណនៃប្រាជ្ញា និងយោបល់ ជាវិញ្ញាណនៃគំនិតវាងវៃ
និងឥទ្ធិឫទ្ធិ ជាវិញ្ញាណនៃសេចក្តីចេះដឹង និងសេចក្តីកោតខ្លាច
ដល់ព្រះអម្ចាស់;
៣ ហើយលោកនឹងរីករហ័សចំពោះសេចក្តីកោតខ្លាចដល់
ព្រះអម្ចាស់; ហើយលោកនឹងមិន[ក]ជំនុំជំរះតាមភ្នែកមើលឃើញ
ឬសំរេច សេចក្តីតាមត្រចៀកស្តាប់ឮនោះឡើយ ។
៤ ប៉ុន្តែនឹងជំនុំជំរះពួកទាល់ក្រ[ក]ដោយសេចក្តីសុចរិត ហើយ
[ខ]សំរេចក្តីឲ្យមនុស្សស្លូតបូតនៅផែនដី ដោយសេចក្តីទៀងត្រង់;
ហើយ លោកនឹងវាយផែនដីដោយរំពាត់នៃមាត់ខ្លួន ព្រមទាំងសម្លាប់
មនុស្សដែលប្រព្រឹត្តអាក្រក់ ដោយខ្យល់ដង្ហើមពីបបូរមាត់ផង ។
៥ ឯសេចក្តីសុចរិតនឹងបាន[ក]ជាខ្សែក្រវាត់ចង្កេះរបស់អ្នកនោះ
ហើយសេចក្តីស្មោះត្រង់ជាខ្សែក្រវាត់កម្លាំងផង ។
៦ ឆ្កែព្រៃនឹងនៅជាមួយនឹងកូនចៀម ឯខ្លារខិននឹងដេកនៅជា
មួយនឹងកូនពពែ ឯកូនគោជាមួយនឹងសិង្ហស្ទាវ ព្រមទាំងសត្វ
បំប៉នយ៉ាងធាត់នឹងនៅជាមួយគ្នាដែរ; ហើយក្មេងតូចៗជាអ្នក
គង្វាលវា ។
៧ ហើយគោញី និងខ្លាឃ្មុំនឹងរកស៊ីជាមួយគ្នា; ហើយកូនវា
នឹងដេកនៅជាមួយដែរ; ឯសិង្ហនឹងស៊ីចំបើងដូចជាគោវិញ ។
៨ ហើយកូនមនុស្សដែលនៅបៅដោះ នឹងលេងនៅត្រង់
មាត់[ក]រន្ធពស់ហនុមាន ហើយក្មេងលែងដោះនឹងលូក ដៃ
ចូលទៅក្នុង [ខ]រូងពស់វែកបាន ។
៩ វារាល់គ្នានឹង[ក]មិនធ្វើទុក្ខ ឬបំផ្លាញគ្នានៅគ្រប់លើភ្នំបរិសុទ្ធ
របស់យើង ត្បិតគ្រប់ទាំងអស់នឹង[ខ]ស្គាល់ព្រះអម្ចាស់ ពាសពេញ
លើផែន ដី ដូចជាទឹកនៅពាសពេញក្នុងសមុទ្រដែរ ។
១០ ហើយនៅថ្ងៃនោះ [ក]ឫសនៃ[ខ]អ៊ីសាយនឹងបានតាំងឡើង ទុកជា
ទង់ដល់ជនជាតិទាំងឡាយ; ឯ[គ]គ្រប់[ឃ]សាសន៍ដទៃ គេនឹងស្វែងរកអ្នក
នោះ; ឯទីសំរាករបស់អ្នកនោះ នឹងបានជាទីរុងរឿងឧត្តម ។
១១ ហើយហេតុការណ៍នឹងកើតឡើងថា នៅថ្ងៃនោះ ព្រះ
អម្ចាស់ទ្រង់នឹងលូកព្រះហស្តទ្រង់ទៅ[ក]ម្តងទៀត ដើម្បីនឹងប្រមូលពួក

៣៣ *ក* ហេលេ. ៤:១២–១៣.
**២១** ១ *ក* គ. និង ស. ១១៣:៣–៤.
*ខ* គ. និង ស. ១១៣:១–២.
*គ* អ៊ីសាយត្រូវជាបិតារបស់ដាវីឌ; សេចក្តីយោងនេះត្រូវបានប្រាប់អំពីរាជវង្សរបស់ស្តេចដាវីឌ ដែលព្រះយេស៊ូវបានប្រសូតមក. មីកា ៥:២; ហេព្រើរ ៧:១៤. ស.ប. អ៊ីសាយ.
២ *ក* អេសាយ ៦១:១–៣.
៣ *ក* យ៉ូហាន ៧:២៤.
៤ *ក* ទំនុក. ៧២:២–៤; ម៉ូសាយ ២៩:១២.
*ខ* ហេ. សំរេចចិត្ត.
*គ* ស.ប. ស្លូតបូត, ភាពស្លូតបូត.
៥ *ក* ឬ ចង្កេះ.
៨ *ក* ជាពស់តូចមួយដ៏មានពិស នៅស្រុកអេស៊ីព្ទ.
*ខ* ជាពស់ម្យ៉ាងទៀតដែលមានពិស.
៩ *ក* អេសាយ ២:៤.
*ខ* ស.ប. សហស្សវត្សរ៍.
*ខ* គ. និង ស. ១០១:៣២–៣៣; ១៣០:៩.
១០ *ក* ក.ន. ថ្ងៃចុងក្រោយ. ឃ.ស.— ប្រវត្តិ ១:៤០.
*ខ* រ៉ូម ១៥:១២; គ. និង ស. ១១៣:៥–៦.
*គ* ឬ ដល់លោក.
*ឃ* គ. និង ស. ៤៥:៩–១០.
១១ *ក* ២ នីហ្វៃ ៦:១៤; ២៥:១៧; ២៩:១.

សំណល់នៃរាស្ត្រទ្រង់ដែលសល់នៅ ឲ្យមកពីស្រុកអាសស៊ើរ ស្រុកអេស៊ីព្ទ ស្រុកប៉ាត្រូស ស្រុកគូស ស្រុកអេឡាំ ស្រុកស៊ីណើរ ស្រុកហាម៉ាត ហើយពីអស់ទាំងកោះនៅសមុទ្រមកវិញ ។

១២ ហើយទ្រង់នឹងលើកទង់មួយឡើងសំរាប់សាសន៍ទាំងឡាយ ហើយនឹងប្រមូលពួកព្រាត់ប្រាស នៃសាសន៍អ៊ីស្រាអែល ព្រមទាំងរួបរួមពួកខ្ចាត់ខ្ចាយរបស់សាសន៍យូដា មកពីទិសទាំងបួននៃផែនដី ។

១៣ ឯសេចក្ដីច្រណែនរបស់ពួកអេប្រាអិម នោះនឹងបាត់ទៅ ហើយអស់អ្នកក្នុងពួកយូដាដែលធ្វើទុក្ខគេ នឹងត្រូវកាត់ចេញដែរ; ពួកអេប្រាអិមនឹងលែងមានសេចក្ដីច្រណែនចំពោះពួកយូដា ហើយពួកយូដានឹងលែងធ្វើទុក្ខដល់ពួកអេប្រាអិម ។

១៤ តែគេនឹងរួមចិត្តគ្នាឆាបចុះទៅលើស្មាសាសន៍ភីលីស្ទីននៅទិសខាងលិច; គេនឹងប្លន់ពួកអ្នកនៅ ស្រុកខាងកើតជាមួយគ្នា; គេនឹងលូកដៃទៅបង្ក្រាបសាសន៍អេដំម និងសាសន៍ម៉ូអាប់; ឯពួកកូនចៅអាំម៉ូន នឹងស្ដាប់បង្គាប់គេដែរ ។

១៥ នោះព្រះអម្ចាស់ទ្រង់នឹងបំផ្លាញដៃសមុទ្រអេស៊ីព្ទអស់រលីង; ហើយទ្រង់នឹងលើកព្រះហស្តទៅលើទន្លេ បញ្ចេញខ្យល់ដ៏ខ្លាំងរបស់ទ្រង់ ទៅវាយទន្លេឲ្យបែកជា៧ផ្លូវ ដើម្បីឲ្យមនុស្សពាក់ស្បែកជើងដើរឆ្លងទៅបាន ។

១៦ ហើយនឹងមានថ្នល់១សំរាប់ពួកសំណល់នៃរាស្ត្រទ្រង់ ដែលរួចពីស្រុកអាសស៊ើរមក ដូចជាមានសំរាប់សាសន៍អ៊ីស្រាអែល នៅគ្រាដែលគេឡើងរួចពីស្រុកអេស៊ីព្ទមកដែរ ៕

## ជំពូកទី ២២

*នៅរយៈពេលមួយពាន់ឆ្នាំ មនុស្សគ្រប់រូបនឹងសរសើរដំកើងព្រះអម្ចាស់ — ទ្រង់នឹងគង់នៅក្នុងចំណោមពួកគេ — ចូរប្រៀបធៀប នឹងគម្ពីរអេសាយ ១២ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយនៅថ្ងៃនោះ អ្នកនឹងនិយាយថា៖ ឱព្រះអម្ចាស់អើយ ទូលបង្គំនឹងសរសើរដំកើងដល់ទ្រង់; ត្បិតទោះបើទ្រង់បានខ្ញាល់នឹងទូលបង្គំ ក៏ដោយ តែឥឡូវនេះ សេចក្ដីខ្ញាល់នោះបានបែរចេញទៅ ហើយទ្រង់បានកំសាន្តចិត្តទូលបង្គំវិញ ។

២ មើលចុះ ព្រះទ្រង់ជាសេចក្ដីសង្គ្រោះរបស់ខ្ញុំ; ខ្ញុំនឹងទុកចិត្តឥតមានសេចក្ដីខ្លាចឡើយ; ព្រោះព្រះអម្ចាស់ ដែលជាព្រះយេហូវ៉ា ទ្រង់ជាកម្លាំង ហើយជាបទចម្រៀងរបស់ខ្ញុំ; ហើយទ្រង់ជាសេចក្ដីសង្គ្រោះខ្ញុំដែរ ។

៣ ដោយហេតុនោះ អ្នករាល់គ្នានឹងដងទឹកពីអណ្ដូងនៃសេចក្ដីសង្គ្រោះដោយអំណរ ។

៤ ហើយនៅថ្ងៃនោះ អ្នករាល់គ្នានឹងពោលថា៖ ចូរសរសើរដំកើងដល់ព្រះអម្ចាស់ ចូរអំពាវនាវដល់ព្រះនាមទ្រង់ ចូរសរសើរពីកិច្ចការទាំងប៉ុន្មានរបស់ទ្រង់ចុះ ក្នុងចំណោមប្រជាជនទាំងឡាយ ចូរប្រកាសប្រាប់ថា ព្រះនាមទ្រង់ខ្ពស់វិសេស ។

៥ ចូរច្រៀងថ្វាយព្រះអម្ចាស់; ព្រោះទ្រង់បានធ្វើការដ៏ប្រសើរ; ត្រូវឲ្យមនុស្សដឹងដំណឹងនេះនៅពេញលើផែនដីផង ។

៦ ឱពួកអ្នកនៅក្រុងស៊ីយ៉ូនអើយ ចូរបន្លឺសម្លេងឡើង ហើយស្រែកហ៊ោដោយអំណរចុះ; ត្បិតព្រះដ៏បរិសុទ្ធ នៃសាសន៍អ៊ីស្រាអែល ទ្រង់ធំប្រសើរនៅកណ្ដាលអ្នករាល់គ្នា ៕

## ជំពូកទី ២៣

*ការបំផ្លិចបំផ្លាញក្រុងបាប៊ីឡូន គឺជាគំរូអំពីការបំផ្លិចបំផ្លាញនៅគ្រាដែលព្រះយាងមកលើកទីពីរ — នោះគឺជាថ្ងៃនៃការពិរោធ និងការ សងសឹក — ក្រុងបាប៊ីឡូន (លោកិយ) នឹងធ្លាក់ដរាបតទៅ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ១៣ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

១២ *ក* ស.ប. ទង់.
*ខ* ៣ នីហ្វៃ ១៥:១៥; ១៦:១–៤.
*គ* នេហ. ១:៩;
១ នីហ្វៃ ២២:១០–១២;
គ. និង ស. ៤៥:២៤–២៥.
ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
១៣ *ក* យេរ. ៣:១៨.
*ខ* ពួកពូជអំបូរដែលត្រូវបានដឹកនាំដោយយូដា និងអេប្រាអិម ត្រូវជាខ្មាំងសត្រូវនឹងគ្នាតាំងពីបូរាណមក (បន្ទាប់ពីហេតុការណ៍នៅក្នុងគម្ពីរពង្សាវ. ១២:១៦–២០) ។ នៅថ្ងៃចុងក្រោយ. អេសេ. ៣៧:១៦–២២.
ស.ប. ច្រណែន.
*គ* ស.ប. យូដា.
១៤ *ក* ក.ន. ការវាយនៅទីជំរាលខាងលិចដែលជាទឹកដីរបស់ពួកភីលីស្ទីន.
១៥ *ក* សាការី ១០:១១.
១៦ *ក* អេសាយ ៣៥:៨;
គ. និង ស. ១៣៣:២៧.
**២២** ២ *ក* ម៉ូសាយ ៤:៦; ហេលេ. ១២:១.
*ខ* និក្ខ. ១៥:២; ទំនុក. ៨៣:១៨.
ស.ប. ព្រះយេហូវ៉ា.
៣ *ក* ស.ប. ទឹករស់.
៤ *ក* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
៥ *ក* គ. និង ស. ១៣៦:២៨.
៦ *ក* អេសាយ ៥៤:១; សេផា. ៣:១៤.

[ក]បន្ទុកនៃ[ខ]ក្រុងបាប៊ីឡូន ដែលអេសាយ ជាកូនរបស់អ័ម៉ូសបាន
ឃើញ ។
២ ចូរលើក[ក]ទង់១សំរាប់អ្នករាល់គ្នានៅលើភ្នំត្រងិលចុះ
ចូរបន្លឺសម្លេងឡើង ហើយ[ខ]បោយដៃហៅ ដើម្បីឲ្យគេបាន
ចូលទៅតាមទ្វារ របស់ពួកមនុស្សដ៏មានត្រកូលខ្ពស់ ។
៣ យើងបានបង្គាប់ដល់[ក]ពួកបរិសុទ្ធរបស់យើង យើងបាន
ហៅពួកខ្លាំងពូកែរបស់យើង ព្រោះសេចក្តីកំហឹងរបស់យើង
មិននៅលើ អ្នកណាដែលមានសេចក្តីអំណរអរចំពោះសេចក្តី
ខ្ពង់ខ្ពស់របស់យើងទេ ។
៤ មានឮសូរគឹកកងរបស់មនុស្សកកកុញនៅលើភ្នំ គឺជា
សូរដូចជាប្រជាជាតិយ៉ាងធំ ជាសូរអឺកធឹក របស់[ក]នគរនៃសាសន៍
ទាំងប៉ុន្មាន [ខ]ប្រជុំគ្នា គឺព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់កំពុងតែ
ត្រួតត្រាមើលទ័ពពល សំរាប់ចូលច្បាំង ។
៥ គេមកពីស្រុកឆ្ងាយ ជាប្រទេសនៅជើងមេឃ
ឆ្ងាយបំផុត មែនហើយ គឺព្រះអម្ចាស់ ហើយនឹងគ្រឿងអាវុធ
នៃសេចក្តីគ្នាន់ក្នាញ់ របស់ទ្រង់ ដើម្បីនឹងបំផ្លាញស្រុកនេះទាំង
មូលទៅ ។
៦ ចូរទ្រហោសោកសំរែងចុះ ត្បិតថ្ងៃនៃព្រះអម្ចាស់ជិត
ដល់ហើយ; ថ្ងៃនោះនឹងមកដល់ទុកជាការបំផ្លិចបំផ្លាញ ដែល
មកពីព្រះដ៏មាន គ្រប់ព្រះចេស្តា ។
៧ ដោយហេតុនោះ បានជាដៃមនុស្សទាំងអស់នឹងត្រូវរាប
ហើយចិត្តនៃមនុស្សទាំងអស់នឹងរលត់ដែរ;
៨ នោះគេនឹងស្រយុតចិត្តទៅ; សេចក្តីឈឺចាប់ និងសេចក្តី
សោកសៅនឹងនៅជាប់គេបាន; គេនឹងស្រឡាំង
កាំងមើលគ្នាទៅវិញ ទៅមក; មុខគេដូចជាអណ្តាតភ្លើង ។
៩ មើលចុះ ថ្ងៃនៃព្រះអម្ចាស់កំពុងខិតជិតមក ជាថ្ងៃ
ដ៏អស្ចារ្យដោយសេចក្តីក្រោធ និងកំហឹងយ៉ាងខ្លាំង ដើម្បីនឹង
[ក]បំផ្លាញស្រុកឲ្យរលីង; ហើយទ្រង់នឹងធ្វើឲ្យមនុស្សមាន
បាបសូន្យចេញ ។
១០ ព្រោះអស់ទាំងផ្កាយនៅលើមេឃ និងផ្កាយចក្ររាសី
នឹងលែងបញ្ចេញពន្លឺ; [ក]ព្រះអាទិត្យនឹងងងឹត តាំងតែពីរះឡើង
ហើយព្រះ ច័ន្ទក៏នឹងអាប់រស្មីទៅដែរ ។
១១ ហើយយើងនឹង[ក]ធ្វើទោសដល់លោកិយ ដោយព្រោះ
អំពើអាក្រក់របស់គេ ព្រមទាំងមនុស្សដែលប្រព្រឹត្តបទអាក្រក់
ដោយព្រោះ អំពើទុច្ចរិតរបស់គេផង; យើងនឹងបំបាត់[ខ]សេចក្តី
ឆ្មើងឆ្មៃរបស់ពួកអំនួត ហើយនឹងបន្ទាបបន្ថោកឫកខ្ពស់ របស់
មនុស្សកាចអាក្រក់ ។
១២ យើងនឹងធ្វើឲ្យកម្រមាន[ក]មនុស្ស ដូចជាកម្រមាន
មាសសុទ្ធដែរ; គឺនឹងឲ្យមនុស្សម្នាក់កម្រមាន ជាជាងមាស
ពីស្រុកអូភារទៅទៀត ។
១៣ ហេតុដូច្នេះ យើងនឹងធ្វើឲ្យផ្ទៃមេឃញាប់ញ័រ ហើយ
[ក]ផែនដីនឹងត្រូវកក្រើករំពើកចេញពីកន្លែងធម្មតា គឺក្នុងគ្រានៃ
សេចក្តីក្រោធ របស់ព្រះអម្ចាស់នៃពួកពលបរិវារ ហើយក្នុងថ្ងៃ
នៃសេចក្តីខ្ញាល់ ដ៏អស្ចារ្យរបស់ទ្រង់ ។
១៤ នោះគេនឹងបានដូចជាប្រើសដែលត្រូវគេ[ក]ប្រដេញ
ហើយដូចជាហ្វូងចៀម ដែលឥតមានអ្នកគង្វាល; គ្រប់គ្នា
នឹងវិលទៅឯសាសន៍ របស់ខ្លួនវិញ ហើយរត់ទៅឯស្រុក
របស់ខ្លួនគ្រប់ៗគ្នា ។
១៥ អស់អ្នកដែលមានសេចក្តីឆ្មើងឆ្មៃនឹងត្រូវចាក់ទំលុះ;
មែនហើយ ហើយអស់អ្នកដែលចូលនឹងពួកទុច្ចរិត នោះនឹងត្រូវ
ដួលដោយ ដាវ ។
១៦ កូនរបស់គេក៏នឹងត្រូវបោកខ្ទេចខ្ទីនៅចំពោះភ្នែកដែរ;
ផ្ទះគេនឹងត្រូវរឹបជាន់ ឯប្រពន្ធគេនឹងត្រូវកំហែងចិត្ត ។
១៧ មើលចុះ យើងនឹងញុះញង់សាសន៍មេឌីឲ្យទាស់នឹងគេ
ជាសាសន៍ដែលមិនរាប់អានមាសប្រាក់ ឬក៏ត្រេកអរនឹងមាស
ប្រាក់ដែរ ។
១៨ ឯធ្នូរបស់សាសន៍នោះ ក៏នឹងផ្តួលពួកកំឡោះៗ
អស់រលីងទៅ; ហើយគេនឹងឥតមានមេត្តាចំពោះផលដែល
កើតពីផ្ទៃឡើយ; ភ្នែកគេមិនចេះប្រណីដល់ពួកក្មេងៗដែរ ។
១៩ នោះក្រុងបាប៊ីឡូនដែលជាសិរីល្អនៃអស់ទាំងនគរ ហើយ

**២៣** ១*ក* ក.ន. ជាសារអំពីការហិនវិនាស.
*ខ* សេចក្តីបំផ្លិចបំផ្លាញពីបូរាណអំពីក្រុងបាប៊ីឡូនដែលទុច្ចរិច ត្រូវបានព្យាករនៅក្នុងគម្ពីរអេសាយ ១៣ និង ១៤ ហើយបានយកមកធ្វើជាគំរូអំពីសេចក្តីបំផ្លិចបំផ្លាញនៃពិភពលោកទាំងមូលដែលទុច្ចរិច គ. និង ស. ១៣៣:៥, ៧, ១៤.
ស.ប. បាបិល, បាប៊ីឡូន.
២ *ក* ឬ ទង់.
ស.ប. ទង់.
*ខ* ក.ន. បោយដៃ ឲ្យសំគាល់.
៣ *ក* ក.ន. ពួកបរិសុទ្ធ.
៤ *ក* សាការី ១៤:២–៣.
*ខ* សាការី ១២:៣.
៩ *ក* ស.ប. ផែនដី — ការសំអាតផែនដី.
១០ *ក* ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
១១ *ក* ម៉ាឡាគី ៤:១.
*ខ* គ. និង ស. ៦៤:២៤.
១២ *ក* អេសាយ ៤:១–៤.
១៣ *ក* ស.ប. ផែនដី — ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
១៤ *ក* ឬ ដេញបាញ់ប្រើស.

ជាទីលំអនៃសេចក្ដីអំនួតរបស់សាសន៍ខាល់ដេ នឹងត្រូវដូចជា
កាលព្រះ បានរំលាយក្រុងសូដុំម និងក្រុងកូម៉ូរ៉ាដែរ ។
២០ ក្រុងនោះនឹងគ្មានអ្នកណានៅតទៅទៀតឡើយ ក៏មិន
ដែលមានអ្នកណាអាស្រ័យនៅ ដរាបដល់ អស់ទាំងតំណ
មនុស្សតទៅ ទោះទាំងសាសន៍អារ៉ាប់ គេក៏មិន
ដំឡើងត្រសាលនៅទីនោះ; ហើយពួកគង្វាល ក៏មិននាំហ្វូង
សត្វរបស់គេទៅដេកនៅទីនោះដែរ ។
២១ គឺមានតែសត្វដែលនៅទីរហោស្ថានអាស្រ័យនៅទីនោះវិញ;
ឯផ្ទះគេនឹងមានពេញដោយសម្លេងសត្វយំ; សត្វទីទុយនឹង
អាស្រ័យនៅ ហើយពពែព្រៃនឹងលោតកញ្ឆេងនៅទីនោះ ។
២២ ឯហ្វូងសត្វព្រៃនៃកោះនឹងលូនៅក្នុងដំណាក់ស្ងាត់របស់គេ
ហើយនាគនឹងនៅក្នុងមន្ទីរ ជាទីសប្បាយរបស់គេដែរ;
ឯពេលវេលា របស់ទីក្រុងនោះ ក៏ជិតមកដល់ហើយ ថ្ងៃនោះ
នឹងមិនត្រូវពន្យាទេ ។ ត្បិតយើងនឹងបំផ្លាញទីក្រុងនោះយ៉ាង
រហ័ស; មែនហើយ យើងនឹង អាណិតអាសូរដល់រាស្ត្រយើង
តែពួកទុច្ចរិត ត្រូវតែវិនាស ៕

## ជំពូកទី ២៤

*សាសន៍អ៊ីស្រាអែលនឹងបានប្រមូលមក ហើយនឹង សំរាកក្នុងរយៈពេលមួយពាន់ឆ្នាំ — លូស៊ីហ្វើរត្រូវបាន បណ្ដេញ ចេញពីស្ថានសួគ៌ មកពីការបះបោរ — សាសន៍ អ៊ីស្រាអែលនឹងមានជ័យជំនះលើក្រុងបាប៊ីឡូន (លោកិយ) — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ១៤ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ពីព្រោះព្រះអម្ចាស់ ទ្រង់នឹងអាណិតអាសូរដល់ពួកយ៉ាកុប ហើយ
នឹងរើសអ៊ីស្រាអែលទៀត ព្រមទាំងដាក់គេ ឲ្យនៅក្នុងស្រុក
របស់គេ វិញ; ឯពួកអ្នកដែលស្នាក់នៅនោះ នឹងចូលរួមពួកគេ
ហើយនៅជាប់នឹងពួកវង្សរបស់យ៉ាកុប ។
២ ហើយសាសន៍ទាំងប៉ុន្មាននឹងនាំយកគេទៅឯទីកន្លែង
របស់គេវិញ; មែនហើយ ពីទីឆ្ងាយទៅដល់ចុងផែនដី; ហើយ
ពួកគេនឹង ត្រឡប់ទៅដែនដីសន្យារបស់គេវិញ ។ ហើយពួកវង្ស
អ៊ីស្រាអែលនឹងទទួលពួកសាសន៍ទាំងនោះ ឯដែនដីរបស់ព្រះ
ទុកសំរាប់ ពួកបាវប្រុស និងបាវស្រី នៅក្នុងស្រុករបស់ព្រះ
អម្ចាស់; ហើយគេនឹងចាប់អ្នកទាំង នោះជាឈ្លើយ ជាអ្នក
ដែលពីដើមបានចាប់ខ្លួនគេជា ឈ្លើយនោះឯង; ហើយគេនឹងគ្រប់
គ្រងលើពួកអ្នក ដែលបានសង្កត់សង្កិនខ្លួនវិញ ។
៣ ហើយហេតុការណ៍នឹងកើតឡើងថា នៅថ្ងៃដែលព្រះ
អម្ចាស់បានប្រោសប្រទាន ឲ្យអ្នកបានសំរាកពីសេចក្ដីទុក្ខសោក
ពីសេចក្ដី ភិតភ័យ ហើយពីការបំរើយ៉ាងរឹងរូស ដែលគេបាន
ចាប់អ្នកប្រើ ។
៤ ហើយហេតុការណ៍នឹងកើតឡើងថា នៅថ្ងៃនោះ អ្នក
នឹងពោលពាក្យចំអកនេះ ដាក់ស្ដេចក្រុងបាប៊ីឡូនថា៖ យីអើ
ពួកសង្កត់សង្កិន បានឈប់ទ្រឹងយ៉ាងណាហ្ន៎ !
៥ ព្រះអម្ចាស់ទ្រង់បានបំបាក់ដំបងរបស់មនុស្សអាក្រក់ និង
ដំបងពេជ្រនៃអ្នកគ្រប់គ្រងហើយ ។
៦ ជាអ្នកដែលបានវាយជនជាតិទាំងឡាយមិនឈប់ឈរ
ដោយចិត្តក្រេវក្រោធ ហើយបានគ្រប់គ្រងលើអស់ទាំងសាសន៍
ដោយ សេចក្ដីកំហឹង ហើយញាំញី ដោយឥតមានអ្នកណា
ឃាត់ឃាំងឡើយ ។
៧ ផែនដីទាំងមូលបានស្រាកស្រាន្តអស់ហើយ ក៏ស្ងៀម
ស្ងប់ដែរ; គេបន្លឺសម្លេងច្រៀងចេញមក ។
៨ មែនហើយ ទាំងដើមកកោះក៏អរររីករាយចំពោះអ្នក
និងដើមតាត្រៅនៅភ្នំល្បាណូនផង ដោយពាក្យថា៖ តាំងពីអ្នក
ត្រូវរលំចុះ នោះឥតមានអ្នកណាឡើងមកកាប់រំលំយើងទៀតទេ ។
៩ ឯស្ថាននរកនៅខាងក្រោម មានសេចក្ដីរំជួលដោយព្រោះអ្នក
ដើម្បីនឹងទទួលអ្នកក្នុងកាលដែលអ្នកទៅដល់; ក៏ដាស់ពួកមនុស្ស
ស្លាប់ឡើង ដោយព្រោះអ្នក គឺទាំងពួកអ្នកធំនៅផែនដីផង;

១៩ *ក* ក.ន. ភាពឥតប្រយោជន៍.
*ខ* លោកុ. ១៩:២៤–២៥;
ចោទិ. ២៩:២៣; ២ នីហ្វៃ ១៣:៩.
២០ *ក* យេរេ. ៥០:៣, ៣៩–៤០.
២១ *ក* អេសាយ ៣៤:១៤–១៥.
*ខ* ក.ន. សត្វពពែព្រៃឈ្មោល ឬពួក
អារក្ស.
២២ *ក* ហេ. ដំណាក់.
*ខ* ហេ. (ប្រហែលជា) សត្វចចក
ឬឆ្កែព្រៃ.
**២៤** ១ *ក* សាការី ១:១៧.
*ខ* អេសាយ ៦០:៣–៥, ១០.
២ *ក* ក.ន. ពួកសាសន៍ផ្សេងៗនឹង
ជួយសាសន៍អ៊ីស្រាអែល.
*ខ* ស.ប. ដែនដីសន្យា.
*គ* អេសាយ ៦០:១៤.
៣ *ក* យ៉ូស្វេ ១:១៣;
គ. និង ស. ៨៤:២៤.
៤ *ក* ស.ប. បាបិល, បាប៊ីឡូន.
៧ *ក* អេសាយ ៥៥:១២.
៨ *ក* ហេ. ដើមស្រល់.
*ខ* ក.ន. នៅក្នុងសេចក្ដីស្លាប់.
*គ* ហេ. អ្នកកាប់រំលំ (ឈើ) ពុំទាន់
មកប្រឆាំងនឹងយើងទេ.
៩ *ក* ស.ប. ស្ថាននរក.
*ខ* ក.ន. ពួកវិញ្ញាណ
ដែលចេញពីរាងកាយ.

ក៏បានឲ្យអស់ទាំងស្ដេចនៃសាសន៍ទាំងប៉ុន្មាន ក្រោកពីបល្ល័ង្ក
របស់គេ ។
១០ គេនឹងនិយាយមកអ្នកគ្រប់គ្នាថា៖ នោះនឹ អ្នក
ទៅជាខ្សោយដូចយើងហើយឬ? បានត្រឡប់ដូចជាយើងដែរឬ?
១១ ឯសេចក្ដីរុងរឿងឧត្ដមរបស់អ្នកបានត្រូវនាំចុះមកក្នុងផ្នូរ;
សូរដេញពិណរបស់អ្នកក៏មិនឮ; មានដង្កូវក្រាលក្រោមអ្នក
ហើយមាន ដង្កូវគ្របដណ្ដប់អ្នកដែរ ។
១២ ឱលូស៊ីហ្វើរ ជាបុត្រានៃពេលព្រឹកអើយ អ្នកបាន
ធ្លាក់ចុះពីលើមេឃហើយ ! អ្នកដែលបានផ្ដួលសាសន៍ទាំង
ឡាយឲ្យរាប អ្នកបានត្រូវកាប់រំលំដល់ដីដែរហ្ន៎ !
១៣ អ្នកបានគិតក្នុងចិត្តថា៖ ខ្ញុំនឹងឡើងទៅឯស្ថានសួគ៌ ខ្ញុំនឹង
ដំកើងបល្ល័ង្កខ្ញុំឲ្យខ្ពស់ជាង អស់ទាំងផ្កាយរបស់ព្រះ; ហើយខ្ញុំ
នឹងអង្គុយ លើភ្នំជាទីប្រជុំជំនុំ នៅទីបំផុតនៃទិសខាងជើង;
១៤ ខ្ញុំនឹងឡើងទៅផុតទីខ្ពស់នៃពពក; ខ្ញុំនឹងលើកខ្លួនឲ្យបាន
ដូចជាព្រះដ៏ខ្ពស់បំផុត ។
១៥ តែអ្នកបានត្រូវទំលាក់ចុះដល់ស្ថាននរកវិញ
គឺដល់ទីជំរៅនៃជង្ហុកធំ ។
១៦ ពួកអ្នកដែលឃើញអ្នក គេនឹងសំឡឹងមើលចំអ្នក
ហើយនឹងពិចារណាអ្នក ដោយពាក្យថា៖ តើមនុស្សនេះឬអី
ដែលធ្លាប់ធ្វើឲ្យ ផែនដីញាប់ញ័រ ហើយឲ្យនគរ
ទាំងប៉ុន្មានកក្រើករំពើកនោះ ?
១៧ ហើយតើជាអ្នកដែលបានធ្វើឲ្យលោកិយរលីងដូចជា
ទីរហោស្ថាន ព្រមទាំងបំផ្លាញទីក្រុងទាំងប៉ុន្មាន ឥតដែលលែង
ពួកឈ្លើយ ឬអី ?
១៨ ឯសពនៃអស់ទាំងស្ដេចរបស់សាសន៍ទាំងប៉ុន្មាន មែន
ហើយ សុទ្ធតែដេកនៅក្នុងទីរុងរឿងនាម៉ឺងរបស់គេរៀងខ្លួន ។
១៩ តែអ្នកបានត្រូវបណ្ដេញចេញឆ្ងាយពីផ្នូរអ្នកទៅ ដូចជា
មែកដ៏គួរខ្ពើមឆ្អើមវិញ ហើយដូចជាសពនៃពួកអ្នកដែលត្រូវ
គេសម្លាប់ ត្រូវចាក់ទំលុះដោយដាវ ហើយបោះចុះទៅលើថ្ម
ក្នុងរណ្ដៅ; ដូចជាសាកសព ដែលគេជាន់ឈ្លីដោយជើង ។
២០ អ្នកនឹងមិនបានចូលទៅជាមួយនឹងគេនៅក្នុងផ្នូរទេ ពីព្រោះ
អ្នកបានបំផ្លាញស្រុករបស់អ្នក ហើយបានសម្លាប់ប្រជាជនរបស់
អ្នក ផង; ឯពូជនៃមនុស្សប្រព្រឹត្តអំពើអាក្រក់ នឹងឥតមានអ្នក
ណាចេញឈ្មោះគេ នៅអស់កល្បជានិច្ច ។
២១ ចូរចាត់ចែងការកាប់សម្លាប់ពួកកូន ដោយព្រោះអំពើ
ទុច្ចរិតទាំងឡាយរបស់ឪពុកវា ដើម្បីកុំឲ្យវាតាំងខ្លួនឡើង
ធ្វើជាម្ចាស់ ផែនដីទៀត ហើយសង់ទីក្រុងឲ្យពាសពេញ
ក្នុងលោកិយឡើយ ។
២២ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា៖
យើងនឹងក្រោកឡើងទាស់នឹងគេ ហើយកាត់ទាំងឈ្មោះ និង
សំណល់ មនុស្ស ទាំងកូន និងចៅចេញពីក្រុងបាប៊ីឡូនផង
នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ។
២៣ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា៖
យើងនឹងបំផ្លាស់ទីនោះ ឲ្យទៅជាលំនៅ របស់សត្វប្រមា
ហើយជា ត្រពាំងទឹក; ហើយយើងក៏នឹងបោសដោយ
អំបោសជាការបំផ្លាញ ។
២៤ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់បានស្បថថា៖ ពិត
ប្រាកដជានឹងកើតមាន ដូចជាយើងបានគិត; ហើយក៏នឹងសំរេច
ដូចជាយើង បានកំណត់ទុកផង —
២៥ គឺយើងនឹងនាំពួកអាសស៊ើរចូលមកក្នុងស្រុកយើង
ហើយនឹងជាន់ឈ្លីគេនៅលើភ្នំរបស់យើង; ខណៈនោះ នឹមរបស់គេ
នឹងបាត់ ទៅ ហើយបន្ទុករបស់គេនឹងបាត់ពីស្មាដែរ ។

១២ *ក* គ. និង ស. ៧៦:២៦.
*ខ* ហេ. ផ្កាយព្រឹក ជាបុត្រានៃពេល ព្រឹក ។ អ្នកគ្រប់គ្រងពិភពលោកដ៏ទុច្ចរិច (បាប៊ីឡូន) គឺតែងតែនិយាយអំពីលូស៊ីហ្វើរ ជាអ្នកគ្រប់គ្រងនៃអស់ទាំងសេចក្ដីទុច្ចរិច.
ស.ប. អារក្ស; លូស៊ីហ្វើរ.
១៣ *ក* ម៉ូសេ ៤:១–៤.
*ខ* ក.ន. ជាដំណាក់នៃព្រះ ស្របតាមជំនឿរបស់ពួកបាប៊ីឡូន.
ទំនុក. ៤៨:២.
១៥ *ក* ១ នីហ្វៃ ១៤:៣.
១៦ *ក* ហេ. សម្លឹងមើលចំអ្នក ហើយពិចារណាអ្នក.
១៨ *ក* ក.ន. ផ្នូរនៃគ្រួសាររបស់លោក.
១៩ *ក* ក.ន. មែកដែលគេមិនទទួលស្គាល់ ដែលត្រូវកាត់ ហើយបោះចោល.
*ខ* ក.ន. បាត.
២០ *ក* ទំនុក. ២១:១០–១១; ៣៧:២៨.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
២១ *ក* និក្ខ. ២០:៥.
២២ *ក* សុភា. ១០:៧.
*ខ* យ៉ូប ១៨:១៩.
២៣ *ក* អេសាយ ៣៤:១១–១៥.
*ខ* ឬ អំបោស.
២៥ *ក* កម្មវត្ថុបែរទៅនិយាយអំពីការវាយរបស់ពួកអាសស៊ើរ និង អំពីការរលំនៅស្រុកយូដា, ៧០១ ម.គ.ស. (ខ ២៤–២៧).
២ ពង្សាវ. ១៩:៣២–៣៧;
អេសាយ ៣៧:៣៣–៣៨.
*ខ* ក.ន. ភ្នំទាំងឡាយនៅស្រុកយូដា និងស្រុកអ៊ីស្រាអែល.
*គ* អេសាយ ១០:២៧.

២៦ នោះហើយជាការដែលបានសំរេចនឹងធ្វើនៅលើផែនដីទាំង
មូល; ហើយនេះជាព្រះហស្ត ដែលបានសន្ធឹងទៅលើសាសន៍
ទាំង អស់ ។
២៧ ត្បិតព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់បានសំរេចនឹងធ្វើ
ហើយ តើអ្នកណានឹងរំលប់រំលាងបាន? ហើយព្រះហស្តនៃទ្រង់
បានលូក ទៅ ហើយតើអ្នកណានឹងបង្វិលឲ្យត្រឡប់ទៅវិញបាន?
២៨ នៅឆ្នាំដែលស្តេចអេហាសសុគតទៅ នោះមាន
បន្ទុកយ៉ាងធ្ងន់នេះ ។
២៩ គឺថា នែ ពួកភីលីស្ទីនអើយ កុំឲ្យអររីករាយពេញស្លុង
ដោយព្រោះរំពាត់ដែលធ្លាប់វាយអ្នកបានបាក់
ហើយនោះឡើយ; ត្បិតនឹង កើតមានពស់វែកចេញពីពូជសត្វ
ពស់មក ហើយកូនរបស់វានឹងទៅជាពស់ភ្លើងហោះ ។
៣០ នោះកូនច្បងរបស់ពួកមនុស្សទាល់ក្រ នឹងមាន
អាហារបរិភោគ ហើយមនុស្សកំសត់ទុគ៌តនឹងដេក
ទៅដោយសុខសាន្ត; តែយើងនឹងធ្វើឲ្យឫសអ្នកស្លាប់ទៅដោយ
អំណត់អត់វិញ ហើយសំណល់នៃអ្នក នឹងត្រូវគេសម្លាប់បង់ ។
៣១ ឱទ្វារក្រុងអើយ ចូរស្រែកទ្រហោ; ឱទីក្រុងអើយ
ចូរយំពិលាបចុះ; ឱស្រុកភីលីស្ទីនអើយ អ្នកត្រូវរលាយទាំង
អស់ហើយ; ត្បិតមានផ្សែងចេញមកពីទិសខាងជើង ឥតមាន
អ្នកណាមួយ ក្នុងកងទ័ពរបស់គេ ដែលតាមគ្នាមិនទាន់ឡើយ ។
៣២ ដូច្នេះ តើត្រូវឆ្លើយដល់ពួករាជទូតនៃសាសន៍នោះយ៉ាង
ណាទៅ ? គឺត្រូវថា ព្រះអម្ចាស់ទ្រង់បានតាំងក្រុងស៊ីយ៉ូនឡើង
ហើយពួករាស្ត្ររបស់ទ្រង់ដែលទាល់ក្រ គេនឹងពឹងជ្រកក្នុង
ក្រុងនោះ ៕

## ជំពូកទី ២៥

*នីហ្វៃសរសើរដំកើងនៅក្នុងការច្បាស់លាស់ — ពាក្យព្យាករណ៍ទាំងឡាយរបស់អេសាយនឹងបានយល់ នៅគ្រាចុងក្រោយបង្អស់ — ពួកសាសន៍យូដានឹងត្រឡប់ពីក្រុងបាប៊ីឡូនមកវិញ, នឹងឆ្កាងព្រះមែស៊ី ហើយនឹងត្រូវបែកខ្ញែក ហើយរងទុក្ខ — គេនឹងត្រូវបានតាំងឡើង វិញ កាលគេជឿដល់ព្រះមែស៊ី — ទ្រង់នឹងយាងមកលើកដំបូង ក្រោយពីលីហៃចេញពីក្រុងយេរូសាឡិមអស់រយៈពេល៦០០ឆ្នាំ — ពួកសាសន៍នីហ្វៃ កាន់តាមក្រិត្យវិន័យលោកម៉ូសេ ហើយជឿដល់ព្រះគ្រីស្ទ ដែលជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ឥឡូវនេះ ខ្ញុំ នីហ្វៃ នឹងនិយាយពីពាក្យខ្លះៗដែលខ្ញុំបានសរសេរ
គឺជាពាក្យដែលបានពោលដោយមាត់របស់លោកអេសាយ ។
ត្បិតមើលចុះ លោកអេសាយបាននិយាយពីការណ៍ជាច្រើន
ដែលពិបាកឲ្យប្រជាជនខ្ញុំភាគច្រើនយល់បាន; ព្រោះពួកគេមិន
ដឹងពីរបៀប ព្យាករ នៅក្នុងចំណោមពួកសាសន៍យូដាទេ ។
២ ត្បិតខ្ញុំ នីហ្វៃ មិនដែលបានបង្រៀនពួកគេ ពីការណ៍
ជាច្រើនដែលទាក់ទងនឹងរបៀបនៃពួកសាសន៍យូដាឡើយ;
ត្បិតកិច្ចការ ទាំងឡាយរបស់ពួកគេ គឺជាកិច្ចការទាំងឡាយ
នៃសេចក្តីងងឹត ហើយការប្រព្រឹត្តទាំងឡាយរបស់ពួកគេ គឺជាការ
ប្រព្រឹត្តទាំងឡាយ ដែលគួរខ្ពើមឆ្អើម ។
៣ ដូច្នេះ ខ្ញុំសរសេរសំរាប់រាស្ត្រខ្ញុំ ដល់អស់អ្នកណាដែល
នឹងបានទទួលពាក្យ ដែលខ្ញុំសរសេរទាំងនេះ ក្នុងពេលក្រោយ
ដើម្បីឲ្យ គេអាចដឹងពីសេចក្តីយុត្តិធម៌ទាំងឡាយនៃព្រះ ថាការណ៍
ទាំងនេះ នឹងកើតឡើងមកលើគ្រប់ទាំងសាសន៍ ស្របតាមព្រះ
បន្ទូលរបស់ទ្រង់ ។
៤ ហេតុដូច្នោះហើយ ឱប្រជាជនខ្ញុំ ជាវង្សអ៊ីស្រាអែល
អើយ ចូរស្តាប់ ហើយចូរផ្ទៀងត្រចៀកស្តាប់ពាក្យសំដីខ្ញុំចុះ;
ត្បិតដោយ ព្រោះពាក្យពេចន៍នៃលោកអេសាយមិនច្បាស់ដល់អ្នក
ទោះជាយ៉ាងនេះក៏ដោយ គង់តែពាក្យទាំងនោះច្បាស់ ដល់អ្នក
ណាដែល ពោរពេញទៅដោយវិញ្ញាណនៃការព្យាករណ៍ដែរ;
ប៉ុន្តែខ្ញុំឲ្យពាក្យព្យាករណ៍មួយដល់អ្នក ស្របតាមវិញ្ញាណដែល
នៅក្នុងខ្ញុំ; ហេតុដូច្នោះហើយ ខ្ញុំនឹងព្យាករ ស្របតាមការ
ច្បាស់លាស់ដែលខ្ញុំមាន ចាប់តាំងពីពេលដែលខ្ញុំចេញពីក្រុង
យេរូសាឡិមមក ជាមួយនឹងឪពុកខ្ញុំម្ល៉េះ; ត្បិតមើលចុះ
ព្រលឹងខ្ញុំត្រេកអរចំពោះការច្បាស់ ដល់ប្រជាជនខ្ញុំ ដើម្បី
ឲ្យពួកគេអាចចេះដឹង ។

២៦ *ក* គ.ន. ពួកសាសន៍ទាំងអស់ដែលប្រកបដោយលោកិយនោះនឹងត្រូវទំលាក់ចុះជាមិនខានឡើយ.
២៨ *ក* គ.ន. ប្រមាណជា ៧០២ ម.គ.ស., បន្ទុក ឬសារអំពីសេចក្តីហិនវិនាសនេះ គឺបានព្យាករប្រាប់អំពី ពួកភីលីស្ទីន ក្នុងកាលពួកយូដានឹងបានរួច.
*ខ* ២ ពង្សាវ. ១៦:២០.
៣២ *ក* ស.ប. ស៊ីយ៉ូន.
*ខ* សេផា. ៣:១២.
*គ* ឬ ស្វែងរកទីជ្រក.
**២៥** ១*ក* ២ នីហ្វៃ ២៥:៥–៦.
២ *ក* ២ ពង្សាវ. ១៧:១៣–២០.
៤ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ខ* ស.ប. ការព្យាករណ៍, ព្យាករ.
*គ* ២ នីហ្វៃ ៣១:៣; ៣៣:៥–៦; យ៉ាកុប ៤:១៣.

៥ មែនហើយ ឯព្រលឹងខ្ញុំត្រេកអរនឹងពាក្យពេចន៍នៃលោកអេសាយ ព្រោះខ្ញុំបានចេញពីក្រុងយេរូសាឡិមមក ហើយភ្នែកខ្ញុំបាន ឃើញការណ៍ទាំងឡាយនៃពួកសាសន៍យូដា ហើយខ្ញុំដឹងថា ពួកសាសន៍យូដាយល់ពីការណ៍ទាំងឡាយនៃពួកព្យាការី ហើយគ្មាន ប្រជាជនឯទៀតណាឡើយ ដែលយល់ការណ៍ទាំងឡាយ ដែលបាននិយាយទៅពួកសាសន៍យូដាដូចជាពួកគេ លើកលែងតែពួកអ្នក ដែលបានរៀនពីរបៀបនៃការណ៍ទាំងឡាយរបស់ពួកសាសន៍យូដា ។

៦ ប៉ុន្តែមើលចុះ ខ្ញុំ នីហ្វៃ មិនបានបង្រៀនកូនចៅខ្ញុំ តាមរបៀបនៃពួកសាសន៍យូដាទេ; ប៉ុន្តែមើលចុះ រីឯខ្លួនខ្ញុំវិញ ខ្ញុំធ្លាប់បានរស់នៅ ក្នុងក្រុងយេរូសាឡិម ហេតុនោះហើយ ខ្ញុំស្គាល់នូវភូមិភាគជុំវិញ; ហើយខ្ញុំធ្លាប់បាននិយាយប្រាប់កូនចៅខ្ញុំ អំពីសេចក្ដីជំនុំជំរះទាំងឡាយ នៃព្រះ ដែលធ្លាប់មានដល់ពួកសាសន៍យូដា ដល់កូនចៅខ្ញុំ ស្របតាមសេចក្ដីទាំងអស់ ដែលលោកអេសាយបាននិយាយ ប៉ុន្តែ ខ្ញុំមិន សរសេរសេចក្ដីទាំងនោះទេ ។

៧ ប៉ុន្តែមើលចុះ ខ្ញុំចាប់ផ្ដើមនឹងពាក្យព្យាករណ៍របស់ខ្ញុំវិញ គឺស្របតាមការច្បាស់លាស់របស់ខ្ញុំ; ដោយខ្ញុំដឹងថា គ្មានអ្នកណាអាច យល់ច្រឡំ ក្នុងការច្បាស់លាស់នេះទេ; ទោះជាយ៉ាងនេះក្ដី គឺនៅគ្រាដែលពាក្យព្យាករណ៍ទាំងឡាយនៃលោកអេសាយនឹងត្រូវបាន បំពេញ នោះមនុស្សលោកនឹងបានដឹងជាប្រាកដ នៅពេលដែលការណ៍ទាំងនោះនឹងកើតឡើង ។

៨ ហេតុដូច្នោះហើយ ពាក្យព្យាករណ៍ទាំងនេះមានប្រយោជន៍ដល់កូនចៅមនុស្ស ហើយអ្នកណាដែលគិតស្មានថា ពាក្យព្យាករណ៍ មិនមានប្រយោជន៍ទេ ជាពិសេស ចំពោះពួកនោះហើយដែលខ្ញុំនឹងនិយាយដល់ ហើយទុកពាក្យទាំងនេះសំរាប់ប្រជាជនខ្ញុំវិញ; ព្រោះខ្ញុំ ដឹងថា ពាក្យទាំងនេះមានប្រយោជន៍ដ៏ធំដល់គេ នៅថ្ងៃចុងក្រោយបង្អស់; ត្បិតនៅថ្ងៃនោះហើយ ដែលគេនឹងយល់ពាក្យទាំងនោះ; ហេតុដូច្នោះហើយ ទើបខ្ញុំសរសេរពាក្យទាំងនេះ ទុកជាប្រយោជន៍ដល់ពួកគេ ។

៩ ហើយដូចជាតំណមួយត្រូវបានបំផ្លាញចោល នៅក្នុងចំណោមពួកសាសន៍យូដា មកពីអំពើទុច្ចរិតរបស់ពួកគេយ៉ាងណា នោះពួកគេក៏ត្រូវបានបំផ្លាញចោល ពីតំណមួយទៅតំណមួយមកពីអំពើទុច្ចរិតទាំងឡាយរបស់ពួកគេយ៉ាងនោះដែរ; ហើយគ្មាន តំណណាមួយត្រូវបានបំផ្លាញចោលឡើយ លើកលែងតែបានប្រាប់ជាមុនដល់ពួកគេ ដោយពួកព្យាការីរបស់ព្រះអម្ចាស់ ។

១០ ហេតុដូច្នោះហើយ ការណ៍នេះត្រូវបានប្រាប់ជាមុនដល់ពួកគេ អំពីការបំផ្លិចបំផ្លាញ ដែលនឹងកើតឡើងដល់ពួកគេបន្ទាប់ពី ឪពុកខ្ញុំបានចាកចេញពីក្រុងយេរូសាឡិមភ្លាម; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេធ្វើចិត្តរឹងរូសដែរ; ហើយស្របតាមពាក្យ ព្យាករណ៍របស់ខ្ញុំ ពួកគេត្រូវបំផ្លាញបង់ លើកលែងតែពួកអ្នកដែលត្រូវចាប់ជាឈ្លើយ យកទៅក្នុងក្រុងបាប៊ីឡូនប៉ុណ្ណោះ ។

១១ ហើយឥឡូវនេះ ខ្ញុំនិយាយពាក្យទាំងនេះ ដោយព្រោះវិញ្ញាណដែលនៅក្នុងខ្ញុំ ។ ហើយទោះបីគេត្រូវចាប់យកទៅក៏ដោយ គង់តែគេនឹងត្រូវបានត្រឡប់មកវិញ ហើយគ្រងដែនដីយេរូសាឡិមដែរ; ហេតុដូច្នោះហើយ ពួកគេនឹងត្រូវបានតាំងឡើងជាថ្មី ឲ្យនៅលើ ដែនដីនៃកេរ្ដិ៍អាកររបស់ពួកគេទៀត ។

១២ ប៉ុន្តែមើលចុះ ពួកគេនឹងមានសង្គ្រាម និងពាក្យចចាមអារាមអំពីសង្គ្រាមទាំងឡាយ; ហើយកាលថ្ងៃនោះមកដល់ គឺជាថ្ងៃដែល ព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា មែនហើយ គឺជាព្រះវរបិតានៃផ្ទៃមេឃ និងផែនដី នោះទ្រង់នឹងសម្ដែងរូបអង្គទ្រង់ឲ្យពួកគេ ឃើញ នៅក្នុងសាច់ឈាម មើលចុះ ពួកគេនឹងមិនទទួលស្គាល់ទ្រង់ទេ ពីព្រោះតែអំពើទុច្ចរិតទាំងឡាយរបស់ពួកគេ និងភាពរឹងរូស នៃចិត្តរបស់ពួកគេ ហើយនឹងការរឹងករបស់ពួកគេ ។

---

៥ *ក* ១ នីហ្វៃ ១៩:២៣;
៣ នីហ្វៃ ២៣:១.
*ខ* ស.ប. ពួកសាសន៍យូដា.
៦ *ក* ២ នីហ្វៃ ៦:៨;
ហេលេ. ៨:២០–២១.
៧ *ក* ២ នីហ្វៃ ៣២:៧;
អាលម៉ា ១៣:២៣.
៨ *ក* ស.ប. បទព្រះគម្ពីរ —
តម្លៃនៃព្រះគម្ពីរ.
*ខ* អេណុស ១:១៣–១៦;
មរមន ៥:១២–១៥;
គ. និង ស. ៣:១៦–២០.
*គ* ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
៩ *ក* យេរេ. ៣៩:៤–១០;
ម៉ាថាយ ២៣:៣៧–៣៨.
*ខ* អេម៉ុស ៣:៧;
១ នីហ្វៃ ១:១៣.
១០ *ក* ១ នីហ្វៃ ៧:១៣;
២ នីហ្វៃ ៦:៨;
អោមណៃ ១:១៥;
ហេលេ. ៨:២០–២១.
*ខ* ២ ពង្សាវ. ២៤:១៤;
យេរេ. ៥២:៣–១៦.
១១ *ក* អែសរ៉ា ១:១–៤;
យេរេ. ២៤:៥–៧.
១២ *ក* ស.ប. បង្កើតតែមួយ.

១៣ មើលចុះ ពួកគេនឹងឆ្កាងទ្រង់; ហើយបន្ទាប់ពីទ្រង់ត្រូវ
បានបញ្ចុះនៅក្នុងផ្នូរអស់ចំនួនបីថ្ងៃ នោះទ្រង់នឹងមានព្រះជន្ម
រស់ឡើងវិញ; ដោយអំណាចប្រោសឲ្យជានៅក្នុងចំអេងស្លាបទ្រង់;
ហើយអស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ នោះនឹងបាន
សង្គ្រោះនៅក្នុងនគរ ព្រះ ។ ហេតុដូច្នោះហើយ ព្រលឹងខ្ញុំត្រេកអរ
នឹងព្យាករអំពីទ្រង់ ត្បិតខ្ញុំបានឃើញថ្ងៃរបស់ទ្រង់ហើយ ហើយ
ចិត្តខ្ញុំសរសើរដំកើងព្រះនាម ដ៏បរិសុទ្ធរបស់ទ្រង់ ។
១៤ ហើយមើលចុះ ហេតុការណ៍នឹងកើតឡើងថា បន្ទាប់ពីព្រះ
មែស៊ីមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ហើយបានសម្ដែងរូបអង្គទ្រង់
ដល់រាស្ត្រទ្រង់ គឺដល់អស់ទាំងអ្នកណាដែលជឿដល់ព្រះនាមទ្រង់
មើលចុះ ក្រុងយេរូសាឡិមនឹងត្រូវបំផ្លាញចោលទៀត; ត្បិតវេទនា
ដល់អ្នកណាដែលទាស់នឹងព្រះ ហើយនឹងរាស្ត្រនៃសាសនា
ចក្ររបស់ទ្រង់ ។
១៥ ហេតុដូច្នោះហើយ ពួកសាសន៍យូដានឹងត្រូវខ្ចាត់ព្រាត់ក្នុង
ចំណោមអស់ទាំងសាសន៍; មែនហើយ ទាំងក្រុងបាប៊ីឡូនផង
ក៏នឹងត្រូវបំផ្លាញចោលដែរ; ហេតុដូច្នោះហើយ ពួកសាសន៍
យូដានឹងត្រូវបំបែកឲ្យខ្ចាត់ព្រាត់ ដោយពួកសាសន៍ផ្សេងៗ ។
១៦ ហើយបន្ទាប់ពីពួកគេត្រូវខ្ចាត់ព្រាត់ ហើយព្រះអម្ចាស់
ព្រះទ្រង់បានធ្វើទុក្ខពួកគេ ដោយពួកសាសន៍ផ្សេងៗ អស់រយៈជា
ច្រើនតំណ មែនហើយ គឺពីតំណមួយទៅតំណមួយ រហូត
ដល់គេត្រូវបានបញ្ចុះបញ្ចូលឲ្យជឿដល់ព្រះគ្រីស្ទ គឺជាព្រះរាជ
បុត្រានៃព្រះ និងដង្វាយធួនដ៏និរន្តរ៍ដល់មនុស្សលោកទាំងអស់ —
ហើយកាលថ្ងៃនោះនឹងមកដល់ នោះពួកគេនឹងជឿដល់ព្រះគ្រីស្ទ
ហើយថ្វាយបង្គំ ដល់ព្រះវរបិតា ដោយនូវព្រះនាមទ្រង់ ដោយ
ចិត្តបរិសុទ្ធ និងដោយដៃស្អាត ហើយឈប់ទន្ទឹងចាំព្រះមែស៊ី
ឯណាទៀត គឺនៅពេលនោះ ថ្ងៃនោះនឹងមកដល់ នោះគឺជាការចាំ
បាច់ ដែលពួកគេត្រូវតែជឿដល់ការណ៍ទាំងនេះ ។

១៧ ហើយព្រះអម្ចាស់ទ្រង់នឹងលើកព្រះហស្តទ្រង់ជាលើកទីពីរ
ដើម្បីតាំងរាស្ត្រទ្រង់ឡើងវិញ ពីស្ថានភាពវង្វេង និងភាពធ្លាក់ ។
ហេតុដូច្នោះហើយ ទ្រង់នឹងចាប់ផ្ដើមធ្វើការមួយយ៉ាងអស្ចារ្យ
ហើយចម្លែក នៅចំណោមកូនចៅមនុស្ស ។
១៨ ហេតុដូច្នោះហើយ ទ្រង់នឹងនាំព្រះបន្ទូលទាំងឡាយ
ទ្រង់ចេញមកឯពួកគេ ជាព្រះបន្ទូលទាំងឡាយដែលនឹងជំនុំជំរះ
ពួកគេ នៅថ្ងៃចុងក្រោយបង្អស់ ត្បិតព្រះបន្ទូលទាំងនោះ នឹង
ត្រូវបានប្រទានដល់ពួកគេ ចំពោះគោលបំណងក្នុងការបរិវត្តន៍
ពួកគេ អំពីព្រះមែស៊ី ដ៏ពិត ដែលពួកគេមិនបានទទួលស្គាល់;
ហើយចំពោះការបរិវត្តន៍ពួកគេថា ពួកគេមិនត្រូវស្វែងរកព្រះមែស៊ី
ឯណាទៀតទេ ព្រោះគ្មាន ឯណាទៀត ដែលនឹងយាងមកឡើយ
លើកលែងតែព្រះមែស៊ីក្លែងក្លាយ ដែលនឹងបោកបញ្ឆោតមនុស្ស
ប៉ុណ្ណោះ; ត្បិតគ្មានព្រះមែស៊ី ឯណាទៀតឡើយ ក្រៅពីព្រះ
មួយអង្គដែលពួកព្យាការីបាននិយាយមកប៉ុណ្ណោះ ហើយព្រះ
មែស៊ីនោះហើយដែលនឹងត្រូវពួកសាសន៍ យូដាមិនទទួលស្គាល់ ។
១៩ ត្បិតស្របតាមពាក្យទាំងឡាយនៃពួកព្យាការី ព្រះមែស៊ី
នឹងយាងមកនៅវេលាឲរយឆ្នាំ បន្ទាប់ពីឪពុកខ្ញុំបាន
ចាកចេញពីក្រុង យេរូសាឡិមមក; ហើយស្របតាមពាកយ
ទាំងឡាយនៃពួកព្យាការី និងពាក្យរបស់ទេវតានៃព្រះផង
គឺព្រះនាមទ្រង់នឹងទៅជា ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រា
នៃព្រះ ។
២០ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំបាន
និយាយយ៉ាងច្បាស់លាស់ ដើម្បីកុំឲ្យបងប្អូនច្រឡំ ។ ហើយ
ប្រាកដ ដូចជាព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះជន្មរស់នៅ
ដែលបាននាំសាសន៍អ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទ ហើយ
បានប្រទានអំណាចឲ្យ លោកម៉ូសេ ដើម្បីឲ្យលោកអាចព្យាបាល
ទាំងសាសន៍ បន្ទាប់ពីពួកគេត្រូវពស់អសិរពិសចិក គឺបើសិនជា

១៣ *ក* លូកា ២៣:៣៣.
*ខ* យ៉ូហាន ១៩:៤១–៤២;
១ នីហ្វៃ ១៩:១០.
*គ* លូកា ២៤:៦–៧;
ម៉ូសាយ ៣:១០.
*ឃ* ស.ប. ដំណើររស់ឡើងវិញ.
*ង* ១ នីហ្វៃ ១១:១៣–៣៤.
១៤ *ក* ស.ប. ព្រះមែស៊ី.
*ខ* លូកា ២១:២៤;
យ.ស. — ម៉ាថាយ ១:១–១៨.
១៥ *ក* ស.ប. ពួកសាសន៍យូដា.
*ខ* នេហេ. ១:៨–៩; ២ នីហ្វៃ ១០:៦.
*គ* ស.ប. បាបិល, បាប៊ីឡូន.
១៦ *ក* ២ នីហ្វៃ ១០:៦–៩;
៣០:៧; មរមន ៥:១៤.
១៧ *ក* ២ នីហ្វៃ ២១:១១–១២; ២៩:១.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* អេសាយ ២៩:១៤;
២ នីហ្វៃ ២៧:២៦;
៣ នីហ្វៃ ២៨:៣១–៣៣.
១៨ *ក* ២ នីហ្វៃ ២៩:១១–១២;
៣៣:១១, ១៤–១៥.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*គ* ២ នីហ្វៃ ២៦:១២–១៣.
*ឃ* ស.ប. អ្នកទទឹងនឹងព្រះគ្រីស្ទ.
១៩ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យ
ព្យាករណ៍ទាំងឡាយអំពីកំណើត
និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ១ នីហ្វៃ ១០:៤;
៣ នីហ្វៃ ១:១, ១៣.
*គ* ២ នីហ្វៃ ១០:៣.
២០ *ក* និក្ខ. ៣:៧–១០;
១ នីហ្វៃ ១៧:២៤, ៣១; ១៩:១០.
*ខ* យ៉ូហាន ៣:១៤;
១ នីហ្វៃ ១៧:៤១.

ពួកគេគ្រាន់តែសម្លឹងទៅ [ក]សត្វពស់ ដែលលោកលើកឡើងនៅខាងមុខគេ ហើយព្រមទាំងបានប្រទានអំណាចឲ្យលោកអាចវាយ[ឃ]ថ្មដា នោះទឹកនឹងហូរចេញមក; មែនហើយ មើលចុះ ខ្ញុំប្រាប់បងប្អូនរាល់គ្នាថា រឿងទាំងនេះជារឿងពិត ហើយប្រាកដដូចជាព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះជន្មរស់ នៅ គឺគ្មាន[ង]នាមណាទៀតនៅ ក្រោមមេឃនេះ ក្រៅពីព្រះយេស៊ូវគ្រីស្ទ ដែលខ្ញុំបាននិយាយមកនេះ ដែលមនុស្សអាចបានសង្គ្រោះនោះឡើយ ។

២១ ហេតុដូច្នោះហើយ ដោយហេតុនេះ បានជាព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានសន្យានឹងខ្ញុំថា រឿងទាំងឡាយដែលខ្ញុំ[ក]សរសេរនេះ នឹងត្រូវបានថែរក្សាទុក ហើយបន្តមកឲ្យពូជខ្ញុំពីតំណមួយទៅតំណមួយ ដើម្បីឲ្យពាក្យសន្យាដល់[ខ]យ៉ូសែបអាចបានបំពេញថា ពូជលោក នឹងពុំត្រូវវិនាសឡើយ ដរាបណាមានផែនដីនេះ ។

២២ ហេតុដូច្នោះហើយ រឿងទាំងនេះនឹងបន្តពីតំណមួយទៅតំណមួយទៀត ដរាបណាមានផែនដីនេះ; ហើយរឿងទាំងនេះនឹងបន្ត ទៅមុខ តាមបំណង និងព្រះហឫទ័យនៃព្រះ; ឯសាសន៍ណាដែលនឹងបានពាក្យទាំងនេះ នោះពួកគេនឹងត្រូវបាន[ក]ជំនុំជំរះ ស្របតាមពាក្យ ទាំងប៉ុន្មាន ដែលបានសរសេរទុក ។

២៣ ត្បិតយើងព្យាយាមខំសរសេរពាក្យទាំងនេះ ដើម្បីបញ្ចុះបញ្ចូល[ក]កូនចៅយើង និងបងប្អូនយើងផង ដើម្បីឲ្យជឿដល់ព្រះគ្រីស្ទ ហើយឲ្យ[ខ]ស្រុះស្រួលនឹងព្រះ; ត្បិតយើងដឹងថា មានតែដោយព្រះគុណទេ ទើបយើងបានសង្គ្រោះ បន្ទាប់ពីអ្វីៗទាំងអស់ ដែលយើងអាច [គ]ធ្វើបាន ។

២៤ ហើយទោះបើយើងមានជំនឿជឿដល់ព្រះគ្រីស្ទក៏ដោយ គង់តែយើង[ក]កាន់តាមក្រិត្យវិន័យលោកម៉ូសេដែរ ហើយទន្ទឹងចាំព្រះ គ្រីស្ទយ៉ាងខ្ជាប់ខ្ជួន រហូតដល់ក្រិត្យវិន័យនោះបានបំពេញ ។

២៥ ត្បិតដោយគោលបំណងនេះហើយ ដែល[ក]ក្រិត្យវិន័យនេះត្រូវបានចែងមក; ហេតុដូច្នោះហើយ ក្រិត្យវិន័យបានក្លាយទៅជា[ខ]ស្លាប់ ចំពោះយើង ហើយយើងត្រូវបានធ្វើឲ្យរស់ឡើងវិញ នៅក្នុងព្រះគ្រីស្ទ ដោយសារសេចក្ដីជំនឿរបស់យើង; តែយើងនៅតែកាន់តាម ក្រិត្យវិន័យនេះ ពីព្រោះមកពីព្រះបញ្ញត្តិទាំងឡាយ ។

២៦ ហើយយើង[ក]និយាយអំពីព្រះគ្រីស្ទ យើង[ខ]អររីករាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ ហើយយើង សរសេរ ស្របតាមពាក្យព្យាករណ៍ទាំងលាយរបស់យើង ដើម្បីឲ្យ[គ]កូនចៅយើងអាចដឹងថា តើត្រូវស្វែងរកប្រភពណាមួយ ដើម្បីឲ្យ បាន[ឃ]ផ្ដាច់បាបរបស់ពួកគេ ។

២៧ ហេតុដូច្នោះហើយ យើងនិយាយអំពីក្រិត្យវិន័យ ដើម្បីឲ្យកូនចៅយើងអាចដឹង នូវភាពស្លាប់នៃក្រិត្យវិន័យនោះ; ហើយដោយ បានដឹងនូវភាពស្លាប់នៃក្រិត្យវិន័យនោះ នោះពួកគេអាចទន្ទឹងដល់ជីវិត ដែលនៅក្នុងព្រះគ្រីស្ទ ហើយដឹងពីហេតុអ្វីបានជាក្រិត្យវិន័យ នេះត្រូវបានប្រទានមក ។ ហើយបន្ទាប់ពីក្រិត្យវិន័យនេះត្រូវបានបំពេញ នៅក្នុងព្រះគ្រីស្ទ នោះពួកគេមិនត្រូវធ្វើចិត្តរឹងរូសទាស់នឹង ទ្រង់ទៀតឡើយ នៅពេលក្រិត្យវិន័យនោះត្រូវបោះបង់ចោលទៅ ។

២៨ ហើយឥឡូវនេះ មើលចុះ ឱប្រជាជនខ្ញុំអើយ អ្នករាល់គ្នាជាមនុស្ស[ក]ក្បាលរឹង; ហេតុដូច្នោះហើយ បានជាខ្ញុំនិយាយយ៉ាងក្បោះក្បាយដល់អ្នក ដើម្បីកុំឲ្យអ្នករាល់គ្នាអាចយល់ច្រឡំ ។ ឯពាក្យទាំងប៉ុន្មាន ដែលខ្ញុំបាននិយាយនេះ នឹងឈរជា[ខ]ទីបន្ទាល់ទាស់នឹងអ្នក; ព្រោះពាក្យទាំងនេះគ្រប់គ្រាន់ សំរាប់បង្រៀនមនុស្សណាម្នាក់អំពី[គ]ផ្លូវត្រឹមត្រូវ; ព្រោះផ្លូវត្រឹមត្រូវ គឺជឿដល់ព្រះគ្រីស្ទ ហើយមិនបដិសេធ ទ្រង់ឡើយ; ព្រោះបើអ្នកមិនទទួលស្គាល់ទ្រង់ នោះអ្នករាល់គ្នាក៏មិនទទួលស្គាល់សេចក្ដីព្យាករណ៍នៃពួកព្យាការី ហើយនឹងក្រិត្យវិន័យ ដែរ ។

២០ *ក* ជនគ. ២១:៨–៩; អាលម៉ា ៣៣:១៩; ហេលេ. ៨:១៤–១៥.
*ឃ* និក្ខ. ១៧:៦; ជនគ. ២០:១១; ១ នីហ្វៃ ១៧:២៩; ២០:២១.
*ង* ហូសេ ១៣:៤; កិច្ចការ ៤:១០–១២; ម៉ូសាយ ៥:៨; ម៉ូសេ ៦:៥២. ស.ប. ព្រះអង្គសង្គ្រោះ.
២១ *ក* ២ នីហ្វៃ ២៧:៦–១៤.
*ខ* អេម៉ុស ៥:១៥; ២ នីហ្វៃ ៣:១៦; អាលម៉ា ៤៦:២៤–២៧.
២២ *ក* ២ នីហ្វៃ ២៩:១១; ៣៣:១០–១៥; ៣ នីហ្វៃ ២៧:២៣–២៧.
២៣ *ក* ស.ប. កូនក្មេង, ពួកកូនក្មេង.
*ខ* រ៉ូម ៣:២៣–២៤; ២ នីហ្វៃ ២:៤–១០; ម៉ូសាយ ១៣:៣២; អាលម៉ា ៤២:១២–១៦; គ. និង ស. ១៣៨:៤. ស.ប. ព្រះគុណ.
*គ* យ៉ាកុប (ព.ស.ថ.) ២:១៤–២៦. ស.ប. កិច្ចការ.
២៤ *ក* យ៉ាកុប ៤:៤–៥.
២៥ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* រ៉ូម ៧:៤–៦.
២៦ *ក* យ៉ាកុប ៤:១២; យ៉ារ៉ុម ១:១១; ម៉ូសាយ ៣:១៣.
*ខ* លូកា ១០:២៣–២៤.
*គ* ស.ប. កូនក្មេង, ពួកកូនក្មេង.
*ឃ* ស.ប. ការផ្ដាច់បាប.
២៨ *ក* ម៉ូសាយ ៣:១៤.
*ខ* ស.ប. ទីបន្ទាល់.
*គ* ២ នីហ្វៃ ៣៣:១០.

២៩ ហើយឥឡូវនេះ មើលចុះ ខ្ញុំប្រាប់អ្នករាល់គ្នាថា ផ្លូវត្រឹមត្រូវ គឺជឿដល់ព្រះគ្រីស្ទ ហើយមិនបដិសេធទ្រង់ឡើយ; ឯព្រះគ្រីស្ទ គឺជា ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល; ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវក្រាបចំពោះទ្រង់ ហើយថ្វាយបង្គំទ្រង់ ឲ្យអស់ពី[ក]សមត្ថភាព អស់ពីគំនិត អស់ពីកម្លាំង ហើយអស់ពីព្រលឹងទាំងមូលរបស់អ្នករាល់គ្នា; ហើយបើសិនជាអ្នករាល់គ្នាធ្វើដូច្នេះ នោះអ្នករាល់គ្នានឹង ពុំត្រូវបានបណ្ដេញចេញឡើយ ។

៣០ ហើយដរាបណាជាការចាំបាច់ នោះអ្នករាល់គ្នាត្រូវតែកាន់តាមពិធីប្រព្រឹត្ត និង[ក]ពិធីបរិសុទ្ធទាំងឡាយនៃព្រះ រហូតដល់ក្រិត្យ វិន័យ ដែលប្រគល់ដល់លោកម៉ូសេនោះបានបំពេញ ៕

## ជំពូកទី ២៦

*ព្រះគ្រីស្ទនឹងយាងទៅបំរើដល់ពួកសាសន៍នីហ្វៃ — នីហ្វៃមើលឃើញជាមុន អំពីការបំផ្លិចបំផ្លាញនៃរាស្ត្រ លោក — ពួកគេនឹងនិយាយ ចេញមកពីធូលីដី — ពួកសាសន៍ដទៃនឹងតាំងសាសនាចក្រក្លែងក្លាយ និងបក្សព័ន្ធសម្ងាត់ — ព្រះអម្ចាស់ទ្រង់ហាមមិនឲ្យមនុស្សប្រព្រឹត្ត ឧបាយកលផ្ទែកសង្ឃ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ឱកូនចៅរបស់ខ្ញុំ និងបងប្អូនរបស់ខ្ញុំអើយ ហើយបន្ទាប់ពីព្រះគ្រីស្ទនឹងមាន[ក]ព្រះជន្មរស់ពីស្លាប់ឡើងវិញ នោះទ្រង់នឹង[ខ]បង្ហាញរូបអង្គទ្រង់ដល់អ្នករាល់គ្នា; ឯព្រះបន្ទូលទាំងឡាយដែលទ្រង់នឹងមានព្រះបន្ទូលមកអ្នក នោះនឹងទៅជា[គ]ក្រិត្យវិន័យ ដែលអ្នករាល់គ្នាត្រូវធ្វើតាម ។

២ ត្បិតមើលចុះ ខ្ញុំប្រាប់អ្នករាល់គ្នាថា ខ្ញុំបានឃើញជាច្រើនតំណបានស្លាប់ទៅ ហើយនឹងមានសង្គ្រាមដ៏ធំៗ និងការទាស់ទែងគ្នា ទាំងឡាយ នៅក្នុងចំណោមប្រជាជនខ្ញុំ ។

៣ ហើយបន្ទាប់ពីព្រះមែស៊ីនឹងយាងមក នោះនឹងមាន[ក]ទីសំគាល់ជាច្រើន ប្រាប់ឲ្យប្រជាជនខ្ញុំដឹងជាមុន អំពី[ខ]កំណើតរបស់ទ្រង់ និងអំពី ការសុគត និងដំណើររស់ឡើងវិញនៃទ្រង់ដែរ; ហើយថ្ងៃនោះនឹងទៅជាថ្ងៃដ៏ធំ ហើយគួរឲ្យស្ញែងខ្លាចចំពោះពួកទុច្ចរិតព្រោះពួកគេ នឹងត្រូវវិនាស; ហើយពួកគេវិនាស ពីព្រោះមកពីពួកគេ បណ្ដេញពួកព្យាការី និងពួកបរិសុទ្ធចេញ ព្រមទាំងចោលថ្ម ហើយសម្លាប់គេ ផង; ហេតុដូច្នោះហើយ [គ]សំរែកនៃឈាមពួកបរិសុទ្ធនឹងបន្លឺពីដីឡើងទៅដល់ព្រះទាស់នឹងពួកគេ ។

៤ ហេតុដូច្នោះហើយ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា អស់ពួកអ្នកដែលឆ្មើងឆ្មៃ និង[ក]ពួកអ្នកដែលប្រព្រឹត្តអំពើ ទុច្ចរិតនោះថ្ងៃនឹងមកដល់ដែលនឹងឆេះពួកគេអស់ ត្បិតពួកគេបីដូចជាចំបើង ។

៥ ឯពួកអ្នកដែលសម្លាប់ពួកព្យាការី និងពួកបរិសុទ្ធ នោះព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា ទីជំរៅនៃផែនដីនឹង [ក]លេបគេ; ហើយ[ខ]ភ្នំនឹងគ្របលើពួកគេ ហើយខ្យល់ព្យុះកំណាចនឹងកួចពួកគេ ហើយអាគារនឹងដួលលើពួកគេ បោកសង្កត់ពួកគេឲ្យបែក ជាដុំៗ ហើយកិនពួកគេឲ្យម៉ត់ដូចម្សៅ ។

៦ ហើយព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា ពួកគេនឹងត្រូវពិនិត្យពិច័យនឹងផ្គរលាន់ និងផ្លេកបន្ទោរ និងផែនដីរញ្ជួយ ព្រមទាំងការបំផ្លិចបំផ្លាញគ្រប់យ៉ាង ព្រោះភ្លើងនៃសេចក្ដីពិរោធនៃព្រះអម្ចាស់ នឹងឆេះឡើងទាស់នឹងគេ ហើយពួកគេនឹងដូចជាចំបើង ហើយថ្ងៃនោះដែលមកដល់នឹងឆេះពួកគេទៅ ។

៧ ឱសេចក្ដីឈឺចាប់ និងសេចក្ដីព្រួយបារម្ភនៃព្រលឹងខ្ញុំចំពោះការស្លាប់បាត់បង់នៃប្រជាជនខ្ញុំអើយ! ត្បិតខ្ញុំ នីហ្វៃ បានឃើញការណ៍ នេះ ហើយវាសឹងតែបំផ្លាញខ្ញុំពីវត្តមាននៃព្រះអម្ចាស់; ប៉ុន្តែខ្ញុំត្រូវអំពាវនាវដល់ព្រះរបស់ខ្ញុំថា៖ ផ្លូវរបស់ទ្រង់ពិតជា[ក]ត្រឹមត្រូវមែន ។

៨ ប៉ុន្តែមើលចុះ ពួកសុចរិតណាដែលប្រុងស្ដាប់តាមពាក្យទាំងឡាយនៃពួកព្យាការី ហើយមិនបំផ្លាញពួកព្យាការីចោលទេ តែទន្ទឹង ចាំព្រះគ្រីស្ទវិញ ដោយចាំមើលយ៉ាងខ្ជាប់ខ្ជួន នូវទីសំគាល់ទាំងឡាយដែលបានផ្ដល់ឲ្យ ទោះជាមាន[ក]ការបៀតបៀនយ៉ាងណាក៏ដោយ — មើលចុះ ពួកគេនេះហើយដែលនឹង[ខ]ពុំត្រូវវិនាសឡើយ ។

២៩ *ក* ចោទិ. ៦:៥;
ម៉ាកុស ១២:២៩–៣១.
៣០ *ក* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
**២៦** ១*ក* ៣ នីហ្វៃ ១១:១–១២.
*ខ* ១ នីហ្វៃ ១១:៧; ១២:៦.
*គ* ៣ នីហ្វៃ ១៥:២–១០.
៣ *ក* ១ នីហ្វៃ ១២:៤–៦.
ស.ប. ទីសំគាល់.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើតនិងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
*គ* លោកុ. ៤:១០; ២ នីហ្វៃ ២៨:១០; មរមន ៨:២៧.
៤ *ក* ៣ នីហ្វៃ ៨:១៤–២៤; ៩:៣, ៩.
៥ *ក* ១ នីហ្វៃ ១៩:១១;
៣ នីហ្វៃ ១០:១៤.
*ខ* ៣ នីហ្វៃ ៨:១០; ៩:៥–៨.
៧ *ក* ស.ប. សេចក្ដីយុត្តិធម៌.
៨ *ក* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
*ខ* ៣ នីហ្វៃ ១០:១២–១៣.

៩ ប៉ុន្តែព្រះរាជបុត្រានៃសេចក្ដីសុចរិត នឹង[ក]លេចមកឲ្យពួក
គេឃើញ; ហើយទ្រង់នឹង[ខ]ប្រោសពួកគេឲ្យជា ហើយពួកគេនឹង
មាន[គ]សេចក្ដី សុខសាន្ត រហូតដល់តំណ[ឃ]ទីបីបានស្លាប់ទៅ ហើយ
មនុស្សជាច្រើននៃតំណ[ង]ទីបួនក៏នឹងស្លាប់ទៅ ក្នុងសេចក្ដីសុចរិតដែរ ។
១០ ហើយកាលការណ៍ទាំងនេះបានកន្លងផុតទៅ នោះ[ក]កការ
បំផ្លិចបំផ្លាញយ៉ាងឆាប់រហ័ស នឹងកើតឡើងដល់ប្រជាជនខ្ញុំ;
ទោះជា មានការឈឺចាប់ក្នុងព្រលឹងខ្ញុំក្ដី គង់តែខ្ញុំបានឃើញ
ការណ៍នេះដែរ; ហេតុដូច្នោះហើយ ខ្ញុំដឹងថា ការណ៍នេះ
នឹងកើតឡើង; ហើយពួកគេ នឹងលក់ខ្លួន ដោយឥតប្រយោជន៍;
ត្បិតសំរាប់រង្វាន់នៃការឆ្មើងឆ្មៃ និងការឥតប្រយោជន៍របស់ពួក
គេ គឺពួកគេនឹងប្រមូលនូវការបំផ្លិច បំផ្លាញ; ពីព្រោះមកពីពួកគេ
ចុះចូលនឹងអារក្ស ហើយរើសឲ្យកិច្ចការទាំងឡាយនៃសេចក្ដី
ងងឹតជាជាងពន្លឺ ហេតុដូច្នោះហើយ ពួកគេ ត្រូវចុះទៅ
[ខ]ស្ថាននរក ។
១១ ព្រោះ[ក]ព្រះវិញ្ញាណនៃព្រះអម្ចាស់ នឹងពុំតស៊ូគង់នៅជា
មួយនឹងមនុស្សជានិច្ចទេ ។ ហើយកាលណាព្រះវិញ្ញាណឈប់តស៊ូ
គង់នៅជាមួយនឹងមនុស្ស ពេលនោះសេចក្ដីបំផ្លិចបំផ្លាញយ៉ាង
ឆាប់រហ័សនឹងមកដល់ ហើយការណ៍នេះធ្វើឲ្យព្រលឹងខ្ញុំកើតទុក្ខ ។
១២ ហើយដូចជាខ្ញុំបាននិយាយអំពី[ក]ការបរិវត្តន៍[ខ]ពួកសាសន៍
យូដាថា ព្រះយេស៊ូវ គឺជា[គ]ព្រះគ្រីស្ទ នោះក៏ជាការចាំបាច់ដែរថា
ពួកសាសន៍ដទៃត្រូវតែបានបរិវត្តថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ
ជាព្រះដ៏នៅអស់កល្បជានិច្ច;
១៣ ហើយថាទ្រង់នឹងសម្ដែងរូបអង្គទ្រង់ដល់អស់អ្នកណា ដែល
ជឿដល់ទ្រង់ ដោយព្រះចេស្ដានៃ[ក]ព្រះវិញ្ញាណបរិសុទ្ធ; មែន
ហើយ គឺដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា
និងគ្រប់ទាំងប្រជាជន ដោយសម្ដែងអព្ភូតហេតុទាំងឡាយ
ទីសំគាល់ទាំងឡាយ និងការណ៍អស្ចារ្យដ៏ធំទាំងឡាយ នៅ
ក្នុងចំណោមកូនចៅមនុស្ស ស្របតាមសេចក្ដីជំនឿរបស់ពួកគេ ។

១៤ ប៉ុន្តែមើលចុះ ខ្ញុំព្យាករប្រាប់អ្នករាល់គ្នាអំពីគ្រាចុង
[ក]ក្រោយបង្អស់; អំពីថ្ងៃដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹង[ខ]ធ្វើឲ្យ
កើតការណ៍អស់ ទាំងនេះដល់កូនចៅមនុស្ស ។
១៥ បន្ទាប់ពីពូជខ្ញុំ និងពូជបងៗរបស់ខ្ញុំ ចុះអន់ថយក្នុង
ការឥតជំនឿ ហើយត្រូវពួកសាសន៍ដទៃវាយ; មែនហើយ
គឺបន្ទាប់ពី ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានបោះទ័ពឡោមព័ទ្ធពួក
គេ ហើយដាក់ទាហានបង្ខាំងនៅជុំវិញពួកគេ ហើយចាត់
ចែងគ្រឿងចំបាំងច្បាំង នឹងពួកគេ ហើយបន្ទាប់ពីពួកគេត្រូវបាន
បន្ទាបចុះដល់ដី ទោះជាយ៉ាងនេះក៏ដោយ គង់តែពួកគេ
មិននៅរស់ដែរ; ពេលនោះ ពាក្យទាំងឡាយរបស់ពួកសុចរិត
នឹងត្រូវបានសរសេរទុក ហើយពាក្យអធិស្ឋានទាំងឡាយនៃពួក
ស្មោះត្រង់នឹងត្រូវបានឮ ឯអស់ពួកអ្នក ដែលបានចុះអន់ថយក្នុង
ការឥតជំនឿ ក៏នឹងមិនត្រូវភ្លេចដែរ ។
១៦ ព្រោះពួកអ្នកដែលនឹងត្រូវបំផ្លាញចោល នឹង
[ក]និយាយចេញពីដី ហើយសំដីរបស់ពួកគេនឹងចេញពីធូលីដីមក
ឯសម្លេងរបស់ពួកគេ បីដូចជាសម្លេងនៃពួកគ្រូខាប; ព្រោះព្រះ
អម្ចាស់ដ៏ជាព្រះ ទ្រង់នឹងប្រទានអំណាចដល់គេ ដើម្បីឲ្យ
គេអាចខ្សឹបអំពីរឿងដែលទាក់ទង នឹងគេ គឺដូចជាសម្លេងចេញពីដី
ហើយសំដីរបស់គេនឹងខ្សឹបចេញពីធូលីដី ។
១៧ ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖
[ក]ពួកគេនឹងសរសេរការណ៍ទាំងឡាយ ដែលនឹងត្រូវបានធ្វើនៅ
ក្នុង ចំណោមពួកគេ ហើយការណ៍ទាំងនោះនឹងត្រូវបានសរសេរ
ទុក ហើយបិទត្រាទុកក្នុងគម្ពីរ១ ឯពួកអ្នកដែលបានចុះអន់ថយ
ក្នុងការ ឥតជំនឿ នឹងពុំបានការណ៍ទាំងនោះទេ ព្រោះពួកគេ
[ខ]រកបំផ្លាញការណ៍ទាំងឡាយនៃព្រះ ។
១៨ ហេតុដូច្នោះហើយ ពួកអ្នកដែលត្រូវបំផ្លាញចោល គឺត្រូវ
បំផ្លាញយ៉ាងឆាប់រហ័ស; ហើយពួកដែលគួរស្ញែងខ្លាចជាច្រើន
ឥតគណនា នឹងស្លាប់បាត់បង់ដូចជា[ក]អង្កាម — មែនហើយ

៩ *ក* ៣ នីហ្វៃ ១១:៨–១៥.
*ខ* ៣ នីហ្វៃ ១៧:៧–៩.
*គ* ៤ នីហ្វៃ ១:១–៤.
*ឃ* ១ នីហ្វៃ ១២:១១–១២;
៣ នីហ្វៃ ២៧:៣០–៣២.
*ង* អាលម៉ា ៤៥:១០–១២;
ហេលេ. ១៣:៩–១០.
១០ *ក* អាលម៉ា ៤៥:៩–១៤;
មរមន ៨:១–៩.
*ខ* ស.ប. ស្ថាននរក.
១១ *ក* អេធើរ ២:១៥.
១២ *ក* ២ នីហ្វៃ ២៥:១៨.
*ខ* ២ នីហ្វៃ ៣០:៧; មរមន ៥:១៤.
ស.ប. ពួកសាសន៍យូដា.
*គ* មរមន ៣:២១.
១៣ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
១៤ *ក* ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
*ខ* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
១៦ *ក* អេសាយ ២៩:៤;
ម៉ូរ៉ូណៃ ១០:២៧;
ម៉ូសេ ៧:៦២.
ស.ប. ព្រះគម្ពីរមរមន.
១៧ *ក* ២ នីហ្វៃ ២៩:១២.
*ខ* អេណុស ១:១៤.
១៨ *ក* មរមន ៥:១៦–១៨.

ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ការណ៍នេះកើតឡើងមួយ ភ្លែត ដោយឥតដឹងមុន ។

១៩ ហើយហេតុការណ៍នឹងកើតឡើងថា ពួកអ្នកដែលចុះអន់ថយក្នុងការឥតជំនឿ នឹងត្រូវវាយដោយដៃនៃពួកសាសន៍ដទៃ ។

២០ ឯពួកសាសន៍ដទៃបានលើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃភ្នែកគេ ហើយក៏ជំពប់ ពីព្រោះមកពីភាពធំណាស់ហួសនៃថ្មជំពប់របស់ពួកគេ គឺពួកគេបានស្ថាបនាសាសនាចក្រជាច្រើនឡើង; ទោះជាយ៉ាងនោះក៏ដោយ គង់តែពួកគេមើលងាយអំណាចនិងអព្ភូតហេតុទាំងឡាយនៃព្រះដែរ ហើយបង្រៀនដល់ខ្លួនគេអំពីប្រាជ្ញា និងចំណេះវិជ្ជារបស់ពួកគេវិញ ដើម្បីពួកគេអាចបានកំរៃ ហើយសង្កត់សង្កិនលើមនុស្សទាល់ក្រ ។

២១ ហើយមានសាសនាចក្រជាច្រើនដែលបានស្ថាបនាឡើងដោយបង្កឲ្យមានការឈ្នានីស ការឈ្លោះប្រកែក និងចិត្តអាក្រក់ ។

២២ ហើយក៏មានបក្សព័ន្ធសម្ងាត់ទាំងឡាយ គឺដូចជាកាលពីជំនាន់ដើមដែរ ស្របតាមបក្សព័ន្ធនៃអារក្ស ត្បិតវាជាអ្នកបង្កើតការណ៍ អស់ទាំងនេះ; មែនហើយ គឺជាអ្នកបង្កើតឃាតកម្ម និងអំពើទាំងឡាយនៃសេចក្ដីងងឹត; មែនហើយ ហើយវាទាក់កពួកគេអូសទៅដោយ ខ្សែបន្លា រហូតដល់វាចងពួកគេ ដោយខ្សែដាប់របស់វារហូតតទៅ ។

២៣ ត្បិតមើលចុះ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំប្រាប់អ្នករាល់គ្នាថា ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ពុំធ្វើការនៅក្នុងសេចក្ដីងងឹត ឡើយ ។

២៤ ទ្រង់មិនធ្វើការណ៍ណាឡើយ លើកលែងតែការណ៍នោះមានប្រយោជន៍ដល់មនុស្សលោក; ត្បិតទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះ បានជាទ្រង់ប្ដូរជីវិតទ្រង់ផ្ទាល់ ដើម្បីទ្រង់អាចទាញមនុស្សទាំងអស់មករកទ្រង់ ។ ហេតុដូច្នោះហើយ ទ្រង់មិនដែលបញ្ជាដល់ អ្នកណាម្នាក់ថា គេនឹងមិនគួរទទួលយកសេចក្ដីសង្គ្រោះរបស់ទ្រង់នោះឡើយ ។

២៥ មើលចុះ តើទ្រង់ដែលបន្លឺសម្លេងដាក់អ្នកណាម្នាក់ថា៖ ថយចេញពីយើងទៅឬអី ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា៖ ទេ; ប៉ុន្តែទ្រង់មានព្រះបន្ទូលថា៖ មករកយើងចុះ អស់អ្នករាល់គ្នានៅចុងផែនដីអើយ ចូរទិញទឹកដោះ និងទឹកឃ្មុំដោយឥតបង់ប្រាក់ ហើយឥតថ្លៃផង ។

២៦ មើលចុះ តើទ្រង់ដែលបានបញ្ជាឲ្យអ្នកណាម្នាក់ចេញពីសាលាជំនុំ ឬចេញពីទីកន្លែងថ្វាយបង្គំទាំងឡាយឬទេ ? មើលចុះ ខ្ញុំប្រាប់អ្នកថា៖ ទេ ។

២៧ តើទ្រង់ដែលបានបញ្ជាមិនឲ្យអ្នកណាម្នាក់ទទួលយកសេចក្ដីសង្គ្រោះរបស់ទ្រង់ឬទេ ? មើលចុះ ខ្ញុំប្រាប់អ្នកថា៖ ទេ; ប៉ុន្តែទ្រង់ បានប្រទានសេចក្ដីសង្គ្រោះនេះ ដោយឥតយកថ្លៃដល់មនុស្សលោកទាំងអស់ ហើយទ្រង់បានបញ្ជាឲ្យរាស្ត្រទ្រង់បញ្ចុះបញ្ចូលមនុស្ស លោកទាំងអស់ ឲ្យប្រែចិត្ត ។

២៨ មើលចុះ តើទ្រង់ដែលបានបញ្ជាមិនឲ្យអ្នកណាម្នាក់ទទួលយកសេចក្ដីល្អសប្បុរសរបស់ទ្រង់ឬទេ ? មើលចុះ ខ្ញុំប្រាប់អ្នកថា៖ ទេ; ប៉ុន្តែមនុស្សលោកទាំងអស់បានទទួលយកឯកសិទ្ធដូចៗគ្នា ហើយគ្មានអ្នកណាម្នាក់ត្រូវបានហាមប្រាមឡើយ ។

២៩ ទ្រង់បញ្ជាថា មិនត្រូវមានឧបាយកលផ្អែកសង្ឃឡើយ; ត្បិតមើលចុះ ឧបាយកលផ្អែកសង្ឃ គឺជាការណ៍ដែលមនុស្សបង្រៀន ហើយតាំងខ្លួនឡើងជាពន្លឺដល់មនុស្សលោកដើម្បីឲ្យពួកគេអាចបានកំរៃ និងការសរសើរដំកើងពីមនុស្សលោក; ប៉ុន្តែពួកគេមិនស្វែង រកសុខុមាលភាពនៃក្រុងស៊ីយ៉ូនឡើយ ។

៣០ មើលចុះ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានហាមមិនឲ្យមានការណ៍នេះ; ហេតុដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានប្រទាន ព្រះបញ្ញត្តិមួយថា មនុស្សលោកទាំងអស់ត្រូវមានសេចក្ដីសប្បុរស ឯសេចក្ដីសប្បុរសនោះ គឺជាសេចក្ដីស្រឡាញ់ បើសិនជាពួកគេគ្មាន សេចក្ដីសប្បុរសទេ នោះពួកគេក៏ពុំមែនជាអ្វីទាំងអស់ ។ ហេតុដូច្នោះហើយ បើសិនជាពួកគេមាន

១៩ *ក* ៣ នីហ្វៃ ១៦:៨–៩; ២០:២៧–២៨.
២០ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ខ* ១ នីហ្វៃ ១៣:២៩, ៣៤.
ស.ប. សេចក្ដីក្បត់សាសនា.
*គ* អេសេ. ១៤:៤.
*ឃ* ១ នីហ្វៃ ១៤:១០; ២២:២៣;
មរមន ៨:២៨.
*ង* មរមន ៩:៧–៨; ២ នីហ្វៃ ៩:២៨.
*ច* អេសាយ ៣:១៥;
២ នីហ្វៃ ១៣:១៥.
២១ *ក* ស.ប. ច្រណែន.
២២ *ក* ស.ប. បក្សព័ន្ធសម្ងាត់.
២៤ *ក* យ៉ូហាន ៣:១៦.
*ខ* ៣ នីហ្វៃ ២៧:១៤–១៥.
២៥ *ក* អាលម៉ា ៥:៣៣–៣៥;
៣ នីហ្វៃ ៩:១៣–១៤.
*ខ* អេសាយ ៥៥:១–២.
២៧ *ក* ស.ប. សេចក្ដីសង្គ្រោះ.
*ខ* អេភេ. ២:៨; ២ នីហ្វៃ ២៥:២៣.
*គ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
២៨ *ក* រ៉ូម ២:១១;
១ នីហ្វៃ ១៧:៣៣–៣៥.
២៩ *ក* ស.ប. ឧបាយកលផ្អែកសង្ឃ.
*ខ* គ. និង ស. ១២១:៣៤–៣៧.
៣០ *ក* ម៉ូរ៉ូណៃ ៧:៤៧–៤៨.
ស.ប. សេចក្ដីសប្បុរស.
*ខ* ស.ប. សេចក្ដីស្រឡាញ់.

សេចក្តីសប្បុរស នោះពួកគេនឹងមិន ទ្រាំឲ្យអ្នកធ្វើការ
នៅក្រុងស៊ីយ៉ូនត្រូវវិនាសឡើយ ។
៣១ ប៉ុន្តែអ្នកធ្វើការនៅក្រុង[ក]ស៊ីយ៉ូន នឹងធ្វើ[ខ]ការ
សំរាប់ក្រុងស៊ីយ៉ូន; ព្រោះបើសិនជាពួកគេធ្វើការដើម្បីប្រាក់
នោះពួកគេនឹងត្រូវ វិនាស ។
៣២ ហើយម៉្យាងទៀត ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បាន
[ក]បញ្ញាថា មនុស្សលោកមិនត្រូវធ្វើឃាតកម្ម; ថាពួកគេមិនត្រូវ
កុហក; ថាពួកគេ មិនត្រូវលួច; ថាពួកគេមិនត្រូវយកព្រះនាម
នៃព្រះអម្ចាស់ដ៏ជាព្រះរបស់គេ ជាអសារឥតការឡើយ; ថា
ពួកគេមិនត្រូវឈ្នានីស; ថាពួកគេ មិនត្រូវមានគំនិតអាក្រក់;
ថាពួកគេមិនត្រូវទាស់គ្នាទៅវិញទៅមក; ថាពួកគេមិនត្រូវ
ប្រព្រឹត្តអំពើសហាយស្មន់ទាំងឡាយ; ហើយថា ពួកគេមិនត្រូវ
ធ្វើអំពើអស់ទាំងនេះឲ្យសោះ ព្រោះអ្នកណាដែលធ្វើអំពើ
ទាំងនោះ នឹងត្រូវវិនាស ។
៣៣ ព្រោះអំពើទុច្ចរិតទាំងនេះ ពុំមែនកើតមកពីព្រះ
អម្ចាស់ទេ; ព្រោះទ្រង់ធ្វើនូវអ្វីដែលសុទ្ធតែល្អ នៅក្នុងចំណោម
កូនចៅមនុស្ស វិញ; ហើយទ្រង់មិនធ្វើការណ៍ឡើយ លើកលែងតែ
ការណ៍នោះច្បាស់លាស់ដល់កូនចៅមនុស្ស; ហើយទ្រង់
អញ្ជើញពួកគេទាំងអស់គ្នា ឲ្យមករកទ្រង់ ហើយទទួលទាននូវ
សេចក្តីល្អសប្បុរសរបស់ទ្រង់; ហើយទ្រង់[ក]ពុំបដិសេធអ្នក
ណាម្នាក់ ដែលមករកទ្រង់ឡើយ គឺទាំងខ្មៅ និងស ទាំង
បាវគេ និងសេរី ទាំងប្រុស និងស្រី; ហើយទ្រង់នឹកចាំដល់ពួក
[ខ]អ្នកឥតសាសនា; ហើយមនុស្ស[គ]ទាំងអស់ ទាំងពួកសាសន៍
យូដា និងពួកសាសន៍ដទៃ ក៏ដូចគ្នានៅចំពោះព្រះដែរ ៕

## ជំពូកទី ២៧

*សេចក្តីងងឹត និងសេចក្តីក្បត់សាសនានឹងគ្របដណ្តប់ផែនដី នៅគ្រាចុងក្រោយបង្អស់ — ព្រះគម្ពីរមរមននឹងចេញមក — ពួកសាក្សី បីនាក់នឹងធ្វើបន្ទាល់អំពីព្រះគម្ពីរមរមន — ពួកអ្នករៀនសូត្រមិនអាចអានគម្ពីរដែលបិទត្រាបានឡើយ — ព្រះអម្ចាស់ទ្រង់នឹងធ្វើការ មួយយ៉ាងអស្ចារ្យ ហើយចម្លែក — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ២៩ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ប៉ុន្តែមើលចុះ នៅគ្រា[ក]ចុងក្រោយបង្អស់ ឬនៅថ្ងៃនៃពួកសាសន៍
ដទៃ — មែនហើយ មើលចុះ សាសន៍ទាំងអស់នៃពួក
សាសន៍ដទៃ និងព្រមទាំងសាសន៍យូដាផង ទាំងពួកអ្នកដែល
នឹងមកនៅលើដែនដីនេះ និងពួកអ្នកដែលមកពីដែនដីដទៃផង
មែនហើយ គឺនៅលើអស់ទាំងដែនដីនៅលើផែនដីនេះ មើលចុះ
ពួកគេនឹងស្រវឹងនឹងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមគ្រប់
ប្រការ ។
២ ហើយកាលថ្ងៃនោះមកដល់ ព្រះអម្ចាស់នៃពួកពលបរិវារ
ទ្រង់នឹងពិនិត្យពិច័យពួកគេដោយផ្គរ និងដោយកក្រើកដី និងដោយ
សូរគ្រាំគ្រេង និងដោយខ្យល់ព្យុះ និងដោយព្យុះសង្ឃរា និងដោយ
[ក]អណ្តាតភ្លើងដែលឆេះបំផ្លាញ ។
៣ ហើយគ្រប់ទាំង[ក]សាសន៍ដែល[ខ]ច្បាំងនឹងក្រុងស៊ីយ៉ូន និងពួក
ដែលធ្វើទុក្ខដល់ទីក្រុងនោះ ពួកគេនឹងប្រៀបដូចជាសប្តិ
គឺជាការនិមិត្ត នៅពេលយប់ទេ; មែនហើយ ការណ៍នោះនឹង
បានកើតដល់ពួកគេដែរ គឺប្រៀបដូចជាមនុស្សឃ្លានដែលបាន
យល់សប្តិ ហើយមើលចុះ យល់សប្តិឃើញថាខ្លួនបានបរិភោគ
តែលុះភ្ញាក់ឡើង នោះព្រលឹងខ្លួននៅទទេ; ឬប្រៀបដូចជាមនុស្ស
ស្រេកដែលបានយល់សប្តិ ហើយ មើលចុះ យល់សប្តិឃើញថាខ្លួន
បានផឹក តែលុះភ្ញាក់ឡើង ហើយមើលចុះ ខ្លួននៅល្វើយ ហើយ
ព្រលឹងគេនៅតែមានសំរេក; មែនហើយ ពួកបណ្តាជនពីគ្រប់ទាំង
សាសន៍ ដែលច្បាំងនឹងភ្នំស៊ីយ៉ូន ពួកគេក៏នឹងទៅជាដូច្នោះដែរ ។
៤ ត្បិតមើលចុះ អស់អ្នកណាដែលធ្វើអំពើទុច្ចរិត ចូរអ្នក
រាល់គ្នានៅជាស្ងាក់ស្ងើរ ហើយភាំងឆ្ងល់ចុះ ត្បិតអ្នករាល់គ្នា
នឹងស្រែក ហើយយំ; មែនហើយ អ្នករាល់គ្នានឹងស្រវឹង តែមិនមែន
ដោយស្រាទំពាំងបាយជូរទេ អ្នករាល់គ្នាទ្រេតទ្រោតទៅ
តែមិនមែនដោយ គ្រឿងស្រវឹងឡើយ ។
៥ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់បានចាក់វិញ្ញាណ ដែល
បណ្តាលឲ្យលក់ស៊ប់ មកលើអ្នករាល់គ្នា ។ ត្បិតមើលចុះ អ្នក
រាល់គ្នាបានបិទ ភ្នែក ហើយអ្នករាល់គ្នាមិនបានទទួលស្គាល់ពួក

៣១ *ក* ស.ប. ស៊ីយ៉ូន.
*ខ* យ៉ាកុប ២:១៧–១៩;
គ. និង ស. ១១:៧; ៣៨:៣៩.
៣២ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
*ខ* ស.ប. សេចក្តីមើលងាយ.
៣៣ *ក* កិច្ចការ ១០:៩–៣៥, ៤៤–៤៥.
*ខ* អាលម៉ា ២៦:៣៧.
*គ* រ៉ូម ២:១១; ១ នីហ្វៃ ១៧:៣៥.
**២៧** ១*ក* ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
២ *ក* អេសាយ ២៤:៦; ៦៦:១៥–១៦;
យ៉ាកុប ៦:៣; ៣ នីហ្វៃ ២៥:១.
៣ *ក* អេសាយ ២៩:៧–៨.
*ខ* ១ នីហ្វៃ ២២:១៤.

ព្យាការី; ហើយទ្រង់បានលាក់កំបាំងអ្នកគ្រប់គ្រងរបស់អ្នក និង
ពួកហោរារបស់អ្នក ពីព្រោះតែអំពើទុច្ចរិតរបស់អ្នក ។
៦ ហើយហេតុការណ៍នឹងកើតឡើងថា ព្រះអម្ចាស់ដ៏ជាព្រះ
ទ្រង់នឹងនាំចេញមកដល់អ្នករាល់គ្នា នូវពាក្យទាំងឡាយនៃគម្ពីរ
មួយ ហើយនោះគឺជាពាក្យទាំងឡាយរបស់ពួកអ្នក ដែលបាន
លង់លក់ ។
៧ ហើយមើលចុះ គម្ពីរនោះនឹងត្រូវបានបិទត្រា; ហើយនៅ
ក្នុងគម្ពីរនោះនឹងមានវិវរណៈពីព្រះ ចាប់ពីកំណើតលោកិយមក
រហូតដល់ ចុងបំផុត ។
៨ ហេតុដូច្នោះហើយ ព្រោះតែការណ៍ទាំងឡាយដែលបាន
បិទត្រាទុក នោះការណ៍ទាំងឡាយដែលបិទត្រាទុកនោះ មិន
ត្រូវបាននាំ ចេញមក នៅក្នុងគ្រាដែលមនុស្សធ្វើអំពើទុច្ចរិត និង
អំពើគួរខ្ពើមឆ្អើមទាំងឡាយឡើយ ។ ហេតុដូច្នោះហើយ គម្ពីរ
នោះនឹងត្រូវបាន លាក់ទុកពីពួកគេ ។
៩ ប៉ុន្តែគម្ពីរនោះ នឹងត្រូវបានប្រគល់មនុស្សម្នាក់ ហើយអ្នក
នោះនឹងនាំពាក្យទាំងឡាយនៅក្នុងគម្ពីរនោះ ដែលជាពាក្យ
ទាំងឡាយ នៃពួកអ្នកដែលបានដេកលង់លក់នៅក្នុងដី ហើយ
អ្នកនោះនឹងប្រគល់ពាក្យទាំងនេះដល់អ្នកផ្សេងទៀត;
១០ ប៉ុន្តែពាក្យណាដែលត្រូវបានបិទត្រាទុក អ្នកនោះនឹងមិន
ត្រូវនាំចេញមក ឬក៏ប្រគល់គម្ពីរនោះឲ្យអ្នកណាដែរ ។ ត្បិត
គម្ពីរនោះ នឹងត្រូវបានបិទត្រា ដោយព្រះចេស្ដានៃព្រះ
ឯវិវរណៈដែលត្រូវបានបិទត្រាទុកនោះ នឹងត្រូវបានរក្សាទុកនៅ
ក្នុងគម្ពីរនោះ រហូតដល់ កំណត់នៃព្រះអម្ចាស់ ដើម្បីឲ្យពាក្យ
ទាំងនោះអាចបាននាំចេញមក; ត្បិតមើលចុះ ពាក្យទាំងនោះប្រាប់
គ្រប់ការណ៍ទាំងអស់ ចាប់តាំង ពីកំណើតលោកិយមក រហូត
ដល់ចុងបំផុត ។
១១ ហើយកាលគ្រានោះមកដល់ ពាក្យទាំងឡាយដែល
ត្រូវបានបិទត្រាទុកនៅក្នុងគម្ពីរនោះ នឹងត្រូវបានយកមកអាននៅលើ
ដំបូលផ្ទះ; ហើយពាក្យទាំងនោះនឹងត្រូវបានអានដោយព្រះចេស្ដា
នៃព្រះគ្រីស្ទ; ហើយគ្រប់ការណ៍ទាំងអស់នឹងត្រូវបានបើកសម្ដែង
ដល់កូនចៅមនុស្ស ប្រាប់ពីអ្វីដែលធ្លាប់មាននៅក្នុងចំណោម
កូនចៅមនុស្ស និងពីអ្វីដែលនឹងមានរហូតដល់ចុងបំផុតផែនដី ។
១២ ហេតុដូច្នោះហើយ នៅថ្ងៃនោះ កាលគម្ពីរនោះនឹងត្រូវ
បានប្រគល់ដល់មនុស្សម្នាក់ ដែលខ្ញុំបាននិយាយមកនោះ គម្ពីរ
នោះ នឹងត្រូវបានលាក់ពីភ្នែកនៃមនុស្សលោក ដើម្បីកុំឲ្យមាន
ភ្នែកអ្នកណាមើលឃើញគម្ពីរនោះឡើយ លើកលែងតែពួក
សាក្សីបីនាក់ ប៉ុណ្ណោះ ដែលនឹងមើលបានឃើញគម្ពីរនោះ
ដោយព្រះចេស្ដានៃព្រះ ក្រៅពីអ្នកនោះដែលត្រូវបានប្រគល់
គម្ពីរ; ហើយពួកគេនឹងធ្វើ បន្ទាល់អំពីសេចក្ដីពិតនៃគម្ពីរនោះ
និងការណ៍ទាំងឡាយដែលនៅក្នុងនោះ ។
១៣ ហើយនឹងគ្មានអ្នកណាផ្សេងទៀតមើលឃើញគម្ពីរ
នោះឡើយ លើកលែងតែមនុស្សមួយចំនួនតូច ស្របតាមព្រះ
ហឫទ័យនៃព្រះ ដើម្បីធ្វើបន្ទាល់អំពីព្រះបន្ទូលរបស់ទ្រង់
ប្រាប់ដល់កូនចៅមនុស្ស; ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មាន
ព្រះបន្ទូលថា ពាក្យទាំងឡាយរបស់ ពួកស្មោះត្រង់នឹងនិយាយ
ហាក់ដូចជាពាក្យមកពីមនុស្សស្លាប់ ។
១៤ ហេតុដូច្នោះហើយ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹង
ចាប់ផ្ដើមនាំពាក្យទាំងឡាយក្នុងគម្ពីរនោះចេញមក; ហើយទ្រង់នឹង
តាំងព្រះ បន្ទូលនៃទ្រង់ ដោយមាត់នៃពួកសាក្សីទាំងប៉ុន្មាន ដែល
ទ្រង់យល់ថាល្អគ្រប់គ្រាន់សំរាប់ទ្រង់ហើយ; ហើយវេទនាដល់
អ្នកណា ដែលមិន ទទួលស្គាល់ព្រះបន្ទូលនៃព្រះ!
១៥ ប៉ុន្តែមើលចុះ ហេតុការណ៍នឹងកើតឡើងថា ព្រះ
អម្ចាស់ដ៏ជាព្រះ ទ្រង់នឹងមានព្រះបន្ទូលទៅអ្នកនោះ ដែលទ្រង់នឹង
ប្រគល់គម្ពីរ នោះថា៖ ចូរយកពាក្យទាំងនេះ ដែលមិនបានបិទត្រា
ទុក ហើយប្រគល់ដល់មនុស្សម្នាក់ទៀត ដើម្បីឲ្យគេអាចបង្ហាញ
ពាក្យទាំងនោះ ដល់អ្នកដែលមានចំណេះម្នាក់ ដោយនិយាយ
ថា៖ សូមលោកអានពាក្យទាំងនេះទៅ ។ ហើយអ្នកដែលមាន
ចំណេះនោះ នឹងនិយាយ ថា៖ ចូរយកគម្ពីរមកណេះ ខ្ញុំនឹង
អានជូន ។
១៦ ហើយឥឡូវនេះ ពីព្រោះតែសេចក្ដីរុងរឿងនៃពិភពលោក

៦ *ក* យ៉ារ៉ុម ១:២; មរមន ៥:១២–១៣.
*ខ* ២ នីហ្វៃ ២៦:១៦–១៧; ២៩:១២.
ស.ប. ព្រះគម្ពីរមរមន.
៧ *ក* អេសាយ ២៩:១១–១២;
អេធើរ ៣:២៥–២៧; ៤:៤–៧.
*ខ* ម៉ូសាយ ៨:១៩.
*គ* អេធើរ ១៣:១–១២.
៨ *ក* អេធើរ ៥:១.
*ខ* ៣ នីហ្វៃ ២៦:៩–១២;
អេធើរ ៤:៥–៦.
៩ *ក* គ. និង ស. ១៧:៥–៦.
*ខ* យ.ស.—ប្រវត្តិ ១:៦៤–៦៥.
១១ *ក* លូកា ១២:៣; មរមន ៥:៨;
គ. និង ស. ១២១:២៦–៣១.
១២ *ក* ២ នីហ្វៃ ១១:៣; អេធើរ ៥:២–៤;
គ. និង ស. ៥:១១, ១៥; ១៧:១.
*ខ* ចោទិ. ១៩:១៥.
១៣ *ក* ២ នីហ្វៃ ៣:១៩–២០;
៣៣:១៣–១៥;
ម៉ូរ៉ូណៃ ១០:២៧.
១៤ *ក* ២ នីហ្វៃ ២៨:២៩–៣០;
អេធើរ ៤:៨.
១៥ *ក* អេសាយ ២៩:១១–១២;
យ.ស.—ប្រវត្តិ ១:៦៥.

ហើយដើម្បី[ក]រកកំរៃ នោះគេនិយាយយ៉ាងនេះ គឺមិនមែនដើម្បី
សិរីល្អនៃព្រះឡើយ ។
១៧ ហើយអ្នកនោះនឹងនិយាយថា៖ ខ្ញុំមិនអាចយកគម្ពីរនោះ
មកបានទេ ព្រោះគម្ពីរនោះត្រូវបានបិទត្រាទុក ។
១៨ ខណៈនោះ អ្នកដែលមានចំណេះនឹងនិយាយថា៖ ខ្ញុំមិន
អាចអានគម្ពីរនោះបានទេ ។
១៩ ហេតុដូច្នោះហើយ ហេតុការណ៍នឹងកើតឡើងថា ព្រះ
អម្ចាស់ដ៏ជាព្រះ ទ្រង់នឹងប្រគល់គម្ពីរនោះ ព្រមទាំងពាក្យទាំង
ឡាយ ទៅអ្នកដែលគ្មានចំណេះវិញ ហើយអ្នកដែលគ្មាន
ចំណេះនឹងនិយាយថា៖ ខ្ញុំគ្មានចំណេះទេ ។
២០ ខណៈនោះ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះ
បន្ទូលទៅគេថា៖ អ្នកដែលមានចំណេះអានមិនបាន ព្រោះគេ
មិនទទួលស្គាល់ ពាក្យទាំងនោះ តែយើងអាចធ្វើកិច្ចការ
របស់យើងបាន; ហេតុដូច្នោះហើយ អ្នកនឹងអានពាក្យទាំងឡាយ
ដែលយើងនឹងឲ្យដល់អ្នក ។
២១ ចូរ[ក]កុំប៉ះពាល់ដល់ការណ៍ណាដែលបិទត្រាទុក ព្រោះយើង
នឹងនាំការណ៍ទាំងនោះចេញមក កាលដល់ពេលកំណត់
របស់យើង; ត្បិតយើងនឹងបង្ហាញដល់កូនចៅមនុស្សថា
យើងអាចធ្វើកិច្ចការរបស់យើងបាន ។
២២ ហេតុដូច្នោះហើយ កាលណាអ្នកបានអានពាក្យទាំង
ឡាយ ដែលយើងបានបញ្ជាឲ្យអ្នកអាននោះ ហើយបាន[ក]ពួក
សាក្សីទាំង ឡាយ ដែលយើងបានសន្យាដល់អ្នក ខណៈនោះ
អ្នកត្រូវបិទត្រាគម្ពីរនោះទៀត ហើយលាក់គម្ពីរនោះថ្វាយ
ដល់យើង ដើម្បីយើងអាច រក្សាពាក្យទាំងឡាយ ដែលអ្នកមិន
ទាន់បានអាននៅឡើយ ដរាបដល់ពេលណា ដែលយើង
យល់ថាសមតាមប្រាជ្ញារបស់យើង ដើម្បីនឹងសម្ដែងគ្រប់ការណ៍
អស់ទាំងនេះ ដល់កូនចៅមនុស្ស ។
២៣ ត្បិតមើលចុះ យើងជាព្រះ; ហើយយើងជាព្រះ
នៃ[ក]អព្ភូតហេតុទាំងឡាយ; ហើយយើងនឹងបង្ហាញដល់មនុស្ស
លោកថា យើងនៅ [ខ]តែដដែល ទោះពីថ្ងៃម្សិល ថ្ងៃនេះ
និងរហូតតទៅ; ហើយយើងមិនធ្វើកិច្ចការណា នៅក្នុងចំណោម
កូនចៅមនុស្សឡើយ លើកលែងតែ [គ]ស្របតាមសេចក្ដីជំនឿ
របស់ពួកគេតែប៉ុណ្ណោះ ។
២៤ ហើយហេតុការណ៍នឹងកើតឡើងទៀតថា ព្រះអម្ចាស់
ទ្រង់នឹងមានព្រះបន្ទូលទៅអ្នក ដែលនឹងអាចអានពាក្យទាំងឡាយ
ដែល នឹងត្រូវបានប្រគល់ទៅគាត់ថា៖
២៥ [ក]ដរាបណារាស្ត្រនេះចូលមកជិតយើង ដោយបបូរមាត់
របស់គេ ហើយថ្វាយកិត្តិនាមដល់យើង ដោយសំដីរបស់គេ
តែបានដកចិត្តគេចេញទៅឆ្ងាយពីយើង ហើយការណ៍ដែល
គេកោតខ្លាចដល់យើង គ្រាន់តែជា[គ]បង្គាប់របស់មនុស្ស ដែល
បង្រៀន គេប៉ុណ្ណោះ ។
២៦ ហេតុនោះ យើងនឹងចាប់ផ្ដើមធ្វើការណ៍មួយយ៉ាង[ក]អស្ចារ្យ
នៅចំណោមរាស្ត្រនេះ មែនហើយ គឺជាការណ៍មួយយ៉ាង
[ខ]អស្ចារ្យ ហើយចម្លែក ត្បិតប្រាជ្ញានៃពួកអ្នកប្រាជ្ញ និងពួក
អ្នកចេះដឹងរបស់គេ នឹងត្រូវសាបសូន្យទៅ ហើយយោបល់នៃ
ពួកវាងវៃរបស់គេ នឹងត្រូវបិទបាំងដែរ ។
២៧ ហើយ[ក]វេទនាដល់ពួកអ្នក ដែលខ្នះខ្នែងរកលាក់គំនិត
របស់ខ្លួនពីព្រះអម្ចាស់ ! ហើយកិច្ចការទាំងឡាយរបស់គេ គឺនៅ
ក្នុងទី កំបាំង; ហើយពួកគេពោលថា៖ តើមានអ្នកណាបានឃើញ
តើមានអ្នកណាបានស្គាល់យើង ? ហើយគេក៏និយាយថា៖
យីអើ អ្នករាល់គ្នាយល់ផ្ទុយអីម្លេះ តើនឹងរាប់ជាង[ខ]ស្មូនទុក ដូចជា
ដីឥដ្ឋដែរឬ ។ ប៉ុន្តែមើលចុះ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់
មាន ព្រះបន្ទូលថា យើងនឹងបង្ហាញដល់គេថា យើងស្គាល់
គ្រប់កិច្ចការទាំងអស់របស់គេ ។ ត្បិតតើរបស់ដែលគេបាន
បង្កើតមកហើយ នឹងពោលពីអ្នកដែលបានបង្កើតខ្លួនថា គេមិន
បានបង្កើតខ្ញុំទេឬ ? ឬរបស់ដែលគេបានស្មូនធ្វើឡើង នឹង
ពោលពីអ្នកដែលបានស្មូនធ្វើ នោះថា គេឥតមានគំរិះ
យោបល់អ្វីឡើយដូច្នេះឬ ?
២៨ ប៉ុន្តែមើលចុះ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះ
បន្ទូលថា៖ យើងនឹងបង្ហាញដល់កូនចៅមនុស្សថា នៅតែបន្តិចទៀត
ប៉ុណ្ណោះទេ នោះព្រៃល្បាណូននឹងត្រឡប់ទៅជាចំការដុះដាល;
ហើយចំការដុះដាល នឹងបានរាប់ទុកដូចជាព្រៃវិញ ។

១៦ ក ស.ប. ឧបាយកលផ្នែកសង្ឃ.
២១ ក អេធើរ ៥:១.
២២ ក ស.ប. ពួកសាក្សីអំពីព្រះគម្ពីរមរមន.
២៣ ក ស.ប. អព្ភូតហេតុ.
ខ ហេព្រើរ ១៣:៨.
គ ហេព្រើរ ១១;
អេធើរ ១២:៧–២២.
២៥ ក អេសាយ ២៩:១៣.
ខ ម៉ាថាយ ១៥:៨.
គ ២ នីហ្វៃ ២៨:៣១.
២៦ ក ១ នីហ្វៃ ២២:៨;
២ នីហ្វៃ ២៩:១–២.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
ខ អេសាយ ២៩:១៤;
២ នីហ្វៃ ២៥:១៧.
២៧ ក អេសាយ ២៩:១៥.
ខ យេរេ. ១៨:៦.

២៩ [ក]ហើយនៅគ្រានោះ មនុស្សគ្រចៀកថ្លង់នឹងឮព្រះបន្ទូល
ក្នុងគម្ពីរនោះ ហើយភ្នែករបស់មនុស្សខ្វាក់ នឹងមើលឃើញពីក្នុង
សភាព ជាងងឹត ហើយសូន្យសុង ។

៣០ [ក]ឯមនុស្សរាបសានឹងកើនឡើង ហើយមាន[ខ]សេចក្ដីអំណរក្នុង
ព្រះអម្ចាស់ ហើយពួកក្រីក្រនៅក្នុងចំណោមបណ្ដាមនុស្ស គេ
នឹងរីករាយនៅក្នុងព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ។

៣១ ពីព្រោះប្រាកដដូចជាព្រះទ្រង់មានព្រះជន្មរស់នៅ នោះគេ
នឹងឃើញថា មនុស្សដែល[ក]គួរស្ញែងខ្លាច បានសូន្យបាត់ទៅ
មនុស្ស ដែលមើលងាយត្រូវឆេះអស់ ហើយពួកមនុស្សដែល
រកតែឱកាសនឹងធ្វើការទុច្ចរិត គេនឹងត្រូវវិនាសបាត់អស់រលីងដែរ;

៣២ ព្រមទាំងពួកអ្នកដែលចាប់ពាក្យមនុស្ស ធ្វើឲ្យគេ[ក]មាន
ទោស ហើយដាក់អន្ទាក់សំរាប់ចាប់ពួកមនុស្ស ដែលក្រើនរំឭក
នៅ [ខ]ត្រង់ទ្វារក្រុង ព្រមទាំង[គ]បង្វែរមនុស្សសុចរិតចេញ ដោយ
រឿងដែលមិនជាហេតុផង ។

៣៣ ហេតុនោះ ព្រះអម្ចាស់ដ៏ជាព្រះដែលប្រោសលោះ
អ័ប្រាហាំ ទ្រង់មានព្រះបន្ទូលពីដំណើរពួកវង្សយ៉ាកុប ដូច្នេះថា៖
ឥឡូវនេះ ពួកយ៉ាកុបមិនត្រូវខ្មាសទៀតឡើយ ក៏មិនត្រូវ
ស្លុតស្លាំងទៀតដែរ ។

៣៤ តែកាលណាគេ[ក]ឃើញកូនចៅគេ បានឃើញកិច្ចការ
ដែលដៃយើងនឹងធ្វើ នៅកណ្ដាលគេ នោះគេនឹងញែក
ឈ្មោះយើងជា បរិសុទ្ធ ហើយរាប់ព្រះដ៏បរិសុទ្ធនៃសាសន៍
យ៉ាកុបទុកជាបរិសុទ្ធដែរ ហើយនឹងកោតខ្លាចដល់ព្រះនៃសាសន៍
អ៊ីស្រាអែលផង ។

៣៥ ឯពួកអ្នកដែលប្រព្រឹត្ត[ក]ខុសខាងវិញ្ញាណ គេនឹង
មានយោបល់វិញ ហើយមនុស្សដែលរអ៊ូរទាំ [ខ]នឹងទទួលសេចក្ដី
ប្រៀនប្រដៅ ៕

---

ជំពូកទី ២៨

---

*សាសនាចក្រក្លែងក្លាយជាច្រើននឹងត្រូវបានស្ថាបនាឡើង នៅគ្រាចុងក្រោយបង្អស់ — សាសនាចក្រទាំងនោះនឹងបង្រៀននូវ លទ្ធិក្លែងក្លាយ ឥតខ្លឹមសារ ហើយឥតប្រយោជន៍ — សេចក្ដីក្បត់សាសនានឹងកើតឡើងពាសពេញ ពីព្រោះតែគ្រូក្លែងក្លាយទាំងឡាយ — អារក្ស នឹងញាំញីនៅក្នុងចិត្តមនុស្ស — វានឹងបង្រៀននូវលទ្ធិក្លែងក្លាយគ្រប់បែបយ៉ាង ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំបាន
និយាយប្រាប់អ្នករាល់គ្នា ស្របតាមដែលព្រះវិញ្ញាណបានបង្គាប់ខ្ញុំ;
ហេតុដូច្នោះហើយ ខ្ញុំដឹងថា ការណ៍ទាំងនោះត្រូវតែកើតជា
ប្រាកដ ។

២ ហើយអ្វីៗដែលនឹងត្រូវបានសរសេរចេញពី[ក]គម្ពីរនោះ នឹង
មាន[ខ]ប្រយោជន៍យ៉ាងធំចំពោះកូនចៅមនុស្ស ហើយជាពិសេស
ចំពោះពូជយើង ដែលជាសំណល់នៃវង្សអ៊ីស្រាអែល ។

៣ ត្បិតហេតុការណ៍នឹងកើតឡើងថា នៅថ្ងៃនោះ [ក]សាសនា
ចក្រទាំងឡាយដែលបានស្ថាបនាឡើង តែមិនបានស្ថាបនាឡើង
សំរាប់ថ្វាយដល់ព្រះអម្ចាស់ទេ កាលសាសនាចក្រមួយនឹង
និយាយសាសនាចក្រមួយទៀតថា៖ មើលចុះ គឺខ្ញុំនេះហើយ
ជាសាសនាចក្រ នៃព្រះអម្ចាស់; ឯសាសនាចក្រផ្សេងៗទៀត
នឹងនិយាយថា៖ គឺខ្ញុំទេតើ ដែលជាសាសនាចក្រនៃព្រះអម្ចាស់;
ហើយសាសនាចក្រ នីមួយៗដែលបានស្ថាបនាឡើង តែងតែ
និយាយថាដូច្នោះ តែមិនបានស្ថាបនាឡើង សំរាប់ថ្វាយដល់
ព្រះអម្ចាស់ឡើយ —

៤ ហើយពួកគេនឹងឈ្លោះប្រកែកគ្នាទៅវិញទៅមក; ហើយ
ពួកសង្ឃរបស់គេក៏ឈ្លោះប្រកែកគ្នាទៅវិញទៅមក ហើយពួក
គេនឹង បង្រៀន[ក]អំពីចំណេះរបស់ខ្លួន តែមិនទទួលស្គាល់ព្រះវិញ្ញាណ
បរិសុទ្ធ ដែលបានប្រទានសំដីនោះទេ ។

៥ ហើយពួកគេ[ក]មិនទទួលស្គាល់[ខ]ព្រះចេស្ដានៃព្រះ ជា
ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែលទេ; ហើយពួកគេនិយាយ
ទៅរកប្រជាជន ថា៖ ចូរប្រុងស្ដាប់តាមយើង ហើយស្ដាប់តាម
លទ្ធិរបស់យើងចុះ; ត្បិតមើលចុះ សព្វថ្ងៃនេះ [គ]គ្មានព្រះទេ
ព្រោះព្រះអម្ចាស់ និងព្រះដ៏ ប្រោសលោះ បានធ្វើកិច្ចការរបស់

---

២៩ *ក* អេសាយ ២៩:១៨.
៣០ *ក* ស.ប. ស្លូតបូត, ភាពស្លូតបូត.
*ខ* គ. និង ស. ១០១:៣៦.
៣១ *ក* អេសាយ ២៩:២០.
៣២ *ក* លូកា ១១:៥៤.
*ខ* អេម៉ុស ៥:១០.
*គ* ២ នីហ្វៃ ២៨:១៦.
៣៤ *ក* អេសាយ ២៩:២៣–២៤.
៣៥ *ក* ២ នីហ្វៃ ២៨:១៤; គ. និង ស. ៣៣:៤.
*ខ* ដានី. ១២:៤.
**២៨** ២ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ១ នីហ្វៃ ១៣:៣៤–៤២; ២២:៩;
៣ នីហ្វៃ ២១:៦.
៣ *ក* ១ កូរិន. ១:១០–១៣;
១ នីហ្វៃ ២២:២៣;
៤ នីហ្វៃ ១:២៥–២៩;
មរមន ៨:២៨, ៣២–៣៨.
៤ *ក* ២ នីហ្វៃ ៩:២៨.
៥ *ក* ២ នីហ្វៃ ២៦:២០.
*ខ* ២ ធីម៉ូ. ៣:៥.
*គ* អាលម៉ា ៣០:២៨.

ទ្រង់រួចស្រេចបាច់ហើយ ហើយទ្រង់បានប្រទានអំណាចរបស់
ទ្រង់មកមនុស្សលោក;
៦ មើលចុះ ចូរប្រុងស្ដាប់តាមលទ្ធិរបស់យើងចុះ; បើសិនជា
ពួកគេប្រាប់ថា មានអព្ភូតហេតុបានសម្ដែងឡើង ដោយ
ព្រះហស្តនៃព្រះ អម្ចាស់ ចូរកុំជឿឲ្យសោះ; ត្បិតសព្វថ្ងៃនេះ
ទ្រង់មិនមែនជាព្រះនៃអព្ភូតហេតុទេ; ទ្រង់បានធ្វើកិច្ចការរបស់
ទ្រង់រួចស្រេចបាច់ហើយ ។
៧ មែនហើយ ហើយនឹងមានមនុស្សជាច្រើននិយាយថា៖
ចូរយើងស៊ីផឹក ហើយអរសប្បាយទៅចុះ ត្បិតស្អែកឡើង
យើងត្រូវស្លាប់ ហើយ; ហើយនឹងបានស្រួលដល់យើង ។
៨ ហើយនឹងមានមនុស្សជាច្រើននិយាយថា៖ ចូរយើងស៊ីផឹក
ហើយអរសប្បាយទៅចុះ; ប៉ុន្តែចូរកោតខ្លាចដល់ព្រះ —
ទ្រង់នឹងរាប់ ថាសុចរិត ក្នុងការប្រព្រឹត្តអំពើបាបបន្តិចបន្តួច; មែន
ហើយ ដូចជានិយាយកុហកបន្តិចបន្តួច ជិះជាន់មនុស្សផ្សេង
ដោយសារសំដីរបស់គេ ជីករណ្ដៅទុកដាក់អ្នកជិតខាងខ្លួន;
គ្មានខុសអ្វីទេចំពោះការណ៍ទាំងនេះ; ហើយចូរយើងប្រព្រឹត្តនូវ
ការណ៍អស់ទាំងនេះទៅចុះ ត្បិតស្អែកឡើង យើងត្រូវស្លាប់ហើយ;
ហើយប្រសិនបើយើងបែរជាមានទោសទៅវិញ នោះព្រះទ្រង់
នឹងវាយយើងពីរបីរំពាត់ ហើយនៅទីបំផុត យើងក៏នឹងត្រូវបាន
សង្គ្រោះនៅក្នុងនគរព្រះដែរ ។
៩ មែនហើយ ហើយនឹងមានមនុស្សជាច្រើនដែលនឹង
បង្រៀនតាមរបៀបនេះ គឺជាលទ្ធិក្លែងក្លាយ ឥតខ្លឹមសារ
ហើយឥតប្រយោជន៍ ហើយនឹងអួតនៅក្នុងចិត្តរបស់ខ្លួន ហើយ
នឹងលាក់គំនិតរបស់ខ្លួនពីព្រះអម្ចាស់; ហើយកិច្ចការរបស់ពួក
គេនឹងនៅក្នុងទីងងឹត ។
១០ ហើយឈាមរបស់ពួកបរិសុទ្ធ នឹងស្រែកចេញពីដីមក
ទាស់នឹងគេ ។
១១ មែនហើយ ពួកគេទាំងអស់បានដើរចេញពីផ្លូវ; ពួកគេ
បានក្លាយទៅជាពុករលួយ ។
១២ ពីព្រោះតែការឆ្មើងឆ្មៃ និងពីព្រោះតែពួកគ្រូក្លែងក្លាយ
និងលទ្ធិក្លែងក្លាយ នោះសាសនាចក្រទាំងឡាយរបស់ពួកគេ
បាន ក្លាយទៅជាពុករលួយ ហើយសាសនាចក្រទាំងឡាយ
របស់ពួកគេបានលើកខ្លួនឡើង; មកពីការឆ្មើងឆ្មៃ ទើបពួកគេ
បានអួតខ្លួនឡើង ។
១៣ ពួកគេប្លន់អ្នកទាល់ក្រ ដោយសារតែទីបរិសុទ្ធដ៏ល្អ
របស់ខ្លួន; ពួកគេប្លន់អ្នកទាល់ក្រ ដោយសារ
តែគ្រឿងសំលៀកបំពាក់ដ៏ល្អ របស់ខ្លួន; ហើយពួកគេបៀតបៀន
អ្នកស្លូតត្រង់ និងអ្នកទាល់ក្រក្នុងចិត្ត ពីព្រោះតែនៅក្នុង
ការឆ្មើងឆ្មៃរបស់ខ្លួន ទើបពួកគេបានអួតខ្លួន ឡើង ។
១៤ ពួកគេធ្វើករឹង ហើយងើយក្បាលខ្ពស់; មែនហើយ
ព្រោះតែការឆ្មើងឆ្មៃ និងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំង
ឡាយ ហើយ នឹងអំពើសហាយស្មន់ នោះពួកគេទាំងអស់
ដើរវង្វេង លើកលែងតែមួយចំនួនតូចប៉ុណ្ណោះ ដែលជាពួក
អ្នកដើរតាមព្រះគ្រីស្ទដោយ រាបសា; ទោះជាយ៉ាងនេះក្ដី គង់
តែមានគ្រាជាច្រើន ដែលពួកគេត្រូវបានដឹកនាំឲ្យធ្វើខុស ព្រោះពួក
គេត្រូវបានបង្រៀន ដោយសិក្ខាបទ ទាំងឡាយនៃមនុស្ស ។
១៥ ឱអ្នកប្រាជ្ញ និងពួកអ្នករៀនសូត្រ និងអ្នកមាន
ដែលអួតខ្លួននៅក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់ពួកគេ និងអស់អ្នកដែល
បង្រៀន លទ្ធិទាំងឡាយដែលក្លែងក្លាយ និងអស់អ្នកដែលប្រព្រឹត្ត
អំពើសហាយស្មន់ទាំងឡាយ ហើយបង្ខូចផ្លូវដ៏ត្រឹមត្រូវនៃព្រះ
អម្ចាស់ មែនហើយ វេទនា វេទនា វេទនាដល់អ្នកទាំងនោះចុះ
ព្រះអម្ចាស់ជាព្រះដ៏មានមហិទ្ធិឫទ្ធិ ទ្រង់មានព្រះបន្ទូលថាដូច្នោះ
ព្រោះពួកគេនឹងត្រូវបោះ ទំលាក់ទៅស្ថាននរក ។
១៦ វេទនាដល់អ្នកណា ដែលបង្វែរមនុស្សយុត្តិធម៌ចេញ

៦ *ក* មរមន ៨:២៦; ៩:១៥–២៦.
៧ *ក* ១ កូរិន. ១៥:៣២;
អាលម៉ា ៣០:១៧–១៨.
៨ *ក* មរមន ៨:៣១.
*ខ* គ. និង ស. ១០:២៥;
ម៉ូសេ ៤:៤.
ស.ប. សេចក្ដីកុហក.
*គ* សុភា. ២៦:២៧;
១ នីហ្វៃ ១៤:៣.
៩ *ក* អេសេ. ១៣:៣;
ហេលេ. ១៣:២៩.
*ខ* ម៉ាថាយ ១៥:៩.
១០ *ក* វិវ. ៦:៩–១១;
២ នីហ្វៃ ២៦:៣;
មរមន ៨:២៧;
អេធើរ ៨:២២–២៤;
គ. និង ស. ៨៧:៧.
១១ *ក* ហេលេ. ៦:៣១.
*ខ* មរមន ៨:២៨–៤១;
គ. និង ស. ៣៣:៤.
១២ *ក* សុភា. ២៨:២៥.
១៣ *ក* អេសេ. ៣៤:៨.
*ខ* ហេលេ. ៤:១២.
*គ* អាលម៉ា ៥:៥៣.
១៤ *ក* សុភា. ២១:៤.
*ខ* អេសាយ ៥៣:៦.
១៥ *ក* សុភា. ៣:៥–៧.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*គ* ៣ នីហ្វៃ ២៩:៥.
១៦ *ក* អេសាយ ២៩:២១.

ដោយរឿងមិនជាហេតុវិញ ហើយដេរប្រមាថដល់អ្វីដែលល្អ
ហើយព្រម ទាំងនិយាយថាគ្មានប្រយោជន៍ទេ! ត្បិតថ្ងៃនោះ
នឹងមកដល់ កាលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងមក
ពិនិត្យពិច័យបណ្ដាជននៅលើផែនដី យ៉ាងឆាប់; ហើយនៅ
ថ្ងៃនោះ កាលណាពួកគេបាន[ខ]ទុំសុសក្នុងសេចក្ដីទុច្ចរិត នោះពួក
គេនឹងត្រូវវិនាសទៅ ។
១៧ ប៉ុន្តែមើលចុះ បើសិនជាបណ្ដាជននៅលើផែនដីនឹងប្រែ
ចិត្តពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ
នោះពួកគេនឹងមិនត្រូវបំផ្លាញចោលឡើយ ព្រះអម្ចាស់នៃពួក
ពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៨ ប៉ុន្តែមើលចុះ សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើមនោះ
[ក]ជាពេស្យានៃអស់ទាំងផែនដី [ខ]ត្រូវតែរលំដួលទៅលើផែនដី
ហើយការ រលំដួលនោះច្បាស់ជាខ្លាំងណាស់ហ្ន៎ ។
១៩ ព្រោះនគរនៃអារក្សនឹង[ក]ត្រូវកក្រើក ឯពួកដែលនៅ
ក្នុងនោះ ត្រូវរំជួលឲ្យប្រែចិត្ត បើពុំនោះសោតទេ [ខ]អារក្សនឹង
ចាប់ពួកគេ ចងដោយច្រវាក់ដ៏ជាប់អស់កល្បជានិច្ច ហើយ
ពួកគេនឹងត្រូវចាក់រុកឲ្យមានកំហឹង ហើយក៏វិនាសទៅ;
២០ ត្បិតមើលចុះ នៅថ្ងៃនោះ វានឹង[ក]ញាំញីនៅក្នុងចិត្តទាំង
ឡាយនៃកូនចៅមនុស្ស ហើយចាក់រុកឲ្យពួកគេមានកំហឹង
ទាស់នឹងអ្វី ដែលជាល្អវិញ ។
២១ ហើយឯអ្នកផ្សេងទៀត វានឹង[ក]បង្ក្រាបឲ្យសុខ ហើយបំពេពួក
គេឲ្យបានសុខខាងរូបកាយ ដែលពួកគេនឹងនិយាយថា៖ អ្វីៗ
បាន ស្រួលទាំងអស់នៅក្រុងស៊ីយ៉ូន; មែនហើយ ក្រុងស៊ីយ៉ូន
បានចំរើនឡើង អ្វីៗស្រួលអស់ហើយ — [ខ]អារក្សបានបញ្ឆោត
ព្រលឹងពួកគេដូច្នោះ ហើយ ហើយនាំពួកគេដោយប្រុង
ប្រយ័ត្នចុះទៅស្ថាននរក ។
២២ ហើយមើលចុះ វាបញ្ចោរអ្នកឯទៀត ហើយប្រាប់ពួក
គេថា គ្មាន[ក]ស្ថាននរកទេ; ហើយវានិយាយទៅពួកគេថា៖ ខ្ញុំមិន
មែនជា អារក្សទេ ត្បិតគ្មានអារក្សឯណា — ហើយវា
ខ្សឹបដាក់ត្រចៀកគេថាដូច្នោះ រហូតដល់វាចាប់ពួកគេជាប់ដោយ
[ខ]ច្រវាក់ដ៏អប្រិយ៍របស់វា ចាប់ពីនោះទៅ គឺគ្មានការរំដោះឲ្យ
រួចបានឡើយ ។
២៣ មែនហើយ ពួកគេត្រូវជាប់ដោយសេចក្ដីស្លាប់ និង
ស្ថាននរក; ហើយសេចក្ដីស្លាប់ និងស្ថាននរក និងអារក្ស
និងអ្នកទាំងអស់ ដែលត្រូវចាប់ទៅនោះ ពួកគេនឹង
ឈរនៅចំពោះបល្ល័ង្កនៃព្រះ ហើយទទួល[ក]ការជំនុំជំរះ
ស្របតាមកិច្ចការទាំងឡាយរបស់ខ្លួន គឺចាប់ ពីនោះទៅ ពួក
គេត្រូវទៅកាន់ទីកន្លែងដែលបានរៀបចំសំរាប់ពួកគេ គឺ[ខ]បឹងភ្លើង
និងស្ពាន់ធ័រ ដែលជាសេចក្ដីទុក្ខវេទនាដ៏មិនចេះចប់
មិនចេះហើយ ។
២៤ ហេតុដូច្នេះហើយ វេទនាដល់អ្នកណា ដែល
បានសុខស្រួលនៅក្រុងស៊ីយ៉ូន!
២៥ វេទនាដល់អ្នកណា ដែលស្រែកថា អ្វីៗបានស្រួល
ទាំងអស់!
២៦ មែនហើយ វេទនាដល់អ្នកណា ដែល[ក]ស្ដាប់តាមសិក្ខាប
ទទាំងឡាយនៃមនុស្ស តែមិនទទួលស្គាល់ព្រះចេស្ដានៃព្រះ និង
អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ!
២៧ មែនហើយ វេទនាដល់អ្នកណាដែលថា យើងបាន
ទទួលហើយ យើងមិន[ក]ត្រូវការទៀតទេ!
២៨ ហើយសរុបសេចក្ដីថា វេទនាដល់អស់អ្នកណាដែល
ញ័រ ហើយ[ក]បះបោរ ដោយសារតែសេចក្ដីពិតនៃព្រះ!
ត្បិតមើលចុះ អ្នកណាដែលសង់ឡើងនៅលើ[ខ]ថ្ម នោះនឹងទទួល
យកសេចក្ដីពិតនោះដោយចិត្តរីករាយ; រីឯអ្នកណាដែល
សង់ឡើងនៅលើខ្សាច់ នោះនឹងញ័រវិញ ក្រែងខ្លួនត្រូវរលំ ។
២៩ វេទនាដល់អ្នកណាដែលនឹងថា៖ យើងបានទទួលព្រះ
បន្ទូលនៃព្រះហើយ ហើយយើង[ក]មិន[ខ]ត្រូវការព្រះបន្ទូលនៃព្រះទៀតទេ
ត្បិតយើងមានល្មមគ្រប់គ្រាន់ហើយ!
៣០ ត្បិតមើលចុះ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូល
ដូច្នេះថា៖ យើងនឹងប្រទានដល់កូនចៅមនុស្ស មួយបន្ទាត់ម្ដងៗ
មួយ[ក]សិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច; នេះមាន

១៦ *ខ* អេធើរ ២:៩–១០.
១៨ *ក* វិវរ. ១៩:២.
*ខ* ១ នីហ្វៃ ១៤:៣, ១៧.
១៩ *ក* ១ នីហ្វៃ ២២:២៣.
*ខ* អាលម៉ា ៣៤:៣៥.
*គ* អាលម៉ា ១២:១១.
២០ *ក* គ. និង ស. ១០:២០–២៧.
២១ *ក* មរមន ៨:៣១.
*ខ* ២ នីហ្វៃ ៩:៣៩.
២២ *ក* ស.ប. ស្ថាននរក.
*ខ* អាលម៉ា ៣៦:១៨.
២៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម; សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*ខ* ២ នីហ្វៃ ៩:១៦, ១៩, ២៦.
២៦ *ក* ២ នីហ្វៃ ៩:២៩.
២៧ *ក* អាលម៉ា ១២:១០–១១.
២៨ *ក* ២ នីហ្វៃ ៩:៤០; ៣៣:៥.
ស.ប. ការបះបោរ.
*ខ* ម៉ាថាយ ៧:២៤–២៧.
ស.ប. ថ្ម.
២៩ *ក* ២ នីហ្វៃ ២៩:៣–១០.
*ខ* ២ នីហ្វៃ ២៧:១៤; អេធើរ ៤:៨.
៣០ *ក* អេសាយ ២៨:៩–១៣;
គ. និង ស. ៩៨:១២.

ពរហើយ ដល់អស់អ្នកណាដែលប្រុងស្ដាប់តាមសិក្ខាបទទាំង
ឡាយរបស់យើង ហើយផ្ទៀងត្រចៀកស្ដាប់ពាក្យទូន្មាន
របស់យើង ត្បិតពួកគេនឹងមានប្រាជ្ញា; ត្បិតចំពោះអ្នកណា
ដែលបានទទួល នោះយើងនឹងឲ្យ ថែមទៀត; តែពីអស់អ្នកណា
ដែលនឹងនិយាយថា យើងមានល្មមគ្រប់គ្រាន់ហើយ ពីពួក
នោះនឹងត្រូវដកយកវិញ ទាំងអ្វីដែលពួកគេមាន នោះផងដែរ ។
៣១ ត្រូវបណ្ដាសាហើយ អ្នកណាដែលដាក់ទីទុកចិត្ត
របស់ខ្លួនទៅលើមនុស្ស ឬយកសាច់ឈាមធ្វើជាដៃរបស់ខ្លួន
ឬប្រុងស្ដាប់តាម សិក្ខាបទនៃមនុស្ស លើកលែងតែសិក្ខាប
ទទាំងឡាយរបស់ពួកគេត្រូវបានប្រទានឲ្យ ដោយព្រះចេស្ដានៃ
ព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ។
៣២ ព្រះអម្ចាស់ដ៏ជាព្រះនៃពួកពលបរិវារ ទ្រង់មានព្រះ
បន្ទូលថាៈ វេទនាដល់ពួកសាសន៍ដទៃ! ព្រោះទោះជាយើង
លូកដៃទៅរក ពួកគេពីថ្ងៃមួយទៅថ្ងៃមួយទៀតក្ដី គង់តែពួក
គេនៅតែមិនទទួលស្គាល់យើងដែរ; ទោះជាយ៉ាងណាក៏ដោយ
គង់តែយើងនឹងមេត្តា ករុណាដល់ពួកគេដែរ ព្រះអម្ចាស់ដ៏ជាព្រះ
ទ្រង់មានព្រះបន្ទូលថាដូច្នោះ បើសិនជាពួកគេប្រែចិត្ត ហើយ
មករកយើង; ត្បិតដៃយើងនៅ តែលូករាល់ៗថ្ងៃ ព្រះអម្ចាស់ដ៏ជា
ព្រះនៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ៕

## ជំពូកទី ២៩

*ពួកសាសន៍ដទៃជាច្រើននឹងមិនទទួលស្គាល់ព្រះគម្ពីរមរមន — ពួកគេនឹងនិយាយថាៈ យើងមិនត្រូវការព្រះគម្ពីរទៀតទេ — ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅរកសាសន៍ជាច្រើន — ទ្រង់នឹងជំនុំជំរះមនុស្សលោក ចេញពីគម្ពីរដែលបានសរសេរមកនេះ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ប៉ុន្តែមើលចុះ នឹងមានមនុស្សជាច្រើន — នៅថ្ងៃដែលយើង
នឹងចាប់ផ្ដើមធ្វើការណ៍មួយដ៏អស្ចារ្យ ក្នុងចំណោមពួកគេ
ដើម្បីយើងអាចនឹកចាំនូវសេចក្ដីសញ្ញាទាំងឡាយរបស់យើង
ដែលយើងបានធ្វើចំពោះកូនចៅមនុស្ស ដើម្បីយើងអាច លូក
ដៃជាលើកទីពីរ ទៅសង្គ្រោះប្រជាជនយើង ដែលជាវង្ស
នៃអ៊ីស្រាអែល;
២ ហើយម្យ៉ាងទៀត ដើម្បីយើងអាចនឹកចាំនូវសេចក្ដី
សន្យាទាំងឡាយ ដែលយើងបានធ្វើចំពោះអ្នក នីហ្វៃ ហើយ
ព្រមទាំង ចំពោះឪពុកអ្នកផងដែរ ដើម្បីយើងអាចនឹកចាំ
ពូជអ្នក; ហើយដើម្បីឲ្យពាក្យទាំងឡាយនៃពូជអ្នក
នឹងចេញពីមាត់យើងទៅពូជអ្នក; ហើយពាក្យទាំងឡាយ
របស់យើង នឹងហួចហៅទៅដល់ចុងផែនដី ទុកជាទង់ជ័យ
ដល់រាស្ត្រយើង ដែលជាវង្សនៃអ៊ីស្រាអែល;
៣ ហើយពីព្រោះពាក្យទាំងឡាយរបស់យើងនឹងហួចហៅ —
ពួកសាសន៍ដទៃជាច្រើននឹងនិយាយថាៈ ព្រះគម្ពីរ! ព្រះគម្ពីរ!
យើងមានព្រះគម្ពីរមួយហើយ ហើយនឹងមិនអាចមានព្រះគម្ពីរ
ឯណាទៀតទេ ។
៤ ប៉ុន្តែ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលដូច្នេះថាៈ
ឱពួកល្ងង់អើយ ពួកគេនឹងមានព្រះគម្ពីរមួយ ហើយព្រះគម្ពីរ
នោះនឹងចេញ មកពីពួកសាសន៍យូដា គឺជារាស្ត្រក្នុងសេចក្ដី
សញ្ញារបស់យើង តាំងពីបុរាណមក ។ ហើយតើពួកគេនឹងដឹង
គុណអ្វីដល់ពួកសាសន៍យូដា ដែលខ្លួនបានទទួលព្រះគម្ពីរពីពួក
នោះ ? មែនហើយ តើពួកសាសន៍ដទៃមានន័យយ៉ាងណា ?
តើពួកគេនឹកចាំពីការឈឺចាប់ទាំងឡាយ និងការនឿយហត់ទាំង
ឡាយ និងការលំបាកឈឺចាប់ទាំងឡាយរបស់ពួកសាសន៍យូដា
និងការព្យាយាមរបស់ពួកគេចំពោះយើង ក្នុងការនាំសេចក្ដី
សង្គ្រោះមកដល់ពួកសាសន៍ដទៃឬអ្វី ?
៥ ឱពួកសាសន៍ដទៃអើយ តើអ្នករាល់គ្នានៅចាំពួកសាសន៍
យូដា គឺជារាស្ត្រក្នុងសេចក្ដីសញ្ញារបស់យើង តាំងពីបុរាណឬអ្វី?
ទេ; ប៉ុន្តែអ្នករាល់គ្នាបានដាក់បណ្ដាសាពួកគេ ហើយបានស្អប់
ពួកគេ ហើយមិនបានស្វែងរកផ្លូវដើម្បីជួយសង្គ្រោះពួកគេសោះ ។

---

៣០ *ខ* ស.ប. ប្រាជ្ញា.
*គ* លូកា ៨:១៨.
*ឃ* អាលម៉ា ១២:១០; គ. និង ស. ៥០:២៤.
៣១ *ក* គ. និង ស. ១:១៩–២០.
៣២ *ក* ១ នីហ្វៃ ១៤:៦.
*ខ* យ៉ាកុប ៥:៤៧; ៦:៤.
២៩ ១*ក* ២ នីហ្វៃ ២៧:២៦. ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*គ* ២ នីហ្វៃ ៦:១៤; ២១:១១–១២; ២៥:១៧. ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
២ *ក* ២ នីហ្វៃ ៣:១៨–២១.
*ខ* អេសាយ ៥:២៦; ២ នីហ្វៃ ១៥:២៦; ម៉ូរ៉ូណៃ ១០:២៨.
*គ* ១ នីហ្វៃ ២១:២២. ស.ប. ទង់.
៣ *ក* ១ នីហ្វៃ ១៣:២៣–២៥. ស.ប. ព្រះគម្ពីរប៊ីប; ព្រះគម្ពីរមរមន.
៤ *ក* គ. និង ស. ៣:១៦.
*ខ* ស.ប. ពួកសាសន៍យូដា.
*គ* ស.ប. យូដា — បន្ទះឈើនៃយូដា.
៥ *ក* ៣ នីហ្វៃ ២៩:៨.

ប៉ុន្តែមើលចុះ យើងនឹងបង្វិលការណ៍ទាំងនេះមកលើក្បាលអ្នក
រាល់គ្នាវិញ ត្បិតយើងជាព្រះអម្ចាស់ មិនទាន់ភ្លេចរាស្ត្រ
របស់យើង នៅឡើយទេ ។
៦ ឱពួកល្ងង់អើយ ដែលនឹងនិយាយថា៖ ព្រះគម្ពីរ យើងបានព្រះ
គម្ពីរមួយហើយ ហើយយើងមិនត្រូវការព្រះគម្ពីរឯណាទៀតទេ ។
តើអ្នកបានព្រះគម្ពីរឯណាមក ក្រៅពីបានព្រះគម្ពីរ មកពីពួក
សាសន៍យូដានោះ ?
៧ តើអ្នករាល់គ្នាមិនដឹងទេថា ក្រៅពីសាសន៍មួយនេះ
នៅមានសាសន៍ជាច្រើនទៀត ? តើអ្នករាល់គ្នាមិនដឹងថា
យើងគឺជាព្រះ អម្ចាស់ដ៏ជាព្រះរបស់អ្នក បានបង្កើតមនុស្ស
ទាំងអស់ ហើយយើងចាំពួកអ្នក ដែលនៅលើកោះនានា
ក្នុងសមុទ្រ; ហើយគឺយើងគ្រប់គ្រង ស្ថានសួគ៌ខាងលើ និងផែនដី
ខាងក្រោម; ហើយយើងនាំពាក្យរបស់យើងចេញមកដល់កូនចៅ
មនុស្ស មែនហើយ គឺគ្រប់ទាំងសាសន៍ លើផែនដីនេះឬអី ?
៨ ហេតុដូច្នោះហើយ ហេតុអ្វីបានជាអ្នករាល់គ្នារអ៊ូរទាំ ពីព្រោះ
តែអ្នករាល់គ្នានឹងទទួលពាក្យរបស់យើងថែមទៀត ? តើអ្នករាល់
គ្នាមិនដឹងទេថា សេចក្ដីបន្ទាល់នៃសាសន៍ពីរ ជាសាក្សីដល់អ្នកថា
យើងជាព្រះ ថាយើងចាំសាសន៍មួយ ក៏ដូចសាសន៍មួយ
ទៀតដែរឬ ? ហេតុដូច្នោះហើយ យើងនិយាយទៅសាសន៍
មួយ ក៏ដូចជាសាសន៍មួយទៀតដែរ ។ ហើយពេលណា
សាសន៍ពីររួមគ្នាទៅជាមួយ នោះសេចក្ដីបន្ទាល់នៃសាសន៍
ទាំងពីរនោះ ក៏នឹងចូលគ្នាទៅជាមួយដែរ ។
៩ ហើយយើងធ្វើយ៉ាងនេះ គឺដើម្បីយើងអាចបញ្ជាក់ដល់
មនុស្សច្រើនគ្នាថា យើងនៅតែដដែល ទោះពីថ្ងៃម្សិល ថ្ងៃនេះ
និងរហូត តទៅ; ហើយថាយើងពោលពាក្យទាំងឡាយ
របស់យើងចេញទៅស្របតាមបំណងរបស់យើង ។ ហើយ
ពីព្រោះយើងបានពោលពាក្យ មួយ ចូរអ្នករាល់គ្នាកុំគិតស្មានថា
យើងមិនអាចពោលពាក្យមួយទៀតបានឡើយ; ត្បិតកិច្ចការ
យើងមិនទាន់បានសំរេចនៅឡើយទេ; ហើយនៅតែមិនទាន់ចប់
រហូតដល់ចុងបំផុតនៃមនុស្ស ហើយចាប់ពីពេលនោះតទៅមុខ
និងរៀងរហូតតទៅ ក៏នៅតែពុំទាន់ចប់ដែរ ។
១០ ហេតុដូច្នោះហើយ ដោយសារអ្នករាល់គ្នាមានព្រះ
គម្ពីរមួយហើយ ចូរអ្នករាល់គ្នាកុំគិតស្មានថា ព្រះគម្ពីរនោះ
មានពាក្យរបស់ យើងទាំងអស់ឡើយ; ហើយចូរអ្នករាល់គ្នា
កុំគិតស្មានផងដែរថា យើងមិនអាចបញ្ជាឲ្យសរសេរ
ថែមទៀតនោះឡើយ ។
១១ ត្បិតយើងបញ្ជាដល់មនុស្សទាំងអស់ ទាំងខាងកើត និង
ខាងលិច និងខាងជើង និងខាងត្បូង ហើយនៅលើកោះនានា
ក្នុង សមុទ្រ ថាពួកគេត្រូវសរសេរនូវពាក្យទាំងឡាយដែល
យើងនិយាយទៅរកពួកគេ; ត្បិតចេញពីគម្ពីរទាំងឡាយ ដែល
បានសរសេរទុក នោះយើងនឹងជំនុំជំរះមនុស្សលោក គឺមនុស្ស
គ្រប់រូបស្របតាមកិច្ចការទាំងឡាយរបស់ខ្លួន គឺស្របតាមអ្វី
ដែលបានសរសេរទុក ។
១២ ត្បិតមើលចុះ យើងនឹងនិយាយទៅរកពួកសាសន៍យូដា
ហើយពួកគេនឹងសរសេរទុក; ហើយយើងនឹងនិយាយទៅរកពួក
សាសន៍នីហ្វៃផងដែរ ហើយពួកគេនឹងសរសេរទុក; ហើយយើងនឹង
និយាយទៅរកពូជអំបូរផ្សេងទៀតនៃវង្សអ៊ីស្រាអែលដែរ ដែល
យើងបាននាំចេញទៅឆ្ងាយ ហើយពួកគេនឹងសរសេរទុក;
ហើយយើងនិយាយទៅរកអស់ទាំងសាសន៍ផង ដែល
នៅលើផែនដីនេះ ហើយពួកគេនឹងសរសេរទុក ។
១៣ ហើយហេតុការណ៍នឹងកើតឡើងថា ពួកសាសន៍
យូដានឹងបានពាក្យទាំងឡាយរបស់ពួកសាសន៍នីហ្វៃ ឯពួក
សាសន៍នីហ្វៃ នឹងបានពាក្យទាំងឡាយរបស់ពួកសាសន៍យូដា;
ហើយពួកសាសន៍នីហ្វៃ និងពួកសាសន៍យូដា នឹងបានពាក្យ
ទាំងឡាយរបស់ពួកពូជអំបូរ នៃសាសន៍អ៊ីស្រាអែលដែលបាត់;
ឯពួកពូជអំបូរនៃសាសន៍អ៊ីស្រាអែលដែលបាត់ នឹងបានពាក្យ
ទាំងលាយរបស់ពួកសាសន៍នីហ្វៃ និងពួកសាសន៍យូដា ។
១៤ ហើយហេតុការណ៍នឹងកើតឡើងថា រាស្ត្រយើង ដែល

៦ *ក* ១ នីហ្វៃ ១៣:៣៨.
៧ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* ១ នីហ្វៃ ២២:៤.
៨ *ក* អេសេ. ៣៧:១៥–២០;
១ នីហ្វៃ ១៣:៣៨–៤១;
២ នីហ្វៃ ៣:១២.
*ខ* ម៉ាថាយ ១៨:១៦.
ស.ប. សាក្សី.
*គ* ហូសេ ១:១១.
៩ *ក* ហេព្រើរ ១៣:៨.
*ខ* ស.ប. វិវរណៈ.
១០ *ក* ស.ប. បទព្រះគម្ពីរ — គម្ពីរដែល
បានព្យាករថានឹងចេញមក.
១១ *ក* អាលម៉ា ២៩:៨.
*ខ* ២ ធីម៉ូ. ៣:១៦.
*គ* ស.ប. សៀវភៅជីវិត.
*ឃ* ២ នីហ្វៃ ២៥:២២; ៣៣:១១,
១៤–១៥.
ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
១២ *ក* ១ នីហ្វៃ ១៣:២៣–២៩.
*ខ* ១ នីហ្វៃ ១៣:៣៨–៤២;
២ នីហ្វៃ ២៦:១៧.
*គ* ២ នីហ្វៃ ២៦:៣៣.
១៣ *ក* មរមន ៥:១២–១៤.
*ខ* ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែលទាំង១០អំបូរដែល
បាត់.

ជាវង្សអ៊ីស្រាអែល នឹងប្រមូលគ្នាមកស្រុកកំណើត នៅលើដែនដី
ទាំង ឡាយដែលជាកេរ្ដិ៍អាកររបស់ពួកគេ; ហើយពាក្យ
របស់យើង ក៏នឹងប្រមូលមកតែមួយដែរ ។ ហើយយើងនឹង
បង្ហាញដល់ពួកគេ ដែល ទាស់នឹងពាក្យយើង ហើយទាស់នឹង
រាស្ត្រ ដែលជាវង្សអ៊ីស្រាអែល ថាយើងជាព្រះ ហើយ
ថាយើងបានធ្វើសេចក្ដីសញ្ញាជាមួយនឹង អ័ប្រាហាំ ថាយើងនឹង
នឹកចាំពូជរបស់លោករហូតតទៅ ៕

## ជំពូកទី ៣០

*ពួកសាសន៍ដទៃដែលបានប្រែចិត្ត នឹងត្រូវបានរាប់បញ្ចូលនឹងរាស្ត្រនៅក្នុងសេចក្ដីសញ្ញា — ពួកសាសន៍លេមិន និងពួកសាសន៍ យូដាជាច្រើន នឹងជឿដល់ព្រះបន្ទូល ហើយក្លាយទៅជាសាសន៍ដែលគួរសម ហើយគួរឲ្យចូលចិត្ត — សាសន៍អ៊ីស្រាអែលនឹងត្រូវ បានសាងឡើងវិញ ឯពួកទុច្ចរិតនឹងត្រូវបំផ្លាញចោល ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ខ្ញុំចង់និយាយទៅរកអ្នករាល់គ្នា; ត្បិតខ្ញុំ នីហ្វៃ មិនទ្រាំឲ្យអ្នករាល់
គ្នា គិតស្មានថា ខ្លួនសុចរិតជាងពួកសាសន៍ដទៃនោះឡើយ ។
ត្បិតមើលចុះ លើកលែងតែអ្នករាល់គ្នាកាន់តាមព្រះបញ្ញត្តិទាំង
ឡាយនៃព្រះ នោះអ្នករាល់គ្នាក៏នឹងវិនាសទៅដែរ; ហើយពីព្រោះ
តែព្រះបន្ទូល ដែលបានថែងមកពីមុន នោះចូរអ្នករាល់គ្នាកុំ
គិតស្មានថា ពួកសាសន៍ ដទៃត្រូវបំផ្លាញសាបសូន្យអស់ឡើយ ។
២ ត្បិតមើលចុះ ខ្ញុំសូមប្រាប់អ្នកថា អស់សាសន៍ដទៃណា
ដែលនឹងប្រែចិត្ត នោះពួកគេនឹងបានទៅជារាស្ត្រនៅក្នុងសេចក្ដី
សញ្ញានៃ ព្រះអម្ចាស់ដែរ; រីឯអស់សាសន៍យូដាណាដែលនឹង
មិនប្រែចិត្ត នោះពួកគេនឹងត្រូវបោះបង់ចោល; ត្បិតព្រះអម្ចាស់
ទ្រង់មិនធ្វើសេចក្ដី សញ្ញានឹងអ្នកណាទេ លើកលែងតែជាមួយ
អ្នកណាដែលប្រែចិត្ត ហើយជឿដល់ព្រះរាជបុត្រាទ្រង់ គឺជា
ព្រះដ៏បរិសុទ្ធនៃសាសន៍ អ៊ីស្រាអែល ។
៣ ហើយឥឡូវនេះ ខ្ញុំចង់ព្យាករបន្តិចទៀតអំពីពួកសាសន៍យូដា
និងពួកសាសន៍ដទៃ ។ ត្បិតបន្ទាប់ពីគម្ពីរដែលខ្ញុំបាននិយាយ
នោះ ចេញមក ហើយត្រូវនឹងបានសរសេរដល់ពួកសាសន៍ដទៃ
ហើយបានបិទត្រាថ្វាយដល់ព្រះអម្ចាស់ទៀត នោះនឹងមាន
មនុស្សជាច្រើន ដែលនឹងជឿដល់ព្រះបន្ទូលទាំងឡាយ ដែល
បានសរសេរទុក; ហើយពួកគេនឹងនាំយកព្រះបន្ទូលទាំងនេះ
ទៅដល់សំណល់នៃពូជយើង ។
៤ ហើយពេលនោះ សំណល់នៃពូជយើងនឹងដឹង
អំពីយើង ពីដំណើរដែលយើងចេញពីក្រុងយេរូសាឡិម
មកយ៉ាងណា ហើយនឹងដឹងថា ពួកគេជាពូជពង្សនៃពួក
សាសន៍យូដា ។
៥ ហើយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នឹងត្រូវបានប្រកាស
ប្រាប់ក្នុងចំណោមពួកគេ; ហេតុដូច្នោះហើយ ពួកគេនឹងបាន
ស្គាល់ ពួកអយ្យកោរបស់ពួកគេឡើងវិញ ហើយក៏នឹងបាន
ស្គាល់ព្រះយេស៊ូវគ្រីស្ទ ដូចដែលបានស្គាល់នៅក្នុងចំណោម
ពួកអយ្យកោ របស់ពួកគេដែរ ។
៦ ហើយពេលនោះ ពួកគេនឹងមានអំណរអរ; ត្បិតពួកគេនឹង
ដឹងថា នោះជាព្រះពរដល់ពួកគេ មកពីព្រះហស្តនៃព្រះ;
ហើយស្រកានៃ សេចក្ដីងងឹតនឹងចាប់ផ្ដើមជ្រុះពីភ្នែករបស់ពួក
គេ; ហើយតំណជាច្រើននឹងមិនស្លាប់ នៅក្នុងចំណោមពួក
គេឡើយ លើកលែងតែពួកគេ ទៅជារាស្ត្រមួយដ៏សុចរិត
ហើយគួរឲ្យចូលចិត្ត ។
៧ ហើយហេតុការណ៍នឹងកើតឡើងថា ពួកសាសន៍យូដាដែល
ត្រូវខ្ចាត់ព្រាត់ ក៏នឹងចាប់ផ្ដើមជឿដល់ព្រះគ្រីស្ទដែរ; ហើយពួក
គេនឹង ចាប់ផ្ដើមប្រមូលគ្នាមកនៅពាសពេញលើដែនដី; ហើយ
អស់អ្នកណាដែលជឿដល់ព្រះគ្រីស្ទ នោះក៏នឹងក្លាយទៅជា
ប្រជាជនដ៏គួរឲ្យចូល ចិត្តដែរ ។
៨ ហើយហេតុការណ៍នឹងកើតឡើងថា ព្រះអម្ចាស់ដ៏ជាព្រះ
ទ្រង់នឹងចាប់ផ្ដើមកិច្ចការរបស់ទ្រង់ នៅក្នុងចំណោមគ្រប់ទាំង
សាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន

១៤ *ក* យេរេ. ៣:១៧–១៨.
*ខ* អេសេ. ៣៧:១៦–១៧.
*គ* ១ នីហ្វៃ ២២:៨–៩.
*ឃ* លោកុ. ១២:១–៣;
១ នីហ្វៃ ១៧:៤០;
៣ នីហ្វៃ ២០:២៧; អ័ប្រា. ២:៩.
ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*ង* គ. និង ស. ១៣២:៣០.
*ច* លោកុ. ១៧:៧.
**៣០** ២ *ក* កាឡាទី ៣:២៦–២៩.
*ខ* ម៉ាថាយ ៨:១០–១៣.
ស.ប. ពួកសាសន៍យូដា.
*គ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
៣ *ក* ៣ នីហ្វៃ ១៦:៦–៧.
*ខ* ១ នីហ្វៃ ២២:៨–៩.
៥ *ក* ៣ នីហ្វៃ ២១:៣–៧, ២៤–២៦.
*ខ* គ. និង ស. ៣:២០.
*គ* ១ នីហ្វៃ ១៥:១៤;
២ នីហ្វៃ ៣:១២;
មរមន ៧:១, ៩–១០.
៦ *ក* គ. និង ស. ៤៩:២៤; ១០៩:៦៥.
៧ *ក* ២ នីហ្វៃ ២៩:១៣–១៤.
*ខ* ២ នីហ្វៃ ២៥:១៦–១៧.

ដើម្បីនាំមកនូវការសាងឡើងវិញ នៃប្រជារាស្ត្រទ្រង់នៅលើផែនដី ។

៩ ហើយព្រះអម្ចាស់ទ្រង់នឹងជំនុំជំរះពួកទាល់ក្រដោយសេចក្ដីសុចរិត ហើយសំរេចក្ដីឲ្យមនុស្សស្លូតបូតនៅផែនដី ដោយសេចក្ដីទៀងត្រង់ ។ ហើយទ្រង់នឹងវាយផែនដីដោយរំពាត់នៃព្រះឱស្ឋទ្រង់; ហើយទ្រង់នឹងសម្លាប់ពួកទុច្ចរិត ដោយខ្យល់ដង្ហើមពីបបូរមាត់ទ្រង់ ។

១០ ពេលនោះនឹងមកដល់យ៉ាងរហ័ស គឺព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងធ្វើឲ្យមានការបែកបាក់ដ៏ធំ នៅក្នុងចំណោមប្រជាជន ហើយទ្រង់នឹងបំផ្លាញពួកទុច្ចរិតចោល; ហើយទ្រង់នឹងប្រណីដល់រាស្ត្រទ្រង់ មែនហើយ ទោះជាទ្រង់ត្រូវបំផ្លាញពួកទុច្ចរិតដោយភ្លើងក៏ដោយ ។

១១ ហើយសេចក្ដីសុចរិតនឹងបានទៅជាខ្សែក្រវាត់ទ្រង់ ហើយសេចក្ដីស្មោះត្រង់ជាខ្សែក្រវាត់កម្លាំងទ្រង់ ។

១២ ហើយពេលនោះ ឆ្កែព្រៃនឹងនៅជាមួយនឹងកូនចៀម; ឯខ្លារខិននឹងដេកនៅជាមួយនឹងកូនពពែ ឯកូនគោជាមួយនឹងសិង្ហស្ទាវ ព្រមទាំងសត្វបំប៉នយ៉ាងធាត់នឹងនៅជាមួយគ្នា; ហើយកូនក្មេងតូចៗ ជាអ្នកគង្វាលវា ។

១៣ ហើយគោញី និងខ្លាឃ្មុំនឹងរកស៊ីជាមួយគ្នា; ហើយកូនវានឹងដេកជាមួយគ្នាដែរ; ឯសិង្ហនឹងស៊ីចំបើងដូចគោវិញ ។

១៤ ហើយកូនមនុស្សដែលនៅបៅ នឹងលេងនៅត្រង់មាត់រន្ធពស់ហនុមាន ហើយក្មេងលែងដោះ នឹងលូកដៃចូលទៅក្នុងរូងពស់វែក បាន ។

១៥ វារាល់គ្នានឹងមិនធ្វើទុក្ខឬបំផ្លាញគ្នា នៅគ្រប់លើភ្នំបរិសុទ្ធរបស់យើង; ត្បិតគ្រប់ទាំងអស់នឹងស្គាល់ព្រះអម្ចាស់ នៅពេញពាសលើផែនដី ដូចជាទឹកនៅពេញពាសក្នុងសមុទ្រដែរ ។

១៦ ហេតុដូច្នោះហើយ ការណ៍ទាំងឡាយនៃសាសន៍ទាំងអស់ នឹងត្រូវបានធ្វើឲ្យដឹង; មែនហើយ គ្រប់ការណ៍ទាំងអស់នឹងត្រូវបាន ធ្វើឲ្យកូនចៅមនុស្សដឹង ។

១៧ គ្មានអ្វីជាអាថ៌កំបាំងឡើយ លើកលែងតែនឹងបានសម្ដែងឲ្យឃើញនោះ; ត្បិតគ្មានកិច្ចការនៃសេចក្ដីងងឹតឡើយ លើកលែងតែ នឹងត្រូវបានសម្ដែងឲ្យឃើញនៅក្នុងពន្លឺ; ហើយគ្មានអ្វីដែលត្រូវភ្ជាប់នៅលើផែនដីឡើយ លើកលែងតែនឹងត្រូវបានស្រាយចេញ ។

១៨ ហេតុដូច្នោះហើយ គ្រប់ការណ៍ទាំងអស់ដែលត្រូវបានបើកសម្ដែងដល់កូនចៅមនុស្ស នោះនឹងត្រូវបានបើកសម្ដែងចេញនៅថ្ងៃនោះដែរ; ហើយអារក្សសាតាំងនឹងគ្មានអំណាច ទៅលើដួងចិត្តនៃកូនចៅមនុស្សទៀតទេ គឺអស់រយៈពេលជាយូរយារ ។ ហើយឥឡូវនេះ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមបញ្ចប់ពាក្យរបស់ខ្ញុំតែត្រឹមនេះសិនចុះ ៕

## ជំពូកទី ៣១

*នីហ្វៃប្រាប់ពីហេតុអ្វីបានជាព្រះគ្រីស្ទទទួលបុណ្យជ្រមុជទឹក — មនុស្សលោកត្រូវដើរតាមព្រះគ្រីស្ទ, ត្រូវទទួលបុណ្យជ្រមុជទឹក, ត្រូវទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយត្រូវកាន់ខ្ជាប់ ដរាបដល់ចុងបំផុត ដើម្បីឲ្យបានសង្គ្រោះ — ការប្រែចិត្ត និងបុណ្យជ្រមុជទឹក គឺជាទ្វារទៅឯផ្លូវតូច ហើយចង្អៀត — ជីវិតដ៏នៅអស់កល្បជានិច្ច មានដល់អស់អ្នកណា ដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយ បន្ទាប់ពីបុណ្យជ្រមុជទឹក ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំ នីហ្វៃ បញ្ចប់នូវការព្យាករណ៍របស់ខ្ញុំដល់អ្នករាល់គ្នា ។ ហើយខ្ញុំមិនអាច សរសេរ គឺគ្រាន់តែសរសេរពីរឿងបន្តិចបន្តួចប៉ុណ្ណោះ ដែលខ្ញុំដឹងថា ច្បាស់ជានឹងកើតឡើង; ខ្ញុំក៏មិនអាចសរសេរ គឺគ្រាន់តែ សរសេរពីរឿងបន្តិចបន្តួចនូវពាក្យពេចន៍របស់យ៉ាកុប ជាប្អូនខ្ញុំ ។

២ ហេតុដូច្នោះហើយ ការណ៍ទាំងឡាយដែលខ្ញុំបានសរសេរមកនេះ ក៏ល្មមគ្រប់គ្រាន់ចំពោះខ្ញុំហើយ លើកលែងតែពាក្យខ្លះដែលខ្ញុំ ត្រូវតែនិយាយ អំពីគោលលទ្ធិនៃព្រះគ្រីស្ទ; ហេតុដូច្នោះហើយ ខ្ញុំនឹងនិយាយទៅកាន់អ្នករាល់គ្នាយ៉ាងច្បាស់លាស់ស្របតាមសេចក្ដី ច្បាស់លាស់នៃការព្យាករណ៍របស់ខ្ញុំ ។

៩ *ក* អេសាយ ១១:៤–៩.
*ខ* ២ នីហ្វៃ ៩:១៥.
*គ* ស.ប. ស្លូតបូត, ភាពស្លូតបូត.
១០ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
*ខ* គ. និង ស. ៦៣:៥៣–៥៤.
*គ* ម៉ូសេ ៧:៦១.
*ឃ* ១ នីហ្វៃ ២២:១៥–១៧, ២៣.
ស.ប. ផែនដី — ការសំអាតផែនដី.
១១ *ក* អេសាយ ១១:៥–៩.
១២ *ក* អេសាយ ៦៥:២៥.
ស.ប. សហស្សវត្សរ៍.
១៦ *ក* គ. និង ស. ១០១:៣២–៣៥; ១២១:២៨–២៩.
*ខ* អេធើរ ៤:៦–៧.
១៧ *ក* គ. និង ស. ១:២–៣.
១៨ *ក* វិវរ. ២០:១–៣; អេធើរ ៨:២៦.
៣១ ១*ក* ២ នីហ្វៃ ២៥:១–៤.
២ *ក* ២ នីហ្វៃ ១១:៦–៧.

៣ ត្បិតព្រលឹងខ្ញុំត្រេកអរចំពោះការច្បាស់លាស់; ត្បិតដោយរបៀបនេះហើយ ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានធ្វើកិច្ចការ នៅក្នុងចំណោមកូនចៅមនុស្ស ។ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានប្រទានពន្លឺដល់យោបល់; ត្បិតទ្រង់មានព្រះបន្ទូលទៅកាន់មនុស្ស ស្របតាមភាសារបស់គេ ចំពោះយោបល់របស់គេ ។

៤ ហេតុដូច្នោះហើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាចងចាំថា ខ្ញុំបាននិយាយទៅអ្នករាល់គ្នា អំពីព្យាការីនោះ ដែលទ្រង់បានបង្ហាញដល់ខ្ញុំ ដែលនឹងធ្វើបុណ្យជ្រមុជទឹកថ្វាយកូនចៀមនៃព្រះ ដែលនឹងយកអំពើបាបទាំងឡាយ នៃមនុស្សលោកចេញ ។

៥ ហើយឥឡូវនេះ បើកូនចៀមនៃព្រះ ដែលជាអង្គបរិសុទ្ធ ត្រូវទទួលបុណ្យជ្រមុជដោយទឹក ដើម្បីបំពេញសេចក្ដីសុចរិតគ្រប់យ៉ាង ឱបើដូច្នោះ តើពួកយើងដែលជាជនមិនបរិសុទ្ធ ត្រូវទទួលបុណ្យជ្រមុជ ច្រើនជាងនេះយ៉ាងណាទៅ មែនហើយ គឺទទួលបុណ្យជ្រមុជ ដោយទឹក !

៦ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំចង់សួរអ្នករាល់គ្នាថា តើមកអំពីហេតុអ្វីបានជាកូនចៀមនៃព្រះបំពេញ សេចក្ដីសុចរិតគ្រប់យ៉ាង ដោយបានទទួលបុណ្យជ្រមុជដោយទឹក ?

៧ តើអ្នករាល់គ្នាពុំជ្រាបទេឬអីថា ទ្រង់បរិសុទ្ធ ? តែទោះបីទ្រង់បរិសុទ្ធក្ដី ក៏គង់តែទ្រង់បង្ហាញដល់កូនចៅមនុស្សថា ស្របតាមសាច់ ឈាម ទ្រង់បន្ទាបខ្លួនចំពោះព្រះវរបិតា ហើយធ្វើបន្ទាល់ដល់ព្រះវរបិតាថា ទ្រង់នឹងគោរពព្រះអង្គ ដោយកាន់តាមព្រះបញ្ញត្តិទាំង ឡាយរបស់ព្រះអង្គ ។

៨ ហេតុដូច្នោះហើយ បន្ទាប់ពីទ្រង់បានទទួលបុណ្យជ្រមុជដោយទឹកហើយ នោះព្រះវិញ្ញាណបរិសុទ្ធក៏យាងចុះមកសណ្ឋិតលើទ្រង់ ក្នុងសណ្ឋានជាសត្វព្រាប ។

៩ ហើយម៉្យាងទៀត ការណ៍នេះបានបង្ហាញដល់កូនចៅមនុស្ស នូវភាពតូចនៃផ្លូវនោះ និងភាពចង្អៀតនៃទ្វារ ដែលគេត្រូវចូលតាម នោះ ទ្រង់បានធ្វើជាគំរូទុកឲ្យពួកគេ ។

១០ ហើយទ្រង់មានព្រះបន្ទូលទៅកូនចៅមនុស្សថា៖ ចូរអ្នករាល់គ្នាមកតាមយើង ។ ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់ របស់ខ្ញុំអើយ តើពួកយើងអាចដើរតាមព្រះយេស៊ូវបានទេ លើកលែងតែពួកយើងយល់ព្រមកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះវរបិតា នោះ ?

១១ ហើយព្រះវរបិតាទ្រង់មានព្រះបន្ទូលថា៖ ចូរអ្នកប្រែចិត្ត ចូរអ្នកប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមនៃព្រះ រាជបុត្រា ដ៏ជាទីស្រឡាញ់របស់យើងចុះ ។

១២ ហើយសម្លេងរបស់ព្រះរាជបុត្រា ក៏បានបន្លឺមកកាន់ខ្ញុំថា៖ អ្នកណាដែលទទួលបុណ្យជ្រមុជទឹក ដោយនូវនាមរបស់យើង នោះព្រះវរបិតាទ្រង់នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធដល់អ្នកនោះ ដូចជាបានប្រទានដល់យើងដែរ; ហេតុដូច្នោះហើយ ចូរមកតាមយើង ហើយធ្វើនូវអ្វីៗដែលអ្នករាល់គ្នាបានឃើញយើងធ្វើចុះ ។

១៣ ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំដឹងថា បើអ្នករាល់គ្នានឹងដើរតាមព្រះរាជបុត្រា ដោយពេញចិត្ត ប្រាថ្នា គឺពុំមានការលាក់ពុត ឬការបោកបញ្ឆោតនៅចំពោះព្រះឡើយ ប៉ុន្តែដោយស្មោះអស់ពីចិត្ត គឺប្រែចិត្តពីអំពើបាបទាំងឡាយ របស់ខ្លួន, ធ្វើបន្ទាល់ចំពោះព្រះវរបិតាថា អ្នករាល់គ្នាយល់ព្រមទទួលយកព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួន, ដោយទទួលបុណ្យជ្រមុជ ទឹក — មែនហើយ ដោយដើរតាមព្រះអម្ចាស់របស់អ្នក និងព្រះអង្គសង្គ្រោះរបស់អ្នក ចុះទៅក្នុងទឹក ស្របតាមព្រះបន្ទូលរបស់ទ្រង់ មើលចុះ ពេលនោះ អ្នកនឹងទទួលព្រះវិញ្ញាណបរិសុទ្ធ; មែនហើយ បន្ទាប់មក ក៏មានបុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណ បរិសុទ្ធ; ហើយបន្ទាប់មក អ្នករាល់គ្នា

---

៣ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* គ. និង ស. ១:២៤.
៤ *ក* ១ នីហ្វៃ ១០:៧; ១១:២៧. ស.ប. យ៉ូហាន-បាទីស្ទ.
*ខ* ស.ប. កូនចៀមនៃព្រះ.
៥ *ក* ម៉ាថាយ ៣:១១–១៧. ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
៧ *ក* យ៉ូហាន ៥:៣០. ស.ប. ការគោរព, ដែលគោរព, គោរព.
៨ *ក* ១ នីហ្វៃ ១១:២៧.
*ខ* ស.ប. ព្រាប, ទីសំគាល់ជា.
៩ *ក* ២ នីហ្វៃ ៩:៤១; ៣ នីហ្វៃ ១៤:១៣–១៤; គ. និង ស. ២២:៤.
១០ *ក* ម៉ាថាយ ៤:១៩; ៨:២២; ៩:៩.
*ខ* ម៉ូរ៉ូណៃ ៧:១១; គ. និង ស. ៥៦:២.
១២ *ក* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
*ខ* លូកា ៩:៥៧–៦២; យ៉ូហាន ១២:២៦.
១៣ *ក* កាឡាទី ៣:២៦–២៧.
*ខ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ; ភ្លើង.

អាចនិយាយដោយភាសានៃពួកទេវតា ហើយស្រែកសរសើរ
ដំកើងដល់ព្រះដ៏បរិសុទ្ធនៃសាសន៍ អ៊ីស្រាអែល ។
១៤ ប៉ុន្តែមើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
សម្លេងនៃព្រះរាជបុត្រាបន្លឺមកខ្ញុំដូច្នេះថា៖ បន្ទាប់ពីអ្នករាល់គ្នា
បានប្រែចិត្តពី អំពើបាបទាំងឡាយរបស់អ្នក ហើយបានធ្វើ
បន្ទាល់ដល់ព្រះវរបិតាថា អ្នកនឹងព្រមកាន់តាមព្រះបញ្ញត្តិទាំង
ឡាយរបស់យើង ដោយទទួល បុណ្យជ្រមុជដោយទឹក ហើយ
បានទទួលបុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ
ហើយអាចនិយាយដោយភាសាថ្មី មែនហើយ គឺភាសានៃពួក
ទេវតា ហើយបន្ទាប់ពីការណ៍នេះ បើសិនជាមិនទទួល
ស្គាល់យើងទៀត នោះប្រសើរជាងបើអ្នកមិនដែល បាន
ស្គាល់យើងសោះ ។
១៥ ហើយខ្ញុំបានឮសម្លេងពីព្រះវរបិតា ដោយមានព្រះ
បន្ទូលថា៖ មែនហើយ ពាក្យទាំងឡាយនៃបុត្រាស្ងួនភ្ងារបស់យើង
គឺពិត ហើយស្មោះត្រង់ ។ អ្នកណាដែលកាន់ខ្ជាប់ ដរាប
ដល់ចុងបំផុត អ្នកនោះនឹងត្រូវបានសង្គ្រោះ ។
១៦ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ដោយពាក្យនេះ ខ្ញុំដឹងថា លើកលែងអ្នកណាដែលកាន់ខ្ជាប់
ដរាបដល់ ចុងបំផុត ដោយធ្វើតាមគំរូនៃព្រះរាជបុត្រានៃ
ព្រះដ៏មានព្រះជន្មរស់នៅនោះ អ្នកនោះនឹងពុំអាចបាន
សង្គ្រោះឡើយ ។
១៧ ហេតុដូច្នោះហើយ ចូរធ្វើនូវអ្វីៗដែលខ្ញុំបានប្រាប់ដល់
អ្នករាល់គ្នាថាខ្ញុំបានឃើញព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ
នៃអ្នកនឹងធ្វើចុះ; ត្បិតដោយហេតុនេះហើយ ទើបការណ៍
ទាំងនោះត្រូវបានបង្ហាញដល់ខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាអាចដឹង
អំពីទ្វារណា ដែលអ្នករាល់គ្នា ត្រូវចូល ។ ត្បិតទ្វារដែលអ្នក
រាល់គ្នាត្រូវចូលនោះ គឺជាការប្រែចិត្ត និងបុណ្យជ្រមុជដោយ
ទឹក; ហើយបន្ទាប់មក គឺការផ្ដាច់បាប ទាំងឡាយរបស់អ្នក
ដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ ។
១៨ ហើយនៅពេលនោះ អ្នករាល់គ្នានៅលើផ្លូវតូច ហើយ
ចង្អៀតនោះ ដែលនាំទៅឯជីវិតដ៏នៅអស់កល្បជានិច្ច; មែន
ហើយ អ្នក រាល់គ្នាបានចូលតាមទ្វារ; អ្នករាល់គ្នាបានធ្វើ
តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះវរបិតា និងព្រះរាជបុត្រា; ហើយ
អ្នករាល់គ្នាបានទទួលព្រះ វិញ្ញាណបរិសុទ្ធ ដែលធ្វើបន្ទាល់អំពី
ព្រះវរបិតា និងអំពីព្រះរាជបុត្រា ចំពោះការបំពេញនូវសេចក្ដី
សន្យា ដែលទ្រង់បានធ្វើថា បើសិនជា អ្នករាល់គ្នាបាន
ចូលតាមផ្លូវ នោះអ្នករាល់គ្នានឹងត្រូវបានទទួល ។
១៩ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
បន្ទាប់ពីអ្នកបានចូលតាមផ្លូវតូច ហើយចង្អៀតនេះហើយ ខ្ញុំសូម
សួរថា តើបានសំរេចសព្វគ្រប់ហើយឬនៅ ? មើលចុះ ខ្ញុំសូម
និយាយទៅអ្នកថា៖ ទេ; ត្បិតអ្នករាល់គ្នាមិនបានមកដល់នេះទេ
លើកលែងតែ ដោយព្រះបន្ទូលនៃព្រះគ្រីស្ទ, ដោយមានសេច
ក្ដីជំនឿដ៏រឹងប៉ឹងដល់ព្រះអង្គ, ដោយពឹងផ្អែកទាំងស្រុង ទៅលើ
បុណ្យគុណរបស់ទ្រង់ ដែលមានឥទ្ធិឫទ្ធិដើម្បីសង្គ្រោះ ។
២០ ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវតែឈានទៅមុខ
ដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ ដោយមានការភ្លឺថ្លានៃ
សេចក្ដីសង្ឃឹមដ៏ ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ
និងមនុស្សគ្រប់រូប ។ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់
គ្នាខិតខំជឿនទៅមុខ ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ
ហើយកាន់ខ្ជាប់ ដរាបដល់ចុងបំផុត មើលចុះ
នោះព្រះវរបិតា ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ អ្នករាល់គ្នានឹង
មានជីវិតដ៏នៅអស់កល្បជានិច្ច ។
២១ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់
ខ្ញុំអើយ នេះគឺជាផ្លូវ ហើយគ្មានផ្លូវឯណាទៀតទេ ឬក៏ឈ្មោះ

១៣ *ក* ២ នីហ្វៃ ៣២:២–៣.
១៤ *ក* ម៉ាថាយ ១០:៣២–៣៣;
អាលម៉ា ២៤:៣០;
គ. និង ស. ១០១:១–៥.
ស.ប. អំពើបាបដ៏អត់ឱនមិនបាន.
*ខ* ២ ពេត្រុស ២:២១.
១៦ *ក* អាលម៉ា ៥:១៣; ៣៨:២;
គ. និង ស. ២០:២៩.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ដំរាប់នៃព្រះយេស៊ូវគ្រីស្ទ.
១៧ *ក* ម៉ូសាយ ១៨:១០.
ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យ
ជ្រមុជទឹក.
*ខ* ស.ប. ការផ្ដាច់បាប.
១៨ *ក* ១ នីហ្វៃ ៨:២០.
*ខ* សុភា. ៤:១៨.
ស.ប. ផ្លូវ.
*គ* កិច្ចការ ៥:២៩–៣២.
១៩ *ក* ម៉ូសាយ ៤:១០.
*ខ* ស.ប. សេចក្ដីជំនឿ.
*គ* គ. និង ស. ៣:២០.
២០ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* ស.ប. សេចក្ដីសង្ឃឹម.
*គ* ស.ប. សេចក្ដីស្រឡាញ់.
*ឃ* ស.ប. កាន់ខ្ជាប់.
២១ *ក* កិច្ចការ ៤:១០–១២;
២ នីហ្វៃ ៩:៤១;
អាលម៉ា ៣៧:៤៦;
គ. និង ស. ១៣២:២២, ២៥.
*ខ* ម៉ូសាយ ៣:១៧.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការ
យកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ
មកដាក់លើខ្លួនយើង.

ណា ទៀតនៅក្រោមមេឃនេះ ដែលមនុស្សអាចបានសង្គ្រោះនៅក្នុងនគរនៃព្រះឡើយ ។ ហើយឥឡូវនេះ មើលចុះ នេះគឺជាគោលលទ្ធិនៃ ព្រះគ្រីស្ទ ហើយគឺជាគោលលទ្ធិតែមួយ ហើយពិតនៃព្រះវរបិតា និងព្រះរាជបុត្រា ហើយនឹងព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះតែមួយ ដែលគ្មានចុងបំផុត ។ អាម៉ែន ៕

## ជំពូកទី ៣២

*ពួកទេវតានិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ — មនុស្សលោកត្រូវអធិស្ឋាន ហើយបានចំណេះពីព្រះវិញ្ញាណបរិសុទ្ធសំរាប់ ខ្លួនឯង ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសន្និដ្ឋានថា អ្នករាល់គ្នារំពឹងគិតនៅក្នុងចិត្ត អំពីកិច្ចការដែលអ្នករាល់គ្នាត្រូវធ្វើ បន្ទាប់ពីបានចូលទៅតាមផ្លូវនោះហើយ ។ ប៉ុន្តែមើលចុះ ហេតុអ្វីបានជាអ្នករាល់គ្នារំពឹងគិត អំពីរឿងទាំងនេះ នៅក្នុងចិត្តរបស់អ្នក ?

២ តើអ្នករាល់គ្នាមិនចាំទេឬអី កាលខ្ញុំបាននិយាយទៅអ្នកថា បន្ទាប់ពីអ្នករាល់គ្នាបានទទួលព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកអាច និយាយដោយភាសានៃពួកទេវតា ? ហើយឥឡូវនេះ តើធ្វើម្ដេចឲ្យអ្នកអាចនិយាយដោយភាសានៃពួកទេវតាបាន លើកលែងតែ ដោយសារព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ?

៣ ពួកទេវតានិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ; ហេតុដូច្នោះហើយ ពួកទេវតានិយាយអំពីព្រះបន្ទូលទាំងឡាយ នៃព្រះគ្រីស្ទ ។ ហេតុដូច្នោះហើយ ខ្ញុំបាននិយាយទៅអ្នករាល់គ្នាថា សូមទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ; ត្បិតមើលចុះ ព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ ដែលអ្នកត្រូវធ្វើ ។

៤ ហេតុដូច្នោះហើយ ឥឡូវនេះ បន្ទាប់ពីខ្ញុំបាននិយាយពាក្យទាំងនេះ បើសិនជាអ្នករាល់គ្នាមិនយល់នូវពាក្យទាំងនេះទេ គឺមកពីអ្នករាល់គ្នាមិនសូម ហើយអ្នករាល់គ្នាក៏មិនគោះដែរ; ហេតុដូច្នោះហើយ អ្នករាល់គ្នាមិនត្រូវបាននាំមកឯពន្លឺឡើយ ប៉ុន្តែត្រូវវិនាសនៅក្នុងទីងងឹតវិញ ។

៥ ត្បិតមើលចុះ ខ្ញុំនិយាយទៅអ្នកទៀតថា បើសិនជាអ្នករាល់គ្នានឹងចូលទៅតាមផ្លូវនោះ ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញដល់អ្នក នូវគ្រប់អ្វីទាំងអស់ ដែលអ្នកត្រូវធ្វើ ។

៦ មើលចុះ នេះគឺជាគោលលទ្ធិនៃព្រះគ្រីស្ទ ហើយនឹងមិនមានគោលលទ្ធិឯណាទៀតទេ ដែលព្រះអង្គប្រទានមក រហូតដល់ក្រោយ ពេលទ្រង់នឹងសម្ដែងរូបអង្គទ្រង់ ដល់អ្នកនៅក្នុងសាច់ឈាម ។ ហើយកាលណាទ្រង់នឹងសម្ដែងរូបអង្គទ្រង់ដល់អ្នកនៅក្នុងសាច់ឈាម នោះអ្វីៗដែលទ្រង់នឹងប្រាប់ដល់អ្នក អ្នកត្រូវគោរពធ្វើតាម ។

៧ ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ មិនអាចនិយាយច្រើនទៀតទេ; ព្រះវិញ្ញាណ ទ្រង់បានបញ្ឈប់សម្លេងខ្ញុំ ហើយទុកឲ្យខ្ញុំសោកសៅព្រោះ តែសេចក្ដីឥតជំនឿ និងសេចក្ដីទុច្ចរិត និងសេចក្ដីល្ងង់ខ្លៅ និងសេចក្ដីរឹងទទឹងនៃមនុស្សលោក; ត្បិតពួកគេមិនស្វែងរកការចេះដឹង ឬក៏យល់នូវការចេះដឹងដ៏ធំឡើយ នៅពេលឲ្យការចេះដឹងដល់ពួកគេយ៉ាងច្បាស់លាស់ គឺច្បាស់លាស់ស្មើនឹងពាក្យនិយាយ ។

៨ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំយល់ថា អ្នករាល់គ្នានៅតែរំពឹងគិតនៅក្នុងចិត្តរបស់អ្នក; ហើយខ្ញុំមានទុក្ខ ដែលត្រូវនិយាយអំពីការណ៍នេះ ។ ត្បិតបើសិនជាអ្នករាល់គ្នាប្រុងស្ដាប់តាមព្រះវិញ្ញាណ ដែលបង្រៀនមនុស្សឲ្យអធិស្ឋាន នោះអ្នក រាល់គ្នានឹងដឹងថា អ្នករាល់គ្នាត្រូវតែអធិស្ឋាន; ត្បិតអារក្សអសោចិ៍មិនបង្រៀនមនុស្សណាមួយឲ្យអធិស្ឋានទេ ប៉ុន្តែបង្រៀនគេមិនឲ្យ អធិស្ឋានវិញ ។

៩ ប៉ុន្តែមើលចុះ ខ្ញុំនិយាយទៅអ្នកថា អ្នករាល់គ្នាត្រូវតែអធិស្ឋានជានិច្ច ឥតរសាយចិត្តឡើយ; គឺអ្នករាល់គ្នាមិនត្រូវធ្វើអ្វីចំពោះព្រះ ឡើយ លើកលែងតែអ្នកអធិស្ឋានដល់ព្រះវរបិតាជាមុនសិន ដោយនូវព្រះនាមនៃព្រះគ្រីស្ទ ដើម្បីទ្រង់នឹង

---

២១ *ឃ* ម៉ាថាយ ៧:២៨;
យ៉ូហាន ៧:១៦–១៧.
*ង* ស.ប. ព្រះ, ក្រុមព្រះ.
*ច* ៣ នីហ្វៃ ១១:២៧, ៣៥–៣៦.
ស.ប. ការរួបរួមតែមួយ.
**៣២** ២ *ក* ៣ នីហ្វៃ ៩:២០.
*ខ* ២ នីហ្វៃ ៣១:១៣.

៣ *ក* ស.ប. ពួកទេវតា.
*ខ* យេរេ. ១៥:១៦.
៤ *ក* ស.ប. សូម.
៦ *ក* ៣ នីហ្វៃ ១១:៨.
៧ *ក* ស.ប. ការឥតជំនឿ.
*ខ* ២ នីហ្វៃ ៣១:២–៣;
យ៉ាកុប ៤:១៣.

៨ *ក* ស.ប. ការអធិស្ឋាន.
*ខ* ម៉ូសាយ ៤:១៤.
ស.ប. អារក្ស.
៩ *ក* ៣ នីហ្វៃ ២០:១;
គ. និង ស. ៧៥:១១.
*ខ* ម៉ូសេ ៥:៨.

ញែកកិច្ចការរបស់អ្នកចេញ ជាបរិសុទ្ធដល់អ្នក ដើម្បីឲ្យ
កិច្ចការរបស់អ្នក អាចបានទៅជាសុខុមាលភាពដល់ព្រលឹង
អ្នក ៕

## ជំពូកទី ៣៣

*ពាក្យសំដីរបស់នីហ្វៃជាពាក្យពិត — ពាក្យទាំងនេះធ្វើបន្ទាល់អំពីព្រះគ្រីស្ទ — អស់អ្នកណាដែលជឿដល់ព្រះគ្រីស្ទ នោះនឹងជឿដល់ពាក្យ របស់នីហ្វៃ ដែលនឹងឈរជាសាក្សីចំពោះវេទិកាជំនុំជំរះ ។ ប្រមាណជាឆ្នាំ ៥៥៩–៥៤៥ ម.គ.ស.។*

ហើយឥឡូវនេះ ខ្ញុំ នីហ្វៃ មិនអាចសរសេរឲ្យអស់ នូវអ្វីដែល
បានបង្រៀននៅក្នុងចំណោមប្រជាជនខ្ញុំ; ហើយខ្ញុំក៏មិនសូវពូកែ
ខាងការ សរសេរ ដូចជាខាងការនិយាយនោះដែរ; ត្បិតកាល
ណាមនុស្សម្នាក់និយាយ ដោយព្រះចេស្ដានៃព្រះវិញ្ញាណ
បរិសុទ្ធ នោះព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ នឹងនាំពាក្យ
ទាំងនោះចូលទៅក្នុងចិត្ត នៃកូនចៅមនុស្ស ។
២ ប៉ុន្តែមើលចុះ មានមនុស្សជាច្រើន ដែលចិត្តរឹងរូសទាស់
នឹងព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះអង្គមិនមានទីកន្លែងនៅក្នុង
ចិត្តគេ ឡើយ; ហេតុដូច្នោះហើយ គេបានបោះបង់ចោល
នូវអ្វីៗដែលបានសរសេរជាច្រើន ហើយរាប់ទុកជារបស់
ឥតប្រយោជន៍ទៅវិញ ។
៣ ប៉ុន្តែខ្ញុំ នីហ្វៃ បានសរសេរនូវអ្វីដែលខ្ញុំបានសរសេរទុក ហើយ
ខ្ញុំរាប់ការណ៍នេះទុកជាមានតម្លៃដ៏ធំ ហើយជាពិសេសចំពោះ
ប្រជាជនរបស់ខ្ញុំ ។ ត្បិតខ្ញុំអធិស្ឋានឲ្យគេ ពុំឈប់ឈរនៅ
ក្នុងពេលថ្ងៃ ហើយនៅពេលយប់ ទឹកភ្នែកខ្ញុំហូរជោកខ្នើយ
ពីព្រោះតែពួកគេ; ហើយខ្ញុំអំពាវនាវដល់ព្រះរបស់ខ្ញុំ នៅ
ក្នុងសេចក្ដីជំនឿ ហើយខ្ញុំដឹងថា ទ្រង់នឹងឮសំរែកខ្ញុំ ។
៤ ហើយខ្ញុំដឹងថា ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងញែកការ
អធិស្ឋានទាំងឡាយរបស់ខ្ញុំ ទុកជាប្រយោជន៍ដល់ប្រជាជន
របស់ខ្ញុំ ។ ហើយពាក្យណាដែលខ្ញុំសរសេរ នៅក្នុងភាព
ទន់ខ្សោយ នោះនឹងបានធ្វើជាខ្លាំងដល់ពួកគេ; ត្បិតពាក្យទាំងនោះ
នឹងបញ្ចុះបញ្ចូលពួកគេ ឲ្យប្រព្រឹត្តអំពើល្អ; ពាក្យទាំងនោះនឹង
ត្រូវបានធ្វើឲ្យពួកគេស្គាល់ពួកអយ្យកោរបស់ខ្លួន; ហើយពាក្យ
ទាំងនោះនិយាយអំពីព្រះយេស៊ូវ ហើយបញ្ចុះបញ្ចូលពួកគេឲ្យ
ជឿដល់ទ្រង់ ហើយឲ្យកាន់ខ្ជាប់ ដរាបដល់ចុងបំផុត ដែល
ជាជីវិតដ៏នៅអស់កល្បជានិច្ច ។
៥ ហើយពាក្យទាំងនោះនិយាយដ៏តឹងតែងទាស់នឹងអំពើបាប
ស្របតាមសេចក្ដីច្បាស់លាស់នៃសេចក្ដីពិត; ហេតុដូច្នោះហើយ
គ្មានមនុស្សណាខឹងនឹងពាក្យទាំងឡាយដែលខ្ញុំបានសរសេរឡើយ
លើកលែងតែអ្នកនោះជាវិញ្ញាណនៃអារក្ស ។
៦ ខ្ញុំសរសើរដំកើងនៅក្នុងសេចក្ដីច្បាស់លាស់; ខ្ញុំសរសើរ
ដំកើងនៅក្នុងសេចក្ដីពិត; ខ្ញុំសរសើរដំកើងនៅក្នុងព្រះយេស៊ូវ
របស់ខ្ញុំ ព្រោះទ្រង់បានប្រោសលោះព្រលឹងខ្ញុំពីស្ថាននរក ។
៧ ខ្ញុំមានសេចក្ដីសប្បុរសចំពោះប្រជាជនខ្ញុំ ហើយមាន
សេចក្ដីជំនឿដ៏មុតមាំដល់ព្រះគ្រីស្ទថា ខ្ញុំនឹងជួបព្រលឹងជាច្រើន
ដែលគ្មាន ទោសនៅឯវេទិកាជំនុំជំរះរបស់ទ្រង់ ។
៨ ខ្ញុំមានសេចក្ដីសប្បុរសចំពោះសាសន៍យូដា — ខ្ញុំនិយាយ
ថា សាសន៍យូដា ពីព្រោះខ្ញុំមានន័យពីពួកអ្នកនៅកន្លែងដែល
ខ្ញុំចេញមក ។
៩ ខ្ញុំក៏មានសេចក្ដីសប្បុរសចំពោះពួកសាសន៍ដទៃផងដែរ ។
ប៉ុន្តែមើលចុះ ខ្ញុំគ្មានសង្ឃឹមអ្វីចំពោះពួកគេសោះ
លើកលែងតែ ពួកគេស្រុះស្រួលជាមួយនឹងព្រះគ្រីស្ទ ហើយ
ចូលតាមទ្វារដ៏ចង្អៀត ហើយដើរតាមផ្លូវតូច ដែលនាំ
ទៅឯជីវិត ហើយបន្តទៅលើផ្លូវនោះ រហូតដល់ចុងបំផុត ក្នុង
ថ្ងៃនៃការសាកល្បង ។
១០ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំ និង
សាសន៍យូដាផង ហើយនឹងអស់អ្នករាល់គ្នា នៅចុងផែនដីអើយ
សូមប្រុង ស្ដាប់តាមពាក្យទាំងនេះ ហើយជឿដល់ព្រះគ្រីស្ទចុះ;

៩ *ក* អាលម៉ា ៣៤:២៧.
៣៣ ១ *ក* អេធើរ ១២:២៣–២៤.
*ខ* គ. និង ស. ១០០:៧–៨.
២ *ក* ហេលេ. ៦:៣៥–៣៦.
៣ *ក* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ខ* អេណុស ១:៩–១២; ព. នៃ ម. ១:៨.
៤ *ក* អេធើរ ១២:២៦–២៧.
*ខ* ម៉ូរ៉ូណៃ ៧:១៣.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៥ *ក* ១ នីហ្វៃ ១៦:១–៣; ២ នីហ្វៃ ៩:៤០.
*ខ* ២ នីហ្វៃ ៣១:៣; យ៉ាកុប ៤:១៣.
៦ *ក* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
៧ *ក* ស.ប. សេចក្ដីសប្បុរស.
៨ *ក* ស.ប. ពួកសាសន៍យូដា.
៩ *ក* ស.ប. ពួកសាសន៍ដទៃ.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ២ នីហ្វៃ ៩:៤១.
*ឃ* ស.ប. ដើរ, ដើរជាមួយព្រះ.
*ង* ហេលេ. ៣:២៩–៣០; គ. និង ស. ១៣២:២២.

ហើយបើសិនជាអ្នករាល់គ្នា មិន[ក]ជឿដល់ពាក្យទាំងនេះទេ ក៏សូមជឿដល់ព្រះគ្រីស្ទ ។ ហើយបើសិនជាអ្នកជឿដល់ព្រះគ្រីស្ទ នោះអ្នករាល់គ្នាក៏នឹងជឿដល់[ខ]ពាក្យទាំងនេះដែរ ព្រោះពាក្យទាំងនេះគឺជា[គ]ព្រះបន្ទូលនៃ ព្រះគ្រីស្ទ ហើយទ្រង់បានប្រទានពាក្យទាំងនេះដល់ខ្ញុំ; ហើយពាក្យទាំងនេះ [ឃ]ប្រដៅមនុស្សទាំងអស់ឲ្យប្រព្រឹត្តអំពើល្អ ។

១១ ហើយបើសិនជាពាក្យទាំងនេះ មិនមែនជាព្រះបន្ទូលនៃព្រះគ្រីស្ទទេ នោះចូរអ្នករាល់គ្នាវិនិច្ឆ័យទៅ — ត្បិតព្រះគ្រីស្ទទ្រង់នឹង បង្ហាញដល់អ្នក ដោយ[ក]ព្រះចេស្តា និងសិរីល្អដ៏ធំថា ពាក្យទាំងនោះគឺជាព្រះបន្ទូលរបស់ទ្រង់ នៅថ្ងៃចុងក្រោយបង្អស់; ហើយអ្នករាល់គ្នា និងរូបខ្ញុំ នឹងឈរប្រទល់មុខគ្នា នៅចំពោះ[ខ]វេទិការបស់ទ្រង់; ហើយអ្នករាល់គ្នានឹងដឹងថា ទ្រង់បានបញ្ជាឲ្យខ្ញុំសរសេរការណ៍ទាំងនេះ ដោយមិនគិតដល់ភាពទន់ខ្សោយរបស់ខ្ញុំឡើយ ។

១២ ហើយខ្ញុំអធិស្ឋានដល់ព្រះវរបិតា ដោយនូវព្រះនាមនៃព្រះគ្រីស្ទ សូមឲ្យពួកយើងជាច្រើននាក់ បើមិនទាំងអស់គ្នាទេ សូមឲ្យ អាចបានសង្គ្រោះនៅក្នុង[ក]នគរទ្រង់ នៅក្នុងថ្ងៃដ៏ធំ និងចុងក្រោយបង្អស់នោះ ។

១៣ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំ គឺអស់ពួកអ្នកដែលជាវង្សអ៊ីស្រាអែល និងអស់អ្នករាល់គ្នានៅចុងផែនដីអើយ ខ្ញុំសូមនិយាយទៅអ្នករាល់គ្នា ដូចជាសម្លេងនៃជនម្នាក់ដែល[ក]ស្រែកចេញពីធូលីដីមកថា៖ សូមលាសិនហើយ រហូតដល់ថ្ងៃដ៏ធំនោះ មកដល់ ។

១៤ ហើយអ្នកណាដែលមិនទទួលទាននូវសេចក្ដីល្អសប្បុរសនៃព្រះ ឬគោរពតាម[ក]ពាក្យទាំងឡាយរបស់ពួកសាសន៍យូដា ឬតាម [ខ]ពាក្យសំដីខ្ញុំផង ឬតាមពាក្យទាំងឡាយដែលចេញមកពីមាត់នៃកូនចៀមនៃព្រះទេ មើលចុះ ខ្ញុំសូមលាអ្នកដល់អស់កល្បជានិច្ច ព្រោះពាក្យទាំងនេះ [គ]នឹងកាត់ទោសដល់អ្នកនៅថ្ងៃចុងក្រោយបង្អស់វិញ ។

១៥ ត្បិតអ្វីដែលខ្ញុំផ្សាភ្ជាប់ទុកនៅលើផែនដីនេះ នឹងត្រូវបានយកមកទាស់នឹងអ្នកនៅវេទិកា[ក]ជំនុំជំរះ; ត្បិតទ្រង់បានបញ្ជាខ្ញុំថាដូច្នេះ ហើយខ្ញុំត្រូវតែគោរពធ្វើតាម ។ អាម៉ែន ៕ :៚

# គម្ពីរយ៉ាកុប

## ប្អូនប្រុសរបស់នីហ្វៃ

ពាក្យពេចន៍ដែលលោកផ្សាយប្រាប់ដល់បងប្អូនរបស់លោក ។ លោកធ្វើឲ្យបុរសម្នាក់ជ្រប់មុខ ដែលចង់រំលំគោលលទ្ធិនៃព្រះគ្រីស្ទ ។ ពាក្យខ្លះៗស្ដីអំពីប្រវត្តិនៃប្រជាជននីហ្វៃ ។

### ជំពូកទី ១

*យ៉ាកុប និងយ៉ូសែបខិតខំបញ្ចុះបញ្ចូលមនុស្សឲ្យជឿដល់ព្រះគ្រីស្ទ ហើយកាន់តាមបញ្ញត្តិរបស់ទ្រង់ — នីហ្វៃស្លាប់ — អំពើទុច្ចរិតកើត មានឡើងនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

ត្បិតមើលចុះ ហេតុការណ៍បានកើតឡើងថា រយៈពេលហាសិបប្រាំឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីពេលដែលលោកលីហៃ បានចាក ចេញពីក្រុងយេរូសាឡិមមក; ហេតុដូច្នោះហើយ នីហ្វៃបានប្រគល់មកខ្ញុំ គឺ[ក]យ៉ាកុប នូវ[ខ]បញ្ញត្តិ១ស្ដីអំពី[គ]ផ្ទាំងតូចទាំងឡាយ ដែលមាន ឆ្លាក់ត្រានូវការណ៍ទាំងឡាយនេះ ។

១០ ក ស.ប. ជំនឿ, ជឿ.
ខ ស.ប. ព្រះគម្ពីរមរមន.
គ ម៉ូរ៉ូណៃ ១០:២៧–២៩.
ឃ ២ នីហ្វៃ ២៥:២៨.
១១ ក អេធើរ ៥:៤; ម៉ូរ៉ូណៃ ៧:៣៥.
ខ វិវរ. ២០:១២; ម៉ូរ៉ូណៃ ១០:៣៤.
១២ ក ស.ប. សិរីល្អនៃសេឡេស្ទាល.
១៣ ក អេសាយ ២៩:៤;
២ នីហ្វៃ ២៦:១៦.
១៤ ក ស.ប. ព្រះគម្ពីរប៊ីប.
ខ ស.ប. ព្រះគម្ពីរមរមន.
គ ២ នីហ្វៃ ២៩:១១;
អេធើរ ៤:៨–១០.
១៥ ក ព. នៃ ម. ១:១១.
[យ៉ាកុប]
១ ១ក ស.ប. យ៉ាកុប, កូនប្រុសរបស់លីហៃ.
ខ យ៉ាកុប ៧:២៧.
គ ២ នីហ្វៃ ៥:២៨–៣៣;
យ៉ាកុប ៣:១៣–១៤.
ស.ប. ផ្ទាំងទាំងឡាយ.

២ ហើយលោកបានឲ្យបញ្ញត្តិ១ដល់ខ្ញុំ យ៉ាកុប ថាខ្ញុំត្រូវកត់នៅលើផ្ទាំងទាំងនេះ នូវរឿងបន្តិចបន្តួច ដែលខ្ញុំចាត់ទុកថាជារឿងដ៏ ពិសេសបំផុត; ថាខ្ញុំមិនត្រូវប៉ះពាល់ គឺគ្រាន់តែបន្តិចបន្តួច អំពីប្រវត្តិនៃប្រជាជននេះ ដែលហៅថាប្រជាជននីហ្វៃ ។

៣ ត្បិតលោកបាននិយាយថា ប្រវត្តិនៃប្រជាជនរបស់លោកត្រូវបានឆ្លាក់នៅលើផ្ទាំងឯទៀតរបស់លោកហើយ ហើយថាខ្ញុំត្រូវរក្សា ផ្ទាំងទាំងនេះទុកឲ្យគង់វង់ ហើយប្រគល់ផ្ទាំងទាំងនេះដល់ពូជខ្ញុំ ពីតំណមួយទៅតំណមួយ ។

៤ ហើយបើសិនជាមានការផ្សាយណាដែលពិសិដ្ឋ ឬវិវរណៈណាមួយធំ ឬការព្យាករណ៍ នោះខ្ញុំត្រូវឆ្លាក់ការណ៍[ក]សំខាន់ៗនៃកិច្ចការទាំងនោះ នៅលើផ្ទាំងទាំងនេះ ហើយត្រូវនិយាយឲ្យបានក្បោះក្បាយ អំពីរឿងទាំងនោះ តាមលទ្ធភាពដែលអាចធ្វើបាន ដោយយល់ដល់ព្រះគ្រីស្ទ ហើយដោយយល់ដល់ប្រជាជនរបស់យើង ។

៥ ត្បិតពីព្រោះមកពីសេចក្ដីជំនឿ និងសេចក្ដីបារម្ភដ៏ខ្លាំង ទើបរឿងនោះត្រូវបានសម្ដែងឲ្យយើងដឹងជាប្រាកដ អំពីប្រជាជនយើង គឺអំពីអ្វីៗដែលនឹង[ក]កើតឡើងដល់ពួកគេ ។

៦ ហើយយើងក៏បានទទួលវិវរណៈទាំងឡាយ និងវិញ្ញាណនៃការព្យាករណ៍ជាច្រើន; ហេតុដូច្នោះហើយ បានជាយើងដឹងអំពី [ក]ព្រះគ្រីស្ទ និងនគររបស់ទ្រង់ដែលនឹងមកដល់ ។

៧ ហេតុដូច្នោះហើយ យើងបានឧស្សាហ៍ធ្វើការនៅក្នុងចំណោមប្រជាជនយើង ក្រែងយើងអាចបញ្ចុះបញ្ចូលពួកគេឲ្យ[ក]មករក ព្រះគ្រីស្ទ ហើយទទួលទាននូវសេចក្ដីល្អសប្បុរសនៃព្រះ ដើម្បីឲ្យពួកគេអាចចូលទៅក្នុង[ខ]ទីសំរាករបស់ទ្រង់បាន ក្រែងតាមមាគ៌ាណា មួយទ្រង់នឹងស្បថ នៅក្នុងព្រះពិរោធថា ពួកគេមិនត្រូវ[គ]ចូល[ឃ]ទៅក្នុងទីនោះទេ ដូចជាការបង្ករឿង នៅក្នុងគ្រាដែលមានការល្បួង កាលដែលកូនចៅនៃអ៊ីស្រាអែល នៅក្នុង[ង]ទីរហោស្ថាននោះ ។

៨ ហេតុដូច្នោះហើយ ទើបយើងសូមដល់ព្រះ[ក] ដើម្បីឲ្យយើងអាចបញ្ចុះបញ្ចូលមនុស្សទាំងអស់ កុំឲ្យគេបះបោរទាស់នឹងព្រះ [ខ]កុំធ្វើឲ្យ ទ្រង់កើតក្ដីពិរោធ តែសូមឲ្យមនុស្សទាំងអស់ជឿដល់ព្រះគ្រីស្ទ[គ] យល់ដល់សារៈប្រយោជន៍នៃការសុគតរបស់ទ្រង់ ហើយលីឈើឆ្កាងទ្រង់ ព្រមទាំងស៊ូរងនូវការអាម៉ាស់នៃមនុស្សលោក; ហេតុដូច្នោះហើយ ខ្ញុំ យ៉ាកុប ទទួលភារកិច្ចដើម្បីបំពេញនូវបញ្ញត្តិរបស់បងខ្ញុំ គឺនីហ្វៃ ។

៩ ឥឡូវនេះ នីហ្វៃបានចាប់ផ្ដើមមានចំណាស់ចាស់ ហើយលោកបានឃើញថា លោកនឹង[ក]ស្លាប់ក្នុងពេលដ៏ខ្លីនេះ; ហេតុដូច្នោះហើយ ទើបលោក[ខ]ចាក់ប្រេងតែងតាំងឲ្យបុរសម្នាក់ធ្វើជាស្ដេច ហើយជាអ្នកគ្រប់គ្រងលើ[គ]ប្រជាជនលោកនៅពេលឥឡូវនេះ តាមការគ្រងរាជ្យ នៃស្ដេចទាំងឡាយ ។

១០ ដោយមកពីប្រជាជនស្រឡាញ់នីហ្វៃជាខ្លាំង ដោយមកពីលោកបានធ្វើជាអ្នកការពារដ៏ឆ្នើមដល់ពួកគេ គឺដោយបាន[ក]ប្រើដាវ ឡាបាន់ ដើម្បីការពារពួកគេ ហើយដោយបានធ្វើការយ៉ាងនឿយហត់អស់មួយជីវិតលោក ដើម្បីសុខុមាលភាពដល់ពួកគេ —

១១ ហេតុដូច្នោះហើយ បានជាប្រជាជនចង់រក្សាឈ្មោះលោកទុកជាអនុស្សាវរីយ៍ ។ ហើយអ្នកណាដែលនឹងសោយរាជ្យត ពីលោកទៅ ប្រជាជននឹងហៅថា នីហ្វៃទីពីរ នីហ្វៃទីបី ជារៀងរហូតតទៅ ស្របតាមការគ្រងរាជ្យនៃស្ដេចទាំងឡាយ; ម្ល៉ោះហើយ ទើបពួកគេត្រូវបានហៅដោយប្រជាជនយ៉ាងដូច្នោះហើយ ទោះជាពួកគេមានឈ្មោះណាក៏ដោយ ។

១២ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃ[ក]ក៏ស្លាប់ទៅ ។

១៣ ឥឡូវនេះ ប្រជាជនណាដែលមិនមែនជាសាសន៍លេមិន គឺជា[ខ]សាសន៍នីហ្វៃទាំងអស់; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេត្រូវបានហៅថា ពួកសាសន៍នីហ្វៃ ពួកសាសន៍យ៉ាកុប

៤ *ក* ក.ន. ការណ៍ធំសំខាន់ៗ.
៥ *ក* ១ នីហ្វៃ ១២.
៦ *ក* ១ នីហ្វៃ ១០:៤–១១; ១៩:៨–១៤.
៧ *ក* ២ នីហ្វៃ ៩:៤១; អោមណៃ ១:២៦; ម៉ូរ៉ូណៃ ១០:៣២.
*ខ* ស.ប. សេចក្ដីសំរាក.
*គ* ជនគ. ១៤:២៣; ចោទិ. ១:៣៥–៣៧; គ. និង ស. ៨៤:២៣–២៥.
*ឃ* ហេព្រើរ ៣:៨.
*ង* ជនគ. ២៦:៦៥; ១ នីហ្វៃ ១៧:២៣–៣១.
៨ *ក* ស.ប. ការបះបោរ.
*ខ* ១ នីហ្វៃ ១៧:៣០; អាលម៉ា ១២:៣៦–៣៧; ហេលេ. ៧:១៨.
*គ* ក.យ.ស., ម៉ាថាយ ១៦:២៥–២៦; លូកា ១៤:២៧.
៩ *ក* ២ នីហ្វៃ ១:១៤.
*ខ* ស.ប. ចាក់ប្រេង.
*គ* ២ នីហ្វៃ ៦:២; យ៉ារ៉ុម ១:៧.
១០ *ក* ១ នីហ្វៃ ៤:៩; ២ នីហ្វៃ ៥:១៤; ព. នៃ ម. ១:១៣; ម៉ូសាយ ១:១៦; គ. និង ស. ១៧:១.
១៣ *ក* អេណុស ១:១៣; គ. និង ស. ៣:១៨.
*ខ* ស.ប. ពួកសាសន៍នីហ្វៃ.

ពួកសាសន៍យ៉ូសែប [គ]ពួកសាសន៍សូរ៉ាំ ពួកសាសន៍លេមិន ពួក
សាសន៍លេមយួល និងពួកសាសន៍អ៊ីសម៉ាអែលផងដែរ ។
១៤ ប៉ុន្តែខ្ញុំ យ៉ាកុប ចាប់ពីអំណះតទៅ នឹងពុំញែកពួក
គេចេញដោយឈ្មោះទាំងនេះទេ តែខ្ញុំនឹង[ក]ហៅពួកណាដែល
ចង់បំផ្លាញ ប្រជាជននីហ្វៃ ទុកជាពួកសាសន៍លេមិនវិញ ឯ[ខ]ពួក
ណាដែលស្រុះស្រួលនឹងនីហ្វៃ នោះខ្ញុំនឹងហៅគេថា ពួក
សាសន៍នីហ្វៃ ឬ[គ]ប្រជាជន នីហ្វៃ ស្របតាមការគ្រងរាជ្យនៃ
ស្ដេចទាំងឡាយ ។
១៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
ក្រោមរជ្ជកាលស្ដេចទីពីរ នោះប្រជាជននីហ្វៃបានចាប់ផ្ដើមធ្វើ
ចិត្តរឹងរូស ហើយបណ្ដោយខ្លួនឲ្យ[ក]ប្រព្រឹត្តអំពើទុច្ចរិត ដូចជាហ្លួង
ដាវីឌជំនាន់ដើម ដែលប្រាថ្នាចង់បានភរិយា និងស្រីស្នំជាច្រើន
ព្រមទាំងសាឡូម៉ូន ជាបុត្ររបស់ទ្រង់ក៏ដូច្នោះដែរ ។
១៦ មែនហើយ ហើយពួកគេក៏ចាប់ផ្ដើមស្វែងរកមាស
ប្រាក់ឲ្យបានច្រើន ហើយបានចាប់ផ្ដើមដំកើងខ្លួនក្នុងការឆ្មើងឆ្មៃ
ខ្លះៗ ។
១៧ ហេតុដូច្នោះហើយ ខ្ញុំ យ៉ាកុប បានឲ្យពាក្យទាំងនេះទៅ
ពួកគេ នៅពេលខ្ញុំ[ខ]បង្រៀនពួកគេនៅ[ក]ក្នុងព្រះវិហារបរិសុទ្ធ ដោយខ្ញុំ
បាន ទទួលភារកិច្ចជាមុន មកពីព្រះអម្ចាស់ ។
១៨ ត្បិតខ្ញុំ យ៉ាកុប និងប្អូនប្រុសខ្ញុំ គឺយ៉ូសែប ត្រូវបាន
[ក]តែងតាំងឡើងជាសង្ឃ ហើយជាគ្រូបង្រៀនដល់ប្រជាជននេះ
ដោយដៃ របស់នីហ្វៃ ។
១៩ ហើយយើងបានដំកើង[ក]ការងាររបស់យើងថ្វាយព្រះ
អម្ចាស់ ដោយបាន[ខ]ទទួលការខុសត្រូវ, ទទួលអំពើបាបទាំង
ឡាយរបស់ ប្រជាជនមកលើក្បាលខ្លួន បើសិនជាយើងមិនបាន
បង្រៀនពួកគេ នូវព្រះបន្ទូលនៃព្រះឲ្យអស់ពីសេចក្ដីព្យាយាមនោះ;
ហេតុដូច្នោះ ហើយ ដោយបានខិតខំធ្វើការដោយសមត្ថភាព
របស់យើង ទើប[គ]ឈាមរបស់ពួកគេ មិនអាចប្រឡាក់មកលើ
សំលៀកបំពាក់យើងបាន សោះ; បើពុំនោះសោតទេ ឈាមរបស់
ពួកគេនឹងប្រឡាក់មកលើសំលៀកបំពាក់យើង ហើយយើងនឹង
ពុំបានឃើញថា ឥតទោស នៅថ្ងៃចុងក្រោយបង្អស់ឡើយ ៕

## ជំពូកទី ២

*យ៉ាកុបស្ដីបន្ទោសចំពោះការស្រឡាញ់ទ្រព្យ ការឆ្មើងឆ្មៃ និងភាពអព្រហ្មចារី — មនុស្សលោកអាចស្វែងរកទ្រព្យដើម្បីជួយមនុស្សទូទៅ — យ៉ាកុបដាក់ទោសដល់ការរៀបអាពាហ៍ពិពាហ៍យកប្រពន្ធច្រើន ដែលគ្មានការអនុញ្ញាត — ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យចំពោះ ព្រហ្មចារីភាពរបស់ស្ត្រី ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

តទៅនេះគឺជាពាក្យទាំងឡាយដែលយ៉ាកុប ជាប្អូនប្រុសរបស់
នីហ្វៃ បាននិយាយទៅប្រជាជននីហ្វៃ ក្រោយពីមរណភាព
របស់នីហ្វៃ ៖
២ ឥឡូវនេះ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំ យ៉ាកុប
ស្របតាមការទទួលខុសត្រូវដែលខ្ញុំមានចំពោះព្រះ ដើម្បីដំកើង
ការងារ របស់ខ្ញុំដោយម៉ឺងម៉ាត់ ហើយដើម្បីឲ្យខ្ញុំអាចកំចាត់
សំលៀកបំពាក់របស់ខ្ញុំ ពីអំពើបាបទាំងឡាយរបស់បងប្អូនរាល់គ្នា
នោះខ្ញុំឡើងមក ឯព្រះវិហារបរិសុទ្ធក្នុងថ្ងៃនេះ ដើម្បីខ្ញុំអាច
ប្រកាសប្រាប់បងប្អូនរាល់គ្នា អំពីព្រះបន្ទូលនៃព្រះ ។
៣ ហើយបងប្អូនរាល់គ្នាក៏ដឹងហើយថា រហូតមកដល់ពេលនេះ
ខ្ញុំបានព្យាយាមបំពេញកិច្ចការ ក្នុងការងាររបស់ខ្ញុំ; ប៉ុន្តែថ្ងៃនេះ
ខ្ញុំផ្ទុកទៅដោយបំណង និងការបារម្ភដ៏លើសលែងទៅទៀត
ចំពោះសុខុមាលភាព ដល់ព្រលឹងបងប្អូនរាល់គ្នា
ជាងពេលណាៗ ទាំងអស់ ។
៤ ត្បិតមើលចុះ រហូតមកដល់ពេលនេះ អ្នករាល់គ្នាបាន
គោរពតាមព្រះបន្ទូលនៃព្រះអម្ចាស់ ដែលខ្ញុំបានប្រគល់ឲ្យអ្នក ។
៥ ប៉ុន្តែមើលចុះ ចូរអ្នករាល់គ្នាប្រុងស្ដាប់តាមខ្ញុំចុះ ហើយដឹងថា
ដោយជំនួយរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដាទាំងអស់ ដែល
បង្កើត ផ្ទៃមេឃ និងផែនដី នោះខ្ញុំអាចប្រាប់អ្នកអំពី[ក]គំនិតទាំង
ឡាយរបស់អ្នកថា អ្នករាល់គ្នាកំពុងតែចាប់ផ្ដើមប្រព្រឹត្តអំពើបាប
ហើយអំពើបាប នោះមានសភាពដ៏គួរខ្ពើមឆ្អើមណាស់ចំពោះខ្ញុំ
មែនហើយ ហើយព្រមទាំងដ៏គួរខ្ពើមឆ្អើមចំពោះព្រះដែរ ។
៦ មែនហើយ វាធ្វើឲ្យព្រលឹងខ្ញុំកើតទុក្ខ ហើយបណ្ដាលឲ្យខ្ញុំរួញ

១៣ គ ១ នីហ្វៃ ៤:៣៥;
៤ នីហ្វៃ ១:៣៦–៣៧.
១៤ ក ម៉ូសាយ ២៥:១២;
អាលម៉ា ២:១១.
ខ ២ នីហ្វៃ ៤:១១.
គ ២ នីហ្វៃ ៥:៩.
១៥ ក គ. និង ស. ១៣២:៣៨–៣៩.
១៧ ក ២ នីហ្វៃ ៥:១៦.
ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃ
ព្រះអម្ចាស់.
ខ ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ.
១៨ ក ២ នីហ្វៃ ៥:២៦.
១៩ ក ស.ប. តំណែង, អ្នកកាន់តំណែង.
ខ គ. និង ស. ១០៧:៩៩–១០០.
ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
គ ២ នីហ្វៃ ៩:៤៤.
២ ៥ ក អាលម៉ា ១២:៣;
គ. និង ស. ៦:១៦.
ស.ប. ព្រះ, ក្រុមព្រះ.

ដោយអៀនខ្មាស់នៅចំពោះវត្តមាននៃព្រះ ដែលបានបង្កើតខ្ញុំមក
ដែលខ្ញុំត្រូវតែធ្វើបន្ទាល់ចំពោះសេចក្ដីទុច្ចរិតនៃចិត្តអ្នករាល់គ្នា ។
៧ ហើយវាក៏ធ្វើឲ្យខ្ញុំកើតទុក្ខ ដែលខ្ញុំត្រូវប្រើពាក្យដ៏ធ្ងន់ធ្ងរ
ដល់អ្នក នៅចំពោះមុខប្រពន្ធរបស់អ្នក និងកូនចៅរបស់អ្នក ដែល
ភាគ ច្រើនមានអារម្មណ៍ទន់ភ្លន់ និងបរិសុទ្ធ និងចិត្តទោទន់
នៅចំពោះព្រះ គឺជាការណ៍ដែលសព្វព្រះហឫទ័យព្រះដល់ព្រះ;
៨ ហើយខ្ញុំសន្និដ្ឋានថា ពួកគេបានឡើងមកទីនេះដើម្បីស្ដាប់
នូវព្រះបន្ទូលដ៏ផ្អែមល្ហែមនៃព្រះ មែនហើយ ជាព្រះបន្ទូល ដែល
ធ្វើឲ្យជា ស្បើយព្រលឹង ដែលមានរបួសឈឺចាប់ ។
៩ ហេតុដូច្នោះហើយ វាផ្ទុកព្រលឹងខ្ញុំ ដល់ខ្ញុំត្រូវជំរុញ
គឺដោយសារព្រះបញ្ញត្តិដ៏តឹងរឹង ដែលខ្ញុំបានទទួលមកពីព្រះ
ឲ្យព្រមានដាស់ តឿនដល់អ្នករាល់គ្នា ស្របតាមទោសទាំង
ឡាយរបស់អ្នក ដើម្បីពង្រីកមុខរបួសដល់អ្នកណាដែលមានរបួស
ជាជាងលួងលោម ហើយមើលឲ្យមុខរបួសទាំងនោះជាវិញ;
រីឯអស់អ្នកណាដែលពុំទាន់ត្រូវរបួសទេនោះ ជាជាងបណ្ដោយឲ្យ
ពួកគេទទួលទាននូវ ព្រះបន្ទូលដ៏ផ្អែមល្ហែម នៃព្រះ នោះបាន
ដាក់កាំបិតស្នៀត ឲ្យចាក់ទំលុះព្រលឹងទាំងឡាយរបស់ពួកគេ
ហើយធ្វើឲ្យគំនិតដ៏ទោទន់របស់ ពួកគេរបួសឈឺចាប់វិញដែរ ។
១០ ប៉ុន្តែ ទោះជាភារកិច្ចរបស់ខ្ញុំមានទំហំធំយ៉ាងនេះក៏ដោយ
គង់តែខ្ញុំត្រូវតែធ្វើតាមព្រះញត្តិដ៏តឹងរឹងនៃព្រះ ហើយប្រាប់អ្នក
រាល់ គ្នាអំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់
អ្នក នៅចំពោះវត្តមាននៃពួកអ្នកដែលមានចិត្តជ្រះថ្លា និងពួក
អ្នកដែលមានចិត្ត សង្រេង ហើយនៅក្រោមការក្រឡេក
ដោយព្រះនេត្រដ៏មុត នៃព្រះដ៏មានមហិទ្ធិឫទ្ធិដែរ ។
១១ ហេតុដូច្នោះហើយ ខ្ញុំត្រូវប្រាប់អ្នករាល់គ្នាពីសេចក្ដីពិត
ស្របតាមសេចក្ដីច្បាស់លាស់នៃព្រះបន្ទូលនៃព្រះ។ ត្បិតមើលចុះ
កាលខ្ញុំសូមដល់ព្រះអម្ចាស់ នោះទ្រង់មានព្រះបន្ទូលមកខ្ញុំ
ដូច្នេះថា៖ យ៉ាកុបអើយ ចូរអ្នកឡើងទៅឯព្រះវិហារបរិសុទ្ធនៅ
ថ្ងៃស្អែក ហើយប្រកាសនូវពាក្យ ដែលយើងនឹងឲ្យដល់អ្នក
ទៅប្រជាជននេះ ។

១២ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
នេះគឺជាព្រះបន្ទូលដែលខ្ញុំប្រកាសដល់អ្នកថា បងប្អូនរាល់គ្នា
ជា ច្រើនបានចាប់ផ្ដើមស្វែងរកមាស និងរកប្រាក់ និងរកជាតិរ៉ែ
ដ៏មានតម្លៃគ្រប់យ៉ាង ដែលដែនដីនេះ ជាដែនដីសន្យាដល់អ្នក
និងដល់កូន ចៅអ្នក មានជាច្រើនអនេក ។
១៣ ហើយបាតដៃនៃទិព្វញ្ញាណបានញញឹមមកលើអ្នករាល់
គ្នា ដើម្បីជួយឲ្យអ្នករកបានទ្រព្យជាច្រើន; ហើយដោយមក
ពីពួកអ្នកខ្លះ រកបានបរិបូរច្រើនជាងបងប្អូនអ្នក នោះអ្នករាល់
គ្នាលើកខ្លួនឡើង ក្នុងកាឆ្មើងឆ្មៃនៃចិត្តរបស់អ្នក ហើយធ្វើក
រឹងព្រមទាំងងើយក្បាល ដោយព្រោះប្រដាប់ស្លៀកពាក់របស់ខ្លួន
មានតម្លៃខ្ពស់ ហើយក៏បៀតបៀនបងប្អូនខ្លួន ព្រោះអ្នក
គិតស្មានថា ខ្លួនគ្រាន់បើជាងគេ ។
១៤ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
ចុះតើអ្នកគិតស្មានថា ព្រះទ្រង់ចាត់អំពើរបស់បងប្អូននេះទុកជា
សុចរិតឬអី ? មើលចុះ ខ្ញុំប្រាប់អ្នកថា៖ ទេ ។ ប៉ុន្តែទ្រង់នឹង
កាត់ទោសអ្នក ហើយបើសិនជាអ្នករាល់គ្នានៅតែទទូចធ្វើការ
នេះតទៅទៀត នោះសេចក្ដីជំនុំជំរះរបស់ទ្រង់ នឹងត្រូវតែ
ធ្លាក់មកលើអ្នកយ៉ាងឆាប់រហ័ស ។
១៥ ឱសូមឲ្យទ្រង់បង្ហាញដល់អ្នកថា ទ្រង់អាចចាក់ទំលុះអ្នក
ហើយគ្រាន់តែមួយក្រឡេកនៃព្រះនេត្ររបស់ទ្រង់
នោះទ្រង់ក៏អាច វាយអ្នកឲ្យទៅជាធូលីដីដែរ!
១៦ ឱសូមឲ្យទ្រង់ដោះអ្នកចេញពីអំពើទុច្ចរិត និងពីអំពើ
គួរខ្ពើមឆ្អើមនេះចុះ។ ហើយឱសូមឲ្យអ្នករាល់គ្នាស្ដាប់តាមព្រះ
បន្ទូលនៃ ព្រះបញ្ញត្តិទ្រង់ ហើយសូមកុំឲ្យសេចក្ដីឆ្មើងឆ្មៃនៃចិត្ត
អ្នក បំផ្លាញព្រលឹងទាំងឡាយរបស់អ្នកឡើយ!
១៧ ចូរគិតពីបងប្អូនរបស់ខ្លួនដូចជាខ្លួនអ្នកដែរ ហើយ
ចូររាប់អានបងប្អូនទាំងអស់ ហើយមានចិត្តទូលំទូលាយចំពោះ
ទ្រព្យរបស់អ្នក ដើម្បីឲ្យគេអាចមានទ្រព្យដូចជាអ្នកដែរ ។
១៨ ប៉ុន្តែ មុនអ្នករាល់គ្នាស្វែងរកទ្រព្យសម្បត្តិ ចូរអ្នករាល់
គ្នាស្វែងរកនគរនៃព្រះសិន ។

៧ *ក* គ. និង ស. ១២១:៤៣.
*ខ* ស.ប. គុណធម៌.
៨ *ក* អាលម៉ា ៣១:៥.
១០ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
*ខ* ២ នីហ្វៃ ៩:៤៤.
១១ *ក* ២ នីហ្វៃ ២៥:៤; ៣១:២–៣.
១២ *ក* ១ នីហ្វៃ ១៨:២៥;
ហេលេ. ៦:៩–១១;
អេធើរ ១០:២៣.
*ខ* ១ នីហ្វៃ ២:២០.
ស.ប. ដែនដីសន្យា.
១៣ *ក* មរមន ៨:៣៥–៣៩.
១៦ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១៧ *ក* ស.ប. ទាន, ការដាក់ទាន;
សុខុមាលភាព.
*ខ* ៤ នីហ្វៃ ១:៣.
១៨ *ក* ១ ពង្សាវ. ៣:១១–១៣;
ម៉ាកុស ១០:១៧–២៧;
២ នីហ្វៃ ២៦:៣១;
គ. និង ស. ៦:៧.
ស.ប. ទ្រព្យសម្បត្តិ.
*ខ* លូកា ១២:២២–៣១.

១៩ ហើយបន្ទាប់ពីអ្នករាល់គ្នាបានសេចក្ដីសង្ឃឹមនៅក្នុង
ព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹងបានទ្រព្យសម្បត្តិ បើសិនជាអ្នក
រាល់គ្នា ស្វែងរករបស់ទាំងនោះ; ហើយអ្នករាល់គ្នា
នឹងស្វែងរកទ្រព្យសម្បត្តិ ដោយមានបំណងចង់ធ្វើល្អ —
គឺដើម្បីបំពាក់ពួកអ្នកអាក្រាត ហើយ ចិញ្ចឹមពួកអ្នកដែល
អត់ឃ្លាន ហើយរំដោះពួកអ្នកដែលត្រូវជាប់ឃុំឃាំង ហើយ
ជួយសង្គ្រោះដល់ពួកអ្នកឈឺ និងពួកអ្នកកំសត់ទុរគតិ ។
២០ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
ខ្ញុំបាននិយាយអំពីសេចក្ដីឆ្មើងឆ្មៃ; ហើយអ្នកណាដែលបានធ្វើ
ទុក្ខដល់អ្នកជិត ខាងខ្លួន ហើយបៀតបៀនគេ ពីព្រោះតែ
អ្នកមានចិត្តក្រអឺតចំពោះវត្ថុទាំងឡាយ ដែលព្រះទ្រង់បាន
ប្រទានដល់អ្នកនោះ ចុះតើអ្នក និយាយយ៉ាងណាដែរ
អំពីរឿងនេះ ?
២១ ចុះតើអ្នកមិនគិតស្មានទេឬថា ការណ៍ទាំងនេះគួរឲ្យ
ខ្ពើមឆ្អើម ចំពោះព្រះដែលបានបង្កើតសាច់ឈាមទាំងអស់មក ?
ហើយ នៅក្រោមព្រះនេត្រទ្រង់ មនុស្សណាក៏មានតម្លៃដូចជា
មនុស្សណាដែរ ។ ហើយសាច់ឈាមទាំងអស់ គឺបានមកពីធូលីដី;
ហើយមក ពីបំណងនោះហើយ ទើបទ្រង់បានបង្កើតគេមក
ដើម្បីឲ្យគេកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយ
សរសើរដំកើងដល់ទ្រង់ ជារៀងដរាប ។
២២ ហើយឥឡូវនេះ ខ្ញុំសូមបញ្ចប់នូវការនិយាយទោដល់
អ្នករាល់គ្នា អំពីការឆ្មើងឆ្មៃតែត្រឹមនេះ ។ ហើយបើខ្ញុំមិនត្រូវ
និយាយ ទោអ្នក អំពីទោសធ្ងន់ដ៏លើសលែងទៅទៀត នោះចិត្តខ្ញុំ
នឹងរីករាយយ៉ាងក្រៃលែង ពីព្រោះអ្នក ។
២៣ ប៉ុន្តែ ព្រះបន្ទូលនៃព្រះផ្ទុកមកលើខ្ញុំ ពីព្រោះតែទោស
ដ៏ធ្ងន់លើសលែងទៅទៀតរបស់អ្នករាល់គ្នា ។ ត្បិតមើលចុះ
ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ រាស្ត្រនេះចាប់ផ្ដើម
កើនអំពើទុច្ចរិត; គេមិនយល់ព្រះគម្ពីរទេ ព្រោះគេរកអត់ឱនឲ្យ
ខ្លួនក្នុងការប្រព្រឹត្ត សហាយស្មន់ ពីព្រោះតែរឿងដែលបាន
សរសេរអំពីហ្លួងដាវីឌ និងសាឡូម៉ូន ជាបុត្រទ្រង់ ។
២៤ មើលចុះ ហ្លួងដាវីឌ និងសាឡូម៉ូន ពិតជាមានភរិយា
និងស្រីស្នំជាច្រើនមែន ហើយជាអំពើគួរខ្ពើមឆ្អើមចំពោះយើង
ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
២៥ ហេតុដូច្នោះហើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល
ដូច្នេះថា៖ យើងបាននាំរាស្ត្រនេះ ចេញពីដែនដីយេរូសាឡិមមក
ដោយ អំណាចនៃដៃយើង ដើម្បីយើងអាចបង្កើតសំរាប់យើង
នូវមែកដ៏សុចរិតមួយ ដែលចេញមកពីផលនៃពោះយ៉ូសែប ។
២៦ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ដ៏ជាព្រះ នឹង
មិនទ្រាំឲ្យប្រជាជននេះ ធ្វើដូចមនុស្សជំនាន់ដើមឡើយ ។
២៧ ហេតុដូច្នោះហើយ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
ចូរស្ដាប់តាមខ្ញុំ ហើយប្រុងស្ដាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់
ដែលថា៖ ត្បិតមិនត្រូវមានបុរសណាមួយឡើយនៅក្នុងចំណោម
អ្នកដែលត្រូវមាន លើកលែងតែមានប្រពន្ធមួយប៉ុណ្ណោះ
រីឯស្រីស្នំក៏គេមិនត្រូវ មានសោះឡើយដែរ;
២៨ ត្បិតយើងជាព្រះអម្ចាស់ដ៏ជាព្រះ សព្វព្រះហឫទ័យ
នឹងព្រហ្មចារីភាពនៃស្ត្រី ។ ឯអំពើសហាយស្មន់ទាំងឡាយ
គឺជាអំពើគួរ ខ្ពើមឆ្អើមចំពោះយើង; ព្រះអម្ចាស់នៃពួកពលបរិវារ
ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
២៩ ហេតុដូច្នោះហើយ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់
មានព្រះបន្ទូលថា៖ រាស្ត្រនេះត្រូវកាន់តាមបញ្ញត្តិទាំងឡាយ
របស់យើង បើពុំនោះសោតទេ ដែនដីនេះនឹងត្រូវប្រទេចផ្ដាសា
ដោយសារពួកគេ ។
៣០ ត្បិតព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូល
ថា៖ បើសិនជាយើងនឹងចិញ្ចឹមពូជមួយសំរាប់យើង នោះយើង
នឹងដាក់ បញ្ញត្តិដល់រាស្ត្រយើង; បើពុំនោះសោតទេ គេនឹងត្រូវ
ប្រុងស្ដាប់រឿងទាំងនេះ ។
៣១ ត្បិតមើលចុះ យើងជាព្រះអម្ចាស់ បានឃើញសេចក្ដី
សោកសៅ ហើយបានឮការទ្បូញសោកនៃពួកកូនស្រីរបស់
រាស្ត្រយើង នៅលើដែនដីយេរូសាឡិម មែនហើយ ហើយនៅគ្រប់
ដែនដីនានានៃរាស្ត្រយើង ដោយសារអំពើទុច្ចរិត និងអំពើ
គួរខ្ពើមឆ្អើម ទាំងឡាយនៃប្ដីរបស់គេ ។
៣២ ហើយព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា៖

១៩ *ក* ម៉ូសាយ ៤:២៦.
២១ *ក* គ. និង ស. ១១:២០;
អ័ប្រា. ៣:២៥–២៦.
២៤ *ក* ១ ពង្សាវ. ១១:១;
នេហេ. ១៣:២៥–២៧.
*ខ* ១ ពង្សាវ. ១១:១–៣;
អែសរ៉ា ៩:១–២;
គ. និង ស. ១៣២:៣៨–៣៩.
២៥ *ក* លោកុ. ៤៩:២២–២៦;
អេម៉ុស ៥:១៥;
២ នីហ្វៃ ៣:៥;
អាលម៉ា ២៦:៣៦.
ស.ប. លីហៃ, ឪពុករបស់នីហ្វៃ.
២៧ *ក* គ. និង ស. ៤២:២២; ៤៩:១៦.
ស.ប. អាពាហ៍ពិពាហ៍, រៀប
អាពាហ៍ពិពាហ៍.
២៨ *ក* ស.ប. ព្រហ្មចារីភាព.
២៩ *ក* អេធើរ ២:៨–១២.
៣០ *ក* ម៉ាឡាគី ២:១៥;
គ. និង ស. ១៣២:៦១–៦៦.

យើងនឹងមិនទ្រាំឲ្យសំរែកនៃពួកកូនស្រីដ៏ស្រស់ល្អៗនៃរាស្ត្រនេះ
ដែលយើងបាននាំចេញពីដែនដីយេរូសាឡិមមក នឹងឮឡើងមក
ដល់យើង ទាស់នឹងពួកបុរសនៃរាស្ត្រយើងឡើយ ព្រះអម្ចាស់នៃ
ពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៣៣ ត្បិតពួកគេមិនត្រូវនាំយកពួកកូនស្រីនៃរាស្ត្រយើងទៅជាប់
ឃុំឃាំង ពីព្រោះតែភាពទន់ភ្លន់របស់គេឡើយ បើពុំនោះសោតទេ
យើងនឹងមកពិនិត្យពិច័យពួកគេដោយបណ្ដាសាដ៏ធ្ងន់
គឺដល់សេចក្ដីបំផ្លិចបំផ្លាញបង់; ត្បិតពួកគេមិនត្រូវប្រព្រឹត្តអំពើ
សហាយស្មន់ទាំង ឡាយ ដូចកាលមនុស្សជំនាន់ដើមនោះឡើយ
ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៣៤ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់
ខ្ញុំអើយ អ្នករាល់គ្នាដឹងថា ព្រះបញ្ញត្តិទាំងនេះ ត្រូវបានប្រទាន
ទៅដល់ លីហៃ ឪពុករបស់យើង; ហេតុដូច្នោះហើយ អ្នក
រាល់គ្នាបានស្គាល់ព្រះបញ្ញត្តិទាំងនេះមកហើយ; ហើយអ្នក
រាល់គ្នាបានទទួលការ ដាក់ទោសដ៏ធំ; ព្រោះអ្នករាល់គ្នាបាន
ប្រព្រឹត្តអំពើទាំងនេះ ដែលអ្នករាល់គ្នាពុំត្រូវប្រព្រឹត្តនោះ ។
៣៥ មើលចុះ អ្នករាល់គ្នាបានប្រព្រឹត្តអំពើទុច្ចរិតលើសជាង
ពួកសាសន៍លេមិន ដែលជាបងប្អូនយើងទៅទៀត ។ អ្នកបាន
ធ្វើឲ្យ ភរិយាដ៏ទន់ភ្លន់របស់អ្នកខូចចិត្ត ហើយធ្វើឲ្យកូនចៅអ្នក
គ្មានសេចក្ដីទុកចិត្ត ព្រោះតែគំរូដ៏អាក្រក់របស់អ្នកនៅចំពោះ
ពួកគេ; ហើយសម្លេងដង្ហក់នៃបេះដូងគេ បានឮឡើងទៅដល់
ព្រះទាស់នឹងអ្នក ហើយដោយសារតែភាពតឹងរឹងនៃព្រះបន្ទូល
នៃព្រះ ដែលចុះ មកទាស់នឹងអ្នក នោះបេះដូងជាច្រើនបាន
ស្លាប់ ដោយត្រូវចាក់ទំលុះឲ្យមានរបួសយ៉ាងជ្រៅ ៕

## ជំពូកទី ៣

*អ្នកដែលមានចិត្តបរិសុទ្ធ ទទួលព្រះបន្ទូលដ៏ផ្អែមល្ហែមនៃព្រះ — សេចក្ដីសុចរិតនៃពួកសាសន៍លេមិន ខ្ពស់ជាងសេចក្ដីសុចរិតនៃពួក សាសន៍នីហ្វៃ — យ៉ាកុបព្រមានទាស់នឹងការកំផិត ការអាសអាភាស និងអំពើបាបគ្រប់បែបយ៉ាង ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

ប៉ុន្តែមើលចុះ ខ្ញុំ យ៉ាកុប ចង់និយាយទៅកាន់អ្នកទាំងឡាយ
ដែលមានចិត្តបរិសុទ្ធ ។ ចូរមើលទៅព្រះ ដោយមាន
គំនិតរឹងប៉ឹង ហើយ អធិស្ឋានដល់ព្រះអង្គ ដោយមានសេច
ក្ដីជំនឿដ៏លើសលប់ នោះទ្រង់នឹងលួងលោមដល់អ្នក ក្នុងគ្រា
ដែលអ្នកមានទុក្ខលំបាក ហើយទ្រង់ នឹងអង្វរដើម្បីប្រយោជន៍
របស់អ្នក ហើយនឹងទំលាក់សេចក្ដីយុត្តិធម៌មកធ្វើទោសពួកអ្នក
ណាដែលស្វែងរកបំផ្លាញអ្នក ។
២ ឱអ្នកដែលមានចិត្តបរិសុទ្ធទាំងអស់គ្នាអើយ ចូរងើបក្បា
លឡើង ហើយទទួលព្រះបន្ទូលដ៏ផ្អែមល្ហែមនៃព្រះ ហើយទទួល
ទាន នូវសេចក្ដីស្រឡាញ់របស់ទ្រង់ចុះ; ព្រោះបើសិនជាអ្នកមាន
គំនិតរឹងប៉ឹង នោះអ្នកនឹងបានទទួលការណ៍ទាំងនេះជរាបតទៅ ។
៣ ប៉ុន្តែ វេទនា វេទនា ដល់អ្នកណាដែលមិនមានចិត្តបរិសុទ្ធ
ដែលជាមនុស្សស្មោកគ្រោកនៅចំពោះព្រះនៅថ្ងៃនេះ; ត្បិតលើក
លែងតែអ្នកប្រែចិត្ត នោះដែនដីនេះនឹងត្រូវបណ្ដាសាពីព្រោះ
តែអ្នក; ឯពួកសាសន៍លេមិន ដែលមិនស្មោកគ្រោកដូចអ្នក
ទោះជាយ៉ាង ណាក៏ដោយ គង់តែពួកគេត្រូវបណ្ដាសាដ៏ធ្ងន់ដែរ
គឺពួកគេនឹងវាយអ្នក រហូតដល់សេចក្ដីបំផ្លិចបំផ្លាញបង់ ។
៤ ហើយពេលនោះនឹងមកដល់យ៉ាងឆាប់ៗ ហើយលើកលែងតែ
អ្នកប្រែចិត្ត នោះពួកគេនឹងបានដែនដីកេរ្តិ៍អាកររបស់អ្នក ហើយព្រះ
អម្ចាស់ដ៏ជាព្រះ ទ្រង់នឹងនាំពួកអ្នកសុចរិត ចេញពីចំណោម
ពួកអ្នក ។
៥ មើលចុះ ពួកសាសន៍លេមិន ជាបងប្អូនរបស់អ្នក ដែល
អ្នករាល់គ្នាស្អប់ ពីព្រោះតែការស្មោកគ្រោករបស់ពួកគេ
និងបណ្ដាសា ដែលបានធ្លាក់មកលើស្បែករបស់ពួកគេ នោះ
ពួកគេសុចរិតលើសពួកអ្នកវិញ; ព្រោះពួកគេពុំទាន់ភ្លេចព្រះ
បញ្ញត្តិនៃព្រះអម្ចាស់នៅឡើយ ដែលបានប្រទានដល់ឪពុក
របស់យើងឡើយ — ដែលថា ពួកគេត្រូវមានប្រពន្ធតែ
មួយប៉ុណ្ណោះ ហើយឯពួកស្រីស្នំក៏ពួកគេមិនត្រូវ មានសោះ
ហើយពុំត្រូវប្រព្រឹត្តអំពើសហាយស្មន់ទាំងឡាយ នៅក្នុង
ចំណោមពួកគេឡើយដែរ ។
៦ ហើយឥឡូវនេះ ព្រះបញ្ញត្តិនេះ ពួកគេប្រតិបត្តិតាម; ហេតុ
ដូច្នោះហើយ ដោយសារការគោរពតាមនេះ គឺក្នុងការកាន់
តាម ព្រះបញ្ញត្តិនេះ បានជាព្រះអម្ចាស់ដ៏ជាព្រះទ្រង់ពុំបំផ្លាញ
ពួកគេចោល តែទ្រង់នឹងមេត្តាករុណាដល់ពួកគេវិញ; ហើយនៅ
ថ្ងៃណាមួយ ពួកគេនឹងក្លាយទៅជាប្រជាជនមួយដ៏មានពរ ។
៧ មើលចុះ ពួកប្ដីៗរបស់គេស្រឡាញ់ប្រពន្ធរបស់ខ្លួន ឯពួក

៣៣ *ក* ស.ប. ខាងកាមរាគ, កាមរាគ; អំពើកាមរាគខុសច្បាប់.
៣៥ *ក* យ៉ាកុប ៣:៥–៧.
៣ ២ *ក* អាលម៉ា ៥៧:២៦–២៧.
៣ *ក* ស.ប. ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក.
*ខ* ១ នីហ្វៃ ១២:២៣.
៤ *ក* អោមណៃ ១:៥–៧, ១២–១៣.
៥ *ក* យ៉ាកុប (ពម.) ២:៣៥.
៦ *ក* ២ នីហ្វៃ ៤:៣, ៦–៧; ហេលេ. ១៥:១០–១៣.
៧ *ក* ស.ប. គ្រួសារ; សេចក្ដីស្រឡាញ់.

ប្រពន្ធៗរបស់គេ ស្រឡាញ់ប្ដីរបស់ខ្លួន; ហើយប្ដីប្រពន្ធរបស់គេ ស្រឡាញ់ កូនៗរបស់ខ្លួន; ឯការឥតជំនឿរបស់ពួកគេ និងការស្អប់របស់ពួកគេចំពោះអ្នកនោះ គឺមកពីអំពើទុច្ចរិតរបស់ពួកអយ្យកោគេទេតើ; ហេតុដូច្នោះហើយ ចុះតើអ្នករាល់គ្នាគ្រាន់បើជាងពួកគេប៉ុណ្ណាទៅ នៅចំពោះព្រះនេត្រនៃព្រះដ៏មហិមាដែលបង្កើតអ្នកមកនោះ ?

៨ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ លើកលែងតែអ្នករាល់គ្នាប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក បើពុំនោះសោតទេ ខ្ញុំខ្លាចតែ ស្បែករបស់ពួកគេ នឹងសជាងស្បែករបស់អ្នកទៅហើយ ក្នុងកាលអ្នកត្រូវបាននាំទៅជាមួយពួកគេ នៅចំពោះបល្ល័ង្កនៃព្រះ ។

៩ ហេតុដូច្នោះហើយ ខ្ញុំសូមប្រគល់ដល់អ្នកនូវព្រះបញ្ញត្តិមួយដែលជាព្រះបន្ទូលនៃព្រះ គឺចូរអ្នករាល់គ្នាកុំជេរប្រមាថពួកគេពីព្រោះតែស្បែកខ្មៅរបស់គេនោះឡើយ; ហើយចូរអ្នកកុំជេរប្រមាថពួកគេ ពីព្រោះតែសេចក្ដីស្មោកគ្រោករបស់ពួកគេដែរ; ប៉ុន្តែ អ្នករាល់គ្នាត្រូវនឹកចាំពីសេចក្ដីស្មោកគ្រោករបស់ខ្លួនវិញ ហើយចូរនឹកចាំថា សេចក្ដីស្មោកគ្រោករបស់ពួកគេ គឺមានមកពីព្រោះតែ ពួកអយ្យកោគេទេតើ ។

១០ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាត្រូវនឹកឃើញដល់[ក]កូនចៅរបស់អ្នកវិញ ពីរបៀបដែលអ្នកបានធ្វើឲ្យកូនចៅអ្នកកើតទុក្ខយ៉ាងណាទៅ ដោយសារតែគំរូដែលអ្នកបានធ្វើឲ្យគេមើល; ហើយក៏ចូរនឹកឃើញថា ពីព្រោះតែសេចក្ដីស្មោកគ្រោករបស់អ្នក នោះអ្នកអាចនាំកូនចៅរបស់អ្នក ទៅរកការបំផ្លិចបំផ្លាញ ហើយអំពើបាបទាំងឡាយរបស់គេ នឹងគរលើក្បាលអ្នកនៅគ្រាចុងក្រោយ បង្អស់វិញ ។

១១ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ចូរប្រុងស្ដាប់តាមពាក្យសំដីរបស់ខ្ញុំចុះ; ចូរដាស់សមត្ថភាពទាំងឡាយនៃព្រលឹងអ្នកឲ្យ[ក]ភ្ញាក់ ឡើង; ចូររលាស់ខ្លួនឲ្យភ្ញាក់ពីដំណេកដ៏យូរអង្វែងនៃសេចក្ដីស្លាប់; ហើយចូរដោះខ្លួនចេញពីការឈឺចាប់នៃ[ខ]ស្ថាននរក ដើម្បីកុំឲ្យខ្លួន អ្នករាល់គ្នាអាចក្លាយទៅជាពួក[គ]ទេវតារបស់អារក្ស ដែលនឹងត្រូវបោះទៅក្នុងបឹងភ្លើង និងស្ពាន់ធ័រនោះ គឺជា[ឃ]សេចក្ដីស្លាប់ទីពីរ ។

១២ ហើយឥឡូវនេះ ខ្ញុំ យ៉ាកុប បាននិយាយជាច្រើនការណ៍ទៀត ទៅប្រជាជននីហ្វៃ ហាមកុំឲ្យគេប្រព្រឹត្ត[ក]ការកំផិត និង[ខ]ការ អាសអាភាស និងអំពើបាបគ្រប់យ៉ាងឡើយ ដោយបានប្រាប់គេ នូវផលដ៏ធ្ងន់ធ្ងរ នៃអំពើទាំងនេះ ។

១៣ ហើយមួយភាគរយនៃដំណើរការរបស់ប្រជាជននេះគឺឥឡូវនេះ កាន់តែច្រើនឡើងៗ គឺមិនអាចយកមកកត់នៅលើផ្ទាំង [ក]ទាំងនេះបានអស់ឡើយ; ប៉ុន្តែដំណើរការរបស់គេជាច្រើន ត្រូវបានកត់នៅលើផ្ទាំងធំ ទាំងសង្គ្រាមទាំងឡាយរបស់គេ និងការ ទាស់ទែងគ្នាទាំងឡាយរបស់គេ និងការគ្រងរាជ្យនៃស្ដេចទាំងឡាយរបស់គេ ។

១៤ ផ្ទាំងទាំងនេះហៅថា ផ្ទាំងយ៉ាកុប គឺបានធ្វើដោយដៃនីហ្វៃ។ ហើយខ្ញុំសូមបញ្ចប់នូវការនិយាយពាក្យទាំងនេះត្រឹមនេះសិនចុះ ៕

## ជំពូកទី ៤

*ពួកព្យាការីទាំងអស់ថ្វាយបង្គំព្រះវរបិតា ដោយនូវព្រះនាមព្រះគ្រីស្ទ — ការដែលលោកអ័ប្រាហាំបូជាអ៊ីសាក គឺជានិមិត្តរូប អំពីព្រះ និងព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ដែរ — មនុស្សត្រូវស្រុះស្រួលនឹងព្រះ តាមរយៈដង្វាយធួន — ពួកសាសន៍យូដានឹង បដិសេធបាតថ្មគ្រឹះ ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

ឥឡូវនេះ មើលចុះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ យ៉ាកុប បានធ្វើការងារបំរើដល់ប្រជាជនខ្ញុំ ដោយពាក្យសំដីជាច្រើន (ហើយ ខ្ញុំមិនអាចកត់ពាក្យទាំងឡាយរបស់ខ្ញុំ លើកលែងតែពាក្យបន្តិចបន្តួចប៉ុណ្ណោះ ដោយមកពីការពិបាកឆ្លាក់ពាក្យយើងលើផ្ទាំង) ហើយយើងដឹងថា រឿងទាំងឡាយដែលយើងកត់នៅលើផ្ទាំង នឹងនៅគង់វង់តទៅ;

២ ប៉ុន្តែ រឿងទាំងឡាយដែលយើងកត់នៅលើវត្ថុផ្សេងទៀតក្រៅពីផ្ទាំងទាំងនេះ នឹងត្រូវវិនាស ហើយរលុបបាត់ទៅ; តែយើងកត់បានពាក្យខ្លះ នៅលើផ្ទាំង ដែលនឹងផ្ដល់ដល់កូនចៅយើង ហើយព្រមទាំងដល់បងប្អូនជាទីស្រឡាញ់របស់យើងផង នូវការចេះដឹងមួយកំរិតតូចអំពីយើង ឬអំពីពួកអយ្យកោរបស់គេ —

៣ ឥឡូវនេះ យើងអរីករាយនឹងការណ៍នេះ; ហើយយើងខំព្យាយាម ដើម្បីឆ្លាក់ពាក្យទាំងនេះ នៅលើផ្ទាំង ដោយសង្ឃឹមថា បងប្អូនជាទីស្រឡាញ់របស់យើង និងកូនចៅយើងនឹងទទួលពាក្យទាំងនេះ ដោយចិត្តអរគុណ ហើយគេមើលពាក្យ

១០ *ក* ស.ប. កូនក្មេង, ពួកកូនក្មេង.
១១ *ក* អាលម៉ា ៥:៦–៩.
*ខ* ស.ប. ស្ថាននរក.
*គ* ២ នីហ្វៃ ៩:៨–៩.
*ឃ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
១២ *ក* ស.ប. អំពើសហាយស្មន់.
*ខ* ស.ប. សំរេកស្រើប; ទុច្ចរិត, អំពើទុច្ចរិត.
១៣ *ក* ១ នីហ្វៃ ១៩:១–៤;
យ៉ាកុប ១:១–៤.

ទាំងនេះ ដើម្បីពួកគេអាចចេះដឹង ដោយសេចក្ដីអំណរ ហើយ
មិនមែនដោយសេចក្ដីសោកសៅ ឬដោយការមើលងាយ
ដល់ឪពុកម្ដាយដើម របស់គេនោះទេ ។
៤ ត្បិតព្រោះដោយគោលបំណងនេះហើយ ដែលយើងបាន
សរសេររឿងទាំងនេះ ដើម្បីឲ្យគេដឹងថា យើងបានដឹងអំពីព្រះគ្រីស្ទ
ហើយ យើងបានសង្ឃឹមដល់សិរីល្អរបស់ទ្រង់ ជាច្រើនរយឆ្នាំមុនទ្រង់
យាងមកម្ល៉េះ; ហើយមិនត្រឹមតែខ្លួនយើងបានសង្ឃឹមដល់
សិរីល្អរបស់ទ្រង់ ប៉ុណ្ណោះទេ គឺអស់ទាំងពួកព្យាការីដ៏បរិសុទ្ធ
ក៏បានសង្ឃឹមមុនយើងមកដែរ ។
៥ មើលចុះ ពួកគេបានជឿដល់ព្រះគ្រីស្ទ ហើយបានថ្វាយបង្គំព្រះ
វរបិតា ដោយនូវព្រះនាមទ្រង់ ឯយើងក៏ថ្វាយបង្គំព្រះវរបិតា
ដោយនូវព្រះនាមទ្រង់ដែរ។ ហើយព្រោះដោយគោលបំណងនេះ
ហើយ ដែលយើងកាន់តាមក្រិត្យវិន័យលោកម៉ូសេ
ពីព្រោះក្រិត្យ វិន័យនោះដឹកនាំព្រលឹងយើងរាល់គ្នាទៅរកទ្រង់;
ហើយដោយហេតុនេះហើយ ដែលក្រិត្យវិន័យនេះត្រូវបាន
ញែកជាបរិសុទ្ធដល់យើង ដើម្បីសេចក្ដីសុចរិត
គឺដូចជារឿងលោកអ័ប្រាហាំ កាលនៅក្នុងទីរហោស្ថាន ដែល
លោកធ្វើតាមព្រះបញ្ញត្តិនៃព្រះ ដោយបានបូជា អ៊ីសាក ជា
កូនប្រុសលោក ទុកជានិមិត្តរូបអំពីព្រះ និងព្រះរាជបុត្រាបង្កើត
តែមួយរបស់ទ្រង់ដែរ ។
៦ ហេតុដូច្នោះហើយ យើងពិចារណាមើលសេចក្ដីព្យាករណ៍នៃ
ពួកព្យាការី ហើយយើងមានវិវរណៈទាំងឡាយ និងវិញ្ញាណ
នៃការ ព្យាករណ៍; ហើយដោយមានទីបន្ទាល់អស់ទាំងនេះ
ទើបយើងមានសេចក្ដីសង្ឃឹម ហើយសេចក្ដីជំនឿរបស់យើង
ក៏ឥតញាប់ញ័រដែរ ដរាបដល់យើងច្បាស់ជាអាចបញ្ជា ដោយនូវ
ព្រះនាមនៃព្រះយេស៊ូវ ហើយគ្រប់ទាំងដើមឈើ ឬក៏ភ្នំ ហើយ
នឹងទឹករលកនៅក្នុងសមុទ្រ ក៏ធ្វើតាមបញ្ជាយើងដែរ ។
៧ ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអម្ចាស់ដ៏ជាព្រះ
ទ្រង់បានបង្ហាញយើងនូវភាពទន់ខ្សោយរបស់យើង ដើម្បីឲ្យ
យើងដឹងថា គឺដោយសារព្រះគុណ និងការបន្ទាបខ្លួនដ៏មហិមា
របស់ទ្រង់ចំពោះកូនចៅមនុស្ស ទើបយើងមានអំណាច ដើម្បីធ្វើនូវ
កិច្ចការទាំង នេះបាន ។
៨ មើលចុះ កិច្ចការទាំងឡាយនៃព្រះអម្ចាស់សុទ្ធតែធំ ហើយ
អស្ចារ្យមែន ។ ឯជំរៅនៃសេចក្ដីអាថ៌កំបាំងទាំងឡាយរបស់
ទ្រង់ ក៏ពុំអាចរកឃើញដែរ; ហើយមនុស្សគ្មានលទ្ធភាពនឹង
រកឃើញផ្លូវរបស់ទ្រង់បានអស់ឡើយ ។ ហើយគ្មានអ្នក
ណាម្នាក់ស្គាល់ផ្លូវទាំង ឡាយរបស់ទ្រង់ទេ លើកលែងតែបាន
សម្ដែងដល់អ្នកនោះប៉ុណ្ណោះ; ហេតុដូច្នោះហើយ ឱបងប្អូនរាល់
គ្នាអើយ ចូរកុំមើលងាយដល់ វិវរណៈទាំងឡាយនៃព្រះឡើយ ។
៩ ត្បិតមើលចុះ ដោយព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ នោះ
មានមនុស្សរស់នៅលើផ្ទៃផែនដីនេះ ឯផែនដីត្រូវបានបង្កើតឡើង
ដោយព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ដែរ ហេតុដូច្នោះហើយ
បើសិនជាព្រះទ្រង់គ្រាន់តែមានព្រះបន្ទូល ក៏ពិភពលោកកើត
មានឡើង ហើយទ្រង់គ្រាន់តែមានព្រះបន្ទូល នោះមនុស្ស
ក៏បានកើតឡើង ចុះតើហេតុអ្វីក៏ទ្រង់ មិនអាចចេញបញ្ជាដល់
ផែនដី ឬផលនៃព្រះហស្ដរបស់ទ្រង់ នៅលើផ្ទៃផែនដី
តាមព្រះហឫទ័យ និងបំណងរបស់ទ្រង់បាន ?
១០ ហេតុដូច្នោះហើយ ឱបងប្អូនរាល់គ្នាអើយ ចូរកុំចង់ទូន្មាន
ដល់ព្រះអម្ចាស់ឡើយ តែចូរទទួលដំបូន្មានពីព្រះហស្ដរបស់
ទ្រង់វិញ ។ ត្បិតមើលចុះ អ្នករាល់គ្នាដឹងហើយថា ទ្រង់ទូន្មាន
ក្នុងប្រាជ្ញា សេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណាដ៏ធំធេង
នៅលើគ្រប់ទាំងកិច្ចការ ទាំងអស់របស់ទ្រង់ ។
១១ ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់អើយ
ចូរស្រុះស្រួលនឹងទ្រង់ទៅតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ គឺជា

៤ ៤*ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* លូកា ២៤:២៥–២៧;
យ៉ាកុប ៧:១១;
ម៉ូសាយ ១៣:៣៣–៣៥;
គ. និង ស. ២០:២៦.
៥ *ក* ម៉ូសេ ៥:៨.
*ខ* ២ នីហ្វៃ ២៥:២៤; យ៉ារ៉ុម ១:១១;
ម៉ូសាយ ១៣:២៧, ៣០;
អាលម៉ា ២៥:១៥–១៦.
ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*គ* កាឡាទី ៣:២៤.
*ឃ* លោកុ. ២២:១–១៤;
យ៉ូហាន ៣:១៦–១៨.
ស.ប. បង្កើតតែមួយ.
៦ *ក* ស.ប. ការព្យាករណ៍, ព្យាករ.
*ខ* ស.ប. សាក្សី.
*គ* ស.ប. អំណាច.
*ឃ* កិច្ចការ ៣:៦–១៦; ៣ នីហ្វៃ ៨:១.
៧ *ក* អេធើរ ១២:២៧.
៨ *ក* រ៉ូម ១១:៣៣–៣៦.
*ខ* គ. និង ស. ១៩:១០; ៧៦:១១៤.
ស.ប. សេចក្ដីអាថ៌កំបាំងទាំង
ឡាយនៃព្រះ.
*គ* ១ កូរិន. ២:៩–១៦;
អាលម៉ា ២៦:២១–២២.
ស.ប. ដំរិះ.
*ឃ* អេសាយ ៥៥:៨–៩.
៩ *ក* មរមន ៩:១៧; ម៉ូសេ ១:៣២.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត;
មនុស្ស, មនុស្សលោក.
*គ* ហេលេ. ១២:៨–១៧.
១០ *ក* ២ នីហ្វៃ ៩:២៨–២៩;
អាលម៉ា ៣៧:១២, ៣៧;
គ. និង ស. ៣:៤, ១៣.
*ខ* ស.ប. ព្រះដ៏ជ្រាបសព្វសារពើ; ប្រាជ្ញា.
១១ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.

[ខ]ព្រះរាជ បុត្រាបង្កើតតែមួយរបស់ទ្រង់ នោះអ្នកអាចបាន
ទទួល[ក]ដំណើររស់ឡើងវិញ តាមរយៈអំណាចនៃដំណើររស់ឡើងវិញ
ដែលនៅក្នុង ព្រះគ្រីស្ទ ហើយត្រូវថ្វាយដល់ព្រះ [ឃ]ជាផលដំបូង
នៃព្រះគ្រីស្ទ ដោយមានសេចក្ដីជំនឿ ហើយបានទទួលសេចក្ដី
សង្ឃឹមដ៏ប្រសើរ នៃសិរីល្អដែលនៅក្នុងទ្រង់ មុនពេលទ្រង់នឹង
សម្ដែងរូបអង្គទ្រង់នៅក្នុងសាច់ឈាម ។
១២ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់អើយ សូមកុំ
ឆ្ងល់ថា ហេតុអ្វីបានជាខ្ញុំប្រាប់អ្នកនូវរឿងទាំងនេះឡើយ;
ព្រោះហេតុអ្វី បានជាមិន[ក]និយាយអំពីដង្វាយធួននៃព្រះគ្រីស្ទ ហើយ
ទទួលការចេះដឹងដោយឥតខ្ចោះអំពីព្រះអង្គ ក៏ដូចជាបានទទួល
ការចេះដឹងអំពី ដំណើររស់ឡើងវិញ និងអំពីពិភពលោកខាង
មុខនេះផង ?
១៣ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ អ្នកណា
ដែលព្យាករ សូមឲ្យគាត់ព្យាករ ដើម្បីឲ្យមនុស្សផងទាំងឡាយ
បានយល់; ព្រោះ[ក]ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលតែការពិត
ហើយមិនកុហកឡើយ ។ ហេតុដូច្នោះហើយ ព្រះវិញ្ញាណ
ទ្រង់មានព្រះបន្ទូលអំពី រឿងទាំងឡាយ តាមដែល
[ខ]មាននៅពេលនេះ ហើយអំពីរឿងទាំងឡាយ តាមដែលនឹង
មាននៅពេលខាងមុខ; ហេតុដូច្នោះហើយ រឿងទាំងនេះត្រូវ
បានសម្ដែងដល់យើង[គ]យ៉ាងច្បាស់ សំរាប់ការសង្គ្រោះដល់
ព្រលឹងយើង ។ ប៉ុន្តែមើលចុះ ពុំមែនមានតែយើងប៉ុណ្ណោះ ទេ
ដែលជាសាក្សីក្នុងរឿងនេះ; ត្បិតព្រះទ្រង់ក៏បានប្រាប់រឿង
ទាំងនេះ ដល់ពួកព្យាការីពីជំនាន់ដើមដែរ ។
១៤ ប៉ុន្តែមើលចុះ ពួកសាសន៍យូដាជាមនុស្ស[ក]រឹងក្បាល; ហើយ
ពួកគេបាន[ខ]មើលងាយដល់ព្រះបន្ទូលដ៏ច្បាស់លាស់ទាំងនេះ ហើយ
បានសម្លាប់ពួកព្យាការី ហើយបានស្វែងរករឿងទាំងឡាយ ដែល
ពួកគេមិនអាចយល់ ។ ហេតុដូច្នោះហើយ ព្រោះមកពី[គ]ការ
ខ្វាក់ របស់ពួកគេ គឺជាការខ្វាក់ដោយមើលហួសទីដៅ នោះ
ពួកគេត្រូវតែរលំ; ត្បិតព្រះទ្រង់បានដកយកភាពដ៏ច្បាស់លាស់
របស់ទ្រង់ចេញ ពីគេហើយ ហើយបានប្រទានឲ្យពួកគេនូវអ្វី
ជាច្រើន ដែលពួកគេ[ឃ]ពុំអាចយល់វិញ ពីព្រោះពួកគេជ្រាថ្នាចង់
បានការណ៍នោះ ។ ហើយពីព្រោះពួកគេប្រាថ្នាចង់បានការណ៍
នោះ ទើបព្រះទ្រង់បានធ្វើការនោះ ដើម្បីឲ្យពួកគេ
អាចជំពប់ដួល ។
១៥ ហើយឥឡូវនេះ ខ្ញុំ យ៉ាកុប ត្រូវបានព្រះវិញ្ញាណបណ្ដាលឲ្យ
ព្យាករ; ត្បិតខ្ញុំយល់ឃើញថា ដោយសារការងារនៃព្រះវិញ្ញាណ
ដែលមាននៅក្នុងខ្លួនខ្ញុំ គឺដោយ[ក]ការជំពប់ដួលរបស់ពួកសាសន៍
យូដា នោះពួកគេនឹងមិនទទួល[ខ]ស្គាល់[គ]ថ្ម ដែលពួកគេអាចសាង
ហើយមានគ្រឹះដ៏ជាប់លួមុតទេ ។
១៦ ប៉ុន្តែមើលចុះ ស្របតាមបទព្រះគម្ពីរទាំងឡាយ [ក]ថ្មនេះ
នឹងក្លាយទៅជា[ខ]គ្រឹះតែមួយដ៏ប្រសើរ ហើយចុងក្រោយបង្អស់
ហើយមាំមួន ដែលពួកសាសន៍យូដាអាចសាងលើ ។
១៧ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
បន្ទាប់ពីមិនទទួលស្គាល់គ្រឹះដ៏មាំមួននោះហើយ ចុះតើធ្វើម្ដេច
ឲ្យគេ[ក]នឹងអាចសាងនៅលើនោះ ដើម្បីឲ្យវាក្លាយទៅជាគោលសី
មានៃផ្ទះគេបាន ?
១៨ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំនឹង
លាតត្រដាងការអាថ៌កំបាំងនេះដល់អ្នក; បើសិនជាខ្ញុំមិន
លាតត្រដាង ដោយមធ្យោបាយណាមួយទេ នោះអ្វីៗ
នឹងត្រូវញ័រពីការខ្ជាប់ខ្ជួនរបស់ខ្ញុំ នៅក្នុងព្រះវិញ្ញាណ
ហើយជំពប់ដួល ដោយសារតែ សេចក្ដីបារម្ភដ៏លើសលប់
របស់ខ្ញុំដល់អ្នក ៕

## ជំពូកទី ៥

*យ៉ាកុបដកស្រង់ពាក្យរបស់លោកស៊ីណូស ស្ដីអំពីរូបាធិដ្ឋាន នៃដើមអូលីវស្រុក និងដើមអូលីវព្រៃ — វាមានដំណើរដូច សាសន៍ អ៊ីស្រាអែល និងពួកសាសន៍ដទៃ — ការខ្ចាត់ព្រាត់*

១១ *ខ* ហេព្រើរ ៥:៩.
*ក* ស.ប. ដំណើររស់ឡើងវិញ.
*ឃ* ម៉ូសាយ ១៥:២១–២៣; ១៨:៩;
អាលម៉ា ៤០:១៦–២១.
១២ *ក* ២ នីហ្វៃ ២៥:២៦.
១៣ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ;
សេចក្ដីពិត.
*ខ* គ. និង ស. ៩៣:២៤.
*គ* អាលម៉ា ១៣:២៣.
១៤ *ក* ម៉ាថាយ ២៣:៣៧–៣៨;
២ នីហ្វៃ ២៥:២.
*ខ* ២ កូរិន. ១១:៣;
១ នីហ្វៃ ១៩:៧;
២ នីហ្វៃ ៣៣:២.
*គ* អេសាយ ៤៤:១៨;
រ៉ូម ១១:២៥.
*ឃ* ២ នីហ្វៃ ២៥:១–២.
១៥ *ក* អេសាយ ៨:១៣–១៥;
១ កូរិន. ១:២៣;
២ នីហ្វៃ ១៨:១៣–១៥.
*ខ* ១ នីហ្វៃ ១០:១១.
*គ* ស.ប. ថ្មជ្រុង; ថ្ម.
១៦ *ក* ទំនុក. ១១៨:២២–២៣.
*ខ* អេសាយ ២៨:១៦;
ហេលេ. ៥:១២.
១៧ *ក* ម៉ាថាយ ១៩:៣០;
គ. និង ស. ២៩:៣០.

*និងការប្រមូលនៃសាសន៍អ៊ីស្រាអែលបានឃើញជាមុន — ពាក្យទាំងឡាយដែល និយាយសំដៅទៅលើពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ហើយនឹងវង្សអ៊ីស្រាអែលទាំងអស់ — ពួកសាសន៍ដទៃនឹងបានបំបៅជាប់ ទៅជាមួយនឹងសាសន៍អ៊ីស្រាអែល — ទីបញ្ចប់ ចំការនឹងត្រូវឆេះជាមិនខានឡើយ ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ចុះតើអ្នកមិនចាំទេឬថា អ្នកបានអានពាក្យរបស់ព្យាការីស៊ីណូស ដែលបានពោលទៅវង្សអ៊ីស្រាអែលថា៖

២ ចូរប្រុងស្ដាប់ ឱវង្សអ៊ីស្រាអែលអើយ ចូរស្ដាប់ពាក្យទាំងឡាយរបស់ខ្ញុំ ជាព្យាការីនៃព្រះអម្ចាស់ ។

៣ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ឱវង្សអ៊ីស្រាអែលអើយ យើងនឹងប្រៀបធៀបអ្នកទៅនឹងដើមអូលីវស្រុក ដែលបុរសម្នាក់បានយកមកដាំ ឲ្យដីជាតិនៅក្នុងចំការរបស់គាត់; ហើយដើមនោះបានដុះឡើង ហើយចាស់ទៅ ហើយក៏ចាប់ផ្ដើមពុក ។

៤ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការចេញមក ក៏ឃើញដើមអូលីវរបស់គាត់ ចាប់ផ្ដើមពុក; គាត់ក៏និយាយថា៖ យើងនឹងកាត់លួសវា ហើយជ្រួយគល់វា ហើយដាក់ជីវា ក្រែងវានឹងដុះមែកទន់ខ្ចី ហើយពុំងាប់ ។

៥ ហើយហេតុការណ៍បានកើតឡើងថា គាត់កាត់លួសវា ហើយជ្រួយគល់វា ហើយដាក់ជីវា ស្របតាមពាក្យរបស់គាត់ ។

៦ ហើយហេតុការណ៍បានកើតឡើងថា ជាច្រើនថ្ងៃកន្លងមក ដើមនោះក៏ចាប់ផ្ដើមដុះមែកទន់ខ្ចីខ្លះៗ; ប៉ុន្តែមើលចុះ មែកធំរបស់វាក៏ ចាប់ផ្ដើមងាប់ទៅ ។

៧ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបានឃើញដូច្នេះ ក៏និយាយទៅអ្នកបំរើរបស់គាត់ថា៖ យើងព្រួយចិត្តដែលយើង ត្រូវខាតបង់ដើមឈើនេះទៅ; ហេតុដូច្នោះហើយ ចូរអ្នកទៅរកមែកអូលីវព្រៃយកមកឲ្យយើង; ហើយយើងនឹងកាត់មែកធំ ដែលកំពុង ស្វិតទៅនោះចេញ ហើយយើងនឹងបោះវាទៅក្នុងភ្លើងឲ្យឆេះ ។

៨ ហើយមើលចុះ ម្ចាស់ចំការនិយាយថា យើងកាត់មែកដ៏ទន់ខ្ចីទាំងនេះចេញជាច្រើន ហើយយើងនឹងយកវាទៅបំបៅជាប់នៅត្រង់ណាតាមដែលយើងពេញចិត្ត; ហើយបើឫសឈើនេះងាប់ទៅក៏មិនទាស់អ្វីដែរ នោះយើងអាចរក្សាផ្លែវាទុកសំរាប់ខ្លួនយើងវិញ; ហេតុដូច្នោះហើយ យើងនឹងយកមែកដ៏ទន់ខ្ចីៗទាំងនេះ ហើយយើងនឹងបំបៅជាប់នៅត្រង់ណា តាមដែលយើងពេញចិត្ត ។

៩ ចូរអ្នកយកមែកអូលីវព្រៃ ហើយបំបៅជាប់ជំនួសវិញចុះ; ហើយមែកទាំងឡាយដែលយើងកាត់ចេញ យើងនឹងបោះវាចោលទៅ ក្នុងភ្លើង ហើយដុតវា ដើម្បីកុំឲ្យវាវាតទីនៅក្នុងចំការរបស់យើង ។

១០ ហើយហេតុការណ៍បានកើតឡើងថា អ្នកបំរើរបស់ម្ចាស់ចំការនោះ ក៏បានធ្វើតាមពាក្យនៃម្ចាស់ចំការ ហើយបានបំបៅជាប់មែក អូលីវព្រៃ ។

១១ ហើយម្ចាស់ចំការ បានប្រើឲ្យជ្រួយគល់ ហើយកាត់លួស ហើយដាក់ជីឲ្យដើមនោះ ដោយនិយាយទៅអ្នកបំរើថា៖ យើងព្រួយ ចិត្តដែលយើងត្រូវខាតបង់ដើមឈើនេះទៅ; ហេតុដូច្នោះហើយ យើងបានធ្វើការនេះ ក្រែងយើងអាចរក្សាឫសវាទុកកុំឲ្យងាប់ ក្រែងយើងអាចរក្សាវាទុកសំរាប់ខ្លួនយើងវិញ ។

១២ ហេតុដូច្នោះហើយ ចូរអ្នកទៅថែទាំដើមឈើ ហើយដាក់ជីឲ្យវា តាមពាក្យទាំងឡាយរបស់យើងទៅ ។

១៣ ហើយយើងនឹងដាក់មែកឈើទាំងនេះ នៅទីទំនាបបំផុតនៅក្នុងចំការយើង ត្រង់ទីណាតាមដែលយើងពេញចិត្ត វាមិនទាស់អ្វីដល់អ្នកទេ; ហើយយើងធ្វើការនេះ ដើម្បីយើងអាចរក្សាទុកសំរាប់ខ្លួនយើង នូវមែកធម្មជាតិនៃដើមឈើនោះ; ហើយម៉្យាងទៀត គឺដើម្បីយើងអាចប្រមូលផ្លែរបស់វាទុកបំរុងរដូវអត់ទុកសំរាប់ខ្លួនយើង; ត្បិតយើងព្រួយចិត្ត ដែលយើងត្រូវខាតបង់ដើមឈើនេះទៅ ព្រមទាំងផ្លែវាផង ។

១៤ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបានទៅ ហើយលាក់មែកធម្មជាតិនៃដើមអូលីវស្រុក នៅត្រង់ទីទាបបំផុតនៃ ចំការ ត្រង់នេះបន្តិច ត្រង់នោះបន្តិច ស្របតាមចំណង់ និងការគាប់ចិត្តរបស់គាត់ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា រយៈពេលដ៏យូរបានកន្លងផុតទៅ ហើយម្ចាស់ចំការនិយាយទៅអ្នកបំរើរបស់គាត់ថា៖ តោះ ចូរយើងចុះទៅក្នុងចំការ ដើម្បីយើងអាចធ្វើការក្នុងចំការ ។

**៥** ១*ក* ស.ប. ស៊ីណូស.
៣ *ក* អេសេ. ៣៦:៨.
ស.ប. អ៊ីស្រាអែល.
*ខ* រ៉ូម ១១:១៧–២៤.
ស.ប. ដើមអូលីវ.
*គ* គ. និង ស. ១០១:៤៤.
ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*ឃ* ស.ប. សេចក្ដីក្បត់សាសនា.
៧ *ក* រ៉ូម ១១:១៧, ២៤.
៩ *ក* រ៉ូម ១:១៣.
១០ *ក* ស.ប. ពួកសាសន៍ដទៃ.
១៣ *ក* ១ នីហ្វៃ ១០:១២.

១៦ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការព្រមទាំងអ្នកបំរើ បានចុះទៅធ្វើការក្នុងចំការ ។ ហើយហេតុការណ៍បានកើត ឡើងថា អ្នកបំរើបាននិយាយទៅកាន់ម្ចាស់គាត់ថាៈ មើលចុះ សូមលោកមើលទីនេះ; សូមមើលដើមឈើនេះ ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការមើលទៅ ក៏ឃើញដើមឈើ ដែលគាត់បានយកមែកអូលីវព្រៃមកបំបៅជាប់ នោះ បានលូតលាស់ ហើយចាប់ផ្ដើមចេញផ្លែ ហើយគាត់ឃើញថាល្អ ឯផ្លែវាក៏ដូចជាផ្លែធម្មជាតិដែរ ។

១៨ ហើយគាត់និយាយទៅកាន់អ្នកបំរើថាៈ មើលចុះ មែកឈើព្រៃទាំងនេះ បានទទួលជីជាតិទឹកពីឫស គឺឫសបានផ្ដល់កម្លាំងយ៉ាង សំបើម; ហើយដោយសារកម្លាំងយ៉ាងសំបើមនៃឫស ទើបមែកព្រៃទាំងនេះ បានផ្ដល់ផ្លែល្អ ។ ឥឡូវនេះ បើសិនជាយើងមិនបានបំបៅ ជាប់មែកទាំងនេះទេ ដើមនោះច្បាស់ជាងាប់ទៅហើយ ។ ហើយឥឡូវនេះ មើលចុះ យើងនឹងបានផ្លែជាច្រើន ដែលដើមនោះបាន ផ្ដល់មក; ហើយផ្លែទាំងនោះ យើងនឹងប្រមូលផ្លែវាទុកបំរុងរដូវអត់ ទុកសំរាប់ខ្លួនយើងផ្ទាល់ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការនិយាយទៅអ្នកបំរើថាៈ តោះ ចូរយើងទៅ កន្លែងទំនាបបំផុតនៃចំការ ហើយ មើលតើមែកធម្មជាតិទាំងឡាយរបស់ដើមនោះ មានផ្ដល់ផ្លែច្រើនដែរឬទេ ដើម្បីយើងអាចប្រមូលផ្លែទាំងនោះទុកបំរុងរដូវអត់ ទុក សំរាប់ខ្លួនយើងផ្ទាល់ ។

២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចេញទៅឯកន្លែង ដែលម្ចាស់ចំការបានលាក់មែកធម្មជាតិនៃដើមនោះ ហើយគាត់បាននិយាយទៅអ្នកបំរើថាៈ ចូរមើលដើមឈើទាំងនេះ ហើយគាត់បានឃើញថា ដើមទីមួយមានផ្លែជាច្រើន; ហើយគាត់ ក៏ឃើញថា ផ្លែទាំងនោះល្អណាស់ ។ ហើយគាត់បាននិយាយទៅអ្នកបំរើថាៈ ចូរអ្នកបេះផ្លែទាំងនេះ ហើយប្រមូលទុកបំរុងរដូវអត់ ដើម្បីយើងអាចរក្សាវាទុកសំរាប់ខ្លួនយើងផ្ទាល់; គាត់បាននិយាយថា ត្បិតមើលចុះ យើងបានថែឈើនេះជាយូរមកហើយ ហើយវាបាន ផ្ដល់ផ្លែជាច្រើន ។

២១ ហើយហេតុការណ៍បានកើតឡើងថា អ្នកបំរើបាននិយាយទៅម្ចាស់របស់គាត់ថាៈ ហេតុអ្វីបានជាលោកមកដាំឈើនេះ ឬក៏មែក នេះត្រង់ណោះ? ត្បិតមើលចុះ ទីនេះជាដីអន់បំផុតនៅក្នុងចំការរបស់លោក ។

២២ ហើយម្ចាស់ចំការបាននិយាយទៅគាត់ថាៈ ចូរអ្នកកុំប្រដៅយើង យើងដឹងហើយថាទីនេះ ជាទីដែលមានដីអន់; ហេតុដូច្នោះ ហើយ ទើបយើងបានប្រាប់អ្នកថា យើងបានថែដើមនេះអស់ពេលជាយូរយ៉ាងនេះ ទើបអ្នកបានឃើញថាវាបានផ្ដល់ផ្លែជាច្រើន ។

២៣ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាននិយាយទៅអ្នកបំរើរបស់គាត់ថាៈ ចូរមើលទីនេះ មើលយើងបានដាំមែក មួយទៀតនៃឈើនោះដែរ; ហើយអ្នកដឹងថា ដីត្រង់នេះអន់ជាងកន្លែងមុននោះទៅទៀត ។ ប៉ុន្តែចូរមើលដើមនេះ យើងបានថែវាជា យូរមកហើយ ហើយវាបានផ្ដល់ផ្លែជាច្រើន; ហេតុដូច្នេះហើយ ចូរបេះផ្លែទាំងនេះ ហើយប្រមូលទុកបំរុងរដូវអត់ ដើម្បីយើងអាចរក្សា វាទុក សំរាប់ខ្លួនយើងផ្ទាល់ ។

២៤ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាននិយាយទៅអ្នកបំរើរបស់គាត់ទៀតថាៈ ចូរមើលទីនេះ មើលមែកមួយ ទៀត ដែលយើងបានដាំ; មើលចុះ យើងក៏បានថែវាដែរ ហើយវាក៏បានផ្ដល់ផ្លែ ។

២៥ ហើយគាត់បាននិយាយទៅអ្នកបំរើថាៈ ចូរមើលទីនេះ ហើយមើលមែកចុងក្រោយនេះ មើលចុះ យើងបានដាំវានៅត្រង់ទីមួយ ដែលមានដីល្អ ហើយយើងបានថែវាអស់ពេលជាយូរដល់ម្ល៉េះ ហើយមានតែមួយភាគនៃដើមនេះប៉ុណ្ណោះ ដែលបានផ្ដល់ផ្លែល្អ ឯមួយ ភាគនៃដើមនេះទៀតបានផ្ដល់ផ្លែព្រៃ; មើលចុះ យើងបានថែដើមនេះ ដូចជាដើមឯទៀតដែរ ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាននិយាយទៅអ្នកបំរើថាៈ ចូរកាត់មែកទាំងឡាយដែលគ្មានផ្លែ ហើយបោះ វាទៅក្នុងភ្លើងចុះ ។

២៧ ប៉ុន្តែមើលចុះ អ្នកបំរើបាននិយាយទៅគាត់ថាៈ ចូរយើងកាត់លួសវា ហើយជួយគល់វា ហើយដាក់ជីវាបន្តិចទៀតមើលក្រែង វាអាចផ្ដល់ផ្លែល្អជូនលោក ដើម្បីលោកអាចប្រមូលវាទុកបំរុងរដូវអត់ ។

២៨ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការព្រមទាំង

១៧ *ក* យ៉ូហាន ១៥:១៦.
២០ *ក* យ៉ាកុប ៥:៣៩.
២៤ *ក* អេសេ. ១៧:២២–២៤;
អាលម៉ា ១៦:១៧;
៣ នីហ្វៃ ១៥:២១–២៤.
២៥ *ក* ១ នីហ្វៃ ២:២០.
*ខ* ៣ នីហ្វៃ ១០:១២–១៣.
២៦ *ក* ម៉ាថាយ ៧:១៥–២០;
អាលម៉ា ៥:៣៦;
គ. និង ស. ៩៧:៧.

អ្នកបំរើរបស់ម្ចាស់ចំការ ក៏បានដាក់ជីដល់ដើមទាំងអស់នៅ
ក្នុងចំការនោះ ។
២៩ ហើយហេតុការណ៍បានកើតឡើងថា ពេលដ៏យូរបាន
កន្លងផុតទៅ ហើយម្ចាស់ចំការបាននិយាយ ទៅអ្នកបំរើរបស់
គាត់ថា៖ តោះ ចូរយើងចុះទៅក្នុងចំការ ដើម្បីយើងអាចធ្វើ
ការក្នុងចំការនោះទៀត ។ ត្បិតមើលចុះ ពេលវេលាជិតមក
ដល់ហើយ ហើយទីបញ្ចប់ នឹងមកដល់ក្នុងពេលដ៏ខ្លីនេះ;
ហេតុដូច្នោះហើយ យើងត្រូវប្រមូលផ្លែទុកបំរុងរដូវអត់
ទុកសំរាប់ខ្លួនយើងផ្ទាល់ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការ និងអ្នក
បំរើក៏ចុះទៅក្នុងចំការ; ហើយពួកគេទៅដល់ដើម ដែលពីមុនគេ
បានកាត់មែកធម្មជាតិវាចេញ ហើយបានយកមែកព្រៃមក
បំបៅជាប់វិញ; ហើយបានឃើញផ្លែគ្រប់យ៉ាងធ្ងន់ដាបមែក ។
៣១ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាន
ភ្លក់ផ្លែឈើមើល គឺគ្រប់មុខតាមលំដាប់របស់វា ។ ហើយ
គាត់បាន និយាយថា៖ មើលចុះ យើងបានថែដើមនេះ
អស់ពេលដ៏យូរ ហើយយើងបានប្រមូលទុកសំរាប់ខ្លួនយើងនូវ
ផ្លែជាច្រើន ទុកបំរុងរដូវអត់ ។
៣២ ប៉ុន្តែមើលចុះ ពេលនេះវាបានផ្តល់ផ្លែជាច្រើន តែគ្មាន
ផ្លែណាមួយល្អសោះឡើយ ។ ហើយមើលចុះ មានផ្លែឈើ
អាក្រក់គ្រប់ មុខ; ហើយវាគ្មានប្រយោជន៍អ្វីដល់យើងទេ ទោះ
យើងបានចំណាយកម្លាំង អស់ជាច្រើនក៏ដោយ; ហើយឥឡូវនេះ
យើងព្រួយចិត្តដែល យើងត្រូវខាតបង់ដើមនេះទៅ ។
៣៣ ហើយម្ចាស់ចំការបាននិយាយទៅអ្នកបំរើថា៖ ចុះតើយើង
ត្រូវធ្វើយ៉ាងណាដល់ដើមនេះ ដើម្បីឲ្យយើងអាចរក្សាផ្លែល្អឡើង
ទុកសំរាប់ខ្លួនយើងផ្ទាល់ ?
៣៤ ហើយអ្នកបំរើបាននិយាយទៅម្ចាស់របស់គាត់ថា៖ មើលចុះ
ពីព្រោះលោកបានយកមែកអូលីវព្រៃមកបំបៅជាប់ មែកទាំង
នោះបានថែឫសឲ្យរស់ ហើយពុំត្រូវងាប់; ហេតុដូច្នោះហើយ
ទើបលោកបានឃើញថា ដើមទាំងនោះល្អនៅឡើយ ។
៣៥ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាន
និយាយទៅអ្នកបំរើរបស់គាត់ថា៖ ដើមឈើនេះគ្មានប្រយោជន៍អ្វី
ដល់ យើងសោះឡើយ ហើយឫសវាក៏គ្មានប្រយោជន៍អ្វី
ដល់យើងដែរ បើវាចេះតែមានផ្លែអាក្រក់យ៉ាងនេះ ។
៣៦ ទោះជាយ៉ាងណាក៏ដោយ គង់តែយើងដឹងថា
ឫសទាំងនេះល្អ ហើយយើងបានរក្សាវាទុក គឺដោយគោ
លបំណងផ្ទាល់ របស់យើង; ហើយដោយវាមានកម្លាំងយ៉ាង
សំបើម នោះវាបានផ្តល់មកដល់ពេលនេះ នូវផ្លែល្អដែលចេញ
មកពីមែកព្រៃ ។
៣៧ ប៉ុន្តែមើលចុះ មែកព្រៃទាំងនេះបានលូតលាស់ ហើយ
បានរាលដាលទៅលើឫស; ហើយដោយមកពីមែកព្រៃទាំងនេះ
បានឈ្នះ លើឫស នោះដើមនេះបានផ្តល់ផ្លែអាក្រក់ជាច្រើន
ហើយដោយមកពីវាបានផ្តល់ផ្លែអាក្រក់ជាច្រើន នោះអ្នកឃើញថា
វាចាប់ផ្តើមងាប់ ទៅ; ហើយវានឹងទុំក្នុងពេលដ៏ខ្លីនេះហើយ
ដែលនឹងត្រូវបោះចោលទៅក្នុងភ្លើង លើកលែងតែយើងធ្វើ
អ្វីដើម្បីរក្សាវាទុក ។
៣៨ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាន
និយាយទៅអ្នកបំរើរបស់គាត់ថា៖ ចូរយើងចុះទៅក្នុងកន្លែង
ទំនាបបំផុត នៃចំការ ហើយមើលតើមែកធម្មជាតិទាំងឡាយ
បានផ្តល់ផ្លែអាក្រក់ដែរឬអី ។
៣៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចុះទៅ
ក្នុងកន្លែងទំនាបបំផុតនៃចំការ ។ ហើយហេតុការណ៍
បានកើតឡើងថា ពួកគេបានឃើញថា ផ្លែទាំងឡាយនៃមែក
ធម្មជាតិទាំងនោះ រលួយអស់រលីងទៅដែរ; មែនហើយ ទាំង
មែកទីមួយ និងទីពីរ និងមែកចុងក្រោយបង្អស់ផងដែរ;
ហើយវាសុទ្ធតែរលួយទាំងអស់ទៅ ។
៤០ ឯផ្លែព្រៃ នៃមែកចុងក្រោយបង្អស់បានដុះឈ្នះលើផ្នែក
នៃដើម ដែលបានផ្តល់ផ្លែល្អ គឺមែកនោះស្វិត ហើយងាប់ទៅ ។
៤១ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការយំ
ហើយនិយាយទៅអ្នកបំរើថា៖ ចុះតើយើង ត្រូវធ្វើអ្វីទៀតដល់
ចំការរបស់ យើងហ្ន៎ ?
៤២ មើលចុះ យើងបានដឹងថា ផ្លែឈើទាំងអស់នៅក្នុង
ចំការ លើកលែងផ្លែទាំងនេះ នោះបានរលួយអស់ទៅ ។
ហើយឥឡូវនេះ ផ្លែទាំងនេះដែលធ្លាប់ជាផ្លែល្អ ក៏បានក្លាយ
ទៅជារលួយអស់ដែរ; ហើយឥឡូវនេះ ដើមទាំងអស់ក្នុង
ចំការរបស់យើង គ្មានប្រយោជន៍អ្វី សោះឡើយ ក្រៅពីត្រូវ
កាប់រំលំ ហើយបោះចោលទៅក្នុងភ្លើងប៉ុណ្ណោះ ។
៤៣ ហើយចូរមើលដើមចុងក្រោយបង្អស់នេះ ដែលមាន

២៩ *ក* គ. និង ស. ១០១:៥៥; ១០៣:២១.
*ខ* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
*គ* ២ នីហ្វៃ ៣០:១០; យ៉ាកុប ៦:២.
៣០ *ក* ស.ប. សេចក្តីក្បត់សាសនា.
៣២ *ក* យ.ស. – ប្រវត្តិ ១:១៩.
៣៧ *ក* គ. និង ស. ៤៥:២៨–៣០.
៣៩ *ក* យ៉ាកុប ៥:២០, ២៣, ២៥.
៤០ *ក* មរមន ៦:៦–១៨.
៤១ *ក* ២ នីហ្វៃ ២៦:២៤.

មែកស្វិតទៅ នោះយើងបានដាំនៅលើកន្លែងដ៏ល្អ; មែនហើយ
គឺជាដី ជំរើសរបស់យើង លើដីផ្សេងៗទៀត នៅក្នុងចំការ
របស់យើង ។
៤៤ ហើយអ្នកបានឃើញថា យើងបានកាប់ដើមផ្សេងទៀតដែរ
ដែលប្រជ្រៀតកន្លែងនេះ ដើម្បីយកកន្លែងដាំដើមនេះវិញ ។
៤៥ ហើយអ្នកបានឃើញថា ដើមនោះមានមួយផ្នែកបាន
ផ្តល់ផ្លែល្អ ឯមួយផ្នែកទៀតផ្តល់ផ្លែព្រៃ; ហើយដោយយើងមិន
បានកាត់មែក ទាំងនោះ ហើយបោះចោលទៅក្នុងភ្លើងទៅ មើលចុះ
វាបានរាលមកលើមែកល្អវិញ ធ្វើឲ្យមែកនោះស្វិតអស់ទៅ ។
៤៦ ហើយឥឡូវនេះ មើលចុះ ទោះជាយើងបានថែចំការ
នេះយ៉ាងណាក្តី គង់តែដើមទាំងនោះបានរលួយខូចទៅហើយ
គឺផ្តល់ផ្លែមិនល្អវិញ; ហើយយើងបានសង្ឃឹមថានឹងរក្សាទុក
ដើមទាំងនេះ ដើម្បីប្រមូលផ្លែទុកបំរុងរដូវរអត់ ទុកសំរា
ប់ខ្លួនយើងផ្ទាល់ ។ ប៉ុន្តែមើលចុះ ដើមទាំងនេះ បានក្លាយ
ទៅដូចជាដើមអូលីវព្រៃវិញ ហើយវាគ្មានប្រយោជន៍
អ្វីសោះឡើយ តែនឹងត្រូវកាប់រំលំ ហើយបោះចោលទៅ
ក្នុងភ្លើងប៉ុណ្ណោះ; ហើយយើងព្រួយចិត្ត ដែលយើងត្រូវ
ខាតបង់ដើមទាំងនោះទៅ ។
៤៧ ប៉ុន្តែ តើយើងត្រូវធ្វើអ្វីទៀតដល់ចំការយើង ? តើយើង
បានទំនេរដៃ ដោយមិនបានដាក់ជីវាឬអី ? ទេ យើងបានថែវា
ហើយយើងបានជួយគល់វា ហើយយើងបានកាត់លួសវា
ហើយយើងបានដាក់ជីវា; ហើយយើងបានលូកដៃយើងស្ទើតែ
មួយថ្ងៃសុទ្ធ ហើយទីបញ្ចប់កាន់តែមកជិត ។ ហើយវាធ្វើឲ្យ
យើងព្រួយ ដែលយើងត្រូវកាប់រំលំអស់ទាំងដើមនៅក្នុងចំការ
យើង ហើយបោះវា ចោលទៅក្នុងភ្លើង ឲ្យវាឆេះអស់ទៅ ។
ចុះតើអ្នកណាទៅបានធ្វើឲ្យចំការយើងខូច ?
៤៨ ហើយហេតុការណ៍បានកើតឡើងថា អ្នកបំរើបាននិយាយ
ទៅម្ចាស់របស់គាត់ថា៖ តើពុំមែនមកពីដើមទាំងនោះដុះ
ខ្ពស់ពេក — តើពុំមែនមកពីមែកវាដុះរាលដាន់លើឫស
ដែលល្អទេឬអី ? ហើយដោយសារមែកវាដុះរាលដាន់លើឫស
មើលចុះ វាបានដុះលឿន ជាងកម្លាំងរបស់ឫសទៅទៀត
ដោយស្រូបយកកម្លាំងពីឫសមកអស់ ។ មើលចុះ ខ្ញុំនិយាយ
ថា តើនេះពុំមែនជាហេតុដែលធ្វើឲ្យដើម ទាំងឡាយ ក្នុង
ចំការនោះខូចទៅទេឬអី ?
៤៩ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបាន
និយាយទៅអ្នកបំរើថា៖ ចូរយើងទៅ ហើយទៅកាប់ដើមទាំងនោះ
ក្នុងចំការ ហើយបោះវាចោលទៅក្នុងភ្លើងទៅ ដើម្បីកុំឲ្យវា
ចង្អៀតដីចំការយើង ត្បិតយើងបានធ្វើសព្វគ្រប់ហើយ ។
តើយើងត្រូវធ្វើ អ្វីទៀតដល់ចំការយើង ?
៥០ ប៉ុន្តែមើលចុះ អ្នកបំរើបាននិយាយទៅម្ចាស់ចំការថា៖
សូមលោកប្រណីឲ្យវាបន្តិចទៀតសិនចុះ ។
៥១ ហើយម្ចាស់ចំការបាននិយាយថា៖ មែនហើយ យើងនឹង
ប្រណីឲ្យវាបន្តិចទៀត ត្បិតយើងព្រួយចិត្ត ដែលយើងត្រូវ
ខាតបង់ ដើមទាំងឡាយក្នុងចំការយើង ។
៥២ ហេតុដូច្នោះហើយ ចូរយើងយកមែកទាំងឡាយ
នៃដើមទាំងនេះ ដែលយើងបានដាំនៅទីទំនាបបំផុតនៃចំការយើង
ហើយចូរយើងយកទៅបំបៅជាប់នឹងដើមមុនរបស់វាវិញ; ហើយ
ចូរយើងកាត់មែកណា ដែលមានផ្លែល្វីងបំផុត ហើយបំបៅជាប់
មែក ធម្មជាតិជំនួសវិញ ។
៥៣ ហើយយើងនឹងធ្វើយ៉ាងនេះ ដើម្បីកុំឲ្យដើមនោះងាប់ទៅ
ក្រែងយើងអាចរក្សាទុកសំរាប់ខ្លួន យើងនូវឫសវា ដើម្បីគោល
បំណងរបស់យើងផ្ទាល់ ។
៥៤ ហើយមើលចុះ ឫសនៃមែកធម្មជាតិ ដែលយើងបាន
ដាំគ្រង់កន្លែង ដែលយើងចូលចិត្តនោះ នៅរស់នៅឡើយទេ;
ហេតុដូច្នោះ ហើយ ដើម្បីយើងអាចរក្សាវា
ទុកសំរាប់គោលបំណងយើងផ្ទាល់ នោះយើងនឹងយកមែក
ឈើនេះ ហើយយើងនឹងយកទៅបំបៅជាប់ នឹងដើមទាំងនោះ ។
មែនហើយ យើងនឹងបំបៅមែកពីដើមកំណើតរបស់វា ជាប់ទៅ
នឹងដើមទាំងនោះ ក្រែងយើងអាចរក្សាឫសទុក សំរាប់ខ្លួនយើង
ផ្ទាល់ផង គឺកាលណាវាមានកម្លាំងល្មមគ្រប់គ្រាន់ ប្រហែល
ជាវាអាចផ្តល់ផ្លែល្អដល់យើង ហើយយើងអាចនៅមាន សិរីល្អ
ដោយសារផ្លែនៅក្នុងចំការយើង ។
៥៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានយក
មែកពីដើមធម្មជាតិ ដែលបានក្លាយទៅជាមែកព្រៃ ទៅបំបៅជាប់
នឹងដើម ធម្មជាតិ ដែលបានក្លាយទៅជាដើមព្រៃនោះដែរ ។
៥៦ ហើយពួកគេក៏បានយកមែកពីដើមធម្មជាតិទាំងឡាយ
ដែលបានក្លាយជាមែកព្រៃ ទៅបំបៅជាប់នឹងដើមកំណើត
របស់វាវិញ ។

៤៣ *ក* ២ នីហ្វៃ ១:៥.
៤៤ *ក* អេធើរ ១៣:២០–២១.
៤៦ *ក* ៣ នីហ្វៃ ២៧:១១.
៤៧ *ក* ២ នីហ្វៃ ២៨:៣២; យ៉ាកុប ៦:៤.
*ខ* ស.ប. ពិភពលោក — ចុងបំផុត នៃផែនដី.
៥០ *ក* យ៉ាកុប ៥:២៧.
៥២ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូល នៃសាសន៍អ៊ីស្រាអែល.
៥៤ *ក* ១ នីហ្វៃ ១៥:១២–១៦.

៥៧ ហើយម្ចាស់ចំការបាននិយាយទៅអ្នកបំរើថាៈ ចូរកុំកាត់មែកព្រៃពីដើម លើកលែងតែមែកណា ដែលមានផ្លែល្វីងបំផុតប៉ុណ្ណោះ; មែកទាំងនោះហើយដែលអ្នកនឹងបំបៅជំនួស តាមពាក្យរបស់យើង ។

៥៨ ហើយយើងនឹងថែដើមនៅក្នុងចំការម្ដងទៀត ហើយយើងនឹងកាត់តំរឹមមែកវា; ហើយយើងនឹងកាត់មែកណា ដែលចាស់ចេញ គឺត្រូវងាប់ ហើយបោះវាចោលទៅក្នុងភ្លើងវិញ ។

៥៩ ហើយយើងធ្វើបែបនេះ ក្រែងឫសវាអាចមានកម្លាំងពីព្រោះសេចក្ដីល្អរបស់វា; ហើយដោយសារការផ្លាស់ប្ដូរមែក ក្រែងមែក ល្អអាចឈ្នះលើមែកអាក្រក់បាន ។

៦០ ហើយដោយសារយើងបានរក្សាមែកធម្មជាតិ និងឫសរបស់វាទុក ហើយយើងបានបំបៅមែក ធម្មជាតិជាប់ទៅនឹងដើមកំណើត របស់វាវិញ ហើយបានរក្សាឫសនៃដើមកំណើតរបស់វាទុក ក្រែងដើមនៃចំការយើងអាចផ្ដល់[ក]ផ្លែល្អទៀត; ហើយក្រែងយើងអាចមាន សេចក្ដីអំណរម្ដងទៀត ដោយសារផ្លែក្នុងចំការយើង ហើយក្រែងយើងអាចមានសេចក្ដីរីករាយជាខ្លាំង ព្រោះយើងបានរក្សាឫសនិង មែក នៃដើមមុនទុក —

៦១ ហេតុដូច្នោះហើយ ចូរទៅចុះ ហើយហៅ[ក]ពួកអ្នកបំរើឯទៀតមក ដើម្បីយើងអាចព្យាយាម[ខ]ធ្វើការដោយសមត្ថភាពរបស់យើង នៅក្នុងចំការ ប្រយោជន៍យើងអាចរៀបចំផ្លូវដើម្បីយើងអាចផ្ដល់ផ្លែឈើធម្មជាតិម្ដងទៀត គឺជាផ្លែធម្មជាតិល្អ ហើយវិសេសបំផុតជាង ផ្លែណាៗទាំងអស់ ។

៦២ ហេតុដូច្នោះហើយ ចូរយើងទៅចុះ ហើយធ្វើការដោយសមត្ថភាពរបស់យើង ជាលើកចុងក្រោយបង្អស់ ត្បិតមើលចុះ ទីបញ្ចប់ខិតជិតមកដល់ហើយ ហើយនេះជាលើកចុងក្រោយបង្អស់ ដែលយើងនឹងកាត់ល្អួសក្នុងចំការយើង ។

៦៣ ចូរបំបៅជាប់មែកទាំងនេះចុះ; ចូរចាប់ផ្ដើមពី[ក]ចុង ដើម្បីឲ្យវាអាចបានទៅជាមុនដំបូង ហើយមែកមុនដំបូងនឹងបានទៅជាចុងវិញ ចូរជ្រួយគល់ទាំងដើមចាស់និងដើមខ្ចី ទាំងដើមមុនដំបូង និងដើមចុងក្រោយបង្អស់ ហើយដើមចុងក្រោយបង្អស់ និងដើមដំបូង ដើម្បីឲ្យ ដើមទាំងអស់អាចបានទទួលជីជាតិជាថ្មីម្ដងទៀត ជាលើកចុងក្រោយបង្អស់ ។

៦៤ ហេតុដូច្នោះហើយ ចូរជ្រួយគល់វា ហើយកាត់ល្អួសវា ហើយដាក់ជីវាម្ដងទៀត ជាលើកចុងក្រោយបង្អស់ ត្បិតទីបញ្ចប់ខិតជិត មកហើយ ។ ហើយបើសិនជាមែកដែលបំបៅជាប់ចុងក្រោយនេះនឹងដុះ ហើយផ្ដល់ផ្លែធម្មជាតិពេលនោះ អ្នកនឹងរៀបចំផ្លូវសំរាប់វា ដើម្បីឲ្យវាអាចដុះ ។

៦៥ ហើយនៅពេលដែលវាចាប់ផ្ដើមដុះ អ្នកត្រូវឆ្កាមែកណាដែលផ្ដល់ផ្លែល្វីង ស្របតាមកម្លាំង និងទំហំនៃផ្លែល្អ; ហើយអ្នករាល់គ្នា មិន[ក]ត្រូវឆ្កាមែកអាក្រក់ទាំងអស់តែម្ដងទេ ក្រែងឫសវាមានកម្លាំងហួសពេកដល់មែក ដែលបំបៅជាប់ ហើយមែកដែលបំបៅជាប់នោះ នឹងងាប់បាត់ទៅ ហើយយើងខាតបង់ដើមទាំងឡាយនៅក្នុងចំការរបស់យើង ។

៦៦ ត្បិតយើងព្រួយចិត្ត ដែលយើងត្រូវខាតបង់ដើមទាំងឡាយនៅក្នុងចំការរបស់យើង; ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវឆ្កាមែក ណាដែលអាក្រក់ចោល តាមដែលមែកល្អដុះ គឺដើម្បីឲ្យឫស និងចុងដើមមានកម្លាំងស្មើគ្នា រហូតដល់មែកល្អឈ្នះលើមែកអាក្រក់ ឯមែកអាក្រក់វិញ នឹងត្រូវកាប់រំលំហើយបោះចោលទៅក្នុងភ្លើង ដើម្បីកុំឲ្យវាចង្អៀតដីចំការរបស់យើង; ហើយយើងនឹងសំអាត មែកអាក្រក់ ចេញពីចំការរបស់យើង បែបដូច្នោះ ។

៦៧ ហើយយើងនឹងបំបៅមែកទាំងឡាយនៃដើមឈើធម្មជាតិជាប់ទៅនឹងដើមធម្មជាតិវិញ;

៦៨ ហើយយើងនឹងបំបៅមែកទាំងឡាយនៃដើមធម្មជាតិជាប់ទៅនឹងមែកធម្មជាតិនៃដើមវាវិញ; ហើយយើងនឹងផ្គុំវាជាមួយគ្នាវិញ បែបដូច្នោះ ដើម្បីនឹងឲ្យផ្ដល់ផ្លែធម្មជាតិ ហើយវានឹងបានទៅជាមួយ ។

៦៩ ហើយដើមណាអាក្រក់នឹងត្រូវបោះចោល មែនហើយ គឺចោលឲ្យផុតពីដីទាំងមូល នៃចំការរបស់យើង; ត្បិតមើលចុះ យើងនឹង [ក]កាត់ល្អួសចំការយើងតែម្ដងនេះទៀតទេ ។

៧០ ហើយហេតុការណ៍បានកើតឡើងថា ម្ចាស់ចំការបានប្រើ[ក]អ្នកបំរើរបស់គាត់ទៅ; ហើយអ្នកបំរើនេះបានទៅធ្វើដូចដែលម្ចាស់ បានបញ្ជា ព្រមទាំងបាននាំពួកអ្នកបំរើផ្សេងៗទៀតមកជាមួយផង; តែពួកគេមានចំនួន[ខ]តិច ។

៦០ *ក* អេសាយ ២៧:៦.
៦១ *ក* យ៉ាកុប ៦:២;
គ. និង ស. ២៤:១៩.
*ខ* គ. និង ស. ៣៩:១១, ១៣, ១៧.
៦៣ *ក* ១ នីហ្វៃ ១៣:៤២;
អេធើរ ១៣:១០–១២.
៦៥ *ក* គ. និង ស. ៨៦:៦–៧.
៦៩ *ក* ១ នីហ្វៃ ២២:១៥–១៧, ២៣;
២ នីហ្វៃ ៣០:៩–១០.
៧០ *ក* គ. និង ស. ១០១:៥៥; ១០៣:២១.
*ខ* ១ នីហ្វៃ ១៤:១២.

៧១ ហើយម្ចាស់ចំការបាននិយាយទៅពួកគេថា៖ ចូរអ្នករាល់គ្នាទៅ ហើយធ្វើការក្នុងចំការដោយសមត្ថភាពរបស់អ្នកចុះ ។ ត្បិតមើលចុះ នេះជាលើកចុងក្រោយបង្អស់ហើយដែលយើងនឹងថែចំការរបស់យើង; ត្បិតទីបញ្ចប់នៅជិតដៃបង្កើយ ហើយរដូវក៏មក យ៉ាងឆាប់រហ័ស; ហើយបើសិនជាអ្នករាល់គ្នាធ្វើការដោយសមត្ថភាពរបស់អ្នកជាមួយនឹងយើង នោះអ្នករាល់គ្នានឹងមានសេចក្ដីអំណរ ដោយសារផ្លែឈើ ដែលយើងនឹងប្រមូលទុកសំរាប់ខ្លួនយើង សំរាប់ពេលដែលជិតមកដល់នោះ។

៧២ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកបំរើបានទៅធ្វើការដោយសមត្ថភាពរបស់ពួកគេ ឯម្ចាស់ចំការវិញក៏ធ្វើការ ជាមួយនឹងពួកគេដែរ ហើយពួកគេបានធ្វើតាមបញ្ជាទាំងឡាយរបស់ម្ចាស់ចំការ ចំពោះកិច្ចការគ្រប់យ៉ាង ។

៧៣ ហើយនៅក្នុងចំការក៏ចាប់ផ្ដើមមានផ្លែធម្មជាតិទៀត; ឯមែកធម្មជាតិបានចាប់ផ្ដើមដុះលូតលាស់ជាច្រើន; ហើយមែកព្រៃទាំង ឡាយ ក៏ចាប់ផ្ដើមកាត់ចោល; ហើយពួកគេបានធ្វើឲ្យឫស និងចុងដើមស្មើគ្នា តាមកម្លាំងវា ។

៧៤ ហើយពួកគេបានធ្វើការដូច្នោះ ដោយអស់ទាំងសេចក្ដីព្យាយាម ស្របតាមបញ្ជារបស់ម្ចាស់ចំការ រហូតដល់មែកអាក្រក់ទាំង ឡាយត្រូវបានបោះចោលចេញពីចំការ ហើយម្ចាស់ចំការបានរក្សាទុកសំរាប់គាត់ នូវដើមឈើទាំងឡាយដែលបានក្លាយទៅជាដើម ដែលមានផ្លែធម្មជាតិវិញ; ហើយវាបានក្លាយទៅដូចជាដើមតែមួយ; ឯផ្លែទាំងឡាយក៏ស្មើគ្នា; ហើយម្ចាស់ចំការបានរក្សាទុកសំរាប់គាត់ នូវផ្លែធម្មជាតិដ៏វិសេសបំផុតសំរាប់លោកចាប់ពីដំបូងមក ។

៧៥ ហើយហេតុការណ៍បានកើតឡើងថា កាលដែលម្ចាស់ចំការបានឃើញថា ផ្លែឈើរបស់គាត់ល្អ ហើយចំការរបស់គាត់ឈប់ខូច ទៀតហើយ នោះគាត់ក៏បានហៅពួកអ្នកបំរើរបស់គាត់មក ហើយប្រាប់ពួកគេថា៖ មើលចុះ នេះជាលើកចុងក្រោយបង្អស់ ដែលយើង រាល់គ្នាថែចំការយើង; ហើយអ្នកបានឃើញថា យើងបានធ្វើតាមចំណង់របស់យើង; ហើយយើងបានរក្សាផ្លែធម្មជាតិទុក ផ្លែណាដែល ល្អគឺដូចផ្លែកាលពីមុនដែរ។ ហើយអ្នកមានពរហើយ; ព្រោះដោយអ្នករាល់គ្នាបានធ្វើការយ៉ាងព្យាយាម ជាមួយនឹងយើងនៅក្នុង ចំការនេះ ហើយបានកាន់តាមបញ្ញត្តិរបស់យើង ហើយបានផ្ដល់ផ្លែធម្មជាតិដល់យើងទៀត ដើម្បីកុំឲ្យចំការយើងរលួយខូចទៀតឡើយ ឯមែកអាក្រក់ទាំងឡាយ ត្រូវបានកាត់បោះចោល ហើយមើលចុះ អ្នករាល់គ្នានឹងមានសេចក្ដីអំណរជាមួយនឹងយើង ដោយសារផ្លែ ឈើនៃចំការរបស់យើង ។

៧៦ ត្បិតមើលចុះ ជាកាលដ៏យូរយារដែលយើងនឹងប្រមូលផ្លែនៃចំការយើង ទុកសំរាប់ខ្លួនយើងផ្ទាល់ បំរុងរដូវ ដែលនឹងមកដល់ យ៉ាងឆាប់រហ័សនេះ; ហើយជាលើកចុងក្រោយបង្អស់ដែលយើងបានថែចំការរបស់យើង ហើយបានកាត់លួសវា ហើយជួយគល់វា ហើយដាក់ជីវា; ហេតុដូច្នោះហើយ យើងនឹងប្រមូលផ្លែទុកសំរាប់ខ្លួនយើង ទុកជាយូរយារ ស្របតាមពាក្យដែលយើងបាននិយាយមក ។

៧៧ ហើយកាលណាពេលនោះមកដល់ គឺផ្លែអាក្រក់នោះនឹងចូលមកក្នុងចំការយើងទៀត ពេលនោះ យើងនឹងបញ្ជាឲ្យបេះផ្លែល្អ និងផ្លែអាក្រក់មក; ហើយយើងនឹងទុកផ្លែល្អសំរាប់ខ្លួនយើង ឯផ្លែអាក្រក់វិញ យើងនឹងបោះចោលទៅកន្លែងវាវិញ ។ ហើយបន្ទាប់មក រដូវ និងទីបញ្ចប់នឹងមកដល់ ហើយយើងនឹងដុតចំការរបស់យើងដោយភ្លើង ៕

## ជំពូកទី ៦

*ព្រះអម្ចាស់ទ្រង់នឹងរើសសាសន៍អ៊ីស្រាអែលឡើងវិញ នៅគ្រាចុងក្រោយបង្អស់ — ពិភពលោកនឹងត្រូវឆេះដោយភ្លើង — មនុស្សលោក ត្រូវដើរតាមព្រះគ្រីស្ទ ដើម្បីឲ្យចៀសវាងរួចពីបឹងភ្លើង និងស្ពាន់ធ័រ ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ដូចជាខ្ញុំបានប្រាប់អ្នករាល់គ្នាថា ខ្ញុំនឹងព្យាករ មើលចុះ នេះគឺជាពាក្យព្យាករណ៍របស់ខ្ញុំ — គឺថាអ្វីៗដែលព្យាការីស៊ីណូស បាននិយាយអំពីវង្សអ៊ីស្រាអែល ដោយបានប្រៀបធៀបពួកគេទៅនឹងដើមអូលីវ ស្រុក នោះប្រាកដជានឹងកើតឡើងមែន ។

៧១ *ក* ម៉ាថាយ ២១:២៨; យ៉ាកុប ៦:២–៣; គ. និង ស. ៣៣:៣–៤.
*ខ* គ. និង ស. ៣៩:១៧; ៤៣:២៨–៣០.
*គ* គ. និង ស. ១៨:១០–១៦.
៧៤ *ក* គ. និង ស. ៣៨:២៧.
៧៥ *ក* ១ នីហ្វៃ ១៣:៣៧.
*ខ* ស.ប. អ៊ីស្រាអែល.
៧៦ *ក* ១ នីហ្វៃ ២២:២៤–២៦. ស.ប. សហស្សវត្សរ៍.
៧៧ *ក* វិវរ. ២០:២–១០; គ. និង ស. ២៩:២២–២៤; ៤៣:២៩–៣៣; ៨៨:១១០–១១៦.
*ខ* ស.ប. ពិភពលោក — ចុងបំផុត នៃផែនដី.
៦ ១*ក* យ៉ាកុប ៥:១.

២ ហើយនៅថ្ងៃដែលទ្រង់នឹងលូកព្រះហស្តទ្រង់ទៀតជាលើកទីពីរ ដើម្បី[ក]រើសរាស្ត្រទ្រង់ឡើងវិញ[ខ] គឺជាថ្ងៃ មែនហើយ គឺជាលើកចុង ក្រោយបង្អស់ ដែលពួកអ្នកបំរើនៃព្រះអម្ចាស់ នឹងចេញទៅថែ[គ]កាត់ល្អួស[ឃ]ចំការរបស់ទ្រង់ ដោយនូវ[ង]អំណាចរបស់ទ្រង់ ហើយបន្ទាប់មក ទើប[ច]ទីបញ្ចប់នឹងមកដល់ ។

៣ ហើយមានពរហើយ ដល់ពួកអ្នកណាដែលបានធ្វើការយ៉ាងព្យាយាម នៅក្នុងចំការរបស់ទ្រង់; តែត្រូវបណ្ដាសាហើយ ដល់ពួក អ្នកណាដែលនឹងត្រូវបានបណ្ដេញចេញទៅក្នុងកន្លែងផ្ទាល់របស់ពួកគេវិញ ! ឯពិភពលោកនឹងត្រូវ[ក]ឆេះដោយភ្លើង ។

៤ ហើយឱព្រះនៃយើង ទ្រង់មានសេចក្ដីមេត្តាករុណាដល់យើងដ៏ម្ល៉េះ ត្បិតទ្រង់នឹកចាំ[ខ]ដល់វង្ស[ក]អ៊ីស្រាអែល ទាំងឫសនិងមែកផង; ហើយទ្រង់លូកព្រះហស្តទ្រង់ទៅរកពួកគេអស់ទាំងថ្ងៃ; តែពួកគេជាមនុស្សរឹងរូស ហើយចូលចិត្តនិយាយបោកគេ; ប៉ុន្តែដរាបណាពួកគេមិនធ្វើចិត្ត[គ]រឹងរូសទេ នោះនឹងត្រូវបានសង្គ្រោះនៅក្នុងនគរនៃព្រះ ។

៥ ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់អើយ ខ្ញុំសូមអង្វរអ្នក ដោយពាក្យពេចន៍ដ៏ម៉ឺងម៉ាត់ថា អ្នករាល់គ្នាត្រូវប្រែចិត្តហើយមកដោយអស់ពីដួងចិត្ត ហើយ[ក]តោងជាប់ទៅនឹងព្រះដូចជាទ្រង់ចូលជាប់នឹងអ្នកដែរ ហើយកាល[ខ]ព្រះពាហុនៃសេចក្ដីមេត្តាករុណា របស់ទ្រង់លាចេញមករកអ្នក នៅក្នុងពន្លឺនៃពេលថ្ងៃ ចូរកុំធ្វើចិត្តរឹងរូសឡើយ ។

៦ មែនហើយ ថ្ងៃនេះ បើសិនជាអ្នករាល់គ្នាឮសម្លេងទ្រង់ ចូរកុំធ្វើចិត្តរឹងរូសឡើយ; ត្បិត[ក]ហេតុអ្វីក៏បងប្អូនចង់ស្លាប់ ?

៧ ត្បិតមើលចុះ បន្ទាប់ពីអ្នករាល់គ្នាត្រូវបានចិញ្ចឹមឲ្យរស់ដោយព្រះបន្ទូលដ៏ល្អនៃព្រះអស់ទាំងថ្ងៃហើយ ចុះតើអ្នករាល់គ្នានឹងផ្ដល់ ផ្លែអាក្រក់មក ដែលនឹងធ្វើឲ្យអ្នកត្រូវកាប់រំលំហើយ[ក]បោះចោលទៅក្នុងភ្លើងឬអី ?

៨ មើលចុះ តើអ្នករាល់គ្នានឹងមិនទទួលស្គាល់ពាក្យទាំងនេះទេឬអី ? ចុះតើអ្នករាល់គ្នានឹងមិនទទួលស្គាល់ពាក្យនៃពួកព្យាការីឬ; ហើយតើអ្នករាល់គ្នានឹងមិនទទួលស្គាល់ពាក្យទាំងឡាយ ដែលបាននិយាយអំពីព្រះគ្រីស្ទ បន្ទាប់ពីមានមនុស្សជាច្រើន បាននិយាយ អំពីទ្រង់ឬ; ហើយតើអ្នករាល់គ្នាមិនទទួលស្គាល់ព្រះបន្ទូលដ៏ល្អរបស់ព្រះគ្រីស្ទ និងព្រះចេស្ដានៃព្រះ និង[ក]អំណោយទានជាព្រះវិញ្ញាណ បរិសុទ្ធឬ ហើយតើអ្នករាល់គ្នានឹងពន្លត់ព្រះវិញ្ញាណបរិសុទ្ធ ហើយចំអកដល់ផែនការដ៏មហិមានៃសេចក្ដីប្រោសលោះ ដែលបានរៀបចំ សំរាប់អ្នកឬ ?

៩ តើអ្នករាល់គ្នាពុំដឹងទេឬថា បើសិនជាអ្នករាល់គ្នាធ្វើការណ៍ទាំងនេះ នោះអំណាចនៃសេចក្ដីប្រោសលោះ និងដំណើររស់ឡើង វិញ ដែលមាននៅក្នុងព្រះគ្រីស្ទ នឹងនាំអ្នកទៅឈរដោយសេចក្ដីខ្មាស់ និង[ក]ទោសដ៏គួរឲ្យស្ញែងខ្លាច នៅ[ខ]ខាងមុខវេទិកានៃព្រះឬ ?

១០ ហើយស្របតាមអំណាចនៃ[ក]សេចក្ដីយុត្តិធម៌ ត្បិតសេចក្ដីយុត្តិធម៌មិនអាចត្រូវបដិសេធបានទេ នោះអ្នករាល់គ្នានឹងត្រូវចុះទៅក្នុង [ខ]បឹងភ្លើង និងស្ពាន់ធ័រ ដែលមានអណ្ដាតភ្លើងមិនអាចរំលត់បាន គឺមានផ្សែងហុយឡើងជារៀងដរាបតទៅឯបឹងភ្លើង និងស្ពាន់ធ័រ គឺជាសេចក្ដីទុក្ខវេទនាដ៏[គ]មិនចេះចប់[ឃ]មិនចេះហើយ ។

១១ បើដូច្នោះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយចូលតាម[ក]ទ្វារតូច ហើយបន្តទៅតាមផ្លូវចង្អៀត រហូតដល់អ្នកបានទទួលជីវិតដ៏នៅអស់កល្បជានិច្ច ។

១២ ចូរមាន[ក]ប្រាជ្ញាឡើង; ចុះតើខ្ញុំអាចនិយាយអ្វីទៀត ?

១៣ ជាទីបញ្ចប់នេះ ខ្ញុំសូមលាអ្នកសិនហើយ រហូតដល់ខ្ញុំនឹងជួបអ្នក នៅចំពោះវេទិកាដ៏សព្វព្រះហឫទ័យនៃព្រះ គឺជាវេទិកាដែលវាយពួកទុច្ចរិត ដោយ[ក]សេចក្ដីបារម្ភ និងភិតភ័យស្ញែងខ្លាច ។ អាម៉ែន ៕

---

២ *ក* ១ នីហ្វៃ ២២:១០–១២;
គ. និង ស. ១១០:១១.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* យ៉ាកុប ៥:៦១.
២ *គ* ១ នីហ្វៃ ១៤:១៤.
*ឃ* យ៉ាកុប ៥:៧១.
*ង* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*ច* ២ នីហ្វៃ ៣០:១០.
៣ *ក* ២ នីហ្វៃ ២៧:២; យ៉ាកុប ៥:៧៧;
៣ នីហ្វៃ ២៥:១.
៤ *ក* ២ សាំយូ. ៧:២៤.
*ខ* យ៉ាកុប ៥:៤៧.
*គ* ម៉ូសាយ ១៣:២៩.
៥ *ក* ស.ប. ការរួបរួមតែមួយ.
*ខ* អាលម៉ា ៥:៣៣–៣៤;
៣ នីហ្វៃ ៩:១៤.
៦ *ក* អេសេ. ១៨:២១–២៣.
៧ *ក* អាលម៉ា ៥:៥១–៥២;
៣ នីហ្វៃ ២៧:១១–១២.
៨ *ក* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
៩ *ក* ម៉ូសាយ ១៥:២៦.
ស.ប. ទោស.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
១០ *ក* ស.ប. សេចក្ដីយុត្តិធម៌.
*ខ* ២ នីហ្វៃ ២៨:២៣.
ស.ប. ស្ថាននរក.
*គ* គ. និង ស. ១៩:១០–១២.
*ឃ* ស.ប. សេចក្ដីផាប់ទោស.
១១ *ក* ២ នីហ្វៃ ៩:៤១.
១២ *ក* មរមន ៩:២៨.
១៣ *ក* អាលម៉ា ៤០:១៤.

## ជំពូកទី ៧

*សេរេមមិនទទួលស្គាល់ព្រះគ្រីស្ទ, ទាស់ជាមួយនឹងយ៉ាកុប, ទាមទាររកទីសំគាល់, ហើយត្រូវព្រះទ្រង់វាយ — ពួកព្យាការីទាំងអស់ បាននិយាយអំពីព្រះគ្រីស្ទ និងអំពីដង្វាយធួនរបស់ទ្រង់ — ពួកសាសន៍នីហ្វៃរស់នៅក្នុងភាពរសាត់គ្មានទិសដៅ, កើតនៅក្នុងសេចក្ដី ទុក្ខវេទនា ហើយត្រូវពួកសាសន៍លេមិនស្អប់ ។ ប្រមាណជាឆ្នាំ ៥៤៤–៤២១ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីច្រើនឆ្នាំបានកន្លងផុតទៅ មានបុរសម្នាក់មកក្នុងចំណោមប្រជាជននីហ្វៃ មានឈ្មោះថា សេរេម ។
២ ហើយហេតុការណ៍បានកើតឡើងថា គាត់បានចាប់ផ្ដើមផ្សាយក្នុងចំណោមបណ្ដាជន ហើយថ្លែងទៅពួកគេថាគ្មានព្រះគ្រីស្ទទេ ។ ហើយគាត់បានផ្សាយរឿងជាច្រើន ដែលបញ្ចោរប្រជាជន; ហើយគាត់ធ្វើយ៉ាងនេះ ក្នុងគោលបំណងចង់រំលំគោលលទ្ធិនៃព្រះគ្រីស្ទ ចោល ។
៣ ហើយគាត់បានខិតខំធ្វើការដោយព្យាយាម ក្រែងគាត់អាចបង្វែរចិត្តប្រជាជនចេញ រហូតដល់គាត់បានបង្វែរចិត្តមនុស្សជាច្រើន ចេញ; ហើយអ្នកនោះបានដឹងថាខ្ញុំ យ៉ាកុបមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ដែលនឹងយាងមក នោះគាត់ស្វែងរកឱកាសមកជួបខ្ញុំ ។
៤ ហើយគាត់ជាអ្នករៀនសូត្រ ម្ល៉ោះហើយ គាត់មានជំរិះដ៏ឥតខ្ចោះអំពីភាសារបស់ប្រជាជន; ហេតុដូច្នោះហើយ ទើបគាត់អាច បញ្ចោរ ហើយរកកលល្បិចនៃសំដីជាច្រើន ដោយអំណាចនៃអារក្ស ។
៥ ហើយគាត់បានសង្ឃឹមថានឹងធ្វើឲ្យខ្ញុំបាត់បង់សេចក្ដីជំនឿ ទោះបីខ្ញុំបានទទួល[ក]វិវរណៈជាច្រើន ហើយបានឃើញរឿងជាច្រើនស្ដី អំពីការណ៍នេះក៏ដោយ; ត្បិតខ្ញុំពិតជាបានឃើញពួកទេវតា ហើយពួកទេវតាបានធ្វើការងារបំរើដល់ខ្ញុំ ។ ហើយមួយទៀត ខ្ញុំក៏បានឮ សម្លេងនៃព្រះអម្ចាស់ បន្ទឹមកខ្ញុំគ្រប់ពាក្យម្ដងម្កាលៗ; ហេតុដូច្នោះហើយ ខ្ញុំមិនអាចបាត់បង់សេចក្ដីជំនឿបានទេ ។
៦ ហើយហេតុការណ៍បានកើតឡើងថា គាត់បានមកជួបខ្ញុំ ហើយបាននិយាយមកខ្ញុំ ដោយពាក្យដូច្នេះថា៖ បងយ៉ាកុប ខ្ញុំបានស្វែង រកឱកាសជាច្រើន ដើម្បីខ្ញុំអាចនិយាយនឹងបង; ត្បិតខ្ញុំបានឮ ហើយបានដឹងថា បងចូលចិត្តដើរផ្សាយនូវអ្វីដែលបងហៅថា ដំណឹងល្អ ឬគោលលទ្ធិនៃព្រះគ្រីស្ទ ។
៧ ហើយបងបាននាំប្រជាជននេះ ជាចំនួនធំ ឲ្យគេបង្ខូចផ្លូវដ៏ត្រឹមត្រូវនៃព្រះ ហើយពុំ[ក]កាន់តាមក្រិត្យវិន័យលោកម៉ូសេ ដែលជាផ្លូវត្រូវ; ព្រមទាំងកែប្រែក្រិត្យវិន័យលោកម៉ូសេ ទៅជាការថ្វាយបង្គំមនុស្សម្នាក់ ដែលបងនិយាយថា នឹងយាងមកក្នុងរយៈពេលជាច្រើនរយ ឆ្នាំទៀត ។ ហើយឥឡូវនេះ មើលចុះ ខ្ញុំ សេរេម សូមប្រកាសប្រាប់បងថា នេះជាសេចក្ដីប្រមាថដល់ព្រះ; ព្រោះ[ខ]គ្មានអ្នកណាអាចដឹង ការណ៍បែបនេះបានទេ; ត្បិតមនុស្សមិនអាចព្យាករអំពីរឿង ដែលនឹងកើតឡើងបានឡើយ ។ ហើយដោយពាក្យបែបនេះហើយដែលសេរេមបានប្រកែកនឹងខ្ញុំ ។
៨ ប៉ុន្តែមើលចុះ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បាន[ក]ស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើព្រលឹងខ្ញុំ ដរាបដល់ខ្ញុំបានធ្វើឲ្យគាត់ជ្រប់មុខ ចំពោះគ្រប់ទាំងពាក្យរបស់គាត់ ។
៩ ហើយខ្ញុំនិយាយទៅគាត់ថា៖ តើអ្នកមិនទទួលស្គាល់ព្រះគ្រីស្ទ ដែលនឹងយាងមកទេឬអី? ហើយគាត់ឆ្លើយថា៖ បើសិនជាមានព្រះគ្រីស្ទមែននោះ ខ្ញុំនឹងពុំប្រកែកថាមិនទទួលស្គាល់ទ្រង់ទេ; ប៉ុន្តែខ្ញុំដឹងថា គ្មានព្រះគ្រីស្ទឡើយ គឺមិនដែលមានពីមុនមក ហើយក៏នឹង គ្មាននៅពេលខាងមុខដែរ ។
១០ ហើយខ្ញុំនិយាយទៅគាត់ថា៖ តើអ្នកជឿដល់បទគម្ពីរទាំងឡាយទេ ? ហើយគាត់ឆ្លើយថា៖ ជឿ ។
១១ ហើយខ្ញុំនិយាយទៅគាត់ថា៖ បើដូច្នោះ អ្នកពុំយល់បទគម្ពីរទាំងនោះទេ; ត្បិតពាក្យទាំងនោះ ពិតជាធ្វើបន្ទាល់អំពីព្រះ គ្រីស្ទហើយ ។ មើលចុះ ខ្ញុំប្រាប់អ្នកថា គ្មាន[ក]ព្យាការីណា ដែលមិនសរសេរ ឬព្យាករ ក្រៅពីនិយាយអំពីព្រះគ្រីស្ទនោះឡើយ ។
១២ ហើយនេះមិនទាន់អស់នៅឡើយទេ — ការណ៍នេះបានសម្ដែងឲ្យខ្ញុំឃើញ ព្រោះខ្ញុំបានទាំងឮ ហើយបានឃើញ; ហើយការណ៍នេះក៏សម្ដែងឲ្យខ្ញុំដឹង ដោយ[ក]ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដែរ; ហេតុដូច្នោះហើយ ខ្ញុំដឹងថា បើសិនជា

**៧** ៥ *ក* ២ នីហ្វៃ ១១:៣; យ៉ាកុប ២:១១.
៧ *ក* យ៉ាកុប ៤:៥.
*ខ* អាលម៉ា ៣០:១៣.
៨ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
១១ *ក* វិវរ. ១៩:១០; ១ នីហ្វៃ ១០:៥; យ៉ាកុប (ព.ម) ៤:៤; ម៉ូសាយ ១៣:៣៣–៣៥; គ. និង ស. ២០:២៦.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.
១២ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ; ព្រះវិញ្ញាណបរិសុទ្ធ.

គ្មានដង្ហាយធួនទេ នោះមនុស្សលោកទាំងអស់ច្បាស់ជានឹង
ត្រូវវង្វេងបង់ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា បុរសនោះបាន
និយាយមកខ្ញុំថា៖ ចូរបងបង្ហាញទីសំគាល់មួយដល់ខ្ញុំ ដោយ
ព្រះចេស្ដានៃ ព្រះវិញ្ញាណបរិសុទ្ធ ដែលបងដឹង
ជាច្រើននេះមើល ។
១៤ ហើយខ្ញុំនិយាយទៅគាត់ថា៖ តើខ្ញុំជាអ្វីទៅ ដែល
នឹងល្បងព្រះ ឲ្យបង្ហាញទីសំគាល់ដល់អ្នក អំពីរឿងដែលអ្នក
ដឹងថាជារឿង ពិតនោះ ? គង់តែអ្នកនឹងមិនទទួល
ស្គាល់រឿងនោះទៀត ពីព្រោះអ្នកជាអ្នកផងអារក្ស ។ ទោះ
ជាយ៉ាងណាក៏ដោយ គឺមិនមែនជា បំណងរបស់ខ្ញុំទេ; តែបើ
សិនជាព្រះទ្រង់នឹងវាយអ្នក ចូរចាត់ទុកថា នោះជាទីសំគាល់
មួយដល់អ្នកហើយ គឺទ្រង់មានអំណាចទាំងនៅ លើស្ថានសួគ៌
និងផែនដីផង; ហើយក៏ជាទីសំគាល់ថា ព្រះគ្រីស្ទនឹងយាង
មក ។ ហើយ ឱព្រះអម្ចាស់អើយ សូមបំណងរបស់ទ្រង់បាន
សំរេចចុះ មិនមែនជាបំណងរបស់ទូលបង្គំឡើយ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា កាលខ្ញុំ យ៉ាកុប បាន
និយាយពាក្យទាំងនេះហើយ ព្រះចេស្ដានៃព្រះអម្ចាស់ បានមកលើ
បុរសនោះ ដរាបដល់គាត់ដួលទៅលើដី ។ ហើយហេតុការណ៍
បានកើតឡើងថា បុរសនោះត្រូវបានគេថែជាច្រើនថ្ងៃ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា គាត់បាននិយាយ
ទៅប្រជាជនថា៖ ចូរប្រជុំគ្នាមកនៅ ថ្ងៃស្អែក ត្បិតខ្ញុំនឹង
ស្លាប់ហើយ; ហេតុដូច្នោះហើយ ខ្ញុំមានប្រាថ្នាចង់និយាយ
ទៅប្រជាជនមុនខ្ញុំនឹងស្លាប់ទៅ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង
ហ្វូងមនុស្សបានប្រជុំគ្នាមក; ហើយបុរសនោះបាននិយាយយ៉ាង
ច្បាស់ លាស់ទៅប្រជាជន ហើយបដិសេធនូវអ្វីៗ ដែលគាត់
បានបង្រៀនពួកគេ ហើយទទួលថ្លែងប្រាប់ពីព្រះគ្រីស្ទ និងព្រះចេស្ដា
នៃព្រះ វិញ្ញាណបរិសុទ្ធ និងការងារបំរើនៃពួកទេវតា ។
១៨ ហើយគាត់បាននិយាយយ៉ាងច្បាស់លាស់ ទៅប្រជាជនថា
គាត់ត្រូវអំណាចនៃអារក្សបោកបញ្ឆោតគាត់ ។ ហើយគាត់
បាន និយាយអំពីស្ថាននរក និងអំពីសេចក្ដីអស់កល្បជានិច្ច និង
អំពីទោសដ៏អស់កល្បជានិច្ច ។
១៩ ហើយគាត់បាននិយាយថា៖ ខ្ញុំខ្លាចក្រែងខ្ញុំបានប្រព្រឹត្ត
អំពើបាប ដ៏អត់ឱនមិនបាន ព្រោះខ្ញុំបានកុហកដល់ព្រះ; ត្បិតខ្ញុំ
មិនទទួល ស្គាល់ព្រះគ្រីស្ទ តែបាននិយាយថា ខ្ញុំជឿព្រះគម្ពីរ;
ហើយព្រះគម្ពីរពិតជាធ្វើបន្ទាល់អំពីទ្រង់មែន ។ ហើយដោយ
សារខ្ញុំបានកុហក ដល់ព្រះយ៉ាងនេះ នោះខ្ញុំខ្លាចយ៉ាង
ក្រៃលែង ក្រែងលោករណីរបស់ខ្ញុំនេះធ្ងន់ធ្ងរពេក; ប៉ុន្តែខ្ញុំសូម
ទទួលសារភាពដល់ព្រះ ។
២០ ហើយហេតុការណ៍បានកើតឡើងថា កាលគាត់បាន
និយាយពាក្យទាំងនេះចប់ហើយ គាត់ក៏មិនអាចនិយាយអ្វីទៀត
បានឡើយ ហើយគាត់ក៏ផុតដង្ហើមទៅ ។
២១ ហើយកាលហ្វូងមនុស្សបានឮពាក្យ ដែលគាត់បាន
និយាយ នៅពេលគាត់ជិតនឹងដាច់ដង្ហើមទៅ ពួកគេក៏មាន
សេចក្ដីអស្ចារ្យ ជាខ្លាំង; ដរាបដល់ព្រះចេស្ដានៃព្រះយាងចុះ
មកសណ្ឋិតលើពួកគេ ហើយពួកគេត្រូវចាញ់ព្រះចេស្ដា
ដោយដួលទៅលើដី ។
២២ ឥឡូវនេះ ការណ៍នេះធ្វើឲ្យខ្ញុំ យ៉ាកុប ពេញចិត្ត
ត្បិតខ្ញុំបានសូមការណ៍នេះពីព្រះវរបិតារបស់ខ្ញុំ ដែលទ្រង់
គង់នៅស្ថានសួគ៌; ព្រោះទ្រង់បានឮសំរែករបស់ខ្ញុំ ហើយបាន
ឆ្លើយតបពាក្យអធិស្ឋានរបស់ខ្ញុំ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា សេចក្ដីសុខសាន្ត
និងសេចក្ដីស្រឡាញ់នៃព្រះ ក៏មានឡើងវិញនៅក្នុងចំណោម
ប្រជាជន; ហើយពួកគេបានពិចារណាមើលព្រះគម្ពីរ ហើយឈប់
ស្ដាប់តាមពាក្យរបស់មនុស្សទុច្ចរិតនេះទៅ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា មានមធ្យោបាយ
ជាច្រើនដែលបានចាត់ចែងឡើង ដើម្បីជួយ ហើយធ្វើឲ្យពួក
សាសន៍ លេមិនបានស្គាល់នូវសេចក្ដីពិតឡើងវិញ; ប៉ុន្តែកិច្ចការ
ទាំងអស់នេះ ឥតបានប្រយោជន៍ឡើយ ព្រោះពួកគេពេញចិត្ត
នឹងសង្គ្រាមទាំង ឡាយ និងការខ្វាយឈាម ហើយពួកគេ
មានសម្អប់ដ៏យូរអង្វែង ទាស់នឹងយើង ជាបងប្អូនរបស់ពួក

១២ ខ ២ នីហ្វៃ ២:២១.
១៣ ក ម៉ាថាយ ១៦:១–៤; អាលម៉ា ៣០:៤៣–៦០. ស.ប. ទីសំគាល់.
១៤ ក អាលម៉ា ៣០:៤១–៤២.
ខ អាលម៉ា ៣០:៥៣.
១៨ ក អាលម៉ា ៣០:៥៣. ស.ប. ការបោក, បញ្ឆោត, សេចក្ដីបញ្ឆោត.
ខ ស.ប. អារក្ស.
១៩ ក ស.ប. អំពើបាបដ៏អត់ឱនមិនបាន.
ខ ម៉ូសាយ ១៥:២៦.
២០ ក យេរេ. ២៨:១៥–១៧.
២១ ក អាលម៉ា ១៩:៦.
២៣ ក អាលម៉ា ១៧:២.
២៤ ក អេណុស ១:២០.
ខ អេណុស ១:១៤.
គ ម៉ូសាយ ១០:១១–១៨.
ឃ យ៉ារ៉ុម ១:៦; អាលម៉ា ២៦:២៣–២៥.
ង ២ នីហ្វៃ ៥:១–៣; ម៉ូសាយ ២៨:២.

គេ ។ ហើយពួកគេបានខិតខំបំផ្លាញ យើងមិនឈប់ឈរឡើយ
ដោយអំណាចនៃដៃរបស់ពួកគេ ។
២៥ ហេតុដូច្នោះហើយ ប្រជាជននីហ្វៃបានព្រួតកម្លាំងតទល់
នឹងពួកគេ ដោយកងទ័ព និងដោយអស់ពីសមត្ថភាពរបស់ខ្លួន
ដោយទុកចិត្តទៅលើព្រះ និងទៅលើថ្មដានៃសេចក្ដីសង្គ្រោះ
របស់ពួកគេ; ហេតុដូច្នោះហើយ បានជាពួកគេចេះតែមាន
ជ័យជំនះ លើពួកខ្មាំងសត្រូវរបស់គេជានិច្ច ។
២៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ យ៉ាកុប បាន
ចាប់ផ្ដើមមានចំណាស់ចាស់; ហើយបញ្ជីអំពីប្រជាជននេះ ត្រូវ
បានកត់ នៅលើផ្ទាំងនីហ្វៃឯទៀត ហេតុដូច្នោះហើយ ខ្ញុំសូម
បញ្ចប់បញ្ជីនេះសិនចុះ ដោយប្រកាសថា ខ្ញុំបានសរសេរតាម
ការចេះដឹងផ្ទាល់ របស់ខ្ញុំ ដោយនិយាយថា ពេលវេលាបាន
កន្លងទៅជាមួយនឹងយើង ហើយឯជីវិតយើងក៏រសាត់ហួសទៅ
ហាក់ដូចជាការយល់សប្ដិ ចំពោះយើង ឯយើងជាមនុស្សឯក
ឯង ហើយស្ងប់ស្ងាត់ ជាអ្នកដើររសាត់ព្រាត់ ត្រូវបាន
ដេញចេញពីក្រុងយេរូសាឡិម យើងបានកើត នៅក្នុងសេចក្ដី
ទុក្ខលំបាកនៅក្នុងទីរហោស្ថាន ហើយត្រូវបងប្អូនយើងស្អប់
ដែលបណ្ដាលឲ្យមានសង្គ្រាមទាំងឡាយ និងការទាស់ទែង
គ្នាទាំងឡាយ; ហេតុដូច្នោះហើយ យើងបានទួញសោកក្នុង
ជីវិតរបស់យើង ។
២៧ ហើយខ្ញុំ យ៉ាកុប បានឃើញថា ខ្ញុំជិតត្រូវចុះទៅក្នុងផ្នូររបស់
ខ្ញុំហើយ; ហេតុដូច្នោះហើយ ខ្ញុំបាននិយាយទៅអេណុស ជាកូន
ប្រុសខ្ញុំថា៖ ចូរកូនយក ផ្ទាំងទាំងនេះចុះ ។ ហើយខ្ញុំបានប្រាប់កូនខ្ញុំ
អំពីរឿងទាំងឡាយ ដែលបងប្រុសខ្ញុំ គឺនីហ្វៃ បានបញ្ជាដល់ខ្ញុំ
ហើយកូនខ្ញុំបានសន្យាថា នឹងគោរពតាមបញ្ជាទាំងនោះ ។
ហើយខ្ញុំសូមបញ្ចប់នូវការសរសេររបស់ខ្ញុំនៅលើផ្ទាំងទាំងនេះ
គឺជាពាក្យ សរសេរដ៏ខ្លី; ហើយចំពោះអ្នកអាន នោះសូម
ជំរាបលា ដោយសង្ឃឹមថា បងប្អូនជាច្រើននឹងបានអានពាក្យ
របស់ខ្ញុំ ឱបងប្អូនអើយ សូមជំរាបលាសិនហើយ ៕ :៚

# គម្ពីរអេណុស

*អេណុសអធិស្ឋានអស់ពីសមត្ថភាព ហើយបានទទួលការផ្ដាច់បាបទាំងឡាយរបស់លោក — សម្លេងនៃព្រះអម្ចាស់ចូលមកក្នុងគំនិតលោក ដោយសន្យាថា នឹងផ្ដល់នូវសេចក្ដីសង្គ្រោះដល់ពួកសាសន៍លេមិន នៅពេលអនាគត — ពួកសាសន៍នីហ្វៃបានស្វែងរកជួយពួកសាសន៍ លេមិន — អេណុសអររីករាយនៅក្នុងព្រះដ៏ប្រោសលោះរបស់លោក ។ ប្រមាណជាឆ្នាំ ៤២០ ម.គ.ស. ។*

មើលចុះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ អេណុស ដឹងថា
ឪពុកខ្ញុំជាមនុស្សសុចរិត — ព្រោះលោកបានបង្រៀនខ្ញុំ
តាមភាសារបស់ លោក និងតាមដំបូន្មាន និងសេចក្ដី
ដាស់តឿនរបស់ព្រះអម្ចាស់ — ហើយសូមឲ្យព្រះនាមនៃ
ព្រះរបស់ខ្ញុំ បានប្រកបដោយព្រះពរ ចំពោះរឿងនេះចុះ —
២ ហើយខ្ញុំនឹងប្រាប់អ្នករាល់គ្នា អំពីការតយុទ្ធដែលខ្ញុំបាន
ធ្វើទៅចំពោះព្រះ នៅមុនពេលខ្ញុំបានទទួលការផ្ដាច់បាបទាំង
ឡាយ របស់ខ្ញុំ ។
៣ មើលចុះ ខ្ញុំបានទៅបរបាញ់សត្វនៅក្នុងព្រៃ; ហើយពាក្យ
ទាំងឡាយដែលខ្ញុំតែងបានឮឪពុកខ្ញុំនិយាយជាញឹកញាប់ អំពី
ជីវិតដ៏នៅ អស់កល្បជានិច្ច និងសេចក្ដីអំណរនៃពួកបរិសុទ្ធ
បានជ្រួតជ្រាបទៅក្នុងដួងចិត្តខ្ញុំ ។
៤ ហើយព្រលឹងខ្ញុំស្រេកឃ្លាន; ហើយខ្ញុំបានលុតជង្គង់ចុះ
នៅចំពោះព្រះដែលបង្កើតខ្ញុំ ហើយខ្ញុំបានអំពាវនាវដល់ព្រះអង្គ

២៥ *ក* ស.ប. ថ្ម.
២៦ *ក* ១ នីហ្វៃ ១៩:១–៦;
យ៉ារ៉ុម ១:១៤–១៥.
ស.ប. ផ្ទាំងទាំងឡាយ.
*ខ* យ៉ាកុប (ព.ស.ថ.) ៤:១៤.
២៧ *ក* អេណុស ១:១.
*ខ* យ៉ាកុប (ព.ម) ១:១–៤.

[អេណុស]
១ ១*ក* ស.ប. អេណុស, កូនប្រុសរបស់
យ៉ាកុប.
*ខ* ២ នីហ្វៃ ២:២–៤.
*គ* ១ នីហ្វៃ ១:១–២.
*ឃ* អេភេ. ៦:៤.
២ *ក* លោកុ. ៣២:២៤–៣២;
អាលម៉ា ៨:១០.
ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. ការផ្ដាច់បាប.
៣ *ក* ស.ប. សេចក្ដីអំណរ.
*ខ* ១ នីហ្វៃ ១០:១៧–១៩;
អាលម៉ា ៣៦:១៧–២១.
៤ *ក* ២ នីហ្វៃ ៩:៥១; ៣ នីហ្វៃ ១២:៦.
*ខ* ស.ប. ការគោរពកោតក្រែង.
*គ* ស.ប. ការអធិស្ឋាន.

ដោយការ អធិស្ឋាន និងការទូលអង្វរដ៏ខ្លាំង សំរាប់ព្រលឹងខ្ញុំផ្ទាល់; ហើយខ្ញុំបានអំពាវនាវដល់ព្រះអង្គអស់ពេញមួយថ្ងៃ; មែនហើយ ហើយដល់ ពេលយប់ ខ្ញុំបានស្រែកអំពាវនាវយ៉ាងខ្លាំង លុះត្រាបានឮដល់ស្ថានសួគ៌ ។

៥ ហើយស្រាប់តែមានសំឡេងបន្លឺមកខ្ញុំថា៖ អេណុស បាបទាំងឡាយរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ ហើយអ្នកនឹងបានពរ ។

៦ ហើយខ្ញុំ អេណុស ដឹងថា ព្រះពុំកុហកឡើយ; ហេតុដូច្នោះហើយ ទោសរបស់ខ្ញុំបានបំបាត់ចោលទៅ ។

៧ ហើយខ្ញុំបានទូលថា៖ ឱព្រះអម្ចាស់អើយ ចុះតើការណ៍នេះបានធ្វើយ៉ាងណាទៅ ?

៨ ហើយទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ពីព្រោះមកពីសេចក្ដីជំនឿដែលអ្នកមានដល់ព្រះគ្រីស្ទ ដែលអ្នកពុំដែលបានឮ ឬឃើញពីមុនមក ឡើយ ។ ហើយច្រើនឆ្នាំនឹងកន្លងផុតទៅមុនទ្រង់នឹងសម្ដែងរូបអង្គទ្រង់ នៅក្នុងសាច់ឈាម; ហេតុដូច្នោះហើយ ចូរអ្នកទៅចុះ សេចក្ដីជំនឿរបស់អ្នក បានជួយសង្គ្រោះអ្នកហើយ ។

៩ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលខ្ញុំឮពាក្យទាំងនេះហើយ នោះខ្ញុំក៏ចាប់ផ្ដើមមានអារម្មណ៍ប្រាថ្នាចង់បានសុខុមាលភាពដល់បងប្អូនខ្ញុំ ជាពួកសាសន៍នីហ្វៃ; ហេតុដូច្នោះហើយ ខ្ញុំបានស្ដុងព្រលឹងខ្ញុំទាំងមូលទៅព្រះ ដើម្បីពួកគេ។

១០ ហើយនៅពេលខ្ញុំកំពុងសញ្ជឹងក្នុងវិញ្ញាណ មើលចុះ សម្លេងនៃព្រះអម្ចាស់បានចូលមកក្នុងគំនិតខ្ញុំទៀតថា៖ យើងនឹងពិនិត្យ ពិច័យបងប្អូនអ្នក ស្របតាមសេចក្ដីព្យាយាមរបស់ពួកគេ ក្នុងការកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ។ យើងបានប្រទានដែនដីនេះ ដល់ពួកគេ ហើយគឺជាដែនដីបរិសុទ្ធ; ហើយយើងនឹងពុំដាក់បណ្ដាសាទេ លើកលែងតែមកពីអំពើទុច្ចរិត; ហេតុដូច្នោះហើយ យើងនឹង ពិនិត្យពិច័យដល់បងប្អូនអ្នក ដូចដែលយើងបានពោលមកហើយនោះ; ឯការរំលងទាំងឡាយរបស់ពួកគេ យើងនឹងទំលាក់ចុះ ដោយនូវ សេចក្ដីសោកសៅ ទៅលើក្បាលពួកគេ ។

១១ ហើយបន្ទាប់ពីខ្ញុំ អេណុស បានឮពាក្យទាំងនេះរួចហើយ នោះសេចក្ដីជំនឿរបស់ខ្ញុំ ក៏ខ្ជាប់ខ្ជួនទៅលើព្រះអម្ចាស់; ហើយខ្ញុំបាន អធិស្ឋានដល់ព្រះអង្គយ៉ាងយូរ ដើម្បីបងប្អូនរបស់ខ្ញុំ គឺពួកសាសន៍លេមិន ។

១២ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីខ្ញុំបានអធិស្ឋាន ហើយធ្វើការដោយអស់ពីចិត្ត នោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល មកខ្ញុំថា៖ យើងនឹងប្រទានដល់អ្នក ស្របតាមសេចក្ដីប៉ងប្រាថ្នាទាំងឡាយរបស់អ្នក ដោយសារសេចក្ដីជំនឿរបស់អ្នក ។

១៣ ហើយឥឡូវនេះ មើលចុះ នេះគឺជាសេចក្ដីប៉ងប្រាថ្នាដែលខ្ញុំបានប្រាថ្នាពីព្រះអង្គ — ថាប្រសិនបើប្រជាជនរបស់ខ្ញុំ គឺសាសន៍នីហ្វៃ ត្រូវធ្លាក់ទៅក្នុងការរំលង ហើយត្រូវបំផ្លាញចោលដោយមធ្យោបាយណាមួយ រីឯពួកសាសន៍លេមិនបែរជាពុំត្រូវបានបំផ្លាញទៅវិញ នោះសូមឲ្យព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់រក្សាបញ្ជីនៃប្រជាជនខ្ញុំ គឺសាសន៍នីហ្វៃ; គឺប្រសិនបើដោយព្រះចេស្ដានៃព្រះពាហុដ៏បរិសុទ្ធរបស់ ព្រះអង្គក៏ដោយ ក៏សូមឲ្យបញ្ជីនោះបានយកចេញមកផ្សាយ ក្នុងពេលអនាគត ដល់ពួកសាសន៍លេមិន ដើម្បីក្រែងពួកគេអាចបាននាំ មកឯសេចក្ដីសង្គ្រោះ —

១៤ ព្រោះនៅបច្ចុប្បន្នកាលនេះ ការប្រឹងប្រែងរបស់យើងបានទៅជាអសារឥតការ ក្នុងការនាំពួកគេមករកសេចក្ដីជំនឿដ៏ត្រឹមត្រូវ វិញ។ ហើយពួកគេបានស្បថនៅក្នុងកំហឹងថា បើមានលទ្ធភាព ពួកគេនឹងបំផ្លាញបញ្ជីរបស់ពួកយើង និងពួកយើងចោលព្រមទាំង ទំនៀមទំលាប់ទាំងឡាយរបស់ពួកអយ្យកោយើងចោលផង ។

១៥ ហេតុដូច្នោះហើយ ខ្ញុំ ដោយដឹងថា ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់អាចថែរក្សាបញ្ជីរបស់ពួកយើងបាន នោះខ្ញុំអំពាវនាវ

៥ *ក* ស.ប. វិវរណៈ.
៨ *ក* អេធើរ ៣:១២–១៣.
ស.ប. សេចក្ដីជំនឿ.
*ខ* ម៉ាថាយ ៩:២២.
៩ *ក* ១ នីហ្វៃ ៨:១២;
អាលម៉ា ៣៦:២៤.
*ខ* ២ នីហ្វៃ ៣៣:៣; ព. នៃ ម. ១:៨;
អាលម៉ា ៣៤:២៦–២៧.
១០ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត;
គំនិត.
*ខ* ១ នីហ្វៃ ២:២០.
*គ* អេធើរ ២:៧–១២.
១២ *ក* មរមន ៥:២១; ៩:៣៦.
*ខ* ទំនុក. ៣៧:៤; ១ នីហ្វៃ ៧:១២;
ហេលេ. ១០:៥.
១៣ *ក* មរមន ៦:១, ៦.
*ខ* ព. នៃ ម. ១:៦–១១;
អាលម៉ា ៣៧:២.
*គ* អាលម៉ា ៣៧:១៩;
អេធើរ ១២:២២;
គ. និង ស. ៣:១៨.
*ឃ* អាលម៉ា ៩:១៧.
១៤ *ក* យ៉ាកុប (ព.ម) ៧:២៤.
*ខ* មរមន ៦:៦.
១៥ *ក* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរ
ដែលត្រូវរក្សាទុក.

ដល់ ព្រះអង្គឥតឈប់ឈរ ព្រោះព្រះអង្គទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ អ្វីក៏ដោយ ដែលអ្នកសូមដោយសេចក្ដីជំនឿ ដោយជឿថា អ្នកនឹង បានទទួល ដោយនូវព្រះនាមនៃព្រះគ្រីស្ទ អ្នកនឹងបានទទួលជាមិនខានឡើយ ។

១៦ នោះខ្ញុំមានសេចក្ដីជំនឿ ហើយខ្ញុំបានអំពាវនាវដល់ព្រះសូមឲ្យព្រះអង្គថែរក្សាបញ្ជីទាំងឡាយ; ហើយទ្រង់បានធ្វើសេចក្ដី សញ្ញានឹងខ្ញុំថា ព្រះអង្គនឹងនាំយកបញ្ជីទាំងនោះ ទៅផ្សាយដល់ពួកសាសន៍លេមិន នៅពេលកំណត់របស់ទ្រង់ ។

១៧ ហើយខ្ញុំ អេណុស បានដឹងថា រឿងនេះនឹងកើតឡើងស្របតាមសេចក្ដីសញ្ញាដែលទ្រង់បានធ្វើ; ហេតុដូច្នោះហើយព្រលឹងខ្ញុំក៏ បានស្ងប់ស្ងៀមទៅ ។

១៨ ហើយព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ពួកអយ្យកោរបស់អ្នកក៏បានសូមដល់យើង អំពីរឿងនេះដែរ; ហើយសំណូមពរ របស់ពួកគេ នឹងបានសំរេចដោយសេចក្ដីជំនឿរបស់ពួកគេ; ត្បិតសេចក្ដីជំនឿរបស់ពួកគេ ក៏ដូចជាសេចក្ដីជំនឿរបស់អ្នកដែរ ។

១៩ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ខ្ញុំអេណុស បានធ្វើដំណើរនៅក្នុងចំណោមប្រជាជននីហ្វៃ ព្យាករអំពីរឿង ដែលនឹងមកដល់ ហើយធ្វើបន្ទាល់អំពីរឿងទាំងឡាយ ដែលខ្ញុំបានឮ ហើយបានឃើញមក ។

២០ ហើយខ្ញុំធ្វើបន្ទាល់ថា ប្រជាជននីហ្វៃបានព្យាយាមស្វែងរកផ្លូវ ដើម្បីតម្រែតម្រង់ពួកសាសន៍លេមិនឡើងវិញឲ្យទៅតាម សេចក្ដីជំនឿដ៏ពិតដល់ព្រះ ។ ប៉ុន្តែការខំប្រឹងប្រែងរបស់ពួកយើង បែរជាឥតប្រយោជន៍ទៅវិញ; សេចក្ដីស្អប់របស់ពួកគេពុំប្រែប្រួល សោះឡើយ ហើយពួកគេត្រូវបានដឹកនាំ ដោយចរិតអាក្រក់របស់ពួកគេ ឲ្យក្លាយទៅជាព្រៃផ្សៃ ហើយកាចសាហាវ ហើយជាជនជាតិ ដែលស្រេកឈាមពោរពេញទៅដោយការគោរពរូបព្រះ និងអំពើស្មោកគ្រោក; ចិញ្ចឹមជីវិតដោយសត្វព្រៃ; អាស្រ័យរស់នៅក្នុង ត្រសាលហើយដើរសោត់ព្រាត់នៅក្នុងទីរហោស្ថាន ដោយស្លៀកប៉ឹងស្បែកដ៏ខ្លីមួយនៅចង្កេះ ហើយក្បាលត្រងោល; ឯថ្វីដៃរបស់គេ គឺនៅលើការប្រើធ្នូ និងដាវ និងពូថៅ ។ ហើយពួកគេភាគច្រើន ពុំបរិភោគអ្វី ក្រៅពីសាច់ឆៅនោះទេ; ហើយពួកគេស្វែងរកបំផ្លាញ ពួកយើង ពុំមានឈប់ឈរសោះ ។

២១ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជននីហ្វៃបានភ្ជួររាស់ដី ហើយដាំស្រូវ និងផ្លែឈើគ្រប់យ៉ាង ហើយចិញ្ចឹមសត្វទាំង ហ្វូងៗ និងហ្វូងគោក្របីគ្រប់មុខ ព្រមទាំងពពែនិងពពែព្រៃ និងសេះជាច្រើនផង ។

២២ ហើយមានព្យាការីជាច្រើនណាស់ នៅក្នុងចំណោមពួកយើង ។ ឯប្រជាជនជាប្រជាជនរឹងចចេសកម្រយល់ ។

២៣ ហើយគ្មានអ្វីក្រៅពីការតឹងតែង ការប្រកាសប្រដៅនិងពាក្យព្យាករណ៍អំពីសង្គ្រាមទាំងឡាយ និងការទាស់ទែងគ្នាទាំងឡាយ និងការបំផ្លិចបំផ្លាញទាំងឡាយ និងការរំឭកពួកគេជាញយៗ អំពីសេចក្ដីស្លាប់ និងដំណើរអមតៈ និងសេចក្ដីជំនុំជំរះទាំងឡាយ និងព្រះចេស្ដានៃព្រះ និងគ្រប់ការណ៍ទាំងអស់នេះ — រំជួលដាស់ពួកគេឥតឈប់ឈរ ដើម្បីធ្វើឲ្យពួកគេកោតខ្លាចដល់ព្រះអម្ចាស់ ។ ខ្ញុំសូមនិយាយថា គ្មានអ្វីក្រៅពីរឿងទាំងនេះ ហើយដោយវាចាដ៏ច្បាស់លាស់ ដែលនឹងឃាយឃាំងកុំឲ្យពួកគេធ្លាក់យ៉ាងលឿន ទៅក្នុងសេចក្ដីបំផ្លិចបំផ្លាញ ។ ហើយដោយរបៀបនេះហើយដែលខ្ញុំសរសេរអំពីពួកគេ ។

២៤ ហើយខ្ញុំបានឃើញសង្គ្រាមទាំងឡាយរវាងពួកសាសន៍នីហ្វៃនឹងពួកសាសន៍លេមិន នៅក្នុងដំណើរនៃជីវិតរបស់ខ្ញុំ ។

២៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានចាប់ផ្ដើមមានចំណាស់ចាស់ ហើយរយៈពេលមួយរយចិតសិបប្រាំបួនឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីពេលដែលលីហៃ ជាអយ្យកោរបស់យើង បានចាកចេញពីក្រុងយេរូសាឡិមមក ។

២៦ ហើយខ្ញុំបានឃើញថា ជិតដល់ពេលខ្ញុំចុះទៅក្នុងផ្នូររបស់ខ្ញុំហើយ ដោយព្រះចេស្ដានៃព្រះបានសណ្ឋិតមកលើខ្ញុំថា ខ្ញុំត្រូវផ្សាយ ហើយព្យាករដល់ប្រជាជននេះ ហើយថ្លែងនូវពាក្យពេចន៍ ស្របតាមសេចក្ដីពិត ដែលមាននៅក្នុងព្រះគ្រីស្ទ ។

---

១៦ *ក* ៣ នីហ្វៃ ៥:១៣–១៥;
គ. និង ស. ៣:១៩–២០;
១០:៤៦–៥០.
*ខ* ស.ប. ព្រះគម្ពីរមរមន.
*គ* ២ នីហ្វៃ ២៧:៦.
២០ *ក* មរ៉ូណៃ ៩:៦.
*ខ* យ៉ារ៉ុម ១:៦.
*គ* ម៉ូសាយ ៩:១២.
ស.ប. ការថ្វាយបង្គំរូបព្រះ.
*ឃ* ម៉ូសាយ ១០:៨.
២១ *ក* ម៉ូសាយ ៩:៩.
២២ *ក* ព. នៃ ម. ១:១៦–១៨.
*ខ* យ៉ារ៉ុម ១:៣.
២៣ *ក* ១ នីហ្វៃ ១៦:២; ២ នីហ្វៃ ៣៣:៥.
*ខ* ស.ប. ផ្សាយ.
*គ* ហេលេ. ១២:៣.
*ឃ* យ៉ារ៉ុម ១:១២; អាលម៉ា ៣១:៥.
២៥ *ក* ១ នីហ្វៃ ២:២–៤.

ហើយខ្ញុំបានថ្លែងពាក្យ ពិតនោះអស់មួយជីវិតរបស់ខ្ញុំ ហើយ
បានអររីករាយក្នុងកិច្ចការនេះ លើកិច្ចការណាៗទាំងអស់នៅ
ក្នុងលោកនេះ ។
២៧ ហើយនៅមិនយូរប៉ុន្មានទេ ខ្ញុំនឹងទៅរក[ក]ទីសំរាករបស់ខ្ញុំ
ហើយ គឺជាទីជាមួយនឹងព្រះដ៏ប្រោសលោះរបស់ខ្ញុំ; ព្រោះខ្ញុំដឹងថា
ខ្ញុំនឹងសំរាកនៅក្នុងព្រះអង្គ ។ ហើយខ្ញុំអររីករាយនៅក្នុងថ្ងៃ
ដែល[ខ]ជីវិតរបស់ខ្ញុំនេះ នឹងបានប្រដាប់ដោយ[គ]អមតភាព ហើយ
នឹងឈរនៅ ចំពោះព្រះអង្គ; ខណៈនោះ ខ្ញុំនឹងបានឃើញ
ព្រះភក្ត្រទ្រង់ ដោយសេចក្ដីសោមនស្ស ហើយព្រះអង្គនឹងមាន
ព្រះបន្ទូលមកខ្ញុំថា៖ ចូរមករក យើងចុះ អ្នកមានពរហើយ មាន
ទីកន្លែងមួយ ដែលបានរៀបចំសំរាប់អ្នក នៅក្នុង[ឃ]វិមានរបស់ព្រះ
វរបិតាយើង ។ អាម៉ែន ៕ :៚

# គម្ពីរយ៉ារ៉ុម

*ពួកសាសន៍នីហ្វៃកាន់តាមក្រិត្យវិន័យលោកម៉ូសេ, ទន្ទឹងចាំការយាងមកនៃព្រះគ្រីស្ទ, ហើយបានចំរើនឡើងនៅលើដែនដី — ព្យាការី ជាច្រើនខិតខំធ្វើការ ដើម្បីរក្សាប្រជាជនឲ្យនៅក្នុងផ្លូវដ៏ពិត ។ ប្រមាណជាឆ្នាំ ៣៩៩–៣៦១ ម.គ.ស. ។*

ឥឡូវនេះ មើលចុះ ខ្ញុំ យ៉ារ៉ុម នឹងសរ[ក]សេរពាក្យខ្លះ
ស្របតាមបញ្ជាពីឪពុកខ្ញុំ គឺអេណុស ដើម្បីឲ្យពង្សាវតារ
របស់យើងអាចបានកត់ទុក ។
២ ហើយដោយ[ក]ផ្ទាំងទាំងនេះ[ខ]តូចពេក ហើយដោយរឿង
ទាំងនេះ[គ]ត្រូវបានសរសេរ ដើម្បីទុកជាប្រយោជន៍ដល់បងប្អូនយើង
គឺពួក[ឃ] សាសន៍លេមិន នោះខ្ញុំត្រូវការសរសេរបន្តិចបន្តួច; ប៉ុន្តែ
ខ្ញុំមិនសរសេរ អំពីរឿងនៃការព្យាករណ៍ ដែលខ្ញុំព្យាករ ឬអំពីរឿង
នៃវិវរណៈ ទាំងឡាយរបស់ខ្ញុំទេ ។ ត្បិតតើខ្ញុំអាចសរសេរ
លើសជាងអ្វីដែលពួកអយ្យកោខ្ញុំបានសរសេរនោះ? ត្បិតតើពួក
អយ្យកោរបស់ខ្ញុំមិន ទាន់បានបើកសម្ដែងប្រាប់ នូវផែនការនៃ
សេចក្ដីសង្គ្រោះរួចហើយទេឬអី ? ខ្ញុំសូមប្រាប់អ្នករាល់គ្នាថា៖
មែនហើយ; ហើយការណ៍នេះ ល្មមគ្រប់គ្រាន់សំរាប់ខ្ញុំហើយ ។
៣ មើលចុះ ជាការចាំបាច់ថា ត្រូវមានការណ៍ច្រើនដែលត្រូវ
ធ្វើឡើងនៅក្នុងចំណោមប្រជាជននេះ ពីព្រោះមកពីភាពរឹងរូស នៃ
ចិត្តរបស់គេ ភាពថ្លង់នៃត្រចៀករបស់គេ ភាពងងឹតងងល់នៃគំនិត
របស់គេ និង[ក]ករឹងរបស់គេ; ទោះជាយ៉ាងណាក៏ដោយ គង់តែ
ព្រះទ្រង់មានសេចក្ដីមេត្តាករុណាជាអតិបរមាដល់គេដែរ
ហើយពុំទាន់[ខ]បោសជំរះគេ ចេញពីផ្ទៃដីនេះនៅឡើយ ។
៤ ហើយមានមនុស្សជាច្រើននៅក្នុងចំណោមពួកយើង ដែល
មាន[ក]វិវរណៈជាច្រើន ព្រោះពួកគេពុំមែនជាមនុស្សរឹងរូសឡើយ
ហើយ អស់អ្នកណាដែលមិនធ្វើចិត្តរឹងរូស តែមានសេចក្ដីជំនឿវិញ
នោះមានសេចក្ដី[ខ]រួបរួមគ្នានឹងព្រះវិញ្ញាណបរិសុទ្ធ គឺដែលសម្ដែងឲ្យ
កូនចៅ មនុស្សឃើញ ស្របតាមសេចក្ដីជំនឿរបស់គេ ។
៥ ហើយឥឡូវនេះ មើលចុះ ពីររយឆ្នាំបានកន្លងផុតទៅ
ឯប្រជាជននីហ្វៃបានទៅជាខ្លាំងពូកែ នៅក្នុងដែនដី ។ ពួកគេ
បាន[ក]គោរព តាមក្រិត្យវិន័យលោកម៉ូសេ ហើយញែក[ខ]ថ្ងៃ
ឈប់សំរាក ទុកជាថ្ងៃបរិសុទ្ធ ថ្វាយព្រះអម្ចាស់ ។ ហើយពួក
គេមិន[គ]ជេរ ឬក៏ពោលពាក្យ[ឃ] ប្រមាថព្រះឡើយ ។ ឯច្បាប់
ដែនដីក៏តឹងរឹងណាស់ ។

២៧ *ក* ស.ប. សេចក្ដីសំរាក.
*ខ* ស.ប. ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់.
*គ* ស.ប. អមតៈ, អមតភាព.
*ឃ* យ៉ូហាន ១៤:២–៣;
អេធើរ ១២:៣២–៣៤;
គ. និង ស. ៧២:៤; ៩៨:១៨.

[យ៉ារ៉ុម]
១ ១*ក* ១ នីហ្វៃ ៣:១២; ៥:១៤.
២ *ក* យ៉ាកុប (ព.ម) ៣:១៤;
អោមណៃ ១:១.
*ខ* ១ នីហ្វៃ ៦:១–៦.
*គ* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ឃ* ២ នីហ្វៃ ២៧:៦; មរមន ៥:១២.
៣ *ក* អេណុស ១:២២–២៣.
*ខ* អេធើរ ២:៨–១០.
៤ *ក* អាលម៉ា ២៦:២២;
ហេលេ. ១១:២៣;
គ. និង ស. ១០៧:១៨–១៩.
ស.ប. វិវរណៈ.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៥ *ក* ២ នីហ្វៃ ២៥:២៤;
អាលម៉ា ៣៤:១៣–១៤.
*ខ* និក្ខ. ៣៥:២.
ស.ប. ថ្ងៃឈប់សំរាក.
*គ* ស.ប. សេចក្ដីមើលងាយ.
*ឃ* ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.

៦ ហើយពួកគេរស់នៅពាសពេញលើផ្ទៃដីជាច្រើន ឯពួក
សាសន៍លេមិនក៏ដូច្នោះដែរ ។ ឯពួកគេមានចំនួនលើសច្រើនជាង
ពួកសាសន៍នីហ្វៃ; ហើយពួកគេចូលចិត្តប្រព្រឹត្តការកាប់សម្លាប់
ហើយហុតឈាមសត្វ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានមកធ្វើ
ចម្បាំងនឹងយើង ជាសាសន៍នីហ្វៃ ជាច្រើនគ្រាច្រើនដង ។
ប៉ុន្តែពួកស្ដេច និងពួកមេដឹកនាំរបស់យើង សុទ្ធតែជាមនុស្ស
ខ្លាំងពូកែ ដែលមានសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់; ហើយ
ពួកគេបានបង្រៀនប្រជាជន អំពីផ្លូវទាំងឡាយនៃព្រះអម្ចាស់;
ហេតុដូច្នោះហើយ ទើបយើងទប់ទល់នឹងពួកសាសន៍លេមិន
បាន ហើយបានបោសជំរះពួកគេចេញ ពីដែនដីយើងផង ហើយ
បានចាប់ផ្ដើមបង្កើនកម្លាំងដល់ទីក្រុងរបស់យើង ឬទីណាដែល
ជាដីកេរ្ដិ៍អាកររបស់យើង ។
៨ ហើយយើងបានកើនចំនួនជាច្រើន ហើយបានរាលពាសពេញ
លើផ្ទៃដែនដី ហើយបានក្លាយទៅជាអ្នកមានដ៏លើសលប់ គឺមាន
មាស ហើយមានប្រាក់ និងវត្ថុមានតម្លៃ និងឈើក្បាច់ និងអាគារ
និងគ្រឿងម៉ាស៊ីន និងដែក និងស្ពាន់ផងដែរ និងលង្ហិន
និងដែកថែបជាច្រើន ដែលយើងយកមកធ្វើជាគ្រឿងឧបករណ៍
គ្រប់យ៉ាង សំរាប់ភ្ជួរដី ព្រមទាំងធ្វើគ្រឿងសស្ត្រាវុធពិជ័យ
សង្គ្រាម ទាំងឡាយ — មែនហើយ ដូចជាព្រួញស្រួច
និងបំពង់ដាក់ព្រួញ និងស្ន និងលំពែង និងអស់ទាំងការរៀបចំ
គ្រប់មុខសំរាប់ធ្វើសង្គ្រាម ។
៩ ហើយយើងបានរៀបចំចាំទប់ទល់នឹងពួកសាសន៍លេមិនយ៉ាង
ដូច្នោះហើយ ទើបពួកគេមិនបានចំរើនឡើងលើសយើងឡើយ ។
ប៉ុន្តែព្រះបន្ទូលនៃព្រះអម្ចាស់ត្រូវបានបញ្ជាក់ ដែលទ្រង់មានព្រះ
បន្ទូលទៅកាន់ពួកអយ្យកោយើងពីមុនថា៖ ដរាបណាអ្នករាល់
គ្នាកាន់ តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹង
បានចំរើនឡើងនៅលើដែនដី ។
១០ ហើយហេតុការណ៍បានកើតឡើងថា ពួកព្យាការីនៃព្រះ
អម្ចាស់បានព្រមានប្រជាជននីហ្វៃ ស្របតាមព្រះបន្ទូលនៃព្រះថា បើ
សិនជាពួកគេពុំកាន់តាមព្រះបញ្ញត្តិទាំងឡាយទេ តែធ្លាក់ទៅ
ក្នុងការរំលងវិញ នោះពួកគេនឹងត្រូវបំផ្លាញឲ្យផុតពីផ្ទៃដី ។
១១ ហេតុដូច្នោះហើយ ពួកព្យាការី និងពួកសង្ឃ និងពួក
គ្រូប្រដៅ បានខិតខំធ្វើការ ដោយដាស់តឿនអស់ពីការអត់ធ្មត់
ឲ្យប្រជា ជនមានការព្យាយាម; ដោយបង្រៀនក្រិត្យវិន័យលោកម៉ូសេ
និងបំណងដែលក្រិត្យវិន័យនេះបានចែងមក; ដោយបញ្ចុះបញ្ចូល
ពួកគេ ឲ្យទន្ទឹងចាំព្រះមែស៊ី ហើយឲ្យជឿដល់ទ្រង់ដែលនឹងយាង
មក ហាក់ដូចជាទ្រង់បានយាងមករួចហើយដូច្នោះ ។ ហើយ
តាមបែបនេះ ហើយដែលពួកគេបានបង្រៀនប្រជាជន ។
១២ ហើយហេតុការណ៍បានកើតឡើងថា ដោយធ្វើ
យ៉ាងនេះ នោះពួកគេបានការពារប្រជាជន មិនឲ្យត្រូវបំផ្លាញ
បង់ពីលើផ្ទៃដីនេះ ទៅ; ព្រោះពួកគេបានចាក់ចិត្តប្រជាជន
ដោយពាក្យសំដី គឺដាស់រំជួលឲ្យប្រជាជនប្រែចិត្តជានិច្ច ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ពីររយសា
មសិបប្រាំបីឆ្នាំបានកន្លងផុត — ដោយមានសង្គ្រាមទាំង
ឡាយ និងការទាស់ ទែងគ្នាទាំងឡាយ និងការបែកបាក់គ្នា
ទាំងឡាយ អស់រយៈពេលជាច្រើន ។
១៤ ហើយខ្ញុំ យ៉ារ៉ុម ឈប់សរសេរទៀតហើយ ព្រោះផ្ទាំង
ទាំងនេះតូចពេក ។ ប៉ុន្តែមើលចុះ ឱបងប្អូនរបស់ខ្ញុំអើយ អ្នក
រាល់គ្នា អាចទៅរកផ្ទាំងនីហ្វៃផ្សេងទៀត; ត្បិតមើលចុះ
នៅលើផ្ទាំងទាំងនោះហើយ ដែលមានបញ្ជីអំពីសង្គ្រាមទាំង
ឡាយនៃយើង ស្របតាម ការកត់ត្រានៃពួកស្ដេច ឬពួកអ្នក
ដែលត្រូវគេចាត់ឲ្យសរសេរ ។
១៥ ហើយខ្ញុំសូមប្រគល់ផ្ទាំងទាំងនេះដល់ដៃអោមណៃ ជា
កូនប្រុសរបស់ខ្ញុំ ដើម្បីឲ្យផ្ទាំងទាំងនេះត្រូវបានកត់ទុក ស្របតាម
បញ្ជា ទាំងឡាយពីពួកអយ្យកោខ្ញុំ ៕ :ល៚

៦ *ក* យ៉ាកុប (ព.ម) ៧:២៤;
អេណុស ១:២០.
៧ *ក* យ៉ាកុប (ព.ម) ១:៩, ១១, ១៥.
*ខ* ព. នៃ ម. ១:១៤.
៨ *ក* ម៉ូសាយ ១០:៨.
១០ *ក* ១ នីហ្វៃ ១២:១៩–២០;
អោមណៃ ១:៥.
១១ *ក* យ៉ាកុប (ព.ម) ៤:៥;
អាលម៉ា ២៥:១៥–១៦.
*ខ* ២ នីហ្វៃ ១១:៤;
អេធើរ ១២:១៨–១៩.
*គ* ២ នីហ្វៃ ២៥:២៤–២៧;
ម៉ូសាយ ៣:១៣; ១៦:៦.
១២ *ក* អេធើរ ២:១០.
*ខ* អាលម៉ា ៣១:៥.
១៤ *ក* ១ នីហ្វៃ ៩:២–៤.
១៥ *ក* យ៉ាកុប (ព.ម) ១:១–៤.

# គម្ពីរអោមណៃ

*អោមណៃ, អ័ម៉ារ៉ុន, កេមីស, អ័ប៊ីណាដុម, និងអាម៉ាលេកៃ ផ្លាស់គ្នាកត់បញ្ជីទាំងឡាយ — ម៉ូសាយជួបប្រទះប្រជាជនសារ៉ាហិមឡា ដែលចេញមកពីក្រុងយេរូសាឡិម នៅក្នុងជំនាន់សេដេគា — ម៉ូសាយត្រូវគេលើកឲ្យធ្វើជាស្ដេច — ពួកពូជពង្សនៃម៉ូលេកនៅឯ សារ៉ាហិមឡា បានជួបកូរីអានទុមើរ ជាមនុស្សចុងក្រោយបង្អស់នៃពួកសាសន៍យ៉ារេឌ — ស្ដេចបេនយ៉ាមីនសោយរាជ្យជំនួសម៉ូសាយ — មនុស្ស លោកត្រូវថ្វាយព្រលឹងខ្លួន ជាដង្វាយថ្វាយដល់ព្រះគ្រីស្ទ ។ ប្រមាណជាឆ្នាំ ៣២៣–១៣០ ម.គ.ស. ។*

មើលចុះ ហេតុការណ៍បានកើតឡើងថា ខ្ញុំ អោមណៃ ដោយបានទទួលបញ្ជាពីឪពុកខ្ញុំ គឺយ៉ារ៉ុម ថាខ្ញុំត្រូវសរសេររឿងខ្លះ នៅលើផ្ទាំង ទាំងនេះ ដើម្បីរក្សាពង្សាវតាររបស់យើងទុកឲ្យបានគង់វង់ —

២ ហេតុដូច្នោះហើយ ក្នុងជីវិតខ្ញុំនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា ខ្ញុំបានប្រយុទ្ធជាច្រើនដងដោយដាវ ដើម្បីការពារប្រជាជនខ្ញុំ គឺសាសន៍នីហ្វៃ កុំឲ្យធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ពួកខ្មាំងសត្រូវរបស់គេ គឺពួកសាសន៍លេមិន ។ ប៉ុន្តែមើលចុះ រូបខ្ញុំនេះផ្ទាល់ជា មនុស្សទុច្ចរិត ហើយខ្ញុំពុំបានកាន់តាមវិន័យ និងព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ដែលខ្ញុំគួរតែកាន់តាមនោះទេ ។

៣ ហើយហេតុការណ៍បានកើតឡើងថា ពីររយចិតសិបប្រាំមួយឆ្នាំបានកន្លងផុតទៅ ហើយយើងបានប្រកបដោយសេចក្ដីសុខសាន្ត ជាច្រើនរដូវ; ហើយយើងមានសង្គ្រាម និងការខ្ចាយឈាមដ៏ធ្ងន់ធ្ងរ អស់ជាច្រើនរដូវដែរ ។ មែនហើយ សរុបសេចក្ដីមក គឺពីររយ ប៉ែតសិបពីរឆ្នាំបានកន្លងផុតទៅ ហើយខ្ញុំបានរក្សាផ្ទាំងទាំងនេះទុក ស្របតាមបញ្ជានៃពួកអយ្យកោខ្ញុំ; ហើយខ្ញុំបានប្រគល់ផ្ទាំងទាំងនេះ ដល់កូនប្រុសខ្ញុំ គឺអ័ម៉ារ៉ុន ហើយខ្ញុំសូមបញ្ចប់តែត្រឹមនេះសិនចុះ ។

៤ ហើយឥឡូវនេះ ខ្ញុំ អ័ម៉ារ៉ុន សរសេរនូវអ្វីៗដែលខ្ញុំសរសេរ គឺរឿងបន្តិចបន្តួច នៅក្នុងសៀវភៅរបស់ឪពុកខ្ញុំ ។

៥ មើលចុះ ហេតុការណ៍បានកើតឡើងថា បីរយម្ភៃឆ្នាំបានកន្លងផុតទៅ ហើយភាគច្រើននៃពួកសាសន៍នីហ្វៃដែលទុច្ចរិតនោះត្រូវ បានបំផ្លាញចោល ។

៦ ត្បិតព្រះអម្ចាស់ទ្រង់មិនទ្រាំ គឺបន្ទាប់ពីទ្រង់បាននាំពួកគេចេញពីដែនដីយេរូសាឡិម ហើយបានការពារពួកគេទុក មិនឲ្យធ្លាក់ ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវពួកគេ មែនហើយ ទ្រង់នឹងមិនទ្រាំឲ្យព្រះបន្ទូលរបស់ទ្រង់ ពុំបានបញ្ជាក់នោះឡើយ ដែលទ្រង់មាន ព្រះបន្ទូលទៅនឹងពួកអយ្យកោយើងថា៖ ដរាបណាអ្នករាល់គ្នាមិនកាន់តាមបញ្ញត្តិទាំងឡាយរបស់យើងទេ នោះអ្នករាល់គ្នានឹងពុំបាន ចំរើនឡើង នៅលើដែនដីសោះឡើយ ។

៧ ហេតុដូច្នោះហើយ ព្រះអម្ចាស់ទ្រង់បានមកពិនិត្យពិច័យពួកគេ ដោយសេចក្ដីជំនុំជំរះដ៏ធំ; ទោះជាយ៉ាងណាក៏ដោយគង់តែទ្រង់ បានប្រណីដល់ពួកសុចរិត ដើម្បីកុំឲ្យពួកគេត្រូវវិនាសឡើយ តែទ្រង់បានរំដោះពួកគេឲ្យរួចពីកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវរបស់គេវិញ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានប្រគល់ផ្ទាំងទាំងឡាយទៅឲ្យប្អូនប្រុសរបស់ខ្ញុំ គឺកេមីស ។

៩ ឥឡូវនេះ ខ្ញុំ កេមីស សរសេរនូវរឿងបន្តិចបន្តួចដែលខ្ញុំសរសេរ នៅក្នុងសៀវភៅដដែល ដែលបងប្រុសខ្ញុំបានសរសេរនោះ; ត្បិតមើលចុះ ខ្ញុំបានឃើញអក្សរចុងក្រោយបង្អស់ ដែលបងខ្ញុំបានសរសេរ គឺលោកបានសរសេរ ដោយដៃលោកផ្ទាល់; ហើយលោក បានសរសេរនៅថ្ងៃ ដែលលោកបានប្រគល់ផ្ទាំងទាំងនេះដល់ខ្ញុំ ។ ហើយតាមរបៀបនេះហើយដែលយើងបានកត់បញ្ជីទាំងឡាយទុក ព្រោះនេះគឺជាបញ្ជាពីពួកអយ្យកោយើង ហើយខ្ញុំសូមបញ្ចប់តែត្រឹមនេះសិនចុះ ។

១០ មើលចុះ ខ្ញុំ អ័ប៊ីណាដុម ជាកូនប្រុសរបស់កេមីស ។ មើលចុះ ហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញសង្គ្រាម និងការទាស់ ទែងគ្នាជាច្រើនរវាងប្រជាជនខ្ញុំ គឺពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន; ហើយដោយដាវផ្ទាល់របស់ខ្ញុំ ខ្ញុំបានផ្ដាច់ជីវិតនៃពួក សាសន៍លេមិនជាច្រើន ដើម្បីការពារបងប្អូនខ្ញុំ ។

១១ ហើយមើលចុះ បញ្ជីនៃប្រជាជននេះ ត្រូវបានឆ្លាក់ត្រានៅលើផ្ទាំងទាំងឡាយ ដែលស្ដេចទាំងឡាយបានរក្សាទុក តាមតំណទាំង ឡាយ; ហើយខ្ញុំពុំស្គាល់វិវរណៈណាទេ លើកលែងតែអ្វីដែលបានសរសេរមកនោះ ឬក៏ការព្យាករណ៍ណាដែរ; ហេតុដូច្នោះហើយ អ្វីដែលបានសរសេរមកនេះគឺល្មមគ្រប់គ្រាន់ហើយ ហើយខ្ញុំសូមបញ្ចប់តែត្រឹមនេះសិនចុះ ។

១២ មើលចុះ ខ្ញុំ អាម៉ាលេកៃ ជាកូនប្រុសរបស់អ័ប៊ីណាដុម ។

[អោមណៃ]
១ ៣ *ក* យ៉ាកុប (ព.ម) ១:១–៤; យ៉ារ៉ុម ១:១៥.
៥ *ក* យ៉ារ៉ុម ១:៩–១០.

មើលចុះ ខ្ញុំសូមនិយាយទៅអ្នកបន្តិចអំពីម៉ូសាយ ដែលត្រូវបាន
តាំង ឲ្យធ្វើជាស្ដេចនៅលើដែនដីសារ៉ាហិមឡា; ត្បិតមើលចុះ
លោកត្រូវបានព្រមានពីព្រះអម្ចាស់ថា លោកត្រូវភៀសខ្លួន
ចេញពីដែនដីនីហ្វៃ ហើយអស់អ្នកណាដែលស្ដាប់តាមសម្លេង
នៃព្រះអម្ចាស់ ក៏គួរតែចាកចេញពីដែនដីនេះជាមួយលោកដែរ
ហើយចូលទៅក្នុង ទីរហោស្ថាន–
១៣ ហើយហេតុការណ៍បានកើតឡើងថា លោកបានធ្វើ
តាមអ្វីដែលព្រះអម្ចាស់ ទ្រង់បានបញ្ជាដល់លោក ។ ហើយ
ពួកគេបាន ចេញពីដែនដី ចូលទៅក្នុងទីរហោស្ថាន គឺអស់អ្នក
ណាដែលស្ដាប់តាមសម្លេងនៃព្រះអម្ចាស់; ហើយពួកគេត្រូវបាន
ដឹកនាំ ដោយការ ផ្សាយសាសនា និងការព្យាករណ៍ជាច្រើន ។
ហើយពួកគេត្រូវបានដាស់តឿនមិនឈប់ឈរ ដោយព្រះបន្ទូល
នៃព្រះ; ហើយពួកគេ ត្រូវបានដឹកនាំ ដោយព្រះចេស្ដានៃ
ព្រះពាហុរបស់ទ្រង់ កាត់តាមទីរហោស្ថាន រហូតដល់ពួកគេ
បានចុះទៅដល់ដែនដីមួយ ដែលហៅថា សារ៉ាហិមឡា ។
១៤ ហើយពួកគេបានជួបប្រទះប្រជាជនមួយ ដែលហៅថា
ប្រជាជនសារ៉ាហិមឡា ។ ឥឡូវនេះ មានការអររីករាយជាខ្លាំង
នៅក្នុងចំណោមប្រជាជនសារ៉ាហិមឡា; ឯសារ៉ាហិមឡាក៏បានអរ
រីករាយជាខ្លាំងដែរ ពីព្រោះព្រះអម្ចាស់ទ្រង់បានបញ្ជូនមកជា
មួយនឹង ប្រជាជនម៉ូសាយ នូវផ្ទាំងលង្ហិន ដែលមានបញ្ជីនៃពួក
សាសន៍យូដា ។
១៥ មើលចុះ ហេតុការណ៍បានកើតឡើងថា ម៉ូសាយបាន
ឃើញថា ប្រជាជនសារ៉ាហិមឡា បានចេញមក
ពីក្រុងយេរូសាឡិមមក នៅក្នុងគ្រាដែលសេដេគា ជាស្ដេច
នៃស្រុកយូដា ត្រូវចាប់ជាឈ្លើយ យកទៅឯក្រុងបាប៊ីឡូន ។
១៦ ហើយពួកគេបានធ្វើដំណើរក្នុងទីរហោស្ថាន ហើយ
ព្រះហស្តនៃព្រះអម្ចាស់ បាននាំឆ្លងកាត់ទឹកដ៏ធំធេង មកឯដែនដី
ដែល ម៉ូសាយបានជួបគេនោះ; ហើយពួកគេបានរស់នៅទីនោះ
ចាប់តាំងពីពេលនោះមក ។
១៧ ហើយនៅពេលដែលម៉ូសាយបានជួបគេ នោះពួកគេ
មានចំនួនច្រើនអនេក ។ ទោះជាយ៉ាងណាក៏ដោយ គង់តែពួក
គេធ្លាប់ មានសង្គ្រាមជាច្រើន និងការទាស់ទែងគ្នាដ៏ធំដែរ
ហើយត្រូវស្លាប់ដោយដាវជាច្រើនគ្រា; ឯភាសារបស់ពួកគេ
បានក្លាយទៅជាប្រែ ប្រួល; ហើយពួកគេមិនបានយកកបញ្ជី
តាមខ្លួនមកឡើយ; ហើយពួកគេមិនទទួលស្គាល់ព្រះដ៏បង្កបង្កើត
របស់ពួកគេទេ; ឯម៉ូសាយ ព្រមទាំងប្រជារាស្ត្ររបស់ម៉ូសាយ
មិនអាចយល់ភាសាគេបានឡើយ ។
១៨ ប៉ុន្តែហេតុការណ៍បានកើតឡើងថា ម៉ូសាយបានធ្វើឲ្យ
ពួកគេរៀនភាសារបស់លោក ។ ហើយហេតុការណ៍
បានកើតឡើងថា បន្ទាប់ពីពួកគេរៀនភាសារបស់ម៉ូសាយហើយ
សារ៉ាហិមឡាបានប្រាប់អំពីពង្សាវតាររបស់ពួកអយ្យកោលោក
ស្របតាមដែលលោក ចាំបាន; ហើយប្រវត្តិទាំងនោះបាន
សរសេរទុក តែមិនមែននៅលើផ្ទាំងទាំងនេះទេ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនសារ៉ាហិមឡា
និងប្រជាជនរបស់ម៉ូសាយបានរួបរួមគ្នា ហើយម៉ូសាយត្រូវបាន
តែងតាំងឡើង ឲ្យធ្វើជាស្ដេចរបស់ពួកគេ ។
២០ ហើយហេតុការណ៍បានកើតឡើងថា នៅជំនាន់
ម៉ូសាយ មានថ្មមួយធំ ដែលគេយកមកឲ្យលោក ដោយមាន
ឆ្លាក់ត្រានៅលើ ថ្មនោះ; ហើយលោកបានបកប្រែឆ្លាក់ត្រានោះ
ដោយអំណោយទាន និងដោយព្រះចេស្ដានៃព្រះ ។
២១ ហើយឆ្លាក់ត្រាទាំងនោះប្រាប់ដំណើររឿងអំពីមនុស្ស
ម្នាក់ឈ្មោះ កកូរីអានទុមមើរ និងការស្លាប់បង់នៃប្រជាជន
លោក ។ ឯកូរីអានទុមមើរ ត្រូវបានជួបប្រទះដោយ
ប្រជាជនសារ៉ាហិមឡា; ហើយលោកបាននៅជាមួយនឹងពួក
គេ អស់រយៈពេលប្រាំបួនខែ ។
២២ នៅលើថ្មនោះ មានចែងបន្តិចបន្តួចអំពីពួកអយ្យកោ
របស់លោក ។ ហើយពួកឪពុកម្ដាយដើមរបស់លោក បានចេញ
មកពីប៉ម នៅពេលដែលព្រះអម្ចាស់ទ្រង់បានបំភាន់ភាសា
មនុស្ស; ហើយការតឹងរឹងនៃព្រះអម្ចាស់ បានធ្លាក់មកលើពួកគេ
ស្របតាមសេចក្ដីជំនុំជំរះ ទាំងឡាយរបស់ទ្រង់ដែលត្រឹមត្រូវ;
ហើយឆ្អឹងរបស់ពួកគេរាយនៅលើដែនដី នៅទិសខាងជើង ។
២៣ មើលចុះ ខ្ញុំ អាម៉ាលេគៃ បានកើតនៅជំនាន់ម៉ូសាយ;

១២ *ក* ២ នីហ្វៃ ៥:៦–៩.
*ខ* យ៉ាកុប (ព.ម) ៣:៤.
១៤ *ក* ស.ប. សារ៉ាហិមឡា.
*ខ* ១ នីហ្វៃ ៣:៣, ១៩–២០;
៥:១០–២២.
១៥ *ក* ម៉ូសាយ ២៥:២.
*ខ* យេរេ. ៣៩:១–១០;
ហេលេ. ៨:២១.
១៧ *ក* ម៉ូសាយ ១:២–៦.
១៩ *ក* ម៉ូសាយ ២៥:១៣.
*ខ* អោមណៃ ១:១២.
២០ *ក* ម៉ូសាយ ៨:១៣–១៩.
ស.ប. អ្នកមើលឆុត.
២១ *ក* អេធើរ ១២:១.
ស.ប. កូរីអានទុមើរ.
២២ *ក* អេធើរ ១:១–៥.
*ខ* លោកុ. ១១:៦–៩;
ម៉ូសាយ ២៨:១៧; អេធើរ ១:៣៣.
*គ* ម៉ូសាយ ៨:៨.

ហើយខ្ញុំបានរស់នៅ រហូតដល់បានឃើញមរណភាពរបស់លោក; ឯបេនយ៉ាមីន ជាបុត្ររបស់លោក ក៏បានសោយរាជ្យជំនួសលោក ។

២៤ ហើយមើលចុះ ខ្ញុំបានឃើញនៅក្នុងជំនាន់ស្ដេចបេនយ៉ាមីន នូវសង្គ្រាមដ៏ធំមួយ និងការខ្ចាយឈាមដ៏ច្រើន រវាងពួកសាសន៍នីហ្វៃនឹងពួកសាសន៍លេមិន ។ ប៉ុន្តែមើលចុះ ពួកសាសន៍នីហ្វៃមានប្រៀបលើពួកគេជាខ្លាំង; មែនហើយ រហូតដល់ស្ដេចបេនយ៉ាមីនបានដេញពួកគេចេញពីដែនដីសារ៉ាហិមឡា ។

២៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំចាប់ផ្ដើមមានចំណាស់ចាស់; ហើយដោយគ្មានកូនតពូជឡើយ ហើយដោយដឹងថាស្ដេចបេនយ៉ាមីន ជាមនុស្សសុចរិត នៅចំពោះព្រះអម្ចាស់ ហេតុដូច្នោះហើយ ខ្ញុំនឹងប្រគល់ផ្ទាំងទាំងនេះ ទៅឲ្យទ្រង់ទូន្មានដល់អស់ ទាំងមនុស្ស ឲ្យមករកព្រះ ជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ហើយឲ្យជឿដល់ការព្យាករណ៍ និងដល់វិវរណៈទាំងឡាយ និងដល់ ការងារបំរើនៃពួកទេវតា និងដល់អំណោយទានខាងការនិយាយភាសាច្រើននិងដល់អំណោយទានខាងការបកប្រែភាសាទាំងឡាយ និងដល់គ្រប់ការណ៍ទាំងអស់ដែលល្អ; ត្បិតឥតមានអ្វីដែលល្អឡើយ លើកលែងតែមកពីព្រះអម្ចាស់; ហើយអ្វីដែលអាក្រក់ គឺមកពីអារក្ស វិញ ។

២៦ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំចង់ឲ្យអ្នកមករកព្រះគ្រីស្ទ ជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ហើយទទួលទាននូវសេចក្ដីសង្គ្រោះរបស់ទ្រង់ និងព្រះចេស្ដានៃសេចក្ដីប្រោសលោះរបស់ទ្រង់ចុះ ។ មែនហើយ ចូរមករកទ្រង់ ហើយចូរថ្វាយព្រលឹងអ្នកទាំងមូល ជាដង្វាយថ្វាយដល់ទ្រង់ ហើយចូរបន្តការតមអាហារ និងការអធិស្ឋាន ហើយកាន់ខ្ជាប់ដរាបដល់ ចុងបំផុត; ហើយប្រាកដដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ នោះអ្នករាល់គ្នានឹងបានសង្គ្រោះ ។

២៧ ហើយឥឡូវនេះ ខ្ញុំចង់និយាយបន្តិច អំពីមនុស្សមួយចំនួនដែលបានឡើងទៅឯទីរហោស្ថាន ដើម្បីត្រឡប់ទៅឯដែនដីនីហ្វៃវិញ; ព្រោះមានមនុស្សមួយចំនួនធំ ដែលមានប្រាថ្នាចង់បានដែនដីនៃកេរ្តិ៍អាកររបស់គេ ។

២៨ ហេតុដូច្នោះហើយ ពួកគេបានឡើងទៅឯទីរហោស្ថាន ។ ឯអ្នកដឹកនាំរបស់គេ គឺជាមនុស្សខ្លាំងពូកែម្នាក់ ហើយក្បាលរឹង ហេតុដូច្នោះហើយ គាត់បានធ្វើឲ្យមានការទាស់ទែងគ្នា នៅក្នុងចំណោមពួកគេ; ហើយពួកគេត្រូវបានស្លាប់ទាំងអស់ នៅក្នុងទីរហោ ស្ថាន លើកលែងតែហាសិបនាក់ប៉ុណ្ណោះ ហើយពួកគេបានត្រឡប់មកដែនដីសារ៉ាហិមឡាវិញ ។

២៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេក៏បាននាំអ្នកផ្សេងទៀត ក្នុងចំនួនគួរសម ហើយបានធ្វើដំណើរទៅឯទីរហោស្ថានទៀត ។

៣០ ហើយខ្ញុំ អាម៉ាលេកៃ មានប្អូនប្រុសម្នាក់ ដែលបានទៅជាមួយនឹងពួកគេដែរ; ហើយចាប់ពីពេលនោះមក ខ្ញុំមិនដែលបានដឹងអំពី ពួកគេទៀតឡើយ ។ ហើយខ្ញុំជិតដេកនៅក្នុងផ្នូររបស់ខ្ញុំហើយ; ឯផ្ទាំងទាំងនេះ ពេញអស់ហើយ ។ ហើយខ្ញុំសូមបញ្ចប់នូវការនិយាយ របស់ខ្ញុំតែត្រឹមនេះសិនចុះ ៕ :៚

# ពាក្យសំដីនៃមរមន

*មរមនសង្ខេបផ្ទាំងធំរបស់នីហ្វៃ — លោកបញ្ចូលផ្ទាំងតូចទៅនឹងផ្ទាំងផ្សេង — ស្ដេចបេនយ៉ាមីនបង្កើតឲ្យមានសេចក្ដីសុខសាន្តនៅ លើដែនដី ។ ប្រមាណជាឆ្នាំ ៣៨៥ គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំ មរមន ជិតប្រគល់បញ្ជីដែលខ្ញុំបានធ្វើមកទៅឲ្យកូនប្រុសខ្ញុំ គឺម៉ូរ៉ូណៃ មើលចុះ ខ្ញុំបានឃើញដល់ការបំផ្លិចបំផ្លាញ ស្ទើរតែទាំងអស់នៃប្រជាជនខ្ញុំ គឺសាសន៍នីហ្វៃ ។

២ ហើយជាច្រើនរយឆ្នាំក្រោយមក បន្ទាប់ពីការយាងមក

២៣ *ក* ព. នៃ ម. ១:៣.
២៥ *ក* ព. នៃ ម. ១:១៧–១៨; ម៉ូសាយ ២៩:១៣.
*ខ* ព. នៃ ម. ១:១០.
*គ* អាលម៉ា ៥:៤០; អេធើរ ៤:១២; ម៉ូរ៉ូណៃ ៧:១៥–១៧.
២៦ *ក* យ៉ាកុប (ព.ម) ១:៧; អាលម៉ា ២៩:២; ម៉ូរ៉ូណៃ ១០:៣២.
*ខ* ស.ប. បូជា, យញ្ញបូជា.
*គ* ៣ នីហ្វៃ ៩:២០.
*ឃ* ស.ប. តម, តំណម.
២៨ *ក* ម៉ូសាយ ៩:១–៤.
៣០ *ក* ១ នីហ្វៃ ៦:១–៦.

[ពាក្យសំដីនៃមរមន]
១ ១*ក* ៣ នីហ្វៃ ៥:៩–១២; មរមន ១:១–៤; ៨:១, ៤–៥. ស.ប. មរមន, ព្យាការីសាសន៍នីហ្វៃ.
២ *ក* មរមន ៦:៥–៦.

នៃព្រះគ្រីស្ទ ដែលខ្ញុំប្រគល់បញ្ជីទាំងនេះដល់ដៃនៃកូនប្រុសខ្ញុំ;
ហើយខ្ញុំសន្និដ្ឋានថា វានឹងធ្វើជាសាក្សីដល់ការបំផ្លិចបំផ្លាញ
នៃប្រជាជនខ្ញុំទាំងស្រុង ។ ប៉ុន្តែសូមព្រះអនុគ្រោះឲ្យវារស់នៅ
ដើម្បីវាអាច សរសេររឿងខ្លះអំពីពួកគេ និងរឿងខ្លះអំពី
ព្រះគ្រីស្ទ ដើម្បីក្រែងថ្ងៃណាមួយ ការណ៍នេះនឹងមាន
ប្រយោជន៍ដល់ពួកគេ ។
៣ ហើយឥឡូវនេះ ខ្ញុំនិយាយខ្លះអំពីអ្វីដែលខ្ញុំបានសរសេរ;
ព្រោះបន្ទាប់ពីខ្ញុំបានធ្វើការសង្ខេបពីផ្ទាំងនីហ្វៃ រហូតមក
ដល់រជ្ជកាល ស្ដេចបេនយ៉ាមីន ដែលអាម៉ាលេកៃបាននិយាយ
មកនោះ នោះខ្ញុំបានពិចារណាមើលក្នុងបញ្ជីទាំងឡាយ ដែល
បានប្រគល់មកក្នុងដៃខ្ញុំ ហើយខ្ញុំបានរកឃើញផ្ទាំងទាំងនេះ
ដែលមាននូវដំណើររឿងដ៏ខ្លីនេះ អំពីពួកព្យាការី ចាប់ពីយ៉ាកុប
រហូតមកដល់រជ្ជកាលនៃ ស្ដេចបេនយ៉ាមីននេះ ព្រមទាំងពាក្យ
ជាច្រើនរបស់នីហ្វៃផង ។
៤ ឯរឿងទាំងឡាយ ដែលមាននៅលើផ្ទាំងទាំងនេះ នោះខ្ញុំ
ពេញចិត្ត ពីព្រោះមកពីពាក្យព្យាករណ៍ទាំងឡាយអំពីការ
យាងមក នៃព្រះគ្រីស្ទ; ហើយពួកអយ្យកោខ្ញុំដឹងថា ពាក្យ
ព្យាករណ៍ទាំងនេះភាគច្រើនត្រូវបានបំពេញហើយ; មែនហើយ
ហើយខ្ញុំក៏ដឹងដែរថា រឿងជាច្រើនដែលបានព្យាករអំពីពួកយើង
រហូតមកដល់ថ្ងៃនេះ ក៏បានបំពេញហើយដែរ ឯរឿងទាំង
ឡាយណាដែលនៅក្រោយថ្ងៃនេះ ច្បាស់ជានឹងបានកើតឡើងជា
ពិតប្រាកដ —
៥ ហេតុដូច្នោះហើយ ខ្ញុំរើសរឿងទាំងនេះ ដើម្បីបញ្ចប់បញ្ជី
របស់ខ្ញុំនៅលើបញ្ជីនេះ ឯបញ្ជីរបស់ខ្ញុំដែលនៅសល់ទាំងប៉ុន្មាន
នោះខ្ញុំនឹងយកពីផ្ទាំងនីហ្វៃ; ហើយខ្ញុំពុំអាចសរសេរឲ្យអស់ទេ
ទោះជាមួយភាគរយ នៃដំណើររឿងរបស់ប្រជាជនខ្ញុំក្ដី ។
៦ ប៉ុន្តែមើលចុះ ខ្ញុំនឹងយកផ្ទាំងទាំងនេះ ដែលមានការព្យាករណ៍
ទាំងឡាយ និងវិវរណៈទាំងឡាយ ហើយដាក់វាជាមួយនឹង
បញ្ជី របស់ខ្ញុំ ដែលនៅសល់ទាំងប៉ុន្មាន ព្រោះសុទ្ធតែជា
ការណ៍ជំរើសចំពោះខ្ញុំ; ហើយខ្ញុំដឹងថា សុទ្ធតែជាការណ៍
ជំរើសចំពោះបងប្អូន ខ្ញុំដែរ ។
៧ ហើយខ្ញុំធ្វើយ៉ាងនេះ ដើម្បីប្រយោជន៍មួយដ៏សំខាន់;
ព្រោះព្រះវិញ្ញាណបានខ្សឹបប្រាប់ខ្ញុំ ស្របតាមការងារនៃ
ព្រះវិញ្ញាណនៃព្រះ អម្ចាស់ ដែលនៅក្នុងខ្ញុំ ។ ហើយឥឡូវនេះ
ខ្ញុំពុំដឹងនូវគ្រប់ការណ៍ទាំងអស់ទេ; តែព្រះអម្ចាស់ទ្រង់
ជ្រាបនូវគ្រប់ការណ៍ទាំងអស់ ដែលនឹងកើតឡើង; ហេតុ
ដូច្នោះហើយ ទ្រង់បានធ្វើការក្នុងខ្ញុំ ដើម្បីធ្វើ
អ្វីៗស្របតាមព្រះហឫទ័យទ្រង់ ។
៨ ហើយការអធិស្ឋានរបស់ខ្ញុំដល់ព្រះ គឺអំពីបងប្អូនខ្ញុំ
ដើម្បីសូមឲ្យពួកគេអាចបានស្គាល់ព្រះម្ដងទៀត មែនហើយ
គឺស្គាល់នូវសេចក្ដី ប្រោសលោះនៃព្រះគ្រីស្ទ; ដើម្បីសូមឲ្យពួក
គេអាចបានត្រឡប់ទៅជាប្រជាជនដ៏គួរស្រឡាញ់ដូចមុន ។
៩ ហើយឥឡូវនេះ ខ្ញុំ មរមន សូមបញ្ចប់បញ្ជីរបស់ខ្ញុំ ដែល
ខ្ញុំយកមកពីផ្ទាំងនីហ្វៃសិនហើយ; ហើយខ្ញុំធ្វើបញ្ជីនេះ ស្របតាម
ការ ចេះដឹង និងស្របតាមយោបល់ដែលព្រះទ្រង់បានប្រទាន
ដល់ខ្ញុំ ។
១០ ហេតុដូច្នោះហើយ ហេតុការណ៍បានកើតឡើងថា
បន្ទាប់ពីអាម៉ាលេកៃបានប្រគល់ផ្ទាំងទាំងនេះដល់ព្រះហស្ដនៃ
ស្ដេច បេនយ៉ាមីនហើយ នោះស្ដេចក៏បានយកផ្ទាំងទាំងនេះ
ទុកជាមួយផ្ទាំងឯទៀត ដែលមានបញ្ជីទាំងឡាយ ដែលបន្ដ
ពីស្ដេចមួយទៅ ស្ដេចមួយ ពីតំណមួយទៅតំណមួយ រហូតមក
ដល់សម័យស្ដេចបេនយ៉ាមីន ។
១១ ហើយផ្ទាំងទាំងនេះ ត្រូវបានបន្ដពីស្ដេចបេនយ៉ាមីន ពីតំណ
មួយទៅតំណមួយ រហូតដល់ធ្លាក់មកក្នុងដៃខ្ញុំ ។ ហើយខ្ញុំ
មរមន សូមអធិស្ឋានដល់ព្រះ សូមឲ្យផ្ទាំងទាំងនេះនៅឲ្យបាន
គង់វង្ស ចាប់ពីពេលនេះរហូតតទៅ ។ ហើយខ្ញុំដឹងថា វានឹង
ត្រូវបានរក្សាទុកឲ្យ បានគង់វង្ស; ត្បិតមានរឿងដ៏សំខាន់ៗបាន
ធ្លាក់នៅលើនោះ ដែលនឹងត្រូវយកមកជំនុំជំរះប្រជាជនខ្ញុំ និង

២ *ខ* គ. និង ស. ៣:១៦–២០.
៣ *ក* គ. និង ស. ១០:៤៤.
*ខ* គ. និង ស. ១០:៣៨–៤០.
*គ* ម៉ូសាយ ១:៦;
ហេលេ. ៣:១៣–១៥;
មរមន ៤:២៣.
*ឃ* អេនុស ១:២៣.
៤ *ក* ១ នីហ្វៃ ៦:៥.
៥ *ក* ក.ន. ការណ៍ដែលលោកពេញចិត្ត
ដែលបានពោលដល់នៅក្នុងខទី ៤.
*ខ* ១ នីហ្វៃ ៩:២.
*គ* ៣ នីហ្វៃ ៥:៨–១១; ២៦:៦–១២.
៧ *ក* ១ នីហ្វៃ ៩:៥; ១៩:៣;
គ. និង ស. ៣:១២–២០;
១០:១–១៩, ៣០–៤៧.
*ខ* ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
៨ *ក* ២ នីហ្វៃ ៣៣:៣–៤;
អេណុស ១:១១–១២.
*ខ* ២ នីហ្វៃ ៣០:៦.
១០ *ក* អោមណៃ ១:២៥, ៣០.
*ខ* ១ នីហ្វៃ ៩:៤.
*គ* យ៉ារ៉ុម ១:១៤.
១១ *ក* ៣ នីហ្វៃ ៥:៨–១២;
មរមន ១:១–៥.
*ខ* ២ នីហ្វៃ ២៥:១៨; ២៩:១១;
៣៣:១១–១៥;
៣ នីហ្វៃ ២៧:២៣–២៧.

បងប្អូនគេ នៅថ្ងៃដ៏ធំ ហើយចុង ក្រោយបង្អស់ ស្របតាមព្រះ
បន្ទូលនៃព្រះដែលបានចែងមក ។
១២ ហើយឥឡូវនេះ អំពីស្តេចបេនយ៉ាមីន — ទ្រង់មាន
ការទាស់ទែងខ្លះ ក្នុងចំណោមប្រជាជនទ្រង់ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពសាសន៍
លេមិនបានចុះមកពី[ក]ដែនដីនីហ្វៃ ដើម្បីមកច្បាំងនឹងពួកសាសន៍
នីហ្វៃ ។ ប៉ុន្តែមើលចុះ ស្តេចបេនយ៉ាមីនបានប្រមូលពលទ័ពទ្រង់
ហើយបានទប់ទល់នឹងពួកគេ; ហើយបានប្រយុទ្ធដោយកម្លាំង
ព្រះហស្តទ្រង់ផ្ទាល់ ដោយប្រើ[ខ]ដាវរបស់ឡាបាន់ ។
១៤ ហើយនៅក្នុងកម្លាំងរបស់ព្រះអម្ចាស់ នោះពួកគេបាន
តទល់នឹងពួកខ្មាំងសត្រូវរបស់គេ រហូតដល់ពួកគេបានសម្លាប់
ពួកលេមិន ជាច្រើនពាន់នាក់ ។ ហើយហេតុការណ៍
បានកើតឡើងថា ពួកគេបានប្រយុទ្ធតទល់នឹងពួកសាសន៍លេមិន
រហូតដល់ពួកគេបានដេញពួក លេមិន ឲ្យចេញអស់ពីដែនដីកេរ្តិ៍អា
កររបស់គេទៅ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីមាន[ក]ព្រះគ្រីស្ទ
ក្លែងក្លាយទាំងឡាយ នោះមាត់គេត្រូវបានបិទ ហើយពួកគេ
បាន ទទួលទុក្ខទោស ស្របតាមបទល្មើសរបស់ខ្លួន;
១៦ ហើយបន្ទាប់ពីមានពួកព្យាការីក្លែងក្លាយ និងពួក
អាចារ្យក្លែងក្លាយ និងពួកគ្រូប្រដៅក្លែងក្លាយ នៅក្នុង
ចំណោមប្រជាជន ហើយពួកអស់ទាំងនេះបានទទួលទុក្ខទោស
ស្របតាមបទល្មើសរបស់ខ្លួន; ហើយបន្ទាប់ពីការទាស់ទែងគ្នា
ជាច្រើន និងការបែកបាក់គ្នា ដ៏ច្រើន ចូលដៃទៅឯពួកសាសន៍
លេមិន មើលចុះ ហេតុការណ៍បានកើតឡើងថា ស្តេចបេនយ៉ាមីន
ដោយមានជំនួយពី[ក]ពួកព្យាការី ដ៏បរិសុទ្ធ ដែលនៅក្នុង
ចំណោមប្រជាជន —
១៧ ត្បិតមើលចុះ ស្តេចបេនយ៉ាមីន ជាមនុស្ស[ក]បរិសុទ្ធម្នាក់
ហើយទ្រង់បានសោយរាជ្យលើរាស្ត្ររបស់ ទ្រង់ ដោយសេចក្តី
សុចរិត ហើយមានមនុស្សបរិសុទ្ធជាច្រើននៅលើដែនដី ហើយ
ពួកគេបានថ្លែងព្រះបន្ទូលនៃព្រះ ប្រកបដោយ[ខ]អានុភាពនិងសិទ្ធិ
អំណាច ហើយ គេបានប្រើវិធានការណ៍[គ]យ៉ាងតឹងរឹង ពីព្រោះ
តែការរឹងទទឹងរបស់ប្រជាជន —
១៨ ហេតុដូច្នោះហើយ ដោយជំនួយពីពួកអ្នកទាំងនេះ
នោះស្តេចបេនយ៉ាមីន ដោយបានធ្វើការដ៏អស់ពីសមត្ថភា
ពនៃកាយរបស់ ទ្រង់ និងអស់ពីសមត្ថភាពនៃព្រលឹងរបស់ទ្រង់
ព្រមទាំងពួកព្យាការីទាំងឡាយផង បានបង្កើតឲ្យមានសេច
ក្តីសុខសាន្តនៅលើដែនដី ម្តងទៀត ៕ :ᨖ

# គម្ពីរម៉ូសាយ

ជំពូកទី ១

*ស្តេចបេនយ៉ាមីនបង្រៀនបុត្រាទាំងឡាយរបស់ទ្រង់ នូវភាសា និងពាក្យព្យាករណ៍នៃពួកអយ្យកោរបស់គេ — សាសនា និងអារ្យធម៌ របស់គេត្រូវបានរក្សាទុក ដោយសារបញ្ជីទាំងឡាយត្រូវបានកត់ទុកនៅលើផ្ទាំងនានា — ម៉ូសាយត្រូវបានរើសឲ្យធ្វើជាស្តេច ហើយត្រូវបានប្រគល់ភារកិច្ច ឲ្យរក្សាបញ្ជី និងវត្ថុផ្សេងៗទុក ។ ប្រមាណជាឆ្នាំ ១៣០–១២៤ ម.គ.ស. ។*

ហើយឥឡូវនេះ ឥតមានការទាស់ទែងគ្នាឡើយ នៅលើ
[ក]ដែនដីសារ៉ាហិមឡាទាំងមូល គឺនៅក្នុងចំណោមប្រជាជន
ទាំងអស់ ដែលជា ប្រជាជនរបស់ស្តេចបេនយ៉ាមីន ម្ល៉ោះហើយ
ទើបស្តេចបេនយ៉ាមីនមានសេចក្តីសុខសាន្តតរៀតទៅ រហូត
ដល់អស់មួយជីវិតទ្រង់ដែល នៅសល់ទាំងប៉ុន្មាន។
២ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់មាន
បុត្រាបីនាក់ ដែលទ្រង់ឲ្យនាមថា ម៉ូសាយ និងហេឡូរុម
និងហេលេមិន ។ ហើយទ្រង់បានឲ្យពួកគេ[ក]រៀន[ខ]ភាសាទាំងអស់
របស់ពួកអយ្យកោទ្រង់ ដើម្បីឲ្យពួកគេអាចបានក្លាយទៅជាមនុស្ស
ដែលប្រកបដោយ យោបល់; ហើយដើម្បីឲ្យពួកគេអាចដឹង
អំពីពាក្យព្យាករណ៍ទាំងឡាយ ដែលចេញពីមាត់នៃពួកអយ្យកោ
របស់គេ ដែលបានប្រទានឲ្យគេ ដោយព្រះហស្តនៃព្រះអម្ចាស់។

១៣ *ក* អោមណៃ ១:១២.
*ខ* ១ នីហ្វៃ ៤:៩; ២ នីហ្វៃ ៥:១៤;
យ៉ាកុប (ព.ម) ១:១០;
ម៉ូសាយ ១:១៦; គ. និង ស. ១៧:១.
១៥ *ក* ស.ប. អ្នកទទឹងនឹងព្រះគ្រីស្ទ.
១៦ *ក* អេណុស ១:២២.
១៧ *ក* អាលម៉ា ១៣:២៦.
*ខ* អាលម៉ា ១៧:២–៣.
*គ* មរ៉ូណៃ ៩:៤;
គ. និង ស. ១២១:៤១–៤៣.
[ម៉ូសាយ]
**១** ១ *ក* អោមណៃ ១:១៣.
២ *ក* ម៉ូសាយ ៤:១៤–១៥;
គ. និង ស. ៦៨:២៥, ២៨.
*ខ* មរមន ៩:៣២.

៣ ហើយទ្រង់ក៏បានបង្រៀនពួកគេ អំពីបញ្ជីទាំងឡាយ ដែលបានចារនៅលើផ្ទាំងលង្ហិនដែរថា៖ ឱបុត្រារបស់បិតាអើយ បិតាចង់ ឲ្យបុត្ររាល់គ្នាចាំថា បើពុំដោយសារផ្ទាំងទាំងនេះ ដែលមានបញ្ជីទាំងនេះ និងព្រះបញ្ញត្តិទាំងនេះទេ យើងច្បាស់ជាត្រូវរងទុក្ខនៅ ក្នុងភាពល្ងង់ខ្លៅ រហូតមកដល់ពេលបច្ចុប្បន្ននេះ ដោយមិនដឹងនូវការអាថ៌កំបាំងទាំងឡាយនៃព្រះសោះឡើយ ។

៤ ត្បិតលីហៃ ជាអយ្យកោរបស់យើង ពុំអាចចាំនូវគ្រប់ការណ៍អស់ទាំងនេះ ដើម្បីយកមកបង្រៀនដល់កូនចៅរបស់លោកបានទេ លើកលែងតែដោយសារជំនួយរបស់ផ្ទាំងទាំងនេះ; ដោយព្រោះលោកបានរៀនជាភាសានៃពួកសាសន៍អេស៊ីព្ទ ហេតុដូច្នេះហើយ ទើបលោកអាចអាននូវចម្លាក់ទាំងនេះបាន ហើយបង្រៀនដល់កូនចៅលោក ដើម្បីឲ្យពួកគេអាចបង្រៀនតទៅកូនចៅរបស់គេទៀត ម្ល៉ោះហើយ បានបំពេញព្រះបញ្ញត្តិទាំងឡាយនៃព្រះ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

៥ ឱបុត្រារបស់បិតាអើយ បិតាសូមប្រាប់ថា បើពុំដោយសារការណ៍ទាំងនេះ ដែលត្រូវបានរក្សាទុកដោយព្រះហស្តនៃព្រះ ដើម្បីឲ្យយើងអាចអាន ហើយយល់នូវការអាថ៌កំបាំងទាំងឡាយរបស់ទ្រង់ ហើយមានព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់នៅចំពោះភ្នែក យើងជានិច្ចនោះទេ នោះពួកអយ្យកោរបស់យើងច្បាស់ជាចុះអន់ថយក្នុងការឥតជំនឿ ហើយយើងច្បាស់ជាដូចពួកសាសន៍លេមិន ដែលជាបងប្អូនយើងដែរ ដែលពុំដឹងអ្វីអំពីរឿងទាំងនេះសោះ ព្រមទាំងមិនជឿនៅពេលពួកគេត្រូវបានបង្រៀនផង គឺដោយមកពី សណ្ដាប់ទាំងឡាយនៃពួកអយ្យកោរបស់គេ ដែលមិនត្រឹមត្រូវ ។

៦ ឱបុត្រារបស់បិតាអើយ បិតាចង់ឲ្យបុត្ររាល់គ្នាចាំថាពាក្យទាំងនេះពិត ហើយបញ្ជីទាំងនេះក៏ពិតដែរ ។ ហើយមើលចុះផ្ទាំងនីហ្វៃដែលមានបញ្ជី និងពាក្យរបស់ពួកអយ្យកោយើងចាប់ពីពេលដែលគេចាកចេញពីក្រុងយេរូសាឡិម មកដល់ឥឡូវនេះ នោះក៏ពិតដែរ; ហើយយើងអាចដឹងអំពីភាពជាក់លាក់នៃវត្ថុទាំងនេះ ពីព្រោះយើងមានវត្ថុទាំងនេះ នៅចំពោះភ្នែកយើងហើយ ។

៧ ហើយឥឡូវនេះ ឱបុត្រារបស់បិតាអើយ បិតាចង់ឲ្យបុត្ររាល់គ្នាចាំថា ត្រូវពិចារណាមើលវត្ថុទាំងនេះ ដោយព្យាយាមដើម្បីបុត្រអាចមានប្រយោជន៍ដោយសារវា; ហើយបិតាចង់ឲ្យបុត្ររាល់គ្នា កាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ដើម្បីឲ្យបុត្ររាល់គ្នា អាចបានចំរើនឡើងនៅលើដែនដី ស្របតាមសេចក្ដីសន្យាទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើដល់ពួកអយ្យកោរបស់យើង ។

៨ ហើយស្ដេចបេនយ៉ាមីន ទ្រង់បានបង្រៀនបុត្រារបស់ទ្រង់នូវការណ៍ច្រើនទៀត ដែលពុំបានសរសេរនៅក្នុងសៀវភៅនេះឡើយ ។

៩ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីស្ដេចបេនយ៉ាមីនទ្រង់បានបញ្ចប់នូវបង្រៀនបុត្រាទ្រង់ហើយ នោះទ្រង់ក៏មានព្រះជន្មចាស់ជរា ហើយទ្រង់បានទតឃើញថា ក្នុងពេលដ៏ខ្លីខាងមុខនេះ ទ្រង់ត្រូវទៅតាមផ្លូវនៃអស់ទាំងផែនដីហើយ; ហេតុដូច្នេះហើយ ទើបទ្រង់គិតថា ជាការចាំបាច់ដែលទ្រង់ត្រូវប្រគល់រាជ្យ ទៅឲ្យបុត្ររបស់ទ្រង់ម្នាក់ ។

១០ ហេតុដូច្នេះហើយ ទើបទ្រង់ឲ្យគេនាំម៉ូសាយមកចំពោះទ្រង់ ហើយនេះជាពាក្យ ដែលទ្រង់មានបន្ទូល ទៅកាន់បុត្រថា៖ បុត្ររបស់បិតាអើយ បិតាចង់ឲ្យបុត្រប្រកាសទូទៅអស់ទាំងដែនដីនេះ នៅក្នុងចំណោមអស់ទាំងប្រជាជននេះឬប្រជាជនសារ៉ាហិមឡា និងប្រជាជនរបស់ម៉ូសាយ ដែលរស់នៅលើដែនដី ដើម្បីឲ្យគេប្រមូលគ្នាមក; ព្រោះថ្ងៃស្អែកនេះ បិតានឹងប្រកាសប្រាប់ប្រជាជននេះ ចេញពីមាត់របស់បិតាផ្ទាល់ថា បុត្រគឺជាស្ដេច ហើយជាអ្នកគ្រប់គ្រងប្រជាជននេះ គឺជាប្រជាជនដែលព្រះអម្ចាស់ជាព្រះនៃយើងទ្រង់បានប្រទានដល់យើង ។

១១ ហើយម៉្យាងទៀត បិតានឹងឲ្យឈ្មោះមួយដល់ប្រជាជននេះ ដើម្បីឲ្យគេអាចញែកចេញពីប្រជាជនទាំងអស់ ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បាននាំចេញពីដែនដីយេរូសាឡិម; ហើយបិតាធ្វើដូច្នេះ ក៏ព្រោះតែពួកគេជាប្រជាជនព្យាយាមកាន់តាមព្រះបញ្ញត្តិទាំង ឡាយនៃព្រះអម្ចាស់ ។

៣ *ក* ស.ប. ផ្ទាំងទាំងឡាយ.
*ខ* អាលម៉ា ៣៧:៨–៩.
៤ *ក* យ.ស. – ប្រវត្តិ ១:៦៤.
៥ *ក* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរដែលត្រូវរក្សាទុក.
*ខ* ចោទិ. ៦:៦–៨.
*គ* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*ឃ* ម៉ូសាយ ១០:១១–១៧.
៦ *ក* ១ នីហ្វៃ ១:៣; ២ នីហ្វៃ ៣៣:១០–១១; ម៉ូរ៉ូណៃ ១០:២៧.
៧ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* ម៉ូសាយ ២:២២; អាលម៉ា ៥០:២០–២២.
*គ* ទំនុក. ១២២:៦; ១ នីហ្វៃ ២:២០.
*ឃ* អាលម៉ា ៩:១២–១៤.
១០ *ក* អោមណៃ ១:១៤.
*ខ* ម៉ូសាយ ២:៣០.
១១ *ក* ម៉ូសាយ ៥:៨–១២.

១២ ហើយបិតានឹងឲ្យគេនូវឈ្មោះមួយ ដែលនឹងមិនត្រូវ
លុបចោលបានឡើយ លើកលែងតែដោយការរំលង ។
១៣ មែនហើយ ម្យ៉ាងទៀត បិតាប្រាប់ទៅបុត្រថា បើ
សិនជាប្រជាជនដ៏សំណប់ជាខ្លាំងនៃព្រះអម្ចាស់នេះធ្លាក់ចុះ ទៅ
ក្នុងការ រំលងច្បាប់ ហើយក្លាយទៅជាប្រជាជនទុច្ចរិត ហើយ
កំផិត នោះព្រះអម្ចាស់ទ្រង់នឹងបោះបង់គេចោល ដើម្បីឲ្យពួក
គេក្លាយទៅជា មនុស្សទន់ខ្សោយ ដូចបងប្អូនរបស់គេ; ហើយ
ទ្រង់នឹងឈប់ថែរក្សាគេ ដោយព្រះចេស្ដាដ៏ផ្ទឹមមិនបាន និង
អស្ចារ្យរបស់ទ្រង់ ដូចជាទ្រង់ បានថែរក្សាពួកអយ្យកោ
របស់យើង ពីមុនមកដល់សព្វថ្ងៃនេះ ។
១៤ ព្រោះបិតាប្រាប់បុត្រថា បើសិនជាទ្រង់ពុំបានលូកព្រះហស្ត
មកថែរក្សាពួកអយ្យកោយើងទេ ពួកគេច្បាស់ជាធ្លាក់ទៅក្នុង
កណ្ដាប់ដៃពួកសាសន៍លេមិនហើយ ហើយទទួល
រងគ្រោះចំពោះការស្អប់របស់ពួកគេ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីស្ដេច
បេនយ៉ាមីនបានបញ្ចប់ពាក្យទាំងនេះ ទៅកាន់បុត្រទ្រង់ហើយ
នោះទ្រង់ក៏ បានបង្គាប់បុត្រពីកិច្ចការទាំងអស់នៃព្រះនគរ ។
១៦ ហើយក្រៅពីនេះទៀត ទ្រង់ក៏បានបង្គាប់បុត្រពីបញ្ជីទាំង
ឡាយ ដែលចារនៅលើផ្ទាំងលង្ហិន; ព្រមទាំងផ្ទាំងនីហ្វៃផង;
ព្រមទាំង ដាវរបស់ឡាបាន់ និងដុំមូល ឬគ្រឿងចង្អុលទិស
ដែលបានដឹកនាំពួកអយ្យកោរបស់យើង ឆ្លងកាត់ទីរហោស្ថាន
ដែលបានរៀបចំឡើង ដោយព្រះហស្តនៃព្រះអម្ចាស់ ដើម្បីដោយ
សារវត្ថុនេះ ពួកគេត្រូវបានដឹកនាំតាមការយកចិត្តទុកដាក់ និង
ការព្យាយាម ដែលពួកគេ បានធ្វើចំពោះទ្រង់ ។
១៧ ហេតុដូច្នេះហើយ កាលណាគេមិនស្មោះត្រង់ នោះគេ
ពុំបានចំរើន ឬជឿនលឿន នៅក្នុងដំណើររបស់គេឡើយ តែ
ត្រូវរុញ ច្រានថយក្រោយវិញ ហើយនាំមកនូវ
ការពុំសព្វព្រះហឫទ័យនៃព្រះមកលើគេ; ហេតុដូច្នេះហើយ គេ
ត្រូវវាយដោយអំណត់អត់ និងការ ទុក្ខវេទនាដ៏ឈឺចាប់
ដើម្បីដាស់រំឭកគេ ឲ្យនឹកចាំដល់ករណីយកិច្ចរបស់គេ ។
១៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ម៉ូសាយបាន
ទៅធ្វើ ដូចបិតាលោកបានបញ្ជាដល់លោក ហើយបានប្រកាស
ប្រាប់ប្រជាជនទាំងអស់ ដែលនៅលើដែនដីសារ៉ាហិមឡា
ឲ្យមកជួបជុំគ្នា ដើម្បីឲ្យគេអាចឡើងទៅឯព្រះវិហារបរិសុទ្ធ
ដើម្បីទៅស្ដាប់ ពាក្យទាំងឡាយ ដែលបិតាលោកនឹងមាន
បន្ទូលទៅកាន់ពួកគេ ៕

## ជំពូកទី ២

*ស្ដេចបេនយ៉ាមីន ថ្លែងទៅកាន់ប្រជាជនរបស់ទ្រង់ — ទ្រង់រៀបរាប់ឡើងវិញនូវសមធម៌ យុត្តិធម៌ និងជីវភាពខាងផ្លូវវិញ្ញាណ នៃ រជ្ជកាលរបស់ទ្រង់ — ទ្រង់ទូន្មានឲ្យគេបំរើព្រះមហាក្សត្រសួគ៌របស់គេ — អស់អ្នកណាដែលបះបោរទាស់នឹងព្រះ នឹងត្រូវរងទុក្ខ ដូចជាអណ្ដាតភ្លើងដែលពន្លត់មិនបាន ។ ប្រមាណ ជាឆ្នាំ ១២៤ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីម៉ូសាយបានធ្វើនូវអ្វីៗ
ដែលបិតាលោកបានបញ្ជាដល់លោក ហើយបានប្រកាស
ទូទៅអស់ ទាំងដែនដី ឲ្យប្រជាជនមកជួបជុំគ្នាទូទៅអស់ទាំងដែនដី
ដើម្បីឲ្យគេអាចឡើងទៅឯព្រះវិហារបរិសុទ្ធ ដើម្បីទៅស្ដាប់
ពាក្យទាំងឡាយ ដែលស្ដេចបេនយ៉ាមីន នឹងមាន
បន្ទូលទៅកាន់ពួកគេ ។
២ ហើយមានចំនួនមនុស្សជាច្រើន គឺមានចំនួនច្រើន រហូត
ដល់គេពុំអាចរាប់បានឡើយ; ព្រោះគេបានរីករាលដុះដាល
យ៉ាងខ្លាំង ហើយមានកម្លាំងខ្លាំងពូកែ នៅលើដែនដីនេះ ។
៣ ហើយគេក៏បាននាំយកមកនូវកូនសត្វច្បង នៃហ្វូងចៀម
របស់គេផងដែរ ដើម្បីគេអាចថ្វាយជាយញ្ញបូជា ហើយ
ជាដង្វាយដុត តាមក្រឹត្យវិន័យលោកម៉ូសេ ។
៤ ហើយក៏ដើម្បីឲ្យពួកគេថ្លែងអំណរគុណថ្វាយព្រះអម្ចាស់
ជាព្រះរបស់គេ ដែលទ្រង់បាននាំពួកគេ ចេញពីដែនដីយេរូសាឡិម
ហើយទ្រង់បានរំដោះពួកគេឲ្យរួចផុតពីកណ្ដាប់ដៃ នៃពួកខ្មាំង
សត្រូវរបស់គេ ហើយបានតែងតាំងបុរសសុចរិតទាំងឡាយ
ឲ្យធ្វើជាគ្រូ បង្រៀនរបស់គេ និងបុរសសុចរិតម្នាក់ ឲ្យធ្វើ

១២ *ក* ស.ប. អំពើបាប.
១៣ *ក* ហេព្រើរ ៦:៤–៦.
*ខ* ហេលេ. ៤:២៤–២៦.
*គ* គ. និង ស. ១០៣:៨–១០.
១៦ *ក* ម៉ូសាយ ១:៣.
*ខ* ១ នីហ្វៃ ៤:៨–១៩;
ព. នៃ ម. ១:១៣;
គ. និង ស. ១៧:១.
*គ* ១ នីហ្វៃ ១៦:១០.
១៧ *ក* ១ នីហ្វៃ ១៨:១២–១៣.
**២** ៣ *ក* លោកុ. ៤:៤.
*ខ* ស.ប. បូជា, យញ្ញបូជា.
*គ* ១ នីហ្វៃ ៥:៩.
*ឃ* ២ នីហ្វៃ ២៥:២៤;
អាលម៉ា ៣០:៣; ៣៤:១៣–១៤.
៤ *ក* ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ.
*ខ* ម៉ូសាយ ១៨:១៨–២២.
ស.ប. បង្រៀន, គ្រូបង្រៀន.

ជាស្ដេចរបស់គេផង ដែលបានបង្កើតឲ្យមានសេចក្ដីសុខសាន្តនៅលើដែនដីសារ៉ាហិមឡា ហើយបានបង្រៀនពួកគេ ឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ដើម្បីឲ្យគេបានអររីករាយ ហើយពោរពេញទៅដោយសេចក្ដី ស្រឡាញ់ចំពោះព្រះ និងចំពោះមនុស្សទាំងអស់ ។

៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានឡើងទៅដល់ព្រះវិហារបរិសុទ្ធហើយ នោះពួកគេបោះត្រសាលរបស់គេ នៅជុំវិញ មនុស្សម្នាក់ៗទៅតាមគ្រួសាររៀងៗខ្លួន ដោយមានភរិយាគេ និងកូនប្រុសគេ និងកូនស្រីគេ និងចៅប្រុសគេ និងចៅស្រីគេ ពីចាស់បំផុត ទៅដល់ក្មេងបំផុត គឺគ្រួសារនីមួយៗនៅដាច់ពីគ្នា ។

៦ ហើយពួកគេបានបោះត្រសាលនៅជុំវិញព្រះវិហារបរិសុទ្ធ មនុស្សម្នាក់ៗមានទ្វារត្រសាលបើកចំហទៅរកព្រះវិហារបរិសុទ្ធ ដើម្បីឲ្យគេអាចនៅក្នុងត្រសាល ហើយស្ដាប់ពាក្យទាំងឡាយ ដែលស្ដេចបេនយ៉ាមីន នឹងមានបន្ទូលមកកាន់ពួកគេ ។

៧ ដោយសារបណ្ដាជនមានចំនួនច្រើនលើសលប់ពេកម្ល៉ោះហើយ បានជាស្ដេចបេនយ៉ាមីន ទ្រង់ពុំអាចបង្រៀនពួកគេទាំងអស់គ្នា នៅក្នុងកំផែងព្រះវិហារបរិសុទ្ធបានឡើយ ហេតុដូច្នេះហើយ ទើបទ្រង់បានបញ្ជាឲ្យគេសង់ប៉មមួយ ដើម្បីឲ្យប្រជាជនអាចឮពាក្យទាំង ឡាយ ដែលទ្រង់នឹងមានបន្ទូលទៅកាន់ពួកគេ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានចាប់ផ្ដើមមានបន្ទូលទៅកាន់ប្រជាជនទ្រង់ ពីលើប៉មនោះមក; ប៉ុន្តែពួកគេពុំអាច ស្ដាប់ឮអស់ទាំងពាក្យរបស់ទ្រង់បានឡើយ ពីព្រោះមកពីមានចំនួនមនុស្សច្រើនពេក; ហេតុដូច្នេះហើយ ទើបទ្រង់បញ្ជាឲ្យគេកត់នូវពាក្យ ទាំងឡាយដែលទ្រង់មានបន្ទូលមកហើយបញ្ជូនទៅក្នុងចំណោមជនទាំងឡាយណា ដែលពុំបាននៅក្រោមសម្លេងទ្រង់ ដើម្បីឲ្យគេអាច បានទទួលនូវពាក្យទាំងឡាយរបស់ទ្រង់ផងដែរ ។

៩ ហើយពាក្យដែលទ្រង់បានមានបន្ទូល ហើយបានបញ្ជាឲ្យគេចម្លងមានដូចតទៅនេះ៖ ឱបងប្អូនទាំងឡាយរបស់យើងអើយ អ្នកទាំងអស់គ្នាដែលបានមកជួបជុំគ្នានៅទីនេះ អ្នកទាំងអស់ដែលអាចស្ដាប់ឮសម្លេងយើង ដែលយើងនឹងនិយាយទៅកាន់អ្នកនៅ ថ្ងៃនេះ; គ្បិតយើងពុំបានបញ្ជាឲ្យអ្នករាល់គ្នាឡើងមកទីនេះ ដើម្បីមើលងាយដល់ពាក្យដែលយើងនិយាយនោះទេ ប៉ុន្តែសូមឲ្យអ្នកប្រុង ស្ដាប់តាមយើងវិញ ហើយសូមបើកត្រចៀកអ្នក ដើម្បីឲ្យអ្នករាល់គ្នាអាចបានឮ និងចិត្តអ្នក ដើម្បីឲ្យរាល់គ្នាអាចបានយល់ និងគំនិតអ្នក ដើម្បីឲ្យសេចក្ដីអាថ៌កំបាំងនៃព្រះអាចបានលាតត្រដាងបង្ហាញដល់អ្នកចុះ ។

១០ យើងពុំបានបញ្ជាឲ្យអ្នកឡើងមកទីនេះ ដើម្បីឲ្យអ្នករាល់គ្នាខ្លាចយើង ឬក៏ដើម្បីឲ្យអ្នករាល់គ្នាគិតថា យើងនេះជាមនុស្សខ្ពស់ ជាងមនុស្សធម្មតានោះទេ ។

១១ ប៉ុន្តែ យើងក៏ដូចអ្នករាល់គ្នាដែរ ដែលមានការទន់ខ្សោយគ្រប់បែបយ៉ាងខាងរូបកាយ និងខាងគំនិត; ក៏ប៉ុន្តែយើងត្រូវបានរើស ដោយប្រជាជននេះ ហើយបានតាំងឡើងដោយបិតាយើង ហើយត្រូវបានទ្រទ្រង់ដោយព្រះហស្តនៃព្រះអម្ចាស់ ដើម្បីឲ្យយើងធ្វើជា អ្នកគ្រប់គ្រង ហើយជាស្ដេចលើប្រជាជននេះ; ហើយត្រូវបានថែរក្សាឲ្យគង់វង្សដោយព្រះចេស្ដាដ៏ឥតប្រៀបផ្ទឹមបានរបស់ទ្រង់ ដើម្បីបំរើអ្នកឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និងអស់ពីកម្លាំង ដែលព្រះអម្ចាស់ទ្រង់បានប្រទានមកឲ្យយើង ។

១២ យើងសូមប្រាប់អ្នកថា យើងបានស៊ូទ្រាំចំណាយពេលវេលាក្នុងជីវិតយើង ដើម្បីបំរើអ្នករាល់គ្នារហូតមកដល់ពេលនេះ ហើយយើងពុំបានស្វែងរកមាសឬប្រាក់ ឬរបស់ទ្រព្យអ្វីពីអ្នកឡើយ;

១៣ ហើយយើងក៏ពុំព្រមឲ្យអ្នករាល់គ្នាត្រូវដាប់ឃុំឃាំងនៅក្នុងគុកងងឹត ឬក៏ឲ្យអ្នករាល់គ្នាធ្វើជាខ្ញុំកញ្ជះរបស់អ្នកឯទៀត ឬឲ្យអ្នក រាល់គ្នាធ្វើឃាត ឬលួច ឬប្លន់ ឬផិតគ្នាឡើយ; ហើយយើងក៏ពុំព្រមឲ្យអ្នករាល់គ្នា ប្រព្រឹត្តអំពើទុច្ចរិតណាមួយឡើយ ហើយបានបង្រៀន អ្នកថា អ្នករាល់គ្នាត្រូវកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នៅគ្រប់ការណ៍ទាំងអស់ដែលទ្រង់បានបញ្ជាដល់អ្នក—

១៤ ហើយសូម្បីតែរូបយើង ក៏បានធ្វើការដោយដៃយើងផ្ទាល់ដើម្បីយើងអាចបំរើអ្នក ហើយដើម្បីកុំឲ្យអ្នករាល់គ្នាត្រូវបង់ពន្ធដារ

៤ ក អោមណៃ ១:១២–១៥.
ឃ យ៉ូហាន ១៥:១០.
ង ស.ប. សេចក្ដីស្រឡាញ់.
៥ ក ស.ប. គ្រួសារ.
៦ ក និក្ខ. ៣៣:៨–១០.
៩ ក ម៉ូសាយ ៨:៣.
ខ គ. និង ស. ៦:១២.
គ ស.ប. ប្រុងស្ដាប់.
ឃ ម៉ូសាយ ១២:២៧;
៣ នីហ្វៃ ១៩:៣៣.
ង ស.ប. គំនិត.
ច ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
១០ ក ស.ប. សេចក្ដីកោតខ្លាច.
១២ ក កិច្ចការ ២០:៣៣–៣៤.
១៤ ក ១ កូរិន. ៩:១៨.

ដ៏ធ្ងន់ ហើយដើម្បីកុំឲ្យមានអ្វីធ្ងន់ធ្ងរកើតមានដល់អ្នក ដែល
ពិបាកនឹងទ្រាំទ្របាន– រឺឯអ្វីៗទាំងអស់ ដែលយើងទើបនិយាយ
នេះ អ្នករាល់គ្នាកំពុងធ្វើជាសាក្សីនៅថ្ងៃនេះហើយ ។
១៥ ក៏ប៉ុន្តែ ឱបងប្អូនទាំងឡាយរបស់យើងអើយ យើងពុំបាន
ប្រព្រឹត្តការណ៍ទាំងនេះ ដើម្បីយើងអាចអួតអាង ឬក៏ប្រាប់
អំពីការណ៍ ទាំងនេះ ដើម្បីចោទប្រកាន់ទោសដល់អ្នកនោះទេ;
ប៉ុន្តែយើងប្រាប់អ្នកនូវការណ៍ទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបាន
ដឹងថា នៅថ្ងៃនេះ យើងអាចឆ្លើយដោយ[ក]សតិសម្បជញ្ញៈដ៏ជ្រះ
ថ្លាចំពោះព្រះ ។
១៦ មើលចុះ យើងសូមប្រាប់អ្នកថា ពីព្រោះយើងបានប្រាប់
អ្នកថា យើងបានចំណាយពេលវេលានៃជីវិតយើង ក្នុងការ
បំរើអ្នក នោះយើងពុំមានបំណងចង់អួតអាងឡើយ ត្បិតយើង
គ្រាន់តែនៅក្នុងការបំរើដល់ព្រះតែប៉ុណ្ណោះ ។
១៧ ហើយមើលចុះ យើងសូមប្រាប់អ្នកនូវការណ៍ទាំងនេះ
ដើម្បីឲ្យអ្នករាល់គ្នាអាចមាន[ក]ប្រាជ្ញា; ដើម្បីឲ្យអ្នករាល់គ្នាអាច
បានដឹងថា កាលណាអ្នករាល់គ្នានៅក្នុង[ខ]ការបំរើដល់[គ]មនុស្ស
ទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបំរើដល់ព្រះរបស់
អ្នកតែ ប៉ុណ្ណោះ ។
១៨ មើលចុះ អ្នករាល់គ្នាបានហៅយើងថាជាស្តេចរបស់
អ្នក; ហើយបើសិនជាយើង ដែលអ្នករាល់គ្នាហៅថាជាស្តេច
របស់អ្នក នោះ[ក]ធ្វើការបំរើដល់អ្នក តើម្តេចឡើយបានជាអ្នក
រាល់គ្នាពុំធ្វើការបំរើគ្នាទៅវិញទៅមក ?
១៩ ហើយមើលចុះទៀតថា បើសិនជាយើង ដែលអ្នករាល់
គ្នាហៅថាជាស្តេចរបស់អ្នក បានចំណាយពេលវេលានៃជីវិត
ខ្លួន នៅក្នុងការបំរើអ្នករាល់គ្នា ប៉ុន្តែបាននៅក្នុងការបំរើដល់
ព្រះទៅវិញ នោះសមនឹងបានទទួលបុណ្យគុណអ្វីពីអ្នករាល់គ្នា
ឱចុះតើអ្នក [ក]ត្រូវថ្លែងអំណរគុណដល់ព្រះរាជាសួគ៌របស់អ្នក
យ៉ាងដូចម្តេចទៅ !
២០ ឱបងប្អូនរបស់យើងអើយ យើងសូមប្រាប់អ្នកថា បើ
សិនជាអ្នកនឹង[ក]ថ្លែងអស់ទាំងអំណរគុណ និងការសរសើរដំកើង
ដែលព្រលឹង ទាំងមូលអ្នកមាន ដើម្បីថ្វាយដល់[ខ]ព្រះ ដែលបាន
បង្កើតអ្នករាល់គ្នាមកនោះ ហើយបានថែរក្សាអ្នកឲ្យបានគង់វង់
ហើយដែលបាន បណ្តាលឲ្យអ្នករាល់គ្នាបានអររីករាយ ហើយបាន
អនុញ្ញាតឲ្យអ្នករាល់គ្នារស់នៅដោយសុខសាន្តជាមួយគ្នា —
២១ យើងសូមប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នានឹងបំរើទ្រង់
ដែលបានបង្កើតអ្នក ចាប់ពីដើមដំបូងមក ហើយកំពុងតែថែរក្សាអ្នក
ឲ្យគង់វង់នៅ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយបានប្រទានដង្ហើមដល់
អ្នក ដើម្បីឲ្យអ្នករាល់គ្នាអាចរស់នៅ ហើយធ្វើចលនា ហើយ
ប្រព្រឹត្តនូវ អ្វីៗ ទៅតាម[ក]ចំណង់របស់ខ្លួន ហើយព្រមទាំងបាន
ជួយគាំទ្រដល់អ្នក ពីរយៈពេលមួយទៅរយៈពេលមួយ —
យើងសូមប្រាប់ថា បើសិនជា អ្នករាល់គ្នានឹងបំរើទ្រង់ ឲ្យអស់ពី
ព្រលឹងទាំងមូលរបស់អ្នកទៅទៀត ក៏អ្នករាល់គ្នានៅតែជាអ្នក
បំរើ [ខ]ដ៏ឥតប្រយោជន៍ដែរ ។
២២ ហើយមើលចុះ ព្រះអង្គទ្រង់គ្រាន់តែតម្រូវ ឲ្យអ្នក[ក]កាន់
[ខ]តាមបញ្ញត្តិទាំងឡាយរបស់ទ្រង់តែប៉ុណ្ណោះ; ហើយព្រះអង្គ
ទ្រង់បាន សន្យានឹងអ្នកថា បើសិនជាអ្នករាល់គ្នានឹងកាន់
តាមបញ្ញត្តិទាំងឡាយរបស់ព្រះអង្គ នោះអ្នករាល់គ្នានឹងបាន
ចំរើនឡើងនៅលើដែនដី; ហើយព្រះអង្គទ្រង់ពុំដែល
[គ]ផ្លាស់ប្តូរនូវអ្វី ដែលព្រះអង្គទ្រង់មានព្រះបន្ទូលនោះឡើយ;
ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នា[ឃ]កាន់តាម ព្រះបញ្ញត្តិ
ទាំងឡាយរបស់ព្រះអង្គ នោះព្រះអង្គទ្រង់នឹងប្រទានពរដល់អ្នក
ហើយធ្វើឲ្យអ្នកចំរើនឡើង ។
២៣ ហើយឥឡូវនេះ ដំបូងបំផុត ព្រះអង្គទ្រង់បានបង្កើតអ្នក
មក ហើយបានប្រទានជីវិតដល់អ្នក ដោយហេតុនេះ អ្នករាល់
គ្នាជំពាក់ បំណុលដល់ព្រះអង្គវិញ ។
២៤ ហើយទីពីរ ព្រះអង្គតម្រូវឲ្យអ្នករាល់គ្នា ធ្វើដូចដែល
ព្រះអង្គទ្រង់បានបញ្ជាដល់អ្នក; [ក]ព្រោះបើសិនជាអ្នករាល់គ្នាធ្វើ
តាមនោះ មែន ព្រះអង្គនឹងប្រទានពរដល់អ្នកភ្លាម; ហេតុ
ដូច្នេះហើយ ព្រះអង្គទ្រង់បានសងអ្នកវិញ ។ ហើយអ្នករាល់
គ្នាក៏នៅតែជំពាក់បំណុល ព្រះអង្គដដែល នៅតែជំពាក់
ហើយជំពាក់ជារៀងដរាបតទៅ; ហេតុដូច្នេះហើយ តើមានអ្វី
ដែលគួរឲ្យអ្នករាល់គ្នាអួតបាន ?

១៥ ក ស.ប. បញ្ញាចិត្ត.
១៧ ក ស.ប. ប្រាជ្ញា.
ខ ម៉ាថាយ ២៥:៤០;
យ៉ាកុប (ព.ស.ថ.) ១:២៧;
គ. និង ស. ៤២:២៩–៣១.
ស.ប. ការបំរើ.
គ ស.ប. ពួកបងប្អូនប្រុស,
បងប្អូនប្រុស; បងប្អូនស្រី.
១៨ ក ម៉ាថាយ ២០:២៦–២៧.
១៩ ក ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
២០ ក ១ នីហ្វៃ ១៨:១៦.
ខ ស.ប. ព្រះ, ក្រុមព្រះ.
២១ ក ស.ប. សិទ្ធិជ្រើសរើស.
ខ លូកា ១៧:៧–១០.
២២ ក លេវី. ២៥:១៨–១៩;
២ នីហ្វៃ ១:៩.
ខ ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
គ គ. និង ស. ៣:១–២.
ឃ គ. និង ស. ១៤:៧; ៥៨:២–៣.
២៤ ក ស.ប. ប្រទានពរ, មានពរ, ព្រះពរ.

២៥ ហើយឥឡូវនេះ យើងសូមសួរថា តើអ្នករាល់គ្នាអាច
និយាយអ្វីអំពីខ្លួនឯងឬទេ ? យើងឆ្លើយថា ទេ ។ អ្នករាល់គ្នាពុំ
អាច និយាយថា អ្នករាល់គ្នាស្មើទៅនឹងធូលីដីនៃផែនដីនេះឡើយ;
ក៏ប៉ុន្តែ អ្នករាល់គ្នាត្រូវបានកើតមកពីធូលីលើផែនដី; ប៉ុន្តែមើលចុះ
ធូលីដីនេះជារបស់ផងព្រះ ដែលបានបង្កើតអ្នករាល់គ្នាមក ។
២៦ ហើយយើង សូម្បីតែរូបយើងនេះ ដែលអ្នករាល់
គ្នាហៅថាជាស្ដេច ក៏ពុំមានអ្វីប្រសើរជាងអ្នករាល់គ្នាឡើយ;
ព្រោះយើងក៏ មកពីធូលីដីដែរ ។ ហើយអ្នករាល់គ្នាឃើញថា
យើងចាស់ ហើយយើងជិតនឹងលះបង់ចោល នូវរូបរាងដែល
អាចស្លាប់នេះទៅឲ្យ ធរណី ដែលជាមាតាខ្លួននោះវិញហើយ ។
២៧ ហេតុដូច្នេះហើយ ដូចជាយើងបានប្រាប់អ្នកថា យើងបាន
បំរើអ្នក គឺបានដើរដោយសតិសម្បជញ្ញៈដ៏ជ្រះថ្លានៅចំពោះព្រះ
ម្ល៉ោះហើយ យើងបានបញ្ជាឲ្យអ្នករាល់គ្នាមកជួបជុំគ្នានៅពេលនេះ
ដើម្បីឲ្យយើងអាចបានឃើញថាឥតទោស ហើយដើម្បីកុំឲ្យ
ឈាម របស់អ្នកប្រឡាក់មកលើយើង នៅពេលដែលយើង
ត្រូវឈរទទួលការជំនុំជំរះពីព្រះ ចំពោះការណ៍ទាំងឡាយ
ដែលព្រះអង្គទ្រង់បាន បញ្ជាដល់យើងអំពីអ្នករាល់គ្នា ។
២៨ យើងសូមប្រាប់អ្នកថា យើងបានបញ្ជាឲ្យអ្នករាល់គ្នាមក
ជួបជុំគ្នានៅទីនេះ ដើម្បីឲ្យយើងអាចកំចាត់សំលៀកបំពាក់យើង
ពីឈាមរបស់អ្នក នៅពេលវេលានេះ កាលដែល
យើងជិតចុះទៅកាន់ផ្នូររបស់យើង ដើម្បីឲ្យយើងអាច
ចុះទៅដោយសុខសាន្ត ហើយឲ្យវិញ្ញាណ អមតៈរបស់យើង
អាចចូលរួមជាមួយនឹងក្រុមចម្រៀងនៅស្ថានលើ ក្នុងការ
ច្រៀងសរសើរដំកើងដល់ព្រះដ៏យុត្តិធម៌ ។
២៩ ហើយថែមទៀត យើងសូមប្រាប់អ្នកថា យើងបាន
បញ្ជាឲ្យអ្នករាល់គ្នាមកជួបជុំគ្នានៅទីនេះ ដើម្បីឲ្យយើងអាច
ប្រកាស ប្រាប់អ្នកថា យើងពុំអាចធ្វើជាគ្រូបង្រៀនអ្នក
តទៅទៀតទេ ឬក៏ធ្វើជាស្ដេចអ្នកទៀតដែរ;
៣០ ព្រោះថា ទោះបីនៅពេលនេះសោត រូបរាង
របស់យើងញ័រចំប្រប់ នៅពេលយើងខំនិយាយទៅកាន់អ្នក;
ប៉ុន្តែព្រះអម្ចាស់ ដ៏ជាព្រះ ទ្រង់បានជួយគាំទ្រយើង ហើយបាន
ទ្រាំឲ្យយើងនិយាយទៅកាន់អ្នករាល់គ្នា ហើយបានបញ្ជាយើងថា
យើងត្រូវប្រកាសប្រាប់ អ្នកនៅថ្ងៃនេះថា ម៉ូសាយ
ជាបុត្ររបស់ខ្ញុំ គឺជាស្ដេច ហើយជាអ្នកគ្រប់គ្រងលើអ្នក ។

៣១ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់យើងអើយ
យើងចង់ឲ្យអ្នករាល់គ្នាធ្វើនូវអ្វី ដែលអ្នករាល់គ្នាបានធ្វើពីមុន
មក ។ ដូចដែលអ្នករាល់គ្នាធ្លាប់បានកាន់តាមបញ្ជារបស់យើង
និងតាមបញ្ជារបស់បិតាយើង ហើយបានចំរើនឡើង ហើយ
ត្រូវបានថែរក្សាកុំឲ្យ ធ្លាក់ទៅក្នុងកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវ
របស់អ្នកយ៉ាងណា នោះបើសិនជាអ្នករាល់គ្នាកាន់តាមបញ្ជា
របស់បុត្រយើង ឬតាមព្រះបញ្ញត្តិ ទាំងឡាយនៃព្រះ ដែលនឹង
ប្រគល់ដល់អ្នកដោយបុត្រយើង នោះអ្នករាល់គ្នានឹងបាន
ចំរើនឡើងនៅលើដែនដីយ៉ាងនោះដែរ ហើយពួក ខ្មាំងសត្រូវ
របស់អ្នកក៏នឹងគ្មានអំណាចអ្វីមកលើអ្នករាល់គ្នាបានឡើយ ។
៣២ ប៉ុន្តែ ឱប្រជាជនរបស់យើងអើយ សូមប្រយ័ត្នប្រយែង
ក្រែងមានការទាស់ទែងគ្នាកើតឡើង នៅក្នុងចំណោមអ្នក ហើយ
ក្រែងអ្នករាល់គ្នាចុះឈ្មោះគោរពតាមវិញ្ញាណអារក្សអសោចិ៍
ដែលបិតាយើង គឺម៉ូសាយ បាននិយាយពីមុនមក ។
៣៣ ត្បិតមើលចុះ មានការវេទនាមួយត្រូវបានដាក់ដល់ជនណា
ដែលចុះឈ្មោះគោរពតាមវិញ្ញាណនោះ; ព្រោះបើសិនជាជន
នោះចុះឈ្មោះគោរពតាមវាមែន ហើយនៅតែស្ដាប់បង្គាប់
ហើយស្លាប់ទៅនៅក្នុងបាបរបស់ខ្លួន ជននោះនឹងផឹកនូវសេច
ក្ដីផាប់ ទោសដល់ព្រលឹងរបស់ខ្លួន; ព្រោះជននោះនឹងទទួល
ទោសដ៏អស់កល្បជានិច្ច សំរាប់ជាឈ្នួលដល់ខ្លួន ដោយបាន
រំលងក្រិត្យវិន័យ នៃព្រះ ដែលផ្ទុយនឹងការចេះដឹងរបស់ខ្លួន ។
៣៤ យើងសូមប្រាប់អ្នកថា គ្មាននរណាម្នាក់នៅក្នុងចំណោម
អ្នករាល់គ្នាឡើយ លើកលែងតែកូនក្មេងតូចៗប៉ុណ្ណោះ ដែល
ពុំ ទាន់ត្រូវបានបង្រៀនអំពីរឿងទាំងនេះ តែចូរដឹងថា អ្នករាល់
គ្នាជាប់ជំពាក់គុណដល់អស់កល្បជានិច្ច ដល់ព្រះវរបិតារបស់
អ្នក ដែល គង់នៅស្ថានសួគ៌ ហើយត្រូវតបស្នងគុណដល់
ព្រះអង្គវិញ នូវអ្វីដែលអ្នករាល់គ្នាមាន; ហើយក៏ត្រូវបាន
បង្រៀនអំពីបញ្ជីទាំងឡាយ ដែលមានកត់នូវពាក្យព្យាករណ៍
ផ្សេងៗ ដែលបានពោលដោយពួកព្យាការីដ៏បរិសុទ្ធទាំងឡាយ
រហូតមកដល់ពេលដែលលីហៃ ជាអយ្យកោរបស់យើង បាន
ចាកចេញពីក្រុងយេរូសាឡិមមក;
៣៥ ហើយព្រមទាំងអ្វីៗទាំងអស់ ដែលពួកអយ្យកោ
របស់យើងបាននិយាយ រហូតមកដល់ពេលឥឡូវនេះផង ។
ហើយមើលចុះ ព្រមទាំងអ្វីៗដែលពួកអយ្យកោរបស់យើងបាន

២៥ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* លោកុ. ៣:១៩;
យ៉ាកុប (ព.ម) ២:២១.
២៧ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* យ៉ាកុប (ព.ម) ១:១៩.
២៨ *ក* យ៉ាកុប (ព.ម) ២:២.
*ខ* ស.ប. វិញ្ញាណ.
*គ* មរមន ៧:៧.
៣២ *ក* ៣ នីហ្វៃ ១១:២៩–៣០.
៣៣ *ក* ស.ប. សេចក្ដីផាប់ទោស.
*ខ* គ. និង ស. ១៩:៦, ១០–១២.

និយាយមក ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាពួកគេ; ហេតុដូច្នេះហើយ អ្វីៗទាំងអស់នោះ ជាការពិត និងត្រឹមត្រូវហើយ ។

៣៦ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់យើងអើយ យើងសូមប្រាប់អ្នកថា បន្ទាប់ពីអ្នករាល់គ្នាបានដឹង ហើយបានរៀន អំពីរឿងទាំងអស់នេះហើយ បើសិនជាអ្នករាល់គ្នានឹងរំលង ហើយដើរផ្ទុយពីអ្វី ដែលបានពោលមកនេះ គឺអ្នករាល់គ្នាដកខ្លួនថយ ចេញពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ដើម្បីកុំឲ្យព្រះវិញ្ញាណមានកន្លែងនៅក្នុងខ្លួនអ្នកទៀតឡើយ ដើម្បីណែនាំអ្នកទៅតាមផ្លូវទាំងឡាយ ខាងប្រាជ្ញា ដើម្បីអ្នករាល់គ្នាអាចបានពរចំរើនឡើង ហើយស្ថិតស្ថេរជាប់នៅ —

៣៧ យើងសូមប្រាប់អ្នកថា ជនណាដែលធ្វើយ៉ាងនេះ គឺជននោះហើយដែលចេញមុខបះបោរទាស់នឹងព្រះ; ហេតុដូច្នេះហើយ ជននោះចុះឈ្មោះគោរពតាមអារក្សអសោចិ៍ ហើយក្លាយទៅជាខ្មាំងសត្រូវដល់គ្រប់ទាំងសេចក្ដីសុចរិត; ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់ពុំមានកន្លែងនៅក្នុងជននោះទេ ត្បិតទ្រង់ពុំគង់នៅក្នុងព្រះវិហារណាដែលឥតបរិសុទ្ធឡើយ ។

៣៨ ហេតុដូច្នេះហើយ បើសិនជាជននោះពុំប្រែចិត្តទេ ហើយនៅដូច្នោះតទៅ ហើយស្លាប់ទៅជាខ្មាំងសត្រូវដល់ព្រះដែរ សេចក្ដីទាមទារនៃសេចក្ដីយុត្តិធម៌ដ៏ឧត្តុង្គឧត្ដម នឹងដាស់ព្រលឹងអមតៈរបស់ជននោះ ឲ្យគេស្គាល់នូវទោសរបស់ខ្លួន ដែលធ្វើឲ្យគេរួញពី វត្តមាននៃព្រះអម្ចាស់ ហើយធ្វើឲ្យទ្រូងរបស់គេពោរពេញទៅដោយទោសកំហុស និងការឈឺចាប់ និងទុក្ខព្រួយ ដូចជាភ្លើងមួយ ដែលពន្លត់មិនបាន ឯអណ្ដាតភ្លើងនឹងសន្ធោសន្ធៅឡើងជារៀងដរាបតទៅ ។

៣៩ ហើយឥឡូវនេះ យើងសូមប្រាប់អ្នកថា សេចក្ដីមេត្តាករុណាពុំអាចទាមទារជននោះបានឡើយ; ហេតុដូច្នេះហើយ ទោសចុងក្រោយបង្អស់របស់ជននោះ គឺត្រូវស៊ូទ្រាំនូវការទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ ។

៤០ ឱអស់អ្នកដែលចាស់ និងអ្នកដែលក្មេង និងអ្នកដែលតូចៗផង ដែលអាចយល់ពាក្យរបស់យើងអើយ ត្បិតយើងបាននិយាយ ដោយច្បាស់លាស់ទៅកាន់អ្នក ដើម្បីឲ្យអ្នករាល់គ្នាយល់ យើងសូមឲ្យអ្នករាល់គ្នាភ្ញាក់ឡើង ដើម្បីចងចាំនូវស្ថានការណ៍ដ៏គួរឲ្យខ្លាចនៃ អស់អ្នកណា ដែលបានធ្លាក់ទៅក្នុងការរំលងច្បាប់ ។

៤១ ហើយថែមទៀត ខ្ញុំចង់ឲ្យអ្នករាល់គ្នាគិតពិចារណាអំពីស្ថានភាពដ៏មានពរ និងរីករាយ នៃអស់អ្នកណាដែលកាន់តាមព្រះ បញ្ញត្តិទាំងឡាយនៃព្រះ ។ ត្បិតមើលចុះ ពួកគេបានពរគ្រប់យ៉ាង ទាំងខាងសាច់ឈាម និងខាងវិញ្ញាណផង; ហើយបើសិនជាពួកគេ រក្សាការស្មោះត្រង់ដរាបដល់ចុងបំផុត នោះពួកគេនឹងត្រូវបានទទួលនៅស្ថានសួគ៌ ដើម្បីឲ្យពួកគេអាចរស់នៅជាមួយនឹងព្រះ ក្នុងស្ថាន ភាពសុភមង្គលដ៏មិនចេះចប់មិនចេះហើយ ។ ឱ សូមចាំ សូមចាំថា រឿងទាំងនេះពិត ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូល ថាដូច្នោះ ៕

---

## ជំពូកទី ៣

*ស្ដេចបេនយ៉ាមីនថ្លែងតទៅទៀត — ព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្ដានឹងធ្វើការងារបំរើនៅក្នុងចំណោមមនុស្សលោក នៅក្នុងរោង ឧបោសថឥដ្ឋ — លោហិតនឹងចេញមកពីគ្រប់រន្ធញើស នៅពេលដែលទ្រង់ធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃពិភពលោក — មានតែ ព្រះនាមរបស់ទ្រង់ទេ ដែលនាំមកនូវសេចក្ដីសង្គ្រោះ — មនុស្សលោកអាចសម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយទៅជា អ្នកបរិសុទ្ធ តាមរយៈដង្វាយធួន — សេចក្ដីផាប់ទោសនៃពួកទុច្ចរិត ប្រៀបបានទៅនឹងបឹងភ្លើង និងស្ពាន់ធ័រ ។ ប្រមាណជាឆ្នាំ ១២៤ ម.គ.ស. ។*

ហើយម្យ៉ាងទៀត ឱបងប្អូនទាំងឡាយរបស់យើងអើយ យើងសូមឲ្យអ្នកយកចិត្តទុកដាក់ ត្បិតយើងនឹងនិយាយទៅកាន់អ្នកទៀត; ត្បិតមើលចុះ យើងមានការណ៍ទាំងឡាយនឹងជំរាបអ្នករាល់គ្នា ស្ដីអំពីអ្វីដែលនឹងកើតឡើង ។

២ ហើយរឿងទាំងឡាយ ដែលយើងនឹងជំរាបបងប្អូន នោះមានទេវតារបស់ព្រះបានមកប្រាប់យើង ហើយទេវតានោះបាននិយាយ មកកាន់យើងថា៖ ចូរភ្ញាក់ឡើង; ហើយយើងក៏ភ្ញាក់ឡើង ហើយមើលចុះ ទេវតានោះឈរចំពោះមុខយើង ។

---

៣៧ *ក* ម៉ូសាយ ៣:១២;
ហេលេ. ៨:២៤–២៥.
ស.ប. ការបះបោរ.
*ខ* អាលម៉ា ៧:២១.
៣៨ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
*គ* ស.ប. ទោស.
៣៩ *ក* អាលម៉ា ៣៤:៨–៩, ១៥–១៦.
ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៤០ *ក* អាលម៉ា ៥:១៨.
៤១ *ក* ៤ នីហ្វៃ ១:១៥–១៨.
ស.ប. សេចក្ដីអំណរ.
*ខ* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*គ* គ. និង ស. ៦:១៣.
*ឃ* ស.ប. ស្ថានសួគ៌.
៣ ២*ក* ស.ប. ពួកទេវតា.

៣ ហើយទេវតាបាននិយាយមកកាន់យើងថាៈ ចូរភ្ញាក់ឡើង
ហើយចូរស្ដាប់ពាក្យទាំងឡាយ ដែលយើងនឹងប្រាប់ដល់អ្នក;
ត្បិតមើលចុះ យើងមកទីនេះ ដើម្បីប្រកាសប្រាប់ដល់អ្នក នូវ
ដំណឹងដ៏រីករាយមួយ ពីសេចក្ដីអំណរយ៉ាងអស្ចារ្យ ។
៤ ត្បិតព្រះអម្ចាស់ ទ្រង់បានឮពាក្យអធិស្ឋានរបស់អ្នក
ហើយបានវិនិច្ឆ័យនូវសេចក្ដីសុចរិតរបស់អ្នក ហើយបានចាត់ឲ្យ
យើងមក ប្រាប់អ្នក ដើម្បីឲ្យអ្នកអាចបានអររីករាយ; ហើយដើម្បីឲ្យ
អ្នកអាចប្រកាសប្រាប់ ដល់ប្រជាជនរបស់អ្នក ដើម្បីឲ្យពួកគេ
អាចបានពោរ ពេញទៅដោយសេចក្ដីអំណរដែរ ។
៥ ត្បិតមើលចុះ ថ្ងៃនោះនឹងមកដល់ គឺមិនយូរប៉ុន្មានទេ
គឺដោយព្រះចេស្ដា នោះព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្ដា
ទ្រង់សោយរាជ្យ គឺព្រះអង្គដ៏មានព្រះជន្មរស់ ចាប់តាំងពីអស់
ទាំងកល្ប ទៅអស់កល្បជានិច្ច ទ្រង់នឹងយាងចុះមកពីស្ថានសួគ៌
មករស់នៅក្នុងចំណោមកូន ចៅមនុស្ស ហើយនឹងគង់នៅក្នុង
រោងឧបោសថឥដ្ឋ ហើយនឹងយាងទៅក្នុងចំណោមមនុស្ស
ដោយសម្ដែងអព្ភូតហេតុផ្សេងៗ ដូចជាធ្វើ អ្នកឈឺឲ្យជា,
ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ, ធ្វើឲ្យអ្នកពិការជើង
អាចដើរបាន, មនុស្សខ្វាក់ឲ្យមើលឃើញ, អ្នកថ្លង់ឲ្យស្ដាប់ឮ,
ហើយមើលឲ្យជាគ្រប់អស់ទាំងរោគា ។
៦ ហើយព្រះអង្គនឹងបណ្ដេញពួកអារក្ស ឬក៏ពួកអារក្សអសោចិ៍
ដែលនៅក្នុងចិត្តនៃកូនចៅមនុស្សចេញ ។
៧ ហើយមើលន៏ ព្រះអង្គនឹងស៊ូទ្រាំនូវការល្បួង និង
ការឈឺចាប់នៃរាងកាយ សេចក្ដីស្រេកឃ្លាន និងការ
នឿយហត់ ច្រើនជាង មនុស្សលោកអាចស៊ូទ្រាំបានទៅទៀត
លើកលែងតែសេចក្ដីស្លាប់ប៉ុណ្ណោះ; ត្បិតមើលចុះ
ព្រះលោហិតចេញមកពីគ្រប់រន្ធញើស សេចក្ដីបារម្ភរបស់
ព្រះអង្គនឹងមានឡើងយ៉ាងខ្លាំង ចំពោះអំពើទុច្ចរិត និងអំពើ
គួរខ្ពើមឆ្អើមទាំងឡាយនៃរាស្ត្ររបស់ទ្រង់ ។
៨ ហើយទ្រង់នឹងត្រូវបានហៅថា ព្រះយេស៊ូវគ្រីស្ទ, ព្រះរាជ
បុត្រានៃព្រះ, ព្រះវរបិតានៃស្ថានសួគ៌ និងផែនដី, ព្រះដែល
បង្កើត វត្ថុសព្វសារពើចាប់តាំងពីដំបូងមក; ហើយមាតារបស់
ព្រះអង្គនឹងត្រូវបានហៅថា ម៉ារា ។
៩ ហើយមើលន៏ ព្រះអង្គនឹងយាងចុះមកក្នុងចំណោមរាស្ត្រទ្រង់
ដើម្បីឲ្យមានសេចក្ដីសង្គ្រោះដល់កូនចៅមនុស្ស ស្របតាមសេចក្ដី
ជំនឿជឿដល់ព្រះនាមទ្រង់; ហើយទោះជាយ៉ាងនេះសោតក្ដី
គង់តែពួកគេនៅតែចាត់ទុកថា ព្រះអង្គជាមនុស្សម្នាក់ ហើយ
ថា ព្រះអង្គ មានអារក្សចូល ហើយនឹងវាយព្រះអង្គ ហើយនឹង
ឆ្កាងព្រះអង្គទៀត ។
១០ ហើយព្រះអង្គនឹងមានព្រះជន្មរស់ពីស្លាប់ឡើងវិញក្នុងបីថ្ងៃ;
ហើយមើលចុះ ព្រះអង្គនឹងឈរ ដើម្បីជំនុំជំរះមនុស្សលោក; ហើយ
មើលចុះ ការណ៍ទាំងអស់នេះ ត្រូវបានធ្វើឡើង ដើម្បីឲ្យសេច
ក្ដីជំនុំជំរះដ៏សុចរិត អាចមានដល់កូនចៅមនុស្ស ។
១១ ត្បិតមើលចុះ ព្រះលោហិតរបស់ទ្រង់ក៏នឹងធ្វើឲ្យធួននឹង
បាបនៃអស់អ្នកណាដែលធ្លាក់ ដោយសារការរំលង
របស់លោកអ័ដាម ហើយស្លាប់ទៅ ដោយមិនបានដឹងអំពី
ព្រះហឫទ័យនៃព្រះ ចំពោះពួកគេ ឬក៏អស់អ្នកណាដែលមាន
បាប ដោយសារល្ងង់ខ្លៅ ។
១២ ប៉ុន្តែ វេទនា វេទនា ដល់អស់អ្នកណាដែលដឹងថាខ្លួនកំពុង

៣ *ក* លូកា ២:១០–១១.
៥ *ក* ស.ប. ព្រះយេហូវ៉ា.
*ខ* ម៉ូសាយ ៧:២៧;
អាលម៉ា ៧:៩–១៣.
*គ* ម៉ាថាយ ៤:២៣–២៤;
កិច្ចការ ២:២២;
១ នីហ្វៃ ១១:៣១.
ស.ប. អព្ភូតហេតុ.
៦ *ក* ម៉ាកុស ១:៣២–៣៤.
៧ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* ម៉ាថាយ ៤:១–២.
*គ* គ. និង ស. ១៩:១៥–១៨.
*ឃ* លូកា ២២:៤៤.
*ង* អេសាយ ៥៣:៤–៥.
៨ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏
ជាព្រះរាជបុត្រា.
*ខ* អាលម៉ា ៧:១០.
*គ* ហេលេ. ១៤:១២;
៣ នីហ្វៃ ៩:១៥.
*ឃ* ម៉ាថាយ ១:១៦;
១ នីហ្វៃ ១១:១៤–២១.
*ង* ស.ប. នាងម៉ារា, មាតារបស់
ព្រះយេស៊ូវ.
៩ *ក* ស.ប. សេចក្ដីសង្គ្រោះ.
*ខ* ស.ប. សេចក្ដីជំនឿ.
*គ* យ៉ូហាន ៨:៤៨.
*ឃ* ម៉ាកុស ១៥:១៥.
*ង* លូកា ១៨:៣៣;
១ នីហ្វៃ ១៩:១០;
២ នីហ្វៃ ១០:៣.
ស.ប. ការឆ្កាង.
១០ *ក* ស.ប. ដំណើររស់ឡើងវិញ.
*ខ* ម៉ាថាយ ១៦:២១;
២ នីហ្វៃ ២៥:១៣;
ហេលេ. ១៤:២០–២៧.
*គ* ស.ប. ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
១១ *ក* ស.ប. លោហិត.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*ឃ* ២ នីហ្វៃ ៩:២៥–២៦.

[ក]បះបោរទាស់នឹងព្រះ! ព្រោះសេចក្ដីសង្គ្រោះនឹងពុំមានដល់ពួក
នេះ ឡើយ លើកលែងតែដោយការប្រែចិត្ត និងសេច
ក្ដីជំនឿជឿ[ខ]ដល់ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។

១៣ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានចាត់ពួកព្យាការី
ទាំងឡាយរបស់ព្រះអង្គ ឲ្យទៅក្នុងចំណោមកូនចៅមនុស្សទាំង
អស់ ដើម្បីប្រកាសប្រាប់ការណ៍ទាំងនេះ ដល់គ្រប់ទាំងពូជ
មនុស្ស គ្រប់សាសន៍ និងគ្រប់ទាំងភាសា ដើម្បីឲ្យអស់អ្នកណា
ដែលជឿថា ព្រះគ្រីស្ទនឹងយាងមក នោះឈ្មោះថា នឹងបាន
ទទួល[ក]ការផ្ដាច់បាបរបស់ខ្លួន ហើយនឹងបានអររីករាយដោយ
សេចក្ដីអំណរដ៏អតិបរិមា ហាក់[ខ]បីដូចជាព្រះអង្គបានយាងមក
ក្នុងចំណោមពួកគេហើយ ។

១៤ ក៏ប៉ុន្តែ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ទតឃើញថា រាស្ត្រព្រះអង្គ
ជាប្រជាជនរឹងរូស ហើយទ្រង់បានចែងក្រិត្យវិន័យមួយដល់ពួក
គេ គឺជា[ក]ក្រិត្យវិន័យលោកម៉ូសេ ។

១៥ ហើយមានទីសំគាល់ និងការអស្ចារ្យ និង[ក]និមិត្តរូប
ហើយស្រមោលជាច្រើន ដែលទ្រង់បានបង្ហាញដល់ពួកគេ
ប្រាប់អំពីការ យាងមករបស់ទ្រង់; ហើយពួកព្យាការីដ៏បរិសុទ្ធ
ក៏បាននិយាយទៅកាន់ពួកគេ អំពីការយាងមករបស់ទ្រង់ដែរ;
ក៏ប៉ុន្តែពួកគេនៅតែ ធ្វើចិត្តរឹងរូស ហើយពុំព្រមយល់ថា
[ខ]ក្រិត្យវិន័យលោកម៉ូសេនឹងពុំមានផលអ្វីឡើយ លើកលែងតែតា
មរយៈដង្វាយធួននៃព្រះលោហិត របស់ទ្រង់ប៉ុណ្ណោះ ។

១៦ ហើយទោះបើ[ក]ពួកកូនក្មេងអាចធ្វើបាបមែន នោះពួកគេ
នឹងពុំអាចបានសង្គ្រោះដែរ; ប៉ុន្តែយើងសូមប្រាប់អ្នកថា ពួក
កូនក្មេង ទាំងនោះមានពរ[ខ]ហើយ; ត្បិតមើលចុះ ដោយមក
ពីលោកអ័ដាម ឬដោយធម្មជាតិ នោះពួកគេបានធ្លាក់ ទោះ
ជាយ៉ាងនេះក្ដី គង់តែព្រះ លោហិតនៃព្រះគ្រីស្ទ នឹងធ្វើឲ្យធួន
នឹងបាបរបស់ពួកគេដែរ ។

១៧ ហើយថែមទៀត យើងសូមប្រាប់អ្នកថា នឹង[ក]ពុំមាននាមណា
មួយ ឬផ្លូវ ឬក៏មធ្យោបាយឯណាទៀតឡើយ ដែលអាចនាំ
សេចក្ដី[ខ] សង្គ្រោះមកឲ្យកូនចៅមនុស្ស មានតែមធ្យោបាយ
មួយប៉ុណ្ណោះ [គ]គឺដោយតាមរយៈព្រះនាមនៃព្រះគ្រីស្ទ ជាព្រះ
អម្ចាស់ដ៏មានគ្រប់ ព្រះចេស្ដា ។

១៨ ត្បិតមើលចុះ ព្រះអង្គជំនុំជំរះ ហើយសេចក្ដីជំនុំជំរះរបស់
ទ្រង់គឺត្រឹមត្រូវ ហើយទារកទាំងឡាយដែលស្លាប់កាលនៅទារក
នៅឡើយ នឹងពុំវិនាសសោះ; ប៉ុន្តែមនុស្សធំផឹកនូវសេច
ក្ដីផាប់ទោសដល់ព្រលឹងរបស់ខ្លួនគេផ្ទាល់ លើកលែងតែគេបន្ទាប
ខ្លួន ហើយ[ក]ក្លាយទៅដូចជាកូនក្មេងតូចៗវិញ ហើយជឿថាសេច
ក្ដីសង្គ្រោះបានកើតឡើង កំពុងកើតឡើង នឹងកើតឡើងនៅពេល
ខាងមុខ គឺដោយតាមរយៈព្រះលោហិត[ខ]ដ៏ធួននៃព្រះគ្រីស្ទ ជា
ព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្ដាប៉ុណ្ណោះ ។

១៩ ព្រោះ[ក]មនុស្សខាងសាច់ឈាមជាសត្រូវដល់ព្រះ ហើយ
មានមកតាំងពី[ខ]ការធ្លាក់នៃលោកអ័ដាមម្ល៉េះ ហើយនឹងនៅ
យ៉ាងនេះ ជារៀងដរាបតទៅ លើកលែងតែ[គ]គេព្រមធ្វើតាម
សេចក្ដីទូន្មាន[ឃ]នៃព្រះវិញ្ញាណបរិសុទ្ធ ហើយសម្រាតភាពខាង
សាច់ឈាមចេញ ហើយក្លាយទៅជា[ង]អ្នកបរិសុទ្ធវិញ
តាមរយៈដង្វាយធួននៃព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ហើយក្លាយ
ទៅដូចជា[ច]កូនក្មេង ងាយប្រដៅ ស្លូតបូត ទាបរាបសា អត់ឱន
ពោរពេញទៅដោយសេចក្ដីស្រឡាញ់ ព្រមទទួលនូវអ្វីៗទាំង
អស់ ដែលព្រះអម្ចាស់ទ្រង់ទតឃើញថាល្អ ដូចជា កូនក្មេងព្រម
ធ្វើតាមឪពុកខ្លួនដូច្នោះ ។

២០ ហើយថែមទៀត យើងសូមប្រាប់អ្នកថា ថ្ងៃនោះនឹងមក
ដល់ កាលណា[ក]ការចេះដឹងអំពីព្រះអង្គសង្គ្រោះ នឹងបានផ្សាយ
ទូទៅ [ខ]គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់
ទាំងប្រជាជន ។

---

១២ *ក* ម៉ូសាយ ២:៣៦–៣៨;
ហេលេ. ៨:២៥.
ស.ប. ការបះបោរ.
*ខ* ស.ប. ព្រះអម្ចាស់.
១៣ *ក* ស.ប. ការផ្ដាច់បាប.
*ខ* ២ នីហ្វៃ ២៥:២៤–២៧;
យ៉ារ៉ុម ១:១១.
១៤ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
១៥ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — គំរូ
និងនិមិត្តរូបទាំងឡាយអំពីព្រះគ្រីស្ទ.
*ខ* ម៉ូសាយ ១៣:២៧–៣២.
១៦ *ក* ស.ប. កូនក្មេង, ពួកកូនក្មេង.
*ខ* មរ៉ូណៃ ៨:៨–៩.
១៧ *ក* កិច្ចការ ៤:១០–១២;
២ នីហ្វៃ ៣១:២១.
*ខ* ស.ប. សេចក្ដីសង្គ្រោះ.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការ
យកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ
មកដាក់លើខ្លួនយើង.
១៨ *ក* ម៉ាថាយ ១៨:៣.
*ខ* ម៉ូសាយ ៤:២; ហេលេ. ៥:៩.
១៩ *ក* ១ កូរិន. ២:១១–១៤;
ម៉ូសាយ ១៦:២–៣.
ស.ប. មនុស្សខាងសាច់ឈាម.
*ខ* ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*គ* ២ របា. ៣០:៨.
*ឃ* មរ៉ូណៃ ១០:៤–៥.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ង* ស.ប. ជនបរិសុទ្ធ.
*ច* ៣ នីហ្វៃ ៩:២២.
២០ *ក* គ. និង ស. ៣:១៦.
*ខ* ស.ប. កិច្ចការផ្សាយសាសនា.

២១ ហើយមើលចុះ ថ្ងៃនោះនឹងពុំមានអ្នកណាម្នាក់ដែល ឃើញថា គ្មានទោសនៅចំពោះព្រះឡើយ លើកលែងតែ កូនក្មេងតូចៗ គឺមានតែតាមរយៈការប្រែចិត្ត និងសេចក្ដីជំនឿជឿដល់ព្រះនាមនៃព្រះអម្ចាស់ ជាព្រះដ៏មានគ្រប់ព្រះចេស្ដាប៉ុណ្ណោះ ។

២២ ហើយសូម្បីតែនៅពេលនេះ កាលដែលអ្នកនឹងបាន ប្រដៅប្រជាជនអ្នក នូវការណ៍ទាំងឡាយ ដែលព្រះអម្ចាស់ ជាព្រះរបស់អ្នក ទ្រង់បានបញ្ជាដល់អ្នក នោះគេក៏នៅតែពុំអាច ចាត់ទុកថា គ្មានទោសនៅចំពោះព្រះដែរ គឺគ្រាន់តែស្របតាម ពាក្យទាំងឡាយ ដែលខ្ញុំបាននិយាយទៅកាន់អ្នកប៉ុណ្ណោះ ។

២៣ ហើយឥឡូវនេះ យើងបាននិយាយនូវពាក្យទាំងឡាយ ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានបញ្ជាយើង ។

២៤ ហើយព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ពាក្យទាំងនេះនឹងទៅជាទីបន្ទាល់ដ៏ជ្រះថ្លា ទាស់នឹងប្រជាជននេះ នៅថ្ងៃជំនុំជំរះ; ជាថ្ងៃដែលពួកគេនឹងត្រូវបានជំនុំជំរះ គឺមនុស្សគ្រប់រូប ស្របតាមកិច្ចការទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ដើម្បីឲ្យ ឃើញថា ពួកគេល្អ ឬក៏ពួកគេអាក្រក់ ។

២៥ ហើយបើសិនជាពួកគេអាក្រក់ ពួកគេនឹងត្រូវបាន ដាក់ទៅឲ្យឃើញភាពដ៏គួរស្ញែងខ្លាចនៃកំហុស និងអំពើ គួរខ្ពើមឆ្អើមទាំង ឡាយរបស់ខ្លួនគេផ្ទាល់ ដែលនឹងធ្វើឲ្យពួក គេរួញពីវត្តមាននៃព្រះអម្ចាស់ ឲ្យធ្លាក់ទៅក្នុងស្ថានភាពមួយ ដ៏វេទនា និងសេចក្ដីទុក្ខវេទនា ដ៏មិនចេះចប់មិនចេះហើយ ជាទីដែលពួកគេពុំអាចត្រឡប់ក្រោយបានឡើយ; ហេតុ ដូច្នេះហើយ ពួកគេបានផឹកនូវសេចក្ដីផាប់ទោស ដល់ព្រលឹង របស់ខ្លួនគេផ្ទាល់ ។

២៦ ហេតុដូច្នេះហើយ ពួកគេបានផឹកពែងនៃការពិរោធនៃ ព្រះ ដែលសេចក្ដីយុត្តិធម៌ពុំអាចបដិសេធពួកគេ លើសជាង បដិសេធថា លោកអ័ដាមត្រូវធ្លាក់ ព្រោះតែការទទួលទាន ផ្លែដែលហាមឃាត់; ហេតុដូច្នេះហើយ សេចក្ដីមេត្តាករុណាពុំ អាចជួយឃ៉ឹតយោងពួកគេ ជាអង្វែងតទៅ ។

២៧ ឯសេចក្ដីទុក្ខវេទនារបស់ពួកគេ គឺបីដូចជាបឹងភ្លើង និង ស្ពាន់ធ័រ ដែលមានអណ្ដាតភ្លើងពុំអាចពន្លត់បាន ហើយមាន ផ្សែងហុយ ឡើងជារៀងដរាបតទៅ ។ ព្រះអម្ចាស់ទ្រង់បាន បញ្ជាខ្ញុំថាដូច្នោះ ។ អាម៉ែន ៕

## ជំពូកទី ៤

*ស្ដេចបេនយ៉ាមីនថ្លែងតទៅទៀត — សេចក្ដីសង្គ្រោះ កើតឡើងក៏ដោយសារដង្វាយធួន — ចូរជឿដល់ព្រះ ដើម្បីឲ្យ បានសង្គ្រោះ — ទទួលការផ្ដាច់បាបតាមរយៈសេចក្ដីស្មោះត្រង់ — ចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួន ឲ្យអ្នកទាល់ក្រ — ធ្វើអ្វីៗទាំងអស់តាមប្រាជ្ញា និងរបៀបរៀបរយ ។ ប្រមាណ ជាឆ្នាំ ១២៤ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល ស្ដេចបេនយ៉ាមីនបានបញ្ចប់នូវការនិយាយពាក្យទាំងឡាយ ដែលទេវតានៃ ព្រះអម្ចាស់ បានប្រាប់ដល់ទ្រង់ហើយ នោះទ្រង់ក៏បានក្រឡេកទតមើលជុំវិញ ទៅលើហ្វូងមនុស្ស ហើយមើលចុះ ពួកគេបានដួលទៅ លើដី ព្រោះការកោតខ្លាច ដល់ព្រះអម្ចាស់បានមកលើពួកគេ ។

២ ហើយពួកគេបានឃើញថា ខ្លួនគេនៅក្នុងស្ថានភាពខាង រូបកាយ អន់ជាងធូលីដីទៅទៀត ។ ហើយពួកគេទាំងអស់គ្នា បាន ស្រែកព្រមគ្នា ដោយសម្លេងតែមួយថា៖ ឱសូមមេត្តាផង ហើយសូមប្រទាននូវព្រះលោហិតដ៏ធួននៃព្រះគ្រីស្ទ ដើម្បីឲ្យ យើងអាចបាន ទទួលនូវការអភ័យទោស ចំពោះអំពើបាបទាំង ឡាយរបស់យើង ហើយដើម្បីឲ្យចិត្តយើងអាចបានជ្រះបរិសុទ្ធ ផងចុះ; ព្រោះយើងជឿ ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជ បុត្រានៃព្រះ ដែលបានបង្កើតផ្ទៃមេឃ និងផែនដី និងរ គ្រប់សព្វសារពើ; ព្រះអង្គនឹងយាងចុះមកក្នុង ចំណោមកូនចៅ មនុស្ស ។

៣ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេបាន ពោលពាក្យទាំងនេះហើយ នោះព្រះវិញ្ញាណនៃព្រះអម្ចាស់ ក៏បាន ចុះ មកសណ្ឋិតលើពួកគេ ហើយពួកគេក៏ពោរពេញទៅដោយ

២១ *ក* ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
២៥ *ក* អាលម៉ា ៥:១៨; ១២:១៤–១៥.
*ខ* មរមន ៨:៣៨.
២៦ *ក* មរមន ៩:១២.
*ខ* លោកុ. ៣:១–១២; ២ នីហ្វៃ ២:១៥–១៩; អាលម៉ា ១២:២១–២៣.
*គ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
២៧ *ក* ស.ប. ទោស.
*ខ* ២ នីហ្វៃ ៩:១៦; យ៉ាកុប (ព.ម) ៦:១០; គ. និង ស. ៧៦:៣៦.
៤ ១ *ក* ស.ប. សេចក្ដីកោតខ្លាច.
២ *ក* ស.ប. ខាងរូបកាយ.
*ខ* ហេលេ. ១២:៧–៨.
*គ* ម៉ូសាយ ៣:១៨; ហេលេ. ៥:៩.
*ឃ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.

សេចក្ដីអំណរ ដោយបានទទួល[ក]ការផ្ដាច់បាបទាំងឡាយរបស់គេ ហើយ ដោយមានសេចក្ដីសុខសាន្ត[ខ]ក្នុងសតិសម្បជញ្ញៈ ព្រោះតែ[គ]សេចក្ដីជំនឿដ៏លើសលប់ ដែលពួកគេមានដល់ព្រះយេស៊ូវគ្រីស្ទ ដែលនឹង យាងមក ស្របតាមពាក្យទាំងឡាយ ដែលស្ដេចបេនយ៉ាមីនមានបន្ទូលមកកាន់ពួកគេ ។

៤ ហើយស្ដេចបេនយ៉ាមីនបានបើកព្រះឱស្ឋចាប់ផ្ដើមមានបន្ទូលទៅកាន់ពួកគេម្ដងទៀតថា៖ ឱមិត្តសំឡាញ់របស់យើង និងពួកបងប្អូន របស់យើង ពួជរបស់យើង និងប្រជាជនរបស់យើងអើយ យើងសូមឲ្យអ្នកយកចិត្តទុកដាក់សារជាថ្មី ដើម្បីឲ្យអ្នករាល់គ្នាអាចបានឮ ហើយបានយល់ នូវពាក្យសំដីរបស់យើង ដែលនៅសល់ទាំងប៉ុន្មាននេះ ដែលយើងនឹងប្រាប់អ្នក ។

៥ ត្បិតមើលចុះ បើសិនជាបានស្គាល់នូវសេចក្ដីល្អសប្បុរស[ក]នៃព្រះ នៅពេលនេះ បានដាស់តឿនអ្នកឲ្យយល់នូវភាពឥតន័យរបស់ខ្លួន និងភាពឥតតម្លៃ ហើយនឹងស្ថានភាពដ៏ធ្លាក់របស់ខ្លួន —

៦ នោះយើងសូមប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នាបាន[ក]ស្គាល់នូវសេចក្ដីល្អសប្បុរសនៃព្រះ និងព្រះចេស្ដាដ៏ឥតប្រៀបផ្ទឹមបាន និងប្រាជ្ញារបស់ព្រះអង្គ និងសេចក្ដីអត់ធន់របស់ព្រះអង្គ និងសេចក្ដីអត់ធ្មត់របស់ព្រះអង្គ ចំពោះកូនចៅមនុស្ស; ហើយព្រមទាំង[ខ]ដង្វាយ ធួន ដែលបានរៀបចំឡើងចាប់តាំងពី[គ]កំណើតលោកិយមក ដើម្បីឲ្យសេចក្ដីសង្គ្រោះអាចមានដល់អ្នកណាដែលដាក់[ឃ]ទីទុកចិត្តរបស់ខ្លួន ទៅលើព្រះអម្ចាស់ ហើយមានចិត្តព្យាយាមក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយបន្តសេចក្ដីជំនឿទៅរហូត ដល់អស់ជីវិតខ្លួន គឺយើងនិយាយអំពីជីវិតនៃរូបកាយខាងសាច់ឈាម —

៧ យើងនិយាយថា គឺជននេះហើយដែលនឹងទទួលសេចក្ដីសង្គ្រោះ តាមរយៈដង្វាយធួនដែលបានរៀបចំឡើងចាប់តាំងពីកំណើត លោកិយមក សំរាប់មនុស្សគ្រប់រូប ទោះជនណាក៏ដោយ ដែលបានរស់នៅ ចាប់តាំងពី[ក]ការធ្លាក់នៃលោកអ័ដាម ឬក៏ជនទាំងឡាយណា ដែលរស់នៅ ឬនឹងរស់នៅ គឺរហូតដល់ចុងបំផុតនៃពិភពលោក ។

៨ ហើយនេះគឺជាមធ្យោបាយដែលនឹងនាំមកនូវសេចក្ដីសង្គ្រោះ ។ ហើយ[ក]គ្មានសេចក្ដីសង្គ្រោះឯណាទៀតទេ លើកលែងតែ សេចក្ដីសង្គ្រោះដែលបាននិយាយមកប៉ុណ្ណោះ; ហើយក៏គ្មានលក្ខខ័ណ្ឌឯណាទៀតដែរ ដែលអាចជួយសង្គ្រោះមនុស្សបានឡើយ លើកលែងតែល័ក្ខខ័ណ្ឌដែលយើងបានប្រាប់អ្នកប៉ុណ្ណោះ ។

៩ សូមជឿដល់ព្រះចុះ; សូមជឿថា ទ្រង់មានព្រះជន្មរស់នៅ ហើយថា ទ្រង់បានបង្កើតវត្ថុសព្វសារពើ ទាំងនៅលើស្ថានសួគ៌ និងនៅលើផែនដីផង; សូមជឿថា ទ្រង់មានគ្រប់[ក]ប្រាជ្ញា និងគ្រប់ព្រះចេស្ដា ទាំងនៅលើស្ថានសួគ៌ និងនៅលើផែនដីផង; សូមជឿថា មនុស្ស[ខ]ពុំយល់នូវអ្វីទាំងអស់ ដែលព្រះទ្រង់អាចយល់បាននោះឡើយ ។

១០ ហើយម្យ៉ាងទៀត សូមជឿថា អ្នករាល់គ្នាត្រូវតែ[ក]ប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន ហើយលះបង់ចោលអំពើបាបទាំងនោះ ទៅ ហើយបន្ទាបខ្លួនចំពោះព្រះ; ហើយសូមអំពាវនាវដោយចិត្តស្មោះ សូមឲ្យ[ខ]ទ្រង់អភ័យទោសដល់អ្នករាល់គ្នា; ហើយឥឡូវនេះ បើសិនជាអ្នករាល់គ្នា[គ]ជឿនូវការណ៍ទាំងអស់នេះ នោះសូមឲ្យអ្នករាល់គ្នាចាប់ផ្ដើម[ឃ]ប្រព្រឹត្តភ្លាមទៅ។

១១ ហើយមួយទៀត យើងសូមប្រាប់អ្នក ដូចដែលយើងបាននិយាយពីមុនមកថា នៅពេលដែលអ្នករាល់គ្នាបាននូវការចេះដឹងអំពី សិរីល្អនៃព្រះ ឬបើសិនជាអ្នករាល់គ្នាបានស្គាល់នូវសេចក្ដីល្អសប្បុរសរបស់ទ្រង់ ហើយ[ក]បានភ្លក់នូវសេចក្ដីស្រឡាញ់របស់ទ្រង់ ហើយបាន ទទួលនូវ[ខ]ការផ្ដាច់បាបទាំងឡាយរបស់ខ្លួន ដែលបណ្ដាលឲ្យមានសេចក្ដីអំណរជាអតិបរមា នៅក្នុងដួងព្រលឹងរបស់អ្នកយ៉ាងណា នោះខ្ញុំចង់ឲ្យអ្នករាល់គ្នាចងចាំ ហើយ

---

៣ *ក* ស.ប. ការផ្ដាច់បាប.
*ខ* ស.ប. បញ្ញាចិត្ត.
*គ* ស.ប. សេចក្ដីជំនឿ.
៥ *ក* ម៉ូសេ ១:១០.
៦ *ក* ស.ប. ព្រះ, ក្រុមព្រះ.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ម៉ូសាយ ១៥:១៩.
*ឃ* ទំនុក. ៣៦:៧; ២ នីហ្វៃ ២២:២; ហេលេ. ១២:១. ស.ប. ទុកចិត្ត.
៧ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
៨ *ក* កិច្ចការ ៤:១២; ២ នីហ្វៃ ៣១:២១; ម៉ូសាយ ៣:១៧.
៩ *ក* រ៉ូម ១១:៣៣—៣៤; យ៉ាកុប ៤:៨—១៣.
*ខ* អេសាយ ៥៥:៩.
១០ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* គ. និង ស. ៦១:២.
*គ* ម៉ាថាយ ៧:២៤—២៧.
*ឃ* ២ នីហ្វៃ ៣១:១៩—២១.
១១ *ក* អាលម៉ា ៣៦:២៤—២៦.
*ខ* ស.ប. ការផ្ដាច់បាប.

ចងចាំជានិច្ចនូវភាពមហិមានៃព្រះ និងភាពឥតន័យរបស់អ្នក
និងសេចក្ដីល្អសប្បុរស និងសេចក្ដី អត់ធ្មត់របស់ទ្រង់ ចំពោះ
អ្នករាល់គ្នា ដែលជាសត្វលោកឥតតម្លៃ ហើយសូមបន្ទាបខ្លួន
របស់អ្នកដល់ជំរៅនៃភាពរាបសា ដោយអំពាវ នាវដល់
ព្រះនាមរបស់ព្រះអម្ចាស់ជារៀងរាល់ថ្ងៃ ហើយឈរយ៉ាង
រឹងប៉ឹង នៅក្នុងសេចក្ដីជំនឿ ជឿដល់អ្វីដែលកើតឡើង ក្នុង
អនាគត ដែលបានពោលដោយមាត់របស់ទេវតា ។
១២ ហើយមើលចុះ យើងសូមប្រាប់អ្នកថា បើសិនជាអ្នក
រាល់គ្នាធ្វើដូច្នេះ នោះអ្នករាល់គ្នានឹងបានអររីករាយជានិច្ច ហើយ
បាន ពោរពេញទៅដោយសេចក្ដីស្រឡាញ់នៃព្រះ ហើយបាន
ទទួលការផ្ដាច់បាបទាំងឡាយរបស់អ្នកជានិច្ច; ហើយអ្នករាល់
គ្នានឹងបានដុះ ដាលនៅក្នុងការស្គាល់ពីសិរីល្អនៃព្រះអង្គ ដែល
បានបង្កើតអ្នកមក ឬនៅក្នុងការស្គាល់ពីអ្វីដែលពិត ហើយ
ត្រឹមត្រូវ ។
១៣ ហើយអ្នករាល់គ្នានឹងពុំមានគំនិតចង់ព្យាបាទគ្នាទៅវិញទៅ
មកឡើយ ប៉ុន្តែចង់រស់នៅដោយសុខសាន្ត ហើយឲ្យដល់
មនុស្សគ្រប់រូប ស្របតាមអ្វីដែលជារបស់ផងអ្នកនោះ ។
១៤ ហើយអ្នករាល់គ្នានឹងពុំទ្រាំឲ្យកូនចៅរបស់អ្នកអត់ឃ្លាន
ឬគ្មានសំលៀកបំពាក់បិទបាំងកាយឡើយ; ហើយអ្នករាល់គ្នា
ក៏ពុំទ្រាំ ឲ្យកូនចៅអ្នករំលងក្រិត្យវិន័យទាំងឡាយនៃព្រះ ហើយ
ឈ្លោះប្រកែកគ្នាទៅវិញទៅមក ហើយបំរើអារក្ស ដែល
ជាចៅហ្វាយនៃ អំពើបាប ឬក៏អារក្សអសោចិ៍ ដែលពួក
អយ្យកោរបស់យើងបាននិយាយដល់ គឺវានេះហើយដែលជា
ខ្មាំងសត្រូវដល់គ្រប់អស់ទាំង សេចក្ដីសុចរិត ។
១៥ ប៉ុន្តែអ្នករាល់គ្នានឹងបង្រៀនកូនចៅអ្នក ឲ្យដើរតាមផ្លូវទាំង
ឡាយដែលពិត ហើយម៉ឺងមាត់; អ្នករាល់គ្នានឹងបង្រៀន
កូនចៅអ្នក ឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយឲ្យបំរើ
គ្នាទៅវិញទៅមក ។
១៦ ហើយរីឯរូបអ្នក ក៏អ្នករាល់គ្នានឹងជួយដល់អស់អ្នកណា
ដែលត្រូវការជំនួយពីអ្នក; អ្នករាល់គ្នានឹងចែករំលែកនូវ ទ្រព្យ
របស់ខ្លួន ដល់អស់អ្នកណាដែលត្រូវការ; ហើយអ្នករាល់គ្នា
នឹងពុំទ្រាំឲ្យអ្នកសុំទាន មកសុំដោយគ្មានបានផលអ្វី តែបណ្ដេញ
គាត់ចេញឲ្យវិនាស បង់ឡើយ ។
១៧ ប្រហែលជាអ្នកនឹងនិយាយថា៖ មនុស្សនេះបាននាំមក
លើខ្លួននូវសេចក្ដីវេទនា; ហេតុដូច្នេះហើយ ខ្ញុំនឹងទុកដៃនៅស្ងៀម
ហើយនឹងពុំឲ្យដល់អ្នកនោះនូវអាហារខ្ញុំឡើយ ឬក៏ចែករំលែក
ដល់អ្នកនោះ នូវទ្រព្យរបស់ខ្ញុំ ដើម្បីកុំឲ្យអ្នកនោះរងទុក្ខ
ត្បិតទោស របស់គាត់ គឺត្រឹមត្រូវហើយ —
១៨ ប៉ុន្តែ យើងសូមប្រាប់អ្នកថា ឱមនុស្សលោកអើយ អ្នក
ណាដែលធ្វើយ៉ាងនេះ អ្នកនោះមានហេតុដ៏ធំសំរាប់ប្រែចិត្ត;
ហើយ លើកលែងតែអ្នកនោះប្រែចិត្តចំពោះអំពើ ដែលគេបាន
ធ្វើ បើពុំនោះសោតទេ គេនឹងត្រូវវិនាសរហូតតទៅ ហើយពុំ
មានផល ប្រយោជន៍អ្វី នៅក្នុងនគរនៃព្រះឡើយ ។
១៩ ត្បិតមើលចុះ តើយើងទាំងអស់គ្នានេះ ពុំមែនជាអ្នក
សុំទានទេឬ ? តើយើងទាំងអស់គ្នានេះ ពុំពឹងផ្អែកទៅលើ
តួអង្គតែមួយ គឺព្រះ ចំពោះអ្វីៗទាំងអស់ដែលយើងមាន
ទាំងស្បៀងអាហារ និងសំលៀកបំពាក់ និងមាស និងប្រាក់
និងទាំងទ្រព្យសម្បត្តិនានា ដែល យើងមានសព្វសារពើទេឬ ?
២០ ហើយមើលចុះ សូម្បីតែនៅពេលនេះក្ដី ក៏អ្នករាល់
គ្នាកំពុងតែអំពាវនាវដល់ព្រះនាមព្រះអង្គ ហើយសូមនូវការ
ផ្ដាច់បាបទាំង ឡាយរបស់អ្នកដែរ ។ ហើយតើព្រះអង្គបាន
ទ្រាំឲ្យអ្នករាល់គ្នាសូមអង្វរ ដោយឥតបានផលដែរឬអី ? ទេ;
ព្រះអង្គទ្រង់បានស្រោច ព្រះវិញ្ញាណទ្រង់មកលើអ្នករាល់គ្នា
ហើយបានធ្វើឲ្យចិត្តរបស់អ្នករាល់គ្នា ពោរពេញទៅដោយ
សេចក្ដីអំណរ ហើយបានធ្វើឲ្យមាត់អ្នក ឈប់ស្ងៀម ដើម្បីកុំឲ្យ
អ្នករាល់គ្នាអាចរកពាក្យវាចាបាន ព្រោះសេចក្ដីអំណររបស់
អ្នក មានគំរិតខ្ពស់ជាអតិបរមា ។
២១ ហើយឥឡូវនេះ បើសិនជាព្រះអង្គដែលបានបង្កើតអ្នក

១១ *ក* ម៉ូសេ ១:១០.
*ឃ* និក្ខ. ៣៤:៦; ម៉ូរ៉ូណៃ ៨:៣.
*ង* ស.ប. បន្ទាបខ្លួន, ចិត្តសុភាព រាបសា.
*ច* ស.ប. ការអធិស្ឋាន.
១២ *ក* ស.ប. សេចក្ដីស្រឡាញ់.
*ខ* ម៉ូសាយ ៤:២៦; អាលម៉ា ៤:១៣–១៤; ៥:២៦–៣៥; គ. និង ស. ២០:៣១–៣៤.
១៣ *ក* ស.ប. អ្នកផ្សះផ្សា.
១៤ *ក* ១ ធីម៉ូ. ៥:៨; គ. និង ស. ៨៣:៤.
*ខ* ស.ប. ការទាស់ទែង.
១៥ *ក* គ. និង ស. ៦៨:២៥–២៨; ម៉ូសេ ៦:៥៨. ស.ប. បង្រៀន, គ្រូបង្រៀន.
*ខ* ស.ប. ដើរ, ដើរជាមួយព្រះ.
*គ* ម៉ូសាយ ១៨:២១.
១៦ *ក* ស.ប. សេចក្ដីសប្បុរស; ការបំរើ.
*ខ* ចោទិ. ១៥:៧–១១; សុភា. ២១:១៣; អេសាយ ១០:១–២.
១៧ *ក* សុភា. ១៧:៥.
២០ *ក* ស.ប. សេចក្ដីអំណរ.

មក ដែលអ្នកពឹងផ្អែកដល់ព្រះអង្គ ចំពោះជីវិតរបស់អ្នក និង
អ្វីៗទាំង អស់ដែលអ្នករាល់គ្នាមាន និងរូបរបស់អ្នកផង
ព្រះអង្គទ្រង់ប្រទានដល់អ្នក នូវអ្វីៗដែលអ្នករាល់គ្នាសូមដែល
ត្រឹមត្រូវ នៅក្នុងសេចក្ដី ជំនឿ ដោយជឿថា អ្នករាល់គ្នានឹង
បានទទួល ឱបើដូច្នោះ អ្នករាល់គ្នាគួរតែ[ក]ចែករំលែកនូវទ្រព្យ
ដែលអ្នករាល់គ្នាមាន ដល់គ្នាទៅវិញ ទៅមក ។
២២ ហើយបើសិនជាអ្នករាល់គ្នា[ក]ថ្កោលទោសដល់មនុស្ស
ដែលមកសុំទានអ្នក ដើម្បីកុំឲ្យខ្លួនវិនាស ហើយអ្នកកាត់ទោស
ដល់ អ្នកនោះវិញ តើការកាត់ទោសអ្នកត្រឹមត្រូវជាងនេះទៅឬអ្វី
ដែលអ្នក[ខ]ឱបក្រសោបទ្រព្យរបស់ខ្លួនទុក ហើយទ្រព្យនោះក៏ពុំ
មែនជារបស់ អ្នកផង តែជារបស់ព្រះទេតើ ឯជីវិតរបស់អ្នក
សោត ក៏ជារបស់ព្រះដែរ; ប៉ុន្តែអ្នករាល់គ្នាពុំបានសុំទាន
ហើយក៏ពុំប្រែចិត្តចំពោះការណ៍ ដែលអ្នកបានប្រព្រឹត្តសោះ ។
២៣ យើងសូមប្រាប់អ្នកថា វេទនានឹងមានដល់អ្នកនោះ
ព្រោះទ្រព្យរបស់គេនឹងវិនាសទៅជាមួយគេដែរ; ហើយឥឡូវនេះ
យើងនិយាយពីការណ៍ទាំងនេះ ទៅកាន់អស់អ្នកណា ដែល
ជាអ្នកមាន គឺមាន[ក]សម្បត្តិទ្រព្យដែលទាក់ទងទៅលើអ្វីៗ
នៃលោកិយនេះ ។
២៤ ហើយមួយទៀត យើងនិយាយទៅកាន់អ្នកទាល់ក្រ
គឺពួកអ្នករាល់គ្នាដែលគ្មានទ្រព្យ តែមានល្មមគ្រប់គ្រាន់ ដើម្បីឲ្យ
អ្នករាល់គ្នាបានទប់ទល់ពីមួយថ្ងៃទៅមួយថ្ងៃ; យើងនិយាយដល់
អស់អ្នកណា ដែលបដិសេធអ្នកសុំទាន ពីព្រោះអ្នករាល់គ្នា
គ្មានអ្វីនឹងឲ្យ; យើងចង់ឲ្យអ្នករាល់គ្នានិយាយនៅក្នុងចិត្តថា៖
ខ្ញុំពុំដាក់ទាន ព្រោះខ្ញុំគ្មានអ្វីសំរាប់ដាក់ទានទេ ប៉ុន្តែបើសិនជា
ខ្ញុំមាន [ក]ខ្ញុំនឹងដាក់ទាន ។
២៥ ហើយឥឡូវនេះ បើសិនជាអ្នករាល់គ្នានិយាយពាក្យនេះនៅ
ក្នុងចិត្តអ្នក នោះអ្នករាល់គ្នានឹងនៅគ្មានទោសទេ បើពុំនោះ
សោតទេ អ្នករាល់គ្នានឹង[ក]ត្រូវជាប់ទោស; ឯការកាត់ទោសមក
លើរូបអ្នក គឺត្រឹមត្រូវហើយ ព្រោះអ្នករាល់គ្នាលោភលន់នូវអ្វី
ដែល អ្នករាល់គ្នាពុំបានទទួល ។
២៦ ហើយឥឡូវនេះ សំរាប់អ្វីៗដែលយើងទើបតែនិយាយ
ទៅកាន់អ្នករាល់គ្នានេះ — គឺថា ដើម្បីឲ្យមានការ
ផ្ដាច់បាបទាំងឡាយ របស់អ្នក ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីឲ្យ
អ្នករាល់គ្នាអាច[ក]ដើរ ដោយឥតទោសនៅចំពោះព្រះ —
យើងចង់ឲ្យអ្នករាល់គ្នា[ខ]ចែករំលែកនូវ ទ្រព្យរបស់ខ្លួន [គ]ដល់អ្នក
ទាល់ក្រ មនុស្សម្នាក់ៗស្របតាមអ្វីដែលគេមាន ដូចជាឲ្យ
[ឃ]អាហារដល់អ្នកអត់ឃ្លាន ឲ្យសំលៀកបំពាក់ដល់អ្នក អាក្រាត
ទៅមើលអ្នកឈឺ ហើយជួយគាំទ្រដល់គេ ទាំងខាងវិញ្ញាណ
និងខាងសាច់ឈាម ស្របទៅតាមសេចក្ដីត្រូវការរបស់គេ ។
២៧ ហើយចូរឲ្យឃើញថា គ្រប់ការណ៍ទាំងនេះត្រូវបាន
ប្រព្រឹត្តឡើងក្នុងប្រាជ្ញា និងរបៀបរៀបរយ; ត្បិតមិនត្រូវឲ្យអ្នក
ណា [ក]រត់លឿនជាងកម្លាំង ដែលគេមាននោះឡើយ ។ ហើយ
មួយទៀត ជាការចាំបាច់ឲ្យអ្នកនោះត្រូវព្យាយាម ដើម្បីគេអាច
បានរង្វាន់; ហេតុដូច្នេះហើយ គ្រប់ការណ៍ទាំងអស់ត្រូវបាន
ប្រព្រឹត្តឡើង តាមរបៀបរៀបរយ ។
២៨ ហើយយើងចង់ឲ្យអ្នករាល់គ្នាចងចាំថា អ្នកណាមួយ
ក្នុងចំណោមពួកអ្នករាល់គ្នាបានខ្ចីអ្វីពីអ្នកជិតខាង ត្រូវតែសង
របស់នោះ ទៅគេវិញ ស្របតាមអ្វីដែលខ្លួនបានសន្យា
ឬពុំនោះសោតទេ អ្នកបានប្រព្រឹត្តអំពើបាប; ហើយក្រែងអ្នក
អាចធ្វើឲ្យអ្នកជិតខាងរបស់ខ្លួន ប្រព្រឹត្តអំពើបាបផងដែរ ។
២៩ ហើយនៅទីបញ្ចប់ យើងពុំអាចប្រាប់អ្នករាល់គ្នាឲ្យអស់
នូវការណ៍ទាំងឡាយ ដែលអ្នករាល់គ្នាអាចប្រព្រឹត្តអំពើ
បាបនោះទេ; ព្រោះមានផ្លូវ និងបែបផ្សេងៗគ្នា គឺមានជាច្រើន
ណាស់ ដែលយើងពុំអាចរៀបរាប់បានឡើយ ។
៣០ ប៉ុន្តែ យើងអាចនិយាយប្រាប់អ្នកតែប៉ុណ្ណោះថា បើ
សិនជាអ្នករាល់គ្នាពុំ[ក]ប្រយ័ត្នខ្លួន ទាំងគំនិតរបស់ខ្លួន និង[គ]ពាក្យ
សំដីរបស់ខ្លួន និងកិច្ចការរបស់ខ្លួន ហើយគោរពតាមព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះ ហើយបន្តទៅក្នុងសេចក្ដីជំនឿជឿដល់អ្វី ដែល
អ្នករាល់គ្នាបានឮ អំពីការយាងមកនៃព្រះអម្ចាស់របស់យើង
រហូតដល់ថ្ងៃចុងក្រោយនៃជីវិតខ្លួនទេ នោះអ្នករាល់គ្នានឹងត្រូវ
វិនាស។ ហើយឥឡូវនេះ ឱមនុស្សលោកអើយ សូមចងចាំ
ហើយកុំវិនាសបង់ឡើយ ៕

២១ *ក* ស.ប. ការបំរើ; សុខុមាលភាព.
២២ *ក* ម៉ាថាយ ៧:១–២;
យ៉ូហាន ៧:២៤.
*ខ* ១ យ៉ូហាន ៣:១៧.
២៣ *ក* គ. និង ស. ៥៦:១៦.
២៤ *ក* ម៉ាកុស ១២:៤៤.
២៥ *ក* គ. និង ស. ៥៦:១៧.
២៦ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* យ៉ាកុប (ព.ម) ២:១៧–១៩.
*គ* សាការី ៧:១០;
អាលម៉ា ១:២៧.
ស.ប. ទាន, ការដាក់ទាន.
*ឃ* អេសាយ ៥៨:១០–១១;
គ. និង ស. ១០៤:១៧–១៨.
២៧ *ក* គ. និង ស. ១០:៤.
៣០ *ក* អាលម៉ា ១២:១៤.
ស.ប. ចាំយាម, ពួកអ្នកចាំយាម.
*ខ* ម៉ាកុស ៧:១៨–២៣.
ស.ប. គំនិត.
*គ* ម៉ាថាយ ១៥:១៨–២០.
ស.ប. សេចក្ដីមើលងាយ.

## ជំពូកទី ៥

*ពួកបរិសុទ្ធក្លាយទៅជាបុត្រាបុត្រីនៃព្រះគ្រីស្ទ តាមរយៈសេចក្ដីជំនឿ — បន្ទាប់មក ពួកគេត្រូវបានហៅតាមព្រះនាមនៃព្រះគ្រីស្ទ — ស្ដេច បេនយ៉ាមីនទូន្មានពួកគេឲ្យតាំងចិត្តឲ្យខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងកិច្ចការដ៏ល្អទាំងឡាយ ។ ប្រមាណជាឆ្នាំ ១២៤ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ស្ដេចបេនយ៉ាមីនបានមានបន្ទូលទៅកាន់ប្រជាជនរបស់ទ្រង់ចប់ហើយ
ទ្រង់បាន ចាត់ឲ្យគេទៅស៊ើបសួរក្នុងចំណោមប្រជាជន ដោយ
មានប្រាថ្នាចង់ដឹងពីប្រជាជនទ្រង់ថា តើពួកគេជឿតាមពាក្យ
សំដី ដែលទ្រង់មាន បន្ទូលទៅកាន់ពួកគេនោះឬទេ ។
២ ហើយពួកគេទាំងអស់គ្នាបានស្រែកឡើងព្រមគ្នាថា៖ ព្រះ
ពរ យើងខ្ញុំជឿតាមពាក្យទាំងអស់ ដែលស្ដេចមានបន្ទូលមក
កាន់ ពួកយើង; ហើយយើងខ្ញុំក៏ដឹងពីការជាក់លាក់ និង
ការពិតនៃពាក្យទាំងនោះដែរ ពីព្រោះតែព្រះវិញ្ញាណនៃព្រះ
អម្ចាស់ដ៏មានគ្រប់ព្រះ ចេស្ដា ដែលបាននាំមកនូវការ
ផ្លាស់ប្ដូរយ៉ាងធំដល់ពួកយើង ឬក៏នៅក្នុងចិត្តយើងខ្ញុំ ដែល
ធ្វើឲ្យយើងខ្ញុំពុំមានបំណងនឹងប្រព្រឹត្តអំពើ ទុច្ចរិតទៀតឡើយ
ប៉ុន្តែចង់ប្រព្រឹត្តអំពើល្អជានិច្ចវិញ ។
៣ ឯខ្លួនយើងខ្ញុំក៏ដូច្នោះដែរ តាមរយៈសេចក្ដីល្អសប្បុរស
ដ៏និរន្តរ៍នៃព្រះ និងឥទ្ធិពលនៃព្រះវិញ្ញាណរបស់ទ្រង់ នោះយើង
ខ្ញុំបាន ឃើញភាពដ៏ធំ អំពីអ្វីដែលនឹងកើតឡើង; ហើយបើ
ជាការចាំបាច់ នោះយើងខ្ញុំអាចព្យាករនូវរឿងគ្រប់យ៉ាងបាន ។
៤ ហើយគឺជាសេចក្ដីជំនឿ ដែលយើងខ្ញុំមានទៅលើការណ៍
ទាំងឡាយ ដែលស្ដេចរបស់យើងខ្ញុំ មានបន្ទូលមកកាន់ពួកយើង
ដែលបាននាំមកដល់យើងខ្ញុំនូវការចេះដឹងដ៏ធំនេះ ម្ល៉ោះហើយ
យើងខ្ញុំអររីករាយដោយសេចក្ដីអំណរដ៏ធំជាអតិបរមា ។
៥ ហើយយើងខ្ញុំយល់ព្រមចូលទៅក្នុងសេចក្ដីសញ្ញា ជា
មួយនឹងព្រះរបស់ពួកយើង ដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់
ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ចំពោះអ្វីៗទាំង
អស់ ដែលទ្រង់នឹងបញ្ជាដល់ពួកយើង នៅក្នុងជីវិតយើងខ្ញុំ
ដែលនៅសល់ ទាំងប៉ុន្មាន ដើម្បីកុំឲ្យយើងខ្ញុំបាននាំមកដល់ខ្លួន
នូវការរងទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ ដូចដែលបាន
ពោលដោយទេវតា ដើម្បីកុំឲ្យយើងខ្ញុំបានផឹកនូវពែងនៃសេច
ក្ដីពិរោធរបស់ព្រះ ។
៦ ហើយឥឡូវនេះ នេះហើយគឺជាពាក្យទាំងឡាយដែល
ស្ដេចបេនយ៉ាមីនប្រាថ្នាចង់បានពីពួកគេ; ហេតុដូច្នេះហើយ
ស្ដេចក៏មាន បន្ទូលទៅកាន់ពួកគេថា៖ អ្នករាល់គ្នាបាននិយាយ
នូវពាក្យសំដី ដែលយើងប្រាថ្នាចង់បាន; ឯសេចក្ដីសញ្ញាដែល
អ្នករាល់គ្នាបានធ្វើ គឺជាសេចក្ដីសញ្ញាមួយដ៏សុចរិត ។
៧ ហើយឥឡូវនេះ មកពីសេចក្ដីសញ្ញាដែលអ្នករាល់គ្នាបានធ្វើ
អ្នករាល់គ្នានឹងត្រូវបានហៅថា ជាកូនចៅនៃព្រះគ្រីស្ទ គឺជាបុត្រា
របស់ទ្រង់ និងបុត្រីរបស់ទ្រង់; ត្បិតមើលចុះ ថ្ងៃនេះទ្រង់បាន
បង្កើតអ្នកខាងវិញ្ញាណហើយ; ត្បិតអ្នករាល់គ្នាបាននិយាយថា ចិត្ត
របស់ អ្នកបានផ្លាស់ប្ដូរ តាមរយៈសេចក្ដីជំនឿជឿដល់ព្រះនាមទ្រង់;
ហេតុដូច្នេះហើយ អ្នករាល់គ្នាបានកើតមកពីទ្រង់ ហើយបាន
ក្លាយទៅជា បុត្រារបស់ទ្រង់ និងបុត្រីរបស់ទ្រង់ដែរ ។
៨ ហើយនៅក្នុងព្រះសិរនេះ អ្នករាល់គ្នាបានទទួលសេរីភាព
ហើយគ្មានព្រះសិរឯណាទៀតឡើយ ដែលអាចធ្វើឲ្យអ្នកមាន
សេរីភាពបាន ។ គ្មាននាមឯណាផ្សេងទៀតទេ ដែលអាចនាំ
មកនូវសេចក្ដីសង្គ្រោះ; ហេតុដូច្នេះហើយ យើងចង់ឲ្យអ្នក
រាល់គ្នាទទួល ដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ គឺអស់អ្នក
រាល់គ្នា ដែលបានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងព្រះថា អ្នក
នឹងគោរពតាមទ្រង់ រហូត ដល់អស់មួយជីវិតរបស់អ្នក ។
៩ ហើយហេតុការណ៍នឹងកើតឡើងថា អស់អ្នកណាដែល
បានធ្វើយ៉ាងនេះ នោះនឹងឃើញថា ខ្លួននៅខាងស្ដាំព្រះហស្ត
នៃព្រះ ត្បិតអ្នកនោះនឹងស្គាល់ឈ្មោះខ្លួន ដែលត្រូវបានហៅ;
ត្បិតអ្នកនោះនឹងត្រូវបានហៅដោយព្រះនាមនៃព្រះគ្រីស្ទ ។
១០ ហើយឥឡូវនេះ ហេតុការណ៍នឹងកើតឡើងថា អស់អ្នក

៥ ២*ក* អាលម៉ា ៥:១៤.
ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ខ* អាលម៉ា ១៩:៣៣.
៥ *ក* ម៉ូសាយ ១៨:១០.
*ខ* ម៉ូសាយ ៣:២៥–២៧.
*គ* ម៉ូសាយ ៣:២.
៧ *ក* ម៉ូសាយ ២៧:២៤–២៦;
ម៉ូសេ ៦:៦៤–៦៨.
ស.ប. បុត្រាបុត្រីនៃព្រះ.
*ខ* ស.ប. បង្កើត.
*គ* ស.ប. ចិត្ត.
*ឃ* ម៉ូសាយ ១៥:១០–១១.
ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ង* គ. និង ស. ១១:៣០.
៨ *ក* រ៉ូម ៦:១៨; កាឡាទី ៥:១;
ហេលេ. ១៤:៣០.
*ខ* កិច្ចការ ៤:១០, ១២;
អាលម៉ា ២១:៩.
*គ* ម៉ូសាយ ២៦:១៨.
*ឃ* កិច្ចការ ១១:២៦;
អាលម៉ា ៤៦:១៥.

ណាដែលពុំទទួលដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទទេ នោះនឹង ត្រូវបានហៅដោយ[ក]ឈ្មោះមួយផ្សេងទៀត; ហេតុដូច្នេះហើយ អ្នកនោះនឹងឃើញថា ខ្លួននៅ[ខ]ខាងឆ្វេងព្រះហស្តនៃព្រះ ។

១១ ហើយយើងចង់ឲ្យអ្នករាល់គ្នាចងចាំដែរថា [ក]ឈ្មោះនេះ ហើយដែលយើងបាននិយាយថា យើងនឹងឲ្យទៅអ្នក ដែលនឹងពុំត្រូវ លុបចេញឡើយ លើកលែងតែតាមរយៈការរំលងច្បាប់ប៉ុណ្ណោះ; ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន កុំរំលងច្បាប់ ដើម្បីកុំឲ្យ ឈ្មោះនោះត្រូវលុបចេញពីដួងចិត្តរបស់អ្នកឡើយ ។

១២ យើងសូមប្រាប់អ្នកថា យើងចង់ឲ្យអ្នករាល់គ្នាចងចាំថា គួរតែ[ក]រក្សាឈ្មោះនេះ ដោយចារិកនៅក្នុងដួងចិត្តរបស់អ្នកជានិច្ច ដើម្បីកុំឲ្យឃើញថា អ្នករាល់គ្នានៅខាងឆ្វេងព្រះហស្តនៃព្រះឡើយ ប៉ុន្តែសូមឲ្យអ្នករាល់គ្នាបានឮ ហើយស្គាល់សម្លេង ដែលនឹងហៅអ្នករាល់គ្នា ព្រមទាំងឈ្មោះដែលទ្រង់នឹងហៅអ្នកដែរ ។

១៣ ក្បិតតើមនុស្សនឹង[ក]ស្គាល់ចៅហ្វាយ ដែលខ្លួនពុំដែលបានបំរើនោះ ហើយដែលជាអ្នកចម្លែកចំពោះមនុស្សនោះ ហើយនៅ ឆ្ងាយពីសតិអារម្មណ៍ និងបំណងនៃដួងចិត្តខ្លួនដូចម្ដេចបាន ?

១៤ ហើយមួយទៀត តើមនុស្សនឹងយកសត្វលា ដែលជារបស់ផងអ្នកជិតខាងមកទុកឬ ? យើងសូមប្រាប់អ្នកថា៖ ទេ; មនុស្សនោះ នឹងពុំព្រមទាំងឲ្យសត្វលានោះ ស៊ីស្មៅក្នុងចំណោមហ្វូងសត្វរបស់ខ្លួនផង ប៉ុន្តែនឹងដេញសត្វលានោះចេញឆ្ងាយវិញ ។ យើងសូម ប្រាប់អ្នកថា ការនោះនឹងកើតដល់អ្នករាល់គ្នាដែរ បើសិនជាអ្នករាល់គ្នាពុំស្គាល់ឈ្មោះដែលអ្នកត្រូវបានហៅ ។

១៥ ហេតុដូច្នេះហើយ យើងចង់ឲ្យអ្នករាល់គ្នាតាំងចិត្តឲ្យខ្ជាប់ខ្ជួន ហើយនឹងនរ គឺពោរពេញទៅដោយអំពើល្អជានិច្ច ដើម្បីឲ្យព្រះ គ្រីស្ទ ដែលជាព្រះអម្ចាស់ ដ៏ជាព្រះដែលមានគ្រប់ព្រះចេស្ដា ទ្រង់បាន[ក]ភ្ជាប់អ្នកទុកជារបស់ផងទ្រង់ ដើម្បីឲ្យអ្នកបាននាំទៅកាន់ស្ថាន សួគ៌ គឺដើម្បីឲ្យអ្នករាល់គ្នាបានសេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ច និងជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈប្រាជ្ញា និងព្រះចេស្ដា និងសេចក្ដីយុត្តិធម៌ និងសេចក្ដីមេត្តាករុណារបស់ព្រះអង្គ ដែលបាន[ខ]បង្កើតវត្ថុសព្វសារពើនៅលើស្ថានសួគ៌ និងនៅលើផែនដី ដែលជា ព្រះលើអ្វីៗទាំងអស់ ។ អាម៉ែន ៕

## ជំពូកទី ៦

*ស្ដេចបេនយ៉ាមីនកត់ឈ្មោះប្រជាជន ហើយតែងតាំងពួកសង្ឃឲ្យបង្រៀនពួកគេ — ម៉ូសាយសោយរាជ្យជាស្ដេចដ៏សុចរិត ។ ប្រមាណជាឆ្នាំ ១២៤–១២១ ម.គ.ស.។*

ហើយឥឡូវនេះ បន្ទាប់ពីមានបន្ទូលទៅប្រជាជនហើយ នោះស្ដេចបេនយ៉ាមីនបានគិតថា ជាការចាំបាច់ដែលទ្រង់ត្រូវ[ក]កត់ឈ្មោះនៃ អស់អ្នកណាដែលបានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះ ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

២ ហើយហេតុការណ៍បានកើតឡើងថា គ្មានមនុស្សណាមួយសោះ ក្រៅពីពួកកូនក្មេង គឺមនុស្សគ្រប់រូបបានធ្វើសេចក្ដីសញ្ញា ហើយបានលើកដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ ។

៣ ហើយម្ដងទៀត ហេតុការណ៍បានកើតឡើងថា កាលស្ដេចបេនយ៉ាមីនបានបញ្ចប់នូវការណ៍អស់ទាំងនេះហើយ ហើយបាន [ក]អភិសេកម៉ូសាយជាបុត្រ ឲ្យធ្វើជាអ្នកគ្រប់គ្រង ហើយជាស្ដេចលើប្រជាជនរបស់ទ្រង់ ព្រមទាំងបានប្រគល់ឲ្យបុត្រនូវបន្ទុកផ្សេងៗ ដែលទាក់ទងទៅនឹងនគរ ហើយក៏បាន[ខ]តែងតាំងពួក[គ]សង្ឃឲ្យបង្រៀនប្រជាជន ដើម្បីឲ្យពួកគេអាចបានឮ ហើយស្គាល់នូវព្រះបញ្ញត្តិទាំង ឡាយនៃព្រះ ហើយដើម្បីដាស់រំជួលពួកគេឲ្យនឹកចាំដល់[ឃ]ពាក្យសម្បថ ដែលគេបានធ្វើរួចស្រេចហើយ នោះទ្រង់បានឲ្យហ្វូងមនុស្សត្រឡប់ទៅវិញ ហើយពួកគេក៏ត្រឡប់ជាមួយគ្រួសារគេទៅកាន់ផ្ទះគេរៀងៗខ្លួន ។

៤ ហើយ[ក]ម៉ូសាយបានចាប់ផ្ដើមសោយរាជ្យជំនួសបិតាទ្រង់ ។ ទ្រង់បានចាប់ផ្ដើមសោយរាជ្យ នៅក្នុងជន្មាយុសាមសិបឆ្នាំ គឺរួមទាំង អស់មក គឺប្រមាណជាបួនរយចិតសិបប្រាំមួយឆ្នាំ ក្រោយពី[ខ]ពេលដែលលីហៃបានចាកចេញពីក្រុងយេរូសាឡិមមក ។

១០ *ក* អាលម៉ា ៥:៣៨–៣៩.
*ខ* ម៉ាថាយ ២៥:៣៣.
១១ *ក* ម៉ូសាយ ១:១១–១២.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើ ខ្លួនយើង.
១២ *ក* គ. និង ស. ១៨:២៣–២៥.
១៣ *ក* ម៉ូសាយ ២៦:២៤–២៧.
១៥ *ក* ស.ប. ការហៅ និងការរើសតាំង; ការញែកជាបរិសុទ្ធ.
*ខ* កូល៉ុស ១:១៦; ម៉ូសាយ ៤:២; អាលម៉ា ១១:៣៩.
**៦** ១ *ក* គ. និង ស. ១២៨:៨.
៣ *ក* ម៉ូសាយ ១:១០; ២:៣០.
*ខ* ស.ប. តែងតាំង, ការតែងតាំង.
*គ* អាលម៉ា ៤:៧.
*ឃ* ម៉ូសាយ ៥:៥–៧.
៤ *ក* ស.ប. ម៉ូសាយ, បុត្ររបស់បេនយ៉ាមីន.
*ខ* ១ នីហ្វៃ ១:៤.

៥ ហើយស្ដេចបេនយ៉ាមីនមានព្រះជន្មរស់នៅបីឆ្នាំទៀត ក៏ទ្រង់សុគតទៅ ។

៦ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចម៉ូសាយបានដើរតាមផ្លូវទាំងឡាយនៃព្រះអម្ចាស់ ហើយបានគោរពតាមសេចក្ដីយុត្តិធម៌របស់ទ្រង់ និងក្រិត្យក្រមទាំងឡាយរបស់ទ្រង់ ហើយបានកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នូវគ្រប់អ្វីៗទាំងអស់ ដែលទ្រង់ បានបញ្ជាដល់លោក ។

៧ ហើយស្ដេចម៉ូសាយបានទូន្មានឲ្យប្រជាជនទ្រង់ថា ពួកគេត្រូវភ្ជួរដី ។ រីឯរូបទ្រង់ក៏បានភ្ជួរដីដែរ ដើម្បីកុំឲ្យរូបទ្រង់ក្លាយទៅជា បន្ទុកមួយដល់ប្រជាជនទ្រង់ ហើយដើម្បីទ្រង់អាចធ្វើតាមគំរូដែលបិតាលោកបានធ្វើ ចំពោះការណ៍សព្វសារពើ ។ ហើយគ្មានការ ទាស់ទែងគ្នា នៅក្នុងចំណោមប្រជាជនទ្រង់ឡើយ អស់រយៈពេលបីឆ្នាំ ៕

## ជំពូកទី ៧

*អាំម៉ូនរកឃើញដែនដីលីហៃ-នីហ្វៃ ដែលមានលិមហៃ ជាស្ដេច — ប្រជាជនរបស់លិមហៃរស់នៅក្រោមសេវកភាពបំរើពួកសាសន៍ លេមិន — លិមហៃរៀបរាប់ពីប្រវត្តិរបស់ពួកគេ — ព្យាការីម្នាក់ (អ័ប៊ីណាដៃ) បានធ្វើបន្ទាល់ថា ព្រះគ្រីស្ទគឺជាព្រះ ហើយជាព្រះវរបិតា លើអ្វីៗទាំងអស់ — អស់អ្នកណាដែលសាបព្រោះការស្មោកគ្រោក នឹងច្រូតកាត់ខ្យល់ព្យុះ ឯអស់អ្នកណាដែលដាក់ទីទុកចិត្តលើ ព្រះអម្ចាស់ នឹងត្រូវបានប្រោសលោះឲ្យរួច ។ ប្រមាណជាឆ្នាំ ១២១ ម.គ.ស.។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ក្រោយពីស្ដេចម៉ូសាយបានទទួលសេចក្ដីសុខសាន្តតរៀងមក អស់រយៈពេលបីឆ្នាំ ទ្រង់ក៏ មានព្រះហឫទ័យចង់ដឹងអំពីប្រជាជន ដែលបានឡើងទៅអាស្រ័យនៅឯដែនដីលីហៃ-នីហ្វៃ ឬនៅទីក្រុងលីហៃ-នីហ្វៃ; ត្បិតប្រជាជនរបស់ ទ្រង់មិនដែលបានឮដំណឹងអ្វីអំពីពួកគេសោះ ចាប់តាំងពីពេលដែលពួកគេចាកចេញពីដែនដីសារ៉ាហិមឡាម្ល៉េះ; ហេតុដូច្នេះហើយ ប្រជាជនទ្រង់បានមករំខានទ្រង់ជាខ្លាំងអំពីរឿងនេះ ។

២ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចម៉ូសាយបានអនុញ្ញាតឲ្យបុរសដ៏ខ្លាំងពូកែ ចំនួនដប់ប្រាំមួយនាក់ ឡើងទៅឯដែនដីលីហៃ-នីហ្វៃ ដើម្បីស៊ើបសួរអំពីបងប្អូនរបស់គេ ។

៣ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើងពួកគេក៏ចាប់ផ្ដើមចេញដំណើរឡើងទៅ ដោយមានបុរសម្នាក់ទៅជាមួយពួកគេ ដែលមានឈ្មោះថា អាំម៉ូន ជាអ្នកមានកម្លាំងខ្លាំងពូកែម្នាក់ ហើយជាពូជពង្សរបស់សារ៉ាហិមឡា ហើយលោកជា មេដឹកនាំរបស់ពួក គេផង ។

៤ ហើយឥឡូវនេះ ពួកគេពុំស្គាល់ផ្លូវ ដែលត្រូវធ្វើដំណើរនៅក្នុងទីរហោស្ថាន ដើម្បីឡើងទៅកាន់ដែនដីលីហៃ-នីហ្វៃឡើយ; ហេតុដូច្នេះហើយ ទើបពួកគេដើរសាត់ព្រាត់អស់ជាច្រើនថ្ងៃនៅក្នុងទីរហោស្ថាន គឺពួកគេដើរសាត់ព្រាត់អស់រយៈពេលសែសិបថ្ងៃ ។

៥ ហើយកាលដែលពួកគេបានដើរសាត់ព្រាត់អស់រយៈពេលសែសិបថ្ងៃ ពួកគេបានទៅដល់ទួលមួយ នៅខាងជើងដែនដីសែមឡោម ហើយពួកគេបានបោះត្រសាលគេនៅទីនោះ ។

៦ ហើយអាំម៉ូនបាននាំបងប្អូនបីនាក់ទៅហើយពួកគេមានឈ្មោះថា អាម៉ាលេគៃ ហេលេម និងហេម ហើយពួកគេបានចុះទៅ ដែនដីនីហ្វៃ ។

៧ ហើយមើលចុះ ពួកគេបានជួបនឹងស្ដេចនៃប្រជាជនដែលនៅលើដែនដីនីហ្វៃ និងនៅលើដែនដីសែមឡោម; ហើយពួកគេត្រូវអ្នក យាមរបស់ស្ដេចឡោមព័ទ្ធជុំវិញ ហើយចាប់យកទៅហើយចង ហើយយកទៅឃុំក្នុងគុក ។

៨ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេបានជាប់គុកអស់រយៈពេលពីរថ្ងៃមក នោះពួកគេត្រូវបាននាំមកគាល់មុខស្ដេច ហើយត្រូវបានស្រាយចំណងដៃចេញ; ហើយពួកគេឈរនៅខាងមុខស្ដេច ហើយត្រូវបានអនុញ្ញាត ឬត្រូវគេបញ្ជាឲ្យឆ្លើយនូវសំនួរ ទាំងឡាយដែលស្ដេចសួរ ។

៩ ហើយស្ដេចមានបន្ទូលទៅកាន់ពួកគេថា៖ មើលចុះ យើងឈ្មោះលិមហៃ ជាបុត្ររបស់ណូអេ ដែលជាបុត្ររបស់ស៊ីនិព្វ ដែលបាន ឡើងមកពីដែនដីសារ៉ាហិមឡា ដើម្បីមកគ្រងដែនដីនេះទុកជាមរតក ដែលជាដែនដីនៃពួកអយ្យកោរបស់គេ ដែលបានលើកឲ្យធ្វើ ជាស្ដេច ដោយសម្លេងរបស់ប្រជាជន ។

១០ ហើយឥឡូវនេះ យើងចង់ដឹងថា ហេតុអ្វីបានជាអ្នករាល់គ្នាហ៊ានមកជិតកំផែងទីក្រុង នៅពេលដែលយើង និងអ្នកយាមរបស់ យើង នៅខាងក្រៅរបងយ៉ាងនេះ ?

១១ ហើយឥឡូវនេះ ដោយហេតុនេះ យើងសុខចិត្តទុកឲ្យអ្នករាល់គ្នានៅរស់ ដើម្បីឲ្យយើងសួរអ្នក បើពុំនោះសោតទេ

៧ *ក* ២ កូរិន. ១១:៩.
៧ ១*ក* អោមណៃ ១:២៧–៣០.
*ខ* អោមណៃ ១:១៣.
៥ *ក* ម៉ូសាយ ៩:៦, ៨, ១៤.
៦ *ក* ២ នីហ្វៃ ៥:៨.
៩ *ក* ម៉ូសាយ ១១:១.

យើងបាន ប្រើឲ្យពួកអ្នកយាមរបស់យើង សម្លាប់អ្នក
ទៅហើយ ។ យើងអនុញ្ញាតឲ្យអ្នកនិយាយមកចុះ ។
១២ ហើយឥឡូវ នៅពេលអាំម៉ូនឃើញថា ខ្លួនត្រូវបាន
អនុញ្ញាតឲ្យនិយាយហើយ លោកបានឈានទៅមុខ ហើយ
ក្រាបនៅចំពោះ ស្ដេច; ហើយក្រោកឡើងវិញ លោកនិយាយ
ថា៖ ក្រាបទូល ឱព្រះរាជាអើយ ទូលបង្គំមានអំណរគុណ
ជាខ្លាំងចំពោះព្រះ ដោយបានរស់ នៅដល់សព្វថ្ងៃនេះ ហើយ
បានអនុញ្ញាតឲ្យនិយាយ; ទូលបង្គំនឹងខិតខំនិយាយដោយក្លាហាន;
១៣ ព្រោះទូលបង្គំជឿជាក់ថា បើសិនជាលោកស្គាល់ទូលបង្គំ
ទ្រង់ច្បាស់ជាមិនទុកឲ្យទូលបង្គំជាប់ចំណងទាំងនេះទេ ។ ត្បិត
ទូលបង្គំជាអាំម៉ូន ជាពូជពង្សរបស់សារ៉ាហិមឡា ហើយ
បានឡើងពីដែនដីសារ៉ាហិមឡាមក ដើម្បីស៊ើបសួរអំពីបងប្អូនយើង
ដែលស៊ីនិព្វ បាននាំឡើងមកពី ដែនដីនោះ ។
១៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
បន្ទាប់ពីលិមហៃបានឮពាក្យសំដីរបស់អាំម៉ូនហើយ នោះទ្រង់មាន
សេចក្ដីរីក រាយជាខ្លាំង ហើយមានបន្ទូលថា៖ ឥឡូវនេះ យើងដឹង
ច្បាស់ថា បងប្អូនយើងដែលនៅឯដែនដីសារ៉ាហិមឡានោះ
នៅរស់នៅឡើយ ។ ហើយឥឡូវនេះ យើងនឹងអររីករាយ; ហើយ
ស្អែកនេះ យើងនឹងប្រាប់ឲ្យប្រជាជនយើងបានអររីករាយដែរ ។
១៥ ត្បិតមើលចុះ ពួកយើងរស់នៅក្នុងសេវកភាពដល់ពួក
សាសន៍លេមិន ហើយត្រូវបង់ពន្ធ ដោយពន្ធដារដ៏ពិបាកនឹងទ្រាំទ្រ
បាន ។ ហើយឥឡូវនេះ មើលចុះ បងប្អូនយើងនឹងដោះលែង
ពួកយើង ឲ្យរួចផុតពីសេវកភាពរបស់យើងរាល់គ្នា ឬឲ្យ
រួចផុតពីកណ្ដាប់ដៃរបស់ ពួកសាសន៍លេមិន ហើយពួកយើង
នឹងក្លាយទៅជាទាសកររបស់ពួកសាសន៍នីហ្វៃវិញ; ព្រោះបើ
យើងរាល់គ្នាធ្វើជាទាសកររបស់ ពួកសាសន៍នីហ្វៃ គ្រាន់បើជាង
ត្រូវនាំសារអាករ ទៅថ្វាយស្ដេចនៃពួកសាសន៍លេមិនដែរ ។
១៦ ហើយឥឡូវនេះ ស្ដេចលិមហៃបានបញ្ជាពួកអ្នកយាមថា
ពួកគេមិនត្រូវចងអាំម៉ូន និងបងប្អូនលោកទៀតទេ តែប្រាប់ឲ្យ
ពួកគេ ទៅកាន់ទួលមួយ នៅខាងជើងដែនដីសែឡោម
ហើយនាំបងប្អូនរបស់លោក ចូលមកក្នុងទីក្រុង ដើម្បីឲ្យពួកគេ
អាចបានបរិភោគ ហើយផឹក ហើយសំរាកខ្លួនពីដំណើរដែល
គេបានធ្វើមក; ព្រោះពួកគេបានរងការវេទនាជាច្រើន ដូចជា
ការស្រេក ការឃ្លាន និងការ នឿយហត់ ។
១៧ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា លុះ
ដល់ស្អែកឡើង ស្ដេចលិមហៃបានចេញសេចក្ដីប្រកាសមួយ
ដល់គ្រប់ ប្រជាជនទ្រង់ ដើម្បីឲ្យពួកគេអាចបានមកជួបជុំគ្នាឯ
ព្រះវិហារបរិសុទ្ធ ដើម្បីស្ដាប់ពាក្យទាំងឡាយ ដែលទ្រង់នឹង
មានបន្ទូលទៅកាន់ ពួកគេ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា កាលដែលប្រជាជន
បានមកជួបជុំគ្នាហើយ ទើបទ្រង់ថ្លែងទៅកាន់ពួកគេយ៉ាងនេះថា៖
ឱអ្នកទាំងឡាយ ដែលជាប្រជាជនរបស់យើងអើយ ចូរអ្នក
ងើបមុខឡើង ហើយបានក្សាន្តចិត្តចុះ; ត្បិតមើលចុះ
ពេលវេលានៅជិតដៃ បង្កើយ ឬនៅមិនយូរប៉ុន្មានទេ កាលពួក
យើងនឹងឈប់នៅក្រោមបង្គាប់នៃពួកខ្មាំងសត្រូវរបស់យើងរា
ល់គ្នាទៀតហើយ ទោះពួក យើងមានការតស៊ូជាច្រើន
លើកមកហើយក៏ដោយ គង់តែពុំបានប្រយោជន៍អ្វីឡើយ;
ក៏ប៉ុន្តែយើងជឿថា ពួកយើងនៅមានការតស៊ូ មួយទៀតដ៏មាន
ប្រសិទ្ធភាព ។
១៩ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាងើបមុខឡើង ហើយអរ
រីករាយចុះ ហើយដាក់ទីទុកចិត្តរបស់អ្នកទៅលើព្រះ គឺទៅលើព្រះ
នោះ ដែលជាព្រះនៃអ័ប្រាហាំ និងអ៊ីសាក និងយ៉ាកុប; ហើយ
ជាព្រះដែលបាននាំកូនចៅអ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទ
ហើយបាន ធ្វើឲ្យពួកគេដើរ — ឆ្លងសមុទ្រក្រហម
ដោយដើរលើដីគោក ហើយបានប្រទានអាហារដល់គេដោយ
នំម៉ាន៉ា ដើម្បីកុំឲ្យពួកគេវិនាសបង់ នៅក្នុងទីរហោស្ថាន;
ហើយមានការណ៍ជាច្រើនទៀត ដែលទ្រង់បានធ្វើសំរាប់ពួកគេ ។
២០ ហើយមួយទៀត គឺព្រះអង្គនោះហើយ ដែលបាននាំពួក
អយ្យកោរបស់យើងចេញពីដែនដីយេរូសាឡិម ហើយបាន
រក្សារាស្ត្រ របស់ទ្រង់ឲ្យគង់វង់ រហូតមកដល់ពេលឥឡូវនេះ;
ហើយមើលចុះ ពីព្រោះតែអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើម
ទាំងឡាយរបស់យើង រាល់គ្នា ទើបទ្រង់បាននាំយើងឲ្យ
ធ្លាក់ទៅក្នុងសេវកភាព ។
២១ ហើយអ្នកទាំងអស់គ្នាធ្វើជាសាក្សីនៅថ្ងៃនេះថា ស៊ីនិព្វ
ដែលបានតាំងឡើងឲ្យធ្វើជាស្ដេចនៃប្រជាជននេះ ដោយមានចិត្ត
ចង់ ទទួលដីរបស់ពួកអយ្យកោលោកហួសប្រមាណ ទើបត្រូវបាន
បោកបញ្ឆោត ដោយឧបាយកលដ៏អាក្រក់របស់ស្ដេចលេមិន
ដែលបាន ធ្វើមេត្រីភាពមួយជាមួយនឹងស្ដេចស៊ីនិព្វ នោះបាន

១៣ *ក* អោមណៃ ១:១២–១៥.
១៥ *ក* ម៉ូសាយ ១៩:១៥.
១៧ *ក* ២ នីហ្វៃ ៥:១៦.
១៩ *ក* និក្ខ. ៣:៦; ១ នីហ្វៃ ១៩:១០.
*ខ* និក្ខ. ១២:៤០–៤១; អាលម៉ា ៣៦:២៨.
*គ* និក្ខ. ១៦:១៥, ៣៥; ជនគ. ១១:៧–៨; យ៉ូស្វេ ៥:១២.
២០ *ក* ១ នីហ្វៃ ២:១–៤.
២១ *ក* ម៉ូសាយ ៩:១–៣.

ប្រគល់ទៅឲ្យពួកគេ នូវផ្នែកនៃដែនដី ឬក៏ទីក្រុងលីហៃ-នីហ្វៃ
ទីក្រុងសៃឡោម និងដែនដីដែលនៅព័ទ្ធជុំវិញ —
២២ ហើយទ្រង់ធ្វើការណ៍ទាំងអស់នេះ ដោយមាន
គោលបំណងតែមួយ គឺ[ក]នាំប្រជាជននេះឲ្យធ្លាក់ទៅក្រោមអំណាច
ឬទៅក្នុង សេវកភាព ។ ហើយមើលចុះ នៅពេលនេះ ពួក
យើងថ្វាយសួយសារអាករ ទៅស្ដេចរបស់ពួកសាសន៍លេមិន
នូវចំនួនពាក់កណ្ដាល នៃពោតរបស់ពួកយើង និងស្រូវរបស់
ពួកយើង ព្រមទាំងធញ្ញជាតិរបស់ពួកយើងគ្រប់មុខ និង
ពាក់កណ្ដាលនៃចំនួនហ្វូងចៀម និងហ្វូង គោ ដែលពួក
យើងចិញ្ចឹមបាន; ហើយគឺទាំងពាក់កណ្ដាលនៃអ្វីៗទាំងអស់
ដែលពួកយើងមាន ឬបាន នោះស្ដេចនៃពួកសាសន៍លេមិន
ដកយកពីយើងទៅ ឬក៏យកជីវិតយើង ។
២៣ ហើយឥឡូវនេះ តើការណ៍នេះមិនពិបាកនឹងទ្រាំទ្របាន
ទេឬ? ហើយការវេទនារបស់ពួកយើងនេះ តើមិនធំហួសប្រមាណ
ទេឬ ? ឥឡូវនេះ មើលចុះ ពួកយើងមានហេតុផលដ៏ធំ
សំរាប់ទួញសោក ។
២៤ មែនហើយ យើងសូមប្រាប់អ្នកថា ពួកយើងមាន
ហេតុផលដ៏ធំទាំងឡាយសំរាប់ទួញសោក; ត្បិតមើលចុះ
បងប្អូនយើងជាច្រើន នាក់ហើយ ត្រូវបានស្លាប់ ឯឈាម
របស់គេត្រូវខ្ចាយដោយឥតប្រយោជន៍ ហើយការណ៍អស់
ទាំងនេះ ក៏ព្រោះតែសេចក្ដីទុច្ចរិត ។
២៥ ព្រោះបើសិនជាប្រជាជននេះ មិនបានធ្លាក់ទៅក្នុងការ
រំលងច្បាប់ទេ ព្រះអម្ចាស់ទ្រង់ក៏មិនទ្រាំឲ្យអំពើអាក្រក់ដ៏ធំនេះ
មកគ្រប សង្កត់គេដែរ ។ ប៉ុន្តែមើលចុះ ពួកគេពុំបានប្រុង
ស្ដាប់តាមព្រះបន្ទូលរបស់ទ្រង់ឡើយ; តែមានការទាស់ទែងគ្នា
ទាំងឡាយនៅក្នុង ចំណោមពួកគេ រហូតដល់ពួកគេបាន
កំចាយឈាមនៅក្នុងចំណោមគ្នាឯងទៅវិញ ។
២៦ ហើយពួកគេបានសម្លាប់[ក]ព្យាការីនៃព្រះអម្ចាស់ម្នាក់;
មែនហើយ គឺជាអ្នកសំណប់នៃព្រះដែលបានរើស បុរសនោះ
បានប្រាប់គេ អំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ
របស់គេ ហើយបានព្យាករអំពីការណ៍ជាច្រើន ដែលនឹងកើតឡើង
មែនហើយ រួមទាំង ការយាងមកនៃព្រះគ្រីស្ទផង ។
២៧ ហើយពីព្រោះលោកបាននិយាយប្រាប់គេថា ព្រះគ្រីស្ទ
គឺជា[ក]ព្រះ ជាព្រះវរបិតានៃវត្ថុទាំងអស់ ហើយបាននិយាយថា
ទ្រង់នឹង យករូបកាយជាមនុស្ស [ខ]គឺជារូបរាងតាមដែល
មនុស្សត្រូវបានបង្កើតឡើងពីដំបូងមក; ឬនិយាយម្យ៉ាងទៀត
លោកបាននិយាយថា មនុស្ស ត្រូវបានបង្កើតឡើង តាមរូបរាង
នៃ[គ]ព្រះ ហើយថា ព្រះនឹងយាងចុះមកក្នុងចំណោមកូនចៅមនុស្ស
ហើយមានសាច់ឈាម ហើយដើរ នៅលើផ្ទៃផែនដី —
២៨ ហើយឥឡូវនេះ ពីព្រោះលោកបាននិយាយយ៉ាងនេះ
នោះពួកគេបានសម្លាប់លោកចោល; ហើយពួកគេបានធ្វើអំពើ
ជាច្រើន ទៀត ដែលនាំឲ្យមានសេចក្ដីពិរោធនៃព្រះមកលើគេ ។
ហេតុដូច្នេះហើយ តើមានអ្នកណាងឿងឆ្ងល់ទៀតថា ហេតុអ្វី
បានជាពួកគេ ធ្លាក់ទៅក្នុងសេវកភាព ហើយត្រូវវាយ ដោយ
សេចក្ដីទុក្ខវេទនាដ៏ឈឺចាប់ដូច្នេះ ?
២៩ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ យើង
នឹង[ក]ពុំជួយសង្គ្រោះរាស្ត្រយើង នៅថ្ងៃដែលគេធ្វើអំពើបាបឡើយ;
តែយើងនឹងយាំងផ្លូវ កុំឲ្យគេរីកចំរើនបាន; ហើយអ្វីដែល
គេធ្វើនោះនឹងក្លាយទៅជាថ្នដំពប់ចំពោះពួកគេវិញ ។
៣០ ហើយមួយទៀត ទ្រង់មានព្រះបន្ទូលថា៖ បើ
សិនជារាស្ត្រយើងសាបព្រោះ[ក]អំពើស្មោកគ្រោក ពួកគេនឹង
[ខ]ច្រូតកាត់បានអង្កាម ដែលនៅក្នុងខ្យល់គួច; ឯលទ្ធផលដែល
បានមក គឺជាពិស ។
៣១ ហើយទ្រង់មានព្រះបន្ទូលទៀតថា៖ បើសិនជារាស្ត្រ[ក]
យើងសាបព្រោះអំពើស្មោកគ្រោក ពួកគេនឹងច្រូតកាត់ខ្យល់ពីទិស
ខាង កើត ដែលនាំមកនូវការបំផ្លិចបំផ្លាញយ៉ាងទាន់ហន់ ។
៣២ ហើយឥឡូវនេះ មើលចុះ សេចក្ដីសន្យារបស់ព្រះ
អម្ចាស់ត្រូវបានបំពេញហើយ ហើយអ្នករាល់គ្នាត្រូវបានវាយ
ហើយរង ទុក្ខវេទនា ។
៣៣ ប៉ុន្តែ បើសិនជាអ្នករាល់គ្នា[ក]បែរត្រឡប់មករកព្រះអម្ចាស់
ដោយស្មោះពីចិត្ត ហើយដាក់ទីទុកចិត្តរបស់អ្នកទៅលើទ្រង់
ហើយបំរើទ្រង់ឲ្យអស់ពីការព្យាយាមនៃគំនិតវិញ បើសិនជាអ្នក
រាល់គ្នាធ្វើយ៉ាងនេះ ទ្រង់នឹងដោះលែងអ្នកឲ្យរួចផុតពីសេវកភាព
ស្របតាមបំណង និងព្រះហឫទ័យរបស់ទ្រង់ ៕

២២ *ក* ម៉ូសាយ ១០:១៨.
២៦ *ក* ម៉ូសាយ ១៧:១២–២០.
២៧ *ក* ស.ប. ព្រះ, ក្រុមព្រះ.
*ខ* លោកុ. ១:២៦–២៨;
អេធើរ ៣:១៤–១៧;
គ. និង ស. ២០:១៧–១៨.
*គ* ម៉ូសាយ ១៣:៣៣–៣៤;
១៥:១–៤.
២៩ *ក* ១ សាំយូ. ១២:១៥;
២ របា. ២៤:២០.
៣០ *ក* ស.ប. ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក.
*ខ* កាឡាទី ៦:៧–៨;
គ. និង ស. ៦:៣៣.
ស.ប. ចំរូត.
៣១ *ក* យេរេ. ១៨:១៧;
ម៉ូសាយ ១២:៦.
៣៣ *ក* មរមន ៩:៦.

## ជំពូកទី ៨

*អាំម៉ូនបង្រៀនប្រជាជនរបស់លិមហៃ — លោកដឹងអំពីផ្ទាំងចំនួនម្ភៃបួនសន្លឹកនៃសាសន៍យ៉ារេឌ — បញ្ជីបុរាណអាចបកប្រែបាន ដោយពួកអ្នកមើលឆុត — គ្មានអំណោយទានណាប្រសើរជាងអំណោយទានជាអ្នកមើលឆុតឡើយ ។ ប្រមាណជាឆ្នាំ ១២១ ម.គ.ស.។*

ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីស្ដេចលិមហៃបាន
បញ្ចប់នូវការនិយាយទៅកាន់ប្រជាជនរបស់ទ្រង់ហើយ ត្បិតទ្រង់
បាន មានបន្ទូលអំពីការណ៍ជាច្រើនទៅកាន់ពួកគេ ប៉ុន្តែខ្ញុំបាន
កត់តែរឿងបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងសៀវភៅនេះ នោះទ្រង់
បានប្រាប់ ប្រជាជនរបស់ទ្រង់ អំពីការណ៍ទាំងអស់ ដែល
ទាក់ទងទៅនឹងបងប្អូនគេ ដែលនៅលើដែនដីសារ៉ាហិមឡា ។
២ ហើយទ្រង់បានបញ្ជាឲ្យអាំម៉ូនក្រោកឈរឡើង នៅចំពោះ
ហ្វូងមនុស្ស ហើយរៀបរាប់ឲ្យគេស្ដាប់ អំពីការណ៍ទាំងអស់
ដែល បានកើតឡើង ដល់បងប្អូនរបស់គេ ចាប់តាំងពីពេល
ដែលស៊ីនិព្វបានឡើងចេញពីដែនដីទៅ រហូតមកដល់ពេល
ដែលអាំម៉ូនបានឡើង មកពីដែនដីដែរ ។
៣ ហើយអាំម៉ូនក៏បានរៀបរាប់ឲ្យគេស្ដាប់ នូវប្រសាសន៍
ចុងក្រោយបង្អស់ ដែលស្ដេចបេនយ៉ាមីនបានបង្រៀនគេ ហើយ
ពន្យល់ ពាក្យទាំងនោះ ប្រាប់ដល់ប្រជាជនរបស់ស្ដេចលិមហៃ
ដើម្បីឲ្យគេអាចបានយល់នូវពាក្យទាំងអស់ ដែលលោកបាន
និយាយ ។
៤ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់លោកពីបាន
ធ្វើការណ៍ទាំងនេះចប់សព្វគ្រប់ហើយ ស្ដេចលិមហៃបានឲ្យ
ហ្វូងមនុស្ស ចេញទៅ ហើយបានអនុញ្ញាតឲ្យប្រជាជន
ត្រឡប់ទៅកាន់ផ្ទះរៀងៗខ្លួនវិញ ។
៥ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានឲ្យគេយកផ្ទាំង
ទាំងឡាយដែលមាន[ក]បញ្ជីអំពីប្រជាជនរបស់ទ្រង់ ចាប់តាំងពីគេ
បានចាកចេញពីដែនដីសារ៉ាហិមឡាមក យកមកឲ្យអាំម៉ូនអាន។
៦ ឥឡូវនេះ នៅពេលអាំម៉ូនបានអានបញ្ជីនោះភ្លាម
ស្ដេចក៏សួរលោកចង់ដឹងថា តើលោកអាចបកប្រែភាសាបានឬទេ
ហើយ អាំម៉ូនបានទូលប្រាប់ទ្រង់ថា លោកមិនអាចបកប្រែភាសា
បានទេ ។
៧ ហើយស្ដេចមានបន្ទូលទៅលោកថា៖ ដោយបារម្ភដល់សេចក្ដី
វេទនានៃប្រជាជនរបស់យើង យើងបានចាត់ឲ្យប្រជាជនយើង
ចំនួនសែសិបបីនាក់ ធ្វើដំណើរចូលក្នុងទីរហោស្ថាន ដើម្បីឲ្យ
គេអាចរកឃើញដែនដីសារ៉ាហិមឡា ដើម្បីពួកយើងអាចធ្វើ
សំណូមពរ ដល់បងប្អូនយើង សូមឲ្យគេដោះលែងពួកយើងឲ្យ
រួចផុតពីសេវកភាព ។
៨ ហើយពួកគេវង្វេងនៅក្នុងទីរហោស្ថាន អស់រយៈពេល
ជាច្រើនថ្ងៃ ក៏ប៉ុន្តែពួកគេមានការព្យាយាម ហើយនៅតែរកដែនដី
សារ៉ាហិមឡាពុំឃើញដែរ តែបានត្រឡប់មកដែនដីនេះវិញ
ក្រោយពីបានធ្វើដំណើរនៅលើដែនដីមួយ ដែលនៅកណ្ដាល
ទឹកជាច្រើន ហើយបានរកឃើញដែនដីមួយ ដែលពោរពេញ
ទៅដោយឆ្អឹងមនុស្ស និងឆ្អឹងសត្វ ហើយពោរពេញទៅ
ដោយអាគារបាក់បែក គ្រប់យ៉ាង ព្រមទាំងបានរកឃើញដែនដី
មួយ ដែលធ្លាប់មានមនុស្សនៅជាច្រើន ស្មើទៅនឹងពួកពល
អ៊ីស្រាអែលដែរ ។
៩ ហើយដើម្បីជាសាក្សីថាអ្វីៗ ដែលគេបាននិយាយនោះជា
ការពិត ពួកគេបានយកមកតាម នូវផ្ទាំងចំនួន[ក]ម្ភៃបួនផ្ទាំង
ដែលពេញ ដោយឆ្លាក់ត្រា ហើយផ្ទាំងទាំងនោះធ្វើពីមាសសុទ្ធ។
១០ ហើយមើលចុះ ពួកគេក៏បានយក[ក]ប្រដាប់បាំងទ្រូងដែលធំ
មកផង ធ្វើពី[ខ]លង្ហិន និងស្ពាន់ ហើយនៅល្អឥតខ្ចោះ ។
១១ ហើយមួយទៀត ពួកគេថែមទាំងយកដាវទាំងឡាយ
តែដងខូចអស់ទៅហើយ ហើយផ្លែក៏ដុះស្និម; ហើយនៅលើដែនដី
គ្មាន មនុស្សណាម្នាក់អាចបកប្រែភាសា ឬឆ្លាក់ត្រានៅលើផ្ទាំង
ទាំងនោះបានឡើយ ។ ហេតុដូច្នេះហើយ យើងសួរអ្នកថា
តើអ្នកអាចបក ប្រែបានទេ ?
១២ ហើយយើងសួរអ្នកទៀតថា៖ តើអ្នកស្គាល់អ្នកណា
ដែលអាចបកប្រែបានទេ? ព្រោះយើងចង់បកប្រែបញ្ជីទាំងនេះ
មកជា ភាសារបស់យើងរាល់គ្នា ព្រោះក្រែងវានឹងប្រាប់ពួក
យើងឲ្យដឹងអំពីសំណល់នៃប្រជាជន ដែលត្រូវបំផ្លាញចោល
ដែលជាប្រភពនៃបញ្ជី ទាំងនេះ; ឬក្រែងវាឲ្យពួកយើងដឹងអំពី
ប្រជាជន ដែលត្រូវបំផ្លាញចោល; ហើយយើងចង់ដឹងអំពី
បុព្វហេតុនៃការបំផ្លិចបំផ្លាញពួកគេ ។
១៣ ឥឡូវនេះ អាំម៉ូនបានទូលទៅស្ដេចថា៖ ឱព្រះរាជាអើយ
ទូលបង្គំសូមជំរាបជាប្រាកដថា មានមនុស្សម្នាក់ ដែលអាច
[ក]បកប្រែ បញ្ជីទាំងនេះបាន; ព្រោះលោកនោះមានគ្រឿងប្រដាប់
ម្យ៉ាង ដែលលោកយកមកឆ្លុះមើល ហើយបកប្រែបញ្ជីទាំងអស់

៨ ៥*ក* ម៉ូសាយ ៩–២២.
៩ *ក* អេធើរ ១:១–២.
១០ *ក* អេធើរ ១៥:១៥.
*ខ* អេធើរ ១០:២៣.
១៣ *ក* ម៉ូសាយ ២៨:១០–១៧.

បាន ដែលជា បញ្ជីបុរាណ; ហើយនេះគឺជាអំណោយទាន ដែល
បានមកពីព្រះ ។ ហើយគ្រឿងប្រដាប់ទាំងនោះ ត្រូវបានហៅថា
ប្រដាប់បកប្រែ ហើយគ្មានអ្នកណាអាចមើលទៅលើប្រដាប់
ទាំងនោះបានឡើយ លើកលែងតែត្រូវបានបញ្ជា ព្រោះខ្លាច
ក្រែងអ្នកនោះ មើលឃើញនូវ អ្វីដែលលោកមិនត្រូវឃើញ
នោះលោកនឹងត្រូវវិនាស ។ ហើយអ្នកណាដែលត្រូវបានបញ្ជាឲ្យ
មើលទៅលើប្រដាប់នោះ អ្នកនោះ ហៅថា អ្នកមើលឆុត ។
១៤ ហើយមើលចុះ ស្ដេចរបស់ប្រជាជនដែលនៅលើដែនដី
សារ៉ាហិមឡា ជាមនុស្សដែលបានបញ្ជាឲ្យធ្វើការទាំងនេះ ហើយ
ជា មនុស្សដែលបានទទួលអំណោយទានដ៏ខ្ពស់នេះអំពីព្រះ ។
១៥ ហើយស្ដេចបានមានបន្ទូលថា អ្នកមើលឆុត
គឺធំជាងព្យាការីទៅទៀត ។
១៦ ហើយអាំម៉ូននិយាយថា អ្នកមើលឆុត គឺជាអ្នកទទួលវិវរណៈ
ហើយជាព្យាការីផងដែរ; ហើយគ្មានអ្នកណាអាចមានអំណោយ
ទានប្រសើរជាងនេះឡើយ លើកលែងតែអ្នកនោះ មាន
ព្រះចេស្ដានៃព្រះប៉ុណ្ណោះ គឺគ្មានមនុស្សណាអាចមានឡើយ;
ក៏ប៉ុន្តែមនុស្ស ម្នាក់អាចមានអំណាចដ៏ធំ ដែលត្រូវបានប្រទាន
មកពីព្រះ ។
១៧ ប៉ុន្តែអ្នកមើលឆុតអាចដឹងអំពីការណ៍ទាំងឡាយដែល
កន្លងមកហើយ និងការណ៍ទាំងឡាយដែលនឹងកើតឡើង នៅពេល
ខាង មុខផង ហើយដោយសារប្រដាប់បកប្រែទាំងនេះ
ទើបគ្រប់ការណ៍ទាំងអស់ត្រូវបានបើកឲ្យឃើញ ឬនិយាយ
ម្យ៉ាងទៀតថា ការណ៍ សម្ងាត់ទាំងឡាយនឹងត្រូវបានសម្ដែងឲ្យ
ដឹង ហើយការណ៍លាក់កំបាំងទាំងឡាយនឹងត្រូវបានចេញមក
ឯពន្លឺ ហើយការណ៍ទាំងឡាយ ដែលគ្មានគេដឹង នោះក៏នឹង
ត្រូវបានធ្វើឲ្យដឹងដោយសារវត្ថុទាំងនេះ ហើយការណ៍ទាំង
ឡាយក៏នឹងត្រូវបានធ្វើដឹង ដោយសារវត្ថុ ទាំងនេះដែរ
បើពុំនោះសោតទេ នឹងពុំមានអ្នកណាអាចដឹងបានឡើយ ។
១៨ ម្ល៉ោះហើយ ព្រះទ្រង់បានប្រទានមធ្យោបាយមួយថា
តាមរយៈសេចក្ដីជំនឿ នោះមនុស្សអាចសម្ដែងអព្ភូតហេតុ
ដ៏អស្ចារ្យផ្សេងៗ; ហេតុដូច្នេះហើយ គេក្លាយទៅជាអ្នកមាន
ប្រយោជន៍ដ៏ធំដល់មនុស្សទូទៅ ។
១៩ ហើយឥឡូវនេះ កាលអាំម៉ូនបានបញ្ចប់នូវការនិយាយ
ពាក្យទាំងនេះហើយ នោះស្ដេចមានសេចក្ដីរីករាយជាខ្លាំង ហើយ
បាន ថ្លែងអំណរគុណដល់ព្រះថា៖ ពិតជាមានការអាថ៌កំបាំងដ៏ធំ
មួយ នៅលើផ្ទាំងទាំងនេះ ឯប្រដាប់បកប្រែទាំងនេះ ពិតជា
ត្រូវបានរៀប ចំឡើងក្នុងគោលបំណង ដើម្បីលាតត្រដាងនូវ
សេចក្ដីអាថ៌កំបាំងទាំងនេះ ដល់កូនចៅមនុស្ស ។
២០ ឱអស្ចារ្យណាស់ហ្ន៎កិច្ចការទាំងឡាយនៃព្រះអម្ចាស់
ហើយទ្រង់នឹងស៊ូទ្រាំជាមួយនឹងរាស្ត្ររបស់ទ្រង់ ដល់កាល
ណាទៅ; មែន ហើយ ឯយោបល់របស់កូនចៅមនុស្សពិតជាង
ងឹតងងល់ ហើយរាក់កំផែលមែន; ព្រោះពួកគេពុំស្វែងរកប្រាជ្ញា
ហើយពួកគេក៏មិនចង់ ឲ្យប្រាជ្ញាដឹកនាំគេដែរ !
២១ មែនហើយ ពួកគេដូចជាចៀមព្រៃមួយហ្វូង ហើយ
រត់គេចពីអ្នកគង្វាល ហើយរត់រសាត់ព្រាត់ ហើយត្រូវសត្វ
សាហាវនៅក្នុង ព្រៃ ដេញហែកស៊ីសាច់ ៕

---

បញ្ជីនៃរបស់សិនិព្វ — ជាដំណើររឿងអំពីប្រជាជនទ្រង់
ចាប់តាំងពីពេលដែលពួកគេបានចាកចេញពីដែនដី
សារ៉ាហិមឡាមក រហូតមក ដល់ពេលដែលពួកគេបាន
ត្រូវដោះលែងឲ្យរួចពីកណ្ដាប់ដៃនៃពួកសាសន៍លេមិន ។

*មានរួមនៅក្នុងជំពូកទី ៩ ទៅ ២២*

---

## ជំពូកទី ៩

*សិនិព្វដឹកនាំមនុស្សមួយក្រុមចេញពីក្រុងសារ៉ាហិមឡា ទៅយកបានដែនដីលីហៃ-នីហ្វៃ — ស្ដេចនៃសាសន៍លេមិនអនុញ្ញាតឲ្យពួកគេ នៅលើដីនោះ — សង្គ្រាមកើតឡើងរវាងពួកសាសន៍លេមិន នឹងប្រជាជនរបស់សិនិព្វ ។ ប្រមាណជាឆ្នាំ ២០០–១៨៧ ម.គ.ស. ។*

ខ្ញុំ សិនិព្វ ដោយបានទទួលការបង្រៀននូវគ្រប់ភាសានៃពួកសាសន៍
នីហ្វៃ ហើយដោយបានដឹងអំពីដែនដីនីហ្វៃ ឬដែនដីនៃកេរ្ដិ៍អាករ
ដំបូងរបស់ពួកអយ្យកោយើង ហើយដោយត្រូវបានចាត់ឲ្យធ្វើ
ជាអ្នកស៊ើបការណ៍ ទៅក្នុងចំណោមពួកសាសន៍លេមិន
ដើម្បីស៊ើបអំពី កងកម្លាំងរបស់គេ ដើម្បីឲ្យកងទ័ពរបស់យើង
មកវាយប្រហារ ហើយបំផ្លាញគេចោល– ប៉ុន្តែ កាលខ្ញុំបាន
ឃើញអ្វីៗដែលល្អនៅក្នុង ចំណោមពួកគេ នោះខ្ញុំមានសេច
ក្ដីប្រាថ្នាថា ពួកគេមិនគួរត្រូវបំផ្លាញចោលឡើយ ។
២ ហេតុដូច្នេះហើយ ខ្ញុំបានជជែកជាមួយនឹងបងប្អូនខ្ញុំនៅ
ក្នុងទីរហោស្ថាន ព្រោះខ្ញុំចង់ឲ្យអ្នកគ្រប់គ្រងរបស់យើង

---

១៣ *ខ* ស.ប. យូរីម និងធូមីម.
*គ* ស.ប. អ្នកមើលឆុត.
១៩ *ក* អេធើរ ៣:២១–២៨; ៤:៤–៥.
៩ ១*ក* ២ នីហ្វៃ ៥:៥–៨;
អោមណៃ ១:១២.

ធ្វើមេត្រីភាពជា មួយនឹងពួកគេ; ប៉ុន្តែគេជាមនុស្សឃោរឃៅ ហើយស្រេកឃ្លាម ទើបបានបញ្ជាថា ត្រូវយកខ្ញុំទៅសម្លាប់ចោលវិញ; តែខ្ញុំត្រូវបាន សង្គ្រោះ ដោយមានការខ្វាយឃ្លាមដ៏ច្រើន; ត្បិតឪពុកប្រយុទ្ធតតាំងនឹងឪពុក បងប្អូនតតាំងនឹងបងប្អូន រហូតដល់កងទ័ពរបស់យើង មួយភាគធំ ត្រូវបានបំផ្លាញចោលបង់ នៅក្នុងទីរហោស្ថាន; ឯពួកយើងដែលនៅសល់ពីស្លាប់ ក៏បានត្រឡប់មកដែនដីសារ៉ាហិមឡាវិញ ដើម្បីតំណាលរឿងប្រាប់ប្រពន្ធគេ និងកូនចៅគេ ។

៣ ក៏ប៉ុន្តែ ដោយខ្ញុំមានចិត្តចង់បានដែនដីនៃកេរ្ដិ៍អាកររបស់ពួកអយ្យកោយើងហួសប្រមាណ ក៏បានប្រមូលអស់អ្នកណាដែលមាន ប្រាថ្នាចង់ឡើងទៅយកដែនដីនោះ ហើយបានចាប់ផ្ដើមដំណើររបស់យើងជាថ្មីម្ដងទៀត ទៅក្នុងទីរហោស្ថាន ដើម្បីឡើងទៅកាន់ ដែនដីនោះ; តែយើងត្រូវរងទុក្ខដោយអំណត់អត់ និងការទុក្ខវេទនាដ៏ឈឺចាប់ផ្សេងៗ; ព្រោះយើងកម្រចាំដល់ព្រះអម្ចាស់ ជាព្រះរបស់ យើង ។

៤ ទោះជាយ៉ាងណាក៏ដោយ គង់តែបន្ទាប់ពីបានដើររសាត់ព្រាត់អស់ជាច្រើនថ្ងៃ នៅក្នុងទីរហោស្ថាន នោះយើងបានបោះ ត្រសាលរបស់យើង នៅត្រង់កន្លែងដែលបងប្អូនយើងត្រូវបានស្លាប់ គឺនៅជិតដែនដីរបស់ពួកអយ្យកោយើង ។

៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានទៅម្ដងទៀតជាមួយនឹងពួកក្រុមខ្ញុំបួននាក់ ចូលទៅក្នុងទីក្រុងមួយទៅគាល់ស្ដេច ដើម្បីឲ្យខ្ញុំអាចបានដឹងអំពីព្រះទ័យរបស់ស្ដេច ហើយដើម្បីឲ្យខ្ញុំអាចបានដឹងថា តើខ្ញុំអាចចូលទៅជាមួយនឹងប្រជាជនខ្ញុំ ហើយគ្រងយក ដែនដីនោះ ដោយសេចក្ដីសុខសាន្តបានឬទេ ។

៦ ហើយខ្ញុំបានចូលទៅគាល់ស្ដេច ហើយទ្រង់បានធ្វើសេចក្ដីសញ្ញាជាមួយនឹងខ្ញុំថា ខ្ញុំអាចយកដែនដីលីហៃ-នីហ្វៃ និងដែនដីសៃឡោមបាន ។

៧ ហើយទ្រង់ក៏បានបញ្ជាឲ្យប្រជាជនរបស់ទ្រង់ចាកចេញពីដែនដីនោះ ហើយខ្ញុំ និងប្រជាជនខ្ញុំបានចូលទៅ ដើម្បីយើងអាចយក ដែនដីនោះ ។

៨ ហើយយើងបានចាប់ផ្ដើមសង់អាគារ ហើយជួសជុលកំផែងទីក្រុង មែនហើយ គឺកំផែងទីក្រុងលីហៃ-នីហ្វៃ និងទីក្រុងសៃឡោម ។

៩ ហើយយើងបានចាប់ផ្ដើមភ្ជួរដីដាំដុះ មែនហើយ ដោយបណ្ដុះគ្រាប់ពូជគ្រប់មុខ មានទាំងគ្រាប់ពោត និងស្រូវសាលី និងស្រូវឱក និងនីអាស និងស៊ីអ៊ុម និងគ្រាប់ពូជនៃផ្លែឈើគ្រប់យ៉ាង; ហើយយើងបានចាប់ផ្ដើមចំរើនឡើងនៅលើដែនដីនោះ ។

១០ ឥឡូវនេះ នេះគឺជា[ក]ឧបាយកល និងកលល្បិចរបស់ស្ដេចលេមិន ដើម្បីនាំប្រជាជនខ្ញុំឲ្យធ្លាក់ទៅក្នុងសេវកភាព បានជាទ្រង់សុខ ចិត្តឲ្យយើងយកដែនដីនោះ ។

១១ ហេតុដូច្នេះហើយ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីយើងបានអាស្រ័យនៅលើដែនដីនេះ អស់រយៈពេល ១២ឆ្នាំមក ស្ដេចលេមិនក៏ចាប់ផ្ដើមមានកង្វល់ក្នុងចិត្តក្រែងលោដោយមធ្យោបាយណាមួយ ប្រជាជនខ្ញុំមានកម្លាំងខ្លាំងពូកែនៅលើដែនដីនេះ ដែលធ្វើឲ្យពួកគេមិនអាចមានជ័យជំនះមកលើប្រជាជនខ្ញុំ ហើយមិនអាចនាំប្រជាជនខ្ញុំឲ្យធ្លាក់ក្នុងសេវកភាពបាន ។

១២ ឥឡូវនេះ ពួកគេជាមនុស្សខ្ជិលច្រអូស ហើយ[ក]ថ្វាយបង្គំរូបព្រះ; ហេតុដូច្នេះហើយ ពួកគេមានបំណងចង់នាំពួកយើងឲ្យធ្លាក់ក្នុង សេវកភាព ដើម្បីគេអាចលោភលន់លើការងារពីកម្លាំងនៃដៃយើង; មែនហើយ ដើម្បីគេអាចយកហ្វូងចៀម នៅលើវាលស្មៅរបស់ យើង ធ្វើជាអាហារ ។

១៣ ហេតុដូច្នេះហើយ ហេតុការណ៍បានកើតឡើងថា ស្ដេចលេមិនបានចាប់ផ្ដើមចាក់រុកប្រជាជនទ្រង់ ឲ្យពួកគេទាស់ទែងនឹង ប្រជាជនខ្ញុំ; ហេតុដូច្នេះហើយ ក៏ចាប់ផ្ដើមមានសង្គ្រាមទាំងឡាយ និងការទាស់ទែងគ្នាទាំងឡាយនៅលើដែនដី ។

១៤ ត្បិតនៅឆ្នាំទីដប់បីនៃរជ្ជកាលខ្ញុំ នៅលើដែនដីនីហ្វៃ នៅខាងត្បូងដែនដីសៃឡោម កាលប្រជាជនខ្ញុំ កំពុងតែឲ្យទឹក និងចំណីដល់ហ្វូងចៀម ហើយកំពុងតែភ្ជួររាស់ដីគេ នោះស្រាប់តែមានពលទ័ពនៃពួកសាសន៍លេមិនមួយកង ដ៏មានចំនួនច្រើនបានវាយ មកលើពួកគេ ហើយបានចាប់ផ្ដើមសម្លាប់ពួកគេ ហើយដណ្ដើមយកហ្វូងចៀម និងពោតពីចំការរបស់គេទៅ ។

១៥ មែនហើយ ហេតុការណ៍បានកើតឡើងថា ពួកគេដែលនៅរស់ពីស្លាប់ទាំងប៉ុន្មាន ក៏បានរត់គេចខ្លួនចូលទៅក្នុងទីក្រុងនីហ្វៃ ហើយបានសូមឲ្យខ្ញុំការពារពួកគេ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានប្រដាប់ពួកគេដោយធ្នូ និងព្រួញ និងដាវ និងសាប និងដំបង និងខ្សែដង្ហក់ និងគ្រឿង សស្ត្រាវុធគ្រប់យ៉ាង ដែលយើងអាចធ្វើបាន ឯខ្ញុំ និងប្រជាជនខ្ញុំ ក៏បានចេញទៅតតាំងនឹងពួកសាសន៍លេមិន ។

១៧ មែនហើយ ដោយកម្លាំងនៃព្រះអម្ចាស់ យើងបាន

១០ *ក* ម៉ូសាយ ៧:២១–២២.

១២ *ក* អេណុស ១:២០.

ស.ប. ការថ្វាយបង្គំរូបព្រះ.

ទៅច្បាំងនឹងពួកសាសន៍លេមិន; ព្រោះខ្ញុំ និងប្រជាជនខ្ញុំ បាន
អំពាវនាវដល់ ព្រះអម្ចាស់ សូមឲ្យទ្រង់ជួយដោះលែងយើងឲ្យ
រួចផុតពីកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវរបស់យើង ព្រោះយើង
បានភ្ញាក់ឡើង ដោយនឹក ឃើញដល់ការដោះលែងនៃពួក
អយ្យកោរបស់យើង ។
១៨ ហើយព្រះទ្រង់បាន[ក]ឮសំរែកអំពាវនាវរបស់យើង ហើយ
បានឆ្លើយតបការអធិស្ឋានរបស់យើង; ហើយយើងបានចេញទៅ
ដោយឥទ្ធិឫទ្ធិរបស់ទ្រង់; មែនហើយ យើងបានចេញទៅតតាំង
នឹងពួកសាសន៍លេមិន ហើយក្នុងរយៈពេលមួយថ្ងៃមួយយប់
យើងបាន សម្លាប់ពួកគេអស់បីពាន់និងសែសិបបីនាក់; យើង
បានសម្លាប់ពួកគេ រហូតដល់យើងដេញពួកគេចេញពីដែនដី
របស់យើងទៅ ។
១៩ រីឯខ្ញុំវិញ បានជួយកប់សាកសពរបស់គេ ដោយដៃខ្ញុំផ្ទាល់ ។
ហើយមើលចុះ យើងមានសេចក្ដីសោកសៅ និងសេចក្ដីទួញ
សោកជាខ្លាំង ចំពោះបងប្អូនយើងចំនួនពីររយចិតសិបប្រាំបួននាក់
ដែលត្រូវបានស្លាប់ ៕

## ជំពូកទី ១០

*ស្ដេចលេមិនសុគត — ប្រជាជនរបស់ទ្រង់ជាមនុស្សព្រៃផ្សៃ ហើយសាហាវ ហើយជឿសណ្ដាប់ខុសឆ្គង — សិនិហ្វ និងប្រជាជនលោក មានជ័យជំនះលើពួកគេ ។ ប្រមាណជាឆ្នាំ ១៨៧–១៦០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា យើងបានចាប់ផ្ដើមកសាង
នគរឡើងវិញ ហើយយើងបានចាប់ផ្ដើមយកដែនដីនោះទៀត
ដោយសេចក្ដីសុខសាន្ត; ហើយខ្ញុំបានបញ្ជាថា ត្រូវ
ធ្វើគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមគ្រប់យ៉ាង ដើម្បីឲ្យខ្ញុំអាចមាន
គ្រឿងសស្ត្រាវុធ សំរាប់ប្រជាជនខ្ញុំ តទល់នឹងពួកសាសន៍លេមិន
នៅពេលពួកនេះនឹងឡើងមកធ្វើសង្គ្រាមនឹងប្រជាជនខ្ញុំទៀត ។
២ ហើយខ្ញុំដាក់ទាហានយាមជុំវិញដែនដី ដើម្បីកុំឲ្យពួក
សាសន៍លេមិនអាចវាយមកលើពួកយើងបាន ដោយពុំដឹងខ្លួន
ហើយ បំផ្លាញពួកយើងចោលទៀត; ហើយខ្ញុំបានការពារប្រជាជន
និងហ្វូងចៀមរបស់ខ្ញុំតាមរបៀបនេះ ហើយការពារគេ កុំឲ្យ
ធ្លាក់ទៅក្នុង កណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវរបស់យើង ។
៣ ហើយហេតុការណ៍បានកើតឡើងថា យើងបានគ្រងដែនដី
របស់ពួកអយ្យកោយើងទុកជាមរតក អស់ជាច្រើនឆ្នាំ មែន
ហើយ គឺអស់រយៈពេលម្ភៃពីរឆ្នាំ ។
៤ ហើយខ្ញុំបានចាត់ឲ្យពួកប្រុសភ្ជួររាស់ដី ហើយ[ក]ដាំគ្រាប់
ធញ្ញជាតិ ព្រមទាំងផ្លែឈើគ្រប់យ៉ាង ។
៥ ហើយខ្ញុំបានចាត់ឲ្យពួកស្ត្រីស្រាវរវៃ ហើយនឿយហត់ធ្វើការ
ហើយធ្វើការងារ ហើយត្បាញសំពត់ទេសឯកយ៉ាងម៉ដ្តគ្រប់យ៉ាង
មែនហើយ និង[ក]សំពត់គ្រប់បែបយ៉ាង ដើម្បីយើងអាចស្លៀកពា
ក់បិទបាំងភាពអាក្រាតរបស់យើង; ម្ល៉ោះហើយ យើងបាន
ចំរើនឡើង នៅលើដែនដី — ម្ល៉ោះហើយ យើងមានសេច
ក្ដីសុខសាន្តនៅលើដែនដីតរៀងមក អស់រយៈពេលម្ភៃពីរឆ្នាំមក ។
៦ ហើយហេតុការណ៍បានកើតឡើងថា [ក]ស្ដេចលេមិន
បានសុគតទៅ ហើយបុត្ររបស់ទ្រង់បានសោយរាជ្យជំនួសទ្រង់ ។
ហើយ ទ្រង់បានចាប់ផ្ដើមចាក់រុកប្រជាជនទ្រង់ឲ្យបះបោរទាស់
នឹងប្រជាជនខ្ញុំ; ហេតុដូច្នេះហើយ ពួកគេបានរៀបចំធ្វើសង្គ្រាម
ហើយឡើង មកច្បាំងនឹងប្រជាជនខ្ញុំ ។
៧ ប៉ុន្តែ ខ្ញុំបានចាត់ឲ្យអ្នកស៊ើបការណ៍ទាំងឡាយ ទៅសព្វទាំង
ដែនដី[ក]សេមឡុន ដើម្បីខ្ញុំអាចបានដឹងអំពីការរៀបចំរបស់ពួកគេ
ដើម្បីខ្ញុំអាចការពារទប់ទល់នឹងពួកគេ កុំឲ្យពួកគេវាយមក
លើប្រជាជនខ្ញុំ ហើយបំផ្លាញប្រជាជនខ្ញុំចោល ។
៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានឡើងមក
ដល់ភាគខាងជើងនៃដែនដីសៃឡោម ដោយមានទ័ពជាច្រើន
បុរស [ក]ប្រដាប់ដោយ[ខ]ធ្នូ និងព្រួញ និងដាវ និងសាប និងក្រួស
និងខ្សែដង្ហក់; ហើយគេកោរក្បាលត្រងោល និងអាក្រាត;
ហើយគេក្រវាត់ស្បែក នៅចង្កេះគេ ។
៩ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានបញ្ជាឲ្យ
ពួកស្ត្រី និងកូនក្មេងនៃប្រជាជនខ្ញុំ ពួននៅក្នុងទីរហោស្ថាន;
ហើយខ្ញុំក៏បាន បញ្ជាពួកបុរសដែលមានវ័យចាស់ តែអាច
ស្ពាយអាវុធបាន ព្រមទាំងពួកកំឡោះទាំងអស់ ដែលអាច
ស្ពាយអាវុធបាន ឲ្យប្រមូលគ្នាមក ដើម្បីទៅច្បាំងនឹងពួក
សាសន៍លេមិន; ហើយខ្ញុំបានដាក់គេតាមលំដាប់ថ្នាក់ ដោយរេ
យាងទៅតាមអាយុរៀងៗខ្លួន ។
១០ ហើយហេតុការណ៍បានកើតឡើងថា យើង
បានឡើងទៅច្បាំងនឹងពួកសាសន៍លេមិន; រីឯខ្ញុំ សូម្បីតែខ្ញុំ

១៨ *ក* ម៉ូសាយ ២៩:២០.
**១០** ៤*ក* ម៉ូសាយ ៩:៩.
៥ *ក* អាលម៉ា ១:២៩.
៦ *ក* ម៉ូសាយ ៩:១០–១១; ២៤:៣.
៧ *ក* ម៉ូសាយ ១១:១២.
៨ *ក* យ៉ារ៉ុម ១:៨.
*ខ* អាលម៉ា ៣:៤–៥.

ដែលមានវ័យចាស់ទៅ ហើយ ក៏បានឡើងទៅច្បាំងនឹងពួក
សាសន៍លេមិនដែរ ។ ហើយហេតុការណ៍បានកើតឡើងថា
យើងបានឡើងទៅច្បាំងដោយ[ក]កម្លាំង នៃព្រះអម្ចាស់ ។
១១ ឥឡូវនេះ ពួកសាសន៍លេមិនពុំបានដឹងអ្វីអំពីព្រះ
អម្ចាស់ឡើយ ក៏ពុំដឹងពីកម្លាំងនៃព្រះអម្ចាស់ដែរ ហេតុដូច្នេះហើយ
ពួកគេពឹង ផ្អែកទៅលើកម្លាំងរបស់គេផ្ទាល់ប៉ុណ្ណោះ ។ ក៏ប៉ុន្តែ
ពួកគេជាប្រជាជនមួយ ដ៏មានកម្លាំងពូកែ តាមកម្លាំងរបស់
មនុស្ស ។
១២ ពួកគេជាប្រជាជនសាហាវ [ក]ព្រៃផ្សៃ ហើយស្រេកឈាម
មានជំនឿទៅលើសណ្តាប់នៃពួកអយ្យកោរបស់គេ ដែលមាន
យ៉ាង ដូច្នេះ — គឺជឿថា ពួកគេត្រូវបាន
ដេញចេញពីដែនដីយេរូសាឡិម មកពីអំពើទុច្ចរិតទាំងឡាយនៃ
ពួកអយ្យកោរបស់គេ ហើយថាប្អូនៗ គេ បានប្រព្រឹត្តខុសទៅលើ
ពួកគេ នៅក្នុងទីរហោស្ថាន ព្រមទាំងបានប្រព្រឹត្តខុសទៅលើ
ពួកគេ កាលដែលកំពុងឆ្លងសមុទ្រដែរ;
១៣ ហើយបានប្រព្រឹត្តខុសទៅលើពួកគេទៀត កាលនៅលើដែ
នដីនៃកេរ្តិ៍អាករ[ក]ដំបូងរបស់គេ បន្ទាប់ពីបានឆ្លងសមុទ្រមក
ហើយ ការណ៍អស់ទាំងនេះ ក៏ព្រោះតែនីហ្វៃស្មោះត្រង់ ក្នុង
ការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ — ហេតុ
ដូច្នេះហើយ ទើបនីហ្វៃ ត្រូវបានប្រោសប្រណីពីព្រះអម្ចាស់
ព្រោះព្រះអម្ចាស់ ទ្រង់បានឮពាក្យអធិស្ឋានទាំងឡាយរបស់លោក
ហើយឆ្លើយតបពាក្យទាំង នោះ ហើយលោកបានដឹកនាំពួកគេ
ក្នុងពេលធ្វើដំណើរក្នុងទីរហោស្ថាន ។
១៤ តែបងៗរបស់លោកបានខឹងនឹងលោក ពីព្រោះពួកគេពុំ
[ក]យល់នូវទំនាក់ទំនងទាំងឡាយនៃព្រះអម្ចាស់ឡើយ; ពួកគេក៏
[ខ]ខឹងនឹង លោកដែរ កាលនៅលើសមុទ្រ ពីព្រោះពួកគេបានធ្វើ
ចិត្តរឹងរូសទាស់នឹងព្រះអម្ចាស់ ។
១៥ ហើយពួកគេបានខឹងនឹងលោកទៀត កាលដែលគេមក
ដល់ដែនដីសន្យា ពីព្រោះពួកគេបាននិយាយថា លោកបាន
ដណ្តើមយក អំណាច[ក]ត្រួតត្រាទៅលើប្រជាជនពីដៃគេ; ហើយ
ពួកគេបានរកសម្លាប់លោកចោល ។
១៦ ហើយពួកគេបានខឹងនឹងលោកទៀត ពីព្រោះលោកបាន
ចាកចូលក្នុងទីរហោស្ថាន [ក]តាមដែលព្រះអម្ចាស់ទ្រង់បានបញ្ជា
ដល់ លោក ហើយបានយកបញ្ជីទាំងឡាយដែលឆ្លាក់នៅលើផ្ទាំង
លង្ហិននោះទៅផង ព្រោះពួកគេបាននិយាយថា លោក[ខ]បាន
លួចយកបញ្ជី ទាំងនោះទៅ ។
១៧ ម្ល៉ោះហើយ ទើបពួកគេបានបង្រៀនកូនចៅគេថា ពួក
គេត្រូវស្អប់ប្រជាជននីហ្វៃ ហើយថា ពួកត្រូវធ្វើឃាតគេ ហើយ
ថា ពួកគេត្រូវលួច ហើយប្លន់គេ ហើយធ្វើអ្វីៗគ្រប់យ៉ាងដែល
គេអាចធ្វើបាន ដើម្បីបំផ្លាញគេចោល; ហេតុដូច្នេះហើយ ពួក
គេមាន សម្អប់ដ៏អស់កល្បជានិច្ច ចំពោះកូនចៅនីហ្វៃ ។
១៨ ដោយមកពីហេតុនេះ ទើបស្តេចលេមិនបានប្រើកលល្បិច
ភូតភរ និងពាក្យសន្យាដ៏ល្អៗ ដើម្បីបោកបញ្ឆោតខ្ញុំ ឲ្យខ្ញុំនាំ
ប្រជាជន របស់ខ្ញុំ មកកាន់ដែនដីនេះ ដើម្បីពួកគេអាចបំផ្លាញ
ប្រជាជនខ្ញុំចោល; មែនហើយ យើងបានរងទុក្ខអស់ជាច្រើនឆ្នាំ
នៅលើដែនដីនេះ ។
១៩ ហើយឥឡូវនេះ ខ្ញុំ ស៊ីនិហ្វ បន្ទាប់ពីបានប្រាប់ប្រជាជនខ្ញុំ
នូវរឿងអស់ទាំងនេះ អំពីពួកសាសន៍លេមិនហើយ នោះខ្ញុំបាន
លើកទឹក ចិត្តគេ ឲ្យទៅធ្វើចម្បាំងដោយសមត្ថភាពរបស់ខ្លួន
ដោយដាក់ទីទុកចិត្តរបស់គេទៅលើព្រះអម្ចាស់; ហេតុដូច្នេះហើយ
យើងបានតតាំង នឹងពួកគេប្រទល់មុខ ។
២០ ហើយហេតុការណ៍បានកើតឡើងថា យើងបានដេញ
ពួកគេ ចេញពីដែនដីរបស់យើងទៀត; ហើយយើងបានសម្លាប់
ពួកគេ ដោយការកាប់សម្លាប់ដ៏ធំ គឺអស់ជាច្រើនដែល
យើងពុំបានរាប់ឡើយ ។
២១ ហើយហេតុការណ៍បានកើតឡើងថា យើងបានត្រឡប់
មកនៅឯដែនដីរបស់យើងវិញ ហើយប្រជាជនខ្ញុំបានចាប់ផ្តើម
ឃ្វាល ហ្វូងចៀមគេ ហើយភ្ជួររាស់ដីទៀត ។
២២ ហើយឥឡូវនេះ ដោយមានវ័យចាស់ ខ្ញុំបានប្រគល់
នគរទៅឲ្យបុត្ររបស់ខ្ញុំម្នាក់; ហេតុដូច្នេះហើយ ខ្ញុំពុំនិយាយ
អ្វីទៀតឡើយ ហើយសូមព្រះអម្ចាស់ទ្រង់ប្រទានពរដល់
ប្រជាជនខ្ញុំផងចុះ ។ អាម៉ែន ៕

## ជំពូកទី ១១

*ស្តេចណូអេគ្រប់គ្រងដោយអំពើទុច្ចរិត — ទ្រង់សប្បាយនៅក្នុងជីវភាពដ៏ពោរពេញទៅដោយអបាយមុខ ដោយមានភរិយានិងស្នំជា ច្រើន — អ័ប៊ីណាដៃព្យាករថា ប្រជាជននឹងត្រូវនាំយក*

១០ *ក* ស.ប. ទុកចិត្ត.
១២ *ក* អាលម៉ា ១៧:១៤.
*ខ* ២ នីហ្វៃ ៥:១–៣.
១៣ *ក* ១ នីហ្វៃ ១៨:២៣.
*ខ* ១ នីហ្វៃ ១៧:៣៥.
១៤ *ក* ១ នីហ្វៃ ១៥:៧–១១.
*ខ* ១ នីហ្វៃ ១៨:១០–១១.
១៥ *ក* ២ នីហ្វៃ ៥:៣.
១៦ *ក* ២ នីហ្វៃ ៥:១២.
*ខ* អាលម៉ា ២០:១០, ១៣.

*ទៅក្នុងសេវកភាព — ស្ដេចណូអេរកប្រហារជីវិតលោកចោល ។ ប្រមាណ ជាឆ្នាំ ១៦០–១៥០ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា សិនិព្វបានប្រគល់
នគរឲ្យទៅណូអេ ជាបុត្ររបស់ទ្រង់ម្នាក់; ហេតុដូច្នេះហើយ
ណូអេ បានចាប់ផ្ដើមសោយរាជ្យជំនួសទ្រង់; ណូអេមិនបាន
ដើរតាមផានរបស់បិតាខ្លួនឡើយ ។
២ ត្បិតមើលចុះ ទ្រង់មិនបានកាន់តាមព្រះបញ្ញត្តិទាំងឡាយ
នៃព្រះនោះទេ តែទ្រង់បានដើរតាមសេចក្ដីប៉ងប្រាថ្នានៃចិត្តរបស់ខ្លួន
ផ្ទាល់ទៅវិញ ។ ហើយទ្រង់មានភរិយា និងស្នំជាច្រើន ។
ហើយទ្រង់បាននាំឲ្យប្រជាជនរបស់ទ្រង់ប្រព្រឹត្តអំពើបាប ហើយ
ប្រព្រឹត្តនូវ អ្វីៗដែលគួរខ្ពើមឆ្អើម ចំពោះព្រះនេត្រនៃព្រះ
អម្ចាស់ ។ មែនហើយ ហើយពួកគេបានប្រព្រឹត្តអំពើ
សហាយស្មន់ និងអំពើទុច្ចរិត គ្រប់បែបយ៉ាង ។
៣ ហើយទ្រង់បានដកពន្ធចំនួនមួយភាគប្រាំនៃអ្វីៗ ដែល
ប្រជាជនទ្រង់មាន គឺមួយភាគប្រាំនៃមាសរបស់ពួកគេ និង
ប្រាក់របស់ពួកគេ និងមួយភាគប្រាំនៃស៊ីព្វរបស់ពួកគេ និងស្ពាន់
របស់ពួកគេ និងលង្ហិនរបស់ពួកគេ និងដែករបស់គេ; ហើយ
មួយភាគប្រាំនៃសត្វធាត់ៗ របស់ពួកគេ; ហើយមួយភាគប្រាំនៃអស់
ទាំងធញ្ញជាតិរបស់គេផង ។
៤ ហើយពន្ធដារទាំងអស់នេះ គឺទ្រង់យកមកចំណាយ
សំរាប់ខ្លួនទ្រង់ និងភរិយាទាំងឡាយទ្រង់ និងស្នំទាំងឡាយ
របស់ទ្រង់; ហើយ ព្រមទាំងពួកសង្ឃទាំងឡាយរបស់ទ្រង់ និង
ភរិយាទាំងឡាយរបស់គេ និងស្នំទាំងឡាយរបស់គេផង;
ម្ល៉ោះហើយ ទ្រង់បានកែប្រែ កិច្ចការរបស់នគរ ។
៥ ព្រោះទ្រង់បានទំលាក់ពួកសង្ឃ ដែលបិតាទ្រង់បាន
តែងតាំងពីមុន ហើយបានតែងតាំងអ្នកថ្មីជំនួសវិញ ពួកនេះបាន
លើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់គេ ។
៦ មែនហើយ ម្ល៉ោះហើយ ពួកគេបានទទួលការគាំទ្រ ក្នុង
ការខ្ជិលច្រអូសរបស់គេ និងការថ្វាយបង្គំរូបព្រះ និងអំពើ
សហាយស្មន់ ទាំងឡាយរបស់គេ ដោយពន្ធដារដែលស្ដេច
ណូអេបានដកយកពីប្រជាជនរបស់ទ្រង់; ម្ល៉ោះហើយ ប្រជាជន
បានធ្វើការយ៉ាងខ្លាំងក្លា ដើម្បីចញ្ចឹមអំពើទុច្ចរិត ។
៧ មែនហើយ ពួកគេក៏បានក្លាយទៅជាអ្នកថ្វាយបង្គំរូបព្រះដែរ
ពីព្រោះពួកគេត្រូវបានបញ្ឆោត ដោយសំដីផ្អែមល្ហែមឥតប្រ
យោជន៍ បញ្ចើចបញ្ចើរបស់ស្ដេច និងពួកសង្ឃ; ព្រោះពួកនេះ
បានពោលពាក្យបញ្ចើចបញ្ចើទៅកាន់គេ ។
៨ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចណូអេបាន
សង់អាគារដ៏ធំ ហើយល្អជាច្រើន; ហើយទ្រង់បានតុបតែងអាគារ
ទាំងនោះ ដោយវត្ថុសិល្បៈដ៏ល្អៗធ្វើពីឈើ និងដោយវត្ថុដ៏មាន
តម្លៃគ្រប់បែបយ៉ាង ធ្វើពីមាស ពីប្រាក់ ពីដែក ពីលង្ហិន ពីស៊ីព្វ
និងពីស្ពាន់ ។
៩ ហើយទ្រង់ក៏បានសង់សំរាប់ខ្លួនទ្រង់នូវរាជវាំងមួយដ៏ធំ ហើយ
មានបល្ល័ង្កមួយនៅចំកណ្ដាល គឺរបស់ទាំងអស់សុទ្ធតែធ្វើ
ពីឈើល្អ ហើយតុបតែងដោយមាស និងប្រាក់ និងដោយវត្ថុ
មានតម្លៃផ្សេងៗទៀត ។
១០ ហើយទ្រង់ក៏បានបញ្ជាឲ្យជាងធ្វើគ្រឿងប្រដាប់ដ៏ល្អៗ
គ្រប់បែបយ៉ាង នៅខាងក្នុងព្រះវិហារបរិសុទ្ធ គឺធ្វើពីឈើល្អ
និងស្ពាន់ និងលង្ហិន ។
១១ ឯកៅអីទាំងឡាយ ដែលចាត់ទុកសំរាប់ពួកសង្ឃជាន់ខ្ពស់
ដែលខ្ពស់ជាងកៅអីឯទៀតៗនោះ ទ្រង់បានតុបតែងដោយមាស
សុទ្ធ; ហើយទ្រង់ឲ្យធ្វើបង្អែកនៅខាងមុខកៅអីទាំងនោះ
ដើម្បីទុកឲ្យពួកសង្ឃជាន់ខ្ពស់ទាំងនោះផ្អែកខ្លួនហើយដាក់ដៃ
នៅពេលគេ និយាយពាក្យភូតភរ និងឥតប្រយោជន៍ទៅកាន់
ប្រជាជន ។
១២ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានសង់ប៉ម
មួយ នៅជិតព្រះវិហារបរិសុទ្ធ; មែនហើយ គឺជាប៉មមួយ
សែនខ្ពស់ គឺខ្ពស់ រហូតដល់ទ្រង់ឈរនៅលើប៉មនោះ ហើយ
អាចទតមើលឃើញដែនដីសែមឡោម និងដែនដីសេមឡុន
ដែលមានពួកសាសន៍លេមិន រស់នៅ; ហើយទ្រង់ថែមទាំង
អាចទតមើលឃើញដែនដី ដែលនៅព័ទ្ធជុំវិញនោះផង ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានឲ្យ
សង់អាគារជាច្រើន នៅដែនដីសែមឡោម; ហើយទ្រង់បាន
បញ្ជាឲ្យគេសង់ប៉ម មួយដ៏ធំ នៅលើទួលខាងជើង
ដែនដីសែមឡោម ដែលធ្លាប់ជាកន្លែងសំណាក់របស់កូនចៅ
នីហ្វៃ នៅពេលគេរត់គេចចេញពីដែនដី; ម្ល៉ោះហើយ កិច្ចការ
ទាំងនេះទ្រង់បានធ្វើដោយទ្រព្យសម្បត្តិ ដែលទ្រង់បានមក
ពីដកពន្ធរបស់ប្រជាជនទ្រង់ ។

១១ ២ *ក* យ៉ាកុប ៣:៥.
*ខ* ១ ពង្សាវ. ១៤:១៥–១៦; ម៉ូសាយ ២៩:៣១.
*គ* ២ នីហ្វៃ ២៨:១៥.
៣ *ក* ហេ. ពាក្យប្រហែលគ្នា : គុណនាម «ភ្លឺចែងចាំង»; កិរិយាស័ព្ទ «ត្រប ឬបិទដោយដែក».
១២ *ក* ម៉ូសាយ ១៩:៥–៦.

១៤ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានដាក់ព្រះទ័យរបស់ទ្រង់ ទៅលើទ្រព្យសម្បត្តិរបស់ទ្រង់ ហើយទ្រង់បានចំណាយ ពេលរបស់ទ្រង់ ទៅលើការរស់នៅដោយអបាយមុខជាមួយនឹងភរិយាទាំងឡាយរបស់ទ្រង់ និងស្នំទាំងឡាយរបស់ទ្រង់; ឯពួកសង្ឃ របស់ទ្រង់ក៏បានចំណាយពេលរបស់គេ ជាមួយនឹងពួកស្រីពេស្យាដែរ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានដាំចំការទំពាំង[ក]បាយជូរ នៅជុំវិញដែនដី; ហើយទ្រង់បានធ្វើប្រដាប់ចំរាញ់ស្រា ហើយបានធ្វើស្រាទំពាំងបាយជូរជាបរិបូរ; ហេតុដូច្នេះហើយ ទ្រង់បានក្លាយទៅជាអ្នកប្រមឹកម្នាក់ ហើយប្រជាជនរបស់ទ្រង់ក៏ដូច្នោះ ដែរ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិនបានចាប់ផ្ដើមវាយមកលើប្រជាជនទ្រង់ គឺទៅលើក្រុមដែលមានគ្នា តិច ហើយបានសម្លាប់ពួកគេនៅលើស្រែ និងនៅពេលដែលពួកគេកំពុងឃ្វាលហ្វូងចៀមគេ ។

១៧ ហើយស្ដេចណូអេបានចាត់ទាហានឲ្យយាមជុំវិញដែនដី ដើម្បីការពារកុំឲ្យពួកសាសន៍លេមិនចូលមក; តែទ្រង់មិនបានចាត់ ឲ្យមានចំនួនគ្រប់គ្រាន់សោះ ហើយពួកសាសន៍លេមិនបានវាយមកលើពួកគេ ហើយបានសម្លាប់គេបង់ ហើយបានដេញហ្វូងចៀម របស់គេចេញពីដែនដី; ម្ល៉ោះហើយ ពួកសាសន៍លេមិនបានចាប់ផ្ដើមបំផ្លាញពួកគេ ហើយបានអនុវត្តការសម្អប់ទៅលើពួកគេ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចណូអេបានចាត់ឲ្យពលទ័ពរបស់ទ្រង់ទៅប្រឆាំងនឹងពួកគេ ហើយពួកគេត្រូវបានដេញ ថយក្រោយវិញ ឬក៏ថា ពួកគេបានដេញពួកលេមិនថយក្រោយបានមួយរយៈ; ហេតុដូច្នេះហើយ ពួកគេក៏ត្រឡប់មកវិញ ដោយអររីក រាយនឹងរបស់របរ ដែលគេដណ្ដើមបានមកវិញ ។

១៩ ហើយឥឡូវនេះ ដោយសារជ័យជំនះដ៏ធំនេះ ពួក[ក]គេបានលើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់គេ; ពួកគេអួតអាងអំពីកម្លាំង របស់គេផ្ទាល់ ដោយនិយាយថា ពួកគេចំនួនហាសិបនាក់ តែអាចតតាំងឈ្នះលើពួកសាសន៍លេមិនរាប់ពាន់នាក់បាន; ម្ល៉ោះហើយ ពួកគេបានអួត ហើយបានពេញចិត្តនឹងឈាម និងការខ្ចាយឈាមបងប្អូនគេ ហើយការណ៍នេះក៏មកពីអំពើទុច្ចរិតរបស់ស្ដេច និងពួកសង្ឃរបស់គេ ។

២០ ហើយហេតុការណ៍បានកើតឡើងថា មានបុរសម្នាក់ក្នុងចំណោមពួកគេ មានឈ្មោះថា [ក]អ័ប៊ីណាដៃ; ហើយលោកចេញទៅក្នុង ចំណោមពួកគេ ហើយបានចាប់ផ្ដើមព្យាករថា៖ មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ហើយទ្រង់បានបញ្ជាមកខ្ញុំដូច្នេះថា ចូរទៅ និយាយនឹងប្រជាជននេះថា ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា — វេទនានឹងកើតមានដល់ប្រជាជននេះ ព្រោះយើងបានឃើញ អំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ និងអំពើទុច្ចរិតរបស់គេ និងអំពើសហាយស្មន់ទាំងឡាយរបស់គេហើយ; ហើយបើសិនជាពួកគេ មិនប្រែចិត្តទេ យើងនឹងមកពិនិត្យពិច័យពួកគេ ក្នុងសេចក្ដីពិរោធរបស់យើង ។

២១ ហើយលើកលែងតែពួកគេប្រែចិត្ត ហើយត្រឡប់មករកព្រះអម្ចាស់ ជាព្រះរបស់គេវិញ មើលចុះ យើងនឹងប្រគល់គេទៅក្នុង កណ្ដាប់ដៃនៃពួក[ក]ខ្មាំងសត្រូវគេ; មែនហើយ ហើយពួកគេនឹងត្រូវធ្លាក់ទៅក្នុងសេវកភាព; ហើយពួកគេនឹងត្រូវរងទុក្ខវេទនា ដោយដៃ នៃពួកខ្មាំងសត្រូវរបស់គេ ។

២២ ហើយហេតុការណ៍នឹងកើតឡើងថា ពួកគេនឹងដឹង[ក]ថា យើងជាព្រះអម្ចាស់ ជាព្រះរបស់គេ ហើយជាព្រះដែលមានសេចក្ដីប្រច័ណ្ឌ នឹងមកពិនិត្យពិច័យអំពើទុច្ចរិតនៃរាស្ត្រយើង ។

២៣ ហើយហេតុការណ៍នឹងកើតឡើងថា លើកលែងតែប្រជាជននេះប្រែចិត្ត ហើយត្រឡប់មករកព្រះអម្ចាស់ ជាព្រះរបស់គេវិញ នោះពួកគេនឹងត្រូវធ្លាក់ទៅក្នុងសេវកភាព; ហើយគ្មាននរណានឹងដោះលែងគេឡើយ លើកលែងតែព្រះអម្ចាស់ ជាព្រះដ៏មានមហិទ្ធិឫទ្ធិ ប៉ុណ្ណោះ ។

២៤ មែនហើយ ហើយហេតុការណ៍នឹងកើតឡើងថា កាលណាពួកគេ[ក]នឹងអំពាវនាវដល់យើង
នោះយើងក្រឮស្ដាប់សំរែករបស់គេ ណាស់; មែនហើយ យើងនឹងទុកឲ្យគេត្រូវវាយ ដោយពួកខ្មាំងសត្រូវរបស់គេវិញ ។

២៥ ហើយលើកលែងតែពួកគេប្រែចិត្ត ដោយស្លៀកពាក់សំពត់ធ្មៃ និងផេះ ហើយស្រែកអំពាវនាវយ៉ាង[ក]ខ្លាំងទៅព្រះអម្ចាស់ ជាព្រះ របស់គេ នោះយើងនឹងពុំឮពាក្យអធិស្ឋានរបស់គេឡើយ ហើយយើងក៏មិនដោះលែងគេឲ្យរួចផុតពីសេចក្ដី

---

១៥ *ក* ស.ប. ពាក្យសំដីនៃប្រាជ្ញាវាងវៃ.
១៩ *ក* គ. និង ស. ៣:៤.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
២០ *ក* ស.ប. អ័ប៊ីណាដៃ.
២១ *ក* ម៉ូសាយ ១២:២; ២០:២១; ២១:១៣–១៥; ២៣:២១–២៣.
២២ *ក* និក្ខ. ២០:៥; ចោទិ. ៦:១៥; ម៉ូសាយ ១៣:១៣.
២៤ *ក* មីកា ៣:៤; ម៉ូសាយ ២១:១៥.
២៥ *ក* អេសាយ ១:១៥; ៥៩:២.

វេទនាទាំងឡាយរបស់គេ ដែរ; ហើយព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលថាដូច្នោះ ហើយទ្រង់បានបញ្ជាមកខ្ញុំថាដូច្នោះ ។
២៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលដែល
អ័ប៊ីណាដៃបាននិយាយពាក្យទាំងនេះ ទៅកាន់ពួកគេហើយ ស្រាប់
តែ ពួកគេខឹងនឹងលោក ហើយបានស្វែងរកផ្ដាច់ជីវិតលោកចោល;
ប៉ុន្តែព្រះអម្ចាស់ទ្រង់បានដោះលែងលោកឲ្យរួចផុតពីកណ្ដាប់ដៃ
នៃពួកគេវិញ ។
២៧ ឥឡូវនេះ កាលស្ដេចណូអេបានឮពាក្យ ដែលអ័ប៊ីណាដៃ
បាននិយាយទៅកាន់ប្រជាជនហើយ ទ្រង់ក៏ខ្ញាល់ដែរ; ហើយ
មាន បន្ទូលថា៖ តើអ័ប៊ីណាដៃ ជាអ្នកណា ដែលមក
ជំនុំជំរះយើង និងប្រជាជនយើង ឬនរណាទៅជាព្រះ ដែល
នឹងនាំមកនូវសេចក្ដីវេទនា ដ៏ធំដល់ប្រជាជនយើងយ៉ាងនេះ ?
២៨ យើងបញ្ជាឲ្យអ្នកទៅហៅអ័ប៊ីណាដៃមកទីនេះ
ដើម្បីយើងនឹងសម្លាប់គាត់ចោល ព្រោះគាត់បាននិយាយនូវ
ពាក្យទាំងនេះ ដើម្បីគាត់អាចបានចាក់រុកឲ្យប្រជាជនយើងខឹង
គ្នាទៅវិញទៅមក ហើយធ្វើឲ្យមានការទាស់ទែងគ្នានៅក្នុង
ចំណោមប្រជាជនយើង; ហេតុដូច្នេះហើយ យើងនឹងសម្លាប់
គាត់ចោល ។
២៩ ឥឡូវនេះ ភ្នែករបស់ប្រជាជនខ្វាក់; ហេតុដូច្នេះហើយ បាន
ជាពួកគេធ្វើចិត្តរឹងរូសទាស់នឹងពាក្យរបស់អ័ប៊ីណាដៃ ហើយ
ចាប់ពី ពេលនោះមក ពួកគេរកចាប់លោក ឯស្ដេចណូអេបាន
ធ្វើចិត្តរឹងរូសទាស់នឹងព្រះបន្ទូលនៃព្រះអម្ចាស់ដែរ ហើយពុំប្រែ
ចិត្តចំពោះអំពើ អាក្រក់ទាំងឡាយរបស់ទ្រង់ឡើយ ៕

## ជំពូកទី ១២

*អ័ប៊ីណាដៃជាប់គុកដោយមកពីបានព្យាករ អំពីការបំផ្លិចបំផ្លាញប្រជាជន និងការសុគតនៃស្ដេចណូអេ — ពួកសង្ឃក្លែងក្លាយដកស្រង់បទ គម្ពីរ ហើយធ្វើពុតជាកាន់តាមក្រិត្យវិន័យលោកម៉ូសេ — អ័ប៊ីណាដៃចាប់ផ្ដើមបង្រៀនពួកគេ អំពីព្រះបញ្ញត្តិទាំងដប់ប្រការ ។ ប្រមាណជាឆ្នាំ ១៤៨ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ក្នុងរយៈពេលពីរឆ្នាំក្រោយមក
អ័ប៊ីណាដៃបានមកក្នុងចំណោមពួកគេ ដោយក្លែងខ្លួនកុំឲ្យពួក
គេ ស្គាល់ ហើយបានចាប់ផ្ដើមព្យាករនៅក្នុងចំណោមពួក
គេថា៖ ព្រះអម្ចាស់ ទ្រង់បានបញ្ជាមកខ្ញុំដូច្នេះថា —
អ័ប៊ីណាដៃ ចូរអ្នកទៅព្យាករ ដល់រាស្ត្រយើងនេះ ព្រោះពួក
គេបានធ្វើចិត្តរឹងរូសទាស់នឹងពាក្យរបស់យើង; ពួកគេពុំបានប្រែ
ចិត្តពីអំពើអាក្រក់របស់គេឡើយ; ហេតុដូច្នេះហើយ យើង
នឹងទៅពិនិត្យពិច័យគេ ដោយសេចក្ដីពិរោធរបស់យើង មែន
ហើយ ដោយសេចក្ដីពិរោធដ៏ខ្លាំងក្លារបស់យើង យើង
នឹងទៅពិនិត្យពិច័យគេ ក្នុងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើម
ទាំងឡាយរបស់គេ ។
២ មែនហើយ វេទនាដល់តំណនេះចុះ! ហើយព្រះអម្ចាស់
ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ចូរលាដៃរបស់អ្នក ហើយព្យាករថា៖
ត្បិត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា ហេតុការណ៍
នឹងកើតឡើងថា មនុស្សជំនាន់នេះ ដោយមកពីអំពើទុច្ចរិតទាំង
ឡាយរបស់ពួកគេ នោះនឹងត្រូវនាំឲ្យធ្លាក់ទៅក្នុងសេវកភាព
ហើយនឹងត្រូវទះកំផ្លៀង; មែនហើយ ហើយត្រូវមនុស្ស
បណ្ដេញចេញ ហើយនឹងត្រូវស្លាប់; ឯត្មាតនៅលើអាកាស
និងឆ្កែ មែនហើយ ព្រមទាំងសត្វព្រៃទាំងឡាយ នឹងហែកសាច់
ស៊ីសាច់គេ ។
៣ ហើយហេតុការណ៍នឹងកើតឡើងថា ជីវិតរបស់ស្ដេចណូអេ
នឹងមានតម្លៃស្មើទៅនឹងសំពត់មួយ នៅក្នុងឡភ្លើងក្ដៅប៉ុណ្ណោះ;
ព្រោះលោកនឹងដឹងថា យើងជាព្រះអម្ចាស់ ។
៤ ហើយហេតុការណ៍នឹងកើតឡើងថា យើងនឹងវាយរា
ស្ត្រយើងនេះ ដោយសេចក្ដីទុក្ខវេទនាដ៏ឈឺចាប់ មែនហើយ
ដោយ អំណត់អត់ ដោយជំងឺអាសន្នរោគ; ហើយយើង
នឹងធ្វើឲ្យពួកគេស្រែកទ្រហោអស់ទាំងថ្ងៃ ។
៥ មែនហើយ ហើយយើងនឹងធ្វើឲ្យមានបន្ទុកជាប់នៅលើខ្នងពួក
គេ; ហើយពួកគេនឹងត្រូវដឹក ដូចជាសត្វលាដែលគ ។
៦ ហើយហេតុការណ៍នឹងកើតឡើងថា យើងនឹងធ្វើឲ្យ
ព្រិលធ្លាក់មកលើចំណោមពួកគេ ហើយព្រិលនឹងវាយគេ;
ហើយគេក៏នឹងត្រូវ បានវាយដោយខ្យល់បូពិ; ហើយសត្វល្អិត
នឹងបំផ្លាញដីគេ ព្រមទាំងស៊ីគ្រាប់ពូជរបស់គេផង ។

២៧ *ក* និក្ខ. ៥:២; ម៉ូសាយ ១២:១៣.
២៩ *ក* ម៉ូសេ ៤:៤.
*ខ* អាលម៉ា ៣៣:២០; អេធើរ ១១:១៣.
១២ ១*ក* អេសាយ ៦៥:៦.
២ *ក* ម៉ូសាយ ១១:២១; ២០:២១; ២១:១៣–១៥; ២៣:២១–២៣.
*ខ* ម៉ូសាយ ២១:៣–៤.
៣ *ក* ម៉ូសាយ ១២:១០.
*ខ* ម៉ូសាយ ១៩:២០.
៤ *ក* គ. និង ស. ៩៧:២៦.
*ខ* ម៉ូសាយ ២១:៩–១០.
៥ *ក* ម៉ូសាយ ២១:៣.
៦ *ក* យេរេ. ១៨:១៧; ម៉ូសាយ ៧:៣១.
*ខ* និក្ខ. ១០:១–១២.

៧ ហើយពួកគេនឹងត្រូវបានវាយដោយអាសន្នរោគដ៏សា
ហាវ — ហើយការណ៍អស់ទាំងនេះ យើងនឹងធ្វើឡើង ពីព្រោះ
តែ[ក]អំពើ ទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ ។
៨ ហើយហេតុការណ៍នឹងកើតឡើងថា លើកលែងតែគេប្រែចិត្ត
បើពុំនោះសោតទេ យើងនឹង[ក]បំផ្លាញគេឲ្យសូន្យបង់ពីលើផ្ទៃផែនដី;
ក៏ប៉ុន្តែគេនឹង[ខ]ទុកបញ្ជីមួយ ហើយយើងនឹងរក្សាបញ្ជីទាំងនោះ
ទុកសំរាប់ពួកសាសន៍ផ្សេងៗទៀត ដែលនឹងមកយកដីនេះ; មែន
ហើយ យើងធ្វើយ៉ាងនេះ ដើម្បីបង្ហាញនូវអំពើគួរខ្ពើមឆ្អើមទាំង
ឡាយរបស់រាស្ត្រនេះ ដល់ពួកសាសន៍ផ្សេងៗទៀត ។ ហើយ
អ័ប៊ីណាដៃបាន ព្យាករការណ៍ជាច្រើនទៀត ទាស់នឹង
ប្រជាជននេះ ។
៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានខឹងនឹងលោក;
ហើយគេចាប់លោកចង នាំយកទៅគាល់ស្តេច ហើយទូលទៅ
ស្តេចថា៖ មើលចុះ យើងខ្ញុំបាននាំបុរសម្នាក់មកចំពោះទ្រង់
ជាអ្នកដែលបានព្យាករអាក្រក់ អំពីប្រជាជនទ្រង់ ហើយបាន
និយាយថា ព្រះទ្រង់នឹងបំផ្លាញប្រជាជនរបស់ទ្រង់ចោល ។
១០ ហើយបុរសនេះថែមទាំងបានព្យាករអាក្រក់ អំពីជីវិត
របស់ទ្រង់ផង ហើយបាននិយាយថា ជីវិតរបស់ទ្រង់ដូចជា
សំពត់ដែល នៅក្នុងឡភ្លើង ។
១១ ហើយមួយទៀត គាត់បាននិយាយថា ទ្រង់នឹងទៅដូចជា
ចំបើង គឺដូចជាចំបើងស្ងួតនៅវាលស្រែ ដែលត្រូវសត្វបោល
ពីលើ ហើយជាន់ឈ្លីក្រោមជើង ។
១២ ហើយមួយទៀត គាត់បាននិយាយថា ទ្រង់នឹងទៅដូចជា
ផ្កាបន្លា កាលណារីកពេញហើយ បើសិនជាខ្យល់បក់ត្រូវ នោះនឹង
រសាត់ទៅលើផ្ទៃដី ។ ហើយគាត់បានធ្វើពុតដូចជាព្រះអម្ចាស់
ទ្រង់មានបន្ទូលដូច្នោះ ។ ហើយគាត់បាននិយាយថា ការណ៍
អស់ទាំង នេះនឹងកើតមានដល់ទ្រង់ លើកលែងតែទ្រង់ប្រែចិត្ត
ហើយនេះក៏ដោយសារតែអំពើទុច្ចរិតទាំងឡាយរបស់ទ្រង់ ។
១៣ ហើយឥឡូវនេះ ឱព្រះរាជាអើយ តើទ្រង់បានធ្វើអំពើ
អាក្រក់ដ៏ធំយ៉ាងណាទៅ ឬក៏ប្រជាជនរបស់ទ្រង់ បានធ្វើអំពើ
បាបដ៏ធំ យ៉ាងណាទៅ បានជាយើងរាល់គ្នានេះ ត្រូវព្រះ
ទ្រង់កាត់ទោស ឬក៏ត្រូវបុរសនេះជំនុំជំរះដូច្នេះ ?
១៤ ហើយឥឡូវនេះ ឱព្រះរាជាអើយ មើលចុះ យើងជា
មនុស្សឥតទោស ឯព្រះរាជា ទ្រង់ក៏ពុំបានធ្វើអំពើបាបដែរ;
ហេតុដូច្នេះ ហើយ បុរសនេះបាននិយាយកុហកអំពីទ្រង់ ហើយ
គាត់បានព្យាករដោយឥតប្រយោជន៍ ។
១៥ ហើយមើលចុះ យើងជាមនុស្សខ្លាំងពូកែ យើងនឹង
ពុំធ្លាក់ទៅក្នុងសេវកភាព ឬក៏នឹងត្រូវចាប់ជាឈ្លើយ ដោយ
ពួកខ្មាំងសត្រូវ របស់យើងឡើយ; មែនហើយ ទ្រង់បាន
ចំរើនឡើងនៅលើដែនដីនេះ ហើយទ្រង់ក៏នឹងចំរើនឡើងនៅថ្ងៃ
ក្រោយដែរ ។
១៦ មើលចុះ នេះគឺជាបុរសនោះហើយ យើងខ្ញុំសូមប្រគល់
គាត់មកក្នុងព្រះហស្តទ្រង់ចុះ; ទ្រង់មានព្រះទ័យចង់ធ្វើអ្វីដល់
គាត់ ក៏សូម ធ្វើតាមព្រះទ័យចុះ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា ស្តេចណូអេបាន
បញ្ជាឲ្យគេយកអ័ប៊ីណាដៃ ទៅដាក់ក្នុងគុក; ហើយទ្រង់បាន
បញ្ជាឲ្យ[ក]ពួក សង្ឃប្រមូលគ្នាមក ដើម្បីទ្រង់អាចបើកការប្រជុំ
ដើម្បីពិភាក្សាថា តើទ្រង់ត្រូវធ្វើអ្វីដល់លោក ។
១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ទូលទ្រង់ថា៖ ចូរនាំលោកនោះមកទីនេះ ដើម្បីពួកយើងចោទ
សួរគាត់; ហើយ ស្តេចបានបញ្ជាឲ្យគេនាំលោកមកចំពោះពួកគេ ។
១៩ ហើយពួកគេបានចាប់ផ្តើមចោទសួរលោក ក្រែងគេអា
ចធ្វើឲ្យលោកនិយាយខុស ដើម្បីឲ្យពួកគេអាចមានឱកាសនឹង
ចាប់ កំហុសលោកបាន; ប៉ុន្តែលោកបានឆ្លើយតបពួក
គេដោយក្លាហាន ហើយបានឆ្លើយបានគ្រប់ទាំងសំនួររបស់ពួក
គេ មែនហើយ [ក]ធ្វើឲ្យពួក គេមានសេចក្តីអស្ចារ្យជាខ្លាំង;
ព្រោះលោកបានឆ្លើយតបបានគ្រប់ទាំងសំនួររបស់ពួកគេ
ហើយបានផ្ចាញ់ផ្ចាល់ពួកគេគ្រប់អស់ទាំងពាក្យ របស់គេផង ។
២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេម្នាក់បាន
និយាយទៅកាន់លោកថា៖ តើពាក្យទាំងឡាយដែលបាន
សរសេរទុក ហើយបានបង្រៀនដោយពួកអយ្យកោរបស់យើង
ដូចតទៅនេះមានន័យថាដូចម្តេច ?
២១ [ក]ឱល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះដែលដើរលើភ្នំ ជា
អ្នកដែលនាំដំណឹងល្អមក; ហើយប្រកាសប្រាប់ពីសេចក្តីសុខសាន្ត;
ជាអ្នក ដែលនាំដំណឹងល្អពីការប្រសើរមក; ហើយ
ថ្លែងប្រាប់ពីសេចក្តីសង្គ្រោះ; គឺជាអ្នកដែលពោល
ដល់ក្រុងស៊ីយ៉ូនថា ព្រះនៃអ្នកទ្រង់សោយ រាជ្យ;
២២ មានឮសម្លេងពួកចាំយាមរបស់អ្នក បន្លឺសម្លេងឡើងច្រៀង

៧ ក គ. និង ស. ៣:១៨.
៨ ក អាលម៉ា ៤៥:៩–១៤.
ខ មរមន ៨:១៤–១៦.
១៧ ក ម៉ូសាយ ១១:១១.
១៩ ក គ. និង ស. ១០០:៥–៦.
២១ ក អេសាយ ៥២:៧–១០;
ណាហ៊ុម ១:១៥.

ជាព្រមគ្នា; ត្បិតគេនឹងឃើញដោយភ្នែករបស់ខ្លួនគេ ក្នុងកាលដែល ព្រះអម្ចាស់ទ្រង់ប្រគល់ក្រុងស៊ីយ៉ូនមកវិញ;

២៣ អស់ទាំងជីឯកការនៃក្រុងយេរូសាឡិមអើយ ចូរបន្លឺសេចក្ដីអំណរ ចូរច្រៀងជាមួយគ្នាចុះ; ត្បិតព្រះអម្ចាស់ទ្រង់បានកំសាន្តទុក្ខរបស់រាស្ត្រទ្រង់ ក៏បានប្រោសលោះក្រុងយេរូសាឡិមហើយ;

២៤ ព្រះអម្ចាស់ទ្រង់បានលាតព្រះពាហុបរិសុទ្ធរបស់ទ្រង់នៅភ្នែកនៃគ្រប់ទាំងសាសន៍ ហើយអស់ទាំងចុងផែនដី នឹងបានឃើញ សេចក្ដីសង្គ្រោះនៃព្រះរបស់យើងរាល់គ្នា ?

២៥ ហើយឥឡូវនេះ អ័ប៊ីណាដៃបាននិយាយទៅពួកគេថា៖ តើមិនមែនអ្នករាល់គ្នាជាសង្ឃទេឬអី ហើយធ្វើពុតជាបង្រៀនប្រជាជននេះ ហើយធ្វើពុតជាយល់វិញ្ញាណនៃការព្យាករណ៍ តែបែរជាមានបំណងចង់ឲ្យខ្ញុំពន្យល់ប្រាប់ពីការណ៍ទាំងនេះទៅវិញ?

២៦ ខ្ញុំសូមប្រាប់អ្នកថា វេទនាដល់អ្នកដែលបង្ខូចផ្លូវទាំងឡាយនៃព្រះអម្ចាស់! ព្រោះបើសិនជាអ្នករាល់គ្នាយល់ការណ៍ទាំងនេះ នោះអ្នករាល់គ្នាមិនបានយកមកបង្រៀនគេទេ; ហេតុដូច្នេះហើយ អ្នករាល់គ្នាបានបង្ខូចផ្លូវទាំងឡាយនៃព្រះអម្ចាស់ហើយ ។

២៧ អ្នករាល់គ្នាពុំបានតាំងចិត្តរៀនឲ្យយល់; ហេតុដូច្នេះហើយ អ្នករាល់គ្នាពុំមានប្រាជ្ញាទេ; ហេតុដូច្នេះហើយ តើអ្នករាល់គ្នាបង្រៀនអ្វីដល់ប្រជាជននេះ?

២៨ ហើយពួកគេបានឆ្លើយថា៖ យើងបង្រៀនក្រិត្យវិន័យលោកម៉ូសេ ។

២៩ ហើយម៉្យាងទៀត លោកបាននិយាយទៅពួកគេថា៖ បើសិនជាអ្នករាល់គ្នាបង្រៀនក្រិត្យវិន័យលោកម៉ូសេមែន ហេតុអ្វីក៏អ្នក រាល់គ្នាមិនកាន់តាមក្រិត្យវិន័យនោះ? ហេតុអ្វីបានជាអ្នករាល់គ្នាទុកចិត្តទៅលើសម្បត្តិទ្រព្យវិញ ? ហេតុអ្វីបានជាអ្នករាល់គ្នាប្រព្រឹត្ត អំពើសហាយស្មន់ទាំងឡាយ ហើយចំណាយកម្លាំងខ្លួនទៅលើពួកស្រីពេស្យា មែនហើយ ហើយបានធ្វើឲ្យប្រជាជននេះប្រព្រឹត្តអំពើ បាប រហូតដល់ព្រះអម្ចាស់ ទ្រង់បានចាត់ឲ្យខ្ញុំមកព្យាករទាស់នឹងប្រជាជននេះ មែនហើយ គឺនឹងមានការណ៍អាក្រក់ដ៏ធំមួយ កើតឡើង ដល់ប្រជាជននេះដូច្នេះ ?

៣០ តើអ្នករាល់គ្នាមិនដឹងទេឬថា ខ្ញុំនិយាយការពិត? មែនហើយ អ្នករាល់គ្នាដឹងថា ខ្ញុំនិយាយការពិត; ហើយអ្នករាល់គ្នាគួរតែ ញ័រចំពោះព្រះ ។

៣១ ហើយហេតុការណ៍នឹងកើតឡើងថា អ្នករាល់គ្នានឹងត្រូវបានវាយ ពីព្រោះតែអំពើទុច្ចរិតទាំងឡាយរបស់អ្នក ត្បិតអ្នករាល់គ្នា បាននិយាយថា អ្នករាល់គ្នាបង្រៀនក្រិត្យវិន័យលោកម៉ូសេ ។ ហើយតើអ្នកដឹងអ្វីខ្លះអំពីក្រិត្យវិន័យលោកម៉ូសេនោះ? តើសេចក្ដីសង្គ្រោះបានមកដោយសារក្រិត្យវិន័យលោកម៉ូសេឬ ? តើអ្នកនិយាយថាដូចម្ដេច ?

៣២ ហើយពួកគេបានឆ្លើយតបថា សេចក្ដីសង្គ្រោះបានមកដោយសារក្រិត្យវិន័យលោកម៉ូសេ ។

៣៣ ប៉ុន្តែឥឡូវនេះ អ័ប៊ីណាដៃបាននិយាយទៅគេថា៖ ខ្ញុំដឹងថា បើសិនជាអ្នករាល់គ្នាកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ អ្នករាល់គ្នានឹងបានសង្គ្រោះហើយ; មែនហើយ បើសិនជាអ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានប្រទានដល់ លោកម៉ូសេ នៅលើភ្នំស៊ីណាយថា៖

៣៤ យើងជាព្រះអម្ចាស់ ជាព្រះនៃអ្នក ដែលបាននាំអ្នកចេញពីផ្ទះពួកបាវបំរើនៅស្រុកអេស៊ីព្ទមក ។

៣៥ អ្នកមិនត្រូវមានព្រះឯណាទៀត នៅចំពោះយើងឲ្យសោះ ។

៣៦ អ្នកមិនត្រូវឆ្លាក់ធ្វើរូបណាសំរាប់អ្នក ឬក៏ធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬអ្វីដែលនៅផែនដីខាងក្រោមឡើយ ។

៣៧ ឥឡូវនេះ អ័ប៊ីណាដៃបាននិយាយទៅពួកគេថា តើអ្នករាល់គ្នាបានធ្វើតាមអស់ទាំងនេះហើយឬនៅ ? ខ្ញុំសូមប្រាប់អ្នកថា ទេ អ្នករាល់គ្នាពុំទាន់បានធ្វើតាមទេ ។ ហើយតើអ្នករាល់គ្នាបានបង្រៀនប្រជាជននេះថា គេត្រូវធ្វើការណ៍អស់ទាំងនេះឬនៅ? ខ្ញុំប្រាប់អ្នកថា ទេ អ្នករាល់គ្នាពុំទាន់បានបង្រៀនគេទេ ៕

## ជំពូកទី ១៣

*អ័ប៊ីណាដៃត្រូវបានការពារដោយអានុភាពពីព្រះ — លោកបង្រៀនព្រះបញ្ញត្តិទាំងដប់ប្រការ — សេចក្ដីសង្គ្រោះពុំបានមកដោយក្រិត្យ វិន័យលោកម៉ូសេតែមួយប៉ុណ្ណោះទេ — ព្រះអង្គផ្ទាល់ត្រូវថ្វាយដង្វាយធួន ហើយប្រោសលោះរាស្ត្ររបស់ទ្រង់ ។ ប្រមាណជាឆ្នាំ ១៤៨ ម.គ.ស. ។*

២៤ *ក* ១ នីហ្វៃ ២២:១១.
២៥ *ក* ម៉ូសាយ ១១:៥.
២៧ *ក* ស.ប. យោបល់.
២៩ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* ស.ប. អំពើកំផិត.
៣១ *ក* ម៉ូសាយ ៣:១៥; ១៣:២៧–៣២; អាលម៉ា ២៥:១៦.
៣៣ *ក* និក្ខ. ១៩:៩, ១៦–២០; ម៉ូសាយ ១៣:៥.
៣៤ *ក* និក្ខ. ២០:២–៤.
*ខ* និក្ខ. ១២:៥១; ១ នីហ្វៃ ១៧:៤០; ម៉ូសាយ ៧:១៩.
៣៥ *ក* ហូសេ ១៣:៤. ស.ប. ការថ្វាយបង្គំរូបព្រះ.
៣៧ *ក* ម៉ូសាយ ១៣:២៥–២៦.

ហើយឥឡូវនេះ កាលស្ដេចបានឮពាក្យអស់នេះហើយ ទ្រង់មានបន្ទូលទៅកាន់ពួកសង្ឃថា៖ ចូរយកបុរសនេះទៅសម្លាប់ចោលទៅ; ព្រោះយើងមិនដឹងទុកគាត់ធ្វើអ្វីទេ ព្រោះគាត់ជាមនុស្សឆ្កួត ។

២ ហើយពួកគេបានស្ទុះមកបំរុងនឹងចាប់លោក តែលោកបានតនឹងគេវិញ ហើយបាននិយាយទៅគេថា៖

៣ ចូរកុំប៉ះខ្ញុំឲ្យសោះ ព្រោះព្រះទ្រង់នឹងវាយអ្នករាល់គ្នាជាមិនខានឡើយ បើសិនជាអ្នករាល់គ្នាដាក់ដៃមកលើខ្ញុំ ព្រោះខ្ញុំពុំទាន់បាន ប្រគល់សារ ដែលព្រះអម្ចាស់ទ្រង់បានចាត់ខ្ញុំឲ្យមកប្រគល់នៅឡើយទេ; ខ្ញុំក៏ពុំទាន់បានប្រាប់អ្នករាល់គ្នា នូវៗអ្វីដែលអ្នករាល់គ្នាសូមឲ្យ ខ្ញុំប្រាប់នោះឡើយដែរ; ហេតុដូច្នេះហើយព្រះទ្រង់នឹងពុំទុកឲ្យខ្ញុំត្រូវបំផ្លាញ នៅពេលនេះទេ ។

៤ ប៉ុន្តែ ខ្ញុំត្រូវបំពេញព្រះបញ្ញត្តិទាំងឡាយ ដែលព្រះទ្រង់បានបញ្ជាដល់ខ្ញុំ; ហើយពីព្រោះខ្ញុំបានប្រាប់ការពិតដល់អ្នកស្រាប់តែអ្នក រាល់គ្នាបានខឹងនឹងខ្ញុំទៅវិញ ។ ហើយមួយទៀតពីព្រោះខ្ញុំបានប្រាប់ពីព្រះបន្ទូលនៃព្រះ នោះអ្នករាល់គ្នាបានវិនិច្ឆ័យមកលើរូបខ្ញុំថា ខ្ញុំជា មនុស្សឆ្កួតវិញ ។

៥ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអ័ប៊ីណាដៃបាននិយាយពាក្យអស់ទាំងនេះហើយ ប្រជាជនរបស់ស្ដេចណូអេ ពុំហ៊ានប៉ះពាល់ដល់លោកឡើយ ព្រោះព្រះវិញ្ញាណនៃព្រះអម្ចាស់ បានសណ្ឋិតមកលើលោក; ហើយមុខលោកភ្លឺចែងចាំង ដូចជាលោក ម៉ូសេ កាលនៅលើភ្នំស៊ីណាយកំពុងទូលនឹងព្រះអម្ចាស់ដូច្នោះហើយ ។

៦ ហើយលោកបាននិយាយដោយអានុភាព និងសិទ្ធិអំណាចពីព្រះ; ហើយលោកបាននិយាយតទៅទៀតថា៖

៧ អ្នករាល់គ្នាឃើញទេថា អ្នករាល់គ្នាគ្មានអំណាចនឹងសម្លាប់ខ្ញុំបានឡើយ ហេតុដូច្នេះហើយ ខ្ញុំសូមបញ្ចប់សាររបស់ខ្ញុំសិនចុះ ។ មែនហើយ ខ្ញុំយល់ថាពាក្យខ្ញុំនេះ កាត់ទំលុះដល់បេះដូងអ្នក ពីព្រោះខ្ញុំប្រាប់អ្នកនូវការពិត អំពីអំពើទុច្ចរិតទាំងឡាយរបស់អ្នក ។

៨ មែនហើយ ហើយពាក្យសំដីរបស់ខ្ញុំធ្វើឲ្យអ្នកពោរពេញទៅដោយការងឿងឆ្ងល់ ការចម្លែក និងកំហឹង ។

៩ ប៉ុន្តែ ខ្ញុំសូមបញ្ចប់សាររបស់ខ្ញុំសិនចុះ; ហើយបន្ទាប់ពីនេះទៅ ទោះជាខ្ញុំទៅទីណាក៏ដោយ ក៏មិនជាការអ្វីដែរ ប្រសិនបើខ្ញុំបានរួច ។

១០ ប៉ុន្តែ ខ្ញុំសូមប្រាប់អ្នកប៉ុណ្ណេះថា បន្ទាប់ពីនេះទៅ អ្វីដែលអ្នកធ្វើដល់ខ្ញុំ នឹងទៅជាគំរូ ហើយជាស្រមោលអំពីអ្វីដែលនឹងកើត ឡើងនៅថ្ងៃក្រោយ ។

១១ ហើយឥឡូវនេះ ខ្ញុំសូមអានជូនអ្នក នូវព្រះបញ្ញត្តិទាំងឡាយនៃព្រះ ដែលនៅសល់ទាំងប៉ុន្មាន ព្រោះខ្ញុំយល់ថាព្រះបញ្ញត្តិទាំង នេះពុំទាន់បានសរសេរទុក នៅក្នុងបេះដូងរបស់អ្នកនៅឡើយទេ; ខ្ញុំយល់ថា អ្នករាល់គ្នាបានរៀន ហើយបានបង្រៀនអំពីអំពើទុច្ចរិតជា ភាគច្រើន នៅក្នុងជីវិតអ្នក ។

១២ ហើយឥឡូវនេះ ចូរអ្នករាល់គ្នាចាំទុកចុះថា ខ្ញុំបាននិយាយទៅកាន់អ្នកថា៖ អ្នកមិនត្រូវឆ្លាក់ធ្វើរូបណាសំរាប់អ្នកឬក៏ធ្វើរូបណាឲ្យដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬអ្វីដែលនៅផែនដីខាងក្រោម ឬអ្វីដែលនៅក្នុងទឹកដែលទាបជាងដីឡើយ ។

១៣ ហើយមួយទៀតថា៖ អ្នកមិនត្រូវក្រាបសំពះនៅចំពោះរបស់ទាំងនោះ ឬបំរើរបស់ទាំងនោះឡើយ; ត្បិតយើងជាព្រះអម្ចាស់ ជាព្រះនៃអ្នក យើងមានសេចក្ដីប្រច័ណ្ឌ ក៏ពិនិត្យពិច័យអំពើទុច្ចរិតទាំងឡាយរបស់ឪពុកទៅលើកូនចៅ រហូតដល់បីហើយបួនតំណ ចំពោះអស់អ្នកណាដែលស្អប់យើង;

១៤ ហើយយើងបង្ហាញសេចក្ដីមេត្តាករុណាដល់ទាំងពាន់តំណ នៃពួកអ្នកដែលស្រឡាញ់យើង ហើយកាន់តាមបញ្ញត្តិទាំងឡាយ របស់យើង ។

១៥ អ្នកមិនត្រូវចេញព្រះនាមនៃព្រះអម្ចាស់ ជាព្រះរបស់អ្នកជាអសារឥតការឡើយ; ត្បិតព្រះអម្ចាស់ទ្រង់នឹងមិនរាប់ជាឥតទោស ដល់អ្នកណា ដែលចេញព្រះនាមរបស់ទ្រង់ជាអសារឥតការនោះទេ ។

១៦ អ្នកត្រូវនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ។

១៧ ក្នុងរវាងប្រាំមួយថ្ងៃ នោះត្រូវឲ្យអ្នកធ្វើអស់ទាំងការណ៍របស់អ្នកចុះ;

១៨ តែឯថ្ងៃទីប្រាំពីរ នោះគឺជាថ្ងៃឈប់សំរាកថ្វាយព្រះអម្ចាស់ ជាព្រះនៃអ្នកវិញ នោះអ្នកមិនត្រូវធ្វើអ្វីឲ្យសោះ ទោះ

**១៣** ៣ *ក* ម៉ូសាយ ១២:២០–២៤.
៥ *ក* និក្ខ. ៣៤:២៩–៣៥.
៦ *ក* ស.ប. អំណាច.
៧ *ក* ១ នីហ្វៃ ១៦:២.
១០ *ក* ម៉ូសាយ ១៧:១៣–១៩; អាលម៉ា ២៥:១០.
១១ *ក* និក្ខ. ២០:១–១៧.
១៦ *ក* ស.ប. ថ្ងៃឈប់សំរាក.

ខ្លួនអ្នក ឬកូនប្រុសអ្នក ឬកូនស្រីអ្នកក្ដី ទោះបាវប្រុសអ្នក ឬបាវស្រី
អ្នកក្ដី ទោះគោក្របីអ្នក ឬអ្នកដទៃដែលនៅផ្ទះអ្នកក្ដី ។
១៩ ត្បិតក្នុងប្រាំមួយថ្ងៃព្រះអម្ចាស់ទ្រង់បានធ្វើផ្ទៃមេឃ និង
ផែនដី និងសមុទ្រ និងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ;
ហេតុដូច្នោះហើយ បានជាព្រះអម្ចាស់ទ្រង់បានប្រទានពរដល់ថ្ងៃ
ឈប់សំរាក ហើយក៏ញែកថ្ងៃនោះចេញជាបរិសុទ្ធ ។
២០ អ្នកត្រូវគោរពប្រតិបត្តិដល់ឪពុកអ្នក និងម្ដាយអ្នក
ដើម្បីឲ្យអ្នកបានអាយុវែងនៅលើផែនដី ដែលព្រះអម្ចាស់ ជា
ព្រះរបស់អ្នក ទ្រង់បានប្រទានឲ្យអ្នក ។
២១ អ្នកមិនត្រូវសម្លាប់មនុស្សឲ្យសោះ ។
២២ អ្នកមិនត្រូវប្រព្រឹត្តអំពើកំផិតឲ្យសោះ ។ អ្នកមិនត្រូវ
លួចឲ្យសោះ ។
២៣ អ្នកមិនត្រូវធ្វើទីបន្ទាល់ក្លែង ទាស់នឹងអ្នកជិតខាង
របស់ខ្លួនឲ្យសោះ ។
២៤ អ្នកមិនត្រូវលោភចង់បានផ្ទះរបស់អ្នកជិតខាងខ្លួនឲ្យសោះ
អ្នកមិនត្រូវលោភចង់បានប្រពន្ធនៃអ្នកជិតខាងខ្លួន ឬក៏បាវប្រុសគេ
ឬបាវស្រីគេក្ដី ឬគោគេ ឬលាគេ ឬរបស់អ្វីផងអ្នកជិតខាង
ខ្លួនឲ្យសោះ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអ័ប៊ីណាដៃ
បានបញ្ចប់នូវពាក្យទាំងនេះហើយ នោះលោកក៏សួរទៅពួកគេថា៖
តើអ្នករាល់គ្នាដែលបានបង្រៀនប្រជាជនថា ពួកគេត្រូវធ្វើនូវ
ការណ៍អស់ទាំងនេះ ដើម្បីគោរពតាមព្រះបញ្ញត្តិទាំងនេះឬទេ ?
២៦ ខ្ញុំសូមប្រាប់អ្នកថា ទេ; ត្បិតបើសិនជាអ្នករាល់គ្នាធ្លាប់
បានបង្រៀនហើយ នោះព្រះអម្ចាស់ទ្រង់នឹងពុំបានចាត់ខ្ញុំឲ្យមក
ទីនេះ ដើម្បីព្យាករអាក្រក់ ដល់ប្រជាជននេះឡើយ ។
២៧ ហើយឥឡូវនេះ អ្នករាល់គ្នាបាននិយាយថា សេចក្ដី
សង្គ្រោះបានមកដោយសារក្រិត្យវិន័យលោកម៉ូសេ ។ ខ្ញុំសូមប្រាប់
អ្នកថា ជាការចាំបាច់ដែលអ្នករាល់គ្នាត្រូវកាន់តាម
ក្រិត្យវិន័យលោកម៉ូសេក្នុងពេលនេះ; តែខ្ញុំសូមប្រាប់អ្នកថា
ពេលវេលានឹងមកដល់ កាល ដែលនឹងពុំចាំបាច់កាន់
តាមក្រិត្យវិន័យលោកម៉ូសេទៀតឡើយ ។
២៨ ហើយក្រៅពីនេះទៀត ខ្ញុំសូមប្រាប់អ្នកថា សេចក្ដី
សង្គ្រោះពុំមែនបានមក ដោយសារក្រិត្យវិន័យតែប៉ុណ្ណោះទេ;
ហើយបើគ្មាន ដង្វាយធួន ដែលព្រះអង្គទ្រង់ផ្ទាល់នឹងធ្វើឡើង
ជំនួសអំពើបាបទាំងឡាយ និងអំពើទុច្ចរិតទាំងឡាយនៃរាស្ត្រទ្រង់ទេ
នោះពួកគេនឹង ចៀសពុំផុតពីសេចក្ដីវិនាសឡើយ ទោះ
ជាគេមានក្រិត្យវិន័យលោកម៉ូសេក៏ដោយ ។
២៩ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា ជាការចាំបាច់ត្រូវ
តែមានក្រិត្យវិន័យមួយ ឲ្យទៅកូនចៅអ៊ីស្រាអែល មែនហើយ
ជាក្រិត្យ វិន័យដ៏តឹងតែងមួយ; ព្រោះពួកគេជាមនុស្សរឹងក្បាល
រហ័សធ្វើអំពើទុច្ចរិត ហើយកម្រចាំព្រះអម្ចាស់ ជាព្រះរបស់គេ;
៣០ ហេតុដូច្នេះហើយ បានជាមានក្រិត្យវិន័យមួយឲ្យទៅពួក
គេ មែនហើយ ជាក្រិត្យវិន័យនៃពិធីប្រព្រឹត្ត និងពិធីបរិសុទ្ធទាំង
ឡាយ ជាក្រិត្យវិន័យមួយ ដែលគេត្រូវគោរពតាមយ៉ាងតឹងរឹង
ជារៀងរាល់ថ្ងៃ ដើម្បីធ្វើឲ្យគេនឹកចាំដល់ព្រះ និងសព្វកាតព្វកិច្ច
របស់គេចំពោះ ទ្រង់ ។
៣១ ប៉ុន្តែមើលចុះ ខ្ញុំសូមប្រាប់អ្នកថា ការណ៍អស់ទាំងនេះ
គឺជាគំរូអំពីការណ៍ដែលនឹងកើតឡើង ។
៣២ ហើយឥឡូវនេះ តើពួកគេបានយល់ក្រិត្យវិន័យនោះឬទេ ?
ខ្ញុំសូមប្រាប់អ្នកថាទេ ពួកគេពុំយល់អស់ទាំងក្រិត្យវិន័យនោះទេ;
ហើយការណ៍នេះក៏ដោយសារតែភាពរឹងរូសនៃចិត្តរបស់ពួកគេ;
ព្រោះពួកគេមិនយល់ថា គ្មានអ្នកណាមួយអាចបាន
សង្គ្រោះឡើយ លើកលែងតែតាមរយៈសេចក្ដីប្រោសលោះ
នៃព្រះប៉ុណ្ណោះ ។
៣៣ ត្បិតមើលចុះ តើមិនមែនលោកម៉ូសេបានព្យាករប្រាប់
ពួកគេ អំពីការយាងមកនៃព្រះមែស៊ីទេឬអី ហើយថា ព្រះទ្រង់
នឹងប្រោស លោះរាស្ត្រទ្រង់ ? មែនហើយ ហើយសូម្បីតែពួក
ព្យាការីទាំងអស់ដែលបានព្យាករ ចាប់តាំងពីកំណើតលោកិយមក

១៩ *ក* លោកុ. ១:៣១.
២០ *ក* ម៉ាកុស ៧:១០.
២១ *ក* ម៉ាថាយ ៥:២១–២២;
គ. និង ស. ៤២:១៨.
ស.ប. ឃាតកម្ម.
២២ *ក* ស.ប. អំពើកំផិត.
*ខ* ស.ប. លួច, ការលួច.
២៣ *ក* សុភា. ២៤:២៨.
ស.ប. សេចក្ដីកុហក.
២៤ *ក* ស.ប. លោភ.
២៧ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* ៣ នីហ្វៃ ៩:១៩–២០; ១៥:៤–៥.
២៨ *ក* កាឡាទី ២:១៦.
ស.ប. ប្រោសលោះ, បាន
ប្រោសលោះ, សេចក្ដីប្រោសលោះ;
សេចក្ដីសង្គ្រោះ.
*ខ* កាឡាទី ២:២១;
ម៉ូសាយ ៣:១៤–១៥;
អាលម៉ា ២៥:១៥–១៦.
*គ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
២៩ *ក* យ៉ូស្វេ ១:៧–៨.
*ខ* អាលម៉ា ៤៦:៨.
៣០ *ក* និក្ខ. ២០.
*ខ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*គ* យ៉ាកុប ៤:៥.
៣១ *ក* ម៉ូសាយ ១៦:១៤;
អាលម៉ា ២៥:១៥.
ស.ប. ការនិមិត្តរូប.
៣២ *ក* ២ នីហ្វៃ ២៥:២៣–២៥.
៣៣ *ក* ១ នីហ្វៃ ១០:៥; យ៉ាកុប ៤:៤; ៧:១១.

ម្ល៉េះ — តើពួកគេ ពុំបាននិយាយតិចឬច្រើន អំពីការណ៍អស់ទាំងនេះទេឬអី ?

៣៤ តើពួកគេពុំបាននិយាយថា [ក]ព្រះអង្គទ្រង់ផ្ទាល់នឹងយាងចុះមកក្នុងចំណោមកូនចៅមនុស្ស ហើយមានរូបរាងជាមនុស្ស ហើយ ចេញមកលើផ្ទៃផែនដីនេះ ដោយព្រះចេស្ដាដ៏ខ្លាំងក្លាទេឬអី ?

៣៥ មែនហើយ តើពួកគេមិនបាននិយាយដែរថា ទ្រង់នឹងបណ្ដាលឲ្យមាន[ក]ដំណើររស់ឡើងវិញ ដល់មនុស្សស្លាប់ ហើយថាព្រះអង្គទ្រង់ផ្ទាល់នឹងត្រូវគេសង្កត់សង្កិន ហើយធ្វើទុក្ខទេឬអី ?

## ជំពូកទី ១៤

*លោកអេសាយនិយាយប្រៀបដូចជាព្រះមែស៊ី — ការដាក់ខ្លួន និងការរងទុក្ខនៃព្រះមែស៊ីត្រូវបានចែងទុក — ទ្រង់ថ្វាយព្រលឹងទ្រង់ ទុកជាយញ្ញបូជា ដើម្បីលោះបាប ហើយអង្វរជំនួសពួកដែលរំលងច្បាប់ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៥៣ ។ ប្រមាណជាឆ្នាំ ១៤៨ ម.គ.ស. ។*

មែនហើយ តើមិនមែនលោកអេសាយនិយាយថា៖ តើមានអ្នកណាបានជឿដំណឹងដែលយើងប្រាប់ ហើយព្រះពាហុនៃព្រះអម្ចាស់ បានសម្ដែងចេញឲ្យអ្នកណាឃើញ ?

២ ត្បិតទ្រង់បានចំរើនធំឡើងនៅចំពោះព្រះអង្គ ដូចជាបំពង់ទន់ខ្ចី ហើយដូចជាឫសដែលពន្លកចេញ ពីដីហួតហែង; ទ្រង់ឥតមាន ទ្រង់ទ្រាយល្អ ឬសណ្ឋានរុងរឿងទេ; ហើយកាលយើងមើលទ្រង់ នោះក៏គ្មានភាពលំអណា ដែលឲ្យយើងរីករាយចិត្តដែរ ។

៣ ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល; ទ្រង់ជាមនុស្សទូទុក្ខ ហើយក៏ធ្លាប់ស្គាល់សេចក្ដីឈឺចាប់; ហើយយើង រាល់គ្នាគេចមុខចេញពីទ្រង់; ទ្រង់ត្រូវគេមើលងាយ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ ។

៤ ទ្រង់បានទ្រាំទ្រ [ក]រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្ដីទុក្ខព្រួយរបស់យើងជាពិត; ប៉ុន្តែ យើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា ។

៥ តែទ្រង់ត្រូវរបួស ដោយព្រោះ[ក]អំពើរំលងទាំងឡាយរបស់យើង ទ្រង់ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតទាំងឡាយរបស់ យើងទេ; ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់; ហើយយើងរាល់គ្នាបាន[ខ]ប្រោសឲ្យជា ដោយសារ ស្នាមរំពាត់នៅអង្គទ្រង់ ។

៦ យើងទាំងអស់គ្នាបានទាសចេញដូចជា[ក]ចៀម; គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន; ហើយព្រះអម្ចាស់ទ្រង់បានទម្លាក់ អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់ ។

៧ ទ្រង់ត្រូវគេសង្កត់សង្កិន ហើយទ្រង់ត្រូវ[ខ]គេធ្វើទុក្ខ [ក]តែទ្រង់មិនបានហើបព្រះឱស្ឋសោះ; គឺទ្រង់ដូចជាកូនចៀម ដែលគេដឹកទៅ សម្លាប់ ហើយដូចជាចៀម ដែលគនៅចំពោះពួកអ្នកកាត់រោមយ៉ាងណា ទ្រង់ក៏មិនបានហើបព្រះឱស្ឋសោះយ៉ាងនោះដែរ ។

៨ ទ្រង់ត្រូវគេដកចេញពីទីឃុំឃាំង ហើយពីសេចក្ដីយុត្តិធម៌; តើអ្នកណានឹងប្រកាសប្រាប់សម័យជំនាន់ទ្រង់ ? ត្បិតទ្រង់បានត្រូវកាត់ ចេញពីស្ថានរបស់មនុស្សរស់; ហើយទ្រង់ត្រូវគេវាយដោយព្រោះអំពើរំលងទាំងឡាយរបស់ប្រជាជនខ្ញុំនោះ ។

៩ ហើយក្នុងកាលដែលទ្រង់សុគត នោះគេក៏បញ្ចុះស[ក]ពទ្រង់នៅជាមួយនឹងពួកអាក្រក់ និងពួកអ្នកមាន; ព្រោះទ្រង់ពុំដែលបានធ្វើ[ខ]អា ក្រក់ ក៏មិនដែលមានការបញ្ឆោតនៅក្នុងព្រះឱស្ឋទ្រង់ផងឡើយ ។

១០ ទោះបើយ៉ាងនោះ គង់តែព្រះអម្ចាស់ទ្រង់បានសព្វព្រះហឫទ័យ នឹងវាយទ្រង់ឲ្យជាំ ហើយឲ្យឈឺចាប់; កាលណាព្រះជន្មទ្រង់បាន ត្រូវ[ក]ថ្វាយទុកជាយញ្ញបូជាលោះបាបហើយ នោះទ្រង់នឹងបានឃើញពូជរបស់ទ្រង់ ហើយនឹងចំរើនព្រះជន្មទ្រង់ឲ្យយឺនយូរ ឯបំណង ព្រះហឫទ័យនៃព្រះអម្ចាស់ នោះនឹងជឿនឡើងដោយព្រះហស្តទ្រង់ ។

១១ ទ្រង់នឹងឃើញការឈឺចាប់នៃព្រលឹងទ្រង់ ហើយនឹងបានស្កប់ស្កល់; អ្នកបំរើដ៏សុចរិតរបស់យើង នឹងរាប់មនុស្ស

---

៣៤ *ក* ម៉ូសាយ ៧:២៧; ១៥:១–៣.
ស.ប. ព្រះ, ក្រុមព្រះ.
៣៥ *ក* អេសាយ ២៦:១៩; ២ នីហ្វៃ ២:៨.
**១៤** ៤*ក* អាលម៉ា ៧:១១–១២.
*ខ* ម៉ាថាយ ៨:១៧.
៥ *ក* ម៉ូសាយ ១៥:៩; អាលម៉ា ១១:៤០.
*ខ* ១ ពេត្រុស ២:២៤–២៥.
៦ *ក* ម៉ាថាយ ៩:៣៦;
២ នីហ្វៃ ២៨:១៤;
អាលម៉ា ៥:៣៧.
៧ *ក* ម៉ាកុស ១៥:៣.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. កូនចៀមនៃព្រះ; បុណ្យរំលង.
៩ *ក* ម៉ាថាយ ២៧:៥៧–៦០;
ម៉ាកុស ១៥:២៧, ៤៣–៤៦.
ស.ប. យ៉ូសែប ពីភូមិអើរីម៉ាថេ.
*ខ* យ៉ូហាន ១៩:៤.
១០ *ក* ម៉ូសាយ ១៥:១០–១៣.

ជាច្រើនថា សុចរិត ដោយគេស្គាល់ដល់ទ្រង់; ត្បិតទ្រង់នឹង
[ក]ទទួលរងទោស ចំពោះអំពើទុច្ចរិតទាំងឡាយរបស់គេ ។
១២ ហេតុដូច្នេះហើយ យើងនឹងឲ្យទ្រង់មានចំណែកជាមួយ
នឹងពួកអ្នកធំ ហើយទ្រង់នឹងចែករបឹបជាមួយនឹងពួកអ្នកដ៏ខ្លាំង
ពូកែ ពីព្រោះទ្រង់បានច្រួចព្រលឹងចេញ រហូតដល់ស្លាប់;
ហើយគេបានរាប់ទ្រង់ជាអ្នកទទឹងច្បាប់; ហើយទ្រង់បានទទួល
រងទោស នៃអំពើបាបរបស់មនុស្សជាច្រើន ហើយបាន
[ក]អង្វរជំនួសមនុស្សដែលទទឹងច្បាប់វិញ ៕

## ជំពូកទី ១៥

*ពីរបៀបដែលព្រះគ្រីស្ទជាព្រះវរបិតា និងជាព្រះរាជបុត្រា — ទ្រង់នឹងជួយអង្វរ ហើយទទួលរងទោសនៃអំពើរំលងទាំងឡាយនៃរាស្ត្រទ្រង់ — ពួកគេ និងអស់ទាំងពួកព្យាការីដ៏បរិសុទ្ធ គឺជាពូជរបស់ទ្រង់ — ទ្រង់នឹងនាំមកនូវដំណើររស់ឡើងវិញ — កូនក្មេងតូចៗមានជីវិតដ៏នៅអស់កល្បជានិច្ច ។ ប្រមាណជាឆ្នាំ ១៤៨ ម.គ.ស. ។*

ហើយឥឡូវនេះ អ័ប៊ីណាដៃបាននិយាយទៅកាន់ពួកគេថាៈ
ខ្ញុំចង់ឲ្យអ្នករាល់គ្នាយល់ថា [ក]ព្រះអង្គទ្រង់[ខ]ផ្ទាល់នឹងយាងចុះមកក្នុង
ចំណោមកូនចៅមនុស្ស ហើយទ្រង់នឹងប្រោសលោះរាស្ត្រទ្រង់។
២ ហើយពីព្រោះទ្រង់[ក]គង់នៅក្នុងសាច់ឈាម នោះទ្រង់នឹង
ត្រូវឲ្យព្រះនាមថា ជាព្រះរាជបុត្រានៃព្រះ ហើយដោយចាត់
សាច់ ឈាមទុកនៅក្រោមព្រះហឫទ័យនៃ[ខ]ព្រះវរបិតា នោះ
គឺជាព្រះវរបិតា ហើយជាព្រះរាជបុត្រា —
៣ ជាព្រះវរបិតា [ក]ពីព្រោះទ្រង់[ខ]ចាប់កំណើតដោយព្រះចេស្ដានៃ
ព្រះ; ហើយជាព្រះរាជបុត្រា ដោយមកពីសាច់ឈាម;
ម្ល៉ោះហើយ ទើបក្លាយទៅជាព្រះវរបិតា ហើយជាព្រះរាជ
បុត្រាដែរ —
៤ ហើយទាំងពីរ គឺជាព្រះ[ក]តែមួយ មែនហើយ [ខ]គឺព្រះវរបិតា
[គ]ដ៏នៅអស់កល្បជានិច្ច នៃផ្ទៃមេឃ និងផែនដី ។
៥ ម្ល៉ោះហើយ សាច់ឈាមនឹងនៅក្រោមអំណាចនៃ
ព្រះវិញ្ញាណ ឬព្រះរាជបុត្រានៅក្រោមអំណាចព្រះវរបិតា
ជាព្រះតែមួយ ទ្រង់[ក]ទ្រាំទ្រការល្បួង ហើយពុំចុះចាញ់ការ
ល្បួងឡើយ តែទ្រង់ស៊ូទ្រាំឲ្យរាស្ត្រទ្រង់[ខ]ចំអកឡកឡឺយ និងវាយ
ហើយបណ្ដេញចេញ ព្រមទាំង[គ]មិនទទួលស្គាល់ទៀត ។
៦ ហើយបន្ទាប់ពីការណ៍អស់ទាំងនេះ បន្ទាប់ពីបានសម្ដែង
អព្ភូតហេតុដ៏អស្ចារ្យជាច្រើន នៅក្នុងចំណោមកូនចៅមនុស្ស
នោះទ្រង់ នឹងត្រូវដឹក មែនហើយ [ក]ដូចជាលោកអេសាយបាន
និយាយថា ដូចជាចៀម ដែលគនៅខាងមុខអ្នកកាត់រោម
ដោយ[ខ]ពុំហើបមាត់ឡើយ ។
៧ មែនហើយ ទោះជាយ៉ាងនេះក៏ដោយ គង់តែទ្រង់ត្រូវគេដឹក
ត្រូវគេ[ក]ឆ្កាង ហើយត្រូវគេ[ខ]ធ្វើគត ឯសាច់ឈាមត្រូវនៅក្រោម
អំណាចនៃសេចក្ដីស្លាប់ គឺព្រះហឫទ័យនៃព្រះរាជបុត្រា ត្រូវ
លេបដណ្ដប់នៅក្នុងព្រះហឫទ័យនៃព្រះវរបិតា ។
៨ ម្ល៉ោះហើយ [ខ]ព្រះទ្រង់បានផ្ដាច់[ក]ចំណងទាំងឡាយនៃសេចក្ដី
ស្លាប់ ដោយបានឈ្នះលើសេចក្ដីស្លាប់; ដោយបានប្រទាន
ព្រះចេស្ដា ដល់ព្រះរាជបុត្រា សំរាប់[គ]អង្វរជំនួសកូនចៅ
មនុស្ស —

១១ *ក* លេវី. ១៦:២១–២២;
១ ពេត្រុស ៣:១៨;
គ. និង ស. ១៩:១៦–១៩.
១២ *ក* ២ នីហ្វៃ ២:៩; ម៉ូសាយ ១៥:៨;
មរ៉ូណៃ ៧:២៧–២៨.
**១៥** ១*ក* ១ ធីម៉ូ. ៣:១៦;
ម៉ូសាយ ១៣:៣៣–៣៤.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. ប្រោសលោះ, បាន
ប្រោសលោះ, សេចក្ដីប្រោសលោះ.
២ *ក* ម៉ូសាយ ៣:៥; ៧:២៧;
អាលម៉ា ៧:៩–១៣.
*ខ* អេសាយ ៦៤:៨;
យ៉ូហាន ១០:៣០; ១៤:៨–១០;
ម៉ូសាយ ៥:៧;
អាលម៉ា ១១:៣៨–៣៩;
អេធើរ ៣:១៤.
៣ *ក* គ. និង ស. ៩៣:៤.
*ខ* លូកា ១:៣១–៣៣;
ម៉ូសាយ ៣:៨–៩;
អាលម៉ា ៧:១០;
៣ នីហ្វៃ ១:១៤.
៤ *ក* ចោទិ. ៦:៤;
យ៉ូហាន ១៧:២០–២៣.
ស.ប. ព្រះ, ក្រុមព្រះ.
*ខ* អាលម៉ា ១១:៣៩.
*គ* ម៉ូសាយ ៣:៨; ហេលេ. ១៤:១២;
៣ នីហ្វៃ ៩:១៥; អេធើរ ៤:៧.
៥ *ក* លូកា ៤:២;
ហេព្រើរ ៤:១៤–១៥.
*ខ* យ៉ូហាន ១៩:១.
*គ* ម៉ាកុស ៨:៣១; លូកា ១៧:២៥.
៦ *ក* អេសាយ ៥៣:៧.
*ខ* លូកា ២៣:៩; យ៉ូហាន ១៩:៩;
ម៉ូសាយ ១៤:៧.
៧ *ក* ស.ប. ការឆ្កាង.
*ខ* លូកា ២២:៤២; យ៉ូហាន ៦:៣៨;
៣ នីហ្វៃ ១១:១១.
៨ *ក* ម៉ូសាយ ១៦:៧; អាលម៉ា ២២:១៤.
*ខ* ហូសេ ១៣:១៤;
១ កូរិន. ១៥:៥៥–៥៧.
*គ* ២ នីហ្វៃ ២:៩.

៩ ដោយបានយាងឡើងទៅស្ថានសួគ៌ ដោយមានចិត្ត
ក្តួលមេត្តា; ពោរពេញទៅដោយចិត្តប្រោសប្រណីដល់កូនចៅ
មនុស្ស; ឈរ នៅចន្លោះពួកគេនឹងសេចក្តីយុត្តិធម៌; ដោយបាន
ផ្តាច់ចំណងទាំងឡាយនៃសេចក្តីស្លាប់ បានទទួលមកលើអង្គ
ទ្រង់នូវអំពើទុច្ចរិតរបស់គេ និងអំពើរំលងទាំងឡាយរបស់គេ
បានប្រោសលោះពួកគេ ហើយបានបំពេញការទាមទារទាំង
ឡាយនៃសេចក្តីយុត្តិធម៌ ។
១០ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា តើអ្នកណានឹង
ប្រកាសប្រាប់សម័យជំនាន់ទ្រង់ ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា
កាលព្រលឹង ទ្រង់ត្រូវបានយកទៅថ្វាយដោយញ្ញបូជាជំនួសអំពើ
បាប នោះទ្រង់នឹងទតឃើញពូជទ្រង់ហើយ ។ ហើយឥឡូវនេះ
តើអ្នករាល់គ្នាថាដូច ម្តេច ? ហើយតើអ្នកណានឹងបានទៅជា
ពូជទ្រង់ ?
១១ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា អស់អ្នកណាដែលបាន
ស្តាប់តាមពាក្យសំដីនៃពួកព្យាការី មែនហើយ គឺអស់ទាំងពួក
ព្យាការី ដ៏បរិសុទ្ធ ដែលបានព្យាករអំពីការយាងមកនៃព្រះ
អម្ចាស់ — ខ្ញុំសូមប្រាប់អ្នកថា អស់អ្នកណាដែលបានប្រុង
ស្តាប់តាមពាក្យសំដីរបស់ ពួកគេ ហើយជឿថា ព្រះអម្ចាស់
ទ្រង់នឹងប្រោសលោះរាស្ត្រទ្រង់ ហើយទន្ទឹងចាំថ្ងៃនោះ ដែល
នឹងផ្តាច់បាបទាំងឡាយរបស់គេ ខ្ញុំសូម ប្រាប់អ្នកថា អ្នក
ទាំងនេះហើយជាពូជរបស់ទ្រង់ ឬពួកគេជាអ្នកគ្រងនគរនៃ
ព្រះទុកជាមរតក ។
១២ ត្បិតពួកគេទាំងនេះហើយដែលទ្រង់បានទទួលរងទោស
នៃអំពើបាបទាំងឡាយរបស់គេ; ពួកគេនេះហើយដែលទ្រង់
បានសុគត ជំនួស ដើម្បីប្រោសលោះគេឲ្យរួចផុតពីអំពើរំលង
ទាំងឡាយរបស់គេ ។ ហើយឥឡូវនេះ តើពួកគេពុំមែនជាពូជ
របស់ទ្រង់ទេឬអី ?
១៣ មែនហើយ តើពុំមែនពួកព្យាការីគ្រប់រូប បានបើកមាត់
ព្យាករ ដែលពុំទាន់ធ្លាក់ទៅក្នុងអំពើរំលង គឺខ្ញុំនិយាយអំពីអស់
ទាំង ពួកព្យាការីដ៏បរិសុទ្ធ ចាប់តាំងពីកំណើតលោកិយនោះឬ?
ខ្ញុំសូមប្រាប់អ្នកថា ពួកគេជាពូជរបស់ទ្រង់ហើយ ។
១៤ ហើយពួកគេនេះហើយដែលបានផ្សាយសេចក្តីសុខសាន្ត
ជាអ្នកដែលបាននាំដំណឹងល្អនៃការល្អ ជាអ្នកដែលបានផ្សាយ
សេចក្តី សង្គ្រោះ; ហើយបាននិយាយទៅក្រុងស៊ីយ៉ូនថា៖ ព្រះ
របស់អ្នក ទ្រង់សោយរាជ្យហើយ!
១៥ ហើយ ឱល្អណាស់ហ្ន៎ គឺជើងនៃពួកគេដែលដើរលើភ្នំ!
១៦ ហើយមួយទៀត ល្អណាស់ហ្ន៎ គឺជើងនៃពួកអ្នកដែល
ដើរលើភ្នំ ជាអ្នកដែលនៅតែផ្សាយសេចក្តីសុខសាន្ត!
១៧ ហើយមួយទៀត ល្អណាស់ហ្ន៎ គឺជើងនៃពួកអ្នកដែល
ដើរលើភ្នំ ជាអ្នកដែលនឹងផ្សាយសេចក្តីសុខសាន្តពីថ្ងៃនេះ
តទៅ មែនហើយ ចាប់ពីពេលនេះទៅមុខ ហើយដរាបតទៅ!
១៨ ហើយមើលចុះ ខ្ញុំសូមប្រាប់អ្នកថា នេះពុំទាន់អស់ទេ ។
ត្បិតឱល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះ ដែលដើរលើភ្នំ ជាអ្នក
ដែលនាំ ដំណឹងល្អមក នោះគឺម្ចាស់នៃសេចក្តីសុខសាន្ត មែន
ហើយ គឺជាព្រះអម្ចាស់ដែលបានប្រោសលោះរាស្ត្រទ្រង់; មែន
ហើយ ទ្រង់បាន ប្រទានសេចក្តីសង្គ្រោះដល់រាស្ត្រទ្រង់ហើយ;
១៩ ព្រោះបើពុំដោយសារសេចក្តីប្រោសលោះ ដែលទ្រង់
បានធ្វើដើម្បីរាស្ត្រទ្រង់ ដែលបានរៀបចំឡើង ចាប់តាំង
ពីកំណើត លោកិយមកទេ នោះខ្ញុំសូមប្រាប់អ្នកថា បើពុំដោយ
សារការណ៍នោះទេ នោះមនុស្សលោកទាំងអស់ ច្បាស់ជា
ត្រូវវិនាសអស់ហើយ ។
២០ ប៉ុន្តែមើលចុះ ចំណងទាំងឡាយនៃសេចក្តីស្លាប់នឹងត្រូវដាច់
ហើយព្រះរាជបុត្រានឹងសោយរាជ្យ ហើយមានព្រះចេស្តាទៅលើ
អ្នកស្លាប់; ហេតុដូច្នេះហើយ ទ្រង់នាំឲ្យមានដំណើររស់ឡើងវិញ
ដល់មនុស្សស្លាប់បាន ។
២១ ហើយដំណើររស់ឡើងវិញនឹងកើតឡើង ជាដំណើរ
រស់ឡើងវិញទីមួយ; មែនហើយ គឺជាដំណើររស់ឡើងវិញ នៃ
ពួកដែល ធ្លាប់រស់នៅ និងពួកដែលកំពុងរស់នៅ និងពួកដែល
នឹងរស់នៅ រហូតដល់ដំណើររស់ឡើងវិញនៃព្រះគ្រីស្ទ —
ព្រោះទ្រង់នឹងត្រូវឲ្យ ព្រះនាមថាដូច្នោះ ។
២២ ហើយឥឡូវនេះ ដំណើររស់ឡើងវិញនៃអស់ទាំងពួក
ព្យាការី និងអស់អ្នកណាដែលបានជឿតាមពាក្យសំដីរបស់គេ

៩ ក អេសាយ ៥៣;
ម៉ូសាយ ១៤:៥–១២.
ខ ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
១០ ក អេសាយ ៥៣:១០; ម៉ូសាយ ៥:៧;
២៧:២៥; ម៉រ៉ូណៃ ៧:១៩.
១១ ក គ. និង ស. ៨៤:៣៦–៣៨.
ខ ស.ប. នគរព្រះ ឬ នគរស្ថានសួគ៌;
សេចក្តីសង្គ្រោះ.
១២ ក ម៉ូសាយ ១៤:១២;
អាលម៉ា ៧:១៣; ១១:៤០–៤១.
១៤ ក អេសាយ ៥២:៧; រ៉ូម ១០:១៥;
១ នីហ្វៃ ១៣:៣៧;
ម៉ូសាយ ១២:២១–២៤.
ស.ប. កិច្ចការផ្សាយសាសនា.
១៨ ក ៣ នីហ្វៃ ២០:៤០;
គ. និង ស. ១២៨:១៩.
ខ យ៉ូហាន ១៦:៣៣.
ស.ប. សេចក្តីសុខសាន្ត.
១៩ ក ម៉ូសាយ ៤:៦.
ខ ២ នីហ្វៃ ៩:៦–១៣.
២១ ក អាលម៉ា ៤០:១៦–២១.

ឬអស់អ្នក ណាដែលបានកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ
នឹងរស់ឡើងវិញ នៅក្នុងដំណើររស់ឡើងវិញទីមួយ; ហេតុ
ដូច្នេះហើយ ពួកគេជា ដំណើររស់ឡើងវិញទីមួយ ។
២៣ ពួកគេត្រូវបានប្រោសឲ្យរស់ឡើង ដើម្បីរស់នៅជាមួយ
នឹងព្រះ ដែលបានប្រោសលោះពួកគេ; ម្ល៉ោះហើយ ពួកគេមាន
ជីវិត ដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះគ្រីស្ទ ជាព្រះដែល
បានផ្តាច់ចំណងទាំងឡាយនៃសេចក្តីស្លាប់ ។
២៤ ហើយពួកគេនេះហើយដែលមានចំណែក នៅក្នុង
ដំណើររស់ឡើងវិញទីមួយ; ហើយពួកគេនេះហើយដែលបាន
ស្លាប់ មុនពេល ដែលព្រះគ្រីស្ទទ្រង់យាងមក គឺស្លាប់នៅក្នុង
ការល្ងិតល្ងង់ ដោយគ្មានអ្នកណាប្រកាសប្រាប់អំពីសេចក្តី
សង្គ្រោះដល់គេឡើយ ។ ម្ល៉ោះហើយ បានជាព្រះអម្ចាស់ទ្រង់
សាងពួកគេឡើងវិញ; ហើយពួកគេមានចំណែក នៅក្នុង
ដំណើររស់ឡើងវិញទីមួយ ឬក៏មានជីវិត ដ៏នៅអស់កល្បជានិច្ច
ដែលបានប្រោសលោះដោយព្រះអម្ចាស់ ។
២៥ ហើយកូនក្មេងតូចៗ ក៏មានជីវិតដ៏នៅអស់កល្បជានិច្ចដែរ ។
២៦ ប៉ុន្តែមើលចុះ ហើយចូរខ្លាច និងញ័រនៅចំពោះព្រះចុះ
ត្បិតអ្នករាល់គ្នាគួរតែញ័រ; ព្រោះព្រះអម្ចាស់ ទ្រង់ពុំប្រោសលោះ
អ្នកណា មួយ ដែលបះបោរទាស់នឹងទ្រង់ ហើយស្លាប់ក្នុងអំពើ
បាបទាំងឡាយរបស់ខ្លួនឡើយ; មែនហើយ គឺអស់ទាំងអ្នកណា
ដែលបានវិនាស ក្នុងអំពើបាបទាំងឡាយរបស់ខ្លួន ចាប់តាំង
ពីកំណើតលោកិយមក គឺដែលបានបះបោរដោយចេតនាទាស់
នឹងព្រះ ដែលបានដឹងនូវ ព្រះបញ្ញត្តិទាំងឡាយនៃព្រះ តែពុំកាន់
តាមបញ្ញត្តិទាំងនោះសោះ; ពួកគេនេះហើយដែលនឹងគ្មាន
ចំណែក នៅក្នុងដំណើររស់ឡើងវិញ ទីមួយទេ ។
២៧ ហេតុដូច្នេះហើយ តើអ្នកមិនគួរញ័រទេឬ? ព្រោះសេចក្តី
សង្គ្រោះ ពុំមកដល់ជនប្រភេទនេះឡើយ; ត្បិតព្រះអម្ចាស់ទ្រង់នឹង
ពុំប្រោសលោះជនប្រភេទនេះទេ; មែនហើយ ព្រះអម្ចាស់ទ្រង់ក៏នឹង
ពុំអាចប្រោសលោះជនបែបនេះបានដែរ; ត្បិតទ្រង់ពុំអាចបដិសេធ
អង្គទ្រង់ឡើយ; ព្រោះទ្រង់ពុំអាចបដិសេធសេចក្តីយុត្តិធម៌ កាលវា
ទាមទារសេចក្តីយុត្តិធម៌វានោះ ។
២៨ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា ពេលនឹងមក
ដល់កាលសេចក្តីសង្គ្រោះនៃព្រះអម្ចាស់ នឹងត្រូវបានប្រកាស
ប្រាប់ដល់គ្រប់ទាំង សាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និង
គ្រប់ទាំងប្រជាជន ។
២៩ មែនហើយ ឱព្រះអម្ចាស់អើយ ពួកអ្នកយាមរបស់ទ្រង់
នឹងបន្លឺសម្លេងគេឡើង; គេនឹងបន្លឺសម្លេងច្រៀងព្រមគ្នា; ត្បិតគេនឹង
ឃើញដោយភ្នែករបស់ខ្លួនគេ ក្នុងកាលដែលព្រះអម្ចាស់ទ្រង់
ប្រគល់ក្រុងស៊ីយ៉ូនមកវិញ ។
៣០ អស់ទាំងជីឯកការនៃក្រុងយេរូសាឡិមអើយ ចូរបន្លឺសេចក្តី
អំណរ ចូរច្រៀងជាមួយគ្នាចុះ; ត្បិតព្រះអម្ចាស់ទ្រង់បានកំសាន្តទុក្ខ
របស់រាស្ត្រទ្រង់ ក៏បានប្រោសលោះក្រុងយេរូសាឡិមហើយ ។
៣១ ព្រះអម្ចាស់ទ្រង់បានលាតព្រះពាហុបរិសុទ្ធរបស់ទ្រង់
នៅភ្នែកនៃគ្រប់ទាំងសាសន៍; ហើយអស់ទាំងចុងផែនដី នឹងបាន
ឃើញ សេចក្តីសង្គ្រោះនៃព្រះរបស់យើងរាល់គ្នា ៕

## ជំពូកទី ១៦

*ព្រះទ្រង់ប្រោសលោះមនុស្សពីស្ថានភាពវង្វេង និងធ្លាក់ — អស់អ្នកណាដែលប្រកបដោយរូបកាយ នឹងទុកដូចជាគ្មានការប្រោសលោះ ឡើយ — ព្រះគ្រីស្ទនឹងនាំឲ្យមានដំណើររស់ឡើងវិញ ដល់ជីវិតដ៏មិនចេះចប់មិនចេះហើយ ឬដល់ការដាក់ទោសដ៏មិនចេះចប់មិនចេះ ហើយ ។ ប្រមាណជាឆ្នាំ ១៤៨ ម.គ.ស.។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអ័ប៊ីណាដៃ
បាននិយាយពាក្យទាំងនេះហើយ នោះលោកបានលាដៃលោក
ហើយនិយាយថាៈ ពេលនឹងមកដល់ កាលគ្រប់ទាំងអស់គ្នា
នឹងឃើញសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ គឺជាពេលដែល
គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំង
ប្រជាជន នឹងឃើញដោយភ្នែកគេផ្ទាល់ ហើយទទួល
ស្គាល់នៅចំពោះព្រះថា សេចក្តីជំនុំជំរះ របស់ទ្រង់ គឺត្រឹមត្រូវ ។
២ ហើយពេលនោះ ពួកទុច្ចរិតនឹងត្រូវបណ្តេញចេញ ហើយ

២៣ *ក* ទំនុក. ២៤:៣–៤;
១ នីហ្វៃ ១៥:៣៣–៣៦;
គ. និង ស. ៧៦:៥០–៧០.
*ខ* ស.ប. សេចក្តីស្លាប់ខាងសាច់ឈាម.
២៤ *ក* ២ នីហ្វៃ ៩:២៥–២៦;
គ. និង ស. ១៣៧:៧.
២៥ *ក* គ. និង ស. ២៩:៤៦; ១៣៧:១០.
ស.ប. សេចក្តីសង្គ្រោះ — សេចក្តីសង្គ្រោះដល់កូនក្មេង.
២៦ *ក* ចោទិ. ៥:២៩; យ៉ាកុប ៦:៩.
*ខ* ១ នីហ្វៃ ២:២១–២៤.
*គ* អេសេ. ១៨:២៦;
១ នីហ្វៃ ១៥:៣២–៣៣;
ម៉ូរ៉ូណៃ ១០:២៦.
*ឃ* អាលម៉ា ៤០:១៩.
*ង* គ. និង ស. ៧៦:៨១–៨៦.
២៧ *ក* អាលម៉ា ៣៤:១៥–១៦; ៤២:១.
២៨ *ក* ស.ប. កិច្ចការផ្សាយសាសនា.
២៩ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
**១៦** ១*ក* ស.ប. សេចក្តីសង្គ្រោះ.
*ខ* ម៉ូសាយ ២៧:៣១.
២ *ក* គ. និង ស. ៦៣:៥៣–៥៤.

ពួកគេនឹងមានហេតុ ដើម្បីស្រែកថ្ងូរ និងយំ និងទូរហោ
និងសង្កៀត ធ្មេញគេ; ហើយនេះគឺមកពីពួកគេពុំប្រុង
ស្ដាប់តាមសម្លេងនៃព្រះអម្ចាស់; ហេតុដូច្នេះហើយ ព្រះ
អម្ចាស់ទ្រង់នឹងពុំប្រោសលោះពួកគេ ឡើយ ។
៣ ព្រោះពួកគេប្រកបដោយស្ថានភាពខាងរូបកាយ និងខាង
អារក្ស ហើយអារក្សមានអំណាចទៅលើពួកគេ; មែនហើយ
គឺជាពស់ពីបុរាណនោះ ដែលបានបញ្ឆោតឪពុកម្ដាយដើម
របស់យើង គឺជាហេតុនៃការធ្លាក់របស់គេ; គឺជាហេតុដែល
ធ្វើឲ្យមនុស្ស លោកទាំងអស់ ក្លាយទៅខាងរូបកាយ ខាង
កាមរោគ ខាងអារក្ស ស្គាល់ខុស និងត្រូវ ដោយ
ដាក់ខ្លួននៅក្រោមអំណាចអារក្ស ។
៤ ម្ល៉ោះហើយ បានជាមនុស្សលោកទាំងអស់ត្រូវវង្វេង;
ហើយមើលចុះ ពួកគេច្បាស់ជាវង្វេងរហូតតទៅ ប្រសិនបើ
ព្រះទ្រង់ពុំបាន ប្រោសលោះរាស្ត្រទ្រង់ ឲ្យផុតពីស្ថានភាពវង្វេង
និងធ្លាក់នោះទេ ។
៥ ប៉ុន្តែចូរចាំថា អ្នកណាដែលស្ថិតនៅក្នុងស្ថានភាពខាង
រូបកាយរបស់ខ្លួន ហើយនៅតែធ្វើអំពើបាប ហើយបះបោរទាស់នឹង
ព្រះ អ្នកនោះនឹងស្ថិតនៅក្នុងស្ថានភាពធ្លាក់តទៅទៀត ហើយ
អារក្សនឹងមានអំណាចទាំងស្រុងទៅលើគេ ។ ហេតុដូច្នេះហើយ
អ្នកនោះ ហាក់បីដូចជាគ្មានការប្រោសលោះឡើយ ព្រោះគេ
ជាខ្មាំងសត្រូវដល់ព្រះ; ឯអារក្សក៏ជាខ្មាំងសត្រូវដល់ព្រះដែរ ។
៦ ហើយឥឡូវនេះ បើសិនជាព្រះគ្រីស្ទពុំបានយាងមក
ឯលោកិយទេ គឺនិយាយអំពីការណ៍ដែលនឹងកើតឡើង
នៅពេលខាងមុខ ទុកដូចជាបានកើតឡើងហើយ នោះនឹងគ្មាន
ការប្រោសលោះឡើយ ។
៧ ហើយបើសិនជាព្រះគ្រីស្ទពុំបានមានព្រះជន្ម
រស់ពីស្លាប់ឡើងវិញទេ ឬពុំបានផ្ដាច់ចំណងទាំងឡាយនៃសេចក្ដី
ស្លាប់ ដើម្បីកុំឲ្យ ផ្នូរមានជ័យជំនះលើ ហើយកុំឲ្យសេចក្ដីស្លាប់
មានទ្រនិចទេ នោះក៏ពុំអាចមានដំណើររស់ឡើងវិញដែរ ។
៨ ប៉ុន្តែមានដំណើររស់ឡើងវិញ ហេតុដូច្នេះហើយ ផ្នូរគ្មាន
ជ័យជំនះលើឡើយ ហើយទ្រនិចនៃសេចក្ដីស្លាប់ ត្រូវបានលេប
បាត់នៅ ក្នុងព្រះគ្រីស្ទ ។
៩ ទ្រង់ជាពន្លឺ ហើយជាជីវិតនៃពិភពលោក; មែនហើយ ជា
ពន្លឺមួយដែលមិនចេះចប់មិនចេះហើយ ដែលពុំអាចធ្វើឲ្យងងឹត
បាន ឡើយ; មែនហើយ ហើយក៏ជាជីវិតមួយដែល
មិនចេះចប់មិនចេះហើយ គឺពុំអាចមានសេចក្ដីស្លាប់ទៀតឡើយ ។
១០ គឺរូបកាយដែលរមែងស្លាប់នេះក៏នឹងត្រូវបានប្រដាប់ដោយ
អមតភាពវិញ ហើយរូបកាយដ៏ពុករលួយនេះ នឹងត្រូវបាន
ប្រដាប់ ដោយភាពមិនពុករលួយវិញ ហើយនឹងត្រូវបាននាំទៅ
ឈរនៅចំពោះវេទិកានៃព្រះ ដើម្បីទទួលការជំនុំជំរះពីទ្រង់
ស្របតាមកិច្ចការ ទាំងឡាយរបស់ខ្លួន ដើម្បីឲ្យឃើញថា
ពួកគេល្អ ឬក៏ពួកគេអាក្រក់ —
១១ បើសិនជាពួកគេល្អ នោះនឹងបានដំណើររស់ឡើងវិញនៃជីវិត
និងសុភមង្គលដ៏មិនចេះចប់មិនចេះហើយ ហើយបើសិនជាពួក
គេ អាក្រក់វិញ នោះនឹងបានដំណើររស់ឡើងវិញនៃការផាប់ទោស
ដ៏មិនចេះចប់មិនចេះហើយ ត្រូវប្រគល់ឲ្យទៅអារក្ស ដែលមាន
អំណាច មកលើគេ គឺជាការផាប់ទោស —
១២ ដោយបានធ្វើតាមចំណង់ និងការប៉ងប្រាថ្នាខាង
រូបកាយរបស់គេផ្ទាល់; ដោយពុំដែលអំពាវនាវដល់ព្រះអម្ចាស់
នៅពេល ដែលព្រះពាហុដ៏ប្រកបដោយសេចក្ដីមេត្តាករុណា
លូកមករកគេ; ត្បិតព្រះពាហុដ៏ប្រកបដោយសេចក្ដីមេត្តាករុណា
បានលូកមករកគេ តែគេពុំចង់បានឡើយ; ពួកគេត្រូវបានព្រមាន

២ *ខ* ម៉ាថាយ ១៣:៤១–៤២;
លូកា ១៣:២៨; អាលម៉ា ៤០:១៣.
៣ *ក* កាឡាទី ៥:១៦–២៥;
ម៉ូសាយ ៣:១៩.
ស.ប. មនុស្សខាងសាច់ឈាម.
*ខ* ២ នីហ្វៃ ៩:៨–៩.
ស.ប. អារក្ស.
*គ* លោកុ. ៣:១–១៣;
ម៉ូសេ ៤:៥–១៩.
*ឃ* ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*ង* ២ នីហ្វៃ ២:១៧–១៨, ២២–២៦.
៤ *ក* អាលម៉ា ៤២:៦–១៤.
៥ *ក* អាលម៉ា ៤១:១១.
ស.ប. ខាងរូបកាយ.
*ខ* ស.ប. ប្រោសលោះ, បាន
ប្រោសលោះ, សេចក្ដីប្រោសលោះ.
៦ *ក* ម៉ូសាយ ៣:១៣.
៧ *ក* ហូសេ ១៣:១៤;
ម៉ូសាយ ១៥:៨, ២០.
៨ *ក* អាលម៉ា ៤២:១៥.
ស.ប. ដំណើររស់ឡើងវិញ.
*ខ* អេសាយ ២៥:៨;
១ កូរិន. ១៥:៥៤–៥៥;
មរមន ៧:៥.
៩ *ក* គ. និង ស. ៨៨:៥–១៣.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
១០ *ក* អាលម៉ា ៤០:២.
ស.ប. អមតៈ, អមតភាព.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*គ* អាលម៉ា ៤១:៣–៦.
១១ *ក* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
*ខ* ស.ប. សេចក្ដីផាប់ទោស.
១២ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.

ប្រាប់អំពីអំពើទុច្ចរិតទាំងឡាយរបស់គេ តែគេនៅតែពុំ
បែរចេញពីអំពើទាំងនោះឡើយ; ហើយពួកគេត្រូវបានបញ្ជាឲ្យ
ប្រែចិត្ត តែគេនៅតែពុំប្រែចិត្តសោះ ។
១៣ ហើយឥឡូវនេះ តើអ្នករាល់គ្នានឹងពុំញ័រ ហើយប្រែចិត្ត
ពីអំពើបាបទាំងឡាយរបស់អ្នក ហើយចាំថា មានតែដោយ
និងតាម រយៈព្រះគ្រីស្ទប៉ុណ្ណោះទេ ទើបអ្នករាល់គ្នាអាចបាន
សង្គ្រោះ ?
១៤ ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាបង្រៀន
[ក]ក្រិត្យវិន័យលោកម៉ូសេ ចូរបង្រៀនថា វាជាស្រមោលនៃការណ៍
ទាំង ឡាយនោះដែលនឹងកើតឡើងនៅថ្ងៃខាងមុខ —
១៥ ចូរបង្រៀនពួកគេថា សេចក្ដីប្រោសលោះបានមកតាម
រយៈព្រះគ្រីស្ទ ជាព្រះអម្ចាស់ គឺពិតជាព្រះវរបិតា [ក]ដ៏នៅ
អស់កល្បជានិច្ច នោះហើយ ។ អាម៉ែន ៕

## ជំពូកទី ១៧

*អាលម៉ាជឿ ហើយកត់ពាក្យសំដីរបស់អ័ប៊ីណាដៃទុក — អ័ប៊ីណាដៃស្លាប់ដោយភ្លើង — លោកព្យាករអំពីជម្ងឺ និងការស្លាប់ដោយភ្លើង ដែលនឹងកើតឡើងដល់ឃាតករលើរូបលោក ។ ប្រមាណជាឆ្នាំ ១៤៨ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលដែល
អ័ប៊ីណាដៃបាននិយាយពាក្យទាំងនេះចប់ហើយ នោះស្ដេច
ក៏បញ្ជាឲ្យ[ក]ពួក សង្ឃនាំលោកយកទៅ ហើយបញ្ជាឲ្យ
គេសម្លាប់លោកចោល ។
២ ប៉ុន្តែនៅក្នុងចំណោមពួកនោះ មានមនុស្សម្នាក់ឈ្មោះ
[ក]អាលម៉ា ជាពូជពង្ស[ខ]របស់នីហ្វៃដែរ ។ ហើយលោកជាអ្នកកំឡោះ
មួយរូប ហើយលោកបានជឿដល់ពាក្យសំដី ដែលអ័ប៊ីណាដៃ
បាននិយាយ ព្រោះលោកបានស្គាល់នូវអំពើទុច្ចរិត ដែល
អ័ប៊ីណាដៃបាន បរិហាទាស់នឹងពួកនោះ; ហេតុដូច្នេះហើយ
លោកបានចាប់ផ្ដើមសូមអង្វរដល់ស្ដេច សូមកុំឲ្យទ្រង់ខ្ញាល់នឹង
អ័ប៊ីណាដៃ ប៉ុន្តែសូមទុកឲ្យ លោកចេញទៅដោយសេច
ក្ដីសុខ ។
៣ ប៉ុន្តែស្ដេចកាន់តែខ្ញាល់ឡើង ហើយបានបញ្ជាឲ្យបណ្ដេញ
អាលម៉ាចេញពីពួកគេ ព្រមទាំងបញ្ជាឲ្យពួកអ្នកបំរើដេញតាម
លោក ដើម្បីគេអាចសម្លាប់លោកចោល ។
៤ ប៉ុន្តែលោកបានរត់គេចពីពួកគេផុត ហើយបានលាក់ខ្លួន
មិនឲ្យពួកគេរកឃើញ ។ [ក]ហើយដោយលោកបានពួនអស់ជាច្រើន
ថ្ងៃមក នោះលោកបានកត់ត្រានូវអស់ទាំងពាក្យដែលអ័ប៊ីណាដៃ
បាននិយាយ ។
៥ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចបានបញ្ជាឲ្យ
ពួកអ្នកយាមទ្រង់ហ៊ុំព័ទ្ធចាប់អ័ប៊ីណាដៃ; ហើយពួកគេចងលោក
ហើយឃុំលោកទុកក្នុងគុក ។
៦ ហើយបីថ្ងៃក្រោយមក បន្ទាប់ពីបានពិភាក្សាគ្នាជាមួយនឹង
ពួកសង្ឃរបស់ទ្រង់ នោះស្ដេចបានបញ្ជាឲ្យគេនាំអ័ប៊ីណាដៃមក
គាល់ ទ្រង់ទៀត ។
៧ ហើយស្ដេចមានបន្ទូលទៅកាន់លោកថា៖ អ័ប៊ីណាដៃអើយ
យើងបានរកឃើញការចោទប្រកាន់ទោសលើរូបអ្នកហើយ ហើយ
អ្នកត្រូវមានទោសដល់ស្លាប់ ។
៨ ព្រោះអ្នកបាននិយាយថា [ក]ព្រះអង្គទ្រង់ផ្ទាល់នឹងយាងចុះ
មកក្នុងចំណោមកូនចៅមនុស្ស; ហើយឥឡូវនេះ មក
ពីហេតុនេះហើយ អ្នកនឹងត្រូវទទួលទោសដល់ជីវិត លើកលែងតែ
អ្នកដកយកអស់ទាំងពាក្យ ដែលអ្នកបាននិយាយអាក្រក់អំពីយើង
និងប្រជាជនរបស់ យើងចេញ ។
៩ ឥឡូវនេះ អ័ប៊ីណាដៃបានទូលទៅកាន់ស្ដេចថា៖ ទូលបង្គំសូម
ទូលទៅកាន់ទ្រង់ ទូលបង្គំនឹងពុំដកយកពាក្យសំដី ដែលទូលបង្គំ
បាននិយាយអំពីប្រជាជននេះវិញទេ ព្រោះពាក្យទាំងនោះពិត;
ហើយដើម្បីឲ្យទ្រង់ជ្រាបនូវភាពពិតនៃពាក្យទាំងនេះ នោះទូលបង្គំ
សុខចិត្តឲ្យរូបទូលបង្គំធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ទ្រង់ចុះ ។
១០ មែនហើយ ទូលបង្គំនឹងស៊ូទ្រាំរហូតដល់ស្លាប់ ហើយ
ទូលបង្គំនឹងពុំដកយកពាក្យសំដីរបស់ទូលបង្គំវិញឡើយ ហើយ
ពាក្យ ទាំងនោះនឹងឈរជាទីបន្ទាល់ទាស់នឹង[ក]ទ្រង់ ។ ហើយបើ
សិនជាទ្រង់សម្លាប់ទូលបង្គំ គឺទ្រង់នឹងកំចាយឈាមជនឥតទោស
ហើយនេះក៏នឹងឈរជាទីបន្ទាល់មួយទៀត ទាស់នឹងទ្រង់នៅថ្ងៃ
ចុងក្រោយបង្អស់ដែរ ។
១១ ហើយឥឡូវនេះ ស្ដេចណូអេបំរុងនឹងដោះលែងលោ
កទៅហើយ ព្រោះទ្រង់ខ្លាចដល់ពាក្យសំដីរបស់លោក;

១៤ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
១៥ *ក* ម៉ូសាយ ៣:៨; ៥:៧;
អេធើរ ៣:១៤.
**១៧** ១*ក* ម៉ូសាយ ១១:១, ៥–៦.
២ *ក* ម៉ូសាយ ២៣:៦, ៩–១០.
ស.ប. អាលម៉ាជាឪពុក.
*ខ* ម៉ូសាយ ២៦:១៥.
៤ *ក* ស.ប. បទព្រះគម្ពីរ.
៨ *ក* ម៉ូសាយ ១៣:២៥, ៣៣–៣៤.
១០ *ក* អាលម៉ា ៦០:១៣.

ហើយទ្រង់ខ្លាច ក្រែងសេចក្ដីជំនុំជំរះទាំងឡាយនៃព្រះ នឹង
ធ្លាក់មកលើរូបទ្រង់មែន ។
១២ ប៉ុន្តែពួកសង្ឃបានស្រែកឡើងទាស់នឹងលោក ហើយ
បានចាប់ផ្ដើមចោទប្រកាន់ដល់លោកថា៖ លោកបានជេរប្រមាថ
ស្ដេច ។ ហេតុដូច្នេះហើយ ពួកគេបានចាក់រុកឲ្យស្ដេចកាន់តែ
ខ្ញាល់ឡើងយ៉ាងខ្លាំង ទើបទ្រង់បានបញ្ជាឲ្យគេយក
លោកទៅសម្លាប់ចោល ។
១៣ ហើយហេតុការណ៍បានកើតឡើងថា គេបានចាប់
ចងលោក ហើយយកអង្កត់ឧសមកដុតស្បែកលោក មែន
ហើយ គឺគេបាន ដុតលោកដល់ស្លាប់ ។
១៤ ហើយឥឡូវនេះ នៅពេលអណ្ដាតភ្លើងឆាបឆេះ
ដល់ខ្លួនលោក នោះលោកបានស្រែកទៅកាន់ពួកគេថា៖
១៥ មើលចុះ គឺដូចដែលអ្នករាល់គ្នាបានធ្វើមកលើរូបខ្ញុំ
យ៉ាងណា នោះពូជរបស់អ្នកនឹងបណ្ដាលឲ្យមនុស្សជាច្រើន
ត្រូវរងការឈឺ ចាប់ដូចជាខ្ញុំរងទុក្ខយ៉ាងនោះដែរ
គឺជាការឈឺចាប់[ក]នៃសេចក្ដីស្លាប់ដោយភ្លើង; ហើយនេះគឺមក
ពីគេជឿដល់សេចក្ដីសង្គ្រោះនៃ ព្រះអម្ចាស់ ជាព្រះរបស់គេ ។
១៦ ហើយហេតុការណ៍នឹងកើតឡើងថា អ្នករាល់គ្នានឹងត្រូវ
រងទុក្ខលំបាក ដោយជម្ងឺគ្រប់ប្រភេទ មកពីអំពើទុច្ចរិតទាំងឡាយ
របស់អ្នក ។
១៧ មែនហើយ ហើយអ្នករាល់គ្នានឹងត្រូវ[ក]វាយពីគ្រប់ទិសទី
ហើយនឹងត្រូវគេដេញខ្ចាត់ខ្ចាយទៅវិញទៅមក គឺដូចជាហ្វូងចៀម
ព្រៃ ដែលត្រូវសត្វកាចសាហាវដេញ ។
១៨ ហើយនៅថ្ងៃនោះ អ្នករាល់គ្នានឹងត្រូវគេដេញចាប់
ហើយអ្នករាល់គ្នានឹងត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃ នៃពួកខ្មាំង
សត្រូវអ្នក ហើយខណៈនោះ អ្នករាល់គ្នានឹងត្រូវរងទុក្ខ ដូចជា
ខ្ញុំរងទុក្ខដែរ គឺជា[ក]ការឈឺចាប់នៃសេចក្ដីស្លាប់ដោយភ្លើង ។
១៩ ព្រះទ្រង់នឹង[ក]សងសឹកដល់អស់អ្នកណាដែលបានបំផ្លាញ
រាស្ត្រទ្រង់យ៉ាងដូច្នោះឯង ។ ឱព្រះអង្គអើយ សូមព្រះអង្គ
ទទួលយក ព្រលឹងរបស់ទូលបង្គំផង ។
២០ ហើយឥឡូវនេះ កាលអ័ប៊ីណាដៃបានពោលនូវពាក្យ
ទាំងនេះហើយ នោះលោកក៏ដួលចុះ ដោយរងទុក្ខ
ដល់ស្លាប់ដោយ ភ្លើងឆេះ; មែនហើយ លោកត្រូវគេសម្លាប់
ពីព្រោះតែលោកពុំព្រមបដិសេធព្រះបញ្ញត្តិទាំងឡាយនៃព្រះ
ហើយបានបិទត្រានូវការពិតនៃ ពាក្យសំដីរបស់ខ្លួន ដោយ
សេចក្ដីស្លាប់របស់លោក ៕

## ជំពូកទី ១៨

*អាលម៉ាបង្រៀនដោយសម្ងាត់ — លោករៀបចំសេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹក ហើយធ្វើបុណ្យជ្រមុជទឹក នៅក្នុងទឹកមរមន — លោក រៀបចំសាសនាចក្រនៃព្រះគ្រីស្ទឡើង ហើយតែងតាំងសង្ឃទាំងឡាយ — ពួកគេចិញ្ចឹមជីវិតដោយខ្លួនឯង ហើយបង្រៀនប្រជាជន — អាលម៉ា និងប្រជាជនរបស់លោក គេចខ្លួនពីស្ដេចណូអេ ចូលទៅក្នុងទីរហោស្ថាន ។ ប្រមាណជាឆ្នាំ ១៤៧–១៤៥ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ាដែល
បានរត់គេចពីពួកអ្នកបំរើរបស់ស្ដេចណូអេ [ក]បានប្រែចិត្តពីអំពើ
បាប និងអំពើទុច្ចរិតទាំងឡាយរបស់ខ្លួន ហើយបានទៅក្នុង
ចំណោមប្រជាជនដោយសម្ងាត់ ហើយបានចាប់ផ្ដើមបង្រៀន
នូវពាក្យទាំងឡាយ របស់អ័ប៊ីណាដៃ —
២ មែនហើយ អំពីអ្វីៗដែលនឹងមកដល់ ហើយអំពីដំណើរ
រស់ឡើងវិញនៃមនុស្សស្លាប់ និង[ក]ការប្រោសលោះដល់មនុស្ស
ដែលនឹង [ខ]កើតឡើងតាមរយៈព្រះចេស្ដា និងការឈឺចាប់ និង
ការសុគតនៃព្រះគ្រីស្ទ និងអំពីដំណើររស់ឡើងវិញ និងការ
យាងទៅស្ថានសួគ៌ នៃព្រះអង្គ ។
៣ ហើយអស់អ្នកណាដែលចង់ស្ដាប់តាមពាក្យរបស់លោក
នោះលោកបានបង្រៀន ។ ហើយលោកបានបង្រៀនពួកគេដោយ
សម្ងាត់ ដើម្បីកុំឲ្យដឹងដល់ស្ដេច ។ ហើយមានមនុស្សជាច្រើន
បានជឿតាមពាក្យសំដីរបស់លោក ។
៤ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែល
បានជឿតាមលោក គេបានទៅដល់កន្លែងមួយ ដែលហៅថា
មរមន ដោយបានឈ្មោះពីស្ដេចមួយ ជា[ក]កន្លែងដែលនៅជាប់
នឹងព្រំប្រទល់នៃដែនដីមួយ ដែលច្រើនតែមានសត្វសាហាវ មក
រុកគួនក្នុង ពេលខ្លះ ឬក៏ក្នុងរដូវខ្លះ ។

១៥ *ក* ម៉ូសាយ ១៣:៩–១០;
អាលម៉ា ២៥:៤–១២.
១៧ *ក* ម៉ូសាយ ២១:១–៥, ១៣.
១៨ *ក* ម៉ូសាយ ១៩:១៨–២០.
១៩ *ក* ស.ប. ការសងសឹក.
**១៨** ១ *ក* ម៉ូសាយ ២៣:៩–១០.
២ *ក* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ខ* ស.ប. ធ្វើឲ្យធូន, ដង្វាយធួន.
៤ *ក* អាលម៉ា ៥:៣.

៥ ឥឡូវនេះ នៅដែនដីមរមន មានប្រភពមួយ ដែលមានទឹកសុទ្ធ ហើយអាលម៉ាបានជ្រកកោននៅទីនោះ នៅក្បែរទឹកមាន ដើមឈើតូចៗដុះយ៉ាងក្រាស់ ជាទីដែលលោកបានពួននៅពេលថ្ងៃ កាលស្ដេចកំពុងស្វែងរក ។

៦ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែលជឿតាមលោក គេបានមកទីនេះដើម្បីស្ដាប់ពាក្យសំដីរបស់លោក។

៧ ហើយហេតុការណ៍បានកើតឡើងថា ជាច្រើនថ្ងៃបានកន្លងទៅ មានមនុស្សជាច្រើនបានមកជួបជុំគ្នានៅទីមរមន ដើម្បីស្ដាប់ពាក្យ សំដីនៃអាលម៉ា ។ មែនហើយ ពួកគេទាំងអស់នោះបានប្រមូលគ្នាមកដោយបានជឿតាមពាក្យរបស់លោក ដើម្បីមកស្ដាប់លោក ។ ហើយលោកបានបង្រៀនពួកគេ ហើយបានប្រកាសប្រាប់ពួកគេអំពីការប្រែចិត្ត និងសេចក្ដីប្រោសលោះ និងសេចក្ដីជំនឿជឿដល់ ព្រះអម្ចាស់ ។

៨ ហើយហេតុការណ៍បានកើតឡើងថា លោកបាននិយាយទៅកាន់ពួកគេថា៖ មើលចុះ នេះជាទឹកមរមន (ព្រោះនេះជាឈ្មោះដែលគេហៅ) ហើយឥឡូវនេះ ដោយអ្នករាល់គ្នាមានបំណងចង់ចូលរួមក្នុងក្រោលនៃព្រះ ហើយដើម្បីឲ្យបានហៅថាជារាស្ត្ររបស់ ទ្រង់ ហើយយល់ព្រមទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឲ្យបន្ទុកនោះបានស្រាល;

៩ មែនហើយ ហើយយល់ព្រមទួញយំជាមួយនឹងអ្នកណាដែលទួញយំ; មែនហើយ ហើយកំសាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវ ការកំសាន្តទុក្ខ ហើយឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែង ដែលអ្នករាល់គ្នាបាននៅ រហូតដល់ពេល ស្លាប់ ដើម្បីឲ្យអ្នករាល់គ្នាអាចបានប្រោសលោះដោយព្រះ ហើយបានរាប់ជាមួយនឹងពួកអ្នកនៃដំណើររស់ឡើងវិញទីមួយ ដើម្បីឲ្យ អ្នករាល់គ្នាអាចមានជីវិតដ៏នៅអស់កល្បជានិច្ច —

១០ ឥឡូវនេះ ខ្ញុំសូមប្រាប់អ្នក បើសិននេះជាបំណងនៅក្នុងចិត្តអ្នក តើមានអ្វីទៅដែលរារាំងអ្នក មិនឲ្យទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមនៃព្រះអម្ចាស់ ដើម្បីធ្វើជាសាក្សីដល់ទ្រង់ថា អ្នករាល់គ្នាបានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងទ្រង់ថា អ្នករាល់គ្នា នឹងបំរើព្រះអង្គ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដើម្បីឲ្យទ្រង់ស្រោចព្រះវិញ្ញាណទ្រង់ មកលើអ្នករាល់គ្នាយ៉ាងបរិបូរណ៍ ?

១១ ហើយឥឡូវនេះ កាលប្រជាជនបានឮពាក្យទាំងនេះ គេក៏បានទះដៃដោយសេចក្ដីអំណរ ហើយស្រែកថា៖ នេះហើយជាបំណង នៃចិត្តរបស់យើងខ្ញុំ ។

១២ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ាបាននាំហេឡាម ជាអ្នកមុនដំបូងបង្អស់ ទៅឈរក្នុងទឹក ហើយស្រែក ឡើងថា៖ ឱព្រះអម្ចាស់អើយ សូមព្រះអង្គស្រោចព្រះវិញ្ញាណរបស់ទ្រង់ មកលើអ្នកបំរើទ្រង់ចុះ ដើម្បីឲ្យគាត់អាចធ្វើការនេះ ដោយដួង ចិត្តបរិសុទ្ធជ្រះថ្លា ។

១៣ ហើយកាលលោកបានពោលនូវពាក្យទាំងនេះហើយ នោះស្រាប់តែព្រះវិញ្ញាណនៃព្រះអម្ចាស់ ក៏មកសណ្ឋិតលើលោក ហើយ លោកពោលថា៖ ឱហេឡាមអើយ ខ្ញុំសូមធ្វើបុណ្យជ្រមុជទឹកឲ្យអ្នក ដោយបានទទួលសិទ្ធិអំណាចពីព្រះដ៏មានមហិទ្ធិឫទ្ធិ ដើម្បីជាទី បន្ទាល់ថា អ្នកបានចូលក្នុងសេចក្ដីសញ្ញាដើម្បីបំរើព្រះអង្គរហូតដល់អ្នកស្លាប់ ខាងឯរូបកាយសាច់ឈាម; ហើយសូមឲ្យព្រះវិញ្ញាណ នៃព្រះអម្ចាស់ ស្រោចមកលើអ្នក; ហើយសូមឲ្យទ្រង់ប្រទានដល់អ្នក នូវជីវិតដ៏នៅអស់កល្បជានិច្ចតាមរយៈសេចក្ដីប្រោសលោះនៃ ព្រះគ្រីស្ទ ជាព្រះដែលបានរៀបចំឡើង ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ ។

១៤ ហើយបន្ទាប់ពីអាលម៉ាបានពោលនូវពាក្យទាំងនេះហើយ នោះអាលម៉ា និងហេឡាម ទាំងពីរនាក់ក៏បង្កប់ខ្លួនចុះទៅក្នុងទឹក; ហើយគេក៏ងើបឡើងវិញ ហើយឡើងពីទឹក ដោយអរ រីករាយ ហើយពោរពេញទៅដោយព្រះវិញ្ញាណ ។

១៥ ហើយម្ដងទៀត អាលម៉ាបាននាំមនុស្សម្នាក់ទៀតចុះទៅក្នុងទឹក ជាលើកទីពីរ ហើយបានធ្វើបុណ្យជ្រមុជទឹកដល់ជននោះដូចជាជនទីមួយដែរ ខុសគ្នាតែត្រឹមលោកពុំបានពន្លិចខ្លួនលោកចុះទៅក្នុងទឹកទៀតប៉ុណ្ណោះ ។

៧ *ក* អាលម៉ា ៥:១១–១៣.
៨ *ក* គ. និង ស. ២០:៣៧.
*ខ* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
*គ* ស.ប. អាណិត.
៩ *ក* ស.ប. កិច្ចការផ្សាយសាសនា; ធ្វើបន្ទាល់; សាក្សី.
*ខ* ម៉ូសាយ ១៥:២១–២៦.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
១០ *ក* ២ នីហ្វៃ ៣១:១៧.
ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. សេចក្ដីសញ្ញា.
១៣ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ខ* ៣ នីហ្វៃ ១១:២៣–២៦;
គ. និង ស. ២០:៧២–៧៤.
*គ* ម. នៃ ស. ១:៥.
ស.ប. បព្វជិតភាព.
*ឃ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ង* ម៉ូសេ ៤:២; ៥:៩.
១៤ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកដោយការពន្លិច.

១៦ គឺតាមរបៀបនេះហើយដែលលោកបានធ្វើបុណ្យ
ជ្រមុជទឹកឲ្យជនគ្រប់ៗគ្នា ដែលបានទៅឯទឹកមរមន; ហើយពួក
គេមានចំនួន ប្រហែលពីររយបួននាក់; មែនហើយ ហើយពួកគេ
បានទទួលបុណ្យជ្រមុជទឹកនៅក្នុងទឹកមរមន ហើយបាន
ពោរពេញទៅដោយព្រះ គុណនៃព្រះ ។
១៧ ហើយពួកគេត្រូវបានហៅថា សាសនាចក្រនៃព្រះ ឬក៏
សាសនាចក្រនៃព្រះគ្រីស្ទ ចាប់តាំងពីពេលនោះមក ។
ហើយហេតុ ការណ៍បានកើតឡើងថា អស់អ្នកណាដែលបាន
ទទួលបុណ្យជ្រមុជទឹក ដោយអានុភាព និងសិទ្ធិអំណាចពីព្រះ
នោះបានបូកបញ្ចូលទៅ ក្នុងសាសនាចក្ររបស់ទ្រង់ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា ដោយ
បានទទួលសិទ្ធិអំណាចពីព្រះ ក៏បានតែងតាំងសង្ឃទាំង
ឡាយឡើង; គឺលោកបានតែងតាំងសង្ឃមួយសំរាប់មនុស្ស
ហាសិបនាក់ ដើម្បីផ្សាយសាសនាដល់ពួកគេ ហើយបង្រៀន
ពួកគេ អំពីសេចក្ដីទាំង ឡាយដែលទាក់ទងទៅនឹងនគរព្រះ ។
១៩ ហើយលោកបានបញ្ជាពួកគេ កុំឲ្យបង្រៀននូវ
អ្វីផ្សេងៗក្រៅពីអ្វីដែលលោកបានបង្រៀន និងអ្វីដែលបាន
និយាយចេញមកពី មាត់នៃពួកព្យាការីដ៏បរិសុទ្ធប៉ុណ្ណោះ ។
២០ មែនហើយ លោកថែមទាំងបានបញ្ជាពួកគេ កុំឲ្យផ្សាយ
សាសនាពីអ្វីឡើយ ក្រៅពីការប្រែចិត្ត និងសេចក្ដីជំនឿជឿ
ដល់ព្រះ អម្ចាស់ ដែលទ្រង់បានប្រោសលោះរាស្ត្ររបស់ព្រះអង្គ ។
២១ ហើយលោកបានបញ្ជាពួកគេថា មិនគួរឲ្យមានការ
ទាស់ទែងគ្នាទៅវិញទៅមកឡើយ តែថា ពួកគេគួរតែមើលទៅមុខ
ដោយ ភ្នែកតែមួយ មានសេចក្ដីជំនឿតែមួយ និងបុណ្យ
ជ្រមុជទឹកតែមួយ មានចិត្តចងក្រងរួមគ្នាដោយសាមគ្គី
ហើយស្រឡាញ់គ្នាទៅវិញទៅ មក ។
២២ ហើយលោកបានបញ្ជាឲ្យគេផ្សាយសាសនាយ៉ាង
ដូច្នេះហើយ ។ ហើយពួកគេបានក្លាយជាកូនចៅនៃព្រះយ៉ាង
ដូច្នេះហើយ ។
២៣ ហើយលោកបានបញ្ជាឲ្យពួកគេគោរពថ្ងៃ
ឈប់សំរាក ហើយញែកថ្ងៃនេះចេញជាថ្ងៃបរិសុទ្ធ ហើយ
ជារៀងរាល់ថ្ងៃ ពួកគេត្រូវ ថ្លែងអំណរគុណដល់ព្រះអម្ចាស់
ជាព្រះរបស់គេ ។
២៤ ហើយលោកក៏បានបញ្ជាដល់ពួកគេដែរថា ពួកសង្ឃ
ដែលលោកបានតែងតាំងឡើង ត្រូវធ្វើការដោយដៃរបស់ខ្លួន
ផ្ទាល់ ដើម្បី ចិញ្ចឹមជីវិត ។
២៥ ហើយជារៀងរាល់អាទិត្យ ត្រូវញែកថ្ងៃមួយទុកសំរាប់ជួបជុំ
គ្នា ដើម្បីបង្រៀនប្រជាជន ហើយដើម្បីថ្វាយបង្គំដល់ព្រះ
អម្ចាស់ ជាព្រះរបស់គេ ហើយពួកគេត្រូវប្រជុំគ្នាជាញឹកញាប់
ដោយសមត្ថភាព ដែលគេអាចធ្វើបាន ។
២៦ ហើយពួកសង្ឃមិនត្រូវពឹងផ្អែកទៅលើប្រជាជន ក្នុង
ការចិញ្ចឹមជីវិតទេ; ប៉ុន្តែពួកគេត្រូវធ្វើការ ដើម្បីទទួលព្រះគុណ
នៃព្រះ ដើម្បីឲ្យគេមានកម្លាំងខ្លាំងឡើង នៅក្នុងព្រះវិញ្ញាណ
ដោយមានការចេះដឹងអំពីព្រះ ដើម្បីគេអាចបង្រៀន ដោយ
អានុភាព និងសិទ្ធិ អំណាចពីព្រះ ។
២៧ ហើយមួយទៀត អាលម៉ាក៏បានបញ្ជាឲ្យប្រជាជន
នៃសាសនាចក្រនេះ ចែករំលែកនូវទ្រព្យសម្បត្តិរបស់ខ្លួន
គឺមនុស្សម្នាក់ៗ ទៅតាមអ្វីដែលគេមាន; បើសិនជាគេមាន
ច្រើនបរិបូរ ក៏ចែកច្រើនបរិបូរ; ហើយឯអ្នកណាដែលមានតិច
នោះក៏ចែកតិច ហើយចំពោះ អ្នកណាដែលគ្មានទ្រព្យរបស់អ្វី
គួរតែឲ្យដល់អ្នកនោះវិញ ។
២៨ ម្ល៉ោះហើយ ពួកគេត្រូវចែករំលែកនូវទ្រព្យសម្បត្តិ
របស់ខ្លួន ដោយចិត្តស្ម័គ្រ និងចិត្តជ្រះថ្លាដល់ព្រះ ហើយ
ចែកដល់ពួកសង្ឃ ទាំងនោះដែលកំពុងខ្វះខាត មែនហើយ
គឺចែកដល់ជនគ្រប់រូប ដែលក្រីក្រខ្វះខាត ។
២៩ ពាក្យទាំងនេះហើយដែលលោកបាននិយាយទៅកាន់
ពួកគេ ដោយបានទទួលបញ្ញាពីព្រះ; ហើយពួកគេបានដើរ
ដោយត្រង់ នៅចំពោះព្រះ គឺបានចែករំលែកគ្នាទៅវិញទៅមក

១៦ *ក* ម៉ូសាយ ២៥:១៨.
*ខ* ស.ប. ព្រះគុណ.
១៧ *ក* ៣ នីហ្វៃ ២៦:២១; ២៧:៣–៨.
ស.ប. សាសនាចក្រនៃព្រះ
យេស៊ូវគ្រីស្ទ.
១៨ *ក* ស.ប. បព្វជិតភាព.
*ខ* ស.ប. បង្រៀន, គ្រូបង្រៀន.
២០ *ក* គ. និង ស. ១៥:៦; ១៨:១៤–១៦.
២១ *ក* ៣ នីហ្វៃ ១១:២៨–៣០.
ស.ប. ការទាស់ទែង.
*ខ* ម៉ាថាយ ៦:២២;
គ. និង ស. ៨៨:៦៧–៦៨.
*គ* ស.ប. ការរួបរួមតែមួយ.
២២ *ក* ម៉ូសាយ ៥:៥–៧;
ម៉ូសេ ៦:៦៤–៦៨.
២៣ *ក* ម៉ូសាយ ១៣:១៦–១៩;
គ. និង ស. ៥៩:៩–១២.
២៤ *ក* កិច្ចការ ២០:៣៣–៣៥;
ម៉ូសាយ ២៧:៣–៥;
អាលម៉ា ១:២៦.
២៥ *ក* ស.ប. ថ្វាយបង្គំ.
២៦ *ក* ស.ប. ព្រះគុណ.
*ខ* ស.ប. ដំរិះ.
២៧ *ក* កិច្ចការ ២:៤៤–៤៥;
៤ នីហ្វៃ ១:៣.
២៩ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* ស.ប. សុខុមាលភាព.

ព្រមទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ស្របតាមសេច
ក្ដីខ្វះខាត និងសេចក្ដី ត្រូវការរបស់គេ ។
៣០ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
ការណ៍ទាំងអស់នេះត្រូវបានធ្វើឡើងនៅទីមរមន មែនហើយ
នៅក្បែរទឹក មរមន គឺនៅក្នុងព្រៃក្បែរទឹកមរមន; មែនហើយ
ឱទីកន្លែងមរមន ទឹកមរមន ព្រៃមរមន ម្ដេចក៏ល្អដល់ម្លេះហ្ន៎
ចំពោះភ្នែកនៃពួកអ្នក ដែលបានស្គាល់ព្រះដ៏ប្រោសលោះ
របស់ខ្លួន; មែនហើយ ឱពួកគេមានពរហើយ ព្រោះពួកគេ
នឹងច្រៀងសរសើរដល់ព្រះអង្គ ជារៀងរហូត ។
៣១ ហើយការណ៍ទាំងនេះបានធ្វើឡើង នៅត្រង់
តំបន់ព្រំប្រទល់ដែនដី ដើម្បីកុំឲ្យដឹងដល់ស្ដេច ។
៣២ ប៉ុន្តែមើលចុះ ហេតុការណ៍បានកើតឡើងថា ដោយ
បានដឹងថា មានចលនានៅក្នុងចំណោមប្រជាជន នោះស្ដេច
ក៏បញ្ជាពួក អ្នកបំរើឲ្យទៅមើលពួកគេ ។ ហេតុដូច្នេះហើយ
នៅថ្ងៃដែលគេបានប្រជុំគ្នា ដើម្បីស្ដាប់ព្រះបន្ទូលនៃព្រះអម្ចាស់
នោះគេបានរក ឃើញជូនស្ដេច ។
៣៣ ហើយឥឡូវនេះ ស្ដេចបានមានបន្ទូលថា អាលម៉ាបាន
ចាក់រុកប្រជាជនឲ្យបះបោរទាស់នឹងទ្រង់; ហេតុដូច្នេះហើយ
ទើបទ្រង់ បានបញ្ជាឲ្យកងទ័ពទៅបំផ្លាញពួកគេចោល ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា និង
រាស្ត្រនៃព្រះអម្ចាស់ ក៏បានដឹងជាមុនស្រេច អំពីដំណើរដែល
កងទ័ពរបស់ ស្ដេចនឹងមក; ហេតុដូច្នេះហើយ ទើបពួកគេបាន
យកត្រសាលគេ និងគ្រួសារគេ ហើយបានធ្វើដំណើរចេញទៅ
ក្នុងទីរហោស្ថាន ។
៣៥ ហើយគេទាំងអស់ មានចំនួនប្រហែលបួនរយហាសិបនាក់ ៕

## ជំពូកទី ១៩

*គេឌានរកប្រហារស្ដេចណូអេ — ពួកសាសន៍លេមិនចូល យកដែនដី — ស្ដេចណូអេសុគតដោយភ្លើង — លិមហៃ គ្រប់គ្រងជាព្រះរាជា ចំណុះ ។ ប្រមាណជាឆ្នាំ ១៤៥–១២១ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា កងទ័ពរបស់ស្ដេចបានត្រឡប់
មកវិញ ក្រោយពីបានរករាស្ត្រនៃព្រះអម្ចាស់ ដោយឥតបានការ ។
២ ហើយឥឡូវនេះ មើលចុះ ពលរបស់ស្ដេចមានចំនួនតិច
ដោយបានបន្ថយចុះ ហើយបានចាប់ផ្ដើមមានការបែកបាក់គ្នានៅ
ក្នុង ចំណោមប្រជាជនដែលនៅសល់ទាំងប៉ុន្មាន ។
៣ ហើយប្រជាជនផ្នែកតិចបានចាប់ផ្ដើមខ្សឹបខ្សៀវ អំពីការ
គំរាមកំហែងទាស់នឹងស្ដេច ហើយក៏ចាប់ផ្ដើមមានការទាស់ទែង
មួយយ៉ាងធំ នៅក្នុងចំណោមពួកគេ ។
៤ ហើយឥឡូវនេះ មានបុរសម្នាក់នៅក្នុងចំណោមពួកគេ
ឈ្មោះថា គេឌាន ហើយលោកជាមនុស្សខ្លាំងពូកែមួយរូប
ហើយជា សត្រូវដល់ស្ដេច ហេតុដូច្នេះហើយ លោកបានដកដាវ
ហើយសច្ចាក្នុងកំហឹងថា លោកនឹងសម្លាប់ស្ដេចចោល ។
៥ ហើយហេតុការណ៍បានកើតឡើងថា លោកបានប្រយុទ្ធជា
មួយនឹងស្ដេច ហើយនៅពេលដែលស្ដេចទតឃើញថា គាត់ជិត
ឈ្នះ ទ្រង់ហើយ នោះទ្រង់ក៏គេច ហើយរត់ទៅឡើងប៉ម ដែល
នៅជិតព្រះវិហារបរិសុទ្ធ ។
៦ ហើយគេឌានដេញតាមពីក្រោយ ហើយរៀប
នឹងឡើងទៅលើប៉ម ដើម្បីសម្លាប់ស្ដេចចោល ស្រាប់តែស្ដេច
បានចោលព្រះនេត្រ ទតមើលជុំវិញ ឆ្ពោះទៅដែនដីសេមឡុន
ហើយមើលចុះ កងទ័ពសាសន៍លេមិន គេកំពុងតែនៅខាងក្នុង
ព្រំប្រទល់នៃដែនដីទៅហើយ ។
៧ ហើយឥឡូវនេះ ស្ដេចស្រែកឡើងដោយក្ដីគ្រាំគ្រា
ពីព្រលឹងទ្រង់ថាៈ គេឌានអើយ សូមទុកជីវិតយើងចុះ ព្រោះ
ពួកលេមិនកំពុង តែមកវាយយើង ហើយពួកគេនឹងបំផ្លាញពួក
យើង; មែនហើយ ពួកគេនឹងបំផ្លាញប្រជាជនយើងហើយ ។
៨ ហើយឥឡូវនេះ ស្ដេចពុំសូវបារម្ភដល់ប្រជាជនរបស់ទ្រង់
ស្មើនឹងទ្រង់បារម្ភដល់ជីវិតផ្ទាល់របស់ទ្រង់ប៉ុន្មានទេ; ទោះ
ជាយ៉ាង នេះក្ដី គង់តែគេឌានបានទុកជីវិតឲ្យទ្រង់ដែរ ។
៩ ហើយស្ដេចបានបញ្ជាឲ្យប្រជាជនរត់គេចចេញពីពួកលេមិន
ហើយទ្រង់ផ្ទាល់ គឺជាអ្នកនាំមុខគេ ហើយពួកគេបានរត់គេច
ចូលទៅ ក្នុងទីរហោស្ថាន ជាមួយនឹងពួកស្ត្រីគេ និងកូនចៅគេ ។
១០ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបាន
ដេញតាមគេ ហើយបានតាមទាន់ ហើយបានចាប់ផ្ដើមសម្លាប់
គេចោល ។
១១ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ស្ដេចបាន
បញ្ជាពួកបុរសទាំងអស់ រត់ចោលប្រពន្ធខ្លួន និងកូនចៅខ្លួន
ហើយគេច ចេញពីពួកលេមិន ។
១២ ឥឡូវនេះ មានមនុស្សជាច្រើន ដែលពុំព្រមរត់ចោល

៣០ *ក* ម៉ូសាយ ២៦:១៥.
៣១ *ក* ម៉ូសាយ ១៨:៤.
៣៤ *ក* ម៉ូសាយ ២៣:១.
១៩ ៥ *ក* ម៉ូសាយ ១១:១២.

ប្រពន្ធកូនខ្លួនទេ តែសុខចិត្តនៅ ហើយវិនាសជាមួយនឹងពួកគេវិញ ។ ហើយក្រោយពីនោះ ក៏បានចោលប្រពន្ធរបស់ខ្លួន និងកូនចៅរបស់ខ្លួន ហើយបានរត់គេចបាត់ទៅ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកដែលនៅជាមួយនឹងប្រពន្ធរបស់ខ្លួន និងកូនចៅរបស់ខ្លួន បានឲ្យពួកកូនក្រមុំ ដ៏ស្រស់ល្អៗរបស់ខ្លួន ចេញទៅអង្វរពួកលេមិន សូមកុំឲ្យសម្លាប់ពួកគេចោលឡើយ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនមានសេចក្ដីអាណិតដល់គេ ព្រោះពួកលេមិន ត្រូវសម្រស់របស់ស្រ្តីទាំង នោះទាក់ចិត្ត ។

១៥ ហេតុដូច្នេះហើយ ពួកលេមិនបានទុកជីវិតឲ្យគេ ហើយបានចាប់គេយកទៅជាឈ្លើយ ហើយនាំគេត្រឡប់ទៅឯដែនដីនីហ្វៃវិញ ហើយបានអនុញ្ញាតឲ្យគេយកដែនដីនោះ នៅក្រោមល័ក្ខខ័ណ្ឌទាំងឡាយថា គេត្រូវប្រគល់ស្ដេចណូអេ ទៅក្នុងកណ្ដាប់ដៃនៃពួកលេមិន ហើយប្រគល់ទ្រព្យរបស់ខ្លួន គឺនូវពាក់កណ្ដាលនៃទ្រព្យសម្បត្តិទាំងអស់ដែលគេមាន ពាក់កណ្ដាលនៃមាសរបស់គេ និងប្រាក់របស់គេ និងវត្ថុមានតម្លៃរបស់គេទាំងអស់ម្ល៉ោះហើយ ពួកគេត្រូវបង់ពន្ធដារទៅឲ្យស្ដេចនៃពួកលេមិនជារៀងរាល់ឆ្នាំ ។

១៦ ហើយឥឡូវនេះ នៅក្នុងចំណោមអ្នកដែលគេចាប់យកទៅជាឈ្លើយ នោះមានមនុស្សម្នាក់នាមថា [ក]លិមហៃ ជាបុត្ររបស់ស្ដេច ។

១៧ ហើយឥឡូវ លិមហៃមិនចង់ឲ្យបិតាខ្លួនត្រូវគេបំផ្លាញចោលឡើយ; ទោះជាយ៉ាងណាក៏ដោយ គង់តែលិមហៃជ្រាបពីអំពើ ទុច្ចរិតទាំងឡាយរបស់បិតាខ្លួនដែរ ទោះជារូបទ្រង់ជាបុរសសុចរិតម្នាក់ក្ដី ។

១៨ ហើយហេតុការណ៍បានកើតឡើងថា គេឌានបានចាត់ឲ្យមនុស្សទៅក្នុងទីរហោស្ថាន ដោយសម្ងាត់ ដើម្បីទៅរកស្ដេច និងពួកអ្នកដែលទៅជាមួយទ្រង់ ។ ហើយហេតុការណ៍បានកើតឡើងថា គេបានជួបនឹងប្រជាជននៅក្នុងទីរហោស្ថានគ្រប់គ្នា លើកលែងតែស្ដេច និងពួកសង្ឃរបស់ទ្រង់ប៉ុណ្ណោះ ។

១៩ ឥឡូវនេះ ពួកគេបានសច្ចានៅក្នុងចិត្តគេថា គេនឹងត្រឡប់ទៅដែនដីនីហ្វៃវិញ ហើយបើសិនជាប្រពន្ធគេ និងកូនចៅគេ ត្រូវគេ សម្លាប់ចោល ហើយព្រមទាំងពួកអ្នកដែលនៅជាមួយនឹងពួកគេផងដែរ នោះពួកគេនឹងរកសងសឹក ហើយនឹងវិនាសជាមួយគ្នាដែរ ។

២០ ហើយស្ដេចបានបញ្ជាមិនឲ្យពួកគេត្រឡប់ទៅវិញឡើយ; ពួកគេ[ក]ក៏ខឹងនឹងស្ដេច ហើយបានធ្វើឲ្យទ្រង់រងទុក្ខវេទនា រហូតដល់ សុគតដោយភ្លើង ។

២១ ហើយពួកគេបំរុងនឹងចាប់ពួកសង្ឃទាំងឡាយផង ហើយយកទៅប្រហារចោល ប៉ុន្តែពួកនោះបានរត់គេចខ្លួនបាត់ទៅ ។

២២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេកំពុងតែនឹងត្រឡប់ទៅកាន់ដែនដីនីហ្វៃវិញ ស្រាប់តែពួកគេបានជួបនឹងពួកកង គេឌាន ។ ហើយពួកកងគេឌានបានប្រាប់ពួកគេអំពីអ្វីៗដែលបានកើតឡើង ដល់ប្រពន្ធពួកគេ និងកូនចៅពួកគេ; ហើយថា ពួកលេមិន បានអនុញ្ញាតឲ្យពួកគេអាចនៅលើដែនដីនោះ ដោយត្រូវបង់ពន្ធដារ ទៅឲ្យពួកលេមិន នូវចំនួនពាក់កណ្ដាលនៃទ្រព្យសម្បត្តិទាំងអស់ ដែលគេមាន ។

២៣ ហើយប្រជាជនទាំងនោះបានប្រាប់ពួកកងគេឌានថា ពួកគេបានសម្លាប់ស្ដេចចោល រីឯពួកសង្ឃរបស់ទ្រង់បានរត់គេចពីពួកគេ ទៅជ្រៅក្នុងទីរហោស្ថាន ។

២៤ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេបានបញ្ចប់ពិធីរួចស្រេចហើយ នោះពួកគេបានត្រឡប់ទៅកាន់ដែនដី នីហ្វៃវិញ ដោយអររីករាយ ពីព្រោះប្រពន្ធរបស់ពួកគេ និងកូនចៅរបស់ពួកគេពុំបានត្រូវគេសម្លាប់ចោល; ហើយពួកគេបានប្រាប់គេឌាន នូវអ្វីៗដែលគេបានធ្វើដល់ស្ដេច ។

២៥ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចរបស់ពួកលេមិនបាន[ក]សច្ចានឹងពួកគេថា ប្រជាជនរបស់ទ្រង់នឹងពុំសម្លាប់ពួកគេ ទៀតឡើយ ។

២៦ រីឯលិមហៃ ជាបុត្ររបស់ស្ដេច [ក]ត្រូវប្រជាជនប្រគល់នគរឲ្យ បានសច្ចាទៅស្ដេចនៃពួកលេមិនថា ប្រជាជនរបស់ទ្រង់នឹងបង់ សួសារអាករទៅឲ្យទ្រង់ គឺនូវចំនួនពាក់កណ្ដាលនៃទ្រព្យសម្បត្តិទាំងអស់ដែលគេមាន ។

២៧ ហើយហេតុការណ៍បានកើតឡើងថា លិមហៃចាប់ផ្ដើមកសាងនគរ ហើយកសាងឲ្យមានសេចក្ដីសុខសាន្តនៅក្នុងចំណោម ប្រជាជនទ្រង់ទៀត ។

២៨ ហើយស្ដេចនៃពួកលេមិនបានចាត់ឲ្យពួកទាហានយាមជុំវិញដែនដី ដើម្បីទ្រង់អាចការពារប្រជាជនរបស់លិមហៃនៅលើដែនដី ដើម្បីកុំឲ្យពួកគេអាចរត់ចូលក្នុងទីរហោស្ថាន;

១៦ *ក* ម៉ូសាយ ៧:៩.
២០ *ក* ម៉ូសាយ ១៧:១៣–១៩; អាលម៉ា ២៥:១១.
២៥ *ក* ម៉ូសាយ ២១:៣.
២៦ *ក* ម៉ូសាយ ៧:៩.

ហើយទ្រង់បានចិញ្ចឹមពួកទាហានយាម ដោយពន្ធដារដែល
ទ្រង់បានទទួលមកពីពួកនីហ្វៃ ។
២៩ ហើយឥឡូវនេះ ស្ដេចលិមហៃបានមានសេចក្ដីសុខសាន្ត
តរៀងមក នៅក្នុងនគររបស់ទ្រង់ អស់រយៈពេលពីរឆ្នាំ ដែល
ពួក លេមិនពុំបានមករុកគួនពួកគេ ឬរកបំផ្លាញពួកគេឡើយ ៕

## ជំពូកទី ២០

*ពួកកូនស្រីខ្លះរបស់ពួកលេមិនត្រូវពួកសង្ឃរបស់ស្ដេចណូអេចាប់យក — ពួកសាសន៍លេមិនធ្វើសង្គ្រាមមកលើលិមហៃ និងប្រជាជន របស់ទ្រង់ — ពួកពលទ័ពលេមិនត្រូវបានវាយច្រានទៅវិញ ហើយត្រូវបានធ្វើឲ្យបាត់ខឹង ។ ប្រមាណជាឆ្នាំ ១៤៥–១២៣ ម.គ.ស. ។*

ឥឡូវនេះ មានកន្លែងមួយនៅដែនដីសេមឡុន ដែលពួកកូនស្រី
របស់ពួកលេមិនបានទៅជួបជុំគ្នា ដើម្បីច្រៀងរាំ ហើយលេង
សប្បាយ ។
២ ហើយហេតុការណ៍បានកើតឡើងថា មានថ្ងៃមួយ ពួកគេ
មួយចំនួនតូចបានមកជួបជុំគ្នា ដើម្បីច្រៀងរាំលេង ។
៣ ហើយឥឡូវនេះ ពួកសង្ឃរបស់ស្ដេចណូអេ ដោយមក
ពីអៀនខ្មាស់ ទើបពុំត្រឡប់ទៅឯទីក្រុងនីហ្វៃវិញទេ មែនហើយ
ហើយក៏ ខ្លាចប្រជាជនសម្លាប់ពួកគេចោលផង ហេតុ
ដូច្នេះហើយ ទើបពួកគេពុំហ៊ានត្រឡប់ទៅជួបប្រពន្ធគេ និង
កូនចៅគេវិញឡើយ ។
៤ ហើយនៅពេលដែលពួននៅក្នុងទីរហោស្ថាន ហើយ
កាលបានប្រទះឃើញពួកកូនក្រមុំរបស់ពួកលេមិន នោះពួកគេ
បានលប មើលពួកកូនក្រមុំទាំងនោះ;
៥ ហើយកាលមានពួកកូនក្រមុំមួយចំនួនតូចមកជួបជុំគ្នារាំ
នោះពួកគេក៏ចេញមកពីទីសម្ងាត់របស់គេ ហើយចាប់យកពួក
កូនក្រមុំ ទាំងនោះ ហើយនាំគេទៅក្នុងទីរហោស្ថាន; មែន
ហើយ ពួកគេបាននាំយកកូនក្រមុំនៃពួកលេមិនចំនួនម្ភៃបួននាក់
ចូលទៅក្នុង ទីរហោស្ថាន ។
៦ ហើយហេតុការណ៍បានកើតឡើងថា ពេលដែលពួក
លេមិនដឹងថា កូនក្រមុំរបស់គេបាត់ខ្លួនទៅ ពួកគេក៏ខឹងនឹង
ប្រជាជនរបស់ លិមហៃ ព្រោះគេគិតស្មានថា ប្រជាជនរបស់
លិមហៃបានធ្វើការនេះ ។
៧ ហេតុដូច្នេះហើយ ពួកគេបានចាត់ឲ្យពលទ័ព
របស់គេចេញទៅ; មែនហើយ សូម្បីតែស្ដេចផ្ទាល់ក៏បានចេញនាំ
មុខប្រជាជន ទ្រង់ដែរ; ហើយពួកគេឡើងទៅដែនដីនីហ្វៃ
ដើម្បីទៅបំផ្លាញប្រជាជនរបស់លិមហៃចោល ។
៨ ហើយឥឡូវនេះ លិមហៃបានទតឃើញពួកគេពីលើប៉ម
ទ្រង់ថែមទាំងទតឃើញពីការរៀបចំធ្វើសង្គ្រាមរបស់គេផង;
ហេតុ ដូច្នេះហើយ ទ្រង់បានប្រជុំប្រជាជនទ្រង់ ហើយបានបង្កប់
ចាំពួកគេ នៅតាមទីវាល និងនៅក្នុងព្រៃ ។
៩ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិន
បានឡើងមកដល់ ស្រាប់តែពួកកងរបស់លិមហៃចាប់ផ្ដើមសំរុក
មក លើពួកគេ ចេញពីកន្លែងបង្កប់ខ្លួន ហើយចាប់ផ្ដើមសម្លាប់
ពួកគេចោល ។
១០ ហើយហេតុការណ៍បានកើតឡើងថា ការប្រយុទ្ធបាន
ក្លាយទៅជាសាហាវអស្ចារ្យ ព្រោះពួកគេប្រយុទ្ធដូចជាសត្វ
សិង្ហប្រយុទ្ធ ដណ្ដើមចំណី ។
១១ ហើយហេតុការណ៍បានកើតឡើងថា ទ័ពរបស់លិមហៃ
បានចាប់ផ្ដើមរុញច្រានពួកលេមិនឲ្យថយពីគេ; ទោះជាគេមាន
ចំនួន តិចជាងពាក់កណ្ដាល នៃចំនួនពួកលេមិនក្ដី ។ ប៉ុន្តែពួក
គេបានប្រយុទ្ធដើម្បីជីវិតគេ និងដើម្បីប្រពន្ធគេ និងដើម្បីកូនចៅគេ;
ហេតុដូច្នេះ ហើយ ទើបពួកគេខំប្រឹងយ៉ាងអស់ពីសមត្ថភាព
ហើយគេបានប្រយុទ្ធដូចជាសត្វនាគច្បាំងគ្នា ។
១២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានឃើញ
ស្ដេចនៃពួកលេមិន នៅក្នុងចំណោមពួកមនុស្សស្លាប់; តែទ្រង់មិន
បានស្លាប់ទេ គឺដោយត្រូវរបួស ហើយត្រូវទុកចោលនៅលើដី
ព្រោះទ័ពរបស់ទ្រង់បានរត់គេចចេញទៅដោយរហ័សពេក ។
១៣ ហើយពួកគេបានយកទ្រង់ ហើយរុំរបួសឲ្យទ្រង់
ហើយនាំយកទ្រង់ទៅគាល់លិមហៃ ហើយទូលថា៖ ក្រាបទូល
នេះគឺស្ដេច របស់ពួកលេមិន; ទ្រង់បានត្រូវរបួស ដួលចុះក្នុង
ចំណោមពួកដែលស្លាប់ ហើយពួកគេបានទុកទ្រង់ចោល;
ហើយមើលចុះ យើងខ្ញុំបាន នាំទ្រង់មកគាល់ទ្រង់; ហើយឥឡូវនេះ
ចូរយើងសម្លាប់ទ្រង់ទៅ ។
១៤ តែលិមហៃមានបន្ទូលទៅកាន់ពួកគេថា៖ អ្នករាល់គ្នា
មិនត្រូវសម្លាប់ទ្រង់ទេ តែនាំទ្រង់មកទីនេះវិញ ដើម្បីឲ្យយើងឃើញ
ទ្រង់ ។ ហើយពួកគេក៏នាំទ្រង់មក ហើយលិមហៃមាន
បន្ទូលទៅកាន់ទ្រង់ថា៖ ចុះតើហេតុអ្វីបានជាទ្រង់ឡើងមកធ្វើ
សង្គ្រាមនឹងប្រជាជនយើង? មើលចុះ ប្រជាជនរបស់យើងពុំបាន
បំពានលើពាក្យសច្ចា ដែលយើងបានធ្វើជាមួយទ្រង់នោះឡើយ;

២០ ១១ក អាលម៉ា ៤៣:៤៥.
១៤ ក ម៉ូសាយ ១៩:២៥–២៦.

ហេតុដូច្នេះហើយ តើហេតុអ្វីបាន ជាទ្រង់បំពានលើពាក្យសច្ចា ដែលទ្រង់បានធ្វើជាមួយនឹងប្រជាជនយើងវិញ ?

១៥ ហើយឥឡូវនេះ ស្ដេចមានបន្ទូលថា៖ យើងបាន បំពានលើពាក្យសច្ចា ពីព្រោះប្រជាជនរបស់ទ្រង់បានចាប់ យកកូនក្រមុំរបស់ ប្រជាជនយើងទៅ; ហេតុដូច្នេះហើយ នៅក្នុងកំហឹងរបស់យើង នោះយើងបាននាំប្រជាជនយើងឡើងមកធ្វើសង្គ្រាមនឹងប្រជាជនទ្រង់ ។

១៦ ហើយឥឡូវនេះ លិមហៃពុំដែលបានឮពីការណ៍នេះសោះ; ហេតុដូច្នេះហើយ ទើបទ្រង់មានបន្ទូលថា៖ យើងនឹងស៊ើបរកក្នុងចំណោមប្រជាជនយើង ហើយអ្នកណាបានធ្វើការណ៍នេះនឹងត្រូវវិនាស ។ ហេតុដូច្នេះហើយ ទ្រង់បានចាត់ឲ្យធ្វើការស៊ើបរកក្នុងចំណោមប្រជាជនទ្រង់ ។

១៧ ឥឡូវនេះ កាល[ក]គេឮខានបានឮរឿងទាំងនេះ គឺលោកជាមេទ័ពម្នាក់របស់ស្ដេច នោះលោកបានចេញមក ហើយទូលស្ដេចថា៖ សូមទ្រង់មេត្តា ហើយសូមកុំស៊ើបរកក្នុងប្រជាជននេះ ហើយកុំយករឿងនេះមកចោទប្រកាន់ដល់ពួកគេឡើយ ។

១៨ ត្បិតតើទ្រង់មិនចាំទេឬថា ពួកសង្ឃរបស់បិតាទ្រង់ ដែលប្រជាជននេះរកបំផ្លាញចោលនោះ ? ហើយតើមិនមែនពួកគេនោះ នៅក្នុងទីរហោស្ថានទេឬ ? ហើយតើមិនមែនពួកគេនោះ ជាអ្នកលួចយកកូនក្រមុំទាំងឡាយនៃពួកលេមិនទេឬអី ?

១៩ ហើយឥឡូវនេះ មើលចុះ សូមទ្រង់ទូលដល់ស្ដេចនូវការណ៍ទាំងនេះ ដើម្បីទ្រង់អាចប្រាប់ប្រជាជនទ្រង់ ដើម្បីឲ្យពួកគេបាត់ខឹង នឹងយើង; ត្បិតមើលចុះ ពួកគេបានរៀបចំជាស្រេច ដើម្បីមកតតាំងនឹងយើងទៀត; ហើយមើលចុះ យើងក៏មានចំនួនតិចផង ។

២០ ហើយមើលចុះ គេមកដោយមានពួកពលដ៏ច្រើន; ហើយលើកលែងស្ដេចនោះធ្វើឲ្យគេបាត់ខឹងនឹងយើង នោះយើងច្បាស់ជា ត្រូវវិនាសជាមិនខានឡើយ ។

២១ ត្បិតតើមិនមែនពាក្យសំដីរបស់អ័ប៊ីណាដៃ [ក]ត្រូវបានបំពេញទេឬអី ដែលលោកបានព្យាករទាស់នឹងយើងនោះ — ហើយការណ៍ អស់ទាំងនេះ ក៏ពីព្រោះយើងមិនព្រមស្ដាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ ហើយបែរចេញពីអំពើទុច្ចរិតទាំងឡាយរបស់យើងឬ ?

២២ ហើយឥឡូវនេះ ចូរយើងសម្រុះសម្រួលជាមួយនឹងស្ដេច ហើយយើងបំពេញនូវពាក្យសច្ចា ដែលយើងបានធ្វើជាមួយនឹងទ្រង់; ដ្បិតបើយើងត្រូវធ្លាក់ទៅក្នុងសេវកភាព នោះគ្រាន់បើជាងយើងត្រូវបាត់បង់ជីវិត; ហេតុដូច្នេះហើយ ចូរយើងបញ្ចប់ការខ្ចាយឈាម ដ៏ច្រើននេះទៅ ។

២៣ ហើយឥឡូវនេះ លិមហៃបានទូលស្ដេចនូវការណ៍ទាំងអស់អំពីបិតាទ្រង់ និង[ក]ពួកសង្ឃដែលបានរត់គៀសខ្លួន ចូលទៅក្នុងទីរហោស្ថាន ហើយទម្លាក់ទោសអំពីការពង្រត់កូនក្រមុំទាំងឡាយនោះទៅលើពួកគេ ។

២៤ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចក៏បាត់ខឹងនឹងប្រជាជនរបស់លិមហៃ; ហើយទ្រង់មានបន្ទូលទៅកាន់គេថា៖ ចូរពួក យើងចេញទៅជួបនឹងប្រជាជនយើង ដោយមិនបាច់យកគ្រឿងអាវុធទៅជាមួយទេ; ហើយយើងសច្ចានឹងអ្នកថា ប្រជាជនយើងនឹងពុំ សម្លាប់ប្រជាជនរបស់ទ្រង់ឡើយ ។

២៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចេញទៅតាមស្ដេច ហើយបានចេញទៅជួបពួកលេមិនដោយគ្មានអាវុធ ជាប់ទៅជាមួយឡើយ ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានជួបនឹងពួកលេមិន ហើយស្ដេចរបស់ពួកលេមិនបានក្រាប ចំពោះពួកគេ ហើយបានដោះសារឲ្យប្រជាជនលិមហៃ ។

២៦ ហើយកាលពួកលេមិនបានឃើញប្រជាជនលិមហៃថា ពួកគេគ្មានប្រដាប់អាវុធឡើយ នោះពួកគេក៏មាន[ក]ចិត្តមេត្តាដល់ប្រជាជន លិមហៃ ហើយបាត់ខឹងនឹងពួកគេដែរ ហើយក៏បានត្រឡប់ទៅដែនដីខ្លួន ជាមួយនឹងស្ដេចរបស់គេវិញ ដោយក្ដីសុខសាន្ត ៕

## ជំពូកទី ២១

*ប្រជាជនរបស់លិមហៃត្រូវពួកលេមិនវាយធ្វើបាប ហើយយកជ័យជំនះលើ — ពួកគេជួបនឹងអាំម៉ូន ហើយបានប្រែចិត្តជឿ — ពួកគេប្រាប់ អាំម៉ូនអំពីផ្ទាំងម្ភៃបួនសន្លឹកនៃសាសន៍យ៉ារេឌ ។ ប្រមាណជាឆ្នាំ ១២២–១២១ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា លិមហៃ និងប្រជាជនរបស់ទ្រង់ បានត្រឡប់ទៅឯទីក្រុងនីហ្វៃវិញ ហើយបានចាប់ផ្ដើមរស់នៅលើ ដែនដីដោយសេចក្ដីសុខសាន្តជាថ្មី ។

២ ហើយហេតុការណ៍បានកើតឡើងថា អស់រយៈពេល

---

១៧ *ក* ម៉ូសាយ ១៩:៤–៨.
២១ *ក* ម៉ូសាយ ១២:១–៨.
២៣ *ក* ម៉ូសាយ ១៩:២១, ២៣.
២៦ *ក* ស.ប. អាណិត.

ជាច្រើនថ្ងៃក្រោយមក ពួកលេមិនបានចាប់ផ្ដើមចាក់រុកឲ្យខឹង
នឹងពួកនីហ្វៃ ទៀត ហើយពួកគេក៏ចាប់ផ្ដើមចូលមកក្នុងតំបន់
ព្រំដែនជុំវិញ ។
៣ ឥឡូវនេះ ពួកគេពុំហ៊ានសម្លាប់គេទេ ព្រោះខ្លាចខុសនឹង
ពាក្យសច្ចា ដែលស្ដេចរបស់គេបានធ្វើជាមួយនឹងលិមហៃ; តែ
ពួកគេ បានទះ[ក]កំផ្លៀង ហើយប្រើអំណាចទៅលើគេ; ហើយ
បានចាប់ផ្ដើមដាក់[ខ]បន្ទុកដ៏ធ្ងន់ៗទៅលើខ្នងគេ ហើយប្រើគេ
ហាក់បីដូចជាសត្វលា ដែលគ —
៤ មែនហើយ ការណ៍អស់ទាំងនេះត្រូវបានធ្វើឡើង ដើម្បីឲ្យ
ព្រះបន្ទូលនៃព្រះអម្ចាស់បានបំពេញ ។
៥ ហើយឥឡូវនេះ ការវេទនានៃពួកសាសន៍នីហ្វៃ មាន
ទំហំធំដ៏អស្ចារ្យ ហើយគ្មានផ្លូវណា ដែលគេអាចដោះខ្លួនឲ្យ
រួចពីកណ្ដាប់ដៃ នៃពួកនោះបានឡើយ ព្រោះពួកលេមិនបាន
ហ៊ុំព័ទ្ធពួកគេគ្រប់ទិសទី ។
៦ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបានចាប់ផ្ដើម
រអ៊ូរទាំនឹងស្ដេច ដោយសារការវេទនារបស់ខ្លួន; ហើយពួកគេ
បាន ចាប់ផ្ដើមចង់ចេញទៅច្បាំងនឹងពួកនោះ ។ ហើយពួកគេ
បានធ្វើឲ្យស្ដេចមានព្រះទ័យកើតទុក្ខជាខ្លាំង ដោយសារការ
ត្អូញត្អែររបស់គេ; ហេតុដូច្នេះហើយ ទើបទ្រង់អនុញ្ញាតឲ្យ
គេធ្វើតាមចំណង់របស់គេចុះ ។
៧ ហើយពួកគេបានប្រមូលគ្នាទៀត ហើយបានពាក់អាវក្រោះ
ហើយបានចេញទៅតតាំងនឹងពួកលេមិន ដើម្បីដេញពួក
គេចេញពី ដែនដីរបស់ខ្លួន ។
៨ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនមាន
ជ័យជំនះលើពួកគេ ហើយបានដេញពួកគេឲ្យថយក្រោយ ហើយ
បានសម្លាប់ ពួកគេអស់ជាច្រើននាក់ ។
៩ ហើយឥឡូវនេះ មានការកាន់ទុក្ខ និង[ក]ការទួញសោកដ៏ខ្លាំងនៅ
ក្នុងចំណោមប្រជាជនលិមហៃ ស្រីមេម៉ាយកាន់ទុក្ខឲ្យប្ដី កូនប្រុស
និងកូនស្រីកាន់ទុក្ខឲ្យឪពុក ហើយបងប្អូនកាន់ទុក្ខឲ្យបងប្អូន ។
១០ ឥឡូវនេះ មានស្រីមេម៉ាយជាច្រើននៅលើដែនដី
ហើយគេបានយំដ៏ខ្លាំងពីថ្ងៃមួយទៅថ្ងៃមួយ ព្រោះការគំរាម
ដ៏ធំរបស់ពួក លេមិនបានធ្លាក់មកលើពួកគេ ។
១១ ហើយហេតុការណ៍បានកើតឡើងថា ការយំសោកដ៏មិន
ឈប់ឈររបស់ពួកគេ បានចាក់រុកប្រជាជនលិមហៃ ដែល
នៅសល់ ទាំងប៉ុន្មាន ឲ្យខឹងនឹងពួកលេមិន; ហើយពួកគេ
បានចេញទៅច្បាំងជាថ្មីទៀត តែពួកគេត្រូវបានរុញច្រានឲ្យ
ថយក្រោយវិញទៀត ដោយបានទទួលការខូចខាតជាដំណំ ។
១២ មែនហើយ ពួកគេបានទៅម្ដងទៀតជាលើកទីបី ហើយក៏
ទទួលការខូចខាតដូចមុន; ឯពួកអ្នកដែលពុំត្រូវគេសម្លាប់ចោល
ក៏បាន ត្រឡប់មកទីក្រុងនីហ្វៃវិញ ។
១៣ ហើយពួកគេបានបន្ទាបខ្លួនស្មើនឹងធូលីដី ដាក់ខ្លួនក្រោមនឹម
នៃសេវកភាព សុខចិត្តឲ្យគេវាយខ្លួន ហើយឲ្យគេដេញទៅមក
ហើយឲ្យផ្ទុកតាមទំនើងចិត្តនៃពួកខ្មាំងសត្រូវរបស់គេ ។
១៤ ហើយគេបានបន្ទាបខ្លួនចុះដល់ជំរៅនៃ[ក]ភាពទន់ទាប;
ហើយគេបានអំពាវនាវជាខ្លាំងទៅរកព្រះ; មែនហើយ គឺពេញ
មួយថ្ងៃ ពួកគេបានស្រែកអំពាវនាវទៅរកព្រះរបស់គេ សូមឲ្យ
ទ្រង់ដោះពួកគេឲ្យផុតពីការវេទនារបស់គេ ។
១៥ ហើយឥឡូវនេះ ព្រះអម្ចាស់ទ្រង់[ក]ក្រឮសំរែករបស់ពួកគេ
ដោយសារតែអំពើទុច្ចរិតរបស់ពួកគេ; ទោះជាយ៉ាងណាក្ដី
គង់តែ ព្រះអម្ចាស់ទ្រង់បានឮសំរែករបស់គេដែរ ហើយបាន
ចាប់ផ្ដើមបន្ទន់ចិត្តពួកលេមិន ដើម្បីពួកគេបានចាប់ផ្ដើមសំរាល
បន្ទុកឲ្យគេ; តែព្រះ អម្ចាស់ទ្រង់មិនបានទតឃើញថាល្មមនឹងដោះ
ពួកគេ ឲ្យផុតពីសេវកភាពនៅឡើយទេ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ចាប់ផ្ដើមចំរើនឡើងបន្តិចម្ដងៗ នៅលើដែនដី ហើយបាន
ចាប់ផ្ដើមផលិត ធញ្ញជាតិជាច្រើនបរិបូរណ៍ និងហ្វូងចៀម និង
ហ្វូងគោ ដើម្បីកុំឲ្យពួកគេវេទនាដោយការអត់ឃ្លាន ។
១៧ ឥឡូវនេះ មានចំនួនស្ត្រីជាច្រើនលើសជាងពួកបុរស;
ហេតុដូច្នេះហើយ ស្ដេចលិមហៃបានបញ្ជាឲ្យបុរសម្នាក់ៗ
ត្រូវ[ក]ជួយទំនុក បំរុងដល់[ខ]ស្ត្រីមេម៉ាយ និងកូនៗរបស់គេផង
ដើម្បីកុំឲ្យគេត្រូវវិនាសដោយអត់ឃ្លាន; ហើយគេធ្វើយ៉ាងនេះ
ក៏ដោយសារតែពួកគេ មួយចំនួនធំត្រូវគេសម្លាប់ចោល ។
១៨ ឥឡូវនេះ ប្រជាជនលិមហៃបានប្រមូលគ្នាមកជាផ្លុងមួយ
ឲ្យមានគ្នាច្រើនដែលអាចរួបរួមបាន ហើយបានការពារធុញ្ញជាតិ
របស់គេ និងសត្វរបស់គេ ។
១៩ សូម្បីតែស្ដេចផ្ទាល់ ក៏ពុំហ៊ានចេញទៅខាងក្រៅ

**២១** ៣ *ក* ម៉ូសាយ ១២:២.
*ខ* ម៉ូសាយ ១២:៥.
៩ *ក* ម៉ូសាយ ១២:៤.
១៤ *ក* ម៉ូសាយ ២៩:២០.
ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
១៥ *ក* សុភា. ១៥:២៩;
ម៉ូសាយ ១១:២៣–២៥;
គ. និង ស. ១០១:៧–៩.
១៧ *ក* ម៉ូសាយ ៤:១៦, ២៦.
*ខ* ស.ប. ស្រីមេម៉ាយ.

កំផែងក្រុងដែរ លើកលែងតែទ្រង់មានពួកអ្នកយាមទៅជាមួយនឹងទ្រង់ដែរ ដោយខ្លាចក្រែងថៃដន្យណាមួយ ទ្រង់ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកលេមិន ។

២០ ហើយទ្រង់បានចាត់ឲ្យប្រជាជនទ្រង់យាមជុំវិញដែនដី ក្រែងថៃដន្យណាមួយ គេអាចចាប់បានពួកសង្ឃដែលបានរត់ចូលទៅក្នុង ទីរហោស្ថាន ដែលបានលួចយក[ក]ពួកកូនក្រមុំរបស់ពួកលេមិន ហើយដែលបានបង្កឲ្យមានការបំផ្លិចបំផ្លាញដ៏ធំបែបនេះមកលើពួកគេ ។

២១ ព្រោះពួកគេចង់ចាប់ពួកនោះ ដើម្បីយកមកធ្វើទោស; ព្រោះពួកគេបានចូលមកលើដែនដីនីហ្វៃ ក្នុងពេលយប់ ហើយបានលួច យកធញ្ញជាតិ និងវត្ថុមានតម្លៃរបស់គេជាច្រើន; ហេតុដូច្នេះហើយ ពួកគេបានបង្កប់ខ្លួនចាំពួកនោះ ។

២២ ហើយហេតុការណ៍បានកើតឡើងថា ពុំមានការរំខានឆាឆៅគ្នារវាងពួកលេមិននឹងប្រជាជនរបស់លិមហៃទៀតឡើយ រហូតដល់ពេលដែល[ក]អាំម៉ូន និងបងប្អូនរបស់លោកចូលមកលើដែនដី ។

២៣ ហើយនៅពេលស្ដេចចេញទៅខាងក្រៅទ្វារកំផែងក្រុងជាមួយនឹងទាហានយាមរបស់ទ្រង់ ក៏បានឃើញអាំម៉ូន និងបងប្អូន របស់លោក; ហើយដោយសន្និដ្ឋានថា ពួកគេជាពួកសង្ឃរបស់ណូអេ ហេតុដូច្នេះហើយ ទើបទ្រង់បានចាត់ឲ្យគេចាប់ពួកគេ ហើយចង ដាក់[ក]ក្នុងគុក ។ ហើយបើសិនជាពួកគេជាសង្ឃរបស់ណូអេមែននោះ ច្បាស់ជាទ្រង់បញ្ជាឲ្យយកគេទៅប្រហារទៅហើយ ។

២៤ ប៉ុន្តែ ពេលទ្រង់បានជ្រាបថា ពួកគេពុំមែនជាពួកសង្ឃទេ តែពួកគេជាបងប្អូនរបស់ទ្រង់ ហើយបានមកពីដែនដីសារ៉ាហិមឡា ទើបទ្រង់ពោរពេញទៅដោយក្ដីសោមនស្សជាអតិបរមា ។

២៥ ឥឡូវនេះ [ក]មុនពេលអាំម៉ូន[ខ]មកដល់ ស្ដេចលិមហៃបានបញ្ជាឲ្យបុរសមួយក្រុមតូចទៅរកដែនដីសារ៉ាហិមឡា; តែពួកគេរកពុំ ឃើញសោះ ហើយគេវង្វេងនៅក្នុងទីរហោស្ថាន ។

២៦ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបានជួបប្រទះឃើញដែនដីមួយ ដែលធ្លាប់មានមនុស្សអាស្រ័យនៅ; មែនហើយ ជាដែនដីមួយដែលពេញដោយ[ក]ឆ្អឹងក្រៀម; មែនហើយ ជាដែនដីមួយ ដែលធ្លាប់មានមនុស្សអាស្រ័យនៅ ហើយត្រូវបានបំផ្លាញចោល; ហើយពួកគេដោយបានគិតស្មានថា នោះជាដែនដីសារ៉ាហិមឡា ក៏បានត្រឡប់ទៅដែនដីនីហ្វៃវិញ បានមកដល់ក្នុងតំបន់ព្រំប្រទល់មិន យូរថ្ងៃប៉ុន្មាន មុនពេលអាំម៉ូនមក ។

២៧ ហើយពួកគេបានយកបញ្ជីមួយមកជាមួយផង ដែលជាបញ្ជីរបស់ប្រជាជន ដែលពួកគេបានជួបប្រទះឃើញឆ្អឹងនោះ; ហើយបញ្ជី នោះចារនៅលើផ្ទាំងដែកទាំងឡាយ ។

២៨ ហើយឥឡូវនេះ លិមហៃបានពោរពេញទៅដោយសេចក្ដីអំណរទៀត កាលបានដឹងពីមាត់របស់អាំម៉ូនមកថា ស្ដេច[ក]ម៉ូសាយ បានអំណោយទានមួយមកពីព្រះ ដោយសារអំណោយទាននោះ ទ្រង់អាចបកប្រែឆ្លាក់ត្រាបែបនេះបាន; មែនហើយ ហើយអាំម៉ូនក៏ អររីករាយផងដែរ ។

២៩ តែអាំម៉ូន និងបងប្អូនលោកពោរពេញដោយសេចក្ដីសោកសៅ ពីព្រោះបងប្អូនលោកជាច្រើនត្រូវគេសម្លាប់ចោល;

៣០ ហើយថែមទាំងព្រួយ ដោយសារស្ដេចណូអេ ព្រមទាំងពួកសង្ឃរបស់ទ្រង់ បានធ្វើឲ្យប្រជាជនប្រព្រឹត្តអំពើបាប និងអំពើទុច្ចរិត ជាច្រើនទាស់នឹងព្រះ; ហើយពួកគេក៏បានកាន់ទុក្ខ[ក]ដល់សេចក្ដីស្លាប់របស់អ័ប៊ីណាដៃ; ហើយ[ខ]ដល់ការចាកចេញទៅរបស់អាលម៉ា និង ប្រជាជនដែលទៅជាមួយលោកផង ដែលបានសាងឡើងនូវសាសនាចក្រនៃព្រះមួយ តាមរយៈកម្លាំងនិងព្រះចេស្ដានៃព្រះ និងសេចក្ដី ជំនឿជឿដល់ពាក្យទាំងឡាយដែលអ័ប៊ីណាដៃបាននិយាយ ។

៣១ មែនហើយ ពួកគេកាន់ទុក្ខដោយសារការចាកចេញទៅនៃពួកនោះ ព្រោះពួកគេពុំដឹងថា តើពួកនោះបានទៅទីណាទេ ។ ឥឡូវនេះ ពួកគេច្បាស់ជាបានរួបរួមគ្នា ដោយរីករាយជាមួយនឹងអ្នកទាំងនោះ ព្រោះពួកគេផ្ទាល់ក៏បានចូលក្នុងសេចក្ដីសញ្ញាជាមួយ នឹងព្រះ ដើម្បីបំរើទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

៣២ ហើយឥឡូវនេះ ចាប់តាំងពីអាំម៉ូនបានមកដល់ នោះស្ដេចលិមហៃក៏បានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងព្រះដែរ ព្រមទាំងប្រជាជនរបស់ទ្រង់ជាច្រើនផង ដើម្បីបំរើទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

៣៣ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចលិមហៃនិងប្រជាជនទ្រង់ជាច្រើន ចង់ទទួលបុណ្យជ្រមុជទឹក; តែគ្មានអ្នកណាម្នាក់ សោះនៅលើដែនដី ដែលមានអំណាចពីព្រះឡើយ ។

២០ *ក* ម៉ូសាយ ២០:៥.
២២ *ក* ម៉ូសាយ ៧:៦–១៣.
២៣ *ក* ហេលេ. ៥:២១.
២៥ *ក* ម៉ូសាយ ៨:៧.
*ខ* ម៉ូសាយ ៧:១៤.
២៦ *ក* ម៉ូសាយ ៨:៨.
២៨ *ក* អោមណៃ ១:២០–២២; ម៉ូសាយ ២៨:១១–១៦.
៣០ *ក* ម៉ូសាយ ១៧:១២–២០.
*ខ* ម៉ូសាយ ១៨:៣៤–៣៥.
៣៣ *ក* ស.ប. សិទ្ធិអំណាច.

ហើយអាំម៉ូនមិនព្រមធ្វើការនេះ ដោយចាត់ថា រូបលោកជាអ្នកបំរើម្នាក់មិន សក្តិសម ។

៣៤ ហេតុដូច្នេះហើយ ពេលនោះពួកគេពុំបានរួបរួមគ្នា ជាសាសនាចក្រមួយនៅឡើយទេ ដោយរង់ចាំព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ ឥឡូវនេះ ពួកគេចង់ឲ្យបានដូចជាអាលម៉ា និងបងប្អូនលោក ដែលបានរត់ចូលទៅក្នុងទីរហោស្ថាន ។

៣៥ ពួកគេចង់ទទួលបុណ្យជ្រមុជទឹក ទុកជាសាក្សី ហើយជាទីបន្ទាល់ថា ពួកគេស្ម័គ្រចិត្តនឹងបំរើព្រះ ឲ្យអស់ពីដួងចិត្តគេ; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបានពន្យាពេលដែរ; ហើយដំណើររឿងអំពីបុណ្យជ្រមុជទឹករបស់ពួកគេ នឹងមានថែងនៅពេល ក្រោយ ។

៣៦ ហើយឥឡូវនេះ ការសិក្សាទាំងស្រុងរបស់អាំម៉ូន និងរាស្ត្ររបស់លោក ព្រមទាំងស្តេចលិមហៃ និងរាស្ត្ររបស់ទ្រង់ គឺដើម្បី ដោះខ្លួនឲ្យរួចពីកណ្តាប់ដៃនៃពួកលេមិន និងពីសេវកភាព ៕

## ជំពូកទី ២២

*ផែនការទាំងឡាយត្រូវរៀបចំឡើង សំរាប់ឲ្យប្រជាជនបានរួចផុតពីសេវកភាពពីពួកលេមិន — ពួកសាសន៍លេមិនត្រូវគេធ្វើឲ្យស្រវឹង — ប្រជាជនលួចរត់ត្រឡប់ទៅដែនដីសារ៉ាហិមឡាវិញ ហើយក្លាយជាប្រជាជនស្តេចម៉ូសាយ ។ ប្រមាណជាឆ្នាំ ១២១–១២០ ម.គ.ស.។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាំម៉ូន និងស្តេចលិមហៃបានចាប់ផ្តើមពិគ្រោះជាមួយនឹងប្រជាជនថា តើគេត្រូវធ្វើយ៉ាង ណា ដើម្បីដោះខ្លួនឲ្យរួចផុតពីសេវកភាព; ហើយពួកគេថែមទាំងបានចាត់ឲ្យប្រជាជនទាំងអស់ប្រមូលគ្នាមក; ហើយគេធ្វើយ៉ាងនេះ ដើម្បីគេអាចបានសម្លេងរបស់ប្រជាជនអំពីបញ្ហានេះ ។

២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេពុំអាចរកឃើញផ្លូវណាមួយឡើយ ដើម្បីដោះខ្លួនឲ្យរួចផុតពីសេវកភាពលើកលែង តែយកប្រពន្ធ និងកូនរបស់គេ និងហ្វូងចៀមរបស់គេ និងហ្វូងគោរបស់គេ និងត្រសាលរបស់គេ ហើយចាកចេញទៅក្នុងទីរហោស្ថាន ប៉ុណ្ណោះ; ព្រោះពួកលេមិនមានគ្នាច្រើនពេក ពុំអាចឲ្យប្រជាជនលិមហៃតតាំងនឹងពួកគេបានទេ បើគិតថាដោះខ្លួនឲ្យរួចផុតពីសេវកភាព ដោយប្រើដាវវិញ ។

៣ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា គេឌានបានឈានទៅមុខ ហើយឈរនៅចំពោះមុខស្តេច ហើយទូលទ្រង់ថា៖ ឥឡូវនេះ សូមព្រះរាជាទ្រង់ជ្រាប ទ្រង់បានស្តាប់តាមពាក្យរបស់ទូលបង្គំជាច្រើនលើកច្រើនគ្រាមកហើយ កាលដែលយើងតតាំង ជាមួយនឹងបងប្អូនរបស់យើង គឺពួកលេមិន ។

៤ ហើយឥឡូវនេះ ឱព្រះរាជាអើយ បើសិនជាទ្រង់ពុំយល់ថារូបទូលបង្គំនេះជាអ្នកបំរើម្នាក់ដ៏ឥតប្រយោជន៍ទេ ឬបើសិនជាពីមុន ទ្រង់បានស្តាប់ពាក្យរបស់ទូលបង្គំខ្លះ ហើយពាក្យទាំងនោះត្រូវបានយកមកប្រើការចំពោះទ្រង់ ហេតុដូច្នេះហើយទូលបង្គំចង់ឲ្យទ្រង់ ស្តាប់ពាក្យទូលបង្គំនៅពេលនេះដែរ ហើយទូលបង្គំនឹងធ្វើជាអ្នកបំរើរបស់ទ្រង់ ហើយដោះប្រជាជននេះឲ្យរួចផុត ពីសេវកភាព ។

៥ ហើយស្តេចបានអនុញ្ញាតឲ្យលោកនិយាយ ហើយគេឌានបានទូលទ្រង់ថា៖

៦ មើលចុះ ផ្លូវខាងក្រោយ កាត់ចូលតាមកំផែងក្រោយដែលនៅផ្នែកខាងក្រោយទីក្រុង ។ ពួកលេមិន ឬពួកទាហានយាមនៃពួក លេមិន វាស្រវឹងនៅពេលយប់; ហេតុដូច្នេះហើយ ចូរយើងចេញការប្រកាសមួយដល់ចំណោមអស់ទាំងប្រជាជននេះ ឲ្យគេប្រមូល ហ្វូងចៀម និងហ្វូងគោរបស់គេ ដើម្បីពួកគេអាចដឹកសត្វទាំងនេះ ចូលទៅក្នុងទីរហោស្ថាន នៅពេលយប់ចុះ ។

៧ ហើយទូលបង្គំនឹងធ្វើតាមបញ្ជារបស់ទ្រង់ ទៅប្រគល់ស្រាទំពាំងបាយជូរ ដែលជាពន្ធដារចុងក្រោយបង្អស់ដល់ពួកលេមិន ហើយពួកគេនឹងស្រវឹង; ហើយយើងនឹងទៅតាមផ្លូវសម្ងាត់ ដែលនៅខាងឆ្វេងបន្ទាយរបស់ពួកគេនោះ កាលពួកគេស្រវឹងដេកលក់ ។

៨ នោះយើងនឹងធ្វើដំណើរចេញទៅជាមួយនឹងពួកស្ត្រីរបស់យើង និងកូនចៅរបស់យើង និងហ្វូងចៀមរបស់យើង និងហ្វូងគោ របស់យើង ចូលទៅក្នុងទីរហោស្ថាន; ហើយយើងនឹងធ្វើដំណើរព័ទ្ធជុំវិញដែនដីសែឡោម ។

៩ ហើយហេតុការណ៍បានកើតឡើងថា ស្តេចបានស្តាប់តាមពាក្យរបស់គេឌាន ។

១០ ហើយស្តេចលិមហៃបានបញ្ជាឲ្យប្រជាជនទ្រង់ ប្រមូលសត្វ

៣៥ *ក* ម៉ូសាយ ២៥:១៧–១៨.

របស់គេ; ហើយទ្រង់បានប្រគល់ពន្លដារ ជាស្រាទំពាំងបាយជូរទៅ
ឲ្យពួកលេមិន; ហើយទ្រង់ក៏បានប្រគល់ស្រាទំពាំងបាយជូរ ជា
អំណោយទៀតដល់ពួកគេ; ហើយពួកគេបានផឹកតាមចិត្ត
នូវស្រាទំពាំង បាយជូរ ដែលស្ដេចលិមហៃបានប្រគល់ឲ្យនោះ។
១១ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជន
របស់ស្ដេចលិមហៃបានចេញដំណើរនៅពេលយប់ ចូលទៅក្នុង
ទីរហោស្ថាន ជាមួយនឹងហ្វូងចៀមរបស់គេ និងហ្វូងគោ
របស់គេ ហើយពួកគេបានដើរព័ទ្ធជុំវិញដែនដីសៃឡោម ក្នុង
ទីរហោស្ថាន ហើយបត់ឆ្ពោះទៅ ដែនដីសារ៉ាហិមឡា ដែល
នាំមុខដោយអាំម៉ូន និងបងប្អូនលោក ។
១២ ហើយពួកគេបានយកអស់ទាំងមាស និងប្រាក់របស់គេ
និងវត្ថុមានតម្លៃរបស់គេទាំងឡាយ ដែលគេអាចយកបាន ព្រមទាំង
ស្បៀងអាហាររបស់គេ ចូលទៅក្នុងទីរហោស្ថានផង ហើយ
ពួកគេបន្ដដំណើររបស់គេទៅ ។
១៣ ហើយបន្ទាប់ពីនៅក្នុងទីរហោស្ថានអស់ជាច្រើនថ្ងៃមក
នោះពួកគេបានមកដល់ដែនដីសារ៉ាហិមឡា ហើយបានរួបរួម
ជាមួយនឹងប្រជាជនរបស់ម៉ូសាយ ហើយក្លាយទៅជាប្រជាជន
របស់ទ្រង់ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ម៉ូ[ក]សាយបានទទួល
ពួកគេដោយសេចក្ដីអំណរ; ហើ[ខ]យទ្រង់ក៏បានទទួលបញ្ជីទាំងឡាយ
របស់ពួកគេផង ព្រមទាំងបញ្ជីទាំងឡាយ ដែលប្រជាជន
លិមហៃ បានជួបប្រទះឃើញនោះផង ។
១៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ពួកលេមិនបានដឹងថា ប្រជាជនលិមហៃបានចេញចោលដែនដីទៅ
នៅ ពេលយប់ នោះពួកគេបានចាត់ឲ្យកងទ័ពមួយចំនួន ចូលទៅ
ក្នុងទីរហោស្ថាន ដើម្បីដេញតាមពួកគេ ។
១៦ ហើយបន្ទាប់ពីពួកគេបានដេញតាមអស់រយៈពេលពីរថ្ងៃមក
នោះពួកគេមិនអាចតាមដានបានទៀតឡើយ; ហេតុដូច្នេះហើយ
ពួកគេក៏វង្វេងនៅក្នុងទីរហោស្ថានទៅ ៕

---

ដំណើររឿងអំពីអាលម៉ា និងរាស្ដ្រនៃព្រះអម្ចាស់ ដែល
ត្រូវដេញឲ្យចូលទៅក្នុងទីរហោស្ថាន ដោយប្រជាជន
របស់ស្ដេចណូអេ ។

*មាននូវមនៅក្នុងជំពូកទី ២៣ និង ២៤ ។*

## ជំពូកទី ២៣

*អាលម៉ាមិនព្រមធ្វើជាស្ដេច — លោកបំរើជាសង្ឃជាន់ខ្ពស់ — ព្រះអម្ចាស់ទ្រង់ប្រដៅរាស្ដ្រទ្រង់ ហើយពួកសាសន៍លេមិនវាយ យកដែនដីហេឡាម — អាមូឡុនជាមេដឹកនាំពួកសង្ឃទុច្ចរិតនៃស្ដេចណូអេ គ្រប់ គ្រងដោយនៅចំណុះក្រោមរាជ្យលេមិន ។ ប្រមាណជាឆ្នាំ ១៤៥–១២១ ម.គ.ស. ។*

ឥឡូវនេះ អាលម៉ា ដោយបានទទួលការព្រមានពីព្រះអម្ចាស់ថា
ពលទ័ពរបស់ស្ដេចណូអេនឹងមកវាយពួកគេ ហើយដោយបាន
ប្រាប់ឲ្យ ប្រជាជនរបស់លោកដឹងរឿងនេះ ហេតុដូច្នេះហើយ
ទើបពួកគេប្រមូលហ្វូងចៀមរបស់គេ ហើយយកធញ្ញជាតិ
របស់គេ ហើយបានចេញ ដំណើរទៅក្នុងទីរហោស្ថាន
មុនពេលពលទ័ពរបស់ស្ដេចណូអេមកដល់ ។
២ ហើយព្រះអម្ចាស់ទ្រង់បានប្រទានកម្លាំងឲ្យពួកគេ ដើម្បីកុំឲ្យ
ពលរបស់ស្ដេចណូអេអាចតាមទាន់ ហើយបំផ្លាញពួកគេចោល
ឡើយ ។
៣ ហើយពួកគេបានធ្វើដំណើរអស់ប្រាំបីថ្ងៃ នៅក្នុងទីរហោស្ថាន។
៤ ហើយពួកគេបានមកដល់ដែនដីមួយ មែនហើយ ជា
ដែនដីដ៏ល្អ ហើយមានសម្រស់ក្រៃលែង ជាដែនដីមួយដែល
មានទឹកសុទ្ធ ។
៥ ហើយពួកគេបានបោះត្រសាល ហើយបានចាប់ផ្ដើមភ្ជួរដី
ហើយចាប់ផ្ដើមសង់អាគារទាំងឡាយ មែនហើយ ពួកគេជា
អ្នក ឧស្សាហ៍ ហើយធ្វើពលកម្មដោយអស់ពីកម្លាំង ។
៦ ហើយប្រជាជនមានបំណងចង់ឲ្យអាល់ម៉ាធ្វើជាស្ដេចពួក
គេ ព្រោះលោកជាមនុស្សម្នាក់ដែលពួកគេស្រឡាញ់ ។
៧ [ក]ប៉ុន្តែ លោកបាននិយាយទៅកាន់ពួកគេថា៖ មើលចុះ
យើងមិនចាំបាច់ត្រូវមានស្ដេចទេ; ត្បិតព្រះអម្ចាស់ ទ្រង់មាន
ព្រះបន្ទូល ដូច្នេះថា៖ អ្នករាល់គ្នាមិនត្រូវលើកដំកើងមនុស្ស
ម្នាក់ ជាងមនុស្សម្នាក់ទៀតឡើយ ឬបុរសម្នាក់មិនត្រូវគិតថា
ខ្លួនខ្ពស់ជាងម្នាក់ទៀតទេ; ហេតុដូច្នេះហើយ ខ្ញុំប្រាប់អ្នករាល់
គ្នាថា អ្នករាល់គ្នាមិនចាំបាច់ត្រូវមានស្ដេចឡើយ ។
៨ ក៏ប៉ុន្តែ បើសិនជាអ្នករាល់គ្នាមានលទ្ធភាពអាចរកបាន
ជានិច្ចនូវបុរសសុចរិតទាំងឡាយ ដើម្បីឲ្យធ្វើជាស្ដេច
នោះប្រសើរហើយ ដែលអ្នកមានស្ដេច ។
៩ ប៉ុន្តែ ចូរចាំនូវអំ[ក]ពើទុច្ចរិតរបស់ស្ដេចណូអេ និងពួកសង្ឃ

២២ ១៤*ក* ម៉ូសាយ ៨:៥.
*ខ* ម៉ូសាយ ៨:៩.

២៣ ៧*ក* ម៉ូសាយ ២៧:៣–៥.
៩ *ក* សុភា. ១៦:១២;
ម៉ូសាយ ១១:១–១៥.

របស់ទ្រង់; ហើយខ្ញុំផ្ទាល់ក៏ធ្លាប់ធ្លាក់ទៅក្នុងអន្ទាក់ ហើយបាន
ធ្វើអំពើគួរ ខ្ពើមឆ្អើមជាច្រើន ចំពោះព្រះអម្ចាស់ ដែលបាន
ធ្វើឲ្យខ្ញុំប្រែចិត្តដ៏ធ្ងន់;
១០ ក៏ប៉ុន្តែ បន្ទាប់ពីបានឆ្លងកាត់ការលំបាកជាច្រើនមក ព្រះ
អម្ចាស់ទ្រង់បានឮសំរែករបស់ខ្ញុំ ហើយបានឆ្លើយតបនឹង
ពាក្យអធិស្ឋាន របស់ខ្ញុំ ហើយបានធ្វើឲ្យខ្ញុំទៅជាគ្រឿង
ឧបករណ៍មួយ នៅក្នុងព្រះហស្តទ្រង់ ដោយបាននាំអ្នករាល់គ្នា
ជាច្រើន ឲ្យស្គាល់នូវសេចក្ដីពិត របស់ទ្រង់ ។
១១ ក៏ប៉ុន្តែ ខ្ញុំមិនយករឿងនេះ មកសរសើរដំកើងដល់ខ្ញុំទេ
ព្រោះខ្ញុំពុំសក្តិសមនឹងដំកើងដល់រូបខ្ញុំដូច្នោះឡើយ ។
១២ ហើយឥឡូវនេះ ខ្ញុំប្រាប់អ្នកថា អ្នករាល់គ្នាធ្លាប់ត្រូវ
ស្ដេចណូអេជិះជាន់ ហើយធ្លាប់នៅក្នុងសេវកភាពបំរើទ្រង់ និង
ពួកសង្ឃ របស់ទ្រង់ ហើយធ្លាប់បានពួកគេនាំចូលទៅក្នុងអំពើ
ទុច្ចរិត; ហេតុដូច្នេះហើយ អ្នករាល់គ្នាត្រូវជាប់ចំណងទាំង
ឡាយនៃអំពើទុច្ចរិត ឡើយ ។
១៣ ហើយឥឡូវនេះ ដូចជាអ្នករាល់គ្នាត្រូវបានដោះខ្លួន
រួចពីចំណងទាំងនេះហើយ ដោយសារព្រះចេស្ដានៃព្រះជាយ៉ាង
ណា; មែនហើយ គឺបានរួចផុតពីកណ្ដាប់ដៃនៃស្ដេចណូអេ និង
ប្រជាជនទ្រង់ ហើយបានរួចពីចំណងទាំងឡាយនៃអំពើទុច្ចរិតផង
នោះខ្ញុំក៏ចង់ឲ្យ អ្នករាល់គ្នាឈរឲ្យរឹងប៉ឹងក្នុងឥស្សរភាពនេះ
ដែលធ្វើឲ្យអ្នករាល់គ្នាមានសេរីជាយ៉ាងនោះដែរ ហើយ
ចូរអ្នករាល់គ្នាកុំទុកចិត្តលើបុរស ណាម្នាក់ ឲ្យធ្វើជាស្ដេចលើ
អ្នករាល់គ្នាឡើយ ។
១៤ ហើយក៏កុំទុកចិត្តលើនរណាម្នាក់ ឲ្យធ្វើជាគ្រូអ្នក ឬជា
សង្ឃប្រដៅអ្នកដែរ លើកលែងតែអ្នកនោះជាអ្នកសំណប់នៃព្រះ
ដែលដើរតាមផ្លូវរបស់ទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំង
ឡាយរបស់ទ្រង់ប៉ុណ្ណោះ ។
១៥ ម្ល៉ោះហើយ អាលម៉ាបានបង្រៀនប្រជាជនលោកថា មនុស្ស
គ្រប់រូបត្រូវស្រឡាញ់អ្នកជិតខាងខ្លួន ឲ្យដូចស្រឡាញ់ខ្លួនឯង
គឺមិនត្រូវមានការទាស់ទែងគ្នាឡើយ ។
១៦ ហើយឥឡូវនេះ អាលម៉ាគឺជាសង្ឃជាន់ខ្ពស់របស់ពួក
គេ គឺលោកជាអ្នកបង្កើតសាសនាចក្ររបស់ពួកគេឡើង ។
១៧ ហើយហេតុការណ៍បានកើតឡើងថា គ្មានអ្នកណាម្នាក់បាន
ទទួលសិទ្ធិអំណាច ដើម្បីផ្សាយសាសនា ឬបង្រៀនឡើយ
លើកលែងតែអ្នកដែលបានទទួលសិទ្ធិអំណាចមកពីព្រះ
ប៉ុណ្ណោះ ។ ហេតុដូច្នេះហើយ លោកបានតាំងអស់ទាំងសង្ឃ
របស់គេ និងអស់ទាំងគ្រូរបស់គេ ហើយគ្មានអ្នកណាម្នាក់បាន
តាំងឡើយ លើកលែងតែពួកគេជាមនុស្សសុចរិត ។
១៨ ហេតុដូច្នេះហើយ ពួកគេបានថែទាំប្រជាជន ហើយបាន
ផ្ដល់ដល់គេ នូវអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ចាប់ផ្ដើមចំរើនឡើងជាអតិបរមានៅលើដែនដី;
ហើយគេហៅដែនដី នោះថា ហេឡាម ។
២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានកើនចំនួន
ហើយបានចំរើនឡើងជាអតិបរមា នៅលើដែនដីហេឡាម;
ហើយគេបានសង់ទីក្រុងមួយ ដែលគេហៅទីក្រុងនោះថា
ទីក្រុងហេឡាម ។
២១ ក៏ប៉ុន្តែ ព្រះអម្ចាស់ទ្រង់យល់ឃើញថាល្មមប្រដៅ
រាស្ត្រទ្រង់; មែនហើយ ទ្រង់បានសាកល្បងសេចក្ដីអត់ធន់
និងសេចក្ដីជំនឿ របស់ពួកគេ ។
២២ ក៏ប៉ុន្តែ — អស់អ្នកណាដែលដាក់ទីទុកចិត្ត
របស់ខ្លួនទៅលើទ្រង់ អ្នកនោះហើយដែលនឹងត្រូវបានលើកឡើង
នៅថ្ងៃចុង ក្រោយបង្អស់ ។ មែនហើយ ចំពោះរាស្ត្រនេះ
គឺដូច្នោះឯង ។
២៣ ត្បិតមើលចុះ ខ្ញុំនឹងបង្ហាញដល់អ្នកថា ពួកគេត្រូវបាននាំឲ្យ
ធ្លាក់ទៅក្នុងសេវកភាព ហើយគ្មានអ្នកណាម្នាក់អាចដោះពួក
គេ បានឡើយ លើកលែងតែព្រះអម្ចាស់ ជាព្រះ
របស់គេប៉ុណ្ណោះ មែនហើយ គឺជាព្រះនៃអ័ប្រាហាំ និងអ៊ីសាក
និងយ៉ាកុប ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានដោះលែង

៩ *ខ* ម៉ូសាយ ១៧:១–៤.
១០ *ក* គ. និង ស. ៥៨:៤.
*ខ* ម៉ូសាយ ១៨:៣៥.
១២ *ក* ២ នីហ្វៃ ២៨:១៩–២២.
១៣ *ក* កាឡាទី ៥:១.
*ខ* ស.ប. ឥស្សរភាព.
*គ* ម៉ូសាយ ២៩:១៣.
១៤ *ក* ម៉ូសាយ ១៨:១៨–២២.
១៥ *ក* ស.ប. សេចក្ដីស្រឡាញ់.
*ខ* ៣ នីហ្វៃ ១១:២៨–២៩.
១៦ *ក* ម៉ូសាយ ២៦:៧.
១៧ *ក* ស.ប. សិទ្ធិអំណាច; បព្វជិតភាព.
១៨ *ក* ១ ធីម៉ូ. ៤:៦.
២១ *ក* ហេលេ. ១២:៣;
គ. និង ស. ៩៨:២១.
ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. សេចក្ដីអត់ធន់.
២២ *ក* ស.ប. ទុកចិត្ត.
*ខ* ១ នីហ្វៃ ១៣:៣៧.

ពួកគេ ហើយទ្រង់បានបង្ហាញនូវព្រះចេស្ដាដ៏ឥទ្ធិឫទ្ធិរបស់ទ្រង់ដល់គេ ហើយគេមានសេចក្ដីសោមនស្សជាអនេក ។

២៥ ត្បិតមើលចុះ ហេតុការណ៍បានកើតឡើងថា កាលពួកគេនៅលើដែនដីហេឡាម មែនហើយ នៅក្នុងទីក្រុងហេឡាមនៅ ពេលកំពុងភ្ជួរដីនៅជុំវិញនោះ មើលចុះ មានកងទ័ពសាសន៍លេមិនបានមកក្នុងតំបន់ព្រំដែន ។

២៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បងប្អូនរបស់អាលម៉ាបានរត់គេចពីទីវាលរបស់គេ ហើយប្រមូលគ្នាមកនៅឯទីក្រុងហេឡាម; ហើយពួកគេតក់ស្លុតជាខ្លាំង ដោយព្រោះឃើញពួកលេមិនលេចមក ។

២៧ ប៉ុន្តែ អាលម៉ាបានចេញទៅ ហើយឈរក្នុងចំណោមពួកគេ ហើយទូន្មានពួកគេថា មិនត្រូវតក់ស្លុតទេ តែគេត្រូវនឹកចាំដល់ ព្រះអម្ចាស់ ជាព្រះរបស់គេវិញ ហើយទ្រង់នឹងដោះលែងពួកគេ ។

២៨ ហេតុដូច្នេះហើយ ពួកគេក៏រំងាប់ការតក់ស្លុតរបស់គេទៅ ហើយបានចាប់ផ្ដើមអំពាវនាវដល់ព្រះអម្ចាស់ សូមឲ្យទ្រង់បន្ធន់ចិត្ត ពួកលេមិន ដើម្បីគេទុកជីវិតឲ្យពួកគេ និងប្រពន្ធគេ និងកូនចៅគេ ។

២៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានបន្ធន់ចិត្តពួកលេមិន ។ ហើយអាលម៉ា និងបងប្អូនលោកបានចេញទៅ ហើយប្រគល់ខ្លួនទៅក្នុងកណ្ដាប់ដៃរបស់ពួកគេ ហើយពួកលេមិនបានយកដែនដីហេឡាម ។

៣០ ឥឡូវនេះ ពលទ័ពសាសន៍លេមិន ដែលបានដេញតាមប្រជាជនរបស់ស្ដេចលិមហៃនោះបានវង្វេង នៅក្នុងទីរហោស្ថានអស់ ជាច្រើនថ្ងៃ ។

៣១ ហើយមើលចុះ ពួកគេបានជួបប្រទះឃើញពួកសង្ឃរបស់ស្ដេចណូអេ នៅត្រង់កន្លែងមួយ ដែលគេហៅថា អាមូឡុន; ហើយ ពួកគេបានចាប់ផ្ដើមយកដែនដីអាមូឡុនហើយចាប់ផ្ដើមភ្ជួររាស់ដីនោះ ។

៣២ ឥឡូវនេះ មេដឹកនាំរបស់ពួកសង្ឃនោះ មានឈ្មោះថា អាមូឡុន ។

៣៣ ហើយហេតុការណ៍បានកើតឡើងថា អាមូឡុនបានអង្វរពួក[ក]លេមិន; ហើយគាត់ថែមទាំងបានចាត់ឲ្យប្រពន្ធខ្លួនដែលជា កូនក្រមុំរបស់ពួកលេមិន ទៅអង្វរដល់បងប្អូនគេសុំកុំឲ្យបំផ្លាញប្ដីរបស់ខ្លួនចោលឡើយ ។

៣៤ ហើយពួកលេមិនមាន[ក]ចិត្តមេត្តាដល់អាមូឡុន និងបងប្អូនរបស់គាត់ ហើយពុំបានបំផ្លាញពួកគេចោលឡើយ ដោយសារតែ ប្រពន្ធរបស់ពួកគេនោះឯង ។

៣៥ ហើយអាមូឡុន និងបងប្អូនគាត់ បានចូលរួបរួមជាមួយនឹងពួកលេមិន ហើយកាលពួកគេកំពុងតែធ្វើដំណើរនៅក្នុងទីរហោស្ថានស្វែងរកដែនដីនីហ្វៃ នោះពួកគេបានប្រទះឃើញដែនដីហេឡាម ដែលមានអាលម៉ា និងបងប្អូនលោករស់នៅនោះ ។

៣៦ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានសន្យាជាមួយនឹងអាលម៉ា និងបងប្អូនលោកថា បើសិនជាពួកគេបង្ហាញ ផ្លូវពួកគេ ដែលនាំទៅកាន់ដែនដីនីហ្វៃ នោះពួកគេនឹងអនុញ្ញាតឲ្យគេមានជីវិតរស់នៅ ហើយឲ្យគេមានឥស្សរភាព ។

៣៧ ប៉ុន្តែ បន្ទាប់ពីអាលម៉ាបានបង្ហាញផ្លូវដល់ពួកគេដែលនាំទៅកាន់ដែនដីនីហ្វៃហើយ នោះស្រាប់តែពួកលេមិនមិនបាន[ក]កាន់ តាមពាក្យសន្យារបស់គេទេ; តែគេបានចាត់ឲ្យមានទាហានយាមព័ទ្ធជុំវិញដែនដីហេឡាម យ៉ាំងអាលម៉ា និងបងប្អូនលោកវិញ ។

៣៨ ហើយពួកគេដែលនៅសល់ទាំងប៉ុន្មាន បានទៅកាន់ដែនដីនីហ្វៃ; ហើយពួកគេមួយចំណែកទៀត បានត្រឡប់មកដែនដីហេឡាមវិញ ហើយបាននាំប្រពន្ធ និងកូនរបស់ពួកទាហានយាមដែលគេបានទុកឲ្យនៅលើដែនដីនោះមកផងដែរ ។

៣៩ ហើយស្ដេចរបស់ពួកលេមិនបានអនុញ្ញាតឲ្យអាមូឡុនធ្វើជាស្ដេច ហើយជាអ្នកគ្រប់គ្រងលើប្រជាជនរបស់គាត់ គឺជាប្រជាជន ដែលរស់នៅលើដែនដីហេឡាម ក៏ប៉ុន្តែគាត់មិនត្រូវមានអំណាចធ្វើអ្វី ដែលផ្ទុយនឹងព្រះទ័យ នៃស្ដេចនៃពួកលេមិនឡើយ ៕

## ជំពូកទី ២៤

*អាមូឡុនបៀតបៀនអាលម៉ា និងប្រជាជនលោក — ពួកគេនឹងត្រូវយកទៅសម្លាប់ចោល បើគេអធិស្ឋាន — ព្រះអម្ចាស់ទ្រង់សំរាល បន្ទុករបស់ពួកគេ — ទ្រង់ដោះពួកគេឲ្យរួចផុតពីសេវកភាព ហើយគេត្រឡប់ទៅសារ៉ាហិមឡាវិញ ។ ប្រមាណជាឆ្នាំ ១៤៥–១២០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា អាមូឡុនបានទទួលការប្រោសប្រណីនៅក្នុងព្រះនេត្រនៃស្ដេចរបស់ពួកលេមិន; ហេតុដូច្នេះហើយ ស្ដេច របស់ពួកលេមិនបានអនុញ្ញាតឲ្យទ្រង់ និង

៣៣ *ក* ម៉ូសាយ ២០:៣–៥.

៣៤ *ក* ស.ប. អាណិត.

៣៧ *ក* ម៉ូសាយ ២៤:៨–១៥.

បងប្អូនរបស់ទ្រង់បានតែងតាំងឡើងជាគ្រូបង្រៀនលើប្រជាជន
មែនហើយ គឺលើ ប្រជាជនដែលនៅលើដែនដីសេមឡុន
ហើយនៅលើដែនដីសៃឡោម ហើយនៅលើដែនដី
អាមូឡុនផងដែរ ។
២ ព្រោះពួកលេមិនបានយកបានដែនដីទាំងអស់នេះ; ហេតុ
ដូច្នេះហើយ ស្ដេចរបស់ពួកលេមិន បានតែងតាំងស្ដេចឲ្យត្រួត
ត្រាលើដែនដីទាំងអស់នេះ ។
៣ ហើយឥឡូវនេះ ស្ដេចរបស់ពួកលេមិន មាននាមថា លេមិន
ដោយដាក់តាមនាមរបស់បិតាទ្រង់; ហេតុដូច្នេះហើយ ទើប
ទ្រង់មាននាមថា ស្ដេចលេមិន ហើយទ្រង់គឺជាស្ដេចលើប្រជាជន
ជាច្រើន ។
៤ ហើយទ្រង់បានតែងតាំងបងប្អូនរបស់អាមូឡុន ឲ្យធ្វើជា
គ្រូបង្រៀន នៅគ្រប់ដែនដីដែលប្រជាជនទ្រង់យកបាន; ម្ល៉ោះហើយ
ទើបភាសានីហ្វៃត្រូវបានចាប់ផ្ដើមបង្រៀននៅក្នុងចំណោម
ប្រជាជនលេមិនទាំងអស់ ។
៥ ហើយពួកគេជាប្រជាជនដែលរាប់អានគ្នា; ទោះជាយ៉ាង
ណាក៏ដោយ គង់តែពួកគេពុំស្គាល់ព្រះដែរ; រីឯបងប្អូនអាមូឡុន
ក៏មិនបានបង្រៀនពួកគេ អំពីព្រះអម្ចាស់ជាព្រះរបស់គេ ឬក៏
អំពីក្រិត្យវិន័យលោកម៉ូសេទេ; ហើយពួកគេក៏មិនបានបង្រៀន
ពួកគេ អំពីពាក្យពេចន៍របស់អ័ប៊ីណាដៃដែរ;
៦ ប៉ុន្តែ ពួកគេបានបង្រៀនពួកនោះថា គេត្រូវកត់បញ្ជី
របស់ខ្លួនទុក ហើយថា គេអាចសរសេររកគ្នាទៅវិញទៅមក ។
៧ ម្ល៉ោះហើយ ពួកលេមិនបានចាប់ផ្ដើមកើននូវទ្រព្យសម្បត្តិ
ហើយបានចាប់ផ្ដើមលក់ដូរទៅវិញទៅមក ហើយបានក្លាយទៅ
ជាខ្លាំងពូកែ ហើយបានចាប់ផ្ដើមទៅជាប្រជាជនមួយ
ដ៏ប្រកបដោយកលល្បិច ហើយមានប្រាជ្ញា ស្របតាមប្រាជ្ញា
នៃលោកិយ មែនហើយ ជាប្រជាជនមួយដ៏ប្រកបដោយកលល្បិច
ចូលចិត្តធ្វើអំពើទុច្ចរិតគ្រប់បែបយ៉ាង ហើយលួចប្លន់
លើកលែងតែគេមិនធ្វើការ នេះនៅក្នុងចំណោមបងប្អូនគេផ្ទាល់
ប៉ុណ្ណោះ ។
៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាមូឡុន
បានចាប់ផ្ដើមអនុវត្ត[ក]សិទ្ធិអំណាចទៅលើអាលម៉ា និងបងប្អូន
របស់លោក ហើយបានចាប់ផ្ដើមបៀតបៀនលោក ហើយឲ្យ
កូនចៅទ្រង់បៀតបៀនកូនចៅរបស់អាលម៉ា និងបងប្អូន
លោកដែរ ។

៩ ព្រោះអាមូឡុនស្គាល់អាលម៉ាថា លោក[ក]ធ្លាប់ធ្វើជាសង្ឃ
របស់ស្ដេច ហើយថា លោកនេះហើយដែលបានជឿតាម
ពាក្យ ពេចន៍របស់អ័ប៊ីណាដៃ ហើយត្រូវបានស្ដេចដេញចេញ
ហេតុដូច្នេះហើយ ទើបទ្រង់ខឹងនឹងលោក; ព្រោះទ្រង់នៅ
ក្រោមបង្គាប់ស្ដេច លេមិន តែទ្រង់បានអនុវត្តសិទ្ធិ
អំណាចទៅលើពួកគេ ហើយដាក់[ខ]ការធ្ងន់ៗឲ្យគេធ្វើ ហើយ
ដាក់អ្នកត្រួតកិច្ចការឲ្យត្រួតត្រាលើពួកគេ ។
១០ ហើយហេតុការណ៍បានកើតឡើងថា សេចក្ដីវេទនា
របស់គេមានទំហំធំណាស់ រហូតដល់គេបានចាប់ផ្ដើមអំពាវនាវ
យ៉ាងខ្លាំងដល់ព្រះ ។
១១ ហើយអាមូឡុនបានបញ្ជាឲ្យពួកគេឈប់អំពាវនាវ; ហើយ
ទ្រង់បានដាក់ពួកទាហានយាមឲ្យមើលពួកគេថា បើឃើញ
អ្នកណាអំពាវនាវដល់ព្រះ អ្នកនោះហើយនឹងត្រូវយក
ទៅសម្លាប់ចោល ។
១២ ហើយអាលម៉ា និងប្រជាជនរបស់លោក ពុំបាន
[ក]បន្លឺសម្លេងអំពាវនាវដល់ព្រះអម្ចាស់ ជាព្រះរបស់គេទេ តែបាន
ថ្វាយ ដួងចិត្តគេដល់ទ្រង់វិញ; ហើយទ្រង់បានជ្រាបនូវគំនិត
ដែលនៅក្នុងចិត្តគេ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា សម្លេងនៃព្រះ
អម្ចាស់បន្លឺមកគេ នៅពេលវេទនារបស់គេថា៖ ចូរងើបក្បាលឡើង
ហើយចូរក្សាន្តចិត្តចុះ ព្រោះយើងដឹងនូវសេចក្ដីសញ្ញា ដែល
អ្នករាល់គ្នាបានធ្វើជាមួយនឹងយើង; ហើយយើងនឹងធ្វើសេចក្ដី
សញ្ញា ជាមួយនឹងរាស្ត្រយើង ហើយនឹងដោះពួកគេឲ្យ
រួចផុតពីសេវកភាព ។
១៤ ហើយយើងនឹងសំរាលបន្ទុកទាំងឡាយដែល
ដាក់នៅលើស្មាអ្នកផង ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាច
ចាប់អារម្មណ៍ថា មានបន្ទុកទាំងនោះនៅលើខ្នងអ្នកឡើយ
ទោះនៅពេលអ្នកជាប់នៅក្នុងសេវកភាព[ក]ក្ដី; ហើយយើងនឹងធ្វើ
ការនេះ ដើម្បីឲ្យអ្នករាល់គ្នា អាចឈរជាសាក្សីដល់យើងពីអំណិះ
តទៅ ហើយដើម្បីឲ្យអ្នករាល់គ្នាអាចដឹងជាពិតប្រាកដថា យើងជា
[ខ]ព្រះអម្ចាស់ដ៏ជាព្រះ មករករាស្ត្រ យើង ក្នុងពេលគេស្ថិតក្នុង
សេចក្ដីវេទនា ។
១៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទុកទាំង
ឡាយដែលដាក់នៅលើអាលម៉ា និងបងប្អូនលោក ត្រូវបាន
សំរាលទៅ; មែនហើយ ព្រះអម្ចាស់ទ្រង់បាន[ក]ចំរើនកម្លាំងឲ្យគេ

**២៤** ៨*ក* គ. និង ស. ១២១:៣៩.
៩ *ក* ម៉ូសាយ ១៧:១–៤; ២៣:៩.
*ខ* ម៉ូសាយ ២១:៣–៦.
១២ *ក* ស.ប. ការអធិស្ឋាន.
១៤ *ក* ស.ប. សាក្សី.
*ខ* ស.ប. សេចក្ដីទំនាស់.
១៥ *ក* ម៉ាថាយ ១១:២៨–៣០.

ដើម្បីឲ្យគេអាចទ្រ[ខ]បន្ទុកទាំងឡាយរបស់គេបានដោយងាយ
ហើយពួក គេបានធ្វើតាមអស់[ក]ទាំងព្រះហឫទ័យនៃព្រះអម្ចាស់
ដោយការរីករាយ និងដោយការអត់ធន់ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា សេចក្ដីជំនឿ
និងសេចក្ដីអត់ធន់របស់គេមានទំហំធំ រហូតដល់សម្លេងនៃព្រះ
អម្ចាស់បានបន្លឺមកគេទៀតថា៖ ចូរក្សាន្តចិត្តចុះ ព្រោះថ្ងៃស្អែក
យើងនឹងដោះអ្នកឲ្យរួចផុតពីសេវកភាពហើយ ។
១៧ ហើយទ្រង់បានមានព្រះបន្ទូលទៅអាលម៉ាថា៖ ចូរអ្នក
នាំមុខប្រជាជននេះ ហើយយើងនឹងទៅជាមួយនឹងអ្នក ហើយ
ដោះប្រជាជននេះឲ្យរួចផុតពី[ក]សេវកភាព ។
១៨ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ា និង
ប្រជាជនរបស់លោក បានប្រមូលហ្វូងចៀមរបស់គេក្នុងពេលយប់
ព្រមទាំងធញ្ញជាតិរបស់គេផង; មែនហើយ គេបានប្រមូល
ហ្វូងចៀមរបស់គេអស់ពេញមួយយប់ ។
១៩ ហើយដល់ព្រឹកឡើង ព្រះអម្ចាស់ទ្រង់សណ្ដំឲ្យពួក
លេមិន[ក]ដេកលក់ស្កប់ មែនហើយ ឯពួកអ្នកត្រួតកិច្ចការរបស់គេ
ទាំង អស់ ក៏លង់លក់ក្នុងដំណេកដែរ ។
២០ ហើយអាលម៉ា និងប្រជាជនរបស់លោក បានចេញ
ដំណើរទៅក្នុងទីរហោស្ថាន; ហើយកាលពួកគេបានធ្វើដំណើរ
អស់រយៈពេញមួយថ្ងៃហើយ នោះគេបានបោះត្រសាលនៅ
ក្នុងច្រកភ្នំមួយ ហើយគេបានហៅច្រកភ្នំថា អាលម៉ា
ពីព្រោះលោកបាននាំផ្លូវ គេនៅក្នុងទីរហោស្ថាន ។
២១ មែនហើយ ហើយនៅក្នុងច្រកភ្នំអាលម៉ា ពួកគេ
បានថ្វាយ[ក]អំណរគុណរបស់គេដល់ព្រះ ពីព្រោះទ្រង់បាន
មេត្តាករុណា ដល់ពួកគេ ហើយបានសំរាលបន្ទុកទាំងឡាយ
របស់គេ ហើយបានដោះគេឲ្យរួចផុតពីសេវកភាព; ព្រោះពួក
គេស្ថិតនៅក្នុងសេវកភាព ហើយគ្មានអ្នកណាម្នាក់អាចដោះ
ពួកគេបានឡើយ លើកលែងតែព្រះអម្ចាស់ ជាព្រះ
របស់គេប៉ុណ្ណោះ ។
២២ ហើយពួកគេបានថ្លែងអំណរគុណដល់ព្រះ មែនហើយ
អស់ទាំងពួកបុរសរបស់គេ និងអស់ទាំងពួកស្ត្រីរបស់គេ និង
អស់ ទាំងកូនចៅរបស់គេ ដែលអាចបន្លឺសម្លេងឡើងក្នុងការ
សរសើរដំកើងដល់ព្រះអម្ចាស់ ជាព្រះរបស់គេ ។
២៣ ហើយឥឡូវនេះ ព្រះអម្ចាស់ទ្រង់បានមានព្រះ
បន្ទូលទៅអាលម៉ាថា៖ ចូរប្រញាប់ឡើង ហើយនាំខ្លួនអ្នក និង
ប្រជាជន នេះចេញពីដែនដីនេះភ្លាម ព្រោះពួកលេមិនបាន
ភ្ញាក់ពីដេកហើយ ហើយកំពុងតែដេញតាមអ្នក; ហេតុដូច្នេះហើយ
ចូរអ្នកចេញពីដែនដី នេះទៅ ហើយយើងនឹងបញ្ឈប់ពួកលេមិន
នៅក្នុងច្រកភ្នំនេះ ដើម្បីកុំឲ្យគេដេញតាមប្រជាជននេះហួស
ពីទីនេះទៅ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេ
បានចេញពីច្រកភ្នំ ហើយបានធ្វើដំណើរចូលក្នុងទីរហោស្ថាន ។
២៥ ហើយបន្ទាប់ពីពួកគេបានចូលក្នុងទីរហោស្ថានអស់រយៈ
ពេល១២ថ្ងៃ នោះពួកគេបានមកដល់ដែនដីសារ៉ាហិមឡា
ហើយស្ដេចម៉ូសាយបានទទួលពួកគេដោយក្ដីអំណរ ៕

## ជំពូកទី ២៥

*ពួកពូជពង្សមូលេកនៅក្រុងសារ៉ាហិមឡា ក្លាយទៅជាពួក សាសន៍នីហ្វៃ — ពួកគេដឹងអំពីប្រជាជនរបស់អាលម៉ា និង របស់សីនិព្វ — អាលម៉ាធ្វើបុណ្យជ្រមុជទឹកជូនលិមហៃ និង ប្រជាជនរបស់ទ្រង់ទាំងអស់ — ម៉ូសាយអនុញ្ញាតឲ្យ អាលម៉ារៀបចំសាសនាចក្រនៃព្រះឡើង ។ ប្រមាណជាឆ្នាំ ១២០ ម.គ.ស. ។*

ហើយឥឡូវនេះ ស្ដេចម៉ូសាយបានបញ្ជាឲ្យប្រជាជនទាំងអស់
ប្រមូលគ្នាមក ។
២ ឥឡូវនេះ កូនចៅនីហ្វៃពុំសូវមាន[ក]ច្រើនប៉ុន្មាន ឬក៏ពុំសូវ
មានពួកជនដែលជា[ខ]ពូជពង្សនីហ្វៃ ស្មើនឹងប្រជាជនសារ៉ាហិមឡា
ដែលជាពូជពង្សមូលេក និងពួកជនដែលមកជាមួយលោកក្នុង
ទីរហោស្ថាននោះទេ ។
៣ ហើយពុំសូវមានប្រជាជននីហ្វៃ និងប្រជាជនសារ៉ាហិមឡា
ឲ្យស្មើទៅនឹងពួកលេមិនទេ; មែនហើយ ពួកគេមិនស្មើនឹង
ពាក់កណ្ដាលពួកលេមិនផង ។
៤ ហើយឥឡូវនេះ ប្រជាជននីហ្វៃទាំងអស់បានប្រមូលគ្នាមក
ហើយប្រជាជនសារ៉ាហិមឡាទាំងអស់ផងដែរ ហើយពួកគេ
បានប្រមូលមកជាពីរក្រុម ។
៥ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសាយបានអាន
ហើយបានបញ្ជាឲ្យគេអានបញ្ជីទាំងឡាយរបស់សីនិព្វ និងប្រជាជន

*ខ* អាលម៉ា ៣១:៣៨; ៣៣:២៣.
*ក* គ. និង ស. ៥៤:១០.
ស.ប. សេចក្ដីអត់ធន់.
១៧ *ក* ស.ប. ការជាប់ឃុំឃាំង.
១៩ *ក* ១ សាំយូ. ២៦:១២.
២១ *ក* ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
**២៥** ២ *ក* អោមណៃ ១:១៣–១៩.
*ខ* ហេលេ. ៦:១០.
ស.ប. មូលេក.

ទ្រង់; មែនហើយ ទ្រង់បានអានបញ្ជីទាំងឡាយ នៃប្រជាជនសឺនិព្វ
ចាប់តាំងពីពេលដែលពួកគេចាកចេញពីដែនដី សារ៉ាហិមឡាទៅ
រហូតដល់ពេលពួកគេបានត្រឡប់មកវិញទៀត ។
៦ ហើយទ្រង់ក៏បានអានដំណើររឿងនៃអាលម៉ា និងបងប្អូន
លោក និងសេចក្ដីវេទនាទាំងអស់របស់គេ ចាប់តាំងពីពេលដែល
គេចាកចេញពីដែនដីសារ៉ាហិមឡាទៅ រហូតដល់ពេលគេត្រឡប់
មកវិញដែរ ។
៧ ហើយឥឡូវនេះ កាលម៉ូសាយបានបញ្ចប់នូវការអានបញ្ជី
ទាំងនេះហើយ នោះប្រជាជនរបស់ទ្រង់ ដែលមិនដែល បាន
ចាកចេញពីដែនដីនេះ កើតសេចក្ដីអស្ចារ្យ ហើយងឿងឆ្ងល់
ជាខ្លាំង ។
៨ ព្រោះពួកគេមិនដឹងជានឹងគិតយ៉ាងណាទេ; ព្រោះកាល
ដែលគេបានឃើញពួកជនដែលបានដោះឲ្យរួចផុតពីសេវកភាព
នោះពួកគេមានសេចក្ដីសោមនស្សជាអតិបរមា ។
៩ ហើយកាលដែលពួកគេនឹកដល់បងប្អូនគេ ដែលត្រូវពួក
លេមិនសម្លាប់ចោល នោះពួកគេពោរពេញទៅដោយសេចក្ដី
សោកសៅ ហើយក៏បានស្រក់ទឹកភ្នែកដ៏ហូរហៀរដោយ
សោកសៅ ។
១០ ហើយមួយទៀត កាលដែលពួកគេនឹកដល់សេច
ក្ដីល្អសប្បុរសដ៏ទាន់ចិត្តនៃព្រះ និងព្រះចេស្ដារបស់ទ្រង់ ក្នុងការ
ដោះ អាលម៉ា និងបងប្អូនលោក ឲ្យរួចផុតពីកណ្ដាប់ដៃនៃពួក
លេមិន និងពីសេវកភាព នោះពួកគេបានបន្លឺសម្លេងឡើង
ហើយថ្លែងអំណរ គុណដល់ព្រះ ។
១១ ហើយមួយទៀត កាលដែលពួកគេនឹកដល់ពួកលេមិន
ដែលជាបងប្អូននឹងគេនោះ ដល់សភាពបាប និងកខ្វក់របស់គេ
នោះ នោះពួកគេក៏ពោរពេញទៅដោយការឈឺចាប់ ហើយ
បារម្ភដល់សុខុមាលភាពនៃព្រលឹងរបស់ពួកគេ ។
១២ ហើយហេតុការណ៍បានកើតឡើងថា អ្នកណាដែលជា
កូនចៅរបស់អាមូឡុន និងបងប្អូនទ្រង់ ដែលបានយកពួក
កូនក្រមុំ នៃពួកលេមិនធ្វើជាប្រពន្ធនោះ មិនពេញចិត្តនឹងចរិយា
របស់ឪពុកខ្លួនទេ ហើយគេមិនចង់ឲ្យគេហៅតាមនាមរបស់
ឪពុកគេតទៅទៀត ឡើយ ហេតុដូច្នេះហើយ ពួកគេបាន
យកនាមនីហ្វៃមកដាក់ឲ្យខ្លួន ដើម្បីឲ្យគេហៅថាជាកូនចៅ
នីហ្វៃទៅវិញ ហើយបានរាប់ក្នុង ចំណោមពួកជនដែលហៅថា
ពួកសាសន៍នីហ្វៃវិញ ។
១៣ ហើយឥឡូវនេះ ប្រជាជនសារ៉ាហិមឡាទាំងអស់ ត្រូវ
បានរាប់ជាមួយនឹងពួកសាសន៍នីហ្វៃ ហើយនេះក៏មកពីនគរ នេះ
ពុំដែលប្រគល់ដល់នរណា ក្រៅពីពូជពង្សនៃនីហ្វៃឡើយ ។
១៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ម៉ូសាយបានបញ្ចប់នូវការនិយាយ និងការអានដល់ប្រជាជន
ទ្រង់ហើយ នោះទ្រង់មានព្រះទ័យចង់ឲ្យអាលម៉ាថ្លែងទៅកាន់
ប្រជាជនផង ។
១៥ ហើយអាលម៉ាបានថ្លែងទៅពួកគេ កាលពួកគេប្រមូល
គ្នាមកជាក្រុមដ៏ធំៗ ហើយលោកបានទៅពីក្រុមមួយទៅក្រុមមួយ
ដោយផ្សាយប្រាប់ដល់ប្រជាជន អំពីការប្រែចិត្ត និងសេច
ក្ដីជំនឿជឿដល់ព្រះអម្ចាស់ ។
១៦ ហើយលោកបានទូន្មានប្រជាជនលិមហៃ និង
បងប្អូនទ្រង់ គឺជនទាំងអស់ដែលបានដោះឲ្យរួចផុតពីសេវកភាព
មក ដើម្បីឲ្យពួកគេចងចាំថា គឺព្រះអម្ចាស់ទ្រង់បានដោះពួក
គេឲ្យរួច ។
១៧ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាលម៉ា
បានបង្រៀនប្រជាជននូវការណ៍ជាច្រើន ហើយបានបញ្ចប់នូវ
ការ និយាយដល់គេហើយ នោះស្ដេចលិមហៃមានព្រះទ័យចង់
ទទួលបុណ្យជ្រមុជទឹក; ហើយប្រជាជនរបស់ទ្រង់ទាំងអស់ក៏មាន
បំណងចង់ ទទួលបុណ្យជ្រមុជទឹកដែរ ។
១៨ ហេតុដូច្នេះហើយ អាលម៉ាបានដើរចុះទៅក្នុងទឹក
ហើយបានធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេ; មែនហើយ លោកបាន
ធ្វើ បុណ្យជ្រមុជទឹកឲ្យពួកគេ តាមរបៀបដែលលោកបានធ្វើ
បុណ្យជ្រមុជទឹកឲ្យបងប្អូនលោក នៅក្នុងទឹកមរមនដែរ; មែន
ហើយ អស់អ្នក ណាដែលលោកបានធ្វើបុណ្យជ្រមុជទឹកឲ្យ
គឺបានរួបរួមចូលក្នុងសាសនាចក្រនៃព្រះ; ហើយការណ៍
នេះក៏ដោយសារតែសេចក្ដីជំនឿ របស់គេ ទៅលើពាក្យសំដី
របស់អាលម៉ានោះឯង ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចម៉ូសាយបាន
អនុញ្ញាតឲ្យអាលម៉ាតាំងសាសនាចក្រជាច្រើនឡើង ទូទៅ
អស់ទាំងដែនដីសារ៉ាហិមឡា; ហើយទ្រង់បានប្រទានដល់លោក
នូវអំណាចសំរាប់តែងតាំងពួកសង្ឃ និងពួកគ្រូបង្រៀន នៅគ្រប់
សាសនាចក្រនីមួយៗ ។
២០ ឥឡូវនេះ ការណ៍នេះបានធ្វើឡើង ពីព្រោះមានមនុស្ស
ជាច្រើន ដែលពួកគេពុំអាចអភិបាលដោយគ្រូតែមួយបានឡើយ;

៨ *ក* ម៉ូសាយ ២២:១១–១៣.
១១ *ក* ម៉ូសាយ ២៨:៣–៤; អាលម៉ា ១៣:២៧.
*ខ* ស.ប. ព្រលឹង — តម្លៃនៃព្រលឹងទាំងឡាយ.
១៣ *ក* អោមណៃ ១:១៩.
១៨ *ក* ម៉ូសាយ ២១:៣៥.
*ខ* ម៉ូសាយ ១៨:៨–១៧.
១៩ *ក* ស.ប. បព្វជិតភាព.

ហើយពួកគេទាំងអស់គ្នាក៏មិនអាចស្ដាប់ព្រះបន្ទូលនៃព្រះ នៅ
ក្នុងជំនុំតែមួយបានដែរ;
២១ ហេតុដូច្នេះហើយ ពួកគេបានរួមប្រជុំជាក្រុមផ្សេងៗគ្នា
ដោយហៅថាសាសនាចក្រទាំងអស់; សាសនាចក្រនីមួយៗ
មានពួកសង្ឃរបស់ខ្លួន និងពួកគ្រូបង្រៀនរបស់ខ្លួន ហើយសង្ឃនី
មួយៗផ្សាយសាសនា ស្របតាមអ្វីៗដែលប្រគល់ទៅឲ្យពួកគេ
ពីមាត់ អាលម៉ាផ្ទាល់ ។
២២ ម្ល៉ោះហើយ ទោះជាគេមានសាសនាចក្រជាច្រើនក្ដី
គង់តែគេទាំងអស់ជាសាសនាចក្រតែមួយដែរ មែនហើយ
គឺជាសាសនាចក្រនៃព្រះ; ព្រោះគ្មានអ្វីដែលគេផ្សាយនៅក្នុង
សាសនាចក្រទាំងអស់នេះឡើយ លើកលែងតែអំពីការប្រែចិត្ត
និងសេចក្ដីជំនឿជឿដល់ព្រះប៉ុណ្ណោះ ។
២៣ ហើយឥឡូវនេះ មានសាសនាចក្រប្រាំពីរ នៅលើដែនដី
សារ៉ាហិមឡា ។ ហើយហេតុការណ៍បានកើតឡើងថា អ្នក
ណាក៏ដោយដែលមានបំណងចង់លើកយកព្រះនាមព្រះគ្រីស្ទ
ឬព្រះនាមនៃព្រះ មកដាក់លើខ្លួន អ្នកទាំងនោះហើយដែលបាន
ចូលរួមក្នុងសាសនាចក្រទាំងឡាយនៃព្រះ ។
២៤ ហើយពួកគេត្រូវបានហៅថា រាស្ត្រនៃព្រះ ។ ហើយព្រះ
អម្ចាស់ទ្រង់បានស្រោចព្រះវិញ្ញាណទ្រង់មកលើពួកគេ ហើយ
ពួកគេបានទទួលពរ ហើយបានចំរើនឡើងនៅលើដែនដីទៅ ៕

## ជំពូកទី ២៦

*សមាជិកនៃសាសនាចក្រជាច្រើននាក់ ត្រូវមនុស្សឥតជំនឿដឹកនាំឲ្យធ្វើបាប — អាលម៉ាត្រូវបានសន្យាឲ្យមានជីវិតដ៏នៅអស់កល្ប ជានិច្ច — អស់អ្នកណាដែលប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក នោះបានការអភ័យទោស — សមាជិកនៃសាសនាចក្រដែលមានបាប ហើយប្រែចិត្ត ហើយសារភាពចំពោះអាលម៉ា និងចំពោះព្រះ នឹងបានអភ័យទោស; បើពុំនោះសោតទេ ពួកគេនឹងមិនត្រូវបានរាប់ចូល ក្នុងចំណោមប្រជាជននៃសាសនាចក្រឡើយ ។ ប្រមាណជាឆ្នាំ ១២០–១០០ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មានមនុស្សជាច្រើន
នៃជំនាន់ដែលកំពុងពេញវ័យ ដែលពុំអាចយល់នូវពាក្យពេចន៍
នៃស្ដេច បេនយ៉ាមីនបានឡើយ ដោយខ្លួននៅក្មេងពេក ក្នុង
កាលទ្រង់បានមានបន្ទូលទៅកាន់ប្រជាជនទ្រង់; ហើយពួកគេពុំ
បានជឿតាម សណ្ដាប់នៃពួកអយ្យកោរបស់គេទេ ។
២ ពួកគេពុំបានជឿនូវអ្វីដែលបាននិយាយអំពីដំណើរ
រស់ឡើងវិញនៃមនុស្សស្លាប់ឡើយ ហើយគេក៏ពុំជឿអំពីការ
យាងមកនៃ ព្រះគ្រីស្ទដែរ ។
៣ ហើយឥឡូវនេះ ពីព្រោះតែការឥតជំនឿរបស់គេ នោះ
ពួកគេពុំអាចយល់នូវព្រះបន្ទូលនៃព្រះបានឡើយ; ឯចិត្តគេ
ត្រូវឡប់ជារឹងរូស ទៅវិញ ។
៤ ហើយពួកគេមិនព្រមទទួលបុណ្យជ្រមុជទឹកទេ; ពួក
គេក៏មិនព្រមចូលរួមនឹងសាសនាចក្រដែរ ។ ហើយពួកគេជា
មនុស្សដោយ ឡែក ស្របតាមសេចក្ដីជំនឿរបស់គេ
ហើយនៅជាយ៉ាងនេះរហូតតទៅ គឺនៅក្នុងស្ថានភាព
របស់គេដែលប្រកបដោយរូបកាយ និងអំពើបាប; ព្រោះពួកគេ
ពុំព្រមអំពាវនាវដល់ព្រះអម្ចាស់ ជាព្រះរបស់គេឡើយ ។
៥ ហើយឥឡូវនេះ នៅក្នុងរាជ្យម៉ូសាយ ពួកគេមាន
ចំនួនមិនស្មើនឹងពាក់កណ្ដាលចំនួននៃរាស្ត្ររបស់ព្រះទេ; ប៉ុន្តែ
ដោយសារការ បែកបាក់គ្នា នៅក្នុងចំណោមបងប្អូន នោះពួក
គេបានក្លាយទៅមានចំនួនច្រើនឡើង ។
៦ ត្បិតហេតុការណ៍បានកើតឡើងថា ពួកគេបានបញ្ឆោត
មនុស្សជាច្រើន ដោយពាក្យបញ្ឆោតរបស់គេ គឺពួកអ្នកដែល
នៅក្នុង សាសនាចក្រ ហើយបានធ្វើឲ្យអ្នកទាំងនោះប្រព្រឹត្ត
អំពើបាបជាច្រើន; ហេតុដូច្នេះហើយ ជាការចាំបាច់ថា អស់
អ្នកណាដែលនៅក្នុង សាសនាចក្រ ដែលប្រព្រឹត្តអំពើបាប
នោះសាសនាចក្រត្រូវព្រមានដាស់តឿន ។
៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេត្រូវបាននាំទៅ
ខាងមុខពួកសង្ឃ ហើយពួកគ្រូបង្រៀនបានប្រគល់គេទៅឲ្យពួក
សង្ឃ ឯពួកសង្ឃបាននាំគេទៅខាងមុខអាលម៉ា ជាសង្ឃ
ជាន់ខ្ពស់ ។
៨ ឥឡូវនេះ ស្ដេចម៉ូសាយបានប្រទានឲ្យអាលម៉ាមានសិទ្ធិ
អំណាចលើសាសនាចក្រ ។
៩ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាពុំបានដឹង

២២ *ក* ម៉ូសាយ ១៨:១៧.
២៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
២៤ *ក* ស.ប. សេចក្ដីសញ្ញា.
**២៦** ៣*ក* ស.ប. យោបល់.
៤ *ក* ស.ប. មនុស្សខាងសាច់ឈាម.
៥ *ក* ស.ប. សេចក្ដីក្បត់សាសនា; ការទាស់ទែង.
៦ *ក* អាលម៉ា ៥:៥៧–៥៨; ៦:៣. ស.ប. ព្រមាន, ពាក្យព្រមាន.
៧ *ក* ម៉ូសាយ ២៩:៤២.

អំពីពួកគេទេ; តែមានសាក្សីចោទពួកគេជាច្រើន; មែនហើយ
មនុស្សទាំង ឡាយបានឈរ ហើយធ្វើបន្ទាល់អំពីអំពើទុច្ចរិតដ៏ច្រើន
របស់គេ ។
១០ ឥឡូវនេះ ពុំដែលមានរឿងបែបនេះកើតឡើង នៅក្នុង
សាសនាចក្រពីមុនសោះ; ហេតុដូច្នេះហើយ អាលម៉ាកើតក្ដី
តប់ប្រមល់ នៅក្នុងវិញ្ញាណលោក ហើយលោកបានឲ្យនាំពួក
នោះទៅគាល់ស្ដេច ។
១១ ហើយលោកទូលស្ដេចថា៖ មើលចុះ យើងខ្ញុំបាននាំមនុស្ស
ជាច្រើនមកចំពោះទ្រង់ ជាអ្នកដែលត្រូវបងប្អូនគេចោទប្រកាន់;
មែន ហើយ ហើយពួកគេត្រូវចាប់បានកាលកំពុងតែប្រព្រឹត្ត
អំពើទុច្ចរិតផ្សេងៗ ។ ហើយពួកគេពុំប្រែចិត្ត ចំពោះអំពើ
ទុច្ចរិតទាំងឡាយរបស់ ខ្លួនឡើយ; ហេតុដូច្នេះហើយ យើងខ្ញុំ
បាននាំពួកគេមកចំពោះទ្រង់ ដើម្បីទ្រង់អាចកាត់ក្ដីពួកគេ តាម
អំពើឧក្រិដ្ឋទាំងឡាយរបស់ពួកគេចុះ ។
១២ ប៉ុន្តែ ស្ដេចម៉ូសាយមានបន្ទូលទៅកាន់អាលម៉ាថា៖
មើលចុះ យើងពុំកាត់ក្ដីពួកគេទេ; ហេតុដូច្នេះហើយ
យើង[ក]ប្រគល់គេទៅក្នុង ដៃអ្នក ដើម្បីកាត់ក្ដីវិញ ។
១៣ ហើយឥឡូវនេះ វិញ្ញាណអាលម៉ាក៏កើតក្ដីតប់ប្រមល់ទៀត;
ហើយលោកបានទៅទូលសួរដល់ព្រះអម្ចាស់ថា តើលោកត្រូវ
ធ្វើ យ៉ាងណាអំពីរឿងនេះ ព្រោះលោកខ្លាច
ក្រែងធ្វើខុសនៅចំពោះព្រះនេត្រព្រះ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា
បន្ទាប់ពីលោកបានថ្វាយព្រលឹងលោកទាំងមូលដល់ព្រះហើយ
នោះស្រាប់តែសម្លេងនៃ ព្រះអម្ចាស់បានបន្លឺមកលោកថា៖
១៥ ឱអាលម៉ាអើយ អ្នកមានពរហើយ ហើយមានពរដល់
អស់អ្នកណា ដែលទទួល[ខ]បុណ្យជ្រមុជទឹកនៅក្នុង[ក]ទឹកមរមន ។
អ្នកបានពរ ដោយព្រោះសេចក្ដីជំនឿដ៏លើសលប់របស់អ្នក ដល់
ពាក្យសំដីរបស់អ័ប៊ីណាដៃ ជាអ្នកបំរើរបស់យើងប៉ុណ្ណោះ ។
១៦ ហើយមានពរហើយ ដល់អស់អ្នកណាដែលមានសេច
ក្ដីជំនឿដ៏លើសលប់ ទៅលើពាក្យសំដី ដែលអ្នកបាននិយាយ
ទៅកាន់ ពួកគេប៉ុណ្ណោះ ។
១៧ ហើយអ្នកមានពរ ពីព្រោះអ្នកបានតាំង[ក]សាសនា
ចក្រមួយឡើង នៅក្នុងចំណោមប្រជាជននេះ; ហើយពួកគេនឹង
ត្រូវបានតាំងឡើង ហើយពួកគេនឹងត្រូវបានទៅជារាស្ត្រ
របស់យើង ។
១៨ មែនហើយ មានពរហើយ ដល់ប្រជាជននេះ ដែលស្ម័
គ្រចិត្តលើកយក[ក]នាមយើង; ត្បិតដោយនូវនាមយើងនេះហើយ
ដែលពួកគេ នឹងត្រូវបានហៅ; ហើយពួកគេជារាស្ត្ររបស់យើង ។
១៩ ហើយពីព្រោះអ្នកបានសួរយើងអំពីពួករំលងច្បាប់ នោះ
អ្នកមានពរហើយ ។
២០ អ្នកជាអ្នកបំរើរបស់យើង; ហើយយើងធ្វើសេចក្ដីសញ្ញា
ជាមួយនឹងអ្នកថា អ្នកនឹងមាន[ក]ជីវិតដ៏នៅអស់កល្បជានិច្ច;
ហើយអ្នកត្រូវ បំរើយើង ហើយចេញទៅក្នុងនាមយើង ហើយ
ត្រូវប្រមូលចៀមរបស់យើង ។
២១ ហើយអ្នកណាដែលព្រមស្ដាប់តាមសម្លេងយើង នោះ
នឹងទៅជា[ក]ចៀមរបស់យើង; ហើយអ្នកត្រូវទទួលអ្នកនោះចូល
ក្នុង សាសនាចក្រ ហើយយើងក៏នឹងទទួលអ្នកនោះដែរ ។
២២ ត្បិតមើលចុះ នេះជាសាសនាចក្ររបស់យើង; អស់
អ្នកណាដែល[ក]ទទួលបុណ្យជ្រមុជទឹក នោះត្រូវទទួលបុណ្យជ្រមុជទឹក
ចំពោះ ការប្រែចិត្ត ។ ហើយអស់អ្នកណាដែលអ្នកទទួល
នោះត្រូវជឿដល់នាមយើង; ហើយយើងនឹង[ខ]អត់ទោសឲ្យអ្នក
នោះដោយសេរី ។
២៣ ត្បិតគឺយើងនេះហើយដែលទទួល[ក]យកអំពើបាបទាំង
ឡាយនៃមនុស្សលោកមកលើខ្លួន; ត្បិតគឺយើងនេះហើយដែល
[ខ]បានបង្កើត គេមក; ហើយគឺយើងនេះហើយដែលបានប្រទាន
ដល់អ្នកណាដែលជឿរហូតដល់ចុងបំផុត នូវកន្លែងមួយនៅ
ខាងស្ដាំដៃយើង ។
២៤ ត្បិតមើលចុះ គឺដោយនូវនាមយើងនេះហើយដែលពួក
គេត្រូវបានហៅ; ហើយបើសិនជាពួកគេ[ក]ស្គាល់យើង នោះពួក
គេ ត្រូវទៅមុខ ហើយនឹងមានកន្លែងមួយដ៏នៅអស់កល្បជានិច្ច
នៅខាងស្ដាំដៃយើង ។
២៥ ហើយហេតុការណ៍នឹងកើតឡើងថា កាលណាសម្លេង

១២ *ក* គ. និង ស. ៤២:៧៨–៩៣.
១៥ *ក* ម៉ូសាយ ១៨:៣០.
*ខ* ម៉ូសាយ ១៧:២.
ស.ប. សេចក្ដីជំនឿ.
១៧ *ក* ម៉ូសាយ ២៥:១៩–២៤.
១៨ *ក* ម៉ូសាយ ១:១១; ៥:៨.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការ
យកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ
មកដាក់លើ ខ្លួនយើង.
២០ *ក* ស.ប. ពួករើសតាំង; ការរើសតាំង;
ជីវិតដ៏នៅអស់កល្បជានិច្ច.
២១ *ក* ស.ប. អ្នកគង្វាលល្អ.
២២ *ក* ២ នីហ្វៃ ៩:២៣.
ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យ
ជ្រមុជទឹក.
*ខ* ស.ប. អត់ទោស, អភ័យទោស;
ការផ្ដាច់បាប.
២៣ *ក* ស.ប. ព្រះដ៏ប្រោសលោះ.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
២៤ *ក* យ៉ូហាន ១៧:៣.

[ក]ត្រែទីពីរបន្លឺឡើង ពេលនោះ ពួកអ្នកដែលមិនដែល[ខ]ស្គាល់យើង
ត្រូវទៅមុខ ហើយឈរនៅចំពោះមុខយើង ។
២៦ ហើយនៅពេលនោះ ពួកគេនឹងដឹងថា យើងជាព្រះ
អម្ចាស់ ជាព្រះរបស់គេ គឺយើងជាព្រះដ៏ប្រោសលោះរបស់គេ;
តែពួកគេនឹងពុំបានប្រោសលោះឡើយ ។
២៧ ហើយពេលនោះ យើងនឹងថ្លែងប្រាប់ទៅគេថា យើងមិន
ដែល[ក]ស្គាល់គេទេ; ហើយពួកគេនឹង[ខ]ចេញទៅក្នុង[គ]ភ្លើងដ៏អស់កល្ប
ជានិច្ច ដែលបានរៀបចំឡើង សំរាប់អារក្ស និងពួកទេវតាវា ។
២៨ ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា អ្នកណាដែល
មិនព្រម[ក]ស្ដាប់តាមសម្លេងយើង អ្នកនោះហើយដែលអ្នកមិន
ត្រូវទទួល ឲ្យចូលក្នុងសាសនាចក្ររបស់យើងឡើយ ត្បិតអ្នក
នោះហើយដែលយើងនឹងពុំទទួលនៅថ្ងៃ
ចុងក្រោយបង្អស់ដែរ ។
២៩ ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា ទៅចុះ; ហើយអស់
អ្នកណាដែលរំលងច្បាប់ទាស់នឹងយើង អ្នកនោះហើយដែល
អ្នក[ខ]ត្រូវ [ក]កាត់ក្ដី ស្របតាមអំពើបាបទាំងឡាយដែលគេបាន
ប្រព្រឹត្ត; ហើយបើសិនជាគេទទួល[គ]សារភាពនូវអំពើបាបទាំង
ឡាយរបស់ខ្លួន ចំពោះអ្នក និងចំពោះយើង ហើយ[ឃ]ប្រែចិត្ត
ដោយស្មោះអស់ពីចិត្ត អ្នកនោះហើយដែលអ្នកត្រូវ[ង]អត់ទោសឲ្យ
ហើយយើងក៏នឹងអត់ទោស ឲ្យគេដែរ ។
៣០ មែនហើយ ហើយ[ក]ដរាបណារាស្ត្រយើង[ខ]ប្រែចិត្ត យើង
នឹងអត់ទោសឲ្យគេ ចំពោះការរំលងច្បាប់ទាំងឡាយដែលគេបាន
ប្រព្រឹត្តទាស់នឹងយើង ។
៣១ ហើយអ្នកក៏ត្រូវ[ក]អត់ទោសឲ្យគ្នាទៅវិញទៅមក
ចំពោះកំហុសរបស់ខ្លួនដែរ; ត្បិតយើងប្រាប់អ្នកជាប្រាកដថា
អ្នកណាដែលមិន អត់ទោសកំហុសនៃអ្នកជិតខាងខ្លួន កាល
គេថាគេបានប្រែចិត្ត អ្នកនោះហើយដែលនឹងដាក់ខ្លួននៅក្រោម
ការកាត់ទោស ។
៣២ ឥឡូវនេះ យើងប្រាប់អ្នកថា ទៅចុះ; ហើយអស់អ្នក
ណាដែលមិនប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួនទេ អ្នកនោះ
ហើយ ដែលនឹងមិនត្រូវបានរាប់ក្នុងចំណោមរាស្ត្ររបស់យើងឡើយ; ហើយការណ៍នេះនឹងត្រូវធ្វើចាប់ពីពេលនេះតទៅ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា កាលអាលម៉ា
បានឮព្រះបន្ទូលទាំងនេះហើយ នោះលោកបាន
កត់ទុកសំរាប់ខ្លួនលោក ហើយទុកសំរាប់កាត់ក្ដីប្រជាជន
នៃសាសនាចក្រនោះ ស្របតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាបានទៅ
ហើយបានកាត់ក្ដីអស់អ្នកណាដែលត្រូវចាប់បានកាលកំពុងតែ
ប្រព្រឹត្ត អំពើទុច្ចរិត ស្របតាមព្រះបន្ទូលនៃព្រះអម្ចាស់ ។
៣៥ ហើយអ្នកណាដែលបានប្រែចិត្តពីអំពើបាបទាំងឡាយ
របស់ខ្លួន ហើយបានទទួល[ក]សារភាពនូវអំពើបាបទាំងនោះ
អ្នកនោះ ហើយដែលលោកបានរាប់ក្នុងចំណោមប្រជាជន
នៃសាសនាចក្រ ។
៣៦ ហើយអស់អ្នកណាដែលមិនព្រមទទួលសារភាពនូវអំពើ
បាបទាំងឡាយរបស់ខ្លួន ហើយមិនព្រមប្រែចិត្តពីអំពើទុច្ចរិត
របស់ខ្លួនទេ អ្នកនោះហើយដែលមិនត្រូវបានរាប់ក្នុង
ចំណោមប្រជាជននៃសាសនាចក្រឡើយ ហើយឈ្មោះ
របស់គេក៏បាន[ក]លុបចោលដែរ ។
៣៧ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាបានចាត់
ចែងគ្រប់ទាំងកិច្ចការនៅក្នុងសាសនាចក្រ; ហើយពួកគេបាន
ចាប់ផ្ដើម មានសេចក្ដីសុខសាន្តទៀត ហើយបាន
ចំរើនឡើងជាអតិបរមា នៅក្នុងកិច្ចការទាំងឡាយនៃសាសនាចក្រ
គេដើរដោយប្រយ័ត្នប្រយែង នៅចំពោះព្រះ ដោយទទួល
មនុស្សជាច្រើន ហើយធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សជាច្រើន ។
៣៨ ហើយឥឡូវនេះ គ្រប់ការណ៍ទាំងនេះហើយដែល
អាលម៉ា និងពួកអ្នកដែលធ្វើការជាមួយលោកបានធ្វើ គឺជាពួក
អ្នកដែលនៅ លើសាសនាចក្រ គឺដើរនៅគ្រប់ការព្យាយាមទាំង
អស់ ដោយបង្រៀនព្រះបន្ទូលនៃព្រះនៅគ្រប់ការណ៍ទាំងអស់

២៥ *ក* គ. និង ស. ៨៨:៩៩, ១០៩.
*ខ* គ. និង ស. ៧៦:៨១–៨៦.
២៧ *ក* ម៉ាថាយ ៧:២១–២៣.
*ខ* លូកា ១៣:២៧.
*គ* គ. និង ស. ៧៦:៤៣–៤៤.
២៨ *ក* ២ នីហ្វៃ ៩:៣១;
គ. និង ស. ១:១៤.
២៩ *ក* ស.ប. ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
*ខ* ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
*គ* ៣ នីហ្វៃ ១:២៥.
ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
*ឃ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ង* ស.ប. អត់ទោស, អភ័យទោស.
៣០ *ក* មរ៉ូណៃ ៦:៨.
*ខ* អេសេ. ៣៣:១១, ១៥–១៦;
កិច្ចការ ៣:១៩–២០;
ម៉ូសាយ ២៩:១៩–២០.
៣១ *ក* ៣ នីហ្វៃ ១៣:១៤–១៥;
គ. និង ស. ៦៤:៩–១០.
៣៥ *ក* ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
៣៦ *ក* និក្ខ. ៣២:៣៣; អាលម៉ា ១:២៤.
ស.ប. សៀវភៅជីវិត; ការកាត់ចេញពីសាសនា.

ដោយរងការវេទនា គ្រប់យ៉ាង ដោយត្រូវបានបៀតបៀន
ពីអស់អ្នកណាដែលពុំនៅក្នុងសាសនាចក្រនៃព្រះ ។
៣៩ ហើយពួកគេបានព្រមានដាស់តឿនដល់បងប្អូនគេ; ឯពួក
គេក៏ត្រូវបានព្រមានដាស់តឿនដោយព្រះបន្ទូលនៃព្រះ គឺមនុស្ស
គ្រប់រូប ស្របតាមអំពើបាបទាំងឡាយរបស់ខ្លួន ឬអំពើបាបទាំង
ឡាយដែលគេបានប្រព្រឹត្ត ដោយត្រូវបានបញ្ជាពីព្រះឲ្យអធិស្ឋាន
ដោយមិនឈប់ ឈរ ហើយឲ្យថ្លែងអំណរគុណក្នុងការណ៍
ទាំងអស់ ៕

## ជំពូកទី ២៧

*ម៉ូសាយហាមមិនឲ្យមានការបៀតបៀន ហើយស្នើរឲ្យមានភាពស្មើគ្នា — អាលម៉ា ជាកូន និងពួកបុត្រាបួននាក់នៃម៉ូសាយស្វែង រកបំផ្លាញសាសនាចក្រ — ទេវតាលេចមក ហើយបញ្ជាគេឲ្យឈប់ពីដំណើរអាក្រក់របស់គេ — អាលម៉ាក្លាយទៅជាគ — មនុស្ស លោកទាំងអស់ត្រូវកើតម្ដងទៀត ដើម្បីទទួលសេចក្ដីសង្គ្រោះ — អាលម៉ា និងពួកបុត្រានៃម៉ូសាយប្រកាសប្រាប់ពីដំណឹងដ៏រីករាយ ។ ប្រមាណជាឆ្នាំ ១០០–៩២ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ការបៀតបៀន
ទាំងឡាយដែលបានធ្វើទុក្ខមកលើសាសនាចក្រ ដោយពួក
ឥតជំនឿ នោះបានក្លាយទៅជាធំដ៏ក្រៃលែង រហូតដល់
សាសនាចក្របានចាប់ផ្ដើមរអ៊ូរទាំ ហើយតវ៉ាដល់ពួកមេដឹកនាំ
របស់គេអំពីរឿងនេះ; ហើយពួកគេបានតវ៉ាដល់អាលម៉ា ។
ហើយអាលម៉ាបានលាតត្រដាងរឿងនេះនៅចំពោះម៉ូសាយ
ជាស្ដេចរបស់គេ ។ ហើយម៉ូសាយ បានប្រឹក្សាជាមួយនឹងពួក
សង្ឃរបស់ទ្រង់ ។
២ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចម៉ូសាយបាន
ផ្ញើសេចក្ដីប្រកាសមួយទូទៅទាំងដែនដីនៅព័ទ្ធជុំវិញថា ជន
ឥតជំនឿមិន ត្រូវបៀតបៀនអស់អ្នកណា ដែលនៅក្នុង
សាសនាចក្រនៃព្រះឡើយ ។
៣ ហើយមានបញ្ជាមួយយ៉ាងតឹងរឹង ទូទៅអស់ទាំង
សាសនាចក្រថា មិនត្រូវមានការបៀតបៀនទាំងឡាយនៅ
ក្នុងចំណោមពួកគេ ឡើយ គឺត្រូវមានភាពស្មើគ្នា នៅក្នុង
ចំណោមមនុស្សទាំងអស់វិញ;
៤ គឺពួកគេមិនត្រូវទុកឲ្យការឆ្មើងឆ្មៃ ឬការឡើងចាងរំខាន
ដល់សេចក្ដីសុខសាន្តរបស់គេឡើយ; គឺមនុស្សគ្រប់រូបត្រូវគោរព
អ្នកជិត ខាងខ្លួន ដូចខ្លួនឯងផ្ទាល់ ដោយធ្វើការដោយដៃ
របស់ខ្លួនផ្ទាល់ ដើម្បីចិញ្ចឹមជីវិត ។
៥ មែនហើយ ហើយពួកសង្ឃ និងពួកគ្រូបង្រៀនទាំងអស់
ត្រូវធ្វើការដោយដៃរបស់គេផ្ទាល់ ដើម្បីចិញ្ចឹមជីវិត នៅក្នុង
គ្រប់ករណី ទាំងអស់ លើកលែងតែនៅក្នុងករណីឈឺ
ឬទាល់ក្រខ្លាំង; ហើយដោយធ្វើនូវការណ៍ទាំងនេះ នោះពួក
គេបានបរិបូរទៅដោយ ព្រះគុណនៃព្រះ ។
៦ ហើយក៏ចាប់ផ្ដើមមានសេចក្ដីសុខសាន្តជាច្រើនទៀត
នៅលើដែនដី; ហើយប្រជាជនបានចាប់ផ្ដើមកើនឡើងជាខ្លាំង
ហើយបាន ចាប់ផ្ដើមបែកចេញទៅពាសពេញលើផ្ទៃផែនដី
មែនហើយ ទៅទិសខាងជើង និងទិសទាងត្បូង ទៅទិស
ខាងកើត និងទិសខាងលិច ដោយសង់ទីក្រុងធំៗ និងភូមិទាំង
ឡាយនៅគ្រប់ទិសទាំងបួននៃដែនដី ។
៧ ហើយព្រះអម្ចាស់ទ្រង់បានយាងមករកពួកគេ ហើយបាន
ធ្វើឲ្យគេចំរើនឡើង ហើយពួកគេបានក្លាយទៅជាប្រជាជនមួយ
ដ៏ធំ ហើយ មានទ្រព្យសម្បត្តិបរិបូរណ៍ ។
៨ ឥឡូវនេះ ពួកបុត្រានៃម៉ូសាយត្រូវបានរាប់ក្នុងចំណោម
ពួកឥតជំនឿ; ហើយកូនប្រុសម្នាក់របស់អាលម៉ា ក៏ត្រូវបាន
រាប់ក្នុង ចំណោមពួកនោះដែរ គឺគាត់ត្រូវបានដាក់ឈ្មោះតាម
ឪពុកគាត់ថា អាលម៉ា; ទោះជាយ៉ាងណាក៏ដោយ គង់តែ
គាត់បានក្លាយទៅជា មនុស្សម្នាក់ដ៏សែនអាក្រក់ ហើយ
ថ្វាយបង្គំរូបព្រះ ។ ហើយគាត់ជាមនុស្សពោលពាក្យច្រើន
ហើយបាននិយាយបញ្ជោរជាច្រើនដល់ ប្រជាជន; ហេតុ
ដូច្នេះហើយ គាត់បានដឹកនាំមនុស្សជាច្រើន ឲ្យធ្វើតាមអំពើ
ទុច្ចរិតទាំងឡាយដែលគាត់ធ្វើ ។
៩ ហើយគាត់បានក្លាយទៅជាការឧបសគ្គមួយដ៏ធំ ជំទាស់ការ
ចំរើនឡើងនៃសាសនាចក្រនៃព្រះ; ដោយបានបង្វែរចិត្ត

៣៩ *ក* ស.ប. ព្រមាន, ពាក្យព្រមាន.
*ខ* ២ នីហ្វៃ ៣២:៨–៩.
*គ* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
**២៧** ២ *ក* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
៣ *ក* ម៉ូសាយ ២៣:៧; ២៩:៣២.
៤ *ក* ស.ប. សេចក្ដីសុខសាន្ត.
*ខ* ស.ប. រាប់អាន.
៥ *ក* ម៉ូសាយ ១៨:២៤, ២៦.
*ខ* ស.ប. ព្រះគុណ.
៨ *ក* ស.ប. អាលម៉ា, កូនប្រុសរបស់អាលម៉ា.
*ខ* ស.ប. ការថ្វាយបង្គំរូបព្រះ.
៩ *ក* ២ សាំយូ. ១៥:១–៦.

មនុស្ស; ដោយបានធ្វើឲ្យមានការបែកបាក់គ្នាជាច្រើននៅក្នុង
ចំណោមប្រជាជន; ដោយបានបើកឱកាសឲ្យខ្មាំងសត្រូវរបស់
ព្រះ អនុវត្តអំណាច របស់វាទៅលើពួកគេ ។
១០ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅពេល
គាត់កំពុងតែចេញទៅកំទេចសាសនាចក្រនៃព្រះ ត្បិតគាត់បាន
ទៅ ដោយសម្ងាត់ ជាមួយនឹងពួកបុត្រានៃម៉ូសាយ ស្វែងរកកំទេច
សាសនាចក្រចោល ហើយដឹកនាំប្រជាជននៃព្រះអម្ចាស់ឲ្យវ
ង្វេងចេញ ផ្ទុយពីព្រះបញ្ញត្តិទាំងឡាយនៃព្រះ ឬនៃស្ដេច —
១១ ហើយដូចជាខ្ញុំបានប្រាប់អ្នកមកហើយថា នៅពេលដែលពួក
គេកំពុងតែចេញទៅបះបោរទាស់នឹងព្រះ មើលចុះ ទេវតានៃព្រះ
អម្ចាស់បានលេចខ្លួនដល់គេ; ហើយទេវតានោះហាក់បីដូចជា
ចុះមកពីលើពពក; ហើយលោកបាននិយាយ ហាក់បីដូចជា
សូរផ្គរលាន់ ដែលធ្វើឲ្យផែនដីកក្រើក នៅត្រង់កន្លែងដែលពួក
គេឈរ;
១២ ហើយពួកគេមានសេចក្ដីអស្ចារ្យជាខ្លាំង រហូត
ដល់គេដួលចុះទៅលើដី ហើយពុំយល់ពាក្យពេចន៍ ដែល
លោកនិយាយមកកាន់ គេសោះ ។
១៣ ទោះជាយ៉ាងណាក៏ដោយ គង់តែលោកបាន
ស្រែកទៀតថា៖ អាលម៉ាអើយ ចូរក្រោកឈរឡើង
ត្បិតតើហេតុអ្វីបានជាអ្នក បៀតបៀនដល់សាសនាចក្រនៃព្រះ?
ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ នេះគឺជាសាសនាចក្រ
របស់យើង ហើយយើងនឹងតាំង វាឡើង; ហើយគ្មានអ្វីនឹងមក
រំលំសាសនាចក្រនេះបានទេ; លើកលែងតែអំពើរំលង
នៃរាស្ត្រយើងប៉ុណ្ណោះ ។
១៤ ហើយម្ដងទៀត ទេវតានិយាយថា៖ មើលចុះ ព្រះ
អម្ចាស់ទ្រង់បានឮពាក្យអធិស្ឋានទាំងឡាយរបស់រាស្ត្រទ្រង់
និងព្រមទាំងពាក្យ អធិស្ឋានទាំងឡាយរបស់អ្នកបំរើទ្រង់ផង
គឺអាលម៉ា ជាឪពុកអ្នក; ត្បិតលោកបានអធិស្ឋានដោយសេចក្ដី
ជំនឿដ៏ជោកជាំអំពីអ្នក សូមឲ្យ អ្នកអាចបាននាំមកឲ្យស្គាល់នូវ
សេចក្ដីពិត; ហេតុដូច្នេះហើយ ដោយគោលបំណងនេះហើយ
ដែលខ្ញុំបានមកបរិវត្តអ្នកអំពីព្រះចេស្ដា និង សិទ្ធិអំណាចនៃព្រះ
ដើម្បីឲ្យពាក្យអធិស្ឋានទាំងឡាយរបស់ពួកអ្នកបំរើរបស់ទ្រង់
អាចបានឆ្លើយតប ស្របតាមសេចក្ដីជំនឿរបស់គេ ។
១៥ ហើយឥឡូវនេះ មើលចុះ តើអ្នកអាចប្រកែកនឹងព្រះចេស្ដា
នៃព្រះបានទេ ? ត្បិតមើលចុះ តើសម្លេងរបស់ខ្ញុំមិនបានធ្វើឲ្យ
ផែនដី កក្រើកទេឬអី ? ហើយតើអ្នកមិនឃើញខ្ញុំនៅខាងមុខ
អ្នកទេឬ ? ហើយខ្ញុំត្រូវបានចាត់មកពីព្រះ ។
១៦ ឥឡូវនេះ ខ្ញុំប្រាប់អ្នកថា៖ ទៅចុះ ហើយចូរនឹកចាំពីកា
រជាប់ឃុំឃាំងរបស់ពួកអយ្យកោអ្នក នៅលើដែនដីហេឡាម
ហើយនៅ លើដែនដីនីហ្វៃ; ហើយចូរនឹកចាំពីការណ៍ដ៏មហិមា
ទាំងឡាយ ដែលទ្រង់បានធ្វើដល់ពួកគេ; ត្បិតពួកគេបាននៅ
ក្នុងសេវកភាព ហើយទ្រង់បានដោះពួកគេឲ្យរួចផុត ។
ហើយឥឡូវនេះ អាលម៉ាអើយ ខ្ញុំប្រាប់អ្នកថា ចូរអ្នក
ទៅតាមផ្លូវរបស់អ្នកចុះ ហើយចូរកុំរក បំផ្លាញសាសនាចក្រ
ទៀតឡើយ ដើម្បីឲ្យពាក្យអធិស្ឋានទាំងឡាយរបស់គេ អាច
បានឆ្លើយតប ហើយនេះទោះជាខ្លួនអ្នក ត្រូវបោះបង់
ចោលក៏ដោយ ។
១៧ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នេះហើយ
ជាពាក្យចុងក្រោយបង្អស់ ដែលទេវតាបាននិយាយទៅកាន់
អាលម៉ា ហើយទេវតានោះក៏ចាកចេញទៅ ។
១៨ ហើយឥឡូវនេះ អាលម៉ា និងពួកអ្នកដែលនៅទីនោះជា
មួយគាត់ ក៏ដួលទៅលើដីទៀត ព្រោះសេចក្ដីអស្ចារ្យរបស់គេមាន
ទំហំធំដ៏ក្រៃលែង; ព្រោះគេបានឃើញទេវតានៃព្រះអម្ចាស់ដោយ
ភ្នែកគេផ្ទាល់; ហើយសម្លេងរបស់ទេវតានោះ ប្រៀបដូចជា
ផ្គរលាន់ ដែលធ្វើឲ្យផែនដីកក្រើក ហើយពួកគេដឹងថា គ្មាន
អ្វីក្រៅពីព្រះចេស្ដានៃព្រះឡើយ ដែលអាចអង្រួនផែនដី
ហើយធ្វើឲ្យផែនដីញ័រ ហាក់បីដូចចង់បែកចេញដូច្នោះ ។
១៩ ហើយឥឡូវនេះ សេចក្ដីអស្ចារ្យរបស់អាលម៉ាមាន
ទំហំធំដ៏ក្រៃលែង រហូតដល់គាត់បានក្លាយទៅជាគ ហើយ
គាត់មិនអាចហើប មាត់គាត់បានឡើយ; មែនហើយ គាត់បាន
ក្លាយទៅជាអស់កម្លាំង គឺគាត់មិនអាចកំរើកដៃរបស់គាត់
បានឡើយ; ហេតុដូច្នេះហើយ គាត់ត្រូវពួកជនដែលនៅជាមួយ
នឹងគាត់នោះ សែងគាត់ទៅដោយឥតកំរើក រហូត
ដល់គេដាក់គាត់ចុះ នៅខាងមុខឪពុកគាត់ ។
២០ ហើយពួកគេបានរៀបរាប់ប្រាប់ឪពុកគាត់ អំពីអ្វីៗ
ទាំងអស់ដែលបានកើតឡើងដល់ពួកគេ; ហើយឪពុកគាត់បាន
អររីករាយ ព្រោះលោកដឹងថា នោះគឺជាព្រះចេស្ដានៃព្រះ ។
២១ ហើយលោកបានចាត់ឲ្យពួកបណ្ដាជនប្រមូលគ្នាមក

១១ *ក* ស.ប. ការបះបោរ.
*ខ* ស.ប. ពួកទេវតា.
*គ* កិច្ចការ ៩:១–៩; អាលម៉ា ៨:១៥.
១៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិរសានៃសាសនាចក្រ.
១៤ *ក* អាលម៉ា ១០:២២.
*ខ* មរមន ៩:៣៦–៣៧.
១៦ *ក* ម៉ូសាយ ២៣:១–៤.

ដើម្បីគេអាចធ្វើជាសាក្សីចំពោះអ្វីៗ ដែលព្រះអម្ចាស់ទ្រង់បាន
ធ្វើដល់ កូនប្រុសលោក ហើយព្រមទាំងធ្វើដល់ពួកជន ដែល
នៅជាមួយនឹងកូនលោកផង ។
២២ ហើយលោកបានចាត់ឲ្យពួកសង្ឃប្រជុំគ្នា; ហើយពួក
គេបានចាប់ផ្ដើមតមអាហារ ហើយអធិស្ឋានទៅព្រះអម្ចាស់
ជាព្រះរបស់គេ សូមឲ្យទ្រង់បើកមាត់អាលម៉ា ដើម្បីឲ្យគាត់
អាចនិយាយបានវិញ ហើយក៏សូមឲ្យដៃជើងរបស់គាត់ អាច
បានកម្លាំងឡើងវិញផង — ដើម្បី ឲ្យភ្នែករបស់មនុស្សអាចបាន
បើកឃើញ ហើយដឹងនូវសេចក្ដីល្អសប្បុរស និងសិរីល្អនៃព្រះ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេ
បានតមអាហារ ហើយបានអធិស្ឋានអស់រយៈពេលពីរថ្ងៃ និង
ពីរយប់មក ហើយ នោះស្រាប់តែដៃជើងរបស់អាលម៉ា ក៏មាន
កម្លាំងឡើងវិញ ហើយគាត់បានក្រោកឈរឡើង ហើយបាន
ចាប់ផ្ដើមនិយាយទៅ កាន់ពួកគេ សូមឲ្យពួកគេបានក្សាន្តចិត្តទៅ៖
២៤ ត្បិតគាត់បាននិយាយថា ខ្ញុំបានប្រែចិត្តពីអំពើបាបទាំង
ឡាយរបស់ខ្ញុំហើយ ហើយព្រះអម្ចាស់ទ្រង់បាន[ក]ប្រោសលោះខ្ញុំ
ហើយ; មើលចុះ ខ្ញុំបានកើតមកពីព្រះវិញ្ញាណ ។
២៥ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ចូរកុំស្ញប់
ស្ញែងថា មនុស្សលោកទាំងអស់ មែនហើយ ទាំងប្រុសទាំងស្រី
គ្រប់ទាំង សាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំង
ប្រជាជន ត្រូវតែ[ក]កើតម្ដងទៀតឡើយ; មែនហើយ គឺកើតមក
ពីព្រះ [ខ]ផ្លាស់ប្រែពីស្ថានភាព [គ]ខាងរូបកាយ និងខាងការធ្លាក់
ទៅកាន់ស្ថានភាពនៃសេចក្ដីសុចរិតវិញ ដោយបានព្រះ
ទ្រង់ប្រោសលោះ នោះនឹងក្លាយទៅជាបុត្រាបុត្រី របស់ទ្រង់;
២៦ ម្ល៉ោះហើយ ពួកគេក្លាយទៅជាសត្វលោកថ្មី;
ហើយលើកលែងតែពួកគេធ្វើយ៉ាងនេះ [ក]នោះពួកគេពុំអាច
គ្រងនគរព្រះទុកជាមរតក បានឡើយ ។
២៧ ខ្ញុំសូមប្រាប់អ្នកថា លើកលែងតែដោយករណីយនេះហើយ
បើពុំនោះសោតទេ ពួកគេនឹងត្រូវបោះបង់ចោល; ហើយ
ការណ៍នេះខ្ញុំដឹង ពីព្រោះខ្ញុំហៀបនឹងត្រូវបោះបង់ចោល ។
២៨ ទោះជាយ៉ាងណាក៏ដោយ គឺបន្ទាប់ពីបានឆ្លងកាត់ការ
វេទនាជាច្រើន បានប្រែចិត្តនៅពេលជិតស្លាប់ នោះនៅ
ក្នុងសេចក្ដីមេត្តា ករុណា ព្រះអម្ចាស់ទ្រង់បានទតឃើញថា
ល្អមទាញយកខ្ញុំចេញពីការ[ក]ឆេះដ៏អស់កល្បជានិច្ច ហើយខ្ញុំ
បានកើតមកពីព្រះ ។
២៩ ព្រលឹងខ្ញុំត្រូវបានប្រោសលោះចេញពីប្រម៉ាត់ល្វីងជូរចត់
និងចំណងទាំងឡាយនៃអំពើទុច្ចរិត ។ ខ្ញុំបាននៅក្នុងជ្រោះជ្រៅ
ងងឹត; ប៉ុន្តែឥឡូវនេះ ខ្ញុំឃើញពន្លឺដ៏អស្ចារ្យនៃព្រះហើយ ។
ព្រលឹងខ្ញុំត្រូវបាន[ក]ញាំញីដោយការទុក្ខវេទនាដ៏អស់កល្បជានិច្ច;
ប៉ុន្តែឥឡូវនេះ ខ្ញុំត្រូវបានទាញចេញមកហើយ ហើយព្រលឹងខ្ញុំ
ពុំឈឺចាប់ទៀតទេ ។
៣០ ខ្ញុំមិនបានទទួលស្គាល់ព្រះប្រោសលោះរបស់ខ្ញុំទេ ហើយបាន
បដិសេធនូវអ្វីៗ ដែលពួកអយ្យកោខ្ញុំបាននិយាយ; ប៉ុន្តែឥឡូវនេះ
ដើម្បីឲ្យពួកគេអាចឃើញជាមុនថា ទ្រង់នឹងយាងមក ហើយ
ថា ទ្រង់នៅនឹកចាំដល់គ្រប់សត្វលោក ដែលទ្រង់បានបង្កើត
មក នោះទ្រង់នឹង សម្ដែងរូបអង្គទ្រង់ដល់មនុស្សទាំងអស់ ។
៣១ មែនហើយ គ្រប់[ក]ជង្គង់នឹងលុតចុះ ហើយគ្រប់អណ្ដាត
នឹងទទួលថ្លែងប្រាប់នៅចំពោះទ្រង់ ។ មែនហើយ គឺនៅថ្ងៃ
ចុងក្រោយបង្អស់ ក្នុងកាល មនុស្សទាំងអស់នឹងឈរដើម្បី
ទទួល[ខ]ការជំនុំជំរះពីទ្រង់ ពេលនោះ ពួកគេនឹងទទួលស្គាល់ថា
ទ្រង់គឺជាព្រះ; ពេលនោះ ពួកគេនឹង ទទួលស្គាល់ គឺពួកអ្នក
ដែលរស់ដោយ[គ]គ្មានព្រះក្នុងលោកិយនេះថា ការជំនុំជំរះនៃ
ទោសដ៏អស់កល្បជានិច្ច គឺត្រឹមត្រូវចំពោះគេហើយ; ហើយ
ពួកគេនឹងញាក់ ហើយញ័រ ហើយរួញនៅក្រោមព្រះនេត្រ
របស់ទ្រង់ [ឃ]ដែលទតឃើញរបស់សព្វសារពើ ។
៣២ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ា
បានចាប់ផ្ដើមបង្រៀនប្រជាជន ចាប់ពីពេលនេះតទៅ ព្រមទាំង
ពួកអ្នក ដែលនៅជាមួយនឹងអាលម៉ា កាលទេវតាបាន
លេចខ្លួនឲ្យគេឃើញនោះផង បានធ្វើដំណើរពាសពេញដែនដី
បានប្រកាសប្រាប់ដល់ប្រជា ជនទាំងអស់ នូវរឿងទាំងឡាយ
ដែលគេបានឮ ហើយបានឃើញមក ហើយបានផ្សាយអំពីព្រះ
បន្ទូលនៃព្រះ ដោយសេចក្ដីវេទនាជាធ្ងន់ ត្រូវបានបៀតបៀន

២៤ *ក* ២ នីហ្វៃ ២:៦–៧.
ស.ប. ប្រោសលោះ, បាន ប្រោសលោះ, សេចក្ដីប្រោសលោះ.
២៥ *ក* រ៉ូម ៦:៣–១១; ម៉ូសាយ ៥:៧; អាលម៉ា ៥:១៤; ម៉ូសេ ៦:៥៩.
ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ខ* ម៉ូសាយ ៣:១៩; ១៦:៣.
*គ* ស.ប. ខាងរូបកាយ.
២៦ *ក* យ៉ូហាន ៣:៥.
២៨ *ក* ២ នីហ្វៃ ៩:១៦.
២៩ *ក* ម៉ូសាយ ២:៣៨.
៣១ *ក* ភីលីព ២:៩–១១; ម៉ូសាយ ១៦:១–២; គ. និង ស. ៨៨:១០៤.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
*គ* អាលម៉ា ៤១:១១.
*ឃ* ស.ប. ព្រះ.

យ៉ាងខ្លាំងពីពួកអ្នកដែលមិនជឿ គឺត្រូវបានវាយដំដោយពួក
នោះជាច្រើននាក់ ។
៣៣ ប៉ុន្តែទោះជាមានការណ៍អស់ទាំងនេះក្តី គង់តែពួកគេ
បាននាំមកនូវការលួងលោមចិត្តយ៉ាងច្រើនដល់សាសនាចក្រដែរ
ដោយបាន បញ្ជាក់នូវសេចក្តីជំនឿរបស់គេ ហើយបានទូន្មាន
ពួកគេ ដោយការអត់ធ្មត់ និងការឈឺចាប់ដ៏ច្រើន ឲ្យកាន់
តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។
៣៤ ហើយពួកគេបួននាក់ គឺជាពួកបុត្រានៃម៉ូសាយ;
ហើយគេមាននាមថា អាំម៉ូន និងអើរ៉ុន និងអោមណើរ និង
ហិមណៃ; នេះហើយគឺ ជានាមរបស់ពួកបុត្រានៃម៉ូសាយ ។
៣៥ ហើយពួកគេបានធ្វើដំណើរទូទៅអស់ទាំងដែនដី
សារ៉ាហិមឡា និងនៅក្នុងចំណោមប្រជាជនទាំងអស់ ដែល
នៅក្រោមរាជ្យនៃ ស្តេចម៉ូសាយ បានខំប្រឹងយ៉ាងអស់ពីចិត្ត
ដើម្បីជួសជុលនូវការខូចខាតទាំងអស់ ដែលពួកគេបានធ្វើដល់
សាសនាចក្រ បានសារភាពនូវ អំពើបាបទាំងអស់របស់គេ
ហើយបានផ្សាយប្រាប់អំពីរឿងទាំងអស់ ដែលគេបានឃើញ
ហើយបានពន្យល់ពាក្យព្យាករណ៍ និងបទគម្ពីរ ទាំងឡាយ ដល់
អស់អ្នកណាដែលមានបំណងចង់ស្តាប់តាមគេ ។
៣៦ ម្ល៉ោះហើយ ពួកគេបានទៅជាគ្រឿងឧបករណ៍ទាំងឡាយ
នៅក្នុងព្រះហស្តនៃព្រះ ក្នុងការនាំមនុស្សជាច្រើន ឲ្យស្គាល់សេចក្តី
ពិត មែនហើយ ឲ្យស្គាល់ព្រះដ៏ប្រោសលោះរបស់គេ ។
៣៧ ហើយពួកគេពិតជាបានពរណាស់ហ្ន៎! ព្រោះពួកគេបាន
ផ្សាយសេចក្តីសុខសាន្ត; ពួកគេបានផ្សាយដំណឹងល្អនៃសេចក្តី
ល្អ; ហើយពួកគេបានប្រកាសប្រាប់ប្រជាជនថា ព្រះអម្ចាស់
ទ្រង់សោយរាជ្យ ៕

## ជំពូកទី ២៨

*ពួកបុត្រានៃម៉ូសាយទៅបង្រៀនសាសនាដល់ពួកសាសន៍លេមិន — ម៉ូសាយបកប្រែផ្ទាំងនៃសាសន៍យ៉ារេឌ ដោយប្រើត្បូងនៃអ្នក មើលឆុតទាំងពីរដុំ ។ ប្រមាណជាឆ្នាំ ៩២ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកបុត្រា
នៃម៉ូសាយ បានធ្វើការណ៍អស់ទាំងនេះហើយ នោះពួកគេបាននាំ
មនុស្សមួយ ចំនួនតូចទៅជាមួយនឹងគេ ហើយបានត្រឡប់ទៅជួប
បិតាខ្លួន ដែលជាស្តេចវិញ ហើយបានសូមឲ្យទ្រង់អនុញ្ញាតឲ្យគេ
ជាមួយនឹងពួកមនុស្ស ដែលគេបានរើសនោះ ឡើងទៅឯដែនដី
នីហ្វៃ ដើម្បីគេអាចបង្រៀននូវរឿងទាំងឡាយ ដែលគេបានឮ
ហើយដើម្បីគេអាចចែកចំលែកនូវ ព្រះបន្ទូលនៃព្រះ ទៅដល់
បងប្អូនគេ គឺពួកសាសន៍លេមិន —
២ ក្រែងគេអាចនាំឲ្យពួកគេស្គាល់ព្រះអម្ចាស់ ជាព្រះរបស់គេ
ហើយបរិវត្តពួកគេអំពីសេចក្តីទុច្ចរិតនៃពួកអយ្យកោគេ; ហើយ
ក្រែងគេ អាចធ្វើឲ្យពួកគេបាត់ស្អប់ដល់ពួកសាសន៍នីហ្វៃ
ដើម្បីគេអាចនាំឲ្យពួកគេបានអររីករាយនៅក្នុងព្រះអម្ចាស់ ជា
ព្រះរបស់គេផង ដើម្បីឲ្យពួកគេ អាចបានក្លាយទៅជាមិត្ត
សំឡាញ់ទៅវិញទៅមក ហើយដើម្បីកុំឲ្យមានការទាស់ទែង
គ្នាតទៅទៀត នៅលើដែនដីទាំងអស់ ដែលព្រះ អម្ចាស់ ជា
ព្រះរបស់គេបានប្រទានដល់គេ ។
៣ ឥឡូវនេះ ពួកគេមានបំណងចង់ប្រកាសប្រាប់ពីសេច
ក្តីសង្គ្រោះដល់សត្វលោកគ្រប់រូប ព្រោះពួកគេពុំអាចទ្រាំឲ្យ
ព្រលឹងមនុស្សណា ម្នាក់ត្រូវវិនាសឡើយ; មែនហើយ ទោះបី
គ្រាន់តែគិតថា ព្រលឹងមនុស្សណាម្នាក់ត្រូវស៊ូទ្រាំនូវការទុក្ខ
វេទនាដ៏មិនចេះចប់មិនចេះហើយ ក៏ធ្វើឲ្យពួកគេញាក់ និង
ញ័រទៅហើយ ។
៤ ហើយព្រះវិញ្ញាណនៃព្រះអម្ចាស់បានប្រព្រឹត្តទៅលើពួក
គេយ៉ាងដូច្នោះហើយ ត្បិតពួកគេធ្លាប់ជាមនុស្សអាក្រក់បំផុត
ក្នុងចំណោម មនុស្សដែលមានបាបទាំងឡាយ ។ ហើយព្រះ
អម្ចាស់ទ្រង់បានទតឃើញ នៅក្នុងសេចក្តីមេត្តាករុណាដ៏និរន្តរ៍
របស់ទ្រង់ថា ល្មមទុកជីវិត ឲ្យពួកគេហើយ; ទោះជាយ៉ាង
ណាក៏ដោយ គង់តែពួកគេបានទ្រាំការសោកសៅដ៏ច្រើននៅ
ក្នុងព្រលឹង ដោយព្រោះអំពើទុច្ចរិតទាំងឡាយ របស់គេបានរង
ទុក្ខវេទនាដ៏ច្រើន ហើយបានខ្លាចក្រែងពួកគេត្រូវ
បោះបង់ចោលរហូតតទៅ ។

៣៤ *ក* ស.ប. អាំម៉ូន, បុត្ររបស់ម៉ូសាយ.
៣៧ *ក* អេសាយ ៥២:៧;
ម៉ូសាយ ១៥:១៤–១៧.
ស.ប. ផ្សាយ.
*ខ* ស.ប. ដំណឹងល្អ.
**២៨** ១*ក* ម៉ូសាយ ២៧:៣៤.
*ខ* អោមណៃ ១:១២–១៣;
ម៉ូសាយ ៩:១.
២ *ក* យ៉ាកុប ៧:២៤.
៣ *ក* អាលម៉ា ១៣:២៧;
៣ នីហ្វៃ ១៧:១៤; ម៉ូសេ ៧:៤១.
*ខ* ស.ប. ព្រលឹង — តម្លៃនៃព្រលឹង
ទាំងឡាយ.
*គ* យ៉ាកុប ៦:១០;
គ. និង ស. ១៩:១០–១២.
៤ *ក* ម៉ូសាយ ២៧:១០.
*ខ* ស.ប. សេចក្តីមេត្តាករុណា,
មេត្តាករុណា.

៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានសូមអង្វរបិតា
របស់ខ្លួន អស់ជាច្រើនថ្ងៃ សូមឲ្យពួកគេអាចបានឡើងទៅដែនដី
នីហ្វៃ ។
៦ ហើយស្ដេចម៉ូសាយបានទៅទូលសួរដល់ព្រះអម្ចាស់ថា
តើទ្រង់ត្រូវឲ្យពួកបុត្រាទ្រង់ឡើងទៅក្នុងចំណោមពួកលេមិន
ដើម្បីបង្រៀន ព្រះបន្ទូលឬអី ?
៧ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកម៉ូសាយថា៖
ចូរឲ្យពួកគេឡើងទៅចុះ ត្បិតនឹងមានមនុស្សជាច្រើនដែល
នឹងជឿដល់ពាក្យសំដី របស់ពួកគេ ហើយពួកគេនឹងមាន
ជីវិតដ៏នៅអស់កល្បជានិច្ច; ហើយយើងនឹងដោះពួកបុត្រា
របស់អ្នក ឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកលេមិន ។
៨ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសាយបាន
អនុញ្ញាតឲ្យពួកគេទៅ ហើយធ្វើតាមសំណូមពររបស់គេចុះ ។
៩ ហើយពួកគេបានចេញដំណើរចូលទៅក្នុងទីរហោស្ថាន
ដើម្បីឡើងទៅផ្សាយព្រះបន្ទូល នៅក្នុងចំណោមពួកសាសន៍
លេមិន; ហើយខ្ញុំ នឹងរៀបរាប់អំពីដំណើរការ
របស់គេនៅពេលក្រោយ ។
១០ ឥឡូវនេះ ស្ដេចម៉ូសាយគ្មាននរណាដើម្បីប្រគល់នគរឲ្យ
ព្រោះគ្មានបុត្រណាម្នាក់ចង់ទទួលនគរឡើយ ។
១១ ហេតុដូច្នេះហើយ ទើបទ្រង់យកបញ្ជីទាំងឡាយ ដែល
ឆ្លាក់នៅលើផ្ទាំងលង្ហិន ព្រមទាំងផ្ទាំងនីហ្វៃផង និងវត្ថុទាំងអស់
ដែលទ្រង់ បានកត់ ហើយបានទុក ហើយថែរក្សា
ស្របតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះនោះមក បន្ទាប់ពីបាន
បកប្រែ ហើយចាត់ឲ្យគេកត់បញ្ជីទាំងនោះ ដែលនៅលើផ្ទាំង
មាស ដែលប្រជាជនរបស់លិមហៃបានប្រទះឃើញ ដែលបាន
ប្រគល់ដល់ទ្រង់ ដោយដៃរបស់លិមហៃ ។
១២ ហើយទ្រង់បានធ្វើយ៉ាងនេះ ក៏ព្រោះតែការបារម្ភជា
ខ្លាំងរបស់រាស្ត្រទ្រង់ ព្រោះពួកគេចង់ដឹងហួសប្រមាណ អំពី
ប្រជាជនដែលត្រូវ បំផ្លាញបង់ ។
១៣ ហើយឥឡូវនេះ ទ្រង់បានបកប្រែបញ្ជីទាំងនេះ ដោយ
ត្បូងទាំងពីរដុំដែលភ្ជាប់ទៅនឹងគែមពីរនៃស៊ុម ។
១៤ ឥឡូវនេះ វត្ថុទាំងនេះត្រូវបានរៀបចំឡើង
ចាប់តាំងពីដើមដំបូងមក ហើយត្រូវបានប្រគល់ពីតំណមួយ
ទៅតំណមួយ ក្នុងគោលបំណង ដើម្បីបកប្រែភាសា ។
១៥ ហើយវត្ថុទាំងនេះ ត្រូវបានរក្សាទុកឲ្យបានគង់វង្ស ដោយ
ព្រះហស្តនៃព្រះអម្ចាស់ ដើម្បីទ្រង់នឹងបើកបង្ហាញដល់សត្វ
លោកគ្រប់រូបណា ដែលនឹងមកតាំងនៅលើដែនដីនេះ នូវអំពើ
ទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយនៃរាស្ត្រទ្រង់ ។
១៦ ហើយអ្នកណាដែលមានវត្ថុទាំងនេះ ត្រូវហៅថា អ្នក
មើលឆុត ស្របតាមរបៀបពីជំនាន់ដើម ។
១៧ ឥឡូវនេះ បន្ទាប់ពីម៉ូសាយបានបកប្រែបញ្ជី
ទាំងនេះចប់ហើយ មើលចុះ បញ្ជីនោះបានរៀបរាប់អំពី
ប្រជាជនដែលត្រូវបំផ្លាញចោល ចាប់តាំងពីពេលដែលគេត្រូវ
បំផ្លាញចោល រហូតទៅដល់ពេលដែលសង់ប៉មធំឡើង
គឺនៅពេលដែលព្រះអម្ចាស់ទ្រង់បានបំភាន់ភាសា មនុស្ស
ហើយពួកគេត្រូវបានខ្ចាត់ខ្ចាយទៅលើផ្ទៃផែនដីទាំងមូល មែន
ហើយ គឺចាប់តាំងពីពេលនោះ រហូតទៅដល់ការ
បង្កើតលោកអ័ដាម ។
១៨ ឥឡូវនេះ ដំណើររឿងនេះបានធ្វើឲ្យប្រជាជនម៉ូសាយ
កើតទុក្ខជាខ្លាំង មែនហើយ ពួកគេបានពោរពេញទៅដោយការ
សោកសៅ; ទោះជាយ៉ាងណាក៏ដោយ គង់តែដំណើរ
រឿងនេះបានផ្ដល់ដល់គេ នូវការចេះដឹងជាច្រើន ម្ល៉ោះហើយ
ទើបគេបានអររីករាយ ។
១៩ ហើយដំណើររឿងនេះនឹងត្រូវបានសរសេរនៅខាងក្រោយ;
ត្បិតមើលចុះ ជាការចាំបាច់ដែលមនុស្សទាំងអស់ត្រូវដឹងនូវ
រឿង ទាំងឡាយ ដែលបានសរសេរនៅក្នុងដំណើររឿងនេះ។
២០ ហើយឥឡូវនេះ ដូចខ្ញុំបាននិយាយប្រាប់អ្នករួចហើយថា
បន្ទាប់ពីស្ដេចម៉ូសាយបានធ្វើការណ៍ទាំងនេះចប់ហើយ នោះទ្រង់
បានយក ផ្ទាំងលង្ហិន និងវត្ថុទាំងអស់ដែលទ្រង់បានកត់ទុក
ហើយបានប្រគល់របស់ទាំងអស់ឲ្យទៅអាលម៉ា ជាកូនប្រុស
របស់អាលម៉ា; មែនហើយ បញ្ជីទាំងអស់ និងព្រមទាំងប្រដាប់
បកប្រែទាំងឡាយផង ហើយបានប្រគល់វត្ថុទាំងអស់ទៅគាត់
ហើយបានបញ្ជាឲ្យគាត់កត់ ហើយរក្សា វត្ថុទាំងនោះ ហើយឲ្យ
កត់បញ្ជីអំពីប្រជាជនទុកផង គឺឲ្យប្រគល់ពីតំណមួយទៅតំណ

៧ *ក* អាលម៉ា ១៩:២២–២៣.
៩ *ក* អាលម៉ា ១៧:៦–៩.
*ខ* អាលម៉ា ១៧–២៦.
១១ *ក* ស.ប. ផ្ទាំងលង្ហិន.
*ខ* ស.ប. ផ្ទាំងមាស.
១៣ *ក* ស.ប. យូរីម និងធូមីម.
១៦ *ក* ម៉ូសាយ ៨:១៣–១៨.
ស.ប. អ្នកមើលឆុត.
១៧ *ក* ម៉ូសាយ ៨:៧–១២.
*ខ* អេធើរ ១:១–៥.
*គ* លោកុ. ១១:៦–៩.
២០ *ក* អាលម៉ា ៣៧:៣–១០.
*ខ* ស.ប. យូរីម និងធូមីម.
*គ* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរ
ដែលត្រូវរក្សាទុក.

មួយ ដូចជាគេធ្លាប់បានប្រគល់មក ចាប់តាំងពីពេល ដែល
លីហៃបានចាកចេញពីក្រុងយេរូសាឡិមមកម្ល៉េះ ៕

## ជំពូកទី ២៩

*ម៉ូសាយស្នើឲ្យរើសតាំងពួកចៅក្រមជំនួសស្តេច — ពួកស្តេចទុច្ចរិតដឹកនាំប្រជាជនខ្លួនចូលក្នុងអំពើបាប — អាលម៉ាជាកូន ត្រូវបានរើសតាំង ជាមេចៅក្រម ដោយសម្លេងរបស់ប្រជាជន — លោកក៏ជាសង្ឃជាន់ខ្ពស់លើសាសនាចក្រផង — អាលម៉ា ជាឪពុក និងម៉ូសាយ បានស្លាប់ទៅ ។ ប្រមាណជាឆ្នាំ ៩២–៩១ ម.គ.ស. ។*

ឥឡូវនេះ កាលម៉ូសាយបានធ្វើការនេះចប់ហើយ ទ្រង់បានផ្ញើសារ
ទូទៅអស់ទាំងដែនដី គឺនៅក្នុងចំណោមប្រជាជនទាំងអស់ ដោយ
ចង់ដឹង បំណងរបស់គេថា តើអ្នកណានឹងធ្វើជាស្តេចរបស់គេ ។
២ ហើយហេតុការណ៍បានកើតឡើងថា សម្លេងរបស់
ប្រជាជនបានប្រាប់មកថាៈ យើងខ្ញុំចង់ឲ្យអើរ៉ុន ជាបុត្ររបស់
ទ្រង់ ធ្វើជាស្តេចហើយ ជាអ្នកគ្រប់គ្រងលើយើង ។
៣ ឥឡូវនេះ អើរ៉ុនបានឡើងទៅដែនដីនីហ្វៃផុតហើយ ហេតុ
ដូច្នេះហើយ ស្តេចពុំអាចប្រគល់នគរទៅលោកបានឡើយ;
ឯអើរ៉ុនក៏មិន ចង់ទទួលនគរដែរ; ហើយ[ក]គ្មានបុត្រនៃម៉ូសាយ
ណាមួយចង់ទទួលនគរឡើយ ។
៤ ហេតុដូច្នេះហើយ ស្តេចម៉ូសាយបានផ្ញើសារ ទៅក្នុង
ចំណោមប្រជាជនទៀត; មែនហើយ គឺផ្ញើសារជាអក្សរទៅកាន់
ប្រជាជន ។ ហើយសារនោះមានពាក្យសរសេរថាៈ
៥ មើលចុះ ឱប្រជាជនរបស់យើង ឬបងប្អូនរបស់យើងអើយ
ត្បិតយើងរាប់អ្នកទុកជាបងប្អូន យើងចង់ឲ្យអ្នករាល់គ្នាពិចារណា
នូវការណ៍ ដែលយើងសូមឲ្យអ្នកពិចារណានោះ — ព្រោះ
អ្នករាល់គ្នា[ក]ប្រាថ្នាចង់បានស្តេច ។
៦ ឥឡូវនេះ យើងប្រកាសប្រាប់អ្នកថា អ្នកដែលមានសិទ្ធិ
ទទួលនគរនោះបានប្រកែក ហើយមិនព្រមទទួលនគរផង ។
៧ ហើយឥឡូវនេះ បើសិនជាមានអ្នកណាមួយ បានតែងតាំង
ជំនួស មើលចុះ យើងខ្លាចក្រែងនឹងកើតការទាស់ទែង នៅក្នុង
ចំណោម ពួកអ្នករាល់គ្នា ។ ហើយតើអ្នកណាដឹងថា បុត្រ
របស់យើង ដែលនឹងបានទទួលនគរនោះនឹងបែរទៅជាខឹង
ហើយបំបែកយកប្រជាជន មួយផ្នែកតាមខ្លួន ជាហេតុដែល
នឹងនាំឲ្យកើតសង្គ្រាម និងការទាស់ទែងគ្នាទាំងឡាយនៅក្នុង
ចំណោមពួកអ្នករាល់គ្នា ដែលនឹងបណ្តាល ឲ្យមាន
ការខ្ចាយឈាមជាច្រើន និងការបង្ខូចផ្លូវនៃព្រះអម្ចាស់ មែន
ហើយ ហើយបំផ្លាញព្រលឹងរបស់មនុស្សច្រើនគ្នា ។
៨ ឥឡូវនេះ យើងប្រាប់អ្នកថា ចូរយើងរាល់គ្នាមានប្រាជ្ញា
ហើយពិចារណារឿងទាំងនេះចុះ ព្រោះយើងរាល់គ្នាគ្មានសិទ្ធិ
នឹងបំផ្លាញ បុត្រយើងទេ ហើយយើងរាល់គ្នាក៏គ្មានសិទ្ធិនឹងបំផ្លាញ
អ្នកណាផ្សេងទៀត ដែលនឹងតែងតាំងជំនួសដែរ ។
៩ ហើយបើសិនជាបុត្រយើងបែរទៅរកការឆ្មើងឆ្មៃ និង
ការឥតប្រយោជន៍ទាំងឡាយវិញនោះ នោះគេនឹងដកយកអ្វីៗ
ដែលគេបាន និយាយពីមុន ហើយទាមទារសិទ្ធិទទួលនគរ
ជាហេតុដែលនឹងនាំឲ្យគេ និងព្រមទាំងប្រជាជននេះប្រព្រឹត្ត
អំពើបាបដ៏ច្រើន ។
១០ ហើយឥឡូវនេះ ចូរយើងរាល់គ្នាមានប្រាជ្ញា ហើយគិត
ដល់ការណ៍ទាំងនេះជាមុនសិនចុះ ហើយធ្វើនូវអ្វីៗ ដែល
នឹងនាំមកនូវសេចក្តី សុខសាន្តដល់ប្រជាជននេះវិញ ។
១១ ហេតុដូច្នេះហើយ យើងនឹងធ្វើជាស្តេចរបស់អ្នក នៅ
ក្នុងថ្ងៃទាំងឡាយដែលនៅសល់ក្នុងជីវិតយើង; ទោះជាយ៉ាង
ណាក៏ដោយ ចូរយើង[ក]តែងតាំងពួកចៅក្រមឡើង ដើម្បី
[ខ]ជំនុំជំរះប្រជាជននេះ ស្របតាមច្បាប់របស់យើង; ហើយយើង
នឹងរៀបចំសារជាថ្មី នូវកិច្ចការ ទាំងឡាយរបស់ប្រជាជននេះ
ព្រោះយើងនឹងតែងតាំងពួកអ្នកប្រាជ្ញ ឲ្យធ្វើជាពួកចៅក្រម ដែល
នឹងជំនុំជំរះប្រជាជននេះ ស្របតាមព្រះ បញ្ញត្តិទាំងឡាយនៃព្រះ ។
១២ ឥឡូវនេះ បើមនុស្សម្នាក់ត្រូវបានជំនុំជំរះដោយព្រះ ជា
ការប្រសើរជាងត្រូវបានជំនុំជំរះដោយមនុស្ស ព្រោះសេចក្តី
ជំនុំជំរះទាំង ឡាយនៃព្រះ ប្រកបដោយសេចក្តីយុត្តិធម៌ជានិច្ច
តែសេចក្តីជំនុំជំរះនៃមនុស្ស ពុំដែលប្រកបដោយសេចក្តីយុត្តិធម៌
ជានិច្ចឡើយ ។
១៣ ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាអាចមាន
[ក]បុរសសុចរិតទាំងឡាយធ្វើជាស្តេចអ្នក ដែលនឹងតាំង
ក្រិត្យវិន័យទាំងឡាយនៃ ព្រះឡើង ហើយជំនុំជំរះប្រជាជននេះ
ស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ មែនហើយ បើ
សិនជាអ្នករាល់គ្នាអាចមានបុរសទាំងនោះ សំរាប់ធ្វើជាស្តេច
របស់អ្នក ដែលនឹងធ្វើឲ្យបានដូចជាបិតារបស់យើង គឺស្តេច
[ខ]បេនយ៉ាមីន បានធ្វើឲ្យប្រជាជននេះ — នោះយើងប្រាប់អ្នកថា

**២៩** ៣*ក* ម៉ូសាយ ២៧:៣៤.
៥ *ក* ១ សាំយូ. ៨:៩–១៩.
១១ *ក* ម៉ូសាយ ២៩:២៥–២៧.
*ខ* និក្ខ. ១៨:១៣–២៤.
១៣ *ក* ម៉ូសាយ ២៣:៨, ១៣–១៤.
*ខ* ព. នៃ ម. ១:១៧–១៨.

បើករណីនេះអាចមានជានិច្ច នោះអ្នករាល់គ្នាចាំបាច់ត្រូវ
តែមានស្ដេចគ្រប់គ្រងលើអ្នកទៅចុះ ។
១៤ ហើយទោះជារូបយើងនេះ ក៏ធ្លាប់បានខិតខំធ្វើការ
អស់ពីកម្លាំង និងសមត្ថភាពដែលយើងមាន ដើម្បីបង្រៀន
អ្នកនូវព្រះបញ្ញត្តិទាំង ឡាយនៃព្រះ ហើយដើម្បីកសាងសេច
ក្ដីសុខសាន្តទូទៅទាំងដែនដី ដើម្បីកុំឲ្យមានសង្គ្រាម ឬការ
ទាស់ទែងគ្នាទាំងឡាយ កុំឲ្យមានការលួច ការប្លន់ ការប្រព្រឹត្ត
អំពើឃាតកម្ម ឬអំពើទុច្ចរិតបែបណាមួយឡើយ ។
១៥ ហើយអ្នកណាដែលប្រព្រឹត្តអំពើទុច្ចរិត អ្នកនោះហើយ
ដែលយើងបានធ្វើទោសតាមបទល្មើស ដែលគេបានប្រព្រឹត្ត
ស្របតាមច្បាប់ ដែលពួកអយ្យកោរបស់យើងបានទុកឲ្យ
យើងរាល់គ្នា ។
១៦ ឥឡូវនេះ យើងប្រាប់អ្នកថា ពីព្រោះមនុស្សមិនសុចរិត
ទាំងអស់គ្នាទេ នោះអ្នករាល់គ្នាពុំចាំបាច់មានស្ដេចមួយ ឬពួក
ស្ដេច ដើម្បី គ្រប់គ្រងលើអ្នកឡើយ ។
១៧ ត្បិតមើលចុះ តើអំពើទុច្ចរិតប៉ុន្មានទៅ ដែលស្ដេច
ទុច្ចរិតម្នាក់អាចបណ្ដាលឲ្យប្រព្រឹត្ត មែនហើយ ហើយតើការ
បំផ្លិចបំផ្លាញធំប៉ុណ្ណាទៅ!
១៨ មែនហើយ ចូរនឹកចាំពីស្ដេចណូអេ អំពើទុច្ចរិត និងអំពើ
គួរខ្ពើមឆ្អើមទាំងឡាយរបស់ទ្រង់ ហើយព្រមទាំងអំពើទុច្ចរិត
និងអំពើគួរ ខ្ពើមឆ្អើមទាំងឡាយរបស់ប្រជាជនទ្រង់ផង ។ មើលចុះ
តើការបំផ្លិចបំផ្លាញធំប៉ុណ្ណាទៅ ដែលបានកើតឡើងដល់ពួក
គេនោះ; ហើយដោយ ព្រោះសេចក្ដីទុច្ចរិតរបស់គេ ទើបគេ
ត្រូវនាំឲ្យធ្លាក់ទៅក្នុងសេវកភាពផង ។
១៩ ហើយបើគ្មានអន្តរាគមន៍អំពីព្រះដ៏បង្កបង្កើត
ដ៏ជ្រាបសព្វសារពើទេ ហើយនេះគឺដោយសារការប្រែចិត្ត
ដ៏ស្មោះស្ម័គ្ររបស់គេ នោះពួក គេច្បាស់ជាត្រូវជាប់នៅ
ក្នុងសេវកភាព ដោយចៀសពុំរួចរហូតដល់ឥឡូវនេះ ។
២០ ប៉ុន្តែមើលចុះ ទ្រង់បានដោះពួកគេឲ្យរួចផុត ពីព្រោះគេ
បានបន្ទាបខ្លួនចុះចំពោះទ្រង់; ហើយពីព្រោះពួកគេបានអំពាវនាវ
ដល់ព្រះអង្គ ជាខ្លាំង បានជាទ្រង់ដោះគេឲ្យរួចផុតពីសេវកភាព;
ហើយព្រះអម្ចាស់ទ្រង់ធ្វើដោយព្រះចេស្ដារបស់ទ្រង់ ក្នុង
គ្រប់ករណី ក្នុងចំណោមកូន ចៅមនុស្សយ៉ាងដូច្នេះហើយ
ដោយលាតព្រះពាហុនៃសេចក្ដីមេត្តាករុណាទៅរកអ្នកណា
ដែលដាក់ទីទុកចិត្តរបស់គេទៅលើទ្រង់ ។
២១ ហើយមើលចុះ ឥឡូវនេះ យើងប្រាប់អ្នកថា អ្នករាល់គ្នាមិន
អាចទម្លាក់ស្ដេចទុច្ចរិតមួយបានឡើយ លើកលែងតែដោយការ
ទាស់ទែង គ្នាដ៏ច្រើន និងការខ្ជាយឈាមដ៏ច្រើន ។
២២ ត្បិតមើលចុះ ស្ដេចនោះមានមិត្តភក្ដិក្នុងអំពើទុច្ចរិត
ហើយទ្រង់ទុកទាហានយាមជុំវិញទ្រង់; ហើយទ្រង់ហែកចោលនូវ
ច្បាប់ទាំង ឡាយរបស់អស់អ្នកដែលបានសោយរាជ្យដោយ
សុចរិតមុនទ្រង់មក; ហើយទ្រង់យកព្រះបញ្ញត្តិទាំងឡាយនៃព្រះ
ទៅជាន់ឈ្លីក្រោមជើង ។
២៣ ហើយទ្រង់បង្កើតច្បាប់ថ្មី ហើយផ្ញើទៅក្នុង
ចំណោមប្រជាជនទ្រង់ មែនហើយ គឺច្បាប់ទាំងឡាយ
ដែលស្របទៅនឹងសេចក្ដីទុច្ចរិត របស់ខ្លួន; ហើយអ្នកណាដែល
ពុំគោរពតាមច្បាប់ទាំងឡាយរបស់ទ្រង់ នោះទ្រង់បញ្ជាឲ្យ
គេបំផ្លាញអ្នកនោះចោល; ហើយអ្នកណាដែល បះបោរទាស់
នឹងទ្រង់ នោះទ្រង់នឹងបញ្ជាឲ្យពលទ័ពរបស់ទ្រង់
ទៅធ្វើសង្គ្រាមតតាំងនឹងគេ ហើយបើសិនជាទ្រង់អាចធ្វើទៅ
បាន នោះទ្រង់ នឹងបំផ្លាញអ្នកទាំងនោះចោល; ហើយស្ដេច
ដែលឥតសុចរិតម្នាក់បង្ខូចផ្លូវទាំង
ឡាយ នៃអស់ទាំងសេចក្ដីសុចរិតយ៉ាងនេះហើយ ។
២៤ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា អំពើ
គួរខ្ពើមឆ្អើមទាំងនេះមិនចាំបាច់កើតមានដល់អ្នកឡើយ ។
២៥ ហេតុដូច្នេះហើយ ចូរអ្នករើសពួកចៅក្រម តាមសម្លេង
របស់ប្រជាជននេះចុះ ដើម្បីអ្នករាល់គ្នាអាចបានជំនុំជំរះ
ស្របតាមច្បាប់ ទាំងឡាយដែលពួកអយ្យកោអ្នកបានឲ្យដល់
អ្នក ដែលជាច្បាប់ត្រឹមត្រូវ ហើយដែលបានប្រទានដល់ពួក
អយ្យកោអ្នក ដោយព្រះហស្តនៃ ព្រះអម្ចាស់ ។
២៦ ឥឡូវនេះ កម្រមានសម្លេងរបស់ប្រជាជនណាដែល
ប្រាថ្នាចង់បាននូវអ្វីៗ ដែលផ្ទុយនឹងអ្វីៗ ដែលត្រឹមត្រូវនោះឡើយ;
តែជាការ ធម្មតាដែលប្រជាជន ភាគតិចមួយ ប្រាថ្នាចង់បានអ្វី
ដែលពុំត្រឹមត្រូវវិញ; ហេតុដូច្នេះហើយ ការណ៍នេះអ្នករាល់គ្នា

១៥ *ក* អាលម៉ា ១:៣២–៣៣.
១៧ *ក* អាលម៉ា ៤៦:៩–១០.
*ខ* ម៉ូសាយ ២៣:៧–៩.
១៨ *ក* ម៉ូសាយ ១១:១–១៥.
*ខ* ១ សាំយូ. ៨:១០–១៨;
ម៉ូសាយ ១២:១–៨;
អេធើរ ៦:២២–២៣.
២០ *ក* ម៉ូសាយ ២១:១៣–១៥.
*ខ* និក្ខ. ២:២៣–២៥;
អាលម៉ា ៤៣:៤៩–៥០.
*គ* អេសេ. ៣៣:១១, ១៥–១៦;
ម៉ូសាយ ២៦:៣០.
*ឃ* ស.ប. ទុកចិត្ត.
២២ *ក* ១ ពង្សាវ. ១២:៨–១៤.
២៣ *ក* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.

ត្រូវអនុវត្ត ហើយទុកជា ច្បាប់របស់អ្នក — គឺធ្វើកិច្ចការ
របស់អ្នក តាម[ក]សម្លេងរបស់ប្រជាជន ។
២៧ ហើយបើពេលណាសម្លេងរបស់ប្រជាជន រើសយក
អំពើទុច្ចរិត ពេលនោះហើយដែលសេចក្ដីជំនុំជំរះទាំងឡាយនៃ
ព្រះនឹងធ្លាក់មក លើអ្នក; មែនហើយ ពេលនោះហើយដែល
ទ្រង់នឹងយាងមកពិនិត្យពិច័យអ្នក ដោយការបំផ្លិចបំផ្លាញដ៏ធំ
ដូចទ្រង់ធ្លាប់បានមកពិនិត្យពិច័យ លើដែនដីនេះ ។
២៨ ហើយឥឡូវនេះ បើសិនជាអ្នករាល់គ្នាមានពួកចៅក្រម
ហើយពួកគេមិនជំនុំជំរះអ្នកតាមច្បាប់ ដែលបានចែងទុកមកនោះទេ
នោះអ្នករាល់គ្នាអាចឲ្យចៅក្រមដែលខ្ពស់ជាងជំនុំជំរះគេវិញ ។
២៩ ហើយបើសិនជាចៅក្រមដែលខ្ពស់ជាង មិនជំនុំជំរះដោ
យការជំនុំជំរះដ៏សុចរិតទេនោះអ្នករាល់គ្នាត្រូវនាំឲ្យចៅក្រមថ្នា
ក់ទាបចំនួន តូចមួយមកប្រជុំគ្នា ហើយពួកគេនឹងជំនុំជំរះចៅ
ក្រមថ្នាក់ខ្ពស់ជាង ស្របតាមសម្លេងរបស់ប្រជាជន ។
៣០ ហើយយើងបញ្ជាឲ្យអ្នកធ្វើការណ៍ទាំងនេះ ដោយ
កោតខ្លាចដល់ព្រះអម្ចាស់; ហើយយើងបញ្ជាឲ្យអ្នកធ្វើការណ៍
ទាំងនេះ ហើយថា អ្នករាល់គ្នាមិនត្រូវមានស្ដេចទេ; បើ
សិនជាប្រជាជនទាំងនេះប្រព្រឹត្តអំពើបាប និងអំពើទុច្ចរិតទាំង
ឡាយ នោះពួកគេនឹងទទួលខុសត្រូវទៅ លើក្បាលគេផ្ទាល់ ។
៣១ ត្បិតមើលចុះ យើងប្រាប់អ្នកថា អំពើបាបទាំងឡាយ
របស់មនុស្សជាច្រើន បានកើតឡើងដោយព្រោះអំពើទុច្ចរិតទាំង
ឡាយនៃស្ដេច របស់គេ; ហេតុដូច្នេះហើយ អំពើទុច្ចរិតទាំង
ឡាយរបស់ពួកគេ នឹងត្រូវធ្លាក់ទៅលើក្បាលរបស់ស្ដេចគេវិញ ។
៣២ ហើយឥឡូវនេះ យើងប្រាថ្នាចង់ឲ្យឈប់មាន
[ក]ការវិសមភាពនេះតទៅទៀត នៅលើដែនដីនេះ ជាពិសេស
នៅក្នុងចំណោមប្រជាជន របស់យើងនេះ; តែយើងប្រាថ្នា
ចង់ឲ្យដែនដីនេះទៅជាដែនដីនៃ[ខ]ឥស្សរភាព ហើយមនុស្ស
[គ]គ្រប់រូបអាចអរសប្បាយក្នុងសិទ្ធិ និងឯកសិទ្ធ របស់ខ្លួន ដែល
មានដូចៗគ្នា ដរាបណាព្រះអម្ចាស់ទ្រង់ទតឃើញថា ល្មមឲ្យ
យើងរស់នៅ ហើយគ្រងដែនដីទុកជាកេរ្ដិ៍មរតក មែនហើយ
គឺដរាបណាកូនចៅរបស់យើងនៅលើផ្ទៃដែនដីនេះ ។
៣៣ ហើយមានការណ៍ជាច្រើនទៀត ដែលស្ដេចម៉ូសាយ
បានសរសេរទៅឲ្យពួកគេ ដោយលាតត្រដាងដល់គេ នូវអស់
ទាំងការសាក ល្បង និងការកង្វល់របស់ស្ដេចដ៏សុចរិតម្នាក់
មែនហើយ គឺអស់ទាំងការឈឺចាប់នៃព្រលឹង ដើម្បីប្រជាជនរបស់
ទ្រង់ ព្រមទាំងការរអ៊ូរទាំ ទាំងអស់របស់ប្រជាជនទៅកាន់ស្ដេច
របស់គេ; ហើយទ្រង់បានពន្យល់ប្រាប់ពីការណ៍ទាំងអស់ដល់គេ ។
៣៤ ហើយទ្រង់បានប្រាប់គេថា ការណ៍ទាំងនេះមិនត្រូវ
មានឡើយ; តែថា បន្ទុកនេះត្រូវធ្លាក់ទៅលើប្រជាជនទាំង
អស់វិញ គឺមនុស្ស គ្រប់រូបអាចផ្ទុកចំណែករបស់ខ្លួន ។
៣៥ ហើយទ្រង់ក៏បានលាតត្រដាងដល់ពួកគេ នូវអស់ទាំង
ការខាតប្រយោជន៍ ដែលពួកគេទទួលយក ដោយមាន
ស្ដេចឥតសុចរិត គ្រប់គ្រងលើពួកគេ ។
៣៦ មែនហើយ អំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងអស់
របស់ស្ដេច និងសង្គ្រាមទាំងអស់ និងការទាស់ទែងគ្នាទាំងអស់
និងការខ្ចាយ ឈាម និងការលួច និងការប្លន់ និងការប្រព្រឹត្ត
អំពើសហាយស្មន់ទាំងឡាយ និងអំពើទុច្ចរិតគ្រប់បែបយ៉ាង
ដែលពុំអាចរាប់ឲ្យអស់បាននោះ — ដោយប្រាប់គេថា ការណ៍
ទាំងនេះមិនត្រូវឲ្យកើតឡើងឡើយ គឺការណ៍ទាំងនេះសុទ្ធតែ
ជាការផ្ទុយទៅនឹងព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។
៣៧ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
បន្ទាប់ពីស្ដេចម៉ូសាយបានផ្ញើសេចក្ដីទាំងនេះ ទៅក្នុង
ចំណោមប្រជាជនហើយ នោះពួកគេត្រូវបានបរិវត្តអំពីសេចក្ដី
ពិត នៃព្រះបន្ទូលរបស់ទ្រង់ ។
៣៨ ហេតុដូច្នេះហើយ ពួកគេបានលះបង់បំណងរបស់គេដែល
ចង់បានស្ដេច ហើយបានក្លាយជាមានចិត្តរសាប់រសល់ជាខ្លាំង
ដែល មនុស្សគ្រប់រូបមានឱកាសស្មើគ្នាទូទៅអស់ទាំងដែនដី;
មែនហើយ ហើយមនុស្សគ្រប់រូបបានចេញវាចាថា យល់ព្រម
នឹងទទួលខុសត្រូវ ចំពោះអំពើបាបរបស់ខ្លួនផ្ទាល់ ។
៣៩ ហេតុដូច្នេះហើយ ហេតុការណ៍បានកើតឡើងថា ពួកគេ
ប្រជុំគ្នាមកជាក្រុមៗ ទូទៅអស់ទាំងដែនដី ដើម្បីបោះសម្លេងគេថា
អ្នកណា មួយដែល[ក]ត្រូវធ្វើជាចៅក្រមរបស់គេ ដើម្បីជំនុំជំរះ
ពួកគេ ស្របតាមច្បាប់ដែលបានឲ្យដល់គេនោះ; ហើយពួកគេ
បានអររីករាយជាខ្លាំង ដោយសារ[ខ]ឥស្សរភាព ដែលបាន
ប្រទានដល់គេ ។
៤០ ហើយពួកគេមានចិត្តស្រឡាញ់ម៉ូសាយជាខ្លាំង; មែន
ហើយ ពួកគេបានគោរពទ្រង់ ជាងអ្នកណាទាំងអស់; ព្រោះ
ពួកគេពុំបានចាត់ទ្រង់ ទុកជាអ្នកប្រើអំណាចផ្ដាច់ការ ដែល

២៧ *ក* អាលម៉ា ១០:១៩.
៣២ *ក* អាលម៉ា ៣០:១១.
*ខ* ២ នីហ្វៃ ១:៧; ១០:១១.
ស.ប. ឥស្សរភាព.
*គ* អាលម៉ា ២៧:៩.
៣៩ *ក* អាលម៉ា ១:១៤.
*ខ* ស.ប. ឥស្សរភាព.

ស្វែងរកកំរៃឡើយ មែនហើយ ព្រោះការស្វែងរកកំរៃធ្វើឲ្យ
ពុករលួយដល់ព្រលឹង; ព្រោះទ្រង់ពុំបាន ដកយកទ្រព្យពីពួក
គេឡើយ ហើយទ្រង់ក៏មិនចូលចិត្តនឹងការខ្ចាយឈាមដែរ;
តែទ្រង់បានកសាង[ក]សេចក្ដីសុខសាន្តនៅលើដែនដីវិញ ហើយ
ទ្រង់បានអនុញ្ញាតដល់ប្រជាជនទ្រង់ថា ពួកគេត្រូវដោះខ្លួនឲ្យ
រួចផុតពីសេវកភាពគ្រប់យ៉ាង; ហេតុដូច្នេះហើយ ទើបពួកគេ
បានគោរពទ្រង់ មែនហើយ គោរពដ៏ខ្លាំងហួសប្រមាណ ។
៤១ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានតែងតាំង
[ក]ពួកចៅក្រមឲ្យគ្រប់គ្រងលើគេ ឬជំនុំជំរះពួកគេតាមច្បាប់;
ហើយការណ៍នេះ គេបានធ្វើទូទៅអស់ទាំងដែនដី ។
៤២ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាត្រូវបាន
តែងតាំងជាមេចៅក្រមទីមួយ ហើយលោកក៏ជាសង្ឃជាន់ខ្ពស់ផង
ដោយ ឪពុកលោក បានប្រគល់តំណែងនេះដល់លោក ហើយ
បានឲ្យលោកទទួលបន្ទុក ខាងកិច្ចការទាំងអស់នៃសាសនាចក្រ ។
៤៣ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ា
បាន[ក]ដើរតាមផ្លូវទាំងឡាយនៃព្រះអម្ចាស់ ហើយលោកបានកាន់
តាមព្រះ បញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយលោកបានជំនុំជំរះ
ដោយសេចក្ដីជំនុំជំរះដ៏សុចរិត ហើយសេចក្ដីសុខសាន្ត
កើតមានតរៀងទៅទូទៅ ទាំងដែនដី ។
៤៤ ម្ល៉ោះហើយ រជ្ជកាលនៃពួកចៅក្រមបានចាប់ផ្ដើមឡើង
ទូទៅអស់ទាំងដែនដីសារ៉ាហិមឡា នៅក្នុងចំណោមប្រជាជន
ទាំងអស់ ដែល ហៅថា ពួកសាសន៍នីហ្វៃ; ហើយអាលម៉ា
គឺជាមេចៅក្រមទីមួយ ។
៤៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ឪពុក
លោកស្លាប់ទៅ កាលមានអាយុប៉ែតសិបពីរឆ្នាំ ដោយបាន
រស់នៅដើម្បីបំពេញ ព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។
៤៦ ហើយហេតុការណ៍បានកើតឡើងថា
ម៉ូសាយក៏បានសុគតទៅដែរ នៅក្នុង
ឆ្នាំទីសាមសិបបីនៃរាជ្យទ្រង់ កាលមាន[ក]ជន្មាយុ ហុកសិបបីឆ្នាំ;
និយាយសរុបមក គឺប្រាំរយប្រាំបួនឆ្នាំ ចាប់តាំងពីពេលដែល
លីហៃបានចាកចេញពីក្រុងយេរូសាឡិមមក ។
៤៧ ម្ល៉ោះហើយ ក៏ចប់នូវការសោយរាជ្យនៃស្ដេចទាំង
ឡាយលើប្រជាជននីហ្វៃទៅ; ម្ល៉ោះហើយ ក៏ចប់នូវជីវិតអាលម៉ា
ដែលជាអ្នកបង្កើត សាសនាចក្ររបស់ពួកគេ ៕ :ៜ—

# គម្ពីរអាលម៉ា

កូនប្រុសរបស់អាលម៉ា

ដំណើររឿងមួយអំពីអាលម៉ា ជាកូនប្រុសរបស់អាលម៉ា ជាមេចៅក្រមទីមួយ ត្រួតលើប្រជាជននីហ្វៃ ហើយជាសង្ឃជាន់ខ្ពស់លើសាសនាចក្រផង ។ ដំណើររឿងមួយអំពីរជ្ជកាលនៃពួកចៅក្រម និងសង្គ្រាមទាំងឡាយ និងការទាស់ទែងគ្នាទាំងឡាយ នៅក្នុង ចំណោមប្រជាជន ។ ហើយព្រមទាំងដំណើររឿងអំពីសង្គ្រាមមួយ រវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ស្របតាមបញ្ជីរបស់អាលម៉ា ជាមេចៅក្រមទីមួយ ។

## ជំពូកទី ១

*នីហូរបង្រៀនលទ្ធិក្លែងក្លាយទាំងឡាយ តាំងសាសនាចក្រមួយ ដែលនាំឲ្យមានឧបាយកលផ្នែកសង្ឃជាលើកដំបូង ហើយប្រហារ គេឌាន — នីហូរត្រូវគេប្រហារជីវិតចំពោះទោសរបស់គាត់ — ឧបាយកលផ្នែកសង្ឃ និងការបៀតបៀនរាលដាលក្នុង ចំណោម ប្រជាជន — ពួកសង្ឃចិញ្ចឹមជីវិតខ្លួនឯង ប្រជាជនថែទាំពួកអ្នកក្រីក្រ ហើយសាសនាចក្រចំរើនឡើង ។ ប្រមាណជាឆ្នាំ ៩១–៨៨ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីមួយ
ក្នុងរជ្ជកាលនៃពួកចៅក្រម លើប្រជាជននីហ្វៃ
ចាប់ពីពេលនេះទៅ ដែលស្ដេច [ក]ម៉ូសាយបាន
ទៅតាមផ្លូវនៃអស់ទាំងផែនដី ដោយបានច្បាំងចម្បាំងយ៉ាងល្អ

៤០ ក ស.ប. អ្នកផ្សះផ្សា.
៤១ ក ម៉ូសាយ ២៩:១១.
៤៣ ក ស.ប. ដើរ, ដើរជាមួយព្រះ.
៤៦ ក ម៉ូសាយ ៦:៤.
[អាលម៉ា]
១ ១ក ម៉ូសាយ ២៩:៤៦.

បានដើរត្រង់ខ្លួននៅចំពោះព្រះ ពុំបានទុកឲ្យអ្នកណាមួយ
សោយរាជ្យជំនួសទ្រង់ឡើយ; ទោះជាយ៉ាងណាក៏ដោយ គង់
តែទ្រង់បានបង្កើតច្បាប់ទាំងឡាយ ហើយប្រជាជនបានទទួល
ស្គាល់ច្បាប់ ទាំងនោះ; ហេតុដូច្នេះហើយ ពួកគេមាន
កាតព្វកិច្ច ដើម្បីប្រតិបត្តិតាមច្បាប់ទាំងឡាយ ដែលទ្រង់បាន
បង្កើតឡើង ។
២ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីមួយ
ក្នុងរជ្ជកាលរបស់អាលម៉ា នៅវេទិកាជំនុំជំរះ នោះមាន
បុរសម្នាក់ដែល ត្រូវបាននាំមកខាងមុខលោក ដើម្បីទទួល
ការជំនុំជំរះ បុរសនោះមាឌធំ ហើយល្បីថា មានកម្លាំង
ខ្លាំងពូកែ ។
៣ ហើយបុរសនោះបានទៅក្នុងចំណោមប្រជាជន ផ្សាយ
ប្រាប់ពួកគេនូវអ្វីៗ ដែលគាត់ហៅថាជាព្រះបន្ទូលនៃព្រះ ដោយធ្វើ
ការ ទាស់នឹងសាសនាចក្រ; ដោយប្រកាសប្រាប់ដល់ប្រជាជនថា
ពួកសង្ឃ និងពួកគ្រូបង្រៀនគ្រប់រូបគួរតែមានប្រជាប្រិយភាព;
ហើយពួកគេ មិនគួរធ្វើការ ដោយដៃរបស់គេទេ តែពួកគេត្រូវ
ទទួលការគាំទ្រពីប្រជាជនវិញ ។
៤ ហើយគាត់ក៏ធ្វើទីបន្ទាល់ទៅប្រជាជនថា មនុស្ស
លោកទាំងអស់ត្រូវតែបានសង្គ្រោះ នៅថ្ងៃចុងក្រោយបង្អស់
ហើយថា ពួកគេមិន ចាំបាច់ខ្លាច ឬញាប់ញ័រទេ តែថា ពួកគេ
អាចងើបមុខឡើង ហើយអររីករាយវិញ; ត្បិតព្រះអម្ចាស់ទ្រង់
បានបង្កើតមនុស្សទាំងអស់ ហើយ បានប្រោសលោះមនុស្ស
ទាំងអស់ផង; ហើយនៅទីបញ្ចប់ មនុស្សទាំងអស់នឹងមាន
ជីវិតដ៏នៅអស់កល្បជានិច្ច ។
៥ ហើយហេតុការណ៍បានកើតឡើងថា គាត់បានបង្រៀន
ការណ៍ទាំងនេះជាច្រើន រហូតដល់មានមនុស្សជាច្រើនបាន
ជឿតាមពាក្យ សំដីរបស់គាត់ គឺមានមនុស្សជាច្រើន ដែលពួក
គេបានចាប់ផ្ដើមគាំទ្រគាត់ ហើយឲ្យប្រាក់ដល់គាត់ ។
៦ ហើយគាត់បានចាប់ផ្ដើមលើកខ្លួនឡើង ក្នុងសេចក្ដីឆ្មើងឆ្មៃ
នៃចិត្តរបស់គាត់ ហើយស្លៀកពាក់នូវប្រដាប់ស្លៀកពាក់ដ៏មាន
តម្លៃថ្លៃ មែនហើយ ហើយព្រមទាំងបានចាប់ផ្ដើមតាំងសាសនា
ចក្រមួយឡើង តាមរបៀបដែលគាត់បង្រៀន ។
៧ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែល
គាត់កំពុងតែទៅផ្សាយសាសនា ដល់អស់អ្នកណាដែលជឿតាម
ពាក្យគាត់ ស្រាប់តែគាត់បានជួបបុរសម្នាក់ ដែលជាមនុស្ស
ផងសាសនាចក្រនៃព្រះ មែនហើយ គឺជាគ្រូបង្រៀនមួយរបស់
ពួកគេ; ហើយគាត់បាន ចាប់ផ្ដើមប្រកែកជាមួយនឹងបុរសនោះ
យ៉ាងខ្លាំង ដើម្បីគាត់អាចដឹកនាំមនុស្សនៃសាសនាចក្រឲ្យវ
ង្វេងផ្លូវ; តែបុរសនោះបានតទល់នឹង គាត់ ដោយព្រមាន
ដាស់តឿនគាត់ដោយព្រះបន្ទូលទាំងឡាយនៃព្រះ ។
៨ ឥឡូវនេះ ឈ្មោះបុរសនោះគឺ គេខាន; គឺលោកនេះហើយ
ដែលជាគ្រឿងឧបករណ៍មួយ នៅក្នុងព្រះហស្តនៃព្រះ ក្នុងការ
ដោះ លែងប្រជាជនលិមហៃឲ្យរួចផុតពីសេវកភាព ។
៩ ឥឡូវនេះ ពីព្រោះគេខានបានតបតនឹងគាត់ ដោយព្រះ
បន្ទូលទាំងឡាយនៃព្រះ នោះគាត់បានខឹងនឹងគេខាន ហើយបាន
ដកដាវ គាត់ ហើយចាប់ផ្ដើមកាប់ចាក់លោក ។ ឥឡូវនេះ
ដោយព្រោះគេខានមានអាយុច្រើន ហេតុដូច្នេះហើយ លោកមិន
អាចទប់ទល់ នឹងដាវរបស់គាត់បានឡើយ ហេតុដូច្នេះហើយ
លោកក៏ត្រូវបានស្លាប់ដោយផ្លែដាវទៅ ។
១០ ឯបុរសដែលសម្លាប់លោក ត្រូវមនុស្សនៃសាសនាចក្រ
ចាប់យកទៅខាងមុខអាលម៉ា ដើម្បីជំនុំជំរះ ស្របតាមទោស
ដែល គាត់បានប្រព្រឹត្ត ។
១១ ហើយហេតុការណ៍បានកើតឡើងថា គាត់បានឈរនៅចំពោះ
អាលម៉ា ហើយបានដោះសាខ្លួន ដោយចិត្តក្លាហាន ។
១២ តែអាលម៉ាបាននិយាយទៅគាត់ថា៖ មើលចុះ នេះ
គឺជាលើកទីមួយហើយដែលឧបាយកលផ្នែកសង្ឃ បាន
ចាប់ផ្ដើមណែនាំមក ក្នុងចំណោមប្រជាជននេះ។ ហើយមើលចុះ
អ្នកមិនត្រឹមតែមានទោស ដោយប្រើឧបាយកលផ្នែកសង្ឃ
តែប៉ុណ្ណោះទេ តែអ្នកបាន ប្រើដាវ ដើម្បីបង្ខំគេឲ្យធ្វើ
តាមទៀត; ហើយបើយកឧបាយកលផ្នែកសង្ឃ មកប្រើនៅក្នុង
ចំណោមពួកប្រជាជននេះ ការណ៍នោះនឹង បញ្ជាក់នូវការ
បំផ្លិចបំផ្លាញរបស់គេទាំងស្រុងហើយ ។
១៣ ហើយអ្នកបានកំចាយឈាមបុរសសុចរិតម្នាក់ មែន
ហើយ ជាបុរសដែលធ្លាប់បានធ្វើការល្អជាច្រើននៅក្នុង

១ *ខ* យ៉ារ៉ុម ១:៥; អាលម៉ា ៤:១៦; ហេលេ. ៤:២២.
២ *ក* អាលម៉ា ១:១៥.
៣ *ក* អេសេ. ១៣:៣.
*ខ* ស.ប. អ្នកទទឹងនឹងព្រះគ្រីស្ទ.
*គ* លូកា ៦:២៦; ១ នីហ្វៃ ២២:២៣.
*ឃ* ម៉ូសាយ ១៨:២៤, ២៦; ២៧:៥.
៦ *ក* ១ នីហ្វៃ ១៤:១០.
៧ *ក* ស.ប. ព្រះបន្ទូលនៃព្រះ.
៨ *ក* ម៉ូសាយ ២០:១៧; ២២:៣.
៩ *ក* អាលម៉ា ៦:៧.
១០ *ក* ម៉ូសាយ ២៩:៤២.
១២ *ក* ២ នីហ្វៃ ២៦:២៩.
ស.ប. ឧបាយកលផ្នែកសង្ឃ.

ចំណោមប្រជាជន នេះ ហើយបើយើងលើកលែងទោសឲ្យអ្នកឃាតរបស់បុរសនោះនឹងមកទាមទារឲ្យយើងសងសឹក ។

១៤ ហេតុដូច្នេះហើយ ត្រូវកាត់ទោសអ្នកដល់ជីវិត ស្របតាមច្បាប់ដែលបានប្រទានមកយើង ដោយម៉ូសាយ ជាស្ដេចចុងក្រោយ បង្អស់របស់យើង; ហើយឯច្បាប់នោះ ប្រជាជននេះបានទទួលស្គាល់ ហេតុដូច្នេះហើយ ប្រជាជននេះត្រូវធ្វើតាមច្បាប់ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា គេនាំបុរសនោះទៅ ហើយគាត់មានឈ្មោះថា នីហ៊ូរ; ហើយគេបានយកគាត់ទៅលើកំពូលភ្នំម៉ាន់តៃ ហើយនៅទីនោះហើយដែលគាត់ត្រូវបានបណ្ដាល ឬក៏ត្រូវបានទទួលស្គាល់ចំពោះមេឃ និងដីថា អ្វីដែលគាត់បាន បង្រៀនប្រជាជននោះ គឺផ្ទុយនឹងព្រះបន្ទូលនៃព្រះ; ហើយនៅទីនោះហើយគាត់បានទទួលការស្លាប់ដ៏ថោកទាប ។

១៦ ទោះជាយ៉ាងណាក៏ដោយ គង់តែការណ៍នេះមិនបានបញ្ឈប់ការរាលដាល នៃឧបាយកលផ្នែកសង្ឃទូទៅទាំងដែនដីដែរ; ព្រោះមានមនុស្សជាច្រើន ដែលស្រឡាញ់ការទាំងឡាយដែលឥតប្រយោជន៍នៃលោកិយ ហើយពួកគេបានចេញទៅផ្សាយអំពី លទ្ធិក្លែងក្លាយទាំងឡាយ ហើយគេធ្វើការនេះ ដើម្បីចង់បានទ្រព្យសម្បត្តិ និងយសសក្ដិ ។

១៧ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេពុំហ៊ានភូតកុហកដែរ ដោយព្រោះខ្លាចច្បាប់ ព្រោះពួកអ្នកដែលកុហកនឹងត្រូវទទួល ទោស; ហេតុដូច្នេះហើយ ពួកគេធ្វើហាក់ដូចជាគេផ្សាយសាសនា ទៅតាមជំនឿរបស់គេ; ហើយឥឡូវនេះ ច្បាប់មិនអាចធ្វើអ្វីដល់ អ្នកនោះ ចំពោះជំនឿរបស់គេបានឡើយ ។

១៨ ហើយពួកគេពុំហ៊ានលួច ដោយព្រោះខ្លាចច្បាប់ ព្រោះអស់អ្នកណាដែលលួចនឹងត្រូវទទួលទោស; ហើយពួកគេក៏មិនហ៊ានប្លន់ ឬធ្វើឃាតដែរ ព្រោះអ្នកណាដែលធ្វើឃាតនឹងត្រូវទទួលទោសដល់ជីវិត ។

១៩ តែហេតុការណ៍បានកើតឡើងថា អ្នកណាដែលមិនចូលរួមក្នុងសាសនាចក្រនៃព្រះ បានចាប់ផ្ដើមបៀតបៀនអស់អ្នកដែលនៅ ក្នុងសាសនាចក្រនៃព្រះ ហើយដែលបានយកព្រះនាមនៃព្រះគ្រីស្ទដាក់លើខ្លួន ។

២០ មែនហើយ ពួកគេបានបៀតបៀនអ្នកទាំងនោះ ហើយធ្វើទុក្ខពួកគេ ដោយប្រើពាក្យគ្រប់យ៉ាង ហើយការណ៍នេះមកពីភាព រាបសាររបស់គេ; ពីព្រោះពួកគេមិនអួតខ្លួននៅចំពោះភ្នែកគេផ្ទាល់ ហើយពីព្រោះពួកគេបានចែករំលែកព្រះបន្ទូលនៃព្រះទៅវិញទៅមក ដោយមិនយកប្រាក់ ឬថ្លៃអ្វីឡើយ ។

២១ ឥឡូវនេះ មានច្បាប់មួយយ៉ាងតឹងរឹង នៅក្នុងចំណោមប្រជាជននៃសាសនាចក្រថា មិនត្រូវមានអ្នកណាម្នាក់ដែលនៅក្នុង សាសនាចក្រ បះបោរ ហើយបៀតបៀនពួកអ្នកដែលមិននៅក្នុងសាសនាចក្រឡើយ ហើយក៏មិនត្រូវមានការបៀតបៀន នៅក្នុង ចំណោមពួកគេដែរ ។

២២ ទោះជាយ៉ាងណាក៏ដោយ គង់តែមានមនុស្សជាច្រើននៅក្នុងចំណោមពួកគេដែរ ដែលបានចាប់ផ្ដើមអួតខ្លួន ហើយបានចាប់ ផ្ដើមតតាំងគ្នាយ៉ាងគគ្រឹកគគ្រេង ជាមួយនឹងពួកមារសត្រូវរបស់គេ រហូតដល់មានការវាយតប់គ្នា; មែនហើយ ពួកគេបានវាយ ប្រដាល់គ្នាដោយដៃ ។

២៣ ឥឡូវនេះ នេះគឺជាឆ្នាំទីពីរក្នុងរជ្ជកាលរបស់អាលម៉ា ហើយនេះគឺជាដើមហេតុនៃការទុក្ខលំបាកដ៏ខ្លាំង ដល់សាសនាចក្រ; មែនហើយ នេះគឺជាដើមហេតុនៃការសាកល្បងដ៏ខ្លាំងក្លាដល់សាសនាចក្រ ។

២៤ ព្រោះមនុស្សជាច្រើនបានធ្វើចិត្តរឹងរូស ហើយឈ្មោះរបស់គេត្រូវបានលុបចេញ ដើម្បីកុំឲ្យឈ្មោះទាំងនោះត្រូវចងចាំតទៅ ទៀត នៅក្នុងចំណោមរាស្ត្រនៃព្រះឡើយ ។ ហើយមនុស្សជាច្រើនបានដកខ្លួនចេញពីពួកគេផង ។

២៥ ឥឡូវនេះ នេះគឺជាការសាកល្បងដ៏ធំមួយ ដល់អស់អ្នកណាដែលឈរយ៉ាងខ្ជាប់ខ្ជួន នៅក្នុងសេចក្ដីជំនឿ; ទោះ

១៣ ក ស.ប. ការសងសឹក.
១៤ ក ស.ប. ការដាក់ទោសដល់ជីវិត.
១៥ ក អាលម៉ា ១:២.
ខ ចោទិ. ១៣:១–៩.
១៦ ក ស.ប. ទ្រព្យសម្បត្តិ; ឥតប្រយោជន៍, ការឥតប្រយោជន៍.
១៧ ក ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់; សេចក្ដីកុហក.
ខ អាលម៉ា ៣០:៧–១២; ម. នៃ ស. ១:១១.
១៨ ក ស.ប. លួច, ការលួច.
ខ ស.ប. ឃាតកម្ម.
គ ស.ប. ការដាក់ទោសដល់ជីវិត.
២០ ក អេសាយ ៥៥:១–២.
២១ ក ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
២៤ ក និក្ខ. ៣២:៣៣; ម៉ូសាយ ២៦:៣៦; អាលម៉ា ៦:៣. ស.ប. ការកាត់ចេញពីសាសនា.
ខ អាលម៉ា ៤៦:៧. ស.ប. សេចក្ដីក្បត់សាសនា.

ជាយ៉ាងណា ក៏ដោយ គង់តែពួកគេនៅតែមានចិត្តខ្ជាប់ខ្ជួន
ហើយមុតមាំ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះដែរ
ហើយពួកគេទ្រាំទ្រ ដោយចិត្តអត់ធន់នូវការបៀតបៀន ដែល
មានគំនរមកលើពួកគេ ។
២៦ ហើយកាលដែលពួកសង្ឃចោលកិច្ចការរបស់ខ្លួន
ដើម្បីទៅរំលែកព្រះបន្ទូលនៃព្រះ ដល់ប្រជាជន
នោះប្រជាជនក៏ចោល កិច្ចការរបស់ខ្លួន ដើម្បីទៅស្ដាប់ព្រះ
បន្ទូលនៃព្រះដែរ ។ ហើយកាលដែលពួកសង្ឃបានរំលែកដល់គេនូវ
ព្រះបន្ទូលនៃព្រះរួចហើយ នោះពួកគេទាំងអស់គ្នាក៏ត្រឡប់ទៅធ្វើ
ការវិញ ដោយមានចិត្តព្យាយាម; ហើយពួកសង្ឃមិនរាប់ថា
ខ្លួនខ្ពស់ជាងពួកអ្នកស្ដាប់ឡើយ ត្បិតអ្នកផ្សាយសាសនាមិន
ប្រសើរជាងអ្នកស្ដាប់ទេ ឯគ្រូបង្រៀនក៏មិនប្រសើរជាងអ្នក
រៀនដែរ; ម្ល៉ោះហើយ ពួកគេស្មើគ្នាទាំងអស់ ហើយពួកគេបាន
ធ្វើការទាំងអស់គ្នា បុគ្គលគ្រប់រូបតាមកម្លាំងរៀងៗខ្លួន ។
២៧ ហើយពួកគេបានចែករំលែកទ្រព្យរបស់ខ្លួន មនុស្ស
គ្រប់រូបស្របតាមអ្វីៗដែលគេមាន ឲ្យអ្នកក្រីក្រ អ្នកខ្វះខាត
អ្នកឈឺ និងអ្នក ដែលមានទុក្ខ; ហើយពួកគេពុំស្លៀកពាក់នូវ
ប្រដាប់ស្លៀកពាក់ដ៏មានតម្លៃឡើយ តែពួកគេស្អាតស្អំ ហើយ
គួរឲ្យស្រឡាញ់វិញ ។
២៨ ហើយពួកគេបានចាត់ចែងកិច្ចការរបស់សាសនាចក្រ
យ៉ាងដូច្នេះហើយ; ម្ល៉ោះហើយ ពួកគេបានចាប់ផ្ដើមមានសេច
ក្ដីសុខសាន្ត តទៅទៀត ទោះជាគេមាន
គ្រប់ការបៀតបៀនក៏ដោយ ។
២៩ ហើយឥឡូវនេះ មកពីការខ្ជាប់ខ្ជួនក្នុងសាសនាចក្រ
នោះពួកគេបានចាប់ផ្ដើមក្លាយទៅជាអ្នកមានដ៏លើសលប់ ដោយ
មានយ៉ាងបរិបូរនូវវត្ថុគ្រប់មុខ ដែលគេត្រូវការ —
គឺបរិបូរទៅដោយហ្វូងចៀម និងហ្វូងសត្វ និងសត្វធាត់គ្រប់
យ៉ាង ហើយក៏បរិបូរ ទៅដោយធញ្ញជាតិ និងមាស និងប្រាក់
និងវត្ថុមានតម្លៃផ្សេងៗ ហើយបរិបូរទៅដោយសូត្រព្រៃ និង
សំពត់ត្បាញដោយអំបោះខ្លូតទេស វេញយ៉ាងខ្មាញ់ និង
ប្រដាប់ប្រដាគ្រប់មុខ សំរាប់ប្រើនៅផ្ទះ ។
៣០ ម្ល៉ោះហើយ នៅក្នុងកាលៈទេសៈដ៏ចំរុងចំរើនរបស់គេ
ពួកគេពុំបានដេញជនណាចេញដែលអាក្រាត ឬជនណាដែល
អត់ឃ្លាន ឬជនណាដែលស្រេក ឬជនណាដែលឈឺ ឬជនណា
ដែលខ្វះការចិញ្ចឹមបីបាច់ឡើយ; ហើយពួកគេមិនបានភ្ជាប់ចិត្ត
គេទៅលើទ្រព្យ សម្បត្តិដែរ; ហេតុដូច្នេះហើយ ទើបពួកគេ
មានចិត្តទូលំទូលាយ ទៅលើមនុស្សគ្រប់រូប ទាំងចាស់
ទាំងក្មេង ទាំងបាវគេទាំងអ្នកសេរី ទាំងប្រុស ទាំងស្រី ទោះ
ជានៅក្រៅសាសនាចក្រ ឬនៅក្នុងសាសនាចក្រនោះក្ដី
ដោយមិនរើសមុខអ្នកណាសោះ ឲ្យតែមាន ការខ្វះខាត ។
៣១ ម្ល៉ោះហើយ ពួកគេបានចំរើនឡើង ហើយបានក្លាយ
ទៅជាអ្នកមានទ្រព្យសម្បត្តិដ៏ច្រើនលើសលប់ ជាងអ្នកដែល
មិននៅក្នុង សាសនាចក្ររបស់គេទៅទៀត ។
៣២ ព្រោះពួកអ្នកដែលពុំនៅក្នុងសាសនាចក្ររបស់គេ បាន
បណ្ដោយខ្លួនទៅតាមអំពើអាបធ្មប់ និងការថ្វាយបង្គំរូបព្រះ ឬ
ការខ្ជិល ច្រអូស និងការនិយាយផ្ដេសផ្ដាស និងការឈ្នានីស
និងការឈ្លោះ; ការស្លៀកពាក់នូវប្រដាប់ស្លៀកពាក់ដ៏មាន
តម្លៃ; ការលើកខ្លួន ឡើងក្នុងសេចក្ដីឆ្មើងឆ្មៃនៃភ្នែកគេផ្ទាល់;
ការបៀតបៀន ការកុហក ការលួច ការប្លន់ ការប្រព្រឹត្តអំពើ
សហាយស្មន់ទាំងឡាយ និងការ ប្រព្រឹត្តអំពើឃាតកម្ម និង
គ្រប់អស់ទាំងអំពើទុច្ចរិតទាំងប៉ុន្មានផង; ទោះជាយ៉ាងណាក៏ដោយ
គង់តែបានដាក់ច្បាប់មកលើអស់អ្នកណា ដែលរំលងច្បាប់
តាមលទ្ធភាពដែលអាចធ្វើបានដែរ ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា ដោយអនុវត្ត
ច្បាប់ទៅលើពួកគេយ៉ាងនេះ មនុស្សគ្រប់រូបត្រូវរងទោស
ស្របតាមអ្វីៗ ដែលខ្លួនបានធ្វើ គេបានក្លាយទៅជាស្លូតបូត
ជាងមុន ហើយពុំហ៊ានប្រព្រឹត្តអំពើទុច្ចរិត ដោយចេញមុខ
ទៀតឡើយ; ហេតុដូច្នេះហើយ មានសេចក្ដីសុខសាន្តដ៏ច្រើន

២៥ ក ស.ប. សេចក្ដីអត់ធន់.
២៦ ក ម៉ូសាយ ១៨:២៤, ២៦; ២៧:៣–៥.
ខ ម៉ូសាយ ៤:២៧; គ. និង ស. ១០:៤.
២៧ ក ស.ប. ទាន, ការដាក់ទាន.
ខ លូកា ១៨:២២; ម៉ូសាយ ៤:២៦; គ. និង ស. ៤២:២៩–៣១.
២៩ ក ស.ប. ទ្រព្យសម្បត្តិ.
ខ អាលម៉ា ៤:៦.
៣០ ក យ៉ាកុប ២:១៧–១៩.
ខ ស.ប. មនុស្សក្រីក្រ.
គ អាលម៉ា ១៦:១៤; គ. និង ស. ១:៣៥.
៣២ ក ស.ប. ការថ្វាយបង្គំរូបព្រះ.
ខ ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
គ ស.ប. ការនិយាយអាក្រក់.
ឃ ស.ប. ច្រណែន.
ង យ៉ាកុប ២:១៣; អាលម៉ា ៣១:២៥; មរមន ៨:២៨. ស.ប. សេចក្ដីឆ្មើងឆ្មៃ.

នៅក្នុងចំណោមប្រជាជននីហ្វៃ រហូតដល់ឆ្នាំទីប្រាំក្នុងរជ្ជកាល
នៃពួកចៅក្រម ៕

## ជំពូកទី ២

*អាំលិសៃស្វែងរកធ្វើជាស្តេច ហើយត្រូវបានបដិសេធសម្លេង
នៃប្រជាជន — ពួកអ្នកដើរតាមលោក គេលើកលោកឲ្យធ្វើ
ជាស្តេច — ពួកសាសន៍អាំលិសៃធ្វើសង្គ្រាមជាមួយនឹងពួក
នីហ្វៃ តែត្រូវបរាជ័យ — ពួកសាសន៍លេមិន និងពួកសាសន៍
អាំលិសៃបង្រួមទ័ពគ្នា តែត្រូវបរាជ័យ — អាលម៉ាប្រហារ
អាំលិសៃចោល ។ ប្រមាណជាឆ្នាំ ៨៧ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីប្រាំក្នុងរជ្ជកាល
របស់គេ នោះចាប់ផ្តើមមានការទាស់ទែងគ្នាមួយ នៅក្នុង
ចំណោម ប្រជាជន; ត្បិតមានបុរសម្នាក់ ដែលហៅថា
អាំលិសៃ គាត់ជាមនុស្សប្រកបដោយកលល្បិច មែនហើយ
ជាមនុស្សមានប្រាជ្ញា ស្រប តាមប្រាជ្ញានៃលោកិយ គាត់ធ្វើ
តាមរបៀបបុរស ដែលបានសម្លាប់គេឌានដោយដាវ ជាអ្នក
ដែលត្រូវប្រហារជីវិតចោលតាមច្បាប់ —
២ ឥឡូវនេះ ឈ្មោះអាំលិសៃនេះ ដោយកលល្បិចរបស់
គាត់ បានទាក់ទាញមនុស្សជាច្រើនឲ្យទៅតាមគាត់; រហូតដល់
ពួកគេបាន ចាប់ផ្តើមមានកម្លាំងដ៏ខ្លាំង; ហើយពួកគេបាន
ចាប់ផ្តើមខិតខំលើកអាំលិសៃ ឲ្យធ្វើជាស្តេចលើប្រជាជន ។
៣ ឥឡូវនេះ ការណ៍នេះធ្វើឲ្យភិតភ័យដល់ប្រជាជននៃសាសនា
ចក្រ ព្រមទាំងដល់អស់អ្នកណាដែលពុំបានទាក់ទាញ តាមការ
បញ្ចុះបញ្ចូលទាំងឡាយរបស់អាំលិសៃ; ត្បិតពួកគេដឹងតាមច្បាប់
របស់គេថា ការណ៍បែបនេះត្រូវតែបានធ្វើឡើងដោយសម្លេង
នៃ ប្រជាជន ។
៤ ហេតុដូច្នេះហើយ ប្រសិនបើអាំលិសៃដែលជាមនុស្ស
ទុច្ចរិត អាចបានទទួលសម្លេងរបស់ប្រជាជន នោះនឹងធ្វើឲ្យ
បាត់បង់សិទ្ធិទាំង ឡាយរបស់គេ និងឯកសិទ្ធទាំងឡាយរបស់
សាសនាចក្រ; ព្រោះគាត់មានបំណងចង់បំផ្លាញសាសនា
ចក្រនៃព្រះចោល ។
៥ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបានប្រជុំគ្នា
ទូទៅអស់ទាំងដែនដី គឺមនុស្សគ្រប់រូបស្របតាមគំនិតរបស់ខ្លួនថា
តើគេគាំទ្រ ឬជំទាស់នឹងអាំលិសៃ តាមក្រុមដោយឡែកៗ ដោយ
មានការជជែកគ្នាជាខ្លាំង និងការទាស់ទែងគ្នាដ៏អស្ចារ្យ ។
៦ ម្ល៉ោះហើយ ពួកគេបានប្រជុំគ្នា ដើម្បីបោះសម្លេងគេ
អំពីរឿងនេះ; ហើយពួកគេបានយកពាក្យទៅលាតត្រដាងខាង
មុខ ពួកចៅក្រម ។
៧ ហើយហេតុការណ៍បានកើតឡើងថា សម្លេងរបស់ប្រជាជន
ទាស់នឹងអាំលិសៃថា គាត់មិនត្រូវធ្វើជាស្តេចលើប្រជាជនទេ ។
៨ ឥឡូវនេះ ការណ៍នេះបានធ្វើឲ្យមានសេចក្តីអំណរជាខ្លាំង
នៅក្នុងចិត្តនៃពួកអ្នកដែលទាស់នឹងគាត់; ប៉ុន្តែអាំលិសៃបាន
ចាក់រុក ពួកអ្នកដែលគាំទ្រគាត់ ឲ្យខឹងនឹងអស់អ្នកណាដែល
មិនគាំទ្រគាត់ ។
៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រជុំគ្នា
ហើយបានញែកអាំលិសៃឲ្យធ្វើជាស្តេចរបស់គេវិញ ។
១០ ឥឡូវនេះ កាលអាំលិសៃបានធ្វើជាស្តេចលើពួក
គេហើយ នោះទ្រង់បានបញ្ជាពួកគេ ឲ្យលើកអាវុធប្រឆាំងនឹង
បងប្អូនខ្លួន; ហើយទ្រង់ធ្វើយ៉ាងនេះ ដើម្បីទ្រង់អាចដាក់ពួក
គេឲ្យនៅក្រោមអំណាចទ្រង់ ។
១១ ឥឡូវនេះ ប្រជាជនអាំលិសៃ ត្រូវបានស្គាល់តាមឈ្មោះ
អាំលិសៃ ដោយបានហៅថា ពួកសាសន៍អាំលិសៃ; ហើយ
ប្រជាជន ដែលនៅសល់ទាំងប៉ុន្មាន ត្រូវបានហៅថា ពួក
សាសន៍នីហ្វៃ ឬរាស្ត្រនៃព្រះ ។
១២ ហេតុដូច្នេះហើយ ប្រជាជននៃសាសន៍នីហ្វៃបាន
ដឹងបំណងរបស់ពួកសាសន៍អាំលិសៃ ម្ល៉ោះហើយ ពួកគេបាន
រៀបចំ ដើម្បីតទល់នឹងពួកគេ; មែនហើយ ពួកគេបាន
ប្រដាប់ខ្លួនដោយដាវ និងកាំបិត និងធ្នូ និងព្រួញ និងក្រួស
និងខ្សែដង្ហក់ និងអស់ទាំង គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមគ្រប់
បែបយ៉ាង ។
១៣ ហើយពួកគេបានរៀបចំខ្លួនយ៉ាងដូច្នោះហើយ ដើម្បី
តទល់នឹងពួកសាសន៍អាំលិសៃ នៅពេលពួកនោះនឹងមកដល់ ។
ហើយ បានតែងតាំងមេទ័ព និងមេទ័ពជាន់ខ្ពស់ និងមេទ័ពឯក
ទាំងឡាយ ស្របតាមចំនួនទ័ព ។
១៤ ហើយហេតុការណ៍បានកើតឡើងថា អាំលិសៃបាន
ប្រដាប់អាវុធដល់ប្រជាជនទ្រង់ ដោយអស់
ទាំងគ្រឿងសស្ត្រាវុធពិជ័យ សង្គ្រាមគ្រប់បែបយ៉ាង; ហើយ

**២** ១ *ក* អាលម៉ា ១:៨.
៣ *ក* ម៉ូសាយ ២៩:២៥–២៧;
អាលម៉ា ៤:១៦.
៤ *ក* អាលម៉ា ១០:១៩; ហេលេ. ៥:២.
៥ *ក* ៣ នីហ្វៃ ១១:២៩.
១១ *ក* អាលម៉ា ៣:៤.
*ខ* យ៉ាកុប ១:១៣–១៤;
ម៉ូសាយ ២៥:១២; អាលម៉ា ៣:១១.
១២ *ក* ម៉ូសាយ ១០:៨; ហេលេ. ១:១៤.

ទ្រង់បានតែងតាំងមេគ្រួតត្រា និងមេដឹកនាំលើប្រជាជនទ្រង់
ដើម្បីនាំគេទៅធ្វើសង្គ្រាមនឹងបងប្អូនរួម ជាតិរបស់ខ្លួន ។
១៥ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍អាំលីសៃ
បានមកលើភ្នំអាំណៃហ៊ូ នៅខាងកើតទន្លេស៊ីដូន ដែលហូរ
បណ្ដោយតាមដែនដីសារ៉ាហិមឡា ហើយនៅទីនោះហើយដែល
ពួកគេបានចាប់ផ្ដើមធ្វើសង្គ្រាមជាមួយនឹងពួកសាសន៍នីហ្វៃ ។
១៦ ឥឡូវនេះ អាលម៉ា ជាមេចៅក្រម ហើយជា
អ្នកអភិបាលលើប្រជាជននីហ្វៃ ហេតុដូច្នេះហើយ
លោកបានឡើងទៅជាមួយនឹង ប្រជាជនរបស់លោក មែន
ហើយ ជាមួយនឹងមេទ័ព និងមេទ័ពឯកទាំងឡាយរបស់លោក
មែនហើយ លោកបានដើរខាងមុខពលទ័ព របស់លោក
ទៅច្បាំងនឹងពួកសាសន៍អាំលីសៃ ។
១៧ ហើយពួកគេបានចាប់ផ្ដើមសម្លាប់ពួកសាសន៍
អាំលីសៃនៅលើភ្នំខាងកើតស៊ីដូន ។ ហើយពួកសាសន៍
អាំលីសៃ បានតតាំងជា មួយនឹងពួកនីហ្វៃ ដោយកម្លាំងដ៏ខ្លាំង
ដរាបដល់មានពួកនីហ្វៃជាច្រើនបានដួលចុះ នៅចំពោះពួក
សាសន៍អាំលីសៃ ។
១៨ ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអម្ចាស់ទ្រង់បាន
ចំរើនកម្លាំងដល់ដៃរបស់ពួកនីហ្វៃដែរ រហូតដល់ពួកគេបានសម្លាប់
ពួក សាសន៍អាំលីសៃដោយការកាប់សម្លាប់ដ៏ធំ ដែលពួកគេ
បានចាប់ផ្ដើមរត់គេចចេញទៅ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកនីហ្វៃបាន
ដេញតាមពួកអាំលីសៃ អស់ពេញមួយថ្ងៃ ហើយបានសម្លាប់
ពួកគេដោយការ កាប់សម្លាប់ដ៏ច្រើន ដរាបដល់ចំនួនពួកអាំលីសៃ
ដែលត្រូវស្លាប់ ឡើងដល់មួយម៉ឺនពីរពាន់ប្រាំរយសាមសិបពីរនាក់;
ហើយពួកនីហ្វៃ ដែលត្រូវបាន ស្លាប់មានចំនួនប្រាំ
មួយពាន់ប្រាំរយហុកសិបពីរនាក់ ។
២០ ហើយហេតុការណ៍បានកើតឡើងថា កាលដែល
អាលម៉ាមិនអាចដេញតាមពួកអាំលីសៃតទៅទៀតទេ នោះលោ
កបានបញ្ជា ឲ្យទ័ពលោក បោះត្រសាលនៅក្នុងច្រកភ្នំគេឌាន
គឺច្រកភ្នំដែលហៅតាមឈ្មោះគេឌាន ដែលត្រូវ
នីហ៊ូរសម្លាប់ដោយដាវនោះ ហើយនៅក្នុងច្រកភ្នំនេះហើយ
ដែលពួកនីហ្វៃបានបោះត្រសាលក្នុងយប់នោះ ។
២១ ហើយអាលម៉ាបានចាត់ឲ្យអ្នកស៊ើបការណ៍ ទៅតាម
ពួកអាំលីសៃ ដែលនៅសល់ទាំងប៉ុន្មាន ដើម្បីលោកអាច
ដឹងនូវផែនការ ទាំងឡាយរបស់ពួកគេ និងគំរោងការទាំង
ឡាយរបស់ពួកគេ ដើម្បីលោកអាចការពារខ្លួនតទល់នឹងពួក
គេ ហើយដើម្បីលោកអាច រក្សាប្រជាជនលោក កុំឲ្យត្រូវ
បំផ្លាញបង់ ។
២២ ឥឡូវនេះ ពួកអ្នកដែលលោកបានចាត់ ឲ្យទៅល
បមើលទីតាំងរបស់ពួកសាសន៍អាំលីសៃ នោះមានឈ្មោះថា
ស៊ីរាំ និង អាំណូរ និងម៉ាន់តៃ និងលិមហើរ; ពួកគេនេះហើយ
ដែលបានចេញទៅជាមួយទ័ពរបស់គេ ដើម្បីទៅលបមើលជំរុំ
របស់ពួកអាំលីសៃ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង
ពួកគេបានត្រឡប់មកដល់ជំរុំរបស់ពួកនីហ្វៃវិញ ដោយប្រញាប់
ប្រញាលជាខ្លាំង ដោយមានការតក់ស្លុតហួសប្រមាណ ព្រម
ទាំងពោរពេញទៅដោយការភិតភ័យ ក៏និយាយថា៖
២៤ មើលចុះ ពួកយើងបានទៅតាមលបមើលជំរុំរបស់ពួក
សាសន៍អាំលីសៃ ហើយយើងមានការតក់ស្លុតយ៉ាងខ្លាំង នៅ
ក្នុងដែនដី ម៉ៃណុន នៅខាងលើដែនដីសារ៉ាហិមឡា ខាងទិស
ដែនដីនីហ្វៃ យើងបានឃើញពួកពលរបស់ពួកលេមិនយ៉ាងច្រើន
កុះករ; ហើយ មើលចុះ ពួកអាំលីសៃបានចូលរួមជាមួយនឹងពួក
គេទៅហើយ;
២៥ ហើយពួកគេបានវាយមកលើបងប្អូនយើងដែល
នៅលើដែនដីនោះ; ហើយបងប្អូនយើងកំពុងតែរត់គេចចេញពីពួក
គេ ជាមួយ នឹងហ្វូងចៀមរបស់គេ និងប្រពន្ធរបស់គេ និង
កូនចៅរបស់គេ ឆ្ពោះមកកាន់ទីក្រុងរបស់យើង;
ហើយលើកលែងតែយើងទៅដោយ រួសរាន់ នោះពួកគេ
នឹងវាយយកទីក្រុងរបស់យើង ហើយឪពុកយើង និងប្រពន្ធយើង
និងកូនចៅយើងនឹងត្រូវពួកគេសម្លាប់ចោលជា មិនខានឡើយ ។
២៦ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជននីហ្វៃបាន
រើត្រសាលរបស់ខ្លួន ហើយចាកចេញពីច្រកភ្នំគេឌាន
ឆ្ពោះទៅកាន់ ទីក្រុងរបស់ខ្លួន គឺជាទីក្រុងសារ៉ាហិមឡាវិញ ។
២៧ ហើយមើលចុះ៖ នៅពេលពួកគេកំពុងតែ
ឆ្លងទន្លេស៊ីដូនឡើយ នោះពួកលេមិន និងពួកអាំលីសៃ ដែល
មានគ្នាច្រើនដូចជា ខ្សាច់នៅមាត់សមុទ្រ បានវាយមកលើគេ
ដើម្បីបំផ្លាញពួកគេចោល ។

១៥ *ក* អាលម៉ា ៣:៣.
*ខ* អោមណៃ ១:១៣–១៥.
១៦ *ក* ម៉ូសាយ ២៩:៤២.
១៩ *ក* អាលម៉ា ៣:១–២, ២៦; ៤:២.
២០ *ក* អាលម៉ា ៦:៧.
*ខ* អាលម៉ា ១:៧–១៥; ១៤:១៦.
២៤ *ក* អាលម៉ា ៣:៤, ១៣–១៨.
*ខ* ២ នីហ្វៃ ៥:៨.
២៦ *ក* អោមណៃ ១:១៤, ១៨.
២៧ *ក* យ៉ារ៉ុម ១:៦.

២៨ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកនីហ្វៃបាន ទទួលកម្លាំងពីព្រះហស្តនៃព្រះអម្ចាស់ដែរ ដោយបាន អធិស្ឋានអស់ពីសមត្ថភាព ទៅទ្រង់ សូមឲ្យទ្រង់ដោះពួកគេ ឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់ពួកគេ ហេតុ ដូច្នេះហើយ ព្រះអម្ចាស់ទ្រង់បានឮសំរែក របស់ពួកគេ ហើយ បានចំរើនកម្លាំងពួកគេ ឯពួកលេមិន និងពួកអាំលិសៃ ក៏ត្រូវ ដួលចុះចំពោះមុខគេទៅ ។

២៩ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាបាន ប្រយុទ្ធជាមួយនឹងអាំលិសៃដោយដាវ ប្រទល់មុខ; ហើយគេ បានប្រយុទ្ធគ្នា ទៅវិញទៅមកយ៉ាងខ្លាំង ។

៣០ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា ជាអ្នក សំណប់នៃព្រះ ដោយបានអនុវត្តសេចក្ដីជំនឿដ៏ច្រើន បាន ស្រែកអំពាវ នាវថា៖ ឱព្រះអម្ចាស់អើយ សូមទ្រង់មានសេចក្ដី មេត្តាករុណា ហើយប្រោសប្រណីដល់ជីវិតទូលបង្គំផង ដើម្បីឲ្យ ទូលបង្គំអាចបានទៅជា ឧបករណ៍មួយនៅក្នុងព្រះហស្តទ្រង់ ដើម្បីជួយសង្គ្រោះ ហើយថែរក្សាប្រជាជននេះ ។

៣១ ឥឡូវនេះ កាលអាលម៉ាបាននិយាយពាក្យទាំងនោះហើយ នោះលោកបានប្រយុទ្ធនឹងអាំលិសៃទៀត; ហើយលោកបានទទួល កម្លាំងដ៏ច្រើន ដរាបដល់លោកបានសម្លាប់អាំលិសៃដោយ ដាវផ្ទាល់ ។

៣២ ហើយលោកក៏បានប្រយុទ្ធនឹងស្ដេចនៃពួកលេមិនដែរ; ប៉ុន្តែស្ដេចរបស់ពួកលេមិនបានរត់ថយចេញពីអាលម៉ា ហើយ បាន បញ្ជាឲ្យពួកទាហានទ្រង់ប្រយុទ្ធជាមួយនឹងអាលម៉ាវិញ ។

៣៣ ប៉ុន្តែ អាលម៉ាជាមួយនឹងពួកទាហានយាមរបស់លោក បានប្រយុទ្ធជាមួយនឹងពួកទាហានយាមរបស់ស្ដេចនៃពួកលេមិន រហូតដល់លោកបានសម្លាប់ ហើយរុញច្រានពួកគេថយក្រោយវិញ។

៣៤ ម្ល៉ោះហើយ លោកបាននាំលើងទីសមរភូមិ ឬនិយាយឲ្យចំ គឺជាទីនៅខាងលិចទន្លេស៊ីដូន ដោយបានបោះសាកសពពួក លេមិន ដែលត្រូវបានស្លាប់ ទៅក្នុងទឹកទន្លេស៊ីដូន ដើម្បីឲ្យទ័ព របស់លោកមានកន្លែងឆ្លង ហើយប្រយុទ្ធនឹងពួកលេមិន និងពួក អាំលិសៃ នៅត្រើយខាងលិចទន្លេស៊ីដូន ។

៣៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបាន ឆ្លងទន្លេស៊ីដូនអស់ហើយ នោះពួកលេមិន និងពួកអាំលិសៃបាន ចាប់ ផ្ដើមរត់គេចពីពួកគេ ទោះជាពួកគេមានគ្នាច្រើនឥតគណនា ដែលមិនអាចរាប់បានក៏ដោយ ។

៣៦ ហើយពួកគេបានរត់គេចចេញពីពួកនីហ្វៃ ឆ្ពោះទៅទីរ ហោស្ថាន ដែលនៅខាងលិច និងខាងជើង ឆ្ងាយផុតពីព្រំប្រទល់នៃ ដែនដី; ហើយពួកនីហ្វៃបានដេញតាមពួកគេដោយសមត្ថភាព របស់ខ្លួន ហើយបានសម្លាប់ពួកគេចោលទៅ ។

៣៧ មែនហើយ ពួកគេត្រូវបានវាយពីគ្រប់ទិសទី ហើយត្រូវ បានស្លាប់ និងត្រូវបានរុញច្រាន រហូតដល់ពួកគេត្រូវ បែកខ្ញែកទៅខាង លិច និងទៅខាងជើង រហូតដល់ពួកគេបាន ទៅដល់ទីរហោស្ថាន ដែលហៅថា ហើម៉ោនត៍; ហើយ គឺជាផ្នែកនៃទីរហោស្ថាន ដែលរស់ នៅដោយពួកសត្វព្រៃ សាហាវៗ ។

៣៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេជាច្រើន ត្រូវស្លាប់នៅក្នុងទីរហោស្ថាននោះ ដោយព្រោះមានរបួស ហើយត្រូវពួក សត្វទាំងនោះ ព្រមទាំងពួកសត្វត្មាត ដែលហើរ នៅលើអាកាស ខាំហែកស៊ីផង; ឯឆ្អឹងពួកគេ ក៏ឃើញ គរចោលនៅពាសពេញលើដី ៕

## ជំពូកទី ៣

*ពួកសាសន៍អាំលិសៃបានគូសខ្លួន តាមពាក្យព្យាករណ៍ — ពួកលេមិនត្រូវបណ្ដាសា មកពីការបះបោររបស់ពួកគេ — មនុស្សលោក នាំបណ្ដាសាមកលើខ្លួនឯង — ពួកនីហ្វៃមាន ជ័យជំនះលើកងទ័ពសាសន៍លេមិនមួយទៀត ។ ប្រមាណ ជាឆ្នាំ ៨៧–៨៦ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកនីហ្វៃដែលពុំត្រូវបាន ស្លាប់ដោយគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាម នោះបានកប់ពួក អ្នកដែល ត្រូវបានស្លាប់ — ឥឡូវនេះ ចំនួនអ្នកដែលត្រូវបាន ស្លាប់នោះមានច្រើនណាស់ មិនអាចរាប់បានឡើយ — ក្រោយពីគេបានកប់ ពួកអ្នកស្លាប់រួចស្រេចហើយ នោះពួកគេ ទាំងអស់គ្នាបានត្រឡប់ទៅដែនដីគេ ហើយទៅរកផ្ទះគេ និង ប្រពន្ធគេ និងកូនចៅគេវិញ ។

២ ឥឡូវនេះ មានស្ត្រី និងក្មេងៗជាច្រើន ដែលត្រូវបាន ស្លាប់ដោយដាវ ព្រមទាំងភាគច្រើននៃហ្វូងចៀមគេ និង ហ្វូងគោគេផង; ហើយព្រមទាំងភាគច្រើននៃស្រែចំការ គេក៏ត្រូវបំផ្លាញចោលដែរ ព្រោះស្រែចំការទាំងនោះត្រូវ កងទ័ពដើរទន្រ្ទានលើ ។

២៨ *ក* ចោទិ. ៣១:៦. | ៣០ *ក* ស.ប. សេចក្ដីជំនឿ. | ៣ ១ *ក* អាលម៉ា ២:១៩; ៤:២.

៣ ហើយឥឡូវនេះ ពួកលេមិន និងពួកអាំលិសៃភាគច្រើន ដែលត្រូវបានស្លាប់នៅឯច្រាំងទន្លេស៊ីដូន នោះក៏ត្រូវបោះចោលទៅក្នុងទឹកទន្លេស៊ីដូន; ហើយមើលចុះ ឆ្អឹងរបស់គេនៅក្នុងទីជំរៅនៃសមុទ្រ ឯឆ្អឹងទាំងនោះមានច្រើនណាស់ ។

៤ ឯពួកអាំលិសៃក៏ត្រូវញែកចេញពីពួកនីហ្វៃ ព្រោះគេបានគូសពណ៌ក្រហមនៅលើថ្ងាសគេ តាមរបៀបពួកសាសន៍លេមិន; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេមិនបានកោរសក់ដូចពួកលេមិនដែរ ។

៥ ឥឡូវនេះ ពួកលេមិនកោរសក់; ហើយពួកគេនៅអាក្រាត លើកលែងតែប៉ុងស្បែកនៅជុំវិញចង្កេះ ហើយមានស្ពាយគ្រឿងអាវុធជុំវិញខ្លួនផង ហើយមានធ្នូរបស់គេ និងព្រួញរបស់គេ និងក្រួសរបស់គេ និងខ្សែដង្ហក់របស់គេជាដើម ។

៦ ហើយស្បែកពួកលេមិនមានពណ៌ក្រមៅស្របតាមគំនូសចំណាំ ដែលមានដាក់ទៅលើពួកអយ្យកោគេ គឺជាការបណ្ដាសា ដល់គេ មកពីការរំលងរបស់គេ និងការបះបោររបស់គេ ទាស់នឹងប្អូនៗគេ ដូចជានីហ្វៃ យ៉ាកុប និងយ៉ូសែប និងសាំ ដែលជាមនុស្ស សុចរិត ហើយបរិសុទ្ធ ។

៧ ហើយពួកបងប្អូនគេបានស្វែងរកផ្លូវបំផ្លាញគេចោល ហេតុដូច្នេះហើយ ពួកគេត្រូវបណ្ដាសា ហើយព្រះអម្ចាស់ ដ៏ជាព្រះទ្រង់បាន គូសចំណាំលើគេ មែនហើយ លើលេមិន និងលេមយួលព្រមទាំងកូនប្រុសទាំងឡាយរបស់អ៊ីសម៉ាអែលផង និងលើស្ត្រីៗនៃពួកអ៊ីសម៉ាអែលដែរ ។

៨ ហើយការណ៍នេះបានធ្វើឡើង ដើម្បីឲ្យពូជគេអាចបានញែកចេញ ពីកូនចៅរបស់ប្អូនៗគេ ដើម្បីព្រះអម្ចាស់ទ្រង់អាចរក្សារាស្ត្ររបស់ទ្រង់ទុក ដើម្បីកុំឲ្យពួកគេទៅលាយឡំ ហើយជឿសណ្ដាប់ដ៏ខុសឆ្គងទាំងឡាយ ដែលនឹងនាំគេទៅកាន់សេចក្ដីបំផ្លិច បំផ្លាញនោះ ។

៩ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែលបានលាយទឹកកាមរបស់ខ្លួនទៅជាមួយនឹងពួកលេមិន អ្នកនោះក៏បាននាំ បណ្ដាសាមកលើពូជរបស់ខ្លួនដែរ ។

១០ ហេតុដូច្នេះហើយ បើអ្នកណាបណ្ដោយឲ្យពួកលេមិនដឹកនាំទៅ នោះនឹងត្រូវបានហៅតាមឈ្មោះនោះ ហើយនឹងមានគំនូស ដៅនៅលើអ្នកនោះផង ។

១១ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែលមិនជឿតាមសណ្ដាប់នៃពួកលេមិន តែជឿតាមបញ្ជីទាំងនោះដែលត្រូវបានយកចេញពីដែនដីយេរូសាឡិមមក ហើយជឿដល់សណ្ដាប់នៃពួកអយ្យកោរបស់គេវិញ ដែលជាសណ្ដាប់ដ៏ត្រូវ ហើយជឿតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ព្រមទាំងកាន់តាមព្រះបញ្ញត្តិផង អ្នកនោះហើយដែលត្រូវបានហៅថា ពួកសាសន៍នីហ្វៃ ឬប្រជាជននីហ្វៃ ចាប់តាំងពីពេលនោះតទៅ —

១២ គឺពួកគេនេះហើយដែលបានកត់បញ្ជីទាំងឡាយទុក គឺជាបញ្ជីដ៏ពិតអំពីប្រជាជនគេ និងព្រមទាំងអំពីពួកសាសន៍លេមិនផង ។

១៣ ឥឡូវនេះ យើងត្រឡប់មកឯពួកអាំលិសៃវិញ ព្រោះពួកគេក៏មានគំនូសលើខ្លួនគេដែរ; មែនហើយ គេគូសគំនូសលើខ្លួនគេ មែនហើយ គឺជាគំនូសក្រហមមួយនៅលើថ្ងាសគេ ។

១៤ ម្ល៉ោះហើយ ព្រះបន្ទូលនៃព្រះត្រូវបានបំពេញ ត្បិតព្រះបន្ទូលទាំងនេះហើយដែលទ្រង់បានប្រាប់ទៅនីហ្វៃថា៖ មើលចុះ យើង បានដាក់បណ្ដាសាដល់ពួកលេមិន ហើយយើងនឹងគូសចំណាំលើគេ ដើម្បីពួកគេ និងពូជគេត្រូវបានញែកចេញពីពួកអ្នក និងពូជអ្នក ចាប់ពីពេលនេះ និងរៀងរហូតតទៅ លើកលែងតែពួកគេប្រែចិត្ត ចំពោះអំពើទុច្ចរិតរបស់គេ ហើយបែរមករកយើងវិញ ទើបយើងអាច មានសេចក្ដីមេត្តាករុណាទៅលើគេ ។

១៥ ហើយម្យ៉ាងទៀត៖ យើងនឹងគូសចំណាំលើជនណា ដែលលាយទឹកកាមរបស់ខ្លួនទៅជាមួយនឹងបងៗរបស់អ្នក ដើម្បីឲ្យពួកគេ អាចត្រូវបណ្ដាសាផងដែរ ។

១៦ ហើយម្យ៉ាងទៀត៖ យើងនឹងគូសចំណាំលើជនណាដែលប្រឆាំងនឹងអ្នក និងពូជអ្នក ។

១៧ ហើយម្យ៉ាងទៀត យើងប្រាប់ថា អ្នកណាដែលចាកចេញពីអ្នកទៅ នោះនឹងឈប់បានហៅថាជាពូជអ្នកទៀតហើយ; ហើយ យើងនឹងប្រទានពរដល់អ្នក ហើយដល់អ្នកណាដែលមានឈ្មោះថាជាពូជអ្នក ចាប់ពីពេលនេះ

៣ *ក* អាលម៉ា ២:១៥.
*ខ* អាលម៉ា ៤៤:២២.
៤ *ក* អាលម៉ា ២:១១.
*ខ* អាលម៉ា ៣:១៣–១៩.
៥ *ក* អេណុស ១:២០; ម៉ូសាយ ១០:៨; អាលម៉ា ៤២:១៨–២១.
៦ *ក* ២ នីហ្វៃ ៥:២១; ២៦:៣៣. ស.ប. បណ្ដាសា, បណ្ដាសាទាំងឡាយ.
៧ *ក* ១ នីហ្វៃ ១២:២៣.
៨ *ក* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍រវាងសេចក្ដីជំនឿ.
*ខ* ម៉ូសាយ ១០:១១–១៨; អាលម៉ា ៩:១៦.
១១ *ក* អាលម៉ា ១៧:៩–១១.
១២ *ក* ម៉ូសាយ ១:៦; អេធើរ ៤:៦–១១.
១៣ *ក* អាលម៉ា ៣:៤.
១៤ *ក* ២ នីហ្វៃ ៣០:៤–៦.

និងរៀងរហូតតទៅ; ហើយនេះគឺជា សេចក្ដីសន្យាទាំងឡាយ
នៃព្រះអម្ចាស់ចំពោះនីហ្វៃ និងពូជរបស់លោក ។
១៨ ឥឡូវនេះ ពួកអាំលិសៃពុំបានដឹងថា គេកំពុងតែបំពេញនូវ
ព្រះបន្ទូលទាំងឡាយនៃព្រះ នៅពេលពួកគេចាប់ផ្ដើមគូសលើថ្ងាស
គេនោះឡើយ; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបាន
បះបោរចេញមុខមកទាស់នឹងព្រះដែរ; ហេតុដូច្នេះហើយ ជា
ការចាំបាច់ ដែលបណ្ដាសាត្រូវធ្លាក់មកលើពួកគេ ។
១៩ ឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាឃើញថា ពួកគេបានទាញយក
បណ្ដាសាមកលើខ្លួនឯង; ហើយក៏ដូច្នោះដែរ គឺអ្នកណាដែលត្រូវ
បណ្ដាសា ក៏នាំការកាត់ទោសមកដាក់លើខ្លួនឯងផ្ទាល់ ។
២០ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មិនជាច្រើនថ្ងៃ
បន្ទាប់ពីចម្បាំង ដែលបានច្បាំងនៅលើដែនដីសារ៉ាហិមឡា
ដោយ ពួកលេមិន និងពួកអាំលិសៃ នោះមានកងទ័ពលេមិន
កងផ្សេងមួយទៀត បានមកវាយមកលើប្រជាជននីហ្វៃ
នៅត្រង់កន្លែងដដែល ដែលកងទ័ពមុនបានជួបនឹងពួក
អាំលិសៃនោះ ។
២១ ហើយហេតុការណ៍បានកើតឡើងថា មានទ័ពមួយកង
ត្រូវបានចាត់ឲ្យទៅរុញច្រានពួកគេចេញពីដែនដី ។
២២ ឥឡូវនេះ អាលម៉ា ដែលត្រូវរបួសផ្ទាល់ ពុំ
បានឡើងទៅច្បាំងនឹងពួកលេមិនពេលនេះទេ;
២៣ ប៉ុន្តែ លោកបានបញ្ជាឲ្យកងទ័ពជាច្រើន ទៅតទល់នឹង
ពួកគេ; ហើយពួកគេបានឡើងទៅ ហើយបានសម្លាប់ពួក
លេមិនអស់ជា ច្រើននាក់ ហើយបានរុញច្រានពួកដែលនៅសល់
ទាំងប៉ុន្មាន ឲ្យចេញទៅក្រៅព្រំប្រទល់ដែនដីគេវិញ ។
២៤ ហើយបន្ទាប់មក ពួកគេបានត្រឡប់មកវិញ ហើយបាន
ចាប់ផ្ដើមកសាងសេចក្ដីសុខសាន្ត នៅលើដែនដីវិញទៀត ដោយ
ពុំមាន រឿងអ្វីទៀត ជាមួយនឹងពួកខ្មាំងសត្រូវរបស់គេអស់
មួយរយៈ ។
២៥ ឥឡូវនេះ ការណ៍អស់ទាំងនេះត្រូវបានកើតឡើង មែន
ហើយ អស់ទាំងសង្គ្រាម និងការទាស់ទែងគ្នា បានចាប់ផ្ដើមឡើង
ហើយក៏ចប់ទៅ នៅឆ្នាំទីប្រាំក្នុងរជ្ជកាលនៃពួកចៅក្រម ។
២៦ ហើយនៅក្នុងរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ មានព្រលឹង
រាប់ពាន់ និងរាប់ម៉ឺន ត្រូវបានបញ្ជូនទៅឯបរលោកដ៏នៅអស់កល្ប
ជានិច្ច ដើម្បីពួកគេអាចច្រូតនូវរង្វាន់ទាំងឡាយ ស្របតាម
កិច្ចការទាំងឡាយរបស់ខ្លួន បើសិនជាពួកគេល្អ ឬក៏បើសិនជា
ពួកគេអាក្រក់ នោះនឹងបានច្រូតសុភមង្គលដ៏អស់កល្បជានិច្ច
ឬក៏សេចក្ដីវេទនាដ៏អស់កល្បជានិច្ច ស្របតាមវិញ្ញាណដែល
គេបានចុះធ្វើតាម ថាតើជា វិញ្ញាណល្អ ឬជាវិញ្ញាណ
អាក្រក់វិញ ។
២៧ ត្បិតមនុស្សគ្រប់រូបទទួលឈ្នួលពីអ្នកណាដែលគេចុះធ្វើ
តាម ហើយនេះគឺស្របតាមពាក្យទាំងឡាយនៃវិញ្ញាណនៃការ
ព្យាករណ៍; ហេតុដូច្នេះហើយ សូមឲ្យបានតាមការពិតចុះ ។
ម៉្លោះហើយ ក៏ចប់ឆ្នាំទីប្រាំក្នុងរជ្ជកាលនៃពួកចៅក្រមទៅ ៕

## ជំពូកទី ៤

*អាលម៉ាធ្វើបុណ្យជ្រមុជទឹកឲ្យអ្នកប្រែចិត្តជឿរាប់ពាន់នាក់ — អំពើទុច្ចរិតចូលក្នុងសាសនាចក្រ ហើយការលូតលាស់នៃសាសនាចក្រ ត្រូវបានបង្អាក់បង្អន់ — នីហ្វៃហាត្រូវបានតែងតាំងឡើងជាមេចៅក្រម — អាលម៉ា ជាសង្ឃជាន់ខ្ពស់ ប្រគល់ខ្លួនចំពោះការងារបំរើតែ ប៉ុណ្ណោះ ។ ប្រមាណជាឆ្នាំ ៨៦–៨៣ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីប្រាំមួយ
ក្នុងរជ្ជកាលនៃពួកចៅក្រម លើប្រជាជននីហ្វៃ គ្មានការទាស់ទែង
គ្នា ឬ សង្គ្រាមនៅលើដែនដីសារ៉ាហិមឡាឡើយ ។
២ ប៉ុន្តែ ប្រជាជនមានទុក្ខ មែនហើយ គឺមានទុក្ខធ្ងន់ប្រមាណ
ព្រោះតែការបាត់បងបងប្អូនរបស់គេ និងព្រមទាំងការបាត់បង់ហ្វូង
ចៀម និងគោរបស់គេផង និងព្រមទាំងការបាត់បង់ផលដំណាំ
នៅឯស្រែចំការរបស់គេផង ដែលត្រូវពួកលេមិនជាន់ឈ្លី
ហើយបំផ្លាញ ចោល ។
៣ ហើយសេចក្ដីទុក្ខវេទនារបស់គេមានទំហំធំណាស់ហ៊ួ
រហូតដល់មនុស្សគ្រប់រូបមានហេតុឲ្យទួញសោក; ហើយពួកគេ
បានជឿថា នោះគឺជាសេចក្ដីជំនុំជំរះទាំងឡាយនៃព្រះ ដែល
បានធ្លាក់មកលើពួកគេ ពីព្រោះតែអំពើទុច្ចរិតរបស់គេ និងអំពើ

១៨ *ក* ៤ នីហ្វៃ ១:៣៨.
ស.ប. ការបះបោរ.
១៩ *ក* ២ នីហ្វៃ ៥:២១–២៥;
អាលម៉ា ១៧:១៥.
២០ *ក* អាលម៉ា ២:២៤.
២២ *ក* អាលម៉ា ២:២៩–៣៣.
២៦ *ក* ស.ប. កិច្ចការ.
២៧ *ក* ម៉ូសាយ ២:៣១–៣៣;
អាលម៉ា ៥:៤១–៤២.
*ខ* រ៉ូម ៦:១៦; ហេលេ. ១៤:២៩–៣១.
ស.ប. ការគោរព, ដែលគោរព,
គោរព.
**៤** ១*ក* អោមណៃ ១:១២–១៩.
២ *ក* អាលម៉ា ២:១៩;
៣:១–២, ២៦.

គួរខ្ពើមឆ្អើមទាំងឡាយ របស់គេ; ហេតុដូច្នេះហើយ ពួកគេ
ត្រូវបានភ្ញាក់ឡើង ដោយនឹកឃើញដល់ភារកិច្ចរបស់ខ្លួន ។
៤ ហើយពួកគេបានចាប់ផ្ដើមតាំងសាសនាចក្រឡើង
យ៉ាងពេញលេញជាងមុន; មែនហើយ មនុស្សជាច្រើនបាន
ទទួលបុណ្យ ទ្រមុជទឹក នៅក្នុងទន្លេស៊ីដូន ហើយបានចូលរួបរួម
ក្នុងសាសនាចក្រនៃព្រះ; មែនហើយ ពួកគេបានទទួលបុណ្យ
ជ្រមុជទឹក ដោយដៃ របស់អាលម៉ា ជាអ្នកដែលបានទទួល
ការតែងតាំងឲ្យធ្វើជាសង្ឃជាន់ខ្ពស់ លើប្រជាជននៃសាសនា
ចក្រ ដោយដៃរបស់អាលម៉ា ជាឪពុកលោក ។
៥ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីប្រាំពីរក្នុងរជ្ជកាល
នៃពួកចៅក្រម មានមនុស្សប្រហែលបីពាន់ប្រាំរយនាក់ដែល
បានចូលរួបរួមក្នុងសាសនាចក្រនៃព្រះ ហើយបានទទួលបុណ្យ
ជ្រមុជទឹក ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប្រាំពីរក្នុងរជ្ជកាលនៃ
ពួកចៅក្រម ទៅលើប្រជាជននីហ្វៃ; ហើយសេចក្ដីសុខសាន្ដក៏
មានតរៀងទៅក្នុងរយៈពេលនោះ ។
៦ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីប្រាំបីក្នុងរជ្ជកាល
នៃពួកចៅក្រម ប្រជាជននៃសាសនាចក្របានចាប់ផ្ដើមវាយឫក
ក្រអោង ដោយសារទ្រព្យសម្បត្តិដ៏លើសលប់របស់គេ និង
សូត្រព្រែរបស់គេ និងសំពត់ត្បាញដោយអំបោះខ្លូតទេសវេញ
យ៉ាងខ្នាញ់ របស់គេ ហើយដោយសារហ្វូងចៀម និងហ្វូង
សត្វជាច្រើនរបស់គេ និងមាសរបស់គេ និងប្រាក់របស់គេ និងវ
ត្ថុដ៏មានតម្លៃគ្រប់បែប យ៉ាងរបស់គេ ដែលគេរកបាន ដោយសារ
ការឧស្សាហ៍របស់ខ្លួន; ហើយដោយសាររបស់ទាំងនេះហើយ
ដែលពួកគេបានលើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃភ្នែករបស់គេ
ព្រោះគេបានចាប់ផ្ដើមស្លៀកពាក់នូវប្រដាប់ស្លៀកពាក់ដ៏មាន
តម្លៃថ្លៃ ។
៧ ឥឡូវនេះ នេះគឺជាហេតុដែលមានសេចក្ដីទុក្ខវេទនា
ដ៏ច្រើនដល់អាលម៉ា មែនហើយ និងដល់មនុស្សជាច្រើននាក់
ដែលអាលម៉ា បានញែកចេញឲ្យធ្វើជាពួកគ្រូបង្រៀន និងពួក
សង្ឃ និងពួកអែលឌើរ នៅក្នុងសាសនាច្រក; មែនហើយ ពួក
គេជាច្រើនកើតទុក្ខជាខ្លាំង ពីព្រោះតែអំពើទុច្ចរិត ដែលពួកគេ
បានឃើញចាប់ផ្ដើមឡើង នៅក្នុងចំណោមប្រជាជនគេ ។
៨ ព្រោះពួកគេបានមើល ហើយឃើញដោយការសោកសៅជា
ខ្លាំងថា ប្រជាជននៃសាសនាចក្របានចាប់ផ្ដើមលើកខ្លួនឡើង
ក្នុងការឆ្មើងឆ្មៃនៃភ្នែករបស់គេ ហើយភ្ជាប់ចិត្ត
គេទៅលើទ្រព្យសម្បត្តិ និងទៅលើវត្ថុទាំងឡាយដែល
ឥតប្រយោជន៍នៃលោកិយ គឺពួកគេបានចាប់ផ្ដើមមើលងាយ
គ្នាទៅវិញទៅមក ហើយពួកគេបានចាប់ផ្ដើមបៀតបៀនដល់
អស់អ្នកណា ដែលមិនជឿតាមចំណង់ និងការប៉ងប្រាថ្នារបស់ ខ្លួន។
៩ ម្ល៉ោះហើយ កាលនៅឆ្នាំទីប្រាំបីនេះក្នុងរជ្ជកាលនៃពួកចៅក្រម
នោះចាប់ផ្ដើមកើតមានការទាស់ទែងដ៏ធំៗ នៅក្នុងចំណោម
ប្រជាជននៃសាសនាចក្រ; មែនហើយ មានការឈ្នានីស និង
ការប្រកួតប្រជែង និងការព្យាបាទ និងការបៀតបៀនទាំង
ឡាយ និងការ ឆ្មើងឆ្មៃ គឺច្រើនជាងការឆ្មើងឆ្មៃ នៃពួកអ្នក
ដែលមិននៅក្នុងសាសនាចក្រនៃព្រះទៅទៀត ។
១០ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រមទៅ;
ហើយអំពើទុច្ចរិតនៃសាសនាចក្រ គឺជាការជំពប់មួយដ៏ធំដល់
ពួកអ្នក ដែលពុំនៅក្នុងសាសនាចក្រ; ម្ល៉ោះហើយ សាសនា
ចក្របានចាប់ផ្ដើមចុះអន់ថយ នូវការលូតលាស់ទៅវិញ ។
១១ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងដើម
ឆ្នាំទីប្រាំបួន អាលម៉ាបានឃើញអំពើទុច្ចរិតរបស់សាសនាចក្រ
ហើយលោក ក៏បានឃើញដែរថា គំរូនៃសាសនាចក្របាន
ចាប់ផ្ដើមនាំពួកអ្នកដែលឥតជំនឿ ពីអំពើទុច្ចរិតមួយ ទៅអំពើ
ទុច្ចរិតមួយទៀត ម្ល៉ោះហើយ គេបាននាំមកនូវការបំផ្លិចបំផ្លាញ
មកលើប្រជាជន ។
១២ មែនហើយ លោកបានឃើញការមិនស្មើគ្នាដ៏ធំ នៅក្នុង
ចំណោមប្រជាជន អ្នកខ្លះលើកខ្លួន ដោយការឆ្មើងឆ្មៃរបស់ខ្លួន
ដោយមើលងាយអ្នកឯទៀត បែរខ្នងដាក់អ្នកខ្វះខាត និងអ្នក
អាក្រាត និងពួកអ្នកដែលអត់ឃ្លាន និងពួកអ្នកដែលស្រេក និង
ពួកអ្នក ដែលឈឺ ហើយមានទុក្ខវេទនា ។
១៣ ឥឡូវនេះ នេះគឺជាមូលហេតុដ៏ធំមួយ ដល់ការ
ទួញសោកនៅក្នុងចំណោមប្រជាជន កាលអ្នកខ្លះទៀតបន្ទាប
ខ្លួន ជួយឧបត្ថម្ភ ដល់ជនទាំងឡាយណា ដែលត្រូវការសេចក្ដី
ឧបត្ថម្ភ ដូចជាចែកទ្រព្យរបស់ខ្លួន ដល់អ្នកក្រីក្រ និងដល់អ្នក

៤ *ក* ម៉ូសាយ ១៨:១០–១៧.
*ខ* ម៉ូសាយ ២៩:៤២.
៥ *ក* ម៉ូសាយ ២៥:១៨–២៣; ៣ នីហ្វៃ ២៦:២១.
៦ *ក* ស.ប. ទ្រព្យសម្បត្តិ.
*ខ* អាលម៉ា ១:២៩.
៧ *ក* ស.ប. សិទ្ធិអំណាច.
៨ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ; ឥតប្រយោជន៍, ការឥតប្រយោជន៍.
*ខ* អាលម៉ា ១:២១.
៩ *ក* ស.ប. ការទាស់ទែង.
*ខ* ស.ប. ច្រណែន.
១១ *ក* ២ សាំយូ. ១២:១៤; អាលម៉ា ៣៩:១១.
១២ *ក* អេសាយ ៣:១៤; យ៉ាកុប ២:១៧.
*ខ* ម៉ូសាយ ៤:២៦.
១៣ *ក* ស.ប. ទាន, ការដាក់ទាន.

ខ្វះខាត ផ្ដល់អាហារដល់អ្នក អត់ឃ្លាន ហើយស៊ូរង[ខ]ការទុក្ខ
វេទនាគ្រប់បែបយ៉ាង ដើម្បីព្រះ[ក]គ្រីស្ទ ដែលទ្រង់នឹងយាងមក
ស្របតាមវិញ្ញាណនៃការព្យាករណ៍;
១៤ ដោយទន្ទឹងចាំថ្ងៃនោះ ដែលនឹងបាន[ក]ទទួល
ការផ្ដាច់បាបទាំងឡាយរបស់គេ; ដោយពោរពេញទៅដោយ
[ខ]សេចក្ដីអំណរដ៏ខ្លាំង ដោយសារដំណើររស់ឡើងវិញនៃមនុស្ស
ស្លាប់ ស្របតាមព្រះហឫទ័យ និងព្រះចេស្ដា និងការ
ដោះលែងរបស់ព្រះយេស៊ូវគ្រីស្ទ ឲ្យរួច ផុតពីចំណងទាំង
ឡាយនៃសេចក្ដីស្លាប់ ។
១៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
អាលម៉ាបានឃើញការទុក្ខវេទនារបស់ពួកជន ដែលបន្ទាប
ខ្លួនដែរ តាមព្រះ និងការបៀតបៀនទាំងឡាយដែលគេ
ទៅលើពួកគេ ពីសំណាក់ប្រជាជនរបស់លោក ដែល
នៅសល់ទាំងប៉ុន្មាន ហើយដោយ បានឃើញ[ក]ការមិនស្មើរគ្នា
របស់គេ នោះលោកបានចាប់ផ្ដើមព្រួយបារម្ភជាខ្លាំង; ទោះ
ជាយ៉ាងណាក៏ដោយ គង់តែព្រះវិញ្ញាណនៃ ព្រះអម្ចាស់
ទ្រង់ពុំបានលះបង់ចោលលោកឡើយ ។
១៦ ហើយលោកបានជ្រើសរើសអ្នកប្រាជ្ញម្នាក់ នៅក្នុង
ចំណោមពួកអែលឌើរនៃសាសនាចក្រ ហើយបានប្រគល់
អំណាចឲ្យ អ្នកនោះ ស្របតាម[ក]សម្លេងរបស់ប្រជាជន ដើម្បីឲ្យ
លោកអាចមានអំណាចចេញ[ខ]ច្បាប់ទាំងឡាយ តាមច្បាប់
ទាំងឡាយដែលបាន ប្រទានឲ្យ ហើយអនុវត្តច្បាប់ទាំងនោះ
ស្របតាមតែអំពើទុច្ចរិត និងទោសទាំងឡាយរបស់
ប្រជាជន។
១៧ ឥឡូវនេះ បុរសនេះមានឈ្មោះថា នីហ្វៃហា
ហើយលោកត្រូវបានតែងតាំងឲ្យធ្វើជា[ក]មេចៅក្រម; ហើយលោ
កបានអង្គុយនៅ វេទិកាជំនុំជំរះ ដើម្បីជំនុំជំរះ ហើយអភិបាល
ដល់ប្រជាជន ។
១៨ ឥឡូវនេះ អាលម៉ាពុំបានប្រគល់ឲ្យលោក នូវមុខ
ងារនៃសង្ឃជាន់ខ្ពស់ លើសាសនាចក្រនោះទេ តែលោកបាន
ទុកមុខងារ នៃសង្ឃជាន់ខ្ពស់នេះ សំរាប់ខ្លួនលោកវិញ; ប៉ុន្តែ
លោកប្រគល់វេទិកាជំនុំជំរះទៅឲ្យនីហ្វៃហា ។
១៩ ហើយលោកបានធ្វើយ៉ាងនេះ គឺដើម្បី[ក]ខ្លួនលោកផ្ទាល់
អាចទៅក្នុងចំណោមប្រជាជនរបស់លោក ឬនៅក្នុងចំណោម
ប្រជាជននីហ្វៃ ដើម្បីលោកអាចផ្សាយ[ខ]ព្រះបន្ទូលនៃព្រះដល់គេ
ដើម្បីដាស់[គ]រំជួលពួកគេ ឲ្យ[ឃ]នឹកចាំដល់ភារកិច្ចរបស់គេ ហើយដើម្បី
លោកអាចទំលាក់ចោល ដោយព្រះបន្ទូលនៃព្រះ នូវអស់ទាំង
ការឆ្មើងឆ្មៃ និងឧបាយកល និងអស់ទាំងការទាស់ទែងគ្នា
ដែលមាននៅ ក្នុងចំណោមប្រជាជនរបស់លោក ដោយ
ពុំឃើញថា មានផ្លូវណាមួយដែលលោកអាចទាមទាញពួកគេ
មកវិញបានឡើយ លើកលែង តែដោយការធ្វើ
[ង]ទីបន្ទាល់ដ៏បរិសុទ្ធទាស់នឹងគេប៉ុណ្ណោះ ។
២០ ម្ល៉ោះហើយ នៅដើមឆ្នាំទីប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម
លើប្រជាជននីហ្វៃ អាលម៉ាបានប្រគល់វេទិកាជំនុំជំរះទៅឲ្យ
[ក]នីហ្វៃហា ហើយបានផ្ដុក[ខ]ខ្លួនទាំងស្រុងទៅលើតំណែងនៃសង្ឃ
ជាន់ខ្ពស់ នៃរបៀបដ៏បរិសុទ្ធនៃព្រះ ទៅលើទីបន្ទាល់នៃព្រះ
បន្ទូល ស្របតាមវិញ្ញាណនៃវិវរណៈ និងការព្យាករណ៍ ៕

---

ពាក្យពេចន៍ដែលអាលម៉ា ជាសង្ឃជាន់ខ្ពស់ ស្របតាមរបៀបដ៏បរិសុទ្ធនៃព្រះ បានប្រកាសប្រាប់ដល់ប្រជាជននៅក្នុងទីក្រុង និងភូមិទាំងឡាយរបស់គេ ទូទៅទាំងដែនដី ។

*មានរួមនៅក្នុងជំពូកទី ៥*

## ជំពូកទី ៥

*ដើម្បីឲ្យបានការសង្គ្រោះ នោះមនុស្សលោកត្រូវតែប្រែចិត្ត ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយ, កើតម្ដងទៀត, ជំរះសំលៀកបំពាក់របស់ខ្លួន ដោយព្រះលោហិតនៃព្រះគ្រីស្ទ, បន្ទាបខ្លួន ហើយកំចាត់ការឆ្មើងឆ្មៃ និងការឈ្នានីសចេញពីខ្លួន ហើយធ្វើ*

---

១៣ *ខ* ស.ប. សេចក្ដីទំនាស់.
*ក* ២ កូរិន. ១២:១០.
១៤ *ក* ម៉ូសាយ ៤:១២;
អាលម៉ា ៥:២៦–៣៥.
ស.ប. ការរាប់ជាសុចរិត,
រាប់ជាសុចរិត.
*ខ* ស.ប. សេចក្ដីអំណរ.
១៥ *ក* គ. និង ស. ៣៨:២៧; ៤៩:២០.
១៦ *ក* អាលម៉ា ២:៣–៧.
*ខ* អាលម៉ា ១:១, ១៤, ១៨.
១៧ *ក* អាលម៉ា ៥០:៣៧.
១៩ *ក* អាលម៉ា ៧:១.
*ខ* អាលម៉ា ៣១:៥;
គ. និង ស. ១១:២១–២២.
*គ* អេណុស ១:២៣.
*ឃ* ម៉ូសាយ ១:១៧; ហេលេ. ១២:៣.
*ង* ស.ប. ទីបន្ទាល់.
២០ *ក* អាលម៉ា ៨:១២.
*ខ* ម៉ូសាយ ២៩:៤២;
អាលម៉ា ៥:៣, ៤៤, ៤៩.

*កិច្ចការ ទាំងឡាយ នៃសេចក្ដីសុចរិត — អ្នកគង្វាលល្អ នឹងហៅប្រជាជនរបស់លោក — អស់អ្នកណាដែលធ្វើកកិច្ចការទាំងឡាយដែលអាក្រក់ គឺជាកូនចៅនៃអារក្ស — អាលម៉ាធ្វើបន្ទាល់អំពីសេចក្ដីពិត នៃលទ្ធិរបស់លោក ហើយបញ្ជាឲ្យមនុស្សប្រែចិត្ត — ឈ្មោះពួកសុចរិត នឹងត្រូវបានកត់ទុកក្នុងសៀវភៅជីវិត ។ ប្រមាណជាឆ្នាំ ៨៣ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ាបានចាប់ផ្ដើមប្រកាសប្រាប់ព្រះបន្ទូលនៃព្រះដល់ប្រជាជន ដំបូងបំផុតនៅឯដែនដីសារ៉ាហិមឡា ហើយបន្ទាប់មក ក៏ប្រកាសជាទូទៅអស់ទាំងដែនដី ។

២ ហើយនេះគឺជាពាក្យពេចន៍ ដែលលោកបានថ្លែងទៅកាន់ប្រជាជន នៅក្នុងសាសនាចក្រ ដែលបានតាំងឡើង នៅទីក្រុងសារ៉ាហិមឡា ស្របតាមបញ្ជីរបស់លោកផ្ទាល់ ថា៖

៣ ខ្ញុំ អាលម៉ា ត្រូវបានញែកជាសង្ឃជាន់ខ្ពស់ នៃសាសនាចក្រនៃព្រះ ដោយឪពុកខ្ញុំឈ្មោះអាលម៉ា ព្រោះលោកមានអានុភាព និងសិទ្ធិអំណាចពីព្រះ ដើម្បីធ្វើនូវកិច្ចការទាំងនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា លោកបានចាប់ផ្ដើមតាំងសាសនាចក្រមួយឡើង នៅឯដែនដីមួយ ត្រង់ព្រំប្រទល់ដែនដីនីហ្វៃ; មែនហើយ ជាដែនដីដែលបានហៅថា ដែនដីមរមន; មែនហើយ លោកបានធ្វើ បុណ្យ ជ្រមុជទឹកឲ្យបងប្អូនទាំងឡាយនៅក្នុងទឹកមរមន ។

៤ ហើយមើលចុះ ខ្ញុំសូមប្រាប់អ្នកថា ពួកគេទាំងនោះ ត្រូវបានដោះឲ្យរួចពីកណ្ដាប់ដៃនៃមនុស្សរបស់ស្ដេចណូអេ ដោយសេចក្ដី មេត្តាករុណា និងដោយព្រះចេស្ដានៃព្រះ ។

៥ ហើយមើលចុះ បន្ទាប់ពីនោះមក ពួកគេត្រូវបានធ្លាក់ទៅក្នុងសេវកភាព ដោយដៃរបស់ពួកលេមិន នៅក្នុងទីរហោស្ថាន; មែនហើយ ខ្ញុំសូមប្រាប់អ្នកថា ពួកគេត្រូវជាប់ក្នុងការឃុំឃាំង ហើយជាថ្មីទៀត ព្រះអម្ចាស់ទ្រង់បានដោះលែងពួកគេឲ្យរួចផុតពីសេវកភាព ដោយព្រះចេស្ដានៃព្រះបន្ទូលរបស់ព្រះអង្គ; ហើយក៏បាននាំយើងមកកាន់ដែនដីនេះ ហើយនៅទីនេះ យើងបានចាប់ផ្ដើម តាំងសាសនាចក្រនៃព្រះឡើង ទូទៅទាំងដែនដីនេះផង ។

៦ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសូមសួរអ្នក គឺពួកអ្នកដែលនៅក្នុងសាសនាចក្រនេះថា តើអ្នកនៅ ចាំបានខ្លះៗឬទេ នូវការជាប់ឃុំឃាំងនៃពួកអយ្យកោរបស់យើង ? មែនហើយ តើបងប្អូននៅចាំបានខ្លះទេនូវសេចក្ដីមេត្តាករុណា និងសេចក្ដីអត់ធ្មត់របស់ព្រះអង្គចំពោះពួកគេ ? ហើយលើសលែងទៅទៀត តើអ្នកនៅចាំបានខ្លះទេថាព្រះអង្គទ្រង់បានដោះព្រលឹង ពួកគេឲ្យរួចផុតពីស្ថាននរក ?

៧ មើលចុះ ទ្រង់បានកែប្រែចិត្តរបស់គេ; មែនហើយ ទ្រង់បានដាស់ពួកគេ ឲ្យភ្ញាក់ពីដំណេកដ៏លង់លក់ ហើយគេក៏បានភ្ញាក់ឡើង ចំពោះព្រះ ។ មើលចុះ ពួកគេនៅកណ្ដាលសេចក្ដីងងឹតសូន្យសុង; ទោះជាយ៉ាងណាក៏ដោយ គង់តែព្រលឹងរបស់គេបានចែងចាំង ដោយពន្លឺនៃព្រះបន្ទូលដ៏អស់កល្បជានិច្ចដែរ; មែនហើយ ពួកគេត្រូវបានហ៊ុំព័ទ្ធ ដោយខ្សែចំណងទាំងឡាយនៃសេចក្ដីស្លាប់ និងច្រវាក់ នៃស្ថាននរក រីឯការបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច បានរង់ចាំពួកគេហើយ ។

៨ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសូមសួរអ្នកថា តើពួកគេត្រូវបំផ្លាញចោលហើយឬអី ? មើលចុះ ខ្ញុំសូម ប្រាប់អ្នកថា ទេ ពួកគេពុំត្រូវបំផ្លាញចោលទេ ។

៩ ហើយខ្ញុំសូមសួរទៀតថា តើខ្សែចំណងទាំងឡាយនៃសេចក្ដីស្លាប់បានដាច់ឬទេ និងច្រវាក់នៃស្ថាននរក ដែលបានហ៊ុំព័ទ្ធពួកគេ នោះ តើមានរបូតឬទេ ? ខ្ញុំសូមប្រាប់អ្នកថា បាទ ច្រវាក់ទាំងនោះត្រូវបានរបូតចេញ ហើយព្រលឹងពួកគេបានរីករាយ ហើយពួកគេបាន ច្រៀងនូវសេចក្ដីស្រឡាញ់ដែលប្រោសលោះ ។ ហើយខ្ញុំសូមប្រាប់អ្នកថា ពួកគេបានសង្គ្រោះហើយ ។

១០ ហើយឥឡូវនេះ ខ្ញុំសូមសួរអ្នកថា តើពួកគេបានសង្គ្រោះដោយលក្ខខ័ណ្ឌយ៉ាងណា ? មែនហើយ តើអាងទៅលើអ្វីដែលពួកគេ សង្ឃឹមថានឹងបានសង្គ្រោះ ? តើមកពីហេតុអ្វីបានជាពួកគេបានរួចពីចំណងទាំងឡាយនៃសេចក្ដីស្លាប់ មែនហើយ ព្រមទាំងពីច្រវាក់នៃ ស្ថាននរកផង ?

១១ មើលចុះ ខ្ញុំអាចប្រាប់អ្នកថា — តើពុំមែនឪពុកខ្ញុំអាលម៉ា បានជឿដល់ពាក្យសំដី ដែលបានប្រកាសចេញពីមាត់របស់អ័ប៊ីណាដៃ ទេឬអី ? ហើយតើលោកពុំមែនជា

---

៥ ១*ក* អាលម៉ា ៤:១៩.
*ខ* អាលម៉ា ៥:៦១.
៣ *ក* ស.ប. តែងតាំង, ការតែងតាំង.
*ខ* អាលម៉ា ៤:៤, ១៨, ២០.
*គ* ម៉ូសាយ ១៨:១៣; ៣ នីហ្វៃ ១១:២៥.
*ឃ* ម៉ូសាយ ១៨:៤; ៣ នីហ្វៃ ៥:១២.
៤ *ក* ម៉ូសាយ ២៣:១–៣.
៥ *ក* ម៉ូសាយ ២៣:៣៧–៣៩; ២៤:៨–១៥.
*ខ* ម៉ូសាយ ២៤:១៧.
៧ *ក* ម៉ូសាយ ១៥:៨.
*ខ* អាលម៉ា ១២:១១; គ. និង ស. ១៣៨:២៣.
១០ *ក* ស.ប. សេចក្ដីសង្គ្រោះ; ផែនការនៃសេចក្ដីប្រោសលោះ.
១១ *ក* ម៉ូសាយ ១៧:១–៤.

ព្យាការីដ៏បរិសុទ្ធទេឬអី ? តើលោកពុំបាននិយាយនូវព្រះបន្ទូល
ទាំងឡាយនៃព្រះ ហើយឪពុកខ្ញុំ អាលម៉ា បានជឿនូវព្រះបន្ទូល
ទាំងនោះទេឬ ?
១២ ហើយដោយសារសេចក្ដីជំនឿរបស់លោក ទើបមាន
[ក]ការផ្លាស់ប្ដូរដ៏ធំនៅក្នុងដួងចិត្តលោក ។ មើលចុះ ខ្ញុំសូមប្រាប់
អ្នកថា ទាំងអស់នេះគឺជារឿងពិត ។
១៣ ហើយមើលចុះ គាត់[ក]បានផ្សាយព្រះបន្ទូលទាំងនោះ ដល់
ពួកអយ្យកោរបស់អ្នក ហើយការផ្លាស់ប្ដូរដ៏ធំមួយបានកើតឡើង
នៅក្នុងដួងចិត្តរបស់ពួកគេ ហើយពួកគេបានបន្ទាបខ្លួន ហើយ
បានដាក់ទី[ខ]ទុកចិត្តរបស់គេទៅលើព្រះដ៏ពិត ហើយមាន[គ]ព្រះជន្ម
រស់នៅ ។ ហើយមើលចុះ ពួកគេមានចិត្តស្មោះត្រង់រហូតដល់
[ឃ]ទីបំផុត; ហេតុដូច្នេះហើយ ទើបពួកគេបានសង្គ្រោះ ។
១៤ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំ
ក្នុងសាសនាចក្រអើយ ខ្ញុំសូមសួរអ្នកថា តើអ្នករាល់គ្នា
បាន[ក]កើតមកពីព្រះ នៅក្នុងវិញ្ញាណហើយឬនៅ ? តើអ្នករាល់
គ្នាបានទទួលព្រះភ័ក្ត្ររបស់ទ្រង់ នៅក្នុង[ខ]ទឹកមុខរបស់អ្នកហើយ
ឬនៅ ? តើអ្នករាល់គ្នាបាន ស្គាល់ការផ្លាស់ប្ដូរដ៏ធំនេះ នៅក្នុង
ដួងចិត្តអ្នកហើយឬនៅ ?
១៥ តើអ្នករាល់គ្នាអនុវត្តសេចក្ដីជំនឿ ទៅលើការប្រោសលោះ
របស់ទ្រង់ ដែល[ក]បានបង្កើតអ្នកមកឬទេ ? តើអ្នករាល់គ្នាទន្ទឹង
ចាំ ដោយភ្នែកនៃសេចក្ដីជំនឿ ហើយមើលមករូបកាយខាង
សាច់ឈាមនេះថា នឹងបាន[ខ]ប្រោសឲ្យទៅជាអមតៈ ហើយឯការ
ពុករលួយនេះ នឹងបានប្រោសទៅជាឥតពុករលួយវិញ
ដើម្បីឈរចំពោះព្រះ ហើយទទួល[គ]ការជំនុំជំរះ តាមអំពើទាំង
ឡាយដែលខ្លួនបានប្រព្រឹត្ត កាល នៅជារូបកាយខាង
ឯសាច់ឈាមនៅឡើយឬ ?
១៦ ខ្ញុំសូមសួរអ្នកថា តើអ្នករាល់គ្នាអាចរមិលមើលខ្លួនឯងថា
អ្នករាល់គ្នាឮសម្លេងនៃព្រះអម្ចាស់ មានព្រះបន្ទូលទៅកាន់អ្នក
ក្នុងថ្ងៃ នោះថា៖ នែ៎ [ក]ពួកជនដ៏មានពរអើយ ចូរមករកយើងចុះ
ត្បិតមើលចុះ កិច្ចការទាំងឡាយរបស់អ្នករាល់គ្នា សុទ្ធសឹង
ជាកិច្ចការសុចរិត នៅលើផ្ទៃផែនដីនេះ ?
១៧ ឬក៏អ្នករាល់គ្នារមិលមើលខ្លួនឯងថា អ្នករាល់គ្នាអាច
កុហកដល់ព្រះអម្ចាស់ នៅក្នុង[ក]ថ្ងៃនោះថា — ឱព្រះ
អម្ចាស់អើយ កិច្ចការ របស់ពួកយើងខ្ញុំ សុទ្ធសឹងជាកិច្ចការ
សុចរិតនៅលើផ្ទៃផែនដីនេះ — ហើយថា ព្រះអង្គនឹង
ជួយសង្គ្រោះដល់អ្នកឬ ?
១៨ ឬក៏និយាយម្យ៉ាងទៀត តើអ្នករាល់គ្នា
អាចរមិលមើលខ្លួនឯងថា ត្រូវបាននាំទៅកណ្ដាលទីជំនុំជំរះនៃ
ព្រះ ដោយព្រលឹងរបស់អ្នក ពោរពេញទៅដោយទោស និង
ការសោកស្ដាយ ដោយ[ក]ចាំនូវអស់ទាំងទោសកំហុសទាំងប៉ុន្មាន
របស់ខ្លួន មែនហើយ ដោយមានការ ចងចាំដ៏ឥតខ្ចោះ នូវ
អំពើទុច្ចរិតរបស់ខ្លួនទាំងអស់ មែនហើយ គឺជាការចងចាំនូវ
ការទាស់នឹងព្រះបញ្ញត្តិទាំងឡាយនៃព្រះ ?
១៩ ខ្ញុំសូមសួរអ្នកថា តើអ្នករាល់គ្នាអាចសម្លឹងមើលទៅព្រះ
នៅក្នុងថ្ងៃនោះ ដោយចិត្តបរិសុទ្ធ និងបាតដៃស្អាតឬ ? ខ្ញុំសូម
សួរអ្នកថា តើអ្នកអាចសម្លឹងទៅលើ ដោយមាន[ក]ព្រះភ័ក្ត្ររបស់
ទ្រង់ឆ្លាក់លើមុខរបស់អ្នកឬ ?
២០ ខ្ញុំសូមសួរអ្នកថា តើអ្នកអាចគិតថានឹងបានសង្គ្រោះ
នៅពេលអ្នកបានបណ្ដោយខ្លួន [ក]ឲ្យធ្លាក់ទៅក្នុងឥទ្ធិពល
នៃអារក្សឬ ?
២១ ខ្ញុំសូមប្រាប់អ្នកថា ដល់ថ្ងៃនោះ អ្នករាល់គ្នានឹងដឹងថា
អ្នករាល់គ្នាពុំអាចបាន[ក]សង្គ្រោះឡើយ ត្បិតគ្មានអ្នកណាអាច
បានសង្គ្រោះ ឡើយ លើកលែងតែ[ខ]សំលៀកបំពាក់របស់អ្នក
នោះត្រូវបានជំរះឲ្យស; មែនហើយ សំលៀកបំពាក់អ្នក
នោះត្រូវតែធ្វើឲ្យ[គ]បរិសុទ្ធ រហូត ដល់បានជ្រះពីអស់ទាំងការ
ប្រឡាក់ តាមរយៈព្រះលោហិតនៃទ្រង់ ជាព្រះអង្គដែលពួក
អយ្យកោរបស់យើងធ្លាប់និយាយដល់នោះ ដែលនឹងយាងមក
សង្គ្រោះរាស្ត្ររបស់ទ្រង់ពីអំពើបាបទាំងឡាយរបស់គេ ។

១២ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
១៣ *ក* ម៉ូសាយ ១៨:៧.
*ខ* ស.ប. ទុកចិត្ត.
*គ* មរមន ៩:២៨;
គ. និង ស. ២០:១៩.
*ឃ* ស.ប. កាន់ខ្ជាប់.
១៤ *ក* ម៉ូសាយ ២៧:២៤–២៧;
អាលម៉ា ២២:១៥.
ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ខ* រ៉ូម ៨:១១–១៧; ម៉ូសាយ ៥:២;
ម៉ូសេ ៦:៦៥.
ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
១៥ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
១៦ *ក* ម៉ាថាយ ២៥:៣១–៤៦.
១៧ *ក* ៣ នីហ្វៃ ១៤:២១–២៣.
១៨ *ក* អេសេ. ២០:៤៣; ២ នីហ្វៃ ៩:១៤;
ម៉ូសាយ ៣:២៥;
អាលម៉ា ១១:៤៣.
១៩ *ក* ១ យ៉ូហាន ៣:១–៣.
២០ *ក* ម៉ូសាយ ២:៣២.
២១ *ក* ស.ប. សេចក្ដីសង្គ្រោះ.
*ខ* ១ នីហ្វៃ ១២:១០;
អាលម៉ា ១៣:១១–១៣;
៣ នីហ្វៃ ២៧:១៩–២០.
*គ* ស.ប. សុទ្ធ, សុទ្ធសាធ.

២២ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសូមសួរអ្នកថា តើអ្នករាល់គ្នានឹងចាប់អារម្មណ៍យ៉ាងណាដែរ បើសិនជាអ្នក រាល់គ្នាឈរនៅខាងមុខវេទិកាជំនុំជំរះនៃព្រះ ដោយមានសំលៀកបំពាក់ប្រឡាក់ដោយឈាម និងសេចក្ដីស្មោកគ្រោកគ្រប់បែបយ៉ាង ? មើលចុះ តើការណ៍នេះនឹងធ្វើទីបន្ទាល់អ្វីខ្លះទាស់នឹងរូបអ្នក ?

២៣ មើលចុះ តើការណ៍ទាំងនេះពុំធ្វើជាទីបន្ទាល់ថា អ្នករាល់គ្នាជាឃាតក មែនហើយ ហើយថា អ្នករាល់គ្នាមានទោស ដោយ អំពើទុច្ចរិតគ្រប់យ៉ាងទេឬ ?

២៤ មើលចុះ ឱបងប្អូនរបស់ខ្ញុំអើយ តើអ្នករាល់គ្នាគិតស្មានថា ជនបែបនេះនឹងអាចមានទីអង្គុយនៅក្នុងនគរនៃព្រះ ជាមួយអ័ប្រាហាំ ជាមួយអ៊ីសាក និងជាមួយយ៉ាកុប ព្រមទាំងជាមួយពួកព្យាការីដ៏បរិសុទ្ធទាំងអស់ផង ដែលមានសំលៀកបំពាក់ដ៏ជ្រះស្អាត ហើយឥតប្រឡាក់, បរិសុទ្ធ ហើយសផងនោះឬ ?

២៥ ខ្ញុំសូមប្រាប់អ្នកថាៈ ទេ; លើកលែងតែអ្នករាល់គ្នាថា ព្រះដែលបង្កើតយើងមក ទ្រង់ជាជនភូតកុហកចាប់ពីដំបូងវិញ ឬក៏គិត ស្មានថា ព្រះអង្គជាជនភូតកុហកពីដើមដំបូងមក នោះអ្នករាល់គ្នាពុំអាចគិតស្មានថា ជនបែបនេះអាចមានទីកន្លែងនៅក្នុងនគរ ស្ថានសួគ៌បានឡើយ; ប៉ុន្តែពួកគេនឹងត្រូវបណ្ដេញចេញ ត្បិតពួកគេជាកូនចៅនៃនគរអារក្សវិញ ។

២៦ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសូមប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នាបានស្គាល់ការផ្លាស់ប្ដូរនៅ ក្នុងដួងចិត្តអ្នក ហើយបើសិនជាអ្នករាល់គ្នាបានចាប់អារម្មណ៍ចង់ច្រៀង នូវចម្រៀងនៃសេចក្ដីស្រឡាញ់ដែលប្រោសលោះ ខ្ញុំសូមសួរថា តើអ្នករាល់គ្នាអាចចាប់អារម្មណ៍យ៉ាងនេះ ឥឡូវនេះទេ ?

២៧ តើអ្នករាល់គ្នាបានដើរ ដោយកាន់ខ្លួនអ្នកថាជាគ្មានទោសនៅចំពោះព្រះឬ ? តើអ្នករាល់គ្នាអាចនិយាយនៅក្នុងចិត្តអ្នក បើសិនជាអ្នករាល់គ្នាត្រូវបានហៅឲ្យទៅស្លាប់ នៅក្នុងពេលនេះថា តើអ្នករាល់គ្នាបានបន្ទាបខ្លួនគ្រប់គ្រាន់ហើយឬនៅ ? តើសំលៀក បំពាក់របស់អ្នកត្រូវបានជំរះ ហើយត្រូវបានធ្វើឲ្យស តាមរយៈព្រះលោហិតនៃព្រះគ្រីស្ទ ដែលទ្រង់នឹងយាងមកសង្គ្រោះរាស្ត្ររបស់ ទ្រង់ពីអំពើបាបទាំងឡាយរបស់គេហើយឬ ?

២៨ មើលចុះ តើអ្នករាល់គ្នាបានរលាស់ចោល នូវការឆ្មើងឆ្មៃរបស់អ្នកហើយឬ ? ខ្ញុំសូមប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នាពុំទាន់បាន រលាស់ចោលទេ នោះអ្នករាល់គ្នាពុំទាន់បានរៀបចំខ្លួន ដើម្បីទៅជួបនឹងព្រះឡើយ ។ មើលចុះ អ្នករាល់គ្នាត្រូវតែរៀបចំឲ្យបានរហ័ស ឡើង; ត្បិតនគរស្ថានសួគ៌នៅជិតដែបង្ហើយ ហើយជនបែបនេះ នឹងពុំមានជីវិតដ៏នៅអស់កល្បជានិច្ចឡើយ ។

២៩ មើលចុះ ខ្ញុំនិយាយថា តើមានអ្នកណាម្នាក់ នៅក្នុងចំណោមអ្នករាល់គ្នា ដែលពុំទាន់ចោលចិត្តច្រណែន ? ខ្ញុំសូមប្រាប់អ្នកថា ជនបែបនេះពុំទាន់ប្រុងប្រៀបខ្លួនទេ; ហើយខ្ញុំចង់ឲ្យជននោះ ប្រុងប្រៀបឲ្យបានរហ័សឡើង ព្រោះពេលនោះនៅជិតដែបង្ហើយ ហើយជននោះពុំបានដឹងថា ពេលនោះនឹងមកដល់កាលណាទេ ហើយជនបែបនេះ នឹងពុំបានចាត់ទុកថាគ្មានទោសឡើយ ។

៣០ ហើយមួយទៀត ខ្ញុំសូមប្រាប់អ្នកថា តើមានអ្នកណាម្នាក់នៅក្នុងចំណោមអ្នករាល់គ្នា ដែលបានចំអកឡកឡឺយដល់បងប្អូនខ្លួន ឬក៏បានគរការបៀតបៀនទៅលើបងប្អូនខ្លួនឬទេ ?

៣១ វេទនាដល់ជនបែបនេះ ព្រោះជននេះពុំបានប្រុងប្រៀបខ្លួនទេ ឯពេលវេលានៅជិតដែបង្ហើយថា ជននោះត្រូវតែប្រែចិត្ត បើពុំនោះសោតទេ គេពុំអាចបានសង្គ្រោះឡើយ !

៣២ មែនហើយ គឺវេទនាដល់អស់អ្នកដែលប្រព្រឹត្តអំពើទុច្ចរិត; ចូរប្រែចិត្តចុះ ចូរប្រែចិត្តចុះ ត្បិតព្រះអម្ចាស់ ដ៏ជាព្រះទ្រង់មានបន្ទូលថាដូច្នោះ !

៣៣ មើលចុះ ទ្រង់បានអញ្ជើញមនុស្សលោកទាំងអស់

២២ *ក* អេសាយ ៥៩:៣.
*ខ* ស.ប. ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក.
២៣ *ក* អេសាយ ៥៩:១២.
២៤ *ក* លូកា ១៣:២៨.
២៥ *ក* ២ នីហ្វៃ ៩:៩.
២៦ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
*ខ* អាលម៉ា ២៦:១៣.
*គ* ម៉ូសាយ ៤:១២;
គ. និង ស. ២០:៣១–៣៤.
២៧ *ក* ស.ប. ការរាប់ជាសុចរិត, រាប់ជាសុចរិត.
*ខ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*គ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
២៨ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
២៩ *ក* ស.ប. ច្រណែន.
៣០ *ក* ស.ប. ការនិយាយអាក្រក់.
៣២ *ក* ទំនុក. ៥:៥.
៣៣ *ក* អាលម៉ា ១៩:៣៦;
៣ នីហ្វៃ ១៨:២៥.

ក្បិត[ខ]ព្រះពាហុនៃសេចក្ដីមេត្តាករុណាបានលាតសន្ធឹងមករកគេ ហើយទ្រង់ មានព្រះបន្ទូលថា៖ ចូរប្រែចិត្តចុះ នោះយើងនឹងទទួលអ្នក ។

៣៤ មែនហើយ ទ្រង់មានព្រះបន្ទូលថា៖ ចូរ[ក]មករកយើងចុះ ហើយអ្នករាល់គ្នានឹងបានទទួលទាននូវ[ខ]ផ្លែនៃដើមជីវិត មែនហើយ អ្នករាល់គ្នានឹងបានទទួលទាន ហើយផឹក នូវ[គ]នំបុ័ង និង[ឃ]ទឹកនៃជីវិតតាមចិត្ត;

៣៥ មែនហើយ ចូរមករកយើង ហើយនាំមកនូវកិច្ចការទាំងឡាយនៃសេចក្ដីសុចរិតចុះ នោះអ្នករាល់គ្នានឹងពុំត្រូវកាប់រំលំ ហើយបោះចោលទៅក្នុងភ្លើងឡើយ —

៣៦ ក្បិតមើលចុះ ពេលវេលានៅជិតដែលបង្ហើយថា អស់អ្នកណាដែលពុំបាន[ក]នាំមកនូវផលល្អ ឬក៏អស់អ្នកណាដែលពុំបានធ្វើកិច្ចការ ទាំងឡាយនៃសេចក្ដីសុចរិត ជននោះហើយដែលនឹងមានហេតុទួញសោក ។

៣៧ ឱអ្នករាល់គ្នា ជាអ្នកដែលប្រព្រឹត្តអំពើទុច្ចរិតអើយ; អ្នករាល់គ្នាដែលអួតខ្លួនចំពោះវត្ថុទាំងឡាយដែល[ក]ឥតប្រយោជន៍នៃលោកិយ អ្នករាល់គ្នាដែលអះអាងថា ខ្លួនដឹងនូវផ្លូវទាំងឡាយនៃសេចក្ដីសុចរិត ប៉ុន្តែបាន[ខ]ដើរវង្វេងផ្លូវ [គ]បីដូចជាចៀមដែលគ្មានអ្នកគង្វាល ទោះបី [ឃ]អ្នកគង្វាលបានស្រែកហៅ ហើយនៅតែស្រែកហៅក៏ដោយ គង់តែអ្នករាល់គ្នា[ង]ពុំព្រមស្ដាប់តាមសម្លេងលោកដែរ !

៣៨ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា [ក]អ្នកគង្វាលល្អនឹងស្រែកហៅអ្នក; មែនហើយ គឺដោយនូវឈ្មោះរបស់លោកផ្ទាល់ដែលលោកនឹង ហៅអ្នក គឺជាព្រះនាមនៃព្រះគ្រីស្ទ; ហើយបើសិនជាអ្នករាល់គ្នាពុំ[ខ]ប្រុងស្ដាប់តាមសម្លេងនៃអ្នកគង្វាល[គ]ល្អ ចំពោះ[ឃ]ឈ្មោះដែលអ្នករាល់គ្នា នឹងត្រូវបានហៅនោះទេ មើលចុះ អ្នករាល់គ្នាពុំមែនជាចៀមនៃអ្នកគង្វាលល្អឡើយ ។

៣៩ ហើយឥឡូវនេះ បើសិនជាអ្នករាល់គ្នាពុំមែនជាចៀមនៃអ្នកគង្វាលល្អទេ តើអ្នករាល់គ្នានៅក្នុង[ក]ក្រោលណា? មើលចុះ ខ្ញុំសូម ប្រាប់អ្នកថា [ខ]អារក្សគឺជាអ្នកគង្វាលរបស់អ្នកវិញ ហើយអ្នករាល់គ្នានៅក្នុងក្រោលរបស់វា; ហើយឥឡូវនេះ តើអ្នកណាអាចបដិសេធ ការណ៍នេះបានឬ ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា អស់អ្នកណាដែលបដិសេធរឿងនេះ គឺជា[គ]ជនភូតកុហក ហើយជា[ឃ]កូនអារក្សវិញ ។

៤០ ក្បិតខ្ញុំសូមប្រាប់អ្នកថា អ្វីក៏ដោយដែល[ក]ល្អចេញមកពីព្រះ ហើយអ្វីក៏ដោយដែលអាក្រក់ចេញមកពីអារក្ស ។

៤១ ហេតុដូច្នេះហើយ បើសិនជាមនុស្សណាម្នាក់ដែលនាំមកនូវកិច្ចការទាំងឡាយដែល[ក]ល្អ គេប្រុងស្ដាប់តាមសម្លេងនៃអ្នកគង្វាលល្អ ហើយគេនឹងដើរតាមលោក; ប៉ុន្តែអស់អ្នកណាដែលនាំមកនូវកិច្ចការទាំងឡាយដែលអាក្រក់ ជននោះក្លាយទៅជា[ខ]កូនអារក្សវិញ ព្រោះគេប្រុងស្ដាប់តាមសម្លេងរបស់វា ហើយដើរតាមវាផង ។

៤២ ហើយអស់អ្នកណាដែលបានធ្វើយ៉ាងនេះ ត្រូវតែទទួល[ក]ឈ្នួលពីវា; ហេតុដូច្នេះហើយ ឯ[ខ]ឈ្នួលនៃជននោះ គឺសេចក្ដីស្លាប់ គឺចំពោះអ្វីៗដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ដោយ[គ]ស្លាប់ចំពោះការល្អគ្រប់យ៉ាង ។

៤៣ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាស្ដាប់ខ្ញុំ ក្បិតខ្ញុំនិយាយនៅក្នុងថាមពលនៃព្រលឹងរបស់ខ្ញុំ; ក្បិតមើលចុះ ខ្ញុំបាននិយាយទៅកាន់អ្នករាល់

៣៣ *ខ* យ៉ាកុប ៦:៥; ៣ នីហ្វៃ ៩:១៤.
៣៤ *ក* ២ នីហ្វៃ ២៦:២៤–២៨; ៣ នីហ្វៃ ៩:១៣–១៤.
*ខ* ១ នីហ្វៃ ៨:១១; ១៥:៣៦.
*គ* ស.ប. នំបុ័ងជីវិត.
*ឃ* ២ នីហ្វៃ ៩:៥០–៥១; អាលម៉ា ៤២:២៧.
៣៦ *ក* ម៉ាថាយ ៣:១០; ៧:១៥–២០; ៣ នីហ្វៃ ១៤:១៩; គ. និង ស. ៩៧:៧.
៣៧ *ក* ស.ប. ឥតប្រយោជន៍, ការឥតប្រយោជន៍.
*ខ* ២ នីហ្វៃ ១២:៥; ២៨:១៤; ម៉ូសាយ ១៤:៦.
*គ* ម៉ាថាយ ៩:៣៦.
*ឃ* សុភា. ១:២៤–២៧; អេសាយ ៦៥:១២.
*ង* យេរេ. ២៦:៤–៥; អាលម៉ា ១០:៦.
៣៨ *ក* ស.ប. អ្នកគង្វាលល្អ.
*ខ* លេវី. ២៦:១៤–២០; គ. និង ស. ១០១:៧.
*គ* ៣ នីហ្វៃ ១៥:២៤; ១៨:៣១.
*ឃ* ម៉ូសាយ ៥:៨; អាលម៉ា ៣៤:៣៨.
៣៩ *ក* ម៉ាថាយ ៦:២៤; លូកា ១៦:១៣.
*ខ* ម៉ូសាយ ៥:១០. ស.ប. អារក្ស.
*គ* ១ យ៉ូហាន ២:២២.
*ឃ* ២ នីហ្វៃ ៩:៩.
៤០ *ក* អេមេណៃ ១:២៥; អេធើរ ៤:១២; ម៉ូរ៉ូណៃ ៧:១២, ១៥–១៧.
៤១ *ក* ៣ នីហ្វៃ ១៤:១៦–២០. ស.ប. កិច្ចការ.
*ខ* ម៉ូសាយ ១៦:៣–៥; អាលម៉ា ១១:២៣.
៤២ *ក* អាលម៉ា ៣:២៦–២៧; គ. និង ស. ២៩:៤៥.
*ខ* រ៉ូម ៦:២៣.
*គ* ហេលេ. ១៤:១៦–១៨. ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.

គ្នាយ៉ាងជាក់ច្បាស់ ដើម្បីកុំឲ្យអ្នករាល់គ្នាអាចភាន់ច្រឡំ ឬក៏ថា ខ្ញុំបាននិយាយនេះ តាម ព្រះបញ្ញត្តិទាំងឡាយនៃព្រះវិញ ។

៤៤ ព្រោះខ្ញុំត្រូវបានហៅឲ្យនិយាយបែបនេះ តាមរបៀបដ៏បរិសុទ្ធនៃព្រះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ; មែនហើយ គឺខ្ញុំត្រូវបាន បញ្ជាឲ្យឈរឡើង ហើយធ្វើបន្ទាល់ដល់ប្រជាជននេះ នូវអ្វីៗដែលពួកអយ្យកោរបស់យើងបាននិយាយ អំពីអ្វីៗដែលនឹងកើតឡើង ។

៤៥ ហើយនេះ នៅពុំទាន់អស់នៅឡើយទេ ។ តើអ្នករាល់គ្នាគិតស្មានថា ខ្ញុំដឹងរឿងទាំងនេះ ដោយខ្លួនឯងឬអី ? មើលចុះ ខ្ញុំសូមធ្វើបន្ទាល់ដល់អ្នករាល់គ្នាថា ខ្ញុំដឹងរឿងដែលខ្ញុំបាននិយាយទាំងអម្បាលម៉ាននេះថាជារឿងពិត ។ ហើយតើអ្នករាល់គ្នាគិត ស្មានថា ខ្ញុំដឹងរឿងទាំងនោះយ៉ាងប្រាកដដូចម្ដេចដែរ ?

៤៦ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា រឿងទាំងនោះគឺព្រះវិញ្ញាណបរិសុទ្ធនៃព្រះទ្រង់បានប្រាប់ដល់ខ្ញុំ ។ មើលចុះ ខ្ញុំបានតមអាហារ ហើយបានអធិស្ឋានជាច្រើនថ្ងៃ ដើម្បីខ្ញុំអាចដឹងនូវរឿងទាំងនេះដោយខ្លួនខ្ញុំ ។ ហើយឥឡូវនេះ ខ្ញុំដឹងរឿងទាំងនោះដោយខ្លួនខ្ញុំថាជារឿងពិត; ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានសម្ដែងប្រាប់ខ្ញុំ ដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់; ហើយនេះគឺជាវិញ្ញាណនៃ វិវរណៈ ដែលមាននៅក្នុងខ្លួនខ្ញុំ ។

៤៧ ហើយម៉្យាងទៀត ខ្ញុំសូមប្រាប់អ្នកថា វិញ្ញាណនេះទើបតែសម្ដែងប្រាប់ដល់ខ្ញុំថា ពាក្យទាំងឡាយដែលពួកអយ្យកោយើងបាន និយាយ គឺជាពាក្យពិត គឺដូចជាវិញ្ញាណនៃការព្យាករណ៍ដែលមាននៅក្នុងខ្លួនខ្ញុំ ក៏បានបង្ហាញដោយសារការបើកសម្ដែងនៃព្រះ វិញ្ញាណនៃព្រះដែរ ។

៤៨ ខ្ញុំសូមប្រាប់អ្នកថា ខ្ញុំដឹងដោយខ្លួនខ្ញុំថា អ្វីក៏ដោយដែលខ្ញុំនឹងប្រាប់អ្នក អំពីអ្វីដែលនឹងកើតឡើង នោះគឺជារឿងពិតដែរ; ហើយខ្ញុំ សូមប្រាប់អ្នកថា ខ្ញុំដឹងថា ព្រះយេស៊ូវគ្រីស្ទនឹងយាងមក មែនហើយ ព្រះរាជបុត្រា ដែលជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា ពោរពេញទៅដោយព្រះគុណ និងសេចក្ដីមេត្តាករុណា និងសេចក្ដីពិត ។ ហើយមើលចុះ គឺព្រះអង្គនេះហើយដែលនឹងយាងមក ដើម្បីយកអំពើបាបទាំងឡាយនៃមនុស្សលោកមែនហើយ គឺអំពើបាបទាំងឡាយនៃមនុស្សគ្រប់រូប ដែលជឿយ៉ាងខ្ជាប់ខ្ជួនដល់ព្រះនាម របស់ទ្រង់ ។

៤៩ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា នេះគឺតំណែងដែលខ្ញុំបានទទួល មែនហើយ គឺដើម្បីផ្សាយប្រាប់បងប្អូនជាទីស្រឡាញ់របស់ខ្ញុំ មែនហើយ និងមនុស្សគ្រប់រូប ដែលរស់នៅលើផែនដីនេះ; មែនហើយ គឺដើម្បីផ្សាយប្រាប់ដល់មនុស្សទាំងអស់ ទាំងចាស់ទាំងក្មេង ទាំងបាវបំរើគេទាំងអ្នកសេរី; មែនហើយ ខ្ញុំសូមប្រាប់ដល់មនុស្សចាស់ និងមនុស្សវ័យកណ្ដាល និងជំនាន់ដែលកំពុងពេញវ័យផង; មែនហើយ ដើម្បីស្រែកប្រាប់ពួកគេថា ពួកគេត្រូវតែប្រែចិត្ត ហើយកើតម្ដងទៀត ។

៥០ មែនហើយ ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ចូរប្រែចិត្តចុះ ឱអស់អ្នកដែលនៅចុងផែនដីអើយ ត្បិតនគរស្ថានសួគ៌ នៅជិតដៃបង្កើយ; មែនហើយ ព្រះរាជបុត្រានៃព្រះទ្រង់នឹងយាងមកក្នុងសិរីល្អរបស់ទ្រង់ ក្នុងឥទ្ធិឫទ្ធិ ឫទ្ធានុភាពព្រះចេស្ដា និងក្នុង អំណាចរបស់ទ្រង់ ។ មែនហើយ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមប្រាប់អ្នកថា ព្រះវិញ្ញាណទ្រង់មានព្រះបន្ទូលថា៖ មើលន៏ សិរីល្អនៃមហាក្សត្រនៃអស់ទាំងផែនដី និងមហាក្សត្រនៃស្ថានសួគ៌ផង នឹងមកចែងចាំងជាឆាប់ៗ ក្នុងចំណោមកូនចៅមនុស្ស លោកទាំងអស់ ។

៥១ ហើយព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលមកកាន់ខ្ញុំ មែនហើយ ទ្រង់បានស្រែកប្រាប់ខ្ញុំ ដោយព្រះសូរសៀងដ៏ឥទ្ធិឫទ្ធិថា៖ ចូរអ្នកធ្វើ ដំណើរទៅមុខ ហើយប្រាប់ប្រជាជនទាំងនេះថា៖ ចូរប្រែចិត្តចុះ ត្បិតលើកលែងតែអ្នករាល់គ្នាប្រែចិត្ត នោះអ្នករាល់គ្នានឹងពុំអាចបាន នគរស្ថានសួគ៌ជាមរតកឡើយ ។

៥២ ហើយមួយទៀត ខ្ញុំសូមប្រាប់អ្នកថា ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលថា៖ មើលចុះ ពូថៅបានទុកនៅក្បែរគល់ឈើ; ហេតុដូច្នេះ ហើយ ដើមណាដែលពុំផ្ដល់នូវផ្លែល្អ នោះនឹងត្រូវកាប់រំលំ ហើយបោះចោលទៅក្នុងភ្លើង មែនហើយ គឺជាភ្លើងមួយដែលពុំចេះស្រូប គឺជាភ្លើងដែលពន្លត់មិនបាន ។ មើលចុះ ហើយចូរចងចាំថា ព្រះដ៏បរិសុទ្ធទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៤៤ *ក* អាលម៉ា ១៣:៦.
៤៥ *ក* ស.ប. ទីបន្ទាល់.
៤៦ *ក* ១ កូរិន. ២:៩–១៦.
*ខ* ស.ប. តម, តំណម.
*គ* ស.ប. វិវរណៈ.
៤៩ *ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ; បព្វជិតភាព.
*ខ* ស.ប. កើតម្ដងទៀត, កើតពីព្រះ.
៥០ *ក* ស.ប. សិរីល្អ; ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ទំនុក. ២៤; ម៉ាថាយ ២:២; លូកា ២៣:២; ២ នីហ្វៃ ១០:១៤; គ. និង ស. ៣៨:២១–២២; ១២៨:២២–២៣; ម៉ូសេ ៧:៥៣.
ស.ប. ព្រះយេស៊ូវគ្រីស្ទ; នគរព្រះ ឬនគរស្ថានសួគ៌.
៥១ *ក* ស.ប. ស្ថានសួគ៌.
៥២ *ក* លូកា ៣:៩; គ. និង ស. ៩៧:៧.
*ខ* យ៉ាកុប ៥:៤៦; ៦:៧; ៣ នីហ្វៃ ២៧:១១–១២.

៥៣ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមសួរគ្នាថា តើអ្នកអាចទ្រាំទ្រនឹងពាក្យទាំងនេះបានឬ; មែនហើយ តើអ្នករាល់គ្នាអាចទុករឿងទាំងនេះមួយអន្លើ ហើយ [ក]ជាន់ឈ្លីព្រះដ៏បរិសុទ្ធ នៅខាងក្រោមជើងខ្លួនបានឬ; មែនហើយ តើអ្នករាល់គ្នាអាច អួតខ្លួន ដោយនូវការ[ខ]ឆ្មើងឆ្មៃក្នុងចិត្តបានឬ; មែនហើយ តើអ្នករាល់គ្នានៅតែប្រឹងពាក់នូវប្រដាប់ស្លៀកពាក់[គ]ដ៏មានតម្លៃតទៅ ហើយភ្ជាប់ ចិត្តអ្នកទៅលើ[ឃ]វត្ថុទាំងឡាយដែលឥតប្រយោជន៍នៃលោកិយ ហើយទៅលើទ្រព្យសម្បត្តិរបស់ខ្លួនឬ ?

៥៤ មែនហើយ តើអ្នករាល់គ្នានៅតែប្រឹងស្មានថា ខ្លួនគ្រាន់បើជាងអ្នកឯទៀតឬ; មែនហើយ តើអ្នករាល់គ្នានៅតែប្រឹងក្នុងការ បៀតបៀនបងប្អូនរបស់ខ្លួន ដែលបានបន្ទាបខ្លួន ហើយដើរតាមរបៀបដ៏បរិសុទ្ធនៃព្រះ ដោយហេតុនេះហើយ ដែលពួកគេត្រូវបាននាំ មកក្នុងសាសនាចក្រនេះ គឺដោយបាន[ក]ញែកជាបរិសុទ្ធ ដោយព្រះវិញ្ញាណបរិសុទ្ធ នោះគេបាននាំមកនូវកិច្ចការទាំងឡាយ ដែល គ្រប់គ្រាន់ដល់ការប្រែចិត្ត —

៥៥ មែនហើយ តើអ្នករាល់គ្នានៅតែរឹងរូស បែរខ្នង[ក]ដាក់អ្នកក្រីក្រ និងអ្នកខ្វះខាត ហើយឱបក្រសោបទ្រព្យសម្បត្តិរបស់ខ្លួន មិនឲ្យ ធ្លាក់ដល់អ្នកទាំងនោះឬអី ?

៥៦ ហើយជាទីបញ្ចប់ អស់អ្នកដែលប្រឹងនៅក្នុងអំពើទុច្ចរិត ខ្ញុំសូមប្រាប់អ្នកថា ពួកគេនេះហើយដែលនឹងត្រូវកាប់រំលំ ហើយបោះ ចោលទៅក្នុងភ្លើង លើកលែងតែពួកគេប្រែចិត្តឲ្យបានទាន់រហ័ស ។

៥៧ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា៖ អស់អ្នកណាដែលប្រាថ្នាចង់ធ្វើតាមសម្លេងនៃ[ក]អ្នកគង្វាលល្អ [ខ]ចូរអ្នករាល់គ្នាចេញពីពួកទុច្ចរិត មក ហើយញែកខ្លួន ហើយចូរកុំប៉ះពាល់ដល់វត្ថុទាំងឡាយដែលឥតស្អាតរបស់[គ]ពួកនោះឡើយ; ហើយមើលចុះ ឈ្មោះរបស់ពួកនោះនឹង ត្រូវលុបចេញ ដើម្បីកុំឲ្យឈ្មោះរបស់ពួកទុច្ចរិតត្រូវបានរាប់ក្នុងចំណោមឈ្មោះនៃពួកសុចរិតឡើយ ដើម្បីឲ្យព្រះបន្ទូលនៃព្រះបានបំពេញ ដែលមានព្រះបន្ទូលថា៖ ឈ្មោះនៃពួកទុច្ចរិតនឹងពុំត្រូវលាយឡំជាមួយនឹងឈ្មោះនៃរាស្ត្ររបស់យើងឡើយ ។

៥៨ ត្បិតឈ្មោះនៃពួកសុចរិត នឹងត្រូវបានកត់នៅក្នុង[ក]សៀវភៅជីវិត ហើយយើងនឹងប្រទានដល់ពួកគេ នូវមរតកឲ្យនៅខាងស្ដាំដៃ របស់យើង ។ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ តើអ្នករាល់គ្នាអាចនិយាយអ្វីទាស់នឹងការណ៍នេះបានឬ ? ខ្ញុំសូម ប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នានិយាយទាស់នឹងព្រះបន្ទូលទាំងនេះ ក៏មិនជាការណ៍អ្វីដែរ ត្បិតព្រះបន្ទូលនៃព្រះត្រូវតែបានបំពេញ ។

៥៩ ត្បិតនៅក្នុងចំណោមអ្នករាល់គ្នា តើមានអ្នកគង្វាលណាមួយ ដែលមានចៀមច្រើន ហើយពុំបានមើលចៀមទាំងនោះ ដើម្បីកុំឲ្យ ចចកចូលមកស៊ីចៀមរបស់ខ្លួន ? ហើយមើលចុះ បើសិនជាចចកណាចូលមកក្នុងហ្វូងចៀមខ្លួន តើអ្នកគង្វាលពុំដេញវាចេញទេឬអី ? មែនហើយ ទីបំផុត បើសិនជាអ្នកនោះអាចធ្វើបាន នោះគាត់នឹងបំផ្លាញចចកនោះចោល ។

៦០ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា អ្នកគង្វាលល្អនឹងហៅរកអ្នក; ហើយបើសិនជាអ្នកស្ដាប់តាមសម្លេងលោក នោះលោកនឹង នាំអ្នកចូលក្នុងក្រោលរបស់លោក ហើយអ្នករាល់គ្នាគឺជាចៀមរបស់លោក; ហើយលោកនឹងបញ្ជាអ្នកថា អ្នកមិនត្រូវទ្រាំឲ្យចចកល្មោភ ស៊ី ចូលមកក្នុងចំណោមអ្នករាល់គ្នាឡើយ ដើម្បីកុំឲ្យអ្នករាល់គ្នាត្រូវបំផ្លាញបង់ ។

៦១ ហើយឥឡូវនេះ ខ្ញុំ អាលម៉ា សូមបញ្ជាដល់អ្នក ក្នុង[ក]ភាសារបស់ព្រះអង្គ ដែលបានបញ្ជាដល់ខ្ញុំ ដើម្បីឲ្យអ្នករាល់គ្នាប្រព្រឹត្ត តាមពាក្យ ដែលខ្ញុំបាននិយាយទៅកាន់អ្នក ។

៦២ ខ្ញុំនិយាយជាការបញ្ជាដល់អ្នកដែលនៅក្នុងសាសនាចក្រ; ហើយដល់អស់អ្នកណាដែលពុំនៅក្នុងសាសនាចក្រនេះទេ នោះខ្ញុំនិយាយជាការអញ្ជើញថា៖ ចូរមក ហើយទទួលបុណ្យជ្រមុជទឹកចំពោះការប្រែចិត្តចុះ ដើម្បីឲ្យអ្នករាល់គ្នាអាចបានទៅជាពួកអ្នក [ក]ទទួលទាននូវផ្លែនៃដើមជីវិតដែរ ៕

## ជំពូកទី ៦

*សាសនាចក្រនៅដែនដីសារ៉ាហិមឡា ត្រូវបានជំរះឲ្យស្អាត*

៥៣ *ក* ១ នីហ្វៃ ១៩:៧.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*គ* ២ នីហ្វៃ ២៨:១១–១៤;
មរមន ៨:៣៦–៣៩.
*ឃ* ទំនុក. ៦២:១០;
គ. និង ស. ៥៦:១៦–១៨.
៥៤ *ក* ស.ប. ការញែកជាបរិសុទ្ធ.
៥៥ *ក* ទំនុក. ១០៩:១៥–១៦;
យ៉ាកុប ២:១៧;
ហេលេ. ៦:៣៩–៤០.
៥៧ *ក* ស.ប. អ្នកគង្វាលល្អ.
*ខ* អែសរ៉ា ៦:២១; ៩:១;
នេហេ. ៩:២; ២ ថែស្សា. ៣:៦;
គ. និង ស. ១៣៣:៥, ១៤.
*គ* ចោទិ. ២៩:២០;
ម៉ូរ៉ូណៃ ៦:៧;
គ. និង ស. ២០:៨.
៥៨ *ក* ស.ប. សៀវភៅជីវិត.
៦១ *ក* អាលម៉ា ៥:៤៤.
៦២ *ក* ១ នីហ្វៃ ៨:១០; ១១:២១–២៣.

*ហើយបានរៀបចំឲ្យមានរបៀបរៀបរយ — អាលម៉ាធ្វើដំណើរទៅក្រុង គេឌាន ដើម្បីផ្សាយសាសនា ។ ប្រមាណជាឆ្នាំ ៨៣ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាលម៉ា
បានបញ្ចប់នូវការនិយាយទៅកាន់ប្រជាជននៅក្នុងសាសនាចក្រ
ដែលត្រូវបានតាំងឡើងនៅទីក្រុងសារ៉ាហិមឡាហើយ នោះលោក
[ក]បានតែងតាំងពួកសង្ឃ និង[ខ]ពួកអែលឌើរ ដោយការដាក់[គ]ដៃ
របស់ លោក តាមរបៀបនៃព្រះ ដើម្បីឲ្យត្រួតត្រា ហើយ
[ឃ]មើលគន់លើសាសនាចក្រ ។
២ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែល
មិននៅក្នុងសាសនាចក្រ ដែលបានប្រែចិត្តពីអំពើបាបទាំង
ឡាយរបស់ខ្លួន នោះបានទទួល[ក]បុណ្យជ្រមុជទឹក ចំពោះការប្រែ
ចិត្ត ហើយបានទទួលឲ្យចូលរួមក្នុងសាសនាចក្រ ។
៣ ហើយហេតុការណ៍បានកើតឡើងដែរថា អស់អ្នកណា
ដែលនៅក្នុងសាសនាចក្រ តែពុំបាន[ក]ប្រែចិត្តចំពោះអំពើទុច្ចរិត
របស់ខ្លួន ហើយពុំបន្ទាបខ្លួនចំពោះព្រះទេ — គឺខ្ញុំនិយាយពីពួក
អ្នកដែលលើកខ្លួនឡើង ក្នុង[ខ]ការឆ្មើងឆ្មៃនៃចិត្តរបស់ខ្លួន —
គឺអ្នកអស់ទាំងនោះ ហើយដែលត្រូវបានបដិសេធ ហើយឈ្មោះ
របស់គេត្រូវបាន[គ]លុបចោល ដើម្បីកុំឲ្យឈ្មោះគេត្រូវបានរាប់ក្នុង
ចំណោមពួកអ្នកដែលសុចរិត ឡើយ ។
៤ ហើយពួកគេបានចាប់ផ្ដើមតាំងរបៀបរៀបរយនៅក្នុង
សាសនាចក្រ នៅក្នុងទីក្រុងសារ៉ាហិមឡា បែបដូច្នោះហើយ ។
៥ ឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាយល់ថា ព្រះបន្ទូលនៃព្រះ
ទុកសំរាប់មនុស្សទាំងអស់ដោយសេរីថា គ្មានអ្នកណាម្នាក់ខ្វះសិទ្ធិ
នឹង មករួមប្រជុំគ្នា ដើម្បីស្ដាប់ព្រះបន្ទូលនៃព្រះឡើយ ។
៦ ទោះជាយ៉ាងណាក៏ដោយ គង់តែកូនចៅនៃព្រះត្រូវបាន
បញ្ជាឲ្យមកជួបជុំគ្នាជាញឹកញាប់ ហើយរួមគ្នាតមអាហារ
ហើយ អធិស្ឋានឲ្យអស់ពីចិត្តដែរ ដើម្បីសុខុមាលភាពដល់
ព្រលឹងនៃពួកអ្នកដែលពុំស្គាល់ព្រះ ។
៧ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
អាលម៉ាបានធ្វើរបៀបចាត់ចែងទាំងនេះហើយ លោកបាន
ចាកចេញពី ពួកគេទៅ មែនហើយ គឺចេញពីសាសនាចក្រ
ដែលនៅក្នុងទីក្រុងសារ៉ាហិមឡា ហើយបានធ្វើដំណើរទៅ
ខាងកើតទន្លេស៊ីដូន នៅក្នុង[ក]ច្រកភ្នំគេឌាន នៅទីនោះមាន
ទីក្រុងមួយដែលបានសង់ឡើង ដែលបានហៅថា ទីក្រុងគេឌាន
នៅក្នុងច្រកភ្នំដែលបានហៅថា [ខ]គេឌាន ដែលបានហៅតាមឈ្មោះ
របស់បុរសម្នាក់ ដែលត្រូវនីហ៊ូរសម្លាប់ដោយដាវ ។
៨ ហើយអាលម៉ាបានទៅ ហើយបានចាប់ផ្ដើមប្រកាសព្រះបន្ទូល
នៃព្រះដល់សាសនាចក្រ ដែលបានតាំងឡើងនៅក្នុងច្រកភ្នំគេឌាន
ស្របតាមវិវរណៈនៃសេចក្ដីពិតនៃព្រះបន្ទូល ដែលពួក
អយ្យកោលោកបាននិយាយមក និងស្របតាម[ក]វិញ្ញាណ
នៃការព្យាករណ៍ ដែលនៅ ក្នុងខ្លួនលោក ស្របតាមទីបន្ទាល់
អំពីព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ដែលនឹងយាង
មកប្រោសលោះរាស្ត្រទ្រង់ពីសេចក្ដីបាប និងស្របតាម
របៀបដ៏បរិសុទ្ធ ដែលបានប្រទានដល់លោក ។ ហើយត្រូវបាន
សរសេរទុកយ៉ាងដូច្នោះហើយ ។ អាម៉ែន ៕

---

ពាក្យពេចន៍របស់អាលម៉ា ដែលបានប្រកាសទៅកាន់ប្រជាជននៅក្រុងគេឌាន តាមបញ្ជីប្រវត្តិរបស់លោក ។

*មានរួមនៅក្នុងជំពូកទី ៧*

---

## ជំពូកទី ៧

*ព្រះគ្រីស្ទនឹងប្រសូតមកពីនាងម៉ារា — ទ្រង់នឹងស្រាយចំណងទាំងឡាយនៃសេចក្ដីស្លាប់ ហើយទទួលរងអំពើបាបរបស់រាស្ត្រទ្រង់ — អ្នកទាំងឡាយណាដែលប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះនឹងមានជីវិតដ៏នៅ អស់កល្បជានិច្ច — ភាពស្មោកគ្រោកមិនអាចគ្រងនគរព្រះទុកជាមរតកបានឡើយ — ត្រូវតែមានសេចក្ដីបន្ទាបខ្លួន សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ។ ប្រមាណជាឆ្នាំ ៨៣ ម.គ.ស. ។*

មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ដោយឃើញថា
ខ្ញុំត្រូវបានអនុញ្ញាតឲ្យមកជួបនឹងអ្នក ហេតុដូច្នេះហើយ

---

៦ ១*ក* ស.ប. តែងតាំង, ការតែងតាំង.
*ខ* ស.ប. អែលឌើរ.
*គ* ស.ប. ដៃ, ការដាក់.
*ឃ* គ. និង ស. ៥២:៣៩.
២ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
៣ *ក* ម៉ូសាយ ២៦:៦.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*គ* និក្ខ. ៣២:៣៣; ម៉ូសាយ ២៦:៣៦; អាលម៉ា ១:២៤; ៥:៥៧–៥៨.
ស.ប. ការកាត់ចេញពីសាសនា.
៦ *ក* ស.ប. តម, តំណម.
៧ *ក* អាលម៉ា ២:២០.
*ខ* អាលម៉ា ១:៩.
៨ *ក* វិវរ. ១៩:១០.

ខ្ញុំខិតខំដើម្បីថ្លែង ទៅកាន់អ្នកដោយភាសារបស់ខ្ញុំ; មែនហើយ
ដោយមាត់ខ្ញុំផ្ទាល់ ដោយឃើញថា នេះជាលើកទីមួយហើយ
ដែលខ្ញុំនិយាយទៅកាន់ អ្នក ដោយសំដីដែលចេញពីមាត់ខ្ញុំ
ព្រោះពីមុនមកខ្ញុំបានចំណាយពេលទាំងស្រុងនៅលើវេទិកាជំនុំជំរះ
ដោយរវល់នឹងកិច្ចការជាច្រើន ដែលមិនអាចឲ្យខ្ញុំមកជួបនឹង
បងប្អូនបាន ។
២ ហើយសូម្បីតែនៅពេលឥឡូវនេះក៏ដោយ គង់តែខ្ញុំមិន
អាចមកបានទេ ប្រសិនបើវេទិកាជំនុំជំរះ ពុំបានប្រគល់ទៅឲ្យ
អ្នកផ្សេង ទៀត ដើម្បីគ្រប់គ្រងជំនួសខ្ញុំ; ហើយព្រះអម្ចាស់
ដោយនូវសេចក្ដីមេត្តាករុណាដ៏ច្រើន ទ្រង់បានអនុញ្ញាតឲ្យខ្ញុំ
មករកអ្នក ។
៣ ហើយមើលចុះ ខ្ញុំមកដោយមានសេចក្ដីសង្ឃឹមដ៏ធំ
និងបំណងដ៏ខ្ពស់ថា ខ្ញុំនឹងឃើញថា អ្នករាល់គ្នាបានបន្ទាបខ្លួន
ចំពោះព្រះ ខ្ញុំនឹងឃើញថា អ្នករាល់គ្នាបន្តការសុំក្ដីសន្ដោស
ពីទ្រង់ ខ្ញុំនឹងឃើញថា អ្នករាល់គ្នាគ្មានទោសនៅចំពោះទ្រង់ឡើយ
ខ្ញុំនឹងឃើញថា អ្នករាល់គ្នាមិននៅក្នុងស្ថានភាពដ៏គួរឲ្យស្ញែងខ្លាច
ដូចបងប្អូនយើងដែលនៅឯដែនដីសារ៉ាហិមឡានោះឡើយ ។
៤ ប៉ុន្តែ សូមឲ្យព្រះនាមនៃព្រះបានប្រកបដោយព្រះពរ
ដែលទ្រង់បានប្រទានឲ្យខ្ញុំដឹង មែនហើយ ទ្រង់បានប្រទានដល់ខ្ញុំ
នូវសេចក្ដី អំណរដ៏ធំលើសលប់ ដោយបានដឹងថា ពួកគេបាន
តាំងឡើងជាថ្មី នៅក្នុងមាគ៌ានៃសេចក្ដីសុចរិតរបស់ទ្រង់ ។
៥ ហើយស្របតាមព្រះវិញ្ញាណនៃព្រះ ដែលនៅក្នុងខ្លួនខ្ញុំ
ខ្ញុំជឿថា ខ្ញុំនឹងមានសេចក្ដីអំណរនឹងបងប្អូនរាល់គ្នា; ទោះ
ជាយ៉ាង ណាក៏ដោយ គង់តែខ្ញុំមិនចង់ឲ្យសេចក្ដីអំណររបស់ខ្ញុំ
នឹងបងប្អូនរាល់គ្នា មានមកដោយសារសេចក្ដីទុក្ខវេទនា និងសេច
ក្ដីសោក សៅដ៏ច្រើន ដែលខ្ញុំមានចំពោះបងប្អូនដែលនៅឯដែនដី
សារ៉ាហិមឡានោះដែរ ត្បិតមើលចុះ សេចក្ដីអំណររបស់ខ្ញុំនឹង
ពួកគេ បានកើតឡើងក្រោយពីបាន លុយកាត់សេចក្ដីទុក្ខវេទនា
និងសេចក្ដីសោកសៅជាច្រើន ។
៦ ប៉ុន្តែមើលចុះ ខ្ញុំជឿថា អ្នករាល់គ្នាពុំនៅក្នុងស្ថានភាព
នៃការឥតជំនឿ ដូចជាបងប្អូនរបស់អ្នកនោះទេ; ខ្ញុំជឿថា អ្នក
រាល់គ្នាក៏ពុំ លើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃចិត្តអ្នកដែរ; មែន
ហើយ ខ្ញុំជឿថា អ្នករាល់គ្នាពុំភ្ជាប់ចិត្តអ្នកទៅលើទ្រព្យសម្បត្តិ
និងវត្ថុទាំងឡាយ ដែលឥតប្រយោជន៍នៃលោកិយឡើយ; មែន
ហើយ ខ្ញុំជឿថា អ្នករាល់គ្នាពុំថ្វាយបង្គំរូបព្រះ តែអ្នករាល់
គ្នាថ្វាយបង្គំព្រះដ៏ពិត ហើយមានព្រះជន្មរស់នៅវិញ ហើយថា
អ្នករាល់គ្នាទន្ទឹងចាំដល់ការផ្ដាច់បាបទាំងឡាយរបស់អ្នក ដោយ
មានសេចក្ដីជំនឿដ៏នៅអស់កល្បជានិច្ច នៅពេលខាងមុខ ។
៧ ត្បិតមើលចុះ ខ្ញុំសូមប្រាប់អ្នកថា នឹងមានការណ៍
ជាច្រើនកើតឡើង ក្នុងពេលអនាគត; ហើយមើលចុះ មាន
រឿងមួយដែល សំខាន់ជាងរឿងទាំងអស់ — ត្បិតមើលចុះ
នៅពេលមិនយូរប៉ុន្មានទេ ព្រះដ៏ប្រោសលោះមានព្រះជន្ម
រស់នៅ ហើយនឹងយាងមកក្នុង ចំណោមរាស្ត្រទ្រង់ ។
៨ មើលចុះ ខ្ញុំមិននិយាយថា ទ្រង់នឹងយាងមកក្នុងចំណោម
ពួកយើង ក្នុងពេលដែលទ្រង់ស្ថិតនៅក្នុងរោងឧបោសថខាង
សាច់ ឈាមនោះទេ ត្បិតមើលចុះ ព្រះវិញ្ញាណ ទ្រង់ពុំបាន
ប្រាប់ខ្ញុំថា នេះជាការណ៍ដែលនឹងកើតឡើងនោះឡើយ ។
ឥឡូវនេះ ចំពោះរឿង នេះ ខ្ញុំមិនដឹងទេ; ប៉ុន្តែខ្ញុំដឹងប៉ុណ្ណោះថា
ព្រះអម្ចាស់ ទ្រង់មានព្រះចេស្ដានឹងធ្វើកិច្ចការបានគ្រប់យ៉ាង
ស្របតាមព្រះបន្ទូលរបស់ទ្រង់ ។
៩ ប៉ុន្តែមើលចុះ ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលមកខ្ញុំ
ប៉ុណ្ណោះថា៖ ចូរស្រែកប្រកាសប្រាប់ដល់ប្រជាជននេះថា —
ចូរប្រែចិត្តចុះ ហើយរៀបចំផ្លូវថ្វាយព្រះអម្ចាស់ ហើយដើរតាមគន្លង
របស់ទ្រង់ ដែលត្រង់; ត្បិតមើលចុះ នគរ
ស្ថានសួគ៌នៅជិតដៃបង្កើយ ហើយព្រះ រាជបុត្រានៃព្រះ នឹង
យាងមកលើផ្ទៃផែនដីនេះ ។
១០ ហើយមើលចុះ ទ្រង់នឹងប្រសូតមកពីនាងម៉ារា
នៅក្រុងយេរូសាឡិម ដែលជាដែនដីរបស់ពួកអយ្យកោដើម
របស់យើង នាងជា ស្ត្រីព្រហ្មចារី គឺជាប្រដាប់ដ៏ជំរើស ហើយ
ពិសេសមួយ ដែលនឹងត្រូវគ្របដណ្ដប់ ហើយចាប់ទំផ្ទៃដោយ
ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងប្រសូតបានបុត្រ
មួយ មែនហើយ គឺជាព្រះរាជបុត្រានៃព្រះ ។

---

៧ ១ *ក* អាលម៉ា ៤:១៩.
*ខ* ម៉ូសាយ ២៩:៤២.
២ *ក* អាលម៉ា ៤:១៦–១៨.
៦ *ក* ២ នីហ្វៃ ៩:៣៧; ហេលេ. ៦:៣១.
*ខ* ដានី. ៦:២៦.
៧ *ក* អាលម៉ា ៩:២៦.
៩ *ក* ម៉ាថាយ ៣:២–៤;
អាលម៉ា ៩:២៥.
*ខ* ម៉ូសាយ ៣:៥;
៧:២៧; ១៥:១–២.
១០ *ក* អេសាយ ៧:១៤; លូកា ១:២៧.
*ខ* ម៉ូសាយ ៣:៨.
ស.ប. នាងម៉ារា, មាតារបស់
ព្រះយេស៊ូវ.
*គ* ១ របា. ៩:៣; ២ របា. ១៥:៩;
១ នីហ្វៃ ១:៤; ៣ នីហ្វៃ ២០:២៩.
*ឃ* ១ នីហ្វៃ ១១:១៣–២១.
*ង* ម៉ាថាយ ១:២០; ម៉ូសាយ ១៥:៣.

១១ ហើយទ្រង់នឹងយាងទៅ ដោយរងការឈឺចាប់ និង[ក]ទុក្ខ
វេទនា និងការល្បួងគ្រប់បែបយ៉ាង; ហើយទ្រង់ធ្វើយ៉ាងនេះ
គឺដើម្បីឲ្យ បានបំពេញនូវពាក្យទាំងឡាយ ដែលបានចែងទុកមក
ថា ទ្រង់នឹងលើកដាក់លើខ្លួនទ្រង់ នូវការឈឺចាប់ និងជម្ងឺទាំង
ឡាយរបស់រាស្ត្រ ទ្រង់ ។
១២ ហើយទ្រង់នឹងយកដាក់លើរូបអង្គទ្រង់ នូវ[ក]សេចក្ដីស្លាប់
ដើម្បីទ្រង់អាចស្រាយចំណងទាំងឡាយនៃសេចក្ដីស្លាប់ ដែល
ចងរាស្ត្រ ទ្រង់; ហើយទ្រង់នឹងដាក់លើរូបអង្គទ្រង់ នូវ
ជម្ងឺឈឺចាប់របស់ពួកគេ ដើម្បីឲ្យព្រះហឫទ័យទ្រង់ បាន
ពោរពេញទៅដោយសេចក្ដីមេត្តា ករុណា ស្របតាម
សាច់ឈាម ដើម្បីទ្រង់អាចដឹង ស្របតាមសាច់ឈាមថា
តើត្រូវ[ខ]ជួយរាស្ត្រទ្រង់បែបណា តាមជម្ងឺរបស់គេ ។
១៣ ឥឡូវនេះ ព្រះវិញ្ញាណ ទ្រង់[ក]ជ្រាបការណ៍សព្វយ៉ាង;
ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះរាជបុត្រានៃព្រះស៊ូរង
ឈឺចាប់ ស្រប តាមសាច់ឈាម ដើម្បីទ្រង់អាច
[ខ]យកដាក់លើរូបអង្គទ្រង់ នូវអំពើបាបទាំងឡាយរបស់រាស្ត្រទ្រង់
ដើម្បីទ្រង់អាចលុបចោល នូវអំពើរំលង ទាំងឡាយរបស់គេ
ស្របតាមព្រះចេស្ដានៃការដោះលែងរបស់ទ្រង់; ហើយឥឡូវនេះ
មើលចុះ នេះគឺជាទីបន្ទាល់ដែលនៅក្នុងខ្លួនខ្ញុំ ។
១៤ ឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា អ្នករាល់គ្នាត្រូវតែប្រែចិត្ត
ហើយកើតម្ដងទៀត; ត្បិតព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលថា
បើសិនជា អ្នករាល់គ្នាមិនបាន[ក]កើតម្ដងទៀតទេ នោះអ្នករាល់
គ្នាមិនអាចគ្រងនគរស្ថានសួគ៌ទុកជាមរតកបានឡើយ; ហេតុ
ដូច្នេះហើយ ចូរមក ហើយទទួលបុណ្យជ្រមុជទឹក ចំពោះការ
ប្រែចិត្តចុះ ដើម្បីឲ្យអ្នករាល់គ្នាអាចបានជ្រះពីអំពើបាបទាំង
ឡាយរបស់អ្នក ដើម្បីឲ្យអ្នករាល់គ្នា អាចមានសេចក្ដីជំនឿជឿ
ដល់កូនចៀមនៃព្រះ ដែលនឹងដកយកអំពើបាបទាំងឡាយ
ពីមនុស្សលោក ដែលមានឥទ្ធិឫទ្ធិដើម្បីសង្គ្រោះ និងដើម្បី
ជំរះឲ្យជ្រះពីអស់ទាំងអំពើដ៏ឥតសុចរិច ។
១៥ មែនហើយ ខ្ញុំសូមប្រាប់អ្នកថា ចូរមកចុះ ហើយចូរកុំ
ខ្លាចអី ហើយចូរបោះបង់ចោលនូវអំពើបាបគ្រប់យ៉ាង ដែ
[ក]ហ៊ុំព័ទ្ធអ្នករាល់គ្នា យ៉ាងងាយៗ ដែលចងអ្នកចុះទៅឯសេចក្ដី
បំផ្លិចបំផ្លាញ មែនហើយ ចូរមក ហើយដើរទៅមុខចុះ ហើយ
ចូរបង្ហាញដល់ព្រះរបស់អ្នកថា អ្នកព្រមប្រែចិត្តពីអំពើបាបទាំង
ឡាយរបស់អ្នក ហើយព្រមចូលសេចក្ដីសញ្ញានឹងទ្រង់ថា នឹង
កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយធ្វើជាទីបន្ទាល់
ចំពោះទ្រង់ នៅក្នុងថ្ងៃនេះ ដោយចុះទៅក្នុងទឹកនៃបុណ្យជ្រមុជ ។
១៦ ហើយអ្នកណាដែលធ្វើយ៉ាងនេះ ហើយកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះ ចាប់ពីពេលនេះតទៅ អ្នកនោះហើយដែល
នឹង នឹកចាំថា ខ្ញុំបានប្រាប់ទៅគេ មែនហើយ អ្នកនោះនឹងនឹកចាំថា
ខ្ញុំបានប្រាប់ទៅគេថា គេនឹងមានជីវិតដ៏នៅអស់កល្បជានិច្ច
ស្របតាម ទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើបន្ទាល់នៅ
ក្នុងខ្លួនខ្ញុំ ។
១៧ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
តើអ្នកជឿការណ៍ទាំងនេះឬទេ ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា
មែនហើយ ខ្ញុំដឹងថា អ្នករាល់គ្នាជឿការណ៍ទាំងនេះ; ហើយហេតុ
ដែលខ្ញុំដឹងថាអ្នករាល់គ្នាជឿ គឺដោយសារការបើកសម្ដែងនៃ
ព្រះវិញ្ញាណ ដែល នៅក្នុងខ្លួនខ្ញុំ ។ ហើយឥឡូវនេះ ដោយ
សារសេចក្ដីជំនឿដ៏មុតមាំរបស់អ្នកចំពោះការណ៍នោះ មែន
ហើយ ចំពោះការណ៍ទាំងឡាយ ដែលខ្ញុំបាននិយាយមកនោះ
ខ្ញុំមានសេចក្ដីអំណរជាខ្លាំង ។
១៨ ត្បិតដូចខ្ញុំបានប្រាប់អ្នកចាប់តាំងពីដើមមកថា ខ្ញុំមាន
បំណងដ៏ធំ គឺមិនចង់ឲ្យអ្នករាល់គ្នា នៅក្នុងស្ថានភាពរងគ្រោះ
ដូចបងប្អូនអ្នក ដូច្នោះខ្ញុំឃើញថា បំណងរបស់ខ្ញុំបាន
ស្កប់ស្កល់ហើយ ។
១៩ ត្បិតខ្ញុំយល់ថា អ្នករាល់គ្នាកំពុងនៅលើផ្លូវទាំងឡាយ
នៃសេចក្ដីសុចរិត; ខ្ញុំយល់ថា អ្នករាល់គ្នាកំពុងនៅលើផ្លូវ
ដែលនាំទៅរក នគរនៃព្រះ មែនហើយ ខ្ញុំយល់ថា អ្នករាល់
គ្នាកំពុងតម្រង់[ក]ផ្លូវរបស់ទ្រង់ ។
២០ ខ្ញុំយល់ថា អ្នករាល់គ្នាធ្លាប់បានដឹង ដោយទីបន្ទាល់នៃ
ព្រះបន្ទូលរបស់ទ្រង់ថា ទ្រង់មិន[ក]ដើរលើផ្លូវវៀចវាងឡើយ; ហើយ
ទ្រង់ក៏ មិនដែលបែរចេញពីអ្វីដែលទ្រង់មានព្រះបន្ទូលដែរ; ហើយ

១១ *ក* អេសាយ ៥៣:៣–៥;
ម៉ូសាយ ១៤:៣–៥.
១២ *ក* ២ នីហ្វៃ ២:៨;
អាលម៉ា ១២:២៤–២៥.
ស.ប. ការឆ្កាង.
*ខ* ហេព្រើរ ២:១៨; ៤:១៥;
គ. និង ស. ៦២:១.
១៣ *ក* ស.ប. ព្រះ, ក្រុមព្រះ.
*ខ* ម៉ូសាយ ១៥:១២.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
១៤ *ក* ស.ប. កើតម្ដងទៀត, កើតពីព្រះ.
១៥ *ក* ២ នីហ្វៃ ៤:១៨.
១៩ *ក* ម៉ាថាយ ៣:៣.
២០ *ក* ១ នីហ្វៃ ១០:១៩;
អាលម៉ា ៣៧:១២;
គ. និង ស. ៣:២.

សូម្បីតែបន្តិចបន្តួច ក៏ទ្រង់មិនងាកពីឆ្វេងទៅស្ដាំ ឬពីខុសមក
ត្រូវដែរ; ហេតុដូច្នេះហើយ ដំណើររបស់ទ្រង់ គឺជាវង់
មួយដ៏នៅអស់កល្បជានិច្ច ។
២១ ហើយទ្រង់ក៏ពុំគង់នៅក្នុងព្រះវិហារណាដែល
[ក]ឥតបរិសុទ្ធឡើយ; ហើយភាពស្មោកគ្រោក ឬអ្វីដែលមិនស្អាត
ក៏មិនអាចទទួល ឲ្យចូលទៅក្នុងនគរនៃព្រះបានដែរ; ហេតុ
ដូច្នេះហើយ ខ្ញុំសូមប្រាប់អ្នកថា ពេលនោះនឹងមកដល់ មែន
ហើយ គឺនៅក្នុងថ្ងៃ[ខ]ចុងក្រោយ បង្អស់ថា អ្នកណាដែល
ស្មោកគ្រោកនឹងនៅក្នុងភាពស្មោកគ្រោករបស់ខ្លួនតទៅ ។
២២ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ខ្ញុំបាននិយាយនូវការណ៍អស់ទាំងនេះទៅកាន់អ្នក ក្រែងខ្ញុំអាចធ្វើឲ្យ
អ្នក ភ្ញាក់រលឹកដល់កិច្ចការរបស់អ្នកចំពោះព្រះ ដើម្បីឲ្យអ្នក
រាល់គ្នាអាចដើរដោយឥតទោសនៅចំពោះទ្រង់ ដើម្បីឲ្យអ្នក
រាល់គ្នាអាចដើរ តាមរបៀបដ៏បរិសុទ្ធនៃព្រះ តាមរបៀបដែល
អ្នករាល់គ្នាបានទទួល ។
២៣ ហើយឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នា[ក]បន្ទាបខ្លួន ហើយ
ចុះចូល ហើយសុភាពទន់ភ្លន់; រហ័សធ្វើតាមការល្អ;
ពោរពេញទៅដោយ ការទ្រាំទ្រ និងការអត់ធ្មត់; សង្កត់ចិត្ត
ក្នុងកិច្ចការគ្រប់យ៉ាង; មានចិត្តព្យាយាមក្នុងការកាន់
តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ឲ្យបានគ្រប់ ពេលវេលា; សូម
នូវអ្វីដែលអ្នកត្រូវការ ទាំងខាងវិញ្ញាណ និងខាង
ឯសាច់ឈាមដែរ; ថ្លែងអំណរគុណដល់ព្រះជានិច្ច ចំពោះអ្វី
ដែល អ្នកបានទទួល ។
២៤ ហើយចូរឲ្យឃើញថា អ្នករាល់គ្នាមាន[ក]សេចក្ដីជំនឿ
សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ហើយនៅពេលនោះ អ្នក
រាល់គ្នានឹង បានបរិបូរទៅដោយកិច្ចការល្អៗជានិច្ច ។
២៥ ហើយសូមឲ្យព្រះអម្ចាស់ទ្រង់ប្រទានពរដល់អ្នក ហើយ
សូមទ្រង់ថែសំលៀកបំពាក់របស់អ្នក កុំឲ្យប្រឡាក់
ដើម្បីនៅទីបញ្ចប់ នោះអ្នករាល់គ្នានឹងអាចបានទៅអង្គុយជា
មួយនឹងអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប និងពួកព្យាការីដ៏បរិសុទ្ធ
ទាំងឡាយ ដែលមានចាប់តាំង ពីកំណើតលោកិយមក
ដោយមានសំលៀកបំពាក់របស់ខ្លួន[ក]ឥតប្រឡាក់អ្វី ដូចជា
សំលៀកបំពាក់របស់ពួកព្យាការីទាំងនោះដែរ នៅក្នុងនគរ
ស្ថានសួគ៌ ដោយពុំចេញទៅក្រៅទៀតឡើយ ។
២៦ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ខ្ញុំបាននិយាយពាក្យទាំងនេះទៅកាន់អ្នក
ស្របតាមព្រះវិញ្ញាណដែលធ្វើ បន្ទាល់នៅក្នុងខ្លួនខ្ញុំ; ហើយ
ព្រលឹងខ្ញុំអររីករាយដ៏ក្រៃលែង ពីព្រោះអ្នករាល់គ្នាបានយក
ចិត្តទុកដាក់ ហើយព្យាយាមស្ដាប់តាមពាក្យ របស់ខ្ញុំ ។
២៧ ហើយឥឡូវនេះ សូមឲ្យសេចក្ដីសុខសាន្តនៃព្រះ សណ្ឋិត
មកលើបងប្អូន និងលើផ្ទះសំបែង និងដែនដីរបស់អ្នក និងលើ
ហ្វូងចៀម និងហ្វូងគោរបស់អ្នក និងលើអ្វីៗទាំងអស់ដែលអ្នកមាន
លើពួកស្ត្រីរបស់អ្នក និងកូនចៅរបស់អ្នក ស្របតាមសេចក្ដី
ជំនឿ និងកិច្ចការល្អ ទាំងឡាយរបស់អ្នក ចាប់ពីពេលនេះ
និងរហូតតទៅ ។ ហើយខ្ញុំបាននិយាយដូច្នោះហើយ ។ អាម៉ែន ៕

## ជំពូកទី ៨

*អាលម៉ាផ្សាយ ហើយធ្វើបុណ្យជ្រមុជទឹកនៅក្រុងមេលេក — គេមិនទទួលស្គាល់លោក នៅក្រុងអាំម៉ូណៃហា ហើយលោកក៏ចាកចេញ ទៅ — ទេវតាបញ្ជាឲ្យ លោកត្រឡប់ទៅវិញ ហើយប្រកាសប្រាប់ប្រជាជនឲ្យប្រែចិត្ត — អាមូលេកទទួលលោក ហើយអ្នកទាំងពីរផ្សាយ នៅក្រុង អាំម៉ូណៃហា ។ ប្រមាណជាឆ្នាំ ៨២ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ាបាន
ត្រឡប់មក[ក]ពីដែនដីគេឌានវិញ ដោយបន្ទាប់ពីបានបង្រៀន
ប្រជាជន គេឌាន នូវការណ៍ជាច្រើន ដែលមិនអាចកត់ទុកបាន
និងដោយបានតាំងរបៀបរៀបរយនៃសាសនាចក្រ តាមដែល
លោកធ្លាប់បាន ធ្វើពីមុនមកនៅដែនដីសារ៉ាហិមឡា មែនហើយ
នោះលោកក៏ត្រឡប់មកផ្ទះរបស់លោក នៅសារ៉ាហិមឡាវិញ
ដើម្បីសំរាកពី កិច្ចការទាំងឡាយដែលលោកបានធ្វើ ។
២ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ ។
៣ ហើយហេតុការណ៍បានកើតឡើងថា នៅដើម

២១ *ក* ១ កូរិន. ៣:១៦–១៧; ៦:១៩;
ម៉ូសាយ ២:៣៧;
អាលម៉ា ៣៤:៣៦.
*ខ* ១ នីហ្វៃ ១៥:៣៣–៣៥;
២ នីហ្វៃ ៩:១៦; មរមន ៩:១៤;
គ. និង ស. ៨៨:៣៥.
២៣ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
២៤ *ក* ១ កូរិន. ១៣:១–១៣;
អេធើរ ១២:៣០–៣៥;
ម៉ូរ៉ូណៃ ៧:៣៣–៤៨.
២៥ *ក* ២ ពេត្រុស ៣:១៤.
២៧ *ក* ស.ប. សេចក្ដីសុខសាន្ត.
៨ ១*ក* អាលម៉ា ២:២០; ៦:៧.

ឆ្នាំទីដប់ក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ
នោះអាលម៉ាបានចេញ ដំណើរ ទៅកាន់ដែនដីមេលេក នៅ
ខាងលិចទន្លេស៊ីដូន នៅខាងលិចដែនដី ជាប់ព្រំប្រទល់នឹង
ទីរហោស្ថាន ។
៤ ហើយលោកបានចាប់ផ្ដើមបង្រៀនប្រជាជន
នៅដែនដីមេលេក ស្របតាមរបៀបដ៏បរិសុទ្ធនៃព្រះ គឺតាម
របៀបដែលលោកត្រូវ បានហៅ; ហើយលោកបានចាប់ផ្ដើម
បង្រៀនប្រជាជនទូទៅអស់ទាំងដែនដីមេលេក ។
៥ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបានមក
រកលោក ពីគ្រប់ទាំងព្រំប្រទល់ ដែលនៅខាងឯទីរហោស្ថាន
ហើយពួក គេបានទទួលបុណ្យជ្រមុជទឹក ទូទៅអស់ទាំងដែនដី;
៦ ម្ល៉ោះហើយ កាលលោកបានបញ្ចប់កិច្ចការរបស់លោក
នៅដែនដីមេលេកហើយ នោះលោកក៏បានចេញដំណើរទៅ
ហើយបាន ធ្វើដំណើរអស់បីថ្ងៃ នៅតំបន់ខាងជើងដែនដីមេលេក;
ហើយលោកបានមកដល់ទីក្រុងមួយហៅថា អាំម៉ូណៃហា ។
៧ ឥឡូវនេះ ពួកប្រជាជននីហ្វៃមានសណ្ដាប់ហៅដែនដី
ទីក្រុង និងភូមិរបស់ខ្លួន មែនហើយ ទាំងភូមិតូចៗទាំងអស់
របស់គេ តាម ឈ្មោះនៃម្ចាស់ទីនោះមុនគេបង្អស់ ហើយដែនដី
អាំម៉ូណៃហា គឺនៅក្នុងករណីនោះដែរ ។
៨ ហើយហេតុការណ៍បានកើតឡើងថា កាលដែលអាលម៉ា
បានមកដល់ទីក្រុងអាំម៉ូណៃហាហើយ នោះលោកបានចាប់ផ្ដើម
ផ្សាយ ព្រះបន្ទូលនៃព្រះដល់ពួកគេ ។
៩ ឥឡូវនេះ អារក្សសាតាំងបានក្ដាប់ជាប់នូវដួងចិត្ត
នៃប្រជាជននៅទីក្រុងអាំម៉ូណៃហា; ហេតុដូច្នេះហើយ ទើបពួក
គេពុំស្ដាប់តាម ពាក្យរបស់អាលម៉ាឡើយ ។
១០ ទោះជាយ៉ាងណាក៏ដោយ គង់តែអាលម៉ាបានធ្វើការ
ជាខ្លាំងខាងវិញ្ញាណ ដោយពុះពារខំអធិស្ឋានដល់ព្រះ សូមឲ្យ
ទ្រង់ស្រោច ព្រះវិញ្ញាណទ្រង់ មកលើប្រជាជនដែលនៅក្នុង
ទីក្រុង; ព្រមទាំងសូមឲ្យទ្រង់អនុញ្ញាតឲ្យលោកធ្វើបុណ្យ
ជ្រមុជទឹកឲ្យពួកគេ ចំពោះការ ប្រែចិត្តផង ។
១១ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបានធ្វើចិត្ត
រឹងរូសដែរ ដោយពោលទៅកាន់លោកថា៖ មើលចុះ
យើងដឹងថា លោកគឺ អាលម៉ា; ហើយយើងដឹងថា លោកជា
សង្ឃជាន់ខ្ពស់លើសាសនាចក្រ ដែលលោកបានតាំងឡើង
នៅច្រើនកន្លែងនៅលើដែនដី ស្របតាមសណ្ដាប់របស់លោក;
ហើយយើងពុំនៅក្នុងសាសនាចក្ររបស់លោកទេ ហើយ
យើងពុំជឿតាមសណ្ដាប់ផ្ដេសផ្ដាស់បែបនេះ ឡើយ ។
១២ ហើយឥឡូវនេះ យើងដឹងថា ពីព្រោះយើងពុំនៅក្នុង
សាសនាចក្ររបស់លោក នោះយើងដឹងថា លោកគ្មាន
អំណាចអ្វីមក លើយើងឡើយ; ហើយលោកបានប្រគល់វេទិកា
ជំនុំជំរះទៅឲ្យនីហ្វៃហាទៅហើយ; ហេតុដូច្នេះហើយ លោកពុំ
មែនជាមេចៅក្រម ត្រួតត្រាលើយើងដែរ ។
១៣ ឥឡូវនេះ កាលដែលប្រជាជនបាននិយាយដូច្នេះ ហើយ
បានប្រកែកនឹងអស់ទាំងពាក្យសំដីរបស់លោក ហើយបានជេរ
ប្រមាថលោក ហើយបានស្ដោះដាក់លោក ហើយបាន
បណ្ដេញលោកចេញពីទីក្រុងរបស់គេ នោះលោកក៏ចេញទៅ
ហើយធ្វើ ដំណើរឆ្ពោះទៅឯទីក្រុងមួយហៅថា អើរ៉ុន ។
១៤ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែល
លោកកំពុងតែធ្វើដំណើរទៅទីនោះ ពោរពេញទៅដោយ
សេចក្ដីសោក សៅ លុយកាត់សេចក្ដីទុក្ខលំបាក និងសេចក្ដី
ត្រាំត្រាក្នុងចិត្តជាខ្លាំង ដោយព្រោះអំពើទុច្ចរិតរបស់ប្រជាជន
ដែលនៅទីក្រុង អាំម៉ូណៃហានោះ នោះហេតុការណ៍
បានកើតឡើងថា កាលអាលម៉ាកំពុងតែពោរពេញទៅដោយក្ដី
សោកសៅ មើលចុះ ស្រាប់តែ មានទេវតាមួយនៃព្រះអម្ចាស់
បានលេចមកឲ្យលោកឃើញ ដោយពោលថា៖
១៥ អាលម៉ាអើយ អ្នកមានពរហើយ; ហេតុដូច្នេះហើយ
ចូរអ្នកងើបមុខឡើង ហើយអររីករាយចុះ ត្បិតអ្នកមានហេតុ
ដ៏ធំចំពោះ ការអររីករាយ; ព្រោះអ្នកមានចិត្តស្មោះក្នុងការ
កាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ចាប់តាំងពីពេលដែល
អ្នកបានទទួលបង្គាប់ទីមួយ ពីទ្រង់ម្ល៉េះ។ មើលចុះ គឺខ្ញុំនេះហើយ
ដែលបានប្រាប់បង្គាប់នោះដល់អ្នក ។
១៦ ហើយមើលចុះ ខ្ញុំបញ្ជាឲ្យអ្នកត្រឡប់ទៅឯទីក្រុង
អាំម៉ូណៃហាវិញ ហើយចូរផ្សាយប្រាប់ប្រជាជន នៅក្នុង
ក្រុងនោះទៀតចុះ ។ មែនហើយ ចូរផ្សាយប្រាប់ពួកគេទៅ ។

៣ *ក* អាលម៉ា ១៦:៦–៧.
៤ *ក* គ. និង ស. ១០៧:២–៤.
ស.ប. បព្វជិតភាពមិលគីស្សាដែក.
៩ *ក* ២ នីហ្វៃ ២៨:១៩–២២;
គ. និង ស. ១០:២០.
១០ *ក* អាលម៉ា ១៧:៥.
*ខ* អេណុស ១:១–១២.
*គ* ៣ នីហ្វៃ ២៧:១.
ស.ប. ការអធិស្ឋាន.
១២ *ក* អាលម៉ា ៤:២០.
១៤ *ក* ស.ប. សេចក្ដីទំនាស់.
*ខ* អាលម៉ា ១០:៧–១០, ២០.
ស.ប. ពួកទេវតា.
១៥ *ក* ម៉ូសាយ ២៧:១១–១៦.

មែនហើយ ចូរប្រាប់ទៅគេថា លើកលែងតែពួកគេ[ក]ប្រែចិត្ត
បើពុំនោះសោតទេ ព្រះអម្ចាស់ ដ៏ជាព្រះ ទ្រង់នឹងបំផ្លាញ
គេចោល ។
១៧ ត្បិតមើលចុះ នៅពេលនេះ ពួកគេកំពុងតែស្វែងរកផ្លូវ
ដើម្បីនឹងបំផ្លាញឥស្សរភាពនៃប្រជាជនអ្នក (ត្បិតព្រះអម្ចាស់
ទ្រង់មាន ព្រះបន្ទូលថាដូច្នោះ) គឺជាការផ្ទុយនឹងក្រិត្យក្រម
និងសេចក្ដីយុត្តិធម៌ និងព្រះបញ្ញត្តិទាំងប៉ុន្មាន ដែលទ្រង់បាន
ប្រទានដល់រាស្ត្រទ្រង់ ។
១៨ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាលម៉ា
បានទទួលបង្គាប់ ពីទេវតានៃព្រះអម្ចាស់ហើយ លោកក៏ត្រឡប់ទៅ
ដែនដីអាំម៉ូណៃហាយ៉ាងរួសរាន់វិញ ។ ហើយលោកបានចូលទៅ
ក្នុងទីក្រុង តាមផ្លូវមួយផ្សេងទៀត មែនហើយ តាមផ្លូវដែល
នៅខាង ត្បូងទីក្រុងអាំម៉ូណៃហា ។
១៩ ហើយនៅពេលដែលលោកចូលទៅក្នុងទីក្រុង
លោកកំពុងតែឃ្លានអាហារ ហើយលោកពោលទៅកាន់
បុរសម្នាក់ថា៖ សូមលោកប្រទានអាហារ ដល់អ្នក
បំរើដ៏រាបទាបនៃព្រះផងចុះ ?
២០ ហើយបុរសនោះតបមកលោកថា៖ ខ្ញុំជាសាសន៍នីហ្វៃ
ហើយខ្ញុំដឹងថា លោកជា[ក]ព្យាការីដ៏បរិសុទ្ធមួយរូបនៃព្រះ
ព្រោះលោកជា បុរស ដែលទេវតាមួយបានប្រាប់ខ្ញុំ នៅក្នុង
ការនិមិត្តថា៖ អ្នកត្រូវទទួលអ្នកនោះ ។ ហេតុដូច្នេះហើយ
សូមលោកមកផ្ទះជាមួយខ្ញុំ ហើយខ្ញុំនឹងរំលែកដល់លោកនូវ
អាហារខ្ញុំ; ហើយខ្ញុំដឹងថា លោកនឹងឲ្យពរដល់ខ្ញុំ ហើយដល់
គ្រួសារខ្ញុំផង ។
២១ ហើយហេតុការណ៍បានកើតឡើងថា បុរសនោះបាន
ទទួលលោកចូលទៅក្នុងផ្ទះគាត់; ហើយបុរសនោះមានឈ្មោះថា
[ក]អាមូលេក; ហើយគាត់បានយកនំប៉័ង និងសាច់មកដាក់ខាង
មុខអាលម៉ា ។
២២ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាបានបរិភោគ
នំប៉័ង ហើយបានឆ្អែត; ហើយលោកបាន[ក]ប្រទានពរដល់អាមូលេក
និងគ្រួសារគាត់ ហើយលោកបានថ្លែងអំណរគុណដល់ព្រះ ។
២៣ ហើយបន្ទាប់ពីលោកបានបរិភោគ ហើយបាន
ឆ្អែតហើយ នោះលោកបានពោលទៅអាមូលេកថា ៖
ខ្ញុំគឺអាលម៉ា ហើយជា [ក]សង្ឃជាន់ខ្ពស់លើសាសនាចក្រនៃព្រះ
ទូទៅទាំងដែនដី ។
២៤ ហើយមើលចុះ ខ្ញុំត្រូវបានហៅឲ្យមកផ្សាយព្រះបន្ទូលនៃ
ព្រះ ដល់អស់ទាំងប្រជាជននេះ ស្របតាមវិញ្ញាណនៃវិវរណៈ
និងការ ព្យាករណ៍; ហើយខ្ញុំបានមកដល់ដែនដីនេះ តែពួកគេពុំ
ទទួលខ្ញុំសោះ ហើយគេបាន[ក]បណ្ដេញខ្ញុំចេញ ហើយខ្ញុំ
ក៏បំរុងនឹងលាចេញ ពីដែនដីនេះរហូតតទៅ ។
២៥ ប៉ុន្តែមើលចុះ ខ្ញុំត្រូវបានបញ្ជាឲ្យត្រឡប់មកព្យាករដល់
ប្រជាជននេះវិញ មែនហើយ ហើយមកធ្វើទីបន្ទាល់ទាស់នឹង
ពួកគេ អំពីអំពើទុច្ចរិតទាំងឡាយរបស់គេ ។
២៦ ហើយឥឡូវនេះ ឱអាមូលេកអើយ ពីព្រោះអ្នកបានផ្ដល់
អាហារដល់ខ្ញុំ ហើយបានទទួលខ្ញុំឲ្យចូលផ្ទះ សូមឲ្យអ្នកបាន
ពរចុះ; ត្បិតខ្ញុំស្រេកឃ្លាន ព្រោះខ្ញុំបានតមអាហារ អស់ជាច្រើន
ថ្ងៃមកហើយ ។
២៧ ហើយអាលម៉ាបានស្នាក់នៅអស់ជាច្រើនថ្ងៃ ជាមួយ
នឹងអាមូលេក មុនពេលលោកចាប់ផ្ដើមផ្សាយប្រាប់ប្រជាជននោះ។
២៨ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជន
កាន់តែធ្លាក់ខ្លួនធ្ងន់ធ្ងរទៅៗ ក្នុងអំពើទុច្ចរិតទាំងឡាយ ។
២៩ ហើយមានពាក្យបន្ទូលប្រាប់ដល់អាលម៉ាថា៖ ចូរទៅចុះ;
ហើយចូរប្រាប់អាមូលេក ជាអ្នកបំរើរបស់យើងផងថា
ចូរចេញទៅ ហើយព្យាករទៅកាន់ប្រជាជននេះថា — ចូរ[ក]ប្រែ
ចិត្តចុះ ត្បិតព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលដូច្នេះថា លើកលែងតែ
អ្នកប្រែចិត្ត បើពុំនោះសោតទេ យើងនឹងមកពិនិត្យពិច័យ
ប្រជាជននេះ ដោយសេចក្ដីពិរោធរបស់យើង; មែនហើយ
យើងនឹងពុំបែរសេចក្ដី ពិរោធដ៏ខ្លាំងរបស់យើងចេញឡើយ ។
៣០ ហើយអាលម៉ា ជាមួយនឹងអាមូលេកផង បានចេញទៅ
ក្នុងចំណោមប្រជាជន ដើម្បីទៅប្រកាសប្រាប់ព្រះបន្ទូលទាំង
ឡាយនៃព្រះ ដល់គេ; ហើយអ្នកទាំងពីរក៏ពោរពេញទៅដោយ
ព្រះវិញ្ញាណបរិសុទ្ធ ។
៣១ ហើយមាន[ក]អានុភាពប្រទានមកឲ្យគេ ដរាបដល់គេមិន
អាចឃុំឃាំង នៅក្នុងគុកបានឡើយ; ក៏គ្មានមនុស្ស
ណាម្នាក់អាចសម្លាប់ គេបានដែរ; ទោះជាយ៉ាងណាក៏ដោយ
គង់តែគេមិនប្រើ[ខ]អានុភាពរបស់គេដែរ ទាល់តែគេត្រូវចាប់

១៦ *ក* អាលម៉ា ៩:១២, ១៨, ២៤.
២០ *ក* អាលម៉ា ១០:៧–៩.
២១ *ក* ស.ប. អាមូលេក.
២២ *ក* អាលម៉ា ១០:១១.
២៣ *ក* អាលម៉ា ៥:៣, ៤៤, ៤៩;
១៣:១–២០.
២៤ *ក* អាលម៉ា ៨:១៣.
២៩ *ក* អាលម៉ា ៩:១២, ១៨.
ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
៣១ *ក* ១ នីហ្វៃ ១:២០.
*ខ* អាលម៉ា ១៤:១៧–២៩.

ចង ហើយដាក់ទៅក្នុងគុក ។ ឥឡូវនេះ គេធ្វើយ៉ាងនេះ គឺដើម្បីព្រះអម្ចាស់ទ្រង់អាចបង្ហាញព្រះចេស្ដារបស់ទ្រង់ដែលនៅក្នុងពួកគេ ។

៣២ ហើយហេតុការណ៍បានកើតឡើងថា គេបានចេញទៅ ហើយបានចាប់ផ្ដើមផ្សាយ ហើយព្យាករដល់ប្រជាជន ស្របតាមវិញ្ញាណ និងអានុភាព ដែលព្រះអម្ចាស់ទ្រង់បានប្រទានដល់គេ ៕

---

ពាក្យពេចន៍នៃអាលម៉ា ព្រមទាំងពាក្យពេចន៍នៃអាមូលេក ដែលបានប្រកាសទៅកាន់ប្រជាជន នៅលើដែនដីអាំម៉ូណៃហា ។ ហើយពួកគេក៏ត្រូវបានចាប់ដាក់គុក ហើយត្រូវបានដោះឲ្យរួច ដោយព្រះចេស្ដាដ៏អស្ចារ្យនៃព្រះ ដែលនៅក្នុងគេ តាមបញ្ជី របស់អាលម៉ា ។

*មានរួមពីជំពូកទី ៩ ដល់ ១៤*

## ជំពូកទី ៩

*អាលម៉ាបញ្ជាឲ្យប្រជាជននៅដែនដីអាំម៉ូណៃហាប្រែចិត្ត — ព្រះអម្ចាស់ទ្រង់នឹងមេត្តាករុណាដល់ពួកសាសន៍លេមិន នៅគ្រាចុង ក្រោយបង្អស់ — បើសិនជាពួកនីហ្វៃបដិសេធពន្លឺ នោះពួកគេនឹងត្រូវបំផ្លាញចោល ដោយពួកលេមិន — ព្រះរាជបុត្រានៃព្រះ នឹងយាងមកក្នុងពេលដ៏ខ្លី — ទ្រង់នឹងប្រោសលោះអស់អ្នកណាដែលប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ហើយមានសេចក្ដី ជំនឿជឿដល់ព្រះនាមទ្រង់ ។ ប្រមាណជាឆ្នាំ ៨២ ម.គ.ស. ។*

ហើយខ្ញុំ អាលម៉ា ដោយបានបញ្ជាពីព្រះថា ខ្ញុំត្រូវនាំអាមូលេក ហើយចេញទៅផ្សាយប្រាប់ប្រជាជននេះទៀត គឺប្រជាជនដែលនៅក្នុង ក្រុងអាំម៉ូណៃហា នោះហេតុការណ៍បានកើតឡើងថា នៅពេលដែលខ្ញុំចាប់ផ្ដើមផ្សាយប្រាប់គេ នោះពួកគេបានចាប់ផ្ដើមជជែកតនឹង ខ្ញុំថា៖

២ តើលោកជាអ្នកណា? តើលោកគិតស្មានថា ពួកយើងនឹងជឿតាមទីបន្ទាល់របស់មនុស្សម្នាក់ ទោះជាអ្នកនោះផ្សាយប្រាប់ យើងថា ផែនដីនេះនឹងកន្លងផុតទៅឬអី ?

៣ ឥឡូវនេះ ពួកគេមិនយល់នូវពាក្យទាំងឡាយ ដែលគេកំពុងតែនិយាយនោះឡើយ; ព្រោះពួកគេពុំដឹងថា ផែនដីនេះនឹងកន្លងផុត ទៅនោះឡើយទេ ។

៤ ហើយពួកគេក៏បាននិយាយដែរថា៖ យើងពុំជឿពាក្យសំដីរបស់លោកទេ ទោះជាលោកព្យាករថា ទីក្រុងដ៏ធំនេះនឹងត្រូវបំផ្លាញ ចោលក្នុងតែមួយថ្ងៃក៏ដោយ ។

៥ ឥឡូវនេះ ពួកគេពុំដឹងថា ព្រះទ្រង់អាចធ្វើបាននូវកិច្ចការដ៏អស្ចារ្យបែបនេះបានឡើយ ព្រោះពួកគេជាប្រជាជនដែលមាន ចិត្តរឹងរូស ហើយក្បាលរឹង ។

៦ ហើយពួកគេបាននិយាយថា៖ តើព្រះជាអ្នកណាទៅ បានជាមិនចាត់ឲ្យអ្វី ដែលមានអំណាចជាជាងមនុស្សម្នាក់ ឲ្យមកក្នុង ចំណោមប្រជាជននេះ ដើម្បីប្រកាសប្រាប់ដល់គេ នូវសេចក្ដីពិតនៃកិច្ចការដ៏ធំ និងអស្ចារ្យបែបនេះ ?

៧ ហើយពួកគេបានស្ទុះមកយាដៃរកវាយខ្ញុំ; ប៉ុន្តែមើលចុះ គេវាយពុំបានសោះ ។ ហើយខ្ញុំបានឈរនៅ ដោយក្លាហានទាំង ប្រកាសប្រាប់ទៅគេ មែនហើយ ខ្ញុំធ្វើទីបន្ទាល់ដោយក្លាហានទៅរកគេថា៖

៨ មើលចុះ នែ៎ ពួកកំណាមនុស្សទុច្ចរិត និងខូចអើយ ហេតុអ្វីបានជាអ្នករាល់គ្នាភ្លេចសណ្ដាប់របស់ពួកអយ្យកោអ្នក; មែនហើយ ហេតុអ្វីបានជាអ្នកឆាប់ភ្លេចព្រះបញ្ញត្តិទាំងឡាយនៃព្រះម្ល៉េះ?

៩ តើអ្នករាល់គ្នាមិនចាំទេឬថា លីហៃ ជាអយ្យកោរបស់យើង ត្រូវបាននាំចេញពីក្រុងយេរូសាឡិម ដោយព្រះហស្តនៃព្រះ ? តើអ្នករាល់គ្នាមិនចាំទេឬថា ទ្រង់បាននាំពួកគេទាំងអស់គ្នា កាត់ទីរហោស្ថាន ?

១០ ហើយតើអ្នករាល់គ្នាឆាប់ភ្លេចម្ល៉េះថា តើប៉ុន្មានលើកហើយដែលទ្រង់បានដោះលែងពួកអយ្យកោយើង ឲ្យរួចផុតពី កណ្ដាប់ដៃនៃពួកខ្មាំងសត្រូវគេ ហើយបានថែរក្សាគេ កុំឲ្យត្រូវបំផ្លាញបង់ ដោយកណ្ដាប់ដៃរបស់បងប្អូនគេផ្ទាល់ផងនោះ ?

១១ មែនហើយ ហើយបើសិនជាពុំដោយព្រះចេស្ដាដ៏ឥតប្រៀបផ្ទឹមបានរបស់ទ្រង់ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ និងសេចក្ដី អត់ធ្មត់របស់ទ្រង់ ចំពោះយើងនោះទេ យើងក៏ច្បាស់ជាត្រូវកាត់ចេញពីផ្ទៃផែនដី ជាយូរទៅហើយ គឺមុនរយៈពេលនេះ ហើយប្រ ហែលជាត្រូវជាប់ឃុំឃាំងក្នុងស្ថានភាពមួយ ដ៏ប្រកបដោយការឈឺចាប់ និងវេទនាដ៏មិនចេះមិនចេះហើយ ។

---

៩ ២ក ចោទិ. ១៧:៦.
៤ ក អាលម៉ា ១៦:៩–១០.
៦ ក និក្ខ. ៥:២; ម៉ូសាយ ១១:២៧; ម៉ូសេ ៥:១៦.
ខ អាលម៉ា ១០:១២.
៨ ក អាលម៉ា ១០:១៧–២៥.
៩ ក ១ នីហ្វៃ ២:១–៧.
១១ ក ម៉ូសាយ ១៦:១១.

១២ មើលចុះ ឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា ទ្រង់បានបញ្ជាឲ្យ
អ្នកប្រែចិត្ត; ហើយលើកលែងតែអ្នករាល់គ្នាប្រែចិត្ត
បើពុំនោះសោតទេ អ្នកមិនអាចគ្រងនគរព្រះទុកជាមរតក
បានឡើយ ។ ប៉ុន្តែមើលចុះ ការណ៍នេះមិនទាន់
អស់នៅឡើយទេ — ទ្រង់បានបញ្ជាឲ្យអ្នកប្រែ ចិត្ត បើពុំ
នោះសោតទេ ទ្រង់នឹងបំផ្លាញអ្នកឲ្យអស់រលីងពីផ្ទៃផែនដីនេះទៅ;
មែនហើយ ទ្រង់នឹងមកពិនិត្យពិច័យអ្នកក្នុងសេចក្ដីពិរោធ របស់
ទ្រង់ ហើយក្នុងសេចក្ដីពិរោធដ៏ខ្លាល់របស់ទ្រង់ នោះទ្រង់នឹង
ពុំបែរចេញឡើយ ។
១៣ មើលចុះ តើអ្នករាល់គ្នាមិនចាំទេឬ នូវព្រះបន្ទូល
ទាំងប៉ុន្មាន ដែលទ្រង់មានព្រះបន្ទូលទៅកាន់លីហៃថា៖ ដ៏រាបណា
អ្នករាល់គ្នា កាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នក
រាល់គ្នានឹងបានចំរើនឡើងនៅលើផែនដី ? ហើយព្រះបន្ទូល
បន្តទៀតថា៖ ដរាបណា អ្នករាល់គ្នាមិនកាន់តាមបញ្ញត្តិទាំង
ឡាយរបស់យើងទេ នោះអ្នករាល់គ្នានឹងត្រូវកាត់ចេញពីវត្តមាន
នៃព្រះអម្ចាស់ ។
១៤ ឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាចាំថា ដរាបណាពួក
សាសន៍លេមិនពុំកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះទេ នោះ
ពួកគេនឹងត្រូវ កាត់ចេញពីវត្តមាននៃព្រះអម្ចាស់ ។ ឥឡូវនេះ
យើងឃើញថា ព្រះបន្ទូលនៃព្រះអម្ចាស់ ត្រូវបានបញ្ជាក់ក្នុង
ការណ៍នេះ ហើយពួក លេមិនត្រូវបានកាត់ចេញពីវត្តមាន
របស់ទ្រង់ ចាប់តាំងពីពេលដែលគេបានធ្វើសេចក្ដីល្មើសនៅ
ក្នុងផែនដីម្លេះ ។
១៥ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំសូមប្រាប់អ្នកថា
នៅថ្ងៃជំនុំជំរះ ពួកគេនឹងទ្រាំបានងាយជាងអ្នករាល់គ្នា បើ
សិនជាអ្នក រាល់គ្នានៅក្នុងអំពើបាបទាំងឡាយរបស់អ្នក មែន
ហើយ ហើយពួកគេនឹងទ្រាំបានងាយជាងអ្នករាល់គ្នា នៅក្នុង
ជីវិតនេះ បើសិនជា អ្នករាល់គ្នាមិនប្រែចិត្តទេ ។
១៦ ត្បិតមានពាក្យសន្យាជាច្រើន ដែលបានពន្យារឲ្យដល់
ពួកសាសន៍លេមិន; ត្បិតមកពីសណ្ដាប់ទាំងឡាយនៃពួក
អយ្យកោរបស់ គេ ដែលបានធ្វើឲ្យពួកគេស្ថិតនៅក្នុង
ស្ថានភាពល្ងិតល្ងង់; ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់នឹងមាន
សេចក្ដីមេត្តាករុណាដល់គេ ហើយទុកឲ្យគេរស់នៅលើផែ
នដីនេះតទៅ ។
១៧ ហើយនៅពេលណាមួយ នោះពួកគេនឹងត្រូវបាននាំឲ្យ
ជឿដល់ព្រះបន្ទូលរបស់ទ្រង់ ហើយឲ្យដឹងនូវការខុសរបស់
សណ្ដាប់ ទាំងឡាយ នៃពួកអយ្យកោរបស់គេ; ហើយពួកគេ
ជាច្រើននឹងបានសង្គ្រោះ ព្រោះព្រះអម្ចាស់ ទ្រង់នឹងមានសេច
ក្ដីមេត្តាករុណាដល់ អស់អ្នកណាដែលអំពាវនាវដល់
ព្រះនាមទ្រង់ ។
១៨ ប៉ុន្តែមើលចុះ ខ្ញុំសូមប្រាប់អ្នកថា បើសិនជាអ្នករាល់
គ្នានៅតែទទឹងធ្វើអំពើទុច្ចរិត នោះជីវិតរបស់អ្នកនឹងពុំត្រូវបាន
ពន្យារ នៅលើផែនដីឡើយ ត្បិតពួកលេមិននឹងត្រូវបានចាត់ឲ្យ
វាយមកលើអ្នកវិញ; ហើយបើអ្នករាល់គ្នាមិនប្រែចិត្តទេ នោះ
ពួកគេនឹងមក ក្នុងពេលដែលអ្នកពុំដឹង ហើយអ្នករាល់គ្នានឹង
ត្រូវជួបនឹងការបំផ្លិចបំផ្លាញទាំងស្រុង; ហើយការណ៍នេះ
នឹងកើតឡើង តាមសេចក្ដី ពិរោធដ៏ខ្លាល់នៃព្រះអម្ចាស់ ។
១៩ ត្បិតទ្រង់នឹងពុំទ្រាំឲ្យអ្នករស់នៅក្នុងសេចក្ដីទុច្ចរិត ដើម្បី
បំផ្លាញរាស្ត្រទ្រង់ឡើយ ។ ខ្ញុំសូមប្រាប់អ្នកថា៖ ទេ; ទ្រង់សុខ
ចិត្តឲ្យពួក លេមិនបំផ្លាញរាស្ត្រទ្រង់ទាំងអស់ ដែលហៅថា
ប្រជាជននីហ្វៃវិញ បើសិនជាពួកគេធ្លាក់ទៅក្នុងអំពើបាបទាំង
ឡាយ និងអំពើល្មើស ទាំងឡាយ ក្រោយពីបានទទួល
ពន្លឺដ៏ច្រើន និងការចេះដឹងដ៏ច្រើន ដែលបានប្រទានឲ្យគេ
ដោយព្រះអម្ចាស់ ជាព្រះរបស់គេ ។
២០ មែនហើយ បន្ទាប់ពីបានទៅជាប្រជាជនដ៏សំណប់
ជាខ្លាំងនៃព្រះ; មែនហើយ បន្ទាប់ពីបានប្រោសប្រណីលើគ្រប់
ទាំងសាសន៍ ទាំងពូជមនុស្ស ទាំងភាសា ទាំងប្រជាជនឯទៀត;
ក្រោយពីបានដឹងនូវកិច្ចការទាំងអស់ ស្របតាមការប៉ងប្រាថ្នា
ទាំងឡាយរបស់គេ និងសេចក្ដីជំនឿ និងការអធិស្ឋានរបស់គេ
នូវអ្វីដែលបានកន្លងផុតទៅ អ្វីដែលមាន និងអ្វីដែល
នឹងកើតឡើងក្នុងថ្ងៃមុខ ។
២១ បានព្រះវិញ្ញាណនៃព្រះយាងមកជួប បានសន្ទនាជាមួយ

១២ *ក* អាលម៉ា ៨:១៦;
១០:១៩, ២៣, ២៧.
*ខ* អាលម៉ា ៨:២៩.
១៣ *ក* ២ នីហ្វៃ ១:២០; ម៉ូសាយ ១:៧;
អាលម៉ា ៣៧:១៣.
១៤ *ក* ២ នីហ្វៃ ៥:២០–២៤;
អាលម៉ា ៣៨:១.
១៥ *ក* ម៉ាថាយ ១១:២២, ២៤.
១៦ *ក* អាលម៉ា ១៧:១៥.
*ខ* ម៉ូសាយ ១៨:១១–១៧.
*គ* ម៉ូសាយ ៣:១១.
*ឃ* ហេលេ. ១៥:១០–១២.
១៧ *ក* អេណុស ១:១៣.
*ខ* អាលម៉ា ៣៨:៥; គ. និង ស. ៣:៨.
១៨ *ក* អាលម៉ា ១៦:២–៣.
*ខ* អាលម៉ា ១៦:៩.
*គ* អាលម៉ា ៨:២៩.
១៩ *ក* ១ នីហ្វៃ ១២:១៥, ១៩–២០;
អាលម៉ា ៤៥:១០–១៤.
*ខ* អាលម៉ា ២៤:៣០.
២០ *ក* ស.ប. វិវរណៈ.

នឹងពួកទេវតា ហើយបានឮសម្លេងនៃព្រះអម្ចាស់មានព្រះបន្ទូល
មករក ហើយមានវិញ្ញាណខាងការព្យាករណ៍ និងវិញ្ញាណ
នៃវិវរណៈ និងអំណោយទានជាច្រើនផង អំណោយទានខាង
ការនិយាយ ភាសា និងអំណោយទាននៃការផ្សាយសាសនា
និងអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ និងអំណោយ
ទានខាងការបកប្រែ;
២២ មែនហើយ ហើយបន្ទាប់ពីបានព្រះទ្រង់ដោះលែងឲ្យ
រួចផុតពីដែនដីយេរូសាឡិម ដោយព្រះហស្តនៃព្រះអម្ចាស់;
បន្ទាប់ពីបាន សង្គ្រោះឲ្យរួចពីអំណត់អត់ និងពីជម្ងឺ និងពីរោគា
គ្រប់បែបយ៉ាង; ហើយពួកគេមានកម្លាំងខ្លាំងពូកែនៅក្នុង
ចម្បាំង ដើម្បីកុំឲ្យពួកគេត្រូវ បំផ្លាញបង់; ត្រូវបាននាំឲ្យ
រួចផុតពីសេវកភាពច្រើនលើកច្រើនគ្រា ហើយត្រូវបានរក្សាឲ្យ
គង់វង់ រហូតដល់ពេលឥឡូវនេះ; ហើយពួក គេបានចំរើនឡើង
រហូតដល់គេមានទ្រព្យគ្រប់បែបយ៉ាង —
២៣ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា បើ
សិនជាប្រជាជននេះ ដែលបានទទួលពរជាច្រើន ពីព្រះហស្តនៃ
ព្រះអម្ចាស់ បែរជាធ្វើអំពើល្មើសផ្ទុយទៅនឹងពន្លឺ និងការចេះដឹង
ដែលគេមានទៅវិញ ខ្ញុំសូមប្រាប់អ្នកថា បើសិនជានៅ
ក្នុងករណីនេះថា បើសិន ជាគេធ្លាក់ទៅក្នុងអំពើល្មើស នោះ
ពួកលេមិននឹងទ្រាំបានងាយជាងពួកគេ ។
២៤ ត្បិតមើលចុះ ខសន្យាទាំងឡាយនៃព្រះអម្ចាស់ ត្រូវ
បានឲ្យទៅពួកលេមិន តែខសន្យាទាំងនោះ មិនឲ្យទៅអ្នកឡើយ
បើសិនជាអ្នករាល់គ្នាធ្វើអំពើល្មើស; ត្បិតតើព្រះអម្ចាស់ទ្រង់ពុំ
បានសន្យាយ៉ាងច្បាស់ ហើយដាក់ច្បាប់ដ៏តឹងរឹងថា បើសិនជា
អ្នករាល់គ្នាបះបោរទាស់នឹងទ្រង់ នោះអ្នករាល់គ្នានឹងត្រូវ
បំផ្លាញចោលឲ្យអស់រលីងចេញពីផ្ទៃផែនដីនេះឬទេ ?
២៥ ហើយឥឡូវ ដោយហេតុនេះថា ដើម្បីកុំឲ្យអ្នករាល់គ្នា
ត្រូវបំផ្លាញបង់ នោះព្រះអម្ចាស់ទ្រង់បានចាត់ឲ្យទេវតារបស់
ទ្រង់ មករករាស្ត្រទ្រង់ជាច្រើនដង ដោយប្រកាសប្រាប់ពួក
គេថា ពួកគេត្រូវចេញទៅ ហើយស្រែកប្រកាសដ៏ខ្លាំងដល់
ប្រជាជននេះថា៖ ចូរប្រែចិត្តចុះ ត្បិតនគរ
ស្ថានសួគ៌នៅជិតដែលបង្កើយ ។
២៦ ហើយនៅមិនយូរថ្ងៃប៉ុន្មានទេ នោះព្រះរាជបុត្រានៃព្រះ
នឹងយាងមក នៅក្នុងសិរីល្អរបស់ទ្រង់; ហើយសិរីល្អរបស់ទ្រង់
នឹងទៅជាសិរីល្អរបស់ព្រះរាជបុត្រាបង្កើតតែមួយនៃ
ព្រះវរបិតា ពោរពេញទៅដោយព្រះគុណ សេចក្ដីយុត្តិធម៌
និងសេចក្ដីពិត ពោរពេញទៅដោយសេចក្ដីអត់ធន់ សេចក្ដី
មេត្តាករុណា ហើយសេចក្ដីអត់ធ្មត់ ឆាប់ឮសំរែករបស់
រាស្ត្រទ្រង់ ហើយឆ្លើយតប ដល់ពាក្យអធិស្ឋានរបស់គេផង ។
២៧ ហើយមើលចុះ ទ្រង់នឹងយាងមកប្រោសលោះអស់អ្នក
ណា ដែលនឹងទទួលបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្ត ស្រប
តាមសេចក្ដីជំនឿជឿដល់ព្រះនាមទ្រង់ ។
២៨ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នារៀបចំផ្លូវទទួលព្រះ
អម្ចាស់ចុះ ព្រោះពេលនោះនៅជិតដែលបង្កើយ ដែលមនុស្ស
លោក ទាំងអស់នឹងប្រូតនូវរង្វាន់នៃកិច្ចការទាំងឡាយរបស់ខ្លួន
ស្របតាមអ្វីៗដែលគេបានប្រព្រឹត្ត — បើសិនជាពួក
គេសុចរិត នោះពួកគេ នឹងប្រូតយកសេចក្ដីសង្គ្រោះដល់
ព្រលឹងគេ ស្របតាមព្រះចេស្ដា និងការដោះលែងនៃ
ព្រះយេស៊ូវគ្រីស្ទ; ហើយបើសិនជាពួកគេ អាក្រក់វិញ នោះ
ពួកគេនឹងប្រូតយកសេចក្ដីផាប់ទោសនៃព្រលឹងទាំងឡាយរបស់គេ
ស្របតាមអំណាច និងការជាប់ឃុំឃាំងនៃអារក្ស ។
២៩ ឥឡូវនេះ មើលចុះ នេះគឺជាសម្លេងនៃទេវតា
ស្រែកប្រកាសដល់ប្រជាជន ។
៣០ ហើយឥឡូវនេះ នែ៎ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ព្រោះអ្នករាល់គ្នាជាបងប្អូនរបស់ខ្ញុំ ហើយអ្នករាល់គ្នា
គួរតែជាទី ស្រឡាញ់ ហើយអ្នករាល់គ្នាគួរតែនាំមកនូវកិច្ចការ
ទាំងឡាយ ដែលសមនឹងការប្រែចិត្ត ដោយឃើញថា ចិត្តអ្នក
បានរឹងទទឹងជាខ្លាំង ទាស់នឹងព្រះបន្ទូលនៃព្រះ ហើយដោយ

២១ *ក* អេមណៃ ១:២០;
ម៉ូសាយ ៨:១៣–១៩;
២៨:១១–១៧.
២២ *ក* ២ នីហ្វៃ ១:៤.
*ខ* ម៉ូសាយ ២៧:១៦.
២៣ *ក* ម៉ាថាយ ១១:២២–២៤.
២៤ *ក* ២ នីហ្វៃ ៣០:៤–៦;
គ. និង ស. ៣:២០.
២៥ *ក* អាលម៉ា ៧:៩; ហេលេ. ៥:៣២.
២៦ *ក* អាលម៉ា ៧:៧.
*ខ* ស.ប. បង្កើតតែមួយ.
*គ* ស.ប. ព្រះគុណ.
*ឃ* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
*ង* ចោទិ. ២៦:៧.
២៧ *ក* ស.ប. ប្រោសលោះ, បាន
ប្រោសលោះ, សេចក្ដីប្រោសលោះ.
*ខ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យ
ជ្រមុជទឹក.
២៨ *ក* គ. និង ស. ១:១០; ៦:៣៣.
*ខ* ទំនុក. ៧:១៦.
*គ* ស.ប. សេចក្ដីផាប់ទោស.
៣០ *ក* ១ យ៉ូហាន ៤:១១.

ឃើញថា អ្នករាល់គ្នាជាប្រជាជនមួយ កំពុងតែវង្វេង ហើយធ្លាក់ ។

៣១ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលដែលខ្ញុំ អាលម៉ា បាននិយាយពាក្យអស់ទាំងនេះហើយ មើលចុះ ប្រជាជន ក្រេវក្រោធនឹងខ្ញុំ ព្រោះខ្ញុំបានប្រាប់គេថា គេជាប្រជាជនមួយ ដែលមានចិត្តរឹងរូស ហើយក្បាលរឹង ។

៣២ ហើយម្យ៉ាងទៀត ពីព្រោះខ្ញុំបានប្រាប់គេថា គេជាប្រជាជនមួយ ដែលវង្វេង ហើយធ្លាក់ផង នោះគេខឹងនឹងខ្ញុំ ហើយរកចាប់ខ្ញុំ ដើម្បីយកទៅដាក់គុក ។

៣៣ ប៉ុន្តែហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់ពុំទុកឲ្យពួកគេ ចាប់ខ្ញុំយកទៅដាក់គុក ក្នុងពេលនោះឡើយ ។

៣៤ ហើយហេតុការណ៍បានកើតឡើងថា អាមូលេក បានចេញទៅឈរនៅខាងមុខ ហើយបានចាប់ផ្តើមផ្សាយប្រាប់ពួកគេផង ។ ហើយឥឡូវនេះ ពាក្យពេចន៍របស់អាមូលេក ពុំបានកត់ទុកទាំងអស់ទេ ទោះជាយ៉ាងណាក៏ដោយ គង់តែពាក្យពេចន៍នៃលោកមួយភាគ បានកត់ទុកក្នុងគម្ពីរនេះដែរ ៕

---

## ជំពូកទី ១០

*លីហៃជាពូជរបស់ម៉ានាសេ — អាមូលេករាប់រៀបអំពីបញ្ជាពីទេវតាឲ្យលោកថែទាំដល់អាលម៉ា — ការអធិស្ឋានទាំងឡាយរបស់ ពួកសុចរិត បានជួយឲ្យប្រជាជនរស់នៅ — ពួកមេធាវី និងពួកចៅក្រមដែលទុច្ចរិត សាងមូលដ្ឋាននៃការបំផ្លិចបំផ្លាញប្រជាជន ។ ប្រមាណជាឆ្នាំ ៨២ ម.គ.ស. ។*

ឥឡូវនេះ ពាក្យទាំងនេះគឺជាពាក្យដែលអាមូលេកបានផ្សាយប្រាប់ដល់ប្រជាជន ដែលនៅដែនដីអាំម៉ូណៃហា ថា៖

២ ខ្ញុំគឺអាមូលេក ជាកូនប្រុសរបស់គីឌូណា ដែលជាកូនប្រុសរបស់អ៊ីសម៉ាអែល ដែលត្រូវជាកូនចៅរបស់អ័មីណាដៃ គឺជា អ៊ីប៊ីណាដៃតែមួយនោះ ដែលបានបកប្រែអក្សរនៅលើជញ្ជាំងនៃព្រះវិហារបរិសុទ្ធ ដែលបានសរសេរដោយអង្គុលីនៃព្រះ ។

៣ ហើយអ៊ីប៊ីណាដៃ ជាពូជពង្សរបស់នីហ្វៃ គឺជាកូនប្រុសរបស់លីហៃ ដែលបានចេញពីដែនដីយេរូសាឡិមមក ដែលត្រូវជាពូជពង្ស នៃម៉ានាសេ ដែលជាកូនប្រុសរបស់យ៉ូសែប ដែលត្រូវបានលក់ទៅស្រុកអេស៊ីព្ទ ដោយស្នាដៃរបស់បងៗលោក ។

៤ ហើយមើលចុះ ខ្ញុំក៏ជាមនុស្សម្នាក់ដ៏ពុំខ្វះមនុស្សរាប់អាននៅក្នុងចំណោមមនុស្សទាំងអស់ ដែលស្គាល់ខ្ញុំទេ; មែនហើយ មើលចុះ ខ្ញុំមានសាច់ញាតិ និងមិត្តជាច្រើន ហើយខ្ញុំក៏រកបានទ្រព្យសម្បត្តិជាច្រើន ដោយដៃដ៏ឧស្សាហ៍របស់ខ្ញុំដែរ ។

៥ ទោះជាមានការណ៍អស់ទាំងនេះក៏ដោយ គង់តែខ្ញុំពុំដែលបានដឹងច្រើន អំពីផ្លូវទាំងឡាយនៃព្រះអម្ចាស់ អំពីសេចក្តីអាថ៌កំបាំង ទាំងឡាយ និងអំពីព្រះចេស្តាដ៏អស្ចារ្យរបស់ទ្រង់ដែរ ។ ខ្ញុំបាននិយាយថា ខ្ញុំមិនដែលបានដឹងច្រើននូវរឿងទាំងនេះ; ប៉ុន្តែមើលចុះ ខ្ញុំភាន់ច្រឡំ ព្រោះខ្ញុំបានឃើញច្រើនផង នូវការអាថ៌កំបាំងទាំងឡាយរបស់ទ្រង់ និងព្រះចេស្តាដ៏អស្ចារ្យរបស់ទ្រង់ មែនហើយ ព្រមទាំងការរក្សាជីវិតនៃប្រជាជននេះទុកឲ្យបានគង់វង់ផង ។

៦ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំបានធ្វើចិត្តរឹងរូសដែរ ត្បិតខ្ញុំត្រូវបានហៅជាច្រើនដង តែខ្ញុំធ្វើជាមិនឮ; ហេតុដូច្នេះហើយ ខ្ញុំបានដឹងអំពីការណ៍ទាំងនេះ តែខ្ញុំធ្វើជាមិនដឹង; ហេតុដូច្នេះហើយ ខ្ញុំបានបះបោរទាស់នឹងព្រះ នៅក្នុងសេចក្តីទុច្ចរិតនៃចិត្តខ្ញុំ រហូត ដល់ថ្ងៃទីបួននៃខែទីប្រាំពីរនេះ ដែលនៅឆ្នាំទីដប់ក្នុងរជ្ជកាលនៃពួកចៅក្រម ។

៧ នៅពេលដែលខ្ញុំកំពុងតែធ្វើដំណើរ ទៅសួរសុខទុក្ខញាតិសន្តានដ៏ជិតម្នាក់ មើលចុះ មានទេវតានៃព្រះអម្ចាស់មួយបានលេច មកឲ្យខ្ញុំឃើញ ហើយនិយាយថា៖ អាមូលេកអើយ ចូរអ្នកត្រឡប់ទៅផ្ទះអ្នកវិញចុះ ព្រោះអ្នកនឹងបានប្រទានអាហារដល់ព្យាការីនៃ ព្រះមួយ; មែនហើយ ជាមនុស្សបរិសុទ្ធម្នាក់ គឺជាអ្នកសំណប់នៃព្រះដែលបានរើស; ត្បិតលោកបានតមអាហារអស់ជាច្រើនថ្ងៃមក ហើយ ពីព្រោះតែអំពើបាបរបស់ប្រជាជននេះ

---

៣០ *ខ* អាលម៉ា ១២:២២.
៣១ *ក* ២ នីហ្វៃ ២៥:២៨; ម៉ូសាយ ៣:១៤.
៣៤ *ក* អាលម៉ា ១០.
**១០** ១*ក* អាលម៉ា ៩:៣៤.
*ខ* អាលម៉ា ៨:២១–២៩.
៣ *ក* លោកុ. ៤១:៥១; ១ របា. ៩:៣.
*ខ* ស.ប. យ៉ូសែប, កូនប្រុសរបស់យ៉ាកុប.
*គ* លោកុ. ៣៧:២៩–៣៦.
៤ *ក* អាលម៉ា ១៥:១៦.
៥ *ក* ស.ប. សេចក្តីអាថ៌កំបាំងទាំងឡាយនៃព្រះ.
៦ *ក* អាលម៉ា ៥:៣៧.
*ខ* គ. និង ស. ៣៩:៩.
៧ *ក* អាលម៉ា ៨:២០.
*ខ* អាលម៉ា ៥:៤៦; ៦:៦.
ស.ប. តម, តំណម.

ហើយលោកកំពុងតែឃ្លានអាហារ ហើយអ្នកត្រូវទទួលលោកចូល
ក្នុងផ្ទះអ្នក ហើយ ត្រូវឲ្យអាហារលោកបរិភោគ ហើយលោកនឹង
ប្រទានពរដល់អ្នក និងគ្រួសារអ្នក; ហើយព្រះពរនៃព្រះអម្ចាស់
នឹងសណ្ឋិតលើអ្នក និងលើគ្រួសារអ្នក ។
៨ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានធ្វើតាមសម្លេង
របស់ទេវតានោះហើយក៏ត្រឡប់មកផ្ទះខ្ញុំវិញ ។ ហើយនៅពេល
ដែលខ្ញុំកំពុងតែធ្វើដំណើរមកផ្ទះវិញ នោះខ្ញុំបានជួបនឹងបុរស
ដែលទេវតាបានប្រាប់ខ្ញុំ ថា៖ អ្នកត្រូវទទួលចូលក្នុងផ្ទះអ្នក —
ហើយ មើលចុះ គឺជាបុរសដដែល ដែលធ្លាប់បាននិយាយ
ទៅកាន់អ្នក អំពីកិច្ចការទាំងឡាយនៃព្រះ ។
៩ ហើយទេវតានោះបានប្រាប់ខ្ញុំថា បុរសនោះជាមនុស្ស
បរិសុទ្ធម្នាក់; ហេតុដូច្នោះហើយ ខ្ញុំដឹងថា លោកជាមនុស្ស
បរិសុទ្ធមែន ពីព្រោះទេវតានៃព្រះបានប្រាប់ថាដូច្នោះ ។
១០ ហើយម្យ៉ាងទៀត ខ្ញុំដឹងថា ការណ៍ទាំងឡាយដែលអ្នក
នោះបានធ្វើបន្ទាល់ គឺជាការពិត; ត្បិតមើលចុះ ខ្ញុំសូមប្រាប់អ្នក
ថា ប្រាកដដូចជាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ ព្រមទាំង
បានចាត់ឲ្យទេវតារបស់ទ្រង់ មកសម្ដែងការណ៍ទាំងនេះដល់ខ្ញុំ;
ហើយ ការណ៍នេះ ទ្រង់បានធ្វើនៅពេលដែលអាលម៉ាស្នាក់នៅ
ក្នុងផ្ទះខ្ញុំ ។
១១ ត្បិតមើលចុះ លោកបានប្រទានពរដល់គ្រួសារខ្ញុំ
លោកបានប្រទានពរដល់ខ្ញុំ និងប្រពន្ធខ្ញុំ និងកូនចៅខ្ញុំ និងឪពុកខ្ញុំ
និងក្រុមញាតិរបស់ខ្ញុំ; មែនហើយ គឺអស់ទាំងញាតិសន្ដាន
របស់ខ្ញុំ ក៏លោកបានប្រទានពរឲ្យដែរ ហើយព្រះពរនៃព្រះបាន
ធ្លាក់មក លើយើង ស្របតាមពាក្យដែលលោកបានថ្លែង ។
១២ ហើយឥឡូវនេះ កាលអាមូលេកបាននិយាយពាក្យ
ទាំងនេះហើយ នោះប្រជាជនបានចាប់ផ្ដើមមានសេចក្ដីអស្ចារ្យ
ដោយឃើញថា មានសាក្សីលើសជាងមួយ ដែលបានធ្វើបន្ទាល់
អំពីការណ៍ដែលពួកគេត្រូវចោទ ហើយអំពីការណ៍ទាំងឡាយ
ដែលនឹងកើតឡើង ក្នុងពេលខាងមុខផង ស្របតាមវិញ្ញាណ
នៃការព្យាករណ៍ ដែលនៅក្នុងពួកគេ ។
១៣ ទោះជាយ៉ាងណាក៏ដោយ គង់តែមានមនុស្សខ្លះនៅ
ក្នុងចំណោមពួកគេ ដែលចង់សួរអ្នកទាំងពីរ ក្រែងគេអាចប្រើកល
ល្បិច ដើម្បីចាប់សំដីអ្នកទាំងពីរ ក្រែងគេអាចរកទីទាស់នឹងអ្នក
ទាំងពីរនោះ ដើម្បីគេអាចប្រគល់អ្នកទាំងពីរ ទៅឲ្យចៅក្រមគេ
យកទៅជំនុំជំរះតាមច្បាប់ ហើយដើម្បីយកអ្នកទាំងពីរទៅសម្លាប់
ឬដាក់គុកចោល តាមទោសដែលគេអាចប្រឌិតឡើង ឬធ្វើជា
សាក្សីទាស់នឹងអ្នកទាំងពីរ ។
១៤ ឥឡូវនេះ ពួកអ្នកដែលចង់បំផ្លាញអ្នកទាំងពីរនោះ
គឺជាពួកមេធាវី ដែលបានជួល ឬបានតែងតាំងឡើងដោយ
ប្រជាជន ដើម្បី អភិបាលច្បាប់ នៅពេលជំនុំ ឬនៅក្នុង
ការជំនុំទោសឧក្រិដ្ឋរបស់ប្រជាជន នៅខាងមុខពួកចៅក្រម ។
១៥ ឥឡូវនេះ ពួកមេធាវីទាំងនេះ បានរៀនចេះនូវការ
ប្រសប់ និងឧបាយកលទាំងអស់នៃប្រជាជន; ហើយការណ៍នេះ
គឺដើម្បីធ្វើឲ្យ គេស្ទាត់ជំនាញ ក្នុងមុខរបររបស់គេ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ចាប់ផ្ដើមសួរអាមូលេក ក្រែងគេអាចធ្វើឲ្យលោក ឆ្លើយខុស
នឹងសំដីខ្លួន ឬផ្ទុយនឹងពាក្យដែលលោកបាននិយាយ ។
១៧ ឥឡូវនេះ ពួកគេពុំបានដឹងថា អាមូលេកអាចដឹងនូវ
បំណងរបស់គេនោះឡើយ ។ ប៉ុន្ដែហេតុការណ៍បានកើតឡើងថា
នៅ ពេលដែលពួកគេចាប់ផ្ដើមសួរលោក នោះលោកបាន
យល់ដល់គំនិតរបស់គេ ហើយលោកបាននិយាយទៅគេថា៖
នែ៎ ពួកតំណ មនុស្សទុច្ចរិត និងខូចអើយ គឺពួកមេធាវី និងពួក
អ្នកមានពុត ត្បិតអ្នករាល់គ្នាកំពុងតែសាងមូលដ្ឋាននៃអារក្ស;
ព្រោះអ្នករាល់គ្នាកំពុង តែដាក់អន្ទាក់ និងអង្គប់ ដើម្បីចាប់
មនុស្សបរិសុទ្ធនៃព្រះទេតើ ។
១៨ អ្នករាល់គ្នាកំពុងតែធ្វើផែនការ ដើម្បីបង្ខូចផ្លូវទាំង
ឡាយនៃពួកសុចរិត ហើយនាំសេចក្ដីពិរោធនៃព្រះ ឲ្យធ្លាក់មក
លើក្បាលអ្នក គឺនាំមកនូវការបំផ្លិចបំផ្លាញដល់ប្រជាជននេះ
ទាំងស្រុង ។
១៩ មែនហើយ ម៉ូសាយ ជាស្ដេចចុងក្រោយបង្អស់របស់យើង
កាលដែលទ្រង់ជិតប្រគល់នគរ តែគ្មានអ្នកណាដែលទ្រង់នឹង
ប្រគល់សោះ ទើបបានឲ្យប្រជាជននេះអភិបាល ដោយសម្លេង
របស់ខ្លួន មានបន្ទូលយ៉ាងច្បាស់ថា — មែនហើយ ទ្រង់បាន
មានបន្ទូល យ៉ាងច្បាស់ថា បើដល់ពេលណាសម្លេងរបស់

៧ *គ* កិច្ចការ ១០:៣០–៣៥.
៨ *ក* អាលម៉ា ៨:១៩–២១.
៩ *ក* ស.ប. បរិសុទ្ធ.
១០ *ក* អាលម៉ា ១១:៣០–៣១.
*ខ* អាលម៉ា ៨:២៧.
១១ *ក* អាលម៉ា ៨:២២.
១២ *ក* អាលម៉ា ៩:៦.
១៣ *ក* អាលម៉ា ១១:២១.
១៤ *ក* អាលម៉ា ១០:២៤; ១១:២០–២១; ១៤:១៨.
១៧ *ក* អាលម៉ា ១២:៣; ២០:១៨, ៣២; គ. និង ស. ៦:១៦.
*ខ* ម៉ាថាយ ៣:៧; អាលម៉ា ៩:៨.
*គ* គ. និង ស. ១០:២១–២៧.
១៨ *ក* កិច្ចការ ១៣:១០.

ប្រជាជន[ក]រើសយកសេចក្ដីទុច្ចរិត បានន័យថា បើដល់ពេលណា
ដែលប្រជាជនធ្លាក់ទៅ ក្នុងអំពើល្មើស គឺពួកគេបានទុំសុស
ដើម្បីបំផ្លិចបំផ្លាញចោលហើយ ។
២០ ហើយឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកថា ព្រះអម្ចាស់ទ្រង់
ជំនុំជំរះយ៉ាងត្រឹមត្រូវ ចំពោះអំពើទុច្ចរិតទាំងឡាយរបស់អ្នក;
ទ្រង់ស្រែក ប្រកាសប្រាប់យ៉ាងដាក់ ដោយសម្លេងនៃ[ក]ពួក
ទេវតារបស់ទ្រង់ មករកប្រជាជននេះថា៖ ចូរអ្នកប្រែចិត្តចុះ
ចូរប្រែចិត្តចុះ ត្បិតនគរស្ថាន សួគ៌នៅជិតដែបង្កើយ ។
២១ មែនហើយ ទ្រង់ស្រែកប្រាប់យ៉ាងដាក់ ដោយសម្លេងនៃ
ពួកទេវតារបស់ទ្រង់ថា៖ [ក]យើងនឹងចុះមកក្នុងចំណោមរាស្ត្រយើង
ដោយសេចក្ដីពិត និងសេចក្ដីយុត្តិធម៌នៅក្នុងដៃយើង ។
២២ មែនហើយ ហើយខ្ញុំសូមប្រាប់អ្នកថា បើសិនជាពុំដោយ
សារ[ក]ការអធិស្ឋានទាំងឡាយនៃពួកសុចរិត ដែលនៅលើដែនដី
ឥឡូវ នេះទេ នោះអ្នករាល់គ្នាច្បាស់ជាឥឡូវនេះត្រូវពិនិត្យពិច័យ
ដោយការបំផ្លិចបំផ្លាញទាំងស្រុងទៅហើយ ទោះពុំត្រូវបំផ្លាញ
ដោយ[ខ]ទឹក ជំនន់ ដូចប្រជាជនក្នុងជំនាន់លោកណូអេក្ដី គង់តែ
នឹងត្រូវបំផ្លាញ ដោយអំណត់អត់ ដោយជម្ងឺអាសន្នរោគ
និងដោយដាវដែរ ។
២៣ តែដោយសារ[ក]ការអធិស្ឋានទាំងឡាយនៃពួកសុចរិត
ទើបអ្នករាល់គ្នាត្រូវបាននៅរស់; ឥឡូវនេះ ហេតុដូច្នេះហើយ
បើសិនជា អ្នករាល់គ្នាបណ្ដេញពួកសុចរិតចេញពីចំណោមអ្នក
ខណៈនោះ ព្រះអម្ចាស់ទ្រង់នឹងពុំទប់ព្រះហស្តរបស់ទ្រង់ឡើយ;
តែនៅក្នុងសេចក្ដី ពិរោធដ៏ខ្លាំងរបស់ទ្រង់ ទ្រង់នឹងមកទាស់នឹង
អ្នក; ខណៈនោះ អ្នកនឹងត្រូវវាយដោយអំណត់អត់ ដោយជម្ងឺ
អាសន្នរោគ និងដោយដាវ; [ខ]ឯពេលនោះជិតមកដល់ហើយ
លើកលែងអ្នកប្រែចិត្ត ។
២៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ប្រជាជន
ខឹងនឹងអាមូលេកកាន់តែខ្លាំងឡើង ហើយពួកគេបានស្រែកថា៖
អ្នកនេះបានជេរប្រមាថដល់ច្បាប់ទាំងឡាយរបស់យើងដែល
ត្រឹមត្រូវ និងដល់ពួកមេធាវីដ៏ឈ្លាសវៃរបស់យើង ដែលយើង
បានរើស តាំងឡើង ។
២៥ តែអាមូលេកបានលាតដៃលោក ហើយស្រែកជា
ខ្លាំងទៅគេថា៖ នែ៎ ពួកតំណមនុស្សទុច្ចរិច និងខូចអើយ
ហេតុអ្វីបានជាត្រូវ អារក្សសាតាំងក្ដាប់ជាប់នូវដួងចិត្តរបស់អ្នក
ដូច្នេះ ? ហេតុអ្វី[ក]បានជាអ្នកបណ្ដោយខ្លួនឲ្យវាមានអំណាចមក
លើអ្នក ធ្វើឲ្យអ្នកងងឹតភ្នែក ដើម្បីកុំឲ្យអ្នកយល់ពាក្យទាំងឡាយ
ដែលបាននិយាយតាមការពិតទៅវិញ ?
២៦ ត្បិតមើលចុះ តើខ្ញុំបានធ្វើបន្ទាល់ទាស់នឹងច្បាប់របស់
អ្នកឬ ? អ្នករាល់គ្នាមិនយល់ទេ; អ្នករាល់គ្នានិយាយថា ខ្ញុំបាន
និយាយទាស់នឹងច្បាប់អ្នកទៅវិញ; តែខ្ញុំពុំបានធ្វើយ៉ាងនោះទេ
តែខ្ញុំបាននិយាយក្នុងការគាំទ្រដល់ច្បាប់របស់អ្នក
ដើម្បីកាត់ទោស ដល់អ្នកវិញទេតើ ។
២៧ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា មូលដ្ឋាន
នៃការបំផ្លិចបំផ្លាញប្រជាជននេះ បានចាប់ផ្ដើមសាងឡើង ដោយ
អំពើ ដ៏ឥតសុចរិតរបស់[ក]ពួកមេធាវី និងពួកចៅក្រមរបស់អ្នក ។
២៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
អាមូលេកបាននិយាយពាក្យទាំងនេះហើយ នោះប្រជាជនបាន
ស្រែក ទាស់នឹងលោកថា៖ ឥឡូវនេះ យើងដឹងថា មនុស្ស
នេះជាកូននៃអារក្ស ព្រោះវាបានកុហកដល់យើង; ព្រោះវាបាន
និយាយទាស់នឹង ច្បាប់របស់យើង ។ ប៉ុន្តែឥឡូវនេះ វា
និយាយថា វាមិនបាននិយាយទាស់នឹងច្បាប់របស់យើងទេ ។
២៩ ហើយម៉្យាងទៀត វាបានបង្អាប់ដល់ពួកមេធាវីរបស់យើង
និងពួកចៅក្រមរបស់យើង ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ពួកមេធាវីបាន
បញ្ចូលទៅក្នុងចិត្តប្រជាជនថា គេត្រូវចាំការណ៍ទាំងនេះ
ដើម្បីទាស់នឹង លោក ។
៣១ ហើយនៅក្នុងចំណោមពួកគេ មានមនុស្សម្នាក់ឈ្មោះ
ស៊ីអែសរ៉ុម ។ ឥឡូវនេះ មនុស្សនេះគឺជាអ្នកដឹកមុខគេ ក្នុង
[ក]ការចោទ ប្រកាន់អាមូលេក និងអាលម៉ា គាត់ជាអ្នក
ជំនាញការបំផុតម្នាក់ ក្នុងចំណោមពួកគេ ដោយមាន
កិច្ចការទាក់ទងជាច្រើន ក្នុងចំណោម ប្រជាជន ។
៣២ ឥឡូវនេះ គោលបំណងរបស់ពួកមេធាវីទាំងនេះ
គឺស្វែងរកកំរៃដល់ខ្លួន ហើយគេបានកំរៃ ស្របតាមមុខរបររបស់
ពួកគេ ៕

១៩ *ក* ម៉ូសាយ ២៩:២៧;
អាលម៉ា ២:៣–៧; ហេលេ. ៥:២.
២០ *ក* អាលម៉ា ៨:១៤–១៦; ១៣:២២.
២១ *ក* ម៉ូសាយ ១៣:៣៤.
២២ *ក* យ៉ាកុប (ព.ស.ថ.) ៥:១៦;
ម៉ូសាយ ២៧:១៤–១៦.
*ខ* លោកុ. ៨:២១;
៣ នីហ្វៃ ២២:៨–១០.
ស.ប. ទឹកជំនន់នៅសម័យណូអេ.
២៣ *ក* ស.ប. ការអធិស្ឋាន.
*ខ* អាលម៉ា ៣៤:៣២–៣៥.
២៥ *ក* ២ កូរិន. ៤:៤; អាលម៉ា ១៤:៦.
២៧ *ក* លូកា ១១:៤៥–៥២.
២៨ *ក* អាលម៉ា ១៤:២.
៣១ *ក* អាលម៉ា ១១:២០–៣៦.

## ជំពូកទី ១១

*ប្រាក់របស់សាសន៍នីហ្វៃត្រូវបានចែងប្រាប់ — អាមូលេកដេញដោលគ្នាជាមួយនឹងស៊ីអែសរ៉ុម — ព្រះគ្រីស្ទ នឹងពុំសង្គ្រោះមនុស្ស ដែល នៅក្នុងអំពើបាបឡើយ — មានតែពួកអ្នកដែលគ្រងនគរស្ថានសួគ៌ទុកជាមរតកទេ ដែលនឹងបានសង្គ្រោះ — មនុស្សលោកទាំងអស់នឹង រស់ពីស្លាប់ឡើងវិញ នៅក្នុងអមតភាព — គ្មានសេចក្ដីស្លាប់ទេ បន្ទាប់ពីដំណើររស់ឡើងវិញ ។ ប្រមាណជាឆ្នាំ ៨២ ម.គ.ស. ។*

ឥឡូវនេះ នៅក្នុងក្រិត្យវិន័យនៃហ្លួងម៉ូសាយ បានចែងថា ជន
គ្រប់រូបដែលជាចៅក្រមនៃច្បាប់ ឬក៏អស់អ្នកណា ដែលត្រូវ
បានតែង តាំងឡើងជាចៅក្រម នឹងបានទទួលឈ្នួល តាម
ពេលវេលា ដែលគេបានធ្វើការជំនុំជំរះ ដល់ពួកអ្នកដែលបាន
នាំមកចំពោះមុខគេ ដើម្បីជំនុំជំរះនោះ ។
២ ឥឡូវនេះ បើសិនជាមនុស្សម្នាក់ជំពាក់អ្នកផ្សេងទៀត
ហើយជននោះពុំសងបំណុលនោះទេ ហើយត្រូវគេប្ដឹងទៅ
ដល់ចៅក្រម; ហើយចៅក្រមអនុវត្តអំណាច ហើយចាត់
ពួកភ្នាក់ងារឲ្យទៅនាំជននោះមកចំពោះចៅក្រម; ហើយចៅក្រមក៏
ជំនុំជំរះជននោះតាមច្បាប់ និងភស្តុតាងទាំងឡាយ ដែលបាន
យកមកទាស់នឹងជននោះ ហើយដោយហេតុនេះ ជននោះត្រូវ
បង្ខំឲ្យសងនូវអ្វីៗ ដែលខ្លួនជំពាក់គេ បើពុំសងទេ នោះនឹងត្រូវ
រឹបយកទ្រព្យសម្បត្តិ ឬក៏ត្រូវបណ្ដេញចេញពីចំណោមពួក
ប្រជាជន ដូចជាចោរលួច និងចោរប្លន់ ។
៣ ហើយចៅក្រមទទួលឈ្នួល តាមពេលវេលារបស់ខ្លួន —
មាសមួយស៊ីណាញសំរាប់មួយថ្ងៃ ឬប្រាក់មួយស៊ីនុម ដែល
ស្មើទៅនឹង មាសមួយស៊ីណាញ; ហើយនេះគឺស្របតាមច្បាប់
ដែលបានចែងទុក ។
៤ ឥឡូវនេះ គឺជាឈ្មោះមាស និងប្រាក់ផ្សេងៗ តាមតម្លៃវា ។
ឯឈ្មោះទាំងនេះត្រូវបានដាក់ដោយពួកសាសន៍នីហ្វៃ ព្រោះ
ពួកគេ ពុំបានគិតតាមរបៀបពួកសាសន៍យូដា ដែល
នៅក្រុងយេរូសាឡិមទេ; ហើយពួកគេក៏ពុំវាស់តាមរបៀបពួក
សាសន៍យូដាដែរ; ប៉ុន្តែពួកគេ បានកែប្រែការគិតគូររបស់ពួក
គេ និងការវាស់របស់ពួកគេ ស្របទៅនឹងគំនិត និង
កាលៈទេសៈ នៃប្រជាជនគ្រប់ជំនាន់ រហូតមកដល់ រជ្ជកាលនៃ
ពួកចៅក្រម ដែលបានបង្កើតឡើង ដោយស្ដេចម៉ូសាយ ។
៥ ឥឡូវនេះ ការគិតគូរបានស្គាល់ដូចតទៅនេះ —
មាសមួយស៊ីណាញ មាសមួយស៊ីអុន មាសមួយស៊ុម និង
មាសមួយលិមណា ។
៦ ប្រាក់មួយស៊ីនុម ប្រាក់មួយអាំណូរ ប្រាក់មួយអែសរុម និង
ប្រាក់មួយអុនតៃ ។
៧ ប្រាក់មួយស៊ីនុមស្មើនឹងមាសមួយស៊ីណាញ ឯណាមួយក៏ស្មើ
នឹងស្រូវឱកមួយរង្វាល់ ហើយក៏ស្មើនឹងមួយរង្វាល់នៃគ្រាប់
ធញ្ញជាតិគ្រប់មុខ ។
៨ ឥឡូវនេះ ចំនួនមាសមួយស៊ីអុន មានតម្លៃស្មើនឹង
ពីរស៊ីណាញ ។
៩ ហើយមាសមួយស៊ុម មានតម្លៃស្មើនឹងពីរស៊ីអុន ។
១០ ហើយមាសមួយលិមណា មានតម្លៃស្មើនឹងចំនួនទាំង
អស់នោះបូករួមមក ។
១១ ហើយប្រាក់មួយអាំណូរស្មើរនឹងពីរស៊ីនុម ។
១២ ហើយប្រាក់មួយអែសរុមស្មើនឹងបួនស៊ីនុម ។
១៣ ហើយមួយអុនតៃស្មើនឹងវត្ថុទាំងអស់នោះបូករួមមក ។
១៤ ឥឡូវនេះ នេះហើយជាតម្លៃនៃលេខតូចជាងក្នុងក្បួន
រាប់របស់គេ —
១៥ មួយស៊ិបឡុនស្មើនឹងកន្លះស៊ីនុម; ហេតុដូច្នេះហើយ មួយ
ស៊ិបឡុនស្មើនឹងកន្លះរង្វាល់ស្រូវឱក ។
១៦ ហើយមួយស៊ិបលុមស្មើនឹងកន្លះស៊ិបឡុន ។
១៧ ហើយមួយលេអាស្មើនឹងកន្លះស៊ិបលុម ។
១៨ ឥឡូវនេះ នេះហើយជាលេខរបស់គេ ស្របតាមក្បួន
រាប់របស់គេ ។
១៩ ឥឡូវនេះ មាសមួយអាន់ទីអូនស្មើនឹងបីស៊ិបឡុន ។
២០ ឥឡូវនេះ ក្នុងគោលបំណងចង់បានកំរៃតែប៉ុណ្ណោះ
ពីព្រោះពួកគេទទួលប្រាក់ខែតាមមុខការ ហេតុដូច្នេះហើយ
ពួកគេបានចាក់ រុកឲ្យប្រជាជនឈ្លោះវាយតប់គ្នា ហើយមាន
ការច្របូកច្របល់ និងអំពើទុច្ចរិតគ្រប់បែបយ៉ាង ដើម្បីឲ្យពួក
គេអាចមានការធ្វើ ច្រើនថែម ឡើងទៀត ដើម្បីពួកគេ
អាចរកប្រាក់បានតាមបណ្ដឹងទាំងឡាយ ដែលគេបានប្ដឹង;
ហេតុដូច្នេះហើយ ពួកគេបានចាក់រុកឲ្យប្រជាជនទាស់នឹង
អាលម៉ា និងអាមូលេក ។
២១ ហើយស៊ីអែសរ៉ុមនេះឯងបានចាប់ផ្ដើមចោទសួរអាមូលេក
ថា៖ តើអ្នកនឹងឆ្លើយនូវសំនួរបន្តិចបន្តួច ដែលខ្ញុំនឹងសួរអ្នកឬទេ?
ឥឡូវនេះ ស៊ីអែសរ៉ុម ជាមនុស្សដែលស្ទាត់ជំនាញនឹង
មធ្យោបាយទាំងឡាយនៃអារក្ស ដើម្បីគាត់អាចបំផ្លាញចោលនូវ

១១ ៤*ក* ម៉ូសាយ ២៩:៤០–៤៤.
២០ *ក* អាលម៉ា ១០:៣២.
២១ *ក* អាលម៉ា ១០:១៣.

អ្វីៗដែលល្អ; ហេតុដូច្នេះហើយ គាត់បាននិយាយទៅកាន់អាមូលេកថា៖ តើអ្នកនឹងឆ្លើយនូវសំនួរទាំងឡាយ ដែលខ្ញុំនឹងសួរអ្នកឬទេ ?

២២ ហើយអាមូលេកបានតបទៅគាត់ថា៖ មែនហើយ បើសិនជាស្របតាម[ក]ព្រះវិញ្ញាណនៃព្រះអម្ចាស់ ដែលនៅក្នុងខ្លួនខ្ញុំ; ត្បិតខ្ញុំនឹងពុំ និយាយអ្វីដែលផ្ទុយនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់ឡើយ ។ ហើយស៊ីអែសរ៉ុមបាននិយាយទៅលោកថា៖ មើលចុះ នេះគឺប្រាក់ប្រាំមួយអុនតៃ ហើយខ្ញុំនឹងប្រគល់ប្រាក់ទាំងអស់នេះដល់អ្នក បើសិនជាអ្នកព្រមបដិសេធថា គ្មានព្រះដ៏ខ្ពស់បំផុតឡើយនោះ ។

២៣ ឥឡូវនេះ អាមូលេកបាននិយាយថា៖ នែ៎[ក]កូននៃស្ថាននរកអើយ ហេតុអ្វីបានជាអ្នកមក[ខ]ល្បួងខ្ញុំ? តើអ្នកដឹងទេថា ពួកសុចរិតពុំ ដែលបណ្ដោយតាមការល្បួងបែបនេះឡើយ ?

២៤ តើអ្នកជឿថាគ្មានព្រះឬ ? ខ្ញុំសូមប្រាប់អ្នកថា ទេ អ្នកដឹងថា មានព្រះមួយអង្គពិត ប៉ុន្តែអ្នកស្រឡាញ់[ក]ប្រយោជន៍ជាងព្រះអង្គ ។

២៥ ហើយឥឡូវនេះ អ្នកបានកុហកដល់ខ្ញុំនៅចំពោះព្រះ ។ អ្នកបាននិយាយមកខ្ញុំថា — មើលចុះ នេះគឺប្រាំមួយអុនតៃ ដែលមាន តម្លៃយ៉ាងច្រើន ខ្ញុំនឹងឲ្យដល់អ្នក — តែនៅពេលនោះ នៅក្នុងចិត្តរបស់អ្នក អ្នកពុំចង់ឲ្យខ្ញុំទេ; ហើយអ្នកមានបំណងចង់ឲ្យខ្ញុំបដិសេធ ព្រះដ៏ពិត ហើយមានព្រះជន្មរស់នៅតែប៉ុណ្ណោះ ដើម្បីអ្នកអាចមានហេតុនឹងបំផ្លាញខ្ញុំទេតើ ។ ហើយឥឡូវនេះ មើលចុះ សំរាប់អំពើអាក្រក់ដ៏ធំនេះ អ្នកនឹងបានទទួលរង្វាន់ហើយ ។

២៦ ហើយស៊ីអែសរ៉ុមបាននិយាយទៅលោកថា៖ តើអ្នកនិយាយថា មានព្រះមួយអង្គដ៏ពិត ហើយមានព្រះជន្មរស់នៅឬ ?

២៧ ហើយអាមូលេកបានឆ្លើយថា៖ មែនហើយ មានព្រះមួយអង្គដ៏ពិត ហើយមានព្រះជន្មរស់នៅ ។

២៨ ឥឡូវនេះ ស៊ីអែសរ៉ុមបាននិយាយថា៖ តើមានព្រះច្រើនជាងមួយអង្គឬ ?

២៩ ហើយលោកបានឆ្លើយថា៖ ទេ ។

៣០ ឥឡូវនេះ ស៊ីអែសរ៉ុមបាននិយាយទៅលោកទៀតថា៖ ហេតុដូចម្ដេចក៏អ្នកដឹងរឿងទាំងនេះ ?

៣១ ហើយលោកបានឆ្លើយថា៖ [ក]ទេវតាមួយបានប្រាប់រឿងនោះឲ្យខ្ញុំដឹង ។

៣២ ហើយស៊ីអែសរ៉ុមបាននិយាយទៀតថា៖ តើនរណាទៅដែលនឹងយាងមក ? ជាព្រះរាជបុត្រានៃព្រះមែនទេ ?

៣៣ ហើយលោកបានតបទៅគាត់ថា៖ មែនហើយ ។

៣៤ ហើយស៊ីអែសរ៉ុមបាននិយាយទៀតថា៖ តើព្រះអង្គនឹងជួយសង្គ្រោះរាស្ត្ររបស់ព្រះអង្គ [ក]ក្នុងអំពើបាបទាំងឡាយរបស់ពួកគេឬ ? ហើយអាមូលេកបានឆ្លើយ ហើយតបទៅគាត់ថា៖ ខ្ញុំសូមប្រាប់អ្នកថា ព្រះអង្គនឹងពុំធ្វើដូច្នោះឡើយ ត្បិតព្រះអង្គពុំអាចបដិសេធពាក្យ របស់ព្រះអង្គបានឡើយ ។

៣៥ ឥឡូវនេះ ស៊ីអែសរ៉ុមបាននិយាយទៅប្រជាជនថា៖ សូមអ្នករាល់គ្នាចាំនូវរឿងទាំងនេះចុះ; ព្រោះមនុស្សនេះបានពោលថា មានព្រះតែមួយអង្គប៉ុណ្ណោះ; ក៏ប៉ុន្តែលោកបានថា ព្រះរាជបុត្រានៃព្រះនឹងយាងមក ប៉ុន្តែព្រះអង្គនឹងពុំសង្គ្រោះរាស្ត្ររបស់ព្រះអង្គឡើយ — ហាក់ដូចជាខ្លួនលោកមានសិទ្ធិអំណាចបញ្ជាដល់ព្រះដូច្នោះ ។

៣៦ ឥឡូវនេះ អាមូលេកបានតបទៅគាត់ទៀតថា៖ មើលចុះ អ្នកកុហកទេ ព្រោះអ្នកបាននិយាយថា ខ្ញុំនិយាយបីដូចជាខ្ញុំមានសិទ្ធិ អំណាចនឹងបញ្ជាដល់ព្រះវិញ ពីព្រោះខ្ញុំបាននិយាយថា ព្រះអង្គនឹងពុំសង្គ្រោះរាស្ត្ររបស់ព្រះអង្គ ក្នុងអំពើបាបទាំងឡាយរបស់ពួកគេទេតើ ។

៣៧ ហើយខ្ញុំសូមប្រាប់អ្នកទៀតថា ព្រះអង្គពុំអាចសង្គ្រោះពួកគេ [ក]ក្នុងអំពើបាបទាំងឡាយរបស់ពួកគេបានឡើយ; ត្បិតខ្ញុំពុំអាច បដិសេធព្រះបន្ទូលរបស់ព្រះអង្គបានទេ ហើយព្រះអង្គទ្រង់មានព្រះបន្ទូលថា [ខ]គ្មានអ្វីដែលឥតស្អាតអាច[គ]គ្រងនគរស្ថានសួគ៌ទុកជាមរតក បានឡើយ; ហេតុដូច្នេះហើយ តើធ្វើដូចម្ដេចឲ្យអ្នករាល់គ្នានឹងសង្គ្រោះបាន លើកលែងតែអ្នកគ្រងនគរស្ថានសួគ៌ទុកជាមរតកជាមុនសិន ? ហេតុដូច្នេះហើយ អ្នករាល់គ្នានឹងពុំអាចបានសង្គ្រោះ ក្នុងអំពើបាបទាំងឡាយរបស់អ្នកឡើយ ។

២២ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២៣ *ក* អាលម៉ា ៥:៤១.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
២៤ *ក* ១ ធីម៉ូ. ៦:១០; ទីតុស ១:១១.
៣១ *ក* អាលម៉ា ១០:៧–១០.
៣៤ *ក* ហេលេ. ៥:១០–១១.
៣៧ *ក* ១ កូរិន. ៦:៩–១០.
*ខ* ១ នីហ្វៃ ១៥:៣៣; អាលម៉ា ៤០:២៦; ៣ នីហ្វៃ ២៧:១៩. ស.ប. ពួកទមិឡល្មើស, អំពើដ៏ឥតបរិសុទ្ធ.
*គ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.

៣៨ ឥឡូវនេះ ស៊ីអែសរ៉ុមបាននិយាយទៅលោកទៀតថា៖ តើព្រះរាជបុត្រានៃព្រះ គឺជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចឬ?

៣៩ ហើយអាមូលេកបានតបទៅគាត់ថា៖ មែនហើយ ព្រះអង្គគឺជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ចតែមួយនៃស្ថានសួគ៌ និងផែនដី និងរបស់សព្វសារពើនៅលើនោះទាំងអស់; ព្រះអង្គជាដើមដំបូង និងជាចុង គឺជាមុន និងជាចុងក្រោយបង្អស់ ។

៤០ ហើយព្រះអង្គនឹងយាងមកឯលោកិយ ដើម្បីមកប្រោសលោះរាស្ត្ររបស់ព្រះអង្គ; ហើយព្រះអង្គនឹងទទួលដាក់លើព្រះអង្គ នូវអំពើ រំលងទាំងឡាយនៃអស់អ្នកណាដែលជឿដល់ព្រះនាមព្រះអង្គ; គឺពួកគេនេះហើយដែលនឹងមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយគ្មាន សេចក្ដីសង្គ្រោះនឹងមកដល់អ្នកណាផ្សេងឡើយ ។

៤១ ហេតុដូច្នេះហើយ ពួកទុច្ចរិតនឹងនៅដូច្នេះ ហាក់ដូចជាគ្មានការប្រោសលោះបានកើតឡើង លើកលែងតែការបន្ធូរនូវចំណងទាំង ឡាយនៃសេចក្ដីស្លាប់ប៉ុណ្ណោះ; ត្បិតមើលចុះ ថ្ងៃនោះនឹងមកដល់ កាលមនុស្សទាំងអស់នឹងរស់ពីស្លាប់ឡើងវិញ ហើយឈរនៅចំពោះព្រះ ហើយទទួលការជំនុំជំរះ ស្របតាមកិច្ចការទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ។

៤២ ឥឡូវនេះ មានសេចក្ដីស្លាប់មួយដែលហៅថា សេចក្ដីស្លាប់ខាងសាច់ឈាម; ហើយការសុគតនៃព្រះគ្រីស្ទនឹងផ្ដាច់ចំណងទាំង ឡាយនៃសេចក្ដីស្លាប់ខាងសាច់ឈាមនេះ ដើម្បីឲ្យមនុស្សទាំងអស់អាចបានរស់ឡើងវិញពីសេចក្ដីស្លាប់ខាងសាច់ឈាមនេះ ។

៤៣ វិញ្ញាណ និងរូបកាយនឹងផ្គុំគ្នាជាថ្មី ក្នុងប្រាណដ៏ល្អឥតខ្ចោះ; អវយវៈទាំងអស់នឹងត្រូវបានផ្គុំគ្នាវិញដោយត្រឹមត្រូវដូចជារូបរាង យើងក្នុងពេលនេះដែរ; ហើយយើងនឹងបាននាំទៅឈរនៅចំពោះព្រះ ដោយដឹងនូវអ្វីៗ ដូចជាយើងដឹងក្នុងពេលឥឡូវនេះ ហើយនឹងនឹក ឃើញឡើងវិញយ៉ាងជាក់ច្បាស់នូវអស់ទាំងទោសកំហុសរបស់យើង ។

៤៤ ឥឡូវនេះ ការសាងឡើងវិញនេះ នឹងកើតឡើងដល់មនុស្សទាំងអស់ ទាំងចាស់ទាំងក្មេង ទាំងបាវគេ និងអ្នកសេរី ទាំងប្រុស ទាំងស្រី ទាំងពួកទុច្ចរិត និងពួកសុចរិត; ហើយសូម្បីតែសក់មួយសរសៃនៅលើក្បាលពួកគេក៏ពុំបាត់ផង; អ្វីៗគ្រប់យ៉ាងនឹងបានប្រោស ឡើងវិញ ជារូបរាងដ៏ល្អឥតខ្ចោះ ដូចជាក្នុងពេលឥឡូវនេះ ឬនៅក្នុងរូបកាយដែរ ហើយនឹងបាននាំមក ហើយហៅ ឲ្យឆ្លើយខាងមុខ វេទិកានៃព្រះគ្រីស្ទដ៏ជាព្រះរាជបុត្រា និងព្រះវរបិតាដ៏ជាព្រះ និងព្រះវិញ្ញាណបរិសុទ្ធ ដែលជាព្រះដ៏នៅអស់កល្បជានិច្ចតែមួយ ដើម្បី ទទួលការជំនុំជំរះស្របតាមកិច្ចការទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ដើម្បីឲ្យឃើញថា ពួកគេល្អ ឬក៏ពួកគេអាក្រក់ ។

៤៥ ឥឡូវនេះ មើលចុះ ខ្ញុំបានប្រាប់អ្នក អំពីសេចក្ដីស្លាប់នៃរូបកាយដែលរមែងស្លាប់ និងព្រមទាំងអំពីដំណើររស់ឡើងវិញនៃរូបកាយ ដែលរមែងស្លាប់ដែរ ។ ខ្ញុំសូមប្រាប់អ្នកថា រូបកាយដែលរមែងស្លាប់នេះ នឹងត្រូវបានប្រោសទៅជារូបកាយអមតៈ គឺប្រោសពីសេចក្ដីស្លាប់ ដែលជាសេចក្ដីស្លាប់ដំបូង ឲ្យមានជីវិតឡើងវិញ ដើម្បីកុំឲ្យពួកគេស្លាប់ទៀតឡើយ; វិញ្ញាណរបស់ពួកគេនឹងមករួមជាមួយនឹងរូបកាយ ពួកគេវិញ ហើយពុំអាចបែកគ្នាបានទៀតឡើយ; ម្ល៉ោះហើយ រូបរាងទាំងមូលនឹងក្លាយទៅជារូបរាងខាងវិញ្ញាណ ហើយអមតៈ ដើម្បីកុំឲ្យគេអាចឃើញការពុករលួយទៀតឡើយ ។

៤៦ ឥឡូវនេះ កាលអាមូលេកបានបញ្ចប់ពាក្យទាំងនេះហើយ នោះប្រជាជនបានចាប់ផ្ដើមមានការអស្ចារ្យជាខ្លាំង ឯស៊ីអែសរ៉ុមក៏បានចាប់ផ្ដើមញ័ររន្ធត់ដែរ ។ ម្ល៉ោះហើយ ក៏ចប់ពាក្យពេចន៍របស់អាមូលេកទៅ ឬក៏នេះគឺជាអ្វីទាំងអស់ដែលខ្ញុំបានកត់ទុក ៕

៣៩ *ក* អេសាយ ៩:៦.
*ខ* កូល៉ុស ១:១៦; ម៉ូសាយ ៤:២.
៤០ *ក* ស.ប. ពិភពលោក.
*ខ* រ៉ូម ១១:២៦–២៧.
*គ* និក្ខ. ៣៤:៦–៧; អេសាយ ៥៣:៥; ១ យ៉ូហាន ២:២; ម៉ូសាយ ១៤:៥; ១៥:១២; គ. និង ស. ១៩:១៦–១៩.
៤១ *ក* អាលម៉ា ១២:១៨; គ. និង ស. ៨៨:៣៣.
*ខ* វិវ. ២០:១២–១៣; អាលម៉ា ៤២:២៣.
*គ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
៤២ *ក* អាលម៉ា ១២:១៦.
៤៣ *ក* ២ នីហ្វៃ ៩:១៣; អាលម៉ា ៤០:២៣.
*ខ* ២ នីហ្វៃ ៩:១៤; ម៉ូសាយ ៣:២៥; អាលម៉ា ៥:១៨.
*គ* ស.ប. ទោស.
៤៤ *ក* អាលម៉ា ៤១:១២–១៥.
*ខ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*គ* ៣ នីហ្វៃ ១១:២៧, ៣៦. ស.ប. ព្រះ, ក្រុមព្រះ.
*ឃ* វិវ. ២០:១២–១៣.
៤៥ *ក* អាលម៉ា ៤០:២៣; គ. និង ស. ៨៨:១៦.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* ស.ប. អមតៈ, អមតភាព.
*ឃ* វិវ. ២១:៤; គ. និង ស. ៦៣:៤៩; ៨៨:១១៦.
*ង* ១ កូរិន. ១៥:៤៤.

## ជំពូកទី ១២

*អាលម៉ាជជែកដេញដោលគ្នាជាមួយនឹងស៊ីអែសរ៉ុម — សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ អាចប្រទានដល់តែមនុស្សស្មោះត្រង់ — មនុស្សលោកនឹងបានទទួលការជំនុំជំរះ តាមគំនិត ជំនឿ ពាក្យសំដី និងកិច្ចការរបស់គេ — ពួកទុច្ចរិតនឹងរងទុក្ខសេចក្ដីស្លាប់ខាងវិញ្ញាណ — ជីវិតដែលរមែងស្លាប់នេះ គឺជាស្ថានភាពនៃការសាកល្បង — ផែនការនៃសេចក្ដីប្រោសលោះ នាំមកនូវដំណើររស់ឡើងវិញ និងការ ផ្ដាច់បាប តាមរយៈសេចក្ដីជំនឿ — ពួកជនដែលប្រែចិត្តនឹងទទួលនូវសេចក្ដីមេត្តាករុណា តាមរយៈព្រះរាជបុត្រាបង្កើតតែមួយនៃព្រះ ។ ប្រមាណជាឆ្នាំ ៨២ ម.គ.ស. ។*

ឥឡូវនេះ អាលម៉ា ដោយបានឃើញថា ពាក្យសំដីរបស់
អាមូលេក បានធ្វើឲ្យស៊ីអែសរ៉ុមបាត់មាត់ ព្រោះលោកឃើញថា
អាមូលេកបាន ចាប់គាត់នៅត្រង់ចំណុច ដែលគាត់[ក]ភូតកុហក
ហើយបញ្ឆោត ដើម្បីបំផ្លាញអាមូលេក ហើយដោយបាន
ឃើញថា គាត់បានចាប់ផ្ដើមញ័រ រន្ធត់ ដោយដឹងនូវកំហុស
របស់ខ្លួន ទើបអាលម៉ាបើកមាត់លោក ហើយបានចាប់ផ្ដើម
និយាយទៅកាន់គាត់ ហើយដើម្បីបញ្ជាក់នូវពាក្យ សំដីរបស់
អាមូលេក ហើយដើម្បីពន្យល់រឿងទាំងអស់ ឲ្យបានជ្រៅជ្រះ
តទៅទៀត ឬក៏ដើម្បីលាតត្រដាងតទៅទៀតនូវបទគម្ពីរទាំង
ឡាយ ដែលអាមូលេកបាននិយាយមកហើយនោះ ។
២ ឥឡូវនេះ ពាក្យសំដីដែលអាលម៉ាបាននិយាយ ទៅកាន់
ស៊ីអែសរ៉ុម នោះប្រជាជននៅជុំវិញបានស្ដាប់ឮ; ត្បិតមានហ្វូង
មនុស្ស ដ៏មហិមា ហើយលោកបាននិយាយដូច្នេះថា៖
៣ ឥឡូវនេះ ស៊ីអែសរ៉ុម ដោយបានឃើញថា អ្នកត្រូវគេ
ចាប់បាននូវការកុហក និងកលល្បិចអ្នកហើយ ត្បិតអ្នកមិន
ត្រឹមតែកុហកដល់ មនុស្សលោកតែប៉ុណ្ណោះទេ តែអ្នកថែម
ទាំងបានកុហកដល់ព្រះទៀត; ត្បិតមើលចុះ ព្រះអង្គទ្រង់ជ្រាប
នូវអស់ទាំង[ក]គំនិតរបស់អ្នក ហើយអ្នក ក៏ឃើញថា ព្រះវិញ្ញាណ
របស់ព្រះអង្គបានធ្វើឲ្យយើងដឹងនូវគំនិតរបស់អ្នកដែរ;
៤ ហើយអ្នកឃើញថាយើងដឹងថា ផែនការរបស់អ្នកជាផែនការ
មួយដ៏ល្អិតណាស់ ប្រៀបបានទៅនឹងភាពល្អិតល្អន់នៃអារក្ស
សំរាប់ កុហក ហើយបោកបញ្ឆោតប្រជាជននេះ ដើម្បីអ្នកអាច
ចាក់រុកឲ្យគេទាស់នឹងយើង ដើម្បីឲ្យគេបណ្ដុះបង្អាប់យើង
ហើយបណ្ដេញ យើងចេញ ។
៥ ឥឡូវនេះ នេះគឺជាផែនការនៃ[ក]មារសត្រូវរបស់អ្នក ហើយវា
បានប្រើថាមពលរបស់វានៅក្នុងអ្នក ។ ឥឡូវនេះ ខ្ញុំចង់ឲ្យ
អ្នកចាំថា អ្វីដែលខ្ញុំនិយាយទៅកាន់អ្នក គឺខ្ញុំនិយាយទៅកាន់
មនុស្សទាំងអស់ដែរ ។
៦ ហើយមើលចុះ ខ្ញុំសូមប្រាប់អ្នកទាំងអស់គ្នាថា នេះគឺជា
អន្ទាក់មួយនៃមារសត្រូវ ដែលវាបានដាក់ដើម្បីចាប់ប្រជាជននេះ
ប្រយោជន៍វាអាចនាំអ្នករាល់គ្នាឲ្យធ្លាក់ទៅក្នុងការត្រួតត្រារបស់វា
ដើម្បីវាអាចចងរុំអ្នក នៅក្នុង[ក]ច្រវាក់ទាំងឡាយរបស់វា
ប្រយោជន៍វាអាចចងអ្នកឲ្យធ្លាក់ទៅក្នុងសេចក្ដីបំផ្លិចបំផ្លាញ
ដ៏អស់កល្បជានិច្ច ស្របតាមអំណាចនៃការជាប់ឃុំឃាំង
របស់វា ។
៧ ឥឡូវនេះ កាលអាលម៉ាបានពោលនូវពាក្យទាំងនេះហើយ
នោះស៊ីអែសរ៉ុមបានចាប់ផ្ដើមញ័ររន្ធត់ថែមឡើង ត្បិតគាត់ត្រូវ
បាន បរិវត្តកាន់តែច្រើនឡើងៗ អំពីព្រះចេស្ដានៃព្រះ; ហើយ
គាត់ក៏ត្រូវបានបរិវត្តថា អាលម៉ា និងអាមូលេកបានដឹងអំពីគាត់
ត្បិតគាត់ត្រូវបាន បរិវត្តថា អ្នកទាំងពីរដឹងនូវគំនិត និងបំណងនៅ
ក្នុងចិត្តគាត់; ព្រោះអ្នកទាំងពីរបានទទួលនូវអានុភាព ដែល
គេអាចដឹងនូវរឿងទាំងនេះ ស្របតាម វិញ្ញាណ
នៃការព្យាករណ៍ ។
៨ ហើយស៊ីអែសរ៉ុមក៏ចាប់ផ្ដើមសួរគេដោយចិត្តព្យាយាម
ដើម្បីគាត់អាចដឹងអំពីនគរព្រះទៀត ។ ហើយគាត់បាននិយាយ
ទៅ អាលម៉ាថា៖ តើកាលអាមូលេកបាននិយាយអំពីដំណើរ
រស់ឡើងវិញនៃមនុស្សស្លាប់ ហើយមនុស្សទាំងអស់
នឹងក្រោកពីស្លាប់ឡើងវិញ ទាំងពួកសុចរិត និងពួកឥតសុចរិត
ហើយនឹងត្រូវបាននាំទៅឈរនៅចំពោះព្រះ ដើម្បីទទួល
ការជំនុំជំរះ ស្របតាមកិច្ចការទាំងឡាយ ដែលខ្លួនបានប្រព្រឹត្ត
នោះមានន័យយ៉ាងណា ?
៩ ហើយឥឡូវនេះ អាលម៉ាបានចាប់ផ្ដើមអធិប្បាយរឿង
ទាំងនេះដល់គាត់ថា៖ មានមនុស្សជាច្រើនដែលបានប្រទានឲ្យ
ដឹងនូវ [ក]សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ; ទោះជាយ៉ាង

**១២** ១*ក* អាលម៉ា ១១:២០–៣៨.
*ខ* ស.ប. បញ្ញាចិត្ត.
៣ *ក* យ៉ាកុប (ព.ម) ២:៥;
អាលម៉ា ១០:១៧;
គ. និង ស. ៦:១៦.
៥ *ក* ស.ប. អារក្ស.
៦ *ក* អាលម៉ា ៥:៧–១០.
៩ *ក* អាលម៉ា ២៦:២២.
ស.ប. សេចក្ដីអាថិកំបាំងទាំង
ឡាយនៃព្រះ.

ណាក៏ដោយ គង់តែគេបានទទួលបញ្ជាយ៉ាងតឹងរឹងថា គេពុំ
ត្រូវប្រាប់នរណាឲ្យសោះ លើកលែងតែមួយភាគនៃព្រះបន្ទូល
របស់ព្រះអង្គ ដែលព្រះអង្គបានប្រទានដល់កូនចៅមនុស្ស
ស្របតាមការយកចិត្តទុកដាក់ និងការ ព្យាយាមរបស់គេ
ចំពោះព្រះអង្គប៉ុណ្ណោះ ។
១០ ហេតុដូច្នេះហើយ នរណាដែលធ្វើចិត្តរឹងរូស អ្នកនោះហើយ
ដែលនឹងទទួលព្រះបន្ទូលរបស់ព្រះអង្គមួយភាគតិចប៉ុណ្ណោះ;
ឯនរណាដែលពុំធ្វើចិត្តរឹងរូសទេ អ្នកនោះហើយដែលនឹងបាន
ទទួលព្រះបន្ទូលរបស់ព្រះអង្គ មួយភាគច្រើនជាង រហូតដល់
អ្នកនោះ អាចដឹងនូវសេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ រហូត
ដល់អ្នកនោះដឹងគ្រប់សេចក្ដី ។
១១ ហើយពួកអ្នកណាដែលធ្វើចិត្តរឹងរូស ពួក
គេនោះហើយដែលនឹងទទួលព្រះបន្ទូលរបស់ព្រះអង្គមួយភាគតិច
រហូតដល់ពួកគេពុំ អាចដឹងអ្វី អំពីការអាថ៌កំបាំងទាំងឡាយ
របស់ព្រះអង្គបានឡើយ; ហើយខណៈនោះ ពួកគេនឹងត្រូវអារក្ស
ចាប់ឃុំឃាំង ហើយដឹកនាំតាម អំពើចិត្តរបស់វា ទៅកាន់សេច
ក្ដីបំផ្លិចបំផ្លាញ ។ ឥឡូវនេះ នេះហើយជាន័យនៃពាក្យថា
ច្រវាក់ទាំងឡាយនៃស្ថាននរក ។
១២ ហើយអាមូលេកបាននិយាយយ៉ាងជាក់ច្បាស់ អំពីសេច
ក្ដីស្លាប់ និងអំពីការក្រោកឡើងពីភាពរមែងស្លាប់ទៅរកអមតភាព
ហើយអំពីការនាំទៅមុខវេទិកានៃព្រះ ដើម្បីនឹងទទួលការជំនុំជំរះ
ស្របតាមកិច្ចការទាំងឡាយដែលយើងបានប្រព្រឹត្ត ។
១៣ ខណៈនោះ បើសិនជាយើងបានធ្វើចិត្តរឹងរូស មែនហើយ
បើសិនជាយើងបានធ្វើចិត្តរឹងរូសទាស់នឹងព្រះបន្ទូល ដរាប
ដល់ពុំអាច រកឃើញព្រះបន្ទូលរបស់ព្រះអង្គនៅក្នុងយើងទេ
ខណៈនោះ ស្ថានភាពរបស់យើងគឺគួរឲ្យស្ញែងខ្លាច
ព្រោះគ្រានោះហើយដែលយើងនឹង ត្រូវជាប់ទោស ។
១៤ ត្បិតពាក្យសំដីរបស់យើងនឹងកាត់ទោសយើង មែន
ហើយ កិច្ចការរបស់យើងទាំងអស់នឹងកាត់ទោសយើង; យើង
នឹងពុំអាចបាន ឃើញថាឥតទោសឡើយ; ឯគំនិតរបស់យើង
ក៏នឹងកាត់ទោសយើងដែរ; ហើយនៅក្នុងស្ថានភាព
ដ៏គួរស្ញែងខ្លាចនេះ យើងពុំហ៊ានងើប មើលទៅព្រះទេ;
តែយើងនឹងមានសេចក្ដីរីករាយ បើសិនជាយើងអាចបញ្ជាឲ្យថ្ម
និងភ្នំទាំងឡាយរលំមកលើយើង ដើម្បីបិទបាំងយើងពី វត្តមាន
របស់ទ្រង់វិញ ។
១៥ ប៉ុន្តែការណ៍នេះ ពុំអាចកើតឡើងបានទេ; យើងត្រូវតែ
មកឈរនៅចំពោះព្រះអង្គ នៅក្នុងសិរីល្អរបស់ទ្រង់ និងក្នុង
ព្រះចេស្ដារបស់ ទ្រង់ និងក្នុងឥទ្ធិឫទ្ធិ ឫទ្ធានុភាព និងអំណាច
របស់ទ្រង់ ហើយទទួលស្គាល់ចំពោះសេចក្ដីខ្មាស់អៀន
របស់យើងដ៏អស់ កល្បជានិច្ចថា សេចក្ដីជំនុំជំរះទាំងអស់
របស់ទ្រង់ គឺសុទ្ធតែត្រឹមត្រូវ; ថាព្រះអង្គមានសេចក្ដីយុត្តិធម៌
ក្នុងការងារទាំងអស់របស់ព្រះអង្គ ហើយថា ព្រះអង្គប្រកបដោយ
សេចក្ដីមេត្តាករុណាដល់កូនចៅមនុស្ស ហើយថា ព្រះអង្គមាន
គ្រប់ព្រះចេស្ដា ដើម្បីជួយសង្គ្រោះមនុស្ស គ្រប់រូប ដែលជឿ
ដល់ព្រះនាមទ្រង់ ហើយនាំមកនូវផលដែលសមនឹងសេច
ក្ដីប្រែចិត្ត ។
១៦ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ខណៈនោះ
សេចក្ដីស្លាប់នឹងមកដល់ គឺជាសេចក្ដីស្លាប់ទីពីរ ដែលជាសេច
ក្ដីស្លាប់ខាង វិញ្ញាណ; ខណៈនោះហើយគឺជាពេលវេលា
ដែលអស់អ្នកណាដែលស្លាប់ក្នុងអំពើបាបទាំងឡាយរបស់ខ្លួន
ដែលជាសេចក្ដីស្លាប់ខាង សាច់ឈាម នោះនឹងស្លាប់ផ្នែកសេច
ក្ដីស្លាប់ខាងវិញ្ញាណផងដែរ; មែនហើយ អ្នកនោះនឹងស្លាប់
ចំពោះអ្វីៗដែលទាក់ទងទៅនឹង សេចក្ដីសុចរិត ។
១៧ ខណៈនោះហើយគឺជាពេលវេលា ដែលការទុក្ខវេទនា
របស់ពួកគេនឹងទៅដូចជាបឹងភ្លើង និងស្ពាន់ធ័រ ដែលមាន
អណ្ដាតភ្លើង ឆេះឡើង ជារៀងដរាបតទៅ; ហើយ

៩ *ខ* យ៉ូហាន ១៦:១២; អាលម៉ា ២៩:៨;
៣ នីហ្វៃ ២៦:៨–១១;
អេធើរ ៤:៧.
១០ *ក* ២ នីហ្វៃ ២៨:២៧; អេធើរ ៤:៨.
*ខ* គ. និង ស. ៩៣:៣៩.
*គ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ឃ* ២ នីហ្វៃ ២៨:៣០;
គ. និង ស. ៥០:២៤.
១១ *ក* ម៉ាថាយ ២៥:២៩.
*ខ* ស.ប. សេចក្ដីក្បត់សាសនា.
*គ* យ៉ូហាន ៨:៣៤;
២ នីហ្វៃ ២៨:១៩.
*ឃ* សុភា. ៥:១៨; ២ នីហ្វៃ ២:២៩.
ស.ប. ស្ថាននរក.
១២ *ក* អាលម៉ា ១១:៤១–៤៥.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
១៤ *ក* ម៉ាថាយ ១២:៣៦;
យ៉ាកុប (ព.ស.ថ.) ៣:៦;
ម៉ូសាយ ៤:២៩–៣០.
*ខ* ហូសេ ១០:៨; ២ នីហ្វៃ ២៦:៥.
*គ* យ៉ូប ៣៤:២២; ២ នីហ្វៃ ១២:១០.
១៥ *ក* ម៉ូសាយ ៣:២៥.
*ខ* ២ ពេត្រុស ២:៩.
ស.ប. សេចក្ដីយុត្តិធម៌.
១៦ *ក* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
*ខ* អាលម៉ា ១១:៤០–៤៥.
*គ* ១ នីហ្វៃ ១៥:៣៣;
អាលម៉ា ៤០:២៦.
១៧ *ក* វិវ. ១៩:២០; ២១:៨;
ម៉ូសាយ ៣:២៧.

ខណៈនោះហើយគឺជាពេលវេលា ដែលពួកគេនឹងត្រូវចងជាប់ដោយច្រវាក់ ទៅក្នុងសេចក្ដីបំផ្លិច បំផ្លាញដ៏អស់កល្បជានិច្ច ស្របតាមថាមពលនៃការជាប់ឃុំឃាំង របស់អារក្សសាតាំង គឺវានេះហើយដែលបានធ្វើអ្វីទៅលើពួកគេតាមតែអំពើចិត្តរបស់វា ។

១៨ ហើយខ្ញុំសូមប្រាប់អ្នកថា ពួកគេនឹងស្ថិតនៅក្នុងស្ថានភាពមួយ ដែលហាក់ដូចជាពុំដែលមានការប្រោសលោះកើតឡើងឡើយ; ព្រោះពួកគេនឹងពុំអាចបានប្រោសលោះស្របតាមសេចក្ដីយុត្តិធម៌នៃព្រះឡើយ; ហើយពួកគេពុំអាចស្លាប់ដោយឃើញថា ពុំមានការពុក រលួយកើតឡើងទៀតឡើយ ។

១៩ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលអាលម៉ាបានបញ្ចប់នូវការនិយាយពាក្យទាំងនេះហើយ នោះប្រជាជនបាន ចាប់ផ្ដើមមានសេចក្ដីអស្ចារ្យដ៏លើសលែងទៅទៀត;

២០ ប៉ុន្តែ មានមនុស្សម្នាក់ឈ្មោះ អាន់ទីអូណា ដែលជាមេត្រួតត្រាម្នាក់ ក្នុងចំណោមពួកគេ បានចេញមក ហើយនិយាយទៅកាន់ លោកថា៖ តើអ្វីទៅដែលអ្នកបាននិយាយនេះថា មនុស្សនឹងក្រោកពីសេចក្ដីស្លាប់ឡើងវិញ ហើយប្រែពីភាពរមែងស្លាប់ ទៅជាអមតភាព ដើម្បីឲ្យព្រលឹងពុំអាចស្លាប់ទៅបាននោះ ?

២១ តើបទគម្ពីរមានន័យយ៉ាងណាដែលថា ព្រះទ្រង់បានដាក់រូបចេរូប៊ីន និងដាវដែលមានអណ្ដាតភ្លើងមួយ នៅទិសខាងកើតនៃ សួនច្បារអេដែន ក្រែងឪពុកម្ដាយដើមរបស់យើងចូលទៅទទួលទាននូវផ្លែនៃដើមជីវិត ហើយរស់នៅរហូត ? ដោយហេតុនេះហើយ ទើបយើងឃើញថា ឪពុកម្ដាយយើងគ្មានលទ្ធភាពដើម្បីអាចរស់នៅរហូតបានឡើយ ។

២២ ឥឡូវនេះ អាលម៉ាបាននិយាយទៅគាត់ថា៖ នេះគឺជារឿងដែលខ្ញុំបានបំរុងនឹងពន្យល់ប្រាប់ ។ ឥឡូវនេះ យើងឃើញថាលោក អ័ដាមបានធ្លាក់ ដោយទទួលទាននូវផ្លែដែលហាមឃាត់ស្របតាមព្រះបន្ទូលនៃព្រះ; ដោយហេតុនេះហើយ បានជាយើងឃើញថា ដោយការធ្លាក់របស់លោកអ័ដាមនេះហើយទើបមនុស្សលោកទាំងអស់ ក្លាយទៅជាមនុស្សវង្វេង ហើយធ្លាក់ ។

២៣ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ប្រសិនបើអាចមានលទ្ធភាពឲ្យលោកអ័ដាមទទួលទាន នូវផ្លែនៃដើមជីវិតក្នុងពេលនោះ នោះនឹងពុំមានសេចក្ដីស្លាប់ឡើយ ហើយព្រះបន្ទូលនៃព្រះក៏ត្រូវលុបចោលដែរ ធ្វើឲ្យព្រះទៅជាអ្នកកុហកវិញ ត្បិតព្រះអង្គ មានព្រះបន្ទូលថា៖ បើសិនជាអ្នកបរិភោគ នោះអ្នកនឹងត្រូវស្លាប់ជាពិតប្រាកដ ។

២៤ ហើយយើងឃើញថា សេចក្ដីស្លាប់កើតមានឡើងដល់មនុស្សលោក មែនហើយ សេចក្ដីស្លាប់ដែលអាមូលេកបាននិយាយនោះ ហើយដែលជាសេចក្ដីស្លាប់ខាងសាច់ឈាម; ទោះជាយ៉ាងណាក៏ដោយ គង់តែមានរយៈពេលមួយទុកសំរាប់ឲ្យមនុស្សប្រែចិត្តដែរ; ហេតុ ដូច្នេះហើយ ជីវិតនេះក្លាយទៅជាស្ថានភាពពិសោធន៍មួយ; គឺជាពេលវេលាសំរាប់ប្រុងប្រៀបទៅជួបព្រះ; ជាពេលវេលាសំរាប់ប្រុងប្រៀប ទៅកាន់ស្ថានភាពដ៏មិនចេះចប់មិនចេះហើយ ដែលយើងបាននិយាយ គឺបន្ទាប់ពីដំណើររស់ឡើងវិញដល់មនុស្សស្លាប់ ។

២៥ ឥឡូវនេះ ប្រសិនបើគ្មានផែនការនៃសេចក្ដីប្រោសលោះដែលបានរៀបចំឡើង ចាប់តាំងពីកំណើតលោកិយមកទេ នោះដំណើររស់ឡើងវិញនៃមនុស្សស្លាប់ក៏គ្មានដែរ; ប៉ុន្តែមានផែនការនៃសេចក្ដីប្រោសលោះមួយបានរៀបចំឡើង ដែលនឹងបណ្ដាល ឲ្យមានដំណើររស់ឡើងវិញ ដល់មនុស្សស្លាប់ ដែលបាននិយាយមកនោះ ។

២៦ ហើយឥឡូវនេះ មើលចុះ ប្រសិនបើឪពុកម្ដាយដើមរបស់យើង មានលទ្ធភាពអាចចេញទៅ ហើយទទួលទាននូវផ្លែនៃដើមជីវិត នោះពួកគេនឹងត្រូវវេទនារហូត ដោយពុំមាន

---

១៨ *ក* អាលម៉ា ១១:៤១.
*ខ* វិវ. ២១:៤;
អាលម៉ា ១១:៤៥;
គ. និង ស. ៦៣:៤៩.
២០ *ក* ស.ប. អមតៈ, អមតភាព.
២១ *ក* លោកុ. ៣:២៤;
អាលម៉ា ៤២:២;
ម៉ូសេ ៤:៣១.
ស.ប. ចេរ៉ូប៊ីន.
*ខ* ស.ប. អេដែន.
២២ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*ខ* លោកុ. ៣:៦;
២ នីហ្វៃ ២:១៥–១៩;
ម៉ូសាយ ៣:២៦.
*គ* ម៉ូសាយ ១៦:៤–៥.
២៣ *ក* អាលម៉ា ៤២:២–៩.
*ខ* លោកុ. ២:១៧.
២៤ *ក* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
*ខ* ២ នីហ្វៃ ២:២១;
ម៉ូសេ ៥:៨–១២.
*គ* អាលម៉ា ៣៤:៣២–៣៥.
២៥ *ក* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
*ខ* ២ នីហ្វៃ ២:៨;
អាលម៉ា ៧:១២; ៤២:២៣.
២៦ *ក* លោកុ. ២:៩; ១ នីហ្វៃ ១៥:៣៦;
អាលម៉ា ៣២:៤០.

ស្ថានភាពរៀបចំឡើយ; ដោយហេតុនេះហើយ ទើបផែនការនៃ
សេចក្ដីប្រោសលោះក៏នឹងពុំ បានសំរេច ហើយព្រះបន្ទូលនៃព្រះ
ក៏នឹងត្រូវលុបចោល ដោយពុំមានប្រសិទ្ធិភាពអ្វីឡើយ ។
២៧ ប៉ុន្តែមើលចុះ វាពុំមានការណ៍ដូច្នោះឡើយ; ប៉ុន្តែត្រូវ
បានកំណត់ដល់មនុស្សលោកថា ពួកគេនឹងត្រូវស្លាប់;
ហើយបន្ទាប់ពីការ ស្លាប់ នោះពួកគេត្រូវទទួលសេចក្ដីជំនុំជំរះ
គឺជាសេចក្ដីជំនុំជំរះ ដែលយើងទើបបាននិយាយ គឺជាទីចុងបំផុត ។
២៨ ហើយបន្ទាប់ពីព្រះទ្រង់បានកំណត់នូវការណ៍ទាំងនេះ
ដែលនឹងកើតឡើងដល់មនុស្សលោក មើលចុះ ខណៈនោះ
ទ្រង់បានទត ឃើញថា មនុស្សលោកត្រូវការដឹងជាបន្ទាន់ នូវ
អ្វីៗដែលទ្រង់បានកំណត់ដល់គេ;
២៩ ហេតុដូច្នេះហើយ ទើបទ្រង់បញ្ជាឲ្យពួកទេវតា មក
សន្ទនាជាមួយនឹងពួកគេ ធ្វើឲ្យមនុស្សមើលឃើញនូវសិរីល្អ
របស់ទ្រង់ ។
៣០ ហើយចាប់ពីពេលនោះមក ពួកគេបានចាប់ផ្ដើម
អំពាវនាវដល់ព្រះនាមទ្រង់; ហេតុដូច្នេះហើយ ព្រះទ្រង់បាន
សន្ទនាជាមួយនឹង មនុស្សលោក ហើយបានធ្វើឲ្យមនុស្សដឹងនូវ
ផែនការនៃសេចក្ដីប្រោសលោះ ដែលបានរៀបចំឡើង
ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ; ហើយទ្រង់បានធ្វើឲ្យពួក
គេដឹងនូវរឿងនេះ ស្របតាមសេចក្ដីជំនឿ និងការប្រែចិត្ត
របស់គេ និងកិច្ចការបរិសុទ្ធទាំងឡាយរបស់គេ ។
៣១ ហេតុដូច្នោះហើយ ទើបទ្រង់ប្រទាននូវព្រះបញ្ញត្តិទាំង
ឡាយដល់មនុស្ស ហើយពួកគេបានប្រព្រឹត្តល្មើសជាដំបូង
នូវបញ្ញត្តិដើម ទាំងឡាយ ដែលទាក់ទងទៅនឹងផ្នែកខាង
សាច់ឈាម ហើយក៏បានទៅដូចជាព្រះ ដោយដឹងខុស និងត្រូវ
ដោយតាំងខ្លួននៅក្នុងស្ថានភាព ដើម្បីរើស ឬតាំងខ្លួននៅក្នុង
ស្ថានភាព ដើម្បីរើស ស្របតាមចំណង់ និងការគាប់ចិត្ត
របស់គេ ក្នុងការប្រព្រឹត្តអំពើល្អ ឬប្រព្រឹត្តអំពើអាក្រក់—
៣២ ហេតុដូច្នេះហើយ ទើបព្រះទ្រង់ប្រទានបញ្ញត្តិទាំង
ឡាយដល់គេ បន្ទាប់ពីបានប្រាប់ឲ្យគេដឹង នូវផែនការនៃសេច
ក្ដីប្រោសលោះ ដើម្បីកុំឲ្យពួកគេធ្វើអំពើអាក្រក់ឡើយ
បើពុំនោះសោតទេ នឹងទទួលទោសជាសេចក្ដីស្លាប់ទីពីរ
គឺជាសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច ចំពោះអ្វីៗដែលទាក់ទងទៅ
នឹងសេចក្ដីសុចរិត; ព្រោះថា ចំពោះស្ថានភាពបែបនេះ
ផែនការនៃសេចក្ដីប្រោសលោះនឹងពុំមានអំណាចជួយ បានឡើយ
ព្រោះកិច្ចការទាំងឡាយនៃសេចក្ដីយុត្តិធម៌ ពុំអាចបំផ្លាញចោលបាន
ស្របតាមសេចក្ដីល្អសប្បុរសដ៏ឧត្ដមនៃព្រះទេ ។
៣៣ ប៉ុន្តែ ព្រះទ្រង់បានហៅដល់មនុស្សលោក ដោយនូវ
ព្រះនាមនៃព្រះរាជបុត្រារបស់ទ្រង់ (នេះគឺផែនការនៃសេច
ក្ដីប្រោសលោះ ដែលបានគ្រោងទុក) ថា៖ បើសិនជាអ្នករាល់
គ្នាប្រែចិត្ត ហើយពុំធ្វើចិត្តរឹងរូសទេ ខណៈនោះ យើងនឹងមាន
សេចក្ដីមេត្តាករុណាដល់អ្នក តាមរយៈព្រះរាជបុត្រាបង្កើត
តែមួយរបស់យើង ។
៣៤ ហេតុដូច្នេះហើយ អស់អ្នកណាដែលប្រែចិត្ត ហើយពុំ
មានធ្វើចិត្តរឹងរូសទេ នោះនឹងបានទទួលសេចក្ដីមេត្តាករុណា
តាមរយៈ ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង ចំពោះការ
ផ្ដាច់បាបទាំងឡាយរបស់ខ្លួន; ហើយពួកគេទាំងនោះ នឹងបាន
ចូលទៅក្នុងសេចក្ដីសំរាក របស់យើង ។
៣៥ រីឯអស់អ្នកណាដែលធ្វើចិត្តរឹងរូស ហើយធ្វើអំពើទុច្ចរិត
មើលចុះ យើងសច្ចានៅក្នុងការពិរោធរបស់យើងថា អ្នកនោះ
នឹង ពុំអាចចូលទៅក្នុងសេចក្ដីសំរាករបស់យើងបានឡើយ ។
៣៦ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
មើលចុះ ខ្ញុំសូមប្រាប់អ្នកថា បើសិនជាអ្នកធ្វើចិត្តរឹងរូស នោះ
អ្នករាល់គ្នានឹងពុំ អាចចូលទៅក្នុងសេចក្ដីសំរាកនៃព្រះអម្ចាស់
បានដែរ; ហេតុដូច្នេះហើយ អំពើទុច្ចរិតរបស់អ្នក ធ្វើឲ្យទ្រង់ខ្ញាល់
ហើយទ្រង់នឹងទម្លាក់ទៅលើ អ្នករាល់គ្នា នូវសេចក្ដីពិរោធ
របស់ទ្រង់ ដូចជាការធ្វើឲ្យទ្រង់ខ្ញាល់ជាលើកដំបូងដូច្នោះ
មែនហើយ ស្របតាមព្រះបន្ទូលរបស់ទ្រង់ ក្នុងការ ធ្វើឲ្យ

២៦ *ខ* អាលម៉ា ៣៤:៨–១៦;
៤២:៦–២៨;
ម៉ូសេ ៦:៥៩–៦២.
២៧ *ក* យ៉ូប ៧:១; ហេព្រើរ ៩:២៧;
គ. និង ស. ៤២:៤៨.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
២៩ *ក* ម៉ូរ៉ូណៃ ៧:២៥, ៣១;
គ. និង ស. ២៩:៤២.
៣០ *ក* ម៉ូសេ ៥:៤–៥; ៦:៥១.
*ខ* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
*គ* ម៉ូសាយ ១៨:១៣;
អាលម៉ា ១៣:៣, ៥, ៧–៨.
៣១ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
*ខ* លោកុ. ២:១៦–១៧;
២ នីហ្វៃ ២:១៨–១៩.
*គ* លោកុ. ៣:២២–២៣;
ម៉ូសេ ៤:១១.
*ឃ* ២ នីហ្វៃ ២:១៦.
ស.ប. សិទ្ធិជ្រើសរើស.
៣២ *ក* ម៉ូសេ ៥:៤–៩.
*ខ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
*គ* ម៉ូសាយ ១៥:២៧;
អាលម៉ា ៣៤:១៥–១៦; ៤២:១៥.
៣៤ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
*ខ* ស.ប. ការផ្ដាច់បាប.
*គ* ស.ប. សេចក្ដីសំរាក.
៣៦ *ក* យ៉ាកុប ១:៧–៨;
អាលម៉ា ៤២:៦, ៩, ១៤.

ទ្រង់ខ្ញាល់លើកក្រោយ ក៏ដូចជាលើកដំបូងដែរ នឹងនាំមកនូវ
សេចក្ដីបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ចដល់ព្រលឹងរបស់អ្នក;
ហេតុដូច្នេះ ហើយ ស្របតាមព្រះបន្ទូលរបស់ទ្រង់ គឺនឹងនាំមក
នូវសេចក្ដីស្លាប់ចុងក្រោយបង្អស់ ដូចជាសេចក្ដីស្លាប់ដំបូងដែរ ។
៣៧ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
ដោយឃើញថា យើងដឹងនូវការណ៍ទាំងនេះអស់ហើយ ហើយ
ការណ៍ទាំង នេះពិត នោះចូរយើងប្រែចិត្តចុះ ហើយចូរកុំធ្វើចិត្ត
រឹងរូស ដើម្បីកុំឲ្យយើងធ្វើឲ្យព្រះអម្ចាស់ជាព្រះរបស់យើងខ្ញាល់
កុំឲ្យទ្រង់ចាក់ព្រះ ពិរោធរបស់ទ្រង់មកលើយើង នៅក្នុងព្រះបញ្ញា
ជាលើកទីពីររបស់ព្រះអង្គ ដែលទ្រង់បានប្រទានដល់យើងឡើយ;
ប៉ុន្តែចូរយើងចូលទៅ ក្នុងសេចក្ដីសំរាកនៃព្រះ ដែលបាន
រៀបចំឡើង ស្របតាមព្រះបន្ទូលរបស់ទ្រង់ចុះ ៕

## ជំពូកទី ១៣

*មនុស្សត្រូវបានហៅឲ្យធ្វើជាពួកសង្ឃជាន់ខ្ពស់ ដោយសារសេចក្ដីជំនឿដ៏លើសលប់ និងកិច្ចការដ៏ល្អទាំងឡាយរបស់គេ — ពួកគេត្រូវបង្រៀនព្រះបញ្ញត្តិទាំងឡាយ — តាមរយៈសេចក្ដីសុចរិត នោះពួកគេនឹងបានញែកជាបរិសុទ្ធ ហើយនឹងបានចូលទៅក្នុងទីសំរាកនៃព្រះអម្ចាស់ — លោកមិលគីស្សាដែក គឺជាពួកផងនោះ — ពួកទេវតាប្រកាសប្រាប់ដំណឹងដ៏រីករាយទូទៅទាំងដែនដី — ពួកគេនឹងបើកសម្ដែងប្រាប់អំពីការយាងមក ដ៏ពិតប្រាកដនៃព្រះគ្រីស្ទ ។ ប្រមាណជាឆ្នាំ ៨២ ម.គ.ស. ។*

ហើយម៉្យាងទៀត ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់រំឭក
អ្នកទៀតឲ្យនឹកឃើញដល់ពេល ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បាន
ប្រទាន ព្រះបញ្ញត្តិទាំងនេះដល់កូនចៅរបស់ទ្រង់; ហើយខ្ញុំចង់ឲ្យ
អ្នករាល់គ្នាចាំថា ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានតែងតាំងពួក
សង្ឃទាំងឡាយឡើង តាមរបៀបដ៏បរិសុទ្ធរបស់ទ្រង់ គឺតាម
របៀបនៃព្រះរាជបុត្រាទ្រង់ ដើម្បីបង្រៀនការណ៍ទាំងនេះទៅកាន់
ប្រជាជន ។
២ ហើយពួកសង្ឃទាំងនោះត្រូវបានតែងតាំងឡើង តាមរបៀប
នៃព្រះរាជបុត្រាទ្រង់ តាមវិធីដែលអាចឲ្យប្រជាជនដឹងថា តាម
របៀប ណាមួយ ដើម្បីទន្ទឹងចាំព្រះរាជបុត្រារបស់ទ្រង់ សំរាប់ការ
ប្រោសលោះ ។
៣ ហើយនេះគឺជាវិធីដែលគេត្រូវបានតែងតាំងឡើង —
ដោយបានហៅ ហើយរៀបចំទុក ចាប់តាំងពីកំណើតលោកិយមក
ស្របតាម បុព្វវិជ្ជានៃព្រះ ដោយសារសេចក្ដីជំនឿដ៏លើសលប់
និងកិច្ចការដ៏ល្អទាំងឡាយរបស់គេ; ជាពិសេស គេត្រូវបាន
ទុកឲ្យរើសការល្អ ឬការ អាក្រក់; ហេតុដូច្នេះហើយ គេបាន
រើសយកល្អ ហើយអនុវត្តសេចក្ដីជំនឿដ៏ធំលើសលប់ ត្រូវបាន
ហៅ ដោយតំណែងដ៏បរិសុទ្ធ មែនហើយ ដោយតំណែងដ៏បរិសុទ្ធ
ដែលបានរៀបចំទុកមក និងស្របតាមការប្រោសលោះដែល
បានរៀបចំឡើង សំរាប់មនុស្សបែបនេះ ។
៤ ហើយដោយហេតុនេះ ពួកគេត្រូវបានហៅ មកកាន់
តំណែងដ៏បរិសុទ្ធ ដោយសារសេចក្ដីជំនឿរបស់គេ នៅពេល
អ្នកឯទៀត បដិសេធព្រះវិញ្ញាណនៃព្រះ ដោយមកពីភាព
រឹងរូសនៃចិត្តរបស់គេ និងភាពងងឹតងងល់នៃគំនិតរបស់គេ
ពេលនោះ ប្រសិនបើពុំមកពីហេតុ នេះទេ ពួកគេច្បាស់ជាមាន
ឯកសិទ្ធដ៏ធំស្មើនឹងបងប្អូនគេដែរ ។
៥ ឬក៏សរុបសេចក្ដីមក ជាពិសេស គេមានថ្នាក់ស្មើគ្នានឹង
បងប្អូនគេដែរ; ម្ល៉ោះហើយ តំណែងដ៏បរិសុទ្ធដែលបានរៀបចំឡើង
ចាប់តាំងពីកំណើតលោកិយមក សំរាប់មនុស្សណាដែលពុំធ្វើ
ចិត្តរឹងរូស ដោយបានរៀបចំឡើង តាមរយៈដង្វាយធួននៃព្រះ
រាជបុត្រា បង្កើតតែមួយ ដែលបានរៀបចំទុក —
៦ ហើយដោយហេតុនេះ ត្រូវបានហៅដោយតំណែងដ៏បរិសុទ្ធ
ហើយបានតែងតាំងឡើង ក្នុងបព្វជិតភាពជាន់ខ្ពស់
នៃរបៀបដ៏បរិសុទ្ធ នៃព្រះ ដើម្បីទៅបង្រៀនព្រះបញ្ញត្តិទាំង
ឡាយរបស់ទ្រង់ ដល់កូនចៅមនុស្ស ក៏ដើម្បីឲ្យពួកគេ
អាចចូលទៅក្នុងសេចក្ដីសំរាករបស់ទ្រង់ផង —
៧ បព្វជិតភាពជាន់ខ្ពស់នេះ គឺតាមរបៀបនៃព្រះរាជបុត្រា

៣៦ *ខ* ស.ប. សេចក្ដីផាប់ទោស.
៣៧ *ក* ១ នីហ្វៃ ១៧:៣០; យ៉ាកុប ១:៨; ហេលេ. ៧:១៨.
*ខ* អាលម៉ា ១៣:៦–៩.
**១៣** ១ *ក* អ័ប្រា. ២:៩, ១១.
២ *ក* គ. និង ស. ១០៧:២–៤.
*ខ* អាលម៉ា ១៣:១៦.
៣ *ក* គ. និង ស. ១២៧:២.
ស.ប. ការរើសតាំង; ការតែងតាំងមុនកំណើតលោកិយ.
*ខ* គ. និង ស. ១៣៨:៥៥–៥៦.
*គ* អាលម៉ា ១២:២៥, ៣០.
ស.ប. ជីវិតមុនផែនដី.
*ឃ* គ. និង ស. ៣៨:២.
*ង* ស.ប. សិទ្ធិជ្រើសរើស.
*ច* ស.ប. សេចក្ដីជំនឿ.
*ឆ* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ; បព្វជិតភាព.
៤ *ក* អេធើរ ១២:១០.
*ខ* ១ នីហ្វៃ ១៧:៣២–៣៥.
៥ *ក* ២ នីហ្វៃ ២៦:២៨.
៦ *ក* អាលម៉ា ១២:៣៧; ១៦:១៧.
ស.ប. សេចក្ដីសំរាក.

របស់ទ្រង់ គឺជារបៀបចាប់តាំងពីកំណើតលោកិយមក
ឬនិយាយម្យ៉ាងទៀត គឺគ្មានថ្ងៃចាប់ផ្ដើម ឬឆ្នាំបញ្ចប់ឡើយ
គឺបានរៀបចំពីភាពអស់ទាំងកល្បជានិច្ច ទៅអស់ទាំងភាព
អស់កល្បជានិច្ច ស្របតាមបុព្វវិជ្ជារបស់ទ្រង់ លើការណ៍ទាំង
អស់ —
៨ ឥឡូវនេះ ពួកគេត្រូវបានតែងតាំងឡើងតាមវិធីនេះ —
ដោយបានហៅដោយតំណែងដ៏បរិសុទ្ធ ហើយបានតែងតាំងឡើង
ដោយពិធី បរិសុទ្ធ ហើយលើកយកដាក់លើខ្លួន នូវ
បព្វជិតភាពជាន់ខ្ពស់ នៃរបៀបដ៏បរិសុទ្ធ គឺជាតំណែង និង
ពិធីបរិសុទ្ធ និងបព្វជិតភាពជាន់ខ្ពស់ ដែលគ្មានការចាប់ផ្ដើម
ឬទីបញ្ចប់ឡើយ —
៩ ម្ល៉ោះហើយ ពួកគេក្លាយទៅជាសង្ឃជាន់ខ្ពស់ រហូតតទៅ
តាមរបៀបនៃព្រះរាជបុត្រា ដែលជាព្រះរាជបុត្រាបង្កើតតែ
មួយនៃព្រះ វរបិតា ទ្រង់គ្មានថ្ងៃចាប់ផ្ដើម ឬឆ្នាំបញ្ចប់ឡើយ
ទ្រង់ពោរពេញទៅដោយព្រះគុណ សេចក្ដីទៀងត្រង់ និងសេចក្ដី
ពិត ។ ហើយគឺយ៉ាងដូច្នោះ មែន ។ អាម៉ែន ។
១០ ឥឡូវនេះ ដូចជាខ្ញុំបាននិយាយអំពីរបៀបដ៏បរិសុទ្ធ
ឬបព្វជិតភាពជាន់ខ្ពស់នេះ នោះមានមនុស្សជាច្រើន ដែលត្រូវ
បានតែងតាំងឡើង ហើយបានក្លាយទៅជាពួកសង្ឃជាន់ខ្ពស់នៃ
ព្រះ; ហើយដោយសារតែសេចក្ដីជំនឿដ៏លើសលប់ និងការ
ប្រែចិត្តរបស់គេ និងអំពើសុចរិត របស់គេចំពោះព្រះ នោះគេ
បានជ្រើសរើសយកការប្រែចិត្ត ហើយធ្វើការសុចរិត ជាជាង
ការវិនាស;
១១ ហេតុដូច្នេះហើយ ពួកគេត្រូវបានហៅតាមរបៀបដ៏បរិសុទ្ធនេះ
ហើយបានញែកជាបរិសុទ្ធ ហើយសំលៀកបំពាក់របស់គេក៏បាន
ជំរះឲ្យស តាមរយៈឈាមនៃកូនចៀម ។
១២ ឥឡូវនេះ បន្ទាប់ពីគេត្រូវបានញែកជាបរិសុទ្ធដោយ
ព្រះវិញ្ញាណបរិសុទ្ធ ដោយមានសំលៀកបំពាក់បានធ្វើឲ្យស
ដោយបានបរិសុទ្ធ ហើយគ្មានទោសនៅចំពោះព្រះ នោះគេពុំ
អាចសម្លឹងមើលអំពើបាបទៀតឡើយ លើកលែងតែមើលដោយ
ស្អប់ខ្ពើមប៉ុណ្ណោះ ហើយមាន មនុស្សជាច្រើនឥតគណនា
ដែលបានធ្វើឲ្យបរិសុទ្ធ ហើយចូលទៅក្នុងសេចក្ដីសំរាកនៃព្រះ
អម្ចាស់ ជាព្រះរបស់ពួកគេ ។
១៣ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ
ខ្ញុំចង់ឲ្យអ្នកបន្ទាបខ្លួនចំពោះព្រះ ហើយនាំមកនូវផលដែលសម
នឹងសេចក្ដី ប្រែចិត្ត ដើម្បីឲ្យអ្នកអាចចូលទៅក្នុងសេច
ក្ដីសំរាកនោះដែរ ។
១៤ មែនហើយ ចូរបន្ទាបខ្លួនឲ្យដូចមនុស្ស
ជំនាន់លោកមិលគីស្សាដែក ដែលជាសង្ឃជាន់ខ្ពស់ម្នាក់ដែរ
តាមរបៀបដូចគ្នា ដែលខ្ញុំបាន និយាយនេះ ដែលបាន
លើកដាក់លើខ្លួនលោក នូវបព្វជិតភាពជាន់ខ្ពស់នេះរៀងរហូត ។
១៥ ហើយគឺមិលគីស្សាដែកនេះហើយដែលលោកអ័ប្រាហាំ
បានថ្វាយដង្វាយ១ភាគ១០; មែនហើយ គឺលោកអ័ប្រាហាំ ជា
អយ្យកោ របស់យើង បានថ្វាយ១ភាគក្នុង១០ នូវអ្វីៗដែល
លោកមានដែរ ។
១៦ ឥឡូវនេះ ពិធីបរិសុទ្ធទាំងនេះបានចាត់តាមវិធីនេះ ដើម្បី
តាមរបៀបនេះ ប្រជាជនអាចទន្ទឹងចាំព្រះរាជបុត្រានៃព្រះ ដែល
ជា គំរូមួយនៃរបៀបរបស់ទ្រង់ ឬវាជារបៀបរបស់ទ្រង់ ហើយ
ពួកគេទន្ទឹងចាំទ្រង់ តាមរបៀបនេះ ដើម្បីបានទទួល
ការផ្ដាច់បាបទាំងឡាយ របស់គេ ដើម្បីគេអាចចូលទៅ
ក្នុងសេចក្ដីសំរាកនៃព្រះអម្ចាស់បាន ។
១៧ ឥឡូវនេះ មិលគីស្សាដែកនេះគឺជាស្ដេចនៃស្រុក
សាឡិម; ហើយប្រជាជនរបស់ទ្រង់ប្រព្រឹត្តអំពើទុច្ចរិត និង
អំពើដ៏គួរខ្ពើមឆ្អើម យ៉ាងក្រាស់ក្រែល; មែនហើយ ពួកគេទាំង
អស់បានដើរវង្វេង; ហើយពួកគេពោរពេញទៅដោយសេច
ក្ដីទុច្ចរិតគ្រប់បែបយ៉ាង;

៧ *ក* ហេព្រើរ ៧:៣.
*ខ* ស.ប. ព្រះ, ក្រុមព្រះ.
៨ *ក* គ. និង ស. ៨៤:៣៣–៤២.
ស.ប. បព្វជិតភាពមិលគីស្សាដែក.
៩ *ក* ស.ប. សង្ឃជាន់ខ្ពស់.
*ខ* ២ នីហ្វៃ ២:៦.
ស.ប. ព្រះគុណ.
១០ *ក* គ. និង ស. ៨៤:១៨–២២.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
១១ *ក* ម៉ូសេ ៦:៥៩–៦០.
*ខ* ១ នីហ្វៃ ១២:១០;
អាលម៉ា ៥:២១–២៧;
៣ នីហ្វៃ ២៧:១៩–២០.
១២ *ក* រ៉ូម ៨:១–៩.
ស.ប. ការញែកជាបរិសុទ្ធ.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* ស.ប. សុទ្ធ, សុទ្ធសាធ.
*ឃ* ម៉ូសាយ ៥:២; អាលម៉ា ១៩:៣៣.
*ង* សុភា. ៨:១៣; អាលម៉ា ៣៧:២៩.
១៣ *ក* លូកា ៣:៨.
១៤ *ក* គ. និង ស. ៨៤:១៤. ក.យ.ស.,
លោកុ. ១៤:២៥–៤០.
ស.ប. មិលគីស្សាដែក.
១៥ *ក* ស.ប. អ័ប្រាហាំ.
*ខ* លោកុ. ១៤:១៨–២០;
ម៉ាឡាគី ៣:៨–១០.
ស.ប. ដង្វាយ១ភាគក្នុង១០,
ការថ្វាយដង្វាយ១ភាគ ក្នុង១០.
១៦ *ក* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*ខ* ស.ប. ការនិមិត្តរូប.

១៨ ប៉ុន្តែមិលគីស្សាដែក ដោយបានអនុវត្តសេចក្ដីជំនឿដ៏ខ្លាំង ហើយបានទទួលមុខងារនៃបព្វជិតភាពជាន់ខ្ពស់ស្របតាមរបៀប ដ៏បរិសុទ្ធនៃព្រះ បានបង្រៀនការប្រែចិត្តដល់ប្រជាជនរបស់ទ្រង់ ។ ហើយមើលចុះ ពួកគេបានប្រែចិត្ត ហើយមិលគីស្សាដែកបានបង្កើត សេចក្ដីសុខសាន្តនៅក្នុងស្រុក នៅសម័យទ្រង់; ហេតុដូច្នេះហើយ ទ្រង់ត្រូវបានហៅថាជាម្ចាស់នៃសេចក្ដីសុខសាន្ត ព្រោះទ្រង់ជាស្ដេចនៃ ស្រុកសាឡិម ហើយទ្រង់បានគ្រងរាជ្យក្រោមអំណាចរបស់បិតាទ្រង់ ។

១៩ ឥឡូវនេះ មានមនុស្សជាច្រើនមុនទ្រង់ ហើយមានមនុស្សជាច្រើនក្រោយទ្រង់ដែរ តែគ្មាននរណាប្រសើរជាងទ្រង់ឡើយ; ហេតុដូច្នេះហើយ ទើបគេ ជាពិសេស និយាយអំពីទ្រង់ច្រើនជាងគេ ។

២០ ឥឡូវនេះ ខ្ញុំមិនចាំបាច់និយាយផ្ទួនឡើងវិញនូវការណ៍នេះឡើយ; អ្វីៗដែលខ្ញុំបាននិយាយមកនេះ គឺល្មមគ្រប់គ្រាន់ហើយ ។ មើលចុះ បទគម្ពីរទាំងឡាយមាននៅចំពោះមុខអ្នកហើយ; បើសិនជាអ្នករាល់គ្នាបង្វែរន័យនៃបទគម្ពីរទាំងឡាយ គឺអ្នកនឹងនាំមកនូវការ បំផ្លិចបំផ្លាញដល់ខ្លួនឯង ។

២១ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលដែលអាលម៉ាបាននិយាយពាក្យទាំងនេះ ដល់គេចប់ហើយនោះលោកបាន លាតដៃទៅរកគេ ហើយស្រែកដោយសម្លេងខ្លាំងថា៖ ឥឡូវនេះ គឺជាពេលដែលត្រូវប្រែចិត្ត ព្រោះថ្ងៃនៃសេចក្ដីសង្គ្រោះ ខិតមកជិតដល់ ហើយ;

២២ មែនហើយ ហើយមានសម្លេងនៃព្រះអម្ចាស់ តាមមាត់ពួកទេវតា បានប្រកាសប្រាប់ការណ៍នេះដល់សាសន៍ទាំងអស់; មែនហើយ គឺប្រកាសប្រាប់ការណ៍នេះ ដើម្បីឲ្យគេបានដំណឹងដ៏រីករាយ អំពីសេចក្ដីអំណរយ៉ាងអស្ចារ្យ; មែនហើយ ទ្រង់ផ្សាយដំណឹងដ៏រីករាយ ក្នុងចំណោមប្រជាជនទាំងអស់របស់ទ្រង់ មែនហើយ គឺដល់ពួកអ្នកដែលខ្ចាត់ខ្ចាយក្រៅប្រទេសនៅពាសពេញលើផ្ទៃផែនដី; ហេតុដូច្នោះ ហើយ ដំណឹងដ៏រីករាយទាំងនោះបានមកដល់យើង ។

២៣ ហើយដំណឹងដ៏រីករាយនោះ បានមកឲ្យយើងដឹង ដោយពាក្យដ៏ច្បាស់លាស់ ដើម្បីឲ្យយើងអាចយល់ ដើម្បីកុំឲ្យយើងអាចភាន់ ច្រឡំបានឡើយ; ហើយការណ៍នេះ គឺដោយសារយើងជាជនរសាត់ព្រាត់នៅក្នុងដែនដីចំឡែក; ហេតុដូច្នេះហើយ យើងត្រូវបានប្រោស ប្រណីជាខ្លាំង ព្រោះដំណឹងដ៏រីករាយទាំងនេះបានប្រកាសប្រាប់មកដល់យើង ដល់គ្រប់ផ្នែកនៃចំការយើងហើយ ។

២៤ ត្បិតមើលចុះ ពួកទេវតាកំពុងតែប្រកាសការណ៍នេះប្រាប់ដល់មនុស្សជាច្រើន នៅពេលនេះ នៅក្នុងដែនដីយើង; ហើយការណ៍ នេះមានគោលបំណង ដើម្បីរៀបចំចិត្តនៃកូនចៅមនុស្ស ឲ្យទទួលព្រះបន្ទូលរបស់ទ្រង់ នៅពេលដែលទ្រង់នឹងយាងមកនៅក្នុងសិរីល្អ របស់ទ្រង់ ។

២៥ ហើយឥឡូវនេះ យើងគ្រាន់តែរង់ចាំស្ដាប់ដំណឹងដ៏រីករាយដែលបានប្រកាសប្រាប់មកយើង ដោយមាត់របស់ពួកទេវតាអំពីការយាងមករបស់ទ្រង់ប៉ុណ្ណោះ; ព្រោះពេលនោះនឹងមកដល់ តែយើងមិនដឹងពេលណាទេ ។ សូមបួងសួងដល់ព្រះឲ្យពេលនោះ មកដល់នៅក្នុងជីវិតខ្ញុំចុះ; តែទោះជាយូរ ឬឆាប់ក្ដីគង់តែខ្ញុំត្រេកអរដែរ ។

២៦ ហើយនៅពេលដែលទ្រង់នឹងយាងមក ដំណឹងនោះនឹងត្រូវបានផ្សាយដល់មនុស្សសុចរិត ហើយបរិសុទ្ធ ដោយមាត់របស់ពួកទេវតា ដើម្បីឲ្យពាក្យរបស់ពួកអយ្យកោយើងបានបំពេញស្របតាមអ្វីៗដែលគេបាននិយាយអំពីទ្រង់ គឺស្របតាមវិញ្ញាណនៃការព្យាករណ៍ដែលនៅ ក្នុងគេ ។

២៧ ហើយឥឡូវនេះ ឱបងប្អូនរបស់ខ្ញុំអើយ ខ្ញុំមានបំណងពីជំរៅចិត្តខ្ញុំ មែនហើយ ដោយក្ដីបារម្ភដ៏ធំ គឺដល់ការឈឺចាប់ សូមឲ្យអ្នក រាល់គ្នាស្ដាប់តាមពាក្យសំដីរបស់ខ្ញុំ ហើយបោះបង់ចោលអំពើបាបទាំងឡាយរបស់អ្នក ហើយកុំបង្អែរបង្អង់ដល់ថ្ងៃ សំរាប់ប្រែចិត្តរបស់ អ្នកឡើយ ។

២៨ តែសូមឲ្យអ្នករាល់គ្នាបន្ទាបខ្លួនចំពោះព្រះអម្ចាស់ ហើយអំពាវនាវដល់ព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ហើយចាំយាម និង

១៨ *ក* ស.ប. បព្វជិតភាពមិលគីស្សាដែក.
១៩ *ក* ហេលេ. ៨:១៨;
គ. និង ស. ៨៤:៦–១៦;
១០៧:៤០–៥៥.
*ខ* គ. និង ស. ១០៧:១–៤.
២០ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* ២ ពេត្រុស ៣:១៦;
អាលម៉ា ៤១:១.
២១ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
២២ *ក* អាលម៉ា ១០:២០.
២៣ *ក* ២ នីហ្វៃ ២៥:៧–៨; ៣១:៣;
៣២:៧; យ៉ាកុប ៤:១៣;
អេធើរ ១២:៣៩.
*ខ* យ៉ាកុប ៧:២៦.
២៤ *ក* អាលម៉ា ១០:១០; ៣៩:១៩.
២៥ *ក* ១ នីហ្វៃ ១០:៤; ៣ នីហ្វៃ ១:១៣.
២៦ *ក* អេម៉ុស ៣:៧; លូកា ២:៨–១១.
២៧ *ក* ម៉ូសាយ ២៨:៣.
២៨ *ក* ស.ប. ការអធិស្ឋាន; ចាំយាម, ពួកអ្នកចាំយាម.

អធិស្ឋាន ជានិច្ច ដើម្បីកុំឲ្យអ្នកត្រូវ[ខ]ល្បួងលើសជាងអ្វីដែលអ្នក
រាល់គ្នាអាចអត់ទ្រាំបានឡើយ ម៉្លោះហើយ សូមឲ្យបាននាំ
ដោយព្រះវិញ្ញាណបរិសុទ្ធ សូមឲ្យបានក្លាយទៅជា[គ]រាបទាប
ស្លូតបូត ចុះចូល ទ្រាំទ្រ ពោរពេញទៅដោយ
សេចក្ដីស្រឡាញ់ និងគ្រប់ទាំងសេចក្ដីអត់ធ្មត់;
២៩ សូមឲ្យ[ក]មានសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់; សូមឲ្យ
មានសេចក្ដីសង្ឃឹមមួយថា អ្នករាល់គ្នានឹងទទួល
ជីវិតដ៏នៅអស់កល្បជានិច្ច; សូមឲ្យមាន[ខ]សេចក្ដីស្រឡាញ់នៃ
ព្រះ នៅក្នុងចិត្តអ្នកជានិច្ច ដើម្បីឲ្យអ្នករាល់គ្នាបានលើក[គ]ឡើង
នៅថ្ងៃចុងក្រោយបង្អស់ ហើយចូលទៅក្នុង សេច
ក្ដីសំរាករបស់ទ្រង់ ។
៣០ ហើយសូមឲ្យព្រះអម្ចាស់ទ្រង់ប្រទានដល់អ្នកនូវការ
ប្រែចិត្ត ដើម្បីកុំឲ្យអ្នករាល់គ្នានាំព្រះពិរោធរបស់ទ្រង់មកលើ
អ្នក[ក]ឡើយ ដើម្បីកុំឲ្យអ្នករាល់គ្នាត្រូវជាប់ច្រវាក់ទាំងឡាយ
នៃស្ថាននរក ដើម្បីកុំឲ្យអ្នករាល់គ្នាបានរងទុក្ខនូវ[ខ]សេចក្ដី
ស្លាប់ទីពីរឡើយ ។
៣១ ហើយអាលម៉ាបាននិយាយពាក្យជាច្រើនទៀត ទៅកាន់
ប្រជាជន ដែលពុំបានកត់នៅក្នុងគម្ពីរនេះទេ ៕

---

## ជំពូកទី ១៤

*អាលម៉ា និងអាមូលេក ត្រូវជាប់គុក ហើយត្រូវគេវាយ — ពួកអ្នកជឿ និងព្រះគម្ពីរបរិសុទ្ធរបស់គេត្រូវគេដុតចោលដោយភ្លើង — ពួកស្មរបន្ទាល់ទាំងនេះ ត្រូវបានទទួលដោយព្រះអម្ចាស់នៅក្នុងភាពរុងរឿង — ជញ្ជាំងគុកទាំងឡាយត្រូវប្រេះរលំ — អាលម៉ា និង អាមូលេកត្រូវបានដោះលែង ហើយពួកអ្នកដែលបៀតបៀនគេក៏ត្រូវស្លាប់ទៅ ។ ប្រមាណជាឆ្នាំ ៨២–៨១ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីលោកបានបញ្ចប់
នូវការនិយាយទៅកាន់ប្រជាជនហើយ នោះមានមនុស្ស
ជាច្រើន ជឿតាមពាក្យរបស់[ក]លោក ហើយបានចាប់ផ្ដើមប្រែ
ចិត្ត ហើយពិចារណាមើលបទគម្ពីរទាំងឡាយ ។
២ តែពួកគេភាគច្រើន មានបំណងចង់បំផ្លាញអាលម៉ា និង
អាមូលេកចោល; ព្រោះពួកគេខឹងនឹងអាលម៉ា ព្រោះតែ
ពាក្យដ៏[ក]ក្បោះក្បាយ របស់លោក ទៅកាន់[ខ]ស៊ីអែសរ៉ុម; ហើយ
ពួកគេបាននិយាយដែរថា អាមូលេកបានកុហកគេ ហើយបាន
បន្ទាបបន្ថោកដល់ច្បាប់របស់គេ ហើយបន្ទាបបន្ថោកដល់ពួក
មេធាវី និងចៅក្រមរបស់គេផង ។
៣ ហើយពួកគេក៏ខឹងនឹងអាលម៉ា និងអាមូលេកដែរ; ហើយ
ពីព្រោះអ្នកទាំងពីរបានធ្វើបន្ទាល់យ៉ាងក្បោះក្បាយ ទាស់
នឹងសេចក្ដីទុច្ចរិត របស់គេ ទើបគេស្វែងរកកំទេចអ្នក
ទាំងពីរចោលដោយសម្ងាត់ ។
៤ តែហេតុការណ៍បានកើតឡើងថា គេពុំធ្វើយ៉ាងនោះឡើយ;
តែគេបានចាប់អ្នកទាំងពីរ ហើយចងពួកគេដោយខ្សែដ៏មាំ
ហើយនាំពួក គេទៅខាងមុខមេចៅក្រមនៅដែនដីនោះ ។
៥ ហើយប្រជាជនបានចេញទៅធ្វើសាក្សីទាស់នឹងគេ —
ដោយបរិហារថា ពួកគេបានបង្អាប់ដល់ច្បាប់ និងពួកមេធាវី
និងពួកចៅក្រមនៃ ដែនដីនោះ ហើយព្រមទាំងបង្អាប់ប្រជាជន
ទាំងអស់ ដែលរស់នៅលើដែនដីនោះផង; ហើយបានធ្វើ
បន្ទាល់ផងដែរថា អ្នកទាំងពីរបាន និយាយថា មានព្រះតែ
មួយអង្គ ហើយថា ទ្រង់នឹងចាត់ឲ្យព្រះរាជបុត្រាទ្រង់មកក្នុង
ចំណោមប្រជាជន តែទ្រង់មិនព្រមសង្គ្រោះពួកគេទេ; ហើយ
ប្រជាជនបានធ្វើបន្ទាល់នូវកិច្ចការបែបនេះ ជាច្រើនទាស់នឹង
អាលម៉ា និងអាមូលេក ។ ឥឡូវនេះ ការណ៍នេះបានធ្វើឡើង
នៅខាង មុខមេចៅក្រមនៃដែនដីនោះ ។
៦ ហើយហេតុការណ៍បានកើតឡើងថា ស៊ីអែសរ៉ុមមាន
សេចក្ដីអស្ចារ្យនឹងពាក្យសំដី ដែលប្រជាជនបាននិយាយ;
ហើយគាត់ក៏ដឹងអំពី ការងងឹតងងល់នៃគំនិត ដែលគាត់បាន
បណ្ដាលឲ្យមានក្នុងចំណោមប្រជាជន [ក]ដោយពាក្យកុហក[ខ]
របស់គាត់; ហើយព្រលឹងគាត់ក៏ចាប់ផ្ដើម កើតទុក្ខ ដោយការ
ដឹងនូវកំហុសរបស់ខ្លួន; មែនហើយ គាត់បានចាប់ផ្ដើមឡោមព័ទ្ធ
ដោយការឈឺចាប់នៃស្ថាននរក ។
៧ ហើយហេតុការណ៍បានកើតឡើងថា គាត់[ក]បានចាប់ផ្ដើម
ស្រែកទៅកាន់ប្រជាជនថា៖ មើលចុះ ខ្ញុំមានទោស រីឯអ្នក

---

២៨ *ខ* ១ កូរិន. ១០:១៣.
*គ* ស.ប. ស្លូតបូត, ភាពស្លូតបូត; សេចក្ដីអត់ធន់.
២៩ *ក* អាលម៉ា ៧:២៤.
*ខ* គ. និង ស. ២០:៣១; ៧៦:១១៦. ស.ប. សេចក្ដីសប្បុរស.
*គ* គ. និង ស. ៨៤:២៤.
៣០ *ក* ស.ប. សេចក្ដីផាប់ទោស; ស្ថាននរក.
*ខ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
១៤ ១*ក* ២ ពង្សាវ. ២២:៨–១៣. ស.ប. បទព្រះគម្ពីរ.
២ *ក* អាលម៉ា ១២:៣–៧.
*ខ* អាលម៉ា ១០:២៧.
៦ *ក* អាលម៉ា ១៥:៥.
*ខ* ស.ប. បញ្ញាចិត្ត.
៧ *ក* អាលម៉ា ១១:២១–៣៧.

ទាំងពីរនេះគ្មាន ទោសនៅចំពោះព្រះទេ ។ ហើយគាត់បាន
ចាប់ផ្ដើមអង្វរជំនួសអ្នកទាំងពីរ ចាប់តាំងពីពេលនោះមក; តែ
ប្រជាជនមើលងាយគាត់ ដោយ និយាយថា៖ តើអ្នកឯងត្រូវ
អារក្សចូលហើយឬ? ហើយប្រជាជនបានស្ដោះដាក់គាត់ ហើយ
[ខ]បណ្ដេញគាត់ចេញ ព្រមទាំងអស់អ្នកណាដែល ជឿតាម
ពាក្យ ដែលអាលម៉ា និងអាមូលេកបាននិយាយ; ហើយពួកគេ
បានបណ្ដេញអ្នកទាំងនោះចេញទៅ ហើយបានចាត់មនុស្សឲ្យ
ចោលថ្មលើគេទៀតផង ។

៨ ហើយពួកគេបានយកប្រពន្ធកូនអ្នកទាំងនោះមកមូលគ្នា
ហើយអស់អ្នកណាដែលជឿ ឬត្រូវបានបង្រៀនឲ្យ
ជឿតាមព្រះបន្ទូលនៃព្រះ ក៏គេបញ្ជាឲ្យបោះចោលទៅ
ក្នុងភ្លើងដែរ; ហើយគេក៏បានប្រមូលយកបញ្ជីទាំងឡាយ
របស់ជនទាំងនោះ ដែលមានព្រះគម្ពីរបរិសុទ្ធទាំង ឡាយ
ហើយបោះចោលទៅក្នុងភ្លើងដែរ ដើម្បីឲ្យបញ្ជីប្រវត្តិទាំងនោះឆេះ
ហើយបំផ្លាញទៅដោយភ្លើង ។

៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាននាំអាលម៉ា
និងអាមូលេក ហើយសែងអ្នកទាំងពីរ យកទៅកន្លែងសម្លាប់
ដើម្បីឲ្យអ្នក ទាំងពីរធ្វើសាក្សី នូវការបំផ្លិចបំផ្លាញនៃពួកអ្នក
ដែលត្រូវភ្លើងឆេះ ។

១០ ហើយកាលដែលអាមូលេកបានឃើញការឈឺចាប់
របស់ពួកស្ត្រី និងកូនក្មេង ដែលត្រូវភ្លើងឆេះនោះ
លោកក៏ឈឺចាប់; ហើយ លោកបានពោលទៅអាលម៉ាថា៖
តើយើងអាចមើលឆាកដ៏ស្ញប់ស្ញែងនេះម្ដេចកើត? ហេតុដូច្នេះ
ហើយ ចូរយើងលាតដៃរបស់យើង ហើយអនុវត្ត
[ក]អំណាចនៃព្រះ ដែលនៅក្នុងយើង ហើយជួយអ្នកទាំងនេះ
ពីអណ្ដាតភ្លើងចុះ ។

១១ ប៉ុន្តែ អាលម៉ាបានពោលទៅកាន់លោកថា៖ ព្រះវិញ្ញាណ
ទ្រង់រារាំងមិនឲ្យខ្ញុំលាតដៃឡើយ; ត្បិតមើលចុះ ព្រះអម្ចាស់
ទ្រង់ទទួល យកពួកគេឡើងទៅឯទ្រង់ ក្នុង[ក]សិរីល្អហើយ; ហើយ
ទ្រង់ទ្រាំដើម្បីឲ្យគេអាចធ្វើការនេះ ឬក៏ដើម្បីឲ្យប្រជាជន
អាចធ្វើការនេះដល់ពួកគេ ស្របតាមភាពរឹងរូសនៃចិត្តរបស់គេ
ដើម្បីឲ្យ[ខ]សេចក្ដីជំនុំជំរះទាំងឡាយដែលទ្រង់នឹងអនុវត្តមកលើគេ
នៅក្នុងសេចក្ដីពិរោធរបស់ទ្រង់នោះ អាចបានត្រឹមត្រូវ; ហើយ
[គ]ឈាមរបស់[ឃ]អ្នកឥតទោសនឹងឈរជាសាក្សីទាស់នឹងគេ មែនហើយ
គឺនឹងស្រែកដ៏ខ្លាំងទាស់នឹងគេ នៅថ្ងៃចុង ក្រោយបង្អស់ ។

១២ ឥឡូវនេះ អាមូលេកបានពោលទៅកាន់អាលម៉ាថា៖
មើលចុះ ប្រហែលជាគេនឹងដុតយើងដែរ ។

១៣ ហើយអាលម៉ាបាននិយាយថា៖ ចូរទុកឲ្យការណ៍
នេះកើតឡើង ស្របតាមព្រះហឫទ័យនៃព្រះអម្ចាស់ចុះ ។ ប៉ុន្តែ
មើលចុះ កិច្ចការ របស់យើងមិនទាន់ចប់នៅឡើយទេ;
ហេតុនេះហើយ គេពុំដុតយើងទេ ។

១៤ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលដែល
សាកសពនៃពួកអ្នកដែលត្រូវគេបោះចោលទៅក្នុងភ្លើងបាន
ឆេះអស់ហើយ និងបញ្ជីទាំងឡាយ ដែលគេបានបោះចោលទៅ
ក្នុងភ្លើង ជាមួយគេនោះ ក៏ត្រូវឆេះអស់ហើយដែរ នោះមេចៅក្រម
នៃដែនដីនោះ បានមក ហើយឈរចំពោះមុខអាលម៉ា និង
អាមូលេក ដែលជាប់ចំណង; ហើយគាត់ទះកំផ្លៀងអ្នក
ទាំងពីរនឹងដៃ ហើយបាននិយាយទៅគេ ថា៖ បន្ទាប់ពីអ្វីដែល
អ្នកបានឃើញនេះ តើអ្នកនឹងបង្រៀនប្រជាជននេះទៀត ដើម្បីឲ្យ
ពួកគេត្រូវបោះចោលទៅក្នុង[ក]បឹងភ្លើង និងស្ពាន់ធ័រឬ?

១៥ មើលចុះ អ្នកឃើញថា អ្នកគ្មានអំណាចនឹងជួយពួកអ្នក
ដែលត្រូវបោះចោលទៅក្នុងភ្លើងសោះ; ឯព្រះទ្រង់ក៏មិនបាន
សង្គ្រោះពួកគេ ដែរ ទោះជាពួកគេមានសេចក្ដីជំនឿ
ដូចអ្នកក៏ដោយ ។ ហើយចៅក្រមនោះក៏ទះកំផ្លៀងគេទៀត
ហើយសួរថា៖ តើអ្នកនិយាយថាដូចម្ដេច ទៅអំពីការណ៍នេះ?

១៦ ឥឡូវនេះ ចៅក្រមនេះ ជាអ្នកដើរតាមរបៀប និងសេច
ក្ដីជំនឿរបស់[ក]នីហ្វ ដែលបានសម្លាប់គេឌាន ។

១៧ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា និង
អាមូលេក ពុំបានឆ្លើយតបនឹងគាត់ទាល់តែសោះ; ហើយគេក៏វាយ
អ្នកទាំងពីរ ទៀត ហើយបានប្រគល់គេទៅឲ្យពួកភ្នាក់ងារ
ដើម្បីយកទៅដាក់គុក ។

១៨ ហើយកាលដែលអ្នកទាំងពីរត្រូវគេដាក់គុកអស់បីថ្ងៃ
ហើយ នោះក៏មាន[ក]ពួកមេធាវី ពួកចៅក្រម ពួកសង្ឃ និង
គ្រូបង្រៀនជាច្រើន នាក់ ជាពួកអ្នកដែលកាន់តាមជំនឿនៃនីហ្វរ;
ហើយពួកគេបានមកមើលគេនៅឯគុក ហើយបានសួរអ្នក
ទាំងពីរជាច្រើនប្រការ; តែអ្នកទាំង ពីរពុំបានឆ្លើយអ្វីទាំងអស់ ។

៧ *ខ* អាលម៉ា ១៥:១.
១០ *ក* អាលម៉ា ៨:៣០–៣១.
១១ *ក* ស.ប. សិរីល្អ.
*ខ* ទំនុក. ៣៧:៨–១៣;
អាលម៉ា ៦០:១៣;
គ. និង ស. ១០៣:៣.
ស.ប. សេចក្ដីយុត្តិធម៌.
*គ* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
*ឃ* ម៉ូសាយ ១៧:១០.
១៤ *ក* អាលម៉ា ១២:១៧.
១៦ *ក* អាលម៉ា ១:៧–១៥.
១៨ *ក* អាលម៉ា ១០:១៤; ១១:២០.

១៩ ហើយហេតុការណ៍បានកើតឡើងថា ចៅក្រមនោះបាន
ឈរនៅចំពោះមុខគេ ហើយសួរថា៖ ហេតុអ្វីបានជាអ្នកមិន
ឆ្លើយតបនឹង សំនួររបស់មនុស្សទាំងនេះ? តើអ្នកមិនដឹងទេឬថា
ខ្ញុំមានអំណាចអាចបោះអ្នកចោលទៅក្នុងអណ្ដាតភ្លើងដែរ ?
ហើយគេបានបញ្ជាឲ្យ អ្នកទាំងពីរនិយាយ; តែអ្នកទាំងពីរពុំឆ្លើយអ្វី
ទាំងអស់ ។
២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេ
បានចេញទៅវិញ លុះដល់ស្អែកឡើង ក៏ត្រឡប់មកវិញទៀត;
ហើយចៅក្រមនោះក៏ទះ កំផ្លៀងគេម្ដងទៀត ។ ហើយមនុស្ស
ជាច្រើន ក៏បានមកវាយគេដែរ ដោយនិយាយថា៖ តើអ្នកនឹង
ឈរ ហើយថ្កោលទោសប្រជាជននេះ ហើយទម្លាក់ទោសដល់
ច្បាប់របស់យើងទៀតឬ ? បើសិនជាអ្នកមានអំណាច
ដ៏ខ្លាំងបែបនេះមែន ហេតុអ្វីបានជាអ្នកមិន[ក]ដោះលែងខ្លួន ឯងទៅ ?
២១ ហើយគេបានថាឲ្យអ្នកទាំងពីរជាច្រើន សង្កៀតធ្មេញដាក់គេ
ហើយស្ដោះដាក់គេ ហើយនិយាយថា៖ តើយើងនឹងមាន
រូបរាងដូច ម្ដេច នៅពេលដែលយើងត្រូវជាប់ទោស ?
២២ ហើយរឿងបែបនេះជាច្រើន មែនហើយ អស់
ទាំងកាយវិការបែបនេះ ដែលពួកគេបាននិយាយដាក់អ្នកទាំងពីរ;
ហើយពួកគេ បានចំអកឡកឡឺយ ដាក់អ្នកទាំងពីរអស់ជាច្រើន
ថ្ងៃយ៉ាងនោះហើយ។ ហើយពួកគេបានបង្អត់អាហារអ្នកទាំងពីរ
ដើម្បីឲ្យគេឃ្លាន ហើយបង្អត់ទឹក ដើម្បីឲ្យគេស្រេក; ហើយគេថែម
ទាំងដោះយកសំលៀកបំពាក់ពីគេ ដើម្បីឲ្យគេនៅអាក្រាត;
ហើយគេត្រូវបានចងដោយខ្សែ ដ៏មាំយ៉ាងនេះ ហើយដាក់នៅ
ក្នុងគុក ។
២៣ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេ
រងទុក្ខយ៉ាងនេះអស់ជាច្រើនថ្ងៃមក (ហើយគឺនៅថ្ងៃទីដប់ពីរ នៃខែ
ទីដប់ នៅឆ្នាំទីដប់ក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជន
នីហ្វៃ) គឺថា មេចៅក្រមនៃដែនដីអាំម៉ូណៃហា និងពួក
គ្រូបង្រៀនរបស់គេ និងពួក មេធាវីរបស់គេជាច្រើននាក់បាន
ទៅកាន់គុក ដែលអាលម៉ា និងអាមូលេកត្រូវគេចងដោយ
ចំណងដ៏ជាប់នៅក្នុងទីនោះ ។
២៤ ហើយមេចៅក្រមបានឈរនៅចំពោះមុខគេ
ហើយវាយគេទៀត ហើយបាននិយាយទៅកាន់គេថា៖ បើ
សិនជាអ្នកមានអំណាច នៃព្រះ ចូរអ្នកដោះលែងខ្លួនឯងឲ្យ
រួចផុតពីចំណងនេះមើល ហើយពេលនោះ យើងនឹងជឿថា ព្រះ
អម្ចាស់ទ្រង់នឹងបំផ្លាញប្រជាជននេះ តាមពាក្យសំដីរបស់អ្នកមែន។
២៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេទាំងអស់
គ្នាបានទៅវាយអ្នកទាំងពីរ ដោយនិយាយពាក្យដូចគ្នា រហូតដល់
អ្នកចុង ក្រោយបង្អស់; ហើយកាលដែល[ក]អ្នកចុងក្រោយបង្អស់
បាននិយាយទៅគេចប់ហើយ នោះព្រះចេស្ដានៃព្រះក៏មក
សណ្ឋិតលើអាលម៉ា និង អាមូលេក ហើយគេក៏ក្រោកឈរឡើង ។
២៦ ហើយអាលម៉ាស្រែកថា៖ ឱព្រះអម្ចាស់អើយ តើយើងខ្ញុំ
[ក]ត្រូវរងទុក្ខនូវការឈឺចាប់នេះ ដល់ពេលណាទៅ ? ឱព្រះ
អម្ចាស់អើយ សូមចំរើនកម្លាំងដល់យើងខ្ញុំផង តាមសេចក្ដី
ជំនឿរបស់យើងខ្ញុំ ទៅលើព្រះគ្រីស្ទ ឲ្យយើងដោះខ្លួនឲ្យ
រួចផងចុះ។ ហើយពួកគេក៏ផ្ដាច់ចំណង ដែលចងគេ; ហើយ
កាលដែលប្រជាជនបានឃើញការណ៍នេះ នោះពួកគេបាន
ចាប់ផ្ដើមរត់គេចខ្លួន ព្រោះខ្លាចការបំផ្លាញនឹងធ្លាក់មក
លើគេមែន ។
២៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេគិតភ័យជា
ខ្លាំង រហូតដល់គេដួលទៅលើដី ហើយពុំបានទាំងទៅដល់[ក]ទ្វារគុក
ខាង ក្រៅផង; ហើយផែនដីរញ្ជួយជាខ្លាំង ហើយជញ្ជាំងគុក
បានប្រេះជាពីរ រហូតដល់ធ្លាក់មកលើដី; ហើយមេចៅក្រម
និងពួកមេធាវី និងពួក សង្ឃ និងពួកគ្រូបង្រៀន ដែលបានវាយ
អាលម៉ា និងអាមូលេក គេក៏ត្រូវស្លាប់ដោយជញ្ជាំង
ធ្លាក់សង្កត់លើ ។
២៨ ហើយអាលម៉ា និងអាមូលេក បានចេញពីគុក
ហើយគេពុំមានត្រូវរបួសអ្វីសោះ; ព្រោះព្រះអម្ចាស់ ទ្រង់បាន
ប្រទានអំណាចឲ្យគេ ស្របតាមសេចក្ដីជំនឿរបស់គេ ដែល
ជាសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ។ ហើយអ្នកទាំងពីរបាន
ដើរចេញពីគុកមកភ្លាម; ហើយគេបាន[ក]រួច ពីចំណងដែល
ចងគេ; ហើយគុកបានរលំទៅលើដី ហើយក្រៅពីអាលម៉ា និង
អាមូលេក ឯមនុស្សដែលនៅក្នុងបរិវេណគុកក៏ត្រូវស្លាប់អស់
រលីង ហើយអ្នកទាំងពីរក៏ដើរចេញមកឯទីក្រុងភ្លាម ។
២៩ ឥឡូវនេះ ប្រជាជនបានឮសម្លេងដ៏ខ្លាំង ក៏នាំគ្នារត់ចេញ
មកទាំងហ្វូង ចង់ដឹងថាតើមកពីហេតុអ្វី; ហើយកាលដែលពួក
គេបាន ឃើញអាលម៉ា និងអាមូលេកចេញពីគុកមក ហើយ
ជញ្ជាំងគុកបានរលំទៅលើដី នោះពួកគេក៏កើតសេចក្ដីភិតភ័យជា

២០ *ក* ម៉ាថាយ ២៧:៣៩–៤៣.
២៥ *ក* អាលម៉ា ៨:៣១.
២៦ *ក* យ៉ាកុប (ព.ស.ច.) ៥:១០–១១;
ម៉ូសាយ ១៧:១០–២០;
គ. និង ស. ១២១:៧–៨.
២៧ *ក* កិច្ចការ ១៦:២៦;
អេធើរ ១២:១៣.
២៨ *ក* យ៉ាកុប ៤:៦;
៣ នីហ្វៃ ២៨:១៩–២២.

ខ្លាំង ហើយបានរត់គេច ចេញពីវត្តមាននៃអាលម៉ា និងអាមូលេក
ប្រៀបដូចជាពពែនាំកូនរត់គេចចេញពីគោពីរយ៉ាងនោះដែរ;
ហើយដោយរបៀបនេះ ពួកគេបាន រត់គេចចេញពីវត្តមាន
នៃអាលម៉ា និងអាមូលេក ៕

## ជំពូកទី ១៥

*អាលម៉ា និងអាមូលេកទៅដែនដីសៃដុម ហើយតាំងសាសនាចក្រមួយឡើង — អាលម៉ាព្យាបាលស៊ីអែសរ៉ុម ហើយគាត់ចូលរួមនឹង សាសនាចក្រ — មនុស្សជាច្រើនបានទទួលបុណ្យជ្រមុជទឹក ហើយសាសនាចក្រចំរើនលូតលាស់ — អាលម៉ា និងអាមូលេក ទៅឯក្រុង សារ៉ាហិមឡា ។ ប្រមាណជាឆ្នាំ ៨១ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា និងអាមូលេក
ត្រូវបានបញ្ជាឲ្យចេញពីទីក្រុងនោះ; ហើយគេបានចេញទៅ
ដល់ដែនដីសៃដុម; ហើយមើលចុះ នៅទីនោះ គេបានប្រទះឃើញ
ប្រជាជនទាំងអស់ ដែលបានចាកចេញពីដែនដីអាំម៉ូណៃហា
ជាមនុស្សដែលត្រូវគេបណ្ដេញ ហើយចោលថ្មលើ
ពីព្រោះគេជឿតាមពាក្យសំដីនៃអាលម៉ា ។
២ ហើយអ្នកទាំងពីរបានរៀបរាប់ប្រាប់គេពីរឿងទាំងអស់
ដែលបានកើតឡើងដល់ប្រពន្ធ និងកូនចៅគេ និងពីខ្លួនអ្នក
ទាំងពីរផង និងពីអំណាចនៃការដោះលែងរបស់គេ ។
៣ ហើយស៊ីអែសរ៉ុមបានដេកឈឺនៅសៃដុម ដោយ
គ្រុនក្ដៅដែលកំពុងដុតរោល ដែលបណ្ដាលមកអំពីសេចក្ដីទុក្ខ
ដ៏ធំនៅក្នុងគំនិតគាត់ ដោយព្រោះសេចក្ដីទុច្ចរិត ដែលគាត់
បានប្រព្រឹត្ត ព្រោះគាត់បានគិតស្មានថា អាលម៉ា និង
អាមូលេកពុំរស់នៅទៀតទេ; ហើយគាត់បានគិត ស្មានថា អ្នក
ទាំងពីរត្រូវគេសម្លាប់ចោល ពីព្រោះតែសេចក្ដីទុច្ចរិតរបស់
គាត់ ។ ហើយអំពើបាបដ៏ធំនេះ និងអំពើបាបជាច្រើនទៀត
របស់គាត់ បានធ្វើឲ្យគំនិត គាត់កើតទុក្ខ រហូតដល់ធ្វើឲ្យ
គាត់ឈឺជាខ្លាំង ដោយគ្មានច្រកចេញ; ហេតុដូច្នេះហើយ
ទើបគាត់ចាប់ផ្ដើមដុតរោលដោយ កំដៅដ៏ឆេះឆួល ។
៤ ឥឡូវនេះ កាលដែលគាត់បានឮថា អាលម៉ា និង
អាមូលេក បានមកក្នុងដែនដីសៃដុមហើយ នោះចិត្តគាត់
ចាប់ផ្ដើមមានសេចក្ដី ក្លាហានឡើង; ហើយគាត់បានផ្ញើសារ
មួយ ទៅអ្នកទាំងពីរភ្លាម ចង់ឲ្យអ្នកទាំងពីរមកជួបនឹងគាត់ ។
៥ ហើយហេតុការណ៍បានកើតឡើងថា អ្នកទាំងពីរក៏មកភ្លាម
ធ្វើតាមសារដែលគាត់បានផ្ញើទៅពួកគេ; ហើយគេបានចូលទៅ
ក្នុងផ្ទះ ទៅរកស៊ីអែសរ៉ុម; ហើយគេបានឃើញគាត់ដេកនៅលើគ្រែ
ឈឺអស់កម្លាំង ដោយមកពីគ្រុនក្ដៅដែលកំពុងដុតរោល; ឯគំនិត
គាត់ក៏ឈឺចាប់ ជាខ្លាំង ពីព្រោះតែអំពើទុច្ចរិតទាំងឡាយរបស់
គាត់; ហើយកាលគាត់បានឃើញអ្នកទាំងពីរ នោះគាត់ក៏លាតដៃ
ហើយសូមអង្វរឲ្យអ្នកទាំង ពីរជួយព្យាបាលគាត់ផង ។
៦ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាបាននិយាយ
ទៅគាត់ ទាំងចាប់ដៃគាត់ថា៖ តើអ្នកជឿដល់ព្រះចេស្ដានៃ
ព្រះគ្រីស្ទ ក្នុងការសង្គ្រោះឬទេ ?
៧ ហើយគាត់បានឆ្លើយថា៖ បាទ ខ្ញុំជឿពាក្យទាំងអស់ដែល
លោកបានបង្រៀន ។
៨ ហើយអាលម៉ាបាននិយាយថា៖ បើសិនជាអ្នកជឿដល់ការ
ប្រោសលោះនៃព្រះគ្រីស្ទ នោះអ្នកនឹងអាចបានជាសះស្បើយ ។
៩ ហើយគាត់បាននិយាយថា៖ បាទ ខ្ញុំជឿតាមពាក្យសំដី
របស់លោក ។
១០ ហើយលំដាប់នោះ អាលម៉ាបានអំពាវនាវដល់ព្រះ
អម្ចាស់ថា៖ ឱព្រះអម្ចាស់ជាព្រះរបស់យើងខ្ញុំអើយ សូមទ្រង់
មានសេចក្ដីមេត្តា ករុណាដល់បុរសនេះ ហើយព្យាបាល
គាត់ឲ្យបានជាផងចុះ ស្របតាមសេចក្ដីជំនឿរបស់គាត់ ដែល
មានទៅលើព្រះគ្រីស្ទ ។
១១ ហើយកាលអាលម៉ាបាននិយាយពាក្យទាំងនេះហើយ
នោះស៊ីអែសរ៉ុមក៏ស្ទុះក្រោកឈរ ហើយចាប់ផ្ដើមដើរ; ហើយ
ការណ៍ នេះបានផ្ដល់នូវការអស្ចារ្យជាខ្លាំង ដល់ប្រជាជនទាំងអស់
ហើយដំណឹងនេះបានខ្ចរខ្ចាយទៅគ្រប់ទិសទី លើដែនដីសៃដុម ។
១២ ហើយអាលម៉ាធ្វើបុណ្យជ្រមុជទឹកឲ្យស៊ីអែសរ៉ុមថ្វាយព្រះ
អម្ចាស់; ហើយចាប់ពីពេលនោះមក លោកក៏ចាប់ផ្ដើមប្រកាស
ប្រាប់ ប្រជាជន ។
១៣ ហើយអាលម៉ាបានតាំងសាសនាចក្រមួយឡើង
នៅលើដែនដីសៃដុម ហើយបានញែកពួកសង្ឃ និងពួក
គ្រូបង្រៀននៅលើដែនដី ដើម្បីធ្វើបុណ្យជ្រមុជទឹកថ្វាយព្រះអម្ចាស់
ឲ្យអស់អ្នកណាដែលមានបំណងចង់ទទួលបុណ្យជ្រមុជទឹក ។

**១៥** ១*ក* អាលម៉ា ១៦:២–៣, ៩, ១១.
*ខ* អាលម៉ា ១៤:៧.
២ *ក* អាលម៉ា ១៤:៨–១៤.
*ខ* អាលម៉ា ១៤:២៨.
៣ *ក* អាលម៉ា ១៤:៦–៧.
៦ *ក* ម៉ាកុស ៩:២៣.
៨ *ក* ស.ប. ប្រោស, ការប្រោស.
១០ *ក* ម៉ាកុស ២:១–១២.
១១ *ក* កិច្ចការ ៣:១–១១.

១៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេមានចំនួនច្រើន; ព្រោះពួកគេបានប្រមូលគ្នាមកពីគ្រប់តំបន់ ដែលនៅជុំវិញក្រុងសៃដុម ហើយបានទទួលបុណ្យជ្រមុជទឹក ។

១៥ ប៉ុន្តែ រីឯប្រជាជនដែលនៅឯដែនដីអាំម៉ូណៃហា ពួកគេនៅតែមានចិត្តរឹងរូស និងក្បាលរឹង; ហើយគេមិនប្រែចិត្តពីអំពើបាបទាំង ឡាយរបស់គេឡើយ ដោយចោទថា អំណាចទាំងអស់របស់អាលម៉ា និងអាមូលេក គឺជារបស់ផងអារក្ស; ព្រោះពួកគេជាអ្នកកាន់តាម ជំនឿនៃ[ក]នីហ័រ ហើយពុំជឿដល់ការប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេឡើយ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា និងអាមូលេក ឯអាមូលេកបាន[ក]បោះបង់ចោលមាស និងប្រាក់ទាំងអស់របស់គាត់ និងវត្ថុមានតម្លៃៗរបស់លោក ដែលនៅឯដែនដីអាំម៉ូណៃហា ដើម្បីព្រះបន្ទូលនៃព្រះ លោកត្រូវបាន[ខ]បដិសេធដោយពួកអ្នកដែលធ្លាប់ជា មិត្តភក្តិរបស់លោក និងដោយឪពុកលោក និងញាតិសន្តានរបស់លោកផងដែរ ។

១៧ ហេតុដូច្នេះហើយ ក្រោយពីអាលម៉ាបានតាំងសាសនាច[ក]ក្រមួយឡើងនៅក្រុងសៃដុម នោះលោកសង្កេតឃើញមានជ័យជំនះ មួយ ដ៏ធំ មែនហើយ លោកឃើញថា ប្រជាជនបានឈ្នះលើការឆ្មើងឆ្មៃនៃចិត្តរបស់គេ ហើយបានចាប់ផ្ដើម[ខ]បន្ទាបខ្លួននៅចំពោះព្រះ ហើយបាន ចាប់ផ្ដើមជួបជុំគ្នានៅក្នុងទីបរិសុទ្ធទាំងឡាយរបស់គេ ដើម្បី[គ]ថ្វាយបង្គំព្រះ នៅចំពោះទីអាសនា ដោយ[ឃ]ចាំយាម ហើយអធិស្ឋានជានិច្ច ដើម្បីឲ្យគេបានដោះរួចផុតពីអារក្សសាតាំង និង[ង]ពីសេចក្តីស្លាប់ និងពីសេចក្តីបំផ្លិចបំផ្លាញ —

១៨ ឥឡូវនេះ ដូចជាខ្ញុំបាននិយាយមកហើយថា កាលអាលម៉ាបានឃើញការណ៍អស់ទាំងនេះហើយ ហេតុដូច្នេះហើយ លោក បាននាំអាមូលេក ហើយបានមកឯដែនដីសារ៉ាហិមឡា ហើយបាននាំអាមូលេកមកឯផ្ទះរបស់លោកផ្ទាល់ ហើយបានជួយលោក នៅពេលលោកមានទុក្ខ ហើយចំរើនកម្លាំងដល់លោក នៅក្នុងព្រះអម្ចាស់ ។

១៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់ក្នុងរជ្ជកាលនៃពួកចៅក្រមទៅលើប្រជាជននីហ្វៃ ៕

## ជំពូកទី ១៦

*ពួកលេមិនបំផ្លាញប្រជាជននៅដែនដីអាំម៉ូណៃហា — សូរាំដឹកនាំពួកនីហ្វៃ ឲ្យបានជ័យជំនះលើពួកលេមិន — អាលម៉ា និងអាមូលេក និងអ្នកឯទៀតជាច្រើន ប្រកាសប្រាប់ព្រះបន្ទូល — ពួកគេបង្រៀនថា ក្រោយពីដំណើររស់ឡើងវិញ នោះព្រះគ្រីស្ទនឹងលេច មកឲ្យពួកសាសន៍នីហ្វៃឃើញ ។ ប្រមាណជា ឆ្នាំ ៨១–៧៧ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីដប់មួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នៅថ្ងៃទីប្រាំ នៃខែទីពីរ មាន សេចក្តីសុខសាន្តដ៏ច្រើន នៅលើដែនដីសារ៉ាហិមឡា គ្មានសង្គ្រាម ឬការទាស់ទែងគ្នាអស់ប៉ុន្មានឆ្នាំ គឺរហូតដល់ថ្ងៃទីប្រាំនៃខែទីពីរ នៅក្នុងឆ្នាំទីដប់មួយ មានសំរែកនៃសង្គ្រាមឮទូទៅទាំងដែនដី ។

២ ត្បិតមើលចុះ ពលទ័ពសាសន៍លេមិន បានមកពីខាងទិសនៃទីរហោស្ថាន ចូលមកក្នុងព្រំប្រទល់ដែនដី គឺចូលមកដល់ទីក្រុង[ក]អាំម៉ូណៃហា ហើយបានចាប់ផ្ដើមសម្លាប់ប្រជាជន និងបំផ្លាញទីក្រុងចោល ។

៣ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មុនពេលពួកនីហ្វៃអាចកើនទ័ពឲ្យបានគ្រប់គ្រាន់ ដើម្បីរុញច្រានពួកវាចេញពីដែនដីទៅ ពួកនោះបាន[ក]បំផ្លាញប្រជាជន ដែលនៅក្នុងទីក្រុងអាំម៉ូណៃហា និងអ្នកខ្លះដែលនៅខាងត្បូងព្រំប្រទល់នឹងដែនដីណូអេផង ហើយបានចាប់អ្នកខ្លះទៀតយកទៅជាឈ្លើយចូលទៅក្នុងទីរហោស្ថាន ។

៤ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកនីហ្វៃមានបំណងចង់បានពួកអ្នក ដែលត្រូវចាប់យកទៅជាឈ្លើយ ចូលទៅក្នុងទីរហោស្ថានមកវិញ ។

៥ ហេតុដូច្នេះហើយ មនុស្សម្នាក់ដែលត្រូវបានរើសឡើងឲ្យធ្វើជាមេទ័ពឯកលើពលទ័ពសាសន៍នីហ្វៃ (ហើយឈ្មោះគាត់គឺសូរាំ ហើយលោកមានកូនប្រុសពីរនាក់ គឺលីហៃ និងអ័ហា) — ឥឡូវនេះ សូរាំ និងកូនប្រុសលោកទាំងពីរនាក់ដឹងថា អាលម៉ាជាសង្ឃជាន់ ខ្ពស់ក្នុងសាសនាចក្រ ហើយបានឮថា

---

១៥ *ក* អាលម៉ា ១:២–១៥.
១៦ *ក* លូកា ១៤:៣៣;
អាលម៉ា ១០:៤.
*ខ* ស.ប. បៀតបៀន, សេចក្តីបៀតបៀន.
១៧ *ក* អាលម៉ា ១៦:២១.
*ខ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*គ* ស.ប. ថ្វាយបង្គំ.
*ឃ* ស.ប. ការអធិស្ឋាន; ចាំយាម, ពួកអ្នកចាំយាម.
*ង* ស.ប. សេចក្តីស្លាប់ខាងវិញ្ញាណ.
**១៦** ២ *ក* អាលម៉ា ១៥:១, ១៥–១៦.
៣ *ក* អាលម៉ា ៩:១៨.

លោកមានវិញ្ញាណនៃការព្យាករណ៍ ហេតុដូច្នេះហើយ ពួក
គេក៏ទៅជួបនឹងលោក ហើយសួរ លោកចង់ដឹងថា តើព្រះ
អម្ចាស់ទ្រង់មានព្រះហឫទ័យចង់ឲ្យពួកគេចូលទៅក្នុង
ទីរហោស្ថាន ដើម្បីទៅរកបងប្អូនគេ ដែលពួកលេមិន បាន
ចាប់យកទៅជាឈ្លើយនោះឬទេ ។
៦ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ាបាន[ក]សូម
ដល់ព្រះអំពីរឿងនេះ ។ ហើយអាលម៉ាបានត្រឡប់មកវិញ
ហើយបាន ប្រាប់ពួកគេថា៖ មើលចុះ ពួកលេមិននឹងឆ្លងទន្លេស៊ីដូន
នៅក្នុងទីរហោស្ថានខាងត្បូង នៅឯខាងនាយព្រំប្រទល់ដែនដី
ម៉ាន់តៃ ។ ហើយមើលចុះ គឺទីនោះហើយដែលអ្នកត្រូវ
ទៅជួបគេ គឺនៅខាងកើតទន្លេស៊ីដូន ហើយនៅទីនោះ ព្រះ
អម្ចាស់ទ្រង់នឹងប្រគល់បងប្អូន អ្នកដែលពួកលេមិនបានចាប់យក
ទៅជាឈ្លើយនោះឲ្យអ្នកហើយ ។
៧ ហើយហេតុការណ៍បានកើតឡើងថា សូរាំ និង
កូនប្រុសលោកទាំងពីរនាក់ ក៏ឆ្លងទន្លេស៊ីដូន ជាមួយនឹងពល
ទ័ពរបស់គេ ហើយ បានដើរទៅហួសព្រំប្រទល់ដែនដីម៉ាន់តៃ
ចូលទៅក្នុងទីរហោស្ថានខាងត្បូង គឺនៅប៉ែកខាងកើត
នៃទន្លេស៊ីដូន ។
៨ ហើយពួកគេបានវាយប្រហារពលទ័ពលេមិន ហើយពួក
លេមិនក៏ខ្ចាត់ខ្ចាយ ហើយត្រូវរុញច្រានចូលទៅក្នុងទីរហោស្ថាន;
ហើយពួកគេបាននាំពួកបងប្អូនគេ ដែលពួកលេមិនបានចាប់យក
ទៅជាឈ្លើយ ហើយគ្មានអ្នកណាមួយ ដែលត្រូវបានយក
ទៅជាឈ្លើយ បាត់បង់សោះឡើយ ។ ហើយពួកគេបាន
នាំបងប្អូនគេវិលមកដែនដីខ្លួន ដើម្បីទៅគ្រប់គ្រងដីធ្លីរបស់ខ្លួនវិញ ។
៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់មួយក្នុងរជ្ជកាលនៃពួកចៅក្រមទៅ
ដោយពួកលេមិនត្រូវបានរុញច្រានឲ្យចេញពីដែនដីទៅ រីឯ
ប្រជាជនអាំម៉ូណៃហាក៏[ក]ត្រូវបំផ្លាញចោលទៅ; មែនហើយ អស់
ទាំងសាសន៍អាំម៉ូណៃហាត្រូវ[ខ]បំផ្លាញចោល ព្រមទាំងទីក្រុង
ដ៏ធំរបស់គេ ផង ដែលគេបាននិយាយថា ព្រះទ្រង់មិន
អាចបំផ្លាញបានឡើយ ពីព្រោះតែសភាពដ៏ធំរបស់វា ។
១០ ប៉ុន្តែមើលចុះ [ក]គ្រាន់តែមួយថ្ងៃប៉ុណ្ណោះ ទីក្រុងនោះត្រូវ
បំផ្លាញសាបសូន្យចោលទៅ; ហើយសាកសពទាំងឡាយត្រូវ
ឆ្កែ និងសត្វព្រៃហែកស៊ីអស់ នៅក្នុងទីរហោស្ថាន ។
១១ ទោះជាយ៉ាងណាក៏ដោយ គង់តែច្រើនថ្ងៃក្រោយមក
សាកសពរបស់គេត្រូវបានគរនៅពាសពេញលើផ្ទៃផែនដី ហើយ
ត្រូវ បានកប់យ៉ាងរាក់ៗ ។ ហើយឥឡូវនេះ ទីនោះមាន
ក្លិនស្អុយជាខ្លាំង រហូតដល់គ្មានមនុស្សណាទៅយកដីនៅ
អាំម៉ូណៃហាឡើយ អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។
ហើយគេបានហៅទីនោះថាជា [ក]ទីចោលស្ងាត់នៃពួកនីហ៊ូរ; ព្រោះ
ពួកគេជាអ្នកកាន់តាមជឿនៃ នីហ៊ូរ ដែលត្រូវគេសម្លាប់ចោល
ហើយដែនដីទាំងឡាយរបស់គេ នៅជាស្ងាត់សូន្យឈឹងតទៅ ។
១២ ហើយពួកលេមិនពុំបានមកធ្វើសង្គ្រាមជាមួយនឹងពួក
នីហ្វៃទៀតទេ រហូតដល់ឆ្នាំទីដប់បួនក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើ ប្រជាជននីហ្វៃ ។ ម្ល៉ោះហើយ ប្រជាជននីហ្វៃមាន
សេចក្ដីសុខសាន្តតរៀងមក អស់រយៈបីឆ្នាំនៅលើអស់ទាំងដែនដី ។
១៣ ហើយអាលម៉ា និងអាមូលេក បានចេញទៅប្រកាស
ប្រាប់អំពីការប្រែចិត្តដល់ប្រជាជន នៅក្នុង[ក]ព្រះវិហារបរិសុទ្ធ
ទាំងឡាយ របស់គេ និងនៅក្នុងទីបរិសុទ្ធទាំងឡាយរបស់គេ
និងនៅក្នុង[ខ]សាលាប្រជុំទាំងឡាយរបស់គេដែរ ដែលបាន
សង់ឡើងតាមរបៀប ពួកសាសន៍យូដា ។
១៤ ហើយដរាបណាមានមនុស្សដែលចង់ស្ដាប់ពាក្យសំដី
របស់គេ គឺពួកនោះហើយដែលពួកគេបាននាំលែកព្រះបន្ទូលនៃព្រះ
ជារៀង រហូត ដោយ[ក]មិនយោគយល់ខាងអ្នកណាឡើយសោះ ។
១៥ ម្ល៉ោះហើយ អាលម៉ា និងអាមូលេកបានចេញទៅ
ហើយព្រមទាំងមនុស្សជាច្រើនទៀតផង ដែលត្រូវបានរើសឡើង
សំរាប់ធ្វើ កិច្ចការនេះ ក៏បានចេញទៅប្រកាសប្រាប់ព្រះបន្ទូល
ទូទៅអស់ទាំងដែនដី ។ ហើយការតាំងសាសនាចក្រ ក៏កើត
ឡើងទូទៅទាំងដែនដី គឺនៅគ្រប់តំបន់ព័ទ្ធជុំវិញ នៅក្នុង
ចំណោមប្រជាជន នៃសាសន៍នីហ្វៃទាំងអស់ ។
១៦ ហើយគ្មានការមិនស្មើ[ក]គ្នានៅក្នុងចំណោមពួកគេឡើយ;
ព្រះអម្ចាស់ទ្រង់បានស្រោចព្រះវិញ្ញាណទ្រង់មកលើអស់ទាំងផ្ទៃផែនដី
ដើម្បីរៀបចំចិត្តគំនិតនៃកូនចៅមនុស្ស ឬក៏ដើម្បីរៀបចំ[ខ]ចិត្តគេ
ឲ្យទទួលព្រះបន្ទូល ដែលនឹងត្រូវបានបង្រៀននៅក្នុងចំណោម
ពួកគេ នៅពេលដែលទ្រង់នឹងយាងមក —
១៧ ដើម្បីកុំឲ្យគេរឹងទទឹងនឹងព្រះបន្ទូល ដើម្បីកុំឲ្យគេអាចទៅជា
ឥតជំនឿ ហើយដើរឆ្ពោះទៅរកការបំផ្លិចបំផ្លាញឡើយ

៦ *ក* អាលម៉ា ៤៣:២៣–២៤.
៩ *ក* អាលម៉ា ៨:១៦; ៩:១៨–២៤; មរមន ៦:១៥–២២.
*ខ* អាលម៉ា ២៥:១–២.
១០ *ក* អាលម៉ា ៩:៤.
១១ *ក* អាលម៉ា ១:១៥; ២៤:២៨–៣០.
១៣ *ក* ២ នីហ្វៃ ៥:១៦.
*ខ* អាលម៉ា ២១:៤–៦, ២០.
១៤ *ក* អាលម៉ា ១:៣០.
១៦ *ក* ម៉ូសាយ ១៨:១៩–២៩; ៤ នីហ្វៃ ១:៣.
*ខ* ស.ប. ចិត្តសង្រេង.

តែដើម្បី ឲ្យគេអាចទទួលព្រះបន្ទូល ដោយសេចក្ដីអំណរវិញ ហើយដើម្បីឲ្យបានទៅដូចជាមែកមួយ ដែលបានបំបៅជាប់ទៅនឹងដើមទំពាំងបាយ ជូរពិត ដើម្បីឲ្យគេអាចចូលទៅក្នុងសេចក្ដីសំរាកនៃព្រះអម្ចាស់ ជាព្រះរបស់គេបាន ។

១៨ ឥឡូវនេះ ពួកសង្ឃទាំងនោះ ដែលបានចេញទៅក្នុងចំណោមប្រជាជន ក៏បានប្រកាសទាស់នឹងការកុហក ការបញ្ឆោត ការឈ្នានីស ការជណ្ដើម ការគំនុំ ការបង្អាប់ ការលួច ការប្លន់ ការបង្ខំ ការធ្វើឃាតកម្ម ការផិត និងការអាសអាភាសគ្រប់បែបយ៉ាង ដោយស្រែកប្រកាសសូមកុំឲ្យមានការអស់ទាំងនេះកើតឡើងឡើយ —

១៩ ពួកគេបានពន្យល់ប្រាប់អំពីការណ៍ដែលជិតនឹងកើតឡើង; មែនហើយ បានពន្យល់ប្រាប់អំពីការយាងមក នៃព្រះរាជបុត្រានៃព្រះ ការរងទុក្ខ និងការសុគតរបស់ទ្រង់ ព្រមទាំងដំណើររស់ឡើងវិញនៃមនុស្សស្លាប់ ។

២០ ហើយមនុស្សជាច្រើន បានសួរចង់ដឹងអំពីទីកន្លែង ដែលព្រះរាជបុត្រានៃព្រះនឹងយាងមក; ហើយពួកគេត្រូវបានប្រាប់ថាទ្រង់នឹងលេចមកឲ្យពួកគេឃើញ បន្ទាប់ពីដំណើររស់ឡើងវិញរបស់ទ្រង់; ហើយប្រជាជនបានឮការណ៍នេះ ដោយសេចក្ដីអំណរ និងដោយសេចក្ដីរីករាយពន់ប្រមាណ ។

២១ ហើយឥឡូវនេះ បន្ទាប់ពីសាសនាចក្រត្រូវបានតាំងឡើងទូទៅអស់ទាំងដែនដីហើយ — ដោយមានជ័យជំនះលើអារក្ស ហើយព្រះបន្ទូលនៃព្រះ ក៏ត្រូវបានប្រកាសប្រាប់នៅក្នុងភាពត្រឹមត្រូវ នៅពាសពេញទាំងដែនដី ហើយព្រះអម្ចាស់ទ្រង់ចាក់ព្រះពរ ទាំងឡាយរបស់ទ្រង់មកលើប្រជាជន — ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់បួនក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ៕

---

ដំណើររឿងរបស់ពួកបុត្រានៃម៉ូសាយ ដែលបានបដិសេធសិទ្ធិរបស់គេ ក្នុងការទទួលនគរ ព្រោះតែព្រះបន្ទូលនៃព្រះ ហើយបាន ឡើងទៅដែនដីនីហ្វៃ ដើម្បីទៅប្រកាសប្រាប់ពួកលេមិន; សេចក្ដីវេទនាទាំងឡាយ និងការដោះលែងរបស់គេ — ស្របតាមបញ្ជី របស់អាលម៉ា ។

*មានរួមពីជំពូកទី ១៧ ដល់ ២៦*

---

## ជំពូកទី ១៧

*ពួកបុត្រានៃម៉ូសាយប្រកបដោយវិញ្ញាណនៃការព្យាករណ៍ និងវិវរណៈ — ពួកគេទៅផ្លូវរៀងៗខ្លួន ទៅប្រកាសប្រាប់ព្រះបន្ទូលដល់ពួក លេមិន — អាំម៉ូនទៅដែនដីអ៊ីសម៉ាអែល ហើយក្លាយទៅជាអ្នកបំរើស្ដេចឡាម៉ូណៃ — អាំម៉ូនជួយសង្គ្រោះហ្វូងចៀមរបស់ស្ដេច ហើយសម្លាប់ពួកខ្មាំងសត្រូវរបស់ទ្រង់ នៅត្រង់ទឹកស៊ីប៊ុស ។ ខទី ១–៣, ប្រមាណជាឆ្នាំ ៧៧ ម.គ.ស.; ខទី ៤, ប្រមាណជាឆ្នាំ ៩១–៧៧ ម.គ.ស.; ហើយខទី ៥–៣៩, ប្រមាណជាឆ្នាំ ៩១ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលអាលម៉ាកំពុងតែធ្វើដំណើរពីដែនដីគេឌាន ទៅឯទិសខាងត្បូងគឺឆ្ពោះទៅរក ដែនដីម៉ាន់តៃ មើលចុះ លោកមានសេចក្ដីអស្ចារ្យជាខ្លាំង ដោយបានជួបនឹងពួកបុត្រានៃម៉ូសាយ ដែលកំពុងតែធ្វើដំណើរទៅដែនដី សារ៉ាហិមឡា ។

២ ឥឡូវនេះ ពួកបុត្រានៃម៉ូសាយទាំងនេះ បាននៅជាមួយនឹងអាលម៉ា នៅពេលដែលទេវតាបានលេចមកជាលើកដំបូងដល់លោក; ហេតុដូច្នេះហើយ អាលម៉ាបានអររីករាយជាខ្លាំងនៅពេលបានជួបបងប្អូនរបស់លោកទៀត; រីឯសេចក្ដីអំណររបស់លោក កាន់តែកើន ឡើងថែមទៀត ព្រោះពួកគេនៅជាបងប្អូនរបស់លោក ក្នុងព្រះអម្ចាស់នៅឡើយ; មែនហើយ ពួកគេបានមាំមួននៅក្នុងការស្គាល់ពី សេចក្ដីពិត; ព្រោះពួកគេជាមនុស្សដែលមានយោបល់ដ៏ជ្រាលជ្រៅ ហើយគេបានព្យាយាមពិចារណាមើលបទគម្ពីរ ដើម្បីឲ្យគេអាចស្គាល់ព្រះបន្ទូលនៃព្រះ ។

៣ ប៉ុន្តែ នេះពុំទាន់អស់នៅឡើយទេ; ពួកគេបានប្រគល់ខ្លួនទៅក្នុងការអធិស្ឋាន និងការតមអាហារជាច្រើន; ហេតុដូច្នេះហើយ

---

១៧ *ក* យ៉ាកុប ៥:២៤.
*ខ* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*គ* អាលម៉ា ១២:៣៧; ១៣:១០–១៣.
១៨ *ក* អាលម៉ា ១៥:១៣.
*ខ* ស.ប. ការបោក, បញ្ឆោត, សេចក្ដីបញ្ឆោត.
*គ* ស.ប. ច្រណែន.
១៩ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
២០ *ក* ២ នីហ្វៃ ២៦:៩; ៣ នីហ្វៃ ១១:៧–១៤.
*ខ* ១ នីហ្វៃ ១២:៤–៦.
២១ *ក* អាលម៉ា ១៥:១៧.
**១៧** ១ *ក* អាលម៉ា ២៧:១៦.
*ខ* ម៉ូសាយ ២៧:៣៤.
២ *ក* ម៉ូសាយ ២៧:១១–១៧.
*ខ* ស.ប. បទព្រះគម្ពីរ.
៣ *ក* ស.ប. តម, តំណម; ការអធិស្ឋាន.

ពួកគេប្រកបដោយវិញ្ញាណនៃការព្យាករណ៍ និងវិញ្ញាណនៃវិវរណៈ ហើយកាលណាគេបង្រៀន គឺគេបង្រៀនដោយអានុភាព និងសិទ្ធិអំណាចពីព្រះ ។

៤ ហើយពួកគេបានបង្រៀនព្រះបន្ទូលនៃព្រះ អស់រយៈពេលដប់បួនឆ្នាំ នៅក្នុងចំណោមពួកលេមិន ដោយបានទាំងទទួលការជោគ ជ័យជាច្រើន ក្នុងការនាំមនុស្សជាច្រើនឲ្យបានស្គាល់ពីសេចក្ដីពិត; មែនហើយ ដោយអំណាចនៃពាក្យរបស់គេ នោះមនុស្សជាច្រើន ត្រូវបាននាំទៅខាងមុខអាសនានៃព្រះ ដើម្បីអំពាវនាវដល់ព្រះនាមទ្រង់ ហើយទទួលសារភាពនូវអំពើបាបទាំងឡាយរបស់គេនៅ ចំពោះទ្រង់ ។

៥ ឥឡូវនេះ នេះគឺជាកាលៈទេសៈ ដែលបានកើតឡើងដល់គេក្នុងការធ្វើដំណើរ ព្រោះគេមានការវេទនាជាច្រើន; គេបានរងទុក្ខ ជាច្រើន ទាំងផ្លូវកាយ និងផ្លូវចិត្ត ដូចជាការអត់ឃ្លានការស្រេក និងការនឿយហត់ ព្រមទាំងការនឿយហត់ខាងផ្លូវវិញ្ញាណផង ។

៦ ឥឡូវនេះ នេះគឺដំណើររបស់គេៈ ក្រោយពីបានលាបិតាខ្លួនគឺម៉ូសាយ នៅឆ្នាំទីមួយនៃរជ្ជកាលនៃពួកចៅក្រម; ដោយបានប្រកែកមិនព្រមទទួលនគរ ដែលបិតាគេចង់ប្រគល់ឲ្យគេឯបំណងរបស់ប្រជាជនក៏ដូច្នោះដែរ;

៧ ទោះជាយ៉ាងណាក៏ដោយ គង់តែគេបានចាកចេញពីដែនដីសារ៉ាហិមឡាទៅ ហើយបានយកដាវរបស់គេ លំពែងរបស់គេធ្នូរបស់គេ ព្រួញរបស់គេ និងខ្សែដង្ហក់របស់គេទៅផង; ហើយគេធ្វើយ៉ាងនេះ គឺដើម្បីគេអាចរកអាហារសំរាប់ខ្លួនគេពេលនៅក្នុង ទីរហោស្ថាន ។

៨ ម្ល៉ោះហើយ ពួកគេបានចេញទៅក្នុងទីរហោស្ថាន ជាមួយនឹងមនុស្សមួយចំនួន ដែលគេបានរើស ដើម្បីឡើងទៅឯដែនដីនីហ្វៃ គឺទៅ ប្រកាសប្រាប់ព្រះបន្ទូលនៃព្រះដល់ពួកលេមិន ។

៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើដំណើរអស់ជាច្រើនថ្ងៃ នៅក្នុងទីរហោស្ថាន ហើយគេបានតមអាហារជាខ្លាំង ហើយបានអធិស្ឋានជាខ្លាំង ដើម្បីសូមឲ្យព្រះអម្ចាស់ទ្រង់ប្រទានចំណែកនៃព្រះវិញ្ញាណរបស់ទ្រង់ដល់គេ ឲ្យទៅជាមួយនឹងគេ ហើយស្ថិតនៅជាមួយនឹងគេ ដើម្បីឲ្យគេអាចបានទៅជាគ្រឿងឧបករណ៍មួយ នៅក្នុងព្រះហស្តនៃព្រះ ប្រសិនបើមានលទ្ធភាព គឺដើម្បី នាំបងប្អូនគេ គឺពួកលេមិនឲ្យស្គាល់សេចក្ដីពិត ឲ្យស្គាល់នូវសេចក្ដីអាក្រក់ នៃសណ្ដាប់ទាំងឡាយ នៃពួកអយ្យកោរបស់គេ ដែលជា សណ្ដាប់មិនត្រឹមត្រូវ ។

១០ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានយាងមករកគេ ដោយព្រះវិញ្ញាណរបស់ទ្រង់ ហើយមានព្រះបន្ទូល ទៅគេថាៈ ចូរក្សាន្តចិត្តចុះ ហើយពួកគេក៏បានក្សាន្តចិត្តទៅ ។

១១ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅគេដែរថាៈ ចូរទៅក្នុងចំណោមពួកលេមិន ដែលជាបងប្អូនអ្នក ហើយតាំងពាក្យរបស់យើងចុះ; តែអ្នកត្រូវអត់ធន់ក្នុងការអត់ធ្មត់ និងការឈឺចាប់ ដើម្បីអ្នកអាចបង្ហាញនូវគំរូល្អទាំងឡាយ ដល់ពួកគេក្នុងយើង ហើយ យើងនឹងយកអ្នកធ្វើជាគ្រឿងឧបករណ៍មួយក្នុងដៃយើង ដល់ការសង្គ្រោះព្រលឹងជាច្រើន ។

១២ ហើយហេតុការណ៍បានកើតឡើងថា ចិត្តរបស់ពួកបុត្រានៃម៉ូសាយ ព្រមទាំងជនទាំងឡាយ ដែលនៅជាមួយនឹងគេក៏មាន សេចក្ដីក្លាហានឡើង ដើម្បីទៅជួបនឹងពួកលេមិនដើម្បីប្រកាសប្រាប់គេនូវព្រះបន្ទូលនៃព្រះ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានមកដល់ព្រំប្រទល់ដែនដីនៃពួកលេមិនហើយ នោះគេក៏បានបែកគ្នាហើយ បានដើរចេញពីគ្នារៀងៗខ្លួន ដោយទុកចិត្តទៅលើព្រះអម្ចាស់ថា ពួកគេនឹងជួបគ្នាទៀត នៅពេលចប់រដូវច្រូតកាត់; ព្រោះគេបាន សន្និដ្ឋានថា កិច្ចការដែលគេបានទទួលធ្វើនេះមានទំហំធំធេងណាស់ ។

១៤ ហើយការនេះជាការធំប្រាកដមែន ព្រោះពួកគេបានទទួលភារកិច្ច ដើម្បីទៅប្រកាសប្រាប់ព្រះបន្ទូលនៃព្រះ ដល់ប្រជាជនមួយ ដែលព្រៃផ្សៃ រឹងរូស និងសាហាវ; ជាប្រជាជនមួយដែលចូលចិត្តក្នុងការធ្វើឃាតកម្មដល់ពួកនីហ្វៃ និងការ

៣ *ខ* ស.ប. បង្រៀន, គ្រូបង្រៀន — ការបង្រៀនដោយនូវព្រះវិញ្ញាណ.
៤ *ក* អាលម៉ា ២៩:១៤.
*ខ* ស.ប. កិច្ចការផ្សាយសាសនា.
*គ* ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
៥ *ក* អាលម៉ា ៨:១០.
៦ *ក* ម៉ូសាយ ២៨:១, ៥–៩.
*ខ* ម៉ូសាយ ២៩:៣.
៩ *ក* អាលម៉ា ២៥:១៧.
ស.ប. ការអធិស្ឋាន.
*ខ* ម៉ូសាយ ២៣:១០; អាលម៉ា ២៦:៣.
*គ* អាលម៉ា ៣:១០–១២.
១០ *ក* គ. និង ស. ៥:១៦.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* អាលម៉ា ២៦:២៧.
១១ *ក* អាលម៉ា ២០:២៩.
ស.ប. សេចក្ដីអត់ធន់.
១៣ *ក* អាលម៉ា ២១:១.
*ខ* ម៉ាថាយ ៩:៣៧.
១៤ *ក* ម៉ូសាយ ១០:១២.

លួចប្លន់គេ; ហើយចិត្តគេត្រូវ បានភ្ជាប់ទៅលើទ្រព្យសម្បត្តិ
ឬទៅលើមាស និងប្រាក់ និងត្បូងដ៏មានតម្លៃ; តែគេតែងតែស្វែងរក
របស់ទាំងនេះ ដោយការធ្វើឃាតកម្ម និងការលួចប្លន់ ដែល
គេមិនចាំបាច់ធ្វើការនឿយហត់ ដើម្បីរករបស់ទាំងនោះដោយ
ដៃឯងឡើយ ។
១៥ ម្ល៉ោះហើយ ពួកគេជាប្រជាជនមួយ[ក]ដ៏ខ្ជិលច្រអូស ពួក
គេជាច្រើនបានថ្វាយបង្គំរូបព្រះ ហើយ[ខ]បណ្ដាសានៃព្រះបាន
ធ្លាក់មកលើ ពួកគេ ពីព្រោះតែសណ្ដាប់ទាំងឡាយនៃពួក
អយ្យកោគេ; ទោះជាយ៉ាងណាក៏ដោយ គង់តែសេចក្ដីសន្យានៃ
ព្រះអម្ចាស់ ក៏ប្រទានដល់ ពួកគេដែរ[ក] កាលណាគេប្រែចិត្ត ។
១៦ ហេតុដូច្នេះហើយ នេះគឺជាមូលហេតុ ដែលនាំឲ្យពួក
បុត្រានៃម៉ូសាយបានទទួលធ្វើកិច្ចការនេះ ក្រែងពួកគេអាច
នាំឲ្យមានការ ប្រែចិត្តដល់គេផង ក្រែងពួកគេអាចនាំគេឲ្យ
ស្គាល់ផែនការនៃសេចក្ដីប្រោសលោះ ។
១៧ ហេតុដូច្នេះហើយ ពួកគេបានបែកគ្នា ហើយបានចេញទៅ
ក្នុងចំណោមពួកគេរៀងៗខ្លួន តាមព្រះបន្ទូល និងតាមព្រះចេស្ដា
នៃព្រះ ដែលបានប្រទានដល់គេ ។
១៨ ឥឡូវនេះ អាំម៉ូន ធ្វើជាមេដឹកនាំគេ ឬបើនិយាយឲ្យចំ
គឺលោកបានធ្វើការងារបំរើពួក[ក]គេ ហើយលោកបាន
ចាកចេញពីគេទៅ បន្ទាប់ពីបានប្រទានពរដល់គេ តាមតំណែងនានា
របស់គេ ដោយបានរំលែកនូវព្រះបន្ទូលនៃព្រះដល់គេ ឬបាន
ធ្វើការងារបំរើគេមុន ពេលលោកចេញដំណើរទៅ; ហើយដោយ
របៀបនេះ គេបានធ្វើដំណើររៀងៗខ្លួន ទូទៅទាំងដែនដី ។
១៩ ហើយអាំម៉ូនបានទៅដែនដីអ៊ីសម៉ាអែល[ក] ជាដែនដីដែល
បានហៅតាមឈ្មោះពួកកូនប្រុសរបស់អ៊ីសម៉ាអែល ដែលបាន
ក្លាយ ទៅជាពួកសាសន៍លេមិនដែរ ។
២០ ហើយកាលអាំម៉ូនបានចូលទៅក្នុងដែនដីអ៊ីសម៉ាអែល
នោះពួកលេមិនបានចាប់លោក ហើយចងលោក ជាសណ្ដាប់
របស់ ពួកគេ គឺចងសាសន៍នីហ្វៃទាំងអស់ណា ដែលធ្លាក់មក
ក្នុងកណ្ដាប់ដៃរបស់គេ ហើយក៏នាំយកទៅទូលស្ដេច; ម្ល៉ោះហើយ
តាមតែ ព្រះទ័យស្ដេច ទោះជាចង់សម្លាប់ពួកគេ ឬទុកពួក
គេឲ្យនៅក្នុងការជាប់ឃុំឃាំង ឬយកពួកគេទៅដាក់គុក
ឬដេញពួកគេចេញក្រៅ ដែនដីក្ដី ក៏ស្រេចតែបំណង និងព្រះ
ទ័យរបស់ស្ដេច ។
២១ ម្ល៉ោះហើយ អាំម៉ូនក៏ត្រូវបាននាំទៅចំពោះស្ដេច ដែល
គ្រប់គ្រងលើដែនដីអ៊ីសម៉ាអែល; ហើយទ្រង់មានព្រះនាមថា
ឡាម៉ូណៃ; ហើយទ្រង់ត្រូវជាពូជពង្សរបស់អ៊ីសម៉ាអែល ។
២២ ហើយស្ដេចក៏សួរអាំម៉ូន ចង់ដឹងថាតើលោកចង់
អាស្រ័យនៅក្នុងដែនដី ក្នុងចំណោមពួកលេមិន ឬក្នុង
ចំណោមប្រជាជនរបស់ ទ្រង់ឬទេ ។
២៣ ហើយអាំម៉ូនទូលទៅទ្រង់ថា៖ ព្រះពរ ទូលបង្គំចង់
អាស្រ័យនៅក្នុងចំណោមប្រជាជននេះមួយរយៈពេលដែរ មែន
ហើយ គឺប្រហែលជារហូតដល់ថ្ងៃទូលបង្គំស្លាប់ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចឡាម៉ូណៃ
សព្វព្រះទ័យនឹងអាំម៉ូន ហើយបានបញ្ជាឲ្យស្រាយចំណងលោក
ចេញ; ហើយទ្រង់ចង់ឲ្យអាំម៉ូនយកបុត្រីរបស់ទ្រង់ម្នាក់ធ្វើជា
ភរិយា ។
២៥ តែអាំម៉ូនទូលទៅទ្រង់ថា៖ ទេ តែទូលបង្គំនឹងធ្វើជាអ្នក
បំរើរបស់ទ្រង់វិញ ។ ហេតុដូច្នេះហើយ អាំម៉ូនបានក្លាយទៅជា
អ្នក បំរើស្ដេចឡាម៉ូណៃ ។ ហើយហេតុការណ៍បានកើតឡើងថា
លោកត្រូវចាត់ឲ្យទៅឃ្វាលហ្វូងចៀមរបស់ឡាម៉ូណៃ ជាមួយ
នឹងពួកអ្នក បំរើឯទៀត តាមសណ្ដាប់របស់ពួកលេមិនទៅ ។
២៦ ហើយក្រោយពីលោកបានបំរើស្ដេចអស់បីថ្ងៃ នៅពេល
ដែលលោកនៅជាមួយនឹងពួកអ្នកបំរើសាសន៍លេមិនឯទៀត កំពុង
តែនាំហ្វូងចៀមទៅកាន់កន្លែងដែលមានទឹក ដែលបានហៅថា
ទឹកស៊ីប៊ុស គឺជាកន្លែងដែលពួកលេមិនទាំងអស់ នាំហ្វូង
ចៀមគេទៅផឹកទឹកដែរ —
២៧ ហេតុដូច្នេះហើយ កាលអាំម៉ូន និងពួកអ្នកបំរើ
របស់ស្ដេច កំពុងតែនាំហ្វូងចៀម ទៅកាន់កន្លែងដែលមាន
ទឹកនោះ មើលចុះ មានពួកលេមិនមួយចំនួន ដែលបាននាំ
ហ្វូងចៀមរបស់គេទៅរកទឹកនោះដែរ បានក្រោកឈរឡើង ហើយ
បានដេញបង្ហើលហ្វូងចៀម របស់អាំម៉ូន និងពួកអ្នកបំរើរបស់ស្ដេច
ហើយគេធ្វើឲ្យចៀមទាំងឡាយរត់បែកខ្ចែកទៅគ្រប់ទិសទី ។
២៨ ឥឡូវនេះ ពួកអ្នកបំរើរបស់ស្ដេច ក៏ចាប់ផ្ដើមរអ៊ូរទាំថា៖
ឥឡូវនេះ ស្ដេចនឹងសម្លាប់យើងហើយ ដូចជាទ្រង់ធ្លាប់បានសម្លាប់
បងប្អូនយើងឯទៀតដែរ ពីព្រោះហ្វូងចៀមគេត្រូវខ្ចាត់ខ្ចាយ
ដោយអំពើទុច្ចរិតរបស់ពួកមនុស្សទាំងនេះ ។ ហើយពួកគេបាន
ចាប់ផ្ដើម យំជាខ្លាំងថា៖ មើលចុះ ហ្វូងចៀមរបស់យើងត្រូវ
ខ្ចាត់ខ្ចាយអស់ហើយ ។
២៩ ឥឡូវនេះ ពួកគេបានយំព្រោះខ្លាចត្រូវប្រហារចោល ។

១៥ *ក* អាលម៉ា ៣:៦–១៩;
៣ នីហ្វៃ ២:១៥–១៦.
*ខ* អាលម៉ា ៩:១៦–២៤; ១៨:៥.
១៦ *ក* ម៉ូសាយ ២៨:១–៣.
១៨ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
១៩ *ក* ១ នីហ្វៃ ៧:៤–៦.

ឥឡូវនេះ កាលអាំម៉ូនបានឃើញការណ៍នេះ ចិត្តលោករីកឡើង
ដោយសេចក្ដីអំណរ; ព្រោះលោកនិយាយថា ខ្ញុំនឹងបង្ហាញ
អំណាចរបស់ខ្ញុំ ដល់ពួកអ្នកបំរើទូទៅដូចរូបខ្ញុំទាំងនេះ ឬក៏
អំណាចដែល នៅក្នុងខ្លួនខ្ញុំ ក្នុងការនាំហ្វូងចៀមទាំងនេះ
មកឲ្យស្ដេចវិញ ដើម្បីខ្ញុំអាចយកចិត្តពួកអ្នកបំរើទូទៅដូចរូបខ្ញុំនេះ
ដើម្បីខ្ញុំអាចដឹកនាំពួកគេ ឲ្យជឿដល់ពាក្យពេចន៍របស់ខ្ញុំផង ។
៣០ ហើយឥឡូវនេះ នេះគឺជាការគិតរបស់អាំម៉ូន កាល
ដែលលោកបានឃើញ ការទុក្ខព្រួយរបស់អ្នកទាំងនោះ ដែល
លោក បានចាត់ទុកថាជាបងប្អូនរបស់លោក ។
៣១ ហើយហេតុការណ៍បានកើតឡើងថា លោកបាន
លួងលោមគេ ដោយពាក្យសំដីលោកថា៖ ឱបងប្អូនទាំងឡាយ
របស់ខ្ញុំអើយ ចូរមានសេចក្ដីសង្ឃឹមចុះ ហើយចូរយើងនាំ
គ្នាទៅរកហ្វូងចៀម នោះយើងនឹងប្រមូលពួកវាមកវិញ ហើយ
នាំវាទៅឯកន្លែងដែលមាន ទឹកចុះ ហើយដោយបែបនេះ យើងនឹង
រក្សាហ្វូងចៀមឲ្យស្ដេច ហើយទ្រង់នឹងពុំសម្លាប់យើងចោលឡើយ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ទៅរកហ្វូងចៀមទាំងនោះ ហើយពួកគេបានដើរតាមអាំម៉ូន
ហើយគេបាន រត់យ៉ាងលឿន ហើយបានស្ទាក់មុខហ្វូងចៀម
ទាំងឡាយរបស់ស្ដេច ហើយបានប្រមូលហ្វូងចៀមទាំងនោះ
មកវិញទៀត ហើយបាននាំ ទៅកាន់កន្លែងដែលមានទឹក ។
៣៣ ហើយពួកជនទាំងនោះ ក៏ក្រោកឡើងបង្អើលហ្វូងចៀម
របស់គេទៀត; តែអាំម៉ូនពោលទៅកាន់បងប្អូនលោកថា៖ ចូរហ៊ុំ
ជុំវិញហ្វូងចៀមកុំឲ្យវារត់បាន; ហើយខ្ញុំនឹងទៅតតាំងជាមួយ
នឹងជនទាំងនេះ ដែលបង្អើលហ្វូងចៀមរបស់យើង ។
៣៤ ហេតុដូច្នេះហើយ ពួកគេបានធ្វើតាមបង្គាប់របស់អាំម៉ូន
ហើយលោកបានចេញទៅតតាំងនឹងពួកជន ដែលឈរនៅក្បែរ
ទឹកស៊ីប៊ុស; ឯពួកនោះមានគ្នាមិនតិចទេ ។
៣៥ ហេតុដូច្នេះហើយ ពួកគេពុំខ្លាចអាំម៉ូនសោះ ព្រោះគេ
បានគិតស្មានថា ពួកគេតែម្នាក់ក៏អាចសម្លាប់លោក តាមទំនើង
ចិត្តគេ បានដែរ ព្រោះពួកគេពុំដឹងថា ព្រះទ្រង់បានសន្យានឹង
ម៉ូសាយថា ទ្រង់នឹងដោះពួកបុត្រាលោកឲ្យរួចផុតពីកណ្ដាប់ដៃពួក
គេ; ហើយពួកគេ ក៏ពុំបានដឹងអ្វីទាល់តែសោះ អំពីព្រះអម្ចាស់;
ហេតុដូច្នេះហើយ ពួកគេចូលចិត្តក្នុងការបំផ្លិចបំផ្លាញបងប្អូនគេ;
ហើយដោយហេតុនេះ បានជាគេឈរចាំបង្អើលហ្វូងចៀម
របស់ស្ដេច ។
៣៦ តែអាំម៉ូនបានក្រោកឈរឡើង ហើយបានចាប់ផ្ដើម
បាញ់ក្រួសទៅលើគេនឹងខ្សែដង្ហក់របស់លោក; មែនហើយ
លោកបាន បាញ់ក្រួសទៅលើគេ ដោយអំណាចដ៏ខ្លាំង;
ហើយហេតុនេះ លោកបានសម្លាប់ពួកគេមួយចំនួន រហូត
ដល់ធ្វើឲ្យពួកគេបានចាប់ផ្ដើម មានសេចក្ដីអស្ចារ្យនឹងអានុភាព
របស់លោក; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេខឹងដែរ
មកពីបងប្អូនគេត្រូវស្លាប់ ហើយពួកគេ តាំងចិត្តថា នឹង
រំលំលោក; ហេតុដូច្នេះហើយ ដោយឃើញថា ពួកគេមិនអាច
បាញ់ក្រួសត្រូវលោកទេ នោះគេក៏វាយលោកនឹងដំបង
ដើម្បីសម្លាប់លោកចោល ។
៣៧ ប៉ុន្តែមើលចុះ នៅពេលមនុស្សម្នាក់លើកដំបងឡើងវាយ
អាំម៉ូន នោះលោកក៏កាត់ដៃគេ ដោយដាវរបស់លោក;
ត្បិតលោក បានទប់នឹងការវាយរបស់គេ ដោយកាប់ដៃគេនឹង
មុខដាវរបស់លោក ដរាបដល់ធ្វើឲ្យពួកគេចាប់ផ្ដើមមានសេចក្ដី
អស្ចារ្យជាខ្លាំង ហើយបានចាប់ផ្ដើមរត់គេចពីលោក; មែន
ហើយ ហើយពួកគេពុំមែនមានចំនួនតិចទេ; ហើយលោកបាន
ធ្វើឲ្យពួកគេរត់ ដោយកម្លាំងដៃ របស់លោក ។
៣៨ ឥឡូវនេះ ពួកគេចំនួនប្រាំមួយនាក់ដែលត្រូវដួលដោយ
សារខ្សែដង្ហក់ តែលោកមិនបានសម្លាប់នរណាម្នាក់ ដោយ
ដាវរបស់ លោកឡើយ លើកលែងតែអ្នកនាំមុខប៉ុណ្ណោះ;
ហើយលោកបានកាត់ដៃរបស់ពួកគេ នៅពេលគេលើកដៃ
មកវាយលោក ហើយ ដៃទាំងនោះពុំមែនតិចទេ ។
៣៩ ហើយកាលដែលលោកបានរុញច្រានពួកគេទៅឆ្ងាយហើយ
នោះលោកក៏ត្រឡប់មកវិញ ហើយគេបានឲ្យហ្វូងចៀមរបស់គេ
ផឹកទឹក ហើយក៏នាំហ្វូងចៀមត្រឡប់ទៅវាលស្មៅរបស់ស្ដេចវិញ
រួចហើយ បានទៅគាល់ស្ដេច ដោយបានយកដៃទាំងឡាយ
ដែលបាន កាត់ផ្ដាច់ដោយដាវរបស់អាំម៉ូន គឺជាដៃរបស់ពួកដែល
រកសម្លាប់លោកចោល; ហើយដៃទាំងនោះត្រូវបាននាំយក
ទៅគាល់ស្ដេច ដើម្បីជាទីបន្ទាល់ដល់ការណ៍ដែលបានធ្វើមក ៕

## ជំពូកទី ១៨

*ស្ដេចឡាម៉ូណៃស្មានថា អាំម៉ូនជាព្រះវិញ្ញាណដ៏មហិមា — អាំម៉ូនបង្រៀនស្ដេចអំពីការបង្កបង្កើត, អំពីទំនាក់ទំនងនៃព្រះជាមួយនឹង មនុស្ស, និងអំពីការប្រោសលោះ ដែលនឹងមកតាមរយៈព្រះគ្រីស្ទ — ឡាម៉ូណៃជឿ ហើយដួលទៅលើដីហាក់ដូចជាសុគត ។ ប្រមាណជាឆ្នាំ ៩០ ម.គ.ស. ។*

៣៥ *ក* ម៉ូសាយ ២៨:៧; អាលម៉ា ១៩:២២–២៣.
៣៦ *ក* អេធើរ ១២:១៥.
*ខ* អាលម៉ា ១៨:១៦.
*គ* អាលម៉ា ១៨:៣.

ហើយហេតុការណ៍បានកើតឡើងថា ស្ដេចឡាម៉ូណៃបានបញ្ជាឲ្យ
ពួកអ្នកបំរើរបស់ទ្រង់ ឈរហើយធ្វើបន្ទាល់នូវការណ៍ទាំងអស់
ដែល គេបានឃើញអំពីរឿងនេះ ។
២ ហើយកាលពួកគេទាំងអស់គ្នាបានធ្វើបន្ទាល់ចប់ នូវអ្វីៗ
ដែលគេបានឃើញហើយ នោះទ្រង់បានដឹងអំពីការស្មោះត្រង់
របស់ អាំម៉ូន ក្នុងការថែរក្សាហ្វូងចៀមរបស់ទ្រង់ ព្រមទាំង
អំណាចដ៏ខ្លាំងរបស់លោក ក្នុងការតតាំងនឹងពួកដែល
រកសម្លាប់លោកចោល ទ្រង់ក៏មានសេចក្ដីអស្ចារ្យជាខ្លាំង ហើយ
មានបន្ទូលថា៖ ប្រាកដណាស់ នេះមិនមែនជាមនុស្សធម្មតាទេ។
មើលចុះ តើនេះមិនមែនជា ព្រះវិញ្ញាណដ៏មហិមា ដែល
ដាក់ទោសដ៏ធំ មកលើប្រជាជននេះ មកពីអំពើ
ឃាតកម្មរបស់គេទេឬ ?
៣ ហើយពួកគេឆ្លើយទូលទៅស្ដេចថា៖ យើងខ្ញុំមិនដឹងថា
អ្នកនេះជាព្រះវិញ្ញាណដ៏មហិមា ឬជាមនុស្សទេ; ប៉ុន្តែ
យើងខ្ញុំដឹងតែ ប៉ុណ្ណេះថា មនុស្សនេះមិនអាចត្រូវសត្រូវ
របស់ស្ដេចសម្លាប់បានឡើយ; ហើយពួកគេក៏មិនអាចបង្អើល
ហ្វូងចៀមរបស់ស្ដេចបានដែរ នៅពេលលោកនៅជាមួយ
នឹងយើងខ្ញុំ មកពីការជំនាញ និងកម្លាំងដ៏មហិមារបស់លោក;
ហេតុដូច្នេះហើយ យើងខ្ញុំដឹងថា លោក ជាមិត្តរបស់ស្ដេច
មួយ ។ ហើយឥឡូវនេះ ឱព្រះរាជាអើយ យើងខ្ញុំមិនជឿថា
មនុស្សនេះមានអំណាចដ៏ខ្លាំងបែបនេះឡើយ ព្រោះ យើងខ្ញុំដឹងថា
លោកមិនអាចត្រូវគេសម្លាប់បានទេ ។
៤ ហើយឥឡូវនេះ កាលស្ដេចបានឮពាក្យទាំងនេះរួចហើយ
នោះទ្រង់មានបន្ទូលទៅគេថា៖ ឥឡូវនេះ យើងដឹងថា នេះ
គឺជាព្រះ វិញ្ញាណដ៏មហិមាមែន; ហើយលោកបានចុះមក
ក្នុងពេលនេះ ដើម្បីរក្សាជីវិតអ្នករាល់គ្នា ដើម្បីកុំឲ្យយើងសម្លាប់
អ្នក ដូចយើងបាន សម្លាប់បងប្អូនអ្នកមុនៗមក ។ ឥឡូវនេះ នេះ
គឺព្រះវិញ្ញាណដ៏មហិមា ដែលពួកអយ្យកោរបស់យើងធ្លាប់
បាននិយាយមកនោះហើយ ។
៥ ឥឡូវនេះ នេះគឺជាសណ្ដាប់របស់ឡាម៉ូណៃ ដែលទ្រង់បាន
ទទួលពីបិតាទ្រង់ថា មានព្រះវិញ្ញាណដ៏មហិមាមួយ ។ ទោះបី
ពួកគេ ជឿដល់ព្រះវិញ្ញាណដ៏មហិមាក្ដី គង់តែគេបានគិតស្មានថា
អ្វីៗដែលគេធ្វើ គឺត្រូវទាំងអស់ ។ ទោះជាយ៉ាងណាក៏ដោយ
គង់តែ ឡាម៉ូណៃបានចាប់ផ្ដើមខ្លាចជាខ្លាំងដែរ ព្រោះខ្លាច
ក្រែងទ្រង់បានធ្វើខុស ក្នុងការប្រហារពួកអ្នកបំរើរបស់ទ្រង់ ។
៦ ព្រោះទ្រង់បានសម្លាប់ពួកគេជាច្រើនមកហើយ ពីព្រោះ
បងប្អូនគេបានធ្វើឲ្យហ្វូងចៀមបែកខ្ញែកនៅកន្លែងទឹក; ម្ល៉ោះហើយ
មកពីហ្វូងចៀមរបស់គេត្រូវបានបែកខ្ញែក ទើបពួកគេត្រូវស្លាប់។
៧ ឥឡូវនេះ នេះគឺជាសណ្ដាប់របស់ពួកលេមិន ដែល
ឈរនៅក្បែរទឹកស៊ីប៊ុស ដើម្បីដេញបង្អើលហ្វូងចៀមរបស់
ប្រជាជន ដើម្បីគេ អាចកៀងចៀម ដែលរត់បែកខ្ញែកនោះ
ទៅដីរបស់គេ នោះគឺជារបៀបប្លន់មួយរបស់គេដែរ ។
៨ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចឡាម៉ូណៃ
បានសួរទៅពួកអ្នកបំរើរបស់ទ្រង់ថា៖ តើអ្នកដែលមានអំណាច
ដ៏មហិមា នេះនៅឯណា ?
៩ ហើយពួកគេបានទូលទៅទ្រង់ថា៖ មើលចុះ អ្នកនោះកំពុងតែឲ្យ
ស្មៅដល់សេះទាំងឡាយរបស់ទ្រង់ ។ ឥឡូវនេះ ស្ដេចបានប្រើ
ពួកអ្នកបំរើរបស់ទ្រង់ មុនពេលដែលគេនាំហ្វូងចៀមទៅផឹកទឹកថា
ពួកគេត្រូវរៀបចំសេះ និងរាជរថទាំងឡាយរបស់ទ្រង់ ហើយ
នាំ ទ្រង់ទៅដែនដីនីហ្វៃ; ព្រោះមានការជប់លៀងមួយយ៉ាង
ធំនៅដែនដីនីហ្វៃ ដែលបានធ្វើឡើងដោយបិតារបស់ឡាម៉ូណៃ
គឺជាស្ដេចលើ ដែនដីទាំងមូល ។
១០ ឥឡូវនេះ កាលដែលស្ដេចឡាម៉ូណៃបានឮថា
អាំម៉ូនកំពុងតែរៀបចំសេះ និងរាជរថទាំងឡាយរបស់ទ្រង់
ទ្រង់ក៏កាន់តែមាន សេចក្ដីអស្ចារ្យ មកពីចិត្តស្មោះត្រង់របស់អាំម៉ូន
ដោយមានបន្ទូលថា៖ ប្រាកដជាគ្មានអ្នកបំរើរបស់យើងណាមួយ
ដែលមានចិត្តស្មោះ ត្រង់ដូចបុរសនេះសោះ; ព្រោះគាត់ចាំបញ្ជា
របស់យើងទុកទាំងអស់ ហើយក៏អនុវត្តតាមបញ្ជាទាំងនោះដែរ។
១១ ឥឡូវនេះ យើងដឹងប្រាកដថា នេះគឺជាព្រះវិញ្ញាណ
ដ៏មហិមានោះមែន ហើយយើងចង់ឲ្យគាត់មកជួបនឹងយើង
តែយើងមិន ហ៊ានសោះ ។
១២ ហើយហេតុការណ៍បានកើតឡើងថា កាលដែលអាំម៉ូន
បានរៀបចំសេះ និងរាជរថទាំងឡាយរួចស្រេចសំរាប់ស្ដេច
និងពួក អ្នកបំរើរបស់ទ្រង់ហើយ នោះលោកបានចូលទៅគាល់ស្ដេច
ហើយលោកបានឃើញទឹកមុខរបស់ស្ដេចផ្លាស់ប្ដូរ; ហេតុ
ដូច្នេះហើយ បានជាលោកបំរុងនឹងវិលចេញពីវត្តមានរបស់ទ្រង់ ។
១៣ ហើយអ្នកបំរើម្នាក់របស់ស្ដេច បាននិយាយទៅលោកថា
រ៉ាបាណា ប្រែថា ស្ដេចដ៏ធំ ឬឧត្ដម ដោយចាត់ទុកថា ស្ដេចរបស់
គេមានអានុភាព; ម្ល៉ោះហើយ អ្នកនោះនិយាយទៅលោកថា៖
រ៉ាបាណា ស្ដេចចង់ឲ្យអ្នកនៅទីនេះ ។
១៤ ហេតុដូច្នេះហើយ អាំម៉ូនបានបែរទៅរកស្ដេច ហើយ
ទូលទៅកាន់ទ្រង់ថា៖ ឱព្រះរាជាអើយ តើព្រះអង្គចង់ឲ្យ

១៨ ៣ *ក* អាលម៉ា ១៧:៣៤–៣៨.
៤ *ក* អាលម៉ា ១៧:២៨–៣១.
៥ *ក* អាលម៉ា ១៩:២៥–២៧.
ស.ប. ព្រះ, ក្រុមព្រះ.

ទូលបង្គំធ្វើអ្វីថ្វាយ? ហើយស្ដេចពុំបានឆ្លើយតបនឹងលោកសោះ
អស់រយៈពេលមួយម៉ោង តាមម៉ោងរបស់ពួកគេ ព្រោះទ្រង់
មិនដឹងជានិយាយជាមួយ នឹងលោកដូចម្ដេចទេ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូនបាន
ទូលទៅកាន់ទ្រង់ទៀតថា៖ តើព្រះអង្គចង់ឲ្យទូលបង្គំធ្វើអ្វី ?
តែស្ដេចក៏នៅតែ មិនឆ្លើយតបនឹងលោកទៀតឡើយ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូនបាន
ពោរពេញទៅដោយព្រះវិញ្ញាណនៃព្រះ ហេតុដូច្នេះហើយ
ទើបលោកយល់ [ក]គំនិតរបស់ស្ដេច ។ ហើយលោកបាន
ទូលទៅទ្រង់ថា៖ តើពីព្រោះទ្រង់បានឮថា ទូលបង្គំបានការពារ
ពួកអ្នកបំរើរបស់ទ្រង់ និងហ្វូងចៀម របស់ទ្រង់ ហើយ
បានសម្លាប់ពួកគេចំនួនប្រាំពីរនាក់ ដោយខ្សែដង្ហក់ និងដាវ
ហើយបានកាត់ផ្ដាច់ដៃរបស់អ្នកឯទៀត ដើម្បីការពារហ្វូង
ចៀម និងពួកអ្នកបំរើរបស់ទ្រង់; មើលចុះ តើការណ៍នេះឬ
ដែលបណ្ដាលឲ្យទ្រង់ឆ្ងល់ ?
១៧ ទូលបង្គំសូមទូលសួរទ្រង់ តើអ្វីទៅដែលធ្វើឲ្យទ្រង់
ឆ្ងល់ដ៏ខ្លាំងបែបនេះ? មើលចុះ ទូលបង្គំជាមនុស្សទេតើ ហើយ
ជាអ្នកបំរើ របស់ទ្រង់; ហេតុដូច្នេះហើយ ទោះជាទ្រង់ចង់ឲ្យ
ទូលបង្គំធ្វើអ្វីក៏ដោយ ឲ្យតែជាការត្រូវ គង់តែទូលបង្គំនឹងធ្វើ
ទាំងអស់ ។
១៨ ឥឡូវនេះ កាលដែលស្ដេចបានឮពាក្យទាំងនេះហើយ
ទ្រង់ក៏កាន់តែឆ្ងល់ឡើងទៀត ព្រោះទ្រង់ឃើញថា [ក]អាំម៉ូនអាចយល់
គំនិតរបស់ទ្រង់; តែទោះជាយ៉ាងនេះក៏ដោយ គង់តែស្ដេច
ឡាម៉ូណៃបានបើកព្រះឱស្ឋដែរ ហើយមានបន្ទូលទៅលោកថា៖
តើលោកជា អ្នកណា ? តើលោកជា[ខ]ព្រះវិញ្ញាណដ៏មហិមា
ដែលជ្រាបរឿងទាំងអស់នោះឬអី ?
១៩ អាំម៉ូនបានឆ្លើយ ហើយទូលទៅទ្រង់ថា៖ ទេ ទូលបង្គំមិន
មែនទេ ។
២០ ហើយស្ដេចមានបន្ទូលថា៖ ម្ដេចក៏លោកជ្រាបគំនិត
ដែលនៅក្នុងចិត្តយើងបាន? ចូរនិយាយដោយក្លាហាន ហើយ
ប្រាប់យើង អំពីរឿងទាំងនេះចុះ; ហើយចូរប្រាប់យើងផងថា
តើដោយអំណាចអ្វីដែលលោកបានសម្លាប់ ហើយកាត់ដៃបងប្អូន
ដែលបានបង្ហើលហ្វូង ចៀមរបស់យើងនោះ —
២១ ហើយឥឡូវនេះ បើសិនជាលោកប្រាប់យើងអំពីរឿង
ទាំងនេះ នោះលោកចង់បានអ្វីក៏យើងឲ្យដែរ; ហើយប្រសិនបើ
ជាការ ចាំបាច់ យើងនឹងការពារលោកដោយពលទ័ព
របស់យើង; តែយើងដឹងថា លោកមានអំណាចជាងអស់
ទាំងពលទ័ពយើងទៅទៀត; ក៏ប៉ុន្តែទោះជាអ្វីក៏ដោយដែល
លោកចង់បានពីយើង ក៏យើងនឹងឲ្យលោកដែរ ។
២២ ឥឡូវនេះ អាំម៉ូន ជាមនុស្សឈ្លាសវៃ តែមិនបៀតបៀន
អ្នកណាឡើយ នោះលោកបានទូលទៅឡាម៉ូណៃថា៖ តើព្រះអង្គ
នឹង ស្ដាប់តាមពាក្យសំដីរបស់ទូលបង្គំទេ បើសិនជាទូលបង្គំប្រាប់
ព្រះអង្គថាដោយអំណាចអ្វី ដែលទូលបង្គំបានធ្វើការទាំងនេះ ?
នេះហើយគឺការណ៍ដែលទូលបង្គំចង់បានពីព្រះអង្គ ។
២៣ ហើយស្ដេចបានឆ្លើយតបទៅលោកថា៖ មែនហើយ
យើងនឹងជឿពាក្យលោកទាំងអស់ ។ ហើយដោយហេតុនេះ
ទ្រង់ក៏បាន ជាប់ក្នុងកលោបាយ ។
២៤ ហើយអាំម៉ូនបានចាប់ផ្ដើមទូលទៅទ្រង់ ដោយ[ក]ក្លាហាន
ហើយទូលទ្រង់ថា៖ តើព្រះអង្គជឿថា មានព្រះឬទេ ?
២៥ ហើយទ្រង់បានឆ្លើយតប ហើយមានបន្ទូលទៅលោកវិញថា៖
យើងមិនដឹងថា ពាក្យនេះមានន័យយ៉ាងណាទេ ។
២៦ ហើយខណៈនោះ អាំម៉ូនបានទូលថា៖ តើព្រះអង្គជឿថា
មានព្រះវិញ្ញាណដ៏មហិមាមួយឬទេ ?
២៧ ហើយទ្រង់បាននិយាយថា ជឿ ។
២៨ ហើយអាំម៉ូនបានទូលថា៖ នេះហើយជាព្រះ ។ ហើយ
អាំម៉ូនបានទូលទៅទ្រង់ទៀតថា៖ តើព្រះអង្គជឿថា ព្រះវិញ្ញាណដ៏
មហិមានេះ ដែលជាព្រះបានបង្កើតរបស់សព្វសារពើ ដែល
នៅលើស្ថានសួគ៌ និងនៅលើផែនដីឬទេ ?
២៩ ហើយទ្រង់មានបន្ទូលថា៖ មែនហើយ យើងជឿថា ទ្រង់
បានបង្កើតរបស់សព្វសារពើនៅលើផែនដី តែយើងមិនដឹងថា
ស្ថានសួគ៌ជាអ្វីទេ ។
៣០ ហើយអាំម៉ូនបានទូលទៅទ្រង់ថា៖ ស្ថានសួគ៌គឺជាទីកន្លែង
ដែលព្រះ និងពួកទេវតាបរិសុទ្ធទាំងអស់របស់ទ្រង់គង់នៅ ។
៣១ ហើយស្ដេចឡាម៉ូណៃបាននិយាយថា៖ តើនៅពីលើផែនដីឬ?
៣២ ហើយអាំម៉ូនបានទូលថា៖ ក្រាបទូល ហើយទ្រង់សម្លឹង
ចុះមកក្រោម ទតមើលកូនចៅមនុស្សទាំងអស់; ហើយទ្រង់
ជ្រាបនូវ [ក]គំនិតទាំងអស់ និងបំណងទាំងអស់នៅក្នុងចិត្ត; ព្រោះ
ដោយព្រះហស្ដរបស់ទ្រង់នោះហើយដែលរបស់សព្វសារពើ
ត្រូវបានបង្កើតឡើង ចាប់ពីដើមដំបូងមកម្ល៉េះ ។
៣៣ ហើយស្ដេចឡាម៉ូណៃមានបន្ទូលថា៖ យើងជឿ

១៦ ក អាលម៉ា ១២:៣.
១៨ ក ស.ប. ការសង្កេតស្គាល់, អំណោយ ទាបខាង.
ខ ស.ប. ព្រះ, ក្រុមព្រះ.
២៤ ក អាលម៉ា ៣៨:១២.
៣២ ក អេម៉ុស ៤:១៣; ៣ នីហ្វៃ ២៨:៦; គ. និង ស. ៦:១៦.

ការណ៍ដែលលោកនិយាយទាំងអស់នេះ ។ ចុះតើព្រះទ្រង់បានចាត់លោកឲ្យ មកឬ ?

៣៤ អាំម៉ូនបានទូលទៅទ្រង់ថា៖ ទូលបង្គំជាមនុស្សម្នាក់; ហើយកាលពីដើមដំបូងឡើយ មនុស្សត្រូវបានបង្កើតឡើង តាមរូបភាពនៃព្រះ ហើយទូលបង្គំក៏ត្រូវបានហៅ ដោយព្រះវិញ្ញាណដ៏បរិសុទ្ធរបស់ទ្រង់ ឲ្យមកបង្រៀនពីការណ៍ទាំងនេះ ដល់ប្រជាជននេះ ដើម្បីនាំ ឲ្យគេស្គាល់នូវអ្វីៗដែលត្រឹមត្រូវ ហើយពិត;

៣៥ ហើយមួយភាគនៃព្រះវិញ្ញាណនេះគង់នៅក្នុងទូលបង្គំ ដែលប្រទានដល់ទូលបង្គំនូវដំរិះ និងអំណាចផង ស្របតាមសេចក្ដីជំនឿ និងបំណងរបស់ទូលបង្គំដែលនៅក្នុងព្រះ ។

៣៦ ឥឡូវនេះ កាលអាំម៉ូនបាននិយាយពាក្យអស់ទាំងនេះចប់អស់ហើយ នោះលោកក៏ចាប់ផ្ដើមនិយាយ អំពីការបង្កបង្កើត លោកិយ ព្រមទាំងការបង្កើតលោកអ័ដាមផង ហើយបានប្រាប់ទ្រង់នូវការណ៍ទាំងអស់ អំពីការធ្លាក់នៃមនុស្ស ហើយបាននិយាយសារ ឡើងវិញ និងលាតត្រដាងនៅចំពោះទ្រង់ នូវបញ្ជីទាំងឡាយ និងបទគម្ពីរទាំងឡាយនៃប្រជាជន ដែលបាននិយាយដោយពួកព្យាការី រហូតមក ដល់ពេលដែលលីហៃ ជាអយ្យកោរបស់លោក បានចាកចេញពីក្រុងយេរូសាឡិមមក ។

៣៧ ហើយលោកក៏បាននិយាយសារឡើងវិញ ឲ្យពួកគេស្ដាប់ (ព្រោះលោកនិយាយទៅស្ដេច និងពួកអ្នកបំរើរបស់ទ្រង់) នូវការ ធ្វើដំណើរទាំងអស់របស់ពួកអយ្យកោលោក នៅក្នុងទីរហោស្ថាន និងការឈឺចាប់របស់គេ ដោយការស្រេកឃ្លាន និងទុក្ខរបស់គេ ជាដើម ។

៣៨ ហើយលោកក៏បាននិយាយសារឡើងវិញប្រាប់ពួកគេ អំពីការបះបោររបស់លេមិន និងលេមយួល និងកូនប្រុសៗទាំងអស់របស់ អ៊ីសម៉ាអែលដែរ មែនហើយ គឺអស់ទាំងការបះបោររបស់ពួកគេ នោះលោកបានរៀបរាប់ប្រាប់គេ; ហើយលោកបានអធិប្បាយប្រាប់គេ នូវបញ្ជី និងបទគម្ពីរទាំងអស់ ចាប់ពីពេលដែលលីហៃបានចាកចេញពីក្រុងយេរូសាឡិម រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

៣៩ ប៉ុន្តែ ការណ៍នេះពុំទាន់អស់នៅឡើយទេ; ព្រោះលោកបានអធិប្បាយប្រាប់គេ អំពីផែនការនៃសេចក្ដីប្រោសលោះ ដែលត្រូវ បានរៀបចំឡើង ចាប់តាំងពីកំណើតលោកិយមក; ហើយលោកក៏បានប្រាប់ឲ្យគេដឹង អំពីការយាងមកនៃព្រះគ្រីស្ទ ហើយលោកបានប្រាប់ ឲ្យគេដឹង នូវកិច្ចការទាំងអស់នៃព្រះអម្ចាស់ ។

៤០ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីលោកបានប្រាប់រឿងអស់ទាំងនេះ ហើយបានអធិប្បាយរឿងទាំងនេះដល់ស្ដេច ហើយ នោះស្ដេចក៏ជឿតាមពាក្យទាំងអស់របស់លោក ។

៤១ ហើយទ្រង់បានចាប់ផ្ដើមអំពាវនាវដល់ព្រះអម្ចាស់ថា៖ ឱព្រះអម្ចាស់អើយ សូមទ្រង់មានសេចក្ដីមេត្តាករុណា តាមសេចក្ដី មេត្តាករុណាដ៏បរិបូរ ដែលទ្រង់ធ្លាប់មានដល់ប្រជាជននីហ្វៃ មកលើទូលបង្គំ និងប្រជាជនរបស់ទូលបង្គំផងចុះ ។

៤២ ហើយឥឡូវនេះ កាលទ្រង់បានពោលដូច្នេះហើយ នោះទ្រង់ក៏ដួលចុះទៅលើដី ហាក់ដូចជាសុគត ។

៤៣ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកបំរើរបស់ទ្រង់បានសែងទ្រង់ចូលទៅឲ្យអគ្គមហេសីទ្រង់ ហើយបានដាក់ទ្រង់ចុះ នៅលើគ្រែ; ហើយទ្រង់បានផ្ទំហាក់ដូចជាសុគតអស់រយៈពេលពីរថ្ងៃ និងពីរយប់; ហើយអគ្គមហេសីទ្រង់ និងពួកបុត្រាទ្រង់ និងពួកបុត្រី ទ្រង់បានកាន់ទុក្ខឲ្យទ្រង់ តាមរបៀបពួកលេមិន ដោយទួញសោកចំពោះការបាត់បង់រូបទ្រង់ ៕

## ជំពូកទី ១៩

*ឡាម៉ូណៃទទួលពន្លឺនៃជីវិតដ៏អស់កល្បជានិច្ច ហើយឃើញព្រះដ៏ប្រោសលោះ — រាជវង្សារបស់ទ្រង់ធ្លាក់ទៅក្នុងការសណ្ដំ ហើយមនុស្សជាច្រើនឃើញពួកទេវតា — អាំម៉ូនត្រូវបានរក្សាទុកដោយអព្ភូតហេតុ — លោកធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សជាច្រើន ហើយតាំងសាសនាចក្រមួយឡើងនៅក្នុងចំណោមពួកគេ ។ ប្រមាណជាឆ្នាំ ៩០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពីរថ្ងៃ និងពីរយប់ក្រោយមក នោះពួកគេបំរុងនឹងនាំយកសាកសពរបស់ទ្រង់ ទៅបញ្ចុះក្នុង ផ្នូរ ដែលគេបានធ្វើសំរាប់កប់មនុស្សស្លាប់ ។

២ ឥឡូវនេះ ព្រះអគ្គមហេសីបានឮល្បីអំពីអាំម៉ូន ហេតុ

៣៤ *ក* ម៉ូសាយ ៧:២៧;
អេធើរ ៣:១៣–១៦.
*ខ* ស.ប. បង្រៀន, គ្រូបង្រៀន — ការបង្រៀនដោយនូវព្រះវិញ្ញាណ.
៣៥ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
*ខ* ស.ប. ដំរិះ.
៣៦ *ក* ម៉ូសាយ ១:៤;
អាលម៉ា ២២:១២; ៣៧:៩.
*ខ* ស.ប. បទព្រះគម្ពីរ.
*គ* កិច្ចការ ៣:១៨–២១.
៣៩ *ក* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
៤១ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.

ដូច្នេះហើយ ព្រះនាងបានចាត់ឲ្យគេទៅ ហើយមានព្រះទ័យ
ចង់ឲ្យលោក ចូលមកគាល់ព្រះនាង ។
៣ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូនបានធ្វើតាម
ដែលលោកត្រូវបានបញ្ជា ហើយបានចូលទៅគាល់ព្រះអគ្គមហេសី
ហើយចង់ដឹងថា តើព្រះនាងចង់ឲ្យលោកធ្វើអ្វី ។
៤ ហើយព្រះនាងបានមានបន្ទូលទៅកាន់លោកថា៖ ពួកអ្នកបំរើ
របស់ព្រះស្វាមីយើង បានប្រាប់ឲ្យយើងដឹងថា លោកគឺជាព្យាការី
នៃព្រះដ៏បរិសុទ្ធ ហើយថា លោកមានអំណាចធ្វើការដ៏អស្ចារ្យ
ជាច្រើន ដោយនូវព្រះនាមទ្រង់;
៥ ហេតុដូច្នេះហើយ បើសិនជាករណីនេះពិតមែន យើងចង់ឲ្យ
លោកចូលទៅមើលព្រះស្វាមីយើង ព្រោះទ្រង់បានផ្ទុំនៅលើគ្រែ
អស់រយៈពេលពីរថ្ងៃ និងពីរយប់មកហើយ; ហើយអ្នកខ្លះទៀត
និយាយថា ទ្រង់មិនទាន់សុគតទេ តែអ្នកខ្លះនិយាយថា ទ្រង់
សុគត ហើយថា ទ្រង់មានក្លិនស្អុយទៅហើយ ហើយថា គេ
ត្រូវតែបញ្ចុះទ្រង់ក្នុងផ្នូរ; តែចំពោះខ្លួនយើងផ្ទាល់ យើងឃើញថា
ទ្រង់ពុំទាន់ធំក្លិន ស្អុយទេ ។
៦ ឥឡូវនេះ ការណ៍នេះគឺជាការណ៍ដែលអាំម៉ូនប្រាថ្នា
ព្រោះលោកបានដឹងថា ស្ដេចឡាម៉ូណៃនៅក្រោមព្រះចេស្ដា
នៃព្រះ; លោកបានដឹងថា ស្បៃខ្មៅនៃការឥតជំនឿ កំពុងតែបាន
លាតចេញពីគំនិតទ្រង់ ហើយពន្លឺដែលបានបំភ្លឺគំនិតទ្រង់ គឺជា
ពន្លឺដែលជា សិរីល្អនៃព្រះ គឺជាពន្លឺដ៏អស្ចារ្យនៃសេចក្ដីល្អសប្បុរស
របស់ទ្រង់ — មែនហើយ ពន្លឺនេះបានធ្វើឲ្យសេចក្ដីអំណរ
ជ្រួលជ្រាបទៅក្នុង ព្រលឹងរបស់ទ្រង់ ឯពពកនៃភាពងងឹត
ក៏បានផាត់ចេញ ហើយពន្លឺដែលជាជីវិតដ៏អស់កល្បជានិច្ច ត្រូវ
បានអុជឡើងនៅក្នុងព្រលឹងទ្រង់ មែនហើយ លោកដឹងថា
ការណ៍នេះបានឈ្នះលើរូបរាងកាយធម្មជាតិរបស់ទ្រង់ ហើយ
ទ្រង់ក៏បាននាំយកទៅដោយព្រះ —
៧ ហេតុដូច្នេះហើយ អ្វីៗដែលព្រះអគ្គមហេសីចង់ឲ្យលោកធ្វើ
នោះគឺជាបំណងរបស់លោកប៉ុណ្ណោះ ។ ហេតុដូច្នេះហើយ
លោកបានចូលទៅមើលស្ដេច តាមសំណូមពររបស់អគ្គមហេសី;
ហើយលោកបានឃើញស្ដេច ហើយលោកបានដឹងថា ទ្រង់ពុំទាន់
សុគតនៅឡើយទេ ។
៨ ហើយលោកបានទូលទៅកាន់ព្រះអគ្គមហេសីថា៖ ទ្រង់ពុំទាន់
សុគតទេ តែទ្រង់ផ្ទុំនៅក្នុងព្រះប៉ុណ្ណោះ ហើយថ្ងៃស្អែក ទ្រង់នឹង
ក្រោកឡើងវិញ; ហេតុដូច្នេះហើយ ចូរកុំបញ្ចុះទ្រង់ឡើយ ។
៩ ហើយអាំម៉ូនបានទូលទៅព្រះនាងថា៖ តើព្រះនាងជឿ
ការណ៍នេះទេ ? ហើយព្រះនាងបានមានបន្ទូលទៅលោកថា៖
យើងគ្មាន សាក្សីឯណាទេ ក្រៅពីពាក្យរបស់លោក និងពាក្យ
របស់ពួកអ្នកបំរើរបស់យើងប៉ុណ្ណោះ; ទោះជាយ៉ាងណាក៏ដោយ
គង់តែយើងជឿថា វានឹងដូចជាពាក្យរបស់លោកនិយាយមែន។
១០ ហើយអាំម៉ូនបានទូលទៅកាន់ព្រះនាងថា៖ ព្រះនាងមាន
ពរហើយ មកពីសេចក្ដីជំនឿដ៏លើសលប់របស់ព្រះនាង; ឱព្រះនាង
អើយ ទូលបង្គំសូមប្រាប់ព្រះនាងថា ក្នុងចំណោមប្រជាជន
នៃសាសន៍នីហ្វៃទាំងអស់ នោះគ្មានអ្នកណាមានសេចក្ដីជំនឿ
ដ៏មុតមាំបែប នេះឡើយ ។
១១ ហើយហេតុការណ៍បានកើតឡើងថា ព្រះនាង
បាននៅចាំយាមគ្រែរបស់ព្រះស្វាមីរបស់នាង ចាប់ពីពេលនោះ
មក រហូតដល់ ថ្ងៃស្អែក ដែលអាំម៉ូនបានកំណត់ថា ទ្រង់
នឹងក្រោកឡើងវិញ ។
១២ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់ក៏ក្រោកឡើង
តាមពាក្យសំដីរបស់អាំម៉ូនមែន; ហើយពេលទ្រង់តើនឡើង
នោះទ្រង់បានហុចព្រះហស្ដទៅព្រះអគ្គមហេសី ហើយមាន
បន្ទូលថា៖ សូមឲ្យព្រះនាមនៃព្រះ បានប្រកបដោយព្រះពរ
ហើយព្រះនាង មានពរហើយ ។
១៣ ព្រោះប្រាកដដូចព្រះនាងរស់នៅដែរ មើលចុះ យើង
បានឃើញព្រះដ៏ប្រោសលោះរបស់យើងហើយ; ហើយទ្រង់នឹង
យាងមក ហើយនឹងប្រសូតពីស្ត្រីម្នាក់ ហើយទ្រង់នឹងប្រោសលោះ
មនុស្សលោកទាំងអស់ ដែលជឿដល់ព្រះនាមទ្រង់។ ឥឡូវនេះ
កាលដែលទ្រង់ មានបន្ទូលនូវពាក្យទាំងនេះ ចិត្តរបស់ទ្រង់រីកឡើង
ហើយទ្រង់ក៏ស្រុតចុះវិញ ដោយសេចក្ដីអំណរ; ហើយព្រះ
អគ្គមហេសីក៏ស្រុតចុះដែរ ដោយព្រះវិញ្ញាណសណ្ដំ ។
១៤ ឥឡូវនេះ អាំម៉ូន ដោយឃើញថា តាមការអធិស្ឋាន
របស់លោក ព្រះវិញ្ញាណនៃព្រះអម្ចាស់បានស្រោចមកលើពួក
លេមិន គឺជាបងប្អូនលោក ដែលជាដើមហេតុនៃការទួញសោកជា
ខ្លាំងនៅក្នុងចំណោមពួកនីហ្វៃ ឬនៅក្នុងចំណោមប្រជាជនទាំង
អស់នៃព្រះ មកពីអំពើទុច្ចរិត និងសណ្ដាប់ទាំងឡាយរបស់គេ

១៩ ៤*ក* ស.ប. ព្យាការី.
៦ *ក* ២ កូរិន. ៤:៣–៤.
ស.ប. វាំងនន.
*ខ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
១០ *ក* លូកា ៧:៩.
ស.ប. សេចក្ដីជំនឿ.
១៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យ
ព្យាករណ៍ទាំងឡាយអំពីកំណើត
និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ១ នីហ្វៃ ១១:១៣–២១.
១៤ *ក* គ. និង ស. ៤២:១៤.
*ខ* ម៉ូសាយ ១:៥.

នោះលោកបានលុតជង្គង់ចុះ ហើយបានចាប់ផ្ដើមអធិស្ឋាន
ដ៏អស់ពីចិត្ត ហើយបានថ្លែង អំណរអរគុណដល់ព្រះ ចំពោះ
អ្វីៗដែលទ្រង់បានធ្វើដល់បងប្អូនលោក; ហើយលោកក៏បាន
ពោរពេញទៅដោយសេចក្ដីអំណរ; ហើយនោះ ពួកគេ
ទាំងបីនាក់ក៏ដួលទៅលើដីទាំងអស់គ្នា ។
១៥ ឥឡូវនេះ កាលដែលពួកអ្នកបំរើរបស់ស្ដេច បានឃើញ
ពួកគេដួល នោះពួកគេក៏ចាប់ផ្ដើមអំពាវនាវទៅព្រះ ត្បិតការ
ខ្លាចដល់ ព្រះអម្ចាស់បានធ្លាក់មកលើគេដែរ ព្រោះពួក
គេនេះហើយដែលបានឈរនៅចំពោះស្ដេច ហើយបានថ្លែងជា
សាក្សីទៅកាន់ស្ដេច អំពីអំណាចដ៏អស្ចារ្យរបស់អាំម៉ូន ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានអំពាវនាវ
ដល់ព្រះនាមនៃព្រះអម្ចាស់ ដោយនូវសមត្ថភាពគេ រហូតដល់
ពួកគេ ទាំងអស់គ្នាដួលទៅលើដីដែរ លើកលែងតែស្ត្រីសាសន៍
លេមិនម្នាក់ ដែលមានឈ្មោះថា អ័ប៊ីស នាងបានប្រែចិត្តជឿ
ដល់ព្រះអម្ចាស់ ជាច្រើនឆ្នាំមកហើយ ដោយសារការនិមិត្ត
មួយដ៏អស្ចារ្យនៃឪពុកនាង —
១៧ ម្ល៉ោះហើយ ដោយបានប្រែចិត្តជឿដល់ព្រះអម្ចាស់
តែមិនដែលឲ្យគេដឹង ហេតុដូច្នេះហើយ កាលដែលនាងឃើញថា
ពួកអ្នក បំរើទាំងអស់របស់ឡាម៉ូណៃ បានដួលទៅលើដី ព្រម
ទាំងម្ចាស់ក្សត្រីរបស់នាង គឺជាព្រះអគ្គមហេសី និងស្ដេច និង
អាំម៉ូនដេកស្ដូកនៅ លើដី នោះនាងដឹងថា នេះហើយជា
ព្រះចេស្ដានៃព្រះ; ហើយនាងបានគិតថា នេះគឺជាឱកាសមួយ
ដើម្បីធ្វើឲ្យប្រជាជនដឹងនូវហេតុ ការណ៍ ដែលបានកើតឡើង
ក្នុងចំណោមពួកគេ គឺដោយឃើញឥទ្ធិពលនេះ នឹងបណ្ដាលឲ្យពួក
គេជឿដល់ព្រះចេស្ដានៃព្រះ ហេតុដូច្នេះហើយ នាងបានរត់ពីផ្ទះ
មួយទៅផ្ទះមួយ ទៅប្រាប់ឲ្យប្រជាជនបានដឹង ។
១៨ ហើយពួកគេបានចាប់ផ្ដើមប្រជុំគ្នា នៅឯដំណាក់របស់ស្ដេច។
ហើយនៅទីនោះ មានមនុស្សមួយហ្វូងបានមក ហើយគេមាន
សេចក្ដីអស្ចារ្យជាខ្លាំង កាលដែលគេបានឃើញព្រះអគ្គមហេសី
និងស្ដេច និងអស់ពួកអ្នកបំរើ ដេកស្ដូកនៅលើដីដូច្នោះ ហើយ
អ្នកទាំង អស់នោះដេកហាក់ដូចជាស្លាប់; ហើយពួកគេក៏បាន
ឃើញអាំម៉ូនដែរ ហើយមើលចុះ លោកគឺជាសាសន៍នីហ្វៃ ។
១៩ ហើយឥឡូវនេះ ប្រជាជនបានចាប់ផ្ដើមរអ៊ូរទាំក្នុង
ចំណោមពួកគេ; ខ្លះនិយាយថា នេះគឺជាអំពើអាក្រក់មួយដ៏ធំ
ដែលបានកើត ឡើងមកលើអ្នកទាំងនោះ ឬមកលើស្ដេច និង
រាជវង្សារបស់ទ្រង់ ពីព្រោះទ្រង់បានទុកឲ្យសាសន៍នីហ្វៃមកនៅ
ក្នុងដែនដី ។
២០ តែអ្នកខ្លះទៀតស្ដីបន្ទោសគេថា៖ ស្ដេចបាននាំអំពើ
អាក្រក់នេះ មកដល់រាជវង្សារបស់ទ្រង់ ពីព្រោះទ្រង់បានសម្លាប់
ពួកអ្នកបំរើ ដែលបានទុកឲ្យហ្វូងចៀមគេរត់ខ្ចាត់ខ្ចាយ
នៅឯទឹកស៊ីប៊ុស ។
២១ ហើយគេក៏ត្រូវស្ដីបន្ទោស ដោយពួកមនុស្សដែល
ឈរនៅឯទឹកស៊ីប៊ុស ហើយបានដេញបង្អើលហ្វូងចៀមដែល
ជារបស់ផង ស្ដេចនោះ ព្រោះពួកគេបានខឹងនឹងអាំម៉ូន មក
ពីចំនួនមនុស្សដែលលោកបានសម្លាប់បងប្អូនគេនៅឯទឹកស៊ីប៊ុស
កាលដែលកំពុងការ ពារហ្វូងចៀមរបស់ស្ដេច ។
២២ ឥឡូវនេះ មានមនុស្សម្នាក់ក្នុងចំណោមពួកគេ ដែល
មានបងប្អូនត្រូវស្លាប់ដោយដាវរបស់អាំម៉ូន ដោយបានខឹងនឹង
អាំម៉ូន ជាខ្លាំង ទើបដកដាវខ្លួន ហើយស្ទុះមកដើម្បីគាត់អាច
នឹងចាក់ទៅលើអាំម៉ូន ដើម្បីប្រហារលោកចោល; តែនៅពេល
ដែលគាត់កំពុង លើកដាវឡើងនឹងចាក់លោក មើលចុះ
គាត់ក៏ដួលស្លាប់ទៅ ។
២៣ ឥឡូវនេះ យើងឃើញថា គេមិនអាចប្រហារអាំម៉ូនបានទេ
ព្រោះព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅម៉ូសាយ ដែលជា
បិតារបស់លោកថា៖ យើងនឹងរក្សាគេទុក ហើយការណ៍នេះ
នឹងកើតឡើងដល់គេ ដោយសេចក្ដីជំនឿរបស់អ្នក — ហេតុ
ដូច្នេះហើយ ម៉ូសាយបានទុកដាក់គេនឹងព្រះ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា កាលដែលបណ្ដាជន
បានឃើញថា អ្នកដែលបានលើកដាវបំរុងនឹងប្រហារអាំម៉ូន បាន
ដួលស្លាប់ទៅ នោះការភ័យខ្លាចក៏បានធ្លាក់មកលើគេទាំងអស់គ្នា
ហើយគេមិនហ៊ានលូកដៃទៅប៉ះលោក ឬជនណាមួយ ដែល
បាន ដួលចុះនោះឡើយ; ហើយគេបានចាប់ផ្ដើមឆ្ងល់ នៅក្នុង
ចំណោមពួកគេទៀត មិនដឹងថា តើអ្វីទៅជាប្រភពនៃអំណាច
ដ៏អស្ចារ្យនេះ ឬក៏ការណ៍ទាំងអស់នេះ មានន័យយ៉ាង
ណានោះទេ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្សជាច្រើន

១៤ *ក* ស.ប. សេចក្ដីអំណរ.
*ខ* អាលម៉ា ២៧:១៧.
១៥ *ក* អាលម៉ា ១៨:១–២.
១៧ *ក* ម៉ូសាយ ២៧:១៤.
១៩ *ក* អាលម៉ា ១៧:២២–២៣.
២០ *ក* អាលម៉ា ១៧:២៦; ១៨:៧.
២១ *ក* អាលម៉ា ១៧:២៧; ១៨:៣.
២២ *ក* អាលម៉ា ១៧:៣៨.
២៣ *ក* ម៉ូសាយ ២៨:៧; អាលម៉ា ១៧:៣៥.
*ខ* ស.ប. ទុកចិត្ត.

នៅក្នុងចំណោមពួកគេបាននិយាយថា អាំម៉ូនគឺជាព្រះវិញ្ញាណ
*ក*ដ៏មហិមា ឯអ្នកខ្លះទៀតបាននិយាយថា ព្រះវិញ្ញាណដ៏មហិមា
បានចាត់ឲ្យលោកមក ។
២៦ តែអ្នកខ្លះទៀត បានស្តីបន្ទោសអ្នកអស់ទាំងនោះថា
លោកគឺជាប្រេតអារក្ស ដែលពួកនីហ្វៃបានចាត់ឲ្យមកធ្វើទុក្ខ
ពួកគេ ។
២៧ ហើយមានអ្នកខ្លះទៀតនិយាយថា ព្រះវិញ្ញាណដ៏មហិមា
បានចាត់ឲ្យអាំម៉ូនមកធ្វើទុក្ខដល់ពួកគេ មកពីអំពើទុច្ចរិតទាំងឡាយ
របស់ពួកគេហើយ; ហើយថា នោះហើយជាព្រះវិញ្ញាណ
ដ៏មហិមា ដែលតែងតែយាងមកជួបនឹងពួកនីហ្វៃ គឺធ្លាប់ដោះ
ពួកនីហ្វៃឲ្យរួចផុត ពីកណ្ដាប់ដៃពួកគេ; ហើយគេបាននិយាយ
ថា នេះហើយជាព្រះវិញ្ញាណដ៏មហិមា ដែលបានបំផ្លាញ
បងប្អូនគេជាច្រើន គឺពួកសាសន៍ លេមិន ។
២៨ ហើយការប្រកែកគ្នាបានចាប់ផ្ដើមធំធេងឡើងយ៉ាងនេះ
នៅក្នុងចំណោមពួក*ក*គេ ។ ហើយកាលដែលពួកគេកំពុងតែ
ប្រកែក គ្នា នោះនាងបំរើដែលបានទៅហៅបណ្ដាជនឲ្យមក
ជួបជុំគ្នានោះបានចូលមក ហើយកាលនាងឃើញថា មានការ
ប្រកែកគ្នា នៅក្នុង ចំណោមបណ្ដាជន នោះនាងកើតសេចក្ដី
សោកសៅជាខ្លាំង រហូតដល់ស្រក់ទឹកភ្នែក ។
២៩ ហើយហេតុការណ៍បានកើតឡើងថា នាងបាន
ទៅចាប់ព្រះហស្តនៃព្រះអគ្គមហេសី ក្រែងនាងអាចគ្រា
ព្រះនាងឡើងពីដី; ហើយកាលនាងប៉ះព្រះហស្តព្រះនាងភ្លាម
នោះព្រះនាងក៏តើន ហើយបានក្រោកឈរឡើង ហើយបាន
ស្រែកយ៉ាងខ្លាំងថា៖ ឱព្រះយេស៊ូវដ៏ប្រកបដោយព្រះពរ ដែល
ទ្រង់បានសង្គ្រោះទូលបង្គំឲ្យរួចពីស្ថាននរក *ខ* *ក*ដ៏គួរឲ្យស្ញែងខ្លាច!
ឱព្រះដ៏ប្រកបដោយព្រះពរ សូមទ្រង់មានសេចក្ដីមេត្តាករុណា
ដល់ប្រជាជននេះផងចុះ!
៣០ ហើយកាលព្រះនាងបានមានបន្ទូលយ៉ាងនេះហើយ
នោះព្រះនាងក៏លើកព្រះហស្តប្រណំ ដោយពោរពេញទៅដោយ
សេចក្ដី អំណរ ព្រះនាងបានមានបន្ទូលនូវពាក្យដ៏ច្រើន ដែល
គេមិនយល់ ហើយបន្ទាប់ពីព្រះនាងបានធ្វើយ៉ាងនេះហើយ
នោះព្រះនាងបានចាប់ ព្រះហស្តស្ដេចឡាម៉ូណៃ ហើយមើលចុះ
ទ្រង់តើន ហើយក៏ក្រោកឈរឡើង ។
៣១ ហើយកាលបានឃើញប្រជាជនទ្រង់កំពុងតែប្រកែកគ្នា
នោះទ្រង់ក៏ទៅ *ក*ហើយបានចាប់ផ្ដើមស្ដីបន្ទោសគេមួយរំពេច
ហើយ បង្រៀនគេនូវពាក្យទាំងឡាយ ដែលទ្រង់បានឮពីមាត់
អាំម៉ូន; ហើយអស់អ្នកណាដែលបានឮព្រះបន្ទូលទាំងឡាយ
របស់ទ្រង់ ក៏ជឿ ហើយបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ។
៣២ ប៉ុន្តែ មានពួកគេជាច្រើននាក់ មិនព្រមស្ដាប់តាមព្រះ
បន្ទូលទាំងឡាយរបស់ទ្រង់ឡើយ; ហេតុដូច្នេះហើយ ពួក
គេក៏បែកទៅ តាមផ្លូវរបស់គេទៅ ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា កាលដែលអាំម៉ូន
បានភ្ញាក់ឡើង លោកក៏បានបង្រៀនប្រជាជន ព្រមទាំងពួកអ្នក
បំរើ ទាំងអស់របស់ឡាម៉ូណៃដែរ; ហើយគេទាំងអស់គ្នាបាន
ប្រកាសប្រាប់ប្រជាជន នូវពាក្យដែលដូចគ្នា — ថាចិត្តគេ
*ក*បានផ្លាស់ប្ដូរ; ថាគេគ្មានបំណង*ខ*នឹងធ្វើអំពើអាក្រក់ទៀតឡើយ ។
៣៤ ហើយមើលចុះ មនុស្សជាច្រើនបានប្រកាសប្រាប់
ប្រជាជនថា ពួកគេបានឃើញពួក*ក*ទេវតា ហើយព្រមទាំងបាន
និយាយជាមួយ នឹងពួកទេវតាផង; ម្ល៉ោះហើយ ពួកគេបាន
ប្រាប់ប្រជាជន ពីការណ៍ទាំងឡាយនៃព្រះ និងពីសេចក្ដីសុចរិត
របស់ទ្រង់ ។
៣៥ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្ស
ជាច្រើនបានជឿដល់ពាក្យសំដីរបស់គេ; ហើយអស់អ្នកណា
ដែលជឿ *ក*ក៏បានទទួលបុណ្យជ្រមុជទឹក; ហើយពួកគេបានក្លាយ
ទៅជាប្រជាជនដ៏សុចរិតមួយ ហើយពួកគេបានតាំងសាសនា
ចក្រមួយឡើង នៅក្នុងចំណោមពួកគេ ។
៣៦ ម្ល៉ោះហើយ កិច្ចការនៃព្រះអម្ចាស់បានចាប់ផ្ដើមឡើង
នៅក្នុងចំណោមពួកសាសន៍លេមិន; ព្រះអម្ចាស់ទ្រង់បាន
ចាប់ផ្ដើម ស្រោចព្រះវិញ្ញាណទ្រង់មកលើគេយ៉ាងដូច្នេះហើយ;
ហើយយើងឃើញថា ព្រះពាហុរបស់ទ្រង់ បានហុចទៅឲ្យ
*ក*មនុស្សទាំងអស់ ដែលនឹងប្រែចិត្ត ហើយជឿដល់
ព្រះនាមទ្រង់ ៕

២៥ *ក* អាលម៉ា ១៨:២–៥.
២៨ *ក* អាលម៉ា ១៩:១៦.
២៩ *ក* ១ នីហ្វៃ ១៤:៣.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៣១ *ក* អាលម៉ា ១៨:៣៦–៣៩.
៣៣ *ក* ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ខ* ម៉ូសាយ ៥:២; អាលម៉ា ១៣:១២.
៣៤ *ក* ស.ប. ពួកទេវតា.
៣៥ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
៣៦ *ក* ២ នីហ្វៃ ២៦:៣៣; អាលម៉ា ៥:៣៣.

## ជំពូកទី ២០

*ព្រះអម្ចាស់ទ្រង់ចាត់ឲ្យអាំម៉ូនទៅមិឌូណៃ ដើម្បីជួយលែងដោះបងប្អូនលោកដែលជាប់គុក — អាំម៉ូន និងឡាម៉ូណៃ ជួបនឹងបិតារបស់ ឡាម៉ូណៃ ដែលជាមហាក្សត្រគ្រប់គ្រងលើដែនដីទាំងមូល — អាំម៉ូនបង្ខំឲ្យស្ដេចចាស់យល់ ព្រមជួយដោះលែងបងប្អូនលោក ។ ប្រមាណជាឆ្នាំ ៩០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានតាំងសាសនា
ចក្រមួយឡើង នៅលើដែនដីរួចហើយ នោះស្ដេចឡាម៉ូណៃ
មានព្រះទ័យចង់ឲ្យអាំម៉ូនទៅជាមួយនឹងទ្រង់ ទៅឯដែនដីនីហ្វៃ
ដើម្បីទ្រង់អាចបង្ហាញលោកដល់បិតារបស់ទ្រង់ ។
២ ហើយសម្លេងនៃព្រះអម្ចាស់បានបន្លឺមកអាំម៉ូនថា៖ អ្នកមិន
ត្រូវឡើងទៅឯដែនដីនីហ្វៃទេ ត្បិតមើលចុះ ស្ដេចនៅទីនោះនឹង
ស្វែងរកជីវិតអ្នក; តែអ្នកត្រូវទៅឯដែនដីមិឌូណៃវិញ;
ត្បិតមើលចុះ ប្អូនអ្នកឈ្មោះ អើរ៉ុន ព្រមទាំងមូឡូកៃ និងអាំម៉ា
ផងកំពុងតែ ជាប់គុកនៅទីនោះ ។
៣ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលអាំម៉ូនបាន
ឮយ៉ាងនោះហើយ នោះលោកបានទូលទៅឡាម៉ូណៃថា៖ មើលចុះ
ប្អូនទូលបង្គំ និងបងប្អូនទូលបង្គំ កំពុងតែជាប់គុកនៅដែនដី
មិឌូណៃ ហើយទូលបង្គំនឹងទៅទីនោះ ដើម្បីដោះលែងពួកគេ ។
៤ ឥឡូវនេះ ឡាម៉ូណៃបានមានបន្ទូលទៅអាំម៉ូនថា៖
យើងដឹងថា ដោយនូវកម្លាំងនៃព្រះអម្ចាស់ នោះលោកនឹង
អាចធ្វើបាននូវ ការណ៍គ្រប់យ៉ាង ។ ប៉ុន្តែមើលចុះ យើង
នឹងទៅជាមួយនឹងអ្នក ទៅឯដែនដីមិឌូណៃ; ព្រោះស្ដេច
ដែនដីមិឌូណៃ ដែលមាននាមថា អាន់ទីអូមណូ គឺជាមិត្ត
របស់យើង; ហេតុដូច្នេះហើយ យើងនឹងទៅដែនដីមិឌូណៃ
ដើម្បីយើងអាចលួងលោមស្ដេចនៃដែនដីនោះ ឲ្យទ្រង់ដោះលែង
បងប្អូនអ្នកឲ្យរួចពីគុក។ ឥឡូវនេះ ឡាម៉ូណៃមានបន្ទូលទៅលោ
កថា៖ តើនរណាប្រាប់អ្នកថា បងប្អូនអ្នកកំពុងតែ ជាប់គុក ?
៥ ហើយអាំម៉ូនទូលទៅទ្រង់ថា៖ គ្មានអ្នកណាប្រាប់ទូលបង្គំទេ
ក្រៅពីព្រះ; ហើយទ្រង់បានប្រាប់ទូលបង្គំថា– ចូរទៅដោះបង
ប្អូនអ្នក ព្រោះពួកគេកំពុងតែជាប់គុក នៅដែនដីមិឌូណៃ ។
៦ ឥឡូវនេះ កាលឡាម៉ូណៃបានឮការណ៍នេះ នោះទ្រង់បញ្ជាឲ្យ
ពួកអ្នកបំរើរៀបចំសេះ និងរាជរថទាំងឡាយឲ្យបានស្រេច ។
៧ ហើយទ្រង់បានមានបន្ទូលទៅអាំម៉ូនថា៖ តោះ យើង
នឹងទៅជាមួយនឹងអ្នក ចុះទៅដែនដីមិឌូណៃ ហើយនៅទីនោះ
យើងនឹង អង្វរស្ដេចឲ្យទ្រង់ដោះលែងបងប្អូនអ្នកឲ្យរួចពីគុក ។
៨ ហើយហេតុការណ៍បានកើតឡើងថា កាលអាំម៉ូន និង
ឡាម៉ូណៃ កំពុងតែធ្វើដំណើរទៅទីនោះ ស្រាប់តែគេបានជួប
នឹងបិតា របស់ឡាម៉ូណៃ ដែលជាមហាក្សត្រលើដែនដីទាំងអស់ ។
៩ ហើយមើលចុះ បិតារបស់ឡាម៉ូណៃ បានមាន
បន្ទូលទៅទ្រង់ថា៖ ហេតុអ្វីបានជាបុត្រមិនបានមករួម ក្នុងពិធី
បុណ្យជប់លៀងនៅ ថ្ងៃដ៏មហិមានោះ កាលដែលបិតាបានធ្វើ
បុណ្យជប់លៀងដល់បុត្រទាំងឡាយ និងប្រជាជនរបស់បិតា ?
១០ ហើយទ្រង់ក៏បានមានបន្ទូលទៀតថា៖ តើបុត្រទៅឯណា
ជាមួយនឹងសាសន៍នីហ្វៃនេះ ដែលជាកូនចៅនៃមនុស្សភូតកុហក ?
១១ ហើយហេតុការណ៍បានកើតឡើងថា ឡាម៉ូណៃបាន
រៀបរាប់ប្រាប់បិតាខ្លួន អំពីទីកន្លែងដែលទ្រង់កំពុងតែទៅ
ព្រោះទ្រង់ខ្លាច ក្រែងជំទាស់បិតា ។
១២ ហើយទ្រង់ក៏បានប្រាប់ទៅបិតាដែរ អំពីហេតុដែលធ្វើឲ្យ
ទ្រង់ នៅប្រចាំនគររបស់ទ្រង់ ដែលទ្រង់មិនបានទៅរួមក្នុងពិធី
បុណ្យ ជប់លៀង ដែលបិតាទ្រង់បានរៀបចំនោះ ។
១៣ ហើយឥឡូវនេះ កាលដែលឡាម៉ូណៃបានប្រាប់បិតាខ្លួន
នូវរឿងអស់ទាំងនេះហើយ មើលចុះ ទ្រង់មានសេចក្ដីអស្ចារ្យ
ជាខ្លាំង ព្រោះបិតាទ្រង់ខឹងនឹងទ្រង់ទៅវិញ ហើយមានបន្ទូល
ថា៖ ឡាម៉ូណៃ តើបុត្រនឹងទៅដោះលែងពួកសាសន៍នីហ្វៃ
ទាំងនេះ ដែលជាកូន ចៅនៃមនុស្សភូតកុហកឬ ? មើលចុះ
វាប្លន់ពួកអយ្យកោរបស់យើង; ហើយឥឡូវនេះ កូនចៅរបស់វា
មកក្នុងចំណោមពួកយើង ដើម្បីនឹងបោកបញ្ឆោតយើង
ដោយកលល្បិច និងដោយពាក្យភូតកុហក ដើម្បីវាអាចប្លន់
ទ្រព្យសម្បត្តិយើងជាថ្មីទៀត ។
១៤ ឥឡូវនេះ បិតារបស់ឡាម៉ូណៃ បានបញ្ជាឲ្យទ្រង់ប្រហារ
អាំម៉ូននឹងដាវ ។ ហើយទ្រង់ក៏បញ្ជាឡាម៉ូណៃថា ទ្រង់មិនត្រូវ
ធ្វើ ដំណើរទៅដែនដីមិឌូណៃឲ្យសោះ តែឲ្យត្រឡប់ទៅដែនដី
អ៊ីសម៉ាអែលជាមួយនឹងទ្រង់វិញ ។
១៥ ប៉ុន្តែ ឡាម៉ូណៃបានមានបន្ទូលទៅទ្រង់ថា៖ ទូលបង្គំ
មិនប្រហារអាំម៉ូនទេ ហើយទូលបង្គំក៏មិនត្រឡប់ទៅដែនដី
អ៊ីសម៉ាអែល វិញដែរ តែទូលបង្គំនឹងទៅដែនដីមិឌូណៃវិញ

**២០** ៤ *ក* អាលម៉ា ២៦:១២.
*ខ* អាលម៉ា ២០:២៨–៣០.
៦ *ក* អាលម៉ា ១៨:៩–១០.
៨ *ក* អាលម៉ា ២២:១.
៩ *ក* អាលម៉ា ១៨:៩.
១០ *ក* ម៉ូសាយ ១០:១២–១៧.
១៤ *ក* អាលម៉ា ១៧:១៩.

ដើម្បីទូលបង្គំអាចដោះលែងបងប្អូនរបស់អាំម៉ូន ព្រោះ
ទូលបង្គំដឹងថា ពួកគេជាមនុស្ស សុចរិត ហើយជា
ព្យាការីបរិសុទ្ធទាំងឡាយនៃព្រះដ៏ពិត ។
១៦ ឥឡូវនេះ កាលបិតាទ្រង់បានឮពាក្យទាំងនេះហើយ
នោះស្រាប់តែទ្រង់ខឹងនឹងឡាម៉ូណៃ ហើយទ្រង់បានដកដាវបំរុងនឹង
ចាក់ ឡាម៉ូណៃឲ្យដួលទៅលើដី ។
១៧ ប៉ុន្តែ អាំម៉ូនបានស្ទុះមក ហើយទូលទៅទ្រង់ថា៖
មើលចុះ ទ្រង់មិនគួរប្រហារបុត្ររបស់ទ្រង់ឡើយ; ទោះ
ជាយ៉ាងណាក៏ដោយ បើបុត្ររបស់ទ្រង់ត្រូវដួលចុះ នោះគង់
[ក]តែគ្រាន់បើជាងទ្រង់ដែរ ត្បិតមើលចុះ បុត្ររបស់ទ្រង់[ខ]បានប្រែ
ចិត្តពីអំពើបាបទាំងឡាយរបស់គេ ហើយ ប៉ុន្តែបើសិនជាទ្រង់
ត្រូវដួលនៅក្នុងពេលនេះវិញ គឺនៅក្នុងកំហឹងរបស់ទ្រង់
នោះព្រលឹងរបស់ទ្រង់មិនអាចបានសង្គ្រោះឡើយ ។
១៨ ហើយម៉្យាងទៀត ជាការចាំបាច់ដែលទ្រង់ត្រូវស៊ូទ្រាំ
អត់ធ្មត់; ព្រោះបើសិនជាទ្រង់[ក]ប្រហារបុត្ររបស់ទ្រង់ ដែលជា
មនុស្សឥត ទោស នោះលោហិតរបស់បុត្រទ្រង់នឹងស្រែកពីដី
ទៅដល់ព្រះអម្ចាស់ដែលជាព្រះរបស់បុត្រទ្រង់ សូមឲ្យមាន
ការសងសឹកធ្លាក់មក លើទ្រង់; នោះប្រហែលជាទ្រង់នឹង
[ខ]បាត់បង់ព្រលឹងរបស់ទ្រង់ជាមិនខានឡើយ ។
១៩ ឥឡូវនេះ កាលអាំម៉ូនបានទូលពាក្យទាំងនេះទៅកាន់
ទ្រង់ហើយ នោះទ្រង់មានបន្ទូលឆ្លើយមកលោកវិញថា៖
យើងដឹងថា បើសិនជាយើងប្រហារបុត្ររបស់យើង នោះយើង
នឹងកំចាយឈាមនៃជនឥតទោស; ព្រោះអី អ្នកទេតើដែល
រកបំផ្លាញបុត្រយើង ។
២០ ហើយទ្រង់យាព្រះហស្តបំរុងនឹងប្រហារអាំម៉ូនបង់ ។
ប៉ុន្តែអាំម៉ូនរងដាវទ្រង់ ព្រមទាំងវាយព្រះហស្តទ្រង់ បណ្ដាលឲ្យ
ទ្រង់មិន អាចប្រើព្រះហស្តនោះបានឡើយ ។
២១ ឥឡូវនេះ កាលស្ដេចបានទតឃើញថា
អាំម៉ូនអាចប្រហារទ្រង់បាន នោះទ្រង់បានចាប់ផ្ដើមអង្វរអាំម៉ូន
ឲ្យលើកលែងជីវិត ឲ្យទ្រង់ ។
២២ ប៉ុន្តែ អាំម៉ូនបានលើកដាវឡើង ហើយទូលទៅទ្រង់ថា៖
មើលចុះ ទូលបង្គំនឹងចាក់ទ្រង់ លើកលែងតែទ្រង់អនុញ្ញាតឲ្យ
ទូលបង្គំ ទៅដោះលែងបងប្អូនទូលបង្គំចេញពីគុក ។
២៣ ឥឡូវនេះ ដោយខ្លាចបាត់បង់ជីវិតរបស់ទ្រង់ នោះស្ដេច
មានបន្ទូលថា៖ បើសិនជាអ្នកលើកលែងជីវិតឲ្យយើង នោះយើង
នឹង អនុញ្ញាតឲ្យអ្នក នូវអ្វីដែលអ្នកសូម សូម្បីតែពាក់កណ្ដាល
នគររបស់យើងក៏បានដែរ ។
២៤ ឥឡូវនេះ កាលអាំម៉ូនបានឃើញថា លោកអាចធ្វើឲ្យ
ស្ដេចចំណាស់នេះ ធ្វើតាមបំណងរបស់លោកហើយ នោះលោក
ក៏ទូលទៅកាន់ទ្រង់ថា៖ បើសិនជាទ្រង់អនុញ្ញាតឲ្យបងប្អូនទូលបង្គំ
បានចេញពីគុកមែន ហើយឲ្យឡាម៉ូណៃរក្សានគររបស់គេផង
ហើយ សូមទ្រង់កុំខឹងនឹងឡាម៉ូណៃ តែអនុញ្ញាតឲ្យឡាម៉ូណៃ
ធ្វើតាមបំណង [ក]ទោះជាអ្វីដែលឡាម៉ូណៃយល់ឃើញ
នោះទូលបង្គំនឹងលើកលែង ជីវិតឲ្យទ្រង់; បើពុំនោះសោតទេ
ទូលបង្គំនឹងចាក់ទ្រង់ឲ្យដួលចុះទៅលើដី ។
២៥ ឥឡូវនេះ កាលអាំម៉ូនបានទូលពាក្យទាំងនេះហើយ
នោះស្ដេចក៏ចាប់ផ្ដើមអររីករាយ ព្រោះបានរួចជីវិត ។
២៦ ហើយកាលទ្រង់បានទតឃើញថា អាំម៉ូនគ្មានបំណងចង់
បំផ្លាញទ្រង់ចោលទេ ហើយកាលទ្រង់បានទតឃើញនូវសេចក្ដី
ស្រឡាញ់ដ៏ធំធេងដែលលោកមានចំពោះឡាម៉ូណៃ ដែល
ជាបុត្ររបស់ទ្រង់ផងដែរ នោះទ្រង់មានសេចក្ដីអស្ចារ្យជាខ្លាំង
ហើយមាន បន្ទូលថា៖ ពីព្រោះអ្នកគ្រាន់តែមានបំណងសូមឲ្យ
យើងដោះលែងបងប្អូនលោក ហើយសុខចិត្តឲ្យឡាម៉ូណៃ
ដែលជាបុត្ររបស់យើង បាននគររបស់គេវិញ មើលចុះ យើង
នឹងអនុញ្ញាតដល់អ្នកថា បុត្រយើងអាចបាននគររបស់គេវិញ
ចាប់ពីពេលនេះរហូតតទៅ; ហើយយើងនឹងពុំត្រួតត្រាលើបុត្រ
របស់យើងទៀតឡើយ —
២៧ ហើយយើងនឹងអនុញ្ញាតដល់អ្នកថា បងប្អូនអ្នកនឹងត្រូវ
បានដោះចេញពីគុក ហើយអ្នក និងបងប្អូនអ្នកអាចមកជួប
នឹងយើង នៅនគររបស់យើង; ព្រោះយើងមានបំណងចង់ជួប
នឹងអ្នកជាខ្លាំង ។ ត្បិតស្ដេចមានសេចក្ដីអស្ចារ្យជាខ្លាំងនឹង
ពាក្យសំដីដែលលោក បានទូល ព្រមទាំងភ្ញាក់នឹងពាក្យពេចន៍
ដែលឡាម៉ូណៃ ជាបុត្ររបស់ទ្រង់បានទូលដែរ ហេតុ
ដូច្នេះហើយ ទ្រង់មាន[ក]ព្រះទ័យចង់ដឹងអំពី ពាក្យទាំងនោះ ។
២៨ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូន និង
ឡាម៉ូណៃបានបន្តដំណើររបស់គេ ឆ្ពោះទៅឯដែនដីមិឌូណៃ ។
ហើយ ឡាម៉ូណៃបានទទួលការប្រោសប្រណីនៅក្នុងព្រះនេត្រ
នៃស្ដេចលើដែនដីនោះ; ហេតុដូច្នេះហើយ ទើបបងប្អូនរបស់
អាំម៉ូន ត្រូវបាន ដោះលែងពីគុកមក ។
២៩ ហើយកាលអាំម៉ូនបានជួបនឹងពួកគេហើយ នោះលោកមាន

១៧ *ក* អាលម៉ា ៤៨:២៣.
*ខ* អាលម៉ា ១៩:១២–១៣.
១៨ *ក* ស.ប. ឃាតកម្ម.
*ខ* គ. និង ស. ៤២:១៨.
២៤ *ក* អាលម៉ា ២១:២១–២២.
២៧ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.

ចិត្តព្រួយជាខ្លាំង ត្បិតមើលចុះ ពួកគេនៅខ្លួនអាក្រាត ហើយ
ស្បែកគេក៏សឹកជាខ្លាំង មកពីត្រូវចងដោយចំណងដ៏ធំៗ ។
ហើយពួកគេថែមទាំងមានទុក្ខខាងការអត់ឃ្លាន ការស្រេក
និងទុក្ខវេទនា គ្រប់បែបយ៉ាង; ទោះជាយ៉ាងណាក៏ដោយ
គង់តែពួកគេមានចិត្តទ្រាំទ្រ ចំពោះការទុក្ខលំបាកអស់
ទាំងនេះដែរ ។
៣០ ហើយការណ៍នោះបានកើតឡើង គឺដោយសារចំណែក
របស់គេត្រូវធ្លាក់ ទៅក្នុងកណ្ដាប់ដៃរបស់មនុស្ស ដែលមាន
ចិត្តរឹងរូស និងក្បាលរឹងលើសលែងទៅទៀត; ហេតុ
ដូច្នេះហើយ ប្រជាជនទាំងនោះ មិនព្រមស្ដាប់តាមពាក្យសំដី
របស់ពួកគេឡើយ ហើយបាន ដេញគេចេញ ហើយបាន
វាយគេ ហើយបានរុញច្រានពួកគេ ពីផ្ទះមួយទៅផ្ទះមួយ និង
ពីកន្លែងមួយទៅកន្លែងមួយ រហូតដល់ពួកគេបាន មក
ដល់ដែនដីមិឌូណៃ ហើយនៅទីនោះ ពួកគេត្រូវបានចាប់យក
ទៅដាក់គុក ហើយត្រូវចងដោយចំណងដ៏ធំៗ ហើយត្រូវ
ដាក់ក្នុងគុក អស់ជាច្រើនថ្ងៃ ហើយក៏បានរួចដោយ
សារឡាម៉ូណៃ និងអាំម៉ូន ៕

---

ដំណើររឿងអំពីការផ្សាយរបស់អើរ៉ុន និងមូឡូគៃ និង
បងប្អូនគេ ដល់ពួកសាសន៍លេមិន ។

*មានរួមពីជំពូកទី ២១ ដល់ ២៦*

## ជំពូកទី ២១

*អើរ៉ុនបង្រៀនពួកសាសន៍អាម៉ាលេកៃ អំពីព្រះគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ — អើរ៉ុន និងបងប្អូនលោក ត្រូវជាប់ គុកនៅដែនដី មិឌូណៃ — បន្ទាប់ពីគេបានរួច ពួក គេក៏បង្រៀននៅក្នុងសាលាប្រជុំទាំងឡាយ ហើយធ្វើឲ្យ មនុស្សជាច្រើនប្រែចិត្តជឿ — ឡាម៉ូណៃ អនុញ្ញាតឲ្យមាន សេរីភាព នៅខាងផ្លូវសាសនា ដល់ប្រជាជននៅក្នុងដែនដី អ៊ីសម៉ាអែល ។ ប្រមាណជាឆ្នាំ ៩០–៧៧ ម.គ.ស. ។*

ឥឡូវនេះ កាលអាំម៉ូន និងបងប្អូនលោក បានបែកផ្លូវគ្នា
នៅឯព្រំប្រទល់ដែនដីនៃពួកលេមិនហើយ មើលចុះ អើរ៉ុនបាន
ធ្វើដំណើរ ឆ្ពោះទៅឯដែនដីមួយ ដែលពួកលេមិនហៅថា
យេរូសាឡិម គឺហៅតាមដែនដីកំណើតរបស់ពួកអយ្យកោគេ
ហើយដែនដីនេះជាប់ នឹងដែនដីមរមន ។
២ ឥឡូវនេះ ពួកសាសន៍លេមិន និងពួកសាសន៍អាម៉ាលេកៃ
និងប្រជាជនរបស់អាមូឡុន បានកសាងទីក្រុងដ៏ធំមួយ ដែល
ហៅថា យេរូសាឡិម ។
៣ ឥឡូវនេះ ពួកសាសន៍លេមិន គឺជាសាសន៍ដ៏រឹងរូស
ណាស់ទៅហើយ តែពួកសាសន៍អាម៉ាលេកៃ និងពួកសាសន៍
អាមូឡុន រឹងរូសជាងនេះទៅទៀត; ហេតុដូច្នេះហើយ ពួកគេ
បានបណ្ដាលឲ្យពួកលេមិន កាន់តែធ្វើចិត្តរឹងរូសថែមទៀត ដើម្បីឲ្យ
ពួកគេជោកជាំ នៅក្នុងអំពើទុច្ចរិត និងអំពើដ៏គួរខ្ពើមឆ្អើមទាំង
ឡាយរបស់គេ ។
៤ ហើយហេតុការណ៍បានកើតឡើងថា អើរ៉ុនបានមក
ដល់ទីក្រុងយេរូសាឡិម ហើយមុនដំបូង បានចាប់ផ្ដើមផ្សាយ
សាសនាប្រាប់ ពួកសាសន៍អាម៉ាលេកៃ ។ ហើយលោកបាន
ចាប់ផ្ដើមផ្សាយសាសនាប្រាប់ពួកគេ នៅក្នុងសាលាប្រជុំទាំង
ឡាយរបស់គេ ព្រោះគេ បានស្ថាបនាសាលាប្រជុំទាំងឡាយ
តាមរបៀបពួកនីហ័រ ព្រោះពួកសាសន៍អាម៉ាលេកៃ និងពួក
សាសន៍អាមូឡុនជាច្រើន ធ្វើតាម របៀបពួកនីហ័រ ។
៥ ហេតុដូច្នេះហើយ នៅពេលដែលអើរ៉ុនកំពុងតែចូលទៅក្នុង
សាលាប្រជុំ ដើម្បីផ្សាយសាសនាប្រាប់ប្រជាជន ហើយនៅពេល
ដែលលោកកំពុងតែនិយាយទៅកាន់ពួកគេ មើលចុះ ស្រាប់
តែមានសាសន៍អាម៉ាលេកៃម្នាក់បានក្រោកឡើង ហើយបាន
ចាប់ផ្ដើម ប្រកែកនឹងលោកថា៖ តើលោកបានធ្វើទីបន្ទាល់អំពី
អ្វីនោះ ? តើលោកបានឃើញទេវតាឬ ? ហេតុអ្វីបានជាពួក
ទេវតាមិនឲ្យយើង ឃើញផង ? មើលចុះ តើប្រជាជននេះ
មិនល្អដូចជាប្រជាជនលោកទេឬ ?
៦ លោកនិយាយដែរថា លើកលែងតែយើងប្រែចិត្ត នោះយើង
នឹងត្រូវវិនាស ។ ហេតុដូចម្ដេចក៏លោកដឹងគំនិត និងបំណងនៅ
ក្នុងចិត្តយើង ? ហេតុដូចម្ដេចក៏លោកដឹងថា យើងមានហេតុ
ដល់ទៅប្រែចិត្ត ? ហេតុដូចម្ដេចក៏លោកដឹងថា ពួកយើងមិន
មែនជា ប្រជាជនសុចរិត ? មើលចុះ យើងបានសង់ទីបរិសុទ្ធ
ទាំងឡាយ ហើយយើងមកប្រជុំគ្នាមកថ្វាយបង្គំព្រះ យើងជឿថា
ព្រះនឹងជួយ សង្គ្រោះមនុស្សទាំងអស់ ។

២៩ *ក* អាលម៉ា ១៧:១១.
៣០ *ក* អាលម៉ា ២៦:២៩.
**២១** ១ *ក* អាលម៉ា ១៧:១៣, ១៧.
២ *ក* មូសាយ ២៤:១; អាលម៉ា ២៥:៤–៩.
៤ *ក* អាលម៉ា ១:២–១៥.
៥ *ក* មូសាយ ២៧:១១–១៥.

៧ ឥឡូវនេះ អើរ៉ុនបាននិយាយទៅគាត់ថា៖ តើអ្នកជឿថា
ព្រះរាជបុត្រានៃព្រះនឹងយាងមកប្រោសលោះមនុស្សលោក
ពីអំពើបាប ទាំងឡាយរបស់គេឬទេ ?
៨ ហើយជននោះបាននិយាយទៅកាន់លោកថា៖ យើងមិន
ជឿថា លោកដឹងការណ៍បែបនេះឡើយ ។ យើងមិនជឿ
សណ្ដាប់ដ៏ឆ្កួត លីលាបែបនេះទេ ។ យើងមិនជឿថា
លោកដឹង[ក]ការណ៍ដែលនឹងកើតឡើង នៅពេលខាងមុខទេ
ហើយក៏មិនជឿថា ពួកអយ្យកោរបស់ លោក និងពួកអយ្យកោ
របស់យើងផង ដឹងអំពីការណ៍ទាំងឡាយដែលគេនិយាយ
គឺអំពីអ្វីៗដែលនឹងកើតឡើងនោះទេ ។
៩ ឥឡូវនេះ អើរ៉ុនបានចាប់ផ្ដើមបើកព្រះគម្ពីរទាំងឡាយឲ្យ
គេមើល អំពីការយាងមកនៃព្រះគ្រីស្ទ ព្រមទាំងអំពីដំណើរ
រស់ឡើងវិញ នៃមនុស្សស្លាប់ ហើយថា នឹង[ក]មិនត្រូវមានការ
ប្រោសលោះដល់មនុស្សលោកឡើយ លើកលែងតែដោយ
ការសុគត ការរងទុក្ខវេទនា របស់ព្រះគ្រីស្ទ និង[ខ]ដង្វាយ
ធួននៃព្រះលោហិតរបស់ទ្រង់ប៉ុណ្ណោះ ។
១០ ហើយហេតុការណ៍បានកើតឡើងថា កាលលោកបាន
ចាប់ផ្ដើមអធិប្បាយប្រាប់ការណ៍ទាំងនេះដល់គេហើយ ស្រាប់
តែពួកគេខឹង នឹងលោកទៅវិញ ហើយបាន
ចាប់ផ្ដើមចំអកឡកឡឺយលោក; ហើយគេមិនព្រមស្ដាប់តាម
ពាក្យសំដី ដែលលោកបាននិយាយសោះ ។
១១ ហេតុដូច្នេះហើយ កាលលោកបានឃើញថា ពួកគេមិនព្រម
ស្ដាប់តាមពាក្យសំដីលោកទេ នោះលោកក៏ចេញពីសាលាប្រជុំ
របស់គេទៅ ហើយបានមកដល់ភូមិមួយទៀតដែលហៅថា
អានៃ-អាន់តៃ ហើយនៅទីនោះ លោកបានជួបនឹងម៉ូឡូកៃ
កំពុងតែផ្សាយ ព្រះបន្ទូលទៅពួកគេ ព្រមទាំងអាំម៉ា និង
បងប្អូនលោកផង ។ ហើយគេបានប្រកែកគ្នាជាមួយនឹងមនុស្ស
ជាច្រើនអំពីព្រះបន្ទូល ។
១២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានឃើញថា
ប្រជាជនធ្វើចិត្តរឹងរូស ហេតុដូច្នេះហើយ ពួកគេបានចាកចេញពីទី
នោះទៅ ហើយបានមកឯដែនដីមិឌូណៃ ។ ហើយពួកគេបាន
ផ្សាយព្រះបន្ទូលដល់មនុស្សជាច្រើន ហើយមនុស្សចំនួនភាគតិច
បានជឿ តាមពាក្យសំដីដែលគេបានបង្រៀន ។
១៣ ទោះជាយ៉ាងណាក៏ដោយ គង់តែអើរ៉ុន និង
បងប្អូនលោកមួយចំនួន ត្រូវគេចាប់ដាក់គុកដែរ ហើយអ្នក
ដែលនៅសល់ប៉ុន្មាន ក៏គេចចេញពីដែនដីមិឌូណៃ ទៅតាមតំបន់
ដែលនៅជុំវិញនោះ ។
១៤ ហើយពួកអ្នកដែលជាប់គុកទាំងនោះ [ក]បានរងទុក្ខ
វេទនាជាច្រើនយ៉ាង ហើយពួកគេបានរួច ដោយស្នាដៃរបស់
ឡាម៉ូណៃ និងអាំម៉ូន ហើយគេបានទទួលអាហារ និង
សំលៀកបំពាក់ ។
១៥ ហើយពួកគេបានចេញទៅប្រកាសព្រះបន្ទូលទៀត ហើយ
ពួកគេបានរួចពីគុក ជាលើកទីមួយយ៉ាងដូច្នោះ; ហើយគេក៏បានរង
ទុក្ខយ៉ាងនោះដែរ ។
១៦ ហើយគេបានចេញទៅគ្រប់ទិសទី តាម[ក]តែព្រះវិញ្ញាណ
នៃព្រះអម្ចាស់ទ្រង់នាំ ដោយផ្សាយព្រះបន្ទូលនៃព្រះ នៅគ្រប់
សាលា ប្រជុំរបស់ពួកសាសន៍អាម៉ាលេកៃ ឬក៏នៅគ្រប់ទីជំនុំ
របស់ពួកលេមិន ឲ្យតែគេអនុញ្ញាតឲ្យចូល ។
១៧ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
បានចាប់ផ្ដើមប្រទានពរដល់គេ ដរាបដល់ពួកគេបាននាំមនុស្ស
ជាច្រើន ឲ្យស្គាល់សេចក្ដីពិត; មែនហើយ ពួកគេបាន[ក]បរិវត្ត
មនុស្សជាច្រើនពីអំពើបាបទាំងឡាយរបស់គេ និងសណ្ដាប់
ទាំងឡាយនៃពួកអយ្យកោ គេ ដែលជាសណ្ដាប់ខុសឆ្គង ។
១៨ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូន និងឡាម៉ូណៃ
បានត្រឡប់ពីដែនដីមិឌូណៃ មកដែនដីអ៊ីសម៉ាអែលវិញ គឺជា
ដែន ដីនៃកេរ្តិ៍អាកររបស់គេ ។
១៩ ហើយស្ដេចឡាម៉ូណៃមិនព្រមឲ្យអាំម៉ូនបំរើទ្រង់ ឬក៏ធ្វើ
ជាអ្នកបំរើរបស់ទ្រង់ទៀតឡើយ ។
២០ ប៉ុន្តែ ទ្រង់បានបញ្ជាឲ្យគេស្ថាបនាសាលាប្រជុំទាំងឡាយ
នៅលើដែនដីអ៊ីសម៉ាអែល; ហើយទ្រង់បានបញ្ជាឲ្យប្រជាជនរបស់
ទ្រង់ ឬប្រជាជនដែលនៅក្រោមរាជ្យរបស់ទ្រង់មកប្រជុំគ្នា ។
២១ ហើយទ្រង់បានអរីករាយចំពោះគេ ហើយទ្រង់បានបង្រៀន
គេអំពីការណ៍ជាច្រើន ។ ហើយទ្រង់បានប្រកាសប្រាប់ទៅគេដែរ
ថា ពួកគេជាប្រជាជនដែលនៅក្រោមការគ្រប់គ្រងរបស់ទ្រង់
ហើយថា ពួកគេជាប្រជាជនសេរីមួយ គឺគេមិននៅក្រោមការ
រឹបជាន់ របស់ស្ដេច ដែលជាបិតាទ្រង់ឡើយ; ព្រោះអ៊ីបិតា
ទ្រង់បានអនុញ្ញាតឲ្យទ្រង់អាចសោយរាជ្យលើប្រជាជន ដែល
នៅលើដែនដី អ៊ីសម៉ាអែល ហើយនៅក្នុងតំបន់ជុំវិញទាំង
អស់ផង ។
២២ ហើយទ្រង់ក៏បានប្រកាសប្រាប់ដល់គេដែរថា ពួកគេអាច

៨ ក យ៉ាកុប ៧:១–៨.
៩ ក ម៉ូសាយ ៥:៨; អាលម៉ា ៣៨:៩.
ខ ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
១៤ ក អាលម៉ា ២០:២៩.
១៦ ក អាលម៉ា ២២:១.
១៧ ក គ. និង ស. ១៨:៤៤.

មាន[ក]ឥស្សរភាព ក្នុងការថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់គេ តាម បំណងរបស់គេ នៅទីណាក៏ដោយ ឲ្យតែនៅលើដែនដី ដែលនៅក្រោមរាជ្យរបស់ស្ដេចឡាម៉ូណៃ ។

២៣ ហើយអាំម៉ូនបានផ្សាយសាសនាដល់ប្រជាជនរបស់ស្ដេចឡាម៉ូណៃ; ហើយហេតុការណ៍បានកើតឡើងថា លោកបានបង្រៀន ពួកគេនូវគ្រប់ការណ៍ទាំងអស់ អំពីការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ។ ហើយលោកបានទូន្មានពួកគេ ជារៀង រាល់ថ្ងៃ ដោយអស់ពីការព្យាយាម; ហើយពួកគេបានស្ដាប់តាមពាក្យលោក ហើយគេក៏មានចិត្តឧស្សាហ៍ចំពោះការកាន់តាម ព្រះបញ្ញត្តិទាំងឡាយនៃព្រះ ៕

## ជំពូកទី ២២

*អើរ៉ុនបង្រៀនបិតារបស់ឡាម៉ូណៃអំពីការបង្កបង្កើត, អំពីការធ្លាក់នៃលោកអ័ដាម, និងអំពីផែនការនៃសេចក្ដីប្រោសលោះ តាមរយៈ ព្រះគ្រីស្ទ — មហាក្សត្រ និងរាជវង្សរបស់ទ្រង់ទាំងអស់បានប្រែចិត្តជឿ — របៀបចែកដីរវាងពួកនីហ្វៃនឹងពួកលេមិន ត្រូវបានអធិប្បាយ ប្រាប់ ។ ប្រមាណជាឆ្នាំ ៩០–៧៧ ម.គ.ស. ។*

ឥឡូវនេះ នៅពេលដែលអាំម៉ូនកំពុងតែបង្រៀនប្រជាជនឡាម៉ូណៃយ៉ាងនោះតទៅ នោះយើងនឹងត្រឡប់មករៀបរាប់ អំពីអើរ៉ុន និង បងប្អូនរបស់លោកវិញ; ព្រោះបន្ទាប់ពីលោកបានចាកចេញពីដែនដីមិឌូណៃ[ក]ទៅ នោះព្រះវិញ្ញាណ ទ្រង់បាននាំលោកទៅកាន់ដែន ដីនីហ្វៃ គឺទៅដល់ដំណាក់[ខ]របស់ស្ដេច ដែលគ្រប់គ្រងលើដែនដីទាំងអស់ លើកលែងតែដែនដីអ៊ីសម៉ាអែល ប៉ុណ្ណោះ; ហើយស្ដេចនោះ គឺជាបិតារបស់ឡាម៉ូណៃ ។

២ ហើយហេតុការណ៍បានកើតឡើងថា លោកបានចូលទៅគាល់ស្ដេចក្នុងរាជវាំងរបស់ទ្រង់ ជាមួយនឹងបងប្អូនលោក ហើយបាន ក្រាបចំពោះស្ដេច ហើយទូលទ្រង់ថា៖ ក្រាបទូល ព្រះរាជា យើងខ្ញុំ[ក]ជាបងប្អូនរបស់អាំម៉ូន ដែលទ្រង់បានដោះលែងឲ្យរួចពីគុកនោះ ។

៣ ហើយឥឡូវនេះ ឱព្រះរាជាអើយ បើសិនជាទ្រង់លើកលែងជីវិតឲ្យយើងខ្ញុំ នោះយើងខ្ញុំនឹងធ្វើជាអ្នកបំរើទ្រង់ ។ ហើយស្ដេចមានបន្ទូលទៅគេថា៖ ក្រោកឡើងចុះ ព្រោះយើង នឹងប្រោសប្រណីជីវិតឲ្យអ្នក ហើយយើងមិនឲ្យអ្នករាល់គ្នាធ្វើជាអ្នកបំរើរបស់យើង ទេ; តែយើងនឹងទទូចសូមឲ្យអ្នករាល់គ្នាបង្រៀនយើងវិញ; ព្រោះយើងមានកង្វល់នៅក្នុងចិត្ត ដោយសារចិត្តទូលំទូលាយ និងពាក្យ ថ្លៃថ្នូររបស់អាំម៉ូន ដែលជាបងរបស់អ្នក; ហើយយើងមានបំណងចង់ដឹងថា ហេតុអ្វីបានជាអាំម៉ូនមិនបានឡើងមកពីដែនដីមិឌូណៃ ជាមួយនឹងអ្នកផង ។

៤ ហើយអើរ៉ុនទូលទៅស្ដេចថា៖ ក្រាបទូល ព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់បានហៅឲ្យលោកទៅផ្លូវមួយទៀត; លោកបានទៅកាន់ ដែនដីអ៊ីសម៉ាអែល ដើម្បីទៅបង្រៀនប្រជាជនឡាម៉ូណៃ ។

៥ ឥឡូវនេះ ស្ដេចមានបន្ទូលទៅពួកគេថា៖ តើអ្វីទៅដែលអ្នកបាននិយាយអំពីព្រះវិញ្ញាណនៃព្រះអម្ចាស់នោះ ? មើលចុះ គឺរឿង នេះហើយដែលធ្វើឲ្យយើងខ្វល់ ។

៦ ហើយតើអ្វីដែលអាំម៉ូនបាននិយាយផងថា — [ក]បើសិនជាអ្នករាល់គ្នាប្រែចិត្ត នោះអ្នករាល់គ្នានឹងបានសង្គ្រោះ ហើយបើសិនជាអ្នក រាល់គ្នាមិនប្រែចិត្តទេ នោះអ្នករាល់គ្នានឹងត្រូវបោះបង់ចោល នៅថ្ងៃចុងក្រោយបង្អស់ ?

៧ ហើយអើរ៉ុនបានឆ្លើយតបទ្រង់វិញថា៖ តើទ្រង់ជឿថា មានព្រះឬទេ? ហើយស្ដេចមានបន្ទូលថា៖ យើងដឹងថា ពួកសាសន៍អាម៉ាលេកៃថា មានព្រះមួយអង្គ ហើយយើងបានអនុញ្ញាតឲ្យពួកគេ សង់ទីបរិសុទ្ធទាំងឡាយ ដើម្បីឲ្យពួកគេអាចប្រជុំគ្នាថ្វាយបង្គំទ្រង់ ។ ហើយឥឡូវនេះ បើសិនជាអ្នកនិយាយថា មានព្រះមួយអង្គមែន មើលចុះ យើងនឹង[ក]ជឿ ។

៨ ហើយឥឡូវនេះ កាលដែលអើរ៉ុនបានឮដូច្នេះ នោះចិត្តរបស់លោកក៏ចាប់ផ្ដើមអររីករាយ ហើយលោកបានទូលថា៖ មើលចុះ ឱព្រះរាជាអើយ ពិតជាមានព្រះមួយអង្គមែន ដូចជាទ្រង់មានព្រះជន្មរស់នៅដូច្នោះដែរ ។

៩ ហើយស្ដេចមានបន្ទូលថា៖ តើព្រះវិញ្ញាណ[ក]ដ៏មហិមា ដែលបាននាំពួកអយ្យកោយើងចេញពីដែនដីយេរូសាឡិម នោះគឺជាព្រះឬ ?

១០ ហើយអើរ៉ុនឆ្លើយតបទៅទ្រង់ថា៖ ក្រាបទូល ទ្រង់គឺជាព្រះវិញ្ញាណដ៏មហិមានោះ ហើយទ្រង់បាន[ក]បង្កើតរបស់សព្វសារពើទាំងនៅលើស្ថានសួគ៌ និងនៅលើផែនដីផង តើទ្រង់ជឿការណ៍នេះឬទេ ?

២២ *ក* គ. និង ស. ១៣៤:១–៤;
ម. នៃ ស. ១:១១.
ស.ប. ឥស្សរភាព.
**២២** ១ *ក* អាលម៉ា ២១:១៦–១៧.
*ខ* អាលម៉ា ២១:២១–២២.
២ *ក* អាលម៉ា ២០:២៦.
៦ *ក* អាលម៉ា ២០:១៧–១៨.
៧ *ក* គ. និង ស. ៤៦:១៣–១៤.
៩ *ក* អាលម៉ា ១៨:១៨–២៨.
១០ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.

១១ ហើយទ្រង់មានបន្ទូលថា៖ មែនហើយ យើងជឿថា
ព្រះវិញ្ញាណដ៏មហិមាបានបង្កើតរបស់សព្វសារពើមែន ហើយ
យើងមាន បំណងចង់ឲ្យអ្នករាល់គ្នាប្រាប់យើងពីការណ៍អស់
ទាំងនេះ ហើយយើងនឹង[ក]ជឿតាមពាក្យសំដីរបស់អ្នក ។
១២ ហើយហេតុការណ៍បានកើតឡើងថា កាលដែលអើរ៉ុន
បានឃើញថា ស្ដេចនឹងជឿតាមពាក្យសំដីរបស់ខ្លួន
នោះលោកបាន ចាប់ផ្ដើម[ក]អានព្រះគម្ពីរថ្វាយស្ដេច
ចាប់ពីកំណើតលោកអ័ដាមមក — អំពីព្រះទ្រង់បានបង្កើត
មនុស្ស តាមរូបភាពទ្រង់ផ្ទាល់ ហើយព្រះ ទ្រង់បានប្រទាន
ដល់គេ នូវព្រះបញ្ញត្តិទាំងឡាយ ហើយដោយព្រោះអំពើរលង
បានជាមនុស្សត្រូវធ្លាក់ចុះ ។
១៣ ហើយអើរ៉ុនបានអធិប្បាយប្រាប់ទ្រង់អំពីបទគម្ពីរ
ចាប់ពី[ក]កំណើតលោកអ័ដាមមក ដោយលាតត្រដាងប្រាប់
អំពីការធ្លាក់នៃមនុស្ស លោកដល់ទ្រង់ និងស្ថានភាពខាង
រូបកាយរបស់មនុស្ស និង[ខ]ផែនការនៃសេចក្ដីប្រោសលោះ
តាមរយៈព្រះគ្រីស្ទផង ដែលបានរៀបចំ ឡើង
[គ]ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ សំរាប់អស់អ្នកណា
ដែលជឿដល់ព្រះនាមទ្រង់ ។
១៤ ហើយមកពីមនុស្សលោកបាន[ក]ធ្លាក់ បានជាមនុស្សមិន
អាចបាន[ខ]បុណ្យអ្វីដោយសារខ្លួនឯងឡើយ; ប៉ុន្តែការរងទុក្ខ និង
ការសុគត នៃព្រះគ្រីស្ទ បានធ្វើឲ្យ[គ]ធួននឹងអំពើបាបទាំងឡាយ
របស់មនុស្សវិញ តាមរយៈសេចក្ដីជំនឿ និងការប្រែចិត្ត
ជាដើម; ហើយទ្រង់ផ្ដាច់ចំណង ទាំងឡាយនៃសេចក្ដីស្លាប់
ដើម្បីកុំឲ្យ[ឃ]ផ្នូរមានជ័យជំនះ ហើយដើម្បីឲ្យទ្រនិចនៃសេចក្ដីស្លាប់
ត្រូវបានលេបទៅក្នុងសេចក្ដីសង្ឃឹមនៃ សិរីល្អ; ហើយអើរ៉ុនបាន
អធិប្បាយប្រាប់ការណ៍អស់ទាំងនេះដល់ស្ដេច ។
១៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអើរ៉ុនបាន
អធិប្បាយប្រាប់ការណ៍ទាំងនេះដល់ទ្រង់ហើយ នោះស្ដេចមាន
បន្ទូល ថា៖ [ក]តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យយើងអាចបាន
ជីវិតដ៏នៅអស់កល្បជានិច្ច ដែលអ្នកបាននិយាយមកនោះ ?
មែនហើយ តើយើងត្រូវ ធ្វើអ្វីខ្លះ ដើម្បីឲ្យយើងអាចបាន[ខ]កើត
ពីព្រះ ដោយដកយកវិញ្ញាណអាក្រក់នេះចេញពីទ្រូងយើង
ហើយទទួលយកព្រះវិញ្ញាណរបស់ទ្រង់ វិញ ដើម្បីឲ្យ
យើងអាចបានពោរពេញទៅដោយសេចក្ដីអំណរ ដើម្បីកុំឲ្យ
យើងត្រូវបោះបង់ចោល នៅថ្ងៃចុងក្រោយបង្អស់នោះ ?
មើលចុះ ទ្រង់មានបន្ទូលថា៖ យើងនឹងបោះបង់ចោលនូវអ្វីៗ
[គ]ទាំងអស់ដែលយើងមាន មែនហើយ យើងនឹងទំលាក់នគរ
យើង ដើម្បី ឲ្យយើងអាចបានទទួលសេចក្ដីអំណរដ៏ធំនេះ ។
១៦ តែអើរ៉ុនបានទូលទៅកាន់ទ្រង់ថា៖ បើសិនជាទ្រង់មាន
[ក]បំណងចង់បានការណ៍នេះ បើសិនជាទ្រង់ក្រាបចំពោះព្រះ
មែនហើយ បើសិនជាទ្រង់ប្រែចិត្តពីអំពើបាបទាំងអស់របស់ទ្រង់
ហើយក្រាបចំពោះព្រះ ហើយអំពាវនាវដល់ព្រះនាមទ្រង់
ដោយនូវសេចក្ដី ជំនឿ ដោយជឿថា ទ្រង់នឹងទទួល
ពេលនោះទ្រង់នឹងទទួល[ខ]នូវសេចក្ដីសង្ឃឹម ដែលទ្រង់
ប៉ងប្រាថ្នា ។
១៧ ហើយហេតុការណ៍បានកើតឡើងថា កាលដែលអើរ៉ុន
បាននិយាយពាក្យទាំងនេះហើយ ស្រាប់តែស្ដេចក៏បាន[ក]លុត
ជង្គង់ក្រាប ចំពោះព្រះអម្ចាស់ មែនហើយ ព្រមទាំង
ដួលនៅលើដី ហើយ[ខ]អំពាវនាវជាខ្លាំងថា៖
១៨ ឱព្រះអង្គអើយ អើរ៉ុនបានប្រាប់ទូលបង្គំថា មានព្រះ
មួយអង្គពិត; ហើយបើសិនជាមានព្រះមួយអង្គមែន ហើយបើ
សិនជាទ្រង់ជា ព្រះ សូមទ្រង់ធ្វើឲ្យទូលបង្គំស្គាល់ផង ហើយ
ទូលបង្គំនឹងបោះបង់ចោលអស់ទាំងអំពើបាបរបស់ទូលបង្គំ
ដើម្បីឲ្យបានស្គាល់ទ្រង់ ហើយ ដើម្បីទូលបង្គំអាចបានប្រោសឡើ
ងពីស្លាប់ ហើយបានសង្គ្រោះនៅថ្ងៃចុងក្រោយបង្អស់ ។
ហើយឥឡូវនេះ កាលដែលស្ដេចមាន បន្ទូលនូវពាក្យទាំង
នេះហើយ ស្រាប់តែទ្រង់សន្លប់ទៅ ហាក់ដូចជា
សុគត ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកបំរើទ្រង់
បានរត់ទៅប្រាប់អគ្គមហេសី នូវការណ៍ទាំងអស់ដែល

១១ *ក* ស.ប. ជំនឿ, ជឿ.
១២ *ក* ១ នីហ្វៃ ៥:១០–១៨;
អាលម៉ា ៣៧:៩.
១៣ *ក* លោកុ. ១:២៦–២៨.
*ខ* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
*គ* ២ នីហ្វៃ ៩:១៨.
១៤ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*ខ* ២ នីហ្វៃ ២៥:២៣;
អាលម៉ា ៤២:១០–២៥.
*គ* អាលម៉ា ៣៤:៨–១៦.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ឃ* អេសាយ ២៥:៨;
១ កូរិន. ១៥:៥៥.
១៥ *ក* កិច្ចការ ២:៣៧.
*ខ* អាលម៉ា ៥:១៤, ៤៩.
*គ* ម៉ាថាយ ១៣:៤៤–៤៦;
១៩:១៦–២២.
១៦ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
*ខ* អេធើរ ១២:៤.
១៧ *ក* គ. និង ស. ៥:២៤.
*ខ* ស.ប. ការអធិស្ឋាន.

បានកើតឡើងដល់ ស្ដេច ។ ហើយព្រះនាងក៏បានចូលមកឯស្ដេច; ហើយកាលដែលព្រះនាងបានទតឃើញទ្រង់ផ្ដួលដូចជាសុគត ហើយអើរ៉ុន និងបងប្អូន លោកឈរ ហាក់ដូចជាពួកគេជាដើមហេតុដែលនាំឲ្យទ្រង់ដួល ស្រាប់តែព្រះនាងខឹងនឹងពួកគេ ហើយបានបញ្ជាពួកអ្នកបំរើរបស់ ព្រះនាង ឬក៏អ្នកបំរើរបស់ស្ដេច ឲ្យចាប់ពួកគេយកទៅសម្លាប់ចោល ។

២០ ឥឡូវនេះ ពួកអ្នកបំរើបានឃើញដើមហេតុដែលនាំឲ្យស្ដេចដួលចុះ ហេតុដូច្នេះហើយ ពួកគេពុំហ៊ានប៉ះពាល់ដល់អើរ៉ុន និងបង ប្អូនលោកឡើយ; ហើយពួកគេបានសូមអង្វរអគ្គមហេសីថា៖ ហេតុអ្វីបានជាព្រះនាងបញ្ជាឲ្យយើងសម្លាប់បុរសទាំងនេះ មើលចុះ កាល គ្រាន់តែពួកគេម្នាក់[ក]ក៏ខ្លាំងជាងយើងទាំងអស់គ្នាទៅហើយ ? ហេតុដូច្នេះហើយ យើងនឹងដួលចុះចំពោះពួកគេជាមិនខានឡើយ ។

២១ ឥឡូវនេះ កាលដែលអគ្គមហេសីបានទតឃើញការភិតភ័យនៃពួកអ្នកបំរើ នោះព្រះនាងក៏ចាប់ផ្ដើមភិតភ័យជាខ្លាំងដែរ ព្រោះ ខ្លាចក្រែងមានរឿងអាក្រក់ណាមួយកើតឡើងដល់ព្រះនាងដែរ ។ ហើយព្រះនាងបានបញ្ជាពួកអ្នកបំរើ ឲ្យទៅហៅប្រជាជនមក ដើម្បីឲ្យពួកគេមកសម្លាប់អើរ៉ុន និងបងប្អូនលោកវិញ ។

២២ ឥឡូវនេះ កាលអើរ៉ុនបានឃើញការដាច់ចិត្តរបស់អគ្គមហេសី នោះលោកក៏ដឹងពីភាពរឹងរូសនៃចិត្តរបស់ប្រជាជនដែរ ហើយ លោកខ្លាចក្រែងបើបណ្ដាជនប្រជុំគ្នាមកនោះនឹងមានការទាស់ទែងគ្នា និងការចលាចលនៅក្នុងចំណោមពួកគេជាមិនខានឡើយ; ហេតុដូច្នេះហើយ លោកបានលូកដៃទៅលើកស្ដេចឡើងពីដី ហើយបានទូលទៅកាន់ទ្រង់ថា៖ សូមទ្រង់ក្រោកឈរឡើង ។ ហើយទ្រង់ក៏ក្រោកឈរឡើង ដោយបានទទួលកម្លាំងរបស់ទ្រង់វិញ ។

២៣ ឥឡូវនេះ ការណ៍នេះបានធ្វើឡើងនៅវត្តមាននៃអគ្គមហេសី និងពួកអ្នកបំរើជាច្រើន ។ ហើយកាលពួកគេបានឃើញការណ៍ នេះហើយ នោះពួកគេបានកើតសេចក្ដីឆ្ងល់ជាខ្លាំង ហើយបានចាប់ផ្ដើមភ័យខ្លាច ។ ហើយស្ដេចក៏ឈានទៅមុខ ហើយបានចាប់ផ្ដើម [ក]បង្រៀនពួកគេ ។ ហើយទ្រង់បានបង្រៀនពួកគេជាច្រើន ដរាបដល់រាជវង្សាទ្រង់ទាំងមូល បាន[ខ]ប្រែចិត្តជឿដល់ព្រះអម្ចាស់ ។

២៤ ឥឡូវនេះ មានមនុស្សមួយហ្វូងបានមកប្រជុំគ្នា ពីព្រោះតែបញ្ជារបស់អគ្គមហេសី ហើយក៏បានចាប់ផ្ដើមមានការរអ៊ូរទាំដ៏ធំមួយ នៅក្នុងចំណោមពួកគេ ពីព្រោះតែអើរ៉ុន និងបងប្អូនលោក ។

២៥ ប៉ុន្ដែ ស្ដេចឈរក្នុងចំណោមពួកគេ ហើយបានបង្រៀនគេ ។ ហើយពួកគេក៏បាត់ខឹងនឹងអើរ៉ុន និងពួកជនដែលនៅជាមួយ នឹងលោក ។

២៦ ហើយហេតុការណ៍បានកើតឡើងថា កាលដែលស្ដេចបានទតឃើញថា ប្រជាជនបាត់ខឹងហើយ នោះទ្រង់ក៏បញ្ជាឲ្យអើរ៉ុន និងបងប្អូនលោក ចេញមកឈរក្នុងចំណោមហ្វូងមនុស្ស ហើយឲ្យគេផ្សាយព្រះបន្ទូលដល់បណ្ដាជន ។

២៧ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចបានចេញ[ក]ការប្រកាសមួយទូទៅអស់ទាំងដែនដី គឺក្នុងចំណោមប្រជាជនរបស់ទ្រង់ទាំងអស់ដែលនៅលើដែនដីរបស់ទ្រង់ ដែលនៅតាមតំបន់ជុំវិញ ដែលនៅតាមជាយដែន រហូតទៅដល់សមុទ្រ[ខ]នៅខាងកើត និងខាងលិច ហើយដែលបែកពីដែនដីសារ៉ាហិមឡា ដោយទីរហោស្ថានមួយផ្នែកតូច ដែលចេញពីសមុទ្រខាងកើតមកដល់សមុទ្រ ខាងលិច ហើយនៅឯតំបន់ទាំងឡាយជាប់នឹងឆ្នេរសមុទ្រ និងតំបន់ទាំងឡាយជាប់នឹងទីរហោស្ថាន នៅទិសខាងជើងជិតដែនដី សារ៉ាហិមឡា ឆ្លងកាត់ព្រំប្រទល់ដែនដីម៉ាន់តៃ នៅជិតប្រភពទន្លេស៊ីដូន ដែលហូរពីកើតទៅលិច — ហើយពួកសាសន៍លេមិន និងពួកសាសន៍នីហ្វៃបានបែកចេញពីគ្នាបែបដូច្នោះហើយ ។

២៨ ឥឡូវនេះ ភាគច្រើននៃពួកលេមិនដែល[ក]ខ្ជិលច្រអូស បានរស់នៅក្នុងទីរហោស្ថាន ហើយអាស្រ័យនៅក្នុងត្រសាលទាំងឡាយ; ហើយពួកគេរាយពាសពេញទីរហោស្ថានផ្នែកខាងលិចនៅលើដែនដីនីហ្វៃ; មែនហើយ ព្រមទាំងនៅខាងលិចដែនដីសារ៉ាហិមឡាផង នៅក្នុងតំបន់ព្រំប្រទល់ជិតឆ្នេរសមុទ្រ និងនៅខាងលិច នៅលើដែនដីនីហ្វៃ គឺត្រង់កន្លែងដែលជាកេរ្តិ៍អាករដំបូងរបស់ពួកអយ្យកោគេ គឺនៅស្របតាមឆ្នេរសមុទ្រ ។

២៩ ហើយក៏មានពួកលេមិនជាច្រើន នៅខាងកើតជិតឆ្នេរសមុទ្រផង ត្រង់កន្លែងដែលពួកនីហ្វៃបានរុញច្រានគេទៅនោះ ។ ម្ល៉ោះ ហើយ ពួកនីហ្វៃសឹងតែត្រូវហ៊ុំព័ទ្ធដោយពួកលេមិន; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកនីហ្វៃបានយកដី

២០ *ក* អាលម៉ា ១៨:១–៣.
២៣ *ក* ស.ប. ធ្វើការងារបំរើ; ផ្សាយ; បង្រៀន, គ្រូបង្រៀន.
*ខ* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
២៧ *ក* អាលម៉ា ២៣:១–៤.
*ខ* អោមណៃ ១:១៣–១៧.
២៨ *ក* ២ នីហ្វៃ ៥:២២–២៥.

ភាគខាងជើងទាំងអស់ ដែលនៅស្របតាមទីរហោស្ថានដែរ
នៅត្រង់ប្រភពទន្លេស៊ីដូន ពីខាងកើត ទៅខាងលិច នៅជុំវិញ
តំបន់ខាងទីរហោស្ថាន; នៅខាង ជើង រហូតទៅទល់នឹងដែនដី
មួយ ដែលគេហៅថា [ក]បរិបូរណ៍ ។
៣០ ហើយដែនដីនោះនៅជាប់ព្រំប្រទល់នឹងដែនដីមួយ ដែល
ហៅថា [ក]ទីចោលស្ងាត់ ដែលនៅឆ្ងាយ ទៅខាងជើង ទៅទល់
នឹងដែន ដីមួយដែលពីដើមមានមនុស្សអាស្រ័យនៅ ហើយត្រូវ
បំផ្លាញចោល ដែលយើងធ្លាប់បាននិយាយពីមុនមកថា
ឆ្អឹងរបស់គេត្រូវបានប្រទះ ឃើញដោយប្រជាជនសារ៉ាហិមឡា
ទីនោះគឺជាកន្លែងដែលប្រជាជននេះឡើងមកពីសមុទ្រ[ខ]ដំបូង ។
៣១ ហើយពួកគេបានមកពីទីនោះ ឡើងទៅក្នុង
ទីរហោស្ថានខាងត្បូង ។ ម្ល៉ោះហើយ ដីដែលនៅខាងជើង
ត្រូវបានហៅថា [ក]ទីចោលស្ងាត់ ហើយដីដែលនៅខាងត្បូង
បានហៅថា បរិបូរណ៍ គឺជាទីរហោស្ថាន ដែលមាន
ពោរពេញទៅដោយសត្វព្រៃគ្រប់បែប យ៉ាង សត្វព្រៃទាំងនេះ
មួយចំនួន បានមកពីដីភាគខាងជើង [ក]ស្វែងរកអាហារ ។
៣២ ហើយឥឡូវនេះ គឺគ្រាន់តែចម្ងាយមួយថ្ងៃកន្លះប៉ុណ្ណោះ
សំរាប់ឲ្យសាសន៍នីហ្វៃម្នាក់ធ្វើដំណើរ ពីព្រំប្រទល់ដែនដីបរិបូរណ៍
ទៅដល់ដែនដីនៃទីចោលស្ងាត់ពីសមុទ្រខាងកើត ទៅសមុទ្រ
ខាងលិច; ម្ល៉ោះហើយ ដែនដីនីហ្វៃ និងដែនដីសារ៉ាហិមឡា
ស៊ឹងតែត្រូវ [ខ]ឡោមព័ទ្ធដោយសមុទ្រ ដោយមានដីមួយចន្លោះ
តូច ភ្ជាប់តំបន់ខាងជើង និងតំបន់ខាងត្បូង ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍នីហ្វៃ
ធ្លាប់បានមកអាស្រ័យនៅលើដែនដីបរិបូរណ៍ គឺពីសមុទ្រ
ខាងកើត ទៅសមុទ្រខាងលិច ម្ល៉ោះហើយ ដោយនូវប្រាជ្ញា
របស់គេ បានជាពួកសាសន៍នីហ្វៃបានឲ្យកងយាមដែនដី ហើយ
ពលទ័ពរបស់គេឃាំង ពួកលេមិននៅទិសខាងត្បូង ដើម្បីកុំឲ្យ
ពួកសាសន៍លេមិន មកវាយដណ្ដើមយកដីនៅទិសខាងជើង
បានថែមទៀត ។
៣៤ ហេតុដូច្នេះហើយ ពួកលេមិនមិនអាចយកដីទៀតបានទេ
លើកលែងតែដែនដីនីហ្វៃ និងទីរហោស្ថាន ដែលនៅព័ទ្ធជុំវិញ
ប៉ុណ្ណោះ ។ ឥឡូវនេះ នេះគឺជាប្រាជ្ញារបស់ពួកសាសន៍នីហ្វៃ —
ដរាបណាពួកសាសន៍លេមិន ជាពួកខ្មាំងសត្រូវរបស់គេ នោះគេ
មិនទ្រាំឲ្យពួកលេមិនមកធ្វើទុក្ខគេពីគ្រប់ទិសទីឡើយហើយគេធ្វើ
យ៉ាងនេះក៏ដើម្បីឲ្យមានដែនដីមួយ សំរាប់គេរត់ទៅជ្រក តាម
ចំណង់របស់គេ ។
៣៥ ហើយឥឡូវនេះ បន្ទាប់ពីបាននិយាយការណ៍
ទាំងនេះហើយ ខ្ញុំសូមត្រឡប់មកនិយាយអំពីអាំម៉ូន និងអើរ៉ុន
អោមណើរ និងហិមណៃ និងបងប្អូនគេទៀត ៕

## ជំពូកទី ២៣

*សេរីភាពខាងសាសនាត្រូវបានប្រកាស — ពួកសាសន៍លេមិននៅលើដែនដី និងនៅទីក្រុងទាំងប្រាំពីរ បានប្រែចិត្តជឿ — ពួកគេហៅ ខ្លួនគេថា ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ហើយបានរួចផុតពីពាក្យបណ្ដាសា — ពួកសាសន៍អាម៉ាលេកៃ និងពួកសាសន៍អាំមូឡុន បដិសេធសេចក្ដីពិត ។ ប្រមាណជាឆ្នាំ ៩០—៧៧ ម.គ.ស. ។*

មើលចុះ [ក]ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ស្ដេចនៃពួក
លេមិនចេញការប្រកាសមួយ ទៅក្នុងចំណោមប្រជាជនទាំង
អស់ របស់ទ្រង់ថា ពួកគេមិនត្រូវប៉ះពាល់អាំម៉ូន ឬអើរ៉ុន
ឬអោមណើរ ឬហិមណៃ ឬក៏បងប្អូនរបស់គេណាមួយ ដែល
ដើរផ្សាយព្រះបន្ទូល នៃព្រះឡើយ ទោះជាពួកគេនៅក្នុង
ទីណា ឬភាគណាមួយនៃដែនដីរបស់គេក៏ដោយ ។
២ មែនហើយ ទ្រង់បានចេញជាក្រឹត្យមួយ នៅក្នុងចំណោម
ពួកគេថា ពួកគេមិនត្រូវដាក់ដៃទៅលើគេ ដើម្បីចងគេ
ឬដាក់គេទៅក្នុង គុកឡើយ; ហើយពួកគេក៏មិនត្រូវស្ដោះដាក់អ្នក
ទាំងនោះ ឬវាយដំគេ ឬបណ្ដេញគេចេញពីសាលាប្រជុំទាំង
ឡាយរបស់ខ្លួន ឬធ្វើទុក្ខ ដល់គេឡើយ; ហើយពួកគេក៏មិន
ត្រូវចោលអ្នកទាំងនោះនឹងថ្មដែរ តែត្រូវឲ្យអ្នកទាំងនោះចេញ
ចូលតាមផ្ទះគេបានដោយសេរី និងព្រះវិហារបរិសុទ្ធទាំង
ឡាយរបស់គេ និងទីបរិសុទ្ធទាំងឡាយរបស់គេផង ។
៣ ម្ល៉ោះហើយ ទើបពួកគេអាចទៅផ្សាយព្រះបន្ទូលតាមចំណង់
របស់គេ ព្រោះស្ដេចបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ព្រមទាំង
រាជវង្សារបស់ទ្រង់ទាំងអស់ផង; ហេតុដូច្នេះហើយ ទ្រង់បានចេញ
ការប្រកាសមួយ ទៅកាន់ប្រជាជនរបស់ទ្រង់ទូទៅទាំងដែនដី

២៩ *ក* អាលម៉ា ៥២:៩; ៦៣:៥.
៣០ *ក* អាលម៉ា ៥០:៣៤; មរមន ៤:១–៣.
*ខ* ម៉ូសាយ ៨:៧–១២; ២៨:១១–១៩.
*គ* ហេលេ. ៦:១០.
៣១ *ក* ហេលេ. ៣:៥–៦.
៣២ *ក* ហេលេ. ៤:៧.
*ខ* អាលម៉ា ៥០:៣៤.
**២៣** ១*ក* អាលម៉ា ២២:២៧.

ដើម្បីកុំឲ្យព្រះបន្ទូលនៃព្រះអាចបានជួបប្រទះនឹងឧបសគ្គ តែ
សូមឲ្យព្រះបន្ទូលបានផ្សាយទូទៅអស់ទាំងដែនដីវិញ ដើម្បីឲ្យ
ប្រជាជន របស់ទ្រង់អាចបានបរិវត្តអំពី[ក]សណ្ដាប់អាក្រក់ទាំង
ឡាយ នៃពួកអយ្យកោរបស់គេ ហើយដើម្បីឲ្យពួកគេអាចបាន
បរិវត្តថា គេទាំង អស់គ្នាជាបងប្អូននឹងគ្នា ហើយដើម្បីកុំឲ្យ
គេធ្វើឃាត ឬប្លន់ ឬលួច ឬផិតគ្នា ឬប្រព្រឹត្តអំពើទុច្ចរិតបែបណា
ាមួយឡើយ ។
៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ស្ដេចបានចេញសេចក្ដីប្រកាសនេះហើយ នោះអើរ៉ុន និង
បងប្អូនលោក ក៏ទៅពីក្រុងមួយទៅក្រុងមួយ និងពីទីថ្វាយបង្គំ
មួយទៅទីថ្វាយបង្គំមួយ ដោយតាំងសាសនាចក្រទាំងឡាយ
ហើយតែងតាំងពួកសង្ឃ និងពួកគ្រូបង្រៀនទូទៅទាំងដែនដី
នៅក្នុងចំណោមពួកលេមិន ដើម្បីផ្សាយ ហើយបង្រៀនព្រះ
បន្ទូលនៃព្រះ នៅក្នុងចំណោមពួកគេ; ម្ល៉ោះហើយ ពួកគេបាន
ចាប់ផ្ដើមមានជោគជ័យដ៏ធំ ។
៥ ហើយមនុស្សរាប់ពាន់នាក់ ត្រូវបាននាំមកឲ្យស្គាល់ព្រះ
អម្ចាស់ មែនហើយ មនុស្សរាប់ពាន់នាក់ត្រូវបាននាំមកឲ្យ
ជឿដល់ [ក]សណ្ដាប់ទាំង[ខ]ឡាយរបស់ពួកសាសន៍នីហ្វៃ; ហើយ
ពួកគេត្រូវបានបង្រៀនពីបញ្ជីទាំងឡាយ និងសេចក្ដីព្យាករណ៍
ទាំងឡាយ ដែលបានបន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ ។
៦ ហើយប្រាកដដូចជាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ
ក៏មានមនុស្សជាច្រើនបានជឿ ឬក៏មនុស្សជាច្រើន ដែលត្រូវបាន
នាំមកឲ្យ ស្គាល់សេចក្ដីពិត តាមរយៈការផ្សាយរបស់អាំម៉ូន
និងបងប្អូនលោក ស្របតាមវិញ្ញាណនៃវិវរណៈ និងវិញ្ញាណ
នៃការព្យាករណ៍ និងព្រះ ចេស្ដានៃព្រះ ដែលសម្ដែង
អព្ភូតហេតុនៅក្នុងពួកគេ — មែនហើយ ខ្ញុំសូមប្រាប់អ្នកថា
ដរាបណាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ គឺដរាបណា
មានពួកលេមិនជាច្រើនបានជឿតាមការផ្សាយរបស់គេ ហើយ
បាន[ក]ប្រែចិត្តជឿដល់ព្រះអម្ចាស់ នោះពួកគេ[ខ]ពុំបោះបង់ចោល
សាសនាឡើយ ។
៧ ព្រោះពួកគេបានក្លាយទៅជាប្រជាជនមួយដ៏សុចរិត; ពួក
គេបានដាក់គ្រឿងសស្ត្រាវុធនៃការបះបោររបស់គេចុះ ដែលកុំឲ្យ
ពួកគេ ប្រយុទ្ធនឹងព្រះ ឬតតាំងនឹងបងប្អូនរបស់គេទៀតឡើយ ។
៨ ឥឡូវនេះ [ក]ពួកអ្នកទាំងនេះហើយដែលបានប្រែចិត្តជឿដល់
ព្រះអម្ចាស់ គឺៈ
៩ ប្រជាជននៃពួកសាសន៍លេមិន ដែលនៅលើដែនដី
អ៊ីសម៉ាអែល;
១០ ហើយព្រមទាំងប្រជាជននៃពួកសាសន៍លេមិន ដែល
នៅលើដែនដីមិឌដូណៃផង;
១១ ហើយព្រមទាំងប្រជាជននៃពួកសាសន៍លេមិន ដែលនៅ
ក្នុងទីក្រុងនីហ្វៃផង;
១២ ហើយព្រមទាំងប្រជាជននៃពួកសាសន៍លេមិន ដែល
នៅលើដែនដីសៃឡោម និងពួកអ្នកដែលនៅលើដែនដីសេមឡុន
និងនៅក្នុងទីក្រុងលេមយួល និងនៅក្នុងទីក្រុង[ក]ស៊ីមណៃឡោមផង ។
១៣ ហើយនោះគឺជាឈ្មោះនៃទីក្រុងទាំងឡាយរបស់ពួកលេមិន
ដែលបាន[ក]ប្រែចិត្តជឿដល់ព្រះអម្ចាស់; ហើយនោះគឺជាពួកអ្នក
ដែល បានដាក់គ្រឿងសស្ត្រាវុធនៃការបះបោររបស់គេចុះ មែន
ហើយ គឺគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមទាំងអស់របស់គេ;
ហើយពួកគេ សុទ្ធតែជាសាសន៍លេមិនទាំងអស់ ។
១៤ ឯពួកសាសន៍អាម៉ាលេកៃ មិនបាន[ក]ប្រែចិត្តជឿទេ
លើកលែងតែមនុស្សម្នាក់ប៉ុណ្ណោះ; ឯពួកសាសន៍
[ខ]អាមូឡុនក៏ដូច្នោះដែរ; ប៉ុន្តែ ពួកគេបានធ្វើចិត្តរឹងរូស និងចិត្តនៃ
ពួកលេមិនផងដែលនៅលើភូមិភាគនៃដែនដីនោះ ដែល
គេអាស្រ័យរស់នៅ មែនហើយ និងអស់ទាំង ភូមិរបស់គេ និង
អស់ទាំងទីក្រុងរបស់គេ ។
១៥ ហេតុដូច្នេះហើយ ទើបយើងបានរាប់ឈ្មោះអស់ទាំង
ទីក្រុងនៃពួកលេមិន ដែលបានប្រែចិត្ត ហើយបានស្គាល់សេចក្ដី
ពិត ហើយបានប្រែចិត្តជឿ ។
១៦ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ស្ដេច
និងពួកអ្នកដែលបានប្រែចិត្តជឿ គេមានបំណងចង់បានឈ្មោះមួយ
ដើម្បីពួកគេអាចញែកចេញពីបងប្អូនគេ; ហេតុដូច្នេះហើយ
ស្ដេចបានពិភាក្សាជាមួយនឹងអើរ៉ុន និងពួកសង្ឃជាច្រើន
អំពីឈ្មោះ ណាមួយ ដែលពួកគេគួរដាក់យក ដើម្បីគេអាច
ញែកចេញ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានហៅ
ខ្លួនគេថា [ក]ពួកសាសន៍អាន់ទៃ-នីហ្វៃ-លីហៃ; ហើយពួកគេក៏បាន

៣ *ក* អាលម៉ា ២៦:២៤.
៥ *ក* អាលម៉ា ៣៧:១៩.
*ខ* អាលម៉ា ៦៣:១២.
ស.ប. បទព្រះគម្ពីរ.
៦ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
*ខ* អាលម៉ា ២៧:២៧.
៨ *ក* អាលម៉ា ២៦:៣, ៣១.
១២ *ក* ម៉ូសាយ ២២:៨, ១១.
១៣ *ក* អាលម៉ា ៥៣:១០.
១៤ *ក* អាលម៉ា ២៤:២៩.
*ខ* ម៉ូសាយ ២៣:៣១–៣៩.
១៧ *ក* ស.ប. អាន់ទៃ-នីហ្វៃ-លីហៃ.

ហៅតាម ឈ្មោះនេះ ហើយឈប់ហៅថាជាពួកសាសន៍
លេមិនតទៅទៀតហើយ ។
១៨ ហើយពួកគេបានចាប់ផ្ដើមក្លាយទៅជាប្រជាជនមួយ
ដ៏មានចិត្តឧស្សាហ៍; មែនហើយ ហើយពួកគេជាមិត្តនឹងពួក
សាសន៍នីហ្វៃ; ហេតុដូច្នេះហើយ ពួកគេបានបើកការទាក់ទង
ជាមួយនឹងពួកគេ ឯ[ក]ពាក្យបណ្ដាសានៃព្រះ ក៏ឈប់តាមពួក
គេទៀតដែរ ៕

---

## ជំពូកទី ២៤

*ពួកលេមិនមកទាស់នឹងរាស្ត្រនៃព្រះ — ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃបានអររីករាយនៅក្នុងព្រះគ្រីស្ទ ហើយពួកទេវតាបានមកជួប ពួកគេ — ពួកគេសុខចិត្តស៊ូទ្រាំដល់ស្លាប់ជាជាងការពារខ្លួន — មានពួកលេមិនថែមទៀតប្រែចិត្តជឿ។ ប្រមាណជាឆ្នាំ ៩០–៧៧ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍អាម៉ាលេកៃ
និងពួកសាសន៍អាមូឡុន និងពួកសាសន៍លេមិន ដែល
នៅលើដែនដី អាមូឡុន និងលើដែនដីហេឡាមផង និងពួកជន
ដែលលើដែនដី[ក]យេរូសាឡិម ហើយសរុបសេចក្ដីមក គឺនៅអស់
ទាំងដែនដីព័ទ្ធជុំវិញ ដែលមិនទាន់បានប្រែចិត្តជឿ ហើយដែល
មិនទាន់បានលើកយកឈ្មោះ [ខ]អាន់តៃ-នីហ្វៃ-លីហៃ ត្រូវពួក
សាសន៍អាម៉ាលេកៃ និងពួក សាសន៍អាមូឡុន ចាក់រុកឲ្យខឹង
នឹងបងប្អូនគេ ។
២ ហើយសេចក្ដីស្អប់ដែលគេមានចំពោះបងប្អូនគេនោះ បាន
ក្លាយទៅមានទំហំធំពន់ប្រមាណ គឺដរាបដល់គេបានចាប់ផ្ដើម
បះបោរ ទាស់នឹងស្ដេចរបស់គេ ដរាបដល់ពួកគេមិនចង់ឲ្យ
ទ្រង់ធ្វើជាស្ដេចរបស់គេឡើយ; ហេតុដូច្នេះហើយ ពួកគេបាន
កាន់អាវុធប្រឆាំងនឹង ប្រជាជនអាន់តៃ-នីហ្វៃ-លីហៃ ។
៣ ឥឡូវនេះ ស្ដេចបានប្រគល់នគរឲ្យទៅបុត្រទ្រង់ ហើយ
ទ្រង់បានឲ្យនាមបុត្រថា អាន់តៃ-នីហ្វៃ-លីហៃ ។
៤ ហើយស្ដេចបានសុគតទៅ នៅក្នុងឆ្នាំនោះឯង ដែលពួក
លេមិនបានចាប់ផ្ដើមរៀបចំធ្វើសង្គ្រាមតទល់នឹងរាស្ត្រនៃព្រះ ។
៥ ឥឡូវនេះ ពេលអាំម៉ូន និងបងប្អូនលោក និងអស់អ្នកដែល
បានឡើងមកជាមួយលោក បានឃើញការរៀបចំរបស់ពួកលេមិន
ដើម្បីមកបំផ្លាញបងប្អូនរបស់គេបង់ នោះពួកគេបានធ្វើដំណើរ
មកដល់ដែនដីម៉ាឌាន ហើយនៅទីនោះ អាំម៉ូនបានជួបនឹង
បងប្អូនលោក ទាំងអស់គ្នា; ហើយចាប់ពីទីនោះមក ពួកគេបាន
មកឯដែនដីអ៊ីសម៉ាអែល ដើម្បីគេអាចមាន[ក]ការប្រឹក្សាជាមួយ
នឹងឡាម៉ូណៃ ព្រមទាំង ជាមួយនឹងអនុជរបស់ទ្រង់ គឺអាន់តៃ-
នីហ្វៃ-លីហៃ អំពីអ្វីដែលគេត្រូវធ្វើ ដើម្បីការពារខ្លួនទប់ទល់នឹង
ពួកលេមិន ។
៦ ឥឡូវនេះ គ្មាននរណាម្នាក់សោះក្នុងចំណោមប្រជាជនទាំង
អស់ ដែលបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ចង់លើកអាវុធប្រឆាំង
នឹង បងប្អូនគេឡើយ; ទេ ពួកគេក៏មិនទាំងចង់រៀបចំធ្វើ
សង្គ្រាមដែរ; មែនហើយ ហើយស្ដេចរបស់គេក៏បានបញ្ជាពួក
គេថា គេមិនត្រូវធ្វើ ដូច្នោះដែរ ។
៧ ឥឡូវនេះ នេះហើយគឺជាពាក្យដែលទ្រង់មានបន្ទូលទៅកាន់
ប្រជាជនអំពីរឿងនេះថា៖ ឱប្រជាជនជាទីស្រឡាញ់
របស់យើងអើយ យើងសូមអរព្រះគុណដល់ព្រះរបស់យើង ដែល
ព្រះដ៏មហិមានៃយើង នៅក្នុងសេចក្ដីល្អសប្បុរស បានចាត់ឲ្យ
បងប្អូនយើងទាំងឡាយ គឺសាសន៍នីហ្វៃទាំងនេះ មករកយើងរាល់
គ្នា ដើម្បីមកផ្សាយដល់យើង ហើយដើម្បីបរិវត្តយើងអំពី
[ក]សំណ្ដាប់ទាំងឡាយរបស់ពួក អយ្យកោដ៏ទុច្ចរិតរបស់យើង ។
៨ ហើយមើលចុះ យើងសូមអរព្រះគុណដល់ព្រះដ៏មហិមា
របស់យើង ដែលបានប្រទានដល់យើងរាល់គ្នា នូវចំណែកនៃ
ព្រះ វិញ្ញាណរបស់ទ្រង់ ដើម្បីបន្ទន់ចិត្តយើង ដែលបានធ្វើឲ្យ
យើងបើកការទាក់ទងជាមួយនឹងបងប្អូនយើង គឺពួកសាសន៍
នីហ្វៃ ។
៩ ហើយមើលចុះ យើងក៏សូមអរព្រះគុណដល់ព្រះរបស់យើង
ដោយបានបើកឲ្យមានការទាក់ទងនេះហើយ ទើបយើងត្រូវ
បានបរិវត្ត ពី[ក]អំពើបាបទាំងឡាយរបស់យើង និងអំពើ
ឃាតកម្មជាច្រើន ដែលយើងបានប្រព្រឹត្ត ។
១០ ហើយយើងក៏សូមអរព្រះគុណដល់ព្រះរបស់យើង មែន
ហើយ ព្រះដ៏មហិមារបស់យើង ដែលទ្រង់បានអនុញ្ញាតឲ្យ
យើងទាំង ឡាយអាចប្រែចិត្តពីការណ៍ទាំងនេះ ព្រមទាំងបាន
[ក]អភ័យទោសឲ្យយើងរាល់គ្នា ចំពោះអំពើបាប និងអំពើ
ឃាតកម្មដ៏ច្រើនរបស់យើង ដែលយើងបានប្រព្រឹត្ត ហើយបាន

---

១៨ *ក* ១ នីហ្វៃ ២:២៣;
២ នីហ្វៃ ៣០:៥–៦;
៣ នីហ្វៃ ២:១៤–១៦.

**២៤** ១ *ក* អាលម៉ា ២១:១.
*ខ* អាលម៉ា ២៥:១, ១៣.
៥ *ក* អាលម៉ា ២៧:៤–១៣.

៧ *ក* ម៉ូសាយ ១:៥.
៩ *ក* គ. និង ស. ១៨:៤៤.
១០ *ក* ដានី. ៩:៩.

ដកយក[ខ]ទោសចេញពីក្នុងចិត្តយើង តាមរយៈបុណ្យគុណទាំង
ឡាយនៃព្រះរាជបុត្រារបស់ទ្រង់ ។
១១ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយ
របស់យើងអើយ ការណ៍ទាំងអស់នេះហើយដែលយើងរាល់
គ្នាអាចធ្វើ (ព្រោះ យើងជាអ្នកវង្វេងជាងគេបង្អស់ នៅក្នុង
ចំណោមមនុស្សលោក) ដើម្បីប្រែចិត្តពីអំពើបាបទាំងអស់
របស់យើង និងអំពើឃាតកម្មជាច្រើន ដែលយើងបានប្រព្រឹត្ត
ហើយដើម្បីសូមឲ្យព្រះទ្រង់[ក]ដកយកអំពើទាំងនោះចេញពីចិត្ត
របស់យើង ព្រោះមានតែការណ៍ទាំងនេះ ហើយដែល
យើងអាចធ្វើ ដើម្បីប្រែចិត្តឲ្យបានល្មមគ្រប់គ្រាន់ចំពោះព្រះ
ដើម្បីទ្រង់នឹងដកស្នាមប្រឡាក់របស់យើងចេញ —
១២ ឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់បំផុតរបស់យើងអើយ
ដោយសារព្រះទ្រង់បានដកស្នាមប្រឡាក់របស់យើងរាល់គ្នាចេញ
ហើយដាវរបស់យើងរាល់គ្នាបានក្លាយទៅជាជ្រះថ្លា នោះចូរយើង
កុំធ្វើឲ្យដាវយើងរាល់គ្នាប្រឡាក់ដោយឈាមរបស់បងប្អូនយើង
ទៀតឡើយ ។
១៣ មើលចុះ យើងប្រាប់អ្នករាល់គ្នាថា ទេ ចូរយើងរាល់
គ្នារក្សាដាវយើងទុក ដើម្បីកុំឲ្យវាប្រឡាក់ដោយឈាមរបស់
បងប្អូនយើង ឡើយ; ត្បិតប្រសិនបើយើងធ្វើឲ្យដាវយើង
ប្រឡាក់ម្ដងទៀត នោះវានឹងមិនអាចបាន[ក]ជំរះឲ្យជ្រះថ្លា
តាមរយៈព្រះលោហិតនៃព្រះ រាជបុត្រានៃព្រះដ៏មហិមា
របស់យើងទៀតឡើយ ដែលនឹងត្រូវច្រួចចេញ ដើម្បីធ្វើឲ្យធួន
នឹងអំពើបាបទាំងឡាយរបស់យើង ។
១៤ ហើយព្រះដ៏មហិមា ទ្រង់មានសេចក្ដីមេត្តាករុណា
ដល់យើងរាល់គ្នា ហើយបានធ្វើឲ្យយើងដឹងការណ៍ទាំងនេះ
ដើម្បីកុំឲ្យយើង រាល់គ្នាត្រូវវិនាស; មែនហើយ ហើយទ្រង់បាន
ធ្វើឲ្យយើងដឹងការណ៍ទាំងនេះជាមុន ពីព្រោះទ្រង់ស្រឡាញ់
[ក]ព្រលឹងយើងទាំងឡាយ ដូចជាទ្រង់ស្រឡាញ់កូនចៅ
របស់យើងដែរ; ហេតុដូច្នេះហើយ ដោយនូវសេចក្ដីមេត្តាករុណា
របស់ទ្រង់ នោះទ្រង់យាងមកពិនិត្យ ពិច័យយើង ដោយពួក
ទេវតារបស់ទ្រង់ ដើម្បី[ខ]ធ្វើឲ្យបានដឹងដល់យើង ព្រមទាំងដល់
មនុស្សជំនាន់ក្រោយដែរ ។
១៥ ឱព្រះរបស់យើង ទ្រង់ប្រកបដោយសេចក្ដីមេត្តាករុណា
អ្វីម្ល៉េះ! ហើយឥឡូវនេះ មើលចុះ ដោយសារយើងរាល់គ្នា
អាចធ្វើបាន តែប៉ុណ្ណេះ ដើម្បីកំចាត់ស្នាមប្រឡាក់របស់យើង
ទាំងឡាយចេញ ហើយធ្វើឲ្យដាវរបស់យើងជ្រះថ្លា នោះចូរយើង
លាក់វាទុក ដើម្បីឲ្យ វានៅតែជ្រះថ្លា ទុកជាទីបន្ទាល់មួយដល់
ព្រះរបស់យើងនៅថ្ងៃចុងក្រោយបង្អស់ ឬនៅថ្ងៃដែលយើងនឹង
ត្រូវបាននាំទៅឈរចំពោះទ្រង់ ដើម្បីទទួលការជំនុំជំរះថា
យើងមិនបានធ្វើឲ្យដាវរបស់យើងប្រឡាក់ដោយឈាមរបស់
បងប្អូនយើងឡើយ ចាប់ពីពេលដែលទ្រង់បាន ប្រទានព្រះបន្ទូល
របស់ទ្រង់ដល់យើង ហើយបានធ្វើឲ្យយើងជ្រះស្អាតដោយការណ៍
នោះ ។
១៦ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់យើងអើយ
បើសិនជាបងប្អូនយើងស្វែងរកបំផ្លាញយើងរាល់គ្នាចោល
មើលចុះ យើងនឹងលាក់ដាវរបស់យើងទុក មែនហើយ គឺយើង
នឹងកប់វាឲ្យជ្រៅទៅក្នុងដី ដើម្បីទុកឲ្យវាជ្រះថ្លា ទុកជា
ទីបន្ទាល់មួយ នៅថ្ងៃចុង ក្រោយបង្អស់ថា យើងមិនដែល
បានប្រើវាឡើយ; ហើយបើសិនជាបងប្អូនយើងបំផ្លាញ
យើងរាល់គ្នាបង់ មើលចុះ យើងទាំងឡាយនឹង [ក]ទៅរកព្រះ
របស់យើង ហើយនឹងបានសង្គ្រោះ ។
១៧ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលស្ដេច
បានបញ្ចប់នូវការនិយាយពាក្យទាំងនេះហើយ នោះប្រជាជន
បានមក ប្រជុំគ្នាទាំងអស់ ហើយពួកគេបានយកដាវរបស់គេ
និងគ្រឿងសស្ត្រាវុធទាំងអស់ដែលប្រើសំរាប់ការខ្ចាយឈាម
មនុស្ស ហើយគេបាន [ក]កប់វត្ថុទាំងនោះយ៉ាងជ្រៅទៅក្នុងដី ។
១៨ ហើយគេធ្វើការនេះ ដើម្បីទុកជាទីបន្ទាល់ចំពោះព្រះ
និងចំពោះមនុស្សដែរថា គេនឹង[ក]ពុំប្រើគ្រឿងសស្ត្រាវុធ សំរាប់ការ
ខ្ចាយ ឈាមមនុស្សទៀតទេ; ហើយគេធ្វើការនេះ ដើម្បីបញ្ជាក់
ហើយធ្វើ[ខ]សេចក្ដីសញ្ញាជាមួយនឹងព្រះថា ពួកគេនឹង[គ]លះបង់
ជីវិតគេផ្ទាល់ ជាជាងកំចាយឈាមបងប្អូនគេ; ហើយគេនឹងឲ្យ
ទៅបងប្អូនគេ ជាជាងយកពីបងប្អូនគេវិញ; ហើយគេនឹងធ្វើ
ការយ៉ាងសំបើម ដោយដៃ គេផ្ទាល់ ជាជាងចំណាយពេល
ដោយខ្ជិលច្រអូស ។
១៩ ម្ល៉ោះហើយ យើងឃើញថា កាលពួកលេមិនទាំងនេះត្រូវ
បាននាំមកឲ្យជឿ ហើយស្គាល់ការពិត នោះពួកគេមានចិត្ត

១០ *ខ* ស.ប. ទោស.
១១ *ក* អេសាយ ៥៣:៤–៦.
១៣ *ក* វិវរ. ១:៥.
១៤ *ក* ស.ប. ព្រលឹង — តម្លៃនៃព្រលឹង
ទាំងឡាយ.
*ខ* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
១៦ *ក* អាលម៉ា ៤០:១១–១៥.
១៧ *ក* ហេលេ. ១៥:៩.
១៨ *ក* អាលម៉ា ៥៣:១១.
*ខ* ស.ប. សេចក្ដីសញ្ញា.
*គ* ស.ប. បូជា, យញ្ញបូជា.

[ក]រឹងប៉ឹង ហើយសុខចិត្តស៊ូទ្រាំដល់ស្លាប់ ជាជាងប្រព្រឹត្តអំពើបាប; ម៉្លោះហើយ យើងឃើញថា គេកប់គ្រឿងសស្ត្រាវុធនៃសេចក្ដីសុខសាន្ត របស់គេ ឬគេកប់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ដើម្បីសេចក្ដីសុខសាន្ត ។

២០ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនដែលជាបងប្អូនគេ បានរៀបចំធ្វើសង្គ្រាម ហើយបានលើកទ័ពឡើងមកឯដែនដីនីហ្វៃ ដោយមានគោលបំណងមកបំផ្លាញស្ដេចចោល ហើយដើម្បីដាក់អ្នកផ្សេងជំនួសទ្រង់ ហើយព្រមទាំងបំផ្លាញប្រជាជន អាន់ទី-នីហ្វៃ-លីហៃ ចេញពីដែនដី ។

២១ ឥឡូវនេះ កាលប្រជាជនបានឃើញថា ពួកគេកំពុងតែមកទាស់នឹងខ្លួនដូច្នោះ ពួកគេបានចេញទៅជួបគេ ហើយ[ក]បានក្រាបទៅ លើដីនៅខាងមុខគេ ហើយបានចាប់ផ្ដើមអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់; ម៉្លោះហើយ ពួកគេនៅក្នុងសភាពបែបនេះ ក្នុងកាល ពួកលេមិនចាប់ផ្ដើមវាយសំរុកមកលើពួកគេ ហើយបានចាប់ផ្ដើមសម្លាប់ពួកគេចោលដោយដាវ ។

២២ ម៉្លោះហើយ ដោយពុំជួបនឹងការប្រឆាំងតបវិញ នោះគេបានសម្លាប់ពួកគេអស់ចំនួនមួយពាន់ប្រាំនាក់; ហើយយើងដឹងថាពួកគេបានទទួលព្រះពរ ព្រោះគេបានទៅនៅជាមួយនឹងព្រះរបស់គេហើយ ។

២៣ ឥឡូវនេះ កាលពួកលេមិនបានឃើញថា បងប្អូនគេមិនរត់គេចចេញពីមុខដាវ ឬក៏ងាកទៅឆ្វេង ឬស្ដាំទេ តែពួកគេបានសុខ ចិត្តដួលចុះ ហើយ[ក]វិនាស ហើយសរសើរដំកើងដល់ព្រះវិញ ទោះជាស្ថិតនៅក្នុងការវិនាសដោយមុខដាវក៏ដោយ —

២៤ ឥឡូវនេះ កាលពួកលេមិនបានឃើញដូច្នោះ នោះពួកគេក៏ឈប់[ក]សម្លាប់គេទៅ; ហើយមានមនុស្សជាច្រើនដែលមានចិត្ត[ខ]ក្ដួល អាណិតមេត្តាដល់បងប្អូនគេ ដែលបានដួលនៅក្រោមផ្លែដាវ ព្រោះពួកគេបានប្រែចិត្តចំពោះការណ៍ទាំងឡាយដែលគេបានប្រព្រឹត្ត ។

២៥ ហើយហេតុការណ៍បានកើតឡើងថា គេបានបោះចោលគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ហើយគេមិនព្រមកាន់អាវុធ ទាំងនោះទៀតឡើយ ព្រោះគេមានការឈឺចាប់ចំពោះអំពើឃាតកម្មទាំងឡាយ ដែលគេបានប្រព្រឹត្ត; ហើយគេបានដួល ដូចបងប្អូន គេដែរ ដោយរំពឹងដល់សេចក្ដីមេត្តាករុណានៃពួកជន ដែលលើកដៃសម្លាប់គេចោល ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ចំនួនមនុស្សដែលរួបរួមជាមួយនឹងរាស្ត្រនៃព្រះ មានច្រើនជាងចំនួនដែលត្រូវស្លាប់; ហើយពួកអ្នកដែលត្រូវគេសម្លាប់ គឺជាមនុស្សសុចរិតហេតុដូច្នេះហើយ យើងគ្មានហេតុអ្វីដែលនាំឲ្យសង្ស័យថា ពួកគេពុំបាន[ក]សង្គ្រោះ នោះឡើយ ។

២៧ ហើយគ្មានមនុស្សទុច្ចរិតណាម្នាក់ត្រូវប្រហារនៅក្នុងចំណោមពួកនោះឡើយ; ប៉ុន្តែមានមនុស្សចំនួនជាងមួយពាន់នាក់ត្រូវបាន នាំមកឲ្យស្គាល់សេចក្ដីពិត; ម៉្លោះហើយ យើងឃើញថា ព្រះអម្ចាស់ទ្រង់បានប្រើ[ក]មធ្យោបាយច្រើនយ៉ាងដើម្បីធ្វើការសង្គ្រោះដល់ រាស្ត្រទ្រង់ ។

២៨ ឥឡូវនេះ កងពលលេមិនភាគច្រើន ដែលបានសម្លាប់បងប្អូនគេដ៏ច្រើននោះ គឺជាពួកសាសន៍អាម៉ាលេកៃ និង[ក]ពួកសាសន៍ អាមូឡុន ពួកនេះភាគច្រើន គឺជាអ្នកដើរតាមរបៀប[ខ]ពួកនីហ៊ូរ ។

២៩ ឥឡូវនេះ នៅក្នុងចំណោមពួកអ្នកដែលចូលរួបរួមនឹងរាស្ត្រនៃព្រះ [ក]គ្មានពួកសាសន៍អាម៉ាលេកៃ ឬពួកសាសន៍អាមូឡុន ទាល់តែសោះ ឬក៏គ្មានជនដែលដើរតាមរបៀបនីហ៊ូរឡើយ តែពួកគេ គឺជាកូនចៅពិតប្រាកដរបស់លេមិន និងលេមយ្អូល ។

៣០ ហើយដោយហេតុនេះ យើងអាចវែកញែកយ៉ាងច្បាស់ថាក្រោយពីប្រជាជនមួយ ដែលធ្លាប់[ក]បានបំភ្លឺដោយព្រះវិញ្ញាណនៃព្រះ ហើយដែលធ្លាប់មាន[ខ]ការចេះដឹងដ៏ច្រើន អំពីការណ៍ទាំងឡាយដែលទាក់ទងទៅនឹងសេចក្ដីសុចរិត តែបន្ទាប់មក[គ]បានធ្លាក់ទៅក្នុង អំពើបាប និងអំពើរំលង នោះពួកគេក្លាយទៅជារឹងរូសលើសលែងទៅទៀត ម៉្លោះហើយ ស្ថានភាពរបស់គេក្លាយទៅជា[ឃ]អាក្រក់ ជាជាងបើគេមិនដែលបានស្គាល់ការណ៍ទាំងនេះទៅវិញ ៕

១៩ *ក* ស.ប. សេចក្ដីជំនឿ.
២១ *ក* អាលម៉ា ២៧:៣.
២៣ *ក* អាលម៉ា ២៦:៣២.
២៤ *ក* អាលម៉ា ២៥:១.
*ខ* ស.ប. អាណិត.
២៦ *ក* វិវរ. ១៤:១៣.
២៧ *ក* អេសាយ ៥៥:៨–៩;
អាលម៉ា ៣៧:៦–៧.
២៨ *ក* អាលម៉ា ២១:៤.
*ខ* អាលម៉ា ១:១៥; ២:១, ២០.
២៩ *ក* អាលម៉ា ២៣:១៤.
៣០ *ក* ម៉ាថាយ ១២:៤៥.
*ខ* ហេព្រើរ ១០:២៦;
អាលម៉ា ៤៧:៣៦.
*គ* ២ នីហ្វៃ ៣១:១៤;
អាលម៉ា ៩:១៩.
ស.ប. សេចក្ដីក្បត់សាសនា.
*ឃ* ២ ពេត្រុស ២:២០–២១.

## ជំពូកទី ២៥

*អំពើឈ្នានីសទាំងឡាយនៃពួកលេមិនរាលដាលឡើង — ពូជរបស់ពួកសង្ឃនៃណូអេត្រូវវិនាស ដូចអ័ប៊ីណាដៃបានព្យាករមក — ពួកសាសន៍លេមិនជាច្រើនប្រែចិត្តជឿ ហើយចូលរួមជាមួយនឹងប្រជាជនអាន់ទៃ-នីហ្វៃ-លីហៃ — ពួកគេជឿដល់ព្រះគ្រីស្ទ ហើយ កាន់តាមក្រិត្យវិន័យលោកម៉ូសេ ។ ប្រមាណជាឆ្នាំ ៩០–៧៧ ម.គ.ស. ។*

ហើយមើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកលេមិនទាំងនោះកាន់តែខឹងខ្លាំងឡើង ពីព្រោះពួកគេបានសម្លាប់បងប្អូន ខ្លួន; ហេតុដូច្នេះហើយ ពួកគេបានសច្ចាថានឹងសងសឹកទៅលើពួកនីហ្វៃ; ហើយពួកគេមិនបានខំសម្លាប់ប្រជាជន[ក]អាន់ទៃ-នីហ្វៃ-លីហៃ ទៀតទេ នៅពេលនោះ ។

២ ប៉ុន្តែ ពួកគេបានយកពលទ័ពរបស់គេ ហើយបានចូលទៅឯព្រំប្រទល់ទាំងឡាយនៃដែនដីសារ៉ាហិមឡា ហើយបានវាយមកលើ ប្រជាជនដែលនៅលើដែនដីអាំម៉ូណៃហា ហើយ[ក]បានបំផ្លាញប្រជាជនទាំងនោះចោល ។

៣ ហើយបន្ទាប់ពីនោះមក ពួកគេបានប្រយុទ្ធជាច្រើនលើកជាមួយនឹងពួកនីហ្វៃ នៅក្នុងការប្រយុទ្ធទាំងនោះ ពួកគេត្រូវរុញច្រាន ហើយត្រូវស្លាប់ ។

៤ ហើយនៅក្នុងចំណោមពួកលេមិនដែលត្រូវស្លាប់នោះសឹងតែ[ក]ពូជទាំងអស់នៃអាមូឡុន និងបងប្អូនទ្រង់ ដែលជាពួកសង្ឃ នៃណូអេ ហើយពួកគេត្រូវបានសម្លាប់ចោលដោយដៃពួកនីហ្វៃ;

៥ ហើយចំនួនដែលនៅសល់ ដោយបានរត់ចូលទៅក្នុងទីរហោស្ថានខាងកើត ហើយដោយបានដណ្ដើមយកអានុភាព និងសិទ្ធិ អំណាចទៅលើពួកលេមិន នោះបានធ្វើឲ្យពួកលេមិនជាច្រើន[ក]ត្រូវវិនាស ដោយភ្លើង ដោយសារតែជំនឿរបស់គេ —

៦ ព្រោះ[ក]ពួកគេជាច្រើននាក់ ដោយបន្ទាប់ពីត្រូវរងការខូចខាតដ៏ធ្ងន់ធ្ងរ និងការវេទនាដ៏ច្រើន នោះបានចាប់ផ្ដើមរំជួលនឹកឃើញដល់[ខ]ពាក្យសំដីដែលអើរ៉ុន និងបងប្អូនលោកបានផ្សាយដល់ពួកគេនៅឯដែនដីគេ; ហេតុដូច្នេះហើយ ពួកគេបានចាប់ផ្ដើមឈប់ជឿដល់ [គ]សណ្ដាប់ទាំងឡាយ នៃពួកអយ្យកោខ្លួន ហើយជឿដល់ព្រះអម្ចាស់ ហើយជឿថា ទ្រង់បានប្រទានព្រះចេស្ដាដ៏ខ្លាំងក្លាដល់ពួកនីហ្វៃ; ម្ល៉ោះហើយ ទើបពួកគេជាច្រើនបានប្រែចិត្តជឿនៅក្នុងទីរហោស្ថាន ។

៧ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកត្រួតត្រាទាំងនេះដែលជាសំណល់នៃកូនចៅរបស់[ក]អាមូឡុន បានបញ្ជាឲ្យយកពួកគេទៅ[ខ]ប្រហារចោល មែនហើយ គឺអស់អ្នកណាដែលជឿដល់ការណ៍ទាំងនេះ ។

៨ ឥឡូវនេះ ទុក្ករកម្មនេះបានបណ្ដាលឲ្យបងប្អូនគេជាច្រើនចាក់រុកគ្នាឲ្យមានកំហឹង; ហើយក៏ចាប់ផ្ដើមមានការទាស់ទែងគ្នានៅក្នុងទីរហោស្ថាន; ហើយពួកលេមិនបានចាប់ផ្ដើម[ក]ដេញចាប់ពូជរបស់អាមូឡុន និងបងប្អូនទ្រង់ ហើយបានចាប់ផ្ដើមសម្លាប់ពួកនោះ ចោល; ហើយពួកគេបានរត់ភៀសខ្លួន ចូលទៅក្នុងទីរហោស្ថានខាងកើត ។

៩ ហើយមើលចុះ សព្វថ្ងៃពួកគេត្រូវពួកលេមិនដេញចាប់ ។ ម្ល៉ោះហើយ ពាក្យសំដីនៃអ័ប៊ីណាដៃត្រូវបានសំរេច ដែលលោកបាន និយាយអំពីពូជនៃពួកសង្ឃ ដែលបានបញ្ជាឲ្យលោកត្រូវរងទុក្ខដល់ស្លាប់ដោយភ្លើងនោះ ។

១០ ព្រោះលោកបាននិយាយទៅកាន់ពួកគេថា៖ អ្វីដែលអ្នក[ក]ធ្វើដល់ខ្ញុំ នឹងទៅជាគំរូអំពីអ្វីដែលនឹងកើតឡើងនៅថ្ងៃក្រោយ ។

១១ ហើយឥឡូវនេះ អ័ប៊ីណាដៃគឺជាមនុស្សមុនដំបូងបង្អស់ដែលត្រូវរងទុក្ខដល់[ក]ស្លាប់ដោយភ្លើង ដោយព្រោះជំនឿរបស់លោក ដល់ព្រះ; ឥឡូវនេះ នេះហើយដែលមានន័យថាមនុស្សជាច្រើននឹងត្រូវរងទុក្ខដល់ស្លាប់ដោយភ្លើង ដូចដែលលោកបានរងទុក្ខដូច្នោះ ដែរ ។

១២ ហើយលោកបាននិយាយទៅកាន់ពួកសង្ឃរបស់ណូអេថាពូជរបស់គេនឹងធ្វើឲ្យមនុស្សជាច្រើន ត្រូវគេយកទៅប្រហារជីវិតចោល ដូចរបៀបដែលលោកត្រូវស្លាប់ដូច្នោះដែរ ហើយថាពួកគេនឹងត្រូវខ្ចាត់ខ្ចាយទៅគ្រប់ទិសទី ហើយត្រូវស្លាប់ គឺបីដូចជាសត្វ ចៀមដែលគ្មានអ្នកគង្វាល ត្រូវរុញច្រាន ហើយត្រូវស្លាប់ដោយសត្វសាហាវទាំងឡាយ; ហើយឥឡូវនេះ មើលចុះ

**២៥** ១*ក* ស.ប. អាន់ទៃ-នីហ្វៃ-លីហៃ.
២ *ក* អាលម៉ា ៨:១៦; ១៦:៩.
៤ *ក* ម៉ូសាយ ២៣:៣៥.
៥ *ក* ម៉ូសាយ ១៧:១៥.
៦ *ក* ក.ន. ពួកសាសន៍លេមិន.
*ខ* អាលម៉ា ២១:៩.
*គ* អាលម៉ា ២៦:២៤.
៧ *ក* អាលម៉ា ២១:៣; ២៤:១, ២៨–៣០.
*ខ* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
៨ *ក* ម៉ូសាយ ១៧:១៨.
១០ *ក* ម៉ូសាយ ១៣:១០.
១១ *ក* ម៉ូសាយ ១៧:១៣.

ពាក្យទាំងនេះត្រូវ បានបញ្ជាក់ ព្រោះពួកគេត្រូវរុញច្រានដោយ
ពួកលេមិន ហើយត្រូវគេដេញចាប់ ហើយពួកគេត្រូវគេវាយ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិន
បានឃើញថា ពួកគេមិនអាចយកឈ្នះលើពួកនីហ្វៃបានទេ នោះគេ
ក៏ត្រឡប់ទៅកាន់ដែនដីគេវិញ; ហើយពួកគេជាច្រើននាក់ បាន
មកអាស្រ័យនៅឯដែនដីរបស់អ៊ីសម៉ាអែល និងដែនដីនីហ្វៃ
ហើយបាន ចូលរួមជាមួយនឹងរាស្ត្រនៃព្រះ ដែលជាប្រជាជន
[ក]អាន់តៃ-នីហ្វៃ-លីហៃ ។
១៤ ហើយពួកគេក៏បាន[ក]កប់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាម
របស់គេផង ដូចដែលបងប្អូនគេបានធ្វើ ហើយពួកគេបាន
ចាប់ផ្ដើមក្លាយ ទៅជាមនុស្សមួយដ៏សុចរិត; ហើយពួកគេបាន
ដើរតាមផ្លូវទាំងឡាយនៃព្រះអម្ចាស់ ហើយបានប្រតិបត្តិ
តាមព្រះបញ្ញត្តិ និងក្រិត្យក្រមទាំង ឡាយរបស់ទ្រង់ ។
១៥ មែនហើយ ហើយពួកគេបានកាន់តាមក្រិត្យវិន័យលោកម៉ូសេ;
ត្បិតជាការចាំបាច់ថា ពួកគេត្រូវកាន់តាមក្រិត្យវិន័យលោក
ម៉ូសេសិន ត្បិតក្រិត្យវិន័យនោះពុំទាន់បានបំពេញនៅឡើយទេ។
តែទោះជាមាន[ក]ក្រិត្យវិន័យលោកម៉ូសេក៏ដោយ គង់តែពួកគេ
បាន ទន្ទឹងចាំ ដល់ការយាងមកនៃព្រះ[ខ]គ្រីស្ទដែរ ដោយ
ចាត់ទុកថា ក្រិត្យវិន័យលោកម៉ូសេជាគំរូអំពីការយាងមក
របស់ទ្រង់ ហើយជឿថា ពួកគេត្រូវកាន់តាមការប្រព្រឹត្ត
[គ]ខាងក្រៅទាំងនេះ រហូតដល់ពេលដែលទ្រង់នឹងសម្ដែងរូបអង្គ
ទ្រង់ដល់ពួកគេ ។
១៦ ឥឡូវនេះ ពួកគេពុំបានគិតស្មានថា [ក]សេចក្ដីសង្គ្រោះបាន
មកដោយសារ[ខ]ក្រិត្យវិន័យលោកម៉ូសេនោះទេ; ប៉ុន្តែ
ក្រិត្យវិន័យលោក ម៉ូសេបានជួយពង្រឹងសេចក្ដីជំនឿរបស់គេក្នុង
ព្រះគ្រីស្ទ; ម្ល៉ោះហើយ ទើបពួកគេមាន[គ]សេចក្ដីសង្ឃឹមមួយ
តាមរយៈសេចក្ដីជំនឿ ដល់សេច ក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច
ដោយអាងទៅលើវិញ្ញាណនៃការព្យាករណ៍ ដែលបាននិយាយ
អំពីការណ៍ទាំងនេះ ដែលនឹងកើត ឡើង ។
១៧ ហើយឥឡូវនេះ មើលចុះ អាំម៉ូន និងអើរ៉ុន និងអោមណើរ
និងហិមណៃ ហើយបងប្អូនគេបានត្រេកអរីករាយជាអតិបរមា
ចំពោះការជោគជ័យដែលគេមានទៅលើពួកលេមិន ដោយ
បានឃើញថា ព្រះអម្ចាស់ទ្រង់បានប្រទានដល់គេ ស្របតាម
[ក]ការអធិស្ឋាន ទាំងឡាយរបស់គេ ហើយថា ទ្រង់បាន
បញ្ជាក់ព្រះបន្ទូលរបស់ទ្រង់ចំពោះគេនៅគ្រប់ករណីទាំងអស់ ៕

## ជំពូកទី ២៦

*អាំម៉ូនសរសើរដំកើងក្នុងព្រះអម្ចាស់ — ពួកស្មោះត្រង់ត្រូវបានចំរើនកម្លាំងដោយព្រះអម្ចាស់ ហើយត្រូវបានប្រទានការចេះដឹង — ដោយសារសេចក្ដីជំនឿ មនុស្សលោកអាចនាំផនរាប់ពាន់នាក់ទៅកាន់ការប្រែចិត្ត — ព្រះទ្រង់មានគ្រប់ព្រះចេស្ដា ហើយជ្រាប គ្រប់ការណ៍ទាំងអស់ ។ ប្រមាណជាឆ្នាំ ៩០–៧៧ ម.គ.ស. ។*

ហើយឥឡូវនេះ នេះគឺជាពាក្យសំដីនៃអាំម៉ូន ដែលបាន
វាចាទៅបងប្អូនលោកដូច្នេះថា៖ ឱប្អូនទាំងឡាយរបស់ខ្ញុំ
និងបងប្អូនទាំង ឡាយរបស់ខ្ញុំអើយ មើលចុះ ខ្ញុំសូមនិយាយ
ទៅកាន់បងប្អូនថា យើងមានហេតុដ៏ធំនឹងអររីករាយ; ព្រោះ
កាលពីយើងចាប់ផ្ដើម ចេញពីដែនដីសារ៉ាហិមឡាមក តើយើង
បានគិតស្មានថា ព្រះទ្រង់នឹងប្រទានដល់យើងនូវព្រះពរទាំង
ឡាយដ៏មហិមាបែបនេះឬ ?
២ ហើយឥឡូវនេះ ខ្ញុំសូមសួរថា តើព្រះពរទាំងឡាយ
ដ៏មហិមា ដែលទ្រង់បានប្រទានដល់យើងគឺជាអ្វីទៅ ? តើអ្នក
រាល់គ្នាអាច ប្រាប់ខ្ញុំបានទេ ?
៣ មើលចុះ ខ្ញុំសូមឆ្លើយជំនួសអ្នកចុះ; ត្បិតបងប្អូនរបស់យើង
ដែលជាពួកសាសន៍លេមិន ធ្លាប់នៅក្នុងភាពងងឹត មែនហើយ
គឺនៅក្នុងជ្រោះដ៏ងងឹតបំផុត ប៉ុន្តែមើលចុះ តើពួកគេ[ក]ប៉ុន្មាននាក់
ដែលបាននាំមកឲ្យឃើញពន្លឺដ៏អស្ចារ្យនៃព្រះ! នេះហើយគឺជា
ព្រះពរ ដែលបានប្រទានដល់យើង ដែលថាយើងបានធ្វើជា
[ខ]គ្រឿងឧបករណ៍ នៅក្នុងព្រះហស្តនៃព្រះ ដើម្បីនាំមកនូវ
កិច្ចការដ៏មហិមានេះ ។
៤ មើលចុះ ពួកគេ[ក]រាប់ពាន់នាក់បានអររីករាយ ហើយត្រូវ
បាននាំចូលក្នុងក្រោលនៃព្រះ ។

១៣ *ក* អាលម៉ា ២៣:១៦–១៧.
១៤ *ក* អាលម៉ា ២៤:១៥; ២៦:៣២.
១៥ *ក* យ៉ាកុប ៤:៥; យ៉ារ៉ុម ១:១១.
ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* ម៉ូសាយ ៣:១៤–១៥; ១៦:១៤.
*គ* ម៉ូសាយ ១៣:២៩–៣២.
១៦ *ក* ម៉ូសាយ ១២:៣១–៣៧;
១៣:២៧–៣៣.
*ខ* ២ នីហ្វៃ ១១:៤.
*គ* ១ ថែស្សា. ៥:៨–៩.
១៧ *ក* អាលម៉ា ១៧:៩.
**២៦** ១ *ក* ម៉ូសាយ ២៨:៩;
អាលម៉ា ១៧:៦–១១.
៣ *ក* អាលម៉ា ២៣:៨–១៣.
*ខ* ២ កូរិន. ៤:៥;
ម៉ូសាយ ២៣:១០.
៤ *ក* អាលម៉ា ២៣:៥.

៥ មើលចុះ [ក]ចំការទុំហើយ ហើយអ្នករាល់គ្នាមានពរហើយ
ព្រោះអ្នករាល់គ្នាបានលូក[ខ]កណ្ដៀវ ហើយបានច្រូតកាត់ដោយ
សមត្ថភាពរបស់ខ្លួន មែនហើយ គឺពេញមួយថ្ងៃ អ្នករាល់គ្នា
បានធ្វើការ; ហើយមើលចុះ កណ្ដាប់ស្រូវទាំងឡាយដែលអ្នក
[គ]ច្រូតបាន! ហើយកណ្ដាប់ស្រូវទាំងនេះ នឹងត្រូវបានប្រមូលយក
ទៅទុកក្នុងជង្រុក ដើម្បីកុំឲ្យវាខាតបង់ ។
៦ មែនហើយ វានឹងមិនត្រូវបក់បោកដោយខ្យល់ព្យុះ នៅថ្ងៃ
ចុងក្រោយបង្អស់ឡើយ; មែនហើយ វាក៏នឹងពុំត្រូវគួច ដោយ
ខ្យល់ គំនួចឡើយ; តែកាលណា[ក]ខ្យល់ព្យុះមកដល់ វានឹងបាន
ប្រមូលគ្នាមកក្នុងកន្លែងរបស់វា ដើម្បីកុំឲ្យខ្យល់ព្យុះ
អាចបក់ទម្លុះទៅដល់គេ; មែនហើយ ពួកគេក៏នឹងពុំត្រូវ
គួចដោយខ្យល់កំណាចយកទៅកន្លែងណា ដែលខ្មាំងសត្រូវ
ចង់នាំពួកគេយកទៅនោះដែរ ។
៧ ប៉ុន្ដែមើលចុះ ពួកគេស្ថិតនៅក្នុងព្រះហស្តនៃព្រះ
អម្ចាស់នៃរដូវ[ក]ច្រូតកាត់ ហើយពួកគេជារបស់ផងទ្រង់; ហើយ
ទ្រង់នឹង[ខ]លើក គេឡើង នៅថ្ងៃចុងក្រោយបង្អស់ ។
៨ សូមឲ្យព្រះនាមនៃព្រះរបស់យើងប្រកបដោយព្រះពរ;
ចូរយើង[ក]ច្រៀងសរសើរដល់ទ្រង់ មែនហើយ ចូរយើង
[ខ]ថ្លែងអំណរគុណ ដល់ព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ព្រោះទ្រង់ធ្វើ
ការសុចរិតដរាបតទៅ ។
៩ ព្រោះបើសិនជាយើងមិនបានឡើងមកពីដែនដីសារ៉ាហិមឡាទេ
នោះបងប្អូនជាទីស្រឡាញ់របស់យើងទាំងនេះ គឺជាអ្នកដែល
ស្រឡាញ់យើងជាខ្លាំងនោះ ច្បាស់ជានៅតែត្រូវញាំញី
ដោយ[ក]សម្អប់យើង មែនហើយ ហើយពួកគេក៏ច្បាស់ជានៅជាជន
ចម្លែក ចំពោះព្រះដែរ ។
១០ ហើយហេតុការណ៍បានកើតឡើងថា កាលអាំម៉ូនបាន
ពោលពាក្យទាំងនេះហើយ នោះអើរ៉ុន ដែលជាប្អូនលោកបាន
បន្ទោស លោកថា៖ អាំម៉ូន ខ្ញុំខ្លាចតែសេចក្ដីអំណររបស់បង
នាំឲ្យបងអួតហួសហេតុទេដឹង ។
១១ តែអាំម៉ូនបានឆ្លើយតបថា៖ ខ្ញុំមិន[ក]អួតក្នុងកម្លាំងខ្ញុំផ្ទាល់
ឬក៏ក្នុងប្រាជ្ញាខ្ញុំផ្ទាល់នោះទេ ប៉ុន្ដែមើលចុះ សេចក្ដីអំណររបស់
ខ្ញុំបាន ពោរពេញហើយ មែនហើយ បេះដូងខ្ញុំហូរហៀរ
ទៅដោយ[ខ]សេចក្ដីអំណរ ហើយខ្ញុំនឹងអររីករាយ នៅក្នុងព្រះ
របស់ខ្ញុំវិញ ។
១២ មែនហើយ ខ្ញុំដឹងថា ខ្ញុំគ្មានន័យអ្វីទាំងអស់; រីឯ
ចំពោះកម្លាំងរបស់ខ្ញុំវិញ ខ្ញុំទន់ខ្សោយ; ហេតុដូច្នេះហើយ
ខ្ញុំនឹងពុំ[ក]អួតពីខ្លួនខ្ញុំ ឡើយ តែខ្ញុំនឹងអួតពីព្រះរបស់ខ្ញុំវិញ ត្បិតនៅ
ក្នុង[ខ]កម្លាំងរបស់ទ្រង់ ខ្ញុំអាចធ្វើគ្រប់ការណ៍ទាំងអស់; មែនហើយ
មើលចុះ មានអព្ភូតហេតុ ដ៏អស្ចារ្យជាច្រើន ដែលយើងបាននាំ
មកលើដែនដីនេះ ដោយហេតុនេះហើយ ទើបយើងសរសើរ
ដល់ព្រះនាម ទ្រង់ដរាបតទៅ ។
១៣ មើលចុះ តើបងប្អូនយើងប៉ុន្មានពាន់នាក់ ដែលទ្រង់
បានស្រាយឲ្យរួចពី[ក]ការឈឺចាប់នៃស្ថាននរក; ហើយពួកគេត្រូវបាន
នាំឲ្យ [ខ]ច្រៀងនូវសេចក្ដីស្រឡាញ់ដែលប្រោសលោះ
ហើយនេះក៏ដោយព្រោះព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ ដែល
នៅក្នុងយើង ហេតុដូច្នេះ ហើយ តើយើងមិនមានហេតុដ៏ធំ
នឹងអររីករាយទេឬអី ?
១៤ មែនហើយ យើងមានហេតុ ដើម្បីសរសើរដំកើង
ទ្រង់ដរាបតទៅ ព្រោះព្រះអង្គជាព្រះដ៏ខ្ពស់បំផុត ហើយ
បានស្រាយបងប្អូន យើងឲ្យរួចពី[ក]ច្រវាក់ទាំងឡាយនៃស្ថាននរក ។
១៥ មែនហើយ ពួកគេត្រូវបានហ៊ុំព័ទ្ធជុំវិញ ដោយសេច
ក្ដីងងឹត និងសេចក្ដីបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច; ប៉ុន្ដែមើលចុះ
ទ្រង់បាន នាំពួកគេចូលទៅក្នុង[ក]ពន្លឺដ៏អស់កល្បជានិច្ចរបស់ទ្រង់
មែនហើយ ទៅក្នុងសេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ច; ហើយ
ពួកគេត្រូវបាន ហ៊ុំព័ទ្ធជុំវិញ ដោយសេចក្ដីស្រឡាញ់របស់ទ្រង់
ដ៏ឥតប្រៀបផ្ទឹមបាន; មែនហើយ យើងជាគ្រឿងឧបករណ៍ នៅ
ក្នុងព្រះហស្តទ្រង់ ដែលធ្វើកិច្ចការដ៏មហិមា និងអស្ចារ្យនេះ ។
១៦ ហេតុដូច្នេះហើយ ចូរយើង[ក]អួត មែនហើយ យើងអួត[ខ]ក្នុង

៥ *ក* យ៉ូហាន ៤:៣៥–៣៧;
គ. និង ស. ៤:៤.
*ខ* យ៉ូអែល ៣:១៣.
*គ* គ. និង ស. ៣៣:៧–១១; ៧៥:២, ៥.
៦ *ក* ហេលេ. ៥:១២;
៣ នីហ្វៃ ១៤:២៤–២៧.
៧ *ក* ស.ប. ចំរូត.
*ខ* ម៉ូសាយ ២៣:២២;
អាលម៉ា ៣៦:២៨.
៨ *ក* គ. និង ស. ២៥:១២.
*ខ* ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
៩ *ក* ម៉ូសាយ ២៨:១–២.
១១ *ក* ២ កូរិន. ៧:១៤.
*ខ* គ. និង ស. ១៨:១៤–១៦.
ស.ប. សេចក្ដីអំណរ.
១២ *ក* យេរេ. ៩:២៤; អាលម៉ា ២៩:៩.
*ខ* ទំនុក. ១៨:៣២–៤០;
ភីលីព ៤:១៣; ១ នីហ្វៃ ១៧:៣.
១៣ *ក* ស.ប. ស្ថាននរក.
*ខ* អាលម៉ា ៥:២៦.
១៤ *ក* អាលម៉ា ១២:១១.
១៥ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
១៦ *ក* រ៉ូម ១៥:១៧; ១ កូរិន. ១:៣១.
*ខ* ២ កូរិន. ១០:១៥–១៨;
គ. និង ស. ៧៦:៦១.

ព្រះអម្ចាស់; មែនហើយ យើងនឹងអររីករាយ ព្រោះសេចក្ដីអំណរ របស់យើងបានពោរពេញហើយ; មែនហើយ យើងនឹងសរសើរដំកើងដល់ព្រះរបស់យើងរហូតតទៅ ។ មើលចុះ តើនរណាអាចអួត ហួសពេក នៅក្នុងព្រះអម្ចាស់? មែនហើយ តើនរណាអាចនិយាយច្រើនពេក អំពីព្រះចេស្ដាដ៏មហិមារបស់ទ្រង់ និងអំពី[ក]សេចក្ដីមេត្តា ករុណារបស់ទ្រង់ និងអំពីសេចក្ដីអត់ធ្មត់របស់ទ្រង់ ចំពោះកូនចៅមនុស្ស? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ខ្ញុំមិនអាចនិយាយបាន ទោះជា មួយផ្នែកតូចបំផុតដែលខ្ញុំចាប់អារម្មណ៍ផង ។

១៧ តើនរណាអាចគិតស្មានថា ព្រះរបស់យើងមានសេចក្ដីមេត្តាករុណាដល់ម្ល៉េះ រហូតដល់បានទាញយើងចេញពីស្ថានភាពរបស់យើង ដែលគួរឲ្យស្ញែងខ្លាច ពេញទៅដោយបាប ហើយកខ្វក់បែបនេះ?

១៨ មើលចុះ យើងបានចេញទៅនៅក្នុងកំហឹង ដោយការគំរាមកំហែងដ៏ខ្លាំងថានឹង[ក]បំផ្លាញសាសនាចក្ររបស់ទ្រង់ចោល ។

១៩ ឱពេលនោះ ហេតុអ្វីបានជាទ្រង់មិនដាក់ទោសឲ្យយើងធ្លាក់ទៅក្នុងការបំផ្លិចបំផ្លាញដ៏ស្ញែងខ្លាច មែនហើយ ហេតុអ្វីបានជា ទ្រង់មិនទុកឲ្យដាវនៃសេចក្ដីយុត្តិធម៌ធ្លាក់មកលើយើង ហើយពិន័យទោសយើងឲ្យអស់សង្ឃឹមរហូតតទៅ?

២០ ឱព្រលឹងខ្ញុំអើយ ស្ទើរតែរត់គេចទៅ នៅពេលគិតដល់ការណ៍នេះ។ មើលចុះ ទ្រង់ពុំបានអនុវត្តសេចក្ដីជំនុំជំរះរបស់ទ្រង់ មកលើយើងទេ តែនៅក្នុងសេចក្ដីមេត្តាករុណាដ៏មហិមារបស់ទ្រង់ នោះទ្រង់បាននាំយើងឆ្លង[ក]កាត់ជង្ហុកនៃសេចក្ដីស្លាប់ និងសេចក្ដី វេទនាដ៏អស់កល្បជានិច្ច គឺរហូតដល់សេចក្ដីសង្គ្រោះដល់ព្រលឹងរបស់យើងផង ។

២១ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ តើមាន[ក]មនុស្សខាងសាច់ឈាមណាមួយ ដែល[ខ]ស្គាល់ការណ៍ទាំងនេះ? ខ្ញុំសូមប្រាប់អ្នកថា គ្មានអ្នកណាម្នាក់ដឹងការណ៍ទាំងនេះទេ លើកលែងតែអ្នកដែលបានប្រែចិត្តប៉ុណ្ណោះ ។

២២ មែនហើយ អ្នកណាដែលបាន[ក]ប្រែចិត្ត ហើយអនុវត្ត [ខ]សេចក្ដីជំនឿ ហើយបញ្ចេញមកនូវកិច្ចការល្អៗ ហើយអធិស្ឋានរហូត ដោយឥតឈប់ឈរ — អ្នកនោះហើយដែលនឹងត្រូវបានប្រទានឲ្យស្គាល់នូវ[គ]សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ; មែនហើយ អ្នកនោះ ហើយដែលនឹងត្រូវបានប្រទានឲ្យបើកសម្ដែងការណ៍ទាំងឡាយ ដែលមិនបានដែលបានបើកសម្ដែងពីមុនមក; មែនហើយ អ្នកនោះ ហើយដែលនឹងត្រូវបានប្រទានឲ្យនាំមនុស្សរាប់ពាន់នាក់ទៅកាន់ការប្រែចិត្ត ដូចជាបានប្រទានដល់យើងឲ្យនាំបងប្អូនយើងទាំង នេះមក ទៅកាន់ការប្រែចិត្តដូច្នោះដែរ ។

២៣ ឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ តើអ្នករាល់គ្នាចាំទេថា យើងបាននិយាយទៅបងប្អូនយើងនៅឯដែនដីសារ៉ាហិមឡាថា យើងនឹងឡើងទៅដែនដីនីហ្វៃ ដើម្បីទៅផ្សាយប្រាប់បងប្អូនយើង គឺពួកសាសន៍លេមិន ហើយពួកគេបានសើចចំអក ដល់យើង?

២៤ ព្រោះពួកគេបាននិយាយមកយើងថា៖ តើអ្នករាល់គ្នាគិតស្មានថា អ្នករាល់គ្នាអាចនាំពួកលេមិនឲ្យស្គាល់សេចក្ដីពិតបានឬ? តើអ្នករាល់គ្នាគិតស្មានថា អ្នករាល់គ្នាអាចបរិវត្តពួកលេមិនអំពី[ក]សណ្ដាប់ខុសឆ្គងទាំងឡាយ នៃពួកអយ្យកោរបស់គេឬ បើពួកគេជា [ខ]មនុស្សរឹងរូសបែបនេះ; ឯចិត្តគេសប្បាយនឹងការខ្ចាយឈាម; ជីវិតគេបានចំណាយក្នុងការធ្វើអំពើទុច្ចរិតដ៏អាក្រក់បំផុត; ផ្លូវរបស់គេ គឺជាផ្លូវនៃអ្នកល្មើស ចាប់តាំងពីដើមមក? ឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ អ្នករាល់គ្នាចាំទេ នេះគឺជាពាក្យសំដីរបស់ ពួកគេ ។

២៥ ហើយគេថែមទាំងបាននិយាយថា៖ ចូរយើងលើកអាវុធប្រឆាំងនឹងពួកគេ ដើម្បីយើងអាចបំផ្លាញគេចោល និងអំពើទុច្ចរិត របស់គេឲ្យអស់ពីដែនដី បើពុំនោះសោតទេ ពួកគេនឹងមានជ័យជំនះលើយើង ហើយនឹងបំផ្លាញយើងបង់ ។

២៦ ប៉ុន្តែមើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ យើងបានចូលមកក្នុងទីរហោស្ថាន ពុំមែនមានបំណងចង់បំផ្លាញបងប្អូនយើងទេ តែមានបំណងក្រែងយើងអាចសង្គ្រោះព្រលឹងពួកគេបានខ្លះ ។

២៧ ឥឡូវនេះ កាលណាយើងនឿយណាយក្នុងចិត្ត ហើយយើងសឹងតែត្រឡប់ទៅវិញ មើលចុះ ព្រះអម្ចាស់ ទ្រង់បាន[ក]កំសាន្តចិត្ត យើង ហើយមានព្រះបន្ទូលថា៖ ចូរទៅក្នុងចំណោមបងប្អូនអ្នក គឺពួកសាសន៍លេមិន ហើយចូរទ្រាំដោយ

១៦ *ក* ទំនុក. ៣៦:៥–៦.
១៨ *ក* ម៉ូសាយ ២៧:៨–១០.
២០ *ក* ២ នីហ្វៃ ១:១៣; ហេលេ. ៣:២៩–៣០.
២១ *ក* ស.ប. មនុស្សខាងសាច់ឈាម.
*ខ* ១ កូរិន. ២:៩–១៦; យ៉ាកុប ៤:៨.
២២ *ក* អាលម៉ា ៣៦:៤–៥. ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. សេចក្ដីជំនឿ.
*គ* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
២៤ *ក* ម៉ូសាយ ១០:១១–១៧.
*ខ* ម៉ូសាយ ១៣:២៩.
២៧ *ក* អាលម៉ា ១៧:៩–១១.

[ខ]សេចក្ដីអត់ធ្មត់ នូវការ [ក]ទុក្ខវេទនាទាំងឡាយរបស់អ្នកចុះ ហើយយើងនឹងប្រទានដល់អ្នកនូវជ័យជំនះ ។

២៨ ហើយឥឡូវនេះ មើលចុះ យើងបានមកដល់ ហើយបានចូលក្នុងចំណោមពួកគេ; ហើយយើងបានអត់ធ្មត់ក្នុងការរងទុក្ខទាំងឡាយរបស់យើង ហើយយើងបានរងទុក្ខនូវគ្រប់ការខ្វះខាត; មែនហើយ យើងបានធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយ ដោយពឹង ផ្អែកទៅលើសេចក្ដីមេត្តាករុណានៃមនុស្សលោក — ពុំគ្រាន់តែពឹងផ្អែកទៅលើសេចក្ដីមេត្តាករុណា នៃមនុស្សលោកប៉ុណ្ណោះទេ តែពឹងផ្អែកទៅលើសេចក្ដីមេត្តាករុណារបស់ព្រះផង ។

២៩ ហើយយើងបានចូលទៅក្នុងផ្ទះរបស់ពួកគេ ហើយបានបង្រៀនពួកគេ ហើយយើងបានបង្រៀនពួកគេ នៅតាមថ្នល់ទាំងឡាយ របស់គេ; មែនហើយ យើងបានបង្រៀនពួកគេនៅលើភ្នំទាំងឡាយរបស់គេ; ហើយយើងបានចូលទៅក្នុងវិហារបរិសុទ្ធទាំងឡាយ របស់គេ និងសាលាជំនុំទាំងឡាយរបស់គេ ហើយបានបង្រៀនពួកគេ; ហើយយើងត្រូវគេបណ្ដេញចេញ ហើយចំអកឡកឡឺយ ហើយស្ដោះដាក់ ហើយទះកំផ្លៀង; ហើយយើងត្រូវគេចោលថ្ម ហើយចាប់ចងដោយ ខ្សែដ៏មាំ ហើយដាក់ក្នុងគុក; ហើយតាម រយៈព្រះចេស្ដា និងប្រាជ្ញានៃព្រះ នោះយើងត្រូវបានដោះលែងវិញ ។

៣០ ហើយយើងបានរងទុក្ខនូវគ្រប់ការទុក្ខលំបាក និងគ្រប់ការណ៍ទាំងអស់ ដើម្បីយើងអាចទៅជាមាគ៌ា [ក]ក្នុងការសង្គ្រោះព្រលឹង ខ្លះ; ហើយយើងបានគិតស្មានថា សេចក្ដីអំណររបស់យើងនឹងបានពោរពេញ ប្រសិនបើយើងអាចទៅជាមាគ៌ា ក្នុងការសង្គ្រោះមនុស្ស បានខ្លះ ។

៣១ ឥឡូវនេះ មើលចុះ យើងអាចសម្លឹងមើលទៅមុខ ហើយឃើញផលទាំងឡាយនៃការងាររបស់យើង; ហើយតើវាតិចពេកឬ? ខ្ញុំសូមប្រាប់អ្នកថា ទេ [ក]វាច្រើនណាស់; មែនហើយ យើងអាចធ្វើជាសាក្សីអំពីចិត្តស្មោះស្ម័គ្ររបស់គេ មកពីសេចក្ដីស្រឡាញ់របស់គេ ដែលគេមានចំពោះបងប្អូនគេ និងចំពោះយើងផង ។

៣២ ត្បិតមើលចុះ ពួកគេបានសុខចិត្ត[ក]បូជាជីវិតរបស់គេ ជាជាងយកជីវិតរបស់ខ្មាំងសត្រូវគេវិញ; ហើយពួកគេបាន[ខ]កប់គ្រឿង សស្ត្រាវុធពិជ័យសង្គ្រាមរបស់គេយ៉ាងជ្រៅទៅក្នុងដី មកពីសេចក្ដីស្រឡាញ់របស់គេ ដែលគេមានចំពោះបងប្អូនគេ ។

៣៣ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា តើដែលមានសេចក្ដីស្រឡាញ់ដ៏ធំដល់ម្លេះឬនៅលើអស់ទាំងដែនដីនេះ ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ទេ មិនដែលមានទេ សូម្បីតែនៅក្នុងចំណោមពួកសាសន៍នីហ្វៃក៏ដោយ ។

៣៤ ត្បិតមើលចុះ ពួកគេនឹងលើកអាវុធប្រឆាំងនឹងបងប្អូនគេ; ពួកគេមិនទ្រាំទុកឲ្យខ្លួនត្រូវគេសម្លាប់ចោលឡើយ ។ ប៉ុន្តែមើលចុះ ពួកគេទាំងនេះប៉ុន្មាននាក់ដែលបានបូជាជីវិតរបស់ខ្លួន; ហើយយើងដឹងថា ពួកគេបានទៅជួបនឹងព្រះរបស់ពួកគេហើយ; មកពីសេចក្ដី ស្រឡាញ់របស់គេ និងការស្អប់បាបរបស់គេនោះ ។

៣៥ ឥឡូវនេះ តើយើងគ្មានហេតុនឹងអររីករាយទេឬអី ? មែនហើយ ខ្ញុំសូមប្រាប់អ្នកថា មិនដែលមានមនុស្សឯណាដែលមាន ហេតុដ៏ធំនឹងអររីករាយស្មើនឹងយើងនេះទេ ចាប់តាំងពីកំណើតលោកិយមកម្លេះ; មែនហើយ ហើយសេចក្ដីអំណររបស់ខ្ញុំត្រូវបានហួស [ក]ហេតុ រហូតដល់បានអួតនៅក្នុងព្រះរបស់ខ្ញុំ; ត្បិតទ្រង់មានគ្រប់ព្រះចេស្ដា គ្រប់ទាំងប្រាជ្ញា និងគ្រប់ទាំងយោបល់; ទ្រង់[ខ]ជ្រាបនូវគ្រប់ [គ]ការណ៍ទាំងអស់ ហើយទ្រង់ជាតួអង្គមួយដែលប្រកបដោយសេចក្ដីមេត្តាករុណា គឺដល់សេចក្ដីសង្គ្រោះ ដល់អស់អ្នកណាដែលនឹង ប្រែចិត្ត ហើយជឿដល់ព្រះនាមទ្រង់ ។

៣៦ ឥឡូវនេះ បើសិននេះជាការអួត ម្ល៉ោះហើយ ខ្ញុំនឹងអួត; ត្បិតនេះជាជីវិតខ្ញុំ និងពន្លឺរបស់ខ្ញុំ, សេចក្ដីអំណររបស់ខ្ញុំ និងសេច ក្ដីសង្គ្រោះរបស់ខ្ញុំ, និងសេចក្ដីប្រោសលោះរបស់ខ្ញុំ ពីការវេទនាដ៏អស់កល្បជានិច្ច ។ មែនហើយ សូមឲ្យព្រះនាមនៃព្រះរបស់ខ្ញុំបាន ប្រកបដោយព្រះពរ ដែលបានចងចាំប្រជាជននេះ ដែលជា[ក]មែកមួយនៃដើមអ៊ីស្រាអែល ហើយដែលបានវង្វេងចេញពីដើម នៅដែនដី ចម្លែកមួយ; មែនហើយ ខ្ញុំសូមប្រាប់ថា សូមឲ្យព្រះនាមនៃព្រះរបស់ខ្ញុំបានប្រកបដោយព្រះពរ ដែលបានចងចាំដល់យើង ដែលជាជន [ខ]ខ្ចាត់ព្រាត់នៅដែនដីចម្លែក ។

៣៧ ឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ យើងឃើញថា

២៧ *ខ* ស.ប. សេចក្ដីអត់ធន់.
*ក* អាលម៉ា ២០:២៩–៣០.
ស.ប. សេចក្ដីទំនាស់.
៣០ *ក* គ. និង ស. ១៨:១៥–១៦.
៣១ *ក* អាលម៉ា ២៣:៨–១៣.
៣២ *ក* អាលម៉ា ២៤:២០–២៤.
*ខ* អាលម៉ា ២៤:១៥.
៣៥ *ក* ស.ប. អំណាច.
*ខ* គ. និង ស. ៨៨:៤១.
*គ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៣៦ *ក* លោកុ. ៤៩:២២–២៦; យ៉ាកុប ២:២៥; ៥:២៥.
*ខ* យ៉ាកុប ៧:២៦.

ព្រះទ្រង់ចងចាំអស់ទាំងប្រជាជន ទោះជាគេនៅលើដែនដីណា
ក៏ដោយ; មែនហើយ ទ្រង់រាប់ចំនួនរាស្ត្រទ្រង់ ហើយព្រះហឫទ័យ
នៃសេចក្ដីមេត្តាករុណារបស់ទ្រង់គ្របដណ្ដប់ផែនដីទាំងមូល ។
ឥឡូវនេះ នេះគឺសេចក្ដីអំណររបស់ខ្ញុំ និងជាអំណរគុណដ៏ធំ
របស់ខ្ញុំ; មែនហើយ ខ្ញុំនឹងថ្លែងអំណរគុណដល់ព្រះរបស់
ខ្ញុំរហូតតទៅ ។ អាម៉ែន ៕

## ជំពូកទី ២៧

*ព្រះអម្ចាស់ទ្រង់បញ្ជាអាំម៉ូនឲ្យនាំប្រជាជនអាន់តៃ-នីហ្វៃ-លីហៃ ទៅដល់ទីសុខ — ពេលបានជួបនឹងអាលម៉ា អាំម៉ូនមានសេចក្ដីអំណរ ហួសកម្លាំងលោក — ពួកនីហ្វៃប្រគល់ដែនដីយេរុសុនឲ្យពួកអាន់តៃ-នីហ្វៃ-លីហៃ — ពួកគេត្រូវបានហៅថាជាប្រជាជនអាំម៉ូន ។ ប្រមាណជាឆ្នាំ ៩០–៧៧ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលពួកសាសន៍លេមិន
ទាំងប៉ុន្មាននោះ ដែលបានទៅធ្វើសង្គ្រាមទាស់នឹងពួកសាសន៍នីហ្វៃ
បានឃើញថា ក្រោយពីបានខំបំផ្លាញពួកគេជាច្រើនលើក តែ
ការណ៍នោះប្រែទៅជាឥតប្រយោជន៍ ក្នុងការខំស្វែងរកការ
បំផ្លិចបំផ្លាញ ដល់ពួកគេ ទើបពួកគេត្រឡប់មកដែនដីនីហ្វៃវិញ។
២ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍
អាម៉ាលេកៃក៏ខឹងជាខ្លាំង ដោយសារបរាជ័យរបស់ខ្លួន។ ហើយ
កាល គេបានឃើញថា គេមិនអាចសងសឹកនឹងពួកនីហ្វៃបានទេ
នោះពួកគេបានចាប់ផ្ដើមចាក់រុកឲ្យប្រជាជនខឹងនឹងបងប្អូនរបស់ខ្លួន
គឺប្រជាជនអាន់តៃ-នីហ្វៃ-លីហៃ; ហេតុដូច្នេះហើយ ពួកគេបាន
ចាប់ផ្ដើមបំផ្លាញពួកនោះចោលទៀត ។
៣ ឥឡូវនេះ ប្រជាជននេះក៏នៅតែមិនព្រមលើកអាវុធ
តាំងឡើយ ហើយពួកគេសុខចិត្តឲ្យពួកខ្មាំងសត្រូវរបស់ខ្លួន
សម្លាប់ចោល តាមចិត្ត ។
៤ ឥឡូវនេះ កាលអាំម៉ូន និងបងប្អូនលោក បានឃើញ
ការបំផ្លិចបំផ្លាញនៅក្នុងចំណោមពួកអ្នកដែលជាទីស្រឡាញ់
របស់គេ និងនៅក្នុងចំណោមពួកអ្នកដែលស្រឡាញ់គេ
យ៉ាងនេះ — ព្រោះពួកគេត្រូវបានចាត់ដូចជាទេវតា ដែល
ព្រះទ្រង់បានចាត់ឲ្យមក សង្គ្រោះគេ ឲ្យរួចពីការបំផ្លិចបំផ្លាញ
ដ៏អស់កល្បជានិច្ច — ហេតុដូច្នេះហើយ កាលអាំម៉ូន និង
បងប្អូនលោក បានឃើញការបំផ្លិចបំផ្លាញ ដ៏ធំបែបនេះ នោះ
ពួកគេមានចិត្តក្ដួលអាណិត ហើយគេក៏បានទូលទៅស្ដេចថា៖
៥ ចូរយើងប្រមូលរាស្ត្រនៃព្រះអម្ចាស់មក ហើយ
ចូរយើងចុះទៅដែនដីសារ៉ាហិមឡា ទៅរកបងប្អូនយើង ជាពួក
សាសន៍នីហ្វៃ ហើយគេចចេញពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ
របស់យើង ដើម្បីកុំឲ្យយើងត្រូវគេបំផ្លាញចោល ។
៦ តែស្ដេចមានបន្ទូលទៅពួកគេថា៖ មើលចុះ ពួកសាសន៍
នីហ្វៃនឹងបំផ្លាញយើង ដោយព្រោះអំពើឃាតកម្ម និងអំពើ
បាបជាច្រើន ដែលយើងធ្លាប់បានធ្វើទាស់នឹងគេ ។
៧ ហើយអាំម៉ូនបានទូលថា៖ ទូលបង្គំនឹងទៅសូមដល់ព្រះ
អម្ចាស់ ហើយបើសិនជាទ្រង់ប្រាប់ឲ្យយើងចុះទៅរកបងប្អូនយើង
តើទ្រង់នឹងយាងទៅឬទេ ?
៨ ហើយស្ដេចបានមានបន្ទូលទៅលោកថា៖ មែនហើយ បើសិន
ព្រះអម្ចាស់ទ្រង់ប្រាប់ឲ្យយើងទៅ នោះយើងនឹងចុះទៅរកបងប្អូន
យើង ហើយយើងនឹងធ្វើជាខ្ញុំបំរើរបស់គេ រហូត
ដល់ពេលយើងសងអំពើឃាតកម្ម និងអំពើបាបទាំងឡាយ
ដែលយើងបានប្រព្រឹត្ត ទៅលើពួកគេនោះអស់សិន ។
៩ តែអាំម៉ូនបានទូលទៅទ្រង់ថា៖ នេះគឺផ្ទុយនឹងច្បាប់របស់
បងប្អូនយើង ដែលបានតែងឡើង ដោយបិតារបស់ទូលបង្គំថា
មិនត្រូវ ឲ្យមានខ្ញុំបំរើនៅក្នុងចំណោមពួកគេឡើយ; ហេតុ
ដូច្នេះហើយ ចូរយើងចុះទៅទីនោះ ហើយពឹងផ្អែកទៅលើចិត្ត
មេត្តាករុណា របស់បងប្អូនយើងវិញ ។
១០ ប៉ុន្តែស្ដេចបានមានបន្ទូលទៅលោកថា៖ ចូរទៅសូមដល់
ព្រះអម្ចាស់ចុះ ហើយបើសិនជាទ្រង់ប្រាប់ឲ្យយើងទៅ នោះយើង
នឹងទៅ បើពុំនោះសោតទេ យើងនឹងវិនាសនៅក្នុងដែនដីនេះឯង។
១១ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូនបាន
ទៅសូមដល់ព្រះអម្ចាស់ ហើយព្រះអម្ចាស់ទ្រង់ មានព្រះបន្ទូល
មកលោកថា៖
១២ ចូរនាំប្រជាជននេះចេញពីដែនដីនេះទៅ ដើម្បីកុំឲ្យ
គេត្រូវវិនាស; ព្រោះអារក្សសាតាំងបានក្ដាប់យ៉ាងខ្ជាប់ នូវដួង
ចិត្តរបស់ ពួកសាសន៍អាម៉ាលេកៃ ដែលចាក់រុកពួកលេមិនឲ្យ
ខឹងនឹងបងប្អូនរបស់ខ្លួន ឲ្យសម្លាប់បងប្អូនរបស់ខ្លួន; ហេតុ
ដូច្នេះហើយ ចូរអ្នក ចេញពីដែនដីនេះទៅ; ហើយមានពរដល់
ប្រជារាស្ត្រនេះ ក្នុងជំនាន់នេះហើយ ព្រោះយើងនឹងរក្សាគេទុក។

៣៧ *ក* កិច្ចការ ១០:៣៤–៣៥;
២ នីហ្វៃ ២៦:៣៣.
**២៧** ២ *ក* អាលម៉ា ៤៣:១១.
*ខ* អាលម៉ា ២៥:១.
ស.ប. អាន់តៃ-នីហ្វៃ-លីហៃ.
៣ *ក* អាលម៉ា ២៤:២១–២៦.
៤ *ក* អាលម៉ា ២៤:៥.
៩ *ក* ម៉ូសាយ ២:១៣;
២៩:៣២, ៣៨, ៤០.

១៣ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាំម៉ូនបានទៅ ហើយទូលស្ដេចនូវព្រះបន្ទូលទាំងអស់ ដែលព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកលោក ។

១៤ ហើយពួកគេបានប្រមូលអស់ទាំងប្រជាជនមកជុំគ្នា មែនហើយ គឺអស់ទាំងរាស្ត្រនៃព្រះអម្ចាស់ ហើយបានប្រមូលអស់ទាំងហ្វូងចៀម និងហ្វូងសត្វរបស់គេ ហើយបានចាកចេញពីដែនដី ហើយបានមកក្នុងទីរហោស្ថាន ដែលបំបែកដែនដីនីហ្វៃ និងដែនដី សារ៉ាហិមឡា ហើយបានមកដល់ជិតព្រំប្រទល់ដែនដី ។

១៥ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូនបាននិយាយទៅពួកគេថាៈ មើលចុះ ខ្ញុំ និងបងប្អូនខ្ញុំ នឹងចូលទៅក្នុងដែនដី សារ៉ាហិមឡា ហើយអ្នករាល់គ្នាត្រូវនៅទីនេះ រហូតដល់យើងត្រឡប់មកវិញ; ហើយយើងនឹងសាកល្បងចិត្តរបស់បងប្អូនយើងមើល ថាតើពួកគេចង់ឲ្យអ្នករាល់គ្នា ចូលទៅក្នុងដែនដីគេទេឬអី ។

១៦ ហើយហេតុការណ៍បានកើតឡើងថា កាលអាំម៉ូនកំពុងតែចូលទៅក្នុងដែនដីហើយ នោះលោក និងបងប្អូនលោក បានជួប អាលម៉ា នៅត្រង់[ក]កន្លែងដែលបាននិយាយមកពីមុន; ហើយមើលចុះ នេះគឺជាការជួបជុំមួយដ៏ប្រកបដោយអំណរ ។

១៧ ឥឡូវនេះ [ក]សេចក្ដីអំណរនៃអាំម៉ូនមានទំហំដ៏ធំ រហូតដល់លោកបានពោរពេញ; មែនហើយ លោកត្រូវបាន[ខ]លេបទៅក្នុងសេចក្ដីអំណរនៃព្រះរបស់លោក រហូតដល់អស់កម្លាំងពីខ្លួន; ហើយលោកបាន[គ]ដួលទៅលើដីទៀត ។

១៨ ឥឡូវនេះ តើនេះមិនមែនជាសេចក្ដីអំណរដ៏ខ្លាំងទេឬ ? មើលចុះ នេះគឺជាសេចក្ដីអំណរ ដែលគ្មានអ្នកណាបានទទួល លើកលែងតែអ្នកដែលប្រែចិត្តដោយពិតប្រាកដ និងអ្នកដែលស្វែងរកសុភមង្គលដ៏សុភាពរាបសា ។

១៩ ឥឡូវនេះ សេចក្ដីអំណរនៃអាលម៉ា កាលបានជួបនឹងបងប្អូនលោក នោះមានទំហំពិតជាធំណាស់ ហើយសេចក្ដីអំណរនៃ អើរ៉ុន អោមណើរ និងហិមណៃក៏ដូច្នោះដែរ; ប៉ុន្តែមើលចុះ សេចក្ដីអំណររបស់គេ ពុំមែនជាសេចក្ដីអំណរដែលហួសកម្លាំងគេនោះទេ ។

២០ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ាបាននាំបងប្អូនលោក ត្រឡប់ទៅឯដែនដីសារ៉ាហិមឡាវិញ; គឺទៅ [ក]ផ្ទះរបស់លោកផ្ទាល់ ។ ហើយពួកគេបានទៅ ហើយប្រាប់មេចៅក្រម នូវគ្រប់ការណ៍ទាំងអស់ ដែលបានកើតឡើងដល់គេ នៅដែនដី នីហ្វៃ នៅក្នុងចំណោមពួកសាសន៍លេមិន ដែលជាបងប្អូនរបស់គេ ។

២១ ហើយហេតុការណ៍បានកើតឡើងថា មេចៅក្រមបានចេញប្រកាសមួយទូទៅអស់ទាំងដែនដី ចង់ដឹងសម្លេងរបស់ប្រជាជន អំពីរឿងទទួលយកបងប្អូនគេ ដែលជាប្រជាជនអាន់តៃ-នីហ្វៃ-លីហៃ ។

២២ ហើយហេតុការណ៍បានកើតឡើងថា សម្លេងរបស់ប្រជាជនបន្លឺឲ្យដឹងថាៈ មើលចុះ យើងនឹងប្រគល់ដែនដីយើសុន ដែលនៅ ខាងកើតជិតទៅនឹងសមុទ្រ ដែលជាប់នឹងដែនដីបរិបូរណ៍ គឺនៅខាងត្បូងដែនដីបរិបូរណ៍; ហើយដែនដីយើសុននេះ គឺជាដែនដីដែល យើងនឹងឲ្យទៅបងប្អូនយើងទុកជាកេរ្តិ៍អាករ ។

២៣ ហើយមើលចុះ យើងនឹងដាក់ពលទ័ពយើងនៅចន្លោះដែនដីយើសុន និងដែនដីនីហ្វៃ ដើម្បីយើងអាចការពារបងប្អូនយើង ដែលនៅក្នុងដែនដីយើសុន; ហើយការណ៍នេះយើងធ្វើ ដើម្បីបងប្អូនយើង ព្រោះពួកគេខ្លាចបាប មិនព្រមលើកអាវុធប្រឆាំងនឹងបង ប្អូនគេ; ហើយការភ័យខ្លាចដ៏ធំនេះចេញមកពីការប្រែចិត្តដ៏ខ្លាំងរបស់គេ ព្រោះគេធ្លាប់បានធ្វើអំពើឃាតកម្ម និងអំពើទុច្ចរិតដ៏អាក្រក់ ជាច្រើន ។

២៤ ហើយឥឡូវនេះ មើលចុះ ការណ៍នេះយើងនឹងធ្វើចំពោះបងប្អូនយើង ដើម្បីឲ្យគេអាចគ្រងដែនដីយើសុនទុកជាមរតក; ហើយយើងនឹងការពារពួកគេពីពួកខ្មាំងសត្រូវរបស់គេ ដោយពលទ័ពរបស់យើង នៅក្នុងករណីយមួយថា គេត្រូវផ្ដល់ដល់យើងនូវ របស់របរគេមួយផ្នែក ដើម្បីជួយយើងចិញ្ចឹមពលទ័ពយើង ។

២៥ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលអាំម៉ូនបានឮដូច្នេះហើយ នោះលោកក៏ត្រឡប់ទៅឯប្រជាជន អាន់តៃ-នីហ្វៃ-លីហៃវិញ ហើយបាននាំអាលម៉ាទៅជាមួយផង គឺទៅក្នុងទីរហោស្ថាន ត្រង់កន្លែងដែលគេបានបោះត្រសាល ហើយបានប្រាប់ឲ្យពួកគេដឹងនូវគ្រប់ការណ៍អស់ទាំងនេះ ។ ហើយអាលម៉ាបានរៀបរាប់ប្រាប់គេអំពីការដែលលោកបាន[ក]ប្រែចិត្តជឿ ព្រមទាំងអាំម៉ូន និងអើរ៉ុន និងបងប្អូនលោកដែរ ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ការណ៍នេះបានធ្វើឲ្យពួកគេមានសេចក្ដីអំណរជាខ្លាំងនៅក្នុងចំណោមពួកគេ។ ហើយពួកគេបានចុះទៅដែនដីយើសុន ហើយបានយក

១៦ *ក* អាលម៉ា ១៧:១–៤.
១៧ *ក* ស.ប. សេចក្ដីអំណរ.
*ខ* ១ នីហ្វៃ ១:៧.
*គ* អាលម៉ា ១៩:១៤.
២០ *ក* អាលម៉ា ៤:១៦–១៨.
២៥ *ក* ម៉ូសាយ ២៧:១០–២៤.

ដែនដីយើសុន; ហើយពួកគេត្រូវពួកនីហ្វៃហៅថា ប្រជាជន
អាំម៉ូន; ហេតុដូច្នេះហើយ ពួកគេត្រូវបានញែកចេញ ដោយ
ឈ្មោះនេះ ចាប់តាំងពីពេលនោះរហូតមក ។
២៧ ហើយពួកគេនៅក្នុងចំណោមប្រជាជននីហ្វៃ ហើយត្រូវ
បានរាប់ក្នុងចំណោមប្រជាជន ដែលនៅក្នុងសាសនាចក្រនៃ
ព្រះ ។ ហើយពួកគេត្រូវបានញែកចេញ ដោយព្រោះគេមាន
ចិត្តឧស្សាហ៍ដល់ព្រះ និងដល់មនុស្សលោកផង; ព្រោះពួកគេ
មានចិត្តទៀងត្រង់ និងសុចរិតដោយឥតខ្ចោះ ក្នុងគ្រប់ការណ៍
ទាំងអស់; ហើយពួកគេមានចិត្តរឹងប៉ឹង នៅក្នុងសេចក្ដីជំនឿជឿ
ដល់ព្រះគ្រីស្ទ គឺរហូតដល់ ចុងបំផុត ។
២៨ ហើយពួកគេមើលទៅការខ្ចាយឈាមបងប្អូនគេ
ទុកជាទីស្អប់ខ្ពើមដ៏ធំបំផុត; ហើយគ្មាននរណាអាចនិយាយឲ្យ
គេលើក អាវុធប្រឆាំងនឹងបងប្អូនគេទៀតឡើយ; ហើយពួកគេ
មិនមើលសេចក្ដីស្លាប់ ទុកជាការតក់ស្លុតសោះឡើយ ដោយ
ព្រោះសេចក្ដីសង្ឃឹម និងយោបល់ ដែលគេមានអំពីព្រះគ្រីស្ទ
និងដំណើររស់ឡើងវិញ; ហេតុដូច្នេះហើយ ចំពោះគេ សេចក្ដី
ស្លាប់ត្រូវបានលេបដោយ ជ័យជំនះនៃព្រះគ្រីស្ទទៅលើវា ។
២៩ ហេតុដូច្នេះហើយ ពួកគេសុខចិត្តរងទុក្ខដល់ស្លាប់
ដោយឈឺចាប់ ហើយវេទនាបំផុត ដែលធ្វើឡើងដោយបងប្អូនគេ
មុនគេនឹងលើកដាវ ឬលំពែងវាយតគេវិញ ។
៣០ ម្ល៉ោះហើយ ពួកគេជាប្រជាជនមួយ ដែលមានចិត្ត
ឧស្សាហ៍ ហើយគួរឲ្យស្រឡាញ់ គឺជាប្រជាជនមួយដ៏សំណប់
ជាខ្លាំង នៃព្រះអម្ចាស់ ៕

## ជំពូកទី ២៨

*ពួកលេមិនត្រូវបរាជ័យនៅក្នុងចម្បាំងមួយដ៏ធំ — មនុស្ស រាប់ម៉ឺននាក់ត្រូវប្រហារចោល — ពួកទុច្ចរិតត្រូវដាក់ឲ្យនៅ ក្នុងស្ថានភាព វេទនាមួយដ៏មិនចេះចប់មិនចេះហើយ; ពួកសុចរិត ទទួលសុភមង្គលដ៏មិនចេះចប់មិនចេះហើយ ។ ប្រមាណជា ឆ្នាំ ៧៧–៧៦ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីប្រជាជន
អាំម៉ូនបានតាំងនៅលើដែនដីយើសុន ហើយសាសនាចក្រមួយ
ត្រូវបានតាំងឡើងនៅក្នុងដែនដីយើសុន ហើយពលទ័ពសាសន៍
នីហ្វៃត្រូវបានដាក់នៅព័ទ្ធជុំវិញដែនដីយើសុនហើយ មែនហើយ
នៅតាមព្រំប្រទល់ជុំវិញដែនដីសារ៉ាហិមឡា មើលចុះ ពលទ័ព
សាសន៍លេមិន បានមកតាមបងប្អូនគេនៅក្នុងទីរហោស្ថាន ។
២ ម្ល៉ោះហើយ ទើបមានការប្រយុទ្ធយ៉ាងធំមួយ; មែនហើយ
ជាការប្រយុទ្ធ ដែលមិនដែលបានស្គាល់ពីមុនមក នៅក្នុងចំណោម
គ្រប់ទាំងប្រជាជន នៅលើដែនដីនេះ ចាប់តាំងពីពេលដែល
លីហៃបានចាកចេញពីក្រុងយេរូសាឡិមមក; មែនហើយ ពួក
លេមិនរាប់ម៉ឺន នាក់ត្រូវស្លាប់ ហើយត្រូវខ្ចាត់ខ្ចាយ ។
៣ មែនហើយ ព្រមទាំងមានការកាប់សម្លាប់យ៉ាងធំមួយ
នៅក្នុងចំណោមប្រជាជននីហ្វៃ; ទោះជាយ៉ាងណាក៏ដោយ
គង់តែ ពួកលេមិនត្រូវបានរុញច្រានចេញដែរ ហើយត្រូវបែក
ខ្ចាត់ខ្ចាយ រីឯប្រជាជននីហ្វៃ គេបានត្រឡប់មកដែនដីគេវិញ ។
៤ ហើយឥឡូវនេះ នេះជាពេលមួយដែលមានការកាន់ទុក្ខ
ដ៏ធំ ហើយសម្លេងទួញសោក បានឮទូទៅអស់ទាំងដែនដី នៅ
ក្នុង ចំណោមប្រជាជននីហ្វៃទាំងអស់ —
៥ មែនហើយ ទំនួញរបស់ពួកស្ត្រីមេម៉ាយ ដែលកាន់ទុក្ខដល់
ប្ដីរបស់ខ្លួន និងទំនួញរបស់ឪពុកកាន់ទុក្ខដល់ពួកកូនប្រុសរបស់ខ្លួន
ហើយកូនស្រីកាន់ទុក្ខដល់បងប្រុស មែនហើយ បងប្រុសកាន់
ទុក្ខដល់ឪពុក; ម្ល៉ោះហើយ ទំនួញសោកសៅ ត្រូវបាន
ឮឡើងនៅក្នុង ចំណោមពួកគេ គឺកាន់ទុក្ខដល់ញាតិសន្ដាន
របស់ខ្លួនដែលត្រូវស្លាប់ ។
៦ ហើយឥឡូវនេះ នេះពិតជាថ្ងៃដ៏សោកសៅមួយ មែន
ហើយ គឺជាពេលដ៏សំខាន់ ហើយជាពេលសំរាប់តមអាហារ
និងអធិស្ឋាន ឲ្យច្រើន ។
៧ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់ប្រាំក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ;
៨ ហើយនេះគឺជាដំណើររឿងរបស់អាំម៉ូន និងបងប្អូនលោក
ការធ្វើដំណើរទាំងឡាយរបស់គេនៅឯដែនដីនីហ្វៃ ការរងទុក្ខ
ទាំង ឡាយរបស់គេនៅដែនដីនោះ ការទុក្ខសោកទាំងឡាយ
របស់គេ និងទុក្ខវេទនាទាំងឡាយរបស់គេ និងសេចក្ដីអំណរ
របស់គេ ដ៏មិនអាចថ្លែងអស់បាន និងការទទួលយក និង
ការសុខសាន្ដរបស់បងប្អូនគេ នៅដែនដីយើសុន។ ហើយឥឡូវនេះ
សូមព្រះអម្ចាស់ ដែលជាព្រះដ៏ប្រោសលោះមនុស្សលោកទាំង
អស់ ប្រទានពរដល់ព្រលឹងគេរហូតតទៅ ។

២៧ *ក* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់.
*ខ* អាលម៉ា ២៣:៦.
២៩ *ក* អាលម៉ា ២៤:២០–២៣.
**២៨** ១ *ក* អាលម៉ា ២៧:២២; ៣០:១, ១៩.
៣ *ក* អាលម៉ា ៣០:១.
៦ *ក* អាលម៉ា ៣០:២.
៨ *ក* អាលម៉ា ២៧:១៦–១៩.

៩ ហើយនេះគឺជាដំណើររឿងនៃសង្គ្រាម និងការទាស់ទែង
គ្នាទាំងឡាយ នៅក្នុងចំណោមពួកនីហ្វៃ ហើយអំពីសង្គ្រាម
ទាំងឡាយ រវាងពួកនីហ្វៃនឹងពួកលេមិនផង; ហើយឆ្នាំទីដប់ប្រាំ
ក្នុងរជ្ជកាលនៃពួកចៅក្រមក៏ចប់ទៅ ។
១០ ហើយចាប់ពីឆ្នាំទីមួយទៅដល់ឆ្នាំទីដប់ប្រាំ ត្រូវបាននាំ
មកនូវការបំផ្លិចបំផ្លាញជីវិតនៃមនុស្សជាច្រើនពាន់នាក់; មែន
ហើយ ត្រូវបាននាំមកនូវឆាកកំចាយឈាមដ៏ស្ញប់ស្ញែង ។
១១ ហើយកាលសាកសពជាច្រើនពាន់បានកប់ជ្រៅទៅក្នុងដី
នៅពេលនោះមានសាកសពជាច្រើនពាន់នាក់ទៀត ដែល[ក]ត្រូវ
រលួយជាគំនរនៅលើ[ខ]ផ្ទៃដី; មែនហើយ ហើយមនុស្ស
ជាច្រើនពាន់នាក់កំពុងតែកាន់ទុក្ខ ចំពោះការបាត់បង់ញាតិសន្តាន
របស់គេ ពីព្រោះគេមានហេតុនឹងភ័យ ស្របតាមពាក្យ
សន្យាទាំងឡាយនៃព្រះអម្ចាស់ដែលថា ពួកគេនឹងត្រូវដាក់ទៅ
ក្នុងស្ថានភាពវេទនាមួយ ដ៏មិនចេះចប់មិនចេះហើយ ។
១២ នៅពេលមនុស្សជាច្រើនពាន់នាក់ទៀត កាន់ទុក្ខយ៉ាង
ពិតប្រាកដ ចំពោះការបាត់បង់ញាតិសន្តានរបស់គេ តែគេអរ
រីករាយ ហើយរំភើបនៅ[ក]ក្នុងសេចក្ដីសង្ឃឹម ហើយដោយដឹងថា
ស្របតាមពាក្យសន្យាទាំងឡាយនៃព្រះអម្ចាស់ នោះពួកគេនឹង
ត្រូវបានប្រោស ឡើងវិញ ដើម្បីទៅនៅខាងស្ដាំព្រះហស្តនៃព្រះ
នៅក្នុងស្ថានភាពនៃសុភមង្គលដ៏មិនចេះចប់មិនចេះហើយ ។
១៣ ម្ល៉ោះហើយ យើងឃើញថា [ក]ភាពមិនស្មើគ្នារបស់
មនុស្សមានទំហំធំយ៉ាងណា ដោយព្រោះអំពើបាប និងអំពើ
រំលង និងអំណាចនៃអារក្ស [ខ]ដែលកើតឡើងដោយផែនការ
ដែលប្រកបដោយកលល្បិច ដែលវាធ្វើឡើង ដើម្បីដាក់អន្ទាក់ចិត្ត
មនុស្ស ។
១៤ ម្ល៉ោះហើយ យើងឃើញការហៅមនុស្សឲ្យមានចិត្ត
ព្យាយាមដ៏ខ្លាំង ដើម្បីធ្វើការនៅក្នុង[ក]ចំការទំពាំងបាយជូរនៃព្រះ
អម្ចាស់; ម្ល៉ោះហើយ យើងឃើញហេតុដ៏ធំនៃការសោកសៅ
និងការអររីករាយផង — ការសោកសៅដោយព្រោះសេច
ក្ដីស្លាប់ និងការបំផ្លិច បំផ្លាញ នៅក្នុងចំណោមមនុស្សលោក
ហើយសេចក្ដីអំណរ ដោយព្រោះ[ខ]ពន្លឺនៃព្រះគ្រីស្ទដល់ជីវិត ៕

## ជំពូកទី ២៩

*អាលម៉ាមានបំណងចង់ស្រែកប្រកាសប្រាប់អំពីការប្រែចិត្ត ដោយការឧស្សាហ៍ដូចទេវតា — ព្រះអម្ចាស់ទ្រង់ប្រទានពួកគ្រូបង្រៀនដល់គ្រប់សាសន៍ — អាលម៉ាអួតនៅក្នុងកិច្ចការនៃព្រះអម្ចាស់ និងនៅក្នុងជ័យជំនះរបស់អាំម៉ូន និងបងប្អូនលោក ។ ប្រមាណជាឆ្នាំ ៧៦ ម.គ.ស. ។*

ឱ បើសិនជាខ្ញុំបានទៅជាទេវតាមួយ ហើយអាចបំពេញបំណង
ចិត្តខ្ញុំ គឺឲ្យខ្ញុំអាចទៅនិយាយដោយត្រែនៃព្រះ ដោយសម្លេង
ដែល ធ្វើឲ្យញ័រផែនដី ហើយស្រែកហៅឲ្យមានការប្រែចិត្ត
ដល់មនុស្សគ្រប់រូប!
២ មែនហើយ ខ្ញុំនឹងប្រកាសដល់មនុស្សគ្រប់រូប ដូចជា
សូរផ្គរលាន់ នូវការ[ក]ប្រែចិត្ត និងផែនការនៃសេចក្ដីប្រោសលោះថា
គេត្រូវ តែប្រែចិត្ត ហើយមករកព្រះនៃយើងវិញ ដើម្បីកុំឲ្យមាន
ការសោកសៅនៅលើផ្ទៃផែនដីទៀតឡើយ ។
៣ ប៉ុន្តែមើលចុះ ខ្ញុំជាមនុស្សទេតើ ហើយធ្វើអំពើបាបនៅ
ក្នុងសេចក្ដីប៉ងប្រាថ្នារបស់ខ្ញុំ ព្រោះខ្ញុំគួរតែពេញចិត្តនឹងកិច្ចការ
ដែលព្រះ អម្ចាស់ទ្រង់បានប្រទានដល់ខ្ញុំវិញ ។
៤ ខ្ញុំមិនគួរខ្វល់ខ្វាយនៅក្នុងបំណងទាំងឡាយរបស់ខ្ញុំទេ
អំពីច្បាប់ដ៏តឹងរឹងនៃព្រះដ៏យុត្តិធម៌ ព្រោះខ្ញុំដឹងថា ទ្រង់ប្រទានឲ្យ
មនុស្ស [ក]តាមបំណងរបស់គេ ទោះជាសេចក្ដីស្លាប់ ឬសេចក្ដី
រស់ក្ដី; មែនហើយ ខ្ញុំដឹងថា ទ្រង់ប្រទានដល់មនុស្ស មែនហើយ
ចេញជាច្បាប់ ទាំងឡាយឲ្យគេ ដែលមិនអាចប្រែប្រួល
បានតាម[ខ]ឆន្ទៈរបស់គេ ទោះជាសេចក្ដីសង្គ្រោះ ឬសេចក្ដី
បំផ្លិចបំផ្លាញក្ដី ។
៥ មែនហើយ ហើយខ្ញុំដឹងថា សេចក្ដីល្អ និងសេចក្ដី
អាក្រក់បានកើតឡើង ចំពោះមនុស្សទាំងអស់; អ្នកណាដែល
មិនដឹងខុសពីត្រូវ ចាត់ទុកជាគ្មានទោស; ប៉ុន្តែ អ្នកដែល
[ក]ដឹងខុសនិងត្រូវ អ្នកនោះហើយដែលនឹងបានត្រូវទទួល តាមបំណង
ចិត្តរបស់គេ ទោះជាគេចង់ បានល្អ ឬអាក្រក់ សេចក្ដីរស់

១១ ក អាលម៉ា ១៦:១១.
ខ អាលម៉ា ៤៨:២៣;
គ. និង ស. ៤២:៤៥–៤៦.
១២ ក អាលម៉ា ១១:៤១.
១៣ ក ១ នីហ្វៃ ១៧:៣៥.
ខ ២ នីហ្វៃ ៩:២៨.
១៤ ក ស.ប. ចំការទំពាំងបាយជូរនៃព្រះ អម្ចាស់.
ខ ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
២៩ ២ក អោមណៃ ១:២៦;
៣ នីហ្វៃ ២១:២០.
៤ ក ទំនុក. ៣៧:៤.
ខ ស.ប. សិទ្ធិជ្រើសរើស.
៥ ក ២ នីហ្វៃ ២:១៨, ២៦;
ម៉ូរ៉ូណៃ ៧:១៥–១៩.
ស.ប. ការសង្កេតស្គាល់, អំណោយ ទានខាង.

ឬសេចក្ដីស្លាប់ សេចក្ដីអំណរ ឬសេចក្ដីសោកស្ដាយនៃ
សតិសម្បជញ្ញៈក្ដី ។
៦ ឥឡូវនេះ ដោយឃើញថា ខ្ញុំដឹងការណ៍ទាំងនេះ ហេតុអ្វី
ក៏ខ្ញុំប៉ងប្រាថ្នាច្រើនជាងធ្វើកិច្ចការ ដែលបានប្រគល់មកឲ្យខ្ញុំ ?
៧ ហេតុអ្វីក៏ខ្ញុំប៉ងប្រាថ្នាចង់ធ្វើជាទេវតា ដើម្បីខ្ញុំអាច
និយាយទៅគ្រប់ទិសទីនៃផែនដី ?
៨ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់ប្រទានដល់អស់ទាំងសាសន៍
នូវសាសន៍ និងភាសាគេផ្ទាល់ ឲ្យបង្រៀនព្រះបន្ទូលរបស់ទ្រង់
មែនហើយ នៅក្នុងប្រាជ្ញា នូវអស់ទាំងអ្វីដែលទ្រង់ទតឃើញថា
ល្អមនឹងឲ្យគេមាន; ហេតុដូច្នេះហើយ យើងឃើញថា ព្រះអម្ចាស់
ទ្រង់ទូន្មាននៅក្នុងប្រាជ្ញា តាមអ្វីដែលត្រឹមត្រូវ ហើយពិត ។
៩ ខ្ញុំដឹងនូវអ្វីដែលព្រះអម្ចាស់ទ្រង់បានបញ្ជាដល់ខ្ញុំ
ហើយខ្ញុំអួតនៅក្នុងការណ៍នោះ ។ ខ្ញុំមិនអួតដោយខ្លួនខ្ញុំផ្ទាល់ទេ
តែខ្ញុំអួត នៅក្នុងអ្វី ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាខ្ញុំវិញ;
មែនហើយ ហើយនេះគឺជាការអួតរបស់ខ្ញុំ ក្រែងខ្ញុំអាចបាន
ទៅជាគ្រឿងឧបករណ៍មួយ នៅក្នុងព្រះហស្ដនៃព្រះ ដើម្បីនាំ
មនុស្ស ខ្លះ ទៅកាន់ការប្រែចិត្ត; ហើយនេះគឺសេចក្ដីអំណរ
របស់ខ្ញុំ ។
១០ ហើយមើលចុះ កាលខ្ញុំឃើញបងប្អូនខ្ញុំជាច្រើន បានប្រែ
ចិត្តជាពិតប្រាកដ ហើយមករកព្រះអម្ចាស់ ជាព្រះរបស់គេ
នៅពេល នោះ ព្រលឹងខ្ញុំពោរពេញទៅដោយសេចក្ដីអំណរ;
នៅពេលនោះ ខ្ញុំនឹកឃើញនូវអ្វីៗ ដែលព្រះអម្ចាស់ទ្រង់បានធ្វើ
ដើម្បីខ្ញុំ មែនហើយ គឺទ្រង់បានឮពាក្យអធិស្ឋានរបស់ខ្ញុំ; មែនហើយ
នៅពេលនោះ ខ្ញុំនឹកឃើញព្រះពាហុរបស់ទ្រង់ ដ៏ប្រកបដោយ
សេចក្ដីមេត្តាករុណា ដែលទ្រង់ហុចមករកខ្ញុំ ។
១១ មែនហើយ ខ្ញុំក៏នឹកឃើញផងដែរ នូវការជាប់ឃុំឃាំងនៃ
ពួកអយ្យកោខ្ញុំ; ត្បិតខ្ញុំដឹងយ៉ាងច្បាស់ថា ព្រះអម្ចាស់ទ្រង់បាន
ដោះ លែងពួកគេ ឲ្យរួចផុតពីសេវកភាព ហើយហេតុនេះ
ទ្រង់បានតាំងសាសនាចក្ររបស់ទ្រង់; មែនហើយ ព្រះ
អម្ចាស់ដ៏ជាព្រះ គឺព្រះនៃ អ័ប្រាហាំ ព្រះនៃអ៊ីសាក និងព្រះ
នៃយ៉ាកុប បានដោះលែងពួកគេ ឲ្យរួចផុតពីសេវកភាព ។
១២ មែនហើយ ខ្ញុំចងចាំជានិច្ចនូវការជាប់ឃុំឃាំងនៃពួក
អយ្យកោខ្ញុំ; ហើយចាំថា ព្រះដដែលនោះ ទ្រង់បានដោះលែងពួក
គេឲ្យ រួចផុតពីកណ្ដាប់ដៃពួកសាសន៍អេស៊ីព្ទ បានដោះលែង
ពួកគេឲ្យរួចផុតពីសេវកភាព ។
១៣ មែនហើយ ព្រះដដែលនោះបានតាំងសាសនាចក្ររបស់
ទ្រង់ នៅក្នុងចំណោមពួកគេ; មែនហើយ ហើយព្រះដដែល
នោះ បានហៅខ្ញុំ ក្នុងតំណែងដ៏បរិសុទ្ធ ឲ្យទៅផ្សាយព្រះបន្ទូល
ដល់ប្រជាជននេះ ហើយបានប្រទានឲ្យខ្ញុំ នូវការជោគជ័យ
ដ៏ច្រើន ដែលនាំឲ្យ ខ្ញុំពោរពេញទៅដោយសេចក្ដីអំណរ ក្នុង
ការជោគជ័យនេះ ។
១៤ ប៉ុន្តែ ខ្ញុំមិនមានសេចក្ដីអំណរ នៅក្នុងការជោគជ័យរបស់ខ្ញុំ
តែប៉ុណ្ណោះទេ តែសេចក្ដីអំណររបស់ខ្ញុំ ពោរពេញថែមឡើង
ដោយព្រោះការជោគជ័យរបស់បងប្អូនខ្ញុំ ដែល
បានឡើងទៅឯដែនដីនីហ្វៃ ។
១៥ មើលចុះ ពួកគេបានខិតខំធ្វើការជាខ្លាំង ហើយបាននាំ
មកនូវលទ្ធផលដ៏ច្រើន ឯរង្វាន់របស់គេ មហិមាណាស់!
១៦ ឥឡូវនេះ កាលខ្ញុំនឹកដល់ការជោគជ័យរបស់បងប្អូនទាំងនេះ
នោះព្រលឹងខ្ញុំត្រូវបានបណ្ដែតចេញទៅ គឺឃ្លាតចេញពីរូបកាយ
នៅពេលនោះ សេចក្ដីអំណររបស់ខ្ញុំធំអស្ចារ្យណាស់ ។
១៧ ហើយឥឡូវនេះ សូមព្រះទ្រង់ប្រទានឲ្យបងប្អូនខ្ញុំទាំងនេះ
ឲ្យគេអាចអង្គុយនៅក្នុងនគរព្រះ; មែនហើយ ហើយព្រមទាំង
ជនទាំងអស់ណា ដែលជាលទ្ធផលនៃកិច្ចការរបស់គេ ដើម្បីកុំឲ្យ
អ្នកទាំងនេះ ចេញទៅក្រៅទៀតឡើយ តែឲ្យគេសរសើរដំកើង
ដល់ទ្រង់រហូតតទៅ ។ ហើយសូមព្រះអនុញ្ញាតឲ្យការណ៍នេះ
អាចបានសំរេចតាមពាក្យសំដីរបស់ខ្ញុំ ដូចខ្ញុំបាននិយាយផងចុះ ។
អាម៉ែន ៕

## ជំពូកទី ៣០

*កូរីហូរជាអ្នកទទឹងនឹងព្រះគ្រីស្ទ សើចចំអកដល់ព្រះគ្រីស្ទ, ដល់ដង្វាយធួន, និងដល់វិញ្ញាណនៃការព្យាករណ៍ — វាបង្រៀនថា គ្មានព្រះ, គ្មានការធ្លាក់នៃមនុស្ស, គ្មានទោសចំពោះអំពើបាប, ហើយគ្មានព្រះគ្រីស្ទទេ — អាលម៉ាធ្វើបន្ទាល់ថា ព្រះគ្រីស្ទនឹងយាងមក ហើយថា គ្រប់ការណ៍ទាំងអស់បញ្ជាក់ថាមានព្រះមែន — កូរីហូរទាមទាររកទីសំគាល់មួយ*

៥ *ខ* ស.ប. បញ្ញាចិត្ត.
៨ *ក* ២ នីហ្វៃ ២៩:១២.
*ខ* គ. និង ស. ៩០:១១.
*គ* អាលម៉ា ១២:៩–១១.
៩ *ក* អាលម៉ា ២៦:១២.
១០ *ក* ម៉ូសាយ ២៧:១១–៣១.
១១ *ក* ម៉ូសាយ ២៤:១៦–២១; អាលម៉ា ៥:៣–៥.
១២ *ក* និក្ខ. ១៤:៣០–៣១.
១៣ *ក* គ. និង ស. ១៨:១៤–១៦.
១៤ *ក* អាលម៉ា ១៧:១–៤.

*ហើយត្រូវធ្វើឲ្យគ — អារក្សបានលេចមកឲ្យកូរីហូរ ឃើញជាទេវតាមួយ ហើយបង្រៀនវាឲ្យនិយាយ — មនុស្សជាន់លើវា ហើយវាក៏ស្លាប់ទៅ ។ ប្រមាណជាឆ្នាំ ៧៦–៧៤ ម.គ.ស. ។*

មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់[ក]ពីប្រជាជន
អាំម៉ូនបានតាំងទីលំនៅ នៅដែនដីយើសុនហើយ មែនហើយ
ព្រមទាំងបន្ទាប់ពីពួកលេមិនត្រូវ[ខ]រុញច្រានចេញពីដែនដី ហើយ
សាកសពទាំងឡាយរបស់គេបានត្រូវកប់ដោយប្រជាជននៅក្នុង
ដែនដី នោះ—

២ ឥឡូវនេះ សាកសពរបស់ពួកគេមិនអាចរាប់បានទេ ដោយ
មានចំនួនច្រើនពេក; ឯសាកសពរបស់ពួកសាសន៍នីហ្វៃ ក៏មិនអាច
រាប់បានដែរ — ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួក
គេបានកប់សាកសពទាំងនោះហើយ ហើយបន្ទាប់ពីបាន
តមអាហារ អស់ជាច្រើនថ្ងៃ និងកាន់ទុក្ខ និងអធិស្ឋាន (ហើយ
គឺនៅឆ្នាំទីដប់ប្រាំមួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជន
នីហ្វៃ) នោះចាប់ ផ្ដើមមានសេចក្ដីសុខសាន្តតរៀងទៅនៅលើដែនដី
ទាំងមូល ។

៣ មែនហើយ ហើយប្រជាជនបានប្រតិបត្តិតាមព្រះបញ្ញត្តិទាំង
ឡាយនៃព្រះអម្ចាស់; ហើយពួកគេតឹងរឹងក្នុងការប្រតិបត្តិតាម
[ក]ពិធី បរិសុទ្ធទាំងឡាយនៃព្រះ [ខ]ស្របតាមក្រិត្យវិន័យលោកម៉ូសេ;
ព្រោះពួកគេត្រូវបានបង្រៀន ឲ្យកាន់តាមក្រិត្យវិន័យលោកម៉ូសេ
រហូតដល់ ក្រិត្យនោះបានបំពេញ ។

៤ ម្ល៉ោះហើយ ប្រជាជនពុំមានការច្របូកច្របល់ ពេញ
ឆ្នាំទីដប់ប្រាំមួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

៥ ហើយហេតុការណ៍បានកើតឡើងថា នៅដើម
ឆ្នាំទីដប់ប្រាំពីរក្នុងរជ្ជកាលនៃពួកចៅក្រម ក៏មានសេចក្ដីសុខសាន្ត
តរៀងមក ។

៦ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា នៅជិតទៅចុងឆ្នាំទីដប់ប្រាំពីរ
មានបុរសម្នាក់បានចូលមកក្នុងដែនដីសារ៉ាហិមឡា ហើយ វា
ជា[ក]អ្នកទទឹងនឹងព្រះគ្រីស្ទ ព្រោះវាបានចាប់ផ្ដើមបង្រៀនប្រជាជន
ទាស់នឹងពាក្យព្យាករណ៍ទាំងឡាយដែលបានថ្លែង ដោយពួក
ព្យាការី អំពីការយាងមកនៃព្រះគ្រីស្ទ ។

៧ ឥឡូវនេះ គ្មានច្បាប់អ្វីដែលជំទាស់នឹង[ក]ជំនឿរបស់មនុស្ស
នោះទេ; ព្រោះថាបើមានច្បាប់ណាមួយ ដែលធ្វើឲ្យមនុស្ស
ពុំស្មើភាព គ្មាននោះ គឺជាទំនាស់ដ៏ខ្លាំងដល់ព្រះបញ្ញត្តិទាំងឡាយ
នៃព្រះ ។

៨ ត្បិតបទគម្ពីរបានចែងដូច្នោះថា៖ ចូរ[ក]រើសយកព្រះណា
ដែលអ្នកនឹងបំរើនៅថ្ងៃនេះចុះ។

៩ ឥឡូវនេះ បើមនុស្សចង់បំរើព្រះ នោះគឺជាសិទ្ធិរបស់អ្នក
នោះ ឬនិយាយម្យ៉ាងទៀតថា បើអ្នកនោះជឿព្រះ នោះគឺជាសិទ្ធិ
របស់ គេក្នុងការបំរើទ្រង់ ប៉ុន្តែបើគេមិនជឿទ្រង់ទេ គឺគ្មានច្បាប់
ឯណាមកធ្វើទោសដល់អ្នកនោះឡើយ ។

១០ ប៉ុន្តែ បើសិនជាគេធ្វើឃាតមនុស្ស នោះគេត្រូវទទួលទោស
ដល់[ក]ជីវិត; ហើយបើសិនជាគេប្លន់ គេក៏ត្រូវទទួលទោស;
ហើយបើ សិនជាគេលួច ក៏ត្រូវទទួលទោសដែរ; ហើយបើ
សិនជាគេប្រព្រឹត្តអំពើកំផិត ក៏ត្រូវទទួលទោសដែរ; មែនហើយ
ចំពោះអំពើទុច្ចរិតអស់ ទាំងនេះ គេត្រូវទទួលទោស ។

១១ ព្រោះមានច្បាប់មួយថា មនុស្សត្រូវទទួលការជំនុំជំរះ
ទៅតាមទោសរបស់គេ។ ទោះជាយ៉ាងណាក៏ដោយ គង់តែគ្មាន
ច្បាប់ឯណាដែលទាស់នឹងជំនឿ របស់មនុស្សនោះឡើយ; ហេតុ
ដូច្នេះហើយ មនុស្សទទួលទុក្ខទោសចំពោះតែទោស ដែលខ្លួន
បាន ប្រព្រឹត្តតែប៉ុណ្ណោះ; ហេតុដូច្នេះហើយ មនុស្សទាំងអស់មាន
សិទ្ធិ[ក]ស្មើគ្នា ។

១២ ហើយជនដែលទទឹងនឹងព្រះគ្រីស្ទ មានឈ្មោះថា កូរីហូរ
(ហើយច្បាប់មិនអាចចាប់កំហុសគាត់បានទេ) បានចាប់ផ្ដើម
បង្រៀន ប្រជាជនថា គ្មានព្រះគ្រីស្ទទេ ។ ហើយតាម
បែបនេះហើយដែលវាបានផ្សាយ ដោយនិយាយថា៖

១៣ នែ៎ អ្នករាល់គ្នា ដែលត្រូវចងភ្ជាប់នៅនឹងសេចក្ដីសង្ឃឹម
មួយ ដែលរវើរវាយ ហើយឥតប្រយោជន៍អើយ ហេតុអ្វីបានជា
អ្នក រាល់គ្នាដាក់នឹមមកលើខ្លួន ដោយការរវើរវាយបែបនេះ ?
ហេតុអ្វីបានជាអ្នកស្វែងរកព្រះគ្រីស្ទ ? ព្រោះគ្មានមនុស្សណាអាច
ដឹង នូវអ្វីដែលនឹងកើតឡើងនោះទេ ។

១៤ មើលចុះ ការណ៍ទាំងនេះដែលអ្នករាល់គ្នាហៅថា ពាក្យ
ព្យាករណ៍នោះ ដែលអ្នករាល់គ្នានិយាយថា បានឲ្យបន្តមក
ដោយ ពួកព្យាការីដ៏បរិសុទ្ធ មើលចុះ នោះគឺជាសណ្ដាប់ដ៏ឆ្កួត
លីលាទាំងឡាយរបស់ពួកអយ្យកោអ្នកទេ ។

---

៣០ ១*ក* អាលម៉ា ២៧:២៥–២៦.
ស.ប. អាន់តៃ-នីហ្វៃ-លីហៃ.
*ខ* អាលម៉ា ២៨:១–៣.
៣ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* ២ នីហ្វៃ ២៥:២៤–២៧;
អាលម៉ា ២៥:១៥.
៦ *ក* ស.ប. អ្នកទទឹងនឹងព្រះគ្រីស្ទ.
៧ *ក* អាលម៉ា ១:១៧.
៨ *ក* យ៉ូស្វេ ២៤:១៥.
ស.ប. សិទ្ធិជ្រើសរើស.
១០ *ក* ស.ប. ការដាក់ទោសដល់ជីវិត.
១១ *ក* ម៉ូសាយ ២៩:៣២.

១៥ តើអ្នករាល់គ្នាធ្វើដូចម្ដេចនឹងដឹងការពិតប្រាកដ នៃការណ៍
ទាំងនោះបាន ? មើលចុះ អ្នករាល់គ្នាមិនអាចដឹងនូវធ្វើៗ ដែល
អ្នក រាល់គ្នា[ក]មើលមិនឃើញនោះទេ; ហេតុដូច្នេះហើយ អ្នករាល់
គ្នាមិនអាចដឹងថា នឹងមានព្រះគ្រីស្ទមួយអង្គនោះឡើយ ។

១៦ អ្នកទន្ទឹងចាំ ហើយនិយាយថា អ្នករាល់គ្នាឃើញ
ការផ្ដាច់បាបទាំងឡាយរបស់អ្នក ។ ប៉ុន្តែមើលចុះ នោះគឺជា
ឥទ្ធិភាពនៃគំនិត ដ៏ឆ្កួតវង្វេងមួយប៉ុណ្ណោះ ហើយវិកលភាព
នៃគំនិតរបស់អ្នកគឺកើតឡើង ដោយសារសណ្ដាប់ទាំងឡាយ
របស់ពួកអយ្យកោអ្នក ដែលដឹក នាំអ្នកឲ្យជឿនូវអ្វីៗ ដែលគ្មាន
ពិតប្រាកដ ។

១៧ ហើយរឿងបែបនេះជាច្រើនទៀត ដែលវាបាននិយាយ
ទៅកាន់ប្រជាជន ដោយប្រាប់គេថា ពុំអាចមានដង្វាយធួនដែល
ធ្វើ ឡើង ដើម្បីធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សទេ
ប៉ុន្តែមនុស្សគ្រប់រូបរស់នៅក្នុងជីវិតនេះ ស្របតាមការរៀបចំនៃខ្លួន;
ហេតុដូច្នេះហើយ មនុស្សគ្រប់រូបបានចំរើនឡើង ស្របតាម
ការឈ្លាសវៃរបស់ខ្លួន ហើយមនុស្សគ្រប់រូបដណ្ដើមយក
ស្របតាមកម្លាំង របស់ខ្លួន; ហើយអ្វីៗក៏ដោយដែលមនុស្សបាន
ប្រព្រឹត្ត គឺគ្មានទោសសោះ ។

១៨ ហើយវាបានផ្សាយបែបនេះទៅកាន់ពួកគេ ដោយបង្វែរ
ចិត្តមនុស្សជាច្រើនចេញ ដោយធ្វើឲ្យគេងើយក្បាលនៅក្នុង
អំពើទុច្ចរិត មែនហើយ ដោយបង្វែរស្ត្រីចេញជាច្រើន និងបុរស
ផង ឲ្យប្រព្រឹត្តអំពើសហាយស្មន់ — ដោយប្រាប់គេថា កាល
ណាមនុស្ស ស្លាប់ទៅនោះគឺជាចុងបំផុតហើយ ។

១៩ ឥឡូវនេះ បុរសនេះក៏ទៅដែនដីយេរ៉ូសុនផងដែរ
ដើម្បីទៅផ្សាយប្រាប់ការណ៍ទាំងនេះ នៅក្នុងចំណោមប្រជាជន
អាំម៉ូន ដែល ពីមុនជាប្រជាជននៃពួកសាសន៍លេមិន ។

២០ ប៉ុន្តែមើលចុះ ពួកគេឈ្លាសវៃជាងពួកនីហ្វៃចំនួនច្រើន
ព្រោះពួកគេចាប់បុរសនោះ ហើយចងវា ហើយនាំវាទៅចំពោះ
អាំម៉ូន ដែលជាសង្ឃជាន់ខ្ពស់នៅលើប្រជាជននោះ ។

២១ ហើយហេតុការណ៍បានកើតឡើងថា អាំម៉ូនបានបញ្ជាឲ្យ
ដេញវាចេញពីដែនដី ។ ហើយវាបានមកឯដែនដីគេឌាន ហើយ
បានចាប់ផ្ដើមផ្សាយដល់ពួកគេផង; ហើយនៅទីនេះ វាពុំបាន
ជោគជ័យច្រើនទេ ព្រោះវាត្រូវគេចាប់វា ហើយចងវា ហើយនាំ
យកទៅ ចំពោះសង្ឃជាន់ខ្ពស់ និងចំពោះមេចៅក្រមដែលត្រួត
ត្រាលើដែនដីនោះ ។

២២ ហើយហេតុការណ៍បានកើតឡើងថា សង្ឃជាន់ខ្ពស់បាន
និយាយទៅវាថា៖ ហេតុអ្វីបានជាអ្នកដើរបង្ខូចផ្លូវទាំងឡាយនៃព្រះ
អម្ចាស់យ៉ាងនេះ ? ហេតុអ្វីបានជាអ្នកបង្រៀនប្រជាជននេះថា ពុំ
មានព្រះគ្រីស្ទទេ ធ្វើនេះដើម្បីបង្អាក់ការអររីករាយរបស់គេឬអី ?
ហេតុអ្វីបានជាអ្នកនិយាយទាស់នឹងអស់ទាំងពាក្យព្យាករណ៍ នៃ
ពួកព្យាការីដ៏បរិសុទ្ធ ?

២៣ ឥឡូវនេះ សង្ឃជាន់ខ្ពស់មានឈ្មោះថា គីឌដូណា ។
ហើយកូរីហ័របាននិយាយទៅលោកថា៖ ពីព្រោះតែខ្ញុំពុំបង្រៀន
សណ្ដាប់ដ៏ឆ្កួតលីលាទាំងឡាយ របស់ពួកអយ្យកោលោក
ហើយពីព្រោះតែខ្ញុំពុំបង្រៀនប្រជាជននេះ ឲ្យចងខ្លួនគេភ្ជាប់ទៅ
នឹង ពិធីបរិសុទ្ធ និងការប្រព្រឹត្តដ៏ឆ្កួតលីលា ដែលចែងមកដោយ
ពួកសង្ឃពីដើម ដើម្បីដណ្ដើមអានុភាព និងសិទ្ធិអំណាចពីពួកគេ
ដើម្បីទុក ពួកគេនៅក្នុងការល្ងង់ខ្លៅ ដើម្បីកុំឲ្យគេងើបក្បាលរួច
តែត្រូវសង្កត់ចុះតាមពាក្យសំដីរបស់លោក ។

២៤ លោកនិយាយថា ប្រជាជននេះ គឺជាប្រជាជនសេរី ។
មើលចុះ ខ្ញុំនិយាយថា ពួកគេនៅក្នុងសេវកភាព ។
លោកនិយាយ ថា ពាក្យព្យាករណ៍ជំនាន់ដើមទាំងនោះសុទ្ធតែ
ពិត ។ មើលចុះ ខ្ញុំនិយាយថា លោកពុំដឹងថា ពាក្យព្យាករណ៍
ទាំងនោះពិតទេ ។

២៥ លោកនិយាយថា ប្រជាជននេះ គឺជាប្រជាជនមួយ
ដែលមានទោស ហើយបានធ្លាក់ ដោយព្រោះអំពើរំលងនៃ
ឪពុកគេម្នាក់ ។ មើលចុះ ខ្ញុំនិយាយថា កូនពុំមានទោស ដោយ
ព្រោះឪពុកម្ដាយខ្លួនទេ ។

២៦ ហើយលោកនិយាយដែរថា ព្រះគ្រីស្ទនឹងយាងមក ។ ប៉ុន្តែ
មើលចុះ ខ្ញុំនិយាយថា លោកពុំដឹងថានឹងមានព្រះគ្រីស្ទ[ក]ទេ ។
ហើយលោកនិយាយដែរថា ទ្រង់នឹងត្រូវសុគត ជំនួសអំពើបាប
ទាំងឡាយនៃមនុស្សលោក —

២៧ ម្ល៉ោះហើយ លោកនាំប្រជាជននេះឲ្យដើរតាម
សណ្ដាប់ដ៏ឆ្កួតលីលាទាំងឡាយ របស់ពួកអយ្យកោលោក
ហើយទៅតាម ចំណង់ផ្ទាល់ខ្លួនរបស់លោក; ហើយលោកសង្កត់
ពួកគេចុះ បីដូចជានៅក្នុងសេវកភាព ដើម្បីលោកអាចបំប៉នខ្លួនលោក
ដោយផលនៃ ការងាររបស់ដៃគេ ដើម្បីកុំឲ្យគេហ៊ានងើបសម្លឹង
ដោយក្លាហាន ហើយដើម្បីកុំឲ្យគេហ៊ានសប្បាយនៅក្នុងសិទ្ធិ
និងឯកសិទ្ធទាំងឡាយ របស់គេ ។

២៨ មែនហើយ ពួកគេមិនហ៊ានប្រើអ្វីដែលជា
របស់គេផ្ទាល់ខ្លួនសោះ ដោយខ្លាចក្រែងគេជំទាស់ចិត្តពួកសង្ឃ
របស់គេ ដែលជា អ្នកដាក់នឹមទៅលើគេតាមចំណង់របស់ខ្លួន

១៥ *ក* អេធើរ ១២:៥–៦.

២៦ *ក* អេសាយ ៥៣:៤–៧.

ហើយបាននាំគេឲ្យជឿ ដោយសណ្ដាប់ទាំងឡាយរបស់គេ និងការយល់សប្ដិទាំងឡាយ របស់គេ និងគំនិតរវើរវាយទាំងឡាយរបស់គេ និងការនិមិត្តទាំងឡាយរបស់គេ និងការអាថ៌កំបាំងទាំងឡាយ ដែលគេប្រឌិតឡើង ដើម្បីឲ្យប្រជាជនជឿថា បើសិនជាពួកគេមិនធ្វើតាមពាក្យសំដីរបស់គេទេ គឺជំទាស់ចិត្តតួអង្គដ៏ពុំស្គាល់មួយ ដែលពួកគេនិយាយថា គឺជាព្រះ — ជាតួអង្គមួយដែលគ្មានអ្នកណាដែលបានឃើញ ឬស្គាល់ ដែលជាតួអង្គដែលមិនដែលមាន ឬមិនមាននៅពេលខាងមុខ ។

២៩ ឥឡូវនេះ កាលដែលសង្ឃជាន់ខ្ពស់ និងមេចៅក្រមបានឃើញភាពរឹងរូសនៃចិត្តរបស់វា មែនហើយ កាលពួកគេបានឃើញថា បុរសនោះបណ្ដុះបង្អាប់រហូតដល់ព្រះ ពួកគេពុំឆ្លើយតបនឹងពាក្យរបស់អ្នកនោះឡើយ; តែគេបញ្ជាឲ្យចងអ្នកនោះវិញ; ហើយពួកគេបាន ប្រគល់វាទៅក្នុងដៃរបស់នាយទាហ៊ានទាំងឡាយ ហើយបានបញ្ជូនវាទៅដែនដីសារ៉ាហិមឡា ដើម្បីគេអាចនាំវាទៅចំពោះអាលម៉ា និងមេចៅក្រម ដែលត្រួតត្រាលើអស់ទាំងដែនដី ។

៣០ ហើយហេតុការណ៍បានកើតឡើងថា កាលដែលវាត្រូវគេនាំទៅចំពោះអាលម៉ា និងមេចៅក្រម នោះវាបានធ្វើកិរិយាដូចជា វាបានធ្វើនៅក្នុងដែនដីគេឌានដែរ មែនហើយ វានៅតែបន្ត[ក]ការប្រមាថ ។

៣១ ហើយវាបានតម្លើងសម្លេង ដោយនិយាយពាក្យ[ក]ក្រអេឺងដាក់មុខអាលម៉ា ហើយបានជេរប្រមាថដល់ពួកសង្ឃ និងពួកគ្រូបង្រៀន ដោយចោទប្រកាន់ពួកគេថា បានដឹកនាំប្រជាជនឲ្យវង្វេង ទៅតាមសណ្ដាប់ដ៏ល្ងិតល្ងង់ទាំងឡាយ នៃពួកអយ្យកោរបស់គេ ដោយសារចង់បំប៉នខ្លួនលើការងាររបស់ប្រជាជន ។

៣២ ឥឡូវនេះ អាលម៉ាបាននិយាយទៅវាថា៖ តើអ្នកដឹងថា យើងមិនបានបំប៉នខ្លួនលើការងាររបស់ប្រជាជននេះទេ; ត្បិតមើលចុះ ខ្ញុំបានធ្វើការចាប់តាំងពីការចាប់ផ្ដើមរជ្ជកាលនៃពួកចៅក្រមរហូតមកដល់ពេលឥឡូវនេះ ធ្វើការដោយដៃខ្ញុំផ្ទាល់ ដើម្បីចិញ្ចឹមខ្លួនខ្ញុំ ទោះបីខ្ញុំត្រូវធ្វើដំណើរពាសពេញដែនដី ដើម្បីប្រកាសប្រាប់ព្រះបន្ទូលនៃព្រះ ដល់ប្រជាជនខ្ញុំក៏ដោយ ។

៣៣ ហើយទោះបីកិច្ចការនឿយហត់ជាច្រើន ដែលខ្ញុំបានធ្វើនៅក្នុងសាសនាចក្រក៏ដោយ គង់តែខ្ញុំមិនដែលបានទទួល ទោះជា មួយ[ក]ស៊ីណាញ ដើម្បីការងារខ្ញុំដែរ; ឯបងប្អូនខ្ញុំក៏មិនដែលបានទទួលអ្វីដែរ លើកលែងតែនៅក្នុងវេទិកាជំនុំជំរះ ហើយនៅពេលនោះយើងបានទទួលត្រឹមតែចំនួន ដែលស្របទៅតាមច្បាប់ សំរាប់តែពេលវេលារបស់យើងប៉ុណ្ណោះ ។

៣៤ ហើយឥឡូវនេះ បើសិនជាយើងមិនទទួលអ្វីទាំងអស់សំរាប់កម្លាំងកាយរបស់យើង នៅក្នុងសាសនាចក្រទេ តើយើងបាន ប្រយោជន៍អ្វី ដែលធ្វើការនៅក្នុងសាសនាចក្រលើកលែងតែប្រកាសប្រាប់សេចក្ដីពិត ដើម្បីយើងអាចបានអរ[ក]រីករាយ ក្នុងសេចក្ដីអំណរ របស់បងប្អូនយើងប៉ុណ្ណោះ ?

៣៥ លំដាប់នោះ ហេតុអ្វីបានជាអ្នកនិយាយថា យើងផ្សាយប្រាប់ប្រជាជននេះ ដើម្បីរកកំរៃ នៅពេលដែលខ្លួនអ្នកផ្ទាល់ក៏ដឹងថា យើងមិនបានទទួលកំរៃទេនោះ ? ហើយឥឡូវនេះ តើអ្នកជឿថា យើងបញ្ឆោតប្រជាជននេះ ដែលបណ្ដាលឲ្យមានសេចក្ដីអំណរក្នុង ចិត្តគេបែបនេះឬ ?

៣៦ ហើយកូរីហូរបានឆ្លើយតបទៅលោកថា បាទ ។

៣៧ ហើយលំដាប់នោះ អាលម៉ាបាននិយាយទៅវាថា៖ តើអ្នកជឿថា មានព្រះទេ ?

៣៨ ហើយវាឆ្លើយថា ទេ ។

៣៩ ឥឡូវនេះ អាលម៉ាបាននិយាយទៅវាថា ៖ តើអ្នកនឹងបដិសេធទៀតថា គ្មានព្រះ ហើយក៏បដិសេធផងដែរថា គ្មានព្រះគ្រីស្ទឬ ? ត្បិតមើលចុះ ខ្ញុំប្រាប់អ្នកថា ខ្ញុំដឹងថា មានព្រះមួយអង្គ ហើយក៏ដឹងផងថា ព្រះគ្រីស្ទនឹងយាងមក ។

៤០ ហើយឥឡូវនេះ តើអ្នកមានភស្តុតាងអ្វី ដែលថា គ្មាន[ក]ព្រះ ឬថា ព្រះគ្រីស្ទនឹងពុំយាងមកទេនោះ ? ខ្ញុំសូមប្រាប់អ្នកថា អ្នកគ្មាន ភស្តុតាងអ្វីទាំងអស់ លើកលែងតែពាក្យរបស់អ្នកប៉ុណ្ណោះ ។

៤១ ប៉ុន្តែមើលចុះ ខ្ញុំមានគ្រប់ការណ៍ទាំងអស់ដែលជា[ក]ទីបន្ទាល់ថា ការណ៍ទាំងនេះពិត; ហើយអ្នកក៏មានគ្រប់ការណ៍ទាំងអស់ ជាទីបន្ទាល់ដល់អ្នកថា ការណ៍ទាំងនោះពិតដែរ; ហើយតើអ្នកនឹងបដិសេធការណ៍ទាំងនោះឬ ? តើអ្នកជឿទេថា ការណ៍ទាំងនេះពិត ?

៤២ មើលចុះ ខ្ញុំដឹងថា អ្នកជឿ តែអ្នកត្រូវវិញ្ញាណភូតកុហកចូលក្នុងខ្លួនអ្នក; ហើយអ្នកបានច្រានចោលព្រះវិញ្ញាណនៃព្រះ ដើម្បី កុំឲ្យព្រះវិញ្ញាណមានកន្លែងនៅក្នុងអ្នក; ប៉ុន្តែអារក្សមានអំណាចទៅលើអ្នក ហើយវានាំអ្នកទៅគ្រប់កន្លែង ដោយធ្វើនូវគ្រប់កលល្បិច ដើម្បីវាអាចបំផ្លាញកូនចៅនៃព្រះចោល ។

៤៣ ហើយឥឡូវនេះ កូរីហូរបាននិយាយទៅអាលម៉ាថា៖ បើ

៣០ *ក* ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.
៣១ *ក* ហេលេ. ១៣:២២.
៣៣ *ក* អាលម៉ា ១១:៣.
៣៤ *ក* ស.ប. សេចក្ដីអំណរ.
៤០ *ក* ទំនុក. ១៤:១.
៤១ *ក* ស.ប. សាក្សី.

សិនជាលោកបង្ហាញខ្ញុំនូវ[ក]ទីសំគាល់មួយ ដើម្បីឲ្យខ្ញុំអាចបានបរិវត្ត
ថា មានព្រះមួយអង្គ មែនហើយ ចូរបង្ហាញខ្ញុំថា ទ្រង់មាន
ព្រះចេស្ដា ហើយនៅពេលនោះ ខ្ញុំនឹងត្រូវបានបរិវត្តអំពីសេចក្ដី
ពិតនៃសំដីរបស់ លោក ។
៤៤ ប៉ុន្តែ អាលម៉ាបាននិយាយទៅវាថា៖ អ្នកបានទទួល
ទីសំគាល់ល្មមគ្រប់គ្រាន់ហើយ; តើអ្នកចង់សាកល្បងព្រះរបស់
អ្នកធ្វើអ្វី ? តើអ្នកនៅតែនិយាយថា ចូរបង្ហាញខ្ញុំនូវទីសំគាល់មួយ
នៅពេលដែលអ្នកមានទីបន្ទាល់នៃបងប្អូនរបស់អ្នក[ក]អស់ទាំងនេះ
និងអស់ទាំង ពួកព្យាការីដ៏បរិសុទ្ធផងឬ ? បទគម្ពីរទាំងឡាយត្រូវ
បានបើកត្រដាងនៅចំពោះអ្នក មែនហើយ ហើយគ្រប់ការណ៍
[ខ]ទាំងអស់បង្ហាញថា មានព្រះមួយអង្គមែន; មែនហើយ ហើយ
សូម្បីតែផែនដី និងរបស់សព្វសារពើដែលនៅលើ[គ]ផ្ទៃផែនដី មែន
ហើយ [ឃ]និងចលនារបស់ផែនដី មែនហើយ ព្រមទាំង[ង]ពិភពទាំង
អស់ ដែលធ្វើចលនាតាមទម្រង់ធម្មតារបស់គេ ក៏ធ្វើជាសាក្សីថា
មានព្រះបង្កបង្កើតដ៏មហិមាមួយអង្គ ។
៤៥ ហើយតើអ្នកនៅតែដើរគ្រប់កន្លែង ដឹកនាំចិត្តប្រជាជននេះ
ឲ្យវង្វេង ដោយធ្វើបន្ទាល់ទៅកាន់គេថា គ្មានព្រះឬ ? ហើយតើ
អ្នកនៅតែបដិសេធនឹងសាក្សីអស់ទាំងនេះឬ ? ហើយវានិយាយ
ថា៖ បាទ ខ្ញុំនឹងបដិសេធ លើកលែងតែលោកនឹងបង្ហាញទីសំគាល់
មួយដល់ខ្ញុំ ។
៤៦ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាលម៉ា
បាននិយាយទៅវាថា៖ មើលចុះ ខ្ញុំព្រួយចិត្ត ដោយព្រោះអ្នក
មានចិត្ត រឹងរូស មែនហើយ ដោយព្រោះអ្នកនៅតែទាស់
នឹងវិញ្ញាណនៃការពិត ដើម្បីឲ្យព្រលឹងអ្នកត្រូវបំផ្លាញបង់ ។
៤៧ ប៉ុន្តែមើលចុះ ជាការប្រសើរបើព្រលឹងអ្នកត្រូវបាត់បង់
ជាជាងទុកឲ្យរូបអ្នកធ្វើជាផ្លូវនាំព្រលឹងជាច្រើនទៅក្នុងការបំផ្លិច
បំផ្លាញ ដោយការភូតកុហករបស់អ្នក និងដោយពាក្យ
បញ្ចើចបញ្ចើររបស់អ្នក; ហេតុដូច្នេះហើយ បើសិនជាអ្នកនឹង
បដិសេធទៀត មើលចុះ ព្រះទ្រង់នឹងវាយអ្នក ដើម្បីឲ្យអ្នកក្លាយ
ទៅជាគ ដើម្បីកុំឲ្យអ្នកបើកមាត់អ្នកទៀត ដើម្បីកុំឲ្យអ្នកបញ្ឆោត
ប្រជាជននេះទៀត ឡើយ ។
៤៨ ឥឡូវនេះ កូរីហ៊ូរបាននិយាយទៅលោកថា៖ ខ្ញុំមិន
បដិសេធថា មានព្រះរស់នៅទេ តែខ្ញុំមិនជឿថា មានព្រះ
មួយអង្គឡើយ; ហើយខ្ញុំក៏និយាយផងថា លោកមិនដឹងថា មាន
ព្រះទេ; ហើយលើកលែងតែលោកបង្ហាញទីសំគាល់មួយដល់ខ្ញុំ
នោះខ្ញុំនឹងពុំជឿឡើយ ។
៤៩ ឥឡូវនេះ អាលម៉ាបាននិយាយទៅវាថា៖ នេះខ្ញុំនឹងឲ្យអ្នក
ទុកជាទីសំគាល់មួយថា អ្នកនឹងត្រូវក្លាយ[ក]ទៅជាគ ស្របតាម
ពាក្យ សំដីរបស់ខ្ញុំ; ហើយខ្ញុំនិយាយថា ដោយនូវព្រះនាមនៃព្រះ
អ្នកនឹងត្រូវក្លាយជាគ ដើម្បីកុំឲ្យអ្នកចេញវាចាបានទៀតឡើយ ។
៥០ ឥឡូវនេះ កាលអាលម៉ាបាននិយាយពាក្យទាំងនេះហើយ
នោះកូរីហ៊ូរក៏ក្លាយទៅជាគ ដើម្បីកុំឲ្យវាអាចចេញវាចាបាន
ទៀត ឡើយ ស្របតាមពាក្យសំដីរបស់អាលម៉ា ។
៥១ ហើយឥឡូវនេះ កាលមេចៅក្រមបានឃើញការណ៍
នេះហើយ នោះលោកក៏លូកដៃមកសរសេរ ឲ្យកូរីហ៊ូរមើលថា៖
តើអ្នក ត្រូវបានបរិវត្តអំពីព្រះចេស្ដានៃព្រះហើយឬនៅ? តើអ្នក
ណាទៅដែលអ្នកចង់ឲ្យអាលម៉ាបង្ហាញទីសំគាល់របស់លោក ?
តើអ្នកចង់ឲ្យ លោកធ្វើឲ្យអ្នកផ្សេងទៀតវេទនា ដើម្បីបង្ហាញ
ទីសំគាល់មួយដល់អ្នកឬ ? មើលចុះ លោកបានបង្ហាញទីសំគាល់
មួយដល់អ្នកហើយ ហើយឥឡូវនេះ តើអ្នកចង់ប្រកែកទៀតឬ ?
៥២ ហើយកូរីហ៊ូរបានលូកដៃមកសរសេរថា៖ ខ្ញុំដឹងថា ខ្ញុំគ
ព្រោះខ្ញុំពុំអាចនិយាយបាន; ហើយខ្ញុំដឹងថា គ្មានអ្វីសោះឡើយ
លើកលែងតែព្រះចេស្ដានៃព្រះប៉ុណ្ណោះ ដែលអាចនាំការណ៍
នេះមកលើខ្ញុំបាន; មែនហើយ ហើយខ្ញុំ[ក]បានដឹងជារហូតមកថា
មានព្រះមួយអង្គមែន ។
៥៣ ប៉ុន្តែមើលចុះ អារក្សបាន[ក]បញ្ឆោតខ្ញុំ; ព្រោះ[ខ]វាបានលេច
មកឲ្យខ្ញុំឃើញ នៅក្នុងរូបរាងជាទេវតាមួយរូប ហើយបាននិយាយ
មក ខ្ញុំថា៖ ចូរអ្នកទៅទាមទារប្រជាជននេះមកវិញ ព្រោះពួកគេ
ទាំងអស់គ្នា បានដើរវង្វេងតាមព្រះដ៏ពុំស្គាល់មួយអង្គ ។ ហើយវា
បានប្រាប់ ខ្ញុំថា៖ [គ]គឺគ្មានព្រះទេ; មែនហើយ វាបានបង្រៀនខ្ញុំនូវអ្វី
ៗដែលខ្ញុំត្រូវនិយាយ ។ ហើយខ្ញុំបានបង្រៀនពាក្យពេចន៍របស់វា;
ហើយខ្ញុំបាន បង្រៀនពាក្យទាំងនោះ ព្រោះអីពាក្យទាំងនោះធ្វើឲ្យ
ស្កប់ស្កល់ដល់គំនិតខាង[ឃ]រូបកាយ; ហើយខ្ញុំបានបង្រៀនពាក្យ
ទាំងនោះ រហូតដល់ ខ្ញុំបានទទួលការជោគជ័យដ៏ច្រើន ដរាប

៤៣ *ក* យ៉ាកុប ៧:១៣–២១;
គ. និង ស. ៤៦:៨–៩.
ស.ប. ទីសំគាល់.
៤៤ *ក* ម៉ូសាយ ១៣:៣៣–៣៤.
*ខ* ទំនុក. ១៩:១; គ. និង ស. ៨៨:៤៧.
*គ* យ៉ូប ១២:៧–១០.
*ឃ* ហេលេ. ១២:១១–១៥.
*ង* ម៉ូសេ ៦:៦៣.
៤៧ *ក* ១ នីហ្វៃ ៤:១៣.
៤៩ *ក* ២ របា. ១៣:២០.
៥២ *ក* អាលម៉ា ៣០:៤២.
៥៣ *ក* យ៉ាកុប ៧:១៤.
*ខ* ២ កូរិន. ១១:១៤; ២ នីហ្វៃ ៩:៩.
*គ* ទំនុក. ១០:៤.
*ឃ* ស.ប. ខាងរូបកាយ.

ដល់ខ្ញុំជឿមែនទែនថា ពាក្យទាំងនោះពិត; ហើយដោយហេតុនេះ ខ្ញុំតទល់នឹងសេចក្ដីពិត រហូត ដល់ខ្ញុំបាននាំមកនូវបណ្ដាសាដ៏ធំនេះមកលើខ្លួន ។

៥៤ ឥឡូវនេះ កាលវាបាននិយាយយ៉ាងនេះហើយ នោះវាក៏បានសុំអង្វរអាលម៉ា ឲ្យអធិស្ឋានដល់ព្រះ ដើម្បីឲ្យពាក្យបណ្ដាសា នេះបានដកចេញពីវា ។

៥៥ តែអាលម៉ាបាននិយាយទៅវាថា៖ បើសិនជាពាក្យបណ្ដាសានេះត្រូវដកចេញពីអ្នក នោះអ្នកច្បាស់ជា នឹងដឹកនាំចិត្តប្រជាជន នេះឲ្យវង្វេងទៀត; ហេតុដូច្នេះហើយ ពាក្យបណ្ដាសានេះត្រូវដាក់លើអ្នក តាមព្រះហឫទ័យនៃព្រះចុះ ។

៥៦ ហើយហេតុការណ៍បានកើតឡើងថា ពាក្យបណ្ដាសានេះក៏ពុំបានដកចេញពីកូរីហ៊ូរទេ; តែវាត្រូវគេបណ្ដេញចេញ ហើយដើរ ពីផ្ទះមួយទៅផ្ទះមួយ សុំទានរកអាហារចិញ្ចឹមខ្លួន ។

៥៧ ឥឡូវនេះ ដំណឹងអំពីអ្វីៗដែលបានកើតឡើងដល់កូរីហ៊ូរនេះបានផ្សាយភ្លាមៗ ទូទៅអស់ទាំងដែនដី; មែនហើយ សេចក្ដីប្រកាសត្រូវបានផ្សាយដោយមេចៅក្រម ទៅដល់អស់ទាំងប្រជាជននៅក្នុងដែនដី ដោយប្រកាសទៅដល់ពួកជនដែលបានជឿដល់ ពាក្យពេចន៍របស់កូរីហ៊ូរថា ពួកគេត្រូវតែប្រែចិត្តឲ្យបានឆាប់រហ័ស ក្រែងលោសេចក្ដីជំនុំជំរះដដែលនេះ នឹងធ្លាក់មកលើពួកគេដែរ ។

៥៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេទាំងអស់គ្នាត្រូវបានបរិវត្តអំពីអំពើទុច្ចរិតរបស់កូរីហ៊ូរ; ហេតុដូច្នេះហើយ ពួកគេទាំងអស់គ្នាបានប្រែចិត្តជឿដល់ព្រះអម្ចាស់ទៀត; ហើយការណ៍នេះបានបញ្ចប់អំពើទុច្ចរិតតាមរបៀបកូរីហ៊ូរ ។ ហើយកូរីហ៊ូរបានដើរ ពីផ្ទះមួយទៅផ្ទះមួយ សុំទានអាហារយកមកចិញ្ចឹមជីវិត ។

៥៩ ហើយហេតុការណ៍បានកើតឡើងថា នៅពេលវាចេញទៅក្នុងចំណោមប្រជាជន មែនហើយ គឺក្នុងចំណោមប្រជាជន ដែលបានបំបែកខ្លួនចេញពីពួកសាសន៍នីហ្វៃ ហើយបានហៅខ្លួនគេថាពួកសាសន៍សូរ៉ាំ ដែលត្រូវបានដឹកនាំ ដោយបុរសម្នាក់ឈ្មោះសូរ៉ាំ — ហើយពេលដែលវាចេញទៅក្នុងចំណោមពួកនេះមើលចុះ វាត្រូវមនុស្សរត់ជាន់លើ រហូតដល់ស្លាប់ ។

៦០ ម្ល៉ោះហើយ យើងឃើញទីបញ្ចប់របស់វា ដែលបាន[ក]បង្ខូចផ្លូវទាំងឡាយ[ខ]នៃព្រះអម្ចាស់; ម្ល៉ោះហើយ យើងឃើញថាអារក្ស ពុំដែលគាំទ្រដល់កូនចៅរបស់វាទេ នៅ[គ]ថ្ងៃចុងក្រោយបង្អស់ តែវាទាញពួកគេយ៉ាងឆាប់រហ័ស ទៅកាន់ស្ថាននរកវិញ ៕

## ជំពូកទី ៣១

*អាលម៉ាដឹកនាំក្រុមបេសកកម្មមួយទៅកែប្រែពួកសូរ៉ាំ ដែលក្បត់សាសនាមកវិញ — ពួកសាសន៍សូរ៉ាំ មិនទទួលស្គាល់ព្រះគ្រីស្ទ, ជឿតាមការជ្រើសរើសដែលខុស, ហើយថ្វាយបង្គំដោយការអធិស្ឋានដែល តែងទុកជាមុន– សាសនទូតទាំងឡាយពោរពេញដោយ ព្រះវិញ្ញាណបរិសុទ្ធ — ការទុក្ខវេទនាទាំងឡាយរបស់គេ ត្រូវបានលេបទៅដោយសេចក្ដីអំណរ នៅក្នុងព្រះគ្រីស្ទ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីកូរីហ៊ូរបានបាត់ទៅ នោះអាលម៉ាបានទទួលដំណឹងថា ពួកសាសន៍សូរ៉ាំកំពុងតែ បង្ខូចផ្លូវទាំងឡាយនៃព្រះអម្ចាស់ ហើយសូរ៉ាំដែល[ក]ជាអ្នក[ខ]ដឹកនាំរបស់គេ កំពុងតែដឹកនាំចិត្តប្រជាជនឲ្យក្រាប[គ]ថ្វាយបង្គំដល់រូបព្រះ ដែលគទាំងឡាយ ចិត្តលោកក៏ចាប់ផ្ដើមចុកចាប់ទៀត ដោយព្រោះអំពើទុច្ចរិតរបស់ប្រជាជននេះ ។

២ ព្រោះនេះគឺជាហេតុដែលនាំឲ្យអាលម៉ាមានការ[ក]សោកសៅយ៉ាងធំ ដោយដឹងពីអំពើទុច្ចរិត នៅក្នុងចំណោមប្រជាជននេះ; ហេតុដូច្នេះហើយ ចិត្តលោកក្រៀមក្រំជាអតិបរមា ដោយព្រោះការបែកគ្នានៃពួកសាសន៍សូរ៉ាំ ពីពួកសាសន៍នីហ្វៃ ។

៣ ឥឡូវនេះ ពួកសាសន៍សូរ៉ាំបានប្រជុំគ្នាមកនៅដែនដីមួយដែលគេហៅថា អាន់ទិអូនុម គឺនៅខាងកើតដែនដីសារ៉ាហិមឡាគឺនៅជិតតាមមាត់សមុទ្រ គឺនៅខាងត្បូងដែនដីយើសុន ដែលនៅតាមទីរហោស្ថានខាងត្បូងដែរ គឺជាទីរហោស្ថាន ដែលមានពោរ ពេញទៅដោយពួកលេមិន ។

៤ ឥឡូវនេះ ពួកនីហ្វៃភិតភ័យជាខ្លាំង ខ្លាចក្រែងពួកសូរ៉ាំធ្វើការទាក់ទងជាមួយនឹងពួកលេមិន ហើយការណ៍នោះគឺជាហេតុដែល នឹងនាំឲ្យមានការខូចខាតយ៉ាងធំដល់ពួកនីហ្វៃ ។

៥ ហើយឥឡូវនេះ ដោយការ[ក]ផ្សាយ[ខ]ព្រះបន្ទូល មានបណ្ដាការ

---

៦០ *ក* ស.ប. អារក្ស.
*ខ* អាលម៉ា ៣:២៦–២៧; ៥:៤១–៤២; គ. និង ស. ២៩:៤៥.
*គ* ស.ប. ស្ថាននរក.

៣១ ១*ក* និក្ខ. ២០:៥; ម៉ូសាយ ១៣:១៣.
*ខ* ២ នីហ្វៃ ៩:៣៧. ស.ប. ការថ្វាយបង្គំរូបព្រះ.
*គ* អាលម៉ា ៣៥:១៥.
២ *ក* ម៉ូសាយ ២៨:៣; ៣ នីហ្វៃ ១៧:១៤; ម៉ូសេ ៧:៤១.
៥ *ក* អេណុស ១:២៣; អាលម៉ា ៤:១៩. ស.ប. ផ្សាយ.
*ខ* ហេព្រើរ ៤:១២; យ៉ាកុប ២:៨; អាលម៉ា ៣៦:២៦.

ដ៏ធំក្នុងការដឹកនាំប្រជាជន ឲ្យធ្វើនូវអ្វីៗដែលត្រឹមត្រូវ — មែន
ហើយ វាមានប្រសិទ្ធភាពទៅលើគំនិតមនុស្សច្រើនជាងផ្លែដាវ
ឬអ្វីផ្សេងៗទៀត ដែលកើតឡើងដល់គេ — ហេតុដូច្នេះហើយ
អាលម៉ាបាន គិតថា ជាការចាំបាច់ ដែលគេត្រូវពិសោធគុណ
ធម៌នៃព្រះបន្ទូលនៃព្រះ ។

៦ ហេតុដូច្នេះហើយ លោកបាននាំអាំមូ៉ន និងអើរ៉ុន
និងអោមណើរ; រីឯហិមណៃវិញ លោកបានទុកឲ្យនៅក្នុងសាសនា
ចក្រនៅ សារ៉ាហិមឡា; ប៉ុន្តែឯអ្នកបីនាក់មុននោះ លោកបាននាំ
ទៅជាមួយនឹងលោក ព្រមទាំងអាមូលេក និងស៊ីអែស្រ៉ុម ដែល
នៅឯមេលេក ហើយលោកក៏បាននាំកូនប្រុសរបស់លោ
កពីរនាក់ទៅផងដែរ ។

៧ ឥឡូវនេះ កូនប្រុសច្បងលោកមិនយកទៅជាមួយគេទេ ហើយ
គាត់មានឈ្មោះថា ហេលេមិន; រីឯឈ្មោះនៃអ្នកទាំងពីរដែល
លោកបានយកទៅជាមួយ គឺស៊ិបឡុន និងកូរីអានតុន; ហើយនេះ
គឺជាឈ្មោះនៃអ្នកដែលទៅជាមួយនឹងលោក ទៅក្នុងចំណោម
ពួកសូរាំ ដើម្បីទៅផ្សាយព្រះបន្ទូលដល់គេ ។

៨ ឥឡូវនេះ ពួកសូរាំ គឺជាអ្នកដែលបែកចេញពីពួកសាសន៍
នីហ្វៃ; ហេតុដូច្នេះហើយ ពួកគេធ្លាប់បានទទួលព្រះបន្ទូលនៃព្រះ
ដែល បានផ្សាយដល់គេពីមុនដែរ ។

៩ ប៉ុន្តែ ពួកគេបានធ្លាក់ទៅក្នុងកំហុសយ៉ាងធំ ព្រោះគេ
ពុំប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ និងព្រះក្រិត្យក្រមទាំង
ឡាយ របស់ទ្រង់ ស្របតាមក្រិត្យវិន័យលោកម៉ូសេទេ ។

១០ ហើយពួកគេក៏មិនគោរពតាមការប្រព្រឹត្តទាំងឡាយ
នៃសាសនាចក្រ ដើម្បីបន្តការអធិស្ឋាន និងការទូលអង្វរដល់ព្រះ
ជា រៀងរាល់ថ្ងៃ ដើម្បីកុំឲ្យគេត្រូវធ្លាក់ទៅក្នុងការល្បួងនោះឡើយ ។

១១ មែនហើយ សរុបសេចក្ដីមក ពួកគេបានបង្ខូចផ្លូវទាំង
ឡាយនៃព្រះអម្ចាស់ ជាច្រើនលើកច្រើនគ្រាណាស់; ហេតុ
ដូច្នេះហើយ ដោយហេតុនេះ អាលម៉ា និងបងប្អូនលោក បាន
ចូលទៅក្នុងដែនដីនោះ ដើម្បីទៅផ្សាយព្រះបន្ទូលដល់ពួកគេ ។

១២ ឥឡូវនេះ កាលដែលពួកគេបានមកដល់ដែនដីនោះហើយ
មើលចុះ គេមានសេចក្ដីអស្ចារ្យជាខ្លាំង ដោយបានឃើញថា ពួក
សាសន៍សូរាំ បានសង់សាលាជំនុំទាំងឡាយ ហើយពួកគេបាន
ជួបជុំគ្នានៅថ្ងៃមួយ ក្នុងមួយសប្ដាហ៍ គឺជាថ្ងៃដែលគេបានហៅថា
ថ្ងៃនៃព្រះអម្ចាស់; ហើយពួកគេបានថ្វាយបង្គំ តាមរបៀបម្យ៉ាង
ដែលអាលម៉ា និងបងប្អូនលោកមិនដែលបានឃើញពីមុនសោះ;

១៣ ព្រោះពួកគេមានកន្លែងមួយដែលសង់ឡើង
នៅកណ្ដាលសាលាជំនុំរបស់គេ ជាកន្លែងមួយសំរាប់ឈរ ដែល
នៅខ្ពស់ជាង ក្បាល; ហើយលើនោះ មានកន្លែងសំរាប់តែ
មនុស្សម្នាក់ប៉ុណ្ណោះ ។

១៤ ហេតុដូច្នេះហើយ អ្នកណាចង់ថ្វាយបង្គំ នោះត្រូវ
ទៅឈរនៅលើនោះ ហើយលើកដៃតម្រង់ទៅស្ថានសួគ៌ ហើយ
ស្រែកដោយ សម្លេងយ៉ាងខ្លាំងថា៖

១៥ បរិសុទ្ធ ឱព្រះដ៏បរិសុទ្ធអើយ; យើងខ្ញុំជឿថា ព្រះអង្គគឺជា
ព្រះ ហើយយើងខ្ញុំជឿថា ព្រះអង្គបរិសុទ្ធ ហើយថា ព្រះអង្គជាព្រះ
វិញ្ញាណពីមុន ហើយថា ព្រះអង្គជាព្រះវិញ្ញាណនៅសព្វថ្ងៃនេះ
ហើយថា ព្រះអង្គជាព្រះវិញ្ញាណរហូតតទៅ ។

១៦ ឱព្រះដ៏បរិសុទ្ធអើយ យើងខ្ញុំជឿថា ព្រះអង្គបាន
បំបែកយើងចេញពីបងប្អូនយើង; ហើយយើងខ្ញុំមិនជឿ តាម
សណ្ដាប់នៃបងប្អូន យើងខ្ញុំ ដែលបានឲ្យបន្តមកដល់គេ ដោយ
សារការរវើរវាយនៃពួកអយ្យកោរបស់គេទេ; ប៉ុន្តែយើងខ្ញុំជឿថា
ព្រះអង្គបានរើសតាំង យើងខ្ញុំ ទុកជាកូនចៅដ៏បរិសុទ្ធរបស់ព្រះអង្គ;
ហើយព្រះអង្គក៏បានធ្វើឲ្យយើងខ្ញុំដឹងដែរថា នឹងពុំមានព្រះគ្រីស្ទទេ ។

១៧ ប៉ុន្តែ ព្រះអង្គនៅតែដដែល ទោះពីថ្ងៃម្សិល ថ្ងៃនេះ
និងរហូតតទៅ; ហើយព្រះអង្គបានរើសតាំងយើងខ្ញុំ ដើម្បីឲ្យ
យើងខ្ញុំបាន សង្គ្រោះ នៅពេលអ្នកឯទៀតនៅជុំវិញយើងខ្ញុំ ត្រូវ
បានរើសតាំងឡើង ដើម្បីបោះចោលទៅក្នុងស្ថាននរក; ឱព្រះអង្គ
អើយ ដោយសារ បរិសុទ្ធភាពនេះ យើងខ្ញុំសូមអរព្រះគុណដល់
ព្រះអង្គ; ហើយយើងខ្ញុំក៏សូមអរព្រះគុណដល់ព្រះអង្គ ដែលបាន
រើសតាំងយើងខ្ញុំ ដើម្បីកុំឲ្យ យើងខ្ញុំត្រូវបានដឹកនាំឲ្យវង្វេងទៅតាម
សណ្ដាប់ដ៏ឆ្កួតលីលា របស់បងប្អូនយើងខ្ញុំ ដែលចងគេចុះទៅនឹង
ជំនឿជឿដល់ព្រះគ្រីស្ទ ដែលដឹក នាំចិត្តគេឲ្យ
ខ្វាត់ព្រាត់ចេញឆ្ងាយពីព្រះអង្គ ដែលជាព្រះរបស់យើងខ្ញុំ ។

១៨ ហើយមួយទៀត យើងខ្ញុំសូមអរព្រះគុណដល់ព្រះអង្គ
ឱព្រះអង្គអើយ ដែលយើងខ្ញុំជាប្រជារាស្ត្រដ៏ជំរើស និងបរិសុទ្ធ
មួយ ។ អាម៉ែន ។

១៩ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាលម៉ា

៥ *គ* យ៉ារ៉ុម ១:១១–១២;
គ. និង ស. ១១:២.
៧ *ក* ស.ប. ហេលេមិន, កូនប្រុសរបស់
អាលម៉ា.
*ខ* អាលម៉ា ៣០:៥៩.
៨ *ក* អាលម៉ា ២៤:៣០.
៩ *ក* ស.ប. សេចក្ដីក្បត់សាសនា.
១៤ *ក* ម៉ាថាយ ៦:១–៧.
១៦ *ក* អាលម៉ា ៣៨:១៣–១៤.
*ខ* អេសាយ ៦៥:៣, ៥.
១៧ *ក* ស.ប. ឥតប្រយោជន៍,
ការឥតប្រយោជន៍.

និងបងប្អូនលោក និងកូនប្រុសលោក បានឮពាក្យអធិស្ឋាន
ទាំងនេះហើយ នោះពួកគេមានសេចក្ដីអស្ចារ្យដ៏ហួសកំរិត ។
២០ ត្បិតមើលចុះ មនុស្សគ្រប់រូបបានឡើងទៅសូត្រនូវ
ពាក្យអធិស្ឋានដូចៗគ្នា ។
២១ ឥឡូវនេះ ពួកគេបានហៅទីនោះថា រ៉ាមីអុមតុម ដែល
បកប្រែមកថា កន្លែងឈរដ៏បរិសុទ្ធ ។
២២ ឥឡូវនេះ នៅកន្លែងឈរនោះពួកគេបានអធិស្ឋាន គឺមនុស្ស
គ្រប់រូប នូវពាក្យដដែលៗទៅដល់ព្រះ ដោយអរព្រះគុណដល់
ព្រះ របស់គេ ដែលទ្រង់បានរើសពួកគេ ហើយដែលទ្រង់មិនបាន
នាំពួកគេ ឲ្យដើរវង្វេងតាមសណ្ដាប់របស់បងប្អូនគេ ហើយដែល
ចិត្តគេមិនបាន នាំឲ្យជឿដល់ការណ៍ទាំងឡាយ ដែលនឹងកើតឡើង
នៅពេលខាងមុខ ដែលពួកគេពុំដឹងអ្វីទាល់តែសោះ ។
២៣ ឥឡូវនេះ បន្ទាប់ពីប្រជាជនទាំងអស់គ្នាបានថ្លែងអំណរគុណ
តាមរបៀបនេះហើយ នោះពួកគេក៏ត្រឡប់ទៅផ្ទះគេវិញ
ដោយ[ក]មិន និយាយអំពីព្រះរបស់គេទៀតឡើយ រហូតដល់ពួកគេ
បានជួបជុំគ្នាទៀត នៅកន្លែងឈរដ៏បរិសុទ្ធនោះ ដើម្បី
ថ្លែងអំណរគុណតាមរបៀបនោះ ។
២៤ [ក]ឥឡូវនេះ កាលអាលម៉ាបានឃើញការណ៍នេះ នោះចិត្ត
លោកព្រួយបារម្ភ; ព្រោះលោកបានឃើញថា ពួកគេជាប្រជាជន
មួយដ៏ទុច្ចរិត និងខូច; មែនហើយ លោកបានឃើញថា ចិត្តពួកគេ
ត្រូវបានភ្ជាប់ទៅលើមាស និងទៅលើប្រាក់
និងទៅលើរបស់របរដ៏មានតម្លៃគ្រប់យ៉ាង ។
២៥ មែនហើយ ហើយលោកបានឃើញថា ចិត្តពួកគេត្រូវ
បាន[ក]លើកឡើង ដល់ការអួតអាងយ៉ាងធំ នៅក្នុងសេចក្ដី
ឆ្មើងឆ្មៃរបស់គេ ។
២៦ ហើយលោកបានបន្លឺសម្លេងទៅលើមេឃ ហើយ[ក]ស្រែកថា៖
ឱព្រះអម្ចាស់អើយ តើដល់ពេលណាទៅ ដែលទ្រង់ទុកឲ្យអ្នកបំរើ
របស់ ទង់ទាំងឡាយរស់នៅស្ថានក្រោមនេះ ក្នុងសាច់ឈាម
ដើម្បីមើលអំពើទុច្ចរិតដ៏អាក្រក់បែបនេះ នៅក្នុងចំណោមកូនចៅ
មនុស្ស ?
២៧ មើលចុះ ឱព្រះអង្គអើយ ពួកគេ[ក]អំពាវនាវដល់ព្រះអង្គ តែ
ចិត្តរបស់គេត្រូវបានលេបទៅក្នុងសេចក្ដីឆ្មើងឆ្មៃរបស់គេ ។ មើលចុះ
ឱព្រះអង្គអើយ ពួកគេអំពាវនាវដល់ព្រះអង្គតែបបូរមាត់ កាល
គេកំពុងតែ[ខ]អួតខ្លួន ដល់កំរិតខ្ពស់ ទៅលើវត្ថុទាំងឡាយដែល
ឥតប្រយោជន៍ នៃលោកិយ ។
២៨ មើលចុះ ឱព្រះរបស់ទូលបង្គំអើយ ប្រដាប់ស្លៀកពាក់ដ៏មាន
តម្លៃរបស់គេ និងកងរបស់គេ និង[ក]ខ្សែដៃរបស់គេ និងគ្រឿងអលង្ការ
របស់គេ ដែលធ្វើពីមាស និងវត្ថុមានតម្លៃទាំងអស់របស់គេ ដែល
គុបតែងខ្លួនគេ; ហើយមើលចុះ ចិត្តគេត្រូវបានភ្ជាប់ទៅលើវត្ថុទាំងនោះ
តែគេបែរទៅជាអំពាវនាវដល់ព្រះអង្គ ហើយទូលថា — យើងខ្ញុំ
សូមអរព្រះគុណដល់ព្រះអង្គ ឱព្រះអង្គអើយ ព្រោះយើងខ្ញុំជារាស្ត្រ
ជ្រើសរើសដល់ទ្រង់ នៅពេលអ្នកផ្សេងទៀតត្រូវវិនាស ។
២៩ ព្រះពរ ហើយពួកគេទូលថា ព្រះអង្គបានធ្វើឲ្យពួក
គេដឹងថា នឹងពុំមានព្រះគ្រីស្ទទេ ។
៣០ ឱព្រះអម្ចាស់ដ៏ជាព្រះអើយ តើព្រះអង្គស៊ូទ្រាំដល់ណាទៅ
ឲ្យអំពើទុច្ចរិត និងអំពើមិនស្មោះត្រង់បែបនេះ មាននៅក្នុង
ចំណោមរាស្ត្រ នេះ ? ឱព្រះអម្ចាស់អើយ សូមព្រះអង្គប្រទាន
កម្លាំងដល់ទូលបង្គំផង ដើម្បីទូលបង្គំអាចស៊ូទ្រាំ ដោយសេចក្ដី
ទន់ខ្សោយរបស់ទូលបង្គំ ។ ព្រោះទូលបង្គំទន់ខ្សោយ ហើយអំពើ
ទុច្ចរិតបែបនេះ ដែលនៅក្នុងចំណោមប្រជាជននេះ ធ្វើឲ្យ
ឈឺចាប់ក្នុងព្រលឹងទូលបង្គំ ។
៣១ ឱព្រះអម្ចាស់អើយ ចិត្តទូលបង្គំសោកសៅជាខ្លាំង;
សូមព្រះអង្គធ្វើឲ្យ[ក]ព្រលឹងទូលបង្គំបានក្សាន្ត នៅក្នុងព្រះគ្រីស្ទផងចុះ ។
ឱព្រះ អម្ចាស់អើយ សូមព្រះអង្គប្រទានដល់ទូលបង្គំ ឲ្យទូលបង្គំ
មានកម្លាំង ដើម្បីទូលបង្គំអាចស៊ូទ្រាំដោយការអត់ធន់ នូវការទុក្ខ
វេទនាទាំងនេះ ដែលនឹងធ្លាក់មកលើទូលបង្គំ ដោយព្រោះអំពើ
ទុច្ចរិតនៃប្រជាជននេះ ។
៣២ ឱព្រះអម្ចាស់អើយ សូមព្រះអង្គធ្វើឲ្យព្រលឹងទូលបង្គំបាន
ក្សាន្តផង ហើយសូមប្រទានដល់ទូលបង្គំ នូវការជោគជ័យ ព្រម
ទាំងអ្នកធ្វើ ការជាមួយនឹងទូលបង្គំទាំងនេះផងចុះ — ព្រះពរ
គឺអាំមូ៉ន និងអេរ៉ុន និងអោមណើរ ព្រមទាំងអាមូលេក និង
ស៊ីអែសរ៉ុម និងកូនប្រុស ទូលបង្គំទាំង[ក]ពីរនាក់នេះផងចុះ — ព្រះ
ពរ ឱព្រះអម្ចាស់អើយ សូមព្រះអង្គធ្វើឲ្យអស់អ្នកទាំងនេះបានក្សេ
មក្សាន្ត ។ ព្រះពរ សូមព្រះអង្គធ្វើឲ្យ ព្រលឹងគេបានក្សេមក្សាន្ត
នៅក្នុងព្រះគ្រីស្ទផងចុះ ។
៣៣ សូមព្រះអង្គប្រទានឲ្យពួកគេមានកម្លាំង ដើម្បីពួកគេអាច

២៣ *ក* យ៉ាកុប (ព.ស.ថ.) ១:២១–២៥.
២៤ *ក* លោកុ. ៦:៥–៦.
២៥ *ក* យ៉ាកុប (ព.ម) ២:១៣;
អាលម៉ា ១:៣២.
២៦ *ក* ម៉ូសេ ៧:៤១–៥៨.
២៧ *ក* អេសាយ ២៩:១៣.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
២៨ *ក* អេសាយ ៣:១៦–២៤.
៣១ *ក* យ៉ូហាន ១៦:៣៣.
៣២ *ក* អាលម៉ា ៣១:៧.

ស៊ូទ្រាំនឹងសេចក្ដីទុក្ខវេទនា ដែលនឹងកើតឡើងដល់គេ ដោយ
ព្រោះអំពើ ទុច្ចរិតនៃប្រជាជននេះ ។
៣៤ ឱព្រះអម្ចាស់អើយ សូមព្រះអង្គប្រទានដល់យើងខ្ញុំ
ឲ្យយើងខ្ញុំមានជ័យជំនះ ក្នុងការដឹកនាំពួកគេមករកព្រះអង្គនៅ
ក្នុងព្រះគ្រីស្ទវិញចុះ ។
៣៥ មើលចុះ ឱព្រះអម្ចាស់អើយ ព្រលឹងរបស់គេមានតម្លៃ
ហើយពួកគេជាច្រើន គឺជាបងប្អូនយើងខ្ញុំ; ហេតុដូច្នេះហើយ
ឱព្រះអម្ចាស់អើយ សូមប្រទានដល់យើងខ្ញុំនូវអានុភាព និងប្រាជ្ញា
ដើម្បីយើងខ្ញុំអាចនាំបងប្អូនយើងទាំងនេះ មករកព្រះអង្គវិញ ។
៣៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលដែល
អាលម៉ាបានទូលពាក្យទាំងនេះហើយ នោះលោកបានទះ
ដៃទៅលើអ្នកទាំង ឡាយ ដែលនៅជាមួយនឹងលោក ។
ហើយមើលចុះ នៅពេលលោកទះដៃទៅលើពួកគេ នោះពួកគេ
បានពោរពេញទៅដោយ ព្រះវិញ្ញាណបរិសុទ្ធ ។
៣៧ ហើយបន្ទាប់ពីនោះមក ពួកគេបានបំបែកគ្នារៀងៗខ្លួន
ដោយពុំគិតថា តើគេនឹងមានអ្វីបរិភោគ ឬមានអ្វីផឹក ឬមានអ្វី
មកស្លៀកពាក់ ឡើយ ។
៣៨ ហើយព្រះអម្ចាស់ទ្រង់បានផ្គត់ផ្គង់ឲ្យពួកគេ ដើម្បីមិនឲ្យ
គេឃ្លាន ហើយមិនឲ្យគេស្រេកឡើយ; មែនហើយ ទ្រង់បាន
ប្រទានកម្លាំង ដល់គេ ដើម្បីកុំឲ្យគេរងទុក្ខនូវសេចក្ដីទុក្ខវេទនា
ដោយប្រការណាមួយឡើយ លើកលែងតែការណ៍នោះត្រូវបាន
លេបទៅក្នុងសេចក្ដីអំណរ នៃព្រះគ្រីស្ទប៉ុណ្ណោះ ។ ឥឡូវនេះ
ការណ៍នេះគឺស្របតាមការអធិស្ឋានរបស់អាលម៉ា; ហើយនេះ
គឺពីព្រោះលោកបានអធិស្ឋាន ដោយនូវ សេចក្ដីជំនឿ ៕

## ជំពូកទី ៣២

*អាលម៉ាបង្រៀនពួកអ្នកក្រីក្រ ព្រោះការទុក្ខវេទនាទាំងឡាយ បានធ្វើឲ្យគេរាបទាប — សេចក្ដីជំនឿគឺជាសេចក្ដីសង្ឃឹមមួយ ទៅលើអ្វីៗ ដែលមើលមិនឃើញ តែពិត — អាលម៉ាធ្វើបន្ទាល់ថា ពួកទេវតាធ្វើការងារបំរើដល់ទាំងមនុស្សប្រុស មនុស្សស្រី និងក្មេងៗ — អាលម៉ា ប្រៀបធៀបព្រះបន្ទូលទៅនឹងគ្រាប់ពូជមួយ — វាត្រូវតែដាំ ហើយថែរក្សា — រួចទើបវាដុះទៅជាដើម ដែលបានបេះផ្លែនៃជីវិតដ៏នៅអស់កល្បជានិច្ចមក ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើចេញទៅ
ហើយបានចាប់ផ្ដើមផ្សាយព្រះបន្ទូលនៃព្រះ ដល់ប្រជាជន ដោយ
បានចូល ទៅក្នុងសាលាជំនុំទាំងឡាយរបស់គេ និងផ្ទះទាំង
ឡាយរបស់គេ; មែនហើយ គេថែមទាំងបានផ្សាយប្រាប់
នៅតាមថ្នល់របស់គេផង ។
២ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីគេមានការ
នឿយហត់ជាខ្លាំង នោះគេបានទទួលជោគជ័យ នៅក្នុងចំណោម
បណ្ដាជន ក្រីក្រ; ត្បិតមើលចុះ ពួកជនទាំងនេះត្រូវ
គេបណ្ដេញចេញពីសាលាជំនុំទាំងឡាយ ដោយ
ព្រោះសំលៀកបំពាក់របស់គេពុំល្អ —
៣ ហេតុដូច្នេះហើយ ពួកគេពុំបានអនុញ្ញាត ឲ្យចូលទៅក្នុង
សាលាជំនុំទាំងឡាយរបស់គេ ដើម្បីថ្វាយបង្គំព្រះទេ តែត្រូវ
គេមើលងាយ ថាជាស្មោកគ្រោកវិញ; ហេតុដូច្នេះហើយ ពួក
គេជាមនុស្សក្រីក្រ; មែនហើយ ពួកគេត្រូវបងប្អូន
របស់ខ្លួនមើលងាយថាជាអាចម៍សំណល់; ហេតុដូច្នេះហើយ ពួក
គេមានសេចក្ដីកំសត់ខាងឯអ្វីៗនៃលោកិយ; ហើយពួកគេក៏ថែម
ទាំងមានសេចក្ដីកំសត់ខាងឯចិត្តផងដែរ ។
៤ ឥឡូវនេះ នៅពេលអាលម៉ាកំពុងតែបង្រៀន ហើយនិយាយ
ទៅកាន់ប្រជាជននៅលើភ្នំអូណៃដា មានហ្វូងមនុស្សដ៏ធំមួយបាន
មករក លោក គឺជាពួកអ្នកដែលយើងទើបតែបាននិយាយមក
ដែលជាពួកអ្នកដែលមានសេចក្ដីកំសត់ខាងឯចិត្ត ដោយ
ព្រោះសេចក្ដីកំសត់ខាង ឯអ្វីៗនៃលោកិយ ។
៥ ហើយពួកគេបានមកជួបនឹងអាលម៉ា ហើយជនម្នាក់ដែល
នៅខាងមុខគេបង្អស់ បាននិយាយមករកលោកថា៖ មើលចុះ
តើបងប្អូនខ្ញុំទាំង នេះត្រូវធ្វើអ្វីទៅ ព្រោះអស់ទាំងមនុស្សស្អប់គេ
ដោយព្រោះសេចក្ដីកំសត់របស់គេ មែនហើយ ជាពិសេស
គឺពួកសង្ឃរបស់យើង; ត្បិតពួកគេ បានបណ្ដេញយើងចេញ

៣៤ *ក* ២ នីហ្វៃ ២៦:៣៣.
៣៥ *ក* ស.ប. ព្រលឹង — តម្លៃនៃព្រលឹងទាំងឡាយ.
៣៦ *ក* ៣ នីហ្វៃ ១៨:៣៦–៣៧.
*ខ* ស.ប. ដៃ, ការដាក់.
៣៧ *ក* ម៉ាថាយ ៦:២៥–៣៤; ៣ នីហ្វៃ ១៣:២៥–៣៤.
៣៨ *ក* ម៉ាថាយ ៥:១០–១២; ម៉ូសាយ ២៤:១៣–១៥; អាលម៉ា ៣៣:២៣.
*ខ* ស.ប. សេចក្ដីជំនឿ.
**៣២** ២ *ក* ស.ប. មនុស្សក្រីក្រ.
៣ *ក* អាលម៉ា ៣៤:៤០.
៤ *ក* ស.ប. មនុស្សក្រីក្រ — កំសត់ខាងវិញ្ញាណ.
៥ *ក* សុភា. ១៨:២៣.
*ខ* អាលម៉ា ៣៣:១០.

ពីសាលាប្រជុំទាំងឡាយរបស់ពួកយើង ដែលយើងបានធ្វើយ៉ាងនឿយហត់ជាអតិបរមា ដើម្បីសង់ឡើង ដោយដៃរបស់យើងផ្ទាល់; ហើយពួកគេបានបណ្ដេញយើងចេញ ដោយព្រោះយើងមានសេចក្ដីកំសត់ហួសកំរិត; ហើយយើងគ្មានទីកន្លែងណាមួយ ដើម្បីថ្វាយបង្គំព្រះយើងទេ; ហើយមើលចុះ [គ]តើយើងត្រូវធ្វើដូចម្ដេចទៅ ?

៦ ហើយឥឡូវនេះ កាលអាលម៉ាបានឮយ៉ាងនេះហើយ នោះលោកបានបែរមកសម្លឹងចំមុខជននោះ ហើយលោកបានមើលដោយសេចក្ដី អំណរជាខ្លាំង; ត្បិតលោកបានឃើញថា [ក]ការទុក្ខវេទនាទាំងឡាយរបស់គេ ពិតជាបានធ្វើឲ្យគេ[ខ]បន្ទាបខ្លួន ហើយពួកគេ[គ]កំពុងតែប្រុងប្រៀប នឹងស្ដាប់តាមព្រះបន្ទូល ។

៧ ហេតុដូច្នេះហើយ លោកពុំបានថ្លែងទៅកាន់ហ្វូងមនុស្សផ្សេងទៀតទេ; ប៉ុន្តែលោកបានហុចដៃលោកចេញ ហើយបានស្រែកជាខ្លាំង ទៅពួកអ្នកដែលលោកបានមើលនោះ ដែលជាពួកជនដែលបានប្រែចិត្តដ៏ពិត ហើយបាននិយាយទៅកាន់ពួកគេថា៖

៨ ខ្ញុំបានឃើញថា អ្នករាល់គ្នាមាន[ក]ចិត្តទាបរាបសា; ហើយបើសិនជាដូច្នោះមែន ពួកអ្នករាល់គ្នាមានពរហើយ ។

៩ មើលចុះ បងរបស់អ្នកបានសួរថា តើយើងត្រូវធ្វើអ្វីទៅ? — ព្រោះយើងត្រូវគេបណ្ដេញចេញពីសាលាប្រជុំទាំងឡាយ ហើយយើងពុំ អាចថ្វាយបង្គំព្រះរបស់យើងបានទេនោះ ។

១០ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា តើអ្នករាល់គ្នាគិតស្មានថា អ្នករាល់គ្នាមិនអាច[ក]ថ្វាយបង្គំព្រះបាន លើកលែងតែនៅក្នុងសាលាប្រជុំ របស់អ្នកប៉ុណ្ណោះឬ ?

១១ ហើយលើសលែងទៅទៀត ខ្ញុំសូមសួរថា តើអ្នករាល់គ្នាគិតស្មានថា យើងមិនត្រូវថ្វាយបង្គំព្រះ គឺគ្រាន់តែម្ដងក្នុងមួយអាទិត្យឬ ?

១២ ខ្ញុំសូមប្រាប់អ្នកថា ជាការស្រួលហើយដែលអ្នករាល់គ្នាត្រូវគេបណ្ដេញចេញពីសាលាប្រជុំរបស់អ្នក ដើម្បីឲ្យអ្នករាល់គ្នាមានកិរិយា រាបទាប ហើយដើម្បីឲ្យអ្នករាល់គ្នាអាចមាន[ក]ប្រាជ្ញា; ត្បិតជាការចាំបាច់ ដែលអ្នករាល់គ្នាត្រូវចេះមានប្រាជ្ញា; ត្បិតពីព្រោះអ្នករាល់គ្នាត្រូវគេ [ខ]បណ្ដេញចេញ ដែលអ្នករាល់គ្នាត្រូវបងប្អូនអ្នកស្អប់ ដោយព្រោះអ្នកទាល់ក្រហួសកំរិត ទើបអ្នករាល់គ្នាត្រូវបាននាំឲ្យមានចិត្តទាបរាបសា; ត្បិតអ្នករាល់គ្នាចាំបាច់ត្រូវតែមានចិត្តសុភាពរាបសា ។

១៣ ហើយឥឡូវនេះ ពីព្រោះអ្នកត្រូវគេបង្ខំឲ្យមានចិត្តសុភាពរាបសា នោះអ្នករាល់គ្នាមានពរហើយ; ព្រោះជនម្នាក់ជួនកាល បើសិនជាអ្នកណាត្រូវគេបង្ខំឲ្យមានចិត្តសុភាពរាបសា ទើបស្វែងរកការប្រែចិត្ត; ហើយឥឡូវនេះ ប្រាកដណាស់ថា អស់អ្នកណាដែលប្រែចិត្ត នោះនឹងបានសេចក្ដីមេត្តា[ក]ករុណា; ហើយអ្នកណាដែលបានសេចក្ដីមេត្តាករុណា ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត អ្នកនោះហើយដែល នឹងបានសង្គ្រោះ ។

១៤ ហើយឥឡូវនេះ ដូចខ្ញុំទើបបានប្រាប់អ្នកហើយថា ពីព្រោះអ្នករាល់គ្នាត្រូវគេបង្ខំ ឲ្យមានចិត្តសុភាពរាបសា នោះអ្នករាល់គ្នា មានពរហើយ តើអ្នករាល់គ្នាពុំគិតស្មានទេឬថា ពួកអ្នកណាដែលមានចិត្តសុភាពរាបសាដោយខ្លួនឯង ដោយព្រោះព្រះបន្ទូលនោះ តើនឹងបានទទួលពរដល់ថ្នាក់ណាទៅ ?

១៥ មែនហើយ អ្នកណាដែលពិតមានចិត្តរាបសា ដោយខ្លួនឯង ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន និងកាន់ខ្ជាប់ ដរាបដល់ ចុងបំផុត អ្នកនោះហើយដែលនឹងមានពរ — មែនហើយ មានពរច្រើនជាងពួកអ្នកដែលត្រូវគេបង្ខំឲ្យមានចិត្តសុភាពរាបសាទៅទៀត ដោយព្រោះសេចក្ដីក្រខ្សត់ដ៏ហួសកំរិតរបស់គេ ។

១៦ ហេតុដូច្នេះហើយ មានពរហើយដល់ពួកអ្នកណា ដែល[ក]បានបន្ទាបខ្លួនដោយពុំបាច់គេបង្ខំ; ឬនិយាយម្យ៉ាងទៀតថា មានពរហើយដល់ អ្នកណាដែលជឿដល់ព្រះបន្ទូលនៃព្រះ ហើយទទួលបុណ្យជ្រមុជទឹក ដោយពុំមានចិត្តរឹងរូស មែនហើយ ដោយពុំបាច់ឲ្យគេនាំឲ្យស្គាល់ ព្រះបន្ទូល ឬពុំបាច់ឲ្យគេបង្ខំឲ្យស្គាល់ព្រះបន្ទូល មុនពេលគេនឹងជឿនោះឡើយ ។

១៧ មែនហើយ មានមនុស្សជាច្រើនដែលនិយាយថា៖ បើអ្នកបង្ហាញដល់យើងនូវ[ក]ទីសំគាល់មួយពីស្ថានសួគ៌ នោះយើងនឹងដឹងដោយពិត ប្រាកដ; លំដាប់នោះ ទើបយើងនឹងជឿ ។

១៨ ឥឡូវនេះ ខ្ញុំសូមសួរថា នេះឬគឺសេចក្ដីជំនឿ ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ទេ; ត្បិតបើសិនជាមនុស្សដឹងរឿងអ្វីមួយ គេក៏គ្មាន ហេតុ[ក]នឹងជឿសោះឡើយ ព្រោះគេដឹងរឿងនោះទៅហើយ។

១៩ ហើយឥឡូវនេះ អ្នកណាដែលបាន[ក]ស្គាល់ព្រះហឫទ័យនៃព្រះ ហើយពុំបានធ្វើតាម នោះតើនឹងត្រូវបណ្ដាសាធ្ងន់ជាងអ្នក

---

៥ *គ* កិច្ចការ ២:៣៧–៣៨.
៦ *ក* ស.ប. សេចក្ដីទំនាស់.
*ខ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*គ* អាលម៉ា ១៦:១៦–១៧; គ. និង ស. ១០១:៨.
៨ *ក* ម៉ាថាយ ៥:៣–៥.
១០ *ក* ស.ប. ថ្វាយបង្គំ.
១២ *ក* សាស្ដា ៤:១៣.
*ខ* សុភា. ១៦:៨.
១៣ *ក* អាលម៉ា ៣៨:២.
១៦ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
១៧ *ក* ស.ប. ទីសំគាល់.
១៨ *ក* អេធើរ ១២:១២, ១៨.
១៩ *ក* យ៉ូហាន ១៥:២២–២៤.

ណា ដែលគ្រាន់តែជឿ ឬក៏មានហេតុនឹងជឿ ហើយបានធ្លាក់ក្នុង
ការលែងទេឬអី ?
២០ ឥឡូវនេះ អំពីការណ៍នេះហើយដែលអ្នកត្រូវវិនិច្ឆ័យ ។
មើលចុះ ខ្ញុំសូមប្រាប់អ្នកថា នៅដៃនេះក៏ដូចជានៅដៃនោះដែរ;
ហើយ ការណ៍នោះនឹងកើតមានឡើងដល់មនុស្សគ្រប់រូប
ស្របតាមកិច្ចការរបស់ខ្លួន ។
២១ ហើយឥឡូវនេះ ដូចខ្ញុំបាននិយាយអំពីសេចក្ដីជំនឿ —
[ក]សេចក្ដីជំនឿគឺពុំមែនជាដំរិះដ៏ឥតខ្ចោះ នូវអ្វីៗទាំងឡាយនោះទេ;
ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាមានសេចក្ដីជំនឿ
នោះអ្នករាល់គ្នា[ខ]សង្ឃឹមទៅលើអ្វីៗ ដែល[គ]មើលមិនឃើញ ហើយ
ដែលពិត ។
២២ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នករាល់គ្នា
ហើយខ្ញុំចង់ឲ្យអ្នកចងចាំថា ព្រះទ្រង់ប្រកបដោយសេចក្ដី
មេត្តាករុណា ដល់អស់អ្នកណា ដែលជឿដល់ព្រះនាមទ្រង់;
ហេតុដូច្នេះហើយ ទ្រង់មានព្រះហឫទ័យជាដំបូងបំផុតថា អ្នក
រាល់គ្នាគួរតែជឿ មែនហើយ គឺជឿដល់ព្រះបន្ទូល របស់ទ្រង់ ។
២៣ ហើយឥឡូវនេះ ទ្រង់[ក]រំលែកព្រះបន្ទូលរបស់ទ្រង់ដល់
មនុស្ស ដោយពួកទេវតា មែនហើយ មិនត្រឹមតែដល់ពួកបុរសទេ
តែដល់ពួក ស្ត្រីផងដែរ ។ ឥឡូវនេះ នេះពុំទាន់អស់នៅឡើយទេ;
[ខ]កូនក្មេងតូចៗក៏បានទទួលនូវព្រះបន្ទូលទាំងឡាយជាច្រើនដងដែរ
ដែលមានពេលខ្លះ បានធ្វើឲ្យអ្នកប្រាជ្ញ និងអ្នកចេះដឹងជ្រប់មុខ ។
២៤ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ
ដោយអ្នកចង់ដឹងពីខ្ញុំថា តើអ្នកត្រូវធ្វើអ្វី ពីព្រោះអ្នកមានទុក្ខ
វេទនា ហើយត្រូវ គេបណ្ដេញចេញ — ឥឡូវនេះ ខ្ញុំពុំចង់ឲ្យ
អ្នករាល់គ្នាគិតស្មានថា ខ្ញុំចង់ថ្កោលទោសអ្នកឡើយ ត្បិតខ្ញុំ
គ្រាន់តែនិយាយតាមអ្វីដែលពិត–
២៥ ព្រោះពុំមែនខ្ញុំចង់និយាយថា អ្នករាល់គ្នាត្រូវគេបង្ខំឲ្យ
បន្ទាបខ្លួននោះទេ; ហើយខ្ញុំជឿជាក់ថា មានអ្នកខ្លះនៅក្នុង
ចំណោមអ្នករាល់គ្នា ដែលចង់បន្ទាបខ្លួន ទោះជានៅក្នុង
កាលៈទេសៈណាក៏ដោយ ។
២៦ ឥឡូវនេះ ដូចដែលខ្ញុំបាននិយាយអំពីសេចក្ដីជំនឿ —
ថាវាពុំមែនជាដំរិះដ៏ឥតខ្ចោះនោះទេ — គឺដូចគ្នានឹងពាក្យ
សំដីរបស់ខ្ញុំដែរ ។ អ្នករាល់គ្នាពុំអាចដឹងនូវភាពពិតប្រាកដនៃ
ពាក្យទាំងនោះជាដំបូង ដល់ភាពឥតខ្ចោះបានឡើយ ក៏ដូចគ្នា
នឹងសេចក្ដីជំនឿ ថាជាដំរិះដ៏ឥត ខ្ចោះនោះដែរ ។
២៧ ប៉ុន្តែមើលចុះ បើសិនជាអ្នករាល់គ្នាចង់ភ្ញាក់ឡើង ហើយ
ដាស់សមត្ថភាពទាំងឡាយរបស់ខ្លួន គឺដើម្បីធ្វើការពិសោធន៍ដល់
ពាក្យ សំដីរបស់ខ្ញុំ ហើយអនុវត្តសេចក្ដីជំនឿមួយភាគតូច មែន
ហើយ គឺបើសិនជាអ្នករាល់គ្នាពុំអាចធ្វើអ្វីក៏ដោយក្រៅពីការ
[ក]ចង់ជឿ នោះសូមឲ្យ ចំណង់នេះមាននៅក្នុងខ្លួនអ្នក គឺរហូតដល់
អ្នកអាចទុកកន្លែងមួយ សំរាប់ពាក្យសំដីរបស់ខ្ញុំមួយភាគចុះ ។
២៨ ឥឡូវនេះ យើងនឹងប្រៀបធៀបព្រះបន្ទូល ទៅនឹង[ក]គ្រាប់
ពូជមួយគ្រាប់ ។ ឥឡូវនេះ បើសិនជាអ្នករាល់គ្នាទុកកន្លែងមួយ
សំរាប់ឲ្យ [ខ]គ្រាប់ពូជនោះអាចដុះនៅក្នុង[គ]ចិត្តរបស់អ្នក មើលចុះ
បើសិនជាគ្រាប់ពូជនោះជាគ្រាប់ពិត ឬជាគ្រាប់ល្អ បើសិនជា
អ្នករាល់គ្នាពុំបោះវាចោល ដោយការឥតជំនឿរបស់អ្នក ដែល
[ឃ]ធ្វើឲ្យអ្នករឹងទទឹងនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់ទេ មើលចុះ
គ្រាប់ពូជនោះនឹងចាប់ផ្ដើមរីកឡើងនៅក្នុង ទ្រូងរបស់អ្នក;
ហើយនៅពេលអ្នកចាប់អារម្មណ៍ថា គ្រាប់នោះរីកឡើង នោះ
អ្នករាល់គ្នានឹងនិយាយដោយខ្លួនឯងថា នេះច្បាស់ជាគ្រាប់ពូជ ល្អ
ឬក៏ព្រះបន្ទូលនោះល្អ ព្រោះវាចាប់ផ្ដើមពង្រីកព្រលឹងរបស់ខ្ញុំ;
មែនហើយ វាចាប់ផ្ដើម[ង]បំភ្លឺយោបល់របស់ខ្ញុំ មែនហើយ វា
ចាប់ផ្ដើមមាន រសជាតិឆ្ងាញ់ចំពោះខ្ញុំ ។
២៩ ឥឡូវនេះ មើលចុះ តើការណ៍នេះពុំពង្រីកសេចក្ដីជំនឿ
របស់អ្នកទេឬអី ? ខ្ញុំសូមប្រាប់អ្នកថា ការណ៍នេះពង្រីកសេច
ក្ដីជំនឿ របស់អ្នកមែន; ទោះជាយ៉ាងណាក៏ដោយ គង់តែវាពុំ
បានដុះដាលឡើង ឲ្យទៅជាដំរិះដ៏ឥតខ្ចោះនោះដែរ ។
៣០ ប៉ុន្តែមើលចុះ នៅពេលគ្រាប់ពូជនោះរីក និងពន្លក ហើយ
ចាប់ផ្ដើមដុះ ពេលនោះ អ្នកត្រូវនិយាយថា គ្រាប់ពូជនោះល្អ;
ត្បិតមើលចុះ វាបានរីកឡើង និងពន្លក ហើយចាប់ផ្ដើមដុះ ។
ហើយឥឡូវនេះ មើលចុះ តើការណ៍នេះពុំពង្រឹងសេចក្ដីជំនឿ
របស់អ្នកទេឬអី ? មែនហើយ វានឹងពង្រឹងសេចក្ដីជំនឿរបស់អ្នក
ត្បិតអ្នករាល់គ្នានឹងនិយាយថា ខ្ញុំដឹងថា គ្រាប់ពូជនេះល្អ;
ត្បិតមើលចុះ វាពន្លកឡើង ហើយក៏ចាប់ផ្ដើមដុះ ។

២១ *ក* យ៉ូហាន ២០:២៩; ហេព្រើរ ១១.
*ខ* ស.ប. សេចក្ដីសង្ឃឹម.
*គ* អេធើរ ១២:៦.
២៣ *ក* យ៉ូអែល ២:២៨–២៩.
*ខ* ម៉ាថាយ ១១:២៥; លូកា ១០:២១;
៣ នីហ្វៃ ២៦:១៤–១៦;
គ. និង ស. ១២៨:១៨.
២៧ *ក* ម៉ាកុស ១១:២៤.
២៨ *ក* អាលម៉ា ៣៣:១.
*ខ* លូកា ៨:១១.
*គ* ស.ប. ចិត្ត.
*ឃ* ម៉ាថាយ ១៧:២០.
*ង* ស.ប. យោបល់.

៣១ ឥឡូវនេះ មើលចុះ តើអ្នករាល់គ្នាដឹងជាប្រាកដថា
នេះជាគ្រាប់ល្អឬ ? ខ្ញុំសូមប្រាប់អ្នកថា មែនហើយ;[ក] ត្បិតគ្រាប់នី
មួយៗ តែងតែនាំ មកនូវដើមឈើមួយពីពូជនោះ ។
៣២ ហេតុដូច្នេះហើយ បើសិនជាគ្រាប់មួយដុះ គ្រាប់នោះល្អ
ប៉ុន្តែបើវាពុំដុះទេ មើលចុះ គឺជាគ្រាប់ពុំល្អវិញ ហេតុដូច្នេះហើយ
វានឹងត្រូវ គេបោះចោល ។
៣៣ ហើយឥឡូវនេះ មើលចុះ ពីព្រោះអ្នករាល់គ្នា
បានសាកល្បងធ្វើការពិសោធន៍ ហើយបានដាំគ្រាប់ពូជ ហើយវា
បានរីកឡើង និងពន្លក ហើយចាប់ផ្ដើមដុះ នោះអ្នករាល់គ្នាត្រូវ
ដឹងថា គ្រាប់ពូជនោះល្អ ។
៣៤ ហើយឥឡូវនេះ មើលចុះ តើដំរិះ[ក]របស់អ្នកបានឥតខ្ចោះ[ខ]ឬ ?
មែនហើយ ដំរិះរបស់អ្នកបានឥតខ្ចោះចំពោះរឿងនេះ ឯសេច
ក្ដីជំនឿ របស់អ្នកសម្ងំនៅស្ងៀម; ការណ៍នេះក៏ដោយសារតែ
អ្នកដឹង ត្បិតអ្នករាល់គ្នាដឹងថា ព្រះបន្ទូលបានពង្រីកព្រលឹង
របស់អ្នក ហើយអ្នករាល់គ្នា ក៏ដឹងថា វាបានពន្លកឡើង
ឯយោបល់របស់អ្នកក៏បានភ្លឺឡើង ហើយគំនិត[គ]របស់អ្នក
ក៏ចាប់ផ្ដើមរីកឡើង ។
៣៥ ឱបើដូច្នោះ តើការណ៍នេះពុំមែនពិតទេឬអី ?
ខ្ញុំសូមប្រាប់អ្នកថា មែនហើយ ពីព្រោះនេះជាពន្លឺ[ក];
ហើយអ្វីក៏ដោយដែលជាពន្លឺ គឺល្អ ពីព្រោះវាអាចញែកចេញ
បាន ហេតុដូច្នេះហើយ អ្នកត្រូវដឹងថាវាល្អ; ហើយឥឡូវនេះ
មើលចុះ បន្ទាប់ពីអ្នករាល់គ្នាបានភ្លក់នូវពន្លឺនេះ តើ ដំរិះរបស់
អ្នកបានឥតខ្ចោះហើយឬ ?
៣៦ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ទេ; ហើយអ្នករាល់គ្នាក៏ពុំ
ត្រូវទុកសេចក្ដីជំនឿរបស់ខ្លួនមួយអន្លើឡើយ ត្បិតអ្នករាល់គ្នាទើបតែ
អនុវត្ត សេចក្ដីជំនឿរបស់ខ្លួន ដើម្បីដាំគ្រាប់ពូជប៉ុណ្ណោះ ដើម្បី
អ្នករាល់គ្នាអាចសាកធ្វើការពិសោធន៍ឲ្យដឹងថា តើគ្រាប់
ពូជនោះល្អឬទេ ។
៣៧ ហើយមើលចុះ នៅពេលដើមចាប់ផ្ដើមដុះឡើង នោះ
អ្នករាល់គ្នានឹងនិយាយថា: ចូរយើងថែទាំវា ដោយថ្នាក់ថ្នម
ដើម្បីវាអាច ដុះឫស ដើម្បីវាអាចដុះឡើង ហើយនឹងផ្ដល់ផ្លែផ្កា
ដល់យើង ។ ហើយឥឡូវនេះ មើលចុះ បើសិនជាអ្នករាល់គ្នា
ថែទាំវាដោយថ្នាក់ថ្នម នោះវានឹងចាក់ឫសដុះឡើង ហើយ
នឹងផ្ដល់ផ្លែផ្កា ។
៣៨ ប៉ុន្តែ បើសិនជាអ្នករាល់គ្នាបោះបង់[ក]ដើមនោះ ហើយពុំ
បានគិតដល់ការថែទាំវា មើលចុះ វានឹងពុំចាក់ឫសទេ; ហើយ
កាលណា កំដៅថ្ងៃមកដល់ នោះនឹងដុតរោលវាទៅវិញ
ពីព្រោះវាគ្មានឫស វានឹងក្រៀមស្ងួតទៅ ហើយអ្នករាល់គ្នានឹង
ដកវាឡើង ហើយបោះវា ចោលទៅ ។
៣៩ ឥឡូវនេះ នេះពុំមែនមកពីគ្រាប់ពុំល្អទេ ហើយក៏ពុំមែនមក
ពីផ្លែនោះពុំគួរឲ្យប្រាថ្នាដែរ; ប៉ុន្តែមកពីដី[ក]របស់អ្នកឥតដីជាតិ
ហើយមកពី អ្នករាល់គ្នាពុំថែទាំដើមនោះ ហេតុដូច្នេះហើយ អ្នក
ពុំអាចបានទទួលផ្លែឈើនោះឡើយ ។
៤០ ម្ល៉ោះហើយ បើសិនជាអ្នករាល់គ្នាពុំថែទាំព្រះបន្ទូល ពុំ
ទន្ទឹងចាំដោយភ្នែកនៃសេចក្ដីជំនឿ ដល់ផលនៃព្រះបន្ទូលនោះទេ
នោះអ្នក រាល់គ្នានឹងពុំអាចបេះផ្លែនៃដើម[ក]ជីវិតបានឡើយ ។
៤១ ប៉ុន្តែ បើសិនជាអ្នករាល់គ្នាថែទាំព្រះបន្ទូល មែនហើយ
ថែទាំដើមនៅពេលវាចាប់ផ្ដើមដុះ ដោយសេចក្ដីជំនឿរបស់អ្នក
ដោយ សេចក្ដីព្យាយាមដ៏ខ្លាំងក្លា និងដោយសេចក្ដីអត់ធន់[ក] ហើយ
ទន្ទឹងចាំផ្លែឈើនោះ នោះវានឹងចាក់ឫស; ហើយមើលចុះ វា
នឹងក្លាយទៅជា ដើមមួយ[ខ] ពន្លកឡើងជាជីវិតដ៏អស់កល្បជានិច្ច ។
៤២ ហើយដោយសារសេចក្ដីព្យាយាម[ក]របស់អ្នក និងសេច
ក្ដីជំនឿរបស់អ្នក និងសេចក្ដីអត់ធន់របស់អ្នក ទៅលើព្រះបន្ទូល
ដោយថែ ទាំព្រះបន្ទូលនោះ ដើម្បីឲ្យវាចាក់ឫសនៅក្នុង[ខ]ខ្លួនអ្នក
មើលចុះ នៅមិនយូរមិនឆាប់ អ្នករាល់គ្នានឹងបេះបានផ្លែឈើនោះ
ដែលពិសេសបំផុត ដែលផ្អែមជាងអ្វីៗដែលផ្អែមទាំងអស់ ហើយ
ដែលសជាងអ្វីៗដែលសទាំងអស់ មែនហើយ ហើយស្អាតជាងអ្វី
ៗដែលស្អាតទាំងអស់; ហើយអ្នក រាល់គ្នានឹងទទួលទានផ្លែនេះ
រហូតដល់អ្នករាល់គ្នាបានឆ្អែតឆ្អន់ ដើម្បីកុំឲ្យអ្នករាល់គ្នាឃ្លាន
ហើយកុំឲ្យអ្នករាល់គ្នាស្រេកទៀតឡើយ ។
៤៣ នៅពេលនោះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ អ្នក
រាល់គ្នានឹងច្រូតកាត់ នូវរង្វាន់នៃសេចក្ដីជំនឿរបស់អ្នក និងសេច
ក្ដីព្យាយាម របស់អ្នក និងសេចក្ដីអត់ធន់ និងសេចក្ដីអត់ធ្មត់
ដោយរង់ចាំឲ្យដើមផ្ដល់ផ្លែផ្កាដល់អ្នក ៕

៣១ ក លោកុ. ១:១១–១២.
៣៤ ក ស.ប. ដំរិះ.
ខ អេធើរ ៣:១៩.
គ ស.ប. គំនិត.
៣៥ ក យ៉ូហាន ៣:១៨–២១.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៣៨ ក ស.ប. សេចក្ដីក្បត់សាសនា.
៣៩ ក ម៉ាថាយ ១៣:៥.
៤០ ក លោកុ. ២:៩; ១ នីហ្វៃ ១៥:៣៦.
៤១ ក ស.ប. សេចក្ដីអត់ធន់.
ខ អាលម៉ា ៣៣:២៣;
គ. និង ស. ៦៣:២៣.
៤២ ក ស.ប. ព្រះដ៏ប្រោសឡោះ.
ខ ១ នីហ្វៃ ៨:១០–១២.

## ជំពូកទី ៣៣

*ស៊ីណូសបានបង្រៀនថា មនុស្សត្រូវអធិស្ឋាន ហើយថ្វាយបង្គំនៅគ្រប់ទីកន្លែង ហើយថាសេចក្ដីជំនុំជំរះទាំងឡាយត្រូវបង្វែរចេញដោយសារព្រះរាជបុត្រា — ស៊ីណុកបានបង្រៀនថា សេចក្ដីមេត្តាករុណាត្រូវបានប្រទានមកឲ្យ ដោយសារព្រះរាជបុត្រា — ម៉ូសេបានលើកនិមិត្តរូបមួយឡើង នៅក្នុងទីរហោស្ថាន ដែលជាតំណាងអំពីព្រះរាជបុត្រានៃព្រះ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ឥឡូវនេះ បន្ទាប់ពីអាលម៉ាបាននិយាយពាក្យទាំងនេះហើយ
នោះគេបានចាត់ឲ្យមនុស្សមកជួបនឹងលោក ដោយចង់ដឹងថា
តើគេត្រូវជឿ ព្រះមួយអង្គ ដើម្បីគេអាចបាននូវផល ដែល
លោកបាននិយាយ ឬគេត្រូវបណ្ដុះគ្រាប់ ឬព្រះបន្ទូលដែល
លោកបាននិយាយមកនោះយ៉ាងណា គឺលោកបាននិយាយថា
ត្រូវដាំនៅក្នុងចិត្តរបស់គេ ឬគេត្រូវចាប់ផ្ដើមអនុវត្តសេចក្ដីជំនឿ
របស់គេ ដោយរបៀបណា ។
២ ហើយអាលម៉ាបាននិយាយទៅគេថា៖ មើលចុះ អ្នករាល់
គ្នាបាននិយាយថា អ្នកមិនអាចថ្វាយបង្គំដល់ព្រះរបស់អ្នក
ពីព្រោះអ្នករាល់គ្នា ត្រូវគេបណ្ដេញចេញពីសាលាប្រជុំទាំង
ឡាយរបស់អ្នក ។ ប៉ុន្តែមើលចុះ ខ្ញុំសូមប្រាប់អ្នកថា បើសិនជា
អ្នកគិតស្មានថា អ្នករាល់គ្នាពុំអាចថ្វាយ បង្គំព្រះ នោះអ្នក
រាល់គ្នាគិតខុសយ៉ាងធំ; ហើយអ្នករាល់គ្នាគួរតែ
ពិចារណាមើលបទគម្ពីរទាំងឡាយ; បើសិនជាអ្នករាល់គ្នា
គិតស្មានថា បទគម្ពីរទាំងឡាយត្រូវបានបង្រៀនដល់អ្នក
យ៉ាងនេះ នោះអ្នកពុំយល់បទគម្ពីរទេ ។
៣ តើអ្នករាល់គ្នាចាំបានទេ ដែលធ្លាប់បានអានអំពីពាក្យដែល
លោកស៊ីណូស ដែលជាព្យាការីពីដើម បាននិយាយអំពីការ
អធិស្ឋាន ឬការថ្វាយបង្គំ ?
៤ ត្បិតលោកបានទូលថា៖ ឱព្រះអង្គអើយ ព្រះអង្គប្រកបដោយ
សេចក្ដីមេត្តាករុណា ព្រោះព្រះអង្គបានឮពាក្យអធិស្ឋានរបស់
ទូលបង្គំ ទាំង កាលដែលទូលបង្គំនៅក្នុងទីរហោស្ថាននៅឡើយ;
ព្រះពរ ព្រះអង្គប្រកបដោយសេចក្ដីមេត្តាករុណា កាលដែល
ទូលបង្គំអធិស្ឋានអំពីពួកជន ដែលជាពួកខ្មាំងសត្រូវនៃទូលបង្គំ
ហើយព្រះអង្គបានធ្វើឲ្យគេត្រឡប់មករកទូលបង្គំវិញ ។
៥ ព្រះពរ ឱព្រះអង្គអើយ ហើយព្រះអង្គបានមេត្តាករុណាដល់
ទូលបង្គំ កាលដែលទូលបង្គំបានអំពាវនាវដល់ព្រះអង្គ នៅឯចំការ
របស់ទូលបង្គំ; កាលទូលបង្គំបានអំពាវនាវដល់ព្រះអង្គ នៅក្នុង
ការអធិស្ឋានរបស់ទូលបង្គំ នោះព្រះអង្គបានឮទូលបង្គំ ។
៦ ហើយមួយទៀត ឱព្រះអង្គអើយ កាលដែលទូលបង្គំបាន
ត្រឡប់ទៅផ្ទះទូលបង្គំវិញ ព្រះអង្គបានឮពាក្យអធិស្ឋានរបស់
ទូលបង្គំ ។
៧ ហើយកាលដែលទូលបង្គំបានចូលក្នុងបន្ទប់របស់ទូលបង្គំ
ឱព្រះអម្ចាស់អើយ ហើយទូលបង្គំបានអធិស្ឋានដល់ព្រះអង្គ
នោះព្រះអង្គបាន ឮទូលបង្គំ។
៨ ព្រះពរ ព្រះអង្គមេត្តាករុណាដល់កូនចៅរបស់ព្រះអង្គ
កាលណាគេអំពាវនាវរកព្រះអង្គ ដើម្បីឲ្យទ្រង់ឮ ហើយមិន
មែនឲ្យមនុស្សឮទេ ហើយព្រះអង្គនឹងឮពួកគេ ។
៩ ព្រះពរ ឱព្រះអង្គអើយ ព្រះអង្គបានមេត្តាករុណាដល់
ទូលបង្គំ ហើយបានឮពាក្យអំពាវនាវរបស់ទូលបង្គំ នៅកណ្ដាល
ក្រុមជំនុំរបស់ទ្រង់ ។
១០ ព្រះពរ ព្រះអង្គក៏បានឮទូលបង្គំ កាលដែលទូលបង្គំត្រូវពួក
ខ្មាំងសត្រូវរបស់ទូលបង្គំបណ្ដេញចេញ ហើយស្អប់; ព្រះពរ
ព្រះអង្គបានឮ ពាក្យអំពាវនាវរបស់ទូលបង្គំ ហើយបានខឹងនឹងពួក
ខ្មាំងសត្រូវរបស់ទូលបង្គំ ហើយព្រះអង្គបានយាងទៅពិនិត្យពិច័យ
ពួកគេ នៅក្នុងព្រះ ពិរោធរបស់ទ្រង់ ដោយការបំផ្លិចបំផ្លាញ
យ៉ាងឆាប់រហ័ស ។
១១ ហើយព្រះអង្គបានឮទូលបង្គំ ដោយសារការទុក្ខវេទនា
ទាំងឡាយរបស់ទូលបង្គំ និងចិត្តស្មោះរបស់ទូលបង្គំ; ហើយ
គឺដោយសារ ព្រះរាជបុត្រារបស់ព្រះអង្គ ទើបទ្រង់បាន
មេត្តាករុណាដល់ទូលបង្គំយ៉ាងនេះ ហេតុដូច្នេះហើយ ទូលបង្គំ
នឹងអំពាវនាវដល់ព្រះអង្គ នូវគ្រប់ ការទុក្ខវេទនាទាំងឡាយរបស់
ទូលបង្គំ ព្រោះនៅក្នុងព្រះអង្គ គឺជាសេចក្ដីអំណររបស់ទូលបង្គំ;
ព្រោះព្រះអង្គបានបង្វែរសេចក្ដីជំនុំជំរះចេញពី ទូលបង្គំ ដោយ
សារព្រះរាជបុត្រារបស់ព្រះអង្គ ។

---

៣៣ ១ *ក* ២ នីហ្វៃ ៣១:២១;
ម៉ូសាយ ១៥:២–៤.
*ខ* អាលម៉ា ៣២:២៨–៤៣.
២ *ក* អាលម៉ា ៣២:៥.
*ខ* អាលម៉ា ៣៧:៣–១០.
៣ *ក* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរ ដែលបាត់; ស៊ីណូស.
*ខ* ស.ប. ថ្វាយបង្គំ.
៤ *ក* ម៉ាថាយ ៥:៤៤.
៥ *ក* អាលម៉ា ៣៤:២០–២៥.
៧ *ក* ម៉ាថាយ ៦:៥–៦;
អាលម៉ា ៣៤:២៦.
១០ *ក* អាលម៉ា ៣២:៥.

១២ ហើយឥឡូវនេះ អាលម៉ាបាននិយាយទៅពួកគេថា៖ តើអ្នករាល់គ្នាជឿបទគម្ពីរទាំងនោះ ដែលបានសរសេរដោយមនុស្សជំនាន់ ដើមឬទេ ?

១៣ មើលចុះ បើសិនជាអ្នករាល់គ្នាជឿ នោះអ្នករាល់គ្នាត្រូវជឿនូវអ្វីៗ ដែលលោកស៊ីណូសបាននិយាយ; ត្បិតមើលចុះ លោកបាន និយាយថា៖ ព្រះអង្គបានបង្វែរសេចក្ដីជំនុំជំរះរបស់ព្រះអង្គចេញ ដោយសារព្រះរាជបុត្រារបស់ព្រះអង្គ ។

១៤ ឥឡូវនេះ មើលចុះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសូមសួរថា តើអ្នករាល់គ្នាបានអានបទគម្ពីរទាំងនោះឬនៅ ? បើសិនជាអ្នក បានអានហើយ ហេតុអ្វីបានជាអ្នកមិនជឿដល់ព្រះរាជបុត្រានៃព្រះ ?

១៥ ព្រោះបទគម្ពីរពុំបានថែងថា មានតែលោកស៊ីណូសម្នាក់ទេ ដែលបាននិយាយអំពីការណ៍ទាំងនេះ តែលោកស៊ីណុកផង ក៏បាននិយាយអំពីការណ៍ទាំងនេះដែរ —

១៦ ត្បិតមើលចុះ លោកបានទូលថា៖ ឱព្រះអម្ចាស់អើយ ព្រះអង្គខឹងនឹងប្រជាជននេះ ព្រោះគេមិនយល់ពីសេចក្ដីមេត្តាករុណាទាំងឡាយ របស់ព្រះអង្គ ដែលព្រះអង្គបានប្រទានដល់គេ ដោយសារព្រះរាជបុត្រារបស់ព្រះអង្គ ។

១៧ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ អ្នករាល់គ្នាឃើញថា ព្យាការីជំនាន់ដើមទីពីរ បានធ្វើបន្ទាល់អំពីព្រះរាជបុត្រា នៃព្រះ ហើយដោយមកពីប្រជាជនមិនយល់ពាក្យពេចន៍របស់លោក ទើបគេចោលថ្មលើលោកដល់ស្លាប់ ។

១៨ ប៉ុន្តែមើលចុះ នេះពុំទាន់អស់នៅឡើយទេ; ពុំមែនមានតែអ្នកទាំងនេះទេ ដែលបាននិយាយអំពីព្រះរាជបុត្រានៃព្រះ ។

១៩ មើលចុះ លោកម៉ូសេក៏បាននិយាយដល់ទ្រង់ដែរ; មែនហើយ ហើយមើលចុះ និមិត្តរូបមួយបានត្រូវលើកឡើង នៅក្នុងទីរហោស្ថាន ដើម្បីឲ្យអស់អ្នកណាដែលសម្លឹងមើលនិមិត្តរូបនោះនឹងអាចរស់នៅ ។ ហើយមនុស្សជាច្រើនបានសម្លឹងមើល ហើយបានរស់នៅ ។

២០ ប៉ុន្តែមានមនុស្សភាគតិច ដែលយល់ន័យអំពីការណ៍ទាំងនោះ ហើយនេះក៏មកពីភាពរឹងរូសនៃចិត្តរបស់គេ ។ ប៉ុន្តែមានមនុស្សជាច្រើន ដែលរឹងរូសខ្លាំងពេក រហូតដល់គេមិនសម្លឹងមើល ហេតុដូច្នេះហើយ ទើបគេវិនាសទៅ ។ ឥឡូវនេះ ឯហេតុដែលគេមិនព្រមសម្លឹង មើលនោះ គឺមកពីពួកគេមិនជឿថាវានឹងព្យាបាលគេឲ្យជាឡើយ ។

២១ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ បើសិនជាអ្នករាល់គ្នាអាចបានជា ដោយគ្រាន់តែចោលភ្នែកមើល ដើម្បីឲ្យអ្នករាល់គ្នាអាចបានជា តើអ្នករាល់គ្នាមិនមើលជាយ៉ាងឆាប់ទេឬអី ឬក៏អ្នករាល់គ្នាបែរជាធ្វើចិត្តរឹងរូស ក្នុងការឥតជំនឿ ហើយខ្ជិលច្រអូស រហូតដល់អ្នករាល់គ្នា មិនព្រមចោលភ្នែកមើលដោយទុកឲ្យខ្លួនវិនាសទៅវិញឬ ?

២២ បើដូច្នោះ សេចក្ដីវេទនានឹងកើតឡើងដល់អ្នក; ប៉ុន្តែ បើមិនដូច្នោះទេ លំដាប់នោះ ចូរអ្នកចោលភ្នែកមើល ហើយចាប់ផ្ដើមជឿដល់ ព្រះរាជបុត្រានៃព្រះចុះ ថាទ្រង់នឹងយាងមកប្រោសលោះរាស្ត្រទ្រង់ ហើយថាទ្រង់នឹងរងទុក្ខ ហើយសុគតដើម្បីធ្វើឲ្យធួននឹងអំពើបាបទាំង ឡាយរបស់ពួកគេ; ហើយថាទ្រង់នឹងមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ដែលនឹងនាំមកនូវដំណើររស់ឡើងវិញ ថាមនុស្សទាំងអស់នឹងឈរ នៅចំពោះទ្រង់ ដើម្បីទទួលការជំនុំជំរះ នៅថ្ងៃចុងក្រោយបង្អស់ ហើយជាថ្ងៃជំនុំជំរះ ស្របតាមកិច្ចការទាំងឡាយរបស់គេ ។

២៣ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាបណ្ដុះពាក្យនេះ នៅក្នុងចិត្តអ្នក ហើយនៅពេលពាក្យនេះចាប់ ផ្ដើមរីកឡើង ចូរថែទាំវា ដោយសេចក្ដីជំនឿរបស់អ្នក ។ ហើយមើលចុះ វានឹងបានទៅជាដើមមួយ ដោយលូតលាស់ឡើងនៅក្នុងខ្លួនអ្នក ដល់ជីវិតដ៏អស់កល្បជានិច្ច ។ ហើយបន្ទាប់មកសូមព្រះទ្រង់សំរាលបន្ទុករបស់អ្នក តាមរយៈសេចក្ដីអំណរនៃព្រះរាជបុត្រារបស់ទ្រង់ ។ ហើយការណ៍អស់ទាំងនេះ អ្នករាល់គ្នាអាចធ្វើបាន បើសិនជាអ្នករាល់គ្នាចង់ធ្វើ ។ អាម៉ែន ៕

១២ *ក* ស.ប. បទព្រះគម្ពីរ.
១៣ *ក* អាលម៉ា ៣៤:៧.
១៥ *ក* យ៉ាកុប (ព.ម) ៤:៤.
*ខ* ១ នីហ្វៃ ១៩:១០; អាលម៉ា ៣៤:៧.
១៧ *ក* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
១៩ *ក* ចោទិ. ១៨:១៥, ១៨; អាលម៉ា ៣៤:៧.
*ខ* ជនគ. ២១:៩; ២ នីហ្វៃ ២៥:២០; ម៉ូសាយ ៣:១៥.
*គ* យ៉ូហាន ៣:១៤; ហេលេ. ៨:១៤–១៥.
២០ *ក* ១ នីហ្វៃ ១៧:៤០–៤១.
២២ *ក* អាលម៉ា ៣២:២៧–២៨.
*ខ* អាលម៉ា ២២:១៤; ៣៤:៨–៩.
*គ* ស.ប. ដំណើររស់ឡើងវិញ.
*ឃ* អាលម៉ា ១១:៤៤.
*ង* ស.ប. កិច្ចការ.
២៣ *ក* អាលម៉ា ៣៣:១; ៣៤:៤.
*ខ* អាលម៉ា ៣២:៤១; គ. និង ស. ៦៣:២៣.
*គ* អាលម៉ា ៣១:៣៨.

## ជំពូកទី ៣៤

*អាមូលេកធ្វើបន្ទាល់ថា ព្រះបន្ទូលនោះគឺនៅក្នុងព្រះគ្រីស្ទ ដើម្បីនាំមកនូវសេចក្ដីសង្គ្រោះ — លើកលែងតែមានដង្វាយធួន បើពុំនោះសោត ទេ មនុស្សទាំងអស់នឹងត្រូវវិនាស — ក្រិត្យវិន័យលោកម៉ូសេទាំងស្រុងចង្អុលទៅការបូជានៃព្រះរាជបុត្រានៃព្រះ — ផែនការនៃសេចក្ដីប្រោស លោះដ៏អស់កល្បជានិច្ច ត្រូវយោងទៅលើសេចក្ដីជំនឿ និងការប្រែចិត្ត — ចូរអធិស្ឋានសូមឲ្យបានព្រះពរទាំងឡាយខាងសាច់ឈាម និងខាងវិញ្ញាណ — ជីវិតនេះគឺជាពេលវេលាសំរាប់មនុស្សប្រុងប្រៀបទៅជួបនឹងព្រះ — បង្ហើយនូវសេចក្ដីសង្គ្រោះរបស់អ្នក ដោយការ កោតខ្លាចចំពោះព្រះ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាលម៉ាបាននិយាយនូវពាក្យទាំងនេះទៅកាន់ពួកគេហើយ នោះលោកអង្គុយចុះ ទៅលើដី ឯអាមូលេកក៏[ក]ក្រោកឈរឡើង ហើយបានចាប់ផ្ដើមបង្រៀនពួកគេថា៖

២ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំយល់ថា អ្នករាល់គ្នាពុំអាចនឹងស្គាល់អំពីរឿងទាំងឡាយ ដែលបាននិយាយ អំពីការយាងមកនៃ ព្រះគ្រីស្ទ ដែលបានបង្រៀនដល់យើងថា ជាព្រះរាជបុត្រានៃព្រះ; មែនហើយ ខ្ញុំដឹងថា [ក]រឿងទាំងនេះត្រូវបានបង្រៀនដល់អ្នកយ៉ាងបរិបូរ មុនពេល អ្នកបែកចេញពីពួកយើងទៅ ។

៣ ហើយដោយអ្នករាល់គ្នា បានសួរបងជាទីស្រឡាញ់របស់ខ្ញុំថា សូមឲ្យលោកប្រាប់ដល់អ្នកថា តើអ្នករាល់គ្នាត្រូវធ្វើអ្វី ដោយព្រោះការ ទុក្ខវេទនាទាំងឡាយរបស់អ្នក; ហើយលោកបាននិយាយទៅកាន់អ្នកខ្លះៗ ដើម្បីរៀបចំចិត្តគំនិតរបស់អ្នក; មែនហើយ ហើយលោកបាន ទូន្មានអ្នករាល់គ្នា ឲ្យមានសេចក្ដីជំនឿ និងសេចក្ដីអត់ធន់ —

៤ មែនហើយ ទាំងទូន្មានអ្នករាល់គ្នា ឲ្យមានសេចក្ដីជំនឿដ៏ច្រើន រហូតដល់[ក]បណ្ដុះព្រះបន្ទូល នៅក្នុងដួងចិត្តអ្នក ដើម្បីឲ្យអ្នករាល់គ្នា អាចពិសោធនូវការល្អនោះ ។

៥ ហើយយើងបានឃើញថា សំនួរដ៏មហិមា ដែលនៅក្នុងចិត្តអ្នកនោះ គឺតើព្រះបន្ទូលនោះ នៅក្នុងព្រះរាជបុត្រនៃព្រះ ឬក៏នឹងគ្មាន ព្រះគ្រីស្ទទេ ។

៦ ហើយអ្នករាល់គ្នាបានឃើញ[ក]ថា បងរបស់ខ្ញុំបានបញ្ជាក់ដល់បងប្អូនជាច្រើនលើកហើយ ថាពាក្យនោះនៅក្នុងព្រះគ្រីស្ទ ចំពោះសេចក្ដីសង្គ្រោះ ។

៧ បងខ្ញុំបានដកស្រង់ពាក្យពេចន៍របស់លោកស៊ីណុស ថាសេចក្ដីសង្គ្រោះនឹងបានមកតាមរយៈព្រះរាជបុត្រានៃព្រះ ហើយបានដកស្រង់ ពាក្យពេចន៍របស់លោកស៊ីណុក ព្រមទាំងបានលើកយកលោកម៉ូសេមកនិយាយដែរ ដើម្បីបញ្ជាក់ថា រឿងទាំងនេះពិត ។

៨ ហើយឥឡូវនេះ មើលចុះ ខ្ញុំនឹង[ក]ធ្វើបន្ទាល់ដល់អ្នករាល់គ្នាដោយខ្លួនខ្ញុំផ្ទាល់ថា រឿងទាំងនោះពិត ។ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ខ្ញុំដឹងថាព្រះគ្រីស្ទនឹងយាងមក ក្នុងចំណោមកូនចៅមនុស្ស ដើម្បីទទួលយកនូវអំពើរំលងទាំងឡាយនៃប្រជារាស្ត្ររបស់ទ្រង់ ហើយថា ទ្រង់នឹង[ខ]ធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក; ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៩ ព្រោះជាការចាំបាច់ត្រូវតែមាន[ក]ដង្វាយធួនមួយកើតឡើង; ក្បិតស្របតាម[ខ]ផែនការដ៏មហិមានៃព្រះដ៏នៅអស់កល្បជានិច្ចនោះត្រូវ តែមានដង្វាយធួនមួយកើតឡើង បើពុំនោះសោតទេ មនុស្សលោកទាំងអស់នឹងពុំអាចចៀសផុតពីសេចក្ដីវិនាសបានឡើយ; មែនហើយ មនុស្សទាំងអស់មានចិត្តរឹងរូស; មែនហើយ មនុស្សទាំងអស់បាន[គ]ធ្លាក់ ហើយវង្វេង ហើយត្រូវតែវិនាស លើកលែងតែតាមរយៈដង្វាយធួន ជាការចាំបាច់ត្រូវកើតឡើង ។

១០ ព្រោះជាការចាំបាច់ ត្រូវតែមាន[ក]ការបូជាមួយដ៏មហិមា និងចុងក្រោយបង្អស់; មែនហើយ ពុំមែនជាការបូជារបស់មនុស្ស ឬក៏របស់ សត្វទេ ឬក៏របស់សត្វស្លាបណាដែរ; ព្រោះវាពុំមែនជាការបូជានៃមនុស្សទេ; ប៉ុន្តែត្រូវមាន[ខ]ការបូជាមួយ[គ]ដ៏និរន្តរ៍ និងអស់កល្បជានិច្ច ។

១១ ឥឡូវនេះ គ្មានមនុស្សណាម្នាក់ អាចបូជាលោហិតរបស់ខ្លួនផ្ទាល់ ដែលនឹងធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃជនដទៃបានឡើយ ។ ឥឡូវនេះ បើសិនជាជនណាម្នាក់ធ្វើឃាតមនុស្ស

៣៤ ១*ក* អាលម៉ា ៨:២១.
២ *ក* អាលម៉ា ១៦:១៣–២១.
៤ *ក* អាលម៉ា ៣៣:២៣.
៦ *ក* យ៉ូហាន ១:១, ១៤.
៨ *ក* ស.ប. ធ្វើបន្ទាល់.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
៩ *ក* អាលម៉ា ៣៣:២២.
*ខ* អាលម៉ា ១២:២២–៣៣; ម៉ូសេ ៦:៦២.
*គ* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
១០ *ក* ម៉ូសេ ៥:៦–៧.
*ខ* ២ នីហ្វៃ ៩:៧.
*គ* ស.ប. បូជា, យញ្ញបូជា.

មើលចុះ តើច្បាប់របស់យើងដែលត្រឹមត្រូវ នឹងយកជីវិតរបស់
បងប្អូនជននោះជំនួសឬ ? ខ្ញុំសូមប្រាប់អ្នកថា៖ ទេ ។
១២ ប៉ុន្តែច្បាប់បានទាមទារនូវជីវិតនៃជន ដែលបានធ្វើ
ឃាតវិញ; ហេតុដូច្នេះហើយ ពុំអាចមានអ្វីក្រៅពីដង្វាយធួនមួយ
ដ៏និរន្តរ៍ ទើបអាចគ្រប់គ្រាន់ សំរាប់ធ្វើឲ្យធួននឹងអំពើបាបទាំង
ឡាយនៃមនុស្សលោកនេះបាន ។
១៣ ហេតុដូច្នេះហើយ ជាការចាំបាច់ ត្រូវតែមានការបូជា
មួយដ៏មហិមា និងចុងក្រោយបង្អស់ ហើយលំដាប់នោះ នឹងមាន
ឬក៏ជាការ ចាំបាច់ ត្រូវតែមានការឈប់កំចាយឈាម;
លំដាប់នោះ ទើបក្រិត្យវិន័យលោកម៉ូសេត្រូវបានបំពេញ; មែន
ហើយ ទាំងអស់ត្រូវបានបំពេញ គឺគ្រប់ប៉ាំងឈើ និងក្បៀស
ហើយនឹងពុំមានអ្វីត្រូវកន្លងផុតឡើយ ។
១៤ ហើយមើលចុះ នេះគឺន័យទាំងស្រុងរបស់ក្រិត្យវិន័យ
ចំណុចនីមួយៗតែងចង្អុលទៅការបូជាដ៏មហិមា និង
ចុងក្រោយបង្អស់; ឯការបូជាដ៏មហិមា និងចុងក្រោយបង្អស់នោះ
គឺជាព្រះរាជបុត្រានៃព្រះ មែនហើយ គឺនិរន្តរ៍ និងអស់កល្បជានិច្ច ។
១៥ ម្ល៉ោះហើយ ទ្រង់នឹងនាំមកនូវសេចក្ដីសង្គ្រោះ ដល់អស់
អ្នកណាដែលនឹងជឿដល់ព្រះនាមទ្រង់; នេះគឺជាគោលបំណង
នៃការបូជា ចុងក្រោយបង្អស់នេះឯង ដើម្បីនាំមកនូវចិត្ត
ក្ដួលមេត្តា ដែលមានអំណាចលើសេចក្ដីយុត្តិធម៌ ដើម្បីនឹងនាំមក
នូវមធ្យោបាយទាំងឡាយ ដល់មនុស្ស ដើម្បីឲ្យគេមានសេច
ក្ដីជំនឿ ចំពោះការប្រែចិត្ត ។
១៦ ម្ល៉ោះហើយ សេចក្ដីមេត្តាករុណាអាចធ្វើឲ្យស្កប់ស្កល់
ដល់ការទាមទារនៃសេចក្ដីយុត្តិធម៌ ហើយឱបក្រសោបពួកគេនៅ
ក្នុងដៃនៃ សេចក្ដីសុខ នៅពេលដែលអ្នកនោះពុំអនុវត្តសេចក្ដីជំនឿ
ចំពោះការប្រែចិត្ត នោះត្រូវលាតត្រដាងនៅក្នុងច្បាប់ទាំងមូល
ចំពោះការ ទាមទារនៃសេចក្ដីយុត្តិធម៌; ហេតុដូច្នេះហើយ
មានតែដល់អ្នកណាដែលមានសេចក្ដីជំនឿ ចំពោះការប្រែចិត្ត
ទើបនាំមកនូវផែនការ នៃសេចក្ដីប្រោសលោះដ៏មហិមា និង
អស់កល្បជានិច្ចបាន ។
១៧ ហេតុដូច្នេះហើយ សូមព្រះប្រទានដល់អ្នក ឱបងប្អូនទាំង
ឡាយរបស់ខ្ញុំអើយ ដើម្បីឲ្យអ្នករាល់គ្នាអាចចាប់ផ្ដើមអនុវត្តសេច
ក្ដីជំនឿ ចំពោះការប្រែចិត្ត ដើម្បីឲ្យអ្នកចាប់ផ្ដើមអំពាវនាវដល់
ព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ដើម្បីឲ្យទ្រង់មានសេចក្ដីមេត្តាករុណា
ដល់អ្នករាល់គ្នា;
១៨ មែនហើយ ចូរអំពាវនាវដល់សេចក្ដីមេត្តាករុណារបស់
ទ្រង់ចុះ; ព្រោះទ្រង់មានឫទ្ធិនឹងសង្គ្រោះ ។
១៩ មែនហើយ ចូរបន្ទាបខ្លួន ហើយអធិស្ឋានជានិច្ចដល់ទ្រង់ ។
២០ ចូរអំពាវនាវដល់ទ្រង់ នៅពេលអ្នករាល់គ្នានៅឯវាលស្រែ
របស់អ្នក មែនហើយ អំពាវនាវសំរាប់ហ្វូងចៀមរបស់អ្នក។
២១ ចូរអំពាវនាវដល់ទ្រង់ នៅក្នុងផ្ទះសំបែងរបស់អ្នក មែន
ហើយ សំរាប់មនុស្សក្នុងគ្រួសារអ្នកទាំងអស់ ទាំងពេលព្រឹក ថ្ងៃត្រង់
និងពេលល្ងាច ។
២២ មែនហើយ ចូរអំពាវនាវដល់ទ្រង់ ដើម្បីតតាំងនឹង
អំណាចនៃពួកខ្មាំងសត្រូវរបស់អ្នក ។
២៣ មែនហើយ ចូរអំពាវនាវដល់ទ្រង់ ដើម្បីតតាំងនឹងអារក្ស
ដែលជាខ្មាំងសត្រូវនៃគ្រប់ទាំងសេចក្ដីសុចរិត ។
២៤ ចូរអំពាវនាវដល់ទ្រង់ សំរាប់ដំណាំនៅក្នុងចំការរបស់
អ្នក ដើម្បីឲ្យអ្នករាល់គ្នាអាចបានចំរើនឡើងដោយសារនោះ ។
២៥ ចូរអំពាវនាវសំរាប់ហ្វូងចៀម នៅឯវាលស្រែរបស់អ្នក
ដើម្បីឲ្យវាអាចកើនឡើង ។
២៦ ប៉ុន្តែនេះពុំទាន់អស់នៅឡើយទេ; អ្នករាល់គ្នាត្រូវ
បញ្ចាក់បញ្ចេញព្រលឹងរបស់ខ្លួន នៅក្នុងបន្ទប់របស់អ្នក និងនៅ
ក្នុងទីសម្ងាត់របស់អ្នក និងនៅក្នុងទីរហោស្ថានរបស់អ្នក ។
២៧ មែនហើយ ហើយនៅពេលអ្នករាល់គ្នាពុំអំពាវនាវដល់
ព្រះអម្ចាស់ ចូរអ្នករាល់គ្នាមានចិត្តពោរពេញ ដោយការអធិស្ឋាន
ដល់ ទ្រង់ជានិច្ច ដើម្បីសុខុមាលភាពរបស់អ្នក និងដើម្បីសុខុមាល
ភាពដល់ជនទាំងឡាយ ដែលនៅជុំវិញអ្នកផង ។
២៨ ហើយឥឡូវនេះ មើលចុះ ឱបងប្អូនជាទីស្រឡាញ់របស់
ខ្ញុំអើយ ខ្ញុំសូមប្រាប់អ្នក សូមកុំគិតស្មានថា នេះគឺចប់

១១ *ក* ចោទិ. ២៤:១៦; ម៉ូសាយ ២៩:២៥.
១២ *ក* ស.ប. ការដាក់ទោសដល់ជីវិត; ឃាតកម្ម.
១៣ *ក* ៣ នីហ្វៃ ៩:១៧, ១៩–២០.
*ខ* ៣ នីហ្វៃ ១៥:៥.
១៤ *ក* អាលម៉ា ៣០:៣.
*ខ* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*គ* គ. និង ស. ១៣៨:៣៥.
១៥ *ក* ស.ប. សេចក្ដីសង្គ្រោះ.
១៦ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
*គ* អាលម៉ា ១២:៣២.
*ឃ* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
១៧ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* ស.ប. ការអធិស្ឋាន.
២១ *ក* ទំនុក. ៥:១–៣; ៣ នីហ្វៃ ១៨:២១.
២៣ *ក* ៣ នីហ្វៃ ១៨:១៥, ១៨.
*ខ* ស.ប. អារក្ស.
*គ* ស.ប. សុចរិត, សេចក្ដីសុចរិត.
២៦ *ក* ម៉ាថាយ ៦:៥–៦.
២៧ *ក* ស.ប. ចិត្ត.
*ខ* ស.ប. រំពឹងគិត.

សព្វគ្រប់ហើយនោះទេ; ព្រោះបន្ទាប់ពីអ្នករាល់គ្នាបានធ្វើនូវការណ៍ទាំងនេះសព្វគ្រប់ហើយ បើសិនជាអ្នករាល់គ្នាបែរចេញពីមនុស្សដែលខ្វះខាត និងមនុស្សដែល អាក្រាត ហើយពុំទៅសាកសួរដល់អ្នកដែលឈឺ និងអ្នកដែលមានទុក្ខវេទនា ហើយពុំចែករំលែកទ្រព្យរបស់ខ្លួន បើសិនជាអ្នករាល់គ្នាមាន ចូរចែកទៅដល់ជនដែលខ្វះខាត — ខ្ញុំសូមប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នាពុំបានធ្វើនូវការណ៍ទាំងនេះទេ មើលចុះ ការអធិស្ឋានរបស់អ្នក គឺឥតប្រយោជន៍ទេ ហើយពុំនាំមកឲ្យអ្នកនូវផលអ្វីសោះ ហើយអ្នករាល់គ្នាក៏ដូចជាពួកលាក់ពុត ដែលបដិសេធសេចក្ដីជំនឿដែរ ។

២៩ ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាពុំចាំថា ត្រូវមានចិត្តសប្បុរស អ្នករាល់គ្នាក៏ដូចជាអាចម៍សំណល់ ដែលនឹងត្រូវចម្រាញ់ចោល ទៅក្រៅ (ព្រោះគ្មានតម្លៃ) ហើយនឹងត្រូវមនុស្សជាន់ឈ្លីនៅក្រោមជើង ។

៣០ ហើយឥឡូវនេះ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសង្ឃឹមថា បន្ទាប់ពីអ្នករាល់គ្នាបានទទួលនូវសាក្សីជាច្រើន ដោយបានឃើញ ថាបទគម្ពីរដ៏បរិសុទ្ធទាំងឡាយ បានធ្វើបន្ទាល់អំពីរឿងទាំងនេះ នោះចូរអ្នករាល់គ្នាចេញមក ហើយបង្កើតផលដល់សេចក្ដីប្រែចិត្តចុះ ។

៣១ មែនហើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាចេញមក ហើយចូរកុំធ្វើចិត្តរឹងរូសទៀតឡើយ; ត្បិតមើលចុះ ឥឡូវនេះគឺជាពេលវេលានិងថ្ងៃនៃ សេចក្ដីសង្គ្រោះរបស់អ្នកហើយ; ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាប្រែចិត្ត ហើយពុំធ្វើចិត្តរឹងរូសទេ រំពេចនោះផែនការនៃសេចក្ដី ប្រោសលោះដ៏មហិមានឹងបានមកដល់អ្នក ។

៣២ ត្បិតមើលចុះ ជីវិតនេះគឺជាពេលវេលាសំរាប់ឲ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ; មែនហើយ មើលចុះ ពេលវេលានៃជីវិតនេះ គឺជាពេលវេលាសំរាប់ឲ្យមនុស្សប្រព្រឹត្តការងារទាំងឡាយរបស់ខ្លួន ។

៣៣ ហើយឥឡូវនេះ ដូចដែលខ្ញុំបានប្រាប់អ្នកពីមុនមក ដោយអ្នករាល់គ្នាមានសាក្សីជាច្រើន ហេតុដូច្នេះហើយ ខ្ញុំសូមអង្វរដល់អ្នកថា ចូរអ្នករាល់គ្នាកុំបង្អង់នូវពេលវេលាចំពោះការប្រែចិត្តទុកដល់ទីអវសាននោះឡើយ; ព្រោះបន្ទាប់ពីពេលវេលានៃជីវិតនេះដែលបានប្រទាន ដល់យើង ដើម្បីប្រុងប្រៀបខ្លួនសំរាប់ដល់ភាពដ៏នៅអស់កល្បជានិច្ច មើលចុះ បើសិនជាយើងពុំបានធ្វើល្អឡើង កាលនៅក្នុងជីវិតនេះទេ លំដាប់នោះ យប់នៃសេចក្ដីងងឹតនឹងមកដល់ ហើយយើងនឹងពុំអាចប្រព្រឹត្តការងារអ្វីទៀតនៅក្នុងពេលនោះបានឡើយ ។

៣៤ អ្នករាល់គ្នាពុំអាចនិយាយថា ចាំដល់ពេលណាអ្នករាល់គ្នា ធ្លាក់ទៅក្នុងវិបត្តិដ៏យង់ឃ្នងនោះហើយ ទើបនិយាយថា ខ្ញុំនឹងប្រែចិត្ត ថាខ្ញុំនឹងត្រឡប់ទៅរកព្រះរបស់ខ្ញុំវិញទេ ។ អ្នករាល់គ្នាពុំអាចនិយាយយ៉ាងនេះទេ; ព្រោះវិញ្ញាណដែលជាម្ចាស់រូបកាយរបស់អ្នក កាលអ្នក រាល់គ្នាចេញពីជីវិតនេះហើយ គឺថាវិញ្ញាណដដែលនោះ នឹងមានអំណាចធ្វើជាម្ចាស់រូបកាយរបស់អ្នក នៅក្នុងស្ថានដ៏នៅអស់កល្បជា និច្ចនោះដែរ ។

៣៥ ត្បិតមើលចុះ បើសិនជាអ្នករាល់គ្នាបង្អង់ថ្ងៃសំរាប់ការប្រែចិត្តរបស់អ្នក រហូតដល់មរណកាល មើលចុះ អ្នករាល់គ្នានៅក្រោមអំណាច របស់វិញ្ញាណនៃអារក្ស ហើយវានឹងភ្ជាប់វិញ្ញាណវាជាមួយនឹងវិញ្ញាណរបស់អ្នក; ហេតុដូច្នេះហើយ ព្រះវិញ្ញាណនៃព្រះអម្ចាស់ទ្រង់ដកថយ ចេញពីអ្នក ហើយគ្មានកន្លែងនៅក្នុងអ្នកទៀតទេ ឯអារក្ស វានឹងមានអំណាចគ្រប់គ្រងលើអ្នក; ហើយនេះគឺជាស្ថានភាពចុងក្រោយបំផុតនៃ ពួកទុច្ចរិត ។

៣៦ ហើយខ្ញុំដឹងយ៉ាងនេះបាន ពីព្រោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ទ្រង់ពុំគង់នៅក្នុងព្រះវិហារណាដែលឥតបរិសុទ្ធឡើយ ប៉ុន្តែទ្រង់នឹងគង់នៅក្នុងចិត្តនៃពួកសុចរិតវិញ; មែនហើយ ហើយទ្រង់ក៏មានព្រះបន្ទូលថា ពួកសុចរិតនឹងអង្គុយនៅក្នុងនគររបស់ទ្រង់ ដើម្បីនឹងពុំចេញទៅក្រៅទៀតឡើយ; ប៉ុន្តែសំលៀកបំពាក់របស់គេនឹងត្រូវបានធ្វើឲ្យស តាមរយៈឈាមនៃកូនចៀម ។

៣៧ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំមានបំណងចង់ឲ្យអ្នករាល់គ្នាចងចាំនូវការណ៍ទាំងនេះ ហើយថាអ្នករាល់ គ្នាត្រូវបង្ហើយសេចក្ដីសង្គ្រោះរបស់ខ្លួន ដោយ

២៨ *ក* ស.ប. មនុស្សក្រីក្រ.
*ខ* ស.ប. ទាន, ការដាក់ទាន.
*គ* ម៉ាថាយ ១៥:៧–៨.
*ឃ* ម៉ូរ៉ូណៃ ៧:៦–៨.
២៩ *ក* ស.ប. សេចក្ដីសប្បុរស.
៣០ *ក* ម៉ាថាយ ៣:៨; អាលម៉ា ១៣:១៣.
៣១ *ក* រ៉ូម ១៣:១១–១២.
៣២ *ក* ២ នីហ្វៃ ២:២១;
អាលម៉ា ១២:២៤; ៤២:៤–៦.
៣៣ *ក* ហេលេ. ១៣:៣៨;
គ. និង ស. ៤៥:២.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*គ* យ៉ូហាន ៩:៤;
គ. និង ស. ៤៥:១៧.
*ឃ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ;
សេចក្ដីស្លាប់ខាងវិញ្ញាណ.
៣៤ *ក* អាលម៉ា ៤០:១៣–១៤.
៣៥ *ក* ២ នីហ្វៃ ២៨:១៩–២៣.
*ខ* ២ នីហ្វៃ ៩:៩.
៣៦ *ក* ម៉ូសាយ ២:៣៧; អាលម៉ា ៧:២១;
ហេលេ. ៤:២៤.
*ខ* ស.ប. សុចរិត, សេចក្ដីសុចរិត.
៣៧ *ក* ភីលីព ២:១២.

កោតខ្លាចដល់ព្រះ ហើយថាអ្នករាល់គ្នាមិនគួរបដិសេធ នូវការ
យាងមកនៃព្រះគ្រីស្ទទៀតទេ ។
៣៨ សូមអ្នករាល់គ្នាកុំទាស់ទល់នឹងព្រះវិញ្ញាណ
បរិសុទ្ធទៀតឡើយ ប៉ុន្តែសូមឲ្យអ្នករាល់គ្នាទទួលយកចុះ
ហើយលើកដាក់លើខ្លួន នូវព្រះ នាមនៃព្រះគ្រីស្ទ; សូមអ្នកបន្ទាប
ខ្លួនឲ្យរាបដល់ធូលីដី ហើយថ្វាយបង្គំព្រះ ទោះនៅទីណាដែល
អ្នកនៅក្ដី នៅក្នុងវិញ្ញាណ និងនៅក្នុងការពិត; ហើយសូមអ្នក
រាល់គ្នារស់នៅក្នុងអំណរគុណ ជារៀងរាល់ថ្ងៃ ចំពោះសេច
ក្ដីមេត្តាករុណា និងព្រះពរដ៏ច្រើន ដែលទ្រង់ប្រទានដល់អ្នក ។
៣៩ មែនហើយ ឱបងប្អូនទាំងឡាយរបស់ខ្ញុំអើយ ខ្ញុំសូមទូន្មាន
ដល់អ្នកដែរថា អ្នករាល់គ្នាគួរចាំយាមក្នុងការអធិស្ឋានជានិច្ច
ដើម្បីកុំឲ្យ អ្នករាល់គ្នាត្រូវដឹកនាំដោយការល្បួងទាំងឡាយ
នៃអារក្សឡើយ ដើម្បីកុំឲ្យវាមានអំណាចមកលើអ្នក ដើម្បីកុំឲ្យ
អ្នករាល់គ្នា ធ្លាក់នៅក្រោម អំណាចគ្រប់គ្រងរបស់វា នៅថ្ងៃ
ចុងក្រោយបង្អស់ឡើយ; ត្បិតមើលចុះ វាគ្មានឲ្យរង្វាន់ល្អដល់
អ្នកទេ ។
៤០ ហើយឥឡូវនេះ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូម
ទូន្មានដល់អ្នកឲ្យមានចិត្តអត់ធន់ ហើយឲ្យរងនូវការទុក្ខវេទនាគ្រប់
បែបយ៉ាង; ហើយសូមបងប្អូនកុំជេរប្រមាថដល់អស់អ្នកណា
ដែលបណ្ដេញអ្នកចេញ ដោយព្រោះការទាល់ក្រដ៏ហួសកំរិតឡើយ
ក្រែងអ្នករាល់គ្នាក្លាយទៅជាអ្នកមានបាបដូចពួកគេដែរ ។
៤១ ប៉ុន្តែ សូមឲ្យអ្នករាល់គ្នាមានចិត្តអត់ធន់ ហើយរងនូវការ
ទុក្ខវេទនាទាំងនោះ ដោយមានសេចក្ដីសង្ឃឹមយ៉ាងមាំមួនថា នៅ
ថ្ងៃ ណាមួយ អ្នករាល់គ្នានឹងបានសំរាកពីគ្រប់អស់ទាំងការទុក្ខ
វេទនារបស់អ្នក ៕

## ជំពូកទី ៣៥

*ការផ្សាយព្រះបន្ទូលបំផ្លាញកលល្បិចរបស់ពួកសាសន៍សូរាំ — ពួកគេបណ្ដេញពួកជនដែលប្រែចិត្តជឿ ហើយដែលរួបរួមជាមួយនឹង ប្រជាជនអាំម៉ូន នៅដែនដីយើសុនចេញ — អាលម៉ាមានទុក្ខសោកដោយព្រោះអំពើទុច្ចរិតនៃប្រជាជន ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាមូលេកបាន
បញ្ចប់នូវពាក្យទាំងនេះហើយ នោះពួកគេបានដកខ្លួនថយចេញពីហ្វូង
មនុស្ស ហើយបានឆ្លងចូលទៅដែនដីយើសុន ។
២ មែនហើយ ឯបងប្អូនឯទៀតក្រៅពីនេះ បន្ទាប់ពីបានផ្សាយ
ព្រះបន្ទូលដល់ពួកសូរាំហើយ ក៏បានឆ្លងមកឯដែនដីយើសុនដែរ ។
៣ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួក
សាសន៍សូរាំមួយភាគច្រើន បានប្រឹក្សាគ្នាអំពីព្រះបន្ទូលទាំងឡាយ
ដែលបានផ្សាយ ប្រាប់គេ នោះពួកគេក៏ខឹង ដោយព្រោះព្រះ
បន្ទូលទាំងនោះ ត្បិតព្រះបន្ទូលទាំងនោះបានបំផ្លាញកលល្បិច
របស់គេ; ហេតុដូច្នោះហើយ ពួកគេពុំព្រមស្ដាប់តាមព្រះបន្ទូល
ទាំងនោះឡើយ ។
៤ ហើយពួកគេបានចាត់ឲ្យហៅ ហើយឲ្យប្រជាជនទាំងអស់
ទូទៅអស់ទាំងដែនដី ឲ្យមកជួបជុំគ្នា ហើយពិគ្រោះនឹងពួកគេ
អំពីព្រះបន្ទូល ទាំងឡាយដែលបាននិយាយមក ។
៥ ឥឡូវនេះ ពួកអ្នកត្រួតត្រារបស់គេ និងពួកសង្ឃរបស់គេ
និងពួកគ្រូរបស់គេ ពុំបានឲ្យប្រជាជនដឹងអំពីបំណងរបស់គេឡើយ;
ហេតុដូច្នោះ ហើយ ពួកគេបានដឹងអំពីគំនិតនៃប្រជាជនទាំង
អស់ដោយសម្ងាត់ ។
៦ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេបានដឹង
អំពីគំនិតនៃប្រជាជនទាំងអស់ហើយ គឺអស់អ្នកណាដែលគាំទ្រព្រះ
បន្ទូល ដែលបានថ្លែងដោយអាលម៉ា និងបងប្អូនលោក នោះត្រូវ
គេបណ្ដេញចេញពីដែនដី; ហើយពួកគេមានចំនួនច្រើន; ហើយ
ពួកគេក៏ឆ្លងមកឯ ដែនដីយើសុនដែរ ។
៧ ហើយហេតុការណ៍បានកើតឡើងថា អាលម៉ា និង
បងប្អូនលោកបានធ្វើការងារបំរើដល់ពួកគេ ។
៨ ឥឡូវនេះ ប្រជាជននៃសាសន៍សូរាំខឹងនឹងប្រជាជនអាំម៉ូន
ដែលនៅដែនដីយើសុន ហើយមេត្រួតត្រានៃពួកសូរាំ ដែលជា
មនុស្សសែន ទុច្ចរិត បានចាត់ឲ្យមនុស្សទៅសុំឲ្យប្រជាជនអាំម៉ូន
បណ្ដេញចេញពីដែនដីគេ នូវអស់អ្នកណា ដែលមកពីពួកគេ
ដែលបានឆ្លងចូលមក ក្នុងដែនដីនោះ ។
៩ ហើយគាត់បានបញ្ចេញពាក្យគំរាមកំហែងជាច្រើនទាស់នឹង
ពួកគេ ។ ហើយឥឡូវនេះ ប្រជាជនអាំម៉ូន ពុំខ្លាចពាក្យសំដី
របស់ពួកគេទេ; ហេតុដូច្នេះហើយ ពួកគេពុំបានបណ្ដេញអ្នក

៣៨ *ក* ស.ប. ការទាស់ទែង.
*ខ* ម៉ូសាយ ៥:៨; អាលម៉ា ៥:៣៨.
*គ* ស.ប. ថ្វាយបង្គំ.
*ឃ* ទំនុក. ៦៩:៣០; គ. និង ស. ៥៩:៧.
ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
៣៩ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
*គ* អាលម៉ា ៣០:៦០.
៤០ *ក* ស.ប. សេចក្ដីអត់ធន់.
*ខ* គ. និង ស. ៣១:៩.
**៣៥** ៣ *ក* ស.ប. ឧបាយកលផ្ទែកសង្ឃ.

ទាំងនោះចេញឡើយ ប៉ុន្តែពួកគេបានទទួលអស់អ្នកក្រៅនៃពួក
សាសន៍សូរ៉ាំ ដែលបានឆ្លងចូល មករកគេ; ហើយគេបានចិញ្ចឹម
ពួកនោះ ហើយបានផ្ដល់សំលៀកបំពាក់ ហើយបានឲ្យដី
ទុកជាកេរ្ដិ៍អាករដល់គេ; ហើយពួកគេបានជួយឧបត្ថម្ភ អ្នក
ទាំងនោះ ស្របតាមអ្វីៗដែលគេត្រូវការ ។
១០ ឥឡូវនេះ ការណ៍នេះបានចាក់រុកឲ្យពួកសូរ៉ាំកាន់តែខឹង
នឹងប្រជាជនអាំម៉ូន ហើយពួកគេបានចាប់ផ្ដើមរួបរួមជាមួយនឹង
ពួកលេមិន ហើយចាក់រុកឲ្យពួកគេខឹងនឹងប្រជាជនអាំម៉ូនដែរ ។
១១ ម្ល៉ោះហើយ ពួកសូរ៉ាំ និងពួកលេមិនបានចាប់ផ្ដើម
រៀបចំធ្វើសង្គ្រាមប្រឆាំងនឹងប្រជាជនអាំម៉ូន ព្រមទាំងប្រឆាំងនឹង
ពួកនីហ្វៃផង ។
១២ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់ប្រាំពីរក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ ។
១៣ ហើយប្រជាជនអាំម៉ូនបានចាកចេញពីដែនដីយើសុន
ហើយបានឆ្លងចូលមកក្នុងដែនដីមេលេក ហើយបានទុកកន្លែងក្នុង
ដែនដីយើសុន សំរាប់ពលទ័ពសាសន៍នីហ្វៃវិញ ដើម្បីពួកគេអាច
តតាំងជាមួយនឹងពលទ័ពសាសន៍លេមិន និងពលទ័ពសាសន៍សូរ៉ាំ;
ម្ល៉ោះហើយ សង្គ្រាម បានចាប់ផ្ដើមឡើង រវាងពួកលេមិននឹងពួក
នីហ្វៃ នៅឆ្នាំទីដប់ប្រាំបីក្នុងរជ្ជកាលនៃចៅក្រម; ហើយដំណើរ
រឿងអំពីសង្គ្រាមទាំងឡាយរបស់គេ នឹងត្រូវបានរៀបរាប់នៅពេល
ខាងក្រោយ ។
១៤ ហើយអាលម៉ា និងអាំម៉ូន និងបងប្អូនគេ និងកូនប្រុស
ពីរនាក់របស់អាលម៉ា ក៏ត្រឡប់ទៅដែនដីសារ៉ាហិមឡាវិញ
បន្ទាប់ពីបានធ្វើជា គ្រឿងឧបករណ៍ នៅក្នុងព្រះហស្តនៃព្រះ ក្នុង
ការនាំពួកសាសន៍សូរ៉ាំជាច្រើនឲ្យប្រែចិត្ត; ហើយអស់អ្នកណា
ដែលត្រូវបាននាំឲ្យប្រែចិត្តនោះ ត្រូវគេបណ្ដេញចេញពីដែនដី;
ប៉ុន្តែ ពួកគេមានដីទុកសំរាប់ជាកេរ្ដិ៍អាករដល់គេ នៅក្នុង
ដែនដីយើសុន ហើយពួកគេបានកាន់អាវុធ ដើម្បីការ ពារខ្លួន និង
ប្រពន្ធ និងកូនចៅរបស់គេ និងដីរបស់គេ ។
១៥ ឥឡូវនេះ អាលម៉ា ដោយកើតទុក្ខព្រោះតែអំពើទុច្ចរិត
របស់ប្រជាជនលោក មែនហើយ ព្រោះតែសង្គ្រាមទាំងឡាយ
និងការខ្ចាយ ឈាម និងការទាស់ទែងគ្នានៅក្នុងចំណោមពួក
គេ; ហើយដោយបានប្រកាសប្រាប់នូវព្រះបន្ទូល ឬបានចាត់ឲ្យ
ទៅប្រកាសព្រះបន្ទូល នៅក្នុង ចំណោមប្រជាជនទាំង
អស់នៅគ្រប់ទីក្រុង; ហើយដោយបានឃើញថា ចិត្តរបស់
ប្រជាជនបានចាប់ផ្ដើមរឹងរូស ហើយថា ពួកគេបានចាប់ផ្ដើម
អាក់អន់ចិត្ត ដោយព្រោះភាពតឹងរឹងនៃព្រះបន្ទូល នោះចិត្ត
លោកមានការសោកសៅជាខ្លាំង ។
១៦ ហេតុដូច្នេះហើយ លោកបានចាត់ឲ្យកូនប្រុស
ៗរបស់លោកមកប្រជុំគ្នា ដើម្បីលោកអាចប្រទាន កិច្ចការ
កាន់កាប់មួយរៀងៗខ្លួន ដាច់ឡែកពីគ្នា អំពីការណ៍ទាំងឡាយ
ដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ។ ហើយយើងមាន
ដំណើររឿងអំពីបញ្ញាទាំងឡាយរបស់លោក ដែលលោកបាន
ប្រទានឲ្យពួកគេ ស្របតាមបញ្ជីរបស់លោកផ្ទាល់ ៕

---

បញ្ញាទាំងឡាយរបស់អាលម៉ា ទៅដល់ហេលេមិន ជា
កូនប្រុសរបស់លោក ។

*មានរួមនៅក្នុងជំពូកទី ៣៦ និង ៣៧*

---

## ជំពូកទី ៣៦

*អាលម៉ាធ្វើបន្ទាល់ទៅហេលេមិន អំពីការដែលលោកប្រែចិត្តជឿ បន្ទាប់ពីបានឃើញទេវតាមួយ — លោកបានរងការឈឺចាប់នៃព្រលឹង ដែលជាប់ទោស; លោកបានអំពាវនាវដល់ព្រះនាមព្រះយេស៊ូវ ហើយបន្ទាប់មកបានកើតមកអំពីព្រះ — សេចក្ដីអំណរដ៏ផ្អែមល្ហែមបាន ពោរពេញក្នុងព្រលឹងលោក — លោកបានឃើញពួកទេវតាជាច្រើនឥតគណនា កំពុងតែសរសើរដំកើងដល់ព្រះ — ពួកអ្នកដែលបាន ប្រែចិត្តជឿជាច្រើនបានភ្លក់ ហើយបានឃើញ ដូចដែលលោកបានភ្លក់ ហើយបានឃើញដែរ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ឱកូនប្រុសរបស់ឪពុកអើយ ចូរផ្ទៀងត្រចៀកស្ដាប់តាមពាក្យសំដី
របស់ឪពុក ព្រោះឪពុកសច្ចានឹងកូនថា ដរាបណាកូនកាន់
តាមព្រះ បញ្ញត្តិទាំងឡាយនៃព្រះ នោះកូននឹងបានចំរើនឡើង
នៅលើដែនដី ។
២ ឪពុកចង់ឲ្យកូនធ្វើដូចដែលឪពុកបានធ្វើ ក្នុងការចងចាំ
ដល់ការជាប់ឃុំឃាំង នៃពួកអយ្យកោរបស់យើង; ព្រោះពួក
អយ្យកោយើង បាននៅជាប់ក្នុងសេវកភាព ហើយគ្មានអ្នក

---

៩ *ក* ម៉ូសាយ ៤:២៦.
ស.ប. សុខុមាលភាព.
១៣ *ក* អាលម៉ា ៤៣:៣.
១៤ *ក* អាលម៉ា ៣៥:៦.
១៥ *ក* ស.ប. សេចក្ដីក្បត់សាសនា.
១៦ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការ
កាន់កាប់ត្រួតត្រា.
**៣៦** ១ *ក* ហេលេ. ៥:៩–១៤.
២ *ក* ម៉ូសាយ ២៣:២៣;
២៤:១៧–២១.

ណាអាចដោះលែងគេបានឡើយ លើកលែងតែព្រះនៃអ័ប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះនៃ យ៉ាកុប; ហើយទ្រង់បានដោះលែងគេឲ្យរួចផុតពីការទុក្ខវេទនាជាពិតប្រាកដ ។

៣ ហើយឥឡូវនេះ ឱហេលេមិន កូនប្រុសរបស់ឪពុកអើយ មើលចុះ កូននៅវ័យក្មេង ហេតុដូច្នេះហើយ ឪពុកសង្ឃឹមថា កូននឹង ស្ដាប់តាមពាក្យសំដីរបស់ឪពុក ហើយរៀនអំពីឪពុក; ព្រោះឪពុកដឹងថា នរណាដែលដាក់ទីទុកចិត្តរបស់ខ្លួនទៅលើព្រះ អ្នកនោះហើយ ដែលនឹងបានគាំទ្រ នៅក្នុងការពិសោធន៍របស់គេ និងវិបត្តិរបស់គេ និងការទុក្ខវេទនារបស់គេ ហើយនឹងត្រូវបានលើកឡើង នៅថ្ងៃចុង ក្រោយបង្អស់ ។

៤ ហើយឪពុកមិនចង់ឲ្យកូនគិតថា ឪពុកដឹងការណ៍នេះដោយខ្លួនឯងទេ — ពុំមែនដោយការណ៍ខាងសាច់ឈាមទេ តែដោយការណ៍ខាងវិញ្ញាណ ពុំមែនដោយគំនិតខាងរូបកាយទេ តែដោយគំនិតខាងព្រះវិញ ។

៥ ឥឡូវនេះ មើលចុះ ឪពុកប្រាប់កូនថា បើសិនជាឪពុកពុំបានកើតមកអំពីព្រះទេ ឪពុកក៏ពុំបានដឹងការណ៍ទាំងនេះដែរ; ប៉ុន្តែព្រះទ្រង់ បានធ្វើឲ្យឪពុកដឹងការណ៍ទាំងនេះ ដោយមាត់របស់ទេវតាដ៏បរិសុទ្ធរបស់ទ្រង់ ពុំមែនដោយការសក្ដិសមអ្វីរបស់ឪពុកទេ ។

៦ ព្រោះឪពុកបានទៅជាមួយនឹងពួកបុត្រានៃម៉ូសាយ ដោយស្វែងរកបំផ្លាញសាសនាចក្រនៃព្រះ; ប៉ុន្តែមើលចុះ ព្រះទ្រង់បានចាត់ឲ្យ ទេវតាដ៏បរិសុទ្ធរបស់ទ្រង់ មកបញ្ឈប់យើងនៅតាមផ្លូវ ។

៧ ហើយមើលចុះ ទេវតាបាននិយាយមកកាន់យើង ដូចជាសូរផ្គរលាន់ ហើយផែនដីទាំងមូលបានរញ្ជួយនៅក្រោមជើងយើង; ហើយយើងទាំងអស់គ្នា បានដួលទៅលើដី ព្រោះការកោតខ្លាចចំពោះព្រះ បានធ្លាក់មកលើយើង ។

៨ ប៉ុន្តែមើលចុះ សម្លេងនោះបានបន្លឺមកឪពុកថា៖ ចូរក្រោកឡើង។ ហើយឪពុកក៏ក្រោកឈរឡើង ហើយបានឃើញទេវតាមួយ ។

៩ ហើយទេវតានោះបាននិយាយមកឪពុកថា៖ ទោះជាខ្លួនអ្នកត្រូវបំផ្លាញបង់ក៏ដោយ ចូរឈប់រកបំផ្លាញសាសនាចក្រនៃព្រះទៅ។

១០ ហើយហេតុការណ៍បានកើតឡើងថា ឪពុកក៏ដួលទៅលើដី; ហើយអស់រយៈពេលបីយប់បីថ្ងៃ នោះឪពុកមិនអាចបើកមាត់ ឬក៏កំរើកដៃជើងបានដែរ ។

១១ ហើយទេវតានោះបានប្រាប់ការណ៍ជាច្រើនទៀតដល់ឪពុក ដែលបងប្អូនឪពុកបានឮ តែឪពុកពុំបានឮទេ; ត្បិតកាលឪពុកបានឮ ពាក្យថា — ទោះជាខ្លួនអ្នកត្រូវបំផ្លាញបង់ក៏ដោយ ចូរឈប់រកបំផ្លាញសាសនាចក្រនៃព្រះទៅ — នោះឪពុកក៏តក់ស្លុត ដោយការភិត ភ័យ និងភ្ញាក់ផ្អើលដ៏ខ្លាំង ព្រោះខ្លាចឪពុកត្រូវបំផ្លាញបង់ រហូតដល់ឪពុកដួលទៅលើដី ហើយក៏ពុំបានឮអ្វីទៀតទេ ។

១២ តែឪពុកត្រូវញាំញីដោយការទុក្ខវេទនា ដ៏នៅអស់កល្បជានិច្ច ព្រោះព្រលឹងឪពុកត្រូវកើតទុក្ខជាអតិបរមា ហើយត្រូវញាំញីដោយអស់ទាំងអំពើបាបរបស់ឪពុក ។

១៣ មែនហើយ ឪពុកបានចាំនូវអំពើបាប និងអំពើទុច្ចរិតទាំងអស់របស់ខ្លួន ដោយហេតុនេះហើយ ឪពុកត្រូវទទួលទោសដោយការ ឈឺចាប់នៃស្ថាននរក; មែនហើយ ឪពុកបានឃើញថា ឪពុកបានបះបោរទាស់នឹងព្រះរបស់ឪពុក ហើយថា ឪពុកមិនបានកាន់តាមព្រះ បញ្ញត្តិដ៏បរិសុទ្ធរបស់ទ្រង់សោះ ។

១៤ មែនហើយ ឪពុកបានធ្វើឃាតដល់កូនចៅរបស់ទ្រង់អស់ជាច្រើន ឬនិយាយម្យ៉ាងទៀតថា បាននាំពួកគេទៅកាន់ការបំផ្លិច បំផ្លាញ; មែនហើយ សរុបសេចក្ដីមក អំពើទុច្ចរិតរបស់ឪពុកមានទំហំធំណាស់ រហូតដល់គ្រាន់តែគិតដល់ការចូលទៅក្នុងវត្តមាន នៃព្រះរបស់ឪពុក ក៏បានញាំញីព្រលឹងឪពុកទៅហើយដោយសេចក្ដីរន្ធត់ដ៏មិនអាចថ្លែងបាន ។

១៥ ឱ ឪពុកគិតថា ឪពុកចង់ឲ្យខ្លួនត្រូវបាត់សូន្យបង់ ហើយរលត់ទៅទាំងព្រលឹងទាំងរូបកាយ ដើម្បីឪពុកមិនអាចនាំទៅឈរនៅ វត្តមាននៃព្រះ ដើម្បីទទួលការជំនុំជំរះ អំពីអំពើទាំងឡាយដែលឪពុកបានប្រព្រឹត្ត ។

១៦ ហើយឥឡូវនេះ អស់បីយប់បីថ្ងៃ ឪពុកត្រូវបានញាំញីដោយការឈឺចាប់នៃព្រលឹងដែលជាប់ទោស ។

២ *ខ* និក្ខ. ៣:៦; អាលម៉ា ២៩:១១.
៣ *ក* រ៉ូម ៨:២៨.
*ខ* ម៉ូសាយ ២៣:២១–២២.
៤ *ក* ១ កូរិន. ២:១១; អាលម៉ា ៥:៤៥–៤៦. ស.ប. ដំរិះ.
*ខ* ស.ប. ខាងរូបកាយ.
៥ *ក* ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ខ* អាលម៉ា ២៦:២១–២២.
*គ* ស.ប. សក្ដិសម, ភាពសក្ដិសម.
៦ *ក* ម៉ូសាយ ២៧:១០.
៧ *ក* ម៉ូសាយ ២៧:១៨.
*ខ* ស.ប. សេចក្ដីកោតខ្លាច — សេចក្ដីកោតខ្លាចដល់ព្រះ.
១០ *ក* ម៉ូសាយ ២៧:១៩–២៣.
១២ *ក* គ. និង ស. ១៩:១១–១៥.
១៣ *ក* ស.ប. ទោស.
១៥ *ក* វិវរ. ៦:១៥–១៧; អាលម៉ា ១២:១៤.
*ខ* អាលម៉ា ៤១:៣; គ. និង ស. ១:៩–១០.
១៦ *ក* ស.ប. សេចក្ដីជាប់ទោស.

១៧ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលឪពុកត្រូវញាំញីដោយការទុក្ខវេទនា នៅពេលដែលឪពុកកើតទុក្ខដោយ ការនឹកឃើញដល់អំពើបាបដ៏ច្រើនរបស់ឪពុក មើលចុះ ឪពុកក៏នឹកឃើញថា ធ្លាប់បានឮបិតារបស់ឪពុក ព្យាករទៅកាន់ប្រជាជន អំពីការ យាងមកនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដើម្បីមកធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក ។

១៨ ឥឡូវនេះ នៅពេលដែលឪពុកនឹកគិតទៅលើរឿងនេះ នោះឪពុកបានយំនៅក្នុងចិត្តថា៖ ឱព្រះយេស៊ូវអើយ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ សូមព្រះអង្គមានសេចក្ដីមេត្តាករុណាមកលើទូលបង្គំផង ដែលជាអ្នកនៅក្នុងប្រមាត់ល្វីងជូរចត់ ហើយកំពុងតែឡោមព័ទ្ធទៅដោយច្រវាក់ដ៏អស់កល្បជានិច្ចនៃសេចក្ដីស្លាប់ ។

១៩ ហើយឥឡូវនេះ មើលចុះ នៅពេលដែលឪពុកកំពុងតែគិតយ៉ាងនេះ នោះឪពុកក៏ឈប់នឹកឃើញការឈឺចាប់ទៀត មែនហើយ ឪពុកក៏អស់កើតទុក្ខដោយការនឹកឃើញអំពើបាបរបស់ខ្លួនទៀតទៅ។

២០ ហើយ ឱសេចក្ដីអំណរ និងរស្មីដ៏អស្ចារ្យ ដែលឪពុកបានឃើញ; មែនហើយ ព្រលឹងឪពុកបានពោរពេញ ទៅដោយសេចក្ដី អំណរ លើសជាងការឈឺចាប់របស់ឪពុកទៅទៀត!

២១ មែនហើយ ឪពុកប្រាប់កូនថា ឱកូនប្រុសរបស់ឪពុកអើយ គ្មានអ្វីដែលជ្រួតជ្រាប ហើយល្វីងជូរចត់ឲ្យស្មើនឹងការឈឺចាប់របស់ ឪពុកបានឡើយ ។ មែនហើយ ជាថ្មីទៀត ឱកូនប្រុសរបស់ឪពុកអើយ ឪពុកប្រាប់កូនថា ផ្ទុយទៅវិញ គឺគ្មានអ្វីជ្រួតជ្រាបហើយផ្អែម ល្ហែម ឲ្យស្មើនឹងសេចក្ដីអំណររបស់ឪពុកបានឡើយ ។

២២ មែនហើយ ឪពុកហាក់ដូចជាបានឃើញ ដូចជាលីហៃជាអយ្យកោរបស់យើង បានឃើញដែរ គឺឃើញ ព្រះកំពុងតែគង់នៅលើ បល្ល័ង្ករបស់ទ្រង់ ដោយមានពួកពលបរិវារទេវតាដ៏ឥតគណនាហែរហមជុំវិញ នៅក្នុងអាកប្បកិរិយាកំពុងតែច្រៀងហើយសរសើរ ដំកើងដល់ព្រះរបស់គេ; មែនហើយ ព្រលឹងឪពុករំពឹងចង់បាននៅទីនោះ ។

២៣ ប៉ុន្តែមើលចុះ ដៃជើងរបស់ឪពុកបានទទួលកម្លាំងឡើងវិញ ហើយឪពុកក្រោកឈរឡើង ហើយបានបង្ហាញប្រជាជនថា ឪពុកបានកើតមកអំពីព្រះ ។

២៤ មែនហើយ ចាប់តាំងពីពេលនោះមកដល់ពេលឥឡូវនេះ ឪពុកបានធ្វើការមិនឈប់ឈរ ដើម្បីឪពុកអាចនាំមនុស្សឲ្យប្រែចិត្ត; ដើម្បីឪពុកអាចនាំគេឲ្យភ្លក់នូវសេចក្ដីអំណរដ៏លើសលប់ ដូចដែលឪពុកធ្លាប់បានភ្លក់; ដើម្បីឲ្យគេអាចកើតមកអំពីព្រះដែរ ហើយបាន ពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ។

២៥ មែនហើយ ឥឡូវនេះ មើលចុះ ឱកូនប្រុសរបស់ឪពុកអើយ ព្រះអម្ចាស់ទ្រង់បានប្រទានឲ្យឪពុក នូវសេចក្ដីអំណរដ៏ធំលើសលប់ ដែលជាលទ្ធផលនៃការងារទាំងឡាយរបស់ឪពុក;

២៦ ត្បិតដោយសារព្រះបន្ទូល ដែលទ្រង់បានប្រទានឲ្យឪពុក មើលចុះ មនុស្សជាច្រើនបានកើតមកអំពីព្រះ ហើយបានភ្លក់ដូចជាឪពុកធ្លាប់បានភ្លក់ ហើយបានឃើញផ្ទាល់នឹងភ្នែក ដូចជាឪពុកធ្លាប់បានឃើញ; ហេតុដូច្នេះហើយ ពួកគេដឹងនូវការណ៍ទាំងនេះដែល ឪពុកបាននិយាយមក ដូចឪពុកដឹង; ហើយដំរិះរបស់ឪពុកនេះ គឺបានមកពីព្រះ ។

២៧ ហើយឪពុកបានទទួលការគាំទ្រនៅគ្រប់ការសាកល្បងនិងវិបត្តិគ្រប់ប្រការ មែនហើយ នៅក្នុងការទុក្ខវេទនាគ្រប់បែបយ៉ាង; មែនហើយ ព្រះទ្រង់បានដោះលែងឪពុកឲ្យរួចពីគុក និងពីចំណង និងពីសេចក្ដីស្លាប់; មែនហើយ គឺឪពុកដាក់ទីទុកចិត្តរបស់ឪពុកទៅ លើទ្រង់ ហើយទ្រង់នឹងនៅតែដោះលែងឪពុក ។

២៨ ហើយឪពុកដឹងថា ទ្រង់នឹងប្រោសឪពុកឡើងនៅថ្ងៃចុងក្រោយបង្អស់ ដើម្បីឲ្យរស់នៅជាមួយនឹងទ្រង់ នៅក្នុងសិរីល្អ; មែនហើយ ហើយឪពុកនឹងសរសើរដំកើងដល់ទ្រង់រហូតតទៅ ព្រោះទ្រង់បាននាំពួកអយ្យកោរបស់យើង ចេញពីស្រុកអេស៊ីព្ទ ហើយទ្រង់បានពន្លិចពួកសាសន៍អេស៊ីព្ទ នៅក្នុងសមុទ្រក្រហម; ហើយទ្រង់បាននាំពួកអយ្យកោរបស់យើង ដោយព្រះចេស្ដារបស់ទ្រង់ ទៅឯដែនដីសន្យា មែនហើយ ទ្រង់បានដោះលែងពួកគេ ឲ្យរួចផុតពីសេវកភាព និងការជាប់ឃុំឃាំងជាច្រើនលើកច្រើនគ្រា ។

២៩ មែនហើយ ទ្រង់ថែមទាំងបាននាំពួកអយ្យកោរបស់យើង ចេញពីដែនដីយេរូសាឡិម; ហើយដោយព្រះចេស្ដាដ៏អស់កល្បជានិច្ច របស់ទ្រង់ នោះទ្រង់ក៏បានដោះលែងពួកគេ

១៧ *ក* ២ កូរិន. ៧:១០.
១៨ *ក* ក.ន. ការសោកស្ដាយដ៏ខ្លាំង.
*ខ* ២ នីហ្វៃ ៩:៤៥; ២៨:២២; អាលម៉ា ១២:១១; ម៉ូសេ ៧:២៦.
១៩ *ក* ស.ប. ទោស.
២០ *ក* ស.ប. សេចក្ដីអំណរ.
២២ *ក* ១ នីហ្វៃ ១:៨.
២៣ *ក* ម៉ូសេ ១:១០.
*ខ* អាលម៉ា ៥:១៤.
ស.ប. កើតម្ដងទៀត, កើតពីព្រះ.
២៤ *ក* ១ នីហ្វៃ ៨:១២; ម៉ូសាយ ៤:១១.
*ខ* ២ នីហ្វៃ ៣២:៥; ៣ នីហ្វៃ ៩:២០.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២៦ *ក* អាលម៉ា ៣១:៥.
២៧ *ក* ទំនុក. ៣៤:១៧.
២៨ *ក* ៣ នីហ្វៃ ១៥:១.
*ខ* ស.ប. សិរីល្អ.
*គ* និក្ខ. ១២:៥១.
*ឃ* និក្ខ. ១៤:២៦–២៧.

ឲ្យរួចផុតពី[ក]សេវកភាព និងការជាប់ឃុំឃាំងជាច្រើនលើកច្រើនគ្រា រហូតមកដល់សព្វថ្ងៃ នេះផង; ហើយឪពុកចងចាំជានិច្ច នូវការជាប់ឃុំឃាំងរបស់ពួកគេ; មែនហើយ កូនក៏ត្រូវតែចងចាំជានិច្ចដែរ នូវការជាប់ឃុំឃាំងរបស់ ពួកគេ ដូចជាឪពុកបានចាំដែរ ។

៣០ ប៉ុន្តែមើលចុះ កូនប្រុសរបស់ឪពុកអើយ នេះមិនទាន់អស់ទេ; ព្រោះកូនត្រូវដឹង ដូចដែលឪពុកដឹងថា [ក]ដរាបណាកូនកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះកូននឹងបានចំរើនឡើងនៅលើដែនដី; ហើយកូនក៏ត្រូវដឹងដែរថា ដរាបណាកូនមិនកាន់តាមព្រះបញ្ញត្តិទាំង ឡាយនៃព្រះទេ នោះកូននឹងត្រូវកាត់ចេញពីវត្តមានរបស់ទ្រង់ ។ ឥឡូវនេះ នេះគឺស្របតាមព្រះបន្ទូលរបស់ទ្រង់ ៕

## ជំពូកទី ៣៧

*ផ្ទាំងលង្ហិន និងគម្ពីរផ្សេងៗទៀតបានត្រូវរក្សាទុក ដើម្បីនាំមនុស្សទៅកាន់សេចក្ដីសង្គ្រោះ — ពួកសាសន៍យ៉ារេឌត្រូវបំផ្លាញបង់ ដោយ ព្រោះសេចក្ដីទុច្ចរិតរបស់គេ — ពាក្យសម្បថ និងសេចក្ដីសញ្ញាសម្ងាត់ៗរបស់គេត្រូវបានលាក់ មិនឲ្យប្រជាជនដឹង — ចូរប្រឹក្សាជាមួយ នឹងព្រះអម្ចាស់ ក្នុងគ្រប់កិច្ចការទាំងអស់របស់អ្នក — ដូចជាលីអាហូណា (ត្រីវិស័យ) ដែលបានដឹកនាំពួកសាសន៍នីហ្វៃ រីឯព្រះបន្ទូលនៃ ព្រះគ្រីស្ទ ក៏នឹងដឹកនាំមនុស្សទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ចដែរ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយឥឡូវនេះ ឱហេលេមិន កូនប្រុសរបស់ឪពុកអើយ ឪពុកបញ្ជាកូនឲ្យ[ក]យកបញ្ជីទាំងឡាយ ដែលបាន[ខ]ប្រគល់ដល់ឪពុក ។

២ ហើយឪពុកក៏បញ្ជាឲ្យកូន កត់បញ្ជីអំពីប្រជាជននេះ ដូចដែលឪពុកបានធ្វើមក នៅលើផ្ទាំងនីហ្វៃ ហើយចូររក្សាវត្ថុអស់ទាំងនេះឲ្យ បានពិសិដ្ឋដែលឪពុកបានរក្សាមក គឺដូចជាឪពុកបានរក្សាមក; ព្រោះនេះគឺនៅក្នុងប្រយោជន៍[ក]ដ៏វាងវៃមួយ ដែលវត្ថុទាំងនេះត្រូវបាន រក្សាទុក ។

៣ ហើយ[ក]ផ្ទាំងលង្ហិនមានចំណារទាំងនេះ គឺមានបញ្ជីអំពីបទគម្ពីរដ៏បរិសុទ្ធទាំងឡាយ គឺមានពង្សាវតារនៃពួកអយ្យកោរបស់យើង ចាប់តាំងពីដើមដំបូងមក —

៤ មើលចុះ ការណ៍នេះបានព្យាករដោយពួកអយ្យកោរបស់យើងថា វត្ថុទាំងនេះត្រូវបានរក្សាទុក ហើយប្រគល់បន្តពីតំណមួយទៅ តំណមួយ ហើយត្រូវរក្សា និងថែទាំឲ្យគង់វង់ដោយព្រះហស្តនៃព្រះអម្ចាស់ រហូតដល់វត្ថុទាំងនេះបានផ្សព្វផ្សាយទៅគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ដើម្បីឲ្យគេដឹងនូវ[ក]ការអាថ៌កំបាំងទាំងឡាយនៅក្នុងនោះ ។

៥ ហើយឥឡូវនេះ មើលចុះ បើសិនជាវត្ថុទាំងនេះបានរក្សាទុក វារក្សានូវភាពភ្លឺចិញ្ចែងរបស់វា; មែនហើយ វានឹងរក្សាភាពភ្លឺចិញ្ចែងរបស់វា; មែនហើយ ឯផ្ទាំងទាំងអស់ ដែលមានកត់នូវព្រះបញ្ញត្តិដ៏បរិសុទ្ធ ក៏នឹងបានដូច្នោះដែរ ។

៦ ឥឡូវនេះ កូនអាចសន្និដ្ឋានថា នេះគឺ[ក]ការឆ្កួតវង្វេងរបស់ឪពុកហើយ; ប៉ុន្តែមើលចុះ ឪពុកប្រាប់កូនថា ដោយកិច្ចការ[ខ]តូចតាច និង ងាយ ទើបនាំឲ្យកើតកិច្ចការដ៏ធំៗបាន; ហើយនៅក្នុងករណីជាច្រើន មធ្យោបាយដ៏តូចតាចធ្វើឲ្យពួកអ្នកប្រាជ្ញជ្រប់មុខ ។

៧ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ប្រើមធ្យោបាយទាំងឡាយដើម្បីសំរេចគោលបំណងទាំងឡាយដ៏មហិមា និងដ៏នៅអស់កល្បជា និច្ចរបស់ទ្រង់; ហើយដោយមធ្យោបាយដ៏សែនតូច នោះព្រះអម្ចាស់ ទ្រង់ធ្វើឲ្យអ្នកប្រាជ្ញជ្រប់មុខ ហើយនាំមកនូវការសង្គ្រោះដល់មនុស្ស ជាច្រើន ។

៨ ហើយឥឡូវនេះ គឺដោយសារប្រាជ្ញាដែលនៅក្នុងព្រះ ទើបវត្ថុទាំងនេះត្រូវបានថែរក្សាទុក; ត្បិតមើលចុះ វត្ថុទាំងនេះបាន[ក]ពង្រីក ស្មារតីរបស់ប្រជាជននេះ មែនហើយ បានបរិវត្តមនុស្សជាច្រើនអំពីកំហុសនៃផ្លូវរបស់ខ្លួន ហើយបាននាំគេឲ្យស្គាល់ព្រះរបស់គេ ដើម្បីឲ្យបានការសង្គ្រោះដល់ព្រលឹងគេ ។

៩ មែនហើយ ឪពុកប្រាប់កូនថា [ក]បើពុំមែនសំរាប់ការណ៍ទាំងនេះ ដែលមានចែងនៅក្នុងបញ្ជីទាំងនេះ ដែលនៅលើផ្ទាំង

២៩ ក ម៉ូសាយ ២៤:១៧; ២៧:១៦; អាលម៉ា ៥:៥–៦.
៣០ ក ២ នីហ្វៃ ១:៩–១១; អាលម៉ា ៥០:១៩–២២.
៣៧ ១ក អាលម៉ា ៤៥:២–៨.
ខ ម៉ូសាយ ២៨:២០.
២ ក អេណុស ១:១៣–១៨; ព. នៃ ម. ១:៦–១១; អាលម៉ា ៣៧:៩–១២.
៣ ក ១ នីហ្វៃ ៥:១០–១៩. ស.ប. ផ្ទាំងលង្ហិន.
៤ ក ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
៦ ក ១ កូរិន. ២:១៤.
ខ ១ នីហ្វៃ ១៦:២៨–២៩; គ. និង ស. ៦៤:៣៣; ១២៣:១៥–១៧.
៧ ក អេសាយ ៥៥:៨–៩.
ខ ២ ពង្សាវ. ៥:១–១៤.
៨ ក ២ ធីម៉ូ. ៣:១៥–១៧; ម៉ូសាយ ១:៣–៥.
៩ ក ម៉ូសាយ ១:៥.

ទាំងនេះទេ នោះអាំម៉ូន និងបងប្អូនលោក ក៏មិនអាចបរិវត្តពួក
លេមិនជាច្រើនពាន់នាក់ អំពីសណ្ដាប់ដ៏ខុសឆ្គង នៃពួកអយ្យកោ
របស់គេដែរ; មែនហើយ បញ្ជីទាំងនេះ និងពាក្យនៅក្នុងនោះ
បាននាំពួកគេទៅកាន់ការប្រែចិត្ត; បានន័យថា គេបាននាំអ្នក
ទាំងនោះឲ្យស្គាល់ ព្រះអម្ចាស់ជាព្រះរបស់គេ ហើយដើម្បីអរ
រីករាយ នៅក្នុងព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះរបស់គេ ។
១០ ហើយតើនរណាដឹងថាតើរបស់ទាំងនេះ
នឹងទៅជាមធ្យោបាយទាំងឡាយ ក្នុងការនាំពួកគេជាច្រើនពាន់នាក់
មែនហើយ ព្រមទាំងមនុស្សច្រើនពាន់នាក់ នៅក្នុង
ចំណោមបងប្អូនយើង គឺពួកសាសន៍នីហ្វៃដែលរឹងក្បាល ប៉ុន្តែ
ឥឡូវនេះ កំពុងតែធ្វើចិត្តរឹងរូស នៅក្នុងអំពើបាប និងអំពើទុច្ចរិត
ទាំងឡាយ ឲ្យស្គាល់ព្រះដ៏ប្រោសលោះរបស់គេ ?
១១ ឥឡូវនេះ សេចក្ដីអាថ៌កំបាំងទាំងនេះ មិនទាន់ធ្វើឲ្យឪពុក
បានស្គាល់គ្រប់យ៉ាងនៅឡើយទេ; ហេតុដូច្នេះហើយ ឪពុកនឹង
អត់ធ្មត់រង់ចាំ ។
១២ ហើយឪពុកគ្រាន់តែនិយាយថា របស់ទាំងនេះបាន
ថែរក្សាទុក ដើម្បីប្រយោជន៍ដ៏វាងវៃមួយ គឺជាប្រយោជន៍ដែល
ព្រះទ្រង់ ជ្រាប; ព្រោះទ្រង់ទូន្មាននៅក្នុងប្រាជ្ញា ទៅលើអស់ទាំង
កិច្ចការរបស់ទ្រង់ ហើយផ្លូវរបស់ទ្រង់ត្រង់ រីឯដំណើររបស់ទ្រង់
គឺជាវង់មួយ ដ៏នៅអស់កល្បជានិច្ច ។
១៣ ឱហេលេមិន កូនប្រុសរបស់ឪពុកអើយ ចូរចងចាំ
ចូរចងចាំថា តើព្រះបញ្ញត្តិទាំងឡាយនៃព្រះ តឹងរឹងយ៉ាង
ណាទៅ ។ ហើយទ្រង់មានព្រះបន្ទូលថា៖ បើសិនជាអ្នករាល់គ្នា
កាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹងបាន
ចំរើនឡើង នៅលើដែនដី– ប៉ុន្តែ បើសិនជាអ្នករាល់គ្នាមិនកាន់
តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ទេ នោះអ្នករាល់គ្នានឹងត្រូវ
កាត់ចេញពីវត្តមាន របស់ទ្រង់ ។
១៤ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ចូរចាំថា
ព្រះទ្រង់បានទុកដាក់មកលើកូន នូវវត្ថុទាំងនេះដែលពិសិដ្ឋ
ដែលទ្រង់បាន រក្សាទុកឲ្យបានពិសិដ្ឋ ហើយដែលទ្រង់នឹង
ថែរក្សាទុកឲ្យ បានគង់វង់ ដើម្បីប្រយោជន៍ដ៏វាងវៃមួយ ដែល
នៅក្នុងទ្រង់ ដើម្បីទ្រង់អាច បង្ហាញព្រះចេស្ដារបស់ទ្រង់ ដល់
ពួកជំនាន់ក្រោយ ។
១៥ ហើយឥឡូវនេះ មើលចុះ ឪពុកប្រាប់កូនដោយវិញ្ញាណ
នៃការព្យាករណ៍ថា បើសិនជាកូនរំលងព្រះបញ្ញត្តិទាំងឡាយនៃ
ព្រះ មើលចុះ វត្ថុពិសិដ្ឋទាំងនេះនឹងត្រូវដកយកចេញពីកូនទៅ
ដោយព្រះចេស្ដានៃព្រះ ហើយកូននឹងត្រូវប្រគល់ឲ្យទៅអារក្ស
សាតាំង ដើម្បីវានឹងអុំកូនដូចជាអង្កាម ដែលនៅខាងមុខខ្យល់ ។
១៦ ប៉ុន្តែ បើសិនជាកូនកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ
ហើយថែវត្ថុពិសិដ្ឋទាំងនេះ ស្របតាមការដែលព្រះ ទ្រង់បាន
បញ្ជាកូន (ព្រោះកូនត្រូវសូមដល់ព្រះអម្ចាស់ នូវអស់ទាំងវត្ថុណា
ដែលកូនត្រូវការប្រើ) មើលចុះ គ្មានអំណាចនៃផែនដី
ឬស្ថាននរកអាចដកយក វត្ថុទាំងនោះពីកូនបានឡើយ ព្រោះព្រះ
ទ្រង់ប្រកបដោយព្រះចេស្ដា ក្នុងការធ្វើឲ្យព្រះបន្ទូលទាំងអស់
របស់ទ្រង់បានបំពេញ ។
១៧ ព្រោះទ្រង់នឹងបំពេញអស់ទាំងពាក្យសន្យារបស់ទ្រង់ ដែល
ទ្រង់នឹងធ្វើជាមួយនឹងកូន ត្បិតទ្រង់បានបំពេញពាក្យសន្យាទាំង
ឡាយ ដែលទ្រង់បានធ្វើជាមួយនឹងពួកអយ្យកោរបស់យើងដែរ ។
១៨ ព្រោះទ្រង់បានសន្យានឹងគេថា ទ្រង់នឹងថែរក្សាវត្ថុទាំងនេះ
សំរាប់ប្រយោជន៍ដ៏វាងវៃមួយ ដែលនៅក្នុងទ្រង់ ដើម្បីទ្រង់អាច
បង្ហាញព្រះចេស្ដារបស់ទ្រង់ ដល់ពួកជំនាន់ក្រោយ ។
១៩ ហើយឥឡូវនេះ មើលចុះ ទ្រង់បានបំពេញប្រយោជន៍មួយ
រួចមកហើយ គឺការនាំពួកលេមិនជាច្រើនពាន់នាក់ ឲ្យស្គាល់សេចក្ដី
ពិត; ហើយទ្រង់បានបង្ហាញព្រះចេស្ដារបស់ទ្រង់ក្នុងពួកគេ ហើយ
ទ្រង់នឹងនៅតែបង្ហាញព្រះចេស្ដារបស់ទ្រង់ក្នុងពួកគេ ទៅដល់ជំនាន់
ក្រោយ; ហេតុដូច្នេះហើយ វត្ថុទាំងនោះនឹងត្រូវបានថែរក្សាទុក ។
២០ ហេតុដូច្នេះហើយ ឱហេលេមិន កូនប្រុសរបស់ឪពុកអើយ
ឪពុកបញ្ជាកូនថា កូនត្រូវព្យាយាម ក្នុងការបំពេញពាក្យទាំងអស់
របស់ឪពុក ហើយថា កូនត្រូវព្យាយាម ក្នុងការកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះ ដូចដែលបានកត់មក ។
២១ ហើយឥឡូវនេះ ឪពុកនឹងប្រាប់កូន អំពីផ្ទាំងទាំងម្ភៃបួនសន្លឹក
ដែលកូនត្រូវថែរក្សានោះ ដើម្បីឲ្យការអាថ៌កំបាំងទាំងឡាយ និង

៩ *ខ* អាលម៉ា ១៨:៣៦; ២២:១២.
*គ* ស.ប. ដំណឹងល្អ.
១២ *ក* ២ នីហ្វៃ ៩:២៨; យ៉ាកុប ៤:១០.
*ខ* ១ នីហ្វៃ ១០:១៩; អាលម៉ា ៧:២០.
១៣ *ក* ២ នីហ្វៃ ៩:៤១.
*ខ* អាលម៉ា ៩:១៣; ៣ នីហ្វៃ ៥:២២.
*គ* ម៉ូសាយ ១:៧; អាលម៉ា ៥០:២០.
១៤ *ក* គ. និង ស. ៣:៥.
*ខ* ស.ប. បរិសុទ្ធ.
*គ* ១ នីហ្វៃ ៩:៣–៦.
១៦ *ក* យ.ស.––ប្រវត្តិ ១:៥៩.
១៨ *ក* គ. និង ស. ៥:៩.
១៩ *ក* អាលម៉ា ២៣:៥.
*ខ* អេណុស ១:១៣;
មរមន ៧:៨–១០.
២១ *ក* អេធើរ ១:១–៥.
*ខ* ស.ប. បក្សព័ន្ធសម្ងាត់.

កិច្ចការទាំងឡាយ ដែលនៅក្នុងទីងងឹត និងកិច្ចការសម្ងាត់ទាំងឡាយរបស់គេ ឬកិច្ចការសម្ងាត់របស់ពួកមនុស្ស ដែលត្រូវបំផ្លាញ ទាំងនោះ អាចបានសម្ដែងដល់ប្រជាជននេះ; មែនហើយ អស់ទាំងអំពើឃាតកម្មរបស់គេ និងអំពើលួចរបស់គេ និងអំពើប្លន់របស់គេ និងអស់ទាំងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ អាចបានសម្ដែងដល់ប្រជាជននេះ; មែនហើយ ហើយចូរកូនថែ [ក]រក្សាប្រដាប់បកប្រែទាំងនេះទុក ។

២២ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់បានទតឃើញថា រាស្ត្ររបស់ទ្រង់បានចាប់ផ្ដើម ធ្វើការនៅក្នុងទីងងឹត មែនហើយ ធ្វើអំពើឃាតកម្ម និងអំពើគួរខ្ពើមឆ្អើមទាំងឡាយដោយសម្ងាត់; ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា បើសិនជាគេមិនប្រែចិត្តទេ នោះគេនឹងត្រូវបំផ្លាញឲ្យអស់ពីលើផ្ទៃផែនដីទៅ ។

២៣ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ យើងនឹងរៀបចំសំរាប់អ្នកបំរើរបស់យើង គឺកាសេឡិម នូវ[ក]ត្បូងមួយ ដែលនឹងបំភ្លឺក្នុង ទីងងឹតឲ្យទៅជាពន្លឺ ដើម្បីយើងអាចបង្ហាញដល់រាស្ត្រយើង ដែលជាអ្នកបំរើយើង ដើម្បីយើងអាចបង្ហាញគេ នូវកិច្ចការរបស់បងប្អូនគេ មែនហើយ កិច្ចការសម្ងាត់ទាំងឡាយរបស់គេ កិច្ចការទាំងឡាយនៃសេចក្ដីងងឹតរបស់គេ និងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំង ឡាយរបស់គេ ។

២៤ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ប្រដាប់សំរាប់បកប្រែទាំងនេះបានរៀបចំឡើង ដើម្បីព្រះបន្ទូលនៃព្រះនឹងបាន បំពេញ គឺទ្រង់មានព្រះបន្ទូលថា៖

២៥ យើងនឹង[ក]យកចេញពីទីងងឹតទៅកាន់ពន្លឺ នូវកិច្ចការសម្ងាត់ទាំងអស់របស់គេ និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ; ហើយ លើកលែងតែគេមិនប្រែចិត្ត បើពុំនោះសោតទេ យើងនឹង[ខ]បំផ្លាញពួកគេឲ្យផុតពីលើផ្ទៃផែនដី; ហើយយើងនឹងនាំទៅកាន់ពន្លឺ នូវអំពើ ស្ងាត់កំបាំង និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ បង្ហាញដល់គ្រប់ទាំងសាសន៍ ដែលនឹងមកយកដែនដីនេះនៅថ្ងៃមុខ ។

២៦ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ យើងឃើញថាពួកគេពុំបានប្រែចិត្តទេ; ហេតុដូច្នេះហើយ ទើបគេត្រូវបំផ្លាញចោល ម្ល៉ោះហើយរហូតមកដល់ពេលនេះ ព្រះបន្ទូលនៃព្រះត្រូវបានបំពេញ; មែនហើយ អំពើគួរខ្ពើមឆ្អើមដ៏សម្ងាត់ទាំងឡាយរបស់គេ ត្រូវបាននាំចេញពីទីងងឹត ហើយធ្វើឲ្យយើងដឹង ។

២៧ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកបញ្ជាទៅកូនថា កូនត្រូវរក្សាទុក នូវពាក្យសម្បថទាំងឡាយរបស់គេ និង សេចក្ដីសញ្ញា និងការរួមព្រមនៅក្នុងអំពើគួរខ្ពើមឆ្អើមដ៏សម្ងាត់ទាំងឡាយរបស់គេ; មែនហើយ និង[ក]ទីសំគាល់ និងការចម្លែកទាំងអស់ របស់គេ កូនត្រូវរក្សាកុំឲ្យប្រជាជននេះដឹង ព្រោះខ្លាចក្រែងពួកគេនឹងត្រូវធ្លាក់ទៅក្នុងភាពងងឹតដែរ ហើយនឹងត្រូវបំផ្លាញចោល ។

២៨ ត្បិតមើលចុះ មាន[ក]ពាក្យបណ្ដាសាមួយដាក់មកលើដែនដីនេះ ថាការបំផ្លិចបំផ្លាញនឹងកើតមានឡើង ដល់អស់អ្នកអ្នកណាដែលធ្វើកិច្ចការនៃសេចក្ដីងងឹត ស្របតាមព្រះចេស្ដានៃព្រះ គឺកាលណាពួកគេទុំសុស; ហេតុដូច្នេះហើយ ឪពុកមិនចង់ឲ្យប្រជាជននេះត្រូវបំផ្លាញបង់ទេ ។

២៩ ហេតុដូច្នេះហើយ កូនត្រូវរក្សាផែនការសម្ងាត់នៃ[ក]ពាក្យសម្បថរបស់គេ និងសេចក្ដីសញ្ញាទាំងឡាយរបស់គេពីប្រជាជននេះ គឺគ្រាន់តែអំពើទុច្ចរិតរបស់គេ និងអំពើឃាតកម្មរបស់គេ និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេតែប៉ុណ្ណោះដែលកូនត្រូវឲ្យគេដឹង; ហើយកូនត្រូវបង្រៀនគេឲ្យ[ខ]ស្អប់អំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ និងអំពើឃាតកម្មបែបនេះ; ហើយកូនក៏ត្រូវបង្រៀនគេ ដែរថា ប្រជាជនទាំងនោះត្រូវបានបំផ្លាញចោល ដោយមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ និងអំពើឃាតកម្មទាំងឡាយរបស់គេ ។

៣០ ត្បិតមើលចុះ ពួកគេបានធ្វើឃាតដល់អស់ទាំងពួកព្យាការីនៃព្រះអម្ចាស់ ដែលបានមកក្នុងចំណោមគេ ដើម្បីប្រកាសដល់គេ អំពីសេចក្ដីទុច្ចរិតទាំងឡាយរបស់គេ; ហើយឈាមរបស់អស់អ្នកដែលត្រូវគេធ្វើឃាតនោះ បានអំពាវនាវដល់ព្រះអម្ចាស់ជាព្រះ របស់គេ សូមឲ្យសងសឹកដល់អស់អ្នកណាដែលជាឃាតកលើរូបគេ; ម្ល៉ោះហើយ សេចក្ដីជំនុំជំរះទាំងឡាយនៃព្រះ ក៏បានធ្លាក់មកលើ ពួកអ្នកដែលធ្វើកិច្ចការនៃសេចក្ដីងងឹត និងបក្សព័ន្ធសម្ងាត់ ។

៣១ មែនហើយ ហើយត្រូវបណ្ដាសាដល់ដែនដីនោះជារៀងរហូតតទៅ ដល់ពួកអ្នកដែលធ្វើកិច្ចការនៃសេចក្ដីងងឹត និងបក្សព័ន្ធ សម្ងាត់ គឺរហូតដល់ការបំផ្លិចបំផ្លាញចោល លើកលែតែគេប្រែចិត្ត មុនពេលគេទុំសុស ។

២១ *ក* ស.ប. យូរីម និងធូមីម.
២៣ *ក* ម៉ូសាយ ៨:១៣.
២៥ *ក* គ. និង ស. ៨៨:១០៨–១១០.
*ខ* ម៉ូសាយ ២១:២៦.
២៧ *ក* ហេលេ. ៦:២២.
២៨ *ក* អាលម៉ា ៤៥:១៦;
អេធើរ ២:៧–១២.
២៩ *ក* ហេលេ. ៦:២៥.
*ខ* អាលម៉ា ១៣:១២.

៣២ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ចូរកូនចាំពាក្យដែលឪពុកបាននិយាយទៅកូនចុះ; ចូរកុំឲ្យផែនការណ៍សម្ងាត់ទាំង នោះដល់ប្រជាជននេះឡើយ តែចូរបង្រៀនគេឲ្យមានការស្អប់ដ៏អស់កល្បជានិច្ច ទាស់នឹងអំពើបាប និងអំពើទុច្ចរិត ។

៣៣ ចូរផ្សាយប្រាប់ពួកគេអំពីការប្រែចិត្ត និងសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ; ចូរបង្រៀនពួកគេ ឲ្យបន្ទាបខ្លួន និងស្លូតបូត ហើយមានចិត្តសុភាព; ចូរបង្រៀនពួកគេឲ្យទប់ទល់នឹងគ្រប់ការល្បួងនៃអារក្ស ដោយសេចក្ដីជំនឿរបស់គេ ជឿដល់ព្រះអម្ចាស់យេស៊ូវ គ្រីស្ទ ។

៣៤ ចូរបង្រៀនពួកគេ កុំឲ្យនឿយហត់ឲ្យសោះ ក្នុងកិច្ចការល្អ តែឲ្យស្លូតបូត ហើយមានចិត្តសុភាពវិញ; ព្រោះអ្នកដែលធ្វើដូច្នេះ នឹងបានសេចក្ដីសំរាកដល់ព្រលឹងខ្លួន ។

៣៥ ឱកូនប្រុសរបស់ឪពុកអើយ ចូរចងចាំ ហើយឲ្យចេះមានប្រាជ្ញា នៅក្នុងយុវ័យរបស់កូនចុះ; មែនហើយ ចូររៀននៅក្នុងយុវ័យ របស់កូន ឲ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។

៣៦ មែនហើយ ចូរអំពាវនាវដល់ព្រះ នូវអស់ទាំងការគាំទ្ររបស់កូន; មែនហើយ ចូរធ្វើអ្វីៗទាំងអស់ចំពោះព្រះអម្ចាស់ ហើយទោះ ជាទីណាដែលកូនទៅ គឺកូនទៅក្នុងព្រះអម្ចាស់; មែនហើយ ចូរបំបែរមនោសញ្ចេតនាទាំងអស់របស់កូន ឆ្ពោះទៅរកព្រះអម្ចាស់វិញ; មែនហើយ ចូរដាក់ចិត្តមេត្រីរបស់កូន ទៅលើព្រះអម្ចាស់ជរាបតទៅ ។

៣៧ ចូរប្រឹក្សាជាមួយនឹងព្រះអម្ចាស់នូវគ្រប់កិច្ចការរបស់កូន ហើយទ្រង់នឹងដឹកនាំកូនទៅរកការល្អ; មែនហើយ កាលណាកូនដេក ចុះ នៅពេលយប់ ចូរដេកនៅក្នុងព្រះអម្ចាស់ ដើម្បីឲ្យទ្រង់មើលថែទាំកូន ពេលកូនដេក; ហើយពេលកូនក្រោកឡើងនៅពេលព្រឹក ចូរ ចិត្តកូនពោរពេញ ទៅដោយអំណរគុណដល់ព្រះ; ហើយបើសិនជាកូនធ្វើការទាំងនេះ នោះកូននឹងត្រូវបានលើកឡើង នៅថ្ងៃចុង ក្រោយបង្អស់ ។

៣៨ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកត្រូវនិយាយខ្លះ អំពីវត្ថុដែលពួកអយ្យកោយើង បានហៅថា ដុំមូល ឬប្រដាប់ នាំផ្លូវ — ឬដែលពួកអយ្យកោយើងបានហៅវាថា លីអាហូណា គឺបកប្រែមកថា ត្រីវិស័យ; ហើយព្រះអម្ចាស់ទ្រង់បានរៀបចំវត្ថុនោះ ឡើង ។

៣៩ ហើយមើលចុះ មិនអាចមានមនុស្សណាធ្វើបាននូវវត្ថុដ៏ចម្លែកយ៉ាងនេះបានឡើយ ។ ហើយមើលចុះ វត្ថុនោះត្រូវបានរៀបចំ ឡើង ដើម្បីបង្ហាញដល់ពួកអយ្យកោយើង នូវផ្លូវដែលគេត្រូវធ្វើដំណើរ នៅក្នុងទីរហោស្ថាន ។

៤០ ហើយវាបានធ្វើការឲ្យគេ ស្របតាមសេចក្ដីជំនឿរបស់គេនៅក្នុងព្រះ; ហេតុដូច្នេះហើយ បើសិនជាពួកគេមានសេចក្ដីជំនឿ ជឿថាព្រះទ្រង់អាចធ្វើឲ្យទ្រនិចទាំងនោះចង្អុលប្រាប់ផ្លូវ ដែលគេត្រូវទៅ មើលចុះ ការណ៍នោះក៏ត្រូវបានសំរេច; ហេតុដូច្នេះហើយ ពួកគេមានអព្ភូតហេតុនេះ និងអព្ភូតហេតុឯទៀតជាច្រើនផង ដែលបានមកដោយព្រះចេស្ដានៃព្រះ ពីថ្ងៃមួយទៅថ្ងៃមួយ ។

៤១ ទោះជាយ៉ាងណាក៏ដោយ ពីព្រោះអព្ភូតហេតុទាំងនោះត្រូវបានធ្វើឡើងដោយមធ្យោបាយដ៏តូចតាច នោះវាបានបង្ហាញពួកគេ នូវកិច្ចការដ៏អស្ចារ្យទាំងឡាយ ។ ពួកគេខ្ជិលច្រអូស ហើយភ្លេចអនុវត្តសេចក្ដីជំនឿ និងសេចក្ដីព្យាយាមរបស់គេ ហើយបន្ទាប់មក ការណ៍ដ៏អស្ចារ្យទាំងនោះក៏ឈប់មាន ហើយពួកគេពុំអាចធ្វើដំណើរទៅមុខទៀតបានទេ ។

៤២ ហេតុដូច្នេះហើយ ពួកគេនៅក្នុងទីរហោស្ថាន ឬពុំបានធ្វើដំណើរតាមផ្លូវត្រង់ ហើយត្រូវរងទុក្ខ ដោយការស្រេកឃ្លាន ដោយព្រោះអំពើរំលងទាំងឡាយរបស់គេ ។

៤៣ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកចង់ឲ្យកូនយល់ថា ការណ៍ទាំងនេះពុំមែនគ្មានស្រមោលនោះទេ; ត្បិតដូចជា ពួកអយ្យកោយើងខ្ជិលច្រអូស ក្នុងការស្ដាប់បង្គាប់តាមត្រីវិស័យនេះយ៉ាងណា (ឥឡូវនេះ វត្ថុទាំងនេះជាវត្ថុខាងសាច់ឈាម) នោះពួកគេមិនបានចំរើនឡើងឡើយ; ឯកិច្ចការទាំងឡាយខាងផ្លូវវិញ្ញាណក៏ដូច្នោះដែរ ។

៤៤ ត្បិតមើលចុះ ដូចជាងាយស្ដាប់បង្គាប់តាមព្រះបន្ទូលនៃព្រះគ្រីស្ទ ដែលនឹងចង្អុលបង្ហាញកូន នូវផ្លូវមួយដ៏ត្រង់ ទៅកាន់សុភមង្គល ដ៏នៅអស់កល្បជានិច្ចយ៉ាងណា ក៏ដូចជាករណី

៣២ *ក* ២ នីហ្វៃ ៤:៣១.
៣៣ *ក* ស.ប. ផ្សាយ.
*ខ* ស.ប. ស្លូតបូត, ភាពស្លូតបូត.
*គ* ស.ប. ល្បួង, សេចក្ដីល្បួង.
៣៤ *ក* ទំនុក. ៣៧:៤–៧;
ម៉ាថាយ ១១:២៨–៣០.
៣៥ *ក* ស.ប. ប្រាជ្ញា.
៣៦ *ក* ស.ប. ការអធិស្ឋាន.
៣៧ *ក* យ៉ាកុប ៤:១០; គ. និង ស. ៣:៤.
*ខ* គ. និង ស. ៤៦:៣២.
៣៨ *ក* ១ នីហ្វៃ ១៦:១០; ១៨:១២;
គ. និង ស. ១៧:១.
៤០ *ក* ១ នីហ្វៃ ១៦:២៨.
៤១ *ក* អាលម៉ា ៣៧:៦–៧.
៤៤ *ក* ទំនុក. ១១៩:១០៥;
១ នីហ្វៃ ១១:២៥;
ហេលេ. ៣:២៩–៣០.

ដែលពួកអយ្យកោយើងស្ដាប់បង្គាប់តាមត្រីវិស័យនេះ ដែល
នឹងចង្អុលប្រាប់គេ នូវផ្លូវត្រង់មួយ ទៅកាន់ដែនដីសន្យាដែរ ។
៤៥ ហើយឥឡូវនេះ ឪពុកប្រាប់ថា តើគ្មានគំរូមួយនៅក្នុង
ការណ៍នេះទេឬអី ? ព្រោះប្រាកដដូចជាប្រដាប់នាំផ្លូវនេះ បាន
នាំពួក អយ្យកោយើង ឲ្យដើរតាមទិសដែលវាបង្ហាញ ទៅកាន់
ដែនដីសន្យាយ៉ាងណា ឯព្រះបន្ទូលនៃព្រះគ្រីស្ទក៏ដូច្នោះដែរ
បើសិនជាយើង ដើរតាមផ្លូវដែលពាក្យទាំងនោះបង្ហាញ
នោះវានឹងនាំយើងឲ្យផុតច្រកភ្នំ នៃការសោកសៅនេះ ទៅ
ដល់ដែនដីសន្យាមួយ ដ៏សែនល្អ ជាងនេះដែរ ។
៤៦ ឱកូនប្រុសរបស់ឪពុកអើយ ចូរយើងកុំខ្ជិលច្រអូស
ដោយព្រោះផ្លូវងាយឡើយ; ព្រោះនោះគឺជាករណីនៃពួក
អយ្យកោយើងដែរ; ព្រោះវាត្រូវបានរៀបចំឡើងសំរាប់ពួកគេ
ថាបើសិនជាគេក្រឡេកមើល នោះគេអាចរស់នៅ;
ឯយើងក៏ដូច្នោះដែរ ។ ផ្លូវនោះត្រូវ បានរៀបចំជាស្រេច ហើយបើ
សិនជាយើងនឹងមើល នោះយើងអាចរស់នៅរហូតតទៅ ។
៤៧ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ចូរឲ្យឃើញថា
កូនថែរក្សាវត្ថុពិសិដ្ឋទាំងនេះ មែនហើយ ចូរឲ្យឃើញថា កូនមើល
ទៅព្រះ ហើយរស់នៅ ។ ចូរកូនទៅក្នុងចំណោមប្រជាជននេះ
ហើយប្រកាសប្រាប់ព្រះបន្ទូល ហើយមានចិត្តរឹងប៉ឹង ។ កូនប្រុស
របស់ ឪពុកអើយ ឪពុកលាសិនហើយ ៕

---

បញ្ជាទាំងឡាយនៃអាលម៉ា ដល់ស៊ិបឡុន ជាកូនប្រុស
របស់លោក ។

*មានរួមនៅក្នុងជំពូកទី ៣៨*

---

## ជំពូកទី ៣៨

*ស៊ិបឡុនត្រូវគេបៀតបៀន ដោយសារសេចក្ដីសុចរិត — សេចក្ដីសង្គ្រោះគឺនៅក្នុងព្រះគ្រីស្ទ ដែលជាជីវិត និងជា ពន្លឺនៃមនុស្សលោក — ចូរទប់តណ្ហាទាំងអស់របស់ខ្លួន ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ឱកូនប្រុសរបស់ឪពុកអើយ ចូរផ្ទៀងត្រចៀកតាមពាក្យសំដី
របស់ឪពុក ព្រោះឪពុកប្រាប់កូន ដូចជាឪពុកបាន
ប្រាប់ទៅហេលេមិនដែរថា ដរាបណាកូនកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះ នោះកូននឹងបានចំរើនឡើងនៅលើដែនដី
ហើយដរាបណាកូនមិនកាន់តាមព្រះ បញ្ញត្តិទាំងឡាយនៃព្រះទេ
នោះកូននឹងត្រូវកាត់ចេញពីវត្តមានរបស់ទ្រង់ ។
២ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកជឿថា
ឪពុកនឹងមានសេចក្ដីអំណរដ៏មហិមា ដោយសារកូន ដោយ
ព្រោះចិត្ត នឹងនរ និងចិត្តស្មោះត្រង់របស់កូនចំពោះព្រះ; ព្រោះ
ដូចជាកូនបានចាប់ផ្ដើមរំពឹងទៅរកព្រះអម្ចាស់ ជាព្រះរបស់កូន
នៅក្នុងយុវវ័យជា យ៉ាងណា នោះឪពុកសង្ឃឹមថា កូននឹងកាន់
តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់រហូតតទៅជាយ៉ាងនោះដែរ;
ព្រោះមានពរហើយ ដល់អស់អ្នកណា ដែលកាន់ខ្ជាប់ ដរាប
ដល់ចុងបំផុត ។
៣ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកប្រាប់កូនថា ឪពុកមាន
សេចក្ដីអំណរជាខ្លាំងមកហើយ ដោយសារកូន ដោយ
ព្រោះសេចក្ដីស្មោះ ត្រង់ និងសេចក្ដីព្យាយាមរបស់កូន និងសេច
ក្ដីអត់ធន់របស់កូន និងសេចក្ដីអត់ធ្មត់របស់កូន ក្នុង
ចំណោមប្រជាជននៃសាសន៍សូរាំ ។
៤ ព្រោះឪពុកដឹងថា កូនធ្លាប់ជាប់ចំណង; មែនហើយ ឪពុកក៏
ដឹងដែរថា កូនត្រូវគេចោលនឹងថ្ម ដោយសារព្រះបន្ទូល; ហើយ
កូន បានរងនូវការណ៍អស់ទាំងនេះ ដោយសេចក្ដីអត់ធន់
ពីព្រោះព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងកូន; ហើយឥឡូវនេះ
កូនដឹងថា ព្រះអម្ចាស់ ទ្រង់បានដោះលែងកូនហើយ ។
៥ ហើយឥឡូវនេះ ឱស៊ិបឡុន កូនប្រុសរបស់ឪពុកអើយ ឪពុក
ចង់ឲ្យកូនចាំថា ដរាបណាកូនដាក់ទីទុកចិត្តរបស់កូននៅលើព្រះ
នោះកូននឹងបានដោះលែងឲ្យរួចផុត ពីការសាកល្បងទាំងឡាយ
របស់កូន និងពីសេចក្ដីអំពល់របស់កូន និងពីសេចក្ដីទុក្ខវេទនាទាំង
ឡាយរបស់កូន ហើយកូននឹងត្រូវបានលើកឡើង នៅថ្ងៃ
ចុងក្រោយបង្អស់ ។
៦ ឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកមិនចង់ឲ្យកូន
គិតថា ឪពុកដឹងការណ៍អស់ទាំងនេះ ដោយខ្លួនឯងទេ ប៉ុន្តែ

---

៤៦ *ក* ១ នីហ្វៃ ១៧:៤០–៤១.
*ខ* យ៉ូហាន ១៤:៥–៦;
២ នីហ្វៃ ៩:៤១; ៣១:១៧–២១;
គ. និង ស. ១៣២:២២, ២៥.
*គ* យ៉ូហាន ១១:២៥; ហេលេ. ៨:១៥;
៣ នីហ្វៃ ១៥:៩.
**៣៨** ២ *ក* អាលម៉ា ៦៣:១–២.
*ខ* ២ នីហ្វៃ ៣១:១៥–២០;
៣ នីហ្វៃ ១៥:៩; ២៧:៦, ១៦–១៧.
៣ *ក* អាលម៉ា ៣១:៧.
៤ *ក* ស.ប. សេចក្ដីអត់ធន់.
*ខ* រ៉ូម ៨:៣៥–៣៩.
៥ *ក* អាលម៉ា ៣៦:២៧.
ស.ប. ទុកចិត្ត.
*ខ* ម៉ាថាយ ១១:២៨–៣០.
*គ* គ. និង ស. ៣:៨; ១២១:៧–៨.

គឺព្រះ វិញ្ញាណនៃព្រះ ដែលគង់នៅក្នុងឪពុកទេតើ ដែលបានធ្វើឲ្យឪពុកដឹងការណ៍ទាំងនេះ; ព្រោះបើឪពុកពុំបានកើតមកអំពីព្រះទេ នោះឪពុក ក៏ពុំបានដឹងការណ៍ទាំងនេះដែរ ។

៧ ប៉ុន្តែមើលចុះ ដោយសេចក្ដីមេត្តាករុណាដ៏មហិមារបស់ទ្រង់ នោះព្រះអម្ចាស់ទ្រង់បានចាត់ឲ្យទេវតារបស់ទ្រង់មួយ មកប្រកាសប្រាប់ឪពុកថា ឪពុកត្រូវបញ្ឈប់ការបំផ្លិចបំផ្លាញក្នុងចំណោមរាស្ត្រទ្រង់; មែនហើយ ឪពុកបានឃើញទេវតាមួយ ផ្ទាល់នឹងមុខហើយ ទេវតានោះបាននិយាយជាមួយនឹងឪពុក ហើយសម្លេងលោកហាក់បីដូចជាផ្គរលាន់ ហើយវាធ្វើឲ្យញ័រផែនដីទាំងមូល ។

៨ ហើយហេតុការណ៍បានកើតឡើងថា ឪពុកមានការឈឺចាប់ដ៏ជូរចត់ និងការបារម្ភនៅក្នុងព្រលឹង អស់រយៈពេលបីយប់បីថ្ងៃ; ហើយ រហូតដល់ឪពុកបានអំពាវនាវ ដល់ព្រះយេស៊ូវគ្រីស្ទ សូមសេចក្ដីមេត្តាករុណា ទើបឪពុកបានទទួលការផ្ដាច់បាបទាំងឡាយរបស់ឪពុក ។ ប៉ុន្តែមើលចុះ ឪពុកបានអំពាវនាវដល់ទ្រង់ ហើយឪពុកបានសេចក្ដីសុខសាន្តដល់ព្រលឹងឪពុក ។

៩ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកបានប្រាប់កូននូវការណ៍នេះ ដើម្បីឲ្យកូនអាចរៀននូវប្រាជ្ញា ដើម្បីឲ្យកូនអាចរៀនអំពីឪពុកថា គ្មានផ្លូវ ឬមធ្យោបាយឯណាផ្សេងទៀតទេ ដែលនាំឲ្យមនុស្សបានសង្គ្រោះ មានតែដោយ និងតាមរយៈព្រះគ្រីស្ទមួយប៉ុណ្ណោះ ។ មើលចុះ ទ្រង់គឺជាជីវិត ហើយជាពន្លឺនៃពិភពលោក ។ មើលចុះ ទ្រង់គឺជាព្រះបន្ទូលនៃសេចក្ដីពិត និងសេចក្ដីសុចរិត ។

១០ ហើយឥឡូវនេះ ដូចជាកូនបានចាប់ផ្ដើមបង្រៀនព្រះបន្ទូលយ៉ាងណា នោះឪពុកសង្ឃឹមថា កូនក៏នឹងបង្រៀនយ៉ាងនេះតទៅ; ហើយឪពុកសង្ឃឹមថា កូននឹងមានការព្យាយាម ហើយចេះទប់ចិត្តក្នុងគ្រប់ការណ៍ទាំងអស់ ។

១១ ចូរកូនប្រយ័ត្នកុំលើកខ្លួនឡើងទៅជាឆ្មើងឆ្មៃ; មែនហើយ ចូរឲ្យឃើញថា កូនមិនអួតអាងក្នុងប្រាជ្ញាផ្ទាល់របស់កូន ឬក្នុងកម្លាំង ដ៏ច្រើនរបស់កូនឡើយ ។

១២ ចូរប្រើសេចក្ដីក្លាហាន ប៉ុន្តែកុំកោងកាច; ហើយចូរឲ្យឃើញថា កូនទប់អស់ទាំងតណ្ហារបស់កូន ដើម្បីឲ្យកូនអាចបានពោរពេញ ទៅដោយសេចក្ដីស្រឡាញ់; ចូរឲ្យឃើញថា កូនទប់ខ្លួនកុំឲ្យធ្លាក់ទៅក្នុងការខ្ជិលច្រអូស ។

១៣ ចូរកុំអធិស្ឋានដូចពួកសាសន៍សូរាំធ្វើ ព្រោះកូនបានឃើញថា ពួកគេអធិស្ឋានដើម្បីឲ្យមនុស្សស្ដាប់ ហើយដើម្បីឲ្យគេកោត សរសើរប្រាជ្ញារបស់គេ ។

១៤ ចូរកុំទូលថា៖ ឱព្រះអង្គអើយ ទូលបង្គំសូមថ្លែងអំណរគុណដល់ព្រះអង្គ ដោយយើងខ្ញុំល្អប្រសើរជាងបងប្អូនរបស់យើងខ្ញុំ; តែត្រូវ ទូលយ៉ាងនេះវិញថា៖ ឱព្រះអម្ចាស់អើយ សូមអភ័យទោសដល់ភាពមិនសក្តិសមរបស់ទូលបង្គំផង ហើយសូមព្រះអង្គចងចាំដល់បងប្អូន របស់ទូលបង្គំ ដោយសេចក្ដីមេត្តាករុណា — មែនហើយ ចូរទទួលស្គាល់ភាពមិនសក្តិសមរបស់កូន នៅចំពោះព្រះ នៅគ្រប់ពេល វេលា ។

១៥ ហើយសូមឲ្យព្រះអម្ចាស់ ទ្រង់ប្រទានពរដល់ព្រលឹងកូន ហើយទទួលយកកូននៅថ្ងៃចុងក្រោយបង្អស់ ឲ្យចូលទៅក្នុងនគររបស់ ទ្រង់ ឲ្យកូនអង្គុយនៅក្នុងសេចក្ដីសុខសាន្តចុះ ។ ឥឡូវនេះទៅចុះកូនប្រុសរបស់ឪពុក ហើយបង្រៀនព្រះបន្ទូលទៅដល់ប្រជាជននេះ ។ ចូរមានចិត្តរឹងប៉ឹង ។ កូនប្រុសរបស់ឪពុកអើយ ឪពុកលាសិនហើយ ៕

---

បញ្ញាទាំងឡាយនៃអាលម៉ា ដល់កូរីអានតុន ជាកូនប្រុសរបស់លោក ។

*មានរួមនៅក្នុងជំពូកទី ៣៩ ទៅ ៤២*

## ជំពូកទី ៣៩

*អំពើបាបខាងកាមគុណ គឺជាអំពើគួរខ្ពើមឆ្អើមមួយ — អំពើបាបរបស់កូរីអានតុន ឃាត់យាំងពួកសាសន៍សូរាំមិនឲ្យទទួលព្រះបន្ទូល — សេចក្ដីប្រោសលោះរបស់ព្រះគ្រីស្ទ មានប្រតិកម្មក្នុងការសង្គ្រោះពួកស្មោះត្រង់ ដែលបានរស់នៅពីមុននោះ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកចង់និយាយនឹងកូនខ្លះទៀត ក្រៅអំពីអ្វីៗ ដែលឪពុកបាននិយាយនឹងបងរបស់កូន; ត្បិតមើលចុះ តើកូនពុំបានយកចិត្តទុកដាក់ ដល់ភាពនឹងធឹងរបស់បងប្រុសកូនទេឬ និងសេចក្ដីស្មោះត្រង់របស់គេ និងសេចក្ដីព្យាយាម

---

៦ *ក* អាលម៉ា ៣៦:២៦;
គ. និង ស. ៥:១៦.
ស.ប. កើតម្ដងទៀត, កើតពីព្រះ.
៧ *ក* ម៉ូសាយ ២៧:១១–១៧.
*ខ* អាលម៉ា ២៦:១៧–១៨;
៣៦:៦–១១.
៨ *ក* ស.ប. ការផ្ដាច់បាប.
៩ *ក* ហេលេ. ៥:៩.
*ខ* ម៉ូសាយ ១៦:៩.
១១ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១៤ *ក* អាលម៉ា ៣១:១៦.
*ខ* លូកា ១៨:១០–១៤.

របស់គេ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ? មើលចុះ
តើបងរបស់កូន ពុំមែនជាគំរូមួយ សំរាប់កូនទេឬអី ?
២ ព្រោះកូនពុំបានយកចិត្តទុកដាក់ស្ដាប់តាមពាក្យសំដីរបស់
ឪពុក ដូចបងប្រុសរបស់កូន នៅក្នុងចំណោមប្រជាជន
នៃសាសន៍សូរាំ ទេ។ ឥឡូវ នេះគឺជាការណ៍ដែលឪពុកជំទាស់
នឹងកូន; កូនបានអួតអាង ដល់កម្លាំងរបស់កូន និងប្រាជ្ញារបស់កូន ។
៣ ហើយនេះ ពុំទាន់អស់នៅឡើយទេ កូនប្រុសរបស់ឪពុក
អើយ ។ កូនបានធ្វើនូវអ្វីៗ ដែលនាំឲ្យឪពុកព្រួយបារម្ភ; ព្រោះកូន
បាន បោះបង់ចោលការងារបំរើ ហើយបានទៅតាមស្រីខូច
អ៊ីសាបែល ឆ្លងទៅឯដែនដីសៃរ៉ុន នៅតាមព្រំប្រទល់ដែនដីនៃពួក
សាសន៍ លេមិន ។
៤ មែនហើយ ស្រីនោះបានបោកចិត្តមនុស្សជាច្រើន; ប៉ុន្តែនេះ
ពុំមែនជាការដោះសាសំរាប់កូនទេ ឱកូនប្រុសរបស់ឪពុកអើយ ។
កូនគួរតែបំពេញការងារបំរើ ដែលបានប្រគល់ដល់កូន ។
៥ កូនប្រុសរបស់ឪពុកអើយ តើកូនពុំដឹងទេឬថា អំពើទាំងនេះ
គឺជាអំពើគួរខ្ពើមឆ្អើមនៅចំពោះព្រះនេត្រនៃព្រះអម្ចាស់; មែនហើយ
គឺគួរខ្ពើមឆ្អើមបំផុតជាងបាបទាំងអស់ ក្រៅពីការខ្ចាយឈាមជន
ឥតទោស ឬបដិសេធព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ?
៦ ត្បិតមើលចុះ បើសិនជាកូនបដិសេធព្រះវិញ្ញាណបរិសុទ្ធ
ក្នុងពេលដែលទ្រង់មានទីកន្លែងនៅក្នុងកូនមកហើយ ហើយកូន
ដឹងថា កូនបានបដិសេធទ្រង់ មើលចុះ នេះគឺជាអំពើបាបមួយ
ដែលអត់ឱនមិនបានឡើយ; មែនហើយ ហើយជនណាដែលធ្វើ
ឃាត ក្រោយពី បានទទួលពន្លឺ និងការចេះដឹងអំពីព្រះ ជននោះ
ពុំងាយនឹងបានទទួលការអភ័យទោសឡើយ; មែនហើយ
កូនប្រុសរបស់ឪពុកអើយ ឪពុកប្រាប់កូនថា ជននោះពុំងាយនឹង
បានទទួលការអភ័យទោសឡើយ ។
៧ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុក
បានសូមអង្វរដល់ព្រះ ដើម្បីកុំឲ្យកូនមានទោសដ៏ធំបែបនេះ ។
ឪពុកពុំគួរ និយាយច្រំដែលអំពីទោសរបស់កូន ដើម្បីធ្វើឲ្យ
កូនកើតទុក្ខក្នុងចិត្តទេ ប្រសិនបើពុំមែនសំរាប់ឲ្យកូនបានល្អ ។
៨ ប៉ុន្តែមើលចុះ កូនពុំអាចលាក់បាំងទោសកំហុស របស់កូន
ពីព្រះបានឡើយ; ហើយលើកលែងកូនប្រែចិត្ត បើពុំនោះសោតទេ
ទោសទាំងនោះនឹងឈរជាទីបន្ទាល់ ទាស់នឹងកូននៅថ្ងៃ
ចុងក្រោយបង្អស់ ។
៩ ឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកចង់ឲ្យកូនប្រែចិត្ត
ហើយបោះបង់ចោលអំពើបាបទាំងឡាយរបស់កូន ហើយ
កុំទៅតាម សេចក្ដីសំរើបនៃភ្នែករបស់ខ្លួនទៀតឡើយ ប៉ុន្តែត្រូវ
ចៀសវាងនូវអំពើទាំងនេះ; ត្បិតលើកលែងតែកូនធ្វើរបៀបនេះ
បើពុំនោះសោតទេ កូននឹងពុំអាចមានមធ្យោបាយណាទៀត នឹង
គ្រងនគរព្រះទុកជាមរតកបានឡើយ ។ ឱសូមកូនចងចាំ ហើយ
ប្រតិបត្តិតាមពាក្យឪពុក ហើយចៀសវាងនូវអំពើទាំងនេះចុះ ។
១០ ហើយឪពុកបញ្ជាដល់កូនថា ត្រូវប្រឹក្សាជាមួយនឹង
បងៗរបស់កូន នូវគ្រប់កិច្ចការរបស់កូន; ត្បិតមើលចុះ កូននៅ
ក្នុងយុវវ័យ ហើយកូនត្រូវការបីបាច់ដោយបងៗរបស់កូន ហើយ
ចូរស្ដាប់បង្គាប់តាមសេចក្ដីទូន្មានរបស់គេចុះ ។
១១ ចូរកូនកុំបណ្ដោយខ្លួនឲ្យវង្វេង ដោយការឥតប្រយោជន៍
និងឆ្កួតលីលាឡើយ; ចូរកុំបណ្ដោយឲ្យអារក្សទាក់ទាញចិត្ត
របស់កូន ឲ្យទៅតាមពួកស្រីខូចដ៏ទុច្ចរិតនោះទៀតឡើយ ។
មើលចុះ ឱកូនប្រុសរបស់ឪពុកអើយ កូនបាននាំមកនូវអំពើទុច្ចរិត
ដ៏ធំដល់ពួកសាសន៍ សូរាំ; ព្រោះកាលណាគេឃើញចរិយា
របស់កូន នោះគេពុំជឿដល់ពាក្យសំដីរបស់ឪពុកទេ ។
១២ ហើយឥឡូវនេះ ព្រះវិញ្ញាណនៃព្រះអម្ចាស់ ទ្រង់មានព្រះ
បន្ទូលមកឪពុកថា៖ ចូរបញ្ជាដល់កូនៗរបស់អ្នក ឲ្យធ្វើអំពើល្អ
ក្រែង ពួកវានឹងដឹកនាំចិត្តមនុស្សជាច្រើន ទៅរកសេច
ក្ដីបំផ្លិចបំផ្លាញ; ហេតុដូច្នេះហើយ ទើបឪពុកបញ្ជាដល់កូន
ឱកូនប្រុសរបស់ឪពុកអើយ ដោយកោតខ្លាចដល់ព្រះ ចូរកូន
ឈប់ធ្វើនូវអំពើទុច្ចរិតទាំងឡាយរបស់កូនទៅ ។
១៣ ចូរកូនបែរទៅរកព្រះអម្ចាស់ ដោយអស់ពីដួងចិត្ត និង
អស់សមត្ថភាព និងអស់កម្លាំងរបស់កូនចុះ; ហើយចូរកូនកុំដឹកនាំ
ចិត្ត ជនណាទៀត ឲ្យធ្វើអំពើទុច្ចរិតឡើយ; តែផ្ទុយមកវិញ
កូនត្រូវត្រឡប់ទៅរកគេ ហើយទទួលស្គាល់កំហុសរបស់ខ្លួន និង
ការខុសឆ្គង ដែលកូនបានប្រព្រឹត្តមក ។

៣៩ ២ *ក* អាលម៉ា ៣៨:៣.
៣ *ក* ស.ប. ខាងកាមរាគ, កាមរាគ.
៤ *ក* សុភា. ៧:៦–២៧.
៥ *ក* ស.ប. អំពើកាមរាគខុសច្បាប់.
៦ *ក* គ. និង ស. ៧៦:៣៥–៣៦.
*ខ* ស.ប. អំពើបាបដ៏អត់ឱនមិនបាន.
*គ* គ. និង ស. ៦៤:១០.
ស.ប. អត់ទោស, អភ័យទោស.
៧ *ក* ស.ប. ទោស.
៩ *ក* ស.ប. ខាងរូបកាយ.
*ខ* ៣ នីហ្វៃ ១២:៣០.
១១ *ក* អាលម៉ា ៣៥:២–១៤.
*ខ* រ៉ូម ២:២១–២៣; ១៤:១៣;
អាលម៉ា ៤:១១.
១២ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ;
បង្រៀន, គ្រូបង្រៀន.
១៣ *ក* ម៉ូសាយ ២៧:៣៤–៣៥.

១៤ ចូរកុំស្វែងរកទ្រព្យសម្បត្តិ ឬវត្ថុទាំងឡាយដែលឥតប្រយោជន៍នៃលោកិយនេះឡើយ; ត្បិតមើលចុះ កូនពុំអាចយកវាទៅជាមួយ កូនបានទេ ។

១៥ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកចង់និយាយនឹងកូន អំពីការយាងមកនៃព្រះគ្រីស្ទ ។ មើលចុះ ឪពុកចង់ និយាយនឹងកូនថា គឺព្រះអង្គនេះហើយដែលពិតជានឹងយាងមក ដើម្បីយកអំពើបាបទាំងឡាយនៃមនុស្សលោកចេញ; មែនហើយ ទ្រង់នឹងយាងមក ដើម្បីប្រកាសប្រាប់ដល់រាស្ត្ររបស់ទ្រង់នូវដំណឹងដ៏រីករាយ អំពីសេចក្តីសង្គ្រោះ ។

១៦ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ នេះហើយជាការងារបំរើ ដែលកូនត្រូវបានហៅ គឺដើម្បីប្រកាសប្រាប់ដំណឹងដ៏រីករាយទាំងនេះដល់ប្រជាជននេះ ដើម្បីប្រុងប្រៀបចិត្តគំនិតរបស់គេ; ឬម៉្យាងទៀត គឺដើម្បីឲ្យសេចក្តីសង្គ្រោះអាចបានមកដល់ពួកគេ ដើម្បីឲ្យគេរៀបចំចិត្តគំនិតនៃកូនចៅរបស់គេឲ្យស្តាប់តាមព្រះបន្ទូល នៅពេលដែលទ្រង់នឹងយាងមក ។

១៧ ហើយឥឡូវនេះ ឪពុកនឹងបន្ធូរបន្ថយដល់ចិត្តរបស់កូនខ្លះនៅក្នុងរឿងនេះ ។ មើលចុះ កូនច្បាស់ជាឆ្ងល់ថា ហេតុអ្វីបានជាការណ៍នេះត្រូវដឹងជាមុន ក្នុងរយៈពេលដ៏យូរ ។ មើលចុះ ឪពុកប្រាប់កូនថា តើពុំមែនព្រលឹងដែលនៅក្នុងពេលនេះ មានតម្លៃចំពោះព្រះ ស្មើនឹងព្រលឹង ដែលនៅពេលទ្រង់នឹងយាងមកទេឬអី ?

១៨ តើពុំមែនជាការចាំបាច់ដែលផែនការនៃសេចក្តីប្រោសលោះត្រូវបានផ្សព្វផ្សាយដល់ប្រជាជននេះ ក៏ដូចជាបានផ្សព្វផ្សាយដល់កូនចៅរបស់គេទេឬអី ?

១៩ តើពុំមែនជាការងាយដល់ព្រះ នៅក្នុងពេលនេះដើម្បីបញ្ជាឲ្យទេវតារបស់ទ្រង់ប្រកាសប្រាប់ នូវដំណឹងដ៏រីករាយទាំងនេះដល់យើង និងដល់កូនចៅរបស់យើងទេឬអី ឬក៏ក្រោយពេលដែលទ្រង់នឹងយាងមក ?

## ជំពូកទី ៤០

*ព្រះគ្រីស្ទនាំមកនូវដំណើររស់ឡើងវិញ ដល់មនុស្សទាំងអស់ — ពួកសុចរិតដែលបានស្លាប់ទៅ នឹងទៅឯស្ថានបរមសុខ ឯពួកទុច្ចរិតនឹងទៅឯភាពងងឹតខាងក្រៅ ដើម្បីរង់ចាំថ្ងៃនៃដំណើររស់ឡើងវិញ — នៅក្នុងដំណើររស់ឡើងវិញ នោះអ្វីៗទាំងអស់ នឹងបានសាង ទៅ ជារូបរាងដ៏ត្រឹមត្រូវ និងល្អឥតខ្ចោះឡើងវិញ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

*ឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកចង់និយាយនឹងកូនថែមទៀត; ព្រោះឪពុកយល់ឃើញថា កូនកំពុងខ្វល់នៅក្នុងគំនិត អំពី ដំណើររស់ឡើងវិញនៃមនុស្សស្លាប់ ។*

២ មើលចុះ ឪពុកប្រាប់កូនថា គ្មានដំណើររស់ឡើងវិញទេ ឬក៏ឪពុកចង់និយាយម៉្យាងទៀតថា រូបកាយដែលរមែងស្លាប់នេះពុំអាច ប្រដាប់ដោយអមតភាពបានឡើយ ឯរូបកាយដ៏ពុករលួយនេះក៏ពុំអាចប្រដាប់ដោយភាពមិនពុករលួយបានដែរ — រហូតដល់ពេលក្រោយ ព្រះគ្រីស្ទយាងមកសិន ។

៣ មើលចុះ ទ្រង់នឹងនាំមកនូវដំណើររស់ឡើងវិញដល់មនុស្សស្លាប់ ។ ប៉ុន្តែមើលចុះ កូនប្រុសរបស់ឪពុកអើយ ដំណើររស់ឡើងវិញ នោះពុំទាន់មកដល់ទេ ។ ឥឡូវនេះ ឪពុកបើកប្រាប់កូននូវការអាថ៌កំបាំងមួយ; ទោះជាយ៉ាងណាក៏ដោយគង់តែមានការអាថ៌កំបាំងជា ច្រើនដែលត្រូវរក្សាទុក ដែលគ្មាននរណាដឹង ក្រៅពីព្រះប៉ុណ្ណោះ ។ ប៉ុន្តែ ឪពុកបង្ហាញដល់កូននូវការណ៍មួយ ដែលឪពុកបាន ព្យាយាមសាកសួរដល់ព្រះដើម្បីឲ្យឪពុកបានដឹង — គឺអំពីដំណើររស់ឡើងវិញ ។

៤ មើលចុះ មានពេលមួយដែលបានកំណត់ទុក សំរាប់មនុស្សទាំងអស់ នឹងបានរស់ពីស្លាប់ឡើងវិញ ។ ឥឡូវនេះ កាលណាពេល នោះនឹងមកដល់ នោះគ្មាននរណាដឹងទេ; ប៉ុន្តែព្រះទ្រង់ជ្រាបនូវពេលដែលកំណត់ទុក ។

៥ ឥឡូវនេះ ទោះបីពេលដែលបានកំណត់ទុកនោះ មានម្តងពីរដង ឬបីដង ដើម្បីមនុស្សអាចរស់ពីស្លាប់ វាពុំមែនជាការណ៍អ្វីទេ; ព្រោះព្រះទ្រង់ជ្រាបនូវការណ៍អស់ទាំងនេះហើយ; ហើយឪពុកគ្រាន់តែដឹងថា ការណ៍នោះមែនពិត ក៏ជាការគ្រប់គ្រាន់ហើយ — គឺថា មានពេលមួយដែលបានកំណត់ទុកដើម្បីឲ្យមនុស្សទាំងអស់អាចរស់ពីស្លាប់ឡើងវិញ ។

---

១៤ *ក* ម៉ាថាយ ៦:២៥–៣៤;
យ៉ាកុប ២:១៨–១៩;
គ. និង ស. ៦:៦–៧; ៦៨:៣១–៣២.
១៦ *ក* ស.ប. គ្រួសារ — កាតព្វកិច្ចរបស់ឪពុកម្តាយ.
៤០ ២ *ក* ម៉ូសាយ ១៦:១០–១៣.
ស.ប. អមតៈ, អមតភាព.
*ខ* ១ កូរិន. ១៥:៥៣–៥៤.
*គ* ១ កូរិន. ១៥:២០.
៣ *ក* ស.ប. ដំណើររស់ឡើងវិញ.
*ខ* ស.ប. សេចក្តីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*គ* គ. និង ស. ២៥:៤; ១២៤:៤១.
៤ *ក* យ៉ូហាន ៥:២៨–២៩.
៥ *ក* ម៉ូសាយ ២៦:២៤–២៥;
គ. និង ស. ៤៣:១៨; ៧៦:៨៥.
*ខ* ស.ប. ព្រះ, ក្រុមព្រះ.

៦ ឥឡូវនេះ ត្រូវតែមានចន្លោះមួយ រវាងពេលនៃសេចក្ដីស្លាប់នឹងពេលនៃដំណើររស់ឡើងវិញ ។

៧ ហើយឥឡូវនេះ ឪពុកសួរថា តើ[ក]ព្រលឹងរបស់មនុស្ស នៅក្នុងស្ថានភាពណា ចាប់ពីពេលនៃសេចក្ដីស្លាប់នេះ ទៅដល់ពេលដែល បានកំណត់ទុក សំរាប់ដំណើររស់ឡើងវិញ ?

៨ ឥឡូវនេះ ទោះបីពេលដែលបានកំណត់ទុក សំរាប់មនុស្សរស់ឡើងវិញនោះ មានច្រើនជាងមួយផង ក៏វាពុំជាការណ៍អ្វីដែរ; ព្រោះមនុស្សទាំងអស់ ពុំមែនស្លាប់ព្រមគ្នាតែម្ដងទេ ហើយនេះក៏ពុំជាការណ៍អ្វីដែរ; ទាំងអស់នេះទុកដូចជាមួយថ្ងៃសំរាប់ព្រះ ឯពេលវេលារាប់សំរាប់តែមនុស្សទេ ។

៩ ហេតុដូច្នេះហើយ មានពេលមួយដែលបានកំណត់ទុកដល់មនុស្ស ដើម្បីឲ្យគេរស់ពីស្លាប់ឡើងវិញ; ហើយមានចន្លោះរវាងពេលនៃ សេចក្ដីស្លាប់នឹងដំណើររស់ឡើងវិញ ។ ហើយឥឡូវនេះ នៅក្នុងរយៈពេលនោះ តើព្រលឹងមនុស្សនឹងនៅក្នុងសភាពណា នោះជារឿង ដែលឪពុកបានសូមដល់ព្រះអម្ចាស់យ៉ាងព្យាយាម ដើម្បីឲ្យបានដឹង; ហើយនេះគឺជារឿងដែលឪពុកដឹង ។

១០ ហើយកាលណាដល់ពេល ដែលមនុស្សទាំងអស់ត្រូវរស់ឡើងវិញ ខណៈនោះ គេនឹងដឹងថា ព្រះទ្រង់[ក]ជ្រាបពេលទាំងអស់ ដែលបានកំណត់ដល់មនុស្ស ។

១១ ឥឡូវនេះ ស្ដីអំពីស្ថានភាពនៃព្រលឹងនៅក្នុងចន្លោះ[ក]រវាងសេចក្ដីស្លាប់នឹងដំណើររស់ឡើងវិញ — មើលចុះ មានទេវតាបាន ប្រាប់ឲ្យឪពុកដឹងថា វិញ្ញាណរបស់មនុស្សទាំងអស់ នៅមួយរំពេចដែលចាកចេញពីរូបកាយសាច់ឈាមនេះទៅ មែនហើយ វិញ្ញាណ របស់មនុស្សទាំងអស់ ទោះគេល្អ ឬអាក្រក់ក្ដីនឹងបានត្រឡប់ទៅ[ខ]ផ្ទះវិញ គឺទៅជួបនឹងព្រះ ដែលទ្រង់បានប្រទានជីវិតដល់គេ ។

១២ ហើយបន្ទាប់មក ហេតុការណ៍នឹងកើតឡើងថា វិញ្ញាណរបស់ពួកសុចរិត នឹងបានទទួលស្ថានភាពនៃ[ក]សុភមង្គល ដែលជា[ខ]ស្ថានបរមសុខ ដែលជាស្ថានភាពឈប់[គ]សំរាក ស្ថានភាព[ឃ]សុខសាន្ត ជាកន្លែងដែលគេនឹងបានសំរាកពីអស់ទាំងកង្វល់ ពីអស់ទាំងការបារម្ភ និងពីទុក្ខព្រួយ ។

១៣ ហើយបន្ទាប់មក ហេតុការណ៍នឹងកើតឡើងថា វិញ្ញាណនៃពួកទុច្ចរិត មែនហើយ គឺជាមនុស្សអាក្រក់ — ត្បិតមើលចុះ ពួកគេ ពុំមានចំណែក ឬភាគនៃព្រះវិញ្ញាណនៃព្រះអម្ចាស់បន្តិចបន្តួចសោះ; ត្បិតមើលចុះ គេបានរើសអំពើអាក្រក់ជាងអំពើល្អ; ហេតុដូច្នេះ ហើយ វិញ្ញាណរបស់អារក្សបានចូលក្នុងពួកគេ ហើយធ្វើជាម្ចាស់នៃផ្ទះរបស់គេ — ហើយពួកមនុស្សទាំងនេះនឹងត្រូវបោះចោលទៅ [ក]ភាពងងឹតខាងក្រៅ; នៅទីនោះ នឹងមាន[ខ]ការយំសោក ការថ្ងូរ និងការសង្កៀតធ្មេញ ហើយនេះគឺដោយព្រោះអំពើទុច្ចរិតរបស់ពួកគេ ផ្ទាល់ ដែលទុកឲ្យអារក្សដឹកនាំទៅជាប់ឃុំឃាំងដោយទំនើងចិត្តវា ។

១៤ ឥឡូវនេះ នេះហើយគឺជាស្ថានភាពនៃព្រលឹងរបស់[ក]ពួកទុច្ចរិត មែនហើយ គឺនៅក្នុងសេចក្ដីងងឹត និងជាស្ថានភាពដ៏ស្ញើបស្ញែង រង់ចាំយ៉ាង[ខ]ភ័យខ្លាចនៃសេចក្ដីគ្នាន់ក្នាញ់ដ៏ឆួលឆាបនូវការពិរោធរបស់ព្រះមកលើពួកគេ; ពួកគេត្រូវស្ថិតនៅក្នុង[គ]ស្ថានភាពបែបនេះ នៅពេលដែលពួក សុចរិត នៅក្នុងស្ថានបរមសុខ រហូតដល់ពេលនៃដំណើររស់ឡើងវិញរបស់គេ ។

១៥ ឥឡូវនេះ មនុស្សខ្លះបានយល់ថា ស្ថានភាពនៃសុភមង្គលនិងស្ថានភាពវេទនានៃព្រលឹងនេះ នៅមុនដំណើររស់ឡើងវិញ គឺជាដំណើររស់ឡើងវិញទីមួយ ។ មែនហើយ ឪពុកក៏ទទួលស្គាល់ថានេះគួរតែហៅថាដំណើររស់ឡើងវិញបាន គឺការប្រោសវិញ្ញាណឬព្រលឹង និងភាពរស់នៅ ទៅដល់សុភមង្គល ឬសេចក្ដីវេទនាស្របតាមពាក្យទាំងឡាយ ដែលបាននិយាយមក ។

១៦ ហើយមើលចុះ ដូចដែលបាននិយាយហើយថា មានដំណើររស់ឡើងវិញជា[ក]លើកទីមួយ គឺជា[ខ]ដំណើររស់ឡើងវិញ ដល់ជនណាដែលបានរស់នៅ កំពុងរស់នៅ ឬនឹងរស់នៅក្នុងពេលអនាគតរហូតដល់ដំណើររស់ឡើងវិញ នៃព្រះគ្រីស្ទពីសេចក្ដីស្លាប់ ។

១៧ ឥឡូវនេះ យើងពុំសន្និដ្ឋានថា ដំណើររស់ឡើងវិញលើកទីមួយ តាមរបៀបដែលទើបនិយាយមកនេះ ជាដំណើរ

៧ ក អាលម៉ា ៤០:២១;
គ. និង ស. ១៣៨.
ស.ប. ព្រលឹង.
១០ ក កិច្ចការ ១៧:២៦.
១១ ក លូកា ១៦:២២–២៦;
១ ពេត្រុស ៣:១៨–១៩; ៤:៦;
គ. និង ស. ៧៦:៧១–៧៤; ១៣៨.
ខ សាស្ដា ១២:៧; ២ នីហ្វៃ ៩:៣៨.
១២ ក ស.ប. សេចក្ដីអំណរ.
ខ ស.ប. ស្ថានបរមសុខ.
គ ស.ប. សេចក្ដីសំរាក.
ឃ គ. និង ស. ៤៥:៤៦.
ស.ប. សេចក្ដីសុខសាន្ត.
១៣ ក ស.ប. ស្ថាននរក.
ខ ម៉ាថាយ ៨:១២; ម៉ូសាយ ១៦:២.
១៤ ក គ. និង ស. ១៣៨:២០.
ខ យ៉ាកុប ៦:១៣; ម៉ូសេ ៧:១.
គ អាលម៉ា ៣៤:៣៤.
១៦ ក យ៉ាកុប ៤:១១;
ម៉ូសាយ ១៥:២១–២៣.
ខ ស.ប. ដំណើររស់ឡើងវិញ.

រស់ឡើងវិញ នៃព្រលឹង និង[ក]ភាពរស់នៅ ទៅដល់សុភមង្គល
ឬសេចក្ដីវេទនាទេ ។ កូនពុំអាចសន្និដ្ឋានថា ការណ៍នេះមានន័យ
ដូច្នោះឡើយ ។
១៨ មើលចុះ ឪពុកនិយាយនឹងកូនថា ទេ; ប៉ុន្តែវាមានន័យថា
ការជួបជុំនៃព្រលឹងនឹងរូបកាយនៃជនទាំងឡាយ ចាប់តាំងពីជំនាន់
លោកអ័ដាម រហូតដល់[ក]ដំណើររស់ឡើងវិញនៃព្រះគ្រីស្ទម្ល៉េះ ។
១៩ ឥឡូវនេះ ទោះបីព្រលឹង និងរាងកាយនៃជនទាំងឡាយ
ដែលបាននិយាយដល់ នឹងបានជួបគ្នាឡើងវិញភ្លាមឬទេ ពួក
ទុច្ចរិតក៏ ដូចជាពួកសុចរិត នោះឪពុកពុំបាច់និយាយទេ; ឪពុក
គ្រាន់តែនិយាយថា មនុស្សទាំងអស់នឹងរស់ឡើងវិញ ឬនិយាយ
ម្យ៉ាងទៀតថា ដំណើររស់ឡើងវិញរបស់អ្នកទាំងនេះនឹងកើតឡើង
[ក]មុនពេលដំណើររស់ឡើងវិញ សំរាប់ជនទាំងឡាយដែលស្លាប់
ក្រោយដំណើររស់ ឡើងវិញនៃព្រះគ្រីស្ទ ។
២០ ឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកពុំនិយាយថា
ដំណើររស់ឡើងវិញដល់គេ នឹងកើតឡើងព្រមគ្នានឹងដំណើរ
រស់ឡើង វិញនៃព្រះគ្រីស្ទទេ; ប៉ុន្តែមើលចុះ ឪពុកឲ្យយោបល់ថា
ព្រលឹង និងរាងកាយនៃពួកសុចរិត នឹងបានរួបរួមគ្នាវិញ ព្រមគ្នា
នឹងដំណើររស់ ឡើងវិញនៃព្រះគ្រីស្ទ និង[ក]ការយាងទៅស្ថានសួគ៌
របស់ទ្រង់វិញ ។
២១ ប៉ុន្តែ ទោះបីនៅក្នុងពេលជាមួយគ្នានឹងដំណើរ
រស់ឡើងវិញរបស់ទ្រង់ ឬក្រោយក្ដី នោះឪពុកពុំនិយាយទេ; ប៉ុន្តែ
ឪពុកនិយាយ តែប៉ុណ្ណោះថា មាន[ក]ចន្លោះពេលមួយ រវាងសេច
ក្ដីស្លាប់នឹងដំណើររស់ឡើងវិញនៃរាងកាយ និងស្ថានភាពនៃ
ព្រលឹង[ខ]ក្នុងសុភមង្គល ឬ[គ]ក្នុងសេចក្ដីវេទនា រហូតដល់ពេលដែល
បានកំណត់ទុកដោយព្រះថា មនុស្សស្លាប់នឹងរស់ឡើងវិញ ហើយ
ព្រលឹង និងរាងកាយនឹងបាន ជួបជុំគ្នាឡើងវិញ នឹង[ឃ]ត្រូវនាំ
ទៅឈរនៅចំពោះព្រះ ហើយទទួលការជំនុំជំរះ ស្របតាម
កិច្ចការរបស់ខ្លួន ។
២២ មែនហើយ ការណ៍នេះនាំមកនូវការសាងឡើងវិញ នូវអ្វី
ៗដែលបាននិយាយចេញពីមាត់នៃពួកព្យាការី ។
២៣ [ក]ព្រលឹងនឹងបាន[ខ]ផ្គុំចូលទៅក្នុង[គ]រាងកាយ ឯរាងកាយ ក៏នឹង
បានផ្គុំទៅនឹងព្រលឹង; មែនហើយ អវៈយវៈទាំងអស់ និង
គ្រប់សន្លាក់ឆ្អឹង ត្រូវបានផ្គុំទៅនឹងរាងកាយវិញ; មែនហើយ ទាំង
សក់មួយសរសៃនៅលើក្បាល ក៏ពុំបាត់ដែរ; ហើយអ្វីៗទាំងអស់
នឹងបានសាងទៅជារូប រាងដ៏ត្រឹមត្រូវ និងល្អឥតខ្ចោះឡើងវិញ ។
២៤ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ នេះហើយ
គឺការសាងឡើងវិញ ដូចដែល[ក]បាននិយាយចេញពីមាត់នៃពួក
ព្យាការី—
២៥ ហើយបន្ទាប់មក មនុស្សសុចរិតនឹងចែងចាំងនៅក្នុង
នគរព្រះ ។
២៦ ប៉ុន្តែមើលចុះ [ក]សេចក្ដីស្លាប់ដ៏គួរស្ញែងខ្លាច នឹងមកដល់ពួក
ទុច្ចរិត; ព្រោះពួកគេស្លាប់ចំពោះអ្វីៗ ដែលទាក់ទងទៅនឹងសេចក្ដី
សុចរិត; ព្រោះពួកគេឥតស្អាត ហើយគ្មានអ្វីដែល[ខ]ឥតស្អាត អាច
គ្រងនគរព្រះ ទុកជាមរតកបានឡើយ; ប៉ុន្តែ គេនឹងត្រូវ
បណ្ដេញចេញ ហើយត្រូវផ្ដន្ទាទោសឲ្យទទួលនូវផលទាំងឡាយ
នៃកិច្ចការទាំងឡាយ ឬការងារទាំងឡាយរបស់ខ្លួន ដែល
ជាកិច្ចការអាក្រក់; ហើយគេ នឹងផឹកនូវកាកនៃពែងល្វីងជូរចត់ ៕

## ជំពូកទី ៤១

*នៅក្នុងដំណើររស់ឡើងវិញ មនុស្សលោកនឹងស្ថិតនៅក្នុងស្ថានភាពមួយ ដែលប្រកបទៅដោយសុភមង្គលដ៏មិនចេះចប់មិនចេះហើយ ឬសេចក្ដីវេទនាដ៏មិនចេះចប់មិនចេះហើយ — សេចក្ដីទុច្ចរិតគឺមិនមែនជាសុភមង្គលទេ — មនុស្សខាងសាច់ឈាមរស់នៅដោយ គ្មានព្រះ នៅក្នុងពិភពលោកនេះ — ជនគ្រប់រូបទទួលបានក្នុងការសាងឡើងវិញ នូវលក្ខណៈ និងគុណភាពទាំងឡាយទៀត ដែលខ្លួនធ្លាប់មាន ពេលរស់នៅជាមនុស្សលោក ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកនឹងនិយាយ
រឿងខ្លះ អំពីការសាងឡើងវិញ ដូចដែលទើបនិយាយរួចមក

១៧ *ក* គ. និង ស. ៧៦:១៧, ៣២, ៥០–៥១.
១៨ *ក* ម៉ាថាយ ២៧:៥២–៥៣.
១៩ *ក* ម៉ូសាយ ១៥:២៦.
២០ *ក* ស.ប. ការយាងឡើង.
២១ *ក* លូកា ២៣:៣៩–៤៣.
*ខ* ស.ប. ស្ថានបរមសុខ.
*គ* ស.ប. ស្ថាននរក.
*ឃ* អាលម៉ា ៤២:២៣.
២៣ *ក* ក.ន. វិញ្ញាណ.
គ. និង ស. ៨៨:១៥–១៧.
ស.ប. ព្រលឹង.
*ខ* ២ នីហ្វៃ ៩:១២–១៣;
អាលម៉ា ១១:៤០–៤៥.
*គ* ស.ប. រូបកាយ.
២៤ *ក* អេសាយ ២៦:១៩.
២៦ *ក* ១ នីហ្វៃ ១៥:៣៣;
អាលម៉ា ១២:១៦.
*ខ* អាលម៉ា ១១:៣៧.

ហើយនេះ; ត្បិតមើលចុះ មានមនុស្សខ្លះបាន*ក*បង្វែរន័យនៃបទគម្ពីរទាំងឡាយ ហើយបានដើរ*ខ*វង្វេងទៅឆ្ងាយ ដោយព្រោះរឿងនេះ ។ ហើយឪពុក យល់ឃើញថា ចិត្តកូនក៏កំពុងតែកង្វល់អំពីរឿងនេះដែរ។ ប៉ុន្តែមើលចុះ ឪពុកនឹងពន្យល់រឿងនេះប្រាប់ដល់កូន ។

២ កូនប្រុសរបស់ឪពុកអើយ ឪពុកប្រាប់កូនថា ផែនការនៃការសាងឡើងវិញ ជាការចាំបាច់ដល់សេចក្ដីយុត្តិធម៌នៃព្រះ; ព្រោះ ជាការចាំបាច់ថា វត្ថុសព្វសារពើត្រូវបានសាងឡើងវិញ ឲ្យត្រឹមត្រូវតាមរបៀប ។ មើលចុះ នេះជាការចាំបាច់ ហើយត្រឹមត្រូវ ស្របតាមព្រះចេស្ដា និងដំណើររស់ឡើងវិញនៃព្រះគ្រីស្ទ ថាព្រលឹងមនុស្ស នឹងបានផ្គុំទៅក្នុងរាងកាយវិញ ហើយ*ក*ផ្នែកទាំងអស់នៃ រាងកាយ នឹងបានផ្គុំឡើងវិញដូចដើម ។

៣ ហើយជាការចាំបាច់ដល់*ក*សេចក្ដីយុត្តិធម៌នៃព្រះ ថាមនុស្សនឹងបានទទួល*ខ*ការជំនុំជំរះ ស្របតាម*គ*កិច្ចការរបស់ខ្លួន; ហើយបើសិនជា កិច្ចការទាំងឡាយរបស់គេល្អនៅក្នុងជីវិតនេះ ហើយបំណងនៅក្នុងចិត្តគេល្អ នោះនៅថ្ងៃចុងក្រោយបង្អស់ គេក៏*ឃ*នឹងបានសាងឡើងវិញ ឲ្យបានល្អដែរ ។

៤ ហើយបើសិនជាកិច្ចការទាំងឡាយរបស់គេអាក្រក់ នោះគេនឹង*ក*បានសាងឡើងវិញជាអាក្រក់ដែរ ។ ហេតុដូច្នេះហើយ វត្ថុសព្វសារពើនឹងបានសាងឡើងវិញ ឲ្យបានត្រឹមត្រូវតាមរបៀប គឺអ្វីៗគ្រប់មុខនឹងបានសាងឡើងវិញ ឲ្យតាមរូបរាងធម្មជាតិ — *ខ*ភាពដែលរមែងស្លាប់នឹងបានប្រោសទៅជាអមតភាព *គ*ឯភាពពុករលួយទៅជាភាពឥតពុករលួយ — គឺប្រោសឲ្យដល់នូវ*ឃ*សុភមង្គល ដ៏មិនចេះចប់មិនចេះហើយ ដើម្បីគ្រងនគរព្រះទុកជាមរតក ឬឲ្យដល់នូវទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ ដើម្បីគ្រងនគរអារក្ស ទុកជាមរតក គឺអ្នកខ្លះនៅខាងណេះ អ្នកខ្លះនៅ ខាងណោះ —

៥ មនុស្សម្នាក់បានប្រោសដល់ទៅឯសុភមង្គល តាមបំណងរបស់គេដែលចង់បានសុភមង្គល ឬក៏បានល្អ តាមបំណងរបស់គេដែល ចង់បានល្អ; ឯមនុស្សម្នាក់ទៀតបានអាក្រក់ តាមបំណងរបស់គេ ដែលចង់បានអាក្រក់; ព្រោះដូចជាមនុស្សនោះមានបំណងចង់ធ្វើអាក្រក់ ពេញទាំងពេលថ្ងៃយ៉ាងណា ជននោះនឹងបានទទួលរង្វាន់អាក្រក់ នៅវេលាយប់មកដល់ជាយ៉ាងនោះដែរ ។

៦ ហើយផ្ទុយមកវិញក៏ដូច្នោះដែរ ។ បើសិនជាអ្នកនោះប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន ហើយចង់បានសេចក្ដីសុចរិតរហូតដល់ថ្ងៃអវសាននៃជីវិត អ្នកនោះនឹងបានទទួលរង្វាន់ចំពោះសេចក្ដីសុចរិត ។

៧ ពួក*ក*អ្នកនោះហើយដែលព្រះអម្ចាស់ទ្រង់បានប្រោសលោះ; មែនហើយ ពួកអ្នកនោះហើយដែលបានយកចេញ ដែលបានដោះឲ្យរួចផុតពីរាត្រីដ៏មិនចេះចប់មិនចេះហើយនៃសេចក្ដីងងឹតនោះ; ម្ល៉ោះហើយ គេឈរឡើង ឬដួលចុះ; ត្បិតមើលចុះ ពួកគេគឺជាចៅក្រម ជំនុំជំរះ*ខ*ខ្លួនផ្ទាល់ ទោះបីក្នុងការធ្វើល្អ ឬធ្វើអាក្រក់ក្ដី ។

៨ ឥឡូវនេះ ក្រិត្យក្រមទាំងឡាយនៃព្រះ *ក*ពុំអាចប្រែប្រួលបានឡើយ; ហេតុដូច្នេះហើយ ផ្លូវត្រូវបានរៀបចំស្រេចហើយ ថាអស់អ្នក ណាដែលចង់ នោះអាចដើរនៅលើផ្លូវនោះ ហើយបានសង្គ្រោះ ។

៩ ហើយឥឡូវនេះ មើលចុះ កូនប្រុសរបស់ឪពុកអើយ ចូរកុំប្រថុយធ្វើ*ក*អំពើប្រមាថដល់ព្រះម្ដងទៀតឡើយ ចំពោះចំណុចទាំងឡាយ នៃលទ្ធិនេះ ជាចំណុចដែលកូនបានប្រថុយបំពារបំពានបាប ។

១០ ចូរកូនកុំគិតស្មានថា ពីព្រោះគេបាននិយាយ ដល់ការសាងឡើងវិញ ថាកូននឹងបានសាងពីបាបឡើងវិញ ទៅកាន់សុភមង្គល នោះទេ ។ មើលចុះ ឪពុកប្រាប់កូនថា *ក*សេចក្ដីទុច្ចរិតពុំដែលជាសុភមង្គលឡើយ ។

១១ ហើយឥឡូវនេះ កូនប្រុសរបស់ឪពុកអើយ មនុស្សទាំង

៤១ ១*ក* ២ ពេត្រុស ១:២០; ៣:១៦; អាលម៉ា ១៣:២០.
*ខ* ស.ប. សេចក្ដីក្បត់សាសនា.
២ *ក* អាលម៉ា ៤០:២៣.
៣ *ក* ស.ប. សេចក្ដីយុត្តិធម៌.
*ខ* ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួល ខុសត្រូវ; ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
*គ* ស.ប. កិច្ចការ.
*ឃ* ហេលេ. ១៤:៣១.
៤ *ក* អាលម៉ា ៤២:២៨.
*ខ* ២ នីហ្វៃ ៩:១២–១៣; គ. និង ស. ១៣៨:១៧. ស.ប. ដំណើររស់ឡើងវិញ.
*គ* ១ កូរិន. ១៥:៥១–៥៥.
*ឃ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៧ *ក* គ. និង ស. ៧៦:៥០–៧០.
*ខ* ២ នីហ្វៃ ២:២៦; អាលម៉ា ៤២:២៧; ហេលេ. ១៤:៣០. ស.ប. សិទ្ធិជ្រើសរើស.
៨ *ក* គ. និង ស. ១:៣៨.
៩ *ក* គ. និង ស. ៤២:២៣–២៨.
១០ *ក* ទំនុក. ៣២:១០; អេសាយ ៥៧:២០–២១; ហេលេ. ១៣:៣៨.

អស់ណា ដែលនៅក្នុងស្ថានភាព[ក]ខាងសាច់ឈាម ឪពុកចង់និយាយថា នៅក្នុងស្ថានភាព[ខ]ខាងរូបកាយ គឺនៅក្នុងប្រមាត់ល្វីងជូរចត់ និងនៅក្នុងចំណងទាំងឡាយនៃអំពើទុច្ចរិត; ពួកគេ[គ]គ្មានព្រះក្នុងលោកិយ នេះឡើយ ហើយពួកគេបានដើរផ្ទុយពីព្រះហឫទ័យនៃព្រះ; ហេតុដូច្នេះហើយ ពួកគេនៅក្នុងស្ថានភាពមួយ ផ្ទុយទៅនឹងស្ថានភាពនៃ សុភមង្គល ។

១២ ហើយឥឡូវនេះ មើលចុះ តើន័យនៃពាក្យថាសាងឡើងវិញ គឺយកវត្ថុមួយពីស្ថានភាពធម្មជាតិ ហើយដាក់ទៅក្នុងស្ថានភាពពុំធម្មជាតិ ឬដាក់របស់នោះ ទៅក្នុងស្ថានភាពមួយផ្ទុយនឹងធម្មជាតិរបស់វាឬ ?

១៣ ឱកូនប្រុសរបស់ឪពុកអើយ រឿងនេះពុំមែនដូច្នោះទេ; ប៉ុន្តែន័យរបស់ពាក្យថាសាងឡើងវិញនោះ គឺធ្វើជាថ្មីឡើងវិញ អាក្រក់ទៅជាអាក្រក់វិញ ឬរូបកាយទៅជារូបកាយវិញ របស់ផងអារក្សទៅជាផងអារក្សវិញ — ល្អទៅជាល្អវិញ; សុចរិតទៅ ជាសុចរិតវិញ; ត្រឹមត្រូវទៅជាត្រឹមត្រូវវិញ; មេត្តាករុណាទៅជាមេត្តាករុណាវិញ ។

១៤ ហេតុដូច្នេះហើយ កូនប្រុសរបស់ឪពុកអើយ ចូរកូនមេត្តាករុណាដល់បងប្អូនរបស់កូនចុះ; ចូររាប់រកគ្នាដោយ[ក]យុត្តិធម៌ [ខ]វិនិច្ឆ័យ ដោយសុចរិត ហើយ[គ]ធ្វើល្អជានិច្ច; ហើយបើសិនជាកូនធ្វើការទាំងអស់នេះ នោះកូននឹងបានទទួលរង្វាន់; មែនហើយ [ឃ]សេចក្ដីមេត្តា ករុណានឹងបានសាងឡើងដល់កូនវិញ; សេចក្ដីយុត្តិធម៌នឹងបានសាងឡើងដល់កូនវិញ; ការវិនិច្ឆ័យដោយសុចរិតនឹងបានសាងឡើង ដល់កូនវិញ; ហើយនឹងបានការល្អប្រទានដល់កូនវិញ ។

១៥ ព្រោះអី អ្វីៗដែលកូនបានធ្វើទៅ នឹងត្រឡប់មករកកូនវិញ ហើយបានសាងឡើងវិញ; ហេតុដូច្នេះហើយ ពាក្យថាសាងឡើងវិញ គឺកាត់ទោសដល់មនុស្សមានបាបដ៏ពេញទំហឹង ហើយមិនរាប់ថាជននោះសុចរិតជាដាច់ខាត ៕

## ជំពូកទី ៤២

*ការរស់នៅជាមនុស្សលោកនេះ គឺជាពេលវេលាសាកល្បង ដើម្បីឲ្យមនុស្សអាចប្រែចិត្ត ហើយបំរើព្រះ — ការធ្លាក់បាននាំមកនូវ សេចក្ដីស្លាប់ខាងសាច់ឈាម និងខាងវិញ្ញាណ មកដល់មនុស្សលោកទាំងអស់ — សេចក្ដីប្រោសលោះកើតឡើងតាមរយៈការប្រែចិត្ត — ព្រះអង្គផ្ទាល់នឹងធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក — សេចក្ដីមេត្តាករុណាបានដល់ជនណាដែលប្រែចិត្ត — អស់អ្នកផ្សេង ទៀតនៅក្រោមសេចក្ដីយុត្តិធម៌នៃព្រះ — សេចក្ដីមេត្តាករុណាបានមកដោយសារដង្វាយធួន — មានតែជនដែលប្រែចិត្តដ៏ពិតប្រាកដប៉ុណ្ណោះដែលបានសង្គ្រោះ ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកយល់ឃើញថានៅមានការខ្លះទៀត ដែលធ្វើឲ្យកូន[ក]ងល់ក្នុងគំនិត ដែលកូនពុំអាច យល់ — គឺជារឿងស្ដីអំពីសេចក្ដីយុត្តិធម៌នៃព្រះ ក្នុងការធ្វើទោសដល់ជនដែលមានបាប; ព្រោះកូនខំគិតស្មានថា ជាការអយុត្តិធម៌ ដែលជនមានបាប ត្រូវដាក់ទៅក្នុងស្ថានភាពទុក្ខវេទនា ។

២ ឥឡូវនេះ មើលចុះ កូនប្រុសរបស់ឪពុកអើយ ឪពុកនឹងពន្យល់រឿងនេះប្រាប់ដល់កូន ។ ត្បិត[ក]មើលចុះ បន្ទាប់ពីព្រះអម្ចាស់ ដ៏ជាព្រះ [ខ]ទ្រង់បណ្ដេញឪពុកម្ដាយដើមរបស់យើងចេញពីសួនច្បារអេដែន ឲ្យទៅភ្ជួររាស់ដី ដែលទ្រង់បានយកមកបង្កើតពួកគេ — មែនហើយ ទ្រង់បានបណ្ដេញមនុស្សចេញ ហើយ[គ]ទ្រង់បានដាក់ នៅទិសខាងកើតនៃសួនច្បារអេដែន នូវចេរូប៊ីន និង[ឃ]ដាវដែលមាន អណ្ដាតភ្លើងដែលវេរបែរគ្រប់ទិស ដើម្បីនឹងរក្សាដើមជីវិត —

៣ ឥឡូវនេះ យើងឃើញថា មនុស្សបានក្លាយទៅដូចព្រះ ដោយដឹងខុស និងត្រូវ; ហើយដោយខ្លាច ក្រែងមនុស្សលូកដៃទៅបេះផ្លែនៃដើមជីវិតមកបរិភោគ ហើយរស់នៅរហូត ទើបព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ដាក់ចេរូប៊ីន និងដាវដែលមានអណ្ដាតភ្លើង ដើម្បីកុំឲ្យមនុស្ស អាចទទួលទានផ្លែឈើនោះបាន —

៤ ម្ល៉ោះហើយ យើងឃើញថា មាន[ក]ពេលមួយដែលទុកសំរាប់ឲ្យមនុស្សប្រែចិត្ត មែនហើយ ជាពេលសាកល្បង ជាពេលមួយដើម្បីប្រែចិត្ត ហើយបំរើព្រះ ។

១១ *ក* ម៉ូសាយ ៣:១៩.
ស.ប. មនុស្សខាងសាច់ឈាម.
*ខ* ស.ប. ខាងរូបកាយ.
*គ* អេភេ. ២:១២.
១៤ *ក* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់.
*ខ* យ៉ូហាន ៧:២៤; គ. និង ស. ១១:១២.
*គ* គ. និង ស. ៦:១៣; ៥៨:២៧–២៨.
*ឃ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
**៤២** ១*ក* ២ នីហ្វៃ ២៦:៧; ម៉ូសាយ ១៥:២៦–២៧. ស.ប. សេចក្ដីយុត្តិធម៌.
២ *ក* លោកុ. ៣:២៣–២៤; ម៉ូសេ ៤:២៨–៣១.
*ខ* ស.ប. អេដែន.
*គ* ស.ប. ចេរ៉ូប៊ីន.
*ឃ* លោកុ. ២:៩.
៤ *ក* អាលម៉ា ៣៤:៣២–៣៣.

៥ ត្បិតមើលចុះ បើសិនជាលោកអ័ដាមបានលូកដៃភ្លាម ទៅបេះហើយទទួលទាននូវផ្លែនៃដើមជីវិត នោះលោកនឹងបានរស់នៅរហូត ស្របតាមព្រះបន្ទូលនៃព្រះ ដោយពុំមានពេលសំរាប់ប្រែចិត្តទេ; មែនហើយ ឯព្រះបន្ទូលនៃព្រះ ក៏នឹងត្រូវលុបចោលដែរ ហើយផែនការនៃសេចក្ដីសង្គ្រោះដ៏មហិមា នឹងត្រូវខកខាន ។

៦ ប៉ុន្តែមើលចុះ មនុស្សបានត្រូវកំណត់ឲ្យស្លាប់ — ហេតុដូច្នេះហើយ នៅពេលគេត្រូវកាត់ផ្ដាច់ពីដើមជីវិត គេក៏ត្រូវវិនាសបាត់ពីផ្ទៃ ផែនដីនេះដែរ — ហើយមនុស្សក្លាយទៅជាវង្វេងផ្លូវរហូត មែនហើយ គេបានក្លាយទៅជាមនុស្សដែលធ្លាក់ ។

៧ ហើយឥឡូវនេះ កូនឃើញតាមរឿងនេះថា ឪពុកម្ដាយដើមរបស់យើង ត្រូវកាត់ផ្ដាច់ទាំងខាងសាច់ឈាម និងខាងវិញ្ញាណចេញពីវត្តមាននៃព្រះអម្ចាស់; ម្ល៉ោះហើយ គេមានសេរីភាពនឹងធ្វើអ្វីៗ តាមចំណង់របស់គេ ។

៨ ហើយឥឡូវនេះ មើលចុះ វាពុំជាការចាំបាច់ទៀតទេ ដែលមនុស្សត្រូវរួចផុតពីសេចក្ដីស្លាប់ខាងសាច់ឈាម ព្រោះការណ៍នេះនឹង បំផ្លាញផែនការនៃសុភមង្គលដ៏មហិមា ។

៩ ហេតុដូច្នេះហើយ ដោយព្រលឹងពុំអាចស្លាប់បានឡើយ នោះការធ្លាក់ត្រូវបាននាំមកដល់មនុស្សលោក នូវសេចក្ដីស្លាប់ខាង វិញ្ញាណ ព្រមទាំងសេចក្ដីស្លាប់ខាងសាច់ឈាមដែរ មានន័យថា ពួកគេនឹងត្រូវកាត់ចេញពីវត្តមាននៃព្រះអម្ចាស់ គឺជាការចាំបាច់ដែល មនុស្សលោកត្រូវរួចផុតពីសេចក្ដីស្លាប់ខាងវិញ្ញាណ ។

១០ ហេតុដូច្នេះហើយ ដោយមនុស្សប្រកបដោយរូបកាយកាមរាគ និងអាក្រក់តាមធម្មជាតិ នោះស្ថានភាពសាកល្បងនេះបានក្លាយទៅជាស្ថានភាពមួយ សំរាប់ឲ្យគេរៀបចំ គឺជាស្ថានភាពរៀបចំ ។

១១ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ចូរចងចាំថា បើសិនជាពុំមានផែនការនៃសេចក្ដីប្រោសលោះទេ (ទុកផែន ការនេះដោយឡែកសិន) នៅពេលគេស្លាប់ភ្លាមទៅ នោះព្រលឹងរបស់គេ នឹងទទួលទុក្ខវេទនា ដោយត្រូវកាត់ចេញ ពីវត្តមាន នៃព្រះអម្ចាស់ ។

១២ ហើយឥឡូវនេះ គ្មានផ្លូវនឹងទាមទារមនុស្ស ពីស្ថានភាពធ្លាក់នេះមកវិញបានឡើយ គឺជាស្ថានភាពដែលមនុស្សបាននាំមកលើខ្លួនឯង ដោយព្រោះការមិនកោតខ្លាចរបស់គេផ្ទាល់ ។

១៣ ហេតុដូច្នេះហើយ ស្របតាមសេចក្ដីយុត្តិធម៌ ផែនការនៃសេចក្ដីប្រោសលោះពុំអាចនឹងអនុវត្តបានឡើយ លើកលែងតែលក្ខខណ្ឌទាំងឡាយនៃការប្រែចិត្តរបស់មនុស្ស នៅក្នុងស្ថានភាពសាកល្បង នេះត្រូវបានសំរេច មែនហើយ គឺស្ថានភាពសាកល្បងនេះ; ត្បិតលើកលែងតែមានលក្ខខ័ណ្ឌទាំងនេះ បើពុំនោះសោតទេ សេចក្ដីមេត្តាករុណាពុំអាចមានប្រសិទ្ធិភាពឡើយ លើកលែងតែវា ត្រូវបំផ្លាញកិច្ចការនៃសេចក្ដីយុត្តិធម៌ចោល ។ ឥឡូវនេះ កិច្ចការនៃសេចក្ដីយុត្តិធម៌ពុំអាចនឹងត្រូវបំផ្លាញបានឡើយ; បើដូច្នោះមែន នោះព្រះនឹងឈប់ទៅជាព្រះទៀតហើយ ។

១៤ ម្ល៉ោះហើយ យើងឃើញថា មនុស្សលោកទាំងអស់ត្រូវធ្លាក់ ហើយគេនៅក្នុងកណ្ដាប់ដៃនៃសេចក្ដីយុត្តិធម៌; មែនហើយ សេចក្ដីយុត្តិធម៌នៃព្រះ ដែលដាក់ទោសដល់គេ ថាត្រូវកាត់ចេញពីវត្តមានរបស់ទ្រង់រហូត ។

១៥ ហើយឥឡូវនេះ ផែនការនៃសេចក្ដីមេត្តាករុណា ពុំអាចអនុវត្តទៅបាន លើកលែងតែមានដង្វាយធួនកើតឡើង; ហេតុដូច្នេះ ហើយ ព្រះអង្គទ្រង់ផ្ទាល់បានធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក ដើម្បីនាំមកនូវផែនការនៃសេចក្ដីមេត្តាករុណា ដើម្បីធ្វើ ឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្ដីយុត្តិធម៌ ដើម្បីព្រះជាព្រះដ៏ល្អឥតខ្ចោះ ហើយត្រឹមត្រូវ និងជាព្រះដែលប្រកបដោយសេចក្ដី មេត្តាករុណាផង ។

៦ *ក* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
*ខ* ម៉ូសាយ ១៦:៣–៥.
ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
៧ *ក* ២ នីហ្វៃ ២:៥; ៩:៦; ហេលេ. ១៤:១៦. ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
*ខ* ស.ប. សិទ្ធិជ្រើសរើស.
៨ *ក* អាលម៉ា ៣៤:៩; ម៉ូសេ ៦:៦២.
៩ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
១០ *ក* ស.ប. ខាងរូបកាយ.
*ខ* ស.ប. មនុស្សខាងសាច់ឈាម.
*គ* ស.ប. ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់.
១១ *ក* ២ នីហ្វៃ ៩:៧–៩.
១៣ *ក* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*គ* ២ នីហ្វៃ ២:១៣–១៤.
១៤ *ក* អាលម៉ា ២២:១៣–១៤.
*ខ* ២ នីហ្វៃ ២:៥.
១៥ *ក* ២ នីហ្វៃ ៩:៧–១០; ម៉ូសាយ ១៦:៧–៨.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
*គ* ស.ប. សេចក្ដីយុត្តិធម៌.
*ឃ* ៣ នីហ្វៃ ១២:៤៨.

១៦ ឥឡូវនេះ ការប្រែចិត្តពុំអាចមានដល់មនុស្សទេ លើកលែងតែមានទោស ដែលនៅអស់កល្បជានិច្ច ដូចជាជីវិតនៃព្រលឹងដែរ ដែលបានភ្ជាប់ទុក ផ្ទុយទៅនឹងផែនការនៃសុភមង្គល ដែលនៅអស់កល្បជានិច្ច ដូចជាជីវិតនៃព្រលឹងដែរ ។

១៧ ឥឡូវនេះ តើមនុស្សអាចប្រែចិត្តម្ដេចកើត លើកលែងតែគេបានធ្វើបាប ? តើធ្វើម្ដេចឲ្យមនុស្សមានបាប បើសិនជាគ្មានច្បាប់ ? ហើយធ្វើម្ដេចអាចមានច្បាប់បាន លើកលែងតែមានទោស ?

១៨ ឥឡូវនេះ មានទោសដែលបានភ្ជាប់ទុក ហើយច្បាប់ដ៏ត្រឹមត្រូវបានដាក់ឡើង ដែលនាំមកនូវការសោកស្ដាយនៅក្នុងស្មារតី មនុស្ស ។

១៩ ឥឡូវនេះ បើសិនជាគ្មានច្បាប់ចែងឡើង — ថាបើសិនជាមនុស្សធ្វើឃាត នោះគេត្រូវស្លាប់ — តើអ្នកនោះខ្លាចស្លាប់ទេ បើសិនជាគេធ្វើឃាត ?

២០ ហើយម្យ៉ាងទៀត បើសិនជាគ្មានច្បាប់ទាស់នឹងអំពើបាបទេ នោះមនុស្សនឹងពុំខ្លាចនឹងធ្វើបាបឡើយ ។

២១ ហើយបើសិនជាគ្មានច្បាប់ចែងឡើងថា បើសិនជាមនុស្សប្រព្រឹត្តអំពើបាប តើសេចក្ដីយុត្តិធម៌អាចធ្វើអ្វីកើត ? ឬសេចក្ដីមេត្តា ករុណាក៏ដូច្នោះដែរ ព្រោះសេចក្ដីយុត្តិធម៌និងសេចក្ដីមេត្តាករុណាគ្មានអំណាចអ្វីដល់មនុស្សលោកទេ ។

២២ ប៉ុន្តែ មានច្បាប់មួយបានតែងឡើង និងទោសមួយបានភ្ជាប់ទុក និងការប្រែចិត្តមួយ បានប្រទានឲ្យ; ជាការប្រែចិត្ត ដែលទាម ទារដោយសេចក្ដីមេត្តាករុណា; បើពុំនោះសោតទេ សេចក្ដីយុត្តិធម៌ទាមទារសត្វលោក ហើយអនុវត្តច្បាប់ ហើយច្បាប់ធ្វើទុក្ខទោស; បើពុំនោះសោតទេ កិច្ចការទាំងឡាយនៃសេចក្ដីយុត្តិធម៌ នឹងត្រូវបំផ្លាញចោល ហើយព្រះទ្រង់នឹងឈប់ទៅជាព្រះទៀតហើយ ។

២៣ ប៉ុន្តែ ព្រះទ្រង់មិនឈប់ធ្វើជាព្រះទេ ឯសេចក្ដីមេត្តាករុណាការពារដល់ជនណាដែលប្រែចិត្ត ហើយសេចក្ដីមេត្តាករុណាបាន មក ដោយសារដង្វាយធួន; ឯដង្វាយធួននឹងនាំមកនូវដំណើររស់ឡើងវិញដល់មនុស្សស្លាប់; ហើយដំណើររស់ឡើងវិញដល់មនុស្ស ស្លាប់ នឹងនាំមនុស្សឲ្យត្រឡប់ទៅវត្តមាននៃព្រះវិញ; ម្ល៉ោះហើយ គេនឹងបានសាងឡើងវិញ នៅឯវត្តមានរបស់ទ្រង់ ដើម្បីទទួលការ ជំនុំជំរះ ស្របតាមកិច្ចការទាំងឡាយរបស់ខ្លួន គឺស្របតាមច្បាប់ និងសេចក្ដីយុត្តិធម៌ ។

២៤ ត្បិតមើលចុះ សេចក្ដីយុត្តិធម៌អនុវត្តនូវសេចក្ដីទាមទារទាំងអស់របស់វា ឯសេចក្ដីមេត្តាករុណាក៏ទាមទារនូវអ្វីៗ ដែលនៅក្នុងអំណាចរបស់វាដែរ; ម្ល៉ោះហើយ គ្មាននរណាឡើយក្រៅពីជនដែលប្រែចិត្ត ដែលនឹងបានសង្គ្រោះ ។

២៥ តើកូនគិតស្មានថា សេចក្ដីមេត្តាករុណាអាចកោងសេចក្ដីយុត្តិធម៌បានឬ ? ឪពុកប្រាប់កូនថា៖ ទេ; ពុំអាចទាល់តែសោះ ។ បើដូច្នោះមែន នោះព្រះទ្រង់នឹងពុំមែនជាព្រះទៀតទេ ។

២៦ ម្ល៉ោះហើយ ព្រះទ្រង់បាននាំមកនូវគោលបំណងទាំងឡាយដ៏មហិមា ហើយដ៏នៅអស់កល្បជានិច្ច ដែលបានរៀបចំឡើង ចាប់តាំងពីកំណើតលោកិយមក ។ ម្ល៉ោះហើយ ទើបមានសេចក្ដីសង្គ្រោះ និងសេចក្ដីប្រោសលោះដល់មនុស្ស និងសេចក្ដីបំផ្លិចបំផ្លាញ និងសេចក្ដីទុក្ខវេទនាដល់គេផងដែរ ។

២៧ ហេតុដូច្នេះហើយ ឱកូនប្រុសរបស់ឪពុកអើយ អស់អ្នកណាដែលចង់មក អាចមក ហើយទទួលទានទឹកនៃជីវិតដោយសេរីចុះ; ឯអស់អ្នកណាដែលពុំចង់មកទេ គេក៏ពុំត្រូវបង្ខិតបង្ខំឲ្យមកដែរ; ប៉ុន្តែនៅថ្ងៃចុងក្រោយបង្អស់ នឹងត្រូវបានសាងដល់គេវិញ ស្របតាមអ្វីៗ ដែលគេបានប្រព្រឹត្ត ។

២៨ បើសិនជាអ្នកនោះមានបំណងចង់ធ្វើអាក្រក់ ហើយពុំបានប្រែចិត្តនៅក្នុងជីវិតគេទេ មើលចុះ អំពើអាក្រក់នោះ នឹងត្រូវឲ្យទៅ គេវិញ ស្របតាមការសាងឡើងវិញនៃព្រះ ។

២៩ ហើយឥឡូវនេះ កូនប្រុសរបស់ឪពុកអើយ ឪពុកពុំមានបំណងចង់ឲ្យរឿងទាំងនេះ ធ្វើឲ្យកូនកង្វល់ចិត្តតទៅទៀតទេ ហើយ

១៦ *ក* គ. និង ស. ១៩:១០–១២.
១៧ *ក* ស.ប. អំពើបាប.
*ខ* រ៉ូម ៤:១៥.
១៨ *ក* ស.ប. បញ្ញាចិត្ត.
១៩ *ក* ស.ប. ឃាតកម្ម.
២១ *ក* ២ នីហ្វៃ ៩:២៥–២៦;
ម៉ូសាយ ៣:១១.
២២ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
២៣ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ២ នីហ្វៃ ២:៨; ៩:៤;
អាលម៉ា ៧:១២; ១១:៤១–៤៥;
១២:២៤–២៥;
ហេលេ. ១៤:១៥–១៨;
មរមន ៩:១៣.
*ឃ* អាលម៉ា ៤០:២១–២៤.
*ង* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
២៥ *ក* ស.ប. សេចក្ដីយុត្តិធម៌.
២៦ *ក* ២ នីហ្វៃ ២:១៤–៣០;
ម៉ូសេ ១:៣៩.
*ខ* អាលម៉ា ១៣:៣;
៣ នីហ្វៃ ១:១៤.
២៧ *ក* អាលម៉ា ៥:៣៤;
ហេលេ. ១៤:៣០.
ស.ប. សិទ្ធិជ្រើសរើស.
*ខ* អាលម៉ា ៤១:១៥.
*គ* អេសាយ ៥៩:១៨; វិវរ. ២០:១២.
២៨ *ក* អាលម៉ា ៤១:២–៥.

ទុក ឲ្យតែអំពើបាបរបស់កូនបារម្ភដល់កូនតែប៉ុណ្ណោះបានហើយ
គឺការបារម្ភនេះហើយ ដែលអាចញាំងឲ្យកូនប្រែចិត្ត ។
៣០ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកមានបំណងចង់ឲ្យកូន
ឈប់បដិសេធសេចក្ដីយុត្តិធម៌នៃព្រះតទៅទៀត ។ ចូរកូនកុំ
ខិតខំដោះ សារខ្លួន ដោយនូវចំណុចតូចតាច ដោយព្រោះអំពើ
បាបទាំងឡាយរបស់កូន ដោយបដិសេធនូវសេចក្ដីយុត្តិធម៌នៃ
ព្រះឡើយ ។ ប៉ុន្តែ ចូរកូនទុកឲ្យសេចក្ដីយុត្តិធម៌នៃព្រះ
និងសេចក្ដីមេត្តាករុណារបស់ទ្រង់ និងសេចក្ដីអត់ធ្មត់របស់ទ្រង់
មានប្រសិទ្ធិភាពយ៉ាងពេញទំហឹងនៅ ក្នុងចិត្តកូនចុះ; ហើយ
ទុកឲ្យការណ៍ទាំងនេះ នាំកូនចុះទៅដល់ធូលីដីក្នុងភាព
រាបសា ។
៣១ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ព្រះទ្រង់បាន
ហៅឲ្យកូនផ្សាយព្រះបន្ទូល ដល់ប្រជាជននេះ ។ ហើយឥឡូវនេះ
កូនប្រុសរបស់ឪពុកអើយ ចូរកូនធ្វើដំណើរទៅចុះ ទៅប្រកាស
ប្រាប់ព្រះបន្ទូល ដោយការពិត និងការម៉ឺងម៉ាត់ ដើម្បីកូនអាចនាំ
មនុស្សទាំងឡាយទៅរកការប្រែចិត្ត ដើម្បីឲ្យផែនការនៃសេច
ក្ដីមេត្តាករុណាដ៏មហិមា អាចទាមទាររកគេផង ។ ហើយសូមឲ្យ
ព្រះប្រទានដល់កូន ស្របតាមពាក្យពេចន៍របស់ឪពុកផងចុះ ។
អាម៉ែន ៕

## ជំពូកទី ៤៣

*អាលម៉ា និងពួកកូនប្រុសរបស់លោកផ្សាយព្រះបន្ទូល — ពួកសាសន៍សូរាំ និងពួកជនដែលបែកចេញពីសាសន៍នីហ្វៃ ក្លាយទៅជា សាសន៍លេមិន — ពួកសាសន៍លេមិនមកប្រឆាំងនឹងពួកសាសន៍នីហ្វៃ នៅក្នុងសង្គ្រាម — មរ៉ូណៃប្រដាប់ពួកសាសន៍នីហ្វៃ ដោយអាវ ក្រោះសំរាប់ការពារ — ព្រះអម្ចាស់ទ្រង់បើកសំដែងដល់អាលម៉ា នូវយុទ្ធសាស្ត្ររបស់ពួកសាសន៍លេមិន — ពួកសាសន៍នីហ្វៃការពារ ផ្ទះសំបែង សេរីភាព គ្រួសារ និងសាសនារបស់គេ — ពលទ័ពរបស់មរ៉ូណៃ និងលីហៃ ហ៊ុំព័ទ្ធពួកលេមិន ។ ប្រមាណជាឆ្នាំ ៧៤ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកកូនប្រុសរបស់
អាលម៉ា បានទៅក្នុងចំណោមប្រជាជន ដើម្បីប្រកាសប្រាប់ព្រះ
បន្ទូលដល់ពួកគេ ។ ហើយអាលម៉ាផ្ទាល់ ក៏មិនអាចសំរាកឡើយ
ហើយលោកក៏បានទៅដែរ ។
២ ឥឡូវនេះ យើងពុំនិយាយទៀតទេ អំពីការផ្សព្វផ្សាយរបស់
ពួកគេ លើកលែងតែថា ពួកគេបានផ្សាយព្រះបន្ទូល និងសេចក្ដី
ពិត ស្របតាមវិញ្ញាណនៃការព្យាករណ៍ និងវិវរណៈ; ហើយពួក
គេបានផ្សាយតាមរបៀបដ៏បរិសុទ្ធនៃព្រះ ដែលពួកគេត្រូវបាន
ហៅឲ្យធ្វើ ។
៣ ហើយឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីសង្គ្រាមទាំង
ឡាយ រវាងពួកសាសន៍នីហ្វៃនឹងពួកសាសន៍លេមិនវិញ
នៅឆ្នាំទីដប់ប្រាំបី ក្នុងរជ្ជកាលនៃពួកចៅក្រម ។
៤ ត្បិតមើលចុះ ហេតុការណ៍បានកើតឡើងថា ពួក
សាសន៍សូរាំបានក្លាយទៅជាសាសន៍លេមិន; ហេតុដូច្នេះហើយ
នៅដើមឆ្នាំ ទីដប់ប្រាំបី នោះប្រជាជននៃពួកនីហ្វៃបានឃើញថា ពួក
សាសន៍លេមិនលើកមកវាយប្រហារគេ; ហេតុដូច្នេះហើយ ពួក
គេបានរៀបចំធ្វើ សង្គ្រាម; មែនហើយ ពួកគេបានប្រមូលពល
ទ័ពរបស់គេ មកក្នុងដែនដីយើសុន ។
៥ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានលើកគ្នា
មកជាច្រើនពាន់នាក់; ហើយពួកគេបានចូលមកក្នុងដែនដីអាន់ទីអូនុម
ដែលជាដែនដីរបស់ពួកសាសន៍សូរាំ; ហើយមានបុរសម្នាក់ឈ្មោះ
សេរ៉ាហិមណា គឺជាអ្នកដឹកនាំរបស់គេ ។
៦ ហើយឥឡូវនេះ ដោយពួកសាសន៍អាម៉ាលេកៃ មាន
ចរិតអាក្រក់ ហើយចូលចិត្តធ្វើឃាតមនុស្សជាងពួកសាសន៍លេមិន
ដោយ ខ្លួនគេ ហេតុដូច្នេះហើយ ទើបសេរ៉ាហិមណាបាន
តែងតាំងពួកមេទ័ពឯកលើពួកសាសន៍លេមិន ហើយពួកគេសុទ្ធតែ
ពួកសាសន៍ អាម៉ាលេកៃ និងពួកសាសន៍សូរាំ ។
៧ ឥឡូវនេះ គាត់ធ្វើបែបនេះ គឺដើម្បីគាត់អាចទុកឲ្យ
គេមានសម្អប់ដល់ពួកសាសន៍នីហ្វៃ ដើម្បីគាត់អាចនាំពួកនេះ
ឲ្យនៅក្រោម អំណាចរបស់គាត់ ដើម្បីគាត់អាចសំរេចគោល
បំណងទាំងឡាយរបស់គាត់ ។
៨ ត្បិតមើលចុះ គោលបំណងរបស់គាត់ គឺដើម្បីចាក់រុកឲ្យ
ពួកសាសន៍លេមិនខឹងនឹងពួកសាសន៍នីហ្វៃ; គាត់ធ្វើបែបនេះ គឺដើម្បី
គាត់អាចដណ្ដើមយក អំណាចដ៏ធំទៅលើពួកគេ ហើយក៏ដើម្បី
គាត់អាចមានអំណាចទៅលើពួកសាសន៍នីហ្វៃ ដោយនាំពួក
គេទៅ ក្នុងសេវកភាព ។
៩ ហើយឥឡូវនេះ គោលបំណងរបស់ពួកសាសន៍នីហ្វៃ
គឺគាំទ្រដែនដីរបស់គេ ផ្ទះសំបែងរបស់គេ និងប្រពន្ធរបស់គេ និង
កូនចៅ របស់គេ ដើម្បីគេអាចថែរក្សាគេឲ្យរួចផុតពីកណ្ដាប់ដៃ

៣០ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
៤៣ ២ *ក* ស.ប. បព្វជិតភាពមិលគីស្សាដែក.
៤ *ក* អាលម៉ា ៣៥:២–១៤; ៥២:៣៣.
៩ *ក* អាលម៉ា ៤៤:៥; ៤៦:១២.

នៃពួកខ្មាំងសត្រូវរបស់គេ; ហើយក៏ដើម្បីគេអាចរក្សាសិទ្ធិ និង
ឯកសិទ្ធិរបស់គេ មែនហើយ ព្រមទាំង[ខ]ឥស្សរភាពរបស់គេផង
ដើម្បីគេអាចថ្វាយបង្គំដល់ព្រះគេ តាមបំណងរបស់គេ ។
១០ ព្រោះគេបានដឹងថា បើសិនជាគេត្រូវធ្លាក់ទៅក្នុង
កណ្ដាប់ដៃនៃពួកសាសន៍លេមិន ថាអស់អ្នកណាដែលនឹង
[ក]ថ្វាយបង្គំព្រះ ដោយ[ខ]វិញ្ញាណ និងសេចក្ដីពិត គឺព្រះដ៏ពិត ហើយ
មានព្រះជន្មរស់នៅ នោះពួកលេមិននឹងបំផ្លាញចោល ។
១១ មែនហើយ ពួកគេក៏បានដឹងនូវសម្អប់ដ៏ធំរបស់ពួកសាសន៍
លេមិនដល់[ក]បងប្អូនគេ ដែលជាប្រជាជនអាន់តៃ- នីហ្វៃ-លីហៃ
ដែលគេ ហៅថា ប្រជាជនអាំម៉ូន — ហើយពួកគេ
ពុំព្រមកាន់អាវុធសោះ មែនហើយ ពួកគេបានចូលក្នុងសេចក្ដី
សញ្ញាមួយ ហើយគេមិនព្រម បំពាក់ឡើយ — ហេតុ
ដូច្នេះហើយ បើសិនជាគេត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃ នៃពួក
សាសន៍លេមិន នោះពួកគេនឹងត្រូវបំផ្លាញបង់ ។
១២ ហើយពួកសាសន៍នីហ្វៃពុំទុកឲ្យគេត្រូវបំផ្លាញចោលទេ;
ហេតុដូច្នេះហើយ ទើបគេបានឲ្យពួកនោះ នូវដីសំរាប់ជាកេរ្ដិ៍អាករ ។
១៣ ហើយប្រជាជនអាំម៉ូនបានឲ្យពួកសាសន៍នីហ្វៃ នូវទ្រព្យ
របស់គេមួយភាគធំ ដើម្បីចិញ្ចឹមពលទ័ពរបស់គេ; ហេតុ
ដូច្នេះហើយ ពួកសាសន៍នីហ្វៃត្រូវបង្ខំចិត្ត ឲ្យទប់ទល់នឹងពួក
សាសន៍លេមិនតែឯង ដែលជាជនជាតិចំរុះ រវាងសាសន៍លេមិន
នឹងលេមយួល និងកូន ចៅរបស់អ៊ីសម៉ាអែល និងជនទាំងអស់
ដែលបែកចេញពីពួកសាសន៍នីហ្វៃ គឺពួកសាសន៍អាម៉ាលេកៃ
និងពួកសាសន៍សូរាំ និង[ក]ពូជពង្ស របស់ពួកសង្ឃនៃស្ដេចណូអេ ។
១៤ ឥឡូវនេះ ពូជពង្សទាំងនោះមានគ្នាច្រើន ជិតស្មើនឹងពួក
សាសន៍នីហ្វៃ; ម្ល៉ោះហើយ ពួកសាសន៍នីហ្វៃត្រូវបានបង្ខំឲ្យតតាំង
នឹង បងប្អូនខ្លួន គឺរហូតដល់មានការខ្ចាយឈាម ។
១៥ ហើយហេតុការណ៍បានកើតឡើង គឺនៅពេលដែលពល
ទ័ពសាសន៍លេមិន បានប្រមូលគ្នានៅក្នុងដែនដី អាន់ទីអូនុម
មើលចុះ ពលទ័ពសាសន៍នីហ្វៃបានរៀបចំខ្លួន ដើម្បីទៅជួបពួក
គេនៅឯដែនដីយើសុន ។
១៦ ឥឡូវនេះ មេដឹកនាំពួកនីហ្វៃ ឬបុរសដែលត្រូវបាន
តែងតាំងឡើងជាមេទ័ពឯកលើពួកនីហ្វៃ — ឥឡូវនេះ មេទ័ពឯក
គឺជាអ្នក ត្រួតត្រាលើពលទ័ពសាសន៍នីហ្វៃទាំងអស់ —
ហើយលោកមានឈ្មោះថា មរ៉ូណៃ;
១៧ ហើយមរ៉ូណៃ ជាអ្នកបញ្ជាការ ហើយជាអភិបាល
នៃសង្គ្រាមរបស់គេទាំងអស់ ។ ហើយលោកមាន
អាយុតែម្ភៃប្រាំឆ្នាំប៉ុណ្ណោះ នៅពេលលោកត្រូវបានតែងតាំងឡើង
ឲ្យធ្វើជាមេទ័ពឯកលើពលទ័ពសាសន៍នីហ្វៃ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា លោកបានជួបតទល់
នឹងពួកលេមិន នៅឯព្រំប្រទល់ដែនដីយើសុន ហើយទ័ព
របស់លោក បានប្រដាប់ខ្លួនដោយដាវទាំងឡាយ និងសាបទាំង
ឡាយ និងអស់ទាំងគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមគ្រប់យ៉ាង ។
១៩ ហើយកាលពលដែលទ័ពសាសន៍លេមិនបានឃើញថា
ប្រជាជននីហ្វៃ ឬថាមរ៉ូណៃ បានប្រដាប់ឲ្យទ័ពលោកនូវអាវក្រោះ
ទាំង ឡាយ និងខែលដៃទាំងឡាយ មែនហើយ ព្រម
ទាំងខែលការពារក្បាលទាំងឡាយ ហើយពួកគេបាន
ស្លៀកពាក់នូវសំលៀកបំពាក់ ដ៏ក្រាស់ៗផង—
២០ ឥឡូវនេះ កងទ័ពរបស់សេរ៉ាហិមណា ពុំបានរៀបចំនូវ
គ្រឿងប្រដាប់បែបនេះទេ; ពួកគេមានតែដាវទាំងឡាយរបស់គេ
និង សាបទាំងឡាយរបស់គេ ធ្នូទាំងឡាយបស់គេ និងព្រួញ
ទាំងឡាយរបស់គេ ក្រួសទាំងឡាយរបស់គេ និងខ្សែដង្ហក់ទាំង
ឡាយរបស់គេ ប៉ុណ្ណោះ; ហើយពួកគេនៅ[ក]ខ្លួនអាក្រាត
លើកលែងតែស្បែកមួយបន្ទះ ដែលក្រវាត់នៅចង្កេះ; មែនហើយ
គេទាំងអស់គ្នានៅ អាក្រាត លើកលែងតែពួកសាសន៍សូរាំ និង
ពួកសាសន៍អាម៉ាលេកៃប៉ុណ្ណោះ;
២១ តែពួកគេមិនបានពាក់អាវក្រោះទាំងឡាយ ឬខែលទាំង
ឡាយទេ — ហេតុដូច្នេះហើយ ពួកគេខ្លាចពលទ័ពសាសន៍នីហ្វៃ
ក្រៃលែង ដោយសារគ្រឿងប្រដាប់ក្រោះរបស់គេ ទោះជាពួក
គេមានចំនួនច្រើនជាងពួកសាសន៍នីហ្វៃដ៏លើសលប់ក៏ដោយ ។
២២ មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួក
គេមិនហ៊ានវាយប្រហារពួកនីហ្វៃ នៅឯព្រំប្រទល់ដែនដីយើសុនទេ;
ហេតុដូច្នេះហើយ ពួកគេបានចេញពីដែនដីអាន់ទីអូនុម ទៅក្នុង
ទីរហោស្ថាន ហើយបានធ្វើដំណើរជុំវិញក្នុងទីរហោស្ថាន ទៅខាង
ដើមទន្លេស៊ីដូន ដើម្បីគេអាចចូលទៅឯដែនដីម៉ាន់តៃ ហើយមក
ដែនដីនោះ; ព្រោះពួកគេពួនបានគិតស្មានថា ពលទ័ពរបស់មរ៉ូណៃ
មិនដឹងថា គេបានទៅទីណាឡើយ ។
២៣ តែហេតុការណ៍បានកើតឡើងថា កាលដែលពួកគេបាន
ចូលទៅក្នុងទីរហោស្ថានភ្លាម នោះមរ៉ូណៃបានចាត់ឲ្យពួកអ្នកស៊ើប

៩ *ខ* ស.ប. ឥស្សរភាព.
១០ *ក* ស.ប. ថ្វាយបង្គំ.
*ខ* យ៉ូហាន ៤:២៣–២៤.
១១ *ក* អាលម៉ា ២៤:១–៣, ៥, ២០;
២៥:១, ១៣; ២៧:២, ២១–២៦.
១៣ *ក* អាលម៉ា ២៥:៤.
២០ *ក* អេណុស ១:២០.

ការណ៍ ចូលទៅក្នុងទីរហោស្ថាន ដើម្បីលបមើលជំរុំរបស់គេ;
ហើយមរ៉ូណៃ ដោយដឹងនូវការព្យាករណ៍ទាំងឡាយរបស់
អាលម៉ា ក៏បានចាត់ឲ្យមនុស្សខ្លះទៅជួបនឹងលោក សូមឲ្យ
លោកសួរដល់ព្រះអម្ចាស់ថា [ក]តើកលទ័ពទាំងឡាយសាសន៍
នីហ្វៃត្រូវទៅទីណា ដើម្បីការពារខ្លួនគេពីពួកលេមិន ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ព្រះបន្ទូលនៃព្រះ
អម្ចាស់បានប្រាប់មកអាលម៉ា ហើយអាលម៉ាឲ្យដំណឹង ទៅអ្នក
នាំសារ ទាំងឡាយរបស់មរ៉ូណៃថា ពលទ័ពសាសន៍លេមិន
កំពុងដើរជុំវិញ នៅក្នុងទីរហោស្ថាន ដើម្បីគេអាចចូលទៅឯ
ដែនដីម៉ាន់តៃ ដើម្បី គេអាចចាប់ផ្ដើមការវាយប្រហារ ទៅលើ
ផ្នែកប្រជាជនដែលទន់ខ្សោយ ។ ហើយពួកអ្នកនាំសារទាំងនោះ
បាននាំដំណឹងទៅប្រាប់ មរ៉ូណៃ ។
២៥ ឥឡូវនេះ មរ៉ូណៃ ដោយបានទុកកងទ័ពរបស់លោកមួយ
ភាគ នៅឯដែនដីយើសុន ខ្លាចក្រែងពួកលេមិនមួយភាគនឹង
ចូលទៅ ឯដែនដីនោះ ហើយដណ្ដើមយកទីក្រុង នោះលោកបាន
យកកងទ័ពរបសលោក ដែលនៅសល់ទាំងប៉ុន្មាន ហើយបានធ្វើ
ដំណើរទៅឯ ដែនដីម៉ាន់តៃ ។
២៦ ហើយលោកបានបញ្ជា ឲ្យប្រជាជនទាំងអស់ នៅភូមិភាគ
នៃដែនដីប្រមូលគ្នា មកវាយតទល់នឹងពួកលេមិន ដើម្បី[ក]ការពារ
ដែនដី របស់គេ និងប្រទេសរបស់គេ និងសិទ្ធិរបស់គេ
និងសេរីភាពរបស់គេ; ហេតុដូច្នេះហើយ ពួកគេបានប្រុងប្រៀប
ខ្លួនចាំ នៅពេលដែល ពួកលេមិននឹងមក ។
២៧ ហើយហេតុការណ៍បានកើតឡើងថា មរ៉ូណៃបានបញ្ជាឲ្យ
កងទ័ពរបស់លោក ពួននៅក្នុងច្រកភ្នំ ជិតច្រាំងទន្លេស៊ីដូន គឺនៅ
ត្រើយខាងលិចទន្លេស៊ីដូន នៅក្នុងទីរហោស្ថាន ។
២៨ ហើយមរ៉ូណៃបានដាក់ពួកអ្នកស៊ើបការណ៍នៅជុំវិញ
ដើម្បីឲ្យដឹងថា កាលណាពួកលេមិននឹងមកដល់ ។
២៩ ហើយឥឡូវនេះ មរ៉ូណៃបានដឹងនូវបំណងរបស់ពួកសាសន៍
លេមិនថា បំណងរបស់គេ គឺដើម្បីបំផ្លាញបងប្អូនគេចោល ឬដាក់
ពួកគេឲ្យនៅក្រោមអំណាច ហើយយកពួកគេទៅក្នុងសេវកភាព
ដើម្បីគេអាចបង្កើតនគរសំរាប់ខ្លួនគេ នៅលើអស់ទាំងដែនដី;
៣០ ហើយលោកក៏ដឹងថា បំណងតែមួយរបស់ពួកសាសន៍
នីហ្វៃ គឺដើម្បីការពារដែនដីរបស់គេ និង[ក]ឥស្សរភាពរបស់គេ និង
សាសនាចក្ររបស់គេ ហេតុដូច្នេះហើយ លោកបានគិតថា គ្មាន
បាបអ្វីទេ ដែលលោកត្រូវការពារពួកគេ ដោយប្រើឧបាយ;
ហេតុដូច្នេះហើយ លោកបានដឹងពីពួកអ្នកស៊ើបការណ៍មកថា
តើពួកលេមិននឹងដើរតាមផ្លូវណា ។
៣១ ហេតុដូច្នេះហើយ លោកបានបំបែកកងទ័ពរបស់លោក
ហើយយកមួយផ្នែកទៅក្នុងច្រកភ្នំ ហើយពួននៅខាងកើត និង
ខាង ត្បូងភ្នំរីពឡា;
៣២ ហើយទ័ពដែលនៅសល់ទាំងប៉ុន្មាន នោះលោកបាន
លាក់នៅខាងលិចច្រកភ្នំ នៅខាងលិចទន្លេស៊ីដូន រហូតទៅទល់
នឹង ព្រំដែននៃដែនដីម៉ាន់តៃ ។
៣៣ ម្ល៉ោះហើយ ដោយបានដាក់កងទ័ពទៅតាមបំណង
របស់លោក នោះលោកបានប្រុងប្រៀបខ្លួន ដើម្បីទៅជួបនឹងពួក
គេ ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិន
បានឡើងមកខាងជើងភ្នំ ជាកន្លែងដែលមានកងទ័ពរបស់មរ៉ូណៃ
មួយផ្នែក បង្កប់នៅទីនោះ ។
៣៥ ហើយនៅពេលដែលពួកលេមិនបានឆ្លងហួសភ្នំរីពឡា
ហើយបានចូលមកក្នុងច្រកភ្នំ ហើយបានចាប់ផ្ដើមឆ្លងទន្លេស៊ីដូន
នោះកងទ័ពដែលបានពួននៅខាងត្បូងភ្នំ នៅក្រោមការដឹកនាំ
របស់បុរសម្នាក់ឈ្មោះ [ក]លីហៃ ក៏បានចេញមកហ៊ុំព័ទ្ធពួកលេមិន
ពីខាងក្រោយ ពីទិសខាងកើត ។
៣៦ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលពួក
លេមិនបានឃើញពួកនីហ្វៃ មកវាយប្រហារគេពីខាងក្រោយ
ក៏បែរមក ក្រោយវិញ ហើយបានចាប់ផ្ដើមតតាំងនឹងកងទ័ពលីហៃ ។
៣៧ ហើយការស្លាប់ក៏បានចាប់ផ្ដើមមានដល់ពលទ័ព
ទាំងសងខាង ប៉ុន្តែ ផ្នែកខាងពួកលេមិនច្រើនជាង ព្រោះខ្លួន
របស់ពួកគេ នៅ[ក]ទំទេ ត្រូវទទួលរងការវាយប្រហាររបស់ពួក
នីហ្វៃយ៉ាងខ្លាំង ដែលប្រដាប់ដោយដាវទាំងឡាយរបស់គេ និង
សាបទាំងឡាយរបស់ គេ ដែលធ្វើឲ្យមានការស្លាប់សឹងតែ
គ្រប់ពេលដែលកាប់ចាក់ ។
៣៨ រីឯផ្ទុយមកវិញ នៅខាងពួកនីហ្វៃ ម្ដងម្កាល ទើបមាន
មនុស្សម្នាក់ដួលចុះ ដោយសារដាវទាំងឡាយរបស់ពួកគេ ហើយ
ត្រូវហូរ អស់ឈាម ពួកគេត្រូវស្រោបត្រង់ផ្នែក នៃរាងកាយដែល
សំខាន់ ឬផ្នែកសំខាន់ទាំងឡាយ នៃរាងកាយត្រូវបាន
ស្រោបការពារ ពីការកាប់ចាក់របស់ពួកលេមិន ដោយ

២៣ *ក* អាលម៉ា ៤៨:១៦.
២៦ *ក* គ. និង ស. ១៣៤:១១.
៣០ *ក* អាលម៉ា ៤៦:១២, ៣៥.
៣៥ *ក* អាលម៉ា ៤៩:១៦.
៣៧ *ក* អាលម៉ា ៣:៥.

[ក]អាវក្រោះទាំងឡាយរបស់គេ និងខែលដៃទាំងឡាយរបស់គេ
និងមួកការពារក្បាលទាំងឡាយ របស់គេ; ម្ល៉ោះហើយ ពួកនីហ្វៃ
បានបន្តការកាប់សម្លាប់ នៅក្នុងចំណោមពួកលេមិន ។
៣៩ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនមាន
ការតក់ស្លុត ដោយព្រោះការបំផ្លិចបំផ្លាញដ៏មហិមា នៅក្នុង
ចំណោម ពួកគេ គឺរហូតដល់ពួកគេបានចាប់ផ្ដើមរត់ភៀសខ្លួន
ឆ្ពោះទៅទន្លេស៊ីដូន ។
៤០ ហើយពួកគេត្រូវលីហៃ និងទ័ពរបស់លោកដេញតាម;
ហើយគេត្រូវរុញច្រានដោយលីហៃ ឲ្យធ្លាក់ទៅក្នុងទឹកទន្លេស៊ីដូន
ហើយ ពួកគេបានឆ្លងទន្លេស៊ីដូន ។ ហើយលីហៃបានបញ្ឈប់ពល
ទ័ពរបស់លោក នៅត្រង់ច្រាំងទន្លេស៊ីដូន មិនឲ្យឆ្លង ។
៤១ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃ និងកងទ័ព
របស់លោក ប្រទះនឹងពួកលេមិននៅក្នុងច្រកភ្នំ នៅខាងនាយទន្លេ
ស៊ីដូន ហើយបានចាប់ផ្ដើមវាយ ហើយសម្លាប់ពួកគេចោល ។
៤២ ហើយពួកលេមិនបានរត់គេចពីពួកគេទៀត សំដៅទៅដែនដី
ម៉ាន់ទី; ហើយពួកគេក៏ជួបប្រទះនឹងពលទ័ពរបស់ម៉ូរ៉ូណៃជាថ្មីទៀត ។
៤៣ ឥឡូវនេះ ក្នុងករណីនេះ ពួកលេមិនបានវាយតបតយ៉ាង
អស់ទំហឹង; មែនហើយ គ្មានពេលណាសោះ ដែលពួកលេមិន
ប្រយុទ្ធដោយអស់ពីកម្លាំង និងសេចក្ដីក្លាហានដ៏ខ្លាំងបែបនេះទេ
គ្មានទេ ទោះចាប់តាំងពីដើមដំបូងមកក៏ដោយ ។
៤៤ ហើយពួកគេត្រូវបានបំផុសគំនិត ដោយ[ក]ពួកសាសន៍ស៊ូរ៉ាំ
និងពួកសាសន៍អាម៉ាលេកៃ ដែលជាមេទ័ពឯក ហើយជាមេដឹកនាំ
របស់គេ និងដោយសេរ៉ាហិមណា ដែលជាមេទ័ពឯក ឬមេដឹកនាំ
ហើយជាមេបញ្ជាការរបស់គេ; មែនហើយ ពួកគេបានប្រយុទ្ធ
ដូចនាគរាជ ហើយពួកនីហ្វៃជាច្រើនត្រូវស្លាប់ ដោយស្នាដៃពួកគេ
មែនហើយ ព្រោះគេបានកាប់ជាពីរ នូវមួកការពារក្បាល ជាច្រើន
ហើយគេបានចាក់ធ្លុះអាវក្រោះជាច្រើនរបស់គេ ហើយគេបាន
កាត់ដៃគេដាច់ជាច្រើន; ម្ល៉ោះហើយ ពួកលេមិនបានកាប់សម្លាប់
ដោយកំហឹងដ៏ពុះពាររបស់គេ ។
៤៥ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកនីហ្វៃត្រូវបាន
លើកទឹកចិត្តដែរ ដោយហេតុមួយ ដ៏ប្រសើរលើសលែងទៅទៀត
ព្រោះគេមិនបាន[ក]ប្រយុទ្ធ ដើម្បីរាជាធិបតេយ្យ ឬ[ខ]ដើម្បីអំណាចទេ
ប៉ុន្តែគេបានប្រយុទ្ធ ដើម្បីផ្ទះសំបែងរបស់គេ និងសេរីភាពរបស់គេ
និងប្រពន្ធរបស់គេ និងកូនចៅរបស់គេ និងអ្វីៗទាំងអស់ ដែល
គេមាន មែនហើយ ដើម្បីពិធីថ្វាយបង្គំ និងសាសនាចក្ររបស់គេ ។
៤៦ ហើយពួកគេបានធ្វើនូវអ្វីៗ ដែលគេយល់ថា ជា[ក]កិច្ចការ
ដែលគេត្រូវធ្វើចំពោះព្រះរបស់គេ; ព្រោះព្រះអម្ចាស់[ខ] ទ្រង់មាន
ព្រះ បន្ទូលទៅកាន់គេ និងពួកអយ្យកោគេផងថា៖ ដរាបណាអ្នក
រាល់គ្នាពុំមានទោសនៃការបង្អាក់បង្អន់[គ]ចិត្តទីមួយ ឬទីពីរទេ នោះ
អ្នកនឹង ពុំត្រូវស្លាប់ ដោយដៃនៃពួកខ្មាំងសត្រូវរបស់អ្នកឡើយ ។
៤៧ ហើយមួយទៀត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ អ្នក
[ក]ត្រូវការពារគ្រួសាររបស់អ្នក គឺរហូតដល់ការខ្ចាយឈាម ។ ហេតុ
ដូច្នេះ ដោយសារហេតុកាណ៍នេះហើយ ទើបពួកនីហ្វៃបាន
តតាំងនឹងពួកលេមិន ដើម្បីការពារខ្លួនគេ និងគ្រួសាររបស់គេ
និងដែនដីរបស់គេ ប្រទេសរបស់គេ និងសិទ្ធិរបស់គេ និង
សាសនារបស់គេ ។
៤៨ ហើយហេតុការណ៍បានកើតឡើងថា កាលដែលទ័ពរបស់
ម៉ូរ៉ូណៃបានឃើញភាពសាហាវ និងកំហឹងរបស់ពួកលេមិន នោះគេ
ស្ទើរតែនឹងដកថយ ហើយរត់គេចពីពួកគេទៅ ។ ហើយម៉ូរ៉ូណៃ
ដោយបានដឹងបំណងរបស់ពួកគេ ក៏បានឲ្យមនុស្សទៅលើកទឹកចិត្ត
គេ ដោយយោបល់ទាំងនេះ — មែនហើយ នេះគឺជាយោបល់
អំពីដែនដីរបស់គេ ឥស្សរភាពរបស់គេ មែនហើយ សេរីភាព
របស់ពួកគេ ពីសេវកភាព ។
៤៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេវាយតបតនឹង
ពួកលេមិនវិញ ហើយគេបាន[ក]អំពាវនាវ ដោយសម្លេងតែមួយ
ដល់ព្រះអម្ចាស់ជាព្រះរបស់គេ សូមឥស្សរភាពរបស់ពួកគេ
និងសេរីភាពរបស់ពួកគេពីទាសភាព ។
៥០ ហើយពួកគេបានចាប់ផ្ដើម តទល់ប្រឆាំងនឹងពួកលេមិន
ដោយខ្លាំងក្លា; ហើយនៅក្នុងម៉ោងនោះដែលគេបានអំពាវនាវ
ដល់ព្រះ សូមសេរីភាពរបស់គេ នោះពួកលេមិនបានចាប់ផ្ដើម
រត់គេចចេញពីគេទៅ ហើយពួកវារត់ទៅដល់ទន្លេស៊ីដូន ។
៥១ ឥឡូវនេះ ពួកលេមិនមានចំនួនជាច្រើន មែនហើយ
ច្រើនជាងពួកនីហ្វៃពីរដងទៅទៀត; ទោះជាយ៉ាងណាក៏ដោយ
គង់តែពួក គេត្រូវរុញច្រានជាខ្លាំងដែរ រហូតដល់រួមមកជាក្រុម
មួយ នៅក្នុងច្រកភ្នំ នៅលើច្រាំងក្បែរទន្លេស៊ីដូន ។
៥២ ហេតុដូច្នេះហើយ ពលទ័ពរបស់ម៉ូរ៉ូណៃបានឡោមព័ទ្ធពួក

៣៨ ក អាលម៉ា ៤៤:៨–៩.
៤៤ ក អាលម៉ា ៤៣:៦.
៤៥ ក អាលម៉ា ៤៤:៥.
ខ ស.ប. ឥស្សរភាព.
៤៦ ក ស.ប. កាតព្វកិច្ច.
ខ អាលម៉ា ៤៨:១៤;
គ. និង ស. ៩៨:៣៣–៣៦.
គ ៣ នីហ្វៃ ៣:២១;
គ. និង ស. ៩៨:២៣–២៤.
៤៧ ក គ. និង ស. ១៣៤:១១.
៤៩ ក និក្ខ. ២:២៣–២៥;
ម៉ូសាយ ២៩:២០.

គេជុំជិត មែនហើយ ទាំងសងខាងទន្លេ ត្បិតមើលចុះ នៅទិស
ខាងកើត គឺទ័ពរបស់លីហៃ ។
៥៣ ហេតុដូច្នេះហើយ កាលដែលសេរ៉ាហិមណា បានឃើញ
ទ័ពរបស់លីហៃនៅខាងកើតទន្លេស៊ីដូន ហើយពលទ័ពរបស់ម៉ូរ៉ូណៃ
នៅខាងលិចទន្លេស៊ីដូន គឺគេត្រូវហ៊ុំព័ទ្ធជុំវិញដោយពួកនីហ្វៃ នោះ
ពួកគេក៏កើតសេចក្ដីតក់ស្លុតជាខ្លាំង ។
៥៤ ឥឡូវនេះ ម៉ូរ៉ូណៃ កាលលោកបានឃើញសេចក្ដីតក់ស្លុត
របស់ពួកគេ ក៏បានបញ្ជាទ័ពរបស់លោក ឲ្យឈប់កំចាយឈាម
ពួកគេ តទៅទៀត ៕

## ជំពូកទី ៤៤

*ម៉ូរ៉ូណៃបញ្ជាឲ្យពួកលេមិនចុះសេចក្ដីសញ្ញាសន្ដិភាព បើពុំនោះ សោតទេ នឹងត្រូវបំផ្លាញចោល — សេរ៉ាហិមណាបដិសេធ សេចក្ដីស្នើ ហើយចម្បាំងក៏បន្ដទៅទៀត — ពលទ័ពរបស់ ម៉ូរ៉ូណៃ វាយពួកលេមិនឲ្យបរាជ័យ ។ ប្រមាណជាឆ្នាំ ៧៤– ៧៣ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានឈប់ ហើយ
បានថយចេញមួយរយៈពីពួកគេ ។ ហើយម៉ូរ៉ូណៃនិយាយទៅកាន់
សេរ៉ាហិមណាថា៖ មើលចុះ សេរ៉ាហិមណា យើង[ក]មិនចង់ធ្វើជា
អ្នកចូលចិត្តកំចាយឈាមទេ។ អ្នកដឹងថា អ្នកនៅក្នុងកណ្ដាប់ដៃ
របស់យើងហើយ តែយើងមិនចង់សម្លាប់អ្នកទេ ។
២ មើលចុះ យើងមិនបានមកធ្វើចម្បាំងនឹងអ្នក ដើម្បីយើងអាច
កំចាយឈាមអ្នក ដើម្បីអំណាចនោះទេ; ហើយយើងក៏មិនចង់យក
អ្នកណាម្នាក់ទៅដាក់ក្នុងនឹមនៃសេវកភាពឡើយ ។ ប៉ុន្តែនេះ
គឺជាហេតុដែលនាំឲ្យអ្នករាល់គ្នា មកប្រឆាំងនឹងយើង; មែនហើយ
អ្នករាល់គ្នាខឹងនឹងយើង ដោយសារសាសនារបស់យើងទេតើ ។
៣ ប៉ុន្តែឥឡូវនេះ អ្នកឃើញថា ព្រះអម្ចាស់ទ្រង់គង់នៅជាមួយ
នឹងយើង; ហើយអ្នកឃើញថា ទ្រង់បានប្រគល់អ្នក មកក្នុង
កណ្ដាប់ដៃ យើងហើយ ។ ហើយឥឡូវនេះ ខ្ញុំចង់ឲ្យអ្នកយល់ថា
ការណ៍ដែលយើងបានមកយ៉ាងនេះ ក៏ដោយសារសាសនា
របស់យើង និងសេចក្ដី ជំនឿរបស់យើងនៅក្នុងព្រះគ្រីស្ទ ។
ហើយឥឡូវនេះ អ្នកឃើញថា អ្នកមិនអាចបំផ្លាញសេចក្ដីជំនឿ
របស់យើងនេះបានទេ ។
៤ ឥឡូវនេះ អ្នកឃើញថា នេះគឺជាសេចក្ដីជំនឿពិតដល់ព្រះ;
មែនហើយ អ្នកឃើញថា ព្រះទ្រង់នឹងទ្រទ្រង់ ហើយនឹង
ថែរក្សាយើងឲ្យ គង់វង់ ដរាបណាយើងមានចិត្តស្មោះត្រង់
ចំពោះទ្រង់ ចំពោះសេចក្ដីជំនឿរបស់យើង និងសាសនា
របស់យើង; ហើយព្រះអម្ចាស់ទ្រង់ នឹងពុំទុកឲ្យយើងត្រូវ
បំផ្លាញឡើយ លើកលែងតែយើងធ្លាក់ទៅក្នុងអំពើរំលង
ហើយបដិសេធសេចក្ដីជំនឿរបស់យើងប៉ុណ្ណោះ ។
៥ ហើយឥឡូវនេះ សេរ៉ាហិមណា ខ្ញុំបញ្ជាអ្នកថា ដោយនូវ
ព្រះនាមនៃព្រះ ដ៏ប្រកបដោយគ្រប់ទាំងព្រះចេស្ដានោះ ដែល
ទ្រង់បាន ចំរើនកម្លាំងដល់ដៃរបស់យើង ដើម្បីឲ្យយើងមាន
អំណាចលើអ្នក ដោយសេចក្ដីជំនឿរបស់យើង ដោយសាសនា
របស់យើង ដោយ [ក]ពិធីថ្វាយបង្គំ ដោយសាសនាចក្ររបស់យើង
ដោយការគាំទ្រដ៏ពិសិដ្ឋ អំពីសំណាក់ប្រពន្ធកូនយើង ដោយ
[ខ]ឥស្សរភាពដែលភ្ជាប់យើង ទៅនឹងដែនដី និងប្រទេសរបស់យើង;
មែនហើយ ព្រមទាំងដោយការរក្សា នូវព្រះបន្ទូលដ៏ពិសិដ្ឋនៃព្រះ
ដោយសារការណ៍ទាំងនោះ ហើយដែលយើងទាំងអស់គ្នា
មានសុភមង្គល ហើយដោយអ្វីៗទាំងអស់ ដែលមានតម្លៃបំផុត
ចំពោះយើង —
៦ មែនហើយ នេះពុំទាន់អស់នៅឡើយទេ; ខ្ញុំបញ្ជាអ្នក ដោយ
អស់ទាំងបំណងរបស់អ្នក សំរាប់ជីវិត ឲ្យអ្នកប្រគល់គ្រឿងសស្ត្រាវុធ
ពិជ័យសង្គ្រាមមកយើង ហើយយើងនឹងពុំកំចាយឈាមអ្នកទេ
តែយើងនឹងលើកលែងជីវិតឲ្យអ្នក បើសិនជាអ្នកចេញទៅ
ហើយឈប់ មកធ្វើសង្គ្រាមនឹងយើងទៀត ។
៧ ហើយឥឡូវនេះ បើសិនជាអ្នកមិនធ្វើយ៉ាងនេះទេ មើលចុះ
អ្នកនៅក្នុងកណ្ដាប់ដៃរបស់យើងហើយ ហើយខ្ញុំនឹងបញ្ជាទ័ព
របស់ខ្ញុំ ឲ្យវាយមកលើអ្នក ហើយធ្វើឲ្យអ្នកមានរបួសដល់ស្លាប់
ដើម្បីធ្វើឲ្យអ្នកវិនាសសូន្យអស់រលីង; ហើយពេលនោះ យើង
នឹងឃើញថា តើនរណានឹងមានអំណាចមកលើប្រជាជននេះ;
មែនហើយ យើងនឹងឃើញថា តើនរណានឹងត្រូវនាំឲ្យធ្លាក់ទៅ
ក្នុងសេវកភាព ។
៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
សេរ៉ាហិមណាបានឮពាក្យទាំងនេះហើយ នោះគាត់ក៏ចេញមក
ហើយ ប្រគល់ដាវរបស់គាត់ និងសាបរបស់គាត់ និងធ្នូរបស់
គាត់ដល់ដៃម៉ូរ៉ូណៃ ហើយបាននិយាយទៅលោកថា៖ មើលចុះ
នេះគឺជាគ្រឿង សស្ត្រាវុធពិជ័យសង្គ្រាមរបស់យើង; យើងនឹង
ប្រគល់ឲ្យអ្នករាល់គ្នា ប៉ុន្តែយើងមិនស៊ូទ្រាំធ្វើ[ក]កិច្ចសច្ចាដល់អ្នកទេ

៤៤ ១*ក* អាលម៉ា ៤៣:៤៥.
៥ *ក* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*ខ* ស.ប. ឥស្សរភាព.
៨ *ក* ស.ប. សម្បថ.

ព្រោះយើងដឹងថា យើងនឹងបំពានលើកិច្ចសច្ចានោះ ហើយកូនចៅយើងក៏ដូច្នោះដែរ; ប៉ុន្តែ ចូរអ្នកយកគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងចុះ ហើយទុកឲ្យយើងចូលទៅក្នុងទីរហោស្ថានវិញ; បើពុំនោះសោតទេ យើងនឹងទុកដាវរបស់យើង ហើយយើងនឹងវិនាស ឬក៏យើងឈ្នះ ។

៩ មើលចុះ យើងមិននៅក្នុងសេចក្ដីជំនឿអ្នកទេ; យើងមិនជឿថា គឺព្រះដែលបានប្រគល់យើង ទៅក្នុងកណ្ដាប់ដៃអ្នកនោះទេ; តែយើងជឿថា គឺជាកលល្បិចរបស់អ្នកវិញទេតើ ដែលបានថែរក្សាអ្នកឲ្យរួចផុតពីដាវទាំងឡាយរបស់យើង ។ មើលចុះ [ក]គឺអាវក្រោះ ទាំងឡាយរបស់អ្នក និងខែលទាំងឡាយរបស់អ្នក ដែលបានថែរក្សាអ្នកឲ្យគង់នៅ ។

១០ ហើយឥឡូវនេះ កាលសេរ៉ាហិមណាបានបញ្ចប់នូវការនិយាយពាក្យទាំងនេះហើយ នោះម៉ូរ៉ូណៃបានឲ្យដាវ និងគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមទាំងឡាយ ដែលលោកបានទទួល ទៅសេរ៉ាហិមណាវិញ ដោយនិយាយថា៖ មើលចុះ យើងនឹងបញ្ចប់ ចំបាំងនេះ ។

១១ ឥឡូវនេះ ខ្ញុំមិនអាចដកយកវិញនូវពាក្យទាំងឡាយ ដែលខ្ញុំបាននិយាយនោះទេ ហេតុដូច្នេះហើយ ប្រាកដដូចជាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ នោះអ្នករាល់គ្នាមិនអាចចេញទៅបានឡើយ លើកលែងតែអ្នកចេញទៅដោយពាក្យសច្ចាថា អ្នកនឹងមិន ត្រឡប់មកធ្វើចម្បាំងនឹងយើងទៀតទេ ។ ឥឡូវនេះ អ្នកនៅក្នុងកណ្ដាប់ដៃយើង យើងនឹងកំចាយឈាមអ្នកទៅលើដី ឬក៏អ្នកត្រូវ ធ្វើតាមលក្ខខ័ណ្ឌទាំងឡាយដែលខ្ញុំបានស្នើ ។

១២ ហើយឥឡូវនេះ កាលម៉ូរ៉ូណៃបាននិយាយពាក្យទាំងនេះហើយ នោះសេរ៉ាហិមណាបានយកដាវរបស់គាត់វិញ ហើយគាត់ខឹង នឹងម៉ូរ៉ូណៃ ហើយគាត់បានស្ទុះមកប្រុងនឹងសម្លាប់ម៉ូរ៉ូណៃ; ប៉ុន្តែពេលគាត់យាដាវឡើង មើលចុះ ទាហានម្នាក់របស់ម៉ូរ៉ូណៃបានវាយ ធ្លាក់ដាវនោះទៅដល់ដី ហើយបាក់ចេញពីដង; ហើយទាហាននោះក៏បានកាប់សេរ៉ាហិមណា ដាច់លលាក្បាលមួយដុំធ្លាក់ទៅលើដី ។ ហើយសេរ៉ាហិមណាបានថយចេញពីពួកគេ ចូលទៅកណ្ដាលទាហានរបស់ខ្លួនវិញ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ទាហានដែលបានឈរនៅក្បែរនោះ ដែលបានកាប់ដាច់រលាក្បាលរបស់សេរ៉ាហិមណា នោះបានចាប់សក់រើសយកលលាក្បាលនោះឡើងពីដី ហើយដោតវានៅខាងចុងដាវរបស់ខ្លួន ហើយលើកបង្ហាញពួកគេ ដោយ និយាយសម្លេងខ្លាំងទៅកាន់ពួកគេថា៖

១៤ ដូចជាលលាក្បាលនេះ ដែលជាលលាក្បាលរបស់មេបញ្ជាការអ្នករាល់គ្នា បានធ្លាក់ទៅដីយ៉ាងណា នោះអ្នករាល់គ្នាក៏នឹងដួលចុះ ទៅលើដីយ៉ាងនោះដែរ លើកលែងតែអ្នកប្រគល់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់អ្នក ហើយចេញទៅដោយធ្វើសេចក្ដីសញ្ញា សន្តិភាព ។

១៥ ឥឡូវនេះ មានមនុស្សជាច្រើន កាលគេបានឮពាក្យទាំងនេះ ហើយឃើញលលាក្បាលដែលនៅចុងដាវ ក៏កើតសេចក្ដីភិតភ័យ; ហើយមានមនុស្សជាច្រើន បានចេញមក ហើយបានបោះគ្រឿងសស្ត្រាវុធ[ក]ពិជ័យសង្គ្រាមរបស់គេ នៅក្បែរជើងម៉ូរ៉ូណៃ ហើយបានចូល ក្នុងសេចក្ដីសញ្ញាសន្តិភាពមួយ ។ ហើយអស់អ្នកណាដែលបានចូលសេចក្ដីសញ្ញាមួយ នោះពួកគេត្រូវបានអនុញ្ញាតឲ្យចេញទៅក្នុង ទីរហោស្ថាន ។

១៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា សេរ៉ាហិមណាខឹងជាខ្លាំង ហើយគាត់បានចាក់រុកពួកទាហានរបស់គាត់ ដែលនៅ សល់ទាំងប៉ុន្មានឲ្យខឹង ដើម្បីតតាំងឲ្យខ្លាំងជាងមុនប្រឆាំងនឹងពួកនីហ្វៃ ។

១៧ ហើយឥឡូវនេះ ម៉ូរ៉ូណៃខឹង ដោយព្រោះការរឹងក្បាលរបស់ពួកសាសន៍លេមិន; ហេតុដូច្នេះហើយ លោកបានបញ្ជាឲ្យទ័ព របស់លោកវាយសម្រុកទៅលើពួកគេ ហើយសម្លាប់ពួកគេចោល ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចាប់ផ្ដើម សម្លាប់ពួកនោះចោល; មែនហើយ ឯពួកលេមិនបានតតាំងដោយដាវទាំងឡាយរបស់គេ និងដោយសមត្ថភាពរបស់គេ ។

១៨ ប៉ុន្តែមើលចុះ ស្បែកទទេ និងក្បាលទទេរបស់គេ ត្រូវរងមុខដាវដ៏មុតរបស់ពួកនីហ្វៃ; មែនហើយ មើលចុះ ពួកគេត្រូវចាក់ទម្លុះ ហើយត្រូវកាប់ មែនហើយ ហើយបានដួលចុះយ៉ាងឆាប់រហ័ស ចំពោះដាវទាំងឡាយរបស់ពួកនីហ្វៃ; ហើយពួកគេត្រូវបានចាប់ផ្ដើម បោសឲ្យរាបចុះ ដូចពាក្យរបស់ទាហានម្នាក់របស់ម៉ូរ៉ូណៃបានព្យាករមក ។

១៩ ឥឡូវនេះ សេរ៉ាហិមណា កាលគាត់បានឃើញថា ពួកគេជិតត្រូវបំផ្លាញចង់អស់ ក៏ស្រែកយ៉ាងខ្លាំងទៅកាន់ម៉ូរ៉ូណៃ ដោយ សន្យាថា គាត់នឹងធ្វើសេចក្ដីសញ្ញា ព្រមទាំងទ័ពរបស់គាត់ក៏ដូច្នោះដែរ បើសិនជាគេលើកលែងជីវិតឲ្យពួកគេ ដែល

៩ ក អាលម៉ា ៤៣:៣៨.

១៥ ក ១ នីហ្វៃ ៤:៣៧; អាលម៉ា ៥០:៣៦.

នៅសល់ទាំង ប៉ុន្មានថា ពួកគេនឹងពុំមកធ្វើសង្គ្រាមនឹងគេទៀតឡើយ ។

២០ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃបានបញ្ជាឲ្យឈប់ធ្វើការកាប់សម្លាប់ នៅក្នុងចំណោមពួកមនុស្សទាំងនេះ ។ ហើយលោកបានយកគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមពីពួកលេមិន; ហើយបន្ទាប់ពីពួកគេបានធ្វើសេចក្ដីសញ្ញាសន្តិភាពជាមួយនឹងលោកហើយ នោះពួកគេត្រូវបានទុកឲ្យចេញទៅក្នុងទីរហោស្ថាន ។

២១ ឥឡូវនេះ ចំនួនពួកគេដែលស្លាប់ នោះពុំបានរាប់ឡើយ ដោយព្រោះមានចំនួននោះច្រើនពេក; មែនហើយ ពួកគេដែលស្លាប់ មានចំនួនច្រើនលើសលប់ ទាំងខាងពួកនីហ្វៃ និងខាងពួកលេមិនដែរ ។

២២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានបោះអ្នកស្លាប់ ចុះក្នុងទឹកទន្លេស៊ីដូន ហើយសាកសពទាំងនោះអណ្ដែតទៅ ហើយត្រូវកប់ទៅក្នុងទីជំរៅនៃសមុទ្រ ។

២៣ ហើយពលទ័ពសាសន៍នីហ្វៃ ឬរបស់ម៉ូរ៉ូណៃក៏ត្រឡប់ទៅផ្ទះរបស់គេ និងដែនដីរបស់គេវិញ ។

២៤ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់ប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រមទៅលើប្រជាជននីហ្វៃ ។ ម្ល៉ោះហើយ ក៏ចប់បញ្ជីរបស់អាលម៉ា ដែលបានសរសេរទុកនៅលើផ្ទាំងនីហ្វៃ ៕

---

ដំណើររឿងអំពីប្រជាជននីហ្វៃ និងសង្គ្រាមទាំងឡាយ និងការបែកបាក់គ្នារបស់គេ នៅក្នុងជំនាន់ហេលេមិន ស្របតាមបញ្ជីរបស់ហេលេមិន ដែលលោកបានកត់ទុកនៅក្នុងជំនាន់លោក ។

*មានរួមពីជំពូកទី ៤៥ ដល់ ៦២*

## ជំពូកទី ៤៥

*ហេលេមិនជឿតាមពាក្យរបស់អាលម៉ា — អាលម៉ាព្យាករអំពីការបំផ្លិចបំផ្លាញនៃពួកសាសន៍នីហ្វៃ — លោកប្រទានពរ ហើយដាក់ប ណ្ដាសាដល់ដែនដី — អាលម៉ាប្រហែលជាត្រូវព្រះវិញ្ញាណ នាំយកទៅលើ គឺដូចលោកម៉ូសេ — ការបែកបាក់គ្នារីកធំឡើងនៅក្នុង សាសនាចក្រ ។ ប្រមាណជាឆ្នាំ ៧៣ ម.គ.ស. ។*

មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ប្រជាជននីហ្វៃបានអររីករាយជាខ្លាំង ពីព្រោះព្រះអម្ចាស់ទ្រង់បានដោះលែងពួកគេ ឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់គេទៀត; ហេតុដូច្នេះហើយ ពួកគេបានថ្លែងអំណរគុណដល់ព្រះអម្ចាស់ ជាព្រះរបស់គេ; មែនហើយ ពួកគេបានតមអាហារជាច្រើន និងអធិស្ឋានជាច្រើន ហើយគេបានថ្វាយបង្គំដល់ព្រះ ដោយសេចក្ដីអំណរដ៏ធំលើសលប់ ។

២ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីដប់ប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នោះអាលម៉ាបាន មករកហេលេមិន ជាកូនប្រុសរបស់លោក ហើយនិយាយទៅគាត់ថា៖ តើកូនជឿនូវពាក្យដែលឪពុកបាននិយាយនឹងកូនអំពីបញ្ជី ទាំងនោះ ដែលបានកត់ទុកឬទេ?

៣ ហើយហេលេមិនបានតបទៅលោកថា៖ បាទ ខ្ញុំជឿ ។

៤ ហើយអាលម៉ាបាននិយាយទៀតថា៖ តើកូនជឿដល់ព្រះយេស៊ូវគ្រីស្ទ ដែលនឹងយាងមកឬទេ?

៥ ហើយគាត់បានឆ្លើយថា៖ បាទ ខ្ញុំជឿនូវពាក្យទាំងអស់ ដែលឪពុកមានប្រសាសន៍ ។

៦ ហើយអាលម៉ាបាននិយាយទៅកូនទៀតថា៖ តើកូននឹងរក្សាបញ្ញត្តិរបស់ឪពុកឬទេ?

៧ ហើយគាត់បានឆ្លើយថា៖ បាទ ខ្ញុំនឹងរក្សាបញ្ញត្តិទាំងឡាយរបស់ឪពុកឲ្យអស់ពីដួងចិត្ត ។

៨ ខណៈនោះ អាលម៉ាបាននិយាយទៅកាន់កូនថា៖ កូនមានពរហើយ ហើយសូមឲ្យព្រះអម្ចាស់ទ្រង់ ធ្វើឲ្យកូនបានចំរើនឡើងនៅ លើដែនដីនេះចុះ ។

៩ ប៉ុន្តែមើលចុះ ឪពុកមានការណ៍ខ្លះ ចង់ព្យាករប្រាប់កូន; ប៉ុន្តែអ្វីដែលឪពុកព្យាករប្រាប់កូន នោះកូនមិនត្រូវប្រាប់ឲ្យនរណាដឹងឲ្យសោះ; មែនហើយ អ្វីដែលឪពុកព្យាករប្រាប់ នោះកូនមិនត្រូវបញ្ចេញឲ្យគេដឹងឡើយ គឺរហូតដល់ពេលការព្យាករណ៍នោះបានបំពេញ; ហេតុដូច្នេះហើយ ចូរកូនកត់នូវពាក្យទាំងឡាយដែលឪពុកនឹងនិយាយចុះ ។

១០ ហើយនេះគឺជាពាក្យទាំងនោះ៖ មើលចុះ ដោយវិញ្ញាណនៃវិវរណៈ ដែលនៅក្នុងខ្លួនឪពុក ឪពុកយល់ឃើញថា ប្រជាជននេះគឺពួកសាសន៍នីហ្វៃ ក្រោយរយៈពេលបួនរយឆ្នាំ ចាប់តាំងពីពេល

---

១៩ *ក* អាលម៉ា ៤៧:៦.
២០ *ក* អាលម៉ា ៦២:១៦–១៧.
**៤៥** ១ *ក* ស.ប. តម, តំណម.
២ *ក* អាលម៉ា ៣៧:១–៥; ៥០:៣៨.
៦ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ; ការគោរព, ដែលគោរព, គោរព.
៨ *ក* ១ នីហ្វៃ ៤:១៤; អាលម៉ា ៤៨:១៥–១៦, ២៥.
៩ *ក* ស.ប. ការព្យាករណ៍, ព្យាករ.
១០ *ក* ១ នីហ្វៃ ១២:១០–១៥; ហេលេ. ១៣:៩; មរមន ៨:៦–៧.

ដែលព្រះយេស៊ូវគ្រីស្ទនឹងសម្ដែងរូបអង្គទ្រង់ដល់ពួកគេ នោះពួកគេ នឹង[ខ]ចុះអន់ថយក្នុងការឥតជំនឿ ។

១១ មែនហើយ ហើយនៅពេលនោះ ពួកគេនឹងឃើញសង្គ្រាមទាំងឡាយ និងជម្ងឺអាសន្នរោគទាំងឡាយ មែនហើយ អំណត់អត់ និងការខ្ចាយឈាម គឺរហូតដល់ប្រជាជននីហ្វៃត្រូវ[ក]សាបសូន្យអស់ទៅ ។

១២ មែនហើយ ការណ៍នេះក៏ដោយសារពួកគេចុះអន់ថយក្នុងការឥតជំនឿ ហើយធ្លាក់ទៅក្នុងកិច្ចការទាំងឡាយនៃសេចក្ដីងងឹត និង[ក]អំពើអាសអាភាស និងគ្រប់អំពើទុច្ចរិតទាំងអស់; មែនហើយ ឪពុកប្រាប់កូនថា ដោយមកពីពួកគេ ធ្វើអំពើបាបទាស់នឹងពន្លឺ និងការ ចេះដឹងដ៏មហិមា មែនហើយ ឪពុកប្រាប់កូនថា ចាប់តាំងពីថ្ងៃនោះមក គឺតំណទីបួននឹងមិនទាន់ស្លាប់ទៅផង នោះអំពើទុច្ចរិតដ៏មហិមា នេះនឹងកើតឡើង ។

១៣ ហើយកាលណាថ្ងៃដ៏មហិមានោះមកដល់ មើលចុះ ពេលនោះមកដល់យ៉ាងឆាប់រហ័ស ដែលអស់អ្នកណាការស់នៅសព្វថ្ងៃនេះ ឬពូជពង្សនៃអស់អ្នកណាដែលត្រូវបានរាប់ក្នុងចំណោមប្រជាជននីហ្វៃនៅពេលឥឡូវនេះ នឹងមិនត្រូវបានរាប់ក្នុងចំណោមប្រជាជន នីហ្វៃ[ក]ទៀតទេ ។

១៤ ប៉ុន្តែ អស់អ្នកណាដែលនៅសល់ ហើយដែលមិនត្រូវបំផ្លាញបង់ នៅក្នុងថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចនោះ នឹងត្រូវ[ក]បានរាប់ក្នុងចំ ណោមពួកសាសន៍លេមិន ហើយនឹងក្លាយទៅដូចជាពួកនោះទាំងអស់គ្នា លើកលែងតែមួយចំនួនតូច ដែលនឹងត្រូវបានហៅថា ពួកសិស្សនៃព្រះអម្ចាស់ប៉ុណ្ណោះ; ហើយឯពួកគេនេះ ពួកសាសន៍លេមិននឹង[ខ]ដេញសម្លាប់ រហូតដល់ពួកគេនឹងត្រូវសាបសូន្យអស់ទៅ ។ ហើយឥឡូវនេះ ដោយព្រោះសេចក្ដីទុច្ចរិត នោះការព្យាករណ៍នេះនឹងត្រូវបានបំពេញ ។

១៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីអាលម៉ាបាននិយាយប្រាប់ពាក្យទាំងនេះទៅហេលេមិនចប់ហើយ នោះ លោកបានប្រទានពរឲ្យហេលេមិន ព្រមទាំងកូនប្រុសឯទៀតរបស់លោកផង; ហើយលោកក៏បានប្រទានពរដល់ផែនដីដើម្បីមនុស្ស [ក]សុចរិត ។

១៦ ហើយលោកបាននិយាយថា៖ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលដូច្នេះថា — [ក]ដែនដីនឹងត្រូវបណ្ដាសា មែនហើយ គឺដែនដីនេះ ដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ដែលធ្វើអំពើទុច្ចរិត ដល់សេចក្ដីបំផ្លិចបំផ្លាញ កាលណាពួកគេទុំស៊ុស; ហើយដូចជាឪពុកបាននិយាយមកយ៉ាងណា នោះនឹងកើតឡើងយ៉ាងនោះដែរ; ព្រោះនេះគឺជាការដាក់ បណ្ដាសា និង[ខ]ការប្រទានពររបស់ព្រះមកលើដែនដីនេះ ព្រោះព្រះអម្ចាស់ទ្រង់មិនអាចទតមើលអំពើបាប [គ]សូម្បីតែបន្តិចបន្តួចក៏មិន បានឡើយ ។

១៧ ហើយឥឡូវនេះ កាលអាលម៉ាបានពោលពាក្យទាំងនេះហើយ នោះលោកក៏ប្រទានពរដល់[ក]សាសនាចក្រ មែនហើយ ដល់អស់ អ្នកណាដែលឈរយ៉ាងរឹងប៉ឹង នៅក្នុងសេចក្ដីជំនឿ ចាប់ពីពេលនោះតទៅ ។

១៨ ហើយកាលអាលម៉ាបានធ្វើយ៉ាងនេះហើយ នោះលោកបានធ្វើដំណើរចេញពីដែនដីសារ៉ាហិមឡា ហាក់ដូចជាចូលទៅក្នុងដែនដីមេលេក ។ ហើយហេតុការណ៍បានកើតឡើងថា គ្មានអ្នកណាឮដំណឹងអ្វី ពីលោកទៀតឡើយ; ឯការស្លាប់ ឬការបញ្ចុះសព របស់លោកក៏យើងពុំដឹងដែរ ។

១៩ មើលចុះ យើងដឹងយ៉ាងនេះថា លោកគឺជាមនុស្សសុចរិតម្នាក់; ហើយមានពាក្យពោលពេញតាមសាសនាចក្រថា លោកត្រូវ បានព្រះវិញ្ញាណនាំយកទៅ ឬត្រូវបាន[ក]បញ្ចុះដោយព្រះហស្តនៃព្រះអម្ចាស់ គឺដូចជាលោកម៉ូសេដែរ; ប៉ុន្តែមើលចុះ បទគម្ពីរទាំងឡាយ បានចែងថា ព្រះអម្ចាស់ទ្រង់បានយកលោកម៉ូសេទៅឯព្រះអង្គ; ហើយយើងសន្និដ្ឋានថា ទ្រង់ក៏បានទទួលយកអាលម៉ា នៅក្នុងវិញ្ញាណ ទៅឯព្រះអង្គដែរ; ហេតុដូច្នេះ ដោយហេតុនេះហើយ យើងពុំដឹងអ្វីទាំងអស់ អំពីការស្លាប់ និងការបញ្ចុះសពរបស់លោកឡើយ ។

២០ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើង គឺនៅដើមឆ្នាំទីដប់ប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នោះហេលេមិនបានចេញទៅក្នុងចំណោមប្រជាជន ដើម្បីប្រកាសប្រាប់ព្រះបន្ទូលដល់ពួកគេ ។

១០ *ខ* ស.ប. សេចក្ដីក្បត់សាសនា; ការឥតជំនឿ.
១១ *ក* យ៉ារ៉ុម ១:១០; មរមន ៨:២–៣, ៦–៧.
១២ *ក* ស.ប. សំរេកស្រើប.
១៣ *ក* ហេលេ. ៣:១៦.
១៤ *ក* មរ៉ូណៃ ៩:២៤.
*ខ* មរ៉ូណៃ ១:១–៣.
១៥ *ក* អាលម៉ា ៤៦:១០; ៦២:៤០.
១៦ *ក* ២ នីហ្វៃ ១:៧; អាលម៉ា ៣៧:៣១; អេធើរ ២:៨–១២.
*ខ* គ. និង ស. ១៣០:២១.
*គ* គ. និង ស. ១:៣១.
១៧ *ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
១៩ *ក* ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.

២១ គឺត្បិតមើលចុះ ដោយព្រោះសង្គ្រាមទាំងឡាយរបស់គេជាមួយនឹងពួកសាសន៍លេមិន ហើយការបែកបាក់គ្នាតូចៗជាច្រើន និងការបះបោរទាំងឡាយ ដែលបានកើតឡើង [ក]នៅក្នុងចំណោមប្រជាជន គឺវាក្លាយទៅជាការចាំបាច់ថា ព្រះបន្ទូលនៃព្រះត្រូវតែបាន ប្រកាសនៅក្នុងចំណោមពួកគេ មែនហើយ គឺរបៀបចាត់ចែងមួយត្រូវតែធ្វើឡើងទូទៅទាំងសាសនាចក្រ ។

២២ ហេតុដូច្នេះហើយ ហេលេមិន និងបងប្អូនលោក បានចេញទៅតាំងសាសនាចក្រជាថ្មី នៅអស់ទាំងដែនដី មែនហើយ នៅគ្រប់ ទីក្រុងទូទៅអស់ទាំងដែនដី ដែលជាកម្មសិទ្ធរបស់ប្រជាជននីហ្វៃ ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានតែងតាំងពួកសង្ឃ និងពួកគ្រូទូទៅអស់ទាំងដែនដី នៅលើគ្រប់ទាំងសាសនាចក្រ ។

២៣ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីហេលេមិន និងបងប្អូនលោកបានតែងតាំងពួកសង្ឃ និងពួកគ្រូឲ្យនៅ លើសាសនាចក្ររួចហើយ ក៏កើតមាន[ក]ការបែកបាក់គ្នាមួយ នៅក្នុងចំណោមពួកគេ ហើយពួកគេមិនស្ដាប់បង្គាប់តាមពាក្យពេចន៍របស់ ហេលេមិន និងបងប្អូនលោកឡើយ ។

២៤ តែពួកគេបានទៅជាឆ្មើងឆ្មៃទៅវិញ ដោយលើកខ្លួន[ខ]ឡើងក្នុងចិត្តរបស់គេ ដោយព្រោះ[ក]ទ្រព្យដ៏ច្រើនលើសលប់របស់គេ; ហេតុដូច្នេះហើយ ពួកគេបានទៅជាអ្នកមាន នៅចំពោះភ្នែករបស់គេផ្ទាល់ ហើយពុំស្ដាប់បង្គាប់តាមពាក្យពេចន៍របស់អ្នកទាំងនោះ ដើម្បីដើរដោយត្រង់នៅចំពោះព្រះឡើយ ៕

## ជំពូកទី ៤៦

*អាម៉ាលិកាយប្រើឧបាយកល ដើម្បីធ្វើជាស្ដេច — មរ៉ូណៃលើកទង់ឥស្សរភាព — លោកប្រមូលប្រជាជន ឲ្យការពារសាសនារបស់ខ្លួន — ពួកអ្នកជឿពិតត្រូវបានហៅថា ពួកគ្រីស្ទាន — ពួកសំណល់នៃយ៉ូសែបនឹងត្រូវបានរក្សាទុក — អាម៉ាលិកាយ និងពួកអ្នកដែលបែក ចេញ រត់ទៅដែនដីនីហ្វៃ — ពួកអ្នកដែលមិនគាំទ្រឧត្ដមគតិនៃសេរីភាព ត្រូវគេយកទៅប្រហារជីវិតចោល ។ ប្រមាណជាឆ្នាំ ៧៣–៧២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា មនុស្សជាច្រើនដែលមិនព្រម ស្ដាប់តាមពាក្យសំដីរបស់ហេលេមិន និងបងប្អូនលោក បានប្រមូលគ្នា មកទាស់នឹងបងប្អូនខ្លួន ។

២ ហើយឥឡូវនេះ មើលចុះ ពួកគេខឹងហួសប្រមាណ ដរាបដល់ពួកគេបានប្ដេជ្ញាចិត្តថា នឹងសម្លាប់ពួកនោះចោល ។

៣ ឥឡូវនេះ មេដឹកនាំរបស់ពួកអ្នក ដែលខឹងនឹងបងប្អូនខ្លួននោះ គឺជាបុរសម្នាក់ ដែលមានមាឌធំ ហើយមានកម្លាំងខ្លាំង; ហើយ ឈ្មោះគាត់គឺ អាម៉ាលិកាយ ។

៤ ហើយអាម៉ាលិកាយចង់ធ្វើជាស្ដេច; ឯពួកអ្នកដែលខឹងទាំងនោះ ក៏ចង់ឲ្យអាម៉ាលិកាយធ្វើជាស្ដេច[ក]របស់ខ្លួនដែរ; ហើយពួកគេភាគ ច្រើន គឺជាពួកចៅក្រមថ្នាក់ទាបនៅលើដែនដី ហើយពួកគេស្វែងរកអំណាច ។

៥ ហើយពួកគេត្រូវបានដឹកនាំ ដោយការបញ្ជោររបស់អាម៉ាលិកាយថា បើសិនជាពួកគេគាំទ្រវា ហើយលើកវាធ្វើជាស្ដេចរបស់ពួកគេ នោះវានឹងឲ្យពួកគេធ្វើជាអ្នកត្រួតត្រាលើបណ្ដាជន ។

៦ ម្ល៉ោះហើយ ពួកគេត្រូវអាម៉ាលិកាយ នាំឲ្យមានការបែកបាក់គ្នា ទោះជាមានការប្រៀនប្រដៅរបស់ហេលេមិន និងបងប្អូនលោក ក៏ដោយ មែនហើយ ទោះជាមានការថែទាំដ៏ខ្លាំងជាអតិបរមារបស់គេ ទៅលើសាសនាចក្រ ព្រោះពួកគេ គឺជាពួកសង្ឃជាន់ខ្ពស់ នៅក្នុងសាសនាចក្រ ។

៧ ហើយមានមនុស្សជាច្រើននៅក្នុងសាសនាចក្រ ដែលជឿតាមពាក្យបញ្ជោរទាំងឡាយរបស់អាម៉ាលិកាយ ហេតុដូច្នេះហើយ បានជាពួកគេបែកចេញ ព្រមទាំងចេញពីសាសនាចក្រ; ម្ល៉ោះហើយ ស្ថានការណ៍របស់ប្រជាជននីហ្វៃមានភាពមិននឹងនរ ហើយប្រកប ដោយគ្រោះថ្នាក់ជាអតិបរមា ទោះបីពួកគេមាន[ក]ជ័យជំនះដ៏ធំ ទៅលើពួកសាសន៍លេមិន និងការអររីករាយដ៏ខ្លាំងរបស់គេ ដែលត្រូវបាន ដោះលែងដោយព្រះហស្តនៃព្រះអម្ចាស់ក្ដី ។

៨ ម្ល៉ោះហើយ យើងឃើញថា កូនចៅមនុស្ស[ក]ឆាប់ភ្លេចព្រះអម្ចាស់ ជាព្រះរបស់គេយ៉ាងណា មែនហើយ គេឆាប់ធ្វើអំពើទុច្ចរិតយ៉ាង ណា ហើយត្រូវបានដឹកនាំដោយអ្នកអាក្រក់ ។

៩ មែនហើយ យើងក៏ឃើញដែរ នូវ[ក]អំពើទុច្ចរិតដ៏ធំ ដែលមនុស្សទុច្ចរិតម្នាក់ អាចធ្វើឡើងនៅក្នុងចំណោមកូនចៅមនុស្ស ។

១០ មែនហើយ យើងឃើញថា អាម៉ាលិកាយ ដោយមកពីវា

២១ *ក* អាលម៉ា ៣១:៥.
២៣ *ក* ៣ នីហ្វៃ ១១:២៨–២៩.
២៤ *ក* ស.ប. ទ្រព្យសម្បត្តិ.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
៤៦ ៤ *ក* ម៉ូសាយ ២៩:១១, ២៨–២៩.
៧ *ក* អាលម៉ា ៤៤:១៩–២០.
៨ *ក* ហេលេ. ១២:២, ៤–៥.
៩ *ក* ម៉ូសាយ ២៩:១៧–១៨.

ជាមនុស្សមានកលល្បិច ហើយជាមនុស្ស ដែលមានពាក្យ
បញ្ចោរច្រើន ទើបវានាំចិត្តមនុស្សជាច្រើន ឲ្យធ្វើអំពើទុច្ចរិត;
មែនហើយ ឲ្យស្វែងរកបំផ្លាញសាសនាចក្រនៃព្រះចោល
ហើយបំផ្លាញមូលដ្ឋាននៃ ឥស្សរភាព ដែលព្រះទ្រង់បាន
ប្រទានឲ្យពួកគេ ឬព្រះពរដែលទ្រង់បានប្រទានលើផ្ទៃដែនដីនេះ
ដោយយល់ដល់ពួកសុចរិត ។

១១ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ម៉ូរ៉ូណៃ ជាមេបញ្ជាការនៃពលទ័ពសាសន៍នីហ្វៃ បានឮអំពីការ
បែកបាក់ ទាំងនេះ នោះលោកក៏ខឹងនឹងអាម៉ាលិកាយ ។

១២ ហើយហេតុការណ៍បានកើតឡើងថា លោកបានហែកអាវ
របស់លោក; ហើយលោកបានយកក្រណាត់អាវមួយជាយ ហើយ
សរសេរនៅលើនោះថា — នៅក្នុងការចងចាំដល់ព្រះរបស់យើង
សាសនា និងសេរីភាពរបស់យើង និងសេចក្ដីសុខសាន្ត
របស់យើង ភរិយារបស់យើង និងកូនចៅរបស់យើង —
ហើយលោកបានចងវានៅចុងថ្នោលមួយ ។

១៣ ហើយលោកបានពាក់មួករបស់លោក និងរបាំងទ្រូង
របស់លោក និងខែលរបស់លោក ហើយក្រវាត់អាវក្រោះ
របស់លោក ជុំវិញចង្កេះ; ហើយលោកបានយកថ្នោលនេះ ដែល
នៅខាងចុងមានចងក្រណាត់អាវរបស់លោក (ហើយលោកបាន
ហៅថា ទង់ឥស្សរភាព) ហើយលោកបានក្រាបដល់ដី
ហើយលោកបានអធិស្ឋានជាខ្លាំង ដល់ព្រះរបស់លោក សូមព្រះ
ពរនៃឥស្សរភាព ឲ្យបានមកដល់បងប្អូនលោក ដរាបណានៅសល់
ពួកគ្រីស្ទានមួយក្រុម ដើម្បីយកដែនដីនេះ —

១៤ ព្រោះឯអស់ទាំងអ្នកជឿពិតទៅលើព្រះគ្រីស្ទ ដែលនៅ
ក្នុងសាសនាចក្រនៃព្រះ ត្រូវបានហៅដោយពួកអ្នក ដែលពុំនៅ
ក្នុង សាសនាចក្រដូច្នេះឯង ។

១៥ ហើយពួកអ្នកដែលនៅក្នុងសាសនាចក្រ មានចិត្តស្មោះត្រង់;
មែនហើយ អស់អ្នកណាដែលជាអ្នកជឿពិតទៅលើព្រះគ្រីស្ទ គេ
បានលើកយកដាក់លើខ្លួនដោយរីករាយ នូវព្រះនាមនៃព្រះគ្រីស្ទ
ឬពួកគ្រីស្ទាន ដូចដែលគេត្រូវបានហៅ ដោយសារជំនឿ
របស់គេ ទៅលើព្រះគ្រីស្ទ ដែលនឹងយាងមក ។

១៦ ហេតុដូច្នេះហើយ នៅក្នុងពេលនេះ ម៉ូរ៉ូណៃបាន
អធិស្ឋានសូមឲ្យឧត្តមគតិនៃពួកគ្រីស្ទាន និងសេរីភាពនៃដែនដីនេះ
អាចបានគាំទ្រ ។

១៧ ហើយហេតុការណ៍បានកើតឡើងថា កាលលោកបាន
ទម្លាយដួងព្រលឹងរបស់លោកថ្វាយដល់ព្រះ លោកបាន
រាប់ឈ្មោះអស់ ទាំងដែនដី ដែលនៅខាងត្បូង
ដែនដីចោលស្ងាត់ មែនហើយ សរុបសេចក្ដីមក គឺដែនដី
ទាំងអស់ ទាំងនៅខាងជើង និងខាងត្បូង — ជាដែនដី
ជំរើស និងដែនដីនៃឥស្សរភាព ។

១៨ ហើយលោកបានពោលថា៖ ប្រាកដណាស់ ព្រះទ្រង់នឹង
ពុំទុកឲ្យយើង ត្រូវគេមើលងាយ ដោយសារយើង
យកដាក់លើខ្លួន នូវព្រះ នាមនៃព្រះគ្រីស្ទ នឹងត្រូវគេជាន់ឈ្លី
ហើយបំផ្លាញចោលឡើយ លើកលែងតែយើងនាំយកការណ៍
នោះមកលើខ្លួន ដោយអំពើរំលងទាំង ឡាយរបស់យើងផ្ទាល់ ។

១៩ ហើយកាលម៉ូរ៉ូណៃបាននិយាយនូវពាក្យទាំងនេះចប់ហើយ
នោះលោកក៏ចូលទៅក្នុងចំណោមប្រជាជន ដោយ
គ្រវីក្រណាត់អាវ របស់លោកទៅលើអាកាស ដើម្បីឲ្យមនុស្ស
ទាំងអស់អាចមើលឃើញអក្សរ ដែលលោកបានសរសេរ
នៅលើក្រណាត់នោះ ហើយ លោកស្រែកដោយសម្លេងយ៉ាង
ខ្លាំងថា៖

២០ មើលចុះ អស់អ្នកណាដែលចង់រក្សាទង់នេះនៅលើដែនដីនេះ
ចូរឲ្យគេចេញមកក្នុងកម្លាំងនៃព្រះអម្ចាស់ ហើយចូលក្នុងសេចក្ដី
សញ្ញាថា គេនឹងរក្សានូវសិទ្ធិរបស់គេ និងសាសនារបស់គេ
ដើម្បីឲ្យព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់ប្រទានព្រះពរដល់គេ ។

២១ ហើយហេតុការណ៍បានកើតឡើងថា កាលម៉ូរ៉ូណៃបាន
ប្រកាសពាក្យទាំងនេះហើយ មើលចុះ ប្រជាជនបាននាំគ្នារត់មក
ដោយ មានទាំងគ្រឿងសស្ត្រាវុធក្រវាត់ជាប់នៅនឹងចង្កេះ
របស់គេផង គេហែកអាវគេទុកជាទីសំគាល់ ឬជាសេចក្ដី
សញ្ញាថា ពួកគេពុំបដិសេធ ព្រះអម្ចាស់ ជាព្រះរបស់គេឡើយ;
ឬនិយាយម្យ៉ាងទៀតថា បើសិនជាពួកគេបំពានទៅលើព្រះបញ្ញត្តិ
ទាំងឡាយនៃព្រះ ឬធ្លាក់ទៅក្នុងអំពើ រំលង ហើយមានក៏ការ
អៀនខ្មាស់ ក្នុងការលើកដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ
សូមឲ្យព្រះអម្ចាស់ទ្រង់ហែកពួកគេចុះ ដូចជាពួកគេ បាន
ហែកសំលៀកបំពាក់របស់គេយ៉ាងនោះដែរ ។

២២ ឥឡូវនេះ នេះគឺជាសេចក្ដីសញ្ញា ដែលពួកគេបានធ្វើ
ហើយពួកគេបានបោះអាវរបស់គេ ទៅក្បែរជើងម៉ូរ៉ូណៃ ដោយ
និយាយថា៖ យើងខ្ញុំធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះរបស់យើងថា

១០ *ក* ២ នីហ្វៃ ១:៧; ម៉ូសាយ ២៩:៣២.
*ខ* ២ នីហ្វៃ ១:៧.
១១ *ក* អាលម៉ា ៤៣:១៦–១៧.
១២ *ក* នេហេ. ៤:១៤; អាលម៉ា ៤៤:៥.
១៥ *ក* ម៉ូសាយ ៥:៧–៩.
*ខ* កិច្ចការ ១១:២៦;
១ ពេត្រុស ៤:១៦.
១៧ *ក* អាលម៉ា ២២:៣០–៣១.
១៩ *ក* ស.ប. ទង់.
២១ *ក* ១ នីហ្វៃ ៨:២៥–២៨;
មរមន ៨:៣៨.

យើងខ្ញុំនឹងត្រូវបំផ្លាញបង់ ដូចបងប្អូនយើងខ្ញុំ ដែលនៅក្នុងដែនដី
ខាងជើង បើសិនជា យើងខ្ញុំធ្លាក់ទៅក្នុងអំពើរំលង; មែនហើយ
ទ្រង់នឹងបោះយើងខ្ញុំទៅក្បែរជើងនៃពួកខ្មាំងសត្រូវរបស់យើងខ្ញុំ
ដូចជាយើងខ្ញុំបានបោះអាវ របស់យើងខ្ញុំ ទៅក្បែរជើងលោក
ដើម្បីនឹងត្រូវជាន់ឈ្លីក្រោមជើងចុះ បើសិនជាយើងធ្លាក់ទៅក្នុង
អំពើរំលង ។
២៣ ម៉ូរ៉ូណៃបាននិយាយទៅពួកគេថា៖ មើលចុះ យើងគឺជា
សំណល់នៃពូជយ៉ាកុប; មែនហើយ យើងគឺជាសំណល់នៃ[ក]ពូជ
[ខ]យ៉ូសែប [គ]ឯអាវលោកត្រូវបងៗហែកចោលទៅជាកំទេចច្រើន;
មែនហើយ ឥឡូវនេះ មើលចុះ ចូរយើងចងចាំកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយនៃ ព្រះចុះ បើពុំនោះសោតទេ អាវរបស់ពួកយើងនឹង
ត្រូវបងប្អូនយើងហែកចោលដែរ ហើយយើងនឹងត្រូវគេដាក់ក្នុង
គុក ឬត្រូវគេលក់ ឬត្រូវគេសម្លាប់ចោល ។
២៤ មែនហើយ ចូរយើងរក្សាឥស្សរភាពរបស់យើងទុកជា
[ក]សំណល់នៃយ៉ូសែបចុះ; មែនហើយ ចូរយើងចងចាំពាក្យទាំង
ឡាយរបស់ យ៉ាកុប មុនពេលដែលលោកស្លាប់ទៅ
គ្បិតមើលចុះ លោកបានឃើញថា សំណល់មួយផ្នែកនៃអាវ
របស់យ៉ូសែប ត្រូវបានរក្សាទុក ហើយ ពុំត្រូវ
ពុករលួយឡើយ ។ ហើយលោកបាននិយាយថា៖ គឺដូចជា
[ខ]សំណល់អាវរបស់កូនខ្ញុំនេះ ដែលត្រូវបានរក្សាទុក
ឯសំណល់នៃពូជ របស់កូនខ្ញុំ ក៏នឹងត្រូវបានរក្សាទុក ដោយ
ព្រះហស្តនៃព្រះដែរ ហើយនឹងត្រូវបានយកទៅឯព្រះអង្គ ក្នុង
កាលចំណែកពូជយ៉ូសែប ដែល នៅសល់ក្រៅពីនេះ នឹងត្រូវ
វិនាស ដូចគ្នានឹងសំណល់របស់អាវវាដែរ ។
២៥ ឥឡូវនេះ មើលចុះ ការណ៍នេះនាំឲ្យព្រលឹងខ្ញុំសោកសៅ;
ទោះជាយ៉ាងណាក៏ដោយ គង់តែព្រលឹងខ្ញុំមានសេចក្ដីអំណរ
នៅក្នុង កូនប្រុសខ្ញុំដែរ ដោយសារផ្នែកនៃពូជរបស់វានោះ
ដែលនឹងត្រូវបានយកទៅឯព្រះ ។
២៦ ឥឡូវនេះ មើលចុះ នេះគឺជាវាចារបស់យ៉ាកុប ។
២៧ ហើយឥឡូវនេះ តើនរណាដឹងបានថា សំណល់នៃពូជ
យ៉ូសែប ដែលនឹងត្រូវវិនាសដូចអាវរបស់លោកនោះ តើមិនមែន
ជាពួកអ្នក ដែលបានបែកបាក់ចេញពីយើងនោះទេឬអី? មែន
ហើយ វាគឺជាពួកយើងដែរ បើសិនជាយើងពុំឈរឲ្យខ្ជាប់ខ្ជួន
នៅក្នុងសេចក្ដីជំនឿជឿ ដល់ព្រះគ្រីស្ទ ។
២៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ម៉ូរ៉ូណៃបានពោលពាក្យទាំងនេះហើយ នោះលោកបាន
ចាកចេញទៅ ហើយក៏បានចាត់ឲ្យមនុស្សទៅគ្រប់ទិសទីក្នុងដែនដី
ត្រង់កន្លែងណាដែលមានការបែកបាក់គ្នា ហើយប្រជុំអស់ទាំង
ប្រជាជន ដែលចង់ រក្សាឥស្សរភាពរបស់គេ ឲ្យតតាំងនឹង
អាម៉ាលិកាយ និងពួកអ្នកដែលបានបែកបាក់គ្នាចេញ ដែលត្រូវ
បានហៅថា ពួកសាសន៍ អាម៉ាលិកាយ ។
២៩ ហើយហេតុការណ៍បានកើតឡើងថា កាលអាម៉ាលិកាយបាន
ឃើញថា ប្រជាជនរបស់ម៉ូរ៉ូណៃ មានចំនួនច្រើនជាងពួកសាសន៍
អាម៉ាលិកាយ — ព្រមទាំងបានឃើញថា ប្រជាជន
របស់វាសង្ស័យអំពីសេចក្ដីយុត្តិធម៌ នៃហេតុដែលគេបានធ្វើ —
ហេតុដូច្នេះហើយ ដោយ ខ្លាចក្រែងវាពុំអាចសំរេចគោលបំណង
របស់វាបាន នោះវាបាននាំប្រជាជនរបស់វា ដែលចង់តាមវា
ហើយបានចេញដំណើរចូលទៅក្នុង ដែនដីនីហ្វៃ ។
៣០ ឥឡូវនេះ ម៉ូរ៉ូណៃបានគិតថា មិនគួរឲ្យពួកសាសន៍លេមិន
មានកម្លាំងថែមឡើងទេ; ហេតុដូច្នេះហើយ លោកបានគិតថា
ត្រូវស្ទាត់ ផ្លូវប្រជាជនអាម៉ាលិកាយ ឬត្រូវចាប់ពួកនេះ ហើយ
នាំត្រឡប់មកវិញ ហើយត្រូវប្រហារអាម៉ាលិកាយចោល; មែន
ហើយ ព្រោះ លោកបានដឹងថា វានឹងចាក់រុកពួកសាសន៍លេមិន
ឲ្យខឹងនឹងពួកគេ ហើយបណ្ដាលឲ្យពួកនោះមកច្បាំងនឹងពួកគេ;
ហើយលោកបាន ដឹងថា អាម៉ាលិកាយធ្វើការនេះ ដើម្បីវាអាច
សំរេចនូវគោលបំណងរបស់វា ។
៣១ ហេតុដូច្នេះហើយ ម៉ូរ៉ូណៃបានគិតថា ជាការចាំបាច់ថា
លោកត្រូវនាំពលទ័ពរបស់លោក ដែលបានប្រមូលគ្នាមក ហើយ
បាន ប្រដាប់ខ្លួនដោយអាវុធ ហើយបានចូលក្នុងសេចក្ដីសញ្ញាថា
នឹងរក្សាសេចក្ដីសុខសាន្ត — ហើយហេតុការណ៍
បានកើតឡើងថា លោកបាន នាំកងទ័ពរបស់លោក ហើយបាន
យកទង់របស់លោក ដើរចូលទៅក្នុងទីរហោស្ថាន ដើម្បីទៅស្ទាត់
ផ្លូវរបស់អាម៉ាលិកាយ នៅក្នុង ទីរហោស្ថាន ។
៣២ ហើយហេតុការណ៍បានកើតឡើងថា លោកបានធ្វើ
តាមបំណងរបស់លោក ហើយបានដើរចូលទៅក្នុងទីរហោស្ថាន
ហើយបាន ស្ទាក់មុខពលទ័ពរបស់អាម៉ាលិកាយ ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា អាម៉ាលិកាយបាន
រត់គេចខ្លួនចេញ ជាមួយនឹងទ័ពរបស់វាមួយចំនួនតូច ឯប្រជាជន

២៣ *ក* លោកុ. ៤៩:២២–២៦;
១ នីហ្វៃ ៥:១៤–១៥.
*ខ* ស.ប. យ៉ូសែប, កូនប្រុសរបស់
យ៉ាកុប.
*គ* លោកុ. ៣៧:៣, ៣១–៣៦.
២៤ *ក* អេម៉ុស ៥:១៥;
៣ នីហ្វៃ ៥:២១–២៤; ១០:១៧.
*ខ* ២ នីហ្វៃ ៣:៥–២៤;
អេធើរ ១៣:៦–៧.

ដែល នៅសល់ទាំងប៉ុន្មាន បានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់
ម៉ូរ៉ូណៃ ហើយត្រូវនាំត្រឡប់ទៅឯដែនដីសារ៉ាហិមឡាវិញ ។
៣៤ ឥឡូវនេះ ម៉ូរ៉ូណៃគឺជាមនុស្សដែលបានតែងតាំងឡើង
ដោយមេចៅក្រមទាំងឡាយ និងដោយសម្លេងប្រជាជន ហេតុ
ដូច្នេះ ហើយ លោកមានអំណាចបញ្ជាពលទ័ពសាសន៍នីហ្វៃ
តាមបំណងរបស់លោក ដើម្បីតាំង ហើយអនុវត្តសិទ្ធិ
អំណាចទៅលើពួកគេ ។
៣៥ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍
អាម៉ាលិកាយណា ដែលមិនព្រមចូលក្នុងសេចក្ដីសញ្ញា ដើម្បី
គាំទ្រសិទ្ធិនៃ សេរីភាព គឺដើម្បីពួកគេអាចរក្សានូវរដ្ឋាភិបាលសេរី
មួយទេ នោះលោកបានបញ្ជាឲ្យយកទៅប្រហារជីវិតចោល;
ហើយមានមនុស្ស ចំនួនតិច ដែលមិនព្រមចូលក្នុងសេចក្ដីសញ្ញា
នៃសេរីភាព ។
៣៦ ហើយហេតុការណ៍បានកើតឡើងផងដែរថា លោកបាន
បញ្ជាឲ្យគេដំឡើងទង់ឥស្សរភាពឡើង នៅលើគ្រប់ប៉ម នៅអស់
ទាំង ដែនដី ដែលពួកសាសន៍នីហ្វៃគ្រងលើ; ម្ល៉ោះហើយ ម៉ូរ៉ូណៃ
បានដោតទង់ឥស្សរភាព នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ។
៣៧ ហើយពួកគេបានចាប់ផ្ដើមមានសេចក្ដីសុខសាន្តទៀតនៅ
លើដែនដី; ម្ល៉ោះហើយ ពួកគេបានរក្សាសេចក្ដីសុខសាន្តនៅលើដែនដី
រហូតដល់ជិតចប់ឆ្នាំទីដប់ប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម ។
៣៨ ហើយហេលេមិន និងពួកសង្ឃជាន់ខ្ពស់ បាន
រក្សារបៀបរៀបរយនៅក្នុងសាសនាចក្រផងដែរ; មែនហើយ
គឺរហូតដល់អស់រយៈ ពេលបួនឆ្នាំ ពួកគេមានសេចក្ដីសុខសាន្ត
និងសេចក្ដីអររីករាយដ៏ច្រើននៅក្នុងសាសនាចក្រ ។
៣៩ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្ស
ជាច្រើន បានស្លាប់ទៅដោយជឿជាក់ថា ព្រលឹងរបស់គេត្រូវ
បានប្រោសលោះ ដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទ; ម្ល៉ោះហើយ
ពួកគេបានលាចាកលោកនេះ ទៅដោយសេចក្ដីអររីករាយ ។
៤០ ហើយមានអ្នកខ្លះដែលបានស្លាប់ដោយគ្រុន ដែលកើតមាន
ជាញឹកញាប់នៅក្នុងដែនដី គឺនៅរដូវខ្លះក្នុងឆ្នាំ — ប៉ុន្តែគ្រុន
ទាំងនេះ មិនធ្វើឲ្យស្លាប់ច្រើនគ្នាទេ ដោយព្រោះគុណភាព
ដ៏ប្រសើររបស់ដើមឈើ និងឫសឈើជាច្រើនដែលព្រះទ្រង់បាន
រៀបចំឲ្យមាន ដើម្បី កំចាត់ដើមហេតុនៃជម្ងឺទាំងឡាយ ដែល
កើតដល់មនុស្ស ដោយសារធម្មជាតិនៃធាតុអាកាស —
៤១ ប៉ុន្តែ មានមនុស្សជាច្រើន ដែលស្លាប់ដោយចាស់ជរា;
ហើយអស់អ្នកណាដែលស្លាប់នៅក្នុងសេចក្ដីជំនឿជឿដល់
ព្រះគ្រីស្ទ បានសប្បាយក្នុងទ្រង់ ដូចយើងត្រូវសន្និដ្ឋានដូច្នោះ ៕

## ជំពូកទី ៤៧

*អាម៉ាលិកាយប្រើការក្បត់ ឃាតកម្ម និងកលល្បិច ដើម្បីបានធ្វើជាស្ដេចនៃពួកសាសន៍លេមិន — ពួកសាសន៍នីហ្វៃ ដែលបែកក្រុមចេញ នោះអាក្រក់ ហើយសាហាវជាងពួកសាសន៍លេមិនទៅទៀត ។ ប្រមាណជាឆ្នាំ ៧២ ម.គ.ស. ។*

ឥឡូវនេះ យើងនឹងត្រឡប់មកឯបញ្ជីយើងវិញ ស្ដីអំពីអាម៉ាលិកាយ
និងពួកជនដែលបានរត់ទៅជាមួយវា ចូលទៅក្នុងទីរហោស្ថាន;
ត្បិតមើលចុះ វាបាននាំពួកអ្នកដែលទៅជាមួយវានោះ ហើយ
បានឡើងទៅឯដែនដីនីហ្វៃ នៅក្នុងចំណោមសាសន៍លេមិន ហើយ
បានចាក់រុកឲ្យពួក សាសន៍លេមិន ខឹងនឹងប្រជាជននីហ្វៃ ដរាប
ដល់ស្ដេចរបស់ពួកសាសន៍លេមិន បានចេញសេចក្ដីប្រកាសមួយ
ទូទៅអស់ទាំងដែនដី នៅក្នុងចំណោមប្រជាជនទាំងអស់របស់
ទ្រង់ថា ពួកគេត្រូវប្រមូលគ្នាមក ដើម្បីទៅច្បាំងនឹងពួកសាសន៍
នីហ្វៃទៀត ។
២ ហើយហេតុការណ៍បានកើតឡើងថា កាលដែល
សេចក្ដីប្រកាសនោះបានឮដល់ពួកគេហើយ នោះពួកគេមានការ
ភិតភ័យជាខ្លាំង; មែនហើយ គេខ្លាចក្រែងធ្វើឲ្យស្ដេចអាក់អន់ចិត្ត
ហើយគេក៏ខ្លាចទៅច្បាំងនឹងពួកសាសន៍នីហ្វៃ ខ្លាចក្រែងត្រូវ
បាត់បង់ជីវិត ។ ហើយហេតុ ការណ៍បានកើតឡើងថា ពួកគេមិន
ព្រម ឬពួកគេភាគច្រើន មិនព្រមធ្វើតាមបញ្ជារបស់ស្ដេចទេ ។
៣ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ស្ដេចមាន
ការខ្ញាល់ ដោយព្រោះការមិនគោរពបញ្ជានេះ; ហេតុដូច្នេះហើយ
ទ្រង់បានប្រគល់ឲ្យអាម៉ាលិកាយ នូវបញ្ជាផ្នែកនៃកងទ័ព ដែល
ស្ដាប់បញ្ជារបស់ទ្រង់ ហើយបានបញ្ជាឲ្យអាម៉ាលិកាយ
ចេញទៅបង្ខំឲ្យ ប្រជាជនប្រដាប់អាវុធ ។
៤ ឥឡូវនេះ មើលចុះ នេះគឺជាបំណងរបស់អាម៉ាលិកាយ;
ព្រោះវាជាមនុស្សឈ្លាសវៃក្នុងការធ្វើអំពើអាក្រក់ ហេតុដូច្នេះហើយ
វាបានគ្រោងការមួយនៅក្នុងចិត្តវា ដើម្បីទម្លាក់ស្ដេចនៃពួក
សាសន៍លេមិន ពីបល្ល័ង្កចោល ។

៣៤ *ក* អាលម៉ា ៤៣:១៦.
៣៨ *ក* អាលម៉ា ៤៦:៦.
៣៩ *ក* ម៉ូរ៉ូណៃ ៧:៣, ៤១.
៤០ *ក* គ. និង ស. ៨៩:១០.
៤១ *ក* វិវ. ១៤:១៣.
**៤៧** ១*ក* អាលម៉ា ៤៦:៣៣.
*ខ* ២ នីហ្វៃ ៥:៥–៨;
អោមណៃ ១:១២–១៣.

៥ ហើយឥឡូវនេះ វាបានក្ដាប់បញ្ជានៃកងទ័ពលេមិនទាំងឡាយ ដែលគាំទ្រស្ដេច; ហើយវាបានស្វែងរកការគាំទ្រពីពួកអ្នកដែលមិន ស្ដាប់បង្គាប់ស្ដេច; [ក]ហេតុដូច្នេះហើយ វាបានទៅកាន់កន្លែងមួយ ដែលគេហៅថា អូណៃដា ព្រោះនោះជាកន្លែងដែលមានពួកលេមិន រត់គេចចេញ; ព្រោះពួកគេបានដឹងថា មានកងទ័ពកំពុងធ្វើដំណើរមក ដោយគិតស្មានថា កងទ័ពកំពុងតែមកបំផ្លាញពួកគេចោល ហេតុដូច្នេះហើយ ពួកគេបានរត់គេចទៅឯអូណៃដា ទៅកន្លែងដែលមានអាវុធ ។

៦ ហើយពួកគេបានតែងតាំងបុរសម្នាក់ ឲ្យធ្វើជាស្ដេច និងជាមេដឹកនាំពួកគេ ដោយតាំងក្នុងចិត្តនូវការប្ដេជ្ញាចិត្តយ៉ាងមុតមាំថា ពួកគេមិនព្រមច្បាំងនឹងពួកសាសន៍នីហ្វៃឡើយ ។

៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រមូលគ្នាមកនៅលើកំពូលភ្នំមួយ ដែលហៅថា អាន់ទីប៉ាស ដើម្បីរៀបចំធ្វើចម្បាំង ។

៨ ឥឡូវនេះ ពុំមែនអាម៉ាលិកាយមានបំណងចចង់ទៅច្បាំងនឹងពួកគេតាមបញ្ជារបស់ស្ដេចទេ; ប៉ុន្តែមើលចុះ ជាបំណងរបស់វាដើម្បីបានការគាំទ្រពីពលទ័ពសាសន៍លេមិនវិញ ដើម្បីវាអាចធ្វើជាមេពួកនោះ ហើយទម្លាក់ស្ដេចពីបល្ល័ង្កចោល និងយកនគរ ។

៩ ហើយមើលចុះ ហេតុការណ៍បានកើតឡើងថា វាបានបញ្ជាឲ្យកងទ័ពវាបោះត្រសាលរបស់គេនៅក្នុងច្រកភ្នំ នៅជិតភ្នំអាន់ទីប៉ាស ។

១០ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ពេលយប់ វាបានប្រើឲ្យសារទូតសម្ងាត់ម្នាក់ ទៅកាន់ភ្នំអាន់ទីប៉ាស ដោយមាន បំណងចង់ឲ្យមេដឹកនាំរបស់ពួកអ្នក ដែលនៅលើភ្នំ ដែលមានឈ្មោះថាលីហុនតៃ ឲ្យចុះមកឯជើងភ្នំ ព្រោះវាមានបំណងចង់និយាយ ជាមួយនឹងអ្នកនោះ ។

១១ ហើយហេតុការណ៍បានកើតឡើងថា កាលលីហុនតៃបានទទួលសារនោះហើយ គាត់មិនហ៊ានចុះទៅឯជើងភ្នំទេ ។ ហើយហេតុ ការណ៍បានកើតឡើងថា អាម៉ាលិកាយបានចាត់ឲ្យមនុស្សទៅជាលើកទីពីរ ដោយមានបំណងចង់ឲ្យអ្នកនោះចុះមក ។ ហើយហេតុ ការណ៍បានកើតឡើងថា លីហុនតៃមិនព្រមចុះមកសោះ ហើយវាក៏បានចាត់មនុស្សទៅជាលើកទីបី ។

១២ ហើយហេតុការណ៍បានកើតឡើងថា កាលអាម៉ាលិកាយឃើញថា វាមិនអាចហៅលីហុនតៃ ឲ្យចុះមកពីលើភ្នំបានទេ វាក៏ឡើង ទៅលើភ្នំ ជិតដល់ជំរុំរបស់លីហុនតៃ; ហើយវាបានចាត់ឲ្យសារទូតរបស់វា ទៅជួបលីហុនតៃម្ដងទៀតគឺជាលើកទីបួន ដោយមានបំណង ចង់ឲ្យគាត់ចុះមក ហើយថាគាត់អាចនាំអ្នកយាមមកជាមួយផង ។

១៣ ហើយហេតុការណ៍បានកើតឡើងថា កាលលីហុនតៃបានចុះមកជាមួយនឹងពួកអ្នកយាមរបស់គាត់ ដើម្បីទៅជួបនឹងអាម៉ាលិកាយ នោះអាម៉ាលិកាយមានបំណងចង់ឲ្យលោក នាំកងទ័ពរបស់លោកចុះមកក្នុងពេលយប់ ហើយឡោមព័ទ្ធពួកទាហានដែលនៅក្នុងជំរុំ ដែលជាពួកទាហាន ដែលស្ដេចបានប្រគល់ឲ្យវាបញ្ជា ហើយថាវានឹងប្រគល់ពួកទាហានទាំងនេះទៅក្នុងកណ្ដាប់ដៃរបស់លីហុនតៃ បើសិនជាលោកព្រមឲ្យវា (អាម៉ាលិកាយ) ធ្វើជាមេដឹកនាំរងទៅលើកងទ័ពទាំងមូល ។

១៤ ហើយហេតុការណ៍បានកើតឡើងថា លីហុនតៃបានចុះមកជាមួយទ័ពលោក ហើយបានឡោមព័ទ្ធទ័ពរបស់អាម៉ាលិកាយ ដើម្បីឲ្យ បានមុនពេលពួកគេភ្ញាក់ពីដេក នៅពេលព្រលឹម នោះពួកគេត្រូវបានឡោមព័ទ្ធជុំវិញ ដោយពលទ័ពរបស់លីហុនតៃ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានឃើញថា ពួកគេត្រូវបានឡោមព័ទ្ធជុំវិញ ពួកគេក៏អង្វរអាម៉ាលិកាយសូមឲ្យ វាបណ្ដោយឲ្យពួកគេចុះចូលជាមួយនឹងបងប្អូនគេ ដើម្បីកុំឲ្យពួកគេត្រូវបំផ្លាញបង់ ។ ឥឡូវនេះ នេះគឺជាការណ៍ដែលអាម៉ាលិកាយ ប៉ងប្រាថ្នា ។

១៦ ហើយហេតុការណ៍បានកើតឡើងថា វាបានប្រគល់ទ័ពរបស់វា [ក]ផ្ទុយនឹងបញ្ជារបស់ស្ដេច ។ ឥឡូវនេះ នេះគឺការណ៍ដែល អាម៉ាលិកាយប៉ងប្រាថ្នា ដើម្បីឲ្យវាអាចសំរេចផែនការរបស់វា ដើម្បីទម្លាក់ស្ដេចពីបល្ល័ង្កចោល ។

១៧ ឥឡូវនេះ គឺជាទំលាប់ក្នុងចំណោមពួកសាសន៍លេមិន បើសិនជាមេដឹកនាំធំរបស់គេត្រូវស្លាប់ គឺត្រូវតែងតាំង មេដឹកនាំរងឲ្យ ធ្វើជាមេដឹកនាំធំរបស់គេ ។

១៨ ហើយហេតុការណ៍កើតឡើងថា អាម៉ាលិកាយបានបញ្ជាឲ្យអ្នកបំរើរបស់វាម្នាក់ ដាក់ថ្នាំបំពុលលីហុនតៃជាសន្សឹមៗ ដើម្បីឲ្យ លោកស្លាប់ ។

១៩ ឥឡូវនេះ កាលលីហុនតៃបានស្លាប់ទៅ នោះពួកសាសន៍លេមិន បានតែងតាំងអាម៉ាលិកាយឡើង ឲ្យធ្វើជាអ្នកដឹកនាំរបស់គេ និងជាអគ្គមេបញ្ជាការរបស់គេ ។

២០ ហើយហេតុការណ៍បានកើតឡើងថា អាម៉ាលិកាយបាននាំពលទ័ពរបស់វា (ព្រោះវាបានសំរេចដូចបំណងរបស់វាហើយ)

៥ ក អាលម៉ា ៣២:៤.

១៦ ក អាលម៉ា ៤៧:៣.

ទៅកាន់ដែនដីនីហ្វៃ គឺទៅកាន់ទីក្រុងនីហ្វៃ ដែលជាទីក្រុងសំខាន់បំផុត ។

២១ ហើយស្ដេចបានចេញមកជួបនឹងវា ជាមួយនឹងពួកអ្នកយាមរបស់ទ្រង់ ព្រោះទ្រង់បានគិតស្មានថា អាម៉ាលិកាយបានបំពេញបញ្ជា ទាំងឡាយរបស់ទ្រង់ហើយ ហើយថាអាម៉ាលិកាយបានប្រមូលកងទ័ពយ៉ាងច្រើនដូច្នេះ ដើម្បីទៅច្បាំងនឹងពួកសាសន៍នីហ្វៃ ។

២២ ប៉ុន្តែមើលចុះ នៅពេលស្ដេចគំបុងតែយាងចេញមកជួបវា នោះអាម៉ាលិកាយបានបញ្ជាឲ្យពួកអ្នកបំរើរបស់វាចេញទៅជួបស្ដេច ។ ហើយពួកគេបានទៅ ហើយបានក្រាបចំពោះស្ដេច ហាក់បីដូចជាសម្ដែងការគោរពកោតក្រែងដល់ទ្រង់ ដោយព្រោះអំណាចរបស់ទ្រង់ ។

២៣ ហើយហេតុការណ៍បានកើតឡើងថា ស្ដេចបានហុចព្រះហស្ដទៅលើកគេឡើង គឺជាសណ្ដាប់របស់ពួកសាសន៍លេមិន ទុកជាទី សំគាល់មួយនៃសេចក្ដីសុខសាន្ដ ដែលជាទំលាប់ពួកគេយកបានមកពីពួកសាសន៍នីហ្វៃ ។

២៤ ហើយហេតុការណ៍បានកើតឡើងថា កាលទ្រង់បានលើកអ្នកទីមួយពីដីហើយ មើលចុះ វាបានចាក់ស្ដេចចំបេះដូង; ហើយទ្រង់ ក៏ដួលទៅលើដី ។

២៥ ឥឡូវនេះ ពួកអ្នកបំរើរបស់ស្ដេចបានរត់គេចចេញ; ហើយពួកអ្នកបំរើរបស់អាម៉ាលិកាយបានស្រែកឡើងថា៖

២៦ មើលចុះ ពួកអ្នកបំរើរបស់ស្ដេចបានចាក់ទ្រង់ចំបេះដូង ហើយទ្រង់បានដួល ហើយពួកគេបានរត់គេចខ្លួន; មើលចុះ ចូរមក ហើយមើលចុះ ។

២៧ ហើយហេតុការណ៍បានកើតឡើងថា អាម៉ាលិកាយបានបញ្ជាថា ពលទ័ពរបស់វាគួរតែដើរទៅមុខ ហើយមើលថា តើអ្វីបានកើត ឡើងដល់ស្ដេច; ហើយកាលពួកគេបានមកដល់កន្លែងនោះ ហើយបានឃើញស្ដេចដេកនៅក្នុងថ្លុកឈាមរបស់ទ្រង់ នោះអាម៉ាលិកាយធ្វើ ពុតជាខឹង ហើយបាននិយាយថា៖ អស់អ្នកណាដែលស្រឡាញ់ស្ដេច ចូរឲ្យគេចេញមក ហើយដេញតាមពួកអ្នកបំរើរបស់ទ្រង់ចុះ ដើម្បីឲ្យ ពួកគេអាចបានស្លាប់ ។

២៨ ហើយហេតុការណ៍បានកើតឡើងថា អស់ពួកអ្នកដែលស្រឡាញ់ស្ដេច កាលពួកគេបានឮពាក្យទាំងនេះហើយ ក៏ចេញមក ហើយបានដេញតាមពួកអ្នកបំរើរបស់ស្ដេច ។

២៩ ឥឡូវនេះ កាលពួកអ្នកបំរើរបស់ស្ដេចបានឃើញទ័ពមួយកងកំពុងដេញតាមខ្លួន នោះពួកគេភិតភ័យជាថ្មីទៀត ហើយបានរត់ គេចខ្លួនចូលទៅក្នុងទីរហោស្ថាន ហើយបាន[ក]ឆ្លងទៅឯដែនដីសារ៉ាហិមឡា ហើយបានចូលរួបរួមនឹងប្រជាជនអាំម៉ូន ។

៣០ ហើយកងទ័ពដែលដេញតាមពួកគេនោះ បានត្រឡប់មកវិញ កាលបានដេញតាមពួកគេដោយគ្មានបានលទ្ធផល; ម្ល៉ោះហើយ អាម៉ាលិកាយ ដោយការបន្លំរបស់វា ក៏យកបានទឹកចិត្តរបស់ប្រជាជន ។

៣១ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង នោះវាបានចូលទៅក្នុងទីក្រុងនីហ្វៃ ជាមួយនឹងពលទ័ពរបស់វា ហើយ បានគ្រប់គ្រងយកទីក្រុងទៅ ។

៣២ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អគ្គមហេសីស្ដេច កាលព្រះនាងបានឮថា ស្ដេចត្រូវគេសម្លាប់ — ព្រោះអាម៉ាលិកាយបានចាត់ឲ្យសារទូតម្នាក់ ទៅជួបនឹងអគ្គមហេសីស្ដេច ដើម្បីឲ្យដំណឹងដល់ព្រះនាងថា ស្ដេចត្រូវសុគត ដោយពួកអ្នកបំរើ របស់ទ្រង់ ថាវាបានដេញតាមពួកគេដោយកងទ័ពរបស់វា ប៉ុន្តែគ្មានបានលទ្ធផលអ្វីឡើយ ហើយពួកគេបានរត់គេចខ្លួនទៅហើយ —

៣៣ ហេតុដូច្នេះហើយ កាលអគ្គមហេសីស្ដេចបានទទួលសារនេះហើយ នោះព្រះនាងបានចាត់ឲ្យមនុស្ស ទៅជួបនឹងអាម៉ាលិកាយ ដោយមានព្រះទ័យចង់ឲ្យវាលើកលែងជីវិតឲ្យប្រជាជននៅទីក្រុងនេះ; ហើយព្រះនាងក៏មានព្រះទ័យចង់ឲ្យវាមកគាល់ព្រះនាង ហើយព្រះ នាងក៏មានព្រះទ័យចង់ឲ្យវានាំពួកសាក្សីមកជាមួយវាផង ដើម្បីធ្វើបន្ទាល់អំពីការសុគតរបស់ស្ដេច ។

៣៤ ហើយហេតុការណ៍បានកើតឡើងថា អាម៉ាលិកាយបាននាំអ្នកបំរើដដែល ដែលបានសម្លាប់ស្ដេចនោះ និងអស់ទាំងពួកដែលនៅ ជាមួយនឹងវា ហើយបានចូលទៅគាល់អគ្គមហេសីស្ដេចត្រង់កន្លែងដែលព្រះនាងអង្គុយ; ហើយពួកគេទាំងអស់គ្នា បានធ្វើទីបន្ទាល់ដល់ ព្រះនាងថា ស្ដេចត្រូវសុគតដោយពួកអ្នកបំរើផ្ទាល់របស់ទ្រង់; ហើយពួកគេក៏បានទូលដែរថា៖ ពួកគេបានរត់គេចខ្លួន; តើពុំមែនការណ៍ នេះធ្វើបន្ទាល់ទាស់នឹងពួកគេទេឬ? ម្ល៉ោះហើយ ពួកគេបានធ្វើឲ្យអគ្គមហេសីស្ដេចស្កប់ចិត្តអំពីសេចក្ដីសុគតរបស់ស្ដេច ។

៣៥ ហើយហេតុការណ៍បានកើតឡើងថា អាម៉ាលិកាយបានស្វែងរកការប្រោសប្រណីពីអគ្គមហេសីស្ដេច ហើយបានយកព្រះនាង ធ្វើជាភរិយាវា; ម្ល៉ោះហើយ ដោយការរៀចបន្លំរបស់វា

២៩ *ក* អាលម៉ា ៤៣:១១–១២. | ស.ប. អាន់តៃ-នីហ្វៃ-លីហៃ.

និងដោយជំនួយនៃពួកអ្នកបំរើរបស់វា ដែលប្រកបដោយកលល្បិច
វាយកបាន នគរ; មែនហើយ វាត្រូវបានទទួលស្គាល់ថាជាស្ដេច
ទូទៅអស់ទាំងផែនដី នៅក្នុងចំណោមអស់ទាំងប្រជាជននៃពួក
លេមិន ដែលមានរួម ទាំងពួកសាសន៍លេមិន និងពួកសាសន៍
លេមយួល និងពួកសាសន៍អ៊ីសម៉ាអែល និងអស់ទាំងពួកដែល
បែកចេញពីពួកសាសន៍នីហ្វៃ ចាប់តាំងពីរជ្ជកាលនៃនីហ្វៃ រហូត
មកដល់ពេលបច្ចុប្បន្ននេះ ។
៣៦ ឥឡូវនេះ ពួកអ្នកដែលបែកចេញទាំងនេះ មានសេចក្ដី
បង្គាប់ដូចគ្នា និងពតិមានដូចគ្នានឹងពួកសាសន៍នីហ្វៃ មែនហើយ
ដោយ ត្រូវបានបង្គាប់ក្នុងការចេះដឹង អំពីព្រះអម្ចាស់ដូចគ្នា ទោះ
ជាយ៉ាងណាក៏ដោយ គង់តែជាការចម្លែកមួយដែរ គឺបន្ទាប់ពីការ
បែកចេញ របស់គេមកមិនយូរប៉ុន្មានទេ នោះពួកគេបានក្លាយ
ទៅជាមានចិត្តរឹងទទឹងខ្លាំងឡើង ហើយគ្មានចិត្តនឹកស្ដាយ
និងព្រៃផ្សៃ ទុច្ចរិត និងសាហាវ ច្រើនជាងពួកសាសន៍លេមិន
ទៅទៀត — គ្រេបជញ្ជក់នូវសណ្ដាប់ទាំងឡាយរបស់ពួក
សាសន៍លេមិន ដែលនាំឲ្យមានការ ខ្ជិលច្រអូស និងអំពើ
អាសអាភាសគ្រប់យ៉ាង; មែនហើយ គឺភ្លេចព្រះអម្ចាស់ ជាព្រះ
របស់គេទាំងស្រុង ៕

## ជំពូកទី ៤៨

*អាម៉ាលិកាយញុះញង់ពួកសាសន៍លេមិន ឲ្យទាស់នឹងពួកសាសន៍នីហ្វៃ — ម៉ូរ៉ូណៃប្រុងប្រៀបប្រជាជនលោក ឲ្យការពារឧត្ដមគតិរបស់ពួក គ្រីស្ទាន — លោកអររីករាយក្នុងឥស្សរភាពនិងសេរីភាព ហើយជាមនុស្សសំណប់ដ៏ខ្លាំងក្លាម្នាក់របស់ព្រះ ។ ប្រមាណជាឆ្នាំ ៧២ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
អាម៉ាលិកាយយកនគរបានភ្លាម ទ្រង់បានចាប់ផ្ដើមបណ្ដាលចិត្ត
ពួកសាសន៍លេមិន ឲ្យទាស់នឹងប្រជាជននីហ្វៃ; មែនហើយ ទ្រង់
បានចាត់ឲ្យមនុស្សថ្លែងទៅកាន់ពួកសាសន៍លេមិន ពីលើប៉មទាំង
ឡាយរបស់គេ ជំទាស់នឹង ពួកសាសន៍នីហ្វៃ ។
២ ម្ល៉ោះហើយ ទ្រង់បានបណ្ដាលចិត្តពួកគេឲ្យទាស់នឹងពួក
សាសន៍នីហ្វៃ ដរាបដល់ចុងឆ្នាំទីដប់ប្រាំបួនក្នុងរជ្ជកាលនៃ
ពួកចៅក្រម ដោយទ្រង់បានសំរេចគំរោងការទាំងឡាយរបស់
ទ្រង់ដល់នេះ មែនហើយ ដោយបានធ្វើជាស្ដេចលើពួកសាសន៍
លេមិន ទ្រង់ក៏ស្វែងរក គ្រប់គ្រងលើដែនដីទាំងអស់ដែរ មែន
ហើយ និងប្រជាជនទាំងអស់ ដែលនៅលើដែនដីនោះ ទាំងពួក
សាសន៍នីហ្វៃ ទាំងពួក សាសន៍លេមិនផង ។
៣ ហេតុដូច្នេះហើយ ទ្រង់បានសំរេចគំរោងការរបស់ទ្រង់
ព្រោះទ្រង់បានធ្វើឲ្យពួកសាសន៍លេមិនមានចិត្តរឹងទទឹង ហើយបាន
ធ្វើឲ្យគំនិត គេងងឹត ហើយបានចាក់រុកពួកគេឲ្យខឹង ដរាបដល់
ទ្រង់ប្រមូលបានពលទ័ពមួយក្រុមដ៏កុះករ ដើម្បីទៅច្បាំងនឹងពួក
សាសន៍នីហ្វៃ ។
៤ ព្រោះទ្រង់ប្ដេជ្ញា ដោយព្រោះចំនួនទ័ពដ៏ច្រើនរបស់ទ្រង់ ថា
នឹងមានជ័យជំនះទៅលើពួកសាសន៍នីហ្វៃ ហើយនឹងនាំពួកគេទៅ
ក្នុងសេវកភាពបាន ។
៥ ម្ល៉ោះហើយ ទ្រង់បានតែងតាំងពួកសាសន៍សូរាំឡើងជា
មេទ័ពឯក ព្រោះពួកនេះធ្លាប់ស្គាល់ជាងគេបំផុត នូវកម្លាំងរបស់
ពួកសាសន៍ នីហ្វៃ និងទីតាំងទាំងឡាយរបស់ពួកគេ និងផ្នែកទាំង
ឡាយដែលខ្សោយបំផុត នៃទីក្រុងទាំងឡាយរបស់ពួកគេ; ហេតុ
ដូច្នេះហើយ ទ្រង់បានតែងតាំងពួកគេឡើង ឲ្យធ្វើជាពួក
មេទ័ពឯកលើពលទ័ពរបស់ទ្រង់ ។
៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានយកជំរុំ
របស់គេ ហើយបានធ្វើដំណើរឆ្ពោះទៅកាន់ដែនដីសារ៉ាហិមឡា
នៅក្នុងទី រហោស្ថាន ។
៧ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅពេល
អាម៉ាលិកាយកំពុងតែយកបានអំណាចដោយការបន្លំ និងការ
បោកបញ្ឆោត យ៉ាងនេះ ផ្ទុយទៅវិញ ម៉ូរ៉ូណៃកំពុងតែ
ប្រុងប្រៀបចិត្តគំនិតរបស់ប្រជាជន ឲ្យស្មោះត្រង់ចំពោះព្រះ
អម្ចាស់ ជាព្រះរបស់ពួកគេ ។
៨ មែនហើយ លោកបានពង្រឹងកម្លាំងពលទ័ពសាសន៍នីហ្វៃ
ហើយបានសង់បន្ទាយតូចៗ ឬទីតាំងទាំងឡាយ; បាន
លើកទំនប់ដីទាំង ឡាយជុំវិញ ដើម្បីឡោមព័ទ្ធពលទ័ព
របស់លោក ហើយស្ថាបនាកំផែងថ្មទាំងឡាយផង
ដើម្បីឡោមព័ទ្ធជុំវិញពួកគេ គឺជុំវិញទីក្រុងទាំង ឡាយរបស់
ពួកគេ និងព្រំប្រទល់ទាំងឡាយនៃដែនដីរបស់គេ; មែនហើយ
គឺនៅជុំវិញដែនដីគេទាំងអស់ ។
៩ ហើយឯបន្ទាយទាំងឡាយ ដែលខ្សោយបំផុត លោកបាន

៣៥ *ក* យ៉ាកុប ១:១៣–១៤.
៣៦ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* ហេព្រើរ ១០:២៦–២៧;
អាលម៉ា ២៤:៣០.
*គ* យេរេ. ៨:១២.
៤៨ ៥ *ក* អាលម៉ា ៤៣:៦.
៧ *ក* អាលម៉ា ៤៩:៨.

ដាក់ទ័ពច្រើនជាង; ម្ល៉ោះហើយ លោកបានពង្រឹង ហើយបន្ថែមកម្លាំង
ដល់ដែនដីដែលពួកសាសន៍នីហ្វៃអាស្រ័យនៅ ។
១០ ម្ល៉ោហហើយ លោកកំពុងតែរៀបចំដើម្បីគាំទ្រឥស្សរភាព
របស់ពួកគេ ដែនដីរបស់ពួកគេ ប្រពន្ធរបស់ពួកគេ និងកូនចៅ
របស់ ពួកគេ និងសន្តិភាពរបស់ពួកគេ ហើយដើម្បីពួកគេអាច
រស់នៅ ចំពោះព្រះអម្ចាស់ ជាព្រះរបស់ពួកគេ ហើយដើម្បីពួក
គេអាចទ្រទ្រង់ នូវអ្វីដែលពួកខ្មាំងសត្រូវរបស់ពួកគេហៅថា
ឧត្តមគតិនៃពួកគ្រីស្ទាន ។
១១ ហើយមរ៉ូណៃ ជាបុរសម្នាក់ដ៏មានកម្លាំង ហើយខ្លាំងក្លា;
លោកជាមនុស្សម្នាក់ដែលប្រកបទៅដោយយោបល់ដ៏ឥតខ្ចោះ;
មែនហើយ ជាមនុស្សម្នាក់ដែលមិនចូលចិត្តការខ្ចាយឈាម; ជា
មនុស្សម្នាក់ដែលមានព្រលឹង ត្រេកអរក្នុងឥស្សរភាព និងសេរីភាព
នៃ ប្រទេសរបស់លោក និងបងប្អូនលោក ដែលផុតពីសេវកភាព
និងទាសភាព ។
១២ មែនហើយ ជាមនុស្សម្នាក់ ដែលមានចិត្តរីកពេញទៅដោយ
អំណរគុណ ដល់ព្រះរបស់លោក ចំពោះឯកសិទ្ធនិងពរដ៏ច្រើន
ដែលទ្រង់បានប្រទានដល់រាស្ត្រទ្រង់; ជាមនុស្សម្នាក់ ដែល
ធ្វើការងារយ៉ាងលើសលប់ ដើម្បីសុខុមាលភាព និងសន្តិសុខ
ដល់ប្រជាជន របស់លោក ។
១៣ មែនហើយ ហើយលោកជាមនុស្សម្នាក់ដែលរឹងប៉ឹង នៅ
ក្នុងសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ ហើយលោកបានស្បថ ដោយ
ពាក្យ សម្បថថានឹងការពារប្រជាជនរបស់លោក សិទ្ធិទាំងឡាយ
របស់លោក និងប្រទេសរបស់លោក និងសាសនារបស់លោក
រហូតដល់ អស់ឈាមរបស់លោក ។
១៤ ឥឡូវនេះ ពួកសាសន៍នីហ្វៃត្រូវបានបង្រៀនឲ្យការពារខ្លួន
ពីពួកខ្មាំងសត្រូវរបស់ពួកគេ រហូតដល់ត្រូវកំចាយឈាម
ប្រសិនបើជា ការចាំបាច់; មែនហើយ ហើយពួកគេក៏ត្រូវបាន
បង្រៀនដែរថា មិនត្រូវធ្វើជាទីបង្អាក់ចិត្ត មែនហើយ ហើយ
មិនត្រូវលើកដាវឡើយ លើកលែងតែប្រឆាំងនឹងខ្មាំងសត្រូវ
លើកលែងតែត្រូវរក្សាជីវិតរបស់ខ្លួនប៉ុណ្ណោះ ។
១៥ ហើយនេះគឺសេចក្តីជំនឿរបស់ពួកគេ គឺថាដោយធ្វើដូច្នេះ
ព្រះទ្រង់នឹងធ្វើឲ្យគេចំរើនឡើងនៅលើដែនដី ឬនិយាយ
ម៉្យាងទៀតថា បើសិនជាពួកគេស្មោះត្រង់ ក្នុងការកាន់
តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះទ្រង់នឹងធ្វើឲ្យ
គេចំរើនឡើងនៅលើដែនដី; មែនហើយ ទ្រង់នឹងព្រមានពួកគេ
ឲ្យរត់គេច ឬរៀបចំធ្វើសង្គ្រាម ស្របតាមការគ្រោះថ្នាក់របស់គេ;
១៦ ហើយព្រះទ្រង់នឹងធ្វើឲ្យគេដឹងដែរថា តើពួកគេគួរទៅទីណា
ដើម្បីការពារខ្លួនពីពួកខ្មាំងសត្រូវរបស់គេ ហើយដោយធ្វើដូច្នេះ
នោះព្រះអម្ចាស់ទ្រង់នឹងដោះលែងពួកគេ; ហើយនេះគឺជាសេចក្តី
ជំនឿរបស់មរ៉ូណៃ ហើយចិត្តលោកក៏សរសើរដំកើងនៅក្នុងការណ៍
នោះ; ពុំមែនក្នុងការខ្ចាយឈាមទេ តែក្នុងការធ្វើល្អ ក្នុងការ
រក្សាប្រជាជនរបស់លោក មែនហើយ គឺក្នុងការកាន់
តាមព្រះបញ្ញត្តិទាំង ឡាយនៃព្រះ មែនហើយ ហើយទប់នឹង
អំពើទុច្ចរិត ។
១៧ មែនហើយ ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើសិនជា
មនុស្សទាំងអស់ដែលធ្លាប់រស់នៅ ហើយកំពុងរស់នៅ ហើយនឹង
រស់ នៅ ដូចមរ៉ូណៃ មើលចុះ អំណាចទាំងឡាយរបស់ស្ថាននរក
នឹងត្រូវញ័ររន្ធត់រហូតតទៅ; មែនហើយ អារក្សនឹងគ្មាន
អំណាចទៅលើ ចិត្តនៃកូនចៅមនុស្សឡើយ ។
១៨ មើលចុះ លោកគឺជាមនុស្សម្នាក់ ដូចជាអាំម៉ូន ជាបុត្រ
របស់ហ្លួងម៉ូសាយ មែនហើយ និងដូចពួកបុត្រាឯទៀតរបស់ហ្លួង
ម៉ូសាយ មែនហើយ និងព្រមទាំងអាលម៉ា និងពួកកូនប្រុស
របស់លោកដែរ ព្រោះពួកគេទាំងអស់គ្នាជាមនុស្សសំណប់នៃព្រះ។
១៩ ឥឡូវនេះ មើលចុះ ហេលេមិន និងបងប្អូនលោកក៏បំរើ
ដល់ប្រជាជនមិនអន់ជាងមរ៉ូណៃដែរ; ព្រោះពួកគេបានផ្សាយព្រះ
បន្ទូល នៃព្រះ ហើយពួកគេបានធ្វើបុណ្យជ្រមុជទឹក ចំពោះការ
ប្រែចិត្ត ដល់អស់ទាំងមនុស្សណា ដែលព្រមស្តាប់តាមពាក្យ
សំដីរបស់ពួកគេ ។
២០ ម្ល៉ោះហើយ ពួកគេបានចេញទៅ ហើយប្រជាជនបាន
បន្ទាបខ្លួន ដោយសារពាក្យសំដីរបស់ពួកគេ ដរាបដល់គេបាន
ទៅជាទី សំណប់ដ៏ខ្លាំងនៃព្រះអម្ចាស់ ម្ល៉ោះហើយ ពួកគេបាន
រួចផុតពីសង្គ្រាមទាំងឡាយ និងសេចក្តីទាស់ទែងគ្នាទាំងឡាយ
នៅក្នុងចំណោមពួក គេ មែនហើយ រហូតដល់
អស់រយៈពេលបួនឆ្នាំ ។
២១ ប៉ុន្តែ ដូចខ្ញុំបាននិយាយមកថា នៅចុងឆ្នាំទីដប់ប្រាំបួន មែន
ហើយ ទោះបីជាមានសេចក្តីសុខសាន្ត នៅក្នុងចំណោមពួកគេក្តី

១០ *ក* អាលម៉ា ៤៦:១២–១៣.
១១ *ក* ស.ប. យោបល់.
១២ *ក* ស.ប. សុខុមាលភាព.
១៣ *ក* អាលម៉ា ៤៦:២០–២២.
១៤ *ក* អាលម៉ា ៤៣:៤៦–៤៧;
៣ នីហ្វៃ ៣:២០–២១;
មរមន ៣:១០–១១;
គ. និង ស. ៩៨:១៦.
១៦ *ក* អាលម៉ា ៥៥:១៩.
១៧ *ក* ១ នីហ្វៃ ២២:២៦;
៣ នីហ្វៃ ៦:១៥.
២០ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ១ នីហ្វៃ ១៧:៣៥.

គង់តែពួកគេត្រូវជំរុញ ដោយរុញរាឲ្យទាស់ទែងនឹងបងប្អូនគេ គឺពួកសាសន៍លេមិន ។

២២ មែនហើយ ហើយសរុបសេចក្ដីមក សង្គ្រាមទាំងឡាយរបស់ពួកគេ ជាមួយនឹងពួកសាសន៍លេមិន ពុំឈប់ឈរសោះ គឺអស់រយៈ ពេលជាច្រើនឆ្នាំ ទោះបីពួកគេមានការរុញរាជាច្រើនក្ដី។

២៣ ឥឡូវនេះ ពួកគេមានចិត្តសោកសៅ ដោយបានលើកអាវុធប្រឆាំងនឹងពួកសាសន៍លេមិន ព្រោះពួកគេពុំចូលចិត្តក្នុងការខ្ចាយ ឈាមសោះ; មែនហើយ ហើយនេះមិនទាន់អស់នៅឡើយទេ — ពួកគេមានចិត្តសោកសៅ ដែលបានធ្វើជាមធ្យោបាយទាំងឡាយនៃការ បញ្ជូនបងប្អូនគេជាច្រើនឲ្យចាកចេញពីលោកនេះ ចូលទៅឯលោកមួយដ៏នៅអស់កល្បជានិច្ច ដោយពុំបានរៀបចំដើម្បីទៅជួបព្រះរបស់ ពួកគេឡើយ ។

២៤ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេពុំអាចទ្រាំប្ដូរជីវិតរបស់គេ ដើម្បីឲ្យប្រពន្ធរបស់គេ និងកូនចៅរបស់គេ ត្រូវស្លាប់រង្គាល ដោយភាពឃោរឃៅ ព្រៃផ្សៃរបស់ពួកអ្នក ដែលធ្លាប់ជាបងប្អូនគេពីមុននោះឡើយ មែនហើយ ហើយបានបែកចេញពីសាសនាចក្ររបស់ ពួកគេ ហើយបានចាកចោលពួកគេ ហើយបានមកបំផ្លាញពួកគេ ដោយទៅរួបរួមនឹងពួកសាសន៍លេមិន។

២៥ មែនហើយ ពួកគេមិនអាចទ្រាំទ្រឲ្យបងប្អូនគេ អររីករាយនឹងឈាមនៃពួកសាសន៍នីហ្វៃឡើយ ដរាបណានៅមានអ្នកកាន់តាម ព្រះបញ្ញត្តិទាំងឡាយនៃព្រះ ព្រោះពាក្យសន្យានៃព្រះអម្ចាស់ គឺថាបើសិនជាពួកគេកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះពួកគេនឹង បានចំរើនឡើងនៅលើដែនដី ៕

## ជំពូកទី ៤៩

*ពួកលេមិនដែលឈ្លានពាននោះ មិនអាចយកទីក្រុងអាំម៉ូណៃហា និងណូអេ ដ៏មាំមួនបានទេ — អាម៉ាលិកាយជេរប្រទេចព្រះ ហើយស្បថ ថានឹងផឹកឈាមមរ៉ូណៃ — ហេលេមិន និងបងប្អូនលោក បន្តការចំរើនកម្លាំងដល់សាសនាចក្រ ។ ប្រមាណជាឆ្នាំ ៧២ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅខែទីដប់មួយក្នុងឆ្នាំទីដប់ប្រាំបួន ទៅថ្ងៃទីដប់នៃខែនោះ នោះពលទ័ពសាសន៍លេមិនត្រូវគេឃើញដើរឆ្ពោះទៅដែនដីអាំម៉ូណៃហា ។

២ ហើយមើលចុះ ទីក្រុងនេះត្រូវបានស្ថាបនាឡើងវិញ ហើយមរ៉ូណៃបានដាក់ទ័ពមួយកង នៅតាមព្រំប្រទល់ទាំងឡាយនៃទីក្រុង ហើយ ពួកគេបានពូនដីជុំវិញ ដើម្បីបាំងពួកគេ កុំឲ្យត្រូវព្រួញ និងក្រួសរបស់ពួកលេមិន; ត្បិតមើលចុះ ពួកគេប្រយុទ្ធដោយប្រើក្រួស និងព្រួញ ។

៣ មើលចុះ ខ្ញុំបានប្រាប់ថា ទីក្រុងអាំម៉ូណៃហាត្រូវបានស្ថាបនាឡើងវិញ ។ ខ្ញុំសូមប្រាប់អ្នកថា មែនហើយ គឺវាត្រូវបានស្ថាបនាឡើង វិញ តាមកន្លែងខ្លះៗ; ហើយពីព្រោះពួកលេមិនបានបំផ្លាញវាម្ដង ដោយព្រោះសេចក្ដីទុច្ចរិតរបស់ប្រជាជន នោះពួកគេបានសន្និដ្ឋានថា វាជាទិសដៅដ៏ងាយសំរាប់ពួកគេម្ដងទៀត ។

៤ ប៉ុន្តែមើលចុះ ពួកគេខកចិត្តជាខ្លាំង; ត្បិតមើលចុះ ពួកនីហ្វៃបានជីកធ្វើជាភ្លឺដីមួយជុំវិញពួកគេដែលខ្ពស់ រហូតដល់ពួកលេមិនមិនអាច បាញ់ក្រួស និងព្រួញទៅលើពួកគេ ដើម្បីវាអាចមានប្រសិទ្ធិភាពបានសោះ ហើយពួកគេក៏មិនអាចវាយលុកចូលទៅលើពួកគេបានដែរ លើកលែងតែតាមផ្លូវចូលរបស់គេប៉ុណ្ណោះ ។

៥ ឥឡូវនេះ នៅពេលនេះ ពួកមេទ័ពឯកនៃសាសន៍លេមិន មានការភ្ញាក់ផ្អើលហួសប្រមាណ ដោយព្រោះប្រាជ្ញារបស់ពួកសាសន៍នីហ្វៃ ក្នុងការរៀបចំទីកន្លែងសន្តិសុខទាំងឡាយរបស់ពួកគេ ។

៦ ឥឡូវនេះ មេដឹកនាំទាំងឡាយរបស់សាសន៍លេមិន បានសន្និដ្ឋានថា ដោយព្រោះពួកគេមានចំនួនច្រើនលើសលប់ មែនហើយ ពួកគេបានសន្និដ្ឋានថា ពួកគេនឹងមានប្រៀបក្នុងការវាយប្រហារពួកគេ ដូចដែលពួកគេធ្លាប់បានធ្វើមក; មែនហើយ ហើយពួកគេក៏បាន ប្រុងប្រៀបខ្លួនដែរ ឲ្យមានខែលទាំងឡាយ និងប្រដាប់បាំងទ្រូងទាំងឡាយ; ហើយពួកគេក៏បានរៀបចំខ្លួនដែរ នូវសំលៀកបំពាក់ ដែលធ្វើ ពីស្បែក មែនហើយ សំលៀកបំពាក់ដ៏ក្រាស់មាំ ដើម្បីបិទបាំងភាពអាក្រាតរបស់ពួកគេ។

៧ ហើយដោយបានរៀបចំដូច្នេះ ពួកគេបានសន្និដ្ឋានថា គេនឹងយកឈ្នះយ៉ាងងាយ ហើយដាក់បងប្អូនគេឲ្យនៅក្រោមនឹមនៃសេវកភាព ឬសម្លាប់ និងកាប់សម្លាប់ពួកគេរង្គាល តាមចិត្តរបស់ពួកគេ ។

៨ ប៉ុន្តែមើលចុះ ពួកគេបានភ្ញាក់ផ្អើលហួសប្រមាណ ពួកគេបានប្រុងប្រៀបខ្លួនចាំពួកគេ តាមរបៀបមួយ ដែលមិនដែលបានស្គាល់ក្នុង ចំណោមកូនចៅរបស់លីហៃឡើយ ។ ឥឡូវនេះ ពួកគេបានប្រុងប្រៀបខ្លួនចាំពួកសាសន៍លេមិន ដើម្បីច្បាំងតាមរបៀបនៃសេចក្ដី បង្គាប់ទាំងឡាយរបស់មរ៉ូណៃ ។

៩ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិន

២៣ *ក* គ. និង ស. ៤២:៤៥.
២៤ *ក* អាលម៉ា ៤៦:១២.
*ខ* ស.ប. សេចក្ដីក្បត់សាសនា.
៤៩ ៣ *ក* អាលម៉ា ១៦:២–៣, ៩, ១១.
៨ *ក* អាលម៉ា ៤៨:៧–១០.

ឬពួកសាសន៍អាម៉ាលិកាយបានភ្ញាក់ផ្អើលជាអតិបរមា ចំពោះ
របៀបរៀបចំ ធ្វើសង្គ្រាមរបស់ពួកគេនេះ ។
១០ ឥឡូវនេះ បើសិនជាស្ដេចអាម៉ាលិកាយបានចុះមក
[ក]ពីដែនដីនីហ្វៃ នៅខាងមុខកងទ័ពរបស់ទ្រង់ ប្រហែលជាទ្រង់បាន
បញ្ជាឲ្យ ពួកលេមិនវាយប្រហារពួកនីហ្វៃ នៅឯទីក្រុង
អាំម៉ូណៃហាទៅហើយ; ត្បិតមើលចុះ ទ្រង់មិនគិតដល់ឈាម
របស់ប្រជាជនទ្រង់ឡើយ ។
១១ ប៉ុន្តែមើលចុះ អាម៉ាលិកាយមិនបានចុះមក
ច្បាំងផ្ទាល់ខ្លួនទេ ។ ហើយមើលចុះ ពួកមេទ័ពឯករបស់ទ្រង់ ពុំ
ហ៊ានវាយប្រហារពួក នីហ្វៃ នៅទីក្រុងអាំម៉ូណៃហាទេ ត្បិត
មរ៉ូណៃបានផ្លួសផ្លុលការអភិបាលកិច្ចការ នៅក្នុងចំណោមពួក
សាសន៍នីហ្វៃ ដរាបដល់ពួកសាសន៍ លេមិនខកចិត្ត នៅក្នុង
ទីតាំងទាំងឡាយរបស់ពួកគេ ហើយពួកគេមិនអាចវាយលុកមក
លើពួកគេបានឡើយ ។
១២ ហេតុដូច្នេះហើយ ពួកគេក៏ដកថយទៅក្នុងទីរហោស្ថានវិញ
ហើយយកជំរុំរបស់គេ ដើរឆ្ពោះទៅដែនដីណូអេ ដោយ
សន្និដ្ឋានថា នោះគឺជាទីកន្លែងដ៏ល្អបន្ទាប់ សំរាប់ពួកគេវាយលុក
ចូលទៅលើពួកនីហ្វៃបាន ។
១៣ ព្រោះពួកគេពុំដឹងថា មរ៉ូណៃបានពង្រឹង ឬបានស្ថា
[ក]បនាបន្ទាយសន្តិសុខទាំងឡាយ សំរាប់ទីក្រុងនីមួយៗ ដែលនៅ
ក្នុងដែនដី ជុំវិញទាំងអស់; ហេតុដូច្នេះហើយ ពួកគេបាន
ដើរឆ្ពោះទៅឯដែនដីណូអេ ដោយមានការប្ដេជ្ញាយ៉ាងមុតមាំ
មួយ; មែនហើយ ពួកមេទ័ពឯក របស់គេបានចេញមក ហើយ
ស្បថថា ពួកគេនឹងបំផ្លាញប្រជាជន នៅទីក្រុងនោះឲ្យបាន ។
១៤ ប៉ុន្តែមើលចុះ ជាការភ្ញាក់ផ្អើលរបស់ពួកគេវិញ ឯទីក្រុង
ណូអេ ដែលធ្លាប់ជាកន្លែងមួយដ៏ខ្សោយ ឥឡូវនេះ មក
ពីមធ្យោបាយទាំង ឡាយរបស់មរ៉ូណៃ បានក្លាយទៅជាមាំទាំ
មែនហើយ មាំទាំជាងទីក្រុងអាំម៉ូណៃហាទៅទៀត ។
១៥ ហើយឥឡូវនេះ មើលចុះ នេះគឺជាប្រាជ្ញារបស់មរ៉ូណៃ;
ព្រោះលោកបានសន្និដ្ឋានថា ពួកគេនឹងភិតភ័យ នៅឯទីក្រុង
អាំម៉ូណៃហា; ហើយដោយសារទីក្រុងណូអេ ធ្លាប់ជាកន្លែង
ដ៏ខ្សោយបំផុតនៃដែនដី ហេតុដូច្នេះហើយ ពួកគេនឹងទៅទីនោះ
ដើម្បីច្បាំង ហើយនេះគឺ ស្របតាមបំណងរបស់លោក ។
១៦ ហើយមើលចុះ មរ៉ូណៃបានតែងតាំងលីហៃ [ក]ឲ្យធ្វើ
ជាមេទ័ពឯកលើទ័ពនៃទីក្រុងនោះ; ហើយនោះគឺជាលីហៃដដែល
ដែលបាន ប្រយុទ្ធជាមួយនឹងពួកលេមិន នៅក្នុងច្រកភ្នំ នៅ
ខាងកើតទន្លេស៊ីដូន ។
១៧ ហើយឥឡូវនេះ មើលចុះ ហេតុការណ៍បានកើតឡើងថា
កាលពួកលេមិនបានដឹងថា លីហៃបញ្ជាការនៅទីក្រុងនោះ ពួក
គេក៏ខក ចិត្តជាថ្មីទៀត ព្រោះពួកគេខ្លាចលីហៃជាខ្លាំង; ទោះ
ជាយ៉ាងណាក៏ដោយ គង់តែពួកមេទ័ពឯករបស់គេបានស្បថ
ដោយពាក្យសម្បថមួយ ថានឹងវាយប្រហារទីក្រុងនោះ; ហេតុ
ដូច្នេះហើយ ពួកគេបាននាំពលទ័ពគេទៅ ។
១៨ ឥឡូវនេះ មើលចុះ ពួកលេមិនមិនអាចចូល ទៅក្នុង
បន្ទាយសន្តិសុខទាំងឡាយរបស់ពួកគេ ដោយផ្លូវណាផ្សេង
ក្រៅពីតាមទ្វារ ចូលបានឡើយ មកពីកំពស់នៃភ្លឺដែលបាន
ពូនឡើង និងជំរៅនៃរណ្ដៅដែលត្រូវបានជីកជុំវិញ លើកលែងតែ
ត្រង់ទ្វារចូលប៉ុណ្ណោះ ។
១៩ ម្ល៉ោះហើយ ពួកសាសន៍នីហ្វៃបានរៀបចំ ដើម្បីបំផ្លាញ
អស់ជនណា ដែលបំរុងឡើងចូលទៅក្នុងបន្ទាយ ដោយផ្លូវណា
ផ្សេងៗ ដោយបាញ់ក្រួស និងព្រួញទៅលើពួកគេ ។
២០ ម្ល៉ោះហើយ ពួកគេបានរៀបចំ មែនហើយ នូវមនុស្ស
ដ៏ខ្លាំងពូកែរបស់គេមួយកង ដោយមានដាវរបស់គេ និងខ្សែដង្ហ
ក់របស់គេ ដើម្បីវាយរំលំអស់ជនណា ដែលនឹងបំរុងចូលទៅក្នុង
ទីសន្តិសុខរបស់គេ តាមទ្វារចូលរបស់គេ; ម្ល៉ោះហើយ ពួកគេ
បានរៀបចំការពារ ខ្លួនពីពួកលេមិន ។
២១ ហើយហេតុការណ៍បានកើតឡើងថា ពួកមេទ័ពសាសន៍
លេមិន បាននាំពលទ័ពរបស់ខ្លួន មកខាងមុខទ្វារចូល ហើយបាន
ចាប់ផ្ដើម ប្រយុទ្ធនឹងពួកនីហ្វៃ ដើម្បីចូលទៅក្នុងកន្លែងសន្តិសុខ
របស់ពួកគេ; ប៉ុន្តែមើលចុះ ពួកគេត្រូវរុញច្រានថយក្រោយ
ម្ដងហើយម្ដងទៀត ដរាបដល់ពួកគេត្រូវស្លាប់ ដោយការ
កាប់សម្លាប់ដ៏ធ្ងន់ធ្ងរ ។
២២ ឥឡូវនេះ កាលពួកគេបានឃើញថា ពួកគេមិនអាច
យកឈ្នះដោយកម្លាំងទៅលើពួកសាសន៍នីហ្វៃ នៅតាមទ្វារចូល
បានទេ ពួកគេបានចាប់ផ្ដើមជីកទម្លុះភ្លឺដីទាំងឡាយរបស់ពួកគេ
ដើម្បីគេអាចធ្វើបានចន្លោះមួយ ឲ្យពលទ័ពរបស់គេចូល ដើម្បី
ពួកគេអាចមាន ប្រៀបស្មើគ្នា ដើម្បីប្រយុទ្ធ; ប៉ុន្តែមើលចុះ ក្នុង
ការប៉ុនប៉ងទាំងនេះ ពួកគេត្រូវគៀរទម្លាក់ដោយក្រួស និងព្រួញ
ទាំងឡាយ ដែលបាញ់មក លើពួកគេ; ហើយជាជាងការ
ទាញភ្លឺដីទាំងនោះចុះបំពេញរណ្ដៅទាំងឡាយ វាត្រូវបំពេញ

១០ *ក* ២ នីហ្វៃ ៥:៨; អោមណៃ ១:១២; អាលម៉ា ៤៧:១.
១៣ *ក* អាលម៉ា ៤៨:៨.
១៦ *ក* អាលម៉ា ៤៣:៣៥.

មួយកំរិត ដោយសាកសពរបស់គេ និងទ័ព ទាំងឡាយ
របស់គេដែលត្រូវរបួស ។
២៣ ម្ល៉ោះហើយ ពួកសាសន៍នីហ្វៃមានអំណាចទាំងស្រុង
ទៅលើពួកខ្មាំងសត្រូវរបស់គេ; ម្ល៉ោះហើយ ពួកសាសន៍លេមិន
បានខិតខំ បំផ្លាញពួកសាសន៍នីហ្វៃ រហូតដល់ពួកមេទ័ពឯក
របស់គេត្រូវស្លាប់អស់; មែនហើយ ហើយពួកលេមិនជាង
មួយពាន់នាក់ត្រូវស្លាប់ តែផ្ទុយ ទៅវិញ ពុំមានសាសន៍នីហ្វៃ
ណាម្នាក់ត្រូវស្លាប់ឡើយ ។
២៤ មានប្រហែលហាសិបនាក់ត្រូវរបួស ដោយត្រូវនឹងព្រួញ
ទាំងឡាយរបស់ពួកលេមិន តាមចន្លោះចេញចូល ប៉ុន្តែពួកគេ
ត្រូវបាន បាំងដោយខែលទាំងឡាយរបស់គេ និងប្រដាប់បាំងទ្រូង
ទាំងឡាយរបស់គេ និងមួកក្បាលទាំងឡាយរបស់គេ ដរាបដល់
មានរបួសភាគ ច្រើន នៅលើជើងរបស់គេ រីឯរបួសជាច្រើននោះ
មានទម្ងន់ធ្ងន់ណាស់ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិន
បានឃើញថា ពួកមេទ័ពឯករបស់គេទាំងអស់ត្រូវស្លាប់ នោះពួក
គេក៏រត់គេច ចូលទៅក្នុងទីរហោស្ថាន ។ ហើយហេតុការណ៍
បានកើតឡើងថា ពួកគេបានត្រឡប់ទៅឯដែនដីនីហ្វៃវិញ ដើម្បីឲ្យ
ដំណឹងដល់ស្ដេច របស់គេ គឺអាម៉ាលិកាយ ដែលមានដើម
កំណើតជាសាសន៍នីហ្វៃ អំពីបរាជ័យដ៏ធំរបស់ពួកគេ ។
២៦ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានខឹងនឹងទ័ព
របស់ទ្រង់ជាខ្លាំង ពីព្រោះទ្រង់ពុំបានសំរេចបំណងរបស់ខ្លួន ទៅលើ
ពួក សាសន៍នីហ្វៃសោះ; ទ្រង់ពុំបានដាក់ពួកគេឲ្យនៅក្រោមនឹម
នៃសេវកភាពឡើយ ។
២៧ មែនហើយ ទ្រង់ខឹងជាអតិបរមា [ខ] ហើយទ្រង់[ក]បាន
ជេរប្រទេចព្រះ និងម៉ូរ៉ូណៃផង ដោយស្បថនឹងពាក្យសម្បថមួយ
ថា ទ្រង់នឹងផឹក ឈាមរបស់លោក; ហើយនេះក៏ពីព្រោះម៉ូរ៉ូណៃ
បានកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ក្នុងការរៀបចំ
សំរាប់សន្តិសុខរបស់ប្រជាជន របស់លោក ។
២៨ ហើយហេ[ក]តុការណ៍បានកើតឡើងថា ផ្ទុយទៅវិញ
ប្រជាជននីហ្វៃបានអរព្រះគុណដល់ព្រះអម្ចាស់ ជាព្រះរបស់គេ
ដោយសារព្រះ ចេស្ដាដ៏ឥតប្រៀបផ្ទឹមបាន ក្នុងការដោះលែង
ពួកគេ ឲ្យរួចផុតពីកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវរបស់គេ ។
២៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់ប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ ។
៣០ មែនហើយ ហើយមានសេចក្ដីសុខសាន្តតរៀងមកនៅក្នុង
ចំណោមពួកគេ ហើយមានការចំរើនខាងសាសនាចក្រជាអតិបរមា
ដោយសារការយកចិត្តទុកដាក់ និងការព្យាយាមរបស់គេ ដែល
ពួកគេមានចំពោះព្រះបន្ទូលនៃព្រះ ដែលត្រូវបានប្រកាសដល់គេ
ដោយ ហេលេមិន និងស៊ិបឡុន និងកូរីអានតុន និងអាំម៉ូន និង
បងប្អូនរបស់លោក មែនហើយ និង[ក]ដោយអស់ពួកអ្នកដែល ត្រូវ
បានតែងតាំងឡើង ដោយរបៀបដ៏បរិសុទ្ធនៃព្រះ ដោយបាន
ទទួលបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្ត ហើយត្រូវបានចាត់ឲ្យ
ទៅផ្សាយ នៅក្នុងចំណោម ប្រជាជន ៕

## ជំពូកទី ៥០

*ម៉ូរ៉ូណៃពង្រឹងដែនដីទាំងឡាយនៃពួកនីហ្វៃ — ពួក
គេស្ថាបនាទីក្រុងថ្មីៗជាច្រើន — សង្គ្រាមទាំងឡាយ និង
ការបំផ្លិចបំផ្លាញទាំងឡាយ ធ្លាក់មកលើពួកសាសន៍នីហ្វៃ
នៅក្នុងថ្ងៃទាំងឡាយនៃអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំង
ឡាយរបស់គេ — ម៉ូរីអានតុន និងពួកបែក ចេញរបស់វា
ត្រូវបរាជ័យដោយទីអានគុម — នីហ្វៃហាស្លាប់ ហើយ
កូនប្រុសលោក គឺពេហូរ៉ានបំពេញវេទិកាជំនុំជំរះ ។ ប្រ
មាណជាឆ្នាំ ៧២–៦៧ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃពុំបាន
ឈប់ធ្វើការរៀបចំធ្វើសង្គ្រាម ឬការពារប្រជាជនលោកតទល់
នឹងពួក សាសន៍លេមិនឡើយ; ព្រោះលោកបានបញ្ជាឲ្យពល
ទ័ពលោកចាប់ផ្ដើម នៅដើមឆ្នាំទីម្ភៃក្នុងរជ្ជកាលនៃពួកចៅក្រម
ថាពួកគេត្រូវ ចាប់ផ្ដើមជីកដីគឡើង នៅជុំវិញទីក្រុងទាំងអស់
ទូទៅអស់ទាំងដែនដី ដែលមានពួកសាសន៍នីហ្វៃតាំងនៅ ។
២ ហើយនៅលើភ្លឺដីទាំងនេះ លោកបានបញ្ជាឲ្យមានឈើ មែន
ហើយ របងឈើទាំងឡាយ ដែលសង់ឡើង ឲ្យមានកំពស់ស្មើ
នឹងកំពស់មនុស្ស នៅជុំវិញទីក្រុងទាំងឡាយ ។
៣ ហើយលោកបានបញ្ជាឲ្យដោតនៅលើរបងឈើទាំងនោះ
នូវចំរូងស្រួចទាំងឡាយ លើរបងឈើនៅជុំវិញ; ហើយវាមាំ
ហើយខ្ពស់ ។
៤ ហើយលោកបានបញ្ជាឲ្យសង់ប៉មទាំងឡាយ ដែល
បែរឆ្ពោះទៅពីលើចំរូងទាំងនោះ ហើយលោកបានបញ្ជាឲ្យ
សង់កន្លែងសន្តិសុខ ទាំងឡាយ នៅលើប៉មទាំងនោះ ដើម្បីក្រួស

២៧ *ក* ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.
*ខ* កិច្ចការ ២៣:១២.
២៨ *ក* ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
៣០ *ក* អាលម៉ា ៤៣:២.

និងព្រួញទាំងឡាយ របស់ពួកសាសន៍លេមិន មិនអាចធ្វើឲ្យពួកគេរបួសបានឡើយ ។

៥ ហើយពួកគេបានរៀបចំជាស្រេច ដើម្បីពួកគេអាចចោលថ្មពីលើនោះ តាមចំណង់ និងកម្លាំងរបស់ពួកគេ ហើយសម្លាប់ជនណា ដែលនឹងប៉ុនប៉ងមកជិតកំផែងទីក្រុង ។

៦ ម្ល៉ោះហើយ មរ៉ូណៃបានរៀបចំតំបន់ការពារប្រឆាំងនឹងការវាយលុក នៃពួកខ្មាំងសត្រូវរបស់គេនៅជុំវិញគ្រប់ទីក្រុងនៅអស់ទាំង ដែនដី ។

៧ ហើយហេតុការណ៍បានកើតឡើងថា មរ៉ូណៃបានបញ្ជាឲ្យពលទ័ពរបស់លោក ធ្វើដំណើរចូលទៅក្នុងទីរហោស្ថានខាងកើត; មែនហើយ ហើយពួកគេបានទៅ ហើយរុញច្រានពួកសាសន៍លេមិនទាំងអស់ ដែលនៅក្នុងទីរហោស្ថានខាងកើត ឲ្យចូលទៅក្នុងដែនដី របស់គេផ្ទាល់ ដែលនៅខាងត្បូងដែនដីសារ៉ាហិមឡា ។

៨ ហើយដែនដីនីហ្វៃ មាននៅតាមផ្លូវត្រង់ចាប់ពីសមុទ្រខាងកើត ទៅខាងលិច ។

៩ ហើយហេតុការណ៍បានកើតឡើងថា កាលមរ៉ូណៃបានរុញច្រានពួកសាសន៍លេមិនទាំងអស់ ចេញពីទីរហោស្ថានខាងកើត គឺនៅ ខាងជើងដែនដីទាំងឡាយ ដែលជារបស់គេហើយនោះលោកបានបញ្ជាឲ្យបណ្ដាជន ដែលនៅក្នុងដែនដីសារ៉ាហិមឡា និងដែនដីជុំវិញ នោះ ឲ្យចូលទៅក្នុងទីរហោស្ថានខាងកើត គឺរហូតដល់ព្រំប្រទល់ទាំងឡាយ ជិតឆ្នេរសមុទ្រ ហើយយកដីនោះ ។

១០ ហើយលោកក៏បានដាក់ពលទ័ព នៅទិសខាងត្បូង នៅក្នុងព្រំប្រទល់ទាំងឡាយ នៃដែនដីរបស់គេ ហើយបានបញ្ជាឲ្យពួកគេលើក តំបន់ការពារទាំងឡាយ ដើម្បីពួកគេអាចរក្សាសន្តិសុខដល់ពលទ័ពរបស់គេ និងដល់ប្រជាជនរបស់គេ ពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ របស់គេ ។

១១ ម្ល៉ោះហើយ លោកបានកាត់ផ្ដាច់អស់ទាំងតំបន់ការពារទាំងឡាយ របស់ពួកសាសន៍លេមិន ដែលនៅក្នុងទីរហោស្ថានខាងកើត មែនហើយ ហើយនៅខាងលិចផងដោយបង្កើនកម្លាំង ដល់ខ្សែការពារនៅចន្លោះពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន នៅចន្លោះ ដែនដីសារ៉ាហិមឡា និងដែនដីនីហ្វៃ ពីសមុទ្រខាងលិច កាត់តាមក្បាលទន្លេស៊ីដូន — ពួកសាសន៍នីហ្វៃមានដែនដីទាំងអស់ទៅទិសខាង ជើង មែនហើយ និងដែនដីទាំងអស់ ដែលនៅខាងជើងដែនដីបរិបូរណ៍តាមចំណង់របស់គេ ។

១២ ម្ល៉ោះហើយ មរ៉ូណៃជាមួយនឹងពលទ័ពរបស់លោក ដែលបានកើនឡើងជារៀងរាល់ថ្ងៃ ដោយសារការធានាការពារ ដែលកិច្ចការរបស់លោកបាននាំមកឲ្យពួកគេ បានរកកាត់ផ្ដាច់កម្លាំង និងអំណាចរបស់ពួកសាសន៍លេមិន ពីដែនដីរបស់ពួកគេ ដើម្បីកុំឲ្យពួកគេ មានអំណាចនៅលើដែនដីទាំងឡាយរបស់ពួកគេឡើយ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍នីហ្វៃបានចាប់ផ្ដើមស្ថាបនាទីក្រុងមួយ ហើយគេបានឲ្យឈ្មោះទីក្រុងនោះថា មរ៉ូណៃ; ហើយគឺនៅក្បែរសមុទ្រខាងកើត ហើយនៅទិសខាងត្បូង ជិតព្រំប្រទល់ដែនដី នៃពួកសាសន៍លេមិន ។

១៤ ហើយពួកគេក៏បានចាប់ផ្ដើមស្ថាបនាទីក្រុងមួយដែរ នៅចន្លោះទីក្រុងមរ៉ូណៃ និងទីក្រុងអើរ៉ុន ជាប់នឹងព្រំប្រទល់ក្រុងអើរ៉ុន និងក្រុង មរ៉ូណៃ; ហើយពួកគេបានឲ្យឈ្មោះទីក្រុងនោះ ឬដែនដីនោះថា នីហ្វៃហា ។

១៥ ហើយពួកគេបានចាប់ផ្ដើម ក្នុងឆ្នាំដដែលនោះ ស្ថាបនាទីក្រុងជាច្រើននៅទិសខាងជើង ដោយរបៀបពិសេសដែលគេហៅថា លីហៃ ដែលនៅខាងជើងជិតព្រំប្រទល់ទាំងឡាយនៃឆ្នេរសមុទ្រ ។

១៦ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីម្ភៃទៅ ។

១៧ ហើយនៅក្នុងកាលៈទេសៈដ៏ចំរើនទាំងនេះ ប្រជាជននីហ្វៃបានរស់នៅដើមឆ្នាំទីម្ភៃមួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

១៨ ហើយពួកគេបានចំរើនឡើងដ៏លើសលប់ ហើយពួកគេបានក្លាយទៅជាអ្នកមានទ្រព្យដ៏លើសលប់; មែនហើយ ហើយពួកគេបាន កើនចំនួនឡើង និងខ្លាំងពូកែនៅក្នុងដែនដី ។

១៩ ម្ល៉ោះហើយ យើងឃើញថា ទំនាក់ទំនងទាំងអស់របស់ព្រះអម្ចាស់ ប្រកបដោយសេចក្ដីមេត្តាករុណា ហើយត្រឹមត្រូវពន់ប្រមាណ ក្នុងការបំពេញព្រះបន្ទូលទាំងអស់របស់ទ្រង់ ដល់កូនចៅមនុស្ស; មែនហើយ យើងអាចមើលឃើញថា ព្រះបន្ទូលទាំងឡាយរបស់ទ្រង់ ត្រូវបានបញ្ជាក់ ដូចជានៅពេលនេះ ដែលទ្រង់មានព្រះបន្ទូលទៅកាន់លីហៃថា៖

២០ អ្នកមានពរហើយ និងកូនចៅអ្នកផង; ហើយពួកគេនឹងបានពរ ដរាបណាពួកគេកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះ

៥០ ១០*ក* អាលម៉ា ៤៩:១៨–២២.

ពួកគេ នឹងបានចំរើនឡើងនៅលើដែនដី ។ ប៉ុន្តែ ចូរចាំថា ដរាបណា
ពួកគេពុំកាន់តាមបញ្ញត្តិទាំងឡាយរបស់យើងទេ នោះពួកគេនឹង
ត្រូវកាត់ ចេញពីវត្តមាននៃព្រះអម្ចាស់ ។
២១ ហើយយើងឃើញថា ពាក្យសន្យាទាំងនេះ ត្រូវបាន
បញ្ជាក់ជាពិត ដល់ប្រជាជននីហ្វៃ; ព្រោះដោយមកពីជម្លោះ
ទាំងឡាយ របស់គេ និងការទាស់ទែងទាំងឡាយរបស់គេ មែន
ហើយ អំពើឃាតកម្មទាំងឡាយរបស់គេ និងអំពើលួចប្លន់ទាំង
ឡាយរបស់គេ ការថ្វាយបង្គំរូបព្រះរបស់គេ អំពើ
សហាយស្មន់ទាំងឡាយរបស់គេ និងអំពើគួរខ្ពើមឆ្អើមទាំង
ឡាយរបស់គេ ដែលមាននៅក្នុងចំណោម ពួកគេផ្ទាល់ ដែល
នាំមកលើពួកគេនូវសង្គ្រាមទាំងឡាយរបស់គេ និងការ
បំផ្លិចបំផ្លាញទាំងឡាយរបស់គេ ។
២២ ហើយអស់អ្នកណាដែលស្មោះត្រង់ ក្នុងការកាន់តាមព្រះ
បញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ ត្រូវបានដោះលែងគ្រប់ពេលវេលា
នៅពេលដែលបងប្អូនគេ ដែលទុច្ចរិតរាប់ពាន់នាក់ ត្រូវដាក់ទៅ
ក្នុងសេវកភាព ឬត្រូវវិនាសបង់ដោយដាវ ឬចុះអន់ថយក្នុង
ការឥត ជំនឿ ហើយនៅលាយឡំជាមួយនឹងពួកសាសន៍លេមិន ។
២៣ ប៉ុន្តែមើលចុះ ពុំដែលមានពេលណានៅក្នុង
ចំណោមប្រជាជននីហ្វៃ ដែលសប្បាយជាងសម័យមរ៉ូណៃឡើយ
ចាប់តាំងពីសម័យ នីហ្វៃមក មែនហើយ ទាំងក្នុងពេលនេះ
នៅឆ្នាំទីម្ភៃមួយក្នុងរជ្ជកាលនៃពួកចៅក្រម ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីម្ភៃពីរក្នុងរជ្ជកាល
នៃពួកចៅក្រម ក៏ចប់ក្នុងសន្តិភាពដែរ; មែនហើយ ហើយ
ឆ្នាំទីម្ភៃបីផង ។
២៥ ហើយហេតុការណ៍បានកើតឡើងថា នៅដើម
ឆ្នាំទីម្ភៃបួនក្នុងរជ្ជកាលនៃពួកចៅក្រម ប្រាកដជាមានសន្តិភាពនៅ
ក្នុងចំណោម ប្រជាជននីហ្វៃ ប្រសិនបើគ្មានការទាស់ទែងគ្នាមួយ
ដែលកើតឡើងនៅក្នុងចំណោមពួកគេ អំពីដែនដីលីហៃ និង
ដែនដីម៉ូរីអានតុន ដែលនៅជាប់ព្រំប្រទល់ដែនដីលីហៃ; ដែនដី
ទាំងពីរនៅជាប់នឹងឆ្នេរសមុទ្រ ។
២៦ ត្បិតមើលចុះ ប្រជាជនដែលយកដែនដីម៉ូរីអានតុន បាន
ទាមទារយកដែនដីលីហៃមួយភាគ; ហេតុដូច្នេះហើយ ក៏ចាប់ផ្ដើម
មានការ ទាស់ទែងគ្នាដ៏ក្ដៅមួយរវាងពួកគេ ដរាបដល់ប្រជាជន
នៃដែនដីម៉ូរីអានតុន បានលើកអាវុធទាស់នឹងបងប្អូនខ្លួន ហើយពួក
គេបានប្ដេជ្ញា ចិត្តថា នឹងសម្លាប់ពួកគេចោលដោយដាវ ។
២៧ ប៉ុន្តែមើលចុះ ប្រជាជនដែលយកដែនដីលីហៃ បាន
រត់ភៀសខ្លួនទៅខាងជំរុំនៃមរ៉ូណៃ ហើយបានអង្វរឲ្យលោកជួយ;
ត្បិតមើលចុះ ពួកគេពុំមានកំហុសអ្វីសោះ ។
២៨ ហើយហេតុការណ៍បានកើតឡើងថា កាលប្រជាជន
ម៉ូរីអានតុន ដែលដឹកនាំដោយបុរសម្នាក់ មានឈ្មោះថា ម៉ូរីអានតុន
បានដឹងថា ប្រជាជនលីហៃបានភៀសខ្លួនទៅខាងជំរុំមរ៉ូណៃ នោះ
ពួកគេភិតភ័យជាខ្លាំង ខ្លាចក្រែងកងទ័ពរបស់មរ៉ូណៃ នឹង
មកវាយ មកលើពួកគេ ហើយបំផ្លាញគេចោល ។
២៩ ហេតុដូច្នេះហើយ ម៉ូរីអានតុនបានដាក់ក្នុងចិត្តគេថា ពួកគេ
ត្រូវរត់ភៀសខ្លួន ទៅឯដែនដីដែលនៅខាងជើង ដែលឡោមព័ទ្ធជុំវិញ
ទៅដោយទឹកដ៏ច្រើន ហើយយកដែនដីនោះ ដែលនៅទិស
ខាងជើង ។
៣០ ហើយមើលចុះ ពួកគេច្បាស់ជាអនុវត្តផែនការនេះ (ដែល
ច្បាស់ជាដើមហេតុមួយគួរឲ្យយំសោក) ប៉ុន្តែមើលចុះ ម៉ូរីអានតុន
ជាមនុស្សម្នាក់ ប្រកបទៅដោយចិត្តក្ដៅ ហេតុដូច្នេះហើយ វាខឹង
នឹងស្ត្រីបំរើម្នាក់ ហើយវាបានសង្គ្រុបនាង ហើយវាយនាងជាខ្លាំង ។
៣១ ហើយហេតុការណ៍បានកើតឡើងថា នាងបាន
រត់ភៀសខ្លួន ហើយបានមកខាងជំរុំនៃមរ៉ូណៃ ហើយបានប្រាប់
មរ៉ូណៃនូវគ្រប់ ការណ៍ទាំងអស់ ដែលទាក់ទងនឹងរឿងនេះ ព្រម
ទាំងអំពីបំណងទាំងឡាយរបស់គេ ចង់រត់ភៀស ទៅក្នុង
ដែនដីផ្នែកខាងជើងផង ។
៣២ ឥឡូវនេះ មើលចុះ ប្រជាជនដែលនៅឯដែនដីបរិបូរណ៍
ឬនិយាយឲ្យចំ គឺមរ៉ូណៃ ខ្លាចក្រែងពួកគេស្ដាប់តាមពាក្យរបស់
ម៉ូរីអានតុន ហើយរួបរួមជាមួយនឹងប្រជាជនរបស់វា ម្ល៉ោះហើយ
វានឹងយកបានផ្នែកទាំងឡាយនៃដែនដីនោះ ដែលជាមូលដ្ឋាន
សំរាប់ផលវិបាកដ៏ធ្ងន់ធ្ងរទាំងឡាយ នៅក្នុងចំណោមប្រជាជននីហ្វៃ
មែនហើយ ដែលជាផលវិបាកនាំឲ្យរំលំឥស្សរភាពរបស់គេ ។
៣៣ ហេតុដូច្នេះហើយ មរ៉ូណៃបានចាត់ឲ្យទ័ពមួយកង ជា
មួយនឹងជំរុំរបស់គេ ចេញទៅស្ទាក់មុខប្រជាជនរបស់ម៉ូរីអានតុន
ដើម្បីបញ្ឈប់ការភៀសខ្លួន ចូលទៅដែនដីខាងជើង ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេពុំបានស្ទាក់មុខ
ពួកនោះ រហូតដល់គេបានមកដល់ព្រំប្រទល់ នៃដែនដីចោលស្ងាត់;
ហើយនៅទីនោះ ពួកគេបានស្ទាក់មុខពួកនោះ តាមច្រកដ៏ចង្អៀត
ដែលនៅតាមបណ្ដោយសមុទ្រ ដែលនាំទៅកាន់ដែនដីទិសខាងជើង
មែនហើយ នៅជិតសមុទ្រនៅខាងលិច និងនៅខាងកើត ។

២០ *ក* គ. និង ស. ១:១៤.
២៣ *ក* ម៉ូសាយ ២:៤១.
២៥ *ក* ស.ប. ការទាស់ទែង.
៣២ *ក* ស.ប. ឥស្សរភាព.
៣៤ *ក* អាលម៉ា ៤៦:១៧.

៣៥ ហើយហេតុការណ៍បានកើតឡើងថា កងទ័ពដែលម៉ូរ៉ូណៃបានចាត់ឲ្យទៅនោះ ដែលបានដឹកនាំដោយមនុស្សម្នាក់ដែលមាន ឈ្មោះថា ទីអានគុម បានជួបនឹងប្រជាជនរបស់ម៉ូរីអានតុន; ហើយប្រជាជនរបស់ម៉ូរីអានតុន រឹងរូសក្រៃលែង (ដោយត្រូវបានញុះញង់ ដោយអំពើទុច្ចរិតរបស់វា និងពាក្យបញ្ជោររបស់វា) រហូតដល់មានការប្រយុទ្ធមួយចាប់ផ្ដើមឡើងរវាងពួកគេ ហើយនៅក្នុងការប្រយុទ្ធ នោះ ទីអានគុមបានសម្លាប់ម៉ូរីអានតុន ហើយធ្វើឲ្យបរាជ័យដល់កងទ័ពរបស់វា ហើយបានចាប់ពួកវាយកទៅជាឈ្លើយ ហើយបាន ត្រឡប់ទៅកាន់ជំរុំនៃម៉ូរ៉ូណៃវិញ ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីម្ភៃបួនក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

៣៦ ម្ល៉ោះហើយ ប្រជាជនរបស់ម៉ូរីអានតុនត្រូវបាននាំមកវិញ ។ ហើយកាលពួកគេធ្វើសេចក្ដីសញ្ញាថានឹងរក្សាសន្ដិភាព នោះពួកគេ ត្រូវបានឲ្យទៅនៅដែនដីម៉ូរីអានតុនវិញ ហើយការសាមគ្គីក៏កើតឡើងរវាងពួកគេនឹងប្រជាជនលីហៃ; ហើយពួកគេក៏បានដីទៅគេវិញដែរ ។

៣៧ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំដដែលដែលប្រជាជននីហ្វៃបានសន្ដិភាពមកវិញ នោះនីហ្វៃហាជាមេចៅក្រម ទីពីរបានស្លាប់ទៅ បន្ទាប់ពីបានបំពេញវេទិកាជំនុំជំរះ ដោយភាពស្មោះត្រង់ ដ៏ឥតខ្ចោះនៅចំពោះព្រះ ។

៣៨ ទោះជាយ៉ាងណាក៏ដោយ គង់តែលោកបានប្រកែកនឹងអាលម៉ាដែរ មិនព្រមយកបញ្ជីទាំងឡាយ និងវត្ថុទាំងឡាយដែលអាលម៉ា និងពួកអយ្យកោលោក ចាត់ទុកជាពិសិដ្ឋបំផុត; ហេតុដូច្នេះហើយ អាលម៉ាបានប្រគល់របស់ទាំងនេះ ទៅកូនប្រុសរបស់លោក គឺហេលេមិន ។

៣៩ មើលចុះ ហេតុការណ៍បានកើតឡើងថា កូនប្រុសរបស់នីហ្វៃហា ត្រូវបានតែងតាំងឡើងឲ្យបំពេញវេទិកាជំនុំជំរះជំនួសឪពុករបស់ ខ្លួន; មែនហើយ លោកត្រូវបានតែងតាំងឡើងជាមេចៅក្រម និងជាអ្នកអភិបាលលើប្រជាជនដោយពាក្យសម្បថ និងពិធីពិសិដ្ឋថា នឹងជំនុំជំរះដោយសុចរិតហើយនឹងរក្សាសន្ដិភាព និងសេរីភាពរបស់ប្រជាជន ហើយប្រទានដល់ពួកគេ នូវឯកសិទ្ធដ៏ពិសិដ្ឋទាំងឡាយ របស់គេ ក្នុងការថ្វាយបង្គំព្រះអម្ចាស់ ជាព្រះរបស់ពួកគេ មែនហើយ ដើម្បីគាំទ្រហើយរក្សានូវឧត្ដមគតិនៃព្រះអស់មួយជីវិតលោក ហើយដើម្បីនាំពួកទុច្ចរិត ទៅរកសេចក្ដីយុត្តិធម៌ តាមទោសឧក្រិដ្ឋរបស់គេ ។

៤០ ឥឡូវនេះ មើលចុះ ឈ្មោះលោកគឺ ពេហូរ៉ាន ហើយពេហូរ៉ានបានបំពេញវេទិការបស់ឪពុកលោក ហើយបានចាប់ផ្ដើមរជ្ជកាល របស់លោក នៅចុងឆ្នាំទីម្ភៃបួន ទៅលើប្រជាជននីហ្វៃ ។

## ជំពូកទី ៥១

*ពួកនិយមស្ដេចរកកែប្រែក្រិត្យវិន័យ ហើយលើកស្ដេចមួយឡើង — ពេហូរ៉ាន និងពួកសេរី ត្រូវបានគាំទ្រដោយសម្លេងរបស់ប្រជាជន — ម៉ូរ៉ូណៃបង្ខំពួកនិយមស្ដេច ឲ្យការពារសេរីភាពរបស់ពួកគេ ឬក៏ត្រូវយកទៅប្រហារជីវិតចោល — អាម៉ាលិកាយ និងពួកសាសន៍លេមិន យកបានទីក្រុងដ៏មាំមួនជាច្រើន — ទីអានគុមកំចាត់ការវាតត្បាតនៃពួកលេមិន ហើយប្រហារអាម៉ាលិកាយ នៅក្នុងត្រសាលរបស់ទ្រង់ ។ ប្រមាណជាឆ្នាំ ៦៧–៦៦ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីម្ភៃប្រាំ ក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ពួកគេបានសាងសន្ដិភាព រវាងប្រជាជនរបស់លីហៃនឹងប្រជាជនរបស់ម៉ូរីអានតុន អំពីដែនដីទាំងឡាយរបស់គេ ហើយបានចាប់ផ្ដើមឆ្នាំទីម្ភៃប្រាំ ក្នុងសន្ដិភាព ។

២ ក៏ប៉ុន្តែ ពួកគេពុំបានរក្សាសន្ដិភាពទាំងស្រុងនៅលើដែនដីយូរប៉ុន្មានទេ ព្រោះចាប់ផ្ដើមមានការទាស់ទែងគ្នាមួយ នៅក្នុង ចំណោមប្រជាជន អំពីមេចៅក្រមពេហូរ៉ាន; ត្បិតមើលចុះ មានប្រជាជនមួយផ្នែក ដែលមានបំណងចង់ឲ្យចំណុចពិសេសខ្លះនៃ ក្រិត្យវិន័យត្រូវកែប្រែ ។

៣ ប៉ុន្តែមើលចុះ ពេហូរ៉ានពុំព្រមកែប្រែ ឬពុំសុខចិត្តឲ្យក្រិត្យវិន័យនោះ ត្រូវបានកែប្រែសោះ; ហេតុដូច្នេះហើយ លោកពុំបានស្ដាប់ តាមពួកជនដែលដាក់ពាក្យសំណូមពរ អំពីការកែប្រែក្រិត្យវិន័យនោះឡើយ ។

៤ ហេតុដូច្នេះហើយ ពួកជនដែលចង់ឲ្យក្រិត្យវិន័យត្រូវកែប្រែនោះក៏ខឹងនឹងលោក ហើយមានបំណងចង់ឲ្យលោកឈប់ធ្វើជាមេចៅក្រម លើដែនដីនេះតទៅទៀតហើយ; ហេតុដូច្នេះហើយក៏កើតមានការទាស់ទែងដ៏ក្ដៅមួយអំពីរឿងនេះ ប៉ុន្តែមិនដល់មានការខ្ចាយឈាមទេ ។

៥ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកដែលមានបំណងចង់ឲ្យពេហូរ៉ាន ត្រូវធ្លាក់ពីវេទិកាជំនុំជំរះនោះ ត្រូវបានហៅថា ពួកនិយមស្ដេច ព្រោះពួកគេមានបំណងចង់ឲ្យក្រិត្យវិន័យ ត្រូវកែប្រែតាមរបៀបមួយ ដែលរំលំរដ្ឋាភិបាលសេរី ហើយបង្កើតឲ្យមាន ស្ដេចមួយលើដែនដីនេះ ។

៦ ហើយពួកអ្នកដែលមានបំណងចង់ឲ្យពេហូរ៉ាន នៅធ្វើជាមេចៅក្រមលើដែនដីនេះ បានដាក់ឈ្មោះពួកគេថា ពួកសេរី; ម្ល៉ោះហើយ មានការបែកបាក់នៅក្នុងចំណោមពួកគេ ព្រោះពួកសេរីបានស្បថ ឬបានធ្វើសេចក្ដីសញ្ញាថា នឹងរក្សាសិទ្ធិរបស់ពួកគេ និងឯកសិទ្ធិទាំងឡាយនៃសាសនារបស់ពួកគេ ដោយរដ្ឋាភិបាលសេរីមួយ ។

៧ ហើយហេតុការណ៍បានកើតឡើងថា បញ្ហានៃការទាស់ទែងគ្នារបស់ពួកគេនេះ ត្រូវបានដោះស្រាយ ដោយសម្លេងរបស់ប្រជាជន ។ ហើយហេតុការណ៍បានកើតឡើងថា សម្លេងរបស់ប្រជាជនបានគាំទ្រពួកសេរី ហើយពេហូរ៉ានបានរក្សាវេទិកាជំនុំជំរះ ដែលនាំឲ្យ មានការអររីករាយជាខ្លាំង នៅក្នុងចំណោមបងប្អូនរបស់ពេហូរ៉ាន និងប្រជាជននៃឥស្សរភាពជាច្រើនគ្នាផង ពួកគេក៏បានធ្វើឲ្យពួក និយមស្ដេចស្ងប់ស្ងាត់ ដែលពួកគេមិនហ៊ានប្រឆាំងតបតឡើយ តែត្រូវបានបង្ខំឲ្យរក្សាឧត្ដមគតិនៃសេរីភាពវិញ។

៨ [ក] ឥឡូវនេះ ពួកជនដែលគាំទ្រស្ដេច គឺជាពួកអ្នកដែលមានត្រកូលខ្ពស់ ហើយពួកគេបានស្វែងរកធ្វើជាស្ដេច; ហើយពួកគេត្រូវបាន គាំទ្រ ដោយពួកអ្នកដែលស្វែងរកអានុភាព និងសិទ្ធិអំណាចលើប្រជាជន ។

៩ ប៉ុន្តែមើលចុះ នេះគឺជាពេលដ៏សំខាន់មួយ ដែលមានការទាស់ទែងគ្នាទាំងឡាយបែបនេះ នៅក្នុងចំណោមប្រជាជននីហ្វៃ; ត្បិត មើលចុះ អាម៉ាលិកាយបានចាក់រុកចិត្តនៃពួកសាសន៍លេមិនជាថ្មីទៀត ឲ្យទាស់នឹងប្រជាជននៃសាសន៍នីហ្វៃ ហើយទ្រង់កំពុងតែប្រមូល ពួកទាហាន ពីគ្រប់តំបន់នៃអស់ទាំងដែនដីរបស់ទ្រង់ ហើយប្រដាប់អាវុធឲ្យគេ ហើយរៀបចំធ្វើសង្គ្រាម[ក] ដោយអស់ទាំងការព្យាយាម; ព្រោះទ្រង់បានស្បថថា នឹងផឹកឈាមរបស់ម៉ូរ៉ូណៃ ។

១០ ប៉ុន្តែមើលចុះ យើងនឹងឃើញថា ពាក្យសន្យារបស់ទ្រង់ដែលទ្រង់បានធ្វើនោះ គឺគ្មានការប្រយ័ត្នប្រយែងសោះ; ទោះជាយ៉ាង ណាក៏ដោយ គង់តែទ្រង់បានរៀបចំខ្លួន និងពលទ័ពរបស់ទ្រង់ដែរ ដើម្បីមកធ្វើចម្បាំងតទល់នឹងពួកសាសន៍នីហ្វៃ ។

១១ ឥឡូវនេះ ពលទ័ពរបស់ទ្រង់ពុំសូវធំដូចពួកគេពីមុនទេ ដោយព្រោះច្រើនពាន់នាក់ត្រូវស្លាប់ ដោយដៃនៃពួកសាសន៍នីហ្វៃ; ប៉ុន្តែ ទោះជាគេមានការខូចខាតដ៏ធំក៏ដោយ គង់តែអាម៉ាលិកាយប្រមូលបានកងទ័ពដ៏ធំអស្ចារ្យមួយដែរ ដរាបដល់ទ្រង់មិនខ្លាចចុះមកដែនដី សារ៉ាហិមឡាឡើយ ។

១២ មែនហើយ ទាំងអាម៉ាលិកាយក៏បានចុះមកផ្ទាល់ នៅខាងមុខពួកលេមិន ។ ហើយនៅឆ្នាំទីម្ភៃប្រាំក្នុងរជ្ជកាលនៃពួកចៅក្រម ហើយនៅក្នុងពេលដដែលនេះ ដែលពួកគេបានចាប់ផ្ដើមដោះស្រាយរឿងរ៉ាវ នៃការទាស់ទែងគ្នារបស់ពួកគេអំពីមេចៅក្រម ពេហូរ៉ាន ។

១៣ ហើយហេតុការណ៍បានកើតឡើងថា កាលពួកអ្នកដែលខ្លួនហៅថា ពួកនិយមស្ដេច បានឮថា ពួកសាសន៍លេមិនកំពុងតែមក ច្បាំងនឹងពួកគេ នោះពួកគេសែនរីករាយនៅក្នុងចិត្ត; ហើយពួកគេបានប្រកែកមិនព្រម[ក]កាន់អាវុធសោះ ព្រោះពួកគេខឹងនឹងមេចៅក្រម និងប្រជាជននៃឥស្សរភាពផងថា ពួកគេមិនព្រមកាន់អាវុធ ការពារប្រទេសរបស់គេទេ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា កាលម៉ូរ៉ូណៃបានឃើញដូច្នោះ ហើយបានឃើញផងដែរថា ពួកលេមិនកំពុងតែលើក ទ័ពមក ក្នុងព្រំប្រទល់ទាំងឡាយនៃដែនដី នោះលោកក៏ខឹងជាអតិបរមា ដោយព្រោះភាពរឹងទទឹងរបស់ពួកជន ដែលលោកបានខិតខំធ្វើ ការដោយសេចក្ដីព្យាយាមជាខ្លាំងដើម្បីរក្សា; មែនហើយ លោកបានខឹងជាអតិបរមាព្រលឹងលោកពោរពេញទៅដោយកំហឹងខឹងនឹង ពួកគេ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា លោកបានធ្វើសំណូមពរមួយ តាមសម្លេងរបស់ប្រជាជន ទៅលោកអភិបាលនៃដែនដី សូមឲ្យលោកអានវា ហើយប្រទានដល់លោក (ម៉ូរ៉ូណៃ) នូវអំណាច ដើម្បីបង្ខំពួកជនដែលបែកចេញទាំងនោះឲ្យការពារប្រទេស របស់គេ ឬក៏ត្រូវប្រហារជីវិតបង់ ។

១៦ ព្រោះគឺជាការកង្វល់ទីមួយរបស់លោក គឺបញ្ចប់នូវការទាស់ទែងគ្នា និងការបែកចេញបែបនេះ ក្នុងចំណោមប្រជាជន; ត្បិតមើលចុះ តាំងពីមុនមក ការណ៍នេះហើយដែលជាដើមហេតុនៃអស់ទាំងសេចក្ដីបំផ្លិចបំផ្លាញរបស់ពួកគេ ។ ហើយហេតុការណ៍បានកើតឡើងថា ការណ៍នោះត្រូវបានយល់ព្រម តាមសម្លេងរបស់ប្រជាជន ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃបានបញ្ជាទ័ពរបស់លោកថា ត្រូវប្រឆាំងនឹងពួកនិយមស្ដេចទាំងនោះដើម្បីទាញ ទម្លាក់នូវសេចក្ដីឆ្មើងឆ្មៃរបស់គេ និងអភិជនភាពរបស់គេ ហើយពង្រាបវាដល់ដី ឬក៏ពួកគេត្រូវកាន់អាវុធហើយគាំទ្រដល់ឧត្ដមគតិនៃ ឥស្សរភាព ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពបានលើកទៅទាស់នឹងពួកគេ; ហើយពួកគេត្រូវបានទាញទម្លាក់នូវ

៥១ ៨ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ. | ៩ *ក* អាលម៉ា ៤៩:២៦–២៧. | ១៣ *ក* អាលម៉ា ៤៦:១០–១៦.

សេចក្ដីឆ្មើងឆ្មៃ របស់ពួកគេ និងអភិជនភាពរបស់ពួកគេ
ដរាបដល់ពេលណាដែលពួកគេបានលើកគ្រឿងសស្ត្រាវុធពិជ័យ
សង្គ្រាមរបស់គេ ដើម្បី ប្រយុទ្ធតទល់នឹងទ័ពរបស់មរ៉ូណៃ នោះ
ពួកគេត្រូវកាប់ទម្លាក់ចុះ ហើយត្រូវពង្រាបដល់ដី ។
១៩ ហើយហេតុការណ៍បានកើតឡើងថា មានពួកដែល
បែកចេញនោះចំនួនបួនពាន់នាក់ ដែលត្រូវកាប់ទម្លាក់ចុះដោយ
ដាវ ហើយពួកមេដឹកនាំរបស់គេទាំងនោះ ដែលពុំត្រូវ
ស្លាប់ក្នុងសមរភូមិ នោះត្រូវចាប់ ហើយដាក់ក្នុងគុក ព្រោះគ្មាន
ពេលសំរាប់ជំនុំជំរះ ពួកគេ នៅក្នុងរយៈពេលនេះទេ ។
២០ ហើយពួកអ្នកដែលបែកចេញ ដែលនៅសល់ទាំងប៉ុន្មាន
ដោយពុំចង់ត្រូវកាប់ទម្លាក់ទៅលើដីដោយដាវ ក៏បានចុះចូលក្រោម
ទង់ឥស្សរភាព ហើយត្រូវបានបង្ខំឲ្យលើកទង់ឥស្សរភាពឡើងលើ
ប៉មទាំងឡាយរបស់ពួកគេ និងនៅក្នុងទីក្រុងទាំងឡាយរបស់ពួក
គេ ហើយលើកអាវុធការពារប្រទេសរបស់ពួកគេផង ។
២១ ម្ល៉ោះហើយ មរ៉ូណៃបានកំចាត់ពួកនិយមស្ដេចទាំងនោះ
រហូតដល់គ្មានអ្នកណាម្នាក់មាននាមថា ជាអ្នកនិយម
ស្ដេចទៀតសោះ; ម្ល៉ោះហើយ លោកបានបញ្ចប់ភាពរឹងទទឹង
និងសេចក្ដីឆ្មើងឆ្មៃ របស់ពួកមនុស្សដែលអះអាងថា ជាឈាម
អភិជន; ប៉ុន្តែពួកគេត្រូវបាន នាំចុះឲ្យធ្វើខ្លួនទន់ទាប ដូចបងប្អូនគេ
ហើយប្រយុទ្ធយ៉ាងអង់អាច ដើម្បីសេរីភាពរបស់ពួកគេ
ដែលរួចផុតពីសេវកភាព ។
២២ មើលចុះ ហេតុការណ៍បានកើតឡើងថា នៅពេលដែល
មរ៉ូណៃកំពុងតែបញ្ឈប់សង្គ្រាម និងការទាស់ទែងគ្នាទាំងឡាយ
បែប នេះ នៅក្នុងចំណោមប្រជាជនផ្ទាល់របស់លោក ហើយ
ដាក់ឲ្យគេរស់នៅក្នុងសេចក្ដីសុខសាន្ត និងអារ្យធម៌ ហើយធ្វើ
ការចាត់ចែង ទាំងឡាយ ដើម្បីរៀបចំធ្វើសង្គ្រាមនឹងពួកសាសន៍
លេមិន មើលចុះ ពួកលេមិនបានចូលមកលើដែនដីមរ៉ូណៃ ដែល
នៅក្នុងព្រំប្រទល់ ជិតមាត់សមុទ្រ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍នីហ្វៃ
ពុំមានកម្លាំងគ្រប់គ្រាន់ នៅក្នុងទីក្រុងមរ៉ូណៃឡើយ; ហេតុ
ដូច្នេះហើយ អាម៉ាលិកាយបានរុញច្រានពួកគេ ដោយប្រហារ
មនុស្សអស់ជាច្រើន ។ ហើយហេតុការណ៍បានកើតឡើងថា
អាម៉ាលិកាយយកបាន ទីក្រុងនោះ មែនហើយ យកអស់ទាំង
បន្ទាយការពាររបស់ពួកគេ ។
២៤ ហើយពួកអ្នកដែលបានរត់ភៀសចេញពីទីក្រុងមរ៉ូណៃ
បានទៅដល់ទីក្រុងនីហ្វៃហា; ហើយព្រមទាំងប្រជាជននៃទីក្រុង
លីហៃផង បានប្រមូលគ្នាមក ហើយបានធ្វើការរៀបចំ ហើយបាន
ប្រុងប្រៀបខ្លួន ដើម្បីច្បាំងនឹងពួកលេមិន ។
២៥ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា អាម៉ាលិកាយមិនឲ្យ
ពួកលេមិន ទៅច្បាំងនឹងទីក្រុងនីហ្វៃហាទេ ប៉ុន្តែ ទុកពួក
គេនៅជិតឆ្នេរ សមុទ្រ ដោយដាក់ទ័ពនៅគ្រប់ទីក្រុង ដើម្បីរក្សា
ហើយការពារទីក្រុងនោះ ។
២៦ ម្ល៉ោះហើយ ទ្រង់បានបន្តទៅ គឺយកបានទីក្រុងជាច្រើន
ទីក្រុងនីហ្វៃហា និងទីក្រុងលីហៃ និងទីក្រុងម៉ូរីអានតុន និងទីក្រុង
អោមណើរ និងទីក្រុងគីឌ និងទីក្រុងមូលេក ទីក្រុងអស់ទាំងនេះ
នៅលើព្រំប្រទល់ខាងកើតទាំងឡាយ ជិតឆ្នេរសមុទ្រ ។
២៧ ម្ល៉ោះហើយ ពួកលេមិនយកបាន គឺដោយកលល្បិចរបស់
អាម៉ាលិកាយ នូវទីក្រុងជាច្រើន ដោយចំនួនទ័ពដ៏ច្រើនឥតគណនា
របស់ពួកគេ គឺទីក្រុងទាំងអស់នេះត្រូវបានសង់យ៉ាងមាំមួន តាម
របៀបបន្ទាយទាំងឡាយរបស់មរ៉ូណៃ; ទីក្រុងទាំងអស់នេះត្រូវ
បាន ទៅជាតំបន់ការពារទាំងឡាយ សំរាប់ពួកលេមិន ។
២៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើ
ដំណើរទៅដល់ព្រំប្រទល់ទាំងឡាយ នៃដែនដីបរិបូរណ៍ ដោយ
រុញច្រាន ពួកនីហ្វៃនៅខាងមុខគេ ហើយប្រហារអស់ជាច្រើន ។
២៩ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា ពួកគេបានជួបប្រទះ
នឹងទីអានគុម ដែលបានសម្លាប់ម៉ូរីអានតុន ហើយបានស្កាក់មុខ
ប្រជាជនរបស់វា នៅពេលវារត់ភៀសខ្លួន ។
៣០ ហើយហេតុការណ៍បានកើតឡើងថា លោកក៏បាន
ស្កាក់មុខអាម៉ាលិកាយដែរ នៅពេលទ្រង់កំពុងតែធ្វើដំណើរទៅ
មុខ ជាមួយនឹងកងទ័ពដ៏ច្រើនរបស់ទ្រង់ ដើម្បីទ្រង់អាចវាយយក
ដែនដីបរិបូរណ៍ និងដែនដីដែលនៅខាងជើងផង។
៣១ ប៉ុន្តែមើលចុះ ទ្រង់បានជួបប្រទះនឹងការខកចិត្ត ដោយត្រូវ
រុញឲ្យថយក្រោយ ដោយទីអានគុម និងទ័ពរបស់លោក ព្រោះពួក
គេជាអ្នកចម្បាំងដ៏ខ្លាំងពូកែ; ព្រោះមនុស្សគ្រប់គ្នារបស់ទីអានគុម
ឈ្នះពួកសាសន៍លេមិន ខាងវិស័យកម្លាំង និងខាងការប៉ិនប្រសប់
ក្នុងសង្គ្រាម ដរាបដល់ពួកគេមានប្រៀបទៅលើពួកលេមិន ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានវាយ
រំខានពួកគេ ដរាបដល់ពួកគេបានសម្លាប់ពួកនោះចោល រហូត
ដល់មេឃ ងងឹត ។ ហើយហេតុការណ៍បានកើតឡើងថា ទីអានគុម
និងទ័ពរបស់លោក បានបោះត្រសាលរបស់ខ្លួន នៅឯព្រំប្រ

១៩ *ក* អាលម៉ា ៦០:១៦.
២០ *ក* អាលម៉ា ៤៦:១២–១៣.
២២ *ក* ស.ប. មរ៉ូណៃ, មេទ័ព.
២៧ *ក* អាលម៉ា ៤៨:៨–៩.
២៩ *ក* អាលម៉ា ៥០:៣៥.

ទល់នៃដែនដី បរិបូរណ៍; ហើយអាម៉ាលិកាយបានបោះត្រសាល
របស់ទ្រង់ នៅក្នុងព្រំប្រទល់លើឆ្នេរខ្សាច់ជិតមាត់សមុទ្រ ហើយ
តាមរបៀបនេះ ពួកគេត្រូវរុញច្រាន ។

៣៣ ហើយហេតុការណ៍បានកើតឡើងថា លុះពេលយប់មក
ដល់ នោះទីអានគុម និងអ្នកបំរើរបស់លោក បានលួចចេញទៅក្រៅ
នៅពេលយប់ ហើយបានទៅក្នុងជំរុំរបស់អាម៉ាលិកាយ; ហើយ
មើលចុះ ការលង់លក់បានឈ្នះលើពួកគេ ព្រោះពួកគេនឿយហត់ជា
ខ្លាំង ដែលបណ្ដាលមកពីការធ្វើការ ដោយកម្លាំង និងកំដៅថ្ងៃ ។

៣៤ ហើយហេតុការណ៍បានកើតឡើងថា ទីអានគុមបានលួច
ចូលទៅដោយសម្ងាត់ ទៅក្នុងត្រសាលស្ដេច ហើយបាន
ចាក់លំពែង ទៅលើបេះដូងរបស់ទ្រង់; ហើយលោកបានធ្វើឲ្យ
ស្ដេចសុគតមួយរំពេច ដោយពុំបានធ្វើឲ្យពួកអ្នកបំរើរបស់ទ្រង់
ភ្ញាក់ឡើយ ។

៣៥ ហើយលោកបានត្រឡប់មកជំរុំរបស់លោកវិញ
ដោយសម្ងាត់ ហើយមើលចុះ ទ័ពរបស់លោកកំពុងដេកលក់
ហើយលោកបាន ដាស់ពួកគេឡើង ហើយប្រាប់ពួកគេ
ពីគ្រប់ការណ៍ទាំងអស់ដែលលោកបានធ្វើ ។

៣៦ ហើយលោកបានបញ្ជាឲ្យពលទ័ពលោកប្រុងប្រៀបខ្លួន
ជាស្រេច ខ្លាចក្រែងពួកលេមិនបានក្រោកឡើង ហើយ
មកវាយលុកលើ ពួកគេ ។

៣៧ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីម្ភៃប្រាំក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ; ម្ល៉ោះហើយ ក៏ចប់នូវ
ជីវិតអាម៉ាលិកាយទៅ ៕

## ជំពូកទី ៥២

*អាំម៉ូរ៉ុនបន្តរាជជាស្ដេចនៃពួកសាសន៍លេមិនពីអាម៉ាលិកាយ —
ម៉ូរ៉ូណៃ ទីអានគុម និងលីហៃ ដឹកនាំពួកសាសន៍នីហ្វៃ នៅក្នុង
សង្គ្រាម មួយដ៏ប្រកបដោយជោគជ័យ ប្រឆាំងនឹងពួកសាសន៍
លេមិន — ទីក្រុងមូលេកត្រូវយកបានមកវិញ ហើយយ៉ាកុប
ជាសាសន៍សូរាំត្រូវស្លាប់ ។ ប្រមាណជាឆ្នាំ ៦៦–៦៤ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើង គឺនៅឆ្នាំទីម្ភៃប្រាំ
មួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ មើលចុះ
កាលពួក លេមិនបានភ្ញាក់ឡើង នៅព្រឹកទីមួយនៃខែទីមួយ មើលចុះ
ពួកគេបានឃើញថា អាម៉ាលិកាយសុគត នៅក្នុងត្រសាលផ្ទាល់
របស់ទ្រង់; ហើយពួកគេក៏បានឃើញដែរថា ទីអានគុមបាន
ប្រុងប្រៀបខ្លួនជាស្រេច ដើម្បីមកច្បាំងនឹងពួកគេក្នុងថ្ងៃនោះ ។

២ ហើយឥឡូវនេះ កាលពួកលេមិនបានឃើញយ៉ាងនេះ ពួកគេ
តក់ស្លុតជាខ្លាំង; ហើយពួកគេបានបោះបង់ចោលគំរោងការ ក្នុង
ការលើក ទ័ពទៅដែនដីទិសខាងជើង ហើយបានដកថយ ជាមួយ
នឹងកងទ័ពទាំងអស់របស់គេ ចូលទៅក្នុងទីក្រុងមូលេក ហើយបាន
ស្វែងរកកិច្ចការពារ នៅក្នុងបន្ទាយការពារទាំងឡាយរបស់គេវិញ ។

៣ ហើយហេតុការណ៍បានកើតឡើង គឺព្រះអនុជរបស់
អាម៉ាលិកាយ ត្រូវបានតែងតាំងឡើងឲ្យធ្វើជាស្ដេចលើប្រជាជន
ហើយទ្រង់មាន នាមថា អាំម៉ូរ៉ុន; ម្ល៉ោះហើយ ស្ដេចអាំម៉ូរ៉ុន គឺជា
ព្រះអនុជរបស់ស្ដេចអាម៉ាលិកាយ ត្រូវបានតែងតាំងឡើងឲ្យ
សោយរាជ្យជំនួសទ្រង់ ។

៤ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាឲ្យទ័ព
ទ្រង់រក្សាទីក្រុងទាំងនោះ ដែលពួកគេយកបាន ដោយការ
ខ្ចាយឈាម; ត្បិតពួកគេពុំដែលយកបានទីក្រុងណា ដោយពួក
គេពុំបានបាត់បង់ឈាមជាច្រើននោះឡើយ ។

៥ ហើយឥឡូវនេះ ទីអានគុមបានឃើញថា ពួកសាសន៍លេមិន
តាំងចិត្តរក្សាទីក្រុងទាំងនោះ ដែលគេយកបាន និងផ្នែកទាំង
ឡាយនៃ ដែនដីដែលពួកគេយកបាន ហើយដោយបានឃើញដែរ
នូវចំនួនទ័ពរបស់ពួកគេដ៏ច្រើនក្រៃលែង ទើបទីអានគុមគិតថា ពុំ
មែនជាការចាំបាច់ ដែលលោកត្រូវខំវាយប្រហារពួកគេ នៅក្នុង
បន្ទាយរបស់គេទេ ។

៦ ប៉ុន្តែ លោកបានរក្សាទ័ពរបស់លោកនៅជុំវិញ
ហាក់បីដូចរៀបចំធ្វើសង្គ្រាម មែនហើយ ហើយការពិត
លោកកំពុងតែរៀបចំការ ពារខ្លួន ទប់ទល់នឹងពួកគេ ដោយ
[ក]ពូនជាជញ្ជាំងជុំវិញ ហើយរៀបចំទីកន្លែងលាក់ទ័ពទាំងឡាយ ។

៧ ហើយហេតុការណ៍បានកើតឡើងថា លោកបានបន្តការ
រៀបចំធ្វើសង្គ្រាមបែបដូច្នេះ រហូតដល់ម៉ូរ៉ូណៃបានបញ្ជូនទ័ពមួយ
ចំនួនធំ មកបន្ថែមលើកម្លាំងកងទ័ពរបស់លោក ។

៨ ហើយម៉ូរ៉ូណៃបានផ្ញើបញ្ជាទាំងឡាយមកលោកថា
លោកត្រូវរក្សាទុកអស់ទាំងឈ្លើយ ដែលបានធ្លាក់មកក្នុង
កណ្ដាប់ដៃរបស់លោក; ព្រោះកាលណាពួកលេមិនចាប់បាន
ជាឈ្លើយចំនួនច្រើន លោកត្រូវរក្សាទុក អស់ទាំងឈ្លើយនៃពួក
សាសន៍លេមិន ដើម្បីជាតម្លៃលោះ ពួកជន ដែលត្រូវពួក
លេមិនចាប់យកទៅ ។

៥២ ៦*ក* អាលម៉ា ៥០:១–៦; ៥៣:៣–៥.

៩ ហើយលោកបានផ្ញើបញ្ជាទាំងឡាយទៅលោកថា លោកត្រូវពង្រឹងដែនដីបរិបូរណ៍ ហើយរក្សាផ្លូវដ៏ចង្អៀត ដែលនាំទៅកាន់ដែន ដីប៉ែកខាងជើង ខ្លាចក្រែងពួកសាសន៍លេមិន យកបានចំណុចនោះ ហើយមានអំណាចនឹងវាយរំខានពួកគេតាមគ្រប់ទិស ។

១០ ហើយម៉ូរ៉ូណៃក៏បានផ្ដាំមកលោកដែរ ដោយមានបំណងចង់ឲ្យលោកមានចិត្តស្មោះត្រង់ ក្នុងការរក្សាដែនដីមួយភាគនេះ ហើយថា លោកត្រូវស្វែងរកគ្រប់ឱកាស ដើម្បីវាយពួកសាសន៍លេមិននៅភូមិភាគនោះ ឲ្យច្រើនតាមកម្លាំងរបស់លោក ក្រែងលោកអាចយកបាន មកវិញ ដោយឧបាយសឹក ឬមធ្យោបាយអ្វីផ្សេងទៀត នូវទីក្រុងទាំងឡាយ ដែលត្រូវពួកគេយកបានទៅ ហើយថា លោកក៏ត្រូវពង្រឹង និងបន្ថែមកម្លាំងដល់ទីក្រុងទាំងឡាយ ដែលនៅព័ទ្ធជុំវិញផង ដែលពុំទាន់ធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកសាសន៍លេមិន ។

១១ ហើយលោកក៏បានប្រាប់មកលោកថា ខ្ញុំចង់មកជួបនឹងអ្នក ប៉ុន្តែមើលចុះ ពួកលេមិននៅខាងមុខពួកយើង ក្នុងព្រំប្រទល់ដែនជិតសមុទ្រ ខាងលិច; ហើយមើលចុះ ខ្ញុំទៅតតាំងនឹងពួកគេ ហេតុដូច្នេះហើយ ខ្ញុំមិនអាចមកជួបអ្នកបានទេ ។

១២ ឥឡូវនេះ ស្ដេច (អាំម៉ូរ៉ុន) បានចាកចេញពីដែនដីសារ៉ាហិមឡា ហើយបានប្រាប់ឲ្យអគ្គមហេសីស្ដេចជ្រាប អំពីការសុគតនៃព្រះជេដ្ឋា របស់ទ្រង់ ហើយបានប្រមូលមនុស្សមួយចំនួនធំ ហើយបានលើកទៅវាយទល់នឹងពួកសាសន៍នីហ្វៃ នៅឯព្រំប្រទល់ជិតសមុទ្រខាងលិច ។

១៣ ម្ល៉ោះហើយ ទ្រង់បានខិតខំដើម្បីបង្ក្រាបពួកសាសន៍នីហ្វៃ និងដើម្បីដេញចេញនូវកងកម្លាំងរបស់គេមួយភាគពីភូមិភាគនោះ នៅពេល ដែលទ្រង់បានបញ្ជាដល់ពួកជនដែលទ្រង់បានដាក់ឲ្យនៅតាមទីក្រុងទាំងឡាយ ដែលទ្រង់យកបាននោះ គឺពួកគេក៏ត្រូវវាយបង្ក្រាបពួកសាសន៍ នីហ្វៃ នៅលើព្រំប្រទល់ទាំងឡាយជិតសមុទ្រខាងកើត ហើយត្រូវយកដែនដីពួកគេឲ្យបានច្រើនតាមកម្លាំងរបស់គេ តាមកម្លាំងរបស់ពល ទ័ពគេ ។

១៤ ម្ល៉ោះហើយ ពួកនីហ្វៃស្ថិតនៅក្នុងកាលៈទេសៈទាំងឡាយប្រកបដោយគ្រោះថ្នាក់ គឺនៅចុងឆ្នាំទីម្ភៃប្រាំមួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

១៥ ប៉ុន្តែមើលចុះ ហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីម្ភៃប្រាំពីរក្នុងរជ្ជកាលនៃពួកចៅក្រម គឺទីអានគុម តាមបញ្ជារបស់ម៉ូរ៉ូណៃ — ដែលជាអ្នកបានបង្កើតពលទ័ពដើម្បីការពារព្រំប្រទល់ខាងត្បូង និងខាងលិចរបស់ដែនដី ហើយបានចាប់ផ្ដើមធ្វើដំណើរ ឆ្ពោះទៅឯដែន ដីបរិបូរណ៍ ដើម្បីលោកអាចជួយទីអានគុម និងទ័ពរបស់លោក នៅក្នុងការដណ្ដើមយកទីក្រុងទាំងឡាយ ដែលគេបានបាត់បង់នោះមកវិញ —

១៦ ហើយហេតុការណ៍បានកើតឡើងថា ទីអានគុមបានទទួលបញ្ជាទាំងឡាយ ឲ្យធ្វើការវាយប្រហារទៅលើទីក្រុងមូលេក ហើយយកវា មកវិញ ប្រសិនបើមានលទ្ធភាពធ្វើបាន ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ទីអានគុមបានធ្វើការរៀបចំ ដើម្បីវាយប្រហារទីក្រុងមូលេក ហើយលើកទ័ពលោកទៅវាយពួកលេមិន; ប៉ុន្តែលោកបានឃើញថា គ្មានលទ្ធភាពឲ្យលោកយកឈ្នះលើពួកគេបានឡើយ នៅពេលដែលពួកគេនៅក្នុងបន្ទាយការពារ របស់គេ; ហេតុដូច្នេះហើយ លោកបានបោះបង់ចោលផែនការទាំងឡាយរបស់លោក ហើយបានត្រឡប់ទៅទីក្រុងបរិបូរណ៍វិញ ដើម្បីរង់ចាំ ម៉ូរ៉ូណៃមកដើម្បីលោកអាចទទួលកម្លាំងដល់កងទ័ពលោក ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃបានមកដល់ជាមួយនឹងកងទ័ពរបស់លោក នៅឯដែនដីបរិបូរណ៍ នៅចុងឆ្នាំទីម្ភៃប្រាំពីរ ក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

១៩ ហើយនៅដើមឆ្នាំទីម្ភៃប្រាំបី នោះម៉ូរ៉ូណៃ និងទីអានគុម និងពួកមេទ័ពឯកជាច្រើន បានប្រជុំក្រុមប្រឹក្សាសង្គ្រាម — នូវអ្វីៗដែលពួកគេ ត្រូវធ្វើ ដើម្បីធ្វើឲ្យពួកលេមិនចេញមកច្បាំងនឹងពួកគេ ឬថា ពួកគេអាចប្រើមធ្យោបាយយ៉ាងណា ដើម្បីបញ្ឆោរពួកគេឲ្យចេញមក ពីតំបន់ការ ពារទាំងឡាយរបស់គេ ដើម្បីពួកគេអាចយកប្រៀបលើពួកនោះ ហើយយកទីក្រុងមូលេកវិញ ។

២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចាត់អ្នកសារទូតទាំងឡាយ ឲ្យទៅកន្លែងកងទ័ពសាសន៍លេមិន ដែលការពារទីក្រុង មូលេក ជួបនឹងមេដឹកនាំរបស់ពួកគេ ដែលមានឈ្មោះថា យ៉ាកុប ដោយមានបំណងចង់ឲ្យគាត់ចេញមកជាមួយនឹងពលទ័ពគាត់ ដើម្បីជួប នឹងពួកគេនៅលើទីវាលនៅចន្លោះទីក្រុងទាំងពីរ ។ ប៉ុន្តែមើលចុះ យ៉ាកុបដែលជាសាសន៍សូរាំ មិនព្រមចេញមកជាមួយនឹងកងទ័ពរបស់ គាត់ ដើម្បីជួបនឹងពួកគេនៅលើទីវាលឡើយ ។

២១ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃគ្មានសេចក្ដីសង្ឃឹមថានឹងបានជួបពួកគេនៅលើទីដែលល្អទេ ហេតុដូច្នេះហើយលោក បានសំរេចចិត្តទៅលើផែនការមួយថា លោកនឹងបញ្ឆោតពួកលេមិន ឲ្យចេញពីតំបន់ការពារទាំងឡាយរបស់គេ ។

៩ *ក* អាលម៉ា ២២:៣២; មរមន ២:២៩.

២២ ហេតុដូច្នេះហើយ លោកបានបញ្ជាឲ្យទីអានគុម នាំយកទ័ពមួយចំនួនតូច ហើយដើរទៅជិតឆ្នេរសមុទ្រ; រីឯមរ៉ូណៃ និងកងទ័ពលោក នៅពេលយប់ បានដើរទៅក្នុងទីរហោស្ថាន នៅខាងលិចទីក្រុងមូលេក; ម្ល៉ោះហើយ ដល់ស្អែកឡើង កាលពួកអ្នកយាមរបស់ពួកលេមិន បានឃើញទីអានគុម ពួកគេបានរត់ទៅប្រាប់ការណ៍នេះដល់យ៉ាកុប ជាមេដឹកនាំរបស់ខ្លួន ។

២៣ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពសាសន៍លេមិន បានលើកទៅប្រយុទ្ធនឹងទីអានគុម ដោយសន្និដ្ឋានថា មកពីចំនួនទ័ព ពួកគេនោះពួកគេនឹងឈ្នះទីអានគុម ព្រោះលោកមានទ័ពតិច ។ ហើយនៅពេលទីអានគុមបានឃើញពលទ័ពសាសន៍លេមិន ចេញមកតតាំង នឹងលោក នោះលោកបានចាប់ផ្ដើមដកថយ ទៅតាមឆ្នេរសមុទ្រ នៅទិសខាងជើង ។

២៤ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិនបានឃើញថា លោកបានចាប់ផ្ដើមរត់គេច នោះពួកគេកើតចិត្តក្លាហានឡើង ហើយបានដេញតាមពួកគេដោយខ្លាំងក្លា ។ ហើយកាលទីអានគុមកំពុងតែនាំពួកលេមិន ដែលដេញតាមពួកគេ ដោយឥតបានផលអ្វីសោះ មើលចុះ មរ៉ូណៃបានបញ្ជាឲ្យកងទ័ពលោកមួយភាគ ដែលនៅជាមួយនឹងលោក លើកចូលក្នុងទីក្រុង ហើយយកទីក្រុងនោះទៅ ។

២៥ ម្ល៉ោះហើយ ពួកគេបានធ្វើដូច្នោះ ហើយបានសម្លាប់អស់អ្នកដែលត្រូវទុកឲ្យនៅការពារទីក្រុងនោះ មែនហើយ គឺអស់អ្នកដែលមិន ព្រមដាក់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមចុះចាញ់ ។

២៦ ម្ល៉ោះហើយ មរ៉ូណៃយកបានទីក្រុងមូលេក ដោយប្រើកងទ័ពមួយភាគរបស់លោក នៅពេលដែលលោកលើកទ័ពដែលនៅសល់ ទាំងប៉ុន្មាន ទៅជួបប្រយុទ្ធនឹងពួកលេមិន នៅពេលដែលពួកគេត្រឡប់ ពីដេញតាមទីអានគុមមកវិញ ។

២៧ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានដេញតាមទីអានគុម រហូតដល់ពួកគេបានទៅជិតដល់ទីក្រុងបរិបូរណ៍ ហើយ នៅពេលនោះ ពួកគេបានជួបនឹងលីហៃ និងកងទ័ពមួយតូច ដែលត្រូវបានទុក ដើម្បីការពារទីក្រុងបរិបូរណ៍ ។

២៨ ហើយឥឡូវនេះ មើលចុះ កាលពួកមេទ័ពឯករបស់ពួកលេមិន បានឃើញលីហៃ និងកងទ័ពរបស់លោក មកតតាំងនឹងពួកគេ នោះពួកគេបានរត់គេច ដោយច្របូកច្របល់ជាខ្លាំង ខ្លាចក្រែងពួកគេមិនអាចទៅដល់ទីក្រុងមូលេកវិញ មុនពេលលីហៃវាយពួកគេឲ្យ បរាជ័យ; ព្រោះពួកគេនឿយហត់ ដោយព្រោះដំណើរទ័ពរបស់គេ ហើយទ័ពរបស់លីហៃនៅថ្មី ។

២៩ ឥឡូវនេះ ពួកលេមិន មិនបានដឹងថា មរ៉ូណៃនៅពីក្រោយពួកគេ ជាមួយនឹងកងទ័ពរបស់លោកទេ; ហើយពួកគេគ្រាន់តែខ្លាចលីហៃ និងទ័ពរបស់លោកតែប៉ុណ្ណោះ ។

៣០ ឥឡូវនេះ លីហៃពុំមានបំណងចង់វាយទៅលើពួកគេមុនពេលពួកគេជួបប្រយុទ្ធនឹងមរ៉ូណៃ និងកងទ័ពរបស់លោកនោះឡើយ ។

៣១ ហើយហេតុការណ៍បានកើតឡើងថា មុនពេលពួកលេមិនដកថយបានឆ្ងាយ នោះពួកគេត្រូវហ៊ុំព័ទ្ធ ដោយពួកនីហ្វៃ ដោយទ័ពរបស់ មរ៉ូណៃនៅម្ខាង ហើយទ័ពរបស់លីហៃនៅម្ខាងទៀត ទ័ពអស់ទាំងនេះនៅថ្មី ហើយពោរពេញទៅដោយកម្លាំង; តែពួកលេមិននឿយហត់ ដោយព្រោះដំណើរដ៏ឆ្ងាយរបស់គេ ។

៣២ ហើយមរ៉ូណៃបានបញ្ជាទ័ពរបស់លោកថា ត្រូវវាយប្រហារពួកគេ រហូតដល់ពួកគេប្រគល់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមចុះចាញ់ ។

៣៣ ហើយហេតុការណ៍[ក]បានកើតឡើងថា យ៉ាកុប ដែលជាមេដឹកនាំរបស់ពួកគេ ជាសាសន៍សូរាំផង ហើយមានចិត្តមិនចុះចាញ់ វាបាន ដឹកនាំពួកលេមិនច្បាំងតទៅទៀត យ៉ាងខ្លាំងក្លាក្រៃលែង តទល់នឹងមរ៉ូណៃ ។

៣៤ ដោយមរ៉ូណៃនៅឃាំងផ្លូវពួកគេ ហេតុដូច្នេះហើយ យ៉ាកុបប្ដេជ្ញាថា នឹងសម្លាប់ពួកគេ ហើយបើកផ្លូវទៅទីក្រុងមូលេកឲ្យបាន ។ ប៉ុន្តែមើលចុះ មរ៉ូណៃ និងទ័ពរបស់លោកមានកម្លាំងជាង; ហេតុដូច្នេះហើយ ពួកគេពុំបានបើកផ្លូវឲ្យពួកលេមិនឡើយ ។

៣៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រយុទ្ធដោយដៃទាំងពីរ ដោយសេចក្ដីខ្លាំងក្លាហួសប្រមាណ; ហើយមានមនុស្សជា ច្រើនត្រូវស្លាប់ទាំងសងខាង; មែនហើយ ហើយមរ៉ូណៃត្រូវរបួស ហើយយ៉ាកុបក៏ស្លាប់ទៅ ។

៣៦ ហើយលីហៃវាយសម្រុកពីខាងក្រោយពួកគេ ដោយភាពខ្លាំងក្លា ដោយកងពលដ៏ខ្លាំងពូកែរបស់លោក ធ្វើឲ្យពួកលេមិន ដែលនៅ ខាងក្រោយ ដាក់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមចុះចាញ់; ហើយពួកវាដែលនៅសល់ទាំងប៉ុន្មាន ដោយមានការច្របូកច្របល់ជាខ្លាំង មិនដឹងថា ត្រូវទៅ ឬត្រូវវាយទេ ។

៣៧ ឥឡូវនេះ មរ៉ូណៃ ដោយបានឃើញពួកវាមានការច្របូកច្របល់ ទើបលោកនិយាយទៅគេថា៖ បើសិនជាអ្នករាល់គ្នាយកគ្រឿង សស្ត្រាវុធពិជ័យសង្គ្រាមរបស់អ្នក ហើយទម្លាក់ចុះចាញ់ មើលចុះ យើងនឹងហាមមិនឲ្យកំចាយឈាមអ្នកទេ ។

៣៣ *ក* អាលម៉ា ៣១:១២.

៣៨ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិន
បានឮពាក្យទាំងនេះហើយ នោះពួកមេទ័ពឯករបស់គេ អស់
ទាំងជនដែលមិន បានស្លាប់នៅឡើយ បានចេញមក ហើយបាន
បោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ទៅក្បែរជើងរបស់
ម៉ូរ៉ូណៃ ហើយក៏បានបញ្ជាទៅ ទ័ពរបស់គេផងថា ពួកគេត្រូវធ្វើ
ដូច្នោះដែរ ។
៣៩ ប៉ុន្តែមើលចុះ មានពួកគេច្រើននាក់មិនព្រមធ្វើឡើយ;
ហើយពួកអ្នកដែលពុំបានប្រគល់ដាវរបស់គេ ត្រូវចាប់ ហើយចង
ហើយគ្រឿង សស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ត្រូវបានដកយក
ពីគេ ហើយពួកគេត្រូវបានបង្ខំឲ្យដើរជាមួយនឹងបងប្អូនគេ
ទៅដែនដីបរិបូរណ៍ ។
៤០ ហើយឥឡូវនេះ ចំនួនពួកឈ្លើយ ដែលត្រូវចាប់នោះ មាន
ច្រើនជាងចំនួនពួកអ្នកដែលត្រូវស្លាប់ មែនហើយ ច្រើនជាង
ពួកអ្នក ដែលត្រូវស្លាប់ទាំងសងខាង ៕

---

## ជំពូកទី ៥៣

*ពួកឈ្លើយសាសន៍លេមិនត្រូវបានប្រើឲ្យពង្រឹងទីក្រុងបរិបូរណ៍ — ការបែកចេញទាំងឡាយនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ធ្វើឲ្យពួកសាសន៍លេមិនមានជ័យជំនះ — ហេលេមិនបញ្ជាកូនប្រុសពីរពាន់នាក់ ជាកូនរបស់ប្រជាជនអាំម៉ូន ។ ប្រមាណជាឆ្នាំ ៦៤–៦៣ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចាត់មនុស្សឲ្យ
យាមពួកឈ្លើយសាសន៍លេមិន ហើយបានបង្ខំពួកគេ ឲ្យធ្វើ
ដំណើរទៅ និងកប់ពួកអ្នកស្លាប់របស់គេ មែនហើយ និងពួកអ្នក
ស្លាប់សាសន៍នីហ្វៃដែលត្រូវស្លាប់ផង; ហើយម៉ូរ៉ូណៃបានដាក់មនុ
ស្សឲ្យយាមពួកគេ នៅពេលពួកគេធ្វើការងារទាំងឡាយរបស់គេ ។
២ ហើយម៉ូរ៉ូណៃបានទៅទីក្រុងមូលេក ជាមួយនឹងលីហៃ
ហើយបានប្រគល់បញ្ជាទីក្រុងនេះឲ្យទៅលីហៃ ។ ឥឡូវនេះ
មើលចុះ លីហៃនេះគឺជាមនុស្សម្នាក់ ដែលធ្លាប់បាននៅជាមួយ
នឹងម៉ូរ៉ូណៃ សឹងតែគ្រប់ទីចំបាំងរបស់លោក; ហើយលោកជា
មនុស្សម្នាក់ [ក]ដូចជាម៉ូរ៉ូណៃ ហើយពួកគេបានអររីករាយនឹង
សន្តិសុខរបស់គេទៅវិញទៅមក; មែនហើយ ពួក
គេស្រឡាញ់រាប់អានគ្នា ហើយត្រូវបាន ស្រឡាញ់ ដោយ
ប្រជាជននីហ្វៃទាំងអស់ផង ។
៣ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកលេមិន
បានកប់ ពួកអ្នកស្លាប់របស់គេហើយ និងពួកអ្នកស្លាប់សាសន៍
នីហ្វៃផង នោះពួកគេត្រូវបាននាំដើរត្រឡប់ទៅក្នុងដែនដីបរិបូរណ៍;
ហើយទីអានគុម តាមបញ្ជាទាំងឡាយរបស់ម៉ូរ៉ូណៃ បាន
បញ្ជាឲ្យពួកគេចាប់ផ្ដើម ធ្វើការជីករណ្ដៅមួយជុំវិញដែនដី
ឬទីក្រុងបរិបូរណ៍ ។
៤ ហើយលោកបានបញ្ជាឲ្យពួកគេ[ក]ស្ថាបនារបង ដែលធ្វើ
ពីដើមឈើ នៅលើមាត់រណ្ដៅផ្នែកខាងក្នុង; ហើយពួកគេបាន
ជីកដីក្នុងរណ្ដៅ មកទប់នឹងរបង ដែលធ្វើពីឈើនោះ; ម្ល៉ោះហើយ
ពួកគេបានបញ្ជាឲ្យពួកសាសន៍លេមិនធ្វើការ រហូតដល់ពួកគេ
បានព័ទ្ធជុំវិញទីក្រុងបរិបូរណ៍ ដោយកំផែងមួយដ៏មាំ ដែលធ្វើ
ពីឈើ និងដី ដ៏មានកំពស់យ៉ាងខ្ពស់ ។
៥ ហើយទីក្រុងនេះ បានក្លាយទៅជាតំបន់ការពារមួយ
ដ៏មាំទាំរហូតទៅ; ហើយនៅក្នុងទីក្រុងនេះ ពួកគេបានយាមពួក
ឈ្លើយសាសន៍ លេមិន; មែនហើយ គឺនៅខាងក្នុងកំផែង ដែល
ពួកគេបានបញ្ជាពួកវាឲ្យស្ថាបនា ដោយដៃពួកវាផ្ទាល់ ។ ឥឡូវនេះ
ម៉ូរ៉ូណៃត្រូវបានបង្ខំចិត្ត ឲ្យបញ្ជាពួកលេមិនឲ្យធ្វើការ ពីព្រោះជា
ការងាយយាមពួកវា នៅពេលពួកវាធ្វើការ; ហើយលោកមាន
បំណងចង់បានកងកម្លាំងរបស់លោក ទាំងអស់ កាលលោកត្រូវ
ធ្វើការវាយប្រហារទៅលើពួកលេមិន ។
៦ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃ ទើបយក
ជ័យជំនះបានទៅលើពលទ័ពសាសន៍លេមិនមួយដ៏ធំបំផុត ហើយ
យកទីក្រុង មូលេកបាន ដែលជាទីការពារដ៏មាំបំផុតមួយរបស់
ពួកលេមិន នៅក្នុងដែនដីនីហ្វៃ; ហើយលោកក៏បានស្ថាបនាទីតាំង
ការពារមួយយ៉ាងនេះ ដើម្បីរក្សាទុកពួកឈ្លើយរបស់លោក ។
៧ ហើយហេតុការណ៍បានកើតឡើងថា លោកពុំបំរុងនឹងធ្វើ
ចម្បាំងជាមួយពួកលេមិន នៅក្នុងឆ្នាំនោះទៀតទេ ប៉ុន្តែ
លោកបានប្រើឲ្យទ័ព របស់លោក រៀបចំធ្វើសង្គ្រាម មែនហើយ
ហើយពង្រឹងទីការពារ ដើម្បីទប់ទល់នឹងពួកលេមិន មែនហើយ
ហើយក៏ដោះលែងពួកស្ត្រីរបស់គេ និងកូនចៅរបស់គេ
ឲ្យរួចផុតពីអំណត់អត់ និងសេចក្ដីទុក្ខវេទនាផង ហើយផ្ដល់
អាហារដល់ពលទ័ពរបស់គេ ។
៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពលទ័ព
សាសន៍លេមិននៅខាងត្បូង គឺខាងសមុទ្រខាងលិច នៅពេល
ដែលម៉ូរ៉ូណៃពុំ បាននៅទីនោះ ដោយរវល់នឹងឧបាយកលខ្លះ នៅ
ក្នុងចំណោមពួកសាសន៍នីហ្វៃ ដែលនាំឲ្យមានការបែកចេញទាំង
ឡាយ នៅក្នុងចំណោម ពួកគេ យកបានដែនដីខ្លះពីពួកសាសន៍

---

**៥៣** ២ *ក* អាលម៉ា ៤៨:១៦–១៧.
៤ *ក* អាលម៉ា ៥០:២–៣.

នីហ្វៃ មែនហើយ ដវាបដល់ពួកគេ យកទីក្រុងគេមួយចំនួនបាន
ដែលនៅភូមិភាគនេះនៃដែនដី ។
៩ ម្ល៉ោះហើយ ដោយព្រោះសេចក្ដីទុច្ចរិតនៅក្នុងចំណោមពួក
គេ មែនហើយ ដោយព្រោះការបែកចេញទាំងឡាយ និង
ឧបាយកល នៅក្នុងចំណោមពួកគេផ្ទាល់ នោះពួកគេត្រូវស្ថិតនៅ
ក្នុងកាលៈទេសៈទាំងឡាយ ដ៏ប្រកបទៅដោយគ្រោះថ្នាក់បំផុត ។
១០ ហើយឥឡូវនេះ មើលចុះ ខ្ញុំមានការណ៍ខ្លះគួរនិយាយ
[ក]អំពីប្រជាជនអាំម៉ូន កាលពីដើម គឺជាពួកសាសន៍លេមិន; ប៉ុន្តែ
ដោយអាំម៉ូន និងបងប្អូនលោក ឬនិយាយឲ្យចំ គឺដោយ
ព្រះចេស្ដា និងព្រះបន្ទូលនៃព្រះ នោះពួកគេត្រូវបាន[ខ]ប្រែចិត្តជឿ
ដល់ព្រះអម្ចាស់; ហើយពួកគេត្រូវ បាននាំចុះមកឯដែនដី
សារ៉ាហិមឡា ហើយចាប់ពីពេលនោះមក ត្រូវបានការពារ
ដោយពួកសាសន៍នីហ្វៃ ។
១១ ហើយដោយព្រោះពាក្យសម្បថរបស់គេ នោះពួកគេ
ពុំព្រមកាន់អាវុធ ប្រឆាំងនឹងបងប្អូនគេទេ; ព្រោះពួកគេបានស្បថ
ថា ពួកគេនឹង[ក]ពុំ កំចាយឈាមទៀតឡើយ; ហើយស្របតាម
ពាក្យសម្បថរបស់គេ នោះពួកគេច្បាស់ជាត្រូវវិនាស; មែន
ហើយ ពួកគេច្បាស់ជាត្រូវរង ទុក្ខវេទនា ដោយត្រូវធ្លាក់ទៅក្នុង
កណ្ដាប់ដៃនៃបងប្អូនគេ បើកុំតែដោយសារសេចក្ដីអាណិតអាសូរ
និងសេចក្ដីស្រឡាញ់ដ៏លើសលប់ ដែលអាំម៉ូន និងបងប្អូនលោក
មានចំពោះពួកគេ ។
១២ ម្ល៉ោះហើយ ពួកគេត្រូវបាននាំចុះមកឯដែនដីសារ៉ាហិមឡា;
ហើយពួកគេត្រូវបាន[ក]ការពារ ដោយពួកសាសន៍នីហ្វៃ ចាប់តាំងពី
ពេលនោះរហូតមក ។
១៣ ប៉ុន្តែហេតុការណ៍បានកើតឡើងថា កាលពួកគេបាន
ឃើញគ្រោះថ្នាក់ និងសេចក្ដីទុក្ខវេទនា និងសេចក្ដីទុក្ខ
លំបាកជាច្រើន ដែលពួក សាសន៍នីហ្វៃបាន[ក]រងជំនួសពួកគេ នោះ
ពួកគេមានចិត្តក្ដួលអាណិត ហើយមានបំណងចង់កាន់អាវុធ
ដើម្បីការពារប្រទេសរបស់គេ ។
១៤ ប៉ុន្តែមើលចុះ នៅពេលពួកគេរៀបនឹង
កាន់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាម នោះពួកគេត្រូវចាញ់ពាក្យ
បញ្ចុះបញ្ចូលរបស់ហេលេមិន និងបងប្អូនលោកថា ពួក
គេជិត[ក]បំភាន់នឹង[ខ]ពាក្យសម្បថដែលពួកគេបានធ្វើ ។
១៥ ហើយហេលេមិនខ្លាចក្រែងធ្វើដូច្នេះ នោះពួកគេនឹង
បាត់បង់ព្រលឹងរបស់គេទៅ ;ហេតុដូច្នេះហើយ អស់អ្នកដែលបាន
ចូលក្នុងសេចក្ដី សញ្ញានេះ ត្រូវបង្ខំចិត្តឲ្យមើលបងប្អូនគេឆ្លងកាត់
នូវសេចក្ដីទុក្ខវេទនាទាំងឡាយរបស់គេ នៅក្នុងកាលៈទេសៈ
ទាំងឡាយ ដ៏ប្រកបដោយ គ្រោះថ្នាក់របស់គេក្នុងពេលនេះ ។
១៦ ប៉ុន្តែមើលចុះ ហេតុការណ៍បានកើតឡើងថា ពួកគេមាន
កូនប្រុសជាច្រើន ដែលពុំបានចូលក្នុងសេចក្ដីសញ្ញាថា គេមិន
កាន់គ្រឿង សស្ត្រាវុធពិជ័យសង្គ្រាមការពារខ្លួនគេ ដើម្បីប្រឆាំង
នឹងពួកខ្មាំងសត្រូវរបស់គេទេ; ហេតុដូច្នេះហើយ ពួកគេបានមក
ប្រជុំគ្នាក្នុងពេលនេះ អស់អ្នកណាដែលអាចកាន់អាវុធបាន
ហើយពួកគេបានហៅខ្លួនគេថា សាសន៍នីហ្វៃ ។
១៧ ហើយពួកគេបានធ្វើសេចក្ដីសញ្ញាមួយថា នឹងប្រយុទ្ធដើម្បី
ឥស្សរភាពដល់ពួកសាសន៍នីហ្វៃ មែនហើយ ដើម្បីការពារដែនដី
រហូត ដល់ត្រូវប្ដូរជីវិតរបស់ខ្លួន; មែនហើយ គឺពួកគេថែម
ទាំងបានធ្វើសេចក្ដីសញ្ញាថា ពួកគេនឹងពុំបោះបង់[ក]ឥស្សរភាព
របស់គេជាដាច់ខាត ប៉ុន្តែពួកគេនឹងប្រយុទ្ធ ក្នុងគ្រប់ករណីទាំងអស់
ដើម្បីការពារពួកសាសន៍នីហ្វៃ និងខ្លួនគេឲ្យរួចផុតពីសេវកភាព ។
១៨ ឥឡូវនេះ មើលចុះ កំលោះទាំងនោះមានចំនួនពីរពាន់នាក់
ដែលបានចូលក្នុងសេចក្ដីសញ្ញានេះ ហើយបានកាន់គ្រឿងសស្ត្រាវុធ
ពិជ័យសង្គ្រាម ដើម្បីការពារប្រទេសរបស់ខ្លួន ។
១៩ ហើយឥឡូវនេះ មើលចុះ ពួកគេពុំដែលបានធ្វើអ្វីពីមុនមក
ឲ្យមានការខូចខាតដល់ពួកសាសន៍នីហ្វៃឡើយ ឥឡូវនេះ ពួកគេ
បានក្លាយ ទៅជាការគាំទ្រដ៏ធំមួយ ក្នុងរយៈពេលនេះ; ព្រោះពួក
គេបានកាន់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ហើយពួកគេ
ចង់ឲ្យហេលេមិន ធ្វើជាមេដឹកនាំរបស់គេ ។
២០ ហើយពួកគេទាំងអស់គ្នាជាកំលោះ ហើយពួកគេមាន
[ក]ចិត្តក្លាហានអង់អាចជាអតិបរមា ហើយមានកម្លាំង និងសកម្មភាព
ជាអតិបរមា ដែរ; ប៉ុន្តែមើលចុះ នេះពុំទាន់អស់នៅឡើយទេ —
ពួកគេជា[ខ]មនុស្សស្មោះត្រង់ គ្រប់ពេលវេលា ទោះនៅក្នុង
កិច្ចការណាក៏ដោយ ដែលពួកគេទទួលផ្ទុក ។
២១ មែនហើយ ពួកគេគឺជាមនុស្សស្មោះត្រង់ ហើយម៉ឺងម៉ាត់
ព្រោះពួកគេត្រូវបានបង្ហាត់ ឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃ
ព្រះ ហើយឲ្យ [ក]ដើរដោយស្មោះត្រង់ នៅចំពោះទ្រង់ ។

១០ ក អាលម៉ា ២៧:២៤–២៦.
ខ អាលម៉ា ២៣:៨–១៣.
១១ ក អាលម៉ា ២៤:១៧–១៩.
១២ ក អាលម៉ា ២៧:២៣.
១៣ ក អាលម៉ា ៥៦:៧.
១៤ ក ជនគ. ៣០:២.
ខ ស.ប. សម្បថ.
១៧ ក អាលម៉ា ៥៦:៤៧.
ស.ប. ឥស្សរភាព.
២០ ក ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន.
ខ ស.ប. សេចក្ដីស្មោះ.
២១ ក ស.ប. ដើរ, ដើរជាមួយព្រះ.

២២ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ហេលេមិន
បានដើរនាំមុខកងពលកំលោះ[ក]ពីរពាន់នាក់របស់លោក ទៅគាំទ្រ
ដល់ប្រ ជាជន ដែលនៅព្រំប្រទល់ទាំងឡាយ នៃដែនដីផ្នែកខាង
ត្បូង ជិតសមុទ្រខាងលិច ។
២៣ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីម្ភៃប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ ៕

---

## ជំពូកទី ៥៤

*អាំម៉ូរ៉ុន និងមូរ៉ូណៃចរចារ ដើម្បីប្ដូរឈ្លើយសង្គ្រាម — មូរ៉ូណៃទាមទារឲ្យពួកលេមិនដកថយចេញ ហើយបញ្ឈប់ការវាយប្រហារដែលសម្លាប់ មនុស្សរបស់គេ — អាំម៉ូរ៉ុនទាមទារឲ្យពួកនីហ្វៃដាក់អាវុធចុះ ហើយធ្វើជាចំណុះពួកសាសន៍លេមិន ។ ប្រមាណជាឆ្នាំ ៦៣ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅដើម
ឆ្នាំទីម្ភៃប្រាំបួននៃពួកចៅក្រម នោះ[ក]អាំម៉ូរ៉ុនបានចាត់ឲ្យមនុស្ស
ទៅស្នើមូរ៉ូណៃថា ទ្រង់ចង់ប្ដូរឈ្លើយ ។
២ ហើយហេតុការណ៍បានកើតឡើងថា មូរ៉ូណៃមានសេចក្ដី
អររីករាយជាខ្លាំង ចំពោះការស្នើសុំនេះ ព្រោះលោកមាន
បំណងចង់បាន ស្បៀង ដែលយកទៅចិញ្ចឹមពួកឈ្លើយសាសន៍
លេមិនទាំងនេះ ដើម្បីទុកចិញ្ចឹមប្រជាជនរបស់លោកផ្ទាល់
ហើយលោកក៏មានបំណង ចង់បានប្រជាជនលោកផ្ទាល់ផង
ដើម្បីពង្រឹងកម្លាំងកងទ័ពរបស់លោក ។
៣ ឥឡូវនេះ ពួកលេមិនបានចាប់ពួកស្ត្រី និងកូនក្មេងជាច្រើន
ហើយគ្មានស្ត្រីណាម្នាក់ ឬក្មេងណាម្នាក់នៅក្នុង
ចំណោមឈ្លើយទាំងអស់ របស់មូរ៉ូណៃ ឬពួកឈ្លើយដែលត្រូវ
មូរ៉ូណៃចាប់នោះឡើយ; ហេតុដូច្នេះហើយ មូរ៉ូណៃ
សំរេចឧបាយសឹកថា នឹងយកពួកឈ្លើយសាសន៍នីហ្វៃ ពីពួក
លេមិនឲ្យបានកាន់តែច្រើនឡើងដែលអាចធ្វើបាន ។
៤ ហេតុដូច្នេះហើយ លោកបានសរសេរសំបុត្រមួយច្បាប់
ហើយបានផ្ញើតាមអ្នកបំរើរបស់អាំម៉ូរ៉ុន គឺជាអ្នកដែលបាននាំយក
សំបុត្រមួយ មកឲ្យមូរ៉ូណៃនោះ ។ ឥឡូវនេះ នេះគឺជាពាក្យទាំង
ឡាយ ដែលលោកបានសរសេរទៅកាន់អាំម៉ូរ៉ុនថា៖
៥ មើលចុះ អាំម៉ូរ៉ុន ទូលបង្គំបានសរសេរមកទ្រង់នូវកិច្ចការខ្លះ
អំពីសង្គ្រាមនេះ ដែលទ្រង់បានបង្កឡើងប្រឆាំងនឹងប្រជាជនទូលបង្គំ
ឬបើនិយាយឲ្យចំ គឺ[ក]ព្រះជេដ្ឋារបស់ទ្រង់ បានបង្កឡើងប្រឆាំងនឹង
ពួកគេ ហើយជាចម្បាំងដែលទ្រង់ ក៏នៅតែប្ដេជ្ញានឹងធ្វើបន្តទៅទៀត
បន្ទាប់ពីព្រះជេដ្ឋាទ្រង់បានសុគតទៅហើយ ។
៦ មើលចុះ ទូលបង្គំចង់ប្រាប់ទ្រង់ខ្លះ អំពី[ក]សេចក្ដីយុត្តិធម៌នៃព្រះ
និងដាវនៃព្រះពិរោធដ៏មានមហិទ្ធិឫទ្ធិរបស់ព្រះ ដែល
ព្យួរនៅពីលើទ្រង់ លើកលែងតែទ្រង់ប្រែចិត្ត ហើយដកពលទ័ព
របស់ទ្រង់ ថយចេញទៅក្នុងដែនដីទ្រង់វិញ ឬដែនដីដែលជា
របស់ផងទ្រង់ គឺជាដែនដីនីហ្វៃ ។
៧ មែនហើយ ទូលបង្គំចង់ប្រាប់ទ្រង់ពីការណ៍ទាំងនេះ បើ
សិនជាទ្រង់មានសមត្ថភាពធ្វើតាមវា មែនហើយ ទូលបង្គំ
ចង់ប្រាប់ទ្រង់អំពី [ក]ស្ថាននរកដ៏គួរឲ្យស្ញែងខ្លាចនោះ ដែលរង់ចាំ
ទទួល[ខ]ឃាតកទាំងឡាយ ដូចជារូបទ្រង់ និងព្រះជេដ្ឋារបស់
ទ្រង់នេះ លើកលែងតែទ្រង់ប្រែចិត្ត ហើយដកចេញនូវគោល
បំណងសម្លាប់មនុស្សរបស់ទ្រង់ ហើយត្រឡប់ជាមួយនឹងពលទ័ព
របស់ទ្រង់ ទៅកាន់ដែនដីផ្ទាល់របស់ទ្រង់វិញ ។
៨ ប៉ុន្តែ ដូចជាទ្រង់ធ្លាប់បានបដិសេធ ការណ៍ទាំងនេះ
ម្ដងទៅហើយ ហើយបានប្រយុទ្ធប្រឆាំងនឹងរាស្ត្រនៃព្រះអម្ចាស់
យ៉ាងណា នោះ ទូលបង្គំអាចសន្និដ្ឋានថា ទ្រង់ក៏នឹងធ្វើ
យ៉ាងនោះទៅទៀតដែរ ។
៩ ហើយឥឡូវនេះ មើលចុះ យើងបានប្រុងប្រៀបខ្លួនជាស្រេច
ដើម្បីទទួលទ្រង់ហើយ; មែនហើយ ហើយលើកលែងតែទ្រង់បោះបង់
ចោលគោលបំណងទាំងឡាយរបស់ទ្រង់ បើពុំនោះសោតទេ
មើលចុះ ទ្រង់នឹងទាញចុះមកនូវសេចក្ដីពិរោធរបស់ព្រះអង្គនោះ
ដែលទ្រង់បានបដិសេធ មកលើទ្រង់ គឺរហូតដល់ការបំផ្លិចបំផ្លាញ
ដល់ទ្រង់ទាំងស្រុង ។
១០ ប៉ុន្តែ ប្រាកដដូចជាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ នោះ
ពលទ័ពរបស់យើងនឹងវាយប្រហារទៅលើទ្រង់ លើកលែងតែទ្រង់ដក
ថយចេញ ហើយសេចក្ដីស្លាប់នឹងមករកទ្រង់នៅក្នុងពលឆាប់ៗនេះ
ព្រោះយើងនឹងរក្សាទុក នូវទីក្រុងទាំងឡាយ និងដែនដីទាំង
ឡាយរបស់ យើង មែនហើយ ហើយយើងនឹងទ្រទ្រង់នូវ
សាសនារបស់យើង និងឧត្តមគតិនៃព្រះរបស់យើង ។
១១ ប៉ុន្តែមើលចុះ ទូលបង្គំសន្និដ្ឋានថា ទូលបង្គំនិយាយនឹងទ្រង់
អំពីការណ៍ទាំងនេះ ដោយឥតប្រយោជន៍; ឬក៏ទូលបង្គំសន្និដ្ឋានថា

---

២២ *ក* អាលម៉ា ៥៦:៣–៥.
**៥៤** ១ *ក* អាលម៉ា ៥២:៣.
៥ *ក* អាលម៉ា ៤៨:១.
៦ *ក* ស.ប. សេចក្ដីយុត្តិធម៌.
៧ *ក* ស.ប. ស្ថាននរក.
*ខ* អាលម៉ា ៤៧:១៨, ២២–២៤.
ស.ប. ឃាតកម្ម.

ទ្រង់ជាកូន[ក]នៃស្ថាននរក; ហេតុដូច្នេះហើយ ទូលបង្គំនឹងបញ្ចប់
សំបុត្ររបស់ទូលបង្គំដោយប្រាប់ទ្រង់ថា ទូលបង្គំនឹងពុំប្ដូរពួក
ឈ្លើយទេ លើកលែងតែដោយលក្ខខ័ណ្ឌទាំងឡាយថា ទ្រង់
នឹងដោះលែងបុរសម្នាក់ និងប្រពន្ធរបស់គាត់ និងកូនចៅរបស់
គាត់ សំរាប់ឈ្លើយម្នាក់ បើសិនជានេះជាករណីដែលទ្រង់នឹងធ្វើ
នោះទូលបង្គំនឹងប្ដូរ ។
១២ ហើយមើលចុះ បើសិនជាទ្រង់មិនធ្វើដូច្នេះទេ ទូលបង្គំ
នឹងវាយប្រហារទ្រង់ដោយពលទ័ពរបស់ទូលបង្គំ; មែនហើយ
គឺទូលបង្គំនឹង ប្រដាប់អាវុធឲ្យពួកស្រ្ដីរបស់ទូលបង្គំ និងកូនចៅ
របស់ទូលបង្គំ ហើយទូលបង្គំនឹងវាយប្រហារទ្រង់ ហើយ
ទូលបង្គំនឹងតាមទ្រង់រហូតដល់ក្នុង ដែនដីផ្ទាល់របស់ទ្រង់
ដែលជាដែនដីកេរ្ដិ៍[ក]អាករដំបូងរបស់យើង; មែនហើយ ហើយ
នឹងយកឈាមប្ដូរឈាម មែនហើយ ជីវិតប្ដូរជីវិត; ហើយ
ទូលបង្គំនឹងច្បាំងនឹងទ្រង់ រហូតដល់ទ្រង់ត្រូវបំផ្លាញចេញ
ពីលើផ្ទៃផែនដីនេះទៅ ។
១៣ មើលចុះ ទូលបង្គំកំពុងខឹង ហើយប្រជាជនរបស់
ទូលបង្គំក៏ដូច្នោះដែរ; ទ្រង់បានរកកាប់សម្លាប់ពួកយើង ហើយយើង
គ្រាន់តែរកការ ពារខ្លួនប៉ុណ្ណោះ ។ ប៉ុន្តែមើលចុះ បើសិនជាទ្រង់
រកបំផ្លាញយើងថែមទៀត នោះយើងនឹងរកបំផ្លាញទ្រង់វិញ; មែន
ហើយ ហើយយើងនឹង ស្វែងរកដែនដីយើង គឺជា
ដែនដីកេរ្ដិ៍អាករដំបូងរបស់យើង ។
១៤ ឥឡូវនេះ ទូលបង្គំសូមបញ្ចប់សំបុត្ររបស់ទូលបង្គំហើយ ។
ទូលបង្គំជាមរ៉ូណៃ; ទូលបង្គំជាមេដឹកនាំម្នាក់របស់ប្រជាជននីហ្វៃ ។
១៥ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា អាំម៉ូរ៉ុន កាល
ទ្រង់បានទទួលសំបុត្រនេះហើយ ក៏មានព្រះទ័យខ្ញាល់; ហើយទ្រង់
បាន សរសេរសំបុត្រមួយទៀតទៅឲ្យមរ៉ូណៃ ហើយនេះគឺជា
ពាក្យទាំងឡាយ ដែលទ្រង់បានសរសេរថា៖
១៦ យើងជាអាំម៉ូរ៉ុន ជាស្ដេចរបស់[ក]ពួកសាសន៍លេមិន;
យើងជាព្រះអនុជរបស់អាម៉ាលិកាយ ដែលអ្នកបានធ្វើឃាតនោះ ។
មើលចុះ យើងនឹងសងឈាមឲ្យទ្រង់ទៅលើអ្នក មែនហើយ
ហើយយើងនឹងវាយអ្នកដោយពលទ័ពរបស់យើង ព្រោះយើងមិន
ខ្លាចពាក្យគំរាមកំហែង របស់អ្នកទេ ។
១៧ ត្បិតមើលចុះ ពួកអយ្យកោអ្នកបានធ្វើខុសឆ្គងជាមួយនឹង
បងប្អូនគេ រហូតដល់ពួកគេបានប្លន់យកសិទ្ធិ[ក]របស់គេក្នុងរដ្ឋាភិបាល
នៅពេល តាមច្បាប់ វាជារបស់ពួកគេ ។
១៨ ហើយឥឡូវនេះ មើលចុះ បើសិនជាអ្នកនឹងដាក់អាវុធចុះ
ហើយប្រគល់ខ្លួនជាចំណុះ ក្រោមការអភិបាលនៃអ្នកទាំងឡាយ
ដែលមាន សិទ្ធិភិបាល ពេលនោះ យើងនឹងបញ្ជាឲ្យទ័ពយើង
ដាក់គ្រឿងសស្ត្រាវុធគេចុះដែរ ហើយឈប់ធ្វើសង្គ្រាមតទៅទៀត ។
១៩ មើលចុះ អ្នកបានហាមាត់បញ្ចេញ នូវការគំរាមកំហែង
ជាច្រើនទាស់នឹងយើង និងប្រជាជនយើង; ប៉ុន្តែមើលចុះ
យើងមិនខ្លាចពាក្យ គំរាមកំហែងរបស់អ្នកទេ ។
២០ ក៏ប៉ុន្តែ យើងនឹងអនុញ្ញាតឲ្យប្ដូរឈ្លើយ តាមសេចក្ដីស្នើ
របស់អ្នកដោយរីករាយ ដើម្បីយើងអាចសន្សំទុកនូវស្បៀងអាហារ
សំរាប់ពួក មនុស្សថ្មើកចំបាំងរបស់យើង; ហើយយើងនឹង
បង្កសង្គ្រាមមួយដ៏នៅអស់កល្បជានិច្ច ដើម្បីដាក់ពួកសាសន៍
នីហ្វៃ ជាចំណុះក្រោមអំណាចយើង ឬក៏ឲ្យពួកគេវិនាស
សាបសូន្យអស់កល្បជានិច្ចទៅ ។
២១ រីឯអំពីព្រះ ដែលអ្នកនិយាយថា យើងបានបដិសេធនោះ
មើលចុះ យើងពុំស្គាល់តួអង្គបែបនោះឡើយ; ឯអ្នកក៏មិនស្គាល់ដែរ;
ប៉ុន្តែប្រសិនបើមានតួអង្គបែបនោះមួយមែន យើងពុំដឹងអ្វីក្រៅពីថា
ទ្រង់បានបង្កើតយើងមក ដូចជាបានបង្កើតអ្នកមកដូច្នោះដែរ ។
២២ ហើយបើសិនជាមានអារក្សមួយ និងស្ថាននរកមួយ មើលចុះ
តើវានឹងពុំបញ្ជូនអ្នកទៅទីនោះ ដើម្បីរស់នៅជាមួយព្រះជេដ្ឋារបស់
យើង ដែលអ្នកបានធ្វើឃាត ដែលអ្នកបានប្រាប់ថា ទ្រង់បាន
ទៅកន្លែងនោះទេឬអី? ប៉ុន្តែមើលចុះ ការណ៍ទាំងនេះមិនជាអ្វីទេ ។
២៣ យើងជាអាំម៉ូរ៉ុន ហើយជាពូជរបស់[ក]សូរាំម្នាក់ ដែលពួក
អយ្យកោរបស់អ្នក បានបង្ខំ ហើយនាំចេញពីក្រុងយេរូសាឡិមមក ។
២៤ ហើយមើលចុះ ឥឡូវនេះ យើងជាសាសន៍លេមិនដ៏ក្លាហាន
ម្នាក់; មើលចុះ សង្គ្រាមនេះត្រូវបានបង្កឡើង ដើម្បីសងសឹកដល់
អំពើខុសឆ្គងទាំងឡាយរបស់ពួកគេ ហើយដើម្បីទ្រទ្រង់ និងដើម្បីយក
សិទ្ធិទាំងឡាយរបស់គេ ក្នុងរដ្ឋាភិបាលវិញ; ហើយយើងបញ្ចប់
សំបុត្ររបស់យើងទៅកាន់មរ៉ូណៃ ។

## ជំពូកទី ៥៥

*មរ៉ូណៃមិនព្រមប្ដូរឈ្លើយ — ពួកអ្នកយាមសាសន៍លេមិនត្រូវបង្អកស្រាឲ្យស្រវឹង ហើយពួកឈ្លើយសាសន៍នីហ្វៃ ត្រូវបានដោះលែង — ទីក្រុងគីឌត្រូវយកបាន ដោយពុំមានការខ្ចាយឈាម ។ ប្រមាណជាឆ្នាំ ៦៣–៦២ ម.គ.ស. ។*

១១ *ក* យ៉ូហាន ៨:៤២–៤៤.
១២ *ក* ២ នីហ្វៃ ៥:៥–៨.
១៦ *ក* អាលម៉ា ៥១:៣៤.
១៧ *ក* ២ នីហ្វៃ ៥:១–៤;
ម៉ូសាយ ១០:១២–១៧.
២៣ *ក* ១ នីហ្វៃ ៤:៣១–៣៥.

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលមរ៉ូណៃបានទទួលសំបុត្រនេះហើយ នោះលោកកាន់តែខឹងខ្លាំងឡើង ព្រោះលោកបានដឹងថា អាំម៉ូរ៉ុនបានដឹងដ៏ឥតខ្ចោះ នូវការបន្លំរបស់លោក; មែនហើយ លោកបានដឹងថា អាំម៉ូរ៉ុនបានដឹងថា គឺពុំមែនជាឧត្តមគតិមួយដ៏ត្រឹមត្រូវទេ ដែលបានបណ្ដាលឲ្យទ្រង់បង្កសង្គ្រាមប្រឆាំងនឹងប្រជាជននីហ្វៃ ។

២ ហើយលោកបាននិយាយថា៖ មើលចុះ ខ្ញុំនឹងមិនប្ដូរឈ្លើយជាមួយនឹងអាំម៉ូរ៉ុនទេ លើកលែងតែទ្រង់ នឹងដកគោលបំណងរបស់ទ្រង់ ដូចខ្ញុំបាននិយាយនៅក្នុងសំបុត្ររបស់ខ្ញុំ; ព្រោះខ្ញុំនឹងមិនអនុញ្ញាតឲ្យទ្រង់មានកម្លាំងច្រើនជាងកម្លាំង ដែលទ្រង់មានរួចហើយនោះទេ ។

៣ មើលចុះ ខ្ញុំស្គាល់កន្លែងដែលពួកសាសន៍លេមិនឃាំងប្រជាជនខ្ញុំទុក ដែលពួកវាបានចាប់យកទៅជាឈ្លើយ; ហើយដូចជាអាំម៉ូរ៉ុន មិនយល់ព្រមតាមសេចក្ដីស្នើ នៅក្នុងសំបុត្ររបស់ខ្ញុំទេ មើលចុះ ខ្ញុំនឹងឲ្យទ្រង់តាមពាក្យសំដីរបស់ខ្ញុំ; មែនហើយ ខ្ញុំនឹងស្វែងរកសេចក្ដីស្លាប់ ឲ្យពួកវា រហូតដល់ពួកគេសុំអង្វររកសន្តិភាព ។

៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលមរ៉ូណៃបាននិយាយពាក្យទាំងនេះហើយ នោះលោកបានចាត់ឲ្យស្វែងរកក្នុង ចំណោមពលរបស់លោក ក្រែងលោកអាចរកបានបុរសម្នាក់ ដែលជាពូជលេមិន នៅក្នុងចំណោមពួកគេ ។

៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេរកបានម្នាក់ដែលមានឈ្មោះថា លេមិន; ហើយគាត់ជាអ្នកបំរើម្នាក់របស់ស្ដេចដែលត្រូវ ធ្វើឃាត ដោយអាម៉ាលិកាយ ។

៦ ឥឡូវនេះ មរ៉ូណៃបានបញ្ជាឲ្យលេមិន និងពលលោកមួយចំនួនតូច ទៅរកពួកអ្នកដែលយាមពួកនីហ្វៃ ។

៧ ឥឡូវនេះ ពួកសាសន៍នីហ្វៃត្រូវបានឃាំងទុកនៅក្នុងទីក្រុងគីឌ; ហេតុដូច្នេះហើយ មរ៉ូណៃបានចាត់លេមិន ហើយបានបញ្ជាឲ្យពួក ពលមួយចំនួនតូច ទៅជាមួយនឹងគាត់ ។

៨ ហើយលុះដល់ពេលព្រលប់ នោះលេមិនបានទៅឯពួកអ្នកដែលយាមពួកនីហ្វៃ ហើយមើលចុះ ពួកគេបានឃើញគាត់មកហើយពួកគេ ក៏ស្រែកហៅគាត់; ប៉ុន្តែគាត់បាននិយាយទៅគេថា៖ ចូរកុំខ្លាចអី មើលចុះ ខ្ញុំជាសាសន៍លេមិនម្នាក់ ។ មើលចុះ យើង
បានរត់រួចពីពួកសាសន៍ នីហ្វៃ ហើយពួកគេដេកលក់; ហើយមើលចុះ ពួកយើងបានយកស្រាទំពាំងបាយជូររបស់គេ ហើយបានយកមកជាមួយយើងផង ។

៩ ឥឡូវនេះ កាលពួកលេមិនបានឮពាក្យទាំងនេះហើយ នោះពួកគេបានទទួលគាត់ដោយសេចក្ដីអំណរ; ហើយពួកគេបាននិយាយទៅ គាត់ថា៖ ចូរឲ្យយើងនូវស្រាទំពាំងបាយជូររបស់អ្នកមក ដើម្បីយើងអាចបានផឹក; យើងត្រេកអរ ដែលអ្នកបានយកស្រាទំពាំងបាយជូរ មកជា មួយនឹងអ្នក ព្រោះយើងកំពុងតែនឿយហត់ ។

១០ ប៉ុន្តែ លេមិនបាននិយាយទៅគេថា៖ ចូរយើងទុកស្រាទំពាំងបាយជូររបស់យើង ទាល់តែយើងទៅច្បាំងនឹងពួកនីហ្វៃ ។ ប៉ុន្តែការ និយាយនេះ គ្រាន់តែធ្វើឲ្យពួកគេចង់ផឹកស្រាទំពាំងបាយជូរកាន់តែខ្លាំងឡើង ។

១១ ព្រោះពួកគេបាននិយាយថា៖ យើងកំពុងតែនឿយហត់ ហេតុដូច្នេះហើយ ចូរឲ្យយើងយកស្រាទំពាំងបាយជូរនេះចុះ ហើយនៅមិន យូរមិនឆាប់ យើងនឹងទទួលចំណែកបន្តិចម្ដងៗ ដែលនឹងធ្វើឲ្យយើងមានកម្លាំង ដើម្បីទៅប្រឆាំងនឹងពួកនីហ្វៃ ។

១២ ហើយលេមិនបាននិយាយទៅពួកគេថា៖ ពួកអ្នកអាចធ្វើតាមចំណង់អ្នកចុះ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានយកស្រាផឹកតាមទំនើងចិត្ត; ហើយវាមានរសជាតិឆ្ងាញ់ ត្រូវនឹងចំណូលចិត្តរបស់គេ ហេតុដូច្នេះហើយ ពួកគេកាន់តែផឹកតាមទំនើងចិត្តច្រើនឡើង; ហើយវាជាស្រាខ្លាំង ដោយត្រូវបានបិតឲ្យខ្លាំងដូច្នោះ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានផឹកហើយបានអរសប្បាយ ហើយមិនយូរមិនឆាប់ ពួកគេក៏ស្រវឹងទាំងអស់គ្នាទៅ ។

១៥ ហើយឥឡូវនេះ កាលលេមិន និងពលរបស់គាត់បានឃើញថា ពួកគេស្រវឹងទាំងអស់គ្នាហើយ ហើយដេកលក់យ៉ាងស្កប់ នោះពួកគេ ក៏ត្រឡប់ទៅជួបនឹងមរ៉ូណៃវិញ ហើយបានជំរាបលោកពីគ្រប់ការណ៍ទាំងអស់ ដែលបានកើតឡើង ។

១៦ ហើយឥឡូវនេះ នេះគឺស្របតាមផែនការរបស់មរ៉ូណៃ ។ ហើយមរ៉ូណៃបានប្រុងប្រៀបទ័ពរបស់លោក ឲ្យប្រដាប់ដោយគ្រឿង សស្ត្រាវុធពិជ័យសង្គ្រាម; ហើយលោកទៅទីក្រុងគីឌនៅពេលដែលពួកលេមិនកំពុងតែដេកលក់ស្កប់ ហើយស្រវឹងហើយបានបោះគ្រឿង សស្ត្រាវុធពិជ័យសង្គ្រាម ទៅឲ្យពួកឈ្លើយ ដរាបដល់ពួកគេទាំងអស់គ្នាបានប្រដាប់ដោយអាវុធ ។

១៧ មែនហើយ គឺដល់ពួកស្ត្រីរបស់គេ និងពួកកូនក្មេងទាំងអស់របស់គេ គឺដល់អស់អ្នកណាដែលអាចប្រើគ្រឿងសស្ត្រាវុធពិជ័យ

៥៥ ១*ក* អាលម៉ា ៤៧:១២–៣៥.

៥ *ក* អាលម៉ា ៤៧:២៩.

សង្គ្រាមបាន ក្នុងកាលមរ៉ូណៃបានប្រដាប់អាវុធឲ្យពួកឈ្លើយទាំងអស់នោះ; ហើយការណ៍អស់ទាំងនោះ ត្រូវបានធ្វើឡើង នៅក្នុងសភាព ស្ងាត់ស្ងៀមជាខ្លាំង ។

១៨ ប៉ុន្តែ ប្រសិនជាពួកគេធ្វើឲ្យពួកលេមិនភ្ញាក់ មើលចុះ ពួកវាកំពុងតែស្រវឹង ហើយពួកនីហ្វៃច្បាស់ជាអាចសម្លាប់ពួកវាចោលបាន ។

១៩ ប៉ុន្តែមើលចុះ នេះពុំមែនជាបំណងរបស់មរ៉ូណៃទេ; លោកពុំចូលចិត្តក្នុងការធ្វើឃាត [ក]ឬការខ្វាយឈាមទេ តែលោកចូលចិត្តក្នុងការ ជួយសង្គ្រោះប្រជាជនរបស់លោកពីការបំផ្លិចបំផ្លាញវិញ; ហើយដោយហេតុនេះ លោកពុំអាចនាំមកលើរូបលោក នូវការអយុត្តិធម៌ទេ លោកក៏ពុំអាចវាយប្រហារពួកលេមិន ហើយបំផ្លាញពួកវា នៅពេលពួកវាកំពុងតែស្រវឹងនោះទេ ។

២០ ប៉ុន្តែលោកបានបំពេញបំណងទាំងឡាយរបស់លោក; ព្រោះលោកបានប្រដាប់អាវុធ ឲ្យពួកឈ្លើយសាសន៍នីហ្វៃទាំងនោះ ដែល នៅខាងក្នុងកំផែងនៃទីក្រុង ហើយបានប្រគល់ឲ្យគេនូវកម្លាំង ដើម្បីដណ្ដើមយកផ្នែកទាំងនោះ ដែលនៅខាងក្នុងកំផែងទាំងឡាយ ។

២១ ហើយបន្ទាប់មក លោកបានបញ្ជាឲ្យទ័ព ដែលនៅជាមួយលោក ឲ្យដកថយចេញពីពួកគេមួយជំហាន ហើយហ៊ុំព័ទ្ធពលទ័ពសាសន៍ លេមិន ។

២២ ឥឡូវនេះ មើលចុះ ការណ៍នេះត្រូវបានធ្វើនៅពេលយប់ដើម្បីនៅពេលពួកលេមិនភ្ញាក់ឡើង នៅពេលព្រឹក នោះពួកគេនឹងឃើញ ថា គេត្រូវបានឡោមព័ទ្ធដោយពួកនីហ្វៃនៅខាងក្រៅ ហើយពួកឈ្លើយរបស់គេ ប្រដាប់ដោយអាវុធនៅខាងក្នុង ។

២៣ ម្ល៉ោះហើយ ពួកគេបានឃើញថា ពួកនីហ្វៃមានអំណាចលើពួកគេ; ហើយនៅក្នុងកាលៈទេសៈនេះ ទើបពួកគេបានឃើញថា ពួកគេមិនចាំបាច់ត្រូវប្រយុទ្ធនឹងពួកនីហ្វៃទេ; ហេតុដូច្នេះហើយ ពួកមេទ័ពឯករបស់គេ បានដកយកគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ហើយពួកគេបាននាំយកទៅបោះ នៅក្បែរជើងរបស់ពួកនីហ្វៃ ដោយអង្វរសូមក្ដីមេត្តា ។

២៤ ឥឡូវនេះ មើលចុះ នេះគឺជាបំណងរបស់មរ៉ូណៃ ។ លោកបានចាប់ពួកគេយកទៅជាឈ្លើយសឹក ហើយបានយកទីក្រុង ហើយបាន បញ្ជាឲ្យដោះលែងឈ្លើយទាំងអស់ណាដែលជាសាសន៍នីហ្វៃ; ហើយពួកគេបានចូលរួមកងទ័ពរបស់មរ៉ូណៃ ហើយជាកម្លាំងដ៏ធំមួយ ដល់កងទ័ពរបស់លោក ។

២៥ ហើយហេតុការណ៍បានកើតឡើងថា លោកបានបញ្ជាឲ្យពួកលេមិន ដែលលោកបានចាប់ធ្វើជាឈ្លើយនោះថា ពួកគេត្រូវចាប់ផ្ដើម [ក]ធ្វើការពង្រឹងបន្ទាយការពារនៅជុំវិញទីក្រុងគីឌ ។

២៦ ហើយហេតុការណ៍បានកើតឡើងថា កាលលោកបានពង្រឹងទីក្រុងគីឌ ស្របតាមបំណងទាំងឡាយរបស់លោកហើយនោះលោកបានបញ្ជាឲ្យនាំពួកឈ្លើយរបស់លោក ទៅទីក្រុងបរិបូរណ៍; ហើយលោកបានយាមទីក្រុងនោះ ដោយកងកម្លាំងមួយ ដ៏ខ្លាំងហួសប្រមាណ ។

២៧ ហើយហេតុការណ៍បានកើតឡើងថា ទោះជាមានអស់ទាំងកលល្បិច របស់ពួកសាសន៍លេមិនក៏ដោយ គង់តែពួកគេបានរក្សា ហើយការពារអស់ទាំងពួកឈ្លើយ ដែលគេបានចាប់ដែរ ហើយបានរក្សាដីទាំងអស់ និងទ្រព្យដែលពួកគេយកបានមកវិញ ។

២៨ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍នីហ្វៃបានចាប់ផ្ដើមមានជ័យជំនះជាថ្មី ហើយយកបានមកវិញនូវសិទ្ធិទាំងឡាយ របស់គេ និងឯកសិទ្ធទាំងឡាយរបស់គេ ។

២៩ ពួកលេមិនបំរុងនឹងព័ទ្ធជុំវិញពួកគេនៅពេលយប់ជាច្រើនលើក ប៉ុន្តែនៅក្នុងការប៉ុនប៉ងទាំងនេះ ពួកគេត្រូវបានបាត់បង់ទៅជាឈ្លើយជាច្រើន ។

៣០ ហើយពួកគេបានបំរុងបង្អកស្រាទំពាំងបាយជូរ ដល់ពួកនីហ្វៃជាច្រើនលើក ក្រែងគេអាចបំផ្លាញពួកគេ ដោយថ្នាំបំពុល ឬដោយការ ស្រវឹងបាន ។

៣១ ប៉ុន្តែមើលចុះ សាសន៍នីហ្វៃពុំយឺតយូរ ក្នុង[ក]ការចងចាំដល់ព្រះអម្ចាស់ ជាព្រះរបស់គេ ក្នុងកាលមានទុក្ខវេទនារបស់ពួកគេនោះឡើយ ។ ពួកគេពុំអាចជាប់ក្នុងអន្ទាក់របស់ពួកវាបានឡើយ; មែនហើយ ពួកគេមិនផឹកស្រាទំពាំងបាយជូររបស់ពួកវាសោះ លើកលែងតែពួកគេ ឲ្យទៅពួកឈ្លើយសាសន៍លេមិនខ្លះផឹកមុន ។

៣២ ម្ល៉ោះហើយ ពួកគេបានប្រយ័ត្នប្រយែងខ្លួន ដើម្បីកុំឲ្យត្រូវថ្នាំបំពុលនៅក្នុងចំណោមគេ; ព្រោះបើសិនជាស្រាទំពាំងបាយជូររបស់គេ ធ្វើឲ្យសាសន៍លេមិនម្នាក់ពុល វាក៏នឹងធ្វើឲ្យសាសន៍នីហ្វៃម្នាក់ពុលដែរ; ម្ល៉ោះហើយ ពួកគេបានសាកល្បងស្រាទាំងអស់របស់គេ ។

៣៣ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ជាការចាំបាច់ឲ្យមរ៉ូណៃធ្វើការរៀបចំ ដើម្បីវាយលុកទីក្រុងម៉ូរីអានតុន; ត្បិតមើលចុះ ពួកលេមិនបានធ្វើការប្រឹងប្រែង ពង្រឹងទីក្រុងម៉ូរីអានតុន រហូតវាបានក្លាយទៅជាទីការពារមួយ ដ៏មាំក្រៃលែង ។

១៩ ក អាលម៉ា ៤៨:១៦.
២៥ ក អាលម៉ា ៥៣:៣—៥.
៣១ ក អាលម៉ា ៦២:៤៩—៥១.

៣៤ ហើយពួកគេបាននាំកងកម្លាំងថ្មីៗ ទៅទីក្រុងនោះ ដោយមិនឈប់ឈរ ព្រមទាំងស្បៀងផ្គត់ផ្គង់ថ្មីៗផង ។

៣៥ ម្លោះហើយ ក៏ចប់ឆ្នាំទីម្ភៃប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ៕

## ជំពូកទី ៥៦

*ហេលេមិនផ្ញើសំបុត្រមួយច្បាប់ទៅមរ៉ូណៃ រាប់រៀបអំពីស្ថានភាពសង្គ្រាមនឹងពួកសាសន៍លេមិន — អាន់ទីផុស និងហេលេមិនយក បានជ័យជំនះមួយដ៏ធំលើពួកលេមិន — កូនប្រុសពីរពាន់នាក់របស់ហេលេមិន ប្រយុទ្ធដោយកម្លាំងដ៏អស្ចារ្យ ហើយគ្មានពួកគេណា ម្នាក់ត្រូវស្លាប់ឡើយ ។ ខទី១, ប្រមាណជាឆ្នាំ ៦២ ម.គ.ស.; ខទី២–១៩, ប្រមាណជាឆ្នាំ ៦៦ ម.គ.ស.; ហើយខទី២០–៥៧, ប្រមាណជា ឆ្នាំ ៦៥–៦៤ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីសាមសិបក្នុងរជ្ជកាលនៃពួកចៅក្រម នៅថ្ងៃទីពីរ ក្នុងខែទីមួយ នោះមរ៉ូណៃបានទទួលសំបុត្រមួយច្បាប់ពីហេលេមិន ថែងអំពីកិច្ចការទាំងឡាយរបស់ប្រជាជន នៅក្នុងភូមិភាគនៃដែនដីនោះ ។

២ ហើយនេះគឺជាពាក្យពេចន៍ដែលលោកបានសរសេរថា៖ ជូនចំពោះមរ៉ូណៃ ជាបងប្រុសជាទីស្រឡាញ់របស់ខ្ញុំ ទោះនៅក្នុងព្រះអម្ចាស់ ក៏ដូចជានៅក្នុងសេចក្ដីទុក្ខលំបាកនៃសង្គ្រាមដែរ; មើលចុះ បងប្រុសជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំមានការណ៍ខ្លះនឹងជំរាបបង អំពីកិច្ចការសង្គ្រាមនៃយើង ខាងភាគនៃដែនដីនេះ ។

៣ មើលចុះ កូនប្រុសពីរពាន់នាក់ របស់ពួកអ្នកដែលអាំម៉ូនបាននាំចេញពីដែនដីនីហ្វៃនោះ — ឥឡូវនេះ ដូចបងបានដឹងហើយថា ពួកនេះជាពូជពង្សលេមិន ដែលជាកូនប្រុសច្បងរបស់លីហៃជាអយ្យកោរបស់យើង ។

៤ ឥឡូវនេះ ខ្ញុំមិនចាំបាច់រំឭកឡើងវិញជូនបង អំពីសណ្ដាប់ទាំងឡាយរបស់ពួកគេ ឬការឥតជំនឿរបស់ពួកគេនោះទេ ព្រោះបងបានដឹងអំពីការណ៍អស់ទាំងនេះហើយ —

៥ ហេតុដូច្នេះហើយ ខ្ញុំគ្រាន់តែជំរាបបងថា កំឡោះពីរពាន់នាក់នេះ បានកាន់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ហើយចង់ ឲ្យខ្ញុំ ធ្វើជាមេដឹកនាំរបស់គេ; ហើយយើងបានចេញទៅការពារប្រទេសរបស់យើង ។

៦ ហើយឥឡូវនេះ បងក៏ដឹងអំពីសេចក្ដីសញ្ញា ដែលពួកអយ្យកោគេបានធ្វើដែរ គឺពួកគេមិនព្រមកាន់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាម ទាស់នឹងបងប្អូនរបស់គេ ដើម្បីកំចាយឈាមនោះឡើយ ។

៧ ប៉ុន្តែ នៅក្នុងឆ្នាំទីម្ភៃប្រាំមួយ កាលពួកគេបានឃើញសេចក្ដីទុក្ខវេទនារបស់យើង និងសេចក្ដីទុក្ខលំបាករបស់យើង ជំនួសពួកគេ នោះពួកគេបំរុងនឹងបំបាក់សេចក្ដីសញ្ញា ដែលគេបានធ្វើ ហើយលើកគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ដើម្បីការពារពួកយើង ។

៨ ប៉ុន្តែ ខ្ញុំមិនទ្រាំទុកឲ្យពួកគេបំបាក់សេចក្ដីសញ្ញានេះ ដែលពួកគេបានធ្វើ ដោយសន្និដ្ឋានថា ព្រះទ្រង់នឹងចំរើនកម្លាំងដល់យើង ដរាបដល់មិនឲ្យយើងរងទុក្ខថែមទៀត ដោយសារការបំពេញពាក្យសម្បថ ដែលគេបានស្បថនោះឡើយ ។

៩ ប៉ុន្តែមើលចុះ នេះគឺជាការណ៍មួយ ដែលអាចឲ្យយើងមានសេចក្ដីអំណរដ៏ធំ ។ ត្បិតមើលចុះ នៅក្នុងឆ្នាំទីម្ភៃប្រាំមួយ គឺខ្ញុំហេលេមិន បានដើរនាំមុខកំឡោះពីរពាន់នាក់នេះ ទៅកាន់ទីក្រុងយូដា ដើម្បីទៅជួយអាន់ទីផុស ជាអ្នកដែលបងបានតែងតាំងឡើងឲ្យធ្វើជាមេដឹកនាំ លើប្រជាជននៅភាគនៃដែនដីនោះ ។

១០ ហើយខ្ញុំបានរួបរួមកូនប្រុសពីរពាន់នាក់របស់ខ្ញុំ (ព្រោះពួកគេសមនឹងបានហៅថា កូនប្រុស) ទៅក្នុងកងទ័ពរបស់អាន់ទីផុសក្នុងកម្លាំងបែបនេះ អាន់ទីផុសអររីករាយជាអតិបរមា; ត្បិតមើលចុះ កងទ័ពរបស់លោកត្រូវបន្ថយចំនួន ដោយពួកលេមិន ពីព្រោះកងកម្លាំងរបស់ពួកវា បានសម្លាប់ទ័ពរបស់យើងមួយចំនួនធំ ដែលជាហេតុនាំឲ្យយើងកាន់ទុក្ខ ។

១១ ទោះជាយ៉ាងណាក៏ដោយ គង់តែយើងអាចលួងចិត្តយើងក្នុងចំណុចនេះថា ពួកគេបានស្លាប់ក្នុងឧត្តមគតិនៃប្រទេសរបស់គេ និងព្រះរបស់គេ មែនហើយ ហើយពួកគេសប្បាយរីករាយ ។

១២ ហើយពួកលេមិន ក៏បានរក្សាពួកឈ្លើយជាច្រើនទុកដែរ គេទាំងអស់នោះជាមេទ័ពឯក ព្រោះក្រៅពីនោះ គ្មានអ្នកណាម្នាក់ដែលគេទុកជីវិតឲ្យឡើយ។ ហើយយើងសន្និដ្ឋានថា ឥឡូវនេះ ក្នុងពេលនេះ ពួកគេនៅក្នុងដែនដីនីហ្វៃ; គឺដូច្នោះមែន បើសិនជាពួកគេពុំទាន់ស្លាប់ទេ ។

១៣ ហើយឥឡូវនេះ នេះគឺជាទីក្រុងទាំងឡាយ ដែលពួកលេមិនយកបាន ដោយការខ្ចាយឈាមនៃបុរស ដ៏ក្លាហានជាច្រើន នាក់របស់យើង គឺ៖

**៥៦** ៣*ក* អាលម៉ា ៥៣:២២.
៦ *ក* អាលម៉ា ២៤:១៧–១៨.
៧ *ក* អាលម៉ា ៥៣:១៣–១៥.
១១ *ក* អាលម៉ា ២៨:១២.

១៤ ដែនដីម៉ាន់តៃ ឬទីក្រុងម៉ាន់តៃ និងទីក្រុងស៊ីអែសរ៉ុម និង ទីក្រុងគូមេណៃ និងទីក្រុងអាន់ទីប៉ារ៉ា ។

១៥ ហើយនេះគឺជាទីក្រុងទាំងឡាយ ដែលពួកគេយកបាន កាលខ្ញុំបានទៅដល់ទីក្រុងយូដា; ហើយខ្ញុំបានឃើញអាន់ទីផុស និងទ័ពរបស់លោក កំពុងតែប្រឹងធ្វើការដោយសមត្ថភាពរបស់គេ ដើម្បីពង្រឹងទីក្រុង ។

១៦ មែនហើយ ហើយពួកគេថប់ចិត្ត ទាំងខាងរូបកាយ និង ខាងវិញ្ញាណ ព្រោះពួកគេបានប្រយុទ្ធយ៉ាងអង់អាច នៅពេលថ្ងៃ ហើយបានធ្វើការដោយកម្លាំង ក្នុងពេលយប់ ដើម្បីទ្រទ្រង់ទីក្រុង ទាំងឡាយរបស់គេ; ម្ល៉ោះហើយ ពួកគេបានទទួលសេចក្ដីទុក្ខ វេទនា ដ៏ធំគ្រប់បែបយ៉ាង ។

១៧ ហើយឥឡូវនេះ ពួកគេបានប្ដេជ្ញាថា នឹងយកជ័យជំនះនៅ ក្នុងទីនេះឲ្យបាន ឬក៏ស្លាប់; ហេតុដូច្នេះហើយ បងអាចសន្និដ្ឋាន ថា កងកម្លាំងដ៏តូចដែលខ្ញុំនាំមកជាមួយខ្ញុំនេះ មែនហើយ កូនប្រុសទាំងនោះរបស់ខ្ញុំ បានផ្ដល់ឲ្យពួកគេនូវសេចក្ដីសង្ឃឹមដ៏ធំ និងសេច ក្ដីអំណរដ៏ខ្លាំង ។

១៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលពួក លេមិនបានឃើញថា អាន់ទីផុសបានទទួលកម្លាំងថែម ឲ្យកងទ័ព របស់លោក នោះពួកគេបានទទួលបញ្ជាពីអាំម៉ូរ៉ុន ហាមមិនឲ្យ ទៅវាយប្រហារទីក្រុងយូដា ឬច្បាំងតទល់នឹងយើងទេ ។

១៩ ម្ល៉ោះហើយ ពួកយើងត្រូវបានប្រោសប្រណីពីព្រះអម្ចាស់; ត្បិតបើពួកគេមកវាយប្រហារពួកយើង នៅពេលដ៏ទន់ខ្សោយ របស់យើងនេះ នោះពួកគេប្រហែលជាបានបំផ្លាញកងទ័ពដ៏តូច របស់យើងនេះទៅហើយ; ប៉ុន្តែ យើងត្រូវបានថែរក្សាឲ្យគង់បែប ដូច្នេះ ។

២០ ពួកគេត្រូវបានបញ្ជាដោយអាំម៉ូរ៉ុន ឲ្យរក្សាទីក្រុងទាំង ឡាយ ដែលពួកគេយកបាន ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីម្ភៃប្រាំមួយ ទៅ ។ ហើយនៅដើមឆ្នាំទីម្ភៃប្រាំពីរ យើងបានរៀបចំទីក្រុង របស់យើង និងខ្លួនយើង ដើម្បីការពារ ។

២១ ឥឡូវនេះ យើងមានបំណងចង់ឲ្យពួកលេមិន មកវាយប្រហារយើង ព្រោះយើងមិនចង់ទៅវាយប្រហារពួកគេ នៅក្នុង ទីតាំងការពាររបស់ពួកគេឡើយ ។

២២ ហើយហេតុការណ៍បានកើតឡើងថា យើងបានចាត់ឲ្យ មានពួកអ្នកស៊ើបការណ៍ទៅជុំវិញ ដើម្បីសង្កេតចលនាទាំង ឡាយ របស់ពួកលេមិន ដើម្បីកុំឲ្យពួកគេអាចឆ្លងកាត់ពួកយើង នៅពេលយប់ ឬក៏ពេលថ្ងៃ ដើម្បីវាយប្រហារមកលើទីក្រុង របស់យើងឯទៀត ដែលនៅទិសខាងជើងបានឡើយ ។

២៣ ព្រោះយើងបានដឹងថា នៅក្នុងទីក្រុងទាំងនោះ ពួកគេមិន មានកម្លាំងគ្រប់គ្រាន់ ដើម្បីប្រយុទ្ធនឹងពួកវាបានឡើយ; ហេតុ ដូច្នេះហើយ យើងមានបំណងថា បើសិនជាពួកវាដើរកាត់ ក្បែរយើង នោះយើងនឹងវាយប្រហារពួកវាពីខាងក្រោយ ដើម្បីឃាំងផ្លូវ ពួកវាពីខាងក្រោយ នៅពេលនោះ ពួកវាក៏ត្រូវ ជួបប្រយុទ្ធនៅខាងមុខ ។ យើងបានសន្និដ្ឋានថា យើងអាច យកឈ្នះលើពួកវាបាន ប៉ុន្តែមើលចុះ យើងបានខកចិត្តក្នុងបំណង របស់យើងនេះ ។

២៤ ពួកគេមិនហ៊ានឆ្លងកាត់ក្បែរយើង ដោយកងទ័ពទាំងមូល របស់គេទេ ហើយគេក៏មិនហ៊ានឆ្លងកាត់ជាផ្នែកៗដែរ ព្រោះពួក គេ ខ្លាចពុំមានកម្លាំងគ្រប់គ្រាន់ ឬពួកគេត្រូវបរាជ័យ ។

២៥ ពួកគេមិនហ៊ានលើកទ័ពទៅវាយទីក្រុងសារ៉ាហិមឡា ហើយគេក៏មិនហ៊ានឆ្លងកាត់ តាមក្បាលទន្លេស៊ីដូន ទៅកាន់ទីក្រុង នីហ្វៃហាដែរ ។

២៦ ម្ល៉ោះហើយ ដោយកងកម្លាំងរបស់គេ នោះពួកគេបាន ប្ដេជ្ញាថា នឹងរក្សាទីក្រុងទាំងឡាយដែលគេយកបាន ។

២៧ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅខែ ទីពីរក្នុងឆ្នាំនេះ មានស្បៀងជាច្រើន ត្រូវបាននាំមកឲ្យយើង ពីឪពុកទាំងឡាយរបស់កូនប្រុសពីរពាន់នាក់របស់ខ្ញុំនោះ ។

២៨ ហើយក៏មានទ័ពចំនួនពីរពាន់នាក់ ត្រូវបានបញ្ជូនមកឲ្យ យើង ពីដែនដីសារ៉ាហិមឡាដែរ ។ ម្ល៉ោះហើយ ពួកយើងបាន ប្រុង ប្រៀបជាស្រេច ដោយមានទ័ពចំនួនមួយម៉ឺននាក់ និងស្បៀងសំរាប់ពួកគេ និងសំរាប់ប្រពន្ធគេ និងកូនចៅគេផង ។

២៩ ហើយពួកលេមិន ដោយបានឃើញកងកម្លាំងរបស់យើង កើនឡើងជារៀងរាល់ថ្ងៃដូច្នោះ ហើយស្បៀងក៏មកដល់សំរាប់ គាំទ្រដល់យើង នោះពួកគេបានចាប់ផ្ដើមភិតភ័យ ហើយបាន ចាប់ផ្ដើមស្ទុះចេញមក ប្រសិនបើមានលទ្ធភាពធ្វើបាន ដើម្បី បញ្ឈប់កុំឲ្យ យើងទទួលស្បៀង និងកម្លាំងបាន ។

៣០ ឥឡូវនេះ កាលពួកយើងបានឃើញថា ពួកលេមិនបាន ចាប់ផ្ដើមមានការបារម្ភខ្លាំងឡើងចំពោះស្បៀតនេះ នោះពួក យើង មានបំណងចង់យកឧបាយសឹកមួយ មកប្រើលើពួកគេ; ហេតុដូច្នេះហើយ អាន់ទីផុសបានបញ្ជាថា ខ្ញុំត្រូវនាំកូនប្រុសតូច ៗទាំងឡាយ របស់ខ្ញុំ ដើរទៅទីក្រុងជិតខាងមួយ ហាក់បីដូចជា នាំយកស្បៀង ទៅកាន់ទីក្រុងជិតខាងនោះ ។

៣១ ហើយយើងត្រូវធ្វើដំណើរជិតទីក្រុងអានទីប៉ារ៉ា ហាក់បីដូចជាយើងកំពុងតែទៅកាន់ទីក្រុងមួយ ដែលនៅហួស ពីនោះ ក្នុងព្រំប្រទល់ជិតឆ្នេរសមុទ្រ ។

៣២ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានដើរទៅធ្វើដូចជាយកស្បៀងទៅជាមួយនឹងយើង ទៅកាន់ទីក្រុងនោះ ។

៣៣ ហើយហេតុការណ៍បានកើតឡើងថា អាន់ទីផុសបានធ្វើដំណើរចេញទៅជាមួយនឹងកងទ័ពរបស់លោកមួយផ្នែក ដោយទុកឲ្យទ័ពដែលនៅសល់ទាំងប៉ុន្មានរក្សាទីក្រុង ។ ប៉ុន្តែលោកពុំបានចេញទៅទេ ទាល់តែខ្ញុំបានចេញទៅជាមួយនឹងកងទ័ពតូចរបស់ខ្ញុំ ហើយបានមកជិតទីក្រុងអាន់ទីប៉ារ៉ាសិន ។

៣៤ ហើយឥឡូវនេះ នៅក្នុងទីក្រុងអាន់ទីប៉ារ៉ា នោះមានកងទ័ពសាសន៍លេមិននៅដ៏ខ្លាំងបំផុត; មែនហើយ មានចំនួនច្រើនបំផុត ។

៣៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានពត៌មានពីអ្នកស៊ើបការណ៍ទាំងឡាយរបស់ពួកគេ នោះពួកគេបាន ចេញមកជាមួយនឹងកងទ័ពរបស់គេ ហើយបានលើកមកតតាំងនឹងពួកយើង ។

៣៦ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានរត់គេចចេញពីគេទៅទិសខាងជើង ។ ម្ល៉ោះហើយ ពួកយើងបាននាំ កងទ័ពដ៏ខ្លាំងបំផុត របស់ពួកសាសន៍លេមិនចេញ ។

៣៧ មែនហើយ គឺទៅដល់ចម្ងាយដ៏ឆ្ងាយ ដរាបដល់ពេលដែលពួកគេបានឃើញកងទ័ពរបស់អាន់ទីផុស ដេញតាមពួកគេដោយ សមត្ថភាពរបស់គេ នោះពួកគេពុំបានបត់បែរទៅស្ដាំ ឬទៅឆ្វេងទេ តែបន្តដំណើររបស់គេត្រង់ទៅមុខ តាមក្រោយពួកយើង; ហើយបើតាមយើងសន្និដ្ឋាន គឺពួកគេមានបំណងចង់សម្លាប់ពួកយើងចោល មុនពេលអាន់ទីផុសដេញទាន់ពួកគេ ហើយយ៉ាងនេះ គឺដើម្បីកុំឲ្យពួកគេត្រូវអាចបានឡោមព័ទ្ធ ដោយទ័ពរបស់យើង ។

៣៨ ហើយឥឡូវនេះ អាន់ទីផុស កាលបានឃើញការគ្រោះថ្នាក់របស់ពួកយើង ក៏បានបង្កើនល្បឿនទ័ពរបស់លោក ។ ប៉ុន្តែមើលចុះ នោះជាពេលយប់; ហេតុដូច្នេះហើយ ពួកគេដេញតាមយើងមិនទាន់ទេ ឯអាន់ទីផុស ក៏ដេញតាមពួកគេមិនទាន់ដែរ; ហេតុដូច្នេះហើយ ពួកយើងបានបោះជំរុំសំរាប់យប់នោះ ។

៣៩ ហើយហេតុការណ៍បានកើតឡើងថា នៅមុនពេលព្រលឹមស្រាង នៃវេលាព្រឹក មើលចុះ ពួកលេមិនដេញតាមពួកយើង ។ ឥឡូវនេះ ពួកយើងពុំមានកម្លាំងគ្រប់គ្រាន់ ដើម្បីតតាំងនឹងពួកគេទេ; មែនហើយ ខ្ញុំពុំសុខចិត្តឲ្យកូនប្រុសតូចៗរបស់ខ្ញុំត្រូវធ្លាក់ទៅ ក្នុងកណ្ដាប់ដៃនៃពួកគេឡើយ; ហេតុដូច្នេះហើយ ពួកយើងក៏បានបន្តដំណើរទៅមុខ ហើយយើងបានធ្វើដំណើរចូលទៅក្នុងទីរហោ ស្ថាន ។

៤០ ឥឡូវនេះ ពួកគេពុំហ៊ានបត់បែរស្ដាំ ឬឆ្វេងទេ ព្រោះខ្លាចគេត្រូវឡោមព័ទ្ធ; ឯខ្ញុំក៏មិនបត់បែរស្ដាំ ឬឆ្វេងដែរ ព្រោះខ្លាច ក្រែងពួកគេដេញខ្ញុំទាន់ ហើយពួកយើងពុំអាចទប់ទល់នឹងពួកគេបានទេ តែនឹងត្រូវស្លាប់វិញ ហើយពួកគេនឹងរត់រួច; ម្ល៉ោះហើយ ពួកយើងបានរត់គេចអស់ពេញមួយថ្ងៃនោះចូលទៅក្នុងទីរហោស្ថាន គឺរហូតដល់ពេលយប់ងងឹត ។

៤១ ហើយហេតុការណ៍បានកើតឡើងថា ជាថ្មីទៀត កាលពន្លឺនៃពេលព្រឹកមកដល់ ពួកយើងបានឃើញពួកលេមិនមករកយើង ហើយយើងបានរត់ចេញពីពួកគេទៅ ។

៤២ ប៉ុន្តែហេតុការណ៍បានកើតឡើងថា ពួកគេពុំដេញយើងបានឆ្ងាយ មុនពេលគេឈប់នោះទេ; ហើយនោះគឺជាពេលព្រឹកនៃ ថ្ងៃទីបី នៃខែទីប្រាំពីរ ។

៤៣ ហើយឥឡូវនេះ តើពួកគេត្រូវអាន់ទីផុសតាមទាន់ឬអី នោះយើងមិនដឹងទេ ប៉ុន្តែខ្ញុំបាននិយាយទៅទ័ពរបស់ខ្ញុំថា៖ មើលចុះ យើងមិនដឹងទេថា តើពួកគេបានឈប់ក្នុងគោលបំណងចង់ឲ្យយើងមកវាយប្រហារគេ ដើម្បីពួកគេអាចចាប់ពួកយើង នៅក្នុងអន្ទាក់ របស់គេឬអី ។

៤៤ ហេតុដូច្នេះហើយ តើអ្នករាល់គ្នាថាដូចម្ដេច កូនប្រុសទាំងឡាយរបស់ឪពុកអើយ តើអ្នករាល់គ្នានឹងទៅច្បាំងនឹងពួកគេឬ ?

៤៥ ហើយឥឡូវនេះ បងម្ល៉ៃណៃ ជា[ក]ទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមប្រាប់បងថា ខ្ញុំមិនដែលបានឃើញសេចក្ដីក្លាហានដ៏ធំយ៉ាងនេះទេ ទោះនៅក្នុងចំណោមពួកសាសន៍នីហ្វៃទាំងអស់ក្ដី ។

៤៦ ព្រោះដូចខ្ញុំធ្លាប់ហៅពួកគេថា កូនប្រុសរបស់ខ្ញុំ (ព្រោះគេទាំងអស់គ្នានៅក្មេងណាស់) នោះពួកគេបាននិយាយមកខ្ញុំថា៖ ឪពុកអើយ មើលចុះ ព្រះរបស់យើងទ្រង់គង់នៅជាមួយនឹងយើង ហើយទ្រង់នឹងពុំទុកឲ្យយើងត្រូវដួលចុះទេ; ខណៈនោះចូរឲ្យយើង ទៅ; ពួកយើងនឹងពុំសម្លាប់បងប្អូនរបស់យើងទេ បើសិនជាពួកគេពុំធ្វើអ្វីដល់យើង; ហេតុដូច្នេះហើយ ចូរឲ្យយើងទៅ ព្រោះខ្លាច ក្រែងពួកគេមានជ័យជំនះ ទៅលើកងទ័ពរបស់អាន់ទីផុស ។

៤៧ ឥឡូវនេះ ពួកគេមិនដែលធ្លាប់បានប្រយុទ្ធមក[ក]ទេ តែគេពុំខ្លាចស្លាប់ឡើយ; ហើយពួកគេបានគិតជាច្រើន ដល់ឥស្សរភាពរបស់ឪពុកគេ ជាងគិតដល់ជីវិតរបស់ខ្លួន; មែនហើយ ពួកគេត្រូវ

៤៥ *ក* អាលម៉ា ៥៣:២០–២១.

៤៧ *ក* អាលម៉ា ៥៣:១៦–១៨.

បានបង្រៀនដោយម្ដាយ[ខ]គេថា បើសិនជាពួកគេពុំសង្ស័យទេ នោះព្រះទ្រង់នឹងដោះលែងពួកគេឲ្យរួច ។

៤៨ ហើយពួកគេបានរៀបរាប់ប្រាប់ខ្ញុំនូវពាក្យពេចន៍របស់ម្ដាយគេថា៖ យើងខ្ញុំមិនសង្ស័យសោះថា ម្ដាយយើងដឹងការណ៍នេះ ។

៤៩ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានត្រឡប់ជាមួយនឹងកូនពីរពាន់នាក់របស់ខ្ញុំ ទៅច្បាំងនឹងពួកលេមិនទាំងនេះ ដែលបានដេញតាមយើង ។ ហើយឥឡូវនេះ មើលចុះ ពលទ័ពរបស់អាន់ទិផុស បានតាមពួកគេទាន់ ហើយការប្រយុទ្ធដ៏ឃោរឃៅមួយបានចាប់ផ្ដើមឡើង ។

៥០ កងទ័ពរបស់អាន់ទិផុស ដោយនឿយហត់ មកពីការធ្វើដំណើរឆ្ងាយ ក្នុងរយៈពេលដ៏ខ្លី នោះជិតត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកសាសន៍លេមិន; ហើយបើកុំតែបានខ្ញុំត្រឡប់មកវិញ ជាមួយនឹងកងពីរពាន់នាក់របស់ខ្ញុំទេ ម្ល៉េះពួកគេច្បាស់ជាបានសំរេចគោលបំណងរបស់ពួកគេហើយ ។

៥១ ព្រោះអាន់ទិផុសត្រូវដួលដោយដាវ និងមេដឹកនាំរបស់លោកជាច្រើនដែរ ដោយសារការនឿយហត់ ដែលបណ្ដាលមកពី ដំណើរទ័ពដ៏លឿន — ហេតុដូច្នេះហើយ កងទ័ពរបស់អាន់ទិផុស ដោយមានការច្របូកច្របល់ ព្រោះការដួលចុះនៃមេដឹកនាំរបស់ គេ ក៏ចាប់ផ្ដើមបើកផ្លូវឲ្យពួកលេមិន ។

៥២ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានឡើងចិត្តក្លាហាន ហើយបានចាប់ផ្ដើមដេញតាមពួកគេ; ម្ល៉ោះហើយ ពួកលេមិនកំពុងតែដេញតាមពួកគេ យ៉ាងពេញទំហឹង នៅពេលហេលេមិនមកវាយប្រហារពីខាងក្រោយពួកគេ ជាមួយនឹងកងពីរ ពាន់នាក់របស់លោក ហើយចាប់ផ្ដើមសម្លាប់ពួកគេច្រើនហួសប្រមាណ ដរាបដល់កងទ័ពសាសន៍លេមិនឈប់ ហើយបែរមកលើ ហេលេមិនវិញ ។

៥៣ ឥឡូវនេះ កាលដែលទ័ពរបស់អាន់ទិផុស បានឃើញថាពួកលេមិនបានបែរក្រោយ នោះពួកគេក៏បានប្រមូលគ្នា ហើយមក វាយពីខាងក្រោយពួកលេមិនទៀត ។

៥៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកយើងដែលជាទ័ពរបស់នីហ្វៃ ទ័ពរបស់អាន់ទិផុស ហើយខ្ញុំជាមួយនឹងកង ពីរពាន់នាក់របស់ខ្ញុំ បានព័ទ្ធជុំវិញពួកលេមិន ហើយបានសម្លាប់ពួកគេ; មែនហើយ គឺដរាបដល់ពួកគេត្រូវបង្ខំឲ្យប្រគល់គ្រឿង សស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ព្រមទាំងខ្លួនគេធ្វើជាឈ្លើយសឹក ។

៥៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលពួកគេបានប្រគល់ខ្លួនសុំចុះចាញ់ពួកយើងហើយ មើលចុះ ខ្ញុំបានរាប់ ចំនួនកំឡោះទាំងនោះ ដែលបានប្រយុទ្ធជាមួយនឹងខ្ញុំ ព្រោះខ្លាចពួកគេត្រូវស្លាប់អស់ច្រើន ។

៥៦ ប៉ុន្តែមើលចុះ ខ្ញុំមានសេចក្ដីអំណរជាខ្លាំង គ្មានអ្នកណាម្នាក់[ក]ក្នុងពួកគេ បានដួលចុះទៅលើដីឡើយ; មែនហើយ ហើយពួក គេបានប្រយុទ្ធ ហាក់បីដូចជាមានកម្លាំងនៃព្រះ; មែនហើយពុំដែលដឹងថា មនុស្សអាចប្រយុទ្ធដោយកម្លាំងដ៏អស្ចារ្យបែបនេះទេ; ហើយដោយអានុភាពដ៏ខ្លាំងក្លាបែបនេះ ពួកគេបានវាយប្រហារពួកលេមិន ដែលពួកគេបានធ្វើឲ្យពួកវាតក់ស្លុត; ហើយដោយហេតុនេះ ទើបពួកលេមិនបានប្រគល់ខ្លួន ធ្វើជាឈ្លើយសឹក ។

៥៧ ហើយដោយពួកយើងគ្មានកន្លែង សំរាប់ឈ្លើយរបស់យើងដើម្បីយើងអាចយាមពួកគេ ការពារពួកគេពីពលទ័ពសាសន៍ លេមិន ហេតុដូច្នេះហើយ យើងបានបញ្ជូនពួកគេ ទៅឯដែនដីសារ៉ាហិមឡា ហើយចាត់ទ័ពមួយភាគរបស់អាន់ទិផុស ដែលមិន ត្រូវស្លាប់នោះឲ្យទៅជាមួយនឹងពួកគេ; ឯចំនួនដែលនៅសល់ ខ្ញុំបានយកមកបញ្ចូលជាមួយនឹងពួកកំឡោះសាសន៍[ក]អាំម៉ូនរបស់ខ្ញុំ ហើយបានធ្វើដំណើរត្រឡប់ទៅទីក្រុងយូដាវិញ ៕

## ជំពូកទី ៥៧

*ហេលេមិនរៀបរាប់អំពីការវាយយកក្រុងអាន់ទីប៉ារ៉ាមកវិញ និងការចុះចូល ហើយបន្ទាប់មក អំពីកិច្ចការពារក្រុងគូមេណៃ — យុវជន សាសន៍អាំម៉ូនទាំងឡាយរបស់លោក ប្រយុទ្ធយ៉ាងអង់អាច; ហើយទាំងអស់គ្នាត្រូវរបួស តែគ្មានអ្នកណាម្នាក់ត្រូវស្លាប់ឡើយ — គឺឧរាយការណ៍អំពីការកាប់សម្លាប់ និងការរត់រួចនៃពួកឈ្លើយសាសន៍លេមិន ។ ប្រមាណជាឆ្នាំ ៦៣ ម.គ.ស. ។*

*ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ខ្ញុំបានទទួលសំបុត្រមួយច្បាប់ពីអាំម៉ូរ៉ុន ដែលជាស្ដេចថែងថា បើសិនជាខ្ញុំព្រមដោះ លែងពួកឈ្លើយសឹក ដែលយើងចាប់បានទាំងនោះ ទ្រង់នឹងប្រគល់ទីក្រុងអាន់ទីប៉ារ៉ាមកឲ្យយើង ។*

២ ប៉ុន្តែ ខ្ញុំបានផ្ញើសំបុត្រមួយច្បាប់ទៅស្ដេចថា ពួកយើងដឹង

៤៧ *ខ* អាលម៉ា ៥៧:២១.
ស.ប. ម្ដាយ.
៥៦ *ក* អាលម៉ា ៥៧:២៥; ៥៨:៣៩.
៥៧ *ក* អាលម៉ា ២៧:២៦;
៥៣:១០–១១, ១៦.

ច្បាស់ថា កងកម្លាំងរបស់យើងមានគ្រប់គ្រាន់ ដើម្បីវាយយក
ទីក្រុង អាន់ទីប៉ារ៉ា ដោយកម្លាំងរបស់យើង; ហើយការ
ដោះលែងពួកឈ្លើយ ដើម្បីប្ដូរយកទីក្រុង នោះយើងគិតថា
ជាឆោតទៅវិញ ហើយយើងគ្រាន់តែចង់ដោះលែងពួក
ឈ្លើយរបស់យើង ដើម្បីប្ដូរឈ្លើយតែប៉ុណ្ណោះ ។
៣ ហើយអាំម៉ូរ៉ុន ជំទាស់សំបុត្ររបស់ខ្ញុំ ព្រោះទ្រង់មិន
ព្រមប្ដូរពួកឈ្លើយទេ; ហេតុដូច្នេះហើយ យើងបានចាប់ផ្ដើមធ្វើ
ការរៀបចំ ដើម្បីទៅវាយយកទីក្រុងអាន់ទីប៉ារ៉ា ។
៤ ប៉ុន្តែទ័ពរបស់អាន់ទីប៉ារ៉ា បានចាកចេញពីទីក្រុង ហើយបាន
រត់គៀសទៅទីក្រុងឯទៀត ដែលជារបស់គេ ដើម្បីពង្រឹងកម្លាំង
ពួកគេ; ហើយទីក្រុងអាន់ទីប៉ារ៉ាត្រូវបានធ្លាក់មកក្នុងកណ្ដាប់ដៃពួក
យើងបែបនេះ ។
៥ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីម្ភៃប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រមទៅ។
៦ ហើយហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីម្ភៃប្រាំបួន
ពួកយើងបានទទួលស្បៀងមួយចំនួន ព្រមទាំងកងទ័ពបន្ថែមឲ្យ
យើងផង ពីដែនដីសារ៉ាហិមឡា និងពីដែនដីដែលនៅព័ទ្ធជុំវិញ
ដល់មានចំនួនប្រាំមួយពាន់នាក់ ក្រៅពីនោះ មានកូនប្រុស
សាសន៍ អាំម៉ូន ហុកសិបនាក់បានមករួបរួមនឹងបងប្អូនរបស់គេ
គឺជាក្រុមតូចពីរពាន់ក្មេងតូចៗរបស់ខ្ញុំ ។ ហើយឥឡូវនេះ មើលចុះ
យើងមាន កម្លាំង មែនហើយ ហើយយើងមានស្បៀងបរិបូរ
ដែលនាំមកឲ្យយើង ។
៧ ហើយហេតុការណ៍បានកើតឡើងថា យើងមាន
បំណងចង់ទៅប្រយុទ្ធនឹងកងទ័ព ដែលត្រូវបានដាក់ឲ្យការពារ
ទីក្រុងគូមេណៃ ។
៨ ហើយឥឡូវនេះ មើលចុះ ខ្ញុំនឹងបង្ហាញដល់បងថា យើង
បានសំរេចបំណងយើងក្នុងពេលដ៏ខ្លី; មែនហើយ ដោយមានកង
កម្លាំងដ៏ខ្លាំង ឬដោយផ្នែកមួយនៃកងកម្លាំងដ៏ខ្លាំងរបស់យើង
ពួកយើងបានព័ទ្ធជុំវិញទីក្រុងគូមេណៃ ក្នុងពេលយប់ គឺមុនពេល
មួយ ថ្ងៃ ដែលពួកគេទទួលស្បៀងបន្ថែម ។
៩ ហើយហេតុការណ៍បានកើតឡើងថា យើងបាន
បោះជំរុំជុំវិញទីក្រុងនោះ អស់ជាច្រើនយប់; ប៉ុន្តែយើងបាន
ដេកកើយដាវរបស់ យើង ហើយចាំយាម ដើម្បីកុំឲ្យពួកលេមិន
អាចវាយប្រហារយើង នៅពេលយប់ ហើយសម្លាប់យើងបាន
ដែលពួកគេបានប៉ុនប៉ងជា ច្រើនលើក; ប៉ុន្តែអស់ជាច្រើនលើក
ដែលពួកគេប៉ុនប៉ងនោះ ឈាមរបស់គេត្រូវខ្ចាយ ។
១០ នៅទីបញ្ចប់ ស្បៀងរបស់ពួកគេបានមកដល់ ហើយស្បៀង
ជិតចូលទៅក្នុងទីក្រុងនៅពេលយប់ ។ ហើយពួកយើងជា ទ័ពនីហ្វៃ
មិនមែនជាទ័ពលេមិនទេ; ហេតុដូច្នេះហើយ ពួកយើងបានចាប់
ពួកគេ និងស្បៀងរបស់គេ ។
១១ ហើយទោះបីពួកលេមិនត្រូវកាត់ផ្ដាច់ពីការផ្គត់ផ្គង់ តាម
របៀបនេះក៏ដោយ គង់តែពួកគេនៅតែប្ដេជ្ញាថា នឹងរក្សាទីក្រុង
នោះ; ហេតុដូច្នេះហើយ ជាការចាំបាច់ដែលយើងត្រូវតែយក
ស្បៀងទាំងនោះ ហើយបញ្ជូនវាទៅឯក្រុងយូដា រីឯពួក
ឈ្លើយរបស់ យើង ទៅឯដែនដីសារ៉ាហិមឡា ។
១២ ហើយហេតុការណ៍បានកើតឡើងថា មិនយូរថ្ងៃប៉ុន្មាន
ពួកលេមិនក៏ចាប់ផ្ដើមអស់សេចក្ដីសង្ឃឹមថាបានជំនួយ; ហេតុដូច្នេះ
ហើយ ពួកគេបានប្រគល់ទីក្រុងនោះដល់ដៃយើង; ម្ល៉ោះហើយ យើង
បានសំរេចផែនការណ៍របស់យើង ក្នុងការយកទីក្រុងគូមេណៃ ។
១៣ ប៉ុន្តែហេតុការណ៍បានកើតឡើងថា ពួកឈ្លើយរបស់យើង
មានចំនួនច្រើនពេក ទោះជាពួកយើងមានចំនួនច្រើនសំបើមក្ដី គង់
តែពួកយើងត្រូវបង្ខំឲ្យប្រើកងកម្លាំងយើងទាំងអស់ ដើម្បីយាម
ពួកគេ ឬក៏យកពួកគេទៅប្រហារជីវិតចោល ។
១៤ ត្បិតមើលចុះ ពួកគេបានបះបោរក្នុងចំនួនជាច្រើននាក់
ហើយបានប្រយុទ្ធដោយប្រើថ្ម និងដំបង ឬវត្ថុណាក្ដីដែលគេអាច
រក បានមកក្នុងដៃគេ ដរាបដល់យើងបានសម្លាប់ពួកគេអស់ជាង
ពីរពាន់នាក់ ក្រោយពីពួកគេបានចុះចាញ់ធ្វើជាឈ្លើយសឹក ។
១៥ ហេតុដូច្នេះហើយ ជាការចាំបាច់សំរាប់យើង ដែលយើង
ត្រូវបញ្ចប់ជីវិតគេ ឬយាមគេដោយដាវនៅក្នុងដៃ ចុះទៅដែនដី
សារ៉ាហិមឡា; ហើយស្បៀងរបស់យើងផង ក៏មិនមាន
លើសពីគ្រប់គ្រាន់សំរាប់តែទ័ពយើង ទោះជាមានទាំងស្បៀង
ដែលយើង យកបានពីពួកលេមិនក្ដី ។
១៦ ហើយឥឡូវនេះ នៅក្នុងកាលៈទេសៈដែលប្រកបដោយ
គ្រោះថ្នាក់នេះ វាក្លាយទៅការណ៍មួយដ៏សែនសំខាន់ ថាត្រូវ
សំរេចចិត្តយ៉ាងណា អំពីពួកឈ្លើយសឹកទាំងនេះ; ទោះជាយ៉ាង
ណាក៏ដោយ គង់តែពួកយើងបានសំរេចថា នឹងបញ្ជូនពួកគេ
ទៅឯដែនដីសារ៉ាហិមឡាដែរ; ហេតុដូច្នេះហើយ ពួកយើងបាន
រើសទ័ពរបស់យើងមួយភាគ ហើយបានប្រគល់ភារៈឲ្យគេនាំពួក
ឈ្លើយរបស់យើង ចុះទៅឯដែនដីសារ៉ាហិមឡា ។
១៧ ប៉ុន្តែហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង
ពួកគេបានត្រឡប់មកវិញ ។ ហើយឥឡូវនេះ មើលចុះ ពួក
យើងមិន បានសួរគេអំពីពួកឈ្លើយរបស់យើងទេ; ត្បិតមើលចុះ
ពួកលេមិនកំពុងតែវាយប្រហារយើង ហើយពួកគេបានត្រឡប់

៥៧ ៦ក អាលម៉ា ៥៣:១៦–១៨.

មកវិញចំពេល ដើម្បីជួយសង្គ្រោះយើង កុំឲ្យធ្លាក់ទៅក្នុង
កណ្ដាប់ដៃរបស់ពួកវា ។ ត្បិតមើលចុះ អាំម៉ូរ៉ុនបានបញ្ជូនមក
ជួយពួកវា នូវស្បៀង និងទ័ព មួយកងដ៏ច្រើនផង ។
១៨ ហើយហេតុការណ៍បានកើតឡើថា ទ័ពដែលយើងចាត់ឲ្យ
នាំពួកឈ្លើយទៅនោះ បានមកដល់ទាន់ពេល ដើម្បីបញ្ឈប់ពួកវា
នៅពេលពួកវាជិតយកជ័យជំនះលើពួកយើង ។
១៩ ប៉ុន្ដែមើលចុះ ក្រុមតូចពីរពាន់ហុកសិបនាក់របស់ខ្ញុំ បាន
ប្រយុទ្ធយ៉ាងបួរផ្ដាច់; មែនហើយ ពួកគេរឹងប៉ឹងនៅចំពោះពួកលេមិន
ហើយបានធ្វើឲ្យស្លាប់ដល់អស់ពួកណាដែលមកតតាំងនឹងគេ ។
២០ ហើយនៅពេលកងទ័ពរបស់យើង ដែលនៅសល់ទាំងប៉ុន្មាន
ជិតបើកផ្លូវឲ្យមុខពួកលេមិន មើលចុះ ពួកពីរពាន់ហុកសិប
នាក់នោះនៅរឹងប៉ឹង ហើយក្លាហានយ៉ាងបួរផ្ដាច់ ។
២១ មែនហើយ ហើយពួកគេបានគោរព ហើយប្រតិបត្ដិ
តាមគ្រប់ពាក្យបញ្ជា ដោយត្រូវតតល្អៀង; មែនហើយ ហើយ
គឺស្រប តាមសេចក្ដីជំនឿរបស់គេ ដែលបណ្ដាលឲ្យគេធ្វើ
យ៉ាងនេះ; ហើយខ្ញុំបានចាំនូវពាក្យពេចន៍ដែលគេបាននិយាយមក
ខ្ញុំថា [ក]ម្ដាយ របស់គេបានបង្រៀនពួកគេ ។
២២ ហើយឥឡូវនេះ មើលចុះ គឺដោយសារកូនប្រុសរបស់ខ្ញុំ
ទាំងនេះ និងទ័ពដែលត្រូវបានរើសឲ្យនាំពួកឈ្លើយ ចំពោះអ្នក
ទាំង នេះហើយដែលពួកយើងជំពាក់ជ័យជំនះដ៏ធំនេះ; ព្រោះ
គឺពួកគេនេះហើយដែលបានឈ្នះលើពួកលេមិន; ហេតុដូច្នេះហើយ
ពួកវាត្រូវ បានរុញច្រានឲ្យថយទៅឯទីក្រុងម៉ាន់តៃវិញ ។
២៣ ហើយយើងបានរក្សាទីក្រុងគូមេណៃរបស់យើងទុក
ហើយពុំត្រូវបំផ្លាញអស់ដោយដាវទេ; ទោះជាយ៉ាងណាក៏ដោយ
គង់តែយើងបានរងការបាត់បង់ដ៏ធំ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកលេមិន
បានរត់ទៅ ខ្ញុំបានចេញបញ្ជាភ្លាមថា ទ័ពរបស់ខ្ញុំដែលត្រូវរបួស
នោះត្រូវយកចេញពីក្នុងចំណោមអ្នកស្លាប់ ហើយត្រូវរុំអបមុខ
របួសឲ្យគេ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា មានចំនួនពីររយនាក់
នៅក្នុងចំណោមពីរពាន់ហុកសិបនាក់របស់ខ្ញុំ ដែលត្រូវសន្លប់
ដោយសារអស់ឈាម; ទោះជាយ៉ាងណាក៏ដោយ គង់
តែស្របតាមសេចក្ដីល្អសប្បុរសនៃព្រះ និងចំពោះសេចក្ដីអស្ចារ្យ
របស់យើង ជាខ្លាំង[ក] និងចំពោះសេចក្ដីអំណររបស់កងទ័ពយើង
ទាំងមូលផង នោះគ្មានអ្នកណាម្នាក់ នៅក្នុងចំណោមពួកគេត្រូវ
វិនាសឡើយ; មែនហើយ ហើយគ្មានអ្នកណាម្នាក់ នៅក្នុង
ចំណោមពួកគេដែលពុំមានរបួសច្រើនដែរ ។
២៦ ហើយឥឡូវនេះ ការណ៍ដែលគេត្រូវបានរក្សាឲ្យគង់វង់
គឺជាការណ៍មួយដ៏គួរឲ្យឆ្ងល់ ដល់កងទ័ពយើងទាំងមូល មែន
ហើយ ថាពួកគេត្រូវបានសំចៃទុក នៅពេលដែលបងប្អូនយើង
មួយពាន់នាក់ត្រូវស្លាប់ ។ ហើយយើងសន្មតដោយត្រឹមត្រូវថា
ការណ៍នេះគឺ មកពី[ក]ព្រះចេស្ដាដ៏អស្ចារ្យនៃព្រះ ដោយសារ
[ខ]សេចក្ដីជំនឿដ៏លើសលប់របស់គេ នៅក្នុងអ្វីៗ ដែលពួកគេត្រូវ
បានបង្រៀនឲ្យជឿ —ថាមានព្រះដ៏យុត្តិធម៌មួយអង្គ ហើយ
អស់អ្នកណាដែលមិនសង្ស័យ អ្នកនោះនឹងត្រូវបានរក្សាទុកឲ្យ
គង់វង្ស ដោយព្រះចេស្ដាដ៏ អស្ចារ្យរបស់ទ្រង់ ។
២៧ ឥឡូវនេះ នេះគឺជាសេចក្ដីជំនឿនៃពួកអ្នកទាំងនេះ ដែលខ្ញុំ
បាននិយាយមកនេះ; ពួកគេនៅក្មេង ហើយគំនិតគេរឹងប៉ឹង ហើយ
ពួកគេដាក់ទីទុកចិត្តរបស់គេទៅលើព្រះរហូត ។
២៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួក
យើងបានថែទាំដល់ពួកអ្នករបួសរបស់យើង ហើយបានបញ្ចុះពួក
អ្នកស្លាប់ និងពួកលេមិនដែលស្លាប់ ដែលមានច្រើនហើយ មើលចុះ
យើងបានសួរគីឌ អំពីពួកឈ្លើយ ដែលពួកគេបានចាប់ផ្ដើមនាំចុះ
ទៅឯដែនដីសារ៉ាហិមឡានោះ ។
២៩ ឥឡូវនេះ គីឌ គឺជាមេទ័ពឯកលើក្រុមទ័ពដែលត្រូវចាត់ឲ្យ
យាមពួកគេនាំចុះទៅដែនដីនោះ ។
៣០ ហើយឥឡូវនេះ នេះគឺជាពាក្យពេចន៍ដែលគីឌបាននិយាយ
មកខ្ញុំ៖ មើលចុះ យើងបានចាប់ផ្ដើមធ្វើដំណើរចុះទៅដែនដី
សារ៉ាហិមឡា ជាមួយនឹងពួកឈ្លើយរបស់យើង ។
ហើយហេតុការណ៍បានកើតឡើងថា យើងបានជួបនឹងពួក
អ្នកស៊ើបការណ៍ នៃពលទ័ពរបស់យើង ដែលត្រូវបានចាត់ឲ្យ
ទៅឃ្លាំមើលជំរុំរបស់ពួកលេមិន ។
៣១ ហើយពួកគេបានស្រែកប្រាប់យើងថា — មើលចុះ
ពលទ័ពសាសន៍លេមិនកំពុងលើកសំដៅ ទៅឯទីក្រុងគូមេណៃ;
ហើយ មើលចុះ ពួកវានឹងវាយប្រហារពួកគេ មែនហើយ ហើយ
នឹងបំផ្លាញប្រជាជនរបស់យើងចោល ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ពួកឈ្លើយរបស់យើង
បានឮសំរែកទាំងឡាយរបស់ពួកគេ ដែលបានធ្វើឲ្យពួកវាឡើង
ចិត្តក្លាហាន; ហើយពួកវាបានបះបោរឡើងប្រឆាំងនឹងយើង ។
៣៣ ហើយហេតុការណ៍បានកើតឡើង គឺដោយមក

២១ *ក* អាលម៉ា ៥៦:៤៧–៤៨.
២៥ *ក* អាលម៉ា ៥៦:៥៦.
២៦ *ក* ស.ប. អំណាច.
*ខ* ស.ប. សេចក្ដីជំនឿ.

ពីការបះបោររបស់ពួកគេ ទើបយើងបានប្រើដាវរបស់យើង
ប្រយុទ្ធនឹងគេ ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេ
បានផ្ដុំគ្នាជាក្រុមៗ រត់មកបុកនឹងដាវរបស់ពួកយើង នៅក្នុង
ការធ្វើនេះ ពួកគេចំនួនច្រើន ត្រូវស្លាប់ ឯពួកគេដែល
នៅសល់ទាំងប៉ុន្មាន បានបែកចេញ ហើយ
រត់គេចចេញពីយើងទៅ ។
៣៤ ហើយមើលចុះ កាលពួកគេបានរត់គេចទៅ ហើយពួក
យើងមិនអាចតាមគេទាន់ នោះយើងបានធ្វើដំណើរយ៉ាងលឿន
ឆ្ពោះមកឯទីក្រុងគូមេណៃ; ហើយមើលចុះ យើងបានមកដល់
ទាន់ពេល ដើម្បីយើងអាចជួយបងប្អូនយើង ក្នុងការ
រក្សាទីក្រុងនេះទុក ឲ្យគង់ ។
៣៥ ហើយមើលចុះ ពួកយើងត្រូវបានដោះលែងជាថ្មីទៀត
ឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវយើង ។ ហើយសូមឲ្យ
ព្រះនាមនៃព្រះរបស់យើងប្រកបដោយព្រះពរ; ត្បិតមើលចុះ
គឺទ្រង់នេះហើយដែលបានដោះលែងពួកយើងឲ្យរួច; មែនហើយ
ដែលបានធ្វើកិច្ចការដ៏ធំនេះដល់យើង ។
៣៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលខ្ញុំ
គឺហេលេមិន បានឮពាក្យទាំងនេះពីគីឌហើយ នោះខ្ញុំបានពោរពេញ
ទៅដោយសេចក្ដីអំណរដ៏លើសលប់ ដោយសារសេចក្ដី
ល្អសប្បុរសនៃព្រះ ក្នុងការរក្សាយើងទុកឲ្យគង់ ដើម្បីកុំឲ្យ
យើងវិនាសទាំង អស់គ្នា; មែនហើយ ហើយខ្ញុំ[ក]ជឿថា ព្រលឹង
របស់ពួកអ្នកដែលបានស្លាប់ទៅ នោះបានចូលទៅក្នុងទីសំរាក នៃ
ព្រះរបស់ពួកគេហើយ ៕

## ជំពូកទី ៥៨

*ហេលេមិន គីឌ និងទីអុមណើរដណ្ដើមយកទីក្រុងម៉ាន់ទៃ ដោយឧបាយសឹកមួយ — ពួកលេមិនដកថយ — កូនប្រុសទាំងឡាយរបស់ ប្រជាជនអាំម៉ូន ត្រូវបានថែរក្សាទុកឲ្យគង់ ក្នុងកាលពួកគេឈរយ៉ាងរឹងប៉ឹង ក្នុងកិច្ចការពារឥស្សរភាព និងសេចក្ដីជំនឿរបស់គេ ។ ប្រមាណជាឆ្នាំ ៦៣–៦២ ម.គ.ស. ។*

ហើយមើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
ទិសដៅបន្ទាប់របស់យើង គឺយកទីក្រុងម៉ាន់ទៃ; ប៉ុន្តែមើលចុះ
គ្មានមធ្យោបាយណា ដែលយើងអាចនាំពួកគេឲ្យចេញពីទីក្រុង
ដោយក្រុមទ័ពតូចៗរបស់យើងបានទេ ។ ត្បិតមើលចុះ ពួក
គេចាំនូវអ្វីដែលយើង បានធ្វើពីមុន; ហេតុដូច្នេះហើយ ពួក
យើងមិនអាចបញ្ឆោត[ក]ពួកគេឲ្យចេញឆ្ងាយ ពីទីតាំងការពារ
របស់ពួកគេបានឡើយ ។
២ ហើយពួកគេមានចំនួនច្រើនជាងកងទ័ពយើង នាំឲ្យ
យើងមិនហ៊ានទៅវាយប្រហារពួកគេ នៅក្នុងទីតាំងការពារ
របស់គេទេ ។
៣ មែនហើយ ហើយវាបានក្លាយទៅជាការចាំបាច់ថា ពួក
យើងត្រូវប្រើទ័ពយើងក្នុងការរក្សាផ្នែកទាំងឡាយ នៃដែនដីដែល
យើងយកបានមកវិញ; ហេតុដូច្នេះហើយ វាបានក្លាយទៅជា
ការចាំបាច់ថា យើងត្រូវរង់ចាំ ដើម្បីយើងអាចទទួលកម្លាំង
បន្ថែមពី ដែនដីសារ៉ាហិមឡា ព្រមទាំងស្បៀងថ្មីផង ។
៤ ហើយហេតុការណ៍បានកើតឡើងថា ហេតុនោះ ខ្ញុំបាន
បញ្ជូនសារទូតមួយ ទៅឯលោកអភិបាលរបស់ដែនដីយើង ដើម្បីរាយ
ការណ៍ជំរាបលោក អំពីកិច្ចការទាំងឡាយរបស់ទ័ពយើង ។
ហើយហេតុការណ៍បានកើតឡើងថា យើងបានរង់ចាំទទួលស្បៀង
និងកម្លាំងពីដែនដីសារ៉ាហិមឡា ។
៥ ប៉ុន្តែមើលចុះ ការណ៍នេះគ្មានបានប្រយោជន៍ដល់យើងសោះ
គ្រាន់តែបន្តិចបន្តួចប៉ុណ្ណោះ; ព្រោះពួកលេមិនក៏ទទួលកម្លាំង
ដ៏ច្រើនរាល់ថ្ងៃ និងស្បៀងជាច្រើនផង; ម្ល៉ោះហើយ នេះ
គឺជាកាលៈទេសៈរបស់យើងនៅរយៈពេលនោះ ។
៦ ហើយពួកលេមិនបានស្ទុះចេញមកវាយយើងម្ដងម្កាល ដោយ
ប្ដេជ្ញាថា នឹងបំផ្លាញយើងបង់ ដោយប្រើឧបាយសឹក; ទោះជា
យ៉ាងណាក៏ដោយ គង់តែយើងមិនអាចទៅច្បាំងនឹងពួកគេបាន
ទេ ព្រោះគេថយទៅក្នុងទីជំរក និងទីតាំងការពាររបស់គេវិញ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានរង់ចាំ
នៅក្នុងកាលៈទេសៈដ៏ពិបាកទាំងនេះ អស់រយៈពេលជាច្រើនខែ
រហូតដល់យើងជិតវិនាសបង់ ដោយអត់អាហារ ។
៨ ប៉ុន្តែហេតុការណ៍បានកើតឡើងថា ពួកយើងបានទទួលអាហារ
ដែលនាំមកឲ្យយើង ដោយទ័ពមួយកង ចំនួនពីរពាន់នាក់ ដើម្បី
ជាជំនួយដល់យើង; ហើយនេះគឺជាជំនួយទាំងអស់ ដែលយើង
បានទទួល ដើម្បីការពារខ្លួនយើង និងប្រទេសរបស់យើង កុំឲ្យ
ធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់យើង មែនហើយ
ដើម្បីតតាំងនឹងកងទ័ពមួយ ដែលច្រើនឥតគណនា ។
៩ ហើយឥឡូវនេះ ហេតុដែលបណ្ដាលឲ្យយើង មាន
ការពិបាកទាំងនេះ ឬហេតុអ្វីដែលពួកគេមិនបញ្ជូនកម្លាំងបន្ថែមឲ្យ
យើង នោះយើងមិនដឹងទេ; ហេតុដូច្នេះហើយ ពួកយើងមានទុក្ខ
ព្រួយ ហើយពោរពេញទៅដោយការភិតភ័យផង ក្រែងលោដោយ

៣៦ *ក* អាលម៉ា ១២:៣៤.
**៥៨** ១ *ក* អាលម៉ា ៥២:២១; ៥៦:៣០.

មធ្យោបាយណាមួយ នោះសេចក្ដីជំនុំជំរះទាំងឡាយនៃព្រះ នឹងធ្លាក់មកលើដែនដីយើង ធ្វើឲ្យមានការរលំរលើង និងការបំផ្លិចបំផ្លាញដល់យើងទាំងស្រុង ។

១០ ហេតុដូច្នេះហើយ យើងបានខិតខំអស់ពីដួងចិត្ត នៅក្នុងការអធិស្ឋានដល់ព្រះ សូមឲ្យទ្រង់ចំរើនកម្លាំងដល់យើង ហើយដោះលែងយើងឲ្យរួចផុតពីកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវរបស់យើង មែនហើយ ហើយសូមប្រទានដល់យើងផងដែរនូវកម្លាំង ដើម្បីយើងអាចរក្សាទីក្រុងទាំងឡាយទុក និងដែនដីទាំងឡាយរបស់យើង ហើយទ្រព្យសម្បត្តិរបស់យើង ដើម្បីចិញ្ចឹមប្រជាជនយើង ។

១១ មែនហើយ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ជាព្រះរបស់យើង ទ្រង់បានយាងមកជួបយើង ដោយនូវការ អះអាងទាំងឡាយថា ទ្រង់នឹងដោះលែងពួកយើងឲ្យរួច; មែនហើយ ដរាបដល់ទ្រង់មានព្រះបន្ទូល នូវសេចក្ដីសុខសាន្តដល់ព្រលឹង ពួកយើង ហើយបានប្រទានដល់យើងនូវសេចក្ដីជំនឿដ៏ធំ ហើយបានធ្វើឲ្យយើងមានសេចក្ដីសង្ឃឹម ដល់ការដោះលែងពួកយើង ក្នុងទ្រង់ ។

១២ ហើយយើងបានឡើងចិត្តក្លាហាន ដោយនូវកងកម្លាំងដ៏តូចដែលយើងបានទទួល ហើយប្ដេជ្ញាថា ក នឹងយកជ័យជំនះ លើពួកខ្មាំងសត្រូវរបស់យើង ហើយនឹងរក្សាដែនដី និងទ្រព្យសម្បត្តិរបស់យើង និងប្រពន្ធរបស់យើង និងកូនចៅរបស់យើង និងឧត្តមគតិនៃ ខ ឥស្សរភាពរបស់យើងឲ្យបាន ។

១៣ ម្ល៉ោះហើយ យើងបានចេញទៅ ដោយអស់ពីសមត្ថភាពរបស់យើង ទៅតតាំងនឹងពួកលេមិន ដែលនៅក្នុងទីក្រុងម៉ាន់តៃ ហើយយើងបានបោះត្រសាលជិតទីរហោស្ថាន ដែលនៅជិតទីក្រុងនោះ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង កាលពួកលេមិនបានឃើញថា យើងនៅក្នុងព្រំប្រទល់ក្បែរទីរហោស្ថាន ដែលនៅជិតទីក្រុងនោះ នោះពួកគេបានចាត់ឲ្យពួកអ្នកស៊ើបការណ៍ទៅជុំវិញយើង ក្រែងពួកគេអាចដឹងនូវចំនួន និងកម្លាំងរបស់កងទ័ពយើង ។

១៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេឃើញថា យើងពុំមានកម្លាំងទេ ស្របតាមចំនួនទ័ពរបស់យើង ហើយដោយខ្លាចក្រែងយើងនឹងកាត់ផ្ដាច់ពួកគេពីជំនួយ លើកលែងតែពួកគេចេញមកច្បាំងនឹងពួកយើង ហើយសម្លាប់ពួកយើង ហើយដោយសន្និដ្ឋានផងដែរថា ពួកគេអាចបំផ្លាញយើងដោយងាយ ដោយកងពលដ៏ច្រើនរបស់គេ ទើបពួកគេបានចាប់ផ្ដើមធ្វើការរៀបចំ ដើម្បីចេញមកច្បាំងតតាំងនឹងយើង ។

១៦ ហើយកាលពួកយើងបានឃើញថា ពួកគេកំពុងតែរៀបចំដើម្បីមកច្បាំងនឹងយើង មើលចុះ ខ្ញុំបានបញ្ជាឲ្យគីឌនាំទ័ពមួយចំនួនតូច ទៅពួនលាក់ខ្លួននៅក្នុងទីរហោស្ថាន ហើយទីអុមណើរនិងទ័ពមួយចំនួនតូចផង ត្រូវទៅពួនលាក់ខ្លួន នៅក្នុងទីរហោស្ថានដែរ ។

១៧ ឥឡូវនេះ គីឌ និងទ័ពរបស់លោកនៅខាងស្ដាំ ឯអ្នកឯទៀតនៅខាងឆ្វេង; ហើយកាលពួកគេបានទៅពួនលាក់ខ្លួនហើយ មើលចុះ ខ្ញុំនៅជាមួយនឹងកងទ័ពរបស់ខ្ញុំ ដែលនៅសល់ទាំងប៉ុន្មាន នៅក្នុងកន្លែងដដែល គឺកន្លែងដែលយើងបានបោះត្រសាល មុនដំបូង រង់ចាំពួកលេមិនមកច្បាំង ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានចេញមក ដោយមានកងទ័ពយ៉ាងច្រើនមកប្រឆាំងនឹងយើង ហើយ កាលពួកគេបានមក ហើយជិតនឹងវាយប្រហារមកលើយើងដោយដាវ នោះខ្ញុំបានបញ្ជាឲ្យទ័ពរបស់ខ្ញុំ គឺពួកដែលនៅជាមួយខ្ញុំ ត្រូវថយចូលទៅក្នុងទីរហោស្ថាន ។

១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានដេញតាមយើងយ៉ាងលឿនអស្ចារ្យ ព្រោះពួកគេប៉ុនប៉ងជាខ្លាំងថា នឹងដេញយើងឲ្យទាន់ ដើម្បីគេអាចសម្លាប់យើងចោល; ហេតុដូច្នេះហើយ ពួកគេបានដេញតាមយើង ចូលទៅក្នុងទីរហោស្ថាន ហើយពួកយើងបានកាត់តាមចន្លោះកណ្ដាលគីឌ និងទីអុមណើរ គឺដរាបដល់ពួកគេពុំបានត្រូវពួកលេមិនរកឃើញឡើយ ។

២០ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិនបានឆ្លងផុតហើយ ឬក៏កាលកងទ័ពបានឆ្លងផុតហើយ នោះគីឌ និងទីអុមណើរបានក្រោកឡើង ចេញពីកន្លែងពួនទាំងឡាយ ហើយបានកាត់ផ្ដាច់ពួកអ្នកស៊ើបការណ៍របស់ពួកលេមិន ដើម្បីកុំឲ្យពួកគេ ត្រឡប់ទៅទីក្រុងវិញបាន ។

២១ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានកាត់ផ្ដាច់ពួកវាហើយ នោះពួកគេក៏រត់ទៅកាន់ទីក្រុង ហើយបានវាយប្រហារទៅលើពួកអ្នកយាម ដែលនៅយាមទីក្រុង ដរាបដល់ពួកគេបានបំផ្លាញពួកវាចោល ហើយយកបានទីក្រុង ។

២២ ឥឡូវនេះ ការណ៍នេះធ្វើទៅបាន ពីព្រោះពួកលេមិនបានឲ្យកងទ័ពគេទាំងមូល ត្រូវបានបញ្ឆោតឲ្យចូលទៅក្នុងទីរហោស្ថាន លើកលែងតែពួកអ្នកយាមបន្តិចបន្តួចប៉ុណ្ណោះ ។

១២ ក អាលម៉ា ៤៦:១២–១៣; មរមន ២:២៣. ខ ស.ប. ឥស្សរភាព.

២៣ ហើយហេតុការណ៍បានកើតឡើងថា គិឌ និងទីអុមណើរ ដោយបានប្រើមធ្យោបាយនេះ ក៏យកទីតាំងការពារទាំងឡាយរបស់ពួកគេបាន ។ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានធ្វើដំណើរតទៅអស់ជាយូរ នៅក្នុងទីរហោស្ថានឆ្ពោះទៅ ឯដែនដីសារ៉ាហិមឡា ។

២៤ ហើយកាលពួកលេមិនបានឃើញថា ពួកគេកំពុងតែធ្វើដំណើរឆ្ពោះទៅឯដែនដីសារ៉ាហិមឡា នោះពួកគេភិតភ័យជាខ្លាំងក្រែងលោមានផែនការអ្វីមួយ ដែលនាំពួកគេទៅកាន់សេចក្ដីបំផ្លិចបំផ្លាញ; ហេតុដូច្នេះហើយ ពួកគេបានចាប់ផ្ដើមដកថយចូលទៅ ក្នុងទីរហោស្ថានវិញ មែនហើយ គឺត្រឡប់តាមផ្លូវដដែលដែលគេបានមក ។

២៥ ហើយមើលចុះ នោះគឺនៅពេលយប់ ហើយពួកគេបានបោះត្រសាលរបស់គេ ព្រោះពួកមេទ័ពឯករបស់ពួកលេមិនបានសន្និដ្ឋានថា ពួកនីហ្វៃកំពុងតែនឿយហត់ ដោយសារការធ្វើដំណើរ; ហើយដោយសន្និដ្ឋានថា ពួកវាបានដេញតាមទ័ពគេទាំងមូល ហេតុដូច្នេះហើយ ពួកវាពុំបានគិតដល់ទីក្រុងម៉ាន់តៃឡើយ ។

២៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា លុះដល់ពេលយប់ នោះខ្ញុំបានបញ្ជាទ័ពខ្ញុំកុំឲ្យដេក តែពួកគេត្រូវធ្វើដំណើរ តាមផ្លូវមួយផ្សេងទៀត សំដៅទៅឯទីក្រុងម៉ាន់តៃ ។

២៧ ហើយដោយសារការធ្វើដំណើរ របស់យើងក្នុងពេលយប់ មើលចុះ ដល់ស្អែកឡើង ពួកយើងបានឆ្លងហួសពួកលេមិន ដរាបដល់យើងបានមកដល់ទីក្រុងម៉ាន់តៃមុនពួកគេ ។

២៨ ម្ល៉ោះហើយ ហេតុការណ៍បានកើតឡើងថា ដោយឧបាយសឹកនេះ យើងយកទីក្រុងម៉ាន់តៃបាន ដោយគ្មានការខ្ចាយឈាម ឡើយ ។

២៩ ហើយហេតុការណ៍បានកើតឡើងថា កាលពលទ័ពសាសន៍លេមិនបានមកដល់ជិតទីក្រុង ហើយបានឃើញថា ពួកយើងកំពុង តែប្រុងប្រៀបខ្លួនចាំប្រយុទ្ធនឹងគេ នោះពួកគេក៏មានសេចក្ដីអស្ចារ្យជាខ្លាំង ហើយកើតក្ដីភិតភ័យជាអតិបរមា ដរាបដល់ពួកគេរត់ចូល ទៅក្នុងទីរហោស្ថាន ។

៣០ មែនហើយ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពលេមិនបានរត់គេចចេញពីគ្រប់ភូមិភាគទាំងអស់នេះនៃដែនដី ប៉ុន្តែមើលចុះ ពួកគេបាននាំយកទៅ នូវពួកស្ត្រី និងកូនក្មេងជាច្រើនចេញពីដែនដី ។

៣១ ហើយ[ក]ទីក្រុងទាំងឡាយ ដែលត្រូវពួកលេមិនយកបានពីមុននោះ នៅរយៈពេលនេះ ទាំងអស់ត្រូវបានមកជាកម្មសិទ្ធរបស់ យើង; ហើយពួកឪពុកយើង និងប្រពន្ធយើង និងកូនចៅយើងក៏ត្រឡប់មកផ្ទះវិញ លើកលែងតែពួកអ្នកដែលត្រូវចាប់យកទៅជា ឈ្លើយ ហើយនាំយកទៅដោយពួកលេមិន។

៣២ ប៉ុន្តែមើលចុះ ពលទ័ពរបស់យើងតូច ហើយត្រូវរក្សាទីក្រុងដ៏ច្រើន និងទ្រព្យសម្បត្តិដ៏ច្រើន ។

៣៣ ប៉ុន្តែមើលចុះ យើងទុកចិត្តទៅលើព្រះរបស់យើង ដែលបានប្រទានដល់យើង នូវជ័យជំនះលើដែនដីទាំងនោះ ដរាប ដល់ពួកយើងយកទីក្រុងទាំងនោះបាន និងដែនដីទាំងនោះ ដែលជារបស់យើងផ្ទាល់ ។

៣៤ ឥឡូវនេះ យើងមិនដឹងជាហេតុអ្វី បានជារដ្ឋាភិបាលមិនបន្ថែមកម្លាំងឲ្យយើងសោះ; ហើយពួកអ្នកដែលបានមកជាមួយយើង ក៏មិនដឹងជាហេតុអ្វី បានជាយើងមិនទាន់បានទទួលកម្លាំងបន្ថែមដែរ ។

៣៥ មើលចុះ ពួកយើងមិនដឹងថា បងពុំមានជ័យជំនះ ហើយបងបាននាំយកកងកម្លាំង ទៅកាន់ភូមិភាគនោះនៃដែនដី; បើសិន ជាដូច្នោះមែន យើងមិនចង់រអ៊ូរទាំទេ ។

៣៦ ហើយបើពុំមែនជាដូច្នោះទេ មើលចុះ [ក]ខ្លាចតែមានការបាក់បែកគ្នា នៅក្នុងរដ្ឋាភិបាល ដែលនាំឲ្យពួកគេពុំបញ្ជូនទ័ពជា ជំនួយដល់យើង; ព្រោះយើងដឹងថា ពួកគេមានច្រើនជាងចំនួនដែលគេបានបញ្ជូន ។

៣៧ ប៉ុន្តែមើលចុះ ការណ៍នេះមិនជាអ្វីទេ — យើងជឿថា ព្រះទ្រង់[ក]នឹងដោះលែងយើងឲ្យរួច ទោះបីជាមានការទន់ខ្សោយនៃ ពលទ័ពរបស់យើងក្ដី មែនហើយ ហើយដោះលែងយើងឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់យើង ។

៣៨ មើលចុះ នេះគឺជាឆ្នាំទីម្ភៃប្រាំបួន គឺនៅចុងឆ្នាំ ហើយយើងយកដែនដីទាំងឡាយរបស់យើងបាន; ហើយពួកលេមិនបានរត់ទៅឯដែនដីនីហ្វៃ ។

៣៩ ហើយពួកកូនប្រុសទាំងឡាយ របស់ប្រជាជនអាំម៉ូន ដែលខ្ញុំបាននិយាយសរសើរជាខ្លាំងនោះ នៅជាមួយនឹងខ្ញុំ នៅក្នុង ទីក្រុងម៉ាន់តៃ; ហើយព្រះអម្ចាស់ទ្រង់បានទ្រទ្រង់ដល់ពួកគេ មែនហើយ ហើយបានរក្សាពួកគេ កុំឲ្យដួលចុះដោយដាវ ដរាបដល់គ្មាន [ក]អ្នកណាម្នាក់ត្រូវស្លាប់ឡើយ ។

៤០ ប៉ុន្តែមើលចុះ ពួកគេបានត្រូវរបួសជាច្រើន; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេឈរយ៉ាងរឹងប៉ឹង នៅក្នុង[ក]ឥស្សរភាព

៣១ *ក* អាលម៉ា ៥៦:១៤.
៣៦ *ក* អាលម៉ា ៦១:១–៥.
៣៧ *ក* ២ ពង្សាវ. ១៧:៣៨–៣៩.
៣៩ *ក* អាលម៉ា ៥៦:៥៦.
៤០ *ក* ស.ប. ឥស្សរភាព.

ដែលព្រះទ្រង់បានធ្វើឲ្យគេមានសេរីដែរ; ហើយពួកគេចងចាំយ៉ាង
ខ្ជាប់ ដល់ព្រះអម្ចាស់ជាព្រះរបស់គេ ជារៀងរាល់ថ្ងៃ; មែនហើយ
ពួកគេប្រតិបត្តិតាមក្រិត្យក្រមរបស់ទ្រង់ និងសេចក្ដីយុត្តិធម៌របស់
ទ្រង់ និងព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ពុំឈប់ឈរ; ហើយសេចក្ដី
ជំនឿរបស់ពួកគេមុតមាំ នៅក្នុងការព្យាករណ៍ទាំងឡាយ អំពី
អ្វីៗដែលនឹងកើតឡើង ។
៤១ ហើយឥឡូវនេះ ម៉ូរ៉ូណៃ បងជាទីស្រឡាញ់របស់ខ្ញុំអើយ
សូមឲ្យព្រះអម្ចាស់ជាព្រះរបស់យើង ដែលបានប្រោសលោះយើង
ហើយដោះលែងយើង រក្សាបងក្នុងវត្តមានរបស់ទ្រង់តទៅចុះ;
មែនហើយ ហើយសូមទ្រង់ប្រោសប្រណីដល់ប្រជាជននេះ គឺព្រម
ទាំង ឲ្យបងអាចមានជ័យជំនះ ក្នុងការយកមកវិញនូវអ្វីៗទាំង
អស់ ដែលពួកសាសន៍លេមិន បានយកពីយើងទៅ ដែល
ទុកសំរាប់គាំទ្រ ពួកយើង ។ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូម
បញ្ចប់សំបុត្ររបស់ខ្ញុំសិនហើយ ខ្ញុំ ជាហេលេមិន ជាកូនប្រុស
របស់អាលម៉ា ៕

## ជំពូកទី ៥៩

*ម៉ូរ៉ូណៃសូមឲ្យពេហូរ៉ានបន្ថែមកម្លាំងទ័ពឲ្យហេលេមិន — ពួកលេមិនយកទីក្រុងនីហ្វៃហា — ម៉ូរ៉ូណៃខឹងនឹងរដ្ឋាភិបាល ។ ប្រមាណជាឆ្នាំ ៦២ ម.គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើង គឺនៅឆ្នាំទីសាមសិ
បក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ក្រោយពីម៉ូរ៉ូណៃ
បានទទួល ហើយបានអានសំបុត្ររបស់ហេលេមិនហើយ
នោះលោកមានសេចក្ដីអររីករាយជាខ្លាំង មកពីសុខុមាលភាព
មែនហើយ និងជោគជ័យដ៏ធំ ដែលហេលេមិនបានទទួល នៅក្នុង
ការយកបានដែនដីទាំងឡាយ ដែលបាត់បង់ទៅ ។
២ មែនហើយ ហើយលោកបានប្រកាស ទៅប្រជាជន
របស់លោកទាំងអស់ នៅគ្រប់ដែនដីព័ទ្ធជុំវិញ ដែលនៅក្នុង
ភូមិភាគ ដែលលោកនៅនោះ ឲ្យដឹងការណ៍នេះ ដើម្បីឲ្យពួកគេ
បានអររីករាយផង ។
៣ ហើយហេតុការណ៍បានកើតឡើងថា លោកបានផ្ញើសំបុត្រ
[ក]មួយច្បាប់ ទៅ[ខ]ពេហូរ៉ានភ្លាម សូមឲ្យលោកបញ្ជាឲ្យប្រមូលទ័ព
មក ដើម្បីបន្ថែមកម្លាំងឲ្យហេលេមិន ឬពលទ័ពរបស់ហេលេមិន
ដើម្បីឲ្យលោកអាចថែរក្សាដោយងាយ នូវភូមិភាគនោះ នៃដែនដី
ដែល លោកយកបានមកវិញ ដោយអព្ភូតហេតុ ។
៤ ហើយហេតុការណ៍បានកើតឡើងថា កាលម៉ូរ៉ូណៃបានផ្ញើ
សំបុត្ររបស់លោក ទៅដែនដីសារ៉ាហិមឡា នោះលោកចាប់ផ្ដើម
រៀបចំផែនការមួយទៀត ដើម្បីលោកអាចយកទ្រព្យសម្បត្តិ និង
ទីក្រុងដែលនៅសល់ទាំងប៉ុន្មាន ដែលពួកលេមិនបានយកពីពួក
គេទៅ ។
៥ ហើយហេតុការណ៍បានកើតឡើងថា នៅពេល
ម៉ូរ៉ូណៃកំពុងតែធ្វើការរៀបចំយ៉ាងនេះ ដើម្បីទៅច្បាំងនឹងពួក
លេមិន មើលចុះ ប្រជាជននីហ្វៃហា ដែលត្រូវបានប្រមូលមក
ពីទីក្រុងម៉ូរ៉ូណៃ និងទីក្រុងលីហៃ និងក្រុងម៉ូរីអានតុន ត្រូវ
វាយប្រហារចោលដោយពួក លេមិន ។
៦ មែនហើយ ព្រមទាំងពួកដែលត្រូវបានបង្ខំឲ្យរត់ចេញពីដែនដី
ម៉ាន់ទៃ និងពីដែនដីព័ទ្ធជុំវិញនោះ បានមក ហើយបានរួមកម្លាំង
នឹងពួកលេមិន នៅក្នុងភូមិភាគនៃដែនដីនេះ ។
៧ ម្ល៉ោះហើយ គេមានចំនួនច្រើនដ៏ឥតគណនា មែនហើយ
ដោយបានទទួលកម្លាំងជារាល់ថ្ងៃ តាមបញ្ជារបស់អាំម៉ូរ៉ុន នោះ
ពួក គេបានចេញមកប្រឆាំងនឹងប្រជាជននីហ្វៃហា ហើយពួកគេ
បានចាប់ផ្ដើមសម្លាប់គេ ដោយការកាប់សម្លាប់ដ៏ធំអស្ចារ្យ ។
៨ ហើយពលទ័ពរបស់គេមានចំនួនច្រើនដ៏ឥតគណនា រហូត
ដល់ធ្វើឲ្យប្រជាជននីហ្វៃហា ដែលនៅទាំងប៉ុន្មាន ត្រូវបង្ខំឲ្យរត់
ចេញពីគេ; ហើយពួកគេជានមក ហើយបានចូលរួមនឹងកងទ័ព
របស់ម៉ូរ៉ូណៃ ។
៩ ហើយឥឡូវនេះ ដោយម៉ូរ៉ូណៃបានសន្និដ្ឋានថា ត្រូវ
បញ្ជូនទ័ពទៅទីក្រុងនីហ្វៃហា ដើម្បីជួយប្រជាជនរក្សាទីក្រុងនោះ
ហើយដឹង ថា ជាការងាយក្នុងការរក្សាកុំឲ្យទីក្រុងនោះ ធ្លាក់ទៅ
ក្នុងកណ្ដាប់ដៃនៃពួកសាសន៍លេមិន ជាងវាយយកវាពីពួកគេ
មកវិញ លោក បានសន្និដ្ឋានថា ពួកគេនឹងរក្សាទីក្រុងនោះបាន
ដោយងាយ ។
១០ ហេតុដូច្នោះហើយ លោកបានរក្សាកងកម្លាំង
របស់លោកទាំងអស់ទុក ដើម្បីរក្សាកន្លែងទាំងនោះ ដែល
លោកយកបាន មកវិញ ។
១១ ហើយឥឡូវនេះ កាលម៉ូរ៉ូណៃបានឃើញថា ទីក្រុងនីហ្វៃ
ហាត្រូវបាត់បង់ទៅ នោះលោកមានសេចក្ដីសោកសៅជាខ្លាំង
ហើយបានចាប់ផ្ដើមសង្ស័យថា មកពីសេចក្ដីទុច្ចរិតរបស់ប្រជាជន
ទើបពួកគេត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃបងប្អូនគេ ។
១២ ឥឡូវនេះ នេះគឺជាករណីនៃអស់ទាំងពួកមេទ័ពឯក
របស់លោក ។ ពួកគេក៏សង្ស័យ ហើយជឿងឆ្ងល់ដែរថា មក

៥៩ ១*ក* អាលម៉ា ៥៦:១.
៣ *ក* អាលម៉ា ៦០:១–៣.
*ខ* អាលម៉ា ៥០:៤០.

ពីសេចក្ដី ទុច្ចរិតរបស់ប្រជាជន ហើយនេះគឺដោយព្រោះ
ជ័យជំនះរបស់ពួកលេមិនមកលើពួកគេ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃក៏ខឹងនឹង
រដ្ឋាភិបាល ដោយសារការមិនអើពើរបស់គេ ចំពោះសេរីភាពនៃ
ដែនដីរបស់ខ្លួន ៕

## ជំពូកទី ៦០

*ម៉ូរ៉ូណៃត្អូញត្អែរទៅកាន់ពេហូរ៉ាន់អំពីការណ៍ ដែលរដ្ឋាភិបាលមិន អើពើដល់ពលទ័ព — ព្រះអម្ចាស់ទ្រង់ទុកឲ្យជនសុចរិតត្រូវស្លាប់ — ពួកសាសន៍នីហ្វៃត្រូវប្រើកម្លាំង និងមធ្យោបាយទាំងអស់របស់គេ ដើម្បីដោះលែងពួកគេ ឲ្យរួចផុតពីពួកខ្មាំងសត្រូវរបស់គេ — ម៉ូរ៉ូណៃ គំរាមថានឹងប្រយុទ្ធតទល់នឹងរដ្ឋាភិបាល ប្រសិនបើជំនួយមិនត្រូវផ្ដល់ ទៅឲ្យពលទ័ពរបស់លោកទេ ។ ប្រមាណជាឆ្នាំ ៦២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា លោកបានសរសេរ
ទៅលោកអភិបាលដែនដីទៀត គឺលោកពេហូរ៉ាន់ ហើយនេះគឺជា
ពាក្យពេចន៍ ដែលលោកបានសរសេរថា៖ មើលចុះ ខ្ញុំសរសេរ
សំបុត្រនេះមកពេហូរ៉ាន់ នៅក្នុងទីក្រុងសារ៉ាហិមឡា ដែលជា
មេចៅក្រម និងជា អភិបាលលើដែនដីនេះ និងមកដល់អស់អ្នក
ដែលត្រូវប្រជាជននេះរើសឲ្យអភិបាល ហើយចាត់ចែងកិច្ចការ
សង្គ្រាមនេះ ។
២ ត្បិតមើលចុះ ខ្ញុំមានពាក្យខ្លះចង់ប្រាប់ដល់ពួកគេ ទុកជាការ
កាត់ទោស; ត្បិតមើលចុះ គឺអ្នករាល់គ្នាដឹងខ្លួនហើយថា អ្នក
រាល់ គ្នាត្រូវបានតែងតាំងឡើងឲ្យប្រមូលទ័ព ហើយប្រដាប់ពួក
គេដោយដាវទាំងឡាយ និងសាបទាំងឡាយ និងអស់ទាំង
គ្រឿងសស្ត្រាវុធ ពិជ័យសង្គ្រាមគ្រប់បែបយ៉ាង ហើយបញ្ជូនឲ្យទៅ
ប្រឆាំងនឹងពួកលេមិន ទោះជានៅទីណា ដែលពួកគេចូលមកក្នុង
ដែនដីយើង ក៏ដោយ ។
៣ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា រូបខ្ញុំផ្ទាល់
និងទ័ពរបស់ខ្ញុំផង និងហេលេមិន និងទ័ពរបស់លោកផង ត្រូវទទួល
ការទុក្ខវេទនាយ៉ាងធំហួសប្រមាណ; មែនហើយ គឺការអត់ឃ្លាន
ការស្រេក និងការនឿយហត់ និងការទុក្ខវេទនាគ្រប់បែបយ៉ាង ។
៤ ប៉ុន្តែមើលចុះ បើពួកយើងស៊ូទ្រាំតែប៉ុណ្ណោះទេ នោះយើងមិន
រអ៊ូរទាំ ឬត្អូញត្អែរអ្វីឡើយ ។
៥ ប៉ុន្តែមើលចុះ មានការកាប់សម្លាប់ដ៏ធំមួយ នៅក្នុង
ចំណោមប្រជាជនយើង; មែនហើយ មនុស្សរាប់ពាន់នាក់ត្រូវ
ដួលចុះ ដោយដាវ នៅក្នុងពេលនោះ វាប្រហែលជាពុំដូច្នោះទេ
បើសិនជាអ្នករាល់គ្នាបានបន្ថែមកម្លាំងគ្រប់គ្រាន់មកឲ្យពល
ទ័ពយើង ហើយជួយសង្គ្រោះពួកគេ ។ មែនហើយ ពួកអ្នកមាន
ការធ្វេសប្រហែសយ៉ាងធំចំពោះពួកយើង ។
៦ ហើយឥឡូវនេះ មើលចុះ ពួកយើងមានបំណងចង់ដឹង
មូលហេតុ នៃការធ្វេសប្រហែសដ៏ធំនេះ; មែនហើយ ពួកយើង
មានបំណង ចង់ដឹងមូលហេតុ នៃការខ្វះរិះគន់របស់ពួកអ្នក ។
៧ តើអ្នកអាចគិតថា អង្គុយនៅលើបល្ល័ង្ករបស់អ្នក នៅក្នុង
សភាពទ្រឹងខ្វះការគិតដូច្នេះ នៅពេលពួកខ្មាំងសត្រូវរបស់អ្នក
កំពុងតែ ពង្រាលការសម្លាប់ជុំវិញអ្នកឬ? មែនហើយ នៅពេល
ពួកគេកំពុងតែកាប់សម្លាប់បងប្អូនអ្នករាប់ពាន់នាក់—
៨ មែនហើយ នៅពេលពួកគេផ្ញើបសម្លឹងទៅអ្នក ដើម្បីរកសេចក្ដី
ការពារ មែនហើយ បានដាក់ពួកអ្នកក្នុងស្ថានការមួយ ដែលអ្នក
អាចជួយសង្គ្រោះពួកគេបាន មែនហើយ អ្នករាល់គ្នាអាចបញ្ជូន
ពលទ័ពទៅឲ្យគេ ដើម្បីបន្ថែមកម្លាំងឲ្យគេ ហើយជួយសង្គ្រោះ
មនុស្ស រាប់ពាន់នាក់ កុំឲ្យដួលចុះដោយដាវ ។
៩ ប៉ុន្តែមើលចុះ ការណ៍នេះមិនទាន់អស់ទេ — ពួកអ្នកបាន
ឃាំងស្បៀងរបស់អ្នកទុកពីពួកគេ ដរាបដល់ធ្វើឲ្យមនុស្សជាច្រើន
បានប្រយុទ្ធ ហើយខ្ចាយឈាមដល់ស្លាប់ ដោយព្រោះបំណង
ដ៏ធំរបស់គេ ដែលគេមានចំពោះសុខុមាលភាពដល់ប្រជាជននេះ;
មែនហើយ ហើយពួកគេបានធ្វើយ៉ាងនេះ កាលពួកគេជិតវិនាសបង់
ដោយអត់អាហារ ព្រោះតែការធ្វេសប្រហែសដ៏ធំហួស ប្រមាណ
របស់ពួកអ្នក ចំពោះគេ ។
១០ ហើយឥឡូវនេះ បងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ —
ព្រោះអ្នករាល់គ្នាត្រូវបានស្រឡាញ់ មែនហើយ ហើយអ្នករាល់
គ្នា ត្រូវតែដាស់ខ្លួនអ្នក ឲ្យព្យាយាមថែមឡើង ចំពោះសុខុមាល
ភាព និងសេរីភាពដល់ប្រជាជននេះ; ប៉ុន្តែមើលចុះ អ្នករាល់គ្នា
បានបោះបង់ពួកគេចោល ដរាបដល់ធ្វើឲ្យឈាមរបស់គេរាប់ពាន់
នាក់ នឹងត្រូវធ្លាក់មកលើក្បាលអ្នក ដើម្បីសងសឹក; មែនហើយ
ព្រោះព្រះ ទ្រង់បានជ្រាបអស់ទាំងសំរែករបស់ពួកគេ និងអស់ទាំង
ការឈឺចាប់ទាំងឡាយរបស់គេ —
១១ មើលចុះ តើអ្នករាល់គ្នាអាចគិតស្មានថា អ្នកអាចអង្គុយ
លើបល្ល័ង្ករបស់អ្នក ហើយដោយសារសេចក្ដីល្អសប្បុរស ដ៏លើស

១៣ *ក* អាលម៉ា ៥៨:៣៤; ៦១:២–៣. | **៦០** ១ *ក* អាលម៉ា ៥០:៣៩–៤០. | ៩ *ក* អាលម៉ា ៥៨:៧.

លប់នៃព្រះ អ្នកពុំអាចធ្វើអ្វីសោះឡើយ ហើយទ្រង់នឹងដោះលែង
អ្នកឲ្យរួចឬ ? មើលចុះ បើសិនជាអ្នករាល់គ្នាគិតស្មានថាដូច្នោះ
គឺអ្នករាល់គ្នាបានគិតស្មានដោយឥតប្រយោជន៍ហើយ ។
១២ តើអ្នករាល់គ្នា[ក]គិតស្មានថា ពីព្រោះបងប្អូនអ្នកជាច្រើន
ត្រូវបានស្លាប់នោះ គឺដោយសារសេចក្ដីទុច្ចរិតរបស់គេឬ ? ខ្ញុំសូម
ប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នាបានគិតស្មានថាដូច្នោះ គឺអ្នក
រាល់គ្នាបានគិតស្មានដោយឥតប្រយោជន៍ហើយ; ត្បិតខ្ញុំ
សូមប្រាប់ អ្នករាល់គ្នាថា មានមនុស្សជាច្រើន ដែលត្រូវបាន
ដួលចុះដោយដាវ; ហើយមើលចុះ នោះគឺជាការកាត់ទោស
ដល់អ្នកទេតើ ។
១៣ ត្បិតព្រះអម្ចាស់ទ្រង់ទ្រាំ[ក]ពួកសុចរិតត្រូវស្លាប់បង់ ដើម្បីសេចក្ដី
យុត្តិធម៌របស់ទ្រង់ និងសេចក្ដីជំនុំជំរះរបស់ទ្រង់ អាចធ្លាក់មក
លើពួកទុច្ចរិត; ហេតុដូច្នេះហើយ អ្នករាល់គ្នាមិនបាច់គិតស្មានថា
ពួកសុចរិតត្រូវបាត់បង់ ព្រោះពួកគេត្រូវស្លាប់នោះឡើយ; ប៉ុន្ដែ
មើលចុះ ពួកគេបានចូលទៅក្នុងទីសំរាកនៃព្រះអម្ចាស់ ជាព្រះ
របស់គេហើយ ។
១៤ ហើយឥឡូវនេះ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ខ្ញុំខ្លាច
ជាអតិបរមាថា សេចក្ដីជំនុំជំរះទាំងឡាយនៃព្រះ នឹងធ្លាក់មក
លើប្រជា ជននេះ ដោយព្រោះការខ្ជិលច្រអូស ដ៏លើសលប់
របស់គេ មែនហើយ គឺការខ្ជិលច្រអូសរបស់រដ្ឋាភិបាលរបស់យើង
និងការធ្វេស ប្រហែសដ៏ធំហួសប្រមាណរបស់ពួកគេ ចំពោះ
បងប្អូនរបស់គេ មែនហើយ ចំពោះពួកអ្នក[ក]ដែលត្រូវស្លាប់ ។
១៥ ព្រោះប្រសិនបើមិនមែនដោយសារសេចក្ដីទុច្ចរិត ដែល
ចាប់ផ្ដើមជាដំបូង នៅក្នុងក្បាលរបស់យើងទេ នោះយើងច្បាស់
ជាអាចទប់ទល់នឹងពួកខ្មាំងសត្រូវរបស់យើងបាន ដែលពួកវាពុំ
អាចមានអំណាចមកលើពួកយើងឡើយ ។
១៦ មែនហើយ ប្រសិនបើពុំមែនដោយសារ[ក]សង្គ្រាម ដែល
កើតឡើងនៅក្នុងចំណោមពួកយើងផ្ទាល់ទេ មែនហើយ ប្រសិន
បើពុំមែនមកពីពួក[ខ]និយមស្ដេចទាំងនេះ ដែលបានបណ្ដាលឲ្យមាន
ការខ្ចាយឈាមជាច្រើន នៅក្នុងចំណោមពួកយើងផ្ទាល់ទេ; មែន
ហើយ នៅពេលនោះយើងកំពុងតែឈ្លោះគ្នាឯង បើសិនជាយើង
បានរួបរួមកម្លាំងយើង ដូចយើងបានធ្វើពីមុនមក; មែនហើយ
ប្រសិនបើពុំមែនដោយសារការចង់បានអានុភាព និងសិទ្ធិអំណាច
នៃពួកនិយមស្ដេច មកលើពួកយើង; ប្រសិនបើពួកគេស្មោះត្រង់
ចំពោះឧត្ដមគតិនៃសេរីភាពរបស់យើង ហើយរួបរួមនឹងយើង
ហើយចេញទៅប្រឆាំងនឹងពួកខ្មាំងសត្រូវរបស់យើង ជាជាង
កាន់ដាវ តទល់នឹងយើង ដែលជាហេតុនាំឲ្យមានការខ្ចាយឈាម
ដ៏ច្រើន នៅក្នុងចំណោមពួកយើងផ្ទាល់ទេ; មែនហើយ ប្រសិន
បើពួកយើង បានចេញទៅប្រយុទ្ធនឹងពួកគេ ដោយកម្លាំងនៃព្រះ
អម្ចាស់ នោះយើងច្បាស់ជាបានកំចាត់ ពួកខ្មាំងសត្រូវ
របស់យើងចោលហើយ ព្រោះវានឹងត្រូវបានសំរេច ស្របតាម
ការបំពេញនៃព្រះបន្ទូលរបស់ទ្រង់ ។
១៧ ប៉ុន្ដែមើលចុះ ឥឡូវនេះ ពួកលេមិនកំពុងតែ
មកវាយប្រហារយើង យកដីយើង ហើយពួកគេ កំពុងតែ
កាប់សម្លាប់ប្រជាជន យើងនឹងដាវ មែនហើយ គឺពួកស្ដ្រី
របស់យើង និងកូនចៅរបស់យើង ហើយចាប់យកពួកគេទៅផង
ដោយធ្វើឲ្យពួកគេរងទុក្ខវេទនា គ្រប់បែបយ៉ាង ហើយការណ៍នេះ
គឺដោយព្រោះសេចក្ដីទុច្ចរិតដ៏ធំរបស់ពួកជនដែលកំពុងស្វែងរកអានុ
ភាព និងសិទ្ធិអំណាច មែនហើយ គឺពួកនិយមស្ដេចទាំងនោះ ។
១៨ ប៉ុន្ដែ ហេតុអ្វីក៏ខ្ញុំនិយាយច្រើនអំពីរឿងនេះទៅវិញ?
ព្រោះយើងមិនដឹងថា សូម្បីតែរូបខ្លួនអ្នករាល់គ្នា ក៏កំពុងតែស្វែងរក
សិទ្ធិអំណាច ។ យើងមិនដឹងថា សូម្បីតែអ្នករាល់គ្នាក៏ជាមនុស្ស
ក្បត់ប្រទេសរបស់អ្នកដែរ ។
១៩ ឬក៏ការដែលអ្នករាល់គ្នា បានបោះបង់ពួកយើងចោល
តើមកពីអ្នករាល់គ្នា នៅកណ្ដាលប្រទេសយើង ហើយអ្នករាល់
គ្នា ត្រូវបានឡោមព័ទ្ធជុំវិញដោយសន្ដិសុខឬ ដែលបណ្ដាលឲ្យ
អ្នករាល់គ្នា មិនចាត់ឲ្យបញ្ជូនស្បៀងអាហារមកឲ្យយើង និង
មនុស្សមក បន្ថែមកម្លាំងឲ្យពលទ័ពរបស់យើងផង ?
២០ តើអ្នករាល់គ្នាភ្លេចព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ គឺជា
ព្រះរបស់អ្នកហើយឬ ? មែនហើយ តើអ្នករាល់គ្នាភ្លេចការជាប់
ឃុំឃាំងនៃពួកអយ្យកោយើងហើយឬ ? តើអ្នករាល់គ្នាភ្លេចច្រើន
ដងច្រើនគ្រា ដែលពួកយើងត្រូវបានដោះលែងឲ្យរួចផុតពីកណ្ដាប់ដៃ
នៃពួកខ្មាំងសត្រូវរបស់យើងហើយឬ ?
២១ ឬក៏អ្នករាល់គ្នាគិតស្មានថា ព្រះអម្ចាស់ទ្រង់
នឹងនៅតែដោះយើងឲ្យរួច នៅពេលយើងអង្គុយលើបល្ល័ង្ក
របស់យើង ហើយពុំ ប្រើនូវមធ្យោបាយទាំងឡាយ ដែលព្រះ
អម្ចាស់ទ្រង់បានប្រទានដល់យើងឬអី ?
២២ មែនហើយ តើអ្នករាល់គ្នានឹងអង្គុយក្នុងការខ្ជិលច្រអូសឬ

១២ *ក* លូកា ១៣:១–៥.
១៣ *ក* អាលម៉ា ១៤:១០–១១;
គ. និង ស. ៤២:៤៦–៤៧.
១៥ *ក* អាលម៉ា ៥១:៩, ១៣.
១៦ *ក* អាលម៉ា ៥១:១៦–១៩.
*ខ* អាលម៉ា ៥១:៥, ៨.

នៅពេលអ្នករាល់គ្នាត្រូវបានចោមរោម ដោយពួករាប់ពាន់នាក់ទៀត មែនហើយ និងរាប់ម៉ឺននាក់ដែលអង្គុយក្នុងការខ្ជិលច្រអូសផង នៅពេលនោះ មានមនុស្សរាប់ពាន់នាក់នៅជុំវិញ ក្នុងទីព្រំប្រទល់ នៃដែនដី ដែលកំពុងតែដួលចុះដោយដាវ មែនហើយ ត្រូវរបួស ហើយខ្ចាយឈាម ?

២៣ តើអ្នករាល់គ្នាគិតស្មានថា ព្រះទ្រង់នឹងទតមើលមកអ្នករាល់គ្នាថាឥតទោសឬ នៅពេលអ្នករាល់គ្នាអង្គុយនៅស្ងៀម ហើយ មើលឃើញការណ៍ទាំងនេះ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ទេ ។ ឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាចងចាំថា ព្រះទ្រង់មានព្រះបន្ទូលថា [ក] ខាងក្នុងប្រដាប់នឹងត្រូវលាងជាមុន នោះទើបខាងក្រៅប្រដាប់នឹងត្រូវបានស្អាតដែរ ។

២៤ ហើយឥឡូវនេះ លើកលែងតែអ្នករាល់គ្នា ប្រែចិត្តនូវអ្វីៗដែលអ្នករាល់គ្នាបានធ្វើ ហើយចាប់ផ្ដើមក្រោកឡើង ហើយធ្វើការ ហើយបញ្ជូនស្បៀង និងទ័ពមកឲ្យយើង និងទៅឲ្យហេលេមិនផង ដើម្បីលោកអាចទ្រទ្រង់ដល់ផ្នែកទាំងឡាយនៃប្រទេសយើង ដែលលោកយកបានមកវិញនោះ ហើយដើម្បីយើងអាចយកមកវិញផង នូវដីទាំងឡាយដែលជារបស់ផងយើង ដែលនៅសល់ទាំង ប៉ុន្មាននៅក្នុងផ្នែកនេះ មើលចុះ ជាការចាំបាច់ ដែលយើងឈប់តតាំងនឹងពួកលេមិនទៀត រហូតដល់យើងលាងខាងក្នុងប្រដាប់របស់ យើងជាមុនសិន មែនហើយ គឺជាមេធំនៃរដ្ឋាភិបាលរបស់យើង ។

២៥ ហើយលើកលែងតែអ្នករាល់គ្នា យល់ព្រមតាមសំបុត្ររបស់ខ្ញុំ ហើយចេញមក ហើយបង្ហាញដល់ខ្ញុំ [ក] នូវនិស្ស័យជាសេរីភាព ដ៏ពិត ហើយខិតខំពង្រឹង ហើយបន្ថែមកម្លាំងឲ្យពលទ័ពរបស់យើង ហើយផ្ដល់ឲ្យគេនូវស្បៀង ដើម្បីចិញ្ចឹមពួកគេ មើលចុះ ខ្ញុំនឹងទុក ទ័ពសេរីរបស់ខ្ញុំមួយភាគឲ្យថែរក្សាផ្នែកនេះនៃដែនដីយើង ហើយខ្ញុំនឹងទុកកម្លាំង និងព្រះពរទាំងឡាយនៃព្រះឲ្យពួកគេ ដើម្បីកុំឲ្យ កម្លាំងអ្វីផ្សេងទៀតអាចមកតតាំងនឹងពួកគេបាន —

២៦ ហើយនេះគឺដោយសារសេចក្ដីជំនឿ ដ៏លើសលប់របស់គេ និងសេចក្ដីអត់ធន់របស់គេក្នុងការទុក្ខលំបាក —

២៧ ហើយខ្ញុំនឹងមករកអ្នក ហើយបើសិនជាមានអ្នកណាមួយនៅក្នុងចំណោមអ្នក ដែលមានបំណងចង់បានសេរីភាព មែនហើយ បើសិនជាមានសេរីភាពតែបន្តិចបន្តួចដែលនៅសល់ មើលចុះ ខ្ញុំនឹងចាក់រុកឲ្យមានការបះបោរទាំងឡាយ នៅក្នុងចំណោមអ្នក គឺរហូត ដល់ពួកជនដែលចង់ដណ្ដើមអានុភាព និងសិទ្ធិអំណាចត្រូវវិនាសសាបសូន្យអស់ទៅ ។

២៨ មែនហើយ មើលចុះ ខ្ញុំមិនខ្លាចកម្លាំងរបស់អ្នក ឬអំណាចរបស់អ្នកទេ តែគឺជា[ក]ព្រះរបស់ខ្ញុំទេតើ ដែលខ្ញុំខ្លាច; ហើយគឺស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ដែលខ្ញុំយកដាវរបស់ខ្ញុំ មកការពារឧត្ដមគតិនៃប្រទេសរបស់ខ្ញុំ ហើយគឺដោយព្រោះសេចក្ដីទុច្ចរិត របស់អ្នក ដែលយើងត្រូវរងនូវការបាត់បង់ដ៏ច្រើន ។

២៩ មើលចុះ ដល់ពេលហើយ មែនហើយ ឥឡូវនេះ ពេលវេលានៅជិតដែបង្អើយ ថាលើកលែងតែអ្នករាល់គ្នាស្ទុះស្ទាឡើង នៅក្នុងសេចក្ដីការពារប្រទេសរបស់អ្នក និងកូនតូចៗរបស់អ្នក [ក] នោះដាវនៃសេចក្ដីយុត្តិធម៌នឹងព្យួរនៅលើអ្នករាល់គ្នា; មែនហើយ ហើយវានឹងធ្លាក់ចុះទៅលើអ្នក និងធ្វើទោសអ្នក រហូតដល់ការបំផ្លិចបំផ្លាញអ្នកចោលទាំងស្រុង ។

៣០ មើលចុះ ខ្ញុំរង់ចាំជំនួយពីអ្នក; ហើយលើកលែងអ្នកជួយពួកយើង បើពុំនោះសោតទេ មើលចុះ ខ្ញុំនឹងមករកអ្នក គឺនៅឯដែនដី សារ៉ាហិមឡា ហើយវាយអ្នកនឹងដាវនេះ ដរាបដល់អ្នករាល់គ្នាគ្មានកម្លាំងទៀត ដើម្បីបង្អាក់ការជឿនលឿនរបស់ប្រជាជននេះ ក្នុងឧត្ដមគតិនៃសេរីភាពរបស់យើងឡើយ ។

៣១ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់នឹងពុំទ្រាំឲ្យអ្នករាល់គ្នារស់នៅ ហើយខ្លាំងពូកែនៅក្នុងសេចក្ដីទុច្ចរិតទាំងឡាយរបស់អ្នក ដើម្បីបំផ្លាញប្រជាជនសុចរិតរបស់ទ្រង់ទេ ។

៣២ មើលចុះ តើអ្នករាល់គ្នាអាចគិតស្មានថា ព្រះអម្ចាស់ទ្រង់នឹងលើកលែងឲ្យអ្នក ហើយចេញមកទាស់ពួកសាសន៍លេមិនក្នុងសេចក្ដីជំនុំជំរះ ក្នុងកាលសណ្ដាប់នៃពួកអយ្យកោរបស់គេទេតើ ដែលបានបណ្ដាលឲ្យគេមានការស្អប់នោះ មែនហើយ ហើយវាបានកើនឡើងជាពីរ ដោយពួកជនដែលបានបែកចេញពីយើងក្នុងកាលសេចក្ដីទុច្ចរិតរបស់អ្នករាល់គ្នាទេតើ ដែលជាហេតុផលនៃការស្រឡាញ់ភាពរុងរឿងរបស់អ្នក និងវត្ថុទាំងឡាយដែលឥតប្រយោជន៍នៃលោកិយនេះ ?

៣៣ អ្នករាល់គ្នាដឹងថា អ្នករាល់គ្នាប្រព្រឹត្តរំលងក្រិត្យវិន័យទាំងឡាយនៃព្រះ ហើយអ្នករាល់គ្នាដឹងថា អ្នករាល់គនាយកវាទៅជាន់ឈ្លីនៅក្រោមជើងអ្នក ។ មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ បើសិនជាអស់អ្នកដែលអ្នកបានលើកតាំងឲ្យធ្វើជាអភិបាលរបស់អ្នក ពុំប្រែចិត្តពីអំពើបាប និងអំពើទុច្ចរិតទាំងឡាយរបស់គេទេ នោះអ្នកត្រូវឡើងទៅច្បាំងតទល់នឹងពួកគេ ។

២៣ *ក* ម៉ាថាយ ២៣:២៥–២៦.
២៥ *ក* អាលម៉ា ៥១:៦; ៦១:១៥.
២៨ *ក* កិច្ចការ ៥:២៦–២៩.
២៩ *ក* ហេលេ. ១៣:៥; ៣ នីហ្វៃ ២:១៩.

៣៤ ហើយឥឡូវនេះ មើលចុះ ខ្ញុំ ជាម៉ូរ៉ូណៃ ត្រូវបានបង្ខំស្របតាមសេចក្ដីសញ្ញាដែលខ្ញុំបានធ្វើថា នឹងកាន់តាមព្រះបញ្ញត្តិទាំង ឡាយនៃព្រះរបស់; ហេតុដូច្នេះហើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាប្រតិបត្តិតាមព្រះបន្ទូលនៃព្រះ ហើយប្រញាប់បញ្ជូនឲ្យខ្ញុំ នូវស្បៀងរបស់អ្នក និងទ័ពរបស់អ្នក ហើយឲ្យដល់ហេលេមិនផង ។

៣៥ ហើយមើលចុះ បើសិនជាអ្នករាល់គ្នាមិនធ្វើដូច្នេះទេ ខ្ញុំនឹងមករកអ្នកជាប្រញាប់; ត្បិតមើលចុះ ព្រះទ្រង់ពុំទ្រាំឲ្យយើងវិនាស ដោយការអត់អាហារឡើយ; ហេតុដូច្នេះហើយ ទ្រង់នឹងប្រទានឲ្យយើង នូវស្បៀងអាហាររបស់អ្នក ទោះជាត្រូវប្រើដាវក្ដី ។ ឥឡូវនេះ ចូរឲ្យឃើញថា អ្នករាល់គ្នាបំពេញព្រះបន្ទូលនៃព្រះចុះ ។

៣៦ មើលចុះ ខ្ញុំ ជាម៉ូរ៉ូណៃ ជាមេទ័ពឯករបស់អ្នក ។ ខ្ញុំមិនស្វែងរកអំណាចទេ តែរកទាញទម្លាក់វាចុះវិញ ។ ខ្ញុំមិនស្វែងរកកិត្តិយសនៃលោកិយទេ តែស្វែងរកសិរីល្អនៃព្រះរបស់ខ្ញុំ និងសេរីភាព និងសុខុមាលភាពរបស់ប្រទេសខ្ញុំវិញ ។ ម្ល៉ោះហើយ ខ្ញុំសូម បញ្ចប់សំបុត្ររបស់ខ្ញុំសិនហើយ ៕

ជំពូកទី ៦១

*ពេហូរ៉ាន់ប្រាប់ម៉ូរ៉ូណៃអំពីការបះបោរ និងការបះរឹងទទឹងទាស់នឹងរដ្ឋាភិបាល — ពួកនិយមស្ដេចយកក្រុងសារ៉ាហិមឡា ហើយចង សម្ព័ន្ធមិត្តជាមួយនឹងពួកសាសន៍លេមិន — ពេហូរ៉ាន់សូមជំនួយយោធាមកប្រឆាំងនឹងពួកបះបោរ ។ ប្រមាណជាឆ្នាំ ៦២ ម.គ.ស. ។*

មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មិនយូរប៉ុន្មានបន្ទាប់ពីម៉ូរ៉ូណៃបានផ្ញើសំបុត្ររបស់លោក ទៅលោកមេអភិបាលនោះលោកក៏បានទទួលសំបុត្រមួយច្បាប់ពីពេហូរ៉ាន់ ជាមេអភិបាល។ ហើយនេះគឺជាពាក្យដែលលោកបានទទួល ថា៖

២ ខ្ញុំ ពេហូរ៉ាន់ ជាមេអភិបាលនៃដែនដីនេះ ផ្ញើពាក្យទាំងនេះមកម៉ូរ៉ូណៃ ជាមេទ័ពឯកលើកងទ័ព ។ មើលចុះ ខ្ញុំសូមប្រាប់អ្នកគឺម៉ូរ៉ូណៃថា ខ្ញុំពុំមានសេចក្ដីអំណរនៅក្នុងសេចក្ដីទុក្ខវេទនាដ៏ធំទាំងឡាយរបស់អ្នកទេ មែនហើយ វាធ្វើឲ្យមានទុក្ខដល់ព្រលឹងខ្ញុំវិញ ។

៣ ប៉ុន្តែមើលចុះ មានពួកអ្នកដែលមានសេចក្ដីអំណរ ក្នុងសេចក្ដីទុក្ខវេទនាទាំងឡាយរបស់អ្នក មែនហើយ ដរាបដល់ធ្វើឲ្យពួកគេបះបោរទាស់នឹងខ្ញុំ និងប្រជាជនរបស់ខ្ញុំទាំងនោះផង ដែលជាពួកសេរី មែនហើយ ហើយពួកអ្នកដែលបានបះបោរនោះមានគ្នាច្រើនដ៏លើសលប់ ។

៤ ហើយគឺពួកអ្នកដែលបានខិតខំដណ្ដើមយកវេទិកាជំនុំជំរះពីខ្ញុំនោះ ដែលបានបណ្ដាលឲ្យមានសេចក្ដីទុច្ចរិតដ៏ធំនេះ; ព្រោះពួកគេ បានប្រើពាក្យបញ្ចោរដ៏ធំ ហើយពួកគេបានបញ្ឆោតចិត្តមនុស្សជាច្រើន ដែលជាមូលហេតុ នៃសេចក្ដីទុក្ខវេទនាដ៏ធ្ងន់ធ្ងរនៅក្នុង ចំណោមពួកយើង; ពួកគេបានឃាត់ទុកស្បៀងរបស់យើង ហើយបានគំរាមកំហែងពួកសេរីរបស់យើង ដែលធ្វើឲ្យពួកគេពុំហ៊ានទៅរក អ្នកឡើយ ។

៥ ហើយមើលចុះ ពួកគេបានរុញច្រានខ្ញុំចេញពីគេ ហើយខ្ញុំបានរត់ទៅឯដែនដីគេឌាន ជាមួយនឹងទ័ពទាំងប៉ុន្មាន ដែលខ្ញុំមានលទ្ធភាពអាចយកទៅបាន ។

៦ ហើយមើលចុះ ខ្ញុំបានផ្ញើសេចក្ដីប្រកាសមួយ ទូទៅក្នុងភូមិភាគនៃដែនដីនេះ; ហើយមើលចុះ ពួកគេបានប្រមូលគ្នាមកជារៀង រាល់ថ្ងៃ ដើម្បីកាន់អាវុធការពារប្រទេសរបស់គេ និងសេរីភាពរបស់គេ ហើយដើម្បីសងសឹកដល់ការខុសឆ្គងដែលមានមកលើពួកយើង ។

៧ ហើយពួកគេបានមករកយើងជាច្រើន ដរាបដល់ពួកអ្នកដែលបានបះបោរទាស់នឹងយើង ត្រូវនៅក្នុងស្ថានភាពទល់នឹងការជំនះ មែនហើយ ដរាបដល់ពួកគេខ្លាចយើង ហើយមិនហ៊ានមកច្បាំងតតាំងនឹងយើងទេ ។

៨ ពួកគេយកបានដែនដី ឬទីក្រុងសារ៉ាហិមឡា; ពួកគេបានតែងតាំងស្ដេចមួយលើពួកគេ ហើយទ្រង់បានសរសេរសំបុត្រទៅស្ដេច នៃពួកសាសន៍លេមិន នៅក្នុងនោះ ទ្រង់បានចូលសម្ព័ន្ធមិត្តជាមួយនឹងទ្រង់; នៅក្នុងសម្ព័ន្ធមិត្តនេះ ទ្រង់បានសុខចិត្តថែរក្សាទីក្រុង សារ៉ាហិមឡា ឯការថែរក្សានេះទ្រង់បានសន្និដ្ឋានថា នឹងផ្ដល់លទ្ធភាពឲ្យពួកលេមិន វាយយកដែនដីដែលនៅសល់ទាំងប៉ុន្មានឲ្យបាន ហើយទ្រង់នឹងត្រូវបានតាំងឲ្យធ្វើជាស្ដេចលើប្រជាជននេះ កាលណាពួកគេនឹងត្រូវត្រួតត្រាក្រោមពួកសាសន៍លេមិន ។

៩ ហើយឥឡូវនេះ នៅក្នុងសំបុត្ររបស់អ្នក អ្នកបានរិះគន់ខ្ញុំ ប៉ុន្តែវាមិនជាអ្វីទេ; ខ្ញុំមិនខឹងទេ ប៉ុន្តែអររីករាយនឹងចិត្តខ្ពង់ខ្ពស់របស់អ្នក ។ ខ្ញុំ ពេហូរ៉ាន់ ពុំស្វែងរកអំណាចទេ គ្រាន់តែចង់រក្សាវេទិកាជំនុំជំរះរបស់ខ្ញុំទុកប៉ុណ្ណោះ ដើម្បីខ្ញុំអាចរក្សាសិទ្ធិទាំង

៣៦ ក គ. និង ស. ១២១:៣៩–៤២.
៦១ ១ក អាលម៉ា ៥០:៣៩–៤០.
២ ក អាលម៉ា ៦០:៣–៩.
៣ ក អាលម៉ា ៥១:៦–៧.
៦ ក ស.ប. សេរី, សេរីភាព; ឥស្សរភាព.

ឡាយ និងឥស្សរភាពរបស់ប្រជាជនខ្ញុំ ។ ព្រលឹងខ្ញុំឈររឹងប៉ឹង
នៅក្នុងឥស្សរភាពនោះ នៅក្នុងនោះ ព្រះទ្រង់បានធ្វើឲ្យ
យើងរាល់គ្នាមានសេរី ។
១០ ហើយឥឡូវនេះ មើលចុះ យើងនឹងតទល់នឹងសេចក្ដីទុច្ចរិត
រហូតដល់ទៅការខ្ចាយឈាម ។ យើងមិនកំចាយឈាមពួក
សាសន៍លេមិនទេ បើសិនជាពួកគេនៅក្នុងដែនដីគេផ្ទាល់ ។
១១ យើងមិនកំចាយឈាមបងប្អូនយើងទេ បើសិនជាពួកគេ
មិនបះបោរឡើង ហើយកាន់ដាវប្រឆាំងនឹងយើង ។
១២ យើងនឹងដាក់ខ្លួនយើង ក្រោមនឹមនៃសេវកភាព ប្រសិន
បើការណ៍នេះតម្រូវដោយសេចក្ដីយុត្តិធម៌នៃព្រះ ឬប្រសិនបើទ្រង់
បញ្ជាឲ្យយើងធ្វើយ៉ាងនេះ ។
១៣ ប៉ុន្តែមើលចុះ ទ្រង់មិនបានបញ្ជាយើងថា យើងត្រូវចំណុះ
ខ្លួនទៅឲ្យពួកខ្មាំងសត្រូវយើងទេ ប៉ុន្តែថា យើងត្រូវដាក់ទីទុកចិត្ត
របស់យើងទៅលើទ្រង់ ហើយទ្រង់នឹងដោះលែងពួកយើងឲ្យរួច។
១៤ ហេតុដូច្នេះហើយ ម៉ូរ៉ូណៃ បងជាទីស្រឡាញ់របស់ខ្ញុំអើយ
ចូរយើងតទល់នឹងសេចក្ដីអាក្រក់ រីឯសេចក្ដីអាក្រក់ណាដែល
យើងមិនអាចតទល់បាន ដោយពាក្យសំដីរបស់យើងទេ មែនហើយ
ដូចជាការបះបោរ និងការបែកចេញទាំងឡាយ នោះចូរយើង
តទល់នឹងវាដោយដាវរបស់យើងវិញ ដើម្បីយើងអាចរក្សាសេរីភាព
របស់យើងទុក ដើម្បីយើងអាចបានអររីករាយ នៅក្នុងឯកសិទ្ធដ៏ធំ
នៃសាសនាចក្ររបស់យើង និងក្នុងឧត្ដមគតិនៃព្រះដ៏ប្រោសលោះ
របស់យើង និងព្រះរបស់យើង ។
១៥ ហេតុដូច្នេះហើយ ចូរមករកខ្ញុំជាប្រញាប់ ជាមួយនឹងទ័ព
របស់អ្នកបន្តិចបន្តួច ហើយទុកចំនួនដែលនៅសល់ទាំងប៉ុន្មាន ឲ្យនៅ
ក្រោមបង្គាប់របស់លីហៃ និងទីអានគុមចុះ; ចូរឲ្យពួកគេនូវ
អំណាច ដើម្បីធ្វើបញ្ជាចម្បាំង នៅក្នុងភូមិភាគនៃដែនដីនោះ
ស្របតាមព្រះ វិញ្ញាណនៃព្រះ ដែលជានិស្ស័យនៃសេរីភាពផង
គឺនៅក្នុងពួកគេ ។
១៦ មើលចុះ ខ្ញុំបានបញ្ជូនស្បៀងខ្លះទៅឲ្យគេ ដើម្បីកុំឲ្យពួក
គេវិនាសបង់ រហូតដល់អ្នកអាចមករកខ្ញុំ ។
១៧ ចូរប្រមូលកងកម្លាំង ដែលអ្នកអាចធ្វើបាន នៅពេលអ្នក
ធ្វើដំណើរមកទីនេះ ហើយយើងនឹងប្រញាប់ទៅប្រឆាំងនឹងពួកដែល
បែកចេញនោះ នៅក្នុងកម្លាំងនៃព្រះរបស់យើង ស្របតាម
សេចក្ដីជំនឿ ដែលនៅក្នុងយើង ។
១៨ ហើយយើងនឹងយកទីក្រុងសារ៉ាហិមឡា ដើម្បីយើងអាច
បានស្បៀងអាហារបន្ថែម ផ្ញើទៅឲ្យលីហៃ និងទីអានគុម; មែន
ហើយ ពួកយើងនឹងចេញទៅប្រឆាំងនឹងពួកគេ នៅក្នុងកម្លាំងនៃ
ព្រះអម្ចាស់ ហើយយើងនឹងបញ្ចប់សេចក្ដីទុច្ចរិតដ៏ធំនេះឲ្យបាន ។
១៩ ហើយឥឡូវនេះ ម៉ូរ៉ូណៃ ខ្ញុំមានសេចក្ដីអំណរ នៅក្នុងការ
ទទួលសំបុត្ររបស់អ្នក ព្រោះខ្ញុំបារម្ភមិនដឹងជាត្រូវធ្វើអ្វី មិនដឹងថា
តើវាត្រឹមត្រូវឬទេ បើយើងទៅវាយតទល់នឹងបងប្អូនយើង ។
២០ ប៉ុន្តែ អ្នកបាននិយាយថា លើកលែងពួកគេប្រែចិត្ត
បើពុំនោះសោតទេ នោះព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យអ្នក ទៅវាយ
តទល់នឹងពួកគេហើយ ។
២១ ចូរឲ្យឃើញថា អ្នកជួយចំរើនកម្លាំងដល់លីហៃ និង
ទីអានគុម នៅក្នុងព្រះអម្ចាស់ចុះ; ចូរប្រាប់ពួកគេ កុំឲ្យខ្លាចឡើយ
ព្រោះព្រះទ្រង់នឹងដោះលែងពួកគេឲ្យរួច មែនហើយ និងអស់អ្នក
ណាដែលឈររឹងប៉ឹងនៅក្នុងឥស្សរភាពផង ដោយសារនោះ
ព្រះទ្រង់បានធ្វើឲ្យពួកគេមានសេរី ។ ហើយឥឡូវនេះ ខ្ញុំសូម
បញ្ចប់សំបុត្ររបស់ខ្ញុំ ទៅកាន់ម៉ូរ៉ូណៃ ជាបងដ៏ជាទីស្រឡាញ់
របស់ខ្ញុំ សិនហើយ ៕

## ជំពូកទី ៦២

*ម៉ូរ៉ូណៃធ្វើដំណើរទៅជួយពេហូរ៉ាន នៅដែនដីគេឌាន — ពួកនិយមស្ដេច ដែលប្រកែកមិនព្រមការពារប្រទេសគេ ត្រូវយកទៅ ប្រហារជីវិតចោល — ពេហូរ៉ាន និងម៉ូរ៉ូណៃយកក្រុងនីហ្វៃហាបានមកវិញ — ពួកសាសន៍លេមិនជាច្រើន រួបរួមជាមួយនឹងប្រជាជន អាំម៉ូន — ទីអានគុមសម្លាប់អាំម៉ូរ៉ុន ហើយត្រូវគេសម្លាប់គាត់វិញ — ពួកសាសន៍លេមិនត្រូវរុញច្រានចេញពីដែនដី ហើយសន្តិភាព ត្រូវបានបង្កើតឡើងវិញ — ហេលេមិនត្រឡប់ទៅធ្វើការងារបំរើ និងស្ដាបនាសាសនាចក្រឡើង។ ប្រមាណជាឆ្នាំ ៦២–៥៧ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលម៉ូរ៉ូណៃបាន
ទទួលសំបុត្រនេះហើយ នោះលោកមានចិត្តក្លាហានឡើង ហើយ
បាន ពោរពេញទៅដោយសេចក្ដីអំណរដ៏ខ្លាំងពន់ប្រមាណ ដោយ
សារសេចក្ដីស្មោះត្រង់របស់ពេហូរ៉ាន ព្រោះលោកមិនមែនជា
មនុស្ស ក្បត់សេរីភាព និងឧត្ដមគតិរបស់ប្រទេសលោកទេ ។
២ ប៉ុន្តែលោកបានកើតទុក្ខជាខ្លាំងណាស់ដែរ ដោយព្រោះ
សេចក្សីទុច្ចរិត នៃពួកជនដែលបានរុញច្រាន ពេហូរ៉ានចេញពីវេទិកា

៩ *ក* យ៉ូហាន ៨:៣១–៣៦;
គ. និង ស. ៨៨:៨៦.
១៣ *ក* ស.ប. សេចក្ដីជំនឿ; ទុកចិត្ត.
១៤ *ក* អាលម៉ា ៤៣:៤៧.
១៥ *ក* ២ កូរិន. ៣:១៧.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២១ *ក* សាការី ១០:១២.
**៦២** ១*ក* អាលម៉ា ៦០:១៨.

ជំនុំជំរះ មែនហើយ សរុបសេចក្ដីមក គឺមកពីពួកជនដែលបាន
បះបោរប្រឆាំងនឹងប្រទេសរបស់គេ និងព្រះរបស់គេផងដែរ ។
៣ ហើយហេតុការណ៍បានកើតឡើងថា មរ៉ូណៃបាននាំទ័ព
មួយចំនួនតូច ស្របតាមបំណងរបស់ពេហូរ៉ាន ហើយបានប្រគល់
ឲ្យលីហៃ និងទីអានគុមនូវបញ្ជាការលើទ័ព ដែលនៅសល់
ទាំងប៉ុន្មាន ហើយលោកបានធ្វើដំណើរឆ្ពោះទៅដែនដីគេឌាន ។
៤ ហើយលោកបានលើកទង់[ក]តំ[ខ]ស្សរភាព នៅទីណាក៏ដោយ
ដែលលោកចូលទៅ ហើយរកបានទ័ពបន្ថែម ដែលលោកអាចធ្វើ
បាន នៅគ្រប់ដំណើររបស់លោក ឆ្ពោះទៅឯដែនដីគេឌាន ។
៥ ហើយហេតុការណ៍បានកើតឡើងថា មនុស្សរាប់ពាន់នាក់
បាននាំគ្នាមករកទង់របស់លោក ហើយបានចាប់យកដាវរបស់គេ
ក្នុងកិច្ចការពារសេរីភាពរបស់គេ ដើម្បីកុំឲ្យពួកគេអាចធ្លាក់ ទៅ
ក្នុងសេវកភាពបានឡើយ ។
៦ ម្លោះហើយ កាលមរ៉ូណៃបានប្រមូលចំនួនទ័ព ដែល
លោកអាចធ្វើបាន នៅតាមគ្រប់ដំណើររបស់លោក នោះលោ
កបានមកដល់ ដែនដីគេឌាន; ហើយដោយបានរួបរួមកងកម្លាំង
របស់លោក ជាមួយនឹងកងកម្លាំងរបស់ពេហូរ៉ាន នោះហពួកគេ
បានក្លាយទៅជាខ្លាំងក្លា ជា[ក]អតិបរមា គឺខ្លាំងជាងទ័ព
របស់ពេគូសទៅទៀត ដែលជាស្ដេចនៃពួកអ្នកដែលបានបែកចេញ
ដែលបានបណ្ដេញ[ខ]ពួកសេរីចេញពីដែនដី សារ៉ាហិមឡា ហើយ
បានយកដែនដីនោះ ។
៧ ហើយហេតុការណ៍បានកើតឡើងថា មរ៉ូណៃ និងពេហូរ៉ាន
បាននាំពលទ័ពរបស់ខ្លួន ចុះទៅដែនដីសារ៉ាហិមឡា ហើយបាន
ទៅច្បាំងនឹងទីក្រុងនោះ ហើយបានជួបនឹងទ័ពរបស់ពេគូស ដរាប
ដល់ពួកគេបានចេញមកច្បាំង ។
៨ ហើយមើលចុះ ពេគូសបានស្លាប់ ឯទ័ពរបស់ទ្រង់ត្រូវបាន
ចាប់ជាឈ្លើយ ហើយពេហូរ៉ានត្រូវបានប្រគល់ឡើងវិញ នូវ
វេទិកា ជំនុំជំរះរបស់លោក ។
៩ ហើយទ័ពរបស់ពេគូស ត្រូវបានទទួលការជំនុំជំរះតាមច្បាប់
ហើយពួកនិយមស្ដេចផង ត្រូវបានចាប់ ហើយត្រូវបានដាក់គុក;
ហើយពួកគេត្រូវ[ក]ធ្វើទោសដល់ជីវិតតាមច្បាប់; មែនហើយ ទ័ព
របស់ពេគូសទាំងប៉ុន្មាននោះ និងពួកនិយមស្ដេច គឺអស់អ្នកណា
ដែលមិនព្រមកាន់អាវុធការពារប្រទេសខ្លួន តែប្រយុទ្ធតទល់នឹង
ប្រទេសខ្លួនវិញ ត្រូវយកទៅប្រហារជីវិតចោល ។
១០ ម្លោះហើយ ជាការចាំបាច់ ដែលច្បាប់នេះត្រូវបានអនុវត្ត
យ៉ាងតឹងរឹង ដើម្បីសន្តិសុខរបស់ប្រទេសគេ; មែនហើយ ហើយ
អស់អ្នកណាដែលបដិសេធសេរីភាព ត្រូវបានយកទៅប្រហារជីវិត
ជាប្រញាប់តាមច្បាប់ ។
១១ ម្លោះហើយ ក៏ចប់ឆ្នាំទីសាមសិបក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ; មរ៉ូណៃ និងពេហូរ៉ានបានសាងសន្តិភាព
ឡើងវិញ ដល់ដែនដីសារ៉ាហិមឡា នៅក្នុងចំណោមប្រជាជន
គេផ្ទាល់ ដោយបានផ្ដល់សេចក្ដីស្លាប់ទៅអស់អ្នកណា ដែល
មិនស្មោះ ត្រង់នឹងឧត្ដមគតិនៃសេរីភាព ។
១២ ហើយហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីសាមសិប
មួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នោះ
មរ៉ូណៃបានបញ្ជាភ្លាមថា ត្រូវបញ្ជូនស្បៀង ហើយព្រមទាំងទ័ព
មួយកងមានចំនួនប្រាំមួយពាន់នាក់ផង ត្រូវបញ្ជូនទៅឲ្យហេលេមិនដែរ
ដើម្បីជួយលោក នៅក្នុងការរក្សាភូមិភាគនៃដែនដីនោះ ។
១៣ ហើយលោកក៏បានបញ្ជាដែរថា ទ័ពមួយកងចំនួនប្រាំ
មួយពាន់នាក់ ជាមួយនឹងស្បៀងគ្រប់គ្រាន់ ត្រូវបញ្ជូនទៅឲ្យពលទ័ព
របស់លីហៃ និងទីអានគុម ។ ហើយហេតុការណ៍បានកើតឡើងថា
ការណ៍នេះត្រូវបានធ្វើឡើង ដើម្បីពង្រឹងដែនដីប្រឆាំងនឹង ពួក
លេមិន ។
១៤ ហើយហេតុការណ៍បានកើតឡើងថា មរ៉ូណៃ និងពេហូរ៉ាន
កានបានទុកទ័ពមួយក្រុមយ៉ាងធំ នៅក្នុងដែនដីសារ៉ាហិមឡា
ហើយនោះ ក៏បានធ្វើដំណើរជាមួយនឹងកងទ័ពមួយក្រុមយ៉ាងធំ
ឆ្ពោះទៅឯដែនដីនីហ្វៃហា ដោយប្ដេជ្ញាថា នឹងយកជ័យជំនះលើពួក
លេមិននៅទីក្រុងនោះឲ្យបាន ។
១៥ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលពួក
គេកំពុងតែដើរសំដៅទៅដែនដីនោះ នោះពួកគេចាប់បានទ័ពមួយ
ក្រុមធំនៃពួកសាសន៍លេមិន ហើយបានសម្លាប់ពួកគេអស់ជាច្រើន
ហើយបានយកស្បៀង និងគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់
ពួកគេ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីពួកគេបាន
ចាប់ពួកវាហើយ នោះគេបានបញ្ជាឲ្យពួកវា ចូលក្នុងសេចក្ដី
សញ្ញា មួយថា ពួកវាឈប់កាន់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាម
ប្រឆាំងនឹងពួកសាសន៍នីហ្វៃទៀតហើយ ។
១៧ ហើយកាលពួកគេបានចូលក្នុងសេចក្ដីសញ្ញានេះហើយ

៤ *ក* អាលម៉ា ៤៦:១២–១៣, ៣៦.
ស.ប. ទង់.
*ខ* ស.ប. ឥស្សរភាព.
៦ *ក* អាលម៉ា ៦១:៤–៨.
*ខ* អាលម៉ា ៥១:៥–៧.
៩ *ក* ស.ប. ការដាក់ទោសដល់ជីវិត.

នោះពួកគេបានបញ្ជូនពួកវាទៅនៅជាមួយនឹងប្រជាជនអាំម៉ូន
ហើយពួកវាមានចំនួនប្រហែលបួនពាន់នាក់ ដែលពុំបានស្លាប់ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបាន
បញ្ជូនពួកវាទៅហើយ នោះពួកគេបានបន្តដំណើរ ទៅឯដែនដី
នីហ្វៃហា ទៀត ។ ហើយហេតុការណ៍បានកើតឡើងថា កាលពួក
គេបានទៅដល់ទីក្រុងនីហ្វៃហាហើយ នោះពួកគេបានបោះត្រសាល
នៅក្នុង ទីវាលទំនាបនៃនីហ្វៃហា ដែលនៅជិតទីក្រុងនីហ្វៃហា ។
១៩ ឥឡូវនេះ ម៉ូរ៉ូណៃមានបំណងចង់ឲ្យពួកលេមិនចេញមក
ច្បាំងតតាំងនឹងពួកគេ នៅលើវាលទំនាប; ប៉ុន្តែពួកលេមិនបាន
ស្គាល់ នូវសេចក្ដីក្លាហានដ៏ខ្លាំងអស្ចារ្យរបស់ពួកគេ ហើយដោយ
បានឃើញពួកគេមានចំនួនច្រើន ហេតុដូច្នេះហើយ ពួកគេពុំ
ហ៊ានចេញមក តតាំងនឹងគេឡើយ; ហេតុដូច្នេះហើយ ពួកវាពុំ
បានចេញមកច្បាំងនៅថ្ងៃនោះទេ ។
២០ ហើយកាលយប់មកដល់ នោះម៉ូរ៉ូណៃបានដើរទៅ
ក្នុងយប់ងងឹត ហើយបានទៅដល់កំផែង ដើម្បីស៊ើបការណ៍ឲ្យ
ដឹងថា តើនៅ ផ្នែកណាមួយនៃទីក្រុង ដែលពួកលេមិនបានបោះជំរុំ
ជាមួយនឹងកងទ័ពរបស់គេ ។
២១ ហើយហេតុការណ៍បានកើតឡើងថា ពួកគេនៅទិស
ខាងកើត គឺជិតទ្វារចូល; ហើយពួកវាទាំងអស់កំពុងតែដេកលក់ ។
ហើយឥឡូវនេះ ម៉ូរ៉ូណៃបានត្រឡប់មកឯកងទ័ពលោកវិញ ហើយ
បានបញ្ជាថា ពួកគេត្រូវរៀបចំយ៉ាងប្រញាប់ នូវខ្សែពួរដ៏មាំ និង
ជណ្ដើរទាំងឡាយ ទុកសំរាប់ដាក់ចុះពីលើកំផែង ទៅផ្នែកខាងក្នុង
កំផែង ។
២២ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃបានបញ្ជាឲ្យ
ទ័ពរបស់លោកដើរទៅមុខ ហើយឡើងទៅលើកំផែង ហើយចុះ
ទៅផ្នែកនោះនៃទីក្រុង មែនហើយ គឺនៅខាងលិច ជាកន្លែងដែល
ពួកលេមិនពុំបានបោះជំរុំ ជាមួយនឹងពលទ័ពរបស់ពួកគេ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ពួកគេទាំងអស់គ្នា
ត្រូវបានចុះទៅខាងក្នុងទីក្រុង នៅពេលយប់ ដោយប្រើខ្សែពួរ
ដ៏មាំរបស់គេ និងជណ្ដើរទាំងឡាយរបស់គេ; ម្ល៉ោះហើយ កាល
ព្រឹកឡើង នោះពួកគេទាំងអស់គ្នាបាននៅខាងក្នុងកំផែងក្រុង ។
២៤ ហើយឥឡូវនេះ កាលពួកលេមិនភ្ញាក់ឡើង ហើយបាន
ឃើញពលទ័ពរបស់ម៉ូរ៉ូណៃ នៅខាងក្នុងកំផែងទាំងឡាយ ពួកគេ
តក់ស្លុតជាខ្លាំង ដរាបដល់ពួកគេបានរត់គេចតាមច្រកចេញ ។
២៥ ហើយឥឡូវនេះ កាលម៉ូរ៉ូណៃបានឃើញថា ពួកវាកំពុងតែ
រត់គេចចេញពីលោក នោះលោកបានបញ្ជាឲ្យទ័ពរបស់លោក
ដេញតាមពួកវា ហើយសម្លាប់ពួកវាជាច្រើនចោល ហើយបាន
ព័ទ្ធជុំវិញពួកវាជាច្រើនទៀត ហើយបានចាប់ពួកវាធ្វើជាឈ្លើយ;
ហើយពួកវាដែលនៅសល់ទាំងប៉ុន្មាន បានរត់ទៅក្នុងដែនដីម៉ូរ៉ូណៃ
គឺនៅក្នុងព្រំប្រទល់ជិតឆ្នេរសមុទ្រ ។
២៦ ម្ល៉ោះហើយ ម៉ូរ៉ូណៃ និងពេហូរ៉ាន់ យកបានទីក្រុងនីហ្វៃ
ហា ដោយពុំបាត់បង់មនុស្សម្នាក់សោះ; ហើយមានពួកលេមិនជា
ច្រើនត្រូវស្លាប់ ។
២៧ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួក[ក]សាសន៍
លេមិនជាច្រើនដែលជាឈ្លើយ មានបំណងចង់ចូលរួមនឹងប្រជាជន
អាំម៉ូន ហើយក្លាយទៅជាប្រជាជនសេរី ។
២៨ ហើយហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែល
មានបំណងចង់បានដូច្នោះ ពួកគេនោះហើយដែលត្រូវបានប្រគល់ឲ្យ
ស្របតាមបំណងរបស់គេ ។
២៩ ហេតុដូច្នេះហើយ ពួកឈ្លើយសាសន៍លេមិនទាំងអស់
បានចូលរួមជាមួយនឹងប្រជាជនអាំម៉ូន ហើយបានចាប់ផ្ដើមធ្វើការ
យ៉ាង ខិតខំ ភ្ជួររាស់ដី ដាំធញ្ញជាតិគ្រប់ធុន ចិញ្ចឹមហ្វូងចៀម
និងហ្វូងសត្វគ្រប់មុខ; ម្ល៉ោះហើយ ពួកសាសន៍នីហ្វៃបាន
រួចពីបន្ទុកដ៏ធ្ងន់; មែនហើយ ដរាបដល់ពួកគេបានរួចពីអស់
ទាំងពួកឈ្លើយសាសន៍លេមិន ។
៣០ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃ
បន្ទាប់ពីយកបានទីក្រុងនីហ្វៃហាហើយ ដោយបានចាប់យក
ឈ្លើយជាច្រើន ដែលបានបន្ថយចំនួនពលទ័ពសាសន៍លេមិនជា
ខ្លាំង ហើយដោយបានមកវិញ នូវសាសន៍នីហ្វៃជាច្រើន ដែល
ត្រូវបានចាប់យកទៅជា ឈ្លើយ ការនេះបានបន្ថែមកម្លាំង
ដល់កងទ័ពរបស់ម៉ូរ៉ូណៃជាខ្លាំង; ហេតុដូច្នេះហើយ ម៉ូរ៉ូណៃ
បានចេញពីដែនដីនីហ្វៃហាទៅដែនដីលីហៃ ។
៣១ ហើយហេតុការណ៍បានកើតឡើងថា កាលពួកលេមិន
បានឃើញថាម៉ូរ៉ូណៃកំពុងតែមកវាយពួកវា នោះពួកវាកើតសេចក្ដី
តក់ ស្លុតជាថ្មីទៀត ហើយបានរត់គេចចេញពីកងទ័ពរបស់ម៉ូរ៉ូណៃ ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃ និងកងទ័ព
របស់លោក បានដេញតាមពួកគេពី ក្រុងមួយទៅក្រុងមួយ រហូត
ដល់ពួកវាត្រូវបានប្រទះនឹងលីហៃ និងទីអានគុម; ហើយពួក
លេមិនបានរត់គេចពីលីហៃ និងពីទីអានគុម គឺចុះទៅដល់ព្រំប្រទល់
ជិតឆ្នេរសមុទ្រ រហូតដល់ពួកវាទៅដល់ដែនដីម៉ូរ៉ូណៃ ។

២៧ ក ស.ប. អាន់តៃ-នីហ្វៃ-លីហៃ.

៣៣ ហើយពលទ័ពសាសន៍លេមិនបានប្រមូលគ្នាមកជាក្រុមមួយ នៅលើដែនដីម៉ូរ៉ូណៃ ។ ឥឡូវនេះ អាំម៉ូរ៉ុន ដែលជាស្ដេចនៃពួកសាសន៍លេមិន ក៏គង់នៅជាមួយពួកវាដែរ ។

៣៤ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃ និងលីហៃ និងទីអានគុម បានបោះជំរុំជាមួយនឹងពលទ័ពរបស់ខ្លួន នៅជុំវិញនៅព្រំប្រទល់នៃដែនដីម៉ូរ៉ូណៃ ដរាបដល់ពួកលេមិនត្រូវព័ទ្ធជុំវិញនៅព្រំប្រទល់ជិតទីរហោស្ថានខាងត្បូង និងនៅព្រំប្រទល់ជិតទីរហោស្ថានខាងកើត ។

៣៥ ម្ល៉ោះហើយ ពួកគេបានបោះជំរុំសំរាប់យប់នោះ ។ ត្បិតមើលចុះ ពួកនីហ្វៃ និងពួកលេមិនផង មានការនឿយហត់ដោយសារ ការធ្វើដំណើរដ៏ឆ្ងាយ; ហេតុដូច្នេះហើយ ពួកគេពុំបានសំរេចនឹងយកឧបាយសឹកណាមួយមកប្រើ ក្នុងវេលាយប់នោះទេ លើកលែងតែ ទីអានគុមមួយប៉ុណ្ណោះ; ព្រោះលោកខឹងនឹងអាំម៉ូរ៉ុនជាខ្លាំង ដរាបដល់លោកចាត់ទុកថា អាំម៉ូរ៉ុន និងអាម៉ាលិកាយជាព្រះជេដ្ឋាទ្រង់ [ក]គឺជាមូលហេតុនៃសង្គ្រាមដ៏ធំ ហើយយូរនេះ រវាងពួកគេនឹងពួកលេមិន ដែលជាមូលហេតុនៃសង្គ្រាម និងការខ្ចាយឈាមដ៏ច្រើន មែនហើយ និងអំណត់អត់ដ៏ច្រើន ។

៣៦ ហើយហេតុការណ៍បានកើតឡើងថា ទីអានគុម នៅក្នុងកំហឹង បានចូលទៅក្នុងជំរុំរបស់ពួកលេមិន ហើយបានចុះពីលើកំផែងទីក្រុង ។ ហើយលោកបានយកខ្សែពួរមួយចង្វាយទៅជាមួយផង គឺទៅពីកន្លែងមួយទៅកន្លែងមួយ ដរាបដល់លោកបានរកឃើញស្ដេច; ហើយលោកបាន[ក]ចាក់ទ្រង់នឹងលំពែង ដែលបានទម្លុះទ្រង់ត្រង់ជិតបេះដូង ។ ប៉ុន្តែមើលចុះ ស្ដេចបានធ្វើឲ្យពួកអ្នកបំរើទ្រង់ភ្ញាក់ មុនពេលទ្រង់សុគត ធ្វើឲ្យពួកគេដេញតាមទីអានគុម ហើយសម្លាប់លោក ។

៣៧ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលលីហៃ និងម៉ូរ៉ូណៃបានដឹងថា ទីអានគុមស្លាប់ទៅហើយ នោះពួកគេកើតទុក្ខ ជាខ្លាំង; ត្បិតមើលចុះ លោកគឺជាបុរសម្នាក់ ដែលធ្លាប់បានប្រយុទ្ធយ៉ាងអង់អាច ដើម្បីប្រទេសរបស់លោក មែនហើយ ជាមិត្តដ៏ស្មោះ ម្នាក់នៃឥស្សរភាព; ហើយលោកធ្លាប់បានរងសេចក្ដីទុក្ខវេទនាដ៏ធ្ងន់ធ្ងរជាច្រើន ។ ប៉ុន្តែមើលចុះ លោកបានស្លាប់ ហើយបានទៅតាម ផ្លូវនៃអស់ទាំងផែនដី ។

៣៨ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃបានធ្វើដំណើរទៅ នៅថ្ងៃស្អែកឡើង ហើយបានវាយប្រហារពួកលេមិន ដរាបដល់ពួកគេបានសម្លាប់ពួកវា ក្នុងការកាប់សម្លាប់មួយដ៏ធំ; ហើយពួកគេបានរុញច្រានពួកវាចេញពីដែនដី; ហើយពួកវាបានរត់ គេច គឺថា ពួកគេពុំបានត្រឡប់មកប្រឆាំងនឹងពួកនីហ្វៃនៅពេលនោះឡើយ ។

៣៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីសាមសិបមួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ; ម្ល៉ោះហើយ ពួកគេធ្លាប់មានសង្គ្រាម ទាំងឡាយ និងការខ្ចាយឈាមទាំងឡាយ និងអំណត់អត់ និងសេចក្ដីទុក្ខវេទនា អស់រយៈពេលជាច្រើនឆ្នាំ ។

៤០ ហើយធ្លាប់មានការឃាតកម្មទាំងឡាយ និងការទាស់ទែងគ្នាទាំងឡាយ និងការបែកគ្នាទាំងឡាយ និងអស់ទាំងអំពើ ទុច្ចរិតគ្រប់បែបយ៉ាង នៅក្នុងចំណោមប្រជាជននីហ្វៃ; ទោះជាយ៉ាងណាក៏ដោយ គឺដើម្បី[ក]ពួកសុចរិត មែនហើយ ដោយសារការ អធិស្ឋានទាំងឡាយនៃពួកសុចរិត នោះពួកគេត្រូវបានលើកលែងជីវិតឲ្យ ។

៤១ ប៉ុន្តែមើលចុះ មកពីរយៈពេលដ៏យូរក្រៃលែងនៃសង្គ្រាម រវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន នោះមនុស្សជាច្រើនបានក្លាយទៅជារឹងទទឹង មកពីរយៈពេលដ៏យូរក្រៃលែងនៃសង្គ្រាម; ហើយមនុស្សជាច្រើនមានចិត្តទន់ភ្លន់ មកពី[ក]សេចក្ដីទុក្ខវេទនា ទាំងឡាយរបស់គេ ដរាបដល់ពួកគេបានបន្ទាបខ្លួននៅចំពោះព្រះ គឺនៅក្នុងជំរៅនៃភាពទន់ទាប ។

៤២ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីម៉ូរ៉ូណៃបានពង្រឹងភាគទាំងនោះ នៃដែនដីដែលចំហដល់ពួកសាសន៍លេមិន រហូតដល់ពួកគេមានកម្លាំងគ្រប់គ្រាន់ហើយ លោកបានត្រឡប់ទៅឯទីក្រុងសារ៉ាហិមឡាវិញ; ហើយហេលេមិនផង ក៏បានត្រឡប់ទៅឯ កន្លែងកេរ្តិ៍អាកររបស់លោកដែរ; ហើយសន្តិភាពត្រូវបានបង្កើតឡើងម្ដងទៀត នៅក្នុងចំណោមប្រជាជននីហ្វៃ ។

៤៣ ហើយម៉ូរ៉ូណៃបានប្រគល់បញ្ជារបស់ពលទ័ពលោក ទៅក្នុងដៃរបស់កូនប្រុសលោក ដែលមានឈ្មោះថា ម៉ូរ៉ូណៃហា; ហើយលោកបានចូលនិវត្ត នៅឯផ្ទះរបស់លោកផ្ទាល់ ដើម្បីលោកអាចចំណាយ ពេលវេលារបស់លោក ដែលនៅសល់ទាំងប៉ុន្មានក្នុងសន្តិភាព ។

៤៤ ហើយពេហូរ៉ាន បានត្រឡប់ទៅឯវេទិកាជំនុំជំរះរបស់លោកវិញ; ហើយហេលេមិនបានទទួលបន្ទុកជាថ្មី នៅក្នុងការផ្សាយ ប្រាប់ប្រជាជន នូវព្រះបន្ទូលនៃព្រះ; ដោយ

៣៥ *ក* អាលម៉ា ៤៨:១.
៣៦ *ក* អាលម៉ា ៥១:៣៣–៣៤.
៤០ *ក* អាលម៉ា ៤៥:១៥–១៦.
៤១ *ក* ស.ប. សេចក្ដីទំនាស់.

ព្រោះសង្គ្រាម និងការទាស់ទែងគ្នាជាច្រើន វាជាការចាំបាច់ថា
របៀបចាត់ចែងមួយត្រូវបាន ធ្វើឡើងជាថ្មី នៅក្នុងសាសនាចក្រ ។
៤៥ ហេតុដូច្នេះហើយ ហេលេមិន និងបងប្អូនលោក
ក៏បានចេញទៅ ហើយបាន[ក]ប្រកាសប្រាប់ព្រះបន្ទូលនៃព្រះ ដោយ
អំណាចដ៏ ច្រើន ចំពោះការបរិវត្តន៍មនុស្សជាច្រើនអំពីសេច
ក្ដីទុច្ចរិតរបស់គេ ដែលបានធ្វើឲ្យពួកគេប្រែចិត្តពីអំពើបាបទាំង
ឡាយរបស់គេ ហើយបានទទួលបុណ្យជ្រមុជទឹកថ្វាយព្រះអម្ចាស់
ជាព្រះរបស់គេ ។
៤៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានតាំងជាថ្មី
នូវសាសនាចក្រនៃព្រះទូទៅអស់ទាំងដែនដី ។
៤៧ មែនហើយ ហើយការចាត់ចែងទាំងឡាយ ត្រូវបាន
ធ្វើ[ក]ឡើងអំពីច្បាប់ ។ ហើយចៅក្រមទាំងឡាយរបស់ពួកគេ
និងមេចៅ ក្រមទាំងឡាយរបស់ពួកគេ ក៏បានរើសឡើង ។
៤៨ ហើយប្រជាជននីហ្វៃបានចាប់ផ្ដើម[ក]ចំរើនឡើងទៀត
នៅលើដែនដី ហើយបានចាប់ផ្ដើមកើនចំនួនឡើង និងខ្លាំងពូកែដ៏
លើស លប់ទៀតនៅលើដែនដី ហើយពួកគេបានចាប់ផ្ដើម
ដុះដាល មានទ្រព្យច្រើនជាអតិបរមា ។
៤៩ ប៉ុន្តែ ទោះជាគេមានទ្រព្យដ៏ស្ដុកស្ដម ឬមានកម្លាំង ឬមាន
ការចំរើនក្ដី គង់តែពួកគេពុំលើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃភ្នែក
របស់គេទេ; ហើយពួកគេក៏មិនកម្រនឹកឃើញដល់ព្រះអម្ចាស់
ជាព្រះរបស់ពួកគេដែរ; ប៉ុន្តែពួកគេបានបន្ទាបខ្លួនជាខ្លាំង
នៅចំពោះទ្រង់ ។
៥០ មែនហើយ ពួកគេបាននឹកឃើញដល់កិច្ចការដ៏អស្ចារ្យទាំង
ឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើដើម្បីពួកគេថា ទ្រង់បានដោះ
លែងពួកគេឲ្យរួចផុតពីសេចក្ដីស្លាប់ និងពីសេវកភាព និងពីគុក
និងពីសេចក្ដីទុក្ខវេទនាគ្រប់បែបយ៉ាង ហើយទ្រង់បានដោះលែង
ពួកគេ ឲ្យរួចផុតពីកណ្ដាប់ដៃ នៃពួកខ្មាំងសត្រូវរបស់ពួកគេ ។
៥១ ហើយពួកគេបានអធិស្ឋានដល់ព្រះអម្ចាស់ ជាព្រះរបស់
ពួកគេ មិនឈប់ឈរឡើយ ដរាបដល់ព្រះអម្ចាស់ ទ្រង់បាន
ប្រទានពរ ដល់ពួកគេ តាមព្រះបន្ទូលរបស់ទ្រង់ ដើម្បីឲ្យពួកគេ
បានខ្លាំងពូកែ ហើយបានចំរើនឡើងនៅលើដែនដី ។
៥២ ហើយហេតុការណ៍បានកើតឡើងថា កិច្ចការទាំង
អស់នេះត្រូវបានសំរេច។ ហើយហេលេមិនបានស្លាប់ទៅ គឺនៅឆ្នាំទី
សាមសិបប្រាំក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ៕

## ជំពូកទី ៦៣

*ស៊ិបឡុន ហើយក្រោយមក ហេលេមិន យកបញ្ជីពិសិដ្ឋទាំងឡាយ — ពួកសាសន៍នីហ្វៃជាច្រើនធ្វើដំណើរទៅដែនដី ដែលនៅទិស ខាងជើង — ហាកូតសង់សំពៅទាំងឡាយ ដែលបើកនៅក្នុងសមុទ្រខាងលិច — ម៉ូរ៉ូណៃហាធ្វើឲ្យពួកលេមិនបរាជ័យនៅក្នុងចម្បាំង ។ ប្រមាណជាឆ្នាំ៥៦–៥២ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីសាមសិបប្រាំ
មួយក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នោះ[ក]ស៊ិបឡុន
បានទទួលយក[ខ]បញ្ជីពិសិដ្ឋទាំងឡាយ ដែលអាលម៉ាបាន
ប្រគល់ទៅឲ្យហេលេមិននោះ ។
២ ហើយលោកគឺជាមនុស្សសុចរិតម្នាក់ ហើយលោកបាន
ដើរដោយត្រង់នៅចំពោះព្រះ; ហើយលោកបានប្រតិបត្តិតាមការ
ធ្វើ ល្អរហូត ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់
ជាព្រះរបស់លោក ហើយប្អូនលោកក៏ដូច្នោះដែរ ។
៣ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃបាន
ស្លាប់ទៅដែរ ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីសាមសិបប្រាំមួយ
ក្នុងរជ្ជកាលនៃ ពួកចៅក្រមទៅ ។
៤ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីសាមសិប
ប្រាំពីរក្នុងរជ្ជកាលនៃពួកចៅក្រម នោះមានមនុស្សមួយក្រុមធំ
គឺមាន ចំនួនដល់ទៅប្រាំពាន់បួនរយនាក់ ជាមួយនឹងប្រពន្ធ និង
កូនចៅគេផង បានចាកចេញពីដែនដីសារ៉ាហិមឡា ទៅកាន់
ដែនដីដែលនៅ [ក]ទិសខាងជើង ។
៥ ហើយហេតុការណ៍បានកើតឡើងថា ហាកូត លោកជា
មនុស្សដែលចង់ចេះចង់ដឹងជាខ្លាំង ហេតុដូច្នេះហើយ
លោកបានចេញ ទៅ ហើយបានសង់សំពៅមួយដ៏ធំអស្ចារ្យ
នៅត្រង់ព្រំប្រទល់នៃដែនដីបរិបូរណ៍ នៅជិតដែនដីចោលស្ងាត់[ក]
ហើយបានដាក់វាចុះ ទៅក្នុង សមុទ្រខាងលិច នៅជិតចន្លោះតូច
ដែលនាំទៅកាន់ដែនដីទិសខាងជើង ។
៦ ហើយមើលចុះ មានសាសន៍នីហ្វៃជាច្រើន ដែលបាន
ចូលទៅក្នុងនោះ ហើយបានបើកទៅដោយមានស្បៀងជាច្រើន
ហើយ មានពួកស្ត្រី និងកូនក្មេងជាច្រើនផង; ហើយពួកគេ
បានធ្វើដំណើរឆ្ពោះទៅឯទិសខាងជើង ។ ម្ល៉ោះហើយ
ក៏ចប់ឆ្នាំទីសាមសិបប្រាំពីរ ទៅ ។

---

៤៥ *ក* គ. និង ស. ១៨:៤៤.
៤៧ *ក* ម៉ូសាយ ២៩:៣៩.
៤៨ *ក* អាលម៉ា ៥០:២០.

**៦៣** ១ *ក* អាលម៉ា ៣៨:១–២.
*ខ* អាលម៉ា ៣៧:១–១២.
ស.ប. បរិសុទ្ធ.

៤ *ក* អាលម៉ា ២២:៣១.
៥ *ក* អាលម៉ា ២២:៣២;
អេធើរ ១០:២០.

៧ ហើយនៅក្នុងឆ្នាំទីសាមសិបប្រាំបី បុរសនេះបានសង់
សំពៅឯទៀតទាំងឡាយ ហើយសំពៅទីមួយបានត្រឡប់មកវិញផង
ហើយ មនុស្សជាច្រើនទៀតបានចូលទៅក្នុងនោះ ហើយពួក
គេក៏បានយកស្បៀងជាច្រើនផង ហើយបើកចេញទៅជាថ្មី
ទៅកាន់ដែនដីទិស ខាងជើង ។
៨ ហើយហេតុការណ៍បានកើតឡើងថា ពុំដែលឮដំណឹងពីពួក
នោះទៀតឡើយ ។ ហើយយើងបានសន្និដ្ឋានថា ពួកគេត្រូវ
លិចលង់នៅក្នុងជំរៅនៃសមុទ្រ ។ ហើយហេតុការណ៍
បានកើតឡើងថា សំពៅមួយផ្សេងទៀត ក៏បានបើកចេញទៅដែរ
ហើយវា ទៅទីណា នោះយើងមិនដឹងទេ ។
៩ ហើយហេតុការណ៍បានកើតឡើងថា នៅ[ក]ក្នុងឆ្នាំនេះ មាន
មនុស្សជាច្រើន ដែលបានចេញទៅដែនដីនៅទិសខាងជើង ។
ម៉្លោះហើយ ក៏ចប់ឆ្នាំទីសាមសិបប្រាំបីទៅ ។
១០ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីសាមសិ
បប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម នោះស៊ិបឡុនក៏បាន
ស្លាប់ទៅដែរ ហើយកូរីអានតុនបានចេញទៅដែនដីនៅទិស
ខាងជើង តាមសំពៅមួយ ដើម្បីយកស្បៀងទៅឲ្យប្រជាជន
ដែលបានទៅ ដែនដីនោះ ។
១១ ហេតុដូច្នេះហើយ វាក្លាយទៅជាការចាំបាច់ដល់ស៊ិបឡុនថា
ត្រូវប្រគល់វត្ថុពិសិដ្ឋទាំងនោះ នៅមុនពេលលោកស្លាប់ ទៅឲ្យ
កូនប្រុសរបស់[ក]ហេលេមិន ដែលហៅថា ហេលេមិន ដោយបាន
ហៅតាមឈ្មោះឪពុកលោក ។
១២ ឥឡូវនេះ មើលចុះ [ក]ចម្លាក់ទាំងអស់នោះ ដែលនៅក្នុងការ
ថែរក្សារបស់ហេលេមិន ត្រូវបានចម្លង ហើយផ្សព្វផ្សាយទៅក្នុង
ចំណោមពួកកូនចៅមនុស្សទូទៅអស់ទាំងដែនដី លើកលែងតែ
ភាគទាំងឡាយ ដែលត្រូវបានបញ្ជាដោយអាលម៉ាថា [ខ]មិនត្រូវ
ផ្សាយ ។
១៣ ទោះជាយ៉ាងណាក៏ដោយ គង់តែវត្ថុទាំងនេះត្រូវបាន
រក្សាទុកជាពិសិដ្ឋ ហើយ[ក]បន្តពីតំណមួយទៅតំណមួយ; ហេតុ
ដូច្នេះ ហើយ នៅក្នុងឆ្នាំនេះ វាត្រូវបានប្រគល់ទៅឲ្យហេលេមិន
មុនពេលស៊ិបឡុនស្លាប់ទៅ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនេះ
ក៏មានពួកអ្នកបែកចេញខ្លះ បានចូលទៅខាងពួកសាសន៍លេមិនផង;
ហើយពួកវាត្រូវបានចាក់រុកជាថ្មី ឲ្យខឹងនឹងពួកសាសន៍នីហ្វៃ ។
១៥ ហើយនៅក្នុងឆ្នាំដដែលនេះដែរ ពួកគេបានយកកងទ័ព
ដ៏ច្រើន ចុះមកប្រឆាំងនឹងប្រជាជនម៉ូរ៉ូណៃហា ឬប្រឆាំងនឹង
កងទ័ព របស់[ក]ម៉ូរ៉ូណៃហា នៅក្នុងសង្គ្រាមនោះ ពួកគេត្រូវបាន
វាយ ហើយត្រូវបានរុញច្រានថយក្រោយវិញ ទៅដល់ដែនដីទាំង
ឡាយរបស់ ពួកគេផ្ទាល់ ដោយរងនូវការខូចខាតដ៏ធំ ។
១៦ ម៉្លោះហើយ ក៏ចប់ឆ្នាំទីសាមសិបប្រាំបួនក្នុងរជ្ជកាលនៃ
ពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។
១៧ ម៉្លោះហើយ ក៏ចប់នូវការរៀបរាប់របស់អាលម៉ា
និងហេលេមិន ជាកូនប្រុសរបស់លោក និងស៊ិបឡុនផង ដែលជា
កូនប្រុស របស់លោក ៕ :៚–

# គម្ពីរហេលេមិន

ដំណើររឿងមួយអំពីពួកសាសន៍នីហ្វៃ ។ សង្គ្រាមទាំងឡាយ និងការទាស់ទែងគ្នាទាំងឡាយរបស់គេ និងការបែកបាក់គ្នាទាំងឡាយ របស់គេ ។ ហើយព្រមទាំងសេចក្ដីព្យាករណ៍ទាំងឡាយ របស់ពួកព្យាការីបរិសុទ្ធជាច្រើនផង មុនការយាងមកនៃព្រះគ្រីស្ទ ស្របតាម បញ្ជីរបស់ហេលេមិន ដែលជាកូនរបស់ហេលេមិន និងស្របតាមបញ្ជីនៃពួកកូនប្រុសរបស់លោកផង គឺរហូតមកដល់ការយាងមកនៃ ព្រះគ្រីស្ទ ។ ហើយពួកសាសន៍លេមិនជាច្រើនផងបានប្រែចិត្តជឿ ។ ដំណើររឿងមួយអំពីការប្រែចិត្តរបស់ពួកគេ ។ ដំណើររឿងមួយ អំពីសេចក្ដីសុចរិត នៃពួកសាសន៍លេមិន និងសេចក្ដីទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ នៃពួកសាសន៍នីហ្វៃ ស្របតាមបញ្ជីរបស់ ហេលេមិន និងពួកកូនប្រុសរបស់លោក គឺរហូតមកដល់ការយាងមកនៃព្រះគ្រីស្ទ នោះត្រូវបានហៅថា គម្ពីរហេលេមិន ។ល។

៩ *ក* ហេលេ. ៣:១១–១២.
១១ *ក* សូមមើលចំណងជើងគម្ពីរហេលេមិន.
១២ *ក* អាលម៉ា ១៨:៣៦.
*ខ* អាលម៉ា ៣៧:២៧–៣២.
១៣ *ក* អាលម៉ា ៣៧:៤.
១៥ *ក* អាលម៉ា ៦២:៤៣.

## ជំពូកទី ១

*ពេហូរ៉ានទីពីរ ធ្វើជាមេចៅក្រម ហើយត្រូវគិសគូមេនធ្វើឃាត — ពេគូមេណៃបំពេញវេទិកាជំនុំជំរះ — កូរីអានទុមមើរ ដឹកនាំពលទ័ព សាសន៍លេមិន វាយយកសារ៉ាហិមឡា ហើយសម្លាប់ពេគូមេណៃ — មូរ៉ូណៃហាវាយពួកលេមិនឲ្យបរាជ័យ ហើយយកសារ៉ាហិមឡា មកវិញ ហើយកូរីអានទុមមើរត្រូវស្លាប់ ។ ប្រមាណជាឆ្នាំ ៥២–៥០ ម.គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីសែសិបក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នោះចាប់ផ្ដើមមានការពិបាកយ៉ាងធ្ងន់ធ្ងរមួយ នៅក្នុងចំណោមប្រជាជននៃពួកសាសន៍នីហ្វៃ ។

២ ត្បិតមើលចុះ [ក]ពេហូរ៉ានបានស្លាប់ ហើយទៅតាមផ្លូវនៃអស់ទាំងផែនដី; ហេតុដូច្នេះហើយ ក៏ចាប់ផ្ដើមមានការទាស់ទែងគ្នាដ៏ខ្លាំងមួយ អំពីនរណាត្រូវបានវេទិកាជំនុំជំរះ នៅក្នុងចំណោមបងប្អូនដែលជាពួកកូនប្រុសរបស់ពេហូរ៉ាន ។

៣ ឥឡូវនេះ នេះគឺជាឈ្មោះទាំងឡាយរបស់ពួកគេ ដែលបានដណ្ដើមវេទិកាជំនុំជំរះ ជាអ្នកដែលបាននាំឲ្យប្រជាជនទាស់គ្នាផងគឺ៖ ពេហូរ៉ាន ពេអានកៃ និងពេគូមេណៃ ។

៤ ឥឡូវនេះ កូនប្រុសទាំងអស់របស់ពេហូរ៉ាន ពុំមែនមានតែប៉ុណ្ណោះទេ (ព្រោះលោកមានច្រើន) ប៉ុន្តែពួកគេទាំងនេះហើយដែល បានប្រឆាំងគ្នាយកវេទិកាជំនុំជំរះ; ហេតុដូច្នេះហើយ ពួកគេបានបណ្ដាលឲ្យមានការបែកបាក់ជាបីផ្នែក នៅក្នុងចំណោមប្រជាជន ។

៥ ទោះជាយ៉ាងណាក៏ដោយ គង់តែហេតុ[ក]ការណ៍បានកើតឡើងថា ពេហូរ៉ានត្រូវបានតែងតាំងឡើង ដោយសម្លេងប្រជាជនឲ្យធ្វើជាមេចៅក្រម និងជាអ្នកអភិបាល លើប្រជាជននីហ្វៃ ។

៦ ហើយហេតុការណ៍បានកើតឡើងថា ពេគូមេណៃ កាលលោកបានឃើញថា លោកមិនអាចយកវេទិកាជំនុំជំរះបានទេ នោះលោក ក៏យល់ព្រមតាមសម្លេងរបស់ប្រជាជន ។

៧ ប៉ុន្តែមើលចុះ ពេអានកៃ និងពួកប្រជាជនដែលចង់ឲ្យលោកធ្វើជាអ្នកអភិបាលរបស់គេនោះ ខឹងជាខ្លាំង; ហេតុដូច្នេះហើយ លោករៀបនឹងបញ្ឆោរឲ្យពួកប្រជាជនទាំងនោះបះបោរឡើងទាស់នឹងបងប្អូនរបស់ខ្លួន ។

៨ ហើយហេតុការណ៍បានកើតឡើងថា នៅពេលលោករៀបតែនឹងធ្វើយ៉ាងនេះ មើលចុះ លោកត្រូវគេចាប់យកទៅ ហើយត្រូវជំនុំជំរះ តាមសម្លេងរបស់ប្រជាជន ហើយត្រូវកាត់ទោសដល់ជីវិត ព្រោះលោកបានធ្វើការបះបោរ ហើយបានស្វែងរកបំផ្លាញ [ក]ឥស្សរភាពរបស់ប្រជាជន ។

៩ ឥឡូវនេះ កាលពួកប្រជាជនដែលចង់លើកលោក ឲ្យធ្វើជាអ្នកអភិបាលរបស់គេ បានឃើញថា លោកត្រូវកាត់ទោសដល់ជីវិត ហេតុដូច្នេះហើយ ពួកគេខឹង ហើយមើលចុះ ពួកគេបានចាត់ឲ្យមនុស្សម្នាក់ឈ្មោះ គិសគូមេន ទៅឯវេទិកាជំនុំជំរះរបស់ពេហូរ៉ាន ហើយធ្វើឃាតពេហូរ៉ាន នៅពេលដែលលោកអង្គុយនៅលើវេទិកាជំនុំជំរះ ។

១០ ហើយវាត្រូវពួកអ្នកបំរើរបស់ពេហូរ៉ានដេញតាម ប៉ុន្តែមើលចុះ គិសគូមេនរត់លឿនហួសពេក គ្មានអ្នកណាអាចតាមទាន់ឡើយ ។

១១ ហើយវាបានមកជួបនឹងពួកអ្នក ដែលបានចាត់ឲ្យវាទៅនោះ ហើយពួកគេទាំងអស់គ្នាបានធ្វើសេចក្ដីសញ្ញាមួយមែនហើយ ស្បថនឹងព្រះបង្កើតគេដ៏គង់នៅអស់កល្បជានិច្ចថាពួកគេពុំប្រាប់នរណាឡើយថា គិសគូមេនបានធ្វើឃាតពេហូរ៉ានបង់ ។

១២ ហេតុដូច្នេះហើយ គិសគូមេនពុំមានគេស្គាល់ថានៅក្នុងចំណោមប្រជាជននីហ្វៃឡើយ ព្រោះវាបានក្លែងខ្លួន នៅពេលវាធ្វើឃាតពេហូរ៉ាន ។ ហើយគិសគូមេន និងបក្សពួករបស់វា ដែលបានធ្វើសេចក្ដីសញ្ញាជាមួយគេនោះ បាននៅលាយឡំខ្លួននៅក្នុងចំណោមប្រជាជន នៅក្នុងរបៀបដែលមិនអាចមានអ្នកណារកឃើញពួកគេទាំងអស់បានឡើយ[ក]; ប៉ុន្តែពួកអ្នកណាដែលត្រូវបាន រកឃើញ គឺត្រូវកាត់ទោសដល់ជីវិត ។

១៣ ហើយឥឡូវនេះ មើលចុះ ពេគូមេណៃត្រូវបានតែងតាំងឡើង តាមសម្លេងរបស់ប្រជាជន ឲ្យធ្វើជាមេចៅក្រម និងជាអ្នក អភិបាលទៅលើប្រជាជន ដើម្បីគ្រប់គ្រងជំនួសបងប្រុសរបស់លោក គឺពេហូរ៉ាន; ហើយគឺស្របតាមសិទ្ធិរបស់លោក ។ ហើយការណ៍អស់ទាំងនេះ ត្រូវបានធ្វើនៅឆ្នាំទីសែសិបក្នុងរជ្ជកាលនៃពួកចៅក្រម ហើយវាក៏ចប់ទៅ ។

១៤ ហើយហេតុការណ៍បានកើតឡើង គឺនៅឆ្នាំទីសែសិបមួយក្នុងរជ្ជកាលនៃពួកចៅក្រម នោះពួកសាសន៍លេមិនបានប្រមូលទ័ពមួយកង ដ៏មានគ្នាច្រើនឥតគណនា ហើយបានប្រដាប់ដោយដាវទាំងឡាយ និងសាបទាំងឡាយ និងធ្នូទាំងឡាយ និងព្រួញទាំង ឡាយ និងមួកដែកទាំងឡាយ និងប្រដាប់បាំងដើមទ្រូងទាំងឡាយ និងអស់ទាំងខែលគ្រប់ប្រភេទ ។

---

[ហេលេមិន]
១ ២ *ក* អាលម៉ា ៥០:៤០.
៥ *ក* ម៉ូសាយ ២៩:២៦–២៩.
៨ *ក* ស.ប. ឥស្សរភាព.
១២ *ក* ស.ប. ការដាក់ទោសដល់ជីវិត.

១៥ ហើយពួកគេបានចុះមកទៀត ដើម្បីគេអាចបោះជំរុំច្បាំងនឹងពួកសាសន៍នីហ្វៃ ។ ហើយពួកគេត្រូវបានដឹកនាំ ដោយបុរសម្នាក់ដែលមានឈ្មោះថា កូរីអានទុមមើរ; ហើយវាជាពូជពង្សនៃសារ៉ាហិមឡា ហើយវាជាអ្នកដែលបែកចេញពីពួកសាសន៍នីហ្វៃ ហើយវាជាបុរសម្នាក់ដែលមានមាឌធំ ហើយខ្លាំងពូកែ ។

១៦ ហេតុដូច្នេះហើយ ស្ដេចនៃពួកសាសន៍លេមិន ដែលមាននាមថា ទូបាឡុត ដែលត្រូវជាបុត្ររបស់អាំម៉ូរ៉ុន[ក] ដោយបានគិតស្មានថា កូរីអានទុមមើរ ជាបុរសដ៏ខ្លាំងពូកែម្នាក់ អាចប្រឆាំងតទល់នឹងពួកសាសន៍នីហ្វៃបាន ដោយមកពីកម្លាំងរបស់វា និងប្រាជ្ញាដ៏ជ្រៅជ្រះ របស់វាផង ដរាបដល់បានសន្និដ្ឋានថា ដោយបានបញ្ជូនវាទៅ នោះទ្រង់នឹងយកជ័យជំនះ លើពួកសាសន៍នីហ្វៃបាន —

១៧ ហេតុដូច្នេះហើយ ទ្រង់បានចាក់រុកឲ្យពួកគេមានកំហឹង ហើយទ្រង់បានប្រមូលពលទ័ពរបស់ទ្រង់មក ហើយទ្រង់បានតែងតាំងកូរីអានទុមមើរ ឲ្យធ្វើជាមេដឹកនាំរបស់ពួកគេ ហើយបានបញ្ជាឲ្យពួកគេលើកទ័ព ចុះទៅឯដែនដីសារ៉ាហិមឡា ដើម្បីទៅច្បាំងនឹងពួកសាសន៍នីហ្វៃ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ដោយមកពីការទាស់ទែងគ្នាដ៏ច្រើន និងការពិបាកដ៏ខ្លាំង នៅក្នុងរដ្ឋាភិបាល ទើបពួកគេ ពុំបានទុកទាហានយាមឲ្យគ្រប់គ្រាន់ នៅដែនដីសារ៉ាហិមឡាទេ; ព្រោះពួកគេសន្និដ្ឋានថា ពួកលេមិនពុំហ៊ានចូលមកដល់កណ្ដាល ដែនដីរបស់គេ ដើម្បីមកវាយប្រហារទីក្រុងសារ៉ាហិមឡាដ៏ធំនោះឡើយ ។

១៩ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា កូរីអានទុមមើរបានដឹកនាំមុខពលទ័ពដ៏ច្រើនរបស់វាមក ហើយបានវាយប្រហារមកលើ បណ្ដាជននៅទីក្រុងនោះ ហើយដំណើរទ័ពរបស់គេ មានល្បឿនយ៉ាងលឿនហួសប្រមាណ ដែលធ្វើឲ្យពួកសាសន៍នីហ្វៃគ្មានពេល គ្រប់គ្រាន់នឹងប្រមូលពលទ័ពរបស់គេបានសោះ ។

២០ ហេតុដូច្នេះហើយ កូរីអានទុមមើរបានកាប់សម្លាប់អ្នកយាមនៅត្រង់ទ្វារចូលទីក្រុង ហើយបានលើកទ័ពរបស់វាទាំងមូលចូល ច្បាំងទៅក្នុងទីក្រុង ហើយពួកគេបានសម្លាប់អស់ទាំងជនណា ដែលប្រឆាំងនឹងពួកគេ រហូតដល់ពួកគេយកបានទីក្រុងទាំងមូល ។

២១ ហើយហេតុការណ៍បានកើតឡើងថា ពេគូមេណៃ ដែលជាមេចៅក្រមបានរត់គេចខ្លួនចេញពីកូរីអានទុមមើរទៅដល់កំផែងទីក្រុង ។ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមមើរបានវាយលោក ផ្ទប់នឹងកំផែងក្រុង ដរាបដល់លោកស្លាប់ ។ ម្ល៉ោះហើយ ក៏ចប់នូវជីវិតរបស់ពេគូមេណៃទៅ ។

២២ ហើយឥឡូវនេះ កាលកូរីអានទុមមើរបានឃើញថា វាយកបានទីក្រុងសារ៉ាហិមឡា ហើយបានឃើញថាបពួកសាសន៍នីហ្វៃបាន រត់គេចខ្លួនចេញពីពួកគេ ហើយត្រូវស្លាប់ និងត្រូវចាប់ និងត្រូវដាក់គុក ហើយថា វាយកបានទីតាំងការពារដ៏មាំបំផុត នៅអស់ទាំង ដែនដីហើយ នោះវាបានឡើងចិត្តក្លាហាន ដរាបដល់វាចង់ទៅវាយយកអស់ទាំងដែនដី ។

២៣ ហើយឥឡូវនេះ វាពុំនៅក្នុងដែនដីសារ៉ាហិមឡាទេ តែវាបានធ្វើដំណើរទៅជាមួយនឹងកងទ័ពដ៏ធំមួយ គឺឆ្ពោះទៅឯទីក្រុងបរិបូរណ៍; ព្រោះនេះគឺជាការសំរេចចិត្តរបស់វាថា នឹងធ្វើដំណើរឆ្ពោះទៅមុខ ហើយឆ្កាផ្លូវរបស់វាដោយដាវ ដើម្បីវាអាចដកផ្នែក ខាងជើងទាំងឡាយនៃដែនដី ។

២៤ ហើយដោយបានសន្និដ្ឋានថា កម្លាំងដ៏ខ្លាំងបំផុតរបស់គេគឺនៅកណ្ដាលដែនដី ទើបវាបានធ្វើដំណើរទៅ ដោយពុំទុកពេលឲ្យ ពួកគេប្រមូលគ្នាបានឡើយ លើកលែងតែជាក្រុមតូចៗ; ហើយដោយរបៀបនេះ ពួកគេវាយប្រហារទៅលើពួកគេ ហើយកាប់សម្លាប់ ពួកគេឲ្យដួលចុះទៅលើដី ។

២៥ ប៉ុន្តែមើលចុះ ដំណើររបស់កូរីអានទុមមើរនេះកាត់ទៅកណ្ដាលដែនដី បានផ្ដល់ឲ្យម៉ូរ៉ូណៃហាមានប្រៀបដ៏ធំលើពួកគេ ទោះបីជា ពួកសាសន៍នីហ្វៃមួយចំនួនធំត្រូវស្លាប់ក៏ដោយ ។

២៦ ត្បិតមើលចុះ ម៉ូរ៉ូណៃហាបានសន្និដ្ឋានថា ពួកលេមិនពុំហ៊ានចូលមកកណ្ដាលដែនដីឡើយ ប៉ុន្តែពួកវានឹងវាយប្រហារទីក្រុងទាំង ឡាយដែលនៅជុំវិញតាមព្រំប្រទល់ ដូចជាពួកគេធ្លាប់បានធ្វើមកពីមុន; ហេតុដូច្នេះហើយ ម៉ូរ៉ូណៃហាបានបញ្ជាឲ្យពលទ័ពដ៏ខ្លាំងពូកែ ឲ្យរក្សាផ្នែកទាំងឡាយ ដែលនៅជុំវិញជិតព្រំប្រទល់ ។

២៧ ប៉ុន្តែមើលចុះ ពួកលេមិនពុំតក់ស្លុត តាមបំណងរបស់លោកនោះទេ ប៉ុន្តែពួកគេបានចូលមកកណ្ដាលដែនដី ហើយបានវាយយក រដ្ឋធានី គឺទីក្រុងសារ៉ាហិមឡា ហើយកំពុងតែធ្វើដំណើរឆ្លងកាត់ តាមផ្នែកទាំងឡាយដ៏សំខាន់ៗបំផុតនៃដែនដី សម្លាប់មនុស្សដោយ ការកាប់សម្លាប់មួយដ៏ធំ ទាំងប្រុស ទាំងស្រី និងកូនក្មេង យកបានទីក្រុងជាច្រើន និងទីតាំងការពារជាច្រើនផង ។

២៨ ប៉ុន្តែកាលម៉ូរ៉ូណៃហាបានដឹងការនេះ លោកបានបញ្ជាឲ្យ

១៦ *ក* អាលម៉ា ៥២:៣.

លីហើយកទ័ពមួយកង វាយស្កាត់មុខពួកគេភ្លាម មុនពេលពួក
គេទៅ ដល់ដែនដីបរិបូរណ៍ ។
២៩ ម្ល៉ោះហើយ ទើបលោកធ្វើយ៉ាងនោះ; ហើយលោកបាន
ស្កាត់មុខពួកគេ មុនពេលពួកគេទៅដល់ដែនដីបរិបូរណ៍ ហើយ
ច្បាំង នឹងពួកគេ ដរាបដល់ធ្វើឲ្យពួកគេដកថយ ឆ្ពោះទៅកាន់
ដែនដីសារ៉ាហិមឡាវិញ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃហាបាន
ស្កាត់ផ្លូវដកថយរបស់ពួកគេ ហើយបានច្បាំងនឹងពួកគេ ដរាប
ដល់ក្លាយ ទៅជាការប្រយុទ្ធមួយដ៏ជោកជាំដោយឈាម; មែន
ហើយ មនុស្សជាច្រើនត្រូវស្លាប់ ហើយនៅក្នុងចំណោមអ្នក
ដែលត្រូវស្លាប់ទាំង ប៉ុន្មាននេះ នោះគេបានឃើញ[ក]គូរីអានទុមមើរផង ។
៣១ ហើយឥឡូវនេះ មើលចុះ ពួកលេមិនពុំអាចដកថយទៅ
ខាងណាបានទេ ទៅខាងជើងក៏ពុំបាន ទៅខាងត្បូងក៏ពុំបាន ទៅ
ខាង កើតក៏ពុំបាន ទៅខាងលិចក៏ពុំបាន ព្រោះពួកគេត្រូវព័ទ្ធ
គ្រប់ទិសដោយពួកនីហ្វៃ ។
៣២ ម្ល៉ោះហើយ គូរីអានទុមមើរបាននាំពួកលេមិនសម្រុកចូល
កណ្ដាលពួកនីហ្វៃ ដរាបដល់ធ្វើឲ្យពួកគេធ្លាក់ទៅក្រោមអំណាច
របស់ ពួកនីហ្វៃ ហើយរូបវាផ្ទាល់ត្រូវស្លាប់ ហើយពួកលេមិនបាន
ប្រគល់ខ្លួន ទៅក្នុងកណ្ដាប់ដៃនៃពួកនីហ្វៃ ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ូណៃហាយកបាន
ទីក្រុងសារ៉ាហិមឡាមកវិញ ហើយបានបញ្ជាឲ្យពួកលេមិន
ដែលត្រូវ ចាប់ជាឈ្លើយនោះ ត្រូវចាកចេញពីដែនដីដោយសេច
ក្ដីសុខសាន្ត ។
៣៤ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីសែសិបមួយក្នុងរជ្ជកាលនៃ
ពួកចៅក្រមទៅ ៕

## ជំពូកទី ២

*ហេលេមិន ជាកូននៃហេលេមិនក្លាយទៅជាមេចៅក្រម — កាឌីអានតុនដឹកនាំបក្សពួកគិសគូមេន — អ្នកបំរើរបស់ហេលេមិនសម្លាប់ គិសគូមេនចោល ហើយបក្សពួកកាឌីអានតុនរត់គេចចូលទៅក្នុងទីរហោស្ថាន ។ ប្រមាណជាឆ្នាំ ៥០–៤៩ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីសែសិបពីរក្នុងរជ្ជកាល
នៃពួកចៅក្រម ក្រោយពីម៉ូរ៉ូណៃហាបានកសាងសន្តិភាពឡើងវិញ
រវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន មើលចុះ គ្មាន
នរណាម្នាក់បំពេញវេទិកាជំនុំជំរះទេ; ហេតុដូច្នេះហើយ ក៏ចាប់ផ្ដើម
មាន ការទាស់ទែងគ្នាមួយទៀត នៅក្នុងចំណោមប្រជាជនថា
តើនរណាត្រូវបំពេញវេទិកាជំនុំជំរះ ។
២ ហើយហេតុការណ៍បានកើតឡើងថា ហេលេមិនដែលត្រូវ
ជាកូនរបស់ហេលេមិន ត្រូវបានតែងតាំងឡើង ឲ្យបំពេញវេទិកា
ជំនុំជំរះ ដោយសម្លេងរបស់ប្រជាជន ។
៣ ប៉ុន្តែមើលចុះ [ក]គិសគូមេន ជាអ្នកដែលធ្វើឃាតពេហូរ៉ាន
បានដេកចាំបំផ្លាញហេលេមិនដែរ; ហើយវាត្រូវបានគាំទ្រដោយ
បក្សពួករបស់វា ដែលបានចុះសេចក្ដីសញ្ញាមួយថា ពុំឲ្យ
នរណាម្នាក់ដឹងនូវអំពើទុច្ចរិតរបស់វាឡើយ ។
៤ ព្រោះមានតែ[ក]កាឌីអានតុនម្នាក់ ដែលជាមនុស្សប៉ិនប្រសប់
ខាងពាក្យសំដី និងខាងកលល្បិចផង ដើម្បីប្រព្រឹត្ត
កិច្ចការសម្ងាត់ នៃការឃាតកម្ម និងការប្លន់; ហេតុដូច្នេះហើយ
វាបានក្លាយទៅជាមេដឹកនាំបក្សពួករបស់គិសគូមេន ។
៥ ហេតុដូច្នេះហើយ វាបានបញ្ឆោរពួកគេ និង
គិសគូមេនផងថា បើសិនជាពួកគេដាក់វានៅក្នុងវេទិកាជំនុំជំរះ
នោះវានឹងអនុញ្ញាត ដល់ពួកអ្នកដែលនៅក្នុងបក្សពួកវាថា ពួក
គេនឹងត្រូវបានដាក់ឲ្យមានអានុភាព និងសិទ្ធិអំណាច នៅក្នុង
ចំណោមប្រជាជន; ហេតុដូច្នេះ ហើយ គិសគូមេនបាន
ស្វែងរកបំផ្លាញហេលេមិនចោល ។
៦ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែល
វាដើរឆ្ពោះទៅវេទិកាជំនុំជំរះ ដើម្បីបំផ្លាញហេលេមិន មើលចុះ
អ្នកបំរើម្នាក់ របស់ហេលេមិន ដោយចេញទៅក្រៅនៅពេលយប់
ហើយដោយបានក្លែងខ្លួន ក៏បានដឹងអំពីផែនការទាំងនោះ ដែល
បានគ្រោងទុក ដោយបក្សពួកនេះ ដើម្បីបំផ្លាញហេលេមិន ។
៧ ហើយហេតុការណ៍បានកើតឡើងថា គាត់បានជួបនឹង
គិសគូមេន ហើយគាត់បានធ្វើសញ្ញាមួយឲ្យវា; ហេតុដូច្នេះហើយ
ទើប គិសគូមេនឲ្យគាត់ដឹងនូវគោលដៅនៃបំណងរបស់វា ចង់ឲ្យ
គាត់នាំទៅឯវេទិកាជំនុំជំរះ ដើម្បីវាអាចធ្វើឃាតហេលេមិនបង់ ។
៨ ហើយកាលអ្នកបំរើរបស់ហេលេមិន បានដឹងចិត្តទាំងអស់
របស់គិសគូមេន ហើយដឹងថា បំណងរបស់វា គឺធ្វើឃាត
ហើយដឹង ដែរថា បំណងរបស់ពួកជនទាំងអស់ ដែលនៅក្នុង
បក្សពួករបស់វា គឺដើម្បីធ្វើឃាត និងដើម្បីប្លន់ និងដើម្បីបាន
អំណាច (ហើយនេះ គឺជា[ក]ផែនការសម្ងាត់របស់ពួកគេ និង

៣០ *ក* ហេលេ. ១:១៥.
**២** ៣ *ក* ហេលេ. ១:៩.
៤ *ក* ស.ប. ពួកចោរកាឌីអានតុន.
៨ *ក* ២ នីហ្វៃ ១០:១៥.
ស.ប. បក្សព័ន្ធសម្ងាត់.

ការរួមគំនិតរបស់ពួកគេ) នោះអ្នកបំរើរបស់ហេលេមិនបាននិយាយទៅកាន់គិសគូមេនថា៖ ចូរយើងទៅឯវេទិកាជំនុំជំរះ ។

៩ ឥឡូវនេះ ការនេះធ្វើឲ្យគិសគូមេនពេញចិត្តជាខ្លាំង ព្រោះវាបានគិតស្មានថា វានឹងសំរេចផែនការរបស់វាហើយ; ប៉ុន្តែមើលចុះ អ្នកបំរើរបស់ហេលេមិន នៅពេលពួកគេកំពុងតែដើរឆ្ពោះទៅឯវេទិកាជំនុំជំរះ បានចាក់គិសគូមេនត្រង់បេះដូង ធ្វើឲ្យវាដួលស្លាប់ដោយគ្មានបានស្រែកថ្ងូរឡើយ ។ ហើយគាត់បានរត់ទៅជំរាបហេលេមិននូវគ្រប់ការណ៍ទាំងអស់ ដែលគាត់បានឃើញ និងបានឮ និងបានធ្វើ ។

១០ ហើយហេតុការណ៍បានកើតឡើងថា ហេលេមិនបានចាត់ឲ្យទៅចាប់បក្សពួកចោរប្លន់ និងពួកឃាតកសម្ងាត់នេះ ដើម្បីអាច ប្រហារជីវិតពួកវាចោលតាមច្បាប់ ។

១១ ប៉ុន្តែមើលចុះ កាលកាឌីអានតុនបានដឹងថា គិសគូមេនមិនបានត្រឡប់មកវិញទេ នោះវាខ្លាចក្រែងវាត្រូវគេបំផ្លាញបង់; ហេតុដូច្នេះហើយ វាបានបញ្ជាឲ្យបក្សពួកវាមកតាមវា ។ ហើយពួកវាបានរត់ចេញទៅក្រៅដែនដី តាមផ្លូវសម្ងាត់មួយ ចូលទៅក្នុងទីរហោ ស្ថាន; ម្ល៉ោះហើយ ពេលហេលេមិនបានចាត់ឲ្យទៅចាប់ពួកវា ក៏មិនអាចរកពួកវាឃើញឡើយ ។

១២ ហើយកាឌីអានតុននេះនឹងត្រូវបាននិយាយដល់ទៀតនៅពេលក្រោយ ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីសែសិបពីរក្នុងរជ្ជកាលនៃពួក ចៅក្រម ទៅលើប្រជាជននីហ្វៃ ។

១៣ ហើយមើលចុះ នៅទីបញ្ចប់នៃគម្ពីរនេះ អ្នករាល់គ្នានឹងឃើញថា [ក]កាឌីអានតុននេះ គឺជាមូលហេតុនៃការរលំ មែនហើយ សឹងតែការបំផ្លិចបំផ្លាញទាំងស្រុងនៃប្រជាជននីហ្វៃ ។

១៤ មើលចុះ ពុំមែនខ្ញុំនិយាយថា ទីបញ្ចប់នៃគម្ពីរហេលេមិនទេ ប៉ុន្តែខ្ញុំចង់និយាយអំពីទីបញ្ចប់នៃគម្ពីរនីហ្វៃវិញ ដែលខ្ញុំបានយក ពីនោះ នូវដំណើររឿងទាំងអស់ ដែលខ្ញុំបានសរសេរមកនេះ ៕

## ជំពូកទី ៣

*ពួកសាសន៍នីហ្វៃជាច្រើនផ្លាស់ទីលំនៅទៅដែនដីខាងជើង — ពួកគេសង់ផ្ទះអំពីស៊ីម៉ងត៍ ហើយរក្សាបញ្ជីជាច្រើន — មនុស្សរាប់ម៉ឺន នាក់បានប្រែចិត្តជឿ ហើយបានទទួលបុណ្យជ្រមុជទឹក — ព្រះបន្ទូលនៃព្រះនាំ មនុស្សទៅកាន់សេចក្ដីសង្គ្រោះ — នីហ្វៃដែលត្រូវ ជាកូនរបស់ហេលេមិន បំពេញវេទិកាជំនុំជំរះ ។ ប្រមាណជាឆ្នាំ ៤៩–៣៩ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីសែសិបបីក្នុងរជ្ជកាលនៃពួកចៅក្រម គ្មានការទាស់ទែងគ្នា នៅក្នុងចំណោម ប្រជាជននីហ្វៃទេ លើកលែងតែការឆ្មើងឆ្មៃបន្តិចបន្តួចដែលមាននៅក្នុងសាសនាចក្រ ដែលបានធ្វើឲ្យមានការបែកបាក់គ្នាបន្តិចបន្តួច នៅក្នុងចំណោមប្រជាជន ការណ៍នេះត្រូវបានសម្រុះសម្រួល នៅចុងឆ្នាំទីសែសិបបី ។

២ ហើយគ្មានការទាស់ទែងគ្នា នៅក្នុងចំណោមប្រជាជន នៅក្នុងឆ្នាំទីសែសិបបួនទេ; ហើយក៏គ្មានការទាស់ទែងគ្នាអ្វីច្រើន នៅក្នុង ឆ្នាំទីសែសិបប្រាំដែរ ។

៣ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីសែសិបប្រាំមួយ មែនហើយ មានការទាស់ទែងគ្នាជាខ្លាំង និងការបែកបាក់គ្នាជាច្រើន; នៅក្នុងនោះ មានមនុស្សជាច្រើនហួសប្រមាណ ដែលបានចាកចេញពីដែនដីសារ៉ាហិមឡា ហើយបានទៅកាន់ដែនដី[ក]ខាងជើង ដើម្បីគ្រោងយកដែនដី ។

៤ ហើយពួកគេបានធ្វើដំណើរទៅយ៉ាងឆ្ងាយ ដរាបដល់ពួកគេទៅដល់[ក]ផ្ទៃទឹកធំៗ និងទន្លេជាច្រើន ។

៥ មែនហើយ ហើយពួកគេបានរាលទៅមុខ ទៅក្នុងគ្រប់ផ្នែកនៃដែនដី ចូលទៅក្នុងទីកន្លែងណា ដែលពុំត្រូវឆ្កា និងពុំត្រូវ កាប់អស់ដើមឈើ ព្រោះបណ្ដាជនជាច្រើន ដែលធ្លាប់បានមកនៅដែនដីនេះពីមុន ។

៦ ហើយឥឡូវនេះ គ្មានផ្នែកណានៃដែនដីនោះត្រូវគ្មានមនុស្សនៅឡើយ លើកលែងតែព្រៃឈើប៉ុណ្ណោះ; ប៉ុន្តែដោយមកពី[ក]ការបំផ្លិច បំផ្លាញដ៏ធំ នៃប្រជាជនដែលធ្លាប់បានមកនៅលើដីនេះពីមុន វាត្រូវបានហៅថា [ខ]ទីចោលស្ងាត់។

៧ ហើយនៅទីនោះ មានព្រៃឈើតែបន្តិចបន្តួចប៉ុណ្ណោះនៅលើផ្ទៃដីទោះជាយ៉ាងណាក៏ដោយ គង់តែប្រជាជនដែលមកនៅទីនេះបានក្លាយទៅជាអ្នកប៉ិនប្រសប់ជាខ្លាំងដែរ ក្នុងការប្រើស៊ីម៉ងត៍; ហេតុដូច្នេះហើយ ពួកគេបានសង់ផ្ទះទាំងឡាយពីស៊ីម៉ងត៍ ដែលគេ បានរស់នៅក្នុងនោះ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានកើនចំនួនហើយបានរាលដាលឡើង និងបានពង្រីកពីដីនៅខាងត្បូងទៅដែនដីខាងជើង ហើយវាតទីធំឡើង ដរាបដល់ពួកគេបានចាប់ផ្ដើម

១៣ *ក* ហេលេ. ៦:១៨; ៤ នីហ្វៃ ១:៤២.
**៣** ៣*ក* អាលម៉ា ៦៣:៤.
៤ *ក* ម៉ូសាយ ៨:៨; មរមន ៦:៤.
៦ *ក* ម៉ូសាយ ២១:២៥–២៧.
*ខ* អាលម៉ា ២២:៣១.

នៅពេញផ្ទៃដីទាំងមូល ចាប់ពីសមុទ្រខាងត្បូង ទៅដល់សមុទ្រ
ខាងជើង ចាប់ពី[ក]សមុទ្រខាងលិច ទៅដល់សមុទ្រខាងកើត ។
៩ ហើយប្រជាជនដែលនៅលើដែនដីផ្នែកខាងជើង បាន
រស់នៅក្នុងរោងត្រសាលទាំងឡាយ និងនៅក្នុងផ្ទះទាំងឡាយ
ដែលធ្វើពី ស៊ីម៉ងត៍ ហើយពួកគេទុកឲ្យឈើណាក៏ដោយ
ឲ្យតែដុះនៅលើផ្ទៃដីទុកឲ្យវាដុះធំឡើង ដើម្បីដល់ពេលណាមួយ
នោះពួកគេអាចមាន ឈើ ដើម្បីសង់ផ្ទះរបស់គេ មែនហើយ
ទីក្រុងទាំងឡាយរបស់គេ និងព្រះវិហារបរិសុទ្ធទាំងឡាយ និង
សាលាប្រជុំទាំងឡាយ និងទីបរិសុទ្ធទាំងឡាយ និងអស់
ទាំងអាគារគ្រប់បែបរបស់គេ ។
១០ ហើយហេតុការណ៍បានកើតឡើងថា ដោយមក
ពីឈើកម្រកបាន នៅលើដែនដីភាគខាងជើង នោះពួកគេបាន
បញ្ជូនឈើជា ច្រើន[ក]ទៅតាមផ្លូវទឹក ។
១១ ម្ល៉ោះហើយ ពួកគេបានបណ្ដាលឲ្យប្រជាជននៅលើដី
ខាងជើង អាចសង់ទីក្រុងជាច្រើន ដែលធ្វើពីឈើ និងស៊ីម៉ងត៍ ។
១២ ហើយហេតុការណ៍បានកើតឡើងថា មាន[ក]ប្រជាជនអាំម៉ូន
ជាច្រើន ដែលជាសាសន៍លេមិនពីកំណើត បានចូលទៅក្នុងដែន
ដីនេះដែរ ។
១៣ ហើយឥឡូវនេះ មានបញ្ជីជាច្រើន ដែលត្រូវបាន
កត់ទុកនូវដំណើរការអំពីប្រជាជននេះ ដោយប្រជាជននេះជាច្រើន
ជាពិសេស ហើយភាគច្រើនស្ដីអំពីពួកគេ ។
១៤ ប៉ុន្តែមើលចុះ មួយភាគរយនៃដំណើរការរបស់ប្រជាជននេះ
មែនហើយ គឺដំណើររឿងរបស់ពួកសាសន៍លេមិន និងពួក
សាសន៍នីហ្វៃ និងសង្គ្រាមទាំងឡាយរបស់ពួកគេ និងការទាស់ទែង
គ្នា និងការបែកបាក់ និងការផ្សាយរបស់គេ និងការព្យាករណ៍
របស់គេ និងការប្រើនាវារបស់គេ និងការសង់នាវារបស់គេ និង
ការសង់[ក]ព្រះវិហារបរិសុទ្ធទាំងឡាយរបស់គេ និងការសង់
សាលាប្រជុំ និងទីបរិសុទ្ធទាំងឡាយរបស់គេ និងសេចក្ដីសុចរិត
របស់គេ និងសេចក្ដីទុច្ចរិតរបស់គេ និងការឃាតកម្មរបស់គេ និង
ការលួចរបស់គេ និងការប្លន់របស់គេ និងការគួរខ្ពើមឆ្អើម និង
ការសហាយស្មន់គ្រប់បែបយ៉ាង ពុំអាចដាក់ក្នុងការសរសេរនេះ
បានអស់ឡើយ ។
១៥ ប៉ុន្តែមើលចុះ មានសៀវភៅជាច្រើន និងបញ្ជីជាច្រើនគ្រប់
បែបយ៉ាង ហើយវត្ថុទាំងនេះ ត្រូវបានកត់ទុកដោយពួកសាសន៍
នីហ្វៃប៉ុណ្ណោះ ។
១៦ ហើយវត្ថុទាំងនោះ ត្រូវបាន[ក]បន្តពីតំណមួយទៅតំណមួយ
ទៀត ដោយពួកសាសន៍នីហ្វៃ គឺរហូតដល់ពេលពួកគេធ្លាក់ទៅ
ក្នុង អំពើរំលង ហើយត្រូវបានធ្វើឃាតចោល ប្លន់ និងដេញចាប់
និងរុញច្រាន និងប្រហារ និងខ្ចាត់ព្រាត់លើផ្ទៃផែនដី និង
លាយឡំទៅជា មួយនឹងពួកសាសន៍លេមិន រហូតដល់ពួកគេ
[ខ]ឈប់បានហៅថា ពួកសាសន៍នីហ្វៃទៀត ដោយបានក្លាយទៅជា
ទុច្ចរិត ហើយព្រៃផ្សៃ និងកាចសាហាវ មែនហើយ គឺក្លាយ
ទៅជាពួកសាសន៍លេមិនផង ។
១៧ ហើយឥឡូវនេះ ខ្ញុំត្រឡប់មកឯដំណើររឿងរបស់ខ្ញុំវិញ;
ហេតុដូច្នេះហើយ អ្វីដែលខ្ញុំបាននិយាយមក បានកើតឡើង
បន្ទាប់ពី មានការទាស់ទែងគ្នាទាំងឡាយដ៏ធំ និងការរំជើប
រំជួល និងសង្គ្រាម និងការបែកបាក់ នៅក្នុងចំណោមប្រជាជន
នីហ្វៃ ។
១៨ ឆ្នាំទីសែសិបប្រាំមួយក្នុងរជ្ជកាលនៃពួកចៅក្រមក៏ចប់ទៅ;
១៩ ហើយហេតុការណ៍បានកើតឡើងថា នៅតែមានការ
ទាស់ទែងគ្នាដ៏ធំ នៅក្នុងដែនដី មែនហើយ គឺរហូតដល់
ឆ្នាំទីសែសិបប្រាំពីរ ហើយនៅក្នុងឆ្នាំទីសែសិបប្រាំបីផង ។
២០ ទោះជាយ៉ាងណាក៏ដោយ គង់តែហេលេមិនបានបំពេញ
វេទិកាជំនុំជំរះ ដោយយុត្តិធម៌ និងសមភាពដែរ; មែនហើយ
លោកបាន ប្រតិបត្តិតាមក្រិត្យក្រម និងសេចក្ដីយុត្តិធម៌ និង
ព្រះបញ្ញត្តិទាំងឡាយនៃព្រះ; ហើយលោកបានធ្វើនូវអ្វីៗ ដែល
ត្រឹមត្រូវនៅចំពោះព្រះ នេត្រនៃព្រះរហូត; ហើយលោកបាន
ដើរតាមផ្លូវទាំងឡាយរបស់ឪពុកលោក ដរាបដល់លោកបាន
ចំរើនឡើងនៅលើដែនដី ។
២១ ហើយហេតុការណ៍បានកើតឡើងថា លោកមានកូនប្រុស
ពីរនាក់ ។ លោកបានឲ្យឈ្មោះកូនច្បងថា [ក]នីហ្វៃ ហើយកូនពៅថា
[ខ]លីហៃ ។ ហើយពួកគេបានចាប់ផ្ដើមធំឡើង នៅក្នុងព្រះអម្ចាស់ ។
២២ ហើយហេតុការណ៍បានកើតឡើងថា សង្គ្រាម និងការ
ទាស់ទែងគ្នាទាំងឡាយ បានចាប់ផ្ដើមឈប់នៅក្នុងមួយកំរិតតូច
នៅក្នុង ចំណោមប្រជាជននៃសាសន៍នីហ្វៃ គឺនៅចុងឆ្នាំទីសែសិប
ប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

៨ *ក* អាលម៉ា ២២:២៧, ៣២.
១០ *ក* អាលម៉ា ៦៣:៥–៨.
១២ *ក* អាលម៉ា ២៧:២១–២៦.
១៤ *ក* ២ នីហ្វៃ ៥:១៦; យ៉ាកុប ១:១៧; ៣ នីហ្វៃ ១១:១.
១៦ *ក* ១ នីហ្វៃ ៥:១៦–១៩; អាលម៉ា ៣៧:៤.
*ខ* អាលម៉ា ៤៥:១២–១៤.
២១ *ក* ស.ប. នីហ្វៃ, កូនប្រុស របស់ហេលេមិន.
*ខ* ស.ប. លីហៃ, សាសនទូតសាសន៍ នីហ្វៃ.

២៣ ហើយហេតុការណ៍បានកើតឡើង គឺនៅឆ្នាំទីសែសិប
ប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម មានសន្តិភាពតរៀងមក ដែល
បាន បង្កើតឡើងនៅលើដែនដី លើកលែងតែបក្សព័ន្ធសម្ងាត់
ដែលចោរឈ្មោះ [ក]កាឌីអានតុនបានកសាងឡើង នៅតំបន់ទាំង
ឡាយដែល មានបណ្តាជនច្រើននៅក្នុងដែនដី នៅពេលនោះ
ឧបាយកលនេះ ពុំបានដឹងដល់អ្នក ដែលជាមេដឹកនាំរដ្ឋាភិបាលទេ;
ហេតុដូច្នេះហើយ ពួកគេពុំត្រូវបានបំផ្លាញឲ្យផុតពីដែនដីឡើយ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំដដែលនេះ
មានការចំរុងចំរើនយ៉ាងខ្លាំងហួសប្រមាណ នៅក្នុងសាសនាចក្រ
ដារបដល់មានមនុស្សរាប់ពាន់ បានចូលរួមក្នុងសាសនាចក្រ
ហើយបានទទួលបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្ត ។
២៥ ហើយការចំរុងចំរើននៃសាសនាចក្រ មានកិរិតធំណាស់
ហើយព្រះពរជាច្រើន ត្រូវបានចាក់ស្រោចទៅលើប្រជាជន ដែល
សូម្បីតែពួកសង្ឃជាន់ខ្ពស់ និងពួកគ្រូផ្ទាល់ក៏មានសេចក្តីអស្ចារ្យ
ហួសប្រមាណ ។
២៦ ហើយហេតុការណ៍បានកើតឡើងថា កិច្ចការនៃព្រះអម្ចាស់
បានចំរើនឡើង ក្នុងបុណ្យជ្រមុជទឹក ហើយបង្រួបបង្រួមមកក្នុង
សាសនាចក្រនៃព្រះ នូវមនុស្សជាច្រើន មែនហើយ គឺរាប់ម៉ឺននាក់។
២៧ ម្ល៉ោះហើយ យើងអាចឃើញថា ព្រះអម្ចាស់ទ្រង់
ប្រកបដោយសេចក្តីមេត្តាករុណា ដល់អស់អ្នកណាដែល
អំពាវនាវដល់ព្រះ នាមដ៏បរិសុទ្ធរបស់ទ្រង់ ដោយចិត្តស្មោះស ។
២៨ មែនហើយ ម្ល៉ោះហើយ យើងឃើញថា [ក]ក្លោងទ្វារនៃស្ថានសួគ៌
បានបើកចំហដល់មនុស្ស[ខ]ទាំងអស់ គឺដល់អស់អ្នកណាដែល
នឹងជឿដល់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ។
២៩ មែនហើយ យើងឃើញថា នរណាក៏ដោយដែលចង់បាន
នោះអាចបានទទួល[ក]ព្រះបន្ទូលនៃព្រះ ដែល[ខ]រស់ ហើយពូកែ ដែល
នឹង ផ្តាច់អស់ទាំងកលល្បិច និងអន្ទាក់ និងឧបាយរបស់អារក្សឲ្យ
ដាច់ពីគ្នា ហើយដឹកនាំអ្នកសំណាប់នៃព្រះគ្រីស្ទ ចូលទៅ
ក្នុងផ្លូវមួយដ៏[គ]តូច ហើយចង្អៀត ឆ្លងកាត់[ឃ]ជង្ហុកនៃសេចក្តីវេទនា
ដ៏អស់កល្បជានិច្ចនោះ ដែលត្រូវបានរៀបចំឡើង ដើម្បីកប់ពួក
ទុច្ចរិត —

៣០ ហើយដាក់ព្រលឹងរបស់គេ មែនហើយ ព្រលឹង
ដ៏អមតៈរបស់គេ [ក]នៅខាងស្តាំព្រះហស្តនៃព្រះ នៅក្នុងនគរ
ស្ថានសួគ៌ ដើម្បីអង្គុយ ជាមួយនឹងអ័ប្រាហាំ និងអ៊ីសាក និង
យ៉ាកុប និងជាមួយពួកអយ្យកោ ដ៏បរិសុទ្ធទាំងអស់របស់យើង
ដើម្បីកុំចេញពីទីនេះទៅទៀតឡើយ ។
៣១ ហើយនៅក្នុងឆ្នាំនេះ មានការអររីករាយតរៀងមក នៅ
ក្នុងដែនដីសារ៉ាហិមឡា និងនៅតាមតំបន់ជុំវិញទាំងអស់ គឺនៅលើ
ដែនដីទាំងអស់ ដែលយកបានដោយពួកសាសន៍នីហ្វៃ ។
៣២ ហើយហេតុការណ៍បានកើតឡើងថា មានសន្តិភាព
និងសេចក្តីអំណរដ៏លើសលប់ នៅក្នុងរយៈពេលដែលនៅសល់
ទាំងប៉ុន្មាន នៃឆ្នាំទីសែសិបប្រាំបួន; មែនហើយ ហើយមាន
សន្តិភាព និងសេចក្តីអំណរដ៏ធំតរៀងមក នៅឆ្នាំទីហាសិ
បក្នុងរជ្ជកាលនៃពួកចៅក្រម ដែរ ។
៣៣ ហើយនៅឆ្នាំទីហាសិបមួយក្នុងរជ្ជកាលនៃពួកចៅក្រម
ក៏មានសន្តិភាពដែរ លើកលែងតែការឆ្មើងឆ្មៃ ដែលបានចាប់ផ្តើម
ចូលទៅក្នុងសាសនាចក្រ — ពុំមែនទៅក្នុងសាសនាចក្រនៃ
ព្រះទេ ប៉ុន្តែទៅក្នុងចិត្តនៃប្រជាជន ដែលប្រកាសខ្លួនថា នៅក្នុង
សាសនាចក្រនៃព្រះប៉ុណ្ណោះ —
៣៤ ហើយពួកគេបានលើកខ្លួនឡើង [ក]ក្នុងការឆ្មើងឆ្មៃ
គឺដល់ទៅធ្វើការបៀតបៀនដល់បងប្អូនខ្លួនជាច្រើន ។ ឥឡូវនេះ
នេះគឺជាអំពើ អាក្រក់ដ៏ធំមួយ ដែលបណ្តាលឲ្យពួកប្រជាជន
ដែលសុភាពរាបសា ត្រូវរងការបៀតបៀនដ៏ធំទាំងឡាយ ហើយ
ត្រូវលុយកាត់សេចក្តី ទុក្ខវេទនាជាច្រើន ។
៣៥ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបាន[ក]តមអាហារ
ហើយបាន[ខ]អធិស្ឋានជាញឹកញាប់ដែរ ហើយបានមុតមាំខ្លាំង
ឡើងៗនៅក្នុង[គ]ភាពរាបសារបស់គេ ហើយបានរឹងប៉ឹងឡើងៗនៅ
ក្នុងសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ នាំឲ្យចិត្តគេបានពោរពេញទៅ
ដោយសេចក្តីអំណរ និងការលួងលោមចិត្ត មែនហើយ គឺរហូត
ដល់ធ្វើឲ្យចិត្តគេ[ឃ]បរិសុទ្ធ ហើយ[ង]ញែកចិត្តគេចេញជាបរិសុទ្ធ
រឹងការញែក ចិត្តចេញបរិសុទ្ធបានមក ដោយសារពួកគេបាន
[ច]ប្រគល់ចិត្តដល់ព្រះ ។

២៣ *ក* ហេលេ. ២:៤.
២៨ *ក* ២ នីហ្វៃ ៣១:៩, ១៧.
*ខ* កិច្ចការ ១០:២៨;
រ៉ូម ២:១០–១១.
២៩ *ក* ស.ប. ព្រះបន្ទូលនៃព្រះ.
*ខ* ហេព្រើរ ៤:១២;
គ. និង ស. ១១:២.
*គ* ២ នីហ្វៃ ៩:៤១; ៣៣:៩.
*ឃ* ១ នីហ្វៃ ១៥:២៨–៣០.
៣០ *ក* ម៉ាថាយ ២៥:៣៣–៣៤.
៣៤ *ក* ស.ប. សេចក្តីឆ្មើងឆ្មៃ.
៣៥ *ក* ស.ប. តម, តំណម.
*ខ* ស.ប. ការអធិស្ឋាន.
*គ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ឃ* ស.ប. សុទ្ធ, សុទ្ធសាធ.
*ង* ស.ប. ការញែកជាបរិសុទ្ធ.
*ច* ២ របា. ៣០:៨; ម៉ូសាយ ៣:១៩.

៣៦ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីហាសិបពីរបាន
ចប់ទៅ នៅក្នុងសន្តិភាពដែរ លើកលែងតែការឆ្មើងឆ្មៃដ៏ធំហួស
ប្រមាណ ដែលបានចូលទៅក្នុងចិត្តរបស់ប្រជាជន; ហើយនេះគឺមក
ពីសម្បត្តិទ្រព្យដ៏ច្រើនលើសលប់របស់គេ និងការចំរុងចំរើនរបស់គេ
នៅលើដែនដី ហើយវាបានដុះដល់គេជារៀងរាល់ថ្ងៃ ។
៣៧ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីហាសិប
បីក្នុងរជ្ជកាលនៃពួកចៅក្រម នោះហេលេមិនក៏ស្លាប់ទៅ ហើយ
នីហ្វៃ ដែលជាកូនច្បងរបស់លោក បានចាប់ផ្ដើមគ្រប់
គ្រងជំនួសលោក ។ ហើយហេតុការណ៍បានកើតឡើថា
លោកបានបំពេញវេទិកា ជំនុំជំរះ ដោយយុត្តិធម៌ និងសមភាព;
មែនហើយ លោកបានកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ
ហើយបានដើរនៅក្នុងផ្លូវទាំងឡាយ របស់ឪពុកលោក ៕

## ជំពូកទី ៤

*ពួកសាសន៍នីហ្វៃដែលបែកបាក់ និងពួកសាសន៍លេមិនរួមកម្លាំងគ្នា ហើយវាយយកដែនដីសារ៉ាហិមឡា — បរាជ័យរបស់សាសន៍ នីហ្វៃកើតឡើង ព្រោះតែសេចក្ដីទុច្ចរិតរបស់គេ — សាសនាចក្រចុះអន់ថយ ហើយប្រជាជនក្លាយទៅជាទន់ខ្សោយដូចពួកសាសន៍ លេមិន ។ ប្រមាណជាឆ្នាំ ៣៨–៣០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីហាសិបបួន
មានការបែកបាក់ជាច្រើន នៅក្នុងសាសនាចក្រ ហើយមានការ
ទាស់ទែងគ្នាដែរ នៅក្នុងចំណោមប្រជាជន ដរាបដល់មាន
ការខ្ចាយឈាមជាច្រើន ។
២ ហើយពួកដែលបះបោរ នោះត្រូវសម្លាប់ចោល ហើយត្រូវ
រុញច្រានឲ្យចេញពីដែនដី ហើយពួកគេបានទៅជួបនឹងស្ដេច
នៃ ពួកសាសន៍លេមិន ។
៣ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានខិតខំ
ចាក់រុកឲ្យពួកសាសន៍លេមិនមានសង្គ្រាមនឹងពួកសាសន៍នីហ្វៃ;
ប៉ុន្តែមើលចុះ ពួកសាសន៍លេមិនបានភិតភ័យជាខ្លាំង ដរាបដល់
ពួកគេពុំស្ដាប់តាមពាក្យរបស់ពួកជន ដែលបែកបាក់ទាំងនោះទេ ។
៤ ប៉ុន្តែហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីហាសិបប្រាំមួយ
ក្នុងរជ្ជកាលនៃពួកចៅក្រម មានពួកបែកបាក់ពីពួកសាសន៍នីហ្វៃ
បានឡើងចូលទៅខាងសាសន៍លេមិន; ហើយពួកគេជាមួយនឹង
ពួកដែលបែកបាក់ឯទៀតទាំងនោះ បានទទួលជោគជ័យក្នុង
ការចាក់រុក ពួកគេឲ្យមានកំហឹងនឹងពួកសាសន៍នីហ្វៃ; ហើយ
ក្នុងពេញមួយឆ្នាំនោះ ពួកគេរៀបចំធ្វើសង្គ្រាម ។
៥ ហើយនៅក្នុងឆ្នាំទីហាសិបប្រាំពីរ ពួកគេបានចុះមកច្បាំងនឹង
ពួកសាសន៍នីហ្វៃ ហើយពួកគេបានចាប់ផ្ដើមធ្វើការសម្លាប់; មែន
ហើយ ដរាបដល់នៅឆ្នាំទីហាសិបប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រម
ពួកគេបានសំរេចនូវជោគជ័យ ក្នុងការវាយយកបានដែនដីសារ៉ា
ហិមឡា; មែនហើយ ហើយដែនដីទាំងអស់ផង រហូតទៅទល់នឹង
ដែនដីដែលនៅជិតដែនដីបរិបូរណ៍ ។
៦ ហើយពួកសាសន៍នីហ្វៃ និងពលទ័ពរបស់ម៉ូរ៉ូណៃហា ត្រូវ
រុញច្រានទៅក្នុងដែនដីបរិបូរណ៍;
៧ ហើយនៅទីនោះ ពួកគេបានពង្រឹងកម្លាំងវាយតបតនឹងពួក
លេមិនវិញ ចាប់ពីសមុទ្រខាងលិច ទៅទល់ខាងកើត; គឺអស់រយៈ
ពេល មួយថ្ងៃ នៃការធ្វើដំណើរសំរាប់ជននីហ្វៃម្នាក់ នៅតាម
ខ្សែដែលពួកគេបានពង្រឹង ហើយដាក់ពលទ័ព ដើម្បីការពារ
ប្រទេសផ្នែកខាង ជើងរបស់គេ ។
៨ ម្ល៉ោះហើយ ពួកសាសន៍នីហ្វៃដែលបានបែកបាក់ទាំងនោះ
ដោយមានជំនួយពីកងទ័ពលេមិនដ៏ច្រើន ក៏យកបានទឹកដីទាំងអស់
របស់ពួកសាសន៍នីហ្វៃ ដែលនៅផ្នែកខាងត្បូង ។ ហើយការណ៍
ទាំងអស់នេះ ត្រូវបានធ្វើឡើង នៅឆ្នាំទីហាសិបប្រាំបីនិងប្រាំបួន
ក្នុងរជ្ជកាលនៃពួកចៅក្រម ។
៩ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីហុកសិបក្នុង
រជ្ជកាលនៃពួកចៅក្រម ម៉ូរ៉ូណៃហាបានសំរេចជោគជ័យ ជាមួយ
នឹង ពលទ័ពរបស់លោក នៅក្នុងការវាយយកបានភាគជាច្រើន
នៃដែនដី; មែនហើយ ពួកគេយកបានមកវិញ នូវទីក្រុងជាច្រើន
ដែលបាន ធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកសាសន៍លេមិនពីមុន ។
១០ ហើយហេតុការណ៍បានកើតឡើង គឺនៅឆ្នាំទីហុកសិប
មួយក្នុងរជ្ជកាលនៃពួកចៅក្រម ពួកគេបានសំរេចជោគជ័យ នៅ
ក្នុង ការយកបានវិញ ដល់ទៅពាក់កណ្ដាលនៃទឹកដីរបស់គេ ។
១១ ឥឡូវនេះ ការបាត់បង់របស់ពួកសាសន៍នីហ្វៃដ៏ធំនេះ និង
ការកាប់សម្លាប់ដ៏ធំ ដែលមាននៅក្នុងចំណោមពួកគេ ច្បាស់ជា
ពុំបានកើតឡើងទេ ប្រសិនបើគ្មានអំពើទុច្ចរិតរបស់ពួកគេ និងអំពើ
គួរខ្ពើមឆ្អើមរបស់ពួកគេ ដែលមានក្នុងចំណោមពួកគេ; មែន
ហើយ ហើយគឺនៅក្នុងចំណោម ពួកជនទាំងនោះផង ដែល
ប្រកាសថាខ្លួន នៅក្នុងសាសនាចក្រនៃព្រះ ។
១២ ហើយគឺដោយសារការឆ្មើងឆ្មៃនៃចិត្តរបស់គេ ដោយ

៣៦ *ក* ស.ប. ទ្រព្យសម្បត្តិ.
៤ ១*ក* ៣ នីហ្វៃ ១១:២៩.
៤ *ក* ហេលេ. ៥:១៧.
១២ *ក* អូបា. ១:៣–៤;
គ. និង ស. ១០១:៤២.

សារ[ខ]ទ្រព្យសម្បត្តិដ៏ច្រើនលើសលប់របស់គេ មែនហើយ គឺដោយ
សារការ ជិះជាន់ដល់[គ]ពួកអ្នកក្រីក្រ ដោយទុកចំណីអាហារ
មិនឲ្យដល់ពួកអ្នកអត់ឃ្លាន ទុកសំលៀកបំពាក់មិនឲ្យដល់ជន
អាក្រាត ហើយទះកំផ្លៀង បងប្អូនគេដែលសុភាពរាបសា
ចំអកឡកឡឺយដល់អ្វីៗដែលពិសិដ្ឋ បដិសេធវិញ្ញាណ
នៃការព្យាករណ៍ និងវិវរណៈ ធ្វើឃាតកម្ម ប្លន់ ភូតភរ លួច
ប្រព្រឹត្តអំពើកំផិត បំបះបំបោរឲ្យកើតការទាស់ទែងគ្នាដ៏ធំ
ហើយបោះបង់ចោលដែនដី ទៅកាន់ដែនដីនីហ្វៃ ក្នុងចំណោម
ពួកសាសន៍លេមិន ។
១៣ ហើយដោយសារអំពើទុច្ចរិតដ៏ធំរបស់គេនេះ និង
[ក]ការអួតអាងរបស់គេ នៅក្នុងកម្លាំងផ្ទាល់របស់គេ នោះពួកគេ
ត្រូវបានទុកឲ្យ ប្រើកម្លាំងរបស់គេផ្ទាល់; ហេតុដូច្នេះហើយ ពួក
គេពុំបានចំរើនឡើងទេ តែត្រូវរងទុក្ខវេទនា ហើយត្រូវវាយ
ហើយត្រូវរុញច្រានដោយ ពួកសាសន៍លេមិន រហូតដល់ពួកគេ
បាត់បង់ដែនដី សឹងតែទាំងអស់របស់គេទៅ ។
១៤ ប៉ុន្តែមើលចុះ មរ៉ូណៃហាបានផ្សាយពីការណ៍ជាច្រើន
ដល់ប្រជាជន ដោយព្រោះអំពើទុច្ចរិតរបស់គេ ហើយ[ក]នីហ្វៃ និង
លីហៃផង គឺជាកូនរបស់ហេលេមិន បានផ្សាយពីការណ៍ជាច្រើន
ដល់ប្រជាជន មែនហើយ ហើយបានព្យាករពីការណ៍ជាច្រើន
ដល់ពួកគេ អំពីអំពើ ទុច្ចរិតទាំងឡាយរបស់គេ និងអំពីអ្វីៗដែល
នឹងកើតមានដល់គេ បើសិនជាពួកគេពុំប្រែចិត្តពីអំពើបាបទាំង
ឡាយរបស់គេទេ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រែចិត្ត
ហើយដរាបណាពួកគេបានប្រែចិត្ត នោះពួកគេបាន
ចាប់ផ្ដើមចំរើនឡើង ។
១៦ ព្រោះកាលមរ៉ូណៃហាបានឃើញថា ពួកគេបានប្រែចិត្ត
នោះលោកមានចិត្តក្លាហាននាំពួកគេ ពីកន្លែងមួយទៅកន្លែងមួយ
និងពី ទីក្រុងមួយទៅទីក្រុងមួយ គឺរហូតដល់ពួកគេយកបាន
មកវិញ ពាក់កណ្ដាលនៃទ្រព្យរបស់គេ និងពាក់កណ្ដាលនៃដែនដី
របស់គេទាំងអស់ ។
១៧ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីហុកសិបមួយក្នុងរជ្ជកាលនៃ
ពួកចៅក្រមទៅ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីហុកសិបពី
រក្នុងរជ្ជកាលនៃពួកចៅក្រម នោះមរ៉ូណៃហាពុំអាចយកដី ពីពួក
សាសន៍លេមិនបានទៀតទេ ។
១៩ ហេតុដូច្នេះហើយ ពួកគេបានបោះបង់ចោលគំរោងការ
របស់គេ ដើម្បីយកដែនដី ដែលនៅសល់ទាំងប៉ុន្មាន ព្រោះពួក
លេមិន មានគ្នាច្រើនណាស់ ដែលជាហេតុនាំឲ្យគ្មានលទ្ធភាព
ឲ្យពួកសាសន៍នីហ្វៃយកឈ្នះលើពួកគេបានឡើយ; ហេតុ
ដូច្នេះហើយ មរ៉ូណៃហាបានប្រើពលទ័ពរបស់លោកទាំងអស់
ក្នុងការរក្សាផ្នែកនៃដីទាំងឡាយ ដែលលោកយកបាន ។
២០ ហើយហេតុការណ៍បានកើតឡើងថា ដោយព្រោះ
ទ័ពលេមិនមានចំនួនច្រើនពេក ទើបពួកសាសន៍នីហ្វៃមានការ
ភិតភ័យ ជាខ្លាំង ខ្លាចក្រែងត្រូវចាញ់កម្លាំង ហើយត្រូវជាន់ឈ្លី
ហើយត្រូវសម្លាប់ ហើយត្រូវបំផ្លាញចោល ។
២១ មែនហើយ ពួកគេបានចាប់ផ្ដើមនឹកឃើញដល់ពាក្យ
ព្យាករណ៍ទាំងឡាយនៃអាលម៉ា និងពាក្យសំដីនៃហ្លូងម៉ូសាយ
ផង; ហើយ ពួកគេបានឃើញថា ពួកគេជាមនុស្សរឹងទទឹង ហើយ
ថា ពួកគេបានបោះបង់ចោលព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។
២២ ហើយថា ពួកគេបានកែប្រែ ហើយជាន់ឈ្លីនៅក្រោមជើងគេ
[ក]នូវក្រិត្យវិន័យទាំងឡាយនៃហ្លូងម៉ូសាយ ឬក្រិត្យវិន័យដែលព្រះ
អម្ចាស់ទ្រង់បានបញ្ជាលោក ឲ្យយកមកប្រទានដល់មនុស្ស;
ហើយពួកគេឃើញថា ក្រិត្យវិន័យរបស់គេ បានក្លាយទៅជា
ពុករលួយ ហើយថា ពួកគេបានក្លាយទៅជាប្រជាជនទុច្ចរិត
ដរាបដល់ថា ពួកគេទុច្ចរិតស្មើនឹងពួកសាសន៍លេមិន ។
២៣ ហើយដោយព្រោះអំពើទុច្ចរិតរបស់គេ នោះសាសនា
ចក្របានចាប់ផ្ដើម[ក]ចុះអន់ថយ; ហើយពួកគេបានចាប់ផ្ដើមមិនជឿ
វិញ្ញាណនៃការព្យាករណ៍ និងវិញ្ញាណនៃវិវរណៈ; ហើយសេចក្ដី
ជំនុំជំរះទាំងឡាយនៃព្រះ បានសម្លឹងមើលគេចំពីមុខ ។
២៤ ហើយពួកគេបានឃើញថា ពួកគេបានក្លាយទៅជាមនុស្ស
[ក]ទន់ខ្សោយ ដូចជាបងប្អូនរបស់គេ គឺពួកសាសន៍លេមិន ហើយ
ថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ ឈប់រក្សាគេ[ខ]ទៀតហើយ; មែន
ហើយ ទ្រង់បានដកថយចេញពីពួកគេ ពីព្រោះព្រះវិញ្ញាណនៃព្រះ
អម្ចាស់ ពុំគង់នៅក្នុងព្រះវិហារណាដែល[គ]ឥតបរិសុទ្ធឡើយ ។
២៥ ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់បានឈប់ថែរក្សាពួក
គេ ដោយព្រះចេស្ដារបស់ទ្រង់ដ៏អស្ចារ្យ និងដ៏ឥតប្រៀបផ្ទឹមបាន

១២ ខ ១ ធីម៉ូ. ៦:១៧; ២ នីហ្វៃ ៩:៤២.
គ គ. និង ស. ៤២:៣០–៣១.
១៣ ក ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១៤ ក ហេលេ. ៣:២១.
២២ ក អាលម៉ា ១:១.
២៣ ក ស.ប. សេចក្ដីក្បត់សាសនា.
២៤ ក ម៉ូសាយ ១:១៣.
ខ ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
គ ម៉ូសាយ ២:៣៧;
អាលម៉ា ៧:២១; ៣៤:៣៦.

ព្រោះ ពួកគេបានធ្លាក់ទៅក្នុងស្ថានភាពឥតជំនឿ និងទុច្ចរិតដ៏គួរស្ញែងខ្លាច; ហើយពួកគេបានឃើញថា ពួកសាសន៍លេមិនមានចំនួនច្រើន លើសលប់ជាងពួកគេ ហើយលើកលែងតែពួកគេស្រវាតោងព្រះអម្ចាស់ ជាព្រះរបស់គេ បើពុំនោះសោតទេ នោះពួកគេត្រូវវិនាស ដោយចៀសមិនផុតជាមិនខានឡើយ ។

២៦ ត្បិតមើលចុះ ពួកគេបានឃើញថា កម្លាំងរបស់ទ័ពលេមិនខ្លាំងស្មើនឹងកម្លាំងគេដែរ គឺរាប់ម្នាក់ទល់នឹងម្នាក់; ម្ល៉ោះហើយពួកគេបានធ្លាក់ទៅក្នុងអំពើរំលងដ៏ធំ; មែនហើយ ពួកគេបានក្លាយទៅជាមនុស្សទន់ខ្សោយ ដោយព្រោះអំពើរំលងរបស់គេ អស់រយៈពេលពុំច្រើនឆ្នាំប៉ុន្មានទេ ៕

---

## ជំពូកទី ៥

*នីហ្វៃ និងលីហៃប្រគល់ខ្លួនចំពោះការផ្សាយ — ឈ្មោះរបស់គេរំឭកគេឲ្យរស់នៅតាមគំរូរបស់ពួកអយ្យកោគេ — ព្រះគ្រីស្ទ ប្រោសលោះអស់អ្នកណាដែលប្រែចិត្ត — នីហ្វៃ និងលីហៃនាំមនុស្សជាច្រើនឲ្យប្រែចិត្តជឿ ហើយត្រូវជាប់គុក ហើយភ្លើងព័ទ្ធជុំ វិញពួកគេ — ពពកនៃសេចក្ដីងងឹតមួយគ្របពីលើមនុស្សបីរយនាក់ — ផែនដីរញ្ជួល ហើយសម្លេងមួយបញ្ជាមនុស្សឲ្យប្រែចិត្ត — នីហ្វៃ និងលីហៃសន្ទនាជាមួយនឹងពួកទេវតា ហើយក្រុមមនុស្ស ត្រូវឡោមព័ទ្ធជុំវិញដោយភ្លើង ។ ប្រមាណជាឆ្នាំ ៣០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំដដែលនេះ មើលចុះ នីហ្វៃបានប្រគល់វេទិកាជំនុំជំរះឲ្យបុរសម្នាក់ ដែលមាន ឈ្មោះថា សេស្សូរាំ ។

២ ព្រោះដោយក្រិត្យវិន័យទាំងឡាយរបស់គេ និងរដ្ឋាភិបាលរបស់គេ ត្រូវបានបង្កើតឡើង ដោយសម្លេងរបស់ប្រជាជន ហើយពួក ជនដែលរើសការអាក្រក់ មានច្រើនជាងពួកជនដែលរើសការល្អ ហេតុដូច្នេះហើយ ពួកគេទុំល្មមសំរាប់ការបំផ្លិចបំផ្លាញហើយ ព្រោះក្រិត្យវិន័យទាំងឡាយ បានក្លាយទៅជាពុករលួយ ។

៣ មែនហើយ ហើយនេះពុំទាន់អស់ទេ; ពួកគេជាប្រជាជនមួយដ៏រឹងទទឹង ដរាបដល់ពួកគេពុំអាចអភិបាល ដោយក្រិត្យវិន័យ ឬសេចក្ដីយុត្តិធម៌បានឡើយ លើកលែងតែដោយការបំផ្លិចបំផ្លាញប៉ុណ្ណោះ ។

៤ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃបានក្លាយទៅជាទន់ខ្សោយ ដោយព្រោះអំពើទុច្ចរិតរបស់ពួកគេ; ហើយលោកបានប្រគល់វេទិកាជំនុំជំរះ ហើយស្ម័គ្រចិត្តទៅផ្សាយព្រះបន្ទូលនៃព្រះនៅថ្ងៃដែលនៅសល់ទាំងប៉ុន្មានរបស់លោក ហើយប្អូនរបស់លោក គឺលីហៃ ក៏ទៅផ្សាយនៅថ្ងៃដែលនៅសល់ទាំងប៉ុន្មានរបស់លោកដែរ;

៥ ព្រោះពួកគេបាននឹកចាំដល់ពាក្យទាំងឡាយ ដែលហេលេមិន គឺជាឪពុកបានពោលទៅគេ; ហើយនេះជាពាក្យដែលលោកបាន និយាយថា៖

៦ មើលចុះ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ឪពុកមានបំណងចង់ឲ្យកូនចាំ ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយឪពុកចង់ឲ្យកូនប្រកាសដល់ប្រជាជន នូវពាក្យទាំងនេះ ។ មើលចុះ ឪពុកបានដាក់ឈ្មោះឲ្យកូន តាមឈ្មោះពួកឪពុកដើមរបស់យើង ដែលបានចេញមកពីដែនដីយេរូសាឡិម; ហើយឪពុកបានធ្វើយ៉ាងនេះ ដើម្បីកាលណាកូនចាំឈ្មោះរបស់កូន នោះកូនអាចនឹកចាំដល់ពួកគេ; ហើយកាលណាកូននឹកចាំដល់ពួកគេ នោះកូនអាចនឹកចាំដល់កិច្ចការទាំងឡាយរបស់គេ; ហើយកាលណា កូននឹកចាំដល់កិច្ចការទាំងឡាយរបស់ពួកគេ នោះកូនអាចដឹងនូវហេតុ ដែលបាននិយាយ ហើយបានសរសេរទុកមកផងថាជាការល្អ ។

៧ ហេតុដូច្នេះហើយ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ឪពុកចង់ឲ្យកូនធ្វើនូវអ្វីៗ ដែលជាការល្អ ដើម្បីឲ្យត្រូវបាននិយាយអំពីកូន ហើយបានសរសេរទុក ដូចជាត្រូវបាននិយាយ ហើយបានសរសេរអំពីពួកគេដែរ ។

៨ ហើយឥឡូវនេះ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ មើលចុះ ឪពុកមានការខ្លះទៀតដែលចង់ឲ្យកូនធ្វើ ឯបំណងនោះគឺថាកូន មិនត្រូវធ្វើការណ៍ទាំងនេះ ដើម្បីកូនអាចអួតអាងទេ ប៉ុន្តែគឺកូនធ្វើការណ៍ទាំងនេះ ដើម្បីរៀបចំសំរាប់ខ្លួន នូវទ្រព្យសម្បត្តិមួយនៅលើ ស្ថានសួគ៌ មែនហើយ ដែលនៅអស់កល្បជានិច្ច ហើយដែលមិនសាបសូន្យទៅឡើយ; មែនហើយ ដើម្បីកូនអាចមានអំណោយទាន ដ៏វិសេស

---

២៥ *ក* ស.ប. ការឥតជំនឿ.
*ខ* យ៉ាកុប ៦:៥.
២៦ *ក* អាលម៉ា ៤៦:៨;
ហេលេ. ១២:៣–៤.

**៥** ១ *ក* ហេលេ. ៣:៣៧.
២ *ក* ម៉ូសាយ ២៩:២៥–២៧.
*ខ* អាលម៉ា ១០:១៩.
៤ *ក* អាលម៉ា ៤:១៥–២០.

៦ *ក* ១ នីហ្វៃ ១:១, ៥.
*ខ* ២ នីហៃ ៣៣.
៨ *ក* ៣ នីហ្វៃ ១៣:១៩–២១.
*ខ* គ. និង ស. ១៤:៧.

នៃជីវិតដ៏នៅអស់កល្បជានិច្ច ដែលយើងមានហេតុផលជឿថា ត្រូវបានឲ្យទៅពួកអយ្យកោរបស់យើង ។

៩ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ចូរចងចាំ ចូរចងចាំនូវពាក្យទាំងឡាយ ដែលស្ដេចបេនយ៉ាមីនបានមានបន្ទូលទៅ កាន់ប្រជាជនរបស់ទ្រង់; មែនហើយ ចូរចងចាំថា គ្មានផ្លូវ ឬមធ្យោបាយផ្សេងទៀត ដែលធ្វើឲ្យមនុស្សបានសង្គ្រោះឡើយ មានតែតាមរយៈព្រះលោហិតដែលធ្វើឲ្យធួននៃព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ដែលនឹងយាងមក; មែនហើយ ចូរចងចាំថា ទ្រង់នឹងយាងមកប្រោសលោះមនុស្សលោក ។

១០ ហើយចូរចងចាំដែរ នូវពាក្យទាំងឡាយ ដែលអាមូលេកបានពោលទៅកាន់ស៊ីអែសរ៉ុម នៅក្នុងទីក្រុងអាំម៉ូណៃហា ;ព្រោះលោកបាននិយាយទៅគាត់ថា ព្រះអម្ចាស់ទ្រង់ប្រាកដជានឹងយាងមកប្រោសលោះរាស្ត្រទ្រង់ ប៉ុន្តែថា ទ្រង់នឹងមិនយាងមកប្រោស លោះពួកគេក្នុងអំពើបាបទាំងឡាយរបស់ពួកគេទេ ប៉ុន្តែមកប្រោសលោះពួកគេពីអំពើបាបរបស់គេវិញ ។

១១ ហើយទ្រង់មានព្រះចេស្ដា ដែលព្រះវរបិតាបានប្រទានដល់ទ្រង់ ដើម្បីប្រោសលោះពួកគេ ពីអំពើបាបរបស់គេ ដោយមក ពីការប្រែចិត្ត; ហេតុដូច្នេះហើយ ទ្រង់បានចាត់ឲ្យពួកទេវតារបស់ទ្រង់ មកប្រកាសដំណឹងល្អអំពីលក្ខខ័ណ្ឌទាំងឡាយនៃការប្រែចិត្ត ដែលនាំទៅកាន់ព្រះចេស្ដានៃព្រះដ៏ប្រោសលោះឲ្យបានដល់សេចក្ដីសង្គ្រោះព្រលឹងរបស់គេ ។

១២ ហើយឥឡូវនេះ ឱកូនប្រុសទាំងឡាយរបស់ឪពុកអើយ ចូរចងចាំចុះ ចូរចងចាំចុះថា គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃ យើង គឺព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវសង់គ្រឹះរបស់កូន; ដើម្បីកាលណាអារក្សបញ្ចេញខ្យល់ដ៏ខ្លាំងក្លារបស់វាមក មែនហើយ ព្រួញរបស់វានៅក្នុងខ្យល់គួច មែនហើយ កាលណាព្រិល និងខ្យល់ព្យុះកំណាចទាំងអស់របស់វាបោកបក់មកលើកូន នោះវា នឹងគ្មានអំណាចមកលើកូនឡើយ ដើម្បីទាញកូនចុះទៅក្នុងជង្ហុកនៃសេចក្ដីវេទនា និងទុក្ខលំបាកដ៏មិនចេះចប់មិនចេះហើយ ពីព្រោះមក ពីសិលាដែលកូនបានសង់នៅលើនោះ ដែលជាគ្រឹះដ៏ខ្ជាប់ខ្ជួនមួយ ជាគ្រឹះមួយបើសិនណាមនុស្សសង់នៅលើនោះ នោះពួកគេមិនអាច រលំបានឡើយ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា នេះគឺជាពាក្យទាំងឡាយដែលហេលេមិន បានបង្រៀនកូនប្រុសទាំងឡាយរបស់លោក; មែនហើយ លោកបានបង្រៀនពួកគេនូវការណ៍ជាច្រើនទៀត ដែលពុំបានសរសេរទុក ហើយការណ៍ជាច្រើនផងដែរ ដែលត្រូវបាន សរសេរទុក ។

១៤ ហើយពួកគេបានចាំពាក្យសំដីរបស់លោក; ហេតុដូច្នេះហើយ ទើបពួកគេបានចេញទៅ ដោយកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃ ព្រះ ដើម្បីទៅបង្រៀនព្រះបន្ទូលនៃព្រះ នៅក្នុងចំណោមប្រជាជននីហ្វៃទាំងអស់ ចាប់ពីទីក្រុងបរិបូរណ៍;

១៥ ហើយចាប់ពីទីនោះ ឆ្ពោះទៅទីក្រុងគីឌ ហើយចាប់ពីទីក្រុងគីឌទៅទីក្រុងមូលេក;

១៦ ហើយពីទីក្រុងមួយ ទៅទីក្រុងមួយទៀត រហូតដល់ពួកគេបានទៅក្នុងចំណោមប្រជាជននីហ្វៃទាំងអស់ ដែលនៅក្នុងដែនដីខាង ត្បូង; ហើយចាប់ពីទីនោះ ទៅក្នុងដែនដីសារ៉ាហិមឡា នៅក្នុងចំណោមពួកសាសន៍លេមិន ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានផ្សាយដោយអំណាចដ៏ធំ ដរាបដល់ពួកគេបានធ្វើឲ្យពួកអ្នក ដែលបែកបាក់ទាំង ឡាយជ្រប់មុខ ដែលបានបែកចេញទៅពីពួកសាសន៍នីហ្វៃ ដរាបដល់ពួកគេបានចេញមក ហើយបានទទួលសារភាពនូវអំពើបាបទាំង ឡាយរបស់គេ ហើយបានទទួលបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្ត ហើយបានត្រឡប់មកខាងពួកសាសន៍នីហ្វៃវិញភ្លាម ដើម្បីខិតខំ កែប្រែនូវការខុសឆ្គងទាំងឡាយ ដែលពួកគេបានប្រព្រឹត្តមក ។

១៨ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃ និងលីហៃបានផ្សាយដល់ពួកសាសន៍លេមិន ដោយអានុភាព និងសិទ្ធិអំណាចដ៏ខ្លាំង ព្រោះពួកគេមានអានុភាព និងសិទ្ធិអំណាច ដែលបានប្រទានដល់គេ ដើម្បីឲ្យគេអាចនិយាយ ហើយពួកគេក៏មានដែរនូវអ្វីៗដែលពួក គេត្រូវនិយាយដែលបានប្រទានដល់គេ ។

១៩ ហេតុដូច្នេះហើយ ពួកគេបាននិយាយ ដែលធ្វើឲ្យមាន

៩ *ក* ម៉ូសាយ ២:៩.
*ខ* ម៉ូសាយ ៣:១៧–១៨.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ឃ* ស.ប. ពិភពលោក — មនុស្សដែលមិនគោរពតាមព្រះបញ្ញត្តិ.
១០ *ក* អាលម៉ា ១១:៣៤.
១១ *ក* អាលម៉ា ១៣:២៤–២៥.
១២ *ក* ម៉ាថាយ ៧:២៤–២៧;
គ. និង ស. ៦:៣៤; ម៉ូសេ ៧:៥៣.
ស.ប. ថ្មជ្រុង; ថ្ម.
*ខ* អេសាយ ២៨:១៦; យ៉ាកុប ៤:១៦.
*គ* ៣ នីហ្វៃ ១៤:២៥, ២៧.
១៣ *ក* ម៉ូសាយ ១:៤.
១៧ *ក* ហេលេ. ៤:៤.
១៨ *ក* គ. និង ស. ១០០:៥–៨.
ស.ប. ការព្យាករណ៍, ព្យាករ.

សេចក្ដីអស្ចារ្យដល់ពួកសាសន៍លេមិនជាខ្លាំង [ក]ក្នុងការបរិវត្តន៍
ពួកគេ ដរាបដល់មានសាសន៍លេមិនប្រាំបីពាន់នាក់ ដែលនៅក្នុង
ដែនដីសារ៉ាហិមឡា និងនៅព័ទ្ធជុំវិញនោះ បានទទួលបុណ្យ
ជ្រមុជទឹក ចំពោះការប្រែចិត្ត ហើយត្រូវបានបរិវត្តអំពីសេច
ក្ដីទុច្ចរិតនៃសណ្ដាប់ទាំងឡាយ នៃពួកអយ្យកោរបស់គេ ។
២០ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃ និងលីហៃបាន
បន្តពីនោះទៅកាន់ដែនដីនីហ្វៃ ។
២១ ហើយហេតុការណ៍បានកើតឡើងថា ពួកគេត្រូវបាន
ចាប់ដោយកងទ័ពលេមិនមួយកង ហើយត្រូវបានដា[ក]គុក; មែន
ហើយ គឺជាគុកដដែល ដែលអាំម៉ូន និងបងប្អូនរបស់លោកត្រូវ
បានដាក់ក្នុងនោះ ដោយពួកអ្នកបំរើរបស់លិមហៃ ។
២២ ហើយបន្ទាប់ពីពួកគេត្រូវបានដាក់គុក ដោយអត់អាហារ
អស់រយៈជាច្រើនថ្ងៃមក មើលចុះ ពួកវាបានចូលមកចាប់ពួកគេ
នៅក្នុងគុក ដើម្បីពួកវាអាចសម្លាប់ពួកគេចោល ។
២៣ ហើយហេតុការណ៍បានកើតឡើយថា នីហ្វៃ និងលីហៃ
ត្រូវបានហ៊ុំព័ទ្ធជុំវិញ ហាក់បីដូចជា[ក]ភ្លើង គឺដរាបដល់ធ្វើឲ្យពួកវា
មិនហ៊ាន យកដៃទៅពាល់ពួកគេឡើយ ព្រោះខ្លាចក្រែងភ្លើងឆេះ ។
ទោះជាយ៉ាងណាក៏ដោយ គង់តែនីហ្វៃ និងលីហៃពុំត្រូវឆេះដែរ;
ហើយ ពួកគេកំពុងតែឈរនៅកណ្ដាលភ្លើង ហើយពុំត្រូវ
ឆេះសោះ ។
២៤ ហើយកាលពួកគេបានឃើញថា ពួកគេត្រូវបានហ៊ុំព័ទ្ធ
[ក]ដោយបង្គោលភ្លើងមួយ ហើយថា វាពុំធ្វើឲ្យគេឆេះសោះ នោះ
ពួកគេ មានចិត្តក្លាហានឡើង ។
២៥ ព្រោះពួកគេបានឃើញថា ទ័ពលេមិនពុំហ៊ានយកដៃមក
ពាល់ពួកគេឡើយ ហើយគេក៏មិនហ៊ានមកជិតពួកគេដែរ តែ
ឈរហាក់ ដូចជាពួកវាត្រូវធ្វើឲ្យគ ដោយការភ្ញាក់ផ្អើល ។
២៦ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃ និងលីហៃ
បានឈរឡើង ហើយបានចាប់ផ្ដើមនិយាយទៅកាន់ពួកគេថា៖
ចូរកុំខ្លាចអី ត្បិតមើលចុះ នេះគឺជាព្រះទេតើ ដែលបានបង្ហាញ
ដល់ពួកអ្នក នូវការណ៍ដ៏អស្ចារ្យនេះ ដែលសម្ដែងឲ្យអ្នក
ឃើញថា អ្នកមិនអាចដាក់ដៃ មកលើយើងបានឡើយ ។
២៧ ហើយមើលចុះ កាលពួកគេបាននិយាយពាក្យទាំងនេះហើយ
នោះផែនដីរញ្ជួយជាខ្លាំង ហើយជញ្ជាំងគុករញ្ជួយ ហាក់បីដូចជា
ជិតរលំទៅដី; ប៉ុន្តែមើលចុះ វាមិនរលំចុះទេ ។ ហើយមើលចុះ
ពួកអ្នកដែលនៅក្នុងគុក គឺសាសន៍លេមិន និងសាសន៍នីហ្វៃ ជា
ពួក អ្នកដែលបានបែកបាក់ចេញ ។
២៨ ហើយហេតុការណ៍បានកើតឡើងថា ពួកវាត្រូវបាន
គ្របដោយពពកនៃ[ក]សេចក្ដីងងឹតមួយ ហើយការស្ញែងខ្លាចដ៏ខ្លាំង
មួយ បានកើតឡើងដល់ពួកវា ។
២៩ ហើយហេតុការណ៍បានកើតឡើងថា មាន[ក]សម្លេង
មួយបន្លឺឡើង ហាក់បីដូចជានៅលើពពកនៃសេចក្ដីងងឹតនោះថា៖
ចូរអ្នករាល់ គ្នាប្រែចិត្តចុះ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយចូរកុំ
ស្វែងរកបំផ្លាញពួកអ្នកបំរើរបស់យើង ដែលយើងបានបញ្ជូនឲ្យ
មករកអ្នក ដើម្បី ប្រកាសដំណឹងល្អនោះឡើយ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា កាលពួកវាបាន
ឮសម្លេងនេះ ហើយបានឃើញថា នោះពុំមែនជាសូរផ្គរលាន់ទេ
ហើយ ក៏ពុំមែនជាសម្លេងអឺងកងដែរ ប៉ុន្តែមើលចុះ នោះគឺជា
សម្លេង[ក]រហៀងៗ នៃភាពស្រទន់ឥតខ្ចោះ ហាក់បីដូចជាពាក្យ
ខ្សឹប ហើយវាបាន ចាក់ទំលុះទៅដល់ទាំងព្រលឹង —
៣១ ហើយទោះជាសម្លេងនោះមានភាពស្រទន់ក្ដី មើលចុះ
ផែនដីបានរញ្ជួយជាខ្លាំងហួសប្រមាណ ហើយជញ្ជាំងគុក
ក៏ញ័រជាថ្មី ទៀត ហាក់បីដូចវាជិតរលំទៅលើដី; ហើយមើលចុះ
ពពកនៃសេចក្ដីងងឹត ដែលបានគ្របលើពួកគេនោះ ពុំបាន
បែកខ្ញែកទៅទេ —
៣២ ហើយមើលចុះ សម្លេងនោះបន្លឺឡើងទៀតថា៖ ចូរអ្នក
រាល់គ្នាប្រែចិត្តចុះ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ត្បិតនគរ
ស្ថានសួគ៌នៅជិត ដៃបង្កើយ; ហើយចូរកុំស្វែងរកបំផ្លាញពួក
អ្នកបំរើរបស់យើងទៀតឡើយ ។ ហើយហេតុការណ៍
បានកើតឡើងថា ផែនដីបានរញ្ជួយជាថ្មី ហើយជញ្ជាំងទាំង
ឡាយក៏ញ័រ ។
៣៣ ហើយសម្លេងនោះមានមកទៀត ជាលើកទីបី ហើយបាន
និយាយមកកាន់ពួកគេ នូវពាក្យទាំងឡាយដ៏អស្ចារ្យ ដែលមិនអាច
និយាយដោយមនុស្ស ហើយជញ្ជាំងទាំងឡាយបានញ័រជាថ្មី
ហើយផែនដីបានរញ្ជួយ ហាក់បីដូចជាចង់ប្រេះចេញពីគ្នា ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិន
ពុំអាចរត់គេចបានសោះ ដោយព្រោះពពកនៃសេចក្ដីងងឹត ដែល

១៩ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ;
កិច្ចការផ្សាយសាសនា.
២១ *ក* ម៉ូសាយ ៧:៦–៧; ២១:២៣.
២៣ *ក* និក្ខ. ៣:២.
២៤ *ក* និក្ខ. ១៤:២៤; ១ នីហ្វៃ ១:៦;
គ. និង ស. ២៩:១២;
យ.ស. – ប្រវត្តិ ១:១៦.
២៨ *ក* និក្ខ. ១៤:២០.
២៩ *ក* ៣ នីហ្វៃ ១១:៣–១៤.
៣០ *ក* ១ ពង្សាវ. ១៩:១២;
គ. និង ស. ៨៥:៦.

គ្រប ដណ្ដប់ពួកគេ; មែនហើយ ហើយពួកគេក៏មិនអាចកម្រើកខ្លួន ដោយព្រោះសេចក្ដីខ្លាច ដែលបានកើតឡើងដល់ពួកគេ ។

៣៥ ឥឡូវនេះ មានមនុស្សម្នាក់ក្នុងចំណោមពួកគេ ដែលជាសាសន៍នីហ្វៃពីកំណើត ដែលពីមុនធ្លាប់នៅក្នុងសាសនាចក្រនៃព្រះ តែបានបែកចេញពីពួកគេទៅ ។

៣៦ ហើយហេតុការណ៍បានកើតឡើងថា គាត់បានបង្វិលខ្លួន ហើយមើលចុះ គាត់បានឃើញកាត់ពពកនៃសេចក្ដីងងឹត នូវ[ក]មុខរបស់ នីហ្វៃ និងលីហៃ; ហើយមើលចុះ មុខទាំងនេះចែងចាំងជាខ្លាំង ដូចមុខរបស់ពួកទេវតា ។ ហើយគាត់បានឃើញថា ពួកគេបើកភ្នែក សម្លឹងមើលទៅលើស្ថានសួគ៌ ហើយពួកគេនៅក្នុងអាកប្បកិរិយា ហាក់បីដូចជាកំពុងសន្ទនា ឬកំពុងបន្លឺសម្លេងរបស់គេ ទៅកាន់តួអង្គ ណាមួយ ដែលពួកគេបានឃើញ ។

៣៧ ហើយហេតុការណ៍បានកើតឡើងថា បុរសនេះបានស្រែកទៅកាន់ហ្វូងមនុស្សឲ្យបែរទៅមើល។ ហើយមើលចុះ ក៏មានអំណាចប្រទានឲ្យទៅពួកគេ ដែលធ្វើឲ្យគេបែរ ហើយមើល; ហើយពួកគេបានឃើញមុខរបស់នីហ្វៃ និងលីហៃ ។

៣៨ ហើយពួកគេបាននិយាយទៅកាន់បុរសនោះថា៖ មើលចុះ តើការណ៍អស់ទាំងនេះ មានន័យយ៉ាងណាដែរ ហើយតើនរណាទៅដែលអ្នកទាំងនេះសន្ទនាជាមួយ ?

៣៩ ឥឡូវនេះ ឈ្មោះរបស់បុរសនោះគឺ អ័មីណាដាប់ ។ ហើយអ័មីណាដាប់បាននិយាយទៅពួកគេថា៖ ពួកគេសន្ទនាជាមួយ នឹងពួកទេវតានៃព្រះ ។

៤០ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិនបាននិយាយទៅគាត់ថា៖ តើយើងត្រូវ[ក]ធ្វើអ្វី ដើម្បីឲ្យពពកនៃសេចក្ដីងងឹតនេះ អាចបក់ចេញកុំឲ្យគ្របលើយើង ?

៤១ ហើយអ័មីណាដាប់បាននិយាយទៅពួកគេថា៖ អ្នករាល់គ្នាត្រូវតែ[ក]ប្រែចិត្ត ហើយអំពាវនាវទៅរកសម្លេងនោះ គឺរហូតដល់អ្នក រាល់គ្នា មាន[ខ]សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ដែលត្រូវបានបង្រៀនដល់អ្នក ដោយអាលម៉ា និងអាមូលេក និងស៊ីអែសរ៉ុម; ហើយកាល ណាអ្នករាល់គ្នាធ្វើយ៉ាងនេះ នោះពពកនៃសេចក្ដីងងឹតនោះនឹងបានបក់ចេញទៅ កុំឲ្យគ្របលើអ្នករាល់គ្នាទៀត ។

៤២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេទាំងអស់គ្នា បានចាប់ផ្ដើមអំពាវនាវទៅកាន់សម្លេងនៃតួអង្គ ដែលបានអង្រួនផែន ដីនោះ; មែនហើយ ពួកគេបានអំពាវនាវ រហូតដល់ពពកនៃសេចក្ដីងងឹតនោះខ្ចាត់ចេញទៅ ។

៤៣ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេចោលភ្នែកមើលជុំវិញ ហើយបានឃើញថា ពពកនៃសេចក្ដីងងឹតខ្ចាត់ទៅ ដោយពុំគ្របលើពួកគេទៀតទេ មើលចុះ ពួកគេបានឃើញថា ពួកគេត្រូវ[ក]បានហ៊ុំព័ទ្ធជុំវិញ មែនហើយ មនុស្សគ្រប់រូបដោយបង្គោល ភ្លើងមួយ ។

៤៤ ហើយនីហ្វៃ និងលីហៃ នៅចំកណ្ដាលពួកគេ; មែនហើយ ពួកគេត្រូវបានហ៊ុំព័ទ្ធ; មែនហើយ ពួកគេហាក់បីដូចជានៅក្នុងកណ្ដាល អណ្ដាតភ្លើង ប៉ុន្តែវាពុំប៉ះពាល់ដល់ពួកគេឡើយ ហើយវាក៏មិនធ្វើឲ្យខូចខាតអ្វីដល់ជញ្ជាំងគុកដែរ; ហើយពួកគេបានពោរពេញទៅ ដោយ[ក]សេចក្ដីអំណរ ដែលមិនអាចនិយាយបាន ហើយពោរពេញទៅដោយសិរីល្អ ។

៤៥ ហើយមើលចុះ [ក]ព្រះវិញ្ញាណបរិសុទ្ធនៃព្រះ ទ្រង់បានយាងចុះមកពីស្ថានសួគ៌ ហើយបានចូលទៅក្នុងចិត្តពួកគេ ហើយពួកគេហាក់ បីដូចជាបានពោរពេញទៅដោយភ្លើង ហើយពួកគេអាច[ខ]និយាយពាក្យសំដីដ៏អស្ចារ្យទាំងឡាយ ។

៤៦ ហើយហេតុការណ៍បានកើតឡើងថា សម្លេងនោះបានបន្លឺមកពួកគេ មែនហើយ គឺជាសម្លេងមួយដ៏ពិរោះស្ដាប់ ហាក់បីដូចជា សម្លេងខ្សឹបថា៖

៤៧ [ក]សេចក្ដីសុខសាន្ត សេចក្ដីសុខសាន្ត ចូរមានដល់អ្នកចុះ ដោយសារសេចក្ដីជំនឿរបស់អ្នក ដល់បុត្រាដ៏ជាទីស្រឡាញ់របស់យើង ដែលមានចាប់តាំងពីកំណើតលោកិយមក ។

៤៨ ហើយឥឡូវនេះ កាលពួកគេបានឮយ៉ាងនេះ ពួកគេបានចោលភ្នែករកមើលថា តើសម្លេងនោះចេញពីណាមក; ហើយមើលចុះ ពួកគេឃើញ[ក]ផ្ទៃមេឃបើកចំហ ហើយពួកទេវតាបានចុះមកពីលើមេឃ ហើយបានធ្វើការងារបំរើពួកគេ ។

៤៩ ហើយមានមនុស្សប្រហែលបីរយនាក់ ដែលបានឃើញ និងបានឮការណ៍ទាំងនេះ; ហើយពួកគេត្រូវបានអញ្ជើញឲ្យចេញទៅ ហើយមិនត្រូវភ្ញាក់ផ្អើលឡើយ ហើយគេក៏មិនត្រូវឆ្ងល់ដែរ ។

៥០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចេញទៅ ហើយបានធ្វើការងារបំរើប្រជាជន ដោយប្រកាសទូទៅអស់ទាំង

៣៦ ក និក្ខ. ៣៤:២៩–៣៥; កិច្ចការ ៦:១៥.
៤០ ក កិច្ចការ ២:៣៧–៣៩.
៤១ ក ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
ខ ស.ប. សេចក្ដីជំនឿ.
៤៣ ក ៣ នីហ្វៃ ១៧:២៤; ១៩:១៤.
៤៤ ក ស.ប. សេចក្ដីអំណរ.
៤៥ ក ៣ នីហ្វៃ ៩:២០; អេធើរ ១២:១៤.
ខ ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
៤៧ ក ស.ប. សេចក្ដីសុខសាន្ត.
៤៨ ក ១ នីហ្វៃ ១:៨.

ភូមិភាគដែលនៅជុំវិញ អំពីគ្រប់ការណ៍ទាំងអស់ដែលពួកគេបាន
ឃើញ ហើយបានឮ ដរាបដល់មានសាសន៍លេមិនភាគច្រើន
ដែលត្រូវបានបរិវត្តអំពីរឿងទាំងនេះ ដោយមកពីភាពមហិមានៃ
ភស្តុតាងទាំងឡាយ ដែលពួកគេបានទទួល ។
៥១ ហើយអស់អ្នកណាដែលត្រូវបានបរិវត្ត នោះក៏បាន
ដាក់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេចុះ និងការស្អប់ និង
សណ្ដាប់នៃ ពួកអយ្យកោរបស់គេផង ។
៥២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រគល់ឲ្យ
ពួកសាសន៍នីហ្វៃវិញ នូវដែនដីទាំងឡាយ ដែលគេយកបានមក ៕

## ជំពូកទី ៦

*ពួកសាសន៍លេមិនដែលសុចរិតផ្សាយដល់ពួកសាសន៍នីហ្វៃដែលទុច្ចរិត — ប្រជាជនទាំងពីរចំរើនឡើង នៅក្នុងកាលសករាជមួយ ប្រកបដោយសន្តិភាព និងបរិបូរ — លូស៊ីហ្វើរ ដែលជាអ្នកនិពន្ធអំពើបាប ដឹកនាំពួកចោរប្លន់កាឌីអានតុននៅក្នុងអំពើឃាតកម្ម និងអំពើទុច្ចរិត — ពួកចោរដណ្ដើមយករដ្ឋាភិបាលលើពួកសាសន៍នីហ្វៃ ។ ប្រមាណជាឆ្នាំ ២៩–២៣ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា កាលឆ្នាំទីហុកសិបពីរ
ក្នុងរជ្ជកាលនៃពួកចៅក្រមបានចប់ទៅ នោះការណ៍អស់ទាំងនេះ
បានកើត ឡើង ហើយពួកសាសន៍លេមិនភាគច្រើន បានក្លាយ
ទៅជាប្រជាជនសុចរិត ដរាបដល់សេចក្ដីសុចរិតរបស់គេ បាន
លើសសេចក្ដី សុចរិតរបស់ពួកសាសន៍នីហ្វៃ ដោយសារការ
រឹងប៉ឹងរបស់គេ និងការខ្ជាប់ខ្ជួនរបស់គេ នៅក្នុងសេចក្ដីជំនឿ ។
២ ត្បិតមើលចុះ មានសាសន៍នីហ្វៃជាច្រើន ដែលបានក្លាយ
ទៅជារឹងទទឹង និងមិនប្រែចិត្ត ហើយអាក្រក់ក្រៃលែង ដរាបដល់
ពួកគេ បានបដិសេធព្រះបន្ទូលនៃព្រះ និងការផ្សាយ និងការ
ព្យាករណ៍ទាំងអស់ ដែលបានមកនៅក្នុងចំណោមពួកគេ ។
៣ ក៏ប៉ុន្តែ ប្រជាជននៃសាសនាចក្រមានសេចក្ដីអំណរជាខ្លាំង
ដោយសារការប្រែចិត្តនៃពួកសាសន៍លេមិន មែនហើយ ដោយ
សារ សាសនាចក្រនៃព្រះ ដែលត្រូវបានតាំងឡើង នៅក្នុង
ចំណោមពួកគេ ។ ហើយពួកគេបានរាប់អានគ្នាទៅវិញទៅមក
ហើយបានអររីក រាយនឹងគ្នា ហើយមានសេចក្ដីអំណរដ៏ធំ ។
៤ ហើយហេតុការណ៍បានកើតឡើងថា សាសន៍លេមិនជាច្រើន
បានចុះមកឯដែនដីសារ៉ាហិមឡា ហើយបានប្រកាសដល់ប្រជាជន
នៃសាសន៍នីហ្វៃ អំពីរបៀបនៃការប្រែចិត្តរបស់គេ ហើយបាន
ទូន្មានពួកគេឲ្យមានសេចក្ដីជំនឿ និងការប្រែចិត្ត ។
៥ មែនហើយ ហើយមនុស្សជាច្រើនបានផ្សាយ ដោយអានុភាព
និងសិទ្ធិអំណាចដ៏ខ្លាំងហួសប្រមាណ ដោយបាននាំពួកគេជាច្រើន
ឲ្យចុះទៅក្នុងជំរៅនៃភាពទន់ទាប ឲ្យបានជាអ្នកដើរតាមព្រះ និង
កូនចៀមដ៏សុភាពរាបសា ។
៦ ហើយហេតុការណ៍បានកើតឡើងថា សាសន៍លេមិនជាច្រើន
បានទៅឯដែនដីខាងជើង ហើយនីហ្វៃ និងលីហៃផង បានទៅឯដែន
ដីខាងជើង ដើម្បីទៅផ្សាយដល់ប្រជាជន ។ ម្ល៉ោះហើយ
ក៏ចប់ឆ្នាំទីហុកសិបបីទៅ ។
៧ ហើយមើលចុះ មានសន្តិភាពនៅក្នុងដែនដីទាំងអស់ ដរាប
ដល់ពួកសាសន៍នីហ្វៃបានទៅទីណាក៏បានដែលគេចង់ ទោះជានៅ
ក្នុង ចំណោមពួកសាសន៍នីហ្វៃ ឬពួកសាសន៍លេមិនក៏ដោយ ។
៨ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិន
ទៅទីណាក៏បាន ឲ្យតែគេចង់ដែរ ទោះជានៅក្នុងចំណោមពួក
សាសន៍ លេមិន ឬនៅក្នុងចំណោមពួកសាសន៍នីហ្វៃក៏ដោយ;
ម្ល៉ោះហើយ ពួកគេបានទាក់ទងគ្នាដោយសេរី ក្នុងការលក់ដូរ
ហើយយកកំរៃ ស្របតាមបំណងរបស់គេ ។
៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានក្លាយទៅជា
មានទ្រព្យសម្បត្តិដ៏លើសលប់ ទាំងសាសន៍លេមិន និងសាសន៍
នីហ្វៃ ផង; ហើយពួកគេមានជាច្រើនលើសលប់នូវមាស និង
ប្រាក់ និងលោហ:ធាតុដ៏មានតម្លៃគ្រប់បែបយ៉ាង ទាំងនៅក្នុង
ដែនដីខាងត្បូង និងនៅក្នុងដែនដីខាងជើង ។
១០ ឥឡូវនេះ ដែនដីខាងត្បូងត្រូវបានហៅថា លីហៃ ហើយ
ដែនដីខាងជើងត្រូវបានហៅថា មូលេក ដែលបាដាក់តាមបុត្រ
របស់ សេដេគា; ព្រោះព្រះអម្ចាស់ទ្រង់បាននាំមូលេកទៅឯដែនដី
ខាងជើង ហើយលីហៃមកឯដែនដីខាងត្បូង ។
១១ ហើយមើលចុះ មានមាសគ្រប់យ៉ាង នៅក្នុងដែនដី
ទាំងពីរ និងប្រាក់ និងជាតិរ៉ែដ៏មានតម្លៃគ្រប់យ៉ាង; ហើយមាន
ជាងដ៏ចំណាន ទាំងឡាយផង ដែលជាអ្នកធ្វើការប្រើជាតិរ៉ែគ្រប់
យ៉ាង ហើយចំរាញ់វា; ម្ល៉ោះហើយ ពួកគេបានទៅជាអ្នកមាន ។
១២ ពួកគេបានដាំធញ្ញជាតិជាច្រើន ទាំងនៅខាងជើង និងខាង

៥១ *ក* អាលម៉ា ៣១:៥.
៦ ១*ក* ហេលេ. ១៣:១.
២ *ក* រ៉ូម ១:២៨–៣២.
៣ *ក* ស.ប. សេចក្ដីប្រកប.
៤ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
៦ *ក* អាលម៉ា ៦៣:៤–៩;
ហេលេ. ៣:១១–១២.
១០ *ក* ម៉ូសាយ ២៥:២–៤;
ហេលេ. ៨:២១.

ត្បូង; ហើយពួកគេបានចំរើនឡើងជាអតិបរមា ទាំងនៅខាងជើង
និងនៅខាងត្បូងផង ។ ហើយពួកគេបានកើនចំនួនឡើង ហើយ
បានទៅជាខ្លាំងពូកែ ជាអតិបរមានៅក្នុងដែនដី ។ ហើយពួកគេ
បាន ចិញ្ចឹមហ្វូងចៀម និងហ្វូងសត្វជាច្រើន មែនហើយ សត្វ
ដែលធាត់ៗជាច្រើន ។
១៣ មើលចុះ ពួកស្ត្រីរបស់គេបានធ្វើការរវៃអំបោះ ហើយបាន
ត្បាញសំពត់គ្រប់យ៉ាង នូវសំពត់ពីអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់
និងសំពត់គ្រប់បែបយ៉ាង ដើម្បីបិទបាំងភាពអាក្រាតរបស់គេ ។
ម៉្លោះហើយ ឆ្នាំទីហុកសិបបួន បានកន្លងផុតទៅក្នុងសន្តិភាព ។
១៤ ហើយនៅក្នុងឆ្នាំទីហុកសិបប្រាំ ពួកគេក៏មានសេចក្ដី
អំណរដ៏ធំមួយ និងសន្តិភាព មែនហើយ ការផ្សាយជាច្រើន
និងការ ព្យាករណ៍ដ៏ច្រើនអំពីអ្វីដែលនឹងមក ។ ម៉្លោះហើយ
ឆ្នាំទីហុកសិបប្រាំបានកន្លងផុតទៅ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំ[ក]ទីហុកសិបប្រាំ
មួយក្នុងរជ្ជកាលនៃពួកចៅក្រម មើលចុះ សេសូរ៉ាំត្រូវបានធ្វើ
ឃាត បង់ដោយដៃអនាមិកមួយ នៅពេលដែលលោកអង្គុយ
នៅលើវេទិកាជំនុំជំរះ ។ ហើយហេតុការណ៍បានកើតឡើងថា នៅ
ក្នុងឆ្នាំ ដដែល កូនប្រុសរបស់លោកដែលត្រូវបានតែងតាំងឡើង
ដោយប្រជាជន ឲ្យធ្វើជំនួសលោក ក៏ត្រូវគេធ្វើឃាតដែរ ។
ម៉្លោះហើយ ក៏ចប់ឆ្នាំទីហុកសិបប្រាំមួយទៅ ។
១៦ ហើយនៅដើមឆ្នាំទីហុកសិបប្រាំពីរ ប្រជាជនបានចាប់ផ្ដើម
ក្លាយទៅជាទុច្ចរិតជាខ្លាំងទៀត ។
១៧ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់បានប្រទានពរដល់ពួកគេ
ជាយូរយារមកហើយ ដោយនូវទ្រព្យទាំងឡាយខាងលោកិយ
ទើប ពួកគេពុំត្រូវបានចាក់រុកឲ្យមានកំហឹង ឲ្យមានសង្គ្រាម ឬក៏
ការខ្ចាយឈាមណាឡើយ; ហេតុដូច្នេះហើយ ពួកគេបាន
ចាប់ផ្ដើមភ្ជាប់ចិត្តគេ ទៅលើទ្រព្យសម្បត្តិរបស់ខ្លួន; មែនហើយ
ពួកគេបានចាប់ផ្ដើមស្វែងរកកំរៃ ដើម្បីពួកគេអាចលើកខ្លួនឡើងលើ
អ្នកឯទៀត[ក]; ហេតុដូច្នេះ ហើយ ពួកគេបានចាប់ផ្ដើមប្រព្រឹត្តអំពើ
ឃាតកម្មសម្ងាត់ ហើយលួចប្លន់ ដើម្បីពួកគេអាចយកកំរៃ ។
១៨ ហើយឥឡូវនេះ មើលចុះ ពួកឃាតក និងពួកលួចប្លន់
ទាំងនោះ គឺជាក្រុមចោរមួយ ដែលត្រូវបានបង្កើតឡើង ដោយ
គិសគូមេន និងកាឌីអានតុន ។ ហើយឥឡូវនេះ ហេតុការណ៍
បានកើតឡើងថា មានមនុស្ស[ក]ជាច្រើន នៅក្នុងចំណោមពួក
សាសន៍នីហ្វៃ ជាក្រុម ចោរកាឌីអានតុន ។ ប៉ុន្តែមើលចុះ ពួកគេ
មានគ្នាជាច្រើនដ៏ឥតគណនានៅក្នុងចំណោមពួកសាសន៍លេមិន
ដែលទុច្ចរិតជាខ្លាំង ។ ហើយពួកគេត្រូវបានហៅថា ពួកចោរ
និងពួកឃាតកកាឌីអានតុន ។
១៩ ហើយគឺពួកគេនេះហើយដែលបានធ្វើឃាតមេចៅក្រមសេសូរ៉ាំ
និងកូនប្រុសរបស់លោក កាលនៅលើវេទិកាជំនុំជំរះ; ហើយមើលចុះ
គេរកពួកវាពុំឃើញឡើយ ។
២០ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលពួក
សាសន៍លេមិនបានឃើញថា មានពួកចោរនៅក្នុងចំណោមពួក
គេ នោះពួកគេមានសេចក្ដីព្រួយជាខ្លាំង; ហើយពួកគេបាន
ប្រើគ្រប់មធ្យោបាយ នៅក្នុងអំណាចរបស់គេ ដើម្បីបំផ្លាញ
ពួកវាចោលពីផ្ទៃផែន ដីនេះទៅ ។
២១ ប៉ុន្តែមើលចុះ អារក្សសាតាំងបានចាក់រុកចិត្តរបស់ពួក
សាសន៍នីហ្វៃភាគច្រើន ដរាបដល់ធ្វើឲ្យពួកគេរួបរួមជាមួយនឹង
ក្រុមចោរ ទាំងនេះ ហើយបានចូលក្នុងសេចក្ដីសញ្ញាទាំងឡាយ
របស់ពួកវា និងសម្បថទាំងឡាយរបស់ពួកវា ថាពួកគេនឹង
ការពារ ហើយថែរក្សា គ្នាទៅវិញទៅមក ទោះជានៅក្នុង
កាលៈទេសៈដ៏ពិបាកណាក៏ដោយ ដែលពួកគេជួបប្រទះ ថា
ពួកវាមិនត្រូវរងទុក្ខ ដោយសារអំពើ ឃាតកម្មទាំងឡាយរបស់
ពួកវា និងអំពើប្លន់របស់វា និងអំពើលួចរបស់វាទេ ។
២២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេមាន
ទីសំគាល់ទាំងឡាយរបស់គេ មែនហើយ ទីសំគាល់[ក]សម្ងាត់ និង
ពាក្យសម្ងាត់ របស់គេ ហើយនេះគឺដើម្បីពួកគេអាចញែកឲ្យដឹង
បងប្អូន ដែលបានចូលក្នុងសេចក្ដីសញ្ញា ថាទោះជាអំពើទុច្ចរិត
យ៉ាងណាក៏ដោយ ដែលបងប្អូនគេធ្វើ វានឹងមិនត្រូវធ្វើឲ្យ
ឈឺចាប់ ដោយបងប្អូនគេ ឬដោយពួកជនដែលបានចូលរួមក្នុង
ក្រុមរបស់គេ ដែលបានចុះក្នុង សេចក្ដីសញ្ញានេះ ។
២៣ ម៉្លោះហើយ ពួកគេអាចធ្វើឃាត និងប្លន់ និងលួច និង
ប្រព្រឹត្តអំពើសហាយស្មន់ និងអំពើទុច្ចរិតគ្រប់បែបយ៉ាង ដែលផ្ទុយនឹង
ក្រិត្យវិន័យនៃប្រទេសគេ ហើយក្រិត្យវិន័យនៃព្រះរបស់គេផង ។
២៤ ហើយអស់អ្នកណាដែលនៅក្នុងក្រុមរបស់គេ បើកសម្ដែង
ប្រាប់មនុស្សលោកអំពី[ក]អំពើទុច្ចរិតរបស់គេ និងអំពើដ៏គួរខ្ពើមឆ្អើម
ទាំងឡាយរបស់គេ អ្នកនោះនឹងត្រូវជំនុំជំរះ គឺពុំ
មែនតាមក្រិត្យវិន័យនៃប្រទេសគេទេ តែតាមក្រិត្យវិន័យនៃអំពើ
ទុច្ចរិតរបស់គេ ដែលត្រូវបានប្រគល់ឲ្យគេ ដោយកាឌីអានតុន
និងគិសគូមេន ។

១៥ *ក* ហេលេ. ៥:១.
១៧ *ក* ៣ នីហ្វៃ ៩:៩.
១៨ *ក* ហេលេ. ២:៤, ១២–១៣.
២២ *ក* ស.ប. បក្សព័ន្ធសម្ងាត់.
២៤ *ក* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.

២៥ ឥឡូវនេះ មើលចុះ [ក]គឺពាក្យសម្បថ និងសេចក្ដីសញ្ញាសម្ងាត់ទាំងនេះ ដែលអាលម៉ាបានបញ្ជាកូនប្រុសរបស់លោក មិនត្រូវ ប្រាប់ទៅមនុស្សលោកឡើយ ខ្លាចក្រែងវាទៅជាមធ្យោបាយមួយនាំមនុស្ស ឲ្យធ្លាក់ទៅក្នុងការបំផ្លិចបំផ្លាញ ។

២៦ ឥឡូវនេះ មើលចុះ ពាក្យសម្បថ និងសេចក្ដីសញ្ញា[ក]សម្ងាត់ទាំងនេះ ពុំបានមកដល់កាឌីអានតុន ពីបញ្ជីទាំងឡាយដែលបាន ប្រគល់ទៅឲ្យហេលេមិននោះទេ ប៉ុន្តែមើលចុះ វាត្រូវដាក់ទៅក្នុងចិត្តរបស់កាឌីអានតុន ដោយ[ខ]តួដដែល ដែលបានបញ្ឆោតឪពុកម្ដាយ ដើមរបស់យើង ឲ្យបរិភោគផ្លែដែលហាមឃាត់នោះ —

២៧ មែនហើយ តួដដែល ដែលបានធ្វើឧបាយកលជាមួយ[ក]កាអ៊ីន ថាបើសិនជាគាត់ធ្វើឃាតប្អូនគាត់ឈ្មោះអេបិល ការណ៍នេះនឹង មិនត្រូវឮដល់មនុស្សលោកឡើយ ។ ហើយវាបានធ្វើឧបាយកលជាមួយកាអ៊ីន និងពួកអ្នកដែលដើរតាមវាចាប់ពីពេលនោះតមក ។

២៨ ហើយគឺតួដដែលនេះហើយដែលបានដាក់ក្នុងចិត្តរបស់ប្រជាជន [ក]ឲ្យសង់ប៉មមួយយ៉ាងខ្ពស់គ្រប់គ្រាន់ ដើម្បីពួកគេអាចឡើងទៅ លើស្ថានសួគ៌បាន ។ ហើយគឺតួដដែលនេះហើយដែលបានដឹកនាំប្រជាជន ដែលមកពីប៉មនោះ មកឯដែនដីនេះ; ជាអ្នកដែលបាន ផ្សាយអំពីកិច្ចការទាំងឡាយនៃសេចក្ដីងងឹត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ពេញលើផ្ទៃដែនដី រហូតដល់វាទាញប្រជាជនចុះ [ខ]ទៅក្នុង សេចក្ដីបំផ្លិចបំផ្លាញទាំងស្រុង និងទៅស្ថាននរកដ៏អស់កល្បជានិច្ច ។

២៩ មែនហើយ គឺតួដដែលនោះហើយដែលបានដាក់ការណ៍នេះ ទៅក្នុងចិត្តរបស់[ក]កាឌីអានតុន ឲ្យបន្តកិច្ចការទាំងឡាយ នៃសេចក្ដី ងងឹត និងអំពើឃាតកម្មសម្ងាត់; ហើយវាបានបន្តការនេះចាប់តាំងពីដើមដំបូងរបស់មនុស្ស រហូតមកដល់ពេលនេះ ។

៣០ ហើយមើលចុះ គឺវានេះហើយដែលជា[ក]អ្នកនិពន្ធអំពើបាបទាំងអស់ ។ ហើយមើលចុះ វាបន្តកិច្ចការទាំងឡាយ នៃសេចក្ដីងងឹត និងអំពើឃាតកម្មសម្ងាត់របស់វា ហើយបន្តឧបាយកលទាំងឡាយរបស់គេ និងពាក្យសម្បថរបស់គេ និងសេចក្ដីសញ្ញារបស់គេ និងផែន ការនៃអំពើទុច្ចរិតដ៏គួរស្ញែងខ្លាចរបស់គេពីតំណមួយទៅតំណមួយ តាមការណ៍ដែលវាអាចក្ដាប់យកចិត្តនៃកូនចៅមនុស្ស ។

៣១ ហើយឥឡូវនេះ មើលចុះ វាបានក្ដាប់ជាប់នូវចិត្តរបស់ពួកសាសន៍នីហ្វៃ; មែនហើយ ដរាបដល់ធ្វើឲ្យពួកគេក្លាយទៅជាមនុស្ស ទុច្ចរិតជាខ្លាំង; មែនហើយ ពួកគេភាគច្រើនបានងាកចេញពីផ្លូវសុចរិត ហើយបាន[ក]ជាន់ឈ្លីនៅក្រោមជើងរបស់ពួកគេ នូវព្រះបញ្ញត្តិទាំង ឡាយនៃព្រះ ហើយបានបែរទៅតាមផ្លូវទាំងឡាយរបស់ខ្លួនផ្ទាល់ ហើយបានសង់ឡើងសំរាប់ខ្លួនគេ នូវរូបសំណាក ដែលធ្វើពីមាស និងពីប្រាក់របស់គេ ។

៣២ ហើយហេតុការណ៍បានកើតឡើងថា អំពើទុច្ចរិតទាំងអស់នេះ បានមកដល់ពួកគេ ក្នុងរយៈពេល[ក]មិនច្រើនឆ្នាំទេ ដរាបដល់ការណ៍ភាគច្រើននេះ បានមកដល់ពួកគេនៅឆ្នាំទីហុកសិបប្រាំពីរក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។

៣៣ ហើយពួកគេបានដុះឡើង ក្នុងអំពើទុច្ចរិតទាំងឡាយរបស់គេ នៅក្នុងឆ្នាំទីហុកសិបប្រាំបីផង នៅចំពោះការទុក្ខសោកដ៏ធំ និងការសោកសៅរបស់អ្នកសុចរិត ។

៣៤ ម្ល៉ោះហើយ យើងឃើញថា ពួកសាសន៍នីហ្វៃបានចាប់ផ្ដើមចុះអន់ថយ ក្នុងការឥតជំនឿ ហើយដុះឡើងក្នុងអំពើទុច្ចរិត និងអំពើ គួរខ្ពើមឆ្អើមទាំងឡាយ នៅពេលដែលពួកសាសន៍លេមិន បានចាប់ផ្ដើមដុះឡើងយ៉ាងខ្លាំង ក្នុងការចេះដឹងអំពីព្រះរបស់ពួកគេ; មែនហើយ ពួកគេបានចាប់ផ្ដើមរក្សាក្រិត្យវិន័យ និងព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយបានដើរនៅក្នុងសេចក្ដីពិត និងសេចក្ដីស្មោះ ត្រង់ចំពោះទ្រង់ ។

៣៥ ម្ល៉ោះហើយ យើងឃើញថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើម[ក]ដកថយពីពួកសាសន៍នីហ្វៃ ដោយសារអំពើទុច្ចរិត និងភាពរឹងរូសនៃចិត្តរបស់គេ ។

៣៦ ម្ល៉ោះហើយ យើងឃើញថា ព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើមស្រោចព្រះវិញ្ញាណទ្រង់ទៅលើពួកសាសន៍លេមិន ដោយព្រោះភាព ស្លូតបូត និងឆន្ទៈរបស់គេ នៅក្នុងការជឿដល់ព្រះបន្ទូលរបស់ទ្រង់ ។

៣៧ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិនបានរកចាប់ក្រុមចោរកាឌីអានតុន; ហើយពួកគេបានផ្សាយព្រះ

២៥ *ក* អាលម៉ា ៣៧:២៧—៣២.
២៦ *ក* ម៉ូសេ ៥:២៩, ៤៩—៥២.
*ខ* ៣ នីហ្វៃ ៦:២៨; ម៉ូសេ ៤:៦—១២.
២៧ *ក* ម៉ូសេ ៥:១៨—៣៣.
២៨ *ក* លោកុ. ១១:១—៤; អេធើរ ១:៣.
*ខ* អេធើរ ៨:៩, ១៥—២៥.
២៩ *ក* ហេលេ. ២:៤—១៣.
៣០ *ក* អាលម៉ា ៥:៣៩—៤២; ម៉ូរ៉ូណៃ ៧:១២, ១៧; ម៉ូសេ ៤:៤.
៣១ *ក* ១ នីហ្វៃ ១៩:៧.
៣២ *ក* អាលម៉ា ៤៦:៨.
៣៥ *ក* ម៉ូសាយ ២:៣៦; គ. និង ស. ១២១:៣៧.

បន្ទូល នៃព្រះ នៅក្នុងចំណោមពួកអ្នកដែលទុច្ចរិត ដរាប
ដល់ក្រុមចោរទាំងនេះត្រូវបំផ្លាញចោល អស់ពីចំណោមពួក
សាសន៍លេមិន ។
៣៨ ហើយហេតុការណ៍បានកើតឡើងថា ផ្ទុយទៅវិញ ពួក
សាសន៍នីហ្វៃបានបង្កបង្កើតវាឡើង ហើយទ្រទ្រង់ពួកគេ
ចាប់តាំងពីពួក គេដែលទុច្ចរិតដ៏ខ្លាំង រហូតដល់ពួកគេរាលដាល
ពាសពេញដែនដីរបស់ពួកសាសន៍នីហ្វៃ ហើយបានទាក់ទាញពួក
មនុស្សដែលសុចរិត រហូតដល់គេជឿដល់កិច្ចការទាំងឡាយ
របស់ពួកគេ ហើយចូលរួមក្នុងការយករបឹបរបស់គេ ហើយ
រួបរួមជាមួយគេក្នុងអំពើឃាតកម្ម និងបក្សព័ន្ធសម្ងាត់ទាំងឡាយ
របស់គេ ។
៣៩ ម្ល៉ោះហើយ ពួកគេយកបានការកាន់កាប់រដ្ឋាភិបាល
ទាំងស្រុង ដរាបដល់ពួកគេបានជាន់ឈ្លីនៅក្រោមជើងរបស់ពួក
គេ ហើយវាយ និងធ្វើទុក្ខ និងបែរខ្នងដាក់ពួកអ្នកក្រីក្រ និងអ្នក
ស្លូតបូត និងអ្នកដែលដើរតាមព្រះ ដោយសុភាពរាបសា ។
៤០ ម្ល៉ោះហើយ យើងឃើញថា ពួកគេកំពុងតែនៅក្នុង
ស្ថានភាពមួយ ដ៏គួរស្ញែងខ្លាច ហើយទុំល្មមសំរាប់ការ
បំផ្លិចបំផ្លាញ ដ៏អស់កល្បជានិច្ច ។
៤១ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីហុកសិប
ប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃក៏ចប់ទៅ ៕

---

សេចក្ដីព្យាករណ៍នៃនីហ្វៃ គឺជាកូនប្រុសរបស់ហេលេមិន — ព្រះទ្រង់គំរាមកំហែងដល់ប្រជាជននីហ្វៃថា ទ្រង់នឹងធ្វើទោសពួកគេ នៅក្នុង សេចក្ដីពិរោធរបស់ទ្រង់ ឲ្យដល់នូវសេចក្ដីបំផ្លិចបំផ្លាញទាំងស្រុង លើកលែងតែពួកគេប្រែចិត្ត ពីអំពើទុច្ចរិតរបស់គេ ។ ព្រះទ្រង់នឹងវាយ ប្រជាជននីហ្វៃដោយអាសន្នរោគ; ពួកគេប្រែចិត្ត ហើយបែរមករកទ្រង់ ។ សាំយូអែល ជាសាសន៍លេមិនមួយរូប ព្យាករដល់ពួកសាសន៍នីហ្វៃ ។

*មានរួមនៅក្នុងជំពូកទី ៧ ទៅ ១៦*

---

## ជំពូកទី ៧

*នីហ្វៃត្រូវគេបដិសេធនៅដែនដីខាងជើង ហើយត្រឡប់មកសារ៉ាហិមឡាវិញ — លោកអធិស្ឋាននៅលើប៉ម ក្នុងសួនរបស់លោក ហើយ បន្ទាប់មក ហៅឲ្យប្រជាជនប្រែចិត្ត ឬក៏ត្រូវវិនាស ។ ប្រមាណជាឆ្នាំ ២៣–២១ ម.គ.ស. ។*

មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីហុកសិប
ប្រាំបួនក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននៃសាសន៍
នីហ្វៃ នោះនីហ្វៃ ជាកូនប្រុសរបស់ហេលេមិន បានត្រឡប់មក
ឯដែនដីសារ៉ាហិមឡា ពីដែនដីខាងជើងវិញ ។
២ ព្រោះលោកបានទៅនៅក្នុងចំណោមប្រជាជន ដែលនៅ
ក្នុងដែនដីខាងជើង ហើយបានផ្សាយព្រះបន្ទូលនៃព្រះទៅគេ
ហើយបាន ព្យាករការណ៍ជាច្រើនទៅគេ ។
៣ ហើយពួកគេបានបដិសេធពាក្យទាំងអស់របស់លោក
ដរាបដល់លោកមិនអាចស្នាក់ នៅក្នុងចំណោមពួកគេបានទៀត
តែត្រូវ ត្រឡប់មកដែនដីកំណើតរបស់លោកវិញ ។
៤ ហើយដោយបានឃើញប្រជាជននៅក្នុងស្ថានភាពមួយ
ដ៏ប្រកបដោយភាពទុច្ចរិតដ៏គួរស្ញែងខ្លាចបែបនេះ ហើយពួកចោរ
កាឌីអានតុនទាំងនោះ បំពេញវេទិកាជំនុំជំរះទាំងឡាយ —
ដោយបានដណ្ដើមយកអានុភាព និងសិទ្ធិអំណាចនៃដែនដី;
ដោយបានទុក ចោលព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយគ្មាន
អ្វីជាស្មោះត្រង់នៅចំពោះមុខទ្រង់សោះ; ដោយពុំបានធ្វើការ
យុត្តិធម៌ ដល់កូនចៅមនុស្ស ឡើយ;
៥ ដោយបានធ្វើការកាត់ទោសដល់ជនសុចរិត ដោយ
ព្រោះសេចក្ដីសុចរិតរបស់គេ; ដោះលែងជនជាប់ទោស និងពួក
ទុច្ចរិតឲ្យរួចខ្លួន ដោយពុំធ្វើទោស ដោយព្រោះប្រាក់របស់គេ;
ហើយថែមទាំងបាននៅលើមុខតំណែង ជាប្រមុខនៃរដ្ឋាភិបាល
ដើម្បីគ្រប់គ្រង ហើយធ្វើ តាមតែទំនើងចិត្តរបស់គេ ដើម្បីពួកគេ
អាចបានកំរៃ និងសិរីល្អនៃពិភពលោក ហើយថែមទៀត គឺដើម្បី
ពួកគេអាចប្រព្រឹត្ត ដោយងាយ នូវអំពើកំផិត និងលួច
និងសម្លាប់ និងធ្វើតាមទំនើងចិត្តរបស់គេ ។
៦ ឥឡូវនេះ អំពើទុច្ចរិតដ៏ធំនេះ បានមកលើពួកសាសន៍នីហ្វៃ
នៅក្នុងពេលមិនយូរឆ្នាំប៉ុន្មានទេ; ហើយកាលនីហ្វៃបានឃើញការណ៍
នេះ នោះចិត្តលោកបានពោរពេញទៅដោយសេចក្ដីព្រួយនៅ
ក្នុងទ្រូងលោក; ហើយលោកបានស្រែកឡើង នៅក្នុងសេចក្ដី
ឈឺចាប់ក្នុង ព្រលឹងលោកថា៖
៧ ឱ ប្រសិនបើខ្ញុំរស់នៅក្នុងសម័យ ដែលអយ្យកោនីហ្វៃរបស់ខ្ញុំ

---

៣៩ *ក* ទំនុក. ១០៩:១៦;
អាលម៉ា ៥:៥៤–៥៦;
គ. និង ស. ៥៦:១៦.

៤០ *ក* ហេលេ. ៥:២; ១១:៣៧;
គ. និង ស. ១៨:៦.
**៧** ១*ក* ហេលេ. ៦:៦.

៥ *ក* ម៉ាថាយ ១៣:២២; ១៦:២៦.

បានចេញមកជាមុនដំបូងពីដែនដីយេរូសាឡិម នោះខ្ញុំអាចមាន
សេចក្ដីអំណរជាមួយនឹងលោក នៅលើដែនដីសន្យា; នៅពេលនោះ
ប្រជាជនរបស់លោក ងាយប្រដៅមុតមាំនៅក្នុងការកាន់តាម
ព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយកម្រដឹកនាំឲ្យធ្វើអំពើទុច្ចរិត
ហើយពួកគេឆាប់ស្ដាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ —
៨ មែនហើយ ប្រសិនបើថ្ងៃទាំងឡាយរបស់ខ្ញុំ គឺនៅក្នុងថ្ងៃ
ទាំងនោះ នោះព្រលឹងរបស់ខ្ញុំ ច្បាស់ជាមានសេចក្ដីអំណរ នៅ
ក្នុងអំពើ សុចរិតរបស់បងប្អូនរបស់ខ្ញុំដែរ ។
៩ ប៉ុន្តែមើលចុះ ខ្ញុំត្រូវរស់ក្នុងសម័យនេះ ហើយចិត្ត
ខ្ញុំពោរពេញទៅដោយសេចក្ដីព្រួយ ពីព្រោះតែអំពើទុច្ចរិតរបស់
បងប្អូនរបស់ខ្ញុំ ។
១០ ហើយមើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
គឺនៅលើប៉មមួយ ដែលនៅក្នុងសួនរបស់នីហ្វៃ នៅជិតផ្លូវនាំ
ចូលទៅ ផ្សារធំ នៅក្នុងទីក្រុងសារ៉ាហិមឡា; ហេតុដូច្នេះហើយ
នីហ្វៃបានក្រាបនៅលើប៉ម ដែលនៅក្នុងសួនរបស់លោក
ប៉មនោះនៅជិតក្លោង ទ្វារសួនផង ដែលនាំទៅកាន់ផ្លូវធំ ។
១១ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្ស
ខ្លះដើរកាត់តាមនោះ ហើយបានឃើញនីហ្វៃ នៅពេលដែល
លោកកំពុងចាក់ ព្រលឹងលោកទៅព្រះ នៅលើប៉ម; ហើយពួក
គេបានរត់ទៅប្រាប់ប្រជាជន អំពីអ្វីៗដែលគេបានឃើញ ហើយ
មនុស្សទាំងហ្វូងៗបាន ប្រមូលគ្នាមក ដើម្បីឲ្យបានដឹងនូវដើមហេតុ
នៃការទួញសោកដ៏ធំ ចំពោះអំពើទុច្ចរិតរបស់ប្រជាជន ។
១២ ហើយឥឡូវនេះ កាលនីហ្វៃបានក្រោកឡើង នោះលោកបាន
ឃើញហ្វូងមនុស្សទាំងឡាយ ដែលបានប្រមូលគ្នាមក ។
១៣ ហើយហេតុការណ៍បានកើតឡើងថា លោកបានហើប
មាត់លោក ហើយបាននិយាយទៅកាន់ពួកគេថា៖ មើលចុះ
[ក]តើហេតុអ្វីបាន ជា អ្នករាល់គ្នាប្រមូលគ្នាមកយ៉ាងនេះ ?
តើដើម្បីឲ្យខ្ញុំប្រាប់អ្នកអំពីអំពើទុច្ចរិតរបស់អ្នកឬ ?
១៤ មែនហើយ ព្រោះតែខ្ញុំបានមកលើប៉មរបស់ខ្ញុំ ដើម្បីខ្ញុំអាច
ចាក់ព្រលឹងខ្ញុំទៅព្រះ ពីព្រោះសេចក្ដីព្រួយបារម្ភ ដ៏ខ្លាំងនៃចិត្ត
របស់ខ្ញុំ គឺដោយសារអំពើទុច្ចរិតទាំងឡាយរបស់អ្នក!
១៥ ហើយដោយសារសេចក្ដីទុក្ខសោក និងព្រួយបារម្ភរបស់ខ្ញុំ
ទើបអ្នករាល់គ្នាបានប្រមូលគ្នាមក ហើយមានចិត្តអស្ចារ្យ; មែន
ហើយ ហើយអ្នករាល់គ្នាមានរឿងដ៏ធំដើម្បីមានចិត្តអស្ចារ្យ;
មែនហើយ អ្នករាល់គ្នាត្រូវតែមានចិត្តអស្ចារ្យ ពីព្រោះអ្នករាល់
គ្នាបានបណ្ដោយ ឲ្យអារក្សក្ដាប់ជាប់ចិត្តរបស់អ្នកយ៉ាងខ្លាំង ។
១៦ មែនហើយ តើហេតុដូចម្ដេចបានជាអ្នករាល់គ្នា
បណ្ដោយឲ្យខ្លួនត្រូវដឹកនាំ ដោយជនដែលស្វែងរកលុញច្រាន
ព្រលឹងអ្នក ចុះទៅ ក្នុងសេចក្ដីទុក្ខដ៏អស់កល្បជានិច្ច និងសេចក្ដី
វេទនាដ៏មិនចេះមិនចេះហើយដូច្នេះ ?
១៧ ឱ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ចូរអ្នករាល់គ្នាប្រែចិត្តចុះ!
[ក]តើហេតុអ្វីទៅ បានជាអ្នករាល់គ្នាចង់ស្លាប់ ? ចូរអ្នករាល់គ្នា
ត្រឡប់ មកវិញចុះ ចូរអ្នករាល់គ្នាត្រឡប់មករកព្រះអម្ចាស់ ជា
ព្រះរបស់អ្នកចុះ ។ តើហេតុអ្វីបានជាទ្រង់បោះបង់ពួកអ្នកចោល ?
១៨ គឺដោយសារអ្នករាល់គ្នាបានធ្វើចិត្ត[ក]រឹងរូស; មែនហើយ
អ្នករាល់គ្នាមិនព្រមស្ដាប់[ខ]តាមសម្លេងនៃអ្នកគង្វាលល្អ; មែន
ហើយ អ្នករាល់គ្នាបានបង្កឲ្យ[ក]ទ្រង់មានកំហឹងនឹងអ្នក ។
១៩ ហើយមើលចុះ ជាជាងប្រមូលពួកអ្នកមក លើកលែងតែ
អ្នកព្រមប្រែចិត្ត មើលចុះ ទ្រង់នឹងធ្វើឲ្យពួកអ្នកត្រូវខ្ចាត់ខ្ចាយ
ដើម្បីឲ្យអ្នក រាល់គ្នាបានក្លាយទៅជាសាច់សំរាប់ឆ្កែ និងសត្វព្រៃ ។
២០ ឱ តើហេតុដូចម្ដេច បានជាពួកអ្នករាល់គ្នាភ្លេចព្រះរបស់
អ្នក ក្នុងថ្ងៃតែមួយដែលទ្រង់បានដោះលែងអ្នកដូច្នេះ ?
២១ ប៉ុន្តែមើលចុះ គឺដើម្បីបានកំរៃ ដើម្បីឲ្យបានមនុស្សសរសើរ
មែនហើយ ហើយដើម្បីអ្នករាល់គ្នាអាចបានមាស និងបានប្រាក់ ។
ហើយអ្នករាល់គ្នាបានភ្ជាប់ចិត្តអ្នកទៅលើទ្រព្យសម្បត្តិ និងវត្ថុទាំង
ឡាយដែលឥតប្រយោជន៍[ក]នៃលោកិយនេះ ដោយសារវត្ថុទាំងនោះ
ទើបអ្នករាល់គ្នា[ខ]ធ្វើឃាត និងប្លន់ និងលួច និងធ្វើបន្ទាល់ទាស់នឹង
អ្នកជិតខាងរបស់ខ្លួន ហើយធ្វើអំពើទុច្ចរិតគ្រប់បែបយ៉ាង ។
២២ ហើយដោយសារហេតុនេះ សេចក្ដីវេទនានឹងមកដល់អ្នក
រាល់គ្នា លើកលែងតែអ្នកប្រែចិត្ត ។ ព្រោះបើសិនជាអ្នករាល់
គ្នា ពុំប្រែចិត្តទេ មើលចុះ ទីក្រុងដ៏ធំនេះ និងទីក្រុងទាំងអស់ដែល
នៅជុំវិញនេះផង ដែលនៅក្នុងដែនដីរបស់យើង នឹងត្រូវ
ដកយកចេញ ដើម្បីឲ្យអ្នករាល់គ្នាគ្មានទីជម្រក[ក]ក្នុងនោះទេ;
ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់នឹងពុំប្រទានឲ្យអ្នកនូវកម្លាំង ដូច

១៣ *ក* ម៉ាថាយ ៣:៥–៨.
១៧ *ក* អេសេ. ១៨:២៣, ៣១–៣២.
១៨ *ក* អេសេ. ៣៤:១២;
យ៉ូហាន ១០:១៤–១៦;
អាលម៉ា ៥:៣៨–៤១, ៥៧–៦០.
ស.ប. អ្នកគង្វាលល្អ.
*ខ* យ៉ាកុប ១:៨;
អាលម៉ា ១២:៣៦–៣៧.
១៩ *ក* ៣ នីហ្វៃ ១០:៤–៧.
២១ *ក* ស.ប. សេចក្ដីប្រកបដោយលោកិយ.
*ខ* និក្ខ. ២០:១៦;
ម៉ាថាយ ១៥:១៩–២០.
២២ *ក* ម៉ូសាយ ៧:២៩.

ដែលទ្រង់ធ្លាប់បានធ្វើមក ដល់ឥឡូវនេះ ដើម្បីប្រឆាំងទប់ទល់នឹង
ពួកខ្មាំងសត្រូវរបស់អ្នកទេ ។
២៣ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖
យើងនឹងពុំបង្ហាញដល់ពួកទុច្ចរិត នូវកម្លាំងរបស់យើង
ឲ្យម្នាក់ច្រើនជាង ម្នាក់ទៀតទេ លើកលែងតែដល់អស់អ្នកណា
ដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេ ហើយប្រុងស្ដាប់តាម
ពាក្យរបស់យើងប៉ុណ្ណោះ។ ឥឡូវនេះ ហេតុដូច្នេះហើយ
ខ្ញុំចង់ឲ្យអ្នករាល់គ្នាឃើញ ឱបងប្អូនរបស់ខ្ញុំអើយ ថាពួក
សាសន៍លេមិននឹងត្រូវបានគ្រាន់បើជាងអ្នក លើកលែងតែអ្នក
រាល់គ្នាប្រែចិត្ត ។
២៤ ត្បិតមើលចុះ ពួកគេសុចរិតជាងអ្នក ព្រោះពួកគេពុំបាន
ធ្វើបាប ប្រឆាំងនឹងការចេះដឹងដ៏មហិមា ដែលអ្នករាល់គ្នាបាន
ទទួល នោះទេ; ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់នឹងមាន
សេចក្ដីមេត្តាករុណាដល់ពួកគេ; មែនហើយ ទ្រង់នឹងពន្យារថ្ងៃ
របស់គេ និងបង្កើនពូជ របស់គេ ក្នុងកាលអ្នករាល់គ្នានឹងត្រូវ
បំផ្លាញឲ្យអស់ លើកលែងតែអ្នកប្រែចិត្ត ។
២៥ មែនហើយ ចូរសេចក្ដីវេទនាមានមកដល់អ្នកចុះ ដោយ
សារអំពើគួរខ្ពើមឆ្អើមដ៏ធំ ដែលមានក្នុងចំណោមអ្នករាល់គ្នា;
ហើយអ្នក រាល់គ្នាបានយកខ្លួន ទៅរួបរួមជាមួយនឹងពួក
នោះ មែនហើយ គឺក្រុមចោរសម្ងាត់ ដែលបានបង្កើតឡើង
ដោយកាឌីអានតុននោះ!
២៦ មែនហើយ ចូរសេចក្ដីវេទនាមានមកដល់អ្នកចុះ ដោយ
សារការឆ្មើងឆ្មៃ ដែលអ្នករាល់គ្នាបានទុកឲ្យចូលក្នុងចិត្តអ្នក ដែល
បានលើកអ្នកឡើងផុតពីអ្វីៗដែលល្អ ដោយព្រោះទ្រព្យសម្បត្តិ
ដ៏ស្ដុកស្ដម្ភរបស់អ្នក!
២៧ មែនហើយ ចូរសេចក្ដីវេទនាមានមកដល់អ្នកចុះ ដោយ
សារអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់អ្នក !
២៨ ហើយលើកលែងអ្នករាល់គ្នាប្រែចិត្ត បើពុំនោះសោតទេ
អ្នករាល់គ្នានឹងត្រូវវិនាសបង់; មែនហើយ សូម្បីតែដែនដីទាំង
ឡាយ របស់អ្នកក៏នឹងត្រូវដកយកពីអ្នកដែរ ហើយអ្នករាល់គ្នា
នឹងត្រូវបំផ្លាញចេញពីលើផ្ទៃផែនដីទៅ ។
២៩ មើលចុះ ឥឡូវនេះ ខ្ញុំពុំនិយាយថា ការណ៍ទាំងនេះ
នឹងកើតឡើងដោយខ្លួនខ្ញុំផ្ទាល់នោះទេ ព្រោះពុំមែនខ្លួនខ្ញុំផ្ទាល់ទេ
ដែល ខ្ញុំដឹងការណ៍ទាំងនេះ; ប៉ុន្តែមើលចុះ ខ្ញុំដឹងថា ការណ៍
ទាំងនេះពិត ព្រោះព្រះអម្ចាស់ ទ្រង់បានធ្វើឲ្យខ្ញុំដឹងការណ៍ទាំងនេះ
ហេតុដូច្នេះ ហើយ ខ្ញុំធ្វើទីបន្ទាល់ថា វានឹងកើតឡើងមែន ៕

## ជំពូកទី ៨

*ពួកចៅក្រមពុករលួយរកញុះញង់ប្រជាជន ឲ្យទាស់នឹងនីហ្វៃ — អ័ប្រាហាំ ម៉ូសេ ស៊ីណូស ស៊ីណុក អេសីយ៉ាស អេសាយ យេរេមា លីហៃ និងនីហ្វៃ ទាំងអស់គ្នាបានធ្វើបន្ទាល់អំពីព្រះគ្រីស្ទ — ដោយការបំភ្លឺ នោះនីហ្វៃប្រកាសប្រាប់អំពីឃាតកម្មដល់មេចៅក្រម ។ ប្រមាណជាឆ្នាំ ២៣–២១ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលនីហ្វៃបាន
និយាយពាក្យទាំងនេះហើយ មើលចុះ មានពួកមនុស្សដែល
ជាចៅក្រម ទាំងឡាយ ជាពួកអ្នកដែលនៅក្នុង
ក្រុមចោរសម្ងាត់កាឌីអានតុនផង នោះពួកគេបានខឹង ហើយពួក
គេបានស្រែកទាស់នឹងលោក ដោយនិយាយទៅប្រជាជនថា៖
តើហេតុអ្វីបានជាអ្នករាល់គ្នា មិនចាប់មនុស្សនេះ ហើយយកវា
មក ដើម្បីឲ្យវាត្រូវជាប់ទោស តាម បទឧក្រិដ្ឋដែលវាបានធ្វើ ?
២ តើហេតុអ្វីបានជាអ្នករាល់គ្នាមើលមនុស្សនេះ ហើយ
ស្ដាប់វាជេរប្រមាថដល់ប្រជាជននេះ ហើយដល់ច្បាប់
របស់យើងដូច្នេះ ?
៣ ត្បិតមើលចុះ នីហ្វៃបាននិយាយទៅកាន់ពួកគេ អំពីអំពើ
ពុករលួយនៃច្បាប់របស់គេ; មែនហើយ ការណ៍ជាច្រើនដែល
នីហ្វៃបាន និយាយ ដែលមិនអាចសរសេរបាន; ហើយលោកពុំ
បាននិយាយអ្វី ផ្ទុយនឹងព្រះបញ្ញត្តិទាំងឡាយនៃព្រះឡើយ ។
៤ ហើយពួកចៅក្រមទាំងនោះក៏ខឹងនឹងលោក ដោយព្រោះលោ
កបាននិយាយ យ៉ាងច្បាស់លាស់ប្រាប់គេ អំពីកិច្ចការសម្ងាត់ទាំង
ឡាយនៃសេចក្ដីងងឹតរបស់គេ; ទោះជាយ៉ាងណាក៏ដោយ គង់
តែពួកគេមិនហ៊ានយកដៃមកប៉ះពាល់ដល់លោកឡើយ ព្រោះ
ពួកគេខ្លាច ក្រែងប្រជាជនស្រែកទាស់នឹងគេ ។
៥ ហេតុដូច្នេះហើយ ពួកគេបានស្រែកទៅប្រជាជនថា៖
តើហេតុអ្វីបានជាអ្នករាល់គ្នា ទុកឲ្យមនុស្សនេះជេរប្រមាថ
យើងដូច្នេះ ? ត្បិតមើលចុះ គាត់កាត់ទោសប្រជាជននេះទាំង
អស់គ្នា ថាត្រូវដល់ទៅសេចក្ដីបំផ្លិចបំផ្លាញផង; មែនហើយ

២៣ *ក* ហេលេ. ១៥:១១–១៥.
២៤ *ក* អាលម៉ា ៩:១៦;
គ. និង ស. ៥:៣៣.
*ខ* អាលម៉ា ៩:១៩.
២៥ *ក* ហេលេ. ៣:២៣.
២៦ *ក* អេសាយ ៥:៨–២៥.
*ខ* យ៉ាកុប ២:១៣.
២៩ *ក* អាលម៉ា ៥:៤៥–៤៦.
៨ ៤ *ក* ១ នីហ្វៃ ១៦:២–៣.

ហើយថា ទីក្រុងទាំងឡាយ ដ៏ធំៗរបស់យើងនេះផង នឹងត្រូវដកយកចេញពីយើង ធ្វើឲ្យយើងអស់កន្លែងនៅក្នុងក្រុងទាំងនោះ ។

៦ ហើយឥឡូវនេះ យើងដឹងថា ការណ៍នេះពុំអាចកើតឡើងទេ ត្បិតមើលចុះ យើងខ្លាំងពូកែ ហើយទីក្រុងទាំងឡាយរបស់យើងក៏ធំ ហេតុដូច្នេះហើយ ពួកខ្មាំងសត្រូវរបស់យើង ពុំអាចមានកម្លាំងអ្វីមកលើយើងបានទេ ។

៧ ហើយហេតុការណ៍បានកើតឡើងថា ដោយរបៀបនេះ ពួកគេបានចាក់រុកឲ្យប្រជាជនមានកំហឹងនឹងនីហ្វៃ ហើយបំបះបំបោរឲ្យមានការទាស់ទែងគ្នា នៅក្នុងចំណោមពួកគេ; ព្រោះមានមនុស្សខ្លះបានស្រែកថា៖ ចូរកុំធ្វើអ្វីដល់មនុស្សនេះឡើយ ព្រោះលោកជាមនុស្សល្អ ហើយការណ៍ទាំងនោះដែលលោកបាននិយាយ នោះនឹងកើតឡើងជាពិតប្រាកដ លើកលែងតែយើងប្រែចិត្ត ។

៨ មែនហើយ មើលចុះ អស់ទាំងសេចក្ដីជំនុំជំរះនឹងមកលើយើង ដែលលោកបានធ្វើបន្ទាល់មកយើងនោះ; ព្រោះយើងដឹងថា លោកបានធ្វើបន្ទាល់ត្រឹមត្រូវដល់យើង អំពីអំពើទុច្ចរិតទាំងឡាយរបស់យើងហើយ ។ ហើយមើលចុះ វាមានច្រើន ហើយលោកក៏ដឹងដែរ នូវកិច្ចការទាំងអស់ ដែលនឹងកើតឡើងដល់យើង ក៏ដូចជាលោក[ក]ដឹងនូវអំពើទុច្ចរិតទាំងឡាយរបស់យើងដែរ ។

៩ មែនហើយ ហើយមើលចុះ បើសិនជាលោកពុំមែនជាព្យាការីមួយរូបទេនោះ លោកមិនអាចធ្វើបន្ទាល់ អំពីកិច្ចការទាំងនោះដែរ ។

១០ ហើយហេតុការណ៍បានកើតឡើងថា ពួកជនដែលស្វែងរកបំផ្លាញនីហ្វៃ ក៏ត្រូវរុញរាដោយសារសេចក្ដីភិតភ័យរបស់គេ ដែលពួក គេមិនបានដាក់ដៃទៅប៉ះពាល់ដល់លោកឡើយ; ហេតុដូច្នេះហើយ លោកបានចាប់ផ្ដើមនិយាយទៅកាន់ពួកគេទៀត ដោយឃើញថា លោកបានទទួលការប្រោសប្រណីនៅក្នុងភ្នែកនៃជនខ្លះ ដរាបដល់អ្នកដែលនៅសល់ទាំងប៉ុន្មានបានខ្លាច ។

១១ ហេតុដូច្នេះហើយ លោកត្រូវបានបង្ខំឲ្យនិយាយទៅកាន់ពួកគេថែមទៀតថា៖ មើលចុះ បងប្អូនរបស់ខ្ញុំអើយ តើអ្នករាល់គ្នាមិន បានអានទេឬថា ព្រះទ្រង់បានប្រទានអំណាចទៅឲ្យមនុស្សម្នាក់ គឺលោកម៉ូសេ ឲ្យវាយទឹក[ក]សមុទ្រក្រហម ហើយទឹកញែកចេញទៅខាង នេះ និងទៅខាងនោះ ដរាបដល់ពួកសាសន៍អ៊ីស្រាអែល ដែលត្រូវជាពួកអយ្យកោយើង ឆ្លងកាត់លើដីគោកបាន ហើយទឹកគ្របមកលើ ពលទ័ពអេស៊ីព្ទ ហើយលេបពួកគេទៅ ?

១២ ហើយឥឡូវនេះ មើលចុះ បើសិនជាព្រះទ្រង់បានប្រទានឲ្យបុរសនេះ នូវអំណាចយ៉ាងនេះ តើហេតុអ្វីបានជាអ្នករាល់គ្នាប្រកែកគ្នា ហើយនិយាយថា ទ្រង់ពុំប្រទានអំណាចឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំអាចដឹងអំពីសេចក្ដីជំនុំជំរះទាំងឡាយ ដែលនឹងមានមកលើអ្នករាល់គ្នា លើកលែង តែអ្នកប្រែចិត្តនោះ ?

១៣ ប៉ុន្តែមើលចុះ អ្នករាល់គ្នាមិនគ្រាន់តែបដិសេធពាក្យទាំងឡាយរបស់ខ្ញុំប៉ុណ្ណោះទេ តែអ្នករាល់គ្នា ថែមទាំងបដិសេធនូវពាក្យ ទាំងឡាយ ដែលបាននិយាយដោយពួកអយ្យកោយើង និងពាក្យទាំងអស់ផង ដែលបាននិយាយដោយបុរសនេះ គឺលោកម៉ូសេ ដែល មានអំណាចដ៏មហិមា ដែលបានប្រទានដល់លោក មែនហើយ ពាក្យទាំងឡាយដែលលោកបាននិយាយអំពីការយាងមកនៃព្រះមែស៊ី ។

១៤ មែនហើយ តើលោកមិនបានធ្វើបន្ទាល់ថា ព្រះរាជបុត្រានៃព្រះនឹងយាងមកទេឬអី ? ហើយពេលលោក [ក]លើកសត្វពស់លង្ហិន ឡើង នៅក្នុងទីរហោស្ថានយ៉ាងណា នោះព្រះអង្គដែលនឹងយាងមក ក៏នឹងត្រូវលើកឡើងយ៉ាងនោះដែរ ។

១៥ ហើយអស់អ្នកណាដែលសម្លឹងមើលទៅឯសត្វពស់នោះ បាន[ក]រស់នៅ ម្ល៉ោះហើយ អស់អ្នកណាដែលនឹងសម្លឹងមើលទៅព្រះរាជបុត្រានៃព្រះ ដោយនូវសេចក្ដីជំនឿ ដោយមានវិញ្ញាណទន់ទាប នឹងអាច[ខ]រស់នៅដែរ គឺមានជីវិតដែលនៅអស់កល្បជានិច្ច ។

១៦ ហើយឥឡូវនេះ មើលចុះ លោកម៉ូសេពុំគ្រាន់តែធ្វើបន្ទាល់ អំពី[ក]ការណ៍អស់ទាំងនេះទេ តែអស់ទាំងព្យាការីដ៏បរិសុទ្ធផង នៅ ក្នុងជំនាន់លោក ទៅទល់នឹងជំនាន់លោកអ័ប្រាហាំ ។

១៧ មែនហើយ ហើយមើលចុះ [ក]លោកអ័ប្រាហាំបានឃើញការយាងមករបស់ទ្រង់ ហើយបានពោរពេញទៅដោយការត្រេកអរ ហើយបានអររីករាយ ។

៨ ក ហេលេ. ៧:២៩.
១១ ក និក្ខ. ១៤:១៦; ១ នីហ្វៃ ១៧:២៦; ម៉ូសាយ ៧:១៩; គ. និង ស. ៨:២–៣; ម៉ូសេ ១:២៥.
១៤ ក ជនគ. ២១:៦–៩; ២ នីហ្វៃ ២៥:២០; អាលម៉ា ៣៣:១៩–២២. ស.ប. ព្រះយេស៊ូវគ្រីស្ទ — គំរូ និងនិមិត្តរូបទាំងឡាយអំពីព្រះគ្រីស្ទ.
១៥ ក ១ នីហ្វៃ ១៧:៤១; អាលម៉ា ៣៧:៤៥–៤៧; ៣ នីហ្វៃ ១៥:៩.
ខ យ៉ូហាន ១១:២៥.
១៦ ក យ៉ាកុប ៤:៤–៥; ៧:១១.
១៧ ក លោកុ. ២២:៨–១៤; យ៉ូហាន ៨:៥៦.

១៨ មែនហើយ ហើយមើលចុះ ខ្ញុំសូមប្រាប់អ្នកថា ពុំគ្រាន់តែលោកអ័ប្រាហាំដឹងនូវការណ៍ទាំងនេះទេ តែមានមនុស្សជាច្រើន ទៀតមុនជំនាន់លោកអ័ប្រាហាំ ដែលត្រូវបានហៅតាមរបៀបនៃព្រះ មែនហើយ គឺតាមរបៀបនៃព្រះរាជបុត្រារបស់ទ្រង់; ហើយនេះ គឺដើម្បីបង្ហាញការណ៍នេះដល់ប្រជាជនអស់រយៈជាច្រើនពាន់ឆ្នាំ មុនការយាងមករបស់ទ្រង់ ថាសេចក្ដីប្រោសលោះនឹងមកដល់ពួកគេ ។

១៩ ហើយឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថា ចាប់តាំងពីជំនាន់លោកអ័ប្រាហាំមក មានពួកព្យាការីជាច្រើន បានធ្វើបន្ទាល់ពី ការណ៍ទាំងនេះ; មែនហើយ មើលចុះ ព្យាការីស៊ីណូសបានធ្វើបន្ទាល់យ៉ាងអង់អាច; ដោយហេតុនោះហើយ ទើបលោកត្រូវគេសម្លាប់ បង់ ។

២០ ហើយមើលចុះ ស៊ីណុកផង និងអេសីយ៉ាសផង និងអេសាយផង និងយេរេមា (យេរេមា គឺជាព្យាការីដដែលនោះដែលបានធ្វើ បន្ទាល់អំពីការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម) ហើយឥឡូវនេះ យើងដឹងថាក្រុងយេរូសាឡិមត្រូវបំផ្លាញចោលតាមពាក្យសំដីរបស់ យេរេមាមែន ។ ឱបើដូច្នោះមែន តើហេតុអ្វីក៏ព្រះរាជបុត្រានៃព្រះមិនយាងមក តាមសេចក្ដីព្យាករណ៍របស់លោក ?

២១ ហើយឥឡូវនេះ តើអ្នកនៅតែប្រកែកថា ក្រុងយេរូសាឡិមពុំត្រូវបំផ្លាញចោលឬ ? តើអ្នករាល់គ្នានិយាយថា ពួកបុត្រានៃសេដេគា ពុំត្រូវសម្លាប់ចោលឬ គឺទាំងអស់គ្នាលើកលែងតែមូលេកប៉ុណ្ណោះ ? មែនហើយ ហើយតើអ្នករាល់គ្នាមិនឃើញទេឬថា វង្សនៃសេដេគា នៅជាមួយនឹងយើង ហើយពួកគេត្រូវបណ្ដេញចេញពីដែនដីយេរូសាឡិម ? ប៉ុន្តែមើលចុះ នេះពុំទាន់អស់ទេ—

២២ លីហៃ ជាអយ្យកោរបស់យើង ត្រូវគេបណ្ដេញចេញពីក្រុងយេរូសាឡិម ពីព្រោះលោកបានធ្វើបន្ទាល់អំពីការណ៍ទាំងនេះ នីហ្វៃបាន ធ្វើបន្ទាល់ពីការណ៍ទាំងនេះដែរ ហើយពួកអយ្យកោយើងសឹងតែគ្រប់គ្នាផង រហូតមកដល់ពេលនេះ; មែនហើយ ពួកគេបាន ធ្វើបន្ទាល់ អំពីការយាងមកនៃព្រះគ្រីស្ទ ហើយបានទន្ទឹងចាំ ហើយបានអរីករាយដល់ថ្ងៃរបស់ទ្រង់ ដែលនឹងមកដល់ ។

២៣ ហើយមើលចុះ ទ្រង់គឺជាព្រះ ហើយទ្រង់គង់នៅជាមួយនឹងពួកគេ ហើយទ្រង់បានសម្ដែងឲ្យពួកគេឃើញថា ពួកគេត្រូវបានប្រោស លោះដោយទ្រង់ ហើយពួកគេបានថ្វាយសិរីល្អដល់ទ្រង់ ដោយសារអ្វីៗដែលនឹងមកដល់ ។

២៤ ហើយឥឡូវនេះ ដោយឃើញថា អ្នករាល់គ្នាដឹងការណ៍ទាំងនេះហើយ ហើយមិនអាចបដិសេធវាបានទេ លើកលែងតែអ្នករាល់ គ្នាកុហក ហេតុដូច្នេះហើយ អ្នករាល់គ្នាបានធ្វើអំពើបាប ព្រោះអ្នករាល់គ្នាបានបដិសេធការណ៍អស់ទាំងនេះ ទោះជាមានភស្តុតាងជា ច្រើន ដែលអ្នករាល់គ្នាបានទទួលក្ដី; មែនហើយ គឺអ្នករាល់គ្នាបានទទួលគ្រប់ការណ៍ទាំងអស់ ទាំងការណ៍នៅលើស្ថានសួគ៌ និងគ្រប់ ការណ៍ទាំងអស់ ដែលនៅលើផែនដីផង ទុកជាសាក្សីថា ការណ៍ទាំងនោះពិត ។

២៥ ប៉ុន្តែមើលចុះ អ្នករាល់គ្នាបានបដិសេធការពិត ហើយបានបះបោរទាស់នឹងព្រះដ៏បរិសុទ្ធរបស់អ្នក; ហើយសូម្បីនៅក្នុងពេលនេះផងដែរ ជាជាងសន្សំទ្រព្យសម្បត្តិទុកសំរាប់ខ្លួន នៅលើស្ថានសួគ៌ ជាកន្លែងដែលគ្មានអ្វីពុករលួយ ហើយជាកន្លែងដែលគ្មានអ្វីអាចមក ដែលមិនស្អាតស្អំ នោះអ្នករាល់គ្នាកំពុងគរសំរាប់ខ្លួន នូវសេចក្ដីឃោរឃៅ ទាស់នឹងថ្ងៃជំនុំជំរះ ។

២៦ មែនហើយ សូម្បីជានៅក្នុងពេលនេះ ក៏អ្នករាល់គ្នាកំពុងតែទុំដែរ ដោយព្រោះអំពើឃាតកម្មទាំងឡាយរបស់អ្នក និងអំពើកំផិត និងអំពើទុច្ចរិតរបស់អ្នក ចំពោះការបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច; មែនហើយ ហើយលើកលែងតែអ្នករាល់គ្នាប្រែចិត្ត បើពុំនោះសោត ទេ វានឹងមករកអ្នកក្នុងពេលដ៏ខ្លី ។

---

១៨ *ក* អាលម៉ា ១៣:១៩;
គ. និង ស. ៨៤:៦–១៦;
១៣៦:៣៧.
*ខ* ស.ប. បព្វជិតភាពមិលគីស្សាដែក.
១៩ *ក* អាលម៉ា ៣៤:៧.
២០ *ក* ១ នីហ្វៃ ១៩:១០;
៣ នីហ្វៃ ១០:១៥–១៦.
ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរដែលបាត់.
*ខ* អេសាយ ៥៣.
*គ* ១ នីហ្វៃ ៥:១៣; ៧:១៤.
*ឃ* យេរេ. ២៦:១៨; ១ នីហ្វៃ ១:៤.
២១ *ក* ២ នីហ្វៃ ៦:៨; អោមណៃ ១:១៥.
*ខ* ២ ពង្សាវ. ២៥:៧;
យេរេ. ៣៩:៦; ៥២:១០.
*គ* អេសេ. ១៧:២២–២៣;
ហេលេ. ៦:១០.
២២ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើតនិងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
២៤ *ក* អាលម៉ា ៣០:៤៤; ម៉ូសេ ៦:៦៣.
២៥ *ក* ម៉ូសាយ ២:៣៦–៣៨; ៣:១២.
*ខ* ហេលេ. ៥:៨;
៣ នីហ្វៃ ១៣:១៩–២១.
*គ* គ. និង ស. ១០:២០–២៣;
១២១:២៣–២៥.
២៦ *ក* ស.ប. អំពើសហាយស្មន់.

២៧ មែនហើយ មើលចុះ ឥឡូវនេះ វានៅឯមាត់ទ្វារអ្នកទៅហើយ; មែនហើយ ចូរអ្នករាល់គ្នាទៅឯវេទិកាជំនុំជំរះ ហើយស្វែងរកចុះ; ហើយមើលចុះ ចៅក្រមរបស់អ្នកត្រូវគេធ្វើឃាតហើយ ហើយលោកដេកនៅក្នុងថ្លុកឈាមរបស់លោក; ហើយលោកត្រូវបានធ្វើឃាត ដោយប្អូនរបស់លោក ដែលរកអង្គុយលើវេទិកាជំនុំជំរះ ។

២៨ ហើយមើលចុះ គេទាំងពីរនាក់នៅក្នុងក្រុមសម្ងាត់របស់អ្នក រីឯអ្នកបង្កើតឡើង គឺកាឌីអានតុន និងអាអាក្រក់ ដែលរកបំផ្លាញ ព្រលឹងមនុស្ស ៕

ជំពូកទី ៩

*ពួកអ្នកនាំសាររកឃើញមេចៅក្រមស្លាប់នៅឯវេទិកាជំនុំជំរះ — ពួកគេត្រូវដាក់គុក ហើយក្រោយមក ត្រូវបានដោះលែង — ដោយ ការបំភ្លឺ នោះនីហ្វៃប្រាប់ថា សិអានទុម ជាឃាតក — នីហ្វៃត្រូវបានទទួលស្គាល់ដោយមនុស្សខ្លះថា ជាព្យាការីម្នាក់ ។ ប្រមាណជាឆ្នាំ ២៣–២១ ម.គ.ស. ។*

មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលនីហ្វៃបាននិយាយពាក្យទាំងនេះហើយ នោះមានមនុស្សខ្លះ នៅក្នុងចំណោម ពួកគេ បានរត់ទៅឯវេទិកាជំនុំជំរះ; មែនហើយ គឺមានមនុស្សប្រាំនាក់ដែលទៅ ហើយពួកគេបាននិយាយគ្នានៅពេលគេទៅថា៖

២ មើលចុះ ឥឡូវនេះ យើងនឹងដឹងយ៉ាងច្បាស់ថា តើបុរសនេះជាព្យាការីមួយរូបឬទេ ហើយព្រះទ្រង់បានបញ្ជាលោកឲ្យព្យាករនូវ កិច្ចការដ៏អស្ចារ្យទាំងនេះដល់យើងឬទេ ។ មើលចុះ យើងមិនជឿថា ទ្រង់បានបញ្ជាទេ; មែនហើយ យើងក៏មិនជឿថា លោកជាព្យាការី មួយរូបដែរ; ទោះជាយ៉ាងណាក៏ដោយ បើសិនជាការណ៍ដែលលោកបាននិយាយអំពីមេចៅក្រមនេះពិតថា លោកស្លាប់ នោះយើងនឹង ជឿថា ពាក្យឯទៀតដែលលោកបាននិយាយមកនោះពិតមែនដែរ ។

៣ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានរត់នៅក្នុងសមត្ថភាពរបស់គេ ហើយបានមកដល់វេទិកាជំនុំជំរះ; ហើយមើលចុះ មេចៅក្រមបានដួលទៅលើដី ហើយបានដេកក្នុងថ្លុកឈាមរបស់លោកមែន ។

៤ ហើយឥឡូវនេះ មើលចុះ កាលពួកគេបានឃើញដូច្នេះ នោះពួកគេមានសេចក្ដីអស្ចារ្យណាស់ ដរាបដល់ពួកគេដួលចុះទៅដី; ព្រោះពួកគេពុំបានជឿពាក្យទាំងឡាយ ដែលនីហ្វៃបាននិយាយអំពីមេចៅក្រមសោះ ។

៥ ប៉ុន្តែឥឡូវនេះ កាលពួកគេបានឃើញ ទើបគេជឿ ហើយការភ័យខ្លាចក៏មានមកដល់ពួកគេ ខ្លាចក្រែងអស់ទាំងសេចក្ដីជំនុំជំរះ ដែលនីហ្វៃបាននិយាយនោះ នឹងធ្លាក់មកលើប្រជាជនមែន; ហេតុដូច្នេះហើយ ទើបពួកគេញ័រ ហើយដួលចុះទៅលើដី ។

៦ ឥឡូវនេះ នៅពេលចៅក្រមត្រូវគេធ្វើឃាតទៅមួយរំពេចនោះ — លោកត្រូវបានចាក់ដោយប្អូនរបស់លោក ដែលស្លៀក ពាក់ក្លែងខ្លួន ហើយវារត់គេចទៅបាត់ ហើយពួកអ្នកបំរើបានរត់ទៅប្រាប់ប្រជាជន ស្រែកប្រាប់គ្នាអំពីឃាតកម្មនៅក្នុងចំណោមពួកគេ;

៧ ហើយមើលចុះ ប្រជាជនបានប្រមូលគ្នាមកឯកន្លែងវេទិកាជំនុំជំរះ — ហើយមើលចុះ គេមានសេចក្ដីអស្ចារ្យណាស់ កាលគេបាន ឃើញមនុស្សប្រាំនាក់ ដួលទៅលើដីនោះ ។

៨ ហើយឥឡូវនេះ មើលចុះ ប្រជាជនពុំដឹងអ្វីសោះ អំពីហ្វូងមនុស្សដែលប្រមូលគ្នាទៅឯសួនរបស់នីហ្វៃ; ហេតុដូច្នេះហើយ ពួកគេបាននិយាយគ្នាថា៖ ពួកអ្នកទាំងនេះហើយដែលបានធ្វើឃាតចៅក្រមចោល ហើយព្រះទ្រង់បានវាយពួកគេ ដើម្បីកុំឲ្យពួកគេអាចរត់ គេចពីយើងបាន ។

៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចាប់អ្នកទាំងនោះ ហើយបានចងគេ ហើយដាក់គេក្នុងគុក ។ ហើយមានសេចក្ដី ប្រកាសមួយ ផ្ញើទៅក្រៅថា ចៅក្រមត្រូវស្លាប់ ហើយពួកឃាតកត្រូវចាប់ខ្លួនបាន ហើយត្រូវដាក់ទៅក្នុងគុក ។

១០ ហើយហេតុការណ៍បានកើតឡើងថា លុះស្អែកឡើងប្រជាជនបានប្រជុំគ្នាមក ដើម្បីកាន់ទុក្ខ ហើយតមអាហារ នៅឯពិធីបញ្ចុះ សពនៃលោកមេចៅក្រមដ៏មហិមា ដែលត្រូវបានស្លាប់ ។

១១ ម្ល៉ោះហើយ ពួកចៅក្រមទាំងនោះផង ដែលនៅឯសួនរបស់នីហ្វៃ ហើយបានឮពាក្យរបស់លោក ក៏បានប្រមូលគ្នាមកឯពិធីបញ្ចុះ សពនេះដែរ ។

១២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានស៊ើបសួរក្នុងចំណោមប្រជាជនថា៖ តើនៅឯណាទៅ ពួកអ្នកទាំងប្រាំ ដែលត្រូវបានចាត់ឲ្យទៅស៊ើបសួរអំពីមេចៅក្រមថា តើលោកបានស្លាប់

២៧ *ក* ហេលេ. ៩:៣, ១៥.
*ខ* ហេលេ. ៩:៦, ២៦–៣៨.
២៨ *ក* ហេលេ. ៦:២៦–៣០.
៩ ៣ *ក* ហេលេ. ៨:២៧.
៨ *ក* ហេលេ. ៧:១០.
១០ *ក* ស.ប. តម, តំណម.

ឬទេនោះ ? ហើយពួកគេបានឆ្លើយថា៖ អំពីអ្នកទាំងប្រាំ ដែល
លោកថា លោកបានចាត់ឲ្យទៅនោះ យើងមិនដឹងទេ ប៉ុន្តែមាន
មនុស្សប្រាំនាក់ ដែលជាឃាតក ដែលយើងបានដាក់ក្នុងគុកទុក ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ពួកចៅក្រមទាំងនោះ
ចង់ឲ្យគេនាំពួកអ្នកទាំងនោះមក ហើយពួកគេត្រូវបាននាំមក;
ហើយមើលចុះ ពួកគេគឺជាជនប្រាំនាក់ ដែលត្រូវបានចាត់ឲ្យទៅនោះ;
ហើយមើលចុះ ពួកចៅក្រមសាកសួរគេឲ្យដឹងអំពីរឿងនោះ ហើយ
ពួកគេបានប្រាប់អំពីអ្វីៗទាំងអស់ដែលគេបានធ្វើថា៖
១៤ យើងបានរត់ទៅដល់កន្លែងវេទិកាជំនុំជំរះ ហើយកាលពួក
យើងបានឃើញគ្រប់ការណ៍ទាំងអស់ ដូចដែលនីហ្វៃបានធ្វើបន្ទាល់
នោះពួកយើងមានសេចក្ដីអស្ចារ្យជាខ្លាំង ដរាបដល់ធ្វើឲ្យ
យើងដួលទៅលើដី; ហើយកាលយើងបានដឹងខ្លួនពីការណ៍
អស្ចារ្យឡើងវិញ មើលចុះ ពួកគេបានដាក់យើងក្នុងគុក ។
១៥ ឥឡូវនេះ រីឯចំពោះអ្នកធ្វើឃាតបុរសនេះ យើងមិនដឹងថា
នរណាជាអ្នកធ្វើទេ; ហើយយើងដឹងតែប៉ុណ្ណោះថា យើងបានរត់
មក តាមដែលលោកមានបំណង ហើយមើលចុះ លោកបាន
ស្លាប់ទៅហើយ តាមពាក្យសំដីរបស់នីហ្វៃ ។
១៦ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកចៅក្រម
បានអធិប្បាយរឿងនេះប្រាប់ដល់ប្រជាជន ហើយបាន
ស្រែកឡើងទាស់ នឹងនីហ្វៃថា៖ មើលចុះ យើងដឹងថា នីហ្វៃនេះ
ច្បាស់ជាបានរួមគំនិតជាមួយនឹងនរណាម្នាក់ ឲ្យសម្លាប់ចៅក្រម
ហើយបន្ទាប់មក លោក អាចប្រកាសការណ៍នេះដល់យើង
ដើម្បីលោកអាចប្រែចិត្តយើង ឲ្យទៅតាមសេចក្ដីជំនឿរបស់លោក
ដើម្បីលោកអាចលើកខ្លួនលោក ជាបុរសដ៏មហិមាម្នាក់ ជា
មនុស្សជំរើសរបស់ព្រះ និងជាព្យាការីម្នាក់ ។
១៧ ហើយឥឡូវនេះ មើលចុះ យើងនឹងស៊ើបសង្កេតបុរសនេះ
ហើយលោកនឹងទទួលសារភាពនូវកំហុសរបស់លោក ហើយ
ប្រាប់ឲ្យ យើងដឹងនូវឃាតកពិតប្រាកដដល់ចៅក្រមនេះ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា ជនប្រាំនាក់នោះត្រូវ
បានដោះលែង នៅក្នុងថ្ងៃពិធីបញ្ចុះសព ។ ទោះជាយ៉ាង
ណាក៏ដោយ គង់តែពួកគេបានតវ៉ានឹងពួកចៅក្រមចំពោះពាក្យ
ទាំងឡាយ ដែលបាននិយាយទាស់នឹងនីហ្វៃដែរ ហើយបាន
ប្រកែកនឹងពួកគេម្នាក់ម្ដងៗ ដរាបដល់ពួកគេបានផ្ចាញ់ផ្ចាលគេ ។
១៩ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបានបញ្ជាឲ្យចាប់
នីហ្វៃហើយចង ហើយនាំយកមកខាងមុខហ្វូងមនុស្សដែរ ហើយ
ពួកគេ បានចាប់ផ្ដើមសួរលោកដោយរបៀបផ្សេងៗ ដើម្បីពួកគេ
អាចចាប់កំហុសលោក ដើម្បីគេអាចចោទទោសប្រហារជីវិត
ដល់លោក —
២០ ដោយបាននិយាយទៅលោកថា៖ អ្នកជាជនផ្សំគំនិត;
តើអ្នកណាដែលបានធ្វើឃាតកម្មនេះ ? ឥឡូវនេះ ប្រាប់យើងមក
ហើយ ទទួលស្គាល់កំហុសរបស់អ្នកចុះ; ដោយបាននិយាយថា
មើលចុះ នេះគឺជាប្រាក់; ហើយយើងក៏នឹងឲ្យអ្នករួចជីវិតផង បើ
សិនជាអ្នកប្រាប់ យើង ហើយទទួលស្គាល់នូវការផ្សំគំនិតគ្នា
ដែលអ្នកបានធ្វើជាមួយនឹងវា ។
២១ ប៉ុន្តែនីហ្វៃបាននិយាយទៅពួកគេថា៖ នែ៎ ពួកអ្នកដែល
[ក]ឆ្កួតលីលាអើយ អ្នករាល់គ្នាដែលមានចិត្តមិនកាត់ស្បែក [ខ]អ្នក
រាល់គ្នា ដែលខ្វាក់ ហើយអ្នករាល់គ្នាដែលជាមនុស្សរឹងរូស
តើអ្នករាល់គ្នាដឹងថា តើព្រះអម្ចាស់របស់អ្នក នឹងទុកឲ្យអ្នក
បន្តការធ្វើបាបរបស់ អ្នកយូរដល់ណាទៅ ?
២២ ឱអ្នករាល់គ្នាគួរតែចាប់ផ្ដើមស្រែកទ្រហោរ ហើយ
[ក]ទួញយំ ព្រោះការបំផ្លិចបំផ្លាញដ៏ធំ ដែលកំពុងរង់ចាំអ្នកនៅ
ក្នុងពេលនេះ លើកលែងតែអ្នកប្រែចិត្ត ។
២៣ មើលចុះ អ្នករាល់គ្នានិយាយថា ខ្ញុំបានផ្សំគំនិតជាមួយ
មនុស្សម្នាក់ ឲ្យទៅធ្វើឃាតសីស្សូរាំ ដែលជាមេចៅក្រម
របស់យើង ។ ប៉ុន្តែមើលចុះ ខ្ញុំសូមប្រាប់អ្នកថា នេះគឺដោយ
ព្រោះខ្ញុំបានធ្វើបន្ទាល់ដល់អ្នក ដើម្បីឲ្យអ្នករាល់គ្នាអាចដឹង
អំពីការណ៍នេះ មែនហើយ គឺដើម្បីជាទីបន្ទាល់មួយដល់អ្នកថា
ខ្ញុំបានដឹងនូវអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ដែល
មាននៅក្នុងចំណោមអ្នករាល់គ្នា ។
២៤ ហើយដោយព្រោះខ្ញុំបានធ្វើការនេះ អ្នករាល់គ្នានិយាយថា
ខ្ញុំបានផ្សំគំនិតជាមួយមនុស្សម្នាក់ ឲ្យគេធ្វើការនេះ; មែនហើយ
ដោយព្រោះខ្ញុំបានបង្ហាញដល់អ្នកនូវទីសំគាល់នេះ ទើបអ្នករាល់
គ្នាខឹងនឹងខ្ញុំ ហើយរកបំផ្លាញជីវិតខ្ញុំទៅវិញ ។
២៥ ហើយឥឡូវនេះ មើលចុះ ខ្ញុំនឹងបង្ហាញដល់អ្នក នូវ
ទីសំគាល់មួយទៀត ហើយមើលថា តើអ្នករាល់គ្នានឹង
រកបំផ្លាញខ្ញុំដោយ ការណ៍នេះឬ ។
២៦ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា៖ ចូរទៅផ្ទះរបស់សីអានទុម
ដែលជា[ក]ប្អូនរបស់សីស្សូរាំ ហើយនិយាយទៅគាត់ថា—
២៧ តើនីហ្វៃ ដែលជាព្យាការីក្លែងក្លាយ ជាអ្នកដែលព្យាករ
អំពីការអាក្រក់ជាច្រើន អំពីប្រជាជននេះបានផ្សំគំនិតជាមួយនឹង

២១ *ក* កិច្ចការ ៧:៥១.
*ខ* ស.ប. ការបះបោរ.
២២ *ក* ម៉ូសាយ ៧:២៤.
២៦ *ក* ហេលេ. ៨:២៧.

អ្នក នៅក្នុងការផ្សំគំនិតនេះ អ្នកបានធ្វើឃាតសិស្សរាំ ដែលត្រូវជាបងអ្នកឬ ?
២៨ ហើយមើលចុះ គាត់នឹងប្រាប់អ្នកថា៖ ទេ ។
២៩ ហើយអ្នករាល់គ្នានឹងនិយាយទៅគាត់ថា៖ តើអ្នកបានធ្វើឃាតបងអ្នកឬ ?
៣០ ហើយគាត់នឹងឈរដោយភិតភ័យ ហើយមិនដឹងជាត្រូវនិយាយអ្វីទេ ។ ហើយមើលចុះ គាត់នឹងប្រកែកចំពោះអ្នក; ហើយគាត់នឹង ធ្វើហាក់ដូចជាគាត់មានសេចក្ដីអស្ចារ្យជាខ្លាំង; ទោះជាយ៉ាងណាក៏ដោយ គង់តែគាត់នឹងប្រកាសដល់អ្នកថាគាត់ឥតទោសសោះ ។
៣១ ប៉ុន្ដែមើលចុះ អ្នករាល់គ្នានឹងពិនិត្យគាត់មើល ហើយអ្នករាល់គ្នានឹងរកឃើញឈាម ជាប់លើជាយអាវក្រៅរបស់គាត់ ។
៣២ ហើយកាលអ្នករាល់គ្នាបានឃើញយ៉ាងនេះ អ្នករាល់គ្នានឹងនិយាយថា៖ តើឈាមនេះមកពីណាមក ? តើពួកយើងមិនដឹងថា នេះគឺជាឈាមរបស់បងអ្នកឬ ?
៣៣ ហើយនៅពេលនោះ គាត់នឹងញ័រ ហើយមានសម្បុរស្លាំងហាក់បីដូចជាសេចក្ដីស្លាប់បានមករកគាត់ ។
៣៤ ហើយនៅពេលនោះ អ្នករាល់គ្នានឹងនិយាយថា៖ ដោយសារការភិតភ័យនេះ និងភាពស្លេកស្លាំងនេះ ដែលមានមកលើមុខ របស់អ្នក មើលចុះ ពួកយើងដឹងថា អ្នកមានទោសហើយ ។
៣៥ ហើយនៅពេលនោះ ការភិតភ័យដ៏ធំនឹងមកដល់គាត់; ហើយនៅពេលនោះ គាត់នឹងទទួលថ្លែងប្រាប់អ្នក ហើយឈប់ប្រកែកថា គាត់មិនបានធ្វើឃាតកម្មនេះតទៅទៀត ។
៣៦ ហើយនៅពេលនោះ គាត់នឹងនិយាយទៅអ្នកថា ខ្ញុំ នីហ្វៃមិនបានដឹងអ្វីអំពីរឿងនេះទេ លើកលែងតែវាត្រូវបានប្រទានដល់ខ្ញុំ ដោយព្រះចេស្ដានៃព្រះប៉ុណ្ណោះ ។ ហើយនៅពេលនោះ អ្នករាល់គ្នានឹងដឹងថា ខ្ញុំជាមនុស្សស្លូតត្រង់ម្នាក់ ហើយថា ខ្ញុំត្រូវបានចាត់មក ដល់អ្នកអំពីព្រះ ។
៣៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានទៅ ហើយបានធ្វើ គឺដូចដែលនីហ្វៃបាននិយាយទៅពួកគេ ។ ហើយមើលចុះ ពាក្យទាំងឡាយដែលលោកបាននិយាយគឺមានពិតមែន; ព្រោះស្របតាមពាក្យទាំងនោះ នោះវាបានប្រកែក ហើយស្របតាមពាក្យ ទាំងនោះ នោះវាបានទទួលសារភាពដែរ ។
៣៨ ហើយវាត្រូវបាននាំយកមក ដើម្បីបញ្ជាក់ថា គឺវាផ្ទាល់ពិតជាឃាតក ដរាបដល់ធ្វើឲ្យមនុស្សប្រាំនាក់នោះ ត្រូវបានដោះលែង ឲ្យមានឥស្សរភាព ហើយនីហ្វៃក៏ដូច្នោះដែរ ។
៣៩ ហើយមានពួកសាសន៍នីហ្វៃខ្លះ ដែលជឿដល់ពាក្យពេចន៍របស់នីហ្វៃ; ហើយមានខ្លះទៀតដែលជឿ ដោយព្រោះទីបន្ទាល់របស់ មនុស្សប្រាំនាក់នោះ ព្រោះពួកគេត្រូវបានប្រែចិត្តជឿនៅពេលពួកគេនៅក្នុងគុក ។
៤០ ហើយឥឡូវនេះ មានមនុស្សខ្លះនៅក្នុងចំណោមប្រជាជនដែលបាននិយាយថា នីហ្វៃគឺជាព្យាការីមួយរូប ។
៤១ ហើយមានអ្នកឯទៀត ដែលបាននិយាយថា៖ មើលចុះ លោកគឺជាព្រះមួយអង្គ ព្រោះបើពុំមែនជាព្រះមួយអង្គទេ នោះលោក ពុំអាចដឹងនូវគ្រប់ការណ៍ទាំងអស់បានទេ ។ ត្បិតមើលចុះ លោកបានប្រាប់យើងនូវគំនិតទាំងឡាយនៃចិត្តរបស់យើង ហើយព្រមទាំង បានប្រាប់យើងអំពីការណ៍ទាំងឡាយ ហើយលោកថែមទាំងបាននាំមកឲ្យយើងស្គាល់ឃាតកដ៏ពិតប្រាកដ
ទៅលើលោកមេចៅក្រម របស់យើង ៕

ជំពូកទី ១០

*ព្រះអម្ចាស់ទ្រង់ប្រទានឲ្យនីហ្វៃ នូវអំណាចភ្ជាប់ — លោកត្រូវបានប្រទានអំណាចចង និងស្រាយនៅលើផែនដី និងនៅលើស្ថានសួគ៌ — លោកបញ្ជាឲ្យប្រជាជនប្រែចិត្ត បើពុំនោះសោតទេ នឹងត្រូវវិនាស — ព្រះវិញ្ញាណនាំលោកពីហ្វូងមនុស្សមួយ ទៅហ្វូងមនុស្សមួយទៀត ។ ប្រមាណជាឆ្នាំ ២១–២០ ម.គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា មានការបែកបាក់មួយផុសឡើងនៅក្នុងចំណោមប្រជាជន ដរាបដល់ពួកគេបានបែកគ្នា ហើយចែកផ្លូវគ្នារៀងៗខ្លួន ចោលនីហ្វៃតែម្នាក់ឯង នៅពេលដែលលោកកំពុងតែឈរនៅកណ្ដាលពួកគេ ។
២ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃបានដើរសំដៅទៅឯផ្ទះរបស់លោក ហើយសញ្ជឹងគិតដល់ការណ៍ទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានបង្ហាញដល់លោក ។
៣ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែលលោកកំពុងតែសញ្ជឹងគិត — ដោយទន់ខ្សោយជាខ្លាំង ដោយព្រោះអំពើ ទុច្ចរិតរបស់ប្រជាជននៃសាសន៍នីហ្វៃ កិច្ចការសម្ងាត់ទាំងឡាយ នៃសេចក្ដីងងឹតរបស់គេ និងអំពើឃាតកម្មទាំងឡាយរបស់គេ និងអំពើ ប្លន់របស់គេ និងអំពើទុច្ចរិតគ្រប់បែបយ៉ាងរបស់គេ — ហើយហេតុការណ៍បានកើតឡើងថា នៅពេល

១០ ២*ក* ស.ប. រំពឹងគិត.

ដែលលោកកំពុងតែសញ្ជឹងគិត នៅក្នុងចិត្តលោកនៅឡើយនោះ
មើលចុះ មានសម្លេងមួយបន្លឺមកលោកថា៖
៤ នីហ្វៃអើយ អ្នកមានពរហើយ ព្រោះការណ៍ទាំងឡាយ
ដែលអ្នកបានធ្វើនោះ; ត្បិតយើងបានឃើញថា អ្នកបានប្រកាស
ប្រាប់ពាក្យ របស់យើង ដោយ[ក]គ្មាននឿយហត់ គឺជាពាក្យដែល
យើងបានប្រទានដល់អ្នក ឲ្យដល់ប្រជាជននេះ ។ ហើយអ្នកពុំបាន
ខ្លាចពួកគេ ហើយពុំ បានរកជីវិតរបស់[ខ]អ្នកផ្ទាល់ ប៉ុន្តែបាន
ស្វែងរក[គ]បំណងរបស់យើងវិញ ហើយបានកាន់តាមបញ្ញត្តិទាំង
ឡាយរបស់យើង ។
៥ ហើយឥឡូវនេះ ពីព្រោះអ្នកបានធ្វើការនេះ
ដោយឥតនឿយហត់ដូច្នេះ មើលចុះ យើងនឹងប្រទានពរឲ្យអ្នក
រហូតតទៅ; ហើយយើង នឹងធ្វើឲ្យអ្នកខ្លាំងពូកែ នៅក្នុងសំដី
និងក្នុងចរិយា ក្នុងសេចក្ដីជំនឿ និងក្នុងកិច្ចការទាំងឡាយ;
មែនហើយ គឺដើម្បី[ខ]ឲ្យគ្រប់[ក]ការណ៍ទាំងអស់ ត្រូវបានសំរេច
ដល់អ្នក ស្របតាមពាក្យរបស់អ្នក ព្រោះអ្នកនឹង[គ]ពុំប្រាថ្នាអ្វី
ដែលផ្ទុយពីបំណងរបស់យើងឡើយ ។
៦ មើលចុះ អ្នកជានីហ្វៃ ហើយយើងជាព្រះ ។ មើលចុះ យើង
ប្រកាសប្រាប់ការណ៍នេះដល់អ្នក នៅវត្តមាននៃពួកទេវតា
របស់យើង ថា អ្នកនឹងមានអំណាចលើប្រជាជននេះ ហើយ
នឹងវាយផែនដីនេះ ដោយ[ក]អំណត់អត់ និងដោយជម្ងឺអាសន្នរោគ
និងការបំផ្លិចបំផ្លាញ ស្របតាមអំពើទុច្ចរិតរបស់ប្រជាជននេះ ។
៧ មើលចុះ យើងប្រទានឲ្យអ្នកនូវអំណាចថា ទោះ
ជាអ្វីក៏ដោយដែលអ្នកនឹង[ក]ភ្ជាប់នៅលើផែនដី ក៏នឹងត្រូវបាន
ភ្ជាប់នៅលើស្ថានសួគ៌ ដែរ; ហើយទោះជាអ្វីក៏ដោយដែលអ្នក
នឹងស្រាយនៅលើផែនដី ក៏នឹងត្រូវបានស្រាយលើស្ថានសួគ៌ដែរ;
ម្ល៉ោះហើយ អ្នកនឹងមានអំណាច នៅក្នុងចំណោមប្រជាជននេះ ។
៨ ម្ល៉ោះហើយ បើសិនជាអ្នកនឹងនិយាយទៅកាន់ព្រះវិហា
របរិសុទ្ធនេះ ឲ្យវាបែកទៅជាពីរ នោះវានឹងបានសំរេចដូច្នោះ ។
៩ ហើយបើសិនជាអ្នកនឹងនិយាយទៅកាន់[ក]ភ្នំនេះថា៖
ចូររងបន្ទាប ហើយរាបស្មើចុះ នោះវានឹងធ្វើបានសំរេចដូច្នោះ។
១០ ហើយមើលចុះ បើសិនជាអ្នកនឹងនិយាយថា ព្រះទ្រង់
នឹងវាយប្រជាជននេះ នោះវានឹងកើតឡើងដូច្នោះ ។

១១ ហើយឥឡូវនេះ មើលចុះ យើងបញ្ជាអ្នកថា អ្នកត្រូវទៅ
ហើយប្រកាសប្រាប់ដល់ប្រជាជននេះថា ព្រះអម្ចាស់ដ៏ជាព្រះ
គឺជាព្រះ ដ៏មានមហិទ្ធិឫទ្ធិ ទ្រង់មានព្រះបន្ទូលដូច្នេះថា៖
លើកលែងតែអ្នករាល់គ្នាប្រែចិត្ត បើពុំនោះសោតទេ នោះអ្នក
រាល់គ្នានឹងត្រូវបានវាយ គឺរហូតដល់[ក]សេចក្ដីបំផ្លិចបំផ្លាញផង ។
១២ ហើយមើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
កាលព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទាំងនេះ ទៅកាន់នីហ្វៃរួចហើយ
នោះលោកបានឈប់ ហើយមិនបានទៅផ្ទះរបស់លោកទេ ប៉ុន្តែ
បានត្រឡប់ទៅឯហ្វូងមនុស្សទាំងឡាយ ដែលនៅ
រាយលើផ្ទៃដែនដីវិញ ហើយបានចាប់ផ្ដើមប្រកាសដល់ពួកគេ
នូវព្រះបន្ទូលនៃព្រះអម្ចាស់ ដែលមានព្រះបន្ទូលមកលោកនោះ
អំពីការបំផ្លិចបំផ្លាញរបស់ពួកគេ បើសិនជាពួកគេមិនប្រែចិត្តទេ ។
១៣ ឥឡូវនេះ មើលចុះ ទោះជាមានអព្ភូតហេតុដ៏ធំ ដែលនីហ្វៃ
បានធ្វើ ដោយប្រាប់ពួកគេអំពីសេចក្ដីស្លាប់របស់លោកមេចៅក្រម
នោះក៏ដោយ គង់តែពួកគេបានធ្វើចិត្តរឹងរូស ហើយពុំបាន
ស្ដាប់តាមព្រះបន្ទូលទាំងឡាយ នៃព្រះអម្ចាស់ឡើយ ។
១៤ ហេតុដូច្នេះហើយ នីហ្វៃបានប្រកាសទៅពួកគេ នូវព្រះ
បន្ទូលនៃព្រះអម្ចាស់ថា៖ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា
លើកលែងតែអ្នករាល់គ្នាប្រែចិត្ត បើពុំនោះសោតទេ នោះអ្នក
រាល់គ្នានឹងត្រូវបានវាយ គឺរហូតដល់សេចក្ដីបំផ្លិចបំផ្លាញផង ។
១៥ ហើយហេតុការណ៍បានកើតឡើងថា កាលនីហ្វៃបាន
ប្រកាសទៅពួកគេនូវព្រះបន្ទូលហើយ មើលចុះ ពួកគេនៅតែធ្វើ
ចិត្តរឹងរូស ហើយមិនព្រមស្ដាប់តាមពាក្យសំដីរបស់លោកសោះ;
ហេតុដូច្នេះហើយ ពួកគេបានជេរប្រមាថលោក ហើយបាន
រកចាប់លោក ដើម្បី ពួកគេអាចដាក់លោកទៅក្នុងគុក ។
១៦ ប៉ុន្តែមើលចុះ ព្រះចេស្ដានៃព្រះស្ថិតនៅជាមួយនឹងលោក
ហើយពួកគេពុំអាចចាប់លោក យកទៅដាក់គុកបានឡើយ ព្រោះ
លោកត្រូវបានព្រះវិញ្ញាណយកទៅ ហើយនាំចេញពីកណ្ដាល
ពួកគេ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា លោកបានទៅមុខ
នៅក្នុងព្រះវិញ្ញាណ គឺពីហ្វូងមនុស្សមួយ ទៅហ្វូងមនុស្សមួយ
ទៀត ដោយបានប្រកាសព្រះបន្ទូលនៃព្រះ គឺរហូតដល់លោកបាន

៤ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* ស.ប. បូជា, យញ្ញបូជា.
*គ* ៣ នីហ្វៃ ១១:១១.
៥ *ក* ៣ នីហ្វៃ ១៨:២០;
គ. និង ស. ៨៨:៦៣–៦៥.
*ខ* អេណុស ១:១២.
*គ* ២ នីហ្វៃ ៤:៣៥;
គ. និង ស. ៤៦:៣០.
៦ *ក* ហេលេ. ១១:៤–១៨.
៧ *ក* ម៉ាថាយ ១៦:១៩.
ស.ប. ភ្ជាប់, ការភ្ជាប់.
៩ *ក* ម៉ាថាយ ១៧:២០; យ៉ាកុប ៤:៦;
មរមន ៨:២៤; អេធើរ ១២:៣០.
១១ *ក* ហេលេ. ៥:២.

ប្រកាសព្រះបន្ទូល ទៅពួកគេទាំងអស់គ្នា ឬបានផ្សាយទៅក្នុង
ចំណោម ប្រជាជនទាំងអស់ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេពុំព្រម
ស្ដាប់តាមពាក្យសំដីរបស់លោកទេ; ហើយក៏ចាប់ផ្ដើមមានការ
ទាស់ទែងគ្នា ដរាបដល់ពួកគេបានបែកគ្នា ហើយបាន
ចាប់ផ្ដើមសម្លាប់គ្នាទៅវិញទៅមកដោយដាវ ។
១៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីចិតសិបមួយក្នុងរជ្ជកាលនៃ
ពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ៕

---

ជំពូកទី ១១

*នីហ្វៃសូមឲ្យព្រះអម្ចាស់ជំនួសសង្គ្រាមដោយអំណត់អត់ — មនុស្សជាច្រើនវិនាស — ពួកគេប្រែចិត្ត ហើយនីហ្វៃបួងសួងដល់ព្រះអម្ចាស់ សូមឲ្យមានភ្លៀង — នីហ្វៃ និងលីហៃ ទទួលវិវរណៈជាច្រើន — ពួកចោរកាឌីអានតុនបង្កប់ខ្លួននៅក្នុងដែនដី ។ ប្រមាណជាឆ្នាំ ២០–៦ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីចិតសិ
បពីរក្នុងរជ្ជកាលនៃពួកចៅក្រម នោះការទាស់ទែងគ្នាទាំងឡាយ
បាន កើតឡើង ដរាបដល់មានសង្គ្រាមទាំងឡាយទូទៅអស់
ទាំងដែនដី នៅក្នុងចំណោមប្រជាជននីហ្វៃទាំងអស់ ។
២ ហើយគឺក្រុមចោរសម្ងាត់នេះហើយដែលបានបន្តការ
បំផ្លិចបំផ្លាញ និងអំពើទុច្ចរិតនេះ ។ ហើយសង្គ្រាមនេះ
បានកើតឡើងអស់ ពេញមួយឆ្នាំ; ហើយនៅក្នុងឆ្នាំទីចិតសិបបី
វាក៏បានបន្តទៅដែរ ។
៣ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនេះ នីហ្វៃ
បានអំពាវនាវដល់ព្រះអម្ចាស់ថា៖
៤ ឱព្រះអម្ចាស់អើយ សូមទ្រង់កុំទុកឲ្យប្រជាជននេះត្រូវ
បំផ្លាញ ដោយដាវឡើយ; តែឱព្រះអម្ចាស់អើយ សូមឲ្យមាន
អំណត់អត់មួយ នៅក្នុងដែនដីវិញនោះជាការប្រសើរជាង
ដើម្បីដាស់រំឭលពួកគេឲ្យនឹកចាំដល់ព្រះអម្ចាស់ ជាព្រះ
របស់គេ ហើយប្រហែលជាពួកគេ នឹងប្រែចិត្ត ហើយបែរមក
រកទ្រង់វិញ ។
៥ ហើយការណ៍នោះត្រូវបានសំរេច ស្របតាមពាក្យសំដី
របស់នីហ្វៃមែន ។ ហើយមានអំណត់អត់មួយយ៉ាងធំ នៅលើ
ដែនដីនេះ នៅក្នុងចំណោមប្រជាជននីហ្វៃទាំងអស់ ។ ហើយនៅ
ក្នុងឆ្នាំទីចិតសិបបួន អំណត់អត់បានបន្តទៅយ៉ាងនេះ ហើយការ
បំផ្លិចបំផ្លាញបាន ឈប់ដោយដាវ តែត្រឡប់ទៅជាឈឺចាប់
ដោយអំណត់អត់ទៅវិញ ។
៦ ហើយការបំផ្លិចបំផ្លាញនេះ ក៏បានបន្តទៅទៀត នៅក្នុង
ឆ្នាំទីចិតសិបប្រាំ ។ ព្រោះដែនដីត្រូវវាយឲ្យរាំងស្ងួត ហើយពុំ
ផ្ដល់ ធញ្ញជាតិ នៅក្នុងរដូវច្រូតកាត់សោះ; ហើយដែនដី
ទាំងមូលត្រូវវាយ ទាំងក្នុងចំណោមពួកសាសន៍លេមិន ក៏ដូចនៅ
ក្នុងចំណោមពួក សាសន៍នីហ្វៃដែរ ដើម្បីពួកគេត្រូវវាយ
ឲ្យគេវិនាសរាប់ពាន់នាក់ នៅក្នុងភាគទាំងឡាយនៃដែនដី ដែល
ទុច្ចរិតច្រើន ។
៧ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបាន
ឃើញថា ពួកគេជិតវិនាសដោយអំណត់អត់ហើយ នោះពួកគេ
បានចាប់ផ្ដើម នឹកឃើញដល់ព្រះអម្ចាស់ ជាព្រះរបស់គេ ហើយ
ពួកគេបានចាប់ផ្ដើមនឹកឃើញ ដល់ពាក្យសំដីរបស់នីហ្វៃ ។
៨ ហើយប្រជាជនបានចាប់ផ្ដើមអង្វរ ដល់ពួកមេចៅក្រម
របស់គេ និងពួកមេដឹកនាំរបស់គេ ឲ្យគេទៅនិយាយនឹងនីហ្វៃថា៖
មើលចុះ យើងដឹងថា លោកជាអ្នកសំណប់នៃព្រះ ហេតុ
ដូច្នេះហើយ សូមអំពាវនាវទៅព្រះអម្ចាស់ ជាព្រះរបស់យើង
ឲ្យទ្រង់បង្វែរអំណត់អត់ នេះចេញពីយើងទៅ ក្រែងលោពាក្យ
ទាំងអស់ដែលលោកបាននិយាយ អំពីការបំផ្លិចបំផ្លាញយើង នឹង
បានសំរេចមែន ។
៩ ហើយហេតុការណ៍បានកើតឡើងថា ពួកចៅក្រមបាននិយាយ
នឹងនីហ្វៃ ស្របតាមពាក្យទាំងឡាយដែលពួកគេចង់ឲ្យនិយាយនោះ។
ហើយហេតុការណ៍បានកើតឡើងថា កាលនីហ្វៃបានឃើញថា
ប្រជាជនបានប្រែចិត្ត ហើយបានបន្ទាបខ្លួន ទាំងស្លៀកសំពត់ធ្មៃ
នោះលោកបានអំពាវនាវដល់ព្រះអម្ចាស់ទៀតថា៖
១០ ឱព្រះអម្ចាស់អើយ មើលន៏ ប្រជាជននេះបានប្រែចិត្ត
ហើយ; ហើយពួកគេបានបោសជម្រះក្រុមកាឌីអានតុន ពីក្នុង
ចំណោម ពួកគេហើយ ដរាបដល់ពួកវាត្រូវបាត់បង់អស់ ហើយ
ពួកវាបានលាក់ផែនការសម្ងាត់របស់វានៅក្នុងដី ។
១១ ឥឡូវនេះ ឱព្រះអម្ចាស់អើយ ដោយភាពទន់ទាបរបស់
ពួកគេ សូមព្រះអង្គដកសេចក្ដីពិរោធរបស់ទ្រង់ចេញ ហើយសូម
សេចក្ដីពិរោធរបស់ព្រះអង្គបានស្ងប់ នៅក្នុងការបំផ្លិចបំផ្លាញពួក
ជនទុច្ចរិតទាំងនោះ ដែលព្រះអង្គបានបំផ្លាញរួចមកហើយ ។
១២ ឱព្រះអម្ចាស់អើយ សូមព្រះអង្គដកសេចក្ដីពិរោធរបស់

---

១១ ២*ក* ហេលេ. ៦:១៨–២៤;
១១:២៥–២៦.
៤ *ក* ១ ពង្សាវ. ១៧:១; ហេលេ. ១០:៦.
៧ *ក* ហេលេ. ១២:៣.
៨ *ក* ហេលេ. ១០:១១–១៤.

ព្រះអង្គចេញ ព្រះពរ សេចក្ដីពិរោធដ៏ខ្លាំងក្លា ហើយសូមធ្វើឲ្យ
អំណត់អត់ នៅលើដែនដីនេះបាត់អស់ទៅ ។
១៣ ឱព្រះអម្ចាស់អើយ សូមព្រះអង្គមេត្តាឮដល់ទូលបង្គំ
ហើយធ្វើឲ្យការណ៍នេះបានសំរេច ស្របតាមពាក្យសំដីរបស់ទូល
បង្គំផង ហើយសូមធ្វើឲ្យមានភ្លៀងធ្លាក់មកលើផ្ទៃផែនដី ដើម្បីឲ្យ
ដីអាចនាំមកនូវផ្លែ និងធញ្ញជាតិនៅក្នុងរដូវប្រូតកាត់ ។
១៤ ឱព្រះអម្ចាស់អើយ ព្រះអង្គបានឮពាក្យទាំងឡាយ
របស់ទូលបង្គំ កាលទូលបង្គំបានទូលថា សូមឲ្យមានអំណត់មួយ
ដើម្បីឲ្យគ្រោះ អាសន្ននៃដាវអាចបានឈប់; ហើយទូលបង្គំដឹងថា
ព្រះអង្គនឹងឮពាក្យទាំងឡាយរបស់ទូលបង្គំ នៅពេលនេះ
ព្រោះព្រះអង្គមានបន្ទូល ថាៈ បើសិនជាប្រជាជននេះប្រែចិត្ត យើង
នឹងលើកលែងឲ្យគេ ។
១៥ ព្រះពរ ឱព្រះអម្ចាស់អើយ ហើយព្រះអង្គទតឃើញថា
ពួកគេបានប្រែចិត្តហើយ ដោយព្រោះអំណត់អត់ និងជម្ងឺ
អាសន្នរោគ និងការបំផ្លិចបំផ្លាញ ដែលកើតឡើងដល់ពួកគេ ។
១៦ ហើយឥឡូវនេះ ឱព្រះអម្ចាស់អើយ សូមព្រះអង្គដកសេចក្ដី
ពិរោធរបស់ព្រះអង្គចេញ ហើយសាកល្បងមើលជាថ្មី បើសិន
ជាពួក គេនឹងបំរើព្រះអង្គឬអី ? ហើយបើយ៉ាងដូច្នោះមែន ឱព្រះ
អម្ចាស់អើយ ព្រះអង្គអាចប្រទានពរដល់ពួកគេ ស្របតាមព្រះបន្ទូល
របស់ព្រះ អង្គ ដែលព្រះអង្គបានថ្លែងចុះ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីចិតសិបប្រាំ
មួយ ព្រះអម្ចាស់ទ្រង់បានបំបែរសេចក្ដីពិរោធរបស់ទ្រង់ចេញ
ពីប្រជាជន ហើយធ្វើឲ្យភ្លៀងធ្លាក់មកលើផែនដី ដរាបដល់វាបាន
នាំមកនូវផល្លានុផលក្នុងរដូវផ្លែ ។ ហើយហេតុការណ៍បានកើត
ឡើងថា វាបាននាំមកនូវធញ្ញជាតិរបស់វា នៅក្នុងរដូវប្រូតកាត់ ។
១៨ ហើយមើលចុះ ប្រជាជនបានអររីករាយ ហើយសរសើរ
ដំកើងដល់ព្រះ ហើយផ្ទៃដែនដីទាំងមូលបានពោរពេញទៅដោយការ
អររីករាយ; ហើយពួកគេបានឈប់រកបំផ្លាញនីហ្វៃទៀត ប៉ុន្តែ
ពួកគេបានគោរពលោកថា ជាព្យាការីដ៏ធំម្នាក់ ហើយជាអ្នក
សំណប់នៃព្រះ ដែលមានអានុភាព និងសិទ្ធិអំណាចដ៏ធំ ដែល
បានប្រទានឲ្យលោកពីព្រះ ។
១៩ ហើយមើលចុះ លីហៃ ដែលត្រូវជាប្អូនរបស់លោក
ក៏មិនអន់ជាងលោកប៉ុន្មានទេ ចំពោះការណ៍ទាំងឡាយដែល
ទាក់ទងទៅ នឹងសេចក្ដីសុចរិត ។
២០ ម្ល៉ោះហើយ ហេតុការណ៍បានកើតឡើងថា ប្រជាជន
នីហ្វៃបានចាប់ផ្ដើមចំរើនឡើងទៀតនៅលើដែនដី ហើយបាន
ចាប់ផ្ដើម កសាងទីកន្លែងទាំងឡាយ ដែលចោលទទេ ហើយបាន
ចាប់ផ្ដើមកើនចំនួនឡើង និងរាលធំឡើង គឺរហូតដល់ពួកគេ
បាននៅពាសពេញ លើផ្ទៃដែនដីទាំងមូល ទាំងខាងជើង និងខាង
ត្បូង ពីសមុទ្រខាងលិច ទៅដល់សមុទ្រខាងកើត ។
២១ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីចិតសិបប្រាំមួយ
បានចប់ទៅក្នុងសេចក្ដីសុខសាន្ត ។ ហើយឆ្នាំទីចិតសិបប្រាំពីរ
បានចាប់ផ្ដើមក្នុងសេចក្ដីសុខសាន្ត; ហើយសាសនាចក្របាន
រាលដាលទូទៅលើផ្ទៃដែនដីទាំងអស់; ហើយប្រជាជនភាគច្រើន
ទាំងសាសន៍នីហ្វៃ និងសាសន៍លេមិន បាននៅក្នុងសាសនាចក្រ;
ហើយពួកគេមានសេចក្ដីសុខសាន្ត ដ៏ធំក្រៃលែងនៅលើដែនដី;
ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីចិតសិបប្រាំពីរទៅ ។
២២ ហើយពួកគេក៏មានសេចក្ដីសុខសាន្តដែរ នៅក្នុង
ឆ្នាំទីចិតសិបប្រាំបី លើកលែងតែមានការទាស់ទែងគ្នាខ្លះ
អំពីគោលចំណុច ទាំងឡាយនៃលទ្ធិ ដែលត្រូវបានដាក់ដោយ
ពួកព្យាការី ។
២៣ ហើយក្នុងឆ្នាំទីចិតសិបប្រាំបួន ក៏ចាប់ផ្ដើមមានការវិវា
ទជាខ្លាំង ។ ប៉ុន្តែហេតុការណ៍បានកើតឡើងថា នីហ្វៃ និងលីហៃ
និងបងប្អូនរបស់គេជាច្រើន ដែលដឹងនូវគោលចំណុចពិតនៃលទ្ធិ
ដោយមានវិវរណៈជាច្រើនរាល់ៗថ្ងៃ ហេតុដូច្នេះហើយ ទើបពួក
គេ បានផ្សាយដល់ប្រជាជន ដរាបដល់គេបានបញ្ចប់ការវិវាទ
របស់គេ នៅក្នុងឆ្នាំដដែលនោះ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីប៉ែតសិ
បក្នុងរជ្ជកាលនៃពួកចៅក្រម ទៅលើប្រជាជននីហ្វៃ នោះមានពួក
អ្នក បែកចេញពីប្រជាជននីហ្វៃមួយចំនួន ដែលពីប៉ុន្មានឆ្នាំមុន
បានចុះចូលទៅខាងសាសន៍លេមិន ហើយបានដាក់ឈ្មោះខ្លួនថា
ជាសាសន៍ លេមិន ហើយមួយចំនួនទៀតផង ដែលជាពូជពង្ស
លេមិនសុទ្ធ ត្រូវបានចាក់រុកឲ្យមានកំហឹងដោយពួកគេ ឬដោយ
ពួកអ្នកបែកចេញ ទាំងនោះ ហេតុដូច្នេះហើយ ពួកគេបាន
ចាប់ផ្ដើមធ្វើសង្គ្រាមមួយ ជាមួយនឹងបងប្អូនរបស់គេ ។
២៥ ហើយពួកគេបានប្រព្រឹត្តអំពើឃាតកម្ម និងការប្លន់;
ហើយបន្ទាប់មក ពួកគេបានបែរទៅក្នុងទីភ្នំ ហើយទៅក្នុង
ទីរហោស្ថាន និងទីកន្លែងសម្ងាត់ៗទាំងឡាយ ដោយបាន

១៣ *ក* ១ ពង្សាវ. ១៨:១, ៤១–៤៦.
១៤ *ក* ហេលេ. ១១:៤.
១៧ *ក* ចោទិ. ១១:១៣–១៧.
១៨ *ក* ហេលេ. ១០:៥–១១.
១៩ *ក* ហេលេ. ៥:៣៦–៤៤.
២១ *ក* ស.ប. សាសនាចក្រនៃព្រះ
យេស៊ូវគ្រីស្ទ.
២៣ *ក* អាលម៉ា ២៦:២២;
គ. និង ស. ១០៧:១៩.

ពួនសម្ងំខ្លួនដើម្បីកុំឲ្យគេរកឃើញ ដោយបានទទួលរាល់ៗថ្ងៃនូវ
ចំនួនមនុស្សបន្ថែម ឲ្យតែមានពួកបែកបាក់ចេញ ដែលបាន
ទៅរកពួកគេ ។
២៦ ម្ល៉ោះហើយ ក្នុងរយៈពេល មែនហើយ គឺក្នុងរយៈពេល
មិនប៉ុន្មានឆ្នាំទេ ពួកគេបានក្លាយទៅជាក្រុមចោរមួយធំដ៏ខ្លាំង;
ហើយពួក គេបានរកផែនការសម្ងាត់ទាំងអស់របស់កាឌីអានតុន;
ម្ល៉ោះហើយ ពួកគេបានក្លាយទៅជាពួកចោររបស់កាឌីអានតុន ។
២៧ ឥឡូវនេះ មើលចុះ ពួកចោរទាំងនេះ បានធ្វើឲ្យមាន
ការខូចខាតដ៏ធំ មែនហើយ គឺការបំផ្លិចបំផ្លាញដ៏ធំ នៅក្នុង
ចំណោម ប្រជាជននីហ្វៃ ហើយនៅក្នុងចំណោមប្រជាជន
លេមិនផង ។
២៨ ហើយហេតុការណ៍បានកើតឡើងថា ជាការចាំបាច់ ត្រូវ
តែបញ្ឈប់ការបំផ្លិចបំផ្លាញនេះ; ហេតុដូច្នេះហើយ ពួកគេបាន
បញ្ជូនកង ទ័ពមួយ ដែលមានមនុស្សខ្លាំងពូកែ ឲ្យទៅក្នុង
ទីរហោស្ថាន ហើយទៅលើភ្នំ ដើម្បីរកក្រុមចោរនេះ
ហើយបំផ្លាញពួកវាចោល ។
២៩ ប៉ុន្តែមើលចុះ ហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំដដែលនោះ ពួកគេត្រូវបានរុញច្រានថយ ទៅក្នុងដែនដីផ្ទាល់
របស់គេ វិញ ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប៉ែតសិបក្នុងរជ្ជកាលនៃ
ពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងដើម
ឆ្នាំទីប៉ែតសិបមួយ ពួកគេបានចេញទៅប្រឆាំងនឹងក្រុមចោរនេះទៀត
ហើយបានបំផ្លាញចោលអស់ជាច្រើន; ហើយពួកគេក៏ត្រូវ
ជួបប្រទះដោយការបំផ្លិចបំផ្លាញដ៏ខ្លាំងក្លា ។
៣១ ហើយពួកគេត្រូវបានបង្ខំឲ្យចេញពីទីរហោស្ថាន
ហើយចេញពីភ្នំទាំងឡាយ មកដែនដីទាំងឡាយរបស់ខ្លួនគេវិញ
ដោយព្រោះ ពួកចោរមានចំនួនច្រើនហួសពេក ដែលនៅ
ពាសពេញក្នុងភ្នំ និងទីរហោស្ថាន ។
៣២ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំនេះក៏ចប់ទៅ ។
ហើយពួកចោរនៅតែកើនចំនួនច្រើនឡើងៗ ហើយមាន កម្លាំងជា
ខ្លាំង ដរាបដល់ពួកគេបានតទល់នឹងពលទ័ពសាសន៍នីហ្វៃទាំងមូល
និងពលទ័ពសាសន៍លេមិនផង; ហើយពួកគេបាននាំឲ្យ មានការ
ភ័យខ្លាចដ៏ធំ មកលើប្រជាជនដែលនៅលើផ្ទៃដែនដី ។
៣៣ មែនហើយ ព្រោះពួកគេបានទៅរុករានភាគជាច្រើន
នៃដែនដី ហើយបានធ្វើការបំផ្លិចបំផ្លាញយ៉ាងធំដល់ពួកគេ; មែន
ហើយ បានសម្លាប់មនុស្សជាច្រើន ហើយបានចាប់ពួកអ្នកឯទៀត
យកទៅជាឈ្លើយ នាំចូលទៅក្នុងទីរហោស្ថាន មែនហើយ
ហើយជាពិសេស ទៅទៀត គឺពួកស្ត្រី និងកូនចៅរបស់គេ ។
៣៤ ឥឡូវនេះ អំពើអាក្រក់ដ៏ធំនេះ ដែលបានធ្លាក់មក
លើប្រជាជន ដោយព្រោះអំពើទុច្ចរិតរបស់គេ បាន
ដាស់រំឭលគេទៀត ឲ្យនឹកឃើញដល់ព្រះអម្ចាស់ ជាព្រះរបស់គេ ។
៣៥ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប៉ែតសិបមួយក្នុងរជ្ជកាលនៃ
ពួកចៅក្រមទៅ ។
៣៦ ហើយក្នុងឆ្នាំទីប៉ែតសិបពីរ ពួកគេបានចាប់ផ្ដើម[ក]ភ្លេចព្រះ
អម្ចាស់ ជាព្រះរបស់គេទៀត ។ ហើយនៅក្នុងឆ្នាំទីប៉ែតសិបបី
ពួកគ្មានចាប់ផ្ដើមធ្វើអំពើទុច្ចរិតដ៏ខ្លាំង ។ ហើយនៅក្នុង
ឆ្នាំទីប៉ែតសិបបួន ពួកគេមិនបានកែប្រែគំនិតរបស់គេទេ ។
៣៧ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីប៉ែតសិបប្រាំ ពួកគេកាន់តែធ្វើខ្លាំងឡើងៗ នៅក្នុងសេច
ក្ដីឆ្មើងឆ្មៃរបស់គេ និងក្នុងអំពើទុច្ចរិតរបស់គេ; ម្ល៉ោះហើយ ពួក
គេបាទុំទៀត ចំពោះការបំផ្លិចបំផ្លាញ ។
៣៨ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប៉ែតសិបប្រាំទៅ ៕

## ជំពូកទី ១២

*មនុស្សមិននឹងន ហើយឆ្កួតលីលា ហើយឆាប់ធ្វើអាក្រក់ — ព្រះអម្ចាស់ទ្រង់វាយផ្ចាលដល់រាស្ត្រទ្រង់ — ភាពឥតការទទេនៃមនុស្ស ប្រៀបធៀបទៅនឹងព្រះចេស្ដានៃព្រះ — នៅក្នុងថ្ងៃជំនុំជំរះ នោះមនុស្សនឹងបានជីវិតដ៏អស់កល្បជានិច្ច ឬក៏ទោសដ៏អស់កល្បជានិច្ច ។ ប្រមាណជាឆ្នាំ ៦ ម.គ.ស. ។*

ម្ល៉ោះហើយ យើងអាចឃើញថា ចិត្តនៃកូនចៅមនុស្សខុសឆ្គង
ហើយគ្មានភាពនឹងនយ៉ាងណា; មែនហើយ យើងអាចឃើញថា
ព្រះអម្ចាស់ នៅក្នុងសេចក្ដីល្អមហិមាដ៏និរន្តរ៍របស់ទ្រង់ ប្រទានពរ
ហើយធ្វើឲ្យ[ក]ចំរើនឡើងដល់អស់អ្នកណា ដែលដាក់ទីទុកចិត្តរបស់
គេទៅលើទ្រង់ ។
២ មែនហើយ ហើយយើងអាចឃើញថា នៅពេលដែល
ទ្រង់ធ្វើឲ្យរាស្ត្រទ្រង់បានចំរើនឡើង មែនហើយ គឺក្នុងការបង្កើន
ស្រែចំការ របស់គេ ហ្វូងចៀមរបស់គេ និងហ្វូងសត្វរបស់គេ
ហើយមាស និងប្រាក់ និងវត្ថុមានតម្លៃសព្វសារពើ និងវត្ថុសិល្បៈ;
លើកលែងជីវិត ឲ្យគេ ហើយដោះលែងពួកគេឲ្យរួចផុតពីកណ្ដាប់ដៃ

៣៦ *ក* អាលម៉ា ៤៦:៨.
**១២** ១*ក* ២ របា. ២៦:៥; ទំនុក. ១:២–៣.
*ខ* ទំនុក. ៣៦:៧–៨;
២ នីហ្វៃ ២២:២; ម៉ូសាយ ៤:៦.
ស.ប. ទុកចិត្ត.

នៃពួកខ្មាំងសត្រូវរបស់គេ; បន្ទន់ចិត្តនៃពួកខ្មាំងសត្រូវរបស់គេ
ដើម្បីកុំឲ្យពួកវាធ្វើ សង្គ្រាមនឹងពួកគេ; មែនហើយ ហើយ
សរុបសេចក្ដីមក ធ្វើនូវគ្រប់ការណ៍ទាំងអស់ ដើម្បីសុខុមាលភាព
និងសុភមង្គលរបស់រាស្ត្រទ្រង់; មែនហើយ នៅពេលនោះហើយ
ដែលពួកគេធ្វើចិត្តរឹងរូស ហើយបំភ្លេចព្រះអម្ចាស់ ជាព្រះរបស់គេ
ហើយជាន់ឈ្លីនៅក្រោមជើងរបស់ គេនូវព្រះដ៏បរិសុទ្ធ —
មែនហើយ ហើយនេះគឺមកពីការងាយស្រួល និងការ
ចំរើនឡើងដ៏ធំហួសប្រមាណរបស់គេ ។
៣ ម្ល៉ោះហើយ យើងឃើញថា លើកលែងតែព្រះអម្ចាស់
ទ្រង់វាយផ្ចាលរាស្ត្រទ្រង់ ដោយការទុក្ខវេទនាដ៏ច្រើន មែន
ហើយ លើកលែងតែទ្រង់ធ្វើទោសពួកគេ ដោយសេចក្ដីស្លាប់
និងដោយភេរវកម្ម និងដោយអំណត់អត់ និងដោយជម្ងឺ
អាសន្នរោគគ្រប់បែប យ៉ាង នោះពួកគេនឹងពុំនឹកឃើញដល់
ទ្រង់ឡើយ ។
៤ ឱកូនចៅមនុស្សអើយ ម្ដេចក៏ឆ្កួតលីលា និងអសារឥតការ
និងអាក្រក់ និងដូចអារក្សម្ល៉េះ ហើយឆាប់ធ្វើអំពើទុច្ចរិត តែកម្រ
ធ្វើ អំពើល្អទៅវិញ; មែនហើយ គឺឆាប់ស្ដាប់តាមពាក្យសំដីនៃជន
អាក្រក់ ហើយភ្ជាប់ចិត្តគេទៅលើវត្ថុទាំងឡាយដែលឥតប្រយោជន៍
នៃ លោកិយ!
៥ មែនហើយ គឺឆាប់លើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃ; មែន
ហើយ គឺឆាប់អួតអាង ហើយធ្វើនូវអ្វីៗគ្រប់យ៉ាងនៃអំពើដែល
ទុច្ចរិត; តែពួកគេកម្រនឹកឃើញដល់ព្រះអម្ចាស់ ជាព្រះរបស់គេ
ឬយកត្រចៀកស្ដាប់តាមដំបូន្មានរបស់ទ្រង់ មែនហើយ គឺកម្រ
ដើរតាមផ្លូវ ទាំងឡាយខាងប្រាជ្ញាទៅវិញ ។
៦ មើលចុះ ពួកគេពុំមានបំណងចង់ឲ្យព្រះអម្ចាស់ ជាព្រះ
របស់គេ ដែលបានបង្កើតគេមក គ្រប់គ្រង និងអភិបាលលើពួក
គេទេ; ទោះជាទ្រង់មានការណ៍ល្អដ៏ធំ និងសេចក្ដីមេត្តាករុណា
ដល់ពួកគេក៏ដោយ គង់តែពួកគេពុំយកជាការ នូវដំបូន្មានទាំង
ឡាយរបស់ទ្រង់ ហើយពួកគេពុំមានបំណងចង់ឲ្យទ្រង់ ធ្វើជាអ្នក
នាំផ្លូវពួកគេឡើយ ។
៧ ឱភាពឥតការទទេនៃកូនចៅមនុស្ស អ្វីក៏ធំធេងម្ល៉េះ; មែន
ហើយ គឺពួកគេអន់ជាងធូលីដីទៅទៀត ។
៨ ត្បិតមើលចុះ ធូលីដីធ្វើចលនាពីកន្លែងមួយទៅកន្លែងមួយ
បែកគ្នាជាពីរ តាមបញ្ជារបស់ព្រះដ៏មហិមា និងដ៏គង់នៅអស់កល្ប
ជានិច្ចរបស់យើង ។
៩ មែនហើយ មើលចុះ តាមព្រះសូរសៀងរបស់ទ្រង់
ភ្នំតូច និងភ្នំធំញ័រ ហើយរញ្ជួយ ។
១០ ហើយដោយព្រះចេស្ដានៃសម្លេងរបស់ទ្រង់ វាបែកចេញ
ហើយក្លាយទៅជារាបស្មើ មែនហើយ គឺដូចជាច្រកភ្នំដូច្នោះ ។
១១ មែនហើយ ដោយព្រះចេស្ដានៃសម្លេងរបស់ទ្រង់ ផែនដី
ទាំងមូលរង្គើ ។
១២ មែនហើយ ដោយព្រះចេស្ដានៃសម្លេងរបស់ទ្រង់ គ្រឹះរណ្ដំ
គឺរហូតដល់ចំកណ្ដាល ។
១៣ មែនហើយ ហើយបើសិនជាទ្រង់មានបន្ទូលទៅ
កាន់ផែនដីថា — ចូរធ្វើចលនា — វានឹងធ្វើចលនា។
១៤ មែនហើយ បើសិនជាទ្រង់មានបន្ទូលទៅកាន់ផែនដីថា —
ចូរថយក្រោយ ដើម្បីវាពន្យាថ្ងៃឲ្យបានច្រើនម៉ោង — នោះនឹង
បានសំរេច;
១៥ ម្ល៉ោះហើយ ស្របតាមព្រះបន្ទូលរបស់ទ្រង់ ផែនដីថយក្រោយ
ហើយវាហាក់បីដូចជាធ្វើឲ្យមនុស្សឃើញថា ព្រះអាទិត្យឈរនៅ
នឹងមួយកន្លែង; មែនហើយ ហើយមើលចុះ ការណ៍នេះ
គឺដូច្នោះមែន; ព្រោះពិតប្រាកដមែន គឺផែនដីដែលធ្វើចលនា
ហើយមិនមែន ព្រះអាទិត្យទេ ។
១៦ ហើយក៏មើលចុះ បើសិនជាទ្រង់មានព្រះបន្ទូលទៅកាន់
ទឹកនៃទីជំរៅដ៏ធំថា — ចូរឯងរីងស្ងួតទៅ — នោះនឹងបាន
សំរេច ។

២ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* អាលម៉ា ៥:៥៣;
៣ នីហ្វៃ ២៨:៣៥.
៣ *ក* ម៉ូសាយ ២៣:២១;
គ. និង ស. ៩៨:២១; ១០១:៨.
*ខ* អេម៉ុស ៤:៦–១១.
៤ *ក* និក្ខ. ៣២:៨.
*ខ* ម៉ាថាយ ១៥:១៩;
ហេព្រើរ ៣:១២.
៥ *ក* សុភា. ២៩:២៣.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ខ* ស.ប. ដើរ, ដើរជាមួយព្រះ.
៦ *ក* អេសាយ ៤៥:៩;
គ. និង ស. ៥៨:៣០;
ម៉ូសេ ៧:៣២–៣៣.
*ខ* គ. និង ស. ៦០:៤.
៧ *ក* អេសាយ ៤០:១៥, ១៧;
ម៉ូសាយ ៤:១៩;
ម៉ូសេ ១:១០.
៩ *ក* ៣ នីហ្វៃ ២២:១០.
១០ *ក* ១ នីហ្វៃ ១៧:៤៦.
១១ *ក* មរមន ៥:២៣;
អេធើរ ៤:៩.
១៤ *ក* យ៉ូស្វេ ១០:១២–១៤.
*ខ* អេសាយ ៣៨:៧–៨.
*គ* ២ ពង្សាវ. ២០:៨–១១.
១៦ *ក* ម៉ាថាយ ៨:២៧.
*ខ* អេសាយ ៤៤:២៧; ៥១:១០.

១៧ មើលចុះ បើសិនជាទ្រង់មានព្រះបន្ទូលទៅកាន់ភ្នំនេះថា —
ចូរឯងផុសឡើងខ្ពស់ ហើយរលំ និងធ្លាក់ទៅលើទីក្រុងនោះ
ដើម្បីវាត្រូវកប់ — មើលចុះ វានឹងបានសំរេច ។
១៨ ហើយមើលចុះ បើសិនជាមនុស្សម្នាក់លាក់កំណប់មួយ
នៅក្នុងដី ហើយព្រះអម្ចាស់មានព្រះបន្ទូលថា — ចូរឲ្យវា
ត្រូវបំណ្ដា សាចុះ ដោយព្រោះអំពើទុច្ចរិតរបស់អ្នកដែលបាន
លាក់វា — មើលចុះ វានឹងត្រូវបណ្ដាសា ។
១៩ ហើយបើសិនជាព្រះអម្ចាស់ទ្រង់នឹងមានព្រះបន្ទូលថា —
ឯងត្រូវបណ្ដាសាហើយ ដើម្បីកុំឲ្យអ្នកណារកឃើញឯងឡើយ
ចាប់ពីពេលនេះ និងរហូតតទៅ — មើលចុះ គ្មានអ្នក
ណារកវាឃើញទេ ចាប់ពីពេលនោះ និងរហូតតទៅ ។
២០ ហើយមើលចុះ បើសិនជាព្រះអម្ចាស់ទ្រង់នឹងមានព្រះ
បន្ទូលទៅកាន់មនុស្សម្នាក់ថា — ដោយព្រោះអំពើទុច្ចរិតទាំង
ឡាយរបស់ អ្នក នោះអ្នកនឹងត្រូវបណ្ដាសារហូតតទៅ —
នោះនឹងត្រូវបានសំរេច ។
២១ ហើយបើសិនជាព្រះអម្ចាស់ទ្រង់នឹងមានព្រះបន្ទូលថា —
ដោយព្រោះអំពើទុច្ចរិតទាំងឡាយរបស់អ្នក នោះអ្នកនឹងត្រូវ
កាត់ ចេញពីវត្តមានរបស់យើង — ទ្រង់នឹងធ្វើឲ្យវាត្រូវបាន
សំរេចដូច្នោះ ។
២២ ហើយវេទនាដល់ជនណា ដែលទ្រង់ប្រាប់ដូច្នោះ ព្រោះ
គឺជាជននេះហើយដែលនឹងធ្វើអំពើទុច្ចរិត ហើយជននោះមិន
អាចបាន សង្គ្រោះឡើយ; ហេតុដូច្នេះហើយ ដោយហេតុនេះ
ដើម្បីឲ្យមនុស្សអាចបានសង្គ្រោះ ទើបការប្រែចិត្តត្រូវបាន
ប្រកាសមក ។
២៣ ហេតុដូច្នេះហើយ មានពរហើយដល់អស់អ្នកណា
ដែលនឹងប្រែចិត្ត ហើយប្រុងស្ដាប់តាមសម្លេងនៃព្រះអម្ចាស់
ជាព្រះរបស់គេ ព្រោះគឺគេទាំងនេះហើយដែលនឹងបាន
សង្គ្រោះ ។
២៤ ហើយសូមឲ្យព្រះ ក្នុងភាពពោរពេញដ៏ធំរបស់ទ្រង់
អនុញ្ញាតឲ្យមនុស្សអាចបាននាំទៅកាន់ការប្រែចិត្ត និងកិច្ចការល្អ
ទាំងឡាយ ដើម្បីឲ្យពួកគេអាចបានសាងឡើងវិញ ពីគុណមួយ
ទៅគុណមួយ ស្របតាមកិច្ចការទាំងឡាយរបស់គេ ។
២៥ ហើយខ្ញុំចង់ឲ្យមនុស្សទាំងអស់បានសង្គ្រោះ ។ ប៉ុន្តែ
យើងអានថា នៅក្នុងថ្ងៃដ៏មហិមា និងចុងក្រោយបង្អស់ មាន
មនុស្សខ្លះ ដែលនឹងត្រូវបោះបង់ចោល មែនហើយ ជាអ្នកដែល
នឹងត្រូវបណ្ដេញចេញ ពីវត្តមាននៃព្រះអម្ចាស់ ។
២៦ មែនហើយ ជាអ្នកដែលនឹងត្រូវដាក់ឲ្យនៅក្នុងស្ថានភាព
នៃសេចក្ដីវេទនាដ៏មិនចេះមិនចេះហើយ ដោយបំពេញនូវពាក្យទាំង
ឡាយដែលថា៖ អស់អ្នកណាដែលធ្វើល្អ នឹងមានជីវិតដ៏អស់ក
ល្បជានិច្ច ហើយអស់អ្នកណាដែលធ្វើអាក្រក់ នឹងមានសេចក្ដី
ផាប់ ទោសដ៏អស់កល្បជានិច្ច ។ ហើយគឺយ៉ាងដូច្នោះមែន ។
អាម៉ែន ៕

---

ពាក្យព្យាករណ៍នៃសាំយូអែល ជាសាសន៍លេមិន ដល់ពួក
សាសន៍នីហ្វៃ ។

*មាននូវមនៅក្នុងជំពូកទី ១៣ ទៅ ១៥*

## ជំពូកទី ១៣

*សាំយូអែល ជាសាសន៍លេមិន ព្យាករអំពីការបំផ្លិចបំផ្លាញដល់ពួកសាសន៍នីហ្វៃ លើកលែងតែពួកគេប្រែចិត្ត — ពួកគេ និងទ្រព្យសម្បត្តិ របស់គេត្រូវបណ្ដាសា — ពួកគេបដិសេធ ហើយចោលថ្មទៅលើពួកព្យាការី, ត្រូវហ៊ុំព័ទ្ធជុំវិញដោយពួកអារក្សប្រែត, ហើយស្វែងរក សុភមង្គលក្នុងការធ្វើអំពើទុច្ចរិត ។ ប្រមាណជាឆ្នាំ ៦ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីប៉ែតសិបប្រាំមួយ នោះពួកសាសន៍នីហ្វៃនៅតែធ្វើអំពើទុច្ចរិត
មែនហើយ ជាអំពើទុច្ចរិតដ៏ធំ នៅពេលដែលពួកសាសន៍លេមិន
បានគោរពយ៉ាងខ្ជាប់ខ្ជួន ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយ
នៃព្រះ ស្របតាម ក្រិត្យវិន័យលោកម៉ូសេ ។
២ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនោះ មាន
ជនម្នាក់ឈ្មោះ សាំយូអែល ជាសាសន៍លេមិន បានចូលមក
ដែនដី សារ៉ាហិមឡា ហើយបានចាប់ផ្ដើមផ្សាយទៅកាន់
ប្រជាជន ។ ហើយហេតុការណ៍បានកើតឡើងថា លោកបាន
ផ្សាយប្រាប់ប្រជាជន អស់ជាច្រើនថ្ងៃ អំពីការប្រែចិត្ត ហើយពួក
គេបានបណ្ដេញលោកចេញ ហើយលោកជិតតែត្រឡប់ទៅកាន់
ដែនដីលោកវិញ ។

---

១៧ *ក* ៣ នីហ្វៃ ៨:១០.
១៨ *ក* មរមន ១:១៨; អេធើរ ១៤:១.
*ខ* ហេលេ. ១៣:១៧.
២៣ *ក* ស.ប. សេចក្ដីសង្គ្រោះ.
២៤ *ក* ស.ប. ព្រះគុណ.
២៦ *ក* ម៉ាថាយ ២៥:៤៦; យ៉ូហាន ៥:២៨–២៩; រ៉ូម ៦:១៣.
*ខ* ស.ប. សេចក្ដីផាប់ទោស.
**១៣** ១ *ក* ហេលេ. ១៥:៤–៥.

៣ ប៉ុន្តែមើលចុះ សម្លេងនៃព្រះអម្ចាស់បានបន្លឺដល់លោកថា
លោកត្រូវត្រឡប់ទៅវិញ ហើយព្យាករដល់ប្រជាជនអំពីអ្វីៗ
ដែលនឹង មក[ក]សណ្ឋិតក្នុងចិត្តលោក ។
៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេពុំព្រមឲ្យលោ
កចូលមកក្នុងទីក្រុងទេ; ហេតុដូច្នេះហើយ លោកបានឡើងទៅលើ
កំផែងក្រុង ហើយបានលើកដៃលោក ហើយបានស្រែកដោយ
សម្លេងខ្លាំងៗ ហើយបានព្យាករដល់ប្រជាជនអំពីអ្វីៗ ដែលព្រះ
អម្ចាស់ ទ្រង់បានដាក់ក្នុងចិត្តលោក ។
៥ ហើយលោកបាននិយាយទៅកាន់ពួកគេថា៖ មើលចុះ ខ្ញុំជា
សាំយូអែល សាសន៍លេមិន និយាយប្រាប់នូវព្រះបន្ទូលនៃព្រះ
ដែល ព្រះអម្ចាស់ទ្រង់បានដាក់មកក្នុងចិត្តខ្ញុំ; ហើយមើលចុះ
ទ្រង់បានដាក់ពាក្យមកក្នុងចិត្តខ្ញុំឲ្យនិយាយទៅកាន់ប្រជាជននេះថា
[ក]ដាវនៃ សេចក្ដីយុត្តិធម៌ត្រូវព្យួរនៅលើប្រជាជននេះ; ហើយរយៈ
ពេលបួនរយឆ្នាំនឹងមិនកន្លងផុតទៅទេ លើកលែងតែដាវនៃសេច
ក្ដីយុត្តិធម៌ ធ្លាក់មកលើប្រជាជននេះ ។
៦ មែនហើយ [ក]ការបំផ្លិចបំផ្លាញដ៏ធ្ងន់ធ្ងរ កំពុងតែរង់ចាំ
ប្រជាជននេះ ហើយវាពិតជានឹងកើតឡើងដល់ប្រជាជននេះ ហើយ
គ្មានអ្វី អាចជួយសង្គ្រោះប្រជាជននេះបានឡើយ លើកលែងតែ
ការប្រែចិត្ត និងសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ
ដែលពិតជានឹង យាងមកលោកិយ ហើយរងទុក្ខនូវ
ការឈឺចាប់ជាច្រើនប្រការ ហើយត្រូវសុគតជំនួសរាស្ត្ររបស់
ទ្រង់ប៉ុណ្ណោះ ។
៧ ហើយមើលចុះ [ក]ទេវតាមួយនៃ[ខ]ព្រះអម្ចាស់ បានប្រកាសរឿងនេះ
ដល់ខ្ញុំ ហើយលោកបាននាំដំណឹងដ៏រីករាយ មកដល់ព្រលឹងខ្ញុំ ។
ហើយមើលចុះ ខ្ញុំត្រូវបានចាត់ឲ្យមកជួបអ្នក ដើម្បីប្រកាស
ប្រាប់រឿងនេះដល់អ្នកផង ដើម្បីឲ្យអ្នករាល់គ្នាអាចមាន
ដំណឹងដ៏រីករាយ ទាំងនេះ; ប៉ុន្តែមើលចុះ អ្នករាល់គ្នាពុំព្រមទទួល
ខ្ញុំសោះ ។
៨ ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖
ដោយមកពីការរឹងទទឹងនៅក្នុងចិត្ត របស់ប្រជាជននៃសាសន៍
នីហ្វៃ ហើយលើកលែងតែគេប្រែចិត្ត បើពុំនោះសោតទេ យើង
[ក]នឹងដកយកពាក្យរបស់យើងចេញពីគេ ហើយយើងនឹងដកយក
ព្រះវិញ្ញាណ របស់យើងចេញពីគេដែរ ហើយយើងនឹង
ពុំអត់ឱនឲ្យពួកគេតទៅទៀតឡើយ ហើយយើងនឹងធ្វើឲ្យបងប្អូន
របស់គេ មានចិត្តទាស់ នឹងគេវិញ ។
៩ ហើយនឹងពុំហួស[ក]ពីបួនរយឆ្នាំទេ យើងនឹងធ្វើឲ្យពួកគេត្រូវ
វាយ មែនហើយ យើងនឹងដាក់ទោសដល់ពួកគេ ដោយដាវ
និង ដោយអំណត់អត់ និងដោយជម្ងឺអាសន្នរោគ ។
១០ មែនហើយ យើងនឹងដាក់ទោសពួកគេ ក្នុងសេច
ក្ដីពិរោធដ៏ខ្លាំងរបស់យើង ហើយពេលនោះ ពួកជនទាំងឡាយ
នៃតំណ[ក]ទីបួន នៃពួកខ្មាំងសត្រូវរបស់អ្នករាល់គ្នា គឺជាអ្នកដែល
នឹងរស់នៅ ដើម្បីមើលការបំផ្លិចបំផ្លាញទាំងស្រុងរបស់អ្នក;
ហើយការណ៍នេះនឹងកើត ឡើងជាប្រាកដ លើកលែងតែអ្នកប្រែ
ចិត្ត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នោះ; ហើយពួកជនក្នុង
តំណទីបួននឹងបណ្ដាលឲ្យមានការ បំផ្លិចបំផ្លាញដល់អ្នករាល់គ្នា ។
១១ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ ប៉ុន្តែបើសិនជាអ្នក
រាល់គ្នានឹងប្រែចិត្ត ហើយ[ក]ត្រឡប់មករកព្រះអម្ចាស់ ជាព្រះរបស់
អ្នកវិញ នោះយើងនឹងដកសេចក្ដីពិរោធរបស់យើងចេញ; មែន
ហើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា មានពរហើយ
ដល់អស់អ្នកណា ដែលប្រែចិត្ត ហើយបែរមករកយើងវិញ
ប៉ុន្តែវេទនាដល់អ្នកណា ដែលមិនប្រែចិត្តវិញ ។
១២ មែនហើយ [ក]វេទនាដល់ទីក្រុងសារ៉ាហិមឡាដ៏ធំនេះ;
ត្បិតមើលចុះ គឺដោយសារពួកជនសុចរិត ទើបវាបានសង្គ្រោះ;
ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា មែនហើយ វេទនាដល់ទីក្រុង
ដ៏ធំនេះ ត្បិតយើងឃើញមនុស្សជាច្រើន មែនហើយ គឺភាគច្រើន
នៃ ទីក្រុងដ៏ធំនេះ នឹងពង្រឹងចិត្តរបស់គេទាស់នឹងយើង ព្រះ
អម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៣ ប៉ុន្តែ មានពរហើយ ដល់អស់អ្នកណាដែលនឹងប្រែចិត្ត
ត្បិតយើងនឹងទុកជីវិតដល់គេ ។ ប៉ុន្តែមើលចុះ បើសិនជាពុំ
មែនដោយ សារពួកសុចរិត ដែលនៅក្នុងទីក្រុងដ៏ធំនេះទេ មើលចុះ
យើងនឹងធ្វើឲ្យ[ក]ភ្លើងធ្លាក់ចុះមកពីលើមេឃ ហើយបំផ្លាញ
ទីក្រុងនេះទៅហើយ ។

៣ *ក* គ. និង ស. ១០០:៥.
៥ *ក* អាលម៉ា ៦០:២៩;
៣ នីហ្វៃ ២:១៩.
៦ *ក* អាលម៉ា ៤៥:១០—១៤;
ហេលេ. ១៥:១៧.
៧ *ក* អាលម៉ា ១៣:២៦.
*ខ* អេសាយ ៥២:៧.
៨ *ក* ហេលេ. ៦:៣៥.
៩ *ក* អាលម៉ា ៤៥:១០—១២.
១០ *ក* ១ នីហ្វៃ ១២:១២;
២ នីហ្វៃ ២៦:៩;
៣ នីហ្វៃ ២៧:៣២.
១១ *ក* ៣ នីហ្វៃ ១០:៥—៧.
១២ *ក* ៣ នីហ្វៃ ៨:៨, ២៤; ៩:៣.
១៣ *ក* លោកុ. ១៩:២៤;
២ ពង្សាវ. ១:៩—១៦;
៣ នីហ្វៃ ៩:១១.

១៤ ប៉ុន្តែមើលចុះ ដោយសារតែពួកសុចរិត ទើបវាត្រូវបានទុក ។ ប៉ុន្តែមើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ពេលវេលានឹងមកដល់ គឺពេលដែលអ្នករាល់គ្នានឹងបណ្ដេញពួកសុចរិតចេញពីចំណោមពួកអ្នករាល់គ្នា លំដាប់នោះ អ្នកនឹងទុំដល់ស្ទើរនឹងការបំផ្លិចបំផ្លាញចោលហើយ; មែនហើយ វេទនាដល់ទីក្រុងដ៏ធំនេះ ពីព្រោះមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ដែលនៅ ក្នុងនោះ ។

១៥ មែនហើយ ហើយវេទនាដល់ទីក្រុងគេឌាន ព្រោះអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ដែលមាននៅក្នុងនោះ ។

១៦ មែនហើយ ហើយវេទនាដល់ទីក្រុងទាំងអស់ ដែលនៅលើដែនដីជុំវិញ ដែលពួកសាសន៍នីហ្វៃគ្រងលើ ពីព្រោះមកពីអំពើ ទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ដែលមាននៅក្នុងនោះ ។

១៧ ហើយ[ក]មើលចុះ ព្រះអម្ចាស់នៃពួកពលបរិវារទ្រង់មានព្រះបន្ទូលថា បណ្ដាសាមួយនឹងធ្លាក់មកលើដែនដីនេះ ពីព្រោះដោយយល់ដល់ប្រជាជនដែលនៅលើដែនដីនោះ មែនហើយ ពីព្រោះមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ ។

១៨ ហើយហេតុការណ៍នឹងកើតឡើងថា ព្រះអម្ចាស់នៃពួកពលបរិវារ មែនហើយ គឺព្រះដ៏ពិត និងមហិមារបស់យើង ទ្រង់មានព្រះ បន្ទូលថា អស់អ្នកណាដែល[ក]លាក់ទ្រព្យសម្បត្តិទាំងឡាយនៅក្នុងដី នោះនឹងពុំអាចរកវាឃើញវិញឡើយ ពីព្រោះមកពីបណ្ដាសាដ៏ធំ ដល់ដែនដី លើកលែងតែជននោះជាជនសុចរិត ហើយលាក់ទ្រព្យសម្បត្តិដល់ព្រះអម្ចាស់ ។

១៩ ព្រោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា យើងចង់ឲ្យពួកគេលាក់ទ្រព្យសម្បត្តិរបស់គេដល់យើង; ហើយមានបណ្ដាសាដល់ពួក អ្នកដែលពុំលាក់ទ្រព្យសម្បត្តិខ្លួនដល់យើង; ព្រោះគ្មានអ្នកណាលាក់ទ្រព្យសម្បត្តិដល់យើងបានឡើយ លើកលែងតែពួកជនសុចរិត ប៉ុណ្ណោះ; ហើយអ្នកណាដែលពុំលាក់ទ្រព្យសម្បត្តិដល់យើងទេ ជននោះត្រូវបណ្ដាសាហើយ ឯទ្រព្យសម្បត្តិរបស់គេ ក៏ត្រូវបណ្ដាសា ដែរ ហើយគ្មានអ្នកណាអាចរកឃើញទ្រព្យសម្បត្តិនោះវិញឡើយ ពីព្រោះមកពីបណ្ដាសាដល់ដែនដី ។

២០ ហើយថ្ងៃនោះនឹងមកដល់ ដែលពួកគេនឹងលាក់ទ្រព្យសម្បត្តិទាំងឡាយរបស់គេ ពីព្រោះពួកគេបានភ្ជាប់ចិត្តគេទៅលើទ្រព្យសម្បត្តិ; ហើយពីព្រោះពួកគេបានភ្ជាប់ចិត្តទៅលើទ្រព្យសម្បត្តិរបស់ខ្លួន ហើយនឹងលាក់ទ្រព្យសម្បត្តិរបស់ខ្លួន នៅពេលពួកគេរត់គេច ចេញពីពួកខ្មាំងសត្រូវរបស់ពួកគេ; ពីព្រោះគេពុំលាក់ទ្រព្យសម្បត្តិដល់យើង នោះពួកគេនឹងត្រូវបណ្ដាសា និងទ្រព្យសម្បត្តិរបស់គេ ក៏ត្រូវបណ្ដាសាដែរ; ហើយនៅថ្ងៃនោះពួកគេនឹងត្រូវវាយ ព្រះអម្ចាស់ទ្រង់មានបន្ទូលដូច្នោះ ។

២១ មើលចុះ អ្នករាល់គ្នាដែលជាប្រជាជននៃទីក្រុងដ៏ធំនេះអើយ ហើយចូរ[ក]ប្រុងស្ដាប់តាមពាក្យពេចន៍របស់ខ្ញុំចុះ; មែនហើយ ចូរប្រុងស្ដាប់នូវពាក្យទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលចុះ; ត្បិតមើលចុះ ទ្រង់មានព្រះបន្ទូលថា អ្នករាល់គ្នានឹងត្រូវបណ្ដាសា ពីព្រោះមកពីទ្រព្យសម្បត្តិរបស់អ្នក ហើយទ្រព្យសម្បត្តិរបស់អ្នកក៏ត្រូវបណ្ដាសាដែរ ពីព្រោះអ្នករាល់គ្នាបានភ្ជាប់ចិត្តអ្នកទៅ លើទ្រព្យទាំងនោះ ហើយពុំបានស្ដាប់តាមព្រះបន្ទូលរបស់ទ្រង់ ដែលទ្រង់បានប្រទានមកដល់អ្នករាល់គ្នាឡើយ ។

២២ អ្នករាល់គ្នាពុំនឹករឭកដល់ព្រះអម្ចាស់ ជាព្រះរបស់អ្នកនូវអ្វីៗដែលទ្រង់បានប្រទានដល់អ្នកទេ ប៉ុន្តែអ្នករាល់គ្នានឹករឭកដល់[ក]ទ្រព្យសម្បត្តិរបស់អ្នករហូត ហើយពុំបានថ្លែងអំណរគុណដល់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ចំពោះទ្រព្យទាំងនេះឡើយ; មែនហើយ ចិត្តរបស់អ្នកពុំផ្ចង់ឆ្ពោះទៅរកព្រះអម្ចាស់ទេ ប៉ុន្តែប៉ោងឡើង ដោយការ[ខ]ឆ្មើងឆ្មៃដ៏ធំ នាំទៅដល់ការអួតអាង សេចក្ដីក្រអឺតក្រទម ការ[គ]ឈ្នានីស ការបែកបាក់ ព្យាបាទ ការបៀតបៀន និងឃាតកម្ម និងអំពើទុច្ចរិតគ្រប់បែបយ៉ាង ។

២៣ ដោយព្រោះហេតុនេះហើយ បានជាព្រះអម្ចាស់ទ្រង់ធ្វើឲ្យបណ្ដាសាត្រូវមានមកលើដែនដីនេះ និងមានមកលើទ្រព្យរបស់អ្នក ផង ហើយនេះក៏មកតែពីអំពើទុច្ចរិតទាំងឡាយរបស់អ្នកប៉ុណ្ណោះ ។

២៤ មែនហើយ វេទនាដល់ប្រជាជននេះ ពីព្រោះពេលនេះបានមកដល់ហើយ គឺពេលដែលអ្នករាល់គ្នា[ក]បណ្ដេញពួកព្យាការីចេញ ហើយចំអកឡកឡឺយដល់គេ និងចោលថ្មទៅលើគេ និងសម្លាប់គេ និងធ្វើនូវអំពើទុច្ចរិតគ្រប់បែបយ៉ាងដល់គេ គឺដូចគ្នានឹងពួកគេបាន ធ្វើកាលពីជំនាន់ដើមដែរ ។

២៥ ហើយឥឡូវនេះ កាលអ្នករាល់គ្នានិយាយ នោះអ្នក

---

១៧ ក ហេលេ. ១២:១៨.
១៨ ក មរមន ១:១៨; អេធើរ ១៤:១.
២១ ក ស.ប. ប្រុងស្ដាប់.
២២ ក លូកា ១២:៣៤. ស.ប. ទ្រព្យសម្បត្តិ; សេចក្ដីប្រកបដោយលោកិយ.
ខ ស.ប. សេចក្ដីឆ្មើងឆ្មៃ.
គ ស.ប. ច្រណែន.
២៤ ក ២ របា. ៣៦:១៥–១៦; ១ នីហ្វៃ ១:២០.

និយាយថា៖ បើសិនពួកយើងរស់នៅក្នុងជំនាន់[ក]ពួកអយ្យកោយើង
ពីជំ នាន់ដើម នោះយើងច្បាស់ជាពុំបានសម្លាប់ពួកព្យាការីទេ;
យើងពុំបានចោលថ្មទៅលើគេ ហើយពុំបានបណ្ដេញគេចេញទេ ។
២៦ មើលចុះ អ្នករាល់គ្នាអាក្រក់ជាងពួកគេទៅទៀត;
ត្បិតប្រាកដដូចជាព្រះអម្ចាស់មានព្រះជន្មរស់នៅ បើសិនជាមាន
[ក]ព្យាការីណា មួយមកក្នុងចំណោមអ្នករាល់គ្នា ហើយប្រកាស
ប្រាប់ដល់អ្នកនូវព្រះបន្ទូលនៃព្រះអម្ចាស់ ដែលធ្វើបន្ទាល់អំពីអំពើ
បាបទាំងឡាយ និងអំពើទុច្ចរិតទាំងឡាយរបស់អ្នក នោះអ្នករាល់
គ្នា[ខ]ខឹងនឹងលោក ហើយបណ្ដេញលោកចេញ
និងស្វែងរកគ្រប់មធ្យោបាយ ដើម្បីបំផ្លាញលោកចោល; មែន
ហើយ អ្នករាល់គ្នានឹងនិយាយថា លោកជា[គ]ព្យាការីក្លែងក្លាយ
ហើយថាលោកជាមនុស្សមានបាប និងជាមនុស្សរបស់អារក្ស
ទៅវិញ ពីព្រោះលោកបាន[ឃ]ធ្វើបន្ទាល់ថា ការប្រព្រឹត្តរបស់អ្នក
គឺអាក្រក់ ។
២៧ ប៉ុន្តែមើលចុះ បើសិនជាមានមនុស្សណាម្នាក់មកក្នុង
ចំណោមអ្នករាល់គ្នា ហើយនិយាយថា៖ ចូរធ្វើយ៉ាងនេះ ហើយ
នឹងគ្មាន អំពើទុច្ចរិតអីទេ; ចូរធ្វើយ៉ាងនោះ ហើយអ្នកនឹងពុំរងទុក្ខ
សោះ; មែនហើយ អ្នកនោះនឹងនិយាយថា៖ ចូរដើរតាម
ការឆ្មើងឆ្មៃនៃចិត្តរបស់ អ្នកផ្ទាល់ចុះ; មែនហើយ ហើយ
ចូរដើរតាមការឆ្មើងឆ្មៃនៃភ្នែករបស់អ្នកចុះ និងធ្វើអ្វីក៏ដោយដែល
ចិត្តអ្នកចង់ — ហើយបើសិនជា មនុស្សណាម្នាក់មកក្នុង
ចំណោមពួកអ្នក ហើយនិយាយ[ក]ដូច្នោះ នោះអ្នករាល់គ្នា
នឹងទទួលគេ ហើយនិយាយថា គេជាព្យាការីមួយ ។
២៨ មែនហើយ អ្នករាល់គ្នានឹងលើកដំកើងអ្នកនោះ ហើយ
អ្នករាល់គ្នានឹងឲ្យដល់អ្នកនោះ នូវទ្រព្យសម្បត្តិរបស់ខ្លួន; អ្នក
រាល់គ្នានឹង ឲ្យដល់ អ្នកនោះ នូវមាសរបស់អ្នក និងប្រាក់របស់អ្នក
ហើយអ្នករាល់គ្នានឹងបំពាក់អ្នកនោះ នូវប្រដាប់[ក]ស្លៀកពាក់ដ៏មាន
តម្លៃ; ហើយ ពីព្រោះអ្នកនោះនិយាយពាក្យបញ្ជោរដល់អ្នក
ហើយប្រាប់ថាអ្វីៗបានស្រួលទាំងអស់ហើយ នោះអ្នករាល់គ្នានឹង
ពុំរកឃើញកំហុស របស់គេឡើយ ។
២៩ ឱពួកអ្នកដែលជាតំណមនុស្សទុច្ចរិតនិងខូចអើយ; ពួកអ្នក
ដែលជាពួកជនរឹងទទឹង និងចចេសអើយ ចុះតើអ្នករាល់
គ្នាយល់ថា ព្រះអម្ចាស់ទ្រង់នឹងអត់ទ្រាំឲ្យពួកអ្នកដល់ណាទៅ ?
មែនហើយ [ខ]តើអ្នករាល់គ្នានឹងបណ្ដោយឲ្យខ្លួន ដឹកនាំដោយ[ក]ពួក
ភូតភរវង្វេង និងពួក ខ្វាក់ដល់ណាទៅ ? មែនហើយ តើអ្នករាល់
គ្នា[គ]រើសភាពងងឹតជាជាង[ឃ]ពន្លឺដល់ណាទៅ ?
៣០ មែនហើយ មើលចុះ សេចក្ដីពិរោធនៃព្រះអម្ចាស់ បាន
ឆេះឡើងទាស់នឹងអ្នកហើយ; មើលចុះ ទ្រង់បានដាក់បណ្ដាសា
ដល់ដែន ដីនេះ ពីព្រោះមកពីអំពើទុច្ចរិតរបស់អ្នករាល់គ្នា ។
៣១ ហើយមើលចុះ ដល់ពេលទ្រង់ដាក់បណ្ដាសា ដល់[ក]ទ្រព្យ
របស់អ្នករាល់គ្នាហើយ ដើម្បីឲ្យទ្រព្យទាំងនោះ ទៅជារអិល
ដើម្បីកុំ ឲ្យអ្នករាល់គ្នាកាន់វាជាប់; ហើយនៅក្នុងពេលអ្នក
ធ្លាក់ទៅក្នុងការក្រខ្សត់ នោះអ្នករាល់គ្នាពុំអាចរក្សាទុកបានទេ ។
៣២ ហើយនៅថ្ងៃដែលអ្នករាល់គ្នាធ្លាក់ទៅក្នុងការក្រខ្សត់
នោះអ្នករាល់គ្នានឹងអំពាវនាវដល់ព្រះអម្ចាស់; ហើយអ្នករាល់គ្នា
អំពាវនាវដោយឥតបានប្រយោជន៍ ព្រោះការកំសត់របស់អ្នក
បានមកដល់អ្នកហើយ ឯការបំផ្លិចបំផ្លាញរបស់អ្នក ក៏មានច្បាស់;
ហើយនៅពេលនោះ អ្នករាល់គ្នានឹងយំ ហើយទ្រហោយំនៅក្នុង
ថ្ងៃនោះ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ។
ហើយនៅពេលនោះ អ្នករាល់គ្នានឹងស្រែកថ្ងូរថា៖
៣៣ ឱ[ក]គួរណាស់តែ[ខ]ខ្ញុំបានប្រែចិត្ត ហើយពុំបានសម្លាប់ពួក
ព្យាការី និងពុំបានចោលថ្មទៅលើគេ និងបណ្ដេញគេចេញទេ ។
មែនហើយ នៅថ្ងៃនោះ អ្នករាល់គ្នានឹងនិយាយថា៖ ឱគួរណាស់
តែយើង បាននឹកឃើញដល់ព្រះអម្ចាស់ ជាព្រះរបស់យើង នៅ
ថ្ងៃដែលទ្រង់ប្រទាន ទ្រព្យសម្បត្តិដល់យើង ហើយនៅពេលនោះ
ទ្រព្យសម្បត្តិនោះច្បាស់ជាវានឹងមិនរអិល ដែលត្រូវឲ្យយើង
បាត់បង់ទ្រព្យសម្បត្តិនោះ ឡើយ; ត្បិតមើលចុះ ទ្រព្យសម្បត្តិ
របស់យើងបានបាត់បង់ពីយើងអស់ទៅហើយ ។
៣៤ មើលចុះ យើងដាក់គ្រឿងឧបករណ៍មួយនៅទីនេះ
ហើយស្អែកឡើងវាទៅបាត់; ហើយមើលចុះ ដាវរបស់យើង
ក៏បាត់ពី យើងអស់ នៅថ្ងៃដែលយើងរកវាដើម្បីច្បាំង ។
៣៥ មែនហើយ យើងបានលាក់ទ្រព្យសម្បត្តិទាំងឡាយ
របស់យើង ហើយវាបានរអិលចេញទៅបាត់ពីយើង ពីព្រោះមក
ពីបណ្ដាសា ដល់ដែនដីនេះ ។
៣៦ ឱគួរណាស់តែយើងបានប្រែចិត្ត នៅថ្ងៃដែលព្រះបន្ទូលនៃ
ព្រះអម្ចាស់បានមកដល់យើង; ត្បិតមើលចុះ ដែនដីនេះត្រូវ

២៥ ក កិច្ចការ ៧:៥១.
២៦ ក ២ របា. ១៨:៧; លូកា ១៦:៣១.
ខ អេសាយ ៣០:៩–១០.
គ ម៉ាថាយ ១៣:៥៧.
ឃ កាឡាទី ៤:១៦.
២៧ ក មីកា ២:១១.
ស.ប. ឧបាយកលផ្អែកសង្ឃ.
២៨ ក ២ ធីម៉ូ. ៤:៣–៤.
២៩ ក ២ នីហ្វៃ ២៨:៩.
ខ ម៉ាថាយ ១៥:១៤.
គ យ៉ូហាន ៣:១៩.
ឃ យ៉ូប ២៤:១៣.
៣១ ក មរមន ១:១៧–១៨.
៣៣ ក មរមន ២:១០–១៥.
ខ ម៉ាថាយ ២៣:៣៧.

បណ្ដាសា ហើយអ្វីៗគ្រប់យ៉ាងបានក្លាយទៅជារអិល
ហើយយើងពុំអាចកាន់បានឡើយ ។
៣៧ មើលចុះ យើងត្រូវហ៊ុំព័ទ្ធជុំវិញ ដោយអារក្សប្រែត
មែនហើយ យើងត្រូវព័ទ្ធជុំវិញដោយពួកទេវតារបស់ជន ដែល
បានស្វែង រកបំផ្លាញព្រលឹងរបស់យើង ។ មើលចុះ អំពើទុច្ចរិត
របស់យើង មានភាពធ្ងន់ធ្ងរណាស់ ។ ឱព្រះអម្ចាស់អើយ
តើទ្រង់ពុំអាចដកព្រះ ពិរោធ ពីយើងចេញបានទេឬ ? ហើយនេះ
គឺជាពាក្យរបស់អ្នករាល់គ្នា នៅក្នុងថ្ងៃនោះ ។
៣៨ ប៉ុន្តែមើលចុះ [ក]ថ្ងៃសាក[ខ]ល្បងរបស់អ្នករាល់គ្នា បាន
កន្លងទៅហើយ; អ្នករាល់គ្នាបានបង្អែរបង្អង់ថ្ងៃ នៃសេច
ក្ដីសង្គ្រោះ របស់អ្នក រហូតដល់ហួសពេលជាអស់កល្បជានិច្ចទៅ
ហើយឯការបំផ្លិចបំផ្លាញអ្នករាល់គ្នា ក៏មានយ៉ាងច្បាស់; មែន
ហើយ ព្រោះ អ្នករាល់គ្នាបាន ស្វែងរកនៅក្នុងថ្ងៃទាំង
អស់នៃជីវិតរបស់អ្នក នូវអ្វីៗ[គ]ដែលអ្នករាល់គ្នាពុំអាចយកបាន;
ហើយអ្នករាល់គ្នាបានស្វែង រកសុភមង្គល ដោយធ្វើ អំពើទុច្ចរិត
ដែលជាការផ្ទុយនឹងធម្មជាតិនៃសេចក្ដីសុចរិតនោះ ដែលមាននៅ
ក្នុងអ្នកគ្រួតគ្រាដ៏មហិមា និងដ៏គង់នៅអស់កល្បជានិច្ចនៃ យើង ។
៣៩ ឱអ្នករាល់គ្នា ដែលជាប្រជាជននៃដែនដីនេះអើយ សូម
អ្នករាល់គ្នាស្ដាប់ឮពាក្យសំដីរបស់ខ្ញុំចុះ! ហើយខ្ញុំសូមអធិស្ឋាន
ឲ្យសេចក្ដីពិរោធនៃព្រះអម្ចាស់ បានបែរចេញពីអ្នករាល់គ្នា
ហើយសូមឲ្យអ្នករាល់គ្នាបានប្រែចិត្ត ហើយបានសង្គ្រោះចុះ ៕

## ជំពូកទី ១៤

*សាំយូអែលព្យាករថាមានពន្លឺនៅក្នុងពេលយប់ ហើយមានផ្កាយថ្មីមួយនៅវេលាកំណើតរបស់ព្រះគ្រីស្ទ — ព្រះគ្រីស្ទប្រោសលោះមនុស្ស ពីសេចក្ដីស្លាប់ខាងសាច់ឈាម និងខាងវិញ្ញាណ — ទីសំគាល់ទាំងឡាយអំពីការសុគតរបស់ទ្រង់ គឺមានភាពងងឹតក្នុងរយៈពេលបីថ្ងៃ ការបែកថ្មទាំងឡាយ និងចលាចលដ៏ធំនៃធម្មជាតិ ។ ប្រមាណជាឆ្នាំ ៦ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា [ក]សាំយូអែល ជា
សាសន៍លេមិន បានព្យាករនូវរឿងដ៏មហិមាជាច្រើនទៀត ដែល
ពុំអាច សរសេរទុកបានឡើយ ។
២ ហើយមើលចុះ លោកបាននិយាយទៅកាន់ពួកគេថា៖
មើលចុះ ខ្ញុំឲ្យទីសំគាល់មួយដល់អ្នករាល់គ្នា; ត្បិតទៅប្រាំឆ្នាំទៀត
ហើយ មើលចុះ ពេលនោះព្រះរាជបុត្រានៃព្រះ ទ្រង់នឹងយាង
មកប្រោសលោះអស់អ្នកណា ដែលជឿដល់ព្រះនាមទ្រង់ ។
៣ ហើយមើលចុះ នេះខ្ញុំនឹង[ក]ឲ្យទីសំគាល់មួយដល់អ្នករាល់គ្នា
គឺនៅពេលទ្រង់នឹងយាងមក; ត្បិតមើលចុះ គឺនឹងមាន
ពន្លឺដ៏មហិមានៅ លើមេឃ ដរាបដល់ក្នុងពេលយប់មុនទ្រង់នឹង
យាងមក គឺពុំមានភាពងងឹតឡើយ ដរាបដល់វាមានសភាព
ដូចជាពេលថ្ងៃចំពោះមនុស្ស ។
៤ ហេតុដូច្នេះហើយ នឹងមានមួយថ្ងៃ និងមួយយប់ និងមួយថ្ងៃ
ហាក់បីដូចជាមួយថ្ងៃប៉ុណ្ណោះ គឺគ្មានយប់ទេ; ហើយនេះ
នឹងទៅជាទី សំគាល់មួយដល់អ្នករាល់គ្នា; ព្រោះអ្នករាល់គ្នានឹង
ដឹងនូវពេលថ្ងៃរះ និងថ្ងៃលិចផង; ហេតុដូច្នេះហើយ គេនឹងដឹង
យ៉ាងច្បាស់ថា នឹងមានពីរថ្ងៃ និងមួយយប់; ទោះជាយ៉ាង
ណាក៏ដោយ យប់នោះពុំងងឹតឡើយ ហើយគឺជាយប់មុនពេល
[ក]ទ្រង់នឹងប្រសូតមក ។
៥ ហើយមើលចុះ នឹងមាន[ក]ផ្កាយថ្មីមួយរះឡើង គឺជាផ្កាយមួយ
ដែលអ្នករាល់គ្នាពុំដែលបានឃើញសោះ; ហើយនេះនឹងទៅជាទី
សំគាល់មួយដល់អ្នក ។
៦ ហើយមើលចុះ នេះពុំទាន់អស់នៅឡើយទេ គឺនឹងមាន
ទីសំគាល់ និងការអស្ចារ្យជាច្រើនទៀតនៅលើមេឃ ។
៧ ហើយហេតុការណ៍នឹងកើតឡើងថា អស់អ្នករាល់គ្នានឹង
មានការភ្ញាក់ផ្អើល ហើយងឿងឆ្ងល់ ដរាបដល់អ្នករាល់
គ្នា[ក]ដួលទៅលើដី ។
៨ ហើយហេតុការណ៍នឹងកើតឡើងថា អស់អ្នកណា
ដែល[ក]ជឿដល់ព្រះរាជបុត្រានៃព្រះ អ្នកនោះនឹងមានជីវិត
ដ៏អស់កល្បជានិច្ច ។
៩ ហើយមើលចុះ ម្ល៉ោះហើយបានជាព្រះអម្ចាស់ទ្រង់បានបញ្ជា
ដល់ខ្ញុំ តាមរយៈទេវតារបស់ទ្រង់ថា ខ្ញុំត្រូវនាំយករឿងនេះ មក
ប្រាប់ អ្នករាល់គ្នា; មែនហើយ ទ្រង់បានបញ្ជាថា ខ្ញុំត្រូវព្យាករនូវ
រឿងទាំងនេះដល់អ្នក; មែនហើយ ទ្រង់មានព្រះបន្ទូលមកកាន់
ខ្ញុំថា៖ ចូរស្រែកប្រកាសប្រាប់ប្រជាជននេះ ឲ្យប្រែចិត្ត
ហើយរៀបចំផ្លូវថ្វាយព្រះអម្ចាស់ចុះ ។

៣៨ *ក* មរមន ២:១៥.
*ខ* អាលម៉ា ៣៤:៣៣–៣៤.
*គ* អាលម៉ា ៤១:១០–១១.
**១៤** ១*ក* ហេលេ. ១៣:២.
៣ *ក* ៣ នីហ្វៃ ១:១៥.
៤ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
៥ *ក* ម៉ាថាយ ២:១–២; ៣ នីហ្វៃ ១:២១.
៧ *ក* ៣ នីហ្វៃ ១:១៦–១៧.
៨ *ក* យ៉ូហាន ៣:១៦.

១០ ហើយឥឡូវនេះ ពីព្រោះខ្ញុំជាសាសន៍លេមិន ហើយបាន
និយាយទៅកាន់អ្នករាល់គ្នា នូវពាក្យទាំងឡាយ ដែលព្រះ
អម្ចាស់ទ្រង់ បានបញ្ជាដល់ខ្ញុំ ហើយពីព្រោះពាក្យនោះធ្ងន់ធ្ងរ
ចំពោះអ្នក នោះអ្នករាល់គ្នាខឹងនឹងខ្ញុំ ហើយស្វែងរកបំផ្លាញខ្ញុំ
ហើយបាន[ក]បណ្ដេញខ្ញុំ ចេញពីចំណោមអ្នករាល់គ្នាទៅវិញ ។
១១ ហើយអ្នករាល់គ្នានឹងបានឮពាក្យសំដីរបស់ខ្ញុំ ព្រោះដោយ
គោលបំណងនេះហើយ បានជាខ្ញុំឡើងមកលើកំផែងនៃទីក្រុង
នេះ ដើម្បីឲ្យអ្នករាល់គ្នាអាចស្ដាប់ឮ ហើយដឹងនូវសេចក្ដី
ជំនុំជំរះទាំងឡាយនៃព្រះ ដែលរង់ចាំអ្នក ពីព្រោះមកពីអំពើ
ទុច្ចរិតទាំងឡាយ របស់អ្នក ហើយដើម្បីឲ្យអ្នករាល់គ្នាអាចដឹងនូវ
លក្ខខណ្ឌទាំងឡាយនៃការប្រែចិត្ត ។
១២ ហើយដើម្បីឲ្យអ្នករាល់គ្នាអាចដឹងផង នូវការយាងមកនៃ
ព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ គឺជា[ក]ព្រះបិតានៃស្ថាន
សួគ៌ និងផែនដី ជាអ្នកបង្កើតអ្វីៗសព្វសារពើចាប់ពីដំបូងមក;
ហើយដើម្បីឲ្យអ្នករាល់គ្នាអាចស្គាល់ នូវទីសំគាល់ទាំងឡាយ
នៃការ យាងមករបស់ទ្រង់ ក្នុងគោលបំណងដើម្បីឲ្យអ្នករាល់គ្នា
អាចជឿដល់ព្រះនាមទ្រង់ ។
១៣ ហើយបើសិនជាអ្នករាល់គ្នា[ក]ជឿដល់ព្រះនាមទ្រង់ នោះ
អ្នករាល់គ្នានឹងប្រែចិត្តពីអស់ទាំងអំពើបាបរបស់អ្នក ដើម្បីឲ្យអ្នក
រាល់គ្នា អាចបានទទួល[ខ]ការផ្ដាច់បាប តាមរយៈព្រះគុណទ្រង់ ។
១៤ ហើយមើលចុះ ខ្ញុំឲ្យទីសំគាល់មួយទៀតដល់អ្នក មែន
ហើយ ជាទីសំគាល់នៃការសុគតរបស់ទ្រង់ ។
១៥ ត្បិតមើលចុះ ទ្រង់ត្រូវតែសុគតជាប្រាកដ ដើម្បីឲ្យ[ក]សេចក្ដី
សង្គ្រោះអាចកើតមានឡើង; មែនហើយ ការសុគតនៃទ្រង់ ជា
ការចាំ បាច់ ហើយត្រឹមត្រូវ ដើម្បីបណ្ដាលឲ្យមាន[ខ]ដំណើរ
រស់ឡើងវិញដល់មនុស្សស្លាប់ ដើម្បីដោយសារការណ៍នេះ
មនុស្សអាចបាននាំទៅឯ វត្តមាននៃព្រះអម្ចាស់ ។
១៦ មែនហើយ មើលចុះ ការសុគតនេះនាំមកនូវដំណើរ
រស់ឡើងវិញ ហើយ[ក]ប្រោសលោះមនុស្សលោកទាំងអស់ ពីសេច
ក្ដីស្លាប់ទី មួយ — គឺសេចក្ដីស្លាប់ខាងវិញ្ញាណ; ព្រោះមនុស្ស
លោកទាំងអស់ ដោយមកពី[ខ]ការធ្លាក់នៃលោកអ័ដាម នោះបាន
ត្រូវ[គ]កាត់ចេញពី វត្តមាននៃព្រះអម្ចាស់ ហើយត្រូវចាត់ទុកថា [ឃ]ស្លាប់
ចំពោះអ្វីៗខាងសាច់ឈាម ព្រមទាំងចំពោះអ្វីៗខាងវិញ្ញាណផង ។
១៧ ប៉ុន្តែមើលចុះ ដំណើររស់ឡើងវិញនៃព្រះគ្រីស្ទ
នឹង[ក]ប្រោសលោះមនុស្សលោក មែនហើយ គឺមនុស្សលោកទាំង
អស់ ហើយនាំ ពួកគេត្រឡប់មកកាន់វត្តមាននៃព្រះអម្ចាស់វិញ ។
១៨ មែនហើយ វានឹងនាំមកនូវលក្ខខ័ណ្ឌទាំងឡាយនៃការប្រែ
ចិត្តថា អស់អ្នកណាដែលប្រែចិត្ត អ្នកនោះនឹងពុំត្រូវកាប់រំលំ
ហើយបោះចោលទៅក្នុងភ្លើងឡើយ; ប៉ុន្តែអស់អ្នកណាដែលពុំ
ប្រែចិត្តទេ នោះនឹងត្រូវកាប់រំលំ ហើយបោះចោលទៅក្នុងភ្លើងវិញ;
ហើយសេចក្ដីស្លាប់ខាងវិញ្ញាណ ក៏កើតមានដល់គេជាថ្មី មែនហើយ
គឺជាសេចក្ដីស្លាប់ទីពីរ ព្រោះពួកគេត្រូវបានកាត់ជាថ្មីចេញពីអ្វីៗ
ដែលទាក់ទងទៅនឹងសេចក្ដីសុចរិត ។
១៩ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ចូរអ្នករាល់
គ្នាប្រែចិត្តចុះ ខ្លាចក្រែងកាលណាអ្នករាល់គ្នាដឹងនូវរឿង
ទាំងនេះ ហើយ ពុំបានធ្វើតាម នោះអ្នករាល់គ្នានឹងនៅក្រោម
ការកាត់ទោស ហើយអ្នករាល់គ្នានឹងត្រូវនាំទៅដល់សេច
ក្ដីស្លាប់ទីពីរនេះ ។
២០ ប៉ុន្តែមើលចុះ ដូចដែលខ្ញុំបាននិយាយទៅកាន់អ្នក
អំពី[ក]ទីសំគាល់មួយទៀត គឺជាទីសំគាល់នៃការសុគតរបស់ទ្រង់
មើលចុះ នៅថ្ងៃនោះ ដែលទ្រង់នឹងរងទុក្ខការសុគត នោះព្រះ
អាទិត្យនឹង[ខ]ទៅជាងងឹត ហើយមិនព្រមឲ្យពន្លឺ ដល់អ្នករាល់គ្នាទេ;
ឯព្រះច័ន្ទ និង តារាទាំងឡាយផងក៏ដូច្នោះដែរ; ហើយនឹងពុំមាន
ពន្លឺនៅលើផ្ទៃផែនដីនេះសោះ ចាប់តាំងពីពេលដែលទ្រង់រងទុក្ខ
ការសុគត អស់រយៈ ពេល[គ]បីថ្ងៃ រហូតដល់ពេលដែលទ្រង់នឹង
មានព្រះជន្មរស់ពីស្លាប់ឡើងវិញ ។
២១ មែនហើយ នៅពេលដែលទ្រង់នឹងបណ្ដោយឲ្យ
ព្រលឹងវិញ្ញាណ យាងចាកចេញទៅ នោះនឹងមាន[ក]រន្ទះ
និងផ្លេកបន្ទោរ អស់ រយៈពេលជាច្រើនម៉ោង ឯផែនដីនឹងញ័ររញ្ជួយ;
ហើយថ្មទាំងឡាយដែលនៅលើផ្ទៃផែនដីនេះ ទោះនៅខាងលើដី

១០ ក ហេលេ. ១៣:២.
១២ ក ម៉ូសាយ ៣:៨;
៣ នីហ្វៃ ៩:១៥;
អេធើរ ៤:៧.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.
១៣ ក កិច្ចការ ១៦:៣០—៣១.
ខ គ. និង ស. ១៩:១៦—២០.
១៥ ក ស.ប. ព្រះអង្គសង្គ្រោះ.
ខ អាលម៉ា ៤២:២៣.
ស.ប. ដំណើររស់ឡើងវិញ.
១៦ ក ស.ប. ផែនការនៃសេចក្ដីប្រោសលោះ.
ខ ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
គ អាលម៉ា ៤២:៦—៩.
ឃ ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
១៧ ក ស.ប. ប្រោសលោះ, បាន
ប្រោសលោះ, សេចក្ដីប្រោសលោះ.
២០ ក ៣ នីហ្វៃ ៨:៥—២៥.
ខ លូកា ២៣:៤៤.
គ ម៉ូសាយ ៣:១០.
២១ ក ៣ នីហ្វៃ ៨:៦.

ឬខាងក្រោមដី ដែលក្នុងពេលនេះ អ្នកដឹងថា វារឹងមាំ
ឬក៏ភាគធំនៃថ្មទាំងនោះ ជាដុំធំ ហើយតាន់ នោះនឹងត្រូវ
បែកបាក់ ។
២២ មែនហើយ វានឹងបែកជាពីរ ហើយរហូតតទៅថ្ងៃក្រោយ
វានឹងឃើញជាថ្ម ដែលមានស្នាមប្រេះបែក ហើយបែកជាដុំ
តូចៗ នៅពាសពេញលើផែនដីទាំងមូល មែនហើយ ទាំងនៅ
ខាងលើ និងខាងក្រោមដីផង ។
២៣ ហើយមើលចុះ នឹងមានព្យុះសង្ឃរាដ៏ធំៗ ហើយភ្នំជាច្រើន
នឹងរាបចុះទៅដូចជាច្រកភ្នំ ហើយនឹងមានទីកន្លែងជាច្រើនទៀត
ដែលឥឡូវនេះហៅថា ច្រកភ្នំ នឹងក្លាយទៅជាភ្នំ ដែលមាន
កំពស់ដ៏អស្ចារ្យ ។
២៤ ហើយផ្លូវធំៗ ជាច្រើននឹងបាក់បែក ឯទីក្រុងជាច្រើន
នឹងបោះបង់ចោល ។
២៥ ហើយផ្នូរខ្មោចជាច្រើននឹងរបើកឡើង ហើយនឹងផ្ដល់ពួក
ស្លាប់ជាច្រើនមកវិញ; ហើយពួកបរិសុទ្ធជាច្រើន នឹងលេចមកឲ្យ
មនុស្សច្រើនគ្នាបានឃើញ ។
២៦ ហើយមើលចុះ នេះគឺជាការណ៍ដែលទេវតាបានមាន
ប្រសាសន៍មកកាន់ខ្ញុំ; ព្រោះទេវតាបានមានប្រសាសន៍មកកាន់ខ្ញុំ
ថា នឹងមានរន្ទះ និងផ្លេកបន្ទោរ អស់ពេលជាច្រើនម៉ោង ។
២៧ ហើយលោកបានប្រាប់ដល់ខ្ញុំថា ការណ៍ទាំងនេះ
នឹងកើតឡើងនៅពេលដែលមានរន្ទះ និងផ្លេកបន្ទោរ និងខ្យល់
ព្យុះសង្ឃរា ហើយភាពងងឹតនឹងគ្របលើផ្ទៃផែនដីទាំងមូល
អស់រយៈពេលបីថ្ងៃ ។
២៨ ហើយទេវតាបានប្រាប់ខ្ញុំថា មនុស្សជាច្រើននឹងឃើញនូវ
រឿងដ៏ធំជាងនេះទៀត ក្នុងបំណងឲ្យគេអាចជឿថា ទីសំគាល់
ទាំងនេះ និងការណ៍អស្ចារ្យទាំងនេះ កើតឡើងនៅពាសពេញ
លើផែនដីនេះ គឺនៅក្នុងបំណងថា ពុំមានហេតុអ្វីដែលនឹងនាំ
ឲ្យមានការឥតជំនឿ ក្នុងចំណោមកូនចៅមនុស្សបានឡើយ។
២៩ ហើយការណ៍នេះ នៅក្នុងបំណងចង់ឲ្យអស់អ្នកណា
ដែលជឿនោះអាចបានសង្គ្រោះ ឯអស់អ្នកណាដែលពុំជឿទេ នោះ
សេចក្ដី ជំនុំជំរះដ៏សុចរិតមួយ នឹងមានដល់ពួកគេ; ហើយបើសិនជា
ពួកគេត្រូវជាប់ទោស គឺដោយមកពីពួកគេបានលើកដាក់លើខ្លួន
ដោយខ្លួន ឯងនូវការកាត់ទោសនោះ ។
៣០ ហើយឥឡូវនេះ ចូរចងចាំចុះ ចូរចងចាំចុះ ឱបងប្អូន
របស់ខ្ញុំអើយ ថាអស់អ្នកណាដែលវិនាស គឺវិនាសដល់ខ្លួនឯង;
ហើយអស់ អ្នកណាដែលប្រព្រឹត្តអំពើទុច្ចរិត គឺធ្វើដល់ខ្លួនឯង;
ត្បិតមើលចុះ អ្នករាល់គ្នាមានសេរីភាព; អ្នករាល់គ្នាត្រូវបាន
អនុញ្ញាតឲ្យធ្វើអ្វីៗ ដើម្បីខ្លួនឯង; ត្បិតមើលចុះ ព្រះទ្រង់បាន
ប្រទានដល់អ្នកនូវការចេះដឹង ហើយទ្រង់បានធ្វើឲ្យអ្នកមានសេរីភាព។
៣១ ទ្រង់បានប្រទានដល់អ្នក នូវការដឹងខុស និងត្រូវ ហើយ
ទ្រង់បានប្រទានឲ្យអ្នក ដើម្បីអ្នកអាចរើសយកការរស់ ឬការស្លាប់;
ហើយអ្នករាល់គ្នាអាចធ្វើល្អ ហើយត្រូវបានសាងឡើងវិញឲ្យ
បានល្អដូចដើម ឬក៏សាងនូវអ្វី ដែលល្អដល់អ្នកវិញ; ឬអ្នកអាចធ្វើ
អាក្រក់ ឯអំពើអាក្រក់នោះ ត្រូវបានសាងដល់អ្នកវិញដែរ ៕

## ជំពូកទី ១៥

*ព្រះអម្ចាស់ទ្រង់បានវាយផ្ចាលពួកសាសន៍នីហ្វៃ ព្រោះទ្រង់ស្រឡាញ់គេ — ពួកលេមិនដែលបានប្រែចិត្តជឿ គេមានចិត្តរឹងប៉ឹង ហើយខ្ជាប់ខ្ជួន នៅក្នុងសេចក្ដីជំនឿ — ព្រះអម្ចាស់ទ្រង់នឹងមានសេចក្ដីមេត្តាករុណា ដល់ពួកសាសន៍លេមិន នៅគ្រាចុងក្រោយ ។ ប្រមាណជាឆ្នាំ ៦ ម.គ.ស. ។*

ហើយឥឡូវនេះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ មើលចុះ
ខ្ញុំសូមប្រកាសដល់អ្នករាល់គ្នាថា លើកលែងតែអ្នករាល់គ្នាប្រែ
ចិត្ត បើពុំនោះសោតទេ ផ្ទះសំបែងរបស់អ្នក នឹងត្រូវចោលស្ងាត់ ។
២ មែនហើយ លើកលែងតែអ្នករាល់គ្នាប្រែចិត្ត បើពុំនោះ
សោតទេ ភរិយារបស់អ្នករាល់គ្នានឹងមានហេតុដ៏ធំសំរាប់យំសោក
នៅថ្ងៃដែលគេបំបៅកូន; ព្រោះអ្នករាល់គ្នានឹងខិតខំរត់គេច តែ
គ្មានទីកន្លែងសំរាប់ជ្រកពួនឡើយ; មែនហើយ ហើយវេទនាដល់
ពួកគេ ដែលមានគភ៌ ព្រោះគេមានទម្ងន់ ហើយពុំអាចរត់គេច
បានឡើយ; ហេតុដូច្នេះហើយ គេនឹងត្រូវជាន់ឈ្លីនៅក្រោមជើង
ហើយនឹងត្រូវ ទុកចោលឲ្យវិនាសបង់ ។

---

២១ *ខ* ៣ នីហ្វៃ ១០:៩.
២២ *ក* ៣ នីហ្វៃ ៨:១៨.
២៤ *ក* ៣ នីហ្វៃ ៩:៣–១២.
២៥ *ក* ម៉ាថាយ ២៧:៥០–៥៤;
៣ នីហ្វៃ ២៣:៩–១១.
២៦ *ក* អាលម៉ា ១៣:២៦.
២៧ *ក* ១ នីហ្វៃ ១៩:១០; ៣ នីហ្វៃ ៨:៣.
២៨ *ក* ១ នីហ្វៃ ១២:៤–៥.
២៩ *ក* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
៣០ *ក* ២ នីហ្វៃ ២:២៦–២៩;
ម៉ូសេ ៦:៥៦.
ស.ប. សិទ្ធិជ្រើសរើស.
*ខ* ស.ប. ដំរិះ.
៣១ *ក* ម៉ូរ៉ូណៃ ៧:១៦.
*ខ* ២ នីហ្វៃ ២:២៨–២៩;
អាលម៉ា ៣:២៦–២៧.
*គ* អាលម៉ា ៤១:៣–៥.
**១៥** ១*ក* ម៉ាថាយ ២៣:៣៧–៣៨.
២ *ក* ម៉ាថាយ ២៤:១៩.

៣ មែនហើយ វេទនាដល់ប្រជាជននេះ ដែលមានឈ្មោះថា ប្រជាជននីហ្វៃ លើកលែងតែគេប្រែចិត្ត កាលគេនឹងឃើញទីសំគាល់ និងការណ៍អស្ចារ្យអស់ទាំងនេះ ដែលនឹងបានបង្ហាញដល់គេ; ត្បិតមើលចុះ ពួកគេធ្លាប់ជាប្រជាជនដ៏ជំរើសនៃព្រះអម្ចាស់; មែនហើយ គឺប្រជាជននីហ្វៃដែលទ្រង់បានស្រឡាញ់ ហើយទ្រង់ក៏បានវាយផ្ចាលពួកគេផង; មែនហើយ នៅក្នុងថ្ងៃដែលគេធ្វើអំពើទុច្ចរិតទាំងឡាយ ទ្រង់បានវាយផ្ចាលដល់គេ ព្រោះទ្រង់បានស្រឡាញ់គេ ។

៤ ប៉ុន្តែមើលចុះ ឱបងប្អូនរបស់ខ្ញុំអើយ គឺពួកសាសន៍លេមិន ដែលទ្រង់បានស្អប់ ព្រោះពួកគេធ្លាប់បានធ្វើអំពើអាក្រក់ជាបន្តបន្ទាប់ ហើយនេះគឺមកពីអំពើទុច្ចរិត នៃសំណប់នៃពួកអយ្យកោរបស់គេទេតើ ។ ប៉ុន្តែមើលចុះ សេចក្ដីសង្គ្រោះបានមកដល់គេតាមរយៈការ ផ្សាយនៃពួកនីហ្វៃ; ហើយដោយគោលបំណងនេះ ហើយបានជាព្រះអម្ចាស់ ទ្រង់ពន្យាថ្ងៃទាំងឡាយរបស់គេ ។

៥ ហើយខ្ញុំចង់ឲ្យអ្នករាល់គ្នាឃើញថា ពួកគេភាគច្រើនដើរតាមគន្លងនៃករណីយកិច្ចរបស់គេ ហើយគេបានដើរដោយប្រយ័ត្ន ប្រយែងនៅចំពោះព្រះ ហើយពួកគេប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និងក្រិត្យក្រមទាំងឡាយរបស់ទ្រង់ និងសេចក្ដីយុត្តិធម៌ ទាំងឡាយរបស់ទ្រង់ ស្របតាមក្រិត្យវិន័យលោកម៉ូសេ ។

៦ មែនហើយ ខ្ញុំសូមប្រាប់អ្នកថា ពួកគេភាគច្រើនកំពុងធ្វើយ៉ាងនេះ ហើយពួកគេខ្នះខ្នែងព្យាយាមពុំឈប់ឈរ ដើម្បីគេអាចនាំបង ប្អូនរបស់គេ ដែលនៅសល់ទាំងប៉ុន្មាន ឲ្យស្គាល់សេចក្ដីពិត; ហេតុដូច្នេះហើយ មានមនុស្សចំនួនច្រើន បានតាមពួកគេជារៀងរាល់ៗថ្ងៃ ។

៧ ហើយមើលចុះ អ្នករាល់គ្នាក៏ដឹងដោយខ្លួនឯងយ៉ាងនេះដែរ ត្បិតអ្នករាល់គ្នាបានឃើញការណ៍នេះយ៉ាងច្បាស់ថា ពួកគេជាច្រើន ត្រូវបាននាំឲ្យស្គាល់សេចក្ដីពិត ហើយឲ្យស្គាល់នូវសណ្ដាប់ដ៏ទុច្ចរិត និងដ៏គួរខ្ពើមឆ្អើមទាំងឡាយ នៃពួកអយ្យកោរបស់គេ ហើយត្រូវបាន ដឹកនាំឲ្យជឿដល់ព្រះគម្ពីរបរិសុទ្ធទាំងឡាយ មែនហើយ សេចក្ដីព្យាករណ៍ទាំងឡាយ នៃពួកព្យាការីដ៏បរិសុទ្ធ ដែលបានកត់ទុក ដែល បាននាំពួកគេ ឲ្យមានសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់ និងដល់ការប្រែចិត្ត គឺជាសេចក្ដីជំនឿ និងការប្រែចិត្ត ដែលនាំមកឲ្យគេនូវការ ផ្លាស់ប្ដូរនៅក្នុងចិត្តគេ —

៨ ហេតុដូច្នេះហើយ អស់អ្នកនាដែលបានដល់ថ្នាក់នេះ អ្នករាល់គ្នាក៏បានដឹងដោយខ្លួនឯងថា គឺជាជនរឹងប៉ឹង និងខ្ជាប់ខ្ជួននៅក្នុងសេចក្ដីជំនឿ និងនៅក្នុងការដែលនាំមកឲ្យគេនូវសេរីភាព ។

៩ ហើយអ្នករាល់គ្នាក៏ដឹងផងដែរថា ពួកគេបានកប់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់គេ ហើយពួកគេពុំហ៊ានយកគ្រឿងអាវុធ នោះឡើង ព្រោះខ្លាចក្រែងគេនឹងធ្វើអំពើបាប; មែនហើយ អ្នករាល់គ្នាអាចឃើញថា ពួកគេខ្លាចបាប — ត្បិតមើលចុះ ពួកគេសុខចិត្ត ទ្រាំឲ្យខ្លួនឯងត្រូវជិះជាន់ និងប្រហារបង់ ដោយពួកខ្មាំងសត្រូវរបស់គេ ហើយពុំព្រមលើកដាវឡើងទាស់នឹងគេវិញសោះ ហើយនេះ ក៏មកពីសេចក្ដីជំនឿរបស់គេជឿដល់ព្រះគ្រីស្ទ ។

១០ ហើយឥឡូវនេះ ពីព្រោះមកពីភាពខ្ជាប់ខ្ជួនរបស់គេ កាលគេជឿនូវអ្វីៗដែលគេជឿ ត្បិតពីព្រោះមកពីការកាន់ចិត្តមុតមាំកាលណាគេត្រូវបានបំភ្លឺ មើលចុះ ព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់គេ ហើយពន្យាថ្ងៃទាំងឡាយរបស់គេ ដោយពុំគិតដល់អំពើទុច្ចរិត របស់គេឡើយ —

១១ មែនហើយ ទោះបីពួកគេចុះអន់ថយក្នុងការឥតជំនឿក្ដី គង់តែព្រះអម្ចាស់ទ្រង់ពន្យាថ្ងៃទាំងឡាយរបស់គេដែរ រហូតដល់ពេល នោះមកដល់ ដែលពួកអយ្យកោយើង បាននិយាយមកនោះ ហើយដោយព្យាការីស៊ីណូសផង និងដោយព្យាការីជាច្រើនទៀត អំពីការ សាងឡើងវិញនៃបងប្អូនរបស់យើង គឺពួកសាសន៍លេមិន ឲ្យស្គាល់សេចក្ដីពិតម្ដងទៀត —

១២ មែនហើយ ខ្ញុំសូមប្រាប់អ្នកថា នៅពេលវេលាចុងក្រោយពាក្យសន្យាទាំងឡាយនៃព្រះអម្ចាស់ នឹងត្រូវបានបន្តទៅដល់បងប្អូនរបស់យើង គឺពួកសាសន៍លេមិន; ទោះបីពួកគេទទួលការទុក្ខវេទនាជាច្រើន និងទោះបីគេត្រូវដេញទៅវិញទៅមក នៅលើផ្ទៃផែនដីនេះ ហើយត្រូវគេរកចាប់ និងត្រូវវាយដំនិងខ្ចាត់ខ្ចាយទៅក្រៅស្រុក ដោយពុំមានទីជម្រកក៏ដោយ គង់តែព្រះអម្ចាស់ទ្រង់ក៏ នឹងមានសេចក្ដីមេត្តាករុណា ចំពោះពួកគេដែរ ។

៣ *ក* សុភា. ៣:១២;
ហេព្រើរ ១២:៥–១១;
គ. និង ស. ៩៥:១.
៤ *ក* ស.ប. សណ្ដាប់.
*ខ* អាលម៉ា ៩:១៦.
៥ *ក* ហេលេ. ១៣:១.
៧ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
៨ *ក* អាលម៉ា ២៣:៦; ២៧:២៧;
៣ នីហ្វៃ ៦:១៤.
៩ *ក* អាលម៉ា ២៤:១៧–១៩.
១១ *ក* អាលម៉ា ៩:១៦.
*ខ* ហេលេ. ៨:១៩.
*គ* ២ នីហ្វៃ ៣០:៥–៨.
១២ *ក* អេណុស ១:១២–១៣.
*ខ* មរមន ៥:១៥.
*គ* ១ នីហ្វៃ ១៣:៣១;
២ នីហ្វៃ ១០:១៨–១៩;
យ៉ាកុប ៣:៥–៦.

១៣ ហើយនេះគឺស្របទៅតាមការព្យាករណ៍ថា ពួកគេនឹង
[ក]ត្រូវបាននាំទៅដល់ការចេះដឹងដ៏ពិត គឺជាការចេះដឹងអំពី
ព្រះដ៏ប្រោស លោះរបស់គេ និង[ខ]អ្នកគង្វាលដ៏ពិត និងមហិមា
របស់គេ ហើយនឹងត្រូវបានរាប់ក្នុងចំណោមចៀមរបស់ទ្រង់ ។
១៤ ហេតុដូច្នេះហើយ ខ្ញុំសូមប្រាប់អ្នកថា ពួកគេនឹងត្រូវ
[ក]បានគ្រាន់បើជាងអ្នករាល់គ្នា លើកលែងតែអ្នករាល់គ្នាប្រែចិត្ត ។
១៥ ត្បិតមើលចុះ [ក]បើសិនជាកិច្ចការទាំងឡាយដ៏អស្ចារ្យត្រូវ
បានបង្ហាញដល់គេ ដូចដែលត្រូវបានបង្ហាញដល់អ្នករាល់គ្នា មែន
ហើយ គឺដល់ពួកគេដែលចុះអន់ថយក្នុងការឥតជំនឿ ពីព្រោះ
មកពីសណ្ដាប់ទាំងឡាយនៃពួកអយ្យកោរបស់គេ នោះអ្នករាល់
គ្នាអាចឃើញ ដោយខ្លួនឯងថា ពួកគេនឹងពុំចុះអន់ថយក្នុង
ការឥតជំនឿទៀតឡើយ ។
១៦ ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖
យើងនឹងពុំបំផ្លាញពួកគេចោលទាំងអស់ទេ ប៉ុន្តែនៅថ្ងៃនៃ
សេចក្ដីប្រាជ្ញា របស់យើង យើងនឹងធ្វើឲ្យពួកគេត្រឡប់មក
រកយើងវិញ គឺព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៧ ហើយឥឡូវនេះ មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល
អំពីប្រជាជននៃសាសន៍នីហ្វៃថា៖ បើសិនជាពួកគេពុំប្រែចិត្ត ហើយ
ពុំធ្វើតាមបំណងរបស់យើងទេ យើងនឹង[ក]បំផ្លាញពួកគេចោលទាំង
អស់ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ពីព្រោះតែ
ការឥតជំនឿរបស់គេ ទោះបីយើងបានធ្វើនូវកិច្ចការដ៏អស្ចារ្យ
ជាច្រើនដល់ពួកគេក៏ដោយ ហើយប្រាកដដូចជាព្រះអម្ចាស់ទ្រង់
មានព្រះ ជន្មរស់នៅ នោះការណ៍ទាំងនេះនឹងកើតឡើង ព្រះ
អម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ៕

## ជំពូកទី ១៦

*ពួកសាសន៍នីហ្វៃណាដែលជឿតាមសាំយូអែល បានទទួលបុណ្យជ្រមុជទឹកពីនីហ្វៃ — សាំយូអែលពុំអាចត្រូវសម្លាប់ដោយព្រួញ និងដោយ ដុំថ្មទាំងឡាយរបស់ពួកគេបានឡើយ — ជនខ្លះធ្វើចិត្តរឹងរូស ហើយជនខ្លះទៀតឃើញពួកទេវតាទាំងឡាយ — ពួកអ្នក ដែលគ្មានជំនឿនិយាយថា វាមិនសមនឹងជឿដល់ព្រះគ្រីស្ទ និងការយាងមកនៃទ្រង់ នៅក្រុងយេរូសាឡិមឡើយ ។ ប្រមាណជាឆ្នាំ ៦–១ ម.គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មានមនុស្ស
ជាច្រើនបានឮពាក្យរបស់សាំយូអែល ជាសាសន៍លេមិន ដែល
លោក បាននិយាយនៅលើកំផែងក្រុង ។ ហើយអស់អ្នកណា
ដែលជឿដល់ពាក្យរបស់លោក ក៏បានទៅ ហើយស្វែងរកនីហ្វៃ;
ហើយកាល ពួកគេបានជួបនឹងលោក គេបានទទួលសារភាព
ដល់លោកនូវអំពើបាបទាំងឡាយរបស់គេ ហើយពុំប្រកែកឡើយ
ដោយមានបំណង ចង់ទទួលបុណ្យជ្រមុជទឹកថ្វាយព្រះអម្ចាស់ ។
២ ប៉ុន្តែអស់អ្នកណាដែលពុំជឿដល់ពាក្យរបស់សាំយូអែល
ក៏ខឹងនឹងលោក; ហើយពួកគេបានចោលដុំថ្មទៅលើលោក នៅ
លើកំផែង ហើយមនុស្សជាច្រើនបានបាញ់ព្រួញទៅលើលោក
នៅពេលលោកឈរលើកំផែង; ប៉ុន្តែព្រះវិញ្ញាណនៃព្រះអម្ចាស់
បានស្ថិតនៅជាមួយនឹងលោក ដរាបដល់គេពុំអាចគប់ដុំថ្មត្រូវ
លោក ឬក៏បាញ់ព្រួញត្រូវលោកឡើយ ។
៣ ឥឡូវនេះ កាលពួកគេបានឃើញថា ពួកគេពុំអាចធ្វើអ្វីត្រូវ
លោកយ៉ាងនេះ មានមនុស្សជាច្រើនទៀត បានជឿដល់ពាក្យ
ពេចនឹ របស់លោក ដរាបដល់គេទៅរកនីហ្វៃ ដើម្បីទទួល
បុណ្យជ្រមុជទឹក ។
៤ ត្បិតមើលចុះ នីហ្វៃកំពុងតែធ្វើបុណ្យជ្រមុជទឹក និងព្យាករ
និងផ្សាយ ស្រែកហៅឲ្យប្រជាជនប្រែចិត្ត បង្ហាញនូវ[ក]ទីសំគាល់
ទាំង ឡាយ និងការណ៍អស្ចារ្យទាំងឡាយ សម្ដែងនូវអព្ភូតហេតុ
ទាំងឡាយ ក្នុងចំណោមប្រជាជន ដើម្បីឲ្យពួកគេអាចដឹងថា
[ខ]ព្រះគ្រីស្ទនឹង យាងមកក្នុងពេលយ៉ាងខ្លី —
៥ ប្រាប់ដល់ពួកគេអំពីការណ៍ទាំងឡាយ ដែលនឹងត្រូវ
កើតឡើងក្នុងពេលយ៉ាងខ្លី ដើម្បីឲ្យពួកគេដឹង ហើយចងចាំនូវ
ពេលដែល ការណ៍ទាំងនោះកើតឡើងថា ការណ៍ទាំងនោះបាន
ប្រាប់ដល់ពួកគេពីមុន ក្នុងគោលបំណងឲ្យពួកគេជឿ; ហេតុ
ដូច្នេះហើយ អស់អ្នក ណាដែលជឿដល់ពាក្យពេចនឹរបស់
សាំយូអែល បានទៅរកលោក ដើម្បីទទួលបុណ្យជ្រមុជទឹក
ព្រោះពួកគេបានមកដោយប្រែចិត្ត ហើយទទួលសារភាពនូវអំពើ
បាបទាំងឡាយរបស់ខ្លួន ។
៦ ប៉ុន្តែពួកគេភាគច្រើន ពុំជឿដល់ពាក្យពេចន៍របស់
សាំយូអែលទេ; ហេតុដូច្នេះហើយ កាលពួកគេបានឃើញថា ពួក
គេពុំអាច ចោលដុំថ្ម និងបាញ់ព្រួញត្រូវលោកទេ ទើបពួកគេបាន
ស្រែកប្រាប់ទៅពួកមេទ័ពរបស់គេថា៖ ចូរចាប់ជននោះ ហើយ

១៣ *ក* ៣ នីហ្វៃ ១៦:១២.
*ខ* ស.ប. អ្នកគង្វាលល្អ.
១៤ *ក* ហេលេ. ៧:២៣.
១៥ *ក* ម៉ាថាយ ១១:២០–២៣.
១៧ *ក* ហេលេ. ១៣:៦–១០.
**១៦** ៤ *ក* ស.ប. អព្ភូតហេតុ.
*ខ* ហេលេ. ១៤:២.

ចងវា ត្បិតមើលចុះ វាមានអារក្សមួយ; ហើយដោយសារ
អំណាចនៃអារក្ស ដែលនៅក្នុងខ្លួនវា នោះពួកយើងពុំ
អាចចោលត្រូវវាដោយដុំថ្ម ហើយពុំអាច បាញ់ព្រួញត្រូវវាទេ;
ហេតុដូច្នេះហើយ ចូរចាប់វាចង ហើយនាំវាយកទៅ ។
៧ ហើយនៅពេលពួកគេទៅចាប់លោក មើលចុះ លោកបាន
លោតចុះពីលើកំផែង ហើយបានរត់គេចចេញពីដែនដីរបស់គេទៅ
មែនហើយ លោកបានទៅដល់ប្រទេសរបស់លោកផ្ទាល់ ហើយ
បានចាប់ផ្ដើមផ្សាយ ហើយព្យាករក្នុងចំណោមប្រជាជន
របស់លោក ។
៨ ហើយមើលចុះ ចាប់ពីពេលនោះមក ពុំដែល
ឮដំណឹងអ្វីពីលោកនៅក្នុងចំណោមពួកនីហ្វៃទៀតឡើយ; ម្ល៉ោះ
ហើយ នោះគឺជា រឿងទាំងឡាយរបស់ប្រជាជន ។
៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប៉ែតសិបប្រាំមួយក្នុងរជ្ជកាលនៃ
ពួកចៅក្រម ទៅលើប្រជាជននីហ្វៃ ។
១០ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីប៉ែតសិបប្រាំពីរក្នុងរជ្ជកាលនៃ
ពួកចៅក្រមទៅ ឯមនុស្សភាគច្រើន ស្ថិតនៅក្នុងភាពឆ្មើងឆ្មៃ
និងសេចក្ដីទុច្ចរិតនៅឡើយ ឯមនុស្សភាគតិច ដើរយ៉ាងត្រង់
តទៅចំពោះព្រះ ។
១១ ហើយនេះគឺជាកាលៈទេសៈទាំងឡាយផងដែរ
នៅឆ្នាំទីប៉ែតសិបប្រាំបីក្នុងរជ្ជកាលនៃពួកចៅក្រម ។
១២ ហើយមានការប្រែប្រួលតែបន្តិចបន្តួចប៉ុណ្ណោះទេ
ក្នុងរឿងប្រជាជន លើកលែងតែប្រជាជនបានចាប់ផ្ដើមរឹងរូសក្នុង
អំពើទុច្ចរិត ហើយបានធ្វើថែមឡើងនូវអ្វីៗ ដែលផ្ទុយនឹង
ព្រះបញ្ញត្តិទាំងឡាយនៃព្រះ នៅឆ្នាំទីប៉ែតសិបប្រាំបួនក្នុងរជ្ជកាល
នៃពួកចៅក្រម ។
១៣ ប៉ុន្តែហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីកៅសិ
បក្នុងរជ្ជកាលនៃពួកចៅក្រម ប្រជាជនបានឃើញទីសំគាល់ដ៏ធំ
ៗជាច្រើន និងការណ៍អស្ចារ្យទាំងឡាយ; ហើយពាក្យពេចន៍
របស់ពួកព្យាការីបានចាប់ផ្ដើមបំពេញ ។
១៤ ហើយពួកទេវតាបានលេចមកឯមនុស្ស និងពួកអ្នកប្រាជ្ញ
ហើយបានប្រកាសដល់ពួកគេ នូវដំណឹងដ៏រីករាយ អំពីសេច
ក្ដីអំណរ យ៉ាងអស្ចារ្យ; ម្ល៉ោះហើយ នៅក្នុងឆ្នាំនេះបទគម្ពីរទាំង
ឡាយបានចាប់ផ្ដើមបំពេញ ។
១៥ ទោះជាយ៉ាងណាក៏ដោយ គង់តែប្រជាជនបាន
ចាប់ផ្ដើមធ្វើចិត្តរឹងរូសដែរ គឺពួកគេទាំងអស់ លើកលែងតែភាគ
មួយ ដែលមានជំនឿខ្ពស់ជាងគេប៉ុណ្ណោះ គឺទាំងពួកសាសន៍នីហ្វៃ
និងពួកសាសន៍លេមិនផង ហើយបានចាប់ផ្ដើមពឹងផ្អែកទៅលើកម្លាំង
ផ្ទាល់ខ្លួនរបស់គេ និងទៅលើប្រាជ្ញាផ្ទាល់ខ្លួនរបស់គេ ដោយ
និយាយថាៈ
១៦ ការណ៍ខ្លះៗពួកគេអាចស្មានត្រូវ នៅក្នុងចំណោម
ការណ៍ជាច្រើន; ប៉ុន្តែមើលចុះ យើងដឹងថា កិច្ចការដ៏មហិមា
និងអស្ចារ្យ ទាំងអស់នេះ ដែលបាននិយាយមកនេះ នឹងពុំ
អាចកើតឡើងបានទេ ។
១៧ ហើយពួកគេបានចាប់ផ្ដើមទាញហេតុផល និងទាស់គ្នាក្នុង
ចំណោមពួកគេ ដោយនិយាយថាៈ
១៨ ជាការណ៍មួយពុំសមហេតុសមផលដែលថា តួអង្គមួយ
ដូចជាព្រះគ្រីស្ទនឹងយាងមកទេ; បើសិនជាដូច្នោះមែន ហើយ
ទ្រង់ជាព្រះ រាជបុត្រានៃព្រះ ជាព្រះវរបិតានៃស្ថានសួគ៌និងផែនដី
ដូចដែលបាននិយាយមែន ហេតុអ្វីបានជាទ្រង់ ពុំបង្ហាញរូបអង្គ
ទ្រង់ដល់យើង នៅទីនេះផង ដូចជាទ្រង់បង្ហាញរូបអង្គទ្រង់ដល់
ពួកគេ នៅឯក្រុងយេរូសាឡិម ?
១៩ មែនហើយ ហេតុអ្វីបានជាទ្រង់ពុំបង្ហាញរូបអង្គ
ទ្រង់នៅលើដែនដីនេះផង ដូចជានៅលើដែនដីយេរូសាឡិម ?
២០ ប៉ុន្តែមើលចុះ យើងដឹងថា នេះគឺជាសណ្ដាប់អាក្រក់
ដែលត្រូវបានបន្តមកដល់យើង ដោយពួកអយ្យកោរបស់យើង
ដើម្បីធ្វើឲ្យ យើងជឿដល់ការណ៍ដ៏មហិមា និងអស្ចារ្យ ដែល
នឹងកើតឡើង ប៉ុន្តែពុំមែននៅក្នុងចំណោមពួកយើងទេ ប៉ុន្តែនៅ
ក្នុងដែនដី ដែលនៅ សែនឆ្ងាយ ជាដែនដីមួយ ដែល
យើងពុំស្គាល់; ហេតុដូច្នេះហើយ ទើបពួកគេអាចទុកឲ្យ
យើងនៅក្នុងភាពល្ងង់ខ្លៅ ព្រោះយើងពុំអាច មើលឃើញ
ដោយភ្នែកផ្ទាល់របស់យើងបានទេថា ការណ៍ទាំងនោះពិត ។
២១ ហើយដោយការវៃឆ្លាត និងបច្ចេកទេសអាថ៌កំបាំងនៃអ្នក
អាក្រក់ ពួកគេនឹងធ្វើឡើងនូវការអាថ៌កំបាំងដ៏អស្ចារ្យ ដែល
យើង ពុំអាចយល់ ដែលនឹងរក្សាយើងទុកជាអ្នកបំរើដល់ពាក្យ
របស់គេ និងជាអ្នកបំរើដល់គេផង ព្រោះយើងពឹងផ្អែកទៅលើគេ
ដើម្បីបង្រៀន យើងនូវព្រះបន្ទូល; ម្ល៉ោះហើយ ពួកគេនឹង
ទុកយើងឲ្យល្ងង់ខ្លៅ បើសិនជាយើងបណ្ដោយខ្លួនឲ្យគេធ្វើយ៉ាងនេះ
គឺអស់មួយជីវិតរបស់ យើង ។

១៣ *ក* ៣ នីហ្វៃ ១:៤.
*ខ* ហេលេ. ១៤:៣–៧.
១៤ *ក* អាលម៉ា ១៣:២៦.
១៥ *ក* អេសាយ ៥:២១.
១៨ *ក* អាលម៉ា ៣០:១២–១៣.
២០ *ក* ស.ប. សណ្ដាប់.
*ខ* អេធើរ ១២:៥–៦, ១៩.

២២ ហើយប្រជាជននៅមានការណ៍ជាច្រើនទៀត ដែល
ប្រជាជនសន្និដ្ឋានឃើញនៅក្នុងចិត្តគេ ដែលជាការឆ្កួតលីលា
និង[ក]ឥត ប្រយោជន៍; ហើយពួកគេត្រូវរំខានជាខ្លាំង ព្រោះអារក្ស
សាតាំងបានចាក់រុកគេឲ្យធ្វើអំពើទុច្ចរិតពុំឈប់ឈរ; មែនហើយ
វាបាន ដើរផ្សាយ នូវពាក្យចចាមអារាមទាំងឡាយ និងការ
ទាស់ទែងគ្នាទាំងឡាយនៅពាសពេញលើផ្ទៃដែនដី ដើម្បីវា
អាចធ្វើឲ្យចិត្ត មនុស្សរឹងទទឹងទាស់នឹងអ្វីៗដែលល្អ ហើយទាស់
នឹងអ្វីៗដែលនឹងកើតឡើង ។
២៣ ហើយទោះបីជាមានទីសំគាល់ និងការណ៍អស្ចារ្យទាំង
ឡាយ កើតឡើងនៅក្នុងចំណោមប្រជាជនរបស់ព្រះអម្ចាស់
និង ការណ៍ដ៏អស្ចារ្យជាច្រើន ដែលគេបានធ្វើក៏ដោយ
គង់តែអារក្សសាតាំងនៅតែក្ដាប់ជាប់ដួងចិត្តមនុស្សភាគច្រើន
នៅលើផ្ទៃដែនដីនេះ ។
២៤ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទិកៅសិបក្នុងរជ្ជកាលនៃពួកចៅក្រម
ទៅលើប្រជាជននីហ្វៃ ។
២៥ ម្ល៉ោះហើយ ក៏ចប់គម្ពីរហេលេមិន ស្របតាមបញ្ជី
របស់ហេលេមិន និងពួកកូនប្រុសរបស់លោក ៕ :៙:–

# នីហ្វៃទី ៣
# គម្ពីរនីហ្វៃ

កូនប្រុសរបស់នីហ្វៃ ដែលត្រូវជាកូនប្រុសរបស់ហេលេមិន

ហើយហេលេមិន ជាកូនប្រុសរបស់ហេលេមិន ដែលជាកូនប្រុសរបស់អាលម៉ា ដែលជាកូនប្រុសរបស់អាលម៉ា ជាពូជពង្សរបស់នីហ្វៃ ដែលជាកូនប្រុសរបស់លីហៃ ដែលបានចាកចេញពីក្រុងយេរូសាឡិម នៅក្នុងឆ្នាំទី ១ នៃរាជ្យសេដេគា ស្ដេចស្រុកយូដា ។

## ជំពូកទី ១

*នីហ្វៃដែលជាកូនប្រុសរបស់ហេលេមិន ចាកចេញពីដែនដី ហើយនីហ្វៃជាកូនប្រុសរបស់លោក រក្សាបញ្ជីទាំងឡាយ — ទោះជាមាន ទីសំគាល់ទាំងឡាយ និងការណ៍អស្ចារ្យទាំងឡាយក្ដី គង់តែពួកទុច្ចរិតមានគំរោងការនឹងសម្លាប់ពួកសុចរិតដែរ — យប់នៃថ្ងៃកំណើត ព្រះគ្រីស្ទមកដល់ — ទីសំគាល់បាន ស្ដែងឡើង ហើយផ្កាយថ្មីមួយរះឡើង — ការភូតកុហក និង ការបោកបញ្ឆោតកើតឡើង ហើយពួកចោរ កាឌីអានតុនសម្លាប់ មនុស្សអស់ជាច្រើន ។ ប្រមាណជាឆ្នាំ ១–៤ គ.ស. ។*

ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ឆ្នាំទីកៅសិបមួយ
បានកន្លងផុតទៅ ហើយគឺ[ក]ប្រាំមួយរយឆ្នាំ ក្រោយពីលីហៃ
បានចាកចេញ ពីក្រុងយេរូសាឡិមមក ហើយគឺជាឆ្នាំដែល
ឡាកូនីអូសធ្វើជាមេចៅក្រម និងជាអ្នកត្រួតត្រាលើដែនដីនេះ ។
២ ហើយនីហ្វៃ ដែលជាកូនប្រុសរបស់ហេលេមិន បានចេញ
ដំណើរពីដែនដីសារ៉ាហិមឡា ដោយបានប្រគល់បន្ទុកឲ្យកូនប្រុស
របស់ លោក ឈ្មោះ[ក]នីហ្វៃ ដែលជាកូនប្រុសប្រុសច្បង ឲ្យកត់
[ខ]ផ្ទាំងលង្ហិន និងបញ្ជីទាំងអស់ដែលបានកត់ទុក និងអស់ទាំងវត្ថុ
ឯទៀត ដែលត្រូវ បានរក្សាទុកជាពិសិដ្ឋ ចាប់តាំងពីដំណើរ
របស់លីហៃ ចេញពីក្រុងយេរូសាឡិមមក ។
៣ បន្ទាប់មក លោកបានចាកចេញពីដែនដី ហើយលោកទៅ
[ក]ឯណានោះ គឺគ្មាននរណាដឹងទេ; ហើយនីហ្វៃ ជាកូនប្រុស
របស់លោក បានកត់បញ្ជីទាំងឡាយជំនួសលោក មែនហើយ
គឺបញ្ជីអំពីប្រជាជននេះ ។
៤ ហើយហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីកៅសិបពីរ
មើលចុះ ការព្យាករណ៍របស់ពួកព្យាការីបានចាប់ផ្ដើមបំពេញ
ដោយពេញលេញ; ព្រោះចាប់ផ្ដើមមានទីសំគាល់ដ៏ច្រើនឡើង
និងអព្ភូតហេតុដ៏ច្រើនឡើង នៅក្នុងចំណោមប្រជាជន ។

២២ *ក* ស.ប. ឥតប្រយោជន៍,
ការឥតប្រយោជន៍.
[៣ នីហ្វៃ]
១ ១*ក* ២ នីហ្វៃ ២៥:១៩.
២ *ក* ស.ប. នីហ្វៃ, កូនប្រុសរបស់នីហ្វៃ
ដែលជាកូនប្រុសរបស់ហេលេមិន.
*ខ* អាលម៉ា ៣៧:៣–៥.
៣ *ក* ៣ នីហ្វៃ ២:៩.

៥ ប៉ុន្តែមានអ្នកខ្លះបានចាប់ផ្ដើមនិយាយថា ពេលវេលាបាន
កន្លងហួសហើយ សំរាប់ពាក្យទាំងនោះត្រូវបានបំពេញ គឺជា
ពាក្យ[ក]ដែលបាននិយាយដោយសាំយូអែល ដែលជាសាសន៍
លេមិននោះ ។
៦ ហើយពួកគេបានចាប់ផ្ដើមអរវីករាយនឹងបងប្អូនរបស់គេ
ដោយនិយាយថា៖ មើលចុះ ពេលនោះបានកន្លងផុតទៅហើយ
ឯពាក្យរបស់សាំយូអែលពុំបានបំពេញទេ; ហេតុដូច្នេះហើយ
សេចក្ដីអំណរ និងសេចក្ដីជំនឿរបស់អ្នកអំពីរឿងនេះ បែរជាឥត
ប្រយោជន៍ទៅវិញ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានបង្កើត
ចលាចលយ៉ាងធំមួយទូទាំងដែនដី; ឯប្រជាជនដែលបានជឿ
ក៏កើតសេចក្ដីព្រួយជាខ្លាំង ខ្លាចក្រែងដោយសារមធ្យោបាយ
ណាមួយ រឿងទាំងឡាយដែលបាននិយាយមកពីមុន នឹង
ពុំកើតឡើង ។
៨ ប៉ុន្តែមើលចុះ ពួកគេបានរង់ចាំមើលយ៉ាងខ្ជាប់ខ្ជួននូវថ្ងៃនោះ
និងយប់នោះ ហើយថ្ងៃនោះត្រូវជាមួយថ្ងៃ ដែលហាក់បីដូចជា
គ្មាន យប់សោះ ដើម្បីគេអាចដឹងថា សេចក្ដីជំនឿរបស់គេពុំ
ឥតប្រយោជន៍ ។
៩ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មានមួយថ្ងៃដែល
បានកំណត់ទុកដោយពួកអ្នកដែលពុំជឿថា អស់អ្នកណាដែល
ជឿតាមសណ្ដាប់ទាំងនោះ នឹង[ក]ត្រូវប្រហារជីវិតចោល
លើកលែងតែមានទីសំគាល់កើតឡើង ដែលបានប្រាប់ដោយ
សាំយូអែល ជាព្យាការី ។
១០ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលនីហ្វៃ ជា
កូនប្រុសរបស់នីហ្វៃ បានឃើញនូវអំពើទុច្ចរិតនៃប្រជាជនរបស់
លោក ចិត្តលោកបានពោរពេញទៅដោយទុក្ខព្រួយជាអតិបរមា ។
១១ ហើយហេតុការណ៍បានកើតឡើងថា លោកបានចេញទៅក្រៅ
ហើយបានក្រាបទៅលើដី ហើយបានអំពាវនាវយ៉ាងខ្លាំង ដល់
ព្រះរបស់លោក ជំនួសប្រជាជនរបស់លោក មែនហើយ គឺឯ
សង្ឃកនាដែលជិតនឹងត្រូវបំផ្លាញចោល ដោយសារតែសេចក្ដី
ជំនឿ របស់គេ នៅក្នុងសណ្ដាប់នៃពួកអយ្យកោរបស់គេ ។
១២ ហើយហេតុការណ៍បានកើតឡើងថា លោកបាន
អំពាវនាវ[ក]យ៉ាងខ្លាំងដល់ព្រះពេញមួយថ្ងៃ; ហើយមើលចុះ
សម្លេងនៃព្រះ អម្ចាស់បានបន្លឺមកកាន់លោកថា៖
១៣ ចូរងើបឡើង ហើយមានសេចក្ដីសង្ឃឹមចុះ; ត្បិតមើលចុះ
ពេលនោះជិតមកដល់ហើយ ហើយនៅក្នុងយប់នេះ ទីសំគាល់
នឹងលេចមក ហើយ[ក]ថ្ងៃស្អែកឡើង យើងនឹងចុះមកឯលោកិយ
ដើម្បីបង្ហាញដល់មនុស្សលោកថា យើងនឹងបំពេញនូវអ្វីៗទាំង
អស់ ដែលយើងបានបណ្ដាល[ខ]ឲ្យនិយាយ ដោយមាត់នៃពួក
ព្យាការីបរិសុទ្ធរបស់យើង ។
១៤ មើលចុះ យើងនឹង[ក]មកឯរាស្ត្រយើង ដើម្បី[ខ]បំពេញនូវការណ៍
ទាំងអស់ដែលយើងបានប្រាប់ដល់កូនចៅមនុស្ស ចាប់តាំង
ពី[គ]កំណើតលោកិយមក ហើយដើម្បីធ្វើតាមព្រះហឫទ័យ[ឃ]នៃ
ព្រះវរបិតា និងព្រះរាជបុត្រា — ព្រះហឫទ័យនៃព្រះវរបិតា
ពីព្រោះតែយើង ហើយព្រះហឫទ័យនៃព្រះរាជបុត្រា ពីព្រោះ
តែសាច់របស់យើង ។ ហើយមើលចុះ ពេលនោះនៅជិតដែបង្កើយ
ហើយយប់នេះ ទីសំគាល់នឹងមកហើយ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា ពាក្យដែលបាន
បន្លឺដល់នីហ្វៃ ត្រូវបានបំពេញមែន ស្របតាមពាក្យទាំងនេះដែល
បាន និយាយមក; ត្បិតមើលចុះ នៅវេលាថ្ងៃលិច ក៏[ក]ពុំងងឹតសោះ;
ហើយប្រជាជនបានចាប់ផ្ដើមមានសេចក្ដីអស្ចារ្យ ពីព្រោះពុំមាន
ភាពងងឹត សោះ កាលពេលយប់មកដល់។
១៦ ហើយមនុស្សជាច្រើន ដែលពុំបានជឿដល់ពាក្យពេចន៍របស់
ព្យាការី ដែលបាន[ក]ដួលទៅលើដី ហើយបានក្លាយទៅហាក់ដូចជា
គេស្លាប់ ព្រោះគេដឹងថា [ខ]ផែនការនៃការបំផ្លិចបំផ្លាញដ៏មហិមា
ដែលគេបានដាក់សំរាប់អស់អ្នកណា ដែលជឿដល់ពាក្យពេចន៍
របស់ ព្យាការី ត្រូវគ្មានប្រសិទ្ធិភាព; ព្រោះទីសំគាល់ដែលបានឲ្យ
ពីមុន នោះមកដល់ហើយ ។
១៧ ហើយពួកគេបានចាប់ផ្ដើមដឹងថា ព្រះរាជបុត្រានៃព្រះ
នឹងលេចមកក្នុងពេលយ៉ាងខ្លី; មែនហើយ សរុបសេចក្ដីមក
ប្រជាជនទាំងអស់ដែលនៅលើផែនដីនេះ ចាប់ពីទិសខាងលិច
ទៅដល់ទិសខាងកើត ទាំងនៅផ្នែកខាងជើង និងផ្នែកខាងត្បូង
មានសេចក្ដីអស្ចារ្យយ៉ាងខ្លាំង រហូតដល់គេដួលទៅលើដី ។
១៨ ព្រោះពួកគេបានដឹងថា ពួកព្យាការីបានធ្វើបន្ទាល់ នូវរឿង

៥ *ក* ហេលេ. ១៤:២–៤.
៩ *ក* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
១២ *ក* អេណុស ១:៤; អាលម៉ា ៥:៤៦.
១៣ *ក* លូកា ២:១០–១១.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
១៤ *ក* យ៉ូហាន ១:១១.
*ខ* ម៉ាថាយ ៥:១៧–១៨.
*គ* អាលម៉ា ៤២:២៦.
*ឃ* គ. និង ស. ៩៣:៣–៤.
១៥ *ក* ហេលេ. ១៤:៣.
១៦ *ក* ហេលេ. ១៤:៧.
*ខ* ៣ នីហ្វៃ ១:៩.

ទាំងនេះជាច្រើនឆ្នាំមក ហើយបានដឹងថា ទីសំគាល់ដែលត្រូវបាន
ប្រាប់មកនោះបានមកដល់ហើយ; ហើយពួកគេបានចាប់ផ្ដើមភិតភ័យ
ពីព្រោះមកពីអំពើទុច្ចរិតរបស់គេ និងការឥតជំនឿរបស់គេ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ពេញមួយយប់នោះ
គ្មានភាពងងឹតអ្វីសោះ ប៉ុន្តែភ្លឺដូចពេលកណ្ដាលថ្ងៃត្រង់ ។ ហើយ
ហេតុការណ៍បានកើតឡើងថា ព្រះអាទិត្យក៏បានរះឡើងជាថ្មី
នៅពេលព្រឹកជាប្រក្រតី; ហើយពួកគេបានដឹងថា នេះគឺជាថ្ងៃ
ដែល ព្រះអម្ចាស់ទ្រង់ត្រូវប្រសូត ពីព្រោះមកពីទីសំគាល់ដែល
បានឲ្យមកជាមុន ។
២០ ហើយអ្វីៗបានកើតឡើង មែនហើយ គឺអ្វីៗទាំងអស់
គ្រប់ការណ៍ទាំងអស់ ស្របតាមពាក្យពេចន៍របស់ពួកព្យាការី ។
២១ ហើយហេតុការណ៍បានកើតឡើងថា ផ្កាយថ្មីមួយបាន
រះឡើង ស្របតាមពាក្យទំនាយ ។
២២ ហើយហេតុការណ៍បានកើតឡើងថា ចាប់តាំងពីពេលនោះ
មក ក៏ចាប់ផ្ដើមមានពាក្យកុហកផ្សព្វផ្សាយនៅក្នុង
ចំណោមប្រជាជន ដោយអារក្សសាតាំង ដើម្បីធ្វើឲ្យចិត្តពួកគេ
រឹងរូស នៅក្នុងបំណងដើម្បីកុំឲ្យពួកគេជឿដល់ទីសំគាល់ និង
ការណ៍អស្ចារ្យទាំងឡាយ នោះ ដែលពួកគេបានឃើញ;
ប៉ុន្តែទោះមានការកុហក និងការបំភាន់ទាំងនេះក៏ដោយ គង់តែ
ប្រជាជនភាគច្រើនបានជឿ ហើយបាន ប្រែចិត្តជឿដល់ព្រះ
អម្ចាស់ដែរ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃបានចេញទៅ
ក្នុងចំណោមប្រជាជន និងមនុស្សជាច្រើនទៀតផង ដើម្បីធ្វើ
បុណ្យ ជ្រមុជទឹក ចំពោះការប្រែចិត្ត នៅក្នុងនោះ មានការ
ផ្ដាច់បាបដ៏មហិមា ។ ម្ល៉ោះហើយ ប្រជាជនបានចាប់ផ្ដើមមាន
សន្តិភាពជាថ្មី នៅលើដែនដី ។
២៤ ហើយពុំមានការទាស់ទែងគ្នាទៀតទេ លើកលែងតែមាន
មនុស្សមួយចំនួនតូច បានចាប់ផ្ដើមផ្សាយ ដើម្បីឧបញ្ជាក់តាម
បទគម្ពីរទាំងឡាយថា ពុំជាការចាំបាច់ត្រូវគោរពតាមក្រិត្យវិន័យ
លោកម៉ូសេតទៅទៀតឡើយ ។ ឥឡូវនេះ នៅក្នុងរឿងនេះ
ពួកគេ បានភាន់ច្រឡំ ហើយដោយពុំយល់បទគម្ពីរទាំងឡាយទេ ។
២៥ ប៉ុន្តែហេតុការណ៍បានកើតឡើងថា មិនយូរប៉ុន្មាន ពួកគេ
បានប្រែចិត្តជឿ ហើយត្រូវបានបរិវត្តអំពីកំហុស ដែលពួកគេ
បានធ្វើ ព្រោះត្រូវបានធ្វើឲ្យពួកគេដឹងថា ក្រិត្យវិន័យនោះ
ពុំទាន់បានបំពេញនៅឡើយទេ ហើយថា វានឹងត្រូវតែបាន
បំពេញដោយសព្វគ្រប់; មែនហើយ ពាក្យនោះត្រូវបាន
ប្រាប់ដល់ពួកគេថា វាត្រូវតែបានបំពេញ; មែនហើយ ទោះ
ជាបាំងឈើមួយ ឬក្បៀសមួយ ក៏មិនត្រូវកន្លង ចោលដែរ
រហូតដល់បានបំពេញ; ហេតុដូច្នេះហើយ នៅក្នុងឆ្នាំដដែល
នេះ ពួកគេបានត្រូវនាំឲ្យស្គាល់នូវកំហុសរបស់ខ្លួន ហើយបាន
ទទួលសារភាពនូវកំហុសរបស់ខ្លួន ។
២៦ ម្ល៉ោះហើយ ឆ្នាំទីកៅសិបពីរបានកន្លងផុតទៅ ដោយបាន
នាំមកនូវដំណឹងដ៏រីករាយដល់ប្រជាជន ពីព្រោះទីសំគាល់ ទាំង
ឡាយបានកើតឡើង ស្របតាមពាក្យព្យាករណ៍ទាំងឡាយនៃពួក
ព្យាការីបរិសុទ្ធទាំងអស់ ។
២៧ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីកៅសិបបីបាន
កន្លងផុតទៅដោយសន្តិភាពដែរ លើកលែងតែមានពួកចោរ
កាឌីអានតុន ដែលរស់នៅតាមភ្នំ បានរាតត្បាតដល់ដែនដី;
ព្រោះជំរុំពួកវា និងទីកន្លែងសម្ងាត់ទាំងឡាយរបស់ពួកវា
មាំមួនណាស់ ដែលប្រជាជនពុំអាចវាយបំបែកបានឡើយ; ហេតុ
ដូច្នេះហើយ ពួកវាបានប្រព្រឹត្តឃាតកម្មជាច្រើន ហើយបានធ្វើ
ការកាប់សម្លាប់ យ៉ាងសំបើម នៅក្នុងចំណោមប្រជាជន ។
២៨ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីកៅសិបបួន
ពួកវាបានកើនចំនួនយ៉ាងច្រើន ពីព្រោះមានមនុស្សជាច្រើនដែល
បានបែកចេញពីពួកសាសន៍នីហ្វៃ បានភៀសខ្លួនទៅរកពួកវា
ដែលបានបណ្ដាលឲ្យមានទុក្ខព្រួយជាខ្លាំង ដល់ពួកសាសន៍នីហ្វៃ
ដែលនៅ សល់ក្នុងដែនដីទាំងប៉ុន្មាន ។
២៩ ហើយមានហេតុមួយ ដែលនាំឲ្យមានទុក្ខសោកនៅក្នុង
ចំណោមពួកលេមិនផងដែរ; ត្បិតមើលចុះ ពួកគេមានកូនចៅជា
ច្រើនដែលធំឡើង ហើយបានចាប់ផ្ដើមមានវ័យធំ ដែលពួកគេ
បានក្លាយទៅជាមានគំនិតផ្ទាល់ខ្លួន ហើយត្រូវបានដឹកនាំដោយ
ពួក សាសន៍សូរាំ ខ្លះដោយប្រើការភូតកុហក និងពាក្យបញ្ឆោត
ធ្វើឲ្យពួកគេចូលរួមជាមួយពួកចោរកាឌីអានតុន ។
៣០ ម្ល៉ោះហើយ ពួកសាសន៍លេមិនក៏ត្រូវបានរងទុក្ខវេទនាដែរ
ហើយបានចាប់ផ្ដើមបន្ថយនូវសេចក្ដីជំនឿ និងសេចក្ដីសុចរិត
របស់គេ ពីព្រោះមកពីអំពើទុច្ចរិត នៃជំនាន់ដែលកំពុងធំឡើង ៕

---

១៩ *ក* លូកា ២:១–៧.
២១ *ក* ម៉ាថាយ ២:១–២;
ហេលេ. ១៤:៥.
២៣ *ក* ស.ប. ការផ្ដាច់បាប.
២៤ *ក* អាលម៉ា ៣៤:១៣.
២៥ *ក* ម៉ាថាយ ៥:១៧–១៨.
*ខ* ម៉ូសាយ ២៦:២៩.
២៧ *ក* ស.ប. ពួកចោរកាឌីអានតុន.
២៩ *ក* អាលម៉ា ៣០:៥៩.

## ជំពូកទី ២

*អំពើទុច្ចរិត និងអំពើខ្ពើមឆ្អើមទាំងឡាយ កើនឡើងនៅក្នុង
ចំណោមប្រជាជន — ពួកសាសន៍នីហ្វៃ និងពួកសាសន៍
លេមិនរួបរួមគ្នា ដើម្បីការពារខ្លួនប្រឆាំងនឹងពួកចោរកាឌីអានតុន
— ពួកសាសន៍លេមិនដែលប្រែចិត្តជឿ ក្លាយទៅជាស ហើយ
ត្រូវបានហៅថា សាសន៍នីហ្វៃ ។ ប្រមាណជាឆ្នាំ ៥–១៦ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីកៅសិបប្រាំបាន
កន្លងផុតទៅយ៉ាងនេះដែរ ហើយប្រជាជនបាន
ចាប់ផ្ដើមភ្លេចទីសំគាល់ និង ការអស្ចារ្យទាំងឡាយ ដែលពួកគេ
បានឮនោះ ហើយបានចាប់ផ្ដើមមានសេចក្ដីអស្ចារ្យកាន់តែតិចទៅៗ
ចំពោះទីសំគាល់ ឬការ អស្ចារ្យនីមួយៗអំពីស្ថានសួគ៌ ដរាបដល់
ពួកគេបានចាប់ផ្ដើមរឹងរូស នៅក្នុងចិត្តរបស់គេ និង
ងងឹតងងល់នៅក្នុងគំនិតរបស់គេ ហើយបាន ចាប់ផ្ដើមមិនជឿអ្វី
ៗទាំងអស់ ដែលពួកគេបានឃើញហើយបានឮ —
២ ដោយនឹកក្នុងចិត្តដល់ការឥតប្រយោជន៍ថា ការណ៍
នោះត្រូវបានធ្វើឡើងដោយមនុស្ស និងដោយអំណាចរបស់
អារក្ស ដើម្បីបញ្ឆោត និងដឹកនាំចិត្តមនុស្សឲ្យវង្វេង; ម្ល៉ោះហើយ
អារក្សសាតាំងបានចាប់យកដួងចិត្តមនុស្សបានជាថ្មីទៀត ដរាប
ដល់វាបាន ធ្វើឲ្យគេខ្វាក់ភ្នែក ហើយនាំគេឲ្យវង្វេង ឲ្យជឿថា
គោលលទ្ធិព្រះគ្រីស្ទ គឺជាការណ៍មួយដ៏ឆ្កួតលីលា
ហើយឥតប្រយោជន៍ទៅវិញ ។
៣ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបាន
ចាប់ផ្ដើមមានកម្លាំងមុតមាំ នៅក្នុងអំពើទុច្ចរិត និងអំពើខ្ពើមឆ្អើម
ទាំងឡាយ; ហើយពួកគេមិនជឿថា នឹងមានទីសំគាល់ ឬការ
អស្ចារ្យឯណាទៀតទេ ដែលនឹងត្រូវបានប្រទានមក; ហើយអារក្ស
សាតាំង បានចេញ ទៅ ដើម្បីនាំចិត្តមនុស្សឲ្យវង្វេង ល្បួងពួក
គេ ហើយបណ្ដាលឲ្យពួកគេ ធ្វើអំពើទុច្ចរិតដ៏ធំនៅលើផែនដី ។
៤ ហើយឆ្នាំទីកៅសិបប្រាំមួយ បានកន្លងផុតទៅយ៉ាងនេះ និង
ឆ្នាំទីកៅសិបប្រាំពីរផងដែរ និងឆ្នាំទីកៅសិបប្រាំបីផង និងឆ្នាំ
ទីកៅសិបប្រាំបួនផង ។
៥ ហើយមួយរយឆ្នាំបានកន្លងទៅដែរ ចាប់ពីសម័យហ្លួង
ម៉ូសាយ ដែលជាស្ដេចលើប្រជាជននៃសាសន៍នីហ្វៃ ។
៦ ហើយប្រាំមួយរយប្រាំបួនឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីកាល
ដែលលីហៃ បានចាកចេញពីក្រុងយេរូសាឡិមមក ។
៧ ហើយប្រាំបួនឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីកាលដែល
ទីសំគាល់ត្រូវបានប្រទានមក ដែលបាននិយាយដោយពួក
ព្យាការីថា ព្រះគ្រីស្ទនឹងយាងមកឯលោកិយ ។
៨ ឥឡូវនេះ ពួកសាសន៍នីហ្វៃបានចាប់ផ្ដើមរាប់ពេលវេលារបស់គេ
ចាប់ពីរយៈពេលដែលទីសំគាល់បានប្រទានមកនេះ ឬចាប់ពី ការ
យាងមកនៃព្រះគ្រីស្ទ; ហេតុដូច្នោះហើយ ប្រាំបួនឆ្នាំបាន
កន្លងផុតទៅ ។
៩ ហើយនីហ្វៃ ដែលត្រូវជាឪពុករបស់នីហ្វៃ ដែលជាអ្នក
មានភារៈរក្សាបញ្ជីទាំងឡាយ ពុំបានត្រឡប់ទៅដែនដី
សារ៉ាហិមឡា វិញទេ ហើយក៏មិនអាចរកឃើញនៅក្នុងអស់
ទាំងដែនដីដែរ ។
១០ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជននៅតែស្ថិតក្នុង
អំពើទុច្ចរិត ទោះជាមានការផ្សាយ និងការព្យាករណ៍ជាច្រើន
ដែលបានធ្វើឡើងនៅក្នុងចំណោមពួកគេក្ដី ហើយឆ្នាំទីដប់បាន
កន្លងផុតទៅដូច្នោះដែរ; ហើយឆ្នាំទីដប់មួយក៏បានកន្លងផុតទៅ
នៅ ក្នុងអំពើទុច្ចរិតដែរ ។
១១ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីដប់បី
ចាប់ផ្ដើមមានសង្គ្រាមទាំងឡាយ និងការទាស់ទែងគ្នាទាំងឡាយ
ទូទៅអស់ទាំងដែនដី; ព្រោះពួកចោរកាឌីអានតុន បានក្លាយទៅជា
មានចំនួនដ៏ច្រើនឥតគណនា ហើយបានសម្លាប់ប្រជាជនអស់ជា
ច្រើន ហើយបានធ្វើឲ្យទីក្រុងជាច្រើនគ្មានមនុស្សនៅ ហើយបាន
ពង្រាលសេចក្ដីស្លាប់ និងការកាប់សម្លាប់ដ៏ច្រើនទូទៅទាំងដែនដី
ដែលក្លាយទៅជាការចាំបាច់ថា ប្រជាជនទាំងអស់ ទាំងពួក
សាសន៍នីហ្វៃ និងពួកសាសន៍លេមិន ត្រូវលើកអាវុធប្រឆាំងនឹង
ពួកវា ។
១២ ហេតុដូច្នេះហើយ សាសន៍លេមិនទាំងអស់ ដែលបាន
ក្លាយទៅជាអ្នកប្រែចិត្តជឿដល់ព្រះអម្ចាស់ បានរួបរួមជាមួយ
គ្នានឹង បងប្អូនរបស់គេ គឺពួកសាសន៍នីហ្វៃ ហើយ
ត្រូវបង្ខំចិត្តលើកអាវុធប្រឆាំងនឹងពួកចោរកាឌីអានតុនទាំងនោះ
ដើម្បីការពារជីវិតរបស់គេ និងប្រពន្ធរបស់គេ និងកូនរបស់គេ
មែនហើយ ហើយរក្សាសិទ្ធិទាំងឡាយរបស់គេផង និងឯកសិទ្ធិ
ទាំងឡាយ នៃសាសនាចក្ររបស់គេ និងការថ្វាយបង្គំរបស់គេ
និងសេរីភាពរបស់គេ និងឥស្សរភាពរបស់គេ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា មុនឆ្នាំទីដប់បីនេះ
កន្លងផុតទៅ ពួកសាសន៍នីហ្វៃត្រូវគំរាមកំហែង ឲ្យដល់នូវការ

---

២ ២*ក* ស.ប. ការបោក, បញ្ឆោត, សេចក្ដីបញ្ឆោត.
៣ *ក* គ. និង ស. ១០:២៧.
៥ *ក* ម៉ូសាយ ២៩:៤៦–៤៧.
៩ *ក* ៣ នីហ្វៃ ១:២–៣.
១២ *ក* ស.ប. សេរី, សេរីភាព.
*ខ* ស.ប. ឥស្សរភាព.

បំផ្លិច បំផ្លាញទាំងស្រុង ដោយសារសង្គ្រាមនេះ ដែលបានក្លាយ
ទៅជាឃោរឃៅជាខ្លាំង ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិន
ទាំងនោះ ដែលបានរួបរួមជាមួយនឹងពួកសាសន៍នីហ្វៃ ត្រូវបាន
រាប់ ក្នុងចំណោមពួកសាសន៍នីហ្វៃ ។
១៥ ហើយ[ក]បណ្ដាសារបស់[ខ]គេត្រូវបានដកចេញ ហើយ
ស្បែករបស់គេបានក្លាយមកជាពណ៌ស ដូចពួកសាសន៍នីហ្វៃ ។
១៦ ហើយពួកកំឡោះ និងពួកកូនក្រមុំរបស់គេ បានក្លាយ
ទៅជាស្រស់ល្អដ៏លើសលប់ ហើយពួកគេត្រូវបានរាប់ក្នុងចំណោម
ពួកសាសន៍នីហ្វៃ ហើយត្រូវបានហៅថា សាសន៍នីហ្វៃ ។
ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់បីទៅ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា នៅដើមឆ្នាំទីដប់បួន
សង្គ្រាមរវាងពួកចោរនឹងប្រជាជននីហ្វៃ បានបន្តទៅមុខ ហើយ
បានក្លាយទៅជាឃោរឃៅយ៉ាងខ្លាំង; ទោះជាយ៉ាងណាក៏ដោយ
គង់តែប្រជាជននីហ្វៃបានយកប្រៀបលើពួកចោរបានដែរ ដរាប
ដល់ ពួកគេបានរុញច្រានពួកវា ឲ្យថយក្រោយចេញពីដែនដីគេ
ទៅក្នុងភ្នំទាំងឡាយ និងក្នុងទីសម្ងាត់ទាំងឡាយរបស់ពួកវាវិញ ។
១៨ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់បួនទៅ ។ ហើយនៅក្នុង
ឆ្នាំទីដប់ប្រាំ ពួកវាបានចេញមកតតាំងនឹងប្រជាជននីហ្វៃ; ហើយ
មកពី អំពើទុច្ចរិតរបស់ប្រជាជននីហ្វៃ និងការទាស់ទែង និងការ
បែកបាក់គ្នាជាច្រើនរបស់គេ នោះពួកចោរកាឌីអានតុនយក
ប្រៀបលើ គេបាន ។
១៩ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីដប់ប្រាំទៅ ម្ល៉ោះហើយ ប្រជាជន
បាននៅក្នុង[ក]ស្ថានភាពមួយ ដែលមានសេចក្ដីទុក្ខវេទនាដ៏ច្រើន;
ហើយដាវនៃការបំផ្លិចបំផ្លាញបានព្យួរនៅពីលើគេ ដរាប
ដល់គេជិតត្រូវវាយកាប់រំលំចោល ហើយនេះគឺមកពីអំពើទុច្ចរិត
របស់គេ ៕

## ជំពូកទី ៣

*គីឌគីអានហៃ ដែលជាមេដឹកនាំពួកកាឌីអានតុនទាមទារឲ្យឡាកូនីអូស និងពួកសាសន៍នីហ្វៃចុះចាញ់ ហើយប្រគល់ដែនដីរបស់គេ — ឡាកូនីអូសតែងតាំងគីឌគីឌូណៃ ជាមេកងទ័ពឯកលើពលទ័ព — ពួកសាសន៍នីហ្វៃប្រមូលគ្នានៅក្រុងសារ៉ាហិមឡា និងក្រុងបរិបូរណ៍ ដើម្បីការពារខ្លួន ។ ប្រមាណជាឆ្នាំ ១៦–១៨ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីដប់ប្រាំ
មួយ ចាប់ពីកាលព្រះគ្រីស្ទយាងមក នោះឡាកូនីអូស ដែល
ជាចៅ ហ្វាយដែនដី បានទទួលសំបុត្រមួយច្បាប់ពីមេដឹកនាំ
និងចៅហ្វាយនៃក្រុមចោរនេះ; ហើយនេះគឺជាពាក្យដែលបាន
សរសេរមកថា៖
២ លោកឡាកូនីអូសដ៏ឧត្ដម និងជានាយចៅហ្វាយនៃដែនដីអើយ
មើលចុះ ខ្ញុំសរសេរសំបុត្រនេះមកលោក ហើយសូមជូន សេចក្ដី
សរសើរដ៏ធំលើសលប់ដល់លោក ដោយសារភាពរឹងប៉ឹង
របស់លោក និងភាពរឹងប៉ឹងរបស់ប្រជាជនលោកផង នៅក្នុងការ
ទ្រទ្រង់នូវអ្វីៗ ដែលលោកសន្មតថា ជាសិទ្ធិ និងឥស្សរភាព
របស់លោក; មែនហើយ លោកឈរយ៉ាងរឹងប៉ឹង
ហាក់បីដូចជាលោក ត្រូវបានគាំទ្រ ដោយព្រះហស្តនៃព្រះមួយអង្គ
នៅក្នុងកិច្ចការពារឥស្សរភាពរបស់លោក និងទ្រព្យសម្បត្តិ
របស់លោក និងប្រទេស របស់លោក ឬអ្វីៗដែល
លោកហៅដូច្នោះ ។
៣ ហើយហាក់ដូចជាការអាណិតលោក ឱលោកឡាកូនីអូស
ដ៏ឧត្ដមអើយ ថាលោកបែរជាឆោត និងឥតគំនិត ដោយគិត
ស្មានថា លោកអាចទប់ទល់នឹងកងទ័ពដ៏ក្លាហានជាច្រើន
យ៉ាងនេះ ដែលនៅក្រោមបញ្ជារបស់ខ្ញុំ ដែលនៅពេលឥឡូវនេះ
កំពុងតែ កាន់អាវុធ ហើយរង់ចាំយ៉ាងអន្ទះសាន្ទូវពាក្យថា —
ចូរចុះទៅវាយសម្រុកទៅលើពួកនីហ្វៃ ហើយបំផ្លាញ
ពួកវាចោលទៅ ។
៤ ហើយខ្ញុំ ដោយដឹងនូវទឹកចិត្តដ៏អង់អាចរបស់ពួកគេ ដែល
ត្រូវបានបញ្ជាក់បង្ហាញ នៅលើទីសមរភូមិ និងដោយដឹ
ងនូវសម្អប់ដ៏នៅ អស់កល្បជានិច្ចរបស់ពួកគេចំពោះពួកលោក
មកពីកំហុសដ៏ច្រើន ដែលពួកលោកបានធ្វើទៅលើពួកគេ
ហេតុដូច្នោះហើយ បើសិនជា ពួកគេវាយចុះសម្រុកទៅលើ
ពួកលោក នោះពួកគេនឹងមករកលោកដោយការបំផ្លិចបំផ្លាញ
ទាំងស្រុង ។
៥ ហេតុដូច្នេះហើយ ខ្ញុំបានសរសេរសំបុត្រនេះ បិទវាដោយដៃ
ខ្ញុំផ្ទាល់ ដោយយល់ដល់សុខុមាលភាពរបស់លោក មកពីភាព
រឹងប៉ឹងរបស់លោក ចំពោះអ្វីៗដែលលោកជឿថាត្រូវ និងទឹកចិត្ត
ដ៏ឧត្ដមរបស់លោក នៅក្នុងទីសមរភូមិ ។
៦ ហេតុដូច្នេះហើយ ខ្ញុំសរសេរមកលោក ចង់ឲ្យ
លោកប្រគល់ដល់ប្រជាជនខ្ញុំ នូវទីក្រុងទាំងឡាយរបស់លោក
ដែនដីទាំងឡាយ របស់លោក និងទ្រព្យសម្បត្តិរបស់លោក

១៥ *ក* អាលម៉ា ១៧:១៥; ២៣:១៨.
*ខ* ២ នីហ្វៃ ៥:២១; ៣០:៦; យ៉ាកុប ៣:៨.
១៩ *ក* អាលម៉ា ៦០:២៩.

ជាផាងទុកឲ្យពួកគេត្រូវមករកលោកដោយដាវ ហើយជាផាងទុកឲ្យការបំផ្លិចបំផ្លាញត្រូវ កើតមានដល់លោក ។

៧ ឬនិយាយម៉្យាងទៀតថា ចូរប្រគល់ខ្លួនដល់យើងមក ហើយរួបរួមជាមួយនឹងយើង ហើយស្គាល់នូវកិច្ចការសម្ងាត់[ក]ទាំងឡាយ របស់យើង ហើយក្លាយទៅជាបងប្អូនរបស់យើង ដើម្បីឲ្យពួកលោកបានដូចជាពួកយើង — គឺពុំមែនជាខ្ញុំបំរើរបស់យើងទេ តែជាបងប្អូន ដៃគូទាំងឡាយនៃទ្រព្យទាំងអស់របស់យើង ។

៨ ហើយមើលចុះ ខ្ញុំសច្ចា[ក]នឹងលោកថា បើសិនជាលោកធ្វើយ៉ាងនេះ ដោយសម្បថមួយ នោះពួកលោកនឹងមិនត្រូវបំផ្លាញចោល ឡើយ ប៉ុន្តែបើសិនជាលោកមិនធ្វើយ៉ាងនេះទេ ខ្ញុំសច្ចានឹងលោកដោយពាក្យសម្បថមួយថា នៅខែក្រោយនោះខ្ញុំនឹងបញ្ជាឲ្យពលទ័ព ខ្ញុំចុះមកតតាំងនឹងលោក ហើយពួកគេនឹងពុំសំចៃដៃ ហើយនឹងពុំលើកលែងឡើយ ប៉ុន្តែនឹងសម្លាប់ពួកលោក ហើយនឹងទុកឲ្យដាវធ្លាក់ ទៅលើលោក គឺរហូតដល់ពួកលោកត្រូវវិនាសសូន្យទៅ ។

៩ ហើយមើលចុះ ខ្ញុំគឺ គីឌឌីអានហៃ; ហើយខ្ញុំជាចៅហ្វាយនៃសង្គមសម្ងាត់[ក]នៃកាឌីអានតុន; ជាសង្គម និងកិច្ចការទាំងឡាយដែលខ្ញុំដឹងថា ជាការល្អ[ខ]; ហើយជាកិច្ចការទាំងឡាយដែលបានបង្កបង្កើតឡើងតាំង[គ]ពីបុរាណមក ហើយជាកិច្ចការទាំងឡាយដែល បានបន្តមកដល់ពួកយើង ។

១០ ហើយខ្ញុំសរសេរសំបុត្រនេះមកលោកឡាកូនីអូស ហើយខ្ញុំសង្ឃឹមថា លោកនឹងប្រគល់ដែនដីទាំងឡាយរបស់លោក និងទ្រព្យ សម្បត្តិរបស់លោក ដោយពុំមានការខ្ចាយឈាម ដើម្បីឲ្យប្រជាជនរបស់ខ្ញុំអាចយកមកវិញ នូវសិទ្ធិទាំងឡាយ និងរដ្ឋាភិបាលរបស់គេ ដែលជាអ្នកដែលបានបែកចេញពីពួកលោកមកពីសេចក្ដីទុច្ចរិតរបស់ពួកលោក នៅក្នុងការយកចេញពីពួកគេ នូវសិទ្ធិទាំងឡាយនៃ រដ្ឋាភិបាល ហើយលើកលែងតែពួកលោកធ្វើដូចនេះ បើពុំនោះសោតទេ ខ្ញុំនឹងសងសឹកចំពោះការខុសឆ្គងទាំងឡាយមកលើពួកគេ ។ ខ្ញុំគឺ គីឌឌីអានហៃ ។

១១ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើង គឺកាលឡាកូនីអូសបានទទួលសំបុត្រនេះហើយ នោះលោកមានសេចក្ដីអស្ចារ្យ ជាខ្លាំង ពីការឥតកោតញញើតរបស់គីឌឌីអានហៃ ក្នុងការទាមទារយកដែនដីរបស់ពួកសាសន៍នីហ្វៃ ហើយថែមទាំងពីការគំរាម កំហែងប្រជាជន និងពីការសងសឹកដល់ការខុសឆ្គង[ក]ទាំងឡាយ ឲ្យពួកអ្នកដែលគ្មានបានទទួលការខុសឆ្គង លើកលែងតែពួកគេបាន ធ្វើខុសដោយខ្លួនគេ ដោយបែកចេញទៅរួមជាមួយនឹងពួកចោរទុច្ចរិត និងគួរខ្ពើមឆ្អើមទាំងនោះ ។

១២ ឥឡូវនេះ មើលចុះ ឡាកូនីអូសនេះ ដែលជាចៅហ្វាយជាមនុស្សសុចរិតម្នាក់ ហើយពុំអាចធ្វើឲ្យខ្លាច ដោយសារការទាមទារ និងការគំរាមកំហែងទាំងឡាយ របស់ចោរ[ក]ម្នាក់បានឡើយ; ហេតុដូច្នេះហើយ លោកពុំបានស្ដាប់តាមសំបុត្ររបស់គីឌឌី អានហៃ ដែលជាចៅហ្វាយនៃពួកចោរនោះទេ ប៉ុន្តែលោកបានឲ្យប្រជាជនលោក អំពាវនាវដល់ព្រះអម្ចាស់ សូមឲ្យមានកម្លាំងសំរាប់តតាំង នៅពេលពួកចោរចុះមកវាយប្រហារគេ ។

១៣ មែនហើយ លោកបានផ្ញើសេចក្ដីប្រកាសមួយ ទៅក្នុងចំណោមប្រជាជនទាំងអស់ថា ពួកគេត្រូវប្រមូលប្រពន្ធរបស់គេ និង កូនចៅរបស់គេ និងហ្វូងចៀមរបស់គេ និងហ្វូងសត្វរបស់គេ និងទ្រព្យទាំងអស់របស់គេ លើកលែងតែដែនដីរបស់គេមកមួយកន្លែង ។

១៤ ហើយលោកបានបញ្ជាឲ្យសង់កំផែងការពារទាំងឡាយព័ទ្ធជុំវិញពួកគេ ដោយមានសភាពមាំមួនជាអតិបរមា ។ ហើយលោកបានបញ្ជាឲ្យពលទ័ព ទាំងពួកនីហ្វៃ និងពួកលេមិន ឬទ័ពទាំងអស់ដែលត្រូវបានរាប់ក្នុងចំណោមសាសន៍នីហ្វៃ ត្រូវទុកឲ្យចាំយាមនៅជុំវិញ ដើម្បីចាំមើលពួកគេ ហើយយាមពួកគេពីពួកចោរទាំងយប់ទាំងថ្ងៃ ។

១៥ មែនហើយ លោកបាននិយាយទៅគេថា៖ ប្រាកដដូចជាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ លើកលែងតែអ្នករាល់គ្នាប្រែចិត្ត ចំពោះអំពើទុច្ចរិតទាំងអស់របស់អ្នក ហើយអំពាវនាវដល់ព្រះអម្ចាស់ នោះអ្នករាល់គ្នានឹងគ្មានមធ្យោបាយណាផ្សេងទៀតដើម្បី ឲ្យបានដោះផុតពីកណ្ដាប់ដៃ នៃពួកចោរកាឌីអានតុនទាំងនោះបានឡើយ ។

១៦ ហើយពាក្យសំដី និងពាក្យព្យាករណ៍ទាំងឡាយរបស់ឡាកូនីអូស នោះមហិមា និងអស្ចារ្យណាស់ រហូតដល់ធ្វើឲ្យមាន ការភិតភ័យ នៅក្នុងចំណោមប្រជាជនទាំងអស់; ហើយពួកគេបានខិតខំយ៉ាងខ្លាំងនៅក្នុងសមត្ថភាពរបស់គេ ដើម្បីធ្វើតាមពាក្យ របស់ឡាកូនីអូស ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ឡាកូនីអូសបាន

៣ ៧ *ក* ហេលេ. ៦:២២–២៦.
៨ *ក* អេធើរ ៨:១៣–១៤.
៩ *ក* ស.ប. បក្សព័ន្ធសម្ងាត់.
*ខ* អាលម៉ា ៣០:៥៣.
*គ* ហេលេ. ៦:២៦–៣០;
ម៉ូសេ ៥:២៩, ៤៩–៥២.
១១ *ក* ហេលេ. ១៤:៣០.
១២ *ក* អាលម៉ា ៥៤:៥–១១;
៣ នីហ្វៃ ៤:៧–១០.

តែងតាំងពួកមេទ័ពឯកលើអស់ទាំងពលទ័ពសាសន៍នីហ្វៃ ឲ្យបញ្ជា
ពួកគេ នៅពេលណាពួកចោរចេញមកពីទីរហោស្ថាន ចុះមកវាយ
ពួកគេ ។
១៨ ឥឡូវនេះ មេធំបំផុតក្នុងចំណោមមេទ័ពឯកទាំងអស់
និងមេបញ្ជាការធំនៃអស់ទាំងពលទ័ពសាសន៍នីហ្វៃ ត្រូវបានតែង
តាំងឡើង ហើយលោកមានឈ្មោះថា គីឌគីឌដូណៃ ។
១៩ ឥឡូវនេះ នេះជាទំលាប់នៅក្នុងចំណោមអស់ទាំងពួក
សាសន៍នីហ្វៃ ដើម្បីតែងតាំងពួកមេទ័ពឯករបស់គេ (លើកលែងតែ
នៅក្នុងសម័យទុច្ចរិត) នូវអ្នកណាម្នាក់ដែលមានវិញ្ញាណ
នៃវិវរណៈ និងការព្យាករណ៍ផង; ហេតុដូច្នេះហើយ
គីឌគីឌដូណៃនេះ គឺជាព្យាការីម្នាក់ដ៏មហិមា នៅក្នុងចំណោម
ពួកគេ ដូចលោកមេចៅក្រមដែរ ។
២០ ឥឡូវនេះ ប្រជាជនបាននិយាយទៅកាន់គីឌគីឌដូណៃថា៖
សូមអធិស្ឋានទៅព្រះអម្ចាស់ ហើយចូរយើងឡើងទៅលើភ្នំ
ហើយចូលទីរហោស្ថាន ដើម្បីយើងអាចវាយទៅលើពួកចោរ
ហើយបំផ្លាញពួកវាចោល នៅលើដែនដីទាំងឡាយរបស់ពួកវា
ផ្ទាល់ ។
២១ ប៉ុន្តែ គីឌគីឌដូណៃបាននិយាយទៅកាន់ពួកគេថា៖ ព្រះ
អម្ចាស់ទ្រង់ហាមមិនឲ្យធ្វើយ៉ាងនេះទេ; ព្រោះបើសិនជាយើងឡើង
ទៅវាយពួកវា នោះព្រះអម្ចាស់ទ្រង់នឹងប្រគល់យើងទៅក្នុង
កណ្ដាប់ដៃនៃពួកវា; ហេតុដូច្នេះហើយ យើងនឹងប្រុងប្រៀបខ្លួន
នៅកណ្ដាល ដីរបស់យើង ហើយយើងនឹងប្រមូលពលទ័ពយើង
ទាំងអស់មក ហើយយើងនឹងពុំទៅវាយពួកវាឡើយ ប៉ុន្តែយើង
នឹងរង់ចាំ រហូតដល់ពួក វាមកវាយយើងវិញ; ហេតុដូច្នេះហើយ
ប្រាកដដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ បើ
សិនជាយើងធ្វើយ៉ាងនេះ នោះទ្រង់នឹង ប្រគល់ពួកវាមកក្នុង
កណ្ដាប់ដៃរបស់យើង ។
២២ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីដប់ប្រាំពីរ
គឺនៅចុងឆ្នាំ សេចក្ដីប្រកាសរបស់ឡាកូនីអូសបានផ្សព្វផ្សាយ
ទូទៅ អស់ទាំងផ្ទៃដែនដី ហើយពួកគេបានយកសេះទាំងឡាយ
របស់គេ និងរទេះទាំងឡាយរបស់គេ និងហ្វូងគោរបស់គេ និង
ហ្វូងចៀមរបស់ គេទាំងអស់ និងហ្វូងសត្វទាំងឡាយរបស់គេ
និងស្រូវ និងទ្រព្យទាំងអស់របស់គេ ហើយបានធ្វើដំណើរ
រាប់ពាន់នាក់ និងរាប់ម៉ឺននាក់ រហូតដល់ពួកគេបានទៅដល់កន្លែង
ដែលបានចាត់ទុកឲ្យពួកគេប្រមូលគ្នាមក ដើម្បីការពារខ្លួនប្រឆាំង
នឹងពួកខ្មាំងសត្រូវរបស់គេ ។
២៣ ហើយដែនដីដែលបានចាត់ទុកនោះ គឺដែនដីសារ៉ាហិមឡា
និងដីដែលនៅចន្លោះដែនដីសារ៉ាហិមឡា និងដែនដីបរិបូរណ៍
មែនហើយ ទៅទល់នឹងព្រំដែននៃដែនដីបរិបូរណ៍ និង
ដែនដីចោលស្ងាត់ ។
២៤ ហើយមានមនុស្សជាច្រើនពាន់នាក់ ដែលហៅថាសាសន៍
នីហ្វៃ បានប្រមូលគ្នាមកលើដែនដីនេរ ។ ឥឡូវនេះ ឡាកូនីអូស
បានបញ្ជាឲ្យពួកគេប្រមូលគ្នា មកនៅលើដែនដីប៉ែកខាងត្បូង
ពីព្រោះមកពីបណ្ដាសាដ៏ធំ ត្រូវបានដាក់លើដែនដីប៉ែកខាងជើង ។
២៥ ហើយពួកគេបានពង្រឹងខ្លួនដើម្បីតតាំងនឹងពួកខ្មាំងសត្រូវ
របស់គេ; ហើយពួកគេបាននៅលើដែនដីមួយ និងជាក្រុមមួយ
ហើយពួកគេបានខ្លាចពាក្យទាំងឡាយ ដែលបាននិយាយដោយ
ឡាកូនីអូស ដរាបដល់ពួកគេបានប្រែចិត្តពីអស់ទាំងអំពើបាបរបស់
ពួកគេ; ហើយពួកគេបានអធិស្ឋានទៅព្រះអម្ចាស់ ជាព្រះរបស់គេ
ដើម្បីសូមឲ្យទ្រង់ដោះលែងពួកគេ នៅពេលណាពួកខ្មាំងសត្រូវ
របស់គេ ចុះមកច្បាំងនឹងពួកគេ ។
២៦ ហើយពួកគេកើតទុក្ខជាអតិបរមា ដោយសារពួកខ្មាំង
សត្រូវរបស់គេ ។ ហើយគីឌគីឌដូណៃបានបញ្ជាឲ្យពួកគេធ្វើគ្រឿង
សស្ត្រាវុធពិជ័យសង្គ្រាមគ្រប់បែបយ៉ាង ហើយធ្វើឲ្យពួកគេមាន
កម្លាំង ដោយមានគ្រឿងការពារខ្លួន និងខែល និងខែលដៃ តាម
ការ បង្គាប់របស់លោក ៕

## ជំពូកទី ៤

*ពលទ័ពសាសន៍នីហ្វៃវាយពួកចោរកាឌីអានតុនឲ្យបរាជ័យ — គីឌឌីអានហៃត្រូវស្លាប់ ហើយអ្នកដែលបន្តតំណែងពីវាឈ្មោះសេមណារ៉ៃហា ត្រូវគេចងក — ពួកសាសន៍នីហ្វៃសរសើរដំកើងដល់ព្រះអម្ចាស់ ចំពោះជ័យជំនះទាំងឡាយរបស់គេ ។ ប្រមាណជាឆ្នាំ ១៨–២២ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅចុងឆ្នាំទីដប់ប្រាំបី ពល
ទ័ពពួកចោរទាំងនោះ បានរៀបចំទៅច្បាំង ហើយបាន
ចាប់ផ្ដើមចុះមក និងរាលចេញពីភ្នំតូច ភ្នំធំ និងទីរហោស្ថាន និង
ទីតាំងការពារទាំងឡាយរបស់គេ និងទីសម្ងាត់ទាំងឡាយ

១៨ *ក* ៣ នីហ្វៃ ៦:៦.
១៩ *ក* ស.ប. ការព្យាករណ៍, ព្យាករ.
២១ *ក* អាលម៉ា ៤៨:១៤.
*ខ* ១ សាំយូ. ១៤:១២.
២៤ *ក* អាលម៉ា ២២:៣១.
២៥ *ក* ស.ប. ទុកចិត្ត.
២៦ *ក* ២ នីហ្វៃ ៥:១៤.

របស់គេ ហើយបានចាប់ ផ្ដើមវាយយកដែនដី ទាំងនៅក្នុងតំបន់ខាងត្បូង និងនៅក្នុងតំបន់ខាងជើងផង ហើយបានចាប់ផ្ដើមយក[ក] ដែនដីទាំងអស់ ដែលពួក សាសន៍នីហ្វៃបានបោះបង់ចោល និងទីក្រុងទាំងឡាយ ដែលបានបោះបង់ចោលឲ្យស្ងាត់ជ្រងំ ។

២ ប៉ុន្តែមើលចុះ គ្មានសត្វព្រៃ ឬសត្វសំរាប់បរបាញ់សោះ នៅលើដីទាំងនោះ ដែលបានបោះបង់ចោល ដោយពួកសាសន៍នីហ្វៃ; ហើយគ្មានសត្វសំរាប់បរបាញ់ដើម្បីពួកចោរឡើយ លើកលែងតែនៅក្នុងទីរហោស្ថានប៉ុណ្ណោះ ។

៣ ហើយពួកចោរមិនអាចរស់នៅទីណា ក្រៅពីទីរហោស្ថានបានឡើយ ព្រោះត្រូវការចំណីអាហារ; ត្បិតពួកសាសន៍នីហ្វៃបាន ចោលដីរបស់គេឲ្យស្ងាត់ជ្រងំ ហើយបានប្រមូលហ្វូងចៀមរបស់គេ និងហ្វូងសត្វរបស់គេ និងទ្រព្យទាំងអស់របស់គេ ហើយពួក គេនៅតែមួយក្រុម ។

៤ ហេតុដូច្នេះហើយ គ្មានឱកាសណាសំរាប់ឲ្យពួកចោរមកប្លន់ និងយកចំណីអាហារបានសោះ លើកលែងតែឡើងមកច្បាំង ចេញមុខប្រឆាំងនឹងពួកសាសន៍នីហ្វៃប៉ុណ្ណោះ; ហើយពួកសាសន៍នីហ្វៃ ដោយនៅតែមួយក្រុម ហើយមានចំនួនច្រើនជាខ្លាំង ហើយ បានសន្សំទុកនូវស្បៀងអាហារសំរាប់ខ្លួនគេ និងសេះ និងសត្វគោ ក្របី និងហ្វូងសត្វគ្រប់មុខ ដើម្បីឲ្យពួកគេអាចរស់នៅក្នុងរយៈពេល ប្រាំពីរឆ្នាំ នៅក្នុងរយៈពេលនោះ ពួកគេសង្ឃឹមថា នឹងបំផ្លាញពួកចោរ ចេញពីលើផ្ទៃដីឲ្យបាន; ម្ល៉ោះហើយ ឆ្នាំទីដប់ប្រាំបីក៏បានកន្លង ផុតទៅ ។

៥ ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំទីដប់ប្រាំបួន គីឌឌីអានហៃ យល់ឃើញថា ជាការចាំបាច់វាត្រូវឡើងទៅច្បាំងនឹង សាសន៍នីហ្វៃ ព្រោះគ្មានមធ្យោបាយណា ដែលឲ្យពួកវាអាចរស់នៅ ក្រៅពីទៅប្លន់ និងដណ្ដើម និងធ្វើឃាតមនុស្សចោលនោះទេ ។

៦ ហើយពួកវាពុំហ៊ានរាយគ្នាឲ្យធំនៅលើផ្ទៃដែនដី ដើម្បីវាអាចដាំស្រូវឡើយ ខ្លាចក្រែងពួកសាសន៍នីហ្វៃ មកវាយពួកវា ហើយ សម្លាប់ពួកវាចោល; ហេតុដូច្នេះហើយ គីឌឌីអានហៃបានឲ្យបញ្ជាទៅពលទ័ពវាថា ក្នុងឆ្នាំនេះ ពួកវាត្រូវឡើងទៅច្បាំងនឹងពួកសាសន៍ នីហ្វៃ ។

៧ ហើយហេតុការណ៍បានកើតឡើងថា ពួកវាក៏បានឡើងមកច្បាំង; ហើយគឺនៅខែទីប្រាំមួយ; ហើយមើលចុះ ថ្ងៃដែលពួកគេបាន ឡើងមកច្បាំងនោះ ធំ និងគួរឲ្យខ្លាចមែន; ហើយពួកវាបានស្លៀកពាក់តាមរបៀបពួកចោរ; ហើយពួកវាមានស្បែកចៀមរុំជុំវិញចង្កេះ ហើយពួកវាលាបឈាម ហើយកោរក្បាល ហើយពួកវាមានមួកដែកពាក់ពីលើ; ហើយរូបរាងនៃពលទ័ពរបស់គីឌឌីអានហៃ ធំ និងគួរឲ្យ ខ្លាចមែន គឺមកពីគ្រឿងការពារខ្លួនរបស់ពួកវា និងមកពីខ្លួនវាលាបឈាម ។

៨ ហើយហេតុការណ៍បានកើតឡើងថា រីឯពលទ័ពសាសន៍នីហ្វៃ កាលពួកគេបានឃើញរូបរាងនៃកងទ័ពរបស់គីឌឌីអានហៃ ក៏ដួលទៅលើដីគ្រប់គ្នា ហើយបានបន្លឺសម្លេងឡើងទៅព្រះអម្ចាស់ ជាព្រះរបស់គេ សូមឲ្យទ្រង់អនុគ្រោះពួកគេ ហើយដោះលែងពួកគេឲ្យ រួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់គេ ។

៩ ហើយហេតុការណ៍បានកើតឡើងថា កាលពលទ័ពរបស់គីឌឌីអានហៃ បានឃើញយ៉ាងនេះហើយ នោះពួកវាបានចាប់ផ្ដើម ស្រែកដោយសម្លេងដ៏ខ្លាំង ពីព្រោះមកពីសេចក្ដីអំណររបស់គេ ត្បិតពួកវាបានគិតស្មានថា ពួកសាសន៍នីហ្វៃបានដួលចុះ ដោយការ ភិតភ័យ ដោយមកពីភាពគួរស្ញែងខ្លាចនៃពលទ័ពរបស់ពួកវា ។

១០ ប៉ុន្តែក្នុងការណ៍នេះ ពួកវាត្រូវ[ក]ខកចិត្ត ព្រោះពួកនីហ្វៃពុំខ្លាចពួកវាទេ; ប៉ុន្តែគេកោតខ្លាចព្រះរបស់គេវិញ ហើយបានសូមកិច្ចការពារពីទ្រង់; ហេតុដូច្នេះហើយ កាលពលទ័ពគីឌឌីអានហៃបានវាយសម្រុកមកលើគេ នោះពួកគេបានប្រុងខ្លួនតទល់នឹងពួកវា; មែនហើយ គឺនៅក្នុងកម្លាំងនៃព្រះអម្ចាស់ ពួកគេបានទទួលពួកវា ។

១១ ហើយការប្រយុទ្ធបានចាប់ផ្ដើមឡើង នៅក្នុងខែទីប្រាំមួយ; ហើយការប្រយុទ្ធនេះធំ និងគួរឲ្យខ្លាចមែន មែនហើយ ការកាប់ សម្លាប់នោះធំ និងគួរឲ្យខ្លាចមែន ដរាបដល់មិនដែលមានការកាប់សម្លាប់ឯណាធំជាងនេះទេ នៅក្នុងចំណោមប្រជាជនរបស់លីហៃ ទាំងអស់ ចាប់តាំងពីលោកបានចាកចេញពីក្រុងយេរូសាឡិមមក ។

១២ ហើយទោះជា[ក]ការគំរាមកំហែងទាំងឡាយ និងការស្បថស្បែទាំងឡាយ ដែលគីឌឌីអានហៃបានធ្វើក្ដី មើលចុះ ពួកនីហ្វៃបាន ឈ្នះលើពួកវា ដរាបដល់ធ្វើឲ្យពួកវាថយក្រោយទៅវិញ។

១៣ ហើយហេតុការណ៍បានកើតឡើងថា [ក]គីឌគីឌូណៃបានបញ្ជាពលទ័ពលោក ឲ្យដេញតាមពួកវាទៅដល់ព្រំប្រទល់ទីរហោស្ថាន ហើយមិនឲ្យលើកលែងជនណាមួយ ដែលធ្លាក់មកក្នុងកណ្ដាប់ដៃគេ នៅតាមផ្លូវឡើយ; ម្ល៉ោះហើយ ពួកគេបានដេញតាមពួកវា ហើយបានសម្លាប់ពួកវា ទៅទល់នឹងព្រំប្រទល់ទីរហោស្ថាន

៤ ១ក ៣ នីហ្វៃ ៣:១៣–១៤, ២២.
១០ ក ស.ប. សេចក្ដីកោតខ្លាច.
១២ ក ៣ នីហ្វៃ ៣:១–១០.
១៣ ក ៣ នីហ្វៃ ៣:១៨.

គឺរហូតដល់ពួកគេបានបំពេញនូវបញ្ជារបស់គីឌគីឌូណៃ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា គីឌខីអានហៃ ដែល
បានឈរ ហើយប្រយុទ្ធយ៉ាងក្លាហាន ត្រូវដេញតាមនៅពេលវារត់;
ហើយដោយនឿយហត់មកពីការប្រយុទ្ធដ៏ខ្លាំងរបស់វា នោះវា
ត្រូវតាមទាន់ ហើយត្រូវបានសម្លាប់ចោល ។ ម្ល៉ោះហើយ ក៏ចប់
នូវចោរ គីឌខីអានហៃទៅ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពសាសន៍
នីហ្វៃបានត្រឡប់មកទីកន្លែងដ៏សន្តិសុខរបស់គេវិញ ។ ហើយហេតុ
ការណ៍បានកើតឡើងថា ឆ្នាំទីដប់ប្រាំបួននេះបានកន្លងផុតទៅ
ហើយពួកចោរពុំបានមកច្បាំងទៀតទេ; ហើយពួកវាក៏មិនមកនៅ
ក្នុង ឆ្នាំទីម្ភៃទៀតដែរ ។
១៦ ហើយនៅក្នុងឆ្នាំទីម្ភៃមួយ នោះពួកវាពុំបានឡើងមកច្បាំងទេ
តែពួកវាមកគ្រប់ទិសទី ដើម្បីឡោមព័ទ្ធជុំវិញប្រជាជននីហ្វៃ;
ព្រោះពួកវាបានគិតស្មានថា បើសិនជាពួកវាកាត់ផ្ដាច់ប្រជាជន
នីហ្វៃ ពីដែនដីទាំងឡាយរបស់គេបាន ហើយព័ទ្ធពួកគេពីគ្រប់ទិស
ហើយបើសិនជាពួកវាកាត់ផ្ដាច់ពួកគេ ពីឯកសិទ្ធិទាំងអស់ នៅ
ខាងក្រៅបាន នោះពួកវាអាចធ្វើឲ្យគេចុះចាញ់ ស្របតាមបំណង
ទាំង ឡាយរបស់ពួកវាបាន ។
១៧ ឥឡូវនេះ ពួកវាបានតែងតាំងសំរាប់ពួកវា នូវមេដឹកនាំ
ម្នាក់ទៀត មានឈ្មោះថា សេមណារីហា; ហេតុដូច្នេះហើយ
គឺសេមណារីហានេះហើយដែលបានបញ្ជាឲ្យមានការព័ទ្ធនេះ ។
១៨ ប៉ុន្តែមើលចុះ នេះគឺជាប្រៀបមួយដល់ពួកសាសន៍នីហ្វៃ
ព្រោះពួកចោរគ្មានលទ្ធភាពណា នឹងធ្វើការហ៊ុំព័ទ្ធឲ្យបានយូរគ្រប់
គ្រាន់ ដើម្បីឲ្យមានផលវិបាក ដល់ពួកសាសន៍នីហ្វៃបានសោះ
មកពីស្បៀងអាហារដ៏ច្រើនរបស់គេ ដែលពួកគេបានប្រមូលទុក,
១៩ ហើយមកពីការខ្វះខាតស្បៀងអាហារ នៅក្នុងចំណោម
ពួកចោរ; ត្បិតមើលចុះ ពួកវាគ្មានអ្វី ក្រៅពីសាច់សំរាប់បរិភោគ
គឺជាសាច់ដែលពួកវារកបាន នៅក្នុងទីរហោស្ថានប៉ុណ្ណោះ ។
២០ ហើយហេតុការណ៍បានកើតឡើងថា [ក]សត្វព្រៃ
សំរាប់បរបាញ់កាន់តែហោចទៅ នៅក្នុងទីរហោស្ថាន ដរាប
ដល់ពួកចោរជិត វិនាសបង់ ដោយតែការអត់ឃ្លាន ។
២១ ហើយពួកសាសន៍នីហ្វៃ ក៏នៅតែលើកទ័ពចេញទៅក្រៅ
ទាំងយប់ទាំងថ្ងៃ ហើយវាយទៅលើពលទ័ពពួកវា ហើយកំចាត់
ពួកវាទាំងពាន់ និងទាំងម៉ឺននាក់ចោល ។
២២ ម្ល៉ោះហើយ ប្រជាជនរបស់សេមណារីហា ក្លាយទៅជា
មានបំណងចង់ដកចេញពីផែនការរបស់ពួកវា ដោយមកពីការ
បំផ្លិច បំផ្លាញដ៏ធំ ដែលបានធ្លាក់មកលើពួកវាទាំងយប់ទាំងថ្ងៃ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា សេមណារីហា
បានបញ្ជាទៅទ័ពរបស់វាថា ពួកវាត្រូវដកខ្លួនចេញពីការហ៊ុំព័ទ្ធនេះ
ហើយធ្វើដំណើរទៅផ្នែកដែនដី ដែលនៅខាងជើងបំផុតវិញ ។
២៤ ហើយឥឡូវនេះ គីឌគីឌូណៃ ដោយបានដឹងនូវផែនការ
របស់ពួកវា ហើយដោយដឹងអំពីចំណុចខ្សោយរបស់ពួកវា ដោយ
ព្រោះចង់បានស្បៀងអាហារ និងអំពីការកាប់សម្លាប់ដ៏ធំ ដែល
បានកើតឡើងនៅក្នុងចំណោមពួកវា ហេតុដូច្នេះហើយ លោកបាន
បញ្ជា ឲ្យពលទ័ពលោក ចេញទៅក្នុងពេលយប់ ហើយបានកាត់
ផ្ដាច់ផ្លូវដកថយរបស់ពួកវាចេញ ហើយបានដាក់ពលទ័ពរបស់លោក
តាមផ្លូវ ដកថយរបស់ពួកវាវិញ ។
២៥ ហើយការណ៍នេះ ពួកគេបានធ្វើនៅក្នុងពេលយប់ ហើយ
បានធ្វើដំណើរទៅហួសពួកចោរ ដើម្បីដល់ថ្ងៃស្អែកឡើង នៅពេល
ពួកចោរចាប់ផ្ដើមធ្វើដំណើរ នោះពួកវានឹងត្រូវជួបប្រទះនឹងពល
ទ័ពសាសន៍នីហ្វៃ ទាំងនៅខាងមុខពួកវា និងនៅខាងក្រោយពួកវា ។
២៦ ហើយពួកចោរដែលនៅខាងត្បូង ក៏ត្រូវកាត់ផ្ដាច់ពីទីកន្លែង
ដកថយទាំងឡាយដែរ ។ ហើយការណ៍ទាំងអស់នេះ ត្រូវបាន
ធ្វើឡើង តាមបញ្ជារបស់គីឌគីឌូណៃ ។
២៧ ហើយពួកវាជាច្រើនពាន់នាក់ បានប្រគល់ខ្លួនជាឈ្លើយដល់
ពួកនីហ្វៃ ហើយពួកវាដែលនៅសល់ទាំងប៉ុន្មាន ត្រូវបានសម្លាប់
ចោលបង់ ។
២៨ ហើយសេមណារីហា ជាមេដឹកនាំរបស់វាត្រូវចាប់បាន
ហើយត្រូវចងកលើដើមឈើមួយ មែនហើយ គឺនៅលើចុងឈើ
រហូតដល់វាស្លាប់ទៅ ។ ហើយកាលពួកគេបានចងកវា រហូត
ដល់ស្លាប់ហើយ នោះពួកគេបានរំលំឈើនោះមកដី ហើយបាន
ស្រែក យ៉ាងខ្លាំងថា៖
២៩ សូមឲ្យព្រះអម្ចាស់រក្សាប្រជាជនទ្រង់ នៅក្នុងសេចក្ដីសុចរិត
និងនៅក្នុងបរិសុទ្ធភាពនៃដួងចិត្ត ប្រយោជន៍ឲ្យពួកគេអាចធ្វើឲ្យ
រលំមកលើដី នូវជនទាំងអស់ណា ដែលរកសម្លាប់ពួកគេ ដោយ
មកពីអំណាច និងបក្សព័ន្ធសម្ងាត់ទាំងឡាយ ដូចជាបុរសនេះត្រូវ
រលំមកលើដីដែរ ។
៣០ ហើយពួកគេបានអររីករាយ ហើយ[ក]ស្រែកឡើងជាសម្លេងតែ
មួយទៀតថា៖ សូមឲ្យព្រះនៃអ័ប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះ
នៃយ៉ាកុប ការពារប្រជាជននេះ នៅក្នុងសេចក្ដីសុចរិត ដរាបណា

២០ ក ១ នីហ្វៃ ១៨:២៥.
៣០ ក អាលម៉ា ២៩:១១.

ពួកគេ អំពាវនាវដល់ព្រះនាម នៃព្រះរបស់គេ សូមនូវសេចក្ដី
ការពារ ។
៣១ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ស្រែកច្រៀងព្រមគ្នាឡើង ហើយសរសើរដំកើងដល់ព្រះ
របស់គេ ចំពោះ ការណ៍ដ៏មហិមា ដែលទ្រង់បានធ្វើដើម្បីពួកគេ
នៅក្នុងការរក្សាពួកគេទុក កុំឲ្យធ្លាក់ទៅក្នុងកណ្ដាប់ដៃ នៃពួក
ខ្មាំងសត្រូវរបស់គេ ។
៣២ មែនហើយ ពួកគេបានស្រែកថា៖ ហូសាណាដល់
ព្រះដ៏ខ្ពស់បំផុត ។ ហើយពួកគេបានស្រែកថា៖ សូមឲ្យព្រះនាម
នៃ ព្រះអម្ចាស់ ជាព្រះដ៏មានមហិទ្ធិឫទ្ធិ គឺជាព្រះដ៏ខ្ពស់បំផុត បាន
ប្រកបដោយព្រះពរ ។
៣៣ ហើយចិត្តគេបានរីកឡើង ដោយសេចក្ដីអំណរ រហូត
ដល់ហូរទឹកភ្នែកចេញជាច្រើន មកពីសេចក្ដីល្អសប្បុរសដ៏ធំនៃ
ព្រះ នៅក្នុងការដោះលែងពួកគេឲ្យរួចផុតពីកណ្ដាប់ដៃនៃពួក
ខ្មាំងសត្រូវរបស់គេ; ហើយពួកគេបានដឹងថា គឺមកពីប្រែចិត្ត និង
ភាពទន់ទាប ទើបពួកគេត្រូវបានដោះលែងឲ្យរួចផុតពីការ
បំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច ៕

## ជំពូកទី ៥

*ពួកសាសន៍នីហ្វៃប្រែចិត្ត ហើយលះបង់អំពើបាបទាំងឡាយ របស់គេចោល — មរមនសរសេរប្រវត្តិអំពីប្រជាជនលោក ហើយប្រកាស ប្រាប់ព្រះបន្ទូលដ៏អស់កល្បជានិច្ចដល់ពួកគេ — ពួកអ៊ីស្រាអែលនឹងត្រូវបានប្រមូលមកពីការខ្ចាត់ព្រាត់ ដ៏យូរលង់ របស់គេវិញ ។ ប្រមាណជាឆ្នាំ ២២–២៦ គ.ស. ។*

ហើយឥឡូវនេះ មើលចុះ គ្មានជនណាម្នាក់សោះ ដែលរស់នៅ
ក្នុងចំណោមប្រជាជននៃសាសន៍នីហ្វៃទាំងអស់ ដែលបានសង្ស័យ
សូម្បីតែបន្ដិចបន្ដួច ដល់ពាក្យទាំងឡាយ របស់ព្យាការីបរិសុទ្ធ
ទាំងអស់ ដែលបានថ្លែងមក; ព្រោះពួកគេបានដឹងថា ជាការចាំ
បាច់ថា ត្រូវតែបានបំពេញ ។
២ ហើយពួកគេបានដឹងថា ជាការចាំបាច់ ព្រះគ្រីស្ទទ្រង់បាន
យាងមក ដោយមកពីទីសំគាល់ជាច្រើន ដែលត្រូវបានប្រទានមក
តាមពាក្យទាំងឡាយរបស់ពួកព្យាការី; ហើយដោយមកពីការណ៍
ទាំងឡាយ ដែលបានកើតឡើងរួចហើយ នោះពួកគេបានដឹងថា
ជាការចាំបាច់ថា គ្រប់ការណ៍ទាំងអស់ត្រូវកើតឡើង ស្របតាម
អ្វីៗដែលបាននិយាយទុក ។
៣ ហេតុដូច្នេះហើយ ពួកគេបានលះបង់អស់ទាំងអំពើបាប
របស់គេ និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ និងអំពើសហាយ
ស្មន់ទាំងឡាយរបស់គេ ហើយបានបំរើព្រះ ដោយអស់ពីការ
ព្យាយាម ទាំងយប់ទាំងថ្ងៃ ។
៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលពួក
គេចាប់បានពួកចោរទាំងអស់ យកមកជាឈ្លើយ ដរាបដល់គ្មាន
នរណាម្នាក់រត់រួច ដោយមិនត្រូវសម្លាប់ចោលឡើយ នោះពួក
គេបានដាក់ពួកឈ្លើយរបស់គេទៅក្នុងគុក ហើយបានបណ្ដាលឲ្យ
មាន ព្រះបន្ទូលនៃព្រះផ្សាយដល់ពួកគេ; ហើយអស់អ្នកណា
ដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេ ហើយធ្វើសេចក្ដី
សញ្ញាថា ពួកគេនឹង ឈប់ធ្វើឃាតមនុស្សទៀត នោះគេត្រូវបាន
ដោះលែងឲ្យមានឥស្សរភាព ។
៥ ប៉ុន្តែ អស់អ្នកណាដែលមិនចូលក្នុងសេចក្ដីសញ្ញា
ហើយនៅតែបន្តការឃាតកម្មមនុស្ស ដោយសម្ងាត់នៅក្នុងចិត្ត
មែនហើយ អស់អ្នកណាដែលឃើញថា បញ្ចេញនូវការ
គំរាមកំហែងទាំងឡាយ ប្រឆាំងនឹងបងប្អូនរបស់គេ នោះបានត្រូវ
កាត់ទោស ហើយ ត្រូវធ្វើទោសតាមច្បាប់ ។
៦ ម្ល៉ោះហើយ ពួកគេបានបញ្ចប់នូវការផ្សំគំនិតទាំងនោះ
ដែលទុច្ចរិត និងសម្ងាត់ និងគួរខ្ពើមឆ្អើម នៅក្នុងនោះមាន
ការទុច្ចរិត ដ៏ច្រើន និងអំពើឃាតកម្មដ៏ច្រើន ដែលបាន
ប្រព្រឹត្តមក ។
៧ ម្ល៉ោះហើយ ឆ្នាំទីម្ភៃពីរបានកន្លងផុតទៅ និងឆ្នាំទីម្ភៃបីផង
និងទីម្ភៃបួន និងទីម្ភៃប្រាំ; ម្ល៉ោះហើយ ម្ភៃប្រាំឆ្នាំបាន
កន្លងផុតទៅ ។
៨ ហើយការណ៍ជាច្រើនបានកើតឡើង នៅចំពោះភ្នែកអ្នកខ្លះ
គឺជាការដ៏ធំ និងអស្ចារ្យ; ទោះជាយ៉ាងណាក៏ដោយ គង់តែ
ការណ៍ទាំងនោះ មិនអាចយកមកសរសេរឲ្យអស់ នៅក្នុងគម្ពីរ
នេះបានទេ; មែនហើយ គម្ពីរនេះមិនអាចដាក់បានសោះ សូម្បីតែ
មួយភាគរយនូវអ្វីៗដែលបានធ្វើឡើង នៅក្នុងចំណោមប្រជាជន
ជាច្រើន នៅក្នុងរយៈពេលម្ភៃប្រាំឆ្នាំ ។

៣០ *ខ* អេធើរ ៤:១៥.
៣១ *ក* អាលម៉ា ២៦:៨.
ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
៣២ *ក* ស.ប. ហូសាណា.
*ខ* ១ នីហ្វៃ ១:១៤.
ស.ប. ព្រះ, ក្រុមព្រះ.
**៥** ៤ *ក* ស.ប. ឥស្សរភាព.
៧ *ក* ៣ នីហ្វៃ ២:៨.
៨ *ក* ៣ នីហ្វៃ ២៦:៦–១២.

៩ ប៉ុន្តែមើលចុះ មាន[ក]បញ្ជីទាំងឡាយដែលមានកត់ អំពីដំណើរ
ការទាំងអស់របស់ប្រជាជននេះ; ហើយដំណើររឿងមួយខ្លីជាងនេះ
តែពិត នោះបានកត់ដោយនីហ្វៃ ។
១០ ហេតុដូច្នេះហើយ ខ្ញុំបានធ្វើបញ្ជីរបស់ខ្ញុំ អំពីការណ៍ទាំងនេះ
ស្របតាមបញ្ជីរបស់នីហ្វៃ ដែលបានឆ្លាក់នៅលើផ្ទាំងទាំងឡាយ
ដែលហៅថា ផ្ទាំងនីហ្វៃ ។
១១ ហើយមើលចុះ ខ្ញុំធ្វើបញ្ជីលើផ្ទាំងទាំងឡាយ ដែលខ្ញុំបាន
ធ្វើដោយដៃខ្ញុំផ្ទាល់ ។
១២ ហើយមើលចុះ ខ្ញុំឈ្មោះ [ក]មរមន ដោយបានហៅតាម
[ខ]ដែនដីមរមន គឺជាដែនដីដែលអាលម៉ា បានតាំងសាសនាចក្រឡើង
នៅក្នុងចំណោមប្រជាជន មែនហើយ គឺជាសាសនាចក្រទីមួយ
ដែលបានតាំងឡើង នៅក្នុងចំណោមពួកគេ ក្រោយពីអំពើរំលង
របស់គេ ។
១៣ មើលចុះ ខ្ញុំជាសិស្សម្នាក់នៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជ
បុត្រានៃព្រះ ។ ខ្ញុំត្រូវបានហៅដោយទ្រង់ ឲ្យប្រកាសព្រះបន្ទូល
របស់ទ្រង់ នៅក្នុងចំណោមប្រជាជនទ្រង់ ដើម្បីឲ្យពួកគេអាច
បានជីវិតដ៏អស់កល្បជានិច្ច ។
១៤ ហើយជាការចាំបាច់ ស្របតាមព្រះហឫទ័យនៃព្រះ ថា
ពាក្យអធិស្ឋានទាំងឡាយរបស់ពួកជន ដែលបានចាកលោកទៅហើយ
នោះ គឺជាពួកជនបរិសុទ្ធ ត្រូវតែបានសំរេចតាមសេចក្ដីជំនឿ
របស់គេ ថាខ្ញុំត្រូវកត់[ក]បញ្ជីមួយអំពីការណ៍ទាំងនេះ ដែល
បានកើតឡើងមក ហើយ —
១៥ មែនហើយ ជាបញ្ជីមួយតូចអំពីអ្វីៗដែលបានកើតឡើង
ចាប់តាំងពីពេលដែលលីហៃ បានចាកចេញពីក្រុងយេរូសាឡិម
រហូតមកដល់សព្វថ្ងៃនេះ ។
១៦ ហេតុដូច្នេះហើយ ខ្ញុំធ្វើបញ្ជីរបស់ខ្ញុំចេញពីដំណើររឿង
ទាំងឡាយ ដែលបានកត់ដោយពួកអ្នកដែលបានរស់នៅមុនខ្ញុំ
រហូតដល់ការចាប់ផ្ដើមនៃជីវិតរបស់ខ្ញុំ;
១៧ ហើយបន្ទាប់មក ខ្ញុំធ្វើ[ក]បញ្ជីមួយអំពីការណ៍ទាំងឡាយ
ដែលខ្ញុំបានឃើញដោយភ្នែកខ្ញុំផ្ទាល់ ។
១៨ ហើយខ្ញុំដឹងថា បញ្ជីដែលខ្ញុំធ្វើនេះ គឺជាបញ្ជីមួយដ៏ត្រឹមត្រូវ
ហើយពិត; ទោះជាយ៉ាងណាក៏ដោយ គង់តែមានការណ៍ជា
ច្រើន ទៀត ត្បិតតាមភាសារបស់យើង នោះយើងពុំអាច
[ក]សរសេរបានឡើយ ។
១៩ ហើយឥឡូវនេះ ខ្ញុំសូមបញ្ចប់នូវការនិយាយរបស់ខ្ញុំ
គឺអំពីខ្លួនខ្ញុំនោះ ហើយចាប់ផ្ដើមប្រាប់ពីដំណើររឿងខ្ញុំ ចំពោះការណ៍
ទាំង ឡាយ ដែលកើតឡើងមុនខ្ញុំ ។
២០ ខ្ញុំជាមរមន ហើយជាពូជពង្សនៃលីហៃសុទ្ធ ។ ខ្ញុំមាន
ហេតុដើម្បីសរសើរដល់ព្រះរបស់ខ្ញុំ និងព្រះអង្គសង្គ្រោះរបស់ខ្ញុំ
គឺព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បាននាំពួកអយ្យកោរបស់យើង
ចេញពីដែនដីយេរូសាឡិមមក (ហើយ[ក]គ្មាននរណាម្នាក់ដឹងការណ៍
នេះ ឡើយ ក្រៅពីព្រះអង្គទ្រង់ផ្ទាល់ និងពួកជនដែលទ្រង់បាន
នាំចេញពីដែនដីនោះប៉ុណ្ណោះ) ហើយដែលទ្រង់បានប្រទានដល់ខ្ញុំ
និងប្រជាជនខ្ញុំនូវការចេះដឹងដ៏ច្រើន អំពីសេចក្ដីសង្គ្រោះដល់
ព្រលឹងរបស់យើងទាំងឡាយ ។
២១ ជាប្រាកដមែន ទ្រង់បានប្រទានពរឲ្យ[ក]វង្ស[ខ]យ៉ាកុប ហើយ
[គ]ធ្លាប់មានសេចក្ដីមេត្តាដល់ពូជរបស់យ៉ូសែប ។
២២ ហើយដរាបណា[ក]កូនចៅរបស់លីហៃ កាន់តាមព្រះ
បញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះទ្រង់បានប្រទានពរដល់គេ
ហើយចំរុង ចំរើនពួកគេ ស្របតាមព្រះបន្ទូលរបស់ទ្រង់ ។
២៣ មែនហើយ ហើយជាប្រាកដមែន ទ្រង់នឹងនាំ[ក]សំណល់នៃពូជ
របស់យ៉ូសែប [ខ]ឲ្យស្គាល់ព្រះអម្ចាស់ ជាព្រះរបស់គេទៀត ។
២៤ ហើយប្រាកដដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ
នោះទ្រង់នឹង[ក]ប្រមូលមកពីទិសទាំងបួននៃផែនដី នូវសំណល់ទាំង
អស់នៃវង្សយ៉ាកុប ដែលត្រូវខ្ចាត់ព្រាត់ទៅក្រៅស្រុក នៅ
ពាសពេញលើផ្ទៃផែនដី ។
២៥ ហើយដូចជាទ្រង់បានធ្វើសេចក្ដីសញ្ញា ជាមួយនឹងវ
ង្សយ៉ាកុបទាំងអស់យ៉ាងណា នោះសេចក្ដីសញ្ញា ដែលទ្រង់បាន
ធ្វើជាមួយ នឹងវង្សយ៉ាកុប [ក]នឹងត្រូវបានបំពេញ តាមពេលដែល
ទ្រង់បានកំណត់ផ្ទាល់ នាំឲ្យសាងឡើងវិញ នូវវង្សរបស់យ៉ាកុប
ទាំងអស់ឲ្យស្គាល់ នូវសេចក្ដីសញ្ញា ដែលទ្រង់បានធ្វើជាមួយនឹង
ពួកគេ ។

៩ ក ហេលេ. ៣:១៣–១៥.
១២ ក មរមន ១:១–៥.
ខ ម៉ូសាយ ១៨:៤; អាលម៉ា ៥:៣.
១៤ ក អេណុស ១:១៣–១៨;
គ. និង ស. ៣:១៩–២០.
១៧ ក មរមន ១:១.
១៨ ក អេធើរ ១២:២៥.
២០ ក ១ នីហ្វៃ ៤:៣៦.
២១ ក ស.ប. អ៊ីស្រាអែល.
ខ លោកុ. ៣២:២៨.
គ ចោទិ. ៣៣:១៣–១៧.
២២ ក ២ នីហ្វៃ ១:២០.
២៣ ក អាលម៉ា ៤៦:២៤.
ខ ២ នីហ្វៃ ៣:១២.
២៤ ក ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
២៥ ក ៣ នីហ្វៃ ១៦:៥.

២៦ ហើយនៅពេលនោះ ពួកគេនឹង[ក]ស្គាល់ព្រះដ៏ប្រោសលោះ
របស់គេ គឺព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ;
ហើយនៅ ពេលនោះ ពួកគេនឹងត្រូវបានប្រមូលមកពីទិសទាំងបួន
នៃផែនដី មកលើដីរបស់គេផ្ទាល់ គឺជាកន្លែងដែលពួកគេត្រូវខ្ចា
ត់ព្រាត់ចេញ ទៅនោះ; មែនហើយ ប្រាកដដូចជាព្រះអម្ចាស់
ទ្រង់មានព្រះជន្មរស់នៅ នោះការណ៍នេះនឹងកើតឡើងយ៉ាង
ដូច្នោះមែន ។ អាម៉ែន ៕

## ជំពូកទី ៦

*ពួកសាសន៍នីហ្វៃចំរើនឡើង — ការឆ្មើងឆ្មៃ ទ្រព្យ និងការ
បែកវណ្ណៈកើតឡើង — សាសនាចក្រត្រូវបាក់បែកដោយការ
បែកចេញ — អារក្សសោតាំងដឹកនាំប្រជាជន ទៅក្នុងការ
បះបោរចេញមុខ — ពួកព្យាការីជាច្រើន ស្រែកហៅឲ្យធ្វើ
ការប្រែចិត្ត ហើយត្រូវសម្លាប់ ចោល — ឃាតកទាំងឡាយ
របស់គេ ធ្វើឧបាយកល ដើម្បីដណ្ដើមយករដ្ឋាភិបាល ។
ប្រមាណជាឆ្នាំ ២៦–៣០ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ប្រជាជន
នៃសាសន៍នីហ្វៃទាំងអស់គ្នា បានត្រឡប់ទៅកាន់ដីផ្ទាល់
របស់គេវិញ នៅក្នុង ឆ្នាំទីម្ភៃប្រាំមួយ មនុស្សរាល់រូបជាមួយនឹង
គ្រួសារគេ ហ្វូងចៀម និងហ្វូងសត្វទាំងឡាយរបស់គេ សេះ
និងគោក្របីរបស់គេ និង វត្ថុគ្រប់យ៉ាងឲ្យតែជារបស់គេ ។
២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេពុំទាន់បរិភោគ
អស់ នូវស្បៀងរបស់គេនៅឡើយទេ; ហេតុដូច្នេះហើយ ទើបពួក
គេ បានយកមកជាមួយពួកគេ នូវអស់ទាំងអ្វីៗ ដែលគេពុំទាន់បាន
បរិភោគ គឺមានស្រូវគ្រប់មុខរបស់គេ និងមាសរបស់គេ និង
ប្រាក់របស់គេ និងវត្ថុដ៏មានតម្លៃទាំងអស់របស់គេ ហើយពួកគេ
បានត្រឡប់មកដីផ្ទាល់របស់គេ និងរបស់របររបស់គេវិញ ទាំងនៅ
ខាងជើង និងនៅ ខាងត្បូង ទាំងនៅលើដែនដីខាងជើង
និងលើដែនដីខាងត្បូង ។
៣ ហើយពួកគេបានផ្ដល់ដីដល់ពួកចោរទាំងឡាយ ដែលបាន
ចូលក្នុងសេចក្ដីសញ្ញាថានឹងរក្សាសន្តិភាពនៅក្នុងដែនដី ជាពួក
អ្នក ដែលមានបំណងចង់នៅជាសាសន៍លេមិន តាមចំនួនរបស់
ពួកគេ ដើម្បីពួកគេអាចមានទីកន្លែងសំរាប់ចិញ្ចឹមជីវិត ដោយ
ប្រកបពលកម្ម; ម្ល៉ោះហើយ ពួកគេបានសាងសន្តិភាពឡើង
នៅលើអស់ទាំងដែនដី ។
៤ ហើយពួកគេបានចាប់ផ្ដើមចំរើនឡើង និងមានកម្លាំង
ដ៏ខ្លាំងទៀត; ហើយឆ្នាំទីម្ភៃប្រាំមួយ និងម្ភៃប្រាំពីរ បានកន្លងផុតទៅ
ហើយ មានរបៀបរៀបរយដ៏ខ្លាំងនៅលើដែនដី; ហើយពួកគេ
បានបង្កើតច្បាប់ទាំងឡាយរបស់គេ ស្របតាមសមភាព
និងសេចក្ដីយុត្តិធម៌ ។
៥ ហើយឥឡូវនេះ គ្មានអ្វីនៅលើអស់ទាំងដែនដី ដែលរារាំង
ប្រជាជន ក្នុងការចំរុងចំរើនយ៉ាងខ្ជាប់ខ្ជួនសោះ លើកលែងតែ
ពួកគេ ត្រូវធ្លាក់ក្នុងអំពើរំលងប៉ុណ្ណោះ ។
៦ ហើយឥឡូវនេះ គឺឧគីឌដូណៃ និងចៅក្រមឡាកូនីអូស
និងពួកអ្នកដែលត្រូវបានតែងតាំងឡើងជាមេដឹកនាំ ជាអ្នកដែល
បានសាងសន្តិភាពដ៏ធំនេះនៅលើដែនដីឡើង ។
៧ ហើយហេតុការណ៍បានកើតឡើងថា មានទីក្រុងជាច្រើន
ត្រូវបានសង់ថ្មី ហើយមានទីក្រុងចាស់ៗជាច្រើនត្រូវបានជួសជុល
ឡើងវិញ ។
៨ ហើយមានផ្លូវថ្នល់ទាំងឡាយ ត្រូវបានលើកឡើង ហើយ
ផ្លូវជាច្រើនត្រូវបានធ្វើ ដែលនាំពីទីក្រុងមួយទៅទីក្រុងមួយ ហើយ
ពីដែន ដីមួយទៅដែនដីមួយ ហើយពីកន្លែងមួយទៅកន្លែងមួយ ។
៩ ម្ល៉ោះហើយ ឆ្នាំទីម្ភៃប្រាំបីបានកន្លងផុតទៅ ហើយប្រជាជន
ក៏មានសេចក្ដីសុខសាន្តតរៀងមក ។
១០ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីម្ភៃប្រាំបួន
ក៏ចាប់ផ្ដើមមានការទាស់ទែងគ្នាខ្លះ នៅក្នុងចំណោមប្រជាជន;
ហើយអ្នកខ្លះត្រូវបានលើកខ្លួនឡើង [ក]ក្នុងការឆ្មើងឆ្មៃ និង
ការអួតអាង ដោយមកពីទ្រព្យសម្បត្តិដ៏ច្រើនលើសលប់របស់គេ
មែនហើយ គឺរហូតដល់មានការបៀតបៀនដ៏ធំ;
១១ ព្រោះមានអ្នកជំនួញជាច្រើននៅលើដែនដី ហើយមាន
មេធាវីជាច្រើន និងពួកភ្នាក់ងារជាច្រើនផង ។
១២ ហើយប្រជាជនបានចាប់ផ្ដើមញែកចេញតាមឋានៈ
គឺស្រប[ក]តាមទ្រព្យសម្បត្តិរបស់គេ និងឱកាសក្នុងការរៀនសូត្រ
របស់គេ; មែនហើយ អ្នកខ្លះល្ងិតល្ងង់ ដោយសារការក្រខ្សត់
របស់គេ ហើយអ្នកខ្លះទៀត បានទទួលការរៀនសូត្រដ៏ច្រើន
ដោយសារទ្រព្យ សម្បត្តិរបស់គេ ។
១៣ អ្នកខ្លះក៏លើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃ ឯអ្នក
ខ្លះទៀតក៏រាបសាក្រៃលែង; អ្នកខ្លះបានបណ្ដោះបង្អាប់សងនឹង

២៦ *ក* ២ នីហ្វៃ ៣០:៥–៨;
៣ នីហ្វៃ ២០:២៩–៣៤.

៦ ១០*ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១២ *ក* ១ ធីម៉ូ. ៦:១៧–១៩;
ហេលេ. ៤:១២.

បណ្ដុះបង្គាប់ នៅ ពេលអ្នកខ្លះទៀត បានទទួលការបណ្ដុះបង្គាប់
និង*ក*ការបៀតបៀន និងសេចក្ដីទុក្ខវេទនាគ្រប់បែបយ៉ាង ហើយ
*ខ*មិនតបត ហើយមើលងាយ វិញសោះ តែមានចិត្តរាបសា
ហើយសារភាពនៅចំពោះព្រះ ។
១៤ ម្ល៉ោះហើយ ទើបបានក្លាយទៅជាមានភាពមិនស្មើគ្នា
ដ៏ខ្លាំង នៅលើអស់ទាំងផែនដី ដរាបដល់សាសនាចក្របាន
ចាប់ផ្ដើម បែកបាក់; មែនហើយ ដរាបដល់នៅក្នុង
ឆ្នាំទីសាមសិប នោះសាសនាចក្រត្រូវបែកបាក់នៅលើអស់
ទាំងផែនដី លើកលែងតែនៅក្នុង ចំណោមពួកសាសន៍លេមិន
មួយចំនួនតូច ដែលបានប្រែចិត្តជឿចំពោះសេចក្ដីជំនឿពិតប៉ុណ្ណោះ;
ហើយពួកគេពុំចាកចេញពីសេចក្ដីជំនឿ ពិតឡើយ ព្រោះពួក
គេរឹងប៉ឹង និងខ្ជាប់ខ្ជួន និងមុតមាំ ដោយសុខចិត្តធ្វើ
ការ*ក*ព្យាយាមគ្រប់យ៉ាង ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយ
នៃព្រះអម្ចាស់ ។
១៥ ឥឡូវនេះ ហេតុនៃការខ្វះសមភាពនៃប្រជាជននេះគឺថា —
អារក្សសាតាំងមានអំណាចដ៏ធំ ក្នុងការចាក់រុកឲ្យប្រជាជនធ្វើ
អំពើ ទុច្ចរិតគ្រប់បែបយ៉ាង ហើយនៅក្នុងការបំប៉ោងពួក
គេដោយការឆ្មើងឆ្មៃ ល្បួងពួកគេឲ្យស្វែងរកអានុភាព និងសិទ្ធិ
អំណាច និងទ្រព្យ សម្បត្តិ និងវត្ថុទាំងឡាយដែល
ឥតប្រយោជន៍នៃលោកិយ ។
១៦ ហើយអារក្សសាតាំងក៏បានបង្វែរចិត្តប្រជាជន ឲ្យធ្វើអំពើ
ទុច្ចរិតគ្រប់បែបយ៉ាង; ហេតុដូច្នេះហើយ ពួកគេបានត្រេកអរនឹង
សន្តិភាពតែតិចឆ្នាំប៉ុណ្ណោះ ។
១៧ ម្ល៉ោះហើយ នៅដើមឆ្នាំទីសាមសិប — ប្រជាជនបាន
ប្រគល់ខ្លួនអស់រយៈពេលដ៏យូរលង់ ឲ្យដឹកនាំដោយ*ក*ការល្បួង
ទាំងឡាយ របស់អារក្ស ទោះជាវាមានសេចក្ដីប៉ងប្រាថ្នាចង់នាំ
ពួកគេទៅទីណា ឬឲ្យធ្វើអំពើទុច្ចរិតណាក៏ដោយ ដែលវាមាន
សេចក្ដីប៉ងប្រាថ្នា ចង់ឲ្យពួកគេធ្វើ — ហើយនៅដើមឆ្នាំនេះ
គឺឆ្នាំទីសាមសិប ពួកគេនៅក្នុងស្ថានភាពទុច្ចរិតមួយ ដ៏គួរស្ញែងខ្លាច។
១៨ ឥឡូវនេះ ពួកគេមិនបានធ្វើអំពើបាប ដោយ*ក*ល្ងិតល្ងង់នោះទេ
ព្រោះពួកគេដឹងនូវព្រះហឫទ័យនៃព្រះចំពោះពួកគេ ព្រោះត្រូវ
បានបង្រៀនដល់ពួកគេហើយ; ហេតុដូច្នេះហើយ ពួកគេបាន
*ខ*បះបោរដោយចេតនាទាស់នឹងព្រះ ។

១៩ ហើយឥឡូវនេះ គឺនៅក្នុងសម័យឡាកូនីអូស ជាកូនរបស់
ឡាកូនីអូស ព្រោះឡាកូនីអូសបានបំពេញតំណែងរបស់ឪពុកលោក
ហើយបានគ្រប់គ្រងលើប្រជាជននៅឆ្នាំនោះ ។
២០ ហើយក៏ចាប់ផ្ដើមមានពួកមនុស្ស ដែលត្រូវ*ក*បានបំផុស
គំនិតពីស្ថានសួគ៌ា ហើយបានបញ្ជូនមកឲ្យឈរនៅក្នុងចំណោមប្រជាជន
នៅលើអស់ទាំងផែនដី ដើម្បីផ្សាយ និងធ្វើបន្ទាល់យ៉ាងក្លាហាន
ពីអំពើបាប និងអំពើទុច្ចរិតទាំងឡាយនៃប្រជាជន ហើយធ្វើ
បន្ទាល់ទៅគេ ពីសេចក្ដីប្រោសលោះ ដែលព្រះអម្ចាស់នឹងធ្វើ
សំរាប់រាស្ត្រទ្រង់ ឬនិយាយម្យ៉ាងទៀត គឺដំណើររស់*ខ*ឡើងវិញ
នៃព្រះគ្រីស្ទ; ហើយពួកគេបានធ្វើបន្ទាល់យ៉ាងក្លាហាន ពីការសុគត
និងការរងទុក្ខទាំងឡាយរបស់ទ្រង់ ។
២១ ឥឡូវនេះ មានមនុស្សជាច្រើនខឹងជាខ្លាំង ពីព្រោះតែពួក
អ្នកដែលបានធ្វើបន្ទាល់ពីការណ៍ទាំងនេះ; ហើយពួកអ្នកដែល *ក*ខឹង
ទាំងនោះ ភាគច្រើនគឺពួកមេចៅក្រម និងពួកអ្នកដែលធ្លាប់ធ្វើជា
ពួកសង្ឃជាន់ខ្ពស់ និងពួកមេធាវី; មែនហើយ អស់ពួកដែល
ធ្លាប់ជាមេធាវីខឹងនឹងពួកអ្នក ដែលធ្វើបន្ទាល់ពីការណ៍ទាំងនេះ ។
២២ ឥឡូវនេះ គ្មានមេធាវី ឬចៅក្រម ឬសង្ឃជាន់ខ្ពស់ណា
ដែលអាចមានអំណាចកាត់ទោស ជនណាម្នាក់ឲ្យស្លាប់សោះ
លើកលែងតែការកាត់ទោសរបស់ពួកគេ ត្រូវបានចុះហត្ថ
លេខាដោយលោកអភិបាលដែនដីប៉ុណ្ណោះ ។
២៣ ឥឡូវនេះ មានពួកគេជាច្រើន បានធ្វើបន្ទាល់ពីការណ៍ទាំង
ឡាយ ដែលទាក់ទងទៅនឹងព្រះគ្រីស្ទ ដែលបានធ្វើបន្ទាល់យ៉ាង
ក្លាហាន ហើយត្រូវចាប់ ហើយសម្លាប់ចោលដោយសម្ងាត់ដោយ
ពួកចៅក្រម ដែលដំណឹងអំពីការស្លាប់របស់គេនោះមិនបានឮ
ដល់លោកអភិបាលនៃដែនដីឡើយ រហូតដល់ពួកគេបាន
ស្លាប់ទៅហើយ ។
២៤ ឥឡូវនេះ មើលចុះ ការនេះគឺផ្ទុយនឹងច្បាប់ទាំងឡាយ
របស់ដែនដី ដែលថា មនុស្សម្នាក់ត្រូវយកទោសសម្លាប់បាន
លើកលែងតែ មានអំណាចពីលោកអភិបាលនៃដែនដី —
២៥ ហេតុដូច្នោះហើយ ការប្ដឹងមួយបានបញ្ជូនឡើងមកដែនដី
សារ៉ាហិមឡា ជូនចំពោះលោកអភិបាលនៃដែនដី ទាស់នឹង
ពួកចៅ ក្រមទាំងនោះ ដែលបានកាត់ទោសពួកព្យាការីនៃព្រះ
អម្ចាស់ដល់ស្លាប់ ដែលពុំស្របតាមច្បាប់ ។

១៣ *ក* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
*ខ* ម៉ាថាយ ៥:៣៩; ៤ នីហ្វៃ ១:៣៤; គ. និង ស. ៩៨:២៣–២៥.
១៤ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
១៧ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
១៨ *ក* ម៉ូសាយ ៣:១១.
*ខ* ស.ប. ការបះបោរ.
២០ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត; ព្យាការី.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន; ការឆ្កាង.
២១ *ក* គ. និង ស. ១២១:៣៦–៣៧. ស.ប. សេចក្ដីក្បត់សាសនា.

២៦ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកគេត្រូវបាន
ចាប់ ហើយនាំយកមកខាងមុខលោកចៅក្រម ដើម្បីជំនុំជំរះនូវ
បទ ឧក្រិដ្ឋ ដែលពួកគេបានធ្វើឡើង ស្របតាម[ក]ច្បាប់ដែលបាន
ចែងដោយប្រជាជន ។
២៧ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ពួកចៅក្រម
ទាំងនោះ មានមិត្តភក្តិ និងញាតិសន្តានជាច្រើន; រីឯពួកអ្នកដែល
នៅ សល់ទាំងប៉ុន្មាន មែនហើយ ពួកមេធាវី និងពួកសង្ឃជាន់ខ្ពស់
សឹងតែទាំងអស់បានប្រមូលគ្នាមក ហើយរួបរួមនឹងញាត្តិសន្តាន
នៃពួក ចៅក្រម ដែលត្រូវគេយកទៅជំនុំតាមច្បាប់ទាំងនោះ ។
២៨ ហើយពួកគេបានចូល[ក]ក្នុងសេចក្ដីសញ្ញាមួយ ជាមួយនឹង
គ្នា មែនហើយ ដូចគ្នានឹងសេចក្ដីសញ្ញា ដែលធ្វើដោយពួកគេ
ជំនាន់ដើម គឺជាសេចក្ដីសញ្ញាដែលធ្វើឡើង ហើយត្រួត
ត្រាដោយ[ខ]អារក្ស ដើម្បីរួមគ្នាទាស់នឹងសេចក្ដីសុចរិតទាំងអស់ ។
២៩ ហេតុដូច្នេះហើយ ពួកគេបានរួមគ្នាទាស់នឹងរាស្ត្រនៃព្រះ
អម្ចាស់ ហើយចូលក្នុងសេចក្ដីសញ្ញាមួយ ដើម្បីបំផ្លាញពួក
គេបង់ ហើយដោះលែងពួកជនដែលជាប់ទោសសម្លាប់មនុស្ស
ឲ្យរួចផុតពីក្រញាំនៃសេចក្ដីយុត្តិធម៌ ដែលបំរុងនឹងអនុវត្តតាមច្បាប់ ។
៣០ ហើយពួកគេរឹងទទឹងនឹងច្បាប់ និងសិទ្ធិទាំងឡាយរបស់
ប្រទេសគេ; ហើយពួកគេបានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងគ្នា
ដើម្បី បំផ្លាញលោកអភិបាល ហើយដើម្បីបង្កើតឲ្យមាន
ស្ដេចនៅលើដែនដី ដើម្បីកុំឲ្យដែនដីមានឥស្សរភាពតទៅទៀត
តែត្រូវនៅក្រោម អំណាចរបស់[ក]ស្ដេចទាំងឡាយវិញ ៕

## ជំពូកទី ៧

*លោកមេចៅក្រមត្រូវគេធ្វើឃាត រដ្ឋាភិបាលត្រូវបំផ្លាញចោល — ហើយប្រជាជនបែកចេញជាពូជអំបូរទាំងឡាយ — យ៉ាកុប ដែលជា អ្នកទទឹងនឹងព្រះគ្រីស្ទម្នាក់ ក្លាយទៅជាស្ដេចនៃពួកក្រុមផ្សំគំនិតសម្ងាត់មួយ — នីហ្វៃផ្សាយអំពីការប្រែចិត្ត និងសេចក្ដីជំនឿជឿដល់ ព្រះគ្រីស្ទ — ពួកទេវតាធ្វើការងារបំរើលោករាល់ថ្ងៃ ហើយលោកប្រោសប្អូនប្រុសរបស់លោកឲ្យរស់ពីស្លាប់ — មនុស្សជាច្រើនប្រែចិត្ត ហើយបានទទួលបុណ្យជ្រមុជទឹក ។ ប្រមាណជាឆ្នាំ ៣០–៣៣ គ.ស. ។*

ឥឡូវនេះ មើលចុះ ខ្ញុំនឹងបង្ហាញដល់អ្នកថា ពួកគេពុំបានបង្កើតឲ្យ
មានស្ដេចនៅលើដែនដីទេ; ប៉ុន្តែនៅក្នុងឆ្នាំដដែលនេះ មែន
ហើយ គឺឆ្នាំទីសាមសិប នោះពួកគេបានបំផ្លាញនៅលើវេទិកា
ជំនុំជំរះ មែនហើយ គឺបានធ្វើឃាតមេចៅក្រមនៃដែនដី ។
២ ហើយប្រជាជនត្រូវបែកបាក់ពីគ្នា; ហើយពួកគេបាន
បែកចេញពីគ្នា ទៅជាពូជអំបូរទាំងឡាយ គឺមនុស្ស
ម្នាក់ៗទៅតាមគ្រួសារនិង ញាតិសន្តាន និងមិត្តភក្តិរបស់គេ;
ម្ល៉ោះហើយ ពួកគេបានបំផ្លាញរដ្ឋាភិបាលនៃដែនដី ។
៣ ហើយពូជអំបូរនីមួយៗ បានតែងតាំងមេ ឬអ្នកដឹកនាំ
ម្នាក់លើពួកគេ; ម្ល៉ោះហើយ ពួកគេបានក្លាយទៅជាពូជអំបូរទាំង
ឡាយ និងពួកអ្នកដឹកនាំពូជអំបូរទាំងឡាយ ។
៤ ឥឡូវនេះ មើលចុះ គ្មានមនុស្សណាម្នាក់ នៅក្នុងចំណោម
ពួកគេ ដែលគ្មានគ្រួសារ និងញាតិសន្តាន និងមិត្តភក្តិ
ជាច្រើននោះ ឡើយ; ហេតុដូច្នេះហើយ ពូជអំបូរទាំងឡាយ
របស់គេ បានក្លាយទៅជាធំដ៏លើសលប់ ។
៥ ឥឡូវនេះ ការណ៍អស់ទាំងនេះបានកើតឡើង តែពុំទាន់មាន
សង្គ្រាមទាំងឡាយ នៅក្នុងចំណោមពួកគេនៅឡើយទេ; ហើយ
អស់ ទាំងអំពើទុច្ចរិតនេះ បានកើតឡើងដល់ប្រជាជន ដោយមក
ពីពួកគេបាន[ក]បណ្ដោយខ្លួន នៅក្រោមអំណាចរបស់អារក្សសាតាំង ។
៦ ហើយរបៀបចាត់ចែងទាំងឡាយរបស់រដ្ឋាភិបាល ត្រូវ
បំផ្លាញចោល ពីព្រោះមកពីការរួមគំនិត[ក]សម្ងាត់ នៃមិត្តភក្តិ
និងញាតិសន្តាន របស់ពួកជនដែលបានធ្វើឃាតពួកព្យាការី ។
៧ ហើយពួកគេបានបណ្ដាល ឲ្យមានការទាស់ទែងគ្នាមួយ
ដ៏ធំនៅលើដែនដី ដរាបដល់ផ្នែកមនុស្សដែលសុចរិតច្រើន សឹងតែ
ក្លាយ ទៅជាទុច្ចរិតទាំងអស់; មែនហើយ មាននៅសល់តែ
មនុស្សសុចរិតតែបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងចំណោមពួកគេ ។
៨ ម្ល៉ោះហើយ រយៈពេលប្រាំមួយឆ្នាំពុំទាន់ឆ្លងផុតទៅ
ចាប់តាំងពីពេលដែលប្រជាជនភាគច្រើន បានបែរចេញពីភាព
សុចរិតរបស់គេ បីដូចជាឆ្កែបែរទៅរក[ក]កំអួតវា ឬដូចជា
ជ្រូកញីបែរទៅននៀលនៅក្នុងខ្ទាចវិញ ។
៩ ឥឡូវនេះ ពួកផ្សំគំនិតសម្ងាត់នេះ ដែលបាននាំមកនូវការ
ទុច្ចរិតដ៏ធំមកលើប្រជាជន នោះបានប្រមូលគ្នាមក ហើយបាន
លើកធ្វើជា មេរបស់ពួកវា នូវមនុស្សម្នាក់ដែលពួកវាហៅថា
យ៉ាកុប;
១០ ហើយពួកវាបានហៅគាត់ថាជាស្ដេចរបស់ពួកវា; ហេតុ

២៦ *ក* ម៉ូសាយ ២៩:២៥; អាលម៉ា ១:១៤.
២៨ *ក* ស.ប. បក្សព័ន្ធសម្ងាត់.
*ខ* ហេលេ. ៦:២៦–៣០.
៣០ *ក* ១ សាំយូ. ៨:៥–៧;
អាលម៉ា ៥១:៥.
**៧** ៥ *ក* រ៉ូម ៦:១៣–១៦; អាលម៉ា ១០:២៥.
៦ *ក* ២ នីហ្វៃ ៩:៩.
៨ *ក* សុភា. ២៦:១១;
២ ពេត្រុស ២:២២.

ដូច្នេះហើយ គាត់ក្លាយទៅជាស្តេចមួយ លើក្រុមមនុស្សទុច្ចរិតនេះ ហើយទ្រង់គឺជាមេម្នាក់ ដែលបានបញ្ចេញសម្លេងរបស់ទ្រង់ ទាស់នឹងពួកព្យាការី ដែលធ្វើទីបន្ទាល់អំពីព្រះយេស៊ូវ ។

១១ ហើយហេតុការណ៍បានកើតឡើងថា ពួកវាពុំសូវមានចំនួនច្រើន ដូចពួកពូជអំបូររបស់ប្រជាជន ដែលបានរួបរួមគ្នានោះទេ លើកលែងតែមេដឹកនាំរបស់គេ បានបង្កើតច្បាប់ទាំងឡាយ គឺម្នាក់ៗទៅតាមពូជអំបូររបស់ខ្លួន; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេជាពួកខ្មាំងសត្រូវដែរ; ទោះបីពួកគេពុំមែនជាប្រជាជនសុចរិតក្តី គង់តែពួកគេរួមគ្នានៅក្នុងសម្អប់ ទៅលើពួកជន ដែលបានចូលក្នុងសេចក្តីសញ្ញា ដើម្បីបំផ្លាញរដ្ឋាភិបាលចោលដែរ ។

១២ ហេតុដូច្នេះហើយ យ៉ាកុប ដោយបានទតឃើញថា ពួកខ្មាំងសត្រូវរបស់ទ្រង់ មានចំនួនច្រើនជាងខ្លួន ឯទ្រង់ជាស្តេចរបស់ក្រុម នោះ ហេតុដូច្នេះហើយ ទើបទ្រង់បានបញ្ជាប្រជាជនរបស់ទ្រង់ថា ពួកគេត្រូវរត់គេចចូលទៅក្នុងផ្នែក[ក]ខាងជើងបំផុតនៃដែនដី ហើយ នៅទីនោះ ពួកគេបានស្ថាបនានគរមួយ រហូតដល់ពួកគេត្រូវបានរួបរួម ដោយពួកអ្នកដែលបែកបាក់ (ព្រោះទ្រង់បានបញ្ចោរ ពួកគេថា នឹងមានអ្នកបែកបាក់ជាច្រើន) ហើយពួកវាក្លាយទៅជាមានកម្លាំងគ្រប់គ្រាន់ ដើម្បីតតាំងនឹងពួកពូជអំបូររបស់ប្រជាជន; ហើយពួកវាបានធ្វើយ៉ាងនេះ ។

១៣ ហើយពួកវាបានធ្វើដំណើរទៅយ៉ាងលឿន រហូតដល់មិនអាចត្រូវបង្អាក់បាន គឺរហូតដល់ពួកវាបានទៅផុត ពីកណ្តាប់ដៃរបស់ ប្រជាជន ។ ម្ល៉ោះហើយ ក៏ចប់ឆ្នាំទីសាមសិបទៅ; នោះហើយគឺជាកិច្ចការទាំងឡាយរបស់ប្រជាជននីហ្វៃ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីសាមសិបមួយ ពួកគេបានបែកទៅជាពូជអំបូរទាំងឡាយ គឺមនុស្សម្នាក់ៗទៅតាមគ្រួសារ និងញាតិសន្តាន និងមិត្តភក្តិរបស់ខ្លួន; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេបានមកដល់ការព្រមព្រៀងមួយថា ពួកគេពុំធ្វើសង្គ្រាមរវាងគ្នាឡើយ; ប៉ុន្តែពួកគេពុំសាមគ្គីគ្នា ខាងច្បាប់ទាំងឡាយរបស់គេ និងរបៀបនៃរដ្ឋាភិបាលរបស់គេឡើយ ព្រោះច្បាប់ទាំងនោះត្រូវបានរៀបចំឡើងតាមគំនិតទាំងឡាយរបស់ពួកអ្នកដែលជាមេរបស់គេ និងពួកអ្នកដឹកនាំរបស់គេ ។ ប៉ុន្តែពួកគេ បានបង្កើតច្បាប់ទាំងឡាយយ៉ាងតឹងរឹងថា ពូជអំបូរនីមួយៗ ពុំត្រូវបំពារបំពានលើពូជអំបូរមួយទៀតឡើយ ដរាបដល់ពួកគេមាន សន្តិភាពដល់កំរិតមួយនៅលើដែនដី; ទោះជាយ៉ាងណាក៏ដោយ គង់តែចិត្តរបស់គេ ត្រូវបែរចេញពីព្រះអម្ចាស់ ជាព្រះរបស់គេ ហើយពួកគេបានចោលថ្មទៅលើពួកព្យាការី ព្រមទាំងបានបណ្តេញពួកគេ ចេញពីចំណោមគេដែរ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា [ក]នីហ្វៃ — ដោយមានពួកទេវតាមករក ព្រមទាំងសម្លេងនៃព្រះអម្ចាស់ផង ហេតុដូច្នេះ ហើយ ដោយបានឃើញពួកទេវតា និងជាសាក្សី ហើយដោយមានអំណាចប្រទានឲ្យលោក ដើម្បីឲ្យលោកអាចដឹងអំពីការងារ បំរើនៃព្រះគ្រីស្ទ ហើយជាសាក្សីចំពោះការត្រឡប់មកវិញដ៏ឆាប់របស់ពួកគេ ពីភាពសុចរិតទៅកាន់ភាពទុច្ចរិត និងភាពគួរខ្ពើមឆ្អើម ទាំងឡាយ;

១៦ ហេតុដូច្នេះហើយ ដោយព្រួយបារម្ភដល់ភាពរឹងរូសនៃចិត្តរបស់គេ និងភាពងងឹតងងល់នៃគំនិតរបស់គេ នោះលោកបានចេញទៅក្នុងចំណោមពួកគេ ក្នុងឆ្នាំដដែលនោះ ហើយបានចាប់ផ្តើមធ្វើបន្ទាល់យ៉ាងក្លាហាន ពីការប្រែចិត្ត និងការផ្តាច់បាប ដោយសេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។

១៧ ហើយលោកបានធ្វើការងារបំរើជាច្រើនដល់ពួកគេ; ហើយការណ៍ទាំងអស់នោះ មិនអាចយកមកសរសេរបានទេ ហើយមួយផ្នែកនៃការណ៍ទាំងនោះគឺពុំគ្រប់គ្រាន់ដែរ ហេតុដូច្នេះហើយ ពុំបានយកមកសរសេរក្នុងគម្ពីរនេះសោះ។ ហើយនីហ្វៃបានធ្វើការងារបំរើដោយ[ក]អានុភាព និងសិទ្ធិអំណាចដ៏ធំ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេខឹងនឹងលោក គឺពីព្រោះលោកមានអំណាចខ្លាំងជាងពួកគេ ត្បិតគ្មានលទ្ធភាព ណាអាចធ្វើឲ្យពួកគេ [ក]មិនជឿពាក្យទាំងឡាយរបស់លោកបានឡើយ ត្បិតសេចក្តីជំនឿរបស់លោក ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ នោះធំដ៏ក្រៃលែង បានជាពួកទេវតាធ្វើការងារបំរើដល់លោកជារៀងរាល់ថ្ងៃ ។

១៩ ហើយដោយនូវព្រះនាមនៃព្រះយេស៊ូវ នោះលោកបានបណ្តេញពួកអារក្សអសោចិ៍ និងពួក[ក]វិញ្ញាណស្មោកគ្រោកឲ្យចេញ; ហើយលោកថែមទាំងបានប្រោសប្អូនប្រុសរបស់លោកពីស្លាប់ បន្ទាប់ពីលោកត្រូវគេចោលនឹងថ្ម ហើយត្រូវប្រជាជនធ្វើឲ្យស្លាប់ ។

២០ ហើយប្រជាជនបានឃើញការណ៍នេះ ហើយបានធ្វើជាទីបន្ទាល់ដល់ការណ៍នេះ ហើយក៏ខឹងនឹងលោក មកពីអំណាចរបស់លោក; ហើយលោកថែមទាំងបានសម្តែងនូវអព្ភូតហេតុ[ក]ជាច្រើន

១២ *ក* ៣ នីហ្វៃ ៦:៣០.
១៥ *ក* ៣ នីហ្វៃ ១:២.
១៧ *ក* ស.ប. អំណាច.
១៨ *ក* ២ នីហ្វៃ ៣៣:១; អាលម៉ា ៤:១៩.
១៩ *ក* ស.ប. វិញ្ញាណ — អារក្សអសោចិ៍.
២០ *ក* ៣ នីហ្វៃ ៨:១.

ទៀតផង គឺនៅចំពោះភ្នែកនៃប្រជាជន ដោយនូវព្រះនាមនៃ
ព្រះយេស៊ូវ ។
២១ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីសាមសិបមួយ
បានកន្លងផុតទៅ ហើយមានតែមនុស្សចំនួនតិចទេ ដែលបានប្រែ
ចិត្ត ជឿដល់ព្រះអម្ចាស់; ប៉ុន្តែអស់អ្នកណាដែលបានប្រែចិត្តជឿ
នោះបានធ្វើសញ្ញាយ៉ាងពិតប្រាកដដល់ប្រជាជនថា ពួកគេត្រូវ
បានសណ្ឋិត ដោយព្រះចេស្ដា និងព្រះវិញ្ញាណនៃព្រះ ដែលនៅ
ក្នុងព្រះយេស៊ូវគ្រីស្ទ ដែលពួកគេជឿដល់នោះ ។
២២ ហើយអស់អ្នកណាដែលបានបណ្ដេញពួកអារក្សអសោ
ចិ៍ចេញពីខ្លួន ហើយបានជាពីជម្ងឺទាំងឡាយរបស់គេ និងភាព
ពិការ របស់គេ នោះបានសម្ដែងយ៉ាងពិតប្រាកដដល់
ប្រជាជនថា ពួកគេត្រូវបានទ្រទ្រង់ ដោយព្រះវិញ្ញាណនៃព្រះ
ហើយត្រូវបានព្យាបាល ឲ្យជា; ហើយពួកគេបានបង្ហាញ
ទីសំគាល់ទាំងឡាយផង ហើយបានសម្ដែងអព្ភូតហេតុខ្លះ នៅ
ក្នុងចំណោមប្រជាជន ។
២៣ ម្ល៉ោះហើយ ឆ្នាំទីសាមសិបពីរក៏កន្លងផុតទៅដែរ ។
ហើយនីហ្វៃបានស្រែកទៅកាន់ប្រជាជន នៅដើមឆ្នាំទីសាមសិប
បី; ហើយលោកបានផ្សាយដល់ពួកគេ ពីការប្រែចិត្ត និងការ
ផ្ដាច់បាប ។
២៤ ឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាចាំផងថា គ្មានអ្នក
ណាម្នាក់សោះ ដែលត្រូវបាននាំឲ្យមានការប្រែចិត្ត ដែលពុំបាន
ទទួល បុណ្យជ្រមុជដោយទឹកនោះឡើយ ។
២៥ ហេតុដូច្នេះហើយ មានមនុស្សទាំងឡាយ ដែលនីហ្វៃបាន
តែងតាំងឡើង ក្នុងការងារបំរើនេះ ដើម្បីឲ្យអស់អ្នកណាដែល
មក រកពួកគេ នឹងបានទទួលបុណ្យជ្រមុជដោយទឹក ហើយការ
នេះគឺជាសាក្សី និងជាទីបន្ទាល់មួយ នៅចំពោះព្រះ និងដល់
ប្រជាជនថា ពួកគេបានប្រែចិត្ត ហើយបានទទួលការផ្ដាច់បាបទាំង
ឡាយរបស់គេ ។
២៦ ហើយមានមនុស្សជាច្រើននៅដើមឆ្នាំនេះ ដែលបានទទួល
បុណ្យជ្រមុជទឹក ចំពោះការប្រែចិត្ត; ម្ល៉ោះហើយ ភាគច្រើននៃ
ឆ្នាំនេះ បានកន្លងទៅ ៕

ជំពូកទី ៨

*ព្យុះសង្ឃរា ផែនដីរញ្ជួយ ភ្លើង ខ្យល់គួច និងចលាចលទាំងឡាយ បញ្ជាក់នូវការឆ្កាងព្រះគ្រីស្ទ — មនុស្សជាច្រើនត្រូវបំផ្លាញចោល — ភាពងងឹតគ្របដណ្ដប់លើផែនដីអស់រយៈពេលបីថ្ងៃ — ពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន សោកស្ដាយដល់វាសនារបស់ខ្លួន ។ ប្រមាណជាឆ្នាំ ៣៣–៣៤ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា ស្របតាមបញ្ជី
របស់យើង ហើយយើងដឹងថា បញ្ជីរបស់យើងពិត ត្បិតមើលចុះ
គឺជា មនុស្សសុចរិតម្នាក់ ដែលបានកត់បញ្ជីនោះ —
ព្រោះលោកពិតជាបានសម្ដែងនូវអព្ភូតហេតុជាច្រើន ដោយនូវ
ព្រះនាមនៃព្រះយេស៊ូវ; ហើយគ្មានអ្នកណាម្នាក់ ដែលអាច
សម្ដែងនូវអព្ភូតហេតុ ដោយនូវព្រះនាមនៃព្រះយេស៊ូវបានឡើយ
លើកលែងតែអ្នកនោះបានលាង ជ្រះស្រឡះ ពីភាពទុច្ចរិតគ្រប់
មុខរបស់ខ្លួន ។
២ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បើសិនជា
អ្នកនោះពុំបានភាន់ច្រឡំ នូវក្នុងការគិតពេលវេលារបស់ពួកយើងទេ
គឺសាមសិបបីឆ្នាំ បានកន្លងផុតទៅហើយ;
៣ ហើយប្រជាជនបានចាប់ផ្ដើមទន្ទឹងចាំដោយម៉ឺងម៉ាត់ នូវ
ទីសំគាល់ដែលបានប្រាប់ដោយព្យាការីសាំយូអែល ជាសាសន៍
លេមិន មែនហើយ គេទន្ទឹងដល់ ពេលដែលនឹងមានភាពងងឹត
អស់រយៈពេលបីថ្ងៃ នៅលើផ្ទៃផែនដី ។
៤ ហើយចាប់ផ្ដើមមានការសង្ស័យ និងការប្រកែកគ្នាយ៉ាង
ខ្លាំង នៅក្នុងចំណោមប្រជាជន ទោះបីមានទីសំគាល់ជាច្រើន
បាន កើតឡើងហើយក៏ដោយ ។
៥ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីសាមសិបបួន
ក្នុងខែដំបូង ក្នុងថ្ងៃទីបួននៃខែ នោះមានព្យុះមួយបានកើតឡើង
គឺជាព្យុះដ៏ធំមួយ ដែលពុំធ្លាប់ដែលមាននៅលើដែនដីសោះ ។
៦ ហើយមានព្យុះសង្ឃរាដ៏ធំ និងកំណាចមួយបានកើតឡើង;
ហើយមានរន្ទះដ៏កំណាច រហូតដល់ធ្វើឲ្យកក្រើកផែនដីទាំងមូល
ហាក់បីដូចចង់ប្រេះចេញពីគ្នា ។

២៤ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
២៥ *ក* គ. និង ស. ២០:៣៧.
ស.ប. ការផ្ដាច់បាប.
៨ ១*ក* ៣ នីហ្វៃ ៧:១៩–២០;
មរមន ៩:១៨–១៩.
*ខ* កិច្ចការ ៣:៦;
យ៉ាកុប ៤:៦.
២ *ក* ៣ នីហ្វៃ ២:៨.
៣ *ក* ១ នីហ្វៃ ១៩:១០;
ហេលេ. ១៤:២០, ២៧;
៣ នីហ្វៃ ១០:៩.
៤ *ក* ស.ប. ការឆ្កាង.
៦ *ក* ១ នីហ្វៃ ១៩:១១;
ហេលេ. ១៤:២១.
*ខ* ម៉ាថាយ ២៧:៤៥, ៥០–៥១.

៧ ហើយមានផ្លេកបន្ទោរដ៏ភ្លឺអស្ចារ្យ ដែលពុំដែលធ្លាប់បានស្គាល់នៅលើអស់ទាំងដែនដីឡើយ ។

៨ ហើយ[ក]ទីក្រុងសារ៉ាហិមឡាត្រូវឆេះទៅ ។

៩ ហើយទីក្រុងម៉ូរ៉ូណៃ ត្រូវលិចទៅក្នុងជំរៅសមុទ្រ ឯបណ្ដាជននៅទីនោះ ក៏ត្រូវលង់ទឹកស្លាប់ ។

១០ ហើយដីត្រូវពូនឡើង ទៅលើទីក្រុងម៉ូរ៉ូណៃហា ធ្វើឲ្យទីក្រុងនេះ ក្លាយទៅជាភ្នំមួយដ៏ធំ ។

១១ ហើយមានការបំផ្លិចបំផ្លាញដ៏ធំ និងឃោរឃៅមួយនៅដែនដីផ្នែកខាងត្បូង ។

១២ ប៉ុន្តែមើលចុះ នៅលើដែនដីភាគខាងជើង មានការបំផ្លិចបំផ្លាញរឹតតែធំ និងឃោរឃៅជាងនេះទៅទៀត; ត្បិតមើលចុះ ផ្ទៃដីទាំងមូលត្រូវប្រែប្រួលអស់ ដោយមកពីព្យុះសង្ឃរា និងខ្យល់កួច និងរន្ទះ និងផ្លេកបន្ទោរ និងការរញ្ជួយផែនដីទាំងមូលដ៏ខ្លាំងមហិមា ។

១៣ ហើយផ្លូវធំទាំងឡាយត្រូវបាក់បែក ឯ[ក]ផ្ទៃផ្លូវដែលរាបស្មើត្រូវខូចខាត ហើយកន្លែងរាបស្មើជាច្រើន ត្រូវក្លាយជាក្រហេង ក្រហូង ។

១៤ ហើយទីក្រុងដ៏ធំ និងល្បីឈ្មោះជាច្រើនត្រូវ[ក]លិចចុះ ទីក្រុងជាច្រើនទៀតត្រូវឆេះចោល មានទីក្រុងជាច្រើនត្រូវកក្រើកញ័ររហូតដល់អាគារទាំងឡាយរលំមកលើដី ឯបណ្ដាជននៅក្នុងនោះត្រូវស្លាប់ ហើយទីកន្លែងនោះត្រូវបោះបង់ចោលស្ងាត់ឈឹង ។

១៥ ហើយមានទីក្រុងខ្លះនៅសល់; ប៉ុន្តែទទួលការខូចខាតយ៉ាងសែនដំណំ ហើយមានបណ្ដាជនជាច្រើនត្រូវស្លាប់ ។

១៦ ហើយមានមនុស្សខ្លះ ត្រូវខ្យល់កួចយកទៅ; ហើយគ្មាននរណាដឹងថា ទៅឯណាទេ គេគ្រាន់តែដឹងថា មនុស្សទាំងនោះត្រូវ ខ្យល់កួចយកទៅប៉ុណ្ណោះ ។

១៧ ម្ល៉ោះហើយ ផ្ទៃដែនដីទាំងមូលបានក្លាយទៅជាខូចខាតពីព្រោះមកពីព្យុះសង្ឃរា រន្ទះ ផ្លេកបន្ទោរ និងការរញ្ជួយផែនដី ។

១៨ ហើយមើលចុះ [ក]ថ្មទាំងឡាយត្រូវប្រេះបែកជាពីរ; ហើយត្រូវបែកនៅពាសពេញលើផ្ទៃដែនដីទាំងមូល ដរាបដល់បែកទៅជាដុំតូចៗ ហើយមានស្នាមបែកប្រេះ នៅពេញលើផ្ទៃដែនដីទាំងអស់ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា កាលរន្ទះ ផ្លេកបន្ទោរ ខ្យល់ព្យុះ ព្យុះសង្ឃរា និងផែនដីរញ្ជួយបានចប់ទៅ — ត្បិតមើលចុះ ការណ៍ទាំងនេះបានកើតឡើង អស់រយៈពេលប្រហែលបីម៉ោងប៉ុណ្ណោះ; ហើយមានមនុស្សខ្លះបាននិយាយថាអស់ពេល យូរជាងនេះទៅទៀត; ទោះយ៉ាងណាក៏ដោយ គង់តែការណ៍ដ៏មហិមា និងកំណាចទាំងអស់នេះ បានកើតឡើងអស់រយៈពេលប្រហែល តែ[ក]បីម៉ោងទេ — ហើយបន្ទាប់មក មើលចុះ មានភាពងងឹតមកគ្របដណ្ដប់លើផ្ទៃដែនដី ។

២០ ហើយហេតុការណ៍បានកើតឡើងថា មានភាពងងឹតយ៉ាងក្រាស់គ្របដណ្ដប់លើផ្ទៃដែនដី ដរាបដល់បណ្ដាជននៅទីនោះ ដែលពុំទាន់ដួល អាចចាប់[ក]អារម្មណ៍នូវ[ខ]ចំហាយនៃសេចក្ដីងងឹតនេះ;

២១ ហើយពុំអាចមានពន្លឺសោះ ពីព្រោះមកពីភាពងងឹតនេះ ហើយគ្មានទៀន ឬចន្លុះទេ; ហើយគ្មានអ្វីដែលអាចបង្កាត់ភ្លើងដោយឱសដ៏ស្ងួត និងល្អបានឡើយ ម្ល៉ោះហើយ ពុំអាចមានពន្លឺទាល់តែសោះ;

២២ ហើយគ្មានឃើញពន្លឺអ្វីបន្តិចសោះ គ្មានភ្លើង គ្មានរស្មីគ្មានព្រះអាទិត្យ ឬព្រះចន្ទ ឬផ្កាយឡើយ ត្បិតអ័ព្ទនៃសេចក្ដីងងឹតដែលគ្របដណ្ដប់លើផ្ទៃផែនដីនោះក្រាស់ណាស់ ។

២៣ ហើយហេតុការណ៍បានកើតឡើងថា ភាពងងឹតនេះបានស្ថិតនៅអស់រយៈពេល[ក]បីថ្ងៃ ដែលមិនឃើញមានពន្លឺអ្វីបន្តិចសោះ; ហើយមានការទ្រហោយំ និងទ្រហោយំ និងខ្សឹកខ្សួល នៅក្នុងចំណោមប្រជាជនទាំងអស់ដោយពុំចេះដាច់; មែនហើយប្រជាជនយំថ្ងូរ គួរឲ្យខ្លោចផ្សា ពីព្រោះតែភាពងងឹត និងការបំផ្លិចបំផ្លាញដ៏ធំ ដែលមានមកលើពួកគេ ។

២៤ ហើយមានកន្លែងមួយនោះ គេបានឮសំរែកយំថា៖ ឱប្រសិនបើយើងបានប្រែចិត្ត មុនថ្ងៃដ៏ធំ និងកំណាចនេះទៅអេះហើយ ខណៈនោះ ប្រហែលជាបងប្អូនរបស់យើងបានរួចជីវិត ហើយប្រហែលជាពួកគេពុំត្រូវឆេះ នៅក្នុង[ក]ទីក្រុងសារ៉ាហិមឡាដ៏ធំនោះទេ ។

២៥ ហើយមានកន្លែងមួយទៀត គេបានឮសំរែកយំថ្ងូរថា៖ ឱប្រសិនបើយើងបានប្រែចិត្ត មុនថ្ងៃដ៏ធំ និងកំណាចនេះ ប្រសិនបើយើង ពុំបានសម្លាប់ ហើយចោលដុំថ្ម ទៅលើពួកព្យាការីទេ ហើយពុំបានបណ្ដេញគេចេញទេ; នោះប្រហែលជាម្ដាយរបស់យើង និងកូនស្រី ដ៏ស្រស់ល្អៗរបស់យើង និងកូនចៅរបស់យើងបានរួចជីវិត ហើយពុំត្រូវកប់នៅក្នុងទីក្រុងម៉ូរ៉ូណៃហាដ៏ធំនោះទេ ។

៨ ក ៤ នីហ្វៃ ១:៧–៨.
១៣ ក ហេលេ. ១៤:២៤; ៣ នីហ្វៃ ៦:៨.
១៤ ក ១ នីហ្វៃ ១២:៤.
១៨ ក ហេលេ. ១៤:២១–២២.
១៩ ក លូកា ២៣:៤៤.
២០ ក និក្ខ. ១០:២១–២២.
ខ ១ នីហ្វៃ ១២:៥; ១៩:១១.
២៣ ក ១ នីហ្វៃ ១៩:១០.
២៤ ក ហេលេ. ១៣:១២.

ម្ល៉ោះហើយ សំរែកទ្រហោយំរបស់ប្រជាជន គួរឲ្យខ្លោចផ្សាណាស់ ៕

## ជំពូកទី ៩

*នៅក្នុងភាពងងឹត សម្លេងនៃព្រះគ្រីស្ទ ប្រកាសប្រាប់នូវសេចក្ដីបំផ្លិចបំផ្លាញប្រជាជន និងទីក្រុងជាច្រើន ដោយមកពីសេចក្ដីទុច្ចរិតរបស់ ពួកគេ — ទ្រង់ក៏ប្រកាសប្រាប់ពីទេវភាពរបស់ទ្រង់ដែរ ប្រកាសថា ក្រិត្យវិន័យលោកម៉ូសេត្រូវបានបំពេញហើយ ហើយអញ្ជើញ មនុស្សឲ្យមករកទ្រង់ ហើយបានសង្គ្រោះ ។ ប្រមាណ ជាឆ្នាំ ៣៤ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា មានឮ[ក]សម្លេងមួយមកក្នុងចំណោមបណ្ដាជនទាំងអស់នៃផែនដី នៅលើផ្ទៃនៃដែនដីនេះស្រែកថា៖

២ វេទនា វេទនា [ក]វេទនាដល់ប្រជាជននេះ; វេទនាដល់បណ្ដាជននៅលើផែនដីទាំងមូល លើកលែងតែពួកគេប្រែចិត្ត; ព្រោះអារក្ស [ខ]វាសើច ហើយពួកទេវតារបស់វាអររីករាយ ដោយមកពីការស្លាប់នៃកូនប្រុស និងកូនស្រីទាំងឡាយដ៏ស្រស់ល្អៗរបស់ប្រជាជនយើង; ហើយគឺមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់គេ ទើបពួកគេត្រូវដួល!

៣ មើលចុះ ទីក្រុងសារ៉ាហិមឡាដ៏ធំនោះ យើងបានដុតនឹងភ្លើង និងបណ្ដាជនទាំងឡាយក្នុងនោះផង ។

៤ ហើយមើលចុះ ទីក្រុងមរ៉ូណៃដ៏ធំនោះ យើងបានធ្វើឲ្យលិចទៅក្នុងជំរៅសមុទ្រ រីឯបណ្ដាជននៅទីនោះត្រូវលង់ទឹកស្លាប់ ។

៥ ហើយមើលចុះ ទីក្រុងមរ៉ូណៃហាដ៏ធំនោះ យើងបានគ្របដោយដី ព្រមទាំងបណ្ដាជននៅទីនោះផង ដើម្បីបិទបាំងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេពីមុខយើង ដើម្បីកុំឲ្យឈាមរបស់ពួកព្យាការី និងពួកបរិសុទ្ធ មករកយើងទាស់នឹងពួកគេ ទៀតឡើយ ។

៦ ហើយមើលចុះ ទីក្រុងគីលកាល យើងបានធ្វើឲ្យលិច រីឯបណ្ដាជននៅទីនោះត្រូវកប់ទៅក្នុងជំរៅដី;

៧ មែនហើយ ហើយទីក្រុងអូណៃហា ព្រមទាំងបណ្ដាជននៅទីនោះ ហើយទីក្រុងម៉ូគុម ព្រមទាំងបណ្ដាជននៅទីនោះ ហើយទី ក្រុងយេរូសា[ក]ឡិម ព្រមទាំងបណ្ដាជននៅទីនោះផង; ហើយយើងបានធ្វើឲ្យទឹកឡើងនៅកន្លែងទាំងនោះវិញ ដើម្បីបិទបាំងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេពីមុខយើង ដើម្បីកុំឲ្យឈាមរបស់ពួកព្យាការី និងពួកបរិសុទ្ធឡើងមករកយើងទាស់នឹង ពួកគេទៀតឡើយ ។

៨ ហើយមើលចុះ ទីក្រុងកាឌីអានដៃ និងទីក្រុងកាឌីអុមណា និងទីក្រុងយ៉ាកុប និងទីក្រុងគីមគីមណូ[ក] យើងបានធ្វើឲ្យទីក្រុងអស់ទាំង នេះលិច ហើយបានធ្វើឲ្យមានភ្នំ និងច្រកភ្នំទាំងឡាយនៅកន្លែងទាំងនោះវិញ; ហើយបណ្ដាជននៅទីនោះ យើងបានកប់ទៅក្នុងជំរៅដី ដើម្បីបិទបាំងអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេពីមុខយើង ដើម្បីកុំឲ្យឈាមរបស់ពួកព្យាការី និងពួកបរិសុទ្ធ ឡើង មករកយើងទាស់នឹងពួកគេទៀតឡើយ ។

៩ ហើយមើលចុះ ទីក្រុងយ៉ាកុប៊ូកាតដ៏ធំនោះ ដែលមានប្រជាជនរបស់ស្ដេចយ៉ាកុបរស់នៅ យើងបានធ្វើឲ្យឆេះដោយភ្លើងពីព្រោះ មកពីអំពើបាបទាំងឡាយរបស់ពួកគេ និងអំពើទុច្ចរិតរបស់ពួកគេ ដែលលើសជាងអស់ទាំងអំពើទុច្ចរិតនៃផែនដីទាំងមូល ដោយមកពី អំពើឃាតកម្ម និងការផ្សំគំនិតដ៏[ក]សម្ងាត់ទាំងឡាយរបស់ពួកគេ; ត្បិតពួកគេនេះហើយដែលបាន[ខ]បំផ្លាញសន្តិភាពរបស់រាស្ត្រយើង និងរដ្ឋាភិបាលរបស់ដែនដី; ហេតុដូច្នេះហើយ យើងបានធ្វើឲ្យពួកគេត្រូវឆេះ ដើម្បីបំផ្លាញពួកគេចេញពីមុខយើង ដើម្បីកុំឲ្យឈាមរបស់ ពួកព្យាការី និងពួកបរិសុទ្ធ ឡើងមករកយើងទាស់នឹងពួកគេទៀតឡើយ ។

១០ ហើយមើលចុះ ទីក្រុងលេមិន និងទីក្រុងយ៉ូស និងទីក្រុងកាឌ និងទីក្រុងគិសគូមេន យើងបានធ្វើឲ្យឆេះដោយភ្លើង ព្រមទាំង បណ្ដាជននៅទីនោះផង ដោយមកពីអំពើទុច្ចរិតរបស់ពួកគេក្នុងការបណ្ដេញពួកព្យាការី ហើយចោលដុំថ្មទៅលើពួកអ្នកដែលយើង បានចាត់ឲ្យទៅប្រកាសដល់ពួកគេ អំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ ។

១១ ហើយពីព្រោះពួកគេបានបណ្ដេញពួកអ្នកទាំងនោះចេញ ដែលគ្មានអ្នកណាម្នាក់សុចរិតនៅក្នុងចំណោមពួកគេឡើយ ទើបយើង បានចាត់[ក]ភ្លើងឲ្យចុះទៅបំផ្លាញពួកគេចោល ដើម្បីឲ្យអំពើទុច្ចរិត និងអំពើគួរឲ្យខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ អាច

៩ ១*ក* ១ នីហ្វៃ ១៩:១១;
៣ នីហ្វៃ ១១:១០.
២ *ក* ម៉ាថាយ ១១:២០–២១.
*ខ* ម៉ូសេ ៧:២៦.
៧ *ក* អេសេ. ២៦:១៩.
៨ *ក* ១ នីហ្វៃ ១៩:១១.
៩ *ក* ហេលេ. ៦:១៧–១៨, ២១.
*ខ* ម៉ូសាយ ១២:៨.
១១ *ក* ២ពង្សាវ. ១:៩–១៦;
ហេលេ. ១៣:១៣.

បានបិទបាំងពីមុខ[ខ] យើង ដើម្បីកុំឲ្យឈាមរបស់ពួកព្យាការី និង
ពួកបរិសុទ្ធ ដែលយើងបានចាត់ឲ្យទៅក្នុងចំណោមពួកគេនោះ
ស្រែកមករកយើង ពីក្នុងដី ទាស់នឹងពួកគេឡើយ ។
១២ ហើយមានការបំផ្លិចបំផ្លាញដ៏[ក]ធំជាច្រើន ដែលយើងបាន
ធ្វើឲ្យកើតឡើង នៅលើដែនដីនេះ និងលើប្រជាជននេះ ពីព្រោះ
មកពី អំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ ។
១៣ ឱ អស់អ្នកណាដែលត្រូវបានលើកលែង ពីព្រោះអ្នក
រាល់គ្នាសុចរិតជាងពួកគេអើយ [ក]ឥឡូវនេះ តើអ្នករាល់គ្នាមិនចង់
ត្រឡប់មក រកយើង ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់
អ្នក ហើយប្រែចិត្តជឿ ដើម្បីយើងអាច[ខ]ប្រោសអ្នកឲ្យបានជាទេឬ ?
១៤ មែនហើយ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា បើ
សិនជាអ្នករាល់គ្នា[ក]មករកយើង នោះអ្នករាល់គ្នានឹងមានជីវិត
ដ៏[ខ]នៅអស់កល្ប ជានិច្ច; មើលចុះ ដៃ[គ]នៃសេចក្ដីមេត្តាករុណា
របស់យើងសន្ធឹងទៅរកអ្នក ហើយអស់អ្នកណាដែលមក អ្នក
នោះហើយដែលយើងនឹង ទទួល; ហើយមានពរហើយដល់អ្នក
ណាដែលមករកយើង ។
១៥ មើលចុះ យើងគឺព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃ
ព្រះ ។ យើងបាន[ក]បង្កើតផ្ទៃមេឃ និងផែនដី និងរបស់
សព្វសារពើដែល នៅទីនោះ ។ [ខ]យើងបានគង់នៅជាមួយនឹង
ព្រះវរបិតាចាប់ពីដើមដំបូងមកម្ល៉េះ។ យើងគង់នៅក្នុងព្រះវរបិតា
ហើយព្រះវរបិតាគង់នៅ ក្នុងយើង; ហើយនៅក្នុងយើង
នោះព្រះវរបិតាបានសរសើរដំកើងដល់ព្រះនាមទ្រង់ ។
១៦ យើងបានមករករាស្ត្រយើង តែរាស្ត្រយើងមិនបាន[ក]
ទទួលយើងសោះ ។ ហើយបទគម្ពីរទាំងឡាយដែលស្ដីអំពីការ
យាងមក របស់យើង នោះត្រូវបានបំពេញហើយ ។
១៧ ហើយអស់អ្នកណាដែលបាន[ក]ទទួលយើង អ្នកនោះហើយ
ដែលយើងបាន[ខ]ឲ្យក្លាយទៅជាកូនព្រះ; ហើយដូចគ្នានេះ យើងក៏នឹង
ឲ្យដល់អស់អ្នកណាដែលនឹងជឿដល់នាមរបស់យើង ត្បិតមើលចុះ
ដោយសារយើង ទើបមានសេចក្ដី[ខ]ប្រោសលោះកើតឡើង ហើយ
នៅក្នុងយើង នោះក្រិត្យវិន័យលោកម៉ូសេ[គ]ត្រូវបានបំពេញ ។
១៨ យើងគឺជា[ក]ពន្លឺ ហើយជាជីវិតនៃពិភពលោក ។
យើងគឺជា[ខ]អាលផា និងអូមេកា គឺជាដើម ហើយជាចុង ។
១៩ ហើយអ្នករាល់គ្នាមិនត្រូវថ្វាយដល់យើង នូវការ
ខ្ចាយឈាម[ក]ទៀតទេ; មែនហើយ យញ្ញបូជា និងដង្វាយដុតទាំង
ឡាយរបស់អ្នក នឹងត្រូវចោល ត្បិតយើងមិនទទួលយញ្ញបូជា
ទាំងឡាយរបស់អ្នក និងដង្វាយដុតទាំងឡាយរបស់អ្នកឡើយ ។
២០ ហើយអ្នករាល់គ្នា[ក]ត្រូវថ្វាយដល់យើង នូវចិត្តសង្រេង
និងវិញ្ញាណទន់ទាបវិញ ។ ហើយអស់អ្នកណាដែលមករកយើង
ដោយ មានចិត្តសង្រេង និងវិញ្ញាណទន់ទាប អ្នកនោះហើយ
ដែលយើងនឹងធ្វើ[ខ]បុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណ
បរិសុទ្ធ ដូចគ្នានឹង ពួកសាសន៍លេមិនដែរ ដោយសារសេចក្ដី
ជំនឿរបស់ពួកគេជឿដល់យើង នៅក្នុងពេលនៃការប្រែចិត្តជឿ
របស់គេ នោះត្រូវបានទទួល បុណ្យជ្រមុជដោយភ្លើង និងដោយ
ព្រះវិញ្ញាណបរិសុទ្ធ ហើយពួកគេពុំបានដឹងទេ ។
២១ មើលចុះ យើងបានមកឯលោកិយ ដើម្បីនាំសេចក្ដី
ប្រោសលោះមកដល់ពិភពលោក គឺដើម្បីសង្គ្រោះមនុស្ស
លោកពីបាប ។
២២ ហេតុដូច្នេះហើយ អ្នកណាដែល[ក]ប្រែចិត្ត ហើយមករកយើង
ដូច[ខ]ជាកូនក្មេងតូចម្នាក់ អ្នកនោះហើយដែលយើងនឹងទទួល ត្បិត
នគររបស់ព្រះជារបស់ផងអ្នកនោះ ។ មើលចុះ ជំនួសអ្នក
ទាំងនោះហើយដែលយើងបាន[គ]ប្ដូរជីវិតរបស់យើង ហើយបាន
យកជីវិត យើងឡើងវិញ; ហេតុដូច្នោះហើយ ចូរប្រែចិត្ត ហើយ

១១ *ខ* លោកុ. ៤:១០.
១២ *ក* ៣ នីហ្វៃ ៨:៨–១០, ១៤.
១៣ *ក* ៣ នីហ្វៃ ១០:១២.
*ខ* យេរេ. ៣:២២;
៣ នីហ្វៃ ១៨:៣២.
១៤ *ក* ២ នីហ្វៃ ២៦:២៤–២៨;
អាលម៉ា ៥:៣៣–៣៦.
*ខ* យ៉ូហាន ៣:១៦.
*គ* អាលម៉ា ១៩:៣៦.
១៥ *ក* យ៉ូហាន ១:១–៣;
កូល៉ុស ១:១៦;
ហេរេ. ១៤:១២;
អេធើរ ៤:៧; គ. និង ស. ១៤:៩.
*ខ* យ៉ូហាន ១៧:២០–២២;
៣ នីហ្វៃ ១១:២៧; ១៩:២៣, ២៩.
១៦ *ក* យ៉ូហាន ១:១១;
គ. និង ស. ៦:២១.
១៧ *ក* យ៉ូហាន ១:១២.
ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតា ដែលគង់នៅស្ថានសួគ៌; បុត្រាបុត្រីនៃព្រះ.
*ខ* ស.ប. ប្រោសលោះ, បាន ប្រោសលោះ, សេចក្ដីប្រោសលោះ.
*គ* ៣ នីហ្វៃ ១២:១៩, ៤៦–៤៧;
១៥:២–៩.
១៨ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* វិវរ. ១:៨.
ស.ប. អាលផា និងអូមេកា.
១៩ *ក* អាលម៉ា ៣៤:១៣.
២០ *ក* ៣ នីហ្វៃ ១២:១៩;
គ. និង ស. ២០:៣៧.
*ខ* ២ នីហ្វៃ ៣១:១៣–១៤.
២២ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ម៉ាកុស ១០:១៥;
ម៉ូសាយ ៣:១៩;
៣ នីហ្វៃ ១១:៣៧–៣៨.
*គ* យ៉ូហាន ១០:១៥–១៨.

មករកយើង ឱអ្នករាល់គ្នានៅចុងផែនដីអើយ ហើយចូរបាន សង្គ្រោះចុះ ៕

## ជំពូកទី ១០

*មានការស្ងាត់ស្ងៀមនៅក្នុងផែនដីអស់រយៈពេលជាច្រើនម៉ោង — សម្លេងនៃព្រះគ្រីស្ទសន្យាថានឹងប្រមូលរាស្ត្រទ្រង់ ដូចជាមេមាន់មួយប្រមូលកូនរបស់វា — ផ្នែកនៃប្រជាជនដែលសុចរិតច្រើនជាង ត្រូវបានរក្សាទុក ។ ប្រមាណជាឆ្នាំ ៣៤–៣៥ គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ហេតុការណ៍បានកើតឡើងថា ប្រជាជនទាំងអស់នៅលើផែនដី បានឮការនិយាយទាំងនេះ ហើយបានធ្វើ បន្ទាល់ដល់ការណ៍នេះ ។ ហើយបន្ទាប់ពីការនិយាយទាំងនេះមក មានការស្ងាត់ស្ងៀមនៅលើផែនដី អស់រយៈពេលជាច្រើនម៉ោង ។

២ ឯប្រជាជនមានសេចក្ដីអស្ចារ្យជាខ្លាំង រហូតដល់ពួកគេឈប់យំសោក និងទួញ ព្រោះការបាត់បង់ញាតិសន្ដានរបស់គេដែលត្រូវ ស្លាប់; ហេតុដូច្នេះហើយ មានការស្ងាត់ស្ងៀមនៅអស់ទាំងផែនដី អស់រយៈពេលជាច្រើនម៉ោង ។

៣ ហើយហេតុការណ៍បានកើតឡើងថា មានសម្លេងមួយបានបន្លឺមកកាន់ប្រជាជនទៀត ហើយប្រជាជនទាំងអស់បានស្ដាប់ ហើយបានធ្វើបន្ទាល់ដល់ការណ៍នេះថា៖

៤ ឱអ្នករាល់គ្នា ដែលជាប្រជាជនរបស់ទីក្រុងដ៏ធំទាំងនេះ ដែលត្រូវរលំអើយ ដែលជាពង្សរបស់យ៉ាកុប មែនហើយ ដែលត្រូវជា វង្សអ៊ីស្រាអែល ជាញឹកញាប់យ៉ាងណាទៅ ដែលយើងបានប្រមូលអ្នករាល់គ្នា ដូចជាមេមាន់ប្រមូលកូនរបស់វា នៅក្រោមស្លាបវា ហើយបានចិញ្ចឹមអ្នករាល់គ្នា ។

៥ ហើយជាថ្មីទៀត ជាញឹកញាប់យ៉ាងណាទៅ ដែលយើងបានប្រមូលអ្នករាល់គ្នា ដូចជាមេមាន់ប្រមូលកូនរបស់វា នៅក្រោមស្លាប វា មែនហើយ ឱអ្នករាល់គ្នាដែលជាប្រជាជននៃវង្សអ៊ីស្រាអែល ដែលបានដួលចុះអើយ; មែនហើយ ឱអ្នករាល់គ្នាដែលជាប្រជាជន នៃវង្សអ៊ីស្រាអែលអើយ អ្នករាល់គ្នាដែលអាស្រ័យនៅ ឯក្រុងយេរូសាឡិម គឺអ្នករាល់គ្នានេះដែលបានដួលចុះ; មែនហើយ ជាញឹកញាប់ យ៉ាងណាទៅ ដែលយើងបានប្រមូលអ្នករាល់គ្នា ដូចជាមេមាន់ប្រមូលកូនរបស់វា តែអ្នករាល់គ្នាមិនព្រមសោះ ។

៦ ឱអ្នករាល់គ្នាដែលជាវង្សអ៊ីស្រាអែល ជាអ្នកដែលយើងបានលើកលែងអើយ ជាញឹកញាប់យ៉ាងណាទៅ ដែលយើងបានប្រមូល អ្នករាល់គ្នា ដូចជាមេមាន់ប្រមូលកូនរបស់វា នៅក្រោមស្លាបវា បើសិនជាអ្នករាល់គ្នាព្រមប្រែចិត្ត ហើយត្រឡប់មករកយើង ដោយអស់ពីដួងចិត្ត ។

៧ ប៉ុន្ដែ បើពុំនោះសោតទេ ឱវង្សអ៊ីស្រាអែលអើយ ទីកន្លែងទាំងឡាយដែលអ្នកអាស្រ័យនៅ នឹងក្លាយទៅជាស្ងាត់ច្រៀបរហូតដល់ពេលនៃការបំពេញសេចក្ដីសញ្ញាឲ្យដល់ពួកអយ្យកោអ្នក ។

៨ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា បន្ទាប់ពីប្រជាជនបានឮពាក្យទាំងនេះហើយ មើលចុះ ពួកគេបានចាប់ផ្ដើមយំ ហើយស្រែកទួញទៀត ដោយមកពីការបាត់បង់ញាតិសន្ដាន និងមិត្តភក្ដិរបស់ពួកគេ ។

៩ ហើយហេតុការណ៍បានកើតឡើងថា រយៈពេលបីថ្ងៃបានកន្លងផុតទៅ ។ ហើយគឺនៅពេលព្រឹក ហើយភាពងងឹតក៏រសាត់បាត់ពី ផ្ទៃផែនដី ហើយផែនដីក៏ឈប់កក្រើក ហើយថ្មទាំងឡាយក៏ឈប់ប្រេះ ហើយសម្លេងថ្ងូរដ៏អាណោចអាធមទាំងឡាយក៏ឈប់ ហើយសម្លេងកងរំពងទាំងអស់ក៏អស់ទៅ ។

១០ ហើយផែនដីបានភ្ជាប់មកវិញទៀត ដែលធ្វើឲ្យឈរនឹងនៅ; ហើយការទួញសោក និងការយំ និងការថ្ងូររបស់ប្រជាជន ដែលបាន លើកលែងឲ្យរស់ក៏បានឈប់ទៅ; ហើយការទួញសោករបស់ពួកគេ ត្រូវបានបែរទៅជាសេចក្ដីអំណរវិញ ហើយការសោកសៅរបស់គេ ទៅជាការសរសើរដំកើង និងការអរគុណ ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះរបស់គេ ។

១១ ហើយគឺដល់ត្រឹមនេះហើយ ដែលបទគម្ពីរទាំងឡាយត្រូវបានបំពេញ ដែលបាននិយាយដោយពួកព្យាការី ។

១២ ហើយគឺផ្នែកនៃប្រជាជនដែលសុចរិតច្រើនជាងនោះហើយ ដែលបានសង្គ្រោះ ហើយគឺពួកនេះហើយដែលបានទទួលពួកព្យាការី

**១០** ៤*ក* ៣ នីហ្វៃ ៨:១៤.
*ខ* ១ នីហ្វៃ ១៧:៣.
៥ *ក* ម៉ាថាយ ២៣:៣៧;
គ. និង ស. ៤៣:២៤–២៥.
៦ *ក* ៣ នីហ្វៃ ៩:១៣.
*ខ* ១ សាំយូ. ៧:៣;
ហេលេ. ១៣:១១;
៣ នីហ្វៃ ២៤:៧.
*គ* អេសេ. ៣៦:២៦.
៧ *ក* ស.ប. សេចក្ដីសញ្ញា.
៩ *ក* ៣ នីហ្វៃ ៨:១៩.
១១ *ក* កិច្ចការ ៣:១៨–២០.
១២ *ក* ២ នីហ្វៃ ២៦:៨;
៣ នីហ្វៃ ៩:១៣.

ហើយពុំចោលថ្មទៅលើពួកគេ; ហើយគឺពួកនេះហើយដែល
ពុំបានកំចាយឈាមពួកបរិសុទ្ធ ជាអ្នកដែលបានរួចជីវិត —
១៣ ហើយពួកគេបានរួចជីវិត ហើយមិនត្រូវបានពន្លិច ហើយកប់
ទៅក្នុងដីទេ; ហើយពួកគេមិនត្រូវបានពន្លង់នៅក្នុងជំរៅនៃសមុទ្រ
ទេ; ហើយពួកគេមិនត្រូវបានឆេះដោយភ្លើងទេ ហើយក៏មិនត្រូវ
បានសង្កត់លើ ឬត្រូវកិនដល់ស្លាប់ដែរ; ហើយពួកគេពុំត្រូវ
ក្លួចទៅដោយ ខ្យល់ក្លួចទេ; ហើយពួកគេក៏មិនត្រូវគ្របដណ្ដប់
ទៅដោយចំហាយផ្សែង និងចំហាយនៃសេចក្ដីងងឹតដែរ ។
១៤ ហើយឥឡូវនេះ អស់អ្នកណាដែលអាន សូមឲ្យគេយល់ចុះ;
អ្នកដែលមានគម្ពីរ សូមឲ្យគេ[ក]ពិចារណាមើលបទគម្ពីរ ហើយមើល
ហើយឃើញថា តើអស់ទាំងការស្លាប់ និងការបំផ្លិចបំផ្លាញ
ដោយភ្លើង និងដោយផ្សែង និងដោយព្យុះ និងដោយខ្យល់ក្លួច
និងដោយ [ខ]ផែនដីបើកឡើងទទួលពួកគេ ហើយអស់ការណ៍
ទាំងនេះ តើពុំមែនជាការបំពេញនូវពាក្យព្យាករណ៍ទាំងឡាយ
របស់ពួកព្យាការីបរិសុទ្ធ ជាច្រើននោះទេឬអី ?
១៥ មើលចុះ ខ្ញុំសូមនិយាយទៅកាន់អ្នកថា មែនហើយ
មនុស្សជាច្រើនបានធ្វើបន្ទាល់អំពីការណ៍ទាំងនេះ ក្នុងកាល
ព្រះគ្រីស្ទទ្រង់យាងមក ហើយត្រូវគេ[ក]សម្លាប់ចោល ពីព្រោះ
ពួកគេបានធ្វើបន្ទាល់អំពីការណ៍ទាំងនេះ ។
១៦ មែនហើយ ព្យាការី[ក]ស៊ីណូសបានធ្វើបន្ទាល់អំពីការណ៍
ទាំងនេះ ហើយស៊ីណុកបាននិយាយអំពីការណ៍ទាំងនេះដែរ
ពីព្រោះពួក គេធ្វើបន្ទាល់ជាពិសេសអំពីពួកយើង ដែលជា
សំណល់នៃពូជពួកគេ ។
១៧ មើលចុះ យ៉ាកុប ជាអយ្យកោរបស់យើងផង បានធ្វើ
បន្ទាល់អំពី[ក]សំណល់នៃពូជយ៉ូសែប ។ ហើយមើលចុះ តើយើងរាល់
គ្នាមិន មែនជាសំណល់មួយ នៃពូជយ៉ូសែបទេឬអី ? ហើយ
ការណ៍ទាំងនេះដែលធ្វើបន្ទាល់អំពីយើង តើពុំបានកត់នៅលើផ្ទាំង
លង្ហិន ដែល លីហៃ ជាអយ្យកោរបស់យើង បាន
នាំចេញពីក្រុងយេរូសាឡិមមកទេឬអី ?
១៨ ហើយហេតុការណ៍បានកើតឡើងថា នៅចុងឆ្នាំទីសា
មសិបប្អូន មើលចុះ ខ្ញុំនឹងបង្ហាញដល់អ្នករាល់គ្នាថា ប្រជាជន
នីហ្វៃដែល បានរួចជីវិត ព្រមទាំងពួកអ្នកដែលហៅថា សាសន៍
លេមិនផង ដែលបានរួចជីវិត គឺពួកគេបានទទួលការប្រោសប្រណីដ៏ធំ
ហើយព្រះពរ ដ៏ធំទាំងឡាយបានស្រោចមកលើក្បាលពួកគេ ដរាប
ដល់មិនយូរប៉ុន្មាន បន្ទាប់ពីព្រះគ្រីស្ទទ្រង់[ក]យាងឡើងទៅលើស្ថានសួគ៌
ទ្រង់បាន សម្ដែងរូបអង្គទ្រង់ដ៏ពិតដល់ពួកគេ —
១៩ [ក]បង្ហាញព្រះកាយរបស់ទ្រង់ដល់ពួកគេ ហើយធ្វើការងារបំរើពួក
គេ; ហើយដំណើររឿងអំពីការងារបំរើរបស់ទ្រង់ នឹងមាន
ចែងជាក្រោយ ។ ហេតុដូច្នេះហើយ នៅពេលនេះ ខ្ញុំសូមបញ្ចប់
នូវការនិយាយរបស់ខ្ញុំសិនហើយ ៕

---

ព្រះយេស៊ូវគ្រីស្ទទ្រង់បានបង្ហាញរូបអង្គទ្រង់ដល់ប្រជាជននីហ្វៃ នៅពេលហ្វូងមនុស្សកំពុងតែប្រមូលគ្នា នៅលើដែនដីបរិបូរណ៍ ហើយបានធ្វើការងារបំរើពួកគេ; ហើយដោយរបៀបនេះហើយ ដែលទ្រង់បានបង្ហាញរូបអង្គទ្រង់ដល់ពួកគេ ។

*មានរួមនៅក្នុងជំពូកទី ១១ ទៅ ២៦*

---

## ជំពូកទី ១១

*ព្រះវរបិតាធ្វើបន្ទាល់អំពីព្រះរាជបុត្រាដ៏ជាទីស្រឡាញ់របស់ទ្រង់ — ព្រះគ្រីស្ទទ្រង់លេចមក ហើយប្រកាសប្រាប់អំពីដង្វាយធួនរបស់ទ្រង់ — ប្រជាជនស្ទាបស្នាមរបួសទាំងឡាយ នៅក្នុងបាតព្រះហស្ត និងព្រះបាទាទ្រង់ និងចំហៀង — ពួកគេស្រែកហូសាណា ទ្រង់ដាក់របៀបរបបនៃពិធីបុណ្យជ្រមុជទឹក — វិញ្ញាណនៃការទាស់ទែងគ្នា គឺជារបស់ផងអារក្ស — គោលលទ្ធិនៃព្រះគ្រីស្ទគឺថា មនុស្សលោកត្រូវជឿ ហើយត្រូវទទួលបុណ្យជ្រមុជទឹក ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា មានហ្វូងមនុស្ស
ដ៏ធំមួយ គឺប្រជាជននីហ្វៃបានមករួមប្រជុំ នៅជុំវិញព្រះវិហារបរិសុទ្ធ
ដែលនៅលើដែនដីបរិបូរណ៍; ហើយពួកគេមានការងឿងឆ្ងល់
និងភ្ញាក់ផ្អើលទៅវិញទៅមក ហើយចង្អុលប្រាប់គ្នាទៅវិញទៅមក
នូវការ[ក]ផ្លាស់ប្ដូរដ៏មហិមា និងអស្ចារ្យដែលបានកើតឡើង ។
២ ហើយពួកគេបាននិយាយគ្នាអំពីព្រះយេស៊ូវគ្រីស្ទ ដែល
[ក]ទីសំគាល់បានប្រាប់អំពីការសុគតរបស់ទ្រង់ ។

---

១៤ *ក* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ខ* ១ នីហ្វៃ ១៩:១១; ២ នីហ្វៃ ២៦:៥.
១៥ *ក* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
១៦ *ក* ហេលេ. ៨:១៩–២០.
១៧ *ក* ២ នីហ្វៃ ៣:៤–៥; អាលម៉ា ៤៦:២៤; ៣ នីហ្វៃ ៥:២៣–២៤.
១៨ *ក* កិច្ចការ ១:៩–១១.
១៩ *ក* ៣ នីហ្វៃ ១១:១២–១៥.
**១១** ១*ក* ៣ នីហ្វៃ ៨:១១–១៤.
២ *ក* ហេលេ. ១៤:២០–២៧.

៣ ហើយហេតុការណ៍បានកើតឡើងថា នៅពេលពួក
គេកំពុងតែនិយាយគ្នា អំពីរឿងនេះនៅឡើយ នោះពួកគេបានឮ
[ក]សម្លេងមួយ ហាក់បីដូចជាចេញមកពីលើមេឃ; ហើយពួកគេ
បានក្រឡេកមើលជុំវិញខ្លួន ព្រោះពួកគេពុំយល់នូវសម្លេងដែល
គេបានឮនោះឡើយ; ហើយមិនមែនជាសម្លេងស្អក ឬជាសម្លេង
ខ្លាំងទេ; ក៏ប៉ុន្តែទោះបីជាសម្លេង[ខ]តូចក៏ដោយ គង់តែចាក់ទំលុះទៅ
ក្នុងខ្លួនពួកគេ ដរាបដល់ ធ្វើឲ្យខ្លួនប្រាណរបស់គេទាំងមូល
ញ័រចំប្រប់; មែនហើយ សម្លេងនោះបានជ្រួតជ្រាបទៅក្នុងព្រលឹង
របស់ពួកគេ ហើយធ្វើឲ្យចិត្តរបស់ គេឆេះរោលរាល ។
៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន
ឮសម្លេងនោះទៀត ប៉ុន្តែនៅតែពុំយល់សោះ ។
៥ ហើយពួកគេបានឮសម្លេងនោះជាលើកទីបីទៀត ហើយបាន
ផ្ទៀងត្រចៀកស្ដាប់; ហើយភ្នែកគេសម្លឹងឆ្ពោះទៅសម្លេងនោះ;
ហើយគេបានសម្លឹងពុំដាក់ភ្នែកឆ្ពោះទៅលើមេឃ គឺជាទិសដែល
សម្លេងនោះចេញមក ។
៦ ហើយមើលចុះ នៅលើកទីបី ទើបពួកគេយល់នូវសម្លេង
ដែលគេបានឮ; ហើយសម្លេងនោះនិយាយទៅកាន់ពួកគេថា៖
៧ មើលន៏ បុត្រា[ក]ដ៏ជាទីស្រឡាញ់របស់យើង [ខ]ដែលយើងគាប់
ចិត្តណាស់ ដែលបានដំកើងដល់នាមរបស់យើង — ចូរស្ដាប់
តាមបុត្រាយើងចុះ ។
៨ ហើយហេតុការណ៍បានកើតឡើងថា នៅពេលប្រជាជន
យល់នូវពាក្យទាំងនោះហើយ នោះពួកគេបានសម្លឹងមើលទៅលើ
ឆ្ពោះទៅលើមេឃទៀត; ហើយមើលចុះ [ក]គេបានឃើញ
បុរសម្នាក់យាងចុះមកពីលើមេឃ; ហើយលោកពាក់អាវវែងពណ៌ស;
ហើយទ្រង់ យាងចុះមកឈរនៅកណ្ដាលពួកគេ; ហើយហ្វូង
មនុស្សទាំងមូលបានចោលភ្នែកទៅរកទ្រង់ ហើយគេពុំហ៊ានហើប
មាត់និយាយគ្នា ឡើយ ហើយគេក៏ពុំយល់ថា ការណ៍នេះមាន
ន័យយ៉ាងណាដែរ ត្បិតពួកគេបានស្មានថា នេះជាទេវតាមួយរូប
ដែលបានលេចមកឲ្យ គេឃើញ ។

៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះអង្គទ្រង់
ហុចព្រះហស្តទ្រង់ទៅមុខ ហើយមានព្រះបន្ទូលទៅកាន់
ប្រជាជនថា៖
១០ មើលចុះ យើងគឺព្រះយេស៊ូវគ្រីស្ទ ដែលពួកព្យាការីបាន
ធ្វើបន្ទាល់ថា នឹងយាងមកឯលោកិយ ។
១១ ហើយមើលចុះ យើងជា[ក]ពន្លឺ ហើយជាជីវិតនៃពិភពលោក;
ហើយយើងបានផឹក[ខ]នូវពែងល្វីង ដែលព្រះវរបិតាបានប្រគល់
ដល់យើង ហើយបានដំកើងព្រះវរបិតា ដោយបាន[គ]ទទួល
មកដាក់លើខ្លួន នូវបាបទាំងឡាយនៃមនុស្សលោក យើងបានធ្វើ
ការនេះ ដោយបានស៊ូទ្រាំតាម[ឃ]ព្រះហឫទ័យនៃព្រះវរបិតា
ចំពោះគ្រប់ការណ៍ទាំងអស់ ចាប់តាំងពីដើមដំបូងមក ។
១២ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ នោះហ្វូងមនុស្សទាំងមូលបាន
ដួលទៅលើដី; ត្បិតពួកគេនឹកឃើញថា រឿងនេះ[ក]ត្រូវបាន
ព្យាករទុកជាមុន នៅក្នុងចំណោមពួកគេថា ព្រះគ្រីស្ទនឹងបង្ហាញ
រូបអង្គទ្រង់ ដល់ពួកគេ បន្ទាប់ពីព្រះអង្គយាងឡើងទៅស្ថានសួគ៌ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
មានព្រះបន្ទូលទៅកាន់ពួកគេថា៖
១៤ ចូរក្រោកឡើង ហើយមករកយើងចុះ ដើម្បីអ្នករាល់គ្នា
[ក]អាចលូកដៃមកឯចំហៀងយើង និងដើម្បីអ្នករាល់គ្នាអាច[ខ]ស្ទាប
នូវស្នាម ដែកគោល នៅត្រង់ដៃ និងជើងយើង ដើម្បីឲ្យអ្នករាល់
គ្នាអាចដឹងថា យើងគឺជាព្រះនៃសាសន៍អ៊ីស្រាអែល និងជា[គ]ព្រះ
[ឃ]នៃផែនដីទាំងមូល ហើយត្រូវគេធ្វើគតជំនួសអំពើបាបទាំងឡាយ
នៃមនុស្សលោក ។
១៥ ហើយហេតុការណ៍បានកើតឡើងថា ហ្វូងមនុស្សបាន
ដើរទៅមុខ ហើយបានលូកដៃទៅឯចំហៀងព្រះអង្គ ហើយបាន
ស្ទាបស្នាម ដែកគោលនៅត្រង់ព្រះហស្ត និងព្រះបាទារបស់
ព្រះអង្គ; ហើយពួកគេបានយ៉ាងនេះ គឺបានដើរទៅមុខម្ដងម្នាក់ៗ
រហូតដល់ទាំងអស់ គ្នាបានទៅ ហើយបានឃើញ ដោយ

៣ *ក* ចោទិ. ៤:៣៣–៣៦;
ហេលេ. ៥:២៩–៣៣.
*ខ* ១ ពង្សាវ. ១៩:១១–១៣;
គ. និង ស. ៨៥:៦.
៧ *ក* ម៉ាថាយ ៣:១៧; ១៧:៥;
យ.ស.—ប្រវត្តិ ១:១៧.
*ខ* ៣ នីហ្វៃ ៩:១៥.
៨ *ក* ១ នីហ្វៃ ១២:៦;
២ នីហ្វៃ ២៦:១.
១១ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* ម៉ាថាយ ២៦:៣៩, ៤២.
*គ* យ៉ូហាន ១:២៩;
គ. និង ស. ១៩:១៨–១៩.
*ឃ* ម៉ាកុស ១៤:៣៦;
យ៉ូហាន ៦:៣៨;
គ. និង ស. ១៩:២.
១២ *ក* អាលម៉ា ១៦:២០.
១៤ *ក* យ៉ូហាន ២០:២៧.
*ខ* លូកា ២៤:៣៦–៣៩;
គ. និង ស. ១២៩:២.
*គ* អេសាយ ៤៥:៣;
៣ នីហ្វៃ ១៥:៥.
*ឃ* ១ នីហ្វៃ ១១:៦.

ភ្នែកគេផ្ទាល់ ហើយបានស្ទាបដោយដៃគេផ្ទាល់ និងបានដឹង
យ៉ាងជាក់ច្បាស់ និងបានធ្វើបន្ទាល់ថា គឺជា[ក]ព្រះអង្គមែន ដែល
ពួកព្យាការីបានសរសេរទុកពីមុនថា ទ្រង់នឹងយាងមក ។
១៦ ហើយកាលគេទាំងអស់គ្នាបានដើរទៅមុខអស់ហើយ និង
បានឃើញច្បាស់ដោយខ្លួនគេផ្ទាល់ នោះពួកគេក៏បន្លឺសម្លេងព្រម
គ្នា ថា៖
១៧ ហូសាណា! សូមឲ្យព្រះនាមនៃព្រះដ៏ខ្ពស់បំផុត បាន
ប្រកបដោយព្រះពរ! ហើយពួកគេបានក្រាបចុះនៅទាបព្រះបាទា
នៃ ព្រះយេស៊ូវ ហើយបាន[ក]ថ្វាយបង្គំព្រះអង្គ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានមានព្រះ
បន្ទូលទៅកាន់[ក]នីហ្វៃ (ព្រោះនីហ្វៃនៅក្នុងចំណោមហ្វូងមនុស្ស)
ហើយ ទ្រង់បានបញ្ជាឲ្យលោកចេញមក ។
១៩ ហើយនីហ្វៃក៏ក្រោកឡើង ហើយដើរទៅមុខ និងបានក្រាប
ចំពោះព្រះអម្ចាស់ ហើយបានថើបព្រះបាទាទ្រង់ ។
២០ ហើយទ្រង់បានបញ្ជាឲ្យលោកក្រោកឈរឡើង
ហើយលោកក៏ក្រោកឈរចំពោះព្រះអង្គ ។
២១ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅលោកថា៖
យើងប្រទានដល់អ្នកនូវ[ក]អំណាច ថាអ្នកត្រូវ[ខ]ធ្វើបុណ្យជ្រមុជទឹកឲ្យ
ប្រជាជន នេះ នៅពេលយើងឡើងទៅស្ថានសួគ៌វិញ ។
២២ ហើយទ្រង់បានហៅ[ក]អ្នកផ្សេងទៀត និងបាន
ប្រាប់ទៅគេដូច្នោះដែរ; ហើយទ្រង់បានប្រទានដល់ពួកគេនូវ
អំណាច ដើម្បីធ្វើ បុណ្យជ្រមុជទឹក ។ ហើយទ្រង់មានព្រះ
បន្ទូលទៅកាន់ពួកគេថា៖ អ្នករាល់គ្នាត្រូវធ្វើបុណ្យជ្រមុជទឹកតាម
របៀបនេះ ហើយ[ខ]ពុំត្រូវមាន ការប្រកែកគ្នា នៅក្នុងចំណោមអ្នក
រាល់គ្នាឡើយ ។
២៣ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អស់អ្នកណាដែល
ប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន តាម[ក]ពាក្យរបស់អ្នក
ហើយ មាន[ខ]បំណងចង់ទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង
អ្នកត្រូវធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេតាមរបៀបនេះ — មើលចុះ
អ្នកត្រូវចុះ ទៅ[គ]ឈរក្នុងទឹក ហើយដោយនូវនាមយើង នោះអ្នក
ត្រូវធ្វើបុណ្យជ្រមុជទឹកឲ្យគេ ។
២៤ ហើយឥឡូវនេះ មើលចុះ នេះគឺជាពាក្យទាំងឡាយ ដែល
អ្នកត្រូវនិយាយ ដោយហៅពួកគេតាមឈ្មោះ ហើយនិយាយថា៖
២៥ ដោយមាន[ក]សិទ្ធិអំណាច ដែលបានប្រទានដល់ខ្ញុំពី
ព្រះយេស៊ូវគ្រីស្ទ នោះខ្ញុំធ្វើបុណ្យជ្រមុជទឹកឲ្យអ្នក ដោយនូវ
ព្រះនាមព្រះ វរបិតា និងព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។
អាម៉ែន ។
២៦ ហើយបន្ទាប់មក អ្នកត្រូវ[ក]ពន្លិចគេនៅក្នុងទឹក
ហើយងើបឡើងពីទឹកមកវិញ ។
២៧ ហើយតាមរបៀបនេះហើយដែលអ្នកត្រូវធ្វើបុណ្យជ្រមុជទឹក
ដោយនូវនាមយើង; ត្បិតមើលចុះ យើងប្រាប់អ្នករាល់គ្នា ជា
ប្រាកដថា ព្រះវរបិតា និងព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ
គឺជា[ក]ព្រះតែមួយ; ហើយយើងនៅក្នុងព្រះវរបិតា ហើយព្រះវរបិតា
គង់នៅក្នុងយើង ឯព្រះវរបិតា និងយើង គឺតែមួយ ។
២៨ ហើយស្របតាមអ្វីៗ ដែលយើងបានបញ្ជាដល់អ្នក នោះ
អ្នកត្រូវធ្វើបុណ្យជ្រមុជទឹក ដោយរបៀបនេះហើយ ។ ហើយមិន
ត្រូវ មាន[ក]ការប្រកែកគ្នានៅក្នុងចំណោមអ្នករាល់គ្នា ដូចដែល
ធ្លាប់មានពីមុនមកឡើយ; ហើយក៏មិនត្រូវមានការប្រកែកគ្នា នៅ
ក្នុងចំណោម អ្នករាល់គ្នា អំពីចំណុចទាំងឡាយ នៃគោលលទ្ធិ
របស់យើង ដូចដែលធ្លាប់មានពីមុនមកដែរ ។
២៩ ត្បិតប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អស់
អ្នកណាដែលមានវិញ្ញាណនៃ[ក]ការទាស់ទែងគ្នា គឺពុំមែនជារបស់

១៥ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការលេចមករបស់ព្រះគ្រីស្ទក្រោយពីសុគត.
១៧ *ក* ស.ប. ថ្វាយបង្គំ.
១៨ *ក* ៣ នីហ្វៃ ១:២, ១០.
២១ *ក* ស.ប. អំណាច.
*ខ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
២២ *ក* ១ នីហ្វៃ ១២:៧; ៣ នីហ្វៃ ១២:១.
*ខ* ៣ នីហ្វៃ ១៨:៣៤.
២៣ *ក* ៣ នីហ្វៃ ១២:២.
*ខ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការតម្រូវការទាំងឡាយសំរាប់បុណ្យជ្រមុជទឹក.
*គ* ៣ នីហ្វៃ ១៩:១០–១៣.
២៥ *ក* ម៉ូសាយ ១៨:១៣; គ. និង ស. ២០:៧៣. ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — សិទ្ធិអំណាចត្រឹមត្រូវ.
*ខ* ស.ប. ព្រះ, ក្រុមព្រះ.
២៦ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកដោយការពន្លិច.
២៧ *ក* យ៉ូហាន ១៧:២០–២២; ៣ នីហ្វៃ ២៨:១០; មរមន ៧:៧; គ. និង ស. ២០:២៨.
២៨ *ក* ១ កូរិន. ១:១០; អេភេ. ៤:១១–១៤; គ. និង ស. ៣៨:២៧.
២៩ *ក* ២ ធីម៉ូ. ២:២៣–២៤; ម៉ូសាយ ២៣:១៥. ស.ប. ការទាស់ទែង.

ផង យើងទេ ប៉ុន្តែជារបស់ផង[ខ]អារក្សវិញ ដែលជាបិតានៃការទាស់
ទែងគ្នា ហើយវាចាក់រុកចិត្តមនុស្ស ឲ្យមានកំហឹងទាស់ទែងនឹង
គ្នាទៅ វិញទៅមក ។
៣០ មើលចុះ នេះពុំមែនជាគោលលទ្ធិរបស់យើងទេ ដែល
ចាក់រុកចិត្តមនុស្សឲ្យមានកំហឹងទាស់ទែងនឹងគ្នាទៅវិញទៅមក;
ប៉ុន្តែគោលលទ្ធិរបស់យើង គឺត្រូវលះបង់ការណ៍ទាំងនោះចោលវិញ។
៣១ មើលចុះ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា
យើងនឹងប្រកាសប្រាប់អ្នក [ក]នូវគោលលទ្ធិរបស់យើង ។
៣២ ហើយនេះគឺជា[ក]គោលលទ្ធិរបស់យើង ហើយជា[ខ]គោលលទ្ធិ
ដែលព្រះវរបិតាបានប្រទានដល់យើង; ហើយយើងធ្វើបន្ទាល់អំពី
ព្រះ វរបិតា ហើយព្រះវរបិតាធ្វើបន្ទាល់អំពីយើង ហើយ
[គ]ព្រះវិញ្ញាណបរិសុទ្ធ ធ្វើបន្ទាល់អំពីព្រះវរបិតា និងអំពីយើង;
ហើយយើងធ្វើបន្ទាល់ ថា ព្រះវរបិតាទ្រង់បញ្ជាដល់មនុស្សទាំង
អស់ ទោះនៅទីណាក៏ដោយ ឲ្យប្រែចិត្ត ហើយជឿដល់យើង ។
៣៣ ហើយអស់អ្នកណាដែលជឿដល់យើង ហើយ[ក]ទទួល
បុណ្យជ្រមុជទឹក អ្នកនោះហើយដែលនឹងបាន[ខ]សង្គ្រោះ; ហើយ
ពួកគេនោះ ហើយដែលនឹង[គ]គ្រងនគរព្រះទុកជាមរតក ។
៣៤ ហើយអស់អ្នកណាដែលពុំជឿដល់យើង ហើយពុំទទួល
បុណ្យជ្រមុជទឹកទេ នោះនឹងត្រូវជាប់ទោស ។
៣៥ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា
នេះជាគោលលទ្ធិរបស់យើង ហើយយើងធ្វើបន្ទាល់
អំពីគោលលទ្ធិនេះ ពីព្រះវរបិតា; ហើយអស់អ្នកណាដែល[ក]ជឿ
ដល់យើង ក៏ជឿដល់ព្រះវរបិតាផងដែរ; ហើយចំពោះអ្នក
នោះហើយដែលព្រះវរបិតាធ្វើ បន្ទាល់អំពីយើង ត្បិតទ្រង់នឹង
យាងមករកអ្នកនោះដោយ[ខ]ភ្លើង និងដោយ[គ]ព្រះវិញ្ញាណបរិសុទ្ធ ។
៣៦ ម្ល៉ោះហើយ ព្រះវរបិតានឹងធ្វើបន្ទាល់អំពីយើង ឯព្រះវិញ្ញាណ
បរិសុទ្ធនឹងធ្វើបន្ទាល់ ដល់អ្នកនោះ អំពីព្រះវរបិតា និងអំពីយើង;
ត្បិតព្រះវរបិតា និងយើង និងព្រះវិញ្ញាណបរិសុទ្ធ គឺតែមួយ ។
៣៧ ហើយយើងប្រាប់អ្នករាល់គ្នាទៀតថា អ្នកត្រូវតែប្រែចិត្ត
ហើយ[ក]ក្លាយទៅដូចជាកូនក្មេង ហើយទទួលបុណ្យជ្រមុជទឹក
ដោយនូវ នាមយើង បើពុំនោះសោតទេ អ្នករាល់គ្នានឹង
គ្មានមធ្យោបាយណា ដែលអាចទទួលនូវការណ៍ទាំងនេះបានឡើយ។
៣៨ ហើយយើងប្រាប់អ្នករាល់គ្នាទៀតថា អ្នករាល់គ្នាត្រូវតែ
ប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង ហើយ
ក្លាយ ទៅដូចជាកូនក្មេង បើពុំនោះសោតទេ អ្នករាល់គ្នានឹង
គ្មានមធ្យោបាយណា ដែលអាចគ្រងនគរព្រះទុកជាមរតក
បានឡើយ ។
៣៩ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា នេះ
គឺគោលលទ្ធិរបស់យើង ហើយអស់អ្នកណាដែល[ក]សង់នៅលើគោល
លទ្ធិនេះ គឺសង់នៅលើថ្មដារបស់យើង ហើយ[ខ]ទ្វារទាំងឡាយ
នៃស្ថាននរក នឹងពុំអាចឈ្នះលើអ្នកទាំងនោះបានឡើយ ។
៤០ ហើយអស់អ្នកណាដែលនឹងប្រកាសច្រើនជាង ឬតិចជាងនេះ
ហើយតាំងថា វាជាគោលលទ្ធិរបស់យើង អ្នកនោះគឺមកពី
អារក្សវិញ ហើយពុំបានសង់នៅលើថ្មដារបស់យើងទេ;
តែគេសង់នៅលើ[ក]គ្រឹះខ្សាច់វិញ ហើយទ្វារទាំងឡាយ
នៃស្ថាននរកបើក ចំហចាំទទួលមនុស្សបែបនេះ នៅពេល
ទឹកជន់ឡើង ហើយខ្យល់បក់ប៉ះទៅលើពួកគេ ។
៤១ ដូច្នេះ ចូរអ្នករាល់គ្នាចេញទៅឯប្រជាជននេះ ហើយ
ប្រកាសប្រាប់ពាក្យទាំងឡាយ ដែលយើងបាននិយាយមក គឺទៅ
រហូតដល់ចុងផែនដី ៕

## ជំពូកទី ១២

*ព្រះយេស៊ូវហៅ ហើយប្រគល់ភារកិច្ចឲ្យពួក១២នាក់ — ទ្រង់ថ្លែងទៅកាន់ពួកសាសន៍នីហ្វៃ នូវសេចក្ដីថ្លែងមួយ ប្រហាក់ប្រហែល នឹងបទបង្រៀននៅលើភ្នំ — ទ្រង់ថ្លែងបទជូនពរទាំងឡាយ — បទបង្រៀនរបស់ទ្រង់ ខ្ពស់ជាង ហើយមានអាទិភាព ទៅលើក្រិត្យ វិន័យលោកម៉ូសេ — មនុស្ស*

២៩ *ខ* ក.យ.ស., អេភេ. ៤:២៦; ម៉ូសាយ ២:៣២–៣៣.
៣១ *ក* ២ នីហ្វៃ ៣១:២–២១.
៣២ *ក* ស.ប. គោលលទ្ធិនៃព្រះគ្រីស្ទ.
*ខ* ១ យ៉ូហាន ៥:៧.
*គ* ៣ នីហ្វៃ ២៨:១១; អេធើរ ៥:៤.
៣៣ *ក* ម៉ាកុស ១៦:១៦. ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការចាំបាច់.
*ខ* ស.ប. សេចក្ដីសង្គ្រោះ.
*គ* ស.ប. សិរីល្អនៃសេឡេស្ទាល.
៣៥ *ក* អេធើរ ៤:១២.
*ខ* ៣ នីហ្វៃ ៩:២០; ១២:២.
*គ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៣៧ *ក* ម៉ាកុស ១០:១៥; លូកា ១៨:១៧; ម៉ូសាយ ៣:១៩; ៣ នីហ្វៃ ៩:២២.
៣៩ *ក* ម៉ាថាយ ៧:២៤–២៩; ហេលេ. ៥:១២. ស.ប. ថ្ម.
*ខ* ៣ នីហ្វៃ ១៨:១២–១៣.
៤០ *ក* ៣ នីហ្វៃ ១៤:២៤–២៧.

*លោកត្រូវបានបញ្ជាឲ្យបានល្អឥតខ្ចោះ ដូចជាទ្រង់ និង
ព្រះវរបិតារបស់ទ្រង់ បានល្អឥតខ្ចោះដែរ — ចូរប្រៀបធៀប
នឹងគម្ពីរម៉ាថាយ ៥ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់មាន
ព្រះបន្ទូលទាំងនេះទៅកាន់នីហ្វៃ និងទៅកាន់ពួកអ្នកដែលត្រូវបាន
ហៅហើយ (ឥឡូវនេះ ចំនួនមនុស្សដែលត្រូវបានហៅ ហើយបាន
ទទួលអានុភាព និងសិទ្ធិអំណាច ឲ្យធ្វើបុណ្យជ្រមុជទឹក នោះមាន
១២នាក់) ហើយមើលចុះ ទ្រង់ហុចព្រះហស្តទៅមុខ ឆ្ពោះទៅ
ហ្វូងមនុស្ស ហើយមានព្រះបន្ទូលទៅកាន់ពួកគេថា៖ មាន
ពរហើយ អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នាស្ដាប់បង្គាប់តាម
ពាក្យសំដីនៃពួក១២នាក់នេះ ដែលយើងបានរើសពីចំណោមអ្នក
រាល់គ្នាមក ដើម្បីធ្វើការងារបំរើដល់អ្នក ហើយដើម្បីធ្វើជាពួក
អ្នកបំរើរបស់អ្នក; ហើយចំពោះពួកគេនេះហើយដែលយើងបាន
ប្រទានអំណាច ដើម្បីឲ្យគេអាចធ្វើបុណ្យជ្រមុជឲ្យអ្នករាល់
គ្នាដោយទឹក; ហើយបន្ទាប់ពីអ្នករាល់គ្នាបានទទួលបុណ្យជ្រមុជ
ដោយទឹក ហើយមើលចុះ យើងនឹងធ្វើបុណ្យជ្រមុជឲ្យអ្នក
ដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ; ដូច្នេះ មានពរហើយ
អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នាជឿ ដល់យើង ហើយទទួល
បុណ្យជ្រមុជទឹក ក្រោយពីអ្នករាល់គ្នាបានឃើញយើង ហើយដឹងថា
យើងមានព្រះជន្មរស់នៅ ។
២ ហើយម្យ៉ាងទៀត មានពរលើសលែងទៅទៀត ពួកអ្នក
ដែលនឹងជឿដល់ពាក្យសំដីរបស់អ្នករាល់គ្នា ពីព្រោះអ្នករាល់គ្នា
នឹងធ្វើ ទីបន្ទាល់ថា អ្នករាល់គ្នាបានឃើញយើង ហើយថា អ្នក
រាល់គ្នាដឹងថាយើងមានព្រះជន្មរស់នៅ ។ មែនហើយ មាន
ពរហើយ ពួកអ្នក ដែលនឹងជឿដល់ពាក្យសំដីរបស់អ្នករាល់គ្នា
ហើយចុះទៅក្នុងជំរៅនៃភាពទន់ទាប ហើយទទួលបុណ្យជ្រមុជទឹក
ត្បិតពួកគេនឹងបាន មករកដោយភ្លើង និងដោយព្រះវិញ្ញាណ
បរិសុទ្ធ ហើយនឹងបានទទួលការផ្ដាច់បាបទាំងឡាយរបស់គេ ។
៣ មែនហើយ មានពរហើយ អស់អ្នកដែលមានសេចក្ដី
កំសត់ខាងឯវិញ្ញាណ ដែលបានមករកយើង ត្បិតនគរស្ថានសួគ៌
ជារបស់ផង អ្នកទាំងនោះ។
៤ ហើយម្ដងទៀត មានពរហើយ អស់អ្នកដែលយំសោក ត្បិត
អ្នកទាំងនោះនឹងបានសេចក្ដីកំសាន្តចិត្ត ។
៥ ហើយមានពរហើយ អស់អ្នកដែលស្លូតត្រង់ ត្បិតអ្នក
ទាំងនោះនឹងគ្រងផែនដីជាមរតក ។
៦ ហើយមានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្ដី
សុចរិត ត្បិតអ្នកទាំងនោះនឹងបានពោរពេញ ដោយព្រះវិញ្ញាណ
បរិសុទ្ធ ។
៧ ហើយមានពរហើយ អស់អ្នកដែលមានចិត្តមេត្តាករុណា
ត្បិតអ្នកទាំងនោះ នឹងបានទទួលសេចក្ដីមេត្តាករុណាវិញ ។
៨ ហើយមានពរហើយ អស់អ្នកដែលមានចិត្តបរិសុទ្ធ ត្បិតអ្នក
ទាំងនោះនឹងបានឃើញព្រះ ។
៩ ហើយមានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ត្បិតអ្នក
ទាំងនោះនឹងបានហៅថា ជាកូនរបស់ព្រះ ។
១០ ហើយមានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន
ដោយព្រោះនាមយើង ត្បិតនគរស្ថានសួគ៌ ជារបស់ផងអ្នក
ទាំងនោះ ។
១១ ហើយអ្នករាល់គ្នាមានពរហើយ ក្នុងកាលដែលគេជេរអ្នក
រាល់គ្នា និងបៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងអំពើ
អាក្រក់ ទាស់នឹងអ្នករាល់គ្នា ដោយព្រោះយើង;
១២ ត្បិតអ្នករាល់គ្នានឹងមានអំណរដ៏ធំ ហើយរីករាយ
ជាអតិបរមា ត្បិតអ្នករាល់គ្នានឹងមានរង្វាន់ដ៏ធំ នៅស្ថានសួគ៌;
ត្បិតពួកគេបាន បៀតបៀនពួកព្យាការី ដែលនៅមុនអ្នករាល់គ្នា
បែបដូច្នោះដែរ ។
១៣ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា យើងឲ្យ
អ្នករាល់គ្នា ធ្វើជាអំបិលនៃផែនដី ប៉ុន្តែបើអំបិលបាត់ជាតិប្រៃ
ហើយនោះ តើផែនដីនឹងយកអ្វី ដើម្បីធ្វើឲ្យប្រៃឡើងវិញបាន?

**១២** ១*ក* ៣ នីហ្វៃ ១៣:២៥.
*ខ* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*គ* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
២ *ក* គ. និង ស. ៤៦:១៣–១៤.
ស.ប. ជំនឿ, ជឿ.
*ខ* អេធើរ ៤:១៣–១៥.
*គ* ៣ នីហ្វៃ ១១:៣៥; ១៩:១៣.
៣ *ក* គ. និង ស. ៥៦:១៧–១៨.
ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ម៉ាថាយ ១១:២៨–៣០.
៥ *ក* រ៉ូម ១២:១៦; ម៉ូសាយ ៣:១៩.
ស.ប. ស្លូតបូត, ភាពស្លូតបូត.
*ខ* ស.ប. ផែនដី.
៦ *ក* ២ នីហ្វៃ ៩:៥១; អេណុស ១:៤.
*ខ* យេរេ. ២៩:១៣.
*គ* សុភា. ២១:២១.
៧ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
៨ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
*ខ* គ. និង ស. ៩៣:១.
៩ *ក* ស.ប. អ្នកផ្សះផ្សា.
*ខ* ស.ប. បុត្រាបុត្រីនៃព្រះ.
១០ *ក* គ. និង ស. ១២២:៥–៩.
ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
១២ *ក* អេធើរ ១២:៤.
១៣ *ក* គ. និង ស. ១០១:៣៩–៤០.
ស.ប. អំបិល.

ពេលនោះ អំបិលគ្មានប្រយោជន៍ទៀតសោះ មានតែត្រូវ
បោះបង់ចោលទៅក្រៅ ហើយឲ្យមនុស្សដើរជាន់ឈ្លីប៉ុណ្ណោះ ។
១៤ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា យើងឲ្យ
អ្នករាល់គ្នា ធ្វើជាពន្លឺនៃប្រជាជននេះ ទីក្រុងមួយណាដែល
នៅលើភ្នំ នោះលាក់មិនកំបាំងទេ ។
១៥ មើលចុះ តើមនុស្សអុជទៀន ហើយដាក់នៅក្រោមថាំងឬ ?
ទេ ប៉ុន្តែដាក់នៅលើជើងទៀនវិញ នោះទើបនឹងឲ្យពន្លឺដល់អ្នក
ដែលនៅក្នុងផ្ទះទាំងអស់គ្នា ។
១៦ ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខប្រជាជននេះ
ដើម្បីឲ្យគេអាចឃើញការល្អរបស់អ្នករាល់គ្នា ហើយសរសើរ
ដំកើងដល់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ។
១៧ កុំឲ្យគិតស្មានថា យើងមកដើម្បីបំផ្លាញក្រិត្យវិន័យ
ឬសេចក្ដីព្យាករណ៍នៃពួកព្យាការីចោលឡើយ ។ យើងមិនមែន
មកដើម្បី បំផ្លាញទេ តែដើម្បីបំពេញវិញ ។
១៨ ត្បិតយើងប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងគ្មានបាំងឈើ
មួយ ឬក្បៀសមួយនៅក្នុងក្រិត្យវិន័យ ត្រូវកន្លងបាត់ឡើយ ប៉ុន្តែនៅ
ក្នុងយើង នឹងបានបំពេញសព្វគ្រប់វិញ ។
១៩ ហើយមើលចុះ យើងបានប្រទានដល់អ្នករាល់គ្នា នូវ
ក្រិត្យវិន័យ និងបញ្ញត្តិទាំងឡាយ នៃព្រះវរបិតារបស់យើង
ដើម្បីឲ្យអ្នករាល់ គ្នាជឿដល់យើង ហើយដើម្បីឲ្យអ្នករាល់គ្នា
ប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក ហើយមករកយើង
ដោយចិត្តសង្រេង និងវិញ្ញាណ ទន់ទាប ។ មើលចុះ អ្នករាល់គ្នា
មានព្រះបញ្ញត្តិទាំងឡាយ នៅពីមុខអ្នក ហើយក្រិត្យវិន័យ ត្រូវ
បានបំពេញសព្វគ្រប់ហើយ ។
២០ ដូច្នេះ ចូរមករកយើងចុះ ហើយអ្នករាល់គ្នានឹងបាន
សង្គ្រោះ; ត្បិតយើងប្រាប់អ្នករាល់គ្នាជាប្រាកដថា លើកលែងតែ
អ្នករាល់គ្នា កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ដែល
យើងបានបញ្ជាដល់អ្នកក្នុងពេលនេះ បើពុំនោះសោតទេ អ្នក
រាល់គ្នានឹងគ្មានមធ្យោបាយណា ដែលអាចចូលទៅឯនគរ
ស្ថានសួគ៌បានឡើយ ។
២១ អ្នករាល់គ្នាបានឮសេចក្ដីដែលមនុស្សពីបុរាណបានថ្លែង
ហើយបានចែងទុកនៅចំពោះអ្នករាល់គ្នាដែរថា កុំសម្លាប់មនុស្ស
ឲ្យសោះ ហើយអ្នកណាដែលសម្លាប់មនុស្ស នោះក្រែងត្រូវ
ជាប់ជំនុំជំរះនៃព្រះហើយ ។
២២ ប៉ុន្តែយើងប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាដែលខឹង
នឹងបងប្អូនរបស់ខ្លួន នោះក្រែងត្រូវជាប់ជំនុំជំរះរបស់ទ្រង់ដែរ។
ហើយអ្នកណាដែលស្ដីបងប្អូនខ្លួនថា «អាចោរម្សៀត»
នោះក្រែងត្រូវពួកក្រុមជំនុំធ្វើទោស; ហើយអ្នកណាដែល
និយាយថា «អាឆ្កួត» នោះក្រែងត្រូវធ្លាក់ទៅក្នុងភ្លើងនរក ។
២៣ ដូច្នេះ បើអ្នករាល់គ្នាមករកយើង ឬក៏មានបំណងចង់មក
រកយើង តែចាំថា បងប្អូនរបស់អ្នកមានរឿងអ្វីទាស់នឹងអ្នក —
២៤ ចូរអ្នកទៅរកបងប្អូនអ្នក ហើយផ្សះផ្សាជាមួយនឹងបងប្អូន
អ្នកជាមុនសិន រួចហើយ ទើបមករកយើង ដោយអស់ពីដួងចិត្ត
ទើប យើងនឹងទទួលអ្នក ។
២៥ ចូរអ្នករាល់គ្នាព្រមព្រៀង ជាមួយនឹងអ្នកដើមចោទ
អ្នកជាប្រញាប់ ដែលអ្នកកំពុងដើរតាមផ្លូវជាមួយគ្នា
ក្រែងគេនឹងចាប់អ្នកក្នុង ពេលណាមួយ ហើយអ្នកនឹងត្រូវ
គេដាក់ទៅក្នុងគុក ។
២៦ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នក
នឹងចេញពីទីនោះពុំរួចឡើយ លុះត្រាតែអ្នកបង់មួយសិនណាញ
ជាមុនសិន ហើយនៅពេលអ្នកនៅក្នុងគុក តើអ្នកអាចសងគេតែ
មួយសិនណាញបានឬទេ ? ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជា
ប្រាកដថា ទេ ។
២៧ មើលចុះ មនុស្សពីបុរាណបានចែងទុកមកថា កុំឲ្យផិតឲ្យ
សោះ ។
២៨ ប៉ុន្តែយើងប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាគ្រាន់តែ
ក្រឡេកឃើញស្ត្រី ហើយមានដំរេកសំរើបចង់បាន នោះឈ្មោះថា
បានប្រព្រឹត្តសេចក្ដីផិត នៅក្នុងចិត្តខ្លួនហើយ ។
២៩ មើលចុះ យើងឲ្យបញ្ញត្តិមួយដល់អ្នករាល់គ្នាថា ចូរកុំឲ្យ
អ្នករាល់គ្នាទ្រាំបណ្ដោយ ឲ្យអ្វីមួយនៃសេចក្ដីទាំងនេះ ចូលទៅ
ក្នុងចិត្ត របស់អ្នកបានឡើយ ។
៣០ ត្បិតអី ជាការប្រសើរ បើអ្នករាល់គ្នាត្រូវបដិសេធខ្លួន
នូវអំពើទាំងនេះ ហើយលើកលីឈើឆ្កាង ជាជាងអ្នករាល់គ្នាត្រូវ
បោះ ចោលទៅក្នុងស្ថាននរក ។

---

១៥ *ក* លូកា ៨:១៦.
១៦ *ក* ៣ នីហ្វៃ ១៨:២៤.
១៨ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
១៩ *ក* ៣ នីហ្វៃ ៩:២០.
ស.ប. ចិត្តសង្រេង.
*ខ* ៣ នីហ្វៃ ៩:១៧.
២១ *ក* និក្ខ. ២០:១៣;
ម៉ូសាយ ១៣:២១;
គ. និង ស. ៤២:១៨.
២៤ *ក* ស.ប. អត់ទោស, អភ័យទោស.
២៦ *ក* អាលម៉ា ១១:៣.
២៧ *ក* ២ នីហ្វៃ ៩:៣៦; គ. និង ស. ៥៩:៦.
២៨ *ក* គ. និង ស. ៤២:២៣.
ស.ប. សំរេកស្រើប.
២៩ *ក* កិច្ចការ ៨:២២.
៣០ *ក* ម៉ាថាយ ១០:៣៨; ១៦:២៤;
លូកា ៩:២៣.

៣១ សេចក្ដីបានចែងទុកមកថា អ្នកណាដែលចង់លែងប្រពន្ធ
នោះមានតែឲ្យ[ក]សំបុត្រលះលែងដល់នាង ។
៣២ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណា
ដែល[ក]លែងប្រពន្ធ ដោយពុំមែនមកពីប្រពន្ធ[ខ]ផិតប្ដី នោះឈ្មោះថា
បានធ្វើឲ្យនាង[គ]ប្រព្រឹត្តអំពើកំផិត; ហើយបើនរណាយកស្រី
ដែលប្ដីលែងធ្វើជាប្រពន្ធ អ្នកនោះបានប្រព្រឹត្តសេចក្ដីកំផិតដែរ ។
៣៣ ហើយម៉្យាងទៀត មានសេចក្ដីចែងទុកមកថា កុំឲ្យស្បថ
កុហកឡើយ ប៉ុន្តែត្រូវធ្វើឲ្យសំរេចតាមគ្រប់ទាំង[ក]សេចក្ដីដែលស្បថ
នឹងព្រះអម្ចាស់;
៣៤ ប៉ុន្តែប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា កុំឲ្យ
[ក]ស្បថឲ្យសោះ; ទោះនឹងស្ថានសួគ៌ក្ដី ព្រោះជាបល្ល័ង្កនៃព្រះ;
៣៥ ទោះនឹងផែនដីក្ដី ព្រោះជាកំណល់កល់ព្រះបាទទ្រង់;
៣៦ ក៏កុំឲ្យស្បថនឹងក្បាលអ្នកដែរ ពីព្រោះអ្នកពុំអាចធ្វើ
សក់មួយសរសៃ គ្រឡប់ទៅជាស ឬខ្មៅបានឡើយ;
៣៧ ប៉ុន្តែ ត្រូវចេញសំដីថា មែនមែន; ទេទេ ប៉ុណ្ណោះ;
ព្រោះសេចក្ដីណា ដែលលើសអំពីនោះទៅ គឺជាអាក្រក់ ។
៣៨ ហើយមើលចុះ សេចក្ដីបានចែងទុកមកថា [ក]ភ្នែកឲ្យធួននឹង
ភ្នែក ហើយធ្មេញឲ្យធួននឹងធ្មេញ ។
៣៩ ប៉ុន្តែយើងប្រាប់អ្នករាល់គ្នាថា កុំឲ្យ[ក]តតាំងនឹងអំពើ
អាក្រក់ឡើយ ប៉ុន្តែបើអ្នកណាទះកំផ្លៀងស្ដាំនៃអ្នក នោះត្រូវ
[ខ]បែរកំផ្លៀងម្ខាង ទៅឲ្យទៀត;
៤០ ហើយបើអ្នកណាប្ដឹងយកអាវខ្លី របស់អ្នកទៅដល់ច្បាប់
នោះត្រូវបើកឲ្យគេយកទាំងអាវវែងរបស់អ្នកផង;
៤១ ហើយបើអ្នកណាបង្ខំអ្នកឲ្យទៅអស់មួយយោជន៍
នោះចូរទៅជាមួយនឹងគេដល់ពីរយោជន៍ផង ។
៤២ ចូរ[ក]ឲ្យដល់អ្នកណាដែលសូម ហើយកុំឲ្យគេចចេញពីអ្នក
ណាដែលចង់ខ្ចីអ្នកឡើយ ។
៤៣ ហើយមើលចុះ សេចក្ដីបានចែងទុកមកដែរថា ចូរស្រឡាញ់
អ្នកជិតខាងឯង តែស្អប់ខ្មាំងសត្រូវឯងវិញ;
៤៤ ប៉ុន្តែមើលចុះ យើងប្រាប់អ្នករាល់គ្នាថា ត្រូវស្រឡាញ់[ក]ពួក
ខ្មាំងសត្រូវ ត្រូវឲ្យពរដល់អ្នកណា ដែលប្រទេចផ្ដាសាអ្នក ត្រូវ
ប្រ ព្រឹត្តល្អនឹងអ្នកណា ដែលស្អប់អ្នករាល់គ្នា ហើយត្រូវ
[ខ]អធិស្ឋានឲ្យអ្នកណាដែល ធ្វើទុក្ខបៀតបៀន ដល់អ្នករាល់គ្នាវិញ;
៤៥ ដើម្បីឲ្យអ្នករាល់គ្នាបានធ្វើជាកូន របស់ព្រះវរបិតានៃអ្នក
រាល់គ្នា ដែលគង់នៅស្ថានសួគ៌; ព្រោះទ្រង់ធ្វើឲ្យថ្ងៃរបស់ទ្រង់
រះឡើង បំភ្លឺទាំងមនុស្សអាក្រក់ និងមនុស្សល្អ ។
៤៦ ដូច្នេះ សេចក្ដីទាំងឡាយនៃមនុស្សពីបុរាណ ដែលនៅក្នុង
ក្រិត្យវិន័យ នោះត្រូវបានបំពេញសព្វគ្រប់នៅក្នុងយើង ។
៤៧ សេចក្ដីទាំងឡាយ[ក]ពីបុរាណ បានចប់សព្វគ្រប់ ហើយអ្វី
ៗទាំងអស់បានក្លាយទៅជាថ្មី ។
៤៨ ដូច្នេះ យើងចង់ឲ្យអ្នករាល់គ្នា បាន[ក]ល្អឥតខ្ចោះដូចជាយើង
ឬដូចជាព្រះវរបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌
ទ្រង់ល្អឥតខ្ចោះដែរ ៕

## ជំពូកទី ១៣

*ព្រះយេស៊ូវបង្រៀនពួកសាសន៍នីហ្វៃ នូវការអធិស្ឋានដល់ព្រះ
អម្ចាស់ — ពួកគេត្រូវប្រមូលទ្រព្យសម្បត្តិ ទុកនៅស្ថានសួគ៌
— ពួកដប់ពីរ នាក់ត្រូវបានបញ្ជាកុំឲ្យគិតដល់វត្ថុទាំងឡាយ
ខាងសាច់ឈាម នៅពេលពួកគេធ្វើការងារបំរើ —
ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៦ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ប្រាកដមែន យើងប្រាប់ជាប្រាកដថា យើងចង់ឲ្យអ្នករាល់គ្នា[ក]ធ្វើ
ទានដល់អ្នកក្រខ្សត់ ប៉ុន្តែ ចូរប្រយ័ត្ន កុំឲ្យអ្នករាល់គ្នាធ្វើទាននៅមុខ
មនុស្ស ឲ្យតែគេឃើញឡើយ; បើធ្វើដូច្នោះ នោះអ្នករាល់គ្នា
គ្មានរង្វាន់ នៅនឹងព្រះវរបិតានៃអ្នក ដែលទ្រង់
គង់នៅស្ថានសួគ៌ទេ ។
២ ដូច្នេះ កាលណាអ្នកធ្វើទាន នោះកុំឲ្យផ្លុំត្រែនៅមុខអ្នក
ដូចពួកមានពុត ដែលប្រព្រឹត្តនៅក្នុងសាលាប្រជុំ ហើយតាមផ្លូវ
ដើម្បីឲ្យបានមនុស្សលោក[ក]សរសើរខ្លួននោះឡើយ ។ យើងប្រាប់
អ្នករាល់គ្នាជាប្រាកដថា គេបានរង្វាន់គេហើយ ។

៣១ *ក* ស.ប. ការលះលែងគ្នា.
៣២ *ក* ម៉ាកុស ១០:១១–១២.
*ខ* ស.ប. អំពើសហាយស្មន់.
*គ* ស.ប. អំពើកំផិត.
៣៣ *ក* ស.ប. សម្បថ.
៣៤ *ក* ស.ប. សេចក្ដីមើលងាយ.
៣៨ *ក* លេវី. ២៤:២០.
៣៩ *ក* ៣ នីហ្វៃ ៦:១៣;
៤ នីហ្វៃ ១:៣៤;
គ. និង ស. ៩៨:២៣–៣២.
*ខ* ស.ប. សេចក្ដីអត់ធន់.
៤២ *ក* យ៉ាកុប ២:១៧–១៩;
ម៉ូសាយ ៤:២២–២៦.
៤៤ *ក* សុភា. ២៤:១៧;
អាលម៉ា ៤៨:២៣.
*ខ* កិច្ចការ ៧:៥៩–៦០.
៤៧ *ក* ៣ នីហ្វៃ ១៥:២, ៧;
គ. និង ស. ២២:១.
៤៨ *ក* ម៉ាថាយ ៥:៤៨;
៣ នីហ្វៃ ២៧:២៧.
ស.ប. ល្អឥតខ្ចោះ.
**១៣** ១*ក* ស.ប. ទាន, ការដាក់ទាន.
២ *ក* គ. និង ស. ១២១:៣៤–៣៥.

៣ ប៉ុន្តែ កាលណាអ្នកធ្វើទាន នោះកុំឲ្យដៃឆ្វេងដឹងការដែលដៃស្តាំធ្វើឡើយ;

៤ ដើម្បីឲ្យទានរបស់អ្នកបានស្ងាត់កំបាំង នោះព្រះវរបិតានៃអ្នក ដែលទ្រង់ទតឃើញក្នុងទីសម្ងាត់ ទ្រង់នឹងប្រទានរង្វាន់ដល់អ្នកនៅទីប្រចក្សច្បាស់ ។

៥ ហើយកាលណាអ្នកអធិស្ឋាន កុំឲ្យធ្វើដូចមនុស្សមានពុតដែលចូលចិត្តឈរអធិស្ឋាននៅក្នុងសាលាប្រជុំ ហើយនៅជ្រុងផ្លូវ ឲ្យមនុស្សលោកឃើញនោះឡើយ ។ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា គេបានរង្វាន់គេហើយ ។

៦ តែឯអ្នក កាលណាអធិស្ឋាន នោះត្រូវឲ្យចូលទៅក្នុងបន្ទប់ ហើយបិទទ្វារ រួចអធិស្ឋានដល់ព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅទី លាក់កំបាំងចុះ; នោះព្រះវរបិតានៃអ្នក ដែលទតឃើញក្នុងទីលាក់កំបាំង ទ្រង់នឹងប្រទានរង្វាន់ ដល់អ្នកនៅទីប្រចក្សច្បាស់។

៧ តែកាលណាអ្នកអធិស្ឋាន នោះកុំឲ្យពោលពាក្យឥតប្រយោជន៍ផ្ទួនៗ ដូចពួកសាសន៍ដទៃឡើយ ត្បិតគេស្មានថាព្រះទ្រង់នឹង ស្តាប់គេ ដោយគេពោលពាក្យជាច្រើន ។

៨ ដូច្នេះ កុំឲ្យអ្នករាល់គ្នាធ្វើដូចគេឡើយ ត្បិតព្រះវរបិតានៃអ្នក ទ្រង់ជ្រាបនូវរបស់អ្វីដែលអ្នកត្រូវការ មុនដែលអ្នកសូមផង ។

៩ ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះវិញថា៖ ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ ។

១០ សូមឲ្យព្រះហឫទ័យទ្រង់ បានសំរេចនៅផែនដីដូចនៅស្ថានសួគ៌ដែរ ។

១១ ហើយសូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោស ដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ ។

១២ ហើយសូមកុំនាំយើងខ្ញុំ ទៅក្នុងសេចក្តីល្បួងឡើយ តែសូមប្រោសឲ្យយើងខ្ញុំ រួចផុតពីសេចក្តីអាក្រក់វិញ ។

១៣ ត្បិតរាជ្យ ព្រះចេស្តា និងសិរីល្អជារបស់ផងទ្រង់នៅអស់កល្បជានិច្ច ។ អាម៉ែន ។

១៤ ត្បិតបើអ្នករាល់គ្នា អត់ទោសចំពោះការរំលងច្បាប់ដែលមនុស្សលោកប្រព្រឹត្តធ្វើ នោះព្រះវរបិតានៃអ្នក ដែលគង់នៅស្ថាន សួគ៌ ទ្រង់នឹងអត់ទោសឲ្យអ្នករាល់គ្នាដែរ;

១៥ តែបើអ្នករាល់គ្នា មិនអត់ទោសចំពោះការរំលងច្បាប់ឲ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិនអត់ទោស ចំពោះការរំលង ច្បាប់ ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ ។

១៦ ជាម្យ៉ាងទៀត កាលណាអ្នករាល់គ្នាតម នោះកុំឲ្យធ្វើទឹកមុខក្រៀម ដូចជាមនុស្សមានពុតឡើយ ត្បិតគេក្លែងទឹកមុខស្រងូត ឲ្យមនុស្សលោកឃើញថាគេតម ។ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា គេបានរង្វាន់គេហើយ ។

១៧ តែឯអ្នក កាលណាអ្នកតម នោះចូរឲ្យលាបគ្រឿងក្រអូបនៅលើក្បាល ហើយលប់មុខចេញ;

១៨ ដើម្បីកុំឲ្យមនុស្សលោកឃើញថា អ្នកតមឡើយ គឺឲ្យព្រះវរបិតានៃអ្នក ដែលគង់នៅទីលាក់កំបាំង បានឃើញវិញ; នោះព្រះ វរបិតានៃអ្នក ដែលទ្រង់ទតឃើញ នៅទីលាក់កំបាំង ទ្រង់នឹងប្រទានរង្វាន់ដល់អ្នក នៅទីប្រចក្សច្បាស់ ។

១៩ កុំឲ្យប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួននៅផែនដី ជាកន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះ ឡើយ;

២០ តែត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួននៅឯស្ថានសួគ៌វិញ ដែលជាកន្លែងគ្មានកន្លាត ឬច្រែះស៊ីបំផ្លាញឡើយ ក៏គ្មានចោរទំលុះ ឬប្លន់ផង ។

២១ ពីព្រោះសម្បត្តិទ្រព្យរបស់អ្នក ស្ថិតនៅកន្លែងណា នោះចិត្តអ្នកក៏នឹងនៅកន្លែងនោះដែរ ។

២២ ឯពន្លឺរបស់រូបកាយ គឺជាភ្នែក; ដូច្នេះបើភ្នែកអ្នកស្មោះស្ម័គ្រទាំងស្រុង នោះរូបកាយអ្នកទាំងមូល នឹងបានពោរពេញដោយពន្លឺ ។

២៣ តែបើភ្នែកអ្នកអាក្រក់វិញ នោះរូបកាយអ្នកទាំងមូល នឹងបានពោរពេញដោយភាពងងឹតសូន្យ ។ ដូច្នេះ បើពន្លឺដែលនៅក្នុង ខ្លួនអ្នក ជាសេចក្តីងងឹតហើយ ចុះសេចក្តីងងឹតនោះនឹងបានជាខ្លាំងអម្បាលម៉ានទៅហ្ន៎ ។

២៤ គ្មានអ្នកណាអាចនឹងបំរើចៅហ្វាយពីរនាក់បានទេ; ត្បិតអ្នកនោះនឹងស្អប់មួយ ហើយស្រឡាញ់មួយ ឬស្មោះត្រង់នឹងមួយ ហើយមើលងាយមួយ ។ អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ និងទ្រព្យសម្បត្តិផងបានទេ ។

---

៥ *ក* ស.ប. ការអធិស្ឋាន.
៨ *ក* គ. និង ស. ៨៤:៨៣.
៩ *ក* ម៉ាថាយ ៦:៩–១៣.
*ខ* ស.ប. ការអធិស្ឋាន.
*គ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
១២ *ក* ក.យ.ស., ម៉ាថាយ ៦:១៤.
១៤ *ក* ម៉ូសាយ ២៦:៣០–៣១;
គ. និង ស. ៦៤:៩.
ស.ប. អត់ទោស, អភ័យទោស.
១៦ *ក* អេសាយ ៥៨:៥–៧.
ស.ប. តម, តំណម.
១៨ *ក* គ. និង ស. ៣៨:៧.
២០ *ក* ហេលេ. ៥:៨; ៨:២៥.
២២ *ក* គ. និង ស. ៨៨:៦៧.
២៤ *ក* ១ សាំយូ. ៧:៣.

២៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ នោះទ្រង់បានទតមើល ទៅពួក១២នាក់ ដែលទ្រង់បានរើស ហើយមានព្រះបន្ទូលទៅកាន់ពួកគេថា៖ ចូរចងចាំនូវពាក្យ ដែលយើងបាននិយាយនេះចុះ ។ ត្បិតមើលចុះ អ្នករាល់គ្នាជាអ្នកដែលយើងបានរើស ដើម្បីធ្វើការងារបំរើដល់ប្រជាជននេះ ។ ដូច្នេះ យើងប្រាប់អ្នករាល់គ្នាថា កុំឲ្យខ្វល់ខ្វាយនឹងជីវិត ដែលនឹងបរិភោគអ្វី; ឬនឹងរូបកាយ ដែលនឹងស្លៀកពាក់អ្វីនោះឡើយ ។ ឯជីវិត តើមិនវិសេសជាងចំណីអាហារ ហើយរូបកាយតើមិនវិសេសជាងសំលៀកបំពាក់ទេឬអី ?

២៦ មើលចុះ ចូរពិចារណាពីសត្វស្លាបនៅលើអាកាស វាមិនសាបព្រោះ មិនច្រូតកាត់ ឬប្រមូលដាក់ក្នុងជង្រុកផង; តែព្រះវរបិតា នៃអ្នក ដែលគង់នៅស្ថានសួគ៌ទ្រង់ចិញ្ចឹមវា ។ ឯអ្នករាល់គ្នា តើគ្មានតម្លៃលើសជាងសត្វទាំងនោះទេឬអី ?

២៧ ចុះនៅក្នុងពួកអ្នករាល់គ្នា តើមានអ្នកឯណា ដែលអាចនឹងបន្ថែមកំពស់ខ្លួនមួយហត្ថ ដោយសារសេចក្ដីខ្វល់ខ្វាយបានឬទេ ?

២៨ ហើយពីដំណើរសំលៀកបំពាក់ តើអ្នករាល់គ្នាខំខ្វល់ខ្វាយធ្វើអី ? ចូររំពឹងគិតតែផ្កាឈូកនៅក្នុងបឹងដែលវាដុះយ៉ាងដូចម្ដេច; គឺវាមិននឿយហត់នឹងធ្វើការឬស្រាវរវៃទេ;

២៩ តែយើងប្រាប់អ្នករាល់គ្នាថា សូម្បីតែហ្លួងសាឡូម៉ូន ក្នុងគ្រាដែលមានគ្រប់ទាំងសេចក្ដីរុងរឿងរបស់ទ្រង់ នោះទ្រង់មិនបានតែង អង្គដូចជាផ្កាមួយនោះផង ។

៣០ ហេតុដូច្នោះហើយ រឹងតិណជាតិ ដែលដុះនៅវាលក្នុងថ្ងៃនេះ ហើយថ្ងៃស្អែក ត្រូវគេដុតក្នុងជើងក្រាន បើព្រះទ្រង់តុបតែងស្មៅ យ៉ាងដូច្នោះ នោះតើទ្រង់មិនតុបតែងឲ្យអ្នករាល់គ្នា លើសជាងទៅទៀតទេឬអី បើអ្នករាល់គ្នាមិនមែនជាមនុស្សមានសេចក្ដីជំនឿតិច ?

៣១ ដូច្នេះ កុំឲ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី ឬស្លៀកពាក់អ្វីនោះឡើយ ។

៣២ ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយថា អ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ ។

៣៣ ចូរអ្នកស្វែងរកនគរនៃព្រះ និងសេចក្ដីសុចរិតរបស់ទ្រង់ជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទាន មកអ្នករាល់គ្នាថែម ទៀតផង ។

៣៤ ដូច្នេះ កុំឲ្យខ្វល់ខ្វាយនឹងថ្ងៃស្អែកឡើយ ពីព្រោះថ្ងៃស្អែកនឹងខ្វល់ខ្វាយ ចំពោះការរបស់ថ្ងៃនោះឯង ។ សេចក្ដីលំបាកនៅថ្ងៃ ណា នោះគឺល្មមត្រឹមថ្ងៃនោះហើយ ៕

## ជំពូកទី ១៤

*ព្រះយេស៊ូវបញ្ជាថា៖ ចូរកុំថ្កោលទោសឡើយ; ចូរសូមដល់ព្រះ; ចូរប្រយ័ត្នដល់ពួកព្យាការីក្លែងក្លាយ — ទ្រង់សន្យាសេចក្ដីសង្គ្រោះ ដល់អស់អ្នកណា ដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតា — ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៧ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលនូវពាក្យទាំងនោះហើយ នោះទ្រង់បែរឆ្ពោះទៅហ្វូងមនុស្សទៀត ហើយបានបើកព្រះឱសទៅកាន់ពួកគេទៀតថា៖ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា កុំឲ្យថ្កោលទោសឡើយ ដើម្បីកុំឲ្យអ្នកទទួលការថ្កោសទោស ។

២ ត្បិតដោយនូវការថ្កោលទោសណា ដែលអ្នករាល់គ្នាថ្កោលទោស នោះអ្នករាល់គ្នានឹងត្រូវថ្កោលទោសវិញយ៉ាងនោះដែរ; ហើយដោយនូវរង្វាល់ណា ដែលអ្នករាល់គ្នាវាល់ នោះនឹងត្រូវវាល់ឲ្យអ្នករាល់គ្នាវិញយ៉ាងនោះដែរ ។

៣ ហើយហេតុអ្វីបានជាអ្នកមើលឃើញកំទេច ដែលនៅក្នុងភ្នែករបស់បងប្អូនអ្នក តែមិនឃើញធ្នឹម ដែលនៅក្នុងភ្នែករបស់ខ្លួនសោះដូច្នេះ ?

៤ ឬធ្វើដូចម្ដេចឲ្យអ្នកនិយាយនឹងបងប្អូនថា ចូរឲ្យខ្ញុំយកកំទេចពីភ្នែកអ្នកចេញ — ប៉ុន្តែមើលចុះ មានធ្នឹមនៅក្នុងភ្នែកខ្លួនអ្នកវិញ ។

៥ អ្នកមានពុតអើយ ចូរយកធ្នឹមពីភ្នែករបស់ខ្លួនចេញជាមុនសិន; នោះទើបនឹងបានឃើញច្បាស់ អាចនឹងយកកំទេចចេញពីភ្នែករបស់បងប្អូនអ្នកបានដែរ ។

៦ កុំឲ្យរបស់បរិសុទ្ធដល់ឆ្កែ ឬបោះកែវមុក្ដារបស់ខ្លួននៅមុខជ្រូកឡើយ ក្រែងវាជាន់ឈ្លី រួចត្រឡប់ស្ទុះ មកខេះអ្នកវិញ ។

២៥ *ក* ស.ប. ធ្វើការងារបំរើ.
*ខ* អាលម៉ា ៣១:៣៧–៣៨; គ. និង ស. ៨៤:៧៩–៨៥.
៣៣ *ក* លូកា ១២:៣១.
១៤ ១*ក* គ.ឃ.ស., ម៉ាថាយ ៧:១–២; យ៉ូហាន ៧:២៤.
២ *ក* មរមន ៨:១៩.
៥ *ក* យ៉ូហាន ៨:៣–១១.
៦ *ក* ស.ប. បរិសុទ្ធ.

៧ ចូរ[ក]សូម នោះតែងនឹងឲ្យមកអ្នក; ចូររក នោះអ្នកតែង
នឹងឃើញ; ចូរគោះ នោះតែងនឹងបើកឲ្យអ្នក ។

៨ ត្បិតអស់អ្នកណាដែលសូម នោះរមែងបាន; ហើយអ្នកណា
ដែលរក នោះរមែងឃើញ; ហើយនឹងបើកឲ្យអ្នកណា ដែល
គោះដែរ ។

៩ ក្នុងពួកអ្នករាល់គ្នា បើកូនសុំនំបុ័ង តើមានអ្នកណានឹងឲ្យថ្ម
ដល់វា ?

១០ ឬបើវាសុំត្រី តើនឹងឲ្យពស់វិញឬអី ?

១១ ចុះបើអ្នករាល់គ្នាដែលអាក្រក់ អ្នកចេះឲ្យរបស់ល្អដល់កូនខ្លួន
ដូច្នេះ នោះចំណង់បើព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅស្ថាន
សួគ៌ ទ្រង់នឹងប្រទានរបស់ល្អ មកអស់អ្នកដែលសូម តើជាង
អម្បាលម៉ានទៅទៀត ?

១២ ដូច្នេះ អស់ទាំងការអ្វី ដែលអ្នករាល់គ្នាចង់ឲ្យមនុស្ស
លោកប្រព្រឹត្តនឹងខ្លួន នោះ[ក]ត្រូវឲ្យអ្នកប្រព្រឹត្តនឹងគេដូច្នោះដែរ
ត្បិតនេះ ឯងជាក្រិត្យវិន័យ ហើយជាសេចក្ដីព្យាករណ៍របស់
ពួកព្យាការី ។

១៣ ចូរឲ្យចូលតាមទ្វារ[ក]ចង្អៀត; ត្បិតទ្វារដែលនាំទៅឯសេចក្ដី
បំផ្លិចបំផ្លាញ នោះ[ខ]ធំហើយទូលាយផង ក៏មានមនុស្សជាច្រើន
ដែលចូលតាមទ្វារនោះ ។

១៤ តែឯ[ក]ទ្វារដែលនាំទៅឯជីវិត នោះតូចហើយ[ខ]ចង្អៀតវិញ
ក៏មានមនុស្ស[គ]តិចណាស់ ដែលរកផ្លូវនោះឃើញ ។

១៥ ចូរប្រយ័ត្ននឹងពួកព្យាការី[ក]ក្លែងក្លាយ ដែលគេមករកអ្នក
រាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេ
ជាឆ្កែចចក ដែលឆ្នក់ស៊ីវិញ ។

១៦ អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត ។
តើដែលបេះផ្លែទំពាំងបាយជូរពីគុម្ពបន្លា ឬផ្លែល្វាពីដំបងយក្សឬទេ ?

១៧ ដូច្នេះ អស់ទាំងដើមឈើល្អ តែងមានផ្លែល្អ; ឯដើម
អាក្រក់ ក៏តែងមានផ្លែអាក្រក់ដែរ ។

១៨ ធម្មតា ដើមឈើល្អ មិនដែលបញ្ចេញផលអាក្រក់បានទេ
ហើយដើមដែលអាក្រក់ ក៏ពុំអាចនឹងបញ្ចេញផលល្អបានដែរ ។

១៩ អស់ទាំងដើមឈើណា ដែលមិន[ក]កើតផលផ្លែល្អ នោះត្រូវ
កាប់រំលំ ហើយបោះចោលទៅក្នុងភ្លើង ។

២០ ដូច្នេះ ដោយសារ[ក]ផលគេបង្កើត នោះអ្នករាល់គ្នានឹង
ស្គាល់គេបាន ។

២១ មិនមែនអស់អ្នកណា ដែលគ្រាន់តែនិយាយមកយើងថា
ឱព្រះអម្ចាស់ៗអើយ ដែលនឹងចូលទៅក្នុងនគរស្ថានសួគ៌នោះទេ;
តែគឺជាអស់អ្នកដែលធ្វើតាម ព្រះហឫទ័យនៃព្រះវរបិតារបស់យើង
ដែលគង់នៅស្ថានសួគ៌វិញទេតើ ។

២២ នៅថ្ងៃនោះ នឹងមានមនុស្សជាច្រើន[ក]និយាយមកយើងថា
ឱព្រះអម្ចាស់ៗអើយ តើយើងខ្ញុំមិនបានព្យាករ ដោយនូវ
ព្រះនាមទ្រង់ ហើយបណ្ដេញអារក្សចេញ ដោយនូវព្រះនាមទ្រង់
ព្រមទាំងធ្វើការដ៏អស្ចារ្យជាច្រើន ដោយនូវព្រះនាមទ្រង់ទេឬអី ?

២៣ នោះយើងនឹងនិយាយដោយត្រង់ថា៖ យើងមិនដែលបាន
[ក]ស្គាល់អ្នករាល់គ្នាទេ; នែ៎ ពួកទទឹងច្បាប់អើយ ចូរ[ខ]ថយចេញពី
យើងទៅ ។

២៤ ដូច្នេះ អស់អ្នកណាដែលឮពាក្យរបស់យើងទាំងនេះ
ហើយប្រព្រឹត្តតាម យើងនឹងធៀបអ្នកនោះ ដូចជាមនុស្សមាន
គំនិត ដែលសង់ផ្ទះខ្លួននៅលើ[ក]ថ្ម —

២៥ [ក]រួចភ្លៀងធ្លាក់មក [ខ]ទឹកក៏ជន់ឡើង ហើយខ្យល់
បក់ប៉ះនឹងផ្ទះនោះ តែមិនបានរលំទេ ពីព្រោះបានសង់នៅលើថ្ម ។

២៦ ឯអស់អ្នកណាដែលឮពាក្យរបស់យើងទាំងនេះ
តែមិនប្រព្រឹត្តតាម អ្នកនោះត្រូវធៀបដូចជាមនុស្សល្ងង់ ដែល
សង់ផ្ទះខ្លួននៅលើ [ក]ខ្សាច់វិញ —

២៧ រួចភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ហើយខ្យល់
បក់ប៉ះនឹងផ្ទះនោះ; ផ្ទះនោះក៏រលំទៅ ហើយមានការខូចខាតជាធំ ៕

## ជំពូកទី ១៥

*ព្រះយេស៊ូវប្រកាសថា ក្រិត្យវិន័យលោកម៉ូសេ ត្រូវបានបំពេញ
នៅក្នុងទ្រង់ — ពួកសាសន៍នីហ្វៃ គឺជាចៀមឯទៀត ដែលទ្រង់*

៧ *ក* ៣ នីហ្វៃ ២៧:២៩.
ស.ប. ការអធិស្ឋាន.
១២ *ក* ស.ប. អាណិត.
១៣ *ក* លូកា ១៣:២៤;
៣ នីហ្វៃ ២៧:៣៣.
*ខ* គ. និង ស. ១៣២:២៥.
១៤ *ក* ២ នីហ្វៃ ៩:៤១; ៣១:៩, ១៧—១៨;
គ. និង ស. ២២:១—៤.
*ខ* ១ នីហ្វៃ ៨:២០.
*គ* ១ នីហ្វៃ ១៤:១២.
១៥ *ក* យេរេ. ២៣:២១—៣២;
២ នីហ្វៃ ២៨:៩, ១២, ១៥.
១៩ *ក* ម៉ាថាយ ៣:១០;
អាលម៉ា ៥:៣៦—៤១;
គ. និង ស. ៩៧:៧.
២០ *ក* លូកា ៦:៤៣—៤៥; មរ៉ូណៃ ៧:៥.
២២ *ក* អាលម៉ា ៥:១៧.
២៣ *ក* ម៉ូសាយ ៥:១៣; ២៦:២៤—២៧.
*ខ* លូកា ១៣:២៧.
២៤ *ក* ស.ប. ថ្ម.
២៥ *ក* អាលម៉ា ២៦:៦;
ហេលេ. ៥:១២.
*ខ* សុភា. ១២:៧.
២៦ *ក* ៣ នីហ្វៃ ១១:៤០.

*មាន ព្រះបន្ទូលនៅក្រុងយេរូសាឡិម — ដោយមកពីអំពើទុច្ចរិត នោះរាស្ត្របស់ព្រះអម្ចាស់ នៅក្រុងយេរូសាឡិមពុំស្គាល់ចៀមនៃ អ៊ីស្រាអែល ដែលខ្ចាត់ព្រាត់នោះទេ ។ ប្រមាណជា ឆ្នាំ៣៤ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់មានព្រះបន្ទូលចប់ហើយ នោះទ្រង់ទតមើលជុំវិញហ្វូងមនុស្ស
ហើយក៏មានព្រះបន្ទូលថា៖ មើលចុះ អ្នករាល់គ្នាបានឮ
រឿងអម្បាលម៉ាននេះហើយ ដែលយើងបានបង្រៀន
មុនពេលយើងឡើង ទៅជួបព្រះវរបិតាយើងវិញ; ដូច្នេះ អស់អ្នក
ណាដែលចាំពាក្យរបស់យើង ហើយ[ក]ប្រព្រឹត្តតាម នោះយើងនឹង
[ខ]ប្រោសអ្នកនោះ នៅថ្ងៃ ចុងក្រោយបង្អស់វិញ ។
២ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់
មានព្រះបន្ទូលដូច្នោះហើយ នោះទ្រង់ឃើញថា មានអ្នក
ខ្លះងឿងឆ្ងល់ មិនយល់ថា ទ្រង់មានបំណងយ៉ាងណា ចំពោះ
[ក]ក្រិត្យវិន័យលោកម៉ូសេនោះទេ; ត្បិតគេពុំយល់ត្រង់ពាក្យថា៖
សេចក្ដីទាំងឡាយពីបុរាណ បានកន្លងផុតទៅ ហើយអ្វីៗទាំង
អស់បានក្លាយទៅជាថ្មី ។
៣ នោះទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ ចូរកុំងឿងឆ្ងល់ត្រង់
ពាក្យ ដែលយើងប្រាប់អ្នករាល់គ្នាថា សេចក្ដីទាំងឡាយពីបុរាណ
បានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានក្លាយទៅជាថ្មីនោះឡើយ ។
៤ មើលចុះ យើងប្រាប់អ្នករាល់គ្នាថា [ក]ក្រិត្យវិន័យដែលបាន
ប្រទានឲ្យលោកម៉ូសេ នោះត្រូវបានបំពេញសព្វគ្រប់ហើយ ។
៥ មើលចុះ [ក]គឺយើងនេះហើយដែលបានប្រទានក្រិត្យវិន័យនោះ
គឺយើងនេះហើយដែលបានធ្វើសេចក្ដីសញ្ញា ជាមួយនឹងពួក
អ៊ីស្រា អែល ជារាស្ត្ររបស់យើង; ដូច្នេះ ក្រិត្យវិន័យត្រូវបាន
[ខ]បំពេញដោយយើងហើយ ត្បិតយើងបានមក ដើម្បីបំពេញ
ក្រិត្យវិន័យនោះ; ដូច្នេះ វាបានចប់ហើយ ។
៦ មើលចុះ យើង[ក]ពុំបំផ្លាញសេចក្ដីព្យាករណ៍នៃពួក
ព្យាការីចោលទេ ត្បិតអ្វីក៏ដោយដែលពុំទាន់បានបំពេញនៅ
ក្នុងយើង នោះយើង ប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងត្រូវបាន
បំពេញសព្វគ្រប់ ។
៧ ហើយពីព្រោះយើងបានប្រាប់អ្នករាល់គ្នាថា សេចក្ដីទាំង
ឡាយពីបុរាណបានកន្លងផុតទៅ នោះយើងពុំបំផ្លាញនូវអ្វីៗ
ដែលបាន និយាយអំពីរឿងក្នុងពេលអនាគតទេ ។
៨ ត្បិតមើលចុះ [ក]សេចក្ដីសញ្ញាដែលយើងបានធ្វើ ជាមួយនឹង
រាស្ត្ររបស់យើង ពុំទាន់បានបំពេញអស់នៅឡើយទេ; ប៉ុន្តែ
ក្រិត្យវិន័យ ដែលបានប្រទានដល់លោកម៉ូសេ នោះបានចប់នៅ
ក្នុងយើងហើយ ។
៩ មើលចុះ យើងជា[ក]ក្រិត្យវិន័យ ហើយជា[ខ]ពន្លឺ ។ ចូរផ្ចង់មក
យើង ហើយកាន់ខ្ជាប់ ដរាបដល់ចុងបំផុត ទើបអ្នករាល់គ្នា
[គ]នឹងរស់; ត្បិតយើងនឹងប្រទានជីវិតដ៏នៅអស់កល្បជានិច្ច ដល់អ្នក
ណាដែល[ឃ]កាន់ខ្ជាប់ ដរាបដល់ចុងបំផុត ។
១០ មើលចុះ យើងបានប្រទាន[ក]បញ្ញត្តិទាំងឡាយដល់អ្នករាល់
គ្នា; ដូច្នេះ ចូរធ្វើតាមបញ្ញត្តិទាំងឡាយរបស់យើង ។ ហើយនេះ
ជាក្រិត្យវិន័យ ហើយជាសេចក្ដីព្យាករណ៍របស់ពួកព្យាការី ត្បិត
របស់ទាំងនោះបាន[ខ]ធ្វើបន្ទាល់ដ៏ពិតប្រាកដអំពីយើង ។
១១ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលដូច្នោះហើយ នោះទ្រង់មានព្រះ
បន្ទូលទៅ កាន់ពួក១២នាក់ ដែលទ្រង់បានរើសថា៖
១២ អ្នករាល់គ្នាជាសិស្សរបស់យើង; ហើយអ្នករាល់គ្នាជា
ពន្លឺមួយដល់ប្រជាជននេះ ដែលជាសំណល់នៃវង្ស[ក]យ៉ូសែប ។
១៣ ហើយមើលចុះ នេះជា[ក]ដែនដីកេរ្តិ៍អាកររបស់អ្នក; ហើយ
ព្រះវរបិតា ទ្រង់បានប្រទានដែនដីនេះ ដល់អ្នករាល់គ្នា ។
១៤ ហើយពុំដែលមានពេលណាមួយឡើយ ដែលព្រះវរបិតា
ទ្រង់បានបញ្ជាយើង[ក]ឲ្យប្រាប់រឿងនេះដល់បងប្អូនរបស់អ្នករាល់គ្នា
ដែលនៅឯក្រុងយេរូសាឡិម ។
១៥ ហើយក៏ពុំដែលមានពេលណាមួយដែរ ដែលព្រះវរបិតា

**១៥** ១*ក* យ៉ាកុប (ព.ស.ថ.) ១:២២.
*ខ* ១ នីហ្វៃ ១៣:៣៧;
គ. និង ស. ៥:៣៥.
២ *ក* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
៤ *ក* ម៉ូសាយ ១៣:២៧–៣១;
៣ នីហ្វៃ ៩:១៧–២០.
៥ *ក* ១ កូរិន. ១០:១–៤;
៣ នីហ្វៃ ១១:១៤.
ស.ប. ព្រះយេហូវ៉ា.
*ខ* អាលម៉ា ៣៤:១៣.
៦ *ក* ៣ នីហ្វៃ ២៣:១–៥.
៨ *ក* ៣ នីហ្វៃ ៥:២៤–២៦.
៩ *ក* ២ នីហ្វៃ ២៦:១.
*ខ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*គ* យ៉ូហាន ១១:២៥;
គ. និង ស. ៨៤:៤៤.
*ឃ* ស.ប. កាន់ខ្ជាប់.
១០ *ក* ៣ នីហ្វៃ ១២:២០.
*ខ* ម៉ូសាយ ១៣:៣៣.
១២ *ក* ស.ប. យ៉ូសែប, កូនប្រុសរបស់
យ៉ាកុប.
១៣ *ក* ១ នីហ្វៃ ១៨:២២–២៣.
១៤ *ក* ៣ នីហ្វៃ ៥:២០.

ទ្រង់បានបញ្ជាយើងឲ្យប្រាប់ពួកគេ អំពីពូជអំបូរផ្សេងៗនៃ
វង្សអ៊ីស្រាអែល ដែលព្រះវរបិតាទ្រង់បាននាំចេញពីដែនដីនោះទៅ។
១៦ ព្រះវរបិតាទ្រង់បានបញ្ជាយើង ឲ្យប្រាប់ទៅពួក
គេតែប៉ុណ្ណោះថា៖
១៧ យើងក៏មានចៀមឯទៀត ដែលមិននៅក្នុងក្រោល
នេះនៅឡើយ; ត្រូវតែយើងនាំចៀមទាំងនោះមកដែរ វានឹង
ស្ដាប់តាមសម្លេង របស់យើង; នោះនឹងមានក្រោលតែមួយ និង
អ្នកគង្វាលតែមួយវិញ ។
១៨ ហើយឥឡូវនេះ មកពីការរឹងទទឹង និងការឥតជំនឿ នោះ
ពួកគេពុំយល់ពាក្យរបស់យើងសោះ; ដូច្នេះ យើងបានទទួលបញ្ជា
ពីព្រះវរបិតា មិនឲ្យនិយាយប្រាប់ពួកគេ អំពីរឿងនេះទៀតទេ ។
១៩ ប៉ុន្តែ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ព្រះវរបិតាទ្រង់
បានបញ្ជាដល់យើង ហើយយើងប្រាប់អ្នករាល់គ្នាថា អ្នករាល់
គ្នាត្រូវ បែកពីពួកគេ ពីព្រោះមកពីសេចក្ដីទុច្ចរិតរបស់គេ;
ដូច្នេះ គឺមកពីសេចក្ដីទុច្ចរិតរបស់ពួកគេ ទើបគេពុំបានដឹងអំពី
អ្នករាល់គ្នា ។
២០ ហើយយើងប្រាប់អ្នករាល់គ្នាជាប្រាកដទៀតថា
ពូជអំបូរឯទៀត ក៏ត្រូវព្រះវរបិតា ទ្រង់បំបែកចេញពីពួកគេដែរ;
ហើយដោយ មកពីសេចក្ដីទុច្ចរិតរបស់ពួកគេ ទើបពួកគេពុំ
បានដឹងអំពីពូជអំបូរទាំងនោះ ។
២១ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាគឺជាពួក
អ្នកដែលយើងបាននិយាយថា៖ យើងក៏មានចៀមឯទៀត ដែល
មិន នៅក្នុងក្រោលនេះនៅឡើយ ត្រូវតែយើងនាំចៀមទាំងនោះ
មកដែរ ហើយវានឹងស្ដាប់តាមសម្លេងយើង នោះនឹងមាន
ក្រោលតែមួយ និងអ្នកគង្វាលតែមួយវិញ ។
២២ ហើយពួកគេពុំបានយល់សេចក្ដីរបស់យើងសោះ ត្បិត
ពួកគេបានគិតស្មានថា យើងនិយាយអំពីពួកសាសន៍ដទៃ; ត្បិត
ពួកគេ ពុំយល់ថា ពួកសាសន៍ដទៃនឹងត្រូវបានប្រែចិត្តជឿ
តាមរយៈការផ្សាយរបស់គេ ។
២៣ ហើយពួកគេពុំបានយល់សេចក្ដីរបស់យើង កាលយើង
និយាយថា ពួកគេនឹងស្ដាប់តាមសម្លេងយើង; ហើយពួកគេពុំ
យល់ សេចក្ដីរបស់យើង កាលយើងនិយាយថា ពួកសាសន៍
ដទៃនឹងពុំឮសម្លេងរបស់យើងទាល់តែសោះ — គឺយើងនឹង
ពុំសម្ដែងខ្លួនឲ្យពួក សាសន៍ដទៃឃើញទេ លើកលែងតែដោយ
ព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ។
២៤ ប៉ុន្តែមើលចុះ អ្នករាល់គ្នាបានស្ដាប់តាមសម្លេងយើង
ហើយបានឃើញយើងផង; ហើយអ្នករាល់គ្នា គឺជាចៀម
របស់យើង ហើយអ្នករាល់គ្នាត្រូវបានរាប់ក្នុងចំណោមមនុស្ស
ដែលព្រះវរបិតាទ្រង់បានប្រទានដល់យើង ៕

## ជំពូកទី ១៦

*ព្រះយេស៊ូវទ្រង់នឹងយាងមករកចៀមដែលវង្វេងផ្សេងទៀតនៃអ៊ីស្រាអែល — នៅក្នុងគ្រាចុងក្រោយ ដំណឹងល្អនឹងទៅដល់ពួកសាសន៍ដទៃ រួចហើយ ដល់វង្សអ៊ីស្រាអែល — រាស្ដ្រនៃព្រះអម្ចាស់នឹងឃើញដោយភ្នែករបស់ខ្លួនគេ ក្នុងកាលដែលទ្រង់យាងមកឯក្រុងស៊ីយ៉ូនវិញ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា យើងក៏មានចៀម
ឯទៀត ដែលពុំនៅក្នុងដែនដីនេះនៅឡើយ ឬក៏មិននៅដែនដី
យេរូសាឡិម ឬក៏មិននៅទីទាំងឡាយណាជិតតំបន់ ដែលយើង
បានទៅធ្វើការងារបំរើនោះទេ ។
២ ត្បិតពួកអ្នកដែលយើងបាននិយាយនេះ គឺជាពួកអ្នកដែល
ពុំទាន់ស្ដាប់តាមសម្លេងយើងនៅឡើយទេ; ឯយើងក៏ពុំដែលបាន
សម្ដែងខ្លួនឲ្យគេឃើញ ក្នុងពេលណាដែរ ។
៣ ប៉ុន្តែ យើងបានទទួលបញ្ជាមួយពីព្រះវរបិតាថា យើងត្រូវ
ទៅជួបពួកគេ ហើយថា ពួកគេនឹងបានឮសម្លេងរបស់យើង
ហើយនឹងបានរាប់ជាមួយនឹងចៀមរបស់យើង ដើម្បីនឹងអាចមាន
ក្រោលតែមួយ និងអ្នកគង្វាលតែមួយវិញ; ដូច្នេះ យើងទៅ
បង្ហាញខ្លួនដល់គេ ។
៤ ហើយយើងបញ្ជាអ្នកថា អ្នករាល់គ្នាត្រូវសរសេរនូវពាក្យ

---

១៥ *ក* ៣ នីហ្វៃ ១៦:១–៤.
ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែល
ទាំង១០អំបូរដែលបាត់.
១៧ *ក* ស.ប. អ្នកគង្វាលល្អ.
១៨ *ក* គ. និង ស. ១០:៥៩.
២១ *ក* យ៉ូហាន ១០:១៤–១៦.
២២ *ក* ស.ប. ពួកសាសន៍ដទៃ.
*ខ* កិច្ចការ ១០:៣៤–៤៨.
២៣ *ក* ម៉ាថាយ ១៥:២៤.
*ខ* ១ នីហ្វៃ ១០:១១.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២៤ *ក* អាលម៉ា ៥:៣៨;
៣ នីហ្វៃ ១៦:១–៥.
*ខ* យ៉ូហាន ៦:៣៧;
គ. និង ស. ២៧:១៤.
**១៦** ១*ក* ៣ នីហ្វៃ ១៥:១៥.
ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែល
ទាំង១០អំបូរដែលបាត់.
៣ *ក* ៣ នីហ្វៃ ១៧:៤.
៤ *ក* ស.ប. បទព្រះគម្ពីរ.

ទាំងនេះទុក បន្ទាប់ពីយើងចេញទៅ ថាប្រសិនបើរាស្ត្រយើង នៅឯ ក្រុងយេរូសាឡិម គឺពួកអ្នកដែលបានឃើញយើង ហើយ បាននៅជាមួយនឹងយើង ក្នុងការងារបំរើរបស់យើង បើពួកគេពុំ បានសូម ដល់ព្រះវរបិតា ដោយនូវនាមយើង ដើម្បីឲ្យពួកគេ អាចទទួលស្គាល់អ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ និង ពូជអំបូរផ្សេងទៀត ដែលគេពុំបានស្គាល់នោះទេ នោះសូមឲ្យ ពាក្យទាំងនេះដែលអ្នករាល់គ្នានឹងសរសេរបានកត់ទុក ហើយបាន សម្ដែងដល់[ខ]ពួកសាសន៍ ដទៃថា តាមរយៈភាពពោរពេញនៃពួក សាសន៍ដទៃ នោះសំណល់នៃពូជរបស់គេដែលត្រូវខ្ចាត់ខ្ចាយពាស ពេញលើផ្ទៃផែនដី ពីព្រោះតែការឥតជំនឿរបស់គេ នឹងអាច បាននាំមកវិញ ឬអាច[គ]នាំឲ្យស្គាល់យើង ដែលជាព្រះដ៏ ប្រោសលោះពួកគេ ។

៥ ហើយខណៈនោះ យើងនឹង[ក]ប្រមូលពួកគេមក ពីទិសទាំងបួននៃផែនដី; ហើខណៈនោះ យើងនឹងបំពេញ[ខ]សេចក្ដី សញ្ញា ដែល ព្រះវរបិតាបានធ្វើដល់ប្រជាជនទាំងអស់ នៃ [គ]វង្សអ៊ីស្រាអែល ។

៦ មានពរហើយ [ក]ពួកសាសន៍ដទៃ ពីព្រោះតែជំនឿ របស់គេដល់យើង និងដល់[ខ]ព្រះវិញ្ញាណបរិសុទ្ធ ដែល ធ្វើទីបន្ទាល់ដល់ពួកគេ អំពីយើង និងអំពីព្រះវរបិតា ។

៧ មើលចុះ ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា ដោយមក ពីការឥតជំនឿរបស់ពួកគេដល់យើង និងដោយមក ពីការឥតជំនឿ របស់អ្នករាល់គ្នា ឱ៎ វង្សអ៊ីស្រាអែលអើយ នៅ [ក]ថ្ងៃចុងក្រោយ ការពិតនឹងបានមកដល់ពួកសាសន៍ដទៃ ដើម្បីឲ្យ ភាពពោរពេញនៃ ការណ៍ទាំងនេះអាចបានដឹងដល់ពួកគេ ។

៨ ប៉ុន្តែ ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា វេទនាដល់ពួក សាសន៍ដទៃដែលពុំជឿ — ត្បិតទោះជាគេបានមកនៅលើផ្ទៃ ផែនដីនេះ ហើយបាន[ក]បំបែកខ្ចែករាស្ត្រយើង ដែលជាវង្សអ៊ីស្រាអែលក្ដី; ហើយរាស្ត្រយើងដែលជាវង្សអ៊ីស្រាអែល [ខ]ត្រូវគេបណ្ដេញ ចេញ ព្រមទាំងត្រូវគេជាន់ឈ្លីនៅក្រោមជើងផង;

៩ ហើយដោយមកពីសេចក្ដីមេត្តាករុណាទាំងឡាយ របស់ ព្រះវរបិតាដល់ពួកសាសន៍ដទៃ ព្រមទាំងសេចក្ដីជំនុំជំរះរបស់ ព្រះវរបិតាដល់រាស្ត្រយើង ដែលជាវង្សអ៊ីស្រាអែល នោះប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា បន្ទាប់ពីការណ៍អស់ទាំងនេះ ហើយយើងបានធ្វើឲ្យរាស្ត្រយើង ដែលជាវង្សអ៊ីស្រាអែល ត្រូវ គេវាយដំ និងត្រូវគេធ្វើទុក្ខ និងត្រូវគេ[ក]សម្លាប់ចោល និងត្រូវ គេបណ្ដេញ ចេញពីចំណោមពួកគេ ហើយត្រូវក្លាយទៅជា ទីស្អប់ដល់ពួកគេ និងក្លាយទៅជាទីដៀលត្មះ និងទីដំណៀល នៅក្នុងចំណោមពួកគេ —

១០ ម្ល៉ោះហើយ ព្រះវរបិតាទ្រង់បញ្ជាឲ្យយើងប្រាប់អ្នករាល់ គ្នាថា៖ នៅថ្ងៃដែលពួកសាសន៍ដទៃ នឹងប្រព្រឹត្តអំពើបាបទាស់នឹង ដំណឹងល្អរបស់យើង ហើយនឹងបដិសេធនូវភាពពោរពេញ នៃដំណឹងល្អរបស់យើង ហើយនឹង[ក]លើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃ នៃចិត្ត របស់គេ លើអស់ទាំងសាសន៍ និងលើអស់ទាំងប្រជាជន ដែលនៅលើផែនដីទាំងមូល ហើយនឹងពោរពេញទៅដោយការ កុហក និងការបំភាន់ និងការឆបោកគ្រប់បែបយ៉ាង និងការ លាក់ពុត និងឃាតកម្ម និង[ខ]ឧបាយកលផ្ដែកសង្ឃ និងអំពើ សហាយស្មន់ និងអំពើគួរ ខ្ពើមឆ្អើមដ៏សម្ងាត់គ្រប់បែបគ្រប់បទ; ហើយប្រសិនបើពួកគេនឹងធ្វើនូវអំពើទាំងនោះ ហើយនឹង បដិសេធនូវភាពពោរពេញនៃដំណឹងល្អ របស់យើង មើលចុះ ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា យើងនឹងដកភាពពោរពេញ នៃដំណឹងល្អរបស់យើងចេញពីចំណោមពួកគេ ។

១១ ហើយខណៈនោះ យើងនឹង[ក]នឹកឃើញដល់សេចក្ដី សញ្ញារបស់យើង ដែលយើងបានធ្វើជាមួយនឹងរាស្ត្រយើង ឱវង្សអ៊ីស្រា អែលអើយ ហើយយើងនឹងនាំដំណឹងល្អរបស់យើង មកឲ្យគេ ។

១២ ហើយយើងនឹងបង្ហាញដល់អ្នករាល់គ្នា ឱ៎ វង្សអ៊ីស្រាអែល អើយ ថាពួកសាសន៍ដទៃនឹងគ្មានអំណាចលើអ្នករាល់គ្នាឡើយ; តែយើងនឹងនឹកចាំដល់សេចក្ដីសញ្ញាដែលយើងមាននឹងអ្នក ឱវ

៤ ខ ១ នីហ្វៃ ១០:១៤;
៣ នីហ្វៃ ២១:៦.
គ អេសេ. ២០:៤២–៤៤;
៣ នីហ្វៃ ២០:១៣.
៥ ក ស.ប. អ៊ីស្រាអែល — ការប្រមូល នៃសាសន៍អ៊ីស្រាអែល.
ខ ៣ នីហ្វៃ ៥:២៤–២៦.
គ ១ នីហ្វៃ ២២:៩;
៣ នីហ្វៃ ២១:២៦–២៩.
៦ ក ១ នីហ្វៃ ១៣:៣០–៤២;
២ នីហ្វៃ ៣០:៣.
ខ ២ នីហ្វៃ ៣២:៥;
៣ នីហ្វៃ ១១:៣២, ៣៥–៣៦.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៧ ក ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៨ ក ១ នីហ្វៃ ១៣:១៤; មរមន ៥:៩, ១៥.
ខ ៣ នីហ្វៃ ២០:២៧–២៩.
៩ ក អេម៉ុស ៩:១–៤.
១០ ក មរមន ៨:៣៥–៤១.
ខ ២ នីហ្វៃ ២៦:២៩.
១១ ក ៣ នីហ្វៃ ២១:១–១១;
មរមន ៥:២០.

វង្សអ៊ីស្រាអែលអើយ ហើយអ្នករាល់គ្នានឹងបាន
ចេះដឹងពីភាពពោរពេញ នៃដំណឹងល្អរបស់យើង ។
១៣ ប៉ុន្តែបើសិនជាពួកសាសន៍ដទៃប្រែចិត្ត ហើយត្រឡប់
មករកយើងវិញ ព្រះវរបិតាមានព្រះបន្ទូលថា មើលចុះ ពួកគេ
នឹងត្រូវ បានរាប់ក្នុងចំណោមរាស្ត្រយើងដែរ ឱវង្សអ៊ីស្រាអែល
អើយ ។
១៤ ហើយយើងនឹងពុំទុកឲ្យរាស្ត្រយើង ដែលជាវ
ង្សអ៊ីស្រាអែល លុកលុយទៅលើចំណោមគេ ហើយជាន់ឈ្លី
លើគេឡើយ ព្រះវរបិតា ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៥ ប៉ុន្តែ បើសិនជាពួកគេពុំត្រឡប់មករកយើង ហើយប្រុង
ស្ដាប់តាមសម្លេងយើងទេ នោះយើងនឹងទុកឲ្យពួកគេ មែនហើយ
យើងនឹងទុកឲ្យរាស្ត្រយើង ឱវង្សអ៊ីស្រាអែលអើយ គឺទុកឲ្យ
រាស្ត្រយើងលុកលុយទៅលើចំណោមពួកគេ ហើយជាន់ឈ្លីលើ
ពួកគេ ហើយពួកគេនឹងទៅដូចជាអំបិល ដែលបាត់ជាតិប្រៃ ដែល
គ្មានប្រយោជន៍ទៀតសោះ មានតែត្រូវបោះបង់ចោលទៅក្រៅ
ហើយឲ្យ រាស្ត្រយើងដើរជាន់ប៉ុណ្ណោះ ឱវង្សអ៊ីស្រាអែលអើយ ។
១៦ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា
ព្រះវរបិតាទ្រង់បានបញ្ជាដល់យើងដូច្នេះថា — យើងត្រូវ
ប្រទានដល់ រាស្ត្រនេះនូវដែនដីនេះ ទុកជាកេរ្តិ៍អាកររបស់គេ ។
១៧ ហើយខណៈនោះ ពាក្យពេចន៍នៃព្យាការីអេសាយ នឹង
បានត្រូវបានបំពេញដែលនិយាយថា៖
១៨ មានឮសម្លេងពួកអ្នកយាមរបស់អ្នក គេបន្លឺឡើងច្រៀងជា
មួយគ្នា ត្បិតគេនឹងឃើញដោយភ្នែករបស់ខ្លួនគេ ក្នុងកាលដែល
ព្រះអម្ចាស់ទ្រង់យាងមកឯក្រុងស៊ីយ៉ូនវិញ ។
១៩ នែ៎ អស់ទាំងទីខូចបង់ នៃក្រុងយេរូសាឡិមអើយ
ចូរផ្លាយចេញដោយសេចក្ដីអំណរ ចូរច្រៀងជាមួយគ្នាចុះ; ត្បិត
ព្រះអម្ចាស់ ទ្រង់បានកំសាន្តទុក្ខរបស់រាស្ត្រទ្រង់ ទ្រង់ក៏បាន
ប្រោសលោះក្រុងយេរូសាឡិមហើយ ។
២០ ព្រះអម្ចាស់ទ្រង់បានលាតព្រះពាហុបរិសុទ្ធរបស់ទ្រង់
នៅភ្នែកនៃគ្រប់ទាំងសាសន៍; ហើយអស់ទាំងចុងផែនដី នឹងបាន
ឃើញ សេចក្ដីសង្គ្រោះនៃព្រះ ៕

## ជំពូកទី ១៧

*ព្រះយេស៊ូវទ្រង់បង្គាប់ប្រជាជន ឲ្យពិចារណាគិតអំពីព្រះបន្ទូលទាំងឡាយរបស់ទ្រង់ ហើយអធិស្ឋានសូមឲ្យយល់ — ទ្រង់ប្រោសឲ្យពួក អ្នកឈឺបានជា — ទ្រង់អធិស្ឋានជំនួសប្រជាជន ដោយប្រើភាសាមួយ ដែលពុំអាចសរសេរបានឡើយ — ពួកទេវតាធ្វើការងារបំរើ ហើយភ្លើងឡោមព័ទ្ធជុំវិញពួកកូនក្មេងតូចៗ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

មើលចុះ ឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់មានព្រះបន្ទូលដូច្នោះហើយ នោះទ្រង់ទតមើលជុំវិញហ្វូង
មនុស្សទៀត ហើយទ្រង់មានព្រះបន្ទូលថា៖ មើលចុះ
ពេលវេលារបស់យើង ជិតមកដល់ហើយ ។
២ យើងឃើញថា អ្នករាល់គ្នាទន់ខ្សោយ គឺអ្នករាល់គ្នា
ពុំយល់ពាក្យទាំងអស់របស់យើង ដែលព្រះវរបិតាទ្រង់បាន
បញ្ជាឲ្យយើង ប្រាប់អ្នករាល់គ្នាក្នុងពេលនេះទេ ។
៣ ដូច្នេះ ចូរអ្នករាល់គ្នាត្រឡប់ទៅផ្ទះអ្នកវិញចុះ ហើយ
ពិចារណាគិតអំពីរឿងទាំងឡាយ ដែលយើងបាននិយាយ ហើយ
ចូរសូម ដល់ព្រះវរបិតា ដោយនូវនាមយើង ដើម្បីឲ្យអ្នករាល់គ្នា
អាចយល់ ហើយប្រុងប្រៀបចិត្តគំនិតរបស់អ្នកចាំថ្ងៃស្អែក
ហើយយើងនឹង យាងមកជួបអ្នកទៀត ។
៤ ប៉ុន្តែឥឡូវនេះ យើងយាងទៅឯព្រះវរបិតាវិញ ហើយទៅ
បង្ហាញខ្លួន ដល់ពួកពូជអំបូរដែលបាត់ នៃសាសន៍អ៊ីស្រាអែលផង
ព្រោះពួកគេពុំមែនបាត់ពីព្រះវរបិតាទេ ត្បិតទ្រង់ស្គាល់ទីកន្លែង
ដែលទ្រង់បាននាំពួកគេទៅ ។
៥ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់
មានព្រះបន្ទូលដូច្នោះហើយ នោះទ្រង់ទតមើលជុំវិញហ្វូងមនុស្ស

១២ *ក* ហោសេ. ១៥:១២–១៣.
១៣ *ក* កាឡាទី ៣:៧, ២៩;
១ នីហ្វៃ ១៥:១៣–១៧;
២ នីហ្វៃ ១០:១៨;
៣ នីហ្វៃ ៣០:២; អ័ប្រា. ២:៩–១១.
១៥ *ក* មីកា ៥:៨–១៥;
៣ នីហ្វៃ ២០:១៦–១៩;
២១:១២–២១;
គ. និង ស. ៨៧:៥.
១៧ *ក* ៣ នីហ្វៃ ២០:១១–១២.
១៨ *ក* អេសាយ ៥២:៨–១០.
*ខ* អេសេ. ៣៣:១–៧.
ស.ប. ចាំយាម, ពួកអ្នកចាំយាម.
**១៧** ១*ក* ក.ន. វិលទៅរកព្រះវរបិតាវិញ ។
សូមមើល ខទី ៤.
២ *ក* យ៉ូហាន ១៦:១២;
គ. និង ស. ៧៨:១៧–១៨.
៣ *ក* ស.ប. រំពឹងគិត.
*ខ* គ. និង ស. ១៣២:៣.
*គ* ៣ នីហ្វៃ ១៩:២.
៤ *ក* ៣ នីហ្វៃ ១៨:៣៩.
*ខ* ៣ នីហ្វៃ ១៦:១–៣.
*គ* ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់.

ហើយឃើញថា ពួកគេស្រក់ទឹកភ្នែក ហើយបានសម្លឹងមក
រកព្រះអង្គយ៉ាងខ្ជាប់ ហាក់បីដូចជាពួកគេសូមឲ្យទ្រង់ ទ្រាំនៅជា
មួយនឹងគេ បន្ដិចទៀត ។
៦ ហើយទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ មើលចុះ ចិត្ត
យើងពោរពេញទៅដោយសេចក្ដីអាណិតមេត្ដាដល់អ្នករាល់គ្នា ។
៧ តើនៅក្នុងចំណោមអ្នករាល់គ្នា មានអ្នកណាឈឺទេ ? ចូរនាំ
អ្នកទាំងនោះមកទីនេះចុះ ។ តើមាននរណាខ្វិន ឬខ្វាក់ ឬគ
ឬបាក់ដៃបាក់ជើង ឬឃ្លង់ ឬស្លឹកស្រពន់ ឬថ្លង់ ឬក៏ត្រូវរងទុក្ខ
ដោយហេតុណាផ្សេងទៀត? ចូរនាំពួកគេមកទីនេះចុះ ហើយយើង
នឹង ប្រោសឲ្យពួកគេបានជា ត្បិតយើងមានចិត្តអាណិតអាសូរដល់
ពួកអ្នករាល់គ្នា; ចិត្តយើងពោរពេញទៅដោយសេច
ក្ដីមេត្តាករុណា ។
៨ ត្បិតយើងឃើញថា អ្នករាល់គ្នាចង់ឲ្យយើងបង្ហាញដល់អ្នក
រាល់គ្នា នូវអ្វីៗដែលយើងបានធ្វើ ដល់បងប្អូនរបស់អ្នក
នៅក្រុងយេរូសាឡិម ត្បិតយើងឃើញថា សេចក្ដីជំនឿរបស់អ្នក
រាល់គ្នាល្មមគ្រប់គ្រាន់ ដើម្បីឲ្យយើងប្រោសអ្នកឲ្យបានជាហើយ ។
៩ ហើយហេតុការណ៍បានកើតឡើងថា កាលទ្រង់មានព្រះ
បន្ទូលដូច្នោះហើយ នោះហ្វូងមនុស្សទាំងអស់ ក៏ដើរឆ្ពោះទៅ
មុខ ព្រមគ្នា ជាមួយនឹងអ្នកឈឺរបស់គេ និងអ្នករងទុក្ខរបស់គេ
និងអ្នកខ្វិនរបស់គេ និងអ្នកខ្វាក់របស់គេ និងអ្នកថ្លង់របស់គេ និង
អស់ទាំងអ្នក ដែលរងទុក្ខដោយជម្ងឺណាក៏ដោយ; ហើយទ្រង់
បានប្រោសឲ្យជាសះស្បើយគ្រប់ៗគ្នា នៅពេលពួកគេត្រូវនាំមក
រកទ្រង់ ។
១០ ហើយគេទាំងអស់គ្នា ទាំងអ្នកដែលបានធ្វើឲ្យបានជាទាំង
អស់ និងអ្នកដែលមានសុខភាពល្អ បានក្រាបចំពោះព្រះបាទាទ្រង់
ហើយបានថ្វាយបង្គំទ្រង់; ហើយអស់អ្នកណាដែលអាចមកបាន
ជំនួសហ្វូងមនុស្ស ក៏បានថើបព្រះបាទាទ្រង់ ដរាបដល់ព្រះ
បាទាទ្រង់សើម ដោកជាំ ដោយទឹកភ្នែករបស់ពួកគេ ។
១១ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាឲ្យ
គេនាំកូនក្មេងតូចៗមករកព្រះអង្គ ។
១២ ម្ល៉ោះហើយ គេបាននាំកូនក្មេងតូចៗ មកអង្គុយនៅលើទីដី
ជុំវិញព្រះអង្គ ហើយព្រះយេស៊ូវទ្រង់ឈរនៅកណ្ដាល ហើយហ្វូង
មនុស្សបានថយចេញ ទុកកន្លែងឲ្យគេនាំកូនក្មេងតូចៗទាំងអស់មក ។
១៣ ហើយហេតុការណ៍បានកើតឡើងថា កាលកូនក្មេង
បាននាំមកអស់ហើយ ឯព្រះយេស៊ូវទ្រង់ឈរនៅកណ្ដាល
នោះទ្រង់ បានបញ្ជាដល់ហ្វូងមនុស្ស ឲ្យលុតជង្គង់ចុះ
ទៅលើដី ។
១៤ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានលុត
ជង្គង់ទៅលើដីហើយ នោះព្រះយេស៊ូវទ្រង់ថ្ងូរ នៅក្នុង
ខ្លួនព្រះអង្គ ហើយមានព្រះបន្ទូលថា៖ ព្រះវរបិតាអើយ ទូលបង្គំ
មានកង្វល់ក្នុងចិត្ត ពីព្រោះតែអំពើទុច្ចរិត នៃប្រជាជន
នៃវង្សអ៊ីស្រាអែល ។
១៥ ហើយកាលទ្រង់មានព្រះបន្ទូលដូច្នោះហើយ នោះទ្រង់ក៏លុត
ជង្គង់ចុះទៅលើដីដែរ; ហើយមើលចុះ ទ្រង់បានអធិស្ឋានទៅ
ព្រះវរបិតា ហើយអ្វីៗដែលទ្រង់បានអធិស្ឋាននោះ ពុំអាច
យកមកសរសេរបានឡើយ ឯហ្វូងមនុស្សដែលបានឮព្រះអង្គ
អធិស្ឋាន ក៏បាន ធ្វើបន្ទាល់ពីការណ៍នោះ ។
១៦ ហើយពួកគេបានធ្វើបន្ទាល់តាមរបៀបនេះថា៖ ភ្នែកមិន
ដែលឃើញសោះ ឯត្រចៀកក៏មិនដែលបានឮរឿងដ៏មហិមា និង
អស្ចារ្យ ដូចយើងបានឃើញ ហើយបានឮព្រះយេស៊ូវ ទ្រង់មាន
ព្រះបន្ទូលទៅកាន់ព្រះវរបិតាឡើយ ។
១៧ ហើយគ្មានអណ្ដាតណាអាចថ្លែងប្រាប់ ហើយគ្មានមនុស្ស
ណាអាចសរសេរ ហើយក៏គ្មានចិត្តរបស់មនុស្សណាអាច
យល់នូវរឿងដ៏អស្ចារ្យ និងមហិមា ដូចដែលយើងបានឃើញ
ហើយបានឮព្រះយេស៊ូវ ទ្រង់មានព្រះបន្ទូលនោះឡើយ; ហើយ
គ្មានអ្នក ណាមួយអាចយល់នូវសេចក្ដីអំណរដែលពោរពេញ
នៅក្នុងព្រលឹងនៃយើង នៅពេលយើងបានឮទ្រង់អធិស្ឋានដល់
ព្រះវរបិតា សំរាប់ យើងនោះទេ ។
១៨ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់បានបញ្ចប់នូវការអធិស្ឋានដល់ព្រះវរបិតាហើយ នោះទ្រង់
បានក្រោកឡើង; ប៉ុន្ដែសេចក្ដីអំណររបស់បណ្ដាជន នោះមាន
ខ្លាំងហួសប្រមាណ រហូតដល់គេពុំអាចក្រោកឡើងបានឡើយ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់មាន
ព្រះបន្ទូលទៅពួកគេ ហើយសូមឲ្យគេក្រោកឡើង ។
២០ ហើយពួកគេក៏ក្រោកឡើងពីដី ហើយទ្រង់មានព្រះ
បន្ទូលទៅគេថា៖ មានពរហើយ អ្នករាល់គ្នា មកពីសេចក្ដីជំនឿ

៦ *ក* ស.ប. អាណិត.
៨ *ក* លូកា ១៨:៤២.
*ខ* ២ នីហ្វៃ ២៧:២៣;
អេធើរ ១២:១២.
៩ *ក* ម៉ូសាយ ៣:៥; ៣ នីហ្វៃ ២៦:១៥.
១០ *ក* លូកា ៧:៣៨.
១១ *ក* ម៉ាថាយ ១៩:១៣–១៤;
៣ នីហ្វៃ ២៦:១៤, ១៦.
១៣ *ក* លូកា ២២:៤១; កិច្ចការ ២០:៣៦.
១៤ *ក* ម៉ូសេ ៧:៤១.
១៦ *ក* អេសាយ ៦៤:៤; ១ កូរិន. ២:៩;
គ. និង ស. ៧៦:១០, ១១៤–១១៩.
១៧ *ក* ២ កូរិន. ១២:៤.
១៨ *ក* ស.ប. សេចក្ដីអំណរ.

របស់អ្នក ។ ហើយឥឡូវនេះ មើលចុះ សេចក្ដីអំណររបស់យើងបានពោរពេញ ។

២១ ហើយកាលទ្រង់មានព្រះបន្ទូលដូច្នោះហើយ នោះទ្រង់ព្រះកន្សែង ហើយបណ្ដាជនបានធ្វើបន្ទាល់ពីការណ៍នេះ ហើយទ្រង់បានយកកូនក្មេងរបស់ពួកគេ ម្ដងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសំរាប់ពួកវា ។

២២ ហើយកាលទ្រង់បានធ្វើការនេះចប់ហើយ នោះទ្រង់ក៏ព្រះកន្សែងទៀត;

២៣ ហើយទ្រង់មានព្រះបន្ទូលទៅហ្វូងមនុស្សថា៖ មើលន៏កូនតូចៗរបស់អ្នករាល់គ្នា ។

២៤ ហើយនៅពេលពួកគេក្រឡេកមើលទៅ នោះពួកគេបានសម្លឹងមើលទៅលើផ្ទៃមេឃ ហើយឃើញផ្ទៃមេឃបើកចំហ ហើយពួកគេឃើញពួកទេវតាហោះចុះមកពីស្ថានសួគ៌ ហាក់បីដូចជានៅកណ្ដាលភ្លើង; ហើយពួកទេវតាក៏ចុះមកហែរហមជុំវិញពួកកូន ក្មេងទាំងនោះ រីឯភ្លើងក៏ព័ទ្ធជុំវិញពួកវា; ហើយពួកទេវតាបានធ្វើការងារបំរើដល់ពួកកូនក្មេង ។

២៥ ហើយហ្វូងមនុស្សបានឃើញ បានឮ ហើយបានធ្វើបន្ទាល់; ហើយពួកគេដឹងថា ទីបន្ទាល់របស់គេគឺពិត ត្បិតគេទាំងអស់គ្នាបាន ទាំងឃើញ ហើយក៏ឮដោយខ្លួនគេផ្ទាល់; ឯពួកគេមានចំនួនប្រហែល ពីរពាន់ប្រាំរយនាក់ គឺមានទាំងប្រុស ទាំងស្រី និងក្មេងៗ ៕

---

ជំពូកទី ១៨

*ព្រះយេស៊ូវតាំងបុណ្យរំលឹកនៅក្នុងចំណោមពួកសាសន៍នីហ្វៃ — ពួកគេត្រូវបានបញ្ជាឲ្យអធិស្ឋានជានិច្ច ដោយនូវព្រះនាមទ្រង់ — អស់អ្នកណាដែលទទួលទានព្រះកាយរបស់ទ្រង់ ហើយផឹកព្រះលោហិតរបស់ទ្រង់ ដោយមិនសក្ដិសម នឹងត្រូវផាប់ទោស — ពួកសិស្សត្រូវបានប្រទានអំណាចឲ្យប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់បានបញ្ជាពួកសិស្សរបស់ទ្រង់ ឲ្យយកនំប៉័ង និងស្រាទំពាំងបាយជូរមកថ្វាយទ្រង់ ។

២ ហើយនៅពេលពួកគេកំពុងតែទៅយកនំប៉័ង និងស្រាទំពាំងបាយជូរ នោះទ្រង់បានបញ្ជាឲ្យហ្វូងមនុស្សអង្គុយចុះទៅលើដី ។

៣ ហើយកាលពួកសិស្សបានយកនំប៉័ង និងស្រាទំពាំងបាយជូរមកដល់ហើយ នោះទ្រង់យកនំប៉័ងមកកាច់ជាដុំៗ ហើយប្រទាន ពរដល់នំប៉័ងនោះ; ហើយទ្រង់បានប្រគល់ឲ្យទៅពួកសិស្ស ហើយក៏បញ្ជាឲ្យពួកគេបរិភោគ ។

៤ ហើយកាលពួកគេបានបរិភោគ ហើយបានឆ្អែត នោះទ្រង់បានបញ្ជាឲ្យពួកគេចែកនំប៉័ងដល់ហ្វូងមនុស្ស ។

៥ ហើយកាលហ្វូងមនុស្សបានបរិភោគ ហើយបានឆ្អែត នោះទ្រង់មានព្រះបន្ទូលទៅពួកសិស្សរបស់ទ្រង់ថា៖ មើលចុះ នឹងមាន មនុស្សម្នាក់ក្នុងចំណោមពួកអ្នកដែលនឹងបានតែងតាំងឡើង ហើយដល់អ្នកនោះហើយដែលយើងនឹងប្រទានអំណាចឲ្យ ដើម្បីឲ្យគាត់ អាចកាច់នំប៉័ង ហើយប្រទានពរដល់នំប៉័ង ហើយចែកដល់ប្រជាជននៅក្នុងសាសនាចក្ររបស់យើង គឺដល់អស់អ្នកណា ដែលនឹងជឿ ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង ។

៦ ហើយការណ៍នេះ អ្នករាល់គ្នាត្រូវធ្វើជានិច្ច ដូចជាយើងបានធ្វើ គឺដូចដែលយើងបានកាច់ ហើយប្រទានពរនំប៉័ង ហើយ ចែកដល់អ្នករាល់គ្នាដូច្នោះ ។

៧ ហើយការណ៍នេះ អ្នករាល់គ្នាត្រូវធ្វើក្នុងការចងចាំដល់រូបកាយរបស់យើង ដែលយើងបានបង្ហាញដល់អ្នករាល់គ្នា ។ ហើយ ការណ៍នេះ នឹងទៅជាទីបន្ទាល់ដល់ព្រះវរបិតាថា អ្នករាល់គ្នាចងចាំដល់យើងជានិច្ច ។ ហើយបើសិនជាអ្នករាល់គ្នាចងចាំដល់ យើងជានិច្ច នោះអ្នករាល់គ្នានឹងមានព្រះវិញ្ញាណរបស់យើងនៅជាមួយនឹងអ្នក ។

៨ ហើយហេតុការណ៍បានកើតឡើងថា កាលទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ នោះទ្រង់បានបញ្ជាដល់ពួកសិស្សរបស់ទ្រង់ថា ពួកគេត្រូវយកស្រាទំពាំងបាយជូរ ដែលនៅក្នុងពែងមកផឹក ហើយថា ពួកគេត្រូវចែកដល់ហ្វូងមនុស្ស ដើម្បីឲ្យពួកគេបានផឹកផង ។

៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើដូច្នោះមែន គឺបានផឹកស្រាទំពាំងបាយជូរ ហើយបានឆ្អែត; ហើយពួកគេ បានចែកដល់ហ្វូងមនុស្ស ហើយពួកគេបានផឹក ហើយពួកគេបានឆ្អែតផង ។

---

២១ *ក* យ៉ូហាន ១១:៣៥.
*ខ* ម៉ាកុស ១០:១៤–១៦.
២៤ *ក* ហេលេ. ៥:២៣–២៤, ៤៣–៤៥.
១៨ ១*ក* ម៉ាថាយ ២៦:២៦–២៨.
៣ *ក* ស.ប. បុណ្យរំឭក.
៥ *ក* ម រ៉ូណៃ ៤.
៧ *ក* មរ៉ូណៃ ៤:៣.

១០ ហើយកាលពួកសិស្សបានធ្វើដូច្នោះហើយ នោះព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ មានពរហើយ អ្នករាល់គ្នា ចំពោះការទាំងនេះ ដែលអ្នកបានធ្វើ ត្បិតនេះគឺជាការបំពេញបញ្ញត្តិទាំងឡាយរបស់យើង ហើយនេះជាទីបន្ទាល់ដល់ព្រះវរបិតាថា អ្នករាល់ គ្នាព្រមធ្វើនូវអ្វីៗ ដែលយើងបានបញ្ជាដល់អ្នក ។

១១ ហើយការណ៍នេះ អ្នកត្រូវធ្វើជានិច្ច ដល់អស់អ្នកណាដែលប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង; ហើយ អ្នករាល់គ្នាត្រូវធ្វើការនេះ ក្នុងការចងចាំដល់លោហិតរបស់យើង ដែលយើងបានច្រួចជំនួសអ្នក ដើម្បីឲ្យអ្នករាល់គ្នាអាចធ្វើបន្ទាល់ ដល់ព្រះវរបិតាថា អ្នករាល់គ្នាចងចាំដល់យើងជានិច្ច ។ ហើយបើសិនជាអ្នករាល់គ្នាចងចាំដល់យើងជានិច្ច នោះអ្នករាល់គ្នានឹងមាន ព្រះវិញ្ញាណរបស់យើងនៅជាមួយនឹងអ្នក ។

១២ ហើយយើងប្រទានដល់អ្នករាល់គ្នា នូវបញ្ញត្តិមួយថា អ្នកត្រូវធ្វើការទាំងនេះ ហើយបើសិនជាអ្នករាល់គ្នាធ្វើការទាំងនេះជានិច្ច នោះអ្នករាល់គ្នាមានពរហើយ ត្បិតអ្នករាល់គ្នាបានសង់នៅលើ[ក]ថ្មរបស់យើង ។

១៣ ប៉ុន្តែ អស់អ្នកណានៅក្នុងចំណោមអ្នក ដែលនឹងធ្វើច្រើន ឬតិចជាងនេះ គឺពុំបានសង់នៅលើថ្មរបស់យើងទេ ប៉ុន្តែសង់នៅលើ គ្រឹះធ្វើពីខ្សាច់វិញ; ហើយកាលភ្លៀងធ្លាក់មក ទឹកក៏ជន់ឡើង ខ្យល់បក់ប៉ះពួកគេ នោះពួកគេនឹង[ក]រលំ ហើយ[ខ]ទ្វារទាំងឡាយនៃស្ថាននរក នឹងបើកចំហជាស្រេចដើម្បីទទួលយកពួកគេ ។

១៤ ដូច្នេះ មានពរហើយ អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នានឹងកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ដែលព្រះវរបិតា ទ្រង់បានបញ្ជា ឲ្យយើងប្រទានដល់អ្នក ។

១៥ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាត្រូវចាំយាម ហើយ[ក]អធិស្ឋានជានិច្ច ខ្លាចក្រែងអារក្សល្បួងអ្នក ហើយអ្នករាល់គ្នានឹងត្រូវវាចាប់នាំយកទៅឃុំឃាំង ។

១៦ ហើយដូចដែលយើងបានអធិស្ឋាននៅក្នុងចំណោមអ្នករាល់គ្នា នោះអ្នករាល់គ្នាក៏ត្រូវអធិស្ឋាន នៅក្នុងសាសនាចក្ររបស់ យើងយ៉ាងនោះដែរ គឺនៅក្នុងចំណោមរាស្ត្រយើងដែលបានប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង ។ មើលចុះ យើងជា[ក]ពន្លឺ យើងបានធ្វើជា[ខ]គំរូដល់អ្នករាល់គ្នា ។

១៧ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅពួកសិស្ស របស់ទ្រង់យ៉ាងនេះរួចហើយ នោះទ្រង់បែរមកខាងហ្វូងមនុស្សវិញ ហើយមានព្រះបន្ទូលថា៖

១៨ មើលចុះ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាត្រូវចាំយាម ហើយអធិស្ឋានជានិច្ច ខ្លាចក្រែងអ្នកធ្លាក់ទៅក្នុងសេចក្ដីល្បួង; ត្បិត[ក]អារក្សសាតាំងមានបំណងចង់បានអ្នករាល់គ្នា ដើម្បីវាអាចរែងអ្នករាល់គ្នា ដូចជាស្រូវអញ្ចឹង ។

១៩ ដូច្នេះ អ្នករាល់គ្នាត្រូវអធិស្ឋានដល់ព្រះវរបិតា ដោយនូវនាមយើងជានិច្ច;

២០ ហើយ[ក]សូម្បីជាអ្វី ដែលអ្នករាល់គ្នាសុំព្រះវរបិតាដោយនូវនាមយើង ដែលត្រឹមត្រូវ និងដោយជឿថា អ្នកនឹងបានទទួល មើលចុះ នឹងបានប្រទានដល់អ្នក ។

២១ [ក]ចូរអធិស្ឋាននៅក្នុងក្រុមគ្រួសារអ្នក ដល់ព្រះវរបិតាដោយនូវនាមយើងជានិច្ច ដើម្បីឲ្យប្រពន្ធរបស់អ្នក និងកូនចៅរបស់អ្នក អាចបានពរ ។

២២ ហើយមើលចុះ អ្នករាល់គ្នាត្រូវរួមគ្នាប្រជុំជាញឹកញាប់; ហើយអ្នករាល់គ្នាមិនត្រូវហាមឃាត់នរណាមួយ មិនឲ្យគេមករកអ្នក ក្នុងកាលអ្នករាល់គ្នារួមគ្នាប្រជុំនោះឡើយ តែទុកឲ្យគេអាចមករកអ្នក ហើយចូរកុំហាមឃាត់គេឡើយ;

២៣ ប៉ុន្តែ អ្នករាល់គ្នាត្រូវ[ក]អធិស្ឋានឲ្យពួកគេ ហើយមិនត្រូវបណ្ដេញគេចេញឡើយ; ហើយប្រសិនបើគេមករកអ្នកជាញឹកញាប់ នោះអ្នករាល់គ្នាត្រូវអធិស្ឋានដល់ព្រះវរបិតាឲ្យគេដោយនូវនាមយើង ។

២៤ ដូច្នេះ ចូរលើក[ក]ពន្លឺរបស់អ្នករាល់គ្នាឡើង ប្រយោជន៍ឲ្យបានភ្លឺដល់មនុស្សលោក ។ មើលចុះ យើងជា[ខ]ពន្លឺ ដែលអ្នក រាល់គ្នានឹងលើកឡើង — គឺនូវអ្វីៗដែលអ្នករាល់គ្នាបានឃើញយើងធ្វើ ។ មើលចុះ អ្នករាល់គ្នាឃើញថា យើងបានអធិស្ឋានដល់ ព្រះវរបិតា ហើយអ្នកទាំងអស់គ្នាបានធ្វើបន្ទាល់ទុក ។

២៥ ហើយអ្នករាល់គ្នាឃើញថា យើងមិនបានបញ្ជា[ក]នរណា

១២ *ក* ស.ប. ថ្ម.
១៣ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* ៣ នីហ្វៃ ១១:៣៩.
១៥ *ក* អាលម៉ា ៣៤:១៧–២៧.
ស.ប. ការអធិស្ឋាន.
១៦ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ដំរាប់នៃព្រះយេស៊ូវគ្រីស្ទ.
១៨ *ក* លូកា ២២:៣១; ២ នីហ្វៃ ២:១៧–១៨; គ. និង ស. ១០:២២–២៧.
២០ *ក* ម៉ាថាយ ២១:២២; ហេលេ. ១០:៥; មរ៉ូណៃ ៧:២៦; គ. និង ស. ៨៨:៦៣–៦៥.
២១ *ក* អាលម៉ា ៣៤:២១.
២៣ *ក* ៣ នីហ្វៃ ១៨:៣០.
២៤ *ក* ម៉ាថាយ ៥:១៦.
*ខ* ម៉ូសាយ ១៦:៩.
២៥ *ក* អាលម៉ា ៥:៣៣.

មួយក្នុងពួកអ្នក ឲ្យចេញទៅឡើយ ប៉ុន្តែបានបញ្ជាអ្នករាល់គ្នា
ឲ្យមក រកយើងវិញ ដើម្បីឲ្យអ្នករាល់គ្នាអាចស្ទាប ហើយឃើញ
យើង; ម្ល៉ោះហើយ អ្នករាល់គ្នាក៏ត្រូវធ្វើយ៉ាងនោះដល់មនុស្ស
លោកដែរ; ហើយអស់អ្នកណាដែលបំបាក់បញ្ញត្តិនេះ គឺបណ្ដោយ
ខ្លួនឲ្យត្រូវដឹកនាំទៅក្នុងការល្បួងវិញ ។
២៦ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាល
ព្រះយេស៊ូវមានព្រះបន្ទូលទាំងនេះហើយ នោះទ្រង់បែរមករកពួក
សិស្សរបស់ទ្រង់ ដែលទ្រង់បានរើស ហើយក៏មានព្រះបន្ទូលទៅ
ពួកគេថា៖
២៧ មើលចុះ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជា
ប្រាកដថា យើងប្រទានដល់អ្នករាល់គ្នា នូវបញ្ញត្តិមួយទៀត
រួចហើយ យើង នឹងត្រូវទៅជួបព្រះវរបិតានៃយើងវិញ
ដើម្បីយើងអាចបំពេញនូវព្រះបញ្ញត្តិផ្សេងៗទៀត ដែលទ្រង់
បានប្រទានដល់យើង ។
២៨ ហើយឥឡូវនេះ មើលចុះ នេះគឺជាបញ្ញត្តិដែលយើង
ប្រទានដល់អ្នករាល់គ្នាថា អ្នករាល់គ្នាមិនត្រូវបណ្ដោយ
ដោយចេតនា ឲ្យអ្នកណាមួយមកទទួលទានសាច់
និងលោហិតរបស់យើង ដោយពុំសក្តិសម ក្នុងកាលអ្នករាល់
គ្នាធ្វើបុណ្យនោះឡើយ ។
២៩ ព្រោះអស់អ្នកណាដែលទទួលទានសាច់ ហើយ
ផឹកលោហិតរបស់យើងដោយពុំសក្តិសម នោះគឺទទួលទាន
ហើយផឹកនូវ សេចក្ដីដាប់ទោសចំពោះព្រលឹងរបស់គេហើយ;
ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាដឹងថា មនុស្សណាមួយ
ពុំសក្តិសម នឹងទទួលទានសាច់ ហើយផឹកលោហិតរបស់យើង
នោះអ្នករាល់គ្នាត្រូវតែហាមឃាត់គេ ។
៣០ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នករាល់គ្នាមិនត្រូវ
បណ្ដេញអ្នកនោះ ចេញពីចំណោមអ្នកដែរ ប៉ុន្តែអ្នករាល់គ្នាត្រូវ
ធ្វើការ ងារបំរើអ្នកនោះ ហើយអធិស្ឋានដល់ព្រះវរបិតាឲ្យគេ
ដោយនូវនាមយើងវិញ; ហើយប្រសិនបើអ្នកនោះប្រែចិត្ត ហើយ
ទទួលបុណ្យ ជ្រមុជទឹក ដោយនូវនាមយើង ពេលនោះ អ្នករាល់
គ្នាត្រូវទទួលគេ ហើយចែកដល់គេ នូវសាច់ និងលោហិត
របស់យើងបាន ។
៣១ ប៉ុន្តែបើសិនជាគេមិនប្រែចិត្តទេ អ្នកនោះពុំត្រូវរាប់ក្នុង
ចំណោមរាស្ត្រយើងឡើយ ដើម្បីកុំឲ្យគេបំផ្លាញរាស្ត្រយើង
ត្បិតមើលចុះ យើងស្គាល់ចៀមរបស់យើង ហើយចៀមទាំងនោះ
ត្រូវបានរាប់ចំនួនរួចហើយ ។
៣២ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកមិនត្រូវបណ្ដេញ
គេចេញពីសាលាប្រជុំរបស់អ្នក ឬពីកន្លែងថ្វាយបង្គំរបស់អ្នកដែរ
ត្បិតចំពោះអ្នកនោះហើយដែលត្រូវធ្វើការងារបំរើ; ត្បិតអ្នក
រាល់គ្នាពុំដឹងថា ដល់ពេលណាទេ ដែលអ្នកនោះនឹងត្រឡប់
មកវិញ ហើយប្រែចិត្ត ហើយមករកយើង ដោយអស់ពីដួងចិត្ត
ហើយយើងនឹងប្រោសឲ្យគេបានជា; ហើយអ្នករាល់គ្នានឹងទៅជាជា
មធ្យោបាយ ក្នុងការនាំមកនូវសេចក្ដីសង្គ្រោះដល់គេ ។
៣៣ ដូច្នេះ ចូរអ្នករាល់គ្នាកាន់តាមពាក្យទាំងនេះ ដែល
យើងបានបញ្ជាដល់អ្នក ដើម្បីកុំឲ្យអ្នករាល់គ្នានៅក្រោមការ
កាត់ទោស; ត្បិតអ៊ី វេទនាដល់អ្នកណា ដែលព្រះវរបិតា
ទ្រង់កាត់ទោស ។
៣៤ ហើយយើងប្រទានដល់អ្នកនូវបញ្ញត្តិទាំងនេះ ពីព្រោះមក
ពីការទាស់ទែងគ្នា នៅក្នុងចំណោមពួកអ្នក ។ មានពរហើយ
អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នាគ្មានការទាស់ទែង នៅក្នុង
ចំណោមពួកអ្នក ។
៣៥ ហើយឥឡូវនេះ យើងទៅឯព្រះវរបិតាវិញ ពីព្រោះជា
ការចាំបាច់ ដែលយើងត្រូវទៅឯព្រះវរបិតា ដើម្បីអ្នករាល់គ្នា ។
៣៦ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់បានបញ្ចប់នូវពាក្យទាំងនេះហើយ នោះទ្រង់ពាល់ ពួកសិស្ស
ដែលទ្រង់បានរើស ម្ដងម្នាក់ៗ រហូតដល់ទ្រង់បានពាល់គេគ្រប់គ្នា
ហើយទ្រង់ក៏មានព្រះបន្ទូលទៅពួកគេ នៅពេលទ្រង់ពាល់ពួកគេ ។
៣៧ ហើយហ្វូងមនុស្សមិនបានឮ នូវពាក្យទាំងឡាយដែលទ្រង់
មានព្រះបន្ទូលនោះទេ ដូច្នេះ ពួកគេមិនបានធ្វើបន្ទាល់ឡើយ;
តែពួកសិស្សបានធ្វើបន្ទាល់ថា ទ្រង់បានប្រទានពួកគេនូវអំណាច

២៥ *ខ* ៣ នីហ្វៃ ១១:១៤–១៧.
២៧ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*ខ* ៣ នីហ្វៃ ១៦:១–៣.
២៨ *ក* ១ កូរិន. ១១:២៧–៣០.
*ខ* មរមន ៩:២៩.
២៩ *ក* ស.ប. លោហិត; បុណ្យរំឭក.
*ខ* គ. និង ស. ៤៦:៤.
៣០ *ក* គ. និង ស. ៤៦:៣.
៣១ *ក* យ៉ូហាន ១០:១៤; អាលម៉ា ៥:៣៨; ៣ នីហ្វៃ ១៥:២៤.
៣២ *ក* ៣ នីហ្វៃ ៩:១៣–១៤; គ. និង ស. ១១២:១៣.
៣៣ *ក* ស.ប. ដាក់ទោស, ការដាក់ទោស.
៣៤ *ក* ៣ នីហ្វៃ ១១:២៨–៣០.
៣៥ *ក* ១ យ៉ូហាន ២:១; ២ នីហ្វៃ ២:៩; ម៉ូរ៉ូណៃ ៧:២៧–២៨; គ. និង ស. ២៩:៥.
៣៦ *ក* ស.ប. ដៃ, ការដាក់.
*ខ* ១ នីហ្វៃ ១២:៧; ៣ នីហ្វៃ ១៩:៤.
៣៧ *ក* ស.ប. អំណាច.

ដើម្បីប្រគល់[ខ]ព្រះវិញ្ញាណបរិសុទ្ធ ។ ហើយខ្ញុំនឹងបង្ហាញដល់អ្នក
រាល់គ្នា នៅពេលក្រោយថា ទីបន្ទាល់នេះគឺពិត ។
៣៨ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់បាន[ក]ពាល់ពួកគេគ្រប់គ្នាហើយ នោះក៏មានពពកមួយបានមក
គ្របដណ្ដប់ហ្វូងមនុស្ស ដែលធ្វើឲ្យគេមិនអាចមើលឃើញ
ព្រះយេស៊ូវឡើយ ។
៣៩ ហើយនៅពេលពពកគ្របដណ្ដប់ពួកគេ នោះទ្រង់
យាងចេញពីពួកគេទៅ ហើយបានយាងឡើងទៅស្ថានសួគ៌ ។
ហើយពួកសិស្សបានឃើញ ហើយបានធ្វើបន្ទាល់ថា ទ្រង់បាន
យាងឡើងទៅស្ថានសួគ៌វិញ ៕

## ជំពូកទី ១៩

*ពួកសិស្ស១២នាក់ធ្វើការងារបំរើដល់ប្រជាជន ហើយអធិស្ឋានសូមព្រះវិញ្ញាណបរិសុទ្ធ — ពួកគេបានទទួលបុណ្យជ្រមុជទឹក ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ និងការងារបំរើពីពួកទេវតា — ព្រះយេស៊ូវទ្រង់អធិស្ឋាន ដោយប្រើពាក្យសំដីដែលមិនអាច សរសេរទុកបានឡើយ — ទ្រង់បញ្ជាក់នូវសេចក្ដីជំនឿដ៏ធំក្រៃលែង របស់ពួកសាសន៍នីហ្វៃទាំងនេះ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់បានយាងឡើងទៅស្ថានសួគ៌វិញហើយ នោះហ្វូងមនុស្សក៏បែក
ចេញពីគ្នា ហើយគេបាននាំប្រពន្ធរបស់គេ និងកូនចៅរបស់គេ
ត្រឡប់ទៅផ្ទះគេវិញរៀងៗខ្លួន ។
២ ហើយរំពេចនោះ ក៏មានសម្លេងអ៊ូអរពាសពេញ ក្នុង
ចំណោមប្រជាជន នៅ មុនពេលព្រលប់ថា ហ្វូងមនុស្សបាន
ឃើញព្រះ យេស៊ូវ ហើយថា ទ្រង់បានធ្វើការងារបំរើដល់ពួកគេ
ហើយថា ទ្រង់នឹងបង្ហាញរូបអង្គទ្រង់ ដល់ហ្វូងមនុស្ស នៅថ្ងៃ
ស្អែកទៀត ។
៣ មែនហើយ នៅពេញមួយយប់ ចេះតែមានសម្លេងអ៊ូអរ
ពាសពេញ អំពីព្រះយេស៊ូវ; ហើយដរាបដល់បានឮដល់មនុស្ស
ជាច្រើន មែនហើយ មានចំនួនមនុស្សដ៏ច្រើនលើសលប់ បាន
ធ្វើការយ៉ាងខិតខំអស់មួយយប់ស្មើ ដើម្បីស្អែកឡើង គេ
អាចទៅកាន់ទីកន្លែង ដែលព្រះយេស៊ូវទ្រង់នឹងបង្ហាញរូបអង្គទ្រង់
ដល់ហ្វូងមនុស្សទៀត ។
៤ ហើយហេតុការណ៍បានកើតឡើងថា លុះដល់ស្អែកឡើង
កាលហ្វូងមនុស្សបានប្រមូលគ្នាមក មើលចុះ នីហ្វៃ និងប្អូន
របស់លោក ដែលលោកបានប្រោសពីស្លាប់មកវិញ មាន
ឈ្មោះថា ធីម៉ូថេ និងកូនប្រុសលោកផង មានឈ្មោះថា
យ៉ូណាស ព្រមទាំង ម៉ាថូណៃ និងប្អូនលោក គឺម៉ាថូណៃហា
និងគូមេន និងគូមេណូនហៃ និងយេរេមា និងសេមណុន និង
យ៉ូណាស និងសេដេគា និងអេសាយ — ឥឡូវនេះ ពួក
គេនេះហើយដែលជាសិស្ស ដែលព្រះយេស៊ូវទ្រង់បានរើស —
ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានដើរទៅឈរ
នៅកណ្ដាលចំណោមហ្វូងមនុស្ស ។
៥ ហើយមើលចុះ ហ្វូងមនុស្សមានចំនួនច្រើនពេក ទើបពួកគេ
បានបញ្ជាឲ្យបណ្ដាជនបែកគ្នាចេញជា១២ក្រុម ។
៦ ហើយពួក១២នាក់ បានបង្រៀនហ្វូងមនុស្ស;
ហើយមើលចុះ ពួកគេបានបញ្ជាឲ្យហ្វូងមនុស្សលុតជង្គង់ចុះ
ទៅលើផ្ទៃផែនដី ហើយអធិស្ឋានដល់ព្រះវរបិតា ដោយនូវ
ព្រះនាមព្រះយេស៊ូវ ។
៧ ហើយពួកសិស្សក៏អធិស្ឋានដល់ព្រះវរបិតា ដោយនូវ
ព្រះនាមព្រះយេស៊ូវដែរ ។ ហើយហេតុការណ៍បានកើតឡើងថា
ពួកគេ បានក្រោកឡើង ហើយបានធ្វើការងារបំរើដល់ប្រជាជន ។
៨ ហើយកាលពួកគេបានធ្វើការងារបំរើ នូវពាក្យទាំងឡាយ
នោះ ដែលព្រះយេស៊ូវទ្រង់មានបន្ទូល — គឺពុំមានខុសពីពាក្យ
ដែលព្រះយេស៊ូវ ទ្រង់មានព្រះបន្ទូលបន្តិចសោះឡើយ —
មើលចុះ គេបានលុតជង្គង់ទៀត ហើយបានអធិស្ឋានដល់ព្រះវរបិតា
ដោយនូវព្រះនាមព្រះយេស៊ូវ ។
៩ ហើយពួកគេបានអធិស្ឋាន[ក]សូមនូវអ្វីៗ ដែលគេចង់បានបំផុត;
ហើយពួកគេមានប្រាថ្នាសូមឲ្យព្រះវិញ្ញាណបរិសុទ្ធបាន ប្រទាន
ដល់ពួកគេ ។
១០ ហើយកាលពួកគេបានអធិស្ឋានចប់ហើយ នោះពួកគេបាន
ដើរចុះទៅឯមាត់ទឹក ឯហ្វូងមនុស្សក៏ដើរតាមពួកគេ ។
១១ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃបាន[ក]ចុះទៅក្នុង
ទឹក ហើយបានទទួលបុណ្យជ្រមុជទឹក ។
១២ ហើយលោកបានងើបឡើងពីទឹកមកវិញ ហើយក៏
ចាប់ផ្ដើមធ្វើបុណ្យជ្រមុជទឹក ។ ហើយលោកបានធ្វើបុណ្យ
ជ្រមុជទឹកឲ្យ អ្នកអស់ទាំងនោះ ដែលព្រះយេស៊ូវទ្រង់បានរើស ។
១៣ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេទាំង

៣៧ *ខ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.

៣៨ *ក* និក្ខ. ១៩:៩, ១៦.

១៩ ៩*ក* ៣ នីហ្វៃ ៩:២០.

១១ *ក* ៣ នីហ្វៃ ១១:២៣.

អស់គ្នាបាន[ក]ទទួលបុណ្យជ្រមុជទឹក និងងើបឡើងពីទឹកមកហើយ
នោះព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកសណ្ឋិតលើគេ ហើយពួក
គេបានពោរពេញទៅដោយ[ខ]ព្រះវិញ្ញាណបរិសុទ្ធ និងដោយភ្លើង ។
១៤ ហើយមើលចុះ ពួកគេត្រូវបាន[ក]ឡោមព័ទ្ធ
ហាក់បីដូចជាដោយភ្លើង; ហើយភ្លើងនោះបានចុះមកពីស្ថានសួគ៌
ហើយបណ្ដា ជនបានឃើញ ហើយបានធ្វើបន្ទាល់អំពីការណ៍នេះ;
ហើយពួកទេវតាបានចុះមកពីស្ថានសួគ៌ ហើយបានធ្វើការងារបំរើដល់
ពួកគេ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា នៅពេលពួក
ទេវតាកំពុងតែធ្វើការងារបំរើដល់ពួកសិស្ស មើលចុះ ព្រះយេស៊ូវ
ទ្រង់បានយាងមកឈរនៅចំកណ្ដាល ហើយបានធ្វើការងារបំរើដល់
ពួកគេ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់មានព្រះបន្ទូលទៅ
ហ្វូងមនុស្ស ហើយបានបញ្ជាឲ្យពួកគេលុតជង្គង់ចុះទៅលើដី
ទៀត ហើយឲ្យពួកសិស្សរបស់ទ្រង់លុតជង្គង់ចុះទៅលើដីដែរ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេទាំង
អស់គ្នាបានលុតជង្គង់ចុះទៅលើដីហើយ នោះទ្រង់បានបញ្ជាឲ្យ
ពួក សិស្សរបស់ទ្រង់អធិស្ឋាន ។
១៨ ហើយមើលចុះ ពួកគេបានចាប់ផ្ដើមអធិស្ឋាន; ហើយពួក
គេបានអធិស្ឋានដល់ព្រះយេស៊ូវ ដោយហៅទ្រង់ថា ជាព្រះ
អម្ចាស់ របស់គេ និងជាព្រះរបស់ពួកគេ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់
យាងចេញពីកណ្ដាលពួកគេ ហើយបានយាងទៅឆ្ងាយបន្តិចពីពួក
គេ ក៏ក្រាបចុះទៅដី ហើយទ្រង់មានព្រះបន្ទូលថា៖
២០ ព្រះវរបិតាអើយ ទូលបង្គំសូមអរគុណព្រះអង្គ ដែលទ្រង់
បានប្រទានព្រះវិញ្ញាណបរិសុទ្ធ ដល់ពួកអ្នកដែលទូលបង្គំបានរើស
ទាំងនេះ; ហើយនេះគឺមកពីជំនឿរបស់ពួកគេដល់ទូលបង្គំ
ទើបទូលបង្គំបានរើសពួកគេចេញពីមនុស្សលោកមក ។
២១ ព្រះវរបិតាអើយ ទូលបង្គំសូមអធិស្ឋានដល់ព្រះអង្គ
សូមទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធ ដល់អស់អ្នកណា ដែល
នឹងជឿដល់ ពាក្យសំដីរបស់ពួកគេ ។
២២ ព្រះវរបិតាអើយ ព្រះអង្គបានប្រទានព្រះវិញ្ញាណបរិសុទ្ធ
ដល់ពួកគេ ពីព្រោះពួកគេបានជឿដល់ទូលបង្គំ; ហើយព្រះអង្គ
ទតឃើញថា ពួកគេជឿដល់ទូលបង្គំ ពីព្រោះព្រះអង្គឮពួកគេ
ហើយពួកគេអធិស្ឋានដល់ទូលបង្គំ; ហើយពួកគេអធិស្ឋានដល់
ទូលបង្គំ ពីព្រោះទូលបង្គំនៅជាមួយនឹងពួកគេ ។
២៣ ហើយឥឡូវនេះ ឱព្រះវរបិតាអើយ ទូលបង្គំសូម
អធិស្ឋានដល់ព្រះអង្គសំរាប់ពួកគេ និងសំរាប់អស់អ្នកណា
ដែលនឹងជឿ ដល់ពាក្យសំដីរបស់ពួកគេ សូមឲ្យពួកគេ
អាចជឿដល់ទូលបង្គំ ដើម្បីទូលបង្គំអាចនៅក្នុងពួកគេ
ឱព្រះវរបិតាអើយ [ក]ដូចជាព្រះអង្គគង់ នៅក្នុងទូលបង្គំ ដើម្បីឲ្យ
[ខ]យើងអាចទៅជាមួយ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់បានអធិស្ឋានដល់ព្រះវរបិតាចប់ហើយ នោះទ្រង់បានយាង
មក ឯពួកសិស្សរបស់ទ្រង់ ហើយមើលចុះ ពួកគេនៅតែអធិស្ឋាន
គ្មានឈប់សោះ គឺអធិស្ឋានដល់ទ្រង់; ហើយពួកគេមិនបាន[ក]បន្ថែម
ពាក្យ [ខ]ច្រើនឡើយ ត្បិតត្រូវបានប្រទានដល់ពួកគេនូវអ្វីដែលពួក
គេត្រូវអធិស្ឋានហើយ ហើយពួកគេបានពោរពេញទៅដោយ
សេចក្ដីប្រាថ្នា ។
២៥ ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់បាន
ប្រទានពរដល់ពួកគេ ក្នុងកាលពួកគេអធិស្ឋានដល់ទ្រង់; [ក]ហើយ
ព្រះភក្ត្ររបស់ទ្រង់បានញញឹមទៅរកពួកគេ ហើយរស្មីនៃព្រះភក្ត្រ
របស់ទ្រង់បានភ្លឺទៅលើពួកគេ ហើយមើលចុះ ពួកគេមាន
[ខ]ពណ៌សដូច ជាព្រះភក្ត្រ និងព្រះពស្ត្ររបស់ព្រះយេស៊ូវដែរ;
ហើយមើលចុះ ឯសេចក្ដីសនោះ គឺសេចក្ដីស សជាងអ្វីៗទាំង
អស់ មែនហើយ គឺគ្មាន អ្វីនៅលើផែនដីនេះ ដែលស
ដូចជាសេចក្ដីសនោះឡើយ ។
២៦ ហើយព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅពួកគេថា៖
ចូរបន្តការអធិស្ឋានចុះ; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេ
ពុំ ឈប់អធិស្ឋានដែរ ។
២៧ ហើយទ្រង់បានបែរចេញពីពួកគេទៀត ហើយបាន
យាងទៅឆ្ងាយបន្តិច ហើយបានក្រាបចុះទៅដី; ហើយទ្រង់បាន
អធិស្ឋាន ដល់ព្រះវរបិតាទៀតថា៖
២៨ ឱព្រះវរបិតាអើយ ទូលបង្គំសូមអរគុណដល់ព្រះអង្គ

១៣ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ខ* ៣ នីហ្វៃ ១២:២; មរមន ៧:១០. ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
១៤ *ក* ហេលេ. ៥:២៣–២៤, ៤៣–៤៥; ៣ នីហ្វៃ ១៧:២៤.
២៣ *ក* ៣ នីហ្វៃ ៩:១៥.
*ខ* យ៉ូហាន ១៧:២១–២៣. ស.ប. ការរួបរួមតែមួយ.
២៤ *ក* ម៉ាថាយ ៦:៧.
*ខ* គ. និង ស. ៤៦:៣០.
២៥ *ក* ជនគ. ៦:២៣–២៧.
*ខ* ស.ប. ការប្រែរូប — ពួកអ្នកដែលបានប្រែរូប.

ដែលទ្រង់បានញាំងពួកអ្នកដែលទូលបង្គំបានរើសឲ្យ[ក]បរិសុទ្ធ
ពីព្រោះ មកពីសេចក្ដីជំនឿរបស់ពួកគេ ហើយទូលបង្គំអធិស្ឋាន
សំរាប់ពួកគេ និងសំរាប់អស់អ្នកណា ដែលនឹងជឿដល់ពាក្យ
សំដីរបស់ពួកគេ សូមឲ្យពួកគេបានបរិសុទ្ធនៅក្នុងទូលបង្គំ
តាមរយៈសេចក្ដីជំនឿជឿដល់ពាក្យសំដីរបស់ពួកគេ ដូចជាពួក
គេបានបរិសុទ្ធនៅក្នុង ទូលបង្គំដែរ ។
២៩ ឱព្រះវរបិតាអើយ ទូលបង្គំពុំអធិស្ឋានសំរាប់មនុស្ស
លោកទេ ប៉ុន្តែសំរាប់អស់អ្នកណា ដែលទ្រង់បានប្រទានដល់
ទូលបង្គំ [ក]ចេញមកពីមនុស្សលោកវិញ ពីព្រោះមកពីសេចក្ដីជំនឿ
របស់គេ សូមឲ្យពួកគេបានបរិសុទ្ធនៅក្នុងទូលបង្គំ ដើម្បីឲ្យ
ទូលបង្គំអាចនៅក្នុង ពួកគេ ដូចជាព្រះវរបិតាគង់នៅក្នុងទូលបង្គំ
ដើម្បីឲ្យយើងអាចបានទៅជាមួយ ដើម្បីឲ្យទូលបង្គំអាចបាន
រុងរឿងនៅក្នុងពួកគេ ។
៣០ ហើយកាលព្រះយេស៊ូវមានព្រះបន្ទូលយ៉ាងនេះហើយ
នោះទ្រង់បានយាងមកឯពួកសិស្សរបស់ទ្រង់វិញ; ហើយមើលចុះ
ពួកគេនៅតែអធិស្ឋានដល់ព្រះអង្គយ៉ាងខ្ជាប់ខ្ជួន គ្មានឈប់សោះ;
ហើយទ្រង់បានញញឹមទៅរកពួកគេទៀត; ហើយមើលចុះ ពួក
គេ[ក]ស ដូចជាព្រះយេស៊ូវដែរ ។
៣១ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បាន
យាងចេញទៅឆ្ងាយបន្តិចទៀត ហើយបានអធិស្ឋានដល់ព្រះវរបិតា;
៣២ ហើយគ្មានអណ្ដាតណាអាចថ្លែង[ក]ប្រាប់ពាក្យ ដែលទ្រង់
បានអធិស្ឋាន ហើយគ្មានមនុស្សណាអាចសរសេរនូវពាក្យ ដែល
ទ្រង់បានអធិស្ឋាននោះឡើយ ។
៣៣ ហើយហ្វូងមនុស្សបានឮ ហើយបានធ្វើបន្ទាល់; ហើយ
ចិត្តគេបានបើក បណ្ដាលឲ្យគេយល់នៅក្នុងចិត្តគេ នូវពាក្យ ទាំង
ឡាយដែលទ្រង់បានអធិស្ឋាន ។
៣៤ ទោះជាយ៉ាងណាក៏ដោយ គង់តែពាក្យទាំងឡាយដែល
ទ្រង់អធិស្ឋាននោះមហិមា ហើយអស្ចារ្យណាស់ ដែលពួកគេមិន
អាចកត់ទុកបានឡើយ ហើយគ្មានមនុស្សណាអាច[ក]ពោលបានដែរ ។
៣៥ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់បានបញ្ចប់នូវការអធិស្ឋានហើយ នោះទ្រង់បានយាងមកឯ
ពួកសិស្សវិញ ហើយមានព្រះបន្ទូលទៅពួកគេថា៖ យើងពុំដែល
បានឃើញ[ក]សេចក្ដីជំនឿដ៏មហិមាបែបនេះ នៅក្នុងចំណោមពួក
សាសន៍ យូដាឡើយ; ហេតុដូច្នោះហើយ បានជាយើងពុំអាចបង្ហាញ
ដល់ពួកគេ នូវអព្ភូតហេតុដ៏មហិមាយ៉ាងនេះទេ ពីព្រោះតែ
[ខ]ការឥតជំនឿនៃ ពួកគេ ។
៣៦ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា គ្មានអ្នកណាមួយក្នុង
ពួកគេ ដែលបានឃើញនូវការណ៍ដ៏មហិមាទាំងឡាយ ដូចដែល
អ្នករាល់គ្នាបានឃើញនោះទេ; ហើយពួកគេក៏ពុំដែលបានឮនូវការណ៍
ដ៏មហិមាទាំងឡាយ ដូចដែលអ្នករាល់គ្នាបានឮនោះឡើយ ៕

## ជំពូកទី ២០

*ព្រះយេស៊ូវទ្រង់ប្រទាននំប៉័ង និងស្រាទំពាំងបាយជូរយ៉ាងប្លែកអស្ចារ្យ ហើយធ្វើបុណ្យរំឭកម្ដងទៀតដល់ពួកគេ — សំណល់នៃយ៉ាកុប នឹងស្គាល់ព្រះអម្ចាស់ ជាព្រះរបស់គេ ហើយនឹងគ្រងទ្វីបអាមេរិកទុកជាមរតក — ព្រះយេស៊ូវគឺជាព្យាការីដូចជាម៉ូសេ ហើយពួកសាសន៍ នីហ្វៃ គឺជាកូនចៅរបស់ពួកព្យាការី — រាស្ត្រឯទៀតរបស់ព្រះអម្ចាស់ នឹងបានប្រមូលមកឯក្រុងយេរូសាឡិម ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាឲ្យហ្វូង
មនុស្សឈប់អធិស្ឋាន ព្រមទាំងពួកសិស្សរបស់ទ្រង់ផង ។ ហើយ
ទ្រង់បាន បញ្ជាដល់ពួកគេថា ពួកគេមិនត្រូវឈប់[ក]អធិស្ឋាននៅក្នុង
ចិត្តរបស់គេឡើយ ។
២ ហើយទ្រង់បានបញ្ជាឲ្យពួកគេក្រោកឈរឡើង ។ ហើយ
ពួកគេក៏ក្រោកឈរឡើង ។
៣ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានកាច់
នំប៉័ងជាថ្មី ហើយប្រទានពរដល់នំប៉័ង ហើយក៏ប្រទានឲ្យពួក
សិស្ស បរិភោគ ។
៤ ហើយកាលពួកគេបានបរិភោគរួចហើយ នោះទ្រង់បាន
បញ្ជាឲ្យពួកគេកាច់នំប៉័ង ហើយចែកទៅហ្វូងមនុស្ស ។
៥ ហើយកាលពួកគេឲ្យនំប៉័ងទៅបណ្ដាជនហើយ នោះទ្រង់
ប្រទានស្រាទំពាំងបាយជូរឲ្យពួកគេផឹក ហើយក៏បញ្ជាដល់ពួកគេ
ឲ្យចែកដល់ហ្វូងមនុស្ស ។

២៨ *ក* មរ៉ូណៃ ៧:៤៨;
គ. និង ស. ៥០:២៨–២៩;
៨៨:៧៤–៧៥.
ស.ប. សុទ្ធ, សុទ្ធសាធ.
២៩ *ក* យ៉ូហាន ១៧:៦.
៣០ *ក* ម៉ាថាយ ១៧:២.
៣២ *ក* គ. និង ស. ៧៦:១១៦.
៣៤ *ក* ២ កូរិន. ១២:៤;
៣ នីហ្វៃ ១៧:១៧.
៣៥ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* ម៉ាថាយ ១៣:៥៨.
ស.ប. ការឥតជំនឿ.
**២០** ១*ក* ២ នីហ្វៃ ៣២:៩;
ម៉ូសាយ ២៤:១២.

៦ ឥឡូវនេះ គ្មាន[ក]នំបុ័ង ឬក៏ស្រាទំពាំងបាយជូរដែលពួកសិស្ស ឬហ្វូងមនុស្សបានយកមកឡើយ;

៧ ប៉ុន្តែ ទ្រង់បានប្រទាន[ក]នំបុ័ងទៅឲ្យពួកគេបរិភោគ និងស្រាទំពាំងបាយជូរ ទៅឲ្យពួកគេផឹកជាពិតប្រាកដ ។

៨ ហើយទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ អ្នកណា[ក]ទទួលទាននំបុ័ងនេះ គឺទទួលទានរូបកាយយើង ទៅក្នុងព្រលឹងអ្នកនោះ; ហើយអ្នកណាផឹកស្រាទំពាំងបាយជូរនេះ គឺផឹកលោហិតយើង ទៅក្នុងព្រលឹងអ្នកនោះ; ហើយព្រលឹងអ្នកនោះ នឹងពុំចេះស្រេកឃ្លាន ឡើយ តែបានឆ្អែតជានិច្ច ។

៩ ឥឡូវនេះ កាលបណ្ដាជនគ្រប់គ្នាបានបរិភោគ និងផឹករួចហើយ មើលចុះ ពួកគេបានពោរពេញទៅដោយព្រះវិញ្ញាណ; ហើយពួកគេបានបន្លឺសម្លេងព្រមគ្នា ហើយសរសើរដំកើងដល់ព្រះយេស៊ូវ គឺជាព្រះដែលពួកគេបានឃើញ ហើយបានឮ ។

១០ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានសរសើរដំកើងដល់ព្រះយេស៊ូវហើយ នោះទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ មើលចុះ ឥឡូវនេះ យើងបានបង្ហើយនូវបញ្ញត្តិដែលព្រះវរបិតា ទ្រង់បានបញ្ជាដល់យើង អំពីប្រជាជននេះ ដែលជាសំណល់ នៃវង្សអ៊ីស្រាអែល ។

១១ អ្នករាល់គ្នាចាំថា យើងបាននិយាយជាមួយនឹងអ្នករាល់គ្នា ហើយប្រាប់អ្នករាល់គ្នាថា កាលណា[ក]ពាក្យពេចន៍របស់[ខ]អេសាយ បានបំពេញ — មើលចុះ ពាក្យទាំងនោះបានកត់ទុកហើយ ហើយអ្នករាល់គ្នាមានពាក្យទាំងនោះ នៅខាងមុខអ្នក ដូច្នេះ ចូរពិចារណា មើលចុះ —

១២ ហើយប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា កាលណាពាក្យទាំងនោះនឹងត្រូវបានបំពេញ នោះ[ក]សេចក្ដីសញ្ញាដែលព្រះវរបិតា ទ្រង់បានធ្វើជាមួយនឹងប្រជាជននេះ ក៏នឹងត្រូវបានបំពេញដែរ ឱវង្សអ៊ីស្រាអែលអើយ ។

១៣ ហើយដល់ពេលនោះ [ក]សំណល់ទាំងឡាយដែលនឹងត្រូវបាន[ខ]ខ្ចាត់ព្រាត់ ពាសពេញលើផ្ទៃផែនដី នោះនឹងត្រូវបាន[គ]ប្រមូលមកពីទិសខាងកើត និងពីខាងលិច និងពីខាងត្បូង និងពីខាងជើង; ហើយពួកគេនឹងត្រូវបាននាំមកឲ្យ[ឃ]ស្គាល់ព្រះអម្ចាស់ជាព្រះរបស់គេ ដែលបានប្រោសលោះពួកគេ ។

១៤ ហើយព្រះវរបិតាទ្រង់បានបញ្ជាដល់យើងថា យើងត្រូវប្រទាន[ក]ដែនដីនេះ ដល់អ្នករាល់គ្នាទុកជាមរតក ។

១៥ ហើយយើងប្រាប់អ្នករាល់គ្នាថា បើសិនជាពួកសាសន៍ដទៃពុំប្រែចិត្តទេ បន្ទាប់ពីគេបានទទួលព្រះពរ គឺបន្ទាប់ពីគេបានធ្វើរាស្ត្រយើងឲ្យខ្ចាត់ព្រាត់ —

១៦ ពេលនោះ អ្នករាល់គ្នាដែលជាសំណល់នៃវង្សយ៉ាកុបនឹងទៅក្នុងចំណោមពួកគេ; ហើយអ្នករាល់គ្នានឹងនៅកណ្ដាលពួកគេ ដែលមានចំនួនច្រើន; ហើយអ្នករាល់គ្នានឹងនៅក្នុងចំណោមពួកគេ បីដូចជា[ក]សត្វសិង្ហមួយ នៅកណ្ដាលសត្វព្រៃទាំងឡាយ ហើយបីដូចជាកូនសត្វសិង្ហមួយនៅក្នុងហ្វូងចៀម បើសិនជាវាដើរឆ្លងកាត់ វានឹងជាន់ឈ្លីនៅក្រោមជើង ហើយហែកឲ្យទៅជាដុំៗ ហើយគ្មានអ្នកណាអាចដោះលែងបានឡើយ ។

១៧ ដៃរបស់អ្នករាល់គ្នានឹងត្រូវបានលើកឡើង វាយមារសត្រូវទាំងឡាយរបស់អ្នក ហើយពួកខ្មាំងសត្រូវរបស់អ្នកទាំងអស់ នឹងត្រូវកាត់កាល់ចេញ ។

១៨ ហើយយើងនឹង[ក]ប្រមូលរាស្ត្រយើង បីដូចជាមនុស្សម្នាក់ប្រមូលកណ្ដាប់ស្រូវដាក់ក្នុងជង្រុក ។

១៩ ត្បិតយើងនឹងធ្វើឲ្យរាស្ត្រយើង ដែលព្រះវរបិតាទ្រង់បានធ្វើសេចក្ដីសញ្ញាជាមួយ មែនហើយ យើងនឹងធ្វើឲ្យ[ក]ស្នែងអ្នករាល់ គ្នាបានទៅជាដែក ហើយយើងនឹងធ្វើឲ្យក្រចកអ្នករាល់គ្នាបានទៅជាលង្ហិន ។ ហើយអ្នករាល់គ្នានឹងវាយរាស្ត្រឯទៀតឲ្យខ្ទេចខ្ទី ជាកំណាត់; ហើយយើងនឹងថ្វាយផលប្រយោជន៍របស់គេដល់ព្រះអម្ចាស់ និងទ្រព្យសម្បត្តិរបស់គេ ដល់ព្រះ

៦ *ក* ម៉ាថាយ ១៤:១៩–២១.
៧ *ក* យ៉ូហាន ៦:៩–១៤.
៨ *ក* យ៉ូហាន ៦:៥០–៥៨;
៣ នីហ្វៃ ១៨:៧.
ស.ប. បុណ្យរំឭក.
១១ *ក* ៣ នីហ្វៃ ១៦:១៧–២០;
២៣:១–៣.
*ខ* ២ នីហ្វៃ ២៥:១–៥;
មរមន ៨:២៣.
១២ *ក* ៣ នីហ្វៃ ១៥:៧–៨.
១៣ *ក* ៣ នីហ្វៃ ១៦:១១–១២;
២១:២–៧.
*ខ* ស.ប. អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
*គ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ឃ* ៣ នីហ្វៃ ១៦:៤–៥.
១៤ *ក* ស.ប. ដែនដីសន្យា.
១៥ *ក* ៣ នីហ្វៃ ១៦:១០–១៤.
១៦ *ក* មរមន ៥:២៤;
គ. និង ស. ១៩:២៧.
*ខ* មីកា ៥:៨–៩;
៣ នីហ្វៃ ១៦:១៤–១៥; ២១:១២.
១៨ *ក* មីកា ៤:១២.
១៩ *ក* មីកា ៤:១៣.

អម្ចាស់នៃផែនដីទាំងមូល ។ ហើយមើលចុះ គឺយើងនេះហើយដែលធ្វើការនេះ ។

២០ ហើយហេតុការណ៍នឹងកើតឡើងថា ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា [ក]ដាវយុត្តិធម៌របស់យើង នឹងព្យួរនៅលើពួកគេ នៅថ្ងៃនោះ; ហើយលើកលែងពួកគេប្រែចិត្ត បើពុំនោះសោតទេ ដាវនោះនឹងធ្លាក់មកលើពួកគេ ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា មែនហើយ ទាំងធ្លាក់មកលើសាសន៍ទាំងអស់នៃពួកសាសន៍ដទៃ ។

២១ ហើយហេតុការណ៍បានកើតឡើងថា ឱវង្សអ៊ីស្រាអែលអើយ គឺយើងនឹងតាំង[ក]រាស្ត្រយើងឡើង ។

២២ ហើយមើលចុះ ប្រជាជននេះហើយដែលយើងនឹងតាំងឡើង នៅលើដែនដីនេះ ចំពោះការបំពេញនូវ[ក]សេចក្ដីសញ្ញា ដែល យើងបានធ្វើជាមួយនឹងពួកអយ្យកោអ្នក គឺយ៉ាកុប; ហើយដែនដីនេះនឹងទៅជាក្រុង[ខ]យេរូសាឡិមថ្មីមួយ ។ ហើយអំណាចទាំងឡាយ នៃស្ថានសួគ៌ នឹងមាននៅកណ្ដាលប្រជាជននេះ; មែនហើយ [គ]សូម្បីតែយើង ក៏នឹងនៅកណ្ដាលអ្នករាល់គ្នាដែរ ។

២៣ មើលចុះ [ក]គឺយើងនេះហើយដែលលោកម៉ូសេមានប្រសាសន៍ថា៖ មានព្យាការីម្នាក់ដែលព្រះអម្ចាស់ជាព្រះនៃអ្នករាល់គ្នា នឹងបង្កើតឡើងដល់អ្នករាល់គ្នា ពីពួកបងប្អូនរាល់គ្នាមក ឲ្យដូចខ្ញុំ; លោកនោះហើយដែលអ្នករាល់គ្នាត្រូវស្ដាប់តាមគ្រប់ការណ៍ទាំង អស់ ដែលលោកនឹងប្រាប់ដល់អ្នក ។ ហើយហេតុការណ៍បានកើតឡើងថា អ្នកណាដែលមិនព្រមស្ដាប់តាមព្យាការីនោះទេ នោះនឹងត្រូវកាត់កាល់ចេញពីចំ ណោមប្រជាជន ។

២៤ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា មែនហើយ [ក]អស់ទាំងព្យាការី ចាប់តាំងពីសាំយូអែល និងពួកដែលមកតាមក្រោយទាំងប៉ុន្មាន ដូចដែលបាននិយាយ គឺបានធ្វើបន្ទាល់អំពីយើង ។

២៥ ហើយមើលចុះ អ្នករាល់គ្នាគឺជាកូនចៅនៃពួកព្យាការី; ហើយអ្នករាល់គ្នាគឺជាវង្សអ៊ីស្រាអែល; ហើយអ្នករាល់គ្នានៅក្នុង [ក]សេចក្ដីសញ្ញា ដែលព្រះវរបិតាទ្រង់បានធ្វើជាមួយនឹងពួកអយ្យកោអ្នក ដោយព្រះបន្ទូលទៅលោកអ័ប្រាហាំថា៖ [ខ]ដោយសារពូជអ្នក នោះគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងបានពរ ។

២៦ ព្រះវរបិតា ដោយបានប្រោសយើងឲ្យរស់ឡើងវិញ ដល់អ្នករាល់គ្នាមុនគេបង្អស់ ហើយបាន[ក]ចាត់ឲ្យយើងមកប្រទានពរដល់ អ្នករាល់គ្នា ក្នុងការនាំអ្នករាល់គ្នាគ្រប់រូប ចេញពីអំពើទុច្ចរិតរបស់ខ្លួន ការនេះគឺមកពីអ្នករាល់គ្នាជាកូនចៅក្នុងសេចក្ដីសញ្ញា —

២៧ ហើយបន្ទាប់ពីអ្នករាល់គ្នាបានពរហើយ នោះព្រះវរបិតានឹងបំពេញសេចក្ដីសញ្ញា ដែលទ្រង់បានធ្វើជាមួយនឹងលោកអ័ប្រាហាំ ដែលថា៖ [ក]ដោយសារពូជអ្នក នោះគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងបានពរ — គឺដោយចាក់ស្រោចព្រះវិញ្ញាណបរិសុទ្ធតាមរយៈយើង [ខ]ទៅលើពួកសាសន៍ដទៃ គឺជាព្រះពរទៅលើពួកសាសន៍ដទៃ ដែលនឹងធ្វើឲ្យគេខ្លាំងពូកែជាងរាស្ត្រឯទៀតចំពោះការ កំចាត់រាស្ត្រយើង ឱវង្សអ៊ីស្រាអែលអើយ ។

២៨ ហើយពួកគេនឹងទៅជា[ក]រំពាត់ដល់ប្រជាជននៅដែនដីនេះ ។ ទោះជាយ៉ាងណាក៏ដោយ គង់តែកាលណាពួកគេបានទទួល នូវភាពពោរពេញនៃដំណឹងល្អរបស់យើងហើយ ពេលនោះ បើសិនជាពួកគេធ្វើចិត្តរឹងរូសទាស់នឹងយើង នោះយើងនឹងបង្វិលអំពើទុច្ចរិតរបស់គេ មកលើក្បាលគេវិញ គឺព្រះវរបិតាទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

២៩ ហើយយើងនឹង[ក]នឹកចាំដល់សេចក្ដីសញ្ញា ដែលយើងបានធ្វើជាមួយនឹងរាស្ត្រយើង; ហើយយើងបានធ្វើសេចក្ដីសញ្ញាជាមួយ នឹងពួកគេ ថាយើងនឹង[ខ]ប្រមូលពួកគេ តាមពេលដែលយើងកំណត់ ថាយើងនឹងប្រគល់ដល់គេវិញ [គ]នូវដែនដីនៃពួកអយ្យកោគេទុកជា មរតក គឺជាដែនដី[ឃ]យេរូសាឡិម ដែលជាដែនដីសន្យា សំរាប់គេរៀងរហូត គឺព្រះវរបិតាទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

២០ *ក* ៣ នីហ្វៃ ២៩:៤.
២១ *ក* ៣ នីហ្វៃ ១៦:៨–១៥.
២២ *ក* លោកុ. ៤៩:២២–២៦;
គ. និង ស. ៥៧:២–៣.
*ខ* អេសាយ ២:២–៥;
៣ នីហ្វៃ ២១:២៣–២៤;
អេធើរ ១៣:១–១២;
គ. និង ស. ៨៤:២–៤.
ស.ប. ក្រុងយេរូសាឡិមថ្មី.
*គ* អេសាយ ៥៩:២០–២១;
ម៉ាឡាគី ៣:១; ៣ នីហ្វៃ ២៤:១.
២៣ *ក* ចោទិ. ១៨:១៥–១៩;
កិច្ចការ ៣:២២–២៣;
១ នីហ្វៃ ២២:២០–២១.
២៤ *ក* កិច្ចការ ៣:២៤–២៦;
១ នីហ្វៃ ១០:៥; យ៉ាកុប ៧:១១.
២៥ *ក* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*ខ* លោកុ. ១២:១–៣; ២២:១៨.
២៦ *ក* សុភា. ១៦:៦.
២៧ *ក* កាឡាទី ៣:៨; ២ នីហ្វៃ ២៩:១៤;
អ័ប្រា. ២:៩.
*ខ* ៣ នីហ្វៃ ១៦:៦–៧.
២៨ *ក* ៣ នីហ្វៃ ១៦:៨–៩.
២៩ *ក* អេសាយ ៤៤:២១;
៣ នីហ្វៃ ១៦:១១–១២.
*ខ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*គ* អេម៉ុស ៩:១៤–១៥.
*ឃ* ស.ប. ក្រុងយេរូសាឡិម.

៣០ ហើយហេតុការណ៍នឹងកើតឡើងថា ពេលនោះនឹងមកដល់ កាលភាពពោរពេញនៃដំណឹងល្អរបស់យើង នឹងត្រូវបានផ្សាយដល់ពួកគេ;

៣១ ហើយពួកគេនឹង[ក]ជឿដល់យើង ថាយើងជាព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ហើយនឹងអធិស្ឋានដល់ព្រះវរបិតា ដោយនូវនាមយើង ។

៣២ នៅពេលនោះ [ក]ពួកអ្នកយាមរបស់ពួកគេនឹងបន្លឺសម្លេងឡើង ហើយគេនឹងច្រៀងព្រមគ្នា; ត្បិតពួកគេនឹងយល់ឃើញ ព្រមព្រៀងគ្នា ។

៣៣ នៅពេលនោះ ព្រះវរបិតាទ្រង់នឹងប្រមូលពួកគេមកវិញ ហើយនឹងប្រគល់ក្រុងយេរូសាឡិមដល់ពួកគេ ទុកជាដែនដីនៃកេរ្តិ៍អាកររបស់គេ ។

៣៤ នៅពេលនោះ គេនឹងផ្លាយទៅក្នុងសេចក្ដីអំណរ — ឱទីស្ងាត់ជ្រងំនៃក្រុងយេរូសាឡិមអើយ [ក]ចូរច្រៀងព្រមគ្នាឡើង; ត្បិតព្រះវរបិតាទ្រង់បានកំសាន្តរាស្ត្រព្រះអង្គហើយ គឺទ្រង់បានប្រោសលោះក្រុងយេរូសាឡិម ។

៣៥ ព្រះវរបិតាទ្រង់បានលាតព្រះពាហុដ៏បរិសុទ្ធរបស់ទ្រង់នៅភ្នែកនៃគ្រប់ទាំងសាសន៍; ហើយគ្រប់ទាំងចុងផែនដីនេះនឹងឃើញសេចក្ដីសង្គ្រោះនៃព្រះវរបិតា; ហើយព្រះវរបិតានិងយើង គឺតែមួយ ។

៣៦ ហើយនៅពេលនោះ អ្វីៗដែលបានកត់ត្រាទុកនឹងកើតឡើងដែលថា៖ [ក]ចូរភ្ញាក់ឡើង ចូរភ្ញាក់ឡើង ឱក្រុងស៊ីយ៉ូនអើយ ចូរពាក់កម្លាំងរបស់អ្នក; ឱយេរូសាឡិមជាទីក្រុងបរិសុទ្ធអើយ ចូរប្រដាប់ដោយសំលៀកបំពាក់ដ៏រុងរឿងរបស់អ្នកចុះ ត្បិតពីនេះទៅមុខ នឹងគ្មានពួកមិនកាត់ស្បែក ឬពួកស្មោកគ្រោក ចូលមកក្នុងអ្នកទៀតឡើយ ។

៣៧ ចូររលាស់ខ្លួនចេញពីធូលីដី; ឱក្រុងយេរូសាឡិមអើយ ចូរក្រោកអង្គុយឡើង; ឱកូនស្រីនៃក្រុងស៊ីយ៉ូន ដែលជាឈ្លើយអើយ ចូរដោះចំណងពីកអ្នកចេញ ។

៣៨ ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ អ្នករាល់គ្នាបានត្រូវលក់ខ្លួនឥតយកថ្លៃ ហើយអ្នករាល់គ្នានឹងបានលោះមកវិញ ឥតបង់ប្រាក់ដែរ ។

៣៩ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា រាស្ត្រយើងនឹងស្គាល់នាមយើង; មែនហើយ នៅថ្ងៃនោះ ពួកគេនឹងស្គាល់ថាគឺយើងនេះហើយដែលបាននិយាយ ។

៤០ ហើយនៅពេលនោះ ពួកគេនឹងនិយាយថា៖ ល្អណាស់[ក]ហ្ន៎ គឺជើងនៃអ្នកនោះ ដែលដើរលើភ្នំ ជាអ្នកដែលនាំដំណឹងល្អមកដល់ពួកគេ ហើយ[ខ]ប្រកាសប្រាប់ពីសេចក្ដីសុខសាន្ត; ជាអ្នកដែលនាំដំណឹងល្អ ពីការប្រសើរមក ហើយថ្លែងប្រាប់ពីសេចក្ដីសង្គ្រោះ ដែលជាអ្នកពោលដល់ក្រុងស៊ីយ៉ូនថា៖ ព្រះនៃអ្នកទ្រង់សោយរាជ្យ!

៤១ ហើយនៅពេលនោះ នឹងមានសំរែកមួយស្រែកឡើងថា៖ [ក]ចូរចេញទៅ ចូរចេញទៅ ចូរឲ្យអ្នករាល់គ្នា ចេញពីទីនេះទៅចុះ ចូរកុំពាល់អ្វីដែល[ខ]មិនស្អាតឡើយ; ចូរចេញពីកណ្ដាលទីក្រុងនេះទៅ; ឱពួកអ្នក[គ]ដែលលើកយកគ្រឿងនៃព្រះអម្ចាស់អើយ ចូរញែកខ្លួនចេញជាស្អាតចុះ ។

៤២ ត្បិតអ្នករាល់គ្នានឹង[ក]ពុំត្រូវចេញទៅដោយរួសរាន់ ឬក៏រត់គេចឡើយ; ត្បិតព្រះអម្ចាស់ទ្រង់នឹងយាងទៅខាងមុខអ្នករាល់គ្នា ឯព្រះនៃសាសន៍អ៊ីស្រាអែលនឹងនៅពីខាងក្រោយអ្នក ។

៤៣ មើលចុះ អ្នកបំរើរបស់យើង នឹងប្រព្រឹត្តដោយប្រុងប្រយ័ត្ន; ទ្រង់នឹងបានដំកើងឡើង និងសរសើរ ហើយនឹងបានខ្ពស់បំផុត ។

៤៤ មានមនុស្សជាច្រើនប៉ុណ្ណាបានត្រូវស្រឡាំងកាំងដោយឃើញទ្រង់ — ព្រះភ័ក្ត្រទ្រង់ត្រូវខូចទៅខុសជាងមនុស្សនានា ហើយរាងកាយទ្រង់ក៏ខុសនឹងរាងកាយរបស់កូនចៅមនុស្សទាំងឡាយផង —

៤៥ នោះទ្រង់នឹងព្រួសលើសាសន៍ជា[ក]ច្រើនប៉ុណ្ណោះដែរ; ពួកមហាក្សត្រនឹងបិទមាត់ នៅចំពោះទ្រង់ ត្បិតគេនឹងឃើញការណ៍ដែលឥតមានអ្នកណាប្រាប់ដល់គេឡើយ; ហើយសេចក្ដីដែលគេមិនបានឮថ្លែងប្រាប់មកសោះ នោះគេនឹងបានយល់ច្បាស់វិញ ។

៣១ *ក* ៣ នីហ្វៃ ៥:២១–២៦;
២១:២៦–២៩.
៣២ *ក* អេសាយ ៥២:៨;
៣ នីហ្វៃ ១៦:១៨–២០.
ស.ប. ចាំយាម, ពួកអ្នកចាំយាម.
៣៤ *ក* អេសាយ ៥២:៩.
៣៦ *ក* អេសាយ ៥២:១–៣;
គ. និង ស. ១១៣:៧–១០.
ស.ប. ស៊ីយ៉ូន.
៤០ *ក* អេសាយ ៥២:៧; ណាហ៊ុម ១:១៥;
ម៉ូសាយ ១៥:១៣–១៨;
គ. និង ស. ១២៨:១៩.
*ខ* ម៉ាកុស ១៣:១០;
១ នីហ្វៃ ១៣:៣៧.
៤១ *ក* អេសាយ ៥២:១១–១៥.
*ខ* ស.ប. ស្អាត និងឥតស្អាត.
*គ* គ. និង ស. ១៣៣:៥.
៤២ *ក* ៣ នីហ្វៃ ២១:២៩.
៤៥ *ក* អេសាយ ៥២:១៥.

៤៦ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ការណ៍
ទាំងអស់នេះនឹងកើតមានឡើងយ៉ាងពិតប្រាកដ គឺដូចដែលព្រះ
វរបិតា ទ្រង់បានបញ្ជាដល់យើង ។ នោះសេចក្ដីសញ្ញាដែល
ព្រះវរបិតា ទ្រង់បានធ្វើជាមួយនឹងរាស្ត្រព្រះអង្គនឹងត្រូវបាន
បំពេញ; ហើយនៅពេលនោះ ក្រុងយេរូសាឡិមនឹងមានមនុស្ស
នៅទៀត ដោយរាស្ត្រយើង ហើយនឹងទៅជាដែនដីនៃកេរ្ដិ៍អាករ
របស់ពួកគេ ៕

## ជំពូកទី ២១

*ពួកអ៊ីស្រាអែលនឹងបានប្រមូលមកវិញ ពេលដែលព្រះគម្ពីរមរមនចេញមក — ពួកសាសន៍ដទៃនឹងបានតាំងឡើង ជាប្រជាជនសេរីមួយ នៅទ្វីបអាមេរិក — ពួកគេនឹងបានសង្គ្រោះ បើសិនជាពួកគេជឿ ហើយប្រតិបត្តិតាម; បើពុំនោះសោតទេ ពួកគេនឹងត្រូវកាត់កាល់ចេញ ហើយបំផ្លាញចោល — ពួកអ៊ីស្រាអែលនឹងសង់ក្រុងយេរូសាឡិមថ្មី ហើយពួកពូជអំបូរដែលវង្វេងទាំងប៉ុន្មាន នឹងត្រឡប់មកវិញ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយយើងប្រាប់អ្នករាល់គ្នាជាប្រាកដថា យើងឲ្យដល់អ្នករាល់
គ្នានូវទីសំគាល់មួយ ដើម្បីឲ្យអ្នករាល់គ្នាអាចដឹងថា ពេលណា
ការណ៍ ទាំងនោះបំរុងនឹងកើតឡើង — គឺយើងនឹងប្រមូល
រាស្ត្រយើងមកវិញ បន្ទាប់ពីគេត្រូវខ្ចាត់ព្រាត់អស់ពេលដ៏យូរ
ឱវង្សអ៊ីស្រាអែលអើយ ហើយនឹងតាំងក្រុងស៊ីយ៉ូន
របស់យើងឡើងវិញ នៅក្នុងចំណោមពួកគេ;
២ ហើយមើលចុះ នេះគឺជាការណ៍ដែលយើងនឹងឲ្យដល់អ្នក
រាល់គ្នាទុកជាទីសំគាល់មួយ — ត្បិតយើងប្រាប់អ្នករាល់គ្នា
ជាប្រាកដថា កាលណាការណ៍ទាំងនេះ ដែលយើងបានប្រកាស
ដល់អ្នករាល់គ្នា ហើយដែលយើងនឹងប្រកាសដល់អ្នករាល់គ្នា
ពេលក្រោយ ដោយ ខ្លួនយើងផ្ទាល់ និងដោយព្រះចេស្ដានៃ
ព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងបានប្រទានដល់អ្នកពីព្រះវរបិតា
នោះនឹងធ្វើឲ្យពួកសាសន៍ដទៃដឹង ដើម្បីឲ្យពួកគេអាចដឹងអំពី
ប្រជាជននេះ គឺជាសំណល់នៃវង្សយ៉ាកុប និងអំពីរាស្ត្រយើង
ដែលនឹងត្រូវពួកគេកំចាត់ឲ្យខ្ចាត់ព្រាត់ ។
៣ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា កាលណា
ការណ៍ទាំងនេះនឹងបានធ្វើឲ្យពួកគេដឹងដោយព្រះវរបិតា ហើយ
នឹង ចេញមកពីព្រះវរបិតា គឺចេញពីពួកគេមកដល់អ្នករាល់គ្នា;
៤ ត្បិតគឺជាប្រាជ្ញានៅក្នុងព្រះវរបិតាថា គេនឹងត្រូវ
បានតាំងឡើងនៅលើដែនដីនេះ ហើយឲ្យទៅជាប្រជាជនសេរី
មួយ ដោយព្រះ ចេស្ដានៃព្រះវរបិតា ដើម្បីឲ្យការណ៍ទាំងនេះ
បានមកពីគេ ដល់សំណល់មួយនៅក្នុងពូជអ្នករាល់គ្នា ដើម្បីឲ្យ
សេចក្ដីសញ្ញានៃព្រះវរបិតា អាចបានបំពេញ ដែលទ្រង់បានធ្វើ
សេចក្ដីសញ្ញាជាមួយនឹងរាស្ត្រទ្រង់ ឱវង្សអ៊ីស្រាអែលអើយ ។
៥ ដូច្នេះ កាលណាកិច្ចការទាំងនេះ និងកិច្ចការទាំងឡាយដែល
នឹងកើតឡើង នៅក្នុងចំណោមពូជអ្នករាល់គ្នា ពីពេលនេះតទៅ
នោះនឹងបានចេញពីពួកសាសន៍ដទៃ មកដល់ពូជរបស់អ្នករាល់គ្នា
ដែលនឹងចុះអន់ថយក្នុងការឥតជំនឿ ដោយមកពីអំពើទុច្ចរិត;
៦ ត្បិតព្រះវរបិតាទ្រង់ទតឃើញថា ការណ៍នោះនឹងចេញមក
ពីពួកសាសន៍ដទៃ ដើម្បីទ្រង់អាចបង្ហាញ នូវព្រះចេស្ដារបស់
ទ្រង់ដល់ ពួកសាសន៍ដទៃ ត្បិតដោយហេតុនេះហើយដែលពួក
សាសន៍ដទៃ បើសិនជាពួកគេមិនធ្វើចិត្តរឹងរូសទេ នោះពួកគេ
អាចប្រែចិត្ត ហើយ មករកយើង ហើយទទួលបុណ្យជ្រមុជទឹក
ដោយនូវនាមរបស់យើង ហើយដឹងចំណុចពិតប្រាកដ នៃគោលលទ្ធិ
របស់យើង ដើម្បីពួកគេ អាចបានរាប់ក្នុងចំណោមរាស្ត្រយើង
ឱវង្សអ៊ីស្រាអែលអើយ ។
៧ ហើយកាលណាការណ៍ទាំងនេះកើតឡើង នោះពូជរបស់
អ្នកនឹងចាប់ផ្ដើមដឹងនូវការណ៍ទាំងនេះ — នឹងមានទីសំគាល់
មួយ ដល់ពួកគេ ដើម្បីឲ្យគេអាចដឹងថា កិច្ចការនៃព្រះវរបិតា
បានចាប់ផ្ដើមរួចហើយ ចំពោះការបំពេញសេចក្ដីសញ្ញា ដែល
ទ្រង់បានធ្វើជា មួយនឹងប្រជាជន ដែលជាវង្សអ៊ីស្រាអែល ។
៨ ហើយកាលណាថ្ងៃនោះនឹងមកដល់ ហេតុការណ៍
នឹងកើតឡើងថា មហាក្សត្រទាំងឡាយនឹងបិទមាត់ខ្លួនជិត; ត្បិតគេ
នឹងឃើញ ការណ៍ ដែលឥតមានអ្នកណាប្រាប់ដល់គេឡើយ;

៤៦ *ក* អេធើរ ១៣:៥, ១១.
**២១** ១ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
៣ *ក* អេធើរ ៤:១៧; យ.ស.—ប្រវត្តិ ១:៣៤–៣៦.
៤ *ក* ១ នីហ្វៃ ១៣:១៧–១៩; គ. និង ស. ១០១:៧៧–៨០.
*ខ* មរមន ៥:២០. ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
៥ *ក* ៣ នីហ្វៃ ២៦:៨.
*ខ* ២ នីហ្វៃ ៣០:៤–៥; មរមន ៥:១៥; គ. និង ស. ៣:១៨–១៩.
៦ *ក* ១ នីហ្វៃ ១០:១៤; យ៉ាកុប ៥:៥៤; ៣ នីហ្វៃ ១៦:៤–៧.
*ខ* កាឡាទី ៣:៧, ២៩; ៣ នីហ្វៃ ១៦:១៣; អ័ប្រា. ២:៩–១១.
៧ *ក* ៣ នីហ្វៃ ៥:២១–២៦.

ហើយសេចក្ដីដែលគេ មិនបានឮថ្លែងប្រាប់មកសោះ នោះគេនឹងបានយល់ច្បាស់វិញ ។

៩ ត្បិតនៅថ្ងៃនោះ ដោយយល់ដល់រូបយើង នោះព្រះវរបិតាទ្រង់នឹងធ្វើកិច្ចការមួយ ដែលនឹងទៅជាកិច្ចការដ៏ធំ ហើយ[ក]អស្ចារ្យ នៅក្នុងចំណោមពួកគេ; ហើយនៅក្នុងចំណោមពួកគេនឹងមានអស់អ្នកដែលពុំជឿកិច្ចការនោះ ទោះបីមានបុរសម្នាក់នឹងប្រកាស កិច្ចការនោះ ដល់ពួកគេក៏ដោយ ។

១០ ប៉ុន្តែមើលចុះ ជីវិតរបស់អ្នកបំរើយើង នឹងនៅក្នុងកណ្ដាប់ដៃយើង; ហេតុដូច្នេះហើយ ពួកគេពុំអាចព្យាបាទអ្នកនោះបានឡើយ ទោះបីគេអាច[ក]ធ្វើឲ្យទឹកមុខអ្នកនោះខូចក៏ដោយ គង់តែយើងនឹងប្រោសអ្នកនោះឲ្យជាដែរ ត្បិតយើងនឹងបង្ហាញដល់ពួកគេថា ប្រាជ្ញា[ខ]របស់ យើងធំជាងកលល្បិចរបស់អារក្ស ។

១១ ហេតុដូច្នេះហើយ ហេតុការណ៍នឹងកើតឡើងថា អស់អ្នកណាដែលពុំជឿដល់ពាក្យយើង គឺព្រះយេស៊ូវគ្រីស្ទ ដែលព្រះវរបិតា [ក]ទ្រង់នឹងចាត់ឲ្យនាំពាក្យទាំងនេះមកដល់ពួកសាសន៍ដទៃ ព្រមទាំងនឹងប្រទានដល់ទ្រង់នូវអំណាចផង ដើម្បីឲ្យទ្រង់អាចនាំពាក្យទាំង នេះ មកដល់ពួកសាសន៍ដទៃ (ហើយនឹងបានសំរេចដូចលោកម៉ូសេបានមានប្រសាសន៍មក) ពួកគេនឹងត្រូវ[ខ]កាត់កាល់ចេញ ពីចំណោម រាស្ត្រយើង ដែលនៅក្នុងសេចក្ដីសញ្ញា ។

១២ ហើយរាស្ត្រយើង គឺជាសំណល់នៃវង្សយ៉ាកុប នឹងនៅក្នុងចំណោមពួកសាសន៍ដទៃ មែនហើយ នៅកណ្ដាលពួកគេបីដូចជា [ក]សត្វសិង្ហមួយ នៅកណ្ដាលសត្វព្រៃទាំងឡាយ ហើយបីដូចជាកូនសត្វសិង្ហមួយនៅក្នុងហ្វូងចៀម បើសិនជាវាដើរឆ្លងកាត់ វានឹង[ខ]ជាន់ឈ្លី នៅក្រោមជើង ហើយហែកឲ្យទៅជាដុំៗ ហើយគ្មានអ្នកណាអាចដោះលែងបានឡើយ ។

១៣ ដៃពួកគេនឹងលើកឡើង វាយមារសត្រូវទាំងឡាយរបស់គេ ហើយពួកខ្មាំងសត្រូវរបស់គេទាំងអស់ នឹងត្រូវកាត់កាល់ចេញ ។

១៤ មែនហើយ វេទនានឹងមានដល់ពួកសាសន៍ដទៃ លើកលែងតែពួកគេ[ក]ប្រែចិត្ត; ត្បិតហេតុការណ៍នឹងកើតឡើងថា នៅថ្ងៃនោះ ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា យើងនឹងសម្លាប់សេះទាំងឡាយ ពីចំណោមពួកអ្នកចេញ ហើយយើងនឹងបំផ្លាញរទេះទាំងឡាយ របស់ពួកអ្នកចោល;

១៥ ហើយយើងនឹងកាត់ទីក្រុងទាំងឡាយ នៅក្នុងដែនដីរបស់អ្នកចេញ ហើយរលំអស់ទាំងទីតាំងការពាររបស់អ្នកចោល;

១៦ ហើយយើងនឹងកាត់មន្តអាគម ចេញពីដែនដីអ្នក ហើយអ្នករាល់គ្នានឹងគ្មានគ្រូទាយ ឯណាទៀតឡើយ;

១៧ [ក]រូបចម្លាក់ទាំងឡាយរបស់អ្នករាល់គ្នា ក៏នឹងត្រូវយើងកាត់ចេញដែរ ហើយអ្នករាល់គ្នានឹងពុំអាចថ្វាយបង្គំស្នាដៃរបស់អ្នកទៀត ឡើយ;

១៨ ហើយយើងនឹងដកដើមឈើទាំងឡាយរបស់អ្នកចេញពីទីកណ្ដាលអ្នករាល់គ្នាយ៉ាងណា នោះយើងក៏នឹងបំផ្លាញចោលទីក្រុង ទាំងឡាយ របស់អ្នកយ៉ាងនោះដែរ ។

១៩ ហើយហេតុការណ៍នឹងកើតឡើងថា អំពើ[ក]ភូតកុហកនិងបោកបញ្ឆោត និងឈ្នានីស និងលោភលន់ និងឧបាយកលផ្ដែកសង្ឃ្រ និងអំពើសហាយស្មន់ទាំងអស់នេះត្រូវតែចប់ ។

២០ ត្បិតហេតុការណ៍នឹងកើតឡើង ព្រះវរបិតាទ្រង់មានព្រះបន្ទូលថា ឱវង្សអ៊ីស្រាអែលអើយ នៅថ្ងៃនោះ អស់អ្នកណាដែលពុំប្រែចិត្ត ហើយមករកបុត្រាដ៏ជាទីស្រឡាញ់របស់យើងទេ នោះយើងនឹងកាត់អ្នកនោះ ចេញពីរាស្ត្រយើង;

២១ ហើយយើងនឹងអនុវត្តការសងសឹក និងកំហឹងទៅលើពួកគេ ដូចជាទៅលើពួកឥតជំនឿដែរ គឺជាការណ៍ដែលគេឥតបានឮ ។

២២ តែបើពួកគេនឹងប្រែចិត្ត ហើយស្ដាប់តាមពាក្យរបស់យើង ហើយពុំធ្វើចិត្តរឹងទទឹងទេ នោះយើងនឹង[ក]តាំងសាសនាចក្ររបស់យើងឡើង នៅក្នុងចំណោមពួកគេ ហើយពួកគេនឹងចូលក្នុងសេចក្ដីសញ្ញា ហើយនឹងត្រូវបាន[ខ]រាប់ក្នុងចំណោមសំណល់នៃវង្សយ៉ាកុប ដែលយើងបានប្រទានដែនដីនេះទុកជាមរតក ។

២៣ ហើយពួកគេនឹងជួយរាស្ត្រយើង ដែលជាសំណល់នៃវង្សយ៉ាកុប និងព្រមទាំងវង្សអ៊ីស្រាអែលទាំងអស់

៩ *ក* អេសាយ ២៩:១៣;
កិច្ចការ ១៣:៤១;
១ នីហ្វៃ ២២:៨.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
១០ *ក* គ. និង ស. ១៣៥:១–៣.
*ខ* គ. និង ស. ១០:៤៣.
១១ *ក* ២ នីហ្វៃ ៣:៦–១៥;
មរមន ៨:១៦, ២៥.
*ខ* គ. និង ស. ១:១៤.
១២ *ក* មីកា ៥:៨–១៥;
៣ នីហ្វៃ ២០:១៦.
*ខ* ៣ នីហ្វៃ ១៦:១៣–១៥.
១៤ *ក* ២ នីហ្វៃ ១០:១៨; ៣៣:៩.
១៧ *ក* និក្ខ. ២០:៣–៤;
ម៉ូសាយ ១៣:១២–១៣;
គ. និង ស. ១:១៦.
ស.ប. ការថ្វាយបង្គំរូបព្រះ.
១៩ *ក* ៣ នីហ្វៃ ៣០:២.
២២ *ក* ស.ប. គ្រាកាន់កាប់ត្រួតត្រា.
*ខ* ២ នីហ្វៃ ១០:១៨–១៩;
៣ នីហ្វៃ ១៦:១៣.

ដែលនឹងមក ដើម្បីឲ្យ ពួកគេអាចសង់ទីក្រុងមួយ ដែលត្រូវ
ហៅថា ក្រុងយេរូសាឡិមថ្មី ។
២៤ ហើយនៅពេលនោះ ពួកគេនឹងជួយរាស្ត្រយើង
ដើម្បីគេអាចប្រមូលមក ពួកអ្នកដែលខ្ចាត់ព្រាត់ នៅពាសពេញ
លើផ្ទៃដែនដី ចូលមកឯក្រុងយេរូសាឡិមថ្មី ។
២៥ ហើយនៅពេលនោះ អំណាចនៃស្ថានសួគ៌នឹងចុះមករកពួក
គេ; ហើយយើងក៏នឹងនៅកណ្ដាលពួកគេដែរ ។
២៦ ហើយខណៈនោះ កិច្ចការរបស់ព្រះវរបិតានឹង
ចាប់ផ្ដើមឡើងនៅថ្ងៃនោះ ក្នុងកាលដំណឹងល្អនេះនឹងត្រូវបានផ្សាយ
នៅក្នុង ចំណោមសំណល់នៃប្រជាជននេះ ។ យើងប្រាប់អ្នករាល់
គ្នាជាប្រាកដថា នៅថ្ងៃនោះ កិច្ចការរបស់ព្រះវរបិតានឹង
ចាប់ផ្ដើមឡើង នៅក្នុងចំណោមរាស្ត្រយើងទាំងអស់ ដែលត្រូវ
ខ្ចាត់ព្រាត់ មែនហើយ ព្រមទាំងក្នុងចំណោមពូជអំបូរទាំងឡាយ
ដែលវង្វេងផង ដែលព្រះវរបិតាទ្រង់បាននាំចេញ
ពីក្រុងយេរូសាឡិមទៅ ។
២៧ មែនហើយ កិច្ចការនោះនឹងចាប់ផ្ដើមឡើង នៅក្នុង
ចំណោមរាស្ត្រយើងទាំងអស់ ដែលត្រូវខ្ចាត់ព្រាត់ ដោយមាន
ព្រះវរបិតា រៀបចំមាគ៌ា សំរាប់ឲ្យពួកគេអាចមករកយើងវិញ
ដើម្បីគេអាចអំពាវនាវដល់ព្រះវរបិតា ដោយនូវនាមរបស់យើង ។
២៨ មែនហើយ នៅពេលនោះ កិច្ចការនោះនឹងចាប់ផ្ដើមឡើង
ដោយមានព្រះវរបិតាគង់នៅក្នុងចំណោមសាសន៍ទាំងអស់ ក្នុង
ការ រៀបចំមាគ៌ា សំរាប់ឲ្យរាស្ត្រទ្រង់អាចប្រមូលគ្នាមកកាន់
មាតុភូមិ នៅលើដែនដីនៃកេរ្ដិ៍អាកររបស់គេ ។
២៩ ហើយពួកគេនឹងចេញពីគ្រប់ទាំងសាសន៍មក; ហើយពួក
គេនឹងពុំចេញដោយរួសរាន់ ឬដោយរត់គេចឡើយ ត្បិតយើង
នឹងទៅ ខាងមុខគេ ហើយយើងនឹងនៅពីក្រោយពួកគេដែរ នេះ
គឺព្រះបន្ទូលនៃព្រះវរបិតា ៕

## ជំពូកទី ២២

*នៅគ្រាចុងក្រោយបង្អស់ ក្រុងស៊ីយ៉ូន និងចំរឹងទាំងឡាយ របស់នាង នឹងបានបង្កើតឡើង ហើយអ៊ីស្រាអែលនឹងត្រូវបាន ប្រមូល ដោយ សេចក្ដីមេត្តាករុណា និងភាពថ្នាក់ថ្នម — ពួកគេនឹងមានជ័យជំនះ — ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៥៤ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយនៅពេលនោះ ការដែលបានកត់ត្រាទុកនោះនឹងកើតឡើង៖
ឱស្ត្រីអារ ដែលមិនបានបង្កើតកូនអើយ ចូរច្រៀងឡើង; ឱអ្នក
ដែល មិនបានឈឺចាប់នឹងសំរាលអើយ ចូរធ្លាយចេញជាប
ទចម្រៀង ហើយបន្លឺឡើងចុះ; ត្បិតព្រះអម្ចាស់ទ្រង់មានបន្ទូលថា
កូនរបស់ស្ត្រីដែល បង់ខ្លួននៅតែឯងនោះ មានច្រើនជាងកូន
របស់ស្ត្រី ដែលមានប្ដីទៅទៀត ។
២ ចូរពង្រីកទីដំឡើងត្រសាលអ្នកឲ្យធំឡើង ហើយឲ្យវារាល់
គ្នាសន្ធឹងសំយាយសំពត់ត្រសាលរបស់អ្នកទៅ; កុំឲ្យសំចៃឡើយ
ត្រូវឲ្យ បន្ដខ្សែឲ្យវែង ហើយបោះចំរឹងឲ្យមាំឡើងចុះ;
៣ ត្បិតអ្នកនឹងបានរានទីចេញទៅខាងស្ដាំនិងខាងឆ្វេង ហើយ
ពូជពង្សរបស់អ្នកនឹងចាប់បាន អស់ទាំងសាសន៍ដទៃជារបស់
ផងខ្លួន ហើយឲ្យអស់ទាំងទីក្រុងដែលចោលស្ងាត់ បានមាន
មនុស្សអាស្រ័យនៅវិញ ។
៤ កុំឲ្យខ្លាចឲ្យសោះ ត្បិតអ្នកនឹងមិនដែលត្រូវខ្មាស់ឡើយ;
ក៏កុំឲ្យរង្កៀសចិត្តដែរ; ពីព្រោះអ្នកនឹងមិនដែលត្រូវមានសេច
ក្ដីខ្មាស់ទេ អ្នកនឹងភ្លេចសេចក្ដីខ្មាស់ ដែលអ្នកមាន
ពីកាលនៅវ័យក្មេង ហើយអ្នកនឹងមិននឹកចាំពីសេចក្ដី ដែល
គេត្មះតិះដៀល ពីកាលនៅមេម៉ាយ តទៅទៀតដែរ ។
៥ ត្បិតព្រះដែលបង្កើតអ្នកមក ទ្រង់ជាប្ដីរបស់អ្នក ហើយ
ព្រះនាមទ្រង់ គឺព្រះអម្ចាស់នៃពួកពលបរិវារ; ហើយព្រះដ៏
ប្រោសលោះអ្នក គឺជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល —
គេនឹងហៅទ្រង់ថា ជាព្រះនៃលោកិយទាំងមូល ។
៦ ត្បិតព្រះរបស់អ្នកទ្រង់មានព្រះបន្ទូលថា ព្រះអម្ចាស់ ទ្រង់
បានហៅអ្នកទុក ដូចជាស្ត្រីដែលប្ដីបោះបង់ចោល ហើយដែល
មានចិត្ត ក្នាន់ក្នាញ់ គឺជាប្រពន្ធក្រមុំកំឡោះ ដែលត្រូវ
បង់ចោលហើយ ។

២៣ *ក* ៣ នីហ្វៃ ២០:២២;
អេធើរ ១៣:១–១២.
ស.ប. ក្រុងយេរូសាឡិមថ្មី.
២៥ *ក* ១ នីហ្វៃ ១៣:៣៧.
*ខ* អេសាយ ២:២–៤;
៣ នីហ្វៃ ២៤:១.
២៦ *ក* ១ នីហ្វៃ ១៤:១៧;
៣ នីហ្វៃ ២១:៦–៧.
*ខ* ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់.
២៧ *ក* ៣ នីហ្វៃ ១៦:៤–៥.
២៨ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
២៩ *ក* អេសាយ ៥២:១២;
៣ នីហ្វៃ ២០:៤២.
**២២** ១ *ក* ស.ប. ច្រៀង.
២ *ក* ស.ប. ចំរឹង, ស្តេក.
៣ *ក* ស.ប. ពួកសាសន៍ដទៃ.
៤ *ក* ២ នីហ្វៃ ៦:៧, ១៣.

៧ យើងបានបោះបង់ចោលអ្នកតែមួយភ្លែតទេ តែយើងនឹងទទួលអ្នកមកវិញ ដោយសេចក្ដីមេត្តាជាខ្លាំង ។

៨ ព្រះអម្ចាស់ ជាព្រះប្រោសលោះអ្នក ទ្រង់មានបន្ទូលថា យើងបានគេចមុខចេញពីអ្នកនៅតែមួយភ្លែតនោះ ដោយមានសេចក្ដី ក្រោធដ៏ហូរហៀរ តែយើងនឹងអាណិតអាសូរដល់អ្នក ដោយសេចក្ដីសប្បុរសដ៏អស់កល្បជានិច្ចវិញ ។

៩ ការណ៍នេះប្រៀបដូចជាទឹកជន់នៅជំនាន់លោកណូអេដល់យើង ហើយដែលយើងបានស្បថថា ទឹកជន់នៅជំនាន់លោកណូអេ នឹងមិនដែលគ្របលើផែនដីទៀតជាយ៉ាងណា នោះយើងក៏ស្បថថា យើងនឹងមិនដែលមានសេចក្ដីក្រោធចំពោះអ្នក តទៅយ៉ាងនោះ ដែរ ។

១០ ពីព្រោះអស់ទាំងភ្នំធំនឹងបាត់ទៅបាន ហើយអស់ទាំងភ្នំតូចនឹងរើចេញទៅបានដែរ ប៉ុន្តែសេចក្ដីសប្បុរសរបស់យើង នឹងមិនដែល ឃ្លាតបាត់ពីអ្នកឡើយ ហើយសេចក្ដីសញ្ញា ពីសេចក្ដីមេត្រីរបស់យើង ក៏មិនត្រូវរើចេញដែរ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដែលទ្រង់ ប្រោសមេត្តាដល់អ្នក ។

១១ ឱអ្នកដែលរងទុក្ខវេទនា ដែលត្រូវខ្យល់ព្យុះបោក ឥតមានសេចក្ដីកំសាន្តចិត្តអើយ! មើលចុះ យើងនឹងរៀបថ្មអ្នកឡើងដោយ បាយអមានពណ៌ស្រស់ល្អ ហើយដាក់ជើងជញ្ជាំងអ្នកដោយត្បូងកណ្ដៀង ។

១២ យើងនឹងធ្វើកំផែងសីមាអ្នកពីត្បូងទទឹម ហើយទ្វារអ្នកពីត្បូងបារកេត និងក្បាច់អ្នកទាំងប៉ុន្មាន ពីត្បូងមានតម្លៃ ។

១៣ ឯកូនចៅទាំងប៉ុន្មានរបស់អ្នក នឹងធ្វើជាសិស្សរបស់ព្រះអម្ចាស់; ហើយវារាល់គ្នានឹងមានសន្តិសុខជាបរិបូរ ។

១៤ អ្នកនឹងបានតាំងមាំមួននៅដោយសេចក្ដីសុចរិត; ហើយនឹងនៅឆ្ងាយពីការសង្កត់សង្កិន ត្បិតអ្នកនឹងមិនខ្លាចអ្វីសោះ ក៏នឹងនៅ ឆ្ងាយពីសេចក្ដីស្ញែងខ្លាចដែរ ពីព្រោះសេចក្ដីនោះនឹងមិនមកជិតអ្នកឡើយ ។

១៥ មើលចុះ នឹងមានគេលើកគ្នាឡើងទាស់នឹងអ្នក តែនោះមិនមែនមកពីយើងទេ; ឯអ្នកណាដែលលើកគ្នាទាស់នឹងអ្នក គេនឹងដួល ចុះដោយព្រោះអ្នក ។

១៦ មើលចុះ យើងបានបង្កើតទាំងជាងដែក ដែលសប់ភ្លើងធ្វើគ្រឿងសស្ត្រាវុធ សំរាប់ជាការរបស់ខ្លួន; ហើយយើងក៏បានបង្កើត មេបំផ្លាញ ទុកសំរាប់នឹងបំផ្លាញផង ។

១៧ ឯគ្រឿងសស្ត្រាវុធណាដែលគេធ្វើឡើង នោះគ្មានណាមួយនឹងអាចទាស់នឹងអ្នកបានឡើយ; ហើយអស់ទាំងអណ្ដាតណាដែល ជេរប្រមាថអ្នកក្នុងរឿងក្ដី នោះអ្នកនឹងកាត់ទោសឲ្យវិញ ។ នេះហើយជាសេចក្ដី ដែលពួកអ្នកបំរើរបស់ព្រះអម្ចាស់ នឹងទទួលជាមរតក ហើយសេចក្ដីសុចរិតរបស់គេក៏មកពីយើង នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ ។

## ជំពូកទី ២៣

*ព្រះយេស៊ូវយល់ព្រមទទួលពាក្យទាំងឡាយរបស់អេសាយ — ទ្រង់បញ្ជាឲ្យប្រជាជនពិចារណាមើលសេចក្ដីព្យាករណ៍នៃពួកព្យាការី — ពាក្យទាំងឡាយរបស់សាំយូអែល ជាសាសន៍លេមិន ស្ដីអំពីដំណើររស់ឡើងវិញ ត្រូវបានបន្ថែមចូលក្នុងបញ្ជីទាំងឡាយរបស់ពួកគេ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នាត្រូវពិចារណាមើលការណ៍ទាំងនេះ ។ មែនហើយ យើងឲ្យបញ្ញត្តិមួយ ដល់អ្នករាល់គ្នាថា ចូរអ្នករាល់គ្នាពិចារណាមើលការណ៍ទាំងនេះដោយព្យាយាម; ត្បិតពាក្យពេចន៍របស់អេសាយ ជាពាក្យដ៏មហិមា ។

២ ត្បិតលោកបានមានប្រសាសន៍ជាប្រាកដ ពីគ្រប់ទាំងការណ៍ ដែលទាក់ទងនឹងរាស្ត្រយើង គឺជាវង្សអ៊ីស្រាអែល; ដូច្នេះ លោកត្រូវ តែប្រាប់ទៅពួកសាសន៍ដទៃផងដែរ ។

៣ ហើយគ្រប់ទាំងការណ៍ដែលលោកមានប្រសាសន៍នោះបានកើតឡើង ហើយនឹងកើតឡើង គឺស្របតាមពាក្យពេចន៍ដែលលោក បានប្រាប់ ។

៤ ហេតុដូច្នេះ ចូរស្ដាប់បង្គាប់តាមពាក្យរបស់យើងចុះ; ចូរសរសេរនូវអ្វីៗ ដែលយើងបានប្រាប់ដល់អ្នក; ហើយស្របតាមពេល វេលា និងព្រះហឫទ័យនៃព្រះវរបិតា ការណ៍ទាំងនោះនឹងចេញទៅដល់ពួកសាសន៍ដទៃ ។

---

៨ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៩ *ក* អេសាយ ៥៤:៩.
*ខ* ស.ប. ទឹកជំនន់នៅសម័យណូអេ.
១០ *ក* អេសាយ ៤០:៤.
*ខ* ទំនុក. ៩៤:១៤; គ. និង ស. ៣៥:២៥.
១១ *ក* វិវរ. ២១:១៨–២១.
១៣ *ក* យេរេ. ៣១:៣៣–៣៤.
១៤ *ក* ស.ប. សុចរិត, សេចក្ដីសុចរិត.
**២៣** ១ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* ២ នីហ្វៃ ២៥:១–៥; មរមន ៨:២៣. ស.ប. អេសាយ.
៣ *ក* ៣ នីហ្វៃ ២០:១១–១២.

៥ ហើយអស់អ្នកណាដែលប្រុងស្ដាប់តាមពាក្យរបស់យើង ហើយប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក អ្នកនោះហើយដែលនឹងបាន សង្គ្រោះ ។ ចូរពិចារណាមើលសេចក្ដីព្យាករណ៍នៃពួក[ក]ព្យាការី ត្បិតមានជាច្រើនដែលបានធ្វើបន្ទាល់អំពីការណ៍ទាំងនេះ ។

៦ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលយ៉ាងនេះហើយ នោះទ្រង់ក៏មានព្រះបន្ទូល ទៅពួកគេទៀត គឺបន្ទាប់ពីទ្រង់បានពន្យល់ប្រាប់ពួកគេនូវបទគម្ពីរទាំងឡាយ ដែលគេបានទទួល នោះទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ មើលចុះ យើងចង់ឲ្យអ្នករាល់គ្នាកត់ទុក នូវបទគម្ពីរផ្សេងៗទៀត ដែលអ្នករាល់គ្នាពុំទាន់មាន ។

៧ ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅនីហ្វៃថា៖ ចូរយកបញ្ជីដែលអ្នកបានកត់ទុកមកឯណេះ។

៨ ហើយកាលនីហ្វៃបានយកបញ្ជីមក ក៏ដាក់ចុះនៅចំពោះទ្រង់ហើយ នោះទ្រង់ទតសម្លឹងមើលបញ្ជីទាំងនោះ ហើយមានព្រះបន្ទូល ថា៖

៩ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា យើងបានបញ្ជាឲ្យអ្នកបំរើយើង គឺ[ក]សាំយូអែល ជាសាសន៍លេមិន ឲ្យលោកធ្វើបន្ទាល់ដល់ប្រ ជាជននេះថា នៅថ្ងៃដែលព្រះវរបិតានឹងដំកើងព្រះនាមទ្រង់ នៅក្នុងយើង នោះនឹង[ខ]មានពួក[គ]បរិសុទ្ធជាច្រើន [ឃ]បានរស់ពីស្លាប់ឡើងវិញ ហើយនឹងលេចមកឲ្យមនុស្សជាច្រើនបានឃើញ ហើយនឹងធ្វើការងារបំរើដល់ពួកគេ ។ ហើយទ្រង់មានព្រះបន្ទូលទៅគេថា៖ តើពុំមែន ដូច្នោះទេឬអី ?

១០ ហើយពួកសិស្សរបស់ទ្រង់ឆ្លើយថា៖ ព្រះពរ ព្រះអម្ចាស់ សាំយូអែលបានព្យាករដូចពាក្យរបស់ព្រះអង្គមែន ហើយពាក្យទាំងអស់ នោះបានបំពេញហើយ ។

១១ ហើយព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ ចុះហេតុអ្វីបានជាអ្នករាល់គ្នា ពុំទាន់កត់ការណ៍នេះទុក ដែលថាមានពួក បរិសុទ្ធជាច្រើនបានរស់ឡើងវិញ ហើយបានលេចមកឲ្យមនុស្សជាច្រើនបានឃើញ ហើយក៏បានធ្វើការងារបំរើដល់មនុស្សទាំងនោះ ?

១២ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃនឹកឃើញថាការណ៍នេះពុំទាន់បានសរសេរទុកនៅឡើយទេ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់បានបញ្ជាឲ្យសរសេរការណ៍នោះទុក; ដូច្នេះ ការណ៍នោះក៏បានសរសេរ ទុក ដូចដែលទ្រង់បានបញ្ជាមក ។

១៤ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់[ក]បានពន្យល់ប្រាប់អស់ទាំងបទគម្ពីរតែមួយ ដែលពួកគេ បានសរសេរទុក នោះទ្រង់បានបញ្ជាថា ពួកគេត្រូវបង្រៀនការណ៍ទាំងឡាយ ដែលទ្រង់បានពន្យល់ប្រាប់ដល់ពួកគេ ៕

## ជំពូកទី ២៤

*ទូតរបស់ព្រះអម្ចាស់នឹងរៀបចំផ្លូវថ្វាយ ដល់ការយាងមកជាលើកទីពីរ — ព្រះគ្រីស្ទនឹងអង្គុយជំនុំជំរះ — សាសន៍អ៊ីស្រាអែលត្រូវបាន បញ្ជាឲ្យថ្វាយដង្វាយមួយភាគដប់ និងដង្វាយទាំងឡាយ — សៀវភៅរំឭកបានកត់ទុក — ចូរប្រៀបធៀបនឹងគម្ពីរម៉ាឡាគី ៣ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបញ្ជាឲ្យពួកគេសរសេរទុកនូវពាក្យទាំងឡាយ ដែលព្រះវរបិតា ទ្រង់បានប្រទានឲ្យ ម៉ាឡាគី ដែលទ្រង់នឹងប្រាប់ដល់គេ។ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីគេបានកត់ហើយ នោះទ្រង់ក៏ពន្យល់ប្រាប់ពាក្យ ទាំងនោះ ហើយនេះគឺពាក្យទាំងឡាយ ដែលទ្រង់បានប្រាប់ទៅគេថា៖ ព្រះវរបិតាទ្រង់មានព្រះបន្ទូលទៅម៉ាឡាគីដូច្នេះថា — មើលចុះ យើងចាត់[ក]ទូតយើងឲ្យទៅ គាត់នឹងរៀបចំផ្លូវនៅមុខយើង ហើយព្រះអម្ចាស់ដែលអ្នករាល់គ្នាស្វែងរកនោះ ទ្រង់នឹងយាងមកដល់ព្រះ វិហារបរិសុទ្ធរបស់ទ្រង់ភ្លាម ឯទូតដែលនាំសេចក្ដីសញ្ញាមក ជាសេចក្ដីសញ្ញាដែលអ្នករាល់គ្នាចង់បានទាំងនោះ; មើលន៏ ទ្រង់យាងមក នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ នៃពួកពលបរិវារ ។

២ តែមានអ្នកឯណា[ក]ធន់នៅបាន ក្នុងកាលដែលទ្រង់យាងមកនោះ តើអ្នកណានឹងឈរ នៅក្នុងកាលដែលទ្រង់លេចមក ? ត្បិតទ្រង់ ប្រៀបដូចជាភ្លើង[ខ]របស់ជាងសំរង ហើយដូចជាក្បុងរបស់ជាងប្រមោក ។

៣ ហើយទ្រង់នឹងគង់ចុះ ដូចជាជាងសំរង ហើយនឹងដេញ

៥ *ក* លូកា ២៤:២៥–២៧.
៩ *ក* ហេលេ. ១៣:២.
*ខ* ហេលេ. ១៤:២៥.
*គ* ស.ប. ជនបរិសុទ្ធ.
*ឃ* ម៉ាថាយ ២៧:៥២–៥៣.
ស.ប. ដំណើររស់ឡើងវិញ.
១៤ *ក* លូកា ២៤:៤៤–៤៦.
**២៤** ១*ក* គ. និង ស. ៤៥:៩.
២ *ក* ៣ នីហ្វៃ ២៥:១.
*ខ* សាការី ១៣:៩;
គ. និង ស. ១២៨:២៤.
ស.ប. ផែនដី — ការសំអាតផែនដី; ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.

អាចម៍ប្រាក់; ហើយទ្រង់នឹងសំអាត[ក]ពួកកូនចៅលេវី ហើយសំរងគេដូចជា មាស ហើយនិងប្រាក់ នោះគេនឹង[ខ]ថ្វាយដង្វាយ ដល់ព្រះអម្ចាស់ ដោយសេចក្ដីសុចរិត ។

៤ គ្រានោះ ដង្វាយរបស់ពួកយូដា និងក្រុងយេរូសាឡិម នឹងទៅជាទីគាប់ដល់ព្រះហឫទ័យនៃព្រះអម្ចាស់ ដូចកាលពីដើម គឺដូចកាល ពីចាស់បុរាណនោះ ។

៥ ហើយយើងនឹងមកជិតអ្នករាល់គ្នា ដើម្បីនឹងជំនុំជំរះ; ហើយយើងនឹងធ្វើជាសាក្សីយ៉ាងរហ័ស ទាស់នឹងពួកមន្តអាគម ហើយទាស់ នឹងពួកកំផិត ហើយទាស់នឹងពួកដែលស្បថបំពាន ហើយទាស់នឹងពួក ដែលកេងបំបាត់ឈ្នួលរបស់កូនឈ្នួល ព្រមទាំងសង្កត់សង្កិន ស្រីមេម៉ាយ [ក]និងមនុស្សកំព្រាផង ហើយដែលបែរចេញពីពួកអ្នកចម្លែក ហើយឥតកោតខ្លាចដល់យើងដែរ នេះជាព្រះបន្ទូលរបស់ព្រះ អម្ចាស់ នៃពួកពលបរិវារ ។

៦ ត្បិតយើង គឺព្រះអម្ចាស់ យើងមិនប្រែប្រួលឡើយ; ហេតុនោះ ឱពួកកូនចៅយ៉ាកុបអើយ អ្នករាល់គ្នាមិនបានត្រូវវិនាសទេ ។

៧ អ្នករាល់គ្នាបាន[ក]បោះបង់ចោល ពិធីបរិសុទ្ធរបស់យើង ចាប់តាំងពីគ្រាពួកអយ្យកោរៀងមក ឥតកាន់តាមឡើយ ។ ព្រះអម្ចាស់នៃ ពួកពលបរិវារទ្រង់បង្គាប់ថា ចូរ[ខ]វិលមកឯយើងវិញចុះ នោះយើងនឹងត្រឡប់មកអ្នកដែរ ។ តែអ្នករាល់គ្នាថា៖ តើយើងនឹងវិលទៅយ៉ាង ដូចម្ដេច ?

៨ ចុះតើមនុស្សនឹងកោងយករបស់ព្រះឬ ? ប៉ុន្តែអ្នករាល់គ្នាបានកោងយករបស់យើងហើយ ។ រួចបែរជាសួរថា៖ តើយើងបានកោង យករបស់ទ្រង់ឯណា ? គឺ[ក]ក្នុងដង្វាយមួយភាគដប់ ហើយ[ខ]ក្នុងដង្វាយលើកចុះឡើងនោះឯង ។

៩ អ្នករាល់គ្នា គឺមនុស្សនៅនគរនេះទាំងមូល ត្រូវបណ្ដាសាហើយ ដោយព្រោះតែងតែកោងយករបស់យើងយ៉ាងដូច្នេះ ។

១០ ចូរ[ក]នាំយកដង្វាយមួយភាគដប់ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ ដើម្បីឲ្យមានស្បៀងអាហារនៅ ក្នុងដំណាក់នៃយើង; ហើយល្បងលយើងឥឡូវនេះ បើយើងមិនបើកបង្អួចស្ថានសួគ៌ ដើម្បី[ខ]ចាក់ព្រះពរមកលើអ្នក ដែលនឹងគ្មានកន្លែងល្មមទុកបានទេ នេះហើយជា ព្រះបន្ទូលរបស់ព្រះអម្ចាស់ នៃពួកពលបរិវារ ។

១១ ដូច្នេះ ដោយយល់ដល់អ្នករាល់គ្នា នោះយើងនឹងបន្ទោសដល់សត្វដែលស៊ីបង្ខូច មិនឲ្យវាបំផ្លាញផល ដែលកើតពីដីអ្នកឡើយ; ឯដើមទំពាំងបាយជូរនៅចំការរបស់អ្នក ក៏មិនជំរុះផ្លែពីកាលនៅខ្ចីដែរ នេះហើយជាព្រះបន្ទូល របស់ព្រះអម្ចាស់នៃពួកពលបរិវារ ។

១២ យ៉ាងនោះ គ្រប់ទាំងសាសន៍នឹងថា អ្នករាល់គ្នាមានពរ ត្បិតដែនដីរបស់អ្នករាល់គ្នា នឹងបានជាដែនដីសប្បាយណាស់ នេះជា ព្រះបន្ទូលរបស់ព្រះអម្ចាស់ នៃពួកពលបរិវារ ។

១៣ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ពាក្យសំដីរបស់អ្នករាល់គ្នា បានទាស់នឹងយើងជាខ្លាំង ។ ទោះបីយ៉ាងនោះក៏អ្នករាល់គ្នាថា៖ តើយើងបាននិយាយអ្វីទាស់នឹងទ្រង់ ?

១៤ អ្នករាល់គ្នាបានពោលថា៖ ជាការឥតប្រយោជន៍ទេដែលបំរើព្រះ ហើយតើមានប្រយោជន៍អ្វី ដែលយើងកាន់តាមក្រឹត្យក្រមទាំងឡាយរបស់ទ្រង់ ហើយដែលយើងដើរដោយសោកសៅ នៅចំពោះព្រះអម្ចាស់នៃពួកពលបរិវារ ?

១៥ ហើយឥឡូវនេះ យើងរាប់មនុស្សឆ្មើងឆ្មៃ ទុកជាសប្បាយហើយ; មែនហើយ ពួកអ្នកដែលប្រព្រឹត្តការអាក្រក់ បានតាំងឡើង; មែនហើយ គេល្បងលព្រះ ហើយក៏រួចខ្លួនផង ។

១៦ គ្រានោះ ពួកអ្នកដែលកោតខ្លាចដល់ព្រះអម្ចាស់ [ក]ក៏និយាយគ្នាទៅវិញទៅមកជាញយៗ ហើយព្រះអម្ចាស់ទ្រង់ប្រុងស្ដាប់ក៏បានឮ; រួចមាន[ខ]សៀវភៅរំឭកបានកត់ទុក នៅចំពោះព្រះអម្ចាស់សំរាប់អ្នក ដែលកោតខ្លាចដល់ទ្រង់ និងពួកអ្នកដែលនឹកដល់ ព្រះនាមទ្រង់ ។

១៧ ព្រះអម្ចាស់នៃពួកពលបរិវារទ្រង់មានព្រះបន្ទូលថា នៅថ្ងៃដែលយើង[ក]ធ្វើការនេះ នោះគេនឹងបានជារបស់ផងយើង គឺជារបស់ផងយើងពិត; ហើយយើងនឹងប្រណីដល់គេ ដូចជាមនុស្សប្រណីដល់កូនខ្លួនដែរ គឺជាកូនដែលគោរពដល់ខ្លួនពិត ។

១៨ គ្រានោះ អ្នករាល់គ្នានឹងត្រឡប់មក ហើយ[ក]ចេះវែកញែក រវាងសេចក្ដីសុចរិត និងសេចក្ដីអាក្រក់ រវាងមនុស្សដែលគោរពដល់ព្រះ និងមនុស្សដែលមិនគោរពផង ៕

៣ *ក* ចោទិ. ១០:៨;
គ. និង ស. ៨៤:៣១–៣៤.
*ខ* គ. និង ស. ១៣:១.
៥ *ក* យ៉ាកុប (ព.ស.ថ.) ១:២៧.
៧ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* ហេលេ. ១៣:១១;
៣ នីហ្វៃ ១០:៦; មរ៉ូណៃ ៩:២២.
៨ *ក* ស.ប. ដង្វាយ១ភាគក្នុង១០,
ការថ្វាយដង្វាយ១ភាគក្នុង១០.
*ខ* ស.ប. ដង្វាយ.
១០ *ក* គ. និង ស. ៦៤:២៣; ១១៩:១–៧.
*ខ* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
១៦ *ក* មរ៉ូណៃ ៦:៥.
*ខ* គ. និង ស. ៨៥:៩; ម៉ូសេ ៦:៥.
ស.ប. សៀវភៅរំឭក.
១៧ *ក* គ. និង ស. ១០១:៣.
១៨ *ក* ស.ប. ការសង្កេតស្គាល់, អំណោយទាបខាង.

## ជំពូកទី ២៥

*គ្រាយាងមកលើកទីពីរ ពួកអ្នកឆ្មើងឆ្មៃ និងពួកទុច្ចរិតនឹងត្រូវឆេះដូចជាជញ្ជ្រាំង — អេលីយ៉ានឹងត្រឡប់មកវិញ មុនថ្ងៃដ៏ធំ ហើយគួរ ស្ញែងខ្លាចនោះ — ចូរប្រៀបធៀបនឹងគម្ពីរម៉ាឡាគី ៤ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ត្បិតមើលចុះ ថ្ងៃនោះកំពុងតែមកដល់ ថ្ងៃនោះ[ក]ឆេះឆ្លោ ដូចជាគុកភ្លើង; នោះ[ខ]អស់ពួកអ្នកឆ្មើងឆ្មៃ មែនហើយ ហើយនិងអស់ពួកអ្នក ដែលប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាជញ្ជ្រាំង; ហើយថ្ងៃដែលត្រូវមកដល់នោះ នឹងឆេះបន្សុសគេទាំងអស់ទៅ ឥតទុកឲ្យគេមានឫស ឬមែកនៅសល់ឡើយ នេះហើយជាព្រះបន្ទូលរបស់ព្រះអម្ចាស់នៃពួកពលបរិវារ ។

២ តែ[ក]ព្រះរាជបុត្រានៃសេចក្ដីសុចរិតនឹងរះឡើង មានទាំងអំណាចប្រោសឲ្យជា នៅក្នុងចំអេងស្លាបទ្រង់ សំរាប់អ្នករាល់គ្នាដែល កោតខ្លាចដល់នាមយើង; នោះអ្នករាល់គ្នានឹងចេញទៅ[ខ]លោតកញ្ឆ្លោងដូចជា[គ]កូនគោ ដែលលែងចេញពីក្រោល ។

៣ ហើយព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថា នៅថ្ងៃដែលធ្វើការនោះ អ្នករាល់គ្នានឹង[ក]ជាន់ឈ្លីពួកអាក្រក់បង់; ត្បិតគេនឹងដូចជាផេះ នៅក្រោមបាទជើងរបស់អ្នករាល់គ្នា ។

៤ ចូរនឹកចាំពីក្រិត្យវិន័យលោកម៉ូសេ ជាអ្នកបំរើយើង ដែលយើងបានបញ្ជាដល់លោក នៅលើ[ក]ភ្នំហូរេប សំរាប់ពួកអ៊ីស្រាអែល ទាំងអស់គ្នា គឺអស់ទាំងក្រិត្យក្រម និងបញ្ញត្តិច្បាប់ទាំងប៉ុន្មាននោះ ។

៥ មើលចុះ មុនដែល[ក]ថ្ងៃដ៏ធំ ហើយ[ខ]គួរស្ញែងខ្លាចរបស់ព្រះអម្ចាស់បានមកដល់ នោះយើងនឹងចាត់អេលីយ៉ា គឺជាព្យាការីឲ្យមកអ្នក រាល់គ្នា ។

៦ ហើយលោកនឹងបង្វែរចិត្តពួកឪពុក[ក]មកឯកូន និងចិត្តកូនមកឯឪពុកវិញ ក្រែងយើងមកវាយផែនដី ដោយសេចក្ដីបណ្ដាសា ៕

## ជំពូកទី ២៦

*ព្រះយេស៊ូវទ្រង់ពន្យល់ប្រាប់ការណ៍ទាំងអស់ចាប់ពីដំបូង ទៅដល់ទីបញ្ចប់ — ពួកទារក និងពួកក្មេងតូចពោលនូវការណ៍ដ៏អស្ចារ្យ ទាំងឡាយ ដែលមិនអាចសរសេរទុកបានឡើយ — ពួកអ្នកដែលនៅក្នុងសាសនាចក្រនៃព្រះគ្រីស្ទ មានរបស់របរទាំងអស់រួមគ្នាទូទៅ ក្នុងចំណោមពួកគេ ។ ប្រមាណជាឆ្នាំ ៣៤ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់បានប្រាប់ការណ៍ទាំងនេះហើយ នោះទ្រង់បានពន្យល់ប្រាប់ដល់បណ្ដាជន; ហើយទ្រង់បានពន្យល់ប្រាប់ការណ៍ទាំងអស់ដល់ពួកគេ ទាំងរឿងធំ និងរឿងតូច ។

២ ហើយទ្រង់មានព្រះបន្ទូលថា៖ បទគម្ពីរ[ក]ទាំងនេះ ដែលអ្នករាល់គ្នាពុំទាន់មាន នោះព្រះវរបិតាទ្រង់ បានបញ្ជាឲ្យយើងប្រទានដល់ អ្នក; ត្បិតនេះជាប្រាជ្ញានៅក្នុងទ្រង់ ដែលរបស់ទាំងនេះត្រូវបានប្រទានដល់មនុស្សជំនាន់ក្រោយ ។

៣ ហើយទ្រង់បានពន្យល់ប្រាប់ការណ៍ទាំងអស់ តាំងពីដំបូងរហូតដល់ពេល ដែលទ្រង់នឹងយាងមកក្នុង[ក]សិរីល្អរបស់ទ្រង់ — មែនហើយ គឺការណ៍ទាំងអស់ដែលកើតឡើងនៅលើផ្ទៃផែនដីនេះ រហូតដល់ថ្ងៃដែល[ខ]វត្ថុគ្រប់យ៉ាង នឹងរលាយដោយកំដៅដ៏អស្ចារ្យ ហើយផែនដី នឹងត្រូវ[គ]រមូរដូចរមូរក្រដាស ហើយផ្ទៃមេឃ និងផែនដីត្រូវកន្លងផុតទៅ ។

**២៥** ១*ក* អេសាយ ២៤:៦;
១ នីហ្វៃ ២២:១៥;
៣ នីហ្វៃ ២៤:២;
គ. និង ស. ២៩:៩;
៦៤:២៣–២៤; ១៣៣:៦៤;
យ.ស.—ប្រវត្តិ ១:៣៧.
ស.ប. ផែនដី — ការ
សំអាតផែនដី.
*ខ* ២ នីហ្វៃ ២០:៣៣.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
២ *ក* អេធើរ ៩:២២.
*ខ* គ. និង ស. ៤៥:៥៨.
*គ* អេម៉ុស ៦:៤; ១ នីហ្វៃ ២២:២៤.
៣ *ក* ៣ នីហ្វៃ ២១:១២.
៤ *ក* និក្ខ. ៣:១–៦.
៥ *ក* ២ ពង្សាវ. ២:១–២;
គ. និង ស. ២:១; ១១០:១៣–១៦;
១២៨:១៧–១៨.
ស.ប. អេលីយ៉ា; សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់;
ភ្ជាប់, ការភ្ជាប់.
*ខ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៦ *ក* គ. និង ស. ២:២.

**២៦** ២*ក* ក.ន. គម្ពីរម៉ាឡាគី ជំពូកទី ៣
និង ៤ ដែលបានស្រង់នៅក្នុងគម្ពីរ
នីហ្វៃ ទី ៣ ជំពូកទី ២៤ និង ២៥.
៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិរីល្អ
នៃព្រះយេស៊ូវគ្រីស្ទ.
*ខ* អេម៉ុស ៩:១៣;
២ ពេត្រុស ៣:១០, ១២;
មរមន ៩:២.
ស.ប. ផែនដី — ការ
សំអាតផែនដី; ពិភពលោក —
ចុងបំផុតនៃផែនដី.
*គ* មរមន ៥:២៣.

៤ ហើយគឺដល់ថ្ងៃដ៏មហិមា និងចុងក្រោយបង្អស់ គ្រាដែលគ្រប់ទាំងប្រជាជន និងគ្រប់ទាំងពូជមនុស្ស និងគ្រប់ទាំងសាសន៍ ហើយ និងគ្រប់ទាំងភាសានឹងឈរនៅចំពោះព្រះ ដើម្បីទទួលការជំនុំជំរះ ចំពោះកិច្ចការទាំងឡាយរបស់ខ្លួន ដើម្បីឲ្យឃើញថា ពួកគេល្អ ឬក៏ពួកគេអាក្រក —

៥ បើសិនជាពួកគេល្អ នោះនឹងបានដំណើររស់ឡើងវិញ ដល់ជីវិតដ៏អស់កល្បជានិច្ច; តែបើសិនជាពួកគេអាក្រក់ នោះនឹងបានដំណើររស់ឡើងវិញ នៃការផាប់ទោស; គឺនៅបណ្ដោយគ្នាមួយខាងនេះ ហើយមួយទៀត នៅខាងនោះ ស្របតាមសេចក្ដីមេត្តា ករុណា និងសេចក្ដីយុត្តិធម៌ និងបរិសុទ្ធភាព ដែលនៅក្នុងព្រះគ្រីស្ទ គឺទ្រង់នៅមុន ពេលលោកិយនេះចាប់ផ្ដើមម្ល៉េះ ។

៦ ហើយឥឡូវនេះ គេពុំអាចកត់ទុកក្នុងគម្ពីរនេះបានទេ សូម្បីតែមួយភាគរយនៃការណ៍ទាំងឡាយ ដែលព្រះយេស៊ូវទ្រង់បានបង្រៀន យ៉ាងពិតប្រាកដដល់ប្រជាជនក៏ដោយ;

៧ ប៉ុន្តែមើលចុះ ឯផ្ទាំងនីហ្វៃមាននូវភាគច្រើននៃការណ៍ទាំងឡាយ ដែលទ្រង់បានបង្រៀនប្រជាជន ។

៨ ហើយការណ៍ទាំងឡាយ ដែលខ្ញុំបានសរសេរមកនេះ គឺជាភាគមួយតូច នៃការណ៍ដែលទ្រង់បានបង្រៀនប្រជាជន; ហើយខ្ញុំសរសេរការណ៍ទាំងនេះទុក ក្នុងគោលបំណងថា ការណ៍ទាំងនេះអាចបាននាំមកឲ្យប្រជាជននេះ ពីពួកសាសន៍ដទៃ តាមពាក្យដែល ព្រះយេស៊ូវទ្រង់មានព្រះបន្ទូល ។

៩ ហើយគ្រាដែលពួកគេបានទទួលការណ៍ទាំងនេះ គឺចាំបាច់ថា គេត្រូវតែមានការណ៍ទាំងនេះមុន ដើម្បីសាកល្បងសេចក្ដីជំនឿ របស់គេ ហើយប្រសិនបើពួកគេជឿនូវការណ៍ទាំងនេះ នោះការណ៍ដែលធំលើសលប់ទៅទៀត នឹងត្រូវបានសម្ដែងដល់ពួកគេ ។

១០ តែប្រសិនបើពួកគេពុំជឿនូវការណ៍ទាំងនេះទេ នោះការណ៍ដ៏ធំលើសលែងទៅទៀត នឹងពុំត្រូវបានសម្ដែងដល់ពួកគេឡើយ គឺទុកជាការកាត់ទោសដល់គេវិញ ។

១១ មើលចុះ ខ្ញុំបំរុងនឹងសរសេរការណ៍ទាំងនេះ គឺគ្រប់ទាំងការណ៍ដែលបានឆ្លាក់ នៅលើផ្ទាំងនីហ្វៃ ប៉ុន្តែព្រះអម្ចាស់ទ្រង់ហាម យាត់ខ្ញុំថា៖ យើងនឹងសាកល្បងសេចក្ដីជំនឿនៃរាស្ត្រយើងវិញ ។

១២ ហេតុដូច្នេះហើយ ខ្ញុំមរមន សរសេរនូវការណ៍ទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាដល់ខ្ញុំ ។ ហើយឥឡូវនេះ ខ្ញុំ មរមន សូមបញ្ចប់នូវការនិយាយរបស់ខ្ញុំ ហើយចាប់ផ្ដើមសរសេរនូវអ្វីៗ ដែលព្រះទ្រង់បានបញ្ជាដល់ខ្ញុំវិញ ។

១៣ ហេតុដូច្នេះហើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាឃើញថា ព្រះអម្ចាស់ទ្រង់បានបង្រៀនដល់ប្រជាជនជាពិតប្រាកដគឺអស់រយៈពេលបីថ្ងៃ; ហើយបន្ទាប់ពីនោះមក ទ្រង់បានបង្ហាញរូបអង្គទ្រង់ដល់ពួកគេជាញឹកញយ ហើយបានកាច់នំបុ័ងជាញឹកញយ ហើយប្រទានពរដល់នំបុ័ង ហើយប្រទានឲ្យទៅពួកគេ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានបង្រៀន ហើយធ្វើការងារបំរើដល់ពួកកូនក្មេងនៃហ្វូងមនុស្ស ដែលបានរៀបរាប់ មកនេះ ហើយទ្រង់បានស្រាយអណ្ដាតវា ដើម្បីឲ្យវានិយាយប្រាប់ពួកឪពុកវា នូវការណ៍ដ៏ធំ និងអស្ចារ្យធំជាងការណ៍ដែលទ្រង់បាន ប្រាប់ដល់ប្រជាជនទៀត ហើយទ្រង់បានស្រាយ អណ្ដាតវា ដើម្បីឲ្យវាអាចនិយាយបាន ។

១៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីទ្រង់បានយាងឡើងទៅស្ថានសួគ៌ — គឺលើកទីពីរ ដែលទ្រង់បានបង្ហាញរូបអង្គ ទ្រង់ដល់ពួកគេ ហើយបានទៅជួបនឹងព្រះវរបិតា គឺបន្ទាប់ពីបានប្រោសឲ្យអស់អ្នកឈឺ និងអ្នកពិការបានជា និងបើកភ្នែកអ្នកខ្វាក់ និងបើក ត្រចៀកអ្នកថ្លង់ ព្រមទាំងបានព្យាបាលរោគាសព្វសារពើ នៅក្នុងចំណោមពួកគេ ហើយបានប្រោសបុរសម្នាក់ពីស្លាប់ និងបានបង្ហាញនូវ ព្រះចេស្ដារបស់ទ្រង់ដល់ពួកគេ ហើយក៏បានយាងឡើងទៅជួបព្រះវរបិតា —

១៦ មើលចុះ ហេតុការណ៍បានកើតឡើងថា ដល់ស្អែកឡើងនោះហ្វូងមនុស្សបានមករួមប្រជុំគ្នា ហើយពួកគេបានឃើញ

៤ *ក* ហេលេ. ១២:២៥;
៣ នីហ្វៃ ២៨:៣១.
*ខ* ម៉ូសាយ ១៦:១០–១១.
ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
៥ *ក* ដានី. ១២:២; យ៉ូហាន ៥:២៩.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
*គ* អេធើរ ៣:១៤.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ព្រះគ្រីស្ទមានព្រះជន្មរស់នៅមុនផែនដី.
៦ *ក* យ៉ូហាន ២១:២៥;
៣ នីហ្វៃ ៥:៨.
៧ *ក* ស.ប. ផ្ទាំងទាំងឡាយ.
៨ *ក* ៣ នីហ្វៃ ២១:៥–៦.
៩ *ក* អេធើរ ៤:៤–១០.
១០ *ក* អាលម៉ា ១២:៩–១១.
១១ *ក* អេធើរ ១២:៦.
១៣ *ក* យ៉ូហាន ២១:១៤.
*ខ* ៣ នីហ្វៃ ២០:៣–៩.
ស.ប. បុណ្យរំឭក.
១៤ *ក* ៣ នីហ្វៃ ១៧:១១–១២.
*ខ* អាលម៉ា ៣២:២៣;
៣ នីហ្វៃ ២៦:១៦.
១៥ *ក* ៣ នីហ្វៃ ១៧:៩.
ស.ប. ប្រោស, ការប្រោស; អព្ភូតហេតុ.

ហើយបានឮ ពួកកូនក្មេងទាំងនេះ; មែនហើយ ទាំង[ក]ទារកក៏បាន
បើកមាត់និយាយការណ៍ដ៏អស្ចារ្យទាំងឡាយ; តែការណ៍ទាំង
ឡាយដែលពួកកូនក្មេង បាននិយាយនោះ ត្រូវបានហាមឃាត់
មិនឲ្យអ្នកណាសរសេរទុកឡើយ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា [ក]ពួកសិស្សដែល
ព្រះយេស៊ូវបានរើសទាំងនោះ ចាប់តាំងពីពេលនោះមក បាន
ចាប់ផ្ដើមធ្វើ [ខ]បុណ្យជ្រមុជទឹក ហើយបង្រៀនអស់អ្នកណា ដែល
បានមករកពួកគេ; ហើយអស់អ្នកណា ដែលបានទទួលបុណ្យ
ជ្រមុជទឹក ដោយនូវ ព្រះនាមព្រះយេស៊ូវ ក៏តែងតែបាន
ពោរពេញ ទៅដោយព្រះវិញ្ញាណបរិសុទ្ធ ។
១៨ ហើយពួកគេជាច្រើននាក់ បានឃើញ ហើយបានឮការណ៍
ទាំងឡាយ ដែលពុំអាចប្រាប់បានឡើយ គឺ[ក]មិនត្រូវច្បាប់កត់ទុកទេ ។
១៩ ហើយពួកគេបានបង្រៀន ហើយបានធ្វើការងារបំរើ
គ្នាទៅវិញទៅមក; ហើយពួកគេមានរបស់របរ[ក]ទាំងអស់រួមគ្នា [ខ]ទូទៅ
ក្នុងចំណោមពួកគេ គឺមនុស្សម្នាក់ៗទាក់ទងគ្នាទៅវិញទៅមក
ដោយសេចក្ដីយុត្តិធម៌ ។
២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើការ
ទាំងអស់ ដូចដែលព្រះយេស៊ូវទ្រង់បានបញ្ជាដល់ពួកគេ ។
២១ ហើយពួកអ្នកដែលបានទទួលបុណ្យជ្រមុជទឹក ដោយនូវ
ព្រះនាមព្រះយេស៊ូវ នោះបានហៅថា [ក]សាសនាចក្រនៃព្រះគ្រីស្ទ ៕

## ជំពូកទី ២៧

*ព្រះយេស៊ូវទ្រង់បានបញ្ជាពួកគេឲ្យហៅសាសនាចក្រតាមព្រះនាមរបស់ទ្រង់ — បេសកកម្ម និងការបូជាដ៏ធួនរបស់ទ្រង់បង្កើតជា ដំណឹងល្អរបស់ទ្រង់ — មនុស្សត្រូវបានបញ្ជាឲ្យប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដើម្បីឲ្យពួកគេអាចបានញែកចេញជាបរិសុទ្ធ ដោយព្រះវិញ្ញាណបរិសុទ្ធ — ពួកគេនឹងបានទៅដូចជាព្រះយេស៊ូវគ្រីស្ទ ។ ប្រមាណជាឆ្នាំ ៣៤–៣៥ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅពេលពួកសិស្សនៃ
ព្រះយេស៊ូវកំពុងតែចេញដំណើរ ហើយផ្សាយនូវការណ៍ទាំងឡាយ
ដែលពួកគេបានឮ ហើយបានឃើញ ហើយព្រមទាំងបានធ្វើបុណ្យ
ជ្រមុជទឹក ដោយនូវព្រះនាមព្រះយេស៊ូវផង នោះហេតុការណ៍
បាន [ក]កើតឡើងថា ពួកសិស្សបានរួមគ្នាអធិស្ឋានយ៉ាងខ្លាំង
ហើយ[ខ]បានតមអាហារ ។
២ ហើយព្រះយេស៊ូវ ទ្រង់[ក]បានបង្ហាញរូបអង្គទ្រង់ដល់ពួកគេទៀត
ត្បិតពួកគេកំពុងតែអធិស្ឋានដល់ព្រះវរបិតា ដោយនូវព្រះនាមទ្រង់;
ហើយព្រះយេស៊ូវទ្រង់បានយាងមកឈរនៅកណ្ដាលពួកគេ ហើយ
មានព្រះបន្ទូលទៅពួកគេថា៖ តើអ្នករាល់គ្នាចង់ឲ្យយើងប្រទានអ្វី
ដល់អ្នក ?
៣ ហើយពួកគេបានទូលទ្រង់ថា៖ ឱព្រះអម្ចាស់អើយ យើងខ្ញុំ
សូមឲ្យព្រះអង្គប្រាប់យើងខ្ញុំនូវឈ្មោះ ដែលយើងខ្ញុំនឹងហៅសាសនា
ចក្រ នេះ ត្បិតមានការប្រកែកគ្នា នៅក្នុងចំណោមប្រជាជន
អំពីរឿងនេះ ។
៤ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ ប្រាកដមែន
យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ហេតុអ្វីបានជាប្រជាជនរអ៊ូរទាំ
ហើយប្រកែកគ្នា ដោយសារតែរឿងនេះ ?
៥ តើពួកគេពុំបានអានបទគម្ពីរទាំងឡាយ ដែលបានចែងថា
អ្នករាល់គ្នាត្រូវយក[ក]ព្រះនាមព្រះគ្រីស្ទដាក់លើខ្លួន ដែលជានាមយើង
ទេឬ ? ត្បិតដោយនាមនេះហើយដែលអ្នករាល់គ្នានឹងត្រូវបាន
ហៅនៅថ្ងៃចុងក្រោយបង្អស់;
៦ ហើយអស់អ្នកណាដែលដាក់នាមយើងលើខ្លួន ហើយ
[ក]កាន់ខ្ជាប់ ដរាបដល់ចុងបំផុត អ្នកនោះហើយនឹងបានសង្គ្រោះ
នៅថ្ងៃ ចុងក្រោយបង្អស់ ។
៧ ដូច្នេះ សូម្បីជាអ្វីដែលអ្នករាល់គ្នានឹងធ្វើ នោះអ្នករាល់គ្នា
ត្រូវធ្វើ ដោយនូវនាមយើង; ដូច្នេះ អ្នករាល់គ្នាត្រូវហៅសាសនា
ចក្រ តាមនាមយើង; ហើយអ្នករាល់គ្នាត្រូវអំពាវនាវដល់
ព្រះវរបិតា ដោយនូវនាមយើង ប្រយោជន៍ឲ្យទ្រង់ប្រទានពរដល់
សាសនាចក្រ ដោយយល់ដល់យើង ។

១៦ *ក* ម៉ាថាយ ១១:២៥.
១៧ *ក* ៣ នីហ្វៃ ១៩:៤–១៣.
*ខ* ៤ នីហ្វៃ ១:១.
១៨ *ក* ៣ នីហ្វៃ ២៦:១១.
១៩ *ក* ៤ នីហ្វៃ ១:៣.
*ខ* ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
២១ *ក* ម៉ូសាយ ១៨:១៧.
ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
**២៧** ១ *ក* គ. និង ស. ២៩:៦.
*ខ* អាលម៉ា ៦:៦.
ស.ប. តម, តំណម.
២ *ក* ៣ នីហ្វៃ ២៦:១៣.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការលេចមករបស់ព្រះគ្រីស្ទក្រោយពីសុគត.
៥ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
៦ *ក* ៣ នីហ្វៃ ១៥:៩.

៨ ហើយតើនេះជា[ក]សាសនាចក្រ[ខ]របស់យើងដូចម្ដេចកើតលើកលែងតែហៅតាមនាមយើង ? ត្បិតបើសិនជាសាសនាចក្រនេះ ហៅតាមឈ្មោះលោកម៉ូសេ នោះជាសាសនាចក្ររបស់លោកម៉ូសេហើយ; ឬបើសិនជាសាសនាចក្រនេះហៅតាមឈ្មោះរបស់ បុរសណាម្នាក់ នោះជាសាសនាចក្ររបស់បុរសនោះហើយ; តែបើសិនជាសាសនាចក្រនេះហៅតាមនាមយើង នោះទើបជា សាសនាចក្ររបស់យើង ប្រសិនបើគេបានសង់លើដំណឹងល្អរបស់យើង ។

៩ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាត្រូវបានសង់លើដំណឹងល្អរបស់យើង; ដូច្នេះ អ្នករាល់គ្នាត្រូវហៅនូវអ្វីៗក៏ដោយ ដែលអ្នកធ្វើ តាមនាមយើង; ដូច្នេះ បើសិនជាអ្នករាល់គ្នាអំពាវនាវដល់ព្រះវរបិតា សំរាប់សាសនាចក្រនេះ ប្រសិនបើដោយនូវនាម យើង នោះព្រះវរបិតានឹងឮអ្នករាល់គ្នា ។

១០ ហើយប្រសិនបើសាសនាចក្របានសង់លើដំណឹងល្អរបស់យើងមែន នោះព្រះវរបិតា ទ្រង់នឹងបង្ហាញនូវកិច្ចការទាំងឡាយ របស់ទ្រង់ នៅក្នុងសាសនាចក្រ ។

១១ ប៉ុន្តែ ប្រសិនបើពុំបានសង់លើដំណឹងល្អរបស់យើងទេ ហើយបានសង់លើកិច្ចការទាំងឡាយរបស់មនុស្ស ឬក៏លើកិច្ចការទាំង ឡាយរបស់អារក្សវិញ នោះយើងប្រាប់អ្នករាល់គ្នាជាប្រាកដថា គេនឹងបានសេចក្ដីអំណរនៅក្នុងកិច្ចការទាំងឡាយរបស់គេ មួយរដូវ តែប៉ុណ្ណោះ ហើយមិនយូរមិនឆាប់ ទីបញ្ចប់នឹងមកដល់ ហើយពួកគេត្រូវ[ក]កាប់បំលំ ហើយបោះចោលទៅក្នុងភ្លើង ហើយដល់ពេលនោះ គឺគ្មានការត្រឡប់មកវិញឡើយ ។

១២ ត្បិតកិច្ចការទាំងឡាយរបស់ពួកគេ នឹង[ក]ទៅតាមពួកគេ ត្បិតដោយសារតែកិច្ចការទាំងឡាយរបស់គេនេះហើយបានជាពួកគេ ត្រូវកាប់រំលំចោល; ដូច្នេះ ចូរចងចាំនូវការណ៍ទាំងឡាយ ដែលយើងបានប្រាប់អ្នករាល់គ្នាចុះ ។

១៣ មើលចុះ យើងបានប្រទានដល់អ្នករាល់គ្នានូវ[ក]ដំណឹងល្អរបស់យើង ហើយនេះគឺជាដំណឹងល្អ ដែលយើងបានប្រទានដល់អ្នករាល់គ្នា — គឺយើងបានមកឯលោកិយនេះ ដើម្បីធ្វើតាម[ខ]ព្រះហឫទ័យនៃព្រះវរបិតារបស់យើង ពីព្រោះព្រះវរបិតារបស់យើងទ្រង់បានចាត់ឲ្យយើងមក ។

១៤ ហើយព្រះវរបិតាយើង ទ្រង់បានចាត់ឲ្យយើងមក ដើម្បីឲ្យយើងអាចត្រូវបាន[ក]លើកឡើងលើឈើឆ្កាង; ហើយបន្ទាប់ពីយើងត្រូវ បានលើកឡើងលើឈើឆ្កាង គឺប្រយោជន៍ឲ្យយើងអាច[ខ]ទាញនាំគ្រប់មនុស្សទាំងអស់ ឲ្យមករកយើង ហើយដូចជាយើងត្រូវបានលើក ឡើងលើឈើឆ្កាង ដោយមនុស្សលោកយ៉ាងណា នោះមនុស្សលោកក៏នឹងត្រូវបានលើកឡើង ដោយព្រះវរបិតាយ៉ាងនោះដែរ ដើម្បី ឲ្យឈរចំពោះយើង ដើម្បី[គ]ទទួលការជំនុំជំរះស្របតាមកិច្ចការទាំងឡាយរបស់ខ្លួន ដើម្បីឲ្យឃើញថា ពួកគេល្អ ឬក៏ពួកគេអាក្រក់ —

១៥ ហើយដោយហេតុនេះ ទើបយើងត្រូវបាន[ក]លើកឡើង; ហេតុដូច្នេះហើយ ស្របតាមព្រះចេស្ដានៃព្រះវរបិតា នោះយើងនឹងទាញ នាំគ្រប់មនុស្សទាំងអស់ឲ្យមករកយើង ប្រយោជន៍ឲ្យគេអាចបានទទួលការជំនុំជំរះ ស្របតាមកិច្ចការទាំងឡាយរបស់គេ ។

១៦ ហើយហេតុការណ៍នឹងកើតឡើងថា អស់អ្នកណាដែល[ក]ប្រែចិត្ត ហើយ[ខ]ទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង នោះត្រូវបាន ពោរពេញ ហើយបើអ្នកនោះ[គ]កាន់ខ្ជាប់ ដរាបដល់ចុងបំផុត មើលចុះ យើងនឹងចាត់អ្នកនោះទុកថាជាឥតទោសនៅចំពោះព្រះវរបិតា យើង នៅក្នុងថ្ងៃដែលយើងនឹងឈរជំនុំជំរះមនុស្សលោក ។

១៧ ហើយអ្នកណាដែលមិនកាន់ខ្ជាប់ ដរាបដល់ចុងបំផុតទេ អ្នកនោះក៏នឹងត្រូវកាប់រំលំ ហើយបោះចោលទៅក្នុងភ្លើង គឺជាកន្លែងដែលគេពុំអាចត្រឡប់មកវិញបានឡើយ ពីព្រោះមកពី[ក]សេចក្ដីយុត្តិធម៌នៃព្រះវរបិតា ។

១៨ នេះហើយគឺជាពាក្យដែលទ្រង់បានប្រទានដល់កូនចៅមនុស្ស ។ ហើយដោយហេតុនេះ ទ្រង់បានបំពេញពាក្យទាំងឡាយ ដែលទ្រង់បានប្រទានមក ហើយទ្រង់ពុំកុហកទេ តែបំពេញគ្រប់ទាំងពាក្យរបស់ទ្រង់វិញ ។

---

៨ *ក* គ. និង ស. ១១៥:៤.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិរសានៃសាសនាចក្រ.
១១ *ក* អាលម៉ា ៥:៥២.
១២ *ក* វិវ. ១៤:១៣; គ. និង ស. ៥៩:២.
១៣ *ក* គ. និង ស. ៧៦:៤០–៤២. ស.ប. ដំណឹងល្អ.
*ខ* យ៉ូហាន ៦:៣៨–៣៩.
១៤ *ក* ១ នីហ្វៃ ១១:៣២–៣៣; ម៉ូសេ ៧:៥៥.
*ខ* យ៉ូហាន ៦:៤៤; ២ នីហ្វៃ ៩:៥; គ. និង ស. ២៧:១៨.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
១៥ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
១៦ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*គ* ១ នីហ្វៃ ១៣:៣៧. ស.ប. កាន់ខ្ជាប់.
១៧ *ក* ស.ប. សេចក្ដីយុត្តិធម៌.

១៩ ហើយ[ក]គ្មានអ្វីដែលពុំស្អាតណាអាចចូលទៅក្នុងនគរ
របស់ទ្រង់បានឡើយ; ដូច្នេះ គ្មានអ្នកណាអាចចូលទៅក្នុង
[ខ]ទីសំរាករបស់ទ្រង់ បានទេ លើកលែងតែអ្នកនោះ [គ]បាន
លាងសំលៀកបំពាក់របស់ខ្លួន ដោយនូវលោហិតរបស់យើង
ពីព្រោះមកពីសេចក្ដីជំនឿរបស់គេ និងការប្រែចិត្តពីគ្រប់ទាំង
អំពើបាបរបស់គេ និងការស្មោះត្រង់របស់គេ រហូត
ដល់ទីបំផុត ។
២០ ឥឡូវនេះ នេះគឺជាបញ្ញត្តិថា៖ ចូរ[ក]ប្រែចិត្តចុះ [ខ]ឱអ្នករាល់
គ្នានៅចុងផែនដីអើយ ហើយចូរមករកយើង ហើយទទួលបុណ្យ
ជ្រមុជទឹក ដោយនូវនាមយើងចុះ ប្រយោជន៍ឲ្យអ្នករាល់គ្នា អាច
[គ]បានញែកចេញបរិសុទ្ធ ដោយការទទួលនូវព្រះវិញ្ញាណបរិសុទ្ធ
ប្រយោជន៍ឲ្យ អ្នករាល់គ្នា អាចឈរដោយ[ឃ]គ្មានទោសនៅចំពោះ
យើង នៅថ្ងៃចុងក្រោយបង្អស់ ។
២១ ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា នេះហើយ
ជាដំណឹងល្អរបស់យើង; ហើយអ្នករាល់គ្នាស្គាល់ការណ៍ទាំង
ឡាយ ដែលអ្នករាល់គ្នាត្រូវធ្វើ នៅក្នុងសាសនាចក្ររបស់យើង;
ត្បិតកិច្ចការទាំងឡាយដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាង
ណា នោះអ្នករាល់គ្នាត្រូវធ្វើយ៉ាងនោះដែរ; ត្បិតអ្វីៗដែលអ្នក
រាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នកត្រូវធ្វើតាម
យ៉ាងនោះដែរ ។
២២ ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាធ្វើនូវការណ៍
ទាំងនេះ មានពរដល់អ្នករាល់គ្នាហើយ ត្បិតអ្នករាល់គ្នានឹងត្រូវ
បានលើក ឡើង នៅថ្ងៃចុងក្រោយបង្អស់ ។
២៣ ចូរកត់ការណ៍ទាំងឡាយ ដែលអ្នករាល់គ្នាបានឃើញ
ហើយបានឮទុកចុះ លើកលែងតែការណ៍ណាដែលបាន[ក]ហាមឃាត់។
២៤ ចូរកត់កិច្ចការទាំងឡាយរបស់ប្រជាជននេះទុកចុះ ដែល
នឹងមានដូចដែលបានកត់ទុក នូវកិច្ចការដែលបានកន្លងផុតមក
ហើយដែរ ។
២៥ ត្បិតមើលចុះ ចេញពីគម្ពីរទាំងឡាយដែលបាន
សរសេរទុក ហើយដែលនឹងបានសរសេរទុក នោះប្រជាជននេះ
នឹងបានទទួល [ក]ការជំនុំជំរះ ត្បិតដោយសារគម្ពីរ
ទាំងនេះហើយដែល[ខ]កិច្ចការទាំងឡាយ របស់គេនឹងបានមនុស្ស
លោកស្គាល់ ។
២៦ ហើយមើលចុះ ការណ៍ទាំងអស់ត្រូវបាន[ក]កត់ទុក ដោយ
ព្រះវរបិតា; ហេតុដូច្នេះហើយ ចេញពីគម្ពីរទាំងឡាយដែល
នឹងបាន សរសេរទុក នោះមនុស្សលោកនឹងបានទទួល
ការជំនុំជំរះ ។
២៧ ហើយចូរអ្នករាល់គ្នាដឹងថា [ក]អ្នករាល់គ្នានឹងទៅជាចៅក្រម
ជំនុំជំរះប្រជាជននេះ ស្របតាមសេចក្ដីជំនុំជំរះ ដែលយើងនឹង
ប្រទាន ដល់អ្នក ដែលត្រឹមត្រូវ ។ ដូច្នេះ តើអ្នករាល់គ្នាគួរធ្វើជា
មនុស្ស[ខ]បែបណាទៅ ? យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា
ត្រូវឲ្យបាន[គ]ដូចជា យើង ។
២៨ ហើយឥឡូវនេះ យើង[ក]ទៅឯព្រះវរបិតា ។ ហើយយើង
ប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្វីក៏ដោយដែលអ្នករាល់គ្នា
សូមដល់ព្រះ វរបិតា ដោយនូវនាមយើង នោះនឹងបានប្រទាន
ដល់អ្នក ។
២៩ ដូច្នេះ ចូរ[ក]សូម ហើយអ្នកនឹងបានទទួល; ចូរគោះ នោះ
តែងនឹងបើកឲ្យអ្នក; ត្បិតអ្នកណាដែលសូម នោះនឹងបានទទួល;
រីឯអ្នក ណាដែលគោះ នោះតែងនឹងបើកឲ្យអ្នកនោះ ។
៣០ ហើយឥឡូវនេះ មើលចុះ សេចក្ដីអំណររបស់យើង
ធំណាស់ គឺពេញទំហឹង ដោយព្រោះអ្នករាល់គ្នា និងតំណ
នេះផង; មែន ហើយ ព្រមទាំងព្រះវរបិតាក៏ទ្រង់មានសេចក្ដីអំណរ
ហើយគ្រប់ទាំងពួកទេវតាបរិសុទ្ធផង ដោយព្រោះអ្នករាល់គ្នា
និងតំណនេះ; ត្បិត[ក]គ្មាននរណាម្នាក់បានវង្វេងបាត់ឡើយ ។
៣១ មើលចុះ យើងចង់ឲ្យអ្នករាល់គ្នាយល់; [ខ]ត្បិតយើងមាន
ន័យដល់ពួកអ្នកដែល[ក]ឥឡូវនេះ រស់នៅក្នុងតំណនេះ; ហើយគ្មាន

១៩ ក អាលម៉ា ១១:៣៧.
ខ គ. និង ស. ៨៤:២៤.
ស.ប. សេចក្ដីសំរាក.
គ វិវរ. ១:៥; ៧:១៤;
អាលម៉ា ៥:២១, ២៧;
១៣:១១–១៣.
២០ ក អេធើរ ៤:១៨.
ខ ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក —
ការចាំបាច់.
គ ស.ប. ការញែកជាបរិសុទ្ធ.
ឃ គ. និង ស. ៤:២.
២៣ ក ៣ នីហ្វៃ ២៦:១៦.
២៥ ក ២ នីហ្វៃ ៣៣:១០–១៥;
ព. នៃ ម. ១:១១.
ខ ១ នីហ្វៃ ១៥:៣២–៣៣.
២៦ ក ៣ នីហ្វៃ ២៤:១៦.
ស.ប. សៀវភៅជីវិត.
២៧ ក ១ នីហ្វៃ ១២:៩–១០;
មរមន ៣:១៩.
ខ ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ជំរាប់នៃព្រះយេស៊ូវគ្រីស្ទ.
គ ម៉ាថាយ ៥:៤៨;
៣ នីហ្វៃ ១២:៤៨.
២៨ ក យ៉ូហាន ២០:១៧.
២៩ ក ម៉ាថាយ ៧:៧;
៣ នីហ្វៃ ១៤:៧.
៣០ ក យ៉ូហាន ១៧:១២.
៣១ ក ៣ នីហ្វៃ ៩:១១–១៣; ១០:១២.
ខ ៣ នីហ្វៃ ២៨:២៣.

នរណា ម្នាក់បានវង្វេងបាត់ឡើយ; ហើយដោយសារពួកគេនេះហើយដែលយើងមាន[ក]សេចក្ដីអំណរដ៏ពោរពេញ ។

៣២ [ក]ប៉ុន្ដែមើលចុះ យើងមានសេចក្ដីព្រួយបារម្ភ ពីព្រោះតែតំណទីបួន ពីតំណនេះទៅ ត្បិតពួកគេនឹងត្រូវចាប់ខ្លួននាំយកទៅឃុំឃាំង ដោយកូននៃអន្តរធាន; ត្បិតពួកគេនឹង[ខ]លក់យើង ដើម្បីយកប្រាក់ និងមាស និងដើម្បីអ្វីៗដែលកន្លាតអាចកាត់បំផ្លាញ និងអ្វីៗដែលចោរ អាចចោះទម្លុះប្លន់បាន ។ ហើយនៅថ្ងៃនោះ យើងនឹងមករកពួកគេ ទាំងបង្វិលកិច្ចការរបស់គេ មកស្រោចលើក្បាលរបស់ពួកគេវិញ ។

៣៣ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់បានបញ្ចប់ព្រះបន្ទូលទាំងនេះហើយ នោះទ្រង់មានព្រះបន្ទូលទៅពួកសិស្សរបស់ទ្រង់ថា៖ ចូរអ្នករាល់គ្នាចូលតាម[ក]ទ្វារចង្អៀតចុះ; ត្បិតទ្វារចង្អៀត និងផ្លូវតូច នាំទៅឯជីវិត ហើយមានមនុស្សតិចណាស់ ដែលរកផ្លូវនោះឃើញ; ប៉ុន្តែទ្វារធំ និងផ្លូវទូលាយ នាំទៅឯសេចក្ដីស្លាប់ ក៏មានមនុស្សជាច្រើន ដែលដើរតាមផ្លូវនោះ រហូតដល់ពេល យប់មកដល់ នោះគ្មាននរណាអាចធ្វើការបានឡើយ ៕

## ជំពូកទី ២៨

*ពួកសិស្សប្រាំបួនក្នុងដប់ពីរនាក់ ប៉ងប្រាថ្នា ហើយបានសន្យាថានឹងបានគ្រងមរតក នៅក្នុងនគរព្រះគ្រីស្ទ នៅពេលពួកគេស្លាប់ទៅ — ពួកសាសន៍នីហ្វៃទាំងបីនាក់ប៉ងប្រាថ្នា ហើយបានប្រទាននូវអំណាចឲ្យឈ្នះលើសេចក្ដីស្លាប់ ដើម្បីរស់នៅលើផែនដី រហូតដល់ពេល ព្រះយេស៊ូវទ្រង់យាងមកវិញទៀត — ពួកគេបានប្រែរូប ហើយឃើញកិច្ចការទាំងឡាយ ដែលពុំត្រូវច្បាប់នឹងប្រាប់បានឡើយ ហើយឥឡូវ ពួកគេកំពុងធ្វើការងារបំរើ នៅក្នុងចំណោមមនុស្សលោក ។ ប្រមាណជាឆ្នាំ ៣៤–៣៥ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលយ៉ាងនេះចប់ហើយ នោះទ្រង់ បានប្រាប់ពួកសិស្សរបស់ទ្រង់ ម្ដងម្នាក់ៗថា៖ តើអ្នករាល់គ្នាប្រាថ្នាអ្វីពីយើង បន្ទាប់ពីយើងទៅជួបព្រះវរបិតាវិញ ?

២ ហើយពួកគេទាំងអស់ លើកលែងតែបីនាក់បានទូលថា៖ យើងខ្ញុំសូមប្រាថ្នាថា បន្ទាប់ពីយើងខ្ញុំបានរស់នៅ អស់អាយុមនុស្សហើយ ហើយបានសំរេចការងារបំរើ ដែលព្រះអង្គប្រគល់ដល់យើងខ្ញុំហើយ នោះសូមឲ្យយើងខ្ញុំ អាចបានទៅឯនគររបស់ព្រះអង្គយ៉ាងឆាប់ រហ័ស ។

៣ ហើយទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ មានពរហើយ អ្នករាល់គ្នា ពីព្រោះអ្នករាល់គ្នាប្រាថ្នាសូមការណ៍នេះពីយើង; ដូច្នេះបន្ទាប់ពីអ្នករាល់គ្នាមានអាយុ៧២ឆ្នាំហើយ នោះអ្នករាល់គ្នានឹងបានមកឯយើង នៅឯនគរយើង; ហើយអ្នករាល់គ្នានឹងបាន[ក]សំរាកនៅ ជាមួយនឹងយើង ។

៤ កាលទ្រង់មានព្រះបន្ទូលទៅពួកគេហើយ នោះទ្រង់បែរទៅរកពួកសិស្សបីនាក់ទៀត ក៏មានព្រះបន្ទូលទៅពួកគេថា៖ តើអ្នករាល់ គ្នាមានបំណងចង់ឲ្យយើងគួរធ្វើអ្វីដល់អ្នក ពេលយើងទៅជួបព្រះវរបិតាវិញ?

៥ ហើយពួកគេព្រួយនៅក្នុងចិត្ត ដោយពុំហ៊ានទូលប្រាប់ព្រះអង្គនូវអ្វីដែលគេប្រាថ្នា ។

៦ នោះទ្រង់មានព្រះបន្ទូលទៅពួកគេថា៖ មើលចុះ យើង[ក]ដឹងគំនិតរបស់អ្នកហើយ គឺអ្នករាល់គ្នាចង់បានការដែល[ខ]យ៉ូហាន គឺជាទីស្រឡាញ់របស់យើង ចង់បានពីយើង កាលដែលបាននៅជាមួយនឹងយើង ក្នុងការងារបំរើរបស់យើង គឺមុនពេលយើងត្រូវពួកសាសន៍ យូដាលើកឡើងលើឈើឆ្កាង ។

៧ ដូច្នេះ មានពរដល់អ្នករាល់គ្នាជាងនេះទៅទៀត ត្បិតអ្នករាល់គ្នានឹង[ក]ពុំត្រូវ[ខ]ភ្លក់សេចក្ដីស្លាប់ឡើយ; ប៉ុន្តែអ្នករាល់គ្នានឹងរស់នៅ ដើម្បីមើលឃើញគ្រប់ទាំងកិច្ចការ ដែលព្រះវរបិតាទ្រង់នឹងធ្វើចំពោះកូនចៅមនុស្ស រហូតដល់អ្វីៗទាំងអស់ នឹងបានបំពេញតាម ព្រះហឫទ័យនៃព្រះវរបិតា គឺកាលយើងនឹងយាងមក នៅក្នុងសិរីល្អរបស់យើង ដោយ[គ]អំណាចនៃស្ថានសួគ៌ ។

៨ ហើយអ្នករាល់គ្នានឹងពុំរងទុក្ខនូវការឈឺចាប់ នៃសេចក្ដីស្លាប់ឡើយ; ប៉ុន្តែកាលយើងយាងមក នៅក្នុងសិរីល្អរបស់យើង

៣១ *ក* ស.ប. សេចក្ដីអំណរ.
៣២ *ក* ២ នីហ្វៃ ២៦:៩–១០;
អាលម៉ា ៤៥:១០, ១២.
*ខ* ម៉ាថាយ ៦:១៩–២១;
៣ នីហ្វៃ ១៣:១៩–២១.
៣៣ *ក* ម៉ាថាយ ៧:១៣–១៤;
៣ នីហ្វៃ ១៤:១៣–១៤;
គ. និង ស. ២២:១–៤.
**២៨** ៣ *ក* ស.ប. សេចក្ដីសំរាក.
៦ *ក* អេម៉ុស ៤:១៣;
អាលម៉ា ១៨:៣២.
*ខ* យ៉ូហាន ២១:២១–២៣;
គ. និង ស. ៧:១–៤.
៧ *ក* ៤ នីហ្វៃ ១:១៤;
មរមន ៨:១០–១១;
អេធើរ ១២:១៧.
*ខ* ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.
*គ* ៣ នីហ្វៃ ២០:២២.

នោះអ្នក រាល់គ្នានឹងបានផ្លាស់ពី[ក]ភាពរមែងស្លាប់ ទៅ[ខ]អមតភាព
តែក្នុងមួយពព្រិចភ្នែក; ហើយនៅពេលនោះ អ្នករាល់គ្នានឹង
បានពរ នៅក្នុង នគរនៃព្រះវរបិតាយើង ។
៩ ហើយម្យ៉ាងទៀត អ្នករាល់គ្នានឹងពុំឈឺចាប់សោះ នៅពេល
អ្នករាល់គ្នារស់នៅក្នុងសាច់ឈាម ឬព្រួយបារម្ភឡើយ លើកលែង
តែចំពោះអំពើបាបទាំងឡាយ នៃមនុស្សលោកប៉ុណ្ណោះ; ហើយយើង
នឹងធ្វើគ្រប់ការណ៍ទាំងនេះ ពីព្រោះមកពីអ្វីៗដែលអ្នករាល់គ្នា
បាន ប្រាថ្នាពីយើង ត្បិតអ្នករាល់គ្នាប្រាថ្នាចង់[ក]នាំព្រលឹងមនុស្ស
មករកយើង នៅពេលពិភពលោកឈរនៅ ។
១០ ហើយដោយហេតុនេះ អ្នករាល់គ្នានឹងបានសេចក្ដីអំណ
[ក]រដ៏ពោរពេញ; ហើយអ្នករាល់គ្នានឹងអង្គុយនៅក្នុងនគរនៃព្រះវរបិតា
យើង; មែនហើយ សេចក្ដីអំណរនៃអ្នករាល់គ្នានឹងបានពោរពេញ
ដូចជាព្រះវរបិតាទ្រង់បានប្រទានសេចក្ដីអំណរដ៏ពោរពេញ ដល់យើង
យ៉ាងនោះដែរ; ហើយអ្នករាល់គ្នានឹងបានទៅដូចជាយើង
ហើយយើងបានទៅដូចជាព្រះវរបិតា; ហើយព្រះវរបិតា
និងយើង គឺ[ខ]តែមួយ ។
១១ ហើយ[ក]ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់អំពីព្រះវរបិតា និង
អំពីយើង; ហើយព្រះវរបិតា ទ្រង់ប្រទានព្រះវិញ្ញាណបរិសុទ្ធ
ដល់កូនចៅ មនុស្ស ដោយសារយើង ។
១២ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះយេស៊ូវ
ទ្រង់មានព្រះបន្ទូលយ៉ាងនេះចប់ហើយ នោះទ្រង់ពាល់ពួកគេគ្រប់
គ្នា ដោយព្រះអង្គុលីរបស់ទ្រង់ លើកលែងតែអ្នកទាំងបី ដែល
នឹងនៅលើផែនដី រួចហើយ ទ្រង់ក៏យាងចេញទៅ ។
១៣ ហើយមើលន៏ ផ្ទៃមេឃក៏បើកចំហ ហើយពួកគេត្រូវបាន
[ក]នាំឡើងទៅឯស្ថានសួគ៌ ហើយបានឃើញ ហើយបានឮការណ៍
ទាំង ឡាយ ដែលពុំអាចប្រាប់បានឡើយ ។
១៤ គឺបាន[ក]ហាមមិនឲ្យពួកគេនិយាយ ឬក៏ឲ្យអំណាចដល់ពួក
គេ ដើម្បីគេអាចប្រាប់ការណ៍ទាំងឡាយ ដែលគេបានឃើញ
ហើយបាន ឮនោះឡើយ ។
១៥ ហើយទោះពួកគេនៅក្នុងរូបកាយ ឬក៏នៅក្រៅរូបកាយក្ដី
នោះពួក[ក]គេពុំអាចប្រាប់បានទេ; ត្បិតមើលទៅហាក់ដូចជាពួកគេ
មាន ការប្រែរូប ដែលពួកគេបានប្រែពីរូបកាយខាងសាច់ឈាម
នេះ ទៅក្នុងស្ថានភាពអមតមួយ ដែលបណ្ដាលឲ្យពួកគេ
អាចឃើញការណ៍ ទាំងឡាយនៃព្រះបាន ។
១៦ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា ពួកគេបាន
ធ្វើការងារបំរើនៅលើផ្ទៃផែនដីទៀត; ទោះជាយ៉ាងណាក៏ដោយ
គង់តែពួកគេ ពុំបានធ្វើការងារបំរើពីការណ៍ទាំងឡាយ ដែល
គេបានឮ ហើយបានឃើញនោះទេ ពីព្រោះមកពីបញ្ញត្តិដែលបាន
ប្រទានដល់គេ នៅលើ ស្ថានសួគ៌ ។
១៧ ហើយឥឡូវនេះ ទោះជាពួកគេនៅភាពរមែងស្លាប់
ឬអមតភាព ចាប់ពីថ្ងៃនៃការប្រែរូប នោះខ្ញុំពុំដឹងទេ;
១៨ ប៉ុន្តែ ខ្ញុំដឹងតែប៉ុណ្ណោះថា គឺស្របតាមបញ្ជីដែលបានឲ្យ
មក — នោះពួកគេបានចេញទៅលើផ្ទៃផែនដី ហើយបាន
ធ្វើការងារ បំរើដល់ប្រជាជនទាំងអស់ បានបង្រួបបង្រួមឲ្យចូល
ក្នុងសាសនាចក្រ នូវអស់អ្នកណាដែលជឿដល់ពាក្យផ្សាយ
របស់គេ; បានធ្វើបុណ្យ ជ្រមុជទឹកឲ្យពួកគេ ហើយអស់អ្នកណា
ដែលបានទទួលបុណ្យជ្រមុជទឹក នោះបានទទួលព្រះវិញ្ញាណ
បរិសុទ្ធ ។
១៩ ហើយពួកគេត្រូវគេចាប់ដាក់[ក]គុក ដោយពួកអ្នកដែល
ពុំនៅក្នុងសាសនាចក្រ ។ ប៉ុន្តែគុកទាំងឡាយពុំអាចឃុំពួក
គេទុកបានទេ ត្បិតត្រូវបែកចេញជាពីរ ។
២០ ហើយពួកគេត្រូវបោះចោលទៅក្នុងដី; ប៉ុន្តែពួកគេបាន
វាយដីដោយព្រះបន្ទូលនៃព្រះ ដោយព្រះចេស្ដានៃព្រះ ដរាប
ដល់ពួកគេ បានរួចផុតពីជំរៅដីមក ដោយ[ក]ព្រះចេស្ដារបស់ទ្រង់;
ដូច្នេះហើយ គេពុំអាចជីករណ្ដៅជ្រៅគ្រប់គ្រាន់ ដើម្បីដាក់អ្នក
ទាំងនេះបានទេ ។
២១ ពួកគេត្រូវបោះចោលទៅក្នុង[ក]ឡភ្លើងបីដង តែពុំមាន
គ្រោះថ្នាក់អ្វីឡើយ ។
២២ ហើយពួកគេត្រូវបោះចោលទៅក្នុង[ក]រូងសត្វសាហាវពីរដង;
ហើយមើលចុះ ពួកគេបានលេងជាមួយនឹងសត្វទាំងនោះ ដូចជា

៨ *ក* ៣ នីហ្វៃ ២៨:៣៦–៤០.
ស.ប. ដែលរមែងស្លាប់, ភាពដែល
រមែងស្លាប់.
*ខ* ស.ប. អមត:, អមតភាព.
៩ *ក* ភីលីព ១:២៣–២៤;
គ. និង ស. ៧:៥–៦.
១០ *ក* គ. និង ស. ៨៤:៣៦–៣៨.
*ខ* យ៉ូហាន ១៧:២០–២៣.
១១ *ក* ២ នីហ្វៃ ៣១:១៧–២១;
៣ នីហ្វៃ ១១:៣២.
១៣ *ក* ២ កូរិន. ១២:២–៤.
១៤ *ក* គ. និង ស. ៧៦:១១៤–១១៦.
១៥ *ក* ម៉ូសេ ១:១១.
ស.ប. ការប្រែរូប.
១៩ *ក* កិច្ចការ ១៦:២៦;
អាលម៉ា ១៤:២៦–២៨.
២០ *ក* មរមន ៨:២៤.
២១ *ក* ដានី. ៣:២២–២៧;
៤ នីហ្វៃ ១:៣២.
២២ *ក* ដានី. ៦:១៦–២៣;
៤ នីហ្វៃ ១:៣៣.

កូនក្មេងលេងជាមួយនឹងកូនចៀមដែលនៅបោះដោះ ដោយពុំមាន
គ្រោះថ្នាក់អ្វីសោះ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ដោយហេតុនេះ
ទើបពួកគេបានដើរទៅសព្វក្នុងចំណោមប្រជាជននីហ្វៃ ហើយបាន
ផ្សាយ [ក]ដំណឹងល្អនៃព្រះគ្រីស្ទ ដល់គ្រប់ប្រជាជននៅលើផ្ទៃផែនដី;
ហើយពួកគេបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ហើយចូលរួមក្នុង
សាសនាចក្រ នៃព្រះគ្រីស្ទ ម្ល៉ោះហើយ ប្រជាជននៅក្នុងតំណ
[ខ]នោះ បានទទួលពរ ស្របតាមព្រះបន្ទូលនៃព្រះយេស៊ូវមែន ។
២៤ ហើយឥឡូវនេះ ខ្ញុំ មរមន សូមបញ្ចប់នូវការនិយាយ
អំពីការណ៍ទាំងនេះមួយរយៈសិនចុះ ។
២៥ មើលចុះ ខ្ញុំបំរុងតែនឹងកត់[ក]ឈ្មោះពួកអ្នកដែលពុំត្រូវ
ភ្លក់សេចក្ដីស្លាប់ ប៉ុន្តែព្រះអម្ចាស់ ទ្រង់បានហាមឃាត់ខ្ញុំ; ហេតុ
ដូច្នេះហើយ ខ្ញុំពុំកត់ឈ្មោះពួកគេទេ ត្បិតពួកគេត្រូវបាន
លាក់ពីមនុស្សលោក ។
២៦ ប៉ុន្តែមើលចុះ ខ្ញុំបានឃើញពួកគេ ហើយពួកគេបាន
ធ្វើការងារបំរើដល់ខ្ញុំ ។
២៧ ហើយមើលចុះ ពួកគេនឹងនៅក្នុងចំណោមពួកសាសន៍
ដទៃ តែពួកសាសន៍ដទៃនឹងពុំស្គាល់ពួកគេឡើយ ។
២៨ ហើយពួកគេនឹងនៅក្នុងចំណោមពួកសាសន៍យូដាដែរ
តែពួកសាសន៍យូដានឹងពុំស្គាល់ពួកគេឡើយ ។
២៩ ហើយហេតុការណ៍នឹងកើតឡើងថា កាលណាព្រះ
អម្ចាស់ទ្រង់ទតឃើញថាសមនៅក្នុងប្រាជ្ញារបស់ទ្រង់ ដែលពួក
គេនឹងធ្វើការ ងារបំរើ ដល់ពូជអំបូរដែល[ក]ខ្ចាត់ព្រាត់ទាំង
អស់នៃអ៊ីស្រាអែល និងដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស
គ្រប់ភាសា និងគ្រប់ទាំង ប្រជាជន ហើយនឹងនាំព្រលឹងពួកគេ
ជាច្រើនមករកព្រះយេស៊ូវ ដើម្បីឲ្យសេចក្ដីប្រាថ្នារបស់គេបាន
បំពេញ និងដោយសារព្រះចេស្ដានៃ ព្រះ ដែលបរិវត្តដែលនៅ
ក្នុងពួកគេ ។
៣០ ហើយពួកគេហាក់បីដូចជា[ក]ពួកទេវតានៃព្រះ ហើយបើ
សិនជាពួកគេនឹងអធិស្ឋានដល់ព្រះវរបិតា ដោយនូវ
ព្រះនាមព្រះយេស៊ូវ នោះពួកគេអាចបង្ហាញខ្លួនដល់អ្នក
ណាក៏ដោយ ដែលឃើញថាល្អដល់គេ ។
៣១ ហេតុដូច្នេះហើយ មានកិច្ចការដ៏មហិមា និងដ៏អស្ចារ្យ
ទាំងឡាយដែលពួកគេនឹងបានធ្វើឡើង មុនថ្ងៃ[ក]ដ៏ធំដែលកំពុងតែ
មកដល់ កាលគ្រប់ទាំងមនុស្សត្រូវឈរយ៉ាងពិតប្រាកដ
ចំពោះវេទិកាជំនុំជំរះនៃព្រះគ្រីស្ទ;
៣២ មែនហើយ សូម្បីតែនៅក្នុងចំណោមពួកសាសន៍ដទៃ
ក៏នឹងមានកិច្ចការមួយ[ក]ដ៏មហិមា និងដ៏អស្ចារ្យ ដែលពួក
គេធ្វើឡើងដែរ នៅមុនថ្ងៃជំនុំជំរះ ។
៣៣ ហើយបើសិនជាអ្នករាល់គ្នាមានគ្រប់ទាំងបទគម្ពីរ ដែល
ប្រាប់អំពីដំណើររឿងដ៏អស្ចារ្យនៃព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹង
ដឹងថា ស្របតាមព្រះបន្ទូលនៃព្រះគ្រីស្ទ ការណ៍ទាំងនោះប្រាកដជា
នឹងមកដល់ ។
៣៤ ហើយវេទនាដល់អ្នកណា ដែល[ក]មិន[ខ]ព្រមប្រុង
ស្ដាប់តាមព្រះបន្ទូលនៃព្រះយេស៊ូវ ព្រមទាំងដល់ពួកអ្នកដែល
ទ្រង់បានរើស ហើយ ចាត់ឲ្យទៅក្នុងចំណោមពួកគេផង; ត្បិត
អស់អ្នកណាដែលពុំទទួលយកព្រះបន្ទូលនៃព្រះយេស៊ូវ និង
ពាក្យពេចន៍នៃពួកអ្នក ដែលទ្រង់បាន ចាត់ឲ្យទៅនោះ មាន
ន័យថា ពុំទទួលទ្រង់សោះ; ដូច្នេះហើយ ទ្រង់នឹងពុំទទួលពួកគេ
នៅថ្ងៃចុងក្រោយបង្អស់ដែរ ។
៣៥ ហើយបើសិនជាពួកគេពុំបានកើតមកទេ នោះទុកជាការ
ប្រសើរជាង ។ ត្បិតតើអ្នករាល់គ្នាយល់ថា អ្នករាល់គ្នាអាចកំចាត់
សេចក្ដីយុត្តិធម៌នៃព្រះដែលត្រូវជំទាស់ ដែលត្រូវមនុស្ស
[ក]ជាន់ឈ្លីនៅក្រោមជើង ដើម្បីឲ្យមានសេចក្ដីសង្គ្រោះកើតឡើងបានឬ?
៣៦ ហើយឥឡូវនេះ មើលចុះ នៅពេលខ្ញុំនិយាយអំពីពួកអ្នក
ដែលព្រះអម្ចាស់ទ្រង់បានរើស មែនហើយ គឺមានបីនាក់ ដែល
ត្រូវបាន នាំឡើងទៅឯស្ថានសួគ៌ នោះខ្ញុំពុំដឹងជាពួកគេបាន
លាងពីភាពរមែងស្លាប់ ទៅអមតភាពឬអត់ទេ —
៣៧ ប៉ុន្តែមើលចុះ ចាប់តាំងពីខ្ញុំបានសរសេរមក នោះខ្ញុំ
បានសូមសួរដល់ព្រះអម្ចាស់ ហើយទ្រង់បានសម្ដែងប្រាប់ដល់ខ្ញុំថា
ចាំបាច់ត្រូវតែមានការផ្លាស់ប្ដូរ ដល់រូបកាយទាំងឡាយរបស់
ពួកគេ បើពុំនោះសោតទេ ពួកគេនឹងត្រូវភ្លក់សេចក្ដីស្លាប់;
៣៨ ដូច្នេះ ដើម្បីកុំឲ្យពួកគេអាចភ្លក់សេចក្ដីស្លាប់ នោះមាន
[ក]ការផ្លាស់ប្ដូរមួយ បាននាំមកដល់រូបកាយទាំងឡាយរបស់ពួកគេ

២៣ ក ស.ប. ដំណឹងល្អ.
ខ ៣ នីហ្វៃ ២៧:៣០–៣១.
២៥ ក ៣ នីហ្វៃ ១៩:៤.
២៩ ក ស.ប. អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល; អ៊ីស្រាអែល — ពូជអ៊ីស្រាអែលទាំង១០អំបូរ ដែលបាត់.
៣០ ក ស.ប. ពួកទេវតា.
៣១ ក ហេលេ. ១២:២៥; ៣ នីហ្វៃ ២៦:៤–៥.
៣២ ក ២ នីហ្វៃ ២៥:១៧.
៣៤ ក អេធើរ ៤:៨–១២.
ខ ស.ប. ព្យាការី.
៣៥ ក ហេលេ. ១២:២.
៣៨ ក ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.

ដើម្បីកុំ ឲ្យពួកគេឈឺចាប់ ឬព្រួយបារម្ភ លើកលែងតែព្រួយ
បារម្ភជំនួសអំពើបាបទាំងឡាយ នៃមនុស្សលោកប៉ុណ្ណោះ ។
៣៩ ឥឡូវនេះ ការផ្លាស់ប្ដូរនេះ ពុំស្មើរនឹងការផ្លាស់ប្ដូរដែល
នឹងកើតឡើង នៅថ្ងៃចុងក្រោយបង្អស់ឡើយ; តែការ
ផ្លាស់ប្ដូរមួយ បានធ្វើឡើងដល់ពួកគេ ដរាបដល់អារក្សសាតាំង
ពុំអាចមានអំណាចទៅលើពួកគេបាន ដើម្បីកុំឲ្យវាអាច[ក]ល្បួង
ពួកគេ; ហើយពួកគេត្រូវ [ខ]បានញែកចេញជាបរិសុទ្ធ នៅក្នុង
សាច់ឈាម ដែលធ្វើឲ្យពួកគេទៅជា[គ]បរិសុទ្ធ ហើយអំណាចទាំង
ឡាយនៅលើផែនដី ពុំអាចឃាត់ យាំងពួកគេបានឡើយ ។
៤០ ហើយពួកគេស្ថិតនៅក្នុងស្ថានភាពនេះ រហូតដល់ថ្ងៃ
ជំនុំជំរះនៃព្រះគ្រីស្ទ; ហើយនៅថ្ងៃនោះ ពួកគេនឹងបានទទួល
ការផ្លាស់ប្ដូរ មួយធំជាងនេះទៅទៀត ហើយនឹងបានទទួល ទៅ
ក្នុងនគរនៃព្រះវរបិតា នឹងពុំចេញមកវិញទៀតឡើយ តែ
នឹងនៅជាមួយនឹងព្រះ ដ៏អស់កល្បជានិច្ចនៅលើស្ថានសួគ៌ ៕

## ជំពូកទី ២៩

*ការចេញមកនៃព្រះគម្ពីរមរមន គឺជាទីសំគាល់មួយដែលថា ព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើមប្រមូលពួកសាសន៍អ៊ីស្រាអែល ហើយបំពេញ សេចក្ដីសញ្ញាទាំងឡាយរបស់ទ្រង់ — ពួកអ្នកដែលបដិសេធវិវរណៈទាំងឡាយ និងអំណោយទានទាំងឡាយរបស់ទ្រង់ នៅថ្ងៃចុង ក្រោយ នោះនឹងត្រូវបណ្ដាសា ។ ប្រមាណជាឆ្នាំ ៣៤–៣៥ គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ខ្ញុំប្រាប់អ្នករាល់គ្នាថា កាលណាព្រះ
អម្ចាស់ទ្រង់ទតឃើញថាសមនៅក្នុងប្រាជ្ញារបស់ទ្រង់ថា ពាក្យ
ទាំងឡាយ នេះនឹង[ក]បានមកដល់ពួកសាសន៍ដទៃ [ខ]ស្របតាមព្រះ
បន្ទូលរបស់ព្រះអង្គ នោះអ្នករាល់គ្នាអាចដឹងថា សេចក្ដីសញ្ញា
ដែលព្រះវរបិតា ទ្រង់បានធ្វើជាមួយនឹងកូនចៅអ៊ីស្រាអែល
អំពីការសាងពួកគេឡើងវិញទៅឯដែនដីនៃកេរ្តិ៍អាកររបស់គេ
នោះកំពុងតែចាប់ផ្ដើមបំពេញ ហើយ ។
២ ហើយអ្នករាល់គ្នាអាចដឹងថា ព្រះបន្ទូលទាំងឡាយនៃព្រះ
អម្ចាស់ ដែលពួកព្យាការីបរិសុទ្ធបានថ្លែង នោះក៏នឹងបាន
បំពេញដែរ; ហើយអ្នករាល់គ្នាពុំចាំបាច់និយាយថា ព្រះអម្ចាស់
[ក]ទ្រង់ពន្យាពេលវេលា ដែលទ្រង់នឹងយាងមករកកូនចៅ
អ៊ីស្រាអែលនោះឡើយ ។
៣ ហើយអ្នករាល់គ្នាពុំចាំបាច់ស្មាននៅក្នុងចិត្តថា ព្រះបន្ទូល
ទាំងឡាយដែលបានថ្លែងមក នោះជាការឥតប្រយោជន៍ឡើយ
ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់នឹងនឹកចាំដល់សេចក្ដីសញ្ញា ដែល
ទ្រង់បានធ្វើជាមួយនឹងរាស្ត្រទ្រង់ ជាវង្សអ៊ីស្រាអែល ។
៤ ហើយកាលណាអ្នករាល់គ្នាឃើញថា ពាក្យទាំងអស់នេះចេញ
មកក្នុងចំណោមពួកអ្នក នោះអ្នករាល់គ្នាពុំចាំបាច់មើលងាយ
កិច្ចការទាំងឡាយរបស់ព្រះអម្ចាស់តទៅទៀតឡើយ ត្បិត[ក]ដាវនៃ
[ខ]សេចក្ដីយុត្តិធម៌របស់ទ្រង់ នៅក្នុងព្រះហស្តស្ដាំរបស់ទ្រង់; ហើយ
មើលចុះ នៅថ្ងៃនោះ បើសិនជាអ្នករាល់គ្នាមើលងាយ
ដល់កិច្ចការទាំងឡាយរបស់ទ្រង់ នោះទ្រង់នឹងធ្វើឲ្យដាវនោះ
ធ្លាក់មកលើ អ្នករាល់គ្នាក្នុងពេលដ៏ខ្លី ។
៥ [ក]វេទនាដល់អ្នកណា ដែល[ខ]មើលងាយដល់កិច្ចការទាំងឡាយ
របស់ព្រះអម្ចាស់; មែនហើយ វេទនាដល់អ្នកណា ដែលមិន[គ]ព្រម
ទទួល ស្គាល់ព្រះគ្រីស្ទ ព្រមទាំងកិច្ចការទាំងឡាយរបស់ទ្រង់
ផង!
៦ មែនហើយ [ក]វេទនាដល់អ្នកណា ដែលមិនព្រមទទួល
ស្គាល់វិវរណៈទាំងឡាយ របស់ព្រះអម្ចាស់ ហើយដែលនឹង
និយាយថា ព្រះអម្ចាស់ ទ្រង់នឹងពុំធ្វើការដោយវិវរណៈទៀតទេ
ឬដោយការព្យាករណ៍ ឬដោយ[ខ]អំណោយទានទាំងឡាយ
ឬដោយភាសា ទាំងឡាយ ឬដោយការប្រោសឲ្យជាទាំងឡាយ
ឬដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធឡើយ ។
៧ មែនហើយ វេទនាដល់អ្នកណា ដែលនឹងនិយាយនៅ
ថ្ងៃនោះ ដើម្បី[ក]រកកំរៃថា ពុំអាចមាន[ខ]ការអស្ចារ្យឯណា ដែល
ព្រះយេស៊ូវ គ្រីស្ទទ្រង់នឹងធ្វើឡើងឡើយ; ត្បិតអ្នកណាដែលធ្វើ
យ៉ាងនេះ នោះនឹងក្លាយទៅដូចជា[គ]កូនអន្តរធានហើយ ត្បិតគ្មាន
សេចក្ដីមេត្តា ករុណាសំរាប់អ្នកនោះឡើយ ស្របតាមព្រះបន្ទូល
នៃព្រះគ្រីស្ទ!

៣៩ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* ស.ប. ការញែកជាបរិសុទ្ធ.
*គ* ស.ប. បរិសុទ្ធភាព.
**២៩** ១*ក* ២ នីហ្វៃ ៣០:៣–៨.
*ខ* មរមន ៥:១៤, ២០.
២ *ក* លូកា ១២:៤៥–៤៨.
៤ *ក* ៣ នីហ្វៃ ២០:២០.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
៥ *ក* ២ នីហ្វៃ ២៨:១៥–១៦.
*ខ* មរមន ៨:១៧; អេធើរ ៤:៨–១០.
*គ* ម៉ាថាយ ១០:៣២–៣៣.
៦ *ក* មរមន ៩:៧–១១, ១៥.
*ខ* ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
៧ *ក* ស.ប. ឧបាយកលផ្នែកសង្ឃ.
*ខ* ២ នីហ្វៃ ២៨:៤–៦; មរមន ៩:១៥–២៦.
*គ* ស.ប. ពួកកូនអន្តរធាន.

៨ មែនហើយ អ្នករាល់គ្នាមិនត្រូវធ្វើស៊ីស[ក]ស៊ីស ឬ[ខ]មើលងាយ
ឬចំអកដាក់[គ]ពួកសាសន៍យូដា ឬសំណល់ឯណានៃវង្សអ៊ីស្រាអែល
ឡើយ; ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់នឹកចាំដល់សេចក្ដីសញ្ញា
របស់ទ្រង់ដល់ពួកគេ ហើយទ្រង់នឹងធ្វើដល់ពួកគេ ស្របតាមអ្វី
ៗដែល ទ្រង់បានស្បថនឹងពួកគេ ។
៩ ហេតុដូច្នេះហើយ អ្នករាល់គ្នាមិនត្រូវសន្និដ្ឋានថា អ្នករាល់
គ្នាអាចបង្វិលព្រះហស្តស្ដាំនៃព្រះអម្ចាស់ ទៅឯព្រះហស្តឆ្វេង
ដើម្បីកុំឲ្យទ្រង់អាចអនុវត្តសេចក្ដីជំនុំជំរះ ក្នុងការបំពេញសេចក្ដី
សញ្ញា ដែលទ្រង់បានធ្វើដល់វង្សអ៊ីស្រាអែលនោះឡើយ ៕

## ជំពូកទី ៣០

*ពួកសាសន៍ដទៃនៅថ្ងៃចុងក្រោយ នឹងត្រូវបានបញ្ជាឲ្យប្រែចិត្ត, មករកព្រះគ្រីស្ទ, ហើយនឹងបានរាប់ជាមួយនឹងវង្សអ៊ីស្រាអែល ។ ប្រមាណជាឆ្នាំ ៣៤–៣៥ គ.ស. ។*

ចូរប្រុងស្ដាប់ ឱពួកសាសន៍ដទៃអើយ ហើយឮព្រះបន្ទូលនៃ
ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅចុះ
ដែលទ្រង់ បាន[ក]បញ្ជាឲ្យខ្ញុំនិយាយអំពីអ្នករាល់គ្នា ត្បិតមើលចុះ
ទ្រង់បានបញ្ជាឲ្យខ្ញុំសរសេរថា៖
២ ឱ អស់ទាំង[ក]ពួកសាសន៍ដទៃអើយ ចូរ[ខ]អ្នករាល់គ្នា
បែរចេញពីអំពើទុច្ចរិតរបស់អ្នកចុះ; ហើយចូរប្រែចិត្តពីអំពើ
អាក្រក់របស់អ្នក ពីអំពើកុហក និងការបោកបញ្ឆោតរបស់អ្នក
និងពីអំពើសហាយស្មន់របស់អ្នក និងពីអំពើខ្ពើមឆ្អើមដ៏សម្ងាត់ទាំង
ឡាយរបស់អ្នក និងពី ការគោរពរូបព្រះរបស់អ្នក និងពីអំពើ
ឃាតកម្មរបស់អ្នក និងពីឧបាយកលផ្ទែកសង្ឃរបស់អ្នក និង
ពីការឈ្នានីសរបស់អ្នក និងពីការ ជណ្ដើមប្រជែងរបស់អ្នក និង
ពីអំពើទុច្ចរិត និងអំពើខ្ពើមឆ្អើមគ្រប់បែបយ៉ាងរបស់អ្នកចុះ ហើយ
ចូរមករកយើង ហើយទទួលបុណ្យជ្រមុជ ទឹក ដោយ
នូវនាមយើងចុះ ប្រយោជន៍ឲ្យអ្នករាល់គ្នា អាចបានទទួល
ការផ្ដាច់បាបទាំងឡាយនៃអ្នករាល់គ្នា ហើយបានពោរពេញទៅ
ដោយព្រះវិញ្ញាណបរិសុទ្ធ ប្រយោជន៍ឲ្យអ្នករាល់គ្នា អាចបាន
[គ]រាប់ជាមួយនឹងរាស្ត្រយើង គឺជាវង្សអ៊ីស្រាអែល ៕:ៜ

# នីហ្វៃទី ៤
# គម្ពីរនីហ្វៃ

ជាកូនប្រុសរបស់នីហ្វៃ — ជាសិស្សម្នាក់នៃព្រះយេស៊ូវគ្រីស្ទ

## ដំណើររឿងអំពីប្រជាជននីហ្វៃ ស្របតាមបញ្ជីរបស់លោក

*ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនទាំងអស់គ្នាបានប្រែចិត្តជឿដល់ព្រះអម្ចាស់ — ពួកគេមានរបស់របរទាំងអស់រួមគ្នាទូទៅ សម្ដែងអព្ភូតហេតុទាំងឡាយ ហើយចំរើនឡើងនៅលើដែនដី — ពីរសតវត្សក្រោយមក មានការបែកបាក់ទាំងឡាយ, អំពើអាក្រក់ទាំង ឡាយ, សាសនាចក្រក្លែងក្លាយទាំងឡាយ, និងការបៀតបៀនទាំងឡាយកើតឡើង — បីរយឆ្នាំក្រោយមក ទាំងសាសន៍នីហ្វៃ និង សាសន៍លេមិនទៅជាមនុស្សទុច្ចរិត — អាំម៉ារ៉ុនលាក់ទុកនូវបញ្ជីពិសិដ្ឋទាំងឡាយ ។ ប្រមាណជាឆ្នាំ ៣៥–៣២១ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីសាមសិបបួនបាន
កន្លងផុតទៅ និងឆ្នាំទីសាមសិបប្រាំផង ហើយមើលចុះ
ពួកសិស្សរបស់ព្រះ យេស៊ូវបានតាំងសាសនាចក្រនៃព្រះគ្រីស្ទ នៅ
ពាសពេញលើដែនដីជុំវិញ ។ ហើយអស់អ្នកណាដែលបានមក
រកពួកគេ ហើយបាន ប្រែចិត្តយ៉ាងពិតប្រាកដ ពីអំពើបាបទាំងឡាយ
របស់ខ្លួន នោះបានទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមព្រះ
យេស៊ូវ ហើយពួកគេ ក៏បានទទួលព្រះវិញ្ញាណបរិសុទ្ធផង ។
២ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីសាមសិបប្រាំ
មួយ នោះប្រជាជនទាំងអស់ បានប្រែចិត្តជឿដល់ព្រះអម្ចាស់

៨ *ក* ១ នីហ្វៃ ១៩:១៤.
*ខ* ២ នីហ្វៃ ២៩:៤–៥.
*គ* ស.ប. ពួកសាសន៍យូដា.
៣០ ១*ក* ៣ នីហ្វៃ ៥:១២–១៣.
២ *ក* ស.ប. ពួកសាសន៍ដទៃ.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*គ* កាឡាទី ៣:២៧–២៩;
២ នីហ្វៃ ១០:១៨–១៩;
៣ នីហ្វៃ ១៦:១០–១៣;
២១:២២–២៥; អ័ប្រា. ២:១០.

គឺនៅលើផ្ទៃដែនដីទាំងអស់ ទាំងសាសន៍នីហ្វៃ និងសាសន៍
លេមិនផង ហើយគ្មានការទាស់ទែងខ្វែងគំនិតគ្នារវាងពួកគេឡើយ
ហើយ មនុស្សគ្រប់រូបមានការទាក់ទងគ្នាយ៉ាងត្រឹមត្រូវ ។
៣ ហើយពួកគេមានរបស់របរ[ក]ទាំងអស់រួមគ្នាទូទៅនៅក្នុង
ចំណោមពួកគេ; ហេតុដូច្នេះហើយ គ្មានអ្នកមាន ឬអ្នកក្រ
គ្មានអ្នកបំរើគេ ឬអ្នកសេរីឡើយ តែពួកគេទាំងអស់ត្រូវបាន
ធ្វើឲ្យមានសេរីភាព ហើយជាអ្នកទទួលអំណោយទានខាង
ឯស្ថានសួគ៌ ។
៤ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីសាមសិបប្រាំពីរក៏បាន
កន្លងផុតទៅផង ហើយនៅតែមានសេចក្ដីសុខសាន្តតទៅនៅ
លើដែនដី ។
៥ ហើយមានកិច្ចការដ៏ធំ និងអស្ចារ្យជាច្រើនដែលពួកសិស្ស
របស់ព្រះយេស៊ូវ បានធ្វើ ដរាបដល់បាន[ក]ព្យាបាលអ្នកឈឺ ប្រោស
អ្នកស្លាប់ ឲ្យរស់ឡើងវិញ ធ្វើអ្នកខ្វិនឲ្យដើរបាន អ្នកខ្វាក់ឲ្យ
មើលឃើញ អ្នកថ្លង់ឲ្យស្ដាប់ឮ; ហើយអស់ទាំង[ខ]អព្ភូតហេតុ
ដ៏អស្ចារ្យជាច្រើនទៀត ដែលពួកគេបានសម្ដែងនៅក្នុងចំណោម
កូនចៅមនុស្ស; ហើយកិច្ចការដ៏អស្ចារ្យទាំងនេះ គេតែងតែធ្វើ
ដោយនូវព្រះនាមព្រះយេស៊ូវ ប៉ុណ្ណោះ ។
៦ ម្ល៉ោះហើយ ឆ្នាំទីសាមសិបប្រាំបីបានកន្លងផុតទៅ ព្រមទាំង
ឆ្នាំទីសាមសិបប្រាំបួន ទីសែសិបមួយ និងទីសែសិបពីរផង មែន
ហើយ គឺរហូតដល់ឆ្នាំទីសែសិបប្រាំបួន ក៏បានកន្លងផុតទៅ និង
ឆ្នាំទីហាសិបមួយ និងទីហាសិបពីរ; មែនហើយ គឺរហូតដល់
ឆ្នាំទីហាសិបប្រាំបួន ក៏បានកន្លងផុតទៅ ។
៧ ហើយព្រះអម្ចាស់ ទ្រង់បានធ្វើឲ្យពួកគេបាន
ចំរើនឡើងជាអតិបរមា នៅលើដែនដីនេះ; មែនហើយ ដរាប
ដល់ពួកគេបានស្ថាបនា ទីក្រុងទាំងឡាយឡើងវិញ នៅត្រង់កន្លែង
ដែលមានទីក្រុងឆេះពីមុន ។
៨ មែនហើយ សូម្បីតែ[ក]ទីក្រុងសារ៉ាហិមឡាដ៏ធំនោះ ក៏គេបាន
ស្ថាបនាឡើងវិញដែរ ។
៩ ប៉ុន្តែ មានទីក្រុងជាច្រើនដែលបាន[ក]លិចទៅ ហើយមាន
ទឹកឡើងមកជំនួសវិញ; ដូច្នេះ ទីក្រុងទាំងនោះពុំអាចបាន
ស្ថាបនាឡើង វិញទេ ។
១០ ហើយឥឡូវនេះ មើលចុះ ហេតុការណ៍បានកើតឡើងថា
ប្រជាជននីហ្វៃមានកម្លាំងមាំមួន ហើយបានកើនចំនួនយ៉ាង
ឆាប់រហ័ស ហើយបានក្លាយទៅជាប្រជាជន[ក]ដ៏ស្រស់ល្អ និង
គួរឲ្យស្រឡាញ់ ។
១១ ហើយពួកគេបានរៀបការ ហើយទទួលការរៀបការ ហើយ
បានទទួលពរជាច្រើនប្រការ ដែលព្រះអម្ចាស់ទ្រង់បានសន្យានឹង
ពួកគេ ។
១២ ហើយពួកគេពុំបានដើរតាមពិធី[ក]ប្រព្រឹត្ត និងពិធីបរិសុទ្ធនៃ
[ខ]ក្រិត្យវិន័យលោកម៉ូសេទៀតទេ; តែពួកគេបានដើរតាមព្រះបញ្ញត្តិ
ទាំងឡាយ ដែលពួកគេបានទទួលពីព្រះអម្ចាស់ និងពីព្រះរបស់គេ
គឺដោយបន្ត[គ]ការតមអាហារ និងការអធិស្ឋាន ហើយបានប្រជុំគ្នា
ជាញឹក ញាប់ ដើម្បីអធិស្ឋាន ហើយស្ដាប់ព្រះបន្ទូលនៃព្រះ
អម្ចាស់ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា គ្មានការទាស់ទែង
គ្នា នៅក្នុងចំណោមអស់ទាំងប្រជាជន នៅអស់ទាំងដែនដីឡើយ;
ប៉ុន្តែមានអព្ភូតហេតុដ៏អស្ចារ្យជាច្រើន ដែលពួកសិស្សរបស់
ព្រះយេស៊ូវបានធ្វើឡើង ។
១៤ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីចិតសិបមួយ
បានកន្លងផុតទៅ និងឆ្នាំទីចិតសិបពីរផង មែនហើយ ហើយ
សរុបសេចក្ដី មក រហូតដល់ឆ្នាំទីចិតសិបប្រាំបួនក៏បានកន្លងផុតទៅ;
មែនហើយ ឆ្នាំទីមួយរយក៏បានកន្លងផុតទៅ ឯពួកសិស្សរបស់
ព្រះយេស៊ូវ ដែល ទ្រង់បានរើស គេបានឡើងទៅឯ[ក]ស្ថានបរមសុខ
នៃព្រះអស់ លើកលែងតែ[ខ]បីនាក់ ដែលត្រូវនៅលើផែនដី; ហើយ
មាន[គ]សិស្សឯទៀតដែល ត្រូវបាន[ឃ]តែងតាំងឡើងជំនួសពួកគេ;
ហើយមានមនុស្សជាច្រើននៃ តំណនោះក៏បានស្លាប់ទៅដែរ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា [ក]គ្មានការទាស់ទែង
គ្នា នៅក្នុងដែនដីឡើយ ដោយព្រោះមកពីសេចក្ដីស្រឡាញ់នៃ
ព្រះ ដែលបានស្ថិតនៅក្នុងចិត្តរបស់មនុស្ស ។

[៤ នីហ្វៃ]
១ ៣ *ក* កិច្ចការ ៤:៣២;
៣ នីហ្វៃ ២៦:១៩.
ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
៥ *ក* ស.ប. ប្រោស, ការប្រោស.
*ខ* យ៉ូហាន ១៤:១២.
ស.ប. អព្ភូតហេតុ.
៨ *ក* ៣ នីហ្វៃ ៨:៨.
៩ *ក* ៣ នីហ្វៃ ៩:៤, ៧.
១០ *ក* មរមន ៩:៦.
១២ *ក* ២ នីហ្វៃ ២៥:៣០;
៣ នីហ្វៃ ១៥:២–៨.
*ខ* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*គ* ម៉ូរ៉ូណៃ ៦:៥;
គ. និង ស. ៨៨:៧៦–៧៧.
១៤ *ក* ស.ប. ស្ថានបរមសុខ.
*ខ* ៣ នីហ្វៃ ២៨:៣–៩.
ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.
*គ* ស.ប. សិស្ស.
*ឃ* ស.ប. តែងតាំង, ការតែងតាំង.
១៥ *ក* ស.ប. សេចក្ដីសុខសាន្ត.

១៦ ហើយ[ក]ពុំមានការឈ្នានីស ការទាស់ទែងគ្នា
ការច្របូកច្របល់ ការសហាយស្មន់ ការភូតកុហក ការ
កាប់សម្លាប់ ឬក៏[ខ]អំពើ អាសអាភាសណាមួយឡើយ; ហើយពិត
ជាគ្មានប្រជាជនណា ដែលរីករាយ[គ]សប្បាយជាងប្រជាជនដែល
បានត្រូវបង្កើតដោយ ព្រះហស្តនៃ ព្រះឡើយ ។
១៧ គ្មានចោរប្លន់ គ្មានឃាតក ហើយក៏គ្មានចែកទៅជាពួក
លេមិន ឬពួកណាផ្សេងទៀតឡើយ តែគេទាំងអស់គ្នាទៅជារួប
[ក]មួយ គឺជាកូនចៅនៃព្រះគ្រីស្ទ និងជាអ្នកគ្រងនគរព្រះទុកជាមរតក ។
១៨ ហើយពួកគេបានទទួលពរដល់ម្ល៉េះហ្ន៎! ព្រោះព្រះអម្ចាស់ទ្រង់
បានប្រទានពរដល់ពួកគេ ចំពោះគ្រប់កិច្ចការរបស់គេ; មែនហើយ
ពួកគេបានទទួលពរ ហើយចំរើនឡើង រហូតដល់ឆ្នាំទីមួយរយដប់
បានកន្លងផុតទៅ; ហើយតំណទីមួយ ចាប់ពីព្រះគ្រីស្ទទ្រង់យាង
មក ក៏បានស្លាប់ទៅ ហើយនៅលើដែនដីទាំងមូល ពុំមានការ
ទាស់ទែងអ្វីឡើយ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា នីហ្វៃ ជាអ្នកដែល
កត់បញ្ជីចុងក្រោយនេះ (ហើយលោកបានកត់នៅលើ[ក]ផ្ទាំងនីហ្វៃ)
ក៏បានស្លាប់ទៅ ហើយកូនប្រុសរបស់លោក គឺអេម៉ុស បាន
កត់បញ្ជីជំនួសលោក; ហើយលោកបានកត់នៅលើផ្ទាំងនីហ្វៃដែរ ។
២០ ហើយលោកបានកត់បញ្ជីនេះអស់រយៈប៉ែតសិបបួនឆ្នាំ
ហើយនៅតែមានសេចក្ដីសុខសាន្តនៅលើដែនដី លើកលែងតែមាន
ជនមួយភាគតូច ដែលបានបះបោរទាស់នឹងសាសនាចក្រ ហើយ
បានយកឈ្មោះពួកលេមិនមកដាក់លើខ្លួន; ហេតុដូច្នេះហើយ
ក៏ចាប់ ផ្ដើមមានពួកលេមិន នៅលើដែនដីទៀត ។
២១ ហើយហេតុការណ៍បានកើតឡើងថា អេម៉ុសក៏បាន
ស្លាប់ទៅដែរ (គឺមួយរយកៅសិបបួនឆ្នាំ ចាប់តាំងពីព្រះគ្រីស្ទទ្រង់
បានយាង មក) ហើយកូនប្រុសរបស់លោកគឺ អេម៉ុស បាន
កត់បញ្ជីជំនួសលោក; ហើយលោកក៏បានកត់នៅលើផ្ទាំងនីហ្វៃដែរ;
ហើយបានសរសេរ នៅក្នុងគម្ពីរនីហ្វៃដែរ គឺជាគម្ពីរនេះ ។
២២ ហើយហេតុការណ៍បានកើតឡើងថា ពីររយឆ្នាំបាន
កន្លងផុតទៅ; ហើយមនុស្សតំណទីពីរបានស្លាប់ទៅទាំងអស់
លើកលែងតែ មនុស្សចំនួនតូចមួយ ។
២៣ ហើយឥឡូវនេះ ខ្ញុំ មរមន ចង់ឲ្យអ្នករាល់គ្នាដឹងថា
ប្រជាជនបានកើនចំនួនឡើង ដរាបដល់ពួកគេបានរាយ
ពាសពេញនៅលើ អស់ទាំងផ្ទៃដែនដី ហើយពួកគេបានក្លាយ
ទៅជាអ្នកមានស្ដុកស្ដម្ភ ពីព្រោះមកពីការចំរើនឡើងរបស់គេនៅ
ក្នុងព្រះគ្រីស្ទ ។
២៤ ហើយឥឡូវនេះ នៅក្នុងឆ្នាំទីពីររយមួយ នោះនៅក្នុង
ចំណោមពួកគេ ចាប់ផ្ដើមមានពួកអ្នកដែលបានលើកខ្លួនឡើងក្នុង
ការ [ក]ឆ្មើងឆ្មៃ ដូចជាការពាក់នូវប្រដាប់ស្លៀកពាក់ដ៏មានតម្លៃ និង
កែវមុក្ដាគ្រប់ប្រភេទ និងវត្ថុដ៏ល្អគ្រប់យ៉ាងខាងលោកិយ ។
២៥ ហើយចាប់ពីពេលនោះមក ទ្រព្យសម្បត្តិរបស់គេ ពុំមែន
ជារបស់[ក]រួមគ្នាទៅទៀតឡើយ ។
២៦ ហើយពួកគេបានចាប់ផ្ដើមចែកចេញជាវណ្ណៈ; ហើយពួក
គេបានចាប់ផ្ដើមបង្កើត[ក]សាសនាចក្រទាំងឡាយរបស់គេផ្ទាល់ខ្លួន
ដើម្បី[ខ]រកកំរៃ ហើយបានចាប់ផ្ដើមបដិសេធសាសនាចក្រដ៏ពិតប្រាកដ
របស់ព្រះគ្រីស្ទ ។
២៧ ហើយហេតុការណ៍បានកើតឡើងថា កាលឆ្នាំទីពីររយដប់
បានកន្លងផុតទៅ នោះមានសាសនាចក្រជាច្រើន នៅលើដែនដី;
មែនហើយ មានសាសនាចក្រជាច្រើនបានអះអាងថា
ស្គាល់ព្រះគ្រីស្ទ ក៏ប៉ុន្តែគេបាន[ក]បដិសេធដំណឹងល្អភាគច្រើនរបស់
ទ្រង់ ដរាប ដល់បានទទួលនូវអំពើទុច្ចរិតគ្រប់បែបយ៉ាង ព្រមទាំង
បានប្រគល់អ្វីៗ ដែលពិសិដ្ឋរបស់ទ្រង់ ដល់ទៅពួកអ្នកដែលទ្រង់
បានហាមឃាត់ ដោយមកពីភាពមិនសក្តិសម ។
២៨ ហើយ[ក]សាសនាចក្រនោះបានកើនឡើងយ៉ាងខ្លាំង ដោយ
ព្រោះអំពើទុច្ចរិត ហើយដោយព្រោះអំណាចរបស់អារក្សសាតាំង
ដែលបានក្ដាប់ជាប់នូវដួងចិត្តរបស់ពួកគេ ។
២៩ ហើយមានសាសនាចក្រមួយទៀត ដែលបាន
បដិសេធព្រះគ្រីស្ទ; ហើយពួកគេបាន[ក]បៀតបៀនសាសនាចក្រ
ដ៏ពិតប្រាកដរបស់ព្រះ គ្រីស្ទ ដោយព្រោះភាពទន់ទាប និងជំនឿ
របស់គេដល់ព្រះគ្រីស្ទ; ហើយពួកគេថែមទាំងបានមើលងាយ
ដល់ពួកគេ ដោយព្រោះមាន អព្ភូតហេតុដ៏អស្ចារ្យជាច្រើន បាន
សម្ដែងឡើងក្នុងចំណោមពួកគេ ។

១៦ *ក* ស.ប. ការរួបរួមតែមួយ.
*ខ* ស.ប. សំរេកស្រេប.
*គ* ម៉ូសាយ ២:៤១; អាលម៉ា ៥០:២៣.
ស.ប. សេចក្ដីអំណរ.
១៧ *ក* យ៉ូហាន ១៧:២១.
ស.ប. ស៊ីយ៉ូន.
១៩ *ក* ស.ប. ផ្ទាំងទាំងឡាយ.
២៤ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
២៥ *ក* ៤ នីហ្វៃ ១:៣.
២៦ *ក* ១ នីហ្វៃ ២២:២៣;
២ នីហ្វៃ ២៨:៣;
មរមន ៨:៣២–៣៨.
*ខ* គ. និង ស. ១០:៥៦.
ស.ប. ឧបាយកលផ្នែកសង្ឃ.
២៧ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* ៣ នីហ្វៃ ១៨:២៨–២៩.
២៨ *ក* ស.ប. អារក្ស — សាសនាចក្រ
នៃអារក្ស.
២៩ *ក* ស.ប. បៀតបៀន, សេច
ក្ដីបៀតបៀន.

៣០ ហេតុដូច្នេះហើយ ពួកគេបានអនុវត្តអានុភាព និងសិទ្ធិអំណាចទៅលើពួកសិស្សនៃព្រះយេស៊ូវ ដែលបាននៅជាមួយនឹងពួកគេ ហើយពួកគេបានដាក់សិស្សទាំងនោះក្នុង[ក]គុក; ប៉ុន្តែដោយសារព្រះចេស្ដា នៃព្រះបន្ទូលនៃព្រះ ដែលនៅក្នុងពួកគេ នោះគុកទាំងឡាយ ត្រូវបែកជាពីរ ហើយពួកគេបានចេញទៅសម្ដែងអព្ភូតហេតុដ៏អស្ចារ្យទាំងឡាយ នៅក្នុងចំណោមពួកគេ ។

៣១ ក៏ប៉ុន្តែ ទោះជាមានអព្ភូតហេតុដ៏អស្ចារ្យទាំងនេះក៏ដោយ គង់តែប្រជាជននៅតែធ្វើចិត្តរឹងរូសដែរ ហើយបានរកសម្លាប់ពួកគេ ដូចជាពួកសាសន៍យូដានៅឯក្រុងយេរូសាឡិម បានរកសម្លាប់ព្រះយេស៊ូវដែរ ស្របតាមព្រះបន្ទូលរបស់ទ្រង់ ។

៣២ ហើយពួកគេបានបោះសិស្សទាំងនោះទៅក្នុង[ក][ខ]ឡភ្លើង ហើយពួកសិស្សបានចេញមកវិញ ដោយពុំមានខូចខាតអ្វីសោះ ។

៣៣ ហើយពួកគេបានបោះសិស្សទាំងនោះ ទៅក្នុង[ក]រូងសត្វសាហាវ តែពួកគេបានលេងជាមួយនឹងសត្វសាហាវទាំងនោះហាក់បី ដូចក្មេងម្នាក់លេងជាមួយនឹងកូនចៀម; ហើយពួកគេបានចេញមកវិញ ដោយពុំទទួលគ្រោះថ្នាក់អ្វីសោះ ។

៣៤ ទោះជាយ៉ាងណាក៏ដោយ គង់តែប្រជាជននៅតែធ្វើចិត្តរឹងរូសដែរ ត្បិតពួកគេត្រូវបានដឹកនាំ ដោយពួកសង្ឃ និងពួកព្យាការី ក្លែងក្លាយ ដើម្បីតាំងសាសនាចក្រជាច្រើន ហើយដើម្បីធ្វើអំពើទុច្ចរិតគ្រប់បែបយ៉ាង ។ ហើយពួកគេបាន[ក]វាយរាស្ត្រនៃព្រះយេស៊ូវ; តែរាស្ត្រនៃព្រះយេស៊ូវ ពុំបានវាយតបទៅវិញឡើយ ។ ម្ល៉ោះហើយ ពួកគេបានចុះអន់ថយក្នុងការឥតជំនឿ និងអំពើទុច្ចរិត ពីឆ្នាំមួយ ទៅឆ្នាំមួយ រហូតដល់ឆ្នាំទីពីររយសាមសិបបានកន្លងផុតទៅ ។

៣៥ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនេះ មែនហើយ នៅក្នុងឆ្នាំទីពីររយសាមសិបមួយ មានការបែកបាក់ មួយយ៉ាងធំ នៅក្នុងចំណោមប្រជាជន ។

៣៦ ហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនេះ មានប្រជាជនមួយក្រុមបានផុសឡើង ហៅថា ពួកសាសន៍នីហ្វៃ ហើយ ពួកគេជាអ្នកជឿដល់ព្រះគ្រីស្ទដ៏ពិតប្រាកដ; ហើយនៅក្នុងចំណោមពួកគេ នោះមានអ្នកខ្លះដែលពួកលេមិនហៅថា — ពួកសាសន៍ យ៉ាកុប ពួកសាសន៍យ៉ូសែប និងពួកសាសន៍សូរាំ ។

៣៧ ហេតុដូច្នេះហើយ ពួកអ្នកជឿដល់ព្រះគ្រីស្ទដ៏ពិតប្រាកដ និងពួកអ្នកថ្វាយបង្គំព្រះគ្រីស្ទដ៏ពិតប្រាកដ (នៅក្នុងចំណោមនោះមានសិស្សនៃព្រះយេស៊ូវទាំង[ក]បីនាក់ដែលនៅលើផែនដី) ត្រូវបានហៅថា ពួកសាសន៍នីហ្វៃ ពួកសាសន៍យ៉ាកុប ពួកសាសន៍យ៉ូសែប និងពួកសាសន៍សូរាំ ។

៣៨ ហើយហេតុការណ៍បានកើតឡើងថា ពួកអ្នកណាដែលបដិសេធដំណឹងល្អ ត្រូវបានហៅថា ពួកសាសន៍លេមិន ពួកសាសន៍លេមយួល និងពួកសាសន៍អ៊ីសម៉ាអែល; ហើយពួកនេះពុំបានចុះអន់ថយ ក្នុងការឥតជំនឿទេ តែពួកគេបាន[ក]ប៉ះបោរដោយចេតនា ទាស់នឹង ដំណឹងល្អនៃព្រះគ្រីស្ទ; ហើយពួកគេបានបង្រៀនកូនចៅរបស់គេកុំឲ្យជឿ ពួកគេបានចុះអន់ថយ ដូចជាពួកអយ្យកោរបស់ពួកគេ ដែលបានធ្វើ ចាប់ពីដើមដំបូងមក ។

៣៩ ហើយការណ៍នេះ ក៏ដោយមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមនៃពួកអយ្យកោរបស់ពួកគេ ដូចកាលពីដើមដំបូងមក ។ ហើយ ពួកគេត្រូវបាន[ក]បង្រៀនឲ្យស្អប់កូនចៅនៃព្រះ ដូចជាពួកលេមិនត្រូវបានបង្រៀនឲ្យស្អប់កូនចៅរបស់នីហ្វៃ តាំងពីដើមដំបូងមកដែរ ។

៤០ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីពីររយសែសិបបួនបានកន្លងផុតទៅ ហើយព្រឹត្តិការណ៍នៃប្រជាជនមានយ៉ាងដូច្នោះហើយ ។ ឯភាគខាងជនទុច្ចរិតច្រើន បានចំរើនកម្លាំងខ្លាំងពូកែ ហើយកាន់តែកើនចំនួនច្រើនជាងរាស្ត្រនៃព្រះ ។

៤១ ហើយពួកគេនៅតែបន្តការស្ថាបនាសាសនាចក្រទាំងឡាយសំរាប់ខ្លួនគេ ហើយបានតុបតែងខ្លួន ដោយវត្ថុដ៏មានតម្លៃ ។ ហើយឆ្នាំទីពីររយហាសិបបានកន្លងផុតទៅ និងឆ្នាំទីពីររយហុកសិបក៏បានកន្លងផុតទៅដែរ ។

៤២ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនដែលទុច្ចរិតបានចាប់ផ្ដើមតាំងឡើងវិញនូវសម្បថ និង[ក]បក្សព័ន្ធសម្ងាត់នៃកាឌីអានតុន ។

៤៣ ហើយប្រជាជនដែលហៅថា ប្រជាជននីហ្វៃ ក៏បានចាប់ផ្ដើមក្អេងក្អាងនៅក្នុងចិត្តគេដែរ ដោយមកពីទ្រព្យសម្បត្តិដ៏លើសលប់ របស់គេ ហើយក្លាយទៅជាមនុស្សលោភដូចគ្នានឹងពួកបងប្អូនរបស់គេ គឺពួកសាសន៍លេមិន ។

៣០ ក ៣ នីហ្វៃ ២៨:១៩–២០.
៣២ ក ៣ នីហ្វៃ ២៨:២១.
ខ ដានី. ៣:២៦–២៧.
៣៣ ក ៣ នីហ្វៃ ២៨:២២.
៣៤ ក ៣ នីហ្វៃ ១២:៣៩;
គ. និង ស. ៩៨:២៣–២៧.
៣៧ ក ៣ នីហ្វៃ ២៨:៦–៧;
មរមន ៨:១០–១១.
៣៨ ក ស.ប. ការបះបោរ.
៣៩ ក ម៉ូសាយ ១០:១៧.
៤២ ក ស.ប. បក្សព័ន្ធសម្ងាត់.

៤៤ ហើយចាប់ពីពេលនោះមក ពួកសិស្សបានចាប់ផ្ដើមព្រួយបារម្ភ ពីអំពើបាបទាំងឡាយនៃពិភពលោក ។

៤៥ ហើយហេតុការណ៍បានកើតឡើងថា កាលឆ្នាំទីបីរយបានកន្លងផុតទៅ នោះប្រជាជននីហ្វៃ ព្រមទាំងប្រជាជនលេមិនផងបានក្លាយទៅជាមនុស្សទុច្ចរិតយ៉ាងពេញទំហឹងដូចគ្នា ។

៤៦ ហើយហេតុការណ៍បានកើតឡើងថា ពួកក្រុមចោរកាឌីអានតុន បានរាយពាសពេញនៅលើអស់ទាំងផ្ទៃដែនដី; ហើយពុំមាន បុគ្គលណាម្នាក់ ជាជនសុចរិតឡើយ លើកលែងតែពួកសិស្សនៃព្រះយេស៊ូវប៉ុណ្ណោះ ។ ហើយមានមាស និងប្រាក់យ៉ាងបរិបូរដែល ពួកគេបានប្រមូលទុកក្នុងឃ្លាំង ហើយបានធ្វើជំនួញជួញគ្រប់បែបយ៉ាង ។

៤៧ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឆ្នាំទីបីរយប្រាំបានកន្លងផុតទៅ (ហើយប្រជាជននៅតែទុច្ចរិត) អេមម៉ុសបានស្លាប់; ហើយប្អូនប្រុសរបស់លោក គឺអាំម៉ារ៉ុន បានកត់បញ្ជីជំនួសលោក ។

៤៨ ហើយហេតុការណ៍បានកើតឡើងថា កាលឆ្នាំទីបីរយម្ភៃបានកន្លងផុតទៅ នោះអាំម៉ារ៉ុន ដោយត្រូវបង្ខិតបង្ខំដោយព្រះវិញ្ញាណ បរិសុទ្ធ បានលាក់នូវបញ្ជីដ៏ពិសិដ្ឋទាំងនេះ — មែនហើយ គឺអស់ទាំងបញ្ជីដ៏ពិសិដ្ឋ ដែលបន្តមកពីតំណមួយទៅតំណមួយ ដែលសុទ្ធតែ ពិសិដ្ឋ — គឺរហូតមកដល់ឆ្នាំទីបីរយម្ភៃ ចាប់តាំងពីព្រះគ្រីស្ទទ្រង់បានយាងមក ។

៤៩ ហើយលោកបានលាក់បញ្ជីទាំងនោះថ្វាយព្រះ ដើម្បីឲ្យបញ្ជីទាំងនោះ អាចមកជាថ្មីទៀត គឺដល់សំណល់នៃវង្សយ៉ាកុបស្របតាមពាក្យព្យាករណ៍ និងពាក្យសន្យាទាំងឡាយនៃព្រះ ។ ម្ល៉ោះហើយ ក៏ចប់នូវបញ្ជីរបស់អាំម៉ារ៉ុន ៕ :៚

# គម្ពីរមរមន

ជំពូកទី ១

*អាំម៉ារ៉ុនបង្គាប់មរមន អំពីបញ្ជីពិសិដ្ឋទាំងឡាយ — សង្គ្រាមចាប់ផ្ដើម រវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន — ពួកនីហ្វៃបីនាក់ ត្រូវបាននាំយកទៅ — អំពើទុច្ចរិត ការឥតជំនឿ របៀន និងមន្តអាគម មានអំណាចលើអ្វីផ្សេងៗ ។ ប្រមាណជាឆ្នាំ ៣២១–៣២៦ គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំ មរមន ធ្វើបញ្ជីមួយអំពីការណ៍ទាំងឡាយដែលខ្ញុំបានឃើញ ហើយបានឮ ហើយបានហៅថា គម្ពីរមរមន ។

២ ហើយកាលអាំម៉ារ៉ុនបានលាក់បញ្ជីទាំងនោះថ្វាយព្រះហើយនោះលោកបានមករកខ្ញុំ (កាលនោះខ្ញុំមានអាយុដប់ឆ្នាំ ហើយខ្ញុំបានចាប់ ផ្ដើមរៀនសូត្រតាមលំនាំ នៃការរៀនសូត្ររបស់ប្រជាជនខ្ញុំ) ហើយអាំម៉ារ៉ុនបាននិយាយមកកាន់ខ្ញុំថា៖ ខ្ញុំឃើញថាឯងគឺជាក្មេងម្នាក់ ដ៏ម៉ឺងម៉ាត់ ហើយចេះសង្កេតដោយឆាប់រហ័ស;

៣ ហេតុដូច្នេះហើយ កាលណាឯងអាយុម្ភៃបួនឆ្នាំ ខ្ញុំចង់ឲ្យឯងចងចាំនូវអ្វីៗ ដែលឯងបានសង្កេតមើល ដែលទាក់ទងនឹងប្រជាជននេះ; ហើយកាលណាឯងដល់អាយុនេះ ចូរឯងទៅឯដែនដីអាន់ទុម ត្រង់ភ្នំមួយ ដែលនឹងត្រូវហៅថា ស៊ិម; ហើយនៅទីនោះខ្ញុំបានកប់ទុកដល់ព្រះ នូវចម្លាក់ដ៏ពិសិដ្ឋទាំងអស់ ស្ដីអំពីប្រជាជននេះ ។

៤ ហើយមើលចុះ ចូរឯងយកផ្ទាំងនីហ្វៃ ឯចម្លាក់ដែលនៅសល់ទាំងប៉ុន្មាន ចូរឯងទុកនៅកន្លែងដដែល; ហើយឯងត្រូវឆ្លាក់នៅលើផ្ទាំង នីហ្វៃ នូវការណ៍ទាំងអស់ ដែលឯងបានសង្កេតឃើញ អំពីប្រជាជននេះ ។

៥ ហើយខ្ញុំ មរមន ត្រូវជាពូជពង្សនីហ្វៃ (ឯឪពុកខ្ញុំឈ្មោះមរមន) ខ្ញុំនៅចាំការណ៍ដែលអាំម៉ារ៉ុនបានបញ្ជាដល់ខ្ញុំ ។

៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំមានអាយុដប់មួយឆ្នាំ ត្រូវបានឪពុកខ្ញុំនាំទៅឯដែនដីភាគខាងត្បូង ដល់ដែនដីសារ៉ាហិមឡា ។

៧ នៅលើផ្ទៃដែនដីទាំងមូល មានពាសពេញដោយអាគារ ហើយប្រជាជនមានចំនួនច្រើនកុះករ ហាក់បីដូចជាខ្សាច់នៅមាត់សមុទ្រ ។

៤៤ *ក* ៣ នីហ្វៃ ២៨:៩.
៤៨ *ក* ហេលេ. ៣:១៣, ១៥–១៦.
៤៩ *ក* អេណុស ១:១៣.
[មរមន]
១ ១*ក* ស.ប. មរមន, ព្យាការីសាសន៍នីហ្វៃ.
*ខ* ៣ នីហ្វៃ ៥:១១–១៨.
២ *ក* ៤ នីហ្វៃ ១:៤៧–៤៩.
*ខ* ម៉ូសាយ ១:៣–៥.
៣ *ក* អេធើរ ៩:៣.
៤ *ក* ព. នៃ ម. ១:១, ១១.
ស.ប. ផ្ទាំងទាំងឡាយ.
៥ *ក* ៣ នីហ្វៃ ៥:១២, ២០.

៨ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនេះ មានសង្គ្រាមកើតឡើង រវាងពួកសាសន៍នីហ្វៃ គឺមានពួកសាសន៍នីហ្វៃ ពួកសាសន៍ យ៉ាកុប ពួកសាសន៍យ៉ូសែប និងពួកសាសន៍សូរាំ; ហើយសង្គ្រាមនេះ គឺរវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន និងពួកសាសន៍លេមិន យ៉ូល និងពួកសាសន៍អ៊ីសម៉ាអែល ។

៩ ឥឡូវនេះ ពួកសាសន៍លេមិន ពួកសាសន៍លេមយ៉ូល និងពួកសាសន៍អ៊ីសម៉ាអែល ត្រូវហៅថា សាសន៍លេមិន ឯគូបដិបក្សទាំងពីរ គឺសាសន៍នីហ្វៃ និងសាសន៍លេមិន ។

១០ ហើយហេតុការណ៍បានកើតឡើងថា សង្គ្រាមក៏កើតឡើងរវាងពួកគេ នៅតំបន់ព្រំប្រទល់សារ៉ាហិមឡា ជិតមាត់ទន្លេស៊ីដូន ។

១១ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍នីហ្វៃបានប្រមូលគ្នាមួយចំនួនធំ គឺដល់ទៅមានមនុស្សប្រុសចំនួនច្រើនជាងបីម៉ឺននាក់ ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេមានចម្បាំងជាច្រើនលើក នៅក្នុងឆ្នាំនេះ ហើយពួកសាសន៍នីហ្វៃបានឈ្នះលើពួកសាសន៍ លេមិន ហើយបានសម្លាប់ពួកគេអស់ជាច្រើន ។

១២ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិនបានបោះបង់ចោលបំណងរបស់គេ ហើយក៏មានសេចក្ដីសុខសាន្តនៅលើ ដែនដី; ហើយសេចក្ដីសុខសាន្តបានស្ថិតនៅអស់រយៈពេលប្រហែលបួនឆ្នាំ គឺគ្មានការខ្ចាយឈាមឡើយ។

១៣ ប៉ុន្តែ អំពើទុច្ចរិតក៏នៅមានពាសពេញលើផ្ទៃដែនដីទាំងមូល ដរាបដល់ព្រះអម្ចាស់ទ្រង់បានយកពួកសិស្ស ដ៏ជាទីស្រឡាញ់របស់ទ្រង់ ចេញ ហើយកិច្ចការនៃអព្ភូតហេតុទាំងឡាយ និងការព្យាបាលក៏ឈប់មាន ពីព្រោះមកពីអំពើទុច្ចរិតរបស់ប្រជាជន ។

១៤ ហើយគ្មានអំណោយទានមកពីព្រះអម្ចាស់សោះ ឯព្រះវិញ្ញាណបរិសុទ្ធក៏ពុំបានយាងមកសណ្ឋិតលើនរណាមួយឡើយ ពីព្រោះមកពី អំពើទុច្ចរិត និងការឥតជំនឿរបស់គេ ។

១៥ ហើយកាលនោះ ខ្ញុំមានអាយុដប់ប្រាំឆ្នាំ ហើយមានគំនិតដ៏ម៉ឺងម៉ាត់ ហេតុដូច្នេះហើយ ព្រះអម្ចាស់ ទ្រង់បានយាងមកជួបខ្ញុំ ហើយ បានភ្លក់ ហើយបានស្គាល់នូវសេចក្ដីល្អសប្បុរសនៃព្រះយេស៊ូវ ។

១៦ ហើយខ្ញុំបានខិតខំប្រកាសដល់ប្រជាជននេះ ប៉ុន្តែមាត់ខ្ញុំត្រូវបានបិទទេ ខ្ញុំត្រូវបានហាមឃាត់មិនឲ្យប្រកាសទៅកាន់ពួកគេទេ; ត្បិតមើលចុះ ពួកគេបានបះបោរដោយចេតនា ទាស់នឹងព្រះរបស់គេ; ឯពួកសិស្សដ៏ជាទីស្រឡាញ់ ក៏ត្រូវបានយកចេញពីដែនដីនេះទៅ ពីព្រោះមកពីអំពើទុច្ចរិតរបស់ប្រជាជន ។

១៧ ប៉ុន្តែខ្ញុំបាននៅក្នុងចំណោមពួកគេ តែខ្ញុំត្រូវបានហាមឃាត់មិនឲ្យប្រកាសទៅកាន់ពួកគេសោះ ពីព្រោះមកពីភាពរឹងរូសនៃចិត្តរបស់ ពួកគេ; ហើយដោយសារភាពរឹងរូសនៃចិត្តរបស់គេនេះហើយ ទើបដែនដីនេះត្រូវបណ្ដាសា ព្រោះតែពួកគេ ។

១៨ ឯក្រុមចោរកាឌីអានតុនទាំងនេះ ដែលនៅក្នុងចំណោមពួកសាសន៍លេមិននោះ បានរាលដាលនៅលើដែនដី ដរាបដល់បណ្ដាជន ចាប់ផ្ដើមលាក់ទ្រព្យរបស់គេទុកនៅក្នុងដី; ឯទ្រព្យទាំងនោះបានក្លាយទៅជាររអិល ពីព្រោះព្រះអម្ចាស់ ទ្រង់បានដាក់បណ្ដាសាដល់ដី ដើម្បីមិនឲ្យអ្នកទាំងនេះអាចរក្សាទ្រព្យទាំងនោះជាប់ ឬក៏រកទ្រព្យទាំងនោះឃើញវិញឡើយ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា មានរបៀនមន្តអាគម និងអំពើ; ហើយអំណាចរបស់អ្នកអាក្រក់បានកើតឡើងនៅលើផ្ទៃដែនដី ស្របដូចពាក្យព្យាករណ៍របស់អ័ប៊ីណាដៃ និងរបស់សាំយូអែល ជាសាសន៍លេមិនផង ។

## ជំពូកទី ២

*មរមនដឹកនាំពលទ័ពសាសន៍នីហ្វៃ — ការខ្ចាយឈាម និងការកាប់សម្លាប់មានពាសពេញទូទៅទាំងដែនដី — ពួកសាសន៍នីហ្វៃទួញយំសោក ដោយសេចក្ដីទុក្ខនៃជនដែលជាប់ទោស — ថ្ងៃនៃព្រះគុណបានកន្លងផុតទៅហើយ — មរមនយកផ្ទាំងនីហ្វៃ — សង្គ្រាមទាំងឡាយបន្តទៅ ។ ប្រមាណជាឆ្នាំ ៣២៧–៣៥០ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំដដែលនោះ មានសង្គ្រាមមួយបានចាប់ផ្ដើមឡើងជាថ្មីទៀត រវាងពួកសាសន៍នីហ្វៃ និងពួក សាសន៍លេមិន ។ ហើយទោះជាខ្ញុំនៅក្មេងក៏ដោយ គង់តែខ្ញុំមានមាឌធំដែរ; ហេតុដូច្នេះហើយ ប្រជាជននីហ្វៃបានតែងតាំងខ្ញុំ ឲ្យធ្វើជា មេដឹកនាំរបស់ពួកគេ ឬក៏ជាមេដឹកនាំនៃពលទ័ពរបស់ពួកគេ ។

២ ហេតុដូច្នេះហើយ ហេតុការណ៍បានកើតឡើងថា នៅពេល

១៣ *ក* ៣ នីហ្វៃ ២៨:២, ១២.
១៤ *ក* ម៉ូរ៉ូណៃ ១០:៨–១៨, ២៤.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* ស.ប. ការឥតជំនឿ.
១៦ *ក* ស.ប. ការបះបោរ.
*ខ* មរមន ៨:១០.
១៧ *ក* ២ នីហ្វៃ ១:៧;
អាលម៉ា ៤៥:១០–១៤, ១៦.
១៨ *ក* ហេលេ. ១៣:១៨–២០;
អេធើរ ១៤:១–២.

ខ្ញុំមានអាយុដប់ប្រាំមួយឆ្នាំ ខ្ញុំបានដឹកនាំពួកនីហ្វៃមួយកង ប្រឆាំង
នឹងទ័ព លេមិន; ហេតុដូច្នេះហើយ បីរយម្ភៃប្រាំមួយឆ្នាំបាន
កន្លងផុតទៅ ។
៣ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីបីរយម្ភៃប្រាំពីរ នោះពួកលេមិនបានមកវាយប្រហារពួកយើង
ដោយកម្លាំងដ៏ខ្លាំង លើសលប់ ដរាបដល់ពួកគេបានធ្វើឲ្យពល
ទ័ពរបស់ខ្ញុំភិតភ័យ; ហេតុដូច្នេះហើយ ពួកគេមិនព្រមប្រយុទ្ធ
ហើយពួកគេបានចាប់ផ្ដើមដកថយ ឆ្ពោះទៅដែនដីខាងជើងទាំង
ឡាយ ។
៤ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានមក
ដល់ទីក្រុងអង់គូឡា ហើយពួកយើងយកបានទីក្រុងនោះ ហើយធ្វើ
ការរៀបចំ ការពារខ្លួន ប្រឆាំងនឹងទ័ពលេមិន ។ ហើយហេតុការណ៍
បានកើតឡើងថា ពួកយើងបានពង្រឹងទីក្រុងនោះ ដោយសមត្ថភាព
របស់យើង; ប៉ុន្តែទោះជាមានការពង្រឹងរបស់យើងអស់ទាំងនេះក្ដី
គង់តែទ័ពលេមិនបានមកវាយប្រហារយើង ហើយបានរុញច្រាន
ពួកយើងចេញពីទីក្រុង ដែរ ។
៥ ហើយពួកគេថែមទាំងបានរុញច្រានពួកយើង ផុតពីដែនដីដាវីឌ
ទៀត ។
៦ ហើយពួកយើងបានដើរឆ្ពោះទៅមុខ ហើយបានមក
ដល់ដែនដីយ៉ូស្វេ ដែលនៅក្នុងព្រំប្រទល់ខាងលិចជិតឆ្នេរសមុទ្រ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានប្រមូល
ប្រជាជនយើង យ៉ាងឆាប់រហ័ស ដែលអាចធ្វើបាន ប្រយោជន៍ឲ្យ
ពួកយើងអាច ប្រមូលពួកគេមកជាក្រុមមួយ ។
៨ ប៉ុន្តែមើលចុះ ដែនដីនោះពោរពេញទៅដោយពួកចោរ និង
ពួកសាសន៍លេមិន; ហើយទោះជាមានការបំផ្លិចបំផ្លាញដ៏មហិមា
ព្យួរនៅ ខាងលើប្រជាជនខ្ញុំក្ដី គង់តែពួកគេពុំប្រែចិត្ត អំពីអំពើ
អាក្រក់របស់ពួកគេទេ; ហេតុដូច្នេះហើយ ទើបមានការខ្ចាយឈាម
និងការកាប់សម្លាប់ ពាសពេញទូទៅទាំងផ្ទៃដែនដី ទាំងខាងពួក
សាសន៍នីហ្វៃ និងខាងពួកសាសន៍លេមិនផង; ហើយនោះ
គឺជាការច្របូកច្របល់ដ៏ពេញទំហឹង មួយ ទូទៅលើផ្ទៃដែនដី
ទាំងមូល ។
៩ ហើយឥឡូវនេះ ពួកសាសន៍លេមិនមានស្ដេចមួយ ហើយនាម
របស់ទ្រង់គឺ អ៊ើរ៉ុន; ហើយទ្រង់បានមកច្បាំងនឹងពួកយើង
ដោយមានកង ទ័ពមួយ ដែលមានគ្នាចំនួនបួនម៉ឺនបួនពាន់នាក់ ។
ហើយមើលចុះ ខ្ញុំតតាំងនឹងទ្រង់ ជាមួយនឹងទ័ពបួនម៉ឺនពីរពាន់នាក់ ។
ហើយហេតុការណ៍ បានកើតឡើងថា ខ្ញុំមានជ័យជំនះលើទ្រង់
ជាមួយនឹងកងទ័ពរបស់ខ្ញុំ ធ្វើឲ្យទ្រង់រត់គេចចេញពីខ្ញុំទៅ ។
ហើយមើលចុះ ការណ៍អស់ទាំងនេះ បានកើតឡើង
ហើយបីរយសាមសិបឆ្នាំបានកន្លងផុតទៅ ។
១០ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍នីហ្វៃបាន
ចាប់ផ្ដើមប្រែចិត្ត អំពីអំពើទុច្ចរិតរបស់ខ្លួន ហើយបានចាប់ផ្ដើមយំ
គ្អូញ ដូចដែលសាំយូអែល ដែលជាព្យាការីបានព្យាករមក
ដូច្នោះ; ត្បិតមើលចុះ គ្មានអ្នកណាម្នាក់អាចរក្សាទុកនូវអ្វី ដែល
ជារបស់ផងខ្លួនបាន ឡើយ ព្រោះតែពួកចោរលួច និងចោរប្លន់
និងពួកឃាតក និងមន្តអាគម និងអំពើដែលនៅក្នុងដែនដី ។
១១ ម្ល៉ោះហើយ ក៏ចាប់ផ្ដើមមានការទួញសោក និងទុក្ខព្រួយ
នៅលើដែនដីទាំងមូល ដោយសារការណ៍ទាំងនេះ ហើយជា
ពិសេស ទៅទៀត គឺនៅក្នុងចំណោមប្រជាជននីហ្វៃ ។
១២ ហើយហេតុការណ៍បានកើតឡើងថា កាលខ្ញុំមរមន បាន
ឃើញសេចក្ដីទុក្ខព្រួយ និងសេចក្ដីទួញសោក និងសេចក្ដីព្រួយ
របស់ពួកគេ នៅចំពោះព្រះអម្ចាស់ដូច្នោះ ខ្ញុំក៏ចាប់ផ្ដើមអរ
រីករាយនៅក្នុងចិត្ត ដោយដឹងនូវសេចក្ដីមេត្តាករុណាទាំងឡាយ
និងសេចក្ដីអត់ធ្មត់នៃព្រះ អម្ចាស់ ហេតុដូច្នេះហើយ ដោយ
សន្និដ្ឋានថា ទ្រង់នឹងមេត្តាដល់ពួកគេ ប្រយោជន៍ឲ្យពួកគេក្លាយ
ទៅជាប្រជាជនសុចរិតវិញ ។
១៣ ប៉ុន្តែមើលចុះ [ក]សេចក្ដីអំណររបស់ខ្ញុំនេះបែរទៅជា
អសារឥតការទៅវិញ ត្បិតសេចក្ដីទុក្ខសោករបស់ពួកគេ ពុំនាំ
ទៅរកសេចក្ដី ប្រែចិត្ត ដោយសារសេចក្ដីល្អសប្បុរស[ខ]នៃ
ព្រះនោះឡើយ; ប៉ុន្តែវាជាសេចក្ដីទុក្ខព្រួយរបស់អ្នក[គ]ជាប់ទោស
ពីព្រោះព្រះអម្ចាស់ទ្រង់ពុំទ្រាំឲ្យ ពួកគេមានសុភមង្គលក្នុងអំពើ
បាបសោះ ។
១៤ ហើយពួកគេពុំមករកព្រះយេស៊ូវ[ក] ដោយមានចិត្ត[ខ]សង្រេង
និងវិញ្ញាណទន់ទាបឡើយ ប៉ុន្តែពួកគេបានប្រទេចផ្ដាសាដល់ព្រះ
ហើយចង់ ស្លាប់ទៅវិញ ។ ទោះជាយ៉ាងណាក៏ដោយ គង់តែ
ពួកគេប្រយុទ្ធដោយដាវ ដើម្បីជីវិតពួកគេដែរ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា សេចក្ដី[ក]ព្រួយ[ខ]របស់ខ្ញុំ
វិលមកកាន់ខ្ញុំវិញ ហើយខ្ញុំបានឃើញថា ថ្ងៃនៃព្រះគុណសំរាប់
ពួកគេ[គ] បានកន្លងផុតហើយ ទាំងខាងឯសាច់ឈាម និងទាំងខាង

២ ១៣ ក ២ កូរិន. ៧:១០; អាលម៉ា ៤២:២៩.
ខ ស.ប. សេចក្ដីជាប់ទោស.
គ អាលម៉ា ៤១:១០.
១៤ ក ស.ប. ចិត្តសង្រេង.
ខ ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.
១៥ ក ហេលេ. ១៣:៣៨.
ខ ស.ប. ព្រះគុណ.
គ យេរេ. ៨:២០; គ. និង ស. ៥៦:១៦.

ឯវិញ្ញាណផង; ត្បិតខ្ញុំបានឃើញពួកគេរាប់ពាន់នាក់ ត្រូវ
កាប់រំលំនៅក្នុងការបះបោរ យ៉ាងចេញមុខ ទាស់នឹងព្រះរបស់
ពួកគេ ហើយគរដូចជាអាចម៍សត្វនៅលើផ្ទៃដែនដី ។ ម្ល៉ោះហើយ
បីរយសែសិបបួនឆ្នាំបានកន្លងផុតទៅ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីបីរយសែសិបប្រាំ នោះពួកសាសន៍នីហ្វៃបានចាប់ផ្ដើម
រត់គេចពីពួកសាសន៍លេមិន; ហើយពួកគេត្រូវដេញតាម រហូត
ដល់ពួកគេមកដល់ដែនដីយ៉ាសុន ទើបអាចបញ្ឈប់ការដកថយ
របស់ពួកគេបាន ។
១៧ ហើយឥឡូវនេះ ទីក្រុងយ៉ាសុននៅជិតដែនដី ដែល
អាំម៉ារ៉ុនបានកប់បញ្ជីទាំងឡាយថ្វាយព្រះអម្ចាស់ ដើម្បីកុំឲ្យត្រូវ
បំផ្លាញចោល ។ ហើយមើលចុះ ខ្ញុំបានទៅតាមពាក្យរបស់
អាំម៉ារ៉ុន ហើយយកផ្ទាំងនីហ្វៃ ហើយបានធ្វើបញ្ជីមួយ ស្របតាម
ពាក្យរបស់អាំម៉ារ៉ុន ។
១៨ ហើយនៅលើផ្ទាំងនីហ្វៃ នោះខ្ញុំបានធ្វើការរៀបរាប់នូវ
ដំណើររឿងដ៏ពោរពេញ អំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើម
ទាំងអស់; ប៉ុន្តែ នៅលើផ្ទាំងទាំងនេះ ខ្ញុំពុំរៀបរាប់នូវដំណើរ
រឿងដ៏ពោរពេញ អំពីអំពើទុច្ចរិតនិងអំពើគួរខ្ពើមឆ្អើមទាំង
ឡាយរបស់ពួកគេទេ ត្បិតមើលចុះ ឆាកអំពីអំពើទុច្ចរិត និង
អំពើគួរខ្ពើមឆ្អើមទាំងឡាយកើតឡើងចំពោះភ្នែកខ្ញុំមិនឈប់ឈរ
ចាប់តាំងពីខ្ញុំដឹងក្ដីល្មម ហើយមើលឃើញអំពើទាំង ឡាយ
របស់មនុស្ស ។
១៩ ហើយវេទនាដល់ខ្ញុំ ពីព្រោះមកពីអំពើទុច្ចរិតរបស់ពួកគេ;
ត្បិតដួងចិត្តខ្ញុំត្រូវពោរពេញទៅដោយសេចក្ដីព្រួយ ពិព្រោះមក
ពីអំពើទុច្ចរិត របស់ពួកគេ អស់មួយជីវិតខ្ញុំ; ទោះជាយ៉ាង
ណាក៏ដោយ គង់តែខ្ញុំដឹងថា ខ្ញុំនឹងត្រូវបានដំកើងឡើង នៅថ្ងៃ
ចុងក្រោយបង្អស់ដែរ ។
២០ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំនេះ
ប្រជាជននីហ្វៃត្រូវគេដេញ ហើយត្រូវរុញច្រានជាថ្មីទៀត ។
ហើយហេតុការណ៍ បានកើតឡើងថា ពួកយើងត្រូវគេរុញច្រាន
រហូតដល់ពួកយើងមកខាងជើង ដល់ដែនដីដែលគេហៅថា សិម ។
២១ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានពង្រឹង
ទីក្រុងសិម ហើយពួកយើងបានប្រមូលប្រជាជនយើងជាច្រើន
ដែលអាច ធ្វើបាន ដើម្បីក្រែងពួកយើងអាចសង្គ្រោះពួកគេ
ពីសេចក្ដីបំផ្លិចបំផ្លាញបាន ។
២២ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីបីរយសែសិបប្រាំមួយ នោះពួកគេបានចាប់ផ្ដើមមកវាយប្រហារ
ពួកយើងទៀត ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបាននិយាយ
ទៅកាន់ប្រជាជនខ្ញុំ ហើយបានដាស់តឿនពួកគេយ៉ាងខ្លាំងថា ពួក
គេត្រូវឈរ យ៉ាងក្លាហានប្រឆាំងនឹងពួកសាសន៍លេមិន
ហើយប្រយុទ្ធ ដើម្បីការពារប្រពន្ធរបស់គេ និងកូនចៅរបស់គេ
និងគ្រួសាររបស់គេ និងផ្ទះ សំបែងរបស់គេ ។
២៤ ហើយពាក្យពេចន៍របស់ខ្ញុំ បានដាស់ឲ្យពួកគេមានសេចក្ដី
ក្លាហានបន្តិចឡើង ដរាបដល់ធ្វើឲ្យពួកគេពុំរត់គេចចេញពីទ័ពលេមិន
ឡើយ តែបានឈរយ៉ាងក្លាហានប្រឆាំងនឹងពួកគេវិញ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានយក
ទ័ពចំនួនបីម៉ឺននាក់ទៅប្រយុទ្ធនឹងកងទ័ពចំនួនប្រាំម៉ឺននាក់ ។
ហើយហេតុ ការណ៍បានកើតឡើងថា ពួកយើងបានតតាំងនឹងពួក
គេយ៉ាងម៉ឺងម៉ាត់ រហូតដល់ធ្វើឲ្យពួកគេបានរត់គេចចេញពីពួក
យើងទៅ ។
២៦ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបាន
រត់គេចចេញទៅ នោះពួកយើងបានដេញតាមគេ ដោយពលទ័ព
របស់យើង ហើយបានជួបពួកគេទៀត ហើយបានវាយឈ្នះពួក
គេ; ទោះជាយ៉ាងណាក៏ដោយ គង់តែកម្លាំងនៃព្រះអម្ចាស់ ពុំ
បាននៅជាមួយនឹងពួកយើង ទេ; មែនហើយ ពួកយើងត្រូវបាន
ទុកឲ្យនៅតែឯង គឺព្រះវិញ្ញាណនៃព្រះអម្ចាស់ មិនបានស្ថិតនៅ
ក្នុងយើងឡើយ; ហេតុដូច្នេះហើយ ពួកយើងបានក្លាយ
ទៅជាខ្សោយ ដូចពួកបងប្អូនទាំងឡាយរបស់យើងដែរ ។
២៧ ហើយចិត្តខ្ញុំព្រួយ ពីព្រោះមកពីគ្រោះអាសន្នដ៏ធំនេះ
នៃប្រជាជនខ្ញុំ គឺពីព្រោះមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើម
ទាំងឡាយរបស់គេ ។ ប៉ុន្តែមើលចុះ ពួកយើងបានទៅច្បាំងនឹង
ពួកសាសន៍លេមិន និងពួកចោរកាឌីអានតុន រហូតដល់ពួកយើង
យកដែនដីនៃកេរ្ដិ៍អាកររបស់ យើងបានមកវិញ ។
២៨ ហើយឆ្នាំទីបីរយសែសិបប្រាំបួនបានកន្លងផុតទៅ។ ហើយនៅ
ក្នុងឆ្នាំទីបីរយហាសិប នោះពួកយើងបានចុះមេត្រីភាពមួយ
ជាមួយនឹងពួកសាសន៍លេមិន និងពួកចោរកាឌីអានតុន នៅ
ក្នុងនោះ ពួកយើងបានយកដែនដីកេរ្ដិ៍អាករមកចែក ។
២៩ ហើយពួកសាសន៍លេមិន បានឲ្យយើងដែនដីភាគខាងជើង
មែនហើយ ទៅដល់ចន្លោះតូច ដែលនាំទៅឯដែនដីខាងត្បូង ។

១៧ *ក* មរមន ១:១–៤.
១៨ *ក* ស.ប. ផ្ទាំងទាំងឡាយ.
១៩ *ក* ម៉ូសាយ ២៣:២២; អេធើរ ៤:១៩.
២៣ *ក* ម៉ូសាយ ២០:១១;
អាលម៉ា ៤៣:៤៥.
២៩ *ក* អាលម៉ា ២២:៣២.

ហើយពួកយើងបានឲ្យទៅពួកសាសន៍លេមិន ដែនដីភាគខាងត្បូងទាំងអស់ ៕

## ជំពូកទី ៣

*មរមនស្រែកប្រាប់អំពីការប្រែចិត្តដល់ពួកសាសន៍នីហ្វៃ — ពួកគេយកបានជ័យជំនះដ៏ធំមួយ ហើយបានសរសើរកម្លាំងរបស់ខ្លួន — មរមនប្រកែកមិនព្រមដឹក នាំពួកគេ ហើយសេចក្ដីអធិស្ឋានរបស់លោក ដើម្បីពួកគេ គឺគ្មានសេចក្ដីជំនឿ — ព្រះគម្ពីរមរមន អញ្ជើញពូជអំបូរទាំងដប់ពីរពូជរបស់ អ៊ីស្រាអែល ឲ្យជឿដល់ដំណឹងល្អ ។ ប្រមាណជាឆ្នាំ ៣៦០–៣៦២ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិនពុំបានមកច្បាំងទៀតទេ រហូតដល់ដប់ឆ្នាំបានកន្លងផុតទៅ ។ ហើយមើលចុះ ខ្ញុំបាន ចាត់ឲ្យប្រជាជនខ្ញុំ គឺសាសន៍នីហ្វៃ ឲ្យធ្វើការដើម្បីរៀបចំដែនដីរបស់គេ និងគ្រឿងសស្ត្រាវុធរបស់គេសំរាប់ពេលមានចម្បាំង ។

២ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានមានបន្ទូលមកខ្ញុំថា៖ ចូរស្រែកទៅកាន់ប្រជាជននេះថា — ចូរអ្នករាល់គ្នា ប្រែចិត្តចុះ ហើយមករកយើង ហើយចូរអ្នករាល់គ្នាទទួលបុណ្យជ្រមុជទឹក ហើយស្ថាបនាសាសនាចក្ររបស់យើងទៀត ហើយអ្នករាល់គ្នានឹង បានជីវិតរស់នៅ ។

៣ ហើយខ្ញុំបានស្រែកប្រាប់ប្រជាជននេះ តែគឺជាការឥតប្រយោជន៍ទៅវិញ; ហើយពួកគេពុំបានដឹងថា គឺព្រះអម្ចាស់ដែលបានទុកជីវិតឲ្យ ពួកគេ ហើយបានអនុញ្ញាតឲ្យពួកគេមានឱកាសមួយសំរាប់ការប្រែចិត្ត ។ ហើយមើលចុះ ពួកគេបានធ្វើចិត្តរឹងរូសទាស់នឹងព្រះអម្ចាស់ ជាព្រះរបស់គេ ។

៤ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីឆ្នាំទីដប់នេះបានកន្លងផុតទៅ គឺបើគិតទាំងស្រុង គឺបីរយហុកសិបឆ្នាំចាប់តាំងពីព្រះ គ្រីស្ទទ្រង់បានយាងមក នោះស្ដេចរបស់ពួកសាសន៍លេមិនបានផ្ញើសំបុត្រមួយច្បាប់មកខ្ញុំ ដែលប្រាប់ឲ្យខ្ញុំដឹងថា ពួកគេកំពុងរៀបចំមកច្បាំង នឹងពួកយើងទៀត ។

៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឲ្យប្រជាជនខ្ញុំប្រមូលគ្នាមក នៅឯដែនដីចោលស្ងាត់ នៅត្រង់ទីក្រុងមួយដែលនៅជិត ព្រំប្រទល់ គឺនៅជិតចន្លោះតូច ដែលនាំទៅកាន់ដែនដីភាគខាងត្បូង ។

៦ ហើយនៅទីនោះ ពួកយើងបានដាក់ពលទ័ពរបស់យើង ដើម្បីពួកយើងអាចបញ្ឈប់ពលទ័ពសាសន៍លេមិន ដើម្បីកុំឲ្យពួកគេអាច ដណ្ដើមយកដែនដីណាមួយរបស់ពួកយើងបានឡើយ; ហេតុដូច្នេះហើយ ពួកយើងបានពង្រឹងកម្លាំងទាំងអស់តទល់នឹងពួកគេ ។

៧ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទីបីរយហុកសិបមួយ នោះទ័ពលេមិនបានចុះមកទីក្រុងចោលស្ងាត់ ដើម្បីច្បាំងនឹងពួកយើង; ហើយហេតុការណ៍បានកើតឡើងថា នៅឆ្នាំនោះពួកយើងបានវាយឈ្នះពួកគេ ដរាបដល់ធ្វើឲ្យពួកគេ ត្រឡប់ទៅឯដែនដីផ្ទាល់របស់គេវិញ ។

៨ ហើយនៅក្នុងឆ្នាំទីបីរយហុកសិបពីរ នោះពួកគេបានចុះមកច្បាំងទៀត ។ ហើយពួកយើងបានវាយឈ្នះពួកគេទៀត ហើយបាន សម្លាប់ពួកគេអស់ជាច្រើន ហើយសពពួកគេដែលស្លាប់ត្រូវបោះចោលទៅក្នុងសមុទ្រ ។

៩ ហើយឥឡូវនេះ ពីព្រោះមកពីការណ៍ដ៏ធំនេះ [ក]ដែលប្រជាជនខ្ញុំគឺសាសន៍នីហ្វៃបានធ្វើ នោះពួកគេបានចាប់ផ្ដើមអួតអាង ចំពោះកម្លាំងរបស់ខ្លួនផ្ទាល់ ហើយចាប់ផ្ដើមស្បថចំពោះស្ថានសួគ៌ថាពួកគេនឹងសងសឹកដល់ឈាមរបស់ពួកបងប្អូនរបស់គេ ដែលត្រូវសម្លាប់ចោល ដោយពួកខ្មាំងសត្រូវរបស់គេ ។

១០ ហើយពួកគេបាន[ក]ស្បថដល់ស្ថានសួគ៌ និងចំពោះបល្ល័ង្កនៃព្រះផង គឺថា ពួកគេនឹងឡើងទៅច្បាំងនឹងពួកខ្មាំងសត្រូវរបស់គេ ហើយនឹងកាត់ពួកគេចេញឲ្យអស់ពីលើផ្ទៃដែនដី ។

១១ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំមរមន បានប្រកែកជាដាច់ខាតថា ចាប់ពីពេលនេះតទៅ ខ្ញុំមិនព្រមធ្វើជាមេបញ្ជាការ ហើយជាមេដឹកនាំរបស់ប្រជាជននេះទេ ពីព្រោះមកពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមរបស់ពួកគេ ។

១២ មើលចុះ ខ្ញុំបានដឹកនាំពួកគេ ដោយមិនគិតដល់អំពើទុច្ចរិតរបស់ពួកគេឡើយ ខ្ញុំបានដឹកនាំពួកគេ [ក]ជាច្រើនលើកទៅច្បាំង ហើយបានស្រឡាញ់ពួកគេ ស្របតាមសេចក្ដីស្រឡាញ់នៃព្រះដែលនៅក្នុងខ្ញុំ ដោយអស់ពីដួងចិត្តខ្ញុំ; ហើយព្រលឹងខ្ញុំបានស្រោចចេញ នៅក្នុងការអធិស្ឋានដល់ព្រះរបស់ខ្ញុំពេញទាំងមួយថ្ងៃ [ខ]ដើម្បីពួកគេ; ទោះជាយ៉ាងណាក៏ដោយ គង់តែការណ៍នេះគ្មានសេចក្ដីជំនឿសោះ ពីព្រោះមកពីភាពរឹងរូសនៃចិត្តរបស់គេ ។

១៣ ហើយខ្ញុំបានដោះលែងពួកគេបីដង ឲ្យរួចផុតពីកណ្ដាប់ដៃ

**៣** ៩*ក* ២ នីហ្វៃ ៤:៣៤.
១០ *ក* ៣ នីហ្វៃ ៣:២០–២១;
មរមន ៤:៤.
១២ *ក* ស.ប. សេចក្ដីស្រឡាញ់.
*ខ* មរមន ៥:២.

នៃពួកខ្មាំងសត្រូវរបស់គេ ហើយពួកគេពុំបានប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេសោះ ។

១៤ ហើយកាលពួកគេបានស្បថ ចំពោះអ្វីៗទាំងអស់ ដែលត្រូវបាន[ក]ហាមប្រាមដល់ពួកគេ ដោយព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះយេស៊ូវ គ្រីស្ទរបស់យើង គឺស្បថថា ពួកគេនឹងឡើងទៅច្បាំងនឹងពួកខ្មាំងសត្រូវរបស់គេ ហើយសងសឹកឲ្យឈាមនៃពួកបងប្អូនរបស់គេ មើលចុះ សម្លេងនៃព្រះអម្ចាស់បានបន្លឺមកខ្ញុំថា៖

១៥ [ក]ការសងសឹកគឺជារបស់យើង ហើយយើងនឹង[ខ]សង; ហើយពីព្រោះមកពីប្រជាជននេះពុំប្រែចិត្ត បន្ទាប់ពីយើងបានដោះលែងពួកគេ ឲ្យរួច មើលចុះ ពួកគេនឹងត្រូវកាត់ចេញពីលើផ្ទៃផែនដីនេះទៅ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំប្រកែកជាដាច់ខាតថា ខ្ញុំមិនព្រមឡើងទៅច្បាំងនឹងពួកខ្មាំងសត្រូវរបស់ខ្ញុំទេ; ហើយខ្ញុំបាន ធ្វើដូចដែលព្រះទ្រង់បានបញ្ជាខ្ញុំ; ហើយខ្ញុំបានឈរធ្វើជាសាក្សីមួយគត់ ដើម្បីសម្ដែងប្រាប់ដល់មនុស្សលោកនូវការណ៍ទាំងឡាយ ដែល ខ្ញុំបានឃើញ ហើយបានឮស្របតាមការបើកសម្ដែងនៃព្រះវិញ្ញាណ ដែលបានធ្វើបន្ទាល់ដល់ការណ៍ទាំងឡាយ ដែលនឹងកើតឡើង ។

១៧ ហេតុដូច្នេះហើយ ខ្ញុំ[ក]សរសេរទៅកាន់អ្នក ឱពួកសាសន៍ដទៃអើយ និងទៅកាន់អ្នករាល់គ្នាផង ឱវង្សអ៊ីស្រាអែលអើយ ថាកាល ណាកិច្ចការនោះចាប់ផ្ដើមឡើង នោះអ្នករាល់គ្នាជិតរៀបចំត្រឡប់ទៅឯដែនដីនៃកេរ្តិ៍អាកររបស់អ្នកវិញ ។

១៨ មែនហើយ មើលចុះ ខ្ញុំសរសេរទៅកាន់អស់អ្នក ដែលនៅគ្រប់ទិសទីលើផែនដី; មែនហើយ ទៅកាន់អ្នករាល់គ្នាជាពូជអំបូរទាំង ១២របស់អ៊ីស្រាអែល ដែលនឹងបានទទួល[ក]ការជំនុំជំរះស្របតាមកិច្ចការទាំងឡាយរបស់អ្នក ពីពួក១២នាក់ ដែលព្រះយេស៊ូវទ្រង់បានរើស ឲ្យធ្វើជាសាវករបស់ទ្រង់នៅដែនដីយេរូសាឡិម ។

១៩ ហើយខ្ញុំសរសេរទៅកាន់សំណល់នៃប្រជាជននេះផងដែលនឹងបានទទួលការជំនុំជំរះ[ក]ពីពួក១២នាក់ ដែលព្រះយេស៊ូវទ្រង់បានរើស នៅដែនដីនេះដែរ; ហើយពួកគេនឹងបានទទួលការជំនុំជំរះ ពីពួក១២នាក់ទៀត ដែលព្រះយេស៊ូវទ្រង់បានរើសនៅដែនដីយេរូសាឡិម ។

២០ ហើយការណ៍ទាំងនេះហើយដែលព្រះវិញ្ញាណសម្ដែងដល់ខ្ញុំ; ហេតុដូច្នេះហើយ ខ្ញុំសរសេរទៅកាន់អ្នករាល់គ្នា ។ ហើយដោយ ហេតុនេះ ទើបខ្ញុំសរសេរទៅកាន់អ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាអាចដឹងថា អ្នករាល់គ្នាត្រូវឈរនៅចំពោះវេទិកា[ក]ជំនុំជំរះនៃព្រះគ្រីស្ទ មែនហើយ គឺមនុស្សរាល់រូប ដែលនៅក្នុង[ខ]គ្រួសារមនុស្សជាតិទាំងមូល របស់លោកអ័ដាម; ហើយអ្នករាល់គ្នាត្រូវឈរ ដើម្បីទទួលការ ជំនុំជំរះ ចំពោះកិច្ចការទាំងឡាយរបស់អ្នក ដើម្បីឲ្យឃើញថា ពួកគេល្អ ឬក៏ពួកគេអាក្រក់;

២១ ហើយដើម្បីឲ្យអ្នករាល់គ្នា អាច[ក]ជឿដល់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទផង ដែលអ្នករាល់គ្នានឹងមាន នៅក្នុងចំណោមអ្នករាល់គ្នា; ហើយដើម្បីឲ្យ[ខ]ពួកសាសន៍យូដាផង ដែលជារាស្ត្រដែលនៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ មាន[គ]សាក្សីផ្សេងទៀតក្រៅពីទ្រង់ ដែល ពួកគេបានឃើញ ហើយបានឮ ថាព្រះយេស៊ូវ ដែលពួកគេបានធ្វើគុតនោះ [ឃ]គឺជាព្រះគ្រីស្ទ ហើយជាព្រះនោះពិត ។

២២ ហើយខ្ញុំសង្ឃឹមថា ខ្ញុំអាចបញ្ចុះបញ្ចូល[ក]អស់អ្នករាល់គ្នានៅចុងផែនដី ឲ្យប្រែចិត្ត ហើយប្រុងប្រៀបឈរ នៅចំពោះវេទិកាជំនុំជំរះ នៃព្រះគ្រីស្ទ ៕

## ជំពូកទី ៤

*សង្គ្រាម និងការកាប់សម្លាប់មានតទៅ — ពួកទុច្ចរិតធ្វើទោសដល់ពួកទុច្ចរិត — អំពើទុច្ចរិតដ៏ធំលើសលែងទៅទៀត ស្ថិតនៅលើ ពួកអ៊ីស្រាអែលទាំងស្រុង — ពួកស្ត្រី និងក្មេងៗត្រូវយកទៅបូជាថ្វាយរូបព្រះទាំងឡាយ — ពួកសាសន៍លេមិនចាប់ផ្ដើមកំចាត់ ពួកសាសន៍នីហ្វៃចេញពីមុខ ។ ប្រមាណជាឆ្នាំ ៣៦៣–៣៧៥ គ.ស. ។*

ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា នៅក្នុង

---

១៤ *ក* ៣ នីហ្វៃ ១២:៣៤–៣៧.
១៥ *ក* ស.ប. ការសងសឹក.
*ខ* គ. និង ស. ៨២:២៣.
១៧ *ក* ២ នីហ្វៃ ៣០:៣–៨;
៣ នីហ្វៃ ២៩:១.
១៨ *ក* ម៉ាថាយ ១៩:២៨;
លូកា ២២:២៩–៣០;
គ. និង ស. ២៩:១២.
១៩ *ក* ១ នីហ្វៃ ១២:៩–១០.
២០ *ក* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*ខ* គ. និង ស. ២៧:១១.
២១ *ក* គ. និង ស. ៣:២០.
*ខ* ស.ប. ពួកសាសន៍យូដា.
*គ* ២ នីហ្វៃ ២៥:១៨.
*ឃ* ២ នីហ្វៃ ២៦:១២;
ម៉ូសាយ ៧:២៧.
២២ *ក* អាលម៉ា ២៩:១.

ឆ្នាំទីបីរយហុកសិបបី នោះពួកសាសន៍នីហ្វៃបាននាំពលទ័ព
ឡើងទៅច្បាំងនឹងពួក សាសន៍លេមិន ចេញពីដែនដីចោលស្ងាត់ ។
២ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពសាសន៍
នីហ្វៃ ត្រូវវាយតបឲ្យត្រឡប់ថយមកដែនដីចោលស្ងាត់វិញ ។
ហើយនៅពេលពួក គេកំពុងនឿយហត់នៅឡើយ នោះកងទ័ព
សាសន៍លេមិនដ៏ថ្មីមួយកង បានមកវាយពួកគេ; ហើយពួកគេបាន
ច្បាំងយ៉ាងសាហាវ ដរាបដល់ ទ័ពលេមិនបានដណ្ដើមយក
ទីក្រុងចោលស្ងាត់បាន ហើយបានសម្លាប់ពួកនីហ្វៃជាច្រើន
ហើយបានចាប់មនុស្សជាច្រើនយកទៅជាឈ្លើយ ។
៣ ហើយអ្នកដែលនៅសល់ទាំងប៉ុន្មានបានរត់គេចចេញ ហើយ
បានចូលរួមជាមួយនឹងបណ្ដាជននៃទីក្រុងទីអានគុម ។ ឥឡូវនេះ
ទីក្រុង ទីអានគុមនេះនៅត្រង់ជាយដែនជាប់នឹងសមុទ្រ;
ហើយនៅជិតទីក្រុងចោលស្ងាត់ដែរ ។
៤ [ក]ដោយមកពីពលទ័ពសាសន៍នីហ្វៃ បានឡើងទៅរកវាយពួក
លេមិន បានជាពួកគេត្រូវបរាជ័យ; បើពុំនោះសោតទេ ពួក
លេមិនពុំអាច មានអំណាចអ្វីមកលើពួកគេបានឡើយ ។
៥ ប៉ុន្តែមើលចុះ សេចក្ដីជំនុំជំរះទាំងឡាយនៃព្រះនឹងដេញទាន់
ពួកទុច្ចរិត; ហើយពួកទុច្ចរិតនឹងត្រូវ[ក]ធ្វើទោស ដោយពួកទុច្ចរិត;
ត្បិតពួក ទុច្ចរិតនេះហើយដែលបានចាក់រុកចិត្តកូនចៅមនុស្ស
ឲ្យមានការខ្ចាយឈាម ។
៦ ហើយហេតុការណ៍បានកើតឡើងថា ពួកលេមិនបានធ្វើការ
រៀបចំ ដើម្បីមកប្រឆាំងនឹងទីក្រុងទីអានគុម ។
៧ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីបីរយហុកសិបបួន នោះពួកសាសន៍លេមិនបានមកប្រឆាំងនឹង
ទីក្រុងទីអានគុម ដើម្បីគេអាចដណ្ដើមយកទីក្រុងទីអានគុមផង ។
៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេត្រូវបាន
រុញច្រាន ឲ្យថយទៅក្រោយវិញ ដោយពួកនីហ្វៃ ។ ហើយកាល
ពួកនីហ្វៃបាន ឃើញថា ពួកគេបានរុញច្រានពួកលេមិនឲ្យ
ថយក្រោយ នោះពួកគេក៏អួតអាងចំពោះកម្លាំងរបស់ខ្លួនទៀត;
ហើយពួកគេបានចេញទៅនៅក្នុង សមត្ថភាពរបស់ខ្លួន ដើម្បីទៅ
ដណ្ដើមយកទីក្រុងចោលស្ងាត់មកវិញ ។
៩ ឥឡូវនេះ រឿងទាំងអស់នេះក៏បានកើតឡើងរួចហើយ ហើយ
ទាំងសងខាងមានមនុស្សស្លាប់រាប់ពាន់អ្នក គឺទាំងពួកនីហ្វៃ និង
ពួកលេមិន ។
១០ ហើយហេតុការណ៍បានកើតឡើងថា ឆ្នាំទីបីរយហុកសិបប្រាំ
មួយបានកន្លងផុតទៅ ហើយពួកលេមិនបាននាំគ្នាមកច្បាំងនឹង
ពួក នីហ្វៃទៀត; ក៏ប៉ុន្តែពួកនីហ្វៃពុំប្រែចិត្ត ចេញពីការ
អាក្រក់ដែលគេបានធ្វើឡើយ ហើយនៅតែបន្តអំពើទុច្ចរិត
របស់ខ្លួនទៅទៀត ។
១១ ហើយគ្មានអណ្ដាតឯណាអាចអធិប្បាយបាន ឬក៏គ្មាន
មនុស្សណាអាចសរសេរការអធិប្បាយដោយឥតខ្ចោះ នូវ
ទិដ្ឋភាពដ៏ស្ញែង អស្ចារ្យ នៃការខ្ចាយឈាម និងការកាប់សម្លាប់
ដែលមាននៅក្នុងចំណោមប្រជាជន ទាំងពួកសាសន៍នីហ្វៃ និង
ពួកសាសន៍លេមិនបានឡើយ; ហើយចិត្តរបស់គេរាល់គ្នា
សុទ្ធតែរឹងរូស ម្ល៉ោះហើយ បានជាគេសប្បាយចិត្តក្នុងការ
ខ្ចាយឈាមគ្នាមិនចេះចប់សោះ ។
១២ ហើយពុំដែលមាន[ក]អំពើទុច្ចរិតដ៏ធំបែបនេះ នៅក្នុង
ចំណោមអស់ទាំងកូនចៅរបស់លីហៃ ឬក៏នៅក្នុងចំណោមវ
ង្សអ៊ីស្រាអែល ដូចជានៅក្នុងចំណោមប្រជាជននេះឡើយ
ស្របតាមព្រះបន្ទូលនៃព្រះ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ពួក
លេមិនក៏ដណ្ដើមយកទីក្រុងចោលស្ងាត់បាន ហើយការណ៍នេះ
គឺដោយសារពួកគេមាន [ក]ចំនួនច្រើនជាងពួកនីហ្វៃ ។
១៤ ហើយពួកគេបានលើកទៅវាយយកទីក្រុងទីអានគុមទៀត
ហើយបានបណ្ដេញបណ្ដាជន ចេញពីទីក្រុងនោះ ហើយបាន
យកមនុស្ស ជាច្រើនធ្វើជាឈ្លើយ មានទាំងពួកស្ត្រី [ក]និងកូនក្មេង
ហើយបានចាប់យកពួកនេះទៅប្រហារជីវិត បូជាថ្វាយរូបព្រះ
ទាំងឡាយរបស់គេ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីបីរយហុកសិបប្រាំពីរ នោះពួកសាសន៍នីហ្វៃបានក្រេវក្រោធ
ពីព្រោះពួកសាសន៍ លេមិនបានបូជាពួកស្ត្រី និងកូនក្មេងរបស់ពួក
នីហ្វៃ បានជាពួកគេលើកទ័ព ទៅវាយប្រហារពួកលេមិន ដោយ
សេចក្ដីក្រេវក្រោធជាអតិបរមា ដរាបដល់ពួកគេមានជ័យជំនះលើ
ពួកលេមិន ហើយបានរុញច្រានពួកនេះ ចេញពីដែនដី
របស់គេទៅ ។
១៦ ហើយពួកលេមិនពុំបានត្រឡប់មកច្បាំងនឹងពួកនីហ្វៃទៀតទេ
រហូតដល់ឆ្នាំទីបីរយចិតសិបប្រាំ ។
១៧ ហើយនៅក្នុងឆ្នាំនេះ ពួកគេបានចុះមកច្បាំងជាមួយនឹង
ពួកសាសន៍នីហ្វៃ ដោយអស់សមត្ថភាពរបស់គេ; ហើយពួកគេពុំ
អាចរាប់ចំនួន ទេ ពីព្រោះមកពីពួកនោះមានគ្នាច្រើនឥតគណនា ។

៤ ៤*ក* មរមន ៣:១០.
៥ *ក* គ. និង ស. ៦៣:៣៣.
១២ *ក* លោកុ. ៦:៥; ៣ នីហ្វៃ ៩:៩.
១៣ *ក* មរមន ៥:៦.
១៤ *ក* ស.ប. ការថ្វាយបង្គំរូបព្រះ.

១៨ ហើយចាប់ពីពេលនោះមក ពួកសាសន៍នីហ្វៃពុំមាន
អំណាចអ្វី ទៅលើពួកលេមិនបានឡើយ ប៉ុន្តែបានចាប់ផ្ដើម
កំចាត់ចេញដោយ ពួកលេមិន ហាក់បីដូច
ដំណក់សន្សើមនៅចំពោះព្រះអាទិត្យ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិន
បានចុះមកប្រឆាំងទីក្រុងចោលស្វាត់; ហើយមានចម្បាំងមួយ
ដ៏ឃោរឃៅ បំផុត ដែលបានច្បាំងនៅលើដែនដីចោលស្វាត់
ជាចម្បាំងដែលពួកគេបានឈ្នះពួកនីហ្វៃ ។
២០ ហើយទ័ពនីហ្វៃបានរត់គេចចេញពីពួកគេទៀត ហើយពួក
គេបានមកឯទីក្រុងបូអ៊ូស; នៅទីនោះ ពួកគេបានទប់ទល់នឹង
សាសន៍លេមិន ដោយក្លាហាន ដរាបដល់សាសន៍លេមិនពុំបាន
ឈ្នះពួកគេទេ រហូតដល់ពួកគេត្រឡប់មកជាលើកទីពីរទៀត ។
២១ ហើយកាលពួកគេមកជាលើកទីពីរ នោះពួកសាសន៍
នីហ្វៃត្រូវបានរុញច្រាន ហើយត្រូវសម្លាប់ដោយការកាប់សម្លាប់
មួយដ៏ធំ; ឯពួកស្ត្រីរបស់គេ និងកូនក្មេងរបស់គេត្រូវចាប់
មកប្រហារជីវិតបូជាថ្វាយរូបព្រះទាំងឡាយទៀត ។
២២ ហើយហេតុការណ៍បានកើតឡើងថា ពួកនីហ្វៃបាន
រត់គេចចេញពីពួកគេទៀត ដោយបាននាំបណ្ដាជនទាំងអស់ ទៅជា
មួយពួកគេ ទាំងនៅក្នុងទីក្រុង និងនៅក្នុងភូមិទាំងឡាយផង ។
២៣ ហើយឥឡូវនេះ ខ្ញុំមរមន ដោយបានឃើញថា ពួក
សាសន៍លេមិន ជិតយកដែនដីបានហើយ ហេតុដូច្នេះហើយ
ខ្ញុំបានទៅឯភ្នំស៊ីម ហើយបានយកបញ្ជីទាំងអស់ ដែលអាំម៉ារ៉ុន
បានលាក់ទុកថ្វាយព្រះអម្ចាស់ ៕

## ជំពូកទី ៥

*មរមនដឹកនាំពលទ័ពសាសន៍នីហ្វៃម្ដងទៀត នៅក្នុងចម្បាំងទាំងឡាយ ដែលពោរពេញទៅដោយការខ្ចាយឈាម និងការកាប់សម្លាប់ — ព្រះគម្ពីរមរមននឹងលេចចេញមក ដើម្បីបរិវត្តពួកអ៊ីស្រាអែលទាំងអស់ថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ — ពីព្រោះតែពីការឥតជំនឿរបស់គេ នោះពួកសាសន៍លេមិន នឹងត្រូវកំចាត់កំចាយចេញ ហើយព្រះវិញ្ញាណ ទ្រង់នឹងឈប់តស៊ូនៅជាមួយនឹងពួកគេហើយ — ពួកគេនឹងទទួល ដំណឹងល្អពីពួកសាសន៍ដទៃ នៅថ្ងៃចុងក្រោយ ។ ប្រមាណជាឆ្នាំ ៣៧៥–៣៨៤ គ.ស. ។*

ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានទៅក្នុងចំណោមពួក
សាសន៍នីហ្វៃ ហើយបានប្រែចិត្តពីពាក្យសម្បថដែលខ្ញុំបានធ្វើថា
ខ្ញុំនឹងពុំជួយ ពួកគេទៀតទេ; ហើយពួកគេបានឲ្យខ្ញុំបញ្ជាពលទ័ព
របស់គេទៀត ត្បិតពួកគេមើលមកខ្ញុំ បីដូចជាខ្ញុំអាចដោះលែង
ពួកគេឲ្យរួចផុតពីសេចក្ដី ទុក្ខវេទនាទាំងឡាយរបស់គេ ។
២ ប៉ុន្តែមើលចុះ ខ្ញុំគ្មានសង្ឃឹមឡើយ ត្បិតខ្ញុំបានដឹងថា សេច
ក្ដីជំនុំជំរះទាំងឡាយនៃព្រះអម្ចាស់នឹងធ្លាក់មកលើពួកគេ; ត្បិត
ពួកគេពុំប្រែចិត្ត ចេញពីអំពើទុច្ចរិតទាំងឡាយរបស់គេទេ ប៉ុន្តែ
បានតស៊ូ ដើម្បីជីវិតរបស់គេ ដោយពុំអំពាវនាវដល់តួអង្គ ដែល
បានបង្កើតពួកគេឡើយ ។
៣ ហើយហេតុការណ៍បានកើតឡើងថា ពួកសាសន៍លេមិន
បានមកច្បាំងនឹងយើង នៅពេលពួកយើងរត់ ទៅទីក្រុងយ៉ូរដាន់;
ប៉ុន្តែមើលចុះ ពួកគេត្រូវបានរុញច្រានឲ្យថយក្រោយវិញ ដែល
ពួកគេពុំបានយកទីក្រុងនោះ នៅក្នុងពេលនោះឡើយ ។
៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានមកច្បាំង
នឹងពួកយើងទៀត ហើយពួកយើងបានរក្សាទីក្រុងនោះទុក ។
ហើយមានទី ក្រុងទាំងឡាយឯទៀតផង ដែលត្រូវបានរក្សាទុក
ដោយពួកសាសន៍នីហ្វៃ ដែលមានទីតាំងការពារទាំងឡាយ
ដែលបានផ្ដាច់ផ្លូវពួកគេ ដើម្បី កុំឲ្យពួកគេអាចចូលទៅក្នុងស្រុក
ដែលនៅខាងមុខពួកយើង ដើម្បីមកបំផ្លាញប្រជាជន
នៃដែនដីយើងចោល ។
៥ ប៉ុន្តែ ហេតុការណ៍បានកើតឡើងថា ដែនដីទាំងឡាយណា
ដែលយើងបានឆ្លងកាត់ ហើយបណ្ដាជននៅទីនោះ ពុំប្រមូលគ្នា
មក គឺត្រូវ បំផ្លាញចោលដោយពួកសាសន៍លេមិន ហើយ
ទីផ្សារទាំងឡាយ និងភូមិទាំងឡាយ និងទីក្រុងទាំងឡាយរបស់
ពួកគេ ត្រូវដុតឆេះដោយភ្លើង; ម្ល៉ោះហើយ
បីរយចិតសិបប្រាំបួនឆ្នាំបានកន្លងផុតទៅ ។
៦ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុង
ឆ្នាំទីបីរយប៉ែតសិប នោះពួកសាសន៍លេមិនបានមកច្បាំងនឹងពួក
យើងទៀត ហើយពួក យើងបានតទល់នឹងពួកគេយ៉ាងក្លាហាន;
ប៉ុន្តែគឺជាការឥតប្រយោជន៍ទៅវិញ ត្បិតពួកគេមាន
ចំនួនច្រើនណាស់ ដែលនាំឲ្យពួកគេជាន់ឈ្លី ប្រជាជននៃសាសន៍
នីហ្វៃនៅក្រោមជើងគេ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបាន
រត់គេចទៀត ហើយអស់អ្នកណាដែលរត់លឿនជាងពួកសាសន៍

១៨ *ក* មរមន ៣:៣.
២៣ *ក* មរមន ១:៣.
**៥** ១ *ក* មរមន ៣:១១.
២ *ក* មរមន ៣:១២.

លេមិន ក៏បានរត់រួច ហើយអស់អ្នកណាដែលរត់មិនលឿនជាង
ពួកសាសន៍លេមិន ក៏ត្រូវបោសចេញ ហើយបំផ្លាញចោល ។
៨ ហើយឥឡូវនេះ មើលចុះ ខ្ញុំមរមន ពុំមានបំណងធ្វើឲ្យ
មនុស្សកើតទុក្ខក្នុងដួងព្រលឹង ដោយលាតត្រដាងនៅចំពោះមុខ
គេ នូវឆាក មួយដ៏គួរស្ញែងខ្លាច នៃការខ្ចាយឈាម និងការ
កាប់សម្លាប់ ដូចដែលបានបង្ហាញចំពោះភ្នែកខ្ញុំទេ; ប៉ុន្តែដោយ
ខ្ញុំដឹងថា ការណ៍ទាំងនេះត្រូវ តែឲ្យគេដឹងជាប្រាកដ ហើយថា
អស់ទាំងការណ៍ដែលលាក់កំបាំង ត្រូវតែបើកសម្តែងនៅ
ខាងលើដំបូលផ្ទះ —
៩ ហើយម្យ៉ាងទៀតថា ដំណឹងអំពីហេតុការណ៍ទាំងនេះ ត្រូវ
តែមានដល់សំណល់នៃប្រជាជនទាំងនេះ និងដល់ពួកសាសន៍
ដទៃផង ដែលព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា នឹងបំបែក
ប្រជាជននេះ ហើយប្រជាជននេះ នឹងត្រូវរាប់ជាឥតប្រយោជន៍
នៅក្នុងចំណោមពួកគេ — ហេតុដូច្នេះហើយ ខ្ញុំសរសេរនូវ
សេចក្តីសង្ខេបដ៏ខ្លីមួយ ដោយពុំហ៊ានរៀបរាប់អំពីដំណើររឿង
ដ៏ពោរពេញនៃកាណ៍ទាំងឡាយដែលខ្ញុំបាន ឃើញ ពីព្រោះមក
ពីបញ្ជាដែលខ្ញុំបានទទួល ហើយម្យ៉ាងទៀត គឺដើម្បីកុំឲ្យអ្នករាល់
គ្នា មានទុក្ខសោកខ្លាំងពេក ពីព្រោះមកពីអំពើទុច្ចរិត របស់
ប្រជាជននេះ ។
១០ ហើយឥឡូវនេះ មើលចុះ ការណ៍នេះគឺខ្ញុំនិយាយទៅកាន់
ពូជរបស់ពួកគេ និងទៅកាន់ពួកសាសន៍ដទៃផង ដែល
ថែរក្សាវង្ស អ៊ីស្រាអែល ដែលដឹង ហើយយល់ថា តើព្រះពរ
ទាំងឡាយរបស់ពួកគេបានមកពីណា ។
១១ ត្បិតខ្ញុំដឹងថា ពួកគេទាំងនេះហើយដែលនឹងកើតទុក្ខ
ចំពោះគ្រោះកាចនៃវង្សអ៊ីស្រាអែល; មែនហើយ ពួកគេនឹងកើត
ទុក្ខចំពោះ ការបំផ្លិចបំផ្លាញនៃប្រជាជននេះ; ពួកគេនឹងកើតទុក្ខ
ដោយព្រោះប្រជាជននេះពុំបានប្រែចិត្ត ដើម្បីឲ្យពួកគេអាចបាន
ឱបក្ខាប់នៅក្នុង ព្រះហស្តនៃព្រះយេស៊ូវ ។
១២ ឥឡូវនេះ ការណ៍ទាំងនេះត្រូវបានសរសេរទុក សំរាប់
សំណល់នៃវង្សយ៉ាកុប; ហើយការណ៍ទាំងនេះ ត្រូវបានសរសេរ
តាម របៀបនេះ ពីព្រោះព្រះទ្រង់ជ្រាបថា អំពើទុច្ចរិតនឹងមិន
នាំឲ្យពួកគេ ដឹងនូវការណ៍ទាំងនេះឡើយ; ហើយការណ៍
ទាំងនេះ នឹងត្រូវបាន លាក់ថ្វាយព្រះអម្ចាស់ ដើម្បីឲ្យបានចេញ
មក តាមពេលកំណត់របស់ទ្រង់ផ្ទាល់ ។
១៣ ហើយនេះគឺជាបញ្ជាដែលខ្ញុំបានទទួល; ហើយមើលចុះ
ការណ៍ទាំងនេះនឹងចេញមក ស្របតាមបញ្ជានៃព្រះអម្ចាស់
នៅពេល ដែលទ្រង់នឹងទតឃើញថាសមល្មម តាមប្រាជ្ញារបស់
ទ្រង់ ។
១៤ ហើយមើលចុះ ការណ៍ទាំងនេះនឹងទៅដល់ពួកអ្នកដែល
មិនជឿ ក្នុងពួកសាសន៍យូដា; ហើយដោយគោលបំណងនេះហើយ
ដែល ការណ៍ទាំងនេះនឹងចេញទៅ — គឺដើម្បីឲ្យពួកគេអាច
បានបញ្ចុះបញ្ចូលឲ្យជឿថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះ
រាជបុត្រានៃព្រះ ដ៏មានព្រះជន្មរស់នៅ; ថាព្រះវរបិតា
អាចធ្វើឡើង តាមរយៈព្រះរាជបុត្រាដ៏សំណប់បំផុតរបស់ទ្រង់
នូវគោលបំណងដ៏មហិមា និងអស់កល្ប ជានិច្ច ក្នុងការ
សាងឡើងវិញនូវពួកសាសន៍យូដា ឬវង្សអ៊ីស្រាអែលទាំងអស់
ឲ្យមកកាន់ដែនដីជាកេរ្តិ៍អាកររបស់ពួកគេ ដែលព្រះអម្ចាស់ ជា
ព្រះរបស់ពួកគេ បានប្រទានឲ្យពួកគេ តាមការបំពេញសេចក្តី
សញ្ញារបស់ទ្រង់;
១៥ ហើយដើម្បីឲ្យពូជរបស់ប្រជាជននេះផង អាចជឿ
ដ៏ពេញលេញថែមទៀត ដល់ដំណឹងល្អរបស់ទ្រង់ ដែលនឹងទៅ
ដល់ពួកគេ ពីពួក សាសន៍ដទៃ; ត្បិតប្រជាជននេះនឹងត្រូវ
បែកខ្ញែក ហើយនឹងក្លាយទៅជាប្រជាជនមួយ ដែល
មានសម្បុរខ្មៅ ស្មោកគ្រោក ហើយគួរខ្ពើមឆ្អើម ហួសពីការ
អធិប្បាយនូវអ្វីៗ ដែលធ្លាប់មាននៅក្នុងចំណោមពួកយើងរាល់
គ្នា មែនហើយ ទាំងអ្វីដែលធ្លាប់មាននៅក្នុងចំណោមពួកសាសន៍
លេមិន ហើយនេះគឺដោយសារការឥតជំនឿ និងការ
គោរពរូបព្រះរបស់ពួកគេ ។

៨ *ក* លូកា ១២:២–៣;
២ នីហ្វៃ ២៧:១១;
គ. និង ស. ១:៣.
៩ *ក* ៤ នីហ្វៃ ១:៤៩.
*ខ* ៣ នីហ្វៃ ១៦:៨.
*គ* មរមន ១:១.
១២ *ក* អេណុស ១:១៦;
ហេលេ. ១៥:១១–១៣.
ស.ប. ព្រះគម្ពីរមរមន.
*ខ* គ. និង ស. ៣:១៦–២០.
*គ* មរមន ៨:៤, ១៣–១៤;
ម្រ៉ូណៃ ១០:១–២.
១៤ *ក* ២ នីហ្វៃ ២៩:១៣; ៣០:៧–៨.
ស.ប. ពួកសាសន៍យូដា.
*ខ* ២ នីហ្វៃ ២៥:១៦–១៧.
*គ* ៣ នីហ្វៃ ២៩:១–៣.
១៥ *ក* ៣ នីហ្វៃ ២១:៣–៧, ២៤–២៦.
*ខ* ១ នីហ្វៃ ១៣:២០–២៩, ៣៨;
មរមន ៧:៨–៩.
*គ* ១ នីហ្វៃ ១០:១២–១៤;
៣ នីហ្វៃ ១៦:៨.
*ឃ* ២ នីហ្វៃ ២៦:៣៣.

១៦ ត្បិតមើលចុះ ព្រះវិញ្ញាណនៃព្រះអម្ចាស់ ឈប់[ក]តស៊ូនៅជា
មួយនឹងពួកអយ្យកោរបស់ពួកគេហើយ; ហើយពួកគេ
គ្មានព្រះគ្រីស្ទ និងព្រះនៅក្នុងលោកិយ; ហើយពួកគេត្រូវ
រុញច្រាន ដូចជា[ខ]អង្កាមដែលខ្យល់ផាត់ ។
១៧ ពួកគេធ្លាប់ជាប្រជាជនមួយដ៏គួរឲ្យចូលចិត្ត ហើយពួកគេ
មានព្រះគ្រីស្ទ ជា[ក]អ្នកគង្វាលរបស់ពួកគេ; មែនហើយ ពួកគេត្រូវ
បានដឹកនាំ ដោយព្រះវរបិតាផង ។
១៨ ប៉ុន្តែឥឡូវនេះ មើលចុះ ពួកគេត្រូវបាន[ក]ដឹកនាំដោយអារក្ស
សាតាំង ដូចជាអង្កាមដែលខ្យល់ផាត់ ឬដូចជាភេត្រាមួយ
បោះបោកនៅ លើរលកគ្មានក្ដោង ឬយុថ្កា ឬគ្មានអ្វី
សំរាប់កាច់ចង្កូតវា; ហើយបីដូចជាភេត្រានេះ គឺពួក
គេក៏ដូច្នេះដែរ ។
១៩ ហើយមើលចុះ ព្រះអម្ចាស់ទ្រង់បានទុកព្រះពរទាំងឡាយ
របស់ពួកគេ ដែលគួរណាតែពួកគេបានទទួលនៅដែនដី សំរាប់[ក]ពួក
សាសន៍ ដទៃ ដែលនឹងយកដែនដីនេះ ។
២០ ប៉ុន្តែមើលចុះ ហេតុការណ៍បានកើតឡើងថា ពួកគេនឹង
ត្រូវរុញច្រាន ហើយបំបែកខ្ចែក ដោយពួកសាសន៍ដទៃ;
ហើយក្រោយពី ពួកគេត្រូវរុញច្រាន និងត្រូវបំបែកខ្ចែក ដោយ
ពួកសាសន៍ដទៃហើយ មើលចុះ ពេលនោះ ព្រះអម្ចាស់ទ្រង់នឹង
[ក]នឹកចាំដល់[ខ]សេចក្ដីសញ្ញា ដែលទ្រង់បានធ្វើដល់លោកអ័ប្រាហាំ
និងដល់វង្សអ៊ីស្រាអែលទាំងអស់ ។
២១ ហើយព្រះអម្ចាស់ទ្រង់នឹងនឹកចាំដល់[ក]សេចក្ដីអធិស្ឋានទាំង
ឡាយនៃពួកសុចរិត ដែលត្រូវបានថ្វាយដល់ទ្រង់ ដើម្បីពួកគេ ។
២២ ហើយនៅពេលនោះ ឱពួកសាសន៍ដទៃអើយ តើធ្វើម្ដេចទៅ
អ្នករាល់គ្នានឹងអាចឈរ នៅចំពោះព្រះចេស្ដានៃព្រះបាន
លើកលែងតែអ្នករាល់គ្នាប្រែចិត្ត ហើយបែរចេញពីផ្លូវអាក្រក់ទាំង
ឡាយរបស់អ្នក ?
២៣ តើអ្នករាល់គ្នាមិនដឹងទេឬថា អ្នករាល់គ្នានៅក្នុង
ព្រះហស្តនៃព្រះ? តើអ្នករាល់គ្នាមិនដឹងទេឬថា ទ្រង់មានអស់
ទាំងព្រះចេស្ដា ហើយនៅក្រោម[ក]បញ្ជាដ៏មហិមារបស់ទ្រង់ ផែនដី
នឹង[ខ]ត្រូវមូរចូលគ្នា ជារមូរក្រដាសមួយ ?
២៤ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាប្រែចិត្ត ហើយធ្វើខ្លួន
រាបទាប នៅចំពោះទ្រង់ចុះ ក្រែងទ្រង់នឹងយកសេចក្ដីយុត្តិធម៌
មកទាស់នឹង អ្នករាល់គ្នា — ក្រែងសំណល់មួយនៃពូជយ៉ាកុប
នឹងមកក្នុងចំណោមអ្នក ដូចជា[ក]សត្វសិង្ហមួយ ហើយនឹងហែកអ្នក
រាល់គ្នាទៅជាដុំៗ ហើយ នឹងគ្មានអ្នកណាម្នាក់អាចជួយដោះលែង
អ្នកបានឡើយ ៕

## ជំពូកទី ៦

*ពួកសាសន៍នីហ្វៃប្រមូលគ្នាមកក្នុងដែនដីគូម៉ូរ៉ា ដើម្បីធ្វើការ ប្រយុទ្ធទាំងឡាយជាចុងក្រោយបំផុត — មរមនលាក់បញ្ជីពិសិដ្ឋ ទាំង ឡាយនៅក្នុងភ្នំគូម៉ូរ៉ា — ពួកសាសន៍លេមិនមានជ័យជំនះ ហើយសាសន៍នីហ្វៃត្រូវបំផ្លាញចោល — មនុស្សរាប់រយពាន់នាក់ ត្រូវប្រហារចោលដោយដាវ ។ ប្រមាណជាឆ្នាំ ៣៨៥ គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំបង្ហើយបញ្ជីរបស់ខ្ញុំ អំពី[ក]ការបំផ្លិចបំផ្លាញ
ប្រជាជនខ្ញុំ គឺសាសន៍នីហ្វៃ ។ ហើយហេតុការណ៍បានកើតឡើងថា
ពួកយើងបានចេញទៅប្រយុទ្ធនឹងពួកសាសន៍លេមិន ។
២ ហើយខ្ញុំមរមន បានសរសេរសំបុត្រមួយច្បាប់ ទៅស្ដេច
របស់ពួកសាសន៍លេមិន សូមឲ្យទ្រង់អនុញ្ញាតឲ្យពួកយើងអាច
ប្រមូល គ្នាមកឯ[ក]ដែនដីគូម៉ូរ៉ា នៅត្រង់ភ្នំមួយ ដែលហៅថា ភ្នំ
គូម៉ូរ៉ា ហើយនៅទីនោះ យើងអាចច្បាំងនឹងពួកគេ ។
៣ ហេតុការណ៍បានកើតឡើងថា ស្ដេចរបស់ពួកសាសន៍
លេមិន បានយល់ព្រមតាមសំណូមពររបស់ខ្ញុំ ។
៤ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានដើរទៅ
ដល់ដែនដីគូម៉ូរ៉ា ហើយយើងបានបោះត្រសាលនៅជុំវិញភ្នំគូម៉ូរ៉ា;
គឺជាទីដីមួយដែលមានទឹកជាច្រើន ទន្លេទាំងឡាយ
និងជ្រោះទាំងឡាយ; ហើយនៅទីនេះ ពួកយើងមានសង្ឃឹមថា
នឹងមានប្រៀបទៅ លើពួកសាសន៍លេមិន ។
៥ ហើយកាលបីរយប៉ែតសិបប្រាំឆ្នាំ បានកន្លងផុតទៅ នោះពួក
យើងបានប្រមូលប្រជាជន ដែលនៅសល់ទាំងប៉ុន្មាន មកកាន់
ដែនដី គូម៉ូរ៉ា ។

១៦ ក លោកុ. ៦:៣; អេធើរ ២:១៥.
ខ ទំនុក. ១:៤.
១៧ ក ស.ប. អ្នកគង្វាលល្អ.
១៨ ក ២ នីហ្វៃ ២៨:២១.
១៩ ក ៣ នីហ្វៃ ២០:២៧–២៨.
២០ ក ៣ នីហ្វៃ ១៦:៨–១២.
ខ ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
២១ ក អេណុស ១:១២–១៨;
មរមន ៩:៣៦–៣៧.
២៣ ក ហេលេ. ១២:៨–១៧.
ខ ៣ នីហ្វៃ ២៦:៣.
២៤ ក មីកា ៥:៨; ៣ នីហ្វៃ ២០:១៥–១៦.
៦ ១ ក ១ នីហ្វៃ ១២:១៩; យ៉ារ៉ុម ១:១០;
អាលម៉ា ៤៥:៩–១៤;
ហេលេ. ១៣:៥–១១.
២ ក អេធើរ ៩:៣.

៦ ហើយហេតុការណ៍បានកើតឡើងថា កាលយើងបានប្រមូល
ប្រជាជនយើងទាំងអស់ចូលគ្នា មកកាន់ដែនដីគូម៉ូរ៉ាហើយ មើលចុះ
ខ្ញុំមរមន បានចាប់ផ្ដើមមានវ័យចាស់; ហើយដោយដឹងថា នេះជា
ការតស៊ូចុងក្រោយបំផុតរបស់ប្រជាជនខ្ញុំ ហើយដោយបាន
ទទួលបញ្ជា ពីព្រះអម្ចាស់ថា ខ្ញុំពុំត្រូវទុកឲ្យបញ្ជីដ៏ពិសិដ្ឋទាំង
ឡាយ ហើយដែលបានទុកបន្តមក តាំងពីជំនាន់ពួកអយ្យកោយើង
ធ្លាក់ទៅក្នុងកណ្ដាប់ ដៃនៃពួកសាសន៍លេមិនឡើយ (ព្រោះពួក
សាសន៍លេមិននឹងបំផ្លាញវត្ថុទាំងនោះចោល) ហេតុដូច្នេះហើយ
ខ្ញុំបានធ្វើបញ្ជី[ក]នេះចេញពី ផ្ទាំងនីហ្វៃ ហើយ[ខ]បានលាក់នៅ
ក្នុងភ្នំគូម៉ូរ៉ា នូវបញ្ជីទាំងអស់ ដែលបានប្រគល់មកដល់ខ្ញុំ[គ] ដោយ
ព្រះហស្តនៃព្រះអម្ចាស់ លើកលែងតែ ផ្ទាំងទាំងប៉ុន្មាននេះ ដែល
ខ្ញុំឲ្យទៅកូនប្រុសខ្ញុំ គឺ[ឃ]ម៉ូរ៉ូណៃ ។
៧ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនរបស់ខ្ញុំ ជា
មួយនឹងប្រពន្ធរបស់គេ និងកូនចៅរបស់គេ ឥឡូវនេះ បាន
ឈរមើល [ក]ពលទ័ពរបស់ពួកសាសន៍លេមិន ដើរសំដៅមករកគេ;
ហើយដោយសេចក្ដីភិតភ័យចំពោះសេចក្ដីស្លាប់ ដែលមាន
ពោរពេញនៅក្នុង ទ្រូងនៃពួកទុច្ចរិតទាំងអស់ នោះពួកគេបាន
រង់ចាំពួកលេមិន ។
៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានមកច្បាំងនឹង
ពួកយើង ហើយមនុស្សគ្រប់រូបបានពោរពេញទៅដោយការតក់ស្លុត
ពីព្រោះមកពីពួកលេមិនមានចំនួនច្រើនលើសលប់ ។
៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេវាយសម្រុកមក
លើប្រជាជនខ្ញុំដោយដាវ និងដោយធ្នូ និងដោយព្រួញ និងដោយ
ពូថៅ និងដោយអស់ទាំងគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមគ្រប់
បែបយ៉ាង ។
១០ ហើយហេតុការណ៍បានកើតឡើងថា ទ័ពរបស់ខ្ញុំត្រូវ
កាប់រំលំ មែនហើយ ទាំងមនុស្សចំនួនមួយម៉ឺននាក់ ដែលនៅជា
មួយនឹងខ្ញុំ ហើយខ្ញុំត្រូវរបួសដួលចុះ នៅកណ្ដាលហ្វូងមនុស្ស;
ហើយពួកគេបានដើរបង្ហួសខ្ញុំទៅ ដោយពុំបានផ្ដាច់ជីវិតខ្ញុំឡើយ ។
១១ ហើយកាលពួកគេបានទៅហួស ហើយបានកាប់រំលំប្រជាជន
របស់ខ្ញុំ[ក]ទាំងអស់ លើកលែងតែពួកយើងម្ភៃបួននាក់ប៉ុណ្ណោះ (នៅ
ក្នុងចំណោមនោះ មានកូនប្រុសខ្ញុំឈ្មោះ ម៉ូរ៉ូណៃ) ហើយដោយ
យើងបានរស់ក្នុងចំណោមសាកសពនៃប្រជាជនយើង ដល់ស្អែក
ឡើង ក្នុងកាលពួកលេមិនបានត្រឡប់មកជំរុំពួកគេវិញ ពីលើកំពូល
ភ្នំគូម៉ូរ៉ា នោះយើងបានឃើញប្រជាជនខ្ញុំចំនួនមួយម៉ឺននាក់ ដែល
ត្រូវ កាប់សម្លាប់ ដួលសន្ធឹងនៅពីមុខខ្ញុំ ។
១២ ហើយយើងក៏បានឃើញប្រជាជនខ្ញុំមួយម៉ឺននាក់ ដែលបាន
ដឹកនាំដោយកូនប្រុសខ្ញុំ គឺម៉ូរ៉ូណៃ ។
១៣ ហើយមើលចុះ ទ័ពមួយម៉ឺននាក់របស់គីឌគីឌដូណា បាន
ដួលស្លាប់ រីឯខ្លួនលោកក៏ដួលស្លាប់នៅកណ្ដាលពួកនោះដែរ ។
១៤ ហើយឡាម៉ាបានដួលស្លាប់ ជាមួយនឹងទ័ពមួយ
ម៉ឺននាក់របស់លោក; ហើយគីលកាលបានដួលស្លាប់ ជាមួយនឹង
ទ័ពមួយម៉ឺននាក់ របស់លោក; ហើយលិមហាបានដួលស្លាប់ ជា
មួយនឹងទ័ពមួយម៉ឺននាក់របស់លោក; ហើយយេនើមបានដួលស្លាប់
ជាមួយនឹងទ័ពមួយ ម៉ឺននាក់របស់លោក; ហើយគូមេណៃហា
និងម៉ូរ៉ូណៃហា និងអាន់ទីអូនុម និងស៊ិបឡោម និងសិម
និងយ៉ូស ទាំងអស់នេះបានដួលស្លាប់ ជាមួយនឹងទ័ពមួយ
ម៉ឺននាក់រៀងៗខ្លួន ។
១៥ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្សដប់នាក់ទៀត
ដែលត្រូវដួលស្លាប់ដោយមុខដាវ ជាមួយនឹងទ័ពមួយម៉ឺននាក់
រៀងៗខ្លួន; មែនហើយ ប្រជាជនយើង[ក]ទាំងអស់ត្រូវបានដួលស្លាប់
លើកលែងតែមនុស្សម្ភៃបួននាក់ ដែលនៅជាមួយនឹងខ្ញុំ និងមួយ
ចំនួន តូចដែលបានរត់ភៀសខ្លួន ទៅស្រុកទាំងឡាយភាគខាង
ត្បូង និងមួយចំនួនតូចដែលបានសុំចុះចូលពួកលេមិន; ហើយ
សាច់ និងឆ្អឹង និងឈាមរបស់ពួកគេ ក្រាលនៅលើផ្ទៃផែនដី ត្រូវ
ពួកដែលសម្លាប់គេទុកចោល ឲ្យរលួយនៅលើដី ហើយឲ្យ
បែកធ្លាយ ហើយឲ្យ ត្រឡប់ទៅឯព្រះធរណីវិញ ។
១៦ ហើយព្រលឹងខ្ញុំប្រេះបែកដោយឈឺចាប់ ព្រោះការ
កាប់សម្លាប់នៃប្រជាជនខ្ញុំ ហើយខ្ញុំទ្រហោថា៖
១៧ ឱពួកអ្នកដ៏ស្រស់ល្អអើយ ហេតុអ្វីបានជាអ្នក
បង្វែរចេញពីផ្លូវទាំងឡាយនៃព្រះអម្ចាស់ដូច្នេះ ! ឱពួកអ្នក
ដ៏ស្រស់ល្អអើយ ហេតុអ្វី បានជាអ្នកបដិសេធព្រះយេស៊ូវ ដែល
ទ្រង់បានឈរលាតព្រះពាហុចាំទទួលអ្នកដូច្នេះ ?
១៨ មើលចុះ បើសិនជាអ្នករាល់គ្នាពុំបានធ្វើដូច្នេះទេ នោះអ្នក
រាល់គ្នានឹងពុំបានដួលស្លាប់ឡើយ ។ ប៉ុន្តែមើលចុះ អ្នករាល់គ្នា
បាន ដួលស្លាប់ ហើយខ្ញុំទ្រហោសោក ដោយបាត់បង់អ្នករាល់គ្នា ។
១៩ ឱអ្នករាល់គ្នា ដែលជាកូនប្រុសកូនស្រីដ៏ស្រស់ល្អអើយ
អ្នករាល់គ្នាដែលជាឪពុកម្ដាយ អ្នករាល់គ្នាដែលជាប្ដីប្រពន្ធអ្នក

៦ *ក* ស.ប. ផ្ទាំងទាំងឡាយ.
*ខ* អេធើរ ១៥:១១.
*គ* ព. នៃ ម. ១:២.
*ឃ* មរមន ៨:១.
៧ *ក* ១ នីហ្វៃ ១២:១៥.
១១ *ក* ១ នីហ្វៃ ១២:១៩–២០;
ហេលេ. ១៥:១៧.
១៥ *ក* អាលម៉ា ៩:២៤.

រាល់គ្នា ដ៏ស្រស់ល្អអើយ ហេតុអ្វីក៏អ្នករាល់គ្នាត្រូវដួលស្លាប់
យ៉ាងនេះហ្ន៎!

២០ ប៉ុន្តែមើលចុះ អ្នករាល់គ្នាបានចាកចេញទៅហើយ
ឯសេចក្ដីទុក្ខសោករបស់ខ្ញុំ ពុំអាចនាំអ្នកមកវិញបានទេ ។

២១ ហើយថ្ងៃនោះជិតមកដល់ ក្នុងកាលប្រាណដែលរមែងស្លាប់
របស់អ្នក នឹងត្រូវប្រដាប់ដោយអមតភាពវិញ ហើយរូបកាយទាំង
នេះ ដែលឥឡូវនេះ កំពុងពុករលួយ មិនយូរប៉ុន្មានទេ នឹងក្លាយ
ទៅជារូបកាយទាំងឡាយ ដែល[ក]មិនពុករលួយវិញ; ហើយនៅពេល
នោះ អ្នករាល់គ្នានឹងត្រូវឈរនៅចំពោះវេទិកាជំនុំជំរះនៃព្រះគ្រីស្ទ
ដើម្បីទទួលការជំនុំជំរះ ស្របតាមកិច្ចការទាំងឡាយរបស់អ្នក
ហើយប្រសិនបើអ្នករាល់គ្នាជាមនុស្សសុចរិត ពេលនោះ អ្នកនឹង
បានពរជាមួយនឹងពួកអយ្យកោរបស់អ្នក ដែលបាន
ចាកចេញទៅមុនអ្នក ។

២២ ឱគួរតែអ្នករាល់គ្នាប្រែចិត្ត មុនការបំផ្លិចបំផ្លាញ
ដ៏ធំនេះកើតឡើងដល់អ្នក ។ ប៉ុន្តែមើលចុះ អ្នករាល់គ្នាបាន
ចាកចេញទៅ ហើយ ហើយព្រះវរបិតា មែនហើយ ព្រះវរបិតា
ដ៏នៅអស់កល្បជានិច្ចនៃស្ថានសួគ៌ ទ្រង់ជ្រាបនូវស្ថានភាពរបស់
អ្នក; ហើយទ្រង់នឹងវិនិច្ឆ័យអ្នក ស្របតាម[ក]សេចក្ដីយុត្តិធម៌ និង
[ខ]សេចក្ដីមេត្តាករុណារបស់ទ្រង់ ៕

## ជំពូកទី ៧

*មរមនអញ្ជើញពួកសាសន៍លេមិន នៅថ្ងៃចុងក្រោយ ឲ្យជឿដល់
ព្រះគ្រីស្ទ ទទួលដំណឹងល្អរបស់ទ្រង់ ហើយបានសង្គ្រោះ —
អស់អ្នក ណាដែលជឿដល់ព្រះគម្ពីរប៊ីប នោះនឹងជឿដល់ព្រះ
គម្ពីរមរមនដែរ ។ ប្រមាណជាឆ្នាំ ៣៨៥ គ.ស. ។*

ហើយឥឡូវនេះ មើលចុះ ខ្ញុំចង់និយាយខ្លះដល់
[ក]សំណល់នៃប្រជាជននេះ ដែលបានរួចជីវិត ប្រសិនបើព្រះទ្រង់
អនុញ្ញាតឲ្យពាក្យរបស់ខ្ញុំ បានទៅដល់ពួកគេ ដើម្បីឲ្យពួក
គេដឹងនូវកិច្ចការទាំងឡាយ របស់ពួកអយ្យកោពួកគេ; មែនហើយ
ខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា ដែល ជាសំណល់នៃវង្សអ៊ីស្រាអែល;
ហើយនេះគឺជាពាក្យដែលខ្ញុំនិយាយថា៖

២ ចូរអ្នករាល់គ្នាដឹងថា អ្នករាល់គ្នាជា[ក]វង្សអ៊ីស្រាអែល ។

៣ ចូរអ្នករាល់គ្នាដឹងថា អ្នករាល់គ្នាត្រូវតែប្រែចិត្ត
បើពុំនោះសោតទេ អ្នកនឹងពុំអាចបានសង្គ្រោះឡើយ ។

៤ ចូរអ្នករាល់គ្នាដឹងថា អ្នករាល់គ្នាត្រូវ
ដាក់គ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមចុះ ក៏ពុំត្រូវសប្បាយ នៅ
ក្នុងការខ្ចាយឈាម ហើយពុំត្រូវ កាន់អាវុធវិញឡើយ
លើកលែងតែកាលណាព្រះទ្រង់បញ្ជាដល់អ្នករាល់គ្នាប៉ុណ្ណោះ ។

៥ ចូរអ្នករាល់គ្នាដឹងថា អ្នករាល់គ្នាត្រូវតែ[ក]ស្គាល់ពួក
អយ្យកោរបស់អ្នក ហើយប្រែចិត្តពីអស់ទាំងអំពើបាប និងអំពើ
ទុច្ចរិតរបស់អ្នក ហើយ[ខ]ជឿដល់ព្រះយេស៊ូវគ្រីស្ទ ថាទ្រង់ជាព្រះ
រាជបុត្រានៃព្រះ ហើយថាទ្រង់ត្រូវពួកសាសន៍យូដាធ្វើគុត
ហើយដោយព្រះចេស្ដានៃ ព្រះវរបិតា នោះទ្រង់មានព្រះជន្ម
រស់ឡើងវិញ ដោយហេតុនេះហើយ ទ្រង់មាន[គ]ជ័យជំនះ
លើផ្នូរ; ហើយគឺនៅក្នុងទ្រង់ផង ដែលទ្រនិច នៃសេចក្ដីស្លាប់
បានលេបចូល ។

៦ ហើយទ្រង់បាននាំមក នូវ[ក]ដំណើររស់ឡើងវិញដល់មនុស្ស
ស្លាប់ ដោយហេតុនេះ មនុស្សត្រូវបានប្រោសឲ្យមាន
ជីវិតឡើងវិញ ដើម្បីឈរនៅចំពោះវេទិកា[ខ]ជំនុំជំរះរបស់ទ្រង់ ។

៧ ហើយទ្រង់បាននាំមក នូវ[ក]សេចក្ដីប្រោសលោះដល់ពិភពលោក
ដោយហេតុនេះ អ្នកណាដែលឃើញថា [ខ]ឥតទោសនៅចំពោះទ្រង់
នៅក្នុងថ្ងៃជំនុំជំរះ អ្នកនោះហើយដែលនឹងត្រូវបានអនុញ្ញាតឲ្យ
[គ]រស់នៅក្នុងវត្តមាននៃព្រះ នៅក្នុង[ឃ]នគររបស់ទ្រង់ ដើម្បីច្រៀងដោយ
មិន ឈប់ឈរ ជាមួយនឹងក្រុមចំរៀងនៅស្ថានលើ សរសើរ
ដំកើងដល់ព្រះវរបិតា និងព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ
ដែលជាព្រះ [ង]តែមួយ នៅក្នុងស្ថានភាពមួយ [ច]ដ៏សប្បាយរីករាយ
ហើយគ្មានទីបំផុត ។

---

២១ *ក* ១ កូរិន. ១៥:៥៣–៥៤.
២២ *ក* ស.ប. សេចក្ដីយុត្តិធម៌.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៧ ១ *ក* ហេលេ. ១៥:១១–១៣.
២ *ក* អាលម៉ា ១០:៣.
៥ *ក* ២ នីហ្វៃ ៣:១២.
*ខ* ស.ប. ជំនឿ, ជឿ; សេចក្ដីជំនឿ.
*គ* អេសាយ ២៥:៨; ម៉ូសាយ ១៦:៧–៨.
៦ *ក* ស.ប. ដំណើររស់ឡើងវិញ.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម; សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
៧ *ក* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ខ* ស.ប. ការរាប់ជាសុចរិត, រាប់ជាសុចរិត.
*គ* ១ នីហ្វៃ ១០:២១; គ. និង ស. ៧៦:៦២; ម៉ូសេ ៦:៥៧.
*ឃ* ម៉ូសាយ ២:២៨.
*ង* គ. និង ស. ២០:២៨. ស.ប. ព្រះ, ក្រុមព្រះ.
*ច* ស.ប. សេចក្ដីអំណរ.

៨ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាប្រែចិត្ត ហើយទទួល
បុណ្យជ្រមុជទឹក ដោយនូវព្រះនាមព្រះយេស៊ូវចុះ ហើយកាន់ខ្ជាប់
នូវដំណឹង ល្អនៃព្រះគ្រីស្ទ ដែលនឹងបានបង្ហាញនៅចំពោះមុខអ្នក
ពុំមែនតែនៅក្នុងបញ្ជីនេះទេ តែនៅក្នុងបញ្ជី ដែលនឹងឲ្យដល់ពួក
សាសន៍ដទៃ ពីពួកសាសន៍យូដា ហើយបញ្ជីនោះ នឹងចេញមក
ពីពួកសាសន៍ដទៃ មកដល់អ្នករាល់គ្នា ។
៩ ត្បិតមើលចុះ បញ្ជីនេះបានត្រូវសរសេរឡើង ក្នុងគោលបំណង
ដើម្បីឲ្យអ្នករាល់គ្នាជឿដល់ការណ៍នោះ; ហើយបើសិនជា អ្នក
រាល់គ្នាជឿដល់បញ្ជីនោះ នោះអ្នករាល់គ្នានឹងជឿដល់បញ្ជីនេះដែរ;
ហើយបើសិនជាអ្នកជឿដល់បញ្ជីនេះ នោះអ្នកនឹងដឹងអំពីពួក
អយ្យកោរបស់អ្នក ព្រមទាំងកិច្ចការដ៏អស្ចារ្យទាំងឡាយ ដែល
បានកើតឡើង ដោយព្រះចេស្ដានៃព្រះ នៅក្នុងចំណោមពួកគេ ។
១០ ហើយអ្នករាល់គ្នាក៏នឹងដឹងថា អ្នករាល់គ្នាគឺជាសំណល់
មួយនៃពូជយ៉ាកុប; ហេតុដូច្នេះហើយ អ្នករាល់គ្នានឹងត្រូវបាន
រាប់ក្នុង ចំណោមប្រជាជននៅក្នុងសេចក្ដីសញ្ញាដំបូង;
ហើយបើសិនជាអ្នករាល់គ្នាជឿដល់ព្រះគ្រីស្ទយ៉ាងនោះមែន ហើយ
បានទទួលបុណ្យ ជ្រមុជ ដំបូងដោយទឹក ហើយបន្ទាប់មក
ដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ គឺធ្វើតាមគំរូនៃ
ព្រះអង្គសង្គ្រោះរបស់យើង តាមអ្វីដែលទ្រង់បានបញ្ជាដល់យើង
នោះនឹងបានស្រួលដល់អ្នករាល់គ្នាហើយ នៅក្នុងថ្ងៃជំនុំជំរះ ។
អាម៉ែន ៕

## ជំពូកទី ៨

*ពួកសាសន៍លេមិនស្វែងរកបំផ្លាញពួកសាសន៍នីហ្វៃ — ព្រះគម្ពីរមរមននឹងចេញមកតាមព្រះចេស្ដានៃព្រះ — ការវេទនាទាំងឡាយធ្លាក់ មកលើអស់អ្នកណា ដែលបញ្ចេញកំហឹង និងតំរាមទាស់នឹងកិច្ចការនៃព្រះអម្ចាស់ — បញ្ជីនីហ្វៃនឹងចេញមកនៅក្នុងថ្ងៃមួយដ៏ប្រកបដោយ សេចក្ដីទុច្ចរិត សេចក្ដីអន់ថយ និងសេចក្ដីក្បត់សាសនា ។ ប្រមាណជាឆ្នាំ ៤០០–៤២១ គ.ស. ។*

មើលចុះ ខ្ញុំមរ៉ូណៃ បង្ហើយបញ្ជីរបស់ឪពុកខ្ញុំ គឺមរមន ។ មើលចុះ
ខ្ញុំមានតែការបន្តិចបន្តួចប៉ុណ្ណោះសំរាប់សរសេរ គឺជាការណ៍ទាំង
ឡាយ ដែលឪពុកខ្ញុំបានបញ្ជាដល់ខ្ញុំ ។
២ ហើយឥឡូវនេះ ហេតុការណ៍បានកើតឡើងថា
បន្ទាប់ពីចម្បាំងដ៏ធំ និងខ្លាំងក្លានៅគូម៉ូរ៉ា មើលចុះ ពួក
សាសន៍នីហ្វៃ ដែល បានភៀសខ្លួនទៅឯទិសខាងត្បូង នោះត្រូវ
ពួកសាសន៍លេមិនរកចាប់ រហូតដល់ពួកគេទាំងអស់គ្នាត្រូវបាន
បំផ្លាញចោល ។
៣ ហើយឪពុកខ្ញុំក៏ត្រូវពួកគេសម្លាប់ដែរ ហើយនៅសល់តែខ្ញុំ
ម្នាក់ឯង ដែលសរសេរនូវរឿងដ៏សោកសៅ អំពីការបំផ្លិចបំផ្លាញ
ដល់ប្រជាជនខ្ញុំ ។ ប៉ុន្តែមើលចុះ ពួកគេបានចាកចេញទៅហើយ
ហើយខ្ញុំបំពេញបញ្ជារបស់ឪពុកខ្ញុំ ។ ហើយតើពួកគេនឹងសម្លាប់ខ្ញុំ
ឬអត់ នោះខ្ញុំពុំដឹងទេ ។
៤ ហេតុដូច្នេះហើយ ខ្ញុំនឹងសរសេរ ហើយលាក់បញ្ជី
ទាំងនេះទុកក្នុងដី; ហើយខ្ញុំនឹងទៅឯណាទៀត នោះពុំជាការ
សំខាន់ទេ ។
៥ មើលចុះ ឪពុកខ្ញុំបានធ្វើបញ្ជីនេះ ហើយលោកបានកត់នូវ
គោលបំណងទុកក្នុងនោះ ។ ហើយមើលចុះ ខ្ញុំចង់សរសេរ
ការណ៍ នេះដែរ បើសិនជាខ្ញុំមានកន្លែងនៅក្នុងផ្ទាំងទាំងឡាយ
ប៉ុន្តែខ្ញុំគ្មានទេ; ហើយខ្ញុំគ្មានជាតិលោហធាតុទេ ត្បិតមានតែ
ខ្ញុំម្នាក់ឯង ។ ឪពុកខ្ញុំត្រូវគេសម្លាប់បង់នៅក្នុងចម្បាំង ព្រម
ទាំងសាច់ញាតិរបស់ខ្ញុំទាំងអស់ ហើយខ្ញុំគ្មានមិត្តភក្ដិ ឬទីណា
សំរាប់ទៅឡើយ; ហើយព្រះ ទ្រង់ទ្រាំឲ្យខ្ញុំរស់ ដល់កាលណា
នោះខ្ញុំក៏ពុំដឹងដែរ ។
៦ មើលចុះ បួនរយឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីការយាង
មកនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ។
៧ ហើយមើលចុះ ពួកសាសន៍លេមិនបានដេញតាមប្រជាជន
របស់ខ្ញុំ គឺសាសន៍នីហ្វៃ ពីទីក្រុងមួយទៅទីក្រុងមួយ ហើយពីកន្លែង
មួយ ទៅកន្លែងមួយ គឺរហូតដល់ពួកគេគ្មានសល់មួយសោះ;
ហើយការរលំរបស់គេនោះគឺមហិមាណាស់; មែនហើយ មហិមា
និងអស្ចារ្យ មែន ការបំផ្លិចបំផ្លាញប្រជាជនខ្ញុំ គឺសាសន៍នីហ្វៃ ។
៨ ហើយមើលចុះ នេះគឺជាស្នាដៃនៃព្រះអម្ចាស់ ដែលបានធ្វើ

៨ *ក* ស.ប. ដំណឹងល្អ.
*ខ* ស.ប. ព្រះគម្ពីរប៊ីប.
*គ* ២ នីហ្វៃ ២៩:៤–១៣.
*ឃ* ១ នីហ្វៃ ១៣:៣៨.
៩ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ១ នីហ្វៃ ១៣:៣៨–៤១.
១០ *ក* ២ នីហ្វៃ ៣១:៥–៩.
៨ ១*ក* ស.ប. មរ៉ូណៃ, កូនប្រុសរបស់មរមន.
*ខ* ស.ប. ផ្ទាំងទាំងឡាយ.
២ *ក* មរមន ៦:២–១៥.
*ខ* គ. និង ស. ៣:១៨.
៣ *ក* មរ៉ូណៃ ៩:២២.
៥ *ក* មរមន ២:១៧–១៨.
*ខ* មរមន ៦:៦.
៦ *ក* អាលម៉ា ៤៥:១០.
៧ *ក* ១ នីហ្វៃ ១២:២–៣.

ការនេះ ។ ហើយក៏មើលចុះ ពួកសាសន៍លេមិន បានធ្វើសង្គ្រាមនឹងគ្នា ទៅវិញទៅមក; ហើយនៅលើផ្ទៃដែនដីនេះទាំងមូល មានការកាប់សម្លាប់ ការខ្ចាយឈាម ដ៏ឥតឈប់ឈរ; ហើយគ្មាននរណាដឹងថា កាលណាសង្គ្រាមនឹងចប់ឡើយ ។

៩ ហើយឥឡូវនេះ មើលចុះ ខ្ញុំឈប់និយាយពីពួកគេទៀត ត្បិតគ្មានអ្នកណានៅលើផ្ទៃដែនដីនេះ ក្រៅពីពួកសាសន៍លេមិន និងពួកចោរឡើយ ។

១០ ហើយគ្មាននរណាម្នាក់ស្គាល់ព្រះដ៏ពិតប្រាកដ ក្រៅពីពួកសិស្សនៃព្រះយេស៊ូវប៉ុណ្ណោះ ដែលបាននៅលើដែនដីនេះ រហូតដល់ អំពើទុច្ចរិតរបស់ប្រជាជន មានភាពធ្ងន់ធ្ងរ ដែលព្រះអម្ចាស់ទ្រង់ពុំទ្រាំឲ្យពួកគេ នៅជាមួយនឹងប្រជាជនទៀត; ហើយទោះជាពួកគេ នៅលើផ្ទៃដែនដី ឬអត់ នោះគ្មានអ្នកណាដឹងទេ ។

១១ ប៉ុន្តែមើលចុះ ឪពុកខ្ញុំ និងខ្ញុំបានឃើញពួកគេ ហើយពួកគេបានធ្វើការងារបំរើដល់យើង ។

១២ ហើយអស់អ្នកណាដែលទទួលបញ្ជីនេះ ហើយដែលនឹងមិនថ្កោលទោស ដោយមកពីភាពពុំពេញលេញនៅក្នុងនោះទេ អ្នកនោះហើយដែលនឹងដឹងនូវរឿងដ៏មហិមាលើសលែងទៅទៀត ។ មើលចុះ ខ្ញុំជាមរ៉ូណៃ; ហើយបើមានលទ្ធភាព នោះខ្ញុំនឹងធ្វើឲ្យអ្នករាល់គ្នាដឹងនូវការណ៍ទាំងអស់ ។

១៣ មើលចុះ ខ្ញុំសូមបញ្ចប់នូវការនិយាយអំពីប្រជាជននេះសិនចុះ។ ខ្ញុំជាកូនប្រុសរបស់មរមន ឯឪពុកខ្ញុំ គឺជាពូជពង្សនៃនីហ្វៃ។

១៤ ហើយគឺខ្ញុំនេះហើយដែលបានលាក់បញ្ជីនេះថ្វាយដល់ព្រះអម្ចាស់; ផ្ទាំងទាំងនេះពុំមានតម្លៃអ្វីទេ ដោយមកពីព្រះបញ្ញត្តិនៃព្រះអម្ចាស់; ត្បិតទ្រង់មានព្រះបន្ទូលយ៉ាងប្រាកដថា គ្មានអ្នកណាមួយអាចយកផ្ទាំងទាំងនេះ ដើម្បីស្វែងរកកំរៃឡើ; ប៉ុន្តែបញ្ជីនៅ លើនោះ មានតម្លៃមហិមា; ហើយអស់អ្នកណាដែលនាំបញ្ជីនោះមកឯពន្លឺ អ្នកនោះហើយដែលនោះព្រះអម្ចាស់ទ្រង់នឹងប្រទានពរឲ្យ ។

១៥ ត្បិតគ្មានអ្នកណាមានអំណាចនឹងនាំបញ្ជីនេះមកឯពន្លឺឡើយលើកលែងតែបានប្រទានដល់អ្នកនោះដោយព្រះ; ត្បិតព្រះ ទ្រង់សព្វព្រះហឫទ័យចង់ឲ្យការណ៍នោះ បានធ្វើឡើងដោយភ្នែកស្មោះស្ម័គ្រទាំងស្រុង ចំពោះសិរីល្អរបស់ព្រះអង្គ ឬចំពោះសុខុមាល ភាពដល់ប្រជាជនដែលនៅក្នុងសេចក្ដីសញ្ញានៃព្រះអម្ចាស់ ពីចាស់បុរាណ ដែលត្រូវខ្ចាត់ព្រាត់ដ៏យូរអង្វែង ។

១៦ មានពរហើយ អ្នកណាដែលនាំការណ៍នេះមកឯពន្លឺ; ត្បិតនឹងត្រូវបាននាំពីសេចក្ដីងងឹតមកឯពន្លឺ ស្របតាមព្រះបន្ទូលនៃព្រះ; មែនហើយ គឺនឹងត្រូវបាននាំចេញមកពីក្នុងដី ហើយនឹងចែងចាំងចេញពីសេចក្ដីងងឹត ហើយបានដឹងដល់ប្រជាជន; ហើយការណ៍នេះ នឹងត្រូវបានធ្វើឡើង ដោយព្រះចេស្ដានៃព្រះ ។

១៧ ហើយបើសិនជាមានកំហុសអ្វីសោត កំហុសទាំងនោះគឺជារបស់ផងមនុស្ស; ប៉ុន្តែមើលចុះ យើងពុំស្គាល់នូវកំហុសឡើយ; ប៉ុន្តែព្រះទ្រង់ជ្រាបនូវគ្រប់ការណ៍ទាំងអស់; ហេតុដូច្នេះហើយ អ្នកណាដែលថ្កោលទោស ចូរឲ្យអ្នកនោះប្រយ័ត្នចុះ ក្រែងគេត្រូវធ្លាក់ ទៅក្នុងភ្លើងនរក ។

១៨ ហើយអ្នកណាដែលនិយាយថា៖ ចូរបង្ហាញដល់ខ្ញុំ បើពុំនោះសោតទេ អ្នកនឹងត្រូវវាយ — ចូរឲ្យអ្នកនោះប្រយ័ត្នចុះ ក្រែងបានបញ្ជានូវអ្វី ដែលព្រះអម្ចាស់ទ្រង់បានហាម ។

១៩ ត្បិតមើលចុះ អ្នកណាដែលថ្កោលទោសដោយទ្វេធ្វេស អ្នកនោះហើយដែលនឹងបានទទួលការថ្កោលទោសដោយទ្វេធ្វេសវិញ; ត្បិតស្របតាមឈ្នួលរបស់គេ នោះនឹងបានស្របទៅតាមកិច្ចការរបស់ខ្លួនដែរ; ហេតុដូច្នោះហើយ អ្នកណាដែលវាយគេ នោះនឹងត្រូវ ព្រះអម្ចាស់ទ្រង់វាយវិញ ។

២០ ចូរមើលអ្វីដែលបទគម្ពីរចែងថា — មនុស្សមិនត្រូវវាយ ហើយក៏មិនត្រូវថ្កោលទោសដែរ; ត្បិតការថ្កោលទោស គឺជារបស់ ផងយើង ព្រះអម្ចាស់មានព្រះបន្ទូលថាដូច្នោះ ហើយការសងសឹកក៏ជារបស់ផងយើងដែរ ហើយយើងនឹងសងវិញ ។

២១ ហើយអ្នកណាដែលបញ្ចេញកំហឹង និងគំរាមទាស់នឹងកិច្ចការនៃព្រះអម្ចាស់ ហើយទាស់នឹងរាស្ត្រដែលនៅក្នុងសេចក្ដីសញ្ញានៃ ព្រះអម្ចាស់ គឺជាវង្សអ៊ីស្រាអែល ហើយនឹងនិយាយថា៖ យើងនឹងបំផ្លាញកិច្ចការនៃព្រះអម្ចាស់ចោល ហើយព្រះអម្ចាស់ទ្រង់នឹងពុំនឹកចាំ ដល់សេចក្ដីសញ្ញា ដែលទ្រង់បានធ្វើជា

៨ *ក* ១ នីហ្វៃ ១២:២០–២៣.
៩ *ក* មរមន ២:៨.
១០ *ក* ៣ នីហ្វៃ ២៨:៧; អេធើរ ១២:១៧.
ស.ប. ពួកសិស្សសាសន៍នីហ្វៃបីនាក់.
*ខ* មរមន ១:១៦.
១១ *ក* ៣ នីហ្វៃ ២៨:២៤–២៦.
១២ *ក* ៣ នីហ្វៃ ២៦:៦–១១.
១៣ *ក* ៣ នីហ្វៃ ៥:២០.
១៤ *ក* មរ៉ូណៃ ១០:១–២.
*ខ* យ.ស.—ប្រវត្តិ ១:៤៦.
១៥ *ក* គ. និង ស. ៤:៥.
១៦ *ក* ២ នីហ្វៃ ៣:៦–៧, ១១, ១៣–១៤.
*ខ* អេសាយ ២៩:១៨;
២ នីហ្វៃ ២៧:២៩.
១៧ *ក* មរមន ៩:៣១, ៣៣;
អេធើរ ១២:២៣–២៨.
*ខ* ៣ នីហ្វៃ ២៩:៥; អេធើរ ៤:៨.
១៩ *ក* គ.យ.ស., ម៉ាថាយ ៧:១–២;
៣ នីហ្វៃ ១៤:១–២;
មរ៉ូណៃ ៧:១៤.

មួយនឹងវង្សអ៊ីស្រាអែលឡើយ — អ្នកនោះហើយដែលក្រែង
នឹងត្រូវកាប់រំលំ ហើយបោះចោល ទៅក្នុងភ្លើង ។
២២ ព្រោះ[ក]គោលបំណងទាំងឡាយ ដ៏នៅអស់កល្បជានិច្ចនៃ
ព្រះអម្ចាស់ នឹងដើរទៅមុខ រហូតដល់ពាក្យសន្យាទាំងអស់របស់
ទ្រង់ បានបំពេញ ។
២៣ ចូរពិចារណាមើលពាក្យព្យាករណ៍របស់[ក]លោកអេសាយ
ចុះ ។ មើលចុះ ខ្ញុំពុំអាចកត់នូវពាក្យទាំងនោះបានទេ ។ មែន
ហើយ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ពួកបរិសុទ្ធទាំងនោះ ដែល
បានចាកចេញទៅមុនខ្ញុំហើយ ដែលជាម្ចាស់ដែនដីនេះ គេនឹង
[ខ]ស្រែកឡើង មែនហើយ គេនឹងអំពាវនាវដល់ព្រះ
អម្ចាស់ចេញពីធូលីដីមក; ហើយប្រាកដដូចជាព្រះអម្ចាស់ ទ្រង់
មានព្រះជន្មរស់នៅ នោះទ្រង់នឹង នឹកចាំដល់សេចក្ដីសញ្ញា ដែល
ទ្រង់បានធ្វើជាមួយនឹងពួកគេ ។
២៤ ហើយទ្រង់ជ្រាបនូវពាក្យអធិស្ឋានទាំងឡាយរបស់ពួកគេ
ថាពួកគេបាន[ក]អធិស្ឋានឲ្យពួកបងប្អូនរបស់គេ ។ ហើយទ្រង់ ជ្រាប
នូវសេចក្ដីជំនឿរបស់ពួកគេ ត្បិតដោយនូវព្រះនាមទ្រង់ នោះ
ពួកគេអាច[ខ]រើភ្នំ; ហើយដោយនូវព្រះនាមទ្រង់ នោះពួកគេ
អាចធ្វើឲ្យ ផែនដីកក្រើក; ហើយដោយព្រះចេស្ដានៃព្រះបន្ទូល
របស់ទ្រង់ នោះពួកគេអាចធ្វើឲ្យ[គ]គុកទាំងឡាយរលំទៅលើដី;
មែនហើយ សូម្បីតែ ឡភ្លើង ក៏ពុំអាចបៀតបៀនពួកគេបានដែរ
សូម្បីតែសត្វសាហាវ ឬពស់អាសិរពិសក៏ដូច្នោះដែរ គឺមក
ពីព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ ។
២៥ ហើយមើលចុះ ពាក្យអធិស្ឋានទាំងឡាយរបស់ពួក
គេក៏មានដល់អ្នកនោះ ដែលព្រះអម្ចាស់ទ្រង់ចាត់ឲ្យនាំការណ៍
ទាំងនេះ ចេញមក ។
២៦ ហើយពុំបាច់នរណានិយាយថា ការណ៍ទាំងនេះ នឹង
ពុំកើតឡើងឡើយ ព្រោះការណ៍ទាំងនេះ ប្រាកដជា
នឹងកើតឡើងមែន ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ;
ត្បិតការណ៍ទាំងនោះនឹង[ក]ចេញមកពីដី ដោយព្រះហស្តនៃព្រះ
អម្ចាស់ ហើយគ្មាននរណា អាចរារាំងបានឡើយ; ហើយការណ៍
នោះនឹងកើតឡើង នៅក្នុងថ្ងៃណាមួយ ដែលគេនិយាយថា គ្មាន
[ខ]អព្ភូតហេតុទៀតទេ; ហើយនឹង កើតឡើង បីដូចជាមនុស្ស
និយាយចេញពី[គ]ស្លាប់មក ។
២៧ ហើយនឹងកើតឡើងនៅក្នុងថ្ងៃណាមួយ ដែល[ក]ឈាម
របស់ពួកបរិសុទ្ធនឹងអំពាវនាវដល់ព្រះអម្ចាស់ ពីព្រោះមក
ពី[ខ]បក្សពួកសម្ងាត់ និងកិច្ចការទាំងឡាយនៃសេចក្ដីងងឹត ។
២៨ មែនហើយ គឺនឹងកើតឡើងនៅក្នុងថ្ងៃណាមួយ កាល
ព្រះចេស្ដានៃព្រះនឹងត្រូវគេបដិសេធ ហើយ[ក]សាសនាចក្រទាំង
ឡាយក្លាយ ទៅជាខូច ហើយលើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃ
ចិត្តរបស់គេ; មែនហើយ គឺនៅក្នុងថ្ងៃណាមួយ កាលពួកអ្នក
ដឹកនាំសាសនាចក្រទាំង ឡាយ និងពួកគ្រូបង្រៀននឹងលើកខ្លួនឡើង
នៅក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់ខ្លួន គឺរហូតដល់មានការឈ្នានីស
គ្នា រវាងអ្នកដែលនៅក្នុង សាសនាចក្រជាមួយគ្នា ។
២៩ មែនហើយ គឺនឹងកើតឡើងនៅក្នុងថ្ងៃណាមួយ [ក]កាល
គេឮអំពីភ្លើងឆេះ និងព្យុះសង្ឃរា និង[ខ]ចំហាយផ្សែងនៅឯប្រទេសក្រៅ
ទាំងឡាយ;
៣០ ហើយក៏នឹងឮអំពី[ក]សង្គ្រាម ពាក្យចចាមអារាមអំពី
សង្គ្រាម និងផែនដីរញ្ជួយនៅកន្លែងផ្សេងៗ ។
៣១ មែនហើយ [ក]គឺនឹងកើតឡើងនៅក្នុងថ្ងៃណាមួយ កាល
មានការស្មោកគ្រោកជាខ្លាំង នៅលើផ្ទៃផែនដី; ហើយនឹងមានការ
កាប់ សម្លាប់ និងការប្លន់ និងការភូតកុហក និងការបោកបញ្ឆោត
និងអំពើសហាយស្មន់ និងអំពើគួរខ្ពើមឆ្អើមគ្រប់បែបយ៉ាង;
នៅពេលនោះ នឹងមានមនុស្សជាច្រើននិយាយថា ធ្វើយ៉ាងនេះ
ឬធ្វើយ៉ាងនោះ ហើយគឺគ្មានជាការអ្វីទេ ត្បិតព្រះអម្ចាស់ទ្រង់នឹង

២២ *ក* គ. និង ស. ៣:៣.
២៣ *ក* ៣ នីហ្វៃ ២០:១១; ២៣:១.
*ខ* អេសាយ ២៩:៤;
២ នីហ្វៃ ៣:១៩–២០; ២៦:១៦.
២៤ *ក* អេណុស ១:១២–១៨;
មរមន ៩:៣៦;
គ. និង ស. ១០:៤៦.
*ខ* យ៉ាកុប ៤:៦;
ហេលេ. ១០:៩.
*គ* អាលម៉ា ១៤:២៧–២៩.
២៥ *ក* មរមន ៥:២១.
២៦ *ក* អេសាយ ២៩:៤;
២ នីហ្វៃ ៣៣:១៣.
*ខ* មរមន ៩:១៥–២៦;
ម៉ូរ៉ូណៃ ៧:២៧–២៩, ៣៣–៣៧.
*គ* ២ នីហ្វៃ ២៦:១៥–១៦;
មរមន ៩:៣០;
ម៉ូរ៉ូណៃ ១០:២៧.
២៧ *ក* អេធើរ ៨:២២–២៤;
គ. និង ស. ៨៧:៦–៧.
*ខ* ស.ប. បក្សពួកសម្ងាត់.
២៨ *ក* ២ ធីម៉ូ. ៣:១–៧;
១ នីហ្វៃ ១៤:៩–១០;
២ នីហ្វៃ ២៨:៣–៣២;
គ. និង ស. ៣៣:៤.
២៩ *ក* យ៉ូអែល ២:២៨–៣២;
២ នីហ្វៃ ២៧:២–៣.
*ខ* ១ នីហ្វៃ ១៩:១១;
គ. និង ស. ៤៥:៣៩–៤២.
៣០ *ក* ម៉ាថាយ ២៤:៦;
១ នីហ្វៃ ១៤:១៥–១៧.
៣១ *ក* ២ នីហ្វៃ ២៨:២១–២២.

[ខ]ជួយគាំទ្រដល់ ការណ៍នោះ នៅថ្ងៃចុងក្រោយបង្អស់ ។ [គ]ប៉ុន្តែ
វេទនាដល់អ្នកទាំងនោះ ត្បិតគេកំពុងតែស្ថិតនៅក្នុងប្រមាត់
ល្វីងជូរចត់ និងនៅក្នុង ចំណងនៃអំពើទុច្ចរិត ។
៣២ មែនហើយ គឺនឹងកើតឡើងនៅក្នុងថ្ងៃណាមួយ កាល
មានសាសនាចក្រជាច្រើន បានត្រូវតាំងឡើង ដែលនឹងនិយាយ
ថាៈ ចូរមកខាងខ្ញុំ ហើយដោយទឹកប្រាក់របស់អ្នក នោះអ្នកនឹង
ត្រូវបានអភ័យទោសដល់អំពើបាបទាំងឡាយរបស់អ្នក ។
៣៣ ឱអ្នករាល់គ្នា ដែលជាពួកទុច្ចរិត និងខូច ហើយ
រឹងទទឹងអើយ ហេតុអ្វី[ក]បានជាអ្នករាល់គ្នា បង្កើតសាសនាចក្រ
ទាំងឡាយឡើង ដើម្បីរកកំរៃផ្ទាល់ខ្លួន ? ហេតុអ្វីបានជាអ្នករាល់
គ្នា [ខ]ផ្លាស់ប្រែព្រះបន្ទូលដ៏ពិសិដ្ឋនៃព្រះ ដើម្បីអ្នកអាចនាំមកនូវ
[គ]សេចក្ដីផាប់ទោសមកលើ ព្រលឹងរបស់អ្នកដូច្នេះ ? មើលចុះ
ចូរអ្នកសង្កេតមើលវិវរណៈនៃព្រះ; ត្បិតមើលចុះ នឹងដល់ថ្ងៃមួយ
កាលការណ៍អស់ទាំងនេះនឹងត្រូវ បានបំពេញ ។
៣៤ មើលចុះ ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ខ្ញុំ នូវ
ការណ៍ដ៏ធំ ហើយអស្ចារ្យទាំងឡាយ អំពីអ្វីដែលត្រូវមកដល់
នៅពេលយ៉ាងខ្លីៗ នៅក្នុងថ្ងៃដែលការណ៍ទាំងនេះនឹងកើតឡើង
នៅក្នុងចំណោមពួកអ្នក ។
៣៥ មើលចុះ ខ្ញុំនិយាយទៅកាន់អ្នករាល់គ្នា ហាក់បីដូចជា
អ្នករាល់គ្នានៅទីនេះ ប៉ុន្តែអ្នករាល់គ្នាពុំនៅទីនេះទេ; ប៉ុន្តែ
មើលចុះ ព្រះយេស៊ូវគ្រីស្ទ ទ្រង់បង្ហាញអ្នករាល់គ្នាដល់ខ្ញុំ ហើយ
ខ្ញុំដឹងនូវអ្វីៗ ដែលអ្នករាល់គ្នាធ្វើ ។
៣៦ ហើយខ្ញុំដឹងថា អ្នករាល់គ្នា[ក]ដើរនៅក្នុងសេចក្ដី[ខ]ឆ្មើងឆ្មៃនៃ
ចិតរបស់ខ្លួន; ហើយគ្មានអ្នកណាម្នាក់សោះ លើកលែងតែ
មនុស្សមួយ ចំនួនតូចប៉ុណ្ណោះ ដែលពុំឡើងចាងនៅ
ក្នុងសេចក្ដីឆ្មើងឆ្មៃនៃ[គ]ចិត្តរបស់ខ្លួន រហូតដល់ការពាក់នូវ
ប្រដាប់ស្លៀកពាក់ដ៏វិចិត្រ ហើយដល់ មានការឈ្នានីស និង
ប្រកួតប្រជែង និងកលល្បិច និងការបៀតបៀន និងអំពើទុច្ចរិត
គ្រប់បែបយ៉ាង; ឯសាសនាចក្រទាំងឡាយរបស់ អ្នករាល់គ្នាវិញ
មែនហើយ គឺគ្រប់ទាំងអស់បានក្លាយទៅជាស្អុយក្រខ្វក់ ពីព្រោះ
មកពីសេចក្ដីឆ្មើងឆ្មៃនៃចិត្តរបស់អ្នក ។
៣៧ ត្បិតមើលចុះ អ្នករាល់គ្នា[ក]ស្រឡាញ់ប្រាក់កាស និង
ទ្រព្យសម្បត្តិរបស់ខ្លួន និងប្រដាប់ស្លៀកពាក់ដ៏វិចិត្ររបស់ខ្លួន
ហើយចូល ចិត្តតុបតែងសាសនាចក្រទាំងឡាយរបស់អ្នករាល់
គ្នា ជាជាងស្រឡាញ់អ្នកក្រីក្រ និងអ្នកកំសត់ទុគ៌ត អ្នកឈឺ និង
អ្នកដែលរងទុក្ខវេទនា ។
៣៨ ឱមនុស្សស្អុយក្រខ្វក់ មនុស្សលាក់ពុត និងពួកគ្រូ ដែល
បានលក់ខ្លួនឲ្យអំពើអបាយមុខអើយ ហេតុអ្វីក៏អ្នករាល់គ្នា ធ្វើឲ្យ
សាសនាចក្រដ៏បរិសុទ្ធនៃព្រះក្រខ្វក់ដូច្នេះ ? ហេតុអ្វីក៏អ្នករាល់
[ក]គ្នាខ្មាស់អៀននឹងលើកដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ ?
ហេតុអ្វីក៏អ្នករាល់គ្នា ពុំគិតដល់[ខ]តម្លៃដ៏ធំនៃសុភមង្គលដែល
មិនចេះចប់មិនចេះហើយ ជាងសេចក្ដីវេទនា ដែលពុំអាច
សះស្បើយ — [គ]ពីព្រោះមកពីការសរសើរខាងឯលោកិយឬ ?
៣៩ ហេតុអ្វីក៏អ្នករាល់គ្នាតុបតែងខ្លួន ដោយអ្វីដែលគ្មាន
ជីវិត តែទុកឲ្យពួកអ្នកអត់ឃ្លាន និងអ្នកកំសត់ទុគ៌ត និងអ្នក
អាក្រាត និងអ្នកឈឺ និងអ្នកដែលរងទុក្ខវេទនាដើរទៅហួស
ដោយពុំយកចិត្តទុកដាក់ដល់ពួកគេដូច្នេះ ?
៤០ មែនហើយ ហេតុអ្វីបានជាអ្នករាល់គ្នា បង្កើតអំពើ
គួរខ្ពើមឆ្អើម[ក]ដ៏សម្ងាត់ទាំងឡាយ ដើម្បីរកកំរៃ ហើយទុកឲ្យស្រី
មេម៉ាយទាំង ឡាយ ទួញសោកនៅខាងមុខព្រះអម្ចាស់ ហើយ
ទុកឲ្យពួកក្មេងកំព្រាទួញសោក នៅខាងមុខព្រះអម្ចាស់ ហើយ
ទុកឲ្យឈាមរបស់ ឪពុកពួកគេ និងប្ដីរបស់ពួកគេ អំពាវនាវដល់
ព្រះអម្ចាស់ចេញពីដីមក សូមឲ្យមានការសងសឹកដល់ក្បាល
អ្នករាល់គ្នា ?
៤១ មើលចុះ ដាវនៃការសងសឹក ព្យួរនៅខាងលើពួកអ្នក
រាល់គ្នា; ហើយពេលវេលានឹងមកដល់ ក្នុងពេលឆាប់ៗនេះ ថា
[ក]ទ្រង់នឹងសង សឹកឈាមនៃពួកបរិសុទ្ធ មកលើអ្នករាល់គ្នា
ត្បិតទ្រង់ពុំអាចទ្រាំនឹងការអំពាវនាវ របស់ពួកគេតទៅទៀតទេ ៕

## ជំពូកទី ៩

*មូរ៉ូណៃហៅពួកអ្នកដែលមិនជឿដល់ព្រះគ្រីស្ទឲ្យប្រែចិត្ត — លោកប្រកាសអំពីព្រះនៃអព្ភូតហេតុ ដែលប្រទានវិវរណៈទាំងឡាយ ហើយស្រោចអំណោយទានទាំងឡាយ និងទីសំគាល់*

៣១ *ខ* ២ នីហ្វៃ ២៨:៨.
*គ* អាលម៉ា ៤១:១១.
៣៣ *ក* ស.ប. ឧបាយកលផ្នែកសង្ឃ.
*ខ* ១ នីហ្វៃ ១៣:២៦–២៩.
*គ* ស.ប. សេចក្ដីផាប់ទោស.
៣៦ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* យ៉ាកុប ២:១៣.
*គ* អាលម៉ា ៥:៥៣.
៣៧ *ក* ២ នីហ្វៃ ២៨:៩–១៦.
៣៨ *ក* រ៉ូម ១:១៦; ២ ធីម៉ូ. ១:៨; ១ នីហ្វៃ ៨:២៥–២៨; អាលម៉ា ៤៦:២១.
*ខ* ម៉ូសាយ ៣:២៥.
*គ* ១ នីហ្វៃ ១៣:៩.
៤០ *ក* ស.ប. បក្សព័ន្ធសម្ងាត់.
៤១ *ក* ១ នីហ្វៃ ២២:១៤.

*ទាំងឡាយ មកលើពួកអ្នកស្មោះត្រង់ — អព្ភូតហេតុឈប់មាន ដោយសារ ការឥតជំនឿ — ទីសំគាល់ទាំងឡាយ ទៅតាមពួកអ្នកដែលជឿ — មនុស្សត្រូវបានទូន្មានឲ្យមានប្រាជ្ញា ហើយកាន់តាមព្រះបញ្ញត្តិ ទាំងឡាយ ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស.។*

ហើយឥឡូវនេះ ខ្ញុំនិយាយទៀតអំពីអ្នកទាំងឡាយ ដែលពុំជឿដល់ព្រះគ្រីស្ទ ។
២ មើលចុះ តើអ្នករាល់គ្នាជឿដល់ថ្ងៃពិនិត្យពិច័យរបស់អ្នកឬ—មើលចុះ គឺនៅពេលដែលព្រះអម្ចាស់ទ្រង់នឹងយាងមក មែនហើយ នៅថ្ងៃដ៏ធំនោះ នៅពេលដែលផែនដីនឹងមូរចូលគ្នា ដូចមូរក្រដាស ហើយវត្ថុធាតុទាំងឡាយនឹងរលាយដោយកំដៅដ៏អស្ចារ្យ មែនហើយ នៅថ្ងៃដ៏ធំនោះ អ្នករាល់គ្នានឹងត្រូវបាននាំទៅឈរខាងមុខកូនចៀមនៃព្រះ — នៅពេលនោះ តើអ្នករាល់គ្នានឹងនិយាយថា ពុំមានព្រះឬអី ?
៣ នៅពេលនោះ តើអ្នករាល់គ្នានៅតែបដិសេធព្រះគ្រីស្ទ ឬក៏តើអ្នករាល់គ្នាអាចសម្លឹងមើលទៅកូនចៀមនៃព្រះបានឬទេ ? តើអ្នករាល់គ្នាគិតស្មានថា អ្នករាល់គ្នានឹងនៅជាមួយនឹងព្រះ ដោយមានការដឹងនូវទោសរបស់ខ្លួនឬ ? តើអ្នករាល់គ្នាគិតស្មានថា អ្នករាល់គ្នាអាចសប្បាយរីករាយ ហើយរស់នៅជាមួយនឹងតួអង្គដ៏បរិសុទ្ធនោះ នៅពេលព្រលឹងរបស់អ្នកត្រូវញាំញី ដោយការដឹងនូវ ទោស ដែលអ្នករាល់គ្នាធ្លាប់បានរំលងក្រិត្យវិន័យរបស់ទ្រង់ឬ ?
៤ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា បើអ្នករាល់គ្នារស់នៅជាមួយនឹងព្រះដ៏បរិសុទ្ធ ហើយយុត្តិធម៌ ដោយមានការដឹងនូវអំពើស្មោកគ្រោក របស់ខ្លួន នៅចំពោះទ្រង់ នោះអ្នករាល់គ្នាវេទនាច្រើនជាងរស់នៅជាមួយនឹងពួកជាប់ទោស នៅក្នុងស្ថាននរកទៅទៀត ។
៥ ត្បិតមើលចុះ កាលណាអ្នករាល់គ្នា ត្រូវបាននាំទៅមើលឃើញភាពអាក្រាតរបស់ខ្លួននៅចំពោះព្រះ ហើយឃើញសិរីល្អនៃ ព្រះផង និងបរិសុទ្ធភាពនៃព្រះយេស៊ូវគ្រីស្ទ ពេលនោះអណ្ដាតភ្លើងមួយដែលឥតរំលត់បាន នឹងត្រូវបង្កាត់ឡើងនៅក្នុងខ្លួនអ្នករាល់គ្នា ។
៦ ដូច្នេះ ឱអ្នកទាំងឡាយដែលពុំជឿអើយ ចូរអ្នកបែរមករកព្រះអម្ចាស់ចុះ; ចូរអំពាវនាវដោយអស់ពីពលំដល់ ព្រះវរបិតា ដោយនូវព្រះនាមព្រះយេស៊ូវ ដើម្បីក្រែងអ្នករាល់គ្នាអាចបានឃើញថា គ្មានទោស បានបរិសុទ្ធ ស្រស់ល្អ ហើយសដោយត្រូវបានជំរះ ដោយឈាមនៃកូនចៀម នៅថ្ងៃដ៏ធំ និងចុងក្រោយបង្អស់នោះ ។
៧ ហើយម៉្យាងទៀត ខ្ញុំសូមប្រាប់អ្នកណា ដែលបដិសេធវិវរណៈទាំងឡាយនៃព្រះ ហើយដែលនិយាយថាឥតមានការណ៍ទាំង នោះឡើយ ថាគ្មានវិវរណៈ ឬការព្យាករណ៍ ឬអំណោយទាន ឬការព្យាបាល ឬការនិយាយដោយភាសា ការបកស្រាយនូវភាសា ទៀតទេ ។
៨ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា អ្នកណាដែលបដិសេធនូវការណ៍ទាំងនេះ នោះពុំស្គាល់នូវដំណឹងល្អនៃព្រះគ្រីស្ទទេ; មែនហើយ គេពុំទាន់បានអានបទគម្ពីរទាំងឡាយឡើយ; បើអ្នកនោះអានក៏ពុំយល់អ្វីដែរ ។
៩ ត្បិតតើពុំមែនពួកយើងបានអានហើយឬអីថា ព្រះនៅតែដដែលទោះពីថ្ងៃម្សិល ថ្ងៃនេះ និងរហូតតទៅ ហើយនៅក្នុងព្រះអង្គគឺគ្មានការប្រែប្រួល ឬក៏គ្មានស្រមោលនៃការផ្លាស់ប្ដូរឬ ?
១០ ហើយឥឡូវនេះ បើសិនជាអ្នករាល់គ្នាគិតស្មានដោយខ្លួនឯង នូវព្រះមួយអង្គដែលប្រែប្រួល ហើយនៅក្នុងព្រះអង្គមានស្រមោលនៃការផ្លាស់ប្ដូរ នោះអ្នករាល់គ្នាបានគិតស្មានដោយខ្លួនឯង នូវព្រះមួយអង្គដែលពុំមែនជាព្រះនៃអព្ភូតហេតុឡើយ ។
១១ ប៉ុន្តែមើលចុះ ខ្ញុំនឹងបង្ហាញដល់អ្នក នូវព្រះនៃអព្ភូតហេតុមួយអង្គ គឺជាព្រះនៃអ័ប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះនៃយ៉ាកុប ហើយដែលជាព្រះតែមួយ ដែលបានបង្កើតផ្ទៃមេឃ និងផែនដី និងអ្វីៗសព្វសារពើនៅលើនោះ ។

៩ ២*ក* ម៉ាឡាគី ៤:៥; ៣ នីហ្វៃ ២៨:៣១.
*ខ* មរមន ៥:២៣;
គ. និង ស. ៦៣:២០–២១.
ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
*គ* អេម៉ុស ៩:១៣; ៣ នីហ្វៃ ២៦:៣.
៤ *ក* ស.ប. សេចក្ដីជាប់ទោស.
*ខ* ស.ប. ស្ថាននរក.
៥ *ក* ២ នីហ្វៃ ៩:១៤.
៦ *ក* ស.ប. ការឥតជំនឿ.
*ខ* អេសេ. ១៨:២៣, ៣២;
គ. និង ស. ៩៨:៤៧.
*គ* ស.ប. សុទ្ធ, សុទ្ធសាធ.
*ឃ* ស.ប. កូនចៀមនៃព្រះ.
៧ *ក* ៣ នីហ្វៃ ២៩:៦–៧.
*ខ* ១ កូរិន. ១២:៧–១០;
ម. នៃ ស. ១:៧.
៨ *ក* ស.ប. ដំណឹងល្អ.
*ខ* ម៉ាថាយ ២២:២៩.
៩ *ក* ហេព្រើរ ១៣:៨;
១ នីហ្វៃ ១០:១៨–១៩;
អាលម៉ា ៧:២០; មរ៉ូណៃ ៨:១៨;
គ. និង ស. ២០:១២.
១១ *ក* លោកុ. ១:១;
ម៉ូសាយ ៤:២;
គ. និង ស. ៧៦:២០–២៤.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.

១២ មើលចុះ ទ្រង់បានបង្កើត[ក]លោកអ័ដាម ហើយដោយ
សារលោកអ័ដាម ទើបមានការ[ខ]ធ្លាក់នៃមនុស្ស ។ ហើយដោយ
សារ ការធ្លាក់នៃមនុស្ស ទើបព្រះយេស៊ូវគ្រីស្ទទ្រង់បានយាងមក
គឺជាព្រះវរបិតា និងព្រះរាជបុត្រា; ហើយដោយ
សារព្រះយេស៊ូវគ្រីស្ទ ទើបមាន[គ]សេចក្ដីប្រោសលោះដល់មនុស្ស ។
១៣ ហើយដោយសារសេចក្ដីប្រោសលោះដល់មនុស្ស ដែល
ព្រះយេស៊ូវគ្រីស្ទបាននាំមក ទើបពួកគេត្រូវបាននាំទៅឯវត្តមាននៃ
ព្រះអម្ចាស់វិញ; មែនហើយ គឺតាមរបៀបនេះហើយ ដែលមនុស្ស
ទាំងអស់ត្រូវបានប្រោសលោះ ពីព្រោះសេចក្ដីសុគតនៃព្រះគ្រីស្ទ
នាំឲ្យ មានដំណើរ[ក]រស់ឡើងវិញ ដែលនាំមកនូវសេចក្ដីប្រោសលោះ
[ខ]ពីដំណេកលង់លក់ដ៏មិនចេះចប់មិនចេះហើយ ឯមនុស្សទាំងអស់
នឹងត្រូវ បានដាស់ឲ្យភ្ញាក់ពីដំណេកដ៏លង់លក់នេះ ដោយ
ព្រះចេស្ដានៃព្រះ នៅពេលដែលសម្លេងត្រែបន្លឺឡើង; ហើយពួក
គេនឹងចេញមកទាំង តូចទាំងធំ ហើយទាំងអស់គ្នា នឹងឈរនៅ
ខាងមុខវេទិការបស់ទ្រង់ ដោយបានប្រោសលោះ ហើយ
បានស្រាយ ពី[គ]ចំណងដ៏នៅអស់ កល្បជានិច្ចនៃសេចក្ដីស្លាប់
ឯសេចក្ដីស្លាប់នោះ គឺជាសេចក្ដីស្លាប់ខាងសាច់ឈាម ។
១៤ ហើយនៅពេលនោះ ទើបមាន[ក]សេចក្ដីជំនុំជំរះនៃ
ព្រះដ៏បរិសុទ្ធទៅលើពួកគេ; ហើយនៅពេលនោះ គឺជាពេល
ដែល[ខ]ពួកស្មោក គ្រោកនឹងនៅតែស្មោកគ្រោកដដែល; ឯជនសុចរិត
នឹងនៅតែសុចរិតដដែល; ជនដែលសប្បាយនឹងនៅតែសប្បាយ
ដដែល; ឯជន ដែលពុំសប្បាយនឹងនៅតែពុំសប្បាយដដែល ។
១៥ ហើយឥឡូវនេះ ឱអ្នករាល់គ្នាដែលបានគិតស្មាននូវព្រះ
មួយអង្គ ដែល[ក]ពុំអាចធ្វើនូវអព្ភូតហេតុអើយ ខ្ញុំសូមសួរអ្នកថា អ្វីៗ
ដែលខ្ញុំបាននិយាយនឹងអ្នកទាំងអស់ តើបានកន្លងផុតទៅហើយ
ឬនៅ ? តើចុងបំផុតបានមកដល់ហើយឬនៅ ? មើលចុះ
ខ្ញុំសូមប្រាប់ អ្នកថា នៅទេ; ហើយព្រះទ្រង់ក៏ពុំទាន់ឈប់ទៅជា
ព្រះនៃអព្ភូតហេតុដែរ ។
១៦ មើលចុះ តើការណ៍ទាំងឡាយ ដែលព្រះទ្រង់បានធ្វើនោះ
មិននាំមកនូវការណ៍អស្ចារ្យ ក្នុងភ្នែកអ្នករាល់គ្នាទេឬ ? មែនហើយ
តើនរណាអាចយល់នូវ[ក]កិច្ចការដ៏អស្ចារ្យទាំងឡាយនៃព្រះបាន ?
១៧ តើនរណានឹងនិយាយថា ពុំមែនជាអព្ភូតហេតុទេ ដែល
ផ្ទៃមេឃ និងផែនដីបានកើតឡើង ដោយ[ក]ព្រះបន្ទូលរបស់ទ្រង់;
ហើយ ដោយព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ នោះមនុស្សត្រូវ
បាន[ខ]បង្កើតឡើង[គ]ពីដី; ហើយដោយព្រះចេស្ដានៃព្រះបន្ទូលរបស់
ទ្រង់ នោះអព្ភូតហេតុទាំងឡាយបានកើតឡើង ?
១៨ ហើយតើនរណានឹងនិយាយថា ព្រះយេស៊ូវគ្រីស្ទ ទ្រង់ពុំ
បាន[ក]ធ្វើនូវអព្ភូតហេតុដ៏ច្រើននេះទេ ? ហើយមានអព្ភូតហេតុដ៏ច្រើន
ត្រូវបានធ្វើឡើងដោយដៃនៃពួកសាវក ។
១៩ ហើយបើសិនជាមាន[ក]អព្ភូតហេតុធ្វើឡើងនៅពេលនោះ ហេតុអ្វី
បានជាព្រះទ្រង់ឈប់ទៅជាព្រះនៃអព្ភូតហេតុ តែនៅជាតួអង្គ
មួយដែលពុំចេះប្រែប្រួលនោះ ? ហើយមើលចុះ ខ្ញុំសូមប្រាប់
អ្នកថា ទ្រង់ពុំផ្លាស់ប្ដូរឡើយ; បើសិនជាទ្រង់ចេះផ្លាស់ប្ដូរ
នោះទ្រង់ ឈប់ទៅជាព្រះ ហើយទ្រង់ពុំឈប់ធ្វើជាព្រះទេ ហើយ
ទ្រង់ជាព្រះនៃអព្ភូតហេតុ ។
២០ ហើយហេតុដែលទ្រង់ឈប់ធ្វើនូវ[ក]អព្ភូតហេតុទាំងឡាយ
នៅក្នុងចំណោមកូនចៅមនុស្ស គឺពីព្រោះពួកគេចុះអន់ថយក្នុង
ការ ឥតជំនឿ ហើយឃ្លាតចេញពីផ្លូវត្រូវ ហើយពុំស្គាល់ព្រះ
ដែលគេគួរ[ខ]ទុកចិត្តលើ ។
២១ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា អស់អ្នកណាដែលជឿដល់
ព្រះគ្រីស្ទ ដោយឥតសង្ស័យអ្វី [ក]ទោះអ្វីដែលអ្នកនោះសូមពី
ព្រះវរបិតា ដោយនូវព្រះនាមព្រះគ្រីស្ទ នោះនឹងត្រូវបានប្រទាន
ដល់អ្នកនោះ; ហើយការសន្យានេះ គឺដល់មនុស្សទាំងអស់
រហូតដល់ ចុងផែនដីនេះ ។
២២ ត្បិតមើលចុះ ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ
ទ្រង់មាន[ក]ព្រះបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ ដែលនៅលើផែនដី

---

១២ ក ម៉ូសាយ ៣:២៦.
ខ ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
គ ស.ប. ប្រោសលោះ, បាន ប្រោសលោះ, សេចក្ដីប្រោសលោះ.
១៣ ក ហេលេ. ១៤:១៥–១៨.
ខ គ. និង ស. ៤៣:១៨.
គ គ. និង ស. ១៣៨:១៦.
១៤ ក ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
ខ អាលម៉ា ៧:២១;
គ. និង ស. ៨៨:៣៥.
១៥ ក មរ៉ូណៃ ៧:៣៥–៣៧;
គ. និង ស. ៣៥:៨.
ស.ប. អព្ភូតហេតុ.
១៦ ក ទំនុក. ៤០:៥; គ. និង ស. ៧៦:១១៤;
ម៉ូសេ ១:៣–៥.
១៧ ក យ៉ាកុប ៤:៩.
ខ ស.ប. បង្កបង្កើត, ការបង្កបង្កើត.
គ លោកុ. ២:៧; ម៉ូសាយ ២:២៥.
១៨ ក យ៉ូហាន ៦:១៤.
១៩ ក គ. និង ស. ៦៣:៧–១០.
២០ ក ពួកចៅ. ៦:១១–១៣;
អេធើរ ១២:១២–១៨;
មរ៉ូណៃ ៧:៣៥–៣៧.
ខ ស.ប. ទុកចិត្ត.
២១ ក ម៉ាថាយ ២១:២២;
៣ នីហ្វៃ ១៨:២០.
២២ ក ម៉ាកុស ១៦:១៥–១៦.
ស.ប. កិច្ចការផ្សាយសាសនា.

មែនហើយ ហើយដល់សិស្សទាំងអស់របស់ទ្រង់ផង ដើម្បីឲ្យ
បណ្តាជនជាច្រើនបានឮថា៖ ចូរអ្នករាល់គ្នាទៅគ្រប់ទីកន្លែងក្នុង
លោកិយ ហើយផ្សាយដំណឹងល្អដល់សត្វលោកគ្រប់រូប ។

២៣ ឯអ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះ
នឹងបានសង្គ្រោះ ប៉ុន្តែអ្នកណាដែលពុំជឿ នោះនឹងត្រូវ
[ក]ជាប់ទោសវិញ ។

២៤ ហើយ[ក]ទីសំគាល់ទាំងនេះ នឹងមកតាមអ្នកដែលជឿ —
ដោយនូវនាមយើង ពួកគេនឹង[ខ]បណ្តេញពួកអារក្សចេញ; ពួកគេ
នឹង និយាយដោយភាសាថ្មី; ពួកគេនឹងចាប់ពស់; ហើយបើ
សិនជាពួកគេផឹកនូវអ្វីៗដែលពុល នោះពួកគេនឹងពុំមាន
អន្តរាយសោះ; ពួកគេ នឹង[គ]ដាក់ដៃលើអ្នកឈឺ ហើយគេនឹងជា
សះស្បើយ;

២៥ ហើយអស់អ្នកណាដែលនឹងជឿដល់នាមយើង
ដោយឥតសង្ស័យអ្វី នោះយើងនឹង[ក]បញ្ជាក់ពាក្យរបស់យើងទាំង
អស់ដល់អ្នក នោះ រហូតដល់ចុងផែនដី ។

២៦ ហើយឥឡូវនេះ មើលចុះ តើអ្នកណានឹងឈរទាស់នឹង
កិច្ចការនៃព្រះអម្ចាស់បាន ? តើអ្នកណានឹង[ក]បដិសេធព្រះបន្ទូល
របស់ទ្រង់ ? តើអ្នកណានឹងបះបោរទាស់នឹងព្រះចេស្តាដ៏ធំបំផុត
នៃព្រះអម្ចាស់ ? តើអ្នកណានឹង[ខ]មើលងាយកិច្ចការនៃព្រះអម្ចាស់ ?
តើអ្នកណា នឹងមើលងាយកូនចៅនៃព្រះគ្រីស្ទ ? មើលចុះ អ្នក
ទាំងអស់គ្នា ដែលជាអ្នកមើលងាយដល់កិច្ចការនៃព្រះអម្ចាស់
ត្បិតអ្នករាល់គ្នានឹងភ្ញាក់ ផ្អើល ហើយវិនាសទៅ ។

២៧ បើដូច្នោះ ចូរកុំមើលងាយ ហើយកុំឆ្ងល់ឡើយ
តែចូរប្រុងស្តាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ចុះ ហើយចូរសូម
ដល់ ព្រះវរបិតា ដោយនូវព្រះនាមព្រះយេស៊ូវ នូវអ្វីៗដែលអ្នក
ត្រូវការចុះ ។ ចូរកុំសង្ស័យឡើយ តែចូរជឿ ហើយចាប់ផ្តើមដូច
កាល ជំនាន់ចាស់ ហើយ[ក]មករកព្រះអម្ចាស់ដោយអស់ពី[ខ]ដួងចិត្ត
ចុះ ហើយចូរ[គ]បង្ហើយសេចក្តីសង្គ្រោះរបស់ខ្លួនផ្ទាល់ ដោយមាន
ការកោតខ្លាច និងញាប់ញ័រ នៅចំពោះព្រះអង្គ ។

២៨ ចូរមាន[ក]ប្រាជ្ញា នៅក្នុងថ្ងៃទាំងឡាយ នៃការសាកល្បង
របស់អ្នកចុះ; ចូរគ្រលាស់ចេញពីខ្លួន នូវអំពើពុំស្អាតស្អំទាំងអស់;
ចូរកុំ សូមនូវអ្វីៗដែលអ្នករាល់គ្នាអាចយកមក[ខ]បំរើការសំរើប
របស់អ្នកឡើយ ប៉ុន្តែចូរសូមដោយភាពរឹងប៉ឹង មិនវេរវៀរ
ដើម្បីកុំឲ្យអ្នក បណ្តោយទៅតាមសេចក្តីល្បួង ប៉ុន្តែដើម្បីឲ្យអ្នក
រាល់គ្នាបំរើព្រះដ៏ពិត និងដ៏មាន[គ]ព្រះជន្មរស់វិញ ។

២៩ ចូរឲ្យឃើញថា អ្នករាល់គ្នាពុំទទួលបុណ្យជ្រមុជទឹកដោយ
[ក]មិនសក្តិសមឡើយ; ចូរឲ្យឃើញថា អ្នករាល់គ្នាពុំទទួលទាននូវ
បុណ្យរំឭកពីព្រះគ្រីស្ទ ដោយ[ខ]មិនសក្តិសមឡើយ; ប៉ុន្តែចូរឲ្យ
ឃើញថា អ្នករាល់គ្នាធ្វើនូវគ្រប់ការណ៍ទាំងអស់ [គ]ក្នុងភាព
សក្តិសម ហើយធ្វើការនោះ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ
គឺជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ; ហើយបើសិនជា
អ្នករាល់គ្នា ធ្វើដូច្នេះ ហើយកាន់ខ្ជាប់ ដរាបដល់ចុងបំផុត នោះ
អ្នករាល់គ្នានឹងពុំត្រូវបានបណ្តេញចេញឡើយ ។

៣០ មើលចុះ ខ្ញុំនិយាយទៅកាន់អ្នក ហាក់បីដូចខ្ញុំ[ក]និយាយ
ពីស្លាប់; ត្បិតខ្ញុំដឹងថា អ្នករាល់គ្នានឹងឮពាក្យរបស់ខ្ញុំ ។

៣១ ចូរកុំថ្កោលទោសខ្ញុំ ពីព្រោះមកពី[ក]ភាពមិនល្អឥតខ្ចោះ
របស់ខ្ញុំ ឬក៏ឪពុកខ្ញុំ ពីព្រោះមកពីភាពមិនល្អឥតខ្ចោះរបស់លោក
ឬក៏ពួកគេដែលបានសរសេរមុនឪពុកខ្ញុំឡើយ; ប៉ុន្តែចូរថ្លែងអំណរគុណ
ដល់ព្រះវិញ ដែលទ្រង់បានសម្តែងឲ្យអ្នកឃើញ នូវការឆ្គាំឆ្គង
របស់ពួកយើង ដើម្បីឲ្យអ្នករាល់គ្នាអាចរៀន ឲ្យមានប្រាជ្ញា
ជាងយើងទៅទៀត ។

៣២ ហើយឥឡូវនេះ មើលចុះ យើងបានសរសេរបញ្ជីនេះ
ស្របតាមការចេះដឹងរបស់យើង ជាអក្សរដែលយើងបាន
ហៅថា [ក]អក្សរអេស៊ីព្ទកែទម្រង់ ដែលត្រូវបានតគំណមក
ហើយត្រូវបានកែប្រែដោយពួកយើង ស្របតាមរបៀបនិយាយ
របស់យើង ។

៣៣ ហើយបើសិនជាផ្ទាំងរបស់យើងធំល្មម នោះយើងបាន
សរសេរជាភាសាហេព្រើរហើយ; ប៉ុន្តែភាសាហេព្រើរ ក៏ពួក

២៣ *ក* ស.ប. សេចក្តីជាប់ទោស.
២៤ *ក* ម៉ាកុស ១៦:១៧–១៨.
ស.ប. ទីសំគាល់.
*ខ* កិច្ចការ ១៦:១៦–១៨.
*គ* ស.ប. ការប្រសិទ្ធិពរដល់មនុស្សឈឺ.
២៥ *ក* ស.ប. វិវរណៈ; ទីបន្ទាល់.
២៦ *ក* ៣ នីហ្វៃ ២៩:៤–៧.
*ខ* សុភា. ១៣:១៣.
២៧ *ក* ម៉ូរ៉ូណៃ ១០:៣០–៣២.
*ខ* យ៉ូស្វេ ២២:៥;
គ. និង ស. ៦៤:២២, ៣៤.
ស.ប. ចិត្ត.
*គ* ភីលីព ២:១២.
២៨ *ក* យ៉ាកុប ៦:១២.
*ខ* ស.ប. សំរេកស្រេប.
*គ* អាលម៉ា ៥:១៣.
២៩ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យ
ជ្រមុជទឹក — ការតម្រូវការទាំង
ឡាយសំរាប់បុណ្យជ្រមុជទឹក.
*ខ* ១ កូរិន. ១១:២៧–៣០;
៣ នីហ្វៃ ១៨:២៨–៣២.
*គ* ស.ប. សក្តិសម, ភាពសក្តិសម.
៣០ *ក* មរមន ៨:២៦;
ម៉ូរ៉ូណៃ ១០:២៧.
៣១ *ក* មរមន ៨:១៧;
អេធើរ ១២:២២–២៨, ៣៥.
៣២ *ក* ១ នីហ្វៃ ១:២; ម៉ូសាយ ១:៤.

យើង បានកែប្រែដែរ; ហើយបើសិនជាយើងអាចសរសេរជា
អក្សរហេព្រើរបាន មើលចុះ អ្នករាល់គ្នានឹងពុំឃើញមានការឆ្គាំឆ្គង
នៅក្នុងបញ្ជី នេះឡើយ ។
៣៤ ប៉ុន្តែ ព្រះអម្ចាស់ទ្រង់ជ្រាបនូវការណ៍ទាំងឡាយ ដែល
យើងបានកត់ត្រាមក ហើយទ្រង់ជ្រាបដែរថា គ្មានប្រជាជនឯណាទៀត
ចេះភាសារបស់យើងទេ; ហើយពីព្រោះមកពីគ្មាននរណាទៀត
ចេះភាសារបស់យើង ហេតុដូច្នេះហើយ ទើបទ្រង់បានរៀបចំ
[ក]មធ្យោបាយទាំងឡាយ សំរាប់បកប្រែភាសានោះ ។
៣៥ ហើយការណ៍ទាំងនេះត្រូវបានកត់ត្រាទុក ដើម្បីឲ្យយើងអាច
កំចាត់សំលៀកបំពាក់របស់យើង ឲ្យជ្រះពី[ក]ឈាមនៃពួកបងប្អូន
របស់យើង ដែលបានចុះអន់ថយ ទៅក្នុងការឥតជំនឿ ។

៣៦ ហើយមើលចុះ ការណ៍ទាំងនេះដែលយើង[ក]ប្រាថ្នាចង់បាន
ពីពួកបងប្អូនរបស់យើង មែនហើយ គឺការប្រោសពួកគេឲ្យស្គាល់
ព្រះគ្រីស្ទ គឺស្របទៅតាមការអធិស្ឋានទាំងឡាយនៃពួកបរិសុទ្ធ
ទាំងអស់ ដែលបានរស់នៅលើដែនដីនេះ ។
៣៧ ហើយសូមឲ្យព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់អនុញ្ញាតឲ្យ
ការអធិស្ឋានទាំងឡាយរបស់គេបានសំរេច ស្របទៅតាម
សេចក្ដី ជំនឿរបស់គេចុះ; ហើយសូមឲ្យព្រះវរបិតាទ្រង់
នឹកចាំដល់សេចក្ដីសញ្ញា ដែលទ្រង់បានធ្វើជាមួយនឹងវង្ស
អ៊ីស្រាអែលចុះ; ហើយសូមឲ្យ ព្រះអង្គប្រទានពរដល់ពួក
គេរហូតតទៅ តាមសេចក្ដីជំនឿជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ
ចុះ ។ អាម៉ែន ៕ :៚

# គម្ពីរអេធើរ

*បញ្ជីរបស់ពួកសាសន៍យ៉ារេឌ យកមកពីផ្ទាំង២៤សន្លឹក ដែលបានប្រទះឃើញដោយប្រជាជនលិមហៃ នៅក្នុងជំនាន់ស្ដេចម៉ូសាយ ។*

## ជំពូកទី ១

*ម៉ូរ៉ូណៃសង្ខេបការសរសេររបស់អេធើរ — ពង្សាវតាររបស់អេធើរត្រូវបានថែងប្រាប់ — ភាសារបស់ពួកសាសន៍យ៉ារេឌពុំត្រូវបាន បំភាន់នៅឯប៉មបាបិលទេ — ព្រះអម្ចាស់ទ្រង់សន្យាថានឹងដឹកនាំពួកគេទៅកាន់ដែនដីដ៏វិសេសមួយ ហើយធ្វើឲ្យពួកគេបានទៅជា ប្រជាជាតិមួយដ៏មហិមា ។*

ហើយឥឡូវនេះ ខ្ញុំ[ក]ម៉ូរ៉ូណៃ ចាប់ផ្ដើមរៀបរាប់ដំណើររឿងអំពី
បណ្ដាជនបុរាណទាំងនោះ ដែលត្រូវបំផ្លាញចោល ដោយ
[ខ]ព្រះហស្តនៃ ព្រះអម្ចាស់ នៅលើផ្ទៃដែនដីខាងជើងនេះ ។
២ ហើយខ្ញុំយកដំណើររឿងរបស់ខ្ញុំ ពីផ្ទាំង[ក]២៤សន្លឹក ដែល
ត្រូវបានប្រទះឃើញ ដោយប្រជាជនលិមហៃ ដែលត្រូវបាន
ហៅថា គម្ពីរអេធើរ ។
៣ ហើយដូចជាខ្ញុំសន្និដ្ឋានថា ភាគដើមនៃបញ្ជីនេះ ដែល
និយាយអំពីការបង្កើតពិភពលោក និងអំពីលោកអ័ដាម និង
ដំណើររឿងអំពី ពេលនោះ មកទល់នឹងសម័យ[ក]ប៉មដ៏មហិមា
ហើយអ្វីក៏ដោយ ដែលបានកើតឡើងក្នុងចំណោមកូនចៅមនុស្ស
មកទល់ពេលនោះ គឺពួក សាសន៍យូដាមានហើយ ។
៤ ហេតុដូច្នេះហើយ ខ្ញុំពុំសរសេរនូវការណ៍ទាំងនោះ ដែល
បានកើតឡើងចាប់ពីសម័យ[ក]លោកអ័ដាម មកទល់ពេលនោះទេ;
ប៉ុន្តែ ការណ៍ទាំងនោះមាននៅលើផ្ទាំងរួចហើយ; ហើយអស់អ្នក
ណាដែលប្រទះឃើញផ្ទាំងទាំងនោះ អ្នកនោះហើយដែលនឹង
មានអំណាច ដែលគេអាចដឹងនូវដំណើររឿងទាំងស្រុង ។
៥ ប៉ុន្តែមើលចុះ ខ្ញុំមិនរៀបរាប់ដំណើររឿងទាំងស្រុងទេ ប៉ុន្តែ
ខ្ញុំរាប់រៀបដំណើររឿងមួយភាគ ចាប់ពីសម័យប៉មមកទល់នឹងពេល
ដែលពួកគេត្រូវបំផ្លាញចោល ។
៦ ហើយដោយរបៀបនេះ ខ្ញុំប្រាប់នូវដំណើររឿង ។ អ្នកដែល
សរសេរបញ្ជីនេះ គឺ[ក]អេធើរ ហើយលោកគឺជាពូជពង្សកូរីអានតើរ ។
៧ កូរីអានតើរ គឺជាកូនប្រុសរបស់ម៉ូរ៉ុន ។
៨ ហើយម៉ូរ៉ុន គឺជាកូនប្រុសរបស់អេថិម ។

៣៤ *ក* ម៉ូសាយ ៨:១៣—១៨;
អេធើរ ៣:២៣, ២៨;
គ. និង ស. ១៧:១.
៣៥ *ក* ២ នីហ្វៃ ២៦:១៥.
៣៦ *ក* មរមន ៨:២៤—២៦;
គ. និង ស. ១០:៤៦—៤៩.

[អេធើរ]
១ ១*ក* ស.ប. ម៉ូរ៉ូណៃ, កូនប្រុសរបស់មរមន.
*ខ* មរមន ៥:២៣;
គ. និង ស. ៨៧:៦—៧.
២ *ក* អាលម៉ា ៣៧:២១;
អេធើរ ១៥:៣៣.

៣ *ក* អោមណៃ ១:២២;
ម៉ូសាយ ២៨:១៧;
ហេលេ. ៦:២៨.
៤ *ក* ក.ន. ស្ដីអំពីពេលដូចគ្នានឹងគម្ពីរ
លោកុប្បត្តិ ជំពូកទី ១—១០.
៦ *ក* អេធើរ ១២:២; ១៥:៣៤.

៩ ហើយអេថិម គឺជាកូនប្រុសរបស់អេហា ។

១០ ហើយអេហា គឺជាកូនប្រុសរបស់សេត ។

១១ ហើយសេត គឺជាកូនប្រុសរបស់ស៊ិបឡុន ។

១២ ហើយស៊ិបឡុន គឺជាកូនប្រុសរបស់កុម ។

១៣ ហើយកុម គឺជាកូនប្រុសរបស់កូរីអានទុម ។

១៤ ហើយកូរីអានទុម គឺជាកូនប្រុសរបស់អាំនីកាដា ។

១៥ ហើយអាំនីកាដា គឺជាកូនប្រុសរបស់អេរ៉ុន ។

១៦ ហើយអេរ៉ុន គឺជាកូនប្រុសរបស់ហេត ដែលជាកូនប្រុស
របស់ហេអើថុម ។

១៧ ហើយហេអើថុម គឺជាកូនប្រុសរបស់លិប ។

១៨ ហើយលិប គឺជាកូនប្រុសរបស់គីស ។

១៩ ហើយគីស គឺជាកូនប្រុសរបស់កូរ៉ុម ។

២០ ហើយកូរ៉ុម គឺជាកូនប្រុសរបស់លេវី ។

២១ ហើយលេវី គឺជាកូនប្រុសរបស់គិម ។

២២ ហើយគិម គឺជាកូនប្រុសរបស់ម៉ូរីអានតុន ។

២៣ ហើយម៉ូរីអានតុន គឺជាកូនប្រុសរបស់រីពឡាគិស ។

២៤ ហើយរីពឡាគិស គឺជាកូនប្រុសរបស់សែស ។

២៥ ហើយសែស គឺជាកូនប្រុសរបស់ហេត ។

២៦ ហើយហេត គឺជាកូនប្រុសរបស់កុម ។

២៧ ហើយកុម គឺជាកូនប្រុសរបស់កូរីអានទុម ។

២៨ ហើយកូរីអានទុម គឺជាកូនប្រុសរបស់អេមើរ ។

២៩ ហើយអេមើរ គឺជាកូនប្រុសរបស់អូមើរ ។

៣០ ហើយអូមើរ គឺជាកូនប្រុសរបស់ស៊ូល ។

៣១ ហើយស៊ូល គឺជាកូនប្រុសរបស់គិប ។

៣២ ហើយគិប គឺជាកូនប្រុសរបស់អូរៃហា ដែលជាកូនប្រុស
របស់យ៉ារេឌ ។

៣៣ គឺ[ក]យ៉ារេឌនេះឯង ដែលបានចេញមកជាមួយនឹងបងប្រុស
របស់លោក និងគ្រួសាររបស់ពួកគេ ជាមួយនឹងអ្នកខ្លះទៀត និង
គ្រួសាររបស់ពួកគេ មកពីប៉មដ៏មហិមា នៅក្នុងពេលព្រះអម្ចាស់
ទ្រង់ [ខ]បានបំភាន់ភាសារបស់មនុស្ស ហើយបានស្បថនៅ
ក្នុងសេចក្ដីខ្ញាល់ ថា ពួកគេត្រូវបំបែកខ្ញែកនៅលើអស់
ទាំង[គ]ផ្ទៃផែនដី; ហើយស្របតាមព្រះបន្ទូលនៃព្រះអម្ចាស់ នោះ
មនុស្សត្រូវបែកខ្ញែកមែន ។

៣៤ ហើយ[ក]បងរបស់យ៉ារេឌ ដែលជាបុរសម្នាក់មាឌធំ ហើយ
ខ្លាំងពូកែ ហើយជាបុរសម្នាក់ដ៏សំណប់ជាខ្លាំងនៃព្រះអម្ចាស់
ទើបយ៉ារេឌ ជាប្អូន និយាយទៅលោកថា៖ ចូរអំពាវនាវដល់
ព្រះអម្ចាស់ សូមកុំឲ្យទ្រង់បំភាន់យើង ធ្វើឲ្យយើងមិនយល់ពាក្យ
របស់ យើងឡើយ ។

៣៥ ហើយហេតុការណ៍បានកើតឡើងថា បងរបស់យ៉ារេឌ
បានអំពាវនាវដល់ព្រះអម្ចាស់ ហើយព្រះអម្ចាស់ទ្រង់មាន
ព្រះហឫទ័យ អាណិតអាសូរដល់យ៉ារេឌ; ហេតុដូច្នោះហើយ
ទ្រង់ពុំបានបំភាន់ភាសារបស់យ៉ារេឌទេ; ហើយយ៉ារេឌ និង
បងរបស់លោកពុំត្រូវបាន បំភាន់ឡើយ ។

៣៦ បន្ទាប់មក យ៉ារេឌបាននិយាយទៅកាន់បងរបស់លោកថា៖
ចូរអំពាវនាវដល់ព្រះអម្ចាស់ទៀត ក្រែងទ្រង់នឹងបំបែរសេចក្ដី
ពិរោធរបស់ទ្រង់ចេញពីពួកគេ ដែលជាមិត្តរបស់ពួកយើង
ដើម្បីកុំឲ្យទ្រង់បំភាន់ភាសារបស់ពួកគេផង ។

៣៧ ហើយហេតុការណ៍បានកើតឡើងថា បងរបស់យ៉ារេឌ
បានអំពាវនាវដល់ព្រះអម្ចាស់ ហើយព្រះអម្ចាស់ទ្រង់មាន
ព្រះហឫទ័យ អាណិតអាសូរដល់ពួកមិត្តរបស់គេ និង
គ្រួសារគេផង ទើបពួកគេពុំត្រូវបានបំភាន់ឡើយ ។

៣៨ ហើយហេតុការណ៍បានកើតឡើងថា យ៉ារេឌបាននិយាយ
ទៅកាន់បងរបស់លោកទៀតថា៖ ចូរទៅទូលសួរព្រះអម្ចាស់មើល
ថាតើទ្រង់នឹងដេញពួកយើងចេញពីដែនដីនេះទេ ហើយបើ
សិនជាទ្រង់នឹងដេញពួកយើងចេញពីដែនដី ចូរអំពាវនាវដល់ទ្រង់ថា
តើពួកយើងនឹងទៅទីណា ។ ហើយក្រែងលោព្រះអម្ចាស់ទ្រង់នឹង
នាំយើងទៅក្នុង[ក]ដែនដីមួយ ដែលជាជំរើសលើដែនដីឯទៀតនៅ
លើផែនដី? ហើយប្រសិនបើដូច្នោះមែន ចូរយើងមានចិត្តស្មោះត្រង់
ចំពោះព្រះអម្ចាស់ ដើម្បីពួកយើងអាចទទួលដែនដីនោះទុក
ជាកេរ្ដិ៍អាកររបស់យើង ។

៣៩ ហើយហេតុការណ៍បានកើតឡើងថា បងរបស់យ៉ារេឌ
បានអំពាវនាវដល់ព្រះអម្ចាស់ ស្របតាមអ្វីៗដែលបាននិយាយ
ដោយ មាត់របស់យ៉ារេឌ ។

៤០ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាន
ឮបងរបស់យ៉ារេឌ ហើយមានព្រះហឫទ័យអាណិតអាសូរដល់លោក
ហើយមានព្រះបន្ទូលទៅកាន់លោកថា៖

៤១ ចូរទៅប្រមូលហ្វូងសត្វរបស់អ្នកមក ទាំងឈ្មោលទាំង
ញីគ្រប់ប្រភេទ; និងគ្រាប់ពូជគ្រប់យ៉ាងនៃផែនដីផង; និង

៣៣ *ក* ស.ប. យ៉ារេឌ.
*ខ* លោកុ. ១១:៦–៩.
*គ* ម៉ូសាយ ២៨:១៧.
៣៤ *ក* ស.ប. បងប្រុសរបស់យ៉ារេឌ.
៣៨ *ក* ស.ប. ដែនដីសន្យា.

គ្រួសារទាំង ឡាយរបស់អ្នក; និងយ៉ារេឌជាប្អូនរបស់អ្នក
និងគ្រួសាររបស់គាត់ផង; និងពួកមិត្តភក្តិរបស់អ្នក និងគ្រួសារ
របស់គេ និងមិត្តភក្តិរបស់ យ៉ារេឌ និងគ្រួសាររបស់គេផង ។
៤២ ហើយកាលណាអ្នកបានធ្វើយ៉ាងនេះហើយ នោះអ្នកត្រូវ
ដើរនាំមុខពួកគេចុះទៅក្នុងច្រកភ្នំ ដែលនៅខាងជើង ។ ហើយនៅទី
នោះ យើងនឹងជួបនឹងអ្នក ហើយយើងនឹងនាំអ្នកទៅឯដែនដីមួយ
ដែលជាជំរើសលើដែនដីទាំងអស់នៃផែនដី ។
៤៣ ហើយនៅទីនោះ យើងនឹងប្រទានពរដល់អ្នក និងពូជអ្នក
ហើយនឹងបង្កើតដល់យើងពីពូជអ្នក និងពីពូជនៃប្អូនអ្នក និង
ពីពួកអ្នក ដែលទៅជាមួយនឹងអ្នក នូវប្រជាជាតិដ៏មហិមាមួយ ។
ហើយគ្មានប្រជាជាតិណា មហិមាជាងប្រជាជាតិ ដែលយើង
នឹងបង្កើតពីពូជអ្នក ឡើយ គឺនៅលើអស់ទាំងផ្ទៃផែនដី ។
ម្ល៉ោះហើយ យើងនឹងធ្វើសំរាប់អ្នក ដោយព្រោះអ្នកបាន
អំពាវនាវដល់យើង អស់ពេលដ៏យូរយ៉ាងនេះ ៕

## ជំពូកទី ២

*ពួកសាសន៍យ៉ារេឌរៀបចំការធ្វើដំណើររបស់គេទៅកាន់ដែនដីសន្យា — គឺជាដែនដីជំរើសមួយដែលមនុស្សត្រូវបំរើព្រះគ្រីស្ទ បើពុំនោះសោតទេ នឹងត្រូវកំចាត់ចេញ — ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ទៅកាន់បងរបស់យ៉ារេឌអស់បីម៉ោង — ពួកគេធ្វើភេត្រា ទាំងឡាយ — ព្រះអម្ចាស់ទ្រង់ប្រាប់បងរបស់យ៉ារេឌឲ្យស្នើថា ធ្វើម្ដេចឲ្យភេត្រាមានពន្លឺ ។*

ហើយហេតុការណ៍បានកើតឡើងថា យ៉ារេឌ និងបងរបស់លោក
និងគ្រួសាររបស់ពួកគេ ព្រមទាំងពួកមិត្តភក្តិរបស់យ៉ារេឌ និងបង
របស់លោក និងគ្រួសារគេ បានចុះទៅឯច្រកភ្នំ ដែលនៅទិស
ខាងជើង (ហើយឈ្មោះរបស់ច្រកភ្នំនោះ គឺនីមរ៉ូឌ ដែលត្រូវបាន
ហៅ តាមអ្នកបរបាញ់ដ៏ខ្លាំងពូកែ) ជាមួយនឹងហ្វូងសត្វរបស់ពួក
គេ ដែលពួកគេបានប្រមូលមក ទាំងឈ្មោលទាំងញីគ្រប់ប្រភេទ ។
២ ហើយពួកគេបានដាក់អន្ទាក់ផង ហើយចាប់សត្វស្លាបដែល
នៅលើអាកាស; ហើយពួកគេបានរៀបចំឲ្យមានពាងមួយផង
ដែលពួក គេបានដាក់ទៅជាមួយគេ នូវត្រីពីទឹកទាំងឡាយ ។
៣ ហើយពួកគេបាននាំយកទៅជាមួយផង នូវដេសេរ៉េត
ដែលបកប្រែមកថា សត្វឃ្មុំ; ម្ល៉ោះហើយ ពួកគេបានយកទៅជា
មួយនូវ ឃ្មុំទាំងហ្វូង និងអ្វីៗគ្រប់យ៉ាងនៅលើផ្ទៃដែនដី គឺគ្រាប់
ពូជគ្រប់ប្រភេទ ។
៤ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានចុះ
មកដល់ច្រកភ្នំនីមរ៉ូឌហើយ នោះព្រះអម្ចាស់ទ្រង់បានយាងចុះមក
ហើយមានព្រះបន្ទូលជាមួយនឹងបងរបស់យ៉ារេឌ; ហើយទ្រង់នៅ
ក្នុងពពកមួយ ហើយបងរបស់យ៉ារេឌមើលពុំឃើញទ្រង់ទេ ។
៥ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាន
បញ្ជាពួកគេថា ពួកគេត្រូវចូលទៅក្នុងទីរហោស្ថាន មែនហើយ
គឺទៅ ត្រង់តំបន់មួយ ដែលពុំដែលមានមនុស្សទៅពីមុន ។
ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាននាំមុខ
ពួកគេ ហើយមាន ព្រះបន្ទូលជាមួយនឹងពួកគេ នៅពេល
ទ្រង់ឈរនៅក្នុងពពកមួយផ្ទាំង ហើយបានប្រាប់ទិសដែលពួកគេ
ត្រូវទៅ ។
៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើដំណើរ
ក្នុងទីរហោស្ថាន ហើយបានស្ថាបនាភេត្រាទាំងឡាយ ដែលពួក
គេជិះ ឆ្លងទឹកជាច្រើន គឺត្រូវបានដឹកនាំជានិច្ច ដោយព្រះហស្តនៃ
ព្រះអម្ចាស់ ។
៧ ហើយព្រះអម្ចាស់ទ្រង់ពុំចង់ឲ្យពួកគេឈប់ខាងនាយសមុទ្រ
ដែលនៅក្នុងទីរហោស្ថានឡើយ តែទ្រង់ចង់ឲ្យពួកគេទៅ
មុខ រហូតដល់ដែនដីសន្យា ដែលជាជំរើសលើគ្រប់ទាំងដែនដី
ឯទៀត ដែលព្រះអម្ចាស់ទ្រង់បានរក្សាទុកសំរាប់មនុស្សសុចរិត ។
៨ ហើយទ្រង់បានស្បថក្នុងសេចក្ដីខ្ញាល់ ដល់បងរបស់យ៉ារេឌ
ថា អស់អ្នកណាដែលយកបានដែនដីសន្យានេះ ចាប់ពីពេលនេះ
តទៅរហូត នោះនឹងត្រូវបំរើទ្រង់ ដែលជាព្រះដ៏ពិតតែមួយ
បើពុំនោះសោតទេ ពួកគេនឹងត្រូវកំចាត់ចេញ កាលណាសេចក្ដី
ខ្ញាល់ របស់ទ្រង់ដ៏ពេញទំហឹង ធ្លាក់មកលើពួកគេ ។
៩ ហើយឥឡូវនេះ ពួកយើងអាចឃើញនូវក្រិត្យក្រមទាំង
ឡាយនៃព្រះអំពីដែនដីនេះថា នេះគឺជាដែនដីសន្យា; ហើយ
សាសន៍ណាក៏ ដោយដែលនឹងយកបានដែនដីនេះ គឺត្រូវបំរើព្រះ
បើពុំនោះសោតទេ ពួកគេនឹងត្រូវកំចាត់ចេញ កាលណាសេចក្ដី

៤១ *ក* អេធើរ ៦:២០.
*ខ* អេធើរ ៦:១៦.
៤២ *ក* ១ នីហ្វៃ ២:១–២; អ័ប្រា. ២:៣.
*ខ* គ. និង ស. ៨៤:៨៨.
*គ* ១ នីហ្វៃ ១៣:៣០.
២ ១*ក* លោកុ. ១០:៨.
៤ *ក* ជនគ. ១១:២៥;
គ. និង ស. ៣៤:៧–៩;
យ.ស.—ប្រវត្តិ ១:៦៨.
៥ *ក* និក្ខ. ១៣:២១–២២.
៧ *ក* ១ នីហ្វៃ ៤:១៤.
ស.ប. ដែនដីសន្យា.
៨ *ក* អេធើរ ១៣:២.
*ខ* យ៉ារ៉ុម ១:៣, ១០;
អាលម៉ា ៣៧:២៨; អេធើរ ៩:២០.

ខ្ញាល់របស់ទ្រង់ ពេញទំហឹង នឹងធ្លាក់លើពួកគេ ហើយសេចក្ដី
ខ្ញាល់របស់ទ្រង់ដ៏ពេញទំហឹង នឹងធ្លាក់លើពួកគេ កាលណាពួក
គេទុំស្អុសនៅក្នុងអំពើ ទុច្ចរិត ។
១០ ត្បិតមើលចុះ នេះគឺដែនដីមួយ ជំរើសលើគ្រប់ទាំងដែនដី
ឯទៀត ហេតុដូច្នោះហើយ អ្នកណាដែលយកបានដែនដីនេះ
នោះនឹងត្រូវបំរើព្រះ បើពុំនោះទេ នឹងត្រូវបោសចេញ ត្បិតនេះ
គឺជាក្រិត្យក្រមដ៏អស់កល្បជានិច្ចនៃព្រះ ។ ហើយពួកគេមិនត្រូវ
[ក]បោស ចេញទេ រហូត[ខ]ដល់ភាពពោរពេញនៃអំពើទុច្ចរិត នៅក្នុង
ចំណោមកូនចៅនៃដែនដីនេះ ។
១១ហើយការណ៍នេះមកដល់អ្នក ឱពួកអ្នករាល់គ្នាជា[ក]សាសន៍
ដទៃអើយ ដើម្បីអ្នករាល់គ្នាអាចដឹងនូវក្រិត្យក្រមនៃព្រះ —
ដើម្បីអ្នក អាចប្រែចិត្ត ហើយមិនបន្តអំពើទុច្ចរិតទាំងឡាយរបស់
អ្នក រហូតដល់ភាពពោរពេញនោះមកដល់ ដើម្បីកុំឲ្យអ្នកអាចនាំ
មកនូវភាព ពោរពេញ នៃសេចក្ដីខ្ញាល់របស់ព្រះ មកលើអ្នក
ដូចបណ្ដាជននៅដែនដីនេះធ្លាប់បានធ្វើនោះ ។
១២ មើលចុះ នេះគឺជាដែនដីជំរើសមួយ ហើយសាសន៍
ណាក៏ដោយដែលយកដែនដីនេះបាន នោះនឹង[ក]បានរួចពីសេវកភាព
និងពី ការជាប់ឃុំឃាំង និងពីសាសន៍ឯទៀតទាំងអស់នៅក្រោមមេឃ
បើសិនជាពួកគេគ្រាន់តែ[ខ]បំរើព្រះនៃដែនដីនេះ ដែលជាព្រះយេស៊ូវ
គ្រីស្ទ ដែលជាតួអង្គដែលបានសម្ដែងឲ្យឃើញ ដោយការណ៍
ទាំងឡាយ ដែលពួកយើងបានសរសេរមក ។
១៣ ហើយឥឡូវនេះ ខ្ញុំចាប់ផ្ដើមបញ្ជីរបស់ខ្ញុំ; ត្បិតមើលចុះ
ហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាននាំយ៉ារេឌ
និងពួកបង ប្អូនរបស់លោក ទៅដល់សមុទ្រដ៏ធំនោះ ដែល
ចែកដែនដី ។ ហើយនៅពេលពួកគេទៅដល់សមុទ្រនោះ នោះ
ពួកគេបានបោះ ត្រសាលរបស់គេ; ហើយពួកគេបានហៅឈ្មោះ
ទីនោះថា ម៉ូរីអានគុមើរ; ហើយពួកគេនៅក្នុងត្រសាល
ហើយនៅក្នុងត្រសាលនៅលើ ឆ្នេរសមុទ្រ អស់រយៈពេលបួនឆ្នាំ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា នៅចុងឆ្នាំទីបួន
នោះព្រះអម្ចាស់ទ្រង់បានយាងមកជួបនឹងបងរបស់យ៉ារេឌទៀត
ហើយ ឈរនៅក្នុងពពកមួយផ្ទាំង ហើយមានព្រះបន្ទូលជាមួយ
នឹងលោក ។ ហើយអស់រយៈពេលបីម៉ោង ព្រះអម្ចាស់មានព្រះ
បន្ទូលជាមួយនឹង បងរបស់យ៉ារេឌ ហើយបាន[ក]វាយផ្ចាលលោក
ពីព្រោះលោកពុំបានចាំនឹង[ខ]អំពាវនាវ ដល់ព្រះនាមនៃព្រះអម្ចាស់ ។
១៥ ហើយបងរបស់យ៉ារេឌ បានប្រែចិត្តនូវការអាក្រក់ដែល
លោកបានធ្វើ ហើយបានអំពាវនាវ ដល់ព្រះនាមនៃព្រះអម្ចាស់
ដើម្បីពួក បងប្អូនរបស់លោក ដែលនៅជាមួយនឹងលោក ។
ហើយព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលទៅកាន់លោកថា៖
យើងនឹងអត់ទោសឲ្យអ្នក និងពួកបងប្អូនរបស់អ្នក នូវអំពើ
បាបទាំងឡាយរបស់ពួកគេ; ប៉ុន្តែអ្នកត្រូវឈប់ធ្វើអំពើ
បាបតទៅទៀត ព្រោះអ្នករាល់គ្នាត្រូវចាំថា [ក]វិញ្ញាណ
របស់យើងនឹង[ខ]ពុំតស៊ូនៅជាមួយនឹងមនុស្សជានិច្ចនោះទេ; ហេតុ
ដូច្នោះហើយ បើសិនជាអ្នករាល់គ្នានឹងធ្វើអំពើបាប រហូតដល់
អ្នករាល់គ្នាទុំស្អុស នោះអ្នករាល់គ្នានឹងត្រូវកាត់ចេញពីវត្តមាននៃ
ព្រះអម្ចាស់ ។ ហើយនេះគឺជាបំណងរបស់យើង ចំពោះដែនដី
ដែល យើងនឹងឲ្យទៅអ្នក សំរាប់ជាកេរ្ដិ៍អាករដល់អ្នក; ត្បិតគឺជា
ដែនដី[គ]ជំរើសលើអស់ទាំងដែនដីឯទៀត ។
១៦ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា៖ ចូរទៅធ្វើ
ការចុះ ហើយធ្វើភេត្រា តាមរបៀបធ្វើភេត្រា ដែលអ្នក
រាល់គ្នាធ្លាប់ធ្វើមក ។ ហើយហេតុការណ៍បានកើតឡើងថា
បងរបស់យ៉ារេឌបានទៅធ្វើការ ព្រមទាំងពួកបងប្អូន
របស់លោកផង ហើយបានធ្វើភេត្រាទាំង ឡាយ តាម
របៀបដែលពួកគេធ្លាប់បានធ្វើមក ស្រប[ក]តាមការបង្គាប់ពីព្រះ
អម្ចាស់ ។ ហើយភេត្រានោះតូច ហើយស្រាលនៅលើទឹក
គឺស្រាលដូចសត្វស្លាបនៅលើទឹក ។
១៧ ហើយគឺត្រូវបានធ្វើតាមរបៀបម៉្យាង ដែល[ក]ជិតជាខ្លាំង
រហូតដល់គេអាចដាក់ទឹកបាន ដូចជាចានមួយ; ហើយបាតភេត្រា
ក៏ជិតដូច ជាចាន; ហើយខាងៗក៏ជិតដូចជាចាន; ហើយនៅខាង
ចុងស្រួច; ហើយខាងលើក៏ជិតដូចជាចាន; ហើយបណ្ដោយស្មើ
នឹងបណ្ដោយ ឈើមួយ; ហើយទ្វារកាលណាបិទទៅ នោះ
ជិតដូចជាចាន ។
១៨ ហើយហេតុការណ៍បានកើតឡើងថា បងរបស់យ៉ារេឌ
បានអំពាវនាវដល់ព្រះអម្ចាស់ថា៖ ឱព្រះអម្ចាស់អើយ ទូលបង្គំ
បានធ្វើនូវ កិច្ចការ ដែលទ្រង់បានបញ្ជាទូលបង្គំហើយ ហើយ

១០ *ក* ២ នីហ្វៃ ២៨:១៦.
*ខ* ១ នីហ្វៃ ១៧:៣៧–៣៨.
១១ *ក* ២ នីហ្វៃ ២៨:៣២.
១២ *ក* ស.ប. ឥស្សរភាព.
*ខ* អេសាយ ៦០:១២.
១៤ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. ការអធិស្ឋាន.
១៥ *ក* អេធើរ ១៥:១៩.
*ខ* លោកុ. ៦:៣; ២ នីហ្វៃ ២៦:១១; មរមន ៥:១៦.
*គ* អេធើរ ៩:២០.
១៦ *ក* ១ នីហ្វៃ ១៧:៥០–៥១.
១៧ *ក* អេធើរ ៦:៧.

ទូលបង្គំបានធ្វើគេត្រាទាំងឡាយ ស្របតាមដែលទ្រង់បានដឹកនាំ
ទូលបង្គំ ។
១៩ ហើយមើលចុះ ឱព្រះអម្ចាស់អើយ នៅក្នុងគេត្រាទាំងនោះ
គ្មានពន្លឺទេ; តើយើងខ្ញុំត្រូវកាច់ទៅខាងណា ? ហើយយើងខ្ញុំនឹង
វិនាសបង់ផង ត្បិតនៅក្នុងនោះ យើងខ្ញុំមិនអាចដកដង្ហើមបានទេ
ក្រៅតែពីខ្យល់ដែលនៅក្នុងនោះ; ហេតុដូច្នេះហើយ យើងខ្ញុំនឹង
វិនាសបង់ជាមិនខានឡើយ ។
២០ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ទៅបងរបស់
យ៉ារេឌថាៈ មើលចុះ អ្នកត្រូវចោះរន្ធមួយពីខាងលើ និងនៅខាង
បាតផង; ហើយកាលណាអ្នកខ្វះខ្យល់ដកដង្ហើម នោះអ្នកត្រូវ
បើករន្ធ ដើម្បីទទួលយកខ្យល់ ។ ហើយបើកាលណាទឹកចូលមក
លើអ្នក មើលចុះ អ្នកត្រូវបិទរន្ធនោះ ដើម្បីកុំឲ្យអ្នករាល់គ្នាវិនាស
ក្នុងជំនន់ ។
២១ ហើយហេតុការណ៍បានកើតឡើងថា បងរបស់យ៉ារេឌ
បានធ្វើដូច្នោះ ស្របតាមដែលព្រះអម្ចាស់ទ្រង់បានបញ្ជា ។
២២ ហើយលោកបានអំពាវនាវដល់ព្រះអម្ចាស់ទៀតថាៈ
ឱព្រះអម្ចាស់អើយ មើលចុះ ទូលបង្គំបានធ្វើដូច ដែលទ្រង់បាន
បញ្ជា ដល់ទូលបង្គំហើយ; ហើយទូលបង្គំបានរៀបចំគេត្រាទាំង
ឡាយ សំរាប់ប្រជាជនរបស់ទូលបង្គំ ហើយមើលចុះ គ្មាន
ពន្លឺនៅក្នុងនោះ សោះ ។ មើលចុះ ឱព្រះអម្ចាស់អើយ
តើព្រះអង្គទុកឲ្យយើងខ្ញុំឆ្លងកាត់ទឹកដ៏ធំនេះក្នុងភាពងងឹតឬ ?
២៣ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ទៅបងរបស់
យ៉ារេឌថាៈ តើអ្នកចង់ឲ្យយើងធ្វើអ្វី ដើម្បីឲ្យអ្នកមានពន្លឺ នៅ
ក្នុងគេត្រា ទាំងឡាយរបស់អ្នក ? ត្បិតមើលចុះ អ្នករាល់គ្នាមិន
អាចមានបង្អួច ត្បិតនឹងត្រូវបោកជាដុំៗ; ហើយអ្នករាល់គ្នាក៏មិន
អាចយកភ្លើងជា មួយអ្នកដែរ ត្បិតអ្នករាល់គ្នាមិនត្រូវទៅដោយ
ពន្លឺភ្លើងឡើយ ។
២៤ ត្បិតមើលចុះ អ្នករាល់គ្នានឹងទៅដូចជាត្រីបាឡែន
នៅកណ្ដាលសមុទ្រ; ត្បិតរលកធំដូចភ្នំនឹងបោកមកលើអ្នក ។
ទោះជាយ៉ាង ណាក៏ដោយ [ក]គង់តែយើងនឹងលើកអ្នកេ
ឡើងពីជំរៅនៃសមុទ្រទៀត; ត្បិត[ខ]ខ្យល់បានចេញពីមាត់យើង
ហើយភ្លៀង និងទឹកជំនន់ផង ដែលយើងបានចាត់ឲ្យទៅ ។
២៥ ហើយមើលចុះ យើងរៀបចំអ្នករាល់គ្នា តទល់នឹងការណ៍
ទាំងនេះ; ត្បិតអ្នករាល់គ្នាមិនអាចឆ្លងកាត់ទីជំរៅដ៏ធំនេះបានទេ
លើកលែងតែយើងរៀបចំឲ្យអ្នកតទល់នឹងរលកនៃសមុទ្រ ហើយ
ខ្យល់ដែលបក់ និងទឹកជំនន់ដែលនឹងមក; ហេតុដូច្នេះហើយ តើអ្នក
រាល់គ្នាចង់ឲ្យយើងរៀបចំអ្វីឲ្យអ្នក ដើម្បីឲ្យអ្នករាល់គ្នាមានពន្លឺ
កាលណាអ្នករាល់គ្នាត្រូវលេបទៅក្នុងទីជំរៅនៃសមុទ្រ ? ៕

## ជំពូកទី ៣

*បងរបស់យ៉ារេឌឃើញព្រះអង្គុលីនៃព្រះអម្ចាស់ នៅពេលទ្រង់ពាល់ត្រួស១៦ដុំ — ព្រះគ្រីស្ទទ្រង់បង្ហាញរាងកាយនៃព្រះវិញ្ញាណរបស់ ទ្រង់ដល់បងរបស់យ៉ារេឌ — អស់អ្នកណាដែលស្គាល់ដោយឥតខ្ចោះ ពុំអាចត្រូវបាំងពីខាងក្នុងវាំងននបានឡើយ — ប្រដាប់បកប្រែ ទាំងឡាយត្រូវបានផ្ដល់ឲ្យដើម្បីយកបញ្ជីរបស់សាសន៍យ៉ារេឌមកកាន់ពន្លឺ ។*

ហើយហេតុការណ៍បានកើតឡើងថា បងរបស់យ៉ារេឌ (ឥឡូវនេះ
ចំនួនគេត្រាដែលបានធ្វើហើយ គឺមានប្រាំបីក្បួន) បានទៅឯភ្នំដែល
ពួកគេបានហៅថា ភ្នំសេឡិម ពីព្រោះមកពីកំពស់ខ្ពស់ ហើយ
បានរំលាយថ្មមួយទៅជាក្រួស១៦ដុំតូចៗ; ហើយមានពណ៌សភ្លឺ
ហើយ ថ្លាដូចកញ្ចក់ ហើយលោកបានកាន់នៅក្នុងដៃលោក
នៅលើកំពូលភ្នំ ហើយបានអំពាវនាវទៅព្រះអម្ចាស់ទៀតថាៈ
២ ឱព្រះអម្ចាស់អើយ ទ្រង់មានព្រះបន្ទូលថា យើងខ្ញុំនឹងត្រូវ
ហ៊ុំព័ទ្ធដោយទឹកជំនន់ ។ ឥឡូវនេះ មើលចុះ ឱព្រះអម្ចាស់អើយ
សូមទ្រង់កុំខ្ញាល់នឹងអ្នកបំរើរបស់ទ្រង់ ដោយសារភាពទន់ខ្សោយ
របស់គេ នៅចំពោះទ្រង់ឡើយ; ត្បិតយើងខ្ញុំដឹងថា ទ្រង់បរិសុទ្ធ
ហើយគង់នៅលើស្ថានសួគ៌ [ក]ហើយយើងខ្ញុំ[ខ]នេះមិនសក្តិសម
នៅចំពោះព្រះអង្គទេ; ដោយសារការធ្លាក់ នោះធម្មជាតិនៃយើង
ខ្ញុំបាន ក្លាយទៅជាអាក្រក់ជានិច្ច; ទោះជាយ៉ាងណាក៏ដោយ
ឱព្រះអម្ចាស់អើយ គង់តែទ្រង់បានប្រទានឲ្យយើងខ្ញុំនូវព្រះបញ្ញត្តិ
មួយដែលថា យើងខ្ញុំត្រូវអំពាវនាវដល់ទ្រង់ ដើម្បីដោយសារទ្រង់
នោះយើងខ្ញុំអាចទទួលនូវអ្វីៗ ដែលយើងខ្ញុំប៉ងប្រាថ្នា ។
៣ មើលចុះ ឱព្រះអម្ចាស់អើយ ទ្រង់បានវាយយើងខ្ញុំ ពីព្រោះ
មកពីអំពើទុច្ចរិតរបស់យើងខ្ញុំ ហើយបានបណ្ដេញយើងខ្ញុំទៅ ហើយ
អស់រយៈពេលជាច្រើនឆ្នាំ យើងខ្ញុំបានរស់នៅក្នុង[ក]ទីរហោស្ថាន;
ទោះជាយ៉ាងណាក៏ដោយ គង់តែទ្រង់មានសេចក្ដីមេត្តាករុណា
ដល់ យើងខ្ញុំដែរ ។ ឱព្រះអម្ចាស់អើយ សូមទ្រង់ទតសម្លឹងមក

២៤ *ក* អេធើរ ៦:៥.
*ខ* ទំនុក. ១៤៨:៨.
៣ ២ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
*ខ* ម៉ូសាយ ៣:១៩.
៣ *ក* អេធើរ ១:៣៤–៤៣.

ទូលបង្គំ ក្នុងសេចក្ដីអាណិត ហើយបំបែរសេចក្ដីពិរោធរបស់
ទ្រង់ចេញពី ប្រជាជនរបស់ទ្រង់នេះទៅ ហើយសូមកុំទុកឲ្យពួកគេ
ទៅឆ្លងកាត់ជំរៅដ៏គ្រាំគ្រេង ក្នុងភាពងងឹត; ប៉ុន្តែសូមទតមើលវ
ត្ថុទាំងនេះ ដែលទូលបង្គំបានរំលាយចេញពីថ្ម ។
៤ ហើយ ឱព្រះអម្ចាស់អើយ ទូលបង្គំដឹងថា ទ្រង់មានអស់
ទាំងព្រះចេស្ដា ហើយអាចធ្វើអ្វីក៏ដោយដែលទ្រង់សព្វព្រះហឫទ័យ
ដើម្បី ជាប្រយោជន៍ដល់មនុស្ស; ហេតុដូច្នេះហើយ សូមទ្រង់
ពាល់ក្រួសទាំងនេះ ឱព្រះអម្ចាស់អើយ ដោយព្រះអង្គុលីរបស់
ទ្រង់ ហើយរៀប ចំឲ្យវាអាចបានភ្លឺចែងចាំងក្នុងទីងងឹត; ហើយវា
នឹងភ្លឺចែងចាំងដល់យើងខ្ញុំ នៅក្នុងគេគ្រាដែលយើងខ្ញុំបាន
រៀបចំឡើង ដើម្បីឲ្យ យើងខ្ញុំអាចមានពន្លឺ នៅពេលយើងខ្ញុំឆ្លង
កាត់សមុទ្រ ។
៥ មើលចុះ ឱព្រះអម្ចាស់អើយ ទ្រង់អាចធ្វើការនេះ ។
យើងខ្ញុំដឹងថា ទ្រង់អាចបង្ហាញព្រះចេស្ដាដ៏មហិមា ដែល
មើលដូចជាតូច ចំពោះយោបល់របស់មនុស្ស ។
៦ ហើយហេតុការណ៍បានកើតឡើងថា កាលបងរបស់យ៉ារេឌ
បានទូលពាក្យទាំងនេះហើយ មើលចុះ ព្រះអម្ចាស់ទ្រង់លូកព្រះហស្ត
របស់ទ្រង់មក ហើយបានពាល់ក្រួសទាំងនេះម្ដងមួយៗ ដោយ
ព្រះអង្គុលីរបស់ទ្រង់ ។ ហើយវាំងននត្រូវបានបើកចេញពីភ្នែករបស់
បង របស់យ៉ារេឌ ហើយលោកបានឃើញព្រះអង្គុលីនៃព្រះ
អម្ចាស់; ហើយគឺដូចជាម្រាមដៃរបស់មនុស្ស ដូចសាច់ និង
ឈាម; ហើយបងរបស់ យ៉ារេឌបានដួលចុះ នៅចំពោះព្រះ
អម្ចាស់ ត្បិតលោកត្រូវស្រឡាំងកាំងដោយភិតភ័យ ។
៧ ហើយព្រះអម្ចាស់ទ្រង់បានទតឃើញថា បងរបស់យ៉ារេឌ
បានដួលចុះទៅលើដី; ហើយព្រះអម្ចាស់ទ្រង់ មានព្រះ
បន្ទូលទៅលោក ថា៖ ចូរក្រោកឡើង ហេតុអ្វីក៏អ្នកដួល ?
៨ ហើយលោកទូលទៅព្រះអម្ចាស់ថា៖ ទូលបង្គំបានឃើញ
ព្រះអង្គុលីនៃព្រះអម្ចាស់ ហើយទូលបង្គំខ្លាចក្រែងទ្រង់វាយទូលបង្គំ;
ត្បិតទូលបង្គំពុំដឹងថា ព្រះអម្ចាស់មានសាច់ និងឈាម ។
៩ ហើយព្រះអម្ចាស់មានព្រះបន្ទូលទៅលោកថា៖ ដោយ
សារសេចក្ដីជំនឿរបស់អ្នក នោះអ្នកបានឃើញថា យើងនឹងយក
រូបកាយ ជាសាច់ និងឈាម; ហើយពុំដែលមានមនុស្សឯណា
មកចំពោះយើង ហើយមានសេចក្ដីជំនឿដ៏លើសលប់ដូចអ្នកសោះ;
ត្បិតបើពុំ មែនដូច្នោះទេ នោះអ្នកពុំអាចមើលឃើញម្រាមដៃ
របស់យើងបានឡើយ ។ តើអ្នកបានឃើញអ្វីក្រៅពីនេះទេ ?
១០ ហើយលោកបានទូលឆ្លើយថា៖ ទេ ព្រះអម្ចាស់
សូមព្រះអង្គបង្ហាញរូបអង្គទ្រង់ដល់ទូលបង្គំផង ។
១១ ហើយព្រះអម្ចាស់មានព្រះបន្ទូលទៅលោកថា៖ តើអ្នក
ជឿពាក្យដែលយើងនឹងប្រាប់ឬទេ ?
១២ ហើយលោកបានទូលឆ្លើយថា៖ ព្រះពរ ព្រះអម្ចាស់
ទូលបង្គំដឹងថា ព្រះអង្គមានព្រះបន្ទូលនូវការពិត ត្បិតព្រះអង្គ
គឺជាព្រះនៃ សេចក្ដីពិត ហើយពុំអាចកុហកឡើយ ។
១៣ ហើយកាលលោកបានទូលពាក្យទាំងនេះហើយ មើលចុះ
ព្រះអម្ចាស់ទ្រង់បានបង្ហាញរូបអង្គទ្រង់ដល់លោក ហើយមានព្រះ
បន្ទូលថា៖ ដោយសារអ្នកដឹងនូវការណ៍ទាំងនេះ នោះអ្នកត្រូវ
បានប្រោសលោះពីការធ្លាក់; ហេតុដូច្នេះហើយ អ្នកត្រូវបាននាំ
មកឯ វត្តមានរបស់យើងវិញ; ហេតុដូច្នេះហើយ យើងបង្ហាញ
រូបយើងដល់អ្នក ។
១៤ មើលចុះ យើងគឺជាតួអង្គដែលត្រូវបានរៀបចំទុក
ចាប់តាំងពីកំណើតលោកិយមក ដើម្បីប្រោសលោះរាស្ត្រយើង ។
មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ យើងជាព្រះវរបិតា និងជា
ព្រះរាជបុត្រា ។ ដោយសារយើង នោះមនុស្សលោកទាំងអស់
នឹងមានជីវិត ឯជីវិតនោះគឺនៅអស់កល្បជានិច្ច គឺពួកអ្នកដែល
នឹងជឿដល់នាមយើង ហើយពួកគេនឹងក្លាយទៅជាកូនប្រុស និង
កូនស្រីរបស់យើង ។
១៥ ហើយយើងមិនដែលបង្ហាញរូបយើងដល់មនុស្ស ដែល
យើងបានបង្កើតឡើងទេ ត្បិតមិនដែលមានមនុស្សណាជឿ
ដល់យើង ដូចជាអ្នកជឿឡើយ ។ តើអ្នកឃើញទេថា អ្នកត្រូវ
បានបង្កើតឡើង តាមរូបរបស់យើងផ្ទាល់ ? មែនហើយ មនុស្ស
ទាំងអស់ត្រូវបាន បង្កើតឡើង កាលពីដំបូង តាមរូបយើងផ្ទាល់ ។

៤ *ក* ស.ប. អំណាច.
៥ *ក* អេសាយ ៥៥:៨–៩;
១ នីហ្វៃ ១៦:២៩.
៦ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* អេធើរ ១២:១៩, ២១.
៩ *ក* ស.ប. សាច់; ព្រះយេស៊ូវគ្រីស្ទ;
ដែលរមែងស្លាប់, ភាពដែល
រមែងស្លាប់.
១២ *ក* ហេព្រើរ ៦:១៨.
១៣ *ក* គ. និង ស. ៦៧:១០–១១.
*ខ* អេណុស ១:៦–៨.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ព្រះគ្រីស្ទមានព្រះជន្ម
រស់នៅមុនផែនដី.
១៤ *ក* ស.ប. ប្រោសលោះ, បាន
ប្រោសលោះ, សេចក្ដីប្រោសលោះ;
ព្រះដ៏ប្រោសលោះ.
*ខ* ម៉ូសាយ ១៥:១–៤.
*គ* ម៉ូសាយ ១៦:៩.
*ឃ* ស.ប. បុត្រាបុត្រីនៃព្រះ.
១៥ *ក* ស.ប. ជំនឿ, ជឿ.
*ខ* លោកុ. ១:២៦–២៧;
ម៉ូសាយ ៧:២៧;
គ. និង ស. ២០:១៧–១៨.

១៦ មើលចុះ រូបរាងនេះដែលអ្នកឃើញឥឡូវនេះ គឺជារូបរាង
របស់វិញ្ញាណ[ក]របស់យើង; ហើយមនុស្សដែលយើងបានបង្កើតឡើង
គឺតាមរូបរាងរបស់វិញ្ញាណយើង; ហើយដូចជាយើងលេចមក
ក្នុងវិញ្ញាណ ឲ្យអ្នកឃើញយ៉ាងណា នោះយើងក៏នឹងលេចមកឲ្យ
រាស្ត្រ យើងឃើញក្នុងសាច់ឈាមយ៉ាងនោះដែរ ។
១៧ ហើយឥឡូវនេះ ដូចដែលខ្ញុំមរ៉ូណៃ បាននិយាយថា ខ្ញុំពុំ
អាចរៀបរាប់នូវដំណើររឿងដ៏ពោរពេញ ដែលបានសរសេរ
ទុកទាំង នេះ ឲ្យបានអស់នោះទេ ហេតុដូច្នេះហើយ គឺល្មមឲ្យខ្ញុំ
គ្រាន់តែនិយាយថា ព្រះយេស៊ូវទ្រង់[ក]បានបង្ហាញរូបអង្គទ្រង់ដល់
បុរសនេះ នៅ ក្នុងវិញ្ញាណយ៉ាងណា នោះក៏ដូចរបៀប និង
រូបភាពនៃអង្គតែមួយ ដូចដែលទ្រង់បានបង្ហាញរូបអង្គទ្រង់ដល់
ពួកសាសន៍នីហ្វៃដែរ ។
១៨ ហើយទ្រង់បានធ្វើការងារបំរើដល់លោក ដូចដែលទ្រង់
បានធ្វើការងារបំរើដល់ពួកសាសន៍នីហ្វៃដែរ; ហើយការណ៍អស់
ទាំងនេះ គឺដើម្បីទុកឲ្យបុរសនេះអាចដឹងថា ទ្រង់គឺជាព្រះ
ពីព្រោះមកពីកិច្ចការដ៏មហិមាជាច្រើន ដែលព្រះអម្ចាស់ទ្រង់បាន
បង្ហាញដល់លោក ។
១៩ ហើយដោយសារជំរិះរបស់បុរសនេះ នោះលោកពុំអាច
ត្រូវបាំងមិនឲ្យឃើញ នៅខាងក្នុងវាំង[ក]នននឡើយ; ហើយលោកបាន
ឃើញព្រះអង្គុលីនៃព្រះយេស៊ូវ គឺនៅពេលលោកឃើញ
នោះលោកបានដួលចុះ ដោយភិតភ័យ; ត្បិតលោកបានដឹងថា
នោះគឺជា ព្រះអង្គុលីនៃព្រះអម្ចាស់; ហើយលោកអស់មាន
សេចក្ដីជំនឿទៀតហើយ ត្បិតលោកបានដឹង គឺគ្មានសង្ស័យ
អ្វីឡើយ ។
២០ ហេតុដូច្នោះហើយ ដោយមានជំរិះដ៏ឥតខ្ចោះអំពីព្រះ
នោះលោក[ក]ពុំអាចត្រូវបាំងពីខាងក្នុងវាំងនននបានឡើយ; ហេតុ
ដូច្នេះហើយ លោកបានឃើញព្រះយេស៊ូវ; ហើយទ្រង់បាន
ធ្វើការងារបំរើដល់លោក ។
២១ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
មានព្រះបន្ទូលទៅបងរបស់យ៉ារេឌថា៖ មើលចុះ អ្នកមិនត្រូវ
ទុកឲ្យការណ៍ ទាំងនេះ ដែលអ្នកបានឃើញ ហើយបានឮមក
លេចឮដល់មនុស្សលោកឡើយ រហូតដល់[ក]ពេលនោះមកដល់
កាលយើងនឹងដំកើងនាម យើង នៅក្នុងសាច់ឈាម; ហេតុ
ដូច្នោះហើយ អ្នកត្រូវលាក់ការណ៍ទាំងនេះ ដែលអ្នកបានឃើញ
ហើយបានឮមក ហើយកុំបញ្ចេញ ប្រាប់អ្នកឯណាឲ្យសោះ ។
២២ ហើយមើលចុះ កាលណាអ្នកត្រូវមករកយើង នោះអ្នក
ត្រូវសរសេរអំពីការណ៍នោះ ហើយត្រូវបិទការណ៍នោះទុក
ដើម្បីកុំឲ្យ អ្នកណាម្នាក់អាចបកប្រែបានឡើយ; ត្បិតអ្នកត្រូវ
សរសេរអំពីការណ៍នោះ នៅក្នុងភាសាមួយ ដើម្បីកុំឲ្យការណ៍
នោះអាចអានបាន ។
២៣ ហើយមើលចុះ ត្បូង[ក]ពីរដុំនេះ យើងនឹងឲ្យទៅអ្នក ហើយ
អ្នកត្រូវបិទត្រាទុក ជាមួយនឹងការណ៍ទាំងឡាយ ដែលអ្នកនឹង
សរសេរ ផង ។
២៤ ត្បិតមើលចុះ ភាសាដែលអ្នកត្រូវសរសេរនោះ យើង
បានបំភាន់ហើយ; ហេតុដូច្នោះហើយ ដល់ពេលដែលយើង
កំណត់ទុក នោះយើងនឹងធ្វើឲ្យត្បូងទាំងនេះបង្ហាញយ៉ាង
ច្បាស់ដល់ភ្នែកមនុស្ស នូវការណ៍ទាំងនេះ ដែលអ្នកត្រូវសរសេរ ។
២៥ ហើយកាលព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលនូវពាក្យ
ទាំងនេះហើយ នោះទ្រង់បានបង្ហាញដល់បងរបស់យ៉ារេឌ នូវ
បណ្ដាជនទាំង[ក] អស់នៅលើផែនដី ទាំងពួកអ្នកដែលធ្លាប់រស់នៅ
និងពួកអ្នកដែលនឹងរស់នៅផង; ហើយទ្រង់ពុំបានលាក់ពួកនោះ
ពីភ្នែកលោកឡើយ គឺរហូតដល់ចុងផែនដី ។
២៦ ត្បិតទ្រង់ធ្លាប់បានប្រាប់លោកពីពេលមុនៗថា បើ[ក]
សិនជាលោកជឿ[ខ]ដល់ទ្រង់ ថាទ្រង់អាចបង្ហាញដល់លោកនូវ
ការណ៍ទាំង[គ]អស់ — នោះនឹងត្រូវបានបង្ហាញដល់លោកមែន;
ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់ពុំអាចលាក់អ្វីពីលោកបានឡើយ
ត្បិតលោកបានដឹងថា ព្រះអម្ចាស់ ទ្រង់អាចបង្ហាញលោកនូវ
ការណ៍ទាំងអស់ ។
២៧ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅលោកថា៖
ចូរសរសេរការណ៍ទាំងនេះ ហើយបិទ[ក]ត្រាទុកចុះ; ហើយយើង
នឹងបង្ហាញ ការណ៍នោះដល់កូនចៅមនុស្ស ដល់ពេលកំណត់
របស់យើង ។
២៨ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាន
បញ្ជាដល់លោកថា លោកត្រូវបិទ[ក]ត្បូងទាំងពីរដុំ ដែល

១៦ *ក* ស.ប. វិញ្ញាណ.
១៧ *ក* ៣ នីហ្វៃ ១១:៨–១០.
១៩ *ក* ស.ប. វាំងនន.
២០ *ក* អេធើរ ១២:១៩–២១.
២១ *ក* អេធើរ ៤:១.
២៣ *ក* ស.ប. យូរីម និងធូមីម.
២៥ *ក* ម៉ូសេ ១:៨.
២៦ *ក* អេធើរ ៣:១១–១៣.
*ខ* ស.ប. ជំនឿ, ជឿ.
*គ* អេធើរ ៤:៤.
២៧ *ក* ២ នីហ្វៃ ២៧:៦–៨.
២៨ *ក* គ. និង ស. ១៧:១.

លោកបាន ទទួលនោះទុក ហើយមិនត្រូវបង្ហាញឲ្យសោះ រហូត
ដល់ពេលព្រះអម្ចាស់ ទ្រង់នឹងបង្ហាញត្បូងទាំងនោះ ដល់កូនចៅ
មនុស្ស ៕

## ជំពូកទី ៤

*ម៉ូរ៉ូណៃត្រូវបានបញ្ជាឲ្យបិទត្រានូវការសរសេរទាំងឡាយ របស់បងរបស់យ៉ារេឌទុក — គឺមិនត្រូវបើកបង្ហាញឡើយ រហូតដល់ មនុស្សមានសេចក្ដីជំនឿ ដូចជាបងរបស់យ៉ារេឌ — ព្រះគ្រីស្ទទ្រង់បញ្ជាមនុស្ស ឲ្យជឿដល់ព្រះបន្ទូលរបស់ទ្រង់ និងពាក្យសំដីរបស់ ពួកសិស្សរបស់ទ្រង់ផង — មនុស្សត្រូវបានបញ្ជាឲ្យប្រែចិត្ត ជឿដល់ដំណឹងល្អ ហើយនឹងបានសង្គ្រោះ ។*

ហើយព្រះអម្ចាស់ ទ្រង់បានបញ្ជាទៅបងរបស់យ៉ារេឌ ឲ្យចុះពីលើភ្នំ
ចេញពីវត្តមាននៃព្រះអម្ចាស់ ហើយសរសេរអំពីការណ៍ទាំង
ឡាយ ដែលលោកបានឃើញ; ហើយការណ៍ទាំងនោះត្រូវបាន
ហាមមិនឲ្យដឹងដល់កូនចៅមនុស្សឡើយ រហូតដល់ក្រោយពេល
ដែលទ្រង់ នឹងត្រូវលើកឡើងលើឈើឆ្កាង; ហើយដោយហេតុនេះ
ទើបស្ដេចម៉ូសាយបានរក្សាការណ៍ទាំងនោះទុក ដើម្បីកុំឲ្យ
ការណ៍ទាំងនោះ ដឹងដល់មនុស្សលោក រហូតដល់ក្រោយពេល
ដែលព្រះគ្រីស្ទនឹងបង្ហាញរូបអង្គទ្រង់ដល់រាស្ត្រទ្រង់ ។
២ ហើយបន្ទាប់ពីព្រះគ្រីស្ទពិតជាបានបង្ហាញរូបអង្គទ្រង់ដល់
រាស្ត្រទ្រង់ នោះទ្រង់បានបញ្ជាថា ការណ៍ទាំងនោះត្រូវ
តែសម្ដែងឲ្យដឹង ។
៣ ហើយឥឡូវនេះ បន្ទាប់ពីនោះមក ពួកគេទាំងអស់ចុះ
អន់ថយ ក្នុងការឥតជំនឿ;ហើយគ្មានអ្នកណាឡើយ ក្រៅពីពួក
សាសន៍ លេមិនប៉ុណ្ណោះ ហើយពួកគេបានបដិសេធដំណឹងល្អនៃ
ព្រះគ្រីស្ទ; ហេតុដូច្នេះហើយ ខ្ញុំត្រូវបានបញ្ជាថា ខ្ញុំត្រូវលាក់វត្ថុ
ទាំងនោះទុកនៅ ក្នុងដីទៀត ។
៤ មើលចុះ ខ្ញុំបានសរសេរនៅលើផ្ទាំងទាំងនេះ នូវការណ៍
ទាំងឡាយនោះដែលបងរបស់យ៉ារេឌបានឃើញ; ហើយពុំដែល
មាន ការណ៍អ្វីធំជាងនេះ ដែលបានសម្ដែងឲ្យឃើញ ជាង
ការណ៍ទាំងនោះ ដែលត្រូវបានសម្ដែងឲ្យឃើញ ដល់បងរបស់
យ៉ារេឌនោះទេ ។
៥ ហេតុដូច្នោះហើយ ព្រះអម្ចាស់ទ្រង់បានបញ្ជាខ្ញុំ ឲ្យសរសេរ
អំពីការណ៍ទាំងនោះ; ហើយខ្ញុំបានសរសេរអំពីការណ៍ទាំងនោះ ។
ហើយទ្រង់បានបញ្ជាខ្ញុំថា ខ្ញុំត្រូវបិទទុក; ហើយទ្រង់ក៏បានបញ្ជាថា
ខ្ញុំត្រូវបិទគ្រឿងបកប្រែទុកផង; ហេតុដូច្នោះហើយ ខ្ញុំបានបិទ ប្រ
ដាប់បកប្រែទុក ស្របតាមព្រះបញ្ញត្តិនៃព្រះអម្ចាស់ ។
៦ ត្បិតព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា៖ ការណ៍ទាំងនោះ
ពុំត្រូវទៅដល់ពួកសាសន៍ដទៃឡើយ រហូតដល់ថ្ងៃដែលពួកគេ
នឹងប្រែចិត្ត ពីអំពើទុច្ចរិតរបស់ពួកគេ ហើយក្លាយទៅជាស្អាតស្អំ
នៅចំពោះព្រះអម្ចាស់ ។
៧ ហើយនៅថ្ងៃនោះ ពួកគេនឹងអនុវត្តសេចក្ដីជំនឿជឿ
ដល់យើង ព្រះអម្ចាស់មានព្រះបន្ទូលថាដូច្នេះ គឺដូចដែល
បងរបស់យ៉ារេឌ បានធ្វើ ដើម្បីឲ្យពួកគេអាចក្លាយទៅជាបរិសុទ្ធ
ក្នុងយើង នៅពេលនោះ យើងនឹងសម្ដែងដល់ពួកគេ នូវការណ៍
ទាំងឡាយ ដែលបង របស់យ៉ារេឌបានឃើញ ព្រមទាំង
លាតត្រដាងដល់ពួកគេ នូវវិវរណៈទាំងអស់របស់យើង នេះគឺជា
ព្រះបន្ទូលនៃព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ គឺជា
ព្រះវរបិតានៃស្ថានសួគ៌ និងផែនដី និងរបស់សព្វសារពើដែល
នៅទីនោះ ។
៨ ហើយអ្នកណាដែលនឹងតតាំងទាស់នឹងព្រះបន្ទូលនៃព្រះ
អម្ចាស់ ចូរឲ្យអ្នកនោះត្រូវបណ្ដាសាចុះ; ហើយអ្នកណាដែល
នឹងបដិសេធ ការណ៍ទាំងនេះ ចូរឲ្យអ្នកនោះត្រូវបណ្ដាសាចុះ;
ត្បិតយើងនឹងពុំបង្ហាញអ្វីដែលធំជាងនេះ ដល់ពួកគេឡើយ
ព្រះយេស៊ូវគ្រីស្ទទ្រង់មាន ព្រះបន្ទូលថាដូច្នោះ; ត្បិតយើងនេះហើយ
ដែលបាននិយាយ ។
៩ ហើយតាមបញ្ជារបស់យើង នោះផ្ទៃមេឃត្រូវបានបើក
ហើយបិទ; ហើយតាមពាក្យរបស់យើង នោះផែនដី
នឹងកក្រើក; ហើយតាម បញ្ជារបស់យើង នោះ
បណ្ដាជននៅទីនោះនឹងស្លាប់ទៅ ដូចត្រូវភ្លើងឆេះ ។
១០ ហើយអ្នកណាដែលមិនជឿពាក្យរបស់យើង នោះមិនជឿ

៤ ១*ក* អេធើរ ១២:២៤.
ស.ប. បទព្រះគម្ពីរ.
*ខ* អេធើរ ៣:២១.
៣ *ក* មរមន ៨:១៤.
៥ *ក* អេធើរ ៥:១.
*ខ* គ. និង ស. ១៧:១;
យ.ស. – ប្រវត្តិ ១:៥២.
ស.ប. យូរីម និងធូមីម.
៧ *ក* ស.ប. ការញែកជាបរិសុទ្ធ.
*ខ* ម៉ូសាយ ៣:៨.
៨ *ក* ៣ នីហ្វៃ ២៩:៥–៦;
មរមន ៨:១៧.
*ខ* ២ នីហ្វៃ ២៧:១៤; ២៨:២៩–៣០.
*គ* អាលម៉ា ១២:១០–១១;
៣ នីហ្វៃ ២៦:៩–១០.
៩ *ក* ១ ពង្សាវ. ៨:៣៥;
គ. និង ស. ៧៧:៨.
*ខ* ហេលេ. ១២:៨–១៨;
មរមន ៥:២៣.

ពួកសិស្សរបស់យើងទេ; ហើយប្រសិនបើយើងមិននិយាយទេ ចូរអ្នក រាល់គ្នាវិនិច្ឆ័យចុះ; ត្បិតអ្នករាល់គ្នានឹងដឹងថា គឺយើងនេះហើយដែលបាននិយាយ នៅថ្ងៃចុងក្រោយបង្អស់ ។

១១ ប៉ុន្តែ អ្នកណាដែលជឿដល់ការណ៍ទាំងនេះ ដែលយើងបាននិយាយ គឺអ្នកនោះហើយដែលយើងនឹងមកជួប ដោយសម្ដែងនូវ វិញ្ញាណរបស់យើង ហើយអ្នកនោះនឹងដឹង ហើយធ្វើបន្ទាល់ ។ ព្រោះដោយសារវិញ្ញាណរបស់យើង អ្នកនោះនឹងដឹងថា ការណ៍ទាំង នេះពិត; ត្បិតការណ៍ទាំងនេះបញ្ចុះបញ្ចូលឲ្យមនុស្សធ្វើល្អ ។

១២ ហើយអ្វីក៏ដោយ ដែលបញ្ចុះបញ្ចូលមនុស្សឲ្យធ្វើល្អ គឺមកពីយើង; ត្បិតសេចក្ដីល្អមិនមកពីអ្នកណាក្រៅពីយើងឡើយ ។ យើងគឺ ជាតួអង្គដដែល ដែលបានដឹកនាំមនុស្សទៅដល់អស់ទាំងសេចក្ដីល្អ; អ្នកណាដែលនឹងពុំជឿពាក្យរបស់យើង នោះនឹងពុំជឿយើង — ថាយើងជាព្រះឡើយ; ហើយអ្នកណាដែលនឹងពុំជឿយើង នោះនឹងពុំជឿដល់ព្រះវរបិតា ដែលបានចាត់ឲ្យយើងមកទេ ។ ត្បិតមើលចុះ យើងគឺជាព្រះវរបិតា យើងជាពន្លឺ និងជាជីវិត ហើយជាសេចក្ដីពិតនៃពិភពលោក ។

១៣ ចូរមករកយើង ឱពួកអ្នករាល់គ្នាជាសាសន៍ដទៃអើយ ហើយយើងនឹងបង្ហាញដល់អ្នករាល់គ្នា នូវការណ៍ទាំងឡាយដ៏ធំលើស លែងទៅទៀត គឺការចេះដឹងដែលត្រូវលាក់ទុក ដោយសារការឥតជំនឿ ។

១៤ ចូរមករកយើង ឱអ្នករាល់គ្នាជាវង្សអ៊ីស្រាអែលអើយ ហើយអ្នករាល់គ្នានឹងត្រូវបានសម្ដែងឲ្យឃើញ នូវការណ៍ដ៏មហិមាទាំង ឡាយ ដែលព្រះវរបិតាទ្រង់បានសន្សំទុកឲ្យអ្នក ចាប់តាំងពីកំណើតលោកិយមក; ហើយគឺពុំទាន់បានមកអ្នករាល់គ្នាទេ ដោយសារការ ឥតជំនឿ ។

១៥ មើលចុះ កាលណាអ្នករាល់គ្នាហែករាំងនននៃការឥតជំនឿនោះ ដែលធ្វើឲ្យអ្នកជាប់នៅក្នុងស្ថានភាព នៃការទុច្ចរិត និងការ រឹងរូសនៃចិត្ត និងសេចក្ដីងងឹតនៃគំនិតរបស់អ្នក នៅពេលនោះ ការណ៍ដ៏ធំ និងអស្ចារ្យទាំងឡាយ ដែលត្រូវបានលាក់ទុកពីអ្នក ចាប់តាំង ពីកំណើតលោកិយមក — មែនហើយ កាលណាអ្នករាល់គ្នានឹងអំពាវនាវដល់ព្រះវរបិតា ដោយនូវនាមយើង ដោយចិត្តសង្រេង និងវិញ្ញាណទន់ទាប នៅពេលនោះ អ្នករាល់គ្នានឹងដឹងថា ព្រះវរបិតានឹកចាំដល់សេចក្ដីសញ្ញា ដែលទ្រង់បានធ្វើដល់ពួកអយ្យកោអ្នក ឱវង្សអ៊ីស្រាអែលអើយ ។

១៦ ហើយពេលនោះ ទិវវិវរណៈទាំងឡាយរបស់យើង ដែលយើងបានប្រើឲ្យសរសេរដោយយ៉ូហាន ដែលជាអ្នកបំរើរបស់យើង ត្រូវលាតត្រដាង នៅចំពោះភ្នែកនៃប្រជាជនទាំងអស់ ។ ចូរចាំចុះថា កាលណាអ្នករាល់គ្នា ឃើញការណ៍ទាំងនេះ នោះអ្នករាល់គ្នា នឹងដឹងថា ពេលនោះនៅជិតដែលបង្ហើយ ដែលការណ៍ទាំងនោះនឹងត្រូវបានសម្ដែងសព្វគ្រប់ ។

១៧ ហេតុដូច្នេះហើយ កាលណាអ្នករាល់គ្នានឹងទទួលបញ្ជីនេះ នោះអ្នករាល់គ្នាអាចដឹងថា កិច្ចការរបស់ព្រះវរបិតា បានចាប់ផ្ដើម ឡើង នៅលើអស់ទាំងផ្ទៃផែនដី ។

១៨ ហេតុដូច្នេះហើយ ចូរប្រែចិត្តចុះ អស់អ្នករាល់គ្នា នៅចុងផែនដីអើយ ហើយមករកយើង ហើយជឿដល់ដំណឹងល្អរបស់យើង ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើងចុះ; ត្បិតអ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ; ប៉ុន្តែអ្នកណាដែលមិនជឿ នោះនឹងត្រូវជាប់ទោស; ហើយទីសំគាល់ទាំងឡាយ នឹងទៅតាមពួកគេដែលជឿដល់នាមយើង ។

១៩ មានពរហើយ អ្នកណាដែលឃើញថាមានចិត្តស្មោះត្រង់ចំពោះនាមយើង នៅថ្ងៃចុងក្រោយបង្អស់ ត្បិតអ្នកនោះនឹងត្រូវបាន ដំកើងឡើង ឲ្យរស់នៅក្នុងនគរ ដែលរៀបចំឡើងសំរាប់អ្នកនោះ ចាប់តាំងពីកំណើតលោកិយមក ។ ហើយមើលចុះ គឺយើងនេះ ហើយដែលបាននិយាយ ។ អាម៉ែន ៕

---

១០ *ក* ២ នីហ្វៃ ៣៣:១០–១៥.
១១ *ក* គ. និង ស. ៥:១៦.
*ខ* ស.ប. ទីបន្ទាល់.
*គ* អេធើរ ៥:៣–៤;
មរ៉ូណៃ ១០:៤–៥.
១២ *ក* អាលម៉ា ៥:៤០;
មរ៉ូណៃ ៧:១៦–១៧.
*ខ* ៣ នីហ្វៃ ២៨:៣៤.
*គ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ឃ* យ៉ូហាន ៨:១២; អាលម៉ា ៣៨:៩.
១៣ *ក* ៣ នីហ្វៃ ១២:២–៣.
១៤ *ក* គ. និង ស. ១២១:២៦–២៩.
១៥ *ក* ២ នីហ្វៃ ២៧:១០.
១៦ *ក* វិវ. ១:១; ១ នីហ្វៃ ១៤:១៨–២៧.
១៧ *ក* ៣ នីហ្វៃ ២១:១–៩, ២៨.
១៨ *ក* ៣ នីហ្វៃ ២៧:២០;
មរ៉ូណៃ ៧:៣៤.
*ខ* យ៉ូហាន ៣:៣–៥.
ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការចាំបាច់.
*គ* ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
១៩ *ក* ម៉ូសាយ ២:៤១;
គ. និង ស. ៦:១៣.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទមកដាក់លើខ្លួនយើង.
១៩ *ខ* ២ នីហ្វៃ ៩:១៨.

## ជំពូកទី ៥

*សាក្សីបីនាក់ និងកិច្ចការនេះផ្ទាល់ នឹងឈរជាសាក្សីដល់ភាពពិតនៃព្រះគម្ពីរមរមន ។*

ហើយឥឡូវនេះ ខ្ញុំម៉ូរ៉ូណៃ បានសរសេរនូវពាក្យទាំងឡាយដែលត្រូវបានបញ្ជាដល់ខ្ញុំ ស្របតាមស្មារតីរបស់ខ្ញុំ; ហើយខ្ញុំបានប្រាប់អ្នក រាល់គ្នា អំពីវត្ថុទាំងឡាយដែលខ្ញុំបានបិទ[ក]ទុក; ហេតុដូច្នេះហើយ ចូរកុំប៉ះពាល់នូវវត្ថុទាំងនោះឡើយ ដើម្បីឲ្យអ្នករាល់គ្នាអាចបកប្រែ; ត្បិតការណ៍នោះត្រូវបានហាមដល់អ្នក លើកលែងតែមិនយូរប៉ុន្មានទេ វានឹងទៅជាប្រាជ្ញានៅក្នុងព្រះ ។

២ ហើយមើលចុះ អ្នកអាចមានឯកសិទ្ធិ ថាអ្នករាល់គ្នាអាចបង្ហាញផ្ទាំង[ក]ទាំងនេះ ដល់អស់អ្នកណាដែលនឹងជួយនាំការណ៍នេះ ចេញមក ។

៣ ហើយផ្ទាំងទាំងនោះ នឹងត្រូវបានបង្ហាញដល់មនុស្សបី[ក]នាក់ដោយព្រះចេស្ដានៃព្រះ; ហេតុដូច្នោះហើយ ពួកគេនឹងដឹង[ខ]យ៉ាងច្បាស់ ថាការណ៍ទាំងនេះពិត[គ] ។

៤ ហើយតាមមាត់របស់សាក្សី[ក]បីនាក់ នោះការណ៍ទាំងនេះនឹងត្រូវបានបញ្ជាក់; ហើយទីបន្ទាល់របស់អ្នកទាំងបី និងកិច្ចការនេះ ដែលនៅក្នុងនោះ នឹងបង្ហាញនូវព្រះចេស្ដានៃព្រះ និងព្រះបន្ទូលរបស់ទ្រង់ផង ដែលព្រះវរបិតា និងព្រះរាជបុត្រា និងព្រះវិញ្ញាណ បរិសុទ្ធធ្វើបន្ទាល់ដល់ការណ៍នោះ — ហើយការណ៍អស់ទាំងនេះ នឹងឈរជាសាក្សីទាស់នឹងមនុស្សលោកនៅថ្ងៃចុងក្រោយបង្អស់ ។

៥ ហើយប្រសិនបើពួកគេប្រែចិត្តយ៉ាងនេះមែន ហើយមក[ក]រកព្រះវរបិតា ដោយនូវព្រះនាមព្រះយេស៊ូវ នោះពួកគេនឹងត្រូវបានទទួល ទៅក្នុងនគរព្រះ ។

៦ ហើយឥឡូវនេះ បើសិនជាខ្ញុំគ្មានសិទ្ធិអំណាចអ្វី នៅក្នុងការណ៍អស់ទាំងនេះទេ ចូរអ្នកវិនិច្ឆ័យចុះ; ត្បិតអ្នករាល់គ្នានឹងដឹងថាខ្ញុំមានសិទ្ធិអំណាច កាលណាអ្នកនឹងឃើញខ្ញុំ ហើយយើងរាល់គ្នានឹងឈរនៅចំពោះព្រះ នៅថ្ងៃចុងក្រោយបង្អស់ ។ អាម៉ែន ៕

## ជំពូកទី ៦

*ភេត្រាទាំងឡាយរបស់ពួកយ៉ារេឌ ត្រូវបានរុញច្រានដោយខ្យល់ទៅដល់ដែនដីសន្យា — ប្រជាជនសរសើរដំកើងដល់ព្រះអម្ចាស់ ចំពោះសេចក្ដីល្អសប្បុរសរបស់ទ្រង់ — អូរីហាត្រូវបានតែងតាំងឡើង ឲ្យធ្វើជាស្ដេចលើពួកគេ — យ៉ារេឌ និងបងរបស់លោកស្លាប់ ។*

ហើយឥឡូវនេះ ខ្ញុំ ម៉ូរ៉ូណៃ ប្រាប់អំពីបញ្ជីនៃយ៉ារេឌ និងបងរបស់លោកតទៅទៀត ។

២ ត្បិតហេតុការណ៍បានកើតឡើងថា បន្ទាប់ពីព្រះអម្ចាស់ទ្រង់បានរៀបចំក្រួស[ក]ទាំងឡាយ ដែលបងរបស់យ៉ារេឌបានយកទៅលើភ្នំហើយ នោះបងរបស់យ៉ារេឌបានចុះមកពីលើភ្នំវិញ ហើយលោកបានដាក់ក្រួសទាំងនោះ ទៅក្នុងភេត្រាទាំងឡាយដែលបាន រៀបចំស្រេច គឺក្រួសមួយនៅក្នុងចុងភេត្រានីមួយៗ; ហើយមើលចុះ ក្រួសទាំងនោះបានឲ្យពន្លឺដល់ភេត្រា ។

៣ ម្ល៉ោះហើយ ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យក្រួសទាំងឡាយភ្លឺចែងចាំងនៅក្នុងទីងងឹត ដើម្បីឲ្យពន្លឺដល់មនុស្សប្រុសស្រី និងកូនក្មេង ដើម្បីកុំឲ្យពួកគេអាចឆ្លងកាត់ទឹកដ៏ធំ នៅក្នុងភាពងងឹត ។

៤ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានរៀបចំស្បៀងអាហារគ្រប់យ៉ាងហើយ ដើម្បីទុកសំរាប់ចិញ្ចឹមជីវិត ពេល នៅលើទឹក ព្រមទាំងអាហារសំរាប់ហ្វូងចៀម និងហ្វូងសត្វ និងព្រមទាំងសត្វព្រៃ ឬសត្វស្លាបណា ដែលពួកគេត្រូវយកទៅតាម — ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានធ្វើកិច្ចការទាំងនេះរួចហើយ នោះពួកគេចុះភេត្រាឬទូក ហើយចេញទៅសមុទ្រ ដោយទីពឹងដល់ព្រះអម្ចាស់ ជាព្រះរបស់ពួកគេ ។

៥ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យមានខ្យល់ដ៏[ក]ខ្លាំងមួយ បក់នៅលើផ្ទៃសមុទ្រ ឆ្ពោះទៅឯដែនដី សន្យា; ម្ល៉ោះហើយ ពួកគេត្រូវបក់បោកដោយខ្យល់នៅលើរលកសមុទ្រ ។

៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេត្រូវកប់នៅក្នុង

**៥** ១*ក* ២ នីហ្វៃ ២៧:៧—៨, ២១;
អេធើរ ៤:៤—៧.
២ *ក* ២ នីហ្វៃ ២៧:១២—១៤;
គ. និង ស. ៥:៩—១៥.
៣ *ក* ២ នីហ្វៃ ១១:៣; ២៧:១២.
*ខ* គ. និង ស. ៥:២៥.
*គ* អេធើរ ៤:១១.
៤ *ក* សូមមើល
គ. និង ស. ចំណងជើងកណ្ឌទី ១៧
និង៥ ១—៣; សូមមើលផងដែរ
ទីបន្ទាល់នៃពួកសាក្សីបី នាក់
នៅដើមទំព័រនៃព្រះគម្ពីរមរមន.
៥ *ក* មរមន ៩:២៧;
ម៉ូរ៉ូណៃ ១០:៣០—៣២.
**៦** ២*ក* អេធើរ ៣:៣—៦.
៥ *ក* អេធើរ ២:២៤—២៥.

ជំរោសមុទ្រជាច្រើនគ្រាច្រើនដង ពីព្រោះមកពីរលកទាំងឡាយដូចជាភ្នំ ដែលបានបោកមកលើពួកគេ ព្រមទាំងព្យុះដ៏ធំគួរឲ្យខ្លាចដែលបណ្ដាលមកពីសភាពខ្លាំងក្លានៃខ្យល់ ។

៧ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេត្រូវកប់នៅក្នុងទីជំរៅ នោះគ្មានទឹកអាចចូលទៅបៀតបៀនពួកគេបានឡើយ គឺភេត្រារបស់ពួកគេជិតដូចជាចាន ហើយក៏ជិតដូចទូកធំរបស់លោកណូអេដែរ; ហេតុដូច្នេះហើយ កាលពួកគេត្រូវហ៊ុំព័ទ្ធជុំវិញដោយ ទឹកជាច្រើន នោះពួកគេបានអំពាវនាវទៅព្រះអម្ចាស់ ហើយទ្រង់បាននាំយកពួកគេឡើងមកលើទឹកវិញ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ខ្យល់បក់មិនឈប់ឈរឆ្ពោះទៅដែនដីសន្យា នៅពេលដែលពួកគេនៅលើទឹក; ម្ល៉ោះហើយពួកគេត្រូវបានរុញទៅដោយខ្យល់ ។

៩ ហើយពួកគេបានច្រៀងសរសើរដំកើងដល់ព្រះអម្ចាស់; មែនហើយ បងរបស់យ៉ារេឌបានច្រៀងសរសើរដំកើង ដល់ព្រះអម្ចាស់ ហើយលោកបានថ្លែងអំណរគុណ ហើយសរសើរដំកើងដល់ព្រះអម្ចាស់ពេញមួយថ្ងៃ; ហើយកាលវេលាយប់មកដល់ នោះពួកគេពុំបាន ឈប់សរសើរដំកើងដល់ព្រះអម្ចាស់ឡើយ ។

១០ ម្ល៉ោះហើយ ពួកគេត្រូវបានរុញទៅមុខ; ហើយគ្មានយក្សសមុទ្រអាចបំបាក់ពួកគេឡើយ ហើយត្រីបាឡែនក៏មិនអាចបៀតបៀន ពួកគេដែរ; ហើយពួកគេមានពន្លឺជាប់រហូតទោះជានៅលើទឹក ក៏ដូចជានៅក្រោមទឹកក្ដី ។

១១ ម្ល៉ោះហើយ ពួកគេត្រូវបានរុញទៅមុខអស់រយៈពេលបីរយសែសិបបួនថ្ងៃនៅលើទឹក ។

១២ ហើយពួកគេបានឡើងទៅលើត្រើយ នៃដែនដីសន្យា ។ ហើយកាលពួកគេបានដាក់ជើងលើត្រើយនៃដែនដីសន្យាហើយ នោះពួកគេបានក្រាបទៅលើដី ហើយបានបន្ទាបខ្លួន នៅចំពោះព្រះអម្ចាស់ ហើយបានស្រក់ទឹកភ្នែក ដោយសេចក្ដីអំណរនៅចំពោះ ព្រះអម្ចាស់ ដោយសារសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់ឥតគណនារបស់ទ្រង់ដល់ពួកគេ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានទៅលើផ្ទៃដែនដី ហើយចាប់ផ្ដើមកាប់គាស់ដី ។

១៤ ហើយយ៉ារេឌមានកូនប្រុសបួននាក់; ហើយពួកគេត្រូវបានហៅថា យ៉ាកុម និងគីលកា និងម៉ាហា និងអូរីហា ។

១៥ ហើយបងរបស់យ៉ារេឌក៏បង្កើតបានកូនប្រុស និងកូនស្រីទាំងឡាយ ។

១៦ ហើយពួកមិត្តភក្ដិរបស់យ៉ារេឌ និងបងរបស់លោកមានចំនួនប្រហែលជាម្ភៃពីរនាក់; ហើយពួកគេផងក៏បង្កើតបានកូនប្រុសនិងកូនស្រីទាំងឡាយ មុនពេលពួកគេមកកាន់ដែនដីសន្យា; ហេតុដូច្នេះហើយ ពួកគេបានចាប់ផ្ដើមកើនចំនួនជាច្រើន ។

១៧ ហើយពួកគេត្រូវបានបង្រៀនឲ្យដើរ យ៉ាងរាបទាបនៅចំពោះព្រះអម្ចាស់; ហើយពួកគេក៏ត្រូវបានបង្រៀនពីស្ថានលើ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចាប់ផ្ដើមរាលដាលនៅពាសពេញលើផ្ទៃដែនដី ហើយកើនចំនួន ហើយកាប់គាស់ដី; ហើយពួកគេបានក្លាយទៅជាខ្លាំងពូកែនៅលើដែនដី ។

១៩ ហើយបងរបស់យ៉ារេឌ បានចាប់ផ្ដើមមានវ័យចាស់ ហើយបានឃើញថា មិនយូរប៉ុន្មានទេ លោកនឹងត្រូវចុះទៅក្នុងផ្នូរ; ហេតុ ដូច្នោះហើយ លោកបាននិយាយទៅកាន់យ៉ារេឌថា៖ ចូរយើងប្រមូលប្រជាជនយើងមក ដើម្បីយើងអាចរាប់ចំនួនពួកគេ ដើម្បីយើង អាចដឹងថា តើពួកគេមានប្រាថ្នាចង់បានអ្វីពីយើងមុនពេលយើងចុះទៅក្នុងផ្នូរ ។

២០ ហើយស្របតាមនេះ ប្រជាជនបានប្រមូលគ្នាមក ។ ឥឡូវនេះ ចំនួនកូនប្រុស និងកូនស្រីនៃបងរបស់យ៉ារេឌមានម្ភៃពីរនាក់; ហើយចំនួនកូនប្រុស និងកូនស្រីនៃយ៉ារេឌមានដប់ពីរនាក់ គឺលោកមានកូនប្រុសបួននាក់ ។

២១ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានរាប់ចំនួនប្រជាជនរបស់គេ; ហើយបន្ទាប់ពីពួកគេ បានរាប់ចំនួនពួកគេហើយ នោះពួកគេបានសួរពួកគេ នូវអ្វីដែលពួកគេចង់ឲ្យពួកគេធ្វើ មុនពេលពួកគេចុះទៅក្នុងផ្នូរ ។

២២ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនចង់ឲ្យពួកគេចាក់ប្រេងតាំងកូនប្រុសម្នាក់របស់ពួកគេ ឲ្យធ្វើជាស្ដេចលើពួកគេ ។

២៣ ហើយឥឡូវនេះ មើលចុះ ការណ៍នេះបានធ្វើឲ្យពួកគេព្រួយជាខ្លាំង ។ ហើយបងរបស់យ៉ារេឌបាននិយាយទៅកាន់ពួកគេថា៖ ប្រាកដជាការណ៍នេះនឹងនាំទៅរកការជាប់ឃុំឃាំងជាមិនខានឡើយ ។

២៤ ប៉ុន្តែ យ៉ារេឌបាននិយាយទៅបងរបស់លោកថា៖

៧ *ក* អេធើរ ២:១៧.
*ខ* លោកុ. ៦:១៤; ម៉ូសេ ៧:៤៣.
៩ *ក* ស.ប. ច្រៀង.
*ខ* ១ របា. ១៦:៧–៩; អាលម៉ា ៣៧:៣៧; គ. និង ស. ៤៦:៣២.
១៦ *ក* អេធើរ ១:៤១.
១៧ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* ស.ប. វិវរណៈ.
២២ *ក* ស.ប. ចាក់ប្រេង.
២៣ *ក* ១ សាំយូ. ៨:១០–១៨; ម៉ូសាយ ២៩:១៦–២៣.

ចូរអនុញ្ញាតឲ្យពួកគេមានស្ដេចមួយចុះ ។ ហេតុដូច្នេះហើយ ទើបលោកបាន និយាយទៅពួកគេថា៖ ចូរអ្នករាល់គ្នារើសស្ដេចមួយ ពីចំណោមកូនប្រុសទាំងឡាយរបស់ពួកយើងចុះ នូវអ្នកណាម្នាក់ ដែលអ្នករាល់ គ្នាចង់បាន ។

២៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានរើសយកកូនច្បងនៃបងរបស់យ៉ារេឌ ហើយឈ្មោះលោកគឺ ពេកាក ។ ហើយហេតុការណ៍បានកើតឡើងថា លោកបានប្រកែកមិនព្រមធ្វើជាស្ដេចរបស់ពួកគេឡើយ ។ ហើយប្រជាជនចង់ឲ្យឪពុកលោកបង្ខំ លោក ប៉ុន្តែឪពុកលោកមិនព្រមសោះ; ហើយលោកបានបញ្ជាទៅពួកគេថា ពួកគេមិនត្រូវបង្ខំអ្នកណា ឲ្យធ្វើជាស្ដេចរបស់គេឡើយ ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានរើសអស់ទាំងប្អូនប្រុសរបស់ពេកាក ហើយពួកគេមិនព្រមឡើយ ។

២៧ ហើយហេតុការណ៍បានកើតឡើងថា ពួកកូនប្រុសរបស់យ៉ារេឌក៏មិនព្រមដែរ គឺទាំងអស់គ្នា លើកលែងតែម្នាក់ប៉ុណ្ណោះ; ហើយអូរ៉ៃហាត្រូវបានចាក់ប្រេងតាំង ឲ្យធ្វើជាស្ដេចលើប្រជាជន ។

២៨ ហើយទ្រង់បានចាប់ផ្ដើមសោយរាជ្យ ហើយប្រជាជនបានចាប់ផ្ដើមចំរើនឡើង; ហើយពួកគេបានក្លាយជាមានទ្រព្យសម្បត្តិជា ច្រើនលើសលប់ ។

២៩ ហើយហេតុការណ៍បានកើតឡើងថា យ៉ារេឌបានស្លាប់ទៅ ហើយបងរបស់លោកផង ។

៣០ ហើយហេតុការណ៍បានកើតឡើងថា អូរ៉ៃហាបានដើរយ៉ាងរាបទាបនៅចំពោះព្រះអម្ចាស់ ហើយបាននឹកចាំដល់ការណ៍ដ៏ធំទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើ ដើម្បីបិតារបស់ទ្រង់ ហើយព្រមទាំងបានបង្រៀនប្រជាជនរបស់ទ្រង់ផង អំពីការណ៍ដ៏ធំទាំង ឡាយ ដែលព្រះអម្ចាស់ទ្រង់បានធ្វើ ដើម្បីពួកអយ្យកោរបស់គេ ៕

## ជំពូកទី ៧

*អូរ៉ៃហាសោយរាជ្យនៅក្នុងសេចក្ដីសុចរិត — នៅកណ្ដាលការដណ្ដើមរាជ្យ និងការទាស់ទែងគ្នា នោះនគរស៊ូល និងកូហូរត្រូវបានរៀបចំឡើង — ពួកព្យាការីកាត់ទោសដល់សេចក្ដីទុច្ចរិត និងការថ្វាយបង្គំរូបព្រះរបស់ប្រជាជន បន្ទាប់មក ពួកគេប្រែចិត្ត ។*

ហើយហេតុការណ៍បានកើតឡើងថា អូរ៉ៃហាបានអនុវត្តសេចក្ដីជំនុំជំរះនៅលើដែនដី ដោយនូវសេចក្ដីសុចរិត អស់មួយជីវិតរបស់ទ្រង់ គឺអស់ពេលដ៏យូរ ។

២ ហើយទ្រង់មានបុត្រាបុត្រីទាំងឡាយ; មែនហើយ ទ្រង់មានបុត្រាបុត្រីសាមសិបមួយនាក់ ក្នុងចំណោមនោះ មានបុត្រាម្ភៃបីនាក់ ។

៣ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បង្កើតបានគិបផងក្នុងកាលទ្រង់មានព្រះជន្មាយុចាស់ទៅហើយ ។ ហើយហេតុការណ៍ បានកើតឡើងថា គិបសោយរាជ្យជំនួសទ្រង់; ហើយគិបបង្កើតបានកូរីហូរ ។

៤ ហើយកាលកូរីហូរមានអាយុសាមសិបពីរឆ្នាំ លោកបានបះបោរប្រឆាំងនឹងបិតាលោក ហើយបានឆ្លងទៅនៅលើដែនដីនីហូរ; ហើយលោកមានកូនប្រុស និងកូនស្រីទាំងឡាយ ហើយពួកគេបានក្លាយទៅជាស្រស់ល្អដ៏លើសលប់; ហេតុដូច្នោះហើយកូរីហូរបាន ទាក់ទាញមនុស្សជាច្រើនទៅតាមលោក ។

៥ ហើយកាលលោកប្រមូលបានកងទ័ពមួយហើយ នោះលោកបានឡើងមកដែនដីម៉ូរ៉ុន គឺជាទីដែលស្ដេចគង់ ហើយបានចាប់ទ្រង់ [ក]ធ្វើជាឈ្លើយ ដែលបានសំរេចនូវពាក្យដែលបងរបស់យ៉ារេឌបាននិយាយថា ពួកគេនឹងត្រូវនាំទៅក្នុងការជាប់ឃុំឃាំង ។

៦ ឥឡូវនេះ ដែនដីម៉ូរ៉ុន ជាទីដែលស្ដេចគង់ នៅជិតដែនដីដែលពួកសាសន៍នីហ្វៃហៅថា ដែនដីចោលស្ងាត់ ។

៧ ហើយហេតុការណ៍បានកើតឡើងថា គិបរស់នៅក្នុងការជាប់ឃុំឃាំង ហើយប្រជាជនរបស់ទ្រង់ នៅក្រោមកូរីហូរជាបុត្ររបស់ ទ្រង់ រហូតដល់លោកមានព្រះជន្មាយុចាស់ខ្លាំង; ក៏ប៉ុន្តែគិបមានបុត្រមួយនាម ស៊ូល ក្នុងកាលទ្រង់មានព្រះជន្មាយុចាស់ទៅហើយ គឺនៅក្នុងពេលទ្រង់ត្រូវជាប់ឃុំឃាំងនៅឡើយ ។

៨ ហើយហេតុការណ៍បានកើតឡើងថា ស៊ូលខឹងនឹងព្រះជេដ្ឋារបស់លោក; ហើយស៊ូលបានក្លាយជាខ្លាំងពូកែ ហើយបានក្លាយជា បុរសម្នាក់ ដែលមានកម្លាំងខ្លាំងពូកែ; ហើយលោកក៏ពូកែខាងការជំនុំជំរះផង ។

៩ ហេតុដូច្នោះហើយ លោកបានទៅភ្នំអេប្រាអិម ហើយលោកបានរំលាយចេញពីភ្នំនោះ ហើយធ្វើដាវទាំងឡាយពីដែក សំរាប់ពួក អ្នកដែលលោកបានទាក់ទាញមកជាមួយលោក; ហើយបន្ទាប់ពីលោកបានប្រដាប់អាវុធឲ្យពួកគេដោយដាវហើយ នោះលោកបាន ត្រឡប់ទៅទីក្រុងនីហូរវិញ ហើយ

៧ ៥*ក* អេធើរ ៦:២៣.

បានច្បាំងជាមួយព្រះជេដ្ឋារបស់លោក គឺគូរីហូរ ដោយមធ្យោបាយនេះ លោកយកបាននគរ ហើយ បានថ្វាយនគរទៅគិប ជាបិតាលោក ។

១០ ហើយឥឡូវនេះ ដោយសារការដែលស៊ូលបានធ្វើ នោះបិតាលោកបានប្រគល់នគរឲ្យលោក; ហេតុដូច្នេះហើយ ទ្រង់បាន ចាប់ផ្ដើមសោយរាជ្យជំនួសបិតាលោក ។

១១ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានអនុវត្តសេចក្ដីជំនុំជំរះ ដោយនូវសេចក្ដីសុចរិត; ហើយទ្រង់បានពង្រីកនគររបស់ ទ្រង់ពាសពេញលើងស់ទាំងផ្ទៃដែនដី ត្បិតប្រជាជនមានចំនួនដ៏ច្រើនលើសលប់ ។

១២ ហើយហេតុការណ៍បានកើតឡើងថា ស៊ូលក៏បង្កើតបាន បុត្រាបុត្រីទាំងឡាយ ។

១៣ ហើយគូរីហូរបានប្រែចិត្ត ចំពោះអំពើអាក្រក់ជាច្រើន ដែលលោកបានប្រព្រឹត្ត; ហេតុដូច្នោះហើយ ស៊ូលបានប្រទានអំណាចដល់ លោកនៅក្នុងនគរ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា គូរីហូរមានកូនប្រុស និងកូនស្រីជាច្រើន ។ ហើយក្នុងចំណោមកូនប្រុសរបស់គូរីហូរ នោះមានម្នាក់ឈ្មោះ ណូអេ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា ណូអេបាន បះបោរប្រឆាំងនឹងស៊ូល ដែលជាស្ដេច ព្រមទាំងប្រឆាំងនឹង ឪពុកខ្លួន គឺគូរីហូរ ផង ហើយបានទាក់ទាញបងរបស់ខ្លួន គឺកូហូរទៅជាមួយ ហើយបងប្អូនទាំងអស់របស់លោក និង មនុស្សជាច្រើនផង ។

១៦ ហើយលោកបានធ្វើចម្បាំងនឹងស៊ូលដែលជាស្ដេច ក្នុង ចម្បាំងនោះ លោកយកបានដែនដី ដែលជាកេរ្ដិ៍អាករដំបូងរបស់ ពួកគេ; ហើយលោកបានក្លាយទៅជាស្ដេច លើផ្នែកនៃដែនដីនោះ ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានធ្វើ ចម្បាំងជាថ្មីនឹងស៊ូល ដែលជាស្ដេច ហើយទ្រង់ចាប់បានស៊ូល ដែលជាស្ដេច ហើយនាំទ្រង់យកទៅជាឈ្លើយ ទៅឯម៉ូរ៉ុន ។

១៨ ហើយហេតុការណ៍បានកើតឡើងថា នៅពេលដែល ទ្រង់រៀបនឹងប្រហារលោក នោះពួកបុត្រារបស់ស៊ូលបានលប ចូលទៅ ក្នុងដំណាក់របស់ណូអេ នៅពេលយប់ ហើយ បានសម្លាប់ទ្រង់ចោលទៅ ហើយបានទំលាយទ្វារគុក ហើយបាន នាំបិតាពួកគេចេញមក ហើយបានលើកទ្រង់ដាក់លើបល្ល័ង្ក ក្នុង នគររបស់ទ្រង់ផ្ទាល់ ។

១៩ ហេតុដូច្នោះហើយ បុត្រនៃណូអេ បានកសាងនគរ របស់ទ្រង់ឡើងជំនួសបិតាទ្រង់វិញ; ទោះជាយ៉ាង ណាក៏ដោយ គង់តែពួកគេ ពុំមានអំណាចអ្វី ទៅលើស៊ូល ដែលជាស្ដេចទៀតឡើយ ហើយប្រជាជនដែលនៅក្រោម រាជ្យរបស់ស្ដេចស៊ូល បានចំរើនឡើងជាខ្លាំង ហើយបាន ក្លាយទៅជាខ្លាំងពូកែ ។

២០ ហើយប្រទេសត្រូវបានបែងចែក; ហើយមាននគរពីរ គឺនគររបស់ស៊ូល និងនគររបស់កូហូរ ដែលជាបុត្ររបស់ណូអេ ។

២១ ហើយកូហូរ ដែលជាបុត្ររបស់ណូអេ បានបញ្ជា ប្រជាជនរបស់ទ្រង់ឲ្យទៅច្បាំងនឹងស៊ូល នៅក្នុងចម្បាំងនោះ ស៊ូលបានវាយ ឈ្នះពួកគេ ហើយបានសម្លាប់កូហូរ ។

២២ ហើយឥឡូវនេះ កូហូរមានបុត្រម្នាក់ ដែលមានឈ្មោះថា នីម៉្រូឌ; ហើយនីម៉្រូឌបានព្រមប្រគល់នគររបស់កូហូរទៅឲ្យស៊ូល ហើយលោកបានទទួលការប្រោសប្រណីនៅក្នុងព្រះនេត្រនៃស៊ូល; ហេតុដូច្នោះហើយ ស៊ូលបានប្រទានការប្រោសប្រណីដ៏ច្រើនដល់ លោក ហើយលោកបានធ្វើតាមទំនើងចិត្តខ្លួន នៅក្នុងនគររបស់ ស៊ូល ។

២៣ ហើយនៅក្នុងរាជ្យរបស់ស៊ូល មានពួកព្យាការីមកក្នុង ចំណោមប្រជាជន ដែលត្រូវបានព្រះអម្ចាស់ចាត់ឲ្យមកព្យាករថា អំពើទុច្ចរិត និង[ក]ការថ្វាយបង្គំរូបព្រះនៃប្រជាជន កំពុងតែនាំបណ្ដាសាមួយមកដល់ដែនដីនេះ ហើយពួកគេនឹងត្រូវបំផ្លាញចោល បើសិន ជាពួកគេពុំប្រែចិត្តទេ ។

២៤ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបាន ជេរប្រមាថពួកព្យាការី ហើយបានចំអកឡកឡឺយដាក់ពួកគេ ។ ហើយហេតុ ការណ៍បានកើតឡើងថា ស្ដេចស៊ូលបានអនុវត្តសេចក្ដីជំនុំជំរះ ដល់អស់អ្នកទាំងឡាយណា ដែលបានជេរប្រមាថពួក ព្យាការី ។

២៥ ហើយលោកបានអនុវត្តច្បាប់មួយ ទូទៅអស់ទាំងដែនដី ដែលប្រទានអំណាចទៅពួកព្យាការី ថាពួកគេអាចទៅទីណាក៏ដោយ តាមតែគេចង់ ហើយដោយហេតុនេះ ប្រជាជនត្រូវបាននាំមក ដល់ការប្រែចិត្ត ។

២៦ ហើយពីព្រោះប្រជាជនបានប្រែចិត្តពីអំពើទុច្ចរិតទាំងឡាយ និងការថ្វាយបង្គំរូបព្រះរបស់ពួកគេ នោះព្រះអម្ចាស់ទ្រង់បាន លើក លែងជីវិតឲ្យពួកគេ ហើយពួកគេបាន ចាប់ផ្ដើមចំរើនឡើងនៅលើដែនដីទៀត ។ ហើយហេតុការណ៍

២៣ *ក* ស.ប. ការថ្វាយបង្គំរូបព្រះ.

បានកើតឡើងថា ស៊ូលមានបុត្រា បុត្រីទាំងឡាយ ក្នុងកាលទ្រង់
មានព្រះជន្មាយុចាស់ទៅហើយ ។
២៧ ហើយអស់មានសង្គ្រាមទៀត នៅក្នុងជីវិតស៊ូល;
ហើយទ្រង់បាននឹកចាំដល់ការណ៍ដ៏ធំទាំងឡាយ ដែលព្រះ
អម្ចាស់ទ្រង់បានធ្វើ ដើម្បីពួកអយ្យកោរបស់ទ្រង់ ក្នុងការនាំពួក
គេឆ្លងកាត់ទីជំរៅដ៏ធំ មកដល់ដែនដីសន្យា; ហេតុដូច្នោះហើយ
ទ្រង់បានអនុវត្តសេចក្ដី ជំនុំជំរះ ដោយនូវសេចក្ដីសុចរិត អស់
មួយជីវិតទ្រង់ ៕

ជំពូកទី ៨

*មានការប្រជែង និងការទាស់ទែងគ្នាអំពីនគរ — អ័គីសបង្កើតបក្សព័ន្ធឃាតមួយ ដែលជាប់ពាក្យសម្បថ ដើម្បីសម្លាប់ស្ដេច — បក្សព័ន្ធសម្ងាត់ទាំងឡាយ គឺជារបស់ផងអារក្ស ហើយបណ្ដាលឲ្យមានការបំផ្លិចបំផ្លាញសាសន៍ទាំងឡាយ — ពួកសាសន៍ដទៃ សម័យទំនើប ត្រូវបានព្រមានទប់ទល់នឹងបក្សព័ន្ធសម្ងាត់ ដែលនឹងស្វែងរករំលំសេរីភាពរបស់អស់ទាំងដែនដី, សាសន៍, និងនគរទាំង ឡាយ ។*

ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បង្កើតបានអូមើរ
ហើយអូមើរសោយរាជ្យជំនួសទ្រង់ ។ ហើយអូមើរបង្កើតបាន
យ៉ារេឌ; ហើយយ៉ារេឌបង្កើតបានបុត្រាបុត្រីទាំងឡាយ ។
២ ហើយយ៉ារេឌបានបះបោរប្រឆាំងនឹងបិតាខ្លួន ហើយបានមក
នៅឯដែនដីហេត ។ ហើយហេតុការណ៍បានកើតឡើងថា លោក
បានបញ្ឆោរមនុស្សជាច្រើន ដោយសារសំដីដ៏មានកលល្បិច
របស់លោក រហូតដល់លោកយកបានពាក់កណ្ដាលនគរ ។
៣ ហើយកាលលោកយកនគរបានមួយចំហៀងហើយ
នោះលោកទៅច្បាំងជាមួយនឹងបិតាលោក ហើយលោកបាន
ចាប់បិតាលោក យកទៅក្នុងការជាប់ឃុំឃាំង ហើយបានឲ្យទ្រង់
បំរើនៅក្នុងការជាប់ឃុំឃាំង;
៤ ហើយឥឡូវនេះ នៅសម័យនៃរាជ្យរបស់អូមើរ នោះទ្រង់
បានរស់នៅក្នុងការជាប់ឃុំឃាំង អស់ពាក់កណ្ដាលជីវិតរបស់
ទ្រង់ ។ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បង្កើតបាន
បុត្រាបុត្រីទាំងឡាយ នៅក្នុងចំណោមនោះ គឺមានអេស៊ីរ៉ុម និង
កូរីអានទុមើរ ។
៥ ហើយពួកគេខឹងជាខ្លាំង ដោយសារការទាំងឡាយ ដែល
ព្រះជេដ្ឋារបស់គេ គឺយ៉ារេឌបានធ្វើ ដរាបដល់ពួកគេបានកែនទ័ព
មួយ ហើយទៅច្បាំងនឹងយ៉ារេឌ ។ ហើយហេតុការណ៍
បានកើតឡើងថា ពួកគេបានទៅច្បាំងនឹងលោកនៅពេលយប់ ។
៦ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេ
បានសម្លាប់កងទ័ពរបស់យ៉ារេឌហើយ នោះពួកគេក៏ជិតសម្លាប់លោ
កផងដែរ; ហើយលោកបានអង្វរពួកគេកុំឲ្យសម្លាប់លោកចោល
ហើយលោកព្រមប្រគល់នគរទៅឲ្យបិតាខ្លួនវិញ ។ ហើយហេ
តុការណ៍បាន កើតឡើងថា ពួកគេបានលើកលែងជីវិតឲ្យលោក ។
៧ ហើយឥឡូវនេះ យ៉ារេឌបានកើតទុក្ខជាខ្លាំង ដោយសារ
ការបាត់បង់នគរ ព្រោះលោកភ្ជាប់ចិត្តលោកទៅលើនគរ
និងទៅលើ សេចក្ដីរុងរឿងនៃលោកិយ ។
៨ ឥឡូវនេះ កូនស្រីរបស់យ៉ារេឌ ដែលជាអ្នកជំនាញយ៉ាងខ្លាំង
ហើយដោយបានឃើញសេចក្ដីទុក្ខព្រួយរបស់ឪពុក នាងក៏គិតរក
ផែនការមួយ ដែលនាងអាចយកនគរមកសងឪពុកនាងវិញ ។
៩ ឥឡូវនេះ កូនស្រីរបស់យ៉ារេឌស្រស់ល្អដ៏លើសលប់ ។
ហើយហេតុការណ៍បានកើតឡើងថា នាងបានពិភាក្សាជាមួយ
នឹងឪពុក នាង ហើយបាននិយាយទៅកាន់ឪពុកថា៖ ហេតុអ្វីក៏
ឪពុកកើតទុក្ខដ៏ខ្លាំងយ៉ាងនេះ ? តើឪពុកមិនបានអានបញ្ជី ដែល
ពួកអយ្យកោ យើងបាននាំឆ្លងកាត់ទីជំរៅដ៏ធំនោះទេឬអី ? មើលចុះ
តើពុំមានដំណើររឿងមួយ អំពីមនុស្សជំនាន់ដើមថា ដោយសារ
ការប្រើផែន ការសម្ងាត់របស់ពួកគេ នោះពួកគេយកបាននគរ
ទាំងឡាយ ហើយបានសេចក្ដីរុងរឿងដ៏ធំឬទេអី ?
១០ ហើយឥឡូវនេះ ហេតុដូច្នេះហើយ សូមឪពុកហៅអ័គីស
ជាកូនប្រុសរបស់គិមណូរមក; ហើយមើលចុះ ខ្ញុំស្រស់ល្អ
ហើយខ្ញុំនឹង រាំនៅខាងមុខគាត់ ហើយខ្ញុំនឹងធ្វើឲ្យគាត់ពេញចិត្ត
ដែលគាត់នឹងប្រាថ្នាចង់បានខ្ញុំធ្វើជាប្រពន្ធ; ហេតុដូច្នោះហើយ
បើសិនជាគាត់ប្រាថ្នា ពីឪពុក ចង់ឲ្យឪពុកប្រគល់ខ្ញុំទៅគាត់ធ្វើជា
ប្រពន្ធ ពេលនោះ ឪពុកត្រូវនិយាយថា៖ ខ្ញុំនឹងឲ្យនាង បើសិនជា
អ្នកនាំមកឲ្យខ្ញុំ នូវព្រះសិរ របស់បិតាខ្ញុំជាស្ដេច ។
១១ ហើយឥឡូវនេះ អូមើរ គឺជាមិត្តរបស់អ័គីស; ហេតុ
ដូច្នោះហើយ កាលយ៉ារេឌឲ្យហៅអ័គីសមក នោះកូនស្រីរបស់
យ៉ារេឌ បាន រាំនៅខាងមុខគាត់ នាងបានធ្វើឲ្យគាត់ពេញចិត្ត
ដរាបដល់គាត់ចង់បាននាងយកមកធ្វើជាប្រពន្ធ ។ ហើយហេតុ
ការណ៍បានកើតឡើង ថា គាត់បាននិយាយទៅកាន់យ៉ារេឌថា៖
សូមឲ្យនាងមកខ្ញុំធ្វើជាប្រពន្ធចុះ ។

២៧ *ក* អេធើរ ៦:៤, ១២.
៨ ៩*ក* ៣ នីហ្វៃ ៦:២៨; ហេលេ. ៦:២៦–៣០; ម៉ូសេ ៥:៥១–៥២.
១០ *ក* ម៉ាកុស ៦:២២–២៨.

១២ ហើយយ៉ារេឌបាននិយាយទៅកាន់គាត់ថា៖ ខ្ញុំនឹងឲ្យនាងទៅអ្នក បើសិនជាអ្នកនាំមកឲ្យខ្ញុំ នូវព្រះសិររបស់បិតាខ្ញុំជាស្ដេច ។

១៣ ហើយហេតុការណ៍បានកើតឡើងថា អ័គីសបាននាំអស់ទាំងញាតិសន្ដាន របស់គាត់មកឯផ្ទះរបស់យ៉ារេឌ ហើយបាននិយាយ ទៅពួកគេថា៖ តើអ្នករាល់គ្នាស្បថនឹងខ្ញុំទេថា អ្នករាល់គ្នានឹងស្មោះត្រង់ចំពោះខ្ញុំ ក្នុងកិច្ចការដែលខ្ញុំចង់ឲ្យអ្នករាល់គ្នាធ្វើ ?

១៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេទាំងអស់គ្នា ក បានស្បថនឹងគាត់ ដោយនូវព្រះនាមព្រះនៃស្ថានសួគ៌ និងពួកពលស្ថាន សួគ៌ទាំងឡាយផង និងផែនដីផង និងក្បាលរបស់ពួកគេផងថា បើសិនជាអ្នកណាបែកចិត្តពីកិច្ចការ ដែលអ័គីសចង់ឲ្យគេធ្វើ នោះនឹង ត្រូវកាត់ក្បាលចោល; ហើយបើសិនជាអ្នកណាធ្វើឲ្យខូះខ្ចាយនូវអ្វីៗ ដែលអ័គីសប្រាប់ពួកគេ អ្នកនោះនឹងត្រូវបាត់បង់ជីវិត ។

១៥ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានយល់ព្រមជាមួយនឹងអ័គីសយ៉ាងនេះហើយ ។ ហើយអ័គីសបានធ្វើពិធី ក ស្បថឲ្យ ពួកគេ ដូចគ្នានឹងពិធីដែលមនុស្ស ខ ជំនាន់ដើមបានធ្វើ ដើម្បីស្វែងរកអំណាច គឺបន្តមកពីកាអ៊ីន ដែលជាឃាតកចាប់តាំងពីដើមដំបូងមក ។

១៦ ហើយពាក្យសម្បថទាំងនោះ ត្រូវបានរក្សាទុកដោយអំណាចនៃអារក្ស ដើម្បីធ្វើពិធីសម្បថដល់ប្រជាជន ដើម្បីឃាំងពួកគេឲ្យ នៅក្នុងភាពងងឹត ដើម្បីជួយអ្នកណាដែលស្វែងរកអំណាច ហើយធ្វើឃាត ហើយប្លន់ ហើយកុហក ហើយប្រព្រឹត្តអំពើទុច្ចរិត និងអំពើ សហាយស្មន់គ្រប់បែបយ៉ាង ។

១៧ ហើយគឺជាកូនស្រីរបស់យ៉ារេឌនេះហើយដែលជាអ្នកដាក់វាទៅក្នុងចិត្តលោក ឲ្យស្វែងរកការណ៍ទាំងនេះពីជំនាន់ដើម; ហើយ យ៉ារេឌដាក់ទៅក្នុងចិត្តរបស់អ័គីស; ហេតុដូច្នោះហើយ អ័គីសឲ្យវាទៅញាតិសន្ដាន និងមិត្តភក្ដិរបស់គាត់ នាំពួកគេវង្វេងដោយ សេចក្ដីសន្យាដ៏ល្អៗ ឲ្យធ្វើកិច្ចការណាដែលគាត់ចង់ធ្វើ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានបង្កើត ក បក្សព័ន្ធសម្ងាត់មួយ ដូចជាពួកជំនាន់ដើម ដែលជាអំពើមួយដ៏គួរខ្ពើម ឆ្អើម និងទុច្ចរិតលើសអ្វីៗទាំងអស់នៅចំពោះព្រះនេត្រព្រះ ។

១៩ ត្បិតព្រះអម្ចាស់ ទ្រង់ពុំធ្វើការដោយបក្សព័ន្ធសម្ងាត់ទាំងឡាយទេ ហើយទ្រង់ក៏មិនចង់ឲ្យមនុស្ស កំចាយឈាមដែរ តែហាមមិន ឲ្យធ្វើយ៉ាងនេះ គ្រប់ករណីទាំងអស់ ចាប់តាំងពីកំណើតនៃមនុស្សមក ។

២០ ហើយឥឡូវនេះ ខ្ញុំម៉ូរ៉ូណៃ មិនសរសេរនូវរបៀបនៃសេចក្ដីសម្បថ និងបក្សព័ន្ធរបស់ពួកគេទេ ត្បិតការណ៍នេះត្រូវបានឲ្យខ្ញុំដឹងថា វាមាននៅក្នុងចំណោមប្រជាជនទាំងអស់ ហើយវាមាននៅក្នុងចំណោមពួកសាសន៍លេមិន ។

២១ ហើយពួកគេបានបណ្ដាលឲ្យមាន ក ការបំផ្លិចបំផ្លាញដល់ប្រជាជននេះ ដែលខ្ញុំកំពុងតែនិយាយដល់នៅពេលឥឡូវនេះ ព្រមទាំង ការបំផ្លិចបំផ្លាញដល់ប្រជាជននីហ្វៃផង ។

២២ ហើយសាសន៍ណាក៏ដោយដែលគាំទ្របក្សព័ន្ធសម្ងាត់បែបនេះ ដើម្បីយកអំណាច និងកំរៃ រហូតដល់វារាលដាលពេញទាំង សាសន៍ មើលចុះ សាសន៍នោះនឹងត្រូវបំផ្លាញចោល; ត្បិតព្រះអម្ចាស់ ទ្រង់ពុំទុកឲ្យ ក ឈាមនៃពួកបរិសុទ្ធរបស់ទ្រង់ ដែលនឹងត្រូវខ្ចាយ ដោយពួកគេ ត្រូវអំពាវនាវដល់ទ្រង់ជានិច្ច ខ ពីដីមកសូមការសងសឹកដល់ពួកគេ ដោយទ្រង់នៅតែមិនសងសឹកឲ្យពួកគេនៅឡើយ ។

២៣ ហេតុដូច្នោះហើយ ឱពួកសាសន៍ដទៃអើយ គឺជាប្រាជ្ញានៅក្នុងព្រះ ដែលការណ៍ទាំងនេះត្រូវបានបង្ហាញដល់អ្នក ដើម្បីដោយសារការណ៍នេះ នោះអ្នករាល់គ្នាអាចប្រែចិត្ត ពីអំពើបាបទាំងឡាយរបស់អ្នក ហើយកុំទុកឲ្យបក្សព័ន្ធសម្លាប់ដ៏សម្ងាត់ទាំងនេះត្រួតត្រា លើអ្នករាល់គ្នាបានឡើយ គឺជាពួកដែលបានបង្កើតឡើង ដើម្បីរក ក អំណាច និងកំរៃ — ហើយកិច្ចការ មែនហើយ គឺកិច្ចការនៃការបំផ្លិច បំផ្លាញនឹងធ្លាក់មកលើអ្នករាល់គ្នាមែនហើយ គឺដាវនៃសេចក្ដីយុត្តិធម៌របស់ព្រះ ដ៏នៅអស់កល្បជានិច្ចនឹងធ្លាក់មកលើអ្នករាល់គ្នា ចំពោះការរំលំ និងការបំផ្លិចបំផ្លាញដល់អ្នករាល់គ្នា បើសិនជាអ្នករាល់គ្នានឹងទុកឲ្យការណ៍ទាំងនេះកើតឡើង ។

២៤ ហេតុដូច្នោះហើយ ព្រះអម្ចាស់ ទ្រង់បញ្ជាអ្នករាល់គ្នាថាកាលណាអ្នករាល់គ្នាឃើញការណ៍ទាំងនេះ កើតឡើងក្នុងចំណោម អ្នករាល់គ្នា នោះអ្នករាល់គ្នាត្រូវភ្ញាក់រលឹក ចំពោះស្ថានការដ៏ស្ញែងខ្លាចរបស់អ្នករាល់គ្នា ដោយព្រោះបក្សព័ន្ធសម្ងាត់នេះដែលនឹង មាននៅក្នុងចំណោមអ្នករាល់គ្នា; បើពុំនោះសោតទេ

១៤ *ក* ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.
១៥ *ក* ស.ប. សម្បថ.
*ខ* លោកុ. ៤:៧–៨;
ម៉ូសេ ៥:២៨–៣០.
១៨ *ក* ស.ប. បក្សព័ន្ធសម្ងាត់.
២១ *ក* ហេលេ. ៦:២៨.
២២ *ក* មរមន ៨:២៧, ៤០–៤១.
*ខ* ស.ប. ការសងសឹក.
២៣ *ក* ១ នីហ្វៃ ២២:២២–២៣;
ម៉ូសេ ៦:១៥.

គួរឲ្យវេទនាដល់វាណាស់ ដោយព្រោះឈាមរបស់ពួកអ្នកដែល
ត្រូវស្លាប់; ត្បិតពួកគេអំពាវនាវចេញពីធូលីដី សូមឲ្យមានការ
សងសឹកដល់បក្សព័ន្ធនេះ និងដល់ពួកអ្នកដែលបង្កើតវាឡើងផង ។
២៥ ត្បិតហេតុការណ៍បានកើតឡើងថា អស់អ្នកណាដែល
បង្កើតវាឡើង ដើម្បីស្វែងរករំ[ក]លំសេរីភាពនៃអស់ទាំងដែនដី,
សាសន៍ និងប្រទេសទាំងឡាយ; ហើយវានាំមកនូវការបំផ្លិចបំផ្លាញ
ដល់ប្រជាជនទាំងអស់ ត្បិតវាត្រូវបានបង្កើត[ខ]ឡើងដោយអារក្ស
ដែលជា បិតានៃការកុហកទាំងអស់; គឺជាអ្នកភូតកុហកដដែល
នោះ ដែលបានបញ្ឆោតឪពុកម្ដាយដើមរបស់យើង មែនហើយ
គឺជាអ្នកភូតកុហក ដដែលនោះ ដែលបាននាំឲ្យមនុស្សធ្វើឃាត
ចាប់តាំងពីដើមដំបូងមក; ជាអ្នកដែលបានធ្វើឲ្យចិត្តមនុស្សរឹងទទឹង
ធ្វើឲ្យពួកគេសម្លាប់ពួក ព្យាការី ហើយចោលថ្មទៅលើពួកគេ
ហើយបណ្ដេញពួកគេចេញ ចាប់តាំងពីដំបូងមកម្ល៉េះ ។
២៦ ហេតុដូច្នោះហើយ ខ្ញុំម៉ូរ៉ូណៃ ត្រូវបានបញ្ជាឲ្យសរសេរនូវ
ការណ៍ទាំងនេះ ដើម្បីឲ្យអំពើអាក្រក់ ត្រូវបាត់អស់ទៅ ហើយ
ថាពេល វេលានឹងមកដល់ ដែលអារក្សសាតាំងពុំ[ក]អាចមាន
អំណាច[ខ] ទៅលើដួងចិត្តនៃកូនចៅមនុស្សបានទេ ប៉ុន្តែ ពួកគេអាច
ត្រូវបានបញ្ចុះបញ្ចូល ឲ្យធ្វើល្អពុំឈប់ឈរ ដើម្បីឲ្យពួកគេ អាច
មកដល់ប្រភព នៃអស់ទាំងសេចក្ដីសុចរិត ហើយបានសង្គ្រោះ ៕

## ជំពូកទី ៩

*នគរផ្លាស់ប្ដូរពីម្នាក់ទៅម្នាក់ ដោយការបន្តឲ្យកូនចៅ, កូដោបាយ, និងឃាតកម្ម — អមើរបានឃើញព្រះរាជបុត្រានៃសេចក្ដីសុចរិត — ព្យាការីជាច្រើនស្រែកហៅឲ្យប្រែចិត្ត — អំណត់អត់ និងពស់អសិរពិស បៀតបៀនដល់ប្រជាជន ។*

ហើយឥឡូវនេះ ខ្ញុំម៉ូរ៉ូណៃ បន្តបញ្ជីរបស់ខ្ញុំទៀត ។ ហេតុ
ដូច្នេះហើយ មើលចុះ ហេតុការណ៍បានកើតឡើងថា ដោយសា
របក្សព័ន្ធ សម្ងាត់[ក]របស់អ័គីស និងពួកមិត្តរបស់វា មើលចុះ ពួក
គេបានរំលំនគររបស់អូមើរ ។
២ ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអម្ចាស់ទ្រង់
អាណិតអាសូរដល់អូមើរ និងពួកបុត្រាបុត្រីទាំងឡាយរបស់
ទ្រង់ដែរ ដែលមិន បានស្វែងរកការបំផ្លិចបំផ្លាញទ្រង់ចោល ។
៣ ហើយព្រះអម្ចាស់ទ្រង់ព្រមានដល់អូមើរ នៅក្នុងសុបិនមួយ
ថា ទ្រង់ត្រូវចាកចេញពីដែនដីទៅ; ហេតុដូច្នោះហើយ អូមើរបាន
ចាក ចេញពីដែនដី ទៅជាមួយនឹងរាជវង្សានុវង្សរបស់ទ្រង់ ហើយ
បានធ្វើដំណើរអស់ជាច្រើនថ្ងៃ ហើយបានដើរកាត់តាមភ្នំស៊ិម[ក]
ហើយកាត់តាម ជិត[ខ]កន្លែងដែលពួកសាសន៍នីហ្វៃត្រូវបំផ្លាញបង់
ហើយចាប់ពីទីនោះ ឆ្ពោះទៅទិសខាងកើត ហើយទៅដល់កន្លែង
មួយ ដែលហៅថា អាប់ឡុម នៅជិតឆ្នេរសមុទ្រ ហើយនៅទីនោះ
ទ្រង់បានបោះត្រសាល ព្រមទាំងបុត្រាបុត្រីទាំងឡាយរបស់ទ្រង់
ផង និងរាជវង្សានុវង្សរបស់ ទ្រង់ទាំងអស់ផង លើកលែងតែយ៉ារេឌ
និងគ្រួសារលោក ។
៤ ហើយហេតុការណ៍បានកើតឡើងថា យ៉ារេឌត្រូវបាន
ចាក់ប្រេងតាំងឲ្យធ្វើជាស្ដេចលើប្រជាជន ដោយដៃនៃអំពើ
ទុច្ចរិត; ហើយ ទ្រង់ប្រគល់បុត្រីទៅឲ្យអ័គីស ធ្វើជាប្រពន្ធ ។
៥ ហើយហេតុការណ៍បានកើតឡើងថា អ័គីសបានស្វែងរកជីវិត
ឪពុកក្មេករបស់ខ្លួន; ហើយគាត់បានសូមជំនួយ ពីពួកអ្នក
ដែលគាត់ បានធ្វើពិធីស្បថ ដោយសម្បថនៃពួកចាស់បុរាណ
ហើយពួកគេយកបានព្រះសិររបស់ឪពុកក្មេកគាត់ នៅពេល
ទ្រង់អង្គុយនៅលើបល្ល័ង្ក ធ្វើសវនាការ ដល់ប្រជាជនរបស់គេ ។
៦ ដោយសារសង្គមសម្ងាត់ និងទុច្ចរិត បានរាលដាលយ៉ាង
ធំក្រៃលែង នោះវាបានធ្វើឲ្យចិត្តមនុស្សទាំងអស់ពុករលួយ; ហេតុ
ដូច្នេះ ហើយ យ៉ារេឌត្រូវគេធ្វើឃាតនៅលើបល្ល័ង្ករបស់ទ្រង់
ហើយអ័គីសសោយរាជ្យជំនួសទ្រង់វិញ ។
៧ ហើយហេតុការណ៍បានកើតឡើងថា អ័គីសបាន
ចាប់ផ្ដើមច្រណែននឹងបុត្ររបស់ខ្លួន ហេតុដូច្នេះហើយ ទ្រង់បាន
ឃាំងបុត្រទុកនៅ ក្នុងគុក ហើយឲ្យអាហារបន្តិចបន្តួច ឬក៏ពុំឲ្យ
សោះ រហូតដល់បុត្រស្លាប់ទៅ ។
៨ ហើយឥឡូវនេះ ព្រះអនុជរបស់បុត្រដែលត្រូវសុគតនោះ
(ហើយលោកមាននាមថា នីមរ៉ា) ខឹងនឹងបិតាខ្លួន ដោយសារ
ការដែល បិតាខ្លួនបានធ្វើដល់ព្រះជេដ្ឋាលោក ។
៩ ហើយហេតុការណ៍បានកើតឡើងថា នីមរ៉ាបានប្រមូល
មនុស្សមួយចំនួនតូចមក ហើយបានរត់ចេញពីដែនដី ហើយបាន
មកនៅជា មួយនឹងអូមើរ ។
១០ ហើយហេតុការណ៍បានកើតឡើងថា អ័គីសបង្កើតបាន

២៥ *ក* ស.ប. សេរី, សេរីភាព.
*ខ* លោកុ. ៣:១–១៣;
២ នីហ្វៃ ៩:៩; ម៉ូសាយ ១៦:៣;
ម៉ូសេ ៤:៥–១៩.
២៦ *ក* ១ នីហ្វៃ ២២:២៦.
*ខ* ២ នីហ្វៃ ៣៣:៤;
ម៉ូរ៉ូណៃ ៧:១២–១៧.
**៩** ១*ក* អេធើរ ៨:១៣–១៧.
៣ *ក* មរមន ១:៣; ៤:២៣.
*ខ* មរមន ៦:១–១៥.

បុត្រាទាំងឡាយទៀត ហើយពួកគេបានទទួលការគាំទ្រពីប្រជាជន
ទោះបីពួកគេបានស្បថដល់ទ្រង់ថា នឹងធ្វើអំពើទុច្ចរិតគ្រប់បែប
យ៉ាង ស្របតាមអ្វីដែលទ្រង់ប្រាថ្នាក៏ដោយ ។
១១ ឥឡូវនេះ ប្រជាជនរបស់អ័គីស មានបំណងចង់បានកំរៃ
ដូចគ្នានឹងអ័គីសចង់បានអំណាច; ហេតុដូច្នោះហើយ ពួកបុត្រា
របស់ អ័គីស បានឲ្យប្រាក់ដល់ពួកគេ ដោយមធ្យោបាយនេះ ពួក
គេទាក់ទាញបានប្រជាជនភាគច្រើនតាមពួកគេ ។
១២ ហើយក៏ចាប់ផ្ដើមមានសង្គ្រាមមួយ រវាងពួកបុត្រារបស់
អ័គីសនិងអ័គីស ដែលអស់រយៈពេលជាច្រើនឆ្នាំ មែនហើយ
នាំឲ្យមាន ការបំផ្លិចបំផ្លាញជិតអស់ទាំងប្រជាជននៅក្នុងនគរ
មែនហើយ គឺទាំងអស់គ្នា លើកលែងតែសាមសិបនាក់ និងពួក
ដែលបានរត់ទៅជា មួយនឹងរាជវង្សារបស់អូមើរ ។
១៣ ហេតុដូច្នោះហើយ អូមើរត្រូវបានតាំងឡើង នៅក្នុង
ដែនដីកេរ្ដិ៍អាកររបស់ទ្រង់វិញ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា អូមើរបានចាប់ផ្ដើម
មានព្រះជន្មាយុចាស់; ទោះជាយ៉ាងណាក៏ដោយ គង់តែនៅ
ក្នុងវ័យ ចាស់របស់ទ្រង់ទៅហើយ នោះទ្រង់បង្កើតបាន
អេមើរដែរ; ហើយទ្រង់បានចាក់ប្រេងតាំងអេមើរឲ្យធ្វើជាស្ដេច
សោយរាជ្យជំនួសទ្រង់ ។
១៥ ហើយក្រោយពីទ្រង់បានចាក់ប្រេងតាំងអេមើរឲ្យធ្វើ
ជាស្ដេចស្រេចហើយ នោះទ្រង់បានឃើញសន្តិភាព មាននៅក្នុង
ដែនដីអស់ រយៈពេលពីរឆ្នាំ ហើយទ្រង់ក៏សុគតទៅ ក្រោយពីមាន
ព្រះជន្មាយុដ៏វែង ដែលពោរពេញដោយការសោកសៅ ។
ហើយហេតុការណ៍ បានកើតឡើងថា អេមើរបានសោយរាជ្យជំនួស
ទ្រង់ ហើយបានដើរតាមគន្លងរបស់បិតាខ្លួន ។
១៦ ហើយព្រះអម្ចាស់ទ្រង់បានចាប់ផ្ដើម ដកពាក្យបណ្ដាសា
របស់ទ្រង់ ចេញពីដែនដីជាថ្មី ហើយរាជវង្សារបស់អេមើរបានចំរើន
ឡើងជាខ្លាំង នៅក្នុងរាជ្យរបស់អេមើរ; ហើយក្នុងរយៈពេល
ហុកសិបពីរឆ្នាំ ពួកគេបានក្លាយទៅជាខ្លាំងពូកែជាអតិបរមា
ដរាបដល់ ពួកគេមានទ្រព្យសម្បត្តិដ៏ច្រើនលើសលប់ —
១៧ ដោយមានគ្រប់មុខនូវផ្លែឈើ និងធញ្ញជាតិ និងព្រៃ និង
ក្រណាត់ដ៏ល្អ និងមាស និងប្រាក់ ហើយនិងវត្ថុមានតម្លៃផ្សេងៗ ។
១៨ ព្រមទាំងមានគ្រប់មុខនូវសត្វពាហណៈ គោឈ្មោល
និងគោញី និងចៀម និងជ្រូក និងពពែ ព្រមទាំងសត្វជាច្រើនមុខ
ទៀត ដែលមានប្រយោជន៍ សំរាប់ជាអាហារដល់មនុស្ស ។
១៩ ហើយពួកគេក៏មានសេះ[ក] និងលា ហើយមានដំរី និងគូរី
ឡូម និងគូមុម; សត្វទាំងអស់នេះ មានប្រយោជន៍ដល់មនុស្ស
ហើយជា ពិសេស គឺដំរី និងគូរីឡូម និងគូមុម ។
២០ ម្ល៉ោះហើយ ព្រះអម្ចាស់ទ្រង់បានចាក់[ក]ព្រះពរទាំងឡាយ
របស់ទ្រង់ មកលើដែនដីនេះ ដែលជាដែនដីជំរើស លើអស់
ទាំងដែនដី ឯទៀត; ហើយទ្រង់បានបញ្ជាថា អស់អ្នកណាដែល
យកបានដែនដីនេះ គឺយកវាបានសំរាប់ព្រះអម្ចាស់ បើពុំនោះសោតទេ
ពួកគេនឹងត្រូវ[ខ] បំផ្លាញចោល កាលណាពួកគេទុំសុសនៅក្នុង
អំពើទុច្ចរិត; ត្បិតចំពោះពួកនោះហើយដែល ព្រះអម្ចាស់ទ្រង់
មានព្រះបន្ទូលថាៈ យើងនឹង ចាក់ទៅលើអ្នកទាំងនោះ នូវ
ភាពពោរពេញនៃសេចក្ដីខ្ញាល់របស់យើង ។
២១ ហើយអេមើរបានអនុវត្តសេចក្ដីជំនុំជំរះ ដោយនូវសេចក្ដី
សុចរិត អស់មួយជីវិតទ្រង់ ហើយទ្រង់បង្កើតបានបុត្រាបុត្រីជាច្រើន;
ហើយទ្រង់បង្កើតបានកូរីអានទុម ហើយទ្រង់បានចាក់ប្រេងតាំង
កូរីអានទុម ឲ្យសោយរាជ្យជំនួសទ្រង់ ។
២២ ហើយបន្ទាប់ពីទ្រង់បានចាក់ប្រេងតាំងកូរីអានទុម
ឲ្យសោយរាជ្យជំនួសទ្រង់ហើយ នោះទ្រង់មានព្រះ
ជន្មាយុរស់នៅបួនឆ្នាំ ហើយទ្រង់បានឃើញសន្តិភាពនៅលើដែនដី;
មែនហើយ ហើយទ្រង់ថែមទាំងបានឃើញ[ក]ព្រះរាជបុត្រានៃ
សេចក្ដីសុចរិត ហើយបាន សប្បាយ ហើយរុងរឿងនៅ
ក្នុងសម័យរបស់ទ្រង់; ហើយទ្រង់បានសុគតទៅដោយសុខសាន្ត ។
២៣ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមបាន
ដើរតាមគន្លងរបស់បិតាខ្លួន ហើយបានស្ថាបនាទីក្រុងធំ
ៗជាច្រើន ហើយ បានបង្រៀននូវអ្វីៗដែលល្អ ដល់ប្រជាជន
ទ្រង់ អស់មួយជីវិតទ្រង់ ។ ហើយហេតុការណ៍
បានកើតឡើងថា ទ្រង់គ្មានបុត្រាបុត្រីសោះ រហូតដល់ទ្រង់
មានព្រះជន្មាយុចាស់ជាខ្លាំង ។
២៤ ហើយហេតុការណ៍បានកើតឡើងថា ភរិយាទ្រង់
បានសុគតទៅ ក្នុងព្រះជន្មាយុមួយរយពីរឆ្នាំ ។ ហើយហេតុការណ៍
បានកើត ឡើងថា កូរីអានទុមបានយកភរិយាមួយនៅក្នុងព្រះ
ជន្មាយុចាស់របស់ទ្រង់ គឺជាស្ត្រីក្រមុំម្នាក់ ហើយបង្កើតបាន
បុត្រាបុត្រីទាំងឡាយ; ហេតុដូច្នោះហើយ ទ្រង់មានព្រះជន្ម
រស់ដល់ជន្មាយុមួយរយសែសិបពីរឆ្នាំ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បង្កើតបានកុម
ហើយកុមសោយរាជ្យជំនួសទ្រង់; ហើយទ្រង់សោយរាជ្យបាន

១៩ ក ១ នីហ្វៃ ១៨:២៥.
២០ ក អេធើរ ២:១៥.
ខ អេធើរ ២:៨–១១.
២២ ក ៣ នីហ្វៃ ២៥:២.

សែសិប ប្រាំបួនឆ្នាំ ហើយទ្រង់បង្កើតបានហេត ហើយ
ទ្រង់ក៏បង្កើតបានបុត្រាបុត្រីទាំងឡាយទៀត ។
២៦ ហើយប្រជាជនបានរាលដាលពាសពេញលើអស់ទាំង
ផ្ទៃដែនដី ហើយបានចាប់ផ្ដើមមានអំពើទុច្ចរិតដ៏ធំនៅលើផ្ទៃដែនដីទៀត
ហើយហេតបានចាប់ផ្ដើមឱបក្រសោបផែនការសម្ងាត់ទាំងឡាយទៀត
ដូចជំនាន់ដើម ដើម្បីបំផ្លាញបិតាខ្លួនចោល ។
២៧ ហើយហេតុការណ៍បានកើតឡើងថា លោកបាន
ទំលាក់បិតាខ្លួនពីបល្ល័ង្ក ព្រោះលោកបានសម្លាប់ទ្រង់ចោល ដោយ
ដាវរបស់ លោកផ្ទាល់; ហើយលោកបានសោយរាជ្យជំនួសទ្រង់ ។
២៨ ហើយមានពួកព្យាការីមកលើដែនដីទៀត ដោយ
ស្រែកហៅឲ្យពួកគេប្រែចិត្ត — ថាពួកគេត្រូវរៀបចំផ្លូវថ្វាយព្រះ
អម្ចាស់ បើពុំនោះសោតទេ នឹងមានបណ្ដាសាមួយនៅលើផ្ទៃដែនដី;
មែនហើយ គឺមានអំណត់ដ៏ធំមួយ នៅក្នុងនោះ ពួកគេនឹងត្រូវ
បំផ្លាញបង់ បើសិនជាពួកគេពុំប្រែចិត្តទេ ។
២៩ ប៉ុន្តែប្រជាជនមិនជឿតាមពាក្យពេចន៍របស់ពួកព្យាការីទេ
តែពួកគេបានបណ្ដេញពួកព្យាការីចេញវិញ; ហើយមានខ្លះ ត្រូវ
ពួកគេ បោះទៅក្នុងរណ្ដៅ ហើយទុកឲ្យពួកគេវិនាសបង់ ។
ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានធ្វើការណ៍អស់
ទាំងនេះ ស្របតាម បញ្ជារបស់ស្ដេចហេត ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ក៏ចាប់ផ្ដើមមាន
អំណត់មួយយ៉ាងធំនៅលើដែនដី ហើយបណ្ដាជនបានចាប់ផ្ដើមត្រូវ
បំផ្លាញយ៉ាងឆាប់រហ័ស ដោយសារអំណត់ ដោយព្រោះ
គ្មានភ្លៀងនៅលើផ្ទៃដែនដី ។
៣១ ហើយមានពស់អសិរពិសទាំងឡាយ បានចេញមក
ផងនៅលើផ្ទៃដែនដី ហើយបានចឹកមនុស្សជាច្រើន ។
ហើយហេតុការណ៍ បានកើតឡើងថា ហ្វូងសត្វរបស់ពួកគេបាន
ចាប់ផ្ដើមរត់គេចពីសត្វពស់អសិរពិស ឆ្ពោះទៅដែនដី ដែល
នៅទិសខាងត្បូង ដែលពួក សាសន៍នីហ្វៃហៅថា [ក]សារ៉ាហិមឡា ។
៣២ ហើយហេតុការណ៍បានកើតឡើងថា សត្វជាច្រើនត្រូវ
វិនាសនៅតាមផ្លូវ; ទោះជាយ៉ាងណាក៏ដោយ គង់តែមានខ្លះ
បានរត់ចូល ទៅដែនដី ដែលនៅទិសខាងត្បូង ។
៣៣ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់
បាន[ក]បញ្ជាឲ្យពស់ឈប់ដេញតាមពួកសត្វទាំងនេះទៀត ប៉ុន្តែ
ពស់ទាំង នោះត្រូវឃាំងផ្លូវកុំឲ្យមនុស្សអាចឆ្លងបានថា បើសិនជា
អ្នកណាខិតខំឆ្លងកាត់ ត្រូវស្លាប់ ដោយពស់អសិរពិស ។
៣៤ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបាន
ទៅតាមផ្លូវនៃពួកសត្វ ហើយបានបរិភោគសាកសពរបស់ពួក
សត្វ ដែលបាន វិនាសនៅតាមផ្លូវ រហូតដល់ពួកគេបានបរិភោគ
អស់សាកសពទាំងនោះ ។ ឥឡូវនេះ កាលប្រជាជនបានឃើញថា
ពួកគេ[ក]ត្រូវស្លាប់ នោះពួកគេបានចាប់ផ្ដើមប្រែចិត្ត ពីអំពើទុច្ចរិត
ទាំងឡាយរបស់គេ ហើយអំពាវនាវដល់ព្រះអម្ចាស់ ។
៣៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបាន
[ក]បន្ទាបខ្លួនគ្រប់គ្រាន់ នៅចំពោះព្រះអម្ចាស់ហើយ នោះទ្រង់បាន
ចាត់ឲ្យ មានភ្លៀងមកលើផ្ទៃដែនដី; ហើយប្រជាជនបានចាប់ផ្ដើម
មានកម្លាំងឡើងវិញ ហើយបានចាប់ផ្ដើមមានផ្លែឈើ នៅស្រុក
ផ្នែកខាងជើង និងនៅអស់ទាំងស្រុកជុំវិញ ។ ហើយព្រះអម្ចាស់
ទ្រង់បានបង្ហាញព្រះចេស្ដារបស់ទ្រង់ ដល់ពួកគេ ដោយរក្សាពួក
គេពីអំណត់ ៕

---

ជំពូកទី ១០

*ស្ដេចមួយតពីស្ដេចមួយទៀត — ស្ដេចខ្លះសុចរិត; ខ្លះទៀត
ទុច្ចរិត — កាលណាមានសេចក្ដីសុចរិត នោះប្រជាជនបានពរ
ហើយចំរើន ឡើង ដោយសារព្រះអម្ចាស់ ។*

ហើយហេតុការណ៍បានកើតឡើងថា សែស ដែលជាពូជពង្ស
របស់ហេត — ត្បិតហេតបានសុគតដោយអំណត់ ព្រមទាំង
រាជវង្សារបស់ ទ្រង់ទាំងអស់ លើកលែងតែសែស — ហេតុ
ដូច្នោះហើយ សែសបានចាប់ផ្ដើមកសាងឡើងវិញ នូវប្រជាជន
មួយដែលត្រូវបាក់បែក ។
២ ហើយហេតុការណ៍បានកើតឡើងថា សែសបានចងចាំ
ពីការបំផ្លិចបំផ្លាញដល់ពួកអយ្យកោរបស់ទ្រង់ ហើយទ្រង់បាន
កសាងឡើង នូវនគរមួយដ៏សុចរិត; ត្បិតទ្រង់បានចងចាំពីអ្វីៗ
ដែលព្រះអម្ចាស់ទ្រង់បានធ្វើ ក្នុងការនាំយ៉ារេឌ និង
បងរបស់លោក[ក]ឆ្លងកាត់ទីជំរៅ; ហើយទ្រង់បានដើរតាមផ្លូវទាំង
ឡាយនៃព្រះអម្ចាស់ ហើយទ្រង់បង្កើតបានបុត្រាបុត្រីទាំងឡាយ ។
៣ ហើយបុត្រច្បងរបស់ទ្រង់ ដែលមាននាមថា សែស បាន
បះបោរប្រឆាំងទ្រង់; ទោះចាយ៉ាងណាក៏ដោយ គង់តែសែ
សត្រូវបាន វាយដោយដៃនៃចោរម្នាក់ ដោយព្រោះលោកមាន
ទ្រព្យច្រើនលើសលប់ ដែលបាននាំសន្តិភាពមកឲ្យបិតាខ្លួនវិញ ។
៤ ហើយហេតុការណ៍បានកើតឡើងថា បិតាលោកបាន

---

៣១ *ក* អោមណៃ ១:១៣.
៣៣ *ក* ជនគ. ២១:៦–៩.
៣៤ *ក* អាលម៉ា ៣៤:៣៤; គ. និង ស. ១០១:៨.
៣៥ *ក* គ. និង ស. ៥:២៤.
**១០** ២ *ក* អេធើរ ៦:១–១២.

ស្ថាបនាទីក្រុងជាច្រើន នៅលើផ្ទៃដែនដី ហើយប្រជាជនបាន
ចាប់ផ្ដើមជាថ្មី រាលដាលពាសពេញលើផ្ទៃដែនដី ។ ហើយ
សែសបានរស់នៅរហូតដល់មានព្រះជន្មាយុចាស់ខ្លាំង; ហើយ
ទ្រង់បង្កើតបានរីពឡាគិស ។ ហើយទ្រង់ក៏សុគតទៅ ហើយ
រីពឡាគិសបានសោយរាជ្យជំនួសទ្រង់ ។
៥ ហើយហេតុការណ៍បានកើតឡើងថា រីពឡាគិសពុំបានធ្វើនូវ
អ្វីដែលត្រឹមត្រូវ នៅចំពោះព្រះនេត្រនៃព្រះអម្ចាស់ទេ ត្បិតទ្រង់
មាន ភរិយា [ក]និងស្នំជាច្រើន ហើយបានបំពាក់ទៅលើស្មារបស់
មនុស្ស នូវអ្វីដែលពិបាកនឹងទ្រាំទ្របាន; មែនហើយ ទ្រង់បាន
យកពន្ធពួកគេ ជាទម្ងន់ ហើយពន្ធទាំងនេះ ទ្រង់បានយក
ទៅស្ថាបនាអាគារដ៏ធំទូលាយជាច្រើន ។
៦ ហើយទ្រង់បានស្ថាបនាឡើងសំរាប់ខ្លួនទ្រង់ នូវបល្ល័ង្កមួយ
ដ៏សែនល្អ; ហើយទ្រង់បានសង់គុកជាច្រើន ហើយអស់អ្នកណា
ដែលមិន ព្រមបង់ពន្ធ នោះទ្រង់ដាក់ទៅក្នុងគុក; ហើយអស់អ្នក
ណាដែលមិនអាចបង់ពន្ធ នោះទ្រង់ដាក់ទៅក្នុងគុក; ហើយទ្រង់
បានឲ្យពួកគេធ្វើ ការមិនឈប់ឈរសោះ ប្រយោជន៍បានការទ្រ
ទ្រង់ពីពួកគេ; ហើយអស់អ្នកណាដែលប្រកែកមិនព្រមធ្វើការ
នោះទ្រង់បានបញ្ជាឲ្យយក ទៅសម្លាប់ចោល ។
៧ ហេតុដូច្នោះហើយ ទ្រង់យកបានអស់ទាំងស្នាដៃដ៏ល្អវិចិត្រ
មែនហើយ ទាំងមាសសុទ្ធរបស់ទ្រង់ ក៏ទ្រង់បានឲ្យចំរាញ់នៅក្នុង
គុក ដែរ; ហើយស្នាដៃដ៏ល្អគ្រប់យ៉ាង ក៏ទ្រង់បានចាត់ឲ្យធ្វើនៅ
ក្នុងគុក; ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានធ្វើឲ្យ
ប្រជាជនកើតទុក្ខ វេទនា ដោយសារអំពើសហាយស្មន់ និងអំពើ
គួរខ្ពើមឆ្អើមទាំងឡាយរបស់ទ្រង់ ។
៨ ហើយកាលទ្រង់បានសោយរាជ្យអស់រយៈពេលសែសិបពីរឆ្នាំ
នោះប្រជាជនបានបះបោរឡើងប្រឆាំងនឹងទ្រង់; ហើយក៏ចាប់ផ្ដើម
មានសង្គ្រាមជាថ្មីនៅលើដែនដី ដរាបដល់រីពឡាគិសត្រូវសុគតទៅ
ហើយពួកបុត្រាបុត្ររបស់ទ្រង់ ត្រូវបានដេញឲ្យចេញពីដែនដី ។
៩ ហើយហេតុការណ៍បានកើតឡើងថា ក្រោយពីរយៈពេល
ជាច្រើនឆ្នាំមក នោះម៉ូរីអានតុន (លោកជាពូជពង្សរបស់
រីពឡាគិស) ប្រមូលបានកងទ័ពមួយពីពួកអ្នកដែលត្រូវបាន
បណ្ដេញចេញ ហើយបានលើកទៅច្បាំងនឹងប្រជាជន;
ហើយលោកបានអំណាចលើទីក្រុង ជាច្រើន; ហើយសង្គ្រាម
នោះបានក្លាយជាសាហាវក្រៃលែង ហើយអស់រយៈពេលជាច្រើន
ឆ្នាំ; ហើយលោកបានអំណាចលើអស់ទាំង ដែនដី ហើយបាន
តាំងខ្លួនជាស្ដេចលើអស់ទាំងដែនដី ។
១០ ហើយបន្ទាប់ពីលោកបានតាំងខ្លួនឡើងជាស្ដេច នោះទ្រង់
បានសំរាលបន្ទុករបស់ប្រជាជន ដោយហេតុនេះហើយ ទ្រង់បាន
ទទួលការប្រោសប្រណីនៅក្នុងភ្នែកនៃប្រជាជន ហើយពួកគេបាន
ចាក់ប្រេងតាំងលោក ឲ្យធ្វើជាស្ដេចរបស់ពួកគេ ។
១១ ហើយទ្រង់បានអនុវត្តសេចក្ដីយុត្តិធម៌ដល់ប្រជាជន ប៉ុន្តែ
ពុំមែនសំរាប់ខ្លួនទ្រង់ទេ មកពីអំពើសហាយស្មន់ជាច្រើនរបស់ទ្រង់;
ហេតុដូច្នោះហើយ ទ្រង់ត្រូវបានកាត់ចេញពីវត្តមាននៃព្រះអម្ចាស់។
១២ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរីអានតុនបាន
ស្ថាបនាទីក្រុងជាច្រើន ហើយប្រជាជនបានក្លាយទៅជាមាន
ទ្រព្យសម្បត្តិដ៏ ស្ដុកស្ដម្ភបំផុត នៅក្រោមរាជ្យរបស់ទ្រង់ ទាំង
ខាងអាគារ និងខាងមាស និងប្រាក់ និងខាងការដាំធញ្ញជាតិ និង
ចិញ្ចឹមហ្វូងចៀម និងហ្វូង សត្វ និងអ្វីៗដែលត្រូវបានឲ្យមកពួក
គេវិញ ។
១៣ ហើយម៉ូរីអានតុន បានរស់នៅដល់ព្រះជន្មាយុដ៏ចាស់ណាស់
ហើយបន្ទាប់មក ទ្រង់បង្កើតបានគិម ហើយគិមបានសោយរាជ្យ
ជំនួសបិតាទ្រង់; ហើយទ្រង់បានសោយរាជ្យប្រាំបីឆ្នាំ ហើយបិតា
ទ្រង់ក៏សុគតទៅ ។ ហើយហេតុការណ៍បានកើតឡើងថា គិមមិន
បាន សោយរាជ្យក្នុងសេចក្ដីសុចរិតទេ ហេតុដូច្នោះហើយ
ទ្រង់ពុំបានទទួលការប្រោសប្រណីពីព្រះអម្ចាស់ឡើយ ។
១៤ ហើយព្រះអនុជរបស់ទ្រង់បានបះបោរប្រឆាំងនឹងទ្រង់
ដោយហេតុនេះ លោកបាននាំទ្រង់ទៅក្នុងការជាប់ឃុំឃាំង; ហើយ
ទ្រង់ បាននៅក្នុងការជាប់ឃុំឃាំងអស់មួយជីវិតទ្រង់; ហើយទ្រង់
បង្កើតបានបុត្រាបុត្រីទាំងឡាយ នៅក្នុងការជាប់ឃុំឃាំង
ហើយនៅក្នុងវ័យ ចាស់របស់ទ្រង់ នោះទ្រង់បង្កើតបានលេវី;
ហើយទ្រង់ក៏សុគតទៅ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីការសុគត
របស់បិតាខ្លួន នោះលេវីបានបំរើនៅក្នុងការជាប់ឃុំឃាំង អស់រយៈ
ពេលសែសិបពីរឆ្នាំ ។ ហើយលោកបានធ្វើសង្គ្រាមតទល់
នឹងស្ដេចរបស់ដែនដី ដោយហេតុនេះ ទ្រង់យកបាននគរមកវិញ ។
១៦ ហើយបន្ទាប់ពីទ្រង់យកបាននគរមកវិញហើយ នោះទ្រង់
បានធ្វើនូវអ្វីដែលត្រឹមត្រូវ នៅចំពោះព្រះនេត្រនៃព្រះអម្ចាស់;
ហើយ ប្រជាជនបានចំរើនឡើងនៅលើដែនដី; ហើយទ្រង់មាន
ព្រះជន្មាយុរស់នៅដល់វ័យចាស់ ហើយបង្កើតបានបុត្រាបុត្រីទាំង
ឡាយ; ហើយ ទ្រង់បង្កើតបានកូរ៉ុម ដែលទ្រង់បានចាក់ប្រេងតាំង
ឲ្យធ្វើជាស្ដេចជំនួសទ្រង់ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា កូរ៉ុមបានធ្វើនូវអ្វី

៥ *ក* យ៉ាកុប ៣:៥; ម៉ូសាយ ១១:២.

ដែលល្អ នៅចំពោះព្រះនេត្រនៃព្រះអម្ចាស់ អស់មួយជីវិតទ្រង់; ហើយទ្រង់ បង្កើតបានបុត្រាបុត្រីជាច្រើន; ហើយបន្ទាប់ពីទ្រង់បាន រស់នៅជាយូរអង្វែង នោះទ្រង់ក៏សុគតទៅ ដូចអ្នកឯទៀតនៅលើផែនដីដែរ; ហើយគិសបានសោយរាជ្យជំនួសទ្រង់ ។

១៨ ហើយហេតុការណ៍បានកើតឡើងថា គិសបានសុគតទៅដែរ ហើយលិបសោយរាជ្យជំនួសទ្រង់ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា លិបក៏បានធ្វើនូវអ្វីដែលល្អ នៅចំពោះព្រះនេត្រនៃព្រះអម្ចាស់ដែរ ។ ហើយនៅក្នុងសម័យ លិប នោះសត្វពស់អសិរពិសទាំងឡាយត្រូវបានបំផ្លាញចោលអស់ទៅ ។ ហេតុដូច្នោះហើយ ពួកគេបានទៅឯផែនដីនៅទិសខាងត្បូង ដើម្បីរកអាហារសំរាប់ប្រជាជននៅលើផែនដី ត្បិតផែនដីនោះពោរពេញទៅដោយសត្វព្រៃ ។ ហើយរីឯលិបផ្ទាល់ ក៏បានក្លាយទៅជា អ្នកបរបាញ់ដ៏ជំនាញម្នាក់ដែរ ។

២០ ហើយពួកគេបានស្ថាបនាទីក្រុងមួយដ៏ធំ នៅជិតចន្លោះតូចមួយនៃផែនដី នៅកន្លែងដែលសមុទ្រចែកផែនដីនោះ ។

២១ ហើយពួកគេបានទុកដីផ្នែកខាងត្បូង ជាទីរហោស្ថាន សំរាប់បរបាញ់សត្វ ។ ហើយផ្ទៃផែនដីទាំងមូល ភាគខាងជើង ពោរពេញទៅដោយបណ្ដាជន ។

២២ ហើយពួកគេឧស្សាហ៍ជាខ្លាំង ហើយពួកគេទិញ និងលក់ និងជួញជាមួយគ្នា ដើម្បីរកកំរៃ ។

២៣ ហើយពួកគេបានធ្វើការរកជាតិរ៉ែគ្រប់យ៉ាង ហើយពួកគេបានធ្វើមាស និងប្រាក់ និងដែក និងលង្ហិន និងលោហធាតុគ្រប់បែប យ៉ាង; ហើយពួកគេបានជីកយកវាចេញពីដី; ហេតុដូច្នោះហើយ ពួកគេបានគរដីទាំងឡាយដ៏ធំៗ ដើម្បីរករ៉ែរកមាស និងប្រាក់ និងដែក និងស្ពាន់ ។ ហើយពួកគេបានធ្វើវត្ថុដ៏ល្អគ្រប់បែបយ៉ាង ។

២៤ ហើយពួកគេមានសូត្រព្រៃ និងសំពត់ត្បាញដោយអំបោះខ្លូតទេសវេញយ៉ាងខ្មាញ់; ហើយពួកគេបានត្បាញសំពត់គ្រប់បែបយ៉ាង ដើម្បីពួកគេអាចស្លៀកបិទបាំងខ្លួន ពីភាពអាក្រាត ។

២៥ ហើយពួកគេបានធ្វើគ្រឿងឧបករណ៍គ្រប់បែបយ៉ាង ដើម្បីកាប់គាស់ដី គឺភ្ជួរ និងសាបព្រោះ ច្រូតកាត់ និងបោកផង ។

២៦ ហើយពួកគេបានធ្វើគ្រឿងឧបករណ៍គ្រប់បែបយ៉ាង ដែលគេប្រើសំរាប់ឃ្វាលសត្វរបស់គេ ។

២៧ ហើយពួកគេបានធ្វើគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមគ្រប់បែបយ៉ាង ។ ហើយពួកគេបានធ្វើវត្ថុដ៏ចម្លែកគ្រប់បែបយ៉ាង ។

២៨ ហើយគ្មានប្រជាជនណា ដែលមានពរជាងពួកគេ ហើយ ចំរើនឡើងជាង ដោយព្រះហស្តនៃព្រះអម្ចាស់ឡើយ ។ ហើយពួកគេ នៅលើផែនដីមួយ ដែលជាផែនដីជំរើសលើផែនដីទាំងអស់ ត្បិតព្រះអម្ចាស់ ទ្រង់បានមានព្រះបន្ទូលថាដូច្នោះ ។

២៩ ហើយហេតុការណ៍បានកើតឡើងថា លិបមានព្រះជន្មាយុរស់នៅជាច្រើនឆ្នាំ ហើយបង្កើតបានបុត្រាបុត្រីទាំងឡាយ; ហើយទ្រង់ ក៏បង្កើតបានហេអើថុម ។

៣០ ហើយហេតុការណ៍បានកើតឡើងថា ហេអើថុមបានសោយរាជ្យជំនួសបិតាខ្លួន ។ ហើយកាលហេអើថុមបានសោយរាជ្យបាន ម្ភៃបួនឆ្នាំ មើលចុះ នគរត្រូវដណ្ដើមយកពីទ្រង់ ។ ហើយទ្រង់បានបំរើនៅក្នុងការជាប់ឃុំឃាំងអស់ជាច្រើនឆ្នាំ មែនហើយ គឺអស់មួយ ជីវិតរបស់ទ្រង់។

៣១ ហើយទ្រង់បង្កើតបានហេត ហើយហេតបានរស់នៅក្នុងការជាប់ឃុំឃាំង អស់មួយជីវិតលោក ។ ហើយហេតបង្កើតបានអើរ៉ុន ហើយអើរ៉ុនបានរស់នៅក្នុងការជាប់ឃុំឃាំង អស់មួយជីវិតលោក; ហើយលោកបង្កើតបានអាំនីកាដា ហើយអាំនីកាដាក៏រស់នៅក្នុង ការជាប់ឃុំឃាំង អស់មួយជីវិតលោក; ហើយលោកបង្កើតបានកូរីអានទុម ហើយកូរីអានទុមរស់នៅក្នុងការជាប់ឃុំឃាំង អស់មួយជីវិត លោក; ហើយលោកបង្កើតបានកុម ។

៣២ ហើយហេតុការណ៍បានកើតឡើងថា កុមយកនគរបានពាក់កណ្ដាលមកវិញ ។ ហើយទ្រង់បានសោយរាជ្យលើនគរមួយចំហៀង អស់សែសិបពីរឆ្នាំ; ហើយទ្រង់បានទៅច្បាំងនឹងស្ដេចអាំគីឌ ហើយពួកគេបានច្បាំងអស់រយៈពេលជាច្រើនឆ្នាំ នៅក្នុងរយៈ ពេលនោះ កុមមានអំណាចលើអាំគីឌ ហើយយកបានអំណាចលើផ្នែកនគរដែលនៅសល់ទាំងប៉ុន្មាន ។

៣៣ ហើយនៅសម័យកុម នោះចាប់ផ្ដើមមានពួកចោរនៅលើផែនដី; ហើយពួកគេបានប្រើផែនការទាំងឡាយ ពីជំនាន់ដើម ហើយបានធ្វើពិធីស្បថ តាមរបៀបពួកចាស់បុរាណ ហើយស្វែងរកបំផ្លាញនគរទៀត ។

៣៤ ឥឡូវនេះ កុមបានប្រយុទ្ធនឹងពួកគេជាច្រើន; ទោះជាយ៉ាងណាក៏ដោយ គង់តែទ្រង់ពុំបានឈ្នះលើពួកគេឡើយ ៕

១៩ *ក* អេធើរ ៩:៣១.

២៣ *ក* ២ នីហ្វៃ ៥:១៥.

៣៣ *ក* ស.ប. សម្បថ; បក្សព័ន្ធសម្ងាត់.

## ជំពូកទី ១១

*សង្គ្រាម ការបែកបាក់ និងអំពើទុច្ចរិត គ្រប់គ្រងលើជីវភាពរបស់ សាសន៍យ៉ារេឌ — ពួកព្យាការីព្យាករអំពីការបំផ្លិចបំផ្លាញ ទាំងស្រុង ដល់ពួកសាសន៍យ៉ារេឌ លើកលែងតែពួកគេប្រែចិត្ត — ប្រជាជនបដិសេធពាក្យរបស់ព្យាការី ។*

ហើយនៅសម័យកុម នោះមានព្យាការីជាច្រើន ហើយបាន
ព្យាករអំពីការបំផ្លិចបំផ្លាញប្រជាជនដ៏ធំនេះ លើកលែងពួក
គេប្រែចិត្ត ហើយបែរមករកព្រះអម្ចាស់ ហើយលះបង់ចោលអំពើ
ឃាតកម្ម និងអំពើទុច្ចរិតរបស់ពួកគេ ។
២ ហើយហេតុការណ៍បានកើតឡើងថា ពួកព្យាការីត្រូវ
ប្រជាជនបដិសេធ ហើយពួកគេបានរត់ទៅរកកុម សូមសេចក្ដី
ការពារ ត្បិតប្រជាជនបានស្វែងរកបំផ្លាញពួកគេចោល ។
៣ ហើយពួកគេបានព្យាករដល់កុម នូវការណ៍ជាច្រើន ហើយ
ទ្រង់បានពរអស់មួយជីវិតរបស់ទ្រង់ ។
៤ ហើយទ្រង់មានព្រះជន្មាយុរស់នៅរហូតដល់វ័យចាស់
ហើយបង្កើតបានស៊ិបឡោម; ហើយស៊ិបឡោមបានសោយរាជ្យជំនួស
ទ្រង់ ។ ហើយព្រះអនុជរបស់ស៊ិបឡោមបានបះបោរប្រឆាំងនឹងទ្រង់
ហើយក៏ចាប់ផ្ដើមមានសង្គ្រាមមួយដ៏ធំក្រៃលែង នៅលើអស់
ទាំងដែនដី ។
៥ ហើយហេតុការណ៍បានកើតឡើងថា ព្រះអនុជរបស់
ស៊ិបឡោមបានបញ្ជាថា ពួកព្យាការីទាំងអស់ ដែលបានព្យាករនូវ
ការបំផ្លិច បំផ្លាញដល់ប្រជាជន ត្រូវយកទៅសម្លាប់ចោល ។
៦ ហើយក៏មានគ្រោះដ៏ធំនៅលើអស់ទាំងដែនដី ត្បិតពួកគេ
បានធ្វើបន្ទាល់ថា ពាក្យបណ្ដាសាដ៏ធំមួយ នឹងមកលើដែនដីនេះ
ហើយ មកលើប្រជាជននេះផង ហើយថា នឹងមានការ
បំផ្លិចបំផ្លាញដ៏ធំមួយ នៅក្នុងចំណោមពួកគេ គឺជាការបំផ្លាញ
មួយមិនដែលមាននៅ លើផ្ទៃផែនដីនេះ ហើយឆ្អឹងរបស់ពួកគេនឹង
[ក]គរដូចគំនរដីនៅលើផ្ទៃដែនដី លើកលែងតែពួកគេនឹងប្រែចិត្ត
ពីអំពើទុច្ចរិតរបស់គេ ។
៧ ហើយពួកគេពុំស្ដាប់តាមសម្លេងនៃព្រះអម្ចាស់ឡើយ
ដោយព្រោះតែបក្សព័ន្ធទុច្ចរិតរបស់ពួកគេ; ហេតុដូច្នោះហើយ
ក៏ចាប់ផ្ដើម មានសង្គ្រាម និងការទាស់ទែងគ្នានៅលើអស់ទាំង
ដែនដី ហើយមានអំណត់អត់ និងជម្ងឺអាសន្នរោគ ដរាបដល់មាន
ការបំផ្លិចបំផ្លាញ មួយយ៉ាងធំ ដែលមិនធ្លាប់មានពីមុនមក
នៅលើផ្ទៃផែនដី; ហើយការណ៍អស់ទាំងនេះ
បានកើតឡើងនៅសម័យស៊ិបឡោម ។
៨ ហើយប្រជាជនបានចាប់ផ្ដើមប្រែចិត្ត ពីអំពើទុច្ចរិតរបស់ពួក
គេ; ហើយដរាបណាពួកគេប្រែចិត្ត នោះព្រះអម្ចាស់ទ្រង់បាន
មាន [ក]សេចក្ដីមេត្តាករុណាដល់ពួកគេ ។
៩ ហើយហេតុការណ៍បានកើតឡើងថា ស៊ិបឡោមត្រូវ
បានសុគតទៅ ហើយសេតត្រូវបាននាំទៅក្នុងការជាប់ឃុំឃាំង
ហើយបាន រស់នៅក្នុងការជាប់ឃុំឃាំង អស់មួយជីវិតលោក ។
១០ ហើយហេតុការណ៍បានកើតឡើងថា អេហាជាបុត្រ
របស់លោក យកបាននគរមកវិញ; ហើយទ្រង់បាន
សោយរាជ្យលើប្រជាជន អស់មួយជីវិតទ្រង់ ។ ហើយទ្រង់
បានធ្វើអំពើទុច្ចរិតគ្រប់បែបយ៉ាង នៅក្នុងជីវិតទ្រង់
ហេតុនេះហើយ ទ្រង់បានធ្វើការខ្ចាយឈាម ជាច្រើន
ហើយជីវិតទ្រង់បានទៅជាខ្លី ។
១១ ហើយអេថិម ដែលជាពូជពង្សរបស់អេហា យកបាននគរ;
ហើយទ្រង់ក៏បានធ្វើអំពើទុច្ចរិត នៅក្នុងជីវិតទ្រង់ដែរ ។
១២ ហើយហេតុការណ៍បានកើតឡើងថា នៅសម័យអេថិម
នោះមានព្យាការីជាច្រើនដែលបានមក ហើយបានព្យាករដល់
ប្រជាជន ទៀត មែនហើយ ពួកគេបានព្យាករថា ព្រះអម្ចាស់ទ្រង់
នឹងបំផ្លាញពួកគេឲ្យអស់ពីលើផ្ទៃផែនដីចោល លើកលែងតែពួក
គេប្រែចិត្ត ពីអំពើទុច្ចរិតទាំងឡាយរបស់ពួកគេ ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបានធ្វើចិត្ត
រឹងទទឹង ហើយមិនព្រម[ក]ស្ដាប់តាមពាក្យពេចន៍របស់ពួកគេឡើយ;
ហើយពួកព្យាការីបានកើតទុក្ខ ហើយបានថយចេញពីចំណោម
ប្រជាជនទៅ ។
១៤ ហើយហេតុការណ៍បានកើតឡើងថា អេថិមបានអនុវត្ត
សេចក្ដីជំនុំជំរះ ដោយនូវសេចក្ដីទុច្ចរិត អស់មួយជីវិតទ្រង់; ហើយ
ទ្រង់ បង្កើតបានម៉ូរ៉ុន ។ ហើយហេតុការណ៍បានកើតឡើងថា
ម៉ូរ៉ុនបានសោយរាជ្យជំនួសទ្រង់; ហើយម៉ូរ៉ុនបានធ្វើការទុច្ចរិត
នៅចំពោះព្រះ អម្ចាស់ ។
១៥ ហើយហេតុការណ៍បានកើតឡើងថា មាន[ក]ការបះបោរមួយ
បានកើតឡើង នៅក្នុងចំណោមប្រជាជន ដោយព្រោះ
តែបក្សព័ន្ធ សម្ងាត់នោះ ដែលត្រូវបានបង្កើតឡើង ដើម្បីយក
អំណាច និងកំរៃ; ហើយមានមនុស្សខ្លាំងពូកែម្នាក់បានផុសឡើង
នៅក្នុងចំណោមពួក គេ ក្នុងអំពើទុច្ចរិត ហើយបានច្បាំងនឹងម៉ូរ៉ុន

១១ ៦*ក* អោមណៃ ១:២២; អេធើរ ១៤:២១.
៨ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
១៣ *ក* ម៉ូសាយ ១៦:២.
១៥ *ក* ស.ប. ការបះបោរ.

ហើយគាត់បានរំលំនគរមួយចំហៀង; ហើយគាត់បានត្រួតត្រា
នគរមួយចំហៀងនោះ អស់ជា ច្រើនឆ្នាំ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ម៉ូរ៉ុនបានរំលំគាត់
ហើយយកបាននគរមកវិញ ។
១៧ ហើយហេតុការណ៍បានកើតឡើងថា មានមនុស្សខ្លាំងពូកែ
ម្នាក់ទៀតបានផុសឡើង; ហើយគាត់ជាពូជពង្សនៃបងរបស់យ៉ារេឌ។
១៨ ហើយហេតុការណ៍បានកើតឡើងថា គាត់បានរំលំម៉ូរ៉ុន
ហើយយកនគរបាន; ហេតុដូច្នោះហើយ ម៉ូរ៉ុនបានរស់នៅក្នុង
ការជាប់ ឃុំឃាំង អស់មួយជីវិតទ្រង់; ហើយទ្រង់បង្កើតបាន
កូរីអានតើរ ។
១៩ ហើយហេតុការណ៍បានកើតឡើងថា កូរីអានតើរបាន
រស់នៅក្នុងការជាប់ឃុំឃាំង អស់មួយជីវិតលោក ។
២០ ហើយនៅសម័យកូរីអានតើរ នោះមានព្យាការីជាច្រើន
ដែលបានមក ហើយបានព្យាករអំពីរឿងដ៏ធំ និងអស្ចារ្យ ហើយ
បាន ស្រែកហៅប្រជាជន ឲ្យមានការប្រែចិត្ត ហើយលើកលែងតែ
ពួកគេប្រែចិត្ត បើពុំនោះសោតទេ ព្រះអម្ចាស់ទ្រង់នឹងអនុវត្ត
[ក]សេចក្ដីជំនុំជំរះ ទាស់នឹងពួកគេ ដោយនូវការបំផ្លិចបំផ្លាញ
ទាំងស្រុងដល់ពួកគេ ។
២១ ហើយថា ព្រះអម្ចាស់ ទ្រង់នឹងចាត់ ឬនាំប្រជាជន[ក]មួយ
ទៀត មកយកដែនដីនេះ ដោយព្រះចេស្ដារបស់ទ្រង់ តាមរបៀប
ដែល ទ្រង់បាននាំពួកអយ្យកោពួកគេមកដូច្នោះ ។
២២ ហើយពួកគេបានបដិសេធពាក្យទាំងអស់ របស់ពួកព្យាការី
ដោយព្រោះតែសង្គមសម្ងាត់ និងអំពើគួរខ្ពើមឆ្អើមដ៏ទុច្ចរិតទាំង
ឡាយ របស់ពួកគេ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា កូរីអានតើរបង្កើត
បាន[ក]អេធើរ ហើយលោកក៏ស្លាប់ទៅ ដោយបានរស់នៅក្នុង
ការជាប់ឃុំ ឃាំង អស់មួយជីវិតលោក ៕

---

## ជំពូកទី ១២

*ព្យាការីអេធើរទូន្មានប្រជាជនឲ្យជឿដល់ព្រះ — ម៉ូរ៉ូណៃរៀបរាប់ឡើងវិញ នូវការណ៍ចម្លែកអស្ចារ្យទាំងឡាយ ដែលធ្វើឡើងដោយ សេចក្ដីជំនឿ — សេចក្ដីជំនឿបានផ្ដល់លទ្ធភាព ដល់បងរបស់យ៉ារេឌ ឲ្យមើលឃើញព្រះគ្រីស្ទ — ព្រះអម្ចាស់ទ្រង់ប្រទានឲ្យមនុស្ស នូវភាពទន់ខ្សោយទាំងឡាយ ដើម្បីឲ្យពួកគេរាបសា — បងរបស់យ៉ារេឌរើភ្នំសឺរីន ដោយសេចក្ដីជំនឿ — សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស មានសារៈសំខាន់ជាចាំបាច់ដល់សេចក្ដីសង្គ្រោះ — ម៉ូរ៉ូណៃបានឃើញព្រះយេស៊ូវទល់នឹងមុខ ។*

ហើយហេតុការណ៍បានកើតឡើងថា អេធើរបានរស់នៅសម័យ
[ក]កូរីអានទុមើរ; ហើយកូរីអានទុមើរ គឺជាស្ដេចលើអស់ទាំងដែនដី ។
២ ហើយ[ក]អេធើរ គឺជាព្យាការីម្នាក់របស់ព្រះអម្ចាស់; ហេតុ
ដូច្នោះហើយ អេធើរបានចេញមកសម័យកូរីអានទុមើរ ហើយ
បាន ចាប់ផ្ដើមព្យាករដល់ប្រជាជន ត្បិតលោកពុំអាច[ខ]ទ្រាំបាន
ដោយសារព្រះវិញ្ញាណនៃព្រះអម្ចាស់ ដែលនៅក្នុងលោក ។
៣ ព្រោះលោកបាន[ក]ស្រែក តាំងពីព្រលឹមទៅដល់ពេលថ្ងៃលិច
ទូន្មានឲ្យ[ខ]ប្រជាជនជឿដល់ព្រះ ដល់ការប្រែចិត្ត បើពុំនោះសោតទេ
ពួកគេនឹងត្រូវបំផ្លាញចោល គឺនិយាយទៅពួកគេថា ដោយសារ
[គ]សេចក្ដីជំនឿ នោះការណ៍ទាំងអស់ត្រូវបានបំពេញ —
៤ ហេតុដូច្នោះហើយ អស់អ្នកណាជឿដល់ព្រះ អាច
[ក]សង្ឃឹមជាប្រាកដថា នឹងបានពិភពលោកមួយ ដ៏ប្រសើរ
លើសលែងទៅទៀត មែនហើយ គឺកន្លែងមួយ ដែលនៅខាង
ស្ដាំព្រះហស្ដនៃព្រះ ឯសេចក្ដីសង្ឃឹមនោះ មកពីសេចក្ដីជំនឿ ធ្វើ
ជា[ខ]យុថ្កាមួយដល់ព្រលឹងមនុស្ស ដែលនឹងធ្វើ[គ]ឲ្យពួកគេស្ថិតស្ថេរ
នៅនឹងធឹង [ឃ]ហើយខ្ជាប់ខ្ជួន គឺនៅក្នុងកិច្ចការល្អដ៏បរិបូរជាដរាប
ដែលនាំឲ្យសរសើរដំកើងដល់ព្រះ ។
៥ ហើយហេតុការណ៍បានកើតឡើងថា អេធើរបានព្យាករនូវ
ការណ៍ដ៏ធំ ហើយអស្ចារ្យដល់ប្រជាជន ដែលពួកគេពុំជឿសោះ
ពីព្រោះពួកគេពុំបានឃើញ ។
៦ ហើយឥឡូវនេះ ខ្ញុំ ម៉ូរ៉ូណៃ ចង់និយាយខ្លះអំពីការណ៍
ទាំងនេះ; ខ្ញុំចង់បង្ហាញដល់មនុស្សលោកថា [ក]សេចក្ដីជំនឿ គឺជាអ្វី
ដែល [ខ]សង្ឃឹមចង់បាន ហើយ[គ]មើលមិនឃើញ; ហេតុដូច្នោះហើយ
ចូរកុំជំទាស់ឡើយ ដោយព្រោះអ្នករាល់គ្នាមើលមិនឃើញ ត្បិតអ្នក

---

២០ *ក* ស.ប. ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
២១ *ក* អេធើរ ១៣:២០–២១.
២៣ *ក* អេធើរ ១:៦; ១៥:៣៣–៣៤.
**១២** ១*ក* អេធើរ ១៣:១៣–៣១.
២ *ក* ស.ប. អេធើរ.
*ខ* យេរេ. ២០:៩; អេណុស ១:២៦; អាលម៉ា ៤៣:១.
៣ *ក* គ. និង ស. ១១២:៥.
*ខ* អេធើរ ១១:១២, ២០–២២.
*គ* ស.ប. សេចក្ដីជំនឿ.
៤ *ក* ស.ប. សេចក្ដីសង្ឃឹម.
*ខ* ហេព្រើរ ៦:១៩.
*គ* ១ កូរិន. ១៥:៥៨.
*ឃ* ៣ នីហ្វៃ ១២:១៦.
៦ *ក* ហេព្រើរ ១១:១.
*ខ* រ៉ូម ៨:២៤–២៥.
*គ* អាលម៉ា ៣២:២១.

រាល់គ្នា ពុំទទួលសាក្សីឡើយ លុះដល់ពេលក្រោយពី[ឃ]ការ
សាកល្បងនៃសេចក្ដីជំនឿរបស់អ្នកសិន ។
៧ ត្បិតគឺដោយសារសេចក្ដីជំនឿនេះហើយដែលព្រះគ្រីស្ទទ្រង់
បានបង្ហាញរូបអង្គទ្រង់ ដល់ពួកអយ្យកោរបស់យើង បន្ទាប់ពីទ្រង់
មានព្រះជន្មរស់ពីស្លាប់ឡើងវិញ; ហើយទ្រង់ពុំបង្ហាញរូបអង្គ
ទ្រង់ដល់ពួកគេឡើយ លុះត្រាក្រោយពីពួកគេមានសេចក្ដី
ជំនឿជឿដល់ ទ្រង់; ហេតុដូច្នោះហើយ ជាការចាំបាច់ថា អ្នកខ្លះ
មានសេចក្ដីជំនឿជឿដល់ទ្រង់ ត្បិតទ្រង់ពុំបង្ហាញរូបអង្គ
ទ្រង់ដល់ពិភពលោកឡើយ ។
៨ ប៉ុន្តែ ដោយសារសេចក្ដីជំនឿរបស់មនុស្ស នោះទ្រង់
បានបង្ហាញរូបអង្គទ្រង់ដល់មនុស្សលោក ហើយបានដំកើង
ព្រះនាមនៃព្រះ វរបិតា ហើយបានរៀបចំផ្លូវមួយ
ដើម្បីដោយសារប្រការនោះ នោះអ្នកឯទៀតអាចបានទទួល
នូវអំណោយទានសួគ៌ ដើម្បីឲ្យពួកគេ អាចសង្ឃឹម
ដល់ការណ៍ទាំងនោះ ដែលពួកគេពុំទាន់បានឃើញ ។
៩ ហេតុដូច្នោះហើយ អ្នករាល់គ្នាក៏អាចមានសេចក្ដីសង្ឃឹម
ហើយធ្វើជាអ្នកទទួលនូវអំណោយទាននោះដែរ បើសិនជាអ្នក
រាល់គ្នា ។គ្រាន់តែមានសេចក្ដីជំនឿ ។
១០ មើលចុះ [ក]គឺដោយសារសេចក្ដីជំនឿនេះហើយដែល
មនុស្សជំនាន់ដើមត្រូវបានហៅ តាមរបៀបដ៏បរិសុទ្ធនៃព្រះ ។
១១ ហេតុដូច្នោះហើយ ដោយសារសេចក្ដីជំនឿ
នោះក្រិត្យវិន័យលោកម៉ូសេត្រូវបានប្រទានមក ។ ប៉ុន្តែដោយ
អំណោយទាននៃ ព្រះរាជបុត្រារបស់ទ្រង់ នោះព្រះទ្រង់បាន
រៀបចំផ្លូវមួយ[ក]ដ៏ប្រសើរលើសលែងទៅទៀត; ហើយគឺដោយ
សេចក្ដីជំនឿនេះហើយដែល វាបានបំពេញ ។
១២ ព្រោះបើសិនជា[ក]គ្មានសេចក្ដីជំនឿ [ខ]នៅក្នុងចំណោម
កូនចៅមនុស្សទេ នោះព្រះទ្រង់ពុំអាចសម្ដែងអព្ភូតហេតុ នៅក្នុង
ចំណោមពួកគេបានឡើយ; ហេតុដូច្នោះហើយ ទ្រង់ពុំបង្ហាញ
រូបអង្គទ្រង់សោះ លុះត្រាក្រោយពីសេចក្ដីជំនឿរបស់ពួកគេសិន ។
១៣ មើលចុះ [ក]គឺដោយសេចក្ដីជំនឿរបស់អាលម៉ា និង
អាមូលេក ដែលបានធ្វើឲ្យគុករលំចុះទៅដី ។
១៤ មើលចុះ [ក]គឺដោយសេចក្ដីជំនឿរបស់នីហ្វៃ និងលីហៃ
ដែលបាននាំឲ្យមានការផ្លាស់ប្ដូរដល់ពួកសាសន៍លេមិន ធ្វើឲ្យពួក
គេបាន [ខ]ទទួលបុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណ
បរិសុទ្ធ ។
១៥ មើលចុះ គឺដោយសេចក្ដីជំនឿរបស់[ក]អាំម៉ូន និងពួកបងប្អូន
របស់លោក ដែលបាននាំមក[ខ]នូវអព្ភូតហេតុដ៏ធំ នៅក្នុងចំណោម
ពួកសាសន៍លេមិន ។
១៦ មែនហើយ ហើយអស់ទាំងពួកគេ ដែលបាននាំមក[ខ]នូវ
[ក]អព្ភូតហេតុ គឺនាំមកដោយសារសេចក្ដីជំនឿ ទាំងពួកអ្នកដែល
បានរស់ នៅមុនព្រះគ្រីស្ទ និងពួកអ្នកដែលរស់នៅក្រោយទ្រង់ផង ។
១៧ ហើយគឺដោយសេចក្ដីជំនឿនេះហើយដែលពួកសិស្ស
បីនាក់បានទទួលសេចក្ដីសន្យាថា ពួកគេ[ក]ពុំត្រូវភ្លក់សេចក្ដី
ស្លាប់ឡើយ; ហើយពួកគេពុំបានសេចក្ដីសន្យានោះទេ
លុះត្រាក្រោយពីសេចក្ដីជំនឿរបស់ពួកគេសិន ។
១៨ ហើយគ្មានពេលណាទេ ដែលអ្នកណាម្នាក់នាំមកនូវ
អព្ភូតហេតុ លុះត្រាក្រោយពីសេចក្ដីជំនឿរបស់ពួកគេសិន; ហេតុ
ដូច្នោះ ហើយ ពួកគេដំបូងបំផុត ជឿដល់ព្រះរាជបុត្រានៃព្រះ ។
១៩ ហើយមានមនុស្សជាច្រើន ដែលមានសេចក្ដីជំនឿដ៏ខ្លាំង
[ក]ទាំងមុនព្រះគ្រីស្ទទ្រង់យាងមកម្ល៉េះ គេមិនអាចត្រូវបិទបាំងពីក្នុង
[ខ]វាំង ននបានទេ តែឃើញយ៉ាងពិត ដោយភ្នែករបស់ពួកគេ នូវ
ការណ៍ទាំងឡាយ ដែលពួកគេធ្លាប់បានឃើញ ដោយ
ភ្នែកនៃសេចក្ដីជំនឿ ហើយពួកគេបានអររីករាយ ។
២០ ហើយមើលចុះ យើងបានឃើញនៅក្នុងបញ្ជីនេះថា
មនុស្សម្នាក់ក្នុងចំណោមនេះ គឺបងរបស់យ៉ារេឌ; ត្បិតសេចក្ដី
ជំនឿរបស់ លោកដល់ព្រះ មានទំហំធំណាស់ គឺនៅពេលព្រះ
ទ្រង់លូក[ក]ព្រះអង្គុលីរបស់ទ្រង់ទៅ ទ្រង់មិនអាចលាក់ពីភ្នែក
នៃបងរបស់យ៉ារេឌបាន ឡើយ ដោយព្រោះព្រះបន្ទូលរបស់ទ្រង់

៦ ឃ ៣ នីហ្វៃ ២៦:១១;
គ. និង ស. ១០៥:១៩; ១២១:៧–៨.
១០ ក អាលម៉ា ១៣:៣–៤.
ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
១១ ក ១ កូរិន. ១២:៣១.
១២ ក ២ នីហ្វៃ ២៧:២៣;
ម៉ូសាយ ៨:១៨; ម៉ូរ៉ូណៃ ៧:៣៧;
គ. និង ស. ៣៥:៨–១១.
ខ ម៉ាថាយ ១៣:៥៨; មរមន ៩:២០.
១៣ ក អាលម៉ា ១៤:២៦–២៩.
១៤ ក ហេលេ. ៥:៥០–៥២.
ខ ហេលេ. ៥:៤៥; ៣ នីហ្វៃ ៩:២០.
១៥ ក អាលម៉ា ១៧:២៩–៣៩.
ខ គ.ន. ដូចដែលបានប្រាប់ដល់អាលម៉ា
ជំពូកទី ១៧–២៦.
១៦ ក ស.ប. អព្ភូតហេតុ.
ខ ហេព្រើរ ១១:៧–៤០.
១៧ ក ៣ នីហ្វៃ ២៨:៧;
មរមន ៨:១០–១២.
១៩ ក ២ នីហ្វៃ ១១:១–៤;
យ៉ាកុប ៤:៤–៥; យ៉ារ៉ុម ១:១១;
អាលម៉ា ២៥:១៥–១៦.
ខ អេធើរ ៣:៦.
ស.ប. វាំងនន.
២០ ក អេធើរ ៣:៤.

ដែលទ្រង់បានមានព្រះបន្ទូលទៅកាន់លោក គឺជាព្រះបន្ទូលដែលលោកបានទទួល ដោយ សេចក្ដីជំនឿ ។

២១ ហើយក្រោយពីបងរបស់យ៉ារេឌ បានឃើញព្រះអង្គុលីនៃព្រះអម្ចាស់ហើយ ដោយសារពាក្យសន្យា ដែលបងរបស់យ៉ារេឌ បានទទួលដោយសេចក្ដីជំនឿ នោះព្រះអម្ចាស់ទ្រង់ពុំអាចលាក់អ្វីពីភ្នែកលោកបានឡើយ; ហេតុដូច្នេះហើយ ទ្រង់បានបង្ហាញលោកនូវ អ្វីៗទាំងអស់ ព្រោះលោកពុំអាចត្រូវឃាត់ឃាំង ឲ្យនៅខាងក្រៅវាំងននទៀតទេ ។

២២ ហើយ គឺដោយសារសេចក្ដីជំនឿនេះហើយដែលពួកអយ្យកោខ្ញុំបានសេចក្ដីសន្យាថា ការណ៍ទាំងនេះនឹងមកដល់ពួកបងប្អូន របស់ពួកគេ តាមរយៈពួកសាសន៍ដទៃ; ហេតុដូច្នេះហើយព្រះអម្ចាស់ទ្រង់បានបញ្ជាខ្ញុំ មែនហើយ គឺព្រះយេស៊ូវគ្រីស្ទ ។

២៣ ហើយខ្ញុំបានទូលទៅកាន់ទ្រង់ថា៖ ព្រះអម្ចាស់អើយ ពួកសាសន៍ដទៃនឹងចំអកឡកឡឺយ ដល់ការណ៍ទាំងនេះ ដោយសារភាព ទន់ខ្សោយរបស់យើងខ្ញុំ ខាងការសរសេរ; ត្បិតព្រះអម្ចាស់អើយ ព្រះអង្គបានធ្វើឲ្យយើងខ្ញុំខ្លាំងពូកែខាងពាក្យសំដីដោយសេចក្ដីជំនឿ ប៉ុន្តែព្រះអង្គពុំបានធ្វើឲ្យយើងខ្ញុំ ខ្លាំងពូកែខាងការសរសេរទេ; ត្បិតព្រះអង្គបានធ្វើឲ្យប្រជាជនទាំងអស់នេះអាចនិយាយបានច្រើន មកពី ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានប្រទានដល់ពួកគេ ។

២៤ ហើយព្រះអង្គបានធ្វើឲ្យយើងខ្ញុំអាចសរសេរបានតែបន្តិចបន្តួច ដោយព្រោះភាពគ្គាំគ្គងនៃដៃរបស់យើងខ្ញុំ ។ មើលចុះ ព្រះអង្គ ពុំបានធ្វើឲ្យយើងខ្ញុំ ខ្លាំងពូកែខាងការសរសេរ ដូចបងរបស់យ៉ារេឌទេ ត្បិតព្រះអង្គបានធ្វើដល់លោកថា ការណ៍ទាំងឡាយ ដែលលោក សរសេរ នោះនឹងបានទៅជាខ្លាំងពូកែ ដូចជាព្រះអង្គដែរ ដើម្បីឈ្នះលើអ្នកណាដែលអានការណ៍ទាំងនោះ ។

២៥ ព្រះអង្គក៏បានធ្វើឲ្យពាក្យរបស់យើងខ្ញុំខ្លាំង ហើយវិសេសដែរ ដែលយើងខ្ញុំមិនអាចសរសេរបានឡើយ; ហេតុដូច្នោះហើយ កាលណាយើងខ្ញុំសរសេរ នោះយើងខ្ញុំឃើញភាពទន់ខ្សោយរបស់យើងខ្ញុំ ហើយទាក់ពាក្យ ដោយសារការរៀបពាក្យពេចន៍របស់ យើងខ្ញុំ; ហើយទូលបង្គំខ្លាចក្រែងពួកសាសន៍ដទៃនឹងចំអកឡកឡឺយ ដល់ពាក្យរបស់យើងខ្ញុំ ។

២៦ ហើយកាលខ្ញុំបានទូលដូច្នេះហើយ នោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖ ពួកអ្នកភ្លើទេ ដែលចំអក តែពួកគេនឹងយំសោក ហើយគុណរបស់យើងមានគ្រប់គ្រាន់សំរាប់អ្នកស្លូតត្រង់ ដើម្បីកុំឲ្យពួកគេយកប្រៀបលើភាពទន់ខ្សោយរបស់អ្នករាល់គ្នាបាន ។

២៧ ហើយបើសិនជាមនុស្សលោកមករកយើង នោះយើងនឹងបង្ហាញដល់ពួកគេ នូវភាពទន់ខ្សោយរបស់ពួកគេ ។ យើងឲ្យភាព ទន់ខ្សោយទៅមនុស្ស ដើម្បីឲ្យពួកគេអាចបានរាបសា; ហើយគុណរបស់យើង មានគ្រប់គ្រាន់សំរាប់មនុស្សទាំងអស់ដែលបន្ទាបខ្លួន នៅចំពោះយើង; ត្បិតបើសិនជាពួកគេបន្ទាបខ្លួននៅចំពោះយើង ហើយមានសេចក្ដីជំនឿជឿដល់យើង លំដាប់នោះយើងនឹងធ្វើឲ្យ អ្វីដែលទន់ខ្សោយ ក្លាយទៅជាខ្លាំងពូកែ ចំពោះពួកគេវិញ ។

២៨ មើលចុះ យើងនឹងបង្ហាញដល់ពួកសាសន៍ដទៃ នូវភាពទន់ខ្សោយរបស់ពួកគេ ហើយយើងនឹងបង្ហាញដល់ពួកគេថា សេចក្ដី ជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស នាំពួកគេមកឯយើង — គឺជាប្រភពនៃអស់ទាំងសេចក្ដីសុចរិត ។

២៩ ហើយខ្ញុំម៉ូរ៉ូណៃ បានឮនូវពាក្យទាំងនេះ ក៏បានស្ងប់ចិត្ត ហើយទូលថា៖ ឱព្រះអម្ចាស់អើយ ព្រះហឫទ័យដ៏សុចរិតរបស់ទ្រង់ នឹងបានសំរេច ត្បិតទូលបង្គំដឹងថា ទ្រង់ធ្វើការដល់កូនចៅមនុស្ស ស្របតាមសេចក្ដីជំនឿរបស់ពួកគេ ។

៣០ ព្រោះបងរបស់យ៉ារេឌ បាននិយាយទៅកាន់ភ្នំស៊ើរិនថា ចូររើចេញ– ហើយភ្នំក៏រើចេញទៅ ។ ហើយបើសិនជាលោកពុំមាន សេចក្ដីជំនឿទេ នោះភ្នំពុំរើចេញឡើយ; ហេតុដូច្នោះហើយទ្រង់ធ្វើការក្រោយពីមនុស្សមានសេចក្ដីជំនឿសិន ។

៣១ ត្បិតដោយហេតុនោះហើយ ទើបព្រះអង្គសម្ដែងរូបអង្គទ្រង់ ដល់ពួកសិស្សរបស់ទ្រង់; ត្បិតបន្ទាប់ពីពួកគេមានសេចក្ដី

២១ *ក* អេធើរ ៣:២៥–២៦.
*ខ* អេធើរ ៣:២០;
គ. និង ស. ៦៧:១០–១៣.
២២ *ក* អេណុស ១:១៣.
២៣ *ក* មរមន ៨:១៧; ៩:៣៣.
*ខ* ២ នីហ្វៃ ៣៣:១.
២៤ *ក* ស.ប. ភាសា.
២៥ *ក* ១ កូរិន. ២:១៤.
២៦ *ក* កាឡាទី ៦:៧.
២៧ *ក* យ៉ាកុប ៤:៧.
*ខ* និក្ខ. ៤:១១; ១ កូរិន. ១:២៧.
*គ* ស.ប. ព្រះគុណ.
*ឃ* លូកា ១៨:១០–១៤;
គ. និង ស. ១:២៨.
ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ង* លូកា ៩:៤៦–៤៨;
២ កូរិន. ១២:៩.
២៨ *ក* ១ កូរិន. ១៣:១–១៣;
ម៉ូរ៉ូណៃ ៧:៣៩–៤៧.
៣០ *ក* ម៉ាថាយ ១៧:២០; យ៉ាកុប ៤:៦;
ហេលេ. ១០:៦, ៩.
ស.ប. អំណាច.
៣១ *ក* ស.ប. សេចក្ដីជំនឿ.

ជំនឿ ហើយបានទូលដោយនូវព្រះនាមទ្រង់ នោះព្រះអង្គបាន
បង្ហាញរូបអង្គទ្រង់ដល់ពួកគេ ក្នុងព្រះចេស្ដាដ៏ធំ ។
៣២ ហើយទូលបង្គំក៏ចាំដែរថា ព្រះអង្គមានព្រះបន្ទូលថា
ព្រះអង្គបានរៀបចំវិមានមួយសំរាប់មនុស្ស មែនហើយ គឺក្នុង
ចំណោម [ក]វិមានទាំងឡាយនៃព្រះវរបិតារបស់ទ្រង់ នៅក្នុងនោះ
មនុស្សអាចមានសេចក្ដីសង្ឃឹម ដ៏ប្រសើរលើសលែងទៅទៀត;
ហេតុដូច្នោះ ហើយ មនុស្សត្រូវមាន[ខ]សេចក្ដីសង្ឃឹម
បើពុំនោះសោតទេ គេមិនអាចទទួលមរតកនៅក្នុងកន្លែង ដែល
ទ្រង់បានរៀបចំនោះបានទេ ។
៣៣ ហើយម៉្យាងទៀត ទូលបង្គំចាំថា ព្រះអង្គមានព្រះបន្ទូល
ថា ព្រះអង្គ[ក]ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាព្រះអង្គប្ដូរជីវិត
របស់ទ្រង់ជំនួសមនុស្សលោក ដើម្បីទ្រង់អាចលើកយកជីវិត
មកវិញ ដើម្បីរៀបចំទីកន្លែងមួយ សំរាប់កូនចៅមនុស្ស ។
៣៤ ហើយឥឡូវនេះ ទូលបង្គំដឹងថា [ក]សេចក្ដីស្រឡាញ់នេះ
ដែលព្រះអង្គមានសំរាប់កូនចៅមនុស្ស គឺជាសេចក្ដីសប្បុរស;
ហេតុ ដូច្នោះហើយ លើកលែងតែមនុស្សមានសេចក្ដីសប្បុរស
នោះពួកគេពុំអាចគ្រងទីកន្លែង ដែលព្រះអង្គបានរៀបចំទុក នៅ
ក្នុងវិមាន ទាំងឡាយ នៃព្រះវរបិតារបស់ទ្រង់ ទុកជាមរតក
បានឡើយ ។
៣៥ ហេតុដូច្នោះហើយ ទូលបង្គំដឹងដោយការណ៍នេះ ដែល
ព្រះអង្គបានមានព្រះបន្ទូលថា បើសិនជាពួកសាសន៍ដទៃ ពុំមាន
សេចក្ដីសប្បុរសទេ មកពីភាពទន់ខ្សោយរបស់យើងខ្ញុំ នោះព្រះ
អង្គនឹងសាកល្បងពួកគេ ហើយដកយក[ក]ការប៉ិនប្រសប់របស់ពួក
គេចេញ មែនហើយ ទាំងអ្វីៗដែលពួកគេបានទទួល ហើយឲ្យទៅ
ពួកអ្នកដែលសមនឹងបានលើសលែងទៅទៀត ។
៣៦ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានអំពាវនាវ
ដល់ព្រះអម្ចាស់ សូមឲ្យទ្រង់ប្រទានដល់ពួកសាសន៍ដទៃ នូវ[ក]ព្រះ
គុណ ដើម្បីឲ្យពួកគេអាចមានសេចក្ដីសប្បុរស ។
៣៧ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាន
មានព្រះបន្ទូលមកខ្ញុំថា៖ បើសិនជាពួកគេគ្មានសេចក្ដីសប្បុរសទេ
វាមិនជាសំខាន់អីដល់អ្នកទេ គឺអ្នកបានស្មោះត្រង់; ហេតុ
ដូច្នោះហើយ សំលៀកបំពាក់របស់អ្នកនឹងត្រូវបាន[ក]ធ្វើឲ្យជ្រះស្អាត ។
ហើយពីព្រោះអ្នកបានឃើញ[ខ]ភាពទន់ខ្សោយរបស់ខ្លួន នោះអ្នក
នឹងត្រូវបានធ្វើឲ្យខ្លាំងពូកែ រហូតដល់បានអង្គុយឯទីកន្លែង ដែលយើង
បានរៀបចំទុក នៅក្នុងវិមានទាំងឡាយនៃព្រះវរបិតារបស់យើង ។
៣៨ ហើយឥឡូវនេះ ខ្ញុំម៉ូរ៉ូណៃ សូមលាពួកសាសន៍ដទៃ
សិនហើយ មែនហើយ និងដល់ពួកបងប្អូនរបស់ខ្ញុំផង ដែល
ខ្ញុំស្រឡាញ់ លុះដល់យើងនឹងជួបគ្នា នៅខាងមុខ[ក]វេទិកាជំនុំជំរះ
នៃព្រះគ្រីស្ទ នៅទីនោះ មនុស្សទាំងអស់នឹងដឹងថា
[ខ]សំលៀកបំពាក់របស់ខ្ញុំគ្មាន ប្រឡាក់ដោយឈាមរបស់អ្នកឡើយ ។
៣៩ ហើយលំដាប់នោះ អ្នករាល់គ្នានឹងដឹងថា ខ្ញុំបាន[ក]ឃើញ
ព្រះយេស៊ូវ ហើយថា ទ្រង់បានមានព្រះបន្ទូលជាមួយខ្ញុំ [ខ]ទល់នឹង
មុខ ហើយថា ទ្រង់បានប្រាប់ខ្ញុំ ដោយសេចក្ដីរាបទាប
យ៉ាងក្បោះក្បាយ ដូចជាមនុស្សម្នាក់ ប្រាប់ទៅម្នាក់ទៀត
ដោយភាសារបស់ខ្ញុំផ្ទាល់ អំពីការណ៍ទាំងនេះ;
៤០ ហើយ ខ្ញុំសរសេរបានតែបន្តិចប៉ុណ្ណោះ ដោយមកពីភាព
ទន់ខ្សោយរបស់ខ្ញុំ ខាងការសរសេរ ។
៤១ ហើយឥឡូវនេះ ខ្ញុំចង់ទូន្មានអ្នករាល់គ្នា ឲ្យ
[ក]ស្វែងរកព្រះយេស៊ូវគ្រីស្ទ ដែលពួកព្យាការី និងពួកសាវកបាន
សរសេរមកនេះ សូមឲ្យព្រះគុណនៃព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ
និងព្រះវិញ្ញាណបរិសុទ្ធផង ដែល[ខ]ធ្វើបន្ទាល់អំពីទ្រង់ អាចមក
សណ្ឋិតនៅក្នុងអ្នក រហូតតទៅ ។ អាម៉ែន ៕

## ជំពូកទី ១៣

*អេធើរនិយាយអំពីក្រុងយេរូសាឡិមថ្មីមួយ ដែលនឹងត្រូវបានសាងឡើង នៅទ្វីបអាមេរិក ដោយពូជរបស់យ៉ូសែប — លោកព្យាករ, ត្រូវគេបណ្ដេញចេញ, សរសេរប្រវត្តិនៃសាសន៍យ៉ារេឌ, ហើយទាយអំពីការបំផ្លិចបំផ្លាញពួកសាសន៍យ៉ារេឌ — សង្គ្រាមរាល ដាលពេញលើអស់ទាំងដែនដី ។*

៣២ *ក* យ៉ូហាន ១៤:២; អេណុស ១:២៧;
គ. និង ស. ៧២:៤; ៩៨:១៨.
*ខ* ស.ប. សេចក្ដីសង្ឃឹម.
៣៣ *ក* យ៉ូហាន ៣:១៦–១៧.
៣៤ *ក* ម៉ូរ៉ូណៃ ៧:៤៧.
ស.ប. សេចក្ដីសប្បុរស; សេចក្ដីស្រឡាញ់.
៣៥ *ក* ម៉ាថាយ ២៥:១៤–៣០.
ស.ប. អំណោយទាន; ពាន់.
៣៦ *ក* ស.ប. ព្រះគុណ.
៣៧ *ក* គ. និង ស. ៣៨:៤២;
៨៨:៧៤–៧៥; ១៣៥:៤–៥.
*ខ* អេធើរ ១២:២៧.
៣៨ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
*ខ* យ៉ាកុប ១:១៩.
៣៩ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការលេចមករបស់ព្រះគ្រីស្ទក្រោយពីសុគត.
*ខ* លោកុ. ៣២:៣០; និក្ខ. ៣៣:១១.
៤១ *ក* គ. និង ស. ៨៨:៦៣; ១០១:៣៨.
*ខ* ៣ នីហ្វៃ ១១:៣២.

ហើយឥឡូវនេះ ខ្ញុំ ម្ញរ៉ូណៃ សូមបញ្ចប់បញ្ជីរបស់ខ្ញុំ ស្ដីអំពីការ
បំផ្លិចបំផ្លាញប្រជាជន ដែលខ្ញុំបានសរសេរមកនេះ ។
២ ត្បិតមើលចុះ ពួកគេបានបដិសេធពាក្យទាំងអស់របស់អេធើរ;
លោកពិតជាបានប្រាប់ពួកគេ នូវការណ៍ទាំងអស់ ចាប់តាំងពី
ដើមកំណើតរបស់មនុស្សមក; ហើយថា បន្ទាប់ពីទឹកជំន
ន់បានស្រកពីផ្ទៃដែនដីនេះទៅ នោះវាក៏បានក្លាយទៅជាដែន ដី
ជំរើសមួយ លើអស់ទាំងដែនដីឯទៀត ជាដែនដីដែលបាន
រើសដោយព្រះអម្ចាស់; ហេតុដូច្នោះហើយ ព្រះអម្ចាស់ទ្រង់
ចង់ឲ្យមនុស្សទាំង អស់ ដែលរស់នៅលើផ្ទៃដែនដីនោះបំរើទ្រង់;
៣ ហើយថា នោះគឺជាកន្លែងរបស់ក្រុងយេរូសាឡិមថ្មី ដែល
នឹងចុះមកពីលើស្ថានសួគ៌ ហើយជាទីបរិសុទ្ធ ដ៏ពិសិដ្ឋនៃព្រះ
អម្ចាស់ ។
៤ មើលចុះ អេធើរបានឃើញសម័យនៃព្រះគ្រីស្ទ ហើយលោកបាន
និយាយអំពីក្រុងយេរូសាឡិមថ្មីមួយ នៅលើដែនដីនោះ ។
៥ ហើយលោកក៏បាននិយាយផង អំពីវង្សអ៊ីស្រាអែល ហើយ
ក្រុងយេរូសាឡិម ដែលលីហៃនឹងចេញមកពីនោះ — បន្ទាប់ពីក្រុង
នោះត្រូវបានបំផ្លាញចោល នោះនឹងត្រូវបានស្ថាបនាឡើងវិញ
គឺជាទីក្រុងបរិសុទ្ធមួយថ្វាយព្រះអម្ចាស់; ហេតុដូច្នោះហើយ
ក្រុងនោះ ពុំមែនជាក្រុងយេរូសាឡិមថ្មីទេ ត្បិតធ្លាប់មាននៅ
ក្នុងសម័យដើមរួចហើយ; តែក្រុងនោះនឹងត្រូវបានស្ថាបនាឡើងវិញ
ហើយនឹងក្លាយ ទៅជាទីក្រុងបរិសុទ្ធមួយរបស់ព្រះអម្ចាស់;
ហើយក្រុងនោះនឹងត្រូវបានស្ថាបនាសំរាប់វង្សអ៊ីស្រាអែល —
៦ ហើយថា ក្រុងយេរូសាឡិមថ្មីមួយនឹងត្រូវបានស្ថាបនាឡើង
នៅលើដែនដីនេះ សំរាប់សំណល់នៃពូជរបស់យ៉ូសែប ត្បិតការណ៍
ទាំងនេះបានជាគំរូមួយ ។
៧ ត្បិតដូចជាយ៉ូសែបបាននាំឪពុករបស់លោក ចុះមកស្រុក
អេស៊ីព្ទយ៉ាងណា នោះលោកក៏បានស្លាប់នៅទីនោះដែរ; ហេតុ
ដូច្នោះ ហើយ បានជាព្រះអម្ចាស់នាំសំណល់មួយនៃពូជយ៉ូសែប
ចេញពីដែនដីយេរូសាឡិម ដើម្បីទ្រង់អាចមានសេចក្ដី
មេត្តាករុណាដល់ពូជ យ៉ូសែប ដើម្បីកុំឲ្យពួកគេត្រូវវិនាស
ដូចជាទ្រង់បានមានសេចក្ដីមេត្តាករុណា ដល់ឪពុករបស់
យ៉ូសែបដែរ ដើម្បីកុំឲ្យលោកត្រូវវិនាស ។
៨ ហេតុដូច្នោះហើយ សំណល់នៃពូជយ៉ូសែប នឹងត្រូវបាន
សង់នៅលើដែនដីនេះ; ហើយដែនដីនេះនឹងត្រូវទៅជាដែនដីនៃ
កេរ្ដិ៍អាករ របស់ពួកគេ ហើយពួកគេនឹងស្ថាបនាទីក្រុងបរិសុទ្ធ
មួយថ្វាយព្រះអម្ចាស់ ដូចគ្នានឹងក្រុងយេរូសាឡិមនៅជំនាន់ដើម;
ហើយពួកគេនឹង ពុំត្រូវលាយឡំទៀតឡើយ រហូតដល់ទីបំផុត
គឺជាពេលដែលផែនដីនឹងកន្លងផុតទៅ ។
៩ ហើយនឹងមានផ្ទៃមេឃមួយថ្មី និងផែនដីមួយថ្មី; ហើយរបស់
ទាំងនោះនឹងបានដូចជាផ្ទៃមេឃ និងផែនដីចាស់ លើកលែងតែអ្វី
ដែល របស់ចាស់បានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានក្លាយ
ទៅជាថ្មី ។
១០ ហើយលំដាប់នោះ ក្រុងយេរូសាឡិមថ្មីនឹងមកដល់;
ហើយមានពរហើយ ពួកអ្នកដែលអាស្រ័យនៅទីនោះ ត្បិតពួក
គេនេះហើយ ដែលមានសំលៀកបំពាក់ពណ៌ស តាមរយៈឈាម
នៃកូនចៀម; ហើយពួកគេនេះហើយជាពួកអ្នកដែលត្រូវបាន
រាប់ក្នុងចំណោមសំណល់ នៃពូជយ៉ូសែប ដែលចេញមក
ពីវង្សអ៊ីស្រាអែល ។
១១ ហើយលំដាប់នោះ ក្រុងយេរូសាឡិមចាស់នឹងមក
ដល់ដែរ; ហើយបណ្ដាជននៅទីនោះ មានពរហើយពួកគេ ត្បិត
ពួកគេត្រូវបាន លាងដោយនូវឈាមនៃកូនចៀម; ហើយពួក
គេនេះហើយជាពួកអ្នកដែលបានខ្ចាត់ព្រាត់ ហើយបានប្រមូលមក
ពីទិសទាំងបួននៃផែនដី និងមកពីដែនដីខាងជើង ហើយជាពួកអ្នក
ដែលទទួលនូវការបំពេញសេចក្ដីសញ្ញា ដែលព្រះទ្រង់បានធ្វើជា
មួយនឹងអយ្យកោរបស់ពួកគេ គឺលោកអ័ប្រាហាំ ។
១២ ហើយកាលណាការណ៍ទាំងនេះមកដល់ នោះនឹងបាន

**១៣** ២*ក* លោកុ. ៧:១១–២៤; ៨:៣.
*ខ* អេធើរ ២:៨.
៣ *ក* ៣ នីហ្វៃ ២០:២២; ២១:២៣–២៤.
ស.ប. ក្រុងយេរូសាឡិមថ្មី.
*ខ* វិវរ. ៣:១២; ២១:២.
៤ *ក* ស.ប. ស៊ីយ៉ូន.
៥ *ក* ស.ប. ក្រុងយេរូសាឡិម.
*ខ* ១ នីហ្វៃ ១:១៨–២០.
*គ* វិវរ. ២១:១០;
៣ នីហ្វៃ ២០:២៩–៣៦.
៦ *ក* គ. និង ស. ៤២:៩; ៤៥:៦៦–៦៧;
៨៤:២–៥; ម. នៃ ស. ១:១០.
*ខ* ស.ប. យ៉ូសែប, កូនប្រុសរបស់
យ៉ាកុប.
*គ* អាលម៉ា ៤៦:២៤.
ស.ប. ការនិមិត្តរូប.
៧ *ក* លោកុ. ៤៦:២–៧; ៤៧:៦.
*ខ* ២ នីហ្វៃ ៣:៥.
៨ *ក* ស.ប. ដែនដីសន្យា.
*ខ* ម្ញរ៉ូណៃ ១០:៣១.
៩ *ក* ២ ពេត្រុស ៣:១០–១៣;
វិវរ. ២១:១; ៣ នីហ្វៃ ២៦:៣;
គ. និង ស. ១០១:២៣–២៥.
១០ *ក* វិវរ. ៧:១៤; ១ នីហ្វៃ ១២:១០–១១;
អាលម៉ា ៥:២៧.
១១ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូល
នៃសាសន៍អ៊ីស្រាអែល.
*ខ* គ. និង ស. ១៣៣:២៦–៣៥.
*គ* ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.

សំរេចនូវបទគម្ពីរដែលថែងថា នឹងមាន[ក]មនុស្សមុនទៅជាក្រោយ; ហើយនឹងមានមនុស្សក្រោយទៅជាមុនវិញ ។

១៣ ហើយខ្ញុំប្រុងនឹងសរសេរថែមទៀត តែខ្ញុំត្រូវបានហាមឃាត់; ប៉ុន្តែធំ ហើយអស្ចារ្យណាស់ហ្ន៎ ពាក្យព្យាករណ៍របស់អេធើរ; ប៉ុន្តែ ពួកគេចាត់លោកទុកជាឥតបានការ ហើយបានបណ្ដេញលោកចេញ; ហើយលោកបានលាក់ខ្លួននៅក្នុងក្រហែងថ្មនៅពេលថ្ងៃ ហើយ នៅពេលយប់ លោកបានចេញមកមើលការណ៍ទាំងឡាយ ដែលនឹងកើតឡើងដល់ប្រជាជន ។

១៤ ហើយនៅពេលដែលលោករស់នៅក្នុងក្រហែងថ្ម នោះលោកបានធ្វើបង្ហើយនូវបញ្ជីរបស់លោក ដោយមើលការបំផ្លិចបំផ្លាញទាំងឡាយ ដែលនឹងកើតឡើងដល់ប្រជាជន នៅពេលយប់ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំដដែលដែលលោកត្រូវគេបណ្ដេញចេញពីចំណោមប្រជាជន នោះចាប់ផ្ដើមមានសង្គ្រាមមួយដ៏ធំ ក្នុងចំណោមប្រជាជន ត្បិតមានមនុស្សជាច្រើនបានបះបោរឡើង ដែលជាមនុស្សខ្លាំងពូកែ ហើយបានស្វែងរក បំផ្លាញកូរីអានទុមើរ ដោយផែនការសម្ងាត់នៃអំពើទុច្ចរិតរបស់ពួកគេ ដែលធ្លាប់បានថែងមកពីមុន ។

១៦ ហើយឥឡូវនេះ កូរីអានទុមើរធ្លាប់បានរៀនផ្ទាល់ នូវសិល្បៈខាងចម្បាំង និងល្បិចកលទាំងអស់ របស់ពិភពលោក ហេតុដូច្នោះ ហើយ ទ្រង់បានច្បាំងជាមួយពួកគេ ដែលស្វែងរកបំផ្លាញទ្រង់ ។

១៧ ប៉ុន្តែទ្រង់ពុំប្រែចិត្តទេ ឯបុត្រាបុត្រីដ៏ស្រស់ល្អរបស់ទ្រង់ក៏ដូច្នោះដែរ; ឯបុត្រាបុត្រីដ៏ស្រស់ល្អរបស់កូហូរក៏ដូច្នោះដែរ; ឯបុត្រា បុត្រីដ៏ស្រស់ល្អរបស់កូរីហូរក៏ដូច្នោះដែរ; ហើយសរុបសេចក្ដីមក គឺគ្មានបុត្រាបុត្រីដ៏ស្រស់ល្អណាម្នាក់នៅលើផ្ទៃដែនដីទាំងមូល ប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួនឡើយ ។

១៨ ហេតុដូច្នោះហើយ ហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទី១ ដែលអេធើរបានរស់នៅក្នុងក្រហែងថ្ម [ក]នោះមានមនុស្សជាច្រើនត្រូវបានស្លាប់បង់ដោយដាវនៃបក្សព័ន្ធសម្ងាត់ទាំងនោះ ប្រយុទ្ធតទល់នឹងកូរីអានទុមើរ ដើម្បីពួកគេអាចដណ្ដើមយកនគរ ។

១៩ ហើយហេតុការណ៍បានកើតឡើងថា ពួកបុត្រារបស់កូរីអានទុមើរ បានប្រយុទ្ធជាច្រើន ហើយបានខ្ចាយឈាមជាច្រើន ។

២០ ហើយនៅក្នុងឆ្នាំទី២ នោះព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់អេធើរថា លោកត្រូវទៅព្យាករដល់[ក]កូរីអានទុមើរថា បើសិនជា ទ្រង់ព្រមប្រែចិត្ត ព្រមទាំងរាជវង្សាទាំងអស់របស់ទ្រង់ផង នោះព្រះអម្ចាស់ទ្រង់នឹងប្រទានដល់ទ្រង់នូវនគរ ហើយនឹងលើកលែងជីវិត ដល់ប្រជាជន —

២១ បើពុំនោះសោតទេ ពួកគេនឹងត្រូវបំផ្លាញចោល ព្រមទាំងរាជវង្សាទាំងអស់របស់ទ្រង់ផង លើកលែងតែរូបទ្រង់ប៉ុណ្ណោះ។ ហើយទ្រង់នឹងរស់នៅ គ្រាន់តែមើលឃើញការបំពេញនូវសេចក្ដីព្យាករណ៍ទាំងឡាយ ដែលបានថែងអំពីប្រជាជន[ក]មួយទៀត ដែលនឹង ទទួលដែនដីនេះ សំរាប់ជាកេរ្ដិ៍អាករដល់ពួកគេ; ហើយកូរីអានទុមើរនឹងត្រូវពួកគេបញ្ចុះសព[ខ]; ហើយមនុស្សទាំងអស់នឹងត្រូវបំផ្លាញ ចោល លើកលែងតែកូរីអានទុមើរប៉ុណ្ណោះ ។

២២ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរពុំប្រែចិត្តសោះ ឯរាជវង្សារបស់ទ្រង់ក៏ដូច្នោះដែរ ឯប្រជាជនក៏ដូច្នោះដែរ; ហើយសង្គ្រាមមិនឈប់ឡើយ; ហើយពួកគេបានស្វែងរកសម្លាប់អេធើរចោល ប៉ុន្តែលោកបានគេចចេញពីពួកគេ ហើយបានពួនជាថ្មីនៅ ក្នុងក្រហែងថ្ម ។

២៣ ហើយហេតុការណ៍បានកើតឡើងថា មានម្នាក់ឈ្មោះសារេឌ បានបះបោរឡើង ហើយគាត់បានច្បាំងជាមួយនឹងកូរីអានទុមើរ ផង; ហើយគាត់មានជ័យជំនះលើទ្រង់ រហូតដល់នៅក្នុងឆ្នាំទី៣ គាត់បានចាប់យកទ្រង់ទៅក្នុងការជាប់ឃុំឃាំង។

២៤ ហើយពួកបុត្រារបស់កូរីអានទុមើរ នៅក្នុងឆ្នាំទី៤ បានយកជ័យជំនះលើសារេឌ ហើយយកបាននគរមកឲ្យបិតាខ្លួនវិញ ។

២៥ ឥឡូវនេះ ចាប់ផ្ដើមមានសង្គ្រាមមួយនៅលើអស់ទាំងផ្ទៃដែនដី មនុស្សម្នាក់ៗជាមួយនឹងក្រុមរបស់គេ ប្រយុទ្ធដើម្បីអ្វីដែល គេចង់បាន ។

២៦ ហើយមានពួកចោរ ហើយរួមសេចក្ដីមក មានអំពើទុច្ចរិតគ្រប់បែបយ៉ាង នៅពាសពេញលើអស់ទាំងផ្ទៃដែនដី ។

២៧ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរខឹងនឹងសារេឌជាខ្លាំង ហើយទ្រង់បានលើកពលទ័ពទ្រង់ ទៅច្បាំងនឹងគាត់; ហើយពួកគេបានមកប្រយុទ្ធគ្នាដោយកំហឹងជាខ្លាំង ហើយពួកគេបានប្រយុទ្ធនៅក្នុងច្រកភ្នំគីលកាល; ហើយចម្បាំងនេះបានក្លាយជា សាហាវអស្ចារ្យ ។

២៨ ហើយហេតុការណ៍បានកើតឡើងថា សារេឌបានប្រយុទ្ធ

១២ *ក* ម៉ាកុស ១០:៣១;
១ នីហ្វៃ ១៣:៤២;
យ៉ាកុប ៥:៦៣; គ. និង ស. ៩០:៩.
១៨ *ក* អេធើរ ៨:៩–២៦.
២០ *ក* អេធើរ ១២:១–២.
២១ *ក* អោមណៃ ១:១៩–២១;
អេធើរ ១១:២១.
*ខ* អេធើរ ១៥:២៩–៣២.

ទល់នឹងទ្រង់ អស់រយៈពេលបីថ្ងៃ ។ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរបានឈ្នះគាត់ ហើយបានដេញតាមគាត់ រហូតដល់គាត់មកដល់ទីវាលហែសឡុន ។

២៩ ហើយហេតុការណ៍បានកើតឡើងថា សារេឌបានច្បាំងនឹងទ្រង់ទៀតនៅលើទីវាលនោះ; ហើយមើលចុះ គាត់បានឈ្នះកូរីអានទុមើរ ហើយបានរុញច្រានទ្រង់ឲ្យថយទៅឯច្រកភ្នំគីលកាលវិញ ។

៣០ ហើយកូរីអានទុមើរបានប្រយុទ្ធនឹងសារេឌទៀត នៅក្នុងច្រកភ្នំគីលកាល នៅក្នុងការប្រយុទ្ធនោះ ទ្រង់បានឈ្នះសារេឌ ហើយបានសម្លាប់គាត់ចោល ។

៣១ ហើយសារេឌបានធ្វើឲ្យកូរីអានទុមើររបួសនៅត្រង់ភ្លៅ ដែលធ្វើឲ្យទ្រង់ពុំទៅច្បាំងទៀត អស់រយៈពេលពីរឆ្នាំ នៅក្នុងពេល នេះ ប្រជាជនទាំងអស់នៅលើផ្ទៃដែនដី កំពុងតែកំចាយឈាមគ្នា ហើយគ្មានអ្នកណាម្នាក់ឃាត់ពួកគេបានឡើយ ៕

## ជំពូកទី ១៤

*អំពើទុច្ចរិតរបស់ប្រជាជន នាំមកនូវបណ្ដាសាមួយលើដែនដី — កូរីអានទុមើរធ្វើសង្គ្រាមនឹងកាឡាត ហើយលិប និងស៊ិស — ឈាម និងសាកសពគ្របលើដែនដី ។*

ហើយឥឡូវនេះ ចាប់ផ្ដើមមាន[ក]បណ្ដាសាមួយយ៉ាងធំ នៅលើអស់ទាំងដែនដី ពីព្រោះមកពីអំពើទុច្ចរិតរបស់ប្រជាជន ម្ល៉ោះហើយបើសិនជាមនុស្សណាម្នាក់ដាក់គ្រឿងឧបករណ៍របស់ខ្លួន ឬដាវរបស់ខ្លួន នៅលើធ្នើររបស់ខ្លួន ឬនៅលើទីណាដែលគេចង់ទុកវា មើលចុះ ដល់ស្អែកឡើង គេពុំអាចរកវាឃើញសោះ គឺធំណាស់ហ្ន៎បណ្ដាសាដែលដាក់លើដែនដីនេះ ។

២ ហេតុដូច្នោះហើយ មនុស្សគ្រប់រូបបានកាន់ជាប់ក្នុងដៃ នូវអ្វីដែលជារបស់ផងខ្លួន ហើយមិនខ្ចី ហើយក៏មិនឲ្យគេខ្ចីដែរ; ហើយមនុស្សគ្រប់រូបកាន់ដងដាវរបស់ខ្លួន នៅក្នុងដៃស្ដាំរបស់គេ ដើម្បីការពារទ្រព្យរបស់គេ និងជីវិតរបស់គេផ្ទាល់ និងជីវិតនៃប្រពន្ធ និងកូនចៅរបស់គេ ។

៣ ហើយឥឡូវនេះ ពីរឆ្នាំក្រោយមក ហើយបន្ទាប់ពីការស្លាប់របស់សារេឌ មើលចុះ មានប្អូនរបស់សារេឌបានបះបោរឡើង ហើយគាត់បានច្បាំងនឹងកូរីអានទុមើរ ក្នុងចម្បាំងនោះ កូរីអានទុមើរបានឈ្នះលើគាត់ ហើយបានដេញតាមគាត់ ទៅដល់ទីរហោស្ថាន អ័គីស ។

៤ ហើយហេតុការណ៍បានកើតឡើងថា ប្អូនរបស់សារេឌបានច្បាំងនឹងទ្រង់នៅក្នុងទីរហោស្ថានអ័គីស; ហើយការប្រយុទ្ធនោះ បានក្លាយជាឃោរឃៅជាខ្លាំង ហើយមនុស្សជាច្រើនពាន់បានដួលចុះ ដោយមុខដាវ ។

៥ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរបានព័ទ្ធជុំវិញទីរហោស្ថាន ហើយប្អូនរបស់សារេឌបានលើកទ័ព ចេញពីទីរហោស្ថាននៅពេលយប់ ហើយបានសម្លាប់កងទ័ពមួយភាគរបស់កូរីអានទុមើរ នៅពេលពួកគេកំពុងស្រវឹង ។

៦ ហើយគាត់បានមកដល់ដែនដីម៉ូរ៉ុន ហើយបានដំកើងខ្លួនឡើងលើបល្ល័ង្ករបស់កូរីអានទុមើរ ។

៧ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរ នៅជាមួយនឹងកងទ័ពរបស់ទ្រង់ អាស្រ័យនៅក្នុងទីរហោស្ថាន អស់រយៈពេល ពីរឆ្នាំ ក្នុងពេលនោះ ទ្រង់បានទទួលកម្លាំងដ៏ខ្លាំងដល់កងទ័ពរបស់ទ្រង់ ។

៨ ឥឡូវនេះ ប្អូនរបស់សារេឌ ដែលមានឈ្មោះថា កាឡាត ក៏បានទទួលកម្លាំងយ៉ាងខ្លាំង ដល់កងទ័ពរបស់គាត់ដែរ ពីព្រោះមកពី បក្សព័ន្ធសម្ងាត់ទាំងឡាយ ។

៩ ហើយហេតុការណ៍បានកើតឡើងថា សង្ឃជាន់ខ្ពស់របស់គាត់បានធ្វើឃាតគាត់ចោល នៅពេលដែលគាត់អង្គុយលើបល្ល័ង្ករបស់ ខ្លួន ។

១០ ហើយហេតុការណ៍បានកើតឡើងថា មនុស្សម្នាក់ពីបក្សព័ន្ធសម្ងាត់ បានធ្វើឃាតគាត់ចោល តាមផ្លូវសម្ងាត់មួយ ហើយបាន ទទួលយកនគរដល់ខ្លួន; ហើយគាត់មានឈ្មោះថាលិប; ហើយលិបគឺជាបុរសម្នាក់មានមាឌធំ ធំជាងបុរសណាទាំងអស់ នៅក្នុង ចំណោមប្រជាជន ។

១១ ហើយហេតុការណ៍បានកើតឡើងថា នៅក្នុងឆ្នាំទី១របស់លិប កូរីអានទុមើរបានឡើងមកឯដែនដីម៉ូរ៉ុន ហើយបានច្បាំងជា មួយនឹងលិប ។

១២ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានប្រយុទ្ធជាមួយនឹងលិប នៅក្នុងនោះ លិបបានវាយត្រូវដៃទ្រង់ ធ្វើឲ្យទ្រង់របួស; ក៏ប៉ុន្តែកងទ័ពរបស់កូរីអានទុមើរ បានបន្តការវាយប្រហារទៅលើលិប ធ្វើឲ្យគាត់រត់គេចទៅតំបន់ព្រំប្រទល់ជិតឆ្នេរសមុទ្រ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរបានដេញតាមគាត់ ហើយលិបបានច្បាំងជាមួយនឹងទ្រង់នៅលើឆ្នេរសមុទ្រ ។

១៤ ហើយហេតុការណ៍បានកើតឡើងថា លិបបានវាយកងទ័ព

១៤ ១*ក* ហេលេ. ១២:១៨; ១៣:១៧–២៣; មរមន ១:១៧–១៨; ២:១០–១៤.

របស់កូរីអានទុមើរ ធ្វើឲ្យពួកគេរត់គេចទៅកាន់ទីរហោស្ថានអ័គីស វិញ ។

១៥ ហើយហេតុការណ៍បានកើតឡើងថា លិបបានដេញតាមទ្រង់ រហូតគាត់បានមកដល់ទីវាលអ័កូស ។ ហើយកូរីអានទុមើរបាននាំយកប្រជាជនទាំងអស់ ទៅជាមួយទ្រង់ នៅពេលទ្រង់រត់គេចពីលិប ទៅក្នុងភាគនៃដែនដី ដែលទ្រង់រត់គេចទៅនោះ ។

១៦ ហើយកាលទ្រង់បានមកដល់ទីវាលអ័កូសហើយ នោះទ្រង់បានច្បាំងនឹងលិប ហើយទ្រង់បានវាយគាត់រហូតដល់ស្លាប់; ទោះជា យ៉ាងណាក៏ដោយ គង់តែប្អូនរបស់លិបបានមកច្បាំងនឹងកូរីអានទុមើរជំនួសវិញ ហើយចម្បាំងនោះបានក្លាយទៅជាសាហាវជាខ្លាំង ក្រៃ ក្នុងនោះ កូរីអានទុមើរបានរត់គេចពីកងទ័ពនៃប្អូនរបស់លិបទៀត ។

១៧ ឥឡូវនេះ ឈ្មោះរបស់ប្អូនរបស់លិបគឺ ស៊ិស ។ ហើយហេតុការណ៍បានកើតឡើងថា ស៊ិសបានដេញតាមកូរីអានទុមើរ ហើយ គាត់បានវាយយកបានទីក្រុងជាច្រើន ហើយគាត់បានសម្លាប់ទាំងពួកស្ត្រី និងកូនក្មេង ហើយគាត់បានដុតទីក្រុងជាច្រើនចោល ។

១៨ ហើយការភ័យខ្លាចដល់ស៊ិស បានរួតជ្រាបទូទៅអស់ទាំងដែនដី; មែនហើយ សំរែកមួយបានបន្លឺទូទៅទាំងដែនដីថា — តើអ្នក ណាអាចទប់ទល់នឹងកងទ័ពរបស់ស៊ិសបាន ? មើលចុះ គាត់បោសសំអាតដីពីខាងមុខគាត់ !

១៩ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនបានចាប់ផ្ដើមប្រមូលគ្នាមក ជាពលទ័ពទូទៅអស់ទាំងផ្ទៃដែនដី ។

២០ ហើយពួកគេបានបែកគ្នា; ហើយពួកគេមួយផ្នែក បានរត់ទៅខាងកងទ័ពរបស់ស៊ិស ហើយមួយផ្នែកទៀត បានរត់ទៅខាងកងទ័ព របស់កូរីអានទុមើរ ។

២១ ហើយសង្គ្រាមនោះធំណាស់ ហើយអស់ពេលយ៉ាងយូរ ហើយឆាកនៃការខ្ចាយឈាម និងការកាប់សម្លាប់ បន្តទៅយ៉ាង[ក]យូរ យារ រហូតដល់ផ្ទៃដែនដីទាំងមូល គ្របដណ្ដប់ដោយសាកសពនៃមនុស្សស្លាប់ ។

២២ ហើយសង្គ្រាមនោះ កើតឡើងយ៉ាងឆាប់រហ័សបណ្ដាលឲ្យគ្មាននរណាម្នាក់នៅសល់ ដើម្បីកប់អ្នកស្លាប់ឡើយ ប៉ុន្តែពួកគេ បានដើរចេញពីការខ្ចាយឈាមមួយ ទៅការខ្ចាយឈាមមួយទៀត ដោយទុកចោលសាកសព ទាំងប្រុសទាំងស្រ្តី និងកូនក្មេង រាយលើផ្ទៃដែនដី ឲ្យក្លាយទៅជាចំណីរបស់[ក]ដង្កូវ ។

២៣ ហើយក្លិនស្អុយពាសពេញលើផ្ទៃដែនដី គឺលើអស់ទាំងផ្ទៃដែនដី; ហេតុដូច្នោះហើយ ប្រជាជនមានការលំបាកទាំងយប់ទាំងថ្ងៃ ដោយសារក្លិនស្អុយនោះ ។

២៤ ក៏ប៉ុន្តែ ស៊ិសដេញតាមកូរីអានទុមើរមិនឈប់ឈរសោះ; ត្បិតគាត់បានស្បថថានឹងសងសឹកកូរីអានទុមើរ ដើម្បីឈាមរបស់បង គាត់ ដែលត្រូវបានស្លាប់ ហើយព្រះបន្ទូលនៃព្រះអម្ចាស់បានប្រាប់ដល់អេធើរថា កូរីអានទុមើរនឹងពុំត្រូវស្លាប់ដោយដាវឡើយ ។

២៥ ម្ល៉ោះហើយ យើងឃើញថា ព្រះអម្ចាស់ ទ្រង់បានដាក់ទោសដល់ពួកគេ ក្នុងសេចក្ដីខ្ញាល់ដ៏ពេញទំហឹងរបស់ទ្រង់ ហើយអំពើ ទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ បានរៀបចំផ្លូវឲ្យពួកគេ ទៅកាន់សេចក្ដីបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ស៊ិសបានដេញតាមកូរីអានទុមើរ ឆ្ពោះទៅទិសខាងកើត រហូតដល់តំបន់ព្រំប្រទល់ជិត ឆ្នេរសមុទ្រ ហើយនៅទីនោះ ទ្រង់បានច្បាំងនឹងស៊ិស អស់រយៈពេលបីថ្ងៃ ។

២៧ ហើយការបំផ្លិចបំផ្លាញ ក្នុងចំណោមពលទ័ពរបស់ស៊ិស នោះឃោរឃៅណាស់ ធ្វើឲ្យប្រជាជនចាប់ផ្ដើមភិតភ័យ ហើយចាប់ ផ្ដើមរត់គេចចេញពីពលទ័ពរបស់កូរីអានទុមើរ; ហើយពួកគេបានរត់ទៅដែនដីកូរីហូរ ហើយបោសសំអាតបណ្ដាជន ដែលនៅពីមុខ ពួកគេ គឺអស់អ្នកណាដែលពុំព្រមចូលរួមជាមួយនឹងពួកគេ ។

២៨ ហើយពួកគេបានបោះត្រសាលរបស់គេ នៅក្នុងច្រកភ្នំកូរីហូរ; ហើយកូរីអានទុមើរបានបោះត្រសាលរបស់ទ្រង់ នៅក្នុងច្រកភ្នំស៊េរ ។ ឥឡូវនេះ ច្រកភ្នំស៊េរគឺនៅជិតកូនភ្នំកុមណូរ; ហេតុដូច្នោះហើយ កូរីអានទុមើរបានប្រមូលពលទ័ពរបស់ទ្រង់នៅលើភ្នំកុមណូរ ហើយបានបន្លឺត្រែដល់ពលទ័ពរបស់ស៊ិស ហៅពួកគេឲ្យមកច្បាំង ។

២៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានចេញមក តែត្រូវបានរុញច្រានទៅវិញ; ហើយពួកគេបានមកជាលើកទី២ ហើយ ពួកគេត្រូវបានរុញច្រានទៅវិញទៀត ជាលើកទី២ ។ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានមកម្ដងទៀត ជាលើកទី៣ ហើយការប្រយុទ្ធបានក្លាយទៅជាសាហាវអស្ចារ្យ ។

៣០ ហើយហេតុការណ៍បានកើតឡើងថា ស៊ិសបានវាយត្រូវកូរីអានទុមើរ ធ្វើឲ្យទ្រង់របួសយ៉ាងជ្រៅ ជាច្រើនកន្លែង; ហើយ

២១ *ក* អេធើរ ១១:៦.

២២ *ក* អេសាយ ១៤:៩–១១.

កូរីអានទុមើរ ដោយអស់ឈាមជាច្រើន ក៏សន្លប់ទៅ ហើយត្រូវបានសែងចេញ ហាក់ដូចជាទ្រង់សុគត ។

៣១ ឥឡូវនេះ ការបាត់បង់ប្រុស ស្រី និងកូនក្មេងៗទាំងសងខាង មានចំនួនច្រើនណាស់ ទើបស៊ិសបានបញ្ជាឲ្យទ័ពរបស់គាត់ថា ពួកគេមិនត្រូវដេញតាមពលទ័ពរបស់កូរីអានទុមើរទៀតទេ; ហេតុដូច្នោះ ពួកគេបានត្រឡប់ទៅឯជំរុំរបស់គេវិញ ៕

## ជំពូកទី ១៥

*ពួកសាសន៍យ៉ារេឌរាប់លាននាក់ ត្រូវបានស្លាប់នៅក្នុងចម្បាំង — ស៊ិស និងកូរីអានទុមើរ ប្រមូលប្រជាជនទាំងអស់ មកច្បាំងដល់ស្លាប់ — ព្រះវិញ្ញាណនៃព្រះអម្ចាស់ ឈប់តស៊ូជាមួយនឹងពួកគេ — ប្រជាជាតិយ៉ារេឌត្រូវបំផ្លាញចោលទាំងស្រុង — កូរីអានទុមើរតែម្នាក់គត់ ដែលនៅរស់ ។*

ហើយហេតុការណ៍បានកើតឡើងថា កាលកូរីអានទុមើរបានជាពីរបួស នោះទ្រង់បានចាប់ផ្ដើមនឹកឃើញ ដល់[ក]ពាក្យទាំងឡាយដែលអេធើរបាននិយាយមកទ្រង់ ។

២ ទ្រង់បានទតឃើញថា ប្រជាជនរបស់ទ្រង់ត្រូវស្លាប់ ដោយមុខដាវអស់ជិតពីរលាននាក់ទៅហើយ ហើយទ្រង់បានចាប់ផ្ដើមព្រួយ នៅក្នុងចិត្ត; មែនហើយ បុរសដ៏ខ្លាំងពូកែពីរលាននាក់ ត្រូវស្លាប់ព្រមទាំងប្រពន្ធរបស់គេ និងកូនរបស់គេផង ។

៣ ទ្រង់បានចាប់ផ្ដើមប្រែចិត្ត ពីការអាក្រក់ដែលទ្រង់បានប្រព្រឹត្ត; ទ្រង់បានចាប់ផ្ដើមនឹកឃើញដល់ពាក្យពេចន៍ដែលបាននិយាយចេញ មកពីមាត់របស់អស់ទាំងពួកព្យាការី ហើយទ្រង់បានទតឃើញថា ពាក្យទាំងនោះត្រូវបានបំពេញមកដល់ពេលនេះដ៏សព្វគ្រប់; ហើយព្រលឹងទ្រង់ទួញសោក ហើយមិនព្រមសះស្បើយឡើយ ។

៤ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានសរសេរសំបុត្រមួយច្បាប់ ទៅឲ្យស៊ិស មានប្រាថ្នាចង់ឲ្យគាត់លើកលែងជីវិតឲ្យ ប្រជាជន ហើយទ្រង់នឹងប្រគល់នគរឲ្យ ដើម្បីជីវិតរបស់ប្រជាជន ។

៥ ហើយហេតុការណ៍បានកើតឡើងថា កាលស៊ិសបានទទួលសំបុត្ររបស់ទ្រង់ហើយ នោះគាត់បានសរសេរសំបុត្រមួយច្បាប់មកកូរីអានទុមើរថា បើសិនជាទ្រង់ព្រមចុះចាញ់ ដើម្បីឲ្យគាត់សម្លាប់ទ្រង់ដោយដាវរបស់គាត់ផ្ទាល់ នោះទើបគាត់នឹងលើកលែងជីវិត ឲ្យប្រជាជន ។

៦ ហើយហេតុការណ៍បានកើតឡើងថា ប្រជាជនពុំបានប្រែចិត្ត ពីអំពើទុច្ចរិតរបស់ខ្លួនទេ; ហើយប្រជាជនរបស់កូរីអានទុមើរត្រូវបាន ចាក់រុកឲ្យមានកំហឹងនឹងប្រជាជនរបស់ស៊ិស; ហើយប្រជាជនរបស់ស៊ិសត្រូវបានចាក់រុកឲ្យមានកំហឹងនឹងប្រជាជនរបស់កូរីអានទុមើរ; ហេតុដូច្នោះហើយ ប្រជាជនរបស់ស៊ិសបានច្បាំងនឹងប្រជាជនរបស់កូរីអានទុមើរ ។

៧ ហើយកាលកូរីអានទុមើរបានឃើញថាទ្រង់ជិតចាញ់ នោះទ្រង់បានរត់គេចពីប្រជាជនរបស់ស៊ិស ។

៨ ហើយហេតុការណ៍បានកើតឡើងថា ទ្រង់បានមកដល់សមុទ្ររីពលីអានគុម ដែលបកប្រែមកថាធំ ឬលើសអ្វីទាំងអស់; ហេតុដូច្នោះហើយ កាលពួកគេបានមកដល់សមុទ្រនេះហើយ នោះពួកគេបានបោះត្រសាលរបស់គេ ហើយស៊ិសក៏បានបោះត្រសាលគាត់ នៅជិតពួកគេដែរ; ហេតុដូច្នេះហើយ ដល់ស្អែកឡើង ពួកគេបានច្បាំងគ្នា ។

៩ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រយុទ្ធយ៉ាងសាហាវអស្ចារ្យ នៅក្នុងការប្រយុទ្ធនោះ កូរីអានទុមើរត្រូវរបួស ទៀត ហើយទ្រង់សន្លប់ដោយអស់ឈាម ។

១០ ហើយហេតុការណ៍បានកើតឡើងថា ពលទ័ពរបស់កូរីអានទុមើរបានវាយសំរុកទៅលើពលទ័ពរបស់ស៊ិស រហូតដល់បានវាយ ឈ្នះពួកគេ ធ្វើឲ្យពួកគេរត់គេចចេញពីខ្លួន; ហើយពួកគេបានរត់ទៅទិសខាងត្បូង ហើយបានបោះត្រសាលរបស់ពួកគេ នៅត្រង់កន្លែង មួយដែលហៅថា អូកាត ។

១១ ហើយហេតុការណ៍បានកើតឡើងថា កងទ័ពរបស់កូរីអានទុមើរ បានបោះត្រសាលរបស់ពួកគេ នៅជិតភ្នំរ៉ាម៉ា; ហើយគឺនៅភ្នំដដែលនេះ ដែលឪពុកខ្ញុំ គឺមរមន បាន[ក]លាក់បញ្ជីទាំងឡាយថ្វាយព្រះអម្ចាស់ ដែលជាបញ្ជីពិសិដ្ឋ ។

១២ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រមូលមកនូវអស់ទាំងប្រជាជន នៅលើអស់ទាំងផ្ទៃដែនដី ដែលពុំទាន់ស្លាប់ លើកលែងតែអេធើរ ។

១៣ ហើយហេតុការណ៍បានកើតឡើងថា អេធើរបានឃើញនូវសកម្មភាពទាំងអស់របស់ប្រជាជន; ហើយលោកបានឃើញថាប្រជាជនដែលនៅខាងកូរីអានទុមើរ ត្រូវបានប្រមូលទៅក្នុងកងទ័ពរបស់កូរីអានទុមើរ; រីឯប្រជាជនដែលនៅខាងស៊ិស ត្រូវបាន ប្រមូលទៅក្នុងកងទ័ពរបស់ស៊ិស ។

**១៥** ១*ក* អេធើរ ១៣:២០–២១.

១១ *ក* មរមន ៦:៦.

១៤ ហេតុដូច្នោះហើយ អស់រយៈពេលបួនឆ្នាំ នោះពួកគេ ប្រមូលប្រជាជន ដើម្បីពួកគេអាចប្រមូលមនុស្សទាំងអស់ ដែល នៅ លើផ្ទៃដែនដី ហើយដើម្បីពួកគេអាចទទួលកម្លាំងទាំងអស់ ដែលពួកគេមានលទ្ធភាពអាចទទួល ។

១៥ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបានមក ជុំគ្នាហើយ នោះមនុស្សម្នាក់ៗ នៅក្នុងកងទ័ពដែលគេចង់ ជាមួយ នឹង ប្រពន្ធរបស់គេ និងកូនរបស់គេ — ទាំងប្រុសទាំងស្រី និង កូនក្មេងៗ ត្រូវបានប្រដាប់ដោយគ្រឿងសស្ត្រា[ក]វុធពិជ័យសង្គ្រាម ទាំងឡាយ ដោយមានខែលទាំងឡាយ និងប្រដាប់បាំងដើមទ្រូង ទាំងឡាយ និងមួកដែកទាំងឡាយ ហើយស្លៀកពាក់តាម របៀបសង្គ្រាម — ពួកគេ បានចេញមកច្បាំងតទល់គ្នា ហើយ ពួកគេប្រយុទ្ធពេញមួយថ្ងៃ ហើយពុំឈ្នះ ពុំចាញ់សោះ ។

១៦ ហើយហេតុការណ៍បានកើតឡើងថា ដល់ពេលយប់ ពួក គេនឿយហត់ ហើយត្រឡប់ទៅឯជុំរំ របស់ពួកគេវិញរៀងខ្លួន; ហើយ បន្ទាប់ពីពួកគេបានត្រឡប់ទៅឯជំរុំគេវិញហើយ នោះពួក គេបានស្រែកទ្រហោយំ ហើយទួញសោក ចំពោះការបាត់បង់ ប្រជាជនគេ ដែលត្រូវស្លាប់បង់; ហើយសំរែករបស់ពួកគេ ការទ្រហោយំ និងការទួញសោករបស់គេឮជាខ្លាំង រហូតដល់ បានពុះជ្រែកអាកាសជាពន់ ប្រមាណ ។

១៧ ហើយហេតុការណ៍បានកើតឡើងថា ដល់ស្អែកឡើង ពួក គេបានទៅច្បាំងទៀត ហើយថ្ងៃនោះ ធំ ហើយឃោរឃៅ ណាស់; ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេពុំឈ្នះ ពុំចាញ់ដែរ ហើយនៅពេលយប់មកដល់ទៀត នោះពួកគេបាន ពុះជ្រែកអាកាស ដោយ សំរែករបស់គេ និងការទ្រហោយំ និង ការទួញសោក ចំពោះការបាត់បង់ប្រជាជនគេដែលត្រូវសម្លាប់បង់។

១៨ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរ បានសរសេរសំបុត្រមួយច្បាប់ទៅឲ្យស៊ិសទៀត មានប្រាថ្នាចង់ឲ្យ គាត់ឈប់ មកច្បាំងទៀត តែឲ្យគាត់យកនគរ ហើយលើកលែង ជីវិតឲ្យប្រជាជន ។

១៩ ប៉ុន្តែមើលចុះ ព្រះវិញ្ញាណនៃព្រះអម្ចាស់[ក] ទ្រង់បាន ឈប់តស៊ូជាមួយនឹងពួកគេទៀតហើយ ហើយអារក្សសាតាំង មានអំណាច ទាំងស្រុង ទៅលើដួងចិត្តនៃមនុស្ស; ត្បិតពួកគេបាន បណ្ដោយខ្លួន ទៅក្នុងភាពរឹងរូសនៃចិត្តរបស់គេ និងភាព ងងឹតងងល់នៃគំនិត របស់គេ ដែលបណ្ដាលឲ្យពួកគេត្រូវ បំផ្លាញបង់; ហេតុដូច្នោះហើយ ពួកគេបានចេញទៅច្បាំងទៀត ។

២០ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រយុទ្ធ ពេញមួយថ្ងៃ ហើយកាលពេលយប់មកដល់ នោះពួកគេបានដេក នៅលើដាវរបស់ខ្លួន ។

២១ ហើយដល់ស្អែកឡើង ពួកគេបានប្រយុទ្ធ រហូត ដល់ពេលយប់មកដល់ទៀត ។

២២ ហើយកាលពេលយប់មកដល់ នោះពួកគេស្រវឹង[ក]នឹង កំហឹង ដូចជាមនុស្សស្រវឹងស្រាទំពាំងបាយជូរ; ហើយពួកគេបាន ដេកនៅ លើដាវរបស់ខ្លួនទៀត ។

២៣ ហើយដល់ស្អែកឡើង ពួកគេបានប្រយុទ្ធទៀត ហើយ កាលពេលយប់មកដល់ នោះពួកគេទាំងអស់ត្រូវស្លាប់ដោយ ដាវ លើកលែងតែ ប្រជាជនរបស់កូរីអានទុមើរ ហាសិបពីរនាក់ និងប្រជាជនរបស់ស៊ិស ហុកសិបប្រាំបួននាក់ប៉ុណ្ណោះ ។

២៤ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបាន ដេកនៅលើដាវរបស់ខ្លួន នៅយប់នោះ ហើយដល់ស្អែកឡើង ពួកគេបាន ប្រយុទ្ធទៀត ហើយពួកគេតតាំងគ្នានៅក្នុងសមត្ថភាព របស់គេ ដោយដាវរបស់គេ និងខែលរបស់គេ ពេញមួយថ្ងៃ ។

២៥ ហើយកាលពេលយប់មកដល់ នៅមានប្រជាជនរបស់ ស៊ិស សាមសិបពីរនាក់ និងប្រជាជនរបស់កូរីអានទុមើរ ម្ភៃប្រាំពីរនាក់ ។

២៦ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបរិភោគ ហើយដេក ហើយប្រុងប្រៀបខ្លួន ដើម្បីស្លាប់នៅថ្ងៃស្អែក ។ ហើយពួក គេជាមនុស្សមាឌធំ ហើយខ្លាំងពូកែ បើសិនជា គិតតាមកម្លាំងមនុស្ស ។

២៧ ហើយហេតុការណ៍បានកើតឡើងថា ពួកគេបានប្រយុទ្ធ អស់រយៈពេលបីម៉ោង ហើយពួកគេសន្លប់ដោយអស់ឈាម ។

២៨ ហើយហេតុការណ៍បានកើតឡើងថា កាលទ័ព របស់កូរីអានទុមើរបានទទួលកម្លាំងល្មមគ្រប់គ្រាន់ ដើម្បីពួកគេ អាចដើរបាន នោះពួកគេបំរុងរត់គេច យកតែអាយុរៀងខ្លួន; ប៉ុន្តែ មើលចុះ ស៊ិសបានក្រោកឡើង ព្រមទាំងទ័ពរបស់គាត់ផង ហើយ គាត់បានស្បថនៅ ក្នុងកំហឹងថា គាត់នឹងសម្លាប់កូរីអានទុមើរឲ្យ បាន ឬក៏គាត់នឹងត្រូវវិនាសដោយដាវ ។

២៩ ហេតុដូច្នោះហើយ គាត់បានដេញតាមពួកគេ ហើយ ដល់ស្អែកឡើង គាត់បានតាមទាន់ពួកគេ; ហើយពួកគេបានប្រយុទ្ធ ដោយ ដាវទៀត ។ ហើយហេតុការណ៍បានកើតឡើងថា កាល ពួកគេបានដួលស្លាប់[ក]ទាំងអស់គ្នាដោយដាវទៅ លើកលែងតែ

១៥ *ក* ម៉ូសាយ ៨:៧–១០.
១៩ *ក* ស.ប. អារក្ស.
២២ *ក* ម៉ូរ៉ូណៃ ៩:២៣.
២៩ *ក* អេធើរ ១៣:២០–២១.

កូរីអានទុមើរ និងស៊ិស មើលចុះ ស៊ិសបានសន្លប់ដោយអស់ឈាម ។

៣០ ហើយហេតុការណ៍បានកើតឡើងថា កាលកូរីអានទុមើរបានផ្អែកខ្លួន ទៅលើដាវរបស់ទ្រង់ ដើម្បីទ្រង់សំរាកបន្តិច នោះទ្រង់បានកាត់ក្បាលរបស់ស៊ិស ។

៣១ ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីទ្រង់បានកាត់ក្បាលរបស់ស៊ិសហើយ នោះស៊ិសបានច្រត់ដៃក្រោកឡើងហើយ ដួលចុះ; ហើយបន្ទាប់ពីគាត់ខិតខំរកដង្ហើម គាត់ក៏ស្លាប់ទៅ។

៣២ ហើយហេតុការណ៍បានកើតឡើងថា កូរីអានទុមើរបានដួលចុះទៅលើដី ហើយហាក់បីដូចជាទ្រង់គ្មានជីវិតសោះ ។

៣៣ ហើយព្រះអម្ចាស់មានព្រះបន្ទូល ទៅអេធើរ ហើយប្រាប់លោកថា៖ ចូរចេញទៅចុះ ។ ហើយលោកក៏ចេញទៅហើយបាន ឃើញថា ព្រះបន្ទូលនៃព្រះអម្ចាស់បានបំពេញទាំងអស់មែន; ហើយលោកបានបង្ហើយបញ្ជីរបស់លោក (ហើយមួយភាគរយ ក៏ខ្ញុំមិន បានសរសេរដែរ) ហើយលោកបានលាក់បញ្ជីរបស់លោកទាំងនោះ តាមរបៀបម្យ៉ាង ដែលប្រជាជនលិមហៃបានប្រទះឃើញ ។

៣៤ ឥឡូវនេះ ពាក្យចុងក្រោយបំផុត ដែលបានសរសេរដោយអេធើរ គឺ៖ ទោះជាព្រះអម្ចាស់ទ្រង់ចង់ឲ្យខ្ញុំប្រែរូប ឬឲ្យខ្ញុំរងទុក្ខ ស្របតាមព្រះហឫទ័យនៃព្រះអម្ចាស់ នៅក្នុងសាច់ឈាមក៏ដោយ នោះមិនជាការសំខាន់ទេ ឲ្យតែខ្ញុំបានសង្គ្រោះនៅក្នុងនគរព្រះ ។ អាម៉ែន ៕ :៚

# គម្ពីរមរ៉ូណៃ

## ជំពូកទី ១

*មរ៉ូណៃសរសេរសំរាប់ជាប្រយោជន៍ដល់ពួកសាសន៍លេមិន — ពួកសាសន៍នីហ្វៃណាដែលមិនព្រមបដិសេធព្រះគ្រីស្ទ នោះត្រូវយក ទៅសម្លាប់ចោល ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

ឥឡូវនេះ ខ្ញុំមរ៉ូណៃ បន្ទាប់ពីបានបញ្ចប់នូវការសង្ខេបអំពីដំណើររឿងនៃប្រជាជនយ៉ារេឌហើយ នោះខ្ញុំបានគិតស្មានថា ខ្ញុំមិនត្រូវ សរសេរអ្វីទៀតទេ ប៉ុន្តែខ្ញុំនៅពុំទាន់វិនាសនៅឡើយ; ហើយខ្ញុំពុំបានបង្ហាញខ្លួនឲ្យពួកសាសន៍លេមិនដឹងទេ ខ្លាចក្រែងពួកគេ នឹងបំផ្លាញរូបខ្ញុំចោល ។

២ ត្បិតមើលចុះ សង្គ្រាមរវាងពួកគេ មានសភាពសាហាវជាអតិបរមា; ហើយពីព្រោះតែសម្អប់របស់ពួកគេ នោះពួកគេបានសម្លាប់ សាសន៍នីហ្វៃទាំងអស់ ដែលពុំបដិសេធព្រះគ្រីស្ទ ។

៣ ហើយខ្ញុំមរ៉ូណៃ នឹងពុំបដិសេធព្រះគ្រីស្ទទេ; ហេតុដូច្នោះហើយ ខ្ញុំបានដើរគ្រប់ទិសទី ដែលខ្ញុំអាចទៅបានដើម្បីសេចក្ដីសុខដល់ ជីវិតខ្ញុំ ។

៤ ហេតុដូច្នោះហើយ ខ្ញុំសរសេរនូវការណ៍ខ្លះទៀតដែលផ្ទុយនឹងអ្វីៗដែលខ្ញុំបានសន្និដ្ឋានមក ព្រោះខ្ញុំបានគិតស្មានថាខ្ញុំមិនត្រូវ សរសេរអ្វីទៀតទេ ប៉ុន្តែខ្ញុំសរសេរនូវការណ៍ខ្លះទៀតដែលប្រហែលជាអាចមានប្រយោជន៍ដល់ពួកបងប្អូនរបស់ខ្ញុំ គឺពួកសាសន៍ លេមិន នៅថ្ងៃណាមួយក្នុងអនាគត ស្របតាមព្រះហឫទ័យនៃព្រះអម្ចាស់ ៕

## ជំពូកទី ២

*ព្រះយេស៊ូវទ្រង់បានប្រទានដល់ពួកសិស្សសាសន៍នីហ្វៃទាំង១២នាក់នូវអំណាចដើម្បីផ្ដល់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

ព្រះបន្ទូលនៃព្រះគ្រីស្ទ ដែលទ្រង់មានព្រះបន្ទូលទៅពួកសិស្សរបស់ទ្រង់ទាំង១២នាក់ ដែលទ្រង់បានរើស កាលទ្រង់បានដាក់ព្រះហស្ត ទ្រង់លើពួកគេ —

២ ហើយទ្រង់បានហៅឈ្មោះពួកគេ ហើយមានព្រះបន្ទូលថា៖ អ្នករាល់គ្នាត្រូវអំពាវនាវដល់ព្រះវរបិតា ដោយនូវនាមយើងក្នុងការអធិស្ឋានដ៏ព្យាយាម; ហើយបន្ទាប់ពីអ្នករាល់គ្នាបានធ្វើ

៣២ *ក* អេាមណៃ ១:២០—២២.
៣៣ *ក* ម៉ូសាយ ៨:៩;
អាលម៉ា ៣៧:២១—៣១;
អេធើរ ១:១—៥.
៣៤ *ក* អេធើរ ១២:២.
[មរ៉ូណៃ]
១ ១*ក* ស.ប. មរ៉ូណៃ, កូនប្រុសរបស់មរមន.
២ *ក* ១ នីហ្វៃ ១២:២០—២៣.
*ខ* អាលម៉ា ៤៥:១៤.
៣ *ក* ម៉ាថាយ ១០:៣២—៣៣;
៣ នីហ្វៃ ២៩:៥.
២ ១*ក* ៣ នីហ្វៃ ១៣:២៥.

យ៉ាងនេះហើយ នោះអ្នករាល់គ្នានឹងមាន[ក]អំណាចដើម្បីផ្តល់ព្រះវិញ្ញាណ បរិសុទ្ធ ដល់ជនណាដែលអ្នក[ខ]ដាក់ដៃពីលើ; ហើយដោយនូវនាមយើង នោះ[គ]អ្នកត្រូវឲ្យព្រះវិញ្ញាណបរិសុទ្ធ ត្បិតពួកសាវកទាំងឡាយ របស់យើងបានធ្វើដូច្នោះ ។

៣ ឥឡូវនេះ ព្រះគ្រីស្ទទ្រង់មានព្រះបន្ទូលទាំងនេះទៅពួកគេ នៅពេលទ្រង់បានលេចមកជាលើកទី១; ឯហ្វូងមនុស្សពុំបានឮទេ ប៉ុន្តែពួកសិស្សបានឮ; ហើយអស់មនុស្សណាដែលពួកគេបាន [ក]ដាក់ដៃលើ តែងតែបានទទួលព្រះវិញ្ញាណបរិសុទ្ធ ៕

## ជំពូកទី ៣

*ពួកអែលឌើរតែងតាំងពួកសង្ឃ និងពួកគ្រូ ដោយការដាក់ដៃលើ ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

នេះគឺជារបៀបពួកសិស្ស ដែលមានឈ្មោះថា [ក]អែលឌើរនៃសាសនាចក្រ បាន[ខ]តែងតាំងពួកសង្ឃ និងពួកគ្រូ —

២ បន្ទាប់ពីពួកគេបានអធិស្ឋានដល់ព្រះវរបិតា ដោយនូវព្រះនាមព្រះគ្រីស្ទហើយ នោះពួកគេបានដាក់ដៃលើជនទាំងឡាយ ហើយក៏ ពោលពាក្យថា៖

៣ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ខ្ញុំតែងតាំងអ្នកជាសង្ឃ (ឬបើអ្នកនោះជាគ្រូ ខ្ញុំតែងតាំងអ្នកជាគ្រូ) ដើម្បីផ្សាយនូវការប្រែចិត្ត និងការ[ក]ផ្តាច់បាប តាមរយៈព្រះយេស៊ូវគ្រីស្ទ គឺដោយសេចក្តីជំនឿដ៏ខ្ជាប់ខ្ជួនដល់ព្រះនាមទ្រង់រហូតដល់ទីបំផុត ។ អាម៉ែន ។

៤ ហើយដោយរបៀបនេះហើយដែលពួកគេបាន[ក]តែងតាំងពួកសង្ឃ និងពួកគ្រូ ស្របតាម[ខ]អំណោយទាន និងការហៅទាំងឡាយនៃព្រះ ដែលមានដល់មនុស្សលោក; ហើយពួកគេបានតែងតាំងអ្នកទាំងឡាយ ដោយ[គ]ព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដែលនៅក្នុងពួកគេ ៕

## ជំពូកទី ៤

*របៀបពួកអែលឌើរ និងពួកសង្ឃធ្វើបុណ្យរំឭកផ្នែកនំប៉័ង ត្រូវបានពន្យល់ប្រាប់ ។ ប្រមាណ ជាឆ្នាំ ៤០១–៤២១ គ.ស. ។*

[ក]របៀបពួក[ខ]អែលឌើរ និងពួកសង្ឃរបស់គេ ធ្វើបុណ្យសាច់ និងព្រះលោហិតនៃព្រះគ្រីស្ទដល់សាសនាចក្រ; ហើយពួកគេបាន[គ]ធ្វើបុណ្យ នេះ ស្របតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះគ្រីស្ទ; ហេតុដូច្នោះហើយ យើងដឹងថា របៀបនេះត្រឹមត្រូវ; ហើយអែលឌើរ ឬសង្ឃបានធ្វើ បុណ្យនេះដូចតទៅគឺ —

២ ហើយពួកគេបានលុតជង្គង់ចុះជាមួយនឹងសាសនាចក្រ ហើយអធិស្ឋានដល់ព្រះវរបិតា ដោយនូវព្រះនាមព្រះគ្រីស្ទ ថា៖

៣ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ យើងខ្ញុំសូមដល់ព្រះអង្គ ដោយនូវព្រះនាម នៃព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូវគ្រីស្ទ សូមប្រទានពរ ហើយ[ក]ញែកនំប៉័ងនេះចេញជាបរិសុទ្ធ ដល់ព្រលឹងនៃអស់អ្នកណា ដែលទទួលទាននំប៉័ងនេះ ប្រយោជន៍ឲ្យពួកគេអាចទទួលទាន ដើម្បី[ខ]រំឭកពីព្រះកាយនៃព្រះរាជបុត្រារបស់ព្រះអង្គ ហើយធ្វើបន្ទាល់ដល់ព្រះអង្គ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ ថាពួកគេនឹងព្រមលើកដាក់មកលើ[គ]ខ្លួនគេ នូវព្រះនាមនៃព្រះរាជបុត្រារបស់ព្រះអង្គ ហើយរំឭកពីទ្រង់ជានិច្ច ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដែលទ្រង់បានប្រទានដល់ពួកគេ ប្រយោជន៍ឲ្យពួកគេអាច បាន[ឃ]ព្រះវិញ្ញាណរបស់ទ្រង់ គង់នៅជាមួយនឹងពួកគេជាដរាប ។ អាម៉ែន ៕

## ជំពូកទី ៥

*របៀបធ្វើបុណ្យរំឭកផ្នែកស្រាទំពាំងបាយជូរ ត្រូវបានថែងប្រាប់ ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

២ *ក* ស.ប. អំណាច.
*ខ* ស.ប. ដៃ, ការដាក់.
*គ* ៣ នីហ្វៃ ១៨:៣៧.
៣ *ក* កិច្ចការ ១៩:៦.
**៣** ១*ក* អាលម៉ា ៦:១.
ស.ប. អែលឌើរ.
*ខ* ស.ប. តែងតាំង, ការតែងតាំង.
៣ *ក* ស.ប. ការផ្តាច់បាប.
៤ *ក* គ. និង ស. ១៨:៣២; ២០:៦០.
*ខ* ស.ប. អំណោយទាន.
*គ* ១ នីហ្វៃ ១៣:៣៧; ម៉ូរ៉ូណៃ ៦:៩.
**៤** ១*ក* ៣ នីហ្វៃ ១៨:១–៧.
*ខ* ស.ប. អែលឌើរ.
*គ* គ. និង ស. ២០:៧៦–៧៧.
៣ *ក* ស.ប. បុណ្យរំឭក.
*ខ* លូកា ២២:១៩;
១ កូរិន. ១១:២៣–២៤;
៣ នីហ្វៃ ១៨:៧.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
*ឃ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.

[ក]របៀបធ្វើបុណ្យស្រាទំពាំងបាយជូរ — មើលចុះ ពួកគេបាន
យកពែង ហើយក៏ពោលពាក្យថា៖
២ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ យើងខ្ញុំ
សូមដល់ព្រះអង្គ ដោយនូវព្រះនាម នៃព្រះរាជបុត្រារបស់ព្រះអង្គ
គឺព្រះយេស៊ូវគ្រីស្ទ សូមប្រទានពរ ហើយញែក
[ក]ស្រាទំពាំងបាយជូរនេះចេញជាបរិសុទ្ធ ដល់ព្រលឹងនៃអស់អ្នក
ណាដែលទទួលទាន ស្រាទំពាំងបាយជូរនេះ ប្រយោជន៍ឲ្យពួកគេ
អាចធ្វើយ៉ាងនោះ ដើម្បី[ខ]រំឭកដល់ព្រះលោហិតនៃព្រះរាជបុត្រា
របស់ព្រះអង្គ ដែលបាន ច្រួចជំនួសពួកគេ ប្រយោជន៍ឲ្យពួកគេ
អាចធ្វើបន្ទាល់ដល់ព្រះអង្គ ឱព្រះអង្គ ជាព្រះវរបិតា
ដ៏អស់កល្បជានិច្ចអើយ ថាពួកគេនឹងរំឭកពី ទ្រង់ជានិច្ច
ប្រយោជន៍ឲ្យពួកគេអាចបានព្រះវិញ្ញាណរបស់ទ្រង់ គង់នៅជា
មួយនឹងពួកគេ ។ អាម៉ែន ៕

## ជំពូកទី ៦

*អ្នកណាដែលប្រែចិត្ត បានទទួលបុណ្យជ្រមុជទឹក ហើយបាន
ប្រកបដោយការរាប់អាន — សមាជិកនៃសាសនាចក្រដែល
ប្រែចិត្តត្រូវបាន អត់ទោសឲ្យ — ការប្រជុំទាំងឡាយ ត្រូវបាន
ដឹកនាំ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ ប្រមាណ
ជាឆ្នាំ ៤០១–៤២១ គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំនិយាយអំពី[ក]បុណ្យជ្រមុជទឹក មើលចុះ ពួក
អែលឌើរ ពួកសង្ឃ និងពួកគ្រូ បានទទួលបុណ្យជ្រមុជទឹក; ហើយ
ពួកគេ ពុំបានទទួលបុណ្យជ្រមុជទឹកឡើយ លើកលែងតែពួកគេ
បាននាំមកនូវលទ្ធផល ដែលបង្ហាញឲ្យឃើញថា ពួកគេ[ខ]សម
នឹងទទួល ។
២ ហើយពួកគេក៏ពុំបានទទួលអ្នកណាមួយចំពោះបុណ្យ
ជ្រមុជទឹកឡើយ លើកលែងតែអ្នកនោះមកដោយមានចិត្ត[ក]សង្រេង
និងវិញ្ញាណទន់ទាបប៉ុណ្ណោះ ហើយធ្វើបន្ទាល់ដល់សាសនាចក្រ
ថា ពួកគេប្រាកដជាបានប្រែចិត្តពីអស់ទាំងអំពើបាបរបស់ពួកគេ ។
៣ ហើយគ្មានបានទទួលអ្នកណាមួយចំពោះបុណ្យជ្រមុជទឹកឡើយ
លើកលែងតែអ្នកនោះលើក[ក]ដាក់មកលើខ្លួន នូវព្រះនាមនៃ ព្រះ
គ្រីស្ទ ដោយប្ដេជ្ញាថា នឹងបំរើទ្រង់ដល់ចុងបំផុត ។
៤ ហើយបន្ទាប់ពីពួកគេបានទទួលចំពោះបុណ្យជ្រមុជទឹក ហើយ
ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ បានមកសណ្ឋិតលើ ហើយ
[ក]លាង ជំរះហើយ នោះពួកគេត្រូវបានរាប់ក្នុងចំណោមប្រជាជន
នៃសាសនាចក្ររបស់ព្រះគ្រីស្ទ; ហើយ[ខ]ឈ្មោះរបស់ពួកគេត្រូវ
បានយកទៅ ដើម្បីឲ្យពួកគេអាចបាននឹកចាំ ហើយចិញ្ចឹមបីបាច់
ដោយព្រះបន្ទូលដ៏ល្អនៃព្រះ ដើម្បីរក្សាពួកគេ ឲ្យនៅក្នុងផ្លូវត្រូវ
ដើម្បីឲ្យពួកគេ[គ]ចាំ យាមក្នុងការអធិស្ឋានជានិច្ច ដោយពឹង
[ឃ]ផ្អែកទៅលើតែព្រះគុណនៃព្រះគ្រីស្ទ ដែលជា[ង]មេផ្ដើម ហើយ
ជាមេសំរេច នូវសេចក្ដីជំនឿ របស់ពួកគេ ។
៥ ហើយ[ក]សាសនាចក្របានជួបជុំគ្នាជា[ខ]ញឹកញាប់ ដើម្បី
[គ]តមអាហារ ហើយអធិស្ឋាន ហើយពិគ្រោះគ្នាទៅវិញទៅមក
អំពីសុខុមាល ភាពដល់ព្រលឹងពួកគេ ។
៦ ហើយពួកគេបានជួបជុំគ្នាជាញឹកញាប់ ដើម្បីទទួលទាននំប៉័ង
និងស្រាទំពាំងបាយជូរ ដើម្បីរំឭកពីព្រះអម្ចាស់យេស៊ូវ ។
៧ ហើយពួកគេបានគោរពយ៉ាងតឹងរ៉ឹង ថា[ក]កុំឲ្យមានអំពើទុច្ចរិត
នៅក្នុងចំណោមពួកគេ; ហើយអស់អ្នកណាដែលឃើញថា បាន
ប្រព្រឹត្តអំពើទុច្ចរិត នោះនឹងត្រូវ[ខ]សាក្សីបីនាក់នៃសាសនាចក្រ
កាត់ទោស នៅខាងមុខ[គ]ពួកអែលឌើរ ហើយបើសិនជាពួកគេពុំ
ប្រែចិត្ត ហើយពុំ[ឃ]ទទួលសារភាពទេ នោះឈ្មោះរបស់គេនឹងត្រូវ
[ង]លុបចេញ ហើយពួកគេនឹងពុំត្រូវបានរាប់ក្នុងចំណោមរាស្ត្រ
នៃព្រះគ្រីស្ទទៀត ឡើយ ។

**៥** ១*ក* ៣ នីហ្វៃ ១៨:៨–១១;
គ. និង ស. ២០:៧៨–៧៩.
២ *ក* គ. និង ស. ២៧:២–៤.
ស.ប. បុណ្យរំឭក.
*ខ* លូកា ២២:១៩–២០;
១ កូរិន. ១១:២៥.
**៦** ១*ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យ
ជ្រមុជទឹក.
*ខ* ស.ប. សក្តិសម, ភាពសក្តិសម.
២ *ក* ស.ប. ចិត្តសង្រេង.
៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការ
យកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ
មកដាក់លើខ្លួនយើង.
៤ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
*ខ* គ. និង ស. ២០:៨២.
*គ* អាលម៉ា ៣៤:៣៩;
៣ នីហ្វៃ ១៨:១៥–១៨.
*ឃ* ២ នីហ្វៃ ៣១:១៩;
គ. និង ស. ៣:២០.
*ង* ហេព្រើរ ១២:២.
៥ *ក* ស.ប. សាសនាចក្រនៃព្រះ
យេស៊ូវគ្រីស្ទ.
*ខ* ៣ នីហ្វៃ ១៨:២២;
៤ នីហ្វៃ ១:១២;
គ. និង ស. ៨៨:៧៦.
*គ* ស.ប. តម, តំណម.
៧ *ក* គ. និង ស. ២០:៥៤.
*ខ* គ. និង ស. ៤២:៨០–៨១.
ស.ប. សាក្សី.
*គ* អាលម៉ា ៦:១.
ស.ប. អែលឌើរ.
*ឃ* ស.ប. ឆ្លើយសារភាព, ការឆ្លើយ
សារភាព.
*ង* និក្ខ. ៣២:៣៣;
គ. និង ស. ២០:៨៣.
ស.ប. ការកាត់ចេញពីសាសនា.

៨ ប៉ុន្តែ [ក]ដរាបណាពួកគេប្រែចិត្ត ហើយស្វែងរកការអត់ទោស ដោយស្មោះអស់ពីចិត្ត នោះពួកគេតែងតែនឹងបាន[ខ]អត់ទោសឲ្យ ។

៩ ហើយការប្រជុំទាំងឡាយរបស់ពួកគេ ត្រូវបាន[ក]ដឹកនាំដោយសាសនាចក្រ [ខ]តាមរបៀបការងារនៃព្រះវិញ្ញាណ និងដោយព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ; ត្បិតដូចជាព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ដឹកនាំពួកគេយ៉ាងណា ទោះបីពួកគេប្រកាស ឬឲ្យដំបូន្មាន ឬអធិស្ឋាន ឬបួងសួង ឬច្រៀងក្ដី នោះតែងតែនឹងបានសំរេចយ៉ាងនោះហើយ ៕

---

## ជំពូកទី ៧

*ការអញ្ជើញសូមឲ្យចូលទៅក្នុងសេចក្ដីសំរាកនៃព្រះអម្ចាស់ — ចូរអធិស្ឋានដោយស្មោះអស់ពីចិត្ត — ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ធ្វើឲ្យមនុស្សដឹងខុស និងត្រូវ — អារក្សសាតាំងបញ្ចុះបញ្ចូលមនុស្សឲ្យបដិសេធព្រះគ្រីស្ទ ហើយធ្វើអំពើអាក្រក់ — ពួកព្យាការី សំដែងប្រាប់ពីការយាងមកនៃព្រះគ្រីស្ទ — ដោយសេចក្ដីជំនឿ ទើបអព្ភូតហេតុទាំងឡាយត្រូវបានសំដែងឡើង ហើយពួកទេវតាធ្វើការងារបំរើ — មនុស្សត្រូវសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច ហើយកាន់ជាប់នូវសេចក្ដីសប្បុរស ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

ហើយឥឡូវនេះ ខ្ញុំមរ៉ូណៃ សរសេរបន្តិចអំពីពាក្យពេចន៍របស់ឪពុកខ្ញុំ គឺមរមន ដែលលោកបាននិយាយអំពី[ក]សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស; ត្បិតតាមបែបនេះហើយ ដែលលោកបាននិយាយទៅកាន់ប្រជាជន នៅពេលលោកបានបង្រៀនពួកគេ នៅក្នុង សាលាប្រជុំ ដែលពួកគេបានសង់ឡើង ជាទីកន្លែងសំរាប់ថ្វាយបង្គំ ។

២ ហើយឥឡូវនេះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំមរមន សូមនិយាយទៅកាន់អ្នករាល់គ្នា; ហើយគឺដោយព្រះគុណ នៃព្រះវរបិតា និងព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើងរាល់គ្នា និងព្រះហឫទ័យដ៏បរិសុទ្ធរបស់ទ្រង់ គឺមកពីអំណោយទាន[ក]នៃការហៅ របស់ទ្រង់ដល់ខ្ញុំ ទើបខ្ញុំត្រូវបានអនុញ្ញាត ឲ្យនិយាយទៅកាន់អ្នករាល់គ្នាក្នុងពេលនេះ ។

៣ ហេតុដូច្នោះហើយ ខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នា ដែលនៅក្នុងសាសនាចក្រនេះ ដែលជាអ្នកដើរតាមព្រះគ្រីស្ទដោយសុខសាន្ត ហើយដែលបានទទួលសេចក្ដីសង្ឃឹមដល់គ្រប់គ្រាន់ ដែលធ្វើឲ្យអ្នករាល់គ្នាអាចបានចូលទៅក្នុងសេចក្ដីសំរាកនៃព្រះអម្ចាស់ ចាប់ពីពេលនេះតទៅ រហូតដល់អ្នករាល់គ្នានឹងបាន[ក]សំរាកជាមួយនឹងទ្រង់ នៅឯស្ថានសួគ៌ ។

៤ ហើយឥឡូវនេះ ឱបងប្អូនរបស់ខ្ញុំអើយ ខ្ញុំវិនិច្ឆ័យការណ៍ទាំងនេះអំពីបងប្អូន ពីព្រោះតែ[ក]ដំណើរដ៏សុខសាន្តរបស់បងប្អូនជាមួយនឹងកូនចៅមនុស្ស ។

៥ ត្បិតខ្ញុំនឹកចាំពីព្រះបន្ទូលនៃព្រះដែលថែងថា ដោយកិច្ចការរបស់គេ នោះអ្នករាល់គ្នានឹង[ក]ស្គាល់ពួកគេហើយ; ត្បិតបើសិនជាកិច្ចការរបស់គេល្អ នោះពួកគេក៏ជាមនុស្សល្អដែរ ។

៦ ត្បិតមើលចុះ ព្រះទ្រង់មានព្រះបន្ទូលថា មនុស្សណាដែល[ក]អាក្រក់ ពុំអាចធ្វើនូវអ្វីដែលល្អបានឡើយ; ត្បិតបើសិនជាគេថ្វាយដង្វាយ [ខ]ឬអធិស្ឋានដល់ព្រះ លើកលែងគេធ្វើដោយស្មោះអស់ពីចិត្ត ការនោះនឹងពុំនាំផលប្រយោជន៍អ្វីដល់អ្នកនោះឡើយ ។

៧ ត្បិតមើលចុះ គឺនឹងពុំត្រូវបានចាត់ទុកថា ជាសេចក្ដីសុចរិតដល់អ្នកនោះឡើយ ។

៨ ត្បិតមើលចុះ បើសិនជាមនុស្សណាដែល[ក]អាក្រក់ឲ្យទាន [ខ]អ្នកនោះឲ្យដោយទើសទាល់; ហេតុដូច្នោះហើយ អ្នកនោះត្រូវបានចាត់ ទុកថា ដូចជាទុកទាននោះវិញ; ហេតុដូច្នោះហើយ អ្នកនោះនឹងត្រូវបានចាត់ទុកថា ជាអាក្រក់នៅចំពោះព្រះ ។

៩ ហើយក៏យ៉ាងដូច្នោះដែរ គេនឹងត្រូវបានចាត់ទុកថាជាអាក្រក់ បើសិនជាគេអធិស្ឋាន ហើយបើមិនអធិស្ឋានដោយ[ក]ស្មោះអស់ពី ចិត្តទេ; មែនហើយ ការអធិស្ឋាននោះពុំមានផលប្រយោជន៍អ្វីដល់ជននោះឡើយ ត្បិតព្រះទ្រង់ពុំទទួលមនុស្សបែបនេះទេ ។

១០ ហេតុដូច្នោះហើយ មនុស្សណាដែលអាក្រក់ នោះពុំអាចធ្វើអ្វីដែលល្អបានឡើយ; ហើយគេក៏ពុំឲ្យទានល្អដែរ ។

---

៨ *ក* ម៉ូសាយ ២៦:៣០–៣១.
*ខ* ស.ប. អត់ទោស, អភ័យទោស.
៩ *ក* គ. និង ស. ២០:៤៥; ៤៦:២.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៧ ១*ក* ១ កូរិន. ១៣:១–១៣; អេធើរ ១២:៣–២២, ២៧–៣៧; មរ៉ូណៃ ៨:១៤; ១០:២០–២៣.
២ *ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
៣ *ក* ស.ប. សេចក្ដីសំរាក.
៤ *ក* ១ យ៉ូហាន ២:៦; គ. និង ស. ១៩:២៣.
៥ *ក* ៣ នីហ្វៃ ១៤:១៥–២០.
៦ *ក* ម៉ាថាយ ៧:១៥–១៨.
*ខ* អាលម៉ា ៣៤:២៨. ស.ប. ការអធិស្ឋាន.
៨ *ក* សុភា. ១៥:៨.
*ខ* គ. និង ស. ៦៤:៣៤.
៩ *ក* យ៉ាកុប (ព.ស.ថ.) ១:៦–៧; ៥:១៦; មរ៉ូណៃ ១០:៤.

១១ ត្បិតមើលចុះ [ក]រន្ធទឹកល្វីងពុំអាចផ្ដល់ទឹកសាបបានទេ; រីឯរន្ធទឹកសាបក៏ពុំអាចផ្ដល់ទឹកល្វីងបានដែរ; ហេតុដូច្នោះហើយ មនុស្សណាដែលជាបាវបំរើរបស់អារក្ស នោះពុំអាចដើរតាមព្រះគ្រីស្ទបានទេ; ហើយបើសិនជាគេ[ខ]ដើរតាមព្រះគ្រីស្ទ នោះគេពុំអាច ធ្វើជាបាវបំរើរបស់អារក្សបានដែរ ។

១២ ហេតុដូច្នោះហើយ អ្វីទាំងអស់ដែល[ក]ល្អ កើតមកពីព្រះ; ហើយអ្វីដែល[ខ]អាក្រក់ កើតមកពីអារក្ស; ត្បិតអារក្សគឺជាខ្មាំងសត្រូវ ដល់ព្រះ ហើយប្រឆាំងនឹងទ្រង់ឥតឈប់ឈរ ហើយអញ្ជើញ និងញុះញង់ឲ្យ[គ]ធ្វើបាប ហើយឲ្យធ្វើអ្វីដែលអាក្រក់ឥតឈប់ឈរសោះ ឡើយ ។

១៣ ប៉ុន្តែមើលចុះ អ្វីដែលមកពីព្រះ អញ្ជើញ ហើយញុះញង់ឲ្យធ្វើល្អឥតឈប់ឈរ; ហេតុដូច្នោះហើយ អ្វីក៏ដោយដែល អញ្ជើញ ហើយ[ក]ញុះញង់ឲ្យធ្វើល្អ ហើយឲ្យស្រឡាញ់ព្រះ ហើយឲ្យបំរើទ្រង់ [ខ]គឺផ្ដុសគំនិតមកពីព្រះ ។

១៤ ហេតុដូច្នោះហើយ ចូរប្រយ័ត្នចុះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ដើម្បីកុំឲ្យអ្នករាល់គ្នាវិនិច្ឆ័យថាអ្វីដែល[ក]អាក្រក់ នោះមក ពីព្រះឡើយ ឬក៏ថាអ្វីដែលល្អ ហើយមកពីព្រះទុកជាមកពីអារក្សឡើយ ។

១៥ ត្បិតមើលចុះ ឱបងប្អូនរបស់ខ្ញុំអើយ ត្រូវបានប្រទានដល់អ្នករាល់គ្នាឲ្យ[ក]វិនិច្ឆ័យ ដើម្បីឲ្យអ្នកដឹងខុស និងត្រូវ; ហើយវិធីវិនិច្ឆ័យ នោះច្បាស់លាស់ ដើម្បីឲ្យអ្នករាល់គ្នាអាចដឹងដោយដំរិះដ៏ឥតខ្ចោះ ហាក់បីដូចជាពន្លឺថ្ងៃពីយប់ងងឹត ។

១៦ ត្បិតមើលចុះ [ក]ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ត្រូវបានប្រទានដល់មនុស្សគ្រប់រូប ដើម្បីឲ្យគេអាច[ខ]ដឹងខុស និងត្រូវ; ហេតុដូច្នោះហើយ ខ្ញុំបង្ហាញដល់អ្នកនូវវិធីវិនិច្ឆ័យ; ត្បិតគ្រប់ទាំងអ្វីៗដែលអញ្ជើញឲ្យធ្វើល្អ ហើយដែលបញ្ចុះបញ្ចូលឲ្យជឿដល់ព្រះគ្រីស្ទ នោះគឺបានចាត់ មកពីព្រះចេស្ដា និងអំណោយទាននៃព្រះគ្រីស្ទ; ហេតុដូច្នោះហើយ អ្នករាល់គ្នាអាចដឹងដោយដំរិះដ៏ឥតខ្ចោះថា មកពីព្រះ ។

១៧ ប៉ុន្តែ អ្វីៗដែលបញ្ចុះបញ្ចូលឲ្យមនុស្សធ្វើ[ក]អាក្រក់ ហើយមិនឲ្យជឿដល់ព្រះគ្រីស្ទ ហើយបដិសេធទ្រង់ ហើយមិនបំរើព្រះទេ នោះអ្នករាល់គ្នាអាចដឹងដោយដំរិះដ៏ឥតខ្ចោះថា មកពីអារក្ស; ត្បិតតាមរបៀបនេះហើយដែលអារក្សប្រព្រឹត្ត ត្បិតវាមិនដែល បញ្ចុះបញ្ចូលមនុស្សឲ្យធ្វើល្អឡើយ មិនដែលទេ សូម្បីតែមួយក៏គ្មានសោះ; ហើយពួកទេវតាវាក៏មិនដែលដែរ; ហើយពួកដែល ស្ដាប់បង្គាប់វាក៏មិនដែលដែរ ។

១៨ ហើយឥឡូវនេះ ឱបងប្អូនរបស់ខ្ញុំអើយ ដោយឃើញថាអ្នករាល់គ្នាស្គាល់នូវពន្លឺដែលអ្នករាល់គ្នាអាចយកទៅវិនិច្ឆ័យឯពន្លឺនោះគឺជា[ក]ពន្លឺនៃព្រះគ្រីស្ទ នោះចូរឲ្យឃើញថា អ្នករាល់គ្នាមិនវិនិច្ឆ័យដោយខុសឆ្គងឡើយ; [ខ]ត្បិតដោយការវិនិច្ឆ័យដដែលនេះ ហើយដែលអ្នករាល់គ្នានឹងត្រូវបានវិនិច្ឆ័យវិញ ។

១៩ ហេតុដូច្នោះហើយ ឱបងប្អូនអើយ ខ្ញុំសូមអង្វរដល់អ្នករាល់គ្នាថា អ្នករាល់គ្នាត្រូវព្យាយាមស្វែងរក នៅក្នុង[ក]ពន្លឺនៃព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាអាចដឹងខុស និងត្រូវ; ហើយបើសិនជាអ្នករាល់គ្នាក្ដាប់ជាប់ នូវគ្រប់ទាំងអ្វីៗដែលល្អ ហើយមិនកាត់ទោសរបស់ទាំង នោះទេ នោះអ្នកប្រាកដជា[ខ]កូននៃព្រះគ្រីស្ទមែន ។

២០ ហើយឥឡូវនេះ ឱបងប្អូនរបស់ខ្ញុំអើយ ធ្វើម្ដេចឲ្យអ្នករាល់គ្នាមានលទ្ធភាព ហើយក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អបាន ?

២១ ហើយឥឡូវនេះ ខ្ញុំនិយាយដល់សេចក្ដីជំនឿដែលខ្ញុំបានសន្យាថា ខ្ញុំនឹងនិយាយនោះ; ហើយខ្ញុំនឹងប្រាប់អ្នករាល់គ្នានូវមធ្យោបាយ ដែលអ្នករាល់គ្នាអាចក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ ។

២២ ត្បិតមើលចុះ ព្រះទ្រង់[ក]ជ្រាបគ្រប់រឿងទាំងអស់

១១ *ក* យ៉ាកុប (ព.ស.ថ.) ៣:១១–១២
*ខ* ម៉ាថាយ ៦:២៤;
២ នីហ្វៃ ៣១:១០–១៣;
គ. និង ស. ៥៦:២.
១២ *ក* យ៉ាកុប (ព.ស.ថ.) ១:១៧; ១ យ៉ូហាន ៤:១–២; អេធើរ ៤:១២.
*ខ* អាលម៉ា ៥:៣៩–៤២.
*គ* ហេលេ. ៦:៣០.
ស.ប. អំពើបាប.
១៣ *ក* ២ នីហ្វៃ ៣៣:៤; អេធើរ ៨:២៦.
*ខ* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
១៤ *ក* អេសាយ ៥:២០;
២ នីហ្វៃ ១៥:២០.
១៥ *ក* ស.ប. ការសង្កេតស្គាល់, អំណោយទាបខាង.
១៦ *ក* ស.ប. បញ្ញាចិត្ត; ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* លោកុ. ៣:៥; ២ នីហ្វៃ ២:៥, ១៨, ២៦; ម៉ូសាយ ១៦:៣;
អាលម៉ា ២៩:៥;
ហេលេ. ១៤:៣១.
១៧ *ក* ស.ប. អំពើបាប.
១៨ *ក* ម៉ូសាយ ១៦:៩;
គ. និង ស. ៥០:២៤; ៨៨:៧–១៣.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* ក.យ.ស., ម៉ាថាយ ៧:១–២;
លូកា ៦:៣៧; យ៉ូហាន ៧:២៤.
១៩ *ក* គ. និង ស. ៨៤:៤៥–៤៦.
*ខ* ម៉ូសាយ ១៥:១០–១២; ២៧:២៥.
ស.ប. បុត្រាបុត្រីនៃព្រះ.
២២ *ក* ស.ប. ព្រះ, ក្រុមព្រះ.

ចាប់តាំងពីភាពអស់កល្បជានិច្ច ទៅភាពអស់កល្បជានិច្ច មើលចុះ ទ្រង់បាន ចាត់[ខ]ឲ្យពួកទេវតា មកធ្វើការងារបំរើដល់កូនចៅមនុស្ស គឺដើម្បីមកសម្ដែងឲ្យដឹង អំពីការយាងមកនៃព្រះគ្រីស្ទ; ហើយនៅក្នុងព្រះគ្រីស្ទ នោះអ្វីដែលល្អគ្រប់យ៉ាងនឹងចេញមក ។

២៣ ហើយព្រះទ្រង់ក៏ប្រកាសដល់ពួកព្យាការី ដោយព្រះឱស្ឋទ្រង់ផ្ទាល់ថា ព្រះគ្រីស្ទនឹងយាងមក ។

២៤ ហើយមើលចុះ មានមធ្យោបាយជាច្រើន ដែលទ្រង់បានសម្ដែងការណ៍ផ្សេងៗដល់កូនចៅមនុស្ស ដែលជាការណ៍ល្អ; ហើយ គ្រប់អស់ទាំងការណ៍ណាដែលល្អ នោះចេញមកពីព្រះគ្រីស្ទ; បើពុំនោះសោតទេ មនុស្សលោកត្រូវបាន[ក]ធ្លាក់ ហើយនឹងពុំអាចមាន ការណ៍ល្អណាកើតឡើងដល់គេបានឡើយ ។

២៥ ហេតុដូច្នោះហើយ ដោយការងារបំរើនៃ[ក]ពួកទេវតា និងដោយគ្រប់ពាក្យទាំងអស់ ដែលចេញមកពីព្រះឱស្ឋនៃព្រះ នោះមនុស្ស បានចាប់ផ្ដើមអនុវត្តសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ម្ល៉ោះហើយ ដោយសេចក្ដីជំនឿ នោះពួកគេបានក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ ម្ល៉ោះហើយ គឺយ៉ាងដូច្នោះហើយ រហូតដល់ព្រះគ្រីស្ទទ្រង់យាងមក ។

២៦ ហើយបន្ទាប់ពីទ្រង់បានយាងមក នោះមនុស្សលោកក៏ត្រូវបានសង្គ្រោះ ដោយសេចក្ដីជំនឿជឿដល់ព្រះនាមទ្រង់; ហើយដោយសេចក្ដីជំនឿ នោះពួកគេក្លាយទៅជាកូនព្រះ ។ ហើយប្រាកដដូចជាព្រះគ្រីស្ទមានព្រះជន្មរស់នៅ នោះទ្រង់មានព្រះបន្ទូលទៅកាន់ ពួកអយ្យកោយើងថា៖ [ក]អ្វីក៏ដោយដែលអ្នកសូមពីព្រះវរបិតា ដោយនូវនាមយើង ដែលជាការល្អ ដោយនូវសេចក្ដីជំនឿ ជឿថាអ្នកនឹងបានទទួល មើលចុះ នោះនឹងបានប្រទានឲ្យអ្នក ។

២៧ ហេតុដូច្នោះហើយ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ តើឈប់មាន[ក]អព្ភូតហេតុហើយឬនៅ ពីព្រោះព្រះគ្រីស្ទទ្រង់បាន យាងឡើងទៅឯស្ថានសួគ៌ ហើយបានគង់នៅខាងស្ដាំនៃព្រះ ដើម្បី[ខ]ស្នូមដល់ព្រះវរបិតា នូវសិទ្ធិនៃសេចក្ដីមេត្តាករុណារបស់ទ្រង់ ចំពោះកូនចៅមនុស្សលោក ?

២៨ ត្បិតទ្រង់បានឆ្លើយតបចុងបំផុតនៃក្រិត្យវិន័យ ហើយទ្រង់បានទទួលយកអស់អ្នកណាដែលមានសេចក្ដីជំនឿជឿដល់ទ្រង់; ហើយពួកអ្នកណាដែលមានសេចក្ដីជំនឿជឿដល់ទ្រង់ នោះ[ក]តោងទៅនឹងអ្វីដែលល្អគ្រប់យ៉ាង; ហេតុដូច្នោះហើយ ទ្រង់[ខ]ជួយតវ៉ាដើម្បីឧត្តមគតិរបស់កូនចៅមនុស្ស; ហើយទ្រង់គង់នៅដ៏អស់កល្បជានិច្ច នៅលើស្ថានសួគ៌ ។

២៩ ហើយដោយសារទ្រង់បានធ្វើយ៉ាងនេះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ តើឈប់មានអព្ភូតហេតុហើយឬនៅ ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា៖ ទេ; រីឯពួកទេវតាក៏ពុំឈប់ធ្វើការងារបំរើដល់កូនចៅមនុស្សដែរ ។

៣០ ត្បិតមើលចុះ ពួកទេវតានៅក្រោមបង្គាប់ទ្រង់ ដើម្បីធ្វើការងារបំរើតាមព្រះបន្ទូលនៃបញ្ជារបស់ទ្រង់ ដោយបង្ហាញខ្លួនដល់ ពួកអ្នកដែលមានសេចក្ដីជំនឿដ៏មុតមាំ និងគំនិតដ៏មុះមុតនៅក្នុងគ្រប់ទម្រង់នៃទេវភាព ។

៣១ ឯមុខងារនៃការងារបំរើរបស់ពួកទេវតា គឺហៅឲ្យមនុស្សប្រែចិត្ត ហើយដើម្បីបំពេញ ហើយធ្វើកិច្ចការនៃសេចក្ដីសញ្ញាទាំង ឡាយនៃព្រះវរបិតា ដែលទ្រង់បានធ្វើដល់កូនចៅមនុស្ស ដើម្បីរៀបចំផ្លូវនៅក្នុងចំណោមកូនចៅមនុស្ស ដោយប្រកាសប្រាប់ពី ព្រះបន្ទូលនៃព្រះគ្រីស្ទ ដល់ប្រដាប់ជំរើសទាំងឡាយនៃព្រះអម្ចាស់ ប្រយោជន៍ឲ្យពួកគេអាចធ្វើទីបន្ទាល់ពីទ្រង់ ។

៣២ ហើយដោយធ្វើយ៉ាងនេះ នោះព្រះអម្ចាស់[ក]ទ្រង់បានរៀបចំផ្លូវ សំរាប់ឲ្យមនុស្សដែលនៅសល់ទាំងប៉ុន្មាន មានសេចក្ដីជំនឿជឿ ដល់ព្រះគ្រីស្ទ ប្រយោជន៍ឲ្យព្រះវិញ្ញាណបរិសុទ្ធអាចមានទីកន្លែងនៅក្នុងចិត្តរបស់គេ ស្របតាមព្រះចេស្ដានៃព្រះវិញ្ញាណនោះ; ហើយតាមរបៀបនេះហើយដែលព្រះវរបិតាទ្រង់បាននាំមកនូវសេចក្ដីសញ្ញាទាំងឡាយ ដែលទ្រង់បានធ្វើដល់កូនចៅមនុស្ស ។

៣៣ ហើយព្រះគ្រីស្ទទ្រង់មានព្រះបន្ទូលថា៖ [ក]បើសិនជាអ្នករាល់គ្នាមានសេចក្ដីជំនឿជឿដល់យើង នោះអ្នករាល់គ្នា[ខ]នឹងមានអំណាច ប្រយោជន៍នឹងធ្វើនូវអ្វីៗដែលជាការចាំបាច់ដល់យើង ។

៣៤ ហើយទ្រង់មានព្រះបន្ទូលថា៖ [ក]ចូរប្រែចិត្តចុះ ឱអស់អ្នករាល់គ្នា នៅចុងផែនដីអើយ ចូរមករកយើង ហើយទទួលបុណ្យ

២២ ខ ម៉ូសេ ៥:៥៨.
ស.ប. ពួកទេវតា.
២៤ ក ២ នីហ្វៃ ២:៥.
២៥ ក អាលម៉ា ១២:២៨–៣០.
២៦ ក ៣ នីហ្វៃ ១៨:២០.
ស.ប. ការអធិស្ឋាន.
២៧ ក ស.ប. អព្ភូតហេតុ.
ខ អេសាយ ៥៣:១២;
ម៉ូសាយ ១៤:១២.
២៨ ក រ៉ូម ១២:៩; គ. និង ស. ៩៨:១១.
ខ ១ យ៉ូហាន ២:១; ២ នីហ្វៃ ២:៩.
ស.ប. ព្រះដ៏គាំទ្រ.
៣២ ក ស.ប. សេចក្ដីជំនឿ.
៣៣ ក ម៉ាថាយ ១៧:២០.
ខ គ. និង ស. ៨៨:៦៤–៦៥.
៣៤ ក ៣ នីហ្វៃ ២៧:២០; អេធើរ ៤:១៨.

ជ្រមុជទឹក ដោយនូវនាមយើង ហើយមានសេចក្ដីជំនឿជឿដល់យើងចុះ ប្រយោជន៍ឲ្យអ្នកបានសង្គ្រោះ ។

៣៥ ហើយឥឡូវនេះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ បើករណីដែលខ្ញុំបាននិយាយនឹងអ្នករាល់គ្នានេះជាការ[ក]ពិត ហើយព្រះ ទ្រង់នឹងបង្ហាញដល់អ្នករាល់គ្នា[ខ] ដោយព្រះចេស្ដា និងដោយសេចក្ដីរុងរឿងដ៏មហិមា នៅថ្ងៃចុងក្រោយបង្អស់ថាការណ៍ទាំងនោះពិត ហើយបើសិនជាការណ៍ទាំងនោះពិតមែន តើឈប់មានថ្ងៃនៃអព្ភូតហេតុហើយឬ ?

៣៦ ហើយតើពួកទេវតាឈប់[ក]លេចមកឲ្យកូនចៅមនុស្សឃើញហើយឬ ? ហើយតើទ្រង់បានដកយកព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ពីពួកគេហើយឬ ? ហើយតើទ្រង់នឹងធ្វើយ៉ាងនេះឬអីដរាបណាពេលវេលានៅមាន ហើយតើនឹងមានផែនដីឬ ឬតើនឹងមានមនុស្ស ម្នាក់នៅលើផែនដី ដែលនឹងបានសង្គ្រោះឬ ?

៣៧ មើលចុះ ខ្ញុំសូមប្រាប់អ្នកថា៖ ទេ; ត្បិតដោយសារសេចក្ដីជំនឿនេះហើយ ទើបមាន[ក]អព្ភូតហេតុ; និងដោយសារសេចក្ដីជំនឿនេះហើយ ទើបពួកទេវតាលេចមក ហើយធ្វើការងារបំរើដល់មនុស្ស; ហេតុដូច្នោះហើយ បើសិនជាឈប់មានការណ៍អស់ទាំងនេះ នោះវេទនាហើយកូនចៅមនុស្ស ត្បិតគឺដោយមកពី[ខ]ការឥតជំនឿ នោះអ្វីៗទាំងអស់ក៏ឥតប្រយោជន៍ដែរ ។

៣៨ ត្បិតគ្មានអ្នកណាអាចបានសង្គ្រោះឡើយ ស្របតាមព្រះបន្ទូលនៃព្រះគ្រីស្ទ លើកលែងតែពួកគេមានសេចក្ដីជំនឿជឿដល់ព្រះ នាមទ្រង់; ហេតុដូច្នោះហើយ បើសិនជាឈប់មានការណ៍ទាំងនេះ នោះសេចក្ដីជំនឿក៏ឈប់មានដែរ; ហើយស្ថានភាពមនុស្សនោះ គួរឲ្យស្ញែងខ្លាចណាស់ ត្បិតពួកគេហាក់បីដូចជាគ្មានបានសេចក្ដីប្រោសលោះឡើយ ។

៣៩ ប៉ុន្តែមើលចុះ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំវិនិច្ឆ័យថាអ្នកគ្រាន់បើជាងនេះ ត្បិតខ្ញុំវិនិច្ឆ័យថា អ្នករាល់គ្នាមាន សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ដោយព្រោះភាពស្លូតបូតរបស់អ្នក; ត្បិតបើសិនជាអ្នករាល់គ្នាពុំមានសេចក្ដីជំនឿជឿដល់ទ្រង់ទេ នោះអ្នករាល់គនាពុំ[ក]សមនឹងបានរាប់ក្នុងចំណោមរាស្ត្រនៃសាសនាចក្ររបស់ទ្រង់ឡើយ ។

៤០ ហើយម្យ៉ាងទៀត ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំចង់និយាយទៅកាន់អ្នករាល់គ្នា [ក]អំពីសេចក្ដីសង្ឃឹម ។ តើធ្វើដូចម្ដេចឲ្យ អ្នករាល់គ្នាអាចបានសេចក្ដីជំនឿ លើកលែងអ្នករាល់គ្នានឹងមានសេចក្ដីសង្ឃឹម ?

៤១ ហើយតើអ្វីទៅដែលអ្នករាល់គ្នា[ក]សង្ឃឹមចង់បាន ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា អ្នករាល់គ្នានឹងមានសេចក្ដីសង្ឃឹម ដោយរយៈ[ខ]ដង្វាយធួននៃព្រះគ្រីស្ទនិងអំណាចនៃដំណើររស់ឡើងវិញរបស់ទ្រង់ ដើម្បីឲ្យបានប្រោសឲ្យមាន[គ]ជីវិតដ៏នៅអស់កល្បជានិច្ច ហើយនេះក៏មកពីសេចក្ដីជំនឿរបស់អ្នកដល់ទ្រង់ ស្របតាមពាក្យសន្យា ។

៤២ ហេតុដូច្នោះហើយ បើសិនជាមនុស្សណាម្នាក់មាន[ក]សេចក្ដីជំនឿ នោះគេត្រូវតែមានសេចក្ដីសង្ឃឹម; ត្បិតអត់ពីសេចក្ដីជំនឿទៅ[ខ]នោះពុំអាចមានសេចក្ដីសង្ឃឹមឡើយ ។

៤៣ ហើយម្យ៉ាងទៀត ខ្ញុំសូមប្រាប់អ្នកថា អ្នកនោះពុំអាចមានសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមទេ លើកលែងតែអ្នកនោះ[ក]ស្លូតបូតហើយសុភាពរាបសា ។

៤៤ បើសិនជាយ៉ាងនេះមែន នោះ[ក]សេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមរបស់គេ គឺជាការឥតប្រយោជន៍ទៅវិញ ត្បិតគ្មានអ្នកណាអាច បានទៅជាទីគាប់ចំពោះព្រះឡើយ លើកលែងតែមនុស្សស្លូតបូត ហើយសុភាពរាបសាប៉ុណ្ណោះ; ហើយបើសិនជាមនុស្សនោះស្លូតបូត ហើយសុភាពរាបសា ហើយ[ខ]ទទួលស្គាល់ដោយនូវព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ អ្នកនោះត្រូវតែមាន សេចក្ដីសប្បុរស; ត្បិតបើសិនជាគេគ្មានសេចក្ដីសប្បុរសទេ អ្នកនោះគ្មានជាអ្វីទាំងអស់; ហេតុដូច្នោះហើយ អ្នកនោះត្រូវតែមានសេចក្ដី សប្បុរស ។

៤៥ ហើយ[ក]សេចក្ដីសប្បុរស តែងតែអត់ធ្មត់ ហើយចិត្តល្អហើយពុំចេះ[ខ]ឈ្នានីស ហើយពុំចេះអួតខ្លួន ពុំរកប្រយោជន៍ផ្ទាល់ខ្លួន ពុំរហ័សខឹង ពុំគិតដល់សេចក្ដីអាក្រក់ ហើយពុំដែលអរ

៣៥ *ក* ២ នីហ្វៃ ៣៣:១១.
*ខ* គ. និង ស. ៣៥:៨.
៣៦ *ក* មរ៉ូណៃ ១០:៤–៥, ៧, ១៩.
៣៧ *ក* ម៉ាថាយ ១៣:៥៨; មរមន ៩:២០; អេធើរ ១២:១២–១៨.
*ខ* មរ៉ូណៃ ១០:១៩–២៤.
៣៩ *ក* ស.ប. សក្តិសម, ភាពសក្តិសម.
៤០ *ក* អេធើរ ១២:៤.
ស.ប. សេចក្ដីសង្ឃឹម.
៤១ *ក* គ. និង ស. ១៣៨:១៤.
*ខ* ទីតុស ១:២; យ៉ាកុប ៤:៤; អាលម៉ា ២៥:១៦; មរ៉ូណៃ ៩:២៥.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៤២ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* មរ៉ូណៃ ១០:២០.
៤៣ *ក* ស.ប. ស្លូតបូត, ភាពស្លូតបូត.
៤៤ *ក* អាលម៉ា ៧:២៤; អេធើរ ១២:២៨–៣៤.
*ខ* លូកា ១២:៨–៩.
ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព; ទីបន្ទាល់.
៤៥ *ក* ១ កូរិន. ១៣:១–១៣.
*ខ* ស.ប. ច្រណែន.

រីករាយចំពោះសេចក្ដីទុច្ចរិតឡើយ ប៉ុន្ដែអររីករាយតែនឹងសេចក្ដី
ពិតវិញ គឺទ្រាំទ្រការណ៍ទាំងអស់ ជឿដល់ការណ៍ទាំងអស់
សង្ឃឹមដល់ការណ៍ទាំងអស់ ហើយស៊ូទ្រាំទ្រការណ៍ទាំងអស់ ។
៤៦ ហេតុដូច្នោះហើយ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ
បើសិនជាអ្នករាល់គ្នាគ្មានសេចក្ដីសប្បុរសទេ នោះអ្នករាល់គ្នា
គ្មានជាអ្វីទាំងអស់ ត្បិតសេចក្ដីសប្បុរសពុំបាត់បង់ទៅឡើយ ។
ហេតុដូច្នោះហើយ ចូរតោងជាប់សេចក្ដីសប្បុរស ដែលជាសេច
ក្ដីដ៏ មហិមាបំផុត ត្បិតអ្វីផ្សេងៗទៀតនឹងត្រូវខូចបង់ —
៤៧ ប៉ុន្ដែ សេចក្ដីសប្បុរស គឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធ
នៃព្រះគ្រីស្ទ ហើយស្ថិតស្ថេរនៅជានិច្ច; ហើយអស់អ្នកណាដែល
មាន សេចក្ដីសប្បុរស នៅក្នុងថ្ងៃចុងក្រោយបង្អស់ នឹងបានស្រួល
ដល់អ្នកនោះហើយ ។
៤៨ ហេតុដូច្នោះហើយ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់
ខ្ញុំអើយ ចូរអធិស្ឋានដល់ព្រះវរបិតា ដោយអស់ពីកម្លាំងចិត្ត
ដើម្បីឲ្យអ្នករាល់ គ្នាបានពោរពេញ ដោយសេច
ក្ដីស្រឡាញ់នេះ ដែលទ្រង់បានប្រទានដល់អស់អ្នកណាដែល
ជាអ្នកដើរតាមដ៏ពិត នៃព្រះរាជបុត្រារបស់ ទ្រង់
គឺព្រះយេស៊ូវគ្រីស្ទ; ដើម្បីឲ្យអ្នករាល់គ្នាអាចក្លាយទៅជា
កូនព្រះ; ដើម្បីកាលណាទ្រង់នឹងលេចមក នោះយើងរាល់
គ្នានឹងបានដូច ជាទ្រង់ ត្បិតយើងនឹងឃើញទ្រង់ ជា
ទ្រង់ពិតប្រាកដ; ដើម្បីឲ្យយើងអាចមានសេចក្ដីសង្ឃឹមនេះ;
ដើម្បីឲ្យយើងអាចបានបរិសុទ្ធដូចជា ទ្រង់បរិសុទ្ធ ។ អាម៉ែន ៕

## ជំពូកទី ៨

*បុណ្យជ្រមុជទឹកឲ្យកូនក្មេងតូចៗ គឺជាអំពើគួរខ្ពើមឆ្អើមដ៏អាក្រក់ — កូនក្មេងតូចៗរស់នៅក្នុងព្រះគ្រីស្ទ ដោយសារដង្វាយធួន — សេចក្ដីជំនឿ ការប្រែចិត្ត ភាពស្លូតបូត និងចិត្តសុភាពរាបសា ការទទួលព្រះវិញ្ញាណបរិសុទ្ធ និងការកាន់ខ្ជាប់ ដរាបដល់ចុងបំផុត នោះនាំទៅរកសេចក្ដីសង្គ្រោះ ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

សំបុត្ររបស់ឪពុកខ្ញុំ គឺមរមន សរសេរមកខ្ញុំម៉ូរ៉ូណៃ; ហើយបាន
សរសេរមកខ្ញុំភ្លាមៗ បន្ទាប់ពីខ្ញុំបានហៅឲ្យធ្វើការងារបំរើ ។
ហើយលោកបានសរសេរមកខ្ញុំយ៉ាងនេះថា៖
២ ឱម៉ូរ៉ូណៃ កូនប្រុសសំឡាញ់របស់ឪពុកអើយ ឪពុកអរ
រីករាយជាអតិបរមា ដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់កូន
ទ្រង់បានគិត ដល់កូន ហើយបានហៅឲ្យកូនធ្វើការងារបំរើរបស់
ទ្រង់ ហើយធ្វើកិច្ចការដ៏បរិសុទ្ធរបស់ទ្រង់ ។
៣ ឪពុកនឹកគិតដល់កូន នៅក្នុងពាក្យអធិស្ឋានរបស់ឪពុកជានិច្ច
ឪពុកតែងតែអធិស្ឋានដល់ព្រះវរបិតា ដោយឥតឈប់ឈរ
ដោយនូវ ព្រះនាមនៃព្រះរាជបុត្រាដ៏បរិសុទ្ធ គឺព្រះយេស៊ូវ
សូមឲ្យទ្រង់រក្សាកូន តាមរយៈសេចក្ដីល្អ និងព្រះគុណដ៏និរន្ដរ៍
របស់ទ្រង់ ឲ្យកាន់ខ្ជាប់ក្នុង សេចក្ដីជំនឿជឿដល់ព្រះនាមទ្រង់
ដល់ទីបំផុត ។
៤ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុក
ប្រាប់កូន អំពីការដែលផ្ដល់ទុក្ខដល់ឪពុកជាខ្លាំង; ត្បិតឪពុក
កើតទុក្ខ ដែលមាន ការឈ្លោះប្រកែកគ្នាបានកើតឡើង នៅ
ក្នុងចំណោមពួកកូន ។
៥ ត្បិត បើសិនជាឪពុកបានដឹងដោយពិតមែន នោះមានការ
ឈ្លោះប្រកែកគ្នា ក្នុងចំណោមពួកកូន ដែលទាក់ទងនឹងបុណ្យ
ជ្រមុជទឹក ដល់កូនក្មេងតូចៗ ។
៦ ហើយឥឡូវនេះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកមានប្រាថ្នា
ចង់ឲ្យកូនព្យាយាមធ្វើការ ដើម្បីឲ្យកំហុសដ៏ធំនេះ ត្រូវបាន
ដកចេញពី ក្នុងចំណោមពួកកូនទៅ; ត្បិតដោយគោលបំណង
នេះហើយដែលឪពុកបានសរសេរសំបុត្រនេះ ។
៧ ត្បិតបន្ទាប់ពីឪពុកបានដឹងរឿងទាំងនេះពីកូនភ្លាម នោះឪពុក
បានទូលសួរដល់ព្រះអម្ចាស់ពីរឿងនេះ ។ ហើយព្រះបន្ទូលនៃព្រះ
អម្ចាស់ ក៏បានបន្លឺមកឪពុក ដោយព្រះចេស្ដានៃព្រះវិញ្ញាណ
បរិសុទ្ធ ថា៖
៨ ចូរស្ដាប់តាមព្រះបន្ទូលនៃព្រះគ្រីស្ទ ជាព្រះដ៏ប្រោសលោះ
របស់អ្នក ជាព្រះអម្ចាស់របស់អ្នក និងជាព្រះរបស់អ្នកចុះ;
មើលចុះ យើងបានមកឯពិភពលោក ពុំមែនដើម្បីហៅពួក

៤៧ *ក* ២ នីហ្វៃ ២៦:៣០.
ស.ប. សេចក្ដីសប្បុរស.
*ខ* យ៉ូស្វេ ២២:៥.
ស.ប. សេចក្ដីស្រឡាញ់.
៤៨ *ក* ស.ប. ការអធិស្ឋាន.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ដំរាប់នៃព្រះយេស៊ូវគ្រីស្ទ; ការ
គោរព, ដែលគោរព, គោរព.
*គ* ១ យ៉ូហាន ៣:១–៣;
៣ នីហ្វៃ ២៧:២៧.
*ឃ* ៣ នីហ្វៃ ១៩:២៨–២៩.
ស.ប. សុទ្ធ, សុទ្ធសាធ.

៨ ១ *ក* ព. នៃ ម. ១:១.
៣ *ក* ម៉ូសាយ ៤:១១.
*ខ* ស.ប. ព្រះគុណ.
៤ *ក* ៣ នីហ្វៃ ១១:២២, ២៨; ១៨:៣៤.
៧ *ក* ស.ប. ព្រះបន្ទូលនៃព្រះ.

សុចរិតឲ្យប្រែចិត្តទេ តែហៅពួកមនុស្សបាប ឲ្យប្រែចិត្តវិញ; មនុស្សជាពុំត្រូវការ គ្រូពេទ្យទេ តែមនុស្សឈឺទេតើ ដែលត្រូវការវិញ; ហេតុដូច្នោះហើយ កូនក្មេងតូចៗជាមនុស្សជា ត្បិតពួកវាពុំអាចនឹងប្រព្រឹត្ត អំពើបាបបានឡើយ; ហេតុដូច្នោះហើយ ពាក្យបណ្ដាសាដល់លោកអ័ដាម ត្រូវបានយកចេញពីពួកកូនក្មេងទាំងនេះ ដោយសារយើង ដើម្បីកុំឲ្យពាក្យបណ្ដាសានេះ មានអំណាចទៅលើពួកវាបានឡើយ; ហើយច្បាប់កាត់ស្បែក ក៏ត្រូវបានសំរេចដោយសារយើងដែរ។

៩ ហើយតាមរបៀបនេះហើយដែលព្រះវិញ្ញាណបរិសុទ្ធទ្រង់បានសម្ដែងព្រះបន្ទូលនៃព្រះប្រាប់ដល់ឪពុក; ហេតុដូច្នោះហើយ ឱកូនប្រុសសំឡាញ់របស់ឪពុកអើយ ឪពុកដឹងថា ជាការចំអកឡកឡឺយដ៏ធ្ងន់នៅចំពោះព្រះ ដែលពួកកូនត្រូវធ្វើបុណ្យជ្រមុជទឹកឲ្យ កូនក្មេងតូចៗ ។

១០ មើលចុះ ឪពុកប្រាប់កូនថា នេះជាការណ៍ដែលពួកកូនត្រូវបង្រៀន — គឺការប្រែចិត្ត និងបុណ្យជ្រមុជទឹកដល់អស់អ្នកណា ដែលដឹងខុស និងត្រូវ ហើយមានសមត្ថភាពនឹងប្រព្រឹត្តអំពើបាប; មែនហើយ ចូរបង្រៀនពួកមាតាបិតា ឲ្យប្រែចិត្ត ហើយទទួលបុណ្យ ជ្រមុជទឹក ហើយបន្ទាបខ្លួនដូចជាកូនក្មេងតូចៗចុះ ហើយពួកគេទាំងអស់គ្នានឹងបានសង្គ្រោះ ជាមួយនឹងកូនក្មេងតូចៗរបស់គេដែរ ។

១១ ហើយកូនក្មេងតូចៗរបស់គេ ពុំចាំបាច់មានការប្រែចិត្ត ឬបុណ្យជ្រមុជទឹកឡើយ; មើលចុះ បុណ្យជ្រមុជទឹកគឺចំពោះការប្រែចិត្ត ដើម្បីបំពេញព្រះបញ្ញត្តិទាំងឡាយ ដែលនាំមកនូវការផ្ដាច់បាប ។

១២ ប៉ុន្តែកូនក្មេងតូចៗរស់នៅក្នុងព្រះគ្រីស្ទ គឺចាប់តាំងពីកំណើតលោកិយមកម្ល៉េះ; បើពុំមែនដូច្នោះទេ នោះព្រះគឺជាព្រះដ៏លំអៀង និងជាព្រះដ៏ប្រែប្រួល ហើយចេះរើសមុខមនុស្ស; ត្បិតមានកូនក្មេងជាច្រើនបានស្លាប់ទៅ ដោយពុំបានទទួលបុណ្យជ្រមុជទឹក!

១៣ ហេតុដូច្នោះហើយ បើសិនជាកូនក្មេងតូចៗពុំអាចបានសង្គ្រោះ ដោយគ្មានបុណ្យជ្រមុជទឹកទេ នោះពួកកូនក្មេងទាំងនេះច្បាស់ជានឹងធ្លាក់ទៅក្នុងស្ថាននរក ដ៏មិនចេះចប់មិនចេះហើយជាមិនខានឡើយ ។

១៤ មើលចុះ ឪពុកប្រាប់កូនថា អ្នកណាដែលគិតស្មានថា កូនក្មេងតូចៗត្រូវទទួលបុណ្យជ្រមុជទឹក អ្នកនោះនៅក្នុងប្រមាត់ល្វីង ជូរចត់ ហើយនៅក្នុងចំណងនៃអំពើទុច្ចរិតទៅវិញ; ត្បិតអ្នកនោះគ្មានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម ឬសេចក្ដីសប្បុរសឡើយ; ហេតុដូច្នោះហើយ បើសិនជាគេបានវិនាសបាត់ទៅ នៅពេលមានគំនិតបែបនេះ អ្នកនោះត្រូវចុះទៅស្ថាននរក ។

១៥ ត្បិតជាអំពើទុច្ចរិតដ៏គួរស្ញែងខ្លាចណាស់ ដែលគិតស្មានថា ព្រះទ្រង់សង្គ្រោះក្មេងម្នាក់ ដោយព្រោះតែបុណ្យជ្រមុជទឹក ឯក្មេងឯទៀតត្រូវវិនាស ដោយព្រោះតែគ្មានបុណ្យជ្រមុជទឹក ។

១៦ វេទនាដល់ពួកអ្នកណា ដែលបង្ខូចផ្លូវទាំងឡាយនៃព្រះអម្ចាស់ តាមរបៀបនេះ ត្បិតពួកគេនឹងត្រូវវិនាសទៅ លើកលែងតែពួក គេប្រែចិត្ត ។ មើលចុះ ឪពុកនិយាយយ៉ាងក្លាហាន ដោយបានសិទ្ធិអំណាចពីព្រះ; ហើយឪពុកពុំខ្លាចអ្វី ដែលមនុស្សអាចប្រព្រឹត្តឡើយ; ត្បិតសេចក្ដីស្រឡាញ់ដ៏ឥតខ្ចោះ បំណេញការភ័យខ្លាចចេញអស់ទៅ ។

១៧ ហើយឪពុកបានពោរពេញទៅដោយសេចក្ដីសប្បុរស ដែលជាសេចក្ដីស្រឡាញ់ដ៏អស់កល្បជានិច្ច; ហេតុដូច្នោះហើយ កូនក្មេងទាំងអស់សុទ្ធសឹងដូចៗគ្នា នៅចំពោះឪពុក; ហេតុដូច្នោះហើយ ឪពុកស្រឡាញ់កូនក្មេងតូចៗ ដោយសេចក្ដីស្រឡាញ់ ដ៏ឥតខ្ចោះ; ហើយពួកកូនក្មេងគឺដូចគ្នាទាំងអស់ ហើយជាពួកអ្នកទទួលទាននៃសេចក្ដីសង្គ្រោះ ។

---

៨ ក ម៉ាកុស ២:១៧.
ខ ម៉ាកុស ១០:១៣–១៦.
គ ម៉ូសាយ ៣:១៦;
គ. និង ស. ៧៤:៧.
ឃ ស.ប. អំពើបាប.
ង ២ នីហ្វៃ ២:២៥–២៧.
ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
ច លោកុ. ១៧:១០–១១.
ស.ប. ការកាត់ស្បែក.
១០ ក ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
ខ ស.ប. កូនក្មេង, ពួកកូនក្មេង; បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
១១ ក ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការតម្រូវការទាំងឡាយសំរាប់បុណ្យជ្រមុជទឹក;
កូនក្មេង, ពួកកូនក្មេង.
ខ ស.ប. ការផ្ដាច់បាប.
១២ ក គ. និង ស. ២៩:៤៦–៤៧; ៩៣:៣៨.
ខ អេភេ. ៦:៩; ២ នីហ្វៃ ២៦:៣៣;
គ. និង ស. ៣៨:១៦.
១៤ ក ១ កូរិន. ១៣:១–១៣;
អេធើរ ១២:៦;
មរ៉ូណៃ ៧:២៥–២៨;
១០:២០–២៣.
១៦ ក ស.ប. សិទ្ធិអំណាច.
ខ ស.ប. សេចក្ដីស្រឡាញ់.
គ ១ យ៉ូហាន ៤:១៨.
១៧ ក ស.ប. សេចក្ដីសប្បុរស.
ខ ម៉ូសាយ ៣:១៦–១៩.

១៨ ត្បិតឪពុកដឹងថា ព្រះទ្រង់ពុំមែនជាព្រះដ៏លំអៀង ក៏ពុំមែនជាព្រះដ៏ប្រែប្រួលដែរ; តែទ្រង់ពិតជាឥតប្រែប្រួល តាំងពីភាពអស់កល្ប ជានិច្ច ទៅភាពអស់កល្បជានិច្ច ។

១៩ កូនក្មេងតូចៗពុំអាចប្រែចិត្តទេ; ហេតុដូច្នោះហើយ គឺជាអំពើទុច្ចរិតដ៏គួរស្ញែងខ្លាចណាស់ ដែលបដិសេធសេចក្ដីមេត្តាករុណា ដ៏សុទ្ធសាធនៃព្រះ ចំពោះពួកកូនក្មេងទាំងនេះ ត្បិតពួកវាទាំងអស់គ្នារស់នៅក្នុងទ្រង់ ពីព្រោះតែសេចក្ដីមេត្តាករុណារបស់ទ្រង់ ។

២០ ហើយអ្នកណាដែលនិយាយថា កូនក្មេងតូចៗត្រូវទទួលបុណ្យជ្រមុជទឹក នោះបដិសេធសេចក្ដីមេត្តាករុណានៃព្រះគ្រីស្ទហើយ ហើយចាត់ដង្វាយធួនរបស់ទ្រង់ និងព្រះចេស្ដានៃសេចក្ដីប្រោសលោះរបស់ទ្រង់ថា ជាឥតប្រយោជន៍ ។

២១ វេទនាដល់មនុស្សបែបនេះ ត្បិតពួកគេត្រូវជាប់គ្រោះដល់ស្លាប់, ចុះស្ថាននរក, និងការទុក្ខវេទនាដ៏មិនចេះ ចប់មិនចេះហើយ ។ ឪពុកនិយាយយ៉ាងក្លាហាន; ព្រះទ្រង់បានបញ្ជាដល់ឪពុក ។ ចូរកូនស្ដាប់តាមពាក្យទាំងនេះ ហើយយកចិត្តទុកដាក់ចុះ បើពុំនោះសោត ទេ ពាក្យទាំងនេះនឹងឈរទាស់នឹងកូន នៅឯវេទិកាជំនុំជំរះនៃព្រះគ្រីស្ទ ។

២២ ត្បិតមើលចុះ អស់ទាំងកូនក្មេងតូចៗរស់នៅក្នុងព្រះគ្រីស្ទ ព្រមទាំងអស់អ្នកណាដែលនៅដោយគ្មានច្បាប់ដែរ ។ ត្បិតព្រះចេស្ដានៃសេចក្ដីប្រោសលោះ មានមកដល់អស់អ្នកណាដែលគ្មានច្បាប់; ហេតុដូច្នោះហើយ អ្នកណាដែលពុំបានជាប់ទោស ឬក៏ពុំនៅ ក្រោមការកាត់ទោស នោះពុំអាចមានការប្រែចិត្តឡើយ; ហើយចំពោះមនុស្សបែបនោះ នោះបុណ្យជ្រមុជទឹកនឹងពុំនាំមកនូវផល ប្រយោជន៍អ្វីឡើយ ។

២៣ ប៉ុន្តែការបដិសេធសេចក្ដីមេត្តាករុណានៃព្រះគ្រីស្ទ និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ និងការដាក់ទីទុកចិត្តទៅលើកិច្ចការដែលស្លាប់ គឺជាការចំអកឡកឡឺយដល់ព្រះ ។

២៤ មើលចុះ ឱកូនប្រុសរបស់ឪពុកអើយ ការណ៍នេះពុំត្រូវមានឡើយ; ត្បិតការប្រែចិត្តគឺ សំរាប់ពួកអ្នកដែលនៅក្រោមការកាត់ទោស ហើយនៅក្រោមបណ្ដាសា នៃច្បាប់មួយដែលបានរំលង ។

២៥ ឯផលដំបូងនៃការប្រែចិត្ត គឺបុណ្យជ្រមុជទឹក; ហើយបុណ្យជ្រមុជទឹកកើតឡើង ដោយសារសេចក្ដីជំនឿជឿដល់ការបំពេញនូវ បញ្ញត្តិទាំងឡាយ; រីឯការបំពេញនូវបញ្ញត្តិទាំងឡាយ នោះនាំមកនូវការផ្ដាច់បាប;

២៦ ឯការផ្ដាច់បាប នាំមកនូវការស្លូតបូត និងចិត្តសុភាពរាបសា; ហើយដោយសារការស្លូតបូត និងចិត្តសុភាពរាបសាទើបមាន វត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលជាព្រះដ៏ជាជំនួយ ដែលពោរពេញទៅដោយសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់ដ៏ឥតខ្ចោះ រីឯសេចក្ដីស្រឡាញ់នេះស៊ូទ្រាំដោយសារសេចក្ដីព្យាយាមក្នុងការអធិស្ឋាន រហូតដល់ទីបំផុតមកដល់នៅពេលដែលពួកបរិសុទ្ធ ទាំងអស់នឹងរស់នៅជាមួយនឹងព្រះ ។

២៧ មើលចុះ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកនឹងសរសេរមកកូនទៀត បើសិនជាឪពុកពុំទាន់ចេញទ័ពទៅតទល់នឹងពួកសាសន៍ លេមិន ក្នុងពេលឆាប់ៗនេះទេ ។ មើលចុះ ការឆ្មើងឆ្មៃនៃប្រជាជាតិនេះ ឬក៏នៃប្រជាជននៃសាសន៍នីហ្វៃ បានបញ្ជាក់ឲ្យឃើញនូវ សេចក្ដីបំផ្លិចបំផ្លាញដល់ពួកគេ លើកលែងតែពួកគេប្រែចិត្តប៉ុណ្ណោះ ។

២៨ ឱកូនប្រុសរបស់ឪពុកអើយ ចូរកូនអធិស្ឋានឲ្យពួកគេ

---

១៨ *ក* អាលម៉ា ៧:២០; មរមន ៩:៩.
ស.ប. ព្រះ, ក្រុមព្រះ.
*ខ* មរ៉ូណៃ ៧:២២.
១៩ *ក* លូកា ១៨:១៥–១៧.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
២០ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន; ផែនការនៃសេចក្ដីប្រោសលោះ.
២១ *ក* ស.ប. ស្ថាននរក.
*ខ* យ៉ាកុប ៦:១០; ម៉ូសាយ ២៨:៣; គ. និង ស. ១៩:១០–១២.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
២២ *ក* ស.ប. សេចក្ដីសង្គ្រោះ — សេចក្ដីសង្គ្រោះដល់កូនក្មេង.
*ខ* កិច្ចការ ១៧:៣០; គ. និង ស. ៧៦:៧១–៧២.
*គ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
២៣ *ក* គ. និង ស. ២២:២.
២៤ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
២៥ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការតម្រូវការទាំងឡាយសំរាប់បុណ្យជ្រមុជទឹក.
*ខ* ម៉ូសេ ៦:៥៨–៦០.
*គ* គ. និង ស. ៧៦:៥២.
ស.ប. ការផ្ដាច់បាប.
២៦ *ក* ស.ប. ស្លូតបូត, ភាពស្លូតបូត.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* ស.ប. ព្រះដ៏ជាជំនួយ.
*ឃ* ស.ប. សេចក្ដីសង្ឃឹម.
*ង* ១ ពេត្រុស ១:២២; ១ នីហ្វៃ ១១:២២–២៥.
*ច* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ឆ* ស.ប. ការអធិស្ឋាន.
*ជ* ស.ប. ជនបរិសុទ្ធ.
២៧ *ក* គ. និង ស. ៣៨:៣៩.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.

ដើម្បីឲ្យពួកគេប្រែចិត្ត ។ ប៉ុន្តែមើលចុះ ឪពុកខ្លាចក្រែង
ព្រះវិញ្ញាណ ទ្រង់ ឈប់[ក]តស៊ូនៅជាមួយនឹងពួកគេ; ហើយនៅក្នុង
ភាគនៃដែនដីនេះ ពួកគេក៏បានរកមធ្យោបាយនឹងកំចាត់ចោល នូវ
អានុភាព និងសិទ្ធិ អំណាចទាំងអស់ ដែលបានមកពីព្រះ; ហើយ
ពួកគេកំពុងតែ[ខ]បដិសេធព្រះវិញ្ញាណបរិសុទ្ធ ។
២៩ ហើយបន្ទាប់ពីបានបដិសេធនូវដំរិះដ៏មហិមានេះ
ឱកូនប្រុសរបស់ឪពុកអើយ ពួកគេនឹងត្រូវវិនាសបង់ នៅក្នុងពេល
ឆាប់ៗនេះ ដល់ការបំពេញនូវសេចក្ដីព្យាករណ៍ទាំងឡាយ ដែល
ពួកព្យាការីបាននិយាយមក ព្រមទាំងព្រះបន្ទូលទាំងឡាយនៃ
ព្រះអង្គសង្គ្រោះ របស់យើងរាល់គ្នាដែរ ។
៣០ ឱកូនប្រុសរបស់ឪពុកអើយ ឪពុកលាសិនហើយ លុះដល់
ឪពុកសរសេរមកកូន ឬក៏មកជួបកូនទៀត ។ អាម៉ែន ៕

---

សំបុត្រទីពីរនៃមរមន មកដល់មរ៉ូណៃ ជាកូនប្រុស
របស់លោក ។

*មាននៅក្នុងជំពូកទី ៩*

---

## ជំពូកទី ៩

*ទាំងសាសន៍នីហ្វៃ និងសាសន៍លេមិន កំពុងតែពុករលួយ ហើយចុះអន់ថយ — ពួកគេធ្វើទោស ហើយធ្វើឃាតគ្នាទៅវិញទៅមក — មរមនអធិស្ឋាន សូមឲ្យព្រះគុណ និងសេចក្ដីល្អ ស្ថិតស្ថេរនៅនឹងមរ៉ូណៃ រហូតតទៅ ។ ប្រមាណជាឆ្នាំ ៤០១–៤២១ គ.ស. ។*

ឱកូនប្រុសសំឡាញ់របស់ឪពុកអើយ ឪពុកសរសេរសំបុត្រមក
កូនទៀត ដើម្បីឲ្យកូនដឹងថា ឪពុកនៅរស់នៅឡើយ; ប៉ុន្តែឪពុក
នឹង សរសេរអំពីការណ៍ខ្លះ ដែលប្រកបទៅដោយក្ដីទុក្ខព្រួយ ។
២ ត្បិតមើលចុះ ឪពុកទើបតែមានការប្រយុទ្ធយ៉ាងខ្លាំងមួយ
ជាមួយនឹងពួកសាសន៍លេមិន តែនៅក្នុងការប្រយុទ្ធនោះ ពួកយើង
គ្មានជ័យជំនះទេ; ហើយអើគេអានទុស ត្រូវដួលស្លាប់ដោយ
ផ្លែដាវ ព្រមទាំងលូរាំ និងអែមរ៉ុនផង; មែនហើយ ហើយពួក
យើងត្រូវ បាត់បង់មនុស្សដ៏ចំណានរបស់យើងមួយចំនួនធំ ។
៣ ហើយឥឡូវនេះ មើលចុះ ឱកូនប្រុសរបស់ឪពុកអើយ
ឪពុកខ្លាចក្រែងពួកសាសន៍លេមិននឹងបំផ្លាញប្រជាជននេះចោលទៅ;
ត្បិត ពួកគេពុំប្រែចិត្តសោះ ឯអារក្សសាតាំងវាចេះតែចាក់រុក
ពួកគេដ៏ឥតឈប់ឈរ ឲ្យមានកំហឹងខឹងនឹងគ្នាទៅវិញទៅមក ។
៤ មើលចុះ ឪពុកមានការនឿយហត់ជាមួយនឹងពួកគេរហូត;
ហើយកាលឪពុកពោលនូវព្រះបន្ទូលនៃព្រះ ដោយ[ក]តឹងរ៉ឹង
នោះពួកគេ ក៏ញ័ររន្ធត់ ហើយមានកំហឹងខឹងនឹងឪពុក; ហើយ
កាលឪពុកពុំប្រើពាក្យតឹងរ៉ឹង នោះពួកគេបានធ្វើចិត្ត
រឹងរូសទៅវិញ; ហេតុដូច្នោះហើយ ឪពុកខ្លាចក្រែងព្រះវិញ្ញាណ
នៃព្រះអម្ចាស់ ទ្រង់ឈប់តស៊ូនៅជាមួយនឹងពួកគេហើយ ។
៥ ត្បិតពួកគេមានកំហឹងជាអតិបរមា រហូតដល់ឪពុកយល់ថា
ពួកគេពុំខ្លាចស្លាប់ឡើយ; ហើយពួកគេអត់មានចិត្តស្រឡាញ់
គ្នាទៅ វិញទៅមក; ហើយពួកគេមាន[ក]ការស្រេកឈាម និង
សងសឹកគ្នាឥតឈប់ឈរសោះ ។
៦ ហើយឥឡូវនេះ ឱកូនប្រុសសំឡាញ់របស់ឪពុកអើយ ទោះបី
ពួកគេមានចិត្តរឹងរូសយ៉ាងណាក៏ដោយ ក៏ចូរយើង[ក]ព្យាយាម
ធ្វើការ ចុះ; ត្បិតបើសិនជាយើងឈប់ខិតខំ នោះយើងនឹងត្រូវ
បាននៅក្រោមការកាត់ទោស; ត្បិតយើងមានការណ៍មួយ
សំរាប់ធ្វើ នៅពេល យើងនៅក្នុងរោងឧបោសថឥដ្ឋនេះ ដើម្បីឲ្យ
យើងអាចឈ្នះលើខ្មាំងសត្រូវ នៃអស់ទាំងសេចក្ដីសុចរិត
ឯព្រលឹងរបស់យើងនឹងសំរាក នៅក្នុងនគរព្រះ ។
៧ ហើយឥឡូវនេះ ឪពុកសរសេរអំពីការវេទនាទាំងឡាយ
នៃប្រជាជននេះខ្លះ ។ ត្បិតស្របតាមដំណឹងដែលឪពុកបានទទួល
ពីអ័ម៉ូរ៉ុន មើលចុះ ពួកសាសន៍លេមិនមានឈ្លើយសឹកជាច្រើន
ដែលពួកគេចាប់មកពីប៉មសេរីសា; ហើយមានទាំងប្រុស ទាំងស្រី
និងកូនក្មេងៗផង ។
៨ រីឯពួកប្ដី និងពួកឪពុកនៃពួកស្ត្រី និងពួកកូនក្មេងទាំងនោះ
ត្រូវពួកគេសម្លាប់ចោល; ហើយពួកគេយកសាច់របស់ប្ដីៗ មកឲ្យ
ពួក ស្ត្រីទាំងនោះធ្វើជាអាហារ ឯសាច់របស់ឪពុក មកឲ្យ
កូនក្មេងទាំងនោះ ធ្វើជាអាហារដែរ; ហើយគេពុំឲ្យទឹកទេ គឺឲ្យ
តែបន្តិចបន្តួច ប៉ុណ្ណោះ ។
៩ ហើយទោះបីពួកសាសន៍លេមិន បានធ្វើអំពើគួរខ្ពើមឆ្អើម
យ៉ាងធ្ងន់ដូច្នេះក៏ដោយ គង់តែពុំទាន់ហួសអំពើ ដែល

---

២៨ *ក* មរមន ៥:១៦.
*ខ* អាលម៉ា ៣៩:៦.
ស.ប. អំពើបាបដ៏អត់ឱនមិនបាន.
៩ ៤*ក* ២ នីហ្វៃ ១:២៦–២៧;
គ. និង ស. ១២១:៤១–៤៣.
*ខ* គ. និង ស. ១:៣៣.
៥ *ក* មរមន ៤:១១–១២.
៦ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* យ៉ាកុប ១:១៩; អេណុស ១:២០.
ស.ប. កាតព្វកិច្ច.

ប្រជាជនយើង បានធ្វើនៅម៉ូរីអានទុមដែរ ។ ត្បិតមើលចុះ មាន
កូនស្រីជាច្រើនរបស់ពួកសាសន៍លេមិន ត្រូវបានចាប់យក
ទៅជាឈ្លើយ; ហើយបន្ទាប់ ពីបានយកពីពួកស្ត្រីទាំងនេះ នូវអ្វី
ដែលមានតម្លៃ និងវិសេសបំផុតលើអ្វីៗទាំងអស់ គឺ[ក]ព្រហ្មចារីភាព
និង[ខ]បរិសុទ្ធភាព —
១០ ហើយបន្ទាប់ពីពួកគេបានធ្វើយ៉ាងនេះហើយ នោះពួក
គេបានធ្វើឃាតពួកស្ត្រីទាំងនោះ យ៉ាងឃោរឃៅបំផុត គឺធ្វើ
ទុក្ខដល់ រូបកាយរហូតដល់ស្លាប់; ហើយបន្ទាប់ពីបានធ្វើ
យ៉ាងនេះហើយ នោះពួកគេបានហែកស៊ីសាច់កូនស្រីទាំងនោះ
ហាក់បីដូចសត្វសាហាវ ពីព្រោះមកពីភាពរឹងរូសនៃចិត្ត
របស់ពួកគេ; ហើយពួកគេធ្វើយ៉ាងនេះ ដើម្បីជាសញ្ញា
ដល់សេចក្ដីក្លាហានមួយ ។
១១ ឱកូនប្រុសសំឡាញ់របស់ឪពុកអើយ ម្ដេចក៏ប្រជាជន
បែបនេះ ដែលគ្មានអារ្យធម៌បន្តិច —
១២ (ហើយគ្រាន់តែប៉ុន្មានឆ្នាំមុននេះ ពួកគេជាប្រជាជនមួយ
ដែលមានអារ្យធម៌ ហើយគួរឲ្យស្រឡាញ់)
១៣ ប៉ុន្តែ ឱកូនប្រុសរបស់ឪពុកអើយ ម្ដេចក៏ប្រជាជនបែបនេះ
បែរជាចូលចិត្តធ្វើអំពើគួរខ្ពើមឆ្អើមជាខ្លាំង ?
១៤ ធ្វើម្ដេចឲ្យពួកយើងអាចសង្ឃឹមថា ព្រះទ្រង់នឹង[ក]ឃាត់ទប់
ព្រះហស្តទ្រង់ ចំពោះសេចក្ដីជំនុំជំរះ ទាស់នឹងពួកយើងបាន ?
១៥ មើលចុះ ចិត្តឪពុកស្រែកឡើងថា៖ វេទនាដល់
ប្រជាជននេះ ។ ឱព្រះអង្គអើយ សូមព្រះអង្គបញ្ចេញសេច
ក្ដីជំនុំជំរះចុះ សូមព្រះអង្គបិទបាំងនូវអំពើបាប អំពើទុច្ចរិត និង
អំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ពួកគេ ចេញពីព្រះភក្ត្រ
ព្រះអង្គផង!
១៦ ហើយម្យ៉ាងទៀត កូនប្រុសរបស់ឪពុកអើយ មាន
[ក]ស្ត្រីមេម៉ាយ និងកូនស្រីរបស់គេជាច្រើន ដែលនៅឯសេរីសា;
ឯចំណែក ស្បៀងអាហារ ដែលពួកលេមិនពុំបាននាំយកទៅ
មើលចុះ ពួកកងទ័ពស៊ីនីហៃបាននាំទៅ ហើយទុកឲ្យពួក
គេដើរគ្រប់ទិសទី ស្វែងរក អាហារ; ហើយមានស្ត្រី
ចាស់ៗជាច្រើន បានដួលសន្លប់នៅតាមផ្លូវ ហើយស្លាប់បង់ ។
១៧ ឯកងទ័ពដែលនៅជាមួយនឹងឪពុក មានភាពទន់ខ្សោយ;
ហើយពលទ័ពសាសន៍លេមិន ស្ថិតនៅចន្លោះ រវាងសេរីសា និង
ឪពុក; ហើយអស់អ្នកណាដែលរត់ចូលទៅខាងកងទ័ពរបស់[ក]អើរ៉ុន
ក៏ត្រូវដួលរងគ្រោះ នៃអំពើឃោរឃៅរបស់ពួកគេ ។
១៨ ឱប្រជាជនរបស់ឪពុកអើយ អន់ថយអ្វីម្ល៉េះ! ពួកគេគ្មាន
របៀបរៀបរយ ហើយគ្មានសេចក្ដីមេត្តាករុណាឡើយ ។ មើលចុះ
ឪពុកគឺជាមនុស្សម្នាក់តែប៉ុណ្ណោះ ហើយឪពុកមានគ្រាន់តែកម្លាំង
នៃមនុស្សម្នាក់ ហើយឪពុកពុំអាចបង្ខំឲ្យពួកគេ ស្ដាប់តាមបញ្ជា
របស់ឪពុកតទៅទៀតឡើយ ។
១៩ ហើយពួកគេកាន់តែអាក្រក់ខ្លាំងឡើងនៅក្នុង
អំពើខូចអាក្រក់របស់គេ; ហើយពួកគេឃោរឃៅដូចគ្នា
ពុំអត់ឱនឲ្យនរណា មួយសោះ ទោះចាស់ឬក្មេង; ហើយពួក
គេចូលចិត្តធ្វើអ្វីៗសព្វយ៉ាង លើកលែងតែអំពើល្អប៉ុណ្ណោះ;
ហើយឯការរងទុក្ខវេទនា នៃពួកស្ត្រី និងពួកកូនក្មេង
របស់យើង នៅលើដែនដីនេះ នោះធ្ងន់ធ្ងរលើសអ្វីៗទាំង
អស់; មែនហើយ គ្មានភាសាឯណាអាចថ្លែងបាន ឬក៏អាច
សរសេរបានឡើយ ។
២០ ហើយឥឡូវនេះ កូនប្រុសរបស់ឪពុកអើយ
ឪពុកឈប់សរសេរវែងឆ្ងាយអំពីទិដ្ឋភាព ដ៏គួរឲ្យ
ខ្ពើមឆ្អើមនេះហើយ ។ មើលចុះ កូនដឹងអំពីភាពទុច្ចរិត
នៃប្រជាជននេះហើយ; កូនដឹងថា ពួកគេគ្មាន[ក]ក្រិត្យវិន័យអ្វី
ហើយមានចិត្តរក់រិញ; រីឯអំពើទុច្ចរិតរបស់គេ នោះធំ ជាង
ភាពទុច្ចរិត របស់ពួកសាសន៍លេមិនទៅទៀត ។
២១ មើលចុះ កូនប្រុសរបស់ឪពុកអើយ ឪពុកពុំអាចផ្ដាំផ្ញើពួក
គេដល់ព្រះបានឡើយ ក្រែងទ្រង់វាយឪពុក ។
២២ ប៉ុន្តែមើលចុះ កូនប្រុសរបស់ឪពុកអើយ ឪពុកផ្ដាំផ្ញើកូន
ដល់ព្រះ ហើយឪពុកទុកចិត្តដល់ព្រះគ្រីស្ទថា កូននឹងត្រូវបាន
សង្គ្រោះ; ហើយឪពុកអធិស្ឋានដល់ព្រះ សូមឲ្យទ្រង់[ក]ទុកជីវិតឲ្យ
កូន ដើម្បីឲ្យកូនអាចធ្វើជាសាក្សី ដល់ការបែរនៃរាស្ត្ររបស់ទ្រង់
មករកទ្រង់វិញ ឬក៏ការបំផ្លិចបំផ្លាញសូន្យសុងរបស់ពួកគេ; ត្បិត
ឪពុកដឹងថា ពួកគេត្រូវតែវិនាស លើកលែងតែពួកគេ[ខ]ប្រែចិត្ត
ហើយបែរ មករកទ្រង់វិញ ។
២៣ ហើយបើសិនជាពួកគេវិនាស ក៏ដូចជា[ក]ពួកសាសន៍
យ៉ារេឌដែរ ពីព្រោះតែចិត្តរឹងទទឹង ដោយស្វែងរកការ
ខ្ទាយឈាម [ខ]និងការសងសឹក ។

៩ *ក* ស.ប. ព្រហ្មចារីភាព.
*ខ* ស.ប. គុណធម៌.
១៤ *ក* អាលម៉ា ១០:២៣.
១៦ *ក* ស.ប. ស្រីមេម៉ាយ.
១៧ *ក* មរមន ២:៩.
២០ *ក* ហេលេ. ៦:៣៤–៣៥.
២២ *ក* មរមន ៨:៣.
*ខ* ម៉ាឡាគី ៣:៧;
ហេលេ. ១៣:១១;
៣ នីហ្វៃ ១០:៦; ២៤:៧.
២៣ *ក* មរមន ៤:១១–១២.
*ខ* អេធើរ ១៥:១៥–៣១.

២៤ ហើយប្រសិនបើពួកគេវិនាសមែន យើងដឹងថា មានពួក
បងប្អូនយើងជាច្រើន បានបែកចេញពីយើង ទៅចូលខាងពួក
សាសន៍លេមិន ហើយបងប្អូនច្រើនទៀត នឹងបែកចេញពីយើង
ទៅចូលខាងពួកគេដែរ; ហេតុដូច្នោះហើយ ចូរកូនសរសេរ
ការណ៍ខ្លះទៀត បើសិនជាកូនបានរួចជីវិត ហើយបើឪពុកនឹងត្រូវ
វិនាសទៅ ដោយពុំបានជួបកូន; ប៉ុន្តែ ឪពុកជឿថា ឪពុកនឹងបាន
ជួបកូនក្នុងពេលឆាប់ៗនេះ; ត្បិតឪពុកមានបញ្ជីពិសិដ្ឋទាំងឡាយ
ដែលឪពុកចង់ប្រគល់ឲ្យកូន ។
២៥ ឱកូនប្រុសរបស់ឪពុកអើយ ចូរនៅស្មោះត្រង់
ចំពោះព្រះគ្រីស្ទចុះ; ហើយសូមកុំឲ្យអ្វីដែលឪពុកសរសេរនេះ
ធ្វើឲ្យកូនកើតទុក្ខ រហូតដល់ស្លាប់ឡើយ; តែសូមឲ្យ
ព្រះគ្រីស្ទលើកកូនឡើង ហើយសូមសេចក្ដីស៊ូទ្រាំ និងការសុគត
របស់ទ្រង់ និងការបង្ហាញព្រះកាយ ទ្រង់ដល់ពួកអយ្យកោយើង
និងសេចក្ដីមេត្តាករុណារបស់ទ្រង់ និងការអត់ធ្មត់ និងសេច
ក្ដីសង្ឃឹមចំពោះសិរីល្អរបស់ទ្រង់ និងចំពោះ ជីវិត
ដ៏នៅអស់កល្បជានិច្ច ស្ថិតនៅក្នុងគំនិតរបស់កូន រៀងរហូតតទៅ ។
២៦ ហើយសូមព្រះគុណនៃព្រះដ៏ជាព្រះវរបិតា ដែល
គង់លើបល្ល័ង្កខ្ពស់លើស្ថានសួគ៌ និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ
របស់យើង ដែល គង់នៅខាងស្ដាំនៃព្រះចេស្ដារបស់ទ្រង់ លុះ
ដល់អ្វីៗសព្វសារពើនឹងស្ថិត នៅក្រោមអំណាចរបស់ទ្រង់
សូមឲ្យបាន ហើយស្ថិតស្ថេរនៅ ជាមួយកូនរហូតតទៅចុះ ។
អាម៉ែន ៕

## ជំពូកទី ១០

*ទីបន្ទាល់អំពីព្រះគម្ពីរមរមន មានមកដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ — អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ ត្រូវបាន ប្រទានឲ្យពួកស្មោះត្រង់ — អំណោយទានទាំងឡាយខាងវិញ្ញាណ មានឡើងតាមសេចក្ដីជំនឿជានិច្ច — ពាក្យសំដីរបស់មរ៉ូណៃ និយាយចេញមកពីធូលីដី — ចូរមករកព្រះគ្រីស្ទ ឲ្យបានល្អឥតខ្ចោះក្នុងទ្រង់ ហើយចូរញែកព្រលឹងអ្នកឲ្យបានបរិសុទ្ធចុះ ។ ប្រមាណជាឆ្នាំ ៤២១ គ.ស. ។*

ឥឡូវនេះ ខ្ញុំមរ៉ូណៃ សរសេរខ្លះអំពីអ្វីដែលខ្ញុំយល់ឃើញថាល្អ;
ហើយខ្ញុំសរសេរនេះ ទៅកាន់ពួកបងប្អូនខ្ញុំ គឺពួកសាសន៍លេមិន;
ហើយខ្ញុំចង់ឲ្យពួកគេដឹងថា ជាងបួនរយម្ភៃឆ្នាំបានកន្លងមកហើយ
ចាប់តាំងពីបានទទួលទីសំគាល់ អំពីការយាងមកនៃព្រះគ្រីស្ទ ។
២ ហើយខ្ញុំនឹងបិទបញ្ជីទាំងនេះ បន្ទាប់ពីខ្ញុំបាននិយាយនូវពាក្យ
បន្តិចបន្តួច ទុកជាសេចក្ដីទូន្មានដល់អ្នករាល់គ្នា ។
៣ មើលចុះ ខ្ញុំសូមទូន្មានដល់អ្នករាល់គ្នាថា កាលណាអ្នក
រាល់គ្នាបានអានការណ៍ទាំងនេះ បើសិនជាជាប្រាជ្ញានៅក្នុងព្រះថា
អ្នករាល់គ្នាបានអានការណ៍ទាំងនេះ នោះសូមឲ្យអ្នករាល់គ្នា
នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាង
ណា ដល់កូនចៅមនុស្ស ចាប់តាំងពីកំណើតលោកអ័ដាមមក
រហូតមកដល់ពេលដែលអ្នករាល់គ្នា បានទទួលការណ៍ទាំងនេះ
ហើយសូម រំពឹងគិតនៅក្នុងចិត្តអ្នកចុះ ។
៤ ហើយកាលណាអ្នករាល់គ្នាបានទទួលនូវការណ៍ទាំងនេះ
នោះខ្ញុំសូមទូន្មានដល់អ្នករាល់គ្នា ឲ្យសូមសួរដល់ព្រះជាព្រះវរបិតា
ដ៏គង់ នៅអស់កល្បជានិច្ច ដោយនូវព្រះនាមនៃព្រះគ្រីស្ទ បើ
សិនជាការណ៍ទាំងនេះមិនពិត; ហើយបើសិនជាអ្នករាល់គ្នា សូម
សួរដោយចិត្ត ស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយ
មានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ នោះទ្រង់នឹងសម្ដែងសេចក្ដីពិត
នៃការណ៍នេះដល់អ្នក ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។
៥ ហើយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នក
រាល់គ្នាអាចស្គាល់សេចក្ដីពិតនៃគ្រប់ការណ៍ទាំងអស់ ។
៦ ហើយអ្វីក៏ដោយដែលល្អ គឺត្រឹមត្រូវ ហើយពិត; ហេតុ

២៤ *ក* អាលម៉ា ៤៥:១៤.
*ខ* មរមន ៦:៦.
២៥ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
*គ* ស.ប. គំនិត.
២៦ *ក* លូកា ២២:៦៩; កិច្ចការ ៧:៥៥–៥៦; ម៉ូសាយ ៥:៩; អាលម៉ា ២៨:១២.
**១០** ១*ក* គ. និង ស. ១០:៤៨.
២ *ក* មរមន ៨:៤, ១៣–១៤. ស.ប. បទព្រះគម្ពីរ — គម្ពីរដែលបានព្យាករថានឹងចេញមក.
៣ *ក* ចោទិ. ១១:១៨–១៩. ស.ប. រំពឹងគិត.
*ខ* ចោទិ. ៦:៦–៧.
៤ *ក* ស.ប. ការអធិស្ឋាន.
*ខ* ១ នីហ្វៃ ១៣:៣៩; ១៤:៣០; ម៉ូសាយ ១:៦; អេធើរ ៤:១០–១១; ៥:៣.
*គ* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់.
*ឃ* យ៉ាកុប (ព.ស.ថ.) ១:៥–៧; មរ៉ូណៃ ៧:៩.
*ង* ស.ប. សេចក្ដីជំនឿ.
*ច* ស.ប. វិវរណៈ.
*ឆ* ស.ប. សេចក្ដីពិត.
៥ *ក* គ. និង ស. ៣៥:១៩. ស.ប. ការសង្កេតស្គាល់, អំណោយទាបខាង; ទីបន្ទាល់.
*ខ* យ៉ូហាន ៨:៣២.

ដូច្នេះហើយ គ្មានអ្វីដែលល្អ នឹងបដិសេធព្រះគ្រីស្ទឡើយ តែទទួលស្គាល់ថា ទ្រង់ជាព្រះវិញ ។

៧ ហើយអ្នករាល់គ្នាក៏អាចដឹងថាទ្រង់ជាព្រះ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ; ហេតុដូច្នោះហើយ ខ្ញុំសូមទូន្មានដល់អ្នករាល់គ្នាថា សូមកុំបដិសេធព្រះចេស្ដានៃព្រះឡើយ; ត្បិតទ្រង់ធ្វើការ ដោយព្រះចេស្ដា ស្របតាមសេចក្ដីជំនឿនៃកូនចៅមនុស្ស ថ្ងៃនេះក៏ដូចគ្នានឹងថ្ងៃស្អែក និងរហូតតទៅ ។

៨ ហើយម៉្យាងទៀត ឱបងប្អូនរបស់ខ្ញុំអើយ ខ្ញុំសូមទូន្មានដល់អ្នករាល់គ្នាថា កុំបដិសេធអំណោយទានទាំងឡាយនៃព្រះឡើយ ត្បិត អំណោយទាននោះមានច្រើនណាស់; ហើយអំណោយទានទាំងនោះបានមកពីព្រះតែមួយដដែល ។ ហើយអំណោយទានទាំងនោះ ត្រូវបានផ្ដល់ឲ្យដោយផ្លូវផ្សេងៗ; ប៉ុន្តែគឺជាព្រះតែមួយអង្គដដែល ដែលធ្វើការណ៍ទាំងអស់នេះ; ហើយអំណោយទានទាំងនោះ ត្រូវបាន ប្រទានដល់មនុស្ស តាមការសម្ដែងនៃព្រះវិញ្ញាណនៃព្រះ ដើម្បីជាប្រយោជន៍ដល់ពួកគេ ។

៩ ត្បិតមើលចុះ ចំពោះម្នាក់ត្រូវបានប្រទានឲ្យ ដោយនូវព្រះវិញ្ញាណនៃព្រះ ដើម្បីឲ្យអ្នកនោះអាចបង្រៀនពាក្យសំដីនៃប្រាជ្ញាវាងវៃ;

១០ ហើយចំពោះម្នាក់ទៀត ដើម្បីឲ្យអ្នកនោះ អាចបង្រៀនពាក្យសំដីនៃចំណេះចេះស្ទាត់ ដោយនូវព្រះវិញ្ញាណដដែល;

១១ ហើយចំពោះម្នាក់ទៀត ឲ្យមានសេចក្ដីជំនឿដ៏ធំ; និងចំពោះម្នាក់ទៀត ឲ្យអំណោយទាននៃការប្រោសឲ្យជា ដោយនូវព្រះ វិញ្ញាណដដែល;

១២ ហើយម៉្យាងទៀត ចំពោះម្នាក់ទៀត ដើម្បីឲ្យអ្នកនោះអាចសម្ដែងអព្ភូតហេតុដ៏អស្ចារ្យ;

១៣ ហើយម៉្យាងទៀត ចំពោះម្នាក់ទៀត ដើម្បីឲ្យអ្នកនោះអាចព្យាករអំពីអ្វីៗគ្រប់យ៉ាង;

១៤ ហើយម៉្យាងទៀត ចំពោះម្នាក់ទៀត ឲ្យបានឃើញពួកទេវតា និងវិញ្ញាណទាំងឡាយ ដែលមកធ្វើការងារបំរើ;

១៥ ហើយម៉្យាងទៀត ចំពោះម្នាក់ទៀត ឲ្យចេះគ្រប់ភាសា;

១៦ ហើយម៉្យាងទៀត ចំពោះម្នាក់ទៀត ឲ្យចេះបកប្រែភាសា និងពាក្យផ្សេងៗ;

១៧ ហើយអំណោយទានទាំងអស់នេះ បានមកដោយសារព្រះវិញ្ញាណនៃព្រះគ្រីស្ទ; ហើយអំណោយទានទាំងនេះ ត្រូវបានប្រទាន ដល់មនុស្សគ្រប់គ្នាជាច្រើនដង ស្របតាមបំណងរបស់គេ ។

១៨ ហើយខ្ញុំសូមទូន្មានដល់អ្នករាល់គ្នា ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ សូមឲ្យអ្នករាល់គ្នាចាំថា អំណោយទានដែលល្អ គឺបានមកពីព្រះគ្រីស្ទ ។

១៩ ហើយខ្ញុំសូមទូន្មានដល់អ្នករាល់គ្នា ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ សូមឲ្យអ្នករាល់គ្នាចាំថា ព្រះអង្គគឺនៅតែដដែល ទោះពីថ្ងៃម្សិល ថ្ងៃនេះ និងរហូតតទៅ ហើយអំណោយទានទាំងអស់ដែលខ្ញុំបានរៀបរាប់មកនេះ ដែលជាអំណោយទានខាងវិញ្ញាណ នឹងពុំអាចបាត់បង់ទៅឡើយ ដរាបណាមានពិភពលោកនេះ លើកលែងតែស្របតាមការឥតជំនឿដល់កូនចៅមនុស្សប៉ុណ្ណោះ ។

២០ ហេតុដូច្នោះហើយ ត្រូវតែមានសេចក្ដីជំនឿ; ហើយបើសិនជាមានសេចក្ដីជំនឿ នោះត្រូវតែមានសេចក្ដីសង្ឃឹមផង; ហើយបើ សិនជាមានសេចក្ដីសង្ឃឹម នោះត្រូវតែមានសេចក្ដីសប្បុរសផងដែរ ។

២១ ហើយលើកលែងអ្នករាល់គ្នាមានសេចក្ដីសប្បុរស បើពុំនោះសោតទេ អ្នករាល់គ្នានឹងពុំអាចបានសង្គ្រោះ នៅក្នុងនគរព្រះ ឡើយ; ហើយអ្នករាល់គ្នាក៏ពុំអាចបានសង្គ្រោះនៅក្នុងនគរព្រះដែរ បើសិនជាអ្នករាល់គ្នាគ្មានសេចក្ដីជំនឿ; ហើយអ្នកក៏ពុំអាចបាន សង្គ្រោះនៅក្នុងនគរព្រះដែរ បើសិនជាអ្នកគ្មានសេចក្ដីសង្ឃឹម ។

២២ ហើយបើសិនជាអ្នករាល់គ្នាគ្មានសេចក្ដីសង្ឃឹមទេ នោះអ្នករាល់គ្នាច្បាស់ជានៅក្នុងសេចក្ដីអស់សង្ឃឹមវិញ; ហើយសេចក្ដីអស់ សង្ឃឹមកើតឡើងមកដោយសារតែអំពើទុច្ចរិត ។

២៣ ហើយព្រះគ្រីស្ទមានព្រះបន្ទូលយ៉ាងពិតប្រាកដ ទៅកាន់ពួកអយ្យកោយើងថា៖ បើសិនជាអ្នករាល់គ្នាមានសេចក្ដីជំនឿ

---

៧ ក ១ នីហ្វៃ ១០:១៧–១៩.
៨ ក ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
ខ គ. និង ស. ៤៦:១៥.
៩ ក ១ កូរិន. ១២:៨–១១; គ. និង ស. ៤៦:៨–២៩.
ខ គ. និង ស. ៨៨:៧៧–៧៩, ១១៨.
១១ ក ស.ប. សេចក្ដីជំនឿ.
ខ ស.ប. ប្រោស, ការប្រោស.
១២ ក ស.ប. អព្ភូតហេតុ.
១៦ ក ស.ប. អំណោយទានខាងភាសា.
១៨ ក យ៉ាកុប (ព.ស.ថ.) ១:១៧.
១៩ ក ហេព្រើរ ១៣:៨.
ខ មរ៉ូណៃ ៧:៣៧.
២០ ក អេធើរ ១២:៣–៣៧.
២១ ក ១ កូរិន. ១៣:១–១៣; មរ៉ូណៃ ៧:១, ៤២–៤៨. ស.ប. សេចក្ដីសប្បុរស.
២៣ ក មរ៉ូណៃ ៧:៣៣.

នោះអ្នករាល់គ្នាអាចធ្វើនូវគ្រប់អ្វីៗទាំងអស់ ដែលជាការចំបាច់ដល់យើង ។

២៤ ហើយឥឡូវនេះ ខ្ញុំសូមនិយាយទៅមនុស្សទាំងអស់នៅចុងផែនដីថា — បើសិនជាមានថ្ងៃណាមួយ ដែលព្រះចេស្ដា និងអំណោយទាននៃព្រះ នឹងឈប់មាននៅក្នុងចំណោមអ្នករាល់គ្នា នោះគឺមកពីការឥតជំនឿ ។

២៥ ហើយវេទនាដល់កូនចៅមនុស្ស បើសិនជាដូច្នោះមែន; ត្បិតនៅក្នុងចំណោមពួកគេ នឹងពុំមានជនណាម្នាក់ធ្វើល្អឡើយ គឺសូម្បីតែមួយក៏គ្មានសោះ ។ ត្បិតបើសិនជាមានអ្នកណាម្នាក់នៅក្នុងចំណោមពួកគេធ្វើល្អ អ្នកនោះនឹងធ្វើការដោយព្រះចេស្ដា និងដោយអំណោយទានទាំងឡាយនៃព្រះ ។

២៦ ហើយវេទនាដល់ពួកអ្នកណា ដែលនឹងបំបាត់ចោលនូវការណ៍ទាំងនេះ ហើយស្លាប់ទៅ ត្បិតពួកគេស្លាប់ក្នុងអំពើបាបទាំងឡាយ របស់គេ ហើយពួកគេនឹងពុំអាចបានសង្គ្រោះ នៅក្នុងនគរព្រះបានឡើយ; ហើយខ្ញុំនិយាយការណ៍នេះ ស្របតាមព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយខ្ញុំពុំកុហកទេ ។

២៧ ហើយខ្ញុំសូមទូន្មានដល់អ្នករាល់គ្នា ឲ្យចាំនូវការណ៍ទាំងនេះ; ត្បិតពេលវេលានឹងមកដល់យ៉ាងឆាប់ៗ ដែលអ្នករាល់គ្នាដឹងថា ខ្ញុំពុំកុហកឡើយ ត្បិតអ្នករាល់គ្នានឹងឃើញខ្ញុំនៅឯវេទិកាជំនុំជំរះនៃព្រះ; ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងមានព្រះបន្ទូលទៅកាន់អ្នក រាល់គ្នាថា៖ តើយើងពុំបានប្រកាសពាក្យយើង ដល់អ្នករាល់គ្នាទេឬអី ដែលបានសរសេរទុកដោយបុរសនេះ ហាក់បីដូចជាមនុស្សម្នាក់ ស្រែកចេញមកពីសេចក្ដីស្លាប់ មែនហើយ ហាក់បីដូចជាមនុស្សម្នាក់និយាយចេញមកពីធូលីដី ?

២៨ ខ្ញុំប្រកាសការណ៍ទាំងនេះ ដើម្បីឲ្យពាក្យព្យាករណ៍ទាំងឡាយបានបំពេញ ។ ហើយមើលចុះ ការណ៍ទាំងនេះ គឺចេញមកពីព្រះ ឱស្ឋនៃព្រះដ៏គង់នៅអស់កល្បជានិច្ច; ហើយព្រះបន្ទូលរបស់ទ្រង់ នឹងហ៊ូចហោពីតំណមួយទៅតំណមួយ ។

២៩ ហើយព្រះទ្រង់នឹងបង្ហាញដល់អ្នករាល់គ្នាថា ការណ៍ដែលខ្ញុំបានសរសេរមកនេះគឺពិត ។

៣០ ហើយម៉្យាងទៀត ខ្ញុំសូមទូន្មានដល់អ្នករាល់គ្នា សូមឲ្យអ្នករាល់គ្នាមករកព្រះគ្រីស្ទ ហើយចូរយកនូវអំណោយទានដ៏ល្អទាំងអស់ ហើយកុំប៉ះពាល់ដល់អំណោយទានអាក្រក់ ឬវត្ថុដែលពុំស្អាតឡើយ ។

៣១ ហើយចូរភ្ញាក់ឡើង និងចូរក្រោកឡើងពីធូលីដី ឱក្រុងយេរូសាឡិមអើយ; មែនហើយ ឱកូនស្រីនៃក្រុងស៊ីយ៉ូនអើយ ចូរប្រដាប់ ដោយសំលៀកបំពាក់ដ៏រុងរឿងរបស់អ្នកចុះ; ហើយចូរពង្រឹងចំរឹង ហើយចូរពង្រីកនូវព្រំដែនរបស់ខ្លួនរហូតតទៅ ដើម្បីកុំឲ្យអ្នកត្រូវ លាយឡំ ឱវង្សអ៊ីស្រាអែលអើយ ដើម្បីឲ្យសេចក្ដីសញ្ញានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ដែលបានធ្វើដល់អ្នកអាចបានបំពេញ ។

៣២ មែនហើយ ចូរមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ហើយចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធចុះ; ហើយបើសិនជាអ្នករាល់គ្នានឹងលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ ហើយស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នក នោះព្រះគុណរបស់ទ្រង់ល្មមដល់អ្នកហើយ ដោយសារព្រះគុណនៃព្រះ នោះអ្នករាល់គ្នាអាចបានល្អឥតខ្ចោះ នៅក្នុងព្រះគ្រីស្ទ; ហើយបើសិនជាដោយសារព្រះគុណនៃព្រះ ដែលអ្នករាល់គ្នាបានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ នោះអ្នករាល់គ្នានឹងពុំអាចបដិសេធព្រះចេស្ដានៃព្រះបានឡើយ ។

៣៣ ហើយម៉្យាងទៀត បើសិនជាដោយសារព្រះគុណនៃព្រះ ដែលអ្នករាល់គ្នាបានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ ហើយពុំបាន

២៤ *ក* មរ៉ូណៃ ៧:៣៧.
*ខ* ស.ប. ការឥតជំនឿ.
២៥ *ក* ក.ឃ.ស., ទំនុក. ១៤:១–៧;
រ៉ូម ៣:១០–១២.
២៦ *ក* អេសេ. ១៨:២៦–២៧;
១ នីហ្វៃ ១៥:៣២–៣៣;
ម៉ូសាយ ១៥:២៦.
*ខ* យ៉ូហាន ៨:២១.
២៧ *ក* ២ នីហ្វៃ ៣៣:១០–១១.
*ខ* ២ នីហ្វៃ ៣:១៩–២០; ២៧:១៣;
៣៣:១៣; មរមន ៩:៣០.
*គ* អេសាយ ២៩:៤.
២៨ *ក* ២ នីហ្វៃ ២៩:២.
៣០ *ក* ១ នីហ្វៃ ៦:៤; មរមន ៩:២៧;
អេធើរ ៥:៥.
*ខ* អាលម៉ា ៥:៥៧.
៣១ *ក* អេសាយ ៥២:១–២.
*ខ* ស.ប. ស៊ីយ៉ូន.
*គ* អេសាយ ៥៤:២.
*ឃ* ស.ប. ចំរឹង, ស្តេក.
*ង* អេធើរ ១៣:៨.
៣២ *ក* ម៉ាថាយ ១១:២៨;
២ នីហ្វៃ ២៦:៣៣; យ៉ាកុប ១:៧;
អោមណៃ ១:២៦.
*ខ* ម៉ាថាយ ៥:៤៨;
៣ នីហ្វៃ ១២:៤៨.
ស.ប. ល្អឥតខ្ចោះ.
*គ* គ. និង ស. ៤:២; ៥៩:៥–៦.
*ឃ* ២ នីហ្វៃ ២៥:២៣.

បដិសេធព្រះចេស្ដារបស់ទ្រង់ទេ នោះអ្នករាល់គ្នានឹងត្រូវបាន
[ក]ញែកចេញជាបរិសុទ្ធនៅក្នុងព្រះគ្រីស្ទ ដោយសារព្រះគុណនៃព្រះ
ដោយ[ខ]ការច្រូចព្រះលោហិតនៃព្រះគ្រីស្ទ ដែលមាននៅក្នុងសេចក្ដី
សញ្ញានៃព្រះវរបិតា ចំពោះ[គ]ការផ្ដាច់បាបដល់អ្នករាល់គ្នា ដើម្បីឲ្យ
អ្នករាល់គ្នាបាន[ឃ]បរិសុទ្ធ ដោយគ្មានប្រឡាក់អ្វីសោះឡើយ ។
៣៤ ហើយឥឡូវនេះ ខ្ញុំសូមលាអ្នករាល់គ្នាសិនហើយ ។ មិន
យូរប៉ុន្មានទេ ខ្ញុំនឹងទៅ[ក]សំរាកនៅឯ[ខ]ស្ថានបរមសុខនៃព្រះ លុះដល់
[គ]វិញ្ញាណ និងរូបកាយខ្ញុំបាន[ឃ]រួមគ្នាវិញ ហើយខ្ញុំនឹងត្រូវចេញមក
ដោយជោគជ័យ កាត់តាម[ង]អាកាស ដើម្បីមកជួបអ្នករាល់គ្នា នៅ
ខាង មុខវេទិកាជំនុំជំរះ[ច]ដ៏គាប់ព្រះហឫទ័យ នៃ[ឆ]ព្រះយេហូវ៉ាដ៏មហិមា
ដែលជា[ជ]ចៅក្រមដ៏អស់កល្បជានិច្ច នៃមនុស្សរស់ និងមនុស្ស
ស្លាប់ផង ។ អាម៉ែន ៕ :៚

៣៣ *ក* ស.ប. ការញែកជាបរិសុទ្ធ.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ស.ប. ការផ្ដាច់បាប.
*ឃ* ស.ប. បរិសុទ្ធភាព.
៣៤ *ក* ស.ប. សេចក្ដីសំរាក.
*ខ* ស.ប. ស្ថានបរមសុខ.
*គ* ស.ប. វិញ្ញាណ.
*ឃ* ស.ប. ដំណើររស់ឡើងវិញ.
*ង* ១ ថែស្សា. ៤:១៧.
*ច* យ៉ាកុប ៦:១៣.
*ឆ* ស.ប. ព្រះយេហូវ៉ា.
*ជ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.

# គោលលទ្ធិ
# និង
# សេចក្ដីសញ្ញា

របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ

នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

មាននូវវិវរណៈទាំងឡាយដែលបានប្រទានដល់

យ៉ូសែបស្ម៊ីធ ជាព្យាការី

ជាមួយនឹងវិវរណៈថែមទៀត ពីពួកអ្នកស្នងលោក

ក្នុងគណៈប្រធានទី១ នៃសាសនាចក្រ

# បុព្វកថា

គោលលទ្ធិ និងសេចក្ដីសញ្ញា គឺជាការប្រជុំវិវរណៈទាំងឡាយពីព្រះ និងជាសេចក្ដីប្រកាសដ៏បំភ្លឺទាំងឡាយ ដែលបានប្រទានឲ្យមកសំរាប់ការតាំងឡើង និងការត្រួតត្រានគរព្រះ នៅលើផែនដី នៅថ្ងៃចុងក្រោយបង្អស់ ។ ទោះជាកណ្ឌភាគច្រើន ត្រូវបានតម្រង់ទៅ រកសមាជិកទាំងឡាយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយក៏ដោយ គង់តែសារបទព្រមាន និងពាក្យទូន្មាន ទាំងប៉ុន្មាននោះ ជាប្រយោជន៍ដល់មនុស្សលោកគ្រប់រូប ហើយមានការអញ្ជើញដល់ប្រជាជនទាំងពួង នៅគ្រប់ទិសទី ឲ្យស្ដាប់សម្លេង នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលមានព្រះបន្ទូលទៅកាន់ពួកគេ សំរាប់សុខុមាលភាពខាងសាច់ឈាមរបស់ពួកគេ និងសំរាប់សេចក្ដី សង្គ្រោះដ៏អស់កល្បជានិច្ចរបស់ពួកគេ ។

វិវរណៈភាគច្រើននៅក្នុងការប្រជុំនេះ ត្រូវបានទទួលមកតាមរយៈ យ៉ូសែប ស៊្មីធ ជុញ៉ូរ ជាព្យាការី និងជាប្រធានទីមួយនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ វិវរណៈឯទៀតនោះ ត្រូវបានចេញមកតាមរយៈពួកអ្នកស្នងលោកក្នុងគណៈប្រធានខ្លះៗ (សូមមើលចំណងជើងទាំងឡាយ នៃកណ្ឌទី ១៣៥, ១៣៦, និង១៣៨, និងសេចក្ដីប្រកាសជាផ្លូវការទី១ និងទី២) ។

ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា គឺជាគម្ពីរមួយក្នុងគម្ពីរបមាណីយនៃសាសនាចក្រ ដែលមានរួមនូវព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមន និងកែវមុក្ដាដ៏មានតម្លៃមហិមា ។ ប៉ុន្តែគោលលទ្ធិ និងសេចក្ដីសញ្ញា គឺពិសេស ពីព្រោះវាមិនមែនជាការបកប្រែពីឯកសារបុរាណទេ តែជារបស់មានកំណើតឡើងនៅសម័យទំនើប ហើយត្រូវបានប្រទានឲ្យមកពីព្រះ តាមរយៈពួកព្យាការីជំរើសរបស់ទ្រង់ សំរាប់ការសាងឡើងវិញ នៃកិច្ចការដ៏បរិសុទ្ធ និងសំរាប់ការតាំងឡើងនៃនគរព្រះ នៅលើផែនដីនៅជំនាន់នេះ ។ នៅក្នុងវិវរណៈទាំងឡាយ នោះបុគ្គលម្នាក់ៗឮសម្លេងដ៏ទន់ភ្លន់ តែម៉ឺងម៉ាត់នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលមានព្រះបន្ទូលសារជាថ្មី នៅការកាន់កាប់ ត្រួតត្រា ក្នុងកាលដែលពេញកំណត់; ហើយកិច្ចការដែលបានចាប់ផ្ដើមនៅក្នុងគម្ពីរនេះ គឺជាការប្រុងប្រៀបសំរាប់ការយាងមកលើក ទីពីររបស់ទ្រង់ ដើម្បីទុកជាការសំរេច និងការព្រមព្រៀងនឹងពាក្យពេចន៍ទាំងឡាយ នៃអស់ទាំងពួកព្យាការីបរិសុទ្ធចាប់តាំងពីកំណើត លោកិយមក ។

យ៉ូសែប ស៊្មីធ ជុញ៉ូរ កើតនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៨០៥ នៅភូមិសារ៉ុន យ៉ុវិនសើរ រដ្ឋវ័រម៉ុន្ត ។ កាលលោកនៅក្មេង លោកបានរើជាមួយគ្រួសារលោក ទៅនៅភូមិម៉ែនឆែសស្ទើរ នៅរដ្ឋនូវយ៉ោកភាគខាងលិច ។ គឺកាលលោកកំពុងរស់នៅក្បែរភូមិម៉ែនឆែសស្ទើរ នៅនិទាឃរដូវ ក្នុងឆ្នាំ១៨២០ កាលលោកមានអាយុដប់បួនឆ្នាំនេះហើយ ដែលលោកបានមានការពិសោធន៍អំពីការនិមិត្តទីមួយរបស់លោក រីឯការនិមិត្តនេះ ព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ បានយាងមកជួបលោកផ្ទាល់ ។ លោកត្រូវបានប្រាប់នៅក្នុងការនិមិត្តនេះថា សាសនាចក្រពិតនៃព្រះគ្រីស្ទ ដែលបានតាំងឡើង នៅសម័យព្រះគម្ពីរសញ្ញាថ្មី ហើយដែល បានចាត់តាំងភាពពោរពេញនៃដំណឹងល្អនោះ គឺមិនមាននៅលើផែនដីទៀតទេ ។ មានការបើកសំដែងផ្សេងៗទៀតពីព្រះ ដែល លោកត្រូវបានទទួលការបង្រៀន ដោយពួកទេវតាជាច្រើន; ត្រូវបានបង្ហាញដល់លោកថា ព្រះទ្រង់មានកិច្ចការពិសេសមួយ សំរាប់ ឲ្យលោកធ្វើនៅលើផែនដី ហើយថាតាមរយៈលោក នោះសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នឹងបានសាងឡើងវិញនៅលើផែនដី ។

នៅកំឡុងពេលដែលកន្លងទៅនោះ យ៉ូសែប ស៊្មីធ បានទទួលជំនួយពីព្រះ ដើម្បីបកប្រែ និងបោះពុម្ពផ្សាយព្រះគម្ពីរមរមន ។ នៅពេលនោះ លោក និង អូលីវើរ ខៅឌើរី ត្រូវបានតែងតាំងដោយយ៉ូហាន-បាទីស្ទ ឲ្យកាន់បព្វជិតភាពអើរ៉ុន នៅខែឧសភា ឆ្នាំ១៨២៩ (សូមមើល គ. និង ស. ១៣) ហើយក្រោយពីនោះបន្តិចមក ពួកគេត្រូវបានតែងតាំង ឲ្យកាន់បព្វជិតភាពមិលគិស្សាដែកផងដែរ ដោយពួកសាវកបុរាណ គឺ ពេត្រុស យ៉ាកុប និងយ៉ូហាន (សូមមើល គ. និង ស. ២៧:១២) ។ ការតែងតាំងផ្សេងៗទៀត ដែលមាន ឡើងមកតាមក្រោយ ដែលមានកូនសោទាំងឡាយនៃបព្វជិតភាព នោះត្រូវបានប្រគល់ដល់ពួកគេ ដោយលោកម៉ូសេ អេលីយ៉ា អេលីយ៉ាស និងពួកព្យាការីបុរាណជាច្រើន (សូមមើល គ. និង ស. ១១០; ១២៨:១៨, ២១) ។ តាមពិត ការតែងតាំង

ទាំងឡាយនេះ គឺជាការសាងឡើងវិញនៃសិទ្ធិអំណាចពីព្រះ ដល់មនុស្សនៅលើផែនដី ។ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៣០ គឺនៅក្រោមការដឹកនាំពី ស្ថានសួគ៌ នោះព្យាការីយ៉ូសែប ស្ម៊ីធ បានរៀបចំសាសនាចក្រ ដូច្នេះហើយ សាសនាចក្រដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទ ជាសាសនាចក្រ ដែលអនុវត្ត ម្តងទៀត នៅចំណោមមនុស្សលោក ដោយមានទាំងសិទ្ធិអំណាច ដើម្បីបង្រៀនដំណឹងល្អ ហើយចាត់ចែងពិធីបរិសុទ្ធទាំង ឡាយនៃសេចក្តីសង្គ្រោះ (សូមមើល កែវមុក្តាដ៏មានតម្លៃមហិមា, យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:១—៧៥, និង គ. និង ស. ២០) ។

វិវរណៈដ៏ពិសិដ្ឋទាំងឡាយនេះ ត្រូវបានទទួលមកទុកជាចម្លើយដល់ការអធិស្ឋាន ក្នុងកាលដែលត្រូវការ ហើយចេញពីស្ថានការណ៍នៃជីវិតពិត ដែលមានរួមនូវមនុស្សពិត ។ លោកព្យាការី និងសហការីទាំងឡាយរបស់លោក បានស្វែងរកការណែនាំពីព្រះ ហើយវិវរណៈទាំងឡាយនេះ បញ្ជាក់ថាពួកគេបានទទួលហើយ ។ នៅក្នុងវិវរណៈទាំងឡាយ នោះបុគ្គលឃើញថា ការសាងឡើងវិញ និងការបើកសម្តែងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ និងការនាំមកនូវគ្រាកាន់កាប់ត្រួតត្រាក្នុងកាលដែលពេញកំណត់ ។ ការដែល សាសនាចក្រធ្វើដំណើរទៅទិសខាងលិច ចេញពីរដ្ឋនូវយ៉ោក និងរដ្ឋផែនសិលវេញ៉ា ទៅរដ្ឋអូហៃអូ ទៅរដ្ឋមិសសួរី ទៅរដ្ឋ អិលលីណោយ និងនៅទីបញ្ចប់ ទៅក្រេតបេសិន (ទំនាបដ៏មហិមា) នៃប្រទេសអាមេរិកភូមិភាគខាងលិច ហើយការតស៊ូដ៏ខ្លាំងក្លា របស់ពួកបរិសុទ្ធ ក្នុងការស្វះស្វែងដើម្បីកសាងស៊ីយ៉ូននៅលើផែនដី នៅសម័យទំនើប ក៏ត្រូវបានបង្ហាញផងដែរ នៅក្នុងវិវរណៈទាំង ឡាយនេះ ។

មានកណ្ឌមុនៗភាគច្រើន មានរួមនូវរឿងអំពីការបកប្រែ និងការបោះពុម្ពព្រះគម្ពីរមរមន (សូមមើលកណ្ឌទី៣, ៥, ១០, ១៧, និង ១៩) ។ កណ្ឌក្រោយៗខ្លះ បង្ហាញនូវកិច្ចការនៃព្យាការីយ៉ូសែប ស្ម៊ីធ ក្នុងការធ្វើការបកប្រែព្រះគម្ពីរប៊ីបដ៏ប្រកបដោយការបំផុសគំនិត ក្នុងកាលនោះហើយ ដែលកណ្ឌទាំងឡាយស្តីអំពីគោលលទ្ធិដ៏មហិមាត្រូវបានទទួល (ជាឧទាហរណ៍ សូមមើលកណ្ឌទី៣៧, ៤៥, ៧៣, ៧៦, ៧៧, ៨៦, ៩១, និង ១៣២, ហើយកណ្ឌនីមួយៗនេះ មានទំនាក់ទំនងខ្លះៗ ឆ្ពោះទៅនឹងការបកប្រែព្រះគម្ពីរប៊ីប) ។

នៅក្នុងវិវរណៈទាំងឡាយ គោលលទ្ធិទាំងឡាយនៃដំណឹងល្អ ត្រូវបានចែងប្រាប់ ដោយមានការពន្យល់អំពីគ្រឹះដែលជាមូលដ្ឋានដូចជាស្ថានភាពនៃក្រុមព្រះ កំណើតនៃមនុស្ស ភាពជាក់លាក់នៃអារក្សសាតាំង គោលបំណងនៃភាពរមែងស្លាប់ ការចាំបាច់ឲ្យមាន ការគោរពតាម សេចក្តីត្រូវការឲ្យមានការប្រែចិត្ត ការប្រព្រឹត្តិនៃព្រះវិញ្ញាណបរិសុទ្ធ ពិធីបរិសុទ្ធទាំងឡាយ និងពិធីប្រព្រឹត្តទាំងឡាយ ដែលទាក់ទងទៅនឹងសេចក្តីសង្គ្រោះ វាសនានៃផែនដី លក្ខណៈអនាគតនៃមនុស្ស បន្ទាប់ពីដំណើររស់ឡើងវិញ និងសេចក្តីជំនុំជំរះ ភាពអស់កល្បជានិច្ចនៃទំនាក់ទំនងខាងអាពាហ៍ពិពាហ៍ ហើយនិងស្ថានភាពនៃគ្រួសារដ៏នៅអស់កល្បជានិច្ច ។ ដូចគ្នានេះដែរ ការបើកសំដែងបន្តិចម្តងៗ ប្រាប់អំពីរចនាសម្ព័ន្ធនៃសាសនាចក្រខាងការចាត់ចែង គឺត្រូវបានបង្ហាញដោយការហៅប៊ីស្សពទាំងឡាយ គណៈប្រធានទីមួយ ក្រុម១២នាក់ និងក្រុម៧០នាក់ ហើយនិងការតាំងឡើងនូវតំណែង និងក្រុមត្រួតពិនិត្យទាំងឡាយផ្សេងៗទៀត ។ នៅទីបញ្ចប់ ទីបន្ទាល់ដែលបានថ្លែងប្រាប់អំពីព្រះយេស៊ូវគ្រីស្ទ— ទេវភាពរបស់ទ្រង់ ឫទ្ធានុភាពរបស់ទ្រង់ ភាពល្អឥតខ្ចោះរបស់ទ្រង់ សេចក្តីស្រឡាញ់របស់ទ្រង់ និងព្រះចេស្តាដ៏ប្រកបដោយសេចក្តីប្រោសលោះរបស់ទ្រង់— ធ្វើឲ្យគម្ពីរនេះមានតម្លៃដ៏ធំ ចំពោះគ្រួសារ មនុស្សលោក ហើយធ្វើឲ្យមានតម្លៃជាងទ្រព្យសម្បត្តិទាំងឡាយនៃផែនដីទាំងមូល ។

មានវិវរណៈខ្លះបានបោះពុម្ពនៅទីក្រុងស៊ីយ៉ូន (ក្រុងអ៊ិនឌីប៉ែនដែន្ស) រដ្ឋមិសសួរី នៅឆ្នាំ១៨៣៣ នៅក្រោមចំណងជើងថា *A Book of Commandments for the Government of the Church of Christ* (ព្រះគម្ពីរនៃព្រះបញ្ញត្តិសំរាប់ការ គ្រប់គ្រងសាសនាចក្រនៃព្រះគ្រីស្ទ) ។ ស្តីអំពីការបោះពុម្ពនេះ នោះពួកអែលឌើរទាំងឡាយនៃសាសនាចក្របានថ្លែងទីបន្ទាល់យ៉ាង មុឺងម៉ាត់ថា ព្រះអម្ចាស់ទ្រង់បានធ្វើទីបន្ទាល់ដល់ដួងព្រលឹងរបស់ពួកគេថា វិវរណៈទាំងឡាយនេះគឺពិតជាត្រឹមត្រូវ ។ នៅពេលព្រះ អម្ចាស់ទ្រង់នៅតែបន្តទាក់ទងជាមួយនឹងពួកអ្នកបំរើទាំងឡាយរបស់ទ្រង់ នោះពីរឆ្នាំក្រោយមក ការប្រជុំ

ដ៏ធំជាងនេះ ត្រូវបានបោះពុម្ព នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ដោយមានចំណងជើងថា *Doctrine and Covenants of the Church of the Latter Day Saints* (គោលលទ្ធិ និងសេចក្ដីសញ្ញា នៃសាសនាចក្រនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ) ។ ចំពោះការបោះពុម្ពនេះ ក្នុងឆ្នាំ ១៨៣៥ បានភ្ជាប់ឯកសារដែលមានទីបន្ទាល់របស់ពួកសាវក១២នាក់ ដែលមានដូចតទៅនេះ ៖

ទី បន្ទាល់នៃ
ពួកសាវក១២នាក់ ចំពោះសេចក្ដីពិតនៃ
ព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា

*ទីបន្ទាល់នៃពួកសាក្សី ចំពោះព្រះគម្ពីរនៃព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ គឺជាព្រះបញ្ញត្តិទាំងឡាយ ដែលទ្រង់បាន ប្រទានដល់សាសនាចក្ររបស់ទ្រង់ តាមរយៈ យ៉ូសែប ស៊្មីធ ជុញ៉រ ជាអ្នកដែលត្រូវបានតែងតាំង ដោយសម្លេងនៃសាសនាចក្រសំរាប់គោលបំណងនេះ ៖*

ដូច្នេះ យើងយល់ព្រមនឹងធ្វើទីបន្ទាល់ដល់អស់ទាំងពិភពលោកនៃមនុស្សជាតិ ដល់សត្វលោកគ្រប់រូប នៅលើផ្ទៃផែនដី ថាព្រះអម្ចាស់ទ្រង់បានធ្វើទីបន្ទាល់ដល់ដួងព្រលឹងរបស់យើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតមកលើយើង ថាព្រះ បញ្ញត្តិទាំងឡាយនេះ ត្រូវបានប្រទានមក ដោយសារការបំផុសគំនិតពីព្រះ ហើយទុកជាប្រយោជន៍សំរាប់មនុស្សលោកទាំងអស់ ហើយជាពិតប្រាកដមែន ។

យើងថ្លែងទីបន្ទាល់នេះ ប្រាប់ដល់ពិភពលោក ដោយមានព្រះអម្ចាស់ជាអ្នកជំនួយរបស់យើង; ហើយដោយសារព្រះគុណនៃព្រះដ៏ជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ នោះយើងត្រូវបានអនុញ្ញាតឲ្យមានឯកសិទ្ធិនេះ ដើម្បីធ្វើទីបន្ទាល់នេះដល់ពិភពលោក នៅក្នុងការណ៍នេះ យើងមានចិត្តត្រេកអរជាអនេក ដោយបួងសួងដល់ព្រះអម្ចាស់ជានិច្ច សូមឲ្យកូនចៅមនុស្សអាចបានប្រយោជន៍ ដោយសារទីបន្ទាល់នេះ ។

ឈ្មោះនៃពួក១២នាក់គឺ៖

| | | |
|---|---|---|
| ថូម៉ាស ប៊ី ម៉ាស | អូរសុន ហៃឌ | វិលលាម ស្ម៊ីធ |
| ដាវីឌ ដ័បបុលយូ ប៉ាទិន | វិលលាម អ៊ី ម៉ុកឡេលិន | អូរសុន ប្រាត្ត |
| ព្រិកហាំ យ៉ង់ | ប៉ាលី ភី ប្រាត្ត | យ៉ូហាន អែព បោញគុន |
| ហ៊ីប៊ឺរ ស៊ី គិមបុល | លូកា អែស ចនសុន | ឡៃម៉ាន់ អ៊ី ចនសុន |

ការបោះពុម្ពនៃគោលលទ្ធិនិងសេចក្ដីសញ្ញាក្រោយៗមក វិវរណៈថែមទៀត ឬបញ្ជីរឿងផ្សេងៗទៀត ត្រូវបានបូកបញ្ចូល ក្នុងកាល បានទទួល ហើយបានទទួលស្គាល់ ដោយពួកជំនុំដែលមានសមត្ថភាព ឬដោយសន្និសីទទាំងឡាយនៃសាសនាចក្រ ។

ចាប់ផ្ដើមនឹងការបោះពុម្ពនៅឆ្នាំ១៨៣៥ នោះស៊េរីនៃមេរៀនខាងសាសនាដល់ប្រាំពីរច្បាប់ ត្រូវបានបង្រួមចូល; មេរៀនទាំងនេះមានចំណងជើងថា *Lectures on Faith* (ការបង្រៀនអំពីសេចក្ដីជំនឿ) ។ ការបង្រៀនទាំងនេះត្រូវបានរៀបចំឡើងសំរាប់យក មកប្រើប្រាស់ នៅឯសាលានៃពួកព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ពីឆ្នាំ១៨៣៤ ទៅដល់ឆ្នាំ១៨៣៥ ។ ទោះជាមានប្រយោជន៍ ដល់គោលលទ្ធិ និងការបង្គាប់ក៏ដោយ គង់តែការបង្រៀនទាំងនេះ ត្រូវបានដកចេញពីគោលលទ្ធិ និងសេចក្ដីសញ្ញាដែរ ចាប់តាំងពីការ បោះពុម្ពនៅឆ្នាំ១៩២១ម្ល៉េះ ពីព្រោះការបង្រៀនទាំងនេះ ពុំបានប្រទានឬសំដែងដល់សាសនាចក្រទាំងមូល ថាជាវិវរណៈឡើយ ។

ជាការច្បាស់លាស់ថាមានកំហុសបន្តមកខ្លះៗ នៅក្នុងការបោះពុម្ពផ្សាយចេញជាភាសាអង់គ្លេសមុនៗ ជាពិសេស នៅក្នុង

ផ្នែក ខាងប្រវត្តិនៃចំណងជើងរបស់កណ្ឌ ។ ដោយហេតុនេះ ការបោះពុម្ពលើកនេះ មានការកែថ្ងៃខែ និងឈ្មោះកន្លែងទាំងឡាយ ហើយនិង ការកែបន្តិចបន្តួចផ្សេងៗទៀត ក្នុងកាលឃើញថាសម ។ ការកែប្រែទាំងនេះត្រូវបានធ្វើឡើង ដើម្បីនាំឲ្យឯកសារទាំងឡាយសមស្រប ទៅនឹងឯកសារប្រវត្តិសាស្ត្រ ។ អ្វីៗពិសេសផ្សេងទៀតនៃការបោះពុម្ពចុងក្រោយនេះ មានរួមនូវបសិដ្ឋកម្មខាងឯកសារយោងទៅ មក ចំណងជើងនៃកណ្ឌ និងការសង្ខេបខាងកម្មវត្ថុទាំងឡាយ កិច្ចការទាំងអស់នេះត្រូវបានគ្រោងឡើង ដើម្បីជួយពួកអ្នកអានឲ្យយល់ ហើយគ្រេកអរ ចំពោះសារពីព្រះអម្ចាស់ ដូចដែលបានប្រទានមក ក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ។

បុព្វកថាដល់កណ្ឌទាំងឡាយ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា មាននូវឯកសារយោងដល់ *History of the Church* (ប្រវត្តិនៃសាសនាចក្រ) ។ *History of the Church* គឺជាសៀវភៅប្រាំពីរក្បាល ស្ដីអំពីប្រវត្តិរបស់សាសនាចក្រនៃព្រះយេស៊ូវ គ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពីឆ្នាំ១៨២០ ទៅដល់ឆ្នាំ១៨៤៨ ។ ពីព្រោះសៀវភៅទាំងនេះ ពុំទាន់បានបកប្រែ ហើយមានតែជា ភាសាអង់គ្លេសប៉ុណ្ណោះ ម្ល៉ោះហើយ បានជាប្រភពយោងដល់ប្រវត្តិនៃសាសនាចក្រ នៅក្នុងបុព្វកថាទាំងឡាយនៃការបោះពុម្ពនៃ គោលលទ្ធិ និងសេចក្ដីសញ្ញាលើកនេះ សំដៅទៅលើសៀវភៅអំពីប្រវត្តិនេះក្នុងភាសាអង់គ្លេស ។

## លំដាប់មាតិការដែលរៀងតាមកាល


| *កាល* | | *កន្លែង* | *កណ្ឌ* |
|---|---|---|---|
| ឆ្នាំ១៨២៣ | ខែកញ្ញា | ក្រុងម៉ែនផែសស្តើរ រដ្ឋនូវយ៉ោក | ២ |
| ឆ្នាំ១៨២៨ | ខែកក្កដា | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ៣ |
| | រដូវក្តៅ | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ១០ |
| ឆ្នាំ១៨២៩ | ខែកម្ភៈ | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ៤ |
| | ខែមីនា | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ៥ |
| | ខែមេសា | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ៦, ៧, ៨, ៩ |
| | ខែឧសភា | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ១១, ១២, ១៣ |
| | ខែមិថុនា | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ១៤, ១៥, ១៦, ១៧, ១៨ |
| ឆ្នាំ១៨៣០ | ខែមីនា | ក្រុងម៉ែនផែសស្តើរ រដ្ឋនូវយ៉ោក | ១៩ |
| | ខែមេសា | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ២០*, ២១ |
| | ខែមេសា | ក្រុងម៉ែនផែសស្តើរ រដ្ឋនូវយ៉ោក | ២២, ២៣ |
| | ខែកក្កដា | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ២៤, ២៥, ២៦ |
| | ខែសីហា | ភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា | ២៧ |
| | ខែកញ្ញា | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ២៨, ២៩, ៣០, ៣១ |
| | ខែតុលា | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ៣២*, ៣៣ |
| | ខែវិច្ឆិកា | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ៣៤ |
| | ខែធ្នូ | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ៣៥, ៣៦, ៣៧ |
| ឆ្នាំ១៨៣១ | ខែម៉ករា | ភូមិហ្វាយែត រដ្ឋនូវយ៉ោក | ៣៨, ៣៩, ៤០ |
| | ខែកម្ភៈ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៤១, ៤២, ៤៣, ៤៤ |
| | ខែមីនា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៤៥, ៤៦, ៤៧, ៤៨, ៤៩ |
| | ខែឧសភា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៥០ |
| | ខែឧសភា | ភូមិថមសុន រដ្ឋអូហៃអូ | ៥១ |
| | ខែមិថុនា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៥២, ៥៣, ៥៤, ៥៥, ៥៦ |
| | ខែកក្កដា | ក្រុងស៊ីយ៉ូន ឃុំចាកសុន រដ្ឋមិស៊ីស៊ិបពី | ៥៧ |
| | ខែសីហា | ក្រុងស៊ីយ៉ូន ឃុំចាកសុន រដ្ឋមិស៊ីស៊ិបពី | ៥៨, ៥៩, ៦០ |
| | ខែសីហា | នៅក្បែរទន្លេមិសសួរី រដ្ឋមិសសួរី | ៦១, ៦២ |
| | ខែសីហា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៦៣ |
| | ខែកញ្ញា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៦៤ |
| | ខែតុលា | ភូមិហៃរ៉ាំ រដ្ឋអូហៃអូ | ៦៥ |
| | ខែតុលា | ភូមិអូវេញ រដ្ឋអូហៃអូ | ៦៦ |
| | ខែវិច្ឆិកា | ភូមិហៃរ៉ាំ រដ្ឋអូហៃអូ | ១, ៦៧, ៦៨, ៦៩, ១៣៣ |
| | ខែវិច្ឆិកា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៧០ |
| | ខែធ្នូ | ភូមិហៃរ៉ាំ រដ្ឋអូហៃអូ | ៧១ |
| | ខែធ្នូ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៧២ |
| ឆ្នាំ១៨៣២ | ខែម៉ករា | ភូមិហៃរ៉ាំ រដ្ឋអូហៃអូ | ៧៣, ៧៤ |
| | ខែមករា | ភូមិអាមហើស្ត រដ្ឋអូហៃអូ | ៧៥ |
| | ខែកុម្ភៈ | ភូមិហៃរ៉ាំ រដ្ឋអូហៃអូ | ៧៦ |
| | ខែមីនា | ភូមិហៃរ៉ាំ រដ្ឋអូហៃអូ | ៧៧, ៧៨, ៧៩, ៨០, ៨១ |
| | ខែមេសា | ឃុំចាកសុន រដ្ឋមិសសួរី | ៨២, ៨៣ |
| | ខែមេសា | ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី | ៨៣ |


* នៅចំ ឬនៅជិតកន្លែងដែលបានប្រាប់

| *កាល* | | *កន្លែង* | *កណ្ឌ* |
|---|---|---|---|
| | ខែសីហា | ភូមិហៃរាំ រដ្ឋអូហៃអូ | ៩៩ |
| | ខែកញ្ញា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៨៤ |
| | ខែវិច្ឆិកា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៨៥ |
| | ខែធ្នូ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៨៦, ៨៧*, ៨៨ |
| ឆ្នាំ១៨៣៣ | ខែកុម្ភៈ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៨៩ |
| | ខែមីនា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៩០, ៩១, ៩២ |
| | ខែឧសភា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៩៣, ៩៤ |
| | ខែមិថុនា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៩៥, ៩៦ |
| | ខែសីហា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ៩៧, ៩៨ |
| | ខែតុលា | ភូមិផើរស្បឺក រដ្ឋនូវយ៉ោក | ១០០ |
| | ខែធ្នូ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០១ |
| ឆ្នាំ១៨៣៤ | ខែកុម្ភៈ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០២, ១០៣ |
| | ខែមេសា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០៤* |
| | ខែមិថុនា | ភូមិទន្លេហ្វីស៊ីង រដ្ឋមិសសួរី | ១០៥ |
| | ខែវិច្ឆិកា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០៦ |
| ឆ្នាំ១៨៣៥ | ខែមីនា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០៧ |
| | ខែសីហា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១៣៤ |
| | ខែធ្នូ | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០៨ |
| ឆ្នាំ១៨៣៦ | ខែមករា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១៣៧ |
| | ខែមីនា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១០៩ |
| | ខែមេសា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១១០ |
| | ខែសីហា | ក្រុងសាឡិម រដ្ឋម៉ាស្សាជូសសេីស | ១១១ |
| ឆ្នាំ១៨៣៧ | ខែកក្កដា | ក្រុងខឺតឡង់ រដ្ឋអូហៃអូ | ១១២ |
| ឆ្នាំ១៨៣៨ | ខែមីនា | ភូមិហ្វាវេសត៍ រដ្ឋមិសសួរី | ១១៣* |
| | ខែមេសា | ភូមិហ្វាវេសត៍ រដ្ឋមិសសួរី | ១១៤, ១១៥ |
| | ខែឧសភា | ភូមិស្ព្រីងហៀល ឃុំដាវីស៍ រដ្ឋមិសសួរី | ១១៦ |
| | ខែកក្កដា | ភូមិហ្វាវេសត៍ រដ្ឋមិសសួរី | ១១៧, ១១៨, ១១៩, ១២០ |
| ឆ្នាំ១៨៣៩ | ខែមីនា | គុកលិបើទី ឃុំឃ្លេ រដ្ឋមិសសួរី | ១២១, ១២២, ១២៣ |
| ឆ្នាំ១៨៤១ | ខែមករា | ក្រុងណេវូ រដ្ឋអិលលីណោយ | ១២៤ |
| | ខែមីនា | ក្រុងណេវូ រដ្ឋអិលលីណោយ | ១២៥ |
| | ខែកក្កដា | ក្រុងណេវូ រដ្ឋអិលលីណោយ | ១២៦ |
| ឆ្នាំ១៨៤២ | ខែកញ្ញា | ក្រុងណេវូ រដ្ឋអិលលីណោយ | ១២៧, ១២៨ |
| ឆ្នាំ១៨៤៣ | ខែកុម្ភៈ | ក្រុងណេវូ រដ្ឋអិលលីណោយ | ១២៩ |
| | ខែមេសា | ភូមិរ៉ាមូស រដ្ឋអិលលីណោយ | ១៣០ |
| | ខែឧសភា | ភូមិរ៉ាមូស រដ្ឋអិលលីណោយ | ១៣១ |
| | ខែកក្កដា | ក្រុងណេវូ រដ្ឋអិលលីណោយ | ១៣២ |
| ឆ្នាំ១៨៤៤ | ខែមិថុនា | ក្រុងណេវូ រដ្ឋអិលលីណោយ | ១៣៥ |
| ឆ្នាំ១៨៤៧ | ខែមករា | ភូមិវិនទើរខ្វធើរ (ឥឡូវនៅរដ្ឋណែប្រាស្កា) | ១៣៦ |
| ឆ្នាំ១៨៩០ | ខែតុលា | ទីក្រុងសលត៍លេក រដ្ឋយូថាហ៍ | សេចក្ដីប្រកាសជាផ្លូវការ — ទី១ |
| ឆ្នាំ១៩១៨ | ខែតុលា | ទីក្រុងសលត៍លេក រដ្ឋយូថាហ៍ | ១៣៨ |
| ឆ្នាំ១៩៧៨ | ខែមិថុនា | ទីក្រុងសលត៍លេក រដ្ឋយូថាហ៍ | សេចក្ដីប្រកាសជាផ្លូវការ — ទី២ |


* នៅចំ ឬនៅជិតកន្លែងដែលបានប្រាប់

# គោលលទ្ធិនិងសេចក្ដីសញ្ញា

## កណ្ឌទី១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី នៅឯសន្និសីទពិសេសមួយ សំរាប់ពួកអែលឌើរនៃសាសនាចក្រ ដែលបានធ្វើឡើងនៅក្រុងហៃរ៉ាំ រដ្ឋអូហៃអូ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៨៣១ (*History of the Church*, ១:២២១–២២៤ [ប្រវត្តិនៃសាសនាចក្រ]) មានវិវរណៈជាច្រើនដែលបានទទួលមកពីព្រះអម្ចាស់ មុនពេលនេះ ហើយការប្រមូលវិវរណៈទាំងនេះសំរាប់យកមកបោះពុម្ពផ្សាយចេញជាសៀវភៅ នោះគឺជាកម្មវត្ថុដ៏សំខាន់បំផុតមួយ ដែលបានអនុម័តនៅឯសន្និសីទ ។ កណ្ឌនេះជាអារម្ភកថារបស់ព្រះអម្ចាស់ ចំពោះគោលលទ្ធិ សេចក្ដីសញ្ញា និងព្រះបញ្ញត្តិទាំងឡាយ ដែលបានប្រទានឲ្យមក នៅការកាន់កាប់ត្រួតត្រាសម័យនេះ ។*

*១–៧, សម្លេងនៃការព្រមានគឺត្រូវប្រាប់ដល់មនុស្សទាំងអស់; ៨–១៦, ការក្បត់សាសនា និងអំពើទុច្ចរិតកើតមានឡើងមុនការយាងមក លើកទី២; ១៧–២៣, យ៉ូសែបស្ម៊ីធត្រូវបានហៅឲ្យសាងសេចក្ដីពិត និងព្រះចេស្ដារបស់ព្រះអម្ចាស់ មកលើផែនដីវិញ; ២៤–៣៣, ព្រះគម្ពីរមរមន ត្រូវបានបញ្ចេញមក ហើយសាសនាចក្រដ៏ពិតត្រូវបានតាំងឡើង; ៣៤–៣៦, សេចក្ដីសុខសាន្តនឹងត្រូវបាត់បង់ពីផែនដី; ៣៧–៣៩, ចូរស្ទង់មើលព្រះបញ្ញត្តិទាំងនេះចុះ ។*

ប្រុងប្រយ័ត្ន — **ប**ប្រុង ស្ដាប់ចុះ ឱប្រជារាស្ត្រនៃ [ក]សាសនាចក្រយើងអើយ សម្លេងនៃព្រះដែលគង់នៅលើ ហើយដែលមាន [ខ]ព្រះនេត្រទតមកលើមនុស្ស ទាំងអស់ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ប្រាកដមែន យើងប្រាប់ជាប្រាកដថា៖ ចូរប្រុង [គ]ស្ដាប់ចុះ ឱប្រជាជាតិទាំងប៉ុន្មានដែលនៅឆ្ងាយ អើយ និងអ្នករាល់គ្នា ដែលនៅលើកោះក្នុងសមុទ្រអើយ ចូរស្ដាប់ព្រមគ្នាចុះ ។

២ ត្បិត [ក]សម្លេង[ខ]នៃព្រះអម្ចាស់ប្រាកដជាប្រាប់ដល់មនុស្សទាំងអស់មែន ហើយគ្មាននរណានឹង គេចបានឡើយ ហើយគ្មានភ្នែកណា ដែលនឹងមិនបានឃើញ ឬគ្មាន ត្រចៀកណាដែលនឹងមិនបានឮ ឬគ្មាន [គ]ដួងចិត្តណាដែលនឹងមិនធ្លុះបានឡើយ ។

៣ ហើយ [ក]ពួកអ្នកបះបោរនឹងត្រូវចាក់ទំលុះ ដោយសេចក្ដីទុក្ខសោកដ៏រីងរៃ រីឯសេចក្ដីទុច្ចរិតរបស់ពួកគេនឹងត្រូវ [ខ]ថ្លែងប្រាប់ពីលើដំបូលផ្ទះ ហើយអំពើស្ងាត់កំបាំងរបស់ពួកគេ នឹងត្រូវបើកសំដែងមកឲ្យឃើញ ។

៤ ហើយ [ក]សម្លេងនការព្រមាន នឹងត្រូវប្រាប់ដល់មនុស្សទាំងអស់ ដោយមាត់នៃពួកសិស្សទាំងឡាយរបស់យើង ដែលយើងបានរើស នៅ[ខ]គ្រា ចុងក្រោយបង្អស់នះ ។

៥ ហើយពួកគេនឹង ចេញទៅ ហើយគ្មាននរណានឹងបញ្ឈប់ពួកគេបានឡើយ ត្បិតយើង ជាព្រះអម្ចាស់ បានបញ្ជាពួកគេហើយ ។

៦ មើលចុះ នេះជា [ក]សិទ្ធិអំណាច របស់យើង ហើយជាសិទ្ធិអំណាចនៃពួកអ្នកបំរើរបស់យើង ហើយជាអារម្ភកថារបស់យើងចំពោះព្រះគម្ពីរនៃ ព្រះបញ្ញត្តិទាំងឡាយរបស់យើង ដែលយើងបានប្រទានឲ្យពួកគេ យកទៅ [ខ]បោះពុម្ពផ្សាយដល់អ្នករាល់គ្នា ឱបណ្ដាជននៅលើ ផែនដីអើយ ។

៧ ហេតុដូច្នេះហើយ ចូរ [ក]ខ្លាចហើយ ញ័រចុះ ឱប្រជារាស្ត្រអើយ ត្បិតយើង ជាព្រះអម្ចាស់ បានចេញក្រឹត្យដែលនៅក្នុងព្រះបញ្ញត្តិទាំង ប៉ុន្មាននោះ នឹងត្រូវ [ខ]បានសំរេច ។

៨ ហើយយើងប្រាប់ដល់អ្នករាល់គ្នាជាប្រាកដថា ពួក

---

១ ១*ក* ៣ នីហ្វៃ ២៧:៣;
គ. និង ស. ២០:១.
ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* គ. និង ស. ៣៨:៧–៨.
ស.ប. ព្រះ, ក្រុមព្រះ.
*គ* ចោទិ. ៣២:១.
២ *ក* គ. និង ស. ១៣៣:១៦.
*ខ* ភីលីព ២:៩–១១.
*គ* ស.ប. ចិត្ត.
៣ *ក* ស.ប. ការបះបោរ.
*ខ* លូកា ៨:១៧; ១២:៣;
២ នីហ្វៃ ២៧:១១; មរមន ៥:៨.
៤ *ក* អេសេ. ៣:១៧–២១;
គ. និង ស. ៦៣:៣៧.
ស.ប. កិច្ចការផ្សាយសាសនា; ព្រមាន, ពាក្យព្រមាន.
*ខ* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
៦ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិទ្ធិអំណាច.
*ខ* គ. និង ស. ៧២:២១.
៧ *ក* ចោទិ. ៥:២៩; សាស្ដា ១២:១៣.
*ខ* គ. និង ស. ១:៣៨.

គេដែលចេញទៅ ដោយនាំយកដំណឹងទាំងនេះ ទៅប្រាប់
បណ្ដាជននៅលើផែនដី ចំពោះពួកគេនេះហើយ ដែលបានទទួល
អំណាច ដើម្បី [ក]ភ្ជាប់ពួកអ្នកដែលមិនជឿ [ខ]និងពួកអ្នកដែល
បះបោរនៅលើផែនដី ព្រមទាំងនៅ លើស្ថានសួគ៌ផង;
៩ មែនហើយ ប្រាកដមែន គឺដើម្បីភ្ជាប់ពួកគេទុកចាំ ថ្ងៃណា
មួយ ក្នុងកាល [ក]សេចក្ដីក្រោធនៃព្រះអម្ចាស់នឹងចាក់មកលើ [ខ]ពួក
ទុច្ចរិត ដោយ គ្មានកំរិតឡើយ —
១០ ដល់ [ក]ថ្ងៃដែលព្រះអម្ចាស់ ទ្រង់នឹងយាងមក ដើម្បី [ខ]សង
ដល់មនុស្សរាល់គ្នា តាម [គ]កិច្ចការរបស់ខ្លួន ហើយ [ឃ]វាល់ដល់
មនុស្ស រាល់គ្នា តាមរង្វាល់ ដែលខ្លួនបានវាល់ឲ្យមនុស្ស
ទូទៅទាំងឡាយ ។
១១ ហេតុដូច្នេះហើយ សម្លេងនៃព្រះអម្ចាស់ គឺដល់
អស់ចុងផែនដី ដើម្បីឲ្យមនុស្សទាំងអស់ណាដែលនឹងឮ ចូរឮចុះ ៖
១២ ចូររៀបចំ ចូររៀបចំសំរាប់អ្វីដែលនឹងមកដល់ចុះ ត្បិត
ព្រះអម្ចាស់នៅ ជិតបង្កើយ;
១៣ ហើយ [ក]សេចក្ដីក្រោធនៃព្រះអម្ចាស់បានឆួលឡើង ហើយ
[ខ]ដាវរបស់ទ្រង់បានលាងសំអាតនៅលើស្ថានសួគ៌ហើយ ហើយ
នឹងធ្លាក់មក លើបណ្ដាជនទាំងឡាយនៅលើផែនដី ។
១៤ ហើយ [ក]ព្រះពាហុនៃព្រះអម្ចាស់នឹងបានសំដែងឲ្យឃើញ
ហើយ ថ្ងៃនោះនឹងមកដល់ កាលពួកគេនឹងលែង [ខ]ឮសម្លេងនៃព្រះ
អម្ចាស់ ឬ សម្លេងនៃ ពួកអ្នកបំរើរបស់ទ្រង់ ឬមិន [គ]ស្ដាប់តាម
ពាក្យសំដីនៃពួកព្យាការី និង ពួកសាវកឡើយ នោះនឹង ត្រូវ
[ឃ]កាត់ចេញពីចំណោម ប្រជាជន;
១៥ ត្បិតពួកគេ បាន[ក]វង្វេងចេញពី [ខ]ក្រិត្យក្រមរបស់យើង ហើយ
បាន [គ]បំបាក់សេចក្ដីសញ្ញារបស់យើងដែលនៅ [ឃ]អស់កល្បជានិច្ច;
១៦ ពួកគេពុំ [ក]ស្វែងរកព្រះអម្ចាស់ ដើម្បីតាំងសេចក្ដីសុចរិត
របស់ទ្រង់ឡើយ ប៉ុន្តែមនុស្សគ្រប់រូប ដើរតាម [ខ]ផ្លូវរបស់ ខ្លួនគេ
[គ]ផ្ទាល់ ហើយតាមរូបភាពនៃព្រះរបស់ខ្លួនគេផ្ទាល់ ដែលមាន
រូបភាពដូចជារូបរាងនៃលោកិយ ហើយ[ឃ]សារជាតិដូចជារូបព្រះ
ដែលនឹងទៅ ជា [ង]ចាស់ហើយនឹងវិនាសនៅ[ច]ក្រុងបាប៊ីឡូន គឺជា
ក្រុងបាប៊ីឡូនដ៏ធំ ដែលនឹងរលំនោះ ។
១៧ ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ ដោយជ្រាបនូវ
គ្រោះដែលនឹងមានមកលើ [ក]បណ្ដាជនទាំងឡាយនៅលើផែនដី
នោះបាន ហៅយ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជា អ្នកបំរើរបស់យើង ហើយ
បាននិយាយមកកាន់លោកពីលើស្ថានសួគ៌ ហើយបានប្រទានព្រះ
បញ្ញត្តិ ទាំងឡាយ ដល់លោក;
១៨ ហើយក៏បានប្រទានបញ្ញត្តិទាំងឡាយ ដល់អ្នកដទៃផងដែរ
ថាពួកគេគួរប្រកាសប្រាប់ការណ៍ទាំងនេះដល់ពិភពលោក ហើយ
ការណ៍អស់ទាំងនេះ គឺដើម្បីឲ្យបានសំរេច តាមអ្វីៗដែលបាន
ចែងទុកដោយពួកព្យាការី —
១៩ ពួក[ក]កំសោយនៅពិភពលោកនឹងចេញមក ហើយទំលាក់
ពួកខ្លាំងពូកែចុះ ដើម្បីកុំឲ្យមនុស្ស គួរទូន្មានមនុស្សទូទៅ ឬក៏
ទុកចិត្តទៅ លើ ដៃនៃមនុស្សឡើយ —
២០ ប៉ុន្តែដើម្បីឲ្យមនុស្សគ្រប់រូបអាច [ក]និយាយ ដោយនូវព្រះ
នាមនៃព្រះ ដ៏ជាព្រះអម្ចាស់ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក;
២១ ដើម្បីឲ្យសេចក្ដីជំនឿអាចបានកើនឡើងនៅលើផែនដីផងដែរ;

៨ *ក* ស.ប. ភ្ជាប់, ការភ្ជាប់.
*ខ* ស.ប. ការបះបោរ.
៩ *ក* វិវរ. ១៩:១៥–១៦;
១ នីហ្វៃ ២២:១៦–១៧.
*ខ* ម៉ូសាយ ១៦:២;
យ.ស. — ម៉ាថាយ ១:៣១, ៥៥.
១០ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.
*ខ* អេសេ. ៧:៤; គ. និង ស. ៥៦:១៩.
ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ចៅក្រម.
*គ* សុភា. ២៤:១២;
អាលម៉ា ៩:២៨; ៤១:២–៥;
គ. និង ស. ៦:៣៣.
*ឃ* ម៉ាថាយ ៧:២.
១៣ *ក* គ. និង ស. ៦៣:៦.
*ខ* អេសេ. ២១:៣;
គ. និង ស. ៣៥:១៤.
១៤ *ក* អេសាយ ៥៣:១.
*ខ* ២ នីហ្វៃ ៩:៣១;
ម៉ូសាយ ២៦:២៨.
*គ* គ. និង ស. ១១:២.
*ឃ* កិច្ចការ ៣:២៣;
អាលម៉ា ៥០:២០;
គ. និង ស. ៥០:៨; ៥៦:៣.
១៥ *ក* យ៉ូស្វេ ២៣:១៦;
អេសាយ ២៤:៥.
*ខ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*គ* ស.ប. សេចក្ដីក្បត់សាសនា.
*ឃ* ស.ប. សេចក្ដីសញ្ញាថ្មី
ហើយអស់កល្បជានិច្ច.
១៦ *ក* ម៉ាថាយ ៦:៣៣.
*ខ* អេសាយ ៥៣:៦.
*គ* គ. និង ស. ៨២:៦.
*ឃ* និក្ខ. ២០:៤; ៣ នីហ្វៃ ២១:១៧.
ស.ប. ការថ្វាយបង្គំរូបព្រះ.
*ង* អេសាយ ៥០:៩.
*ច* គ. និង ស. ៦៤:២៤; ១៣៣:១៤.
ស.ប. បាបិល, បាប៊ីឡូន;
សេចក្ដីប្រកបដោយលោកិយ.
១៧ *ក* អេសាយ ២៤:១–៦.
១៩ *ក* កិច្ចការ ៤:១៣; ១ កូរិន. ១:២៧;
គ. និង ស. ៣៥:១៣;
១៣៣:៥៨–៥៩.
ស.ប. ស្លូតបូត, ភាពស្លូតបូត.
*ខ* ២ នីហ្វៃ ២៨:៣១.
ស.ប. ទុកចិត្ត.
២០ *ក* ស.ប. ធ្វើបន្ទាល់.

២២ ដើម្បីឲ្យ [ក]សេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចរបស់យើងអាចបានតាំងឡើង;

២៣ ដើម្បីឲ្យ ភាពពោរពេញនៃ [ក]ដំណឹងល្អរបស់យើង អាច[ខ]បានប្រកាសប្រាប់ ដោយ [គ]ពួកកំសោយ និងពួករាបទាប ដល់អស់ចុងផែនដី និងនៅចំពោះពួកមហាក្សត្រនិង ពួកអ្នកត្រួតត្រាទាំងឡាយ ។

២៤ មើលចុះ យើងជាព្រះ ហើយបានមានបន្ទូលថាដូច្នោះ [ក]ព្រះបញ្ញត្តិទាំងប៉ុន្មាននេះសុទ្ធតែមកពីយើង ហើយត្រូវបានប្រទានដល់ពួកអ្នកបំរើរបស់យើង ដោយនូវភាពទន់ខ្សោយរបស់ពួកគេស្របតាម [ខ]ភាសារបស់ពួកគេ ដើម្បីឲ្យពួកគេអាច[គ]យល់ ។

២៥ ហើយដរាបណាពួកគេ ធ្វើខុសនោះអាចធ្វើឲ្យបានដឹង;

២៦ ហើយដរាបណាពួកគេស្វែងរក [ក]ប្រាជ្ញានោះពួកគេអាចបានទទួល ការបង្គាប់;

២៧ ហើយដរាបណាពួកគេធ្វើបាប នោះពួកគេអាចបានទទួល [ក]ការវាយផ្ចាលដើម្បីឲ្យពួកគេអាច បាន[ខ]ប្រែចិត្ត;

២៨ ហើយដរាបណាពួកគេ [ក]បន្ទាបខ្លួននោះពួកគេអាចបានធ្វើឲ្យជាខ្លាំង ហើយបានព្រះពរមកពីស្ថានខ្ពស់ ហើយបានទទួល [ខ]ចំណេះវិជ្ជា តាមកាលវេលា ។

២៩ ហើយបន្ទាប់ពីបានទទួលបញ្ជីប្រវត្តិ នៃពួកសាសន៍នីហ្វៃ ហើយ មែនហើយ គឺដើម្បីឲ្យយ៉ូសែបស្ម៊ីធ ជាអ្នកបំរើរបស់យើងអាចមាន អំណាចដើម្បីបកប្រែ [ក]ព្រះគម្ពីរមរមនតាមរយៈ សេចក្ដីមេត្តាករុណានៃព្រះ គឺដោយព្រះចេស្ដានៃព្រះ ។

៣០ ហើយដើម្បីឲ្យអស់អ្នកណាដែលបានទទួលព្រះបញ្ញត្តិទាំងឡាយ អាចមាន [ក]អំណាចដើម្បីកសាងគ្រឹះនៃ [ខ]សាសនាចក្រនេះហើយដើម្បីនាំសាសនាចក្រចេញពីទីអាប់អួរនិងពីទីនៃ [គ]សេចក្ដីងងឹត គឺជា[ឃ]សាសនាចក្រតែមួយដែលពិតហើយសកម្មនៅលើផ្ទៃផែនដី ទាំងមូល ដែលយើងជាព្រះអម្ចាស់ [ង]សព្វព្រះហឫទ័យណាស់ ដោយនិយាយដល់សាសនាចក្រទាំងស្រុង ហើយមិនមែននីមួយៗទេ —

៣១ ត្បិតយើងជាព្រះអម្ចាស់ ពុំអាចទតមើល[ក]អំពើបាប សូម្បីតែបន្តិចបន្តួចបានឡើយ;

៣២ ប៉ុន្តែអ្នកណាដែលប្រែចិត្ត ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះនឹងបាន[ក]អត់ទោស;

៣៣ ហើយអ្នកណាដែលមិន[ក]ប្រែចិត្ត នោះនឹងបាន[ខ]យកពីអ្នកនោះវិញ សូម្បីតែពន្លឺដែលគេបានទទួលក្ដី ត្បិត[គ]វិញ្ញាណរបស់យើងនឹង [ឃ]ពុំតស៊ូគង់នៅជាមួយនឹងមនុស្សជានិច្ចទេ ព្រះអម្ចាស់នៃពួកពលបរិវារមានព្រះបន្ទូលថាដូច្នោះ ។

៣៤ ហើយជាថ្មីទៀត ឱបណ្ដាជនទាំងឡាយនៅលើផែនដីអើយ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា៖ យើងជាព្រះអម្ចាស់ ព្រមធ្វើ ឲ្យការណ៍ទាំងនេះ ឲ្យបានដឹងដល់[ក]មនុស្សទាំងអស់;

៣៥ ត្បិតយើងមិន[ក]រើសមុខជនណាទេ ហើយមានបំណងចង់ឲ្យមនុស្សទាំងអស់ដឹងថា [ខ]ថ្ងៃនោះនឹងមកជាឆាប់ៗ ម៉ោងមិនទាន់ដល់ទេ ប៉ុន្តែនៅជិតដែលបង្កើយ កាល[គ]សេចក្ដីសុខសាន្តនឹងត្រូវ

២២ *ក* គ. និង ស. ៣៩:១១.
ស.ប. សេចក្ដីសញ្ញា;
សេចក្ដីសញ្ញាថ្មី
ហើយអស់កល្បជានិច្ច.
២៣ *ក* ស.ប. ដំណឹងល្អ.
*ខ* ស.ប. កិច្ចការផ្សាយសាសនា.
*គ* ១ កូរិន. ១:២៦–២៩.
២៤ *ក* ២ នីហ្វៃ ៣៣:១០–១១;
ម៉ូរ៉ូណៃ ១០:២៧–២៨.
*ខ* ២ នីហ្វៃ ៣១:៣;
អេធើរ ១២:៣៩.
*គ* គ. និង ស. ៥០:១២.
ស.ប. យោបល់.
២៦ *ក* យ៉ាកុប (ព.ស.ថ.) ១:៥;
គ. និង ស. ៤២:៦៨.
ស.ប. ប្រាជ្ញា.
២៧ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
២៨ *ក* ស.ប. បន្ទាបខ្លួន,
ចិត្តសុភាពរាបសា.
*ខ* ស.ប. ដឹងរ.
២៩ *ក* ស.ប. ព្រះគម្ពីរមរមន.
៣០ *ក* គ. និង ស. ១:៤–៥, ១៧–១៨.
*ខ* ស.ប. សាសនាចក្រនៃព្រះ
យេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ
ថ្ងៃចុងក្រោយ;
ការសាងឡើងវិញនៃដំណឹងល្អ.
*គ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
*ឃ* អេភេ. ៤:៥, ១១–១៤.
ស.ប. សាសនាចក្រពិត,
ទីសំគាល់នៃ.
*ង* គ. និង ស. ៣៨:១០.
៣១ *ក* អាលម៉ា ៤៥:១៦;
គ. និង ស. ២៤:២.
ស.ប. អំពើបាប.
៣២ *ក* គ. និង ស. ៥៨:៤២–៤៣.
ស.ប. អត់ទោស, អភ័យទោស.
៣៣ *ក* ម៉ូសាយ ២៦:៣២.
*ខ* អាលម៉ា ២៤:៣០;
គ. និង ស. ៦០:២–៣.
*គ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ឃ* លោកុ. ៦:៣; ២ នីហ្វៃ ២៦:១១;
មរមន ៥:១៦; អេធើរ ២:១៥;
ម៉ូរ៉ូណៃ ៩:៤.
៣៤ *ក* ម៉ាថាយ ២៨:១៩;
គ. និង ស. ១:២; ៤២:៥៨.
៣៥ *ក* ចោទិ. ១០:១៧; កិច្ចការ ១០:៣៤;
ម៉ូរ៉ូណៃ ៨:១២;
គ. និង ស. ៣៨:១៦.
*ខ* ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
*គ* គ. និង ស. ៨៧:១–២.
ស.ប. សេចក្ដីសុខសាន្ត;
ទីសំគាល់អំពីពេលវេលា.

យកចេញពីផែនដីទៅ ហើយ[យ]អារក្សនឹងមានអំណាចលើអាណាចក្ររបស់វា ផ្ទាល់ ។

៣៦ ហើយព្រះអម្ចាស់ក៏នឹងមានព្រះចេស្ដា លើ[ក]ពួកបរិសុទ្ធរបស់ទ្រង់ដែរ ហើយនឹង[ខ]សោយរាជ្យ នៅ[គ]កណ្ដាលពួកគេ ហើយនឹងយាង ចុះ មក[យ]ជំនុំជំរះលើ[ង]ស្រុកអេដំម ឬពិភពលោក ។

៣៧ ចូរពិចារណាមើល[ក]ព្រះបញ្ញត្តិទាំងនេះចុះ ត្បិតព្រះបញ្ញត្តិទាំងនេះពិតហើយស្មោះត្រង់ហើយសេចក្ដីព្យាករណ៍ និង [ខ]សេចក្ដីសន្យា ដែលមានទាំងប៉ុន្មាននៅក្នុងនោះ នោះនឹងបានសំរេចទាំងអស់ ។

៣៨ អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ ហើយយើងពុំកែដោះសារខ្លួនឡើយ ហើយទោះជាផ្ទៃមេឃហើយផែនដី នឹងកន្លងបាត់ទៅក៏ដោយ គង់តែ[ក]ពាក្យរបស់យើង នឹងមិនកន្លងបាត់ដែរ ប៉ុន្តែពាក្យទាំងអស់នឹង[ខ]បានសំរេច ទោះជាដោយ[គ]សម្លេងរបស់យើងផ្ទាល់ ឬក៏ដោយសម្លេងនៃ[យ]ពួកអ្នកបំរើរបស់យើងក្ដី គឺ[ង]ដូចតែគ្នា ។

៣៩ ត្បិតមើលចុះ ហើយមើលន៏ ព្រះអម្ចាស់ ទ្រង់ជាព្រះ ហើយ[ក]ព្រះវិញ្ញាណធ្វើទីបន្ទាល់ ហើយទីបន្ទាល់នោះពិត ហើយ[ខ]សេចក្ដីពិត ជាប់នៅរៀងដរាបតទៅ ។ អាម៉ែន ៕

## កណ្ឌទី២

*ជាសេចក្ដីដកស្រង់ពីពាក្យសំដីនៃទេវតាមរ៉ូណៃ ទៅកាន់យ៉ូសែបស្ម៊ីធ ជាព្យាការី កាលនៅផ្ទះរបស់ឪពុកនៃព្យាការី នៅឯក្រុងម៉ែនឆែស្ទ័រ រដ្ឋនិវយ៉ោក នៅរាត្រីថ្ងៃទី២១ នៃខែកញ្ញា ឆ្នាំ១៨២៣ (*History of the Church*, ១:១២) ។ មរ៉ូណៃជាអ្នកចុង ក្រោយបង្អស់ពីក្រុមប្រវត្តិសាស្ត្រនិដ៏យូរអង្វែង ដែលបានធ្វើបញ្ជី ដែលឥឡូវនេះគេស្គាល់ថាជាព្រះគម្ពីរមរមន នៅចំពោះពិភពលោក (ចូរប្រៀបធៀបនឹងគម្ពីរម៉ាឡាគី ៤:៥–៦; ព្រមទាំងកណ្ឌទី ២៧:៩; ១១០:១៣–១៦; និង១២៨:១៨ ដែរ) ។*

*១, អេលីយ៉ានឹងបើកសំដែងបព្វជិតភាព; ២–៣, សេចក្ដីសន្យាទាំងឡាយនៃពួកឪពុក ត្រូវបានដាក់នៅក្នុងចិត្តនៃកូនចៅ ។*

មើលចុះ យើងនឹងបើកសម្ដែងដល់អ្នករាល់គ្នានូវបព្វជិតភាព ដោយដៃនៃលោក[ក]អេលីយ៉ា ជាព្យាការី មុនដែលថ្ងៃដ៏ធំហើយ ស្ញែងខ្លាច របស់ព្រះអម្ចាស់បានមកដល់ ។

២ ហើយ[ក]លោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅ នូវ[ខ]សេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុក ហើយចិត្តនៃកូនចៅនឹងបានបង្វែរមករក ពួកឪពុករបស់ពួកគេវិញ ។

៣ បើសិនជាមិនមែនដូច្នោះទេ នោះផែនដីទាំងមូល នឹងត្រូវកំទេចចោលសូន្យឈឹង ក្នុងកាលទ្រង់យាងមក ។

៣៥ *យ* ស.ប. អារក្ស.
៣៦ *ក* ស.ប. ជនបរិសុទ្ធ.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — រជ្ជកាលនៃព្រះគ្រីស្ទនៅសហស្សវត្សរ៍.
*គ* សាការី ២:១០–១១;
គ. និង ស. ២៩:១១;
៨៤:១១៨–១១៩.
*យ* ស.ប. ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
*ង* ស.ប. ពិភពលោក.
៣៧ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* គ. និង ស. ៥៨:៣១; ៦២:៦;
៨២:១០.
៣៨ *ក* ២ ពង្សាវ. ១០:១០;
ម៉ាថាយ ៥:១៨; ២៤:៣៥;
២ នីហ្វៃ ៩:១៦;
យ.ស. — ម៉ាថាយ ១:៣៥.
*ខ* គ. និង ស. ១០១:៦៤.
*គ* ចោទិ. ១៨:១៨;
គ. និង ស. ១៨:៣៣–៣៨;
២១:៥.
ស.ប. វិវរណៈ; សម្លេង.
*យ* ស.ប. ព្យាការី.
*ង* ស.ប. សិទ្ធិអំណាច;
ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ.
៣៩ *ក* ១ យ៉ូហាន ៥:៦;
គ. និង ស. ២០:២៧; ៤២:១៧.
*ខ* ស.ប. សេចក្ដីពិត.
២ ១*ក* ម៉ាឡាគី ៤:៥–៦;
៣ នីហ្វៃ ២៥:៥–៦;
គ. និង ស. ១១០:១៣–១៥;
១២៨:១៧;
យ.ស. — ប្រវត្តិ ១:៣៨–៣៩.
ស.ប. អេលីយ៉ា;
កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* គ. និង ស. ៣៤:៦–៩;
៤៣:១៧–២៦.
២ *ក* គ. និង ស. ២៧:៩; ៩៨:១៦–១៧.
*ខ* ស.ប. សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់;
ភ្ជាប់, ការភ្ជាប់.

## កណ្ឌទី៣

*វិវរណៈដែលប្រទានដល់យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហាម៉ូនី រដ្ឋប៉ែនសិលវេញ៉ា ខែកក្កដា ឆ្នាំ១៨២៨ ទាក់ទងទៅនឹងការបាត់ឯកសារ១១៦សន្លឹក ដែលបានបកប្រែចេញពីភាគទីមួយនៃព្រះគម្ពីរមរមន ដែលហៅថា គម្ពីរលីហៃ ។ ព្យាការីបានអនុញ្ញាតទាំងរុញរាឲ្យពីដៃលោកទៅម៉ាទិនហារីស ដែលបានបំរើជាស្មៀនមួយរយៈ ក្នុងការបកប្រែព្រះគម្ពីរមរមន ។ វិវរណៈត្រូវប្រទានឲ្យតាមរយៈ យូរីម និងធូមីម (*History of the Church*, ១:២១–២៣) (សូមមើលកណ្ឌទី១០) ។*

*១–៤, ដំណើររបស់ព្រះអម្ចាស់ជាវង់មួយដ៏នៅអស់កល្បជានិច្ច; ៥–១៥, យ៉ូសែបស្ម៊ីធត្រូវតែប្រែចិត្ត បើពុំនោះសោតទេ នឹងត្រូវបាត់បង់អំណោយទានដើម្បីបកប្រែ; ១៦–២០, ព្រះគម្ពីរមរមនចេញមកដើម្បីជួយសង្គ្រោះពូជនៃលោកលីហៃ ។*

[ក]កិច្ចការ និងផែនការ និងគំរោងការណ៍ទាំងឡាយនៃព្រះ នោះពុំអាចធ្វើឲ្យស្អុគស្អាញ ឬសាបសូន្យបានឡើយ ។

២ ត្បិតព្រះ ទ្រង់មិនយាងលើផ្លូវវៀចវាងឡើយ ឬក៏ទ្រង់ងាកពីឆ្វេងទៅស្ដាំ ឬក៏ទ្រង់បែរចេញពីអ្វីដែលទ្រង់មានបន្ទូលដែរ ម្ល៉ោះហើយ ផ្លូវទាំងឡាយរបស់ទ្រង់ត្រង់ ហើយ[ខ]ដំណើររបស់ទ្រង់ ជាវង់មួយដ៏នៅអស់កល្បជានិច្ច ។

៣ ចូរចាំចុះ ចូរចាំចុះថា មិនមែនជា[ក]កិច្ចការនៃព្រះទេ ដែលស្អុគស្អាញ ប៉ុន្តែជាកិច្ចការនៃមនុស្សលោកទេតើ ។

៤ ត្បិតទោះជាមនុស្សអាចមានវិវរណៈជាច្រើន ហើយមានអំណាចអាចធ្វើកិច្ចការដ៏អស្ចារ្យជាច្រើនបានក៏ដោយ តែបើគេ[ក]អួតអាង ដោយកម្លាំងរបស់ខ្លួន ហើយចាត់[ខ]ដំបូន្មានទាំងឡាយនៃព្រះទុកជាគ្មានតម្លៃ ហើយដើរតាមសេចក្ដីបញ្ជោរនៃបំណងនិងសេចក្ដីប៉ង ប្រាថ្នាខាង[គ]រូបកាយរបស់ខ្លួន អ្នកនោះត្រូវតែធ្លាក់ចុះ ហើយធ្វើឲ្យ [ឃ]សេចក្ដីសងសឹកនៃព្រះដ៏យុត្តិធម៌មានមកលើខ្លួនឯង ។

៥ មើលចុះ អ្នកត្រូវបានផ្ទុកផ្ដាក់នូវការណ៍ទាំងនេះ ប៉ុន្តែព្រះបញ្ញត្តិទាំងឡាយដែលបានប្រទានដល់អ្នកនោះតើតឹងរឹងយ៉ាងណា ហើយចូរចាំផងដែរ ពីសេចក្ដីសន្យាទាំងឡាយ ដែលបានធ្វើដល់អ្នក បើសិនជាអ្នកពុំរំលងព្រះបញ្ញត្តិទាំងនោះ ។

៦ ហើយមើលចុះ អ្នកតែងតែ[ក]រំលងព្រះបញ្ញត្តិ និងក្រិត្យវិន័យទាំងឡាយនៃព្រះ ហើយបានទៅតាម[ខ]ការបញ្ចុះបញ្ចូលទាំងឡាយនៃ មនុស្សលោក ។

៧ ត្បិតមើលចុះ អ្នកមិនត្រូវ[ក]ខ្លាចមនុស្សជាងព្រះឡើយ ទោះជាមនុស្សលោកចាត់ដំបូន្មានទាំងឡាយនៃព្រះទុកជាគ្មានតម្លៃ [ខ]ហើយមើល ងាយព្រះបន្ទូលទាំងឡាយរបស់ទ្រង់ក៏ដោយ —

៨ ប៉ុន្តែអ្នកគួរតែមានចិត្តស្មោះត្រង់ នោះទ្រង់ក៏នឹងសន្ធឹងព្រះពាហុរបស់ទ្រង់ ហើយទ្រទ្រង់អ្នកពីអស់ទាំង[ក]ព្រួញភ្លើងរបស់[ខ]ម៉ារសត្រូវ ហើយទ្រង់ក៏នឹងគង់នៅជាមួយអ្នក គ្រប់ពេលវេលាមាន[គ]ការខ្វល់ខ្វាយដែរ ។

៩ មើលចុះ អ្នកជាយ៉ូសែប ហើយអ្នកត្រូវបានរើសឲ្យធ្វើកិច្ចការនៃព្រះអម្ចាស់ ប៉ុន្តែមកពីការរំលង បើសិនជាអ្នកមិនប្រយ័ត្នប្រយែង នោះអ្នកនឹងធ្លាក់ ។

១០ ប៉ុន្តែ ចូរចាំចុះថា ព្រះទ្រង់ប្រកបដោយសេចក្ដីមេត្តាករុណា ហេតុដូច្នេះហើយ ចូរប្រែចិត្តពីអ្វីដែលអ្នកបានធ្វើ ដែលផ្ទុយទៅនឹងបញ្ញត្តិដែលយើងបានឲ្យដល់អ្នកចុះ ហើយអ្នកក៏នឹងនៅជាអ្នកជំរើសដដែល ហើយអ្នកត្រូវបានហៅឲ្យធ្វើកិច្ចការម្ដងទៀត;

១១ លើកលែងតែអ្នកធ្វើដូច្នេះ នោះអ្នកនឹងត្រូវបោះបង់ចោល

៣ ១*ក* ទំនុក. ៨:៣–៩;
គ. និង ស. ១០:៤៣.
២ *ក* អាលម៉ា ៧:២០.
ស.ប. ព្រះ, ក្រុមព្រះ.
*ខ* ១ នីហ្វៃ ១០:១៨–១៩;
គ. និង ស. ៣៥:១.
៣ *ក* កិច្ចការ ៥:៣៨–៣៩;
មរមន ៨:២២;
គ. និង ស. ១០:៤៣.
៤ *ក* គ. និង ស. ៨៤:៧៣.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ខ* យ៉ាកុប ៤:១០;
អាលម៉ា ៣៧:៣៧.
ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ;
ពាក្យទូន្មាន (ន.).
*គ* ស.ប. ខាងរូបកាយ.
*ឃ* ស.ប. ការសងសឹក.
៦ *ក* គ. និង ស. ៥:២១;
យ.ស. — ប្រវត្តិ ១:២៨–២៩.
*ខ* គ. និង ស. ៤៥:២៩; ៤៦:៧.
៧ *ក* ទំនុក. ២៧:១; លូកា ៩:២៦;
គ. និង ស. ១២២:៩.
ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន;
សេចក្ដីកោតខ្លាច.
*ខ* លេវី. ២៦:៤២–៤៣;
១ នីហ្វៃ ១៩:៧;
យ៉ាកុប ៤:៨–១០.
៨ *ក* អេភេ. ៦:១៦; ១ នីហ្វៃ ១៥:២៤;
គ. និង ស. ២៧:១៧.
*ខ* ស.ប. អារក្ស.
*គ* អាលម៉ា ៣៨:៥.

ហើយក្លាយទៅដូចជាមនុស្សដទៃ ហើយគ្មានអំណោយទាន
ទៀតទេ ។
១២ ហើយកាលអ្នកបានបោះបង់ចោលអ្វីដែលព្រះទ្រង់បាន
ប្រទានដល់អ្នក គឺជាចក្ខុវិស័យ និងអំណាចដើម្បីបកប្រែ នោះ
អ្នកបានបោះបង់ ចោលអ្វីដែលពិសិដ្ឋ ទៅក្នុងកណ្ដាប់ដៃនៃ
មនុស្សទុច្ចរិត,
១៣ ជាអ្នកដែលចាត់ដំបូន្មានទាំងឡាយនៃព្រះទុកជាគ្មានតម្លៃ
ហើយបានបំបាក់សេចក្ដីសន្យាដ៏ពិសិដ្ឋទាំងឡាយ ដែលបានធ្វើនៅ
ចំពោះព្រះ ហើយបានពឹងផ្អែកទៅលើការវិនិច្ឆ័យរបស់ខ្លួន ហើយ
បានអួតអាង ដោយនូវប្រាជ្ញារបស់ខ្លួន ។
១៤ ហើយនេះហើយជាហេតុដែលអ្នកបានបាត់បង់ឯកសិទ្ធិ
អស់មួយរដូវកាល —
១៥ ត្បិតអ្នកបានទ្រាំឲ្យដំបូន្មាននៃព្រះដ៏ណែនាំរបស់អ្នក ត្រូវ
យកទៅជាន់ឈ្លីលើ ចាប់តាំងពីដំបូងមកម្ល៉េះ ។
១៦ ក៏ប៉ុន្តែ កិច្ចការរបស់យើង នឹងចេញទៅ ត្បិតដរាបណា
ដែលដំណឹងអំពីព្រះអង្គសង្គ្រោះ បានដឹងដល់ពិភពលោក តាម
រយៈទី បន្ទាល់នៃពួកសាសន៍យូដាយ៉ាងណា នោះដំណឹងអំពី
ព្រះអង្គសង្គ្រោះក៏នឹងចេញមកពីប្រជារាស្ត្រ
របស់យើងយ៉ាងដូច្នោះដែរ —
១៧ ហើយទៅដល់ពួកសាសន៍នីហ្វៃ និងពួកសាសន៍យ៉ាកុប
និងពួកសាសន៍យ៉ូសែប និងពួកសាសន៍សូរ៉ាំ តាមរយៈទីបន្ទាល់
នៃពួក ឪពុករបស់ពួកគេ —
១៨ ហើយទីបន្ទាល់នេះនឹងបានក្លាយទៅជាដំណឹងដល់ពួក
សាសន៍លេមិន និងពួកសាសន៍លេមយួល និងពួកសាសន៍
អ៊ីសម៉ាអែល ដែលជាពួកចុះអន់ថយក្នុងការឥតជំនឿ ពីព្រោះ
តែសេចក្ដីទុច្ចរិតនៃពួកឪពុករបស់ពួកគេ ដែលព្រះអម្ចាស់ ទ្រង់
បានបណ្ដោយឲ្យ ពួកគេបំផ្លាញចោលពួកសាសន៍នីហ្វៃ ជាបង
ប្អូនរបស់ពួកគេ ពីព្រោះតែសេចក្ដីទុច្ចរិតទាំងឡាយរបស់ពួកគេ
និងអំពើគួរខ្ពើមឆ្អើមទាំង ឡាយរបស់ពួកគេ ។
១៩ ហើយចំពោះគោលការណ៍នេះហើយ បានជាផ្ទាំង
ចារិកទាំងនេះត្រូវបានរក្សាទុក ដែលមានប្រវត្តិបញ្ជីទាំងនេះ —
ដើម្បីឲ្យសេចក្ដី សន្យាទាំងឡាយនៃព្រះអម្ចាស់អាចបានសំរេច
ដែលទ្រង់បានធ្វើជាមួយប្រជារាស្ត្ររបស់ទ្រង់;
២០ ហើយដើម្បីឲ្យពួកសាសន៍លេមិនអាចបានដឹងអំពីពួកឪពុក
របស់ពួកគេ ហើយដើម្បីឲ្យពួកគេអាចដឹងអំពីសេចក្ដីសន្យាទាំង
ឡាយនៃព្រះអម្ចាស់ ហើយដើម្បីឲ្យពួកគេអាចជឿតាមដំណឹងល្អ
ហើយពឹងផ្អែកទៅលើព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ហើយបាន
ដំកើង ឡើង តាមរយៈសេចក្ដីជំនឿជឿដល់ព្រះនាមរបស់ទ្រង់
ហើយដើម្បីឲ្យពួកគេបានសង្គ្រោះ តាមរយៈការប្រែចិត្តរបស់
ពួកគេ ។ អាម៉ែន ៕

## កណ្ឌទី៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះយ៉ូសែបស្ម៊ីធ ស៊ីញ៉័រ ជាឪពុករបស់លោក នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែកុម្ភៈ ឆ្នាំ១៨២៩ (*History of the Church*, ១:២៨)* ។

*១–៤, ការបំរើដ៏ក្លាហានជួយសង្គ្រោះពួកអ្នកបំរើរបស់ព្រះអម្ចាស់; ៥–៦, គុណសម្បត្តិដូចព្រះ ធ្វើឲ្យពួកគេសមនឹងការងារបំរើ; ៧, ត្រូវតែស្វែងរកការណ៍នៃព្រះ ។*

ឥឡូវមើលចុះ កិច្ចការដ៏អស្ចារ្យនឹងចេញមកក្នុងចំណោមកូន
ចៅមនុស្សហើយ ។
២ ហេតុដូច្នេះហើយ ឱអ្នករាល់គ្នា ដែលចាប់ផ្ដើមធ្វើការបំរើ

១២ *ក* គ. និង ស. ១:២៩; ៥:៤.
*ខ* គ. និង ស. ១០:៦–៨.
១៣ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១៥ *ក* ក.ន. ព្រះអម្ចាស់.
១៦ *ក* ស.ប. ព្រះអង្គសង្គ្រោះ.
*ខ* ១ នីហ្វៃ ១៣:២៣–២៥;
២ នីហ្វៃ ២៩:៤–៦.
*គ* ម៉ូសាយ ៣:២០.
១៧ *ក* ២ នីហ្វៃ ៥:៨–៩.
១៨ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ២ នីហ្វៃ ៥:១៤;
អេណុស ១:១៣–១៨.
*គ* ២ នីហ្វៃ ២៦:១៥–១៦.
*ឃ* មរមន ៨:២–៣.
១៩ *ក* ១ នីហ្វៃ ៩:៣, ៥.
*ខ* ស.ប. ផ្ទាំងមាស.
*គ* ៣ នីហ្វៃ ៥:១៤–១៥;
គ. និង ស. ១០:៤៦–៥០.
២០ *ក* ២ នីហ្វៃ ៣០:៣–៦;
គ. និង ស. ២៨:៨; ៤៩:២៤.
*ខ* មរមន ៣:១៩–២១.
*គ* ២ នីហ្វៃ ៣១:១៩; ម៉ូរ៉ូណៃ ៦:៤.
*ឃ* ម៉ូរ៉ូណៃ ៧:២៦, ៣៨.
៤ ១*ក* អេសាយ ២៩:១៤;
១ នីហ្វៃ ១៤:៧; ២២:៨;
គ. និង ស. ៦:១; ១៨:៤៤.
ស.ប. ការស្ដារឡើងវិញនៃដំណឹងល្អ.
២ *ក* ស.ប. ការបំរើ.

ព្រះអើយ សូមឲ្យឃើញថា អ្នករាល់គ្នា[ខ]បំរើទ្រង់ ឲ្យអស់ពី[គ]ចិត្ត
អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង ដើម្បីឲ្យអ្នករាល់គ្នា
អាចបាន[ឃ]ឈរដោយឥតទោសនៅចំពោះព្រះ នៅថ្ងៃចុងក្រោយ
បំផុត។
៣ ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាមាន[ក]បំណងចង់
បំរើព្រះ នោះអ្នករាល់គ្នាបានហៅឲ្យធ្វើកិច្ចការនោះហើយ;
៤ ត្បិតមើលចុះ [ក]ស្រែសស្រាំព្រះលួមច្រូតហើយ ហើយមើលន៏
អ្នកណាដែលលូកកណ្ដៀវរបស់ខ្លួនដោយកម្លាំងរបស់ខ្លួន អ្នក
នោះហើយ បានប្រមូលទុក ដើម្បីកុំឲ្យខ្លួនត្រូវវិនាសឡើយ
ប៉ុន្តែបាននាំសេចក្ដីសង្គ្រោះមកដល់ព្រលឹងខ្លួនវិញ;
៥ ហើយ[ក]សេចក្ដីជំនឿ [ខ]សេចក្ដីសង្ឃឹម [គ]សេចក្ដីសប្បុរស និង
[ឃ]សេចក្ដីស្រឡាញ់ ដោយ[ង]ភ្នែកស្មោះត្រង់ទាំងស្រុង ចំពោះ
[ច]សិរីល្អនៃព្រះ ទើបធ្វើឲ្យគេសមនឹងកិច្ចការ ។
៦ ចូរនឹកចាំពីសេចក្ដីជំនឿ [ក]គុណធម៌ ដំរិះ សេចក្ដីអត់សង្កត់
[ខ]សេចក្ដីអត់ធន់ សេចក្ដីរាប់អានគ្នាជាបងប្អូន សេចក្ដីកោតខ្លាច
ដល់ព្រះ សេចក្ដីសប្បុរស [គ]សេចក្ដីទាបរាបសា [ឃ]សេចក្ដីឧស្សាហ៍
ចុះ ។
៧ [ក]ចូរសូម ហើយអ្នករាល់គ្នានឹងបានទទួល ចូរគោះ ហើយ
តែងនឹងបើកឲ្យអ្នករាល់គ្នា ។ អាម៉ែន ៕

## កណ្ឌទី៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី នៅភូមិហាម៉ូនី រដ្ឋប៉ែនសិលវេញ៉ា នៅខែមីនា ឆ្នាំ១៨២៩ តាមសំណូមពរនៃម៉ាទិនហារិស (*History of the Church, *១:២៨–៣១)* ។

*១–១០, គំណនេះនឹងបានទទួលព្រះបន្ទូលរបស់ព្រះអម្ចាស់តាមរយៈយ៉ូសែបស្ម៊ីធ; ១១–១៨, សាក្សីបីនាក់នឹងធ្វើបន្ទាល់អំពីព្រះគម្ពីរ មរមន; ១៩–២០, ព្រះបន្ទូលនៃព្រះអម្ចាស់នឹងត្រូវបានបញ្ជាក់ដូចជាកាលពីដើម; ២១–៣៥, ម៉ាទិនហារិសអាចប្រែចិត្ត ហើយអាចបាន ធ្វើជាសាក្សីម្នាក់ ។*

មើលចុះ យើងប្រាប់អ្នកថា ដរាបណា[ក]ម៉ាទិនហារិស ជាអ្នក
បំរើរបស់យើង មានបំណងចង់បានសាក្សីពីព្រះហស្តរបស់យើង
ថាអ្នក គឺយ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង មាន[ខ]ផ្ទាំង
ចារិក ដែលអ្នកបានធ្វើបន្ទាល់ ហើយបានធ្វើសាក្សីថាអ្នកបាន
ទទួលពីយើងនោះ;
២ ហើយឥឡូវនេះ មើលចុះ នេះជាពាក្យដែលអ្នកនឹងនិយាយ
ទៅកាន់លោកថា ព្រះទ្រង់ដែលមានព្រះបន្ទូលមកអ្នក ទ្រង់មាន
ព្រះ បន្ទូលដល់អ្នកថា៖ យើងជាព្រះអម្ចាស់ គឺជាព្រះ ហើយបាន
ប្រទានរបស់ទាំងឡាយនេះដល់អ្នក គឺយ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជាអ្នក
បំរើរបស់ យើង ហើយបានបញ្ជាដល់អ្នកថា អ្នកគប្បីឈរជា
[ក]សាក្សីម្នាក់ ចំពោះរបស់ទាំងឡាយនេះ;
៣ ហើយយើងបានធ្វើឲ្យអ្នកចូលក្នុងសេចក្ដីសញ្ញាជាមួយយើង
ថាអ្នកមិនគួរ[ក]បង្ហាញរបស់ទាំងឡាយនេះឡើយ លើកលែងតែ
ដល់អស់ អ្នកណាដែលយើងបានបញ្ជាឲ្យអ្នកបង្ហាញ ហើយអ្នក
គ្មាន[ខ]អំណាចលើរបស់ទាំងឡាយនេះឡើយលើកលែងតែយើង
អនុញ្ញាតដល់អ្នក ប៉ុណ្ណោះ ។

២ *ខ* យ៉ូស្វេ ២២:៥; ១ សាំយូ. ៧:៣;
គ. និង ស. ២០:១៩; ៧៦:៥.
*គ* ស.ប. ចិត្ត; គំនិត.
*ឃ* ១ កូរិន. ១:៨; យ៉ាកុប ១:១៩;
៣ នីហ្វៃ ២៧:២០.
៣ *ក* គ. និង ស. ១១:៤, ១៥; ៣៦:៥;
៦៣:៥៧.
ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ.
៤ *ក* យ៉ូហាន ៤:៣៥;
អាលម៉ា ២៦:៣–៥;
គ. និង ស. ១១:៣; ៣៣:៣, ៧.
*ខ* ស.ប. ចំរូត.
*គ* ១ ធីម៉ូ. ៦:១៩.
៥ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* ស.ប. សេចក្ដីសង្ឃឹម.
*គ* ស.ប. សេចក៏សប្បុរស.
*ឃ* ស.ប. សេចក្ដីស្រឡាញ់.
*ង* ទំនុក. ១៤១:៨; ម៉ាថាយ ៦:២២;
មរមន ៨:១៥.
*ច* ស.ប. សិរីល្អ.
៦ *ក* ស.ប. គុណធម៌.
*ខ* ស.ប. សេចក្ដីអត់ធន់.
*គ* ស.ប. បន្ទាបខ្លួន,
ចិត្តសុភាពរាបសា.
*ឃ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
៧ *ក* ម៉ាថាយ ៧:៧–៨;
២ នីហ្វៃ ៣២:៤.
ស.ប. ការអធិស្ឋាន.
**៥** ១*ក* គ. និង ស. ៥:២៣–២៤;
យ.ស. — ប្រវត្តិ ១:៦១.
*ខ* ស.ប. ផ្ទាំងមាស.
២ *ក* ស.ប. សាក្សី.
៣ *ក* ២ នីហ្វៃ ២៧:១៣.
សូមមើលផងដែរ
ទីបន្ទាល់នៃពួកសាក្សីបីនាក់
និងទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់
នៅដើមទំព័រព្រះគម្ពីរមរមន.
*ខ* ២ នីហ្វៃ ៣:១១.

៤ ហើយអ្នកមានអំណោយទានឲ្យបកប្រែផ្ទាំងចារិកទាំងឡាយ ហើយនេះជាអំណោយទានទីមួយ ដែលយើងបានប្រទានមកលើអ្នក ហើយយើងបានបញ្ជាថា អ្នកមិនគួរស្មានថាមានអំណោយទានឯណាទៀតឡើយ លុះត្រាគោលបំណងរបស់យើងបានសំរេចអំពីការណ៍នេះសិន ត្បិតយើងពុំបានប្រទានអំណោយទានឯណាទៀតដល់អ្នកឡើយ លុះត្រាការណ៍នេះត្រូវបានសំរេច ។

៥ យើងប្រាប់អ្នកជាប្រាកដថា សេចក្ដីវេទនានឹងមកដល់បណ្ដាជនទាំងឡាយនៅលើផែនដី បើសិនជាពួកគេមិនស្ដាប់តាមព្រះបន្ទូលរបស់យើង;

៦ ត្បិតពីអំណិះតទៅអ្នកនឹងត្រូវបានតែងតាំងឡើង ហើយចេញទៅផ្សាយព្រះបន្ទូលរបស់យើងប្រាប់ដល់កូនចៅមនុស្ស ។

៧ មើលចុះ បើសិនជាពួកគេមិនជឿតាមព្រះបន្ទូលរបស់យើងទេ នោះពួកគេក៏នឹងមិនជឿតាមអ្នកដែរ យ៉ូសែបជាអ្នកបំរើរបស់យើងអើយ បើធ្វើទៅបាន ដែលអ្នកនឹងបង្ហាញរបស់អស់ទាំងនេះដល់ពួកគេ ដែលយើងបានប្រទានឲ្យដល់អ្នកក៏ដោយ ។

៨ ឱតំណមនុស្សដ៏ឥតជំនឿនិងក្បាលរឹងអើយ — សេចក្ដីក្រោធរបស់យើងឆួលទាស់នឹងពួកគេហើយ ។

៩ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា យើងបានរក្សារបស់ទាំងឡាយនោះ ដែលយើងបានផ្ទុកផ្ដែកដល់អ្នក យ៉ូសែបជាអ្នកបំរើរបស់យើងអើយ សំរាប់គោលបំណងមួយដ៏ប្រកបដោយប្រាជ្ញាវាងវៃចំពោះយើង ហើយការណ៍នេះនឹងត្រូវបានដឹងដល់តំណក្រោយ;

១០ ប៉ុន្ដែតំណនេះនឹងបានព្រះបន្ទូលរបស់យើង តាមរយៈអ្នក;

១១ ហើយបន្ថែមទៅនឹងទីបន្ទាល់របស់អ្នក នោះមានទីបន្ទាល់នៃពួកអ្នកបំរើរបស់យើងបីនាក់ទៀត ដែលយើងនឹងហៅ ហើយតែងតាំង ជាពួកអ្នកដែលយើងនឹងបង្ហាញរបស់ទាំងឡាយនេះ ហើយពួកគេនឹងចេញទៅដោយមានព្រះបន្ទូលរបស់យើង ដែលបានប្រទានឲ្យមកតាមរយៈអ្នក ។

១២ មែនហើយ ពួកគេនឹងដឹងជាប្រាកដថា របស់ទាំងឡាយនេះពិត ត្បិតយើងនឹងប្រកាសប្រាប់ដល់ពួកគេពីស្ថានសួគ៌ ។

១៣ យើងនឹងប្រទានអំណាចដល់ពួកគេ ដើម្បីឲ្យពួកគេអាចមើល ហើយឃើញរបស់ទាំងឡាយនេះ ដោយជាក់ច្បាស់;

១៤ ហើយយើងនឹងមិនប្រទានអំណាចនេះដល់នរណាទៀតឡើយ ឲ្យទទួលទីបន្ទាល់ដដែលនេះ ក្នុងចំណោមតំណនេះ ក្នុងការណ៍នេះ ដែលជាដើមដំបូងនៃការតាំងឡើង និងការចេញមកនៃសាសនាចក្ររបស់យើងពីទីរហោស្ថាន — គឺភ្លឺត្រចះដូចជាព្រះច័ន្ទ ហើយស្រស់ដូចជាព្រះអាទិត្យ ហើយគួរស្ញែងខ្លាចដូចជាពលទ័ពមានទាំងទង់ជ័យផង ។

១៥ ហើយទីបន្ទាល់នៃពួកសាក្សីបីនាក់ ស្ដីអំពីព្រះបន្ទូលរបស់យើងនេះហើយ ដែលយើងនឹងផ្សាយចេញទៅ ។

១៦ ហើយមើលចុះ អស់អ្នកណាដែលជឿតាមព្រះបន្ទូលរបស់យើង ពួកគេនោះហើយដែលយើងនឹងមករក ដោយការបើកសំដែងនៃព្រះវិញ្ញាណរបស់យើង ហើយពួកគេនឹងបានកើតពីយើង គឺពីទឹក និងពីព្រះវិញ្ញាណ —

១៧ ហើយអ្នកត្រូវចាំបន្តិចទៀតត្បិតអ្នកមិនទាន់បានតែងតាំងនៅឡើយទេ —

១៨ ហើយទីបន្ទាល់របស់ពួកគេក៏នឹងចេញទៅដែរ ចំពោះការដាក់ទោសដល់តំណនេះ បើសិនជាពួកគេពង្រឹងចិត្តទាស់នឹងពួកគេនោះ ។

១៩ ត្បិតការវាយឲ្យសាបសូន្យនឹងចេញទៅក្នុងចំណោមបណ្ដាជននៅលើផែនដី ហើយនឹងធ្លាក់មកម្ដងម្កាលៗ បើសិនជា

---

៥ *ក* យេរេ. ២៦:៤–៥; អាលម៉ា ៥:៣៧–៣៨; គ. និង ស. ១:១៤.
៦ *ក* គ. និង ស. ២០:២–៣. ស.ប. តែងតាំង, ការតែងតាំង.
*ខ* ២ នីហ្វៃ ២៩:៧.
៧ *ក* លូកា ១៦:២៧–៣១; គ. និង ស. ៦៣:៧–១២.
៨ *ក* ស.ប. ការឥតជំនឿ.
*ខ* មរមន ៨:៣៣. ស.ប. សេចក្ដីឆ្មើងឆ្មៃ.
៩ *ក* អាលម៉ា ៣៧:១៨.
១១ *ក* ២ នីហ្វៃ ២៧:១២; អេធើរ ៥:៣–៤; គ. និង ស. ១៧:១–៥.
១៤ *ក* ២ នីហ្វៃ ២៧:១៣.
*ខ* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ; ការសាងឡើងវិញនៃដំណឹងល្អ.
*គ* គ. និង ស. ១០៥:៣១; ១០៩:៧៣.
១៥ *ក* គ. និង ស. ១៧:១–២០. ស.ប. ពួកសាក្សីអំពីព្រះគម្ពីរមរមន.
១៦ *ក* អេធើរ ៤:១១.
*ខ* ១ នីហ្វៃ ២:១៦.
*គ* គ. និង ស. ៨:១–៣.
*ឃ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ង* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក; កើតម្ដងទៀត, កើតពីព្រះ; អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
១៧ *ក* ស.ប. សិទ្ធិអំណាច; តែងតាំង, ការតែងតាំង.
១៨ *ក* ១ នីហ្វៃ ១៤:៧; គ. និង ស. ២០:១៣–១៥.
១៩ *ក* គ. និង ស. ២៩:៨; ៣៥:១១; ៤៣:១៧–២៧. ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ; ទីសំគាល់អំពីពេលវេលា.

ពួកគេ មិន[ខ]ប្រែចិត្តទេ គឺរហូតដល់[ក]អស់រលីងពីផែនដី ហើយបណ្ដាជន
ទាំងនោះ នឹងត្រូវវិនាសហើយបំផ្លាញចោលទាំងស្រុង ដោយ
សារភាពថែងចាំងនៃ[ឃ]ការយាងមករបស់យើង ។
២០ មើលចុះ យើងប្រាប់អ្នកនូវការណ៍ទាំងនេះ គឺដូចជាយើង
[ក]បានប្រាប់ប្រជារាស្ត្រ អំពីការបំផ្លិចបំផ្លាញនៃក្រុង[ខ]យេរូសាឡិមដែរ
ហើយព្រះបន្ទូលរបស់យើងនឹងត្រូវបានបញ្ជាក់នៅពេលនេះ ដូចជា
បានបញ្ជាក់ពីកាលនោះមកហើយដែរ ។
២១ ហើយឥឡូវនេះ យើងបញ្ជាអ្នក យ៉ូសែបជាអ្នកបំរើ
របស់យើងអើយ ឲ្យប្រែចិត្ត ហើយដើរឲ្យតែត្រង់នៅចំពោះយើងចុះ
ហើយចូរ កុំស្ដាប់តាមការបញ្ចុះបញ្ចូលនៃមនុស្សលោកទៀតឡើយ;
២២ ហើយចូរឲ្យអ្នកនៅខ្ជាប់ខ្ជួនក្នុង[ក]ការកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយ ដែលយើងបានបញ្ជាដល់អ្នក ហើយបើសិនជាអ្នកធ្វើ
យ៉ាងដូច្នេះ មើលចុះ យើងប្រទាន[ខ]ជីវិតដ៏នៅអស់កល្បជានិច្ច
ដល់អ្នក សូម្បីតែអ្នកត្រូវគេសម្លាប់ក៏ដោយ ។
២៣ ហើយឥឡូវនេះ ជាថ្មីទៀត យើងមានបន្ទូលដល់អ្នក
យ៉ូសែបជាអ្នកបំរើរបស់យើងអើយស្ដី[ក]អំពីមនុស្សដែលមាន
បំណងបាន សាក្សី —
២៤ មើលចុះ យើងប្រាប់អ្នកនោះថា លោកដំកើងខ្លួន ហើយ
មិនបន្ទាបខ្លួនឲ្យល្មមគ្រប់គ្រាន់នៅចំពោះយើងឡើយ ប៉ុន្តែបើ
លោក នឹងក្រាបចុះនៅចំពោះយើង ហើយបន្ទាបខ្លួន ដោយ
នូវការអធិស្ឋាន និងសេចក្ដីជំនឿដ៏ខ្លាំងក្លា ឲ្យអស់ពី[ក]ដួងចិត្តលោក
ខណៈនោះ យើងនឹងប្រទានដល់លោក ឲ្យមើលរបស់ទាំងឡាយ
ដែលលោកមានបំណងចង់ឃើញនោះ ។
២៥ ហើយខណៈនោះ លោកនឹងប្រាប់ដល់បណ្ដាជននៃតំណ
នេះថា៖ មើលចុះ ខ្ញុំបានឃើញរបស់ទាំងឡាយ ដែលព្រះអម្ចាស់
ទ្រង់បានបង្ហាញដល់យ៉ូសែបស្ម៊ីធ ជុញ្ញ័រ ហើយខ្ញុំ[ក]ដឹងជាប្រាកដថា
របស់ទាំងនោះពិត ត្បិតខ្ញុំបានឃើញរបស់ទាំងនោះហើយ ព្រោះ
របស់ទាំងនោះត្រូវបានបង្ហាញឲ្យខ្ញុំឃើញ ដោយព្រះចេស្ដានៃ
ព្រះ ហើយពុំមែនដោយមនុស្សទេ ។
២៦ ហើយយើងជាព្រះអម្ចាស់ បញ្ជាដល់លោក គឺម៉ាទិន
ហារិស ជាអ្នកបំរើរបស់យើង ថាលោកមិនត្រូវប្រាប់អ្វីដល់ពួក
គេទៀតទេ អំពីរបស់ទាំងឡាយនេះ លើកលែងតែលោកត្រូវថា៖
«ខ្ញុំបានឃើញរបស់ទាំងឡាយ ហើយរបស់ទាំងឡាយនោះត្រូវ
បានបង្ហាញឲ្យខ្ញុំ ឃើញ ដោយសារព្រះចេស្ដានៃព្រះ» នេះហើយ
ជាពាក្យដែលលោកនឹងត្រូវនិយាយ ។
២៧ ប៉ុន្តែ បើសិនជាលោកបដិសេធការណ៍នេះ នោះ
លោកនឹងបំបាក់សេចក្ដីសញ្ញា ដែលលោកបានធ្វើសេចក្ដីសញ្ញា
ជាមួយយើងពីមុន ហើយមើលចុះ លោកនឹងត្រូវជាប់ទោស ។
២៨ ហើយឥឡូវនេះ លើកលែងតែលោកបន្ទាបខ្លួន ហើយ
សារភាពដល់យើងថាអ្វីៗដែលលោកបានធ្វើនោះ គឺខុសឆ្គង
ហើយធ្វើ សេចក្ដីសញ្ញាជាមួយយើង ថាលោកនឹងកាន់តាមបញ្ញត្តិ
ទាំងឡាយរបស់យើង ហើយអនុវត្តសេចក្ដីជំនឿជឿដល់យើង
បើពុំនោះសោតទេ មើលចុះ យើងប្រាប់ដល់លោកថា លោក
នឹងមិនបានឃើញអ្វីទេ ត្បិតយើងនឹងមិនអនុញ្ញាតឲ្យលោកបាន
មើលឃើញរបស់ទាំងឡាយ ដែលយើងបានពោលដល់នោះ
ឡើយ ។
២៩ ហើយបើករណីនេះកើតមែន យ៉ូសែបអើយ យើងបញ្ជា
ដល់អ្នកថា អ្នកត្រូវប្រាប់ដល់លោកថា លោកមិនត្រូវធ្វើទៀតឡើយ
ឬក៏ រំខានដល់យើងទៀតឡើយ អំពីរឿងនេះ ។
៣០ ហើយបើករណីនេះកើតមែន មើលចុះ យ៉ូសែបអើយ
យើងប្រាប់ដល់អ្នកថា កាលណាអ្នកបានបកប្រែសន្លឹកបន្ដិច
បន្តួចទៀត នោះអ្នកត្រូវឈប់មួយរយៈសិនចុះ គឺលុះត្រា
ដល់យើងបញ្ជាដល់អ្នកទៀត ខណៈនោះ អ្នកអាចបកប្រែ
ម្ដងទៀតបាន ។
៣១ ហើយលើកលែងតែអ្នកធ្វើដូច្នេះ មើលចុះ អ្នកនឹងពុំមាន
អំណោយទានឯទៀតឡើយ ហើយយើងនឹងដកយករបស់ទាំង
ឡាយ ដែលយើងបានផ្ទុកផ្ដែកនឹងអ្នក ។
៣២ ហើយឥឡូវនេះ ពីព្រោះយើងបានឃើញជាមុន អំពីការ
លបពួនចាំបំផ្លាញអ្នក មែនហើយ យើងបានឃើញជាមុនថា
បើសិនជា ម៉ាទិនហារិស ជាអ្នកបំរើរបស់យើង មិនបន្ទាប
ខ្លួន ហើយទទួលសាក្សីពីព្រះហស្ដរបស់យើងទេ នោះលោក
នឹងធ្លាក់ទៅក្នុងការរំលង ហើយ ។

---

១៩ *ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ក* អេសាយ ២៤:១, ៥–៦.
*ឃ* អេសាយ ៦៦:១៥–១៦;
គ. និង ស. ១៣៣:៤១.
ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.

២០ *ក* ១ នីហ្វៃ ១:១៨; ២ នីហ្វៃ ២៥:៩.
*ខ* គ. និង ស. ១:៣៨.
២២ *ក* ស.ប. ការគោរព, ដែលគោរព,
គោរព.
*ខ* អាលម៉ា ៦០:១៣;
គ. និង ស. ៦:៣០; ១៣៥:១–៧.

២៣ *ក* គ. និង ស. ៥:១.
២៤ *ក* សូមមើលទីបន្ទាប់នៃពួកសាក្សីបីនាក់
នៅដើមទំព័រព្រះគម្ពីរមរមន.
២៥ *ក* អេធើរ ៥:៣.

៣៣ ហើយមានមនុស្សជាច្រើនដែលពួន[ក]ចាំបំផ្លាញអ្នក ចេញពី
ផ្ទៃផែនដី ហើយមកពីហេតុនេះហើយ ដើម្បីឲ្យអ្នកបានអាយុវែង
បានជាយើងប្រទានបញ្ញត្តិទាំងនេះដល់អ្នក ។
៣៤ មែនហើយ មកពីហេតុនេះហើយ បានជាយើងនិយាយ
ថា៖ ចូរឈប់ ហើយឈរឲ្យនឹង លុះត្រាយើងបញ្ជាដល់អ្នក
ហើយយើងនឹង [ក]ឲ្យមធ្យោបាយណាមួយ ដើម្បីឲ្យអ្នកអាចសំរេច
នូវអ្វី ដែលយើងបានបញ្ជាដល់អ្នកសិន ។
៣៥ ហើយបើសិនជាអ្នកមាន[ក]ចិត្តស្មោះត្រង់ ក្នុងការកាន់តាម
បញ្ញត្តិទាំងឡាយរបស់យើង នោះអ្នកនឹងបាន[ខ]លើកឡើង នៅថ្ងៃ
ចុងក្រោយបង្អស់ ។ អាម៉ែន ៕

## កណ្ឌទី៦

*វិវរណៈដែលបានប្រទានឲ្យយ៉ូសែបស្ម៊ីធ ជាព្យាការី និងអូលីវើរខោឌើរី នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែមេសា ឆ្នាំ១៨២៩ (*History of the Church*, ១:៣២–៣៥) ។ អូលីវើរខោឌើរីបានចាប់ផ្ដើមកិច្ចការរបស់លោកជាស្មៀន ក្នុងការបកប្រែព្រះគម្ពីរមរមន នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៨២៩ ។ លោកបានទទួលការបើកសំដែងមួយពីព្រះ នូវសេចក្ដីពិតអំពីទីបន្ទាល់របស់ព្យាការី ទាក់ទងទៅនឹងផ្ទាំងចារិក ដែលមានចារឹកព្រះគម្ពីរមរមន ។ ព្យាការីបានសូមពីព្រះអម្ចាស់ តាមរយៈយូរីមនិងធូមីម ហើយបានទទួលចម្លើយនេះ ។*

*១–៦, ពួកអ្នកដែលធ្វើការនៅក្នុងស្រែរបស់ព្រះអម្ចាស់នឹងបានសេចក្ដីសង្គ្រោះ; ៧–១៣, គ្មានអំណោយទានឯណាដែលធំជាង អំណោយទាននៃសេចក្ដីសង្គ្រោះឡើយ; ១៤–២៧, សាក្សីអំពីសេចក្ដីពិត បានមកដោយសារព្រះចេស្ដានៃព្រះវិញ្ញាណ; ២៨–៣៧, ចូរមើលទៅព្រះគ្រីស្ទ ហើយធ្វើល្អជារៀងដរាប ។*

កិច្ចការដ៏មហិមា និង[ក]អស្ចារ្យកំពុងតែនឹងចេញមកដល់កូនចៅ
មនុស្សហើយ ។
២ មើលចុះ យើងជាព្រះ ចូរស្ដាប់តាម[ក]ព្រះបន្ទូលរបស់យើង
ដែលរស់នៅ ហើយពូកែផង [ខ]ក៏មុតជាងដាវណាមានមុខពីរ ទាំង
កាត់សន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ហេតុដូច្នេះហើយ ចូរស្ដាប់
តាមព្រះបន្ទូលទាំងឡាយរបស់យើងចុះ ។
៣ មើលចុះ [ក]ស្រែសសំព្រះល្មមច្រូតហើយ ហេតុដូច្នេះហើយ
អស់អ្នកណាមានបំណងចង់ច្រូត ចូរឲ្យអ្នកនោះលូកកណ្ដៀវ
របស់ខ្លួនដោយកម្លាំងរបស់ខ្លួន ហើយច្រូតក្នុងកាលមានថ្ងៃនៅ
ចុះ ប្រយោជន៍ឲ្យអ្នកនោះអាចបានសន្សំទុកសំរាប់ព្រលឹងគេ
នូវសេចក្ដីសង្គ្រោះ ដ៏អស់កល្បជានិច្ច នៅក្នុងនគរព្រះ ។
៤ មែនហើយ អស់អ្នកណាដែលនឹង[ក]លូកកណ្ដៀវរបស់ខ្លួន
ហើយច្រូត អ្នកនោះហើយបានហៅពីព្រះ ។
៥ ហេតុដូច្នេះហើយ បើសិនជាអ្នក[ក]សុំពីយើង នោះអ្នកតែង
នឹងបានទទួល បើសិនជាអ្នកនឹងគោះ នោះតែងនឹងបើកឲ្យអ្នក ។
៦ ឥឡូវនេះ ដូចជាអ្នកបានសូម មើលចុះ យើងប្រាប់អ្នកថា
ចូរកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ហើយ[ក]ស្វែងរក ដើម្បី
នាំមក ហើយតាំងឡើងនូវគតិនៃក្រុង[ខ]ស៊ីយ៉ូនចុះ;
៧ ចូរ[ក]កុំស្វែងរក[ខ]ទ្រព្យសម្បត្តិឡើយ ប៉ុន្តែរក[គ]ប្រាជ្ញាវិញ ហើយ

៣៣ *ក* គ. និង ស. ១០:៦;
៣៨:១៣, ២៨.
៣៤ *ក* ១ នីហ្វៃ ៣:៧.
៣៥ *ក* និក្ខ. ១៥:២៦;
គ. និង ស. ១១:២០.
*ខ* យ៉ូហាន ៦:៣៩–៤០;
១ ថែស្សា. ៤:១៧;
៣ នីហ្វៃ ១៥:១;
គ. និង ស. ៩:១៤; ១៧:៨;
៧៥:១៦, ២២.
**៦** ១ *ក* អេសាយ ២៩:១៤;
គ. និង ស. ៤:១–៧; ១៨:៤៤.
២ *ក* ហេព្រើរ ៤:១២; វិវរ. ១:១៦;
គ. និង ស. ២៧:១.
*ខ* ហេលេ. ៣:២៩;
គ. និង ស. ៣៣:១.
៣ *ក* យ៉ូហាន ៤:៣៥;
គ. និង ស. ៣១:៤;
៣៣:៣; ១០១:៦៤.
៤ *ក* វិវរ. ១៤:១៥–១៩;
អាលម៉ា ២៦:៥;
គ. និង ស. ១១:៣–៤, ២៧.
៥ *ក* ម៉ាថាយ ៧:៧–៨.
៦ *ក* ១ នីហ្វៃ ១៣:៣៧.
*ខ* ស.ប. ស៊ីយ៉ូន.
៧ *ក* អាលម៉ា ៣៩:១៤;
គ. និង ស. ៦៨:៣១.
*ខ* ១ ពង្សាវ. ៣:១០–១៣;
ម៉ាថាយ ១៩:២៣;
យ៉ាកុប ២:១៨–១៩.
ស.ប. ទ្រព្យសម្បត្តិ;
សេចក្ដីប្រកបដោយលោកិយ.
*គ* ស.ប. ប្រាជ្ញា.

មើលចុះ [ឃ]សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ នឹងបានបើកបង្ហាញ
ដល់អ្នក ហើយខណៈនោះ [ង]អ្នកនឹងបានទៅជាអ្នកមាន មើលចុះ
អ្នកណាដែលមានជីវិតដ៏នៅអស់កល្បជានិច្ច ឈ្មោះថាជា អ្នក
មានហើយ ។
៨ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា គឺដរាបណាអ្នក
មានបំណងចង់បានពីយើង នោះនឹងបានសំរេចដល់អ្នក ហើយបើ
សិនជាអ្នកប្រាថ្នា នោះអ្នកនឹងបានទៅជាមធ្យោបាយនៃការធ្វើ
ល្អដ៏ច្រើន នៅក្នុងតំណនេះ ។
៩ ចូរកុំថាអ្វីដល់តំណនេះឡើយ លើកលែងតែ[ក]ការប្រែចិត្ត
ចូរកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ហើយជួយបញ្ចេញកិច្ច
ការរបស់យើងមក ស្របតាមបញ្ញត្តិទាំងឡាយរបស់យើង នោះ
អ្នកនឹងបានពរ ។
១០ មើលចុះ អ្នកមានអំណោយទាន ហើយអ្នកបានពរហើយ
ដោយមកពីអំណោយទានរបស់អ្នក ចូរចាំថាអំណោយទាននេះ
[ក]ពិសិដ្ឋ ហើយបានមកពីលើ —
១១ ហើយបើសិនជាអ្នកនឹង[ក]សុំ នោះអ្នកនឹងបានដឹង[ខ]នូវសេច
ក្ដីអាថ៌កំបាំងទាំងឡាយ ដែលធំហើយអស្ចារ្យ ហេតុដូច្នេះហើយ
ចូរអ្នក [គ]អនុវត្តនូវអំណោយទានរបស់អ្នកចុះ ប្រយោជន៍ឲ្យអ្នក
អាចរកឃើញសេចក្ដីអាថ៌កំបាំងទាំងឡាយ ដើម្បីឲ្យអ្នកអាចនាំ
មនុស្សជាច្រើន ឲ្យបានស្គាល់សេចក្ដីពិត មែនហើយ គឺ[ឃ]ផ្ចាញ់ផ្ចាល
ពួកគេអំពីការខុសឆ្គងនៃផ្លូវទាំងឡាយរបស់ពួកគេ ។
១២ ចូរកុំឲ្យនរណាដឹងអំពីអំណោយទានរបស់អ្នកឡើយ លើក
លែងតែអស់អ្នកណាដែលនៅក្នុងសេចក្ដីជំនឿរបស់អ្នក ។
ចូរកុំ ប្រហែសនឹងការណ៍ដ៏[ក]ពិសិដ្ឋទាំងឡាយឡើយ ។
១៣ បើសិនជាអ្នកនឹងធ្វើល្អ មែនហើយ ហើយ[ក]មាន[ខ]ចិត្ត
ស្មោះត្រង់ដរាបដល់ចុងបំផុត នោះអ្នកនឹងបានសង្គ្រោះនៅក្នុង
នគរព្រះ ដែលជាអំណោយទានដ៏ប្រសើរបំផុត ពីអស់ទាំង
អំណោយទាននៃព្រះ ត្បិតគ្មានអំណោយទានណាប្រសើរជាង
អំណោយទាននៃ[ឃ]សេចក្ដីសង្គ្រោះឡើយ ។
១៤ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នកមានពរហើយ
ចំពោះអ្វីដែលអ្នកបានធ្វើ ព្រោះអ្នកបាន[ក]សូមពីយើង ហើយមើលចុះ
ដរាបណាអ្នកសូមជាញឹកញាប់ នោះអ្នកបានទទួលការបង្គាប់ពីព្រះ
វិញ្ញាណរបស់យើង បើសិនជាពុំនោះសោតទេ អ្នកនឹងពុំបានមក
ដល់ទីដែលអ្នកនៅពេលនេះឡើយ ។
១៥ មើលចុះ អ្នកដឹងហើយថា អ្នកបានសុំពីយើង ហើយយើង
បានបំភ្លឺ[ក]គំនិតរបស់អ្នក ហើយឥឡូវនេះ យើងប្រាប់អ្នកនូវការណ៍
ទាំងឡាយនេះ ដើម្បីឲ្យអ្នកបានដឹងថា អ្នកត្រូវបានបំភ្លឺដោយព្រះ
វិញ្ញាណនៃសេចក្ដីពិត;
១៦ មែនហើយ យើងប្រាប់អ្នក ដើម្បីឲ្យអ្នកអាច[ក]ដឹងថា គ្មាន
នរណាឡើយក្រៅពីព្រះ ដែលជ្រាប[ខ]នូវគំនិតរបស់អ្នក និងបំណង
ដែលនៅក្នុងចិត្តរបស់អ្នក ។
១៧ យើងប្រាប់អ្នកនូវការណ៍ទាំងឡាយនេះ ទុកជាសាក្សីដល់
អ្នក — ថាព្រះបន្ទូលទាំងឡាយ ឬក៏ឯកសារដែលអ្នកបាន
សរសេរ នោះគឺ[ក]ពិត ។
១៨ ហេតុដូច្នេះហើយ ចូរមានចិត្ត[ក]ព្យាយាម; ចូរ[ខ]គាំទ្រយ៉ូសែប
ជាអ្នកបំរើរបស់យើងដោយស្មោះត្រង់ នៅក្នុងកាលៈទេសៈដ៏
ពិបាកៗ ណាក៏ដោយ ដែលលោកអាចមាន ដោយព្រោះព្រះ
បន្ទូល ។
១៩ ចូរព្រមានដាស់តឿនលោក ក្នុងកំហុសរបស់លោក
ហើយក៏ទទួលការព្រមានដាស់តឿនពីលោកដែរ ។ ចូរមានចិត្ត
អត់ធន់ ចូរមានចិត្តម៉ឺងម៉ាត់ ចូរមានចិត្តនឹងធឹង; ចូរមានសេច
ក្ដីអត់ធន់ សេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរសចុះ ។

៧ ឃ គ. និង ស. ៤២:៦១, ៦៥.
ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
ង គ. និង ស. ១៤:៧.
៩ ក អាលម៉ា ២៩:៩;
គ. និង ស. ១៥:៦;
១៨:១៤–១៥; ៣៤:៦.
ស.ប. កិច្ចការផ្សាយសាសនា;
ប្រែចិត្ត, ការប្រែចិត្ត.
១០ ក គ. និង ស. ៦៣:៦៤.
១១ ក គ. និង ស. ១០២:២៣;
យ.ស. — ប្រវត្តិ ១:១៨, ២៦.
ខ ម៉ាថាយ ១១:២៥; ១៣:១០–១១;
អាលម៉ា ១២:៩.
គ ស.ប. អំណោយទាន;
អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
ឃ យ៉ាកុប (ព.ស.ថ.) ៥:២០;
អាលម៉ា ៦២:៤៥;
គ. និង ស. ១៨:៤៤.
១២ ក ម៉ាថាយ ៧:៦.
១៣ ក ១ នីហ្វៃ ១៥:២៤.
ខ ម៉ូសាយ ២:៤១; អេធើរ ៤:១៩;
គ. និង ស. ៥១:១៩; ៦៣:៤៧.
គ ស.ប. កាន់ខ្ជាប់.
ឃ ស.ប. សេចក្ដីសង្គ្រោះ.
១៤ ក ស.ប. ការអធិស្ឋាន.
១៥ ក ស.ប. គំនិត.
១៦ ក ១ របា. ២៨:៩; ម៉ាថាយ ១២:២៥;
ហេព្រើរ ៤:១២;
ម៉ូសាយ ២៤:១២;
៣ នីហ្វៃ ២៨:៦.
ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
១៦ ខ ១ ពង្សាវ. ៨:៣៩.
១៧ ក គ. និង ស. ១៨:២.
១៨ ក ស.ប. ព្រះដ៏ប្រោសឲ្យរួច.
ខ គ. និង ស. ១២៤:៩៥–៩៦.

២០ មើលចុះ អ្នកជាអូលីវើរ ហើយយើងនិយាយទៅកាន់អ្នក មកពីសេចក្ដីប៉ងប្រាថ្នារបស់អ្នក; ហេតុដូច្នេះហើយ ចូររក្សាព្រះបន្ទូលទាំងឡាយនេះ ទុកនៅក្នុងចិត្តរបស់អ្នកចុះ ។ ចូរមានចិត្តស្មោះត្រង់ ហើយមានចិត្តព្យាយាម ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះចុះ ហើយយើងនឹងឱបក្រសោបអ្នក ដោយពាហុនៃសេចក្ដីស្រឡាញ់របស់យើង ។

២១ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ យើងជាអ្នកដដែលនោះ ដែលបានយាងមករករាស្ត្ររបស់យើង តែរាស្ត្ររបស់យើងមិនបានទទួលយើងសោះ ។ យើងជាពន្លឺដែលភ្លឺមកក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ ។

២២ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា បើសិនជាអ្នកមានបំណងចង់បានសាក្សីថែមទៀត ចូរដាក់គំនិតទៅលើយប់ដែលអ្នកបានអំពាវនាវដល់យើង ក្នុងដួងចិត្តរបស់អ្នក ដើម្បីឲ្យអ្នកអាចដឹងនូវសេចក្ដីពិតអំពីការណ៍ទាំងឡាយនេះ ។

២៣ តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នក អំពីការណ៍នោះទេឬអី ? តើអ្នកអាចមានសាក្សីឯណាដែលអស្ចារ្យ ជាងសាក្សីមកពីព្រះ ?

២៤ ហើយឥឡូវនេះ មើលចុះ អ្នកបានទទួលសាក្សី; ត្បិតបើសិនជាយើងបានប្រាប់អ្នកនូវការណ៍ទាំងឡាយ ដែលគ្មានមនុស្សណាដឹង តើអ្នកមិនបានទទួលសាក្សីទេឬអី ?

២៥ ហើយមើលចុះ យើងប្រទានអំណោយទានមួយដល់អ្នក បើសិនជាអ្នកមានបំណងចង់បានពីយើង គឺឲ្យបកប្រែ ដូចជាយ៉ូសែបជាអ្នកបំរើរបស់យើងដូច្នោះដែរ ។

២៦ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា មានបញ្ជីប្រវត្តិទាំងឡាយ ដែលមានដំណឹងល្អរបស់យើងភាគច្រើន ដែលបានរក្សាទុក ពីព្រោះតែអំពើទុច្ចរិតនៃប្រជាជន;

២៧ ហើយឥឡូវនេះ យើងបញ្ជាដល់អ្នកថា បើសិនជាអ្នកមានបំណងល្អ — គឺបំណងចង់ប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួននៅឯស្ថានសួគ៌ — ខណៈនោះ អ្នកនឹងជួយ ក្នុងការនាំមកឯពន្លឺ ដោយសារអំណោយទានរបស់អ្នក នូវភាគទាំងឡាយ នៃបទគម្ពីររបស់យើងដែលបានលាក់ទុក ពីព្រោះតែសេចក្ដីទុច្ចរិត ។

២៨ ហើយឥឡូវនេះ មើលចុះ យើងប្រទានដល់អ្នក ហើយក៏ដល់យ៉ូសែប ជាអ្នកបំរើរបស់យើងផងដែរ នូវកូនសោទាំងឡាយនៃអំណោយទាននេះ ដែលនឹងនាំការងារបំរើនេះមកឯពន្លឺ ហើយដោយមាត់នៃសាក្សីពីរ ឬបីនាក់ នោះគ្រប់ព្រះបន្ទូលនឹងត្រូវបាន ស្ថាបនាឡើង ។

២៩ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា បើសិនជាពួកគេមិនទទួលស្គាល់ព្រះបន្ទូលរបស់យើងទេ ហើយនិងភាគនៃដំណឹងល្អ និង ការងារបំរើរបស់យើងនេះ នោះអ្នករាល់គ្នាមានពរហើយ ត្បិតពួកគេមិនអាចធ្វើអ្វីដល់អ្នក ជាងដល់យើងឡើយ ។

៣០ ហើយសូម្បីតែពួកគេធ្វើដល់អ្នក ដូចជាពួកគេបាន ធ្វើដល់យើង នោះអ្នករាល់គ្នាមានពរហើយ ត្បិតអ្នកនឹងបាននៅជាមួយយើង នៅក្នុងសេចក្ដីរុងរឿង ។

៣១ ប៉ុន្តែបើសិនជាពួកគេមិនបដិសេធបន្ទូលរបស់យើងទេ ដែលនឹងបានបញ្ជាក់ដោយទីបន្ទាល់ ដែលនឹងបានប្រគល់ឲ្យមក នោះពួកគេ មានពរហើយ ហើយនៅខណៈនោះ អ្នករាល់គ្នានឹងមានសេចក្ដីអំណរ ក្នុងផលនៃការងាររបស់អ្នក ។

៣២ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ដូចជាយើងបានប្រាប់ដល់ពួកសិស្សរបស់យើង ថាកន្លែងណាដែលមានពីរឬបីនាក់ប្រជុំជាមួយគ្នា ដោយនូវនាមយើង អំពីការណ៍ណាមួយ មើលចុះ យើងនឹងនៅកណ្ដាលចំណោមពួកគេ — ដូចជាយើងនៅកណ្ដាលចំណោមអ្នកដែរ ។

២០ *ក* អេធើរ ៣:២១;
គ. និង ស. ៨៤:៨៥.
២១ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* យ៉ូហាន ១:១០–១២;
កិច្ចការ ៣:១៣–១៧;
៣ នីហ្វៃ ៩:១៦;
គ. និង ស. ៤៥:៨.
*គ* យ៉ូហាន ១:៥;
គ. និង ស. ១០:៥៨.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ឃ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
២២ *ក* ស.ប. ការសង្កេតស្គាល់,
អំណោយទាខាង.
២៣ *ក* ស.ប. សេចក្ដីសុខសាន្ត.
*ខ* ១ យ៉ូហាន ៥:៩;
គ. និង ស. ១៨:២.
២៥ *ក* ម៉ូសាយ ៨:១៣;
គ. និង ស. ៥:៤; ៩:១–៥, ១០.
២៦ *ក* គ. និង ស. ៨:១; ៩:២.
ស.ប. បទព្រះគម្ពីរ —
គម្ពីរដែលបានព្យាករថានឹងចេញមក.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
២៧ *ក* គ. និង ស. ៣៥:២០.
២៨ *ក* ចោទិ. ១៩:១៥; ២ កូរិន. ១៣:១;
២ នីហ្វៃ ២៧:១២–១៤;
គ. និង ស. ១២៨:៣.
៣០ *ក* គ. និង ស. ៥:២២; ១៣៥:១–៧.
ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
៣០ *ខ* វិវរ. ៣:២១.
*គ* ស.ប. សិរីល្អ.
៣១ *ក* ៣ នីហ្វៃ ១៦:១០–១៤;
គ. និង ស. ២០:៨–១៥.
*ខ* ស.ប. ទីបន្ទាល់.
៣២ *ក* ម៉ាថាយ ១៨:១៩–២០.
ស.ប. ការរួបរួមតែមួយ.
*ខ* គ. និង ស. ២៩:៥; ៣៨:៧.

៣៣ ចូរកុំ [ក]ខ្លាចនឹងធ្វើល្អឡើយ ឱបុត្រារបស់យើងអើយ ត្បិត[ខ]ពូជអ្វីក៏ដោយដែលអ្នករាល់គ្នាព្រួសៈចុះ នោះនឹងច្រូតបានពូជនោះឯង ហេតុដូច្នេះហើយ បើសិនជាអ្នករាល់គ្នាព្រួសៈចុះពូជល្អ នោះអ្នករាល់គ្នាក៏នឹងច្រូតបានពូជល្អ ទុកជារង្វាន់របស់អ្នកដែរ ។

៣៤ ហេតុដូច្នេះហើយ កុំឲ្យខ្លាច ហ្វូងតូចអើយ ចូរធ្វើល្អចុះ; ចូរឲ្យផែនដី និងស្ថាននរករួមគ្នាប្រឆាំងនឹងអ្នកចុះ ត្បិតបើសិនជាអ្នករាល់គ្នាបានសង់នៅលើ[ក]ថ្មដារបស់យើង នោះពួកគេពុំអាចយកឈ្នះបានឡើយ ។

៣៥ មើលចុះ យើងមិនបានកាត់ទោសអ្នកទេ; អញ្ជើញទៅចុះ តែកុំ[ក]ធ្វើបាបទៀតឡើយ; ចូរធ្វើដោយម៉ឺងម៉ាត់ នូវកិច្ចការដែលយើងបាន បញ្ជាដល់អ្នក ។

៣៦ ចូរ[ក]មើលមកឯយើង ដោយនូវគ្រប់ទាំងគំនិត; ចូរកុំសង្ស័យ កុំខ្លាចឡើយ ។

៣៧ ចូរ[ក]មើលស្នាមទាំងឡាយដែលនៅចំហៀងយើង ហើយព្រមទាំងស្នាម[ខ]ដែកគោល នៅដៃនិងជើងរបស់យើងចុះ; ចូរមានចិត្តស្មោះត្រង់ [គ]កាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹង[ឃ]គ្រងនគរស្ថានសួគ៌ទុកជាមរតក ។ អាម៉ែន ៕

## កណ្ឌទី៧

*វិវរណៈដែលបានប្រទានដល់យ៉ូសែបស្ម៊ីធ ជាព្យាការី និងដល់អូលីវើរខៅឌើរី នៅភូមិហាម៉ូនី រដ្ឋផែនស៊ិលវេញ៉ា ខែមេសា ឆ្នាំ១៨២៩ ក្នុងកាលពួកគេបានសួរតាមរយៈយូរីមនិងធូមីម អំពីយ៉ូហាន ជាសិស្សដ៏ជាទីស្រឡាញ់នោះ ថាតើបានរស់នៅក្នុងសាច់ឈាម ឬក៏ស្លាប់ទៅហើយ ។ វិវរណៈនេះជាការបកប្រែពីបញ្ជីដែលយ៉ូហានបានសរសេរទុកនៅលើរមូរក្រដាស ហើយបានលាក់ទុកដោយខ្លួនលោកផ្ទាល់ (*History of the Church, *១:៣៥–៣៦)* ។

*១–៣, យ៉ូហានដ៏ជាទីស្រឡាញ់នឹងរស់នៅ ទាល់តែព្រះអម្ចាស់ទ្រង់យាងមក; ៤–៨, ពេត្រុស យ៉ាកុប និងយ៉ូហាន កាន់កូនសោនៃ ដំណឹងល្អ។*

១ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថាៈ [ក]យ៉ូហាន ដ៏ជាទីស្រឡាញ់របស់យើងអើយ តើអ្នកប្រាថ្នាអ្វី ? ត្បិតបើសិនជាអ្នក នឹងសុំតាមបំណងរបស់អ្នក នោះនឹងបានប្រទានដល់អ្នកហើយ ។

២ ហើយខ្ញុំបានទូលទ្រង់ថាៈ ព្រះអម្ចាស់អើយ សូមប្រទានដល់ទូលបង្គំ នូវអំណាចលើ[ក]សេចក្ដីស្លាប់ ដើម្បីឲ្យទូលបង្គំអាចនៅរស់ ហើយនាំព្រលឹងទាំងឡាយមករកព្រះអង្គ ។

៣ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថាៈ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ពីព្រោះអ្នកចង់បានការណ៍នេះ នោះអ្នក [ក]នឹងនៅ ទាល់តែយើងមក នៅក្នុង[ខ]សិរីល្អរបស់យើង ហើយនឹង[គ]ព្យាករនៅចំពោះសាសន៍ ពូជមនុស្ស ភាសា និងប្រជាជន ។

៤ ហើយមកពីករណីនេះ បានជាព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅពេត្រុសថាៈ បើសិនជាយើងចង់ឲ្យអ្នកនោះនៅ ទាល់តែយើង មក នោះតើអំពល់អ្វីដល់អ្នក ? ត្បិតគាត់បានប្រាថ្នា

៣៣ *ក* ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន.
*ខ* កាឡាទី ៦:៧–៨; ម៉ូសាយ ៧:៣០–៣១; អាលម៉ា ៩:២៨; គ. និង ស. ១:១០.
៣៤ *ក* ទំនុក. ៧១:៣; ម៉ាថាយ ៧:២៤–២៥; ១ កូរិន. ១០:១–៤; ហេលេ. ៥:១២; គ. និង ស. ១០:៦៩; ១៨:៤, ១៧; ៣៣:១៣; ម៉ូសេ ៧:៥៣. ស.ប. ថ្ម.
៣៥ *ក* យ៉ូហាន ៨:៣–១១.
៣៦ *ក* អេសាយ ៤៥:២២; គ. និង ស. ៤៣:៣៤.
៣៧ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការលេចមករបស់ព្រះគ្រីស្ទក្រោយពីសុគត.
*ខ* ស.ប. ការឆ្កាង.
*គ* ម៉ាថាយ ៥:៣, ១០; ៣ នីហ្វៃ ១២:៣, ១០.
*ឃ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
**៧** ១ *ក* ស.ប. យ៉ូហាន, កូនប្រុសរបស់សេបេដេ.
*ខ* ៣ នីហ្វៃ ២៨:១–១០.
២ *ក* លូកា ៩:២៧. ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
៣ *ក* យ៉ូហាន ២១:២០–២៣. ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.
*ខ* ស.ប. សិរីល្អ; ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*គ* វិវរ. ១០:១១.

ការណ៍នោះពីយើង ដើម្បីឲ្យគាត់អាចនាំមនុស្សទាំងឡាយមករកយើង ប៉ុន្តែអ្នកបាន ប្រាថ្នាសូមឲ្យអ្នកអាចបានមកឯយើងនៅឯនគរយើងយ៉ាងឆាប់រហ័សវិញ ។

៥ យើងប្រាប់អ្នកថា ពេត្រុសអើយ នេះជាសំណូមពរដ៏ល្អមួយ ប៉ុន្តែអ្នកដ៏ជាទីស្រឡាញ់របស់យើង គាត់បានប្រាថ្នាសូមឲ្យគាត់ធ្វើលើសទៅទៀត ឬក៏កិច្ចការលើសទៅទៀត នៅក្នុងចំណោមមនុស្ស ជាងអ្វីដែលគាត់ធ្លាប់បានធ្វើពីមុនមក ។

៦ មែនហើយ គាត់បានចាប់ផ្ដើមធ្វើកិច្ចការលើសលែង «មិនស្គាល់ពាក្យ លើសលែង» ទៅទៀត ហេតុដូច្នេះហើយ យើងនឹងធ្វើឲ្យគាត់ទៅដូចជាអណ្ដាតភ្លើង និងជា ទេវតាបំរើ; គាត់នឹងបំរើដល់អស់អ្នកណាដែលនឹងគ្រងសេចក្ដីសង្គ្រោះទុកជាមរតកដែលអាស្រ័យនៅលើផែនដី ។

៧ ហើយយើងនឹងធ្វើឲ្យអ្នកបំរើដល់គាត់ និងដល់យ៉ាកុបជាបងប្អូនរបស់អ្នក រីឯអ្នកទាំងបីវិញ យើងនឹងឲ្យអំណាចនេះនិងកូនសោទាំងឡាយ នៃការងារបំរើនេះ ទាល់តែយើងមក ។

៨ ប្រាកដមែនយើងប្រាប់អ្នករាល់គ្នាថា អ្នកទាំងពីរនឹងបានតាមសេចក្ដីប្រាថ្នារបស់អ្នក ត្បិតអ្នកទាំងពីរមានសេចក្ដីត្រេកអរនឹងអ្វីដែលអ្នកបានប្រាថ្នានោះ ៕

## កណ្ឌទី៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះអូលីវើរខៅឌើរ នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា នៅខែមេសា ឆ្នាំ១៨២៩ (*History of the Church*, ១:៣៦–៣៧)* ។ *ក្នុងដំណើរការបកប្រែព្រះគម្ពីរមរមន នោះអូលីវើរ បន្ដបំរើ ជាស្មៀននៅឡើយ ដោយសរសេរតាមមាត់របស់ព្យាការី គាត់មានបំណងចង់បានគ្រប់ដណ្ដប់ដោយអំណោយទានខាង ការបកប្រែ ។ ព្រះអម្ចាស់ទ្រង់បានឆ្លើយតបនូវការអង្វររបស់លោក ដោយប្រទានវិវរណៈនេះ ។*

*១–៥, វិវរណៈបានមកដោយសារព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ; ៦–១២, ចំណេះអំពីសេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ ហើយអំណាច ដើម្បីបកប្រែបញ្ជីបូរាណនោះបានមកដោយសារសេចក្ដីជំនឿ ។*

អូលីវើរខៅឌើរអើយ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ពិតដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ ជាព្រះរបស់អ្នក និងជាព្រះដ៏ប្រោសលោះរបស់អ្នក នោះអ្នកពិតជានឹងបានទទួលចំណេះអំពីការណ៍ទាំងឡាយណា ដែលអ្នកនឹងសូមដោយសេចក្ដីជំនឿ ដោយមានចិត្តទៀងត្រង់ ដោយជឿថាអ្នកនឹងបានទទួលចំណេះ អំពីចារឹកនៃបញ្ជីប្រវត្តិចំណាស់ ដែលជារបស់បូរាណ ដែលមានភាគទាំងឡាយនោះពីបទគម្ពីររបស់យើង ដែលបានពោលដល់ ដោយការបើកសំដែងនៃវិញ្ញាណរបស់យើង ។

២ មែនហើយ មើលចុះ យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់ អ្នក និងនៅក្នុងចិត្តរបស់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងសណ្ឋិតមកលើអ្នក ហើយដែលនឹងគង់នៅក្នុងចិត្តរបស់អ្នក ។

៣ ឥឡូវនេះ មើលចុះ នេះជាវិញ្ញាណនៃវិវរណៈ មើលចុះ នេះជាវិញ្ញាណដែលលោកម៉ូសេបាននាំកូនចៅអ៊ីស្រាអែលឆ្លងសមុទ្រ ក្រហមលើដីគោក ។

៤ ហេតុដូច្នេះហើយ នេះជាអំណោយទានរបស់អ្នក ចូរអនុវត្តចុះ ហើយអ្នកមានពរហើយ ព្រោះអំណោយទាននេះនឹងដោះលែងអ្នក ឲ្យរួចផុតពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់អ្នក ម្ល៉ោះហើយបើសិនជាពុំនោះសោតទេ ពួកគេនឹងប្រហារអ្នកបង់ ហើយនាំព្រលឹងរបស់ អ្នកទៅរកសេចក្ដីបំផ្លិចបំផ្លាញ ។

៥ ឱ ចូរចងចាំពាក្យទាំងឡាយនេះ ហើយចូរកាន់តាមបញ្ញត្តិ

៤ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
៦ *ក* គ. និង ស. ១៣០:៥.
*ខ* គ. និង ស. ៧៦:៨៦–៨៨.
*គ* យ៉ូហាន ១០:៨–១១; គ. និង ស. ៧៧:១៤.
៧ *ក* ម៉ាថាយ ១៦:១៩; កិច្ចការ ១៥:៧; យ.ស. — ប្រវត្តិ ១:៧២. ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
៨ *ក* ស.ប. សេចក្ដីអំណរ.
**៨** ១*ក* យ.ស. — ប្រវត្តិ ១:៦៦. ស.ប. ខៅឌើរ, អូលីវើរ.
*ខ* ស.ប. ជំរិះ.
*គ* ស.ប. ការអធិស្ឋាន.
*ឃ* គ. និង ស. ៦:២៦–២៧; ៩:២.
*ង* គ. និង ស. ៥:១៦.
២ *ក* គ. និង ស. ៩:៧–៩. ស.ប. វិវរណៈ.
*ខ* ស.ប. ចិត្ត.
*គ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៣ *ក* និក្ខ. ១៤:១៣–២២; ចោទិ. ១១:៤; ១ នីហ្វៃ ៤:២; ម៉ូសាយ ៧:១៩. ស.ប. សមុទ្រក្រហម.
៥ *ក* ចោទិ. ១១:១៨–១៩.

ទាំងឡាយរបស់យើងចុះ ចូរចងចាំចុះថា នេះជាអំណោយទាន
របស់អ្នក។
៦ ឥឡូវនេះពុំមែនជាអំណោយទានរបស់អ្នកទាំងអស់ទេ ត្បិត
អ្នកមានអំណោយទានផ្សេងទៀត ដែលជាអំណោយទាននៃ
លោកអើរ៉ុន មើលចុះ អំណោយទាននេះបានប្រាប់អ្នកនូវការណ៍
ជាច្រើន;
៧ មើលចុះ គ្មានអំណាចឯណាឡើយ ក្រៅពីព្រះចេស្ដានៃព្រះ
ដែលអាចបណ្ដាលឲ្យអ្នកមានអំណោយទាននៃលោកអើរ៉ុននេះ ។
៨ ហេតុដូច្នេះហើយ ចូរកុំសង្ស័យឡើយ ត្បិតនេះជា
អំណោយទាននៃព្រះ ហើយអ្នកនឹងបានអំណោយទាននេះនៅក្នុង
ដៃរបស់អ្នក ហើយ នឹងធ្វើកិច្ចការដ៏អស្ចារ្យទាំងឡាយ ហើយនឹង
គ្មានអំណាចណាអាចយកពីដៃរបស់អ្នកបានឡើយ ត្បិតនេះជា
កិច្ចការនៃព្រះ ។
៩ ហើយ ម្ល៉ោះហើយ អ្វីៗដែលអ្នកនឹងសូមពីយើងឲ្យប្រាប់អ្នក
ដោយមធ្យោបាយទាំងឡាយនោះ នោះយើងនឹងប្រទានដល់អ្នក
ហើយអ្នកនឹងបានដឹងអំពីការណ៍នោះ ។
១០ ចូរចងចាំថា បើគ្មាន[ក]សេចក្ដីជំនឿ នោះអ្នកពុំអាចធ្វើអ្វីបាន
ទេ ហេតុដូច្នេះហើយ ចូរ[ខ]សុំមដោយនូវសេចក្ដីជំនឿ ។ ចូរកុំប្រ
ហែស នឹងការណ៍ទាំងឡាយនេះ ចូរកុំសូមអ្វីដែលអ្នកមិនគួរសូម
នោះឡើយ ។
១១ ចូរសូមដើម្បីឲ្យអ្នកអាចដឹងនូវសេចក្ដីអាថ៌កំបាំងទាំង
ឡាយនៃព្រះ ហើយដើម្បីឲ្យអ្នកអាច[ក]បកប្រែ ហើយទទួលចំណេះ
ពីអស់ទាំង បញ្ជីប្រវត្តិបុរាណទាំងឡាយនោះ ដែលបានលាក់ទុក
ដែលពិសិដ្ឋ ហើយស្របតាមសេចក្ដីជំនឿរបស់អ្នក នោះនឹងបាន
សំរេចដល់អ្នកហើយ ។
១២ មើលចុះ គឺជាយើងនេះហើយ ដែលបានមានបន្ទូល
ពីការណ៍នេះ ហើយយើងជាអ្នកដដែលនោះ ដែលបានមាន
បន្ទូលមកកាន់អ្នក ចាប់តាំងពីដំបូងមកម្ល៉េះ ។ អាម៉ែន ៕

## កណ្ឌទី៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះអូលីវើរខៅឌើរី នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា នៅខែមេសា ឆ្នាំ១៨២៩ (*History of the Church, *១:៣៧–៣៨) ។ អូលីវើរត្រូវបានទូន្មានឲ្យមានចិត្តអត់ធ្មត់ ហើយត្រូវបានជំរុញ ឲ្យពេញចិត្តនឹងការសរសេរតាម ត្បិតនៅពេលនេះ គឺសរសេរតាមមាត់នៃអ្នកបកប្រែ ជាជាងសាកបកប្រែវិញ ។*

*១–៦, បញ្ជីប្រវត្តិបុរាណឯទៀតទាំងប៉ុន្មាន នោះនឹងត្រូវតែបានបកប្រែ; ៧–១៤, ព្រះគម្ពីរមរមន គឺបានបកប្រែដោយការសិក្សា និងដោយការបញ្ជាក់ខាងវិញ្ញាណ ។*

មើលចុះ កូនអើយ យើងប្រាប់អ្នកថា ពីព្រោះអ្នកពុំបាន[ក]បកប្រែ
ស្របតាម[ខ]អ្វីដែលអ្នកមានបំណងចង់បានពីយើង ហើយបាន
ចាប់ផ្ដើម សរសេរជូនយ៉ូសែបស្ម៊ីធ ជុញ៉ោរ ជាអ្នកបំរើរបស់យើង
ម្ដងទៀត ដោយហេតុនោះហើយ យើងសូមឲ្យអ្នកធ្វើតទៅទៀត
ទាល់តែអ្នកបានបញ្ចប់បញ្ជីប្រវត្តិនេះ ដែលយើងបានផ្ដាក់ផ្ទុក
ដល់អ្នក ។
២ ហើយខណៈនោះ មើលចុះ [ក]បញ្ជីប្រវត្តិ[ខ]ឯទៀតទាំងប៉ុន្មាន
ដែលយើងមាន នោះយើងនឹងប្រទានដល់អ្នកនូវអំណាច ដើម្បីឲ្យ
អ្នកអាចជួយបកប្រែបាន ។
៣ ចូរមានចិត្តអត់ធ្មត់ចុះ កូនអើយ ត្បិតនេះជាប្រាជ្ញានៅ
ក្នុងយើង ហើយមិនចាំបាច់ឲ្យអ្នកគួរបកប្រែ នៅពេលនេះទេ ។
៤ មើលចុះ កិច្ចការដែលអ្នកបានហៅឲ្យធ្វើ គឺដើម្បីសរសេរ
ជូនយ៉ូសែប ជាអ្នកបំរើរបស់យើង ។
៥ ហើយមើលចុះ គឺព្រោះថាអ្នកពុំបានធ្វើតទៅទៀត ដូចជា
អ្នកបានចាប់ផ្ដើម កាលអ្នកបានចាប់ផ្ដើមបកប្រែ នោះយើងបាន
ដកឯកសិទ្ធិ នេះចេញពីអ្នក ។
៦ ចូរកុំ[ក]រអ៊ូរទាំឡើយ កូនអើយ ត្បិតនេះជាប្រាជ្ញានៅក្នុងយើង
ដែលយើងបានប្រព្រឹត្តចំពោះអ្នក តាមរបៀបនេះ ។

១០ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* គ. និង ស. ៨៨:៦៣–៦៥.
១១ *ក* គ. និង ស. ៩:១, ១០.
៩ ១*ក* គ. និង ស. ៨:១, ១១.
*ខ* យ.ស. — ប្រវត្តិ ១:៦៧.
២ *ក* ការនិយាយបញ្ឆៀងអំពីការបកប្រែផ្សេងៗទៀត ព្រមទាំងការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស្ម៊ីធ និងគម្ពីរអ័ប្រាហាំ ដែលអូលីវើរ ខៅឌើរីបានជួយក្នុងការធ្វើជាស្មៀន។ ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.).
*ខ* គ. និង ស. ៦:២៦; ៨:១.
៦ *ក* ស.ប. រអ៊ូរទាំ.

៧ មើលចុះ អ្នកពុំយល់ឡើយ អ្នកបានសន្និដ្ឋានថា យើងនឹងប្រទានឯកសិទ្ធិនេះដល់អ្នក កាលអ្នកពុំបានយកមកគិតសោះ ក្រៅពីសុំមពី យើង ។

៨ ប៉ុន្តែមើលចុះ យើងប្រាប់អ្នកថា អ្នកត្រូវ[ក]សិក្សាក្នុងគំនិតរបស់អ្នក រួចហើយ អ្នកត្រូវ[ខ]សួមដល់យើង បើសិនជាការណ៍នោះត្រឹមត្រូវ ហើយបើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្តាលឲ្យ[គ]ទ្រូងរបស់អ្នក[ឃ]ខ្វល់ខ្វាញ់ខាងក្នុង ហេតុដូច្នោះហើយ អ្នកនឹង[ង]មានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ ។

៩ ប៉ុន្តែបើសិនជាការណ៍នោះមិនត្រឹមត្រូវវិញ នោះអ្នកនឹងពុំមានអារម្មណ៍យ៉ាងដូច្នោះឡើយ ប៉ុន្តែអ្នកនឹង[ក]អាប់គំនិត ដែលនឹងបណ្តាល ឲ្យអ្នកភ្លេចនូវអ្វីដែលខុស ម្ល៉ោះហើយ អ្នកមិនអាចសរសេរអ្វីដែលពិសិដ្ឋបានឡើយ លើកលែងតែបានប្រទានឲ្យមកពីយើង ។

១០ ឥឡូវនេះ បើសិនជាអ្នកបានដឹងពីការណ៍នេះ នោះអ្នកអាច[ក]បកប្រែបាន ក៏ប៉ុន្តែ គឺមិនចាំបាច់ឲ្យអ្នកគួរបកប្រែឥឡូវនេះទេ ។

១១ មើលចុះ គឺជាការចាំបាច់ ក្នុងកាលអ្នកបានចាប់ផ្តើម ប៉ុន្តែអ្នកបាន[ក]ភ័យខ្លាច ហើយពេលនោះកន្លងផុតទៅហើយ ហើយឥឡូវនេះ មិនចាំបាច់ទេ ។

១២ ត្បិតតើអ្នកមិនបានឃើញថា យើងបានប្រទានកម្លាំងគ្រប់គ្រាន់ដល់[ក]យ៉ូសែប ជាអ្នកបំរើរបស់យើង ម្ល៉ោះហើយ បានស្កប់ស្កល់ ហើយទេឬអី ? ហើយរីឯអ្នកទាំងពីរ យើងពុំបានកាត់ទោសទេ ។

១៣ ចូរធ្វើនូវការណ៍នេះ ដែលយើងបានបញ្ជាដល់អ្នកចុះ នោះអ្នកនឹងបានចំរើនឡើង ។ ចូរមានចិត្តស្មោះត្រង់ ហើយចូរកុំបណ្តោយ ទៅតាមសេចក្តី[ក]ល្បួងឡើយ ។

១៤ ចូរឈរឲ្យមាំមួនក្នុង[ក]កិច្ចការ ដែលយើងបាន[ខ]ហៅឲ្យអ្នកធ្វើ ហើយសក់១សរសៃលើក្បាលអ្នក ក៏មិនត្រូវបាត់ដែរ ហើយអ្នកនឹងត្រូវ[គ]បានលើកឡើង នៅថ្ងៃចុងក្រោយបង្អស់ ។ អាម៉ែន ៕

## កណ្ឌទី១០

*វិវរណៈដែលបានប្រទានដល់យ៉ូសែបស្ម៊ីធ ជាព្យាការី នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា នៅរដូវក្តៅក្នុងឆ្នាំ១៨២៨ (*History of the Church*, ១:២០–២៣) ។ នៅក្នុងវិវរណៈនេះ ព្រះអម្ចាស់ទ្រង់ប្រាប់យ៉ូសែបស្ម៊ីធអំពីការកែប្រែដែលបានធ្វើឡើងដោយពួកមនុស្សទុច្ចរិត នូវឯកសារ១១៦សន្លឹក ចេញពីការបកប្រែនៃគម្ពីរលីហៃ នៅក្នុងព្រះគម្ពីរមរមន ។ ឯកសារទាំងប៉ុន្មានសន្លឹកនេះត្រូវបានបាត់ពីដៃម៉ាទិនហារិស ជាអ្នកដែលបានផ្ទាក់ផ្ទុកបណ្តោះអាសន្ននូវសន្លឹកទាំងឡាយនោះ ។ (សូមមើលចំណងជើងកណ្ឌទី៣) ។ គំរោងការណ៍ដ៏អាក្រក់ គឺដើម្បីរង់ចាំមើលការបកប្រែម្តងទៀត នូវអ្វីៗដែលមានក្នុងសន្លឹកទាំងឡាយ ដែលបានលួចទៅនោះ ហើយបន្ទាប់មក ដើម្បីបង្ខូចឈ្មោះអ្នកបកប្រែ ដោយបង្ហាញនូវភាពមិនស្របគ្នា ដែលបានធ្វើឡើងដោយការកែប្រែនោះ ។ ហើយគំរោងការណ៍ដ៏ទុច្ចរិតនេះ ដែលបានបង្កើតឡើងដោយអ្នកអាក្រក់ ហើយបានដឹងដល់ព្រះអម្ចាស់ ចាប់តាំងពីមរមន ជាប្រវត្តិសាស្ត្របុរាណ សាសន៍នីហ្វៃ កំពុងធ្វើការសង្ខេបរបស់លោក អំពីផ្ទាំងទាំងឡាយដែលបានប្រមូលទុកមកនោះ គឺបានបង្ហាញនៅក្នុងព្រះគម្ពីរមរមនមក (សូមមើល ពាក្យសំដីនៃមរមន ១:៣–៧) ។*

*១–២៦, អារក្សសាតាំងចាក់រុកពួកមនុស្សទុច្ចរិត ឲ្យជំទាស់នឹងកិច្ចការរបស់ព្រះអម្ចាស់; ២៧–៣៣, វាព្យាយាមរកបំផ្លាញចោលនូវ ព្រលឹងទាំងឡាយនៃមនុស្សលោក; ៣៤–៥២, ដំណឹងល្អនឹងត្រូវបានទៅដល់ពួកសាសន៍លេមិន និងអស់ទាំងសាសន៍ តាមរយៈព្រះគម្ពីរមរមន; ៥៣–៦៣ ព្រះអម្ចាស់ទ្រង់នឹងតាំងឡើងនូវសាសនាចក្ររបស់ទ្រង់ និងដំណឹងល្អរបស់ទ្រង់ ក្នុងចំណោមមនុស្សលោក; ៦៤–៧០, ទ្រង់នឹងប្រមូលពួកអ្នកដែលប្រែចិត្ត ឲ្យចូលរួមក្នុងសាសនាចក្ររបស់ទ្រង់ ហើយនឹងសង្គ្រោះពួកអ្នកដែលគោរពតាម ។*

៨ *ក* ស.ប. រំពឹងគិត.
*ខ* ស.ប. ការអធិស្ឋាន.
*គ* លូកា ២៤:៣២.
*ឃ* ស.ប. ការបំផុសគំនិត, បំផុសគំនិត; ទីបន្ទាល់.
*ង* គ. និង ស. ៨:២–៣.
៩ *ក* គ. និង ស. ១០:២.
១០ *ក* គ. និង ស. ៨:១១.
១១ *ក* ស.ប. សេចក្តីកោតខ្លាច.
១២ *ក* គ. និង ស. ១៨:៨.
១៣ *ក* ស.ប. ល្បួង, សេចក្តីល្បួង.
១៤ *ក* ១ កូរិន. ១៦:១៣.
*ខ* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
*គ* អាលម៉ា ១៣:២៩; គ. និង ស. ១៧:៨.

ឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា គឺមកពីអ្នកបានប្រគល់ឯកសារទាំងឡាយនោះ ដែលអ្នកបានទទួលអំណាច ដើម្បីបកប្រែ ដោយនូវមធ្យោបាយនៃ[ក]យូរីម និងធូមីម ទៅក្នុងកណ្ដាប់ដៃនៃ[ខ]មនុស្សទុច្ចរិត បានជាអ្នកបាត់ឯកសារទាំងនោះទៅ ។

២ ហើយអ្នកក៏នឹងលែងមានអំណោយទានរបស់អ្នក នៅពេលនោះដែរ ហើយ[ក]គំនិតរបស់អ្នកប្រែជាងងឹតងងល់ទៅវិញ ។

៣ ក៏ប៉ុន្តែ អំណោយទាននោះ[ក]ត្រូវបានប្រទានដល់អ្នកវិញហើយ ម្ល៉ោះហើយ ចូរបញ្ជាក់ឲ្យឃើញថា អ្នកមានចិត្តស្មោះត្រង់ ហើយធ្វើការបន្តទៅទៀត ដរាបដល់បញ្ចប់ការបកប្រែដែលនៅសល់ទាំងប៉ុន្មាន ដែលអ្នកបានចាប់ផ្ដើមមកហើយនោះ ។

៤ ចូរកុំ[ក]រត់លឿន ឬធ្វើការលើសជាង[ខ]កម្លាំងដែលអ្នកមាន និងមធ្យោបាយដែលបានផ្ដល់ឲ្យអ្នកអាចបកប្រែនោះឡើយ ប៉ុន្តែចូរមាន[គ]ចិត្ត ព្យាយាម ដរាបដល់ចុងបំផុតចុះ ។

៥ ចូរ[ក]អធិស្ឋានជានិច្ច ប្រយោជន៍ឲ្យអ្នកអាចក្លាយទៅជាអ្នកជំនះបាន មែនហើយ ប្រយោជន៍ឲ្យអ្នកអាចយកឈ្នះលើអារក្សសាតាំងបាន ហើយប្រយោជន៍ឲ្យអ្នកអាចរួចផុតពីកណ្ដាប់ដៃនៃពួកអ្នកបំរើរបស់អារក្សសាតាំង ដែលទ្រទ្រង់កិច្ចការរបស់វានោះ ។

៦ មើលចុះ ពួកគេបានព្យាយាមរក[ក]បំផ្លាញអ្នកបង់ មែនហើយ [ខ]សូម្បីតែអ្នកនោះដែលអ្នកបានទុកចិត្ត ក៏បានព្យាយាមរកបំផ្លាញអ្នកចោលដែរ ។

៧ ហើយដោយហេតុនេះហើយ បានជាយើងថាអ្នកនោះជាមនុស្សទុច្ចរិត ត្បិតគាត់បានខំស្វែងរក ដើម្បីដកយកអ្វីៗដែលអ្នកបានទទួលការផ្ដាក់ផ្ដុកចេញ ហើយគាត់ក៏បានព្យាយាមរកបំផ្លាញអំណោយទានរបស់អ្នកចោលដែរ ។

៨ ហើយពីព្រោះអ្នកបានប្រគល់ឯកសារទាំងឡាយនោះ ទៅក្នុងកណ្ដាប់ដៃរបស់គាត់ មើលចុះ ពួកមនុស្សទុច្ចរិតបានយករបស់ទាំង នោះពីអ្នកទៅ ។

៩ ហេតុដូច្នោះហើយ អ្នកបានប្រគល់របស់ទាំងនោះ មែនហើយ គឺជារបស់ដែលពិសិដ្ឋ ទៅឯអំពើទុច្ចរិត ។

១០ ហើយមើលចុះ [ក]អារក្សសាតាំងបានដាក់ក្នុងចិត្តរបស់ពួកគេ ឲ្យកែប្រែនូវពាក្យពេចន៍ទាំងឡាយ ដែលអ្នកបានបណ្ដាលឲ្យសរសេរ ឬនូវអ្វីដែលអ្នកបានបកប្រែ ដែលបានបាត់ពីដៃអ្នកទៅ ។

១១ ហើយមើលចុះ យើងប្រាប់អ្នកថា គឺមកពីពួកគេបានកែប្រែនូវពាក្យពេចន៍ទាំងឡាយ បានជាពាក្យពេចន៍ទាំងឡាយនោះអានខុសពី អ្វីដែលអ្នកបានបកប្រែ និងដែលបានបណ្ដាលឲ្យសរសេរនោះ;

១២ ហើយតាមមាគ៌ានេះ អារក្សបានខំរក ដើម្បីដាក់ផែនការមួយដ៏ប្រកបដោយកលល្បិច ប្រយោជន៍ឲ្យវាអាចបំផ្លាញកិច្ចការនេះ ចោល;

១៣ ត្បិតវាបានដាក់ក្នុងចិត្តពួកគេ ឲ្យធ្វើការនេះ ថាដោយការកុហក នោះពួកគេអាចនិយាយថាពួកគេបាន[ក]ចាប់អ្នកបាន ដោយនូវ ពាក្យពេចន៍ ដែលអ្នកបន្លំធ្វើជាបានបកប្រែ ។

១៤ ប្រាកដមែន យើងប្រាប់អ្នកថា យើងនឹងមិនទ្រាំឲ្យអារក្សសាតាំងសំរេចនូវគំរោងការណ៍ដ៏អាក្រក់របស់វា ដោយនូវការណ៍នេះ ឡើយ ។

១៥ ត្បិតមើលចុះ វាបានដាក់ទៅក្នុងចិត្តរបស់ពួកគេ ធ្វើឲ្យអ្នកសាកល្បងព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ដោយនូវការសូមឲ្យបកប្រែ ម្ដងទៀត ។

១៦ ហើយបន្ទាប់មក មើលចុះ ពួកគេនឹងនិយាយហើយគិតក្នុងចិត្តគេថា — យើងនឹងមើលថាតើព្រះទ្រង់បានប្រទានអំណាចឲ្យគាត់បក ប្រែមែនឬអី បើសិនជាមែន នោះទ្រង់នឹងប្រទានអំណាចដល់គាត់ម្ដងទៀត;

១៧ ហើយបើសិនជាព្រះទ្រង់ប្រទានអំណាចដល់គាត់ម្ដងទៀត ឬក៏បើសិនជាគាត់បកប្រែម្ដងទៀត ឬម៉្យាងទៀត បើសិនជាគាត់នាំមកនូវពាក្យពេចន៍ដដែល មើលចុះ យើងនឹងមានពាក្យពេចន៍ដូចគ្នានៅជាមួយយើង តែយើងបានកែប្រែពាក្យទាំងនោះ;

១៨ ហេតុដូច្នេះហើយ ពាក្យពេចន៍ទាំងនោះនឹងមិនស្របគ្នាទេ ហើយយើងនឹងថាគាត់បានកុហក ដោយនូវពាក្យពេចន៍របស់គាត់ ហើយថាគាត់គ្មានអំណោយទានទេ ហើយថាគាត់គ្មានអំណាចឡើយ;

១៩ ហេតុដូច្នេះហើយ យើងនឹងបំផ្លាញគាត់ ហើយនិងកិច្ចការនោះផងដែរ ហើយយើងនឹងធ្វើការនេះ ដើម្បីកុំឲ្យ

១០ ១ *ក* ស.ប. យូរីម និងធូមីម.
*ខ* គ. និង ស. ៣:១–១៥.
២ *ក* ស.ប. គំនិត.
៣ *ក* គ. និង ស. ៣:១០.
៤ *ក* ម៉ូសាយ ៤:២៧.
*ខ* និក្ខ. ១៨:១៣–២៦.
*គ* ម៉ាថាយ ១០:២២.
ស.ប. ព្រះដ៏ប្រោសឲ្យរួច.
៥ *ក* ៣ នីហ្វៃ ១៨:១៥–២១.
ស.ប. ការអធិស្ឋាន.
៦ *ក* គ. និង ស. ៥:៣២–៣៣;
៣៨:១៣.
*ខ* គ. និង ស. ៥:១–២.
១០ *ក* ស.ប. អារក្ស.
១៣ *ក* យេរេ. ៥:២៦.

យើងអាម៉ាស់នៅ ទីបញ្ចប់ ហើយដើម្បីឲ្យយើងអាចបានសិរីល្អនៃពិភពលោក ។

២០ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា [ក]អារក្សសាតាំងបានក្ដាប់យ៉ាងជាប់មកលើដួងចិត្តរបស់ពួកគេ វាចាក់រុកពួកគេឲ្យធ្វើ [ខ]សេចក្ដីទុច្ចរិត ទាស់នឹងអ្វីដែលជាល្អ;

២១ ហើយដួង[ក]ចិត្តរបស់ពួកគេពុករលួយ ហើយពោរពេញទៅដោយ[ខ]អំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ ហើយពួកគេ [គ]ស្រឡាញ់[ឃ]សេចក្ដីងងឹត ជាជាងពន្លឺ ពីព្រោះ[ង]អំពើរបស់ពួកគេសុទ្ធតែអាក្រក់ ហេតុដូច្នេះហើយ ពួកគេពុំសុំអ្វីពីយើងឡើយ ។

២២ [ក]អារក្សសាតាំងចាក់រុកពួកគេឡើង ដើម្បីឲ្យវាអាច[ខ]នាំព្រលឹងទាំងឡាយរបស់គេទៅរកសេចក្ដីបំផ្លិចបំផ្លាញ ។

២៣ ហើយដោយហេតុនោះ វាបានដាក់ផែនការមួយដ៏ប្រកបដោយកលល្បិច ដោយគិតដើម្បីបំផ្លាញកិច្ចការនៃព្រះ ចោល ប៉ុន្តែ យើងនឹងទាមទារការណ៍នេះពីដៃរបស់ពួកគេ ហើយការណ៍នេះនឹងបែរទៅជាសេចក្ដីអាម៉ាស់ និងជាសេចក្ដីដាក់ទោសដល់ពួកគេវិញ នៅ[ក]ថ្ងៃជំនុំជំរះ ។

២៤ មែនហើយ វាចាក់រុកដួងចិត្តរបស់ពួកគេ ឲ្យមានកំហឹងទាស់នឹងកិច្ចការនេះ ។

២៥ មែនហើយ វាបានប្រាប់ពួកគេថា៖ ចូរបោកបញ្ឆោត ហើយលបចាំចាប់ចុះ ដើម្បីឲ្យអ្នកអាចបំផ្លាញចោល មើលចុះ ការណ៍នេះ គ្មានខុសអ្វីទេ ។ ហើយដោយហេតុនោះហើយ វាបញ្ឆោរពួកគេ ហើយប្រាប់ពួកគេថាគ្មានបាបអ្វីទេ ដែល[ក]កុហក ដើម្បីឲ្យពួកគេអាច ចាប់មនុស្សដែលកុហក ប្រយោជន៍ឲ្យពួកគេអាចបំផ្លាញអ្នកនោះបង់ ។

២៦ ហើយដោយហេតុនោះហើយ វាបញ្ឆោរពួកគេ ហើយ[ក]នាំពួកគេ លុះត្រាវាបានទាញព្រលឹងទាំងឡាយរបស់ពួកគេចុះទៅរក[ខ]ស្ថាននរក ហើយដោយហេតុនោះហើយ វាបណ្ដាលឲ្យពួកគេចាប់ខ្លួនគេផ្ទាល់ នៅក្នុង[គ]អន្ទាក់របស់ខ្លួន ។

២៧ ហើយដោយហេតុនោះហើយ វាដើរចុះឡើង[ក]ទៅមកនៅលើផែនដី ដោយព្យាយាមរក[ខ]បំផ្លាញព្រលឹងទាំងឡាយ នៃមនុស្ស លោក ។

២៨ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា វេទនាដល់អ្នកណា ដែល[ក]កុហកដើម្បីបោកបញ្ឆោត ពីព្រោះអ្នកនោះសន្និដ្ឋានថាអ្នកដទៃ កុហកដើម្បីបោកបញ្ឆោតដែរ ត្បិតមនុស្សរបៀបនេះពុំបានរួចផុតពី[ខ]សេចក្ដីយុត្តិធម៌នៃព្រះឡើយ ។

២៩ ឥឡូវនេះ មើលចុះ ពួកគេបានកែប្រែពាក្យពេចន៍ទាំងឡាយនេះ ពីព្រោះអារក្សសាតាំងប្រាប់ពួកគេថា៖ អ្នកនោះបានបោកបញ្ឆោតអ្នកហើយ — ដោយហេតុនោះហើយ វាបញ្ឆោរពួកគេឲ្យចេញទៅធ្វើសេចក្ដីទុច្ចរិត ដើម្បីធ្វើឲ្យអ្នក[ក]សាកល្បងព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក ។

៣០ មើលចុះ យើងប្រាប់អ្នកថា អ្នកនឹងមិនត្រូវបកប្រែពាក្យពេចន៍ទាំងឡាយនោះ ដែលបានបាត់ពីដៃរបស់អ្នកទៀតទេ;

៣១ ត្បិតមើលចុះ ពួកគេនឹងពុំបានសំរេចគំរោងការណ៍ដ៏អាក្រក់របស់ពួកគេ ដោយនូវការកុហកជំទាស់នឹងពាក្យពេចន៍ទាំងឡាយ នោះឡើយ ។ ត្បិតមើលចុះ បើសិនជាអ្នកបាននាំមកនូវពាក្យពេចន៍ដដែល នោះពួកគេនឹងថាអ្នកបានកុហក ហើយថាអ្នកបានបន្លំ បកប្រែ ប៉ុន្តែថាអ្នកបានជំទាស់ខ្លួនឯង ។

៣២ ហើយមើលចុះ ពួកគេបានផ្សាយការណ៍នេះ ហើយអារក្សសាតាំងនឹងពង្រឹងចិត្តមនុស្ស ឲ្យចាក់រុកពួកគេឲ្យមានកំហឹងទាស់ នឹងអ្នក ដើម្បីកុំឲ្យពួកគេជឿដល់ពាក្យពេចន៍របស់យើង ។

៣៣ ម្ល៉ោះហើយ [ក]អារក្សសាតាំងគិតដើម្បីមានអំណាចលើទីបន្ទាល់របស់អ្នក នៅក្នុងតំណនេះ ដើម្បីកុំឲ្យកិច្ចការនេះអាចបានកើត ឡើង នៅក្នុងតំណនេះឡើយ ។

៣៤ ប៉ុន្តែមើលចុះ នេះជាប្រាជ្ញា ហើយពីព្រោះយើងបង្ហាញ

២០ *ក* ២ នីហ្វៃ ២៨:២០–២២.
*ខ* ស.ប. អំពើបាប.
២១ *ក* គ. និង ស. ១១២:២៣–២៤.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
*គ* ម៉ូសេ ៥:១៣–១៨.
*ឃ* ម៉ូសាយ ១៥:២៦.
ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
*ង* យ៉ូហាន ៣:១៨–២១;
គ. និង ស. ២៩:៤៥.
២២ *ក* ២ នីហ្វៃ ២:១៧–១៨.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
២៣ *ក* ហេលេ. ៨:២៥;
គ. និង ស. ១២១:២៣–២៥.
២៥ *ក* ២ នីហ្វៃ ២:១៨; ២៨:៨–៩;
អាលម៉ា ១០:១៧; ម៉ូសេ ៤:៤.
ស.ប. សេចក្ដីកុហក.
២៦ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* ស.ប. ស្ថាននរក.
*គ* សុភា. ២៩:៥–៦;
១ នីហ្វៃ ១៤:៣.
២៧ *ក* យ៉ូប ១:៧.
*ខ* ២ នីហ្វៃ ២៨:១៩–២៣;
គ. និង ស. ៧៦:២៨–២៩.
២៨ *ក* ស.ប. ការបោក, បញ្ឆោត,
សេចក្ដីបញ្ឆោត.
*ខ* រ៉ូម ២:៣.
ស.ប. សេចក្ដីយុត្តិធម៌.
២៩ *ក* ម៉ាថាយ ៤:៧.
៣៣ *ក* ស.ប. អារក្ស.

ដល់អ្នកនូវ[ក]ប្រាជ្ញា ហើយប្រទានដល់អ្នកនូវបញ្ញត្តិទាំងឡាយ អំពីការណ៍ ទាំងឡាយនេះ អំពីអ្វីដែលអ្នកគួរធ្វើនោះ ចូរកុំបង្ហាញដល់ពិភពលោកឡើយ លុះត្រាអ្នកបានសំរេចនូវកិច្ចការបកប្រែសិន ។

៣៥ ចូរកុំងឿងឆ្ងល់ត្រង់ពាក្យ ដែលយើងប្រាប់អ្នកថា៖ នេះជាប្រាជ្ញា ចូរកុំបង្ហាញដល់ពិភពលោកឡើយ — ត្បិតយើងបានប្រាប់ថា ចូរកុំបង្ហាញដល់ពិភពលោក ប្រយោជន៍ឲ្យអ្នកអាចបានគង់វង្សនៅ ។

៣៦ មើលចុះ យើងពុំបានប្រាប់ថាអ្នកមិនគួរបង្ហាញដល់ពួកសុចរិតនោះទេ;

៣៧ ប៉ុន្តែពីព្រោះអ្នកមិនអាចវិនិច្ឆ័យជាដរាបថាពួកណា[ក]ជាសុចរិត ឬក៏អ្នកមិនអាចដឹងនូវពួកទុច្ចរិតពីពួកសុចរិត ជាដរាបបានទេ ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា ចូរនៅ[ខ]ស្ងៀមចុះ លុះត្រាយើងនឹងឃើញថាសមល្មមនឹងធ្វើឲ្យអស់ទាំងអ្វីៗបានដឹងដល់ពិភពលោក អំពីការណ៍ទាំងនោះ ។

៣៨ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា ដំណើររឿង[ក]អំពីការណ៍ទាំងឡាយនោះ ដែលអ្នកបានសរសេរ ដែលបានបាត់ពីដៃ របស់អ្នកទៅនោះ គឺបានចារនៅលើ[ខ]ផ្ទាំងនីហ្វៃ;

៣៩ មែនហើយ ហើយអ្នកចាំថាបានពោលនៅក្នុងការសរសេរទាំងឡាយនោះ ថាដំណើររឿងដ៏ល្អិតល្អន់ជាងនេះ ត្រូវបាន ប្រទានឲ្យអំពីការណ៍ទាំងនេះ នៅលើផ្ទាំងនីហ្វៃ ។

៤០ ហើយឥឡូវនេះ ពីព្រោះដំណើររឿងដែលមានចារឹកនៅលើផ្ទាំងនីហ្វៃ គឺល្អិតល្អន់ជាងនេះ អំពីការណ៍ទាំងឡាយនៅក្នុងប្រាជ្ញារបស់យើង នោះយើងនឹងនាំមកឲ្យប្រជារាស្ត្រដឹងដោយសារដំណើររឿងនេះ —

៤១ ហេតុដូច្នេះហើយ អ្នកនឹងត្រូវបកប្រែចារឹកទាំងឡាយដែលមាននៅលើ[ក]ផ្ទាំងនីហ្វៃ ចុះរហូតដល់អ្នកបានមកដល់រជ្ជកាលនៃស្ដេច បេនយ៉ាមីន ឬក៏រហូតដល់អ្នកបានមកដល់កន្លែងដែលអ្នកបានបកប្រែ ដែលអ្នកបានទុក;

៤២ ហើយមើលចុះ អ្នកនឹងត្រូវបោះពុម្ពផ្សាយ ទុកជាបញ្ជីប្រវត្តិនៃនីហ្វៃ ហើយយើងនឹងបំភាន់ពួកអ្នក ដែលបានកែប្រែពាក្យពេចន៍របស់ យើងយ៉ាងដូច្នោះហើយ ។

៤៣ យើងនឹងមិនទ្រាំឲ្យពួកគេបំផ្លាញកិច្ចការរបស់យើងឡើយ មែនហើយ យើងនឹងបង្ហាញដល់ពួកគេថា ប្រាជ្ញារបស់យើងមហិមា ជាងកលល្បិចនៃអារក្សទៅទៀត ។

៤៤ មើលចុះ ពួកគេគ្រាន់តែមានមួយភាគ ឬសេចក្ដីសង្ខេបមួយ អំពីដំណើររឿងនៃនីហ្វៃប៉ុណ្ណោះ ។

៤៥ មើលចុះ មានការណ៍ជាច្រើន ដែលបានចារនៅលើផ្ទាំងនីហ្វៃ ដែលបញ្ចេញយោបល់ជ្រាលជ្រៅទៅទៀត អំពីដំណឹងល្អរបស់យើង ហេតុដូច្នេះហើយ គឺជាប្រាជ្ញានៅក្នុងយើង ដែលអ្នកគួរបកប្រែភាគទី១នៃចារឹករបស់នីហ្វៃ ហើយបញ្ចេញទៅក្នុងកិច្ចការនេះ ។

៤៦ ហើយមើលចុះ អស់ទាំងចំណែក[ក]កិច្ចការនេះដែលនៅសល់ទាំងប៉ុន្មាន គឺមានគ្រប់ទាំងភាគទាំងអស់នោះ អំពី[ខ]ដំណឹងល្អរបស់យើង ដែលពួកព្យាការីដ៏បរិសុទ្ធរបស់យើង មែនហើយ ព្រមទាំងពួកសិស្សរបស់យើង បាន[គ]ប៉ងប្រាថ្នាក្នុងការអធិស្ឋានរបស់ពួកគេ សូមឲ្យបាន ចេញមកដល់ប្រជារាស្ត្រនេះដែរ ។

៤៧ ហើយយើងបានប្រាប់ពួកគេថានឹងត្រូវ[ក]បានអនុញ្ញាតដល់ពួកគេ ស្របតាម[ខ]សេចក្ដីជំនឿរបស់គេ ក្នុងការអធិស្ឋានរបស់ពួកគេ ទាំង ប៉ុន្មាននោះ ។

៤៨ មែនហើយ ហើយនេះគឺជាសេចក្ដីជំនឿរបស់ពួកគេ — ថាដំណឹងល្អរបស់យើង ដែលយើងបានប្រទានដល់ពួកគេ ដើម្បីឲ្យពួកគេអាចប្រកាស នៅក្នុងជីវិតគេ អាចបានចេញមកដល់បងប្អូនរបស់គេ គឺ[ក]ពួកសាសន៍លេមិន ព្រមទាំងអស់អ្នកណាដែលបានក្លាយ ទៅជាពួកសាសន៍លេមិន ពីព្រោះតែការបែកបាក់របស់គេទាំងឡាយនោះ ។

៤៩ ឥឡូវនេះ ការណ៍នេះមិនទាន់អស់ទេ — សេចក្ដីជំនឿរបស់ពួកគេ នៅក្នុងការអធិស្ឋានរបស់ពួកគេ គឺថាដំណឹងល្អត្រូវបានធ្វើ ឲ្យបានដឹងផង បើសិនជាពួកសាសន៍ដទៃយកដែនដីនេះបាន;

៥០ ហើយដោយហេតុនោះហើយ បានជាពួកគេឲ្យពរមក

៣៤ *ក* ស.ប. ប្រាជ្ញា.
៣៧ *ក* ម៉ាថាយ ២៣:២៨.
*ខ* និក្ខ. ១៤:១៤.
៣៨ *ក* នៅក្នុងអារម្ភកថាដល់ព្រះគម្ពីរមរមន លើកទី១ ព្យាការីបានពន្យល់ប្រាប់ថាឯកសារ ១១៦ ទំព័រដែល បាត់នោះ ត្រូវបានបកប្រែចេញពីភាគនៃផ្ទាំងទាំងឡាយដែលហៅថា «គម្ពីរលីហៃ».
*ខ* ស.ប. ផ្ទាំងទាំងឡាយ.
៤១ *ក* ព. នៃ ម. ១:៣–៧.
៤៦ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ស.ប. ដំណឹងល្អ.
*គ* អេណុស ១:១២–១៨; មរមន ៨:២៤–២៦; ៩:៣៤–៣៧.
៤៧ *ក* ៣ នីហ្វៃ ៥:១៣–១៥; គ. និង ស. ៣:១៩–២០.
*ខ* ស.ប. សេចក្ដីជំនឿ.
៤៨ *ក* ម៉ូរ៉ូណៃ ១០:១–៥; គ. និង ស. ១០៩:៦៥–៦៦.

លើដែនដីនេះ នៅក្នុងការអធិស្ឋានរបស់ពួកគេ សូមឲ្យអស់អ្នកណា ដែល ជឿដល់ដំណឹងល្អនេះ នៅលើដែនដីនេះ អាចមានជីវិតដ៏នៅអស់កល្បជានិច្ច;

៥១ មែនហើយ សូមឲ្យដែនដីនេះអាចមានសេរីភាព ដល់អស់ទាំងមនុស្ស ចេញពីសាសន៍ ពូជមនុស្ស ភាសា ឬប្រជាជនណាក្ដី ។

៥២ ហើយឥឡូវនេះ មើលចុះ ស្របតាមសេចក្ដីជំនឿរបស់គេ ក្នុងការអធិស្ឋានរបស់គេ នោះយើងនឹងនាំភាគនេះនៃដំណឹងល្អរបស់ យើង ឲ្យបានដឹងអំពីប្រជារាស្ត្ររបស់យើង ។ មើលចុះ យើងមិននាំមកដើម្បីបំផ្លាញនូវអ្វី ដែលពួកគេបានទទួលហើយនោះទេ ប៉ុន្តែដើម្បីកសាងវាឡើង ។

៥៣ ហើយដោយសារហេតុនេះហើយ បានជាយើងប្រាប់ថា៖ បើសិនជាតំណនេះមិនធ្វើចិត្តរឹងទទឹងទេ នោះយើងនឹងតាំងសាសនាចក្ររបស់យើងឡើង ក្នុងចំណោមពួកគេ ។

៥៤ ឥឡូវនេះ យើងមិនបានប្រាប់ការណ៍នេះ ដើម្បីបំផ្លាញសាសនាចក្ររបស់យើងទេ ប៉ុន្តែយើងប្រាប់ការណ៍នេះ ដើម្បីកសាងសាសនាចក្ររបស់យើងឡើងទេតើ;

៥៥ ហេតុដូច្នេះហើយ អស់អ្នកណាដែលនៅក្នុងសាសនាចក្ររបស់យើង មិនត្រូវខ្លាចឡើយ ត្បិតពួកគេនេះហើយ ដែលនឹងគ្រង នគរស្ថានសួគ៌ទុកជាមរតក ។

៥៦ ប៉ុន្តែគឺពួកអ្នកដែលមិនកោតខ្លាចដល់យើង ឬមិនកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង តែកសាងសាសនាចក្រទាំងឡាយឡើង ដល់ខ្លួនវិញ ដើម្បីរកកម្រៃ មែនហើយ ហើយអស់ពួកអ្នកទាំងឡាយនោះដែលធ្វើអំពើទុច្ចរិត ហើយកសាងនគរអារក្សឡើង — មែនហើយ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា គឺពួកគេនេះហើយ ដែលយើងនឹងរំខាន ហើយបណ្ដាលឲ្យញ័ររន្ធត់ដល់ទ្រូង ។

៥៧ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ។ យើងបានយាងមករករាស្ត្ររបស់យើង តែរាស្ត្ររបស់យើងមិនបាន ទទួលយើងសោះ ។

៥៨ យើងជាពន្លឺដែលភ្លឺមកក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ ។

៥៩ យើងជាអ្នកនោះដែលបាននិយាយថា — យើងមានចៀមឯទៀត ដែលមិនទាន់នៅក្នុងក្រោលនេះនៅឡើយ — ទៅកាន់ពួក សិស្សរបស់យើង ហើយមានមនុស្សជាច្រើនដែលមិនយល់ពាក្យយើង ។

៦០ ហើយយើងនឹងបង្ហាញដល់ប្រជារាស្ត្រនេះ ថាយើងមានចៀមឯទៀត ហើយថាពួកគេជាមែកនៃវង្សយ៉ាកុប;

៦១ ហើយយើងនឹងនាំមកឯពន្លឺ ឲ្យឃើញកិច្ចការដ៏អស្ចារ្យទាំងឡាយ ដែលពួកគេបានធ្វើ ដោយនូវព្រះនាមរបស់យើង;

៦២ មែនហើយ ហើយយើងក៏នឹងនាំមកឯពន្លឺ ឲ្យឃើញដំណឹងល្អរបស់យើង ដែលបានផ្សាយដល់ពួកគេ ហើយមើលចុះ ពួកគេនឹងមិន បដិសេធនូវអ្វី ដែលអ្នកបានទទួលនោះឡើយ ប៉ុន្តែពួកគេនឹងកសាងឡើងវិញ ហើយនឹងនាំមកឯពន្លឺ ឲ្យឃើញនូវចំណុចដ៏ពិតអំពី គោលលទ្ធិរបស់យើង មែនហើយ គឺជាគោលលទ្ធិតែមួយ ដែលនៅក្នុងយើង ។

៦៣ ហើយយើងធ្វើការណ៍នេះ ប្រយោជន៍ឲ្យយើងអាចតាំងដំណឹងល្អរបស់យើង ដើម្បីកុំឲ្យមានការទាស់ទែងគ្នាច្រើនពេក មែនហើយ អារក្សសាតាំងចាក់រុកដួងចិត្តនៃមនុស្សទាំងឡាយឲ្យមានការទាស់ទែងគ្នា អំពីចំណុចទាំងឡាយ នៃគោលលទ្ធិរបស់យើង ហើយនៅក្នុងការណ៍ទាំងឡាយនេះហើយ ដែលពួកគេធ្វើខុស ត្បិតពួកគេបង្វែរបទគម្ពីរទាំងឡាយ ហើយមិនយល់ បទគម្ពីរទាំងនោះទេ ។

៦៤ ហេតុដូច្នេះហើយ យើងនឹងបើកសំដែងដល់ពួកគេ នូវសេចក្ដីអាថ៌កំបាំងដ៏មហិមានេះ;

៦៥ ត្បិតមើលចុះ យើងនឹងប្រមូលពួកគេ ដូចជាមេមាន់ប្រមូលកូនក្រុងក្រោមស្លាប បើសិនជាពួកគេមិនរាជ្រឹងចិត្តរបស់គេ;

៦៦ មែនហើយ បើសិនជាពួកគេចង់មក គេអាចមក ហើយទទួលទានទឹកនៃជីវិតដោយសេរីចុះ ។

៦៧ មើលចុះ នេះហើយជាគោលលទ្ធិរបស់យើង —

៥៥ *ក* ស.ប. សេចក្ដីកោតខ្លាច.
*ខ* ម៉ាថាយ ៥:១០.
*គ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
៥៦ *ក* សាស្ដា ១២:១៣–១៤.
*ខ* ស.ប. អារក្ស — សាសនាចក្រនៃអារក្ស.
*គ* ៤ នីហ្វៃ ១:២៦.
៥៧ *ក* រ៉ូម ១:៤.
៥៨ *ក* គ. និង ស. ៦:២១.
៥៩ *ក* យ៉ូហាន ១០:១៦.
*ខ* ស.ប. អ្នកគង្វាលល្អ.
*គ* ៣ នីហ្វៃ ១៥:១៦–១៨.
៦០ *ក* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
៦២ *ក* ៣ នីហ្វៃ ១១:៣១–៤០.
៦៣ *ក* ស.ប. អារក្ស.
*ខ* ស.ប. ការទាស់ទែង.
*គ* ២ ពេត្រុស ៣:១៦.
៦៥ *ក* លូកា ១៣:៣៤;
៣ នីហ្វៃ ១០:៤–៦;
គ. និង ស. ៤៣:២៤.
៦៦ *ក* ស.ប. ទឹករស់.

គឺអស់អ្នកណាដែលប្រែចិត្ត ហើយ[ក]មករកយើង នោះមានឈ្មោះថាជា [ខ]សាសនាចក្ររបស់យើងហើយ ។

៦៨ អស់អ្នកណាដែល[ក]ប្រកាសលើសឬតិចជាងនេះ នោះមានឈ្មោះថាមិនមែនជារបស់ផងយើងទេ ប៉ុន្តែ[ខ]ប្រឆាំងនឹងយើងវិញ ហេតុដូច្នេះហើយ អ្នកនោះមិនមែនជារបស់ផងសាសនាចក្រយើងទេ ។

៦៩ ហើយឥឡូវនេះ មើលចុះ អស់អ្នកណាដែលជារបស់ផងសាសនាចក្រយើង ហើយកាន់ខ្ជាប់នៅក្នុងសាសនាចក្ររបស់យើង ដរាបដល់ចុងបំផុត អ្នកនោះហើយ ដែលយើងនឹងតាំងឡើងលើ[ក]ថ្មដារបស់យើង ហើយ[ខ]ទ្វារទាំងឡាយនៃស្ថាននរកនឹងពុំ ដែលឈ្នះពួកគេឡើយ ។

៧០ ហើយឥឡូវនេះ ចូរចងចាំនូវពាក្យពេចន៍នៃអ្នកនោះចុះ ដែលជាជីវិត និង[ក]ជាពន្លឺនៃពិភពលោក គឺជាព្រះដ៏ប្រោសលោះរបស់អ្នក ជា[ខ]ព្រះអម្ចាស់របស់អ្នក ហើយជាព្រះរបស់អ្នក ។ អាម៉ែន ៕

## កណ្ឌទី ១១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះហៃរុមស្ម៊ីធ ជាបងប្រុសរបស់លោក នៅហ្វូមិហាម៉ូនី រដ្ឋប៉ិនស៊ិលវេញ៉ា ខែឧសភា ឆ្នាំ១៨២៩ (*History of the Church, *១:៣៩–៤៦)។ វិវរណៈនេះ ត្រូវបានទទួលមកតាមរយៈ យូរីមនិងធូមីម ជាចម្លើយចំពោះការអំពាវនាវ និងសំណូមពររបស់យ៉ូសែប ។* History of the Church *ឲ្យយោបល់ថា វិវរណៈនេះ ត្រូវបានទទួល បន្ទាប់ពីការស្ដារឡើងវិញនៃបព្វជិតភាពអើរ៉ុន ។*

*១–៦, ពួកអ្នកធ្វើការនៅក្នុងចំការទំពាំងបាយជូរ នឹងបានសេចក្ដីសង្គ្រោះ; ៧–១៤, ចូរស្វែងរកប្រាជ្ញា ចូរស្រែកហៅឲ្យមានការប្រែចិត្ត ចូរទុកចិត្តទៅលើព្រះវិញ្ញាណ; ១៥–២២, ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយ ហើយចូរសិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់, ២៣–២៧, ចូរកុំបដិសេធវិញ្ញាណនៃវិវរណៈ និងការព្យាករណ៍ឡើយ; ២៨–៣០, អស់អ្នកណាដែលទទួលព្រះគ្រិស្ទ ត្រឡប់ទៅជាកូនព្រះ ។*

**កិ**ច្ចការដ៏ធំនិង[ក]អស្ចារ្យកំពុងតែនឹងចេញមក ក្នុងចំណោមកូនចៅមនុស្សហើយ ។

២ មើលចុះ យើងជាព្រះ ចូរ[ក]ស្ដាប់តាម[ខ]ព្រះបន្ទូលរបស់យើង ដែលរស់នៅ ហើយ[គ]ពូកែផង ក៏[ឃ]មុតជាងដាវណាមានមុខពីរ ទាំងកាត់ សន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ហេតុដូច្នេះហើយ ចូរស្ដាប់តាមព្រះបន្ទូលរបស់យើងចុះ ។

៣ មើលចុះ [ក]ស្រែសសំព្រះលួមច្រូតហើយ ហេតុដូច្នេះហើយ អស់អ្នកណាមានបំណងចង់ច្រូត ចូរឲ្យអ្នកនោះលូកកណ្ដៀវរបស់ខ្លួន ដោយកម្លាំងរបស់ខ្លួន ហើយច្រូតក្នុងកាលមានថ្ងៃនៅចុះ [ខ]ប្រយោជន៍ឲ្យអ្នកនោះអាចបានសន្សំទុកសំរាប់ព្រលឹងគេ នូវសេចក្ដីសង្គ្រោះ ដ៏[គ]អស់កល្បជានិច្ច នៅក្នុងនគរព្រះ ។

៤ មែនហើយ អស់អ្នកណាដែលនឹងលូក[ក]កណ្ដៀវរបស់ខ្លួន ហើយច្រូត អ្នកនោះហើយបានហៅពីព្រះ ។

៥ ហេតុដូច្នេះហើយ បើសិនជាអ្នក[ក]សុំពីយើង នោះអ្នកតែងនឹងបានទទួល បើសិនជាអ្នកនឹងគោះ នោះតែងនឹងបើកឲ្យអ្នក ។

៦ ឥឡូវនេះ ដូចជាអ្នកបានសុំ មើលចុះ យើងប្រាប់អ្នកថា

៦៧ *ក* ម៉ាថាយ ១១:២៨–៣០.
*ខ* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រិស្ទ.
៦៨ *ក* ៣ នីហ្វៃ ១១:៤០.
*ខ* លូកា ១១:២៣.
៦៩ *ក* ស.ប. ថ្ម.
*ខ* ម៉ាថាយ ១៦:១៨; ២ នីហ្វៃ ៤:៣១–៣២; គ. និង ស. ១៧:៨; ១២៨:១០.
៧០ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រិស្ទ.
*ខ* ស.ប. ព្រះយេស៊ូវគ្រិស្ទ.
**១១** ១ *ក* អេសាយ ២៩:១៤; គ. និង ស. ៤. ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
២ *ក* ១ នីហ្វៃ ១៥:២៣–២៥; គ. និង ស. ១:១៤; ៨៤:៤៣–៤៥.
*ខ* ហេព្រើរ ៤:១២.
*គ* អាលម៉ា ៤:១៩; ៣១:៥.
*ឃ* ហេលេ. ៣:២៩–៣០; គ. និង ស. ៦:២.
៣ *ក* គ. និង ស. ១២:៣.
*ខ* លូកា ១៨:២២; ហេលេ. ៥:៨.
*គ* ១ ធីម៉ូ. ៦:១៩.
៤ *ក* វិវរ. ១៤:១៥; គ. និង ស. ១៤:៣–៤.
៥ *ក* ស.ប. ការអធិស្ឋាន.

ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយស្វែងរកដើម្បីនាំមក ហើយតាំងឡើងនូវគតិនៃក្រុងស៊ីយ៉ូនចុះ ។

៧ ចូរកុំស្វែងរកទ្រព្យសម្បត្តិឡើយ ប៉ុន្តែចូររកប្រាជ្ញាចុះ ហើយមើលចុះ សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ នឹងត្រូវបានបើកបង្ហាញ ដល់អ្នក ហើយខណៈនោះ អ្នកនឹងបានទៅជាអ្នកមាន ។ មើលចុះ អ្នកណាដែលមានជីវិតអស់កល្បជានិច្ច ឈ្មោះថាជាអ្នកមានហើយ ។

៨ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា គឺដរាបណាអ្នកមានបំណងចង់បានពីយើង នោះនឹងបានសំរេចដល់អ្នក ហើយបើសិនជាអ្នក ប្រាថ្នា នោះអ្នកនឹងបានទៅជាមធ្យោបាយនៃការធ្វើល្អដ៏ច្រើន នៅក្នុងតំណនេះ ។

៩ ចូរកុំថាអ្វីដល់តំណនេះឡើយ លើកលែងតែការប្រែចិត្ត ។ ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយជួយបញ្ចេញកិច្ចការ របស់យើងមក ស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នកនឹងបានពរ ។

១០ មើលចុះ អ្នកមានអំណោយទាន ឬក៏អ្នកនឹងបានអំណោយទាន បើសិនជាអ្នកនឹងសុំចង់បានពីយើង ដោយនូវសេចក្ដីជំនឿ ដោយមានចិត្តទៀងត្រង់ ដោយជឿដល់ព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទ ឬជឿដល់ព្រះចេស្ដារបស់យើង ដែលមានព្រះបន្ទូលមកកាន់អ្នក;

១១ ត្បិតមើលចុះ គឺយើងនេះហើយដែលមានព្រះបន្ទូល មើលចុះ យើងជាពន្លឺដែលភ្លឺមកក្នុងសេចក្ដីងងឹត ហើយដោយសារព្រះចេស្ដា របស់យើង នោះយើងប្រទានព្រះបន្ទូលទាំងឡាយនេះដល់អ្នក ។

១២ ហើយឥឡូវនេះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ចូរដាក់ទីទុកចិត្តរបស់អ្នកទៅនឹងព្រះវិញ្ញាណនោះ ដែលនាំឲ្យធ្វើល្អ — មែនហើយ គឺឲ្យធ្វើដោយយុត្តិធម៌ ឲ្យដើរដោយទាបរាបសា ឲ្យវិនិច្ឆ័យដោយសុចរិត ហើយនេះគឺជាព្រះវិញ្ញាណរបស់យើង ។

១៣ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា យើងនឹងរំលែកដល់អ្នក នូវព្រះវិញ្ញាណរបស់យើង ដែលនឹងបំភ្លឺគំនិតរបស់អ្នក ដែលនឹង បំពេញព្រលឹងរបស់អ្នកដោយសេចក្ដីអំណរ ។

១៤ ហើយខណៈនោះ អ្នកនឹងដឹង ឬដោយការណ៍នេះ អ្នកនឹងដឹងគ្រប់ទាំងអស់ដែលអ្នកមានបំណងចង់បានពីយើង ដែលទាក់ទងទៅនឹងការណ៍ទាំងឡាយនៃសេចក្ដីសុចរិត គឺដោយនូវសេចក្ដីជំនឿ ដោយជឿដល់យើងថា អ្នកនឹងបានទទួលនោះ ។

១៥ មើលចុះ យើងបញ្ជាដល់អ្នកថា អ្នកមិនត្រូវសន្និដ្ឋានថាអ្នកត្រូវបានហៅឲ្យទៅផ្សាយ លុះត្រាអ្នកត្រូវបានហៅសិន ។

១៦ ចូរចាំបន្តិច លុះត្រាអ្នកនឹងបានព្រះបន្ទូលរបស់យើង ថ្មដារបស់យើង សាសនាចក្ររបស់យើង និងដំណឹងល្អរបស់យើង ដើម្បីឲ្យអ្នកអាចបានស្គាល់គោលលទ្ធិរបស់យើង ដោយពិតប្រាកដសិនចុះ ។

១៧ ហើយខណៈនោះ មើលចុះ ស្របតាមសេចក្ដីប៉ងប្រាថ្នារបស់អ្នក មែនហើយ គឺស្របតាមសេចក្ដីជំនឿរបស់អ្នក ការណ៍នោះនឹងបាន សំរេចដល់អ្នក ។

១៨ ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ចូរកុំមាត់ចូរអំពាវនាវដល់ព្រះវិញ្ញាណរបស់យើងចុះ;

១៩ មែនហើយ ចូរនៅជាប់នឹងយើង ឲ្យអស់ពីចិត្ត ដើម្បីឲ្យអ្នកអាចជួយនាំមករកពន្លឺ នូវការណ៍ទាំងឡាយនោះ ដែលបានពោលដល់ — មែនហើយ គឺជាការបកប្រែនៃកិច្ចការរបស់យើង ចូរមានចិត្តអត់ធន់ លុះត្រាអ្នកនឹងបានសំរេចការណ៍នោះសិន ។

៦ *ក* អេសាយ ៥២:៧–៨;
គ. និង ស. ៦៦:១១.
ស.ប. ស៊ីយ៉ូន.
៧ *ក* ១ ពង្សាវ. ៣:១១–១៣;
២ នីហ្វៃ ២៦:៣១;
យ៉ាកុប ២:១៧–១៩;
គ. និង ស. ៣៨:៣៩.
*ខ* ស.ប. ប្រាជ្ញា.
៩ *ក* គ. និង ស. ១៩:២១–២២.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*គ* គ. និង ស. ១០៥:៥.
១០ *ក* គ. និង ស. ៤៦:៨–១២.
*ខ* លូកា ៨:១៥.
១១ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* ស.ប. អំណាច.
១២ *ក* គ. និង ស. ៨៤:១១៦.
ស.ប. ទុកចិត្ត.
*ខ* រ៉ូម ៨:១–៩; ១ យ៉ូហាន ៤:១–៦.
*គ* ស.ប. ដើរ, ដើរជាមួយព្រះ.
*ឃ* ស.ប. បន្ទាបខ្លួន,
ចិត្តសុភាពរាបសា.
*ង* ម៉ាថាយ ៧:១–៥;
អាលម៉ា ៤១:១៤–១៥.
១៣ *ក* គ. និង ស. ៧៦:១២.
*ខ* ស.ប. គំនិត.
*គ* ស.ប. សេចក្ដីអំណរ.
១៤ *ក* ស.ប. សុចរិត, សេចក្ដីសុចរិត.
១៥ *ក* ម. នៃ ស. ១:៥.
ស.ប. សិទ្ធិអំណាច; ហៅ,
បានហៅពីព្រះ, ការហៅ.
១៦ *ក* គ. និង ស. ៦:៣៤.
ស.ប. ថ្ម.
១៩ *ក* យ៉ាកុប ៦:៥; គ. និង ស. ៩៨:១១.

២០ មើលចុះ នេះជាកិច្ចការរបស់អ្នក គឺ[ក]កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង មែនហើយ ឲ្យអស់ពីពលំ អស់ពីគំនិត និង អស់ពី កម្លាំងរបស់អ្នក ។

២១ ចូរកុំខំប្រកាសព្រះបន្ទូលរបស់យើងឡើយ ប៉ុន្តែ ចូរខំព្យាយាម ដើម្បីឲ្យ[ក]បានព្រះបន្ទូលរបស់យើងជាមុនសិនចុះ ហើយខណៈនោះ អណ្ដាតរបស់អ្នកនឹងបានធូរ ពេលនោះ បើសិនជាអ្នកមានប្រាថ្នា នោះអ្នកនឹងបានព្រះវិញ្ញារបស់យើង និង ព្រះបន្ទូលរបស់យើង មែន ហើយ គឺជាព្រះចេស្ដានៃព្រះ ដើម្បីបញ្ចុះបញ្ចូលមនុស្សលោក ។

២២ ប៉ុន្តែឥឡូវនេះ ចូរកុំមាត់ ចូរសិក្សាព្រះបន្ទូល[ក]របស់យើង ដែលបានចេញទៅក្នុងចំណោមកូនចៅមនុស្ស ហើយក៏ចូរ[ខ]សិក្សាព្រះ[គ]បន្ទូលរបស់យើង ដែលនឹងចេញមកក្នុងចំណោមកូនចៅមនុស្ស ឬក៏អ្វីដែលកំពុងតែបកប្រែឥឡូវនេះ មែនហើយ លុះត្រាអ្នកបានទទួល នូវអ្វីទាំងអស់ ដែលយើងនឹង[ឃ]ប្រទានដល់កូនចៅមនុស្ស នៅក្នុងគំណនេះ ហើយខណៈនោះ ទើបគ្រប់របស់ទាំងឡាយនឹងបានប្រទាន ថែមទៀត ។

២៣ មើលចុះ អ្នកជា[ក]ហែរុម ជាបុត្ររបស់យើង ចូរ[ខ]ស្វែងរកនគរព្រះចុះ ហើយគ្រប់របស់ទាំងឡាយនឹងបានប្រទានថែមទៀត ស្របតាម អ្វីដែលត្រឹមត្រូវ ។

២៤ ចូរ[ក]សង់នៅលើថ្មដារបស់យើង ដែលជា[ខ]ដំណឹងល្អរបស់យើង;

២៥ ចូរកុំបដិសេធវិញ្ញាណនៃ[ក]វិវរណៈ ឬក៏វិញ្ញាណនៃ[ខ]ការព្យាករណ៍ឡើយ ត្បិតវេទនាដល់អ្នកណា ដែលបដិសេធរបស់ទាំងនេះ;

២៦ ហេតុដូច្នេះហើយ ចូរ[ក]ទុកក្នុងចិត្តរបស់អ្នក លុះត្រាដល់ពេលដែលនៅក្នុងប្រាជ្ញារបស់យើង ថាអ្នកនឹងត្រូវចេញទៅ ។

២៧ មើលចុះ យើងមានបន្ទូលទៅកាន់មនុស្សទាំងអស់ណា ដែលមានសេចក្ដីប៉ងប្រាថ្នាល្អ ហើយដែលបាន[ក]លូកកណ្ដៀវរបស់ខ្លួន មកច្រូត ។

២៨ មើលចុះ យើងជា[ក]ព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ។ យើងជាជីវិត និងជា[ខ]ពន្លឺនៃពិភពលោក ។

២៩ យើងជាអ្នកដដែលនោះ ដែលបានយាងមករករាស្ត្ររបស់យើង តែរាស្ត្ររបស់យើងមិនបានទទួលយើងសោះ ។

៣០ ប៉ុន្តែប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ដរាបណាមនុស្សជាច្រើនទទួលយើង អ្នកទាំងនោះហើយដែលយើងនឹងប្រទាន[ក]អំណាច ឲ្យត្រឡប់ទៅជា[ខ]កូនព្រះ គឺដល់ពួកអ្នកណាដែលជឿដល់ព្រះនាមរបស់យើង ។ អាម៉ែន ៕

## កណ្ឌទី ១២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះយ៉ូសែបណៃត ស៊ីញ៉័រ នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែឧសភា ឆ្នាំ១៨២៩ (*History of the Church*, ១:៤៧–៤៨)* ។ *យ៉ូសែបណៃតបានជឿដល់សំដីរបស់យ៉ូសែបស្ម៊ីធ ស្ដីអំពី ផ្ទាំងនៃ ព្រះគម្ពីរមរមន ដែលលោកមាន និងអំពីការបកប្រែ ដែលកំពុងធ្វើឡើងនៅពេលនោះ ហើយបានផ្ដល់ជំនួយដល់យ៉ូសែបស្ម៊ីធ និងស្មៀនរបស់លោក ជាច្រើនដង ដែលបានធ្វើឲ្យពួកគេអាចបកប្រែតទៅទៀត ។ តាមសំណូមពររបស់យ៉ូសែបណៃត នោះលោក ព្យាការីបានសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈ ។*

*១–៦, ពួកអ្នកធ្វើការនៅក្នុងចំការទំពាំងបាយជូរ នឹងបានសេចក្ដីសង្គ្រោះ; ៧–៩, អស់អ្នកណាដែលមានសេចក្ដីប៉ងប្រាថ្នា ហើយដែល មានគុណសម្បត្តិសម អាចជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។*

២០ *ក* ស.ប. ការគោរព, ដែលគោរព, គោរព.
២១ *ក* អាលម៉ា ១៧:២–៣; គ. និង ស. ៨៤:៨៥.
២២ *ក* ក.ន. ព្រះគម្ពីរប៊ីប.
*ខ* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*គ* ក.ន. ព្រះគម្ពីរមរមន.
*ឃ* អាលម៉ា ២៩:៨.
២៣ *ក* យ.ស. — ប្រវត្តិ ១:៤.
*ខ* ម៉ាថាយ ៦:៣៣.
២៤ *ក* ម៉ាថាយ ៧:២៤–២៧.
*ខ* ស.ប. ដំណឹងល្អ.
២៥ *ក* ស.ប. វិវរណៈ.
*ខ* វិវរ. ១៩:១០. ស.ប. ការព្យាករណ៍, ព្យាករ.
២៦ *ក* ចោទិ. ១១:១៨; គ. និង ស. ៦:២០; ៤៣:៣៤; យ.ស. — ម៉ាថាយ ១:៣៧.
២៧ *ក* ស.ប. កិច្ចការផ្សាយសាសនា.
២៨ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៣០ *ក* យ៉ូហាន ១:១២.
*ខ* ស.ប. បុត្រាបុត្រីនៃព្រះ.

កិច្ចការដ៏ធំនិងអស្ចារ្យកំពុងតែនឹងចេញមក ក្នុងចំណោមកូន
ចៅមនុស្សហើយ ។
២ មើលចុះ យើងជាព្រះ ចូរស្ដាប់តាមព្រះបន្ទូលរបស់យើង
ដែលរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខពីរ ទាំង
កាត់ សន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ហេតុដូច្នេះហើយ ចូរស្ដាប់តាម
ព្រះបន្ទូលរបស់យើងចុះ ។
៣ មើលចុះ ស្រែសសំព្រះល្មមច្រូតហើយ ហេតុដូច្នេះហើយ
អស់អ្នកណាមានបំណងចង់ច្រូត ចូរឲ្យអ្នកនោះលូកកណ្ដៀវ
របស់ខ្លួន ដោយកម្លាំងរបស់ខ្លួន ហើយច្រូតក្នុងកាលមានថ្ងៃនៅចុះ
ប្រយោជន៍ឲ្យអ្នកនោះអាចបានសន្សំទុកសំរាប់ព្រលឹងគេ នូវសេច
ក្ដីសង្គ្រោះ ដ៏អស់កល្ប នៅក្នុងនគរព្រះ ។
៤ មែនហើយ អស់អ្នកណាដែលនឹងលូកកណ្ដៀវរបស់ខ្លួន
ហើយច្រូត អ្នកនោះហើយបានហៅពីព្រះ ។
៥ ហេតុដូច្នេះហើយ បើសិនជាអ្នកសុំពីយើង នោះអ្នកតែងនឹង
បានទទួល បើសិនជាអ្នកនឹងគោះ នោះតែងនឹងបើកឲ្យអ្នក ។
៦ ឥឡូវនេះ ដូចជាអ្នកបានសុំ មើលចុះ យើងប្រាប់អ្នកថា
ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយស្វែងរក
ដើម្បីនាំមក ហើយតាំងឡើងនូវគតិនៃក្រុងស៊ីយ៉ូនចុះ ។
៧ មើលចុះ យើងមានបន្ទូលទៅកាន់អ្នក ហើយដល់អស់អ្នក
ណាដែលមានសេចក្ដីប៉ងប្រាថ្នា ចង់នាំនិងតាំងកិច្ចការនេះឡើង;
៨ ហើយគ្មានអ្នកណាអាចជួយក្នុងកិច្ចការនេះបានឡើយ លើក
លែងតែអ្នកនោះនឹងបន្ទាបខ្លួន ហើយពោរពេញទៅដោយសេច
ក្ដីស្រឡាញ់ ដោយមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និង
សេចក្ដីសប្បុរស ដោយសង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង ដែល
នឹងផ្ទុកផ្ដាក់ ឲ្យគេថែរក្សា ។
៩ មើលចុះ យើងជាជីវិត និងជាពន្លឺនៃពិភពលោក ដែលមាន
បន្ទូលពាក្យទាំងនេះ ហេតុដូច្នេះហើយ ចូរស្ដាប់ឲ្យអស់ពីកម្លាំង
របស់ អ្នកចុះ ហើយខណៈនោះ អ្នកត្រូវបានហៅហើយ ។
អាម៉ែន ៕

## កណ្ឌទី ១៣

*ការតែងតាំងនៃយ៉ូសែបស្ម៊ីធ និងអូលីវើរខៅឌើរី ចំពោះបព្វជិតភាពអើរ៉ុន នៅតាមច្រាំងទន្លេសុសគ្វីហាណា ក្បែរហ្វាមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៨២៩ (*History of the Church*, ១:៣៩–៤២)* ។ *ការតែងតាំងត្រូវបាន ធ្វើឡើង ដោយដៃនៃទេវតាមួយរូប ដែលបានហៅខ្លួនថាជាយ៉ូហាន គឺជាអ្នកដដែល ដែលបានហៅថាយ៉ូហាន–បាទីស្ទ នៅក្នុង ព្រះគម្ពីរសញ្ញាថ្មី ។ ទេវតាបានពន្យល់ប្រាប់ថា លោកកំពុងធ្វើការនៅក្រោមការដឹកនាំពីពេត្រុស យ៉ាកុប និងយ៉ូហាន ជាពួកសាវក បុរាណ ដែលកាន់កូនសោនៃបព្វជិតភាពខ្ពស់ជាង ដែលត្រូវបានហៅថា បព្វជិតភាពម៉ិលគីស្សាដែក ។ សេចក្ដីសន្យាត្រូវបានឲ្យដល់ យ៉ូសែបនិងអូលីវើរ ថានៅវេលាកំណត់ នោះបព្វជិតភាពម៉ិលគីស្សាដែក នឹងត្រូវបានប្រគល់ឲ្យមកលើពួកគេ (សូមមើល កណ្ឌទី ២៧:៧, ៨, ១២)* ។

*កូនសោនិងអំណាចទាំងឡាយ នៃបព្វជិតភាពអើរ៉ុន ត្រូវបានប្រគល់ឲ្យ ។*

ឱនាលើអ្នក ជាពួកអ្នកបំរើដូចរូបខ្ញុំអើយ ដោយនូវព្រះនាមនៃ
ព្រះមែស៊ី ខ្ញុំសូមប្រគល់បព្វជិតភាពអើរ៉ុន ដែលកាន់កូនសោ
ទាំងឡាយ អំពីការបំរើនៃពួកទេវតា និងអំពីដំណឹងល្អនៃការប្រែ
ចិត្ត និងអំពីបុណ្យជ្រមុជទឹក ដោយការពន្លិច សំរាប់ការផ្ដាច់បាប
ហើយបព្វជិត ភាពនេះ នឹងមិនត្រូវបានដកចេញពីផែនដីទៀតឡើយ
រហូតដល់ពេលកូនប្រុសទាំងឡាយនៃលោកលេវី ថ្វាយដង្វាយ
ម្ដងទៀត ដល់ព្រះអម្ចាស់ ដោយសេចក្ដីសុចរិត ។

**១២** ១*ក* សូមមើល គ. និង ស. ១១:១–៦ សំរាប់ការយោងដូចគ្នា.
៨ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ស.ប. សេចក្ដីស្រឡាញ់.
*គ* ស.ប. សេចក្ដីជំនឿ.
*ឃ* ស.ប. សេចក្ដីសង្ឃឹម.
*ង* ស.ប. សេចក្ដីសប្បុរស.

**១៣** ១*ក* យ.ស. — ប្រវត្តិ ១:៦៨–៧៥. ស.ប. តែងតាំង, ការតែងតាំង.
*ខ* គ. និង ស. ២៧:៨; ៨៤:១៨–៣៤. ស.ប. បព្វជិតភាពអើរ៉ុន.
*គ* ស.ប. ពួកទេវតា.
*ឃ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ង* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ច* សូមមើលដំណើររឿងអំពីអូលីវើរ ខៅឌើរី អំពីការសាងឡើងវិញនៃបព្វជិតភាពអើរ៉ុន នៅចុង យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ។ ចោទិ. ១០:៨; ១ របា. ៦:៤៨; គ. និង ស. ១២៨:២៤.
*ឆ* ស.ប. សុចរិត, សេចក្ដីសុចរិត.

## កណ្ឌទី ១៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះដាវីឌវិតមើរ នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែមិថុនា ឆ្នាំ១៨២៩ (*History of the Church*, ១:៤៨–៥០) ។ គ្រួសារត្រកូលវិតមើរបានក្លាយជាចាប់អារម្មណ៍យ៉ាងខ្លាំង អំពីការបកប្រែនៃព្រះគម្ពីរមរមន ។ លោកព្យាការីបានតាំងទីលំនៅ នៅផ្ទះនៃពេត្រុសវិតមើរ ស៊ីញ៉័រ គឺជាទីកន្លែងដែលលោកបានអាស្រ័យនៅ រហូតដល់បញ្ចប់កិច្ចការបកប្រែ និងដល់បានសិទ្ធិលើសៀវភៅដែលនឹងចេញមក ។ ដោយពួកគេម្នាក់ៗ បានទទួលទីបន្ទាល់ អំពីភាព ពិតត្រង់នៃកិច្ចការនោះ ទើបកូនប្រុសបីនាក់ពីត្រកូលវិតមើរ មានការបារម្ភ អំពីការកិច្ចរបស់គេនីមួយៗ ។ វិវរណៈនេះ និងវិវរណៈពីរ តាមក្រោយ (កណ្ឌទី ១៥និង១៦) ត្រូវបានប្រទានឲ្យ ទុកជាចម្លើយចំពោះសំណូមពរ តាមរយៈយូរីមនិងធូមីម ។ ក្រោយមក ដាវីឌវិតមើរបានក្លាយទៅជាបុគ្គលម្នាក់ ក្នុងពួកសាក្សីបីនាក់ចំពោះព្រះគម្ពីរមរមន ។*

*១–៦, ពួកអ្នកធ្វើការនៅក្នុងចំការទំពាំងបាយជូរ នឹងបានសេចក្ដីសង្គ្រោះ; ៧–៨, ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមា បំផុតរបស់ព្រះ; ៩–១១, ព្រះគ្រីស្ទបានបង្កើតផ្ទៃមេឃនិងផែនដី ។*

កិច្ចការដ៏ធំនិង[ក]អស្ចារ្យ កំពុងតែនឹងចេញមកដល់កូនចៅមនុស្សហើយ ។

២ មើលចុះ យើងជាព្រះ ចូរស្ដាប់តាមព្រះបន្ទូលរបស់យើង ដែលរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខពីរ ទាំងកាត់ សន្លាក់ និងខួរឆ្អឹងដាច់ពីគ្នា ហេតុដូច្នេះហើយ ចូរស្ដាប់តាមព្រះបន្ទូលរបស់យើងចុះ ។

៣ មើលចុះ ស្រែបានសសំព្រះលួមច្រូតហើយ ហេតុដូច្នេះហើយ អស់អ្នកណាមានបំណងចង់ច្រូត ចូរឲ្យអ្នកនោះលូកកណ្ដៀវរបស់ខ្លួន ដោយកម្លាំងរបស់ខ្លួន ហើយច្រូតក្នុងកាលមានថ្ងៃនៅចុះ ប្រយោជន៍ឲ្យអ្នកនោះអាចបានសន្សំទុកសំរាប់ព្រលឹងគេ នូវសេចក្ដីសង្គ្រោះ ដ៏អស់កល្ប នៅក្នុងនគរព្រះ ។

៤ មែនហើយ អស់អ្នកណាដែលនឹងលូកកណ្ដៀវរបស់ខ្លួន ហើយច្រូត អ្នកនោះហើយបានហៅពីព្រះ ។

៥ ហេតុដូច្នេះហើយ បើសិនជាអ្នកសុំពីយើង នោះអ្នកតែងនឹងបានទទួល បើសិនជាអ្នកនឹងគោះ នោះតែងនឹងបើកឲ្យអ្នក ។

៦ ចូរស្វែងរក ដើម្បីនាំមក ហើយតាំងឡើងក្រុងស៊ីយ៉ូនរបស់យើងចុះ។ ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នូវគ្រប់អ្វីៗ ទាំងអស់ ។

៧ ហើយ បើសិនជាអ្នក[ក]កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយកាន់[ខ]ខ្ជាប់ដរាបដល់ចុងបំផុត នោះអ្នកនឹងបាន[គ]ជីវិតដ៏នៅ អស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមាបំផុតនូវគ្រប់អំណោយទានទាំងឡាយនៃព្រះ ។

៨ ហើយហេតុការណ៍នឹងកើតឡើងថា បើសិនជាអ្នកនឹងសូមពីព្រះវរបិតា ដោយនូវព្រះនាមរបស់យើង ដោយសេចក្ដីជំនឿជឿ នោះអ្នកនឹងបានទទួល[ក]ព្រះវិញ្ញាណបរិសុទ្ធ ដែលប្រទានសំដី ដើម្បីឲ្យអ្នក[ខ]ឈរជាសាក្សីអំពីរបស់ទាំងឡាយ ដែលអ្នកនឹងបាន[គ]ឮ ព្រមទាំងបានឃើញ ហើយដើម្បីឲ្យអ្នកអាចបានប្រកាសប្រាប់ពីការប្រែចិត្ត ដល់តំណនេះផង ។

១៤ ១*ក* សូមមើល គ. និង ស. ១១:១–៦
សំរាប់ការយោងដូចគ្នា.
៧ *ក* លេវី. ២៦:៣–១២;
យ៉ូហាន ១៥:១០;
ម៉ូសាយ ២:២២, ៤១;
គ. និង ស. ៥៨:២.
*ខ* ស.ប. កាន់ខ្ជាប់.
*គ* ២ នីហ្វៃ ៣១:២០;
គ. និង ស. ៦:១៣.
ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៨ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ខ* ម៉ូសាយ ១៨:៨–១០.
ស.ប. សាក្សី.
*គ* សូមមើលទីបន្ទាប់នៃពួកសាក្សីបីនាក់
នៅដើមទំព័រព្រះគម្ពីរមរមន.

៩ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ ជាអ្នកដែលបានបង្កើតផ្ទៃមេឃ និងផែនដី គឺជាពន្លឺ ដែលពុំអាចលាក់នៅក្នុងសេចក្ដីងងឹតបានឡើយ;
១០ ហេតុដូច្នោះហើយ យើងត្រូវនាំភាពពោរពេញនៃដំណឹងល្អរបស់យើង ចេញពីពួកសាសន៍ដទៃ ទៅដល់វង្សអ៊ីស្រាអែល ។
១១ ហើយមើលចុះ អ្នកជាដាវីឌ ហើយអ្នកត្រូវបានហៅឲ្យជួយ ដែលជាអ្វី បើសិនជាអ្នកធ្វើ ហើយមានចិត្តស្មោះត្រង់នោះអ្នក នឹងបានពរ ទាំងខាងវិញ្ញាណនិងខាងសាច់ឈាម ហើយរង្វាន់របស់អ្នកនឹងធំណាស់ ។ អាម៉ែន ៕

## កណ្ឌទី ១៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះយ៉ូហានវិតមើរ នៅភូមិហ្វាយែត រដ្ឋញូវយ៉ោក ខែមិថុនា ឆ្នាំ១៨២៩ (*History of the Church*, ១:៥០) ។ (សូមមើលចំណងជើងនៃកណ្ឌទី ១៤) ។ សារនេះមានភាពស្និទ្ធស្នាល ជិតដិតយ៉ាងសំបើម ពីព្រោះព្រះអម្ចាស់ ទ្រង់ប្រាប់អំពីអ្វីៗ ដែលមានតែយ៉ូហាននិងព្រះអង្គប៉ុណ្ណោះដែលដឹង ។ ក្រោយមក យ៉ូហាន វិតមើរបានក្លាយទៅជាសាក្សីម្នាក់ ក្នុងចំណោមសាក្សីប្រាំបីនាក់ ដល់ព្រះគម្ពីរមរមន ។*

*១–២, ព្រះពាហុរបស់ព្រះអម្ចាស់នៅលើអស់ទាំងផែនដី; ៣–៦, ដើម្បីផ្សាយដំណឹងល្អ និងសង្គ្រោះព្រលឹងទាំងឡាយ គឺជាការណ៍ដ៏ មានតម្លៃបំផុត ។*

ប្រុងស្ដាប់ យ៉ូហានជាអ្នកបំរើរបស់យើងអើយ ហើយស្ដាប់តាមព្រះបន្ទូលទាំងឡាយនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់អ្នក និងព្រះដ៏ប្រោសលោះរបស់អ្នកចុះ ។
២ ត្បិតមើលចុះ យើងមានបន្ទូលមកកាន់អ្នក ដោយមុតមាំ និងដោយអំណាច ត្បិតពាហុរបស់យើងនៅលើអស់ទាំងផែនដី ។
៣ ហើយយើងនឹងប្រាប់អ្នកថា គ្មានមនុស្សណាដឹងឡើយ លើកលែងតែយើងនិងអ្នកប៉ុណ្ណោះ —
៤ ត្បិតមានគ្រាជាច្រើន ដែលអ្នកបានប្រាថ្នាពីយើង សូមចង់ដឹងនូវអ្វី ដែលមានតម្លៃបំផុតចំពោះអ្នក ។
៥ មើលចុះ អ្នកមានពរហើយ ចំពោះការណ៍នេះ ហើយចំពោះការនិយាយប្រាប់ព្រះបន្ទូលរបស់យើង ដែលយើងបានប្រទានដល់អ្នក ស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ។
៦ ហើយឥឡូវនេះ មើលចុះ យើងមានបន្ទូលមកកាន់អ្នកថា ការណ៍ដែលនឹងមានតម្លៃបំផុតចំពោះអ្នក គឺដើម្បីផ្សាយប្រាប់ពីការប្រែចិត្ត ដល់ប្រជាជននេះ ដើម្បីឲ្យអ្នកអាចនាំព្រលឹងទាំងឡាយមករកយើង ដើម្បីឲ្យអ្នកអាចសំរាកជាមួយពួកគេ នៅក្នុងនគរនៃព្រះវរបិតា របស់យើង ។ អាម៉ែន ៕

## កណ្ឌទី ១៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះពេត្រុសវិតមើរ ជុញ៉រ នៅភូមិហ្វាយែត រដ្ឋញូវយ៉ោក ខែមិថុនា ឆ្នាំ១៨២៩ (*History of the Church*, ១:៥១) ។ (សូមមើលចំណងជើងនៃកណ្ឌទី ១៤) ។ ក្រោយមក ពេត្រុសវិតមើរ ជុញ៉រ បានក្លាយទៅជាសាក្សីម្នាក់ ក្នុងចំណោមសាក្សីប្រាំបីនាក់ អំពីព្រះគម្ពីរមរមន ។*

៩ *ក* ម៉ូសាយ ៤:២;
គ. និង ស. ៧៦:២០–២៤.
*ខ* រ៉ូម ១:៤.
*គ* ដានី. ៦:២៦; អាលម៉ា ៧:៦;
គ. និង ស. ២០:១៩.
*ឃ* យ៉ូហាន ១:១–៣, ១៤;
៣ នីហ្វៃ ៩:១៥;
គ. និង ស. ៤៥:១.
ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ង* អ័ព្រា. ៤:១២, ២៤–២៥.
*ច* ២ សាំយ៉ូ. ២២:២៩.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ឆ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
១០ *ក* គ. និង ស. ២០:៨–៩;
យ.ស. — ប្រវត្តិ ១:៣៤.
*ខ* ស.ប. ពួកសាសន៍ដទៃ.
១៥ ២ *ក* ហេលេ. ៣:២៩–៣០.
ស.ប. អំណាច.
៦ *ក* គ. និង ស. ១៨:១៥–១៦.
ស.ប. កិច្ចការផ្សាយសាសនា.
*ខ* ស.ប. សេចក្ដីសំរាក.
*គ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ឃ* ស.ប. ព្រះវរបិតាដែលគង់នៅស្ថានសួគ៌.

*១–២, ព្រះពាហុរបស់ព្រះអម្ចាស់នៅលើអស់ទាំងផែនដី; ៣–៦, ដើម្បីផ្សាយដំណឹងល្អ និងសង្គ្រោះព្រលឹងទាំងឡាយ គឺជាការណ៍ដ៏ មានតម្លៃបំផុត ។*

ប្រុសស្ដាប់ ពេត្រុសជាអ្នកបំរើរបស់យើងអើយ ហើយស្ដាប់តាមព្រះបន្ទូលទាំងឡាយនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់អ្នក និងព្រះដ៏ប្រោសលោះរបស់អ្នកចុះ ។
២ ត្បិតមើលចុះ យើងមានបន្ទូលមកកាន់អ្នក ដោយមុតមាំ និងដោយអំណាច ត្បិតពាហុរបស់យើងនៅលើអស់ទាំងផែនដី ។
៣ ហើយយើងនឹងប្រាប់អ្នកថា គ្មានមនុស្សណាដឹងឡើយ លើកលែងតែយើងនិងអ្នកប៉ុណ្ណោះ —
៤ ត្បិតមានគ្រាជាច្រើន ដែលអ្នកបានប្រាថ្នាពីយើង សូមចង់ដឹងនូវអ្វី ដែលមានតម្លៃបំផុតចំពោះអ្នក ។
៥ មើលចុះ អ្នកមានពរហើយ ចំពោះការណ៍នេះ ហើយចំពោះការនិយាយប្រាប់ព្រះបន្ទូលរបស់យើង ដែលយើងបានប្រទានចំពោះអ្នក ស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ។
៦ ហើយឥឡូវនេះ មើលចុះ យើងមានបន្ទូលមកកាន់អ្នកថា ការណ៍ដែលនឹងមានតម្លៃបំផុតចំពោះអ្នក គឺផ្សាយប្រាប់ពីការប្រែចិត្ត ដល់ប្រជាជននេះ ដើម្បីឲ្យអ្នកអាចនាំព្រលឹងទាំងឡាយមករកយើង ដើម្បីឲ្យអ្នកអាចសំរាកជាមួយពួកគេ នៅក្នុងនគរនៃព្រះវរបិតា របស់យើង ។ អាម៉ែន ៕

## កណ្ឌទី ១៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី ចំពោះអូលីវើរខៅឌើរី ដាវីឌវិតមើរ និងម៉ាទិនហារិស នៅភូមិ ហ្វាយែត រដ្ឋនូវយ៉ោក ខែមិថុនា ឆ្នាំ១៨២៩ គឺមុនពេលពួកគេបានឃើញផ្ទាំងចារិកទាំងឡាយ ដែលមានបញ្ជីប្រវត្តិនៃព្រះគម្ពីរមរមន (*History of the Church*, ១:៥២–៥៧) ។ យ៉ូសែបនិងអូលីវើរខៅឌើរី ជាស្មៀនរបស់លោក បានរៀនពីការបកប្រែផ្ទាំងទាំង ឡាយនៃព្រះគម្ពីរមរមន ថាត្រូវមានពួកសាក្សីពិសេសបីនាក់តាំងឡើង (សូមមើលគម្ពីរអេធើរ ៥:២–៤; នីហ្វៃទី២ ១១:៣; ២៧:១២) ។ អូលីវើរខៅឌើរី ដាវីឌវិតមើរ និងម៉ាទិនហារិស ត្រូវបានជ្រាបដឹងដោយសេចក្ដីប្រាថ្នាដ៏ប្រកបដោយការបំផុសឲ្យធ្វើជាពួកសាក្សី ពិសេសបីនាក់ ។ លោកព្យាការីបានសូមដល់ព្រះអម្ចាស់ ហើយវិវរណៈនេះត្រូវបានប្រទានឲ្យមកជាចម្លើយតាមរយៈយូរីមនិងធូមីម ។*

*១–៤, ដោយសារសេចក្ដីជំនឿ ពួកសាក្សីបីនាក់នឹងបានឃើញផ្ទាំងទាំងឡាយ និងវត្ថុពិសិដ្ឋៗផ្សេងទៀត; ៥–៩, ព្រះគ្រីស្ទធ្វើទីបន្ទាល់ អំពីទេវភាពនៃព្រះគម្ពីរមរមន ។*

មើលចុះ យើងមានបន្ទូលមកកាន់អ្នកថា អ្នកត្រូវពឹងមកលើព្រះបន្ទូលរបស់យើង គឺបើសិនជាអ្នករាល់គ្នាធ្វើដោយពេញចិត្តប្រាថ្នា នោះអ្នកនឹងបានឃើញផ្ទាំងទាំងឡាយ និងព្រមទាំងប្រដាប់បាំងទ្រូង ដាវរបស់ឡាបាន់ យូរីម និងធូមីម ដែលបានប្រទានដល់បងប្រុស របស់យ៉ារេឌ នៅលើភ្នំ ក្នុងកាលលោកបានទូលជាមួយនឹងព្រះអម្ចាស់ទល់មុខ ហើយនិងរបស់ដៅទិសដ៏អស្ចារ្យ ដែលបានប្រទាន ដល់លោកលីហៃ កាលនៅក្នុងទីរហោស្ថាន នៅតាមព្រំដែនសមុទ្រក្រហម ។
២ ហើយគឺដោយសារសេចក្ដីជំនឿរបស់អ្នករាល់គ្នា ដែលអ្នករាល់គ្នានឹងបានឃើញរបស់ទាំងឡាយ គឺដោយសារសេចក្ដីជំនឿ នោះឯង ដែលពួកព្យាការីបុរាណធ្លាប់មាន ។
៣ ហើយបន្ទាប់ពីអ្នករាល់គ្នាបានសេចក្ដីជំនឿ និងបានឃើញរបស់ទាំងឡាយ ដោយភ្នែករបស់អ្នកហើយ នោះអ្នករាល់គ្នាត្រូវធ្វើ បន្ទាល់អំពីរបស់ទាំងនោះ ដោយព្រះចេស្ដានៃព្រះ ។

**១៦** ១*ក* សូមមើល គ. និង ស. ១៥:១–៥ សំរាប់ការយោងដូចគ្នា.
**១៧** ១*ក* ២ នីហ្វៃ ២៧:១២; អេធើរ ៥:២; គ. និង ស. ៥:១៥ ។ សូមមើលទីបន្ទាប់នៃពួកសាក្សីបីនាក់ នៅដើមទំព័រព្រះគម្ពីរមរមន.
*ខ* មរមន ៦:៦; យ.ស. — ប្រវត្តិ ១:៥២. ស.ប. ផ្ទាំងទាំងឡាយ.
*គ* ១ នីហ្វៃ ៤:៨–៩; ២ នីហ្វៃ ៥:១៤; យ៉ាកុប ១:១០; ម៉ូសាយ ១:១៦.
*ឃ* ស.ប. យូរីម និងធូមីម.
*ង* អេធើរ ៣:១–២៨.
*ច* លោកុ. ៣២:៣០; និក្ខ. ៣៣:១១; ម៉ូសេ ១:២.
*ឆ* ១ នីហ្វៃ ១៦:១០, ១៦, ២៦–២៩; អាលម៉ា ៣៧:៣៨–៤៧.
*ជ* ១ នីហ្វៃ ២:៥.
៣ *ក* ស.ប. ធ្វើបន្ទាល់; សាក្សី.

៤ ហើយការណ៍នេះអ្នករាល់គ្នានឹងធ្វើ ដើម្បីកុំឲ្យយ៉ូសែបស្ម៊ីធ ជាអ្នកបំរើរបស់យើង អាចត្រូវបំផ្លាញ ដើម្បីឲ្យយើងអាចនាំមក នូវ គោលបំណងដ៏សុចរិតរបស់យើង ចំពោះកូនចៅមនុស្ស ដោយនូវកិច្ចការនេះ ។

៥ ហើយអ្នករាល់គ្នានឹងធ្វើទីបន្ទាល់ ថាអ្នកបានឃើញរបស់ទាំងនោះ ដូចជាយ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង បាន ឃើញដែរ ត្បិតគឺដោយសារអំណាចរបស់យើងនោះហើយ ដែលលោកបានឃើញរបស់ទាំងនោះ ហើយនេះគឺដោយ សារលោកមានសេចក្ដី ជំនឿ។

៦ ហើយលោកបានបកប្រែ[ក]ព្រះគម្ពីរ សូម្បីតែ[ខ]ចំណែកនោះ ដែលយើងបានបញ្ជាដល់លោក ហើយប្រាកដដូចជាព្រះអម្ចាស់ របស់អ្នក និងព្រះរបស់អ្នក ទ្រង់មានព្រះជន្មរស់នៅ ការណ៍ នោះពិតមែន ។

៧ ហេតុដូច្នោះហើយ អ្នករាល់គ្នាបានទទួលអំណាចដូចគ្នា និងសេចក្ដីជំនឿដូចគ្នា និងអំណោយទានដូចគ្នា នឹងលោកដែរ;

៨ ហើយបើសិនជាអ្នករាល់គ្នាធ្វើតាមព្រះបញ្ញត្តិចុងក្រោយបង្អស់ របស់យើង ដែលយើងបានប្រទានដល់អ្នក [ក]នោះទ្វារស្ថាន នរកនឹងពុំ ដែលឈ្នះអ្នកឡើយ [ខ]ត្បិតគុណរបស់យើងល្មម ដល់អ្នកហើយ [គ]ហើយអ្នកនឹងបានលើកឡើង នៅថ្ងៃ ចុងក្រោយបង្អស់ ។

៩ ហើយយើង ជាព្រះយេស៊ូវគ្រីស្ទ ជា[ក]ព្រះអម្ចាស់របស់អ្នក និងជាព្រះរបស់អ្នក បានមានបន្ទូលដល់អ្នក ដើម្បីឲ្យយើងអាចនាំ មក នូវគោលបំណងដ៏សុចរិតរបស់យើង ចំពោះកូនចៅមនុស្ស ។ អាម៉ែន ៕

## កណ្ឌទី ១៨

*វិវរណៈចំពោះយ៉ូសែបស្ម៊ីធ ជាព្យាការី អូលីវើរខៅឌើរី និងដាវីឌវិតមើរ នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែមិថុនា ឆ្នាំ១៨២៩ (*History of the Church*, ១:៦០–៦៤) ។ កាលបានប្រគល់ឲ្យបព្វជិតភាពអើរ៉ុន នោះបានសន្យាថានឹងប្រគល់ឲ្យបព្វជិតភាព ម៉ិលគីស្សាដែក (សូមមើលចំណងជើងនៃកណ្ឌទី ១៣) ។ ក្នុងការឆ្លើយតបនូវការអំពាវនាវ សូមការចេះដឹងអំពីការណ៍នេះ នោះព្រះអម្ចាស់ ទ្រង់បានប្រទានវិវរណៈនេះ ។*

*១–៥, បទគម្ពីរបង្ហាញប្រាប់របៀបសាងសាសនាចក្រឡើង; ៦–៨, ពិភពលោកកំពុងទុំស្រុះនៅក្នុងសេចក្ដីទុច្ចរិត; ៩–១៦, តម្លៃនៃព្រលឹង ទាំងឡាយ គឺមហិមាណាស់; ១៧–២៥, ដើម្បីឲ្យបានសេចក្ដីសង្គ្រោះ មនុស្សលោកត្រូវយកព្រះនាមនៃព្រះគ្រីស្ទដាក់មកលើខ្លួន; ២៦–៣៦ តំណែង និងបេសកកម្មនៃពួក១២នាក់ត្រូវបានបើកសំដែងប្រាប់; ៣៧–៣៩, អូលីវើរខៅឌើរី និងដាវីឌវិតមើរ ត្រូវស្វែងរកពួក១២នាក់; ៤០–៤៧, ដើម្បីឲ្យបានសេចក្ដីសង្គ្រោះ មនុស្សលោកត្រូវតែប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយកាន់តាមព្រះបញ្ញត្តិ ទាំងឡាយ ។*

ឥឡូវនេះ មើលចុះ អូលីវើរខៅឌើរី ជាអ្នកបំរើរបស់យើងអើយ ពីព្រោះតែអ្វីដែលអ្នកមានប្រាថ្នាចង់ដឹងពីយើង នោះយើង ប្រទានដល់ អ្នក នូវពាក្យទាំងនេះថា៖

២ មើលចុះ យើងបានសម្ដែងដល់អ្នក ដោយសារព្រះវិញ្ញាណ របស់យើង នៅក្នុងកាលៈទេសៈជាច្រើន ថាការណ៍ទាំងឡាយ ដែលអ្នក បានសរសេរនោះគឺ[ក]ពិត; ហេតុដូច្នេះហើយ អ្នកដឹងថា ការណ៍ទាំងនោះពិត ។

៣ ហើយបើសិនជាអ្នកដឹងថាការណ៍ទាំងនោះពិត មើលចុះ យើងប្រទានដល់អ្នក[ក]នូវបញ្ញត្តិមួយ ដើម្បីឲ្យអ្នកពឹងទៅលើការណ៍ ទាំង នោះ ដែលបានសរសេរទុក;

៦ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ២ នីហ្វៃ ២៧:២២; ៣ នីហ្វៃ ២៦:៧–១០.
៨ *ក* ម៉ាថាយ ១៦:១៨; ៣ នីហ្វៃ ១១:៣៩; គ. និង ស. ១០:៦៩.
*ខ* ស.ប. ព្រះគុណ.
*គ* ១ នីហ្វៃ ១៣:៣៧; ៣ នីហ្វៃ ២៧:១៤–១៥, ២២; គ. និង ស. ៩:១៤.
៩ *ក* ស.ប. ព្រះអម្ចាស់.
១៨ ២*ក* គ. និង ស. ៦:១៥–១៧.
៣ *ក* គ. និង ស. ៩៨:១១. ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.

៤ ត្បិតនៅក្នុងនោះ គឺជាអ្វីៗទាំងអស់ ដែលបានសរសេរទុកស្ដីអំពីគ្រឹះនៃសាសនាចក្ររបស់យើង ដំណឹងល្អរបស់យើង និងថ្មដា របស់យើង ។

៥ ហេតុដូច្នោះហើយ បើសិនជាអ្នកនឹងកសាងសាសនាចក្ររបស់យើងឡើង នៅលើគ្រឹះនៃដំណឹងល្អរបស់យើង និងថ្មដារបស់យើង នោះទ្វារស្ថាននរកនឹងពុំដែលឈ្នះអ្នកឡើយ ។

៦ មើលចុះ ពិភពលោកកំពុងតែទុំស្រុះនៅក្នុងសេចក្ដីទុច្ចរិត ហើយជាចាំបាច់ថា កូនចៅមនុស្សត្រូវតែដាស់រំជួយឲ្យមានការប្រែចិត្ត ទាំងពួកសាសន៍ដទៃ និងវង្សអ៊ីស្រាអែលផងដែរ ។

៧ ហេតុដូច្នោះហើយ ដូចជាអ្នកបានទទួលបុណ្យជ្រមុជទឹកដោយសារដៃយ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើងស្របតាមអ្វីដែលយើងបានបញ្ជាដល់លោក នោះលោកបានបំពេញនូវអ្វីដែលយើងបានបញ្ជាដល់លោកហើយ ។

៨ ហើយឥឡូវនេះ ចូរកុំឆ្ងល់ឡើយ ដែលយើងបានហៅលោកចំពោះគោលបំណងរបស់យើងផ្ទាល់ គឺជាគោលបំណងដែលយើងដឹង ហេតុដូច្នោះហើយ បើសិនជាលោកនឹងមានចិត្តឧស្សាហ៍ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះលោកនឹងបានពរដល់ ជីវិតដ៏នៅអស់កល្បជានិច្ច ហើយឈ្មោះលោកគឺយ៉ូសែប ។

៩ ហើយឥឡូវនេះ អូលីវើរខៅឌើរអើយ យើងមានបន្ទូលដល់អ្នក និងដល់ដាវីឌវិតមើរផងដែរថា តាមរយៈព្រះបញ្ញត្តិ ត្បិតមើលចុះ យើងបញ្ជាមនុស្សលោកទាំងអស់ នៅគ្រប់ទិសទីឲ្យប្រែចិត្ត ហើយយើងមានបន្ទូលដល់អ្នក ដូចជាដល់ប៉ុល ជាសាវករបស់យើងថា ត្បិតអ្នកត្រូវបានហៅ ដូចជាការហៅដដែល ដែលលោកត្រូវបានហៅដែរ ។

១០ ចូរចាំចុះថា តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ចំពោះព្រះនេត្រនៃព្រះ;

១១ ត្បិតមើលចុះ ព្រះអម្ចាស់ដ៏ជាព្រះប្រោសលោះរបស់អ្នកទ្រង់បានរងសេចក្ដីស្លាប់ នៅក្នុងសាច់ឈាម ម្ល៉ោះហើយ ទ្រង់បានរង ការឈឺចាប់នៃមនុស្សលោកទាំងអស់ ដើម្បីឲ្យមនុស្សលោកទាំងអស់អាចប្រែចិត្ត ហើយមករកព្រះអង្គបាន ។

១២ ហើយទ្រង់បានមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ដើម្បីឲ្យព្រះអង្គអាចនាំមនុស្សលោកទាំងអស់មករកទ្រង់ ស្រមតាមលក្ខខ័ណ្ឌនៃ ការប្រែចិត្ត ។

១៣ ហើយសេចក្ដីអំណររបស់ទ្រង់មហិមាណាស់ណ៎ា ចំពោះព្រលឹងណាដែលប្រែចិត្ត!

១៤ ហេតុដូច្នេះហើយ អ្នកត្រូវបានហៅ ឲ្យស្រែកប្រាប់ពីការប្រែចិត្ត ដល់ប្រជាជននេះ ។

១៥ ហើយបើសិនជាអ្នកត្រូវធ្វើការអស់មួយជីវិតអ្នក ដោយស្រែកប្រាប់ពីការប្រែចិត្តដល់ប្រជាជននេះ ហើយគ្រាន់តែនាំព្រលឹងតែមួយ គត់មករកយើង នោះអ្នកនឹងមានសេចក្ដីអំណរដ៏មហិមាជាមួយអ្នកនោះ នៅក្នុងនគរនៃព្រះវរបិតារបស់យើង!

១៦ ហើយឥឡូវនេះ បើសិនជាអ្នកនឹងមានសេចក្ដីអំណរដ៏មហិមាដល់ព្រលឹងតែមួយ ហើយយ៉ាងណាទៅ ដែលអ្នកបាននាំមករកយើង នៅក្នុងនគរនៃ ព្រះវរបិតារបស់យើង នោះអ្នកនឹងមានសេចក្ដីអំណរដ៏មហិមា បើសិនជាអ្នកបាននាំព្រលឹងជាច្រើន មករកយើង!

១៧ មើលចុះ អ្នកមានដំណឹងល្អរបស់យើងនៅខាងមុខអ្នកហើយ និងថ្មដារបស់យើង ហើយនិងសេចក្ដីសង្គ្រោះរបស់យើង ។

១៨ ចូរសូមពីព្រះវរបិតា ដោយនូវនាមរបស់យើង ដោយសេចក្ដីជំនឿជឿថា អ្នកនឹងបានទទួល ហើយអ្នកនឹងបាន

៤ *ក* ស.ប. ដំណឹងល្អ.
*ខ* ស.ប. ថ្ម.
៦ *ក* ស.ប. ពិភពលោក.
*ខ* ស.ប. ពួកសាសន៍ដទៃ.
៧ *ក* យ.ស. — ប្រវត្តិ ១:៧០–៧១.
៨ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* ស.ប. ការគោរព, ដែលគោរព, គោរព.
*គ* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*ឃ* ២ នីហ្វៃ ៣:១៤–១៥.
ស.ប. ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ
៩ *ក* រ៉ូម ១:១.
១០ *ក* ស.ប. ព្រលឹង — តម្លៃនៃព្រលឹងទាំងឡាយ.
*ខ* ស.ប. ព្រលឹង.
១១ *ក* ស.ប. ព្រះដ៏ប្រោសលោះ.
*ខ* ស.ប. ការឆ្កាង.
*គ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ឃ* អេសាយ ៥៣:៤–៥.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
១២ *ក* ស.ប. ដំណើររស់ឡើងវិញ.
*ខ* គ. និង ស. ១៩:៤–១៨.
ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
១៣ *ក* លូកា ១៥:៧.
១៤ *ក* អាលម៉ា ២៩:១–២; គ. និង ស. ៣៤:៥–៦; ៦៣:៥៧.
១៥ *ក* ស.ប. ព្រលឹង — តម្លៃនៃព្រលឹងទាំងឡាយ.
១៦ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ខ* អាលម៉ា ២៦:១១.
ស.ប. សេចក្ដីអំណរ.
*គ* ស.ប. កិច្ចការផ្សាយសាសនា.
១៧ *ក* ស.ប. សេចក្ដីសង្គ្រោះ.
១៨ *ក* ស.ប. ការអធិស្ឋាន.
*ខ* យ៉ូហាន ១៥:១៦.

ព្រះវិញ្ញាណបរិសុទ្ធ ដែលសំដែងប្រាប់នូវគ្រប់ទាំងអ្វីៗ ដែលចាំបាច់ដល់កូនចៅមនុស្ស ។

១៩ ហើយបើសិនជាអ្នកពុំមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរសទេ នោះអ្នកពុំអាចធ្វើអ្វីបានឡើយ ។

២០ ចូរកុំប្រឆាំងនឹងសាសនាចក្រណាឡើយ លើកលែងតែសាសនាចក្រនៃអារក្ស ។

២១ ចូរយកព្រះនាមនៃព្រះគ្រីស្ទមកដាក់លើខ្លួន ហើយនិយាយសេចក្ដីពិត ដោយមានចិត្តម៉ឺងម៉ាត់ចុះ ។

២២ ហើយអស់អ្នកណាដែលប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវនាមយើង គឺជាព្រះយេស៊ូវគ្រីស្ទ ហើយកាន់ខ្ជាប់ដរាប ដល់ចុងបំផុត អ្នកនោះហើយនឹងបានសង្គ្រោះ ។

២៣ មើលចុះ ព្រះយេស៊ូវគ្រីស្ទ គឺជានាម ដែលបានប្រទានមកពីព្រះវរបិតា ហើយគ្មាននាមណាទៀត ដែលមនុស្សអាចបានសង្គ្រោះ នោះឡើយ;

២៤ ហេតុដូច្នោះហើយ មនុស្សទាំងអស់ត្រូវយកព្រះនាមដែលបានប្រទានមកពីព្រះវរបិតា មកដាក់លើខ្លួន ត្បិតដោយនូវព្រះនាមនោះ ហើយ ដែលពួកគេនឹងត្រូវបានហៅ នៅថ្ងៃចុងក្រោយបំផុត;

២៥ ហេតុដូច្នេះហើយ បើសិនជាពួកគេមិនស្គាល់នាម ដែលពួកគេត្រូវហៅនោះទេ នោះពួកគេពុំអាចមានកន្លែង នៅក្នុងនគរនៃព្រះ វរបិតារបស់យើងឡើយ ។

២៦ ហើយឥឡូវនេះ មើលចុះ មានមនុស្សឯទៀត ដែលបានហៅឲ្យផ្សាយដំណឹងល្អរបស់យើង ដល់ព្រមទាំងពួកសាសន៍ដទៃ និងពួកសាសន៍យូដាផងដែរ;

២៧ មែនហើយ គឺមាន១២នាក់ ហើយពួក១២នាក់នោះនឹងត្រូវទៅជាពួកសិស្សរបស់យើង ហើយពួកគេនឹងយកនាមរបស់យើង មកដាក់លើខ្លួនគេ ហើយពួក១២នាក់នេះហើយ ដែលនឹងប្រាថ្នាចង់យកនាមរបស់យើង មកដាក់លើខ្លួនគេ ដោយបំណងចិត្ត ដ៏ពោរពេញ ។

២៨ ហើយបើសិនជាពួកគេប្រាថ្នាចង់យកនាមរបស់យើងមកដាក់លើខ្លួនគេ ដោយបំណងចិត្តដ៏ពោរពេញ នោះពួកគេត្រូវបានហៅ ឲ្យទៅពេញសព្វទាំងពិភពលោក ដើម្បីទៅផ្សាយដំណឹងល្អរបស់យើង ដល់សត្វលោកគ្រប់រូប ។

២៩ ហើយពួកគេនេះហើយ ដែលត្រូវបានតែងតាំងពីយើង ដើម្បីឲ្យធ្វើបុណ្យជ្រមុជទឹក ដោយនូវនាមរបស់យើង ស្របតាមអ្វីដែលបាន សរសេរទុក;

៣០ ហើយអ្នកមានអ្វី ដែលបានសរសេរទុក នៅខាងមុខអ្នក ហើយ ហេតុដូច្នោះហើយ អ្នកត្រូវធ្វើការនោះ ស្របតាមព្រះបន្ទូលដែល បានសរសេរទុក ។

៣១ ហើយឥឡូវនេះ យើងមានបន្ទូលមកកាន់អ្នក គឺពួក១២នាក់ — មើលចុះ គុណរបស់យើងល្មមដល់អ្នកហើយអ្នកត្រូវដើរដោយ ទៀងត្រង់ នៅចំពោះយើង ហើយចូរកុំធ្វើបាបឡើយ ។

៣២ ហើយមើលចុះ អ្នករាល់គ្នាជាពួកអ្នកដែលបានតែងតាំងពីយើង ដើម្បីឲ្យតែងតាំងសង្ឃ និងគ្រូទាំងឡាយ ដើម្បីឲ្យផ្សាយប្រាប់ ដំណឹងល្អរបស់យើង តាមព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធដែលសណ្ឋិតនៅក្នុងអ្នករាល់គ្នា ហើយតាមការហៅ និងអំណោយទាន ទាំងឡាយនៃព្រះ ដែលមានដល់មនុស្សលោក;

៣៣ ហើយយើង គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់អ្នក និងជាព្រះរបស់អ្នក បានមានបន្ទូលថាដូច្នោះ ។

៣៤ ព្រះបន្ទូលទាំងនេះ ពុំមែនជាពាក្យនៃមនុស្សលោក

១៨ *គ* គ. និង ស. ៨៨:៦៣–៦៥.
១៩ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* ស.ប. សេចក្ដីសង្ឃឹម.
*គ* ស.ប. សេចក្ដីសប្បុរស.
២០ *ក* ២ ធីម៉ូ. ២:២៣–២៤;
៣ នីហ្វៃ ១១:២៩–៣០.
*ខ* ស.ប. អារក្ស —
សាសនាចក្រនៃអារក្ស.
២១ *ក* ២ នីហ្វៃ ៣១:១៣; ម៉ូសាយ ៥:៨;
៣ នីហ្វៃ ២៧:៥;
គ. និង ស. ២០:៣៧.
*ខ* គ. និង ស. ១០០:៥–៨.
*គ* រ៉ូម ១២:៣.
២២ *ក* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. កាន់ខ្ជាប់.
២៣ *ក* ម៉ាឡាគី ១:១១; កិច្ចការ ៤:១២;
ម៉ូសាយ ៣:១៧;
ហេលេ. ៣:២៨–២៩.
២៥ *ក* ម៉ូសាយ ៥:៩–១៤.
*ខ* ស.ប. សិរីល្អនៃសេឡេស្ទាល.
២៦ *ក* គ. និង ស. ៩០:៨–៩; ១១២:៤.
២៧ *ក* ស.ប. សាវក.
*ខ* គ. និង ស. ២៧:១២.
២៨ *ក* ម៉ាកុស ១៦:១៥–១៦.
*ខ* ស.ប. ដំណឹងល្អ.
*គ* គ. និង ស. ១:២; ៤២:៥៨.
២៩ *ក* ៣ នីហ្វៃ ១១:២១–២៨;
គ. និង ស. ២០:៧២–៧៤.
៣១ *ក* គ. និង ស. ១០៧:២៣–៣៥.
៣២ *ក* ម៉ូរ៉ូណៃ ៣:១–៤;
គ. និង ស. ២០:៦០; ១០៧:៥៨.
ស.ប. តែងតាំង, ការតែងតាំង.
*ខ* ២ ពេត្រុស ១:២១;
គ. និង ស. ៦៨:៣–៤.
*គ* គ. និង ស. ២០:២៧.
៣៤ *ក* ស.ប. បទព្រះគម្ពីរ.

ឬនៃមនុស្សទេ ប៉ុន្តែជាព្រះបន្ទូលរបស់យើង ហេតុដូច្នេះហើយ អ្នកនឹងធ្វើទី បន្ទាល់ថាព្រះបន្ទូលទាំងនេះ ជាព្រះបន្ទូលរបស់យើង ហើយមិនមែនជាពាក្យនៃមនុស្សទេ;

៣៥ ត្បិតជា[ក]សម្លេងរបស់យើងនេះហើយ ដែលមានបន្ទូលមកកាន់អ្នក ត្បិតព្រះបន្ទូលទាំងនេះត្រូវបានប្រទានដល់អ្នក ដោយព្រះ វិញ្ញាណរបស់យើង និងដោយអំណាចរបស់យើង នោះអ្នកអាចអានឲ្យគ្នាស្ដាប់ទៅវិញទៅមក ហើយលើកលែងតែដោយសារអំណាចរបស់យើង នោះអ្នកក៏ពុំអាចបានព្រះបន្ទូលទាំងនេះដែរ;

៣៦ ហេតុដូច្នោះហើយ អ្នករាល់គ្នាអាច[ក]ធ្វើទីបន្ទាល់ថាអ្នកបានឮសម្លេងរបស់យើង ហើយស្គាល់ព្រះបន្ទូលទាំងឡាយរបស់យើង ។

៣៧ ហើយឥឡូវនេះ មើលចុះយើងប្រទានដល់អ្នក អូលីវើរ ខៅឌើរីអើយ និងដល់ដាវីឌវិតមើរផងដែរថា អ្នកនឹងស្វែងរកពួក១២នាក់ ជាពួកអ្នកដែលមានសេចក្ដីប៉ងប្រាថ្នា ដែលយើងបានមានបន្ទូលមកនោះ;

៣៨ ហើយដោយសារសេចក្ដីប៉ងប្រាថ្នាទាំងឡាយរបស់ពួកគេ និង[ក]កិច្ចការទាំងឡាយរបស់ពួកគេ ទើបអ្នកនឹងស្គាល់ពួកគេបាន ។

៣៩ ហើយកាលណាអ្នកបានរកឃើញពួកគេ នោះអ្នកនឹងបង្ហាញរបស់ទាំងនេះដល់ពួកគេ ។

៤០ ហើយអ្នកនឹងដួលចុះ ហើយ[ក]ថ្វាយបង្គំព្រះវរបិតា ដោយនូវនាមរបស់យើង ។

៤១ ហើយអ្នកត្រូវផ្សាយដល់ពិភពលោក ដោយចេញវាចាថា៖ អ្នករាល់គ្នាត្រូវតែប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹកដោយនូវ ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ;

៤២ ត្បិតមនុស្សលោកទាំងអស់ត្រូវតែប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក គឺមិនគ្រាន់តែពួកបុរសប៉ុណ្ណោះទេ តែពួកស្ត្រីនិងកុមារាកុមារី ដែលមានអាយុនៃ[ក]ការទទួលខុសត្រូវផងដែរ ។

៤៣ ហើយឥឡូវនេះ បន្ទាប់ពីអ្នកបានទទួលការណ៍នេះ អ្នកត្រូវកាន់តាម[ក]ព្រះបញ្ញត្តិទាំងឡាយរបស់យើង នូវគ្រប់ការណ៍ទាំងអស់;

៤៤ ហើយដោយសារដៃទាំងឡាយរបស់អ្នករាល់គ្នា នោះយើងនឹងធ្វើកិច្ចការ[ក]ដ៏អស្ចារ្យមួយ នៅចំណោមកូនចៅមនុស្ស ដើម្បី[ខ]បញ្ជាក់ដល់មនុស្សជាច្រើន អំពីអំពើបាបទាំងឡាយរបស់គេ ដើម្បីឲ្យពួកគេអាចមករកការប្រែចិត្ត ហើយដើម្បីឲ្យពួកគេអាចមករកនគរ នៃព្រះ វរបិតារបស់យើង ។

៤៥ ហេតុដូច្នោះហើយ ព្រះពរទាំងឡាយ ដែលយើងប្រទានដល់អ្នក គឺ[ក]ហួសអ្វីៗទាំងអស់ ។

៤៦ ហើយបន្ទាប់ពីអ្នកបានទទួលការណ៍នេះ បើសិនជាអ្នកមិន[ក]កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងទេ នោះអ្នកមិនអាចបានសង្គ្រោះ នៅក្នុងនគរនៃព្រះវរបិតារបស់យើងឡើយ ។

៤៧ មើលចុះ យើងគឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់អ្នក និងជាព្រះរបស់អ្នក ហើយជាព្រះដ៏ប្រោសលោះរបស់អ្នក ដោយព្រះ ចេស្ដានៃព្រះវិញ្ញាណរបស់យើង បានមានបន្ទូលថាដូច្នោះហើយ ។ អាម៉ែន ៕

## កណ្ឌទី ១៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ នៅក្រុងម៉ែនឆែសស្ទើរ រដ្ឋនូវយ៉ោក ខែមីនា ឆ្នាំ១៨៣០ (*History of the Church, *១:៧២–៧៤)* ។ *នៅក្នុងប្រវត្តិរបស់លោក នោះព្យាការីបានណែនាំថា «ព្រះបញ្ញត្តិមកពីព្រះ ហើយមិនមែនមកពី មនុស្សទេ ទោដល់ម៉ាទិនហារិស ដែលត្រូវបានប្រទានឲ្យមកពីព្រះអង្គទ្រង់ដែលនៅអស់កល្បជានិច្ច» (*History of the Church, *១:៧២)* ។

៣៥ *ក* គ. និង ស. ១:៣៨.
ស.ប. សម្លេង.
៣៦ *ក* ស.ប. ធ្វើបន្ទាល់.
៣៨ *ក* ស.ប. កិច្ចការ.
៤០ *ក* ស.ប. ថ្វាយបង្គំ.
៤២ *ក* គ. និង ស. ២០:៧១; ២៩:៤៧; ៦៨:២៧.
ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
៤៣ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
៤៤ *ក* អេសាយ ២៩:១៤; គ. និង ស. ៤:១.
*ខ* អាលម៉ា ៣៦:១២–១៩; ៦២:៤៥.
៤៥ *ក* គ. និង ស. ៨៤:៣៥–៣៨.
៤៦ *ក* គ. និង ស. ៨២:៣.

*១–៣, ព្រះគ្រីស្ទមានគ្រប់ព្រះចេស្ដា; ៤–៥, មនុស្សលោកគ្រប់រូបត្រូវតែប្រែចិត្ត បើពុំនោះសោតទេ ត្រូវរងទុក្ខ; ៦–១២, ទោសដ៏នៅ អស់កល្បជានិច្ច គឺជាទោសមកពីព្រះ; ១៣–២០, ព្រះគ្រីស្ទបានរងទុក្ខជំនួសមនុស្សលោកគ្រប់រូប ដើម្បីមិនបាច់ឲ្យពួកគេត្រូវរងទុក្ខ បើសិនជាពួកគេប្រែចិត្ត; ២១–២៨, ចូរផ្សាយដំណឹងល្អពីការប្រែចិត្ត; ២៩–៤១, ចូរប្រកាសប្រាប់ពីដំណឹងរីករាយ ។*

យើងគឺជា[ក]អាលផា និងអូមេកា ជា[ខ]ព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ មែនហើយ គឺយើងនេះហើយជាទ្រង់ គឺជាដើម ហើយជាចុង ជាព្រះដ៏ប្រោសលោះ នៃពិភពលោក ។
២ យើង ដោយបានបំពេញនិង[ក]សំរេចតាមព្រះហឫទ័យនៃទ្រង់ ដែលយើងត្រូវជាបុត្រ គឺព្រះវរបិតា ចំពោះយើង — ដោយបានធ្វើការ នេះ ដើម្បីឲ្យយើងអាច[ខ]បញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមអំណាចយើង —
៣ ដោយបានទុកគ្រប់[ក]អំណាចទាំងអស់ គឺដើម្បី[ខ]ការបំផ្លាញ អារក្ស និងកិច្ចការទាំងឡាយរបស់វា នៅ[គ]ចុងបំផុតនៃផែនដី និងនៅថ្ងៃចុង ក្រោយបង្អស់នៃសេចក្ដីជំនុំជំរះ ដែលយើងនឹង បណ្ដាលឲ្យកើតឡើង ដល់បណ្ដាជននៅលើផែនដី ដោយ[ឃ]ជំនុំជំរះមនុស្សគ្រប់រូប តាម [ង]កិច្ចការ និងអំពើទាំងឡាយរបស់គេ ដែលគេបានប្រព្រឹត្តរៀងខ្លួន ។
៤ ហើយប្រាកដមែន មនុស្សគ្រប់រូបត្រូវតែ[ក]ប្រែចិត្ត បើពុំនោះ សោតទេ ត្រូវ[ខ]រងទុក្ខ ត្បិតយើងជាព្រះ [គ]ដ៏មិនចេះសូន្យឡើយ ។
៥ ហេតុដូច្នេះហើយ យើងមិន[ក]ដកសេចក្ដីជំនុំជំរះទាំងឡាយ ដែលយើងនឹងធ្វើឲ្យកើតឡើងនោះចេញទេ ប៉ុន្តែសេចក្ដីវេទនា ទាំង ឡាយនឹងចេញទៅ ដូចជាការយំសោក [ខ]ការថ្ងូរ និងការ សង្កៀតធ្មេញ មែនហើយ គឺដល់អស់អ្នកណា ដែលឃើញនៅ [គ]ខាងឆ្វេងដៃ របស់យើង ។
៦ ទោះជាយ៉ាងណាក៏ដោយ គឺ[ក]ពុំបានចែងទុកមកទេថា គ្មានទីបញ្ចប់ដល់ការរងទុក្ខវេទនានេះ ប៉ុន្តែបានចែងទុកថាជា*ការរងទុក្ខវេទនា [ខ]ដ៏មិនចេះចប់មិនចេះហើយ*វិញ ។
៧ ម្យ៉ាងទៀត គឺបានចែងថា *[ក]ជាសេចក្ដីផាប់ទោសដ៏អស់កល្បជានិច្ច* ហេតុដូច្នោះហើយ អ្វីដែលបានចែងទុក នោះចែងយ៉ាងច្បាស់ លាស់ ជាងបទគម្ពីរផ្សេងៗទៀត ដើម្បីឲ្យអ្វីទាំងនោះអាចប្រព្រឹត្តមកលើចិត្តនៃកូនចៅមនុស្ស ព្រមព្រៀងគ្នាសំរាប់សិរីល្អដល់ព្រះនាម របស់យើង ។
៨ ហេតុដូច្នេះហើយ យើងនឹងពន្យល់ប្រាប់ដល់អ្នករាល់គ្នា នូវការអាថ៌កំបាំងនេះ ត្បិតសមឲ្យអ្នកដឹង ដូចជាពួកសាវក របស់យើងជា ដើម ។
៩ យើងមានបន្ទូលដល់អ្នករាល់គ្នា ដែលត្រូវបានរើសនៅក្នុងការណ៍នេះ ដូចជាមនុស្សតែម្នាក់ ដើម្បីឲ្យអ្នកអាចចូល[ក]ក្នុងសេចក្ដីសំរាក របស់យើងបាន ។
១០ ត្បិតមើលចុះ [ក]សេចក្ដីអាថ៌កំបាំងនៃភាពជាព្រះ នោះមហិមាណាស់ហ្ន៎! ត្បិតមើលចុះ យើងមិនចេះសូន្យឡើយ ហើយទោសដែល យើងធ្វើចេញពីព្រះហស្តរបស់យើងទៅ គឺជាទោសដ៏មិនចេះចប់មិនចេះហើយ ត្បិត[ខ]មិនចេះសូន្យឡើយ គឺជាព្រះនាមរបស់យើង ។ ហេតុដូច្នោះហើយ —
១១ ទោស[ក]ដ៏អស់កល្បជានិច្ច គឺជាទោសមកពីព្រះ ។
១២ ទោសដ៏មិនចេះចប់មិនចេះហើយ គឺជាទោសមកពីព្រះ ។
១៣ ហេតុដូច្នោះហើយ យើងបញ្ជាឲ្យអ្នកប្រែចិត្ត ហើយកាន់[ក]តាមព្រះបញ្ញត្តិទាំងឡាយ ដែលអ្នកបានទទួលពីដៃនៃយ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ដោយនូវព្រះនាមរបស់យើង;

១៩ ១*ក* វិវរ. ១:៨, ១១; ៣ នីហ្វៃ ៩:១៨; គ. និង ស. ៣៥:១; ៦១:១. ស.ប. អាលផា និងអូមេកា.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
២ *ក* យ៉ូហាន ១៧:៤; ៣ នីហ្វៃ ១១:១១.
*ខ* ភីលីព ៣:២១.
៣ *ក* ស.ប. អំណាច.
*ខ* អេសាយ ១៤:១២–១៧; ១ យ៉ូហាន ៣:៨; ១ នីហ្វៃ ២២:២៦; គ. និង ស. ៨៨:១១១–១១៥.
*គ* ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
*ឃ* ស.ប. សេចក្ដីជំនុំជំរះ ចុងក្រោយបំផុត.
*ង* ស.ប. កិច្ចការ.
៤ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* លូកា ១៣:៣; ហេលេ. ១៤:១៩.
*គ* ម៉ូសេ ១:៣.
៥ *ក* គ. និង ស. ៥៦:៤; ៥៨:៣២.
*ខ* ម៉ាថាយ ១៣:៤២.
*គ* ម៉ាថាយ ២៥:៤១–៤៣.
៦ *ក* គ. និង ស. ៧៦:១០៥–១០៦; ១៣៨:៥៩.
*ខ* គ. និង ស. ៧៦:៣៣, ៤៤–៤៥.
៧ *ក* ហេលេ. ១២:២៥–២៦; គ. និង ស. ២៩:៤៤.
៩ *ក* ស.ប. សេចក្ដីសំរាក.
១០ *ក* យ៉ាកុប ៤:៨; គ. និង ស. ៧៦:១១៤–១១៦.
*ខ* ម៉ូសេ ១:៣; ៧:៣៥. ស.ប. មិនចេះចប់មិនចេះហើយ.
១១ *ក* ម៉ាថាយ ២៥:៤៦.
១៣ *ក* គ. និង ស. ៥:២; ១០:៦–៧; ១៧:១–៩.

១៤ ហើយគឺដោយព្រះចេស្ដាដ៏មហិទ្ធិឫទ្ធិរបស់យើង ដែល
អ្នកបានទទួលព្រះបញ្ញត្តិទាំងនោះ;
១៥ ហេតុដូច្នេះហើយ យើងបញ្ជាឲ្យអ្នកប្រែចិត្ត — ចូរប្រែ
ចិត្តចុះ បើពុំនោះសោតទេ យើងនឹងវាយអ្នកដោយរំពាត់នៃព្រះ
ឱស្ឋ របស់យើង ហើយដោយសេចក្ដីខ្ញាល់របស់យើង និងសេច
ក្ដីពិរោធរបស់យើង នោះសេចក្ដីរងទុក្ខវេទនាទាំងឡាយរបស់
អ្នកនឹង ឈឺចាប់ណាស់ — គឺឈឺដល់ណានោះអ្នកមិនដឹងទេ
ជ្រួតជ្រាបដល់ណានោះអ្នកមិនដឹងទេ មែនហើយ ធ្ងន់ធ្ងរដល់
ណានោះអ្នក មិនដឹងទេ ។
១៦ ត្បិតមើលចុះ យើងជាព្រះ បានរងទុក្ខនូវការទាំងនេះ
ជំនួសមនុស្សទាំងអស់ ដើម្បីកុំឲ្យគេអាចរងទុក្ខ បើសិនជាពួកគេ
ប្រែចិត្ត;
១៧ ប៉ុន្តែបើសិនជាពួកគេមិនព្រមប្រែចិត្តទេ នោះពួកគេត្រូវរង
ទុក្ខ ដូចជាយើងដែរ;
១៨ គឺជាសេចក្ដីរងទុក្ខវេទនា ដែលបណ្ដាលឲ្យយើង គឺជាព្រះ
ដែលមហិមាលើអ្វីៗទាំងអស់ ត្រូវញ័រដោយសារតែការឈឺចាប់
ហើយត្រូវហូរចេញលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខ
ព្រមទាំងរូបកាយនិងវិញ្ញាណផង — ហើយដើម្បីកុំឲ្យយើងត្រូវ
ផឹកពែង ល្វីង ហើយរួញខ្លាច —
១៩ ទោះជាយ៉ាងណាក៏ដោយ សូមព្រះវរបិតាបានសិរីល្អ
ហើយយើងបានទទួលទាន និងសំរេចការរៀបចំរបស់យើង ចំពោះ
កូនចៅមនុស្ស ។
២០ ហេតុដូច្នោះហើយ ជាថ្មីទៀត យើងបញ្ជាឲ្យអ្នកប្រែចិត្ត
បើពុំនោះសោតទេ យើងនឹងបន្ទាបអ្នក ដោយព្រះចេស្ដាដ៏មហិទ្ធិឫទ្ធិ
របស់យើង ហើយឲ្យអ្នកសារភាពនូវអំពើបាបទាំងឡាយរបស់អ្នក
បើពុំនោះសោតទេ នោះអ្នកនឹងរងទោសទាំងឡាយ ដែលយើង
បានមានបន្ទូលមក ដែលនៅកំរិតដ៏តូចបំផុត មែនហើយ គឺតិចបំផុត
ដែលអ្នកបានភ្លក់ នៅពេលដែលយើងដកព្រះវិញ្ញាណរបស់យើង
ចេញ ។
២១ ហើយយើងបញ្ជាអ្នកថា ចូរកុំប្រកាសប្រាប់អ្វីឡើយ
ក្រៅពីការប្រែចិត្ត ហើយចូរកុំបង្ហាញការណ៍ទាំងនេះ ដល់ពិភព
លោកឡើយ លុះត្រាជាប្រាជ្ញានៅក្នុងយើង ។
២២ ត្បិតឥឡូវនេះ ពួកគេពុំអាចទ្រាំសាច់បានទេ ប៉ុន្តែពួកគេ
ត្រូវទទួលទានទឹកដោះវិញ ម្ល៉ោះហើយ ពួកគេពុំអាចដឹងអំពីការណ៍
ទាំង នេះឡើយ ក្រែងពួកគេនឹងវិនាសទៅ ។
២៣ ចូររៀនអំពីយើង ហើយស្ដាប់តាមព្រះបន្ទូលទាំងឡាយ
របស់យើងចុះ ចូរដើរក្នុងភាពស្លូតបូតនៃព្រះវិញ្ញាណរបស់យើង
នោះអ្នកនឹងបានសេចក្ដីសុខសាន្តក្នុងយើង ។
២៤ យើងជាព្រះយេស៊ូវគ្រីស្ទ យើងបានមកតាមបំណង
ព្រះហឫទ័យនៃព្រះវរបិតា ហើយយើងធ្វើតាមបំណងព្រះហឫទ័យ
របស់ទ្រង់ ។
២៥ ហើយជាថ្មីទៀត យើងបញ្ជាអ្នកថា កុំលោភចង់បាន
ប្រពន្ធអ្នកជិតខាងខ្លួន ឬក៏ស្វែងរកផ្ដាច់ជីវិតអ្នកជិតខាងខ្លួនឡើយ ។
២៦ ហើយជាថ្មីទៀត យើងបញ្ជាអ្នកថា កុំលោភទ្រព្យសម្បត្តិ
របស់ខ្លួនឡើយ ប៉ុន្តែចូរចំណាយដោយសេរី សំរាប់ការបោះពុម្ពព្រះ
គម្ពីរ មរមន ដែលមានសេចក្ដីពិត និងព្រះបន្ទូលនៃព្រះ —
២៧ ដែលជាព្រះបន្ទូលរបស់យើង ចំពោះពួកសាសន៍ដទៃ
ដើម្បីបន្តិចទៀតនោះ អាចទៅដល់ពួកសាសន៍យូដា ដែលពួក
សាសន៍លេមិនត្រូវជាសំណល់ ដើម្បីឲ្យពួកគេអាចជឿ
ដល់ដំណឹងល្អ ហើយមិនទន្ទឹងចាំព្រះមែស៊ី ដែលបានយាងមក
ហើយនោះឡើយ ។
២៨ ហើយជាថ្មីទៀត យើងបញ្ជាអ្នកថា ចូរអធិស្ឋានឲ្យឮ

១៥ *ក* អាលម៉ា ៣៦:១១–១៩.
១៦ *ក* អាលម៉ា ១១:៤០–៤១.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
*គ* ស.ប. ការផ្ដាច់បាប.
១៧ *ក* គ. និង ស. ២៩:១៧.
១៨ *ក* លូកា ២២:៤២–៤៤.
១៩ *ក* យ៉ូហាន ១៧:៤; ១៩:៣០.
២០ *ក* ជនគ. ៥:៦–៧; ម៉ូសាយ ២៦:២៩; គ. និង ស. ៥៨:៤៣; ៦៤:៧.
ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
២១ *ក* គ. និង ស. ១១:៩.
*ខ* យ.ស. — ប្រវត្តិ ១:៤២.
២២ *ក* គ. និង ស. ៧៨:១៧–១៨.
*ខ* ហេព្រើរ ៥:១១–១៤; គ. និង ស. ៥០:៤០.
២៣ *ក* ម៉ូរ៉ូណៃ ៧:៣–៤.
*ខ* ស.ប. ស្លូតបូត, ភាពស្លូតបូត.
*គ* ស.ប. សេចក្ដីសុខសាន្ត.
២៤ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
២៥ *ក* ស.ប. លោភ.
*ខ* និក្ខ. ២០:១៧; ១ កូរិន. ៧:២–៤.
ស.ប. អំពើកំផិត.
២៦ *ក* ស.ប. សេចក្ដីពិត.
២៧ *ក* ស.ប. ពួកសាសន៍ដទៃ.
*ខ* ស.ប. ពួកសាសន៍យូដា.
*គ* អោមណៃ ១:១៤–១៩; ម៉ូសាយ ២៥:២–៤; ហេលេ. ៨:២១; ៣ នីហ្វៃ ២:១២–១៦.
*ឃ* ស.ប. ព្រះមែស៊ី.
២៨ *ក* ១ ធីម៉ូ. ២:៨.
ស.ប. ការអធិស្ឋាន.
*ខ* គ. និង ស. ២០:៤៧, ៥១; ២៣:៦.

ព្រមទាំងនៅក្នុងចិត្ត មែនហើយ នៅចំពោះពិភពលោក ព្រម
ទាំងនៅក្នុង ទីអាថ៌កំបាំង នៅចំពោះក្នុងទីសាធារណៈ ព្រម
ទាំងនៅក្នុងទីស្ងាត់ផងចុះ ។
២៩ ហើយចូរប្រកាសប្រាប់ដំណឹងដ៏រីករាយ មែនហើយ
ចូរប្រកាសប្រាប់នៅលើភ្នំ និងនៅលើគ្រប់ទីខ្ពស់ៗ និងនៅក្នុង
ចំណោមប្រជា ជនរាល់គ្នា ដែលអ្នកត្រូវបានអនុញ្ញាតឲ្យឃើញ ។
៣០ ហើយអ្នកនឹងធ្វើឡើង ដោយនូវអស់ទាំងភាពរាបសា
ដោយទុកចិត្តដល់យើង ដោយមិនជេរប្រមាថដល់ពួកអ្នកដែល
ជេរប្រមាថ ឡើយ ។
៣១ ហើយអំពីសិក្ខាបទដ៏ជ្រាលជ្រៅទាំងឡាយ នោះចូរកុំ
និយាយដល់ឡើយ ប៉ុន្តែចូរប្រកាសប្រាប់អំពីការប្រែចិត្ត និងសេច
ក្ដីជំនឿជឿ ដល់ព្រះអង្គសង្គ្រោះ និងអំពីការផ្ដាច់បាប ដោយ
សារបុណ្យជ្រមុជទឹក និងដោយសារភ្លើង មែនហើយ គឺដោយ
សារ ព្រះវិញ្ញាណបរិសុទ្ធ វិញ ។
៣២ មើលចុះ នេះជាព្រះបញ្ញត្តិដ៏ធំនិងចុងក្រោយបំផុត ដែល
យើងនឹងប្រទានដល់អ្នក ស្ដីអំពីការណ៍នេះ ត្បិតនេះល្មមសំរាប់
ដំណើរ ជីវិតរាល់ថ្ងៃរបស់អ្នកហើយ គឺរហូតដល់អស់មួយជីវិត
របស់អ្នក ។
៣៣ ហើយអ្នកនឹងបានទទួលសេចក្ដីទុក្ខវេទនា បើសិនជា
អ្នកមិនអើពើដល់ពាក្យដំបូន្មានទាំងនេះ មែនហើយ គឺសេចក្ដី
បំផ្លិចបំផ្លាញ ដល់ខ្លួនអ្នក និងដល់ទ្រព្យសម្បត្តិផងដែរ ។
៣៤ ចូរចំណាយផ្នែកនៃទ្រព្យសម្បត្តិរបស់អ្នក មែនហើយ
គឺផ្នែកនៃដីធ្លីរបស់អ្នក និងអ្វីៗទាំងអស់ លើកលែងតែអ្វីសំរាប់
គាំទ្រគ្រួសារ របស់ អ្នកប៉ុណ្ណោះ ។
៣៥ ចូរសងបំណុលដែលអ្នកបានយល់ព្រមជាមួយនឹងអ្នក
បោះពុម្ព ។ ចូរដោះខ្លួនឲ្យរួចពីសេវកភាពចុះ ។
៣៦ ចូរចេញពីផ្ទះសំបែងរបស់អ្នក លើកលែងតែកាលណា
អ្នកមានបំណងចង់ឃើញគ្រួសាររបស់អ្នក;
៣៧ ហើយចូរនិយាយដោយសេរីទៅកាន់មនុស្សទាំងអស់;
មែនហើយ ចូរផ្សាយ ទូន្មាន ប្រកាសប្រាប់នូវសេចក្ដីពិត
គឺដោយសម្លេង ខ្លាំងៗ ដោយសម្លេងរីករាយ ដោយ
ស្រែកឡើងថា — ហូសាណា ហូសាណា សូមឲ្យព្រះនាម
នៃព្រះអម្ចាស់ ដ៏ជាព្រះ ប្រកបដោយព្រះ ពរ !
៣៨ ចូរអធិស្ឋានជានិច្ច ហើយយើងនឹងចាក់ព្រះវិញ្ញាណ
របស់យើងមកលើអ្នក ហើយពររបស់អ្នកធំណាស់ហ៊ុំ — មែន
ហើយ គឺច្រើនជាងអ្វីដែលអ្នកគប្បីបានទទួលនូវទ្រព្យសម្បត្តិពីផែនដី
និងរបស់ពុករលួយទាំងនោះផង ។
៣៩ មើលចុះ តើអ្នកអាចអានការណ៍នេះ ដោយឥតមានចិត្ត
រីករាយ ហើយលើកចិត្តឡើង ដោយអរសប្បាយបានឬអី ?
៤០ ឬតើអ្នកអាចធ្វើជាអ្នកណែនាំដែលខ្វាក់បន្តទៅទៀតបាន
ឬអី ?
៤១ ឬតើអ្នកអាចមានចិត្តរាបសានិងស្លូតត្រង់ ហើយកាន់ខ្លួន
ដោយវាងវៃនៅចំពោះយើងបានឬអី ? មែនហើយ ចូរមក
រកយើង ជាព្រះអង្គសង្គ្រោះរបស់អ្នកចុះ ។ អាម៉ែន ៕

## កណ្ឌទី ២០

*វិវរណៈអំពីការរៀបចំ និងការគ្រប់គ្រងសាសនាចក្រ ដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែបស្ម៊ីធ ជាព្យាការី នៅខែមេសា ឆ្នាំ១៨៣០ (*History of the Church*, ១:៦៤–៧០)* ។ *បញ្ជីដើមរបស់លោកអំពីវិវរណៈនេះ ព្យាការីបានកត់ថា៖ «យើងបានទទួលពីទ្រង់ [ព្រះយេស៊ូវគ្រីស្ទ] ដែលមានដូចតទៅនេះ ដោយវិញ្ញាណនៃការព្យាករណ៍ និងវិវរណៈ ដែលមិនគ្រាន់តែឲ្យពត៌មានដ៏ច្រើន*

២៩ *ក* ស.ប. កិច្ចការផ្សាយសាសនា.
៣០ *ក* ស.ប. ទុកចិត្ត.
៣១ *ក* ២ ធីម៉ូ. ២:២៣–២៤.
*ខ* ស.ប. សេចក្ដីជំនឿ.
*គ* ស.ប. ការផ្ដាច់បាប.
*ឃ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ង* ម៉ាថាយ ៣:១១.
*ច* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
៣២ *ក* គ. និង ស. ៥៨:២៦–២៩.
៣៣ *ក* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
៣៤ *ក* កិច្ចការ ៤:៣៤–៣៥.
៣៥ *ក* ស.ប. បំណុល.
*ខ* ក.ន. ដើម្បីបង់ថ្លៃបោះពុម្ពព្រះគម្ពីរមរមន លើកទី១.
*គ* សុភា. ២២:៧.
៣៦ *ក* ម៉ាថាយ ១៩:២៩.
៣៧ *ក* គ. និង ស. ៥៨:៤៧; ៦៨:៨; ៧១:៧.
*ខ* គ. និង ស. ៧៥:៤.
៣៨ *ក* លូកា ១៨:១; ២ នីហ្វៃ ៣២:៩; គ. និង ស. ១០:៥.
*ខ* សុភា. ១:២៣; កិច្ចការ ២:១៧.
៤១ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ម៉ាថាយ ១១:២៨–៣០.

*ប៉ុន្តែបាន ចង្អុលប្រាប់ដល់យើង នូវថ្ងៃដ៏ជាក់ ស្របតាមព្រះហឫទ័យរបស់ទ្រង់ ដែលយើងគប្បីចាប់កសាងសាសនាចក្ររបស់ទ្រង់នៅលើ ផែនដីម្ដងទៀត» (*History of the Church, *១:៦៤)* ។

*១–១៦, ព្រះគម្ពីរមរមនបញ្ជាក់នូវទេវភាពនៃកិច្ចការថ្ងៃចុងក្រោយ; ១៧–២៨, គោលលទ្ធិទាំងឡាយអំពីការបង្កបង្កើត ការធ្លាក់ ដង្វាយធួន និងបុណ្យជ្រមុជទឹកត្រូវបានបញ្ជាក់; ២៩–៣៧, ក្រឹត្យវិន័យគ្រប់គ្រងទាំងឡាយអំពីការប្រែចិត្ត ការរាប់ជាសុចរិត ការញែក ចេញជាបរិសុទ្ធ និងបុណ្យជ្រមុជទឹក ត្រូវបានថែងប្រាប់; ៣៨–៦៧, កាតព្វកិច្ចទាំងឡាយនៃពួកអែលឌើរ ពួកសង្ឃ ពួកគ្រូ និងពួកឌីកុន ត្រូវបានសង្ខេបប្រាប់; ៦៨–៧៤, កាតព្វកិច្ចទាំងឡាយនៃសមាជិក ការប្រសិទ្ធិពរដល់កូនក្មេង និងរបៀបធ្វើបុណ្យជ្រមុជទឹកត្រូវបាន បើកសំដែងប្រាប់; ៧៥–៨៤, ការអធិស្ឋានសាក្រាម៉ង់ និងច្បាប់គ្រប់គ្រងសមាជិកភាពនៃសាសនាចក្រ ត្រូវបានថែងប្រាប់ ។*

ការ[ក]តាំងឡើង[ខ]នៃសាសនាចក្រនៃព្រះគ្រីស្ទ នៅថ្ងៃចុងក្រោយទាំងនេះ នៅឆ្នាំមួយពាន់ប្រាំបីរយសាមសិប ចាប់តាំងពីការយាងមកនៃ ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះដ៏ជាព្រះយេស៊ូវគ្រីស្ទរបស់យើង នៅក្នុងសាច់ឈាម ដែលបានរៀបចំនិងតាំងឡើងយ៉ាងត្រឹមត្រូវ ស្របតាមច្បាប់ទាំងឡាយនៃប្រទេសយើង តាមព្រះហឫទ័យនិងព្រះបញ្ញត្តិទាំងឡាយនៃព្រះ នៅខែបួន និងនៅថ្ងៃទីប្រាំមួយ ក្នុងខែ ដែលហៅថា មេសា —

២ ជាព្រះបញ្ញត្តិទាំងឡាយដែលបានប្រទានដល់យ៉ូសែបស្ម៊ីធ ជុញ្ញ័រ ជាអ្នកដែលបាន[ក]ហៅដោយព្រះ ហើយបានតែងតាំងជា[ខ]សាវកនៃ ព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យធ្វើជា[គ]អែលឌើរទី១នៃសាសនាចក្រនេះ;

៣ ហើយដល់អូលីវើរខោឌើរ ជាអ្នកដែលបានហៅដោយព្រះឲ្យធ្វើជាសាវកនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យធ្វើជាអែលឌើរទី២នៃសាសនាចក្រនេះ ហើយបានតែងតាំងនៅក្រោមដៃលោក;

៤ ហើយនេះគឺស្របតាមព្រះគុណនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ដ៏ជាព្រះយេស៊ូវគ្រីស្ទរបស់យើង សូមឲ្យបានប្រកបដោយអស់ទាំងសិរីល្អ ព្រមទាំងនៅពេលឥឡូវនេះ និងរៀងដរាបតទៅ ។ អាម៉ែន ។

៥ បន្ទាប់ពីបានសំដែងដ៏ជាក់ស្ដែងដល់អែលឌើរទី១នេះថា[ក] លោកបានទទួលការផ្ដាច់បាបនៃលោកហើយនោះ លោកត្រូវបានជំពាក់ ក្នុងអំពើអសារឥតការនៃពិភពលោកម្ដងទៀត;

៦ ប៉ុន្តែបន្ទាប់ពីបានប្រែចិត្ត និងបន្ទាបខ្លួនដោយស្មោះពីចិត្ត គឺតាមរយៈសេចក្ដីជំនឿ នោះព្រះទ្រង់បានឧបត្ថម្ភដល់លោកដោយ[ក]ទេវតាដ៏បរិសុទ្ធមួយ ដែលមាន[ខ]ភក្ត្រាដូចផ្លេកបន្ទោរ ហើយដែលមានសំលៀកបំពាក់ល្អសុទ្ធសាធ និងសជាងគ្រប់អ្វីៗទាំងអស់ដែលស;

៧ ហើយបានប្រទានព្រះបញ្ញត្តិទាំងឡាយដល់លោក ដែលបានបំភ្លឺគំនិតលោក;

៨ ហើយបានប្រទានអំណាចដល់លោកមកពីស្ថានដ៏ខ្ពស់ ដោយ[ក]មធ្យោបាយទាំងឡាយដែលបានរៀបចំទុកជាមុន ដើម្បីបកប្រែ ព្រះគម្ពីរមរមន;

៩ ដែលមានបញ្ជីប្រវត្តិអំពីប្រជារាស្ត្រដែលធ្លាក់ និង[ក]ភាពពោរពេញនៃ[ខ]ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដល់ពួកសាសន៍ដទៃ និងដល់ពួក សាសន៍យូដាផងដែរ;

១០ ដែលបានប្រទានឲ្យមក ដោយការបំភ្លឺគំនិត ហើយត្រូវបានបញ្ជាក់ដល់[ក]អ្នក[ខ]ដទៃទាំងឡាយ ដោយការបំរើនៃពួកទេវតា ហើយ ត្រូវបានប្រកាសប្រាប់ដល់ពិភពលោក ដោយសារពួកគេ —

១១ ដោយបញ្ជាក់ដល់ពិភពលោកថា បទគម្ពីរដ៏បរិសុទ្ធទាំងឡាយ គឺ[ក]ត្រឹមត្រូវ ហើយថាព្រះទ្រង់បាន[ខ]បំផុសគំនិតមនុស្សលោក

**២០** ១*ក* យ.ស. — ប្រវត្តិ ១:២.
*ខ* ៣ នីហ្វៃ ២៧:១–៨. ស.ប. សាសនាចក្រ, នាមនៃ; សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ.
*គ* គ. និង ស. ២១:៣.
២ *ក* ស.ប. សិទ្ធិអំណាច; ហៅ, បានហៅពីព្រះ, ការហៅ.
*ខ* ស.ប. សាវក.
*គ* ស.ប. អែលឌើរ.
៥ *ក* យ.ស. — ប្រវត្តិ ១:២៨–២៩.
៦ *ក* យ.ស. — ប្រវត្តិ ១:៣០–៣៥. ស.ប. ពួកទេវតា.
*ខ* ម៉ាថាយ ២៨:២–៣.
៨ *ក* ស.ប. យូរីម និងធូមីម.
៩ *ក* យ.ស. — ប្រវត្តិ ១:៣៤.
*ខ* ស.ប. ដំណឹងល្អ.
១០ *ក* ម៉ូរ៉ូណៃ ៧:២៩–៣២; គ. និង ស. ៥:១១.
*ខ* សូមមើលទីបន្ទាប់នៃពួកសាក្សីបីនាក់ និងទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់ នៅដើមទំព័រព្រះគម្ពីរមរមន.
១១ *ក* ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ខ* ស.ប. ការបំផុសគំនិត, បំផុសគំនិត.

ហើយហៅពួកគេ ឲ្យមករកកិច្ចការដ៏បរិសុទ្ធរបស់ទ្រង់ នៅសម័យ និងជំនាន់នេះ ក៏ដូចជានៅជំនាន់បុរាណដែរ;

១២ តាមផ្លូវនេះហើយ ដោយបង្ហាញថា ទ្រង់ជាព្រះនៅតែដដែល ទោះពីម្សិលមិញ ថ្ងៃនេះ និងរហូតតទៅ ។ អាម៉ែន ។

១៣ ហេតុដូច្នេះហើយ ដោយមានពួកសាក្សីដ៏មហិមា ដោយសារពួកគេនេះហើយ ដែលពិភពលោកនឹងត្រូវបានជំនុំជំរះ គឺពីអំណិះតទៅ មនុស្សជាច្រើននឹងបានដឹងអំពីកិច្ចការនេះ ។

១៤ ហើយអស់អ្នកណាដែលទទួលកិច្ចការ ដោយនូវសេចក្ដីជំនឿ ហើយធ្វើការសុចរិត អ្នកនោះនឹងបានទទួលមកុដនៃជីវិតដ៏នៅអស់ កល្បជានិច្ច;

១៥ ប៉ុន្តែអស់អ្នកណាពង្រឹងចិត្តរបស់ខ្លួន ដោយនូវការឥតជំនឿ ហើយមិនទទួលស្គាល់ នោះការណ៍នេះនឹងបែរទៅជាសេចក្ដីដាក់ ទោសដល់ពួកគេវិញ —

១៦ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានមានព្រះបន្ទូលថាដូច្នោះ ហើយយើង ជាពួកអែលឌើរនៃសាសនាចក្រ បានឮនិងធ្វើទីបន្ទាល់អំពី ព្រះបន្ទូលទាំងឡាយ នៃឫទ្ធានុភាពដ៏រុងរឿង នៅលើស្ថានដ៏ខ្ពស់ សូមឲ្យបានប្រកបដោយសិរីល្អ រហូតរៀងដរាបតទៅ ។ អាម៉ែន ។

១៧ ដោយសារការណ៍ទាំងនេះហើយ បានជាយើងដឹងថា មានព្រះមួយអង្គ គង់នៅលើស្ថានសួគ៌ ដែលនៅជានិរន្តរ៍ និងអស់កល្ប ជានិច្ច គឺពីអស់កល្បទៅអស់កល្បជានិច្ច ជាព្រះដដែល ឥតប្រែប្រួល ជាអ្នកបង្កើតផ្ទៃមេឃនិងផែនដី និងរបស់ទាំងអស់ ដែលនៅស្ថាន ទាំងនោះផង;

១៨ ហើយថា ទ្រង់បានបង្កើតមនុស្ស ជាប្រុសជាស្រី ឲ្យដូចជារូបរបស់ទ្រង់ ហើយឲ្យមានភាពដូចទ្រង់ នោះទ្រង់បានបង្កើតពួកគេឡើង;

១៩ ហើយបានប្រទានព្រះបញ្ញត្តិទាំងឡាយដល់ពួកគេថា ពួកគេគប្បីស្រឡាញ់ហើយបំរើទ្រង់ ជាព្រះដ៏មានព្រះជន្មរស់នៅ និងពិត តែមួយ ហើយថាទ្រង់ ជាព្រះអង្គមួយគត់ ដែលពួកគេគប្បីថ្វាយបង្គំ ។

២០ ប៉ុន្តែដោយសារការរំលងក្រិត្យវិន័យដ៏បរិសុទ្ធទាំងនេះ នោះមនុស្សបានក្លាយទៅជាមានវិស័យខាងកាមរាគ និងខាងអារក្ស ហើយបានក្លាយទៅជាមនុស្សធ្លាក់ ។

២១ ហេតុដូច្នោះហើយ បានជាព្រះដ៏ប្រកបដោយមហិទ្ធិឫទ្ធិ ប្រទានព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ ដូចជាចែងទុកនៅក្នុងបទ គម្ពីរ ដែលបានប្រាប់អំពីទ្រង់នោះ ។

២២ ទ្រង់បានរងទុក្ខសេចក្ដីល្បួងទាំងឡាយ ប៉ុន្តែមិនបានរវីរវល់ដល់សេចក្ដីទាំងនោះឡើយ ។

២៣ ទ្រង់ត្រូវគេឆ្កាង សុគត ហើយបានមានព្រះជន្មរស់ឡើងវិញបីថ្ងៃក្រោយមក;

២៤ ហើយបានយាងឡើងទៅលើស្ថានសួគ៌ ដើម្បីទៅគង់នៅខាងស្ដាំព្រះហស្ដនៃព្រះវរបិតា ដើម្បីទៅសោយរាជ្យដោយព្រះ ចេស្ដាដ៏មហិទ្ធិឫទ្ធិ ស្របតាមបំណងព្រះហឫទ័យនៃព្រះវរបិតា;

២៥ ដើម្បីឲ្យអស់អ្នកណាដែលនឹងជឿ ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមដ៏បរិសុទ្ធរបស់ទ្រង់ ហើយកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿ ដរាបដល់ចុងបំផុត នោះនឹងបានសង្គ្រោះ —

២៦ មិនគ្រាន់តែអស់អ្នកណាដែលជឿ បន្ទាប់ពីទ្រង់បានយាងមក ក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត គឺក្នុងសាច់ឈាមនោះទេ ប៉ុន្តែអស់

---

១១ *ក* ស.ប. បរិសុទ្ធ.
១២ *ក* ហេព្រើរ ១៣:៨; ១ នីហ្វៃ ១០:១៨–១៩; មរមន ៩:៩–១០; គ. និង ស. ៣៥:១; ៣៨:១–៤.
១៤ *ក* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ខ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច; ភាពដំកើងឡើង.
១៥ *ក* ស.ប. ការឥតជំនឿ.
១៧ *ក* គ. និង ស. ៧៦:២២–២៣.
*ខ* យ៉ូស្វេ ២:១១. ស.ប. ព្រះ, ក្រុមព្រះ.
១៨ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* លោកុ. ១:២៦–២៧; ម៉ូសាយ ៧:២៧; អេធើរ ៣:១៤–១៧.
១៩ *ក* ចោទិ. ១១:១; ម៉ាថាយ ២២:៣៧; ម៉ូរ៉ូណៃ ១០:៣២; គ. និង ស. ៥៩:៥–៦.
*ខ* ចោទិ. ៦:១៣–១៥. ស.ប. ការបំរើ.
*គ* ស.ប. ថ្វាយបង្គំ.
២០ *ក* ស.ប. ខាងកាមរាគ, កាមរាគ.
*ខ* ស.ប. អារក្ស.
*គ* ស.ប. មនុស្សខាងសាច់ឈាម.
២១ *ក* ស.ប. បង្កើតតែមួយ.
២២ *ក* ម៉ាថាយ ៤:១–១១; ២៧:៤០.
២៣ *ក* ស.ប. ការឆ្កាង.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
២៤ *ក* ស.ប. ការយាងឡើង.
*ខ* ស.ប. ព្រះវរបិតាដែលគង់នៅស្ថានសួគ៌; ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
២៥ *ក* គ. និង ស. ៣៥:២; ៣៨:៤; ៤៥:៥, ៨; ៦៨:៩; ៧៦:៥១–៥៣.
*ខ* ស.ប. កាន់ខ្ជាប់.
២៦ *ក* គ. និង ស. ៣៩:១–៣.

អ្នកណា ចាប់តាំងពីដំបូងមក គឺមនុស្សជាច្រើនដែលមកមុនទ្រង់ផងដែរ ដែលបានជឿតាមពាក្យពេចន៍ទាំងឡាយនៃ[ខ]ពួកព្យាការីដ៏បរិសុទ្ធ ដែល បានពោល ក្នុងកាលពួកគេត្រូវបានបណ្ដាលដោយសារ[គ]អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ជាអ្នកដែល[ឃ]បានធ្វើទី បន្ទាល់ដ៏ត្រឹមត្រូវ អំពីទ្រង់ ក្នុងការណ៍ទាំងអស់ នោះពួកគេនឹងបានជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ,

២៧ ហើយព្រមទាំងអស់អ្នកណា ដែលនឹងមកតាមក្រោយ ដែលនឹងជឿដល់[ក]អំណោយទាន និងការហៅទាំងឡាយនៃព្រះដោយព្រះ វិញ្ញាណបរិសុទ្ធ ដែល[ខ]ធ្វើទីបន្ទាល់ អំពីព្រះវរបិតា និងអំពីព្រះរាជបុត្រា;

២៨ រីឯព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះ[ក]តែមួយ គង់នៅជានិរន្តរ៍និងអស់កល្បជានិច្ច ដោយគ្មានទីបំផុត ។ អាម៉ែន ។

២៩ ហើយយើងដឹងថាមនុស្សទាំងអស់ ត្រូវតែ[ក]ប្រែចិត្ត ហើយជឿដល់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយថ្វាយបង្គំដល់ព្រះវរបិតា ដោយនូវព្រះនាមរបស់ទ្រង់ ហើយកាន់ខ្ជាប់ នៅក្នុង [ខ]សេចក្ដីជំនឿជឿដល់ព្រះនាមរបស់ទ្រង់ ដរាបដល់ចុងបំផុត បើពុំនោះសោតទេ ពួកគេពុំអាច[គ]បានសង្គ្រោះ នៅក្នុងនគរព្រះបានឡើយ ។

៣០ ហើយយើងដឹងថា [ក]ការរាប់ជាសុចរិត តាមរយៈ[ខ]ព្រះគុណនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ដ៏ជាព្រះយេស៊ូវគ្រីស្ទ នោះគឺយុត្តិធម៌ និងត្រឹមត្រូវ;

៣១ ហើយយើងក៏ដឹងដែរថា [ក]ការញែកជាបរិសុទ្ធ តាមរយៈព្រះគុណនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ដ៏ជាព្រះយេស៊ូវគ្រីស្ទ នោះគឺយុត្តិធម៌ និងត្រឹមត្រូវ ចំពោះអស់អ្នកណាដែលស្រឡាញ់ ហើយបំរើព្រះ ដោយ[ខ]អស់ពីពលំ អស់ពីគំនិត និងអស់ពីកម្លាំង ។

៣២ ប៉ុន្តែមានផ្លូវដែលមនុស្សអាច[ក]ធ្លាក់ចេញពីព្រះគុណ ហើយបោះបង់ព្រះដ៏មានព្រះជន្មរស់នៅ;

៣៣ ហេតុដូច្នេះហើយ ចូរឲ្យសាសនាចក្រប្រយ័ត្ន ហើយអធិស្ឋានជានិច្ច ក្រែងពួកគេធ្លាក់ទៅក្នុងសេចក្ដី[ក]ល្បួង;

៣៤ មែនហើយ គឺចូរឲ្យអស់អ្នកណាដែលបានញែកចេញជាបរិសុទ្ធប្រយ័ត្នផងចុះ ។

៣៥ ហើយយើងដឹងថា ការណ៍ទាំងនេះត្រឹមត្រូវ និងស្រប តាមវិវរណៈនៃលោកយ៉ូហាន [ក]ដោយគ្មានបន្ថែម ឬបន្ថយអ្វីចេញពីការ ព្យាករណ៍នៃគម្ពីររបស់លោកឡើយ គឺជា[ខ]បទគម្ពីរដ៏បរិសុទ្ធ ឬជាវិវរណៈទាំងឡាយពីព្រះដែលនឹងបានចេញមកនៅពេលក្រោយទៀត ដោយសារអំណោយទាន និងព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ គឺជា[គ]សម្លេងនៃព្រះ ឬក៏ការបំរើនៃពួកទេវតា ។

៣៦ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានមានព្រះបន្ទូលថា ដូច្នោះ ហើយសូមថ្វាយកិត្តិនាម ព្រះចេស្ដា និងសិរីល្អ ដល់ព្រះនាមដ៏ បរិសុទ្ធរបស់ព្រះអង្គ ព្រមទាំងនៅពេលឥឡូវនេះ និងរៀងដរាបតទៅ ។ អាម៉ែន ។

៣៧ *ហើយជាថ្មីទៀត តាមបញ្ញត្តិចំពោះសាសនាចក្រ ស្ដីអំពីរបៀបធ្វើបុណ្យជ្រមុជទឹក* — អស់អ្នកណាដែលបន្ទាបខ្លួន នៅចំពោះ ព្រះ ហើយមានបំណងចង់[ក]ទទួលបុណ្យជ្រមុជទឹក ហើយមកដោយមាន[ខ]ចិត្តសង្រេងនិងវិញ្ញាណទន់ទាប ហើយធ្វើបន្ទាល់នៅចំពោះ សាសនាចក្រថា ពួកគេប្រាកដជាបានប្រែចិត្ត ចំពោះអំពើបាបរបស់ពួក[គ]គេទាំងអស់ ហើយយល់ព្រមលើក[ឃ]ដាក់មកលើខ្លួន នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ដោយប្ដេជ្ញាថានឹង[ង]បំរើទ្រង់ដល់ចុងបំផុត ហើយប្រាកដជាសំដែងដោយកិច្ចការទាំងឡាយរបស់ពួកគេថាពួក

២៦ *ខ* យ៉ាកុប ៤:៤; ៧:១១;
ម៉ូសាយ ១៣:៣៣.
*គ* ម៉ូសេ ៥:៥៨.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ឃ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ.
២៧ *ក* គ. និង ស. ១៨:៣២.
*ខ* គ. និង ស. ៤២:១៧.
២៨ *ក* យ៉ូហាន ១៧:២០–២២;
៣ នីហ្វៃ ១១:២៧, ៣៦.
ស.ប. ព្រះ, ក្រុមព្រះ.
២៩ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. សេចក្ដីជំនឿ.
*គ* ស.ប. សេចក្ដីសង្គ្រោះ;
ផែនការនៃសេចក្ដីប្រោសលោះ.
៣០ *ក* ស.ប. ការរាប់ជាសុចរិត,
រាប់ជាសុចរិត.
*ខ* ស.ប. ព្រះគុណ.
៣១ *ក* ស.ប. ការញែកជាបរិសុទ្ធ.
*ខ* ចោទិ. ៦:៥; ម៉ូរ៉ូណៃ ១០:៣២.
៣២ *ក* ស.ប. សេចក្ដីក្បត់សាសនា;
ការបះបោរ.
៣៣ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
៣៥ *ក* វិវ. ២២:១៨–១៩.
*ខ* ស.ប. បទព្រះគម្ពីរ.
*គ* គ. និង ស. ១៨:៣៣–៣៦.
៣៧ *ក* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. ចិត្តសង្រេង.
*គ* ម៉ូសាយ ៥:៧–៩; ១៨:៨–១០.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
*ឃ* ស.ប. កាន់ខ្ជាប់.
*ង* យ៉ាកុប (ព.ស.ថ.) ២:១៨.
ស.ប. កិច្ចការ.

គេបានទទួលពីព្រះវិញ្ញាណនៃព្រះគ្រីស្ទ ចំពោះការ[ច]ផ្ដាច់បាបទាំងឡាយរបស់ពួកគេ ឈ្មោះថានឹងបានទទួល ឲ្យទទួលបុណ្យជ្រមុជទឹកចូល សាសនាចក្ររបស់ទ្រង់ ។

៣៨ *កាតព្វកិច្ចនៃពួកអែលឌើរ ពួកសង្ឃ ពួកគ្រូ ពួកឌីកុន និងសមាជិកទាំងឡាយនៃសាសនាចក្រនៃព្រះគ្រីស្ទ* — [ក]សាវកជា អែលឌើរ ហើយជាការហៅរបស់លោក ដើម្បីធ្វើ[ខ]បុណ្យជ្រមុជទឹក;

៣៩ ហើយដើម្បី[ក]តែងតាំងពួកអែលឌើរ ពួកសង្ឃ ពួកគ្រូ និងពួកឌីកុនផ្សេងៗទៀត;

៤០ ហើយដើម្បី[ក]ចាត់ចែងនំបុ័ងនិងស្រាទំពាំងបាយជូរ — ជាតំណាងទាំងឡាយអំពីសាច់និងព្រះលោហិតនៃព្រះគ្រីស្ទ —

៤១ ហើយដើម្បី[ក]បញ្ជាក់អស់អ្នកណា ដែលបានទទួលបុណ្យជ្រមុជទឹកហើយ ឲ្យចូលសាសនាចក្រ ដោយសារការដាក់[ខ]ដៃលើសំរាប់បុណ្យជ្រមុជដោយភ្លើង និងដោយ[គ]ព្រះវិញ្ញាណបរិសុទ្ធ ស្របតាមបទគម្ពីរទាំងឡាយ;

៤២ ហើយដើម្បីបង្រៀន ពន្យល់ ទូន្មាន ធ្វើបុណ្យជ្រមុជទឹក និងមើលការខុសត្រូវលើសាសនាចក្រ;

៤៣ ហើយដើម្បីបញ្ជាក់សាសនាចក្រ ដោយការដាក់ដៃលើ និងការប្រគល់ព្រះវិញ្ញាណបរិសុទ្ធឲ្យ;

៤៤ ហើយដើម្បីដឹកនាំការប្រជុំទាំងអស់ ។

៤៥ ពួកអែលឌើរត្រូវ[ក]នាំមុខការប្រជុំ នៅពេលព្រះវិញ្ញាណបរិសុទ្ធដឹកនាំ ស្របតាមព្រះបញ្ញត្តិ និងវិវរណៈទាំងឡាយនៃព្រះ ។

៤៦ កាតព្វកិច្ចរបស់[ក]សង្ឃ គឺដើម្បីផ្សាយ [ខ]បង្រៀន ពន្យល់ ទូន្មាន និងធ្វើបុណ្យជ្រមុជទឹក និងចាត់ចែងបុណ្យសាក្រាម៉ង់,

៤៧ ហើយទៅផ្ទះនៃសមាជិកម្នាក់ៗ ដើម្បីសួរសុខទុក្ខ ហើយទូន្មានពួកគេ ឲ្យ[ក]អធិស្ឋាន[ខ]ឲ្យឮ និងនៅទីអាថ៌កំបាំង ហើយឲ្យធ្វើកាតព្វកិច្ច [គ]គ្រួសារគ្រប់យ៉ាង ។

៤៨ ហើយលោកក៏អាច[ក]តែងតាំងពួកសង្ឃ ពួកគ្រូ និងពួកឌីកុនផ្សេងៗទៀតបានផងដែរ ។

៤៩ ហើយលោកត្រូវនាំមុខការប្រជុំ កាលណាគ្មានអែលឌើរនៅទីនោះ;

៥០ ប៉ុន្តែកាលណាមានអែលឌើរនៅទីនោះ នោះលោកគ្រាន់តែត្រូវផ្សាយ បង្រៀន ពន្យល់ ទូន្មាន និងធ្វើបុណ្យជ្រមុជទឹក,

៥១ ហើយទៅផ្ទះនៃសមាជិកម្នាក់ៗ ដើម្បីសួរសុខទុក្ខ ហើយទូន្មានពួកគេ ឲ្យអធិស្ឋានឲ្យឮ និងនៅទីអាថ៌កំបាំង ហើយឲ្យធ្វើកាតព្វកិច្ច គ្រួសារគ្រប់យ៉ាង ។

៥២ ក្នុងកាតព្វកិច្ចទាំងឡាយនេះ សង្ឃត្រូវ[ក]ជួយអែលឌើរ បើសិនជាត្រូវការ ។

៥៣ កាតព្វកិច្ចរបស់[ក]គ្រូ គឺដើម្បី[ខ]មើលការខុសត្រូវលើសាសនាចក្រជានិច្ច ហើយនៅជាមួយ និងចំរើនកម្លាំងពួកគេ;

៥៤ ហើយមើលឲ្យឃើញថា [ក]គ្មានសេចក្ដីទុច្ចរិត នៅក្នុងសាសនាចក្រ ឬក៏មានភាពរឹងទទឹងនឹងគ្នាទៅវិញទៅមក ឬមានការកុហក ការពោលបង្កាច់ ឬក៏មានការនិយាយ[ខ]អាក្រក់ឡើយ;

៥៥ ហើយមើលឲ្យឃើញថា សាសនាចក្រជួបជុំគ្នាជាញឹកញាប់ ហើយក៏មើលឲ្យឃើញថា សមាជិកទាំងអស់ ធ្វើកាតព្វកិច្ចរបស់ខ្លួន ។

៥៦ ហើយលោកត្រូវនាំមុខការប្រជុំ នៅពេលមិនមានអែលឌើរ ឬសង្ឃនៅទីនោះ —

៥៧ ហើយតម្រូវឲ្យជួយជានិច្ច ពី[ក]ពួកឌីកុន ក្នុងកាតព្វកិច្ចទាំងអស់របស់លោក នៅក្នុងសាសនាចក្រ បើសិនជាត្រូវការ ។

៥៨ ប៉ុន្តែគ្មានពួកគ្រូឬពួកឌីកុនណា មានសិទ្ធិអំណាច ដើម្បីធ្វើបុណ្យជ្រមុជទឹក ចាត់ចែងបុណ្យសាក្រាម៉ង់ ឬដាក់ដៃលើបានឡើយ;

៥៩ ប៉ុន្តែពួកគេ ត្រូវព្រមាន ពន្យល់ ទូន្មាន និងបង្រៀន ហើយអញ្ជើញមនុស្សទាំងអស់ ឲ្យមករកព្រះគ្រីស្ទ ។

៦០ [ក]អែលឌើរ សង្ឃ គ្រូ ឬឌីកុនរាល់ៗគ្នា ត្រូវបាន

៣៧ *ច* ស.ប. ការផ្ដាច់បាប.
៣៨ *ក* ស.ប. សាវក.
*ខ* ៣ នីហ្វៃ ១១:២១–២២.
៣៩ *ក* មរ៉ូណៃ ៣:១–៤; គ. និង ស. ១០៧:៥៨.
៤០ *ក* ស.ប. បុណ្យរំឭក.
៤១ *ក* គ. និង ស. ៣៣:១១, ១៤–១៥; ៥៥:៣.
*ខ* ស.ប. ដៃ, ការដាក់.
*គ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
៤៥ *ក* មរ៉ូណៃ ៦:៩; គ. និង ស. ៤៦:២.
៤៦ *ក* គ. និង ស. ៨៤:១១១; ១០៧:៦១. ស.ប. សង្ឃ, បព្វជិតភាពអើរ៉ុន.
*ខ* ស.ប. បង្រៀន, គ្រូបង្រៀន.
៤៧ *ក* ១ ធីម៉ូ. ២:៨.
*ខ* គ. និង ស. ១៩:២៨.
*គ* ស.ប. គ្រួសារ.
៤៨ *ក* ស.ប. តែងតាំង, ការតែងតាំង.
៥២ *ក* គ. និង ស. ១០៧:១៤.
៥៣ *ក* ស.ប. គ្រូ, បព្វជិតភាពអើរ៉ុន.
*ខ* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
៥៤ *ក* ១ ថែស្សា. ៥:១១–១៣.
*ខ* ស.ប. ការនិយាយអាក្រក់.
៥៧ *ក* ស.ប. ឌីកុន.
៦០ *ក* ស.ប. អែលឌើរ.

តែងតាំងឡើង តាមអំណោយទាន និង[ខ]ការហៅទាំងឡាយនៃព្រះ ចំពោះខ្លួន; ហើយលោកត្រូវបានតែងតាំងឡើង ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ដែលនៅក្នុងអ្នកដែលតែងតាំងលោក ។

៦១ ពួកអែលឌើរនានា ដែលធ្វើជាសាសនាចក្រនៃព្រះគ្រីស្ទនេះ ត្រូវជួបជុំគ្នានៅក្នុងសន្និសីទបីខែម្ដង ឬនៅពេលម្ដងៗ ដូចជាសន្និសីទទាំងនេះដឹកនាំ ឬកំណត់;

៦២ ហើយសន្និសីទទាំងនេះ ត្រូវធ្វើកិច្ចការណាដែលជារបស់ផងសាសនាចក្រ ដែលចាំបាច់ឲ្យធ្វើ នៅពេលនោះ ។

៦៣ ពួកអែលឌើរ[ក]ត្រូវទទួលអាជ្ញាប័ណ្ណ ពីពួកអែលឌើរផ្សេងៗទៀត ដោយការអនុមតិពីសាសនាចក្រ ដែលពួកគេចូលរួម ឬពីសន្និសីទទាំងឡាយ ។

៦៤ សង្ឃ គ្រូ ឬឌីកុនម្នាក់ៗ ដែលត្រូវបានតែងតាំងឡើងដោយសង្ឃ គេអាចយកសំបុត្រពីអ្នកតែងតាំងនៅពេលនោះ គឺជា[ក]សំបុត្រពេលប្រគល់ទៅឲ្យអែលឌើរ នោះនឹងឲ្យលោកមានសិទ្ធិទទួលអាជ្ញាប័ណ្ណបាន ដែលនឹងអនុញ្ញាតឲ្យលោកអនុវត្តភារកិច្ចទាំងឡាយ នៃការហៅរបស់លោក ឬលោកអាចបានទទួលអាជ្ញាប័ណ្ណពីសន្និសីទក៏បាន ។

៦៥ គ្មាននរណាអាចបាន[ក]តែងតាំងឡើង ឲ្យកាន់តំណែងណាមួយ នៅក្នុងសាសនាចក្រនេះ នៅកន្លែងមានសាខាមួយដែលបាន រៀបចំឡើងដោយត្រឹមត្រូវ ដោយគ្មាន[ខ]ការអនុមតិពីសាសនាចក្រនោះឡើយ ។

៦៦ ប៉ុន្តែពួកអែលឌើរដែលត្រួតពិនិត្យ ពួកប៊ីស្សបដែលធ្វើដំណើរ ពួកអ្នកប្រឹក្សាជាន់ខ្ពស់ ពួកសង្ឃជាន់ខ្ពស់ និងពួកអែលឌើរទាំងប៉ុន្មាន គេអាចមានឯកសិទ្ធិនៃការតែងតាំង នៅកន្លែងណាដែលគ្មានសាខានៃសាសនាចក្រ សំរាប់ស្នើសុំការអនុមតិនោះ ។

៦៧ គ្រប់ប្រធាននៃបព្វជិតភាពជាន់ខ្ពស់ (ឬអែលឌើរដែលត្រួតត្រា) [ក]ប៊ីស្សព អ្នកប្រឹក្សាជាន់ខ្ពស់ និង[ខ]សង្ឃជាន់ខ្ពស់ ត្រូវបានតែង តាំងឡើង តាមការដឹកនាំពី[គ]ក្រុមប្រឹក្សាជាន់ខ្ពស់ ឬក៏នៅឯសន្និសីទទូទៅ ។

៦៨ *[ក]កាតព្វកិច្ចនៃសមាជិកទាំងឡាយ បន្ទាប់ពីពួកគេបានទទួលឲ្យចូល ដោយបុណ្យជ្រមុជទឹក* — ពួកអែលឌើរ ឬពួកសង្ឃ ត្រូវមានពេលគ្រប់គ្រាន់ ដើម្បីពន្យល់អ្វីៗទាំងអស់ ដែលទាក់ទងទៅនឹងសាសនាចក្រនៃព្រះគ្រីស្ទ ដើម្បីឲ្យគេ[ខ]យល់ មុនពេលពួកគេទទួលទាន[គ]សាក្រាម៉ង់ និងមុនពួកគេទទួលការបញ្ជាក់ដោយការដាក់[ឃ]ដៃលើ ពីពួកអែលឌើរ ដើម្បីឲ្យអ្វីៗទាំងអស់អាចបាន ធ្វើឡើងតាមរបៀបរៀបរយ ។

៦៩ ហើយសមាជិកទាំងឡាយត្រូវសម្ដែង នៅចំពោះសាសនាចក្រ ហើយនៅចំពោះពួកអែលឌើរដែរ ដោយដំណើរ និងវាចាដ៏សុចរិត ដើម្បីឲ្យពួកគេបានសមនឹងការណ៍នោះ ដើម្បីឲ្យមាន[ក]កិច្ចការ និងសេចក្ដីជំនឿ សមស្របទៅនឹងបទគម្ពីរដ៏បរិសុទ្ធទាំងឡាយ — ដោយ ដើរក្នុង[ខ]បរិសុទ្ធភាព នៅចំពោះព្រះអម្ចាស់ ។

៧០ សមាជិកទាំងឡាយនៃសាសនាចក្រនៃព្រះគ្រីស្ទ ដែលមានកូនចៅ នោះត្រូវនាំវាមករកពួកអែលឌើរ នៅចំពោះសាសនាចក្រ ជាអ្នកដែលត្រូវដាក់ដៃលើវា ដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយ[ក]ឲ្យពរដល់វា ដោយនូវព្រះនាមរបស់ទ្រង់ ។

៧១ គ្មាននរណាមួយអាចបានទទួល ឲ្យចូលសាសនាចក្រនៃព្រះគ្រីស្ទបានឡើយ លើកលែងតែអ្នកនោះ មានអាយុនៃ[ក]ការទទួលខុសត្រូវ នៅចំពោះព្រះ ហើយមានសមត្ថភាពអាច[ខ]ប្រែចិត្តបាន ។

៧២ [ក]បុណ្យជ្រមុជទឹកត្រូវចាត់ចែងឡើង តាមរបៀបដែលមានដូចតទៅនេះ ចំពោះអស់អ្នកណាដែលបានប្រែចិត្ត —

៧៣ បុគ្គលដែលត្រូវបានហៅដោយព្រះ ហើយមានសិទ្ធិអំណាចពីព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើបុណ្យជ្រមុជទឹក នោះត្រូវចុះទៅក្នុងទឹក ជាមួយបុគ្គលដែលប្រគល់ខ្លួនលោក ឬខ្លួននាងសំរាប់បុណ្យជ្រមុជទឹក ហើយត្រូវនិយាយ ដោយហៅលោក

៦០ *ខ* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
៦៣ *ក* ស.ប. ការយល់ព្រមទូទៅ.
៦៤ *ក* គ. និង ស. ២០:៨៤; ៥២:៤១.
៦៥ *ក* ស.ប. តែងតាំង, ការតែងតាំង.
*ខ* គ. និង ស. ២៦:២.
ស.ប. ការយល់ព្រមទូទៅ.
៦៧ *ក* ស.ប. ប៊ីស្សព.
*ខ* ស.ប. សង្ឃជាន់ខ្ពស់.
*គ* ស.ប. ក្រុមប្រឹក្សាជាន់ខ្ពស់.
៦៨ *ក* ស.ប. កាតព្វកិច្ច.
*ខ* ស.ប. យោបល់.
*គ* ស.ប. បុណ្យរំឭក.
*ឃ* ស.ប. ដៃ, ការដាក់.
៦៩ *ក* យ៉ាកុប (ព.ស.ថ.) ២:១៤–១៧.
*ខ* ស.ប. បរិសុទ្ធភាព.
៧០ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ — ការប្រទានពរដល់កូនក្មេង.
៧១ *ក* គ. និង ស. ១៨:៤២; ២៩:៤៧; ៦៨:២៥–២៧.
ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ; បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការតម្រូវការទាំងឡាយសំរាប់បុណ្យជ្រមុជទឹក.
*ខ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
៧២ *ក* ៣ នីហ្វៃ ១១:២២–២៨.

ឬនាងតាមឈ្មោះថា៖ ដោយបានទទួលការអនុញ្ញាត ពីព្រះយេស៊ូវគ្រីស្ទ ខ្ញុំធ្វើបុណ្យជ្រមុជទឹកឲ្យអ្នក ដោយនូវព្រះនាម នៃព្រះវរបិតា និងនៃព្រះរាជបុត្រា និងនៃព្រះវិញ្ញាណបរិសុទ្ធ ។ អាម៉ែន ។

៧៤ រួចហើយ អ្នកនោះត្រូវ[ក]ពន្លិចលោក ឬនាងទៅក្នុងទឹក ហើយលើកឡើងពីទឹកមកវិញ ។

៧៥ ជាការចាំបាច់ដែលសាសនាចក្រជួបជុំគ្នាជា[ខ]ញឹកញាប់ ដើម្បី[ក]ទទួលទាននំប៉័ង និងស្រាទំពាំងបាយជូរ ដោយនូវការចងចាំពី ព្រះអម្ចាស់យេស៊ូវ;

៧៦ ហើយអែលឌើរ ឬសង្ឃត្រូវចាត់ចែងនំប៉័ង និងស្រាទំពាំងបាយជូរ ហើយលោកត្រូវធ្វើឡើង [ក]តាមរបៀបនេះ — លោកត្រូវលុតជង្គង់ ជាមួយនឹងសាសនាចក្រ ហើយសូមដល់ព្រះវរបិតា ដោយនូវពាក្យអធិស្ឋានដ៏ម៉ឺងម៉ាត់ ថា៖

៧៧ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ យើងខ្ញុំសូមដល់ព្រះអង្គ ដោយនូវព្រះនាម នៃព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូវគ្រីស្ទ សូមប្រទានពរ ហើយញែក[ក]នំប៉័ងនេះ ចេញជាបរិសុទ្ធ ដល់ព្រលឹងនៃជនទាំងអស់ណា ដែលទទួលទាននំប៉័ងនេះ ប្រយោជន៍ឲ្យពួកគេអាចទទួលទាន ដោយនូវការ[ខ]ចងចាំដល់ព្រះកាយ នៃព្រះរាជបុត្រារបស់ព្រះអង្គ ហើយធ្វើបន្ទាល់ដល់ព្រះអង្គ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ ថាពួកគេនឹង[គ]ព្រមលើកដាក់មកលើខ្លួនគេ នូវព្រះនាមនៃ[ឃ]ព្រះរាជបុត្រារបស់ព្រះអង្គ ហើយចងចាំទ្រង់ជានិច្ច ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ដែល[ង]ទ្រង់បានប្រទានដល់ពួកគេ; ប្រយោជន៍ឲ្យពួកគេអាច បានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងពួកគេជាដរាប ។ អាម៉ែន ។

៧៨ [ក]របៀបប្រគល់ស្រាទំពាំងបាយជូរ — លោកត្រូវយក[ខ]ពែងផងដែរ ហើយថា៖

៧៩ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ យើងខ្ញុំសូមដល់ព្រះអង្គ ដោយនូវព្រះនាម នៃព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូវគ្រីស្ទ សូមប្រទានពរ ហើយ ញែក[ក]ស្រាទំពាំងបាយជូរនេះ ចេញជាបរិសុទ្ធ ដល់ព្រលឹងនៃជនទាំងអស់ណា ដែលទទួលទាន ស្រាទំពាំងបាយជូរនេះ ប្រយោជន៍ឲ្យពួកគេអាចធ្វើយ៉ាងនោះ ដោយនូវការចងចាំដល់ព្រះលោហិត នៃព្រះរាជបុត្រារបស់ព្រះអង្គ ដែលបានច្រួចជំនួសពួកគេ ប្រយោជន៍ឲ្យពួកគេអាចធ្វើបន្ទាល់ដល់ព្រះអង្គ ឱព្រះអង្គ ជាព្រះវរបិតាដ៏អស់កល្បជានិច្ចអើយ ថាពួកគេ នឹងចងចាំទ្រង់ជានិច្ច ប្រយោជន៍ឲ្យពួកគេអាចបានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងពួកគេ ។ អាម៉ែន ។

៨០ សមាជិកសាសនាចក្រនៃព្រះគ្រីស្ទណាម្នាក់ ដែលរំលង ឬបានទាន់ឃើញធ្វើខុសអ្វី នោះត្រូវដោះស្រាយតាមបទគម្ពីរណែនាំ ។

៨១ កាតព្វកិច្ចនៃសាសនាចក្រនានា ដែលជាសាសនាចក្រនៃព្រះគ្រីស្ទ នឹងត្រូវចាត់គ្រូរបស់ពួកគេម្នាក់ឬច្រើន ឲ្យទៅសន្និសីទនានា ដែលពួកអែលឌើរនៃសាសនាចក្រ បានធ្វើឡើង,

៨២ ជាមួយនឹង[ក]បញ្ជីឈ្មោះនៃសមាជិកនានា ដែលចូលខ្លួនរួមជាមួយសាសនាចក្រ ចាប់តាំងពីសន្និសីទមុនមក; ឬក៏បានចាត់ដោយ ដៃនៃសង្ឃម្នាក់; ដើម្បីឲ្យមានបញ្ជីទៀងទាត់អំពីឈ្មោះទាំងឡាយ នៃសាសនាចក្រទាំងមូល អាចបានកត់ទុកនៅក្នុងសៀវភៅ ដោយ ពួកអែលឌើរណាម្នាក់ ដែលពួកអែលឌើរដទៃនឹងតាំងនៅពេលម្ដងៗ;

៨៣ ហើយម៉្យាងទៀត បើសិនជាជនណា ត្រូវបាន[ក]បណ្ដេញចេញពីសាសនាចក្រ នោះដើម្បីឲ្យឈ្មោះគេទាំងឡាយអាចបានលុប ចេញពីបញ្ជីឈ្មោះទូទៅនៃសាសនាចក្រ ។

៨៤ សមាជិកទាំងអស់ណាដែលរើចេញពីក្រុមជំនុំ នៅកន្លែងអាស្រ័យរស់នៅ បើសិនជាទៅក្រុមជំនុំ នៅកន្លែងដែលមិនមានគេឯង ស្គាល់ នោះគេអាចយកលិខិតបញ្ជាក់ថា ពួកគេជាសមាជិកពេញទី ហើយមានជំហរល្អ សំបុត្រនោះអាចបានចុះហត្ថលេខា ដោយ អែលឌើរ ឬសង្ឃណាមួយក៏បាន បើសិនជាសមាជិកដែលទទួលសំបុត្រ ត្រូវជាអ្នកស្គាល់រាប់អានគ្នានឹងអែលឌើរ ឬសង្ឃនោះផ្ទាល់ ឬក៏អាចបានចុះហត្ថលេខាដោយពួកគ្រូ ឬពួកឌីកុននៃសាសនាចក្រក៏បាន ។

---

៧៤ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកដោយការពន្លិច.
៧៥ *ក* កិច្ចការ ២០:៧.
*ខ* ស.ប. បុណ្យរំឭក.
៧៦ *ក* ម៉ូរ៉ូណៃ ៤:១–៣.
៧៧ *ក* លូកា ២២:១៩.
*ខ* ម៉ូសាយ ១៨:៨–១០; គ. និង ស. ២០:៣៧.
*គ* ម៉ូសាយ ៥:៨–១២.
*ឃ* ស.ប. ការគោរព, ដែលគោរព, គោរព.
*ង* យ៉ូហាន ១៤:១៦.
៧៨ *ក* ម៉ូរ៉ូណៃ ៥:១–២.
*ខ* លូកា ២២:២០.
៧៩ *ក* គ. និង ស. ២៧:២–៤.
៨២ *ក* ម៉ូរ៉ូណៃ ៦:៤.
៨៣ *ក* និក្ខ. ៣២:៣៣; អាលម៉ា ៥:៥៧; ម៉ូរ៉ូណៃ ៦:៧. ស.ប. ការកាត់ចេញពីសាសនា.

## កណ្ឌទី ២១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៨៣០ (*History of the Church*, ១:៧៤–៧៩) ។ វិវរណៈនេះត្រូវបានប្រទានឲ្យមក ក្នុងកាលរៀបចំសាសនាចក្រឡើង នៅថ្ងៃទី ដែលបានពោលមកហើយនោះ នៅក្នុងផ្ទះរបស់ ពេត្រុស វិតមើរ ស៊ីញ៉័រ ។ មានបុរសប្រាំមួយនាក់បានចូលរួម ជាពួកអ្នកដែលបាន ទទួលបុណ្យជ្រមុជទឹករួចមកហើយ ។ ដោយការចេញសម្លេងជាឯកច្ឆន្ទ ពួកបុគ្គលទាំងនេះបានសំដែងប្រាប់សេចក្ដីប៉ងប្រាថ្នា និងសេចក្ដី ប្ដេជ្ញារបស់ពួកគេ ដើម្បីរៀបចំសាសនាចក្រ ស្របតាមព្រះបញ្ញត្តិនៃព្រះ (សូមមើល កណ្ឌទី២០) ។ ពួកគេក៏បានបោះឆ្នោត ដើម្បី ទទួលស្គាល់ ហើយគាំទ្រ យ៉ូសែប ស្ម៊ីធ ជុញ៉រ និង អូលីវើរ ខៅឌើរី ឲ្យធ្វើជាអ្នកដឹកនាំដ៏ជាអធិបតីនៃសាសនាចក្រ ។ ដោយសារ ការដាក់ដៃលើ រួចហើយ យ៉ូសែបបានតែងតាំងអូលីវើរ ឲ្យធ្វើជាអែលឌើរនៃសាសនាចក្រ ហើយតាមរបៀបដដែលនោះ អូលីវើរបាន តែងតាំងយ៉ូសែបវិញ ។ បន្ទាប់ពីការចាត់ចែងបុណ្យសាក្រាម៉ង់រួចហើយ នោះយ៉ូសែបនិងអូលីវើរបានដាក់ដៃលើពួកអ្នក ដែលចូលរួម ម្នាក់ៗ សំរាប់ការប្រគល់នូវព្រះវិញ្ញាណបរិសុទ្ធ និងសំរាប់ការបញ្ជាក់សមាជិកនីមួយៗនៃសាសនាចក្រ ។*

*១–៣, យ៉ូសែប ស្ម៊ីធ ត្រូវបានហៅឲ្យធ្វើជាអ្នកមើលឆុត ជាអ្នកបកប្រែ ជាព្យាការី ជាសាវក និងជាអែលឌើរ; ៤–៨, ពាក្យសំដីរបស់ លោកនឹងណែនាំគតិនៃស៊ីយ៉ូន; ៩–១២, ពួកបរិសុទ្ធនឹងជឿតាមពាក្យសំដីរបស់លោក នៅពេលលោកនិយាយតាមការបំភ្លឺពីព្រះដ៏ ជាជំនួយ ។*

មើលចុះ នឹងមានបញ្ជី[ក]មួយកត់ទុក នៅក្នុងចំណោមអ្នករាល់គ្នា; ហើយនៅក្នុងបញ្ជីនោះ អ្នកនឹងត្រូវបានហៅថាជាអ្នក[ខ]មើលឆុត ជាអ្នកបកប្រែ ជាព្យាការី ជា[គ]សាវកនៃព្រះយេស៊ូវគ្រីស្ទ ជាអែលឌើរនៃសាសនាចក្រ តាមព្រះហឫទ័យនៃព្រះ ដ៏ជាព្រះវរបិតា និងព្រះគុណនៃព្រះអម្ចាស់របស់អ្នក ដ៏ជាព្រះយេស៊ូវគ្រីស្ទ ។

២ ដោយបានទទួល[ក]ការបំភ្លឺពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីបង្កើតគ្រឹះនៃសាសនាចក្រ ហើយដើម្បីសាងវាឡើងចំពោះសេចក្ដីជំនឿដ៏បរិសុទ្ធបំផុត ។

៣ ជា[ក]សាសនាចក្រដែល[ខ]ត្រូវបានរៀបចំ និងតាំងឡើង នៅក្នុងឆ្នាំនៃព្រះអម្ចាស់របស់យើង គឺមួយពាន់ប្រាំបីរយសាមសិប នៅខែទីបួន និងនៅថ្ងៃទីប្រាំមួយ នៃខែដែលហៅថា មេសា ។

៤ ហេតុដូច្នោះហើយ និយាយពីសាសនាចក្រ អ្នកត្រូវស្ដាប់តាមគ្រប់អស់ទាំង[ក]ពាក្យសំដី និងបញ្ញត្តិទាំងឡាយរបស់លោក ដែលលោក នឹងឲ្យដល់អ្នក នៅពេលលោកបានទទួលពាក្យទាំងនោះ ដោយដើរក្នុង[ខ]បរិសុទ្ធភាពទាំងអស់ នៅចំពោះយើង;

៥ ត្បិត[ក]ពាក្យសំដីរបស់លោកនោះហើយ អ្នកនឹងបានទទួល ហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់ ដោយសេចក្ដីអត់ធន់ និងសេចក្ដីជំនឿគ្រប់យ៉ាង។

៦ ត្បិតដោយសារការធ្វើការទាំងនេះហើយ [ក]ទ្វារស្ថាននរកនឹងពុំដែលឈ្នះអ្នកឡើយ; មែនហើយ ហើយព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹង [ខ]កំចាត់អំណាចនៃសេចក្ដីងងឹតចេញពីអ្នកទៅ ហើយនឹងបណ្ដាលឲ្យ[គ]ផ្ទៃមេឃញាប់ញ័រ ដើម្បីសេចក្ដីល្អដល់អ្នក និង[ឃ]សិរីល្អដល់ព្រះនាម របស់ទ្រង់ ។

៧ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានមានព្រះបន្ទូលដូច្នោះថា៖ អ្នកនោះហើយដែលយើងបានបំភ្លឺឲ្យកំរើកគតិនៃ[ក]ស៊ីយ៉ូន ដោយអំណាចដ៏ធំដើម្បីសេចក្ដីល្អ ហើយសេចក្ដីព្យាយាម របស់លោកនោះយើងដឹង រីឯសេចក្ដីអធិស្ឋានរបស់លោក នោះយើងបានឮហើយ ។

៨ មែនហើយ ការយំសោករបស់លោកសំរាប់ស៊ីយ៉ូន យើង

**២១** ១*ក* គ. និង ស. ៤៧:១; ៦៩:៣–៨; ៨៥:១.
*ខ* ស.ប. អ្នកមើលឆុត.
*គ* ស.ប. សាវក.
២ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
៣ *ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ.
*ខ* គ. និង ស. ២០:១.
៤ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* ស.ប. បរិសុទ្ធភាព.
៥ *ក* គ. និង ស. ១:៣៨. ស.ប. ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ; ព្យាការី.
៦ *ក* ម៉ាថាយ ១៦:១៨; គ. និង ស. ១០:៦៩.
*ខ* កូល៉ុស ១:១២–១៣.
*គ* គ. និង ស. ៣៥:២៤.
*ឃ* ស.ប. សិរីល្អ.
៧ *ក* ស.ប. ស៊ីយ៉ូន.

បានឃើញ ហើយយើងនឹងមិនបណ្ដាលឲ្យលោកយំសំរាប់ស៊ីយ៉ូន ទៀតឡើយ ត្បិតថ្ងៃនៃសេចក្ដីត្រេកអររបស់លោកទាំងឡាយ នឹងមកដល់ចំពោះសេចក្ដីផ្ដាច់បាបរបស់លោក ហើយសេចក្ដីបើកសំដែងនៃព្រះពរទាំងឡាយរបស់យើង មកលើកិច្ចការទាំងឡាយរបស់លោក ។

៩ ត្បិតមើលចុះ យើងនឹងប្រទានពរដល់អស់អ្នកណា ដែលធ្វើការនៅក្នុងចំការទំពាំងបាយជូររបស់យើង ដោយព្រះពរដ៏ធំ ហើយពួក គេនឹងជឿដល់ពាក្យពេចន៍របស់លោក ដែលបានប្រទានដល់លោក តាមរយៈយើង ដោយសារព្រះដ៏ជាជំនួយ ដែលបើកសំដែងប្រាប់ ថា ព្រះយេស៊ូវត្រូវឆ្កាងដោយពួកមនុស្សបាប ជំនួសអំពើបាបទាំងឡាយនៃពិភពលោក មែនហើយ គឺដើម្បីសេចក្ដីផ្ដាច់បាបទាំងឡាយ ចំពោះពួកអ្នកមានចិត្តសង្រេង ។

១០ ហេតុដូច្នោះហើយ គឺជាការចាំបាច់ដល់យើង ដែលលោកគប្បីបានទទួលការតែងតាំងដោយអ្នក អូលីវើរ ខៅឌើរ ជាសាវករបស់ យើង;

១១ នេះគឺជាការតែងតាំងចំពោះអ្នក ដើម្បីឲ្យអ្នកក្លាយទៅជាអែលឌើរ នៅក្រោមដៃរបស់លោក ព្រោះលោកជាអែលឌើរទី១ដល់អ្នក ដើម្បីឲ្យអ្នកអាចបានទៅជាអែលឌើរដល់សាសនាចក្រនៃព្រះគ្រីស្ទ ដែលមាននាមរបស់យើង —

១២ ហើយជាអ្នកផ្សាយសាសនាទី១ នៃសាសនាចក្រនេះ ដល់សាសនាចក្រ និងចំពោះពិភពលោក មែនហើយ គឺចំពោះពួកសាសន៍ ដទៃ; មែនហើយ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានមានព្រះបន្ទូលដូច្នោះថា៖ មើលន៏ មើលន៏! គឺដល់ពួកសាសន៍យូដាផង ។ អាម៉ែន ៕

## កណ្ឌទី ២២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងម៉ែនឆែសស្ទើរ រដ្ឋនូវយ៉ោក ខែមេសា ឆ្នាំ១៨៣០ (*History of the Church, *១:៧៩–៨០)* ។ *វិវរណៈនេះត្រូវបានប្រទានដល់សាសនាចក្រ មកពីមានមនុស្សខ្លះ ដែលបានទទួល បុណ្យជ្រមុជទឹករួចមកហើយ ដែលមានសេចក្ដីប៉ងប្រាថ្នាចង់ចូលរួមជាមួយសាសនាចក្រ ដោយពុំបាច់ទទួលបុណ្យជ្រមុជទឹកម្ដងទៀត* ។

*១, បុណ្យជ្រមុជទឹកគឺជាសេចក្ដីសញ្ញាថ្មី និងអស់កល្បជានិច្ច; ២–៤, បុណ្យជ្រមុជទឹកត្រូវឲ្យមានសិទ្ធិអំណាចពីព្រះ* ។

មើលចុះ យើងមានបន្ទូលដល់អ្នកថា គ្រប់អស់ទាំងសេចក្ដីសញ្ញាពីបុរាណ យើងបានបណ្ដាលឲ្យចប់ទៅ នៅក្នុងការណ៍នេះ ហើយនេះ ជាសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច គឺជាអ្វីដែលមានតាំងពីដើមដំបូងមកម្ល៉េះ ។

២ ហេតុដូច្នោះហើយ ទោះជាមនុស្សណាបានទទួលបុណ្យជ្រមុជទឹករាប់រយដងក៏ដោយ គង់តែគ្មានប្រយោជន៍ដល់គេដែរ ត្បិតអ្នក ពុំអាចចូលតាមទ្វារចង្អៀត ដោយសារក្រិត្យវិន័យនៃលោកម៉ូសេ ឬក៏ដោយសារកិច្ចការទាំងឡាយដែលស្លាប់នោះបានឡើយ ។

៣ ត្បិតមកពីកិច្ចការទាំងឡាយ ដែលស្លាប់របស់អ្នកនេះហើយ ដែលយើងបានបណ្ដាលឲ្យមានសេចក្ដីសញ្ញា

៨ *ក* គ. និង ស. ២០:៥–៦.
៩ *ក* ១ នីហ្វៃ ១៣:៣៧; យ៉ាកុប ៥:៧០–៧៦.
*ខ* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*គ* ស.ប. ព្រះដ៏ជាជំនួយ.
*ឃ* ស.ប. ធ្វើបន្ទាល់.
*ង* ស.ប. ការឆ្កាង.
*ច* ស.ប. អំពើបាប.
*ឆ* ១ យ៉ូហាន ២:២. ស.ប. ពិភពលោក — មនុស្សដែលមិនគោរពតាមព្រះបញ្ញត្តិ.
*ជ* ស.ប. ចិត្តសង្រេង.
១០ *ក* ស.ប. តែងតាំង, ការតែងតាំង.
១១ *ក* គ. និង ស. ២០:២.
១២ *ក* ១ នីហ្វៃ ១៣:៤២; គ. និង ស. ១៩:២៧; ៩០:៨–៩.
**២២** ១ *ក* ហេព្រើរ ៨:១៣; ៣ នីហ្វៃ ១២:៤៦–៤៧.
*ខ* គ. និង ស. ៦៦:២. ស.ប. សេចក្ដីសញ្ញា; សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច.
២ *ក* កាឡាទី ២:១៦. ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ខ* ម៉ូរ៉ូណៃ ៨:២៣–២៦.

ចុងក្រោយបង្អស់នេះ និងសាសនាចក្រនេះ ដើម្បីឲ្យបានសាងឡើងដល់យើង ដូចជានៅសម័យបុរាណ ។

៤ ហេតុដូច្នោះហើយ ចូរចូលតាមទ្វារចុះ ដូចជាយើងបានបញ្ញា ហើយចូរកុំចង់ទូន្មានដល់ព្រះរបស់អ្នកឡើយ ។ អាម៉ែន ៕

## កណ្ឌទី ២៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងម៉ែនឆេសស្ទើរ រដ្ឋនូវយ៉ោក ខែមេសា ឆ្នាំ១៨៣០ ចំពោះ អូលីវើរ ខៅឌើរី; ហៃរុម ស្ម៊ីធ; សាំយូអែល អេជ ស្ម៊ីធ; យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ; និង យ៉ូសែប ណៃត ស៊ីញ៉័រ (*History of the Church, *១:៨០) ។ មកពីសេចក្ដីប៉ងប្រាថ្នាដ៏ស្មោះស្ម័គ្រពីចំណែកនៃពួកអ្នកប្រាំនាក់ ដែលបានពោលដល់នេះ ចង់ដឹងអំពីកាតព្វកិច្ច របស់ពួកគេរៀងៗខ្លួន នោះព្យាការីបានសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈនេះ ។*

*១–៧, ពួកសិស្សមុនៗទាំងនេះ ត្រូវបានហៅឲ្យផ្សាយ ទូន្មាន និងចំរើនកម្លាំងដល់សាសនាចក្រ ។*

មើលចុះ អូលីវើរ យើងមានបន្ទូលដល់អ្នក នូវពាក្យបន្តិចបន្តួច ។ មើលចុះ អ្នកបានមានពរហើយ ហើយអ្នកពុំនៅក្រោមការកាត់ទោស ទេ ប៉ុន្តែចូរប្រយ័ត្នអំពីសេចក្ដីឆ្មើងឆ្មៃ ខ្លាចក្រែងអ្នកធ្លាក់ទៅក្នុងសេចក្ដីល្បួង ។

២ ចូរប្រាប់ឲ្យគេដឹងអំពីការហៅរបស់អ្នកដល់សាសនាចក្រ ហើយព្រមទាំងដល់ពិភពលោកផងដែរ ហើយចូរឲ្យចិត្តអ្នកបានបើក ដើម្បីផ្សាយសេចក្ដីពិត ចាប់តាំងពីឥឡូវនេះ ជារៀងដរាបតទៅ ។ អាម៉ែន ។

៣ មើលចុះ ហៃរុម យើងមានបន្ទូលដល់អ្នក នូវពាក្យបន្តិចបន្តួច; ត្បិតអ្នកក៏ពុំនៅក្រោមការកាត់ទោសទេ ហើយចិត្តអ្នកបានបើក ហើយអណ្ដាតអ្នកបានរសាយ; ហើយការហៅរបស់អ្នក គឺដើម្បីឲ្យការទូន្មាន ហើយដើម្បីចំរើនកម្លាំងដល់សាសនាចក្រជារៀងរហូត ។ ហេតុដូច្នោះហើយ កាតព្វកិច្ចរបស់អ្នក គឺដល់សាសនាចក្រជារៀងដរាបតទៅ ហើយនេះមកពីគ្រួសាររបស់អ្នក ។ អាម៉ែន ។

៤ មើលចុះ សាំយូអែល យើងមានបន្ទូលដល់អ្នក នូវពាក្យបន្តិចបន្តួច; ត្បិតអ្នកពុំនៅក្រោមការកាត់ទោសទេ ហើយការហៅរបស់អ្នក គឺដើម្បីឲ្យការទូន្មាន ហើយដើម្បីចំរើនកម្លាំងដល់សាសនាចក្រ; ហើយអ្នកពុំទាន់បានហៅឲ្យផ្សាយដល់ពិភពលោកនៅឡើយទេ ។ អាម៉ែន ។

៥ មើលចុះ យ៉ូសែប យើងមានបន្ទូលដល់អ្នក នូវពាក្យបន្តិចបន្តួច; ត្បិតអ្នកពុំនៅក្រោមការកាត់ទោសទេ ហើយការហៅរបស់អ្នក គឺដើម្បីឲ្យការទូន្មាន ហើយដើម្បីចំរើនកម្លាំងដល់សាសនាចក្រដែរ; ហើយនេះជាកាតព្វកិច្ចរបស់អ្នក ចាប់តាំងពីឥឡូវនេះ ជារៀង ដរាបតទៅ ។ អាម៉ែន ។

៦ មើលចុះ យ៉ូសែប ណៃត យើងសំដែងខ្លួនដល់អ្នក ដោយសារព្រះបន្ទូលទាំងនេះ ថាអ្នកត្រូវលើកឈើឆ្កាងរបស់អ្នក គឺថាអ្នកត្រូវ អធិស្ឋានឲ្យឮ នៅចំពោះពិភពលោក ព្រមទាំងនៅទីអាថ៌កំបាំង និងនៅក្នុងគ្រួសាររបស់អ្នក និងនៅក្នុងចំណោមមិត្តភ័ក្តិរបស់អ្នក និង នៅគ្រប់កន្លែងនានា ។

៧ ហើយមើលចុះ គឺជាកាតព្វកិច្ចរបស់អ្នក ដើម្បីចូលរួមជាមួយសាសនាចក្រដ៏ពិត ហើយចូរចេញវាចារបស់អ្នក ដើម្បីទូន្មានជារៀងរហូតចុះ ដើម្បីឲ្យអ្នកអាចបានទទួលរង្វាន់នៃជើងឈ្នួល ។ អាម៉ែន ៕

៤ *ក* ម៉ាថាយ ៧:១៣–១៤;
លូកា ១៣:២៤; ២ នីហ្វៃ ៩:៤១;
៣១:៩, ១៧–១៨;
៣ នីហ្វៃ ១៤:១៣–១៤.
ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
*ខ* យ៉ាកុប ៤:១០.
**២៣** ១*ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
៣ *ក* គ. និង ស. ៨១:៤–៥; ១០៨:៧.
៤ *ក* យ.ស. — ប្រវត្តិ ១:៤.
៦ *ក* ម៉ាថាយ ១០:៣៨;
៣ នីហ្វៃ ១២:៣០.
*ខ* ស.ប. ការអធិស្ឋាន.
*គ* គ. និង ស. ២០:៤៧, ៥១.
៧ *ក* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក —
ការចាំបាច់.

## កណ្ឌទី ២៤

*វិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង អូលីវើរ ខៅឌើរី នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែកក្កដា ឆ្នាំ១៨៣០* (History of the Church, *១:១០១–១០៣*) ។ *ទោះជាតិចជាងបួនខែបានកន្លងផុតទៅ ចាប់តាំងពីសាសនាចក្របានរៀបចំឡើងក្ដី គង់តែសេចក្ដីបៀតបៀនបានក្លាយទៅជាធ្ងន់ធ្ងរដែរ ហើយពួកអ្នកដឹកនាំទាំងប៉ុន្មាន បានស្វែងរកទីជ្រកកោន ឃ្លាតពីមនុស្ស ម្នានៅពេលខ្លះៗ ។ វិវរណៈទាំងបីដែលមានដូចតទៅនេះ ត្រូវបានប្រទានមកនៅពេលនេះ ដើម្បីចំរើនកម្លាំង លើកទឹកចិត្ត និងបង្គាប់ពួកគេ ។*

*១–៩, យ៉ូសែប ស្ម៊ីធ ត្រូវបានហៅឲ្យបកប្រែ ផ្សាយ និងពន្យល់បទគម្ពីរទាំងឡាយ; ១០–១២ អូលីវើរ ខៅឌើរី ត្រូវបានហៅឲ្យផ្សាយ ដំណឹងល្អ; ១៣–១៩, ក្រិត្យវិន័យត្រូវបានបើកសំដែងប្រាប់ ដែលមានទំនាក់ទំនងនឹងអព្ភូតហេតុទាំងឡាយ ការដាក់បណ្ដាសា ទាំងឡាយ ការរលាស់ធូលីពីបាតជើង និងការទៅដោយគ្មានយកកាបូប ឬយាមទៅផង ។*

មើលចុះ អ្នកត្រូវបានហៅ ហើយជ្រើសរើសឲ្យកត់ព្រះ
គម្ពីរមរមន ហើយឲ្យធ្វើការងាររបស់យើង ហើយយើងបាន
លើកអ្នកឡើង ឲ្យរួចពីសេចក្ដីវេទនាទាំងឡាយរបស់អ្នក ហើយ
បានទូន្មានដល់អ្នកថា អ្នកត្រូវបានរំដោះឲ្យរួចផុតពីពួកខ្មាំងសត្រូវ
របស់អ្នក ហើយអ្នក ត្រូវបានរំដោះ ឲ្យរួចផុតពីអំណាចទាំង
ឡាយនៃអារក្សសាតាំង និងពីសេចក្ដីងងឹត!
២ ទោះជាយ៉ាងណាក៏ដោយ គង់តែអ្នកមិនបានរួចផុតពី[ក]អំពើ
រំលងទាំងឡាយរបស់អ្នកដែរ ទោះជាយ៉ាងណាក៏ដោយ ចូរ
អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ ។
៣ ចូរ[ក]ដំកើងការងាររបស់អ្នកចុះ ហើយបន្ទាប់ពីអ្នកបាន
ព្រោះស្រែអ្នក និងបានការពារស្រែនោះរួចស្រេចបាច់ហើយ
ចូរអញ្ជើញទៅរក សាសនាចក្រយ៉ាងឆាប់រហ័ស ដែលនៅ
[ខ]ភូមិខូលស្វិល ភូមិហ្វាយែត និងក្រុងម៉ែនឆែសស្ទើរ ហើយពួកគេ
នឹង[គ]គាំទ្រអ្នក ហើយយើងនឹង ប្រទានពរដល់ពួកគេ ទាំង
ខាងវិញ្ញាណ និងខាងសាច់ឈាមផង;
៤ ប៉ុន្តែបើសិនជាពួកគេមិនទទួលអ្នកទេ នោះយើងនឹង
បញ្ជូនបណ្ដាសាមកលើពួកគេ ជំនួសព្រះពរវិញ ។
៥ ហើយអ្នកត្រូវបួងសួងដល់ព្រះ ដោយនូវព្រះនាមរបស
់យើងរហូត ហើយកត់នូវអ្វីៗ ដែលនឹងបានប្រទានដល់អ្នក ដោយ
[ក]ព្រះដ៏ជាជំនួយ ហើយត្រូវពន្យល់ប្រាប់នូវបទគម្ពីរទាំងឡាយដល់
សាសនាចក្រ ។
៦ ហើយអ្វីដែលអ្នកត្រូវ[ក]និយាយ និងកត់ នឹងបានប្រទានដល់អ្នក
នៅវេលានោះឯង ហើយពួកគេនឹងបានឮអ្វីទាំងនោះ បើពុំនោះ
សោត ទេ យើងនឹងបញ្ជូនបណ្ដាសាដល់ពួកគេ ជំនួសព្រះពរវិញ ។
៧ ត្បិតអ្នកត្រូវ[ក]ថ្វាយការងាររបស់អ្នកទាំងអស់ នៅក្រុង
ស៊ីយ៉ូន ហើយនៅក្នុងការណ៍នេះ អ្នកនឹងបានកម្លាំង ។
៨ ចូរមាន[ក]ចិត្តអត់ធន់ក្នុងការ[ខ]ឈឺចាប់ ត្បិតអ្នកនឹងមាន
ដ៏ច្រើន ប៉ុន្តែចូរ[គ]ទ្រាំទ្រចុះ ត្បិតមើលន៏ យើងនៅជាមួយនឹង
អ្នក [ឃ]គឺដរាបដល់អស់ មួយជីវិតរបស់អ្នក ។
៩ ហើយចំពោះកិច្ចការខាងសាច់ឈាម នោះអ្នកនឹងពុំមាន
កម្លាំងទេ ត្បិតកិច្ចការនេះពុំមែនជាការហៅរបស់អ្នកឡើយ ។
ចូរអនុវត្ត [ក]ការហៅរបស់អ្នក ហើយអ្នកនឹងបាននូវអ្វីដែលអ្នកត្រូវ
ការ ដើម្បីដំកើងតំណែងរបស់អ្នក ហើយដើម្បីពន្យល់ប្រាប់អស់
ទាំងបទគម្ពីរ ហើយចូរបន្តនូវការដាក់ដៃលើ និងការបញ្ជាក់
សាសនាចក្រទាំងឡាយចុះ ។
១០ ហើយអូលីវើរ ជាបងប្អូនប្រុសរបស់អ្នក ត្រូវបន្តនូវ
ការថ្លែងប្រាប់ពីព្រះនាមរបស់យើង នៅចំពោះពិភពលោក និង
ចំពោះ សាសនាចក្រផង ។ ហើយលោកមិនត្រូវសន្និដ្ឋានថា
លោកអាចនិយាយឲ្យបានគ្រប់គ្រាន់ ចំពោះគតិរបស់យើងទេ;
ហើយមើលន៏ យើងនៅជាមួយនឹងលោក ដរាបដល់ចុងបំផុត ។
១១ នៅក្នុងយើង នោះលោកនឹងបានសិរីល្អ ហើយពុំមែន

**២៤** ២ *ក* គ. និង ស. ១:៣១–៣២.
៣ *ក* យ៉ាកុប ១:១៩; ២:២.
*ខ* គ. និង ស. ២៦:១; ៣៧:២.
*គ* គ. និង ស. ៧០:១២.
៥ *ក* ស.ប. ព្រះដ៏ជាជំនួយ.
៦ *ក* និក្ខ. ៤:១២;
ម៉ាថាយ ១០:១៩–២០;
លូកា ១២:១១–១២;
ហេលេ. ៥:១៨–១៩;
គ. និង ស. ៨៤:៨៥; ១០០:៥–៨;
ម៉ូសេ ៦:៣២.
៧ *ក* ស.ប. ការបំរើ.
៨ *ក* ស.ប. សេចក្ដីអត់ធន់.
*ខ* ស.ប. សេចក្ដីទំនាស់.
*គ* ស.ប. កាន់ខ្ជាប់.
*ឃ* ម៉ាថាយ ២៨:២០.
៩ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.

ដោយសារខ្លួនលោកទេ ទោះជានៅក្នុងសេចក្ដីកំសោយ ឬក្នុងកម្លាំង ទោះជាបាវ ឬជាអ្នកសេរីក្ដី;
១២ ហើយនៅគ្រប់ពេល និងគ្រប់ទីកន្លែង លោកត្រូវបើកមាត់ហើយ[ក]ប្រកាសប្រាប់ពីដំណឹងល្អរបស់យើង ហាក់ដូចជាដោយសម្លេង[ខ]ត្រែ ទាំងយប់ទាំងថ្ងៃ ។ ហើយយើងនឹងប្រទានដល់លោកនូវកម្លាំង ដូចជាពុំដែលស្គាល់នៅក្នុងចំណោមមនុស្សមកឡើយ ។
១៣ ចូរកុំសូម[ក]អព្ភូតហេតុឡើយ លើកលែងតែយើងនឹង[ខ]បញ្ជាដល់អ្នក លើកលែងតែចំពោះ[គ]ការដេញ[ឃ]អារក្សអសោចិ៍ចេញ [ង]ការប្រោស មនុស្សឈឺ ហើយការពារពីពស់មាន[ច]ពិស និងអ្វីដែលពុលដល់ស្លាប់;
១៤ ហើយ[ក]ការទាំងនេះ អ្នករាល់គ្នាមិនត្រូវធ្វើឡើយ លើកលែងតែតម្រូវពីអ្នក ដោយពួកអ្នកដែលមានសេចក្ដីប្រាថ្នាប៉ុណ្ណោះ ដើម្បីឲ្យ បទគម្ពីរទាំងឡាយ អាចបានសំរេច; ត្បិតអ្នករាល់គ្នាត្រូវធ្វើតាមអ្វីដែលបានចែងទុក ។
១៥ ហើយនៅទីកន្លែងណាក៏ដោយ ដែលអ្នករាល់គ្នានឹង[ក]ចូលហើយពួកគេមិនទទួលអ្នក ដោយនូវព្រះនាមរបស់យើងទេ នោះអ្នក រាល់គ្នាត្រូវឲ្យបណ្ដាសា ជំនួសឲ្យពរ ដោយរលាស់[ខ]ធូលីពីបាតជើងអ្នកចេញ ទុកជាទីបន្ទាល់ទាស់នឹងពួកគេវិញ ហើយលាងជើងអ្នក តាមផ្លូវ ។
១៦ ហើយហេតុការណ៍នឹងកើតឡើងថា អស់អ្នកណាដែលនឹងដាក់ដៃមកលើអ្នក ដោយអំពើឃោរឃៅ នោះអ្នករាល់គ្នាត្រូវបញ្ជា ឲ្យត្រូវវាយដោយនូវព្រះនាមរបស់យើង ហើយមើលចុះ យើងនឹងវាយពួកគេ ស្របតាមពាក្យសំដីរបស់អ្នក តាមពេលដែលយើង កំណត់ ។
១៧ ហើយអស់អ្នកណាដែលនឹងទៅរកច្បាប់ទាស់នឹងអ្នក អ្នកនោះនឹងត្រូវបណ្ដាសា ដោយសារច្បាប់ ។
១៨ ហើយអ្នកមិនត្រូវយក[ក]កាបូប ឬយាម ឬដំបង ឬអាវ២ទៅឡើយ ត្បិតសាសនាចក្រនឹងឲ្យអ្វីដល់អ្នក នៅចំម៉ោងដែលអ្នកត្រូវការ សំរាប់អាហារ និងសំរាប់សំលៀកបំពាក់ និងសំរាប់ស្បែកជើង និងសំរាប់ប្រាក់កាស និងសំរាប់យាម ។
១៩ ត្បិតអ្នកត្រូវបានហៅ ឲ្យ[ក]កាត់មែកចំការទំពាំងបាយជូររបស់យើង ដោយការកាត់មែកដ៏ខ្លាំងក្លា មែនហើយ គឺនៅពេលចុងក្រោយ បំផុត; មែនហើយ ព្រមទាំងអស់អ្នកណាដែលអ្នកបាន[ខ]តែងតាំងផង ហើយពួកគេនឹងធ្វើតាមគំរូនេះ ។ អាម៉ែន ៕

## កណ្ឌទី ២៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែកក្កដា ឆ្នាំ១៨៣០ (*History of the Church*, ១:១០៣–១០៤) ។ (សូមមើលចំណងជើងនៃកណ្ឌទី ២៤) ។ វិវរណៈនេះសំដែងប្រាប់អំពីព្រះហឫទ័យនៃព្រះអម្ចាស់ ដល់ អិមម៉ា ស្ម៊ីធ ដែលជាភរិយារបស់ព្យាការី ។*

*១–៦, អិមម៉ា ស្ម៊ីធ ជាស្ត្រីជំរើស ត្រូវបានហៅឲ្យជួយ និងកំសាន្តចិត្តដល់ស្វាមីរបស់នាង; ៧–១១, នាងក៏ត្រូវបានហៅឲ្យសរសេរ ឲ្យពន្យល់បទគម្ពីរទាំងឡាយ ហើយឲ្យរើសទំនុកសរសើរដំកើងព្រះផងដែរ; ១២–១៤, បទចំរៀងនៃពួកសុចរិត គឺជាបទអធិស្ឋាន ដល់ព្រះអម្ចាស់; ១៥–១៦, គោលការណ៍ទាំងឡាយនៃការគោរពធ្វើតាម ដែលមាននៅក្នុងវិវរណៈនេះ អនុវត្តដល់មនុស្សទាំងអស់ ។*

ចូរស្ដាប់តាមសម្លេងនៃព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក នៅពេលយើងមានបន្ទូលមកកាន់អ្នក អិមម៉ា ស្ម៊ីធ ជាបុត្រី

១២ *ក* ស.ប. ផ្សាយ.
*ខ* គ. និង ស. ៣៤:៦.
១៣ *ក* ស.ប. អព្ភូតហេតុ; ទីសំគាល់.
*ខ* ១ នីហ្វៃ ១៧:៥០.
*គ* ម៉ាកុស ១៦:១៧.
*ឃ* ស.ប. វិញ្ញាណ — អារក្សអសោចិ៍.
*ង* ស.ប. ប្រោស, ការប្រោស.
*ច* កិច្ចការ ២៨:៣–៩; គ. និង ស. ៨៤:៧១–៧២; ១២៤:៩៨–៩៩.
១៤ *ក* ស.ប. ការប្រសិទ្ធិពរដល់មនុស្សឈឺ.
១៥ *ក* ម៉ាថាយ ១០:១១–១៥.
*ខ* ម៉ាកុស ៦:១១; លូកា ១០:១១; គ. និង ស. ៦០:១៥; ៧៥:១៩–២២; ៩៩:៤–៥.
១៨ *ក* ម៉ាថាយ ១០:៩–១០; លូកា ១០:៤; គ. និង ស. ៨៤:៧៨–៧៩.
១៩ *ក* យ៉ាកុប ៥:៦១–៧៤; គ. និង ស. ៣៩:១៧; ៧១:៤.
*ខ* ស.ប. តែងតាំង, ការតែងតាំង.

របស់យើងអើយ; ត្បិតយើងប្រាប់អ្នកជាប្រាកដថា អស់អ្នកណា
ដែលទទួលដំណឹងល្អរបស់យើង នោះឈ្មោះថាជាបុត្រាបុត្រី
របស់យើង នៅក្នុងនគរ យើងហើយ ។
២ វិវរណៈមួយយើងប្រទានដល់អ្នក ស្ដីអំពីព្រះហឫទ័យ
របស់យើង ហើយបើសិនជាអ្នកមានចិត្តស្មោះត្រង់ ហើយ
ដើរតាមផ្លូវគុណធម៌ នៅចំពោះយើង នោះយើងនឹងទុកជីវិតអ្នកឲ្យ
បានគង់វង្ស ហើយអ្នកនឹងបានទទួលមរតកនៅក្រុងស៊ីយ៉ូន ។
៣ មើលចុះ បាបរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ ហើយ
អ្នកជាស្ត្រីរើសតាំង ជាអ្នកដែលយើងបានហៅ ។
៤ ចូរកុំរអ៊ូរទាំ ដោយសារតែអ្វីដែលអ្នកពុំបានឃើញនោះឡើយ
ត្បិតរបស់ទាំងនោះត្រូវបានទុកមិនឲ្យអ្នក និងមិនឲ្យពិភពលោក
ឃើញទេ ដែលជាប្រាជ្ញានៅក្នុងយើង នៅពេលខាងមុខ ។
៥ ហើយមុខងារនៃការហៅរបស់អ្នកគឺត្រូវធ្វើជាទីកំសាន្តដល់
អ្នកបំរើរបស់យើង គឺដល់ យ៉ូសែប ស្ម៊ីធ ជុញ្ញ៉រ ដែលជាស្វាមី
របស់អ្នក នៅក្នុងសេចក្ដីទុក្ខវេទនាទាំងឡាយរបស់លោក ដោយ
នូវពាក្យលួងលោម ក្នុងវិញ្ញាណនៃភាពស្លូតបូត ។
៦ ហើយអ្នកត្រូវទៅជាមួយនឹងលោក នៅពេលលោកទៅ
ហើយធ្វើជាស្មៀនដល់លោក កាលណាគ្មាននរណាធ្វើស្មៀន
ដល់លោក ដើម្បីឲ្យយើងអាចចាត់ អូលីវើរ ខៅឌើរី ជាអ្នកបំរើ
របស់យើង ឲ្យទៅទីណាក៏បាន តាមព្រះហឫទ័យរបស់យើង ។
៧ ហើយអ្នកនឹងត្រូវបានតែងតាំង នៅក្រោមដៃរបស់លោក
ដើម្បីពន្យល់បទគម្ពីរទាំងឡាយ និងដើម្បីទូន្មានដល់សាសនាចក្រ
ស្របតាមអ្វីដែលនឹងបានប្រទានដល់អ្នក ដោយព្រះវិញ្ញាណ
របស់យើង ។
៨ ត្បិតលោកនឹងដាក់ដៃលើអ្នក ហើយអ្នកនឹងបានទទួល
ព្រះវិញ្ញាណបរិសុទ្ធ ហើយពេលវេលារបស់អ្នក នឹងត្រូវបាន
ប្រទានឲ្យ ដើម្បីការសរសេរ និងដើម្បីការរៀនសូត្រដ៏ច្រើន ។
៩ ហើយអ្នកមិនចាំបាច់ខ្លាចឡើយ ត្បិតស្វាមីរបស់អ្នកនឹង
គាំទ្រអ្នក នៅក្នុងសាសនាចក្រ ត្បិតចំពោះការទាំងនេះហើយ
ជាការងារ របស់លោក ដើម្បីឲ្យរបស់ទាំងអស់ អាចបាន
បើកសំដែងដល់ពួកគេ តាមព្រះហឫទ័យរបស់យើង ស្របតាម
សេចក្ដីជំនឿរបស់ពួកគេ ។
១០ ហើយយើងប្រាប់អ្នកជាប្រាកដថា អ្នកត្រូវទុកចោលរបស់
ទាំងឡាយនៃពិភពលោកនេះ ហើយចូរស្វែងរករបស់ទាំងឡាយ
ណា ដែលគ្រាន់បើជាងនេះវិញ ។
១១ ហើយនឹងបានប្រទានដល់អ្នកផងដែរ ដើម្បីឲ្យធ្វើការ
ជំរើសយកទំនុកសរសើរដំកើងព្រះដ៏ពិសិដ្ឋទាំងឡាយ ដូចជា
នឹងបានប្រទាន ដល់អ្នក ដែលសព្វព្រះហឫទ័យដល់យើង ដើម្បី
ឲ្យមាននៅក្នុងសាសនាចក្ររបស់យើង ។
១២ ត្បិតព្រលឹងរបស់យើងត្រេកអរចំពោះបទចំរៀងពីចិត្ត មែន
ហើយ បទចំរៀងនៃពួកសុចរិត គឺជាបទអធិស្ឋានដល់យើង ហើយ
នឹង បានឆ្លើយតប ដោយនូវព្រះពរ មកលើក្បាលរបស់ពួកគេ ។
១៣ ហេតុដូច្នោះហើយ ចូរលើកចិត្តអ្នកឡើង ហើយ
អរសប្បាយ ហើយចូរនៅជាប់នឹងសេចក្ដីសញ្ញាទាំងឡាយ
ដែលអ្នកបានធ្វើចុះ ។
១៤ ចូរបន្តនៅក្នុងវិញ្ញាណនៃភាពស្លូតបូត ហើយចូរប្រយ័ត្នពី
សេចក្ដីឆ្មើងឆ្មៃ ។ ចូរឲ្យព្រលឹងរបស់អ្នកត្រេកអរនឹងស្វាមីរបស់
អ្នកចុះ និងសិរីល្អ ដែលនឹងមានមកលើលោក ។
១៥ ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរហូត ហើយមកុដនៃ
សេចក្ដីសុចរិតនោះអ្នកនឹងបានទទួល ។ ហើយលើកលែង
តែអ្នកធ្វើការនេះ កន្លែងដែលយើងនៅ នោះអ្នកពុំអាចមក
បានឡើយ ។
១៦ ហើយប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា នេះ
គឺជាសម្លេងរបស់យើង ដល់មនុស្សទាំងពួង ។ អាម៉ែន ៕

**២៥** ១*ក* យ៉ូហាន ១:១២.
ស.ប. បុត្រាបុត្រីនៃព្រះ.
*ខ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
២ *ក* ស.ប. ដើរ, ដើរជាមួយព្រះ.
*ខ* ស.ប. គុណធម៌.
*គ* គ. និង ស. ៥២:៤២;
៦៤:៣០; ១០១:១៨.
ស.ប. ស៊ីយ៉ូន.
៣ *ក* ម៉ាថាយ ៩:២.
*ខ* ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ.
៥ *ក* ស.ប. អាណិត.
៧ *ក* ឬ ញែកចេញ. ស.ប.
ការញែកចេញ.
៨ *ក* ស.ប. ដៃ, ការដាក់.
៩ *ក* ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ; ព្យាការី.
*ខ* ស.ប. ការព្យាករណ៍, ព្យាករ;
វិវរណៈ.
១០ *ក* ស.ប. លោភ; ទ្រព្យសម្បត្តិ.
*ខ* ស.ប. សេចក្ដីប្រកបដោយលោកិយ.
*គ* អេធើរ ១២:៤.
១១ *ក* ស.ប. ទំនុកសរសើរដំកើង.
១២ *ក* ១ របា. ១៦:៩.
ស.ប. ច្រៀង.
*ខ* ស.ប. ចិត្ត.
១៤ *ក* ស.ប. ស្លូតបូត, ភាពស្លូតបូត.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១៥ *ក* ស.ប. មកុដ; ភាពដំកើងឡើង.
*ខ* ស.ប. សុចរិត, សេចក្ដីសុចរិត.
*គ* យ៉ូហាន ៧:៣៤.
១៦ *ក* គ. និង ស. ១:៣៨.

## កណ្ឌទី ២៦

*វិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី អូលីវើរ ខៅឌើរី និងយ៉ូហាន វិតមើរ នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែកក្កដា ឆ្នាំ១៨៣០ (*History of the Church, *១:១០៤)* ។ *(សូមមើលចំណងជើងនៃកណ្ឌទី ២៤)* ។

*១, ពួកគេត្រូវបានបង្គាប់ឲ្យសិក្សាព្រះគម្ពីរ ហើយឲ្យផ្សាយ; ២, ក្រិត្យវិន័យអំពីការយល់ព្រមទូទៅត្រូវបានបញ្ជាក់ ។*

មើលចុះ យើងមានបន្ទូលដល់អ្នកថា អ្នកត្រូវចំណាយពេលវេលារបស់អ្នក ដើម្បីការសិក្សា[ក]ព្រះគម្ពីរ និងដើម្បីការផ្សាយ និងដើម្បីការបញ្ជាក់សាសនាចក្រ នៅភូមិខូលស្វិល ហើយដើម្បីការប្រព្រឹត្តិការងាររបស់អ្នកនៅលើដែនដី ដូចជាបានតម្រូវមក លុះគ្រាអ្នកនឹងទៅ ទិសខាងលិច ដើម្បីទៅធ្វើសន្និសីទក្រោយរួចសិន ហើយនៅខណៈនោះ នោះនឹងត្រូវបានប្រាប់ពីអ្វី ដែលអ្នកនឹងត្រូវធ្វើ ។

២ ហើយរបស់ទាំងអស់នឹងត្រូវបានសំរេច ដោយសារការ[ក]យល់ព្រមទូទៅ នៅក្នុង សាសនាចក្រ ដោយសារការអធិស្ឋាន និង សេចក្ដីជំនឿដ៏ច្រើន ត្បិតរបស់ទាំងអស់នោះ អ្នកនឹងត្រូវបានទទួលដោយសារសេចក្ដីជំនឿ ។ អាម៉ែន ៕

## កណ្ឌទី ២៧

*វិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហាម៉ូនី រដ្ឋផែនសិលវេញ៉ា ខែសីហា ឆ្នាំ១៨៣០ (*History of the Church, *១:១០៦–១០៨)* ។ *នៅក្នុងការរៀបចំសំរាប់ការប្រជុំសាសនា ដែលមានថែកសាក្រាម៉ង់នៃនំប៉័ង និងស្រាទំពាំងបាយជូរ នោះ យ៉ូសែប ស្ម៊ីធ បានចេញទៅយកស្រាទំពាំងបាយជូរ ។ លោកត្រូវបានជួបសារទូតពីស្ថានសួគ៌ម្នាក់ ហើយបានទទួលវិវរណៈនេះ ភាគខ្លះត្រូវបានកត់ទុកនៅពេលនោះ ហើយភាគដែលនៅសល់ទាំងប៉ុន្មាននោះ នៅខែកញ្ញា ។ ឥឡូវនេះ ទឹកត្រូវបានយកមកប្រើ នៅក្នុងការប្រជុំសាក្រាម៉ង់ នៃសាសនាចក្រ ជំនួសស្រាទំពាំងបាយជូរ ។*

*១–៤, តំណាងទាំងឡាយដែលត្រូវយកមកប្រើ នៅក្នុងការទទួលទានសាក្រាម៉ង់ ត្រូវបានថែងប្រាប់; ៥–១៤, ព្រះគ្រីស្ទ និងពួកអ្នក បំរើរបស់ទ្រង់ពីគ្រប់ការកាន់កាប់ត្រួតត្រា ត្រូវទទួលទានសាក្រាម៉ង់; ១៥–១៨, ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ។*

ប្រស្ដាប់តាមសម្លេងនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់អ្នក ជាព្រះរបស់អ្នក ហើយជាព្រះដ៏ប្រោសលោះរបស់អ្នក ឯព្រះ [ក]បន្ទូលរបស់ទ្រង់នោះរស់នៅ ហើយពូកែផង ។

២ ត្បិតមើលចុះ យើងប្រាប់អ្នកថា មិនជាសំខាន់ទេ ពីអ្វីដែលអ្នករាល់គ្នានឹងបរិភោគ ឬពីអ្វីដែលអ្នករាល់គ្នានឹងផឹក នៅពេលអ្នករាល់ គ្នាទទួលទាន[ក]សាក្រាម៉ង់ បើសិនជាអ្នករាល់គ្នាធ្វើឡើងដោយភ្នែកស្មោះត្រង់ទាំងស្រុង ចំពោះ[ខ]សិរីល្អរបស់យើង — គឺដោយការចងចាំ ដល់ព្រះវរបិតា អំពីព្រះកាយរបស់យើង ដែលបានដាក់ចុះដើម្បីអ្នក និងអំពី[គ]ព្រះលោហិតរបស់យើង ដែលបានច្រួចដើម្បី[ឃ]ការផ្ដាច់បាប ទាំងឡាយរបស់អ្នក ។

៣ ហេតុដូច្នោះហើយ យើងប្រទានបញ្ញត្តិមួយដល់អ្នក ថាអ្នកមិនត្រូវទិញស្រាទំពាំងបាយជូរ ឬក៏ភេសជ្ជៈជាតិស្រា ពីពួកខ្មាំងសត្រូវ របស់អ្នកឡើយ;

៤ ហេតុដូច្នោះហើយ អ្នកមិនត្រូវទទួលទានអ្វីឡើយ លើកលែងតែបានធ្វើថ្មី នៅក្នុងចំណោមពួកអ្នក; មែនហើយ ដោយការនេះហើយ ដែលនគរនៃព្រះវរបិតារបស់យើង នឹងត្រូវបានសាងឡើង នៅលើផែនដី ។

៥ មើលចុះ នេះជាប្រាជ្ញានៅក្នុងយើង ដូច្នោះហើយ ចូរកុំឆ្ងល់ឡើយ ត្បិត[ក]ម៉ោងនឹងមកដល់ ដែលយើងនឹងសោយពីផល

**២៦** ១*ក* ស.ប. បទព្រះគម្ពីរ — គម្លៃនៃព្រះគម្ពីរ.
*ខ* គ. និង ស. ២៤:៣; ៣៧:២.
២ *ក* ១ សាំយូ. ៨:៧; ម៉ូសាយ ២៩:២៦.
ស.ប. ការយល់ព្រមទូទៅ.
**២៧** ១*ក* ហេលេ. ៣:២៩; គ. និង ស. ៦:២.
២ *ក* ស.ប. បុណ្យរំលឹក.
*ខ* ស.ប. សិរីល្អ.
*គ* ស.ប. លោហិត.
*ឃ* ស.ប. ការផ្ដាច់បាប.
៥ *ក* ម៉ាថាយ ២៦:២៩; ម៉ាកុស ១៤:២៥; លូកា ២២:១៨.

ផ្លែទំពាំងបាយ ជូរ ជាមួយនឹងអ្នកនៅលើផែនដី ហើយជាមួយនឹង
[ខ]មរ៉ូណៃ ដែលយើងបានចាត់ឲ្យទៅរកអ្នក ដើម្បីបង្ហាញព្រះ
គម្ពីរមរមន ដែលមាន នូវភាពពោរពេញនៃដំណឹងល្អរបស់យើង
ដ៏នៅអស់កល្បជានិច្ច ជាអ្នកដែលយើងបានប្រគល់កូនសោទាំង
ឡាយ នៃបញ្ជីពី[គ]បន្ទះឈើ របស់អេប្រាអិម;
៦ ហើយជាមួយនឹង[ក]អេលីយ៉ាផង ជាអ្នកដែលយើងបាន
ប្រគល់កូនសោទាំងឡាយ នៃការសំរេចនូវការសាងឡើងវិញ
នៃរបស់ទាំង អស់ ដែលបានពោលដោយមាត់នៃពួកព្យាការីបរិសុទ្ធ
ចាប់តាំងពីដើមមក ស្ដីអំពីថ្ងៃចុងក្រោយបង្អស់;
៧ ហើយជាមួយនឹង[ក]យ៉ូហានផង ជាកូនប្រុសរបស់សាការី
គឺជាសាការីដែលលោក (អេលីយ៉ាស) បានទៅជួប ហើយបាន
សន្យាថា លោកនឹងបានកូនប្រុសមួយ ហើយឈ្មោះកូននោះត្រូវ
ហៅថា [ខ]យ៉ូហាន ហើយលោកនឹងបានពោរពេញទៅដោយវិញ្ញាណ
នៃលោក អេលីយ៉ាស;
៨ គឺជាយ៉ូហានដែលយើងបានចាត់ឲ្យទៅរកអ្នក យ៉ូសែប ស្ម៊ីធ
ជុញ្ញ៉រ និង អូលីវើរ ខៅឌើរ ជាពួកអ្នកបំរើរបស់យើង ដើម្បីទៅតែង
តាំងដល់អ្នកនូវ[ក]បព្វជិតភាពទីមួយ ដែលអ្នកបានទទួលមកហើយនោះ
ដើម្បីឲ្យអ្នកអាចបានហៅ ហើយ[ខ]តែងតាំងឡើង ដូចជា[គ]លោក
អើរ៉ុន;
៩ ហើយជាមួយនឹង[ក]អេលីយ៉ាផង ជាអ្នកដែលយើង
ប្រគល់កូនសោទាំងឡាយ នូវអំណាចនៃ[ខ]ការបង្វែរចិត្តពួកឪពុក
មកឯកូន និងចិត្តកូន មកឯឪពុក ដើម្បីកុំឲ្យផែនដីទាំងមូលត្រូវ
វាយដោយសេចក្ដីបណ្ដាសា;
១០ ហើយជាមួយនឹងយ៉ូសែប និងយ៉ាកុប និងអ៊ីសាក និង
អ័ប្រាហាំ ជាពួកអយ្យកោរបស់អ្នកផង ជាពួកអ្នកដែលមាន
[ក]សេចក្ដីសន្យាទាំង ឡាយ;
១១ ហើយជាមួយនឹងមីកែល ឬ[ក]អ័ដាម ជាបិតានៃមនុស្ស
ទាំងអស់ ជាអ្នកត្រួតត្រានៃមនុស្សទាំងអស់ ជាអ្នក
ពីចាស់បុរាណ;
១២ ហើយជាមួយនឹងពេត្រុស និងយ៉ាកុប និងយ៉ូហានផង ជា
ពួកអ្នកដែលយើងបានចាត់ឲ្យទៅរកអ្នក គឺដោយសារពួកគេ
យើងបាន [ក]តែងតាំងអ្នក ហើយបានបញ្ជាក់អ្នកឲ្យធ្វើជាពួក[ខ]សាវក
និងជាពួក[គ]សាក្សីពិសេសអំពីព្រះនាមរបស់យើង ហើយឲ្យកាន់
កូនសោទាំងឡាយ ខាងការងារបំរើរបស់អ្នក និងអំពីរបស់ផង
ទាំងឡាយ ដែលយើងបានបើកសំដែងដល់អ្នក;
១៣ គឺជាពួកអ្នកដែលយើងបាន[ក]ប្រគល់[ខ]កូនសោទាំងឡាយ
នៃនគររបស់យើង និងនៃ[គ]ការកាន់កាប់ត្រួតត្រានៃ[ឃ]ដំណឹងល្អ
សំរាប់[ង]ពេលចុងក្រោយបង្អស់; និងសំរាប់កំណត់កាល
[ច]ដ៏ពោរពេញ ជាពេលដែលយើងនឹងប្រមូលរបស់របរទាំង
អស់ទៅ[ឆ]តែមួយ គឺរបស់នៅលើស្ថានសួគ៌ ព្រមទាំង
របស់នៅលើផែនដីផង;
១៤ ហើយជាមួយនឹងអស់អ្នកណា ដែលព្រះវរបិតារបស់
យើង [ក]បានប្រទានដល់យើង ចេញពីលោកិយផង ។
១៥ ហេតុដូច្នោះហើយ ចូរលើកចិត្តឡើង ហើយអរសប្បាយ
ហើយចូរក្រវាត់ចង្កេះ ហើយយកគ្រប់[ក]គ្រឿងសឹករបស់យើង មក
ពាក់ចុះ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន
ដោយបានតតាំងសព្វគ្រប់ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹង
[ខ]ឈរមាំមួនបាន ។

៥ ខ យ.ស. — ប្រវត្តិ ១:៣០–៣៤.
គ អេសេ. ៣៧:១៦.
ស.ប. អេប្រាអិម — បន្ទះឈើនៃអេប្រាអិម ឬយ៉ូសែប.
៦ ក ស.ប. អេលីយ៉ាស.
៧ ក លូកា ១:១៧–១៩.
ខ លូកា ១:១៣; គ. និង ស. ៨៤:២៧–២៨.
៨ ក គ. និង ស. ១៣:១.
ស.ប. បព្វជិតភាពអើរ៉ុន.
ខ ស.ប. តែងតាំង, ការតែងតាំង.
គ និក្ខ. ២៨:១–៣, ៤១; គ. និង ស. ១០៧:១៣.
៩ ក ១ ពង្សាវ. ១៧:១–២២; ២ ពង្សាវ. ១–២; គ. និង ស. ២:១–៣; ១១០:១៣–១៦; យ.ស. — ប្រវត្តិ ១:៣៨–៣៩.
ស.ប. អេលីយ៉ា; ពង្សាវតារ.
ខ ស.ប. ពង្សាវតារ.
១០ ក ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
១១ ក ស.ប. អ័ដាម.
១២ ក យ.ស. — ប្រវត្តិ ១:៧២.
ស.ប. បព្វជិតភាពមិលគីស្សាដែក.
ខ ស.ប. សាវក.
គ កិច្ចការ ១:៨.
១៣ ក ម៉ាថាយ ១៦:១៩.
ខ ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
គ ស.ប. គ្រាកាន់កាប់ត្រួតត្រា.
ឃ ស.ប. ដំណឹងល្អ.
ង យ៉ាកុប ៥:៧១; គ. និង ស. ៤៣:២៨–៣០.
ច អេភ. ១:៩–១០; គ. និង ស. ១១២:៣០; ១២៤:៤១.
ឆ គ. និង ស. ៨៤:១០០.
១៤ ក យ៉ូហាន ៦:៣៧; ១៧:៩, ១១; ៣ នីហ្វៃ ១៥:២៤; គ. និង ស. ៥០:៤១–៤២; ៨៤:៦៣.
១៥ ក រ៉ូម ១៣:១២; អេភ. ៦:១១–១៨.
ខ ម៉ាឡាគី ៣:២; គ. និង ស. ៨៧:៨.

១៦ ដូច្នេះ ចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្ដីពិតនៅ
ចង្កេះ ដោយពាក់សេចក្ដីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង
ហើយពាក់សេចក្ដីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្ដីសុខសាន្ដ
ទុកជាស្បែកជើង ដែលយើងបានចាត់ពួកទេវតារបស់យើង
ឲ្យមកប្រគល់ ដល់អ្នក;
១៧ ដោយយកសេចក្ដីជំនឿទុកជាខែល ដែលអ្នករាល់គ្នានឹង
អាចរំលត់ អស់ទាំងព្រួញឆេះរបស់ពួកទុច្ចរិត ដោយសារ
ខែលនោះបាន;
១៨ ហើយចូរយកសេចក្ដីសង្គ្រោះទុកជាមួកសឹក និងដាវ
របស់ព្រះវិញ្ញាណរបស់យើង ដែលយើងនឹងចាក់មកលើអ្នក និង
ព្រះបន្ទូល របស់យើង ដែលយើងបើកសំដែងដល់អ្នក ហើយ
ចូរមានចិត្តព្រមព្រៀង ចំពោះអ្វីៗគ្រប់យ៉ាង ដែលអ្នករាល់គ្នា
សូមពីយើង ហើយចូរ មានចិត្តស្មោះត្រង់ រហូតដល់យើង
ត្រឡប់មកវិញចុះ នោះអ្នករាល់គ្នានឹងបានលើកឡើង ប្រយោជន៍ឲ្យ
អ្នករាល់គ្នាបាននៅកន្លែងដែលយើងនៅនោះដែរ ។ អាម៉ែន ៕

## កណ្ឌទី ២៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ អូលីវើរ ខៅឌើរី នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែកញ្ញា ឆ្នាំ១៨៣០ (*History of the Church, *១:១០៩–១១១) ។ ហៃរ៉ាំ ភេច ជាសមាជិកសាសនាចក្រម្នាក់ ដែលមានត្បូងអ្វីមួយ ហើយ អះអាងថាអាចទទួលវិវរណៈទាំងឡាយបាន ដោយសារត្បូងនោះ អំពីទំនាក់ទំនងខាងការសាងក្រុងស៊ីយ៉ូនឡើង និងអំពី របៀបដំណើរសាសនាចក្រ ។ មានសមាជិកដ៏ក្រៃលែងត្រូវបានបំភាន់តាមការអះអាងទាំងនេះ ហើយសូម្បីតែ អូលីវើរ ខៅឌើរី ក៏ត្រូវបានបំភាន់តាមការ អះអាងទាំងនេះដែរ ។ មុនសន្និសីទដែលបានកំណត់ទុកបន្តិច នោះព្យាការីបានអធិស្ឋាននាំសូមពីព្រះអម្ចាស់ អំពីការណ៍នេះ ហើយវិវរណៈនេះក៏បានមកតាមក្រោយ ។*

*១–៧, យ៉ូសែប ស្ម៊ីធ កាន់កូនសោនៃសេចក្ដីអាថ៌កំបាំងទាំងឡាយ ហើយមានតែលោកម្នាក់គត់ ទទួលវិវរណៈទាំងឡាយសំរាប់ សាសនាចក្រ; ៨–១០, អូលីវើរ ខៅឌើរី ត្រូវទៅផ្សាយដល់ពួកសាសន៍លេមិន; ១១–១៦, អារក្សសាតាំងបញ្ឆោត ហៃរ៉ាំ ភេច ហើយបានឲ្យវិវរណៈក្លែងក្លាយទាំងឡាយដល់គាត់ ។*

មើលចុះ អូលីវើរអើយ យើងមានបន្ទូលដល់អ្នកថា នឹងបាន
ប្រទានដល់អ្នក ដើម្បីឲ្យសាសនាចក្របានឮពីអ្នក នូវអ្វីៗគ្រប់
យ៉ាង ដែលអ្នក នឹងបង្រៀនពួកគេ ដោយសារព្រះដ៏ជាជំនួយ
អំពីវិវរណៈទាំងឡាយ និងព្រះបញ្ញត្តិទាំងឡាយ ដែលយើងបាន
ប្រទានមក ។
២ ប៉ុន្ដែមើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា គ្មាន
នរណាម្នាក់ត្រូវបានតាំងឡើង ដើម្បីទទួលបញ្ញត្តិទាំងឡាយ
និងវិវរណៈ ទាំងឡាយ នៅក្នុងសាសនាចក្រនេះឡើយ
លើកលែងតែ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើងប៉ុណ្ណោះ
ត្បិតលោកទទួលរបស់ ទាំងនោះ ដូចជា លោកម៉ូសេ ។
៣ ហើយអ្នកត្រូវគោរពតាមអ្វីៗទាំងឡាយ ដែលយើងនឹង
ប្រទានដល់លោក ដូចជាលោកអើរ៉ុន ដើម្បីទៅប្រកាស
ប្រាប់ពីព្រះបញ្ញត្តិ ទាំងឡាយ និងវិវរណៈទាំងឡាយ ដល់
សាសនាចក្រ ដោយស្មោះត្រង់ ដោយនូវអំណាច និងសិទ្ធិ
អំណាច ។
៤ ហើយបើសិនជានៅពេលណាមួយ អ្នកត្រូវ
ព្រះដ៏ជាជំនួយនាំឲ្យនិយាយ ឬបង្រៀនដល់សាសនាចក្រ

១៦ *ក* អេសាយ ១១:៥.
*ខ* ស.ប. សេចក្ដីពិត.
*គ* អេសាយ ៥៩:១៧.
*ឃ* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ង* ២ នីហ្វៃ ១៩:៦.
*ច* គ. និង ស. ១២៨:១៩–២១.
១៧ *ក* ១ នីហ្វៃ ១៥:២៤;
គ. និង ស. ៣:៨.
១៨ *ក* ១ នីហ្វៃ ១៣:៣៧;
គ. និង ស. ១៧:៨.
*ខ* យ៉ូហាន ១៤:៣.
**២៨** ១ *ក* គ. និង ស. ២០:៣.
*ខ* ស.ប. បង្រៀន, គ្រូបង្រៀន — ការបង្រៀនដោយនូវព្រះវិញ្ញាណ.
*គ* ស.ប. ព្រះដ៏ជាជំនួយ.
២ *ក* គ. និង ស. ៣៥:១៧–១៨;
៤៣:៤.
*ខ* ២ នីហ្វៃ ៣:១៤–២០.
ស.ប. ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ
៣ *ក* ស.ប. អើរ៉ុន, បងប្រុសរបស់ម៉ូសេ.
*ខ* ស.ប. សិទ្ធិអំណាច.
៤ *ក* និក្ខ. ៤:១២–១៦;
គ. និង ស. ២៤:៥–៦.

ឬនៅគ្រប់ពេលណាក៏ដោយ តាមតែព្រះបញ្ញត្តិ នោះអ្នកអាចធ្វើតាម ។

៥ ប៉ុន្តែអ្នកមិនត្រូវកត់ទុកជាព្រះបញ្ញត្តិទេ តែទុកជាប្រាជ្ញាវិញ;

៦ ហើយអ្នកមិនត្រូវបញ្ជាអ្នកណាដែលនៅលើអ្នក និងនៅលើសាសនាចក្រនោះឡើយ;

៧ ត្បិតយើងបានប្រទានដល់លោក នូវ[ក]កូនសោ[ខ]នៃសេចក្ដីអាថិកំបាំង និងវិវរណៈទាំងឡាយ ដែលបានបិទទុក លុះត្រាយើងនឹងតាំងអ្នក ណាមួយជំនួសលោក ដល់ពួកគេ ។

៨ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា អ្នកត្រូវទៅឯ[ក]ពួកសាសន៍លេមិន ហើយផ្សាយ[ខ]ដំណឹងល្អរបស់យើងប្រាប់ពួកគេ ហើយដរាបណាពួកគេទទួលការបង្រៀនទាំងឡាយរបស់អ្នក នោះអ្នកនឹងបណ្ដាលឲ្យសាសនាចក្ររបស់យើងបានតាំងឡើងនៅក្នុងចំណោមពួកគេ ហើយអ្នកនឹងមានវិវរណៈទាំងឡាយ ប៉ុន្តែចូរកុំកត់វិវរណៈទាំងនោះ ទុកជាព្រះបញ្ញត្តិឡើយ ។

៩ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា ពុំបានបើកសំដែងទេ ហើយគ្មាននរណាដឹងពីកន្លែងដែលនឹងសង់[ក]ក្រុង[ខ]ស៊ីយ៉ូនឡើយ ប៉ុន្តែនឹងបានប្រទានឲ្យពីពេលនេះតទៅ ។ មើលចុះ យើងប្រាប់អ្នកថា កន្លែងនោះនឹងនៅចំព្រំប្រទល់ជិតពួកសាសន៍លេមិន ។

១០ អ្នកមិនត្រូវចេញពីកន្លែងនេះ លុះត្រាចប់សន្និសីទសិន ហើយ យ៉ូសែប ជាអ្នកបំរើរបស់យើង នឹងត្រូវបានតាំងឡើងឲ្យត្រួតត្រាលើសន្និសីទ ដោយសារសម្លេង រីឯអ្វីៗដែលលោកនឹងនិយាយប្រាប់ដល់អ្នក នោះអ្នកត្រូវប្រាប់ ។

១១ ហើយជាថ្មីទៀត អ្នកត្រូវនាំ ហៃរ៉ាំ ភេច [ក]ជាបងប្អូនរបស់អ្នក ដោយមានតែអ្នក ហើយនឹងគាត់ ហើយចូរប្រាប់គាត់ថា អ្វីៗទាំងនោះ ដែលគាត់បានកត់ពីត្បូងនោះ នោះពុំមែនមកពីយើងទេ ហើយថាអារក្ស[ខ]សាតាំង[គ]បានបញ្ឆោតគាត់;

១២ ត្បិតមើលចុះ ការណ៍ទាំងនេះពុំបានតាំងដល់គាត់ ឬក៏តាំងអ្វីដល់អ្នកណាមួយក្នុងសាសនាចក្រនេះ ដែលប្រឆាំងទៅនឹងសេចក្ដី សញ្ញាទាំងឡាយនៃសាសនាចក្រឡើយ ។

១៣ ត្បិតគ្រប់ការណ៍ទាំងអស់ ត្រូវធ្វើឡើងតាមរបៀបរៀបរយ និងតាម[ក]ការយល់ព្រមទូទៅ នៅក្នុងសាសនាចក្រ ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ។

១៤ ហើយអ្នកត្រូវជួយ ដើម្បីដោះស្រាយគ្រប់ការណ៍ទាំងអស់ ស្របតាមសេចក្ដីសញ្ញាទាំងឡាយនៃសាសនាចក្រ មុននឹងអ្នកចេញ ដំណើរ ទៅក្នុងចំណោមពួកសាសន៍លេមិន ។

១៥ ហើយនឹង[ក]បានប្រទានដល់អ្នក នូវអ្វីៗដែលអ្នកត្រូវធ្វើ ចាប់តាំងពីពេលដែលអ្នកនឹងចេញទៅ រហូតដល់ពេលអ្នកត្រឡប់មកវិញ ។

១៦ ហើយអ្នកត្រូវបើកមាត់គ្រប់ពេល ហើយប្រកាសប្រាប់ពីដំណឹងល្អរបស់យើង ដោយសម្លេងរីករាយចុះ ។ អាម៉ែន ៕

## កណ្ឌទី ២៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្នុងវត្តមានពួកអែលឌើរប្រាំមួយនាក់ នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែកញ្ញា ឆ្នាំ១៨៣០ (*History of the Church, *១:១១១–១១៥)* ។ *វិវរណៈនេះត្រូវបានប្រទានឲ្យមកបួនដប់ថ្ងៃមុនសន្និសីទ ដែលចាប់ផ្ដើមធ្វើនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៨៣០ ។*

*១–៨, ព្រះគ្រីស្ទប្រមូលពួកដែលទ្រង់បានរើសតាំង; ៩–១១, ការយាងរបស់ទ្រង់បណ្ដាលឲ្យចាប់ផ្ដើមសហស្សវត្សរ៍; ១២–១៣, ពួក១២ នាក់ នឹងជំនុំជំរះពួជអំបូរអ៊ីស្រាអែលទាំងអស់; ១៤–២១, ទីសំគាល់ រោគា និងសេចក្ដីហិនវិនាសនឹងមានឡើងមុនការយាងមកលើក ទីពីរ; ២២–២៨, ដំណើររស់ឡើងវិញ និងសេចក្ដីជំនុំជំរះចុងក្រោយបង្អស់ បន្ទាប់ពីសហស្សវត្សរ៍; ២៩–៣៥, អ្វីៗគ្រប់យ៉ាង គឺសុទ្ធតែ ខាងវិញ្ញាណចំពោះព្រះអម្ចាស់; ៣៦–៣៩, អារក្ស និងពួកពលបរិវារវាត្រូវបានបណ្ដេញចេញពីស្ថានសួគ៌ ដើម្បីឲ្យមកល្បួងមនុស្ស; ៤០–៤៥, ការធ្លាក់ និងដង្វាយធួននាំមកនូវសេចក្ដី*

៧ *ក* គ. និង ស. ៦៤:៥; ៨៤:១៩.
*ខ* ស.ប. សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ.
៨ *ក* ២ នីហ្វៃ ៣:១៨–២២; គ. និង ស. ៣០:៥–៦; ៣២:១–៣.
*ខ* គ. និង ស. ៣:១៩–២០.
៩ *ក* គ. និង ស. ៥៧:១–៣.
*ខ* គ. និង ស. ៥២:៤២–៤៣. ស.ប. ស៊ីយ៉ូន.
១១ *ក* ម៉ាថាយ ១៨:១៥.
*ខ* វិវរ. ២០:១០.
*គ* គ. និង ស. ៤៣:៥–៧.
១៣ *ក* ស.ប. ការយល់ព្រមទូទៅ.
១៥ *ក* ២ នីហ្វៃ ៣២:៣, ៥.

*ក្ដីសង្គ្រោះ; ៤១–៥០, កូនក្មេងតូចៗត្រូវបានប្រោសលោះ
តាមរយៈដង្វាយធួន ។*

ចូរស្ដាប់តាមសម្លេងនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះ
របស់អ្នក ជាព្រះដ៏ជាព្រះដែលមហិមា ដែលបានធ្វើឲ្យធួន
នឹងបាបទាំង ឡាយរបស់អ្នក ដោយពាហុនៃសេចក្ដីមេត្តាករុណា
របស់ទ្រង់;
២ ជាអ្នកដែលនឹងប្រមូលរាស្ត្ររបស់ទ្រង់ ដូចជាមេមាន់ក្រុង
កូនវាឲ្យជ្រកក្រោមស្លាប សូម្បីតែអស់អ្នកណាដែលនឹងស្ដាប់
តាម សម្លេងរបស់យើង ហើយបន្ទាបខ្លួននៅចំពោះយើង ហើយ
អំពាវនាវដល់យើង ក្នុងការអធិស្ឋានដ៏ខ្លាំងក្លា ។
៣ មើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា
នៅពេលនេះ បាបទាំងឡាយរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ
ហេតុដូច្នេះ ហើយ បានជាអ្នករាល់គ្នាទទួលរបស់ទាំងនេះ ប៉ុន្តែ
ចូរចាំទុក ដើម្បីកុំធ្វើបាបទៀតឡើយ ក្រែងអំពើអាក្រក់នឹងមាន
មកលើអ្នក ។
៤ យើងប្រាប់អ្នកជាប្រាកដថា អ្នករាល់គ្នាត្រូវបានរើស
ចេញពីពិភពលោក ដើម្បីឲ្យទៅប្រកាសប្រាប់ពីដំណឹងល្អរបស់
យើង ដោយ សម្លេងរីករាយ ដូចជាសម្លេងត្រែ ។
៥ ចូរលើកចិត្តអ្នកឡើង ហើយអរសប្បាយចុះ ត្បិតយើងនៅ
កណ្ដាលពួកអ្នក ហើយយើងជាព្រះដ៏គាំទ្រអ្នក នៅចំពោះព្រះ
វរបិតា ហើយទ្រង់សព្វព្រះហឫទ័យនឹងប្រទាននគរមកអ្នក
រាល់គ្នា ។
៦ ហើយដូចជាបានចែងទុកមកថា — អ្វីក៏ដោយ ដែល
អ្នកសូម ដោយនូវសេចក្ដីជំនឿ ដោយរួមប្រជុំគ្នាអធិស្ឋាន
ស្របតាមបញ្ញត្តិ របស់ យើង នោះអ្នករាល់គ្នានឹងបានទទួល ។
៧ ហើយអ្នករាល់គ្នាត្រូវបានហៅមក ដើម្បីបណ្ដាលឲ្យមាន
ការប្រមូល នៃពួកដែលយើងបានរើសតាំង ត្បិតពួកដែលយើង
បានរើសតាំង ឮសម្លេងរបស់យើង ហើយមិនពង្រឹងចិត្តរបស់ពួក
គេឡើយ;
៨ ហេតុដូច្នោះហើយ បញ្ញត្តិត្រូវបានចេញពីព្រះវរបិតាថា ពួក
គេនឹងត្រូវបានប្រមូលទៅកន្លែងមួយ នៅលើផ្ទៃផែនដីនេះ ដើម្បីឲ្យ
ប្រុងប្រៀបចិត្តរបស់ពួកគេ ហើយប្រុងប្រៀបជាស្រេច នូវអ្វី
ៗគ្រប់យ៉ាង រង់ចាំថ្ងៃនោះ ក្នុងកាលសេចក្ដីវេទនា និងសេច
ក្ដីហិនវិនាស ត្រូវបានចាត់ឲ្យមានមកលើពួកទុច្ចរិត ។
៩ ត្បិតម៉ោងជិតដល់ហើយ ហើយថ្ងៃនៅជិតដែលបង្ហើយ ក្នុង
កាលផែនដីទុំស្រុស; ហើយអស់ពួកឆ្មើងឆ្មៃ និងអស់ពួកអ្នក ដែល
ប្រព្រឹត្តដោយ អំពើទុច្ចរិត គេនឹងដូចជាជញ្ជ្រាំង; ហើយយើងនឹង
បញ្ឆេះពួកគេឡើង ព្រះអម្ចាស់ដ៏ជាព្រះ នៃពួកពលបរិវារមាន
ព្រះបន្ទូលថាដូច្នោះ ដើម្បីកុំឲ្យមាន អំពើទុច្ចរិត នៅលើផែន
ដីឡើយ;
១០ ត្បិតម៉ោងជិតដល់ហើយ ហើយដើម្បីឲ្យអ្វីៗដែលបាន
ពោលឡើង ដោយពួកសាវករបស់យើង នោះត្រូវបាន
សំរេច ត្បិតដូច ជាពួកគេ បានពោលមក នោះនឹង
បានកើតឡើងមែន;
១១ ត្បិតយើងនឹងសំដែងខ្លួនឲ្យឃើញពីស្ថានសួគ៌ ដោយ
ព្រះចេស្ដា និងសិរីល្អដ៏ធំ ដោយអស់ទាំងពួកពលបរិវារពី
ស្ថានសួគ៌ ហើយនឹងស្ថិត នៅក្នុងសេចក្ដីសុចរិត ជា

**២៩** ១*ក* ស.ប. យើងជាព្រះ.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
*គ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
២ *ក* ម៉ាថាយ ២៣:៣៧; ៣ នីហ្វៃ ១០:៤–៦.
*ខ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
៣ *ក* ស.ប. អត់ទោស, អភ័យទោស.
៤ *ក* អាលម៉ា ២៩:១–២; គ. និង ស. ១៩:៣៧; ៣០:៩.
៥ *ក* ម៉ាថាយ ១៨:២០; គ. និង ស. ៦:៣២; ៣៨:៧; ៨៨:៦២–៦៣.
*ខ* ស.ប. ព្រះដ៏គាំទ្រ.
*គ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
៦ *ក* ម៉ាថាយ ២១:២២; យ៉ូហាន ១៤:១៣.
*ខ* ម៉ាកុស ១១:២៤.
*គ* ៣ នីហ្វៃ ២៧:១–២; គ. និង ស. ៨៤:១.
៧ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* ម៉ាកុស ១៣:២០; គ. និង ស. ៨៤:៣៤. ស.ប. ពួករើសតាំង.
*គ* អាលម៉ា ៥:៣៧–៤១.
*ឃ* ស.ប. ចិត្ត.
៨ *ក* គ. និង ស. ៤៥:៦៤–៦៦; ៥៧:១.
*ខ* គ. និង ស. ៥៨:៦–៩; ៧៨:៧.
*គ* គ. និង ស. ៥:១៩; ៤៣:១៧–២៧.
៩ *ក* ២ នីហ្វៃ ២០:៣៣; ៣ នីហ្វៃ ២៥:១. ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ខ* ណាហ៊ុម ១:១០; ម៉ាឡាគី ៤:១; ១ នីហ្វៃ ២២:១៥, ២៣; យ.ស. — ប្រវត្តិ ១:៣៧.
*គ* គ. និង ស. ៤៥:៥៧; ៦៣:៣៤, ៥៤; ៦៤:២៤; ៨៨:៩៤; ១០១:២៣–២៥; ១៣៣:៦៤. ស.ប. ផែនដី — ការសំអាតផែនដី.
១០ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
១១ *ក* យ.ស. — ម៉ាថាយ ១:៣៧.
*ខ* ស.ប. សុចរិត, សេចក្ដីសុចរិត.

[គ]មួយមនុស្សលោក នៅលើផែនដីអស់មួយពាន់ឆ្នាំ ហើយពួកទុច្ចរិតនឹងពុំឈរមាំមួនឡើយ ។

១២ ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដ ហើយវាបានចេញទៅជាបញ្ញត្តិដ៏តឹងរឹង ដោយព្រះហឫទ័យនៃព្រះវរបិតា ថា[ក]ពួកសាវករបស់យើង គឺពួក១២នាក់ដែលនៅជាមួយនឹងយើង នៅឯការងារបំរើរបស់យើង នៅក្រុងយេរូសាឡិម ពួកគេនឹងឈរ ខាងស្ដាំដៃយើង នៅថ្ងៃនៃការយាងមករបស់យើង ក្នុងបង្គោល[ខ]ភ្លើង ដោយពាក់អាវវែងនៃសេចក្ដីសុចរិត ព្រមទាំងមានមកុដនៅលើក្បាលរបស់ពួកគេផង នៅក្នុង[គ]សិរីល្អ ដូចជាយើង ដើម្បី[ឃ]ជំនុំជំរះពូជអំបូរអ៊ីស្រាអែលទាំងអស់ គឺដូចជាអស់អ្នកណាដែលបានស្រឡាញ់ យើង ហើយកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ហើយគ្មាននរណាទៀតឡើយ ។

១៣ ត្បិត[ក]ត្រែនឹងបន្លឺសូរកាន់តែរន្ទើនខ្លាំងឡើង ដូចជានៅលើភ្នំស៊ីណាយ ហើយអស់ទាំងផែនដីនឹងកក្រើក ហើយពួកគេនឹង[ខ]ចេញមក — មែនហើយ គឺ[គ]ពួកមនុស្សស្លាប់ណាដែលស្លាប់ក្នុងយើង ដើម្បីមកទទួល[ឃ]មកុដនៃសេចក្ដីសុចរិត ហើយដើម្បីបានបំពាក់ [ង]ដូចជាយើង ដើម្បីនៅជាមួយនឹងយើង ប្រយោជន៍ឲ្យយើងទាំងឡាយអាចបានរួមតែមួយ ។

១៤ ប៉ុន្តែមើលចុះ យើងប្រាប់អ្នករាល់គ្នាថា មុន[ក]ថ្ងៃដ៏ធំនោះនឹងមកដល់ [ខ]ថ្ងៃនឹងទៅជាងងឹត ហើយខែនឹងទៅជាឈាម ហើយផ្កាយទាំងឡាយនឹងធ្លាក់ចុះពីលើមេឃ ហើយនឹងមាន[គ]ទីសំគាល់ដ៏ធំជាងនៅលើមេឃ និងនៅលើផែនដីខាងក្រោម;

១៥ ហើយនឹងមានការយំសោក[ក]សង្រេង នៅក្នុងចំណោមហ្វូងមនុស្ស;

១៦ ហើយនឹងមាន[ក]ព្យុះព្រិលដ៏ធំ ចាត់ឲ្យមកបំផ្លាញដំណាំនៃផែនដី ។

១៧ ហើយហេតុការណ៍នឹងកើតឡើង ពីព្រោះតែអំពើទុច្ចរិតនៃពិភពលោក ដែលយើងនឹងដាក់[ក]ការសងសឹកមកលើ[ខ]ពួកទុច្ចរិត ព្រោះពួក គេមិនព្រមប្រែចិត្តសោះ; ព្រោះពែងនៃសេចក្ដីក្ដៅក្រហាយរបស់យើងពេញហើយ ត្បិតមើលចុះ [គ]លោហិតយើងនឹងមិនសំអាតពួកគេ ឡើយ បើសិនជាពួកគេមិនស្ដាប់តាមយើង ។

១៨ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ដ៏ជាព្រះ នឹងចាត់រុយទាំងឡាយឲ្យមកលើផ្ទៃផែនដី ដែលនឹងរុំបណ្ដាជននៅទីនោះ ហើយនឹងស៊ីសាច់ពួកគេ ហើយនឹងបណ្ដាលឲ្យកើតដង្កូវមកលើសាច់ពួកគេ;

១៩ ហើយអណ្ដាតពួកគេនឹងនៅស្ងៀម ដើម្បីកុំឲ្យពួកគេ[ក]ពោលពាក្យទាស់នឹងយើង; ហើយសាច់ពួកគេនឹងរលួយជ្រុះពីឆ្អឹងពួកគេ ហើយភ្នែកពួកគេជ្រុះពីរន្ធភ្នែកពួកគេ;

២០ ហើយហេតុការណ៍នឹងកើតឡើងថា [ក]សត្វសាហាវនៅក្នុងព្រៃ និងសត្វហើរលើអាកាស នឹងមកស៊ីសាច់ពួកគេអស់រលីង ។

២១ ហើយសាសនាចក្រដ៏ធំហើយ[ក]គួរខ្ពើមឆ្អើម ដែលជា[ខ]ពេស្យានៃអស់ទាំងផែនដី នឹងត្រូវរលំចុះដោយ[គ]ភ្លើងឆេះឆាបស្របតាម អ្វីដែលបានពោល ដោយមាត់នៃលោកអេសេគាលជាព្យាការី ជាអ្នកដែលបានពោលអំពីការណ៍ទាំងនេះ ដែលមិនទាន់បានកើត ឡើងនៅឡើយទេ ប៉ុន្តែច្បាស់ជានឹង[ឃ]កើតឡើងដរាបណាដែលយើងមានព្រះជន្មរស់នៅ ត្បិតអំពើដ៏គួរខ្ពើមឆ្អើមនឹងមិនសោយរាជ្យ ឡើយ ។

២២ ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា

១១ *គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — រជ្ជកាលនៃព្រះគ្រីស្ទនៅសហស្សវត្សរ៍; សហស្សវត្សរ៍.
១២ *ក* ស.ប. សាវក.
*ខ* អេសាយ ៦៦:១៥–១៦; គ. និង ស. ១៣០:៧; ១៣៣:៤១.
*គ* ស.ប. សិរីល្អ; ព្រះយេស៊ូវគ្រីស្ទ — សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.
*ឃ* ម៉ាថាយ ១៩:២៨; លូកា ២២:៣០; ១ នីហ្វៃ ១២:៩; មរមន ៣:១៨–១៩.
១៣ *ក* គ. និង ស. ៤៣:១៨; ៤៥:៤៥.
*ខ* គ. និង ស. ៧៦:៥០.
*គ* គ. និង ស. ៨៨:៩៧; ១៣៣:៥៦.
*ឃ* ស.ប. មកុដ; ភាពដំកើងឡើង.
*ង* គ. និង ស. ៧៦:៩៤–៩៥; ៨៤:៣៥–៣៩.
១៤ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* យ៉ូអែល ២:១០; យ.ស. — ម៉ាថាយ ១:៣៣.
*គ* ស.ប. ទីសំគាល់អំពីពេលវេលា.
១៥ *ក* ម៉ាថាយ ១៣:៤២.
១៦ *ក* អេសេ. ៣៨:២២; វិវរ. ១១:១៩; ១៦:២១.
១៧ *ក* វិវរ. ១៦:៧–១១; ២ នីហ្វៃ ៣០:១០; យ.ស. — ម៉ាថាយ ១:៥៣–៥៥. ស.ប. ការសងសឹក.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
*គ* ១ យ៉ូហាន ១:៧; អាលម៉ា ១១:៤០–៤១; គ. និង ស. ១៩:១៦–១៨.
១៩ *ក* សាការី ១៤:១២.
២០ *ក* អេសាយ ១៨:៦; អេសេ. ៣៩:១៧; វិវរ. ១៩:១៧–១៨.
២១ *ក* ស.ប. អារក្ស — សាសនាចក្រនៃអារក្ស.
*ខ* វិវរ. ១៩:២.
*គ* យ៉ូអែល ១:១៩–២០; ២:៣; គ. និង ស. ៩៧:២៥–២៦. ស.ប. ផែនដី — ការសំអាតផែនដី.
*ឃ* គ. និង ស. ១:៣៨.

ក្នុងកាលរយៈមួយពាន់ឆ្នាំបានចប់ទៅ ហើយមនុស្សលោកចាប់ផ្ដើម
បដិសេធព្រះរបស់ពួកគេម្ដងទៀត ខណៈនោះ យើងនឹង
ប្រណីដល់ផែនដីតែមួយរដូវតូចប៉ុណ្ណោះ;
២៣ ហើយចុងបំផុតនឹងមកដល់ ហើយផ្ទៃមេឃ និងផែនដី
នឹងត្រូវបានរលាយ ហើយកន្លងផុតទៅ ហើយនឹងមានផ្ទៃមេឃថ្មី
និងផែន ដីថ្មី ។
២៤ ព្រោះរបស់ចាស់គ្រប់យ៉ាងនឹងកន្លងផុតទៅ ហើយរបស់
ទាំងអស់នឹងក្លាយទៅជាថ្មី សូម្បីតែផ្ទៃមេឃ និងផែនដី និងអស់
ទាំង របស់របរពាសពេញទីនោះផង ព្រមទាំងមនុស្សលោក និង
សត្វជើងបួន ទាំងសត្វហើរលើអាកាស និងត្រីសមុទ្រផង;
២៥ ហើយគ្មានសក់មួយសរសៃ ឬកំទេចណាឡើយ នឹងត្រូវ
វិនាសបាត់ទៅ ត្បិតរបស់ទាំងនោះជាផលនៃព្រះហស្តរបស់យើង ។
២៦ ប៉ុន្តែមើលចុះ យើងប្រាប់អ្នកជាប្រាកដថា មុនផែនដីនឹង
កន្លងផុតទៅ មីកែល ជាមហាទេវតារបស់យើង នឹងបន្លឺត្រែ
របស់លោក ហើយនៅខណៈនោះ ពួកអ្នកស្លាប់ទាំងអស់នឹង
ភ្ញាក់ឡើងវិញ ព្រោះផ្នូររបស់ពួកគេនឹងរបើកឡើង ហើយពួកគេ
នឹងចេញមក —— មែនហើយ គឺមនុស្សទាំងអស់ ។
២៧ ហើយពួកសុចរិតនឹងត្រូវបានប្រមូលមកខាងស្ដាំយើង
ចំពោះជីវិតដ៏អស់កល្បជានិច្ច ហើយពួកទុច្ចរិតនៅខាងឆ្វេង
យើង នោះយើងនឹងមានចិត្តខ្មាស់ចំពោះព្រះវរបិតា ដែលយើង
មានពួកគេ;
២៨ ហេតុដូច្នោះហើយ យើងនឹងមានបន្ទូលដល់ពួកគេថា ——
អ្នករាល់គ្នាដែលត្រូវបណ្ដាសាអើយ ចូរចេញពីយើងទៅក្នុង
ភ្លើង ដ៏នៅអស់កល្បជានិច្ច ដែលបានរៀបចំឡើង សំរាប់អារក្ស
និងពួកទេវតារបស់វាចុះ ។
២៩ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នករាល់គ្នាថា
គ្មានពេលណាមួយសោះ ដែលយើងបានប្រកាស
ប្រាប់ពីមាត់យើងផ្ទាល់ថា ពួកគេគប្បីវិលមកវិញ ត្បិតកន្លែង
ដែលយើងនៅ នោះពួកគេពុំអាចមកបានឡើយ ព្រោះពួកគេពុំ
មានអំណាចសោះ ។
៣០ ប៉ុន្តែចូរចាំចុះថា គ្រប់អស់ទាំងសេចក្ដីជំនុំជំរះរបស់យើង
នោះពុំបានប្រទានដល់មនុស្សលោកទេ ហើយដូចជាពាក្យទាំង
ឡាយ បានចេញពីមាត់យើងទៅយ៉ាងណា នោះពាក្យទាំងនោះ
នឹងបានសំរេចយ៉ាងនោះដែរ ដើម្បីឲ្យពួកអ្នកមុនទៅជាក្រោយ
ហើយដើម្បី ឲ្យពួកអ្នកក្រោយទៅជាមុន ក្នុងគ្រប់អ្វីៗទាំងអស់
ដែលយើងបានបង្កើតមក ដោយសារព្រះបន្ទូលនៃព្រះចេស្ដា
របស់យើង ដែលជាព្រះ ចេស្ដានៃព្រះវិញ្ញាណរបស់យើង ។
៣១ ត្បិតដោយសារព្រះចេស្ដានៃព្រះវិញ្ញាណរបស់យើង
នោះយើងបានបង្កើតរបស់ទាំងនោះ មែនហើយ គឺគ្រប់ទាំងអស់
ទាំងខាង វិញ្ញាណ និងខាងសាច់ឈាមផង ——
៣២ ទីមួយ ខាងវិញ្ញាណ រួចទីពីរ ខាងសាច់ឈាម ដែលត្រូវ
ជាដើមដំបូងនៃកិច្ចការរបស់យើង; ហើយជាថ្មីទៀត ទីមួយ ខាង
សាច់ឈាម ហើយទីពីរ ខាងវិញ្ញាណ ដែលត្រូវជា
ចុងក្រោយបំផុត នៃកិច្ចការរបស់យើង ——
៣៣ ដោយប្រាប់ដល់អ្នករាល់គ្នា ប្រយោជន៍ឲ្យអ្នករាល់គ្នា
អាចយល់តាមធម្មតា ប៉ុន្តែចំពោះរូបយើងវិញ កិច្ចការ
របស់យើងពុំមានចុង បំផុត ឬដើមដំបូងឡើយ; ប៉ុន្តែការណ៍
នេះត្រូវបានប្រទានដល់អ្នករាល់គ្នា ប្រយោជន៍ឲ្យអ្នករាល់គ្នាអាច
បានយល់ ពីព្រោះអ្នករាល់គ្នា បានសូមពីយើង ហើយបាន
យល់ព្រមព្រៀងគ្នា ។
៣៤ ហេតុដូច្នោះហើយ យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា
អស់ទាំងរបស់របរគ្រប់យ៉ាង គឺជាវិញ្ញាណចំពោះយើង ហើយ
គ្មានពេល ណាមួយ ដែលយើងបានប្រទានដល់អ្នក នូវក្រិត្យវិន័យ
ណាមួយ ដែលត្រូវជារបស់ខាងសាច់ឈាមនោះឡើយ; ពុំមែន

២២ *ក* ស.ប. សហស្សវត្សរ៍.
*ខ* វិវ. ២០:៣;
គ. និង ស. ៤៣:៣០–៣១;
៨៨:១១០–១១១.
២៣ *ក* ម៉ាថាយ ២៤:១៤.
ស.ប. ពិភពលោក ——
ចុងបំផុតនៃផែនដី.
*ខ* ម៉ាថាយ ២៤:៣៥;
យ.ស. —— ម៉ាថាយ ១:៣៥.
*គ* ស.ប. ផែនដី ——
ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
២៤ *ក* វិវ. ២១:១–៤.
២៥ *ក* អាលម៉ា ៤០:២៣.
២៦ *ក* ស.ប. អ័ដាម; មីកែល.
*ខ* ស.ប. មហាទេវតា.
*គ* ១ កូរិន. ១៥:៥២–៥៥.
*ឃ* ស.ប. អមតៈ, អមតភាព;
ដំណើររស់ឡើងវិញ.
*ង* យ៉ូហាន ៥:២៨–២៩.
២៧ *ក* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ខ* ម៉ាថាយ ២៥:៣៣.
ស.ប. សេចក្ដីជំនុំជំរះ
ចុងក្រោយបំផុត.
២៨ *ក* ម៉ាថាយ ២៥:៤១;
គ. និង ស. ២៩:៤១.
*ខ* គ. និង ស. ៤៣:៣៣.
*គ* ស.ប. អារក្ស.
២៩ *ក* យ៉ូហាន ៧:៣៤;
គ. និង ស. ៧៦:១១២.
៣០ *ក* ម៉ាថាយ ១៩:៣០;
១ នីហ្វៃ ១៣:៤២.
៣១ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* ម៉ូសេ ៣:៤–៥.
៣២ *ក* ស.ប. ការបង្កបង្កើតខាងវិញ្ញាណ.
៣៣ *ក* ទំនុក. ១១១:៧–៨; ម៉ូសេ ១:៤.

មនុស្សណាមួយ ឬកូនចៅមនុស្សណាដែរ; ពុំមែនលោកអ័ដាម ជាឪពុករបស់អ្នក ដែលយើងបានបង្កើតមកនោះ ។

៣៥ មើលចុះ យើងបានប្រទានដល់លោកថា លោកត្រូវធ្វើជាភ្នាក់ងារចំពោះខ្លួនលោកផ្ទាល់ ហើយយើងបានប្រទានបញ្ញត្តិដល់លោក ប៉ុន្តែ យើងពុំបានប្រទានបញ្ញត្តិខាងសាច់ឈាមណាមួយដល់លោកឡើយ ត្បិតបញ្ញត្តិរបស់យើងទាំងឡាយ ជារបស់ខាងវិញ្ញាណ; បញ្ញត្តិទាំងនោះ ពុំមែនជារបស់ខាងធម្មជាតិ ឬខាងសាច់ឈាមទេ ពុំមែនជាខាងរូបកាយ ឬខាងកាមរាគដែរ ។

៣៦ ហើយហេតុការណ៍បានកើតឡើងថា លោកអ័ដាមដោយត្រូវបានល្បួងដោយអារក្ស — ត្បិតមើលចុះ មានអារក្សមុនមានអ័ដាម ត្បិតវាបានបះបោរទាស់នឹងយើង ដោយទូលថា៖ សូមប្រទានដល់ទូលបង្គំនូវភាពរុងរឿងរបស់ព្រះអង្គ ដែលជាព្រះចេស្ដារបស់យើង; ហើយវាបានបំបែរមួយភាគបីនៃពួកពលបរិវារស្ថានសួគ៌ចេញពីយើងផង ពីព្រោះតែសិទ្ធិជ្រើសរើសរបស់ពួកគេ;

៣៧ ហើយពួកគេត្រូវបានទំលាក់ចុះ ហើយក៏មានអារក្ស និងពួកទេវតារបស់វាយ៉ាងដូច្នោះហើយ;

៣៨ ហើយមើលចុះ មានកន្លែងមួយដែលបានរៀបចំទុកសំរាប់ពួកគេ ចាប់តាំងពីដើមដំបូងមកម្ល៉េះ ជាកន្លែងហៅថាស្ថាននរក ។

៣៩ ហើយជាការចាំបាច់ណាស់ថា អារក្សគួរល្បួងកូនចៅមនុស្ស បើពុំនោះសោតទេ ពួកគេពុំអាចធ្វើជាភ្នាក់ងារចំពោះខ្លួនបានឡើយ ត្បិតបើសិនជាពួកគេពុំដែលមានការល្វីងជូរចត់សោះឡើយ នោះពួកគេក៏ពុំអាចស្គាល់ការផ្អែមល្ហែមដែរ —

៤០ ដូច្នោះហើយ ហេតុការណ៍បានកើតឡើងថា អារក្សបានល្បួងលោកអ័ដាម ហើយលោកក៏បានទទួលទានផ្លែហាមឃាត់ ហើយ បានរំលងលើព្រះបញ្ញត្តិ ដោយសារការនោះហើយ បានជាលោកបានក្លាយទៅជានៅក្រោមបំណងនៃអារក្ស ពីព្រោះលោកបាន បណ្ដោយទៅតាមសេចក្ដីល្បួង ។

៤១ ដូច្នោះហើយ យើង ជាព្រះអម្ចាស់ដ៏ជាព្រះ បានបណ្ដាលឲ្យលោកត្រូវដេញចេញពីសួនច្បារអេដែន គឺចេញពីវត្តមានរបស់យើង ពីព្រោះតែការរំលងរបស់លោក ដោយសារការនោះហើយ បានជាលោកបានក្លាយទៅជាស្លាប់ខាងវិញ្ញាណ ដែលជាសេចក្ដីស្លាប់ ទី១ គឺជាសេចក្ដីស្លាប់ដដែល ដែលជាសេចក្ដីស្លាប់ចុងក្រោយបំផុត ដែលជាសេចក្ដីស្លាប់ខាងវិញ្ញាណ ដែលនឹងត្រូវកាត់ទោសមកលើ ពួកទុច្ចរិត ក្នុងកាលយើងមានបន្ទូលថា៖ អ្នករាល់គ្នាដែលត្រូវបណ្ដាសាអើយ ចូរចេញទៅ ។

៤២ ប៉ុន្តែមើលចុះ យើងប្រាប់អ្នកថា យើងជាព្រះអម្ចាស់ដ៏ជាព្រះ បានប្រទានដល់លោកអ័ដាម និងដល់ពូជលោកថា ពួកគេមិនត្រូវ ស្លាប់ ដូចជាសេចក្ដីស្លាប់ខាងសាច់ឈាមទេ រហូតដល់យើង ជាព្រះអម្ចាស់ដ៏ជាព្រះ នឹងចាត់ពួកទេវតាឲ្យមកប្រកាសប្រាប់ដល់ពួកគេ អំពីការ ប្រែចិត្ត និងសេចក្ដីប្រោសលោះ តាមរយៈសេចក្ដីជំនឿជឿដល់ព្រះនាម នៃបុត្រាបង្កើតតែមួយរបស់យើងសិន ។

៤៣ ហើយយើង ជាព្រះអម្ចាស់ដ៏ជាព្រះ បានកំណត់ដល់មនុស្ស នូវពេលវេលានៃការសាកល្បងរបស់គេយ៉ាងដូច្នោះហើយ — ប្រយោជន៍ឲ្យគេអាចបានប្រោសអមតភាពទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ដោយសារសេចក្ដីស្លាប់ខាងធម្មជាតិរបស់គេ គឺចំពោះ អស់អ្នកណាដែលនឹងជឿ;

៣៥ *ក* ស.ប. សិទ្ធិជ្រើសរើស.
*ខ* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
៣៦ *ក* គ. និង ស. ៧៦:២៥–២៦; ម៉ូសេ ៤:១–៤.
*ខ* ស.ប. ក្រុមប្រឹក្សានៅស្ថានសួគ៌.
*គ* ស.ប. គោរពប្រតិបត្តិ.
*ឃ* អេសាយ ១៤:១២–១៤; គ. និង ស. ៧៦:២៨–២៩.
*ង* វិវ. ១២:៣–៤.
*ច* គ. និង ស. ៣៨:១; ៤៥:១. ស.ប. ជីវិតមុនផែនដី.
*ឆ* ស.ប. សិទ្ធិជ្រើសរើស.
៣៧ *ក* ស.ប. អារក្ស.
*ខ* ២ ពេត្រុស ២:៤; យូដាស ១:៦; ម៉ូសេ ៧:២៦. ស.ប. ពួកទេវតា.
៣៨ *ក* ស.ប. ស្ថាននរក.
៣៩ *ក* ម៉ូសេ ៤:៣–៤. ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* ម៉ូសេ ៦:៥៥.
៤០ *ក* លោកុ. ៣:៦; ម៉ូសេ ៤:៧–១៣.
*ខ* ២ នីហ្វៃ ១០:២៤; ម៉ូសាយ ១៦:៣–៥; អាលម៉ា ៥:៤១–៤២.
៤១ *ក* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
*ខ* ស.ប. អេដែន.
*គ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
*ឃ* អាលម៉ា ៤០:២៦.
*ង* គ. និង ស. ២៩:២៧–២៨; ៧៦:៣១–៣៩.
៤២ *ក* ២ នីហ្វៃ ២:២១. ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
*ខ* អាលម៉ា ១២:២៨–៣០.
*គ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ឃ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ង* ម៉ូសេ ៥:៦–៨.
៤៣ *ក* អាលម៉ា ១២:២៤; ៤២:១០.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* ម៉ូសេ ១:៣៩. ស.ប. អមតៈ, អមតភាព.
*ឃ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.

៤៤ ហើយពួកអ្នកណាដែលពុំជឿ ទៅរក[ក]សេចក្ដីផាប់ទោសដ៏នៅអស់កល្បជានិច្ច ត្បិតពួកគេពុំអាចបានប្រោសលោះឲ្យរួចផុត ពីការ ធ្លាក់ខាងវិញ្ញាណរបស់ពួកគេបានឡើយ ពីព្រោះពួកគេពុំបានប្រែចិត្តទេ;

៤៥ ត្បិតពួកគេស្រឡាញ់សេចក្ដីងងឹត ជាជាងពន្លឺ ពីព្រោះ[ក]អំពើរបស់ពួកគេសុទ្ធតែអាក្រក់ ហើយពួកគេបានទទួល[ខ]ឈ្នួលពីអ្នកណា ដែលពួកគេចុះធ្វើតាម ។

៤៦ ប៉ុន្តែមើលចុះ យើងប្រាប់អ្នករាល់គ្នាថា [ក]កូនក្មេងតូចៗត្រូវ[ខ]បានប្រោសលោះ ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ តាមរយៈព្រះរាជ បុត្រាបង្កើតតែមួយរបស់យើង;

៤៧ ដូច្នោះហើយ ពួកគេពុំអាចធ្វើបាបបានទេ ត្បិតអំណាចពុំបានប្រទានឲ្យអារក្សសាតាំង ដើម្បីទៅ[ក]ល្បួងកូនក្មេងតូចៗទេ លុះត្រា ពួកគេចាប់ផ្ដើម[ខ]ទទួលការខុសត្រូវ នៅចំពោះយើងសិន;

៤៨ ត្បិតត្រូវបានប្រទានដល់ពួកគេ ដូចដែលយើងសព្វព្រះហឫទ័យ គឺតាមបំណងចិត្តរបស់យើងផ្ទាល់ ដើម្បីឲ្យរបស់ដ៏ធំៗអាចតម្រូវពីដៃ នៃ[ក]ឳពុករបស់ពួកគេ ។

៤៩ ហើយជាថ្មីទៀត យើងប្រាប់អ្នករាល់គ្នាថា អស់អ្នកណាដែលមានចំណេះវិជ្ជា តើយើងពុំបានបញ្ជាឲ្យប្រែចិត្តទេឬអី ?

៥០ ហើយអ្នកណាដែលគ្មាន[ក]យោបល់ នោះនៅក្នុងយើងដើម្បីធ្វើតាមអ្វីដែលបានចែងទុក ។ ហើយឥឡូវ យើងមិនប្រកាស ប្រាប់អ្នកទៀតទេ នៅពេលនេះ ។ អាម៉ែន ៕

កណ្ឌទី ៣០

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ ដាវីឌ វិតមើរ, ពេត្រុស វិតមើរ ជុញ៉ូរ, និង យ៉ូហាន វិតមើរ នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែកញ្ញា ឆ្នាំ១៨៣០ បន្ទាប់ពីសន្និសីទបីថ្ងៃ នៅភូមិហ្វាយែត តែមុនពួកអែលឌើរនៃសាសនាចក្រ បានបែកគ្នារៀងៗខ្លួន (*History of the Church*, ១:១១៥–១១៦)* ។ *មុនដំបូង វត្ថុនេះត្រូវបានបោះពុម្ពផ្សាយជាវិវរណៈបី; វាត្រូវបានបង្រួមគ្នាចូលតែមួយ ដោយព្យាការី សំរាប់ការបោះពុម្ពគោលលទ្ធិ និងសេចក្ដីសញ្ញា ឆ្នាំ១៨៣៥ ។*

*១–៤, ដាវីឌ វិតមើរ ត្រូវបានបន្ទោស ព្រោះការខកខាន ដើម្បីបំរើដោយមានចិត្តព្យាយាម; ៥–៨, ពេត្រុស វិតមើរ ជុញ៉ូរ ត្រូវទៅធ្វើ បេសកកម្មជាមួយនឹង អូលីវើរ ខៅឌើរី ចំពោះពួកសាសន៍លេមិន; ៩–១១, យ៉ូហាន វិតមើរ ត្រូវបានហៅឲ្យទៅផ្សាយដំណឹងល្អ ។*

មើលចុះ [ក]ដាវីឌអើយ យើងប្រាប់អ្នកថា អ្នកបាន[ខ]ខ្លាចមនុស្ស ហើយពុំបាន[គ]ពឹងលើយើងដើម្បីកម្លាំង ដូចដែលអ្នកគួរធ្វើនោះទេ ។

២ ប៉ុន្តែគំនិតរបស់អ្នកបានគិតពីរបស់ផងទាំងឡាយនៃ[ក]ផែនដីច្រើនជាងពីរបស់ផងទាំងឡាយនៃយើង ជាអ្នកបង្កើតរបស់អ្នក ហើយពីការងារបំរើ ដែលអ្នកត្រូវបានហៅឲ្យធ្វើ; ហើយអ្នកពុំបានស្ដាប់តាមព្រះវិញ្ញាណរបស់យើង និងចំពោះពួកអ្នកដែលបានតែង តាំងលើអ្នកឡើយ ប៉ុន្តែត្រូវបានបបួលដោយពួកអ្នកដែលយើងពុំបានបញ្ជាទៅវិញ ។

៣ ដូច្នោះហើយ អ្នកត្រូវទុកឲ្យស្មើសួមពីដៃយើងដោយខ្លួនអ្នក ហើយឲ្យ[ក]ពិចារណាគិតអំពីរបស់ទាំងឡាយដែលអ្នកបានទទួល ។

៤ ហើយទីលំនៅរបស់អ្នកត្រូវនៅឯផ្ទះរបស់ឳពុកអ្នក លុះត្រាយើងប្រទានបញ្ញត្តិទាំងឡាយដល់អ្នកថែមទៀត ។ ហើយ

៤៤ *ក* គ. និង ស. ១៩:៧–១២.
ស.ប. សេចក្ដីផាប់ទោស.
៤៥ *ក* យ៉ូហាន ៣:១៨–២០;
គ. និង ស. ៩៣:៣១–៣២.
*ខ* ម៉ូសាយ ២:៣២–៣៣;
អាលម៉ា ៣:២៦–២៧;
៥:៤១–៤២; ៣០:៦០.
៤៦ *ក* ម៉ូរ៉ូណៃ ៨:៨, ១២;
គ. និង ស. ៩៣:៣៨.
ស.ប. កូនក្មេង, ពួកកូនក្មេង.
*ខ* គ. និង ស. ៧៤:៧.
ស.ប. ប្រោសលោះ,
បានប្រោសលោះ,
សេចក្ដីប្រោសលោះ.
៤៧ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* ស.ប. ទទួលខុសត្រូវ,
ចេះទទួលខុសត្រូវ,
ការទទួលខុសត្រូវ.
៤៨ *ក* គ. និង ស. ៦៨:២៥.
៥០ *ក* គ. និង ស. ១៣៧:៧–១០.
ស.ប. យោបល់.
**៣០** ១ *ក* ស.ប. វិតមើរ, ដាវីឌ.
*ខ* កិច្ចការ ៥:២៩.
*គ* ២ របា. ១៦:៧–៩.
២ *ក* គ. និង ស. ២៥:១០.
៣ *ក* ស.ប. រំពឹងគិត.

អ្នកត្រូវធ្វើ [ក]ការងារបំរើនៅក្នុងសាសនាចក្រ និងនៅចំពោះ
ពិភពលោក និងនៅក្នុងភូមិភាគជុំវិញ ។ អាម៉ែន ។
៥ មើលចុះ [ក]ពេត្រុសអើយ យើងប្រាប់អ្នកថា អ្នកត្រូវ
[ខ]ធ្វើដំណើរជាមួយនឹងអូលីវើរ ជាបងប្អូនអ្នក; [គ]ត្បិតពេលវេលាបាន
មកដល់ហើយ គឺជាការចាំបាច់ដល់យើង ដែលអ្នកត្រូវបើកមាត់
របស់អ្នក ដើម្បីប្រកាសប្រាប់ពីដំណឹងល្អរបស់យើង; ដូច្នេះហើយ
ចូរកុំខ្លាចអ្វី ប៉ុន្តែចូរ ស្ដាប់តាមពាក្យសំដី និង[ឃ]ពាក្យដំបូន្មានពី
បងប្អូនអ្នក ដែលគាត់នឹងឲ្យដល់អ្នកចុះ ។
៦ ហើយក្នុងគ្រប់ទាំងសេចក្ដីទុក្ខវេទនារបស់គាត់ នោះ
អ្នកក៏រងទុក្ខដែរ ចូរដំរង់ចិត្តឡើងមកឯយើង ដោយនូវការ
អធិស្ឋាន និងសេចក្ដី ជំនឿ សំរាប់ការរំដោះដល់អ្នក និងគាត់
ត្បិតយើងបានប្រទានអំណាចដល់គាត់ ដើម្បីស្ថាបនា[ក]សាសនា
ចក្ររបស់យើងឡើង នៅ ក្នុងចំណោម[ខ]ពួកសាសន៍លេមិន;
៧ ហើយយើងពុំបានតាំងអ្នកណា ឲ្យធ្វើជាទីប្រឹក្សា[ក]ពីលើ
គាត់នៅក្នុងសាសនាចក្រ អំពីកិច្ចការខាងសាសនាចក្រឡើយ
លើកលែងតែ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាបងប្អូនគាត់ ។
៨ ដូច្នោះហើយ ចូរស្ដាប់តាមរបស់ទាំងនេះ ហើយចូរមាន
ចិត្តព្យាយាម ក្នុងការកាន់តាមបញ្ញត្តិទាំងឡាយរបស់យើងចុះ
នោះអ្នកនឹង បានពរដល់ជីវិតដ៏នៅអស់កល្បជានិច្ច ។ អាម៉ែន ។
៩ មើលចុះ យ៉ូហាន ជាអ្នកបំរើរបស់យើងអើយ យើងប្រាប់
អ្នកថា អ្នកត្រូវចាប់ផ្ដើមពីពេលនេះតទៅ [ក]ដើម្បីប្រកាស
ប្រាប់ពីដំណឹងល្អ របស់យើង ហាក់ដូចជាដោយ[ខ]សម្លេងត្រែ ។
១០ ហើយការងាររបស់អ្នក ត្រូវធ្វើនៅផ្ទះរបស់ភីលីពបើររោ
ជាបងប្អូនរបស់អ្នក និងនៅក្នុងភូមិភាគជុំវិញ មែនហើយ
នៅទីកន្លែង ណាក៏ដោយ ដែលមនុស្សអាចឮអ្នក លុះត្រាយើង
បញ្ជាដល់អ្នក ឲ្យទៅពីទីនោះ ។
១១ ហើយការងារទាំងអស់របស់អ្នកត្រូវធ្វើនៅក្នុងក្រុងស៊ីយ៉ូន
ដោយអស់ពីព្រលឹងរបស់អ្នក ចាប់តាំងពីពេលនេះតទៅ; មែន
ហើយ អ្នកត្រូវហ៊ានបើកមាត់របស់អ្នក ដោយនូវគតិរបស់យើង
[ក]ដោយមិន[ខ]ខ្លាចដល់អ្វីដែលមនុស្សអាចធ្វើឡើយ [គ]ព្រោះយើងនៅជា
មួយអ្នក ។ អាម៉ែន ៕

## កណ្ឌទី ៣១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ ថូម៉ាស ប៊ី ម៉ាស ខែកញ្ញា ឆ្នាំ១៨៣០ (*History of the Church, *១:១១៥–១១៧)* ។ *នៅគ្រាឆាប់ៗបន្ទាប់ពីសន្និសីទនៃសាសនាចក្រ (សូមមើលចំណងជើងនៃកណ្ឌទី ៣០)* ។ *ថូម៉ាស ប៊ី ម៉ាស បានទទួលបុណ្យជ្រមុជទឹកនៅដើមខែ ហើយបានទទួលការតែងតាំងឲ្យធ្វើជាអែលឌើរ ក្នុងសាសនាចក្រ មុនវិវរណៈនេះត្រូវ បានប្រទានមក* ។

*១–៦, ថូម៉ាស ប៊ី ម៉ាស ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ហើយត្រូវបានបញ្ជាក់ថាគ្រួសាររបស់គាត់សុខសប្បាយ; ៧–១៣, គាត់ត្រូវ បានទូន្មានឲ្យមានចិត្តអត់ធន់ អធិស្ឋានជានិច្ច ហើយឲ្យធ្វើតាមព្រះដ៏ជាជំនួយ* ។

[ក]ថូម៉ាស បុត្ររបស់យើងអើយ អ្នកមានពរហើយ ពីព្រោះមក
ពីសេចក្ដីជំនឿរបស់អ្នក នៅក្នុងកិច្ចការរបស់យើង ។
២ មើលចុះ អ្នកបានមានសេចក្ដីទុក្ខវេទនាជាច្រើន ពីព្រោះតែ
គ្រួសាររបស់អ្នក; ទោះជាយ៉ាងណាក៏ដោយ យើងនឹងប្រទានពរ
ដល់អ្នក និងគ្រួសាររបស់អ្នក មែនហើយ គឺកូនតូចៗរបស់អ្នក;
ហើយថ្ងៃនឹងមកដល់ ដែលពួកគេនឹងជឿ ហើយដឹងសេចក្ដីពិត
ហើយនឹងបានរួម តែមួយ ជាមួយនឹងអ្នក នៅក្នុងសាសនាចក្រ
របស់យើង ។
៣ ចូរលើកចិត្តអ្នកឡើង ហើយអរសប្បាយចុះ ត្បិតម៉ោងនៃ

៤ *ក* ស.ប. ធ្វើការងារបំរើ; ការបំរើ.
៥ *ក* ស.ប. វិតមើរ, ពេត្រុស ជុញ្ញ័រ.
*ខ* គ. និង ស. ៣២:១–៣.
*គ* គ. និង ស. ១១:១៥.
*ឃ* ស.ប. ពាក្យទូន្មាន (ន.); ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ.
៦ *ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ.
*ខ* គ. និង ស. ៣:២០; ៤៩:២៤. ស.ប. ពួកសាសន៍លេមិន.
៧ *ក* គ. និង ស. ២០:២–៣.
៩ *ក* គ. និង ស. ១៥:៦.
*ខ* គ. និង ស. ៣៣:២.
១១ *ក* ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន; សេចក្ដីកោតខ្លាច.
*ខ* អេសាយ ៥១:៧.
*គ* ម៉ាថាយ ២៨:១៩–២០.
**៣១** ១*ក* ស.ប. ម៉ាស, ថូម៉ាស ប៊ី.

បេសកកម្មរបស់អ្នកមកដល់ហើយ ហើយអណ្ដាតរបស់អ្នកនឹងបានរសាយ ហើយអ្នកនឹងប្រកាស[ក]ដំណឹងដ៏រីករាយ នៃសេចក្ដីអំណរដ៏ធំ ប្រាប់ដល់តំណមនុស្សនេះ ។
៤ [ក]អ្នកនឹងប្រកាសប្រាប់ពីអ្វីៗ ដែលបានបើកសំដែងដល់យ៉ូសែប ស្ម៊ីធ ជុញ្ញ៉រ ជាអ្នកបំរើរបស់យើង ។ អ្នកនឹងចាប់[ខ]ផ្ដើមផ្សាយពីពេល នេះតទៅ មែនហើយ គឺច្រូតស្រែដែលបានសសំព្រះល្អមនឹងឆេះ ។
៥ ដូច្នេះហើយ ចូរ[ក]លូកកណ្ដៀវរបស់អ្នក ដោយអស់ពីព្រលឹងរបស់អ្នក ហើយបាបទាំងឡាយរបស់អ្នក ត្រូវបាន[ខ]អត់ទោសឲ្យហើយ ហើយអ្នកនឹងបាន[គ]ផ្ទុកកណ្ដាប់ស្រូវពីលើខ្នងរបស់អ្នក ព្រោះអ្នកដែល[ឃ]ធ្វើការសមនឹងបានឈ្នួលរបស់ខ្លួន ។ ហេតុដូច្នោះហើយ គ្រួសារ របស់អ្នកនឹងបានរស់នៅ ។
៦ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា ចូរចេញពីពួកគេទៅគ្រាន់តែមួយរយៈខ្លី ហើយប្រកាសប្រាប់ពីព្រះបន្ទូលរបស់យើងប៉ុណ្ណោះ ហើយយើងនឹងរៀបចំកន្លែងមួយសំរាប់ពួកគេ ។
៧ មែនហើយ យើងនឹង[ក]បើកចិត្តនៃមនុស្សមនា ហើយពួកគេនឹងទទួលអ្នក ។ ហើយយើងនឹងតាំងសាសនាចក្រមួយឡើងដោយសារ ស្នាដៃរបស់អ្នក;
៨ ហើយអ្នកនឹង[ក]ចំរើនកម្លាំងពួកគេ ហើយរៀបចំពួកគេសំរាប់ពេលវេលា ក្នុងកាលពួកគេនឹងត្រូវបានប្រមូលគ្នា ។
៩ ចូរមាន[ក]ចិត្តអត់ធន់ក្នុង[ខ]ការឈឺចាប់ ចូរកុំជេរប្រមាថពួកអ្នកណាដែលជេរប្រមាថឡើយ ។ ចូរត្រួតត្រា[គ]ផ្ទះសំបែងរបស់អ្នកដោយភាព ស្លូតបូត ហើយចូរតាំងចិត្តឲ្យបានខ្ជាប់ខ្ជួនចុះ ។
១០ មើលចុះ យើងប្រាប់អ្នកថា អ្នកនឹងត្រូវទៅជាគ្រូពេទ្យចំពោះសាសនាចក្រ ប៉ុន្តែពុំមែនចំពោះពិភពលោកទេ ក្បិតពួកគេនឹងមិន ទទួលអ្នកឡើយ ។
១១ ចូរចេញដំណើរទៅតាមទីណា តាមព្រះហឫទ័យរបស់យើងចុះ ហើយនឹងត្រូវបានប្រទានដល់អ្នក ដោយ[ក]ព្រះដ៏ជាជំនួយ នូវអ្វីដែល អ្នកត្រូវធ្វើ និងទីណាដែលអ្នកត្រូវទៅ ។
១២ ចូរ[ក]អធិស្ឋានជានិច្ច ក្រែងអ្នកចូលក្នុង[ខ]សេចក្ដីល្បួង ហើយបាត់បង់រង្វាន់របស់អ្នក ។
១៣ ចូរមានចិត្ត[ក]ស្មោះត្រង់រហូតដល់ទីបំផុត ហើយមើលន៏[ខ]យើងនៅជាមួយនឹងអ្នក ។ ព្រះបន្ទូលទាំងនេះ ពុំមែនមកពីមនុស្ស ឬមកពីមនុស្សលោកទេ តែមកពីយើង គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះរបស់អ្នក [គ]តាមបំណងព្រះហឫទ័យនៃព្រះវរបិតា ។ អាម៉ែន ៕

## កណ្ឌទី ៣២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ ប៉ាលី ភី ប្រាត្ត និង សៃបា ភីតើសុន ខែតុលា ឆ្នាំ១៨៣០ (*History of the Church*, ១:១១៨–១២០) ។ បំណង និងក្ដីប៉ងប្រាថ្នាដ៏ធំដែលពួកអែលឌើរមានអារម្មណ៍អំពីពួកសាសន៍ លេមិន ជាពួកដែលសមាជិកសាសនាចក្របានរៀនតាមរយៈព្រះគម្ពីរមរមនថានឹងត្រូវទទួលព្រះពរទាំងឡាយ ។ ម្ល៉ោះហើយ ការទូលអង្វរត្រូវបានធ្វើឡើង សូមឲ្យព្រះអម្ចាស់ប្រាប់ពីព្រះហឫទ័យរបស់ទ្រង់ ថាតើគួរចាត់ពួកអែលឌើរឲ្យទៅរកពួកឥណ្ឌាសាសន៍អាមេរិកាំងដើម នៅទិសខាងលិច នៅពេលនេះឬអី ។ វិវរណៈក៏បានទទួលមកតាមក្រោយ ។*

*១–៣, ប៉ាលី ភី ប្រាត្ត និង សៃបា ភីតើសុន ត្រូវបានហៅឲ្យទៅផ្សាយប្រាប់ពួកសាសន៍លេមិន ហើយឲ្យទៅជាមួយនឹង អូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ្ញ័រ; ៤–៥, ពួកគេត្រូវអធិស្ឋានសូមយោបល់ពីព្រះគម្ពីរ ។*

៣ *ក* អេសាយ ៥២:៧;
លូកា ២:១០–១១;
ម៉ូសាយ ៣:៣–៥.
៤ *ក* ម៉ូសាយ ១៨:១៩;
គ. និង ស. ៤២:១២; ៥២:៣៦.
*ខ* គ. និង ស. ៤:៤–៦.
៥ *ក* វិវរ. ១៤:១៥.
*ខ* ស.ប. អត់ទោស, អភ័យទោស.
*គ* គ. និង ស. ៧៩:៣.
*ឃ* លូកា ១០:៣–១១;
គ. និង ស. ៧៥:២៤.
៧ *ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
៨ *ក* គ. និង ស. ៨១:៥; ១០៨:៧.
៩ *ក* ស.ប. សេចក្ដីអត់ធន់.
*ខ* ស.ប. សេចក្ដីទំនាស់.
*គ* ស.ប. គ្រួសារ — កាតព្វកិច្ចរបស់ឪពុកម្ដាយ.
១១ *ក* ស.ប. ព្រះដ៏ជាជំនួយ;
ព្រះវិញ្ញាណបរិសុទ្ធ.
១២ *ក* ៣ នីហ្វៃ ១៨:១៧–២១.
ស.ប. ការអធិស្ឋាន.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
១៣ *ក* ស.ប. កាន់ខ្ជាប់.
*ខ* ម៉ាថាយ ២៨:២០.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិទ្ធិអំណាច.

ហើយឥឡូវនេះស្ដីអំពី [ក]ប៉ាលី ភី ប្រាត្ត ជាអ្នកបំរើរបស់យើង មើលចុះ យើងប្រាប់គាត់ថា ដរាបណាដែលយើងមានព្រះជន្មរស់នៅ នោះគាត់នឹងត្រូវប្រកាសប្រាប់ពីដំណឹងល្អរបស់យើង ហើយ[ខ]រៀនអំពីយើង ហើយចូរមានចិត្តស្លូតបូត និងសុភាពចុះ ។

២ ហើយអ្វីដែលយើងនឹងតាំងដល់គាត់ គឺថាគាត់[ក]ត្រូវទៅជាមួយនឹង អូលីវើរ ខៅឌើរី និង ពេត្រុស វិតមើរ ជុញ៉ែរ ជាពួកអ្នកបំរើរបស់ យើង គឺចូលទៅក្នុងទីរហោស្ថាន ក្នុងចំណោម[ខ]ពួកសាសន៍លេមិន ។

៣ ហើយ [ក]សែបា ភីតើសុន ក៏ត្រូវទៅជាមួយនឹងពួកគេដែរ ហើយយើងផ្ទាល់ក៏នឹងយាងទៅជាមួយនឹងពួកគេ ហើយនឹងនៅ[ខ]កណ្ដាល ពួកគេ; ហើយយើងជា[គ]ព្រះគាំទ្រពួកគេចំពោះព្រះវរបិតា ហើយគ្មានអ្វីនឹងអាចឈ្នះលើពួកគេបានឡើយ ។

៤ ហើយពួកគេនឹង[ក]ស្ដាប់តាមអ្វីដែលបានចែងទុក ហើយនឹងមិនស្មានថាមាន[ខ]វិវរណៈឯណាទៀតឡើយ ហើយពួកគេនឹងត្រូវអធិស្ឋាន ជានិច្ច ដើម្បីយើងអាច[គ]លាតត្រដាងនូវអ្វីដដែល ឲ្យពួកគេបាន[ឃ]យល់ ។

៥ ហើយពួកគេនឹងត្រូវស្ដាប់តាមព្រះបន្ទូលទាំងនេះ ហើយមិនត្រូវប្រហែសឡើយ ហើយយើងនឹងប្រទានពរដល់ពួកគេ ។ អាម៉ែន ៕

## កណ្ឌទី ៣៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី ចំពោះ អែសរ៉ា ធេយ័រ និង ណូវត្រុព ស៊្វីត នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែតុលា ឆ្នាំ១៨៣០ (*History of the Church*, ១:១២៦–១២៧) ។ ក្នុងការកត់វិវរណៈនេះ ព្យាការីបាន បញ្ជាក់ថា៖ «. . . ព្រះអម្ចាស់ទ្រង់ប្រុងប្រៀបជានិច្ច ដើម្បីបង្គាប់ដល់អស់អ្នកណា ដែលព្យាយាមស្វែងរក ដោយនូវសេចក្ដីជំនឿ» (*History of the Church*, *១:១២៦) ។*

*១–៤, ពួកអ្នកធ្វើការត្រូវបានហៅឲ្យប្រកាសប្រាប់ពីដំណឹងល្អនៅម៉ោងទី១១; ៥–៦, សាសនាចក្រត្រូវបានតាំងឡើង ហើយពួកដែល បានរើសតាំង ត្រូវបានប្រមូលគ្នា; ៧–១០, ចូរប្រែចិត្តចុះ ត្បិតនគរស្ថានសួគ៌នៅជិតដៃបង្កើយ; ១១–១៥, សាសនាចក្រត្រូវបានសាង ឡើងនៅលើថ្មដានៃដំណឹងល្អ; ១៦–១៨, ចូរប្រុងប្រៀបចាំការយាងមកនៃប្ដីថ្មោងថ្មីចុះ ។*

មើលចុះ យើងប្រាប់អ្នកថា អែសរ៉ា និង ណូវត្រុព ជាពួកអ្នកបំរើរបស់យើងអើយ ចូរបើកត្រចៀក ហើយស្ដាប់តាមសម្លេងនៃព្រះអម្ចាស់ ជាព្រះរបស់អ្នកចុះ ឯព្រះបន្ទូលរបស់ទ្រង់នោះនៅរស់ ហើយពូកែផង ក៏មុតជាងដាវ[ក]មានមុខពីរ ដើម្បីកាត់សន្លាក់ និងខួរឆ្អឹង ព្រលឹង និងវិញ្ញាណដាច់ពីគ្នា; ហើយពិចារណាអស់ទាំងគំនិតដែលចិត្ត[ខ]គិត ហើយដែលសំរេចដែរ ។

២ ត្បិតប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នករាល់គ្នាត្រូវបានហៅ ឲ្យបន្លឺសម្លេងរបស់អ្នកឡើង ហាក់ដូចជាដោយ[ក]សម្លេងត្រែ ដើម្បីប្រកាសប្រាប់ពីដំណឹងល្អរបស់យើង ដល់តំណមនុស្សវៀច និងខិលខូច ។

៣ ត្បិតមើលចុះ [ក]ស្រែបានសសំព្រុះល្មមច្រូតហើយ; ហើយត្រូវជាម៉ោង[ខ]ទី១១ហើយ ហើយជាពេល[គ]ក្រោយបង្អស់ ដែលយើងនឹងហៅពួកអ្នកធ្វើការ ឲ្យចូលក្នុងចំការទំពាំងបាយជូររបស់យើង ។

៤ ហើយ[ក]ចំការទំពាំងបាយជូររបស់យើងបានក្លាយទៅជា[ខ]ពុករលួយ គ្រប់ទាំងកន្លែងតូចតាចផង; ហើយគ្មានអ្នកណាដែល

**៣២** ១*ក* ស.ប. ប្រាត្ត, ប៉ាលី ប៉ាកើរ.
*ខ* ម៉ាថាយ ១១:២៨–៣០.
២ *ក* គ. និង ស. ២៨:៨; ៣០:៥.
*ខ* គ. និង ស. ៣:១៨–២០.
៣ *ក* គ. និង ស. ៥៨:៦០.
*ខ* ម៉ាថាយ ១៨:២០;
គ. និង ស. ៦:៣២; ៣៨:៧.
*គ* ស.ប. ព្រះដ៏គាំទ្រ.
៤ *ក* ១ នីហ្វៃ ១៥:២៥;
គ. និង ស. ៨៤:៤៣–៤៤.
*ខ* គ. និង ស. ២៨:២.
*គ* យ.ស. — ប្រវត្តិ ១:៧៤.
*ឃ* ស.ប. យោបល់.

**៣៣** ១*ក* ហេព្រើរ ៤:១២;
ហេលេ. ៣:២៩–៣០.
*ខ* អាលម៉ា ១៨:៣២;
គ. និង ស. ៦:១៦.
២ *ក* អេសាយ ៥៨:១.
៣ *ក* យ៉ូហាន ៤:៣៥;
គ. និង ស. ៤:៤; ១២:៣; ១៤:៣.
*ខ* ម៉ាថាយ ២០:១–១៦.
*គ* យ៉ាកុប ៥:៧១;
គ. និង ស. ៤៣:២៨.
៤ *ក* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
*ខ* ២ នីហ្វៃ ២៨:២–១៤;
មរមន ៨:២៨–៤១.

ប្រព្រឹត្តតាម សេចក្ដីសប្បុរសសោះ លើកលែងតែបន្តិចបន្តួច
ប៉ុណ្ណោះ; ហើយពួកគេធ្វើខុសក្នុងគ្រាជាច្រើន ពីព្រោះមកពី
ឧបាយកលផ្ទែកសង្ឃ គឺជាពួកអស់អ្នកដែលមានគំនិតពុក
រលួយ ។
៥ ហើយប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា សាសនា
ចក្រនេះ យើងបានតាំងឡើង ហើយបានហៅឲ្យចេញមក
ពីទីរហោស្ថាន ។
៦ ហើយទើបយើងប្រមូលពួកដែលយើងរើសតាំង ពីទិស
ទាំងបួននៃផែនដី បែបដូច្នោះហើយ គឺអស់មនុស្សជាច្រើនណា
ដែលនឹង ជឿដល់យើង ហើយស្ដាប់តាមសម្លេងរបស់យើង ។
៧ មែនហើយ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា
ស្រែបានសសំព្រុះល្មមច្រូតហើយ ហេតុដូច្នោះហើយ ចូរលូក
កណ្ដៀវរបស់អ្នក ហើយច្រូតដោយអស់ពីពលំ អស់ពីគំនិត
និងអស់ពីកម្លាំងរបស់អ្នកចុះ ។
៨ ចូរបើកមាត់របស់អ្នកចុះ នោះមាត់នឹងបានពោរពេញ ហើយ
អ្នកនឹងបានក្លាយទៅដូចជានីហ្វៃពីបុរាណ ជាអ្នកដែលបានធ្វើដំណើរ
នៅក្នុងទីរហោស្ថាន ចាកចេញពីក្រុងយេរូសាឡិម ។
៩ មែនហើយ ចូរបើកមាត់របស់អ្នកចុះ ហើយចូរកុំសំចៃឡើយ
ហើយអ្នកនឹងបានផ្ទុកកណ្ដាប់ស្រូវពីលើខ្នងរបស់អ្នក ត្បិតមើលន៏
យើងនៅជាមួយនឹងអ្នក ។
១០ មែនហើយ ចូរបើកមាត់របស់អ្នកចុះ ហើយមាត់នឹងបាន
ពោរពេញ ដោយនិយាយថា៖ ចូរប្រែចិត្តចុះ ចូរប្រែចិត្តចុះ
ហើយចូរអ្នក រាល់គ្នារៀបចំផ្លូវទទួលព្រះអម្ចាស់ ហើយតម្រង់
ផ្លូវថ្វាយទ្រង់ចុះ ត្បិតនគរស្ថានសួគ៌នៅជិតដៃបង្កើយ;
១១ មែនហើយ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យ
ជ្រមុជទឹកទាំងអស់គ្នា សំរាប់ការផ្ដាច់បាបទាំងឡាយរបស់អ្នក;
មែនហើយ ចូរទទួលបុណ្យជ្រមុជដោយទឹក ហើយបន្ទាប់មក នឹង
មានបុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ ។
១២ មើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា
នេះជាដំណឹងល្អរបស់យើង; ហើយចូរចងចាំចុះថា ពួកគេនឹង
ត្រូវមានសេចក្ដីជំនឿជឿដល់យើង បើពុំនោះសោតទេ ពួកគេនឹង
ពុំអាចបានសង្គ្រោះឡើយ;
១៣ ហើយនៅលើថ្មដានេះ យើងនឹងស្ថាបនាសាសនាចក្រ
របស់យើង; មែនហើយ នៅលើថ្មដានេះ អ្នករាល់គ្នាត្រូវបាន
ស្ថាបនាឡើង ហើយបើសិនជាអ្នករាល់គ្នានៅខ្ជាប់ខ្ជួន នោះ
ទ្វារនៃស្ថាននរក នឹងពុំដែលឈ្នះលើអ្នកបានឡើយ ។
១៤ ហើយអ្នករាល់គ្នានឹងបានចាំពីមាត្រា និងសេចក្ដីសញ្ញា
ទាំងឡាយនៃសាសនាចក្រ ដើម្បីកាន់តាមរបស់ទាំងនោះ ។
១៥ ហើយអស់អ្នកណាដែលមានសេចក្ដីជំនឿ នោះអ្នកនឹង
ត្រូវបញ្ជាក់នៅក្នុងសាសនាចក្ររបស់យើង ដោយសារការ
ដាក់ដៃលើ ហើយយើងនឹងប្រទានអំណោយទានជាព្រះវិញ្ញាណ
បរិសុទ្ធ មកលើពួកគេ ។
១៦ ហើយព្រះគម្ពីរមរមន និងព្រះគម្ពីរបរិសុទ្ធត្រូវបានប្រទាន
មកពីយើង សំរាប់ការបង្គាប់ដល់អ្នក; ហើយព្រះចេស្ដានៃ
ព្រះវិញ្ញាណ របស់យើងនឹងប្រោសឲ្យរបស់របរទាំងអស់មានជីវិត
ចំរើនឡើងវិញ ។
១៧ ហេតុដូច្នោះហើយ ចូរមានចិត្តស្មោះត្រង់ ដោយ
អធិស្ឋានជានិច្ច ដោយមានចង្កៀងបង្កាត់ ហើយឆេះ ហើយមាន
ប្រេងនៅជាមួយ អ្នកផង ដើម្បីឲ្យអ្នកអាចបានប្រុងប្រៀបជាស្រេច
ក្នុងកាលការយាងមកនៃប្ដីថ្មោងថ្មី —
១៨ ត្បិតមើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា
យើងមកយ៉ាងឆាប់រហ័ស ។ គឺដូច្នោះមែន ។ អាម៉ែន ៕

៤ *គ* រ៉ូម ៣:១២; គ. និង ស. ៣៥:១២.
*ឃ* ២ នីហ្វៃ ២៨:១៤.
*ង* ស.ប. ឧបាយកលផ្ទែកសង្ឃ.
៥ *ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ.
*ខ* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៦ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* ១ នីហ្វៃ ១៩:១៥–១៧.
៨ *ក* គ. និង ស. ៨៨:៨១.
*ខ* ២ នីហ្វៃ ១:២៦–២៨.
៩ *ក* ទំនុក. ១២៦:៦; អាលម៉ា ២៦:៣–៥; គ. និង ស. ៧៥:៥.
១០ *ក* ម៉ាថាយ ៣:១–៣.
១១ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
១២ *ក* ៣ នីហ្វៃ ២៧:១៣–២២.
១៣ *ក* ស.ប. ថ្ម.
*ខ* ម៉ាថាយ ១៦:១៦–១៩; គ. និង ស. ១០:៦៩–៧០.
១៤ *ក* ស្ដីអំពីកណ្ឌទី ២០–២២; គ. និង ស. ៤២:១៣.
១៥ *ក* គ. និង ស. ២០:៤១.
*ខ* ស.ប. ដៃ, ការដាក់.
*គ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
១៦ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* ២ ធីម៉ូ. ៣:១៦.
*គ* យ៉ូហាន ៦:៦៣.
១៧ *ក* ម៉ាថាយ ២៥:១–១៣. ស.ប. ប្ដីថ្មោងថ្មី.
១៨ *ក* វិវរ. ២២:២០. ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.

## កណ្ឌទី ៣៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ អូរសុន ប្រាត្ត នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៨៣០ (*History of the Church, *១:១២៧–១២៨)* ។ *កាលនោះ បងប្រុសប្រាត្តមានអាយុ១៩ឆ្នាំ ។ គាត់ត្រូវបានប្រែ ចិត្តជឿ ហើយបានទទួលបុណ្យជ្រមុជទឹក ក្នុងកាលគាត់បានឮពីការផ្សាយអំពីដំណឹងល្អដែលបានសាងឡើងវិញ ដោយ ប៉ាលី ភី ប្រាត្ត ជាបងប្រុសរបស់គាត់ ប្រាំមួយអាទិត្យមុន ។ វិវរណៈនេះត្រូវបានទទួល នៅក្នុងផ្ទះរបស់ពេត្រុស វិតមើរ ស៊ីញ៉័រ ។*

*១–៤, ពួកអ្នកស្មោះត្រង់ត្រឡប់ទៅជាកូនព្រះ តាមរយៈដង្វាយធួន; ៥–៩, ការផ្សាយដំណឹងល្អ រៀបចំផ្លូវសំរាប់ការយាងមកលើកទីពីរ; ១០–១២, ការព្យាករណ៍មានមកដោយសារព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។*

[ក]អូរសុន ជាបុត្រយើងអើយ ចូរស្ដាប់ និងបានឮ ហើយមើលនូវអ្វីដែលយើង ជាព្រះអម្ចាស់ដ៏ជាព្រះ នឹងមានបន្ទូលមកកាន់អ្នក គឺព្រះ យេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះរបស់អ្នកចុះ;

២ ជា[ក]ពន្លឺ និងជាជីវិតនៃពិភពលោក ជាពន្លឺដែលភ្លឺមកក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ;

៣ ជាអ្នកដែល[ក]ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជា[ខ]ទ្រង់[គ]ប្រទានជីវិតរបស់ទ្រង់ផ្ទាល់ ដើម្បីឲ្យអស់អ្នកណាដែលជឿ អាចបានត្រឡប់ ទៅជា[ឃ]កូនព្រះ ។ ហេតុដូច្នោះហើយ អ្នកជាបុត្ររបស់យើង;

៤ ហើយអ្នក[ក]បានពរហើយ ពីព្រោះអ្នកបានជឿ;

៥ ហើយអ្នកមានពរលើសលែងទៅទៀត ពីព្រោះអ្នក[ក]ត្រូវបានហៅពីយើង ដើម្បីឲ្យទៅផ្សាយដំណឹងល្អរបស់យើង —

៦ ដើម្បីបន្លឺសម្លេងរបស់អ្នកឡើង ហាក់ដូចជាដោយសម្លេងត្រែ គឺបន្លឺសូរកាន់តែតន្លើនខ្លាំងឡើង ហើយ[ក]ស្រែកប្រាប់ពីការប្រែចិត្ត ដល់តំណមនុស្សវៀច និងខិលខូច ដោយរៀបចំផ្លូវទទួលព្រះអម្ចាស់ [ខ]សំរាប់ការយាងមកលើកទីពីររបស់ទ្រង់ ។

៧ ត្បិតមើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា [ក]ពេលវេលាគឺនៅជិតដែលបង្អើយ ដែលយើងនឹងមក[ខ]លើពពក មានទាំងព្រះ ចេស្ដា និងសិរីល្អដ៏ខ្លាំង ។

៨ ហើយនឹងបានទៅជា[ក]ថ្ងៃដ៏ធំ នៅពេលដែលយើងយាងមក ត្បិតអស់ទាំងសាសន៍នឹង[ខ]ត្រូវញាប់ញ័រ ។

៩ ប៉ុន្ដែមុនថ្ងៃដ៏ធំនោះនឹងមកដល់ ថ្ងៃនឹងទៅជាងងឹត ហើយខែនឹងទៅជាឈាម ហើយផ្កាយទាំងឡាយនឹងមិនព្រមភ្លឺឡើយ ហើយខ្លះ នឹងធ្លាក់ចុះ ហើយសេចក្ដីបំផ្លិចបំផ្លាញដ៏ធំនឹងរង់ចាំពួកទុច្ចរិត ។

១០ ហេតុដូច្នោះហើយ ចូរបន្លឺសម្លេងរបស់អ្នកឡើង ហើយចូរ[ក]កុំសំចៃឡើយ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានមានព្រះបន្ទូលហើយ; ដូច្នេះ ចូរព្យាករចុះ ហើយការព្យាករណ៍នោះនឹង[ខ]ត្រូវបានប្រទានឲ្យ ដោយសារព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

១១ ហើយបើសិនជាអ្នកមានចិត្តស្មោះត្រង់ មើលចុះ យើងនៅជាមួយនឹងអ្នក លុះត្រាយើងយាងមក —

១២ ហើយប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា យើងយាងមកយ៉ាងឆាប់រហ័ស ។ យើងជាព្រះអម្ចាស់របស់អ្នក និងជាព្រះដ៏ប្រោស លោះរបស់អ្នក ។ គឺដូច្នោះមែន ។ អាម៉ែន ៕

**៣៤** ១*ក* ស.ប. ប្រាត្ត, អូរសុន.
២ *ក* យ៉ូហាន ១:១–៥.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៣ *ក* យ៉ូហាន ៣:១៦; ១៥:១៣.
ស.ប. សេចក្ដីស្រឡាញ់.
*ខ* ស.ប. ព្រះដ៏ប្រោសលោះ.
*គ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន; ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ឃ* យ៉ូហាន ១:៩–១២; រ៉ូម ៨:១៤, ១៦–១៧; ម៉ូសេ ៦:៦៤–៦៨.
ស.ប. បុត្រាបុត្រីនៃព្រះ.
៤ *ក* យ៉ូហាន ២០:២៩.
៥ *ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
៦ *ក* គ. និង ស. ៦:៩.
*ខ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៧ *ក* វិវរ. ១:៣.
*ខ* លូកា ២១:២៧.
៨ *ក* យ៉ូអែល ២:១១; ម៉ាឡាគី ៤:៥; គ. និង ស. ៤៣:១៧–២៦.
ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* អេសាយ ៦៤:២.
១០ *ក* អេសាយ ៥៨:១.
*ខ* ២ ពេត្រុស ១:២១.

## កណ្ឌទី ៣៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅ ឬនៅក្បែរភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែធ្នូ ឆ្នាំ១៨៣០ (*History of the Church*, ១:១២៨–១៣១)* ។ *នៅគ្រានេះ ព្យាការីរវល់ស្ទើរតែរាល់ថ្ងៃ ដោយសារការបកប្រែ ព្រះគម្ពីរប៊ីប ។ ការបកប្រែប្រហែលជាបានចាប់ផ្ដើម នៅដើមខែមិថុនា ឆ្នាំ១៨៣០ ហើយ អូលីវើរ ខៅឌើរី និងយ៉ូហាន វិតមើរ ទាំងពីរនាក់បានបំរើធ្វើជាស្មៀន ។ ឥឡូវនេះ មកពីពួកគេត្រូវបានហៅឲ្យធ្វើតំណែងផ្សេងៗទៀត នោះ ស៊ីឌនី រិកដុន ត្រូវបានហៅ ដោយការ ហៅពីព្រះ ឲ្យបំរើធ្វើជាស្មៀនរបស់ព្យាការី នៅក្នុងកិច្ចការនេះ (សូមមើលខ២០)* ។ *ទុកជាបុព្វកថាចំពោះបញ្ជីរបស់លោក អំពីវិវរណៈនេះ ព្យាការីបានសរសេរថា៖ «នៅខែធ្នូ ស៊ីឌនី រិកដុន បានមក [ពីរដ្ឋអូហៃអូ] ដើម្បីមកសូមស្នើពីព្រះ ហើយមាន អែតវឺត ប៉ាទ្រិច មកជាមួយគាត់ដែរ . . .* ។ *ក្រោយពីពួកបងប្រុសពីរនាក់មកដល់បន្តិច ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថាដូច្នោះ» (*History of the Church*, ១:១២៨)* ។

*១–២, ពីរបៀបដែលមនុស្សលោកអាចបានត្រឡប់ទៅជាកូនព្រះ; ៣–៧, ស៊ីឌនី រិកដុន ត្រូវបានហៅឲ្យធ្វើបុណ្យជ្រមុជទឹក និងប្រគល់ ព្រះវិញ្ញាណបរិសុទ្ធ; ៨–១២, ទីសំគាល់ និងអព្ភូតហេតុទាំងឡាយត្រូវបាននាំមកដោយសារសេចក្ដីជំនឿ; ១៣–១៦, ពួកអ្នកបំរើរបស់ ព្រះអម្ចាស់នឹងបញ្ជាន់សាសន៍ទាំងឡាយ ដោយព្រះចេស្ដានៃព្រះវិញ្ញាណ; ១៧–១៩, យ៉ូសែប ស្ម៊ីធ កាន់កូនសោទាំងឡាយនៃសេចក្ដី អាថ៌កំបាំង; ២០–២១, ពួកអ្នកដែលរើសតាំងនឹងធន់នៅ ក្នុងថ្ងៃនៃការយាងមករបស់ព្រះអម្ចាស់; ២២–២៧, សាសន៍អ៊ីស្រាអែលនឹងត្រូវ បានសង្គ្រោះ* ។

ចូរស្ដាប់តាមសម្លេងនៃព្រះ[ក]អម្ចាស់ ជាព្រះរបស់អ្នកចុះ គឺ[ខ]អាលផា និងអូមេកា ជាដើម ហើយជាចុង រីឯ[គ]ដំណើររបស់យើង គឺជាវង់មួយ[ឃ] ដ៏នៅអស់កល្បជានិច្ច គឺនៅតែដដែល ទោះពីថ្ងៃម្សិលមិញ ថ្ងៃនេះ និងរហូតតទៅ ។

២ យើងជាព្រះយេស៊ូវ[ខ]គ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ជាអ្នកមនុស្ស ជាច្រើនដែលនឹងជឿដល់ព្រះនាមយើង ប្រយោជន៍ឲ្យពួកដែលត្រូវគេ[ក]ឆ្កាង ជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក គឺដល់គេអាចបានត្រឡប់ទៅជា[គ]កូនព្រះ គឺឲ្យបានក្លាយទៅ[ឃ]តែមួយក្នុងយើង ដូចជា [ង]យើងរួមគ្នាតែមួយក្នុងព្រះវរបិតា ដូចជាព្រះវរបិតារួមគ្នាតែមួយក្នុងយើង ប្រយោជន៍ឲ្យយើងអាចបានរួមគ្នាទៅតែមួយ ។

៣ មើលចុះ ប្រាកដមែន យើងប្រាប់ដល់ស៊ីឌនី ជាអ្នកបំរើយើងជាប្រាកដថា យើងបានទតមើលមកលើអ្នក និងកិច្ចការរបស់អ្នក ។ យើងបានឮពាក្យអធិស្ឋានទាំងប៉ុន្មានរបស់អ្នក ហើយបានរៀបចំអ្នក សំរាប់កិច្ចការដ៏លើសលែងទៅទៀត ។

៤ អ្នកមានពរហើយ ត្បិតអ្នកនឹងត្រូវបានធ្វើការដ៏ធំធេង ។ មើលចុះ អ្នក[ក]ត្រូវបានចាត់ឲ្យមក ដូចជាយ៉ូហាន ដើម្បីរៀបចំផ្លូវពីមុខយើង ហើយពីមុខ[ខ]លោកអេលីយ៉ា ដែលនឹងត្រូវមក ហើយអ្នកពុំបានដឹងសោះឡើយ ។

៥ អ្នកបានធ្វើបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្ត ប៉ុន្តែពួកគេពុំ[ក]បានទទួលព្រះវិញ្ញាណបរិសុទ្ធទេ ។

៦ ប៉ុន្តែឥឡូវនេះ យើងប្រទានបញ្ញត្តិមួយដល់អ្នកថា អ្នកនឹង[ក]ត្រូវធ្វើបុណ្យជ្រមុជដោយទឹក ហើយពួកគេនឹងបានទទួល[ខ]ព្រះវិញ្ញាណបរិសុទ្ធ ដោយសារការ[គ]ដាក់ដៃលើ ដូចជាពួកសាវកពីបុរាណ ។

៣៥ ១*ក* ស.ប. ព្រះអម្ចាស់.
*ខ* វិវរ. ១:៨.
ស.ប. អាលផា និងអូមេកា.
*គ* ១ នីហ្វៃ ១០:១៩;
គ. និង ស. ៣:២.
*ឃ* ហេព្រើរ ១៣:៨;
គ. និង ស. ៣៨:១–៤;
៣៩:១–៣.
២ *ក* ស.ប. ការឆ្កាង.
*ខ* គ. និង ស. ២០:២៥; ៤៥:៥, ៨.
*គ* ស.ប. បុត្រាបុត្រីនៃព្រះ.
*ឃ* យ៉ូហាន ១៧:២០–២៣.
ស.ប. ការរួបរួមតែមួយ.
*ង* ស.ប. ព្រះ, ក្រុមព្រះ.
៤ *ក* ម៉ាឡាគី ៣:១; ម៉ាថាយ ១១:១០;
១ នីហ្វៃ ១១:២៧;
គ. និង ស. ៨៤:២៧–២៨.
*ខ* ៣ នីហ្វៃ ២៥:៥–៦;
គ. និង ស. ២:១;
១១០:១៣–១៥.
៥ *ក* កិច្ចការ ១៩:១–៦.
៦ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
*គ* ស.ប. ដៃ, ការដាក់.

៧ ហើយហេតុការណ៍នឹងកើតឡើង នឹងមានកិច្ចការមួយ
ដ៏ធំនៅលើផែនដី គឺនៅក្នុងចំណោម[ក]ពួកសាសន៍ដទៃ ត្បិតសេច
ក្តីចំកួត របស់ពួកគេ និងអំពើគួរខ្ពើមឆ្អើមរបស់ពួកគេ នឹងត្រូវបាន
បើកសំដែងឲ្យឃើញដល់ភ្នែកនៃអស់ទាំងមនុស្ស ។
៨ ត្បិតយើងជាព្រះ ហើយដៃរបស់យើងមិន[ក]បានរួញខ្លីឡើយ
ហើយយើងនឹងបង្ហាញ[ខ]អព្ភូតហេតុ [គ]ទីសំគាល់ និងការអស្ចារ្យទាំង
ឡាយ ដល់អស់អ្នកណាដែល[ឃ]ជឿដល់ព្រះនាមយើង ។
៩ ហើយអស់អ្នកណាដែលនឹងសូមអ្វី ដោយនូវព្រះនាមយើង
[ក]ក្នុងសេចក្តីជំនឿ នោះពួកគេនឹង[ខ]បណ្តេញ[គ]ពួកអារក្សចេញ; ពួកគេ
នឹង [ឃ]ប្រោសមនុស្សឈឺ; ពួកគេនឹងធ្វើឲ្យមនុស្សខ្វាក់បានភ្លឺ និង
មនុស្សថ្លង់បានឮ និងមនុស្សគបាននិយាយ និងមនុស្សខ្វិនបាន
ដើររួច ។
១០ ហើយពេលនោះកំពុងតែមកដល់យ៉ាងឆាប់រហ័ស ក្នុង
កាលការអស្ចារ្យដ៏ធំៗ ត្រូវបានបង្ហាញដល់កូនចៅមនុស្ស;
១១ ប៉ុន្តែ[ក]ដោយគ្មានសេចក្តីជំនឿ នោះគ្មានអ្វីនឹងត្រូវបាន
បង្ហាញឡើយ លើកលែងតែ[ខ]សេចក្តីហិនវិនាសទាំងឡាយ មក
លើ[គ]ក្រុង បាប៊ីឡូន គឺជាក្រុងនោះដែលបាន[ឃ]ធ្វើឲ្យអស់ទាំងសាសន៍
ផឹកស្រាទំពាំងបាយជូរនៃសេចក្តីក្រោធនៃសេចក្តីកំផិតរបស់នាង ។
១២ ហើយ[ក]គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្តីសប្បុរសសោះ
លើកលែងតែពួកអ្នកបានប្រុងប្រៀប ដើម្បីទទួលភាពពោរពេញ
នៃ ដំណឹងល្អរបស់យើងប៉ុណ្ណោះ ដែលយើងបានចាត់ឲ្យមក
ឯតំណមនុស្សនេះ ។
១៣ ហេតុដូច្នោះហើយ យើងហៅ[ក]ពួកកំសោយនៅលោកិយ៍
គឺជាពួកអ្នកដែល[ខ]ពុំបានរៀនសូត្រ និងពួកគេមើលងាយ ដើម្បីឲ្យ
បញ្ជាន់សាសន៍ទាំងឡាយ ដោយសារព្រះចេស្តានៃព្រះវិញ្ញាណ
របស់យើង;
១៤ ហើយដៃរបស់ពួកគេនឹងបានទៅជាពាហុរបស់យើង
ហើយយើងនឹងធ្វើជា[ក]ខែលរបស់ពួកគេ និងជាប្រដាប់ការពារ
របស់ពួកគេ ហើយយើងនឹងក្រវាត់ចង្កេះរបស់ពួកគេ ហើយពួក
គេនឹងច្បាំងយ៉ាងក្លាហានជំនួសយើង ហើយពួក[ខ]ខ្មាំងសត្រូវរបស់
ពួកគេនឹងបាន នៅក្រោមជើងរបស់ពួកគេ; ហើយយើងនឹង
បណ្តោយឲ្យ[គ]ដាវធ្លាក់មកដោយសារពួកគេ ហើយដោយសារ
[ឃ]ភ្លើងនៃសេចក្តីក្តៅក្រហាយ របស់យើង នោះយើងនឹងរក្សាពួក
គេទុកឲ្យបានគង់វង់ ។
១៥ ហើយ[ក]ពួកទាល់ក្រ និងមនុស្ស[ខ]ស្លូតត្រង់នឹងត្រូវបាន
ដំណឹងល្អផ្សាយដល់ពួកគេ ហើយពួកគេនឹង[គ]ទន្ទឹងចាំដល់ពេល
ដែលយើងនឹង យាងមក ត្បិតពេលនោះនៅ[ឃ]ជិតដៃបង្កើយ —
១៦ ហើយពួកគេនឹងបានរៀនសេចក្តីប្រៀបប្រដូចពីដើម[ក]ល្វា
ត្បិតសូម្បីតែពេលឥឡូវនេះ រដូវក្តៅជិតដល់ហើយ ។
១៧ ហើយយើងបានចាត់[ក]ភាពពោរពេញនៃដំណឹងល្អរបស់យើង
ដោយសារដៃ[ខ]យ៉ូសែប ជាអ្នកបំរើរបស់យើង ហើយដោយនូវ
សេចក្តីកំសោយ នោះយើងបានប្រទានពរដល់លោក;
១៨ ហើយយើងបានប្រទានដល់លោក នូវ[ក]កូនសោទាំងឡាយ
នៃសេចក្តីអាថ៌កំបាំង អំពីរបស់អស់ទាំងនោះ ដែលបាន[ខ]បិទត្រា
ទុក គឺជារបស់ទាំងឡាយដែលមាន ចាប់តាំងពី[គ]កំណើតលោកិយ៍
មកម្លេះ ហើយជារបស់ទាំងឡាយដែលនឹងចេញមក
ចាប់តាំងពីពេលនេះ លុះត្រាដល់ពេលដែលយើងនឹងយាងមក
បើសិនជាលោកនៅជាប់នឹងយើង ហើយបើសិនជាពុំនៅជាប់

៧ *ក* ស.ប. ពួកសាសន៍ដទៃ.
៨ *ក* អេសាយ ៥០:២; ៥៩:១.
*ខ* ស.ប. អព្ភូតហេតុ.
*គ* ស.ប. ទីសំគាល់.
*ឃ* ស.ប. ជំនឿ, ជឿ.
៩ *ក* ស.ប. សេចក្តីជំនឿ.
*ខ* ម៉ាកុស ១៦:១៧.
*គ* ម៉ាកុស ១:២១–៤៥.
*ឃ* ស.ប. ប្រោស, ការប្រោស.
១១ *ក* គ. និង ស. ៦៣:១១–១២.
*ខ* គ. និង ស. ៥:១៩–២០.
*គ* ស.ប. បាបិល, បាប៊ីឡូន.
*ឃ* វិវរ. ១៨:២–៤.
១២ *ក* រ៉ូម ៣:១០–១២;
គ. និង ស. ៣៣:៤;
៣៨:១០–១១; ៨៤:៤៩.
១៣ *ក* ១ កូរិន. ១:២៧;
គ. និង ស. ១:១៩–២៣;
១២៤:១.
*ខ* កិច្ចការ ៤:១៣.
១៤ *ក* ២ សាំយូ. ២២:២–៣.
*ខ* គ. និង ស. ៩៨:៣៤–៣៨.
*គ* គ. និង ស. ១:១៣–១៤.
*ឃ* គ. និង ស. ១២៨:២៤.
១៥ *ក* ម៉ាថាយ ១១:៥.
*ខ* ស.ប. ស្លូតបូត, ភាពស្លូតបូត.
*គ* ២ ពេត្រុស ៣:១០–១៣;
គ. និង ស. ៣៩:២៣; ៤៥:៣៩;
ម៉ូសេ ៧:៦២.
*ឃ* គ. និង ស. ៦៣:៥៣.
១៦ *ក* ម៉ាថាយ ២៤:៣២;
គ. និង ស. ៤៥:៣៦–៣៨;
យ.ស. — ម៉ាថាយ ១:៣៨.
ស.ប. ទីសំគាល់អំពីពេលវេលា.
១៧ *ក* គ. និង ស. ៤២:១២.
*ខ* គ. និង ស. ១៣៥:៣.
១៨ *ក* គ. និង ស. ៨៤:១៩.
*ខ* ដានី. ១២:៩; ម៉ាថាយ ១៣:៣៥;
២ នីហ្វៃ ២៧:១០–១១;
អេធើរ ៤:៤–៧;
យ.ស. — ប្រវត្តិ ១:៦៥.
*គ* គ. និង ស. ១២៨:១៨.

នឹងយើងទេ នោះយើងនឹង ដាក់អ្នកណាផ្សេងទៀត
ជំនួសលោក ។
១៩ ហេតុដូច្នោះហើយ ចូរមើលលោក ដើម្បីកុំឲ្យសេច
ក្ដីជំនឿរបស់លោកវិនាសបាត់ឡើយ ហើយរបស់ទាំងនោះនឹង
ត្រូវបាន ប្រទានឲ្យ ដោយ[ក]ព្រះដ៏ជាជំនួយ គឺ[ខ]ព្រះវិញ្ញាណ
បរិសុទ្ធ ដែលជ្រាបគ្រប់ទាំងអស់ ។
២០ ហើយយើងប្រទានបញ្ញត្តិមួយដល់អ្នក — ថាអ្នកនឹង
[ក]ត្រូវសរសេរឲ្យលោក; ហើយបទគម្ពីរទាំងឡាយនឹងត្រូវបាន
ប្រទានឲ្យ សូម្បីតែ នៅក្នុងឱរារបស់យើងផ្ទាល់ គឺដើម្បីសេច
ក្ដីសង្គ្រោះដល់ពួកដែលយើង[ខ]រើសតាំង;
២១ ត្បិតពួកគេនឹងបាន[ក]ឮសម្លេងរបស់យើង ហើយនឹងបាន
ឃើញយើង ហើយនឹងមិនងុយងក់ឡើយ ហើយនឹង[ខ]ធន់នៅ ក្នុង
[គ]ថ្ងៃនៃការ យាងមករបស់យើង; ត្បិតពួកគេនឹងត្រូវបានល្អស្អាតបរិសុទ្ធ
ដូចជាយើង[ឃ]ល្អស្អាតបរិសុទ្ធដែរ ។
២២ ហើយឥឡូវនេះ យើងប្រាប់[ក]អ្នកថា ចូរនៅជាមួយ
នឹងលោកចុះ ហើយលោកនឹងធ្វើដំណើរជាមួយនឹងអ្នក; ចូរកុំ
បោះបង់លោក ចោលឡើយ ហើយការណ៍ទាំងឡាយនេះ
ច្បាស់ជានឹងបានសំរេចមែន ។
២៣ ហើយ[ក]ដរាបណាអ្នករាល់គ្នាមិនសរសេរ មើលចុះ នោះ
នឹងបានប្រទានដល់លោកឲ្យព្យាករ; ហើយអ្នកនឹងត្រូវផ្សាយដំណឹង
ល្អរបស់យើង ហើយហៅរក[ខ]ពួកព្យាការីបរិសុទ្ធ ដើម្បីបញ្ជាក់ពាក្យ
ពេចន៍របស់លោក ដូចដែលបានប្រទានដល់លោក ។
២៤ ចូរ[ក]កាន់តាមបញ្ញត្តិ និងសេចក្ដីសញ្ញាទាំងប៉ុន្មាន ដែលអ្នក
រាល់គ្នាជាប់; ហើយយើងនឹងបណ្ដាលឲ្យ[ខ]ផ្ទៃមេឃញាប់ញ័រ
ដើម្បីសេចក្ដី ល្អដល់អ្នក ហើយ[គ]អារក្សសាតាំងនឹងញ័ររន្ធត់ ហើយ
ក្រុង[ឃ]ស៊ីយ៉ូននឹងបានអរសប្បាយនៅលើភ្នំទាំងឡាយ ហើយ
លូតលាស់;
២៥ ហើយសាសន៍[ក]អ៊ីស្រាអែលនឹងត្រូវ[ខ]បានសង្គ្រោះ តាមពេល
ដែលយើងកំណត់; ហើយដោយសារ[គ]កូនសោដែលយើងបាន
ប្រទានឲ្យ នោះពួកគេនឹងត្រូវបាននាំ ហើយគ្មាននរណានឹងត្រូវ
បំភាន់ទៀតឡើយ ។
២៦ ចូរលើកចិត្តអ្នកឡើង ហើយអរសប្បាយចុះ គឺ[ក]សេច
ក្ដីប្រោសលោះរបស់អ្នកជិតមកដល់ហើយ ។
២៧ ចូរកុំខ្លាច ហ្វូងតូចអើយ គឺ[ក]នគរជារបស់ផងអ្នកហើយ
ដរាបដល់យើងយាងមក ។ មើលចុះ យើង[ខ]មកយ៉ាង
ឆាប់រហ័ស ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៣៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ អែតវឺត ប៉ាទ្រិច នៅក្បែរភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែធ្នូ ឆ្នាំ១៨៣០ (*History of the Church, *១:១៣១)* ។ *(សូមមើលចំណងជើងនៃកណ្ឌទី ៣៥)* ។ *ព្យាការីបានប្រាប់ថា អែតវឺត ប៉ាទ្រិច «ជាគំរូអំពីបរិសុទ្ធភាព ហើយជាបុរសដ៏សំបើមម្នាក់របស់ព្រះអម្ចាស់» (*History of the Church, *១:១២៨)* ។

*១–៣, ព្រះអម្ចាស់ទ្រង់ដាក់ព្រះហស្តរបស់ទ្រង់លើ អែតវឺតប៉ាទ្រិច ដោយដៃ ស៊ីឌនី រិកដុន; ៤–៨, បុរសរាល់គ្នាណាដែលទទួលដំណឹងល្អ និងបព្វជិតភាព គឺត្រូវបានហៅ ដើម្បីឲ្យចេញទៅផ្សាយសាសនា ។*

១៩ *ក* យ៉ូហាន ១៤:១៦, ២៦; ១៥:២៦.
ស.ប. ព្រះដ៏ជាជំនួយ.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២០ *ក* នៅពេលនេះ ព្យាការីកំពុងតែធ្វើការបកប្រែព្រះគម្ពីរប៊ីប ស្របតាមវិវរណៈដែលមានស៊ីឌនី រិកដុន ធ្វើជាស្មៀន.
*ខ* ស.ប. ពួករើសតាំង.
២១ *ក* យ៉ូអែល ២:១១;
គ. និង ស. ៤៣:១៧–២៥;
៨៨:៩០; ១៣៣:៥០–៥១.
*ខ* ម៉ាឡាគី ៣:២–៣.
*គ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ឃ* ស.ប. ស្អាត, ស្អាតស្អាត.
២២ *ក* គ. និង ស. ១០០:៩–១១.
២៣ *ក* ក.ន. នៅពេលណាដែលស៊ីឌនី រិកដុន មិនរវល់ខាងការសរសេរ.
*ខ* ក.ន. បទគម្ពីរទាំងឡាយ.
២៤ *ក* គ. និង ស. ១០៣:៧.
*ខ* គ. និង ស. ២១:៦.
*គ* ១ នីហ្វៃ ២២:២៦.
*ឃ* ស.ប. សេចក្ដីអំណរ.
២៥ *ក* ស.ប. អ៊ីស្រាអែល.
*ខ* អេសាយ ៤៥:១៧;
១ នីហ្វៃ ១៩:១៥–១៦; ២២:១២.
*គ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
២៦ *ក* លូកា ២១:២៨.
២៧ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ខ* វិវរ. ២២:២០.

ព្រះអម្ចាស់ដ៏ជាព្រះ ជាព្រះដ៏មហិទ្ធិឫទ្ធិនៃសាសន៍អ៊ីស្រាអែល ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ មើលចុះ អែតវីត ជាអ្នកបំរើរបស់យើង អើយ យើងប្រាប់អ្នកថា អ្នកមានពរហើយ ហើយអំពើបាបទាំងឡាយរបស់អ្នក ត្រូវបានអត់ទោសដល់អ្នកហើយ ហើយអ្នកត្រូវបានហៅ ដើម្បីឲ្យទៅផ្សាយដំណឹងល្អរបស់យើង ហាក់ដូចជាដោយសម្លេងត្រែ;

២ ហើយយើងនឹងដាក់ដៃលើអ្នក ដោយដៃ ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង ហើយអ្នកនឹងបានទទួលព្រះវិញ្ញាណរបស់យើង គឺព្រះវិញ្ញាណបរិសុទ្ធ ជាព្រះដ៏ជាជំនួយ ដែលនឹងបង្រៀនអ្នកអំពីការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តនៃនគរ;

៣ ហើយអ្នកនឹងត្រូវប្រកាសប្រាប់ដំណឹងល្អ ដោយសម្លេងខ្លាំង គឺនិយាយថា៖ ហូសាណា សូមឲ្យព្រះនាមនៃព្រះដ៏ខ្ពស់បំផុតបានប្រកប ដោយព្រះពរ ។

៤ ហើយឥឡូវនេះ តំណែង និងបញ្ញត្តិនេះ យើងបានប្រទានដល់អ្នក ស្ដីអំពីមនុស្សគ្រប់រូប —

៥ ថាអស់មនុស្សជាច្រើនណាដែលនឹងមកខាងមុខ ស៊ីឌនី រិកដុន និង យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាពួកអ្នកបំរើរបស់យើង ដោយឱបក្រសោបតំណែង និងព្រះបញ្ញត្តិនេះ ឈ្មោះថាបានតែងតាំង ហើយបានចាត់ឲ្យចេញទៅ ដើម្បីផ្សាយដំណឹងល្អដ៏អស់កល្បអស់កាល ក្នុងចំណោមសាសន៍ទាំងឡាយ —

៦ ដោយស្រែកប្រាប់ពីការប្រែចិត្ត គឺនិយាយថា៖ ចូរជួយសង្គ្រោះខ្លួនឲ្យរួចពីពូជតំណវៀចនេះ ហើយចេញមកពីភ្លើង ដោយស្អប់ ដល់ទាំងអាវ ដែលត្រូវស្មោកគ្រោក ដោយសាច់ឈាមផង ។

៧ ហើយព្រះបញ្ញត្តិនេះ នឹងត្រូវបានប្រទានដល់ពួកអែលឌើរនៃសាសនាចក្ររបស់យើង ប្រយោជន៍ឲ្យបុរសរាល់គ្នាណាដែលបាន ឱបក្រសោបបញ្ញត្តិនេះ ដោយមានចិត្តព្រមព្រៀងគ្នា អាចបានតែងតាំង ហើយចាត់ចេញទៅ គឺដូចជាយើងបានមានព្រះបន្ទូលមក ។

៨ យើងជាព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ; ហេតុដូច្នោះហើយ ចូរក្រវាត់ចង្កេះអ្នកចុះ ហើយយើងនឹងមកឯព្រះវិហារ របស់យើងភ្លាម ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៣៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅក្បែរភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែធ្នូ ឆ្នាំ១៨៣០ (*History of the Church*, ១:១៣៩) ។ នៅក្នុងវិវរណៈនេះ ត្រូវបានប្រទានបញ្ញត្តិ ស្ដីអំពីការប្រមូល នៅក្នុងកាលនៃការកាន់ កាប់ត្រួតត្រានេះ ។*

*១–៤, ពួកបរិសុទ្ធត្រូវបានហៅ ឲ្យប្រមូលគ្នីគ្នានៅឯរដ្ឋអូហៃអូ ។*

មើលចុះ យើងប្រាប់អ្នកថា មិនជាចាំបាច់ដល់យើងទេ ដែលអ្នករាល់គ្នាត្រូវបកប្រែទៀត លុះត្រាអ្នករាល់គ្នាបានទៅរដ្ឋអូហៃអូសិន ហើយការណ៍នេះ ក៏ព្រោះតែខ្មាំងសត្រូវ និងដោយយល់ដល់អ្នករាល់គ្នា ។

២ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា អ្នករាល់គ្នានឹងមិនត្រូវទៅទេ លុះត្រាតែអ្នករាល់គ្នាបានផ្សាយដំណឹងល្អរបស់យើង នៅភូមិភាគ នោះ ហើយបានចំរើនកម្លាំងយ៉ាងមាំមួនដល់សាសនាចក្រ នៅទីណាក្ដីដែលមានសិន ហើយជាពិសេសនៅភូមិខូលស្វិល; ត្បិតមើលចុះ ពួកគេអធិស្ឋានដល់យើង ដោយនូវសេចក្ដីជំនឿយ៉ាងខ្លាំង ។

៣ ហើយជាថ្មីទៀត មានបញ្ញត្តិមួយដែលយើងប្រទានដល់

៣៦ ១ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ; ព្រះយេហូវ៉ា.
*ខ* គ. និង ស. ៤១:៩–១១.
២ *ក* ស.ប. ដៃ, ការដាក់.
*ខ* ស.ប. ព្រះដ៏ជាជំនួយ; ព្រះវិញ្ញាណបរិសុទ្ធ.
*គ* គ. និង ស. ៤២:៦១.
៥ *ក* គ. និង ស. ៦៣:៥៧.
ស.ប. តែងតាំង, ការតែងតាំង.
*ខ* ស.ប. ផ្សាយ.
៦ *ក* កិច្ចការ ២:៤០.
*ខ* យូដាស ១:២៣.
៨ *ក* ម៉ាឡាគី ៣:១.
៣៧ ១ *ក* ក.ន. ការបកប្រែព្រះគម្ពីរប៊ីបបានចាប់ផ្ដើមហើយ.
២ *ក* គ. និង ស. ២៤:៣; ២៦:១.

សាសនាចក្រថា ជាការចាំបាច់ដល់យើង ដែលពួកគេគួរតែប្រមូលគ្នីគ្នានៅ រដ្ឋអូហៃអូ ទំរាំពេលដែល អូលីវើរ ខៅឌើរ ជាអ្នកបំរើរបស់យើង នឹងត្រឡប់មករកពួកគេវិញ ។

៤ មើលចុះ នេះជាប្រាជ្ញា ហើយចូរបណ្ដោយឲ្យមនុស្សរាល់គ្នារើសសំរាប់ខ្លួនចុះ លុះត្រាយើងនឹងយាងមក ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៣៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ថ្ងៃទី២ ខែមករា ឆ្នាំ១៨៣១ (*History of the Church*, ១:១៤០–១៤៣) ។ ជាពេលវេលានៅឯសន្និសីទនៃសាសនាចក្រ ។*

*១–៦, ព្រះគ្រីស្ទបានបង្កើតរបស់សព្វសារពើ; ៧–៨, ទ្រង់គង់នៅកណ្ដាលពួកបរិសុទ្ធរបស់ទ្រង់ ជាពួកអ្នកដែលនឹងឃើញព្រះអង្គឆាប់ៗ; ៩–១២, គ្រប់ទាំងសាច់សុទ្ធតែពុករលួយនៅចំពោះព្រះអង្គ; ១៣–២២, ទ្រង់បានទុកដែនដីសន្យាមួយសំរាប់ពួកបរិសុទ្ធរបស់ព្រះអង្គ ក្នុងវេលាកាល និងក្នុងអស់កល្បអស់កាល; ២៣–២៧, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យរួបរួមគ្នាតែមួយ ហើយគោរពគ្នាទៅវិញទៅមកដូចជាបងប្អូន; ២៨–២៩, សង្គ្រាមទាំងឡាយត្រូវបានទាយទុក; ៣០–៣៣, ពួកបរិសុទ្ធត្រូវបានប្រទានដោយព្រះចេស្ដាមកពីស្ថានលើ ហើយឲ្យចេញទៅក្នុងចំណោមគ្រប់អស់ទាំងសាសន៍; ៣៤–៤២, សាសនាចក្រត្រូវបានបញ្ជាឲ្យថែរក្សាពួកអ្នកទាល់ក្រ និងពួកអ្នកទុគ៌ត ហើយឲ្យស្វែងរកទ្រព្យសម្បត្តិខាងភាពអស់កល្បជានិច្ច ។*

១ ព្រះអង្គទ្រង់មានព្រះបន្ទូលដូច្នេះថា ព្រះអម្ចាស់ ជាព្រះរបស់
អ្នក គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏មហិមា គឺអាលផា
និងអូមេកា ជាដើម និង ជាចុង ជាព្រះដែល ដែល
ទតមើលមកលើផ្ទៃមេឃនៃភាពអស់កល្បជានិច្ច និងអស់ទាំងពួក
ពលបរិវារសេរាភិមនៃស្ថានសួគ៌ មុនកំណើតលោកិយមកម្ល៉េះ;
២ ជាព្រះដែល ដែលជ្រាបគ្រប់ការណ៍ទាំងអស់ ត្បិត
គ្រប់ការណ៍ទាំងអស់មានវត្តមាននៅចំពោះព្រះនេត្ររបស់យើង;
៣ យើងជាព្រះដែល ដែលបានមានព្រះបន្ទូល ហើយក៏មាន
លោកិយកើតមក ហើយរបស់សព្វសារពើបានកើតមក ដោយ
សារយើង ។
៤ យើងជាព្រះដែល ដែលបានយកក្រុងស៊ីយ៉ូននៃលោក
ហេណុក មកឯឱរារបស់យើង; ហើយប្រាកដមែន យើង
និយាយថា សូម្បីតែអស់អ្នកណា ដែលបានជឿដល់ព្រះនាម
របស់យើង ត្បិតយើងជាព្រះគ្រីស្ទ ហើយដោយនូវព្រះនាម
របស់យើងផ្ទាល់ ដោយសារព្រះគុណធម៌នៃព្រះលោហិត
ដែលយើងបានច្រួច នោះយើងបានអង្វរជំនួសពួកគេ
នៅចំពោះព្រះវរបិតា ។
៥ ប៉ុន្ដែមើលចុះ ពួកទុច្ចរិតទាំងប៉ុន្មានដែលនៅសល់ នោះយើង
បានទុកឲ្យជាប់ច្រវ៉ាក់នៃសេចក្ដីងងឹត លុះដល់សេចក្ដីជំនុំជំរះនៅ
ថ្ងៃដ៏ធំ ដែលនឹងបានមកដល់ នៅចុងបំផុតនៃផែនដី;
៦ ហើយយើងនឹងបណ្ដាលឲ្យពួកទុច្ចរិតយ៉ាងដូច្នោះហើយ
ដែលមិនព្រមឮសម្លេងរបស់យើង ប៉ុន្ដែបានពង្រឹងចិត្តរបស់ពួកគេ
ហើយវេទនា វេទនា វេទនា គឺជាទោសរបស់ពួកគេ ។
៧ ប៉ុន្ដែមើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា

៣ *ក* ក.ន. រដ្ឋអូហៃអូ ។
គ. និង ស. ៣៨:៣១–៣២.
៤ *ក* ស.ប. សិទ្ធិជ្រើសរើស.
**៣៨** ១ *ក* ស.ប. យើងជាព្រះ.
*ខ* វិវរ. ១:៨.
*គ* គ. និង ស. ៤៥:១.
*ឃ* ស.ប. ជីវិតមុនផែនដី.
*ង* ទំនុក. ៩០:២.
២ *ក* គ. និង ស. ៨៨:៤១;
ម៉ូសេ ១:៣៥.
ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
*ខ* សុភា. ៥:២១; ២ នីហ្វៃ ៩:២០.
៣ *ក* ទំនុក. ៣៣:៦–៩.
ស.ប. បង្កបង្កើត, ការបង្កបង្កើត.
៤ *ក* គ. និង ស. ៤៥:១១–១៤;
៧៦:៦៦–៦៧; ៨៤:៩៩–១០០;
ម៉ូសេ ៧:១៨–២១. ក.ឃ.ស.,
លោកុ. ១៤:២៥–៤០.
ស.ប. ស៊ីយ៉ូន.
*ខ* គ. និង ស. ២០:២៥;
៣៥:២; ៤៥:៣–៥.
*គ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
៥ *ក* ស.ប. ឥតសុចរិត,
សេចក្ដីឥតសុចរិត.
*ខ* ២ ពេត្រុស ២:៤; យូដាស ១:៦.
ស.ប. ស្ថាននរក.
*គ* ស.ប. សេចក្ដីជំនុំជំរះ
ចុងក្រោយបំផុត.

ព្រះនេត្ររបស់យើងកំពុងទតមើលមកលើអ្នក ។ យើងនៅកណ្ដាលពួកអ្នក ហើយអ្នករាល់គ្នាពុំអាចមើលយើងឃើញទេ;

៨ ប៉ុន្តែថ្ងៃនោះមកដល់យ៉ាងឆាប់ៗ ដែលអ្នករាល់គ្នានឹងមើលឃើញយើង ហើយនឹងស្គាល់ថាយើងជាព្រះ; ត្បិតវាំងននៃសេចក្ដីងងឹត នឹងត្រូវបានរហែកឆាប់ៗ ហើយអ្នកណាដែលពុំបានជ្រះបរិសុទ្ធ នោះនឹងមិនធន់នៅថ្ងៃនោះទេ ។

៩ ហេតុដូច្នោះហើយ ចូរក្រវាត់ចង្កេះអ្នក ហើយប្រុងប្រៀបចុះ ។ មើលចុះ នគរជារបស់ផងអ្នករាល់គ្នាហើយ ហើយខ្មាំងសត្រូវនឹងពុំ បានឈ្នះឡើយ ។

១០ យើងប្រាប់អ្នកជាប្រាកដថា អ្នករាល់គ្នាស្អាតបាត ប៉ុន្តែមិនមែនទាំងអស់គ្នាទេ; ហើយគ្មាននរណាឯទៀតទេ ដែលយើងសព្វព្រះហឫទ័យឡើយ;

១១ ត្បិតគ្រប់អស់ទាំងសាច់សុទ្ធតែពុករលួយ នៅចំពោះយើង; ហើយអំណាចទាំងឡាយនៃសេចក្ដីងងឹតគ្របដណ្ដប់មកលើផែនដីក្នុងចំណោមកូនចៅមនុស្ស នៅចំពោះវត្តមាននៃអស់ទាំងពួកពលបរិវារស្ថានសួគ៌ —

១២ ដែលបណ្ដាលឲ្យភាពស្ងប់ស្ងាត់សោយរាជ្យ ហើយអស់ទាំងភាពអស់កល្បត្រូវឈឺចាប់ ហើយពួកទេវតាកំពុងរង់ចាំបញ្ជាដ៏ធំ ដើម្បីទៅច្រូតទំលាក់ផែនដី ដើម្បីទៅប្រមូលស្រងែទាំងឡាយ ដើម្បីឲ្យបានដុតបន្សុសចោល; ហើយមើលចុះ ខ្មាំងសត្រូវកំពុងរួមគ្នា ។

១៣ ហើយឥឡូវនេះ យើងបង្ហាញដល់អ្នក នូវសេចក្ដីអាថ៌កំបាំងមួយ ជាការណ៍ដែលមាននៅក្នុងបន្ទប់សម្ងាត់ ដើម្បីនាំឲ្យកើតមានសេចក្ដីបំផ្លិចបំផ្លាញដល់អ្នក កន្លងពេលក្រោយមក ហើយអ្នករាល់គ្នាពុំបានដឹងសោះ;

១៤ ប៉ុន្តែឥឡូវនេះ យើងប្រាប់រឿងនេះដល់អ្នក ហើយអ្នករាល់គ្នាមានពរហើយ ពុំមែនដោយសារសេចក្ដីទុច្ចរិតរបស់អ្នក ឬដោយចិត្តដ៏ឥតជំនឿរបស់អ្នកឡើយ ត្បិតអ្នកខ្លះក្នុងចំណោមអ្នករាល់គ្នាប្រាកដជាមានទោសនៅចំពោះយើង ប៉ុន្តែយើងនឹងមានចិត្តអាណិតអាសូរ ដល់ភាពកំសោយរបស់អ្នក ។

១៥ ហេតុដូច្នេះហើយ ចូរអ្នកមានកម្លាំងខ្លាំងក្លាចាប់តាំងពីពេលនេះតទៅចុះ; ចូរកុំខ្លាច ត្បិតនគរជារបស់ផងអ្នកហើយ ។

១៦ ហើយសំរាប់សេចក្ដីសង្គ្រោះដល់អ្នក នោះយើងប្រទានដល់អ្នកនូវបញ្ញត្តិមួយ ត្បិតយើងបានឮពាក្យអធិស្ឋានទាំងឡាយរបស់អ្នក ហើយពួកអ្នកទាល់ក្របានត្អូញត្អែរនៅចំពោះយើង ហើយពួកអ្នកមាន នោះយើងបានបង្កើត ហើយគ្រប់អស់ទាំងសាច់ជារបស់ផងយើង ហើយយើងមិនរើសមុខមនុស្សណាឡើយ ។

១៧ ហើយយើងបានធ្វើឲ្យផែនដីបានបរិបូរ ហើយមើលចុះ ផែនដីជាកំណល់កល់ជើងយើង ហេតុដូច្នោះហើយ យើងនឹងឈរនៅលើ ផែនដីម្ដងទៀត ។

១៨ ហើយយើងហុច ហើយមេត្តាប្រទានដល់អ្នក នូវទ្រព្យសម្បត្តិដ៏ប្រសើរលើសលែងទៅទៀត គឺជាផែនដីសន្យា ជាផែនដីដែលមាន ទឹកដោះ និងទឹកឃ្មុំហូរហៀរ នៅលើផែនដីនោះនឹងពុំដែលមានបណ្ដាសាឡើយ ក្នុងកាលព្រះអម្ចាស់ទ្រង់នឹងយាងមក;

១៩ ហើយយើងនឹងប្រទានដល់អ្នក ទុកជាដែនដីនៃកេរ្តិ៍អាកររបស់អ្នក បើសិនជាអ្នកស្វែងរក ដោយអស់ពីចិត្តអ្នក ។

២០ ហើយនេះនឹងត្រូវបានទៅជាសេចក្ដីសញ្ញារបស់យើង ជាមួយនឹងអ្នកថា អ្នករាល់គ្នានឹងបានដែនដីនេះទុកជាដែនដីនៃកេរ្តិ៍អាកររបស់អ្នក ហើយជាកេរ្តិ៍អាករដល់កូនចៅរបស់អ្នក ជារៀងដរាបតទៅ ដរាបណាផែនដីនឹងនៅគង់វង្ស ហើយអ្នករាល់គ្នានឹងបានដែនដី នេះម្ដងទៀត ក្នុងភាពអស់កល្ប គឺគ្មានអ្វីនឹងកន្លងផុតទៅឡើយ ។

៧ *ក* គ. និង ស. ១:១.
*ខ* គ. និង ស. ៦:៣២; ២៩:៥.
៨ *ក* វិវរ. ២២:៤–៥.
ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. សុទ្ធ, សុទ្ធសាធ.
*គ* ម៉ាឡាគី ៣:២.
៩ *ក* លូកា ៦:២០.
ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
១០ *ក* ស.ប. ស្អាត និងឥតស្អាត.
*ខ* គ. និង ស. ១:៣០.
១១ *ក* អេសាយ ១:៣–៤;
គ. និង ស. ៣៣:៤.
*ខ* មីកា ៣:៦;
គ. និង ស. ១១២:២៣;
ម៉ូសេ ៧:៦១–៦២.
១២ *ក* ម៉ូសេ ៧:៤១.
*ខ* គ. និង ស. ៨៦:៣–៧.
*គ* ស.ប. ចំរូត.
*ឃ* គ. និង ស. ៨៨:៩៤;
១០១:៦៥–៦៦.
*ង* ម៉ាថាយ ១៣:៣០.
១៣ *ក* គ. និង ស. ៥:៣២–៣៣.
១៥ *ក* ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន.
*ខ* ស.ប. សេចក្ដីកោតខាច —
សេចក្ដីកោតខ្លាចដល់មនុស្ស.
១៦ *ក* ម៉ូសាយ ៤:១៦–១៨.
*ខ* ១ សាំយូ. ២:៧.
*គ* កិច្ចការ ១០:៣៤;
មរ៉ូណៃ ៨:១១–១២;
គ. និង ស. ១:៣៤–៣៥.
១៧ *ក* ១ នីហ្វៃ ១៧:៣៩; អេប្រា. ២:៧.
២០ *ក* គ. និង ស. ៤៥:៥៨.

២១ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា នៅពេលនោះ អ្នករាល់គ្នានឹងពុំមានស្ដេច ឬអ្នកត្រួតត្រាឡើយ ត្បិតយើងនឹងបានទៅជា [ក]មហាក្សត្ររបស់អ្នក ហើយនឹងមើលថែទាំអ្នក ។

២២ ហេតុដូច្នោះហើយ ចូរស្ដាប់តាមសម្លេងរបស់យើង ហើយ [ក]ដើរតាមយើងចុះ ហើយអ្នកនឹងបានទៅជាមនុស្ស[ខ]សេរី ហើយអ្នករាល់គ្នានឹងពុំមានក្រិត្យវិន័យឯណាក្រៅពីក្រិត្យវិន័យយើងឡើយ ក្នុងកាលយើងនឹងយាងមក ត្បិតយើងជា[គ]អ្នកតែងក្រិត្យវិន័យឲ្យអ្នករាល់គ្នា ហើយតើមានអ្នកណាអាចនឹងឃាត់ទប់ដៃយើងបាន ?

២៣ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា ចូរ[ក]បង្រៀនគ្នាទៅវិញទៅមក ស្របតាមតំណែងដែលយើងបានតែងដល់អ្នកចុះ;

២៤ ហើយចូរបណ្ដោយឲ្យមនុស្សគ្រប់រូប [ក]គោរពបងប្អូនខ្លួនដូចជាខ្លួនឯងផ្ទាល់ ហើយប្រព្រឹត្តដោយ[ខ]គុណធម៌ និងដោយ[គ]បរិសុទ្ធភាព នៅចំពោះយើងចុះ ។

២៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា ចូរបណ្ដោយឲ្យមនុស្សគ្រប់រូប គោរពបងប្អូនខ្លួន ដូចជាខ្លួនឯងផ្ទាល់ចុះ ។

២៦ ត្បិតតើមានមនុស្សណានៅចំណោមអ្នក ដែលមានកូនប្រុស១២នាក់ ហើយមិនរើសមុខនរណាសោះ ហើយពួកគេបំរើលោក ដោយគោរព ហើយលោកមានប្រសាសន៍ទៅកាន់ម្នាក់ថា៖ ចូរឯងពាក់អាវ ហើយមកអង្គុយនៅទីនេះចុះ ហើយទៅកាន់ម្នាក់ទៀតថា៖ ចូរឯងពាក់កន្ទប ហើយអង្គុយនៅទីនោះចុះ — ហើយមើលទៅកូនប្រុសទាំងឡាយរបស់លោក ហើយមានប្រសាសន៍ថាខ្លួន យុត្តិធម៌ ?

២៧ មើលចុះ ការណ៍នេះយើងបានប្រទានដល់អ្នក ទុកជាពាក្យប្រៀបប្រដូច ហើយគឺដូចជាយើងដូច្នោះហើយ ។ យើងមានបន្ទូល មកកាន់អ្នកថា ចូររួមគ្នាតែមួយ; ហើយបើសិនជាអ្នករាល់គ្នាមិនរួមគ្នា[ក]តែមួយទេ ឈ្មោះថាអ្នករាល់គ្នាពុំមែនជារបស់ផងយើងឡើយ ។

២៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា ខ្មាំងសត្រូវដែលនៅក្នុងបន្ទប់សម្ងាត់ កំពុងតែស្វែងរក[ក]ជីវិតរបស់អ្នក ។

២៩ អ្នករាល់គ្នាបានឮអំពី[ក]សង្គ្រាមទាំងឡាយពីស្រុកឆ្ងាយ ហើយអ្នកនិយាយថា បន្តិចទៀតនឹងមានសង្គ្រាមដ៏ធំពីស្រុកឆ្ងាយ ប៉ុន្តែ អ្នករាល់គ្នាពុំស្គាល់ចិត្តមនុស្ស នៅដែនដីរបស់ខ្លួនឯងសោះ ។

៣០ យើងប្រាប់អ្នកពីការណ៍ទាំងនេះ ដោយសារតែពាក្យអធិស្ឋានរបស់អ្នកទាំងឡាយ; ហេតុដូច្នោះហើយ ចូរ[ក]រក្សា[ខ]ប្រាជ្ញាទុកនៅក្នុង ដួងចិត្តរបស់អ្នកចុះ ក្រែងអំពើទុច្ចរិតនៃមនុស្សបើកសំដែងប្រាប់ពីការណ៍ទាំងនេះដល់អ្នក ដោយអំពើទុច្ចរិតរបស់ពួកគេ តាមរបៀបណាមួយ ដែលនឹងនិយាយដាក់ត្រចៀកអ្នក ដោយសម្លេងខ្លាំងជាងអ្វីដែលនឹងកំរើកផែនដីទៅទៀត; ប៉ុន្តែបើសិនជាអ្នករាល់គ្នា បានប្រុងប្រៀបទុកជាស្រេច នោះអ្នករាល់គ្នានឹងមិនត្រូវខ្លាចឡើយ ។

៣១ ហើយប្រយោជន៍ឲ្យអ្នករាល់គ្នាអាចបានរួចផុតពីអំណាចនៃខ្មាំងសត្រូវ[ក] ហើយបានប្រមូលគ្នាជារាស្ត្រសុចរិតមករកយើងដោយ ឥតប្រឡាក់ និងឥតទោស —

៣២ ដូច្នោះ ដោយហេតុនេះហើយ យើងបានប្រទានបញ្ញត្តិមួយដល់អ្នកថា អ្នករាល់គ្នាត្រូវ[ក]ទៅរដ្ឋអូហៃអូ ហើយនៅទីនោះយើងនឹង ប្រទាន[ខ]ក្រិត្យវិន័យមួយដល់អ្នក; ហើយនៅទីនោះ អ្នកនឹង[គ]ត្រូវបានទទួលព្រះចេស្ដាមកពីស្ថានលើ;

៣៣ ហើយចេញពីទីនោះ អ្នកណាក៏ដោយដែលយើងសព្វព្រះហឫទ័យ នោះនឹងចេញទៅក្នុងចំណោម[ក]គ្រប់អស់ទាំងសាសន៍ ហើយនឹងត្រូវប្រាប់ដល់ពួកគេ ពីអ្វីដែលពួកគេនឹងត្រូវធ្វើ; ត្បិតយើងមាន[ខ]កិច្ចការដ៏ធំរក្សាទុក ត្បិតសាសន៍អ៊ីស្រាអែលនឹងត្រូវបានសង្គ្រោះ ហើយយើងនឹងនាំពួកគេទៅកន្លែងណា តាមព្រះហឫទ័យរបស់យើង ហើយគ្មានអំណាចឯណានឹង[គ]ឃាត់ទប់ដៃយើងបានឡើយ ។

២១ ក សាការី ១៤:៩; ២ នីហ្វៃ ១០:១៤; អាលម៉ា ៥:៥០.
២២ ក យ៉ូហាន ១០:២៧.
ខ ស.ប. ព្រះយេស៊ូវគ្រីស្ទ — រជ្ជកាលនៃព្រះគ្រីស្ទនៅសហស្សវត្សរ៍.
គ អេសាយ ៣៣:២២; មីកា ៤:២; គ. និង ស. ៤៥:៥៩.
២៣ ក គ. និង ស. ៨៨:៧៧–៧៩, ១១៨, ១២២. ស.ប. បង្រៀន, គ្រូបង្រៀន.
២៤ ក ចោទិ. ១៧:២០; ១ កូរិន. ៤:៦.
ខ គ. និង ស. ៤៦:៣៣. ស.ប. គុណធម៌.
គ ស.ប. បរិសុទ្ធភាព.
២៧ ក យ៉ូហាន ១៧:២១–២៣; ១ កូរិន. ១:១០; អេភេ. ៤:១១–១៤; ៣ នីហ្វៃ ១១:២៨–៣០; ម៉ូសេ ៧:១៨. ស.ប. ការរួបរួមតែមួយ.
២៨ ក គ. និង ស. ៥:៣៣; ៣៨:១៣.
២៩ ក គ. និង ស. ៤៥:២៦, ៦៣; ៨៧:១–៥; ១៣០:១២.
៣០ ក យ.ស. — ម៉ាថាយ ១:៣៧.
ខ ស.ប. ប្រាជ្ញា.
៣១ ក ២ ពេត្រុស ៣:១៤.
៣២ ក គ. និង ស. ៣៧:៣.
ខ គ. និង ស. ៤២.
គ លូកា ២៤:៤៩; គ. និង ស. ៣៩:១៥; ៩៥:៨; ១១០:៩–១០.
៣៣ ក ស.ប. កិច្ចការផ្សាយសាសនា.
ខ អេសាយ ៤៥:១៧; យេរេ. ៣០:១០; គ. និង ស. ១៣៦:២២.
គ ដានី. ៤:៣៥.

៣៤ ហើយឥឡូវនេះ យើងប្រទានបញ្ញត្តិមួយដល់សាសនាចក្រនៅភូមិភាគទាំងនេះ ថាមានមនុស្សខ្លះនៅចំណោមពួកគេ ដែលនឹង ត្រូវបានតែងតាំងឡើង ហើយពួកគេនឹងត្រូវបានតែងតាំងឡើង ដោយសំឡេងនៃសាសនាចក្រ;

៣៥ ហើយពួកគេនឹងមើលពួកអ្នកទាល់ក្រ និងពួកអ្នកទុគ៌ត ហើយឧបត្ថម្ភដល់ការរំដោះពួកគេ ដើម្បីកុំឲ្យពួកគេត្រូវវេទនា; ហើយ ចាត់ពួកគេឲ្យចេញទៅកន្លែង ដែលយើងបានបញ្ជាដល់ពួកគេ;

៣៦ ហើយនេះជាកិច្ចការរបស់ពួកគេ គឺដើម្បីត្រួតត្រាការងារនៃទ្រព្យសម្បត្តិរបស់សាសនាចក្រនេះ ។

៣៧ ហើយពួកអ្នកណាដែលមានស្រែចំការ ដែលពុំអាចលក់បានទេ នោះចូរទុកចោល ឬក៏ដាក់ជួល តាមតែឃើញថាល្អដល់ពួកគេចុះ ។

៣៨ ចូរមើលឲ្យឃើញថាគ្រប់ការណ៍ទាំងអស់ បានរក្សាទុកឲ្យបានគង់វង្ស; ហើយកាលណាមនុស្សបានទទួលអំណោយទានដោយព្រះចេស្ដាមកពីស្ថានលើ ហើយត្រូវបានចាត់ឲ្យចេញទៅ នោះគ្រប់ការណ៍ទាំងអស់នឹងត្រូវបានប្រមូលមកក្នុងឱរានៃសាសនាចក្រ ។

៣៩ ហើយបើសិនជាអ្នករាល់គ្នា ស្វែងរកទ្រព្យសម្បត្តិ ដែលព្រះវរបិតាសព្វព្រះហឫទ័យនឹងប្រទានឲ្យ នោះអ្នករាល់គ្នានឹងបានទៅជា មនុស្សមានជាងគេបំផុត ត្បិតអ្នករាល់គ្នានឹងមានទ្រព្យសម្បត្តិខាងភាពអស់កល្បជានិច្ច; ហើយជាចាំបាច់ថាទ្រព្យសម្បត្តិទាំងឡាយ នៃផែនដី គឺជារបស់ផងយើង ទុកសំរាប់ប្រទានឲ្យ; ប៉ុន្តែចូរប្រយ័ត្នពីសេចក្ដីឆ្មើងឆ្មៃ ក្រែងអ្នករាល់គ្នាក្លាយទៅដូចជាពួកសាសន៍នីហ្វៃ ពីបុរាណ ។

៤០ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា យើងប្រទានបញ្ញត្តិមួយដល់អ្នក ដើម្បីឲ្យមនុស្សរាល់គ្នា ទាំងអែលឌើរ ទាំងសង្ឃទាំងគ្រូ និងទាំងសមាជិកផង ឲ្យទៅធ្វើដោយអស់ពីពលំរបស់ខ្លួននូវការងារនៃដៃរបស់ខ្លួន ដើម្បីរៀបចំ និងសំរេចនូវអ្វីៗ ដែលយើង បានបញ្ជាចុះ ។

៤១ ហើយចូរបណ្ដោយឲ្យការផ្សាយរបស់អ្នក ទៅជាសំឡេងនៃការព្រមានចុះ គឺមនុស្សម្នាក់ៗចំពោះអ្នកជិតខាងរបស់ខ្លួន ដោយនូវភាពទន់ភ្លន់ និងស្លូតបូត ។

៤២ ហើយចូរអ្នករាល់គ្នាចេញពីចំណោមពួកទុច្ចរិតទៅ ។ ចូរជួយសង្គ្រោះខ្លួនឲ្យរួច ។ ចូរអ្នករាល់គ្នាដែលកាន់ប្រដាប់ទាំងឡាយ នៃព្រះអម្ចាស់បានជ្រះស្អាតចុះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៣៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ យ៉េម្ស ខូវិល នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ថ្ងៃទី៥ ខែមករា ឆ្នាំ១៨៣១ (*History of the Church*, ១:១៤៣–១៤៥) ។ យ៉េម្ស ខូវិល ជាអាចារ្យសាសនាចក្រផ្នែកបាទិស្ទ អស់ប្រមាណ ៤០ឆ្នាំមកហើយ លោកបានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់ថា លោកនឹងគោរពតាមបញ្ញត្តិណាមួយក៏ដោយ ដែលព្រះអម្ចាស់ ទ្រង់នឹងប្រទានដល់លោក តាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ។*

*១–៤, ពួកបរិសុទ្ធមានអំណាច នឹងបានត្រឡប់ជាកូនព្រះ; ៥–៦, ដើម្បីបានទទួលដំណឹងល្អ គឺដើម្បីបានទទួលព្រះគ្រីស្ទ; ៧–១៤, យ៉េមស៍ ខូវិលត្រូវបានបញ្ជាឲ្យទទួលបុណ្យជ្រមុជទឹក ហើយធ្វើការងារ នៅក្នុងចំការទំពាំងបាយជូររបស់ព្រះអម្ចាស់; ១៥–២១, ពួកអ្នកបំរើ របស់ព្រះអម្ចាស់ ត្រូវទៅផ្សាយដំណឹងល្អមុនការយាងមកលើកទី២; ២២–២៤, អស់អ្នកណាដែលទទួលដំណឹងល្អ នោះនឹងត្រូវបាន ប្រមូលគ្នាក្នុងវេលាកាល និងក្នុងអស់កល្បអស់កាល ។*

ចូរស្ដាប់តាមចុះ ហើយឮសំឡេងនៃព្រះអង្គ ដែលគង់នៅចាប់តាំងពីភាពអស់កល្ប ដល់ភាពអស់កល្បជានិច្ច ជាព្រះដ៏ជាព្រះ គឺព្រះយេស៊ូវគ្រីស្ទ —

៣៤ *ក* ស.ប. ការយល់ព្រមទូទៅ.
៣៥ *ក* ស.ប. សុខុមាលភាព.
៣៨ *ក* ស.ប. អំណោយទានពិសិដ្ឋ.
៣៩ *ក* យ៉ាកុប ២:១៧–១៩;
គ. និង ស. ១១:៧.
*ខ* ហាកាយ ២:៨.
*គ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ឃ* ម៉ូរ៉ូណៃ ៨:២៧.
៤០ *ក* ១ កូរិន. ៤:១២.
៤១ *ក* ស.ប. ផ្សាយ.
*ខ* ស.ប. ព្រមាន, ពាក្យព្រមាន.
៤២ *ក* អេសាយ ៥២:១១.
**៣៩** ១*ក* ហេព្រើរ ១៣:៨;
គ. និង ស. ២០:១២; ៣៥:១;
៣៨:១–៤.
*ខ* និក្ខ. ៣:១៤.
ស.ប. ព្រះយេហូវ៉ា.

២ ជា[ក]ពន្លឺ និងជាជីវិតនៃពិភពលោក; ជាពន្លឺដែលភ្លឺមកក្នុង
សេចក្ដីងងឹត តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ;
៣ ជាព្រះដដែល ដែលបានយាងមក ក្នុងកាល[ក]ដ៏ខ្ពង់ខ្ពស់បំផុត
ដែលបានយាងមករករាស្ត្ររបស់យើង តែរាស្ត្ររបស់យើង មិន
បាន ទទួលយើងសោះ;
៤ ប៉ុន្តែអស់មនុស្សជាច្រើនណាដែលបានទទួលយើង នោះយើង
បានប្រទានអំណាច ឲ្យត្រឡប់ទៅជា[ក]កូនព្រះ; ហើយយើងក៏នឹង
ប្រទានដល់អស់មនុស្សជាច្រើនណា ដែលនឹងទទួលយើង នូវ
អំណាចដើម្បីត្រឡប់ទៅជាកូនរបស់យើងដែរ ។
៥ ហើយប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នកណា
ដែលទទួលដំណឹងល្អរបស់យើង នោះ[ក]ទទួលយើងដែរ; ហើយអ្នក
ណាដែល មិនទទួលដំណឹងល្អរបស់យើងទេ នោះមិន
ទទួលយើងដែរ ។
៦ ហើយនេះជា[ក]ដំណឹងល្អរបស់យើង — ការប្រែចិត្ត
និងបុណ្យជ្រមុជដោយទឹក ហើយបន្ទាប់មក [ខ]បុណ្យជ្រមុជ
ដោយភ្លើង និងដោយ ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះដ៏ជាជំនួយ
ដែលបង្ហាញគ្រប់ទាំងអស់ ហើយ[គ]បង្រៀនពីរបស់ខាងនគរ ដែល
ប្រកបដោយភាពសុខសាន្ត ។
៧ ហើយឥឡូវនេះ មើលចុះ [ក]យ៉ោមស៍ ជាអ្នកបំរើ
របស់យើងអើយ យើងប្រាប់អ្នកថា យើងបានទតមើលកិច្ចការ
ទាំងឡាយរបស់អ្នក ហើយយើងស្គាល់អ្នកហើយ ។
៨ ហើយយើងប្រាប់អ្នកជាប្រាកដថា ឥឡូវនេះ ដួងចិត្តរបស់
អ្នកត្រឹមត្រូវនៅចំពោះយើង នៅពេលវេលានេះ; ហើយមើលចុះ
យើងបានប្រទានព្រះពរដ៏ធំៗមកលើក្បាលអ្នក;
៩ ទោះយ៉ាងណាក៏ដោយ អ្នកបានជ្រាបឃើញភាពសោកសៅ
ដ៏ធំ ត្បិតអ្នកបានបដិសេធយើងជាច្រើនគ្រាមកហើយ ពីព្រោះតែ
សេចក្ដីឆ្មើងឆ្មៃ និងសេចក្ដីខ្វល់ខ្វាយនៃ[ក]លោកិយ៍ ។
១០ ប៉ុន្តែមើលចុះ ថ្ងៃទាំងឡាយនៃសេចក្ដីរំដោះអ្នកកំពុងមក
ដល់ហើយ បើសិនជាអ្នកនឹងស្ដាប់តាមសម្លេងរបស់យើង ដែល
មាន បន្ទូលមករកអ្នកថាៈ ចូរក្រោកឡើង ហើយ[ក]ទទួលបុណ្យ
ជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ ដោយអំពាវនាវដល់
ព្រះនាមរបស់យើង ហើយអ្នកនឹងបានទទួលព្រះវិញ្ញាណរបស់យើង
និងព្រះពរដ៏មហិមា ដូចជាអ្នកពុំដែលបានស្គាល់មកសោះ ។
១១ ហើយបើសិនជាអ្នកធ្វើដូច្នេះ នោះយើងបានរៀបចំអ្នកទុក
សំរាប់កិច្ចការដ៏ធំលើសលែងទៅទៀត ។ អ្នកនឹងត្រូវផ្សាយ
ពីភាព ពោរពេញនៃដំណឹងល្អ ដែលយើងបានចាត់ឲ្យចេញទៅ
ក្នុងគ្រាចុងក្រោយបង្អស់ គឺជាសេចក្ដីសញ្ញាដែលយើងបាន
ចាត់ឲ្យចេញទៅ [ក]ប្រមូលរាស្ត្រយើងមកវិញ ដែលត្រូវជាវង្ស
អ៊ីស្រាអែល ។
១២ ហើយហេតុការណ៍នឹងកើតឡើងថា អំណាចនឹង
[ក]ស្ថិតនៅលើអ្នក; អ្នកនឹងត្រូវមានសេចក្ដីជំនឿដ៏ធំ ហើយយើង
នឹងនៅជាមួយនឹង អ្នក ហើយទៅពីមុខអ្នក ។
១៣ អ្នកត្រូវបានហៅដើម្បីឲ្យ[ក]ធ្វើការងារ នៅក្នុងចំការ
ទំពាំងបាយជូររបស់យើង និងដើម្បីស្ថាបនាសាសនាចក្ររបស់យើង
ឡើង ហើយ ដើម្បី[ខ]នាំក្រុងស៊ីយ៉ូនចេញមក ប្រយោជន៍ឲ្យ
ក្រុងស៊ីយ៉ូនអាចបានអរសប្បាយនៅលើភ្នំទាំងឡាយ ហើយ
[គ]ល្ហូតលាស់ ។
១៤ មើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នកពុំ
ត្រូវបានហៅឲ្យទៅស្រុកខាងកើតទាំងឡាយឡើយ ប៉ុន្តែអ្នកត្រូវ
បានហៅឲ្យ ទៅរដ្ឋអូហៃអូវិញ ។
១៥ ហើយដរាបណារាស្ត្ររបស់យើងនឹងប្រមូលគ្នីគ្នានៅឯ
រដ្ឋអូហៃអូ នោះយើងបាន[ក]រក្សាពរទុក ដូចជាពុំដែលស្គាល់
នៅក្នុងចំណោម កូនចៅមនុស្សឡើយ ហើយពរនោះនឹង
ត្រូវបានចាក់មកលើក្បាលពួកគេទាំងឡាយ ។ ហើយចាប់តាំង
ពីពេលនោះទៅ មនុស្សនឹងត្រូវ ចេញទៅគ្រប់[ខ]អស់ទាំង
[គ]សាសន៍ ។

២ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៣ *ក* គ. និង ស. ២០:២៦;
ម៉ូសេ ៦:៥៧, ៦២.
៤ *ក* យ៉ូហាន ១:១២.
ស.ប. បុត្រាបុត្រីនៃព្រះ.
៥ *ក* យ៉ូហាន ១៣:២០.
៦ *ក* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក; ដំណឹងល្អ;
ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. កើតម្ដងទៀត, កើតពីព្រះ;
ព្រះវិញ្ញាណបរិសុទ្ធ.
*គ* គ. និង ស. ៤២:៦១.
៧ *ក* គ. និង ស. ៤០:១.
៩ *ក* ម៉ាថាយ ១៣:២២.
១០ *ក* គ. និង ស. ៤០:១–៣.
ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
១១ *ក* ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
១២ *ក* ២ កូរិន. ១២:៩.
១៣ *ក* ម៉ាថាយ ២០:១–១៦.
*ខ* អេសាយ ៥២:៨.
*គ* គ. និង ស. ១១៧:៧.
១៥ *ក* គ. និង ស. ៣៨:៣២; ៩៥:៨;
១១០:៨–១០.
*ខ* គ. និង ស. ១:២.
*គ* ស.ប. កិច្ចការផ្សាយសាសនា.

១៦ មើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ប្រជារាស្ត្រនៅរដ្ឋអូហៃអូអំពាវនាវមករកយើង ដោយនូវសេចក្ដីជំនឿដ៏ខ្លាំង ដោយគិតថាយើងនឹងទប់ដៃរបស់យើងទុក ក្នុងការជំនុំជំរះមកលើសាសន៍ទាំងឡាយ ប៉ុន្តែយើងពុំអាចបដិសេធពាក្យរបស់យើង បានឡើយ ។

១៧ ហេតុដូច្នោះហើយ ចូរចាប់ផ្ដើមធ្វើការដោយអស់ពីកម្លាំងអ្នកចុះ ហើយចូរហៅពួកអ្នកធ្វើការ ដែលស្មោះត្រង់ទាំងប៉ុន្មានឲ្យចូល ក្នុង[ក]ចំការទំពាំងបាយជូររបស់យើងចុះ ប្រយោជន៍ឲ្យចំការយើងត្រូវបានកាត់មែក លើកចុងក្រោយបង្អស់ ។

១៨ ហើយដរាបណាពួកគេប្រែចិត្ត ហើយទទួលនូវភាពពោរពេញនៃដំណឹងល្អរបស់យើង ហើយ[ក]ក្លាយជាបរិសុទ្ធ នោះយើងនឹងទប់ព្រះ ហស្តរបស់យើងទុក ក្នុងការជំនុំជំរះ ។

១៩ ហេតុដូច្នោះហើយ ចូរចេញទៅចុះ ដោយស្រែកឡើងដោយសម្លេងខ្លាំង គឺនិយាយថាៈ នគរស្ថានសួគ៌នៅជិតដែបង្កើយ; ដោយស្រែកថាៈ ហូសាណា! សូមឲ្យព្រះនាមនៃព្រះដ៏ខ្ពស់បំផុត បានប្រកបដោយព្រះពរ ។

២០ ចូរចេញទៅធ្វើបុណ្យជ្រមុជដោយទឹកចុះ ដោយរៀបចំផ្លូវពីមុខព្រះភ័ក្ត្រយើង សំរាប់ពេលដែលយើងនឹង[ក]យាងមក;

២១ ត្បិតពេលនៅជិតដែបង្កើយ ឯ[ក]ត្រង់ថ្ងៃ និងម៉ោងកំណត់នោះគ្មានអ្នកណា[ខ]ដឹងទេ; ប៉ុន្តែពេលនោះនឹងត្រូវមកដល់ជាពិត ។

២២ ហើយអ្នកណាដែលទទួលរបស់ទាំងនេះ ឈ្មោះថាទទួលយើងដែរ ហើយពួកគេនឹងត្រូវបានប្រមូលគ្នីគ្នាមករកយើងក្នុងវេលា កាល និងក្នុងអស់កល្បអស់កាល ។

២៣ ហើយជាថ្មីទៀត ហេតុការណ៍នឹងកើតឡើងថា នៅលើអស់មនុស្សជាច្រើនណា ដែលអ្នករាល់គ្នានឹងធ្វើបុណ្យជ្រមុជដោយទឹក នោះអ្នករាល់គ្នានឹងត្រូវ[ក]ដាក់ដៃលើ ហើយពួកគេនឹងបានទទួល[ខ]អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ហើយនឹង[គ]ទន្ទឹងចាំទីសំគាល់ទាំង ឡាយ អំពី[ឃ]ការយាងមករបស់យើង ហើយនឹងបានស្គាល់យើង ។

២៤ មើលចុះ យើងមកយ៉ាងឆាប់រហ័ស ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៤០

*វិវរណៈដែលបានប្រទានឲ្យមក យ៉ូសែប ស៊្មីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅភូមិហ្វាយែត រដ្ឋនូវយ៉ោក ខែមករា ឆ្នាំ១៨៣១ (*History of the Church*, ១:១៤៥) ។ មុនបញ្ជីនៃវិវរណៈនេះ ព្យាការីបានសរសេរថាៈ «មកពី យ៉េម្ស ខូវិល បានបដិសេធ ព្រះបន្ទូលនៃព្រះអម្ចាស់ ហើយបានវិលទៅរកគោលការណ៍ទាំងឡាយ និងប្រជាជនដើមរបសគាត់ នោះព្រះអម្ចាស់ ទ្រង់បាន ប្រទានដល់ខ្ញុំ និង ស៊ីឌនី រិកដុន នូវវិវរណៈដែលមានដូចតទៅនេះ» (*History of the Church*, *១:១៤៥)* ។

*១–៣, ការខ្លាចពីសេចក្ដីបៀតបៀន និងសេចក្ដីខ្វល់ខ្វាយនៃលោកិយ៍ បណ្ដាលឲ្យមានការបដិសេធពីដំណឹងល្អ ។*

១ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា ដួងចិត្តនៃ[ក]យ៉េមស៍ខូវិលជាអ្នកបំរើរបស់យើង បានត្រឹមត្រូវនៅចំពោះយើង ត្បិតគាត់បានធ្វើ សេចក្ដីសញ្ញាជាមួយនឹងយើងថា គាត់នឹងគោរពតាមព្រះបន្ទូលរបស់យើង ។

២ ហើយគាត់[ក]បានទទួលព្រះបន្ទូល ដោយចិត្តរីករាយ ប៉ុន្តែអារក្សសាតាំងបានល្បួងគាត់ភ្លាម; ហើយការខ្លាចពី[ខ]សេចក្ដីបៀតបៀន និង សេចក្ដីខ្វល់ខ្វាយនៃលោកិយ បានកណ្ដាលឲ្យគាត់[គ]បដិសេធព្រះបន្ទូលទៅវិញ ។

៣ ហេតុដូច្នោះហើយ គាត់បានបំបាក់សេចក្ដីសញ្ញារបស់យើង ហើយយើងមានធុរៈដើម្បីនឹងធ្វើអ្វីដល់គាត់ តាមតែយើងឃើញថាល្អ ។ អាម៉ែន ៕

១៧ *ក* យ៉ាកុប ៥:៦១–៧៥;
គ. និង ស. ២៤:១៩.
១៨ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
២០ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
២១ *ក* ម៉ាថាយ ២៤:៣៦.
*ខ* យ.ស. — ម៉ាថាយ ១:៤០.
២៣ *ក* ស.ប. ដៃ, ការដាក់.
*ខ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
*គ* វិវរ. ៣:៣;
គ. និង ស. ៣៥:១៥;
៤៥:៣៩–៤៤.
*ឃ* ២ ពេត្រុស ៣:១០–១៤.
**៤០** ១*ក* គ. និង ស. ៣៩:៧–១១.
២ *ក* ម៉ាកុស ៤:១៦–១៩.
*ខ* ម៉ាថាយ ១៣:២០–២២.
ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
*គ* ស.ប. សេចក្ដីក្បត់សាសនា.

## កណ្ឌទី ៤១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈយ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះសាសនាចក្រ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៨៣១ (*History of the Church, *១:១៤៦–១៤៧) ។ នៅពេលនេះ សាខានៃសាសនាចក្រប្រចាំក្រុងខឺតឡង់ កំពុងតែ កើនចំនួនយ៉ាងឆាប់រហ័ស ។ សំរាប់បុព្វកថានៃវិវរណៈនេះ ព្យាការីបានសរសេរថា៖ «សមាជិកទាំងឡាយ . . . កំពុងតែខំព្យាយាមធ្វើ តាមព្រះហឫទ័យនៃព្រះ តាមការដែលពួកគេយល់ដឹង ទោះជាមានគំនិតប្លែក និងវិញ្ញាណក្លែងក្លាយទាំងឡាយ បានចូលមកក្នុង ចំណោមពួកគេក៏ដោយ . . . [ហើយ]ព្រះអម្ចាស់ទ្រង់បានប្រទានដល់សាសនាចក្រ ដែលមានដូចតទៅនេះ» (*History of the Church, *១:១៤៦–១៤៧) ។*

*១–៣, ពួកអែលឌើរនឹងត្រួតត្រាសាសនាចក្រ ដោយវិញ្ញាណនៃវិវរណៈ; ៤–៦, ពួកសិស្សដ៏ពិតនឹងទទួល ហើយកាន់តាមក្រិត្យវិន័យ របស់ព្រះអម្ចាស់; ៧–១២, អែតវឺត ប៉ាទ្រិច ត្រូវបានតែងតាំងឲ្យធ្វើជាប៊ីស្សពចំពោះសាសនាចក្រ ។*

ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់បានមានព្រះបន្ទូលដូច្នេះថា ចូរប្រុងស្ដាប់ហើយឮចុះ ឱអ្នករាល់គ្នាជារាស្ត្រយើងអើយ ជាអ្នករាល់គ្នា ដែលយើងសព្វព្រះហឫទ័យនឹង[ក]ប្រទានពរ ដោយព្រះពរដ៏ប្រសើរបំផុត ជាងព្រះពរទាំងអស់ គឺជាអ្នករាល់គ្នាដែលស្ដាប់តាមយើង; ហើយអ្នករាល់គ្នាដែលមិនស្ដាប់តាមយើង ជាពួកអ្នកដែល[ខ]ថាស្គាល់នាមយើង នោះយើងនឹង[គ]ដាក់បណ្ដាសា ដោយពាក្យបណ្ដាសា ដ៏ធ្ងន់ធ្ងរបំផុត ។

២ ចូរប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្រយើង ដែលយើងបានហៅអើយ មើលចុះ យើងប្រទានដល់អ្នកនូវ [ក]បញ្ញត្តិមួយ ប្រយោជន៍ឲ្យអ្នករាល់គ្នានឹងបានជួបជុំគ្នា ដើម្បីយល់ព្រមតាមព្រះបន្ទូលរបស់យើង;

៣ ហើយដោយសារការអធិស្ឋានដោយនូវសេចក្ដីជំនឿរបស់អ្នក នោះអ្នករាល់គ្នានឹងបានទទួល[ក]ក្រិត្យវិន័យរបស់យើង ប្រយោជន៍ ឲ្យអ្នករាល់គ្នាអាចបានចេះត្រួតត្រាសាសនាចក្ររបស់យើង ហើយឲ្យមានអ្វីត្រឹមត្រូវសព្វគ្រប់នៅចំពោះយើង ។

៤ ហើយយើងនឹងធ្វើជា[ក]អ្នកត្រួតត្រារបស់អ្នក ក្នុងកាលយើង[ខ]យាងមក; ហើយមើលចុះ យើងមកយ៉ាងឆាប់រហ័ស ហើយអ្នករាល់គ្នា នឹង មើលឲ្យឃើញថា ក្រិត្យវិន័យរបស់យើងត្រូវបានកាន់តាម ។

៥ អ្នកណាដែល[ក]ទទួលក្រិត្យវិន័យរបស់យើង ហើយ[ខ]ធ្វើតាម អ្នកនោះហើយជាសិស្សរបស់យើង; ហើយអ្នកណាដែលនិយាយថា ខ្លួន ទទួលក្រិត្យវិន័យរបស់យើង តែមិនធ្វើតាមទេ អ្នកនោះមិនមែនជាសិស្សរបស់យើងទេ ហើយនឹងត្រូវបាន[គ]បណ្ដេញចេញពីចំណោម អ្នករាល់គ្នាវិញ;

៦ ត្បិតមិនគួរសមនឹងយកអ្វីដែលជារបស់កូនក្មេងក្នុងនគរ ទៅឲ្យពួកអ្នកដែលមិនសក្ដិសម ឬដល់[ក]ឆ្កែនោះឡើយ ឬក៏បោះ[ខ]កែវមុក្ដានៅ មុខជ្រូកឡើយ ។

៧ ហើយជាថ្មីទៀត គឺគួរសមឲ្យ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ត្រូវបាន[ក]ផ្ទះមួយសង់ សំរាប់ឲ្យលោកនៅ ហើយ[ខ]បកប្រែចុះ ។

៨ ហើយជាថ្មីទៀត គឺគួរសមឲ្យ ស៊ីឌនី រិកដុន រស់នៅតាមដែលឃើញថាល្អដល់គាត់ ដរាបណាគាត់កាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ។

៩ ហើយជាថ្មីទៀត យើងបានហៅ [ក]អែតវឺត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង ហើយប្រទានបញ្ញត្តិមួយថា គាត់គួរតែបានតាំង

៤១ ១ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*ខ* ចោទិ. ១១:២៦–២៨; ១ នីហ្វៃ ២:២៣.
*គ* គ. និង ស. ៥៦:១–៤; ១១២:២៤–២៦.
២ *ក* ស.ប. ការរួបរួមតែមួយ.
៣ *ក* គ. និង ស. ៤២.
៤ *ក* សាការី ១៤:៩; គ. និង ស. ៤៥:៥៩. ស.ប. ព្រះយេស៊ូវគ្រីស្ទ — រជ្ជកាលនៃព្រះគ្រីស្ទនៅសហស្សវត្សរ៍.
*ខ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៥ *ក* ម៉ាថាយ ៧:២៤.
*ខ* យ៉ាកុប (ព.ស.ថ.) ១:២២–២៥; គ. និង ស. ៤២:៦០.
*គ* គ. និង ស. ៥០:៨–៩. ស.ប. ការកាត់ឲ្យចេញពីសាសនា.
៦ *ក* ម៉ាថាយ ១៥:២៦.
*ខ* ម៉ាថាយ ៧:៦.
៧ *ក* គ. និង ស. ៤២:៧១.
*ខ* ក.ន. បកប្រែព្រះគម្ពីរប៊ីប. គ. និង ស. ៤៥:៦០–៦១.
៩ *ក* គ. និង ស. ៣៦:១.

ដោយ សម្លេងនៃសាសនាចក្រ ហើយតែងតាំងឡើងជាប៊ីស្សព ចំពោះសាសនាចក្រ គឺដើម្បីឲ្យគាត់ចេញពីជំនួញរបស់គាត់ ហើយ ចំណាយពេលទាំងអស់ដែលគាត់មាន សំរាប់ការងារនៃសាសនាចក្រ;

១០ ដើម្បីមើលគ្រប់ទាំងអស់ ដូចដែលបានតាំងដល់គាត់ ក្នុងក្រិត្យវិន័យរបស់យើង ក្នុងថ្ងៃដែលយើងនឹងប្រទានដល់ពួកគេ ។

១១ ហើយនេះពីព្រោះតែចិត្តគាត់បរិសុទ្ធនៅចំពោះយើង ត្បិតគាត់ដូចជា ណាថាណែល ពីបុរាណ ដែលឥតមានចិត្តឧបាយឡើយ ។

១២ ពាក្យទាំងនេះគឺត្រូវបានប្រទានដល់អ្នក ហើយពាក្យទាំងនោះគឺបរិសុទ្ធនៅចំពោះយើង; ហេតុដូច្នោះហើយ ចូរប្រយ័ត្នពីរបៀប ដែលអ្នកគិតពីពាក្យទាំងនោះ ត្បិតពាក្យទាំងនោះនឹងត្រូវបានឆ្លើយមកលើព្រលឹងរបស់អ្នក នៅថ្ងៃជំនុំជំរះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៤២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៨៣១ (*History of the Church, *១:១៤៨–១៥៤) ។ វិវរណៈនេះត្រូវបានទទួលនៅមុខពួកអែលឌើរ១២នាក់ ហើយជាការបំពេញសេចក្ដីសន្យា ដែលព្រះអម្ចាស់ទ្រង់បានធ្វើ រួចមកហើយថា ក្រិត្យវិន័យនឹងត្រូវបានប្រទានឲ្យមក នៅរដ្ឋអូហៃអូ (សូមមើលកណ្ឌទី ៣៨:៣២) ។ ព្យាការីបញ្ជាក់ថាវិវរណៈនេះ «មានក្រិត្យវិន័យនៃសាសនាចក្រ» (*History of the Church, *១:១៤៨) ។*

*១–១០, ពួកអែលឌើរត្រូវបានហៅឲ្យទៅផ្សាយដំណឹងល្អ ធ្វើបុណ្យជ្រមុជទឹកឲ្យពួកអ្នកដែលប្រែចិត្តជឿ ហើយស្ថាបនាសាសនាចក្រ ឡើង; ១១–១២, ពួកគេត្រូវបានហៅ និងតែងតាំង ហើយត្រូវទៅបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អ ដែលឃើញមាន នៅក្នុងព្រះគម្ពីរ; ១៣–១៧, ពួកគេត្រូវទៅបង្រៀននិងព្យាករ ដោយសារព្រះចេស្ដានៃព្រះវិញ្ញាណ; ១៨–២៩, ពួកបរិសុទ្ធត្រូវបាន បញ្ជាមិនឲ្យសំឡាប់ លួច កុហក មានដំរេកសំរើប ប្រព្រឹត្តអំពើកំផិត ឬនិយាយអាក្រក់ពីអ្នកណាឡើយ; ៣០–៣៩, ក្រិត្យវិន័យទាំង ឡាយសំរាប់គ្រួតលើការថ្វាយទ្រព្យសម្បត្តិត្រូវបានចែងប្រាប់; ៤០–៤២, សេចក្ដីឆ្មើងឆ្មៃ និងសេចក្ដីខ្ជិលច្រអូសត្រូវបានដាក់ទោស; ៤៣–៥២, អ្នកឈឺត្រូវបានព្យាបាលឲ្យជា តាមរយៈការប្រសិទ្ធិពរ និងដោយសារសេចក្ដីជំនឿ; ៥៣–៦០, ព្រះគម្ពីរគ្រួតគ្រាលើសាសនាចក្រ ហើយ ត្រូវប្រកាសប្រាប់ដល់ពិភពលោក; ៦១–៦៩, កន្លែងសំរាប់ក្រុងយេរូសាឡិមថ្មី និងសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ នឹងត្រូវបាន បង្ហាញ; ៧០–៧៣, ទ្រព្យសម្បត្តិទាំងឡាយណាដែលបានថ្វាយ នោះត្រូវយកមកប្រើប្រាស់ ដើម្បីគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ; ៧៤–៩៣, ក្រិត្យវិន័យទាំងឡាយដែលគ្រួតគ្រាលើអំពើសហាយស្មន់ អំពើកំផិត ការសំឡាប់ ការលួច និងការសារភាពទោសនោះត្រូវ បាន ចែងប្រាប់ ។*

ប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្រយើងអើយ ជាពួកអ្នកដែលបានជួបជុំគ្នា នៅក្នុងនាមយើង គឺព្រះយេស៊ូវ គ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ ជាព្រះអង្គសង្គ្រោះនៃពិភពលោក; ពីព្រោះអ្នករាល់គ្នាជឿដល់ព្រះនាមយើង ហើយកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង ។

២ យើងប្រាប់អ្នកទៀតថា ចូរប្រុងស្ដាប់ហើយឮ ហើយចូរគោរពតាមក្រិត្យវិន័យ ដែលយើងនឹងប្រទានដល់អ្នកចុះ ។

៣ ត្បិតយើងប្រាប់ជាប្រាកដថា ដរាបណាអ្នករាល់គ្នាជួបជុំគ្នា តាមព្រះបញ្ញត្តិដែលយើងបានបញ្ជាដល់អ្នក ហើយព្រមព្រៀងគ្នា ពីការណ៍មួយនេះ ហើយបានសូមដល់ព្រះវរបិតា ដោយនូវព្រះនាមយើង នោះឈ្មោះថាអ្នករាល់គ្នានឹងបានទទួលហើយ ។

៤ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា យើងប្រទានបញ្ញត្តិទី១នេះដល់អ្នកថា អ្នករាល់គ្នាត្រូវចេញទៅ ដោយនូវ

៩ *ខ* គ. និង ស. ៧២:៩–១២; ១០៧:៦៨–៧៥. ស.ប. ប៊ីស្សព.
*គ* គ. និង ស. ៥១.
១១ *ក* យ៉ូហាន ១:៤៧.
*ខ* ស.ប. ឧបាយកល.
**៤២** ២ *ក* គ. និង ស. ៥៨:២៣. ស.ប. ក្រិត្យវិន័យ.
៣ *ក* គ. និង ស. ៣៨:៣២.
*ខ* ម៉ាថាយ ១៨:១៩.

ព្រះនាមយើង គឺអ្នករាល់គ្នា លើកលែងតែ យ៉ូសែប ស៊្មីធ ជុញ្ញ័រ និងស៊ីឌនី រិកដុន ជាពួកអ្នកបំរើរបស់យើងប៉ុណ្ណោះ ។

៥ ហើយយើងប្រទានដល់ពួកគេ នូវបញ្ញត្តិមួយថា ពួកគេត្រូវចេញទៅមួយរដូវខ្លី ហើយនឹងត្រូវបានបង្ហាញប្រាប់ដោយព្រះចេស្ដានៃ ព្រះវិញ្ញាណ នៅពេលណាពួកគេត្រូវវិលមកវិញ ។

៦ ហើយអ្នករាល់គ្នាត្រូវចេញទៅ ដោយនូវព្រះចេស្ដានៃព្រះវិញ្ញាណរបស់យើង ដោយផ្សាយដំណឹងល្អរបស់យើងពីរនាក់ៗ ដោយនូវ ព្រះនាមយើង ដោយបន្លឺសម្លេងឡើង ហាក់ដូចជាសម្លេងត្រែ ដោយប្រកាសប្រាប់ព្រះបន្ទូលយើង ដូចជាពួកទេវតានៃព្រះ ។

៧ ហើយអ្នករាល់គ្នាត្រូវចេញទៅធ្វើបុណ្យជ្រមុជដោយទឹក ដោយនិយាយថា៖ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ត្បិតនគរស្ថានសួគ៌នៅជិតដៃបង្កើយ ។

៨ ហើយចេញពីទីនេះ អ្នករាល់គ្នាត្រូវចេញទៅក្នុងភូមិភាគនៃទិសខាងលិចទាំងឡាយ; ហើយដរាបណាអ្នករាល់គ្នារកឃើញពួក អ្នកដែលនឹងទទួលអ្នក នោះអ្នករាល់គ្នាត្រូវស្ថាបនាសាសនាចក្ររបស់យើងឡើង នៅគ្រប់ភូមិភាគនានា —

៩ លុះត្រាពេលនោះមកដល់ នៅពេលការណ៍នោះត្រូវបានបើកសំដែងដល់អ្នកមកពីលើ នៅពេលទីក្រុងយេរូសាឡិមថ្មីនឹងត្រូវបានរៀបចំ ដើម្បីឲ្យអ្នករាល់គ្នាអាចបានប្រមូលគ្នាតែមួយ ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចបានទៅជារាស្ត្ររបស់យើង ហើយយើងនឹងទៅ ជាព្រះរបស់អ្នក ។

១០ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា អែតវីត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង ត្រូវបំពេញតំណែង ដែលយើងបានតែងតាំងគាត់ ។ ហើយហេតុការណ៍នឹងកើតឡើងថា បើសិនជាគាត់ប្រព្រឹត្តរំលង នោះអ្នកណាមួយផ្សេងទៀតនឹងត្រូវបានតែងតាំងឡើងជំនួសគាត់ ។ គឺដូច្នោះមែន ។ អាម៉ែន ។

១១ ជាថ្មីទៀត យើងប្រាប់អ្នកថា ការណ៍នេះមិនបានអនុញ្ញាតដល់អ្នកណាមួយ ដើម្បីឲ្យចេញទៅផ្សាយដំណឹងល្អរបស់យើង ឬដើម្បីឲ្យ ស្ថាបនាសាសនាចក្ររបស់យើងឡើងឡើយ លើកលែងតែអ្នកនោះបានតែងតាំងឡើង ដោយនរណាម្នាក់ដែលមានសិទ្ធិអំណាច ហើយដែលបានស្គាល់ដោយសាសនាចក្រ ថាអ្នកនោះមានសិទ្ធិអំណាច ហើយបានតែងតាំងដោយត្រឹមត្រូវ ដោយពួកអ្នកដឹកនាំនៃ សាសនាចក្រ ។

១២ ហើយជាថ្មីទៀត ពួកអែលឌើរ ពួកសង្ឃ និងពួកគ្រូក្នុងសាសនាចក្រនេះ ត្រូវបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន គឺជាភាពពោរពេញនៃដំណឹងល្អ ។

១៣ ហើយពួកគេត្រូវគោរព ដើម្បីធ្វើតាមសេចក្ដីសញ្ញា និងមាត្រាទាំងឡាយនៃសាសនាចក្រ ហើយអ្វីៗទាំងនេះ ត្រូវទៅជាសេចក្ដីបង្រៀនរបស់ពួកគេ ដូចជាពួកគេនឹងត្រូវបានដឹកនាំពីព្រះវិញ្ញាណ ។

១៤ ហើយព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នក ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ; ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួល ព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ ។

១៥ ហើយគ្រប់ទាំងអស់នេះ អ្នករាល់គ្នាត្រូវគោរពធ្វើតាមដូចជាយើងបានបញ្ជា អំពីសេចក្ដីបង្រៀនរបស់អ្នក រហូតដល់ភាពពោរពេញនៃព្រះគម្ពីររបស់យើង ត្រូវបានប្រទានឲ្យមកសិន ។

១៦ ហើយដូចជាអ្នករាល់គ្នាត្រូវបន្លឺសម្លេងរបស់អ្នកឡើង ដោយព្រះដ៏ជាជំនួយ នោះអ្នករាល់គ្នាក៏ត្រូវនិយាយ ហើយព្យាករ ដូចដែល យើញថាល្អដល់យើង;

១៧ ត្បិតមើលចុះ ព្រះដ៏ជាជំនួយ ទ្រង់ជ្រាបគ្រប់ទាំងអស់ ហើយធ្វើទីបន្ទាល់ពីព្រះវរបិតា និងពីព្រះរាជបុត្រា ។

---

៥ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៦ *ក* ម៉ាកុស ៦:៧.
ស.ប. កិច្ចការផ្សាយសាសនា.
៩ *ក* គ. និង ស. ៥៧:១–២.
*ខ* អេធើរ ១៣:២–១១;
គ. និង ស. ៤៥:៦៦–៧១;
៨៤:២–៥;
ម៉ូសេ ៧:៦២; ម. នៃ ស. ១:១០.
ស.ប. ក្រុងយេរូសាឡិមថ្មី.
*គ* ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ឃ* សាការី ៨:៨.
១០ *ក* គ. និង ស. ៤១:៩–១១;
១២៤:១៩.
*ខ* គ. និង ស. ៦៤:៤០.
១១ *ក* ស.ប. ផ្សាយ.
*ខ* ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ; តែងតាំង, ការតែងតាំង.
*គ* ស.ប. សិទ្ធិអំណាច; បព្វជិតភាព.
១២ *ក* ស.ប. អែលឌើរ.
*ខ* ម៉ូសាយ ១៨:១៩–២០;
គ. និង ស. ៥២:៩, ៣៦.
ស.ប. បង្រៀន, គ្រូបង្រៀន.
*គ* ស.ប. ព្រះគម្ពីរប៊ីប.
*ឃ* ស.ប. ព្រះគម្ពីរមរមន; បទព្រះ
គម្ពីរ — តម្លៃនៃព្រះគម្ពីរ.
*ង* ស.ប. ដំណឹងល្អ.
១៤ *ក* គ. និង ស. ៦៣:៦៤.
ស.ប. ការអធិស្ឋាន.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ;
បង្រៀន, គ្រូបង្រៀន —
ការបង្រៀនដោយនូវព្រះវិញ្ញាណ.
១៥ *ក* គ. និង ស. ៤២:៥៦–៥៨.
១៦ *ក* ១ កូរិន. ២:១០–១៤;
គ. និង ស. ៦៨:២–៤.
ស.ប. ព្រះដ៏ជាជំនួយ.

១៨ ហើយឥឡូវនេះ មើលចុះ យើងមានបន្ទូលដល់សាសនា
ចក្រ ។ កុំឲ្យ[ក]សំឡាប់មនុស្សឲ្យសោះ; [ខ]ហើយអ្នកណាដែលសំឡាប់
នោះនឹងពុំបានការអត់ទោសឡើយ ទោះនៅនាលោកិយនេះ
ឬនៅបរលោកនាយក្តី ។
១៩ ហើយជាថ្មីទៀត យើងប្រាប់ថា កុំឲ្យសំឡាប់មនុស្សឲ្យ
សោះ; ប៉ុន្តែអ្នកណាដែលសំឡាប់ នោះនឹងត្រូវ[ក]ស្លាប់ ។
២០ ចូរកុំឲ្យ[ក]លួចប្លន់ឲ្យសោះ; អ្នកណាដែលលួចប្លន់ ហើយមិន
ប្រែចិត្ត នោះនឹងត្រូវបណ្តេញចេញ ។
២១ កុំឲ្យ[ក]កុហកឲ្យសោះ; អ្នកណាដែលកុហក ហើយមិន
ប្រែចិត្ត នោះនឹងត្រូវបណ្តេញចេញ ។
២២ ត្រូវ[ក]ស្រឡាញ់ប្រពន្ធខ្លួន ឲ្យអស់អំពីចិត្ត ហើយត្រូវ
[ខ]នៅជាប់នឹងនាង ហើយគ្មាននរណាទៀតឡើយ ។
២៣ ហើយអ្នកណាដែលក្រឡេកឃើញស្ត្រី ហើយមាន
[ក]ដំរេកសំរើបចង់បាន នោះនឹងបោះបង់ចោលសេចក្តីជំនឿ ហើយ
នឹងមិនត្រូវមាន ព្រះវិញ្ញាណឡើយ; ហើយបើសិនជាអ្នកនោះ
មិនប្រែចិត្តទេ នោះនឹងត្រូវបណ្តេញចេញ ។
២៤ កុំឲ្យ[ក]ផិតគ្នាឲ្យសោះ; ហើយអ្នកណាដែលផិតគ្នា ហើយ
មិនប្រែចិត្តទេ នោះនឹងត្រូវបណ្តេញចេញ ។
២៥ ប៉ុន្តែអ្នកណាដែលផិតគ្នា ហើយ[ក]ប្រែចិត្តដោយអស់
អំពីចិត្ត ហើយបោះបង់ចោលអំពើនោះ ហើយមិនប្រព្រឹត្តទៀតទេ
នោះអ្នកត្រូវ [ខ]អភ័យទោសឲ្យ;
២៦ ប៉ុន្តែបើសិនជាអ្នកនោះប្រព្រឹត្ត[ក]ទៀត អ្នកនោះនឹងមិនត្រូវ
អភ័យទោសឲ្យឡើយ ប៉ុន្តែនឹងត្រូវបណ្តេញចេញវិញ ។
២៧ កុំឲ្យ[ក]និយាយអាក្រក់ពីអ្នកជិតខាងខ្លួនឲ្យសោះ ឬធ្វើទុក្ខ
អ្វីដល់គាត់ឡើយ ។
២៨ អ្នកដឹងពីក្រិត្យវិន័យទាំងឡាយរបស់យើង ដែលស្តី
អំពីការណ៍ទាំងនេះ ត្រូវបានប្រទានឲ្យនៅក្នុងព្រះគម្ពីររបស់យើង
ហើយ; អ្នកណាដែលធ្វើបាប ហើយមិនប្រែចិត្តទេ នោះនឹង
ត្រូវ[ក]បណ្តេញចេញ ។
២៩ បើសិនជាអ្នក[ក]ស្រឡាញ់យើង ចូរ[ខ]បំរើយើង ហើយ[គ]កាន់
តាមបញ្ញត្តិទាំងអស់របស់យើងចុះ ។
៣០ ហើយមើលចុះ ចូរនឹកដល់[ក]មនុស្សទាល់ក្រ ហើយ
[ខ]ថ្វាយទ្រព្យសម្បត្តិទាំងឡាយរបស់ខ្លួន សំរាប់[គ]គាំទ្រពួកគេ នូវអ្វី
ៗដែលអ្នកមាន ដើម្បីចែករំលែកដល់ពួកគេ ដោយសេច
ក្តីសញ្ញា និងសំបុត្រស្នាម ដែលមិនអាចផ្តាច់បាន ។
៣១ ហើយដរាបណាអ្នករាល់គ្នា[ក]ចែករំលែកទ្រព្យដល់[ខ]មនុស្ស
ទាល់ក្រ នោះឈ្មោះថា បានធ្វើដល់យើងដែរ; ហើយចូរ
ដាក់ទ្រព្យទាំង នោះនៅខាងមុខ[គ]ប៊ីស្សពនៃសាសនាចក្ររបស់យើង
និងទីប្រឹក្សាទាំងឡាយរបស់គាត់ គឺអែលឌើរ ឬសង្ឃជាន់ខ្ពស់
ពីរនាក់ ហាក់ដូចជា អ្នកនោះត្រូវបានតែងតាំង ឬបានតែងតាំង
ហើយ[ឃ]ញែកចេញ សំរាប់គោលបំណងនោះ ។
៣២ ហើយហេតុការណ៍នឹងកើតឡើងថា បន្ទាប់ពីបានដាក់
ទ្រព្យទាំងនោះ នៅខាងមុខប៊ីស្សពនៃសាសនាចក្ររបស់យើង
និងបន្ទាប់ពី គាត់បានទទួលទីបន្ទាល់ទាំងនេះ ស្តី[ក]អំពីការ
ថ្វាយទ្រព្យសម្បត្តិទាំងឡាយនៃសាសនាចក្ររបស់យើង ដើម្បី
កុំឲ្យទ្រព្យសម្បត្តិទាំងនេះ ត្រូវបានយកពីសាសនាចក្រឡើយ

១៨ *ក* និក្ខ. ២០:១៣–១៧;
ម៉ាថាយ ៥:២១–៣៧;
២ នីហ្វៃ ៩:៣៥;
ម៉ូសាយ ១៣:២១–២៤;
៣ នីហ្វៃ ១២:២១–៣៧.
*ខ* ស.ប. ឃាតកម្ម.
១៩ *ក* ស.ប. ការដាក់ទោសដល់ជីវិត.
២០ *ក* ស.ប. លួច, ការលួច.
២១ *ក* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់;
សេចក្តីកុហក.
២២ *ក* ស.ប. សេចក្តីស្រឡាញ់;
អាពាហ៍ពិពាហ៍,
រៀបអាពាហ៍ពិពាហ៍.
*ខ* លោកុ. ២:២៣–២៤; អេភេ.
៥:២៥, ២៨–៣៣.
២៣ *ក* ម៉ាថាយ ៥:២៨;
៣ នីហ្វៃ ១២:២៨;
គ. និង ស. ៦៣:១៦.
ស.ប. សំរេកស្រើប.
២៤ *ក* ស.ប. អំពើកំផិត.
២៥ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* យ៉ូហាន ៨:៣–១១.
ស.ប. អត់ទោស, អភ័យទោស.
២៦ *ក* ២ ពេត្រុស ២:២០–២២;
គ. និង ស. ៨២:៧.
២៧ *ក* ស.ប. និយាយដើម.
២៨ *ក* ស.ប. ការកាតឲ្យចេញពីសាសនា.
២៩ *ក* យ៉ូហាន ១៤:១៥, ២១.
*ខ* ស.ប. ការបំរើ.
*គ* ស.ប. ការគោរព, ដែលគោរព,
គោរព.
៣០ *ក* ម៉ូសាយ ៤:១៦–២៦;
អាលម៉ា ១:២៧.
ស.ប. មនុស្សក្រីក្រ.
៣០ *ខ* ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ.
*គ* ស.ប. សុខុមាលភាព.
៣១ *ក* ម៉ូសាយ ២:១៧.
ស.ប. ទាន, ការដាក់ទាន.
*ខ* ស.ប. មនុស្សក្រីក្រ.
*គ* ស.ប. ប៊ីស្សព.
*ឃ* ស.ប. ការញែកចេញ.
៣២ *ក* គ. និង ស. ៥១:៤.

ដោយយល់ព្រមតាមបញ្ញត្តិទាំងឡាយរបស់យើងរួចហើយ នោះមនុស្សគ្រប់រូបនឹងត្រូវបានធ្វើឲ្យ ទទួលខុសត្រូវចំពោះយើង គឺធ្វើជានាយតម្រួតការលើទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្វីដែលគាត់បានទទួល ដោយសារការថ្វាយ ដែលច្រើន គ្រប់គ្រាន់សំរាប់ខ្លួននិងគ្រួសារ ។

៣៣ ហើយជាថ្មីទៀត បើសិនជាមានទ្រព្យសម្បត្តិទាំងឡាយ នៅក្នុងកណ្ដាប់ដៃនៃសាសនាចក្រ ឬនៅក្នុងដៃអ្នកណាមួយនៃសាសនាចក្រ នោះមានច្រើនជាងដែលត្រូវការសំរាប់ការគាំទ្រដល់ពួកគេ បន្ទាប់ពីការថ្វាយដំបូងនេះ គឺដែលនៅសល់ទាំងប៉ុន្មាន នោះត្រូវថ្វាយដល់ប៊ីស្សព ទ្រព្យសម្បត្តិនោះនឹងត្រូវរក្សាទុក ដើម្បីឧបត្ថមចែកដល់អស់អ្នកណាដែលពុំមានម្ដងម្កាល ប្រយោជន៍ឲ្យ មនុស្សគ្រប់រូបណាដែលត្រូវការ អាចបានផ្គត់ផ្គង់ ហើយទទួលតាមដែលគេប៉ងប្រាថ្នា ។

៣៤ ហេតុដូច្នេះហើយ របស់ដែលនៅសល់ទាំងប៉ុន្មាន នឹងត្រូវរក្សាទុកនៅក្នុងឃ្លាំងរបស់យើង ដើម្បីឧបត្ថម្ភចែកដល់មនុស្សទាល់ក្រ និងមនុស្ស កំសត់ទុគ៌ត ដូចដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាជាន់ខ្ពស់ នៃសាសនាចក្រ ហើយប៊ីស្សព និងក្រុមប្រឹក្សារបស់គាត់ ។

៣៥ ហើយសំរាប់គោលបំណងនៃការទិញដីធ្លី សំរាប់ប្រយោជន៍ដល់សមាជិកទូទៅនៃសាសនាចក្រ និងការកសាងសាលាសំរាប់ថ្វាយបង្គំទាំងឡាយ និងការស្ថាបនាក្រុងយេរូសាឡិមថ្មីឡើង ដែលនឹងបានបើកសំដែងប្រាប់បន្ទាប់ពីពេលនេះទៅ —

៣៦ ប្រយោជន៍ឲ្យរាស្ត្ររបស់យើង ដែលនៅក្នុងសេចក្ដីសញ្ញា អាចបានប្រមូលគ្នាតែមួយ នៅក្នុងថ្ងៃនោះ កាលដែលយើងនឹងយាង មកព្រះវិហាររបស់យើង ។ ហើយការនេះយើងធ្វើសំរាប់សេចក្ដីសង្គ្រោះដល់រាស្ត្ររបស់យើង ។

៣៧ ហើយហេតុការណ៍នឹងកើតឡើងថា អ្នកណាដែលធ្វើបាប ហើយមិនប្រែចិត្តសោះ នោះនឹងត្រូវបណ្ដេញចេញពីសាសនាចក្រ ហើយនឹងមិនត្រូវទទួលទៀតឡើយ នូវអ្វីដែលគេបានថ្វាយដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌តនៃសាសនាចក្ររបស់យើង ឬម្យ៉ាងទៀតដល់យើង —

៣៨ ត្បិតដរាបណាអ្នករាល់គ្នាធ្វើការទាំងនេះ ដល់អ្នកតូចបំផុតក្នុងពួកមនុស្សទាំងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ ។

៣៩ ត្បិតហេតុការណ៍នឹងកើតឡើងថា អ្វីៗដែលយើងមានបន្ទូល ដោយមាត់នៃពួកព្យាការីរបស់យើង នោះនឹងត្រូវបានសំរេច; ត្បិតយើងនឹងយកទ្រព្យសម្បត្តិទាំងឡាយ នៃអស់អ្នកណាដែលឱបក្រសោបដំណឹងល្អរបស់យើង ក្នុងចំណោមពួកមនុស្សដទៃ ឲ្យដល់មនុស្សទាល់ក្រក្នុងរាស្ត្រយើង ដែលជាវង្សអ៊ីស្រាអែល ។

៤០ ហើយជាថ្មីទៀត កុំឲ្យមានសេចក្ដីឆ្មើងឆ្មៃក្នុងចិត្តឲ្យសោះ; ចូរឲ្យសំលៀកបំពាក់ទាំងអស់របស់អ្នកមានសម្បុរធម្មតា ហើយឲ្យសម្រស់នៃសំលៀកបំពាក់របស់អ្នក ទៅជាសម្រស់ពីស្នាដៃរបស់អ្នកចុះ;

៤១ ហើយចូរឲ្យគ្រប់ទាំងអស់ បានធ្វើដោយភាពស្អាតបាតនៅចំពោះយើង ។

៤២ កុំឲ្យខ្ជិលច្រអូសឲ្យសោះ; ត្បិតអ្នកណាដែលខ្ជិលច្រអូស នោះនឹងមិនត្រូវបរិភោគអាហារ ឬស្លៀកពាក់សំលៀកបំពាក់នៃអ្នកដែល ធ្វើការនោះឡើយ ។

៤៣ ហើយអស់អ្នកណាដែលឈឺនៅក្នុងចំណោមអ្នក ហើយឥតមានសេចក្ដីជំនឿ ដើម្បីឲ្យបានជាស្បើយ ប៉ុន្តែជឿ នោះនឹងត្រូវបាន ថែទាំឲ្យចំណីដោយអស់ពីភាពទន់ភ្លន់ ដោយរុក្ខជាតិ និងអាហារសាបៗ ហើយពុំត្រូវធ្វើដោយដៃនៃខ្មាំងសត្រូវឡើយ ។

៤៤ ហើយពួកអែលឌើរនៃសាសនាចក្រពីរនាក់ ឬលើស នឹងត្រូវហៅ ហើយត្រូវអធិស្ឋានឲ្យ ហើយដាក់ដៃលើពួកគេ ដោយនូវព្រះនាមរបស់យើង; ហើយបើសិនជាពួកគេស្លាប់ នោះពួក

---

៣២ *ខ* គ. និង ស. ៧២:៣–១១.
ស.ប. ទទួលខុសត្រូវ,
ចេះទទួលខុសត្រូវ,
ការទទួលខុសត្រូវ.
*គ* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
*ឃ* គ. និង ស. ៥១:៣.
៣៣ *ក* គ. និង ស. ៤២:៥៥;
៥១:១៣; ១១៩:១–៣.
៣៥ *ក* ស.ប. ក្រុងយេរូសាឡិមថ្មី; ស៊ីយ៉ូន.
៣៦ *ក* គ. និង ស. ៣៦:៨.
*ខ* ម៉ាឡាគី ៣:១.
៣៧ *ក* គ. និង ស. ៤១:៥; ៥០:៨–៩.
ស.ប. ការកាត់ឲ្យចេញពីសាសនា.
*ខ* ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ.
៣៨ *ក* ម៉ាថាយ ២៥:៣៤–៤០.
ស.ប. សេចក្ដីសប្បុរស;
សុខុមាលភាព.
៤០ *ក* សុភា. ១៦:៥.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
៤០ *ខ* ស.ប. ភាពរម្យទម.
៤២ *ក* គ. និង ស. ៦៨:៣០–៣២.
ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
៤៣ *ក* ស.ប. ឈឺ, ជម្ងឺ.
៤៤ *ក* ស.ប. ការប្រសិទ្ធិពរដល់មនុស្សឈឺ;
ដៃ, ការដាក់.

គេនឹង[ខ]ស្លាប់ដើម្បីយើង ហើយបើសិនជាពួកគេរស់ នោះពួកគេនឹងរស់ ដើម្បីយើងដែរ ។

៤៥ ចូរ[ក]រស់នៅជាមួយគ្នា ដោយនូវ[ខ]សេចក្ដីស្រឡាញ់ រហូតដល់អ្នកត្រូវ[គ]យំសោក ចំពោះការបាត់បង់នៃមនុស្សដែលស្លាប់ ហើយជាពិសេសទៀត ចំពោះអស់អ្នកណាដែលគ្មាន[ឃ]សេចក្ដីសង្ឃឹម ដល់ដំណើររស់ឡើងវិញដ៏រុងរឿង ។

៤៦ ហើយហេតុការណ៍នឹងកើតឡើងថា អស់អ្នកណាដែលស្លាប់ក្នុងយើង នោះនឹងមិនត្រូវភ្លក់[ក]សេចក្ដីស្លាប់ឡើយ ត្បិតសេចក្ដីស្លាប់ នឹងបានទៅជា[ខ]សេចក្ដីផ្អែមល្ហែមដល់ពួកគេវិញ ។

៤៧ ហើយពួកអ្នកដែលពុំបានស្លាប់ក្នុងយើងទេ នោះវេទនាដល់ពួកគេហើយ ត្បិតសេចក្ដីស្លាប់របស់ពួកគេ គឺជាសេចក្ដីល្វីងជូរចត់ ។

៤៨ ហើយជាថ្មីទៀត ហេតុការណ៍នឹងកើតឡើងថា អ្នកណាដែលមាន[ក]សេចក្ដីជំនឿជឿដល់យើង ដើម្បីឲ្យបាន[ខ]ជាស្បើយ ហើយដែល [គ]ពុំបានកំណត់ឲ្យស្លាប់ នោះនឹងត្រូវបានជាស្បើយហើយ ។

៤៩ អ្នកណាដែលមានសេចក្ដីជំនឿ ដើម្បីឲ្យបានមើលឃើញ នោះនឹងត្រូវបានមើលឃើញ ។

៥០ អ្នកណាដែលមានសេចក្ដីជំនឿ ដើម្បីឲ្យបានស្ដាប់ឮ នោះនឹងត្រូវបានស្ដាប់ឮ ។

៥១ មនុស្សខ្វិនណាដែលមានសេចក្ដីជំនឿ ដើម្បីឲ្យបានលោតរួច នោះនឹងត្រូវបានលោតរួច ។

៥២ ហើយពួកអ្នកណាដែលពុំមានសេចក្ដីជំនឿ ដើម្បីធ្វើការទាំងនេះ ប៉ុន្តែជឿដល់យើង នោះមានអំណាច ដើម្បីត្រឡប់ទៅជា[ក]កូន របស់យើង ហើយដរាបណាពួកគេមិនបានបំពាក់ក្រិត្យវិន័យទាំងឡាយរបស់យើងទេ នោះអ្នកត្រូវ[ខ]ទ្រាំទ្រនឹងជំងឺឈឺស្កាត់របស់ពួកគេ ផង ។

៥៣ ចូរឈរក្នុងកន្លែងនៃ[ក]ការកាន់កាប់ត្រួតត្រារបស់អ្នកចុះ ។

៥៤ កុំឲ្យយកសំលៀកបំពាក់របស់បងប្អូនរបស់អ្នកឲ្យសោះ អ្នកត្រូវបង់ថ្លៃចំពោះអ្វីដែលអ្នកបានទទួលពីបងប្អូនរបស់អ្នកវិញ ។

៥៥ ហើយបើសិនជាអ្នក[ក]បានទទួលច្រើនជាងដែលត្រូវការសំរាប់គាំទ្រខ្លួន នោះអ្នកត្រូវឲ្យទៅ[ខ]ឃ្លាំងរបស់យើង ដើម្បីឲ្យគ្រប់ទាំងអស់អាចបានសំរេច តាមអ្វីដែលយើងបានមានបន្ទូលមក ។

៥៦ ចូរសូម ហើយ[ក]បទគម្ពីររបស់យើងនឹងត្រូវបានប្រទានឲ្យមកដូចជាយើងបានកំណត់ទុក ហើយបទគម្ពីរទាំងនោះនឹងត្រូវបាន[ខ]រក្សាទុក ឲ្យបានគង់វង្ស ក្នុងកន្លែងមានសុវត្ថិភាព;

៥៧ ហើយជាការចាំបាច់ដែលអ្នកគួរនៅស្ងៀមស្ងាត់អំពីពួកគេ ហើយចូរកុំបង្រៀនបទគម្ពីរទាំងនោះឡើយ លុះត្រាអ្នករាល់គ្នាបាន ទទួល បទគម្ពីរទាំងនោះសព្វគ្រប់សិន ។

៥៨ ហើយយើងប្រទានបញ្ញត្តិមួយដល់អ្នកថា នៅពេលនោះអ្នកត្រូវបង្រៀនបទគម្ពីរទាំងនោះ ដល់មនុស្សទាំងអស់; ត្បិតបទគម្ពីរទាំងនោះ នឹងត្រូវបានបង្រៀនដល់[ក]គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ។

៥៩ ចូរយកអ្វីៗដែលអ្នកបានទទួលមក ដែលបានប្រទានដល់អ្នក នៅក្នុងព្រះគម្ពីររបស់យើង ទុកសំរាប់ជាក្រិត្យវិន័យ ទៅធ្វើជាក្រិត្យ វិន័យ ដើម្បីត្រួតត្រាសាសនាចក្ររបស់យើងចុះ;

៦០ ហើយអ្នកណាដែល[ក]ធ្វើតាមការទាំងនេះ នោះនឹងបានសង្គ្រោះ ហើយអ្នកណាដែលពុំបានធ្វើតាមការទាំងនេះទេ នោះនឹងត្រូវ[ខ]ជាប់ ទោស បើសិនជាអ្នកនោះនៅតែធ្វើតទៅទៀត ។

៦១ បើសិនជាអ្នកសូម នោះអ្នកនឹងបានទទួល[ក]វិវរណៈថែមទៅលើវិវរណៈ [ខ]ដំរិះថែមទៅលើដំរិះ ដើម្បីឲ្យអ្នកអាចបាន

៤៤ *ខ* រ៉ូម ១៤:៨; វិវរ. ១៤:១៣;
គ. និង ស. ៦៣:៤៩.
៤៥ *ក* ១ យ៉ូហាន ៤:១៦, ២០–២១.
*ខ* ស.ប. សេចក្ដីស្រឡាញ់.
*គ* អាលម៉ា ២៨:១១–១២.
*ឃ* ១ កូរិន. ១៥:១៩–២២.
ស.ប. សេចក្ដីសង្ឃឹម.
៤៦ *ក* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
*ខ* វិវរ. ១៤:១៣.
៤៨ *ក* គ. និង ស. ៤៦:១៩.
ស.ប. សេចក្ដីជំនឿ.
*ខ* ស.ប. ប្រោស, ការប្រោស.
*គ* សាស្ដា ៣:១–២;
កិច្ចការ ១៧:២៦; ហេព្រើរ ៩:២៧;
គ. និង ស. ១២២:៩.
៥២ *ក* ស.ប. បុត្រាបុត្រីនៃព្រះ.
*ខ* រ៉ូម ១៥:១.
ស.ប. សេចក្ដីប្រកប.
៥៣ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
៥៥ *ក* គ. និង ស. ៨២:១៧–១៩;
១១៩:១–៣.
*ខ* គ. និង ស. ៤២:៣៤; ៥១:១៣.
៥៦ *ក* ការនិយាយបញ្ចៀងអំពីការបកប្រែ
ព្រះគម្ពីរប៊ីប ។
គ. និង ស. ៤៥:៦០–៦១.
*ខ* ស.ប. បទព្រះគម្ពីរ —
តម្លៃនៃព្រះគម្ពីរ.
៥៨ *ក* គ. និង ស. ១:២.
៦០ *ក* គ. និង ស. ៤១:៥.
ស.ប. ការគោរព, ដែលគោរព,
គោរព.
*ខ* ម៉ូសេ ៥:១៥.
ស.ប. សេចក្ដីជាប់ទោស.
៦១ *ក* ស.ប. វិវរណៈ.
៦១ *ខ* អ័ប្រា. ១:២.
ស.ប. ដំរិះ; ទីបន្ទាល់.

ស្គាល់[គ]សេចក្ដីអាថ៌ កំបាំងទាំងឡាយ និងរបស់ទាំងឡាយ ដ៏[ឃ]ប្រកបដោយសេចក្ដីសុខសាន្ត — ដែលនឹងនាំឲ្យមានសេចក្ដីអំណរ ជាអ្វីដែលនាំឲ្យមានជីវិត ដ៏នៅអស់កល្បជានិច្ច ។

៦២ ចូរសូម ហើយនឹងត្រូវបានបើកសំដែងដល់អ្នក តាមពេលដែលយើងកំណត់ ពីកន្លែងដែល[ក]ក្រុងយេរូសាឡិមថ្មីនឹងត្រូវបានសង់ ។

៦៣ ហើយមើលចុះ ហេតុការណ៍នឹងកើតឡើងថា ពួកអ្នកបំរើរបស់យើង នឹងត្រូវបានចាត់ឲ្យចេញទៅទិសខាងកើត ទៅទិសខាងលិច ទៅទិសខាងជើង និងទៅទិសខាងត្បូង ។

៦៤ ហើយសូម្បីតែពេលឥឡូវនេះ ចូរឲ្យអ្នកណាដែលទៅទិសខាងកើត បង្រៀនពួកអ្នកដែលនឹងប្រែចិត្តជឿ ឲ្យភៀសខ្លួនចេញទៅ[ក]ទិសខាងលិច ហើយនេះនៅក្នុងលំដាប់អំពីអ្វីដែលនឹងមកលើផែនដី និងអំពី[ខ]បក្សព័ន្ធសម្ងាត់ទាំងឡាយ ។

៦៥ មើលចុះ ចូរគោរពតាមគ្រប់ការណ៍ទាំងអស់នេះចុះ ហើយរង្វាន់របស់អ្នកនឹងបានធំណាស់ហ្ន៎ ត្បិតចំពោះអ្នក ត្រូវបានអនុញ្ញាតឲ្យ ដឹងសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ ប៉ុន្តែចំពោះមនុស្សលោក ពុំបានអនុញ្ញាតឲ្យដឹងឡើយ ។

៦៦ អ្នករាល់គ្នាត្រូវគោរពតាមក្រិត្យវិន័យទាំងឡាយ ដែលអ្នករាល់គ្នាបានទទួល ហើយចូរមានចិត្តស្មោះត្រង់ចុះ ។

៦៧ ហើយបន្ទាប់ពីពេលនេះទៅ អ្នករាល់គ្នានឹងបានទទួល[ក]សេចក្ដីសញ្ញាទាំងឡាយ សំរាប់សាសនាចក្រ ដូចដែលបានគ្រប់គ្រាន់ ដើម្បី តាំងអ្នកឡើង ព្រមទាំងនៅទីនេះ និងនៅក្នុងក្រុងយេរូសាឡិមថ្មី ។

៦៨ ហេតុដូច្នេះហើយ អ្នកណាដែលខ្វះ[ក]ប្រាជ្ញា មានតែសូមដល់យើង ហើយយើងនឹងប្រទានដល់អ្នកនោះ ដោយសន្ធាឥតបន្ទោស ផង ។

៦៩ ចូរលើកចិត្តឡើង ហើយអរសប្បាយចុះ ត្បិតដល់អ្នកនោះ[ក]នគរ ឬម្យ៉ាងទៀត [ខ]កូនសោទាំងឡាយនៃសាសនាចក្រត្រូវបានប្រទានឲ្យហើយ ។ គឺដូច្នោះមែន ។ អាម៉ែន ។

៧០ [ក]ពួកសង្ឃ និង[ខ]ពួកគ្រូត្រូវមាន[គ]ការកាន់កាប់ត្រួតត្រារបស់ខ្លួន ដូចជាសមាជិកផងទាំងឡាយ ។

៧១ ហើយពួកអែលឌើរ ឬពួកសង្ឃជាន់ខ្ពស់ណាដែលបានតែងតាំងឲ្យជួយប៊ីស្សព ជាទីប្រឹក្សា ក្នុងគ្រប់ការណ៍ទាំងអស់នោះត្រូវឲ្យ គាំទ្រគ្រួសាររបស់ពួកគេ ចេញពីទ្រព្យសម្បត្តិ ដែល[ក]បានថ្វាយដល់ប៊ីស្សព សំរាប់ប្រយោជន៍ល្អដល់មនុស្សទាល់ក្រ និងសំរាប់ប្រយោជន៍ ផ្សេងៗទៀត ដូចជាបានពោលដល់ហើយនោះ;

៧២ ឬក៏ពួកគេត្រូវទទួលសំណងត្រឹមត្រូវ ចំពោះការទាំងអស់ដែលពួកគេបំរើ ចំពោះការកាន់កាប់ត្រួតត្រា ឬការផ្សេងៗទៀត ដូចដែលឃើញថាល្អបំផុត ឬដែលបានសំរេចដោយទីប្រឹក្សាទាំងឡាយ និងប៊ីស្សព ។

៧៣ ហើយប៊ីស្សពក៏ត្រូវទទួលការគាំទ្រដល់ខ្លួនដែរ ឬក៏សំណងត្រឹមត្រូវ ចំពោះការទាំងអស់ ដែលគាត់បំរើនៅក្នុងសាសនាចក្រ ។

៧៤ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា អស់អ្នកណាក៏ដោយនៅក្នុងចំណោមអ្នក ដែលបានលែងគូស្រករបស់ខ្លួនចេញ ហេតុតែមកពី[ក]សហាយស្មន់ ឬម្យ៉ាងទៀត បើសិនជាពួកគេនឹងធ្វើទីបន្ទាល់នៅចំពោះមុខអ្នក ដោយអស់ពីចិត្តដ៏សុភាពរាបសា ថានេះជាហេតុមែន នោះអ្នករាល់គ្នាមិនត្រូវបណ្ដេញពួកគេចេញពីចំណោមអ្នករាល់គ្នាឡើយ;

៧៥ ប៉ុន្តែបើសិនជាអ្នករាល់គ្នារកឃើញថា នរណាមួយបានទុកចោលគូស្រកររបស់ខ្លួន ព្រោះតែមានបំណង[ក]ចង់ផិត ហើយខ្លួនគេផ្ទាល់ ជាអ្នកធ្វើខុស ហើយគូស្រកររបស់ខ្លួននៅរស់នៅឡើយ ពួកអ្នកនោះហើយដែលត្រូវ[ខ]បណ្ដេញចេញពីចំណោមអ្នករាល់គ្នាវិញ ។

៧៦ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា ចូរ[ក]ចាំយាម ហើយប្រយ័ត្នប្រយែង ដោយសាកសួរឲ្យបានហ្មត់ចត់ចុះ ដើម្បីកុំឲ្យអ្នក

៦១ *គ* គ. និង ស. ៦៣:២៣.
ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*ឃ* គ. និង ស. ៣៩:៦.
*ង* ស.ប. សេចក្ដីអំណរ.
៦២ *ក* គ. និង ស. ៥៧:១–៥.
៦៤ *ក* គ. និង ស. ៤៥:៦៤.
*ខ* ស.ប. បក្សព័ន្ធសម្ងាត់.
៦៧ *ក* គ. និង ស. ៨២:១១–១៥.
៦៨ *ក* យ៉ាកុប (ព.ស.ថ.) ១:៥.
ស.ប. ប្រាជ្ញា.
៦៩ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ខ* ម៉ាថាយ ១៦:១៩;
គ. និង ស. ៦៥:២.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
៧០ *ក* ស.ប. សង្ឃ, បព្វជិតភាពអើរ៉ុន.
*ខ* ស.ប. គ្រូ, បព្វជិតភាពអើរ៉ុន.
*គ* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
៧១ *ក* ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
៧៤ *ក* ស.ប. អំពើសហាយស្មន់; អំពើកាមរាគខុសច្បាប់.
៧៥ *ក* ស.ប. អំពើកំផិត.
*ខ* ស.ប. ការកាត់ឲ្យចេញពីសាសនា.
៧៦ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.

រាល់គ្នា ទទួលមនុស្សបែបនេះ នៅក្នុងចំណោមអ្នករាល់គ្នាឡើយ បើសិនជាពួកគេបានរៀបការហើយនោះ ។

៧៧ ហើយបើសិនជាពួកគេមិនទាន់បានរៀបការទេ ពួកគេត្រូវប្រែចិត្តឲ្យអស់ពីអំពើបាបរបស់ខ្លួន បើពុំនោះសោតទេ ចូរកុំទទួលពួក គេឡើយ ។

៧៨ ហើយជាថ្មីទៀត ចូរឲ្យមនុស្សគ្រប់រូបណាដែលជាសមាជិកនៃសាសនាចក្ររបស់ព្រះគ្រីស្ទ ត្រូវគោរពកាន់តាមអស់ទាំងបញ្ញត្តិ និង សេចក្ដីសញ្ញាទាំងឡាយនៃសាសនាចក្រ ។

៧៩ ហើយហេតុការណ៍នឹងកើតឡើងថា បើសិនជានរណាមួយក្នុងចំណោមអ្នករាល់គ្នា [ក]សំឡាប់គេ នោះពួកគេនឹងត្រូវបញ្ជូន ហើយ កាត់ក្ដីតាមច្បាប់ទាំងឡាយនៃប្រទេស; ត្បិតចូរចងចាំចុះថា អ្នកនោះគ្មានការអភ័យទោសឡើយ; ហើយនឹងត្រូវបានបញ្ជាក់ តាមច្បាប់ ទាំងឡាយនៃប្រទេស ។

៨០ ហើយបើសិនជាបុរស ឬស្ត្រីណាមួយបានផិតគ្នា បុរសឬស្ត្រីនោះត្រូវយកមកកាត់ក្ដី នៅចំពោះពួកអែលឌើរពីរនាក់ ឬលើស ក្នុង សាសនាចក្រ ហើយគ្រប់ទាំងពាក្យសំដីនឹងត្រូវបានយកមកចោទបុរស ឬស្ត្រីនោះ ដោយសាក្សីពីរនាក់ក្នុងសាសនាចក្រ ហើយមិន មែនពីខ្មាំងសត្រូវទេ ប៉ុន្តែបើសិនជាមានសាក្សីច្រើនជាងពីរនាក់ នោះកាន់តែប្រសើរឡើង ។

៨១ ប៉ុន្តែបុរស ឬស្ត្រីនោះនឹងត្រូវកាត់ទោស ដោយមាត់នៃសាក្សីពីរនាក់; ហើយពួកអែលឌើរនឹងដាក់បណ្ដឹងក្ដីនៅចំពោះសាសនាចក្រ ហើយសាសនាចក្រត្រូវលើកដៃទាស់នឹងបុរស ឬស្ត្រីនោះ ប្រយោជន៍ឲ្យពួកគេអាចកាត់ក្ដីបាន តាមក្រិត្យវិន័យនៃព្រះ ។

៨២ ហើយបើសិនជាអាចធ្វើទៅបាន ជាការចាំបាច់ត្រូវមានប៊ីស្សពនៅទីនោះដែរ ។

៨៣ ហើយចូរអ្នករាល់គ្នាធ្វើ ចំពោះបណ្ដឹងគ្រប់យ៉ាង ដែលមាននៅចំពោះមុខអ្នក តាមរបៀបនេះហើយ ។

៨៤ ហើយបើសិនជាបុរស ឬស្ត្រីណាមួយបានប្លន់គេ បុរសឬស្ត្រីនោះត្រូវបញ្ជូនឡើងទៅរកច្បាប់នៃប្រទេស ។

៨៥ ហើយបើសិនជាបុរស ឬស្ត្រីនោះបាន[ក]លួចរបស់គេ បុរសឬស្ត្រីនោះត្រូវបញ្ជូនឡើងទៅរកច្បាប់នៃប្រទេស ។

៨៦ ហើយបើសិនជាបុរស ឬស្ត្រីនោះ[ក]កុហក បុរសឬស្ត្រីនោះត្រូវបញ្ជូនឡើងទៅរកច្បាប់នៃប្រទេស ។

៨៧ ហើយបើសិនជាបុរស ឬស្ត្រីនោះប្រព្រឹត្តសេចក្ដីទុច្ចរិតណាមួយ បុរស ឬស្ត្រីនោះត្រូវបញ្ជូនឡើងទៅរកច្បាប់ គឺជាក្រិត្យវិន័យនៃព្រះ ។

៨៨ ហើយបើសិនជា[ក]បងប្អូនប្រុស ឬស្រីរបស់ខ្លួនណាម្នាក់មាន[ខ]ហេតុទាស់នឹងអ្នក នោះអ្នកត្រូវជួបបងប្អូនប្រុស ឬស្រីនោះ ក្នុងកាលមាន តែអ្នកហើយនិងបងប្អូនប្រុស ឬស្រីនោះ; ហើយបើសិនជាបងប្អូនប្រុស ឬស្រីនោះ[គ]សារភាព នោះអ្នកត្រូវរាប់រកគ្នាវិញ ។

៨៩ ហើយបើសិនជាបងប្អូនប្រុស ឬស្រីនោះមិនសារភាពទេ អ្នកត្រូវបញ្ជូនបងប្អូនប្រុស ឬស្រីនោះទៅសាសនាចក្រ ពុំមែនចំពោះ សមាជិកទាំងឡាយទេ ប៉ុន្តែចំពោះពួកអែលឌើរវិញ ។ ហើយត្រូវសំរេចនៅក្នុងការប្រជុំមួយ ហើយពុំមែននៅចំពោះពិភពលោកឡើយ ។

៩០ ហើយបើសិនជាបងប្អូនប្រុស ឬស្រីរបស់ខ្លួនណាម្នាក់មានហេតុទាស់នឹងមនុស្សដ៏ច្រើន បងប្អូនប្រុស ឬស្រីនោះត្រូវ[ក]ផ្ចាញ់ផ្ចាលនៅ ចំពោះមនុស្សជាច្រើន ។

៩១ ហើយបើសិនជាជនណាមួយមានហេតុទាស់បើកមុខបុរសឬស្ត្រីនោះនឹងត្រូវបន្ទោសបើកមុខ ប្រយោជន៍ឲ្យបុរសឬស្ត្រីនោះអាច មានសេចក្ដីខ្មាស់ ។ ហើយបើសិនជាបុរសឬស្ត្រីនោះមិនសារភាពទេ បុរសឬស្ត្រីនោះនឹងត្រូវបញ្ជូនឡើងទៅរកក្រិត្យវិន័យនៃព្រះ ។

៩២ បើសិនជាជនណាមួយមានហេតុទាស់ដោយសម្ងាត់ បុរសឬស្ត្រីនោះនឹងត្រូវបន្ទោសដោយសម្ងាត់ ប្រយោជន៍ឲ្យបុរសឬស្ត្រីនោះ អាចមានឱកាស ដើម្បីសារភាពដោយសម្ងាត់ ដល់បុរស ឬស្ត្រីណាដែលបុរសឬស្ត្រីនោះបានទាស់ ហើយដល់ព្រះ ប្រយោជន៍កុំឲ្យ សាសនាចក្រអាចនិយាយបន្ទោសដល់បុរសឬស្ត្រីនោះឡើយ ។

៩៣ ហើយអ្នករាល់គ្នាត្រូវប្រព្រឹត្ត ក្នុងគ្រប់កាលៈទេសៈទាំងអស់យ៉ាងដូច្នេះហើយ ៕

៧៩ *ក* ស.ប. ឃាតកម្ម.
៨៥ *ក* ស.ប. លួច, ការលួច.
៨៦ *ក* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់; សេចក្ដីកុហក.
៨៨ *ក* ស.ប. ពួកបងប្អូនប្រុស, បងប្អូនប្រុស; បងប្អូនស្រី.
*ខ* ម៉ាថាយ ១៨:១៥–១៧.
*គ* ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
៩០ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.

## កណ្ឌទី ៤៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែកុម្ភៈ ឆ្នាំ១៨៣១ (*History of the Church, *១:១៥៤–១៥៦) ។ នៅពេលនេះ មានសមាជិកខ្លះក្នុងសាសនាចក្ររកាំចិត្ត ដោយសារមានមនុស្សអះអាងក្លែង ក្លាយថា ជាអ្នកទទួលវិវរណៈទាំងឡាយ ។ ព្យាការីបានសូមដល់ព្រះអម្ចាស់ ហើយបានទទួលការទាក់ទងនេះ ចំពោះពួកអែលឌើរ នៃសាសនាចក្រ ។ ផ្នែកទី១ ទាក់ទងទៅនឹងដំណើរការរៀបចំត្រានៃសាសនាចក្រ; ផ្នែកចុងក្រោយ មានពាក្យព្រមានដែលពួកអែលឌើរ ត្រូវប្រាប់ដល់សាសន៍ទាំងឡាយនៃផែនដី ។*

*១–៧, វិវរណៈ និងព្រះបញ្ញត្តិទាំងឡាយបានមកតាមរយៈអ្នកដែលបានតែងតាំង; ៨–១៤, ពួកបរិសុទ្ធត្រូវបានញែកចេញជាបរិសុទ្ធ ដោយ សារការប្រព្រឹត្តក្នុងបរិសុទ្ធភាពគ្រប់យ៉ាង នៅចំពោះព្រះអម្ចាស់; ១៥–២២, ពួកអែលឌើរត្រូវចាត់ឲ្យចេញទៅស្រែកប្រាប់ពីការប្រែចិត្ត ហើយប្រុងប្រៀបមនុស្សលោក ចាំថ្ងៃដ៏ធំនៃព្រះអម្ចាស់; ២៣–២៨, ព្រះអម្ចាស់ទ្រង់ហៅមនុស្សលោក ដោយសម្លេងរបស់ទ្រង់ផ្ទាល់ ហើយតាមរយៈថាមពលនៃធម្មជាតិ; ២៩–៣៥, សហស្សវត្សរ៍ និងការចងអារក្សសាតាំងនឹងមកដល់ ។*

ប្រូវប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្ររបស់យើងអើយ ហើយចូរផ្ទៀងត្រចៀកចំពោះព្រះបន្ទូលទាំងប៉ុន្មាន ដែលយើងនឹងមានបន្ទូលដល់អ្នកចុះ ។

២ ត្បិតមើលចុះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នករាល់គ្នាបានទទួលបញ្ញត្តិមួយ ទុកជា[ក]ក្រិត្យវិន័យដល់សាសនាចក្ររបស់យើង តាមរយៈអ្នកនោះ ដែលយើងបានតែងតាំងចំពោះអ្នក [ខ]ដើម្បីឲ្យទទួលបញ្ញត្តិ និងវិវរណៈទាំងឡាយ ពីព្រះហស្តរបស់យើង ។

៣ ហើយការណ៍នេះអ្នករាល់គ្នានឹងបានដឹងជាពិត — ថា គ្មានអ្នកឯទៀតណាត្រូវបានតែងតាំងចំពោះអ្នក ដើម្បីឲ្យទទួលបញ្ញត្តិ និងវិវរណៈទាំងឡាយឡើយ រហូតដល់អ្នកនោះត្រូវបានស្លាប់ទៅ បើសិនជាអ្នកនោះ[ក]នៅជាប់នឹងយើង ។

៤ ប៉ុន្តែប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា [ក]គ្មានអ្នកណាផ្សេងទៀតនឹងត្រូវបានតែងតាំងចំពោះអំណោយទាននេះឡើយ លើកលែង តែតាមរយៈអ្នកនោះប៉ុណ្ណោះ; ត្បិតបើសិនជាត្រូវដកចេញពីគាត់ នោះគាត់នឹងពុំមានអំណាចឡើយ ក្រៅពីតែងតាំងអ្នកដទៃទៀត ជំនួសគាត់ប៉ុណ្ណោះ ។

៥ ហើយការណ៍នេះនឹងត្រូវទៅជាក្រិត្យវិន័យចំពោះអ្នក ប្រយោជន៍កុំឲ្យអ្នករាល់គ្នាទទួលការបង្រៀនទាំងឡាយ ទុកជាវិវរណៈ ឬបញ្ញត្តិនានា ពីអ្នកណាដែលនឹងមកចំពោះអ្នកឡើយ;

៦ ហើយការណ៍នេះយើងប្រទានដល់អ្នក ប្រយោជន៍កុំឲ្យអ្នកអាចត្រូវគេ[ក]បញ្ឆោត ប្រយោជន៍ឲ្យអ្នកអាចបានស្គាល់ថា ការណ៍ទាំងនេះ ពុំមែនមកពីយើងឡើយ ។

៧ ត្បិតយើងប្រាប់អ្នកជាប្រាកដថា អ្នកណាដែល[ក]ត្រូវបានតែងតាំងពីយើង នោះនឹងត្រូវមកតាម[ខ]ទ្វារ ហើយបានតែងតាំងដូចជាយើង បានប្រាប់អ្នករួចស្រេចមកហើយ ដើម្បីឲ្យបង្រៀនពីវិវរណៈទាំងនោះ ដែលអ្នកបានទទួល ហើយនឹងបានទទួលតាមរយៈអ្នកនោះ ដែលយើងបានតែងតាំង ។

៨ ហើយឥឡូវនេះ មើលចុះ យើងប្រទានបញ្ញត្តិមួយដល់អ្នកថា កាលណាអ្នករាល់គ្នាជួបជុំគ្នា នោះអ្នករាល់គ្នា[ក]ត្រូវបង្គាប់ ហើយស្អាង គ្នាទៅវិញទៅមក ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចដឹងនូវរបៀបប្រព្រឹត្ត និងរបៀបដឹកនាំសាសនាចក្ររបស់យើង គឺដឹងនូវរបៀបប្រព្រឹត្ត ចំពោះចំណុចទាំងឡាយ នៃក្រិត្យវិន័យ និងបញ្ញត្តិទាំងឡាយរបស់យើង ដែលយើងបានប្រទានមក ។

៩ ហើយយ៉ាងដូច្នោះហើយ ដែលអ្នករាល់គ្នានឹងបានទទួល[ក]ការបង្គាប់ ពីក្រិត្យវិន័យនៃសាសនាចក្ររបស់យើង ហើយបាន

**៤៣** ២ *ក* គ. និង ស. ៤២.
*ខ* ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ; វិវរណៈ.
៣ *ក* យ៉ូហាន ១៥:៤.
៤ *ក* គ. និង ស. ២៨:២–៣.
៦ *ក* គ. និង ស. ៤៦:៧.
ស.ប. ការបោក, បញ្ឆោត, សេចក្ដីបញ្ឆោត.
៧ *ក* ស.ប. តែងតាំង, ការតែងតាំង.
*ខ* ម៉ាថាយ ៧:១៣–១៤; ២ នីហ្វៃ ៩:៤១; ៣១:៩, ១៧–១៨; ៣ នីហ្វៃ ១៤:១៣–១៤; គ. និង ស. ២២:១–៤.
៨ *ក* គ. និង ស. ៨៨:៧៧.
៩ *ក* ស.ប. ការញែកជាបរិសុទ្ធ.

ញែកចេញ ជាបរិសុទ្ធ ដោយសារអ្វីដែលអ្នករាល់គ្នាបានទទួលមក ហើយអ្នករាល់គ្នានឹងត្រូវចងខ្លួន ដើម្បីប្រព្រឹត្តក្នុងបរិសុទ្ធភាពគ្រប់យ៉ាង នៅ ចំពោះយើង —

១០ ព្រោះដរាបណាអ្នករាល់គ្នាធ្វើត្រឹមការណ៍នេះ នោះសិរីល្អនឹងត្រូវបានបន្ថែមទៅនឹងនគរ ដែលអ្នករាល់គ្នាបានទទួល ។ តែបើអ្នក រាល់គ្នាមិនធ្វើត្រឹមការណ៍នេះទេ នោះនឹងត្រូវដកយកវិញ សូម្បីតែអ្វីដែលអ្នករាល់គ្នាបានទទួលផង ។

១១ ចូរខ្ចាក់សេចក្ដីទុច្ចរិតដែលនៅក្នុងចំណោមអ្នករាល់គ្នាចេញ; ចូរញែកខ្លួនចេញជាបរិសុទ្ធនៅចំពោះយើងចុះ;

១២ ហើយបើសិនជាអ្នករាល់គ្នាប្រាថ្នាចង់បានសិរីល្អទាំងឡាយនៃនគរ ចូរតែងតាំងយ៉ូសែប ស៊្មីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ហើយ គាំទ្រលោកនៅចំពោះយើង ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿចុះ ។

១៣ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា បើសិនជាអ្នករាល់គ្នាប្រាថ្នាចង់បានសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ ចូរផ្គត់ផ្គង់អាហារ និងសំលៀកបំពាក់ដល់លោក និងអ្វីៗដែលលោកត្រូវការ ដើម្បីសំរេចកិច្ចការ ដែលយើងបានបញ្ជាដល់លោក;

១៤ ហើយបើសិនជាអ្នករាល់គ្នាមិនធ្វើទេ នោះលោកនឹងនៅជាមួយអ្នកណាដែលទទួលលោក ប្រយោជន៍ឲ្យយើងអាចរក្សាដល់ខ្លួនយើង នូវរាស្ត្រដ៏បរិសុទ្ធនៅចំពោះយើង ។

១៥ យើងប្រាប់ទៀតថា ឱពួកអែលឌើរនៃសាសនាចក្រយើង ដែលយើងបានតែងតាំងអើយ ចូរប្រុងស្ដាប់ចុះថា៖ អ្នករាល់គ្នាពុំមែនត្រូវ បានចាត់ឲ្យទៅទទួលការបង្រៀនទេ ប៉ុន្តែឲ្យទៅ ដើម្បីបង្រៀនកូនចៅមនុស្ស ពីអ្វីៗដែលយើងបានដាក់ក្នុងដៃរបស់អ្នក ដោយព្រះ ចេស្ដា នៃព្រះវិញ្ញាណរបស់យើងវិញ;

១៦ ហើយអ្នករាល់គ្នាត្រូវបានទទួលការបង្រៀនមកពីស្ថានលើ ។ ចូរញែកខ្លួនចេញជាបរិសុទ្ធចុះ ហើយអ្នករាល់គ្នានឹងត្រូវបានទទួល អំណោយទានដោយព្រះចេស្ដា ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចបង្រៀន ដូចជាយើងបានមានបន្ទូលមក ។

១៧ ចូរអ្នករាល់គ្នាប្រុងស្ដាប់ចុះ ត្បិតមើលចុះ ថ្ងៃដ៏ធំនៃព្រះអម្ចាស់ គឺនៅជិតដៃបង្កើយ ។

១៨ ត្បិតថ្ងៃនោះនឹងមកដល់ ដែលព្រះអម្ចាស់ទ្រង់នឹងបញ្ចេញសម្លេងពីស្ថានសួគ៌; ផ្ទៃមេឃនឹងញាប់ញ័រ ហើយផែនដីនឹងញ័ររន្ធត់ ហើយត្រែនៃព្រះនឹងបន្លឺសូរកាន់តែតន្លើនខ្លាំងឡើង ហើយនឹងប្រាប់ដល់សាសន៍ទាំងឡាយដែលលង់លក់ថា៖ អ្នករាល់គ្នាជាពួក បរិសុទ្ធអើយ ចូរភ្ញាក់ឡើង ហើយមានជីវិតរស់ចុះ; រីឯអ្នករាល់គ្នាជាអ្នកមានបាបអើយ ចូរនៅហើយលង់លក់ចុះ រហូតដល់យើងនឹង ហៅម្ដងទៀត ។

១៩ ហេតុដូច្នោះហើយ ចូរក្រវាត់ចង្កេះចុះ ក្រែងលោឃើញអ្នកនៅក្នុងចំណោមពួកទុច្ចរិត ។

២០ ចូរបន្លឺសម្លេងរបស់អ្នកឡើង ហើយចូរកុំសំចៃឡើយ ។ ចូរហៅសាសន៍ទាំងឡាយឲ្យប្រែចិត្តចុះ ទាំងមនុស្សចាស់មនុស្សក្មេង ទាំងបាវគេ និងមនុស្សសេរី ដោយនិយាយថា៖ ចូរប្រុងប្រៀបខ្លួន ចាំថ្ងៃដ៏ធំនៃព្រះអម្ចាស់ចុះ ។

២១ ត្បិតបើសិនជាខ្ញុំ ដែលជាបុរសម្នាក់ បន្លឺសម្លេងរបស់ខ្ញុំឡើង ហើយហៅអ្នកឲ្យប្រែចិត្ត ហើយអ្នករាល់គ្នាស្អប់ខ្ញុំ នោះតើអ្នកនឹង និយាយថាយ៉ាងណា ក្នុងកាលថ្ងៃនោះមកដល់ ដែលនឹងឮផ្គររលាន់ពីចុងផែនដី និយាយប្រាប់ដល់ត្រចៀកនៃមនុស្សទាំងអស់ដែលនៅ រស់ ដោយនិយាយថា — ចូរប្រែចិត្ត ហើយប្រុងប្រៀបចាំថ្ងៃដ៏ធំនៃព្រះអម្ចាស់ចុះ ?

២២ មែន ហើយជាថ្មីទៀត ក្នុងកាលរន្ទះនឹងបាញ់ពីទិសខាងកើតដល់ទិសខាងលិច ហើយនឹងបញ្ចេញសម្លេងប្រាប់ដល់មនុស្សទាំងអស់ ដែលនៅរស់ ហើយធ្វើឲ្យមនុស្សទាំងអស់ដែលឮនឹងខ្ទំត្រចៀក ដោយនិយាយពាក្យទាំងនេះថា — ចូរអ្នករាល់គ្នាប្រែចិត្តចុះ ត្បិតថ្ងៃ ដ៏ធំនៃព្រះអម្ចាស់នឹងមកដល់ហើយ ?

---

១០ *ក* អាលម៉ា ១២:១០.
*ខ* ម៉ាកុស ៤:២៥.
១១ *ក* ស.ប. អំពើបាប.
១២ *ក* ស.ប. ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ.
១៣ *ក* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
១៤ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
១៥ *ក* ស.ប. កិច្ចការផ្សាយសាសនា.
*ខ* ស.ប. បង្រៀន, គ្រូបង្រៀន — ការបង្រៀនដោយនូវព្រះវិញ្ញាណ.
១៦ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
*ខ* ស.ប. ការញែកជាបរិសុទ្ធ.
*គ* លូកា ២៤:៤៩;
គ. និង ស. ៣៨:៣២; ៩៥:៨–៩; ១១០:៨–១០.
១៧ *ក* ម៉ាឡាគី ៤:៥;
គ. និង ស. ២:១; ៣៤:៦–៩.
*ខ* គ. និង ស. ២៩:៨.
ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
១៨ *ក* យ៉ូអែល ២:១១;
គ. និង ស. ១៣៣:៥០.
*ខ* យ៉ូអែល ២:១០; ៣:១៦;
គ. និង ស. ៤៥:៤៨.
*គ* គ. និង ស. ៨៨:៨៧.
*ឃ* គ. និង ស. ២៩:១៣; ៤៥:៤៥.
*ង* ស.ប. ដំណើររស់ឡើងវិញ.
*ច* គ. និង ស. ៧៦:៨៥;
៨៨:១០០–១០១.
*ឆ* មរមន ៩:១៣–១៤.
២១ *ក* ២ នីហ្វៃ ២៧:២;
គ. និង ស. ៨៨:៩០.

២៣ ហើយជាថ្មីទៀត ព្រះអម្ចាស់នឹងបញ្ចេញសម្លេងពីស្ថានសួគ៌ ដោយមានព្រះបន្ទូលថា៖ ចូរប្រុងស្ដាប់ ឱអ្នករាល់គ្នាដែលជា សាសន៍ទាំងឡាយនៃផែនដីអើយ ហើយឮព្រះបន្ទូលទាំងឡាយនៃព្រះ ដែលបានបង្កើតអ្នកចុះ ។

២៤ ឱអ្នករាល់គ្នាដែលជាសាសន៍ទាំងឡាយនៃផែនដីអើយ តើប៉ុន្មានដងហើយ ដែលយើងចង់ប្រមូលអ្នករាល់គ្នា ដូចជា [ក]មេមាន់ក្រុង កូនវាឲ្យជ្រកក្រោមស្លាប តែអ្នករាល់គ្នា[ខ]មិនព្រមសោះ !

២៥ តើប៉ុន្មានដងហើយ ដែលយើង[ក]បានហៅអ្នក ដោយ[ខ]មាត់នៃពួកអ្នកបំរើរបស់យើង និងដោយ[គ]ការងារបំរើនៃពួកទេវតា និងដោយ សម្លេងរបស់យើងផ្ទាល់ និងដោយសូរផ្គរលាន់ និងដោយសូររន្ទះបាញ់ និងដោយសូរខ្យល់ព្យុះ និងដោយសូរផែនដីកក្រើក និងព្រិល ដ៏ធំៗ និងដោយសូរ[ឃ]អំណត់អត់ និងអាសន្នរោគគ្រប់បែបយ៉ាង និងដោយសម្លេងត្រែដ៏ខ្លាំង និងដោយសម្លេងនៃសេចក្ដីជំនុំជំរះ និង ដោយសម្លេងនៃ[ង]សេចក្ដីមេត្តាករុណាពេញមួយថ្ងៃ និងដោយសម្លេងនៃសិរីល្អ និងកិត្តិយស និងទ្រព្យសម្បត្តិខាង[ច]ជីវិតដ៏នៅអស់កល្ប ជានិច្ច ហើយនឹងជួយសង្គ្រោះអ្នក ដោយសេចក្ដីសង្គ្រោះដ៏នៅអស់កល្ប ប៉ុន្តែអ្នករាល់គ្នាមិនព្រមសោះ !

២៦ មើលចុះ ថ្ងៃនោះបានមកដល់ ក្នុងកាលពែងក្រេវក្រោធនៃសេចក្ដីក្ដៅក្រហាយរបស់យើងពេញហើយ ។

២៧ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា នេះគឺជាព្រះបន្ទូលទាំងឡាយនៃព្រះអម្ចាស់ ជាព្រះរបស់អ្នក ។

២៨ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាធ្វើការ ចូរអ្នករាល់[ក]គ្នាធ្វើការ នៅក្នុងចំការទំពាំងបាយជូររបស់យើង ជាលើកចុងក្រោយ បង្អស់ចុះ — ត្បិតជាលើកចុងក្រោយបង្អស់ ដែលហៅបណ្ដាជននៅលើផែនដី ។

២៩ ត្បិតតាមពេលដែលយើងកំណត់ នោះយើងនឹង[ក]យាងមកលើផែនដី ដើម្បីជំនុំជំរះ ហើយរាស្ត្រយើងនឹងត្រូវបានប្រោសលោះ ហើយនឹងសោយរាជ្យជាមួយយើងនៅលើផែនដី ។

៣០ ត្បិត[ក]សហស្សវត្សរ៍ដ៏ធំ ដែលយើងបានមានបន្ទូលដោយមាត់នៃពួកអ្នកបំរើរបស់យើង នោះនឹងមកដល់មែន ។

៣១ ត្បិត[ក]អារក្សសាតាំងនឹងត្រូវបាន[ខ]ចង ហើយកាលណាវាបានស្រាយលែងទៀត នោះវានឹងសោយរាជ្យតែមួយរដូវ[គ]ដ៏ខ្លីប៉ុណ្ណោះ ហើយ ខណៈនោះ [ឃ]ចុងបំផុតនៃផែនដីនឹងមកដល់ ។

៣២ ហើយអ្នកណាដែលរស់នៅដោយ[ក]សេចក្ដីសុចរិត នោះនឹង[ខ]បានផ្លាស់ប្រែក្នុងមួយប៉ប្រិចភ្នែក ហើយផែនដីនឹងកន្លងផុតទៅដូចត្រូវ ភ្លើងឆេះ ។

៣៣ ហើយពួកទុច្ចរិតនឹងចេញទៅក្នុង[ក]ភ្លើងដែលពន្លត់មិនបាន ហើយទីបញ្ចប់របស់ពួកគេនោះ គ្មាននរណានៅលើផែនដីដឹងឡើយ ឬក៏នឹងបានដឹងដែរ រហូតដល់ពួកគេមកចំពោះយើង ដើម្បីទទួល[ខ]ការជំនុំជំរះ ។

៣៤ ចូរអ្នករាល់គ្នាប្រុងស្ដាប់តាមព្រះបន្ទូលទាំងនេះចុះ ។ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ជា[ក]ព្រះអង្គសង្គ្រោះនៃ[ខ]ពិភពលោក ។ ចូរ រក្សាការណ៍ទាំងឡាយនេះ ទុកនៅក្នុងចិត្តរបស់អ្នករាល់គ្នា ហើយចូរឲ្យ[គ]ការម៉ឺងម៉ាត់ អំពីភាពអស់កល្បជានិច្ច [ឃ]ស្ថិតនៅក្នុង [ង]គំនិតរបស់ អ្នករាល់គ្នាចុះ ។

៣៥ ចូរមានចិត្តម៉ឺងម៉ាត់ ។ ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងចុះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

២៤ ក ម៉ាថាយ ២៣:៣៧; ៣ នីហ្វៃ ១០:៤–៦.
ខ ស.ប. ការបះបោរ.
២៥ ក ហេលេ. ១២:២–៤.
ខ ម៉ាថាយ ២៣:៣៤. ស.ប. ព្យាការី.
គ គ. និង ស. ៧:៦; ១៣០:៤–៥.
ឃ យេរេ. ២៤:១០; អេម៉ុស ៤:៦; គ. និង ស. ៨៧:៦; យ.ស. — ម៉ាថាយ ១:២៩.
ង ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
ច ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច; អមតៈ, អមតភាព; សេចក្ដីសង្គ្រោះ.
២៨ ក យ៉ាកុប ៥:៧១; គ. និង ស. ៣៣:៣. ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
២៩ ក ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៣០ ក ស.ប. សហស្សវត្សរ៍.
៣១ ក ១ នីហ្វៃ ២២:២៦. ស.ប. អារក្ស.
ខ គ. និង ស. ៤៥:៥៥; ៨៤:១០០; ៨៨:១១០.
គ វិវរ. ២០:៣; យ៉ាកុប ៥:៧៧; គ. និង ស. ២៩:២២.
ឃ ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
៣២ ក ស.ប. សុចរិត, សេចក្ដីសុចរិត.
ខ ១ កូរិន. ១៥:៥១–៥២; គ. និង ស. ៦៣:៥១; ១០១:៣១. ស.ប. ដំណើររស់ឡើងវិញ.
៣៣ ក ម៉ាថាយ ៣:១២.
ខ ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
៣៤ ក ស.ប. ព្រះអង្គសង្គ្រោះ.
ខ យ.ស. — ម៉ាថាយ ១:៣៧.
គ គ. និង ស. ៨៤:៦១; ១០០:៧–៨.
ឃ ស.ប. រំពឹងគិត.
ង ស.ប. គំនិត.
៣៥ ក រ៉ូម ១២:៣; គ. និង ស. ១៨:២១.

## កណ្ឌទី ៤៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី និងស៊ីឌនី រិកដុន នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ចុងខែកុម្ភៈ ឆ្នាំ១៨៣១ (*History of the Church*, ១:១៥៧) ។ ដើម្បីគោរពតាមសេចក្ដីត្រូវការដែលបានថ្លែងប្រាប់នៅក្នុងវិវរណៈនេះ សាសនាចក្រ កំណត់ឲ្យមានសន្និសីទមួយ នៅដើមខែមិថុនាខាងមុខ ។*

*១–៣, ពួកអែលឌើរត្រូវជួបជុំគ្នានៅឯសន្និសីទ; ៤–៦, ពួកគេត្រូវរៀបចំតាមច្បាប់នៃប្រទេស ហើយត្រូវថែរក្សាមនុស្សទាល់ក្រ ។*

១ មើលចុះ ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលដល់អ្នករាល់គ្នាជាពួកអ្នកបំរើរបស់យើង យ៉ាងដូច្នេះថា ជាការចាំបាច់ដល់យើង ដែលពួក អែលឌើរនៃសាសនាចក្ររបស់យើងគួរត្រូវបានហៅឲ្យមកជួបជុំគ្នា ពីទិសខាងកើត និងពីទិសខាងលិច និងពីទិសខាងជើង និងពីទិស ខាងត្បូង ដោយសំបុត្រ ឬដោយពិធីផ្សេងណាមួយ ។

២ ហើយហេតុការណ៍នឹងកើតឡើងថា ដរាបណាពួកគេមានចិត្តស្មោះត្រង់ ហើយអនុវត្តសេចក្ដីជំនឿជឿដល់យើង នោះយើងនឹងចាក់ ព្រះវិញ្ញាណរបស់យើងមកលើពួកគេ នៅក្នុងថ្ងៃដែលពួកគេជួបជុំជាមួយគ្នា ។

៣ ហើយហេតុការណ៍នឹងកើតឡើងថា ពួកគេនឹងចេញទៅក្នុងភូមិភាគជុំវិញ ហើយ*ក*ផ្សាយប្រាប់ពីការប្រែចិត្តដល់ប្រជាជន ។

៤ ហើយមនុស្សជាច្រើននឹងបាន*ក*ប្រែចិត្តជឿ ដរាបដល់អ្នករាល់គ្នានឹងបានអំណាច ដើម្បីរៀបចំខ្លួន តាមច្បាប់មនុស្ស;

៥ ប្រយោជន៍កុំឲ្យពួក*ក*ខ្មាំងសត្រូវរបស់អ្នកមានអំណាចលើអ្នកបានឡើយ; ប្រយោជន៍ឲ្យអ្នកអាចបានរក្សាទុកឲ្យគង់វង្ស ក្នុងគ្រប់ការណ៍ ទាំងអស់; ដើម្បីឲ្យអ្នកអាច កាន់តាមក្រិត្យវិន័យទាំងឡាយរបស់យើង; ប្រយោជន៍ឲ្យដាច់គ្រប់ទាំងចំណង់ ដែលខ្មាំងសត្រូវស្វែងរក ដើម្បី បំផ្លាញរាស្ដ្រយើងចោល ។

៦ មើលចុះ យើងប្រាប់អ្នកថា អ្នករាល់គ្នាត្រូវទៅ*ក*សួរសុខទុក្ខដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌ត ហើយជួយឧបត្ថម្ភដល់ការ រំដោះពួកគេផង ដើម្បីឲ្យពួកគេអាចបានថែទាំទុករហូតដល់គ្រប់ការណ៍ទាំងអស់បានសំរេច តាមក្រិត្យវិន័យរបស់យើង ដែលអ្នករាល់ គ្នាបានទទួលមក ។ អាម៉ែន ៕

## កណ្ឌទី ៤៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះសាសនាចក្រ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៧ ខែមីនា ឆ្នាំ១៨៣១ (*History of the Church*, ១:១៥៨–១៦៣) ។ ជាបុព្វកថាចំពោះបញ្ជីរបស់លោកអំពីវិវរណៈនេះ ព្យាការីថ្លែង ថា៖ «នៅក្នុងសាសនាចក្រពេលនេះ . . . មានសេចក្ដីរាយការណ៍ក្លែងក្លាយ . . . និងរឿងរ៉ាវឥតប្រយោជន៍ជាច្រើនត្រូវបានបោះពុម្ពផ្សាយ . . . ហើយចែក . . . ដើម្បីការពារកុំឲ្យមានមនុស្សមកស្រាវជ្រាវពីកិច្ចការ ឬឱបក្រសោបយកសេចក្ដីជំនឿ . . . ។ ប៉ុន្តែជាសេចក្ដីអំណរដល់ ពួកបរិសុទ្ធ . . . ខ្ញុំបានទទួលវិវរណៈដែលមានដូចតទៅនេះ» (*History of the Church*, ១:១៥៨) ។*

*១–៥, ព្រះគ្រីស្ទជាព្រះគាំទ្ររបស់យើង ជាមួយនឹងព្រះវរបិតា; ៦–១០, ដំណឹងល្អជាសារទូត ដើម្បីរៀបចំផ្លូវថ្វាយព្រះអម្ចាស់; ១១–១៥, ហេណុក និងបងប្អូនរបស់លោកត្រូវព្រះអម្ចាស់ទ្រង់ទទួលយកទៅចំពោះអង្គទ្រង់; ១៦–២៣, ព្រះគ្រីស្ទបានបង្ហាញទីសំគាល់ទាំងឡាយ អំពីការយាងមករបស់ទ្រង់ ដូចដែលបានបង្ហាញនៅលើភ្នំនៃដើមអូលីវ; ២៤–៣៨, ដំណឹងល្អនឹងបានសាងឡើងវិញ ពេលវេលានៃពួក សាសន៍ដទៃនឹងបានសំរេច ហើយជំងឺដ៏ហិនហោចខ្លោចផ្សានឹងគ្របលើផែនដី; ៣៩–៤៧, ទីសំគាល់ ការអស្ចារ្យទាំងឡាយ និងដំណើររស់ឡើងវិញនឹងកើតឡើងក្នុងការយាងមកលើកទី២; ៤៨–៥៣, ព្រះគ្រីស្ទ*

---

៤៤ ២*ក* កិច្ចការ ២:១៧.
៣*ក* ស.ប. ផ្សាយ.
៤*ក* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
*ខ* គ. និង ស. ៩៨:៥–៧.
៥*ក* ២ នីហ្វៃ ៤:៣៣.
៦*ក* យ៉ាកុប (ព.ស.ថ.) ១:២៧.
ស.ប. អាណិត; សុខុមាលភាព.

*នឹងឈរនៅលើភ្នំនៃដើមអូលីវ ហើយពួកសាសន៍ យូដានឹងឃើញស្នាមទាំងឡាយនៅលើព្រះហស្ត និងព្រះបាទារបស់ទ្រង់; ៥៤–៥៩, ព្រះអម្ចាស់ទ្រង់នឹងសោយរាជ្យ ក្នុងកំឡុងពេលសហស្សវត្សរ៍; ៦០–៦២, ព្យាការីត្រូវបានបង្គាប់ ឲ្យចាប់ផ្ដើមបកប្រែព្រះគម្ពីរសញ្ញាថ្មី ការនោះនឹងបង្ហាញឲ្យស្គាល់ពិតមានដ៏សំខាន់ៗ; ៦៣–៧៥, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យប្រមូលគ្នា ហើយសង់ក្រុងយេរូសាឡិមថ្មី ដើម្បីឲ្យប្រជារាស្ត្រមកពីគ្រប់ទាំងសាសន៍បានមក ។*

ចូរប្រុងស្ដាប់ ឱអ្នករាល់គ្នាជារាស្ត្រនៃសាសនាចក្ររបស់យើង ដែលនគរត្រូវបានប្រទានដល់អើយ; ចូរអ្នករាល់គ្នាប្រុងស្ដាប់ចុះ ហើយ ផ្ទៀងត្រចៀកចំពោះព្រះអង្គដែលបានតាំងឫសផែនដី ដែលបានបង្កើតផ្ទៃមេឃ និងគ្រប់ទាំងពួកបរិវារដែលនៅលើមេឃផង ហើយ ដោយសារទ្រង់ នោះរបស់សព្វសារពើត្រូវបានកើតមក ដែលបានរស់ កំរើក ហើយមាននៅផង ។

២ ហើយជាថ្មីទៀត យើងប្រាប់ថា ចូរប្រុងស្ដាប់តាមសម្លេងរបស់យើងចុះ ក្រែងលោសេចក្ដីស្លាប់នឹងកើតដល់អ្នក; នៅវេលាដែល អ្នករាល់គ្នាមិនគិត នោះរដូវក្ដៅនឹងកន្លង ហើយរដូវច្រូតកាត់បានផុតទៅ ហើយព្រលឹងរបស់អ្នករាល់គ្នាមិនទាន់បានសង្គ្រោះឡើយ ។

៣ ចូរស្ដាប់តាមព្រះអង្គ ដែលជាអ្នកគាំទ្រជាមួយនឹងព្រះវរបិតា ជាអ្នកដែលកំពុងអង្វរជំនួសអ្នករាល់គ្នានៅចំពោះទ្រង់ —

៤ ដោយមានបន្ទូលថា៖ ព្រះវរបិតាអើយ សូមទតមើលការរងទុក្ខទាំងឡាយ និងការសុគតរបស់អ្នក ដែលពុំបានធ្វើបាបឡើយ ជាអ្នកដែលព្រះអង្គសព្វព្រះហឫទ័យចុះ; សូមទតមើលព្រះលោហិតនៃព្រះរាជបុត្រារបស់ព្រះអង្គ ដែលបានច្រួច ជាព្រះលោហិត របស់អ្នក ដែលព្រះអង្គបានប្រទានឲ្យ ដើម្បីឲ្យព្រះអង្គបានដំកើងឡើង;

៥ ហេតុដូច្នោះហើយ ឱព្រះវរបិតាអើយ អ្នកផងទាំងនេះជាបងប្អូនរបស់ទូលបង្គំ ដែលជឿដល់ព្រះនាមរបស់ទូលបង្គំ ដើម្បីឲ្យពួកគេ អាចមករកទូលបង្គំ ហើយមានជីវិតដ៏នៅអស់កល្បជានិច្ច ។

៦ ចូរប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជារាស្ត្រនៃសាសនាចក្រយើងអើយ ហើយឱអ្នករាល់គ្នាជាពួកអែលឌើរអើយ ចូរឮជុំគ្នា ហើយ ស្ដាប់តាមសម្លេងរបស់យើង ក្នុងកាលដែលហៅថាថ្ងៃនេះ ហើយចូរកុំពង្រឹងចិត្តអ្នកឡើយ;

៧ ត្បិតយើងប្រាប់អ្នកជាប្រាកដថា យើងជាអាលផា និងអូមេកា ជាដើម ហើយជាចុង ជាពន្លឺ និងជាជីវិតនៃពិភពលោក — ជាពន្លឺដែលភ្លឺមកក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ ។

៨ យើងបានយាងមករករាស្ត្រយើង ហើយរាស្ត្រយើងមិនបានទទួលយើងទេ; ប៉ុន្តែដល់អស់អ្នកណាដែលជឿដល់ព្រះនាមយើង នោះយើងបានប្រទានអំណាច ដើម្បីធ្វើអព្ភូតហេតុជាច្រើន និងឲ្យបានត្រឡប់ជាកូនព្រះ; ហើយសូម្បីតែដល់ពួកអ្នកណាដែលជឿដល់ព្រះនាមយើង នោះយើងបាន ប្រទានអំណាច ឲ្យបានជីវិតដ៏នៅអស់កល្បជានិច្ចដែរ ។

៩ ម្ល៉ោះហើយបានជាយើងបញ្ជូនសេចក្ដីសញ្ញា ដ៏នៅអស់កល្បអស់កាលជានិច្ចរបស់យើង ឲ្យមកឯពិភពលោក ដើម្បីធ្វើជាពន្លឺដល់មនុស្សលោក ហើយដើម្បីធ្វើជាបមាណីយដល់រាស្ត្រយើង ហើយសំរាប់ឲ្យពួកសាសន៍ដទៃ ស្វែងរកបមាណីយនោះ ហើយដើម្បីធ្វើជា សារទូតនៅចំពោះព្រះភ័ក្ត្ររបស់យើង ដើម្បីរៀបចំផ្លូវថ្វាយយើង ។

៤៥ ១*ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* គ. និង ស. ៥០:៣៥.
*គ* យេរេ. ១៤:២២; ៣ នីហ្វៃ ៩:១៥; គ. និង ស. ១៤:៩. ស.ប. បង្កបង្កើត, ការបង្កបង្កើត.
២ *ក* អាលម៉ា ៣៤:៣៣–៣៥.
*ខ* ម៉ាថាយ ២៤:៤៤.
*គ* យេរេ. ៨:២០; គ. និង ស. ៥៦:១៦. ស.ប. ចំរូត.
៣ *ក* គ. និង ស. ៦២:១. ស.ប. ព្រះដ៏គាំទ្រ.
៤ *ក* គ. និង ស. ១៩:១៨–១៩. ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ហេព្រើរ ៤:១៥.
*គ* យ៉ូហាន ១២:២៨.
៥ *ក* គ. និង ស. ២០:២៥; ៣៥:២; ៣៨:៤.
*ខ* យ៉ូហាន ៣:១៦.
៦ *ក* ហេព្រើរ ៣:១៣; គ. និង ស. ៦៤:២៣–២៥.
៧ *ក* វិវ. ១:៨; ២១:៦; គ. និង ស. ១៩:១.
*ខ* យ៉ូហាន ១:៥.
៨ *ក* ម៉ាថាយ ១០:១. ស.ប. អំណាច.
*ខ* ស.ប. អព្ភូតហេតុ.
*គ* ស.ប. បុត្រាបុត្រីនៃព្រះ.
*ឃ* ស.ប. ជំនឿ, ជឿ; សេចក្ដីជំនឿ.
*ង* គ. និង ស. ១៤:៧.
៩ *ក* ស.ប. សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច.
*ខ* យេរេ. ៣១:៣១–៣៤; មរមន ៥:២០.
*គ* ២ នីហ្វៃ ២៩:២.
*ឃ* អេសាយ ៤២:៦; ២ នីហ្វៃ ១០:៩–១៨.
*ង* ម៉ាឡាគី ៣:១.

១០ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាមករកសេចក្ដីសញ្ញានោះចុះ ហើយអ្នកណាដែលមក នោះយើងនឹងពិភាក្សាជាមួយគ្នា ដូចជា មួយមនុស្សនៅសម័យបុរាណ ហើយយើងនឹងបង្ហាញដល់អ្នក នូវការពិភាក្សា[ក]ដ៏ខ្លាំងក្លា ។

១១ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាស្ដាប់ជុំគ្នា ហើយឲ្យយើងបង្ហាញដល់អ្នក នូវប្រាជ្ញារបស់យើងចុះ — ជាប្រាជ្ញានៃព្រះអង្គ ដែលអ្នករាល់គ្នាថា ជាព្រះនៃ[ក]លោកហេណុក និងបងប្អូនរបស់លោក

១២ ដែលត្រូវ[ក]បានបែកចេញពីផែនដី ហើយត្រូវបានយកមកខ្លួនយើង — [ខ]ទីក្រុងមួយដែលត្រូវបានរក្សាទុករហូតដល់ថ្ងៃនៃសេចក្ដី សុចរិត នឹងមកដល់ — ថ្ងៃមួយដែលត្រូវបានស្វែងរក ដោយអស់ទាំងពួកអ្នកបរិសុទ្ធ ហើយពួកគេរកពុំឃើញឡើយ ពីព្រោះតែអំពើ ទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយ;

១៣ ហើយពួកគេយល់ព្រមថាខ្លួនជា[ក]អ្នកដទៃ និងជាអ្នកសំណាក់នៅលើផែនដីប៉ុណ្ណោះ;

១៤ ប៉ុន្តែ[ក]បានទទួលសេចក្ដីសន្យាថា ពួកគេត្រូវរកថ្ងៃនៃសេចក្ដីសុចរិតនោះឲ្យឃើញ ក្នុងកាលពួកគេនៅក្នុងសាច់ឈាម ។

១៥ ហេតុដូច្នោះហើយ ចូរប្រុងស្ដាប់ចុះ ហើយយើងនឹងពិភាក្សាជាមួយអ្នក ហើយយើងនឹងមានបន្ទូលជាមួយអ្នក ហើយព្យាករ ដូចជាមួយមនុស្សនៅសម័យបុរាណ ។

១៦ ហើយយើងនឹងបង្ហាញការព្យាករណ៍យ៉ាងច្បាស់ ដូចជា[ក]យើងបានបង្ហាញដល់ពួកសិស្សរបស់យើង ក្នុងកាលយើងឈរនៅចំពោះ ពួកគេនៅក្នុងសាច់ឈាម ហើយបានមានបន្ទូលដល់ពួកគេថា៖ ពីព្រោះអ្នករាល់គ្នាបានសូមពីយើង ពី[ខ]ទីសំគាល់ទាំងឡាយ អំពីការ យាងមករបស់យើង ក្នុងថ្ងៃដែលយើងនឹងយាងមក ដោយនូវសិរីល្អ មកលើពពកនៅលើមេឃ ប្រយោជន៍នឹងបំពេញសេចក្ដីសន្យា ទាំងប៉ុន្មាន ដែលយើងបានធ្វើនឹងពួកអយ្យកោរបស់អ្នក,

១៧ ត្បិតពីព្រោះអ្នករាល់គ្នាបានគិតថា[ក]ការបាត់បង់[ខ]វិញ្ញាណរបស់អ្នកជាយូរ ពីរូបកាយរបស់អ្នកទុកជាការជាប់ឃុំឃាំង នោះយើងនឹង បង្ហាញដល់អ្នក ពីថ្ងៃនៃសេចក្ដីប្រោសលោះ ដែលនឹងមកដល់យ៉ាងណា និងព្រមទាំងពី[គ]ការសាងឡើងវិញនៃសាសន៍អ៊ីស្រាអែល ដែល[ឃ]ខ្ចាត់ខ្ចាយផង ។

១៨ ហើយឥឡូវនេះ អ្នករាល់គ្នាមើលព្រះវិហារនេះ ដែលនៅក្នុងក្រុងយេរូសាឡិម ដែលអ្នករាល់គ្នាហៅថា ព្រះវិហារនៃព្រះ ហើយពួកខ្មាំងសត្រូវរបស់អ្នកនិយាយថា ព្រះវិហារនេះនឹងមិនត្រូវរលំឡើយ ។

១៩ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា សេចក្ដីហិនវិនាសនឹងធ្លាក់មកដល់តំណមនុស្សនេះ ដូចជាចោរមកនៅពេលយប់ ហើយប្រជារាស្ត្រ នេះនឹងត្រូវបំផ្លាញចោល ហើយខ្ចាត់ខ្ចាយទៅលើគ្រប់ចំណោមសាសន៍នានា ។

២០ ហើយព្រះវិហារនេះ ដែលអ្នករាល់គ្នាមើលឃើញនៅពេលនេះ នោះនឹងទំលាក់ចុះ ដើម្បីកុំឲ្យមានថ្មនៅត្រួតលើថ្មណាឡើយ ។

២១ ហើយហេតុការណ៍នឹងកើតឡើងថា ពួកសាសន៍យូដាតំណនេះ នឹងពុំត្រូវបានកន្លងផុតឡើយ លុះត្រាសេចក្ដីហិនវិនាសគ្រប់យ៉ាង ដែលយើងបានប្រាប់អ្នកកើតឡើងសិន ។

២២ អ្នករាល់គ្នានិយាយថា អ្នករាល់គ្នាដឹងថា[ក]ចុងបំផុតលោកិយនឹងមកដល់; អ្នករាល់គ្នានិយាយផងដែរថា អ្នករាល់គ្នាដឹងថាផ្ទៃមេឃ និងផែនដីនឹងកន្លងបាត់ទៅ;

២៣ ហើយស្ដីអំពីការណ៍នេះ អ្នករាល់គ្នានិយាយជាពិតជាយ៉ាងនោះមែន; ប៉ុន្តែការណ៍ទាំងនេះដែលយើងបានប្រាប់អ្នកនោះនឹង ពុំបានកន្លងផុតឡើយ ទាល់តែគ្រប់ទាំងអស់ត្រូវបានសំរេចសិន ។

២៤ ហើយការណ៍នេះយើងប្រាប់ដល់អ្នក អំពីក្រុងយេរូសាឡិម; ហើយកាលណាថ្ងៃនោះមកដល់ នោះពួកសំណល់នឹងត្រូវ[ក]ខ្ចាត់ខ្ចាយទៅលើគ្រប់ចំណោមសាសន៍នានា;

---

១០ *ក* អេសាយ ៤១:២១;
គ. និង ស. ៥០:១០–១២.
១១ *ក* ម៉ូសេ ៧:៦៩.
១២ *ក* ក.យ.ស., លោកុ. ១៤:៣០–៣៤;
គ. និង ស. ៣៨:៤; ម៉ូសេ ៧:២១.
*ខ* ម៉ូសេ ៧:៦២–៦៤.
ស.ប. ស៊ីយ៉ូន.
១៣ *ក* ហេព្រើរ ១១:១៣;
១ ពេត្រុស ២:១១.
១៤ *ក* ហេព្រើរ ១១:៨–១៣;
ម៉ូសេ ៧:៦៣.
១៦ *ក* ម៉ាថាយ ២៤;
លូកា ២១:៧–៣៦;
យ.ស. — ម៉ាថាយ ១.
*ខ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
១៧ *ក* គ. និង ស. ១៣៨:៥០.
*ខ* ស.ប. វិញ្ញាណ.
*គ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ឃ* ១ នីហ្វៃ ១០:១២–១៤.
ស.ប. អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
២២ *ក* ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
២៤ *ក* ២ នីហ្វៃ ២៥:១៥.

២៥ ប៉ុន្តែពួកគេនឹង[ក]ត្រូវបានប្រមូលមកវិញទៀត; ប៉ុន្តែពួកគេនឹងនៅរហូតដល់[ខ]ពេលវេលា នៃពួកសាសន៍ដទៃនឹងត្រូវបានសំរេច ។
២៦ ហើយនៅ[ក]ថ្ងៃនោះ នឹងបានឮពី[ខ]សង្គ្រាមហើយពាក្យចចាមអារាមអំពីសង្គ្រាម ហើយផែនដីទាំងមូលនឹងនៅក្នុងស្ថានភាពចលាចល ហើយមនុស្សលោកនឹង[គ]ស្រយុតចិត្ត ហើយពួកគេនឹងនិយាយថា ព្រះគ្រីស្ទទ្រង់[ឃ]ពន្យាពេលវេលា ដែលទ្រង់នឹងយាងមក ទាល់តែដល់ចុង បំផុតនៃផែនដី ។
២៧ ហើយសេចក្ដីស្រឡាញ់របស់មនុស្សជាច្រើន នឹងរសាយអស់ទៅ រីឯសេចក្ដីទុច្ចរិតនឹងចំរើនជាច្រើនឡើងវិញ ។
២៨ ហើយកាលណាពេលវេលារបស់[ក]ពួកសាសន៍ដទៃបានមកដល់ នោះ[ខ]ពន្លឺនឹងចែងចាំងមកក្នុងចំណោមពួកអ្នក ដែលអង្គុយក្នុងសេចក្ដីងងឹត ហើយនឹងបានទៅជាភាពពោរពេញនៃដំណឹងល្អរបស់យើង;
២៩ ប៉ុន្តែពួកគេមិន[ក]ទទួលយកភាពពោរពេញនៃដំណឹងល្អរបស់យើងឡើយ; ត្បិតពួកគេមើលមិនឃើញពន្លឺនោះទេ ហើយពួកគេបែរ[ខ]ចិត្តគេចេញពីយើង ពីព្រោះតែ[គ]សិក្ខាបទនៃមនុស្សលោក ។
៣០ ហើយនៅក្នុងតំណមនុស្សនោះ នោះពេលវេលានៃពួកសាសន៍ដទៃនឹងត្រូវបានសំរេច ។
៣១ ហើយនឹងមានមនុស្សឈររស់នៅក្នុងតំណនោះ ដែលនឹងមិនត្រូវស្លាប់ទៅ លុះត្រាពួកគេនឹងបានឃើញ[ក]ការវាយដំដ៏ហួរហៀរ សិន; ត្បិតជំងឺដ៏ហិនហោចខ្លោចផ្សានឹងគ្របលើផែនដី ។
៣២ ប៉ុន្តែពួកសិស្សរបស់យើងនឹង[ក]ឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយនឹងពុំត្រូវបានរើឡើយ; ប៉ុន្តែនៅក្នុងចំណោមពួកមនុស្ស ទុច្ចរិតវិញ នោះមនុស្សទាំងឡាយនឹងបន្លឺសម្លេង[ខ]គេឡើង ហើយប្រទេចផ្ដាសាដល់ព្រះ ហើយស្លាប់ទៅ ។
៣៣ ហើយនឹងមាន[ក]ផែនដីរញ្ជួយនៅកន្លែងផ្សេងៗដែរ ហើយនិងសេចក្ដីហិនវិនាសជាច្រើនផង; ក៏ប៉ុន្តែមនុស្សលោកនៅតែនឹងពង្រឹង ចិត្តទាស់នឹងយើង ហើយពួកគេនឹង[ខ]លើកដាវប្រឆាំងគ្នា ហើយពួកគេនឹងសំឡាប់គ្នាទៅវិញទៅមក ។
៣៤ ហើយឥឡូវនេះ ក្នុងកាលយើង ជាព្រះអម្ចាស់ មានបន្ទូលនូវពាក្យទាំងនេះដល់ពួកសិស្សរបស់យើងហើយ នោះពួកគេមាន ចិត្តថប់បារម្ភ ។
៣៥ ហើយយើងបានមានបន្ទូលដល់ពួកគេថា៖ ចូរកុំឲ្យមាន[ក]ចិត្តថប់បារម្ភឡើយ ត្បិតកាលណាការណ៍ទាំងនេះនឹងកើតឡើង នោះអ្នក រាល់គ្នានឹងបានដឹងថា សេចក្ដីសន្យាទាំងប៉ុន្មាន ដែលបានធ្វើដល់អ្នក នោះនឹងត្រូវបានសំរេចហើយ ។
៣៦ ហើយកាលណាពន្លឺនឹងចាប់ផ្ដើមចែងចាំងមក នោះនឹងបាននៅជាមួយពួកគេ ដូចជាពាក្យប្រៀបប្រដូច ដែលយើងនឹងបង្ហាញ ដល់អ្នកដែរ —
៣៧ អ្នករាល់គ្នាមើល ហើយឃើញ[ក]ដើមល្វាទាំងឡាយ ហើយអ្នករាល់គ្នាមើលឃើញដោយភ្នែកអ្នកផ្ទាល់ ហើយអ្នករាល់គ្នានិយាយ ថា កាលណាដើមល្វាចាប់ផ្ដើមលាស់ឡើង ហើយស្លឹកវានៅទន់ខ្ចីនៅឡើយ ពេលនោះរដូវក្ដៅនៅជិតដែបង្កើយ;
៣៨ ក៏បែបដូច្នោះដែរនៅថ្ងៃនោះ កាលណាពួកគេនឹងឃើញគ្រប់ការណ៍ទាំងនេះ ខណៈនោះ ពួកគេនឹងដឹងថា ជិតដល់ម៉ោងហើយ ។
៣៩ ហើយហេតុការណ៍នឹងកើតឡើងថា អ្នកណាដែល[ក]កោតខ្លាចដល់យើង នោះនឹង[ខ]ទន្ទឹងចាំដល់[គ]ថ្ងៃដ៏ធំនៃព្រះអម្ចាស់ គឺដល់ [ឃ]ទីសំគាល់ ទាំងឡាយ ពីការយាងមកនៃ[ង]កូនមនុស្ស ។

២៥ *ក* នេហេ. ១:៩;
អេសាយ ១១:១២–១៤;
១ នីហ្វៃ ២២:១០–១២;
២ នីហ្វៃ ២១:១២–១៤.
*ខ* លូកា ២១:២៤.
២៦ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
*ខ* គ. និង ស. ៨៧;
យ.ស. — ម៉ាថាយ ១:២៣.
*គ* លូកា ២១:២៦.
*ឃ* ២ ពេត្រុស ៣:៣–១០.
២៨ *ក* ១ នីហ្វៃ ១៥:១៣.
*ខ* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ; ការសាងឡើងវិញនៃដំណឹងល្អ.
២៩ *ក* យ៉ូហាន ១:៥.
*ខ* ម៉ាថាយ ១៥:៨–៩.
*គ* គ. និង ស. ៣:៦–៨; ៤៦:៧;
យ.ស. — ប្រវត្តិ ១:១៩.
៣១ *ក* គ. និង ស. ៥:១៩–២០; ៩៧:២២–២៥.
៣២ *ក* គ. និង ស. ១០១:២១–២២, ៦៤.
*ខ* វិវ. ១៦:១១, ២១.
៣៣ *ក* គ. និង ស. ៤៣:១៨; ៨៨:៨៧–៩០.
*ខ* គ. និង ស. ៦៣:៣៣.
៣៥ *ក* ម៉ាថាយ ២៤:៦.
៣៧ *ក* ម៉ាកុស ១៣:២៨; លូកា ២១:២៩–៣១.
៣៩ *ក* គ. និង ស. ១០:៥៥–៥៦.
ស.ប. សេចក្ដីកោតខ្លាច — សេចក្ដីកោតខ្លាចដល់ព្រះ; ការគោរព, ដែលគោរព, គោរព.
*ខ* ២ ពេត្រុស ៣:១០–១៣;
គ. និង ស. ៣៥:១៥–១៦;
ម៉ូសេ ៧:៦២.
*គ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ឃ* ស.ប. ទីសំគាល់អំពីពេលវេលា.
*ង* ស.ប. កូនមនុស្ស.

៤០ ហើយពួកគេនឹងឃើញទីសំគាល់ និងការអស្ចារ្យទាំងឡាយ ត្បិតរបស់ទាំងនោះនឹងត្រូវបានបង្ហាញឲ្យឃើញនៅលើមេឃខាងលើ និងនៅលើផែនដីខាងក្រោម ។

៤១ ហើយពួកគេនឹងឃើញឈាម និង[ក]ភ្លើង និងកំស្លួលផ្សែង ។

៤២ ហើយមុនថ្ងៃនៃព្រះអម្ចាស់នឹងមកដល់ នោះ[ក]ថ្ងៃនឹងទៅជាងងឹត ហើយខែនឹងទៅជាឈាម ហើយតារាទាំងឡាយ នឹងធ្លាក់ចុះពីលើមេឃ ។

៤៣ ហើយពួកសំណល់នឹងត្រូវបានប្រមូលគ្នាមកទីនេះ;

៤៤ ហើយនៅខណៈនោះ ពួកគេនឹងសម្លឹងរកមើលយើង ហើយមើលចុះ យើងនឹងយាងមក ហើយពួកគេនឹងឃើញយើងមកលើពពក នៅលើមេឃ បំពាក់ដោយព្រះចេស្ដា និង[ក]សិរីល្អជាខ្លាំង; ជាមួយនឹង[ខ]ពួកទេវតាបរិសុទ្ធទាំងអស់; ហើយអ្នកណាដែលពុំបានចាំមើល យើង នោះនឹងត្រូវកាត់ចេញ ។

៤៥ ប៉ុន្តែមុនព្រះពាហុនៃព្រះអម្ចាស់នឹងធ្លាក់មក នោះទេវតាមួយរូបនឹងបន្លឺ[ក]ត្រែរបស់លោក ហើយពួកបរិសុទ្ធដែលបានដេកលក់នោះ នឹង[ខ]ចេញមក[គ]ជួបយើង នៅលើពពក ។

៤៦ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាបាន[ក]ដេកលក់ក្នុងសេចក្ដីសុខសាន្ត នោះអ្នករាល់គ្នាមានពរហើយ; ត្បិតឥឡូវនេះ ដូចជាអ្នកមើលឃើញយើង ហើយដឹងថាយើងជាព្រះយ៉ាងណា នោះអ្នករាល់គ្នាក៏នឹង[ខ]មករកយើងយ៉ាងនោះដែរ ហើយព្រលឹងរបស់ អ្នករាល់គ្នានឹង[គ]រស់នៅ ហើយសេចក្ដីប្រោសលោះរបស់អ្នក នឹងត្រូវបានល្អឥតខ្ចោះ; ហើយពួកបរិសុទ្ធនឹងចេញមកពីទិសទាំងបួននៃ ផែនដី ។

៤៧ ខណៈនោះ [ក]ព្រះពាហុនៃព្រះអម្ចាស់នឹងធ្លាក់មកលើពួកសាសន៍ទាំងឡាយ ។

៤៨ ហើយខណៈនោះ ព្រះអម្ចាស់នឹងដាក់ព្រះបាទទ្រង់ជាន់លើ[ក]ភ្នំនេះ ហើយនឹងត្រូវពុះញែកជា២ ហើយផែនដីនឹង[ខ]ញ័ររន្ធត់ ហើយទ្រេតទ្រោត ហើយផ្ទៃមេឃក៏[គ]នឹងញាប់ញ័រដែរ ។

៤៩ ហើយព្រះអម្ចាស់ទ្រង់នឹងបន្លឺសម្លេងរបស់ទ្រង់ ហើយអស់ទាំងចុងផែនដីនឹងបានឮ; ហើយសាសន៍ទាំងឡាយនៃផែនដីនឹង[ក]កក់ទ្រូងយំ ហើយពួកគេដែលបានសើចដាក់ នោះនឹងឃើញសេចក្ដីចំកួតរបស់ខ្លួន ។

៥០ ហើយមហន្តរាយនឹងគ្របដណ្ដប់លើពួកចំអកឡកឡឺយ ហើយពួកចំអកមើលងាយនឹងត្រូវសូន្យបាត់ទៅ; ហើយពួកអ្នកដែលរក តែឱកាសនឹងប្រព្រឹត្តសេចក្ដីទុច្ចរិត នោះនឹងត្រូវកាប់បោះចោលទៅក្នុងភ្លើង ។

៥១ ហើយខណៈនោះ [ក]ពួកសាសន៍យូដានឹងសម្លឹងមើលមករកយើង ហើយនិយាយថា៖ ចុះតើរបួសអ្វីនុ៎ះនៅដៃអ្នក និងនៅជើងអ្នក ?

៥២ ខណៈនោះ ពួកគេនឹងដឹងថា យើងជាព្រះអម្ចាស់; ត្បិតយើងនឹងមានបន្ទូលទៅកាន់ពួកគេថា៖ របួសទាំងនេះគឺជារបួសដែលយើង [ក]ត្រូវរបួស នៅក្នុងផ្ទះរបស់មិត្តសំឡាញ់យើង ។ យើងជាអ្នកដែលត្រូវបានលើកឡើង ។ យើងជាព្រះយេស៊ូវដែលត្រូវគេ[ខ]ឆ្កាង ។ យើងជាព្រះរាជបុត្រានៃព្រះ ។

៥៣ ហើយខណៈនោះ ពួកគេនឹង[ក]យំ ពីព្រោះតែសេចក្ដីទុច្ចរិតរបស់ពួកគេ; ខណៈនោះ ពួកគេនឹងទួញសោក ពីព្រោះពួកគេបានធ្វើទុក្ខ [ខ]ស្ដេចរបស់ខ្លួន ។

៥៤ ហើយខណៈនោះ [ក]ពួកអ្នកឥតសាសនានឹងត្រូវបានប្រោសលោះ ហើយពួកគេដែលមិនស្គាល់ច្បាប់ នោះនឹងមានចំណែក ក្នុង [ខ]ដំណើររស់ឡើងវិញទីមួយ; ហើយនឹងបាន[គ]ងាយដល់ពួកគេ ។

៥៥ ហើយ[ក]អារក្សសាតាំងនឹងត្រូវបាន[ខ]ចង ប្រយោជន៍កុំឲ្យវាមានកន្លែង នៅក្នុងដួងចិត្តនៃកូនចៅមនុស្សឡើយ ។

៤១ *ក* គ. និង ស. ២៩:២១; ៩៧:២៥–២៦.
៤២ *ក* យ៉ូអែល ២:១០; វិវរ. ៦:១២; គ. និង ស. ៨៨:៨៧; ១៣៣:៤៩.
៤៤ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ម៉ាថាយ ២៤:៤៣–៥១; ម៉ាកុស ១៣:៣២–៣៧.
៤៥ *ក* គ. និង ស. ២៩:១៣; ៤៣:១៨.
*ខ* គ. និង ស. ៨៨:៩៦–៩៧. ស.ប. ដំណើររស់ឡើងវិញ.
*គ* ១ ថែស្សា. ៤:១៦–១៧.
៤៦ *ក* អាលម៉ា ៤០:១២.
*ខ* អេសាយ ៥៥:៣.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៤៧ *ក* គ. និង ស. ១:១២–១៦.
៤៨ *ក* សាការី ១៤:៤.
*ខ* គ. និង ស. ៤៣:១៨; ៨៨:៨៧.
*គ* យ៉ូអែល ៣:១៦; គ. និង ស. ៤៩:២៣.
៤៩ *ក* គ. និង ស. ៨៧:៦.
៥១ *ក* ស.ប. ពួកសាសន៍យូដា.
*ខ* សាការី ១២:១០.
៥២ *ក* សាការី ១៣:៦.
*ខ* ស.ប. ការឆ្កាង.
៥៣ *ក* វិវរ. ១:៧.
*ខ* លូកា ២៣:៣៨; យ៉ូហាន ១៩:៣, ១៤–១៥.
៥៤ *ក* អេសេ. ៣៦:២៣; ៣៩:២១.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* គ. និង ស. ៧៥:២២.
៥៥ *ក* ស.ប. អារក្ស.
*ខ* វិវរ. ២០:២; ១ នីហ្វៃ ២២:២៦; គ. និង ស. ៤៣:៣១; ៨៨:១១០.

៥៦ ហើយនៅ[ក]ថ្ងៃនោះ ក្នុងកាលដែលយើងនឹងយាងមកដោយនូវសិរីល្អរបស់យើង នោះពាក្យប្រៀបប្រដូចនឹងត្រូវបានសំរេច ដែលយើងបានមានបន្ទូលពីស្រីព្រហ្មចារី១០ នាក់ ។

៥៧ ត្បិតពួកអ្នកណាដែលមានប្រាជ្ញា ហើយបានទទួល[ក]សេចក្ដីពិត ហើយបានទទួលយកព្រះវិញ្ញាណបរិសុទ្ធ ទុកជា[ខ]អ្នកណែនាំរបស់ខ្លួន ហើយដែលពុំត្រូវ[គ]គេបញ្ឆោត — យើងប្រាប់អ្នកជាប្រាកដថា ពួកគេនឹងពុំត្រូវកាប់បោះចោលទៅ[ឃ]ក្នុងភ្លើងឡើយ ប៉ុន្តែនឹងធន់នៅថ្ងៃនោះ ។

៥៨ ហើយ[ក]ផែនដីនឹងត្រូវបានប្រទានដល់ពួកគេ ទុកជា[ខ]មរតក; ហើយពួកគេនឹងកើនចំនួនឡើង និងខ្លាំងពូកែ ហើយកូនចៅពួកគេនឹង [គ]ធំ ឡើងដោយគ្មានបាប ដោយបានទទួល[ឃ]សេចក្ដីសង្គ្រោះ ។

៥៩ ត្បិតព្រះអម្ចាស់ទ្រង់នឹងគង់នៅ[ក]កណ្ដាលពួកគេ ហើយសិរីល្អរបស់ទ្រង់នឹងស្ថិតនៅលើពួកគេ ហើយទ្រង់នឹងទៅជាមហាក្សត្រនៃពួក គេ និង[ខ]ជាអ្នកតែងច្បាប់នៃពួកគេ ។

៦០ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា ការណ៍នេះនឹងមិនត្រូវបានប្រទានឲ្យអ្នកដឹង អំពីជំពូកនេះតទៅទៀតទេ ទាល់តែបាន [ក]បកប្រែព្រះគម្ពីរសញ្ញាថ្មីសិន ហើយនៅក្នុងការបកប្រែនោះ នោះគ្រប់ទាំងអស់នឹងត្រូវបានធ្វើឲ្យដឹង;

៦១ ហេតុដូច្នោះហើយ យើងប្រទានដល់អ្នក ដើម្បីឲ្យអ្នករាល់គ្នាអាចបកប្រែព្រះគម្ពីរសញ្ញាថ្មីនៅពេលនេះ ដើម្បីឲ្យអ្នករាល់គ្នាអាច បានប្រុងប្រៀបសំរាប់ការណ៍ទាំងឡាយដែលនឹងមកដល់ ។

៦២ ត្បិតយើងប្រាប់អ្នកជាប្រាកដថា ការណ៍ដ៏ធំនោះកំពុងតែរង់ចាំអ្នក;

៦៣ អ្នករាល់គ្នាឮអំពី[ក]សង្គ្រាមទាំងឡាយពីស្រុកដទៃ; ប៉ុន្តែមើលចុះ យើងប្រាប់អ្នកថា ការណ៍នោះនៅជិតបង្កើយគឺនៅមាត់ទ្វារ ហើយមិនជាយូរឆ្នាំប៉ុន្មានទេ នោះអ្នករាល់គ្នានឹងឮអំពីសង្គ្រាមទាំងឡាយ នៅក្នុងដែនដីរបស់ខ្លួន ។

៦៤ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់បានមានបន្ទូលថា ចូរអ្នករាល់គ្នាប្រមូលគ្នាពីដែនដី[ក]ខាងកើត ចូរជួបជុំគ្នាចុះ ឱអ្នករាល់គ្នា ជាពួកអែលឌើរនៃសាសនាចក្ររបស់យើងអើយ; ចូរអ្នករាល់គ្នាចេញទៅក្នុងភូមិភាគខាងលិចទាំងឡាយ ចូរស្រែកហៅបណ្ដាជន ឲ្យប្រែចិត្តចុះ ហើយដរាបណាពួកគេប្រែចិត្ត នោះចូរស្ថាបនាសាសនាចក្ររបស់យើងឡើងថ្វាយយើងចុះ ។

៦៥ ហើយដោយមានចិត្តតែមួយ និងគំនិតតែមួយ ចូរប្រមូលទ្រព្យសម្បត្តិទាំងឡាយរបស់អ្នករាល់គ្នា ប្រយោជន៍ឲ្យអ្នករាល់គ្នាអាច[ក]ទិញ ទីមរតក ដែលនឹងត្រូវបានប្រគល់ដល់អ្នកពីពេលនេះតទៅ ។

៦៦ ហើយទីនោះនឹងត្រូវបានហៅថា [ក]ក្រុងយេរូសាឡិមថ្មី ជា[ខ]ដែនដី[គ]សុខសាន្ត គឺជាទីក្រុង[ឃ]ពំនាក់ ជាទីសន្តិសុខសំរាប់ពួកបរិសុទ្ធនៃព្រះ ដ៏ខ្ពស់បំផុត;

៦៧ ហើយ[ក]សិរីល្អនៃព្រះអម្ចាស់នឹងស្ថិតនៅទីនោះ ហើយសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់ក៏នៅទីនោះដែរ គឺដរាបណាពួកមនុស្ស ទុច្ចរិតនឹងមិនមកទីនោះទេ ហើយទីនោះនឹងត្រូវហៅថាក្រុងស៊ីយ៉ូន ។

៦៨ ហើយហេតុការណ៍នឹងកើតឡើង នៅក្នុងចំណោមពួកទុច្ចរិតថា មនុស្សគ្រប់រូបណាដែលនឹងមិនកាន់ដាវប្រឆាំងនឹងអ្នកជិតខាង របស់ខ្លួនទេ នោះច្បាស់ជាត្រូវរត់ទៅរកក្រុងស៊ីយ៉ូន ដើម្បីឲ្យបានសុខ ។

---

៥៦ ក ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
ខ ម៉ាថាយ ២៥:១–១៣;
គ. និង ស. ៦៣:៥៤.
៥៧ ក ស.ប. សេចក្ដីពិត.
ខ ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
គ យ.ស. — ម៉ាថាយ ១:៣៧.
ឃ គ. និង ស. ២៩:៧–៩;
៦៣:៣៤; ៦៤:២៣–២៤;
១០១:២២–២៥.
៥៨ ក ស.ប. សហស្សវត្សរ៍.
ខ ម៉ាថាយ ៥:៥.
គ គ. និង ស. ៦៣:៥១;
១០១:២៩–៣១.
ឃ ស.ប. សេចក្ដីសង្គ្រោះ.
៥៩ ក គ. និង ស. ២៩:១១; ១០៤:៥៩.
ខ លោកុ. ៤៩:១០; សាការី ១៤:៩;
គ. និង ស. ៣៨:២១–២២.
៦០ ក ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.) ។
សូមមើលផងដែរ
ការជំរើសនានាពីការបកប្រែព្រះគម្ពីរប៊ីប ដោយយ៉ូសែប ស្ម៊ីធ.
៦៣ ក គ. និង ស. ៣៨:២៩;
៨៧:១–៥; ១៣០:១២.
៦៤ ក គ. និង ស. ៤២:៦៤.
៦៥ ក គ. និង ស. ៦៣:២៧.
៦៦ ក អេធើរ ១៣:៥–៦; ម៉ូសេ ៧:៦២;
ម. នៃ ស. ១:១០.
ស.ប. ក្រុងយេរូសាឡិមថ្មី; ស៊ីយ៉ូន.
ខ គ. និង ស. ៥៧:១–៣.
គ ស.ប. សេចក្ដីសុខសាន្ត.
ឃ អេសាយ ៤:៦;
គ. និង ស. ១១៥:៦.
៦៧ ក គ. និង ស. ៦៤:៤១–៤៣;
៩៧:១៥–១៨.
ស.ប. ព្រះយេស៊ូវគ្រីស្ទ —
សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.

៦៩ ហើយនឹងមានមនុស្ស[ក]ប្រមូលគ្នាមកក្រុងស៊ីយ៉ូន មកពីគ្រប់សាសន៍នៅក្រោមមេឃ; ហើយនឹងមានតែមនុស្សណាដែលនឹងមិនធ្វើ សង្គ្រាមនឹងគ្នាប៉ុណ្ណោះ ។

៧០ ហើយនឹងត្រូវបានឮនៅក្នុងចំណោមពួកទុច្ចរិតថា៖ ចូរយើងកុំឡើងទៅតតាំងនឹងក្រុងស៊ីយ៉ូនឡើយ ត្បិតពួកបណ្ដាជននៅក្រុងស៊ីយ៉ូនគួរឲ្យស្ញើបខ្លាចណាស់; ហេតុដូច្នោះហើយ ពួកយើងពុំអាចតស៊ូបានឡើយ ។

៧១ ហើយហេតុការណ៍នឹងកើតឡើងថា ពួកសុចរិតនឹងត្រូវបានប្រមូលគ្នាមកពីចំណោមសាសន៍ទាំងអស់ ហើយនឹងមកឯក្រុងស៊ីយ៉ូន ដោយច្រៀង នូវចំរៀងទាំងឡាយអំពីសេចក្ដីអំណរដ៏នៅអស់កល្បអស់កាលជានិច្ច ។

៧២ ហើយឥឡូវនេះ យើងប្រាប់អ្នកថា ចូរទុកការណ៍ទាំងនេះកុំឲ្យឮសាយទៅដល់មនុស្សលោក លុះត្រាជាការចាំបាច់ចំពោះយើង ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចសំរេចកិច្ចការនេះបាន ចំពោះភ្នែកនៃប្រជាជន ហើយចំពោះភ្នែកនៃពួកខ្មាំងសត្រូវរបស់អ្នក ប្រយោជន៍ កុំឲ្យពួកគេអាចដឹងអំពីកិច្ចការទាំងឡាយរបស់អ្នក លុះត្រាអ្នករាល់គ្នាបានសំរេចការណ៍ដែលយើងបានបញ្ជាដល់អ្នកសិន;

៧៣ ព្រោះកាលណាពួកគេដឹងអំពីកិច្ចការនោះ នោះពួកគេអាចពិចារណាពីការណ៍ទាំងនេះ ។

៧៤ ត្បិតកាលព្រះអម្ចាស់ទ្រង់នឹងលេចមក នោះទ្រង់នឹងទៅជាទី[ក]ស្ញើបខ្លាចដល់ពួកគេ ប្រយោជន៍ឲ្យសេចក្ដីកោតខ្លាចនោះអាចគ្រប ដណ្ដប់មកលើពួកគេ ហើយពួកគេនឹងឈរនៅឆ្ងាយ ហើយញ័ររន្ធត់ ។

៧៥ ហើយគ្រប់សាសន៍នឹងត្រូវទៅជាខ្លាច ពីព្រោះតែសេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់ និងព្រះចេស្ដានៃកម្លាំងរបស់ទ្រង់ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៤៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះសាសនាចក្រ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៨៣១ (*History of the Church, *១:១៦៣–១៦៥) ។ នៅសម័យដើមនៃសាសនាចក្រនេះ ពុំទាន់មានរបៀបស្រុះស្រួល គ្នា សំរាប់ចាត់ចែងការងារនៃសាសនាចក្រទេ ។ ប៉ុន្ដែសណ្ដាប់ធ្នាប់អំពីការបង្រួមសមាជិក និងពួកអ្នកស្វែងរកសាសនាចក្រដ៏ស្មោះ ដើម្បីឲ្យចូលរួមក្នុងការប្រជុំសាក្រាម៉ង់ និងការប្រជុំផ្សេងៗទៀតនៃសាសនាចក្រ នោះបានក្លាយទៅជាការទូទៅធម្មតា ។ វិវរណៈនេះថ្លែងប្រាប់ពីបំណងព្រះហឫទ័យនៃព្រះអម្ចាស់ អំពីការទទួលគ្រានិងការចាត់ចែងការប្រជុំទាំងឡាយ ។*

*១–២, ពួកអែលឌើរត្រូវដឹកនាំការប្រជុំ ដូចជាបានណែនាំដោយព្រះវិញ្ញាណបរិសុទ្ធ; ៣–៦, មិនត្រូវបដិសេធពួកអ្នកស្វែងរកសេចក្ដីពិត ពីការប្រជុំសាក្រាម៉ង់ឡើយ; ៧–១២, ចូរសូមដល់ព្រះ ហើយស្វែងរកអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ; ១៣–២៦, ការរាយរាប់ អំពីអំណោយទានទាំងនេះខ្លះៗត្រូវបានថែងប្រាប់; ២៧–៣៣, ពួកមេដឹកនាំសាសនាចក្រត្រូវបានប្រទានអំណាច ដើម្បីឲ្យសង្កេត ស្គាល់នូវអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ ។*

ប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជារាស្ត្រនៃសាសនាចក្រយើងអើយ; ត្បិតយើងប្រាប់អ្នកជាប្រាកដថា ការណ៍ទាំងនេះត្រូវបានប្រាប់ដល់ អ្នក ដើម្បីជា[ក]ប្រយោជន៍ និងជំរិះដល់អ្នក ។

២ ប៉ុន្ដែទោះជាការណ៍ទាំងនោះត្រូវបានសរសេរទុកយ៉ាងណាក៏ដោយ គង់តែការណ៍នោះត្រូវបានប្រទានដល់ពួក[ក]អែលឌើរនៃសាសនាចក្រយើងជានិច្ចដែរ ចាប់តាំងពីដើមដំបូងមកម្ល៉េះ ហើយជារហូតតទៅ ដើម្បីចាត់ចែងការប្រជុំទាំងអស់ ដូចជាពួកគេត្រូវបាន ដឹកនាំនិងណែនាំ ដោយព្រះវិញ្ញាណបរិសុទ្ធ ។

៣ ក៏ប៉ុន្ដែអ្នករាល់គ្នាត្រូវបានបញ្ជា មិនឲ្យបណ្ដេញជនណាមួយចេញពីការប្រជុំទូទៅ ដែលត្រូវធ្វើនៅចំពោះពិភពលោកឡើយ ។

៤ អ្នករាល់គ្នាក៏ត្រូវបានបញ្ជា មិនឲ្យបណ្ដេញជនណាមួយ

៦៩ *ក* ចោទិ. ៣០:៣;
យេរេ. ៣២:៣៧–៣៩;
គ. និង ស. ៣៣:៦.
៧៤ *ក* សេផា. ២:១១.
**៤៦** ១ *ក* ២ ធីម៉ូ. ៣:១៦–១៧.
២ *ក* អាលម៉ា ៦:១.
*ខ* ម៉ូរ៉ូណៃ ៦:៩; គ. និង ស. ២០:៤៥.
៣ *ក* ៣ នីហ្វៃ ១៨:២២–២៥.
ស.ប. សេចក្ដីប្រកប.

ដែលជាសមាជិកសាសនាចក្រ ឲ្យចេញពីការប្រជុំសាក្រាម៉ង់
ទាំងឡាយ របស់អ្នករាល់គ្នាឡើយ; ក៏ប៉ុន្តែ បើសិនជាមាន
ជនណាមួយបានរំលង នោះចូរកុំឲ្យអ្នកនោះទទួលទានឡើយ
លុះត្រាអ្នកនោះធ្វើយ៉ាង ណាឲ្យបានស្រុះស្រួលសិន ។
៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា អ្នករាល់គ្នាមិនត្រូវ
បណ្ដេញជនណាមួយ ដែលកំពុងតែព្យាយាមស្វែងរកនគរ
ឲ្យចេញពីការប្រជុំ សាក្រាម៉ង់ទាំងឡាយរបស់អ្នកឡើយ —
យើងមានបន្ទូលអំពីពួកអ្នកទាំងនោះ ដែលពុំមែនជាសមាជិក
នៃសាសនាចក្រ ។
៦ ហើយជាថ្មីទៀត យើងប្រាប់អ្នកពីការប្រជុំរបស់អ្នកទាំងឡាយ
សំរាប់បុណ្យបញ្ជាក់ថា បើសិនជាមានជនណាមួយ ដែលពុំមែន
ជា សមាជិកនៃសាសនាចក្រ ដែលកំពុងតែព្យាយាមស្វែងរកនគរ
នោះអ្នករាល់គ្នាមិនត្រូវបណ្ដេញពួកគេចេញឡើយ ។
៧ ប៉ុន្តែអ្នករាល់គ្នាត្រូវបានបញ្ជានូវគ្រប់ទាំងអស់ឲ្យសូមដល់ព្រះ
ដែលប្រទានដោយសន្ធា; ហើយអ្វីដែលព្រះវិញ្ញាណធ្វើបន្ទាល់
ដល់អ្នករាល់គ្នា នោះយើងចង់ឲ្យអ្នករាល់គ្នាធ្វើដូច្នោះ ដោយ
អស់ពីបរិសុទ្ធភាពក្នុងចិត្ត គឺដើរដោយស្មោះត្រង់នៅចំពោះយើង
ដោយ ពិចារណាពីចុងបង្ហើយនៃសេចក្ដីសង្គ្រោះរបស់អ្នក
ដោយធ្វើនូវអ្វីគ្រប់ទាំងអស់ ដោយការអធិស្ឋាន និង
អំណរគុណ ដើម្បីកុំឲ្យអ្នក រាល់គ្នា អាចត្រូវបញ្ឆោតដោយ
អារក្សអសោចិ៍ ឬដោយលទ្ធិទាំងឡាយនៃអារក្ស ឬដោយ
បញ្ញត្តិនៃមនុស្សលោកឡើយ; ត្បិតមាន ខ្លះជារបស់ផងមនុស្ស
លោក ហើយខ្លះទៀតជារបស់ផងអារក្សទាំងឡាយ ។
៨ ហេតុដូច្នោះហើយ ចូរប្រយ័ត្ន ក្រែងលោអ្នករាល់គ្នាត្រូវ
គេបញ្ឆោត ហើយប្រយោជន៍កុំឲ្យអ្នករាល់គ្នាត្រូវគេបញ្ឆោត
នោះអ្នក រាល់ត្រូវព្យាយាមស្វែងរកអំណោយទាននានាដែល
វិសេសបំផុតចុះ ដោយចងចាំជានិច្ចថា មកពីហេតុអ្វី បានជា
អំណោយទាន ទាំងនេះត្រូវបានប្រទានមក;
៩ ត្បិតយើងប្រាប់អ្នកជាប្រាកដថា អំណោយទានទាំងនេះត្រូវ
បានប្រទានឲ្យមក ដើម្បីជាប្រយោជន៍ដល់អស់អ្នកណា ដែល
ស្រឡាញ់ យើង ហើយកាន់តាមគ្រប់បញ្ញត្តិទាំងអស់របស់យើង
ហើយនិងដល់អ្នកណាដែលស្វែងរកផង; ដើម្បីឲ្យមនុស្សទាំង
អស់អាចបាន ប្រយោជន៍ ពីអ្នកដែលស្វែងរក ឬដែលសូម
ពីយើង ដែលសូម តែមិនមែនរកទីសំគាល់ ដើម្បីឲ្យពួកគេ
អាចចាយបំពេញសេចក្ដី សំរើបរបស់គេឡើយ ។
១០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា យើងចង់ឲ្យ
អ្នកចងចាំជានិច្ច ហើយទុកក្នុងគំនិតជានិច្ច ពីអំណោយទាន
ទាំងនោះ ដែលបានប្រទានដល់សាសនាចក្រ ។
១១ ត្បិតមនុស្សទាំងអស់ពុំបានគ្រប់អំណោយទាន ដែលបាន
ប្រទានដល់ពួកគេឡើយ; ត្បិតមានអំណោយទានជាច្រើន ហើយ
មនុស្ស រាល់គ្នាត្រូវបានប្រទានអំណោយទានមួយ ដោយព្រះ
វិញ្ញាណនៃព្រះ ។
១២ ចំពោះមនុស្សខ្លះ ត្រូវបានប្រទានឲ្យមួយ រីឯចំពោះមនុស្ស
ខ្លះ ត្រូវបានប្រទានឲ្យមួយផ្សេងទៀត ដើម្បីឲ្យមនុស្សទាំងអស់
អាចបាន ផលប្រយោជន៍ ដោយសាររបៀបនេះ ។
១៣ ចំពោះមនុស្សខ្លះ ត្រូវបានប្រទានដោយព្រះវិញ្ញាណ
បរិសុទ្ធ ឲ្យដឹងថាព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ ហើយ
ថាទ្រង់ត្រូវគេ ឆ្កាងជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក ។
១៤ ចំពោះមនុស្សខ្លះទៀត ត្រូវបានប្រទានឲ្យជឿដល់ពាក្យ
ពេចន៍នៃពួកគេ ប្រយោជន៍ឲ្យពួកគេអាចមានជីវិតដ៏នៅអស់
កល្បជានិច្ចផង ដែរ បើសិនជាពួកគេមានចិត្តស្មោះត្រង់
រហូតតទៅ ។
១៥ ហើយជាថ្មីទៀត ចំពោះមនុស្សខ្លះ ត្រូវបានប្រទានឲ្យ
ដោយព្រះវិញ្ញាណបរិសុទ្ធ ឲ្យដឹងពីការសំដែងផ្សេងៗពីគ្នា ដែល
នឹងសព្វព្រះ ហឫទ័យដល់ព្រះអម្ចាស់ តាមបំណងរបស់ព្រះ
អម្ចាស់ដដែល ដែលសមនឹងសេចក្ដីមេត្តាករុណារបស់ទ្រង់ តាម
លក្ខខ័ណ្ឌនៃកូនចៅ មនុស្ស ។
១៦ ហើយជាថ្មីទៀត ត្រូវបានប្រទានដល់មនុស្សខ្លះ ដោយ

៤ ក ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
ខ ៣ នីហ្វៃ ១៨:២៦–៣២. ស.ប. សាក្រាម៉ង់.
៦ ក ក.ន. សំរាប់ពិធីបញ្ជាក់ដល់ពួកអ្នកដែលទើបតែបានទទួលបុណ្យជ្រមុជទឹក.
៧ ក យ៉ាកុប (ព.ស.ថ.) ១:៥–៦; គ. និង ស. ៨៨:៦៣.
ខ ស.ប. បរិសុទ្ធភាព.
គ ស.ប. រំពឹងគិត.
ឃ ទំនុក. ១០០; អាលម៉ា ៣៤:៣៨. ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
ង ១ ធីម៉ូ. ៤:១–៤; គ. និង ស. ៤៣:៥–៧.
ច ស.ប. អារក្ស.
ឆ គ. និង ស. ៣:៦–៧; ៤៥:២៩.
៨ ក ១ កូរិន. ១២:៣១.
៩ ក ស.ប. ទីសំគាល់.
ខ យ៉ាកុប (ព.ស.ថ.) ៤:៣.
១០ ក ស.ប. គំនិត.
ខ ១ កូរិន. ១៤:១២. ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
១១ ក ១ កូរិន. ១២:៤–១១.
១៣ ក ស.ប. ទីបន្ទាល់.
១៤ ក ៣ នីហ្វៃ ១២:២. ស.ប. ជំនឿ, ជឿ.
១៥ ក ម៉ូរ៉ូណៃ ១០:៨.

សារព្រះវិញ្ញាណបរិសុទ្ធ ឲ្យដឹងពីការងារផ្សេងៗពីគ្នា ទោះជាមកពីព្រះ ក៏ដោយ ប្រយោជន៍ឲ្យការសំដែងនៃព្រះវិញ្ញាណ បានប្រទានមកដល់មនុស្សគ្រប់គ្នា ដើម្បីឲ្យបានផលប្រយោជន៍ ។

១៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ដល់មនុស្សខ្លះ ឲ្យមានពាក្យសំដីនៃប្រាជ្ញាវាងវៃ ដោយសារព្រះវិញ្ញាណនៃព្រះ ។

១៨ ដល់ម្នាក់ទៀត ឲ្យមានពាក្យសំដីនៃចំណេះចេះស្ទាត់ ដើម្បីឲ្យមនុស្សទាំងអស់អាចត្រូវបានបង្រៀន ឲ្យមានប្រាជ្ញា និងឲ្យមាន ចំណេះចេះដឹង ។

១៩ ហើយជាថ្មីទៀត ដល់មនុស្សខ្លះ ត្រូវបានប្រទានឲ្យមានសេចក្ដីជំជឿ ដើម្បីបានប្រោសឲ្យជា;

២០ ហើយដល់ម្នាក់ទៀត ត្រូវបានប្រទានឲ្យមានសេចក្ដីជំជឿ ដើម្បីប្រោសឲ្យជា ។

២១ ហើយជាថ្មីទៀត ដល់មនុស្សខ្លះ ត្រូវបានប្រទានឲ្យអាចសំដែងអព្ភូតហេតុទាំងឡាយ;

២២ ហើយដល់ម្នាក់ទៀត ត្រូវបានប្រទានឲ្យចេះព្យាករ;

២៣ ហើយឲ្យម្នាក់ទៀត ការចេះសង្កេតស្គាល់វិញ្ញាណទាំងឡាយ ។

២៤ ហើយជាថ្មីទៀត ត្រូវបានប្រទានដល់មនុស្សខ្លះ ឲ្យចេះនិយាយភាសាដទៃផ្សេងៗ;

២៥ ហើយដល់ម្នាក់ទៀត ត្រូវបានប្រទានឲ្យចេះបកប្រែភាសាដទៃ ។

២៦ ហើយអំណោយទានទាំងអស់នេះសុទ្ធតែមកពីព្រះ សំរាប់ផលប្រយោជន៍ដល់កូនចៅនៃព្រះ ។

២៧ ហើយដល់ប៊ីស្សពនៃសាសនាចក្រ និងដល់មនុស្សនានា ដែលព្រះទ្រង់នឹងតាំង ហើយតែងតាំងឡើង ដើម្បីឲ្យមើលគន់លើ សាសនាចក្រ ហើយដើម្បីឲ្យធ្វើជាពួកអែលឌើរដល់សាសនាចក្រ នោះត្រូវបានប្រទានដល់ពួកគេឲ្យចេះសង្កេតស្គាល់អំណោយ ទានទាំងអស់នោះ ក្រែងមានមនុស្សណាមួយ នៅក្នុងចំណោមអ្នករាល់គ្នា អះអាងថាមកពីព្រះ ប៉ុន្តែពុំមែនសោះ ។

២៨ ហើយហេតុការណ៍នឹងកើតឡើងថា អ្នកណាដែលសូមដោយនូវព្រះវិញ្ញាណ នោះនឹងបានទទួល ដោយសារព្រះវិញ្ញាណ;

២៩ ប្រយោជន៍ឲ្យមនុស្សខ្លះអាចត្រូវបានប្រទាន ឲ្យមានអំណោយទានទាំងអស់នោះ ប្រយោជន៍ឲ្យអាចមានមេ ដើម្បីឲ្យសមាជិក គ្រប់គ្នាអាចបានផលប្រយោជន៍ ដោយសាររបៀបនេះ ។

៣០ អ្នកណាដែលសូមដោយនូវព្រះវិញ្ញាណ នោះសូមតាមព្រះហឫទ័យរបស់ព្រះ; ហេតុដូច្នោះហើយ ត្រូវបានសំរេចតាមសំណូមពរ របស់គេ ។

៣១ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា គ្រប់ទាំងអស់ត្រូវបានសំរេច ដោយនូវព្រះនាមនៃព្រះគ្រីស្ទ គឺទោះជាអ្វីក៏ដោយ ដែលអ្នកធ្វើ ដោយនូវព្រះវិញ្ញាណ;

៣២ ហើយអ្នករាល់គ្នាត្រូវថ្លែងអំណរគុណដល់ព្រះ ដោយនូវព្រះវិញ្ញាណ សំរាប់ព្រះពរនានា ដែលអ្នករាល់គ្នាបានទទួលមក ។

៣៣ ហើយអ្នករាល់គ្នាត្រូវប្រព្រឹត្តដោយគុណធម៌ និងដោយបរិសុទ្ធភាព នៅចំពោះយើងជានិច្ច ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៤៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៨៣១* (History of the Church, *១:១៦៦)* ។ *មុនពេលនេះ អូលីវើរ ខៅឌើរី បានធ្វើជាប្រវត្តិសាស្ត្រិន និងជាអ្នក*

១៧ *ក* ម៉ូរ៉ូណៃ ១០:៩.
ស.ប. ប្រាជ្ញា.
១៨ *ក* ស.ប. ដំរិះ.
១៩ *ក* គ. និង ស. ៤២:៤៨–៥២.
ស.ប. សេចក្ដីជំនឿ.
២០ *ក* ស.ប. ប្រោស, ការប្រោស.
២១ *ក* ស.ប. អព្ភូតហេតុ.
២២ *ក* ស.ប. ការព្យាករណ៍, ព្យាករ.
២៣ *ក* ម៉ូសេ ១:១៣–១៥.
២៤ *ក* ស.ប. អំណោយទានខាងភាសា.
២៦ *ក* ម៉ូរ៉ូណៃ ១០:៨–១៩.
*ខ* ស.ប. បុត្រាបុត្រីនៃព្រះ.
២៧ *ក* ស.ប. ប៊ីស្សព.
*ខ* ស.ប. ការសង្កេតស្គាល់, អំណោយទាបខាង.
២៨ *ក* គ. និង ស. ៨៨:៦៤–៦៥.
៣០ *ក* គ. និង ស. ៥០:២៩.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*គ* ២ នីហ្វៃ ៤:៣៥.
៣២ *ក* ១ របា. ១៦:៨–១៥;
១ ថែស្សា. ១:២;
អាលម៉ា ៣៧:៣៧;
គ. និង ស. ៥៩:៧, ២១.
ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
៣៣ *ក* ស.ប. គុណធម៌.
*ខ* ស.ប. បរិសុទ្ធភាព.

*កត់បញ្ជីសំរាប់សាសនាចក្រ ។ យ៉ូហាន វិតមើរ ពុំបានស្វែងរកមុខងារជាប្រវត្តិសាស្ត្រិនទេ ប៉ុន្តែត្រូវបានសូមឲ្យបំរើក្នុងការងារនេះ គាត់បានមានប្រសាសន៍ថា គាត់នឹងគោរពតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ ក្នុងការណ៍នេះ ។ គាត់បានបំរើធ្វើជាលេខាធិការដល់ព្យាការីរួចទៅហើយ ក្នុងការកត់វិវរណៈដ៏ច្រើន ដែលបានទទួលនៅតាមតំបន់ភូមិហ្វាយែត រដ្ឋនូវយ៉ោក ។*

*១–៤, យ៉ូហាន វិតមើរ ត្រូវបានចាត់ឲ្យកត់ពីប្រវត្តិនៃសាសនាចក្រ ហើយឲ្យសរសេរជូនព្យាការី ។*

មើលចុះ ជាការចាំបាច់ក្នុងយើង ដែលយ៉ូហានជាអ្នកបំរើរបស់យើង គួរសរសេរហើយ[ក]កត់ពីប្រវត្តិទូទៅ ហើយជួយដល់អ្នក យ៉ូសែប ជាអ្នកបំរើយើងអើយ ក្នុងការកត់ចំឡងគ្រប់ទាំងអស់ ដែលនឹងត្រូវបានប្រទានដល់អ្នក លុះត្រាគាត់ត្រូវបានហៅឲ្យធ្វើភារកិច្ចផ្សេងៗ ទៀត ។

២ ជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា គាត់ក៏អាចបន្លឺសម្លេងគាត់ឡើងក្នុងការប្រជុំ នៅពេលណាក៏ដោយដែលឃើញថាចាំបាច់ ។

៣ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា នឹងត្រូវបានតាំងដល់គាត់ ឲ្យកត់បញ្ជី និងប្រវត្តិសាសនាចក្រជានិច្ច; រីឯ អូលីវើរ ខៅឌើរី វិញ យើង បានតាំងតំណែងឲ្យគាត់ផ្សេងទៀត ។

៤ ហេតុដូច្នោះហើយ ដរាបណាយ៉ូហានមានចិត្ត[ក]ស្មោះត្រង់ នោះនឹងត្រូវបានប្រទានដល់គាត់ ដោយសារព្រះដ៏ជាជំនួយ ឲ្យសរសេរ ការណ៍ទាំងនេះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

កណ្ឌទី ៤៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣១ (*History of the Church, *១:១៦៦–១៦៧)* ។ *ព្យាការីបានសូមដល់ព្រះអម្ចាស់ អំពីរបៀបរកដីសំរាប់ឲ្យពួកបរិសុទ្ធធ្វើទីលំនៅ ។ នេះគឺជា ការណ៍សំខាន់មួយ ពីព្រោះតែការផ្លាស់លំនៅនៃសមាជិកសាសនាចក្រ ដែលមកពីភូមិភាគខាងកើតសហរដ្ឋ ដើម្បីគោរពតាមព្រះ បញ្ញត្តិរបស់ព្រះអម្ចាស់ ថាពួកគេត្រូវជួបជុំគ្នានៅរដ្ឋអូហៃអូ (សូមមើល កណ្ឌទី ៣៧:១–៣; ៤៥:៦៤)* ។

*១–៣, ពួកបរិសុទ្ធនៅរដ្ឋអូហៃអូត្រូវចែកដីធ្លីរបស់ខ្លួនជាមួយនឹងបងប្អូនប្រុសស្រីរបស់គេ; ៤–៦, ពួកបរិសុទ្ធត្រូវទិញដីធ្លីកសាងទីក្រុង មួយ ហើយដើរតាមពាក្យទូន្មានពីមេត្រួតពិនិត្យទាំងឡាយរបស់ខ្លួន ។*

ពាការចាំបាច់ដែលអ្នករាល់គ្នាត្រូវនៅឯទីលំនៅរបស់អ្នកនៅពេលនេះ ដូចជាសមតាមកាលៈទេសៈរបស់អ្នកចុះ ។

២ ហើយដរាបណាអ្នករាល់គ្នាមានដីធ្លី នោះអ្នករាល់គ្នាត្រូវ[ក]ចែកដល់បងប្អូនប្រុសស្រី ដែលមកពីទិសខាងកើត;

៣ ហើយដរាបណាអ្នករាល់គ្នាពុំមានដីធ្លីទេ ចូរឲ្យពួកគេទិញក្នុងភូមិភាគជុំវិញទាំងនោះ នៅពេលនេះ តាមតែឃើញថាល្អដល់ពួកគេ ចុះ ត្បិតជាចាំបាច់ថា ពួកគេមានកន្លែងដើម្បីរស់នៅនៅពេលនេះ ។

៤ ជាចាំបាច់ថា អ្នករាល់គ្នាសន្សំប្រាក់ទាំងអស់ ដែលអ្នករាល់គ្នាអាចធ្វើទៅបាន ហើយថាអ្នករាល់គ្នាមានគ្រប់ទាំងអស់ ដែលអ្នករាល់ គ្នា អាចធ្វើទៅបាន នៅក្នុងសេចក្ដីសុចរិត ប្រយោជន៍ដល់ពេលណាមួយ ដែលអ្នករាល់គ្នាអាចមានឱកាស ដើម្បី[ក]ទិញដីបានទុកជា[ខ]កេរ្តិ៍ អាករ គឺជាទីក្រុងមួយ ។

៥ កន្លែងនោះមិនទាន់បានបើកសំដែងប្រាប់នៅឡើយទេ ប៉ុន្តែបន្ទាប់ពីបងប្អូន[ក]ប្រុសស្រីរបស់អ្នក មកពីទិសខាងកើតសិន នោះត្រូវឲ្យ មាន[ខ]មនុស្សខ្លះតែងតាំងឡើង ហើយដល់ពួកគេ នឹងត្រូវបានប្រទានឲ្យស្គាល់កន្លែង ឬដល់ពួកគេ នឹងត្រូវបានបើកសំដែងប្រាប់ ។

៦ ហើយពួកគេនឹងត្រូវ[ក]បានតែងតាំង ឲ្យទិញដីធ្លី ហើយឲ្យចាប់ផ្ដើមកចាក់គ្រឹះនៃទីក្រុង; ហើយនៅពេលនោះ អ្នករាល់គ្នានឹងចាប់ផ្ដើម ជួបជុំគ្នាជាគ្រួសារៗ មនុស្សគ្រប់រូបតាម

**៤៧** ១*ក* គ. និង ស. ៦៩:២–៨; ៨៥:១–២.
៤ *ក* ស.ប. ព្រះដ៏ជាជំនួយ; ព្រះវិញ្ញាណបរិសុទ្ធ.
**៤៨** ២*ក* ស.ប. សុខុមាលភាព.
៤ *ក* គ. និង ស. ៥៧:៤–៥.
*ខ* គ. និង ស. ៤២:៣៥–៣៦; ៤៥:៦៥–៦៧.
៥ *ក* គ. និង ស. ៥៧:៦–៨.
*ខ* គ. និង ស. ៥៧:១–៣.
៦ *ក* ស.ប. ក្រុងយេរូសាឡិមថ្មី.

ខ្គ្រួសាររៀងៗខ្លួន តាមកាលៈទេសៈរៀងៗខ្លួន ហើយដូចជាបានតែងតាំងដល់អ្នកនោះ ដោយ គណៈប្រធាន និងប៊ីស្សពនៃសាសនាចក្រ តាមក្រិត្យវិន័យ និងព្រះបញ្ញត្តិទាំងឡាយ ដែលអ្នករាល់គ្នាបានទទួលមក ហើយដែលអ្នក រាល់គ្នានឹងបានទទួលពីពេលនេះតទៅ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៤៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះ ស៊ីឌនី រិកដុន, ប៉ាលី ភីប្រ៉ាត, និងលីម៉ាន ខូប្លី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣១ (*History of the Church, *១:១៦៧–១៦៩)* ។ *(ប្រភពខាងប្រវត្តិសាស្ត្រខ្លះៗកាលបរិច្ឆេទ អំពីវិវរណៈនេះ ជាខែឧសភា ឆ្នាំ១៨៣១)* ។ *លីម៉ាន ខូប្លី បានឱបយកដំណឹងល្អ ប៉ុន្តែនៅតែកាន់តាមការបង្រៀនខ្លះៗនៃពួក Shakers* (United Society of Believers in Christ’s Second Appearing) *[ពួកសេកើរ (សមាគមនៃពួកអ្នកជឿ ដល់ការយាងមកលើកទី២របស់ព្រះគ្រីស្ទ)] ដែលគាត់បានចូលរួមពីមុន ។ ជំនឿខ្លះៗដែលពួកសេកើរជឿ គឺថាការយាងមកលើក ទី២របស់ព្រះគ្រីស្ទ នោះបានកើតរួចទៅហើយ ហើយថាទ្រង់បានលេចមកក្នុងរូបរាងជាស្ត្រី ឈ្មោះ អាណេ លី; បុណ្យជ្រមុជដោយទឹក ពុំបានគិតថាជាការសំខាន់ឡើយ; ការបរិភោគសាច់ជ្រូកត្រូវបានហាមផ្ដាច់ ហើយមនុស្សជាច្រើនពុំបានបរិភោគសាច់ណាឡើយ; ហើយភាពនៅព្រហ្មចារីនោះគិតថាខ្ពស់ជាងអាពាហ៍ពិពាហ៍ ។ ក្នុងបុព្វកថាចំពោះវិវរណៈនេះ ព្យាការីបានសរសេរថា៖ «ដើម្បីឲ្យមាន យោបល់ពេញខ្នាតអំពីកម្មវត្ថុ ខ្ញុំបានសូមដល់ព្រះអម្ចាស់ ហើយបានទទួលដូចដែលមានតទៅនេះ»* (History of the Church, *១:១៦៧)* ។ *វិវរណៈឆ្លើយបដិសេធនូវគំនិតជាគោលខ្លះៗរបស់ពួកសេកើរ ។ ពួកបងប្អូនទាំងប៉ុន្មានដែលបាននិយាយដល់នោះ បានចំឡងយកវិវរណៈទៅឯសហគមន៍សេកើរ (នៅក្បែរក្រុងឃ្លីវឡង់ រដ្ឋអូហៃអូ) ហើយអានឲ្យពួកគេស្ដាប់ទាំងស្រុង ប៉ុន្តែវិវរណៈនោះត្រូវគេ បដិសេធ ។*

*១–៧, ថ្ងៃ និងម៉ោងនៃការយាងមករបស់ព្រះគ្រីស្ទ នោះនឹងគ្មាននរណាដឹងឡើយ រហូតដល់ទ្រង់យាងមក; ៨–១៤, មនុស្សលោក ត្រូវប្រែចិត្ត ជឿដល់ដំណឹងល្អ ហើយគោរពតាមពិធីបរិសុទ្ធទាំងឡាយ ដើម្បីឲ្យបានសេចក្ដីសង្គ្រោះ; ១៥–១៦, អាពាហ៍ពិពាហ៍ត្រូវបាន តែងតាំងពីព្រះ; ១៧–២១, ការបរិភោគសាច់ត្រូវបានអនុញ្ញាត; ២២–២៨, ក្រុងស៊ីយ៉ូននឹងលូតលាស់ឡើង ហើយពួកសាសន៍លេមិន នឹងរីកឡើងដូចជាកុឡាប មុនការយាងមកលើកទីពីរ ។*

ចូរប្រុងស្ដាប់ដល់ព្រះបន្ទូលរបស់យើង ស៊ីឌនី និងប៉ាលី និងលីម៉ាន ជាពួកអ្នកបំរើរបស់យើងអើយ; ត្បិតមើលចុះ យើងប្រាប់អ្នកជា ប្រាកដថា យើងប្រទានដល់អ្នកនូវបញ្ញត្តិមួយថា អ្នកត្រូវទៅហើយផ្សាយដំណឹងល្អរបស់យើង ដែលអ្នកបានទទួលមក ដូចជាអ្នករាល់គ្នា បានទទួលមក ទៅប្រាប់ដល់ពួកសេកើរចុះ ។

២ មើលចុះ យើងប្រាប់អ្នកថា ពួកគេប៉ងប្រាថ្នាចង់ដឹងពីសេចក្ដីពិតតាមភាគៗ ប៉ុន្តែមិនមែនទាំងអស់ទេ ព្រោះពួកគេមិនត្រឹមត្រូវនៅ ចំពោះយើងឡើយ ហើយត្រូវការប្រែចិត្ត ។

៣ ហេតុដូច្នោះហើយ ស៊ីឌនី និង ប៉ាលី ជាពួកអ្នកបំរើរបស់យើងអើយ យើងចាត់ឲ្យអ្នកទៅផ្សាយដំណឹងល្អដល់ពួកគេ ។

៤ ហើយលីម៉ាន ជាអ្នកបំរើរបស់យើង ត្រូវបានតែងតាំងឡើងឲ្យធ្វើកិច្ចការនេះ ដើម្បីឲ្យគាត់ពិភាក្សាជាមួយពួកគេ ពុំមែនតាមអ្វីដែល គាត់បានទទួលពីពួកគេនោះទេ ប៉ុន្តែតាមអ្វីដែលនឹងត្រូវបានបង្រៀនដល់គាត់ ដោយពួកអ្នក ជាពួកអ្នកបំរើរបស់យើងវិញ; ហើយដោយ ធ្វើតាមរបៀបនេះ យើងនឹងប្រទានពរដល់គាត់ បើពុំនោះសោតទេ គាត់នឹងមិនលូតលាស់ឡើយ ។

៥ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ; ត្បិតយើងជាព្រះ ហើយបានចាត់ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង ឲ្យមកឯពិភពលោក សំរាប់សេចក្ដីប្រោសលោះពិភពលោក ហើយបានចេញបញ្ញត្តិថា អ្នកណាដែលទទួលទ្រង់ នោះនឹងបាន

៦ *ខ* គ. និង ស. ៥១:៣.
៤៩ ១*ក* ស.ប. ផ្សាយ.
២ *ក* កិច្ចការ ៨:២១.
៤ *ក* ស.ប. ដំណឹងល្អ; សេចក្ដីពិត.
៥ *ក* យ៉ូហាន ៣:១៦–១៧;
គ. និង ស. ១៣២:២៤.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិទ្ធិអំណាច.
*ខ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ; ព្រះដ៏ប្រោសលោះ.

សង្គ្រោះ ហើយអ្នកណាដែល មិនទទួលទ្រង់ទេ នោះនឹងត្រូវ
ជាប់ទោស —
៦ ហើយពួកគេបានប្រព្រឹត្តដល់កូនមនុស្ស តាមតែចិត្តពួកគេ;
ហើយទ្រង់បានទទួលយកព្រះចេស្ដារបស់ទ្រង់ នៅខាងព្រះហស្ត
ស្ដាំ នៃសិរីល្អរបស់ទ្រង់ ហើយឥឡូវនេះ សោយរាជ្យនៅលើ
ស្ថានសួគ៌ ហើយនឹងសោយរាជ្យរហូតដល់ទ្រង់យាងចុះមក
លើផែនដី ដើម្បីដាក់អស់ ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់
រីឯពេលនោះនៅជិតដៃបង្កើយ —
៧ យើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលថាដូច្នោះ; ប៉ុន្តែ
ម៉ោង និងថ្ងៃនោះ នោះគ្មាននរណាដឹងឡើយ សូម្បីតែពួក
ទេវតានៅលើ ស្ថានសួគ៌ផងដែរ ហើយពួកគេក៏នឹងពុំដឹងឡើយ
រហូតដល់ទ្រង់យាងមក ។
៨ ហេតុដូច្នោះហើយ យើងសព្វព្រះហឫទ័យចង់ឲ្យមនុស្ស
លោកទាំងអស់ប្រែចិត្ត ត្បិតមនុស្សទាំងអស់នៅក្រោមអំពើ
បាប លើកលែង តែពួកអ្នកនោះដែលយើងបានទុកសំរាប់យើង
គឺពួកមនុស្សបរិសុទ្ធ ដែលអ្នករាល់គ្នាពុំស្គាល់ឡើយនោះ ។
៩ ហេតុដូច្នោះហើយ យើងប្រាប់អ្នកថា យើងបានបញ្ជូនដល់
អ្នក នូវសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ច គឺជាអ្វីដែលមាន
តាំងពីដើមដំបូង មកម្ល៉េះ ។
១០ ហើយដែលយើងបានសន្យាថានឹងបំពេញ ហើយពួកសាសន៍
ទាំងឡាយនៃផែនដីនឹងក្រាបដល់សេចក្ដីសញ្ញានោះ; ហើយបើ
សិន ជាពុំមែនដោយពួកគេទេ នោះពួកគេនឹងចុះមក ត្បិតអ្វីដែល
ដំកើងឡើងឥឡូវនេះ នឹងត្រូវបន្ទាបអំណាចចុះ ។
១១ ហេតុដូច្នោះហើយ យើងប្រទានបញ្ញត្តិមួយដល់អ្នក ដើម្បីឲ្យ
អ្នកទៅក្នុងចំណោមពួកប្រជារាស្ត្រនេះ ហើយប្រាប់ពួកគេ ដូចជា
សាវកបុរាណរបស់យើង ដែលមានឈ្មោះថាពេត្រុស៖
១២ ចូរជឿដល់ព្រះនាមនៃព្រះអម្ចាស់ដ៏ជាព្រះយេស៊ូវ ដែល
បានគង់នៅលើផែនដី ហើយនឹងយាងមក ជាដើមហើយជាចុងចុះ;
១៣ ចូរប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវ
ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ តាមព្រះបញ្ញត្តិដ៏បរិសុទ្ធ សំរាប់ការ
ផ្ដាច់បាបចុះ;
១៤ ហើយអស់អ្នកណាដែលប្រព្រឹត្តដូច្នេះ នោះនឹងបាន
ទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់
ដៃលើ នៃពួក អែលឌើររបស់សាសនាចក្រ ។
១៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា អស់អ្នក
ណាដែលហាមប្រាមមិនឲ្យរៀបការ នោះពុំមែនបានតែងតាំង
ពីព្រះទេ ត្បិតអាពាហ៍ពិពាហ៍ត្រូវបានតែងតាំងមកពីព្រះដល់
មនុស្ស ។
១៦ ហេតុដូច្នោះហើយ គឺត្រឹមត្រូវតាមច្បាប់ថាបុរសត្រូវមាន
ភរិយាមួយ ហើយអ្នកទាំងពីរនោះនឹងត្រឡប់ជាសាច់តែមួយ
ហើយគ្រប់ ទាំងអស់នេះ ដើម្បីឲ្យផែនដីអាចបំពេញគោលបំណង
នៃការបង្កបង្កើត;
១៧ ហើយដើម្បីឲ្យផែនដីអាចបានពេញទៅដោយមនុស្ស
តាមការបង្កបង្កើតរបស់ខ្លួន មុនកំណើតលោកិយមកម្ល៉េះ ។
១៨ ហើយអស់អ្នកណាដែលហាមប្រាមឲ្យតមសាច់ ដែលថា
មនុស្សមិនត្រូវបរិភោគសាច់ឡើយនោះ ពុំមែនបានតែងតាំង
ពីព្រះទេ;
១៩ ត្បិតមើលចុះ សត្វជើងបួនលើវាល និងសត្វហើរ

៥ *ក* ស.ប. សេចក្ដីជាប់ទោស.
៦ *ក* ស.ប. កូនមនុស្ស.
*ខ* កិច្ចការ ៧:៥៥–៥៦;
គ. និង ស. ៧៦:២០–២៣.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.
*ឃ* ១ កូរិន. ១៥:២៥;
គ. និង ស. ៧៦:៦១.
៧ *ក* ម៉ាថាយ ២៤:៣៦;
ម៉ាកុស ១៣:៣២–៣៧;
វិវរ. ១៦:១៥;
គ. និង ស. ១៣៣:១១.
៨ *ក* កាឡាទី ៣:២២;
ម៉ូសាយ ១៦:៣–៥.
*ខ* ហេព្រើរ ១៣:២;
៣ នីហ្វៃ ២៨:២៥–២៩.
៩ *ក* លោកុ. ១៧:៧; គ. និង ស. ៦៦:២.
ស.ប. សេចក្ដីសញ្ញាថ្មី
ហើយអស់កល្បជានិច្ច.
១០ *ក* សាការី ២:១១;
គ. និង ស. ៤៥:៦៦–៦៩;
៩៧:១៨–២១.
*ខ* អេសាយ ៦០:១៤.
*គ* ម៉ាថាយ ២៣:១២.
១១ *ក* ស.ប. កិច្ចការផ្សាយសាសនា.
១៣ *ក* ៣ នីហ្វៃ ២៧:១៩–២០.
១៤ *ក* ស.ប. អំណោយទានជាព្រះ
វិញ្ញាណបរិសុទ្ធ.
*ខ* ស.ប. ដៃ, ការដាក់.
១៥ *ក* ១ ធីម៉ូ. ៤:១–៣.
*ខ* លោកុ. ២:១៨, ២៤;
១ កូរិន. ១១:១១.
ស.ប. អាពាហ៍ពិពាហ៍,
រៀបអាពាហ៍ពិពាហ៍.
១៦ *ក* យ៉ាកុប ២:២៧–៣០.
*ខ* លោកុ. ២:២៤;
ម៉ាថាយ ១៩:៥–៦.
*គ* ស.ប. ផែនដី —
បង្កើតសំរាប់មនុស្ស.
១៧ *ក* ម៉ូសេ ៣:៤–៥.
ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* ស.ប. ជីវិតមុនផែនដី.
១៨ *ក* ក.ន. សូមឲ្យតម.
*ខ* លោកុ. ៩:៣; ១ ធីម៉ូ. ៤:១–៣.
១៩ *ក* គ. និង ស. ៨៩:១០–១៣.

លើអាកាស ហើយអ្វីដែលកើតមកពីផែនដីផង ត្រូវបាន
តែងតាំងសំរាប់ឲ្យ មនុស្សយកមកប្រើប្រាស់ សំរាប់អាហារ និង
សំរាប់សំលៀកបំពាក់ ហើយដើម្បីឲ្យគេអាចមានជាបរិបូរ ។
២០ ប៉ុន្ដែពុំបានប្រទានឲ្យមក ដើម្បីឲ្យមនុស្សម្នាក់មាន
លើសជាងអ្នកផ្សេងឡើយ ហេតុដូច្នោះហើយ ទើបមនុស្ស
លោកស្ថិតនៅក្នុង អំពើបាប ។
២១ ហើយវេទនាដល់អ្នកណា ដែលខ្ចាយឈាម ឬដែលបំផ្លាញ
សាច់សត្វចោល ហើយមិនត្រូវការ ។
២២ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា កូនមនុស្ស
នឹងមិនយាងមកក្នុងរូបរាងជាស្ដ្រីឡើយ ឬជាបុរសដែលធ្វើ
ដំណើរនៅ លើផែនដីដែរ ។
២៣ ហេតុដូច្នោះហើយ ចូរកុំវង្វេងចេញឡើយ ប៉ុន្ដែ
ចូរនៅឲ្យបានខ្ជាប់ខ្ជួនចុះ ដោយសំឡឹងមើលផ្ទៃមេឃនឹងញាប់
ញ័រ ហើយផែនដី នឹងញ័ររន្ធត់ ហើយទ្រេតទ្រោត ដូចជា
មនុស្សស្រវឹង ហើយច្រកភ្នំទាំងឡាយនឹងត្រូវលើកឡើង
ហើយភ្នំធំៗនឹងត្រូវពង្រាបចុះ ហើយ កន្លែងណាដែល
រដិបរដុបនឹងត្រូវធ្វើឲ្យរាបចុះ — ហើយគ្រប់ទាំងអស់នេះ
ក្នុងកាលទេវតានឹងផ្លុំត្រែរបស់លោក ។
២៤ ប៉ុន្ដែមុនថ្ងៃដ៏ធំនៃព្រះអម្ចាស់មកដល់ នោះយ៉ាកុបនឹង
លូតលាស់នៅក្នុងទីរហោស្ថាន ហើយពួកសាសន៍លេមិននឹងត្រូវ
ផ្កាឡើងដូច ជាកុឡាប ។
២៥ ក្រុងស៊ីយ៉ូននឹងលូតលាស់នៅលើភ្នំតូចៗ ហើយត្រេកអរ
នៅលើភ្នំធំៗ ហើយនឹងជួបជុំគ្នានៅឯកន្លែងដែលយើងបាន
កំណត់ទុក ។
២៦ មើលចុះ យើងប្រាប់អ្នកថា ចូរចេញទៅដូចជាយើងបាន
បញ្ជាអ្នក; ចូរប្រែចិត្តពីអស់ទាំងអំពើបាបរបស់អ្នក; ចូរសូមនោះ
អ្នករាល់ គ្នានឹងបានទទួល; ចូរគោះ នោះតែងនឹងបានបើកឲ្យអ្នក ។
២៧ មើលចុះ យើងនឹងយាងនាំមុខអ្នក ហើយនឹងការពារនៅ
ខាងក្រោយអ្នកផង ហើយយើងនឹងនៅកណ្ដាលអ្នករាល់គ្នា
ហើយអ្នក នឹងមិនត្រូវបំភាន់ឡើយ ។
២៨ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ហើយយើងមកយ៉ាង
ឆាប់រហ័ស ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៥០

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែឧសភា ឆ្នាំ១៨៣១* (History of the Church, *១:១៧០–១៧៣)* ។ *ព្យាការីថ្លែងប្រាប់ថា មានពួកអែលឌើរខ្លះមិនយល់អំពីការបើកសំដែងនៃវិញ្ញាណផ្សេងៗដែល មានពាសពេញនៅលើផែនដីទេ ម្ល៉ោះហើយបានជាវិវរណៈនេះត្រូវបានប្រទានឲ្យមកទុកជាចម្លើយដល់សំណូមពរដ៏វិសេសអំពីរឿងនេះ ។ ដែលហៅថាបាតុភូតខាងវិញ្ញាណ នោះពុំមែនមិនធម្មតានៅក្នុងចំណោមពួកសមាជិកឡើយ មានមនុស្សខ្លះបានអះអាងថាបាន ទទួលការនិមិត្ត និងវិវរណៈទាំងឡាយ ។*

*១–៥, មានវិញ្ញាណក្លែងក្លាយជាច្រើននៅពាសពេញលើផែនដី; ៦–៩, វេទនាដល់ពួកមនុស្សកំពុត និងដល់ពួកអ្នកណាដែលបានកាត់ចេញពីសាសនាចក្រ; ១០–១៤, ពួកអែលឌើរត្រូវផ្សាយដំណឹងល្អ ដោយសារព្រះវិញ្ញាណ; ១៥–២២, ទាំងអ្នកផ្សាយ និងអ្នកស្ដាប់ ត្រូវការឲ្យបានបំភ្លឺដោយសារព្រះវិញ្ញាណ; ២៣–២៥, អ្វីណាមួយដែលពុំស្អាងឡើង នោះពុំមែនមកពីព្រះទេ; ២៦–២៨, ពួកអ្នក ស្មោះត្រង់ជាម្ចាស់នៃរបស់គ្រប់ទាំងអស់; ២៩–៣៦, ពាក្យអធិស្ឋានរបស់ពួកអ្នកដែលត្រូវបាន*

២០ *ក* កិច្ចការ ៤:៣២;
គ. និង ស. ៥១:៣;
៧០:១៤; ៧៨:៦.
*ខ* ស.ប. សេចក្ដីប្រកបដោយលោកិយ.
២១ *ក* ក.យ.ស., លោកុ. ៩:១០–១៥.
២២ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.
២៣ *ក* ម៉ាថាយ ២៤:៤–៥.
*ខ* ២ ពេត្រុស ៣:១២;
គ. និង ស. ៤៥:៣៩.
*គ* អេសាយ ៤០:៤;
គ. និង ស. ១០៩:៧៤.
*ឃ* មីកា ១:៣–៤.
*ង* ម៉ាថាយ ២៤:២៩–៣១.
២៤ *ក* ៣ នីហ្វៃ ៥:២១–២៦.
*ខ* អេសាយ ៣៥:១;
២ នីហ្វៃ ៣០:៥–៦;
៣ នីហ្វៃ ២១:២២–២៥;
គ. និង ស. ៣:២០; ១០៩:៦៥.
២៥ *ក* គ. និង ស. ៣៥:២៤.
*ខ* លោកុ. ៤៩:២៦;
២ នីហ្វៃ ១២:២–៣.
២៦ *ក* គ. និង ស. ៨៨:៦៣.
២៧ *ក* អេសាយ ៥២:១២.
*ខ* ៣ នីហ្វៃ ២០:២២.
*គ* ១ ពេត្រុស ២:៦;
គ. និង ស. ៨៤:១១៦.
២៨ *ក* គ. និង ស. ១:១២.

*ធ្វើឲ្យបរិសុទ្ធត្រូវបានឆ្លើយតប; ៣៧–៤៦, ព្រះគ្រីស្ទ ជាអ្នកគង្វាលល្អ ហើយជាថ្មដានៃសាសន៍អ៊ីស្រាអែល ។*

ចូរប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្ររបស់យើងអើយ ហើយផ្ទៀងត្រចៀកចំពោះសម្លេងនៃព្រះដ៏មាន ព្រះជន្មរស់នៅ; ហើយស្ដាប់តាមពាក្យសំដីនៃប្រាជ្ញាវាងវៃ ដែលនឹងត្រូវបានប្រទានដល់អ្នក តាមអ្វីដែលអ្នករាល់គ្នាបានសូម ហើយ បានយល់ព្រមអំពីសាសនាចក្រ និងវិញ្ញាណទាំងឡាយ ដែលមានពាសពេញនៅលើផែនដី ។

២ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា មានវិញ្ញាណជាច្រើន ដែលជាវិញ្ញាណក្លែងក្លាយ ដែលបានចេញទៅលើផែនដី ដោយបោក បញ្ឆោតមនុស្សលោក ។

៣ ហើយអារក្សសាតាំងក៏បានព្យាយាមបោកបញ្ឆោតអ្នក ដើម្បីវាអាចបានឈ្នះលើអ្នកដែរ ។

៤ មើលចុះ យើងជាព្រះអម្ចាស់ បានទតមើលអ្នក ហើយបានទតឃើញអំពើគួរខ្ពើមឆ្អើមទាំងឡាយ នៅក្នុងសាសនាចក្រ ដែលអះអាង តាមព្រះនាមរបស់យើង ។

៥ ប៉ុន្តែមានពរហើយ ដល់ពួកអ្នកដែលមានចិត្តស្មោះត្រង់ ហើយកាន់ខ្ជាប់ ទោះបីក្នុងជីវិត ឬក្នុងសេចក្ដីស្លាប់ក្ដី ត្បិតពួកគេនឹងបានគ្រង ជីវិតដ៏នៅអស់កល្បជានិច្ចទុកជាមរតក ។

៦ ប៉ុន្តែវេទនាដល់ពួកអ្នកណាដែលជាមនុស្សឆបោក និងមនុស្សកំពុត ត្បិតព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលដូច្នោះថា យើងនឹងនាំពួក គេមកជំនុំជំរះ ។

៧ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា មានមនុស្សកំពុតនៅក្នុងចំណោមពួកអ្នករាល់គ្នា ដែលបានបញ្ឆោតមនុស្សខ្លះៗ ដែលត្រូវបាន ទទួលអំណាចពីមារសត្រូវ; ប៉ុន្តែមើលចុះ ពួកគេនឹងត្រូវបានទាញយកមកវិញ;

៨ ប៉ុន្តែពួកមនុស្សកំពុតនឹងត្រូវចាប់បាន ហើយនឹងត្រូវកាត់ចេញ ទោះបីរស់ ឬស្លាប់ក្ដី តាមព្រះហឫទ័យយើង; ហើយវេទនាដល់ពួកអ្នក ណាដែលបានកាត់ចេញពីសាសនាចក្ររបស់យើង ត្បិតពួកគេនេះហើយដែលបានឈ្នះដោយលោកិយ ។

៩ ហេតុដូច្នោះហើយ ចូរមនុស្សគ្រប់រូបប្រុងប្រយ័ត្ន ក្រែងអ្នកនោះប្រព្រឹត្តអ្វី ដែលពុំមែននៅក្នុងសេចក្ដីពិត និងសេចក្ដីសុចរិតចំពោះ យើង ។

១០ ហើយឥឡូវនេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដោយព្រះវិញ្ញាណ ដល់ពួកអែលឌើរនៃសាសនាចក្ររបស់ទ្រង់ថា តោះចូរយើង ពិភាក្សាជាមួយគ្នា ដើម្បីឲ្យអ្នករាល់គ្នាអាចបានយល់;

១១ ចូរយើងពិភាក្សា ដូចជាមនុស្សពិភាក្សាទល់មុខគ្នា ។

១២ ឥឡូវនេះ កាលណាមនុស្សពិភាក្សា គេបានយល់ដោយសារមនុស្ស ពីព្រោះគេពិភាក្សាដូចជាមនុស្ស; ក៏ដូច្នោះដែរ យើងជាព្រះ អម្ចាស់ពិភាក្សាជាមួយអ្នក ដើម្បីឲ្យអ្នកអាចបានយល់ ។

១៣ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ សួរសំនួរនេះដល់អ្នកថា — តើអ្នករាល់គ្នាត្រូវបានតែងតាំងឲ្យធ្វើអ្វី ?

១៤ គឺដើម្បីផ្សាយដំណឹងល្អរបស់យើង ដោយសារព្រះវិញ្ញាណ គឺព្រះដ៏ជាជំនួយ ដែលបានចាត់ឲ្យចេញទៅបង្រៀនពីសេចក្ដីពិត ។

១៥ ហើយខណៈនោះ អ្នករាល់គ្នាបានទទួលវិញ្ញាណទាំងឡាយ ដែលអ្នករាល់គ្នាពុំអាចយល់ ហើយបានទទួលស្គាល់វិញ្ញាណទាំងនោះ ថាមកពីព្រះ; ហើយនៅក្នុងការណ៍នេះ តើអ្នករាល់គ្នាបានរាប់ជាសុចរិតឬអី ?

១៦ មើលចុះ អ្នករាល់គ្នានឹងឆ្លើយសំនួរនេះដោយខ្លួនឯង; ទោះជាយ៉ាងណាក៏ដោយ យើងនឹងមានសេចក្ដីមេត្តាករុណាដល់អ្នក; អ្នក ណាដែលទន់ខ្សោយក្នុងចំណោមអ្នករាល់គ្នា នឹងត្រូវបានធ្វើឲ្យខ្លាំងក្លា ចាប់តាំងពីពេលនេះតទៅ ។

១៧ យើងប្រាប់អ្នកជាប្រាកដថា អ្នកណាដែលបាន

---

**៥០** ២ *ក* គ. និង ស. ១២៩.
ស.ប. វិញ្ញាណ —
អារក្សអសោចិ៍.
៣ *ក* លូកា ២២:៣១;
៣ នីហ្វៃ ១៨:១៨.
៤ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ការយកព្រះនាមនៃព្រះ
យេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
៥ *ក* ស.ប. កាន់ខ្ជាប់.
៦ *ក* ស.ប. ការបោក, បញ្ឆោត,
សេចក្ដីបញ្ឆោត.
៧ *ក* ម៉ាថាយ ២៣:១៣–១៥;
អាលម៉ា ៣៤:២៨.
*ខ* ស.ប. អារក្ស.
*គ* ម៉ូសាយ ២៧:៨–៩.
*ឃ* ក.ន. ពួកអ្នកដែលត្រូវគេបញ្ឆោត.
៨ *ក* គ. និង ស. ១:១៤; ៥៦:៣;
៦៤:៣៥.
ស.ប. ការកាត់ចេញពីសាសនា.
១០ *ក* អេសាយ ១:១៨;
គ. និង ស. ៤៥:១០.
១២ *ក* គ. និង ស. ១:២៤.
១៣ *ក* ស.ប. តែងតាំង, ការតែងតាំង.
១៤ *ក* គ. និង ស. ៤៣:១៥.
ស.ប. បង្រៀន, គ្រូបង្រៀន —
ការបង្រៀនដោយនូវព្រះ វិញ្ញាណ.
*ខ* ស.ប. ព្រះដ៏ជាជំនួយ.
១៥ *ក* ស.ប. ការសង្កេតស្គាល់,
អំណោយទាបខាង.
១៦ *ក* អេធើរ ១២:២៣–២៧.

តែងតាំងពីយើង ហើយចាត់ឲ្យចេញទៅផ្សាយព្រះបន្ទូលនៃសេចក្ដីពិត ដោយ សារព្រះដ៏ជាជំនួយ ដោយនូវព្រះវិញ្ញាណនៃសេចក្ដីពិត តើអ្នកនោះផ្សាយព្រះបន្ទូលនៃសេចក្ដីពិត ដោយសារព្រះវិញ្ញាណនៃសេចក្ដី ពិត ឬតាមមាគ៌ាណាមួយទៀត ?

១៨ ហើយបើសិនជាមកតាមមាគ៌ាណាមួយទៀត នោះពុំមែនមកពីព្រះទេ ។

១៩ ហើយជាថ្មីទៀត អ្នកណាដែលទទួលព្រះបន្ទូលនៃសេចក្ដីពិត តើអ្នកនោះទទួលព្រះបន្ទូលនៃសេចក្ដីពិត ដោយសារព្រះវិញ្ញាណ នៃសេចក្ដីពិត ឬតាមមាគ៌ាណាមួយទៀត ?

២០ បើសិនជាមកតាមមាគ៌ាណាមួយទៀត នោះពុំមែនមកពីព្រះទេ ។

២១ ហេតុដូច្នោះហើយ ហេតុអ្វីបានជាអ្នករាល់គ្នាមិនអាចយល់ ហើយដឹងថា អ្នកណាដែលទទួលព្រះបន្ទូល ដោយសារព្រះវិញ្ញាណ នៃសេចក្ដីពិត នោះទទួលព្រះបន្ទូល ដូចជាបានផ្សាយដោយព្រះវិញ្ញាណនៃសេចក្ដីពិត ?

២២ ហេតុដូច្នោះហើយ អ្នកដែលផ្សាយ ហើយអ្នកដែលទទួល យល់គ្នាទៅវិញទៅមក ហើយទាំងពីរនាក់ត្រូវបានស្អាងឡើង ហើយ ត្រេកអរជាមួយគ្នា ។

២៣ ហើយអ្វីដែលពុំបានស្អាងឡើង នោះពុំមែនមកពីព្រះទេ តែមកពីសេចក្ដីងងឹតវិញ ។

២៤ អ្វីដែលមកពីព្រះ ជាពន្លឺ ហើយអ្នកណាដែលទទួលពន្លឺ ហើយនៅជាប់ក្នុងព្រះ នោះទទួលពន្លឺថែមទៀត ហើយពន្លឺនោះភ្លឺកាន់ តែ ខ្លាំងឡើងៗ រហូតដល់ថ្ងៃបានល្អឥតខ្ចោះ ។

២៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដមែន ហើយយើងមានបន្ទូល ប្រយោជន៍ឲ្យអ្នកអាចដឹងសេចក្ដីពិត ប្រយោជន៍ឲ្យអ្នកអាច បណ្ដេញសេចក្ដីងងឹត ចេញពីចំណោមអ្នករាល់គ្នា;

២៦ អ្នកណាដែលត្រូវបានតែងតាំងពីព្រះ ហើយចាត់ឲ្យចេញទៅ នោះឈ្មោះថាត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកធំបំផុត ទោះបីអ្នកនោះ តូចជាងគេបំផុត ហើយជាអ្នកបំរើដល់មនុស្សទាំងអស់ក្ដី ។

២៧ ហេតុដូច្នោះហើយ អ្នកនោះជាអ្នកគ្រងគ្រប់ទាំងអស់; ត្បិតគ្រប់ទាំងអស់នៅក្រោមអំណាចអ្នកនោះ ទាំងនៅលើស្ថានសួគ៌ និងនៅលើផែនដីផង ឯជីវិត និងពន្លឺ ព្រះវិញ្ញាណ និងព្រះចេស្ដា ត្រូវបានចាត់ឲ្យមក ដោយសារបំណងព្រះហឫទ័យរបស់ព្រះវរបិតា តាមរយៈព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រារបស់ទ្រង់ ។

២៨ ប៉ុន្តែគ្មានមនុស្សណាគ្រងគ្រប់ទាំងអស់បានឡើយ លើកលែងតែអ្នកនោះបានធ្វើឲ្យសុទ្ធសាត ហើយស្អាតបាតពីអស់ទាំងអំពើបាប សិន ។

២៩ ហើយបើសិនជាអ្នករាល់គ្នាត្រូវបានធ្វើឲ្យសុទ្ធសាត ហើយស្អាតបាតពីអស់ទាំងអំពើបាប នោះអ្នករាល់គ្នាត្រូវសូមអ្វីៗដែលអ្នកប៉ង ប្រាថ្នា ដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយអ្វីៗទាំងនោះនឹងត្រូវបានសំរេច ។

៣០ ប៉ុន្តែចូរយល់ចុះថា នឹងត្រូវបានប្រទានដល់អ្នក នូវអ្វីៗដែលអ្នកនឹងសូម; ហើយដូចជាអ្នករាល់គ្នាត្រូវបានចាត់តាំងឲ្យធ្វើជាមេយ៉ាង ណា នោះវិញ្ញាណទាំងឡាយនឹងនៅក្រោមអំណាចអ្នកយ៉ាងនោះដែរ ។

៣១ ហេតុដូច្នោះហើយ ហេតុការណ៍នឹងកើតឡើងថា បើសិនជាអ្នកមើលឃើញវិញ្ញាណសំដែងខ្លួន ដែលអ្នកពុំអាចយល់ ហើយអ្នក ពុំបានទទួលវិញ្ញាណនោះទេ នោះអ្នករាល់គ្នាត្រូវសូមដល់ព្រះវរបិតា ដោយនូវព្រះនាមនៃព្រះយេស៊ូវ; ហើយបើសិនជាព្រះអង្គពុំបាន ប្រទានវិញ្ញាណនោះដល់អ្នកទេ ខណៈនោះអ្នកអាចដឹងថា វាពុំមែនមកពីព្រះទេ ។

៣២ ហើយនឹងត្រូវបានប្រទានដល់អ្នក ឲ្យមានអំណាចលើវិញ្ញាណនោះ ហើយអ្នកត្រូវប្រកាសទាស់

១៧ *ក* ស.ប. កិច្ចការផ្សាយសាសនា; ផ្សាយ.
*ខ* គ. និង ស. ៦:១៥.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ; សេចក្ដីពិត.
២២ *ក* ១ កូរិន. ១៤:២៦.
*ខ* យ៉ូហាន ៤:៣៦.
២៣ *ក* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
២៤ *ក* ១ យ៉ូហាន ២:៨–១១; ម៉ូរ៉ូណៃ ៧:១៤–១៩; គ. និង ស. ៨៤:៤៥–៤៧; ៨៨:៤៩.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* យ៉ូហាន ១៥:៤–៥, ១០.
*គ* ២ នីហ្វៃ ២៨:៣០.
២៥ *ក* យ៉ូហាន ៨:៣២.
២៦ *ក* ម៉ាថាយ ២៣:១១.
*ខ* ម៉ាកុស ១០:៤២–៤៥.
ស.ប. ការបំរើ.
២៧ *ក* គ. និង ស. ៧៦:៥–១០, ៥៣–៦០; ៨៤:៣៤–៤១.
*ខ* ស.ប. អំណាច.
២៨ *ក* ៣ នីហ្វៃ ១៩:២៨–២៩; គ. និង ស. ៨៨:៧៤–៧៥.
ស.ប. សុទ្ធ, សុទ្ធសាធ; ការញែកជាបរិសុទ្ធ.
*ខ* ១ យ៉ូហាន ១:៧–៩.
២៩ *ក* ហេលេ. ១០:៥; គ. និង ស. ៤៦:៣០.
ស.ប. ការអធិស្ឋាន.
៣០ *ក* ស.ប. សិទ្ធិអំណាច.
៣១ *ក* ១ យ៉ូហាន ៤:១.
ស.ប. វិញ្ញាណ — អារក្សអសោចិ៍.
៣២ *ក* ម៉ាថាយ ១០:១.

នឹងវិញ្ញាណនោះ ដោយសម្លេង យ៉ាងខ្លាំងថា វាពុំមែនមកពីព្រះទេ —

៣៣ [ក]ចូរកុំប្រកែកឡើយ ដើម្បីកុំឲ្យអ្នករាល់គ្នាត្រូវឈ្នះ ឬដោយ[ខ]អួតអាង ឬត្រេកអរឡើយ ក្រែងអ្នករាល់គ្នាត្រូវគេចាប់ដោយសារការ នោះ ។

៣៤ អ្នកណាដែលបានទទួលពីព្រះ ចូរឲ្យអ្នកនោះទទួលស្គាល់ថារបស់នោះមកពីព្រះចុះ ហើយចូរឲ្យអ្នកនោះត្រេកអរដែលព្រះទ្រង់ រាប់ថា សមនឹងទទួលបាន ។

៣៥ ហើយដោយសារការស្ដាប់ និងការប្រព្រឹត្តិការណ៍ទាំងនេះ ដែលអ្នករាល់គ្នាបានទទួល ហើយដែលអ្នករាល់គ្នានឹងត្រូវបានទទួល — ហើយ[ក]នគរត្រូវបានប្រទានដល់អ្នកដោយព្រះវរបិតា និង[ខ]អំណាចឲ្យឈ្នះលើគ្រប់ទាំងអស់ ដែលពុំបានតែងតាំងដោយទ្រង់ —

៣៦ ហើយមើលចុះ យើងប្រាប់អ្នកជាប្រាកដថា ឥឡូវនេះមានពរហើយ ដល់អ្នកណាដែលកំពុងឮព្រះបន្ទូលទាំងឡាយរបស់យើង ដែលចេញមកពីមាត់នៃអ្នកបំរើរបស់យើង ត្បិតអំពើបាបទាំងឡាយរបស់អ្នក ត្រូវបាន[ក]អត់ទោសឲ្យហើយ ។

៣៧ ចូរឲ្យយ៉ូសែប វេកហ្វៀល ជាអ្នកបំរើរបស់យើង ជាទីពេញចិត្តយើងណាស់ និង [ក]ប៉ាលី ភី ប្រាត្ត ជាអ្នកបំរើរបស់យើង ឲ្យចេញទៅ ក្នុងចំណោមសាសនាចក្រទាំងប៉ុន្មាន ហើយចំរើនកម្លាំងដល់ពួកគេ ដោយសារ[ខ]ពាក្យដំបូន្មានចុះ;

៣៨ និងយ៉ូហាន ខូរិល ជាអ្នកបំរើរបស់យើងផង ឬក៏ពួកអ្នកបំរើរបស់យើងជាច្រើនណា ដែលត្រូវបានតែងតាំងឡើង ចំពោះតំណែង នេះ ហើយចូរឲ្យពួកគេធ្វើការនៅក្នុង[ក]ចំការទំពាំងបាយជូរ ហើយចូរកុំឲ្យនរណារារាំងពួកគេ ពីការធ្វើអ្វីដែលយើងបានតែងតាំងដល់ ពួកគេឡើយ —

៣៩ ហេតុដូច្នោះហើយ ក្នុងការណ៍នេះ [ក]អែឌវីត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង ពុំបានរាប់ជាសុចរិតឡើយ; ទោះជាយ៉ាងណាក៏ដោយ ចូរឲ្យគាត់ប្រែចិត្ត ហើយគាត់នឹងត្រូវបានអត់ទោសឲ្យ ។

៤០ មើលចុះ អ្នករាល់គ្នាជាកូនក្មេងតូចៗ ហើយអ្នករាល់គ្នាពុំអាច[ក]ទ្រាំគ្រប់ទាំងអស់បានទេ នៅពេលឥឡូវនេះ; អ្នករាល់គ្នាត្រូវ តែ[ខ]ចំរើនឡើងក្នុង[គ]ព្រះគុណ និងក្នុងការចេះដឹងអំពី[ឃ]សេចក្ដីពិត ។

៤១ [ក]កុំឲ្យខ្លាចឡើយ [ខ]កូនក្មេងតូចៗអើយ ត្បិតអ្នករាល់គ្នាជារបស់ផងយើង ហើយយើងបាន[គ]ឈ្នះលើលោកិយហើយ ហើយអ្នក រាល់គ្នា ជាពួកនោះ ដែលព្រះវរបិតារបស់យើងបាន[ឃ]ប្រទានដល់យើង;

៤២ ហើយគ្មាន[ក]អ្នកណាមួយ ដែលព្រះវរបិតាបានប្រទានដល់យើង ដែលត្រូវវង្វេងបាត់ឡើយ ។

៤៣ ហើយព្រះវរបិតា និងយើង [ក]គឺតែមួយ ។ យើងនៅក្នុងព្រះវរបិតា ហើយព្រះវរបិតានៅក្នុងយើង; ហើយដរាបណាអ្នករាល់គ្នាបាន ទទួលយើង នោះអ្នករាល់គ្នានៅក្នុងយើង ហើយយើងនៅក្នុងអ្នករាល់គ្នាដែរ ។

៤៤ ហេតុដូច្នោះហើយ យើងនៅកណ្ដាលអ្នករាល់គ្នា ហើយយើងជា[ក]អ្នកគង្វាលល្អ ហើយជា[ខ]ថ្មដានៃសាសន៍អ៊ីស្រាអែល។ អ្នកណា ដែលសង់នៅលើ[គ]ថ្មដានេះ នឹង[ឃ]មិនត្រូវរលំឡើយ ។

៤៥ ហើយថ្ងៃនឹងមកដល់ ដែលអ្នករាល់គ្នានឹងឮសម្លេងរបស់យើង ហើយ[ក]ឃើញយើង ហើយដឹងថាយើងជាព្រះ ។

៤៦ ដូច្នេះ ឲ្យ[ក]ចាំយាម ដើម្បីឲ្យអ្នករាល់គ្នាអាចបាន[ខ]ប្រុងប្រៀបជាស្រេច ។ គឺដូច្នោះមែន ។ អាម៉ែន ៕

៣៣ *ក* យូដាស ១:៩.
*ខ* គ. និង ស. ៨៤:៦៧, ៧៣.
៣៥ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ខ* ១ យ៉ូហាន ៤:៤;
គ. និង ស. ៦៣:២០, ៤៧.
៣៦ *ក* គ. និង ស. ៥៨:៤២–៤៣.
ស.ប. អត់ទោស, អភ័យទោស.
៣៧ *ក* ស.ប. ប្រាត្ត, ប៉ាលី ប៉ាកើរ.
*ខ* គ. និង ស. ៩៧:៣–៥.
៣៨ *ក* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
៣៩ *ក* ស.ប. ប៉ាទ្រិច, អែតវីត.
៤០ *ក* ៣ នីហ្វៃ ១៧:២–៣;
គ. និង ស. ៧៨:១៧–១៨.
*ខ* ១ កូរិន. ៣:២–៣;
គ. និង ស. ១៩:២២–២៣.
*គ* ស.ប. ព្រះគុណ.
*ឃ* ស.ប. សេចក្ដីពិត.
៤១ *ក* ១ យ៉ូហាន ៤:១៨.
*ខ* ស.ប. បុត្រាបុត្រីនៃព្រះ.
*គ* យ៉ូហាន ១៦:៣៣.
*ឃ* យ៉ូហាន ១០:២៧–២៩; ១៧:២;
៣ នីហ្វៃ ១៥:២៤;
គ. និង ស. ២៧:១៤; ៨៤:៦៣.
៤២ *ក* យ៉ូហាន ១៧:១២;
៣ នីហ្វៃ ២៧:៣០–៣១.
៤៣ *ក* យ៉ូហាន ១៧:២០–២៣;
៣ នីហ្វៃ ១១:៣៥–៣៦.
ស.ប. ព្រះ, ក្រុមព្រះ.
៤៤ *ក* យ៉ូហាន ១០:១៤–១៥.
ស.ប. អ្នកគង្វាលល្អ.
*ខ* លោកុ. ៤៩:២៤;
១ ពេត្រុស ២:៤–៨. ស.ប. ថ្មជ្រុង.
*គ* ១ កូរិន. ១០:១–៤.
ស.ប. ថ្ម; ព្រះយេស៊ូវគ្រីស្ទ.
*ឃ* ហេលេ. ៥:១២.
៤៥ *ក* គ. និង ស. ៦៧:១០–១៣.
៤៦ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
*ខ* អាលម៉ា ៣៤:៣២–៣៣.

## កណ្ឌទី ៥១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅភូមិថមសុន រដ្ឋអូហៃអូ ខែឧសភា ឆ្នាំ១៨៣១ (*History of the Church, *១:១៧៣–១៧៤) ។ នៅពេលនេះ ពួកបរិសុទ្ធដែលផ្លាស់លំនៅពីរដ្ឋទាំងឡាយនៅទិសខាងកើត បានចាប់ផ្ដើមមក ដល់រដ្ឋអូហៃអូ ហើយជាការចាំបាច់ដើម្បីរកទីកន្លែងសំរាប់ឲ្យពួកគេតាំងទីលំនៅ ។ ជាពិសេស ពីព្រោះការនេះជាភ្នាក់ងារខាង តំណែងរបស់ប៊ីស្សព បានជាលោកប៊ីស្សព អែតវើត ប៉ាទ្រិច ស្វែងរកការបង្គាប់អំពីរឿងនេះ ហើយព្យាការីបានសូមដល់ព្រះអម្ចាស់ ។*

*១–៨, អែតវើត ប៉ាទ្រិច ត្រូវបានចាត់តាំងឲ្យរៀបចំការកាន់កាប់ត្រួតត្រា និងទ្រព្យសម្បត្តិទាំងឡាយ; ៩–១២, ពួកបរិសុទ្ធត្រូវប្រព្រឹត្ត ដោយទៀងត្រង់ ហើយត្រូវបានទទួលដូចគ្នា; ១៣–១៥, ពួកគេត្រូវមានឃ្លាំងប៊ីស្សព ហើយត្រូវរៀបចំទ្រព្យសម្បត្តិទាំងឡាយ តាមក្រិត្យ វិន័យរបស់ព្រះអម្ចាស់; ១៦–២០, រដ្ឋអូហៃអូត្រូវទៅជាកន្លែងសំរាប់ជួបជុំគ្នាបណ្ដោះអាសន្ន ។*

ប្រុងស្ដាប់តាមយើង ព្រះអម្ចាស់ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយយើងនឹងមានបន្ទូលដល់ អែតវើត ប៉ាទ្រិច ជាអ្នក បំរើរបស់យើង ហើយនឹងប្រទានការដឹកនាំទាំងឡាយដល់គាត់; ត្បិតជាការចាំបាច់ ដែលគាត់បានទទួលការដឹកនាំ អំពីរបៀបរៀបចំ ប្រជារាស្ត្រនេះ ។

២ ត្បិតជាការចាំបាច់ ដែលពួកគេត្រូវបានរៀបចំ តាមក្រិត្យវិន័យទាំងឡាយរបស់យើង; បើសិនជាពុំនោះសោតទេ ពួកគេនឹងត្រូវ កាត់ចេញ ។

៣ ហេតុដូច្នោះហើយ ចូរឲ្យ អែតវើត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង ហើយនិងពួកអ្នកទាំងនោះ ដែលគាត់បានរើស ដែលជាទីពេញចិត្ត របស់យើង ចូរឲ្យប្រគល់ចំណែកដល់ប្រជារាស្ត្រនេះរៀងៗខ្លួន គឺមនុស្សគ្រប់រូបត្រូវបានដូចគ្នា តាមគ្រួសាររបស់ខ្លួន តាមកាលៈទេសៈ របស់ខ្លួន និងសេចក្ដីត្រូវការរបស់ខ្លួន ។

៤ ហើយចូរឲ្យ អែតវើត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង កាលណាគាត់ត្រូវប្រគល់ចំណែកដល់អ្នកណាមួយ ចូរឲ្យបង្កាន់ដៃដល់អ្នកនោះ ដែលនឹងធានាដល់គាត់នូវចំណែករបស់គាត់ ដើម្បីឲ្យគាត់ត្រូវបានកាន់របស់នោះ ដែលជាសិទ្ធិនេះ និងកេរ្ដិ៍អាករនេះនៅក្នុង សាសនាចក្រ រហូតដល់អ្នកនោះធ្វើការរំលង ហើយរាប់ថាមិនសម ដោយសារសម្លេងនៃសាសនាចក្រ តាមក្រិត្យវិន័យ និង សេចក្ដីសញ្ញាទាំងឡាយនៃសាសនាចក្រ ដើម្បីឲ្យបានរាប់ថាជារបស់ផងសាសនាចក្រ ។

៥ ហើយបើសិនជាអ្នកនោះនឹងធ្វើការរំលង ហើយរាប់ថាមិនសមជារបស់ផងសាសនាចក្រទេ អ្នកនោះមិនត្រូវមានអំណាចនឹងទាម ទាយកចំណែកនោះ ដែលគាត់បានថ្វាយដល់ប៊ីស្សព សំរាប់ឲ្យដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុរគតិទៅហើយនោះទេ; ហេតុ ដូច្នេះហើយ អ្នកនោះមិនត្រូវយកអំណោយទាននោះបានវិញឡើយ ប៉ុន្តែនឹងបានតែចំណែកណាដែលបានធានាដល់គាត់ប៉ុណ្ណោះ ។

៦ ហើយគ្រប់ទាំងអស់ត្រូវបានធ្វើឡើងដោយត្រឹមត្រូវ តាមក្រិត្យវិន័យរបស់ដែនដីយ៉ាងដូច្នោះហើយ ។

៧ ហើយចូរឲ្យអ្វីដែលជារបស់ផងប្រជារាស្ត្រនេះ ត្រូវបានប្រគល់ដល់ប្រជារាស្ត្រនេះចុះ ។

៨ ហើយប្រាក់កាសទាំងប៉ុន្មានដែលនៅសល់ដល់ប្រជារាស្ត្រនេះ — ចូរឲ្យមានភ្នាក់ងារមួយតែងតាំងឡើង ចំពោះប្រជារាស្ត្រនេះ ដើម្បីយកប្រាក់កាស ទៅផ្ដល់អាហារ និងសំលៀកបំពាក់ តាមសេចក្ដីត្រូវការនៃប្រជារាស្ត្រនេះ ។

៩ ហើយចូរឲ្យមនុស្សគ្រប់រូបប្រព្រឹត្តដោយទៀងត្រង់ ហើយរាប់ដូចគ្នា នៅក្នុងចំណោមប្រជារាស្ត្រនេះ ហើយឲ្យបាន

**៥១** ១*ក* ស.ប. ប៉ាទ្រិច, អែតវើត.
២ *ក* គ. និង ស. ៤២:៣០–៣៩; ១០៥:៥.
ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
៣ *ក* គ. និង ស. ៤៩:២០.
*ខ* កិច្ចការ ២:៤៤–៤៥; ៤ នីហ្វៃ ១:២–៣.
៤ *ក* ក.ន. កណ្ឌទី ២០ និង ២២ ត្រូវបានហៅថា មាត្រា និងសេចក្ដីសញ្ញានៃសាសនាចក្រនៃព្រះគ្រីស្ទ ។ គ. និង ស. ៣៣:១៤; ៤២:១៣ ។ ស.ប. សេចក្ដីសញ្ញា.
៦ *ក* ១ ពេត្រុស ២:១៣; គ. និង ស. ៩៨:៥–៧.
*ខ* គ. និង ស. ៥៨:២១–២២.
៨ *ក* គ. និង ស. ៨៤:១០៤.
*ខ* គ. និង ស. ១០៤:១៥–១៨.
៩ *ក* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់.

ទទួលដូចគ្នា ប្រយោជន៍ ឲ្យអ្នករាល់គ្នាបានរួមគ្នា[ខ]តែ១
គឺដូចជាយើងបានបញ្ជាដល់អ្នក ។
១០ ហើយចូរកុំយកអ្វីដែលជារបស់ផងប្រជារាស្ត្រនេះ ទៅឲ្យ
សាសនាចក្រណា[ក]ផ្សេងទៀតឡើយ ។
១១ ហេតុដូច្នោះហើយ បើសិនជាសាសនាចក្រណាផ្សេងទៀត
ទទួលប្រាក់កាសពីសាសនាចក្រនេះ ចូរឲ្យពួកគេបង់សាសនា
ចក្រនេះ វិញ តាមដែលពួកគេបានយល់ព្រម;
១២ ហើយការណ៍នេះត្រូវបានសំរេចតាមរយៈប៊ីស្សព
ឬភ្នាក់ងារដែលត្រូវបានតែងតាំងឡើង ដោយសារ[ក]សម្លេងនៃ
សាសនាចក្រ ។
១៣ ហើយជាថ្មីទៀត ចូរឲ្យប៊ីស្សពតាំង[ក]ឃ្លាំងមួយឡើង
ចំពោះសាសនាចក្រនេះ; ហើយចូរឲ្យគ្រប់ទាំងអស់ ទាំងប្រាក់
និងអាហារ ដែល មានច្រើនជាង[ខ]សេចក្ដីត្រូវការរបស់
ប្រជារាស្ត្រនេះ រក្សាទុកនៅក្នុងដៃរបស់ប៊ីស្សព ។
១៤ ហើយចូរឲ្យគាត់ទុករបស់របរដល់ខ្លួន សំរាប់សេច
ក្ដីត្រូវការរបស់គាត់ផ្ទាល់ និងសំរាប់សេចក្ដីត្រូវការរបស់
គ្រួសាររបស់គាត់ផង ព្រោះគាត់នឹងត្រូវរវល់ ក្នុងការ
ធ្វើកិច្ចការនេះ ។
១៥ ហើយយើងប្រទានដល់ប្រជារាស្ត្រនេះនូវឯកសិទ្ធិមួយក្នុង
ការរៀបចំខ្លួន តាម[ក]ក្រិត្យវិន័យទាំងឡាយរបស់យើងយ៉ាង
ដូច្នោះហើយ ។
១៦ ហើយយើងតាំង[ក]ដែនដីនេះដល់ពួកគេ សំរាប់មួយរដូវតូច
រហូតដល់យើងជាព្រះអម្ចាស់ នឹងផ្ដល់ដល់ពួកគេតាមផ្លូវណា
មួយ ទៀត ហើយបញ្ជាពួកគេឲ្យចេញពីទីនេះទៅ;
១៧ ហើយម៉ោង និងថ្ងៃនោះ ពុំត្រូវបានប្រាប់ដល់ពួកគេទេ
ហេតុដូច្នោះហើយ ចូរឲ្យពួកគេប្រព្រឹត្តនៅលើដែនដីនេះ ហាក់
ដូចជា នៅច្រើនឆ្នាំ ហើយការណ៍នេះនឹងត្រូវបានត្រឡប់
ទៅជាល្អដល់ពួកគេ ។
១៨ មើលចុះ ការណ៍នេះនឹងត្រូវទៅ[ក]ជាគំរូដល់ អែតរីត ប៉ាទ្រិច
ជាអ្នកបំរើរបស់យើង ក្នុងកន្លែងផ្សេងៗទៀត នៅគ្រប់សាសនា
ចក្រ ។
១៩ ហើយអស់អ្នកណាដែលឃើញថាជា[ក]អ្នកកាន់កាប់ត្រួត
ត្រាដោយស្មោះត្រង់ យុត្តិធម៌ និងឈ្លាសវៃ នោះនឹងត្រូវបាន
ចូលទៅក្នុង [ខ]សេចក្ដីអំណរនៃព្រះអម្ចាស់របស់ខ្លួន ហើយនឹងបាន
គ្រងជីវិតដ៏នៅអស់កល្បជានិច្ចទុកជាមរតក ។
២០ យើងប្រាប់អ្នកជាប្រាកដថា យើងជាព្រះយេស៊ូវគ្រីស្ទ
ដែល[ក]មកយ៉ាងឆាប់រហ័ស នៅ[ខ]វេលាដែលអ្នកមិនគិត ។ គឺដូច្នោះ
មែន ។ អាម៉ែន ៕

## កណ្ឌទី ៥២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី ចំពោះពួកអែលឌើរនៃសាសនាចក្រ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៨៣១ (*History of the Church*, ១:១៧៥–១៧៩)* ។ *សន្និសីទត្រូវបានធ្វើឡើងនៅក្រុងខឺតឡង់ គឺចាប់ផ្ដើមនៅថ្ងៃទី៣ ហើយបង្ហើយនៅថ្ងៃទី៦ ខែមិថុនា ។ នៅឯសន្និសីទនេះ ការតែងតាំងដ៏ច្បាស់លាស់អំពីតំណែងនៃសង្ឃជាន់ ខ្ពស់ត្រូវបានធ្វើឡើង ហើយការសំដែងខ្លះៗអំពីវិញ្ញាណក្លែងក្លាយ និងបញ្ឆោត ត្រូវបានសង្កេតស្គាល់ ហើយបន្ទោស ។*

*១–២, សន្និសីទលើកក្រោយត្រូវបានសំរេចឲ្យធ្វើនៅរដ្ឋមិសសួរី; ៣–៨, ការចាត់ឲ្យពួកអែលឌើរធ្វើដំណើរជាមួយគ្នាត្រូវបានចាត់; ៩–១១, ពួកអែលឌើរត្រូវបង្រៀនពីអ្វីដែលពួកសាវក និងពួកព្យាការីបានសរសេរទុក; ១២–២១, អស់អ្នកណាដែលត្រូវបានបំភ្លឺដោយសារ ព្រះវិញ្ញាណ ត្រូវនាំផលនៃការសរសើរ និងប្រាជ្ញាចេញមក; ២២–៤៤, ពួកអែលឌើរដ៏ច្រើនត្រូវបានតែងតាំងឲ្យចេញទៅផ្សាយដំណឹង ល្អ ក្នុងកាលធ្វើដំណើរទៅរដ្ឋមិសសួរីសំរាប់សន្និសីទ ។*

---

៩ *ខ* គ. និង ស. ៣៨:២៧.
ស.ប. ការរួបរួមតែមួយ.
១០ *ក* ក.ន. សាខាមួយទៀតនៃសាសនាចក្រ ឬនិកាយមួយផ្សេងទៀត.
១២ *ក* ស.ប. ការយល់ព្រមទូទៅ.
១៣ *ក* គ. និង ស. ៤២:៥៥.
ស.ប. ឃ្លាំង.
*ខ* គ. និង ស. ៤២:៣៣–៣៤, ៥៥; ៨២:១៧–១៩.
១៥ *ក* គ. និង ស. ៥១:២.
១៦ *ក* ក.ន. តំបន់ក្រុងខឺតឡង់ រដ្ឋអូហៃអូ.
១៨ *ក* ក.ន. គំរូ.
១៩ *ក* ម៉ាថាយ ២៤:៤៥–៤៧.
ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
*ខ* ស.ប. សេចក្ដីអំណរ.
២០ *ក* វិវរ. ២២:៦–១៦.
*ខ* ម៉ាថាយ ២៤:៤៤.

មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅកាន់ពួកអែលឌើរ ដែលទ្រង់បាន[ក]ហៅហើយរើសនៅគ្រាចុងក្រោយ ដោយសារសម្លេង នៃព្រះវិញ្ញាណរបស់ទ្រង់ —

២ ថា៖ យើងជាព្រះអម្ចាស់ នឹងប្រាប់ឲ្យអ្នករាល់គ្នាដឹងពីអ្វីដែលយើងសព្វព្រះហឫទ័យឲ្យអ្នករាល់គ្នាធ្វើ ចាប់តាំងពីពេលនេះរហូតដល់ មានសន្និសីទក្រោយទៀត ដែលនឹងធ្វើនៅរដ្ឋមិសសួរីនៅលើ[ក]ដែនដីដែលយើងនឹង[ខ]ប្រទានដល់រាស្ត្ររបស់យើង ដែលត្រូវជា[គ]សំណល់ [ឃ]នៃយ៉ាកុប និងពួកអ្នកណាដែលត្រូវជាអ្នកគ្រងមរតក តាមសេចក្ដីសញ្ញា ។

៣ ហេតុដូច្នោះហើយ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យយ៉ូសែប ស៊្មីធ ជុញ្ញ័រ និងស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង ធ្វើដំណើរយ៉ាង ប្រញាប់ កាលបានត្រៀមរួច ដើម្បីចាកចេញពីផ្ទះសំបែងរបស់ពួកគេ ហើយធ្វើដំណើរទៅដែនដីមិសសួរីចុះ ។

៤ ហើយដរាបណាពួកគេមានចិត្តស្មោះត្រង់ចំពោះយើង នោះនឹងត្រូវបានធ្វើឲ្យពួកគេដឹងពីអ្វីដែលពួកគេត្រូវធ្វើ ។

៥ ហើយដរាបណាពួកគេមានចិត្តស្មោះត្រង់ នោះក៏នឹងត្រូវបានធ្វើឲ្យពួកគេដឹងពី[ក]ដែនដីនៃកេរ្តិ៍អាកររបស់អ្នកដែរ ។

៦ ហើយដរាបណាពួកគេមិនមានចិត្តស្មោះត្រង់ នោះពួកគេនឹងត្រូវកាត់ចេញ គឺតាមដែលយើងសព្វព្រះហឫទ័យ តាមតែយើញថាល្អ ដល់យើង ។

៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើង និងយ៉ូហាន ខូរិល ជាអ្នកបំរើរបស់យើង ចេញដំណើរជាបន្ទាន់ចុះ;

៨ ហើយចូរឲ្យយ៉ូហាន មើដក់ ជាអ្នកបំរើរបស់យើង និងហៃរុម ស៊្មីធ ជាអ្នកបំរើរបស់យើង ចេញដំណើររបស់ពួកគេទៅកន្លែងដដែល តាមផ្លូវក្រុងឌីត្រោយត៍ផងចុះ ។

៩ ហើយចូរឲ្យពួកគេធ្វើដំណើរពីទីនោះ គឺផ្សាយព្រះបន្ទូលតាមផ្លូវ ដោយ[ក]គ្មាននិយាយពីអ្វី ក្រៅពីអ្វីដែល[ខ]ពួកព្យាការី និងពួកសាវកបាន សរសេរទុក និងអ្វីដែលត្រូវបានបង្រៀនដល់ពួកគេ ដោយសារ[គ]ព្រះដ៏ជាជំនួយ តាមរយៈពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ។

១០ ចូរឲ្យពួកគេទៅដោយគូៗ ហើយចូរឲ្យពួកគេផ្សាយតាមផ្លូវតាមរបៀបនោះ នៅគ្រប់ទីជំនុំ ដោយធ្វើបុណ្យជ្រមុជដោយទឹក និងដោយការ[គ]ដាក់ដៃលើ នៅក្បែរច្រាំងទឹក ។

១១ ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ យើងនឹងកាត់កិច្ចការរបស់យើងយ៉ាងខ្លី ដោយសេចក្ដីសុចរិត ត្បិតនឹងមានថ្ងៃមកដល់ ដែលយើងនឹងនាំសេចក្ដីជំនុំជំរះឲ្យបានជ័យជំនះ ។

១២ ហើយចូរឲ្យឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើងប្រុងប្រយ័ត្ន ត្បិតសាតាំងចង់[ក]រែងគាត់ដូចជាអង្កាម ។

១៣ ហើយមើលចុះ អ្នកណាដែលមាន[ក]ចិត្តស្មោះត្រង់ នោះនឹងត្រូវបានធ្វើឲ្យត្រួតលើរបស់ជាច្រើន ។

១៤ ហើយជាថ្មីទៀត យើងនឹងប្រទានគំរូដល់អ្នក អំពីគ្រប់ទាំងអស់ ដើម្បីកុំឲ្យអ្នករាល់គ្នាអាចត្រូវគេបញ្ឆោតបាន ត្បិតសាតាំងកំពុង នៅពាសពេញលើដែនដី ហើយវាចេញទៅ ដោយបញ្ឆោតសាសន៍នានា —

១៥ ហេតុដូច្នោះហើយ អ្នកណាដែលអធិស្ឋាន ដែលមាន[ក]វិញ្ញាណទន់ទាប អ្នកនោះឈ្មោះថា [ខ]ត្រូវបានទទួលពីយើងហើយ បើសិនជា អ្នកនោះគោរពតាម[គ]ពិធីបរិសុទ្ធទាំងឡាយរបស់យើង ។

១៦ អ្នកដែលនិយាយ ដែលមានវិញ្ញាណទន់ទាប ដែលប្រើពាក្យសំដីសុភាពហើយស្អាងឡើង អ្នកនោះឈ្មោះថាមកពីព្រះ បើសិនជា អ្នកនោះគោរពតាមពិធីបរិសុទ្ធទាំងឡាយរបស់យើង ។

១៧ ហើយជាថ្មីទៀត អ្នកណាដែលញ័ររន្ធត់ នៅក្រោមព្រះចេស្ដារបស់យើង នោះនឹងត្រូវធ្វើឲ្យ[ក]ខ្លាំងក្លា ហើយនឹងនាំ

---

**៥២** ១*ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
២ *ក* គ. និង ស. ៥៧:១–៣.
*ខ* គ. និង ស. ៥៨:៥៧; ៨៤:៣–៤.
*គ* ទំនុក. ១៣៥:៤; ៣ នីហ្វៃ ៥:២១–២៦.
*ឃ* អ័ប្រា. ២:៦–១១. ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
៥ *ក* គ. និង ស. ៥៧:១–៣.
៩ *ក* ម៉ូសាយ ១៨:១៩–២០.
*ខ* គ. និង ស. ៤២:១២; ៥២:៣៦. ស.ប. បទព្រះគម្ពីរ.
*គ* ស.ប. ព្រះដ៏ជាជំនួយ; ព្រះវិញ្ញាណបរិសុទ្ធ; បង្រៀន, គ្រូបង្រៀន — ការបង្រៀនដោយនូវព្រះ វិញ្ញាណ.
១០ *ក* ម៉ាកុស ៦:៧; គ. និង ស. ៦១:៣៥.
*ខ* យ៉ូហាន ១:២៦.
*គ* កិច្ចការ ៨:១៤–១៧.
១១ *ក* រ៉ូម ៩:២៨.
១២ *ក* លូកា ២២:៣១; ៣ នីហ្វៃ ១៨:១៧–១៨.
១៣ *ក* ម៉ាថាយ ២៥:២៣; គ. និង ស. ១៣២:៥៣.
១៥ *ក* ស.ប. ចិត្តសង្រេង.
*ខ* គ. និង ស. ៩៧:៨.
*គ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
១៧ *ក* គ. និង ស. ៦៦:៨; ១៣៣:៥៨.

ផលនៃការ សរសើរ និង[ខ]ប្រាជ្ញាចេញមក តាមវិវរណៈ និងសេច
ក្ដីពិតទាំងឡាយ ដែលយើងបានប្រទានដល់អ្នក ។
១៨ ហើយជាថ្មីទៀត អ្នកណាដែលត្រូវចាញ់ ហើយមិន[ក]នាំ
ផលទាំងឡាយចេញមក គឺតាមគំរូនេះ នោះពុំមែនមក
ពីយើងទេ ។
១៩ ហេតុដូច្នោះហើយ ដោយសារគំរូនេះ អ្នករាល់គ្នានឹងត្រូវ
[ក]ស្គាល់វិញ្ញាណទាំងឡាយ ក្នុងករណីទាំងអស់ នៅក្រោមមេឃ
ទាំងមូល ។
២០ ហើយនឹងមានថ្ងៃមកដល់ តាមសេចក្ដីជំនឿរបស់មនុស្ស
លោក ដែលនឹងត្រូវបាន[ក]សំរេចចំពោះពួកគេ ។
២១ មើលចុះ ព្រះបញ្ញត្តិនេះត្រូវបានប្រទានដល់ពួកអែលឌើរ
ទាំងអស់ ដែលយើងបានរើស ។
២២ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យ[ក]ថូ
ម៉ាស ប៊ី ម៉ាស ជាអ្នកបំរើរបស់យើង និងអែសរ៉ា ធេយ័រ
ជាអ្នកបំរើរបស់ យើង ចេញដំណើររបស់ពួកគេ ព្រម
ទាំងផ្សាយព្រះបន្ទូល តាមផ្លូវទៅរកដែនដីនេះដែរ ។
២៣ ហើយជាថ្មីទៀត ចូរឲ្យអ៊ីសាក មូរលី ជាអ្នកបំរើ
របស់យើង និងអែសរ៉ា ប៊ូត ជាអ្នកបំរើរបស់យើង ចេញដំណើរ
របស់ពួកគេ ព្រមទាំងផ្សាយព្រះបន្ទូល តាមផ្លូវទៅរកដែនដីនេះ
ដែរ ។
២៤ ហើយជាថ្មីទៀត ចូរឲ្យ[ក]អែគីរីត ប៉ាទ្រិច និងម៉ាទិន ហារិស
ជាពួកអ្នកបំរើរបស់យើង ចេញដំណើររបស់ពួកគេទៅជាមួយ
ស៊ីឌនី រិកដុន និងយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាពួកអ្នកបំរើ
របស់យើង ។
២៥ ចូរឲ្យដាវីឌ វិតមើរ និងហារី វិតឡក់ ជាពួកអ្នកបំរើ
របស់យើង ចេញដំណើររបស់ពួកគេផង ហើយ
ផ្សាយតាមផ្លូវទៅរកដែនដី នេះដែរ ។
២៦ ហើយចូរឲ្យ[ក]ប៉ាលី ភី ប្រាត្ត និង[ខ]អ័ររសុន ប្រាត្ត ជាពួកអ្នកបំរើ
របស់យើង ចេញដំណើររបស់ពួកគេ ហើយផ្សាយតាមផ្លូវ
គឺទៅរក ដែនដីនេះដែរ ។
២៧ ហើយចូរឲ្យសាឡូម៉ូន ហែនខក់ និងស៊ីម្មាន ខាររតើរ ជា
ពួកអ្នកបំរើរបស់យើង ចេញដំណើររបស់ពួកគេផង ទៅរកដែនដី
នេះដែរ ហើយឲ្យផ្សាយតាមផ្លូវ ។
២៨ ចូរឲ្យអែតសុន ហ្វូលលើរ និងយ៉ាកុប ស្កត់ ជាពួកអ្នក
បំរើរបស់យើង ចេញដំណើររបស់ពួកគេផង ។
២៩ ចូរឲ្យលេវី ដ័បបុលយូ ហែនខក់ និងសេបេដេ ខូលទ្រិន
ជាពួកអ្នកបំរើរបស់យើង ចេញដំណើររបស់ពួកគេផង ។
៣០ ចូរឲ្យរេយណូលស៍ ខាហ៊ូន និងសាំយូអែល អេច ស្ម៊ីធ
ជាពួកអ្នកបំរើរបស់យើង ចេញដំណើររបស់ពួកគេផង ។
៣១ ចូរឲ្យវ៉ាលលើរ បាលវិន និងវិលលាម ខាររតើរ ជាពួក
អ្នកបំរើរបស់យើង ចេញដំណើររបស់ពួកគេផង ។
៣២ ហើយចូរឲ្យ[ក]នូវល ណៃត៍ និងសេឡា ជេ គ្រិពហ្វិន ជា
ពួកអ្នកបំរើរបស់យើង ត្រូវបានតែងតាំងទាំងពីរនាក់ ហើយចេញ
ដំណើរ របស់ពួកគេផង ។
៣៣ មែនហើយ យើងប្រាប់ជាប្រាកដថា ចូរឲ្យគ្រប់អ្នក
ទាំងនេះចេញដំណើររបស់ពួកគេ ទៅកន្លែងមួយ តាមផ្លូវផ្សេង
ៗគ្នា ហើយមិន[ក]ត្រូវឲ្យមនុស្សម្នាក់សង់លើជើងជញ្ជាំងរបស់
អ្នកដទៃឡើយ ឬក៏ធ្វើដំណើរតាមផ្លូវរបស់អ្នកដទៃដែរ ។
៣៤ អ្នកណាដែលមានចិត្ត[ក]ស្មោះត្រង់ អ្នកនោះឈ្មោះថាត្រូវ
បានថែរក្សាទុក ហើយបានពរដោយផលដ៏ច្រើន ។
៣៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា ចូរឲ្យយ៉ូសែប
វេកវាល និងសាឡូម៉ូន ហាំព្រី ជាពួកអ្នកបំរើរបស់យើង ចេញ
ដំណើររបស់ ពួកគេ ទៅឯដែនដីទាំងឡាយនៅទិសខាងកើត ។
៣៦ ចូរឲ្យពួកគេធ្វើការជាមួយគ្រួសាររបស់ខ្លួន ដោយ
មិន[ក]ប្រកាសប្រាប់អ្វីផ្សេងទៀតឡើយ [ខ]ក្រៅពីពួកព្យាការី និងពួក
សាវក ដើម្បីឲ្យអ្វី ដែលពួកគេបានឃើញ ហើយបានឮ ហើយ[គ]ជឿ
យ៉ាងជាក់លាក់បំផុត ដើម្បីឲ្យសេចក្ដីព្យាករណ៍ទាំងប៉ុន្មានអាច
បានសំរេច ។
៣៧ ដោយព្រោះតែការរំលង នោះចូរយកអ្វីដែលបានប្រទាន
មកលើ ហ៊ីម៉ាន បាសែត [ក]ចេញពីគាត់ ហើយដាក់លើក្បាល
នៃស៊ីម៉ូនស៍ រ៉ៃឌើរចុះ ។
៣៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យ

១៧ ខ ស.ប. ប្រាជ្ញា.
១៨ ក ម៉ាថាយ ៣:១០.
១៩ ក ស.ប. ការសង្កេតស្គាល់, អំណោយទាបខាង.
២០ ក ម៉ាថាយ ៨:៥–១៣.
២២ ក គ. និង ស. ៥៦:៥. ស.ប. ម៉ាស, ថូម៉ាស ប៊ី.
២៤ ក ស.ប. ប៉ាទ្រិច, អែគីរីត.
២៦ ក ស.ប. ប្រាត្ត, ប៉ាលី ប៉ាកើរ.
ខ ស.ប. ប្រាត្ត, អ័ររសុន.
៣២ ក គ. និង ស. ៥៦:៦–៧.
៣៣ ក រ៉ូម ១៥:២០.
៣៤ ក យ៉ូហាន ១៥:១៦; គ. និង ស. ១៨:១៥–១៦.
៣៦ ក ម៉ូសាយ ១៨:១៩–២០; គ. និង ស. ៥២:៩.
ខ យ៉ូហាន ៣:១១.
គ ស.ប. ជំនឿ, ជឿ.
៣៧ ក ម៉ាថាយ ២៥:២៥–៣០.

យ៉ារេឌ ខារតើរ បានតែងតាំងជាសង្ឃចុះ ហើយនិង ជួច យ៉េមស៍ បានតែងតាំងជាសង្ឃផងចុះ ។

៣៩ ចូរឲ្យពួកអែលឌើរដែលនៅសល់ទាំងប៉ុន្មាន មើលលើសាសនាចក្រទាំងឡាយ ហើយប្រកាសព្រះបន្ទូល នៅភូមិភាគជុំវិញ ពួកគេចុះ ហើយចូរឲ្យពួកគេធ្វើការដោយដៃរបស់ខ្លួន ប្រយោជន៍កុំឲ្យត្រូវប្រព្រឹត្តនូវការថ្វាយបង្គំរូបព្រះ ឬអំពើទុច្ចរិតឡើយ ។

៤០ ហើយចូរនឹកចាំក្នុងគ្រប់ការណ៍ទាំងអស់ ពីមនុស្សទាល់ក្រ និងមនុស្សកំសត់ទុរគតិ និងពីមនុស្សឈឺ និងមនុស្សមានទុក្ខវេទនា ត្បិតអ្នក ណាដែលមិនធ្វើការទាំងនេះទេ អ្នកនោះឈ្មោះថាមិនមែនជាសិស្សរបស់យើងឡើយ ។

៤១ ហើយជាថ្មីទៀត ចូរឲ្យយ៉ូសែប ស្ម៊ិធ ជូញ៉ា និងស៊ីឌនី រិកដុន និងអែឌវីត ប៉ាទ្រិច ជាពួកអ្នកបំរើរបស់យើង យកទៅជាមួយពួកគេ នូវប័ណ្ណពីសាសនាចក្រ ។ ហើយចូរឲ្យមានប័ណ្ណមួយសំរាប់ អូលីវើរ ខៅឌើរ ផងដែរ ។

៤២ ម្ល៉ោះហើយ ដូចជាយើងបានប្រាប់ហើយថា បើសិនជាអ្នករាល់គ្នាមានចិត្តស្មោះត្រង់ នោះអ្នកត្រូវជួបជុំគ្នា ដើម្បីត្រេកអរនៅលើ ដែនដី មិសសួរី ដែលជាដែនដីនៃកេរ្តិ៍អាកររបស់អ្នក ដែលជាដែនដីនៃពួកខ្មាំងសត្រូវរបស់អ្នក នៅពេលឥឡូវនេះ ។

៤៣ ប៉ុន្តែមើលចុះ យើងជាព្រះអម្ចាស់ នឹងបញ្ចៀនឲ្យទីក្រុងឆាប់កើតឡើងនៅពេលកំណត់ ហើយនឹងបំពាក់មកុដដល់ពួកស្មោះត្រង់ ដោយសេចក្ដីអំណរ និងដោយសេចក្ដីរីករាយ ។

៤៤ មើលចុះ យើងជាព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ហើយយើងនឹងលើកពួកគេឡើង នៅថ្ងៃចុងក្រោយបង្អស់ ។ គឺដូច្នោះ មែន ។ អាម៉ែន ៕

## កណ្ឌទី ៥៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ិធ ជាព្យាការី ចំពោះ អាលជើណុន ស៊ីឌនី គិលបឺត នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែមិថុនា ឆ្នាំ១៨៣១ (*History of the Church*, ១:១៧៩–១៨០)* ។ *តាមសំណូមពររបស់ ស៊ីឌនី គិលបឺត នោះព្យាការី បានសូមដល់ព្រះអម្ចាស់ អំពីកិច្ចការ និងភារកិច្ចរបស់បងប្រុសគិលបឺត នៅក្នុងសាសនាចក្រ ។*

*១–៣, ការហៅ និងការរើសតាំងរបស់ ស៊ីឌនី គិលបឺត នៅក្នុងសាសនាចក្រ គឺត្រូវតែងតាំងជាអែលឌើរ; ៤–៧, គាត់ត្រូវបំរើជាភ្នាក់ងាររបស់ប៊ីស្សព ។*

មើលចុះ ស៊ីឌនី គិលបឺត ជាអ្នកបំរើរបស់យើងអើយ យើងប្រាប់អ្នកថា យើងបានឮពាក្យអធិស្ឋានរបស់អ្នកហើយ ហើយអ្នកបានអំពាវ នាវដល់យើង សូមឲ្យព្រះអម្ចាស់របស់អ្នក ធ្វើឲ្យអ្នកដឹងអំពីការហៅ និងការរើសរបស់អ្នក នៅក្នុងសាសនាចក្រ ដែលយើងជាព្រះ អម្ចាស់បាន តាំងឡើងនៅគ្រាចុងក្រោយបង្អស់ទាំងនេះ ។

២ មើលចុះ យើងជាព្រះអម្ចាស់ ដែលត្រូវគេឆ្កាងជំនួសអំពើបាបនៃមនុស្សលោក ប្រទានដល់អ្នកនូវព្រះបញ្ញត្តិមួយ ថាអ្នកត្រូវលះបង់ ចោលលោកិយ ។

៣ ចូរដាក់លើខ្លួន នូវការតែងតាំងរបស់យើង គឺជាការតែងតាំងនៃអែលឌើរ ដើម្បីទៅផ្សាយពីសេចក្ដីជំនឿ និងការប្រែចិត្ត និងការ ផ្ដាច់បាប តាមព្រះបន្ទូលរបស់យើង និងពីការទទួលយកព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ;

៤ ហើយឲ្យធ្វើជាភ្នាក់ងារចំពោះសាសនាចក្រនេះ ក្នុងកន្លែងដែលត្រូវបានចាត់តាំងឡើងដោយប៊ីស្សព តាមព្រះបញ្ញត្តិទាំងឡាយ ដែលត្រូវប្រទានឲ្យ បន្ទាប់ពីនេះទៅ ។

---

៣៨ *ក* គ. និង ស. ៧៩:១.
*ខ* ស.ប. សង្ឃ, បព្វជិតភាពអើរ៉ុន.
៣៩ *ក* អាលម៉ា ៦:១.
*ខ* ស.ប. ការថ្វាយបង្គំរូបព្រះ.
៤០ *ក* គ. និង ស. ១០៤:១៥–១៨. ស.ប. មនុស្សក្រីក្រ.
*ខ* ស.ប. សុខុមាលភាព.
៤១ *ក* គ. និង ស. ២០:៦៤.
៤២ *ក* ស.ប. ស៊ីយ៉ូន.
*ខ* គ. និង ស. ២៥:២; ៥៧:១–៣.
៤៣ *ក* ស.ប. សេចក្ដីអំណរ.
៤៤ *ក* គ. និង ស. ៨៨:៩៦–៩៨.
**៥៣** ១*ក* ស.ប. ការហៅ និងការរើសតាំង; ពួករើសតាំង; ការរើសតាំង.
២ *ក* ស.ប. ការឆ្កាង.
*ខ* ស.ប. ពិភពលោក; សេចក្ដីប្រកបដោយលោកិយ.
៣ *ក* ស.ប. ការផ្ដាច់បាប.
*ខ* ស.ប. ដៃ, ការដាក់.
៤ *ក* គ. និង ស. ៥៧:៦, ៨–១០, ១៤–១៥; ៨៤:១១៣.

៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា អ្នកត្រូវចេញដំណើរទៅជាមួយ យ៉ូសែប ស្ម៊ីធ ជុញ្ញ៉រ និងស៊ីឌនី រិកដុន ជាពួកអ្នកបំរើ របស់យើង ។
៦ មើលចុះ ការណ៍ទាំងនេះគឺជាពិធីបរិសុទ្ធដំបូងទាំងឡាយដែលអ្នកត្រូវបានទទួល; ហើយដែលនៅសល់ទាំងប៉ុន្មាន នោះនឹងត្រូវ បានធ្វើឲ្យដឹងនៅពេលខាងមុខ តាមកិច្ចការរបស់អ្នក នៅក្នុងចំការទំពាំងបាយជូររបស់យើង ។
៧ ហើយជាថ្មីទៀត យើងចង់ឲ្យអ្នករៀនដឹងថា អ្នកណាដែលបានសង្គ្រោះ គឺជាអ្នកដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុតប៉ុណ្ណោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៥៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះនូវល ណៃត៍ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែមិថុនា ឆ្នាំ១៨៣១* (History of the Church, *១:១៨០–១៨១)* ។ *សមាជិកទាំងឡាយនៃសាសនាចក្រក្នុងសាខាប្រចាំភូមិថមសុន រដ្ឋអូហៃអូ ត្រូវបានបែកបាក់គ្នាចំពោះករណីមួយ អំពីការថ្វាយទ្រព្យសម្បត្តិទាំងឡាយ ។ ការកំណាញ់ និងការលោភលន់ត្រូវបានសំដែង ហើយ លីម៉ាន ខូព្លី បានបំបាក់សេចក្ដីសញ្ញារបស់គាត់ ដើម្បីថ្វាយស្រែដ៏ធំរបស់គាត់ ទុកជាកន្លែងសំរាប់ពួកបរិសុទ្ធ ដែលកំពុងមកពី ភូមិខូលស្វិល រដ្ឋនូវយ៉ោក ។ អែសរ៉ា ធេយ័រ បានចូលរួមក្នុងរឿងនេះដែរ ។ ម្ល៉ោះហើយ នូវល ណៃត៍ (ប្រធាននៃសាខាប្រចាំភូមិថមសុន) និងពួកអែលឌើរផ្សេងៗទៀត បានមករកព្យាការី សូមចង់ដឹងថាត្រូវធ្វើដូចម្ដេច ។ ព្យាការីបានសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈនេះ ។ (សូមមើលកណ្ឌទី ៥៦ ដែលជាការបន្តរឿងនេះ) ។*

*១–៦, ពួកបរិសុទ្ធត្រូវកាន់តាមសេចក្ដីសញ្ញានៃដំណឹងល្អ ដើម្បីឲ្យបានសេចក្ដីមេត្តាករុណា; ៧–១០, ពួកគេត្រូវមានចិត្តអត់ធន់ក្នុងសេចក្ដី ទុក្ខលំបាក ។*

មើលចុះ ព្រះអម្ចាស់ គឺអាលផា និងអូមេកា ជាដើម ហើយជាចុង គឺទ្រង់ដែលត្រូវគេឆ្កាងជំនួសអំពើបាបនៃមនុស្សលោក ទ្រង់មាន ព្រះបន្ទូលដូច្នេះថា —
២ មើលចុះ នូវល ណៃត៍ ជាអ្នកបំរើរបស់យើងអើយ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នកត្រូវឈរឲ្យមាំមួនក្នុងតំណែង ដែល យើងបានតែងតាំងដល់អ្នកចុះ ។
៣ ហើយបើសិនជាបងប្អូនរបស់អ្នកមានបំណងចង់ចៀសរួចពីពួកខ្មាំងសត្រូវរបស់ពួកគេ នោះចូរឲ្យពួកគេប្រែចិត្តពីអស់ទាំងអំពើបាប របស់ពួកគេ ហើយចូរត្រឡប់ទៅជាអ្នករាបសាដ៏ពិតនៅចំពោះយើង ហើយមានចិត្តទន់ទាបចុះ ។
៤ ហើយដូចជាសេចក្ដីសញ្ញាដែលពួកគេបានធ្វើដល់យើងបានបាក់បែកយ៉ាងណា សេចក្ដីសញ្ញានោះក៏បានក្លាយទៅជាសោះសូន្យ និងឥតប្រយោជន៍យ៉ាងនោះដែរ ។
៥ ហើយវេទនាដល់អ្នកណា ដែលបង្កើតហេតុឲ្យរវាតចិត្តនេះ ត្បិតវាជាការប្រសើរជាង ប្រសិនបើអ្នកនោះត្រូវបានពន្លង់ទៅក្នុង សមុទ្រទីជ្រៅវិញ ។
៦ ប៉ុន្តែមានពរហើយ ដល់អស់អ្នកណាដែលបានកាន់តាមសេចក្ដីសញ្ញា ហើយគោរពតាមព្រះបញ្ញត្តិ ត្បិតពួកគេបានទទួលសេចក្ដីមេត្តា ករុណាហើយ ។
៧ ហេតុដូច្នោះហើយ ឥឡូវចូរទៅ ហើយរត់ចេញពីដែនដីទៅចុះ ក្រែងពួកខ្មាំងសត្រូវរបស់អ្នកមកលើអ្នក; ហើយចូរចេញដំណើរ របស់អ្នកចុះ ហើយចូរតាំងអ្នកណាមួយដែលអ្នកចង់ឲ្យធ្វើជាមេដឹកនាំរបស់អ្នក និងដើម្បីបង់ប្រាក់ឲ្យអ្នកចុះ ។
៨ ហើយអ្នកត្រូវចេញដំណើររបស់អ្នក ទៅក្នុងភូមិភាគទាំងឡាយនៅទិសខាងលិច ទៅដល់ដែនដីមិសសួរី ទៅដល់ព្រំដែនទាំងឡាយ នៃពួកសាសាន៍លេមិន ។
៩ ហើយបន្ទាប់ពីអ្នកបានធ្វើដំណើររួចហើយ មើលចុះ យើងប្រាប់អ្នកថា ចូរអ្នករាល់គ្នាស្វែងរករបររកស៊ីដូចមនុស្សផ្សេងៗចុះ លុះត្រា យើងរៀបចំកន្លែងមួយសំរាប់អ្នក ។

៧ *ក* ស.ប. កាន់ខ្ជាប់.
**៥៤** ១ *ក* វិវរ. ១:៨; គ. និង ស. ១៩:១.
ស.ប. អាលផា និងអូមេកា.
*ខ* ស.ប. ការឆ្កាង.
៣ *ក* ស.ប. បន្ទាបខ្លួន,
ចិត្តសុភាពរាបសា.
៤ *ក* គ. និង ស. ៤២:៣០–៣៩.
ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ.
*ខ* គ. និង ស. ៥៨:៣២–៣៣.
៥ *ក* ម៉ាថាយ ១៨:៦–៧.
៦ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
៨ *ក* គ. និង ស. ៥២:៤២.
៩ *ក* ១ ថែស្សា. ៤:១១.

១០ ហើយជាថ្មីទៀត ចូរមាន[ក]ចិត្តអត់ធន់ក្នុងសេចក្ដីទុក្ខលំបាក
រហូតដល់យើងនឹង[ខ]យាងមក; ហើយមើលចុះ យើងយាងមកជា
ឆាប់ ទាំងនាំយករង្វាន់មកជាមួយផង ហើយពួកអ្នកណាដែល
[គ]ស្វែងរកយើងពីមុនៗ នោះនឹងត្រូវរកឃើញ[ឃ]សេចក្ដីសំរាកដល់
ព្រលឹងរបស់ ពួកគេ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៥៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះវិលលាម ដ័បបុលយូ ហ្វែលប្ស នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែមិថុនា ឆ្នាំ១៨៣១ (*History of the Church, *១:១៨៤–១៨៦) ។ វិលលាម ដ័បបុលយូ ហ្វែលប្សជាអ្នកបោះពុម្ព ហើយគ្រួសាររបស់គាត់ទើបតែមកដល់ក្រុងខឺតឡង់ ហើយព្យាការីបានទូលដល់ព្រះអម្ចាស់ សូមដំណឹងអំពីគាត់ ។*

*១–៣, វិលលាម ដ័បបុលយូ ហ្វែលប្សត្រូវបានហៅ ហើយរើសឲ្យទទួលបុណ្យជ្រមុជទឹក ឲ្យតែងតាំងជាអែលឌើរ ហើយឲ្យផ្សាយ ដំណឹងល្អ; ៤, គាត់ក៏ត្រូវសរសេរសៀវភៅសំរាប់កូនក្មេង នៅក្នុងសាលានៃសាសនាចក្រដែរ; ៥–៦, គាត់ត្រូវធ្វើដំណើរទៅ រដ្ឋមិសសួរី ដែលនឹងត្រូវទៅជាតំបន់នៃកិច្ចការរបស់គាត់ ។*

មើលចុះ វិលលាម ជាអ្នកបំរើរបស់យើងអើយ ព្រះអម្ចាស់
ទ្រង់មានព្រះបន្ទូលដល់អ្នក មែនហើយ គឺជា[ក]ព្រះអម្ចាស់នៃផែនដី
ទាំងមូល ថាអ្នកត្រូវបានហៅ ហើយរើស ហើយបន្ទាប់ពីអ្នកត្រូវ
បានទទួល[ខ]បុណ្យជ្រមុជដោយទឹក បើសិនជាអ្នកធ្វើដោយភ្នែក
ស្មោះត្រង់ទាំងស្រុង ចំពោះសិរីល្អរបស់យើង នោះអ្នកនឹងត្រូវ
បានទទួលការផ្ដាច់បាបទាំងឡាយរបស់អ្នក និងការទទួលយកព្រះ
វិញ្ញាណបរិសុទ្ធ ដោយសារ ការ[គ]ដាក់ដៃលើ ។
២ ហើយខណៈនោះ អ្នកនឹងត្រូវបានតែងតាំង ដោយដៃរបស់
យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ឲ្យធ្វើជាអែលឌើរ
ចំពោះ សាសនាចក្រនេះ ដើម្បីផ្សាយពីការប្រែចិត្ត និង[ក]ការ
ផ្ដាច់បាបទាំងឡាយ ដោយសារបុណ្យជ្រមុជទឹក ដោយនូវ
ព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះ
ជន្មរស់នៅ ។
៣ ហើយដល់អស់អ្នកណាដែលអ្នកដាក់ដៃលើ បើសិនជាពួក
គេមានចិត្តទន់ទាបនៅចំពោះយើង នោះអ្នកត្រូវមានអំណាច
ដើម្បី ប្រគល់ព្រះវិញ្ញាណបរិសុទ្ធ ។
៤ ហើយជាថ្មីទៀត អ្នកត្រូវបានតែងតាំងឡើង ឲ្យជួយ អូលីវើរ
ខៅឌើរី ជាអ្នកបំរើរបស់យើង ដើម្បី[ក]ធ្វើកិច្ចការខាងបោះពុម្ព និង
ខាង ជ្រើសរើសហើយសរសេរសៀវភៅ សំរាប់សាលារៀន
ទាំងឡាយនៅក្នុងសាសនាចក្រ ប្រយោជន៍ឲ្យកូនក្មេងតូចៗអាច
បានទទួល ការបង្គាប់ផងដែរ នៅចំពោះយើង ដែលគាប់ចិត្ត
ដល់យើង ។
៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ដោយ
សារហេតុនេះ ទើបអ្នកត្រូវចេញដំណើររបស់អ្នក ទៅជាមួយ
យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និងស៊ីឌនី រិកដុន ជាពួកអ្នកបំរើរបស់យើង
ប្រយោជន៍ឲ្យអ្នកអាចបានតាំង[ក]នៅក្នុងដែនដីនៃកេរ្តិ៍អាកររបស់អ្នក
ដើម្បីធ្វើកិច្ចការ នេះ ។
៦ ហើយជាថ្មីទៀត ចូរឲ្យយ៉ូសែប ខូ ជាអ្នកបំរើ
របស់យើង ចេញដំណើររបស់គាត់ទៅជាមួយពួកគេដែរ ។
ហើយដែលនៅសល់ទាំង ប៉ុន្មាន នោះនឹងត្រូវបានធ្វើឲ្យ
ដឹងនៅពេលខាងមុខ តាមដែលយើងសព្វព្រះហឫទ័យ ។
អាម៉ែន ៕

១០ *ក* ស.ប. សេចក្ដីអត់ធន់.
*ខ* វិវរ. ២២:១២.
ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.
*គ* សុភា. ៨:១៧.
ស.ប. ការអធិស្ឋាន.
*ឃ* ម៉ាថាយ ១១:២៨–៣០.
ស.ប. សេចក្ដីសំរាក.
**៥៥** ១*ក* ចោទិ. ១០:១៤; ១ នីហ្វៃ ១១:៦;
២ នីហ្វៃ ២៩:៧.
*ខ* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
*គ* ស.ប. ដៃ, ការដាក់.
២ *ក* ស.ប. ការផ្ដាច់បាប.
៤ *ក* គ. និង ស. ៨៨:១១៨;
១០៩:៧, ១៤.
៥ *ក* អេម៉ុស ៩:១៥.

## កណ្ឌទី ៥៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ខែមិថុនា ឆ្នាំ១៨៣១ (*History of the Church, *១:១៨៦–១៨៨) ។ អែសរ៉ា ធេយ័រ ជាអ្នកដែលត្រូវបានចាត់ឲ្យធ្វើដំណើរទៅរដ្ឋមិសសួរី ជាមួយ ថូម៉ាស ប៊ី ម៉ាស (សូមមើលកណ្ឌទី ៥២:២២) គាត់ពុំអាចចាប់ផ្ដើមបេសកកម្មរបស់គាត់បានទេ កាល ថូម៉ាស បានប្រុងប្រៀបរួចស្រេច ។ អែលឌើរ ធេយ័រ ពុំបានប្រុងប្រៀបនឹងចេញដំណើររបស់គាត់ ពីព្រោះតែការដែលគាត់ឡុកឡំជាមួយនឹងបញ្ហានៅឯភូមិថមសុន រដ្ឋអូហៃអូ (សូមមើលបុព្វកថានៃកណ្ឌទី ៥៤) ។ ព្រះអម្ចាស់ទ្រង់បានឆ្លើយតបសំណូមពររបស់ព្យាការី អំពីការណ៍នោះ ដោយប្រទានវិវរណៈនេះ ។*

*១–២, ពួកបរិសុទ្ធត្រូវផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយដើរតាមព្រះអម្ចាស់ ដើម្បីឲ្យបានសេចក្ដីសង្គ្រោះ; ៣–១៣, ព្រះអម្ចាស់ទ្រង់បញ្ជា ហើយដកចេញ ហើយពួកអ្នកមិនគោរពនោះត្រូវបោះបង់ចោល; ១៤–១៧, វេទនាដល់ពួកអ្នកមាន ដែលមិនជួយអ្នកទាល់ក្រ ហើយវេទនាដល់ពួកអ្នកទាល់ក្រ ដែលពុំមានចិត្តសង្រេង; ១៨–២០, មានពរហើយដល់ពួកអ្នកទាល់ក្រ ដែលមានចិត្តបរិសុទ្ធ ត្បិតពួកគេនឹងបានគ្រងផែនដីទុកជាមរតក ។*

ប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នា ជាប្រជារាស្ត្រដែលអះអាងតាមព្រះនាមរបស់យើងអើយ ព្រះអម្ចាស់ជាព្រះរបស់អ្នកទ្រង់មាន ព្រះបន្ទូលថា៖ ត្បិតមើលចុះ សេចក្ដីខ្ញាល់របស់យើងឆួលឡើងទាស់នឹងពួកបះបោរ ហើយពួកគេត្រូវស្គាល់ពាហុរបស់យើង និងសេចក្ដីក្ដៅក្រហាយរបស់យើង នៅក្នុងថ្ងៃនៃការពិនិត្យពិច័យ និងសេចក្ដីក្រោធ មកលើសាសន៍ទាំងឡាយ ។

២ ហើយអ្នកណាដែលមិនព្រមផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយដើរតាមយើង ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងទេ អ្នកនោះ នឹងមិនត្រូវបានសង្គ្រោះឡើយ ។

៣ មើលចុះ ហើយយើងជាព្រះអម្ចាស់បញ្ជា ហើយអ្នកណាដែលមិនព្រមគោរពតាមទេ នោះនឹងត្រូវកាត់ចេញ កាលដល់ពេលកំណត់ របស់យើង បន្ទាប់ពីយើងបានបញ្ជា ហើយព្រះបញ្ញត្តិនោះត្រូវបាក់ ។

៤ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ បញ្ជាហើយដកចេញ តាមតែឃើញថាល្អដល់យើង; ហើយការណ៍ទាំងអស់នេះ ត្រូវបាន ឆ្លើយមកលើក្បាលរបស់ពួកបះបោរ គឺព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៥ ហេតុដូច្នោះហើយ យើងដកបញ្ញត្តិដែលបានប្រទានដល់ថូម៉ាស ប៊ី ម៉ាស និងអែសរ៉ា ធេយ័រ ជាពួកអ្នកបំរើរបស់យើងចេញ ហើយប្រទានបញ្ញត្តិថ្មីមួយដល់ ថូម៉ាស ជាអ្នកបំរើរបស់យើង ថាគាត់ត្រូវចេញដំណើររបស់គាត់យ៉ាងឆាប់រហ័ស ទៅឯដែនដីមិសសួរី ហើយ សេឡា ជេ គ្រិពហ្វិន ត្រូវទៅជាមួយគាត់ដែរ ។

៦ ត្បិតមើលចុះ យើងដកបញ្ញត្តិដែលបានប្រទានដល់ សេឡា ជេ គ្រិពហ្វិន និង នូវល ណៃត៍ ជាពួកអ្នកបំរើរបស់យើងចេញ ដោយហេតុតែសេចក្ដីរឹងរូសនៃរាស្ត្ររបស់យើង ដែលនៅភូមិថមសុន និងការបះបោរទាំងឡាយរបស់ពួកគេ ។

៧ ហេតុដូច្នោះហើយ ចូរឲ្យ នូវល ណៃត៍ ជាអ្នកបំរើរបស់យើង នៅជាមួយពួកគេចុះ; ហើយមនុស្សជាច្រើនណាដែលអាចទៅបាន ដែលមានចិត្តទន់ទាបនៅចំពោះយើង នោះត្រូវឲ្យគាត់នាំទៅដែនដី ដែលយើងបានចាត់ទុក ។

៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា អែសរ៉ា ធេយ័រ ជាអ្នកបំរើរបស់យើង ត្រូវប្រែចិត្តពីសេចក្ដីឆ្មើងឆ្មៃរបស់ខ្លួន និងពីការ កំណាញ់របស់ខ្លួន ហើយគោរពតាមបញ្ញត្តិមុនៗ ដែលយើងបានប្រទានដល់គាត់ អំពីកន្លែងដែលគាត់រស់នៅ ។

៩ ហើយបើសិនជាគាត់នឹងធ្វើការនេះ ព្រោះមិនត្រូវមានការបែកខ្ញែកនៅលើដែនដីឡើយ នោះគាត់នៅតែត្រូវបានចាត់ឲ្យទៅឯ ដែនដីមិសសួរីដែរ;

**៥៦** ១*ក* គ. និង ស. ៤១:១.
*ខ* អេសាយ ១០:៣–៤; មរមន ៩:២; គ. និង ស. ១:១៣–១៤; ១២៤:១០.
២ *ក* លូកា ១៤:២៧.
*ខ* ១ ពេត្រុស ២:២១; ២ នីហ្វៃ ៣១:១០–១៣; ម៉ូរ៉ូណៃ ៧:១១. ស.ប. ព្រះយេស៊ូវគ្រីស្ទ — ដំរាប់នៃព្រះយេស៊ូវគ្រីស្ទ.
៣ *ក* ស.ប. ការគោរព, ដែលគោរព, គោរព.
*ខ* គ. និង ស. ១:១៤–១៦; ៥០:៨.
៤ *ក* គ. និង ស. ៥៨:៣១–៣៣.
*ខ* ស.ប. ការបះបោរ.
៥ *ក* ស.ប. ម៉ាស, ថូម៉ាស ប៊ី.
៨ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ.

១០ បើពុំនោះសោតទេ គាត់ត្រូវទទួលប្រាក់ ដែលគាត់បានបង់ ហើយត្រូវចេញពីកន្លែង ហើយត្រូវ[ក]កាត់ចេញពីសាសនាចក្រ របស់យើង ព្រះអម្ចាស់ដ៏ជាព្រះនៃពួកពលបរិវា ទ្រង់មានព្រះបន្ទូលថាដូច្នោះ;

១១ ហើយទោះជាផ្ទៃមេឃ ហើយផែនដី នឹងកន្លងបាត់ទៅក៏ដោយ គង់តែពាក្យទាំងនេះ នឹងមិន[ក]កន្លងបាត់ដែរ ប៉ុន្តែនឹងបានសំរេចវិញ ។

១២ ហើយបើសិនជា យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ត្រូវបង់ប្រាក់ មើលចុះ យើងជាព្រះអម្ចាស់ នឹងបង់ឲ្យលោកសារថ្មី នៅឯដែនដីមិសសួរី ប្រយោជន៍ឲ្យអស់អ្នកណាដែលលោកបានទទួល អាចបានរង្វាន់សារថ្មី តាមអ្វីដែលពួកគេបានប្រព្រឹត្ត;

១៣ ត្បិតតាមអ្វីដែលពួកគេបានប្រព្រឹត្ត នោះពួកគេត្រូវបានទទួល ដូចជាដែនដីទុកជាកេរ្តិ៍អាករដល់ពួកគេ ។

១៤ មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់រាស្ត្រយើងថា — អ្នកមានការណ៍ជាច្រើនដែលត្រូវប្រព្រឹត្ត និងត្រូវប្រែចិត្ត; ត្បិត មើលចុះ អំពើបាបទាំងឡាយរបស់អ្នកបានឡើងមកដល់យើង ហើយពុំបានអភ័យទោសឲ្យទេ ពីព្រោះអ្នកស្វែងរក[ក]ដំបូន្មាន តាម អំពើចិត្តរបស់ខ្លួន ។

១៥ ហើយចិត្តរបស់អ្នកទាំងឡាយពុំបានស្កប់ស្កល់ឡើយ ។ ហើយអ្នករាល់គ្នាមិនគោរពតាមសេចក្ដីពិតទេ ប៉ុន្តែបាន[ក]ត្រេកអរក្នុងសេចក្ដីមិនសុចរិតវិញ ។

១៦ វេទនាដល់អ្នកដែល[ក]មាន ដែលមិន[ខ]ឲ្យទ្រព្យសម្បត្តិរបស់ខ្លួនដល់[គ]មនុស្សទាល់ក្រ ត្បិត[ឃ]ទ្រព្យសម្បត្តិទាំងឡាយរបស់អ្នកនឹងធ្វើឲ្យ ព្រលឹងរបស់អ្នកមានដំបៅ; ហើយនេះនឹងត្រូវទៅជាការទួញសោករបស់អ្នក នៅថ្ងៃនៃការពិនិត្យពិច័យ និងការជំនុំជំរះ និងការក្ដៅ ក្រហាយថា៖ [ង]រដូវច្រូតបានផុតទៅ រដូវក្ដៅបានចប់ហើយ រីឯព្រលឹងរបស់ខ្ញុំពុំបានសង្គ្រោះសោះ!

១៧ វេទនាដល់អ្នកដែល[ក]ទាល់ក្រ ដែលមានចិត្តឥតសង្រេង ដែលមានវិញ្ញាណឥតទន់ទាប ហើយដែលមានពោះឥតឆ្អែត ហើយដែល មានដៃឥតទុកពីយករបស់អ្នកផ្សេង ដែលមានភ្នែកពោរពេញទៅដោយ[ខ]ភាពលោភលន់ ហើយដែលមិនព្រមធ្វើការដោយដៃរបស់ខ្លួន សោះ!

១៨ ប៉ុន្តែ មានពរហើយដល់[ក]ពួកអ្នកទាល់ក្រ ដែលមានចិត្តបរិសុទ្ធ ដែលមាន[ខ]ចិត្តសង្រេង ហើយដែលមានវិញ្ញាណទន់ទាប ត្បិតពួក គេនឹងបានឃើញ[គ]នគរព្រះ មកដោយនូវអំណាច និងសិរីល្អដ៏ធំ ចំពោះសេចក្ដីរំដោះរបស់ពួកគេ; ត្បិតផលពី[ឃ]ផែនដីនឹងត្រូវជារបស់ផង អ្នកទាំងនោះ ។

១៩ ត្បិតមើលចុះ ព្រះអម្ចាស់នឹងយាងមក ហើយនឹងយក[ក]រង្វាន់របស់ទ្រង់មកជាមួយផង ហើយទ្រង់នឹងចែកឲ្យគ្រប់គ្នា ហើយពួកមនុស្ស ទាល់ក្រនឹងបានត្រេកអរ;

២០ ហើយតំណមនុស្សទាំងឡាយរបស់ពួកគេ នឹងគ្រងផែនដីទុកជា[ក]មរតក ពីតំណមួយទៅតំណមួយ ជារៀងរហូតតទៅ ។ ហើយឥឡូវ នេះ យើងបញ្ចប់ការនិយាយដល់អ្នកសិនហើយ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៥៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងស៊ីយ៉ូន ឃុំចាកសុន រដ្ឋមិសសួរី ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៨៣១ (*History of the Church*, ១:១៨៩–១៩០) ។ ក្នុងការធ្វើតាមបញ្ជារបស់ព្រះអម្ចាស់ (កណ្ឌទី ៥២) ពួកអែល ឌើរបានធ្វើដំ ណើរពីក្រុងខឺតឡង់ទៅរដ្ឋមិសសួរី ដោយមានការពិសោធន៍ផ្សេងៗពីគ្នា និងការបៀតបៀនខ្លះៗ ។ ក្នុង*

១០ *ក* ស.ប. ការកាត់ចេញពីសាសនា.
១១ *ក* ២ នីហ្វៃ ៩:១៦.
១៤ *ក* យ៉ាកុប ៤:១០.
១៥ *ក* អាលម៉ា ៤១:១០;
៣ នីហ្វៃ ២៧:១១.
១៦ *ក* យេរេ. ១៧:១១; ២ នីហ្វៃ ៩:៣០.
*ខ* ស.ប. ទាន, ការដាក់ទាន.
*គ* សុភា. ១៤:៣១;
អាលម៉ា ៥:៥៥–៥៦.
ស.ប. មនុស្សក្រីក្រ.
*ឃ* យ៉ាកុប (ព.ស.ថ.) ៥:៣.
*ង* យេរេ. ៨:២០;
អាលម៉ា ៣៤:៣៣–៣៥;
គ. និង ស. ៤៥:២.
១៧ *ក* ម៉ូសាយ ៤:២៤–២៧;
គ. និង ស. ៤២:៤២;
៦៨:៣០–៣២.
*ខ* ស.ប. លោភ.
១៨ *ក* ម៉ាថាយ ៥:៣, ៨; លូកា ៦:២០;
៣ នីហ្វៃ ១២:៣.
ស.ប. មនុស្សក្រីក្រ.
*ខ* ស.ប. ចិត្តសង្រេង.
*គ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ឃ* ស.ប. ផែនដី.
១៩ *ក* វិវរ. ២២:១២; គ. និង ស. ១:១០.
២០ *ក* ម៉ាថាយ ៥:៥;
គ. និង ស. ៤៥:៥៦–៥៨.

*ការពិចារណា គិតពីស្ថានភាពរបស់ពួកសាសន៍លេមិន និងការខ្វះខាងអារ្យធម៌ ភាពថ្លៃថ្នូរ និងសាសនាក្នុងចំណោមប្រជាជនទូទៅ នោះព្យាការី បានថ្លែងថា៖ «តើពេលណាទៅដែលទីរហោស្ថាននឹងបានរីកឡើងដូចជាកុឡាប? តើពេលណាទៅដែលក្រុងស៊ីយ៉ូននឹងបានសង់ ឡើង ក្នុងភាពរុងរឿងរបស់នាង ហើយតើកន្លែងណាទៅ ដែលព្រះវិហាររបស់ព្រះអង្គនឹងឈរឡើង ដែលអស់ទាំងសាសន៍នឹងមករក នៅថ្ងៃចុងក្រោយបង្អស់?»* (History of the Church, *១:១៨៩) ។ បន្ទាប់មក លោកបាន ទទួលវិវរណៈនេះ ។*

*១–៣, ក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី គឺជាកន្លែងសំរាប់ទីក្រុងស៊ីយ៉ូន និងព្រះវិហារ; ៤–៧, ពួកបរិសុទ្ធត្រូវទិញដីធ្លី ហើយទទួល កេរ្តិ៍អាករនៅទីនោះ; ៨–១៦, ស៊ីឌនី គិលប៊ឺត ត្រូវតាំងផ្សារមួយ, វិលលាម ដ័បបុលយូ ហ្វែបូ ត្រូវធ្វើជាអ្នកបោះពុម្ព ហើយអូលីវើរ ខៅឌើរី ត្រូវពិនិត្យផ្ទៀងផ្ទាត់សម្ភារៈសំរាប់បោះពុម្ពផ្សាយ ។*

ព្រះអម្ចាស់ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថា ចូរប្រុង
ស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្រ
របស់យើង ជាពួកអ្នក ដែលបានជួបជុំគ្នាអើយ តាមព្រះបញ្ញត្តិ
ទាំងឡាយរបស់យើង នៅក្នុងដែនដីនេះ ដែលជាដែនដីមិសសួរី
គឺជាដែនដីដែលយើងបាន តាំងនិងចាត់ទុកសំរាប់ការជួបជុំគ្នានៃ
ពួកបរិសុទ្ធ ។
២ ហេតុដូច្នោះហើយ នេះជាដែនដីសន្យា ហើយជាកន្លែង
សំរាប់ទីក្រុងស៊ីយ៉ូន ។
៣ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា បើសិនជា
អ្នកព្រមទទួលប្រាជ្ញា នេះហើយជាប្រាជ្ញា ។ មើលចុះ កន្លែង
ដែលហៅថា អ៊ិនឌីប៉ែនដែនស៍ឥឡូវនេះ គឺជាកន្លែងកណ្ដាល
ហើយជាកន្លែងសំរាប់ព្រះវិហារ នោះនៅខាងលិច នៅលើកន្លែង
ដែលមិនសូវឆ្ងាយ ប៉ុន្មានពីសាលាកាត់ក្ដីទេ ។
៤ ហេតុដូច្នោះហើយ គឺជាប្រាជ្ញា ដែលពួកបរិសុទ្ធត្រូវទិញដី
ព្រមទាំងគ្រប់តំបន់នៅទិសខាងលិចផង រហូតដល់ចំខ្សែខណ្ឌ
រវាង សាសន៍យូដា និងសាសន៍ដទៃ;
៥ ហើយព្រមទាំងតំបន់ជាប់ព្រំដែននឹងវាលស្មៅ ដរាបណា
ពួកសិស្សរបស់យើងអាចទិញដីធ្លីបាន ។ មើលចុះ នេះហើយជា
ប្រាជ្ញា ប្រយោជន៍ឲ្យពួកគេអាចបានដីទុកជាកេរ្តិ៍អាករដ៏អស់កល្ប ។
៦ ហើយចូរឲ្យស៊ីឌនី គិលប៊ឺត ជាអ្នកបំរើរបស់យើង
បំពេញតំណែង ដែលយើងបានតាំងដល់គាត់ ដើម្បីទទួល
ប្រាក់កាស ដើម្បីធ្វើ ជាភ្នាក់ងារចំពោះសាសនាចក្រ ដើម្បីទិញ
ដីនៅគ្រប់ភូមិភាគជុំវិញ ដរាបណាដែលអាចធ្វើទៅបាន
ក្នុងសេចក្ដីសុចរិត ហើយតាម ដែលប្រាជ្ញានឹងដឹកនាំ ។
៧ ហើយចូរឲ្យ អែតវើត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង
បំពេញតំណែង ដែលយើងបានតាំងដល់គាត់ ហើយ
ចែកដល់ពួកបរិសុទ្ធ នូវកេរ្តិ៍អាកររបស់ពួកគេ ដូចជាយើង
បានបញ្ជា; ហើយព្រមទាំងពួកអ្នកទាំងនោះ ដែលគាត់បាន
តាំងឲ្យជួយគាត់ផង ។
៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យស៊ីឌនី
គិលប៊ឺត ជាអ្នកបំរើរបស់យើង តាំងខ្លួននៅកន្លែងនេះ ហើយធ្វើ
ផ្សារមួយ ប្រយោជន៍ឲ្យគាត់អាច ទិញរបស់របរ ដោយឥតទោស
ប្រយោជន៍ឲ្យគាត់អាចបានប្រាក់ ដើម្បីទិញដីធ្លីសំរាប់សេចក្ដីល្អ
ដល់ពួកបរិសុទ្ធ ហើយប្រយោជន៍ឲ្យ គាត់អាចបានអ្វីៗនានា
ដែលពួកសិស្សអាចត្រូវការ ដើម្បីតាំងខ្លួននៅក្នុងទីកេរ្តិ៍អាករ
របស់ពួកគេ ។
៩ ហើយព្រមទាំងឲ្យ ស៊ីឌនី គិលប៊ឺត ជាអ្នកបំរើរបស់យើង
ទទួលច្បាប់ — មើលចុះ នេះហើយជាប្រាជ្ញា ហើយអស់អ្នក
ណាដែលអាន ចូរឲ្យអ្នកនោះយល់ចុះ — ដើម្បីឲ្យគាត់
អាចផ្ញើរបស់របរទៅដល់ប្រជាជនផងដែរ គឺតាមពួកអ្នកណា
ដែលគាត់ជួលឲ្យធ្វើជាស្មៀន ឲ្យគាត់ តាមដែលគាត់ប្រាថ្នា;

៥៧ ១*ក* គ. និង ស. ៥២:៤២.
*ខ* គ. និង ស. ២៩:៧–៨; ៤៥:៦៤–៦៦.
*គ* គ. និង ស. ៦១:១៧.
*ឃ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
២ *ក* គ. និង ស. ២៨:៩; ៤២:៩, ៦២.
*ខ* ស.ប. ស៊ីយ៉ូន.
៣ *ក* គ. និង ស. ៥៨:៥៧; ៩៧:១៥–១៧.
៤ *ក* គ. និង ស. ៤៨:៤.
*ខ* ក.ន. «សាសន៍យូដា» នៅទីនេះ សំដៅទៅដល់ពួកសាសន៍លេមិន, ហើយ «សាសន៍ដទៃ» ដល់ពួក អាមេរិកាំងស្បែកស ដែលមករស់នៅ.
៥ *ក* គ. និង ស. ៥៨:៤៩, ៥១; ១០១:៦៨–៧៤.
*ខ* គ. និង ស. ៥៦:២០.
៦ *ក* គ. និង ស. ៥៣.
៧ *ក* គ. និង ស. ៥៨:២៤. ស.ប. ប៉ាទ្រិច, អែតវើត.
*ខ* គ. និង ស. ៤១:៩–១១; ៥៨:១៤–១៨.

១០ ហើយទើបផ្ដល់ដល់ពួកបរិសុទ្ធរបស់យើងយ៉ាងដូច្នោះហើយ ប្រយោជន៍ឲ្យដំណឹងល្អរបស់យើង អាចបានផ្សាយដល់ពួកអ្នកទាំង នោះ ដែលអង្គុយនៅក្នុងសេចក្ដីងងឹត ហើយនៅក្នុងភូមិភាគ និងម្លប់នៃសេចក្ដីស្លាប់ ។

១១ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យវិលលាម ដ័បបុលយូ ហ្វែប្ស ជាអ្នកបំរើរបស់យើង តាំងនៅក្នុងកន្លែងនេះ ហើយស្ថាបនាជាអ្នកបោះពុម្ពចំពោះសាសនាចក្រចុះ ។

១២ ហើយមើលន៏ បើសិនជាពិភពលោកទទួលការសរសេរទាំងឡាយរបស់គាត់ — មើលចុះ នេះហើយជាប្រាជ្ញា — ចូរឲ្យគាត់បាន អ្វីៗដែលគាត់យកបាន ក្នុងសេចក្ដីសុចរិត សំរាប់សេចក្ដីល្អដល់ពួកបរិសុទ្ធចុះ ។

១៣ ហើយចូរឲ្យអូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង ជួយគាត់ គឺតាមដែលយើងបានបញ្ជា នៅកន្លែងណាក៏ដោយ ដែលយើងនឹង តាំងដល់គាត់ ដើម្បីចម្លង និងដើម្បីកែប្រែ និងជ្រើសរើស ប្រយោជន៍ឲ្យគ្រប់ការណ៍ទាំងអស់អាចបានត្រឹមត្រូវនៅចំពោះយើង ដូចជា ត្រូវបានបញ្ជាក់ដោយព្រះវិញ្ញាណ តាមរយៈគាត់នោះឯង ។

១៤ ម្ល៉ោះហើយ ចូរឲ្យពួកអ្នកទាំងនោះ ដែលយើងបានពោលដល់ ត្រូវបានតាំងនៅក្នុងដែនដីស៊ីយ៉ូន យ៉ាងឆាប់ៗដូចដែលអាចធ្វើទៅ បាន ជាមួយនឹងគ្រួសាររបស់ពួកគេ ដើម្បីធ្វើអ្វីៗទាំងនោះ ដូចដែលយើងបានមានបន្ទូលមក ។

១៥ ហើយឥឡូវនេះ ស្ដីអំពីការជួបជុំគ្នា — ចូរឲ្យប៊ីស្សប និងភ្នាក់ងារធ្វើការរៀបចំ សំរាប់គ្រួសារទាំងនោះ ដែលត្រូវបានបញ្ជា ឲ្យមកឯដែនដីនេះយ៉ាងលឿនដូចដែលអាចធ្វើទៅបាន ហើយតាំងពួកគេ នៅក្នុងទីនៃកេរ្តិ៍អាកររបស់ពួកគេចុះ ។

១៦ ហើយចំណែកពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន ទាំងពួកអែលឌើរ និងសមាជិក នោះការដឹកនាំនឹងត្រូវបានប្រាប់តទៅទៀតនៅ ពេលក្រោយ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៥៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងស៊ីយ៉ូន ឃុំចាកសុន រដ្ឋមិសសួរី ថ្ងៃទី១ ខែសីហា ឆ្នាំ១៨៣១ (*History of the Church*, ១:១៩០–១៩៥) ។ នៅថ្ងៃឈប់សំរាកទីមួយ បន្ទាប់ពីព្យាការី និងក្រុមលោកបានមកដល់ពីឃុំ ចាកសុន រដ្ឋមិសសួរី នោះមានការប្រជុំមួយខាងសាសនា ហើយមានសមាជិកពីរនាក់បានទទួលបុណ្យជ្រមុជទឹក ។ នៅក្នុងអាទិត្យ នោះ មានពួកបរិសុទ្ធខ្លះៗពីក្លូមិខូលស្វិល មកពីសាខាថមសុន និងពួកមនុស្សផ្សេងៗទៀតបានមកដល់ (សូមមើលកណ្ឌទី ៥៤) ។ មនុស្សជាច្រើនចង់ដឹងពីព្រះហឫទ័យនៃព្រះអម្ចាស់ អំពីពួកគេនៅកន្លែងជួបជុំគ្នាថ្មី ។*

*១–៥, ពួកអ្នកណាដែលស៊ូទ្រាំការវេទនា នោះនឹងបានពាក់សិរីល្អទុកជាមកុដ; ៦–១២, ពួកបរិសុទ្ធត្រូវរៀបចំសំរាប់អាពាហ៍ពិពាហ៍ នៃកូនចៀម និងអាហារនៃព្រះអម្ចាស់; ១៣–១៨, ប៊ីស្សបត្រូវធ្វើជាចៅក្រមក្នុងចំណោមសាសន៍អ៊ីស្រាអែល; ១៩–២៣, ពួកបរិសុទ្ធ ត្រូវគោរពតាមក្រិត្យវិន័យទាំងឡាយនៃដែនដី; ២៤–២៩, មនុស្សលោកគប្បីប្រើសិទ្ធិជ្រើសរើសរបស់ខ្លួន ដើម្បីធ្វើអំពើល្អ; ៣០–៣៣, ព្រះអម្ចាស់ទ្រង់បញ្ជា ហើយដកចេញ; ៣៤–៤៣, ដើម្បីប្រែចិត្ត មនុស្សលោកត្រូវសារភាព ហើយលះបង់ចោលអំពើបាបទាំងឡាយ របស់ខ្លួន; ៤៤–៥៨, ពួកបរិសុទ្ធត្រូវទិញដីនៃកេរ្តិ៍អាកររបស់ពួកខ្លួន ហើយជួបជុំគ្នានៅរដ្ឋមិសសួរី; ៥៩–៦៥, ដំណឹងល្អត្រូវបានផ្សាយដល់គ្រប់មនុស្សទាំងអស់ ។*

ប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្ររបស់យើងអើយ ហើយចូរផ្ទៀងត្រចៀកចំពោះព្រះបន្ទូលរបស់យើង ហើយរៀនពីយើង តាមអ្វីដែលយើងសព្វព្រះហឫទ័យ អំពីអ្នក និងអំពីដែនដីនេះផង ដែលយើងបានចាត់អ្នកឲ្យទៅ ។

២ ត្បិតយើងប្រាប់អ្នកជាប្រាកដថា មានពរហើយ ដល់អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ទោះបីរស់ ឬស្លាប់ក្ដី; ហើយអ្នកណាដែលមានចិត្តស្មោះត្រង់ក្នុងសេចក្ដីវេទនា រង្វាន់របស់អ្នកនោះនៅនគរស្ថានសួគ៌ គឺប្រសើរជាង ។

១០ *ក* អេសាយ ៩:២; ម៉ាថាយ ៤:១៦. ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
*ខ* ទំនុក. ២៣:៤.
១១ *ក* ស.ប. ហ្វែប្ស, វិលលាម ដ័បបុលយូ.
*ខ* គ. និង ស. ៥៨:៣៧, ៤០–៤១.
១៣ *ក* ស.ប. ខៅឌើរី, អូលីវើរ.
**៥៨** ១ *ក* គ. និង ស. ៥៧:១–៨.
២ *ក* ម៉ូសាយ ២:២២.
*ខ* ១ ពេត្រុស ៤:៦.
*គ* ២ ថែស្សា. ១:៤.
*ឃ* ស.ប. សេចក្ដីទំនាស់.

៣ ត្បិតនៅពេលនេះ អ្នករាល់គ្នាពុំអាចមើលឃើញ ដោយ[ក]ភ្នែកធម្មតារបស់អ្នកឡើយ នូវគំរោងការណ៍នៃព្រះរបស់អ្នក អំពីអ្វីៗទាំង នោះ ដែលត្រូវបានមកនៅពេលក្រោយ និង[ខ]សិរីល្អដែលត្រូវមកតាមក្រោយ បន្ទាប់ពីមានសេចក្ដីវេទនាដ៏ច្រើន ។

៤ ត្បិតបន្ទាប់ពីមាន[ក]ការវេទនាដ៏ច្រើន នោះទើបបាន[ខ]ព្រះពរ ។ ហេតុដូច្នោះហើយ ថ្ងៃនោះនឹងមកដល់ កាលអ្នករាល់គ្នានឹងត្រូវបាន ពាក់[គ]សិរីល្អដ៏ច្រើន ទុកជា[ឃ]មកុដ ម៉ោងមិនទាន់ដល់ទេ ប៉ុន្តែនៅជិតដែបង្កើយ ។

៥ ចូរនឹកចាំពីការណ៍នេះ ដែលយើងប្រាប់អ្នកមកពីមុន ប្រយោជន៍ឲ្យអ្នកអាច[ក]ទុកក្នុងចិត្ត ហើយទទួលយកអ្វីដែលនឹងមកតាមក្រោយ ។

៦ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា ព្រោះដោយហេតុនេះបានជាយើងចាត់អ្នក — ប្រយោជន៍ឲ្យអ្នកអាចគោរពតាម ហើយ ប្រយោជន៍ឲ្យ[ក]ចិត្តអ្នករាល់គ្នា អាចបានប្រុងប្រៀប ដើម្បីថ្លែង[ខ]ទីបន្ទាល់អំពីអ្វីៗ ដែលនឹងមកដល់ ។

៧ ហើយប្រយោជន៍ឲ្យអ្នកអាចបានកិត្តិយសផង ក្នុងការសង់គ្រឹះ និងក្នុងការធ្វើទីបន្ទាល់អំពីដែនដី ដែល[ក]ក្រុងស៊ីយ៉ូននៃព្រះនឹងបានសង់ឡើង;

៨ ហើយប្រយោជន៍ឲ្យការជប់លៀង ដោយម្ហូបមានឱជារសយ៉ាងវិសេស សំរាប់[ក]មនុស្សទាល់ក្រ; មែនហើយ ជាការជប់លៀងដោយម្ហូបមានឱជារសយ៉ាងវិសេស និងស្រាទំពាំងបាយជូរ[ខ]សំរាំងយ៉ាងល្អ ប្រយោជន៍ឲ្យផែនដីអាចបានដឹងថា មាត់នៃពួកព្យាការី នឹងមិនត្រូវខកឡើយ;

៩ មែនហើយ ជាអាហារនៃដំណាក់របស់ព្រះអម្ចាស់ ដែលបានរៀបចំជាស្រេច ដល់គ្រប់ទាំងសាសន៍ណាដែលត្រូវបានអញ្ជើញមក ។

១០ ទីមួយ គឺពួកមនុស្សមាន និងពួកអ្នករៀនសូត្រ ពួកអ្នកប្រាជ្ញ និងពួកដែលមានត្រកូលខ្ពស់;

១១ ហើយបន្ទាប់ពីនោះ គឺថ្ងៃនៃព្រះចេស្ដារបស់យើងនឹងមកដល់; ខណៈនោះ មនុស្សទាល់ក្រ មនុស្សខ្វិន និងមនុស្សខ្វាក់ និងមនុស្ស [ខ]ថ្លង់នឹងមក[ក]រៀបអាពាហ៍ពិពាហ៍នៃកូនចៀម ហើយទទួលទានអាហារនៃព្រះអម្ចាស់ ដែលបានរៀបចំស្រេចសំរាប់ថ្ងៃដ៏ធំដែលនឹងមក ដល់ ។

១២ មើលចុះ យើងជាព្រះអម្ចាស់ បានមានព្រះបន្ទូលហើយ ។

១៣ ហើយប្រយោជន៍ឲ្យ[ក]ទីបន្ទាល់អាចចេញពីក្រុងស៊ីយ៉ូនទៅ មែនហើយ គឺចេញពីមាត់នៃទីក្រុងមរតករបស់ព្រះ —

១៤ មែនហើយ ព្រោះដោយហេតុនេះហើយបានជាយើងចាត់អ្នកឲ្យមកទីនេះ ហើយបានជ្រើសរើស[ក]អែតវីត ប៉ាទ្រិច ជាអ្នកបំរើរបស់ យើង ហើយបានចាត់ចែងបេសកកម្មដល់គាត់ នៅក្នុងដែនដីនេះ ។

១៥ ប៉ុន្តែបើសិនជាគាត់មិនប្រែចិត្តពីអំពើបាបទាំងឡាយរបស់គាត់ ដែលជាការឥតជំនឿ និងការខ្វាក់រឹងទទឹងនៃចិត្តទេ នោះចូរឲ្យគាត់ ប្រុងប្រយ័ត្ន ក្រែងគាត់[ក]ដួល ។

១៦ មើលចុះ បេសកកម្មរបស់គាត់ត្រូវបានប្រគល់ដល់គាត់ហើយ ហើយនឹងមិនត្រូវប្រគល់ដល់គាត់ទៀតទេ ។

១៧ ហើយអស់អ្នកណាដែលប្រព្រឹត្តក្នុងបេសកកម្មនេះ គឺត្រូវបានតាំង[ក]ឲ្យធ្វើជាចៅក្រមក្នុងចំណោមសាសន៍អ៊ីស្រាអែលដូចជានៅ កាលពីចាស់បុរាណ ដើម្បីចែកដែនដីនៃមរតករបស់ព្រះ ដល់[ខ]កូនចៅរបស់ទ្រង់;

១៨ ហើយដើម្បីជំនុំជំរះរាស្ត្ររបស់ទ្រង់ ដោយសារទីបន្ទាល់នៃមនុស្សសុចរិត និងដោយសារជំនួយពីទីប្រឹក្សាទាំងឡាយរបស់គាត់ តាមក្រិត្យវិន័យទាំងឡាយនៃនគរ ដែលបានប្រទានឲ្យមកដោយ[ក]ពួកព្យាការីនៃព្រះ ។

១៩ ត្បិតយើងប្រាប់អ្នកជាប្រាកដថា ក្រិត្យវិន័យរបស់យើងនឹងត្រូវបានកាន់តាមនៅលើដែនដីនេះ ។

២០ ចូរកុំឲ្យមនុស្សណាស្មានថាខ្លួនជាអ្នកគ្រប់គ្រងឡើយ; ប៉ុន្តែចូរឲ្យព្រះទ្រង់គ្រប់គ្រងលើអ្នកដែលជំនុំជំរះវិញ តាមដំបូន្មាន

៣ *ក* ស.ប. ព្រះ, ក្រុមព្រះ.
*ខ* ស.ប. សិរីល្អ.
៤ *ក* ទំនុក. ៣០:៥;
គ. និង ស. ១០១:២–៧;
១០៣:១១–១៤; ១០៩:៧៦.
*ខ* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*គ* ស.ប. មកុដ; ភាពដំកើងឡើង.
*ឃ* រ៉ូម ៨:១៧–១៨;
គ. និង ស. ១៣៦:៣១.
៥ *ក* ចោទិ. ១១:១៨–១៩.
៦ *ក* គ. និង ស. ២៩:៨.
*ខ* ស.ប. ទីបន្ទាល់.
៧ *ក* ស.ប. ស៊ីយ៉ូន.
៨ *ក* ស.ប. មនុស្សក្រីក្រ.
*ខ* អេសាយ ២៥:៦.
១១ *ក* ម៉ាថាយ ២២:១–១៤;
វិវរ. ១៩:៩; គ. និង ស. ៦៥:៣.
*ខ* លូកា ១៤:១៦–២៤.
១៣ *ក* មីកា ៤:២.
១៤ *ក* ស.ប. ប៉ាទ្រិច, អែតវីត.
១៥ *ក* ១ កូរិន. ១០:១២.
១៧ *ក* គ. និង ស. ១០៧:៧២–៧៤.
ស.ប. ប៊ីស្សព.
*ខ* ស.ប. បុត្រាបុត្រីនៃព្រះ.
១៨ *ក* ស.ប. ព្យាការី.

នៃព្រះហឫទ័យរបស់ទ្រង់ផ្ទាល់ ឬក៏ម្យ៉ាងទៀត លើអ្នកណាដែលទូន្មាន ឬអង្គុយនៅលើទីវេទិកាជំនុំជំរះ ។

២១ ចូរកុំឲ្យមនុស្សណាបំពាក់ក្រិត្យវិន័យទាំងឡាយនៃដែនដីឡើយ ត្បិតអ្នកណាដែលកាន់តាមក្រិត្យវិន័យទាំងឡាយនៃព្រះនោះមិន ត្រូវបំពាក់ក្រិត្យវិន័យទាំងឡាយនៃដែនដីទេ ។

២២ ហេតុដូច្នោះហើយ ចូរនៅក្រោមអំណាចទាំងឡាយដែលមានហើយចុះ រហូតដល់ទ្រង់សោយរាជ្យ ដែលមានសិទ្ធិសោយរាជ្យ ហើយដាក់អស់ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់ ។

២៣ មើលចុះ ក្រិត្យវិន័យទាំងឡាយដែលអ្នករាល់គ្នាបានទទួលពីព្រះហស្តរបស់យើង គឺជាក្រិត្យវិន័យទាំងឡាយនៃសាសនាចក្រ ហើយដោយនូវចំណុចនេះហើយបានជាអ្នករាល់គ្នាត្រូវកាន់តាម ។ មើលចុះ នេះហើយជាប្រាជ្ញា ។

២៤ ហើយឥឡូវនេះ ដូចជាយើងមានបន្ទូលអំពីអែតវឺត ប៉ាទ្រិច ជាអ្នកបំរើរបស់យើងថា ដែនដីនេះជាដែនដីនៃទីលំនៅរបស់គាត់ និងពួកអ្នកដែលគាត់បានតាំងឲ្យធ្វើជាទីប្រឹក្សារបស់គាត់; ហើយជាដែនដីនៃទីលំនៅដល់អ្នកណា ដែលយើងបានតាំងឲ្យថែរក្សាឃ្លាំង របស់យើងដែរ;

២៥ ហេតុដូច្នោះហើយ ចូរឲ្យពួកគេនាំគ្រួសាររបស់ពួកគេមកឯដែនដីនេះ ដូចដែលពួកគេត្រូវបានទូន្មានរវាងខ្លួនគេជាមួយនឹងយើង ចុះ ។

២៦ ត្បិតមើលចុះ មិនសមឲ្យយើងត្រូវបញ្ជានូវគ្រប់អ្វីៗទាំងអស់ទេ; ត្បិតអ្នកណាដែលត្រូវគេបង្ខំនូវគ្រប់អ្វីៗទាំងអស់ អ្នកនោះមាន ឈ្មោះថាជាបាវ ខ្ជិលច្រអូស ហើយមិនមានប្រាជ្ញាទៅវិញ; ហេតុដូច្នោះហើយ អ្នកនោះពុំបានទទួលរង្វាន់ឡើយ ។

២៧ យើងប្រាប់ជាប្រាកដថា មនុស្សលោកត្រូវឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ ហើយប្រព្រឹត្តអ្វីៗជាច្រើន តាមបំណងចិត្តរបស់ខ្លួន ហើយនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន;

២៨ ត្បិតអំណាចគឺមាននៅក្នុងខ្លួនគេ ម្ល៉ោះហើយ ពួកគេជាភ្នាក់ងារចំពោះខ្លួនផ្ទាល់ ។ ហើយដរាបណាមនុស្សលោកប្រព្រឹត្តអំពើល្អ នោះពួកគេនឹងពុំត្រូវបាត់បង់រង្វាន់របស់ខ្លួនឡើយ ។

២៩ ប៉ុន្តែអ្នកណាដែលមិនប្រព្រឹត្តអ្វីសោះឡើយ ទាល់តែអ្នកនោះត្រូវបានបញ្ជា ហើយទទួលបញ្ញត្តិនោះ ដោយចិត្តសង្ស័យ ហើយ កាន់តាមដោយចិត្តខ្ជិលច្រអូស អ្នកនោះឈ្មោះថាជាប់ទោសហើយ ។

៣០ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា តើយើងជានរណាទៅ ដែលបានបង្កើតមនុស្សមក ដែលនឹងគិតថាអ្នកនោះគ្មានទោស ដែលពុំគោរពតាមបញ្ញត្តិទាំងឡាយរបស់យើងនោះ ?

៣១ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា តើយើងជានរណាទៅ ដែលបានសន្យា ហើយពុំបានសំរេចនោះ ?

៣២ យើងបញ្ជា ហើយមនុស្សលោកពុំគោរពតាមសោះ; យើងដកយកចេញ ហើយពួកគេពុំបានទទួលព្រះពរឡើយ ។

៣៣ ខណៈនោះ ពួកគេនិយាយក្នុងចិត្តពួកគេថា៖ នេះពុំមែនជាកិច្ចការនៃព្រះអម្ចាស់ទេ ត្បិតសេចក្ដីសន្យាទាំងឡាយរបស់ទ្រង់ពុំ បានសំរេចសោះ ។ ប៉ុន្តែវេទនាដល់មនុស្សរបៀបនោះ ត្បិតរង្វាន់របស់ពួកគេនៅខាងក្រោម ហើយពុំមែនមកពីខាងលើទេ ។

៣៤ ហើយឥឡូវនេះ យើងប្រទានការដឹកនាំអំពីដែនដីនេះតទៅទៀត ។

៣៥ នេះជាប្រាជ្ញានៅក្នុងយើង ដែលម៉ាទិន ហារិស ជាអ្នកបំរើរបស់យើង ត្រូវធ្វើជាគំរូដល់សាសនាចក្រ ដោយនូវការដាក់ប្រាក់ កាសរបស់គាត់ ចំពោះប៊ីស្សពនៃសាសនាចក្រ ។

៣៦ ហើយឥឡូវនេះ នេះជាក្រិត្យវិន័យដល់មនុស្សគ្រប់រូបណាដែលមកឯដែនដីនេះ ដើម្បីទទួលកេរ្ដិ៍អាករ; ហើយអ្នកនោះត្រូវធ្វើអ្វី នឹងប្រាក់កាស តាមតែក្រិត្យវិន័យដឹកនាំចុះ ។

៣៧ ហើយនេះជាប្រាជ្ញាផងដែរ ដែលត្រូវមានដីធ្លីទិញនៅក្រុងអិនឌីប៉ែនដែនស៍ ទុកជាកន្លែងសំរាប់ធ្វើឃ្លាំង និងទុកសំរាប់ធ្វើរោង បោះពុម្ព ។

៣៨ ហើយការដឹកនាំផ្សេងៗទៀត ស្ដីអំពីម៉ាទិន ហារិស ជាអ្នកបំរើរបស់យើង នឹងត្រូវបានប្រទានដល់គាត់ពីព្រះវិញ្ញាណ

២១ *ក* លូកា ២០:២២–២៦; គ. និង ស. ៩៨:៤–១០; ម. នៃ ស. ១:១២. ស.ប. រដ្ឋាភិបាល.
២២ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ; ព្រះមែស៊ី; សហស្សវត្សរ៍.
២៣ *ក* ស.ប. ក្រិត្យវិន័យ.
២៤ *ក* គ. និង ស. ៥១:១៣; ៧០:៧–១១.
២៦ *ក* ម៉ាថាយ ២៤:៤៥–៥១; គ. និង ស. ១០៧:៩៩–១០០.
២៧ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច; កិច្ចការ.
២៨ *ក* ស.ប. សិទ្ធិជ្រើសរើស.
២៩ *ក* ស.ប. សេចក្ដីជាប់ទោស.
៣០ *ក* អេសាយ ៤៥:៩–១០; ហេលេ. ១២:៦.
៣១ *ក* គ. និង ស. ១:៣៧–៣៨; ៨២:១០.
៣២ *ក* គ. និង ស. ៥៦:៣–៤.
៣៣ *ក* គ. និង ស. ២៩:៤៥.
៣៥ *ក* គ. និង ស. ៤២:៣០–៣២.
៣៧ *ក* គ. និង ស. ៥៧:១១–១២.

ប្រយោជន៍ ឲ្យគាត់អាចបានទទួលកេរ្ដិ៍អាកររបស់គាត់ តាមដែលឃើញថាល្អដល់គាត់;

៣៩ ហើយចូរឲ្យគាត់ប្រែចិត្តពីអំពើបាបទាំងឡាយរបស់គាត់ចុះ ត្បិតគាត់ស្វែងរកសេចក្ដីសរសើរដំកើងនៃមនុស្សលោក ។

៤០ ហើយចូរឲ្យវិលលាម ដ័បបុលយូ ហ្វែប្ស ឈរក្នុងតំណែងដែលយើងបានតាំងដល់គាត់ ហើយទទួលកេរ្ដិ៍អាកររបស់គាត់ក្នុងដែនដីផងចុះ;

៤១ ហើយគាត់ត្រូវការប្រែចិត្តផងដែរ ត្បិតយើងជាព្រះអម្ចាស់ មិនសព្វព្រះហឫទ័យនឹងគាត់ឡើយ ត្បិតគាត់ស្វែងរកដើម្បីដំកើងខ្ពស់ ហើយគាត់មិនស្លូតបូតគ្រប់គ្រាន់នៅចំពោះយើងទេ ។

៤២ មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ ។

៤៣ តាមរបៀបនេះ អ្នករាល់គ្នាអាចដឹងបើសិនជាមនុស្សណាម្នាក់ប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួនមែន ឬអត់ — មើលចុះ អ្នកនោះនឹងសារភាពអំពីអំពើបាបទាំងឡាយ ហើយលះបង់ចោលអំពើបាបទាំងនោះ ។

៤៤ ហើយឥឡូវនេះ ប្រាកដមែន យើងស្ដីអំពីពួកអែលឌើរដែលនៅសល់ទាំងប៉ុន្មាននៃសាសនាចក្រយើងថា ពេលវេលាមិនទាន់មក ដល់ទេ គឺនៅច្រើនឆ្នាំទៀត សំរាប់ឲ្យពួកគេទទួលកេរ្ដិ៍អាកររបស់ពួកគេនៅក្នុងដែនដីនេះ លើកលែងតែពួកគេមានបំណងចង់បាន កេរ្ដិ៍អាករនោះ តាមរយៈពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ដូចដែលបានចាត់ដល់ពួកគេពីព្រះអម្ចាស់ប៉ុណ្ណោះ ។

៤៥ ត្បិតមើលចុះ ពួកគេនឹងច្រានប្រជាជនទាំងប៉ុន្មានមកជួបជុំគ្នា មកពីទីបំផុតផែនដី ។

៤៦ ហេតុដូច្នោះហើយ ចូរជួបជុំគ្នាចុះ ហើយពួកអ្នកណាដែលពុំបានចាត់ឲ្យនៅក្នុងដែនដីនេះ ចូរឲ្យពួកគេផ្សាយដំណឹងល្អនៅក្នុង ភូមិភាគជុំវិញ ហើយបន្ទាប់មក ចូរឲ្យពួកគេវិលទៅផ្ទះរបស់ពួកគេវិញចុះ ។

៤៧ ចូរឲ្យពួកគេផ្សាយតាមផ្លូវ ហើយថ្លែងទីបន្ទាល់អំពីសេចក្ដីពិត នៅគ្រប់កន្លែង ហើយហៅពួកអ្នកមាន ទាំងខ្ពស់ និងទាប និងពួក មនុស្សទាល់ក្រឲ្យប្រែចិត្តចុះ ។

៤៨ ហើយចូរឲ្យពួកគេសង់សាសនាចក្រទាំងឡាយឡើង ដរាបណាមានបណ្ដាជននៅលើផែនដី ដែលនឹងប្រែចិត្ត ។

៤៩ ហើយចូរឲ្យមានភ្នាក់ងារមួយតាំងឡើង ដោយសារសម្លេងនៃសាសនាចក្រ ចំពោះសាសនាចក្រនៅរដ្ឋអូហៃអូ ដើម្បីទទួល យកប្រាក់កាសទៅទិញដីធ្លីនៅក្រុងស៊ីយ៉ូនចុះ ។

៥០ ហើយយើងប្រទានបញ្ញត្តិមួយដល់ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើងថា គាត់នឹងត្រូវសរសេរពិពណ៌នាអំពីដែនដីស៊ីយ៉ូន និងសេចក្ដីថ្លែងមួយអំពីព្រះហឫទ័យនៃព្រះ ដូចដែលត្រូវបានធ្វើឲ្យគាត់ដឹងដោយសារព្រះវិញ្ញាណ ។

៥១ ហើយសំបុត្រ និងវិភាគទាន ដើម្បីជូនដល់អស់ទាំងសាសនាចក្រ ដើម្បីទទួលប្រាក់កាស ដើម្បីដាក់ក្នុងដៃនៃប៊ីស្សប ដោយខ្លួន ឬដោយភ្នាក់ងារក្ដី ដូចជាឃើញថាល្អដល់គាត់ ឬដូចជាគាត់នឹងដឹកនាំ ដើម្បីទិញដីធ្លីទុកសំរាប់ជាកេរ្ដិ៍អាករដល់កូនចៅនៃព្រះ ។

៥២ ត្បិតមើលចុះ យើងប្រាប់អ្នកជាប្រាកដថា ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ ចង់ឲ្យពួកសិស្ស និងកូនចៅមនុស្សបើកចិត្តរបស់ពួកគេ គឺដើម្បីទិញភូមិភាគទាំងមូលនៃស្រុកនេះ យ៉ាងឆាប់ៗតាមពេលវេលាអនុញ្ញាត ។

៥៣ មើលចុះ នេះហើយជាប្រាជ្ញា ។ ចូរឲ្យពួកគេធ្វើការនេះ ក្រែងពួកគេមិនបានទទួលកេរ្ដិ៍អាករណាឡើយ លើកលែងតែដោយសារការខ្ចាយឈាម ។

៥៤ ហើយជាថ្មីទៀត ដរាបណាអាចយកដីបាន នោះចូរចាត់ពួកអ្នកធ្វើការគ្រប់បែបយ៉ាងឲ្យមកដែនដីនេះ ដើម្បីធ្វើការសំរាប់ពួកបរិសុទ្ធនៃព្រះ ។

៥៥ ចូរឲ្យគ្រប់របស់អស់ទាំងនេះបានសំរេចតាមរបៀបរៀបរយចុះ; ហើយម្ដងម្កាល ចូរប្រាប់ឲ្យដឹងពីឯកសិទ្ធិដែលមានដីធ្លីដោយ ប៊ីស្សប ឬភ្នាក់ងារនៃសាសនាចក្រ ។

៥៦ ហើយចូរកុំឲ្យកិច្ចការខាងការប្រមូលគ្នាមកដោយប្រញាប់ប្រញាល់ ឬដោយរត់ភៀសខ្លួនឡើយ; ប៉ុន្តែចូរឲ្យធ្វើឡើង

៣៩ *ក* ២ នីហ្វៃ ២៦:២៩;
គ. និង ស. ១២១:៣៤–៣៧.
៤០ *ក* ស.ប. ហ្វែប្ស, វិលលាម ដ័បបុលយូ.
៤២ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* អេសាយ ១:១៨.
ស.ប. អត់ទោស, អភ័យទោស.
*គ* អេសាយ ៤៣:២៥.
៤៣ *ក* គ. និង ស. ១៩:២០; ៦៤:៧.
ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
*ខ* គ. និង ស. ៨២:៧.
៤៥ *ក* ចោទិ. ៣៣:១៧.
ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
៤៧ *ក* គ. និង ស. ៦៨:៨.
៤៨ *ក* ក.ន. សាខាទាំងឡាយនៃសាសនាចក្រ.
៤៩ *ក* ស.ប. ស៊ីយ៉ូន.
៥០ *ក* គ. និង ស. ៦៣:៥៥–៥៦.
៥៣ *ក* គ. និង ស. ៦៣:២៧–៣១.

ដូចដែល បានទូន្មានដោយពួកអែលឌើរនៃសាសនាចក្រនោងសន្និសីទចុះ តាមការចេះដឹងដែលពួកគេបានទទួលម្ដងម្កាល ។

៥៧ ហើយចូរឲ្យស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើងថ្វាយហើយធ្វើបុណ្យឆ្លងដែនដីនេះ និងកន្លែងសំរាប់[ក]ព្រះវិហារចំពោះព្រះ អម្ចាស់ចុះ ។

៥៨ ហើយចូរហៅឲ្យមានការប្រជុំសន្និសីទមួយចុះ; ហើយបន្ទាប់មក ចូរឲ្យស៊ីឌនី រិកដុន និងយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាពួកអ្នកបំរើរបស់ យើង វិលមកវិញចុះ; ហើយចូរឲ្យអូលីវើរ ខៅឌើរ មកជាមួយពួកគេផង ដើម្បីសំរេចនូវកិច្ចការដែលនៅសល់ទាំងប៉ុន្មានដែលយើង បានតាំងដល់ពួកគេ នៅក្នុងដីធ្លីរបស់ពួកគេ និងកិច្ចការដែលនៅសល់ទាំងប៉ុន្មាន ដូចដែល[ក]បានដឹកនាំពីសន្និសីទទាំងឡាយចុះ ។

៥៩ ហើយចូរកុំឲ្យមនុស្សណាមួយវិលពីដែនដីនេះឡើយ លើកលែងតែអ្នកនោះដែល[ក]ថ្លែងទីបន្ទាល់តាមផ្លូវ អំពីអ្វីដែលអ្នកនោះដឹង និងជឿយ៉ាងជាក់លាក់បំផុត ។

៦០ ចូរដកអ្វីដែលបានប្រទានមកលើ ស៊ីបា ភីតើសុន ចេញពីគាត់ចុះ; ហើយចូរឲ្យគាត់ឈរជាសមាជិកនៅក្នុងសាសនាចក្រ ហើយធ្វើ ការដោយដៃរបស់គាត់ផ្ទាល់ ជាមួយនឹងពួកបងប្អូន រហូតដល់គាត់[ក]ត្រូវបន្ទោសឲ្យបានគ្រប់គ្រាន់ សំរាប់អំពើបាបទាំងអស់របស់គាត់ សិន; ត្បិតគាត់ពុំបានសារភាពពីអំពើបាបទាំងនោះឡើយ ហើយគាត់គិតដើម្បីលាក់ទុក ។

៦១ ចូរឲ្យពួកអែលឌើរដែលនៅសល់ទាំងប៉ុន្មាននៃសាសនាចក្រនេះ ជាពួកអ្នកដែលមកដែនដីនេះ ឯអ្នកខ្លះត្រូវបានពរយ៉ាងលើសលប់ ចូរឲ្យពួកគេធ្វើសន្និសីទនៅលើដែនដីនេះចុះ ។

៦២ ហើយចូរឲ្យអែតវីត ប៉ាទ្រិច ជាអ្នកបំរើរបស់យើង ដឹកនាំសន្និសីទ ដែលនឹងធ្វើឡើងដោយពួកគេ ។

៦៣ ហើយចូរឲ្យពួកគេវិលមកវិញផង ដោយផ្សាយដំណឹងល្អតាមផ្លូវ ដោយថ្លែងទីបន្ទាល់អំពីអ្វីៗ ដែលបានបើកសំដែងដល់ពួកគេចុះ ។

៦៤ ត្បិតប្រាកដមែន សម្លេងត្រូវចេញពីកន្លែងនេះទៅដល់ពិភពលោកទាំងអស់ និងទៅដល់ចុងផែនដីបំផុត — គឺដំណឹងល្អ ត្រូវបាន[ក]ផ្សាយដល់សត្វលោកគ្រប់រូប ដោយមាន[ខ]ទីសំគាល់ទាំងឡាយជាប់តាមអស់អ្នកដែលជឿ ។

៦៥ ហើយមើលចុះ កូនមនុស្សនឹង[ក]យាងមក ។ អាម៉ែន ៕

## កណ្ឌទី ៥៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងស៊ីយ៉ូន ឃុំចាកសុន រដ្ឋមិសសួរី ថ្ងៃទី៧ ខែសីហា ឆ្នាំ១៨៣១ (*History of the Church*, ១:១៩៦–២០១)* ។ *ដើមបញ្ជើរបស់លោកអំពីវិវរណៈនេះ ព្យាការីសរសេរពណ៌នាអំពីដែនដីស៊ីយ៉ូន ជាកន្លែងសំរាប់ឲ្យមនុស្សជួបជុំគ្នានៅពេលនោះ ។ ដែនដីត្រូវបានថ្វាយ ដូចដែលព្រះអម្ចាស់ទ្រង់ដឹកនាំ ហើយកន្លែងសំរាប់ព្រះវិហារ នៅថ្ងៃក្រោយត្រូវបានធ្វើបុណ្យឆ្លងដែរ ។ ជាពិសេស ព្រះអម្ចាស់ទ្រង់ធ្វើឲ្យបញ្ញត្តិទាំងនេះមានន័យដល់ពួកបរិសុទ្ធនៅក្រុងស៊ីយ៉ូន ។*

*១–៤, ពួកបរិសុទ្ធដែលមានចិត្តស្មោះត្រង់នៅក្រុងស៊ីយ៉ូននឹងត្រូវបានព្រះពរ; ៥–៨, ពួកគេត្រូវស្រឡាញ់ និងបំរើព្រះអម្ចាស់ ហើយ កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់; ៩–១៩, ដោយសារការញែកថ្ងៃរបស់ព្រះអម្ចាស់ទុកជាបរិសុទ្ធ នោះពួកបរិសុទ្ធត្រូវបានព្រះពរ ខាងសាច់ឈាម និងខាងវិញ្ញាណ; ២០–២៤, ពួកមនុស្សសុចរិតត្រូវបានសន្យាសេចក្ដីសុខសាន្ត នៅនាលោកិយនេះ និងជីវិតដ៏នៅ អស់កល្បជានិច្ចនៅបរលោកនាយ ។*

មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា មានពរហើយដល់អស់អ្នកណាដែលបានឡើងមកឯដែនដីនេះ ដោយ[ក]ភ្នែកស្មោះត្រង់ ទាំងស្រុង ចំពោះសិរីល្អរបស់យើង តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ។

៥៧ *ក* គ. និង ស. ៥៧:៣; ៨៤:៣–៥, ៣១; ៩៧:១០–១៧.
៥៨ *ក* ស.ប. ការយល់ព្រមទូទៅ.
៥៩ *ក* ស.ប. ទីបន្ទាល់.
៦០ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
៦៤ *ក* ស.ប. ផ្សាយ.
*ខ* ស.ប. ទីសំគាល់.
៦៥ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
**៥៩** ១*ក* ម៉ាថាយ ៦:២២–២៤; គ. និង ស. ៨៨:៦៧.

២ ត្បិតអស់អ្នកណាដែលរស់នៅនឹងបានគ្រងផែនដីទុកជាមរតក ហើយអស់អ្នកណាដែលស្លាប់ទៅនឹងបានសំរាកពីការងាររបស់ខ្លួន ហើយកិច្ចការទាំងឡាយរបស់ពួកគេនឹងជាប់តាមពួកគេ; ហើយពួកគេនឹងបានទទួលមកុដ នៅក្នុងវិមានទាំងឡាយនៃព្រះវរបិតារបស់ យើង ដែលយើងបានរៀបចំសំរាប់ពួកគេនោះ ។

៣ មែនហើយ មានពរហើយដល់អស់អ្នកណាដែលដាក់ជើងឈរនៅលើផែនដីស៊ីយ៉ូន ដែលបានគោរពតាមដំណឹងល្អរបស់យើង; ត្បិតពួកគេនឹងបានទទួលសំរាប់ជារង្វាន់របស់ពួកគេ នូវរបស់ល្អៗនៃផែនដី ហើយផែនដីនឹងផលិតក្នុងកំឡាំងខ្លួន ។

៤ ហើយពួកគេនឹងបានពាក់មកុដដោយព្រះពរទាំងឡាយមកពីលើ មែនហើយ និងដោយព្រះបញ្ញត្តិទាំងឡាយដ៏មិនតិចដែរ និងដោយវិវរណៈទាំងឡាយតាមវេលា — គឺជាពួកអ្នកដែលមានចិត្តស្មោះត្រង់ និងឧស្សាហ៍ចំពោះយើង ។

៥ ហេតុដូច្នោះហើយ យើងប្រទានបញ្ញត្តិមួយដល់ពួកគេដោយមានបន្ទូលថា៖ អ្នកត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ ជាព្រះនៃអ្នក ឲ្យអស់ ពីចិត្តនៃអ្នក អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងនៃអ្នក ហើយដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នោះអ្នកត្រូវបំរើទ្រង់ ។

៦ អ្នកត្រូវស្រឡាញ់អ្នកជិតខាងដូចជាខ្លួនអ្នក ។ អ្នកមិនត្រូវលួចឲ្យសោះ; ឬផិតក្បត់ឲ្យសោះ ឬសម្លាប់ឲ្យសោះ ឬប្រព្រឹត្តអំពើអ្វីដូច នោះឲ្យសោះ ។

៧ អ្នកត្រូវថ្វាយអំណរគុណដល់ព្រះអម្ចាស់ ជាព្រះនៃអ្នក នៅគ្រប់ការណ៍ទាំងអស់ ។

៨ អ្នកត្រូវថ្វាយការបូជាដល់ព្រះអម្ចាស់ ជាព្រះនៃអ្នក ដោយសេចក្ដីសុចរិត គឺដោយចិត្តសង្រេងនិងវិញ្ញាណទន់ទាប ។

៩ ហើយប្រយោជន៍ឲ្យអ្នកអាចរក្សាខ្លួនឲ្យបានពេញលេញ កុំឲ្យប្រឡាក់ពីលោកិយ នោះអ្នកត្រូវទៅដំណាក់នៃការអធិស្ឋាន ហើយថ្វាយសាក្រាម៉ង់របស់អ្នកឡើង នៅថ្ងៃបរិសុទ្ធរបស់យើងចុះ;

១០ ត្បិតប្រាកដមែន ថ្ងៃនេះត្រូវបានចាត់ទុកដល់អ្នក ដើម្បីឲ្យសំរាកពីការងារទាំងឡាយរបស់អ្នក ហើយដើម្បីថ្វាយភក្ដីភាពរបស់អ្នក ដល់ព្រះដ៏ខ្ពស់បំផុត;

១១ ទោះជាយ៉ាងណាក៏ដោយ បំណន់ទាំងឡាយរបស់អ្នកត្រូវថ្វាយឡើង ដោយសេចក្ដីសុចរិត នៅគ្រប់ថ្ងៃ និងគ្រប់ពេលវេលា;

១២ ប៉ុន្តែចូរនឹកចាំថានៅថ្ងៃនេះ ជាថ្ងៃរបស់ព្រះអម្ចាស់ អ្នកត្រូវថ្វាយដង្វាយទាំងឡាយរបស់អ្នក និងសាក្រាម៉ង់ទាំងឡាយរបស់អ្នក ដល់ព្រះដ៏ខ្ពស់បំផុត ដោយសារភាពនូវអំពើបាបទាំងឡាយរបស់អ្នក ដល់បងប្អូនរបស់អ្នក និងនៅចំពោះព្រះអម្ចាស់ចុះ។

១៣ ហើយនៅថ្ងៃនេះ អ្នកមិនត្រូវធ្វើអ្វីឡើយ ក្រៅពីរៀបចំអាហាររបស់អ្នក ដោយចិត្តស្មោះស្ម័គ្រប៉ុណ្ណោះ ប្រយោជន៍ឲ្យការតមរបស់ អ្នកអាចបានល្អឥតខ្ចោះ ឬម៉្យាងទៀត ប្រយោជន៍ឲ្យសេចក្ដីអំណររបស់អ្នកអាចបានពេញ ។

១៤ ប្រាកដមែន នេះជាការតម និងការអធិស្ឋាន ឬម៉្យាងទៀត ជាការត្រេកអរ និងការអធិស្ឋាន ។

១៥ ហើយដរាបណាអ្នករាល់គ្នាប្រព្រឹត្តការទាំងនេះ ដោយអំណរគុណ ដោយទឹកចិត្ត និងទឹកមុខរីករាយ ដោយមិន

២ *ក* ម៉ាថាយ ៥:៥;
គ. និង ស. ៦៣:២០, ៤៨–៤៩.
*ខ* វិវ. ១៤:១៣.
ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម; ស្ថានបរមសុខ.
*គ* ស.ប. មកុដ; ភាពដំកើងឡើង.
*ឃ* យ៉ូហាន ១៤:២;
គ. និង ស. ៧២:៤; ៧៦:១១១; ៨១:៦; ៩៨:១៨.
៣ *ក* លោកុ. ៤:១២; ម៉ូសេ ៥:៣៧.
៤ *ក* គ. និង ស. ៤២:៦១; ៧៦:៧; ៩៨:១២; ១២១:២៦–២៩.
ស.ប. វិវរណៈ.
*ខ* ស.ប. សក្ដិសម, ភាពសក្ដិសម.
*គ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
៥ *ក* ចោទិ. ១១:១; ម៉ាថាយ ២២:៣៧; មរ៉ូណៃ ១០:៣២;
គ. និង ស. ២០:១៩.
ស.ប. សេចក្ដីស្រឡាញ់.
*ខ* ស.ប. ចិត្ត.
*គ* ស.ប. ការបំរើ.
៦ *ក* ស.ប. សេចក្ដីប្រកប.
*ខ* ស.ប. លួច, ការលួច.
*គ* ស.ប. អំពើកំផិត.
*ឃ* ស.ប. ឃាតកម្ម.
៧ *ក* ទំនុក. ៩២:១; អាលម៉ា ៣៧:៣៧;
គ. និង ស. ៤៦:៣២.
ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
៨ *ក* ស.ប. បូជា, យញ្ញបូជា.
*ខ* ស.ប. សុចរិត, សេចក្ដីសុចរិត.
*គ* ស.ប. ចិត្តសង្រេង.
៩ *ក* យ៉ាកុប (ព.ស.ថ.) ១:២៧.
*ខ* ស.ប. ថ្ងៃឈប់សំរាក.
១០ *ក* ស.ប. ថ្វាយបង្គំ.
១២ *ក* ក.ន. ដង្វាយទាំងឡាយ ទោះជាពេលវេលា ការប៉ិនប្រសប់ ឬរបស់របរនានាក្ដី ក្នុងការបំរើព្រះ និងមនុស្សទូទៅ. ស.ប. បូជា, យញ្ញបូជា.
*ខ* ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
១៣ *ក* ស.ប. តម, តំណម.
*ខ* ស.ប. សេចក្ដីអំណរ.
១៥ *ក* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
*ខ* និក្ខ. ២៥:២; គ. និង ស. ៦៤:៣៤.
*គ* សុភា. ១៧:២២.

[ឃ]សើចចេក ចាច ឡើយ ត្បិតនេះជាអំពើបាប ប៉ុន្តែដោយចិត្តអរសប្បាយ និងមុខរីករាយវិញ —

១៦ យើងប្រាប់ជាប្រាកដថា ដរាបណាអ្នករាល់គ្នាប្រព្រឹត្តរបៀបនេះ នោះផលបរិបូរនៃផែនដីជារបស់ផងអ្នករាល់គ្នាហើយ គឺសត្វ ជើងបួនលើវាល និងសត្វហើរលើអាកាស និងអ្វីដែលឡើងលើដើមឈើ ហើយដើរនៅលើផែនដីផង;

១៧ មែនហើយ ហើយរុក្ខជាតិ និងអ្វីដែលកើតមកពីផែនដីផង ទោះជាសំរាប់អាហារ ឬសំរាប់សំលៀកបំពាក់ ឬសំរាប់ផ្ទះសំបែង ឬសំរាប់ជង្រុក ឬសំរាប់ចំការ ឬសំរាប់សួនច្បារ ឬសំរាប់ចំការទំពាំងបាយជូរក្ដី;

១៨ មែនហើយ គ្រប់ទាំងអស់ដែលបានមកពី[ក]ផែនដី តាមរដូវកាលវា គឺត្រូវបានបង្កើតឡើងសំរាប់ផលប្រយោជន៍ និងការប្រើប្រាស់ របស់មនុស្ស ទាំងដើម្បីផ្គាប់ភ្នែក និងដើម្បីធ្វើឲ្យចិត្តអរសប្បាយផង ។

១៩ មែនហើយ គឺសំរាប់អាហារ និងសំរាប់សំលៀកបំពាក់ សំរាប់ភ្លក់ និងសំរាប់ហិតក្លិន ដើម្បីចំរើនកម្លាំងដល់រូបកាយ និងដើម្បីធ្វើ ឲ្យព្រលឹងមានជីវិតជីវ៉ាឡើង ។

២០ ហើយការនេះសព្វព្រះហឫទ័យដល់ព្រះ ដែលទ្រង់បានប្រទានគ្រប់ទាំងអស់ដល់មនុស្ស ព្រោះដោយហេតុនេះហើយបានជា របស់ទាំងនេះត្រូវបានបង្កើតមក ដើម្បីឲ្យយកមកប្រើប្រាស់ ដោយការវិនិច្ឆ័យ គឺមិនឲ្យហួសហេតុ ឬដោយការគំរាមកំហែងឡើយ ។

២១ ហើយមនុស្សមិនដែល[ក]ជំទាស់ព្រះ ក្នុងការណ៍ណាមួយឡើយ ឬក៏សេចក្ដីក្រោធរបស់ទ្រង់មិន[ខ]ទាស់នឹងនរណាមួយទេ លើកលែង តែអស់អ្នកណាដែលមិនទទួលស្គាល់ព្រះហស្តរបស់ទ្រង់ ក្នុងគ្រប់ទាំងអស់ ហើយមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ប៉ុណ្ណោះ ។

២២ មើលចុះ នេះគឺតាមក្រិត្យវិន័យ និងពួកព្យាការី; ហេតុដូច្នោះហើយ ចូរកុំរំខានដល់យើងអំពីរឿងនេះទៀតឡើយ ។

២៣ ប៉ុន្តែចូររៀនចុះថា អ្នកណាដែលប្រព្រឹត្តកិច្ចការទាំងឡាយដោយ[ក]សេចក្ដីសុចរិត នោះនឹងបានទទួល[ខ]រង្វាន់របស់ខ្លួន គឺ[គ]សេចក្ដីសុខសាន្ត នៅនាលោកិយនេះ និង[ឃ]ជីវិតដ៏នៅអស់កល្បជានិច្ច នៅបរលោកនាយ ។

២៤ យើងជាព្រះអម្ចាស់ បានមានបន្ទូលថាដូច្នោះហើយ ហើយព្រះវិញ្ញាណធ្វើទីបន្ទាល់ ។ អាម៉ែន ៕

## កណ្ឌទី ៦០

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅឃុំចាកសុន រដ្ឋមិសសួរី ថ្ងៃទី៨ ខែសីហា ឆ្នាំ១៨៣១ (*History of the Church*, ១:២០១–២០២)* ។ *នៅគ្រានេះ ពួកអែលឌើរដែលបានចាត់ឲ្យវិលទៅភូមិភាគទិសខាងកើត គេមានបំណងចង់ដឹងពីរបៀប ដែលពួកគេត្រូវចាប់ផ្ដើម និងតាមផ្លូវ និងរបៀបណា ដែលពួកគេត្រូវធ្វើដំណើរ ។*

*១–៩, ពួកអែលឌើរត្រូវផ្សាយដំណឹងល្អ នៅក្នុងក្រុមជំនុំទាំងឡាយរបស់ពួកមនុស្សអាក្រក់; ១០–១៤, ពួកគេមិនត្រូវបង្ខាតពេលវេលា របស់ខ្លួនចោល ឬកប់ការប៉ិនប្រសប់របស់ខ្លួនចោលដែរ; ១៥–១៧, ពួកគេអាចលាងជើងរបស់ខ្លួនទុកជាទីបន្ទាល់ទាស់នឹងអស់អ្នក ណាដែលបដិសេធដំណឹងល្អ ។*

មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់ពួកអែលឌើរនៃសាសនាចក្ររបស់ទ្រង់ ដែលត្រូវវិលមកដែនដីវិញយ៉ាងឆាប់រហ័ស ពីកន្លែងដែលពួកគេបានមក ថា៖ មើលចុះ យើងសព្វព្រះហឫទ័យ ដែលអ្នកបានឡើងមកទីនេះ;

២ ប៉ុន្តែចំពោះមនុស្ស[ក]ខ្លះ យើងមិនសព្វព្រះហឫទ័យទេ ត្បិត ពួកគេមិនព្រមបើកមាត់គេឡើយ ប៉ុន្តែពួកគេ[ខ]លាក់ការប៉ិនប្រសប់របស់ខ្លួន ដែលយើងបានប្រទានដល់ពួកគេទៅវិញ ពីព្រោះតែការ[គ]ខ្លាចដល់មនុស្ស ។ វេទនាដល់មនុស្សបែបនេះ ត្បិតសេចក្ដីខ្ញាល់របស់យើង ឆួលឡើងទាស់នឹងពួកគេ ។

១៥ *ឃ* គ. និង ស. ៨៨:៦៩.
១៨ *ក* ស.ប. ផែនដី.
២១ *ក* ស.ប. ជំទាស់ចិត្ត.
*ខ* យ៉ូប ១:២១.
២៣ *ក* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ខ* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*គ* ម៉ាថាយ ១១:២៨–៣០.
ស.ប. សេចក្ដីសុខសាន្ត.
*ឃ* គ. និង ស. ១៤:៧.
**៦០** ២ *ក* អេភេ. ៦:១៩–២០.
*ខ* លូកា ៨:១៦, ១៨.
*គ* ម៉ាថាយ ២៥:១៤–៣០.
ស.ប. សេចក្ដីកោតខាច —
សេចក្ដីកោតខ្លាចដល់មនុស្ស.

៣ ហើយហេតុការណ៍នឹងកើតឡើង បើសិនជាពួកគេមិនមានចិត្តស្មោះត្រង់ចំពោះយើងជាងនេះទេ នោះនឹង[ក]ត្រូវយកចេញសូម្បីតែអ្វី ដែលពួកគេមានផង ។

៤ ត្បិតយើងជាព្រះអម្ចាស់ គ្រប់គ្រងនៅស្ថានសួគ៌ខាងលើ និងនៅចំណោម[ក]ពលទ័ពនៅលើផែនដី; ហើយនៅថ្ងៃដែលយើងនឹងធ្វើ [ខ]គ្រឿងអលង្ការទាំងឡាយរបស់យើង នោះមនុស្សទាំងអស់នឹងស្គាល់ថាអ្វីហ្ន៎ដែលវាចាពីព្រះចេស្ដានៃព្រះ ។

៥ ប៉ុន្តែប្រាកដមែន យើងនឹងមានបន្ទូលដល់អ្នក អំពីដំណើររបស់អ្នកទៅរកដែនដី ដែលអ្នកបានចេញមក ។ ចូរឲ្យធ្វើទូកឬទិញ ដូច ដែលឃើញថាល្អដល់អ្នកចុះ វាមិនសំខាន់ដល់យើងឡើយ ហើយចូរចេញដំណើរជាបន្ទាន់ ទៅកន្លែងដែលហៅថា សន្តល្វីស ចុះ ។

៦ ហើយចេញពីទីនោះ ចូរឲ្យស៊ីឌនី រិកដុន, យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និងអូលីវើរ ខៅឌើរី ជាពួកអ្នកបំរើរបស់យើង ចេញដំណើររបស់ ពួកគេ ទៅក្រុងស៊ិនស៊ិនណាទិ;

៧ ហើយនៅកន្លែងនេះ ចូរឲ្យពួកគេបន្លឺសម្លេងរបស់ពួកគេឡើង ហើយប្រកាសព្រះបន្ទូលរបស់យើង ដោយសម្លេងខ្លាំងៗ ដោយឥត ខឹង ឬឈ្លោះប្រកែកឡើយ ដោយលើកដៃបរិសុទ្ធនៅលើពួកគេចុះ ។ ត្បិតយើងអាចធ្វើឲ្យអ្នកក្លាយ[ក]ទៅជាបរិសុទ្ធបាន ហើយអំពើបាប ទាំងឡាយរបស់អ្នក [ខ]ត្រូវបានអត់ទោសឲ្យហើយ ។

៨ ហើយចូរឲ្យពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន ចេញដំណើររបស់ពួកគេទៅក្រុងសន្តល្វីស១គូៗ ហើយផ្សាយព្រះបន្ទូល មិនប្រញាប់ នៅចំណោមក្រុមជំនុំនៃមនុស្សទុច្ចរិត រហូតដល់ពួកគេវិលទៅសាសនាចក្រទាំងឡាយ ដែលពួកគេបានចេញមក ។

៩ ហើយគ្រប់ការណ៍នេះគឺសំរាប់សេចក្ដីល្អដល់សាសនាចក្រទាំងឡាយ; ត្បិតមកពីបំណងនេះហើយដែលយើងបានចាត់ឲ្យពួកគេទៅ ។

១០ ហើយចូរឲ្យ[ក]អែតវើត ប៉ាទ្រិច ជាអ្នកបំរើរបស់យើងចែកប្រាក់ដែលយើងបានប្រទានដល់គាត់ គឺមួយចំនួនដល់ពួកអែលឌើររបស់ យើង ដែលត្រូវបានបញ្ជាឲ្យវិលមកវិញ;

១១ ហើយអ្នកណាដែលអាចធ្វើទៅបាន ចូរឲ្យអ្នកនោះសងប្រាក់វិញ តាមមាគ៌ាខាងភ្នាក់ងារចុះ; ហើយអ្នកណាដែលមិនអាចធ្វើបាន គឺមិនត្រូវឲ្យអ្នកនោះសងឡើយ ។

១២ ហើយឥឡូវនេះ យើងមានបន្ទូលពីពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន ដែលត្រូវឲ្យមកដែនដីនេះ ។

១៣ មើលចុះ ពួកគេត្រូវបានចាត់ឲ្យទៅផ្សាយដំណឹងល្អរបស់យើង នៅចំណោមក្រុមជំនុំនៃមនុស្សទុច្ចរិត; ហេតុដូច្នោះហើយ យើងប្រទានបញ្ញត្តិមួយដល់ពួកគេថា៖ អ្នកមិនត្រូវ[ក]បង្ខាតពេលវេលារបស់ខ្លួន ឬកប់[ខ]ការប៉ិនប្រសប់របស់ខ្លួនចោលប្រយោជន៍កុំឲ្យ បានដឹងនោះឡើយ ។

១៤ ហើយបន្ទាប់ពីអ្នកបានឡើងមកដល់ដែនដីស៊ីយ៉ូន ហើយបានប្រកាសព្រះបន្ទូលរបស់យើងរួចហើយ នោះអ្នកត្រូវវិលទៅវិញជាបន្ទាន់ ដោយប្រកាសព្រះបន្ទូលរបស់យើង នៅចំណោមក្រុមជំនុំនៃមនុស្សទុច្ចរិត ដោយមិនប្រញាប់ ឬដោយ[ក]ខឹង ឬដោយឈ្លោះ ប្រកែកឡើយ ។

១៥ ហើយចូររលាស់[ក]ធូលីពីបាតជើងអ្នកទាស់នឹងពួកអ្នកណាដែលមិនទទួលអ្នក គឺពុំមែននៅវត្តមានរបស់ពួកគេទេ ក្រែងអ្នកធ្វើឲ្យ ពួកគេខឹង ប៉ុន្តែដោយសម្ងាត់; ហើយចូរលាងជើងរបស់អ្នក ទុកជាទីបន្ទាល់ទាស់នឹងពួកគេ នៅថ្ងៃជំនុំជំរះ ។

១៦ មើលចុះ នេះគឺគ្រប់គ្រាន់ដល់អ្នកហើយ ហើយនេះជាព្រះហឫទ័យរបស់ទ្រង់ដែលបានចាត់អ្នកឲ្យទៅ ។

១៧ ហើយដោយសារមាត់នៃយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ការណ៍នេះត្រូវបានធ្វើឲ្យដឹងអំពីស៊ីឌនី រិកដុន និងអូលីវើរ ខៅឌើរី ។ រីឯពួកដែលនៅសល់ទាំងប៉ុន្មាននោះ គឺនៅពេលក្រោយ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

---

៣ *ក* ម៉ាកុស ៤:២៥; គ. និង ស. ១:៣៣.
៤ *ក* អាលម៉ា ៤៣:៥០.
*ខ* អេសាយ ៦២:៣; សាការី ៩:១៦; ម៉ាឡាគី ៣:១៧; គ. និង ស. ១០១:៣.
៧ *ក* ស.ប. បរិសុទ្ធភាព.
*ខ* ស.ប. អត់ទោស, អភ័យទោស.
១០ *ក* ស.ប. ប៉ាទ្រិច, អែតវើត.
១៣ *ក* គ. និង ស. ៤២:៤២. ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
*ខ* ម៉ាថាយ ២៥:២៤–៣០; គ. និង ស. ៨២:១៨.
១៤ *ក* សុភា. ១៤:២៩.
១៥ *ក* ម៉ាថាយ ១០:១៤; លូកា ៩:៥; កិច្ចការ ១៣:៥១; គ. និង ស. ២៤:១៥; ៧៥:២០; ៨៤:៩២.

## កណ្ឌទី ៦១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅច្រាំងទន្លេមិសសួរី ភូមិម៉ុកអ៊ិលវេនស្ព្រិន ថ្ងៃទី១២ ខែសីហា ឆ្នាំ១៨៣១ (*History of the Church*, ១:២០២–២០៥) ។ តាមផ្លូវវិលទៅក្រុងខឺតឡង់វិញ ព្យាការី និងពួកអែលឌើរ ដប់នាក់បានធ្វើដំណើរតាមទូកចុះទន្លេមិសសួរី ។ កាលធ្វើដំណើរបានបីថ្ងៃ នោះមានគ្រោះថ្នាក់ជាច្រើនបានកើតឡើង ។ អែលឌើរ វិលលាម ដ័បបុលយូ ហ្វែបប្ស នៅក្នុងការនិមិត្តពេលថ្ងៃ បានឃើញមេបំផ្លាញកំពុងតែជិះក្នុងអំណាច នៅលើផ្ទៃទឹកទាំងឡាយ ។*

*១–១២, ព្រះអម្ចាស់ទ្រង់បានចេញបញ្ញត្តថា មានការបំផ្លិចបំផ្លាញជាច្រើននៅលើទឹកទាំងឡាយ; ១៣–២២, ទឹកទាំងឡាយត្រូវយ៉ូហានដាក់បណ្ដាសា ហើយមេបំផ្លាញជិះនៅលើទឹកទាំងឡាយ; ២៣–២៩, មនុស្សខ្លះមានអំណាចដើម្បីបញ្ជាដល់ទឹកទាំងឡាយ; ៣០–៣៥, ពួកអែលឌើរត្រូវធ្វើដំណើរពីរនាក់ៗ ហើយផ្សាយដំណឹងល្អ; ៣៦–៣៩, ពួកគេត្រូវប្រុងប្រៀបចាំការយាងមកនៃកូនមនុស្ស ។*

មើលចុះ ហើយចូរប្រុងស្ដាប់តាមសម្លេងនៃអ្នកដែលមានអស់ទាំងព្រះចេស្ដា ជាអ្នកចាប់តាំងពីអស់កល្ប រៀងទៅអស់កល្បជានិច្ច គឺអាលផា និងអូមេកា ជាដើម ហើយជាចុង ។

២ មើលចុះ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នកយ៉ាងដូច្នេះថា៖ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្ររបស់យើង ដែលបានមកជួបជុំគ្នានៅលើកន្លែងនេះ ដែលឥឡូវនេះ អំពើបាបទាំងឡាយរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ ត្បិតយើងជាព្រះ អម្ចាស់ អត់ទោសដល់អំពើបាបទាំងឡាយ ហើយយើងមានចិត្តមេត្តាករុណាដល់អស់អ្នកណា ដែលសារភាពនូវអំពើបាបរបស់ខ្លួន ដោយចិត្តរាបសា;

៣ ប៉ុន្តែយើងប្រាប់ដល់អ្នកជាប្រាកដថា មិនត្រូវឲ្យក្រុមពួកអែលឌើររបស់យើងទាំងមូលនេះ ធ្វើដំណើរយ៉ាងរហ័សនៅលើទឹកទាំង ឡាយឡើយ ក្នុងកាលបណ្ដាជននៅសងខាងកំពុងតែវិនាសក្នុងការឥតជំនឿ ។

៤ ទោះជាយ៉ាងណាក៏ដោយ យើងបានទ្រាំការនោះប្រយោជន៍ឲ្យអ្នករាល់គ្នាអាចធ្វើទីបន្ទាល់; មើលចុះ មានគ្រោះថ្នាក់ជាច្រើន នៅលើទឹកទាំងឡាយ ហើយជាពិសេសមានជាច្រើនទៀត បន្ទាប់ពីពេលនេះទៅ;

៥ ត្បិតយើងជាព្រះអម្ចាស់ បានចេញបញ្ញត្តិនៅក្នុងសេចក្ដីកំហឹងរបស់យើងថា មានការបំផ្លិចបំផ្លាញជាច្រើននៅលើទឹកទាំងឡាយ; មែន ហើយជាពិសេសនៅលើទឹកទាំងនេះ ។

៦ ទោះជាយ៉ាងណាក៏ដោយ សាច់ទាំងអស់នៅក្នុងព្រះហស្តរបស់យើង ហើយអ្នកណាដែលមានចិត្តស្មោះត្រង់ នៅក្នុងចំណោម អ្នករាល់គ្នា នោះនឹងមិនត្រូវវិនាសដោយសារទឹកឡើយ ។

៧ ហេតុដូច្នោះហើយ គឺជាការចាំបាច់ដែល ស៊ីឌនី គិលបឺត ជាអ្នកបំរើរបស់យើង និងវិលលាម ដ័បបុលយូ ហ្វែបប្ស ជាអ្នកបំរើរបស់ យើង ប្រព្រឹត្តដោយរហ័ស ចំពោះភារកិច្ច និងបេសកកម្មរបស់ពួកគេចុះ ។

៨ ទោះជាយ៉ាងណាក៏ដោយ យើងមិនព្រមទ្រាំឲ្យអ្នករាល់គ្នាចេញទៅឡើយ រហូតដល់អ្នកត្រូវបានវាយផ្ចាលពីអស់ទាំងអំពើបាប របស់អ្នកសិន ប្រយោជន៍ឲ្យអ្នកអាចបានទៅតែមួយ ប្រយោជន៍កុំឲ្យអ្នកត្រូវវិនាសបង់ក្នុងអំពើទុច្ចរិតឡើយ;

៩ ប៉ុន្តែឥឡូវនេះ យើងប្រាប់ជាប្រាកដថា ជាការចាំបាច់ដល់យើងដែលអ្នករាល់គ្នាត្រូវចេញទៅ ។ ហេតុដូច្នោះហើយ ចូរឲ្យស៊ីឌនី គិលបឺត និងវិលលាម ដ័បបុលយូ ហ្វែបប្ស ជាពួកអ្នកបំរើរបស់យើង យកក្រុមពីដើមរបស់ពួកគេ ហើយចូរឲ្យពួកគេចេញដំណើររបស់ ពួកគេជាបន្ទាន់ ប្រយោជន៍ឲ្យពួកគេអាចបំពេញបេសកកម្មរបស់ពួកគេ ហើយតាមរយៈសេចក្ដីជំនឿនោះពួកគេអាចបានឈ្នះ;

១០ ហើយដរាបណាពួកគេមានចិត្តស្មោះត្រង់ នោះពួកគេនឹងត្រូវបានរក្សាទុកឲ្យគង់វង់ ហើយយើងជាព្រះអម្ចាស់ នឹងគង់នៅជាមួយពួកគេ ។

១១ ហើយចូរឲ្យពួកនៅសល់ទាំងប៉ុន្មាន យកអ្វីៗដែលត្រូវការសំរាប់សំលៀកបំពាក់ ។

៦១ ១*ក* ស.ប. អំណាច.
*ខ* ស.ប. អាលផា និងអូមេកា.
២ *ក* ម៉ូសាយ ៤:១០–១១.
ស.ប. អត់ទោស, អភ័យទោស.
*ខ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
*គ* ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
៧ *ក* ស.ប. ហ្វែបប្ស, វិលលាម ដ័បបុលយូ.
៨ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.

១២ ចូរឲ្យ ស៊ីឌនី គិលបឺត ជាអ្នកបំរើរបស់យើង យកអ្វីៗដែលមិនត្រូវការទៅជាមួយគាត់ តាមដែលអ្នកនឹងយល់ព្រម ។

១៣ ហើយឥឡូវនេះ មើលចុះ សំរាប់ជាការល្អដល់អ្នក យើងបានប្រទានដល់អ្នក នូវព្រះបញ្ញត្តិមួយ អំពីការណ៍ទាំងនេះ; ហើយយើង ជាព្រះអម្ចាស់ នឹងពិភាក្សាជាមួយអ្នក ដូចជាមួយមនុស្សនៅសម័យបុរាណ ។

១៤ មើលចុះ យើងជាព្រះអម្ចាស់ ក្នុងកាលនៅដើមដំបូងឡើយ បានប្រទានពរដល់ទឹកទាំងឡាយ; ប៉ុន្តែនៅថ្ងៃចុងក្រោយបង្អស់ ដោយ សារមាត់នៃយ៉ូហាន ជាអ្នកបំរើរបស់យើង នោះយើងបានដាក់បណ្ដាសាដល់ទឹកទាំងឡាយវិញ ។

១៥ ហេតុដូច្នោះហើយ នឹងមានថ្ងៃមកដល់ ដែលនឹងពុំមានសាច់ឈាមណាដែលនឹងបានសុខ នៅលើទឹកទាំងឡាយឡើយ ។

១៦ ហើយនឹងបានឮមនុស្សនិយាយនៅក្នុងថ្ងៃដែលនឹងមកដល់ថា គ្មាននរណាមួយអាចឡើងទៅឯដែនដីស៊ីយ៉ូន នៅលើទឹកទាំងឡាយ បានឡើយ លើកលែងតែអ្នកណាដែលមានចិត្តទៀងត្រង់ប៉ុណ្ណោះ ។

១៧ ហើយដូចជាយើង ដែលជាព្រះអម្ចាស់ ក្នុងកាលពីដើមដំបូងឡើយ បានដាក់បណ្ដាសាដល់ដីយ៉ាងណា នោះយើងបានប្រទាន ពរដល់ដី នៅថ្ងៃចុងក្រោយបង្អស់យ៉ាងដូច្នោះដែរ តាមវេលាកាលរបស់វា សំរាប់ជាការប្រើប្រាស់ ដល់ពួកបរិសុទ្ធរបស់យើង ប្រយោជន៍ឲ្យពួកគេអាចទទួលទានផលពីដី ។

១៨ ហើយឥឡូវនេះ យើងប្រទានដល់អ្នក នូវព្រះបញ្ញត្តិមួយថា អ្វីៗដែលយើងប្រាប់ដល់មនុស្សម្នាក់ គឺយើងប្រាប់ដល់មនុស្សទាំងអស់ ដើម្បីឲ្យអ្នកព្រមានដល់បងប្អូនរបស់អ្នកទុកជាមុន អំពីទឹកទាំងនេះ ដើម្បីកុំឲ្យពួកគេធ្វើដំណើរមក នៅលើទឹកទាំងនោះឡើយ ក្រែង សេចក្ដីជំនឿរបស់ពួកគេបាត់បង់ទៅ ហើយពួកគេត្រូវជាប់អន្ទាក់ទាំងឡាយ;

១៩ យើងជាព្រះអម្ចាស់ បានចេញបញ្ញត្តិ ហើយមេបំផ្លាញជិះនៅលើផ្ទៃទឹកទាំងឡាយ ហើយយើងមិនដកបញ្ញត្តិចេញឡើយ ។

២០ យើងជាព្រះអម្ចាស់ បានខឹងនឹងអ្នកពីម្សិលមិញ ប៉ុន្តែថ្ងៃនេះ សេចក្ដីកំហឹងរបស់យើងបានបែរចេញហើយ ។

២១ ហេតុដូច្នោះហើយ ចូរឲ្យពួកអ្នកទាំងនោះដែលយើងបានពោលដល់ ដែលត្រូវចេញដំណើររបស់ពួកគេជាបន្ទាន់ — ជាថ្មីទៀត យើងប្រាប់អ្នកថា ចូរឲ្យពួកគេចេញដំណើររបស់ពួកគេជាបន្ទាន់ចុះ ។

២២ ហើយវាមិនជាអ្វីដល់យើងឡើយ បន្តិចក្រោយមក បើសិនជាពួកគេបំពេញបេសកកម្មរបស់ពួកគេយ៉ាងដូច្នោះមែន ទោះជាពួក គេទៅតាមផ្លូវទឹក ឬតាមផ្លូវដីក្ដី ចូរឲ្យការណ៍នេះកើតឡើង ដូចជាដែលបានធ្វើឲ្យពួកគេដឹង តាមការវិនិច្ឆ័យរបស់ពួកគេ ចាប់ពីពេល នេះទៅ ។

២៣ ហើយឥឡូវនេះ ស្ដីអំពី ស៊ីឌនី រិកដុន, យ៉ូសែប ស៊្មីធ ជុញ្ញ័រ, និង អូលីវើរ ខៅឌើរី ជាពួកអ្នកបំរើរបស់យើង ចូរកុំឲ្យពួកគេមក លើទឹកទាំងឡាយទៀតឡើយ លើកលែងតែមកលើប្រឡាយ ក្នុងកាលធ្វើដំណើរមកផ្ទះរបស់ពួកគេវិញ; ឬម្យ៉ាងទៀត ពួកគេមិនត្រូវ មកលើទឹកទាំងឡាយ ដើម្បីធ្វើដំណើរនោះឡើយ លើកលែងតែមកលើប្រឡាយប៉ុណ្ណោះ ។

២៤ មើលចុះ យើងជាព្រះអម្ចាស់ បានចាត់មាគ៌ាមួយទុកសំរាប់ឲ្យពួកបរិសុទ្ធរបស់យើងធ្វើដំណើរ ហើយមើលចុះ នេះជាមាគ៌ា — ថាបន្ទាប់ពីពួកគេចេញពីប្រឡាយទៅ នោះពួកគេត្រូវធ្វើដំណើរតាមផ្លូវដី ដរាបណាពួកគេត្រូវបានបញ្ជាដើម្បីឲ្យធ្វើដំណើរ ហើយ ឡើងទៅឯដែនដីស៊ីយ៉ូន;

២៥ ហើយពួកគេត្រូវប្រព្រឹត្ត ដូចជាកូនចៅអ៊ីស្រាអែលដែរ ដោយបោះត្រសាលរបស់ពួកគេតាមផ្លូវ ។

២៦ ហើយមើលចុះ បញ្ញត្តិនេះអ្នកត្រូវឲ្យដល់បងប្អូនរបស់អ្នកទាំងអស់ ។

២៧ ទោះជាយ៉ាងណាក៏ដោយ ដល់អស់អ្នកណាដែលបានប្រទានអំណាចឲ្យបញ្ជាទឹក គឺដល់អ្នកនោះហើយដែលត្រូវបានប្រទានដោយព្រះវិញ្ញាណ ដើម្បីឲ្យស្គាល់អស់ទាំងផ្លូវរបស់ទ្រង់ ។

២៨ ហេតុដូច្នោះហើយ ចូរឲ្យអ្នកនោះប្រព្រឹត្ត ដូចព្រះវិញ្ញាណនៃព្រះដ៏មានព្រះជន្មរស់នៅ ទ្រង់បញ្ជាដល់គាត់ចុះ ទោះជានៅលើដី ឬនៅលើទឹកទាំងឡាយក៏ដោយ ដូចជាអំណាចនៅជាមួយយើង ដើម្បីធ្វើពីពេលនេះតទៅ ។

២៩ ហើយចំពោះអ្នករាល់គ្នា គឺត្រូវបានប្រទានផ្លូវសំរាប់ពួកបរិសុទ្ធ ឬមាគ៌ាសំរាប់ពួកបរិសុទ្ធនៃជំរុំរបស់ព្រះអម្ចាស់ ដើម្បីធ្វើដំណើរ ។

៣០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ស៊ីឌនី រិកដុន, យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និង អូលីវើរ ខៅឌើរី ជាពួកអ្នកបំរើ

១៣ ក គ. និង ស. ២១:៦.
ខ ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
១៤ ក លោកុ. ១:២០.
ខ វិវ. ៨:៨–១១.
១៧ ក ម៉ូសេ ៤:២៣.
២៥ ក ជនគ. ៩:១៨.
២៧ ក ស.ប. បព្វជិតភាព; អំណាច.

របស់យើង មិនត្រូវបើកមាត់របស់ពួកគេ នៅក្នុងក្រុមជំនុំទាំងឡាយនៃពួកទុច្ចរិតឡើយ លុះត្រាពួកគេមកដល់ក្រុងស៊ិនស៊ិនណាទីស៊ិន;

៣១ ហើយនៅកន្លែងនោះ ពួកគេត្រូវបន្លឺសម្លេងរបស់ពួកគេដល់ព្រះ ទាស់នឹងប្រជាជន មែនហើយ ដល់ព្រះអង្គដែលមានសេចក្តីខ្ញាល់ ឆ្លលឡើងទាស់នឹងអំពើទុច្ចរិតរបស់ពួកគេ ជាប្រជាជនដែល[ក]ស្ទើរទុំសុស ដើម្បីបំផ្លិចបំផ្លាញចោល ។

៣២ ហើយចេញពីនោះទៅ ចូរឲ្យពួកគេធ្វើដំណើរសំរាប់ក្រុមជំនុំនៃបងប្អូនរបស់ពួកគេវិញ ព្រោះកិច្ចការទាំងឡាយរបស់ពួកគេសូម្បីតែឥឡូវនេះ ក៏ត្រូវការនៅក្នុងចំណោមពួកគេ ខ្លាំងជាងនៅក្នុងចំណោមក្រុមជំនុំទាំងឡាយនៃពួកទុច្ចរិតទៅទៀត ។

៣៣ ហើយឥឡូវនេះ ស្តីអំពីពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន ចូរឲ្យពួកគេ[ក]ធ្វើដំណើរ ហើយប្រកាសព្រះបន្ទូល នៅក្នុងចំណោមក្រុមជំនុំទាំងឡាយនៃពួកទុច្ចរិត ដរាបណាដែលបានប្រទានឲ្យ;

៣៤ ហើយដរាបណាពួកគេប្រព្រឹត្តដូច្នេះ នោះពួកគេនឹង[ក]កំចាត់សំលៀកបំពាក់របស់ពួកគេចេញ ហើយពួកគេនឹងត្រូវឥតប្រឡាក់ នៅចំពោះយើង ។

៣៥ ហើយចូរឲ្យពួកគេធ្វើដំណើរជុំគ្នា [ក]ពីរនាក់ៗ ដូចជាឃើញថាល្អដល់ពួកគេ គ្រាន់តែកុំឲ្យរេយណល្ដ៍ ខាហ៊ូន ជាអ្នកបំរើរបស់ យើង និង សាំយូអែល អេច ស្ម៊ីធ ជាអ្នកបំរើរបស់យើង ដែលយើងសព្វព្រះហឫទ័យជាខ្លាំង បែកគ្នាឡើយ រហូតដល់ពួកគេវិលទៅផ្ទះ សំបែងរបស់ពួកគេសិន ហើយនេះគឺសំរាប់គោលបំណងដ៏វាងវៃនៅក្នុងយើង ។

៣៦ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា ហើយអ្វីដែលយើងប្រាប់ដល់មនុស្សម្នាក់ គឺយើងប្រាប់ដល់មនុស្សទាំងអស់ ចូរសង្ឃឹមឡើង [ក]កូនក្មេងតូចៗអើយ; ត្បិតយើងនៅ[ខ]កណ្តាលពួកអ្នក ហើយយើងពុំបាន[គ]បោះបង់ចោលអ្នកឡើយ;

៣៧ ហើយដរាបណាអ្នកបានបន្ទាបខ្លួននៅចំពោះយើង នោះព្រះពរទាំងឡាយនៃ[ក]នគរ ជារបស់ផងអ្នកហើយ ។

៣៨ ចូរក្រវាត់ចង្កេះ ហើយ[ក]ចាំយាម ហើយមានចិត្តម៉ឺងម៉ាត់ដោយទន្ទឹងចាំការយាងមកនៃកូនមនុស្សចុះ ត្បិតទ្រង់នឹងយាងមក នៅវេលាដែលអ្នកមិនគិត ។

៣៩ ចូរ[ក]អធិស្ឋានជានិច្ច ប្រយោជន៍កុំឲ្យអ្នកធ្លាក់ទៅក្នុង[ខ]សេចក្តីល្បួងឡើយ ដើម្បីឲ្យអ្នកអាចធន់នៅបាន ក្នុងថ្ងៃនៃការយាងមករបស់ទ្រង់ ទោះនៅក្នុងជីវិត ឬក្នុងសេចក្តីស្លាប់ក្តី ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៦២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅច្រាំងទន្លេមិសសួរី ភូមិឈារីតុន រដ្ឋមិសសួរី ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៨៣១ (*History of the Church*, ១:២០៥–២០៦)* ។ *នៅថ្ងៃនេះ ព្យាការី និងក្រុមលោក ជាពួកអ្នកដែលធ្វើដំណើរពី ក្រុងអ៊ិនឌីប៉ែនដែនស៍ ទៅក្រុងខឺតឡង់ បានជួបនឹងពួកអែលឌើរមួយចំនួន ដែលធ្វើដំណើរទៅដែនដីស៊ីយ៉ូន ហើយបន្ទាប់ពីបានជំរាប សួរគ្នាដោយសេចក្តីអំណររួចហើយ ទើបបានទទួលវិវរណៈនេះ ។*

*១–៣, ទីបន្ទាល់ទាំងឡាយត្រូវបានកត់ទុកនៅលើស្ថានសួគ៌; ៤–៩, ពួកអែលឌើរត្រូវធ្វើដំណើរហើយផ្សាយ តាមការវិនិច្ឆ័យ និងដូចដែលបានដឹកនាំដោយព្រះវិញ្ញាណ ។*

មើលចុះ ហើយចូរប្រុងស្តាប់ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្ររបស់យើងអើយ ព្រះអម្ចាស់ជាព្រះរបស់អ្នកទ្រង់មាន ព្រះបន្ទូលថាដូច្នោះ គឺជាព្រះគ្រីស្ទ ជា[ក]ព្រះគាំទ្ររបស់អ្នក ដែលជ្រាបនូវសេចក្តីកំសោយនៃមនុស្ស និងចេះជួយពួកគេដែល[ខ]ត្រូវល្បួង ។

២ ហើយប្រាកដមែន ព្រះនេត្ររបស់យើងទតមកលើពួកអ្នកដែលពុំទាន់បានឡើងទៅឯដែនដីស៊ីយ៉ូននៅឡើយ; ហេតុដូច្នោះហើយ បេសកកម្មរបស់អ្នកពុំទាន់បានសំរេចនៅឡើយទេ ។

៣១ *ក* អាលម៉ា ៣៧:៣១;
ហេលេ. ១៣:១៤;
គ. និង ស. ១០១:១១.
៣៣ *ក* ស.ប. ផ្សាយ; ធ្វើបន្ទាល់.
៣៤ *ក* ២ នីហ្វៃ ៩:៤៤; យ៉ាកុប ២:២;
ម៉ូសាយ ២:២៨.
៣៥ *ក* ស.ប. កិច្ចការផ្សាយសាសនា.
៣៦ *ក* យ៉ូហាន ១៣:៣៣.
*ខ* ម៉ាថាយ ១៨:២០.
*គ* អេសាយ ៤១:១៥–១៧;
១ នីហ្វៃ ២១:១៤–១៥.
៣៧ *ក* គ. និង ស. ៥០:៣៥.
៣៨ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
៣៩ *ក* ស.ប. ការអធិស្ឋាន.
*ខ* ស.ប. ល្បួង, សេចក្តីល្បួង.
**៦២** ១ *ក* គ. និង ស. ៤៥:៣–៥.
ស.ប. ព្រះដ៏គាំទ្រ.
*ខ* ហេព្រើរ ២:១៨; អាលម៉ា ៧:១២.
*គ* ស.ប. ល្បួង, សេចក្តីល្បួង.

៣ ទោះជាយ៉ាងណាក៏ដោយ អ្នករាល់គ្នាត្រូវបានពរ ក្បិតទីបន្ទាល់ដែលអ្នករាល់គ្នាបានថ្លែង នោះត្រូវបានកត់ទុកនៅលើស្ថានសួគ៌ សំរាប់ទុកឲ្យពួកទេវតាមើល; ហើយពួកគេមានចិត្តត្រេកអរមកលើអ្នក ហើយអំពើបាបទាំងឡាយរបស់អ្នក ត្រូវបានអត់ទោសឲ្យហើយ ។

៤ ហើយឥឡូវនេះ ចូរធ្វើដំណើររបស់អ្នកតទៅទៀត ។ ចូរប្រមូលគ្នាមកលើដែនដីស៊ីយ៉ូន; ហើយចូរមានការប្រជុំ និងមានចិត្តត្រេកអរជុំគ្នា ហើយចូរថ្វាយសាក្រាម៉ង់ដល់ព្រះដ៏ខ្ពស់បំផុតចុះ ។

៥ ហើយខណៈនោះ អ្នកអាចវិលទៅថ្លែងទីបន្ទាល់ មែនហើយ គឺជុំព្រមគ្នា ឬពីរនាក់ៗ ដូចដែលឃើញថាល្អដល់អ្នកចុះ វាមិនសំខាន់ ដល់យើងឡើយ; គ្រាន់តែមានចិត្តស្មោះត្រង់ ហើយប្រកាសពីដំណឹងដ៏រីករាយ ប្រាប់ដល់បណ្ដាជននៅលើផែនដី ឬនៅក្នុងចំណោម ក្រុមជំនុំទាំងឡាយ នៃពួកទុច្ចរិតប៉ុណ្ណោះ ។

៦ មើលចុះ យើងជាព្រះអម្ចាស់ បាននាំអ្នកមកជួបជុំគ្នា ប្រយោជន៍ឲ្យសេចក្ដីសន្យាអាចបានសំរេច ដើម្បីឲ្យពួកស្មោះត្រង់ នៅក្នុង ចំណោមអ្នកអាចបានរក្សាទុកឲ្យគង់វង់ ហើយមានចិត្តត្រេកអរជុំគ្នា នៅឯដែនដីមិសសួរី ។ យើងជាព្រះអម្ចាស់ សន្យាដល់ពួកស្មោះ ត្រង់ ហើយមិនអាចកុហកបានឡើយ ។

៧ យើងជាព្រះអម្ចាស់យល់ព្រម បើសិនជាមាននរណាមួយ នៅក្នុងចំណោមអ្នក មានប្រាថ្នាចង់ជិះលើសេះ ឬលើលា ឬលើរទេះ ទាំងឡាយ អ្នកនោះនឹងបានទទួលព្រះពរនេះហើយ បើសិនជាអ្នកនោះទទួលពរពីព្រះហស្តនៃព្រះអម្ចាស់ ដោយមានចិត្តអរគុណក្នុង គ្រប់ការណ៍ទាំងអស់ ។

៨ ការណ៍ទាំងនេះនៅជាមួយអ្នក ដើម្បីប្រព្រឹត្តតាមការវិនិច្ឆ័យ និងតាមការដឹកនាំពីព្រះវិញ្ញាណ ។

៩ មើលចុះ នគរជារបស់ផងអ្នកហើយ ។ ហើយមើលចុះ និងមើលន៏ យើងគង់នៅជាមួយពួកស្មោះត្រង់ជានិច្ច ។ គឺដូច្នោះ មែន ។ អាម៉ែន ៕

## កណ្ឌទី ៦៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ចុងខែសីហា ឆ្នាំ១៨៣១ (*History of the Church, *១:២០៦–២១១) ។ នៅថ្ងៃទី២៧ ខែសីហា ព្យាការី, ស៊ីឌនី រិកដុន និង អូលីវើរ ខៅឌើរី បានមកដល់ក្រុង ខឺតឡង់ បន្ទាប់ពីបានទៅទស្សនកិច្ចរដ្ឋមិសសួរី ។ ទុកជាបុព្វកថាដល់បញ្ជីរបស់លោកនេះ ព្យាការីបានសរសេរថា៖ «នៅដើមកាល នៃសាសនាចក្រ នោះមានការខ្វល់ខ្វាយដ៏ធំ ដើម្បីបានព្រះបន្ទូលនៃព្រះ ចំពោះគ្រប់កិច្ចវត្ថុ ដែលទាក់ទងនឹងសេចក្ដីសង្គ្រោះរបស់យើង យ៉ាងណាក៏ដោយ; ហើយព្រោះឥឡូវនេះ ដែនដីស៊ីយ៉ូនជាវត្ថុមួយខាងសាច់ឈាមដ៏សំខាន់ដែលគិតដល់ នោះខ្ញុំបានទូលដល់ព្រះ អម្ចាស់ សូមពត៌មានតទៅទៀត អំពីការប្រមូលពួកបរិសុទ្ធ និងការទិញដីធ្លី និងការផ្សេងៗទៀត» (*History of the Church, *១:២០៧)* ។

*១–៦, ថ្ងៃនៃសេចក្ដីក្រោធនឹងមកលើពួកទុច្ចរិត; ៧–១២, ទីសំគាល់ទាំងឡាយបានមកដោយសារសេចក្ដីជំនឿ; ១៣–១៩, ពួកអ្នកកំផិត ក្នុងចិត្ត នឹងបដិសេធសេចក្ដីជំនឿ ហើយនឹងត្រូវបោះចោលទៅក្នុងបឹងភ្លើង; ២០, ពួកស្មោះត្រង់នឹងបានទទួលកេរ្ដិ៍មរតកនៅលើផែនដី ដែលបានផ្លាស់ប្រែ; ២១, ដំណើររឿងដ៏ពេញលេញអំពីហេតុការណ៍ទាំងឡាយ នៅលើភ្នំនៃការផ្លាស់ប្រែ ពុំទាន់បានបើកសំដែងប្រាប់ នៅឡើយទេ; ២២–២៣, ពួកគោរពតាមទទួលសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ; ២៤–៣១, កេរ្ដិ៍មរតកទាំងឡាយនៅក្រុងស៊ីយ៉ូន ត្រូវតែទិញ; ៣២–៣៥, ព្រះអម្ចាស់ទ្រង់ចេញបញ្ញត្តិថាមានសង្គ្រាមទាំងឡាយ ហើយថាពួកទុច្ចរិតប្រហារពួកទុច្ចរិត; ៣៦–៤៨, ពួកបរិសុទ្ធត្រូវប្រមូលគ្នាទៅក្រុងស៊ីយ៉ូន ហើយផ្ដល់ប្រាក់កាសដើម្បីកសាងក្រុងនោះឡើង; ៤៩–៥៤, ព្រះពរទាំងឡាយត្រូវបានបញ្ជាក់ ដល់ពួកស្មោះត្រង់ ក្នុងកាលការយាងមកលើកទីពីរ*

៣ *ក* លូកា ១២:៨–៩.
ស.ប. ទីបន្ទាល់.
*ខ* ស.ប. សៀវភៅជីវិត.
*គ* គ. និង ស. ៨៤:៦១.
៤ *ក* គ. និង ស. ៥៧:១–២.
៥ *ក* ស.ប. កិច្ចការផ្សាយសាសនា.
៦ *ក* អេធើរ ៣:១២.
៧ *ក* ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
៩ *ក* គ. និង ស. ៦១:៣៧.
*ខ* ម៉ាថាយ ២៨:២០.

*ក្នុងដំណើររស់ឡើងវិញ និងក្នុងសហស្សវត្សរ៍; ៥៥–៥៨, នេះហើយជាថ្ងៃនៃការ ព្រមាន; ៥៩–៦៦, ព្រះនាមរបស់ព្រះអម្ចាស់ត្រូវយកជាអសារឥតការ ដោយពួកអ្នកដែលយកព្រះនាមមកប្រើ ដោយគ្មានសិទ្ធិអំណាច ។*

ប្រយ័ត្នស្ដាប់ចុះ ឱអ្នករាល់គ្នាជារាស្ត្រអើយ ហើយចូរបើកចំហចិត្តរបស់អ្នក ហើយផ្ទៀងត្រចៀកពីចម្ងាយ; ហើយចូរស្ដាប់ ឱអ្នក ដែលហៅខ្លួនថាជារាស្ត្រនៃព្រះអម្ចាស់អើយ ហើយឮព្រះបន្ទូលនៃព្រះអម្ចាស់ និងព្រះហឫទ័យរបស់ទ្រង់ ដែលមានចំពោះអ្នកចុះ ។

២ មែនហើយ យើងប្រាប់ជាប្រាកដថា ចូរឮព្រះបន្ទូលនៃព្រះអង្គ ដែលមានសេចក្ដីខ្ញាល់ ឆួលឡើងទាស់នឹងពួកទុច្ចរិត និងពួកបះបោរ;

៣ ដែលមានព្រះហឫទ័យចង់យក សូម្បីតែពួកគេដែលទ្រង់នឹងយកទៅ ហើយរក្សាជីវិតពួកគេទុក ដែលទ្រង់មានព្រះហឫទ័យចង់រក្សា ទុកដែរ;

៤ ដែលកសាងឡើង តាមចំណង់ និងព្រះហឫទ័យរបស់ទ្រង់ ហើយបំផ្លាញចោល ក្នុងកាលទ្រង់សព្វព្រះហឫទ័យ ហើយអាចបោះ ព្រលឹងចុះទៅស្ថាននរកបាន ។

៥ មើលចុះ យើងជាព្រះអម្ចាស់ បន្លឺសម្លេងរបស់យើង ហើយសម្លេងរបស់យើងត្រូវគោរពតាម ។

៦ ហេតុដូច្នោះហើយ យើងប្រាប់ជាប្រាកដថា ចូរឲ្យពួកទុច្ចរិតប្រុងប្រយ័ត្ន ហើយចូរឲ្យពួកបះបោរកោតខ្លាច និងភ័យញ័រចុះ; ហើយចូរឲ្យ ពួកដែលឥតជឿទប់មាត់របស់ពួកគេទុក ត្បិតថ្ងៃនៃសេចក្ដីក្រោធនឹងមកលើពួកគេ ដូចជាព្យុះសង្ឃរា ហើយសាច់ឈាមទាំងអស់នឹង ស្គាល់ថាយើងជាព្រះ ។

៧ ហើយអ្នកណាដែលស្វែងរកទីសំគាល់ទាំងឡាយនោះនឹងឃើញទីសំគាល់ទាំងឡាយ ប៉ុន្តែពុំមែនចំពោះសេចក្ដីសង្គ្រោះឡើយ ។

៨ យើងប្រាប់អ្នកជាប្រាកដថា មានអ្នកខ្លះនៅក្នុងចំណោមពួកអ្នក ដែលស្វែងរកទីសំគាល់ទាំងឡាយ ហើយមានមនុស្សបែបនេះចាប់តាំងពីដើមដំបូងមកម្ល៉េះ;

៩ ប៉ុន្តែមើលចុះ សេចក្ដីជំនឿពុំមែនមានឡើង ដោយសារទីសំគាល់ទាំងឡាយឡើយ ប៉ុន្តែទីសំគាល់ទាំងឡាយមកតាមក្រោយអស់អ្នក ដែលជឿវិញ ។

១០ មែនហើយ ទីសំគាល់ទាំងឡាយមានឡើង ដោយសារសេចក្ដីជំនឿ ពុំមែនដោយសារបំណងរបស់មនុស្ស ឬតាមដែលពួកគេចង់ បាននោះទេ ប៉ុន្តែតាមព្រះហឫទ័យនៃព្រះវិញ ។

១១ មែនហើយ ទីសំគាល់ទាំងឡាយមានឡើង ដោយសារសេចក្ដីជំនឿ ចំពោះកិច្ចការដ៏អស្ចារ្យ ត្បិតបើឥតមានសេចក្ដីជំនឿទេ នោះគ្មានមនុស្សណាមួយអាចសព្វព្រះហឫទ័យព្រះបានឡើយ; ហើយអ្នកណាដែលព្រះទ្រង់ខ្ញាល់ នោះទ្រង់នឹងមិនសព្វព្រះហឫទ័យ សោះឡើយ; ហេតុដូច្នោះហើយ ចំពោះមនុស្សបែបនេះ ព្រះអង្គមិនបង្ហាញទីសំគាល់ទាំងឡាយឡើយ គ្រាន់តែសេចក្ដីក្រោធ ចំពោះការដាក់ទោសប៉ុណ្ណោះ ។

១២ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ មិនសព្វព្រះហឫទ័យនឹងអ្នកទាំងនោះ ដែលនៅក្នុងចំណោមពួកអ្នក ដែលស្វែងរកទីសំ គាល់ និងការអស្ចារ្យទាំងឡាយ សំរាប់សេចក្ដីជំនឿ ហើយមិនមែនសំរាប់សេចក្ដីល្អដល់មនុស្សលោក ចំពោះសិរីល្អរបស់យើងឡើយ ។

១៣ ទោះជាយ៉ាងណាក៏ដោយ យើងប្រទានព្រះបញ្ញត្តិទាំងឡាយ ហើយមនុស្សជាច្រើនបានបែរចេញពីព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយពុំបានកាន់តាមទេ ។

១៤ មានពួកកំផិតប្រុសស្រីនៅក្នុងចំណោមអ្នក; ពួកគេខ្លះបានបែរចេញពីអ្នក ហើយអ្នកផ្សេងទៀតបាននៅជាមួយអ្នក ដែលនឹងត្រូវបាន បើកសំដែងប្រាប់ពីពេលនេះតទៅ ។

១៥ ចូរឲ្យមនុស្សបែបនេះប្រុងប្រយ័ត្ន ហើយប្រែចិត្តយ៉ាងឆាប់រហ័សចុះ ខ្លាចក្រែងសេចក្ដីជំនុំជំរះនឹងមានមកលើពួកគេដូចជាលប់ ហើយសេចក្ដីចំកួតរបស់ពួកគេនឹងត្រូវបានសំដែងឲ្យឃើញ ហើយកិច្ចការទាំងឡាយរបស់ពួកគេនឹងទៅតាមពួកគេ នៅក្នុងភ្នែកទាំង ឡាយនៃប្រជាជន ។

១៦ ហើយយើងប្រាប់អ្នកជាប្រាកដ ដូចជាយើងបានប្រាប់ពីមុនថា អ្នកណាដែលគ្រាន់តែក្រឡេកឃើញស្ត្រី ហើយ

**៦៣** ២ *ក* ស.ប. ការបះបោរ.
៣ *ក* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
៦ *ក* ស.ប. សេចក្ដីយុត្តិធម៌;
ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* យេរេ. ៣០:២៣.
*គ* អេសាយ ៤៩:២៦.
៧ *ក* គ. និង ស. ៤៦:៩.
ស.ប. ទីសំគាល់.
១០ *ក* ម៉ូរ៉ូណៃ ៧:៣៧.
ស.ប. សេចក្ដីជំនឿ.
១១ *ក* ហេព្រើរ ១១:៦.
*ខ* គ. និង ស. ៣៥:១១.
*គ* គ. និង ស. ៨៨:៦៥.
១៤ *ក* គ. និង ស. ៤២:២៤–២៥.
១៦ *ក* ម៉ាថាយ ៥:២៧–២៨;
គ. និង ស. ៤២:២៣–២៦.

មាន[ខ]ដំរេកសំរើបចង់ បាន ឬបើសិនជាអ្នកណាមួយប្រព្រឹត្ត
[ក]អំពើកំផិតនៅក្នុងចិត្តរបស់ខ្លួន នោះនឹងមិនមានព្រះវិញ្ញាណឡើយ
ប៉ុន្តែនឹងបោះបង់ចោលសេចក្ដី ជំនឿ ហើយនឹងខ្លាចទៅវិញ ។
១៧ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ បានមានបន្ទូល
ថា [ក]ពួកខ្លាច និងពួកមិនជឿ និងគ្រប់ទាំង[ខ]ពួកកំភូត និងអស់អ្នក
ណាដែល ចូលចិត្ត ហើយប្រព្រឹត្តការ[គ]កុហក និងពួកកំផិត និងពួក
មន្តអាគម គេនឹងមានចំណែក នៅក្នុង[ឃ]បឹងដែលឆេះជាភ្លើង និង
ស្ពាន់ធ័រ គឺជា [ង]សេចក្ដីស្លាប់ទីពីរវិញ ។
១៨ យើងប្រាប់ជាប្រាកដថា ពួកគេនឹងមិនមានចំណែក នៅ
ក្នុង[ក]ដំណើររស់ឡើងវិញលើកទីមួយឡើយ ។
១៩ ហើយឥឡូវនេះ មើលចុះ យើងជាព្រះអម្ចាស់ប្រាប់អ្នកថា
អ្នករាល់គ្នាពុំបាន[ក]រាប់ជាសុចរិតឡើយ ពីព្រោះមានការណ៍ទាំងនេះ
នៅចំណោមពួកអ្នក ។
២០ ទោះជាយ៉ាងណាក៏ដោយ អ្នកណាដែល[ក]កាន់ខ្ជាប់នៅ
ក្នុងសេចក្ដីជំនឿ ហើយប្រព្រឹត្តតាមព្រះហឫទ័យរបស់យើង អ្នក
នោះ ហើយឈ្មោះថាបានឈ្នះ ហើយនឹងបានទទួល[ខ]កេរ្តិ៍មរតក
នៅលើផែនដី កាលថ្ងៃនៃភាពផ្លាស់ប្រែមកដល់;
២១ កាល[ក]ផែនដីនឹង[ខ]ផ្លាស់ប្រែ គឺតាមគំរូដែលបានបង្ហាញដល់
ពួកសាវករបស់យើងនៅលើភ្នំ; រីឯដំណើររឿងដ៏ពេញលេញ
នោះអ្នក រាល់គ្នាពុំទាន់បានទទួលនៅឡើយទេ ។
២២ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា
ដូចជាយើងបានមានបន្ទូលថានឹងធ្វើឲ្យអ្នកដឹងពីព្រះហឫទ័យ
របស់យើង មើលចុះ យើងនឹងធ្វើឲ្យអ្នកដឹងពីព្រះហឫទ័យ
របស់យើងមែន គឺពុំមែនដោយមាត្រាខាងព្រះបញ្ញត្តិនោះទេ
ត្បិតមានមនុស្សជាច្រើនដែលពុំស្វះ ស្វែងកាន់តាមព្រះបញ្ញត្តិ
ទាំងឡាយរបស់យើងឡើយ ។
២៣ ប៉ុន្តែចំពោះអ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយ
របស់យើង នោះយើងនឹងប្រទាន[ក]សេចក្ដីអាថ៌កំបាំងទាំងឡាយនៃ
នគរ របស់យើង ហើយដដែលនេះនឹងនៅក្នុងអ្នកនោះ ដូចជា
[ខ]អណ្ដូងទឹករស់ ដែល[គ]ផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច ។
២៤ ហើយឥឡូវនេះ មើលចុះ នេះហើយជាព្រះហឫទ័យនៃ
ព្រះអម្ចាស់ជាព្រះរបស់អ្នក អំពីពួកបរិសុទ្ធរបស់ទ្រង់ថា ពួកគេ
គួរប្រជុំ គ្នាទៅឯដែនដីស៊ីយ៉ូន ពុំមែនដោយបន្ទាន់ទេ ខ្លាច
ក្រែងត្រូវមានការច្របូកច្របល់ ដែលនាំឲ្យមានអាសន្នរោគ ។
២៥ មើលចុះ ដែនដី[ក]ស៊ីយ៉ូន — យើងជាព្រះអម្ចាស់
កាន់នៅក្នុងព្រះហស្តរបស់យើងផ្ទាល់;
២៦ ទោះជាយ៉ាងណាក៏ដោយ យើងជាព្រះអម្ចាស់ ថ្វាយ
[ក]របស់សេសារទៅសេសារចុះ ។
២៧ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់សព្វព្រះហឫទ័យ
ចង់ឲ្យអ្នកទិញដីធ្លីទាំងឡាយ ប្រយោជន៍ឲ្យអ្នកអាចមានប្រៀបេ
លើពិភព លោក ប្រយោជន៍ឲ្យអ្នកអាចមានសិទ្ធិលើពិភពលោក
ប្រយោជន៍កុំឲ្យពួកគេអាចបានចាក់រុកឲ្យខឹង ។
២៨ ត្បិត[ក]អារក្សសាតាំងដាក់ទៅក្នុងចិត្តរបស់ពួកគេ ដើម្បីឲ្យ
មានកំហឹងខឹងនឹងអ្នក ហើយដើម្បីឲ្យមានការខ្ចាយឈាម ។
២៩ ហេតុដូច្នោះហើយ ដែនដីស៊ីយ៉ូននឹងពុំត្រូវបានឡើយ
លើកលែងតែដោយសារការទិញ ឬដោយសារឈាម បើពុំនោះ
សោតទេ ពុំមានកេរ្តិ៍មរតកសំរាប់អ្នកឡើយ ។
៣០ ហើយបើសិនជាដោយសារការទិញវិញ មើលចុះ អ្នក
ត្រូវបានពរហើយ;
៣១ ហើយបើសិនជាដោយសារឈាមវិញ ព្រោះអ្នកត្រូវបាន
ហាមឃាត់មិនឲ្យកំចាយឈាម មើលន៏ ពួកខ្មាំងសត្រូវរបស់អ្នក
កំពុងមក លើអ្នក ហើយអ្នករាល់គ្នានឹងត្រូវវាយពីទីក្រុងមួយ
ទៅទីក្រុងមួយ និងពីសាលាប្រជុំមួយទៅសាលាប្រជុំមួយ ហើយ
មានតែបន្តិចបន្តួចទេ ដែលនឹងនៅសល់ ដើម្បីទទួលកេរ្តិ៍មរតក ។

១៦ *ខ* ស.ប. សំរេកស្រើប.
*ក* ស.ប. អំពើកំផិត.
១៧ *ក* វិវរ. ២១:៨.
*ខ* ស.ប. សេចក្ដីកុហក.
*គ* វិវរ. ២២:១៥;
គ. និង ស. ៧៦:១០៣.
*ឃ* វិវរ. ១៩:២០;
២ នីហ្វៃ ៩:៨–១៩, ២៦;
២៨:២៣;
យ៉ាកុប ៦:១០;
អាលម៉ា ១២:១៦–១៨;
គ. និង ស. ៧៦:៣៦.
ស.ប. ស្ថាននរក.
*ង* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
១៨ *ក* វិវរ. ២០:៦.
១៩ *ក* ស.ប. ការរាប់ជាសុចរិត,
រាប់ជាសុចរិត.
២០ *ក* គ. និង ស. ១០១:៣៥.
*ខ* ម៉ាថាយ ៥:៥;
គ. និង ស. ៥៩:២;
៨៨:២៥–២៦.
២១ *ក* ស.ប. ផែនដី —
ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
*ខ* ស.ប. ពិភពលោក —
ចុងបំផុតនៃផែនដី.
*គ* ម៉ាថាយ ១៧:១–៣.
២៣ *ក* អាលម៉ា ១២:៩–១១;
គ. និង ស. ៤២:៦១; ៨៤:១៩;
១០៧:១៨–១៩.
*ខ* ស.ប. ទឹករស់.
*គ* យ៉ូហាន ៤:១៤.
២៥ *ក* ស.ប. ស៊ីយ៉ូន.
២៦ *ក* លូកា ២០:២៥;
គ. និង ស. ៥៨:២១–២៣.
ស.ប. រដ្ឋាភិបាល.
២៨ *ក* ស.ប. អារក្ស.

៣២ យើងជាព្រះអម្ចាស់ កំពុងតែខ្ញាល់នឹងពួកទុច្ចរិត; យើង
កំពុងតែទប់ព្រះវិញ្ញាណរបស់យើង ពីបណ្ដាជននៅលើផែនដី ។
៣៣ យើងបានស្បថក្នុងសេចក្ដីក្រោធរបស់យើង ហើយ
បានចេញបញ្ញត្តិថាមាន[ក]សង្គ្រាមទាំងឡាយនៅលើផ្ទៃផែនដី ហើយ
ពួកទុច្ចរិត នឹងប្រហារពួកទុច្ចរិតចោល ហើយសេចក្ដីខ្លាចនឹង
មានមកលើមនុស្ស[ក]គ្រប់រូប;
៣៤ ហើយពួកបរិសុទ្ធក៏វិះនឹងគៀសខ្លួនមិនរួចដែរ; ទោះជាយ៉ាង
ណាក៏ដោយ[ខ] យើងជាព្រះអម្ចាស់ គង់នៅជាមួយពួកគេ ហើយ
នឹងយាងចុះមក[គ]ពីលើស្ថានសួគ៌[ឃ] ពីវត្តមាននៃព្រះវរបិតារបស់យើង
ហើយបញ្ឆេះពួកទុច្ចរិតដោយភ្លើងដែលពន្លត់មិនបាន ។
៣៥ ហើយមើលចុះ នេះមិនទាន់កើតឡើងទេ ប៉ុន្តែនៅបន្តិច
ទៀត ។
៣៦ ហេតុដូច្នោះហើយ ដោយឃើញថាយើងជាព្រះអម្ចាស់
បានចេញបញ្ញត្តិឲ្យមានការណ៍ទាំងនេះកើតឡើងនៅលើផ្ទៃផែនដី
នោះយើងមានប្រាថ្នាថា ពួកបរិសុទ្ធរបស់យើងត្រូវប្រជុំគ្នីគ្នា
នៅលើដែនដីស៊ីយ៉ូន;
៣៧ ហើយថាមនុស្សគ្រប់រូបត្រូវយក[ក]សេចក្ដីសុចរិត[ខ]នៅ
ក្នុងដៃ និងសេចក្ដីស្មោះត្រង់នៅលើចង្កេះ ហើយបន្លឺសម្លេង
ព្រមានដល់ បណ្ដា ជននៅលើផែនដី; ហើយប្រកាសទាំង
ខាងពាក្យសំដី និងខាងការគៀសខ្លួន[គ] ថាសេចក្ដីហិនវិនាស
នឹងមកលើពួកទុច្ចរិត ។
៣៨ ហេតុដូច្នោះហើយ ចូរឲ្យពួកសិស្សរបស់យើង ដែល
នៅក្រុងខឺតឡង់ រៀបចំការងារខាងសាច់ឈាមរបស់ពួកគេ
គឺពួកអ្នកដែល អាស្រ័យនៅលើស្រែនេះ ។
៣៩ ចូរឲ្យ ទីតុស បិលលិង្ស ដែលថែរក្សាស្រែនោះ
កាត់ដីធ្លីចេញ ប្រយោជន៍ឲ្យគាត់អាចបានប្រុងប្រៀបជាស្រេច
នៅនិទាឃរដូវ ខាងមុខ ដើម្បីចេញដំណើររបស់គាត់ ឡើងទៅឯ
ដែនដីស៊ីយ៉ូន ជាមួយអស់អ្នកដែលអាស្រ័យនៅលើផ្ទៃស្រែនោះ
លើកលែងតែអស់ អ្នកដែលយើងនឹងរក្សាទុក ចំពោះ
ខ្លួនយើងប៉ុណ្ណោះ ដែលនឹងមិនត្រូវទៅទេ លុះត្រាយើងបញ្ជា
ពួកគេ ។

៤០ ហើយចូរយកប្រាក់កាសទាំងអស់ ដែលអាចសំចៃបាន វា
មិនសំខាន់ដល់យើងទេ ទោះជាមានតិចឬច្រើនក្ដី ដើម្បី
បញ្ជូនឡើងទៅឯ ដែនដីស៊ីយ៉ូន ទៅដល់អស់អ្នកដែលយើងបាន
តាំងឡើងដើម្បីទទួល ។
៤១ មើលចុះ យើងជាព្រះអម្ចាស់នឹងប្រទានដល់ យ៉ូសែប
ស្ម៊ីធ ជុញ្ញ័រ[ក] ជាអ្នកបំរើរបស់យើងនូវអំណាច ប្រយោជន៍ឲ្យ
លោកអាច សង្កេត ស្គាល់ដោយសារព្រះវិញ្ញាណ ពីអស់អ្នក
ណាដែលត្រូវឡើងទៅឯដែនដីស៊ីយ៉ូន និងអស់អ្នកពីពួកសិស្ស
របស់យើងដែលត្រូវនៅ ។
៤២ ចូរឲ្យនូវែល ខេ វិតនី ជាអ្នកបំរើរបស់យើង ទុកផ្សាររបស់
គាត់ចុះ ឬម្យ៉ាងទៀត គឺផ្សារនោះ ឲ្យមួយរដូវតូចទៀត ។
៤៣ ទោះជាយ៉ាងណាក៏ដោយ ចូរឲ្យគាត់ចែកប្រាក់ទាំងអស់
ដែលគាត់ចែកបាន ដើម្បីបញ្ជូនឡើងទៅឯដែនដីស៊ីយ៉ូនចុះ ។
៤៤ មើលចុះ ការណ៍ទាំងនេះគឺនៅក្នុងដៃរបស់គាត់ហើយ
ចូរឲ្យគាត់ធ្វើតាមប្រាជ្ញាចុះ ។
៤៥ យើងប្រាប់ជាប្រាកដថា ចូរឲ្យគាត់បានតែងតាំងជា
ភ្នាក់ងារដល់ពួកសិស្សដែលនឹងនៅ ហើយចូរឲ្យគាត់បាន
តែងតាំងដល់ អំណាចនេះចុះ;
៤៦ ហើយឥឡូវនេះ ចូរទៅទស្សនកិច្ចសាសនាចក្រទាំង
ឡាយ ដោយបរិយាយប្រាប់នូវការណ៍ទាំងនេះដល់ពួកគេ ជា
មួយនឹង អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង ។ មើលចុះ
នេះហើយជាព្រះហឫទ័យរបស់យើង គឺដោយបានប្រាក់កាស
ដូចដែលយើងបាន ដឹកនាំ ។
៤៧ អ្នកណាដែលមាន[ក]ចិត្តស្មោះត្រង់ ហើយកាន់ខ្ជាប់ នោះ
នឹងបានឈ្នះលើលោកិយ ។
៤៨ អ្នកណាដែលបញ្ជូនទ្រព្យសម្បត្តិទាំងឡាយឡើងទៅឯ
ដែនដីស៊ីយ៉ូន នោះនឹងបានទទួល[ក]កេរ្តិ៍មរតក នៅនាលោកិយនេះ
ហើយ កិច្ចការទាំងឡាយរបស់អ្នកនោះនឹងទៅតាមគាត់ ហើយ
ព្រមទាំងរង្វាន់ នៅបរលោកនាយផង ។
៤៩ មែន ហើយមានពរហើយដល់ពួកអ្នក[ក]ស្លាប់ដែលស្លាប់នៅ
ក្នុងព្រះអម្ចាស់ ពីពេលនេះតទៅ ក្នុងកាលព្រះអម្ចាស់ទ្រង់នឹង

៣៣ *ក* ស.ប. សង្គ្រាម.
៣៤ *ក* ស.ប. ជនបរិសុទ្ធ.
*ខ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*គ* ម៉ាថាយ ៣:១២; ២ នីហ្វៃ ២៦:៦; គ. និង ស. ៤៥:៥៧; ៦៤:២៤; ១០១:២៣–២៥, ៦៦.
ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
*ឃ* ស.ប. ភ្លើង.
៣៧ *ក* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ខ* គ. និង ស. ១:៤.
*គ* អេសាយ ៤៧:១១.
៤១ *ក* ស.ប. ការសង្កេតស្គាល់, អំណោយទាបខាង.
៤៧ *ក* ម៉ូសាយ ២:៤១; គ. និង ស. ៦:១៣.
៤៨ *ក* គ. និង ស. ១០១:១៨.
៤៩ *ក* វិវរ. ១៤:១៣; គ. និង ស. ៤២:៤៤–៤៧.

យាងមក ហើយ សេចក្ដីចាស់ទាំងឡាយបានកន្លងបាត់ទៅ
ហើយគ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ ពួកគេនឹងរស់ពីស្លាប់
ឡើងវិញ ហើយនឹងមិនត្រូវ ស្លាប់ទៀតឡើយ ហើយ
នឹងបានទទួលកេរ្ដិ៍មរតកនៅចំពោះព្រះអម្ចាស់ នៅក្នុងទីក្រុង
ដ៏បរិសុទ្ធ ។
៥០ ហើយអ្នកណាដែលរស់នៅ ក្នុងកាលព្រះអម្ចាស់ទ្រង់
យាងមក ហើយបានរក្សាសេចក្ដីជំនឿ មានពរដល់អ្នកនោះហើយ;
ទោះជាយ៉ាងណាក៏ដោយ គឺត្រូវបានកំណត់ឲ្យអ្នកនោះស្លាប់
តាមអាយុមនុស្ស ។
៥១ ហេតុដូច្នោះហើយ កូនក្មេងនឹងត្រូវធំឡើង រហូត
ដល់វាទៅជាមនុស្សពេញវ័យ; មនុស្សចាស់នឹងត្រូវស្លាប់; ប៉ុន្តែ
ពួកគេនឹងមិនដេក លក់នៅក្នុងធូលីដីទេ ប៉ុន្តែពួកគេនឹងត្រូវផ្លាស់
ប្រែក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ ។
៥២ ហេតុដូច្នោះហើយ ព្រោះដោយហេតុនេះ ទើបពួក
សាវកបានផ្សាយដល់ពិភពលោក អំពីដំណើររស់ឡើងវិញ
នៃមនុស្សស្លាប់ ។
៥៣ ការណ៍ទាំងនេះហើយជាការណ៍ទាំងឡាយ ដែលអ្នក
រាល់គ្នាត្រូវសម្លឹងរក; ហើយតាមព្រះបន្ទូលនៃព្រះអម្ចាស់
ការណ៍ទាំងនេះ នៅជិតដៃបង្កើយ និងនៅពេលខាងមុខ គឺនៅ
ក្នុងថ្ងៃនៃការយាងមករបស់កូនមនុស្ស ។
៥៤ ហើយលុះត្រាដល់ម៉ោងនោះ នឹងមានពួកស្រី
ព្រហ្មចារីល្ងង់ នៅក្នុងចំណោមអ្នកមានគំនិត; ហើយនៅម៉ោង
នោះ នឹងមានការ បំបែកពួកសុចរិត និងពួកទុច្ចរិតទាំងអស់;
ហើយនៅថ្ងៃនោះ យើងនឹងចាត់ពួកទេវតារបស់យើង
ឲ្យទៅដកពួកទុច្ចរិតចេញ ហើយបោះពួកគេចោលទៅ
ក្នុងភ្លើងដែលពន្លត់មិនបាន។
៥៥ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា
យើងជាព្រះអម្ចាស់ មិនសព្វព្រះហឫទ័យនឹង ស៊ីឌនី រិកដុន ជា
អ្នកបំរើរបស់ យើងឡើយ; គាត់បានដំកើងខ្លួននៅក្នុងចិត្តរបស់
គាត់ ហើយមិនទទួលការទូន្មានឡើយ ប៉ុន្តែបានធ្វើឲ្យព្រះវិញ្ញាណ
ព្រួយបារម្ភទៅវិញ;
៥៦ ហេតុដូច្នោះហើយ ការសរសេររបស់គាត់ មិនគួរទទួល
ស្គាល់ដល់ព្រះអម្ចាស់ឡើយ ហើយគាត់ត្រូវធ្វើមួយទៀត ហើយបើ
សិនជា ព្រះអម្ចាស់មិនទទួលការសរសេរនោះទេ មើលចុះ គាត់
មិនត្រូវឈរនៅក្នុងតំណែង ដែលយើងបានតាំងដល់គាត់តទៅ
ទៀតឡើយ ។
៥៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា អស់អ្នក
ណាដែលមានសេចក្ដីប៉ងប្រាថ្នានៅក្នុងចិត្តរបស់ពួកគេ នៅក្នុង
ភាពស្លូតបូត ដើម្បីព្រមានដល់ពួកអ្នកបាប អំពីការប្រែចិត្ត ចូរឲ្យ
ពួកគេបានតែងតាំងដល់អំណាចនេះចុះ ។
៥៨ ត្បិតនេះជាថ្ងៃនៃការព្រមាន ហើយពុំមែនជាថ្ងៃនៃពាក្យ
ពេចន៍ដ៏ច្រើននោះទេ ។ ត្បិតយើងជាព្រះអម្ចាស់ នឹងមិនត្រូវ
គេមើលងាយ នៅថ្ងៃចុងក្រោយបង្អស់ឡើយ ។
៥៩ មើលចុះ យើងមកពីលើ ហើយព្រះចេស្ដារបស់យើងនៅ
ខាងក្រោម ។ ហើយយើងខ្ពស់លើសទាំងអស់ ហើយ
សណ្ឋិតនៅក្នុងទាំង អស់ ហើយគង់នៅកណ្ដាលទាំងអស់
ហើយស្ទង់មើលទាំងអស់ ហើយថ្ងៃនោះនឹងមកដល់ កាលគ្រប់
ទាំងអស់នឹងនៅក្រោមអំណាច យើង ។
៦០ មើលចុះ យើងជាអាលផា និងអូមេកា គឺជា
ព្រះយេស៊ូវគ្រីស្ទ ។
៦១ ហេតុដូច្នោះហើយ ចូរឲ្យមនុស្សលោកទាំងអស់ប្រុង
ប្រយ័ត្ន អំពីរបៀបពួកគេយកព្រះនាមរបស់យើង មកប្រើក្នុង
បបូរមាត់របស់ ពួកគេ —
៦២ ត្បិតមើលចុះ យើងប្រាប់ជាប្រាកដថា មានមនុស្ស
ជាច្រើនដែលនៅក្រោមការដាក់ទោសនេះ ដែលប្រើព្រះនាមនៃ
ព្រះអម្ចាស់ ហើយប្រើព្រះនាមជាអសារឥតការ ដោយគ្មានសិទ្ធិ
អំណាចសោះឡើយ ។
៦៣ ហេតុដូច្នោះហើយ ចូរឲ្យសាសនាចក្រប្រែចិត្តពីអំពើបាប

៤៩ *ខ* ២ កូរិន. ៥:១៧.
*គ* ស.ប. ដំណើររស់ឡើងវិញ.
*ឃ* វិវ. ២១:៤; អាលម៉ា ១១:៤៥;
គ. និង ស. ៨៨:១១៦.
ស.ប. អមតៈ, អមតភាព.
៥០ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*ខ* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
៥១ *ក* ស.ប. សហស្សវត្សរ៍.
*ខ* អេសាយ ៦៥:២០–២២;
គ. និង ស. ៤៥:៥៨;
១០១:២៩–៣១.
*គ* ១ កូរិន. ១៥:៥១–៥២;
គ. និង ស. ៤៣:៣២.
៥៣ *ក* គ. និង ស. ៣៥:១៥.
៥៤ *ក* ម៉ាថាយ ២៥:១–១៣;
គ. និង ស. ៤៥:៥៦–៥៩.
*ខ* ម៉ូសាយ ១៦:២.
៥៥ *ក* ស.ប. រិកដុន, ស៊ីឌនី.
*ខ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
៥៦ *ក* គ. និង ស. ៥៨:៥០.
៥៧ *ក* គ. និង ស. ៤:៣–៦.
*ខ* គ. និង ស. ១៨:១៤–១៥.
ស.ប. កិច្ចការផ្សាយសាសនា;
ព្រមាន, ពាក្យព្រមាន.
៥៩ *ក* ១ កូរិន. ២:១០.
៦០ *ក* ស.ប. អាលផា និងអូមេកា.
៦១ *ក* ស.ប. សេចក្ដីមើលងាយ.

ទាំងឡាយរបស់ពួកគេចុះ ហើយយើងជាព្រះអម្ចាស់នឹងបានពួកគេ; បើពុំនោះសោតទេ ពួកគេនឹងត្រូវកាត់ចេញ ។

៦៤ ចូរចងចាំថា អ្វីដែលមកពីលើ គឺជា[ក]ពិសិដ្ឋ ហើយ[ខ]ត្រូវពោលដល់ដោយយកចិត្តទុកដាក់ និងដោយការទប់ពីព្រះវិញ្ញាណ ហើយនៅក្នុងការណ៍នេះ នោះនឹងគ្មានការដាក់ទោសទេ ហើយអ្នករាល់គ្នាទទួលព្រះវិញ្ញាណ [គ]តាមរយៈការអធិស្ឋាន; ហេតុដូច្នោះហើយ បើគ្មានការណ៍នេះទេ នោះនឹងត្រូវមានការដាក់ទោសតទៅទៀត ។

៦៥ ចូរឲ្យ យ៉ូសែប ស៊្មីធ ជុញ្ញ័រ និង ស៊ីឌនី រិកដុន ជាពួកអ្នកបំរើរបស់យើង ស្វែងរកផ្ទះសំបែង ដូចជាពួកគេត្រូវបានបង្រៀនតាមរយៈ[ក]ការអធិស្ឋាន ដោយព្រះវិញ្ញាណ ។

៦៦ ការណ៍ទាំងនេះនឹងត្រូវយកឲ្យឈ្នះបាន តាមរយៈសេចក្ដីអត់ធ្មត់ ប្រយោជន៍ឲ្យពួកគេអាចបានទទួល[ក]សិរីល្អ[ខ]យ៉ាងធ្ងន់លើសលប់ និងដ៏នៅអស់កល្បជានិច្ច បើពុំនោះសោតទេ នឹងត្រូវមានការដាក់ទោសធំជាងនេះទៅទៀត ។ អាម៉ែន ៕

កណ្ឌទី ៦៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះពួកអែលឌើរនៃសាសនាចក្រ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៨៣១ (*History of the Church*, ១:២១១–២១៤) ។ ព្យាការីកំពុងតែរៀបចំនឹងផ្លាស់ទៅនៅ ភូមិហៃរាំ រដ្ឋអូហៃអូ ដើម្បីវិលទៅធ្វើកិច្ចការរបស់លោកឡើងវិញ អំពីការបកប្រែព្រះគម្ពីរប៊ីប ដែលបានទុកចោលកាលលោកបាននៅ ឯរដ្ឋមិសសួរី ។ ក្រុមបងប្អូនប្រុសៗដែលត្រូវបានបញ្ជាឲ្យធ្វើដំណើរទៅក្រុងស៊ីយ៉ូន (រដ្ឋមិសសួរី) កំពុងតែព្យាយាមក្នុងការរៀបចំ ដើម្បីធ្វើដំណើរចេញទៅនៅខែតុលា ។ វិវរណៈត្រូវបានទទួល នៅពេលនេះដែលកំពុងតែរវល់ ។*

*១–១១, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យអត់ទោសដល់គ្នាទៅវិញទៅមក ក្រែងមានអំពើបាបធំជាងនៅក្នុងខ្លួន; ១២–២២, ពួកអ្នកដែល មិនប្រែចិត្ត ត្រូវយកមកខាងមុខសាសនាចក្រ; ២៣–២៥, អ្នកណាដែលថ្វាយដង្វាយ១ភាគ១០ នឹងមិនត្រូវឆេះឡើយ នៅការយាង មករបស់ព្រះអម្ចាស់; ២៦–៣២, ពួកបរិសុទ្ធត្រូវបានព្រមានអំពីបំណុល; ៣៣–៣៦, ពួកបះបោរនឹងត្រូវកាត់ចេញពីក្រុងស៊ីយ៉ូន; ៣៧–៤០, សាសនាចក្រនឹងជំនុំជំរះសាសន៍ទាំងឡាយ; ៤១–៤៣, ក្រុងស៊ីយ៉ូននឹងបានលូតលាស់ ។*

មើលចុះ ព្រះអម្ចាស់ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលដល់អ្នកដូច្នេះថា៖ ឱអ្នករាល់គ្នាជាពួកអែលឌើរ នៃសាសនាចក្ររបស់យើង អើយ ចូរអ្នករាល់គ្នាប្រុងស្ដាប់ហើយឮ ហើយចូរទទួលយកព្រះហឫទ័យដែលយើងមានចំពោះអ្នកចុះ ។

២ ត្បិតយើងប្រាប់អ្នកជាប្រាកដថា យើងចង់ឲ្យអ្នករាល់គ្នា[ក]ឈ្នះលើលោកិយ; ហេតុដូច្នោះហើយ យើងនឹងមានចិត្ត[ខ]អាណិតមកលើអ្នក ។

៣ មានពួកអ្នកនៅក្នុងចំណោមអ្នករាល់គ្នាដែលបានធ្វើបាប; ប៉ុន្តែយើងប្រាប់ជាប្រាកដ នៅពេលនេះតែម្ដងគត់ ចំពោះ[ក]សិរីល្អរបស់យើង ផ្ទាល់ និងចំពោះសេចក្ដីសង្គ្រោះដល់មនុស្សទាំងឡាយថា យើងបាន[ខ]អត់ទោសឲ្យអ្នក នូវអំពើបាបរបស់អ្នកហើយ ។

៤ យើងនឹងមានសេចក្ដីមេត្តាករុណាដល់អ្នក ត្បិតយើងបានប្រទានដល់អ្នកនូវនគរហើយ ។

៥ ហើយ[ក]កូនសោទាំងឡាយនៃសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ នឹងមិនត្រូវដកយកចេញពី យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង តាមរយៈមាគ៌ាទាំងឡាយដែលយើងបានតាំងឡើងនោះ[ខ]ឡើយ កាលណាលោកនៅរស់ ដរាបណាលោកគោរពតាមពិធី បរិសុទ្ធទាំងឡាយរបស់យើង ។

៦ មានពួកអ្នកដែលបានស្វែងរកឱកាសទាស់នឹងលោកដោយឥតហេតុ;

៦៤ *ក* ស.ប. បរិសុទ្ធ.
*ខ* ស.ប. ការគោរពកោតក្រែង.
*គ* គ. និង ស. ៤២:១៤.
៦៥ *ក* ស.ប. ការអធិស្ឋាន.
៦៦ *ក* ២ កូរិន. ៤:១៧.
*ខ* រ៉ូម ៨:១៨;
គ. និង ស. ៥៨:៤; ១៣៦:៣១.
**៦៤** ២ *ក* ១ យ៉ូហាន ៥:៤.
*ខ* ស.ប. អាណិត.
៣ *ក* ម៉ូសេ ១:៣៩.
*ខ* អេសាយ ៤៣:២៥.
៥ *ក* គ. និង ស. ២៨:៧; ៨៤:១៩.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.

៧ ទោះជាយ៉ាងណាក៏ដោយ លោកបានធ្វើបាប; ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា យើងជាព្រះអម្ចាស់អភ័យទោសចំពោះអំពើបាប ដល់អស់អ្នកណាដែលសារភាពអំពើបាបទាំងឡាយរបស់ខ្លួននៅចំពោះយើង ហើយសូមក្ដីអភ័យទោស ជាអ្នកដែលបានធ្វើបាបមិន ដល់សេចក្ដីស្លាប់ ។

៨ ពួកសិស្សរបស់យើងនៅសម័យបុរាណ បានស្វែងរកឱកាសទាស់នឹងគ្នាទៅវិញទៅមក ហើយមិនអត់ទោសឲ្យគ្នាទៅវិញទៅមក នៅក្នុងចិត្តរបស់ពួកគេទេ ហើយចំពោះការអាក្រក់នេះ ពួកគេត្រូវបានរងទុក្ខ និងបានវាយផ្ចាលជាខ្លាំង ។

៩ ហេតុដូច្នោះហើយ យើងប្រាប់អ្នកថា អ្នកត្រូវអត់ទោសដល់គ្នាទៅវិញទៅមក; ត្បិតអ្នកណាដែលមិនអត់ទោសដល់បងប្អូនរបស់ខ្លួន ចំពោះការរំលងរបស់គេទេ នោះជាប់ទោសនៅចំពោះព្រះអម្ចាស់; ព្រោះនៅជាប់នឹងអ្នកនោះ គឺជាបាបដ៏ធំជាង ។

១០ យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណា ដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញ គឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ ។

១១ ហើយអ្នករាល់គ្នាត្រូវនិយាយនៅក្នុងចិត្តថា — សូមឲ្យព្រះទ្រង់ជំនុំជំរះរវាងអ្នកនឹងខ្ញុំ ហើយសងអ្នក តាមអំពើដែលអ្នកធ្វើចុះ ។

១២ ហើយអ្នកណាដែលមិនប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួនទេ ហើយមិនសារភាពនូវអំពើបាបនោះទេ នោះអ្នករាល់គ្នាត្រូវយក មកចំពោះសាសនាចក្រចុះ ហើយប្រព្រឹត្តដល់អ្នកនោះតាមដែលព្រះគម្ពីរប្រាប់ដល់អ្នក ទោះដោយព្រះបញ្ញត្តិ ឬដោយវិវរណៈក្ដី ។

១៣ ហើយការណ៍នេះអ្នករាល់គ្នាត្រូវប្រព្រឹត្ត ប្រយោជន៍ឲ្យព្រះទ្រង់អាចបានទទួលសិរីល្អ — មិនមែនមកពីអ្នករាល់គ្នាពុំបានអត់ទោស ដោយគ្មានចិត្តអាណិតអាសូរនោះឡើយ ប៉ុន្តែប្រយោជន៍ឲ្យអ្នករាល់គ្នាអាចបានរាប់ជាសុចរិត នៅក្នុងចក្ខុទាំងឡាយនៃក្រិត្យវិន័យ ប្រយោជន៍កុំឲ្យអ្នករាល់គ្នាជំទាស់ព្រះអង្គ ដែលជាអ្នកតែងក្រិត្យវិន័យរបស់អ្នក —

១៤ យើងប្រាប់ជាប្រាកដថា ត្បិតដោយសារហេតុនេះហើយ ទើបអ្នករាល់គ្នាត្រូវប្រព្រឹត្តការណ៍ទាំងនេះ ។

១៥ មើលចុះ យើងជាព្រះអម្ចាស់ កំពុងតែខ្ញាល់នឹងអ្នកនោះ ដែលជាអ្នកបំរើរបស់យើង គឺអែសរ៉ា ប៊ូត ហើយនិង អ៊ីសាក មូលី ជាអ្នក បំរើរបស់យើងដែរ ត្បិតពួកគេពុំបានកាន់តាមក្រិត្យវិន័យ ឬព្រះបញ្ញត្តិឡើយ;

១៦ ពួកគេបានស្វែងរកអំពើអាក្រក់នៅក្នុងចិត្តរបស់ពួកគេ ហើយយើងជាព្រះអម្ចាស់បានទុកព្រះវិញ្ញាណរបស់យើង ។ ពួកគេបានដាក់ ទោសថាជាអំពើអាក្រក់ នូវអ្វីដែលពុំមែនជាអំពើអាក្រក់; ទោះជាយ៉ាងណាក៏ដោយ យើងបានអត់ទោសដល់អ៊ីសាក មូលី ជាអ្នកបំរើ របស់យើងហើយ ។

១៧ ហើយនិង អែតវឺត បាទ្រិច ជាអ្នកបំរើរបស់យើងផង មើលចុះ គាត់បានធ្វើបាប ហើយអារក្សសាតាំងស្វែងរក ដើម្បីបំផ្លាញព្រលឹង គាត់ចោល; ប៉ុន្តែកាលការណ៍ទាំងនេះត្រូវបានធ្វើឲ្យដឹងដល់ពួកគេ ហើយពួកគេប្រែចិត្តពីអំពើអាក្រក់ នោះពួកគេត្រូវបានអត់ទោស ។

១៨ ហើយឥឡូវនេះ យើងប្រាប់ជាប្រាកដថា ជាការចាំបាច់ចំពោះយើង ដែល ស៊ីឌនី គិលបឺត ជាអ្នកបំរើរបស់យើងបន្ទាប់ពីពីរបី អាទិត្យក្រោយមក ត្រូវវិលទៅឯធុរកិច្ចរបស់គាត់ និងទៅឯការងាររបស់គាត់វិញ នៅក្នុងដែនដីស៊ីយ៉ូន;

១៩ ហើយអ្វីដែលគាត់បានឃើញ ហើយបានឮ នោះអាចបានធ្វើឲ្យដឹងដល់ពួកសិស្សរបស់យើង ប្រយោជន៍កុំឲ្យពួកគេត្រូវវិនាសបង់ ។ ហើយដោយសារហេតុនេះ ទើបយើងបានមានបន្ទូលអំពីការណ៍ទាំងនេះ ។

២០ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា អ៊ីសាក មូលី ជាអ្នកបំរើរបស់យើងមិនអាចត្រូវល្បួងហួសកំរិត ដែលគាត់អាចទ្រាំបាន ហើយ ទូន្មានបង្ខុស ដើម្បីបញ្ឈឺអ្នកឡើយ យើងបានបញ្ជាថា ត្រូវលក់ស្រែរបស់គាត់ ។

២១ យើងមិនព្រមឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស លក់ស្រែរបស់គាត់ឡើយ ត្បិតយើងជាព្រះអម្ចាស់ចង់ទុកកន្លែងមាំមួនមួយ នៅ

---

៧ ក ស.ប. អត់ទោស, អភ័យទោស; ការផ្ដាច់បាប.
ខ ជនគ. ៥:៦–៧; គ. និង ស. ១៩:២០; ៥៨:៤៣. ស.ប. ឆ្លើយសារភាព, ការឆ្លើយសារភាព.
គ គ. និង ស. ៧៦:៣១–៣៧.
៨ ក ស.ប. ការទាស់ទែង.
ខ ស.ប. វាយផ្ចាល, ការវាយផ្ចាល.
៩ ក ម៉ាកុស ១១:២៥–២៦; គ. និង ស. ៨២:១.
ខ ម៉ាថាយ ៦:១៤–១៥; អេភេ. ៤:៣២.
១០ ក និក្ខ. ៣៣:១៩; អាលម៉ា ៣៩:៦; គ. និង ស. ៥៦:១៤.
ខ ម៉ូសាយ ២៦:២៩–៣១.
១១ ក ១ សាំយូ. ២៤:១២.
ខ ២ ធីម៉ូ. ៤:១៤.
១២ ក គ. និង ស. ៤២:៨០–៩៣.
១៦ ក ២ នីហ្វៃ ១៥:២០; គ. និង ស. ១២១:១៦.
១៧ ក ស.ប. ប៉ាទ្រិច, អែតវឺត.
ខ ស.ប. អារក្ស.
២០ ក ស.ប. ល្បួង, សេចក្ដីល្បួង.

ក្នុង ដែនដីខឺតឡង់ សំរាប់កំឡុងពេលប្រាំឆ្នាំ នៅពេលនោះ យើងនឹងមិនបំបះពួកទុច្ចរិតទេ ប្រយោជន៍ដោយមាគ៌ានេះ យើងអាចសង្គ្រោះ ពួកគេខ្លះ ។

២២ ហើយបន្ទាប់ពីថ្ងៃនោះមក យើងជាព្រះអម្ចាស់នឹងមិនរាប់ថានរណាមួយមាន[ក]ទោសទេ ដែលនឹងឡើងទៅឯដែនដីស៊ីយ៉ូនដោយ [ខ]បើកចិត្តចំហ; ត្បិតយើងជាព្រះអម្ចាស់តម្រូវចិត្តទាំងឡាយពីកូនចៅមនុស្ស ។

២៣ មើលចុះ ឥឡូវត្រូវបានហៅថា[ក]ថ្ងៃនេះ រហូតដល់[ខ]ការយាងមកនៃកូនមនុស្ស ហើយប្រាកដមែន គឺជាថ្ងៃនៃការ[គ]បូជា និងជាថ្ងៃសំរាប់ ដង្វាយ១ភាគ១០នៃរាស្ត្ររបស់យើង ត្បិតអ្នកណាដែលបានថ្វាយ[ឃ]ដង្វាយ១ភាគ១០ នោះនឹងមិនត្រូវ[ង]ឆេះឡើយ នៅការយាងមក របស់ទ្រង់ ។

២៤ ត្បិតបន្ទាប់ពីថ្ងៃនេះទៅ នឹងមាន[ក]ការឆេះ — នេះគឺនិយាយតាមព្រះបន្ទូលនៃព្រះអម្ចាស់ — ត្បិតយើងប្រាប់ជាប្រាកដថា ថ្ងៃស្អែក អស់ពួក[ខ]ឆ្មើងឆ្មៃ និងអស់ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ នឹងទៅដូចជាជញ្ជ្រាំង; ហើយយើងនឹងបញ្ឆេះពួកគេចោល ត្បិតយើងជាព្រះ អម្ចាស់នៃពួកពលបរិវារ; ហើយយើងនឹងមិនប្រណីនរណាមួយ ដែលនៅក្នុងក្រុង[គ]បាប៊ីឡូនឡើយ ។

២៥ ហេតុដូច្នោះហើយ បើសិនជាអ្នករាល់គ្នាជឿដល់យើង នោះអ្នករាល់គ្នានឹងធ្វើការ ក្នុងកាលដែលហៅថាថ្ងៃនេះចុះ ។

២៦ ហើយមិនសមឲ្យ [ក]នូវល ខេ វិតនី និង ស៊ីឌនី គិលបឺតជាពួកអ្នកបំរើរបស់យើង [ខ]លក់ផ្សាររបស់ពួកគេ និងរបស់របរទាំងឡាយ របស់ពួកគេនៅទីនេះទេ ត្បិតនេះពុំមែនជាប្រាជ្ញាទេ រហូតដល់ពួកអ្នកដែលនៅសល់ក្នុងសាសនាចក្រ ដែលនៅកន្លែងនេះនឹងឡើងទៅ ឯដែនដីស៊ីយ៉ូនសិន ។

២៧ មើលចុះ គឺបានចែងនៅក្នុងក្រឹត្យវិន័យទាំងឡាយរបស់យើង ឬហាមឃាត់ មិនឲ្យមាន[ក]បំណុលពីពួកខ្មាំងសត្រូវរបស់អ្នកឡើយ;

២៨ ប៉ុន្តែមើលចុះ គឺពុំបានចែងក្នុងពេលណាមួយឡើយថាព្រះអម្ចាស់ទ្រង់មិនគួរយក ក្នុងកាលទ្រង់សព្វព្រះហឫទ័យ ហើយសងដូច ដែលឃើញថាល្អដល់ទ្រង់នោះឡើយ ។

២៩ ហេតុដូច្នោះហើយ ព្រោះអ្នករាល់គ្នាជាភ្នាក់ងារទាំងឡាយ បានជាអ្នករាល់គ្នាធ្វើការងាររបស់ព្រះអម្ចាស់; ហើយអ្វីក៏ដោយ ដែលអ្នករាល់គ្នាធ្វើ តាមព្រះហឫទ័យនៃព្រះអម្ចាស់នោះគឺជាធុរកិច្ចរបស់ព្រះអម្ចាស់ហើយ ។

៣០ ហើយព្រះអង្គបានតាំងអ្នកឡើង ដើម្បីផ្គត់ផ្គង់ដល់ពួកបរិសុទ្ធរបស់ទ្រង់ នៅគ្រាចុងក្រោយបង្អស់នេះ ប្រយោជន៍ឲ្យពួកគេអាច បាន[ក]កេរ្តិ៍មរតក នៅក្នុងដែនដីស៊ីយ៉ូន ។

៣១ ហើយមើលចុះ យើងជាព្រះអម្ចាស់ ប្រកាសប្រាប់ដល់អ្នក ហើយ[ក]ព្រះបន្ទូលទាំងឡាយរបស់យើងពិត ហើយនឹងមិន[ខ]ខាតបង់ឡើយ ថាពួកគេនឹងបានទទួលកេរ្តិ៍មរតក ។

៣២ ប៉ុន្តែគ្រប់ទាំងអស់ត្រូវតែកើតឡើង តាមពេលរបស់វា ។

៣៣ ហេតុដូច្នោះហើយ [ក]ចូរកុំណាយចិត្តនឹងធ្វើការល្អឡើយ ត្បិតអ្នករាល់គ្នាកំពុងតែដាក់គ្រឹះនៃកិច្ចការដ៏ធំ ។ ហើយចេញពី ការណ៍[ខ]ដ៏តូចតាច នោះបណ្ដាលឲ្យមានការណ៍ដ៏ធំផេងឡើង ។

៣៤ មើលចុះ ព្រះអម្ចាស់ទ្រង់[ក]តម្រូវ[ខ]ចិត្ត និងគំនិតដែល[គ]ស្ម័គ្រតាម; ហើយពួកដែលស្ម័គ្រចិត្តតាម ហើយស្ដាប់បង្គាប់ នឹងបានបរិភោគផល ល្អនៃដែនដីស៊ីយ៉ូន នៅគ្រាចុងក្រោយបង្អស់នេះ ។

៣៥ ហើយ[ក]ពួកបះបោរនឹងត្រូវបាន[ខ]កាត់ចេញពីដែនដីស៊ីយ៉ូន

២២ ក ស.ប. ទោស.
ខ និក្ខ. ៣៥:៥;
គ. និង ស. ៥៩:១៥; ៦៤:៣៤.
២៣ ក គ. និង ស. ៤៥:៦;
៦៤:២៤–២៥.
ខ ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
គ ស.ប. បូជា, យញ្ញបូជា.
ឃ ម៉ាឡាគី ៣:១០–១១.
ស.ប. ដង្វាយ១ភាគក្នុង១០, ការថ្វាយដង្វាយ១ភាគ ក្នុង១០.
ង ម៉ាឡាគី ៤:១; ៣ នីហ្វៃ ២៥:១;
យ.ស. — ប្រវត្តិ ១:៣៧.
២៤ ក អេសាយ ៦៦:១៥–១៦.
ស.ប. ផែនដី — ការសំអាតផែនដី;
ពិភពលោក — ចុងបំផុតនៃផែនដី.
ខ ម៉ាឡាគី ៣:១៥;
២ នីហ្វៃ ១២:១២; ២៣:១១.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
គ គ. និង ស. ១:១៦.
ស.ប. បាប៊ីឡូន.
២៦ ក ស.ប. វិតនី, នូវល ខេ.
ខ គ. និង ស. ៥៧:៨.
២៧ ក ស.ប. បំណុល.
៣០ ក គ. និង ស. ៦៣:៤៨.
៣១ ក ម៉ាកុស ១៣:៣១;
២ នីហ្វៃ ៣១:១៥;
គ. និង ស. ១:៣៧–៣៨.
ខ គ. និង ស. ៧៦:៣.
៣៣ ក កាឡាទី ៦:៩.
ខ គ. និង ស. ១២៣:១៦.
៣៤ ក មីកា ៦:៨.
ខ ចោទិ. ៣២:៤៦; យ៉ូស្វេ ២២:៥;
មរមន ៩:២៧.
ស.ប. ចិត្ត.
គ អេសាយ ១:១៩.
ស.ប. ការគោរព, ដែលគោរព, គោរព.
៣៥ ក ស.ប. ការបះបោរ.
ខ គ. និង ស. ៤១:៥;
៥០:៨–៩; ៥៦:៣.
ស.ប. ការកាត់ចេញពីសាសនា.

ហើយនឹងត្រូវបណ្ដេញចេញ ហើយនឹងមិនបានគ្រងផែនដីទុកជាមរតក ឡើយ ។

៣៦ ត្បិតយើងប្រាប់ជាប្រាកដថា ពួកបះបោរពុំមែនមកពីឈាម[ក]នៃអេប្រាអិមឡើយ ហេតុដូច្នោះហើយ ពួកគេនឹងត្រូវបោចចេញ ។

៣៧ មើលចុះ យើងជាព្រះអម្ចាស់ បានធ្វើសាសនាចក្ររបស់យើង នៅគ្រាចុងក្រោយបង្អស់នេះ ដូចជាចៅក្រមអង្គុយនៅលើភ្នំ ឬនៅលើកន្លែងខ្ពស់ ដើម្បីជំនុំជំរះសាសន៍ទាំងឡាយ ។

៣៨ ហើយហេតុការណ៍នឹងកើតឡើងថា បណ្ដាជននៃក្រុងស៊ីយ៉ូននឹង [ក]ជំនុំជំរះគ្រប់ទាំងអស់ ដែលទាក់ទងនឹងក្រុងស៊ីយ៉ូន ។

៣៩ ហើយពួកកំភូត និងពួកមានពុតទាំងឡាយ នឹងត្រូវផ្ចាញ់ផ្ចាលដោយពួកគេ ហើយពួកគេដែលពុំមែនជាពួក[ក]សាវក និងពួកព្យាការី នឹងត្រូវបានស្គាល់ ។

៤០ ហើយសូម្បីតែ[ក]ប៊ីស្សព ដែលជា[ខ]ចៅក្រមម្នាក់ និងទីប្រឹក្សាទាំងឡាយរបស់គាត់ បើសិនជាពួកគេមិនមានចិត្តស្មោះត្រង់ ក្នុង [គ]ការកាន់ កាប់ត្រួតត្រារបស់ខ្លួនទេ នោះនឹងត្រូវដាក់ទោស ហើយ[ឃ]អ្នកផ្សេងទៀតនឹងត្រូវដាក់ជំនួសពួកគេ ។

៤១ ត្បិតមើលចុះ យើងប្រាប់អ្នកថា [ក]ក្រុងស៊ីយ៉ូននឹងលូតលាស់ ហើយ[ខ]សិរីល្អនៃព្រះអម្ចាស់នឹងស្ថិតនៅលើក្រុងស៊ីយ៉ូន;

៤២ ហើយក្រុងស៊ីយ៉ូននឹងទៅជា[ក]ទង់ដល់ប្រជាជន ហើយនឹងមានមនុស្សមកក្រុងស៊ីយ៉ូន ចេញមកពីគ្រប់សាសន៍នៅក្រោមមេឃ;

៤៣ ហើយថ្ងៃនោះនឹងមកដល់ កាលសាសន៍ទាំងឡាយនៅលើផែនដីនឹង[ក]ភ័យញ័រ ពីព្រោះតែក្រុងស៊ីយ៉ូន ហើយនឹងខ្លាចពីព្រោះតែ ពួកដ៏ស្ញែងខ្លាចទាំងឡាយនៃក្រុងស៊ីយ៉ូន ។ ព្រះអម្ចាស់ទ្រង់បានមានបន្ទូលហើយ ។ អាម៉ែន ៕

## កណ្ឌទី ៦៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែតុលា ឆ្នាំ១៨៣១ (*History of the Church, *១:២១៨) ។ ព្យាការីសំគាល់វិវរណៈនេះថាជាបទអធិស្ឋាន ។*

*១–២, កូនសោទាំងឡាយនៃនគរព្រះត្រូវបានផ្ទុកផ្ដាក់ដល់មនុស្សនៅលើផែនដី ហើយគតិនៃដំណឹងល្អបន្តនឹងឈ្នះ; ៣–៦, នគរស្ថានសួគ៌ក្នុងសហស្សវត្សរ៍នឹងមកដល់ ហើយចូលរួមនឹងនគរព្រះនៅលើផែនដី ។*

ប្រុងស្ដាប់ ហើយមើលន៏ មានសម្លេងហាក់ដូចជាបានចាត់ឲ្យចុះមកពីស្ថានដ៏ខ្ពស់ ដែលមានឥទ្ធិឫទ្ធិ និងអំណាចដ៏ខ្លាំង ដែល ធ្វើដំណើរទៅដល់ទីបំផុតផែនដី មែនហើយ ជាសម្លេងដល់មនុស្សលោកថា — [ក]ចូររៀបចំផ្លូវទទួលព្រះអម្ចាស់ ចូរតម្រង់ផ្លូវតូច ថ្វាយទ្រង់ចុះ ។

២ [ក]កូនសោទាំងឡាយនៃនគរព្រះត្រូវបានផ្ទុកផ្ដាក់ដល់មនុស្សនៅលើផែនដី ហើយពីពេលនេះ[ខ]តទៅ ដំណឹងល្អនឹងត្រូវរមៀលចេញទៅ ដល់ទីបំផុតផែនដី ដូចជា[គ]ថ្មដែលដាច់ផ្ដាច់ចេញពីភ្នំ ឥតដៃណាធ្វើ នឹងរមៀលចេញទៅ រហូតដល់បាន[ឃ]ពេញផែនដីទាំងមូល ។

៣ មែនហើយ មានសម្លេងស្រែកថា — ចូររៀបចំផ្លូវទទួល

៣៦ *ក* ចោទិ. ៣៣:១៦–១៧.
៣៨ *ក* អេសាយ ២:៣–៤;
គ. និង ស. ១៣៣:២១.
៣៩ *ក* វិវរ. ២:២.
ស.ប. សាវក.
៤០ *ក* ស.ប. ប៊ីស្សព.
*ខ* គ. និង ស. ៥៨:១៧;
១០៧:៧២–៧៤.
*គ* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
*ឃ* គ. និង ស. ១០៧:៩៩–១០០.
៤១ *ក* ស.ប. ស៊ីយ៉ូន.
*ខ* គ. និង ស. ៤៥:៦៧; ៨៤:៤–៥;
៩៧:១៥–២០.
ស.ប. សិរីល្អ.
៤២ *ក* ស.ប. ទង់.
៤៣ *ក* អេសាយ ៦០:១៤;
គ. និង ស. ៩៧:១៩–២០.
**៦៥** ១ *ក* អេសាយ ៤០:៣;
ម៉ាថាយ ៣:៣; យ៉ូហាន ១:២៣.
២ *ក* ម៉ាថាយ ១៦:១៩;
គ. និង ស. ៤២:៦៩.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* គ. និង ស. ៩០:១–៥.
*គ* ដានី. ២:៣៤–៤៥.
*ឃ* ទំនុក. ៧២:១៩.
ស.ប. ដានីយ៉ែល — គម្ពីរដានីយ៉ែល;
គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.

ព្រះអម្ចាស់ ចូររៀបចំ[ក]ភោជនាហារទទួលកូនចៀម ចូររៀបចំជា
ស្រេច ចាំ[ខ]ប្ដីថ្មោងថ្មីចុះ ។
៤ ចូរអធិស្ឋានដល់ព្រះអម្ចាស់ ចូរអំពាវនាវដល់ព្រះនាមដ៏
បរិសុទ្ធរបស់ទ្រង់ ចូរប្រកាសប្រាប់ពីកិច្ចការដ៏អស្ចារ្យរបស់ទ្រង់
នៅក្នុងចំណោមប្រជាជនចុះ ។
៥ ចូរទូលដល់ព្រះអម្ចាស់ ប្រយោជន៍ឲ្យនគររបស់ទ្រង់ អាច
បានចេញទៅលើផែនដី ប្រយោជន៍ឲ្យបណ្ដាជននៅលើទីនោះ
អាចបាន ទទួលនគររបស់ទ្រង់ផង ហើយចូរប្រុងប្រៀបជា
ស្រេចចាំឲ្យថ្ងៃនោះមកដល់ [ក]ក្នុងកាលកូនមនុស្សនឹងចុះមកពី
ស្ថានសួគ៌ [ខ]បំពាក់ដោយ [គ]សិរីល្អរបស់ទ្រង់ក្នុងភាពភ្លឺថ្លា ដើម្បី
[ឃ]ទៅជួបនគរព្រះដែលតាំងនៅលើផែនដី ។
៦ ហេតុដូច្នោះហើយ សូម[ក]ឲ្យនគរព្រះបានចេញទៅ
ប្រយោជន៍ឲ្យ[ខ]នគរស្ថានសួគ៌អាចបានមកដល់ ប្រយោជន៍ឲ្យ
ព្រះអង្គ ឱព្រះអង្គអើយ អាចបានសិរីល្អនៅលើស្ថានសួគ៌
ព្រមទាំងនៅលើផែនដីផង ប្រយោជន៍ឲ្យពួកខ្មាំងសត្រូវ
របស់ទ្រង់អាចបានចាញ់; ត្បិតកិត្តិយស ព្រះចេស្ដា និងសិរីល្អ
[គ]ជារបស់ផងទ្រង់ដ៏អស់កល្បជានិច្ច និងរៀងដរាបតទៅ ។
អាម៉ែន ៕

## កណ្ឌទី ៦៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិអូរ៉េញ រដ្ឋអូហៃអូ ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៨៣១ (*History of the Church, *១:២១៩–២២១)* ។ *នេះជាថ្ងៃទីមួយនៃសន្និសីទដ៏សំខាន់មួយ ។ មុនវិវរណៈនេះ ព្យាការី បានសរសេរថាៈ «តាមសំណូមពររបស់ វិលលាម អ៊ី ម៉ុកឡេលិន នោះខ្ញុំបានសូមដល់ព្រះអម្ចាស់ ហើយបានទទួលដែលមានដូចតទៅនេះ» (*History of the Church, *១:២២០)* ។

*១–៤, សេចក្ដីសញ្ញាដ៏អស់កល្បអស់កាលជានិច្ចគឺជាភាពពោរពេញនៃដំណឹងល្អ; ៥–៨, ពួកអែលឌើរត្រូវទៅផ្សាយ ធ្វើទីបន្ទាល់ និងពិភាក្សាជាមួយប្រជាជន; ៩–១៣, ការបំរើខាងការឧបត្ថម្ភដ៏ស្មោះត្រង់ធានានូវមរតកខាងជីវិតដ៏នៅអស់កល្បជានិច្ច ។*

មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់ វិលលាម អ៊ី ម៉ុក
ឡេលិន ជាអ្នកបំរើរបស់យើងដូច្នេះថា — អ្នកមាន
ពរហើយ ដរាបណាអ្នក បានបែរចេញពីសេចក្ដីទុច្ចរិតទាំងឡាយ
របស់អ្នក ហើយបានទទួលសេចក្ដីពិតទាំងឡាយរបស់យើង ព្រះ
អម្ចាស់ ដ៏ជាព្រះប្រោសលោះ របស់អ្នក គឺជាព្រះអង្គសង្គ្រោះ
នៃពិភពលោកមានព្រះបន្ទូលថាដូច្នោះ គឺដល់មនុស្សទាំងឡាយ
ណាដែល[ក]ជឿដល់ព្រះនាមរបស់យើង ។
២ យើងប្រាប់អ្នកជាប្រាកដថា អ្នកមានពរហើយ ដែលបាន
ទទួលសេចក្ដីសញ្ញាដ៏[ក]អស់កល្បអស់កាលជានិច្ចរបស់យើង គឺជា
ភាពពោរ ពេញនៃដំណឹងល្អរបស់យើង ដែលបានចាត់ឲ្យចេញទៅ
ដល់កូនចៅមនុស្ស ប្រយោជន៍ឲ្យពួកគេអាចមាន[ខ]ជីវិត ហើយ
អាចបានធ្វើ ទៅជាពួកអ្នកមានចំណែកក្នុងសិរីល្អទាំងឡាយ
ដែលនឹងត្រូវបានបើកសំដែង នៅក្នុងគ្រាចុងក្រោយបង្អស់ ដូច
ដែលបានសេរសេរទុក ដោយពួកព្យាការី និងពួកសាវក
នៅសម័យបុរាណ ។
៣ យើងប្រាប់អ្នកជាប្រាកដ ឱ វិលលាម ជាអ្នកបំរើ
របស់យើងអើយ ថាអ្នកបានស្អាតហើយ ប៉ុន្តែពុំមែនទាំងអស់ទេ;
ហេតុដូច្នេះហើយ ចូរប្រែចិត្តពីការណ៍ទាំងនោះ ដែលមិនគាប់
ព្រះហឫទ័យដល់ព្រះនេត្ររបស់យើងទៅ ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលថាដូច្នោះ ត្បិតព្រះ អម្ចាស់ទ្រង់នឹង[ក]បង្ហាញដល់អ្នកហើយ ។
៤ ហើយឥឡូវនេះ ប្រាកដមែន យើងជាព្រះអម្ចាស់នឹងបង្ហាញ
ដល់អ្នក អំពីអ្វីដែលយើងមានព្រះហឫទ័យចំពោះអ្នក ឬក៏អំពីអ្វី
ដែល យើងនឹងមានព្រះហឫទ័យចំពោះអ្នក ។
៥ មើលចុះ យើងប្រាប់អ្នកជាប្រាកដ គឺជាព្រះហឫទ័យ
របស់យើង ថាអ្នកគប្បី[ក]ប្រកាសប្រាប់ដំណឹងល្អរបស់យើង

៣ *ក* ម៉ាថាយ ២២:១–១៤;
វិវរ. ១៩:៩; គ. និង ស. ៥៨:១១.
*ខ* ស.ប. ប្ដីថ្មោងថ្មី.
៥ *ក* ម៉ាថាយ ២៤:៣០.
*ខ* ទំនុក. ៩៣:១.
*គ* ស.ប. សិរីល្អ.
*ឃ* ដានី. ២:៤៤.
៦ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ខ* វិវរ. ១១:១៥.
*គ* ១ របា. ២៩:១១; ម៉ាថាយ ៦:១៣.
**៦៦** ១ *ក* យ៉ូហាន ១:១២.
ស.ប. ជំនឿ, ជឿ.
២ *ក* ស.ប. សេចក្ដីសញ្ញាថ្មី
ហើយអស់កល្បជានិច្ច.
*ខ* យ៉ូហាន ១០:១០;
៣ នីហ្វៃ ៥:១៣.
៣ *ក* យ៉ាកុប ៤:៧; អេធើរ ១២:២៧.
៥ *ក* ម៉ាកុស ១៦:១៥.

ពីដែនដីមួយទៅដែន ដីមួយ និងពីទីក្រុងមួយទៅទីក្រុងមួយ មែនហើយ គឺនៅក្នុងភូមិភាគជុំវិញទាំងនោះ ដែលពុំទាន់បានប្រកាសប្រាប់នៅឡើយ ។

៦ ចូរកុំនៅកន្លែងនេះច្រើនថ្ងៃពេក ចូរកុំទាន់ឡើងទៅឯដែនដីស៊ីយ៉ូនឡើយ ប៉ុន្តែដរាបណាអ្នកអាចបញ្ជូនទៅបាន ចូរបញ្ជូនទៅចុះ បើពុំនោះសាតទេ ចូរកុំគិតពីទ្រព្យសម្បត្តិរបស់អ្នកឡើយ ។

៧ ចូរទៅឯដែនដីទាំងឡាយនៅទិសខាងកើត ចូរថ្លែងទីបន្ទាល់នៅគ្រប់កន្លែង ប្រាប់ដល់គ្រប់ប្រជាជន និងនៅក្នុងសាលាប្រជុំទាំង ឡាយរបស់ពួកគេ ដោយពិភាក្សាជាមួយប្រជាជន ។

៨ ចូរឲ្យ សាំយូអែល អេច ស្ម៊ីធ ជាអ្នកបំរើរបស់យើង ទៅជាមួយអ្នកចុះ ហើយចូរកុំបោះបង់គាត់ចោលឡើយ ហើយចូរឲ្យដល់គាត់ នូវការបង្គាប់ទាំងឡាយរបស់អ្នកផង; ហើយអ្នកណាដែលមានចិត្តស្មោះត្រង់ នោះនឹងត្រូវបានធ្វើឲ្យខ្លាំងពូកែ នៅគ្រប់កន្លែង; ហើយ យើងជាព្រះអម្ចាស់នឹងយាងទៅជាមួយអ្នក ។

៩ ចូរដាក់ដៃអ្នកលើមនុស្សដែលមានជំងឺ ហើយពួកគេនឹងបានជាសះស្បើយ ។ ចូរកុំវិលទៅវិញឡើយ រហូតដល់យើងជា ព្រះអម្ចាស់នឹង ចាត់ឲ្យអ្នកទៅ ។ ចូរមានចិត្តអត់ធន់ក្នុងការឈឺចាប់ ។ ចូរសូម ហើយអ្នករាល់គ្នានឹងបានទទួល; ចូរគោះ ហើយតែង នឹងបើកឲ្យអ្នក រាល់គ្នា ។

១០ ចូរកុំស្វែងរកដើម្បីអំពល់ឡើយ ។ ចូរបោះបង់ចោលអស់ទាំងសេចក្ដីដ៏ឥតសុចរិត ។ ចូរកុំប្រព្រឹត្តអំពើកំផិតឡើយ — ជា សេចក្ដីល្បួងមួយដែលធ្លាប់ធ្វើឲ្យអ្នកមានកង្វល់ ។

១១ ចូរកាន់តាមពាក្យទាំងនេះ ត្បិតពាក្យទាំងនេះពិតហើយស្មោះត្រង់; ហើយអ្នកត្រូវដំកើងតំណែងរបស់ខ្លួន ហើយច្រានមនុស្ស ជាច្រើនទៅក្រុងស៊ីយ៉ូន ដោយសារចំរៀងទាំងឡាយអំពីសេចក្ដីអំណរដ៏អស់កល្បអស់កាលជានិច្ចពាក់លើក្បាលរបស់ពួកគេចុះ ។

១២ ចូរបន្តនៅក្នុងការណ៍ទាំងនេះ រហូតដល់ចុងបំផុតចុះ ហើយអ្នកនឹងបានជីវិតដ៏នៅអស់កល្បជានិច្ចជាមកុដ នៅខាងព្រះហស្តស្ដាំនៃព្រះវរបិតារបស់យើង ដែលពេញដោយព្រះគុណនិងសេចក្ដីពិត ។

១៣ ប្រាកដមែន ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ជាព្រះដ៏ប្រោសលោះរបស់អ្នក គឺព្រះយេស៊ូវគ្រីស្ទ ទ្រង់មានព្រះបន្ទូលថាដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៦៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែវិច្ឆិកា ឆ្នាំ១៨៣១ (*History of the Church*, ១:២២៤–២២៥) ។ នេះជាគ្រានៃសន្និសីទដ៏សំខាន់១ ហើយការបោះពុម្ពផ្សាយវិវរណៈ ទាំងឡាយដែលបានទទួលពីព្រះ អម្ចាស់ជាស្រេច តាមរយៈព្យាការីនោះត្រូវបានយកមកពិចារណាហើយអនុវត្ត (សូមមើលចំណងជើងនៃកណ្ឌទី ១) ។ គឺបានសំរេច ថា អូលីវើរ ខៅឌើរី និង យ៉ូហាន វិតមើរ ត្រូវយកឯកសារអំពីវិវរណៈទាំងឡាយ ទៅក្រុងអ៊ិនឌីប៉ែនដែនស៍ ជាទីដែលដ័បបុលយូ ដ័បបុលយូ ហ្វែប្ស នឹងបោះពុម្ពផ្សាយចេញជា* Book of Commandments *(ព្រះគម្ពីរនៃព្រះបញ្ញត្តិ) ។ បងប្អូនប្រុសៗភាគ ច្រើនបានថ្លែងទីបន្ទាល់យ៉ាងម៉ឺងម៉ាត់ថា វិវរណៈទាំងប៉ុន្មាន ដែលបានប្រមូលបង្រួមសំរាប់បោះពុម្ពផ្សាយ នោះសុទ្ធតែពិត ដូចជាបានធ្វើ បន្ទាល់ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតមកលើពួកគេ ។ ព្យាការីកត់ថា បន្ទាប់ពីបាននទទួលវិវរណៈដែលស្គាល់ថាជា កណ្ឌទីមួយ នោះមានការសន្ទនាជំទាស់មួយ អំពីរបៀបប្រើភាសានៅក្នុងវិវរណៈទាំងឡាយ ។ វិវរណៈនេះត្រូវបានទទួលដូចដែល មានតទៅនេះ ។*

៧ *ក* គ. និង ស. ៧៥:៦.
*ខ* ស.ប. ទីបន្ទាល់.
៨ *ក* គ. និង ស. ៥២:១៧; ១៣៣:៥៨.
៩ *ក* ស.ប. ការប្រសិទ្ធិពរដល់មនុស្សឈឺ; ដៃ, ការដាក់.
*ខ* ម៉ាថាយ ៩:១៨. ស.ប. ប្រោស, ការប្រោស.
*គ* យ៉ាកុប (ព.ស.ថ.) ១:៥.
១០ *ក* ស.ប. អំពើកំផិត.
១១ *ក* គ. និង ស. ៣៥:២៤.
*ខ* គ. និង ស. ១១:៦.
*គ* អេសាយ ៣៥:១០; គ. និង ស. ៤៥:៧១. ស.ប. ច្រៀង.
១២ *ក* ២ ធីម៉ូ. ៣:១៤–១៥; ២ នីហ្វៃ ៣១:២០.
*ខ* អេសាយ ៦២:៣; ម៉ាថាយ ២៥:២១; ១ ពេត្រុស ៥:៤.
១៣ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះរាជបុត្រា.

*១–៣, ព្រះអម្ចាស់ទ្រង់ឮពាក្យអធិស្ឋានទាំងឡាយនៃពួកអែលឌើរ ហើយទតមើលមកលើពួកគេ; ៤–៩, ទ្រង់ស្នើជនដ៏មានប្រាជ្ញាវាងវៃបំផុត ឲ្យសាកសរសេរវិវរណៈរបស់ទ្រង់តែមួយភាគតូចបំផុត ឲ្យបានគ្រាន់បើជាង; ១០–១៤, ពួកអែលឌើរដែលមានចិត្តស្មោះត្រង់ នឹងត្រូវបានប្រោសឲ្យរស់ឡើងវិញដោយសារព្រះវិញ្ញាណ ហើយមើលឃើញព្រះភក្ត្រានៃព្រះ ។*

មើលចុះ និងចូរប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្ររបស់យើង ដែលបានជួបជុំគ្នាអើយ ពាក្យអធិស្ឋានរបស់ ពួកគេយើងបានឮ ហើយដួងចិត្តរបស់ពួកគេយើងបានស្គាល់ ហើយសេចក្ដីប៉ងប្រាថ្នារបស់ពួកគេ បានឡើងមកចំពោះយើងហើយ ។

២ មើលចុះហើយមើលន៏ ភ្នែករបស់យើងកំពុងសម្លឹងមើលមកលើអ្នក ហើយផ្ទៃមេឃ និងផែនដីនៅក្នុងដៃរបស់យើង ហើយទ្រព្យសម្បត្តិទាំងឡាយនៃភាពអស់កល្បជានិច្ច គឺជារបស់ផងយើង ទុកសំរាប់ប្រទានឲ្យ ។

៣ អ្នករាល់គ្នាបានខំព្យាយាម ដើម្បីជឿថាអ្នករាល់គ្នាគប្បីបានទទួលព្រះពរ ដែលបានស្នើផ្ដល់ដល់អ្នក; ប៉ុន្តែមើលចុះ យើងប្រាប់អ្នកជា ប្រាកដថា មានសេចក្ដីខ្លាចនៅក្នុងចិត្តអ្នកទាំងឡាយ ហើយប្រាកដមែន នេះហើយជាហេតុដែលអ្នករាល់គ្នាពុំបានទទួល ។

៤ ហើយឥឡូវនេះ យើងជាព្រះអម្ចាស់ ប្រទានដល់អ្នកនូវទីបន្ទាល់មួយនៃសេចក្ដីពិត អំពីព្រះបញ្ញត្តិទាំងឡាយនេះ ដែលលាតនៅខាង មុខអ្នក ។

៥ ភ្នែករបស់អ្នកទាំងឡាយ បានសម្លឹងមើលមកលើ យ៉ូសែប ស្ម៊ីធ ជុញ្ញ៉រ ជាអ្នកបំរើរបស់យើង ហើយភាសារបស់លោក អ្នកក៏បានដឹង រីឯការមិនល្អឥតខ្ចោះរបស់លោក អ្នកក៏បានដឹង; ហើយអ្នកបានស្វែងរកដំរិះក្នុងចិត្តរបស់អ្នក ប្រយោជន៍ឲ្យអ្នកអាចថ្លែងបានប្រសើរ ជាងភាសារបស់លោក; ការណ៍នេះអ្នកក៏ដឹងផងដែរ ។

៦ ឥឡូវនេះ ចូរអ្នករាល់គ្នារកក្នុងព្រះគម្ពីរនៃព្រះបញ្ញត្តិ គឺមួយណាដែលតូចជាងគេបំផុត ហើយចូរតាំងអ្នកនោះដែលមានប្រាជ្ញាបំផុត ក្នុងចំណោមអ្នករាល់គ្នាចុះ;

៧ ឬក៏បើសិនជាមាននរណាមួយក្នុងចំណោមអ្នករាល់គ្នាដែលនឹងសរសេរវិវរណៈមួយឲ្យបានដូចវិវរណៈនោះ ខណៈនោះទើបអ្នក រាល់គ្នាបានរាប់ថាសុចរិត ក្នុងការនិយាយថា អ្នករាល់គ្នាមិនដឹងថាវិវរណៈទាំងនោះពិត;

៨ ប៉ុន្តែបើសិនជាអ្នករាល់គ្នាមិនអាចសរសេរមួយ ឲ្យបានដូចជាវិវរណៈនោះទេ អ្នករាល់គ្នាកំពុងតែនៅក្រោមសេចក្ដីដាក់ទោស បើសិនជាអ្នករាល់គ្នាមិនថ្លែងទីបន្ទាល់ ថាវិវរណៈទាំងនោះពិត ។

៩ ត្បិតអ្នករាល់គ្នាដឹងថា គ្មានសេចក្ដីឥតសុចរិតនៅក្នុងវិវរណៈទាំងនោះឡើយ ហើយអ្វីដែលសុចរិត នោះសុទ្ធតែមកពីស្ថានលើ គឺមកពីព្រះវរបិតានៃពន្លឺ ។

១០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា គឺជាឯកសិទ្ធិរបស់អ្នក ហើយជាសេចក្ដីសន្យាដែលយើងប្រទានដល់អ្នកដែលបាន តែងតាំងចំពោះការងារបំរើនេះ ដើម្បីជរាបណាអ្នកកំចាត់ខ្លួនចេញពីសេចក្ដីច្រណែន និងសេចក្ដីខ្លាច ហើយបន្ទាបខ្លួននៅចំពោះ យើង ត្បិតអ្នករាល់គ្នាពុំបានបន្ទាបខ្លួនឲ្យបានគ្រប់គ្រាន់ឡើយ នោះវាំងនននឹងត្រូវរហែក ហើយអ្នកនឹងបានឃើញយើង ហើយដឹងថា យើងជាព្រះ — ពុំមែនដោយគំនិតខាងរូបកាយ ឬខាងសាច់ឈាមទេ ប៉ុន្តែខាងវិញ្ញាណវិញ ។

១១ ត្បិតគ្មានមនុស្សណាមួយបានឃើញព្រះនៅក្នុងសាច់ឈាមនៅពេលណាមួយឡើយ លើកលែងតែបានប្រោសឡើង ដោយព្រះ វិញ្ញាណនៃព្រះប៉ុណ្ណោះ ។

១២ ហើយគ្មានមនុស្សខាងសាច់ឈាមណាមួយ អាចនៅក្នុងវត្តមាននៃព្រះបានទេ ឬតាមគំនិតខាងរូបកាយបានឡើយ ។

១៣ អ្នករាល់គ្នាពុំអាចនៅក្នុងវត្តមាននៃព្រះបានឡើយនៅពេលនេះ ឬក៏ការងារបំរើនៃពួកទេវតាដែរ; ហេតុដូច្នោះហើយ

**៦៧** ១*ក* ស.ប. អែលឌើរ.
២ *ក* ទំនុក. ៣៤:១៥.
៣ *ក* ស.ប. សេចក្ដីកោតខ្លាច.
៤ *ក* ស.ប. ទីបន្ទាល់; សេចក្ដីពិត.
៥ *ក* គ. និង ស. ១:២៤.
៦ *ក* ២ នីហ្វៃ ៩:២៨–២៩, ៤២.
៨ *ក* ស.ប. សាក្សី.
៩ *ក* មរ៉ូណៃ ៧:១៥–១៨.
*ខ* យ៉ាកុប (ព.ស.ថ.) ១:១៧; គ. និង ស. ៥០:២៤; ៨៤:៤៥; ៨៨:៤៩.
១០ *ក* ស.ប. ប្រច័ណ្ឌ, សេចក្ដីប្រច័ណ្ឌ.
*ខ* ស.ប. សេចក្ដីកោតខ្លាច.
*គ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ឃ* ស.ប. វាំងនន.
*ង* គ. និង ស. ៨៨:៦៨; ៩៣:១; ៩៧:១៦.
១១ *ក* ក.យ.ស., និក្ខ. ៣៣:២០, ២៣; យ៉ូហាន ១:១៨; ៦:៤៦; ក.យ.ស., ១ យ៉ូហាន ៤:១២; គ. និង ស. ៨៤:១៩–២២; ម៉ូសេ ១:១១, ១៤.
១២ *ក* ម៉ូសាយ ៣:១៩. ស.ប. មនុស្សខាងសាច់ឈាម.

ចូរស៊ូនៅ ក្នុងសេចក្ដីអត់ធន់ចុះ រហូតដល់អ្នករាល់គ្នាបាន
ល្អឥតខ្ចោះ ។
១៤ ចូរកុំបែរគំនិតរបស់អ្នកទៅវិញឡើយ ហើយកាលណា
អ្នករាល់គ្នាបានសក្ដិសម តាមពេលដែលយើងកំណត់ នោះអ្នក
រាល់គ្នា នឹងបានឃើញហើយដឹងនូវអ្វី ដែលបានប្រគល់មកលើ
អ្នក ដោយសារដៃនៃ យ៉ូសែប ស្ម៊ីធ ជុញ៉រ ជាអ្នកបំរើ
របស់យើង ។ អាម៉ែន ៕

## កណ្ឌទី ៦៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែវិច្ឆិកា ឆ្នាំ១៨៣១ តាមសំណូមពរពី អ្ហ្សុន ហៃឌ, លូកា អែស ចនសុន, ឡៃម៉ាន អ៊ី ចនសុន, និង វិលលាម អ៊ី ម៉ុកឡេលិន (*History of the Church, *១:២២៧–២២៩) ។ ទោះជាវិវរណៈនេះត្រូវបានប្រទានឲ្យមក ទុកជាចម្លើយដល់ការទូលអង្វរ សូមឲ្យបានស្គាល់គំនិតនៃព្រះអម្ចាស់ អំពីពួកអែលឌើរ ដែលបានពោលដល់នោះក៏ដោយ គង់តែពាក្យពេចន៍ទាំងនោះ ទាក់ទងទៅនឹងសាសនាចក្រទាំងមូលដែរ ។*

*១–៥, ពាក្យពេចន៍នៃពួកអែលឌើរគឺជាបទគម្ពីរ ក្នុងកាលបានបណ្ដាលដោយសារព្រះវិញ្ញាណបរិសុទ្ធ; ៦–១២, ពួកអែលឌើរត្រូវ ទៅផ្សាយ ហើយធ្វើបុណ្យជ្រមុជទឹក ហើយទីសំគាល់ទាំងឡាយនឹងជាប់តាមអស់អ្នកដែលជឿពិត; ១៣–២៤, កូនច្បងក្នុងចំណោម កូនប្រុសទាំងឡាយរបស់អើរ៉ុន អាចបំរើជាប៊ីស្សពដ៏ជាអធិបតី (នោះគឺជាប៊ីស្សពដែលកាន់កូនសោទាំងឡាយនៃគណៈប្រធាន) នៅក្រោមការដឹកនាំពីគណៈប្រធានទីមួយ; ២៥–២៨, ពួកឪពុកម្ដាយត្រូវបញ្ជាឲ្យបង្រៀនដំណឹងល្អដល់កូនចៅរបស់ខ្លួន; ២៩–៣៥, ពួក បរិសុទ្ធត្រូវប្រព្រឹត្តតាមថ្ងៃឈប់សំរាក ធ្វើការងារដោយមានចិត្តព្យាយាម ហើយអធិស្ឋាន ។*

អ្ហ្សុន ហៃឌ ជាអ្នកបំរើរបស់យើង ត្រូវបានហៅដោយការ
តែងតាំងរបស់គាត់ ដើម្បីប្រកាសប្រាប់ដំណឹងល្អដ៏អស់កល្ប
អស់កាលជា និច្ច ដោយសារព្រះវិញ្ញាណនៃព្រះដ៏មានព្រះជន្ម
រស់នៅ ពីប្រជាជនមួយទៅប្រជាជនមួយ និងពីដែនដីមួយ
ទៅដែនដីមួយ នៅក្នុង ក្រុមជំនុំទាំងឡាយនៃពួកទុច្ចរិត នៅក្នុង
សាលាប្រជុំទាំងឡាយរបស់ពួកគេ ដោយពិភាក្សាជាមួយពួក
គេ ហើយបរិយាយគ្រប់បទគម្ពីរ ដល់ពួកគេ ។
២ ហើយមើលចុះ និងមើលន៏ នេះគឺជាគំរូមួយដល់អស់អ្នក
ណា ដែលបានតែងតាំងចំពោះបព្វជិតភាពនេះ រីឯបេសកម្មរបស់
ពួកគេគឺ ត្រូវបានចាត់ឲ្យពួកគេចេញទៅ —
៣ ហើយនេះគឺជាគំរូមួយដល់ពួកគេ ប្រយោជន៍ឲ្យពួក
គេនិយាយ ដូចដែលបានបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ ។
៤ ហើយអ្វីក៏ដោយដែលពួកគេនឹងនិយាយ កាលណាបណ្ដាល
ដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាបទគម្ពីរ នឹងទៅជាព្រះ
ហឫទ័យនៃព្រះអម្ចាស់ នឹងទៅជាគំនិតនៃព្រះអម្ចាស់ នឹងទៅជា
ព្រះបន្ទូលនៃព្រះអម្ចាស់ នឹងទៅជាសម្លេងនៃព្រះអម្ចាស់ ហើយ
ជាព្រះចេស្ដានៃព្រះ ចំពោះសេចក្ដីសង្គ្រោះ ។
៥ មើលចុះ ឱអ្នករាល់គ្នា ជាពួកអ្នកបំរើរបស់យើងអើយ
នេះហើយជាសេចក្ដីសន្យានៃព្រះអម្ចាស់ដល់អ្នក ។
៦ ហេតុដូច្នោះហើយ ចូរសង្ឃឹមឡើង ហើយចូរកុំខ្លាចឡើយ
ត្បិតយើងជាព្រះអម្ចាស់ គង់នៅជាមួយនឹងអ្នក ហើយនឹង
ឈរនៅក្បែរអ្នក; ហើយអ្នកនឹងថ្លែងទីបន្ទាល់អំពីយើង គឺព្រះ
យេស៊ូវគ្រីស្ទ ថាយើងជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្ម
រស់នៅ ថាយើងគង់នៅ តាំងពីដើម ហើយយើងនៅឥឡូវនេះ
ហើយថាយើងត្រូវយាងមកទៀត ។
៧ នេះគឺជាព្រះបន្ទូលនៃព្រះអម្ចាស់ដល់អ្នក អ្ហ្សុន ហៃឌ ជា
អ្នកបំរើរបស់យើង ព្រមទាំងដល់ លូកា ចនសុន ជាអ្នកបំរើ
របស់យើងផង និងដល់ ឡៃម៉ាន ចនសុន ជាអ្នកបំរើរបស់យើង

១៣ *ក* រ៉ូម ២:៧.
ស.ប. សេចក្ដីអត់ធន់.
*ខ* ម៉ាថាយ ៥:៤៨;
៣ នីហ្វៃ ១២:៤៨.
១៤ *ក* ស.ប. សក្ដិសម, ភាពសក្ដិសម.

**៦៨** ១ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៣ *ក* ២ ពេត្រុស ១:២១;
គ. និង ស. ១៨:៣២;
៤២:១៦; ១០០:៥.
៤ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ; វិវរណៈ.
៤ *ខ* រ៉ូម ១:១៦.
៦ *ក* អេសាយ ៤១:១០.
៧ *ក* ស.ប. ហៃឌ, អ្ហ្សុន.

និងដល់ វិលលាម អ៊ី ម៉ុកឡែលិន ជាអ្នកបំរើរបស់យើង និងដល់អស់ទាំងពួកអែលឌើរ ដែលមានចិត្តស្មោះត្រង់នៃសាសនាចក្ររបស់យើង —

៨ ចូរអ្នករាល់គ្នា[ក]ទៅពេញសព្វក្នុងលោកិយទាំងមូល [ខ]ផ្សាយដំណឹងល្អទៅដល់[គ]គ្រប់សត្វលោកទាំងអស់ ដោយធ្វើការដោយនូវ[ឃ]សិទ្ធិ អំណាច ដែលយើងបានប្រទានដល់អ្នក ដោយ[ង]ធ្វើបុណ្យជ្រមុជទឹក ដោយនូវព្រះនាមនៃព្រះវរបិតា និងព្រះរាជបុត្រា ហើយនិងព្រះ វិញ្ញាណបរិសុទ្ធចុះ ។

៩ ហើយអ្នកណា[ក]ដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងត្រូវបាន[ខ]សង្គ្រោះ ហើយអ្នកណាដែលមិនជឿសោះ នោះនឹងត្រូវ[គ] ជាប់ទោស ។

១០ ហើយអ្នកណាដែលជឿ នោះនឹងបានពរ ដោយមាន[ក]ទីសំគាល់ទាំងឡាយជាប់តាមពីក្រោយ គឺដូចដែលបានសរសេរទុកនោះ ហើយ ។

១១ ហើយចំពោះអ្នក គឺនឹងត្រូវបានប្រទានឲ្យបានស្គាល់[ក]ទីសំគាល់ទាំងឡាយ អំពីសម័យកាល និងទីសំគាល់ទាំងឡាយ អំពីការយាង មកនៃកូនមនុស្ស;

១២ ហើយមនុស្សទាំងឡាយណាដែលព្រះវរបិតានឹងធ្វើទីបន្ទាល់ដល់ នោះនឹងមានអំណាចប្រទានដល់អ្នកដើម្បី[ក]ភ្ជាប់ពួកគេទៅដល់ ជីវិតដ៏នៅអស់កល្បជានិច្ច ។ អាម៉ែន ។

១៣ ហើយឥឡូវនេះ ស្ដីអំពីរឿងផ្សេងៗថែមទៅនឹងសេចក្ដីសញ្ញា និងព្រះបញ្ញត្តិទាំងឡាយ រឿងទាំងនោះគឺថា —

១៤ មានពីពេលនេះតទៅ នៅក្នុងពេលកំណត់នៃព្រះអម្ចាស់ ត្រូវមាន[ក]ប៊ីស្សពផ្សេងៗទៀត ដែលត្រូវញែកចេញចំពោះសាសនាចក្រ ដើម្បីបំរើដូចជាប៊ីស្សពទីមួយដែរ;

១៥ ហេតុដូច្នោះហើយ ពួកគេត្រូវជាពួក[ក]សង្ឃជាន់ខ្ពស់ដែលសក្ដិសម ហើយពួកគេត្រូវបានតែងតាំង ដោយ[ខ]គណៈប្រធានទីមួយ ក្នុងបព្វជិតភាពម៉ិលគីស្សាដែក លើកលែងតែពួកគេត្រូវជា[គ]ពូជពង្សនៃលោកអើរ៉ុនពិត ។

១៦ ហើយបើសិនជាពួកគេជា[ក]ពូជពង្សនៃលោកអើរ៉ុនពិតមែន នោះពួកគេមានសិទ្ធិពេញច្បាប់ចំពោះគណៈប៊ីស្សព បើសិនជាពួកគេត្រូវ ជាកូនច្បង ក្នុងចំណោមកូនប្រុសទាំងឡាយរបស់លោកអើរ៉ុន;

១៧ ត្បិតកូនច្បងកាន់នូវសិទ្ធិនៃគណៈប្រធានលើបព្វជិតភាពនេះ និង[ក]កូនសោទាំងឡាយ ឬសិទ្ធិអំណាចនៃបព្វជិតភាពនេះដែរ ។

១៨ [ក]គ្មានមនុស្សណាម្នាក់មានសិទ្ធិពេញច្បាប់ចំពោះតំណែងនេះ ដើម្បីកាន់កូនសោទាំងឡាយនៃបព្វជិតភាពនេះឡើយ លើកលែងតែ អ្នកនោះជាពូជពង្ស និងជាកូនច្បងនៃលោកអើរ៉ុនពិតប៉ុណ្ណោះ ។

១៩ ប៉ុន្តែ ដូចជា[ក]សង្ឃជាន់ខ្ពស់នៃបព្វជិតភាពម៉ិលគីស្សាដែកមានសិទ្ធិអំណាចដើម្បីធ្វើការ ក្នុងតំណែងតូចជាងក៏ដោយ គង់តែអ្នកនោះ អាចធ្វើការក្នុងតំណែងជា[ខ]ប៊ីស្សពបានដែរ កាលណាមិនអាចរកបានពូជពង្សនៃលោកអើរ៉ុនពិត ឲ្យតែអ្នកនោះត្រូវបានហៅ ហើយញែកចេញ និងតែងតាំងដល់អំណាចនេះ នៅក្រោមដៃនៃគណៈប្រធានទីមួយ ក្នុងបព្វជិតភាពម៉ិលគីស្សាដែក ។

២០ ហើយឯពូជពង្សនៃលោកអើរ៉ុនពិតក៏ត្រូវបាន[ក]ញែកចេញដោយគណៈប្រធាននេះដែរ ហើយឲ្យឃើញថាសក្ដិសម និងលាប និង[ខ]តែងតាំង នៅក្រោមដៃនៃគណៈប្រធាននេះ បើពុំនោះសោតទេ ពួកគេពុំបានអនុញ្ញាត ដោយពេញច្បាប់ ដើម្បីធ្វើការក្នុងបព្វជិតភាព របស់ពួកគេឡើយ ។

២១ ប៉ុន្តែ ដោយគុណធម៌នៃបញ្ញត្តិស្ដីអំពីសិទ្ធិនៃបព្វជិតភាពរបស់ពួកគេ ចុះពីឪពុកមកដល់កូនប្រុសនោះ ពួកគេអាចទាមទារការលាប របស់ពួកគេបាន បើសិនជាពេលណាមួយពួកគេអាចបញ្ជាក់ពីពូជពង្សរបស់ពួកគេបានមែន ឬតាមការ

៨ ក គ. និង ស. ១:២; ៦៣:៣៧.
ខ ស.ប. កិច្ចការផ្សាយសាសនា; ផ្សាយ.
គ ម៉ាកុស ១៦:១៥.
ឃ ស.ប. សិទ្ធិអំណាច.
ង ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
៩ ក ម៉ាកុស ១៦:១៦; គ. និង ស. ២០:២៥.
ខ ស.ប. សេចក្ដីសង្គ្រោះ.
គ ស.ប. សេចក្ដីជាប់ទោស.
១០ ក ស.ប. ទីសំគាល់.
១១ ក ស.ប. ទីសំគាល់អំពីពេលវេលា.
១២ ក គ. និង ស. ១:៨; ១៣២:៤៩. ស.ប. ភ្ជាប់, ការភ្ជាប់.
១៤ ក ស.ប. ប៊ីស្សព.
១៥ ក គ. និង ស. ៧២:១.
ខ ស.ប. គណៈប្រធានទី១.
គ ស.ប. អើរ៉ុន, បងប្រុសរបស់ម៉ូសេ.
១៦ ក គ. និង ស. ១០៧:១៥–១៧. ស.ប. បព្វជិតភាពអើរ៉ុន.
១៧ ក ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
១៨ ក និក្ខ. ៤០:១២–១៥; គ. និង ស. ៨៤:១៨; ១០៧:១៣–១៦, ៧០–៧៦.
១៩ ក ស.ប. សង្ឃជាន់ខ្ពស់.
ខ ស.ប. ប៊ីស្សព.
២០ ក ស.ប. ចាក់ប្រេង.
ខ ស.ប. តែងតាំង, ការតែងតាំង.

បញ្ជាក់ដោយវិវរណៈពីព្រះអម្ចាស់ នៅក្រោមដៃនៃគណៈប្រធានតាមឈ្មោះខាងលើនេះ ។

២២ ហើយជាថ្មីទៀត គ្មានប៊ីស្សព ឬសង្ឃជាន់ខ្ពស់ណាដែលបានញែកចេញសំរាប់ការងារបំរើនេះ ត្រូវកាត់ក្ដី ឬដាក់ទោសចំពោះ អំពើឧក្រិដ្ឋណាមួយឡើយ លើកលែងតែនៅចំពោះគណៈប្រធានទីមួយនៃសាសនាចក្រនេះប៉ុណ្ណោះ;

២៣ ហើយដរាបណាគេរកឃើញថាអ្នកនោះ មានទោសនៅចំពោះគណៈប្រធាននេះមែន ដោយសារទីបន្ទាល់ដែលគ្មានការសង្ស័យ អ្នកនោះត្រូវដាក់ទោស;

២៤ ហើយបើសិនជាគាត់ប្រែចិត្ត អ្នកនោះនឹងត្រូវបានអត់ទោសតាមសេចក្ដីសញ្ញា និងបញ្ញត្តិទាំងឡាយនៃសាសនាចក្រ ។

២៥ ហើយជាថ្មីទៀត ដរាបណាឪពុកម្ដាយមានកូនចៅនៅក្នុងក្រុងស៊ីយ៉ូន ឬនៅក្នុងស្ដេកណាមួយដែលបានរៀបចំឡើងក្ដី ដែលពុំបាន បង្រៀនកូនចៅឲ្យយល់នូវគោលលទ្ធិអំពីការប្រែចិត្ត សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និងអំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ កាលមានអាយុ៨ឆ្នាំទេ នោះអំពើបាបនឹងធ្លាក់មកលើក្បាលរបស់ឪពុកម្ដាយវិញ ។

២៦ ហើយនេះត្រូវទៅជាក្រិត្យវិន័យដល់បណ្ដាជននៃក្រុងស៊ីយ៉ូន ឬនៅក្នុងស្ដេកណាមួយដែលបានរៀបចំឡើង ។

២៧ ហើយកូនចៅរបស់ពួកគេត្រូវទទួលបុណ្យជ្រមុជទឹកសំរាប់ការផ្ដាច់បាបទាំងឡាយរបស់ខ្លួន កាលមានអាយុប្រាំបីឆ្នាំ ហើយទទួលការដាក់ដៃលើ ។

២៨ ហើយពួកគេក៏ត្រូវបង្រៀនកូនចៅរបស់ខ្លួន ឲ្យអធិស្ឋាន និងឲ្យដើរដោយទៀងត្រង់ នៅចំពោះព្រះអម្ចាស់ ។

២៩ ហើយបណ្ដាជននៃក្រុងស៊ីយ៉ូនក៏ត្រូវគោរពថ្ងៃឈប់សំរាកដើម្បីញែកថ្ងៃនោះទុកជាបរិសុទ្ធ ។

៣០ ហើយបណ្ដាជននៃក្រុងស៊ីយ៉ូនក៏ត្រូវចងចាំពីការងារទាំងឡាយរបស់ពួកគេដែរ ដរាបណាដែលពួកគេត្រូវបានចាត់ឲ្យធ្វើការ ដោយនូវអស់ទាំងសេចក្ដីស្មោះត្រង់; ត្បិតមនុស្សខ្ជិលច្រអូសនឹងត្រូវបានចងចាំទុក នៅចំពោះព្រះអម្ចាស់ ។

៣១ ឥឡូវនេះ យើងជាព្រះអម្ចាស់ មិនសព្វព្រះហឫទ័យនឹងបណ្ដាជននៃក្រុងស៊ីយ៉ូនឡើយ ត្បិតពួកគេជាមនុស្សខ្ជិលច្រអូស នៅក្នុងចំណោមពួកគេ; ហើយកូនចៅរបស់ពួកគេក៏កំពុងធំឡើងក្នុងអំពើទុច្ចរិតដែរ; ពួកគេក៏មិនព្យាយាមស្វែងរកទ្រព្យសម្បត្តិទាំងឡាយខាង ភាពអស់កល្បជានិច្ចដែរ ប៉ុន្តែភ្នែកទាំងឡាយរបស់ពួកគេពោរពេញទៅដោយភាពលោភលន់វិញ ។

៣២ ការណ៍ទាំងនេះមិនគួរគប្បីឲ្យមានឡើយ ហើយត្រូវកំចាត់ពីចំណោមពួកគេចេញ; ហេតុដូច្នោះហើយ ចូរឲ្យ អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង នាំពាក្យទាំងនេះទៅប្រាប់ដែនដីស៊ីយ៉ូនចុះ ។

៣៣ ហើយយើងប្រទានបញ្ញត្តិមួយដល់ពួកគេ — ថាអ្នកណាដែលមិនគោរពតាមបទអធិស្ឋានរបស់ខ្លួន នៅចំពោះព្រះអម្ចាស់ នៅក្នុងរដូវនោះទេ ចូរឲ្យអ្នកនោះបាននៅក្នុងការចងចាំនៅចំពោះចៅក្រមនៃប្រជារាស្ត្ររបស់យើងចុះ ។

៣៤ ពាក្យទាំងនេះពិតហើយស្មោះត្រង់; ហេតុដូច្នោះហើយ ចូរកុំរំលងពាក្យទាំងនេះ ឬក៏ដកអ្វីចេញពីពាក្យទាំងនេះឡើយ ។

៣៥ មើលចុះ យើងជាអាលផា និងអូមេកា ហើយយើងយាងមកជាឆាប់ ។ អាម៉ែន ៕

២២ *ក* ស.ប. គណៈប្រធានទី១.
២៤ *ក* ស.ប. អត់ទោស, អភ័យទោស.
២៥ *ក* ស.ប. គ្រួសារ — កាតព្វកិច្ចរបស់ឪពុកម្ដាយ.
*ខ* ស.ប. ចំរឹង, ស្ដេក.
*គ* ស.ប. បង្រៀន, គ្រូបង្រៀន.
*ឃ* គ. និង ស. ១៨:៤២; ២០:៧១.
*ង* យ៉ាកុប (ពៗម.) ១:១៩; គ. និង ស. ២៩:៤៦–៤៨.
២៦ *ក* ស.ប. ស៊ីយ៉ូន.
២៧ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. ការផ្ដាច់បាប.
*គ* ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
២៨ *ក* ស.ប. ការអធិស្ឋាន.
២៩ *ក* គ. និង ស. ៥៩:៩–១២. ស.ប. ថ្ងៃឈប់សំរាក.
៣១ *ក* ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
*ខ* ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
*គ* គ. និង ស. ៦:៧.
៣៣ *ក* ស.ប. ការអធិស្ឋាន.
*ខ* ស.ប. វាយផ្ចាល, ការវាយផ្ចាល; ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
៣៤ *ក* វិវរ. ២២:៦.
*ខ* គ. និង ស. ២០:៣៥; ៩៣:២៤–២៥.
៣៥ *ក* ស.ប. អាលផា និងអូមេកា.
*ខ* គ. និង ស. ១:១២.

## កណ្ឌទី ៦៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅគូមីហែរាំ រដ្ឋអូហៃអូ ខែវិច្ឆិកា ឆ្នាំ១៨៣១ (*History of the Church*, ១:២៣៤–២៣៥) ។ ការប្រមូលផ្ដុំនៃវិវរណៈទាំងឡាយដែលបំរុងសំរាប់បោះពុម្ពផ្សាយលើកមុន នោះត្រូវបានអនុម័ត នៅឯសន្និសិទពិសេសនៅថ្ងៃទី១ ខែវិច្ឆិកា ។ នៅថ្ងៃទី៣ ខែវិច្ឆិកា វិវរណៈនេះលេចចេញមកជាកណ្ឌទី ១៣៣ គឺត្រូវបានបញ្ចូល ហើយហៅថាជាបរិសិដ្ឋ ។ ដោយសារកិច្ចការខាងសន្និសិទ អូលីវើរ ខៅឌើរី ត្រូវបានចាត់ឲ្យកាន់ឯកសារនៃវិវរណៈ និងព្រះបញ្ញត្តិ ទាំងឡាយ ដែលបានប្រមូលផ្ដុំទៅក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី សំរាប់បោះពុម្ពផ្សាយ ។ គាត់ក៏ត្រូវយកប្រាក់ដែលបានដាក់វិភាគ ទានសំរាប់ស្ថាបនាសាសនាចក្រឡើង នៅរដ្ឋមិសសួរី ។ មកពីផ្លូវធ្វើដំណើរត្រូវនាំគាត់ដើរកាត់ស្រុកដែលមិនសូវមានមនុស្សនៅ ទៅដល់ព្រំប្រទល់ នោះបានជាគួរឲ្យមានគូកនធ្វើដំណើរជាមួយ ។*

*១–២, យ៉ូហាន វិតមើរ ត្រូវទៅមិសសួរីជាមួយ អូលីវើរ ខៅឌើរី; ៣–៨, គាត់ក៏ត្រូវផ្សាយ ហើយប្រមូល កត់បញ្ជី និងសរសេរ ទិន្នន័យខាងប្រវត្តិសាស្ត្រផងដែរ ។*

ប្រុងស្ដាប់យើង ព្រះអម្ចាស់ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលដូច្នោះថា ដោយគិតដល់ អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើងចុះ ។ គឺមិនមែនជា ប្រាជ្ញានៅក្នុងយើងទេ ដែលគាត់ត្រូវបានផ្ទុកផ្ដាក់ដោយព្រះបញ្ញត្តិ និងប្រាក់កាសទាំងឡាយ ដែលគាត់ត្រូវកាន់ទៅដែនដីស៊ីយ៉ូន លើក លែងតែមាននរណាម្នាក់ទៅជាមួយគាត់ ដែលនឹងបានទៅជាមនុស្សពិត ហើយស្មោះត្រង់ ។

២ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់សព្វព្រះហឫទ័យចង់ឲ្យ យ៉ូហាន វិតមើរ ជាអ្នកបំរើរបស់យើង គួរទៅជាមួយ អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង;

៣ ហើយក៏ចង់ឲ្យគាត់គួរបន្តនូវការសរសេរ និងការកត់ប្រវត្តិ អំពីការណ៍ដ៏សំខាន់ៗទាំងឡាយ ដែលគាត់នឹងសង្កេតមើល ហើយដឹង ពីសាសនាចក្ររបស់យើង;

៤ ហើយក៏ចង់ឲ្យគាត់ទទួលការទូន្មាន និងជំនួយពី អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង និងពីអ្នកផ្សេងៗទៀតផង ។

៥ ហើយពួកអ្នកបំរើរបស់យើងដែលកំពុងនៅពាសពេញលើផែនដី ក៏ត្រូវផ្ញើដំណើររឿងទាំងឡាយ អំពីការកាន់កាប់ត្រួតត្រារបស់ ពួកគេ ទៅឯដែនដីស៊ីយ៉ូនផងដែរ;

៦ ត្បិតដែនដីស៊ីយ៉ូននឹងត្រូវទៅជាវេទិកា និងកន្លែង ដើម្បីទទួលហើយប្រព្រឹត្តអស់ទាំងការណ៍ទាំងនេះ ។

៧ ទោះជាយ៉ាងណាក៏ដោយ ចូរឲ្យ យ៉ូហាន វិតមើរ ជាអ្នកបំរើរបស់យើង ធ្វើដំណើរជាច្រើនដងពីកន្លែងមួយទៅកន្លែងមួយ ហើយពី សាសនាចក្រមួយទៅសាសនាចក្រមួយ ប្រយោជន៍ឲ្យគាត់អាចបានទទួលដំរិះថែមទៀតដោយងាយៗ —

៨ ការផ្សាយ និងការបរិយាយ ការសរសេរ ការចំឡង ការជ្រើសរើស និងការទទួលគ្រប់ទាំងអស់ ដែលនឹងទៅជាការល្អដល់ សាសនាចក្រ និងដល់តំណមនុស្សមានវ័យធំឡើង ដែលនឹងធំឡើងនៅលើដែនដីស៊ីយ៉ូន ដើម្បីបានដែនដីនេះ ពីតំណមួយទៅតំណមួយ ដល់អស់ កល្បជានិច្ច និងរៀងដរាបតទៅ ។ អាម៉ែន ៕

## កណ្ឌទី ៧០

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៨៣១ (*History of the Church*, ១:២៣៥–២៣៧) ។ ប្រវត្តិដែលបានសរសេរដោយព្យាការី ថ្លែងប្រាប់ថាសន្និសិទដ៏ពិសេសៗ ទាំងបួនត្រូវបានធ្វើឡើងពីថ្ងៃទី១ទៅថ្ងៃទី១២ ក្នុងខែវិច្ឆិកាទាំងស្រុង ។ នៅក្នុងការប្រជុំចុងក្រោយបង្អស់ទាំងនេះ ការសំខាន់ដ៏ធំនៃ A Book of Commandments (ព្រះគម្ពីរនៃព្រះបញ្ញត្តិ) ក្រោយមកហៅថា គោលលទ្ធិ និងសេចក្ដីសញ្ញា ត្រូវបានយកមកពិ ចារណា; ហើយព្យាការីហៅព្រះគម្ពីរនៃព្រះបញ្ញត្តិថាជា «មូលដ្ឋាននៃសាសនាចក្រនៅគ្រាចុងក្រោយបង្អស់នេះ*

៦៩ ១*ក* ស.ប. ខៅឌើរី, អូលីវើរ.
២ *ក* ស.ប. វិតមើរ, យ៉ូហាន.
៣ *ក* គ. និង ស. ៤៧:១–៣; ៨៥:១.
៤ *ក* ស.ប. ពាក្យទូន្មាន (ន.).
៥ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
៨ *ក* ស.ប. ស៊ីយ៉ូន.

*ហើយជា ផលប្រយោជន៍ដល់ពិភពលោក ដោយបង្ហាញថាកូនសោនៃសេចក្ដីអាថ៌កំបាំងទាំងឡាយក្នុងនគររបស់ព្រះអង្គសង្គ្រោះរបស់យើង ត្រូវបានផ្ទុកផ្ដាក់ ដល់មនុស្សទៀតហើយ» (*History of the Church, *១:២៣៥*) ។

*១–៥, ពួកអ្នកកាន់កាប់ត្រួតត្រាត្រូវបានចាត់ឲ្យបោះពុម្ពផ្សាយវិវរណៈទាំងឡាយ; ៦–១៣, ពួកអ្នកទាំងនោះដែលធ្វើការនូវអ្វីៗខាងវិញ្ញាណ សមនឹងបានឈ្នួលរបស់ខ្លួន; ១៤–១៨, ពួកបរិសុទ្ធគួរបានស្មើគ្នាក្នុងអ្វីៗខាងសាច់ឈាម ។*

មើលចុះ ហើយចូរប្រុងស្ដាប់ ឱអ្នករាល់គ្នាជាបណ្ដាជននៅក្រុងស៊ីយ៉ូន និងអស់អ្នករាល់គ្នា ជារាស្ត្រនៃសាសនាចក្ររបស់យើង ដែលនៅឆ្ងាយអើយ ហើយចូរឮព្រះបន្ទូលនៃព្រះអម្ចាស់ ដែលយើងនឹងប្រទានដល់ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង និងដល់ ម៉ាទិន ហារិស ជាអ្នកបំរើរបស់យើងផង និងដល់ អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើងផង និងដល់ យ៉ូហាន វិតមើរ ជាអ្នកបំរើរបស់យើងផង និងដល់ ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើងផង និងដល់ វិលលាម ដ័បុលយូ ហ្វែប្ស ជាអ្នកបំរើរបស់យើងផង តាមបញ្ញត្តិ ដល់ពួកគេ ។

២ ត្បិតយើងប្រទានព្រះបញ្ញត្តិមួយដល់ពួកគេ; ហេតុដូច្នោះហើយ ចូរប្រុងស្ដាប់ ហើយឮចុះ ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់ពួក គេដូច្នោះថា —

៣ យើងជាព្រះអម្ចាស់បានចាត់ពួកគេ ហើយបានតែងតាំងពួកគេឲ្យធ្វើជា[ក]អ្នកកាន់កាប់ត្រួតត្រាលើវិវរណៈ និងព្រះបញ្ញត្តិទាំងឡាយ ដែលយើង បានប្រទានដល់ពួកគេ ហើយដែលយើងនឹងប្រទានដល់ពួកគេពីពេលនេះតទៅ;

៤ ហើយដំណើររឿងអំពីការកាន់កាប់ត្រួតត្រានេះ យើងនឹងតម្រូវពីពួកគេ នៅក្នុងថ្ងៃជំនុំជំរះ ។

៥ ហេតុដូច្នោះហើយ យើងបានចាត់ដល់ពួកគេ ហើយនេះគឺជាមុខងាររបស់ពួកគេ នៅក្នុងសាសនាចក្រនៃព្រះ គឺដើម្បីចាត់ចែង ការណ៍ទាំងនោះ និងរឿងរ៉ាវទាំងនោះ មែនហើយ គឺផលប្រយោជន៍ដែលបានមកពីការណ៍ទាំងនោះ ។

៦ ហេតុដូច្នោះហើយ យើងប្រទានព្រះបញ្ញត្តិមួយដល់ពួកគេ ប្រយោជន៍កុំឲ្យពួកគេឲ្យការណ៍ទាំងនេះដល់សាសនាចក្រ ឬដល់ពិភព លោកឡើយ;

៧ ទោះជាយ៉ាងណាក៏ដោយ ដរាបណាពួកគេទទួលបានអ្វីច្រើនជាងដែលចាំបាច់ ដើម្បីសេចក្ដីត្រូវការរបស់ពួកគេ និងចំណង់របស់ ពួកគេ នោះត្រូវឲ្យទៅ[ក]ឃ្លាំងរបស់យើង;

៨ ហើយផលទាំងប៉ុន្មានត្រូវថ្វាយដល់បណ្ដាជននៅក្រុងស៊ីយ៉ូន និងដល់តំណទាំងឡាយរបស់ពួកគេ ដរាបណាពួកគេត្រឡប់ជា[ក]អ្នកគ្រងមរតក តាមក្រិត្យវិន័យទាំងឡាយនៃនគរ ។

៩ មើលចុះ នេះហើយជាអ្វីដែលព្រះអម្ចាស់ទ្រង់តម្រូវពីមនុស្សរាល់គ្នា នៅក្នុង[ក]ការកាន់កាប់ត្រួតត្រារបស់ខ្លួន គឺដូចជាយើងជាព្រះអម្ចាស់បានចាត់ ឬនឹងចាត់ដល់មនុស្សណាមួយពីពេលនេះតទៅ ។

១០ ហើយមើលចុះ គ្មាននរណាមួយរួចពីក្រិត្យវិន័យនេះឡើយ ដែលជាសមាជិកក្នុងសាសនាចក្រនៃព្រះដ៏មានព្រះជន្មរស់នៅ;

១១ មែនហើយ ទោះបីជាប៊ីស្សព ឬ[ក]ភ្នាក់ងារដែលរក្សាឃ្លាំងរបស់ព្រះអម្ចាស់ ឬអ្នកណាដែលត្រូវបានតែងតាំងឡើងក្នុងការ កាន់កាប់ត្រួតត្រាលើការណ៍ខាងសាច់ឈាមនោះឡើយ ។

១២ អ្នកណាដែលត្រូវបានតែងតាំងឡើងឲ្យចាត់ចែងការណ៍ខាងវិញ្ញាណ អ្នកនោះហើយដែល[ក]សមនឹងបានឈ្នួលរបស់ខ្លួន គឺដូចជាពួកអ្នកដែលត្រូវបានតែងតាំងឡើងដល់ការកាន់កាប់ត្រួតត្រា ដើម្បីចាត់ចែងក្នុងការណ៍ខាងសាច់ឈាមដែរ;

១៣ មែនហើយ គឺមានជាបរិបូរឡើង ជាភាពបរិបូរណ៍ដែលបន្ថែមដល់ពួកគេ តាមរយៈការសំដែងនៃព្រះវិញ្ញាណ ។

១៤ ទោះជាយ៉ាងណាក៏ដោយ រីឯអ្វីៗរបស់អ្នកខាងសាច់ឈាម នោះអ្នកត្រូវបាន[ក]ស្មើគ្នា ហើយនេះពុំមែនដោយច្រណែនទេ បើពុំនោះសោតទេ ភាពបរិបូរណ៍ខាងការសំដែងនៃព្រះវិញ្ញាណ នឹងត្រូវទុក ។

១៥ ឥឡូវនេះ យើង[ក]ប្រទានព្រះបញ្ញត្តិនេះដល់ពួកអ្នកបំរើ

**៧០** ៣*ក* ១ កូរិន. ៤:១;
គ. និង ស. ៧២:២០.
៧ *ក* គ. និង ស. ៧២:៩–១០.
៨ *ក* គ. និង ស. ៣៨:២០.
៩ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
១១ *ក* គ. និង ស. ៥៧:៦.
១២ *ក* លូកា ១០:៧.
១៤ *ក* គ. និង ស. ៤៩:២០. ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
១៥ *ក* ចោទិ. ១០:១២–១៣.

របស់យើង សំរាប់ជាផលប្រយោជន៍ដល់ពួកគេ ក្នុងកាលពួក
គេរស់នៅ សំរាប់ជាការសំដែងអំពីព្រះពរទាំងឡាយរបស់យើង
មកលើក្បាលរបស់ពួកគេ និងសំរាប់ជារង្វាន់ចំពោះ[ខ]ការព្យាយាម
របស់ពួកគេ និងសំរាប់សន្តិសុខរបស់ពួកគេ;
១៦ សំរាប់អាហារ និងសំរាប់[ក]សំលៀកបំពាក់; សំរាប់កេរ្ដិ៍មរតក;
សំរាប់ផ្ទះសំបែង និងសំរាប់ដីធ្លីទាំងឡាយ ទោះជានៅក្នុង
កាលៈទេសៈណាមួយក៏ដោយ ដែលយើងជាព្រះអម្ចាស់នឹង
ដាក់ពួកគេ និងទោះជាទីកន្លែងណាក៏ដោយ ដែលយើងជាព្រះ
អម្ចាស់នឹង ចាត់ឲ្យពួកគេទៅ ។
១៧ ត្បិតពួកគេមានចិត្តស្មោះលើរបស់[ក]ជាច្រើន ហើយបាន
ប្រព្រឹត្តយ៉ាងល្អ ដរាបណាដែលពួកគេមិនបានធ្វើបាប ។
១៨ មើលចុះ [ក]យើងជាព្រះអម្ចាស់ មានសេចក្ដីមេត្តាករុណា
ហើយនឹងប្រទានពរដល់ពួកគេ ហើយពួកគេនឹងបានចូលក្នុងសេច
ក្ដីអំណរ នៃរបស់ទាំងនេះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៧១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅភូមិហៃរាំ រដ្ឋអូហៃអូ ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៨៣១ (*History of the Church*, ១:២៣៨–២៣៩) ។ ព្យាការីបានបន្តការបកប្រែព្រះគម្ពីរប៊ីប ដោយមាន ស៊ីឌនី រិកដុន ជាស្មៀន រហូតដល់បានទទួល វិវរណៈនេះ កាលនោះត្រូវបានឈប់បកប្រែមួយរយៈសិន ដើម្បីឲ្យពួកគេអាចបំពេញការបង្គាប់ ដែលមាននៅក្នុង វិវរណៈនេះ ។ បងប្អូនប្រុសៗត្រូវចេញទៅផ្សាយ ដើម្បីសម្ងប់អារម្មណ៍មិនស្និទស្នាល ដែលបានកើតឡើងទាស់នឹង សាសនាចក្រ មកពី ការបោះពុម្ពផ្សាយនៃអត្ថបទខ្លះៗ ចុះកាសែតដោយ អែសរ៉ា ប៊ូត ដែលបានក្បត់សាសនា ។*

*១–៤, យ៉ូសែប ស៊្មីធ និង ស៊ីឌនី រិកដុន ត្រូវបាន ចាត់ឲ្យចេញទៅប្រកាសប្រាប់ពីដំណឹងល្អ; ៥–១១, ពួកខ្មាំង សត្រូវនៃពួកបរិសុទ្ធនឹងត្រូវ បានបំភាន់ ។*

មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក យ៉ូសែប ស៊្មីធ
ជុញ្ញ័រ និង [ក]ស៊ីឌនី រិកដុន ជាពួកអ្នកបំរើរបស់យើងដូច្នេះថា
ពេលបានមក ដល់ជាប្រាកដមែន ដែលជាសេចក្ដីត្រូវការ[ខ] និងចាំ
បាច់ក្នុងយើង ដែលអ្នកត្រូវបើកមាត់របស់អ្នក ក្នុងការប្រកាស
ប្រាប់ពីដំណឹងល្អរបស់ យើង ពីការណ៍ទាំងឡាយនៃនគរ ដោយ
បរិយាយប្រាប់ពី[គ]សេចក្ដីអាថ៌កំបាំងនៃនគរ ចេញពីបទគម្ពីរ តាម
ចំណែកនៃព្រះវិញ្ញាណ និងព្រះ ចេស្ដានោះ ដែលនឹងត្រូវបាន
ប្រទានដល់អ្នក ដូចដែលយើងសព្វព្រះហឫទ័យ ។
២ យើងប្រាប់អ្នកជាប្រាកដថា ចូរប្រកាសប្រាប់ដល់ពិភពលោក
នៅក្នុងភូមិភាគជុំវិញ និងនៅក្នុងសាសនាចក្រផង សំរាប់មួយ
រដូវ គឺរហូតដល់បានប្រាប់ឲ្យដឹងដល់អ្នក ។
៣ ប្រាកដមែន នេះជាបេសកកម្មមួយរដូវ ដែលយើងប្រទាន
ដល់អ្នក ។
៤ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាធ្វើការនៅក្នុងចំការ
ទំពាំងបាយជូររបស់យើងចុះ ។ ចូរហៅបណ្ដាជននៅលើផែនដី
ហើយ ធ្វើទីបន្ទាល់ ហើយរៀបចំផ្លូវ សំរាប់ព្រះបញ្ញត្តិ
និងវិវរណៈទាំងឡាយ ដែលនឹងមកដល់ ។
៥ ឥឡូវនេះ មើលចុះ នេះហើយជាប្រាជ្ញា; អស់អ្នកណាដែល
អាន ចូរអ្នកនោះ[ក]យល់ ហើយ[ខ]ទទួលយកផងចុះ;
៦ ត្បិតចំពោះអ្នកណាដែលទទួល នោះនឹងបានប្រទានឲ្យមាន
ជា[ក]បរិបូរឡើង គឺអំណាច ។
៧ ហេតុដូច្នោះហើយ ចូរ[ក]បំភាន់ពួកខ្មាំងសត្រូវរបស់អ្នកចុះ;
ចូរហៅពួកគេ[ខ]ឲ្យមកជួបអ្នកបើកមុខ និងដោយសម្ងាត់;
ហើយដរាបណា អ្នករាល់គ្នាមានចិត្តស្មោះត្រង់ នោះសេច
ក្ដីអាម៉ាស់របស់ពួកគេនឹងត្រូវបានសំដែងឲ្យឃើញ ។
៨ ហេតុដូច្នោះហើយ ចូរឲ្យពួកគេនាំមកនូវដើមហេតុដ៏ធ្ងន់មក
ទាស់នឹងព្រះអម្ចាស់ចុះ ។
៩ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក
ដូច្នេះថា — គ្មានគ្រឿង[ក]សស្ត្រាវុធណាមួយដែលបានធ្វើឡើង
នឹងអាចទាស់ នឹងអ្នក បានឡើយ;

១៥ *ខ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
១៦ *ក* គ. និង ស. ៥៩:១៦–២០.
១៧ *ក* ម៉ាថាយ ២៥:២១–២៣.
១៨ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.

**៧១** ១ *ក* ស.ប. រិកដុន, ស៊ីឌនី.
*ខ* ស.ប. កិច្ចការផ្សាយសាសនា.
*គ* គ. និង ស. ៤២:៦១, ៦៥.
៥ *ក* ស.ប. យោបល់.
*ខ* អាលម៉ា ១២:៩–១១.

៦ *ក* ម៉ាថាយ ១៣:១២.
៧ *ក* ម៉ូសេ ៧:១៣–១៧.
*ខ* គ. និង ស. ៦៣:៣៧; ៦៨:៨–៩.
៩ *ក* អេសាយ ៥៤:១៧.

១០ ហើយបើសិនជាមានមនុស្សណាមួយបន្លឺសម្លេងឡើងទាស់នឹងអ្នក អ្នកនោះនឹងត្រូវបានបំភាន់ តាមពេលដែលយើងកំណត់ ។
១១ ហេតុដូច្នោះហើយ ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងចុះ; ព្រះបញ្ញត្តិទាំងឡាយរបស់យើងសុទ្ធតែពិតហើយស្មោះត្រង់ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៧២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៨៣១ (*History of the Church, *១:២៣៩–២៤១)* ។ *ពួកអែលឌើរ និងសមាជិកជាច្រើនបានជួបជុំគ្នា ដើម្បីរៀនពីភារកិច្ចរបស់ពួកគេ និងដើម្បី បានស្អាងតទៅទៀត ក្នុងការបង្រៀនទាំងឡាយនៃសាសនាចក្រ ។ កណ្ឌនេះជាការប្រមូលផ្ដុំនៃវិវរណៈពីរ ដែលបានទទួលនៅថ្ងៃ ដដែល ។ ខ ១ ទៅ ខ ៨ ប្រាប់ឲ្យដឹងអំពីការងាររបស់ នូវែល ខេ វិតនី ជាប៊ីស្សព ។ នៅពេលនោះ គាត់ត្រូវបានហៅហើយតែងតាំង បន្ទាប់មក ទើបបានទទួលពី ខ៩ ទៅ ខ២៦ ដោយប្រាប់ពត៌មានតទៅទៀត អំពីភារកិច្ចទាំងឡាយរបស់ប៊ីស្សព ។*

*១–៨, ពួកអែលឌើរត្រូវឲ្យដំណើររឿងអំពីការកាន់កាប់ត្រួតត្រារបស់ពួកគេដល់ប៊ីស្សព; ៩–១៥, ប៊ីស្សពរក្សាឃ្លាំង ហើយថែរក្សា មនុស្សទ័លក្រ និងមនុស្សកំសត់ទុគ៌ត; ១៦–២៦, ប៊ីស្សពត្រូវបញ្ជាក់នូវភាពសក្ដិសមនៃពួកអែលឌើរ ។*

ប្រុងស្ដាប់ ហើយស្ដាប់ដល់សម្លេងនៃព្រះអម្ចាស់ចុះ ឱអ្នករាល់គ្នាដែលបានជួបជុំគ្នា ដែលជាពួកសង្ឃជាន់ខ្ពស់នៃសាសនាចក្រ របស់យើង ជាអ្នកដែលត្រូវបានប្រទាននគរ និងអំណាចដល់នោះអើយ ។
២ ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលជាប្រាកដថា គឺជាការចាំបាច់ដល់យើង សំរាប់ឲ្យមានប៊ីស្សពមួយតែងតាំងឡើងចំពោះអ្នក ឬអំពី អ្នកចំពោះសាសនាចក្រ នៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូររបស់ព្រះអម្ចាស់ ។
៣ ហើយជាប្រាកដមែន អ្នករាល់គ្នាបានសំរេចដោយមានប្រាជ្ញាវាងវៃ នៅក្នុងការណ៍នេះ ត្បិតព្រះអម្ចាស់តម្រូវពីដៃនៃអ្នកកាន់កាប់ ត្រួតត្រាគ្រប់រូប ដើម្បីឲ្យដំណើររឿងអំពីការកាន់កាប់ត្រួតត្រារបស់ខ្លួន ព្រមទាំងក្នុងវេលាកាល និងក្នុងភាពអស់កល្បជានិច្ចផងដែរ ។
៤ ត្បិតអ្នកណាដែលស្មោះត្រង់ហើយឈ្លាសវៃក្នុងវេលាកាលនោះរាប់ថាសមនឹងបានគ្រងវិមានទាំងឡាយទុកជាមរតក ដែលបាន រៀបចំទុកសំរាប់អ្នកនោះដោយព្រះវរបិតា ។
៥ យើងប្រាប់អ្នកជាប្រាកដថា ពួកអែលឌើរនៃសាសនាចក្ររបស់យើង នៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូររបស់យើងនឹងឲ្យ ដំណើររឿងអំពីការកាន់កាប់ត្រួតត្រារបស់ខ្លួនដល់ប៊ីស្សពដែលនឹងត្រូវបានតែងតាំងឡើងដោយយើង នៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូររបស់យើង ។
៦ ការណ៍ទាំងនេះនឹងត្រូវមានក្នុងបញ្ជីកត់ទុក ដើម្បីប្រគល់ដល់ប៊ីស្សពក្នុងក្រុងស៊ីយ៉ូន ។
៧ ហើយភារកិច្ចនៃប៊ីស្សពនឹងត្រូវបានប្រាប់ឲ្យដឹង ដោយសារព្រះបញ្ញត្តិទាំងឡាយ ដែលបានប្រទានមក និងដោយសារសម្លេងនៃ សន្និសីទ ។
៨ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា នូវែល ខេ វិតនី ជាអ្នកបំរើរបស់យើង គឺជាបុរសដែលនឹងត្រូវតាំង និងតែងតាំងចំពោះ អំណាចនេះ ។ នេះគឺជាព្រះហឫទ័យនៃព្រះអម្ចាស់ ជាព្រះរបស់អ្នក ជាព្រះដ៏ប្រោសលោះរបស់អ្នក ។ គឺដូច្នោះមែន ។ អាម៉ែន ។
៩ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ បន្ថែមទៅនឹងក្រិត្យវិន័យ ដែលបានប្រទានមក ដោយប្រាប់ឲ្យដឹងនូវភារកិច្ចនៃប៊ីស្សព ដែល

**៧២** ១*ក* គ. និង ស. ៦៨:១៤–១៩.
*ខ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
២ *ក* ស.ប. ប៊ីស្សព.
៣ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
*ខ* គ. និង ស. ៤២:៣២; ១០៤:១១–១៣.
*គ* លូកា ១៩:១១–២៧.
៤ *ក* ម៉ាថាយ ២៤:៤៥–៤៧.
*ខ* គ. និង ស. ៥៩:២.
៥ *ក* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
៧ *ក* គ. និង ស. ៤២:៣១; ៤៦:២៧; ៥៨:១៧–១៨; ១០៧:៨៧–៨៨.
៨ *ក* ស.ប. វិតនី, នូវែល ខេ.

បានតែង តាំងដល់សាសនាចក្រ នៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូរ គឺប្រាកដជាយ៉ាងនេះថា —

១០ ដើម្បីរក្សាឃ្លាំង[ក]របស់ព្រះអម្ចាស់; ដើម្បីទទួលមូលនិធិទាំងឡាយនៃសាសនាចក្រ នៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូរ;

១១ ដើម្បីទទួលដំណើររឿងពីពួក[ក]អែលឌើរ ដូចជាបានបញ្ជាពីមុនមកហើយ; និងដើម្បីចាត់ចែងដល់សេចក្ដីត្រូវការទាំងឡាយរបស់ពួកគេ ដែលនឹងបង់សំរាប់អ្វីដែលពួកគេបានទទួលដរាបណាដែលពួកគេមានដើម្បីបង់;

១២ ប្រយោជន៍ឲ្យការណ៍នេះអាចបានថ្វាយដល់ការល្អនៃសាសនាចក្រ គឺដល់មនុស្សទ័លក្រ និងមនុស្សកំសត់ទុគ៌ត ។

១៣ ហើយអ្នកណាដែល[ក]ពុំមានដើម្បីបង់ ត្រូវមានបញ្ជីមួយកត់ទុក ហើយឲ្យទៅប៊ីស្សពនៃក្រុងស៊ីយ៉ូន ដែលនឹងបង់បំណុលចេញពីអ្វី ដែលព្រះអម្ចាស់នឹងដាក់ក្នុងដៃរបស់គាត់ ។

១៤ ហើយការងារទាំងឡាយនៃពួកស្មោះត្រង់ ដែលធ្វើការងារខាងវិញ្ញាណ ក្នុងការចាត់ចែងដំណឹងល្អ និងការណ៍ទាំងឡាយនៃ នគរចំពោះសាសនាចក្រ និងចំពោះពិភពលោកនោះនឹងបង់បំណុលដល់ប៊ីស្សពនៅក្រុងស៊ីយ៉ូន ។

១៥ ម្ល៉ោះហើយ សំណងនោះយកចេញមកពីសាសនាចក្រ ត្បិតតាមក្រិត្យ[ក]វិន័យ មនុស្សគ្រប់រូបដែលឡើងមកក្រុងស៊ីយ៉ូនត្រូវដាក់របស់ទាំងអស់នៅចំពោះប៊ីស្សពនៅក្រុងស៊ីយ៉ូន ។

១៦ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា មកពីអែលឌើរគ្រប់រូបនៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូរ ត្រូវឲ្យដំណើររឿង អំពីការកាន់កាប់ត្រួតត្រារបស់ខ្លួនដល់ប៊ីស្សព នៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូរ —

១៧ ប័ណ្ណ[ក]ពីចៅក្រម ឬប៊ីស្សពនៅក្នុងផ្នែកនេះនៃចំការទំពាំងបាយជូរ ជូនដល់ប៊ីស្សពនៅក្រុងស៊ីយ៉ូន ប្រាប់ឲ្យទទួលស្គាល់មនុស្សនោះ ថាសក្តិសម ហើយឆ្លើយចំពោះការណ៍គ្រប់យ៉ាង សំរាប់ជាកេរ្ដិ៍មរតក និងដើម្បីឲ្យបានទទួលស្គាល់ថាជាអ្នក[ខ]កាន់កាប់ត្រួតត្រាដ៏ឈ្លាសវៃ ហើយជាអ្នកធ្វើការដោយស្មោះត្រង់;

១៨ បើពុំនោះសោតទេ អ្នកនោះនឹងមិនត្រូវទទួលស្គាល់ដោយប៊ីស្សពនៃក្រុងស៊ីយ៉ូនឡើយ ។

១៩ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យអែលឌើរគ្រប់រូបដែលនឹងឲ្យដំណើររឿងដល់ប៊ីស្សពនៃសាសនាចក្រ នៅក្នុងផ្នែកនៃចំការទំពាំងបាយជូរនេះ បានអនុសាសដោយសាសនាចក្រ ឬសាសនាចក្រទាំងឡាយ ជាទីដែលអ្នកនោះធ្វើការប្រយោជន៍ឲ្យអ្នកនោះបណ្ដាលឲ្យខ្លួន និងដំណើររឿងរបស់ខ្លួនបានអនុម័ត នៅគ្រប់ការណ៍ទាំងអស់ ។

២០ ហើយជាថ្មីទៀត ចូរឲ្យពួកអ្នកបំរើរបស់យើងណា ដែលបានតាំងឲ្យធ្វើជាអ្នកកាន់កាប់ត្រួតត្រាលើកាតព្វកិច្ច[ក]ខាងការសរសេរ នៃសាសនាចក្ររបស់យើង បានជំនួយពីប៊ីស្សព ឬពួកប៊ីស្សព នៅគ្រប់ទាំងអស់ —

២១ ប្រយោជន៍ឲ្យវិវរណៈ[ក]ទាំងឡាយអាចបានបោះពុម្ពផ្សាយហើយចេញទៅដល់ទៅចុងបំផុតផែនដី; ប្រយោជន៍ឲ្យពួកគេអាចបាន មូលនិធិទាំងឡាយ ដែលនឹងទៅជាផលប្រយោជន៍ដល់សាសនាចក្រ នៅគ្រប់ទាំងអស់ផង;

២២ ប្រយោជន៍ឲ្យពួកគេអាចបានប្រគល់ខ្លួន ឲ្យបានអនុម័តនៅគ្រប់ទាំងអស់ ហើយបានរាប់ថាជាពួកអ្នកកាន់កាប់ត្រួតត្រាដ៏ឈ្លាស វៃផងដែរ ។

២៣ ហើយឥឡូវនេះ មើលចុះ នេះត្រូវទៅជាគំរូដល់អស់ទាំងសាខាទូទៅនៃសាសនាចក្ររបស់យើង ទោះជានៅដែនដីណាក៏ដោយដែលពួកគេបានតាំងឡើង ។ ហើយឥឡូវនេះ យើងបញ្ចប់ការនិយាយរបស់យើងសិនហើយ ។ អាម៉ែន ។

២៤ មានពាក្យបន្ថិចបន្តួចទៀតដល់ក្រិត្យវិន័យទាំងឡាយនៃនគរ ដែលទាក់ទងទៅនឹងពួកសមាជិកនៃសាសនាចក្រ — ពួកគេដែល ត្រូវបានតែង[ក]តាំងដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យឡើងទៅឯដែនដីស៊ីយ៉ូន និងពួកគេដែលមានឯកសិទ្ធិ ដើម្បីឡើងទៅឯដែនដី ស៊ីយ៉ូនថា —

២៥ ចូរឲ្យពួកគេកាន់ប័ណ្ណឡើងទៅជូនប៊ីស្សព ពីពួកអែលឌើរបីនាក់នៃសាសនាចក្រ ឬក៏ប័ណ្ណពីប៊ីស្សព;

២៦ បើពុំនោះសោតទេ អ្នកណាដែលនឹងឡើងទៅឯដែនដីស៊ីយ៉ូន នោះនឹងមិនត្រូវបានរាប់ថាជាអ្នកកាន់កាប់ត្រួតត្រាដ៏ឈ្លាសវៃ ឡើយ ។ នេះក៏ជាគំរូដែរ ។ អាម៉ែន ៕

១០ *ក* គ. និង ស. ៧០:៧–១១; ៧៨:៣.
ស.ប. ឃ្លាំង.
១១ *ក* គ. និង ស. ៧៥:២៤.
១៣ *ក* ស.ប. មនុស្សក្រីក្រ.
១៥ *ក* គ. និង ស. ៤២:៣០–៣១.
ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ.
១៧ *ក* គ. និង ស. ២០:៦៤, ៨៤.
*ខ* គ. និង ស. ៤២:៣២.
២០ *ក* គ. និង ស. ៧០:៣–៥.
២១ *ក* ស.ប. គោលលទ្ធិ និងសេចក្ដីសញ្ញា.
២៤ *ក* ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ.

## កណ្ឌទី ៧៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅភូមិហៃរ៉ាំ រដ្ឋអូហៃអូ ថ្ងៃទី១០ ខែមករា ឆ្នាំ១៨៣២ (*History of the Church*, ១:២៤១–២៤២) ។ ចាប់តាំងពីដើមខែធ្នូដែលកន្លងផុតមក នោះព្យាការី និងស៊ីឌនី រិកដុនត្រូវបានជាប់រវល់ក្នុងការផ្សាយ ហើយដោយសារមាគ៌ានេះ ទើបបានសំរេចនូវការស្ងប់អារម្មណ៍មិនស្និទស្នាល ដែលបានកើតឡើង ទាស់នឹងសាសនាចក្រ (សូមមើលចំណងជើងកណ្ឌទី ៧១) ។*

*១–២, ពួកអែលឌើរត្រូវផ្សាយតទៅទៀត; ៣–៦, យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន ត្រូវបកប្រែព្រះគម្ពីរប៊ីបតទៅទៀត រហូតដល់បកប្រែរួច ។*

ព្រោះតែប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា គឺជាការចាំបាច់ដល់យើង ដែលពួកគេត្រូវបន្តការផ្សាយដំណឹងល្អ និងក្នុងការ ទូន្មានដល់សាសនាចក្រទាំងឡាយ នៅក្នុងភូមិភាគជុំវិញ រហូតដល់មានសន្និសីទ;

២ ហើយខណៈនោះ មើលចុះ គឺនឹងបានធ្វើឲ្យដឹងដល់ពួកគេ ដោយសារសំឡេងនៃសន្និសីទ អំពីបេសកកម្មរបស់ពួកគេរៀងៗខ្លួន ។

៣ ឥឡូវនេះ ប្រាកដមែន យើងប្រាប់ដល់អ្នក យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និង ស៊ីឌនី រិកដុន ជាពួកអ្នកបំរើរបស់យើងអើយ ព្រះអម្ចាស់ទ្រង់ មានព្រះបន្ទូលថា គឺជាការចាំបាច់ត្រូវបកប្រែម្ដងទៀត;

៤ ហើយដរាបណាដែលអាចធ្វើទៅបាន ត្រូវផ្សាយនៅក្នុងភូមិភាគជុំវិញ រហូតដល់មានសន្និសីទ; ហើយបន្ទាប់ពីនោះ គឺជាការចាំបាច់ ត្រូវបន្តកិច្ចការបកប្រែ រហូតដល់បកប្រែរួច ។

៥ ហើយចូរឲ្យការណ៍នេះទៅជាគំរូដល់ពួកអែលឌើរ រហូតដល់បានដំរិះថែមទៀត ដូចាដែលបានសរសេរទុក ។

៦ ឥឡូវនេះ យើងមិនប្រទានដល់អ្នកទៀតទេនៅពេលនេះ ។ ចូរក្រវាត់ចង្កេះ ហើយមានចិត្តម៉ឺងម៉ាត់ចុះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៧៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរ៉ាំ រដ្ឋអូហៃអូ ខែមករា ឆ្នាំ១៨៣២ (*History of the Church*, ១:២៤២) ។ ព្យាការីសរសេរថា៖ «កាលបានទទួលព្រះបន្ទូលនៃព្រះអម្ចាស់ដែលផុតមកហើយនេះ[គ. និង ស. ៧៣] ខ្ញុំបានចាប់ផ្ដើមការបកប្រែព្រះគម្ពីរ ហើយបានធ្វើការយ៉ាងព្យាយាម រហូតដល់ចំពេលសន្និសីទចាប់ផ្ដើម ដែលនឹងធ្វើឡើងនៅថ្ងៃ ទី២៥ ក្នុងខែមករា ។ នៅពេលនេះ ខ្ញុំក៏បានទទួលវិវរណៈដែលមានដូចតទៅនេះ ទុកជាការពន្យល់ប្រាប់អំពីសំបុត្រទីមួយ ទៅដល់ពួក កូរិនថូស ជំពូកទី៧ ខ១៤»* (*History of the Church*, ១:២៤២) ។

*១–៥, ប៉ុលទូន្មានសាសនាចក្រនៅសម័យលោក កុំឲ្យកាន់តាមក្រិត្យវិន័យនៃលោកម៉ូសេឡើយ; ៦–៧ កូនក្មេងតូចៗសុទ្ធតែបរិសុទ្ធ ហើយបានញែកចេញជាបរិសុទ្ធ តាមរយៈដង្វាយធួនហើយ ។*

ព្រោះតែប្ដីដែលមិនជឿ នោះបានញែកចេញជាបរិសុទ្ធដោយសារប្រពន្ធ ហើយប្រពន្ធដែលមិនជឿ នោះបានញែកចេញជាបរិសុទ្ធ ដោយសារប្ដីដែរ ពុំនោះកូនចៅគេមិនស្អាតទេ តែឥឡូវនេះ វាបរិសុទ្ធហើយ ។

២ ឥឡូវនេះ នៅសម័យពួកសាវក នោះក្រិត្យវិន័យនៃការកាត់

---

**៧៣** ១*ក* ក.ន. ពួកអ្នកផ្សេងទៀតដែលទៅបំរើធ្វើបេសកកម្ម; សូមមើល គ. និង ស. ៥៧–៦៨.
២ *ក* គ. និង ស. ២០:៦៣.
៣ *ក* ក.ន. យ៉ូសែប និង ស៊ីឌនី ត្រូវបានបញ្ជាមុននេះឲ្យឈប់បកប្រែព្រះគម្ពីរប៊ីប ហើយឲ្យទៅផ្សាយដំណឹងល្អ. គ. និង ស. ៧១:២.
*ខ* គ. និង ស. ៤៥:៦០–៦១; ៧៦:១៥. ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.).
៦ *ក* ១ ពេត្រុស ១:១៣.
**៧៤** ១*ក* ១ កូរិន. ៧:១៤–១៩.

ស្បែកត្រូវបានគោរពតាម នៅក្នុងចំណោមពួកសាសន៍យូដាទាំងអស់ ដែលមិនជឿដល់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

៣ ហើយហេតុការណ៍បានកើតឡើងថា មាន[ក]ការទាស់ទែងដ៏ធំមួយកើតឡើង ក្នុងចំណោមប្រជាជន អំពីក្រិត្យវិន័យនៃ[ខ]ការកាត់ស្បែក ត្បិតប្ដីដែលមិនជឿ មានបំណងចង់ឲ្យកូនចៅខ្លួនកាត់ស្បែក ហើយគោរពតាមក្រិត្យវិន័យនៃលោកម៉ូសេ ជា[គ]ក្រិត្យវិន័យ ដែលបាន បំពេញរួចហើយ ។

៤ ហើយហេតុការណ៍បានកើតឡើងថា កូនចៅ ដែលបានចិញ្ចឹមឡើងឲ្យនៅក្រោមក្រិត្យវិន័យនៃលោកម៉ូសេ បានស្ដាប់តាម[ក]សណ្ដាប់ ទាំងឡាយ នៃពួកអយ្យកោរបស់ពួកគេ ហើយមិនជឿតាមដំណឹងល្អនៃព្រះគ្រីស្ទឡើយ ដោយហេតុនេះហើយទើបពួកគេត្រឡប់ជាឥត បរិសុទ្ធ ។

៥ ហេតុដូច្នោះហើយ ត្បិតដោយហេតុនេះ ទើបសាវកនេះបានសរសេរទៅសាសនាចក្រ ដោយឲ្យដល់ពួកគេនូវបញ្ញត្តិមួយពុំមែនមក ពីព្រះអម្ចាស់ទេ តែមកពីខ្លួនលោក ថាអ្នកដែលជឿមិន[ក]គួរចូលរួមនឹងអ្នកដែលមិនជឿឡើយ; លើកលែងតែ[ខ]ក្រិត្យវិន័យនៃលោកម៉ូសេ ត្រូវបានបោះបង់ចោល នៅក្នុងចំណោមពួកគេសិន ។

៦ ប្រយោជន៍ឲ្យកូនចៅរបស់ពួកគេអាចរស់នៅ ដោយគ្មានការកាត់ស្បែកឡើយ; ហើយប្រយោជន៍ឲ្យសណ្ដាប់នោះអាចបានបោះបង់ ចោល ដែលថាកូនក្មេងតូចៗឥតបរិសុទ្ធ; ត្បិតសណ្ដាប់នោះធ្លាប់មាននៅក្នុងចំណោមពួកសាសន៍យូដា;

៧ ប៉ុន្តែ[ក]កូនក្មេងសុទ្ធតែ[ខ]បរិសុទ្ធ ពីព្រោះ[គ]បានញែកចេញជាបរិសុទ្ធតាមរយៈ[ឃ]ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទហើយ; ហើយនេះគឺជាអត្ថន័យនៃបទគម្ពីរ ។

## កណ្ឌទី ៧៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិអាមហើស្ទ រដ្ឋអូហៃអូ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៨៣២ (*History of the Church, *១:២៤២–២៤៥*) ។ *នេះជាគ្រានៃសន្និសីទដែលបានកំណត់ទុក ។ នៅឯសន្និសីទនេះ យ៉ូសែប ស្ម៊ីធ ត្រូវបានគាំទ្រ ហើយតែងតាំងជាប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ។ មានពួកអែលឌើរខ្លះ ដែលបានជួបប្រទះការពិបាកក្នុងការនាំ មនុស្សលោកឲ្យយល់សាររបស់ពួកគេ នោះមានបំណងចង់ដឹងរឿងថែមទៀត អំពីភារកិច្ចនានារបស់ពួកគេជាប្រចាំ ។ វិវរណៈនេះ ក៏បានមកតាមក្រោយ ។*

*១–៥, ពួកអែលឌើរដែលស្មោះត្រង់ ដែលផ្សាយដំណឹងល្អនឹងបានជីវិតដ៏នៅអស់កល្បជានិច្ច; ៦–១២, ចូរអធិស្ឋានដើម្បីឲ្យបានទទួល ព្រះដ៏ជាជំនួយ ដែលបង្រៀនគ្រប់ទាំងអស់; ១៣–២២, ពួកអែលឌើរនឹងអង្គុយក្នុងការជំនុំជំរះអ្នកទាំងនោះ ដែលបដិសេធសារ របស់ពួកគេ; ២៣–៣៦, ក្រុមគ្រួសារនៃពួកអ្នកផ្សាយសាសនាត្រូវបានទទួលជំនួយពីសាសនាចក្រ ។*

ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា យើងជាអ្នកដែលមានបន្ទូល ហាក់ដូចជា[ក]ដោយសារសម្លេង នៃព្រះវិញ្ញាណរបស់យើង [ខ]គឺជាអាលផា និងអូមេកា ជាព្រះអម្ចាស់របស់អ្នក និងជាព្រះរបស់អ្នក —

២ ចូរប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាដែលបានចុះឈ្មោះរបស់ខ្លួនដើម្បីចេញទៅប្រកាសប្រាប់ពីដំណឹងល្អរបស់យើង ហើយដើម្បី[ក]កាត់ មែក[ខ]ចំការទំពាំងបាយជូររបស់យើងអើយ ។

៣ មើលចុះ យើងប្រាប់អ្នកថា គឺជាព្រះហឫទ័យរបស់យើង

៣ *ក* កិច្ចការ ១៥:១–៣៥;
កាឡាទី ២:១–៥.
*ខ* ស.ប. ការកាត់ស្បែក.
*គ* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
៤ *ក* ស.ប. សណ្ដាប់.
៥ *ក* ស.ប. អាពាហ៍ពិពាហ៍,
រៀបអាពាហ៍ពិពាហ៍ —
អាពាហ៍ពិពាហ៍រវាងសេចក្ដីជំនឿ.
*ខ* ២ នីហ្វៃ ២៥:២៤–២៧.
៧ *ក* ម៉ូរ៉ូណៃ ៨:៨–១៥;
គ. និង ស. ២៩:៤៦–៤៧;
១៣៧:១០.
*ខ* ស.ប. បរិសុទ្ធ.
*គ* ស.ប. សេចក្ដីសង្គ្រោះ —
សេចក្ដីសង្គ្រោះដល់កូនក្មេង.
*ឃ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
**៧៥** ១ *ក* ស.ប. វិវរណៈ.
*ខ* វិវរ. ១:៨.
ស.ប. អាលផា និងអូមេកា.
២ *ក* យ៉ាកុប ៥:៦២.
*ខ* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.

ដែលអ្នកគួរចេញទៅ ហើយមិនបង្អង់នៅ ឬក៏[ក]ខ្ជិលច្រអូសឡើយ
ប៉ុន្តែធ្វើការ ដោយកម្លាំងរបស់អ្នកចុះ —
៤ ដោយបន្លឺសម្លេងរបស់អ្នកឡើង ហាក់ដូចជាដោយសម្លេង
ត្រែ ដោយ[ក]ប្រកាសប្រាប់[ខ]សេចក្តីពិត តាមវិវរណៈ និងព្រះបញ្ញត្តិ
ទាំងឡាយ ដែលយើងបានប្រទានដល់អ្នកចុះ ។
៥ ម្ល៉ោះហើយ បើសិនជាអ្នករាល់គ្នាស្មោះត្រង់ នោះអ្នករាល់
គ្នានឹងបាន[ក]ផ្ទុកកណ្តាប់ស្រូវ ហើយអ្នកនឹងបាន[ខ]ពាក់មកុដ[គ]កិត្តិយស
និង[ឃ]សិរីល្អ និង[ង]អមតភាព ហើយនិង[ច]ជីវិតដ៏នៅអស់កល្បជានិច្ច ។
៦ ហេតុដូច្នេះហើយ ប្រាកដមែន យើងប្រាប់អ្នក វិលលាម អ៊ី
ម៉ុកខ្លេលិន ជាអ្នកបំរើរបស់យើងថា យើង[ក]ដកបេសកកម្មដែល
យើង បានប្រទានដល់គាត់ ដើម្បីឲ្យចេញទៅឯស្រុកទាំងឡាយ
នៅខាងកើត;
៧ ហើយយើងប្រទានដល់គាត់ នូវបេសកកម្មថ្មីមួយ និង
ព្រះបញ្ញត្តិថ្មីមួយ ដែលយើងជាព្រះអម្ចាស់ [ក]វាយផ្ចាលគាត់
ព្រោះតែ ការ[ខ]រអ៊ូរទាំ ក្នុងចិត្តរបស់គាត់;
៨ ហើយគាត់បានធ្វើបាប; ទោះជាយ៉ាងណាក៏ដោយ យើង
បានអត់ទោសឲ្យគាត់ ហើយប្រាប់គាត់ទៀតថា ចូរអ្នកទៅ
ក្នុងស្រុកទាំង ឡាយនៅទិសខាងត្បូងចុះ ។
៩ ហើយចូរឲ្យ លូកា ចនសុន ជាអ្នកបំរើរបស់យើង ទៅជា
មួយគាត់ ហើយប្រកាសប្រាប់ពីអ្វីៗ ដែលយើងបានបញ្ជាដល់
ពួកគេចុះ —
១០ ដោយអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ សូម
[ក]ព្រះដ៏ជាជំនួយ ដែលនឹងបង្រៀនពួកគេ នូវគ្រប់ទាំងអស់ ដែលជា
ការចាំបាច់ដល់ ពួកគេ —
១១ ដោយ[ក]អធិស្ឋានជានិច្ច ប្រយោជន៍កុំឲ្យពួកគេរសាយ
ចិត្តឡើយ; ហើយដរាបណាពួកគេប្រព្រឹត្តបែបនេះ នោះយើង
នឹងគង់នៅជា មួយពួកគេ រហូតដល់ចុងបំផុត ។
១២ មើលចុះ នេះហើយជាព្រះហឫទ័យនៃព្រះអម្ចាស់ ជាព្រះ
របស់អ្នក ដែលទ្រង់មានចំពោះអ្នក ។ គឺដូច្នោះមែន ។ អាម៉ែន ។
១៣ ហើយជាថ្មីទៀត ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលដូច្នេះថា ចូរឲ្យ [ក]អ័រសុន ហៃឌ ជាអ្នកបំរើរបស់យើង និង
[ខ]សាំយូអែល អេច ស្ម៊ីធ ជាអ្នកបំរើរបស់យើងចេញដំណើររបស់
ពួកគេ ទៅក្នុងស្រុកទាំងឡាយនៅទិសខាងកើត ហើយប្រកាស
ប្រាប់ពីអ្វីៗ ដែល យើងបានបញ្ជាដល់ពួកគេចុះ ហើយដរាបណា
ពួកគេមានចិត្តស្មោះត្រង់ មើលន៏ យើងនឹង[គ]គង់នៅជាមួយពួកគេ
រហូតដល់ចុងបំផុត ។
១៤ ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់ដល់ ឡៃម៉ាន
ចនសុន ជាអ្នកបំរើរបស់យើង និងដល់ [ក]អ័រសុន ប្រាត្ត ជាអ្នកបំរើ
របស់យើង ថា ពួកគេក៏ត្រូវចេញដំណើររបស់ពួកគេ ទៅ
ក្នុងស្រុកទាំងឡាយនៅទិសខាងកើត ហើយមើលចុះ និងមើលន៏
យើងក៏គង់នៅជាមួយ ពួកគេដែរ គឺរហូតដល់ចុងបំផុត ។
១៥ ហើយជាថ្មីទៀត យើងប្រាប់ដល់ អាសា ដត្ស ជាអ្នកបំរើ
របស់យើង និងដល់ ខាល្វ៊ វិលសុន ជាអ្នកបំរើរបស់យើងថា
ពួកគេក៏ត្រូវ ចេញដំណើររបស់ពួកគេ ទៅឯស្រុកទាំងឡាយ
នៅទិសខាងលិច ហើយប្រកាសប្រាប់ពីដំណឹងល្អរបស់យើង
ដូចជាយើងបានបញ្ជា ពួកគេ ។
១៦ ហើយអ្នកណាដែលស្មោះត្រង់នឹងបានឈ្នះគ្រប់ទាំងអស់
ហើយនឹងបាន[ក]លើកឡើងនៅថ្ងៃចុងក្រោយបង្អស់ ។
១៧ ហើយជាថ្មីទៀត យើងប្រាប់ដល់ មេជើរ អិន អាស្លី
ជាអ្នកបំរើរបស់យើង និងដល់ បើរ រិក្ស ជាអ្នកបំរើ
របស់យើងថា ចូរឲ្យពួកគេ ចេញដំណើររបស់ពួកគេ ទៅ
ក្នុងស្រុកនៅទិសខាងត្បូងផងដែរ ។
១៨ មែនហើយ ចូរឲ្យអស់អ្នកទាំងនោះចេញដំណើររបស់ខ្លួន
ដូចជាយើងបានបញ្ជាដល់ពួកគេ ដោយទៅពីផ្ទះមួយទៅផ្ទះមួយ
ហើយពីភូមិមួយទៅភូមិមួយ និងពីទីក្រុងមួយទៅទីក្រុងមួយចុះ ។
១៩ ហើយនៅក្នុងផ្ទះណាមួយក៏ដោយ ដែលអ្នករាល់គ្នាចូល
ហើយពួកគេទទួលអ្នក នោះចូរទុកពររបស់អ្នករាល់គ្នាមកលើ
ផ្ទះនោះចុះ ។
២០ ហើយនៅក្នុងផ្ទះណាមួយក៏ដោយ ដែលអ្នករាល់គ្នាចូល
ហើយពួកគេមិនទទួលអ្នកទេ នោះអ្នករាល់គ្នាត្រូវចេញយ៉ាង

---

៣ *ក* ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
៤ *ក* ស.ប. កិច្ចការផ្សាយសាសនា.
*ខ* គ. និង ស. ១៩:៣៧.
៥ *ក* ទំនុក. ១២៦:៦; អាលម៉ា ២៦:៥.
*ខ* ស.ប. មកុដ.
*គ* ស.ប. គោរពប្រតិបត្តិ.
*ឃ* ស.ប. សិរីល្អ.
*ង* ស.ប. អមតៈ, អមតភាព.
*ច* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៦ *ក* គ. និង ស. ៦៦:១–១៣.
៧ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. រអ៊ូរទាំ; គំនិត.
១០ *ក* យ៉ូហាន ១៤:២៦.
ស.ប. ព្រះដ៏ជាជំនួយ.
១១ *ក* ២ នីហ្វៃ ៣២:៩.
១៣ *ក* ស.ប. ហៃឌ, អ័រសុន.
*ខ* ស.ប. ស្ម៊ីធ, សាំយូអែល អេច.
*គ* ម៉ាថាយ ២៨:១៩–២០.
១៤ *ក* ស.ប. ប្រាត្ត, អ័រសុន.
១៦ *ក* គ. និង ស. ៥:៣៥.

របស់ពីផ្ទះ នោះ ហើយ[ក]រលាស់ធូលីដីពីជើងអ្នកចេញ ទុកជាទីបន្ទាល់ទាស់នឹងពួកគេ ។

២១ ហើយអ្នកនឹងបានពោរពេញទៅដោយ[ក]សេចក្ដីអំណរ និងសេចក្ដីរីករាយ ហើយចូរដឹងការណ៍នេះថា នៅថ្ងៃ[ខ]ជំនុំជំរះ នោះអ្នកនឹង បានទៅជាចៅក្រមដល់ផ្ទះនោះ ហើយដាក់ទោសពួកគេ;

២២ ហើយនៅថ្ងៃជំនុំជំរះ នោះអ្នកឥតសាសនានឹងទ្រាំបានងាយជាជាងផ្ទះនោះ; ហេតុដូច្នេះហើយ ចូរ[ក]ក្រវាត់ចង្កេះ ហើយមានចិត្ត ស្មោះត្រង់ចុះ ហើយអ្នករាល់គ្នានឹងបានឈ្នះគ្រប់ទាំងអស់ ហើយនឹងបានលើកឡើងនៅថ្ងៃចុងក្រោយបង្អស់ គឺដូច្នោះមែន ។ អាម៉ែន ។

២៣ ហើយជាថ្មីទៀត ឱអ្នករាល់គ្នាជាពួកអែលឌើរនៃសាសនាចក្រយើង ដែលបានចុះឈ្មោះរបស់ខ្លួន ប្រយោជន៍ឲ្យអ្នកអាចបានដឹង អំពីព្រះហឫទ័យ ដែលទ្រង់មានចំពោះអ្នកអើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នកយ៉ាងដូច្នេះថា —

២៤ មើលចុះ យើងប្រាប់អ្នកថា គឺជាភារកិច្ចនៃសាសនាចក្រ ដើម្បីជួយទ្រទ្រង់ក្រុមគ្រួសារនៃពួកអ្នកទាំងនោះ ហើយក៏ដើម្បីទ្រទ្រង់ក្រុម គ្រួសារនៃពួកអ្នកទាំងនោះ ដែលត្រូវបានហៅ ហើយត្រូវបានចាត់ឲ្យទៅក្នុងលោកិយ ដើម្បីប្រកាសប្រាប់ពីដំណឹងល្អដល់មនុស្សលោក ។

២៥ ហេតុដូច្នោះហើយ យើងជាព្រះអម្ចាស់ ប្រទានដល់អ្នកនូវព្រះបញ្ញត្តិនេះថា អ្នករាល់គ្នារកបានកន្លែងនានា សំរាប់គ្រួសាររបស់ ខ្លួនចុះ ដរាបណាបងប្អូនរបស់អ្នកយល់ព្រមដើម្បីបើកចិត្តរបស់ពួកគេ ។

២៦ ហើយចូរឲ្យមនុស្សទាំងអស់ ដែលអាចរកបានកន្លែងនានាសំរាប់គ្រួសាររបស់ខ្លួន ហើយទ្រទ្រង់សាសនាចក្រសំរាប់ពួកគេ ដោយពុំខានទៅក្នុងលោកិយ ទោះជានៅទិសខាងកើត ឬខាងលិច ឬខាងជើង ឬខាងត្បូងក្ដី ។

២៧ ចូរឲ្យពួកគេសូម ហើយពួកគេនឹងបានទទួល ចូរគោះហើយតែងនឹងបើកឲ្យពួកគេ ហើយនឹងបានធ្វើឲ្យពួកគេដឹងមកពីស្ថានខ្ពស់ គឺដោយសារ[ក]ព្រះដ៏ជាជំនួយ ពីទីណាក៏ដោយដែលពួកគេត្រូវទៅ ។

២៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា រីឯមនុស្សគ្រប់រូបណាដែលត្រូវ[ក]ផ្គត់ផ្គង់ដល់[ខ]គ្រួសាររបស់ខ្លួនផ្ទាល់ នោះចូរឲ្យអ្នក នោះផ្គត់ផ្គង់ចុះ ហើយអ្នកនោះនឹងពុំត្រូវបាត់បង់មកុដរបស់ខ្លួនឡើយ; ហើយចូរឲ្យអ្នកនោះធ្វើការនៅក្នុងសាសនាចក្រចុះ ។

២៩ ចូរឲ្យមនុស្សគ្រប់រូបមាន[ក]ចិត្តឧស្សាហ៍ក្នុងគ្រប់ជំពូកទាំងអស់ ។ ហើយពួក[ខ]ខ្ជិលច្រអូសនឹងពុំមានកន្លែងនៅក្នុងសាសនាចក្រឡើយ លើកលែងតែអ្នកនោះប្រែចិត្ត ហើយកែប្រែផ្លូវនានារបស់ខ្លួនវិញ ។

៣០ ហេតុដូច្នោះហើយ ចូរឲ្យ ស៊ីម្មាន ខារតើរ ជាអ្នកបំរើរបស់យើង និង អេមើរ ហារិស ជាអ្នកបំរើរបស់យើង ចូលរួមគ្នាក្នុងការងារ បំរើចុះ;

៣១ ហើយព្រមទាំង អែស្រ៉ា ធេយ័រ ជាអ្នកបំរើរបស់យើង និង [ក]ថូម៉ាស ប៊ី មាស ជាអ្នកបំរើរបស់យើងផង;

៣២ ព្រមទាំង ហៃរុម ស៊្មីធ ជាអ្នកបំរើរបស់យើង និង រេយណុលស្ស ខាហ៊ូន ជាអ្នកបំរើរបស់យើងផង;

៣៣ ហើយព្រមទាំង ដានីយ៉ែល ស្ដានតោន ជាអ្នកបំរើរបស់យើង និង ស៊ីមួរ ព្រុនសុន ជាអ្នកបំរើរបស់យើងផង;

៣៤ ហើយព្រមទាំង សិលវ៉ែស្ទើរ ស៊្មីធ ជាអ្នកបំរើរបស់យើង និង គេឌាន ខារតើរ ជាអ្នកបំរើរបស់យើងផង;

៣៥ ហើយព្រមទាំង រីកកិល្ស អេម្ស ជាអ្នកបំរើរបស់យើង និង ស្ទេផាន បើរណែត ជាអ្នកបំរើរបស់យើងផង;

៣៦ ហើយព្រមទាំង មីកា ប៊ី វែលតោន ជាអ្នកបំរើរបស់យើង ហើយនិង អេដែន ស៊្មីធ ជាអ្នកបំរើរបស់យើងផងដែរ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

២០ *ក* ម៉ាថាយ ១០:១៤;
លូកា ១០:១១–១២;
គ. និង ស. ២៤:១៥; ៦០:១៥.
២១ *ក* ម៉ាថាយ ៥:១១–១២.
*ខ* ស.ប. ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
២២ *ក* អេភេ. ៦:១៤;
គ. និង ស. ២៧:១៥–១៨.
២៧ *ក* ២ នីហ្វៃ ៣២:៥;
គ. និង ស. ៨:២.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២៨ *ក* ១ ធីម៉ូ. ៥:៨; គ. និង ស. ៨៣:២.
*ខ* ស.ប. គ្រួសារ.
២៩ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
៣១ *ក* ស.ប. ម៉ាស, ថូម៉ាស ប៊ី.

## កណ្ឌទី ៧៦

*ការនិមិត្តដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅភូមិហៃរាំ រដ្ឋអូហៃអូ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៨៣២ (*History of the Church, *១:២៤៥–២៥២)* ។ *មុនបញ្ជីរបស់លោកអំពីការនិមិត្តនេះ ព្យាការីបានសរសេរ ថា៖ «បន្ទាប់ពីខ្ញុំបានវិលមកពីសន្និសីទនៅភូមិអាមហើស្ថវិញ ខ្ញុំបានចាប់ផ្ដើមការបកប្រែព្រះគម្ពីរម្ដងទៀត ។ ពីវិវរណៈនានាដែលបាន ទទួលមកឃើញថាចំណុចដ៏សំខាន់ជាច្រើនដែលទាក់ទងទៅនឹងសេចក្ដីសង្គ្រោះនៃមនុស្ស នោះត្រូវ បានដកចេញពីព្រះគម្ពីរប៊ីប ឬក៏បាត់មុនពេលគេប្រមូលផ្ដុំព្រះគម្ពីរ ។ ឃើញថាជាភស្តុតាងយ៉ាងជាក់លាក់តាមសេចក្ដីពិតទាំង ឡាយដែលនៅសល់ ថាបើសិន ជាព្រះទ្រង់ប្រទានរង្វាន់ដល់មនុស្សម្នាក់ៗ តាមការប្រព្រឹត្តទាំងឡាយដែលបានធ្វើនៅក្នុងរូបកាយ នោះពាក្យថា ‹ស្ថានសួគ៌› ដូចជាមានន័យសំរាប់គេហដ្ឋានដ៏នៅអស់កល្បជានិច្ចនៃពួកបរិសុទ្ធ ត្រូវតែមាននគរលើសជាងមួយ ។ ម្ល៉ោះហើយ . . . កាលកំពុងតែបកប្រែដំណឹងល្អតាមលោកយ៉ូហាន រូបខ្ញុំហើយនិង អែលឌើរ រិកដុន បានឃើញការនិមិត្តដែលមានដូច តទៅនេះ» (*History of the Church, *១:២៤៥)* ។ *គឺក្រោយពីព្យាការីបានបកប្រែគម្ពីរយ៉ូហាន ៥:២៩ ដែលការនិមិត្តត្រូវបានប្រទានឲ្យមក ។*

*១–៤ ព្រះអម្ចាស់ទ្រង់ជាព្រះ; ៥–១០, សេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរនឹងត្រូវបានបើកសំដែងដល់ពួកស្មោះត្រង់ទាំងអស់; ១១–១៧, មនុស្សទាំងអស់នឹងចេញមក ក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិត ឬមនុស្សឥតសុចរិត; ១៨–២៤, បណ្ដាជននៃពិភពលោកជាច្រើន សុទ្ធតែបុត្រាបុត្រីបង្កើតចំពោះព្រះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ; ២៥–២៩, ទេវតាមួយនៃព្រះបានធ្លាក់ ហើយបានក្លាយទៅ ជាអារក្ស; ៣០–៤៩, ពួកកូនអន្ដរធានរងទុក្ខនូវសេចក្ដីផាប់ទោសដ៏អស់កល្បជានិច្ច; រីឯមនុស្សគ្រប់រូបឯទៀតបានទទួលកំរិតនៃសេចក្ដី សង្គ្រោះខ្លះ; ៥០–៧០, សិរីល្អ និងរង្វាន់នៃពួកដំកើងឡើងនៅក្នុងនគរសេឡេស្ទាលត្រូវបានអធិប្បាយប្រាប់; ៧១–៨០, អស់អ្នកដែល គ្រងនគរទេរេសទ្រាលទុកជាមរតក ត្រូវបានអធិប្បាយប្រាប់; ៨១–១១៣, ឋានៈនៃអស់អ្នកនៅក្នុងសិរីល្អនៃទេឡេស្ទាល ទេរេសទ្រាល និងសេឡេស្ទាល ត្រូវបានពន្យល់ប្រាប់; ១១៤–១១៩, ពួកស្មោះត្រង់អាចឃើញហើយយល់នូវសេចក្ដីអាថ៌កំបាំងទាំងឡាយអំពីនគរ នៃព្រះ ដោយសារព្រះចេស្ដា នៃព្រះវិញ្ញាណបរិសុទ្ធ ។*

១ ពួកស្ថានសួគ៌អើយ ចូរ[ក]ស្ដាប់ ហើយពួកផែនដីអើយ ចូរផ្ទៀងត្រចៀក ហើយបណ្ដា[ខ]ជននៃទីទាំងនេះអើយ ចូររីករាយ—
សប្បាយចុះ ត្បិតព្រះ អម្ចាស់ទ្រង់ជាព្រះ ហើយក្រៅពីទ្រង់នោះ
[គ]គ្មានព្រះ[ឃ]អង្គសង្គ្រោះឯណាឡើយ ។
២ [ក]មហិមាណាស់ហ្ន៎ប្រាជ្ញារបស់ទ្រង់ [ខ]អស្ចារ្យណាស់ហ្ន៎មាគ៌ា
ទាំងឡាយរបស់ទ្រង់ ហើយទំហំនៃការប្រព្រឹត្តរបស់ទ្រង់ នោះ
គ្មាននរណា អាចយល់ឃើញឡើយ ។
៣ [ក]គោលបំណងរបស់ទ្រង់ពុំដែលផុតទៅ ឬគ្មាននរណាអាច
បញ្ឈប់ព្រះហស្តរបស់ទ្រង់បានឡើយ ។
៤ ពីភាពអស់កល្បទៅភាពអស់កល្បជានិច្ច នោះទ្រង់នៅតែ
[ក]ដដែល ហើយព្រះ[ខ]ជន្មទ្រង់មិនចេះផុតឡើយ ។
៥ ត្បិតព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា — យើងជា
ព្រះអម្ចាស់ [ក]មានសេចក្ដីមេត្តាករុណា និងសេចក្ដីអាណិតអាសូរ
ដល់អស់ អ្នកណាដែល[ខ]កោតខ្លាចដល់យើង ហើយ
សព្វព្រះហឫទ័យនឹងឲ្យកិត្តិយសដល់អស់អ្នកណាដែល[គ]បំរើយើង
ដោយនូវសេចក្ដីសុចរិត និងដោយនូវ សេចក្ដីពិត រហូត
ដល់ចុងបំផុត ។

**៧៦** ១*ក* អេសាយ ១:២.
*ខ* យេរេ. ១០:១០.
ស.ប. ព្រះ, ក្រុមព្រះ —
ព្រះដ៏ជាព្រះរាជបុត្រា.
*គ* អេសាយ ៤៣:១១;
ហូសេ ១៣:៤.
*ឃ* ស.ប. ព្រះអង្គសង្គ្រោះ.
២ *ក* ២ នីហ្វៃ ២:២៤;
គ. និង ស. ៣៨:១–៣.
*ខ* វិវរ. ១៥:៣.
៣ *ក* ១ ពង្សាវ. ៨:៥៦;
គ. និង ស. ១:៣៨; ៦៤:៣១.
៤ *ក* ហេព្រើរ ១៣:៨;
គ. និង ស. ៣៥:១; ៣៨:១–៤;
៣៩:១–៣.
*ខ* ទំនុក. ១០២:២៥–២៧;
ហេព្រើរ ១:១២.
៥ *ក* និក្ខ. ៣៤:៦; ទំនុក. ១០៣:៨.
ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
*ខ* ចោទិ. ៦:១៣;
យ៉ូស្វេ ៤:២៣–២៤.
ស.ប. សេចក្ដីកោតខ្លាច;
ការគោរពកោតក្រែង.
៥ *គ* គ. និង ស. ៤:២.

៦ នឹងមានភាពមហិមាណាស់រង្វាន់របស់ពួកគេ ហើយភាពអស់កល្បជានិច្ចនឹងទៅជាសិរីល្អរបស់ពួកគេ ។

៧ ហើយចំពោះពួកគេ នោះយើងនឹងបើកសំដែងអស់ទាំងសេចក្ដីអាថ៌កំបាំង មែនហើយ គឺអស់ទាំងសេចក្ដីអាថ៌កំបាំងដ៏សម្ងាត់ៗ អំពីនគររបស់យើង ចាប់តាំងពីសម័យបុរាណមក ហើយសំរាប់អស់ទាំងកល្បខាងមុខ នោះយើងនឹងធ្វើឲ្យពួកគេស្គាល់នូវបំណង ព្រះហឫទ័យរបស់យើង អំពីគ្រប់ទាំងអស់ដែលទាក់ទងទៅនឹងនគររបស់យើង ។

៨ មែនហើយ គឺអំពីការអស្ចារ្យទាំងឡាយនៃភាពអស់កល្បជានិច្ច នោះពួកគេនឹងបានស្គាល់ ហើយការណ៍ទាំងឡាយដែលនឹងមាន ឡើង នោះយើងនឹងបង្ហាញដល់ពួកគេ គឺការណ៍ទាំងឡាយអំពីតំណមនុស្សជាច្រើន ។

៩ ហើយប្រាជ្ញារបស់ពួកគេនឹងទៅជាមហិមា ហើយយោបល់របស់ពួកគេឡើងទៅដល់ស្ថានសួគ៌ ហើយនៅចំពោះពួកគេ ប្រាជ្ញានៃពួក អ្នកប្រាជ្ញនឹងវិនាសបាត់ទៅ ហើយយោបល់នៃពួកអ្នកចេះនឹងទៅជាឥតការ ។

១០ ត្បិតដោយសារព្រះវិញ្ញាណរបស់យើង នោះយើងនឹងបំភ្លឺពួកគេ ហើយដោយសារព្រះចេស្ដារបស់យើង នោះយើងនឹងធ្វើឲ្យពួក គេស្គាល់នូវការសម្ងាត់ទាំងឡាយនៃព្រះហឫទ័យរបស់យើង — មែនហើយ គឺសេចក្ដីទាំងនោះដែលភ្នែកមិនដែលឃើញ ឬត្រចៀកមិន ដែលឮ ឬមិនដែលនឹកដល់ចិត្តនៃមនុស្សឡើយ ។

១១ យើងខ្ញុំ គឺយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និង ស៊ីឌនី រិកដុន ដោយបាននៅក្នុងព្រះវិញ្ញាណ នៅថ្ងៃទីដប់ប្រាំមួយ នៃខែកុម្ភៈ ក្នុងឆ្នាំមួយពាន់ ប្រាំបីរយសាមសិបពីរ នៃព្រះអម្ចាស់របស់យើង —

១២ ដោយសារព្រះចេស្ដានៃព្រះវិញ្ញាណ នោះភ្នែករបស់យើងខ្ញុំបានបើក ហើយយោបល់របស់យើងបានភ្លឺ ដើម្បីឲ្យបានឃើញ ហើយ យល់នូវការណ៍ទាំងឡាយនៃព្រះ —

១៣ គឺសេចក្ដីទាំងនោះដែលមានតាំងពីដើមដំបូង មុនមានលោកិយមកម្ល៉េះ ដែលបានតែងតាំងដោយព្រះវរបិតា តាមរយៈព្រះរាជ បុត្រាបង្កើតតែមួយរបស់ទ្រង់ ដែលគង់នៅក្នុងឱរាព្រះវរបិតា គឺតាំងពីដើមដំបូងមកម្ល៉េះ;

១៤ ដែលយើងខ្ញុំថ្លែងទីបន្ទាល់ដល់; ហើយទីបន្ទាល់ដែលយើងខ្ញុំថ្លែង គឺជាភាពពោរពេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលជា ព្រះរាជបុត្រា ដែលយើងខ្ញុំបានឃើញហើយបានទូលជាមួយ នៅក្នុងការនិមិត្តពីស្ថានសួគ៌ ។

១៥ ត្បិតក្នុងកាលយើងខ្ញុំកំពុងតែធ្វើការបកប្រែ ដែលព្រះអម្ចាស់ទ្រង់បានចាត់ដល់យើងខ្ញុំ នោះយើងខ្ញុំបានមកដល់ខម្ពីរប្រាំបួននៃជំពូកទីប្រាំ ក្នុងគម្ពីរយ៉ូហាន ដែលបានប្រទានដល់យើងដែលមានដូចតទៅនេះ —

១៦ ដោយនិយាយអំពីដំណើររស់ឡើងវិញនៃមនុស្សស្លាប់ ស្ដីអំពីអស់អ្នកដែលនឹងឮសម្លេងនៃកូនមនុស្សថា៖

១៧ ហើយនឹងចេញមក គឺពួកអ្នកដែលបានប្រព្រឹត្តល្អ នៅក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិត ឯពួកអ្នកដែលបានប្រព្រឹត្តអាក្រក់ វិញ នៅក្នុងដំណើររស់ឡើងវិញនៃមនុស្សឥតសុចរិត ។

១៨ ឥឡូវសេចក្ដីនេះ បានបណ្ដាលឲ្យយើងខ្ញុំងឿងឆ្ងល់ ត្បិតពាក្យនេះត្រូវបានប្រទានដល់យើងខ្ញុំពីព្រះវិញ្ញាណ ។

១៩ ហើយក្នុងកាលយើងខ្ញុំកំពុងតែពិចារណាពីសេចក្ដីទាំងនេះ នោះព្រះអម្ចាស់ទ្រង់បានពាល់ភ្នែកនៃយោបល់របស់យើងខ្ញុំ ហើយក៏ បានបើក ហើយសិរីល្អនៃព្រះអម្ចាស់បានភ្លឺចែងចាំងជុំវិញ ។

២០ ហើយយើងខ្ញុំបានមើលឃើញសិរីល្អនៃព្រះរាជបុត្រា

៦ *ក* ស.ប. សិរីល្អនៃសេឡេស្ទាល.
៧ *ក* គ. និង ស. ៤២:៦១; ៥៩:៤; ៩៨:១២; ១២១:២៦–៣៣.
*ខ* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
៩ *ក* ស.ប. ប្រាជ្ញា.
*ខ* ស.ប. យោបល់.
*គ* អេសាយ ២៩:១៤; ២ នីហ្វៃ ៩:២៨–២៩.
១០ *ក* ម៉ូរ៉ូណៃ ១០:៥.
*ខ* ស.ប. វិវរណៈ; ទីបន្ទាល់.
*គ* ស.ប. អំណាច.
*ឃ* អេសាយ ៦៤:៤; ១ កូរិន. ២:៩; ៣ នីហ្វៃ ១៧:១៥–១៧; គ. និង ស. ៧៦:១១៤–១១៦.
១១ *ក* វិវរ. ១:១០.
១២ *ក* ស.ប. ការប្រែរូប.
*ខ* គ. និង ស. ១១០:១; ១៣៧:១; ១៣៨:១១, ២៩.
១៣ *ក* ម៉ូសេ ៤:២.
១៤ *ក* គ. និង ស. ១០៩:៥៧.
*ខ* ស.ប. ការនិមិត្ត.
១៥ *ក* ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.).
១៦ *ក* យ៉ូហាន ៥:២៨.
*ខ* ស.ប. កូនមនុស្ស.
១៧ *ក* ស.ប. កិច្ចការ.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* កិច្ចការ ២៤:១៥.
១៩ *ក* ស.ប. រំពឹងគិត.
២០ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.

គង់នៅខាង[ខ]ស្ដាំព្រះហស្ដ[គ]នៃព្រះវរបិតា ហើយបានទទួលភាពពោរពេញ របស់ទ្រង់;

២១ ហើយបានឃើញ[ក]ពួកទេវតាបរិសុទ្ធ និងពួកអ្នកដែលបាន[ខ]ញែកជាបរិសុទ្ធ នៅចំពោះបល្ល័ង្ករបស់ទ្រង់ ដោយ[គ]ថ្វាយបង្គំព្រះ និងកូនចៀម ដែលថ្វាយបង្គំទ្រង់អស់កល្បជានិច្ច និងរៀងដរាបតទៅ ។

២២ ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់ នេះគឺជា[ក]ទីបន្ទាល់ចុងក្រោយបង្អស់ ដែលយើងខ្ញុំសូមថ្លែងអំពី ទ្រង់ះ [ខ]គឺថាទ្រង់មានព្រះជន្មរស់នៅ!

២៣ ត្បិតយើងខ្ញុំបាន[ក]ឃើញទ្រង់ គង់នៅខាងស្ដាំព្រះហស្ដនៃ[ខ]ព្រះ ហើយយើងខ្ញុំបានឮសម្លេងដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជា[គ]បុត្រា បង្កើតតែមួយនៃព្រះវរបិតា —

២៤ ថាដោយសារ[ក]ព្រះអង្គ និងតាមរយៈព្រះអង្គ ហើយពីព្រះអង្គ នោះ[ខ]ពិភពលោកទាំងឡាយ មានឡើង ហើយបានបង្កើតមក ហើយ បណ្ដាជននៅទីនោះ គឺជា[គ]បុត្រាបុត្រីបង្កើតចំពោះព្រះ ។

២៥ ហើយយើងខ្ញុំបានឃើញការណ៍នេះដែរ ហើយថ្លែងទីបន្ទាល់ថា [ក]ទេវតាមួយនៃព្រះ ដែលមានសិទ្ធិអំណាចនៅក្នុងវត្តមាននៃព្រះ ដែល បានបះបោរទាស់នឹងព្រះរាជបុត្រាបង្កើតតែមួយ ដែលព្រះវរបិតាស្រឡាញ់ ហើយដែលគង់នៅក្នុងឱរាព្រះវរបិតា នោះទេវតា នោះត្រូវបានទំលាក់ចុះពីវត្តមាននៃព្រះ និងព្រះរាជបុត្រា,

២៦ ហើយត្រូវបានហៅថាអន្ដរធាន ត្បិតបណ្ដាស្ថានសួគ៌បានយំដោយសារគាត់ — គាត់គឺជា[ក]លូស៊ីហ្វើរ ជាបុត្រានៃពេលព្រឹក ។

២៧ ហើយយើងខ្ញុំបានមើលឃើញ ហើយមើលន៏ គាត់[ក]បានរលំហើយ! បានរលំហើយ គឺជាបុត្រានៃពេលព្រឹក!

២៨ ហើយក្នុងកាលយើងខ្ញុំកំពុងតែនៅក្នុងព្រះវិញ្ញាណនៅឡើយ នោះព្រះអម្ចាស់ទ្រង់បានបញ្ជាដល់យើងខ្ញុំ ថាយើងខ្ញុំគួរសរសេរពី ការនិមិត្តនេះ; ត្បិតយើងខ្ញុំបានមើលឃើញសាតាំងដែលជា[ក]ពស់ពីចាស់បុរាណ គឺជា[ខ]អារក្ស ដែលបាន[គ]បះបោរទាស់នឹងព្រះ ហើយបាន ខំស្វែងរក ដើម្បីយកនគរនៃព្រះរបស់យើង និងព្រះគ្រីស្ទនៃទ្រង់ —

២៩ ហេតុដូច្នោះហើយ វាបាន[ក]ធ្វើសង្គ្រាមជាមួយនឹងពួកបរិសុទ្ធនៃព្រះ ហើយព័ទ្ធជុំវិញពួកគេ ។

៣០ ហើយយើងខ្ញុំបានឃើញការនិមិត្តមួយអំពីសេចក្ដីទុក្ខលំបាក នៃអស់អ្នកដែលគាត់បានធ្វើសង្គ្រាមជាមួយ ហើយបានឈ្នះ ត្បិត សម្លេងនៃព្រះអម្ចាស់បានមានព្រះបន្ទូលមកយើងខ្ញុំថាះ

៣១ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលអំពីអស់អ្នកទាំងនោះដែលស្គាល់ព្រះចេស្ដារបស់យើង ហើយដែលបានធ្វើជាអ្នកទទួលទានព្រះ ចេស្ដា[ក]នោះ ហើយបានបណ្ដោយខ្លួនតាមអំណាចនៃអារក្សដើម្បីឲ្យបានឈ្នះ ហើយដើម្បីបដិសេធសេចក្ដីពិត ហើយបន្ថោកបន្ទាបព្រះ ចេស្ដារបស់យើងដូច្នេះថា —

៣២ ពួកគេនេះហើយដែលជា[ក]ពួកកូន[ខ]អន្ដរធាន ដែលយើងបាន ប្រាប់ថា បើពួកគេមិនបានកើតមកសោះ នោះទុកជាការប្រសើរជាង;

៣៣ ត្បិតពួកគេជាគ្រឿងប្រដាប់គួរនឹងក្រោធ ដែលជាប់ទោសដើម្បីរងទុក្ខសេចក្ដីក្រោធនៃព្រះ ជាមួយនឹងអារក្សព្រមទាំងពួកទេវតា របស់វា នៅក្នុងភាពដ៏អស់កល្បជានិច្ច;

២០ *ខ* កិច្ចការ ៧:៥៦.
*គ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
២១ *ក* ម៉ាថាយ ២៥:៣១; គ. និង ស. ១៣០:៦–៧; ១៣៦:៣៧.
*ខ* ស.ប. ការញែកជាបរិសុទ្ធ.
*គ* ស.ប. ថ្វាយបង្គំ.
២២ *ក* ស.ប. ទីបន្ទាល់.
*ខ* គ. និង ស. ២០:១៧.
២៣ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការលេចមករបស់ព្រះគ្រីស្ទក្រោយពីសុគត.
*ខ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*គ* យ៉ូហាន ១:១៤. ស.ប. បង្កើតតែមួយ.
២៤ *ក* ហេព្រើរ ១:១–៣; ៣ នីហ្វៃ ៩:១៥; គ. និង ស. ១៤:៩; ៩៣:៨–១០.
*ខ* ម៉ូសេ ១:៣១–៣៣; ៧:៣០. ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*គ* កិច្ចការ ១៧:២៨, ២៩; ហេព្រើរ ១២:៩; ស.ប. បុត្រាបុត្រីនៃព្រះ.
២៥ *ក* គ. និង ស. ២៩:៣៦–៣៩; ម៉ូសេ ៤:១–៤. ស.ប. អារក្ស.
២៦ *ក* អេសាយ ១៤:១២–១៧. ស.ប. លូស៊ីហ្វើរ.
២៧ *ក* លូកា ១០:១៨.
២៨ *ក* វិវរ. ១២:៩.
*ខ* ស.ប. អារក្ស.
*គ* ស.ប. សង្គ្រាមនៅស្ថានសួគ៌.
២៩ *ក* វិវរ. ១៣:៧; ២ នីហ្វៃ ២:១៨; ២៨:១៩–២៣.
៣១ *ក* ស.ប. សេចក្ដីក្បត់សាសនា.
៣២ *ក* ស.ប. ពួកកូនអន្ដរធាន.
*ខ* គ. និង ស. ៧៦:២៦; ម៉ូសេ ៥:២២–២៦.

៣៤ ស្ដីអំពីពួកអ្នកដែលយើងបានមានបន្ទូលថា គ្មាន[ក]ការអត់ទោសនៅលោកិយនេះ ឬនៅបរលោកក្ដី —

៣៥ ដោយព្រោះគេបាន[ក]បដិសេធព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីបានទទួលហើយនោះ ហើយដោយព្រោះគេបដិសេធព្រះរាជ[ខ]បុត្រា បង្កើតតែមួយនៃព្រះវរបិតា ដោយព្រោះគេបានឆ្កាងព្រះអង្គចំពោះខ្លួនគេ ព្រមទាំងធ្វើឲ្យទ្រង់ហាលមុខខ្មាសគេ ។

៣៦ ពួកគេនេះហើយដែលនឹងទៅក្នុង[ក]បឹងភ្លើង និងស្ពាន់ធ័រជាមួយនឹងអារក្សព្រមទាំងពួកទេវតារបស់វា —

៣៧ ហើយជាពួកនោះតែប៉ុណ្ណោះគត់ ដែល[ក]សេចក្ដីស្លាប់ទីពីរនឹងមានអំណាចមកលើពួកគេ;

៣៨ មែនហើយ ប្រាកដមែន គឺជាពួកនោះតែប៉ុណ្ណោះគត់[ក] ដែលនឹងពុំបានប្រោសលោះឡើយ នៅកំណត់ពេលនៃព្រះអម្ចាស់ បន្ទាប់ពី ការរងទុក្ខលំបាកចំពោះសេចក្ដីក្រោធរបស់ទ្រង់ ។

៣៩ ត្បិតឯមនុស្សទាំងអស់ទៀត គេនឹងបាន[ក]នាំមក ដោយសារ[ខ]ដំណើររស់ឡើងវិញនៃមនុស្សស្លាប់ តាមរយៈជ័យជំនះ និងសិរីល្អនៃ [គ]កូនចៀម ដែលត្រូវប្រហារ ដែលនៅក្នុងឱរាព្រះវរបិតាចាប់តាំងពីមុនកំណើតភពទាំងឡាយមកម្ល៉េះ ។

៤០ ហើយនេះគឺជា[ក]ដំណឹងល្អ ជាដំណឹងដ៏រីករាយ ដែលសម្លេងចេញពីផ្ទៃមេឃបានថ្លែងទីបន្ទាល់ប្រាប់ដល់យើង —

៤១ ថាទ្រង់បានយាងមកក្នុងពិភពលោក គឺព្រះយេស៊ូវ ដើម្បីត្រូវគេ[ក]ឆ្កាងជំនួសពិភពលោក ហើយដើម្បី[ខ]ផ្ទុកអំពើបាបទាំងឡាយនៃ[គ]ពិភពលោក ហើយដើម្បី[ឃ]ញែកពិភពលោកចេញជាបរិសុទ្ធ ហើយដើម្បី[ង]ជំរះពិភពលោកឲ្យស្អាតចេញពីអំពើដ៏ឥតសុចរិតទាំងអស់ ។

៤២ ថាតាមរយៈព្រះអង្គ នោះមនុស្សទាំងអស់នឹងអាចបាន[ក]សង្គ្រោះ ដែលព្រះវរបិតាបានដាក់ក្នុងព្រះចេស្ដារបស់ទ្រង់ ហើយបានបង្កើត ដោយទ្រង់;

៤៣ ដែលសរសើរដំកើងព្រះវរបិតា ហើយសង្គ្រោះអស់ទាំងការនៃព្រះហស្តទ្រង់ លើកលែងតែពួកកូនអន្តរធានប៉ុណ្ណោះ ដែលបដិសេធព្រះរាជបុត្រា បន្ទាប់ពីព្រះវរបិតាបានបើកសំដែងឲ្យស្គាល់ទ្រង់ ។

៤៤ ហេតុដូច្នោះហើយ ទ្រង់សង្គ្រោះមនុស្សទាំងអស់លើកលែងតែពួកវាប៉ុណ្ណោះ — ពួកវានឹងចេញទៅក្នុង[ក]ការ[ខ]ដាក់ទោសដ៏ នៅអស់កល្បអស់កាលជានិច្ច ជាការដាក់ទោសដ៏មិនចេះចប់មិនចេះហើយ ជាការដាក់ទោសដ៏នៅអស់កល្បជានិច្ច ដើម្បីសោយ រាជ្យជាមួយនិង[គ]អារក្ស ព្រមទាំងពួកទេវតារបស់វា នៅក្នុងភាពដ៏អស់កល្បជានិច្ច ជាកន្លែងដែលមាន[ឃ]ដង្កូវមិនចេះស្លាប់ ហើយភ្លើង មិនដែលរលត់ឡើយ គឺជាការរងទុក្ខវេទនារបស់ពួកវា —

៤៥ ហើយ[ក]ចុងបំផុតនៃការដាក់ទោសនេះ ឬកន្លែងនៃការដាក់ទោសនេះ ឬការរងទុក្ខវេទនារបស់ពួកវា នោះគ្មាននរណាដឹងឡើយ;

៤៦ ការនេះក៏ពុំដែលបានបើកសំដែងមកហើយទេ ឬនៅពេលនេះ ឬក៏នឹងបើកសំដែងដល់មនុស្សដែរ លើកលែងតែពួកអ្នកដែលត្រូវ ធ្វើជាពួកអ្នកទទួលទាននូវការនោះប៉ុណ្ណោះ;

៤៧ ទោះជាយ៉ាងណាក៏ដោយ យើងជាព្រះអម្ចាស់បង្ហាញការនេះដល់មនុស្សជាច្រើន ដោយនូវការនិមិត្ត ប៉ុន្តែបិទទុកវិញភ្លាមៗ;

៤៨ ហេតុដូច្នោះហើយ ចុងបំផុត ទំហឹ[ក] កំពស់ ជំរៅ និងទុក្ខវេទនានៃការនោះ នោះពួកគេពុំយល់ឡើយ គឺគ្មានមនុស្សណា

៣៤ *ក* ម៉ាថាយ ១២:៣១–៣២.
ស.ប. អត់ទោស, អភ័យទោស.
៣៥ *ក* ២ ពេត្រុស ២:២០–២២;
អាលម៉ា ៣៩:៦.
ស.ប. អំពើបាបដ៏អត់ឱនមិនបាន.
*ខ* ហេព្រើរ ៦:៤–៦; ១ នីហ្វៃ ១៩:៧;
គ. និង ស. ១៣២:២៧.
៣៦ *ក* វិវរ. ១៩:២០; ២០:១០; ២១:៨;
២ នីហ្វៃ ៩:១៦; ២៨:២៣;
អាលម៉ា ១២:១៦–១៨;
គ. និង ស. ៦៣:១៧.
៣៧ *ក* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
៣៨ *ក* ស.ប. ពួកកូនអន្តរធាន.
៣៩ *ក* ក.ន. ត្រូវបានប្រោសលោះ;
សូមមើល ខទី ៣៨ ។
មនុស្សទាំងអស់នឹងបានរស់ឡើងវិញ ។
សូមមើល គម្ពីរអាលម៉ា
១១:៤១–៤៥.
ស.ប. ប្រោសឲ្យមានជីវិតឡើងវិញ.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
៤០ *ក* ៣ នីហ្វៃ ២៧:១៣–២២.
ស.ប. ដំណឹងល្អ;
ផែនការនៃសេចក្ដីប្រោសលោះ.
៤១ *ក* ស.ប. ការឆ្កាង.
*ខ* អេសាយ ៥៣:៤–១២;
ហេព្រើរ ៩:២៨.
*គ* ១ យ៉ូហាន ២:១–២.
*ឃ* ស.ប. ការញែកជាបរិសុទ្ធ.
*ង* ស.ប. ប្រោសលោះ,
បានប្រោសលោះ,
សេចក្ដីប្រោសលោះ.
៤២ *ក* ស.ប. សេចក្ដីសង្គ្រោះ.
៤៤ *ក* គ. និង ស. ១៩:៦–១២.
*ខ* ស.ប. សេចក្ដីជាប់ទោស.
*គ* ស.ប. អារក្ស.
*ឃ* អេសាយ ៦៦:២៤;
ម៉ាកុស ៩:៤៣–៤៨.
៤៥ *ក* គ. និង ស. ២៩:២៨–២៩.
៤៨ *ក* វិវរ. ២០:១.

មួយឡើយ លើកលែងតែពួកអ្នកទាំងនោះ ដែលត្រូវបានតែងតាំងចំពោះការផាប់ទោសនេះប៉ុណ្ណោះ ។

៤៩ ហើយយើងខ្ញុំបានឮសម្លេងពោលថា៖ ចូរសរសេរពីការនិមិត្តនេះ ត្បិតមើលន៏ នេះហើយជាចុងបំផុតនៃការនិមិត្តអំពីការរងទុក្ខ វេទនានៃមនុស្សទមិឡល្មើស ។

៥០ ហើយជាថ្មីទៀត យើងខ្ញុំថ្លែងទីបន្ទាល់ — ត្បិតយើងខ្ញុំបានឃើញ ហើយបានឮ ហើយនេះគឺជាទីបន្ទាល់អំពីដំណឹងល្អនៃព្រះគ្រីស្ទ អំពីពួកអ្នកដែលនឹងចេញមក ក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិតថា —

៥១ ពួកគេនេះហើយដែលបានទទួលទីបន្ទាល់ពីព្រះយេស៊ូវ ហើយបានជឿដល់ព្រះនាមទ្រង់ ហើយបានទទួលបុណ្យជ្រមុជទឹក តាម បែបនៃការបញ្ចុះរបស់ទ្រង់ ដោយបានកប់ក្នុងទឹក ដោយនូវព្រះនាមរបស់ទ្រង់ ហើយនេះគឺតាមព្រះបញ្ញត្តិ ដែលទ្រង់បានប្រទានមក —

៥២ ថាដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះពួកគេអាចបានលាង ហើយសំអាតឲ្យជ្រះចេញពីអស់ទាំងអំពើបាបរបស់ពួកគេ ហើយទទួលយកព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ ពីអ្នកណាដែលត្រូវបានតែងតាំង ហើយបានភ្ជាប់ចំពោះអំណាចនេះ;

៥៣ ហើយជាអ្នកដែលបានឈ្នះដោយសារសេចក្ដីជំនឿ ហើយបានភ្ជាប់ដោយសារព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ដែលព្រះវរបិតាចាត់ឲ្យមកលើអស់អ្នកណា ដែលសុចរិតហើយពិត ។

៥៤ ពួកគេនេះហើយដែលជាសាសនាចក្រនៃកូនច្បង ។

៥៥ ពួកគេនេះហើយដែលព្រះវរបិតាបានប្រទានគ្រប់ទាំងអស់ទៅក្នុងដៃរបស់ពួកគេ —

៥៦ ពួកគេនេះហើយដែលជាសង្ឃ និងស្ដេចទាំងឡាយ ដែលបានទទួលភាពពោរពេញរបស់ទ្រង់ និងសិរីល្អរបស់ទ្រង់;

៥៧ ហើយជាពួកសង្ឃនៃព្រះដ៏ខ្ពស់បំផុត តាមរបៀបម៉ិលគីស្សាដែក ដែលត្រូវធ្វើតាមរបៀបហេណុក ដែលត្រូវធ្វើតាមរបៀបនៃព្រះ រាជបុត្រាបង្កើតតែមួយ ។

៥៨ ហេតុដូច្នោះហើយ ដូចជាបានសរសេរទុកថា ពួកគេសុទ្ធតែជាព្រះ គឺជាបុត្រានៃព្រះ —

៥៩ ហេតុដូច្នោះហើយ គ្រប់ទាំងអស់ជារបស់ផងពួកគេ ទោះជាមានជីវិត ឬសេចក្ដីស្លាប់ ឬរបស់នៅជំនាន់សព្វថ្ងៃ ឬទៅមុខក្ដី គឺគ្រប់ទាំង អស់ជារបស់ផងពួកគេ ហើយពួកគេជារបស់ផងព្រះគ្រីស្ទ ហើយព្រះគ្រីស្ទ ទ្រង់ជារបស់ព្រះ ។

៦០ ហើយពួកគេនឹងបានឈ្នះគ្រប់ការណ៍ទាំងអស់ ។

៦១ ហេតុដូច្នោះហើយ ចូរកុំឲ្យអ្នកណាអួតពីមនុស្សឡើយ ប៉ុន្តែចូរឲ្យអ្នកនោះដំកើងព្រះវិញ ដែលនឹងដាក់អស់ទាំងខ្មាំងសត្រូវនៅ ក្រោមព្រះបាទទ្រង់ ។

---

៤៨ *ខ* ក.ន. កាត់ទោស, ធ្វើទុក្ខ.
*គ* អាលម៉ា ៤២:២២.

៥០ *ក* ស.ប. ទីបន្ទាល់.
*ខ* ស.ប. ដំណើររស់ឡើងវិញ.

៥១ *ក* គ. និង ស. ២០:២៥–២៧, ៣៧.
*ខ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*គ* គ. និង ស. ១២៨:១៣.
*ឃ* រ៉ូម ៦:៣–៥.
ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកដោយការពន្លិច.

៥២ *ក* ២ នីហ្វៃ ៩:២៣;
ម៉ូរ៉ូណៃ ៨:២៥–២៦.
*ខ* ស.ប. សុទ្ធ, សុទ្ធសាធ.
*គ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ; ដៃ, ការដាក់.
*ឃ* ស.ប. តែងតាំង, ការតែងតាំង.
*ង* ស.ប. សិទ្ធិអំណាច.

៥៣ *ក* ស.ប. ភ្ជាប់, ការភ្ជាប់.
*ខ* អេភេ. ១:១៣;
គ. និង ស. ៨៨:៣–៥.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា.

៥៤ *ក* ហេព្រើរ ១២:២៣;
គ. និង ស. ៩៣:២១–២២.
ស.ប. កូនច្បង.

៥៥ *ក* ២ ពេត្រុស ១:៣–៤;
គ. និង ស. ៥០:២៦–២៨;
៨៤:៣៥–៣៨.

៥៦ *ក* និក្ខ. ១៩:៦; វិវរ. ១:៥–៦; ២០:៦.

៥៧ *ក* ស.ប. សង្ឃ, បព្វជិតភាពម៉ិលគីស្សាដែក.
*ខ* លោកុ. ៥:២១–២៤.
ស.ប. ហេណុក.
*គ* គ. និង ស. ១០៧:១–៤.

៥៨ *ក* ទំនុក. ៨២:១, ៦;
យ៉ូហាន ១០:៣៤–៣៦.
ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
*ខ* ស.ប. បុត្រាបុត្រីនៃព្រះ.
*គ* គ. និង ស. ១២១:៣២.
ស.ប. ព្រះ, ក្រុមព្រះ.

៥៩ *ក* លូកា ១២:៤២–៤៤;
៣ នីហ្វៃ ២៨:១០;
គ. និង ស. ៨៤:៣៦–៣៨.

៦០ *ក* វិវរ. ៣:៥; ២១:៧.

៦១ *ក* យ៉ូហាន ៥:៤១–៤៤;
១ កូរិន. ៣:២១–២៣.
*ខ* ២ នីហ្វៃ ៣៣:៦;
អាលម៉ា ២៦:១១–១៦.
ស.ប. សិរីល្អ.
*គ* គ. និង ស. ៤៩:៦.

៦២ ពួកអ្នកទាំងនេះនឹង[ក]អាស្រ័យនៅក្នុង[ខ]វត្តមាននៃព្រះ និងព្រះគ្រីស្ទរបស់ទ្រង់ នៅអស់កល្បជានិច្ច និងរៀងដរាបតទៅ ។

៦៣ [ក]ពួកគេនេះហើយ ដែលទ្រង់នឹងនាំមកជាមួយព្រះអង្គ ក្នុងកាលទ្រង់យាងមកក្នុងពពកនៅលើមេឃ ដើម្បី[ខ]មក [គ]សោយរាជ្យលើរាស្ត្រ ទ្រង់នៅលើផែនដី ។

៦៤ ពួកគេនេះហើយដែលនឹងមានចំណែកក្នុងដំណើររស់ឡើងវិញ[ក]ទីមួយ ។

៦៥ ពួកគេនេះហើយ ដែលនឹងចេញមក ក្នុង[ក]ដំណើររស់ឡើងវិញនៃមនុស្សសុចរិត ។

៦៦ ពួកគេនេះហើយ ដែលមកឯ[ក]ភ្នំ[ខ]ស៊ីយ៉ូន ហើយមកឯទីក្រុងនៃព្រះដ៏មានព្រះជន្មរស់នៅ គឺជាទិស្ថានសួគ៌ ជាទីបរិសុទ្ធបំផុតជាងអ្វីៗ ទាំងអស់ ។

៦៧ ពួកគេនេះហើយ ដែលមកឯបណ្ដាទេវតាដ៏ឥតគណនាមកឯជំនុំទូទៅ និងសាសនាចក្រ[ក]នៃហេណុក និង[ខ]នៃកូនច្បង ។

៦៨ ពួកគេនេះហើយ ដែលមានឈ្មោះ[ក]កត់នៅស្ថានសួគ៌ ជាទីដែលព្រះ និងព្រះគ្រីស្ទ[ខ]ជាចៅក្រមនៃមនុស្សទាំងអស់ ។

៦៩ ពួកគេនេះហើយ ដែល[ក]មនុស្សសុចរិតដែលបានធ្វើឲ្យ[ខ]ល្អឥតខ្ចោះ តាមរយៈព្រះយេស៊ូវដ៏ជាអ្នកកណ្ដាលនៃ[គ]សេចក្ដីសញ្ញាថ្មី ដែលបាននាំមកនូវ[ឃ]ដង្វាយធួនដ៏ល្អឥតខ្ចោះនេះ តាមរយៈ[ង]ការច្រួចព្រះលោហិតរបស់ព្រះអង្គផ្ទាល់ ។

៧០ ពួកគេនេះហើយ ដែលមានរូបកាយខាង[ក]សេឡេស្ទាល ដែលមាន[ខ]រស្មីដូចជា[គ]ព្រះអាទិត្យ គឺជាសិរីល្អនៃព្រះ ដែលខ្ពស់បំផុតជាងអ្វីៗ ទាំងអស់ ដែលមានរស្មីដូចជាព្រះអាទិត្យនៅលើផ្ទៃមេឃ ដែលបានសរសេរទុកជានិមិត្តរូប ។

៧១ ហើយជាថ្មីទៀត យើងខ្ញុំបានឃើញពិភព[ក]ទេរេសទ្រាល ហើយមើលចុះ និងមើលន៏ ពួកគេនេះហើយ ដែលជារបស់ផងទេរេស ទ្រាល ដែលមានសិរីល្អទីទៃពីសាសនាចក្រនៃកូនច្បង ដែលបានទទួលភាពពោរពេញនៃព្រះវរបិតា គឺដូចជា[ខ]ព្រះច័ន្ទខុសគ្នាពីព្រះអាទិត្យ នៅលើផ្ទៃមេឃដែរ ។

៧២ មើលចុះ ពួកគេនេះហើយ ដែលបានស្លាប់ទៅ [ក]ដោយគ្មាន[ខ]ក្រិត្យវិន័យ ។

៧៣ ហើយពួកគេក៏ជា[ក]វិញ្ញាណនៃមនុស្សដែល[ខ]ជាប់ឃុំ ដែលព្រះរាជបុត្រាបានយាងទៅជួប [គ]ហើយផ្សាយ[ឃ]ដំណឹងល្អដល់ពួកគេ ដើម្បីឲ្យ ពួកគេអាចបានជាប់ជំនុំជំរះខាងឯសាច់ឈាម តាមបែបមនុស្ស;

៧៤ ដែលពុំបានទទួល[ក]ទីបន្ទាល់ពីព្រះយេស៊ូវ កាលនៅក្នុងសាច់ឈាម ប៉ុន្តែក្រោយមក បានទទួលទីបន្ទាល់នោះ ។

៧៥ ពួកគេនេះហើយ ដែលជាមនុស្សមានកិត្តិយសនៅលើផែនដី ដែលខ្វាក់ដោយសារឧបាយកលនៃមនុស្ស ។

៧៦ ពួកគេនេះហើយ ដែលទទួលសិរីល្អរបស់ទ្រង់ ប៉ុន្តែពុំមែនភាពពោរពេញរបស់ទ្រង់ឡើយ ។

៧៧ ពួកគេនេះហើយ ដែលទទួលវត្តមាននៃព្រះរាជបុត្រា ប៉ុន្តែពុំមែនភាពពោរពេញនៃព្រះវរបិតាឡើយ ។

៧៨ ហេតុដូច្នោះហើយ ពួកគេជា[ក]រូបកាយខាងទេរេសទ្រាល

៦២ *ក* ទំនុក. ១៥:១–៣; ២៤:៣–៤;
១ នីហ្វៃ ១៥:៣៣–៣៤;
ម៉ូសេ ៦:៥៧.
*ខ* គ. និង ស. ១៣០:៧.
ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៦៣ *ក* គ. និង ស. ៨៨:៩៦–៩៨.
ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ម៉ាថាយ ២៤:៣០.
*គ* គ. និង ស. ៥៨:២២.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — រជ្ជកាលនៃព្រះគ្រីស្ទនៅសហស្សវត្សរ៍.
៦៤ *ក* វិវ. ២០:៦.
៦៥ *ក* ស.ប. ដំណើររស់ឡើងវិញ.
៦៦ *ក* អេសាយ ២៤:២៣;
ហេព្រើរ ១២:២២–២៤;
វិវរ. ១៤:១;
គ. និង ស. ៨៤:២; ១៣៣:៥៦.
*ខ* ស.ប. ស៊ីយ៉ូន.
៦៧ *ក* គ. និង ស. ៤៥:៩–១២.
*ខ* ហេព្រើរ ១២:២៣;
គ. និង ស. ៧៦:៥៣–៥៤.
ស.ប. កូនច្បង.
៦៨ *ក* ស.ប. សៀវភៅជីវិត.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
៦៩ *ក* គ. និង ស. ១២៩:៣; ១៣៨:១២.
*ខ* ម៉ូរ៉ូណៃ ១០:៣២–៣៣.
*គ* ស.ប. សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច.
*ឃ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ង* ស.ប. លោហិត.
៧០ *ក* គ. និង ស. ៨៨:២៨–២៩;
១៣១:១–៤; ១៣៧:៧–១០.
ស.ប. សិរីល្អនៃសេឡេស្ទាល.
*ខ* គ. និង ស. ១៣៧:១–៤.
*គ* ម៉ាថាយ ១៣:៤៣.
៧១ *ក* គ. និង ស. ៨៨:៣០.
ស.ប. សិរីល្អនៃទេរេសទ្រាល.
*ខ* ១ កូរិន. ១៥:៤០–៤១.
៧២ *ក* គ. និង ស. ១៣៧:៧, ៩.
*ខ* ស.ប. ក្រិត្យវិន័យ.
៧៣ *ក* អាលម៉ា ៤០:១១–១៤.
ស.ប. វិញ្ញាណ.
*ខ* គ. និង ស. ៨៨:៩៩; ១៣៨:៨.
ស.ប. ស្ថាននរក;
សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់.
*គ* ១ ពេត្រុស ៣:១៩–២០; ៤:៦;
គ. និង ស. ១៣៨:២៨–៣៧.
*ឃ* ស.ប. ដំណឹងល្អ.
៧៤ *ក* ស.ប. ទីបន្ទាល់.
៧៨ *ក* ១ កូរិន. ១៥:៤០–៤២.

ហើយពុំមែនជារូបកាយខាងសេឡេស្ទាលទេ ហើយមានសិរីល្អទីទៃពីគ្នា ដូចជាព្រះច័ន្ទខុសគ្នាពីព្រះអាទិត្យដែរ ។

៧៩ ពួកគេនេះហើយ ដែលពុំ[ក]ក្លាហានក្នុងទីបន្ទាល់ពីព្រះយេស៊ូវ ហេតុដូច្នោះហើយ ពួកគេពុំបានមកុដលើនគរនៃព្រះរបស់យើងឡើយ ។

៨០ ហើយឥឡូវ នេះជាចុងបំផុតនៃការនិមិត្ត ដែលយើងខ្ញុំបានឃើញអំពីពិភពទេរេសទ្រាល ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យយើងខ្ញុំ សរសេរ ក្នុងកាលយើងខ្ញុំនៅក្នុងព្រះវិញ្ញាណនៅឡើយនោះ ។

៨១ ហើយជាថ្មីទៀត យើងខ្ញុំបានឃើញសិរីល្អនៃ[ក]ទេឡេស្ទាល ជាសិរីល្អដ៏តូចជាង គឺដូចជារស្មីនៃតារាទាំងឡាយខុសគ្នាពីរស្មីនៃ ព្រះច័ន្ទនៅលើផ្ទៃមេឃដែរ ។

៨២ ពួកគេនេះហើយ ដែលពុំបានទទួលដំណឹងល្អនៃព្រះគ្រីស្ទ ឬក៏[ក]ទីបន្ទាល់ពីព្រះយេស៊ូវដែរ ។

៨៣ ពួកគេនេះហើយ ដែលពុំបដិសេធព្រះវិញ្ញាណបរិសុទ្ធឡើយ ។

៨៤ ពួកគេនេះហើយ ដែលត្រូវបោះចុះទៅ[ក]ស្ថាននរក ។

៨៥ ពួកគេនេះហើយ ដែលនឹងពុំបានប្រោសលោះពី[ក]អារក្សឡើយ រហូតដល់ដំណើររស់ឡើងវិញចុងក្រោយ[ខ]បង្អស់ រហូតដល់ព្រះ អម្ចាស់ គឺព្រះគ្រីស្ទដ៏ជា[គ]កូនចៀម បានសំរេចកិច្ចការរបស់ទ្រង់ជាស្រេច ។

៨៦ ពួកគេនេះហើយ ដែលពុំបានទទួលភាពពោរពេញរបស់ទ្រង់ នៅក្នុងបរលោកដ៏អស់កល្បជានិច្ចឡើយ ប៉ុន្តែបានទទួលព្រះវិញ្ញាណ បរិសុទ្ធ តាមរយៈការងារខាងទេរេសទ្រាលវិញ;

៨៧ ហើយទេរេសទ្រាលតាមរយៈ[ក]ការងារខាងសេឡេស្ទាល ។

៨៨ ហើយទេឡេស្ទាលក៏ទទួលព្រះវិញ្ញាណបរិសុទ្ធ ពីការងារបំរើនៃពួកទេវតា ដែលបានចាត់ឲ្យបំរើដល់ពួកគេ ឬក៏ពួកអ្នកដែលបាន ចាត់ឲ្យធ្វើជាវិញ្ញាណខាងការងារបំរើដល់ពួកគេ; ត្បិតពួកគេនឹងបានទៅជាអ្នកគ្រងសេចក្ដីសង្គ្រោះទុកជាមរតក ។

៨៩ ហើយយ៉ាងនោះយើងខ្ញុំបានឃើញនៅក្នុងការនិមិត្តពីស្ថានសួគ៌ នូវសិរីល្អនៃទេឡេស្ទាល ដែលហួសលើសពីអស់ទាំងយោបល់;

៩០ ហើយគ្មានមនុស្សណាមួយស្គាល់សិរីល្អនោះឡើយ លើកលែងតែអ្នកនោះដែលព្រះទ្រង់បានបើកសំដែង ឲ្យឃើញសិរីល្អនោះ ប៉ុណ្ណោះ ។

៩១ ហើយយ៉ាងនោះយើងបានឃើញសិរីល្អនៃទេរេសទ្រាល ដែលហួសលើសអស់ទាំងអ្វីៗដែលជាសិរីល្អនៃទេឡេស្ទាលទៅទៀត គឺនៅក្នុងសិរីល្អ និងនៅក្នុងអំណាច និងនៅក្នុងពលំ និងនៅក្នុងអាណាចក្រ ។

៩២ ហើយយ៉ាងនោះយើងបានឃើញសិរីល្អនៃសេឡេស្ទាល ដែលហួសលើសជាងអ្វីៗទាំងអស់ — ជាកន្លែងដែលព្រះ គឺព្រះវរបិតា សោយរាជ្យនៅលើបល្ល័ង្ករបស់ទ្រង់ នៅអស់កល្បជានិច្ច និងរៀងដរាបតទៅ;

៩៣ នៅចំពោះបល្ល័ង្កនោះគ្រប់ទាំងអស់ក្រាបចុះ ដោយនូវ[ក]ការគោរពកោតក្រែងដ៏ទន់ទាបរាបសា ហើយដំកើងដល់ព្រះអង្គអស់កល្ប ជានិច្ច និងរៀងដរាបតទៅ ។

៩៤ ពួកគេដែលអាស្រ័យនៅក្នុង[ក]វត្តមានរបស់ទ្រង់ គឺសុទ្ធតែជា[ខ]សាសនាចក្រនៃកូនច្បង; ហើយពួកគេមើលឃើញដូចជាពួកគេត្រូវបាន មើលឃើញ ហើយ[គ]ស្គាល់ដូចជាពួកគេត្រូវស្គាល់ ដោយបានទទួលនូវភាពពោរពេញរបស់ទ្រង់ និង[ឃ]ព្រះគុណរបស់ទ្រង់;

៩៥ ហើយព្រះអង្គធ្វើឲ្យពួកគេបាន[ក]ស្មើគ្នា នៅក្នុងអំណាច និងនៅក្នុងពលំ និងនៅក្នុងអាណាចក្រ ។

៩៦ ហើយសិរីល្អនៃសេឡេស្ទាលគឺមានម៉្យាង ដូចជា[ក]ព្រះអាទិត្យមានរស្មីម៉្យាង ។

៩៧ ហើយសិរីល្អនៃទេរេសទ្រាលគឺមានម៉្យាង ដូចជាព្រះច័ន្ទមានរស្មីម៉្យាង ។

៩៨ ហើយសិរីល្អនៃទេឡេស្ទាលគឺមានម៉្យាង ដូចជាតារាទាំងឡាយមានរស្មីម៉្យាង; ត្បិតដូចជាតារាមានរស្មីទីទៃពីគ្នាយ៉ាងណានោះនៅពិភពទេឡេស្ទាលក៏មានសិរីល្អទីទៃពីគ្នាយ៉ាងនោះដែរ;

៧៩ *ក* គ. និង ស. ៥៦:១៦.
៨១ *ក* គ. និង ស. ៨៨:៣១.
ស.ប. សិរីល្អនៃទេឡេស្ទាល.
៨២ *ក* គ. និង ស. ១៣៨:២១.
៨៤ *ក* ២ នីហ្វៃ ៩:១២;
អាលម៉ា ១២:១១.
ស.ប. ស្ថាននរក.
៨៥ *ក* ស.ប. អារក្ស.
*ខ* អាលម៉ា ១១:៤១;
គ. និង ស. ៤៣:១៨;
៨៨:១០០–១០១.
*គ* ស.ប. កូនចៀមនៃព្រះ.
៨៧ *ក* គ. និង ស. ១៣៨:៣៧.
៩៣ *ក* ស.ប. ការគោរពកោតក្រែង.
៩៤ *ក* គ. និង ស. ១៣០:៧.
*ខ* ស.ប. កូនច្បង.
៩៤ *គ* ១ កូរិន. ១៣:១២.
*ឃ* ស.ប. ព្រះគុណ.
៩៥ *ក* គ. និង ស. ២៩:១៣; ៧៨:៥–៧;
៨៤:៣៨; ៨៨:១០៧; ១៣២:២០.
៩៦ *ក* ១ កូរិន. ១៥:៤០–៤១.

៩៩ ត្បិតពួកគេទាំងនេះគឺជាពួករបស់ប៉ុល និងរបស់អ័ប៉ុឡូស
និងរបស់កេផាស ។
១០០ ពួកគេនេះហើយ ដែលថាពួកគេខ្លះជារបស់អ្នក
ណាមួយ ហើយខ្លះជារបស់អ្នកណាផ្សេងទៀត — ខ្លះជា
របស់ព្រះគ្រីស្ទ ហើយ ខ្លះជារបស់យ៉ូហាន ហើយខ្លះជា
របស់ម៉ូសេ ហើយខ្លះជារបស់អេលីយ៉ាស ហើយខ្លះជា
របស់អេសាយអាស ហើយខ្លះជារបស់អេសាយ ហើយ
ខ្លះជារបស់ហេណុក;
១០១ ប៉ុន្តែពុំបានទទួលដំណឹងល្អ ឬទីបន្ទាល់ពីព្រះយេស៊ូវ
ឬពីពួកព្យាការី ឬពីសេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាល
ជានិច្ចឡើយ ។
១០២ នៅទីបញ្ចប់ ពួកគេនេះហើយ ដែលនឹងមិនត្រូវបានរួម
គ្នាជាមួយនឹងពួកបរិសុទ្ធ ដើម្បីឲ្យបានលើកឡើងទៅរកសាសនា
ចក្រ នៃកូនច្បង ហើយបានទទួលទៅក្នុងពពកឡើយ ។
១០៣ ពួកគេនេះហើយ ដែលជាពួកកំភូត និងពួកមន្តអាគម
និងពួកកំផិត និងពួកសហាយស្មន់ និងពួកដែលចូលចិត្តហើយ
កុហក ។
១០៤ ពួកគេនេះហើយ ដែលរងទុក្ខសេចក្ដីក្រោធនៃ
ព្រះនៅលើផែនដី ។
១០៥ ពួកគេនេះហើយ ដែលរងទុក្ខទោស ក្នុងភ្លើង
ដ៏ឆេះអស់កល្បជានិច្ច ។
១០៦ ពួកគេនេះហើយ ដែលត្រូវបោះចុះទៅស្ថាននរក ហើយ
រងទុក្ខសេចក្ដីក្រោធនៃព្រះដ៏មហិទ្ធិឫទ្ធិ រហូតដល់ពេលពេញកំណត់
កាលព្រះគ្រីស្ទនឹងដាក់អស់ទាំងខ្មាំងសត្រូវនៅក្រោមព្រះបាទទ្រង់
ហើយនឹងធ្វើឲ្យកិច្ចការរបស់ទ្រង់បានល្អឥតខ្ចោះ;
១០៧ កាលទ្រង់នឹងប្រគល់នគរ ហើយថ្វាយនគរដល់ព្រះវរបិតា
ដោយឥតមានប្រឡាក់ ទាំងមានព្រះបន្ទូលថា៖ ទូលបង្គំបានឈ្នះ
ហើយបានជាន់ក្នុងធុងទំពាំងបាយជូរតែម្នាក់ឯង គឺជាឈ្នាបធុង
នៃស្រាទំពាំងបាយជូរ ជាសេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃ
ព្រះដ៏ មហិទ្ធិឫទ្ធិ ។
១០៨ ខណៈនោះ ទ្រង់នឹងត្រូវបានពាក់សិរីល្អរបស់ទ្រង់ ទុកជា
មកុដ ដើម្បីអង្គុយនៅលើបល្ល័ង្កនៃព្រះចេស្ដារបស់ទ្រង់ ដើម្បី
សោយ រាជ្យនៅអស់កល្បជានិច្ច និងរៀងដរាបតទៅ ។
១០៩ ប៉ុន្តែមើលចុះ ហើយមើលន៏ យើងខ្ញុំបានឃើញសិរីល្អ
និងបណ្ដាជននៃពិភពទេឡេស្ទាល ថាពួកគេមានជាច្រើនដ៏ឥត
គណនា ដូចជាតារា នៅលើផ្ទៃមេឃ ឬដូចជាខ្សាច់
នៅមាត់សមុទ្រ;
១១០ ហើយបានឮសម្លេងនៃព្រះអម្ចាស់មានព្រះបន្ទូលថា៖
ពួកគេទាំងអស់គ្នានឹងលុតជង្គង់ ហើយគ្រប់ទាំងអណ្ដាតនឹង
សារភាពដល់ ទ្រង់ដែលគង់នៅលើបល្ល័ង្ក នៅអស់កល្បជានិច្ច
និងរៀងដរាបតទៅ;
១១១ ត្បិតពួកគេនឹងត្រូវបានជំនុំជំរះ តាមកិច្ចការទាំងឡាយ
របស់ខ្លួន ហើយមនុស្សគ្រប់រូបនឹងបានទទួល តាមកិច្ចការទាំង
ឡាយរបស់ ខ្លួន គឺអាណាចក្ររបស់ខ្លួន នៅក្នុងវិមានទាំងឡាយ
ដែលបានរៀបចំទុក;
១១២ ហើយពួកគេនឹងធ្វើជាពួកអ្នកបំរើនៃព្រះដ៏ខ្ពស់បំផុត;
ប៉ុន្តែឯកន្លែងដែលព្រះនិងព្រះគ្រីស្ទគង់នៅ នោះពួកគេពុំអាចមក
បានឡើយ គឺជាពិភពទាំងឡាយដ៏គ្មានទីបញ្ចប់ ។
១១៣ នេះហើយជាទីបញ្ចប់នៃការនិមិត្ត ដែលយើងខ្ញុំឃើញ
ដែលយើងខ្ញុំត្រូវបានបញ្ជាឲ្យកត់ ក្នុងកាលយើងខ្ញុំនៅក្នុង
ព្រះវិញ្ញាណនៅ ឡើយនោះ ។
១១៤ ប៉ុន្តែមហិមា និងអស្ចារ្យណាស់ហ្ន៎កិច្ចការទាំងឡាយនៃ
ព្រះអម្ចាស់ និងសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគររបស់ទ្រង់
ដែល ទ្រង់បានបង្ហាញដល់យើងខ្ញុំ ដែលហួសលើសអស់

៩៩ *ក* ១ កូរិន. ៣:៤–៧, ២២.
១០១ *ក* ស.ប. សេចក្ដីសញ្ញាថ្មី
ហើយអស់កល្បជានិច្ច.
១០២ *ក* ១ ថែស្សា. ៤:១៦–១៧;
គ. និង ស. ៨៨:៩៦–៩៨.
*ខ* គ. និង ស. ៧៨:២១.
១០៣ *ក* វិវរ. ២១:៨;
គ. និង ស. ៦៣:១៧–១៨.
*ខ* ស.ប. សេចក្ដីកុហក.
*គ* ស.ប. អំពើកំផិត.
១០៤ *ក* ស.ប. សេចក្ដីជាប់ទោស.
១០៥ *ក* យូដាស ១:៧.
១០៦ *ក* ស.ប. ស្ថាននរក.
*ខ* គ. និង ស. ១៩:៣–២០.
*គ* គ. និង ស. ៨៧:៦.
*ឃ* អេភេ. ១:១០.
*ង* ១ កូរិន. ១៥:២៤–២៨.
*ច* ហេព្រើរ ១០:១៤.
១០៧ *ក* វិវរ. ១៩:១៥;
គ. និង ស. ៨៨:១០៦;
១៣៣:៤៦–៥៣.
*ខ* លោកុ. ៤៩:១០–១២;
អេសាយ ៦៣:១–៣.
១០៨ *ក* គ. និង ស. ១៣៧:៣.
១១០ *ក* ភីលីព ២:៩–១១;
ម៉ូសាយ ២៧:៣១.
១១១ *ក* វិវរ. ២០:១២–១៣.
ស.ប. កិច្ចការ.
*ខ* យ៉ូហាន ១៤:២;
គ. និង ស. ៥៩:២; ៨១:៦.
១១២ *ក* គ. និង ស. ២៩:២៩.
*ខ* វិវរ. ២១:២៣–២៧.
១១៤ *ក* វិវរ. ១៥:៣; មរមន ៩:១៦–១៨;
ម៉ូសេ ១:៣–៥.
*ខ* យ៉ាកុប ៤:៨.

ទាំងយោបល់ នៅក្នុងសិរីល្អ និងនៅក្នុងពល់ និងនៅក្នុងអាណាចក្រទៅទៀត;
១១៥ ដែលទ្រង់បានបញ្ជាយើងខ្ញុំ ថាយើងខ្ញុំមិនត្រូវកត់ឡើយ ក្នុងកាលយើងខ្ញុំកំពុងតែនៅក្នុងព្រះវិញ្ញាណ ហើយគ្មានច្បាប់ឲ្យមនុស្សណានិយាយបានឡើយ;
១១៦ ឬមានមនុស្សណាអាចធ្វើឲ្យបានស្គាល់ឡើយ ត្បិតរបស់ទាំងនោះ គ្រាន់តែបានឃើញ ហើយយល់ ដោយសារព្រះចេស្ដានៃព្រះ វិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ដែលព្រះទ្រង់ប្រទានមកលើអស់អ្នកណាដែលស្រឡាញ់ទ្រង់ ហើយសំអាតពួកគេជាបរិសុទ្ធនៅចំពោះទ្រង់;
១១៧ ចំពោះពួកអ្នកទាំងនោះ សូមឲ្យទ្រង់ប្រទានឯកសិទ្ធិនេះឲ្យគេបានឃើញហើយស្គាល់ដោយខ្លួនគេចុះ;
១១៨ ថាតាមរយៈព្រះចេស្ដា និងការងារនៃព្រះវិញ្ញាណ កាលនៅក្នុងសាច់ឈាម នោះសូមឲ្យពួកគេអាចទ្រាំទ្រវត្តមានរបស់ទ្រង់បាន នៅក្នុងពិភពនៃសិរីល្អ ។
១១៩ ហើយចំពោះព្រះ និងកូនចៀម នោះសូមថ្វាយសិរីល្អ និងកិត្តិយស និងអាណាចក្រ នៅអស់កល្បជានិច្ច និងរៀងដរាបតទៅ ។ អាម៉ែន ៕

## កណ្ឌទី ៧៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរ៉ាំ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣២ (*History of the Church, *១:២៥៣–២៥៥) ។ ព្យាការីបានសរសេរថា៖ «ក្នុងការទាក់ទងទៅនឹងការបកប្រែព្រះគម្ពីរ នោះខ្ញុំបានទទួលការពន្យល់ ដែលមានដូចតទៅនេះ ស្ដីអំពីវិវរណៈនៃលោកយ៉ូហាន» (*History of the Church, *១:២៥៣)* ។

*១–៤, សត្វទាំងឡាយមានវិញ្ញាណ ហើយនឹងអាស្រ័យនៅក្នុងការសប្បាយរីករាយដ៏អស់កល្បជានិច្ច នៅលើផែនដីដ៏អមតៈ; ៥–៧, ផែនដីនេះមានជីវិតរស់នៅខាងសាច់ឈាមអស់ ៧.០០០ឆ្នាំ; ៨–១០, ពួកទេវតានានាសាងដំណឹងល្អឡើងវិញ ហើយបំរើនៅលើផែនដី; ១១, ការត្រាប់មនុស្ស ១៤៤.០០០ នាក់; ១២–១៤, ព្រះគ្រីស្ទនឹងយាងមក នៅដើមឆ្នាំទីប្រាំពីរពាន់; ១៥, ព្យាការីពីរនាក់នឹងត្រូវបាន លើកឡើងចំពោះសាសន៍យូដា ។*

សំនួរះ តើអ្វីទៅជាសមុទ្រកែវ ដែលយ៉ូហានបានពោលដល់ នៅជំពូកទី៤ ខ៦ ក្នុងគម្ពីរវិវរណៈ ?
ចម្លើយ៖ គឺជាផែនដី នៅក្នុងស្ថានភាពដែលបានញែកចេញជាបរិសុទ្ធ ប្រកបដោយអមតភាព និងអស់កល្បជានិច្ច ។
២ សំនួរះ តើត្រូវឲ្យយើងយល់យ៉ាងណា ពីសត្វទាំងបួន ដែលបានពោលដល់ នៅក្នុងខដដែលនោះ ?
ចម្លើយ៖ សត្វទាំងបួននោះ គឺជាការនិយាយប្រៀបធៀប ដែលបានប្រើដោយយ៉ូហាន ជាអ្នកទទួលវិវរណៈ ក្នុងការអធិប្បាយអំពី ស្ថានសួគ៌ ជាស្ថានបរមសុខនៃព្រះ អំពីសុភមង្គលនៃមនុស្ស និងសត្វ និងសត្វលូនវារ និងសត្វហើរលើអាកាស; អ្វីដែលជាវិញ្ញាណ មានរូបភាពដូចជាអ្វីខាងសាច់ឈាម; ហើយអ្វីដែលជាសាច់ឈាម មានរូបភាពដូចជាអ្វីខាងវិញ្ញាណ; វិញ្ញាណនៃមនុស្សមានរូប ភាពដូចជាប្រាណរបស់គេ ក៏ដូចជាវិញ្ញាណនៃសត្វ ព្រមទាំងសត្វលោកគ្រប់រូបផង ដែលព្រះទ្រង់បានបង្កើតមក ។
៣ សំនួរះ តើសត្វទាំងបួននោះមានន័យដល់សត្វនីមួយៗតែប៉ុណ្ណោះ ឬក៏ជាតំណាងតាមក្រុម ឬជំពូក ?
ចម្លើយ៖ សត្វទាំងនោះមានន័យដល់សត្វបួនគត់ ដែលបានបង្ហាញដល់យ៉ូហាន ដើម្បីធ្វើជាតំណាងពីសិរីល្អនៃក្រុមទាំង

១១៥*ក* ២ កូរិន. ១២:៤.
១១៦*ក* ៣ នីហ្វៃ ១៧:១៥–១៧; ១៩:៣២–៣៤.
*ខ* ១ កូរិន. ២:១០–១២.
៧៧ ១*ក* គ. និង ស. ១៣០:៦–៩.
*ខ* គ. និង ស. ៨៨:១៧–២០, ២៥–២៦.
*គ* ស.ប. ផែនដី — ស្ថានភាពចុងក្រោយបង្អស់នៃផែនដី; សិរីល្អនៃសេឡេស្ទាល.
២ *ក* ស.ប. ការនិមិត្តរូប.
*ខ* ស.ប. ស្ថានសួគ៌.
*គ* ស.ប. ស្ថានបរមសុខ.
*ឃ* ស.ប. សេចក្ដីអំណរ.
*ង* អេធើរ ៣:១៥–១៦; អ័ប្រា. ៥:៧–៨. ស.ប. វិញ្ញាណ.
*ច* ម៉ូសេ ៣:១៩.

ឡាយនៃ របស់ទាំងនោះ នៅក្នុងជំពូកដែលបាន[ខ]កំណត់ទុក ឬក្នុងវិស័យនៃការបង្កបង្កើត នៅក្នុងអំណរអរចំពោះការសប្បាយរីករាយដ៏នៅអស់ កល្បជានិច្ចរបស់វា ។

៤ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីភ្នែក និងស្លាប ដែលសត្វទាំងនោះមាន ?

ចម្លើយ៖ ភ្នែករបស់វាគឺជាតំណាងនៃពន្លឺ និងដំរិះ គឺថា វាពោរពេញទៅដោយ[ក]ដំរិះ; ហើយស្លាបរបស់វាគឺជាតំណាងនៃ[ខ]អំណាច ដើម្បីកំរើក ដើម្បីប្រព្រឹត្ត ជាដើម ។

៥ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពី[ក]ពួកអែលឌើរ២៤នាក់ ដែលយ៉ូហានបានពោលដល់ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ពួកអែលឌើរទាំងនេះ ដែលយ៉ូហានបានឃើញនោះ គឺជាពួកអែលឌើរដែល[ខ]ស្មោះត្រង់ក្នុងកិច្ចការនៃ ការបំរើ ហើយបានស្លាប់ទៅហើយ; ជាពួកផងសាសនាចក្រទាំង[គ]ប្រាំពីរ ហើយនៅពេលនោះ កំពុងតែនៅក្នុងស្ថានបរមសុខនៃព្រះ ។

៦ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីក្រាំងដែលយ៉ូហានបាន[ក]ឃើញ ដែលបានបិទនៅខាងក្រៅត្រាប្រាំពីរ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ក្រាំងនោះមាននូវព្រះហឫទ័យដែលបានបើកសំដែង [ខ]សេចក្តីអាថិកំបាំង និងកិច្ចការទាំងឡាយនៃព្រះ; ការកាន់កាប់ត្រួតត្រាដ៏លាក់កំបាំងរបស់ទ្រង់ អំពី[គ]ផែនដីនេះ នៅក្នុងរយៈប្រាំពីរពាន់ឆ្នាំដែលផែនដីមានជីវិតរស់នៅ ឬការរស់នៅខាង សាច់ឈាមនៃផែនដី ។

៧ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីត្រា៧ដែលបានបិទ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ត្រាទី១មាននូវអ្វីៗក្នុងរយៈ[ក]១ពាន់ឆ្នាំលើកទី១ ហើយត្រាទី២ក៏អំពីរយៈ១ពាន់ឆ្នាំលើកទី២ ជាដើម រហូតដល់លើកទី៧ ។

៨ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីទេវតា៤រូប ដែលបានពោលដល់ នៅក្នុងជំពូកទី៧ ខ១ ក្នុងគម្ពីរវិវរណៈ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ពួកគេជាទេវតា៤រូប ដែលបានចាត់មកពីព្រះ ដែលត្រូវបានប្រទានឲ្យមានអំណាច លើទិសទាំង៤នៃ ផែនដី ដើម្បីសង្គ្រោះជីវិត និងដើម្បីបំផ្លាញចោល ពួកគេនេះហើយ ដែលមានដំណឹង[ក]ល្អដ៏នៅអស់កល្បអស់កាលជានិច្ច ដើម្បីថ្លែង ប្រាប់ដល់គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា ហើយគ្រប់ទាំងប្រជាជនផង; ដោយមានអំណាចដើម្បីបិទផ្ទៃមេឃ ដើម្បីភ្ជាប់ ទៅដល់ជីវិត ឬដើម្បីបោះចុះទៅក្នុង[ខ]ភូមិភាគនៃសេចក្តីងងឹត ។

៩ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីទេវតាដែលឡើងមកពីទិសខាងកើត ក្នុងគម្ពីរវិវរណៈ ជំពូកទី៧ ហើយខ២ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ទេវតានោះដែលឡើងមកពីទិសខាងកើត គឺជាអ្នកដែលត្រូវបានប្រទានឲ្យមានត្រានៃព្រះដ៏មានព្រះជន្មរស់នៅ លើពូជ[ក]អំបូរអ៊ីស្រាអែលទាំង១២; ហេតុដូច្នោះហើយ លោកប្រកាសប្រាប់ដល់ទេវតា៤រូប ដែលមានដំណឹងល្អដ៏នៅ អស់កល្បអស់កាលជានិច្ច ដោយនិយាយថា៖ កុំឲ្យធ្វើទុក្ខផែនដី ឬសមុទ្រ ឬដើមឈើណាក្តី ទាល់តែបោះត្រានៅត្រង់[ខ]ថ្ងាសនៃពួក បាវបំរើរបស់ព្រះនៃយើងសិន ។ ហើយបើសិនជាអ្នកព្រមទទួលការណ៍នេះ នោះគឺលោកនេះហើយ ជា[គ]លោកអេលីយ៉ាសដែល ត្រូវមក ដើម្បីប្រមូលពូជអំបូរអ៊ីស្រាអែលទាំងឡាយ ហើយ[ឃ]សាងឡើងវិញនូវគ្រប់ទាំងអស់ ។

១០ សំនួរ៖ តើដល់ពេលណានឹងបានសំរេច នូវអ្វីៗដែលបានពោលដល់នៅក្នុងជំពូជនេះ ?

ចម្លើយ៖ ការណ៍ទាំងនេះនឹងត្រូវបានសំរេច នៅក្នុងរយៈ[ក]១ពាន់ឆ្នាំលើកទី៦ ឬក៏ក្នុងកាលបកត្រាទី៦ ។

១១ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីការបោះត្រា[ក]មួយសែនបួនម៉ឺនបួនពាន់នាក់ ចេញពីគ្រប់ពូជអំបូរអ៊ីស្រាអែល — មួយម៉ឺនពីរពាន់នាក់ចេញ ពីពូជអំបូរនីមួយៗ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ពួកអ្នកទាំងនោះដែលត្រូវបានបោះត្រា គឺជាពួក[ខ]សង្ឃជាន់ខ្ពស់ ដែលបានតែងតាំងចំពោះរបៀប បរិសុទ្ធនៃព្រះ ដើម្បីថ្លែងប្រាប់ដំណឹងល្អដ៏នៅអស់កល្បអស់កាលជានិច្ច; ត្បិតពួកគេនេះហើយ ដែលត្រូវបានតែងតាំងចេញពីគ្រប់ទាំង សាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា ហើយ

---

៣ *ក* គ. និង ស. ៩៣:៣០; ម៉ូសេ ៣:៩.
*ខ* គ. និង ស. ៩៣:៣៣–៣៤.
៤ *ក* ស.ប. ដំរិះ.
*ខ* ស.ប. អំណាច.
៥ *ក* វិវរ. ៤:៤, ១០.
*ខ* វិវរ. ១៤:៤–៥.
*គ* វិវរ. ១:៤.
៦ *ក* វិវរ. ៥:១.
*ខ* ស.ប. សេចក្តីអាថិកំបាំងទាំងឡាយនៃព្រះ.
*គ* ស.ប. ផែនដី.
៧ *ក* គ. និង ស. ៨៨:១០៨–១១០.
៨ *ក* វិវរ. ១៤:៦–៧.
*ខ* ម៉ាថាយ ៨:១១–១២; ២២:១–១៤; គ. និង ស. ១៣៣:៧១–៧៣.
៩ *ក* វិវរ. ៧:៤–៨.
*ខ* អេសេ. ៩:៤.
*គ* ស.ប. អេលីយ៉ាស.
*ឃ* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
១០ *ក* វិវរ. ៦:១២–១៧.
១១ *ក* វិវរ. ១៤:៣–៥.
*ខ* ស.ប. សង្ឃជាន់ខ្ពស់.

គ្រប់ទាំងប្រជាជន ដោយសារពួកទេវតា ដែលត្រូវបានប្រទានឲ្យមានអំណាចលើសាសន៍ ទាំងឡាយនៅលើផែនដី ដើម្បីនាំមនុស្សទាំងឡាយណា ដែលនឹងមកឯសាសនាចក្រនៃកូនចៀង[គ] ។

១២ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីការផ្ដុំត្រា[ក] ដែលបានពោលដល់ នៅក្នុងជំពូកទី៨ ក្នុងគម្ពីរវិវរណៈ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ដូចជាព្រះទ្រង់បានបង្កើតលោកិយក្នុងរយៈពេលប្រាំមួយថ្ងៃ[ខ] ហើយនៅថ្ងៃទី៧ ទ្រង់បានសំរេចកិច្ចការរបស់ទ្រង់ ហើយបានញែកថ្ងៃនោះចេញជាបរិសុទ្ធ ហើយក៏បានបង្កើតមនុស្សចេញពីធូលីដី[គ]យ៉ាងណា នោះក៏ដូចជាយ៉ាងដូច្នោះដែរ គឺនៅដើមប្រាំពីរពាន់ឆ្នាំ នោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងញែក[ឃ]ផែនដីចេញជាបរិសុទ្ធ ហើយសំរេចនូវសេចក្ដីសង្គ្រោះដល់មនុស្ស ហើយ ជំនុំជំរះ[ង]គ្រប់ទាំងអស់ ហើយនឹងប្រោសលោះ[ច]គ្រប់ទាំងអស់ លើកលែងតែអ្វីដែលទ្រង់ពុំដាក់ក្នុងអំណាចរបស់ទ្រង់ ក្នុងកាលទ្រង់នឹងបោះត្រាគ្រប់ទាំងអស់ចំពោះចុងបំផុតនៃគ្រប់ទាំងអស់; ហើយការផ្ដុំត្រានៃពួកទេវតាប្រាំពីររូប គឺជាការរៀបចំ និងការបង្ហើយកិច្ចការរបស់ទ្រង់នៅដើមប្រាំពីរពាន់ឆ្នាំ — គឺជាការរៀបចំផ្លូវមុនពេលការយាងមករបស់ទ្រង់ ។

១៣ សំនួរ៖ តើនៅពេលណានឹងបានសំរេច នូវអ្វីៗដែលបានសរសេរទុក នៅក្នុងជំពូកទី៩ ក្នុងគម្ពីរវិវរណៈ ?

ចម្លើយ៖ ការណ៍ទាំងនោះនឹងត្រូវបានសំរេច បន្ទាប់ពីការបកត្រាទី៧ គឺមុនការយាងមកនៃព្រះគ្រីស្ទ ។

១៤ សំនួរ៖ តើត្រូវឲ្យយើងយល់យ៉ាងណា ពីក្រាំងតូចដែលយ៉ូហាន[ក]បានបរិភោគ ដូចជាបានពោលដល់ នៅក្នុងជំពូកទី១០ ក្នុងគម្ពីរវិវរណៈ ?

ចម្លើយ៖ ត្រូវឲ្យយើងយល់ថា ក្រាំងតូចនោះជាបេសកកម្ម ហើយជាពិធីបរិសុទ្ធ សំរាប់ឲ្យលោកប្រមូល[ខ]ពូជអំបូរអ៊ីស្រាអែល; មើលចុះ នេះជាអេលីយ៉ាស ជាអ្នកដែលត្រូវមក ហើយសាង[គ]គ្រប់ទាំងអស់ឡើងវិញ ដូចជាបានសរសេរទុក ។

១៥ សំនួរ៖ តើត្រូវឲ្យយល់យ៉ាងណា ពីស្មរបន្ទាល់[ក]ពីរនាក់នៅក្នុងជំពូកទី១១ ក្នុងគម្ពីរវិវរណៈ ?

ចម្លើយ៖ ពួកគេជាព្យាការីពីរនាក់ ដែលត្រូវបានលើកឡើងចំពោះសាសន៍យូដា[ខ] នៅគ្រាចុងក្រោយបង្អស់[គ] ក្នុងពេលសាងឡើង វិញ[ឃ] ហើយដើម្បីព្យាករដល់ពួកសាសន៍យូដាបន្ទាប់ពីពួកគេបានប្រមូលគ្នា ហើយបានសង់ទីក្រុងយេរូសាឡិមនៅលើដែនដី[ង]នៃពួក អយ្យកោរបស់ពួកគេ ។

## កណ្ឌទី ៧៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣២ (*History of the Church, *១:២៥៥–២៥៧) ។ របៀបត្រូវបានប្រទានពីព្រះអម្ចាស់ដល់ យ៉ូសែប ស្ម៊ីធ សំរាប់គោលបំណងនៃការតាំងឃ្លាំងសំរាប់ មនុស្សទ័លក្រ ។ វាមិនតែងតែសមប្រាប់ដល់ពិភពលោកពីមនុស្សនានា ដែលព្រះអម្ចាស់មានព្រះបន្ទូលដល់ នៅក្នុងវិវរណៈឡើយ; ម្ល៉ោះហើយ នៅក្នុងការបោះពុម្ពវិវរណៈនេះ ព្រមទាំងវិវរណៈក្រោយៗមក នោះពួកបងប្អូនប្រុសៗត្រូវបានហៅតាមឈ្មោះក្រៅ ពីឈ្មោះខ្លួន ។ កាលដែលមិនចាំបាច់លាក់ឈ្មោះ នោះក្រោយមក ឈ្មោះពិតរបស់ពួកគេត្រូវបានដាក់នៅក្នុងវង់ដង្កៀប ។ មកពីគ្មានសេចក្ដីត្រូវការដាក់ឈ្មោះលាក់ទៀតទេនៅសព្វថ្ងៃនេះ បានជាចាប់ពីពេលនេះតទៅ នោះឈ្មោះពិតត្រូវបានយកមកដាក់ក្នុង ឯកសារដើម ។*

១១ *គ* គ. និង ស. ៧៦:៥១–៧០. ស.ប. កូនចៀង.
១២ *ក* វិវរ. ៨:២.
*ខ* លោកុ. ២:១–៣; និក្ខ. ២០:១១; ៣១:១២–១៧; ម៉ូសាយ ១៣:១៦–១៩; ម៉ូសេ ៣:១–៣; អ័ប្រា. ៥:១–៣.
*គ* លោកុ. ២:៧.
*ឃ* គ. និង ស. ៨៨:១៧–២០.
*ង* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
*ច* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
១៤ *ក* អេសេ. ២:៩–១០; ៣:១–៤; វិវរ. ១០:១០.
*ខ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*គ* ម៉ាថាយ ១៧:១១.
១៥ *ក* វិវរ. ១១:១–១៤.
*ខ* ស.ប. ពួកសាសន៍យូដា.
*គ* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
*ឃ* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ង* អេម៉ុស ៩:១៤–១៥.

*១–៤, ពួកបរិសុទ្ធត្រូវរៀបចំ ហើយតាំងឃ្លាំងមួយឡើង; ៥–១២, ការប្រើប្រាស់ទ្រព្យសម្បត្តិដោយឈ្លាសវៃនឹងនាំទៅរកសេចក្ដី សង្គ្រោះ; ១៣–១៤, សាសនាចក្រត្រូវនៅដោយឡែកពីអំណាចខាងផែនដី; ១៥–១៦, មីកែល (អ័ដាម) បំរើនៅក្រោមការដឹកនាំពី ព្រះដ៏បរិសុទ្ធ (ព្រះគ្រីស្ទ); ១៧–២២, មានពរហើយពួកស្មោះត្រង់ ត្បិតពួកគេនឹងបានគ្រងគ្រប់ទាំងអស់ទុកជាមរតក ។*

ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅកាន់ យ៉ូសែប ស៊្មីធ ជុញ៉ែរ ថា៖ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា អ្នករាល់គ្នាដែលបានតែង តាំងចំពោះបព្វជិតភាពដ៏ខ្ពស់ នៃសាសនាចក្ររបស់យើង ដែលបានជួបជុំគ្នាអើយ ចូរប្រុងស្ដាប់ដល់យើងចុះ;
២ ហើយចូរស្ដាប់តាមពាក្យទូន្មាននៃទ្រង់ ដែលបានតែងតាំងអ្នកពីស្ថានដ៏ខ្ពស់ ដែលនឹងមានព្រះបន្ទូលដាក់ត្រចៀកអ្នក ប្រាប់ពីពាក្យ សំដីនៃប្រាជ្ញាវាងវៃ ប្រយោជន៍ឲ្យសេចក្ដីសង្គ្រោះអាចមានដល់អ្នក ដោយនូវការណ៍នោះ ដែលអ្នកបានថ្លែងចំពោះយើង ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៣ ត្បិតយើងប្រាប់អ្នកជាប្រាកដថា ពេលវេលាបានមកដល់ហើយ ហើយឥឡូវនេះនៅជិតដែបង្កើយ; ហើយមើលចុះ និងមើលន៏ គឺជា ចាំបាច់ថា ត្រូវមានអង្គការមួយពីរាស្ត្ររបស់យើង ក្នុងការចាត់ចែង និងតាំងកិច្ចការឃ្លាំង សំរាប់មនុស្សទ័លក្រក្នុងរាស្ត្រយើង ទាំងនៅ កន្លែងនេះ ព្រមទាំងនៅដែនដីស៊ីយ៉ូនផង —
៤ សំរាប់ជាការតាំង និងរបៀបដ៏ស្ថាពរ និងដ៏អស់កល្បអស់កាលជានិច្ច ចំពោះសាសនាចក្ររបស់យើង ដើម្បីបន្តគតិតទៅទៀត ដែល អ្នករាល់គ្នាបានប្រកាន់ ដើម្បីសេចក្ដីសង្គ្រោះដល់មនុស្ស ហើយដើម្បីសិរីល្អដល់ព្រះវរបិតារបស់អ្នក ដែលគង់នៅលើស្ថានសួគ៌;
៥ ប្រយោជន៍ឲ្យអ្នកអាចបានស្មើគ្នា ក្នុងចំណងទាំងឡាយពីអ្វីៗខាងស្ថានសួគ៌ មែនហើយ ព្រមទាំងអ្វីៗខាងផែនដីផង ដើម្បីឲ្យទទួល បានអ្វីៗខាងស្ថានសួគ៌ ។
៦ ត្បិតបើសិនជាអ្នករាល់គ្នាពុំបានស្មើគ្នាក្នុងអ្វីៗខាងផែនដីទេ នោះអ្នករាល់គ្នាក៏ពុំអាចបានស្មើគ្នាក្នុងការទទួលអ្វីៗខាងស្ថានសួគ៌ដែរ;
៧ ត្បិតបើសិនជាអ្នករាល់គ្នាមានបំណងចង់ឲ្យយើងប្រទានដល់អ្នក នូវកន្លែងមួយនៅក្នុងពិភពសេឡេស្ទាល នោះអ្នកត្រូវរៀបចំខ្លួន ដោយសារការប្រព្រឹត្តិនូវអ្វីៗ ដែលយើងបានបញ្ជាដល់អ្នក ហើយតម្រូវពីអ្នក ។
៨ ហើយឥឡូវនេះ ប្រាកដមែនព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា គឺជាការចាំបាច់ដែលគ្រប់ទាំងអស់ត្រូវបានប្រព្រឹត្តដើម្បីសិរីល្អ របស់យើង ដោយសារអ្នករាល់គ្នាដែលបានចូលរួមគ្នាក្នុងរបៀបនេះ;
៩ ឬក៏ម៉្យាងទៀត ចូរឲ្យ នូវល ខេ វិតនី ជាអ្នកបំរើរបស់យើង និង យ៉ូសែប ស៊្មីធ ជុញ៉ែរ ជាអ្នកបំរើរបស់យើង និង ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង អង្គុយប្រឹក្សាជាមួយពួកបរិសុទ្ធ ដែលនៅក្រុងស៊ីយ៉ូនចុះ;
១០ បើពុំនោះសោតទេ អារក្សសាតាំងកំពុងស្វែងរក ដើម្បីបំបែរចិត្តពួកគេចេញពីសេចក្ដីពិត ប្រយោជន៍ឲ្យពួកគេត្រឡប់ទៅជាខ្វាក់ ហើយពុំយល់នូវអ្វីៗ ដែលបានរៀបចំទុកសំរាប់ពួកគេឡើយ ។
១១ ហេតុដូច្នោះហើយ យើងប្រទានបញ្ញត្តិមួយដល់អ្នក ដើម្បីឲ្យប្រុងប្រៀប ហើយរៀបចំខ្លួន ដោយនូវចំណង ឬសេចក្ដីសញ្ញាដ៏អស់ កល្បអស់កាលជានិច្ច ដែលពុំអាចបណ្ដាច់បានឡើយ ។
១២ ហើយអ្នកណាដែលបណ្ដាច់ចំណងនោះ នឹងត្រូវបាត់បង់តំណែង និងជំហរនៅក្នុងសាសនាចក្រ ហើយនឹងត្រូវបានប្រគល់ទៅ ឯការធ្វើទុក្ខរបស់អារក្សសាតាំង រហូតដល់ថ្ងៃប្រោសលោះ ។
១៣ មើលចុះ នេះហើយជាការរៀបចំ ដែលយើងយកមក

**៧៨** ១*ក* ស.ប. បព្វជិតភាពមិលគីស្សាដែក.
២ *ក* ស.ប. ពាក្យទូន្មាន (ន.).
*ខ* ស.ប. តែងតាំង, ការតែងតាំង.
៣ *ក* គ. និង ស. ៨២:១១–១២, ១៥–២១.
*ខ* គ. និង ស. ៧២:៩–១០; ៨៣:៥–៦.
*គ* គ. និង ស. ៤២:៣០–៣១. ស.ប. សុខុមាលភាព.
*ឃ* គ. និង ស. ៥៧:១–២.
៥ *ក* គ. និង ស. ៤៩:២០. ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
៧ *ក* ស.ប. សិរីល្អនៃសេឡេស្ទាល.
*ខ* គ. និង ស. ២៩:៨; ១៣២:៣.
*គ* គ. និង ស. ៨២:១០.
៨ *ក* ម៉ូសេ ១:៣៩.
*ខ* គ. និង ស. ៩២:១.
១០ *ក* ស.ប. អារក្ស.
១១ *ក* ស.ប. សេចក្ដីសញ្ញា.
១២ *ក* ១ កូរិន. ៥:៥; គ. និង ស. ៨២:២១; ១០៤:៨–១០.

រៀបចំអ្នក និងគ្រឹះស្ថាន និងគំរូ ដែលយើងប្រទានដល់អ្នក
ដើម្បីឲ្យអ្នកអាច សំរេចនូវបញ្ញត្តិទាំងឡាយ ដែលបានប្រទាន
ដល់អ្នក;
១៤ ប្រយោជន៍ថាតាមរយៈទិព្វញាណរបស់យើង ទោះជា
មាន[ក]សេចក្ដីវេទនាចុះមកលើអ្នកក៏ដោយ ប្រយោជន៍ឲ្យសាសនា
ចក្រអាច បានឈរដោយឡែក លើសត្វលោកទាំងអស់ ដែល
នៅក្រោមពិភពសេឡេស្ទាល;
១៥ ប្រយោជន៍ឲ្យអ្នកអាចឡើងទៅរក[ក]មកុដ ដែលបាន
រៀបចំទុកសំរាប់អ្នក ហើយត្រូវបានធ្វើឲ្យកើតជា[ខ]អ្នកគ្រប់គ្រងលើ
នគរជាច្រើន ព្រះអម្ចាស់ដ៏ជាព្រះ ជាព្រះដ៏បរិសុទ្ធនៃក្រុងស៊ីយ៉ូន
ដែលបានតាំងគ្រឹះស្ថាននៃក្រុង[គ]អ័ដាម-អុនដៃ-អាម៉ាន ទ្រង់
មានព្រះបន្ទូលថាដូច្នោះ;
១៦ ដែលបានចាត់ [ក]មីកែល ជាចៅហ្វាយរបស់អ្នក ហើយ
តាំងជើងលោកឡើង ហើយដាក់លោកនៅលើកន្លែងខ្ពស់ ហើយ
ប្រទានដល់ លោកនូវកូនសោទាំងឡាយនៃសេចក្ដីសង្គ្រោះ
នៅក្រោមការទូន្មាន និងការដឹកនាំពីព្រះដ៏បរិសុទ្ធ ដែលគ្មានថ្ងៃ
កំណើត ឬថ្ងៃស្លាប់ដែរ ។
១៧ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នករាល់គ្នាជា
កូនក្មេងតូចៗ ហើយអ្នករាល់គ្នាពុំទាន់យល់នៅឡើយទេ អំពីព្រះ
ពរដ៏ធំ ណាស់ហ្ន៎ ដែលព្រះវរបិតាមាននៅក្នុងព្រះហស្តរបស់
ទ្រង់ ហើយបានរៀបចំទុកសំរាប់អ្នក;
១៨ ហើយអ្នករាល់គ្នាពុំអាច[ក]ទ្រាំគ្រប់ទាំងអស់បាន
ឡើយនៅពេលនេះ; ទោះជាយ៉ាងណាក៏ដោយ ចូរសង្ឃឹម
ឡើង ត្បិតយើងនឹង [ខ]ដឹកនាំ អ្នករាល់គ្នា ។ នគរជារបស់ផង
អ្នករាល់គ្នា ហើយព្រះពរទាំងឡាយនៃនគរជារបស់ផងអ្នក
រាល់គ្នា ហើយទ្រព្យសម្បត្តិ ទាំងឡាយ ខាង[គ]ភាព
អស់កល្បជានិច្ចជារបស់ផងអ្នករាល់គ្នា ។
១៩ ហើយអ្នកណាដែលទទួលគ្រប់ទាំងអស់ ដោយ[ក]អំណរ
អរគុណ នោះនឹងត្រូវបានធ្វើឲ្យរុងរឿង; ហើយការខាងផែនដីនេះ
នឹងត្រូវបាន ប្រទានដល់អ្នកនោះថែមទៀត គឺ[ខ]មួយរយភាគថែមទៀត
មែនហើយ គឺច្រើនជាងនោះទៅទៀត ។
២០ ហេតុដូច្នោះហើយ ចូរប្រព្រឹត្តនូវអ្វីៗដែលយើងបានបញ្ជា
ដល់អ្នកចុះ ព្រះដ៏ប្រោសលោះរបស់អ្នក ទ្រង់មានព្រះបន្ទូលថា
ដូច្នោះ គឺជាព្រះរាជបុត្រា[ក]អាម៉ាន ដែលបានរៀបចំគ្រប់ទាំងអស់
មុន[ខ]ទ្រង់យកអ្នកទៅ;
២១ ត្បិតអ្នករាល់គ្នាជា[ក]សាសនាចក្រនៃកូនច្បង ហើយទ្រង់
នឹង[ខ]លើកអ្នកឡើងទៅក្នុងពពក ហើយចែកដល់មនុស្សគ្រប់រូបនូវ
ចំណែក របស់ខ្លួន ។
២២ ហើយអ្នកណាដែលជា[ក]អ្នកកាន់កាប់ត្រួតត្រាដ៏ស្មោះ
ត្រង់ ហើយ[ខ]ឈ្លាសវៃ នោះនឹងគ្រង[គ]គ្រប់ទាំងអស់
ទុកជាមរតក ។ អាម៉ែន ៕

## កណ្ឌទី ៧៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣២ (*History of the Church, *១:២៥៧)* ។

*១–៤, យ៉ារេឌ ខាររើរ ត្រូវបានហៅឲ្យទៅផ្សាយដំណឹងល្អដោយព្រះដ៏ជាជំនួយ ។*

យើងប្រាប់អ្នកជាប្រាកដថា គឺជាព្រះហឫទ័យរបស់យើងថា
យ៉ារេដ ខាររើរ ជាអ្នកបំរើរបស់យើង គួរទៅស្រុកទាំង

១៤ *ក* គ. និង ស. ៥៨:២–៤.
១៥ *ក* ស.ប. មកុដ; ភាពដំកើងឡើង.
*ខ* វិវរ. ៥:១០;
គ. និង ស. ៧៦:៥៦–៦០;
១៣២:១៩.
*គ* ស.ប. អ័ដាម-អុនដៃ-អាម៉ាន.
១៦ *ក* គ. និង ស. ២៧:១១;
១០៧:៥៤–៥៥.
ស.ប. អ័ដាម.
១៨ *ក* យ៉ូហាន ១៦:១២;
៣ នីហ្វៃ ១៧:២–៣;
គ. និង ស. ៥០:៤០.
*ខ* គ. និង ស. ១១២:១០.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
១៩ *ក* ម៉ូសាយ ២:២០–២១.
ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
*ខ* ម៉ាថាយ ១៩:២៩.
២០ *ក* គ. និង ស. ៩៥:១៧.
*ខ* ១ ថែស្សា. ៤:១៧.
២១ *ក* គ. និង ស. ៧៦:៥៣–៥៤.
*ខ* គ. និង ស. ៨៨:៩៦–៩៨.
២២ *ក* គ. និង ស. ៧២:៣–៤.
*ខ* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
*គ* គ. និង ស. ៨៤:៣៨.

ឡាយ នៅទិស ខាងកើតម្ដងទៀត ពីកន្លែងមួយទៅកន្លែងមួយ ហើយពីទីក្រុងមួយទៅទីក្រុងមួយ ដោយនូវអំណាចនៃការតែងតាំង ដែលគាត់ត្រូវ បានតែងតាំងនោះ ដោយប្រកាសប្រាប់ពីដំណឹងដ៏រីករាយនៃសេចក្ដីអំណរដ៏ធំ គឺជាដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ច ។
២ ហើយយើងនឹងចាត់ព្រះដ៏ជាជំនួយ ឲ្យមកសណ្ឋិតលើគាត់ ដែលនឹងបង្រៀនគាត់ពីសេចក្ដីពិត និងពីផ្លូវដែលគាត់ត្រូវទៅ;
៣ ហើយដរាបណាគាត់មានចិត្តស្មោះត្រង់ នោះយើងនឹងបំពាក់គាត់ដោយកណ្ដាប់ស្រូវទុកជាមកុដ ។
៤ ហេតុដូច្នោះហើយ ចូរមានចិត្តសប្បាយចុះ យ៉ារេឌ ខារតើរ ជាអ្នកបំរើរបស់យើងអើយ ហើយចូរកុំខ្លាចឡើយ ព្រះអម្ចាស់របស់អ្នក គឺជាព្រះយេស៊ូវគ្រីស្ទ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ អាម៉ែន ៕

កណ្ឌទី ៨០

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣២ (*History of the Church, *១:២៥៧)* ។

*១–៥, ស្ទីផាន បើរណែត និង អេដែន ស្ម៊ីធ ត្រូវបានហៅឲ្យទៅផ្សាយនៅកន្លែងណាក៏ដោយ ដែលពួកគេជ្រើសរើស ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក គឺ ស្ទីផាន បើរណែត ជាអ្នកបំរើរបស់យើង យ៉ាងដូច្នេះថា៖ ចូរអ្នកទៅ ចូរអ្នកទៅក្នុងលោកិយ ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ ដែលនៅក្រោមសម្លេងរបស់អ្នកចុះ ។
២ ហើយដរាបណាអ្នកមានប្រាថ្នាចង់បានគូកន នោះយើងនឹងប្រទានដល់អ្នក នូវ អេដែន ស្ម៊ីធ ជាអ្នកបំរើរបស់យើង ។
៣ ហេតុដូច្នោះហើយ ចូរអ្នកទៅ ហើយផ្សាយដំណឹងល្អរបស់យើងចុះ ទោះជាទៅទិសខាងជើង ឬទៅទិសខាងត្បូង ទៅទិសខាង កើត ឬទៅទិសខាងលិចក្ដី វាមិនចាំបាច់ឡើយ ត្បិតអ្នកមិនអាចធ្វើខុសឡើយ ។
៤ ហេតុដូច្នេះហើយ ចូរប្រកាសប្រាប់ពីអ្វីៗ ដែលអ្នករាល់គ្នាបានឮ ហើយប្រាកដជាជឿ ហើយដឹងថាពិតចុះ ។
៥ មើលចុះ នេះហើយជាព្រះហឫទ័យនៃព្រះអង្គដែលបានហៅអ្នក ជាព្រះដ៏ប្រោសលោះរបស់អ្នក គឺជាព្រះយេស៊ូវគ្រីស្ទ ។ អាម៉ែន ៕

កណ្ឌទី ៨១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ខែមីនា ឆ្នាំ១៨៣២ (*History of the Church, *១:២៥៧–២៥៨) ។ ហ្វ្រេឌើរិក ជី វិលលាម្ស ត្រូវបានហៅឲ្យធ្វើជាសង្ឃជាន់ខ្ពស់ ហើយជាទីប្រឹក្សានៅក្នុងគណៈប្រធាន នៃបព្វជិតភាពជាន់ខ្ពស់ ។ បញ្ជីខាងប្រវត្តិបង្ហាញថា កាលបានទទួលវិវរណៈនេះ នៅខែមីនា ឆ្នាំ១៨៣២ នោះ ចែស៊ី គស ត្រូវបាន ហៅឲ្យកាន់តំណែងជាទីប្រឹក្សាដល់ យ៉ូសែប ស្ម៊ីធ នៅក្នុងគណៈប្រធាន ។ ប៉ុន្ដែកាលគាត់មិនអាចធ្វើតទៅទៀត នៅក្នុងរបៀបដែល សមរម្យទៅនឹងការតែងតាំងនេះ ម្ល៉ោះហើយ ទើបការហៅនេះត្រូវបានប្ដូរទៅឲ្យ ហ្វ្រេឌើរិក ជី វិលលាមស៍ ។ វិវរណៈ (ចុះនៅខែ មីនា ឆ្នាំ១៨៣២) ត្រូវបានរាប់ថាជាជំហានឆ្ពោះទៅរកការរៀបចំតាមផ្លូវការ នៃគណៈប្រធានទីមួយ ជាពិសេស ការហៅនូវ តំណែងនៃទីប្រឹក្សា នៅក្នុងគណៈនោះ និងការពន្យល់នូវការថ្លៃថ្នូរអំពីការតែងតាំង ។ បងប្រុស គស បានបំរើមួយរយៈ ប៉ុន្ដែបាន កាត់ចេញពីសាសនា នៅខែធ្នូ ឆ្នាំ១៨៣២ ។ បងប្រុស វិលលាម្ស ត្រូវបានតែងតាំងចំពោះតំណែងនេះ នៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៨៣៣ ។*

**៧៩** ១*ក* គ. និង ស. ៥២:៣៨.
ស.ប. តែងតាំង, ការតែងតាំង.
២ *ក* យ៉ូហាន ១៤:២៦.
ស.ប. ព្រះដ៏ជាជំនួយ.
៤ *ក* គ. និង ស. ៦៨:៥–៦.
**៨០** ១*ក* ម៉ាកុស ១៦:១៥.
៤ *ក* ស.ប. ទីបន្ទាល់.
៥ *ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.

*១–២, កូនសោទាំងឡាយនៃនគរត្រូវកាន់ដោយគណៈប្រធានទីមួយរហូត; ៣–៧, បើសិនជា ហ្វ្រេឌើរិក ជី វិលលាមស៍ មានចិត្តស្មោះ ត្រង់ នោះគាត់នឹងបានជីវិតដ៏នៅអស់កល្បជានិច្ច ។*

ប្រាកដមែន យើងប្រាប់ដល់អ្នក គឺហ្វ្រេឌើរិក ជី វិលលាមស៍ ជាអ្នកបំរើរបស់យើងជាប្រាកដថាៈ ចូរស្ដាប់តាមសម្លេងនៃអ្នក ដែល មានព្រះបន្ទូល គឺតាមព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះរបស់អ្នកចុះ ហើយចូរប្រុងស្ដាប់តាមការហៅ ដែលអ្នកត្រូវបានហៅឲ្យកាន់ គឺឲ្យធ្វើជា[ក]សង្ឃជាន់ខ្ពស់ នៅក្នុងសាសនាចក្ររបស់យើង ហើយជាទីប្រឹក្សាដល់ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើងចុះ;

២ ជាអ្នកដែលយើងបានប្រទានឲ្យ[ក]កូនសោទាំងឡាយនៃនគរ ដែលត្រូវជារបស់ផងគណៈប្រធាននៃ[ខ]បព្វជិតភាពជាន់ខ្ពស់រហូតៈ

៣ ហេតុដូច្នោះហើយ យើងទទួលស្គាល់គាត់ជាប្រាកដ ហើយនឹងប្រទានពរដល់គាត់ និងដល់អ្នកដែរ ដរាបណាអ្នកមានចិត្តស្មោះត្រង់ នៅក្នុងការទូន្មាន នៅក្នុងតំណែងដែលយើងបានតែងតាំងដល់អ្នក នៅក្នុងការអធិស្ឋានរហូត ដោយចេញសម្លេងនិងទាំងនៅក្នុង ចិត្តអ្នក នៅទីសាធារណៈ និងទាំងនៅទីសម្ងាត់ ហើយព្រមទាំងនៅក្នុងការងារបំរើរបស់អ្នក ខាងការប្រកាសប្រាប់ពីដំណឹងល្អ នៅ ក្នុងដែនដីនៃមនុស្សរស់ និងនៅក្នុងចំណោមបងប្អូនទាំងឡាយរបស់អ្នកដែរ ។

៤ ហើយនៅក្នុងការប្រព្រឹត្តអ្វីៗទាំងនេះ នោះអ្នកនឹងប្រព្រឹត្តល្អបំផុត ចំពោះមនុស្សទូទៅ ហើយនឹងដំកើង[ក]សិរីល្អដល់ព្រះអង្គដែលជា ព្រះអម្ចាស់របស់អ្នក ។

៥ ហេតុដូច្នោះហើយ ចូរមានចិត្តស្មោះត្រង់ចុះ; ចូរឈរនៅក្នុងតំណែងដែលយើងបានតែងតាំងដល់អ្នក; ចូរ[ក]ជួយអ្នកទន់ខ្សោយ ចូរលើកដៃដែលរោយ ហើយចូរ[ខ]ចំរើនកម្លាំងដល់ក្បាលជង្គង់ដែល[គ]ញ័រផង ។

៦ ហើយបើសិនជាអ្នកមានចិត្តស្មោះត្រង់ដល់ចុងបំផុត នោះអ្នកនឹងបាន[ក]មកុដនៃអមតភាព និង[ខ]ជីវិតដ៏នៅអស់កល្បជានិច្ច នៅក្នុង[គ]វិមាន ទាំងឡាយ ដែលយើងបានរៀបចំទុក នៅក្នុងដំណាក់នៃព្រះវរបិតារបស់យើង ។

៧ មើលចុះ និងមើលន៏ នេះហើយជាព្រះបន្ទូលទាំងឡាយនៃអាលផា និងអូមេកា គឺជាព្រះយេស៊ូវគ្រីស្ទ ។ អាម៉ែន ៕

## កណ្ឌទី ៨២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅឃុំចាកសុន រដ្ឋមិសសួរី ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៨៣២ (*History of the Church, *១:២៦៧–២៦៩) ។ ជាគ្រានៃការប្រឹក្សាទូទៅរបស់សាសនាចក្រ ដែល យ៉ូសែប ស្ម៊ីធ ជាព្យាការី ត្រូវបានគាំទ្រឲ្យធ្វើជាប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ចំពោះតំណែងដែលលោកបានតែងតាំងពីមុនមក នៅឯសន្និសីទនៃសង្ឃជាន់ខ្ពស់ អែលឌើរ និងសមាជិក នៅភូមិអាមហើស្ត រដ្ឋអូហៃអូ ថ្ងៃទី២៥ ខែមករា ឆ្នាំ១៨៣២ (សូមមើលចំណងជើងនៃកណ្ឌទី ៧៥) ។ កាល ពីដើមមានឈ្មោះប្លែកៗបានយកមកប្រើក្នុងការបោះពុម្ពវិវរណៈនេះ ដើម្បីលាក់ឈ្មោះជនទាំងឡាយ (សូមមើលចំណងជើងនៃ កណ្ឌទី ៧៨) ។*

*១–៤, កាលដែលត្រូវបានប្រទានឲ្យច្រើន នោះក៏មានតម្រូវការជាច្រើនវិញ; ៥–៧, សេចក្ដីងងឹតសោយរាជ្យនៅក្នុងពិភពលោក; ៨–១៣, ព្រះអម្ចាស់ទ្រង់ជាប់សន្យា កាលណាយើងប្រព្រឹត្តតាមអ្វីដែលទ្រង់មានព្រះបន្ទូល; ១៤–១៨, ក្រុងស៊ីយ៉ូនត្រូវរីកខាងលំអ និងបរិសុទ្ធភាព; ១៩–២៤, មនុស្សគ្រប់រូបត្រូវស្វែងរកចំណូលចិត្តនៃអ្នកជិតខាងរបស់ខ្លួន ។*

ប្រាកដមែន យើងប្រាប់អ្នករាល់គ្នា ជាពួកអ្នកបំរើរបស់យើងជាប្រាកដថា ដរាបណាអ្នកអត់ទោស ដល់គ្នាទៅវិញទៅមក ចំពោះការ រំលងច្បាប់របស់ខ្លួន នោះសូម្បីតែយើង ជាព្រះអម្ចាស់ក្ដី [ក]ក៏អត់ទោសឲ្យអ្នកដែរ ។

២ ទោះជាយ៉ាងណាក៏ដោយ គង់តែមានពួកអ្នកទាំងនោះនៅក្នុងចំណោមអ្នកដែរ ដែលបានធ្វើបាបដ៏ធ្ងន់ធ្ងរ; មែនហើយ [ក]គឺអស់

៨១ ១*ក* ស.ប. សង្ឃជាន់ខ្ពស់.
២ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* គ. និង ស. ១០៧:៨–៩, ២២.
ស.ប. គណៈប្រធានទី១.
៤ *ក* ម៉ូសេ ១:៣៩.
៥ *ក* ម៉ូសាយ ៤:១៥–១៦.
*ខ* គ. និង ស. ១០៨:៧.
*គ* អេសាយ ៣៥:៣.
៦ *ក* ស.ប. អមតៈ, អមតភាព.
*ខ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច; ភាពដំកើងឡើង.
*គ* យ៉ូហាន ១៤:២–៣;
គ. និង ស. ៥៩:២; ១០៦:៨.
៨២ ១*ក* ម៉ាថាយ ៦:១៤–១៥;
គ. និង ស. ៦៤:៩–១១.
២ *ក* រ៉ូម ៣:២៣.

អ្នក រាល់គ្នាបានធ្វើបាប; ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា ចូរប្រយ័ត្នពីពេលនេះតទៅ ហើយចូរបែរចេញពីអំពើបាប ខ្លាចក្រែងសេចក្ដីជំនុំជំរះ ដ៏ធ្ងន់ធ្ងរនឹងធ្លាក់មកលើក្បាលអ្នក ។

៣ ត្បិតដល់អ្នកណាដែលត្រូវបានប្រទានឲ្យច្រើន នោះក៏មានតម្រូវការជាច្រើនវិញ; ហើយអ្នកណាដែលធ្វើបាបទាស់នឹងពន្លឺដ៏ធំជាង នោះនឹងត្រូវទទួលការដាក់ទោសដ៏ធំជាងដែរ ។

៤ អ្នករាល់គ្នាអំពាវនាវដល់ព្រះនាមរបស់យើង សូមវិវរណៈទាំងឡាយ ហើយយើងប្រទានវិវរណៈទាំងនោះដល់អ្នក; ហើយដរាបណា អ្នករាល់គ្នាមិនកាន់តាមព្រះបន្ទូលទាំងឡាយរបស់យើង ដែលយើងប្រទានដល់អ្នកទេ នោះអ្នករាល់គ្នាត្រឡប់ ទៅជាអ្នករំលងច្បាប់; ហើយសេចក្ដីយុត្តិធម៌ និងសេចក្ដីជំនុំជំរះត្រូវជាទោសដែលភ្ជាប់ទៅនឹងក្រិត្យវិន័យរបស់យើង ។

៥ ហេតុដូច្នេះហើយ អ្វីក៏ដោយដែលយើងមានព្រះបន្ទូលដល់មនុស្សម្នាក់ នោះយើងមានព្រះបន្ទូលដល់មនុស្សទាំងអស់ថា៖ ចូរចាំយាម ត្បិតមារសត្រូវកំពុងតែពង្រីកអាណាចក្រទាំងឡាយរបស់វា ហើយសេចក្ដីងងឹតសោយរាជ្យ;

៦ ហើយសេចក្ដីខ្ញាល់នៃព្រះឆួលឡើងទាស់នឹងបណ្ដាជននៅលើផែនដី; ហើយគ្មាននរណាមួយប្រព្រឹត្តល្អឡើយ ត្បិតគ្រប់មនុស្សទាំង អស់បានចេញពីផ្លូវហើយ ។

៧ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា យើងជាព្រះអម្ចាស់ នឹងមិនដាក់ទោសដល់អំពើបាបអ្នកឡើយ; ចូរទៅចុះ ហើយកុំធ្វើ បាបទៀតឡើយ; ប៉ុន្តែចំពោះអ្នកនោះដែលធ្វើបាប នោះអំពើបាបពីដើមនឹងវិលមកវិញ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នកទ្រង់មានព្រះបន្ទូល ថាដូច្នោះ ។

៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា យើងប្រទានដល់អ្នកនូវបញ្ញត្តិថ្មីមួយ ប្រយោជន៍ឲ្យអ្នកអាចយល់ពីព្រះហឫទ័យ ដែលយើងមាន ចំពោះអ្នក;

៩ ឬក៏ម៉្យាងទៀត យើងប្រទានដល់អ្នក នូវការដឹកនាំទាំងឡាយពីរបៀបដែលអ្នកអាចប្រព្រឹត្តនៅចំពោះយើង ប្រយោជន៍ឲ្យវាអាច បានបែរទៅរកអ្នក សំរាប់សេចក្ដីសង្គ្រោះដល់អ្នក ។

១០ យើងជាព្រះអម្ចាស់ជាប់សន្យា កាលណាអ្នករាល់គ្នាប្រព្រឹត្តតាមអ្វី ដែលយើងមានព្រះបន្ទូល; ប៉ុន្តែកាលណាអ្នករាល់គ្នាមិនប្រព្រឹត្ត តាមអ្វី ដែលយើងមានព្រះបន្ទូលទេ នោះអ្នករាល់គ្នាពុំមានសេចក្ដីសន្យាឡើយ ។

១១ ហេតុដូច្នេះហើយ យើងប្រាប់អ្នកជាប្រាកដថា ជាការចាំបាច់ដល់ អែតវីត បាទ្រិច និង នូវល ខេ វិតនី, អេស៊ីឌនី គិលបឺត និងស៊ីឌនី រិកដុន ជាពួកអ្នកបំរើរបស់យើង និង យ៉ូសែប ស្ម៊ីធ ជាអ្នកបំរើរបស់យើង និង យ៉ូហាន វិតមើរ និង អូលីវើរ ខៅឌើរី និង ដ័បបុលយូ ដ័បបុលយូ ហ្វែលប្ស និង ម៉ាទិន ហារិស ត្រូវបានចង ជុំគ្នា ដោយចំណង និងសេចក្ដីសញ្ញា ដែលពុំអាចបណ្ដាច់បានដោយសារការរំលង ឡើយ លើកលែងតែសេចក្ដីជំនុំជំរះនឹងមកតាមភ្លាមក្នុងការកាន់កាប់ត្រួតត្រានានារបស់អ្នក —

១២ ដើម្បីកាន់កាប់កិច្ចការអំពីមនុស្សទ័លក្រ និងគ្រប់ទាំងអស់ដែលទាក់ទងទៅនឹងគណៈប៊ីស្សព ទាំងនៅក្នុងដែនដីស៊ីយ៉ូន និងនៅ ក្នុងដែនដីខឺតឡង់ដែរ;

១៣ ត្បិតយើងបានទុកដែនដីខឺតឡង់នៅក្នុងពេលកំណត់របស់យើងផ្ទាល់ ទុកសំរាប់ប្រយោជន៍ដល់ពួកបរិសុទ្ធនៃព្រះដ៏ខ្ពស់បំផុត និងសំរាប់ស្តេកមួយដល់ក្រុងស៊ីយ៉ូន ។

១៤ ត្បិតក្រុងស៊ីយ៉ូនត្រូវតែចំរើនខាងលំអ និងខាងបរិសុទ្ធភាព; ព្រំដែនទាំងឡាយរបស់នាងត្រូវតែពង្រីកឡើង; ស្តេកទាំងឡាយ របស់នាងត្រូវបានចំរើនកម្លាំងឡើង; មែនហើយ យើងប្រាប់អ្នកជាប្រាកដថា ក្រុងស៊ីយ៉ូនត្រូវក្រោកឡើង ហើយប្រដាប់ដោយសំលៀក បំពាក់ដ៏រុងរឿងរបស់នាងចុះ ។

១៥ ហេតុដូច្នេះហើយ យើងប្រទានបញ្ញត្តិនេះដល់អ្នក ថាអ្នក

៣ *ក* លូកា ១២:៤៨;
យ៉ាកុប (ព.ស.ថ.) ៤:១៧.
ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួល ខុសត្រូវ.
*ខ* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
*គ* ស.ប. សេចក្ដីក្បត់សាសនា; អំពើបាប.
*ឃ* យ៉ូហាន ១៥:២២–២៤.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៤ *ក* ស.ប. វិវរណៈ.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
៥ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
*ខ* ស.ប. អារក្ស.
*គ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
៦ *ក* រ៉ូម ៣:១២; គ. និង ស. ១:១៦.
៧ *ក* ស.ប. អំពើបាប.
*ខ* គ. និង ស. ១:៣២–៣៣; ៥៨:៤៣.
៨ *ក* យ៉ូហាន ១៣:៣៤.
៩ *ក* គ. និង ស. ៤៣:៨.
១០ *ក* យ៉ូស្វេ ២៣:១៤;
១ ពង្សាវ. ៨:២៣;
គ. និង ស. ១:៣៨;
១៣០:២០–២១.
ស.ប. ប្រទានពរ, មានពរ, ព្រះពរ; ការគោរព, ដែលគោរព, គោរព.
១១ *ក* គ. និង ស. ៧៨:៣–៧, ១១–១៥.
១៣ *ក* អេសាយ ៣៣:២០; ៥៤:២.
ស.ប. ចំរឹង, ស្តេក.
១៤ *ក* ស.ប. ស៊ីយ៉ូន.
*ខ* អេសាយ ៥២:១;
គ. និង ស. ១១៣:៧–៨.

រាល់គ្នាត្រូវភ្ជាប់ខ្លួន ដោយនូវសេចក្ដីសញ្ញានេះ ហើយវានឹងបាន
សំរេច តាមក្រិត្យវិន័យទាំងឡាយនៃព្រះអម្ចាស់ ។
១៦ មើលចុះ នេះហើយជាប្រាជ្ញា នៅក្នុងយើងដែរ
សំរាប់ការល្អដល់អ្នក ។
១៧ ហើយអ្នកត្រូវបាន[ក]ស្មើគ្នា ឬក៏ម្យ៉ាងទៀត អ្នកត្រូវមាន
សិទ្ធិស្មើគ្នាក្នុងទ្រព្យសម្បត្តិទាំងឡាយ ទុកសំរាប់ប្រយោជន៍ដល់
ការកាន់កាប់ កិច្ចការខាងការកាន់កាប់ត្រួតត្រារបស់អ្នក
គឺមនុស្សគ្រប់រូបតាមចំណង់របស់ខ្លួន និងសេចក្ដីត្រូវការរបស់ខ្លួន
ដរាបណាចំណង់របស់ អ្នកនោះយុត្តិធម៌ —
១៨ ហើយគ្រប់ការណ៍ទាំងនេះ ទុកសំរាប់ប្រយោជន៍ដល់
សាសនាចក្រនៃព្រះដ៏មានព្រះជន្មរស់នៅ ប្រយោជន៍ឲ្យមនុស្ស
គ្រប់រូបអាច បានប្រសើរឡើង ចំពោះ[ក]ការប៉ិនប្រសប់របស់ខ្លួន
ប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចបានការប៉ិនប្រសប់ផ្សេងៗទៀត
មែនហើយ គឺរាប់រយ ដើម្បីបោះទៅក្នុង[ខ]ឃ្លាំងរបស់ព្រះអម្ចាស់
ដើម្បីឲ្យបានត្រឡប់ទៅជាទ្រព្យសម្បត្តិទូទៅ សំរាប់សាសនាចក្រ
ទាំងមូល —
១៩ មនុស្សគ្រប់រូបស្វែងរកចំណូលចិត្តនៃអ្នកជិតខាងរបស់ខ្លួន
ហើយប្រព្រឹត្តនូវគ្រប់ការណ៍ទាំងអស់ ដោយមាន[ក]ភ្នែកស្មោះស្ម័គ្រ
ទាំង ស្រុង ចំពោះសិរីល្អនៃព្រះ។
២០ របៀបនេះហើយដែលយើងបានតែងតាំង ចំពោះ[ក]របៀប
ដ៏នៅអស់កល្បអស់កាលជានិច្ចដល់អ្នក និងដល់ពួកជំនួសអ្នក
ទាំងឡាយ ដរាបណាអ្នកមិនធ្វើបាបសោះ ។
២១ ហើយមនុស្សណាដែលធ្វើបាប ហើយពង្រឹងចិត្តខ្លួនទាស់
នឹងសេចក្ដីសញ្ញានេះ នោះនឹងត្រូវដោះស្រាយតាមក្រឹត្យវិន័យ
ទាំងឡាយ នៃសាសនាចក្ររបស់យើង ហើយនឹងត្រូវ
ប្រគល់ទៅឯ[ក]ការធ្វើទុក្ខពីអារក្សសាតាំង ទំរាំដល់ថ្ងៃប្រោសលោះ ។
២២ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា
នេះហើយគឺជាប្រាជ្ញា ចូរធ្វើមិត្តសំឡាញ់ដល់ខ្លួន នូវ
ទ្រព្យសម្បត្តិខាងសេចក្ដីឥត សុចរិត ហើយរបស់ទាំងនោះ
នឹងមិនបំផ្លាញអ្នកឡើយ ។
២៣ ចូរទុកសេចក្ដីជំនុំជំរះនឹងយើងចុះ ត្បិតវាជាសេច
ក្ដីជំនុំជំរះរបស់យើង ហើយយើងនឹង[ក]សងវិញ ។ ចូរមានសេច
ក្ដីសុខសាន្តនៅ ជាមួយអ្នកចុះ; រីឯព្រះពររបស់យើងទាំងប៉ុន្មាន
នឹងនៅជាមួយអ្នកតទៅ ។
២៤ ត្បិតទោះជាបន្តិចទៀតក្ដី [ក]នគររបស់ផងអ្នក ហើយនឹងបាន
ទៅដល់អស់កល្បជានិច្ច បើសិនជាអ្នកមិនធ្លាក់ពីសេចក្ដីខ្ជាប់ខ្ជួន
របស់ ខ្លួនឡើយនោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៨៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៨៣២ (*History of the Church*, ១:២៦៩–២៧០)* ។ *វិវរណៈនេះត្រូវបានទទួលក្នុងកាលព្យាការីកំពុងអង្គុយប្រឹក្សាជាមួយពួកបងប្អូនប្រុសៗរបស់លោក ក្នុងសាសនា ។*

*១–៤, ពួកស្ត្រី និងកូនក្មេងមានសិទ្ធិពឹងពាក់ទៅលើស្វាមី និងឪពុករបស់ពួកគេ សំរាប់ការគាំទ្រជីវិតរបស់ពួកគេ; ៥–៦, ពួកស្រីមេម៉ាយ និងកូនកំព្រា មានសិទ្ធិពឹងពាក់ទៅលើសាសនាចក្រ សំរាប់ការគាំទ្រជីវិតរបស់ពួកគេ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលបន្ថែមទៅនិង
ក្រិត្យវិន័យទាំងឡាយនៃសាសនាចក្រ អំពីពួកស្ត្រី និង
កូនក្មេង ដែលជា សមាជិកចំពោះសាសនាចក្រ ដែលបាន
[ក]បាត់បង់ស្វាមី ឬឪពុករបស់ពួកគេ ដូច្នេះថា៖

១៧ *ក* គ. និង ស. ៥១:៣.
ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ.
១៨ *ក* ម៉ាថាយ ២៥:១៤–៣០;
គ. និង ស. ៦០:១៣.
ស.ប. អំណោយទាន;
អំណោយទានទាំងឡាយនៃ
ព្រះវិញ្ញាណ.
*ខ* គ. និង ស. ៤២:៣០–៣៤, ៥៥;
១១៩:១–៣.
ស.ប. ឃ្លាំង.
១៩ *ក* គ. និង ស. ៨៨:៦៧.
ស.ប. ភ្នែក, ភ្នែកទាំងឡាយ.
២០ *ក* ស.ប. សហសមាគម.
២១ *ក* គ. និង ស. ១០៤:៨–១០.
២៣ *ក* រ៉ូម ១២:១៩; មរមន ៣:១៥.
២៤ *ក* លូកា ១២:៣២;
គ. និង ស. ៦៤:៣–៥.
ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
**៨៣** ១ *ក* យ៉ាកុប (ប.ស.ថ.) ១:២៧.

២ ពួកស្រ្តីមាន[ក]សិទ្ធិពឹងពាក់ទៅលើស្វាមីរបស់ខ្លួន សំរាប់ការចញ្ចឹមជីវិត រហូតដល់ស្វាមីរបស់ខ្លួនត្រូវបានយកទៅ; ហើយបើសិន ជាពួកគេពុំឃើញថាជាអ្នករំលងច្បាប់ទេ នោះពួកគេនឹងត្រូវបានទទួលការរាប់អាន នៅក្នុងសាសនាចក្រ ។

៣ ហើយបើសិនជាពួកគេពុំស្មោះត្រង់ទេ នោះនឹងមិនត្រូវមានការរាប់អាន នៅក្នុងសាសនាចក្រឡើយ; តែពួកគេអាចអាស្រ័យនៅ លើទីនៃកេរ្តិ៍មរតករបស់ពួកគេបាន តាមច្បាប់ទាំងឡាយនៃដែនដី ។

៤ គ្រប់[ក]កូនក្មេងទាំងអស់មានសិទ្ធិពឹងពាក់ទៅលើឪពុកម្ដាយរបស់ខ្លួន សំរាប់ការចញ្ចឹមជីវិត រហូតដល់ពួកគេមានអាយុគ្រប់ ។

៥ ហើយបន្ទាប់ពីពេលនោះមក ពួកគេមានសិទ្ធិពឹងពាក់ទៅលើសាសនាចក្រ ឬម្យ៉ាងទៀត ទៅលើ[ក]ឃ្លាំងរបស់ព្រះអម្ចាស់ បើសិនជា ឪពុកម្ដាយរបស់គេ គ្មានអ្វីនឹងឲ្យពួកគេទុកជាកេរ្តិ៍មរតកឡើយនោះ ។

៦ ហើយឃ្លាំងត្រូវមានរបស់របរ ដោយនូវដង្វាយពីសាសនាចក្រ; ហើយ[ក]ពួកស្រីមេម៉ាយ និងកូនកំព្រាត្រូវផ្គត់ផ្គង់ ព្រមទាំង[ខ]មនុស្ស ទ័លក្រដែរ ។ អាម៉ែន ៕

## កណ្ឌទី ៨៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២២ និង២៣ ខែកញ្ញា ឆ្នាំ១៨៣២ (*History of the Church*, ១:២៨៦–២៩៥)* ។ *នៅក្នុងខែកញ្ញា ពួកអែលឌើរបានចាប់ផ្ដើមវិលទៅធ្វើបេសកកម្មគេវិញ នៅ រដ្ឋទាំងឡាយនៅទិសខាងកើត ហើយដើម្បីរាយការណ៍ប្រាប់ពីការងាររបស់ខ្លួន ។ ក្នុងកាលពួកគេកំពុងតែជួបជុំគ្នាក្នុងរដូវនៃសេចក្ដីអំណរ នោះទើបបានទទួលដំណឹងដែលមានដូតទៅនេះ ។ ព្យាការីបានចាត់វិវរណៈនេះទុកជាវិវរណៈអំពីបព្វជិតភាព ។*

*១–៥, ក្រុងយេរូសាឡិមថ្មី និងព្រះវិហារនឹងត្រូវបានសង់នៅរដ្ឋមិសសួរី; ៦–១៧, ខ្សែបព្វជិតភាពពីលោកម៉ូសេ ទៅដល់លោកអ័ដាមត្រូវ បានប្រាប់; ១៨–២៥, បព្វជិតភាពដ៏ធំជាងនោះ កាន់កូនសោនូវចំណេះវិជ្ជាពីព្រះ; ២៦–៣២, បព្វជិតភាពដ៏តូចជាងនោះ កាន់កូនសោ នូវការបំរើនៃពួកទេវតា និងនៃដំណឹងល្អខាងការរៀបចំ; ៣៣–៤៤, មនុស្សបានជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈសម្បថ និងសេចក្ដី សញ្ញានៃបព្វជិតភាព; ៤៥–៥៣, ព្រះវិញ្ញាណនៃព្រះគ្រីស្ទបំភ្លឺចិត្តមនុស្ស ហើយពិភពលោកដេកនៅក្នុងអំពើបាប; ៥៤–៦១, ពួកបរិសុទ្ធ ត្រូវថ្លែងទីបន្ទាល់ពីការណ៍ទាំងនោះ ដែលពួកគេបានទទួលមក; ៦២–៧៦, ពួកគេត្រូវទៅផ្សាយដំណឹងល្អ ហើយទីសំគាល់ទាំងឡាយ នឹងមកតាមក្រោយ; ៧៧–៩១, ពួកអែលឌើរត្រូវចេញទៅដោយគ្មានកាបូប ឬយាមឡើយ ហើយព្រះអម្ចាស់ទ្រង់នឹងថែទាំនូវសេចក្ដី ត្រូវការរបស់ពួកគេ; ៩២–៩៧, គ្រោះ និងពាក្យបណ្ដាសាររង់ចាំអស់អ្នកណាដែលបដិសេធដំណឹងល្អ; ៩៨–១០២, ចំរៀងថ្មីអំពីសេចក្ដីប្រោសលោះនៃក្រុងស៊ីយ៉ូនត្រូវបានប្រាប់; ១០៣–១១០, ចូរឲ្យមនុស្សគ្រប់រូបឈរនៅក្នុងតំណែងរបស់ខ្លួន ហើយធ្វើការនៅក្នុង ការហៅរបស់ខ្លួនចុះ; ១១១–១២០, ពួកអ្នកបំរើរបស់ព្រះអម្ចាស់ត្រូវប្រកាសប្រាប់ពីអំពើគួរខ្ពើមឆ្អើម ដែលបង្ខូចបំផ្លាញនៅគ្រាចុង ក្រោយបំផុត ។*

វិវរណៈពីព្រះយេស៊ូវគ្រីស្ទចំពោះ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់ទ្រង់ និងពួកអែលឌើរប្រាំមួយនាក់ ក្នុងកាលពួកគេកំពុងតែរួបរួម ចិត្តគ្នា [ក]ហើយបន្លឺសម្លេងរបស់ពួកគេឡើងទៅស្ថានដ៏ខ្ពស់ ។

២ មែនហើយ ព្រះបន្ទូលនៃព្រះអម្ចាស់ អំពីសាសនាចក្ររបស់ ទ្រង់ ដែលបានតាំងឡើងនៅថ្ងៃចុងក្រោយបំផុត សំរាប់[ក]ការសាងរាស្រ្ត [ខ]របស់ទ្រង់ឡើងវិញ ដូចទ្រង់មានព្រះបន្ទូល ដោយមាត់នៃពួកព្យាការីរបស់ទ្រង់ និងសំរាប់ការ

២ *ក* ១ ធីម៉ូ. ៥:៨.
៤ *ក* ម៉ូសាយ ៤:១៤.
៥ *ក* គ. និង ស. ៧៨:៣.
ស.ប. ឃ្លាំង.
៦ *ក* ស.ប. ស្រីមេម៉ាយ.
*ខ* ម៉ូសាយ ៤:១៦–២៦;
ហេលេ. ៤:១១–១៣;
គ. និង ស. ៤២:៣០–៣៩.
ស.ប. មនុស្សក្រីក្រ.
៨៤ ១*ក* ស.ប. ការអធិស្ឋាន.
២ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* កិច្ចការ ៣:១៩–២១.

ប្រមូលពួកបរិសុទ្ធ ឲ្យឈរនៅ លើភ្នំស៊ីយ៉ូន ដែលនឹងត្រូវទៅជាទីក្រុងយេរូសាឡិមថ្មី ។

៣ រីឯទីក្រុងនោះនឹងត្រូវបានសង់ឡើង ចាប់ផ្ដើមនិងទីធ្លានៃព្រះវិហារ ដែលត្រូវបានចាត់ដោយព្រះអង្គុលីនៃព្រះអម្ចាស់ នៅព្រំប្រទល់ ខាងលិចនៃរដ្ឋមិសសួរី ដោយដៃរបស់ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និងពួកអ្នកផ្សេងៗទៀត ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យជាខ្លាំង ។

៤ ប្រាកដមែន នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់ ថាទីក្រុងយេរូសាឡិមថ្មីនឹងត្រូវបានសង់ឡើង ដោយសារការប្រមូលពួកបរិសុទ្ធ ចាប់ផ្ដើមនឹងកន្លែងនេះ គឺជាកន្លែងព្រះវិហារ ជាព្រះវិហារដែលនឹងត្រូវបានតម្លើងឡើងនៅក្នុងតំណនេះ ។

៥ ត្បិតប្រាកដមែន តំណនេះនឹងមិនត្រូវបានកន្លងផុតឡើយ រហូតដល់ដំណាក់មួយបានសង់ឡើងថ្វាយដល់ព្រះអម្ចាស់ ហើយពពកមួយ នឹងសណ្ឋិតនៅលើព្រះវិហារនោះ ជាពពកដែលនឹងទៅដូចជាសិរីល្អនៃព្រះអម្ចាស់ ដែលនឹងមានពាសពេញក្នុងដំណាក់នោះ ។

៦ ហើយកូនប្រុសទាំងឡាយរបស់លោកម៉ូសេ តាមបព្វជិតភាពដ៏បរិសុទ្ធ ដែលលោកបានទទួល នៅក្រោមដៃយេត្រូជាឪពុកក្មេក របស់លោក;

៧ ហើយយេត្រូបានទទួលបព្វជិតភាពនៅក្រោមដៃកាលែប;

៨ ហើយកាលែបបានទទួលបព្វជិតភាពនៅក្រោមដៃអេលីហ៊ូវ;

៩ ហើយអេលីហ៊ូវនៅក្រោមដៃយេរេមា;

១០ ហើយយេរេមានៅក្រោមដៃកាឌ់;

១១ ហើយកាឌ់នៅក្រោមដៃអេលីយ៉ាស;

១២ ហើយអេលីយ៉ាសបានទទួលបព្វជិតភាពនៅក្រោមព្រះហស្តនៃព្រះ ។

១៣ ហើយអេលីយ៉ាសក៏បានរស់នៅសម័យលោកអ័ប្រាហាំ ហើយត្រូវទទួលពរពីលោក —

១៤ រីឯលោកអ័ប្រាហាំបានទទួលបព្វជិតភាពពីលោកមិលគីស្សាដែក ដែលបានទទួលតាមរយៈវង្សានៃពួកអយ្យកោរបស់លោក គឺរហូតដល់ទៅដល់លោកណូអេ;

១៥ ហើយពីលោកណូអេទៅដល់លោកហេណុក តាមរយៈវង្សានៃពួកអយ្យកោរបស់ពួកគេ;

១៦ ហើយពីលោកហេណុកទៅដល់អេបិល ដែលត្រូវបានប្រហារបង់ ដោយសារការរួមគំនិតអាក្រក់នៃបងប្រុសរបស់គាត់ ដែលបាន ទទួលបព្វជិតភាព ដោយបញ្ញត្តិទាំងឡាយពីព្រះ ដោយសារដៃលោកអ័ដាម ជាឪពុករបស់គាត់ ដែលជាមនុស្សទីមួយ —

១៧ រីឯបព្វជិតភាពនេះមានបន្តមក នៅក្នុងសាសនាចក្រនៃព្រះនៅគ្រប់តំណទាំងអស់ ហើយគ្មានថ្ងៃកំណើត ឬឆ្នាំបញ្ចប់ឡើយ ។

១៨ ហើយព្រះអម្ចាស់ទ្រង់បានបញ្ជាក់បព្វជិតភាពមួយមកលើលោកអើរ៉ុន និងពូជពង្សលោកដែរ គឺតាមគ្រប់តំណរបស់ពួកគេទាំងអស់ រីឯបព្វជិតភាពនេះក៏មានបន្តមក ហើយនៅជាប់ដរាបជាមួយនិងបព្វជិតភាព ដែលធ្វើតាមរបៀបដ៏បរិសុទ្ធបំផុតនៃព្រះ ។

១៩ ហើយបព្វជិតភាពដ៏ធំជាងនេះ ចាត់ចែងដំណឹងល្អ ហើយកាន់កូនសោនៃសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ គឺជាកូនសោនៃចំណេះវិជ្ជាពីព្រះ ។

២០ ហេតុដូច្នេះហើយ នៅក្នុងពិធីបរិសុទ្ធទាំងឡាយ

២ *គ* ស.ប. ជនបរិសុទ្ធ.
*ឃ* អេសាយ ២:២–៥;
ហេព្រើរ ១២:២២; វិវរ. ១៤:១;
គ. និង ស. ៧៦:៦៦; ៨៤:៣២;
១៣៣:១៨, ៥៦.
*ង* អេធើរ ១៣:២–១១;
គ. និង ស. ៤២:៨–៩;
៤៥:៦៦–៦៧;
ម. នៃ ស. ១:១០.
ស.ប. ក្រុងយេរូសាឡិមថ្មី.
៣ *ក* គ. និង ស. ៥៧:៣.
៤ *ក* ស.ប. ក្រុងយេរូសាឡិមថ្មី.
*ខ* ស.ប. ព្រះវិហារបរិសុទ្ធ,
ដំណាក់នៃព្រះអម្ចាស់.
៥ *ក* គ. និង ស. ៤៥:៦៧;
៦៤:៤១–៤៣; ៩៧:១៥–២០;
១០៩:១២, ៣៧.
៦ *ក* ស.ប. ដៃ, ការដាក់.
*ខ* ស.ប. យេត្រូ.
១៤ *ក* ស.ប. អ័ប្រាហាំ.
*ខ* ស.ប. មិលគីស្សាដែក.
*គ* ស.ប. ណូអេ,
អយ្យកោក្នុងព្រះគម្ពីរប៊ីប.
១៥ *ក* ស.ប. ហេណុក.
១៦ *ក* ស.ប. អេបិល.
*ខ* ម៉ូសេ ៥:២៩–៣២.
*គ* គ. និង ស. ១០៧:៤០–៥៧.
*ឃ* ស.ប. អ័ដាម.
១៧ *ក* អាលម៉ា ១៣:១–១៩;
អ័ប្រា. ២:៩, ១១.
ស.ប. បព្វជិតភាពមិលគីស្សាដែក.
១៨ *ក* ស.ប. បព្វជិតភាពអើរ៉ុន.
*ខ* ស.ប. អើរ៉ុន, បងប្រុសរបស់ម៉ូសេ.
*គ* គ. និង ស. ១៣:១.
១៩ *ក* គ. និង ស. ៦៣:២៣;
១០៧:១៨–១៩.
ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*ខ* អ័ប្រា. ១:២.
២០ *ក* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.

នៃបព្វជិតភាពដ៏ធំជាងនេះ នោះអំណាចនៃព្រះត្រូវបានសម្ដែងឲ្យ
ឃើញ ។
២១ ហើយបើសិនជាគ្មានពិធីបរិសុទ្ធទាំងឡាយ
នៃបព្វជិតភាពដ៏ធំជាងនេះ និង[ក]សិទ្ធិអំណាចនៃបព្វជិតភាពទេ
នោះអំណាចនៃព្រះ ពុំអាចបានសម្ដែងដល់មនុស្ស នៅក្នុង
សាច់ឈាមបានឡើយ;
២២ ត្បិតបើសិនជាគ្មានការណ៍នេះទេ នោះគ្មាន[ក]មនុស្សណា
មួយ អាចមើលឃើញព្រះភ័ក្ត្រនៃព្រះ គឺព្រះវរបិតា ហើយ
រស់នៅបាន ឡើយ ។
២៣ ឥឡូវនេះ [ក]លោកម៉ូសេនេះហើយបានបង្រៀនយ៉ាង
ច្បាស់លាស់ ដល់កូនចៅអ៊ីស្រាអែល នៅក្នុងទីរហោស្ថាន
ហើយបានព្យា យាមស្វែងរក ដើម្បីញែកប្រជាជនរបស់លោក
[ខ]ចេញជាបរិសុទ្ធ ប្រយោជន៍ឲ្យពួក[គ]គេអាចបានមើលឃើញ
ព្រះភ័ក្ត្រនៃព្រះ ។
២៤ ប៉ុន្តែពួកគេ[ក]ពង្រឹងចិត្តរបស់គេ ហើយពុំអាចទ្រាំវត្តមាន
របស់ទ្រង់បានឡើយ; ហេតុដូច្នេះហើយ ព្រះអម្ចាស់ នៅក្នុង
[ខ]សេចក្ដីក្រោធ របស់ទ្រង់ ត្បិតសេចក្ដីខ្ញាល់របស់ទ្រង់បាន
ឆ្លុលឡើងទាស់នឹងពួកគេ បានជាព្រះអង្គស្បថថា ពួកគេនឹងមិន
[គ]ត្រូវបានចូលក្នុងសេចក្ដីសំរាក របស់ទ្រង់ឡើយ កាលនៅក្នុង
ទីរហោស្ថាន ឯសេចក្ដីសំរាកនេះគឺជាភាពពោរពេញនៃសិរីល្អ
របស់ទ្រង់ ។
២៥ ហេតុដូច្នេះហើយ ព្រះអង្គបានយក[ក]លោកម៉ូសេចេញ
ពីកណ្ដាលពួកគេ [ខ]ព្រមទាំងបព្វជិតភាពដ៏បរិសុទ្ធផងដែរ;
២៦ ហើយ[ក]បព្វជិតភាពដ៏តូចជាងមានបន្តមក ជាបព្វជិតភាព
ដែល[ខ]កាន់កូនសោខាង[គ]ការបំរើនៃពួកទេវតា និងដំណឹងល្អខាង
ការរៀបចំ;
២៧ រីឯដំណឹងល្អនេះ គឺជាដំណឹងល្អ[ក]ពីការប្រែចិត្ត និងពី
[ខ]បុណ្យជ្រមុជទឹក និង[គ]ពីការផ្ដាច់បាប និងពី[ឃ]ក្រិត្យវិន័យអំពីព្រះបញ្ញត្តិ
ទាំងឡាយ [ង]ខាងលោកិយ ដែលព្រះអម្ចាស់ ក្នុងសេចក្ដីក្រោធ
របស់ទ្រង់ បានបណ្ដាលឲ្យមានបន្តមក នៅជាមួយវង្សអើរ៉ុន
ក្នុងចំណោមកូនចៅ អ៊ីស្រាអែល រហូតមកដល់[ច]យ៉ូហាន
ដែលព្រះទ្រង់បានលើកឡើង ដោយបាន[ឆ]ពេញទៅដោយ
ព្រះវិញ្ញាណបរិសុទ្ធ តាំងពីផ្ទៃម្ដាយលោក មក ។
២៨ ត្បិតលោកត្រូវបានទទួលបុណ្យជ្រមុជទឹក តាំងពីលោក
នៅក្មេង ហើយត្រូវបានតែងតាំងដោយទេវតានៃព្រះ ក្នុងកាល
លោក មានអាយុ៨ថ្ងៃ ឲ្យមានអំណាចនេះ ដើម្បីទំលាក់
នគរនៃពួកសាសន៍យូដា ហើយដើម្បី[ក]តម្រង់ផ្លូវថ្វាយព្រះអម្ចាស់
នៅមុខប្រជាជនរបស់ លោក ដើម្បីរៀបចំពួកគេចាំការយាង
មកនៃព្រះអម្ចាស់ ដែលគ្រប់អំណាច[ខ]ទាំងអស់ ត្រូវបានប្រទាន
ដល់ព្រះហស្តរបស់ទ្រង់ ។
២៩ ហើយជាថ្មីទៀត [ក]តំណែងទាំងឡាយនៃអែលឌើរ
និងប៊ីស្សព សុទ្ធតែជាការបន្ថែមបញ្ជាប់ចាំបាច់ ដែលជារបស់
ផងបព្វជិតភាព ជាន់ខ្ពស់ ។
៣០ ហើយជាថ្មីទៀត តំណែងទាំងឡាយនៃគ្រូ និងឌីកុន
សុទ្ធតែជាការបន្ថែមបញ្ជាប់ចាំបាច់ ដែលជារបស់ផង
បព្វជិតភាពតូចជាង គឺជាបព្វជិតភាពដែលត្រូវបានបញ្ជាក់មក
លើលោកអើរ៉ុន និងពួកកូនប្រុសរបស់លោក ។
៣១ ហេតុដូច្នេះហើយ ដូចជាយើងបានមានបន្ទូលអំពីពួក
កូនប្រុសរបស់លោកម៉ូសេ — ត្បិតពួកកូនប្រុសរបស់លោក
ម៉ូសេ ហើយព្រម ទាំងពួកកូនប្រុសរបស់លោកអើរ៉ុនដែរ
ត្រូវថ្វាយ[ក]ដង្វាយ និងយញ្ញបូជាដ៏សមរម្យ នៅក្នុងដំណាក់នៃ
ព្រះអម្ចាស់ គឺជាដំណាក់ដែលនឹង ត្រូវបាន

២១ *ក* ស.ប. សិទ្ធិអំណាច; បព្វជិតភាព.
២២ *ក* គ. និង ស. ៦៧:១១.
២៣ *ក* និក្ខ. ១៩:៥–១១; ៣៣:១១.
*ខ* ស.ប. ការញែកជាបរិសុទ្ធ.
*គ* និក្ខ. ២៤:៩–១១;
គ. និង ស. ៩៣:១.
២៤ *ក* និក្ខ. ២០:១៨–២១; ៣២:៨;
ចោទិ. ៩:២៣;
១ នីហ្វៃ ១៧:៣០–៣១, ៤២.
*ខ* ទំនុក. ៩៥:៨; ហេព្រើរ ៣:៨–១១;
យ៉ាកុប ១:៧–៨;
អាលម៉ា ១២:៣៦.
*គ* ក.យ.ស., និក្ខ. ៣៤:១–២;
ជនគ. ១៤:២៣;
ហេព្រើរ ៤:១–១១.
២៥ *ក* ចោទិ. ៣៤:១–៥.
*ខ* ស.ប. បព្វជិតភាពមិលគីស្សាដែក.
២៦ *ក* ស.ប. បព្វជិតភាពអើរ៉ុន.
*ខ* គ. និង ស. ១៣:១.
*គ* គ. និង ស. ១០៧:២០.
២៧ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
*គ* ស.ប. ការផ្ដាច់បាប.
*ឃ* ស.ប. ក្រិត្យវិន័យលោកម៉ូសេ.
*ង* ហេព្រើរ ៧:១១–១៦.
*ច* ស.ប. យ៉ូហាន-បាទីស្ទ.
*ឆ* លូកា ១:១៥.
២៨ *ក* អេសាយ ៤០:៣;
ម៉ាថាយ ៣:១–៣;
យ៉ូហាន ១:២៣.
*ខ* ម៉ាថាយ ២៨:១៨;
យ៉ូហាន ១៧:២;
១ ពេត្រុស ៣:២២;
គ. និង ស. ៩៣:១៦–១៧.
២៩ *ក* គ. និង ស. ១០៧:៥.
៣១ *ក* គ. និង ស. ១២៨:២៤.

សង់ឡើងថ្វាយដល់ព្រះអម្ចាស់ នៅក្នុងតំណមនុស្សនេះ គឺនៅលើកន្លែងដែលបានធ្វើពិធីឆ្លង ដែលយើងបានកំណត់ទុក —

៣២ ហើយពួកកូនប្រុសនៃលោកម៉ូសេ និងលោកអើរ៉ុន នឹងត្រូវបានពោរពេញទៅដោយសិរីល្អនៃព្រះអម្ចាស់ នៅលើភ្នំស៊ីយ៉ូន នៅក្នុងដំណាក់របស់ព្រះអម្ចាស់ ឯពួកកូនប្រុសរបស់ពួកគេ គឺពួកអ្នករាល់គ្នា; ហើយព្រមទាំងមនុស្សជាច្រើនផង ដែលយើងបានហៅ ហើយចាត់ឲ្យចេញទៅ ដើម្បីសង់សាសនាចក្ររបស់យើងឡើង ។

៣៣ ត្បិតអស់អ្នកណាដែលស្មោះត្រង់ ក្នុងកាលបានបព្វជិតភាពទាំងពីរនេះ ដែលយើងបានពោលដល់ ហើយបានដំកើងការហៅ របស់ខ្លួន នោះត្រូវបានញែកជាបរិសុទ្ធ ដោយសារព្រះវិញ្ញាណ ចំពោះការសាងរូបកាយរបស់ពួកគេជាថ្មី ។

៣៤ ពួកគេត្រឡប់ជាកូនប្រុសនៃលោកម៉ូសេ និងលោកអើរ៉ុន ហើយជាពូជនៃលោកអ័ប្រាហាំ និងជាសាសនាចក្រ និងនគរ និងជាពួករើសតាំងនៃព្រះ ។

៣៥ ហើយអស់អ្នកណាដែលទទួលបព្វជិតភាពនេះ ឈ្មោះថាទទួលយើងដែរ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ;

៣៦ ត្បិតអ្នកណាដែលទទួលពួកអ្នកបំរើរបស់យើង ឈ្មោះថាទទួលយើងដែរ;

៣៧ ហើយអ្នកណាដែលទទួលយើង ឈ្មោះថាទទួលព្រះវរបិតាយើងដែរ;

៣៨ ហើយអ្នកណាដែលទទួលព្រះវរបិតាយើង ឈ្មោះថាទទួលនគររបស់ព្រះវរបិតាយើងដែរ; ហេតុដូច្នេះហើយ គ្រប់អ្វីៗទាំងអស់ ដែលព្រះវរបិតាយើងមាន នោះនឹងត្រូវបានប្រទានដល់អ្នកនោះដែរ ។

៣៩ ហើយការណ៍នេះ គឺស្របតាមសម្បថ និងសេចក្ដីសញ្ញាដែលជារបស់ផងបព្វជិតភាព ។

៤០ ប៉ុន្តែអស់អ្នកទាំងនោះដែលទទួលបព្វជិតភាព ឈ្មោះថាទទួលសម្បថ និងសេចក្ដីសញ្ញានេះ ពីព្រះវរបិតាយើង ដែលទ្រង់ពុំអាច បណ្ដាច់ ឬអាចរើបានឡើយ ។

៤១ ប៉ុន្តែអស់អ្នកណាដែលបណ្ដាច់សេចក្ដីសញ្ញានេះ បន្ទាប់ពីអ្នកនោះបានទទួលរួចស្រេច ហើយបែរចេញប្រងើយ នោះនឹងមិនត្រូវ បានអត់ទោសឲ្យឡើយ ទោះជានៅលោកិយនេះ ឬក៏នៅបរលោកក្តី ។

៤២ ហើយវេទនាដល់អស់អ្នកណា ដែលពុំចូលមកក្នុងបព្វជិតភាពនេះ ដែលអ្នករាល់គ្នាបានទទួល ដែលយើងកំពុងតែបញ្ជាក់មកលើ អ្នកឥឡូវនេះ ដែលជាអ្នកមានវត្តមាននៅថ្ងៃនេះ ដោយសារសម្លេងរបស់យើងផ្ទាល់ចេញមកពីលើមេឃ; ហើយគឺយើងនេះ ហើយ ដែលបានបង្គាប់ដល់ពួកពលបរិវារនៅលើស្ថានសួគ៌ និងពួកទេវតារបស់យើង ពីដំណើរអ្នក ។

៤៣ ហើយឥឡូវនេះ យើងប្រទានបញ្ញត្តិមួយដល់អ្នកដើម្បីឲ្យប្រយ័ត្នប្រយែងខ្លួន ដើម្បីព្យាយាមស្ដាប់តាមព្រះបន្ទូលទាំងឡាយ អំពី ជីវិតដ៏នៅអស់កល្បជានិច្ច ។

៤៤ ត្បិតអ្នកត្រូវរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមក ។

៤៥ ត្បិតព្រះបន្ទូលនៃព្រះអម្ចាស់គឺជាសេចក្ដីពិត ហើយអ្វីៗក៏ដោយដែលជាសេចក្ដីពិត គឺជាពន្លឺ និងអ្វីៗក៏ដោយដែលជាពន្លឺ គឺជា ព្រះវិញ្ញាណ គឺជាព្រះវិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ ។

៤៦ ហើយព្រះវិញ្ញាណប្រទានពន្លឺដល់មនុស្សគ្រប់រូបណា ដែល

---

៣១ *ខ* គ. និង ស. ៥៧:៣.
៣២ *ក* ស.ប. សិរីល្អ.
*ខ* ហេព្រើរ ១២:២២; គ. និង ស. ៧៦:៦៦; ៨៤:២; ១៣៣:៥៦.
*គ* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
៣៣ *ក* ស.ប. សក្ដិសម, ភាពសក្ដិសម.
*ខ* ស.ប. បព្វជិតភាព.
*គ* ស.ប. ការញែកជាបរិសុទ្ធ.
៣៤ *ក* កាឡាទី ៣:២៩; អេប្រា. ២:៩–១១. ស.ប. អ័ប្រាហាំ — ពូជរបស់អ័ប្រាហាំ.
*ខ* គ. និង ស. ១៣២:៣០–៣២. ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*គ* ស.ប. ពួករើសតាំង.
៣៦ *ក* ម៉ាថាយ ១០:៤០–៤២; លូកា ១០:១៦; គ. និង ស. ១១២:២០.
៣៧ *ក* យ៉ូហាន ១៣:២០.
៣៨ *ក* លូកា ១២:៤៣–៤៤; រ៉ូម ៨:៣២; វិវរ. ២១:៧; ៣ នីហ្វៃ ២៨:១០; គ. និង ស. ១៣២:១៨–២០. ស.ប. ភាពដំកើងឡើង.
៣៩ *ក* ស.ប. សម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព.
៤១ *ក* ស.ប. សេចក្ដីក្បត់សាសនា.
*ខ* គ. និង ស. ៧៦:៣៤–៣៨; ១៣២:២៧.
៤២ *ក* គ. និង ស. ៨៤:៨៨.
៤៣ *ក* ១ នីហ្វៃ ១៥:២៣–២៥; គ. និង ស. ១:១៤.
៤៤ *ក* ចោទិ. ៨:៣; ម៉ាថាយ ៤:៤; គ. និង ស. ៩៨:១១.
៤៥ *ក* ទំនុក. ៣៣:៤. ស.ប. ព្រះបន្ទូលនៃព្រះ.
*ខ* ស.ប. សេចក្ដីពិត.
៤៦ *ក* ស.ប. បញ្ញាចិត្ត; ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* យ៉ូហាន ១:៩; គ. និង ស. ៩៣:២.

មកក្នុងលោកិយ; ហើយព្រះវិញ្ញាណបំភ្លឺគ្រប់មនុស្សពាសពេញលោកិយ ដែលប្រុងស្ដាប់តាមសម្លេងនៃព្រះវិញ្ញាណ ។

៤៧ ហើយមនុស្សគ្រប់រូបណា ដែលប្រុងស្ដាប់តាមសម្លេងនៃព្រះវិញ្ញាណ នោះមករកព្រះ គឺព្រះវរបិតា ។

៤៨ ហើយព្រះវរបិតា ទ្រង់បង្រៀនអ្នកនោះអំពីសេចក្ដីសញ្ញា ដែលទ្រង់បានធ្វើជាថ្មី ហើយបានបញ្ជាក់មកលើអ្នករាល់គ្នា ដែលត្រូវបាន បញ្ជាក់មកលើអ្នក ជាប្រយោជន៍ដល់អ្នក ហើយពុំមែនជាប្រយោជន៍ដល់អ្នកតែប៉ុណ្ណោះទេ ប៉ុន្តែជាប្រយោជន៍ដល់ពិភពលោកទាំងមូល ផងដែរ ។

៤៩ ហើយពិភពលោកទាំងមូលដេកនៅក្នុងអំពើបាប ហើយថ្ងូរនៅក្រោមសេចក្ដីងងឹត និងនៅក្រោមចំណងនៃអំពើបាប ។

៥០ ហើយដោយសារការណ៍នេះ ទើបអ្នកអាចដឹងថា ពួកគេកំពុងតែនៅក្រោមចំណងនៃអំពើបាប ពីព្រោះពួកគេពុំមករកយើងឡើយ ។

៥១ ត្បិតអស់អ្នកណា ដែលពុំមករកយើង នោះនៅក្រោមចំណងនៃអំពើបាបហើយ ។

៥២ ហើយអស់អ្នកណា ដែលមិនទទួលសម្លេងយើង នោះពុំដែលស្គាល់សម្លេងយើងទេ ហើយមិនមែនជារបស់ផងយើងឡើយ ។

៥៣ ហើយដោយសារការណ៍នេះ ទើបអ្នកអាចស្គាល់ពួកសុចរិតពីពួកទុច្ចរិតបាន ហើយថាពិភពលោកទាំងមូលថ្ងូរនៅក្រោមអំពើ បាប និងសេចក្ដីងងឹត សូម្បីតែពេលនេះក្ដី ។

៥៤ ហើយពេលកន្លងមកហើយ នោះគំនិតរបស់អ្នកត្រូវបានងងឹត ពីព្រោះតែការឥតជំនឿ ហើយពីព្រោះអ្នកបានរាប់ការណ៍ ទាំងឡាយ ដែលអ្នកបានទទួលមក ទុកជាគ្មានផលប្រយោជន៍វិញ —

៥៥ រីឯការអសារឥតការ និងការឥតជំនឿនេះហើយ ដែលបាននាំសាសនាចក្រទាំងមូល ឲ្យនៅក្រោមការដាក់ទោស ។

៥៦ ហើយការដាក់ទោសនេះ គឺនៅលើពួកកូនចៅនៃក្រុងស៊ីយ៉ូន គឺគ្រប់ទាំងអស់គ្នា ។

៥៧ ហើយពួកគេនឹងត្រូវនៅក្រោមការដាក់ទោសនេះ រហូតដល់ពួកគេប្រែចិត្ត ហើយនឹកចាំដល់សេចក្ដីសញ្ញាថ្មី គឺជាព្រះគម្ពីរមរមន ព្រមទាំងព្រះបញ្ញត្តិមុនៗ ដែលយើងបានប្រទានដល់ពួកគេ មិនគ្រាន់តែសំរាប់ថាទេ ប៉ុន្តែសំរាប់ប្រព្រឹត្ត តាមអ្វីៗដែលយើងបាន សរសេរទុកដែរ —

៥៨ ប្រយោជន៍ឲ្យពួកគេអាចបង្កើតផល ដែលសំណាំនិងនគរនៃព្រះវរបិតារបស់ពួកគេ បើពុំនោះសោតទេ នោះមានការវាយ និងការ ជំនុំជំរះ ដែលនឹងចាក់មកលើពួកកូនចៅនៃក្រុងស៊ីយ៉ូន ។

៥៩ ត្បិតតើត្រូវឲ្យពួកកូនចៅនៃនគរ ធ្វើឲ្យដែនដីដ៏បរិសុទ្ធរបស់យើងកខ្វក់ឬ ? ប្រាកដមែន យើងប្រាប់ដល់អ្នកថា៖ ទេ ។

៦០ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អ្នកណាដែលឮព្រះបន្ទូលរបស់យើងឥឡូវនេះ ដែលជាសម្លេងរបស់យើង នោះអ្នករាល់គ្នា មានពរហើយ ដរាបណាអ្នករាល់គ្នាទទួលការណ៍ទាំងនេះ;

៦១ ត្បិតយើងនឹងអត់ទោសអំពើបាបទាំងឡាយដល់អ្នក ព្រមទាំងព្រះបញ្ញត្តិនេះផងថា — ប្រយោជន៍ឲ្យអ្នកនៅខ្ជាប់ខ្ជួនក្នុងគំនិតអ្នក ក្នុងភាពម៉ឺងម៉ាត់ និងវិញ្ញាណខាងការអធិស្ឋាន ក្នុងការថ្លែងទីបន្ទាល់ដល់សព្វក្នុងលោកិយទាំងមូលអំពីការណ៍ទាំងនោះ ដែលបាន ប្រាប់ដល់អ្នក ។

៦២ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាទៅសព្វក្នុងលោកិយទាំងមូល និងដល់កន្លែងណាក៏ដោយ ដែលអ្នករាល់គ្នាពុំអាចទៅបាន នោះអ្នករាល់គ្នាត្រូវផ្ញើ ប្រយោជន៍ឲ្យទីបន្ទាល់នោះអាចបានចេញពីអ្នក ទៅសព្វក្នុងលោកិយទាំងមូល ដល់គ្រប់មនុស្សទាំងអស់ ។

៦៣ ហើយដូចជាយើងប្រាប់ដល់ពួកសាវករបស់យើងយ៉ាងណា នោះយើងក៏ប្រាប់ដល់អ្នកយ៉ាងនោះដែរ ត្បិតអ្នករាល់គ្នា

៤៨ *ក* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
*ខ* ស.ប. សេចក្ដីសញ្ញា; សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច.
៤៩ *ក* ១ យ៉ូហាន ៥:១៩.
*ខ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
៥០ *ក* កាឡាទី ៤:៩.
*ខ* ស.ប. អំពើបាប.
៥២ *ក* យ៉ូហាន ១០:២៧.
៥៣ *ក* ស.ប. ពិភពលោក.
*ខ* រ៉ូម ៨:២២; ម៉ូសេ ៧:៤៨.
*គ* ស.ប. សេចក្ដីប្រកបដោយលោកិយ.
៥៤ *ក* ស.ប. ការឥតជំនឿ.
៥៥ *ក* ស.ប. ឥតប្រយោជន៍, ការឥតប្រយោជន៍.
៥៧ *ក* យេរេ. ៣១:៣១–៣៤.
*ខ* ស.ប. ព្រះគម្ពីរមរមន.
*គ* ១ នីហ្វៃ ១៣:៤០–៤១.
*ឃ* យ៉ាកុប (ព.ស.ថ.) ១:២២–២៥; គ. និង ស. ៤២:១៣–១៥.
៦០ *ក* គ. និង ស. ១៨:៣៤–៣៦.
៦១ *ក* ដានី. ៩:៩. ស.ប. អត់ទោស, អភ័យទោស.
*ខ* គ. និង ស. ៤៣:៣៤; ៨៨:១២១; ១០០:៧.
៦២ *ក* ម៉ាកុស ១៦:១៥; គ. និង ស. ១:២–៥. ស.ប. កិច្ចការផ្សាយសាសនា.
៦៣ *ក* ស.ប. សាវក.

ជាសាវក របស់យើង គឺជាពួកសង្ឃជាន់ខ្ពស់របស់ព្រះ; [ខ]អ្នករាល់គ្នានេះហើយ ជាពួកអ្នកដែលព្រះវរបិតារបស់យើងបានប្រទានដល់យើង; អ្នករាល់គ្នាជា[គ]មិត្តរបស់យើង;

៦៤ ហេតុដូច្នេះហើយ ដូចជាយើងបានប្រាប់ដល់ពួកសាវករបស់យើងយ៉ាងណា នោះយើងក៏ប្រាប់ដល់អ្នកម្ដងទៀតជាយ៉ាងនោះដែរ ថាមនុស្ស[ក]គ្រប់រូបណា ដែលជឿដល់ព្រះបន្ទូលទាំងឡាយរបស់យើង ហើយទទួលបុណ្យជ្រមុជដោយទឹក[ខ] សំរាប់[គ]ការផ្ដាច់បាបទាំងឡាយ នោះឈ្មោះថានឹងបាន[ឃ]ទទួលព្រះវិញ្ញាណបរិសុទ្ធ ។

៦៥ ហើយ[ក]ទីសំគាល់ទាំងនេះនឹងជាប់តាមពួកអ្នកដែលជឿ —

៦៦ ដោយនូវព្រះនាមរបស់យើង នោះពួកគេនឹងប្រព្រឹត្ត[ក]ការដ៏អស្ចារ្យជាច្រើន;

៦៧ ដោយនូវ[ក]ព្រះនាមរបស់យើង នោះពួកគេនឹងដេញអារក្សចេញ;

៦៨ ដោយនូវព្រះនាមរបស់យើង នោះពួកគេនឹង[ក]ប្រោសមនុស្សឈឺឲ្យជា;

៦៩ ដោយនូវព្រះនាមរបស់យើង នោះពួកគេនឹងបើកភ្នែកមនុស្សខ្វាក់ ហើយស្រាយត្រចៀកមនុស្សថ្លង់;

៧០ ហើយអណ្ដាតនៃមនុស្សគក៏នឹងនិយាយរួច;

៧១ ហើយបើសិនជាមនុស្សណាមួយនឹងដាក់[ក]ពុលដល់ពួកគេ នោះវានឹងមិនធ្វើឲ្យពួកគេឈឺឡើយ;

៧២ ហើយពិសនៃពស់នឹងពុំមានអំណាច ដើម្បីធ្វើទុក្ខដល់ពួកគេឡើយ ។

៧៣ ប៉ុន្ដែយើងប្រទានបញ្ញត្តិមួយដល់ពួកគេ ប្រយោជន៍កុំឲ្យពួកគេ[ក]អួតខ្លួនពីការណ៍ទាំងនេះ ឬនិយាយពីការណ៍ទាំងនេះនៅចំពោះ ពិភពលោក; ត្បិតការណ៍ទាំងនេះ ត្រូវបានប្រទានដល់អ្នក សំរាប់ជាផលប្រយោជន៍ដល់អ្នក និងសំរាប់សេចក្ដីសង្គ្រោះ ។

៧៤ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា ពួកអ្នកដែលមិនជឿដល់ពាក្យសំដីរបស់អ្នក ហើយមិនបាន[ក]ទទួលបុណ្យជ្រមុជក្នុងទឹក ដោយនូវព្រះនាមរបស់យើង សំរាប់ការផ្ដាច់បាបទាំងឡាយរបស់ពួកគេ ប្រយោជន៍ឲ្យពួកគេអាចបានទទួលព្រះវិញ្ញាណបរិសុទ្ធទេ នោះនឹង[ខ]ត្រូវជាប់ទោស ហើយនឹងពុំត្រូវបានចូលមកក្នុងនគររបស់ព្រះវរបិតាយើង ជាទីដែលព្រះវរបិតា និងយើងគង់នៅ ឡើយ ។

៧៥ ហើយវិវរណៈនេះមានដល់អ្នក និងព្រះបញ្ញត្តិនេះផងគឺអនុវត្តចាប់ពីម៉ោងនេះទៅ នៅលើសព្វលោកិយទាំងមូល ហើយដំណឹងល្អ គឺដល់មនុស្សទាំងអស់ដែលពុំបានទទួលដំណឹងល្អ ។

៧៦ ប៉ុន្ដែប្រាកដមែន យើងប្រាប់ដល់អស់អ្នកណា ដែលត្រូវបានប្រទាននគរឲ្យ — ចេញពីអ្នករាល់គ្នា នោះដំណឹងល្អត្រូវតែផ្សាយ ដល់ពួកគេថា ពួកគេត្រូវប្រែចិត្តពីកិច្ចការអាក្រក់របស់ពួកគេពីដើមចេញ; ត្បិតពួកគេត្រូវបានបន្ទោសចំពោះចិត្តអាក្រក់ខាងការ ឥតជំនឿរបស់ពួកគេ ហើយពួកបងប្អូនរបស់អ្នកខាងសាសនានៅក្រុងស៊ីយ៉ូន ចំពោះការបះបោររបស់ពួកគេទាស់នឹងអ្នក នៅពេលយើងបានចាត់ឲ្យអ្នកទៅ ។

៧៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា មិត្តយើងអើយ ត្បិតពីពេលនេះតទៅ យើងនឹងហៅអ្នករាល់គ្នាថាមិត្ត គឺជាការចាំបាច់ដែល យើងប្រទានបញ្ញត្តិនេះដល់អ្នក ប្រយោជន៍ឲ្យអ្នករាល់គ្នាត្រឡប់ទៅជាមិត្តយើង នៅគ្រាដែលយើងបានគង់នៅជាមួយពួកគេ ដោយធ្វើ ដំណើរទៅផ្សាយដំណឹងល្អ ដោយនូវព្រះចេស្ដារបស់យើង;

៧៨ ត្បិតយើងមិនទ្រាំឲ្យពួកគេមាន[ក]កាបូប ឬយាម ឬអាវដល់ទៅពីរឡើយ ។

៧៩ មើលចុះ យើងចាត់អ្នកឲ្យចេញទៅ[ក]បញ្ជាក់ដល់ពិភពលោក ហើយអ្នកដែលធ្វើការនោះគួរនឹងបានឈ្នួលរបស់ខ្លួនហើយ ។

៦៣ *ខ* ៣ នីហ្វៃ ១៥:២៤;
គ. និង ស. ៥០:៤១–៤២.
*គ* យ៉ូហាន ១៥:១៣–១៥;
គ. និង ស. ៩៣:៤៥.
៦៤ *ក* ស.ប. ព្រលឹង.
*ខ* ម៉ាកុស ១៦:១៥–១៦.
ស.ប. ជំនឿ, ជឿ.
*គ* ស.ប. ការផ្ដាច់បាប.
*ឃ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
៦៥ *ក* ម៉ាកុស ១៦:១៧–១៨.
ស.ប. ទីសំគាល់.
៦៦ *ក* ស.ប. កិច្ចការ.
៦៧ *ក* ម៉ាថាយ ១៧:១៤–២១.
៦៨ *ក* ស.ប. ប្រោស, ការប្រោស.
៧១ *ក* ម៉ាកុស ១៦:១៨;
កិច្ចការ ២៨:៣–៩;
គ. និង ស. ២៤:១៣;
១២៤:៩៨–១០០.
៧៣ *ក* គ. និង ស. ១០៥:២៤.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
៧៤ *ក* ២ នីហ្វៃ ៩:២៣;
គ. និង ស. ៧៦:៥០–៥២.
ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — ការចាំបាច់.
*ខ* យ៉ូហាន ៣:១៨.
៧៨ *ក* ម៉ាថាយ ១០:៩–១០;
គ. និង ស. ២៤:១៨.
៧៩ *ក* គ. និង ស. ៣១:៥.

៨០ ហើយមនុស្សណាមួយដែលនឹងទៅ ហើយផ្សាយដំណឹងល្អនេះពីនគរ ហើយមិនខកខាន ដើម្បីមានចិត្តស្មោះត្រង់រហូតតទៅ ក្នុងគ្រប់ទាំងអស់ នោះនឹងពុំមានភាពទន់ខ្សោយខាងគំនិត ឬក៏ងងឹតដែរ ឬខាងរូបកាយ ខាងដៃជើង ឬខាងសន្លាក់ឆ្អឹងដែរ; ហើយ សក់ក្បាលមួយសរសៃរបស់អ្នកនោះ ក៏នឹងមិនជ្រុះទៅដល់ដី ដោយមិនដឹងនោះឡើយ ។ ហើយពួកគេនឹងពុំឃ្លាន ឬស្រេកឡើយ ។

៨១ ហេតុដូច្នេះហើយ ចូរកុំឲ្យអ្នករាល់គ្នាខ្វល់ខ្វាយពីថ្ងៃស្អែក ពីអ្វីដែលអ្នករាល់គ្នាត្រូវបរិភោគ ឬអ្វីដែលអ្នករាល់គ្នាត្រូវផឹក ឬពីអ្វី ដែលអ្នករាល់គ្នាត្រូវស្លៀកពាក់នោះឡើយ ។

៨២ ត្បិតចូររំពឹងគិតតែពីផ្កាឈូកនៅក្នុងបឹង ដែលវាដុះជាយ៉ាងដូចម្ដេច គឺវាមិននឿយហត់នឹងធ្វើការស្រាវរវៃទេ; ហើយរីឯនគរទាំង ឡាយនៅលើពិភពលោក ក្នុងអស់ទាំងភាពរុងរឿងរបស់គេ ក៏ពុំបានតែងដូចជាផ្កាមួយនោះដែរ ។

៨៣ ត្បិតព្រះវរបិតារបស់អ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ ។

៨៤ ហេតុដូច្នេះហើយ ចូរឲ្យថ្ងៃស្អែកខ្វល់ខ្វាយ ចំពោះការរបស់ថ្ងៃនោះចុះ ។

៨៥ ហើយចូរអ្នករាល់គ្នាកុំថប់ព្រួយទុកជាមុន ពីអ្វីដែលអ្នករាល់គ្នាត្រូវថានោះឡើយ ប៉ុន្តែចូររក្សាទុកក្នុងគំនិតរបស់អ្នករាល់គ្នា ជាបន្តនូវព្រះបន្ទូលទាំងឡាយខាងជីវិតវិញ ហើយសេចក្ដីដែលត្រូវនិយាយ នឹងបានប្រទានដល់អ្នករាល់គ្នានៅចំម៉ោងនោះឯងនូវចំណែក ដែលនឹងបានវាល់ដល់មនុស្សគ្រប់រូប ។

៨៦ ហេតុដូច្នេះហើយ ត្បិតបញ្ញត្តិនេះគឺដល់ពួកស្មោះត្រង់ទាំងអស់ ដែលបានហៅពីព្រះ នៅក្នុងសាសនាចក្រឲ្យធ្វើការងារបំរើ គឺពី ម៉ោងនេះ ចូរកុំឲ្យមនុស្សណាមួយក្នុងចំណោមអ្នករាល់គ្នា ដែលចេញទៅផ្សាយពីដំណឹងល្អនេះនៃនគរ យកកាបូប ឬយាមទៅឡើយ ។

៨៧ មើលចុះ យើងចាត់អ្នករាល់គ្នាឲ្យចេញទៅស្ដីបន្ទោសមនុស្សលោក ពីអស់ទាំងអំពើដ៏ឥតសុចរិតរបស់ពួកគេ ហើយឲ្យទៅបង្រៀន ពួកគេ ពីសេចក្ដីជំនុំជំរះមួយដែលត្រូវមក ។

៨៨ ហើយអស់អ្នកណាដែលទទួលអ្នក នោះយើងក៏នឹងនៅទីនោះដែរ ត្បិតយើងនឹងទៅពីមុខអ្នក ។ យើងនឹងនៅខាងស្ដាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង ។

៨៩ អស់អ្នកណាដែលទទួលអ្នក ក៏ទទួលយើងដែរ; ហើយអ្នកនោះហើយ ដែលនឹងឲ្យអាហារដល់អ្នក ហើយបំពាក់សំលៀកបំពាក់ ដល់អ្នក ហើយឲ្យប្រាក់កាសដល់អ្នក ។

៩០ ហើយអ្នកណាដែលឲ្យអាហារដល់អ្នក ឬបំពាក់សំលៀកបំពាក់ឲ្យអ្នក ឬឲ្យប្រាក់កាសដល់អ្នក នោះនឹងពុំត្រូវបាត់រង្វាន់របស់ខ្លួន ឡើយ ។

៩១ ហើយអ្នកណាដែលពុំធ្វើការណ៍ទាំងនេះ នោះឈ្មោះថាពុំមែនជាសិស្សរបស់យើងឡើយ; ដោយសារការណ៍នេះទើបអ្នកអាចស្គាល់ពួកសិស្សរបស់យើង ។

៩២ អ្នកណាដែលមិនទទួលអ្នកទេ នោះចូរចេញពីអ្នកនោះដោយខ្លួនដាច់ឡែក ហើយ លាងជើងអ្នកដោយទឹកគឺទឹកសុទ្ធ ទោះជានៅ ពេលក្ដៅ ឬនៅពេលត្រជាក់ក្ដីហើយថ្លែងទីបន្ទាល់ពីការណ៍នេះចំពោះព្រះវរបិតារបស់អ្នកដែលគង់នៅលើស្ថានសួគ៌ ហើយចូរកុំវិល ទៅរកមនុស្សនោះទៀតឡើយ ។

៩៣ ហើយនៅភូមិ ឬទីក្រុងណាក៏ដោយ ដែលអ្នករាល់គ្នាចូល ចូរធ្វើយ៉ាងដូច្នោះចុះ ។

៩៤ ទោះជាយ៉ាងណាក៏ដោយ ចូរព្យាយាមស្វែងរក ហើយចូរកុំសំចៃឡើយ; ហើយវេទនាដល់ផ្ទះនោះ ឬដល់ភូមិនោះ

---

៨០ *ក* ស.ប. កិច្ចការផ្សាយសាសនា.
*ខ* ស.ប. ដំណឹងល្អ.
*គ* លូកា ២១:១៨.
៨១ *ក* ម៉ាថាយ ៦:២៥–២៨.
៨៣ *ក* ស.ប. ព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
*ខ* ម៉ាថាយ ៦:៨.
៨៤ *ក* ម៉ាថាយ ៦:៣៤.
៨៥ *ក* ម៉ាថាយ ១០:១៩–២០;
លូកា ១២:១១–១២;
គ. និង ស. ១០០:៦.
*ខ* ២ នីហ្វៃ ៣១:២០;
អាលម៉ា ១៧:២–៣;
គ. និង ស. ៦:២០; ១១:២១–២៦.
ស.ប. រំពឹងគិត.
*គ* ស.ប. បង្រៀន, គ្រូបង្រៀន — ការបង្រៀនដោយនូវព្រះវិញ្ញាណ.
៨៦ *ក* ម៉ាថាយ ២៤:៤៤–៤៦;
គ. និង ស. ៥៨:២៦–២៩;
១០៧:៩៩–១០០.
៨៧ *ក* ស.ប. កិច្ចការផ្សាយសាសនា.
៨៨ *ក* ម៉ាថាយ ១០:៤០;
យ៉ូហាន ១៣:២០.
*ខ* គ. និង ស. ៨៤:៤២.
ស.ប. ពួកទេវតា.
៩០ *ក* ម៉ាថាយ ១០:៤២; ម៉ាកុស ៩:៤១.
៩១ *ក* យ៉ូហាន ១៣:៣៥.
៩២ *ក* ម៉ាថាយ ១០:១៤; លូកា ៩:៥;
គ. និង ស. ៦០:១៥.

ឬដល់ទីក្រុង ណាដែលមិនទទួលអ្នក ឬពាក្យសំដីអ្នក ឬទីបន្ទាល់អ្នកថ្លែងអំពីយើង ។

៩៥ យើងប្រាប់ម្ដងទៀតថា វេទនាដល់ផ្ទះនោះ ឬដល់ភូមិនោះ ឬទីក្រុងនោះដែលមិនទទួលអ្នក ឬពាក្យសំដីអ្នក ឬទីបន្ទាល់អ្នកអំពីយើង;

៩៦ ត្បិតយើង ជាព្រះដ៏មាន[ក]មហិទ្ធិឫទ្ធិ បានដាក់ព្រះហស្ត[ខ] របស់យើងមកលើសាសន៍ទាំងឡាយ ដើម្បីវាយពួកគេព្រោះតែ[គ]អំពើទុច្ចរិត របស់ពួកគេ ។

៩៧ ហើយជំងឺអាសន្នរោគនឹងចេញទៅ ហើយជំងឺទាំងនោះនឹងមិនត្រូវដកចេញពីផែនដីឡើយ រហូតដល់យើងបានសំរេចកិច្ចការរបស់ យើងសិន ដែលនឹងត្រូវកាត់[ក]យ៉ាងខ្លី ដោយសេចក្ដីសុចរិត —

៩៨ រហូតដល់មនុស្សទាំងអស់បានស្គាល់យើង ជាអ្នកដែលនៅសល់ទាំងប៉ុន្មាន គឺចាប់តាំងពីមនុស្សតូច ទៅដល់មនុស្សធំ ហើយនឹង ត្រូវបានពោរពេញទៅដោយការចេះដឹងពីព្រះអម្ចាស់ ហើយនឹងបាន[ក]ឃើញដោយភ្នែកផ្ទាល់ ហើយនឹងបន្លឺសម្លេងឡើង និងដោយ សម្លេង[ខ]ច្រៀងព្រមគ្នា នូវចំរៀងថ្មីនេះថា៖

៩៩ ព្រះអម្ចាស់ទ្រង់បាននាំក្រុងស៊ីយ៉ូនចេញមកម្ដងទៀត;
ព្រះអម្ចាស់ទ្រង់បាន[ក]ប្រោសលោះ[ខ]រាស្ត្ររបស់ទ្រង់ គឺសាសន៍អ៊ីស្រាអែល
តាម[គ]ការរើសតាំង ដោយ[ឃ]ព្រះគុណ
ដែលបានបណ្ដាលឲ្យកើតឡើង ដោយសេចក្ដីជំនឿ
និង[ង]សេចក្ដីសញ្ញានៃពួកអយ្យកោរបស់ពួកគេ ។
១០០ ព្រះអម្ចាស់ទ្រង់បានប្រោសលោះរាស្ត្ររបស់ទ្រង់;
ហើយសាតាំង[ក]ត្រូវជាប់ ហើយគ្មានពេលបង្អង់ទៀតឡើយ ។
ព្រះអម្ចាស់ទ្រង់បាន[ខ]ប្រមូលរបស់ទាំងអស់មកតែមួយ ។
ព្រះអម្ចាស់ទ្រង់បាន[គ]ទំលាក់ ក្រុងស៊ីយ៉ូនមកពីស្ថានលើ ។
ព្រះអម្ចាស់ទ្រង់បាន[ឃ]ដំឡើងក្រុងស៊ីយ៉ូនមកពីស្ថានខាងក្រោម ។
១០១ [ក]ផែនដីបានឈឺពោះ ហើយសំរាលបានកម្លាំងនាងមក;
ហើយសេចក្ដីពិតត្រូវបានតាំងឡើងក្នុងពោះនាង;
ហើយស្ថានសួគ៌បានញញឹមដាក់នាង;
ហើយនាងត្រូវបានពាក់ដោយ[ខ]សិរីល្អនៃព្រះរបស់នាង;
ត្បិតទ្រង់ឈរនៅកណ្ដាលរាស្ត្ររបស់ទ្រង់ហើយ ។
១០២ សូមថ្វាយសិរីល្អ និងកិត្តិនាម និងព្រះចេស្ដា និងឥទ្ធិឫទ្ធិ
ដល់ព្រះរបស់យើង; ត្បិតទ្រង់ពោរពេញទៅដោយសេចក្ដីមេត្តាករុណា
សេចក្ដីយុត្តិធម៌ [ក]ព្រះគុណ និងសេចក្ដីពិត និង[ខ]សេចក្ដីសុខសាន្ត
នៅអស់កល្បជានិច្ចរៀងរាបតទៅ ។ អាម៉ែន ។

១០៣ ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា គឺជាការចាំបាច់ថាមនុស្សគ្រប់រូបណាដែលចេញប្រកាសប្រាប់ពីដំ ណឹងល្អដ៏អស់កល្បអស់កាលជានិច្ចរបស់យើង គឺថាដរាបណាពួកគេមានគ្រួសារ ហើយទទួលប្រាក់កាសជារង្វាន់ក្ដីនោះពួកគេត្រូវផ្ញើ ប្រាក់នោះទៅឲ្យគ្រួសារពួកគេ ឬយកមកប្រើប្រាស់សំរាប់ប្រយោជន៍ដល់គ្រួសាររបស់ពួកគេ ដូចជាព្រះអម្ចាស់ទ្រង់នឹងចាត់ដល់ខ្លួនគេ ត្បិតយ៉ាងនោះហើយទើបឃើញថាល្អដល់យើង ។

១០៤ ហើយចូរអស់អ្នកទាំងនោះ ដែលគ្មានគ្រួសារ ដែលទទួល[ក]ប្រាក់កាស ឲ្យផ្ញើប្រាក់ឡើងទៅឲ្យប៊ីស្សពនៅក្រុងស៊ីយ៉ូន ឬទៅឲ្យ ប៊ីស្សពនៅរដ្ឋអូហៃអូ ប្រយោជន៍ឲ្យវាអាចបានថ្វាយទុកសំរាប់ការនាំចេញមកនូវវិវរណៈទាំងឡាយ និងការបោះពុម្ពវិវរណៈទាំងនោះ និងសំរាប់ការតាំងក្រុងស៊ីយ៉ូនឡើង ។

១០៥ ហើយបើសិនជាមនុស្សណាមួយឲ្យអាវមួយ ឬអាវខោមួយកំប្លែ នោះចូរយករបស់ចាស់ ហើយបោះវាទៅឲ្យ[ក]មនុស្សទ័លក្រ ហើយចូរទៅតាមផ្លូវដោយអរសប្បាយចុះ ។

១០៦ ហើយបើសិនជាមានមនុស្សណាមួយ នៅក្នុងចំណោមអ្នករាល់គ្នា មានកម្លាំងខ្លាំងឡើង នៅក្នុងព្រះវិញ្ញាណ ចូរឲ្យអ្នក

៩៦ ក ស.ប. ព្រះដ៏មានគ្រប់ព្រះចេស្ដា.
ខ គ. និង ស. ១:១៣–១៤.
គ ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
៩៧ ក ម៉ាថាយ ២៤:២២.
៩៨ ក អេសាយ ៥២:៨.
ខ ទំនុក. ៩៦:១; វិវ. ១៥:៣; គ. និង ស. ២៥:១២; ១៣៣:៥៦. ស.ប. ច្រៀង.
៩៩ ក វិវ. ៥:៩; គ. និង ស. ៤៣:២៩.
ខ ស.ប. អ៊ីស្រាអែល.
គ ស.ប. ការរើសតាំង.
ឃ ស.ប. ព្រះគុណ.
ង ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
១០០ ក វិវ. ២០:២–៣; គ. និង ស. ៤៣:៣១; ៤៥:៥៥; ៨៨:១១០.
ខ អេភេ. ១:១០; គ. និង ស. ២៧:១៣.
គ គ. និង ស. ៤៥:១១–១៤; ម៉ូសេ ៧:៦២–៦៤. ស.ប. ស៊ីយ៉ូន.
ឃ គ. និង ស. ៧៦:១០២; ៨៨:៩៦.
១០១ ក ស.ប. ផែនដី.
ខ ស.ប. សិរីល្អ.
១០២ ក ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
ខ ស.ប. សេចក្ដីសុខសាន្ត.
១០៤ ក គ. និង ស. ៥១:៨–៩, ១២–១៣.
១០៥ ក ស.ប. មនុស្សក្រីក្រ — ក្រខាងទ្រព្យសម្បត្តិ.

នោះយក[ក] អ្នកណាមួយ ដែលទន់[ខ]ខ្សោយទៅជាមួយគាត់ ប្រយោជន៍ឲ្យអ្នកនោះអាចបានស្អាងឡើង ក្នុងភាពស្លូតបូតគ្រប់យ៉ាង ប្រយោជន៍ឲ្យ អ្នកនោះអាចត្រឡប់ជាមានកម្លាំងខ្លាំងឡើងដែរ ។

១០៧ ហេតុដូច្នេះហើយ ចូរយកអស់អ្នកណាដែលបានតែងតាំងឡើង ចំពោះ[ក]បព្វជិតភាពតូចជាងទៅជាមួយអ្នកចុះ ហើយចាត់ ឲ្យពួកគេ ទៅមុនអ្នក ដើម្បីណាត់ពេលទុក ហើយដើម្បីរៀបចំផ្លូវ និងដើម្បីបំពេញកិច្ចការទាំងឡាយណាដែលរូបអ្នកផ្ទាល់ ខ្លួនពុំអាចបំពេញបាន នោះ ។

១០៨ មើលចុះ នេះហើយជាមាគ៌ាដែលពួកសាវករបស់យើងនៅសម័យបុរាណ បានសាងសាសនាចក្ររបស់យើងឡើងដល់យើង ។

១០៩ ហេតុដូច្នេះហើយ ចូរឲ្យមនុស្សគ្រប់រូបឈរនៅក្នុងតំណែងរបស់ខ្លួន ហើយចូរធ្វើការក្នុងការហៅរបស់ខ្លួនចុះ; ហើយចូរកុំឲ្យ ក្បាលនិយាយដល់ជើងថា ខ្លួនមិនត្រូវការដល់ជើងនោះឡើយ; ត្បិតបើសិនជាគ្មានជើងទេ នោះតើរូបកាយនឹងឈរយ៉ាងណាបាន ?

១១០ រីឯរូបកាយក៏ត្រូវការ[ក]អវយវៈទាំងអស់ដែរ ប្រយោជន៍ឲ្យទាំងអស់អាចបានស្អាងឡើងទាំងអស់គ្នា ប្រយោជន៍ឲ្យអង្គការអាចបាន រក្សាទុកដោយល្អឥតខ្ចោះ ។

១១១ ហើយមើលចុះ [ក]ពួកសង្ឃជាន់ខ្ពស់គួរធ្វើដំណើរ និងពួក[ខ]អែលឌើរផងដែរ និងពួកសង្ឃជាន់ទាបផងដែរ; ប៉ុន្តែពួក[គ]ឌីកុន និង [ឃ]ពួកគ្រូ គួរតែងឲ្យ[ង]មើលលើសាសនាចក្រ ដើម្បីធ្វើជាពួកអ្នកបំរើអចិន្ត្រៃយ៍ ចំពោះសាសនាចក្រ ។

១១២ ហើយប៊ីស្សព នូវល ខេ វិតនី ក៏គួរធ្វើដំណើរជុំវិញ និងនៅក្នុងចំណោមសាសនាចក្រទាំងអស់ ដោយស្វែងរកមនុស្សទាល់ក្រ ដើម្បី[ក]ចាត់ចែងដល់សេចក្ដីត្រូវការរបស់ពួកគេ ដោយ[ខ]បន្ទាបពួកអ្នកមាន និងពួកអ្នកឆ្មើងឆ្មៃ ។

១១៣ គាត់គួរជួល[ក]ភ្នាក់ងារណាមួយ ឲ្យមើលខុសត្រូវ និងធ្វើធុរៈខាងសាច់ឈាមរបស់គាត់ តាមដែលគាត់នឹងចាត់ចែង ។

១១៤ ទោះជាយ៉ាងណាក៏ដោយ ចូរឲ្យប៊ីស្សពទៅឯទីក្រុងនូវយ៉ោក និងទៅទីក្រុងអាលប៉ានីផង និងទៅទីក្រុងបោស្ទុនផងដែរ ហើយ ព្រមានដល់ប្រជាជននៅទីក្រុងទាំងនោះ ដោយសូរសម្លេងពីដំណឹងល្អ ដោយសម្លេងយ៉ាងខ្លាំង ប្រាប់[ក]ពីសេចក្ដីហិនវិនាស និងសេចក្ដី កំទេចសូន្យ ដែលរង់ចាំពួកគេ បើសិនជាពួកគេមិនទទួលការណ៍ទាំងនេះទេ ។

១១៥ ត្បិតបើសិនជាពួកគេមិនទទួលការណ៍ទាំងនេះទេ នោះម៉ោងនៃសេចក្ដីជំនុំជំរះរបស់ពួកគេនៅជិតបង្កើយ ហើយផ្ទះសំបែង របស់ពួកគេនឹង[ក]ត្រូវទុកចោលស្ងាត់សូន្យឈឹងដល់ពួកគេ ។

១១៦ ចូរឲ្យគាត់[ក]ទុកចិត្តដល់យើង ហើយគាត់នឹងមិនត្រូវធ្វើឲ្យ[ខ]ខ្មាសឡើយ; ហើយ[គ]សក់ក្បាលរបស់គាត់មួយសសៃក៏នឹងមិនជ្រុះទៅដល់ដី ដោយមិនដឹងបានឡើយ ។

១១៧ ហើយយើងប្រាប់អ្នកជាប្រាកដថា ពួកអ្នកបំរើរបស់យើងដែលនៅសល់ទាំងប៉ុន្មាន នោះចូរអ្នករាល់គ្នាចេញទៅតាមកាលៈទេសៈ របស់អ្នករាល់គ្នា ដែលអាចធ្វើទៅបាន នៅក្នុងការហៅរបស់អ្នករៀងៗខ្លួន ទៅឯទីក្រុង និងភូមិទាំងឡាយដ៏ធំៗ និងល្បីល្បាញចុះ ដោយស្ដីបន្ទោសពិភពលោក ដោយនូវសេចក្ដីសុចរិត ពីអស់ទាំងអំពើដ៏ឥតសុចរិត និងឥតល្អទាំងឡាយរបស់ពួកគេ ដោយពន្យល់ យ៉ាងច្បាស់លាស់ និងជាក់លាក់ពីសេចក្ដីហិនវិនាសដ៏គួរខ្ពើមឆ្អើម នៅគ្រាចុងក្រោយបង្អស់ ។

១១៨ ត្បិតដោយសារអ្នករាល់គ្នា នោះព្រះអម្ចាស់ដ៏មានមហិទ្ធិឫទ្ធិ ទ្រង់មានព្រះបន្ទូលថា៖ យើងនឹង[ក]បណ្ដាច់នគរទាំងឡាយរបស់ពួក គេ; យើងនឹងមិនគ្រាន់តែ[ខ]ធ្វើឲ្យផែនដីកក្រើកទេ ប៉ុន្តែផ្ទៃមេឃដ៏ពេញទៅដោយផ្កាយនឹងញ័ររន្ធត់ ។

១១៩ ត្បិតយើង ជាព្រះអម្ចាស់ បានដាក់ព្រះហស្តរបស់យើង ដើម្បីបញ្ចេញអំណាចពីស្ថានសួគ៌; អ្នករាល់គ្នាមិន

១០៦ ក ស.ប. សេចក្ដីប្រកប.
ខ ស.ប. ស្លូតបូត, ភាពស្លូតបូត.
១០៧ ក ស.ប. បព្វជិតភាពអើរ៉ុន.
១១០ ក ១ កូរិន. ១២:១២–២៣.
១១១ ក ស.ប. សង្ឃជាន់ខ្ពស់.
ខ ស.ប. សង្ឃ, បព្វជិតភាពអើរ៉ុន.
គ ស.ប. ឌីកុន.
ឃ ស.ប. គ្រូ, បព្វជិតភាពអើរ៉ុន.
ង ស.ប. ចាំយាម, ពួកអ្នកចាំយាម.
១១២ ក ស.ប. សុខុមាលភាព.
ខ គ. និង ស. ៥៦:១៦.
១១៣ ក គ. និង ស. ៩០:២២.
១១៤ ក គ. និង ស. ១:១៣–១៤.
១១៥ ក លូកា ១៣:៣៥.
១១៦ ក ស.ប. ទុកចិត្ត.
ខ ទំនុក. ២២:៥; ១ ពេត្រុស ២:៦.
គ ម៉ាថាយ ១០:២៩–៣១.
១១៨ ក ដានី. ២:៤៤–៤៥.
ខ យ៉ូអែល ២:១០;
គ. និង ស. ៤៣:១៨;
៤៥:៣៣, ៤៨; ៨៨:៨៧, ៩០.
ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ;
ទីសំគាល់អំពីពេលវេលា.

អាចមើលឃើញ អំណាចនោះនៅពេលនេះបានឡើយ តែនៅបន្តិចទៀត ហើយអ្នករាល់គ្នានឹងមើលឃើញអំណាចនោះ ហើយស្គាល់ថាយើងជាព្រះ ហើយថាយើងនឹងយាងមក ហើយសោយរាជ្យនៅជាមួយនឹងរាស្ត្រយើង ។

១២០ យើងជាអាលផា និងអូមេកា ជាដើម ហើយជាចុង ។ អាម៉ែន ៕

## កណ្ឌទី ៨៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៨៣២ (*History of the Church*, ១:២៩៨–២៩៩) ។ កណ្ឌនេះជាសេចក្ដីដកស្រង់ពីសំបុត្រនៃព្យាការី ទៅរក ដ័បបុលយូ ដ័បបុលយូ ហ្វែលប្ស ជាអ្នកដែលរស់នៅក្រុងអ៊ិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី ។ សំបុត្រនោះត្រូវជាចម្លើយឆ្លើយនូវសំនួរទាំងឡាយ អំពីពួកបរិសុទ្ធ ដែលបានផ្លាស់ទៅឯក្រុងស៊ីយ៉ូន ប៉ុន្តែមិនទាន់បានទទួលកេរ្តិ៍មរតករបស់ពួកគេនៅឡើយទេ តាមរបៀបរៀបរយដែលបានតាំងឡើង នៅក្នុងសាសនាចក្រ ។*

*១–៥, កេរ្តិ៍មរតកទាំងឡាយនៅក្រុងស៊ីយ៉ូន ត្រូវបានទទួលតាមរយៈការថ្វាយ; ៦–១២, អ្នកខ្លាំងពូកែនិងមានឫទ្ធិម្នាក់នឹងប្រទាន ដល់ពួកបរិសុទ្ធ នូវកេរ្តិ៍មរតកទាំងឡាយរបស់ពួកគេនៅក្រុងស៊ីយ៉ូន ។*

១ វាជាការកិច្ចនៃស្មៀនរបស់ព្រះអម្ចាស់ ដែលទ្រង់បានតាំងឡើង ដើម្បីឲ្យកត់ប្រវត្តិ និងបញ្ជីទូទៅនៃសាសនាចក្រ អំពីគ្រប់ទាំងអស់ដែល បានកើតឡើងនៅក្រុងស៊ីយ៉ូន និងអំពីគ្រប់មនុស្សទាំងអស់ដែលថ្វាយទ្រព្យសម្បត្តិទាំងឡាយ ហើយទទួលកេរ្តិ៍មរតកទាំងឡាយពី ប៊ីស្សពតាមច្បាប់ ។

២ ហើយអំពីរបៀបរស់នៅរបស់ពួកគេ សេចក្ដីជំនឿ និងកិច្ចការទាំងឡាយរបស់ពួកគេ; ហើយអំពីពួកក្បត់សាសនា ដែលបានក្បត់ សាសនា បន្ទាប់ពីបានទទួលកេរ្តិ៍មរតករបស់ខ្លួន ។

៣ គឺជាការផ្ទុយទៅនឹងព្រះហឫទ័យនិងព្រះបញ្ញត្តិនៃព្រះ ថាពួកអ្នកទាំងនោះដែលពុំបានទទួលកេរ្តិ៍មរតករបស់ខ្លួន ដោយសារ ការថ្វាយ ដោយព្រមព្រៀងតាមច្បាប់របស់ទ្រង់ ដែលទ្រង់បានប្រទាន ប្រយោជន៍ឲ្យទ្រង់អាចយកដង្វាយ១ភាគ១០ពីរាស្ត្ររបស់ទ្រង់ ដើម្បីរៀបចំពួកគេសំរាប់ថ្ងៃនៃការសងសឹក និងការឆេះឆួល ថាពួកអ្នកទាំងនោះគួរមានឈ្មោះរបស់ខ្លួនចូលរួមជាមួយនឹងរាស្ត្រនៃ ព្រះ ។

៤ សូម្បីតែពង្សាវលីរបស់ពួកគេក៏មិនត្រូវកត់ទុក ឬមានទុកនៅក្នុងកន្លែងណាដែលអាចរកឃើញ នៅក្នុងបញ្ជីទាំងឡាយ ឬនៅក្នុង ប្រវត្តិនៃសាសនាចក្រ ។

៥ ឈ្មោះរបស់ពួកគេក៏មិនត្រូវរកឃើញ ព្រមទាំងឈ្មោះទាំងឡាយនៃពួកឪពុកគេ ឬក៏ឈ្មោះទាំងឡាយនៃកូនចៅ ត្រូវបានសរសេរទុក នៅក្នុងសៀវភៅច្បាប់នៃព្រះឡើយ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៦ មែនហើយ សម្លេងតូចរហៀងៗដែលខ្សឹប ហើយទំលុះគ្រប់ទាំងអស់ ហើយជួនកាល ទ្រង់ធ្វើឲ្យឆ្អឹងរបស់ខ្ញុំញ័រ នៅពេលទ្រង់សំដែង ប្រាប់ ដោយមានព្រះបន្ទូលដូច្នេះថា៖

៧ ហើយហេតុការណ៍នឹងកើតឡើងថា យើងជាព្រះអម្ចាស់ដ៏ជាព្រះ នឹងចាត់អ្នកខ្លាំងពូកែ និងមានឫទ្ធិម្នាក់ ឲ្យកាន់នូវដំបងដែកនៃព្រះចេស្ដា នៅក្នុងដៃរបស់លោក ហ៊ុមដោយពន្លឺទុកជាសំលៀកបំពាក់ ឯមាត់របស់លោកនឹងបន្លឺព្រះបន្ទូលទាំងឡាយ ជាព្រះបន្ទូល ទាំងឡាយដ៏នៅអស់កល្បជានិច្ច; រីឯដួងចិត្តរបស់លោកនឹងទៅជាប្រភពនៃសេចក្ដីពិត ដើម្បីតាំងដំណាក់នៃ

១១៩ *ក* គ. និង ស. ១:១២, ៣៥–៣៦; ២៩:៩–១១; ៤៥:៥៩. ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. សហស្សវត្សរ៍.
១២០ *ក* ស.ប. អាលផា និងអូមេកា.
**៨៥** ១ *ក* គ. និង ស. ២១:១; ៤៧:១; ៦៩:៣–៦.
*ខ* គ. និង ស. ៤២:៣០–៣៥.
៣ *ក* ស.ប. ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ.
៣ *ខ* ស.ប. ដង្វាយ១ភាគក្នុង១០, ការថ្វាយដង្វាយ១ភាគក្នុង១០.
*គ* ម៉ាឡាគី ៣:១០–១១, ១៧; គ. និង ស. ៩៧:២៥–២៦.
៥ *ក* ស.ប. សៀវភៅជីវិត.
៦ *ក* ១ ពង្សាវ. ១៩:១១–១២; ហេលេ. ៥:៣០–៣១; ៣ នីហ្វៃ ១១:៣–៧.
*ខ* ហេព្រើរ ៤:១២.

ព្រះឲ្យមានរបៀបរៀបរយ និងដើម្បីរៀបចំតាមប្លង់ នូវ[ក]កេរ្ដិ៍មរតកនៃពួកបរិសុទ្ធ ដែលរកឃើញឈ្មោះរបស់ពួកគេ និងឈ្មោះទាំងឡាយនៃពួកដូនតារបស់ពួកគេ និងនៃកូនចៅរបស់ពួកគេ ដែលបានបញ្ចូលនៅក្នុងសៀវភៅច្បាប់នៃព្រះ;

៨ ប៉ុន្តែមនុស្សនោះដែលត្រូវបានហៅពីព្រះ ហើយបានតែងតាំងឡើង ដែលដាក់ដៃទៅទ[ក]ប់ទូកធំនៃព្រះ នោះនឹងត្រូវដួលដោយសារ ព្រួញនៃសេចក្ដីស្លាប់ ដូចជាដើមឈើដែលត្រូវកំទេចដោយរន្ទះបាញ់ ។

៩ ហើយពួកគេទាំងអស់គ្នាណាដែលពុំបានសរសេរទុក នៅក្នុង[ក]សៀវភៅរំឭក នោះនឹងពុំរកឃើញកេរ្ដិ៍មរតក នៅថ្ងៃនោះឡើយ ប៉ុន្តែពួកគេនឹងត្រូវកាត់ចោលល្អិតល្អោច ហើយចំណែករបស់ពួកគេនឹងមាននៅក្នុងចំណោមពួកមនុស្សមិនជឿ នៅទីនោះនឹង[ខ]យំ ហើយសង្កៀតធ្មេញ ។

១០ ការណ៍ទាំងនេះ ខ្ញុំពុំបានថាដោយសារខ្លួនខ្ញុំទេ; ហេតុដូច្នេះហើយ ដូចជាព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលយ៉ាងណា នោះទ្រង់ក៏នឹង សំរេចយ៉ាងនោះដែរ ។

១១ ហើយពួកអ្នកដែលជាសមាជិកនៃបព្វជិតភាពជាន់ខ្ពស់ ដែលពុំឃើញមានឈ្មោះសរសេរទុក នៅក្នុង[ក]សៀវភៅច្បាប់ ឬដែលឃើញ ថាបាន[ខ]ក្បត់សាសនា ឬដែលបាន[គ]កាត់កាល់ចេញពីសាសនាចក្រ ព្រមទាំងចេញពីបព្វជិតភាពដ៏តូចជាងផង ឬចេញពីសមាជិកទាំង ឡាយ គឺនៅថ្ងៃនោះ នឹងពុំមានកេរ្ដិ៍មរតក នៅក្នុងចំណោមពួកបរិសុទ្ធនៃព្រះដ៏ខ្ពស់បំផុតឡើយ ។

១២ ហេតុដូច្នេះហើយ នឹងត្រូវបានធ្វើដល់ពួកគេ ដូចជាធ្វើដល់កូនចៅនៃសង្ឃ ដូចជាឃើញនៅក្នុងបញ្ជី ដែលបានកត់ទុកនៅក្នុង ជំពូកទីពីរ និងខហុកសិបមួយ និងហុកសិបពីរ នៅក្នុងគម្ពីរអែសរ៉ាដែរ ៕

## កណ្ឌទី ៨៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៨៣២ (*History of the Church*, ១:៣០០) ។ វិវរណៈនេះត្រូវបានទទួល នៅពេលព្យាការីកំពុងតែមើលសារឡើងវិញ និងពិនិត្យផ្ទៀងផ្ទាត់ ឯកសារនៃការបកប្រែព្រះគម្ពីរប៊ីប ។*

*១–៧, ព្រះអម្ចាស់ទ្រង់ប្រទានអត្ថន័យប្រាប់ពីពាក្យប្រៀបប្រដូចអំពីស្រូវសាលី និងស្រងែ; ៨–១១, ទ្រង់ពន្យល់ប្រាប់ពីព្រះពរទាំងឡាយ នៃបព្វជិតភាពដល់អស់អ្នកដែលជាអ្នកគ្រងមរតកពេញច្បាប់ តាមសាច់ឈាម ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នករាល់គ្នាជា ពួកអ្នកបំរើរបស់យើង ពី[ក]ពាក្យប្រៀបប្រដូចអំពីស្រូវសាលី និងស្រងែ ដូច្នេះថា៖

២ មើលចុះ យើងប្រាប់ជាប្រាកដថា ស្រែគឺជាពិភពលោក ហើយពួកសាវកគឺជាពួកអ្នកព្រោះគ្រាប់ពូជ;

៣ ហើយបន្ទាប់ពីពួកគេបានដេកលក់ នោះអ្នកបៀតបៀនដ៏ធំនៃសាសនាចក្រ គឺអ្នកក្បត់សាសនា ជាពេស្យា គឺ[ក]ក្រុងបាប៊ីឡូន ដែលធ្វើ ឲ្យគ្រប់ទាំងសាសន៍ផឹកពីពែងរបស់ខ្លួន នោះខ្មាំងសត្រូវ គឺអារក្សសាតាំង វាអង្គុយនៅក្នុងដួងចិត្តពួកគេ ដើម្បីសោយរាជ្យ — មើលចុះ វាព្រោះ[ខ]ស្រងែ; ហេតុដូច្នោះហើយ ស្រងែប្រជ្រៀតស្រូវសាលី ហើយដេញសាសនាចក្រឲ្យចូលទីរហោស្ថាន ។

៤ ប៉ុន្តែមើលចុះ នៅ[ក]គ្រាចុងក្រោយបង្អស់ សូម្បីតែពេលនេះ នៅពេលព្រះអម្ចាស់ទ្រង់កំពុងតែចាប់ផ្ដើមនាំចេញមកនូវព្រះបន្ទូល ហើយ ស្លឹកកំពុងតែពន្លកឡើង ហើយនៅខ្ចីនៅឡើយ —

៥ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា [ក]ពួកទេវតាកំពុងតែ

៨ *ក* ២ សាំយូ. ៦:៦–៧;
១ របា. ១៣:៩–១០.
ស.ប. ហឹបនៃសេចក្ដីសញ្ញា.
៩ *ក* ៣ នីហ្វៃ ២៤:១៦; ម៉ូសេ ៦:៥–៦.
ស.ប. សៀវភៅរំឭក.
*ខ* គ. និង ស. ១៩:៥.
១១ *ក* ស.ប. សៀវភៅជីវិត.
*ខ* ស.ប. សេចក្ដីក្បត់សាសនា.
*គ* ស.ប. ការកាត់ចេញពីសាសនា.
**៨៦** ១*ក* ម៉ាថាយ ១៣:៦–៤៣;
គ. និង ស. ១០១:៦៤–៦៧.
៣ *ក* វិវរ. ១៧:១–៩.
ស.ប. បាបិល, បាប៊ីឡូន.
*ខ* វិវរ. ១២:៦, ១៤.
៤ *ក* ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ.
៥ *ក* គ. និង ស. ៣៨:១២.

ទួញអង្វរដល់ព្រះអម្ចាស់ទាំងថ្ងៃទាំងយប់ ដែលបានរៀបចំជាស្រេច
ហើយ ទំរាំឲ្យបានចាត់ចេញទៅ[ខ]ច្រូតស្រែ;
៦ ប៉ុន្តែព្រះអម្ចាស់មានព្រះបន្ទូលទៅពួកគេថា ចូរកុំដកស្រងែ
ចេញ នៅពេលស្លឹកវានៅខ្ចីនៅឡើយនោះ (ត្បិតប្រាកដជា
សេចក្ដី ជំនឿរបស់អ្នកទន់ខ្សោយ) ក្រែងអ្នកបំផ្លាញស្រូវសាលី
ទៅដែរ ។
៧ ហេតុដូច្នេះហើយ ចូរទុកឲ្យស្រូវសាលី និងស្រងែដុះជា
មួយគ្នា ដរាបដល់ចំរូតទុំសុសចុះ; ខណៈនោះ អ្នករាល់គ្នាត្រូវ
ប្រមូលស្រូវ សាលីចេញពីស្រងែជាមុនសិន ហើយបន្ទាប់ពីការ
ប្រមូលស្រូវសាលីរួចហើយ មើលចុះហើយមើលន៏ ស្រងែត្រូវ
ចងជាកណ្ដាប់ ហើយ ស្រែត្រូវទុកឲ្យឆេះ ។
៨ ហេតុដូច្នេះហើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក
[ក]ដែលបព្វជិតភាពបានបន្តមក តាមរយៈពូជពង្សនៃពួកអយ្យកោ
របស់អ្នក ដូច្នេះថា —

៩ ត្បិតអ្នករាល់គ្នាជា[ក]អ្នកគ្រងមរតកពេញច្បាប់ ស្របតាម
សាច់ឈាម ហើយ[ខ]បានលាក់ទុកពីពិភពលោក ដោយ
សារព្រះគ្រីស្ទនៅ ក្នុងព្រះ —
១០ ហេតុដូច្នេះហើយ ជីវិត និងបព្វជិតភាពរបស់អ្នកត្រូវបាន
ទុក ហើយត្រូវតែមានតាមរយៈអ្នក និងតាមពូជពង្សអ្នក រហូត
ដល់ [ក]ការសាង ឡើងវិញនូវគ្រប់ទាំងអស់ ដែលបានពោលដល់
ដោយមាត់នៃអស់ទាំងពួកព្យាការីដ៏បរិសុទ្ធ ចាប់តាំងពីកំណើត
លោកិយមកម្ល៉េះ ។
១១ ហេតុដូច្នេះហើយ អ្នករាល់គ្នាមានពរហើយ បើសិនជា
អ្នករាល់គ្នាបន្តនៅក្នុងសេចក្ដីល្អរបស់យើង គឺជា[ក]ពន្លឺដល់ពួក
សាសន៍ដទៃ និងតាមរយៈបព្វជិតភាពនេះ គឺជាអ្នកសង្គ្រោះដល់
រាស្ត្ររបស់យើង គឺសាសន៍[ខ]អ៊ីស្រាអែល ។ ព្រះអម្ចាស់ទ្រង់
បានមានព្រះបន្ទូល ហើយ ។ អាម៉ែន ៕

## កណ្ឌទី ៨៧

*វិវរណៈនិងការព្យាករណ៍អំពីសង្គ្រាម ដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៨៣២ (*History of the Church*, ១:៣០១–៣០២)* ។ *កណ្ឌនេះត្រូវបានទទួលមកក្នុងកាលពួកបងប្អូនប្រុសៗនៃសាសនាកំពុងតែរំពឹងគិត និងពិចារណាអំពីទាសភាពនៃពួកអាហ្វ្រិច នៅលើទ្វីបអាមេរិក និងអំពីទាសភាពនៃកូនចៅមនុស្សទូទៅទាំង ពិភពលោក ។*

*១–៤, សង្គ្រាមត្រូវបានទាយប្រាប់ទុកជាមុន រវាងរដ្ឋទាំងឡាយនៅទិសខាងជើង នឹងរដ្ឋទាំងឡាយនៅទិសខាងត្បូង; ៥–៨, វិបត្តិភ័យដ៏ ធំទាំងឡាយនឹងធ្លាក់មកលើអស់ទាំងបណ្ដាជននៅលើផែនដី ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលអំពីសង្គ្រាមទាំងឡាយ
ដែលនឹងកើតឡើងនៅពេលឆាប់ៗដូច្នេះថា គឺចាប់ផ្ដើម
និងការ [ក]បះបោរពីរដ្ឋសៅខារូឡាញណា ដែលនឹងបញ្ចប់ដោយ
សារការស្លាប់ និងទុក្ខវេទនានៃមនុស្សជាច្រើន;
២ ហើយពេលនឹងមកដល់ ដែល[ក]សង្គ្រាមនឹងចាក់មកលើអស់
ទាំងសាសន៍ ចាប់ផ្ដើមនៅកន្លែងនេះ ។
៣ ត្បិតមើលចុះ រដ្ឋទាំងឡាយនៅទិសខាងត្បូងនឹង
បែកបាក់ទាស់នឹងរដ្ឋទាំងឡាយនៅទិសខាងជើង ហើយរដ្ឋ
ទាំងឡាយនៅទិស ខាងត្បូងនឹងហៅសាសន៍ផ្សេងៗ
គឺសាសន៍ពីអាណាចក្រប្រទេសអង់គ្លេស តាមដែលគេហៅ
ហើយពួកគេក៏នឹងហៅសាសន៍ផ្សេងៗ ទៀត ដើ
ម្បីការពារខ្លួន ប្រឆាំងនឹងសាសន៍ផ្សេងៗ; ហើយនៅខណៈ
នោះ [ក]សង្គ្រាមនឹងចាក់មកលើអស់ទាំងសាសន៍ ។
៤ ហើយហេតុការណ៍នឹងកើតឡើងថា ជាច្រើនថ្ងៃក្រោយមក
នោះ [ក]ពួកទាសករនឹងបះបោរឡើងទាស់និងចៅហ្វាយរបស់ខ្លួន
ដែលនឹងត្រូវត្រៀម ហើយហ្វឹកហាត់សំរាប់សង្គ្រាម ។
៥ ហើយហេតុការណ៍នឹងកើតឡើងថា ពួកសំណល់ទាំងប៉ុន្មាន

៥ *ខ* ស.ប. ចំរូត.
៨ *ក* គ. និង ស. ១១៣:៨.
ស.ប. បព្វជិតភាពមិលគីស្សាដែក.
៩ *ក* អេប្រា. ២:៩–១១.
ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
*ខ* អេសាយ ៤៩:២–៣.
១០ *ក* កិច្ចការ ៣:១៩–២១.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
១១ *ក* អេសាយ ៤៩:៦.
*ខ* គ. និង ស. ១០៩:៥៩–៦៧.
**៨៧** ១*ក* គ. និង ស. ១៣០:១២–១៣.
២ *ក* យ៉ូអែល ៣:៩–១៦;
ម៉ាថាយ ២៤:៦–៧;
គ. និង ស. ៤៥:២៦, ៦៣;
៦៣:៣៣.
៣ *ក* គ. និង ស. ៤៥:៦៨–៦៩.
៤ *ក* គ. និង ស. ១៣៤:១២.

ដែលនៅសល់លើផែនដីក៏នឹងត្រៀមខ្លួនដែរ ហើយនឹងត្រឡប់ជាខ្មាំងជា អនេក ហើយនឹងធ្វើទុក្ខពួកសាសន៍ដទៃ ដោយការធ្វើទុក្ខដ៏ធ្ងន់ធ្ងរ ។

៦ ហើយដូច្នេះ ដោយដាវ និងដោយសារការកំចាយឈាម នោះបណ្ដាជននៅលើផែនដីនឹងយំសោក; ហើយដោយនូវការអំណត់អត់ និងគ្រោះអាសន្ន និងផែនដីរំជួយ និងផ្គរលាន់នៅលើមេឃ និងរន្ទះបាញ់ខ្វាយណាខ្វាយណីផង ទើបបណ្ដាជននៅលើផែនដីនឹងបាន ស្គាល់នូវសេចក្ដីក្រោធ និងសេចក្ដីក្ដៅក្រហាយ និងព្រះហស្តសំរាប់ប្រៀនប្រដៅនៃព្រះដ៏មហិទ្ធិឫទ្ធិ រហូតដល់បានសំរេចឲ្យមានការ បំផ្លាញ ដែលធ្វើឲ្យអស់ទាំងសាសន៍ផុតអស់រលីងទៅ;

៧ ប្រយោជន៍ឲ្យសំរែកនៃពួកបរិសុទ្ធ និងឈាមនៃពួកបរិសុទ្ធ នឹងឈប់បានឮឡើងពីផែនដីទៅដល់ព្រះកាណ៌របស់ព្រះអម្ចាស់នៃសាបោត សូមឲ្យសងសឹកដល់ពួកខ្មាំងសត្រូវរបស់ពួកគេ ។

៨ ហេតុដូច្នោះហើយ ចូរអ្នករាល់គ្នាឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយចូរកុំរើឡើយ រហូតដល់ថ្ងៃនៃព្រះអម្ចាស់មកដល់; ត្បិតមើលចុះ ថ្ងៃនោះនឹងមកដល់យ៉ាងឆាប់រហ័ស ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៨៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៨៣២ (*History of the Church*, ១:៣០២–៣១២) ។ វិវរណៈនេះត្រូវបានញែកចេញដោយព្យាការីថាជា «ស្លឹកអូលីវ . . . ដែលបានបេះពីដើមនៅ ស្ថានបរមសុខ ជាសារអំពីសេចក្ដីសុខសាន្តរបស់ព្រះអម្ចាស់ដល់យើង» (*History of the Church*, ១:៣១៦) ។ នៅក្នុង បញ្ជីប្រវត្តិឃើញថាចំណែកនៃវិវរណៈនេះ ត្រូវបានទទួលនៅថ្ងៃទី២៧ និង២៨ ខែធ្នូ ឆ្នាំ១៨៣២ និងថ្ងៃទី៣ ខែមករា ឆ្នាំ១៨៣៣ ។*

*១–៥, ពួកបរិសុទ្ធដ៏ស្មោះត្រង់ទទួលបានព្រះដ៏ជាជំនួយនោះ ដែលជាសេចក្ដីសន្យាអំពីជីវិតដ៏អស់កល្បជានិច្ច; ៦–១៣, គ្រប់ទាំងអស់ ត្រូវបានត្រួតត្រា និងគ្រប់គ្រងដោយពន្លឺនៃព្រះគ្រីស្ទ; ១៤–១៦, ដំណើររស់ឡើងវិញមានមកតាមរយៈសេចក្ដីប្រោសលោះ; ១៧–៣១, ការគោរពតាមក្រិត្យវិន័យខាងសេឡេស្ទាល ទេរេសទ្រាល ឬទេឡេស្ទាល នោះត្រៀមមនុស្សលោកសំរាប់នគរ និងសិរីល្អតាមលំដាប់ នោះ; ៣២–៣៥, អស់អ្នកណាដែលសុខចិត្តនៅជាប់ក្នុងអំពើបាប ក៏នឹងនៅក្នុងអំពើស្មោកគ្រោកដដែល; ៣៦–៤១, នគរទាំងអស់ត្រូវបានគ្រប់គ្រងដោយក្រិត្យវិន័យ; ៤២–៤៥, ព្រះទ្រង់បានប្រទានក្រិត្យវិន័យដល់គ្រប់ទាំងអស់; ៤៦–៥០, មនុស្សនឹងបានយល់ដូចជាព្រះ; ៥១–៦១, ពាក្យប្រៀបប្រដូចអំពីបុរសម្នាក់ដែលចាត់ពួកអ្នកបំរើរបស់លោកឲ្យទៅស្រែ ហើយទៅមើលពួកគេតាមលំដាប់; ៦២–៧៣, ចូរចូលទៅជិតព្រះអម្ចាស់ ហើយអ្នករាល់គ្នានឹងឃើញព្រះភ័ក្ត្រទ្រង់; ៧៤–៨០, ចូរញែកខ្លួនរាល់គ្នាចេញជាបរិសុទ្ធ ហើយចូរបង្រៀន គ្នាទៅវិញទៅមក នូវគោលលទ្ធិទាំងឡាយអំពីនគរ; ៨១–៨៥, មនុស្សគ្រប់រូបដែលបានទទួលការព្រមាន នោះត្រូវព្រមានអ្នកជិតខាងរបស់ខ្លួនដែរ; ៨៦–៩៤, ទីសំគាល់ទាំងឡាយ ចលាចលខាងធាតុសព្វសារពើ និងពួកទេវតារៀបចំផ្លូវសំរាប់ការយាងមក លើកទីពីររបស់ព្រះអម្ចាស់; ៩៥–១០២, ត្រែនៃពួកទេវតាផ្លុំហៅពួកអ្នកស្លាប់តាមលំដាប់; ១០៣–១១៦, ត្រែនៃពួកទេវតាប្រកាស ប្រាប់អំពីការសាងឡើងវិញនៃដំណឹងល្អ ការរលំនៃក្រុងបាប៊ីឡូន និងចំបាំងនៃព្រះដ៏មហិមា; ១១៧–១២៦, ចូរស្វែងរកការរៀនសូត្រ ចូរតាំងដំណាក់នៃព្រះ (ព្រះវិហារ) ហើយចូរបំពាក់ខ្លួនដោយចំណងនៃសេចក្ដីសប្បុរស; ១២៧–១៤១, របៀបនៃសាលារបស់ពួក ព្យាការីត្រូវបានតែងឡើង ព្រមទាំងពិធីបរិសុទ្ធខាងការលាងជើងផង ។*

៦ *ក* គ. និង ស. ២៩:១៤–២១; ៤៥:៤៩.
*ខ* យ.ស. — ម៉ាថាយ ១:២៩.
*គ* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ឃ* ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
៧ *ក* អេធើរ ៨:២២–២៤.
*ខ* យ៉ាកុប (ព.ស.ថ.) ៥:៤; គ. និង ស. ៨៨:២; ៩៥:៧.
៨ *ក* ម៉ាថាយ ២៤:១៥; គ. និង ស. ៤៥:៣២; ១០១:២១–២២.
*ខ* វិវរ. ៣:១១.

ប្រាកដមែន ដូច្នេះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នករាល់គ្នាដែលបានជួបជុំគ្នា ដើម្បីទទួលព្រះហឫទ័យរបស់ទ្រង់អំពីអ្នកថា:

២ មើលចុះ ការនេះសព្វព្រះហឫទ័យដល់ព្រះអម្ចាស់ ហើយពួកទេវតាមាន[ក]ចិត្តត្រេកអរមកលើអ្នក; [ខ]សំណូមពរនៃពាក្យអធិស្ឋានទាំង ឡាយរបស់អ្នក បានឮទៅដល់ព្រះកាណ៌របស់ព្រះអម្ចាស់នៃ[គ]សាបោត ហើយបានកត់ទុកនៅក្នុង[ឃ]សៀវភៅនាមនៃពួកអ្នកដែលបាន ញែកចេញជាបរិសុទ្ធ គឺជាពួកអ្នកនៅឯពិភពសេឡេស្ទាល ។

៣ ហេតុដូច្នោះហើយ ឥឡូវនេះ យើងចាត់[ក]ព្រះដ៏ជាជំនួយមួយអង្គទៀតឲ្យមកលើអ្នក គឺមកលើអ្នក ជាមិត្តរបស់យើង ប្រយោជន៍ឲ្យបាន នៅជាប់ក្នុងដួងចិត្តរបស់អ្នក គឺជា[ខ]ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យា; រីឯព្រះដ៏ជាជំនួយមួយទៀត គឺដូចជាយើងបានសន្យាដល់ ពួកសិស្សយើងដែរ ដូចជាបានកត់ទុកនៅក្នុងទីបន្ទាល់របស់យ៉ូហាន ។

៤ ព្រះដ៏ជាជំនួយនេះ គឺជាសេចក្តីសន្យាដែលយើងបានប្រទានដល់អ្នក [ក]អំពីជីវិតដ៏នៅអស់កល្បជានិច្ច គឺជា[ខ]សិរីល្អនៃនគរសេឡេស្ទាល;

៥ រីឯសិរីល្អនោះគឺជាសិរីល្អនៃសាសនាចក្ររបស់[ក]កូនច្បង គឺជាសិរីល្អរបស់ព្រះ ដ៏បរិសុទ្ធបំផុតលើគ្រប់ទាំងអស់ តាមរយៈព្រះយេស៊ូវ គ្រីស្ទ ជាព្រះរាជបុត្រារបស់ទ្រង់ —

៦ [ក]ទ្រង់ដែលបានយាងឡើងទៅស្ថានខ្ពស់ ក៏ដូចជា[ខ]ទ្រង់បានយាងចុះក្រោមគ្រប់ទាំងអស់ ដោយហេតុនោះ ទើបទ្រង់[គ]យល់គ្រប់ទាំងអស់ ប្រយោជន៍ឲ្យទ្រង់អាចបានទៅជា[ឃ]ពន្លឺនៃសេចក្តីពិតនៅក្នុងទាំងអស់ និងតាមរយៈគ្រប់ទាំងអស់;

៧ រីឯសេចក្តីពិតនោះភ្លឺ ។ នេះគឺជា[ក]ពន្លឺនៃព្រះគ្រីស្ទ ។ ក៏ដូចជាទ្រង់សណ្ឋិតនៅក្នុងព្រះអាទិត្យ និងពន្លឺនៃព្រះអាទិត្យ និងអំណាចនៃព្រះអាទិត្យ ដែលព្រះអាទិត្យ[ខ]បានបង្កើតឡើងនោះដែរ ។

៨ ក៏ដូចជាទ្រង់សណ្ឋិតនៅក្នុងព្រះច័ន្ទ ហើយជាពន្លឺនៃព្រះច័ន្ទ និងអំណាចនៃព្រះច័ន្ទ ដែលព្រះច័ន្ទបានបង្កើតឡើងនោះដែរ;

៩ ក៏ដូចជាពន្លឺនៃតារាទាំងឡាយ និងអំណាចនៃតារាដែលតារាបានបង្កើតឡើងនោះដែរ;

១០ ហើយផែនដីផងដែរ និងអំណាចនៃផែនដី គឺជាផែនដីដែល[ក]អ្នកឈរលើ ។

១១ ហើយពន្លឺដែលភ្លឺ ដែលឲ្យពន្លឺដល់អ្នក នោះគឺតាមរយៈព្រះអង្គដែលបំភ្លឺភ្នែកអ្នក ដែលជាពន្លឺដដែល ដែលប្រោស[ក]យោបល់ដល់អ្នក;

១២ ជា[ក]ពន្លឺនោះហើយ ដែលចេញមកពីវត្តមាននៃព្រះ ដើម្បី[ខ]បំពេញភាពល្ហល្ហេវនៃមេឃ —

១៣ ពន្លឺដែលនៅ[ក]ក្នុងគ្រប់ទាំងអស់ ដែលផ្តល់[ខ]ជីវិតដល់គ្រប់ទាំងអស់ ដែលជា[គ]ក្រិត្យវិន័យតាមរយៈអ្វីគ្រប់ទាំងអស់ត្រូវបានគ្រប់គ្រង គឺជា ព្រះចេស្តានៃព្រះ ដែលសណ្ឋិតនៅលើបល្ល័ង្ករបស់ទ្រង់ ដែលសណ្ឋិតនៅក្នុងឱរានៃភាពអស់កល្បជានិច្ចដែលគង់នៅកណ្តាលគ្រប់ ទាំងអស់ ។

១៤ ឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា តាមរយៈ[ក]សេចក្តីប្រោសលោះ ដែលបានធ្វើឡើងសំរាប់អ្នក នោះទើបបាននាំឲ្យមានដំណើរ រស់ពីស្លាប់ឡើងវិញ ។

១៥ ហើយ[ក]វិញ្ញាណ និង[ខ]រូបកាយ គឺជា[គ]ព្រលឹងនៃមនុស្ស ។

១៦ ហើយ[ក]ដំណើររស់ពីស្លាប់ឡើងវិញ គឺជាសេចក្តីប្រោសលោះនៃព្រលឹង ។

៨៨ ២ *ក* លូកា ១៥:១០.
*ខ* កិច្ចការ ១០:១–៤.
ស.ប. ការអធិស្ឋាន.
*គ* យ៉ាកុប (ព.ស.ថ.) ៥:៤;
គ. និង ស. ៩៥:៧.
*ឃ* ស.ប. សៀវភៅជីវិត.
៣ *ក* យ៉ូហាន ១៤:១៦.
*ខ* គ. និង ស. ៧៦:៥៣.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យា.
៤ *ក* គ. និង ស. ១៤:៧.
*ខ* ស.ប. សិរីល្អនៃសេឡេស្ទាល.
៥ *ក* ស.ប. កូនច្បង.
៦ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* គ. និង ស. ១២២:៨.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
*ឃ* គ. និង ស. ៩៣:២, ៨–៣៩.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ; សេចក្តីពិត.
៧ *ក* ម៉ូរ៉ូណៃ ៧:១៥–១៩;
គ. និង ស. ៨៤:៤៥.
*ខ* លោកុ. ១:១៦.
ស.ប. បង្កបង្កើត, ការបង្កបង្កើត.
១០ *ក* ម៉ូសេ ២:១.
១១ *ក* ស.ប. យោបល់.
១២ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* យេរេ. ២៣:២៤.
១៣ *ក* កូល៉ុស ១:១៦–១៧.
*ខ* ចោទិ. ៣០:២០;
គ. និង ស. ១០:៧០.
*គ* យ៉ូប ៣៨;
គ. និង ស. ៨៨:៣៦–៣៨.
ស.ប. ក្រិត្យវិន័យ.
១៤ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន; ផែនការនៃសេចក្តីប្រោសលោះ.
១៥ *ក* ស.ប. មនុស្ស, មនុស្សលោក — មនុស្សជាកូនវិញ្ញាណនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌; វិញ្ញាណ.
*ខ* ស.ប. រូបកាយ.
*គ* លោកុ. ២:៧.
ស.ប. ព្រលឹង.
១៦ *ក* អាលម៉ា ១១:៤២.
ស.ប. ដំណើររស់ឡើងវិញ.

១៧ ហើយសេចក្ដីប្រោសលោះនៃព្រលឹង គឺតាមរយៈ
ព្រះអង្គដែលប្រោសគ្រប់ទាំងអស់ឲ្យមានជីវិត ហើយនៅក្នុងឱ
វាព្រះអង្គ គឺត្រូវបានចេញបញ្ញត្តិថា [ក]មនុស្សក្រីក្រ និង[ខ]មនុស្ស
ស្លូតបូតនៅលើ[គ]ផែនដី នឹងបានគ្រងផែនដីទុកជាមរតក ។
១៨ ហេតុដូច្នេះហើយ ផែនដីត្រូវតែបានញែកចេញជាបរិសុទ្ធ
ពីគ្រប់អំពើដ៏ឥតសុចរិតទាំងអស់ ប្រយោជន៍ឲ្យវាបានរៀបចំ
សំរាប់ [ក]សិរីល្អ ខាងសេឡេស្ទាល;
១៩ ត្បិតបន្ទាប់ពីផែនដីបានបំពេញនូវកំរិតនៃការបង្កបង្កើត
របស់នាងហើយនោះ នាងនឹងបានបំពាក់[ក]សិរីល្អទុកជាមកុដ
គឺដោយនៅ វត្តមាន នៃព្រះដ៏ជាព្រះវរបិតា;
២០ ប្រយោជន៍ឲ្យរូបកាយទាំងឡាយ ដែលនៅក្នុងនគរ
សេឡេស្ទាល អាច[ក]បានផែនដីជារៀងដរាបតទៅ; ត្បិតដោយ
សារគោល [ខ]បំណងនេះហើយ ទើបផែនដីត្រូវបានធ្វើ ហើយ
បង្កើតឡើងមក ហើយដោយសារគោលបំណងនេះហើយ ទើប
ពួកគេត្រូវ[គ]បានញែក ចេញជាបរិសុទ្ធ ។
២១ ហើយពួកអ្នកណាដែលពុំបានញែកជាបរិសុទ្ធ តាមរយៈ
ក្រិត្យវិន័យដែលយើងបានប្រទានដល់អ្នក គឺជាក្រិត្យវិន័យនៃព្រះ
គ្រីស្ទ ទេនោះ ត្រូវគ្រងនគរមួយទៀតទុកជាមរតក គឺដែលត្រូវ
ជានគរទេរេសទ្រាល ឬក៏ដែលជានគរទេឡេស្ទាល ។
២២ ត្បិតអ្នកណាដែលពុំអាចនៅជាប់ក្នុង[ក]ក្រិត្យវិន័យនៃនគរ
សេឡេស្ទាលបានទេ នោះពុំអាចនៅជាប់ក្នុងសិរីល្អខាង
សេឡេស្ទាល បានឡើយ ។
២៣ ហើយអ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរ
ទេរេសទ្រាលបានទេ នោះពុំអាចនៅជាប់ក្នុង[ក]សិរីល្អខាងទេរេស
ទ្រាល បានឡើយ ។
២៤ ហើយអ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរ
ទេឡេស្ទាលបានទេ នោះពុំអាចនៅជាប់ក្នុង[ក]សិរីល្អខាងទេឡេស្ទាល
បាន ឡើយ; ហេតុដូច្នេះហើយ អ្នកនោះពុំសមនិងបាននគរនៃ
សិរីល្អឡើយ ។ ហេតុដូច្នេះហើយ អ្នកនោះត្រូវនៅក្នុងនគរ
ដែលពុំមែនជា នគរនៃសិរីល្អទៅវិញ ។
២៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា
[ក]ផែនដីនៅជាប់ក្នុងក្រិត្យវិន័យនៃនគរសេឡេស្ទាល ត្បិតផែនដី
បំពេញកំរិតនៃការ បង្កបង្កើតរបស់នាង ហើយពុំបានរំលង
ក្រិត្យវិន័យឡើយ —
២៦ ហេតុដូច្នោះហើយ ផែនដីត្រូវបាន[ក]ញែកចេញជាបរិសុទ្ធ;
មែនហើយ ទោះជាយ៉ាងណាក៏ដោយ គង់តែផែនដីត្រូវ[ខ]ស្លាប់
នាងនឹង ត្រូវបានប្រោសឲ្យមានជីវិត ហើយនឹងនៅជាប់ក្នុង
អំណាច ដែលបានធ្វើឲ្យនាងមានជីវិត ហើយ[គ]ពួកសុចរិតនឹងបាន
គ្រងផែនដីទុកជា [ឃ]មរតក ។
២៧ ត្បិតទោះជាពួកគេស្លាប់ក៏ដោយ គង់តែពួកគេនឹង
បាន[ក]រស់ឡើងវិញ ជារូបកាយខាង[ខ]វិញ្ញាណដែរ ។
២៨ ពួកអ្នកណាដែលជាវិញ្ញាណនៃសេឡេស្ទាល នោះនឹង
បានទទួលរូបកាយដដែល ដែលជារូបកាយធម្មតា; គឺអ្នករាល់គ្នា
នឹងបាន ទទួលរូបកាយរបស់ខ្លួន ហើយ[ក]សិរីល្អរបស់អ្នកនឹងទៅជា
សិរីល្អ ដែលរូបកាយរបស់អ្នកត្រូវ[ខ]បានប្រោសឲ្យមានជីវិត ។
២៩ អ្នករាល់គ្នាណាដែលត្រូវបានប្រោសឲ្យមានជីវិត ដោយ
សារចំណែកនៃ[ក]សិរីល្អ[ខ]ខាងសេឡេស្ទាល ខណៈនោះ នឹងបាន
ទទួលដដែល គឺជាភាពពោរពេញ ។
៣០ ហើយពួកអ្នកណាដែលត្រូវបានប្រោសឲ្យមានជីវិត
ដោយសារចំណែកនៃ[ក]សិរីល្អខាងទេរេសទ្រាល ខណៈនោះ
នឹងបានដដែល គឺជាភាពពោរពេញ ។
៣១ ហើយពួកអ្នកណាដែលត្រូវបានប្រោសឲ្យមានជីវិត

១៧ ក ស.ប. មនុស្សក្រីក្រ.
ខ ស.ប. ស្លូតបូត, ភាពស្លូតបូត.
គ ស.ប. ផែនដី — ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
១៨ ក ស.ប. សិរីល្អនៃសេឡេស្ទាល.
១៩ ក គ. និង ស. ១៣០:៧–៩.
២០ ក គ. និង ស. ៣៨:២០.
ខ ម៉ូសេ ១:៣៩.
ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
គ ស.ប. ការញែកជាបរិសុទ្ធ.
២២ ក គ. និង ស. ១០៥:៥.
២៣ ក ស.ប. សិរីល្អនៃទេរេសទ្រាល.
២៤ ក ស.ប. សិរីល្អនៃទេឡេស្ទាល.
២៥ ក ស.ប. ផែនដី.
២៦ ក ស.ប. ផែនដី — ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
ខ ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
គ ២ ពេត្រុស ៣:១១–១៤.
ស.ប. សុចរិត, សេចក្ដីសុចរិត.
ឃ ម៉ាថាយ ៥:៥;
គ. និង ស. ៤៥:៥៨; ៥៩:២;
៦៣:៤៩.
២៧ ក ស.ប. ដំណើររស់ឡើងវិញ.
ខ ១ កូរិន. ១៥:៤៤.
២៨ ក ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
ខ គ. និង ស. ៤៣:៣២; ៦៣:៥១;
១០១:៣១.
២៩ ក ស.ប. សិរីល្អនៃសេឡេស្ទាល.
ខ ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
៣០ ក ស.ប. សិរីល្អនៃទេរេសទ្រាល.

ដោយសារចំណែកនៃសិរីល្អ[ក]ខាងទេឡេស្ទាល ខណៈនោះ ក៏នឹងបានទទួល ដដែល គឺជាភាពពោរពេញដែរ ។

៣២ ហើយពួកអ្នកណាដែលនៅសល់ទាំងប៉ុន្មាន នោះក៏នឹង[ក]ត្រូវបានប្រោសឲ្យមានជីវិតដែរ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេ នឹងវិលទៅកន្លែងគេវិញ ដើម្បីត្រេកអរចំពោះអ្វីដែលពួកគេ[ខ]ព្រមទទួល ពីព្រោះពួកគេមិនព្រមត្រេកអរចំពោះអ្វី ដែលពួកគេអាចទទួល បាននោះឡើយ ។

៣៣ ត្បិតតើមានប្រយោជន៍អ្វីដល់មនុស្ស បើសិនជាបានប្រទានអំណោយទានមកលើគេ ហើយគេពុំទទួលយកអំណោយទានសោះ ? មើលចុះ អ្នកនោះពុំត្រេកអរចំពោះអ្វី ដែលបានប្រទានដល់គេ ឬក៏ត្រេកអរចំពោះម្ចាស់ដែលប្រទានអំណោយទាននោះដែរ ។

៣៤ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា អ្វីក៏ដោយដែលត្រូវបានគ្រប់គ្រងដោយសារក្រិត្យវិន័យ នោះក៏ត្រូវបានរក្សាទុកឲ្យបាន គង់វង្ស ដោយសារក្រិត្យវិន័យដែរ ហើយត្រូវបានធ្វើឲ្យល្អឥតខ្ចោះ និងត្រូវបាន[ក]ញែកចេញជាបរិសុទ្ធ ដោយសារក្រិត្យវិន័យដដែល ។

៣៥ អ្វីក៏ដោយដែល[ក]បំបាក់ក្រិត្យវិន័យ ហើយមិននៅជាប់ក្នុងក្រិត្យវិន័យ ប៉ុន្តែស្វែងរកដើម្បីត្រឡប់ទៅជាក្រិត្យវិន័យដល់ខ្លួនគេវិញ ហើយព្រមនៅជាប់ក្នុងអំពើបាប ហើយនៅជាប់ជុំគ្នាក្នុងអំពើបាប នោះពុំអាចញែកចេញជាបរិសុទ្ធ ដោយសារក្រិត្យវិន័យបានឡើយ ឬដោយសារ[ខ]សេចក្តីមេត្តាករុណា [គ]សេចក្តីយុត្តិធម៌ ឬសេចក្តីជំនុំជំរះបានដែរ ។ ហេតុដូច្នេះហើយ ពួកគេត្រូវតែ[ឃ]ជាប់នៅក្នុងភាព ស្មោក គ្រោកដដែល ។

៣៦ គ្រប់នគរទាំងអស់ត្រូវបានប្រទានក្រិត្យវិន័យឲ្យ;

៣៧ ហើយមាននគរជាច្រើន; ត្បិតគ្មានកន្លែងណាដែលគ្មាន[ក]នគរនោះឡើយ; ហើយគ្មាននគរណាដែលគ្មានកន្លែងនោះឡើយ ទោះ ជានគរធំ ឬតូចក្តី ។

៣៨ ហើយចំពោះនគរនីមួយៗ នោះត្រូវបានប្រទាន[ក]ក្រិត្យវិន័យឲ្យ; ហើយចំពោះក្រិត្យវិន័យនីមួយៗ នោះមានកំរិតនិងលក្ខខ័ណ្ឌខ្លះៗ ។

៣៩ គ្រប់មនុស្សទាំងអស់ដែលមិននៅជាប់ក្នុង[ក]លក្ខខ័ណ្ឌទាំងនោះ នោះពុំបាន[ខ]រាប់ថាសុចរិតឡើយ ។

៤០ ត្បិត[ក]បញ្ញានៅជាប់នឹងបញ្ញា; [ខ]ប្រាជ្ញាទទួលប្រាជ្ញា; [គ]សេចក្តីពិតឱបក្រសោបសេចក្តីពិត; [ឃ]គុណធម៌ស្រឡាញ់គុណធម៌; [ង]ពន្លឺនៅជាប់និង ពន្លឺ; សេចក្តីមេត្តាករុណាមានសេចក្តី[ច]អាណិតដល់សេចក្តីមេត្តាករុណា ហើយទទួលស្គាល់អ្វីដែលជារបស់ខ្លួន; សេចក្តីយុត្តិធម៌បន្ត ដំណើររបស់ខ្លួន ហើយទទួលស្គាល់អ្វីដែលជារបស់ផងខ្លួន; សេចក្តីជំនុំជំរះធ្វើឡើងនៅចំពោះព្រះភ័ក្ត្ររបស់ទ្រង់ ដែលគង់នៅលើ បល្ល័ង្ក ហើយគ្រប់គ្រង ហើយអនុវត្តគ្រប់ទាំងអស់ ។

៤១ ព្រះអង្គ[ក]យល់គ្រប់ទាំងអស់ ហើយគ្រប់ទាំងអស់នៅចំពោះទ្រង់ ហើយគ្រប់ទាំងអស់នៅព័ទ្ធជុំវិញទ្រង់; ហើយព្រះអង្គនៅលើគ្រប់ ទាំងអស់ និងនៅក្នុងគ្រប់ទាំងអស់ និងតាមរយៈគ្រប់ទាំងអស់ និងនៅព័ទ្ធជុំវិញគ្រប់ទាំងអស់; ហើយគ្រប់ទាំងអស់គឺដោយសារទ្រង់ និងមកពីទ្រង់ គឺជាព្រះ ជារៀងដរាបតទៅ ។

៤២ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ព្រះអង្គបានប្រទានក្រិត្យវិន័យដល់គ្រប់ទាំងអស់ គឺដោយសារក្រិត្យវិន័យមួយនោះ ទើបរបស់ទាំងនោះដើរតាម[ក]វេលាកាលរបស់ខ្លួន និងរដូវរបស់ខ្លួន;

៤៣ ហើយដំណើររបស់ខ្លួនត្រូវបានតាំងឡើង គឺតាមដំណើរទាំងឡាយនៃផ្ទៃមេឃ និងផែនដី ដែលមានទាំងផែនដី និងពិភពទាំង ឡាយផង ។

៤៤ ហើយរបស់ទាំងនោះឲ្យ[ក]ពន្លឺដល់គ្នាទៅវិញទៅមក តាមវេលាកាលរបស់ខ្លួន និងតាមរដូវរបស់ខ្លួន តាមនាទីរបស់ខ្លួន

៣១ *ក* ស.ប. សិរីល្អនៃទេឡេស្ទាល.
៣២ *ក* អាលម៉ា ១១:៤១–៤៥.
*ខ* ស.ប. សិទ្ធិជ្រើសរើស.
៣៤ *ក* ស.ប. ការញែកជាបរិសុទ្ធ.
៣៥ *ក* ស.ប. ការបះបោរ.
*ខ* ស.ប. សេចក្តីមេត្តាករុណា, មេត្តាករុណា.
*គ* ស.ប. សេចក្តីយុត្តិធម៌.
*ឃ* វិវរ. ២២:១១; ១ នីហ្វៃ ១៥:៣៣–៣៥; ២ នីហ្វៃ ៩:១៦; អាលម៉ា ៧:២១.
៣៧ *ក* គ. និង ស. ៧៨:១៥.
៣៨ *ក* គ. និង ស. ៨៨:១៣.
៣៩ *ក* គ. និង ស. ១៣០:២០–២១.
*ខ* ស.ប. ការរាប់ជាសុចរិត, រាប់ជាសុចរិត.
៤០ *ក* ស.ប. បញ្ញា, បញ្ញាទាំងឡាយ.
*ខ* ស.ប. ប្រាជ្ញា.
*គ* ស.ប. សេចក្តីពិត.
*ឃ* ស.ប. គុណធម៌.
*ង* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ច* ស.ប. អាណិត.
៤១ *ក* ១ យ៉ូហាន ៣:២០; ១ នីហ្វៃ ៩:៦; ២ នីហ្វៃ ៩:២០; គ. និង ស. ៣៨:១–៣. ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
៤២ *ក* ដានី. ២:២០–២២; អេប្រា. ៣:៤–១៩.
៤៤ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.

តាមម៉ោង របស់ខ្លួន តាមថ្ងៃរបស់ខ្លួន តាមអាទិត្យរបស់ខ្លួន តាមខែរបស់ខ្លួន តាមឆ្នាំរបស់ខ្លួន — គ្រប់ទាំងនេះគឺជាមួយឆ្នាំចំពោះព្រះ ប៉ុន្តែពុំមែន ចំពោះមនុស្សទេ ។

៤៥ ផែនដីបង្វិលលើស្លាបរបស់ខ្លួន ហើយព្រះអាទិត្យឲ្យពន្លឺរបស់ខ្លួននៅពេលថ្ងៃ ហើយព្រះច័ន្ទឲ្យពន្លឺរបស់ខ្លួននៅពេលយប់ ហើយតារាទាំងឡាយក៏ឲ្យពន្លឺរបស់ខ្លួនដែរ នៅពេលតារាបង្វិលលើស្លាបរបស់ខ្លួន ដោយនូវសិរីល្អរបស់ខ្លួន នៅកណ្ដាលព្រះចេស្ដានៃព្រះ ។

៤៦ តើយើងត្រូវប្រៀបធៀបនគរទាំងនេះទៅនិងអ្វី ដើម្បីឲ្យអ្នករាល់គ្នាអាចយល់ ?

៤៧ មើលចុះ គ្រប់របស់ទាំងនេះគឺជានគរ ហើយមនុស្សណាមួយដែលបានមើលឃើញរបស់ ឬរបស់តូចតាចបំផុតណាមួយក៏ដោយ នោះបានឃើញព្រះអង្គទ្រង់ចលនា ដោយនូវឫទ្ធានុភាព និងព្រះចេស្ដារបស់ទ្រង់ ។

៤៨ យើងប្រាប់អ្នកថា អ្នកនោះបានឃើញព្រះអង្គហើយ; ទោះជាយ៉ាងណាក៏ដោយ គង់តែព្រះអង្គដែលបានយាងមករករាស្ត្ររបស់ទ្រង់ តែរាស្ត្រទ្រង់មិនទទួលទ្រង់ឡើយ ។

៤៩ ពន្លឺភ្លឺមកក្នុងសេចក្ដីងងឹត ហើយសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ; ទោះជាយ៉ាងណាក៏ដោយ គង់តែថ្ងៃនោះនឹងមកដល់ ក្នុងកាល អ្នកនឹងយល់ពីព្រះ ដោយបានប្រោសឲ្យមានជីវិតនៅក្នុងទ្រង់ និងដោយសារទ្រង់ ។

៥០ ខណៈនោះ អ្នករាល់គ្នាដឹងថាអ្នករាល់គ្នាបានឃើញយើងថាជាព្រះ; ហើយថាយើងជាពន្លឺពិតដែលនៅក្នុងអ្នក ហើយថាអ្នកនៅ ក្នុងយើង; បើពុំនោះសោតទេ អ្នករាល់គ្នាពុំអាចចំរើនលូតលាស់បានឡើយ ។

៥១ មើលចុះ យើងនឹងប្រៀបធៀបនគរទាំងនេះ ទៅនឹងបុរសម្នាក់ដែលមានស្រែ ហើយលោកបានចាត់ពួកអ្នកបំរើរបស់លោក ឲ្យទៅស្រែ ដើម្បីទៅជីក កាប់នៅក្នុងស្រែ ។

៥២ ហើយលោកបានមានប្រសាសន៍ដល់អ្នកទីមួយថា៖ ចូរអ្នកទៅហើយធ្វើការនៅក្នុងស្រែចុះ ហើយនៅម៉ោងទីមួយ នោះយើងនឹង មករកអ្នក ហើយអ្នកនឹងឃើញសេចក្ដីអំណរនៅលើមុខយើង ។

៥៣ ហើយលោកបានមានប្រសាសន៍ទៅអ្នកទីពីរថា៖ ចូរអ្នកទៅក្នុងស្រែផងដែរ ហើយនៅម៉ោងទីពីរ នោះយើងនឹងមកឯអ្នកដោយសេចក្ដីអំណរនៅលើមុខយើង ។

៥៤ ហើយក៏ដល់អ្នកទីបីថា៖ យើងនឹងមកឯអ្នក ។

៥៥ ហើយដល់អ្នកទីបួន និងរៀងរហូតមកដល់អ្នកទីដប់ពីរ ។

៥៦ ហើយចៅហ្វាយស្រែបានទៅរកអ្នកទីមួយ នៅក្នុងម៉ោងទីមួយ ហើយបាននៅជាមួយអ្នកនោះពេញម៉ោងនោះ ហើយអ្នកនោះត្រូវ បានរីករាយ ព្រោះតែរស្មីនៅលើមុខចៅហ្វាយរបស់ខ្លួន។

៥៧ ហើយបន្ទាប់មក លោកបានថយចេញពីអ្នកទីមួយទៅ ប្រយោជន៍ឲ្យលោកអាចទៅឯអ្នកទីពីរផងដែរ និងទីបី និងទីបួន និងរៀង រហូតដល់ទីដប់ពីរ ។

៥៨ ហើយដូច្នេះ ទើបពួកគេទាំងអស់គ្នាបានទទួលរស្មីនៅលើមុខចៅហ្វាយរបស់ខ្លួន គឺមនុស្សម្នាក់ៗ តាមម៉ោងរបស់ខ្លួន និងតាម វេលាកាលរបស់ខ្លួន និងតាមរដូវរបស់ខ្លួន —

៥៩ ចាប់ផ្ដើមនឹងអ្នកទីមួយ ហើយរហូតតទៅដល់អ្នកក្រោយបង្អស់ ហើយពីអ្នកក្រោយបង្អស់ទៅដល់អ្នកទីមួយ ហើយពីអ្នកទីមួយ ទៅដលអ្នកក្រោយបង្អស់;

៦០ មនុស្សគ្រប់រូបតាមលំដាប់ខ្លួន រហូតដល់ម៉ោងរបស់ខ្លួនបានចប់ គឺស្របតាមចៅហ្វាយរបស់ខ្លួនបានបញ្ជាគេ ប្រយោជន៍ឲ្យចៅ ហ្វាយរបស់ខ្លួន អាចបានដំកើងឡើងក្នុងខ្លួន ហើយគេនៅក្នុងចៅហ្វាយរបស់ខ្លួនដែរ ប្រយោជន៍ឲ្យពួកគេទាំងអស់គ្នា អាចបានដំកើង ឡើង ។

៦១ ហេតុដូច្នេះហើយ ទើបយើងប្រៀបពាក្យប្រៀបប្រដូចនេះទៅនិងនគរទាំងអស់នេះ ហើយបណ្ដាជននៅទីនោះ — នគរនីមួយៗ នៅក្នុងម៉ោងរបស់វា និងនៅក្នុងពេលវេលារបស់វា និងនៅក្នុងរដូវរបស់វា គឺស្របតាមបញ្ញត្តិដែលព្រះទ្រង់បានធ្វើ ។

៦២ ហើយជាថ្មីទៀត មិត្តទាំងឡាយរបស់យើងអើយ យើងប្រាប់អ្នកជាប្រាកដថា យើងទុកពាក្យទាំងនេះ ឲ្យអ្នកពិចារណាមើលនៅ ក្នុងចិត្ត ដោយនូវបញ្ញត្តិនេះដែលយើងប្រទានដល់អ្នកថា អ្នករាល់គ្នាត្រូវអំពាវនាវដល់យើង ក្នុងកាលយើងនៅជិត —

---

៤៤ *ខ* ទំនុក. ៩០:៤; ២ ពេត្រុស ៣:៨.
៤៥ *ក* លោកុ. ១:១៦; អ័ប្រា. ៤:១៦.
*ខ* គ. និង ស. ៨៨:៧–១៣.
៤៧ *ក* អាលម៉ា ៣០:៤៤;
ម៉ូសេ ១:២៧–២៨; ៦:៦៣;
អ័ប្រា. ៣:២១.
៤៨ *ក* យ៉ូហាន ១:១១; ៣ នីហ្វៃ ៩:១៦;
គ. និង ស. ៣៩:១–៤.
៤៩ *ក* គ. និង ស. ៦:២១;
៥០:២៣–២៤; ៨៤:៤៥–៤៧.
*ខ* យ៉ូហាន ១៧:៣;
គ. និង ស. ៩៣:១, ២៨.
៥៩ *ក* ម៉ាថាយ ២០:១–១៦.
៦១ *ក* គ. និង ស. ៧៦:២៤.
៦២ *ក* គ. និង ស. ៨៤:៦៣; ៩៣:៤៥.
*ខ* ស.ប. រំពឹងគិត.
*គ* អេសាយ ៥៥:៦;
យ៉ាកុប (ព.ស.ថ.) ១:៥;
គ. និង ស. ៤៦:៧.

៦៣ [ក]ចូរ[ខ]ចូលមកជិតយើង នោះយើងនឹងចូលទៅជិតអ្នក; ចូរព្យាយាមស្វែងរកយើង នោះអ្នករាល់គ្នានឹង[គ]បានជួបយើង; ចូរសូម នោះអ្នករាល់គ្នានឹងបានទទួល; ចូរគោះ នោះតែងនឹងបានបើកឲ្យអ្នក ។

៦៤ អ្វីក៏ដោយដែលអ្នករាល់គ្នា[ក]សូមព្រះវរបិតា ដោយនូវព្រះនាមរបស់យើង នោះនឹងបានប្រទានដល់អ្នក ដែលជា[ខ]ការចាំបាច់ សំរាប់អ្នក;

៦៥ ហើយបើសិនជាអ្នករាល់គ្នាសូមអ្វីណាមួយ ដែលពុំមែនជា[ក]ការចំបាច់សំរាប់អ្នកទេនោះ នោះនឹងត្រឡប់ជាការ[ខ]ដាក់ទោសដល់អ្នក វិញ ។

៦៦ មើលចុះ អ្វីដែលអ្នកឮហាក់ដូចជា[ក]សម្លេងនៃមនុស្សម្នាក់កំពុងតែស្រែកនៅក្នុងទីរហោស្ថាន — នៅក្នុងទីរហោស្ថានពីព្រោះអ្នក រាល់គ្នាពុំអាចមើលឃើញអ្នកនោះឡើយ — គឺជាសម្លេងរបស់យើង ពីព្រោះសម្លេងរបស់យើងគឺជា[ខ]ព្រះវិញ្ញាណ; ព្រះវិញ្ញាណរបស់ យើងគឺជា[គ]សេចក្ដីពិត; សេចក្ដីពិតនៅជាប់ហើយពុំមានទីបំផុតឡើយ; ហើយបើសិនជាសេចក្ដីនោះនៅក្នុងអ្នក សេចក្ដីនោះនឹងបាន ចំរើនឡើងហើយ ។

៦៧ ហើយបើសិនជា[ក]ភ្នែករបស់អ្នកស្មោះស្ម័គ្រទាំងស្រុងទៅចំពោះ[ខ]សិរីល្អរបស់យើង នោះរូបកាយអ្នកទាំងមូលនឹងបានពោរពេញ ទៅដោយពន្លឺ ហើយនឹងពុំមានសេចក្ដីងងឹតនៅក្នុងអ្នកឡើយ; ហើយរូបកាយនោះដែលបានពោរពេញទៅដោយពន្លឺ [គ]យល់គ្រប់ទាំង អស់ ។

៦៨ ហេតុដូច្នេះហើយ ចូរ[ក]ញែកខ្លួនអ្នករាល់គ្នាចេញជាបរិសុទ្ធចុះ ប្រយោជន៍ឲ្យ[ខ]គំនិតរបស់អ្នកស្មោះស្ម័គ្រទាំងស្រុងទៅរកព្រះ ហើយថ្ងៃ ទាំងឡាយនឹងមកដល់ ដែលអ្នកនឹង[គ]បានឃើញព្រះអង្គ; ត្បិតទ្រង់នឹងបើកព្រះភ័ក្ត្ររបស់ទ្រង់ឲ្យអ្នកឃើញ ហើយនឹងកើតឡើងតាមពេល វេលារបស់ទ្រង់ និងតាមផ្លូវរបស់ទ្រង់ និងស្របតាមព្រះហឫទ័យរបស់ទ្រង់ ។

៦៩ ចូរចងចាំនូវសេចក្ដីសន្យាដ៏ធំចុងក្រោយបំផុត ដែលយើងបានធ្វើដល់អ្នកចុះ; ចូរបោះ[ក]គំនិតអសារឥតការទាំងឡាយរបស់អ្នក និង[ខ]សំណើចសើចហួសហេតុរបស់អ្នក ចេញឲ្យឆ្ងាយពីអ្នកចុះ ។

៧០ ចូរអ្នករាល់គ្នានៅ ចូរអ្នករាល់គ្នានៅក្នុងទីកន្លែងនេះ ហើយប្រកាសឲ្យមានជំនុំមុតមាំមួយ គឺទាំងពួកអស់អ្នកដែលជាអ្នកធ្វើការ មុនដំបូង នៅក្នុងនគរចុងក្រោយបង្អស់នេះចុះ ។

៧១ ហើយចូរឲ្យអស់អ្នកណាដែលពួកគេបាន[ក]ព្រមាន ក្នុងកាលពួកគេធ្វើដំណើរ ឲ្យអំពាវនាវដល់ព្រះអម្ចាស់ ហើយពិចារណាពីពាក្យ ព្រមាននៅក្នុងចិត្តរបស់ពួកគេ ដែលពួកគេបានទទួលសំរាប់មួយរដូវតូច ។

៧២ មើលចុះ ហើយមើលន៏ យើងនឹងថែរក្សាហ្វូងរបស់អ្នក ហើយនឹងបណ្ដាលឲ្យមានពួកអែលឌើរកើតឡើង ហើយចាត់ឲ្យទៅរក ពួកគេ ។

៧៣ មើលចុះ យើងនឹងបញ្ឿនកិច្ចការរបស់យើង ឲ្យឆាប់កើតនៅពេលកំណត់ ។

៧៤ ហើយយើងប្រទានដល់អ្នក ដែលជាអ្នក[ក]ធ្វើការមុនដំបូងនៅក្នុងនគរចុងក្រោយបង្អស់នេះ នូវព្រះបញ្ញត្តិមួយថា អ្នកត្រូវជួបជុំគ្នា ហើយរៀបចំខ្លួន ហើយប្រុងប្រៀបខ្លួន ហើយ[ខ]ញែកខ្លួនជាបរិសុទ្ធ; មែនហើយ ចូរជំរះចិត្តរបស់អ្នកឲ្យបានបរិសុទ្ធ ហើយ[គ]លាង ដៃរបស់អ្នក និងជើងរបស់អ្នកនៅចំពោះយើងចុះ ប្រយោជន៍ឲ្យយើងអាចធ្វើឲ្យអ្នកបាន[ឃ]ជ្រះស្អាត;

៦៣ *ក* សាការី ១:៣;
យ៉ាកុប (ព.ស.ថ.) ៤:៨;
វិវរ. ៣:២០.
*ខ* ១ របា. ២៨:៩; អេធើរ ១២:៤១;
គ. និង ស. ១០១:៣៨.
*គ* គ. និង ស. ៤:៧; ៤៩:២៦.
៦៤ *ក* ស.ប. ការអធិស្ឋាន.
*ខ* គ. និង ស. ១៨:១៨;
៤៦:២៨–៣០.
៦៥ *ក* យ៉ាកុប (ព.ស.ថ.) ៤:៣.
*ខ* គ. និង ស. ៦៣:៧–១១.
៦៦ *ក* អេសាយ ៤០:៣;
១ នីហ្វៃ ១៧:១៣;
អាលម៉ា ៥:៣៧–៣៨;
គ. និង ស. ១២៨:២០.
*ខ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ; ពន្លឺ,
ពន្លឺនៃព្រះគ្រីស្ទ.
*គ* ស.ប. សេចក្ដីពិត.
៦៧ *ក* ម៉ាថាយ ៦:២២;
លូកា ១១:៣៤–៣៦;
គ. និង ស. ៨២:១៩.
*ខ* យ៉ូហាន ៧:១៨.
*គ* សុភា. ២៨:៥;
គ. និង ស. ៩៣:២៨.
ស.ប. ការសង្កេតស្គាល់,
អំណោយទានខាង.
៦៨ *ក* ស.ប. ការញែកជាបរិសុទ្ធ.
*ខ* ស.ប. គំនិត.
*គ* គ. និង ស. ៦៧:១០–១៣;
៩៣:១; ៩៧:១៥–១៧.
៦៩ *ក* ម៉ាថាយ ១២:៣៦;
ម៉ូសាយ ៤:២៩–៣០;
អាលម៉ា ១២:១៤.
*ខ* គ. និង ស. ៥៩:១៥; ៨៨:១២១.
៧១ *ក* ស.ប. ព្រមាន, ពាក្យព្រមាន.
៧៤ *ក* ម៉ាថាយ ២០:១, ១៦.
*ខ* លេវី. ២០:៧–៨;
៣ នីហ្វៃ ១៩:២៨–២៩;
គ. និង ស. ៥០:២៨–២៩;
១៣៣:៦២.
*គ* ស.ប. ស្អាត និងឥតស្អាត.
*ឃ* អេធើរ ១២:៣៧.

៧៥ ប្រយោជន៍ឲ្យយើងអាចធ្វើបន្ទាល់ដល់ព្រះវរបិតា របស់អ្នក និងព្រះរបស់អ្នក និងព្រះរបស់យើង ថាអ្នកបាន ជ្រះស្អាតពីឈាមនៃ តំណដ៏ទុច្ចរិតនេះ; ប្រយោជន៍ឲ្យ យើងអាចបំពេញសេចក្ដីសន្យានេះ ជាសេចក្ដីសន្យាដ៏ធំ ចុងក្រោយបង្អស់ ដែលយើងបានធ្វើដល់អ្នក កាលយើង សព្វព្រះហឫទ័យ ។

៧៦ ហើយយើងប្រទានដល់អ្នកផងដែរ នូវព្រះបញ្ញត្តិមួយថា អ្នករាល់គ្នាត្រូវបន្ត ការអធិស្ឋាន និងការតមអាហារ ចាប់តាំង ពីពេល នេះត ទៅ ។

៧៧ ហើយយើងប្រទានដល់អ្នក នូវព្រះបញ្ញត្តិមួយថា អ្នកត្រូវ បង្រៀនគ្នាទៅវិញទៅមក នូវគោលលទ្ធិនៃនគរ ។

៧៨ ចូរអ្នករាល់គ្នាព្យាយាមបង្រៀន ហើយព្រះគុណ របស់យើងនឹងនៅជាមួយអ្នក ដើម្បីឲ្យអ្នកអាចត្រូវបានបង្គាប់ឲ្យ បានល្អទៅទៀត អំពីទ្រឹស្ដី អំពីគោលការណ៍ អំពីគោលលទ្ធិ អំពីក្រិត្យវិន័យនៃដំណឹងល្អ អំពីគ្រប់ទាំងអស់ ដែលទាក់ទងទៅ និងនគរព្រះ ដែលជាការ ចាំបាច់សំរាប់ឲ្យអ្នកយល់;

៧៩ អំពីរបស់ទាំងឡាយនៅលើទាំងស្ថានសួគ៌ និងនៅលើ ផែនដី និងនៅក្រោមផែនដីផង; របស់ទាំងឡាយដែលធ្លាប់មាន មក របស់ទាំងឡាយដែលមានពេលនេះ របស់ទាំងឡាយដែល នឹងកើតឡើងនៅពេលឆាប់ៗ; របស់ទាំងឡាយដែលនៅក្នុងផ្ទះ របស់ ទាំងឡាយនៅស្រុកផ្សេង; សង្គ្រាមទាំងឡាយ និង ការច្របូកច្របល់នៃសាសន៍ទាំងឡាយ និងសេចក្ដីជំនុំជំរះទាំង ឡាយ ដែលនៅលើ ផែនដី; និងដំណឹងអំពីស្រុកទាំងឡាយ និងនគរទាំងឡាយផង —

៨០ ដើម្បីឲ្យអ្នករាល់គ្នាអាចបានរៀបចំ នូវគ្រប់ទាំងអស់ ក្នុង កាលយើងនឹងចាត់អ្នកម្ដងទៀត ឲ្យទៅដើម្បីដំកើងការហៅ ដែលយើងបានហៅអ្នករួចហើយនោះ និងបេសកកម្មដែលយើង បានអនុញ្ញាតដល់អ្នក ។

៨១ មើលចុះ យើងចាត់ឲ្យអ្នកទៅធ្វើបន្ទាល់ ហើយព្រមាន ប្រជាជន ហើយតម្រូវឲ្យមនុស្សម្នាក់ៗណាដែលបានព្រមាន នោះត្រូវ ព្រមានអ្នកជិតខាងរបស់ខ្លួន ។

៨២ ហេតុដូច្នេះហើយ ពួកគេគ្មានពាក្យដោះសារណាឡើយ ហើយអំពើបាបរបស់ពួកគេ គឺនៅលើក្បាលរបស់ពួកគេផ្ទាល់ ។

៨៣ អ្នកណាដែលឆាប់ស្វែងរកយើង នោះនឹងបានជួបយើង ហើយនឹងមិនត្រូវបោះបង់ចោលឡើយ ។

៨៤ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នានៅ ហើយធ្វើការ ដោយមានចិត្តព្យាយាមចុះ ប្រយោជន៍ឲ្យអ្នកអាចបានល្អឥត ខ្ចោះ នៅក្នុង ការបំរើរបស់អ្នក ដើម្បីចេញទៅក្នុងចំណោមពួក សាសន៍ដទៃ នៅពេលចុងក្រោយបង្អស់ គឺមនុស្សជាច្រើនណា ដែលព្រះឱស្ឋនៃ ព្រះអម្ចាស់នឹងសំរេចឲ្យ ដើម្បីចងក្រិត្យវិន័យ ហើយភ្ជាប់ទីបន្ទាល់ និងដើម្បីរៀបចំពួកបរិសុទ្ធ សំរាប់ម៉ោងនៃ សេចក្ដីជំនុំជំរះ ដែលនឹង មកដល់;

៨៥ ប្រយោជន៍ឲ្យព្រលឹងរបស់ពួកគេ អាចបានរួចពីសេច ក្ដីក្រោធនៃព្រះ គឺជាសេចក្ដីស្អប់ខ្ពើមដ៏បង្ខូចបំផ្លាញ ដែលរង់ចាំ ពួកទុច្ចរិតទាំង នៅលោកិយនេះ និងនៅបរលោកផងដែរ ។ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យអស់អ្នកណាដែលពុំមែនជាពួក អែលឌើរទីមួយ ឲ្យបន្តនៅក្នុងចំការទំពាំងបាយជូរ រហូតដល់ព្រះ ឱស្ឋនៃព្រះអម្ចាស់នឹងហៅពួកគេចុះ ត្បិតពេលវេលាពុំទាន់មក ដល់នៅឡើយទេ; សំលៀកបំពាក់របស់ពួកគេពុំបានជ្រះស្អាត ពីឈាមនៃមនុស្សតំណនេះឡើយ ។

៨៦ ចូរអ្នករាល់គ្នានៅជាប់ក្នុងសេរីភាព ដែលត្រូវបានធ្វើឲ្យ អ្នករាល់គ្នាបានរួចចុះ; ចូរកុំបញ្ជាប់ខ្លួននិងអំពើបាបឡើយ ប៉ុន្តែ

៧៥ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា; ព្រះវរបិតាដែលគង់នៅស្ថានសួគ៌; មនុស្ស, មនុស្សលោក — មនុស្សជាកូនវិញ្ញាណនៃ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
៧៦ *ក* ស.ប. ការអធិស្ឋាន.
*ខ* ស.ប. តម, តំណម.
៧៧ *ក* ស.ប. បង្រៀន, គ្រូបង្រៀន.
*ខ* ស.ប. គោលលទ្ធិនៃព្រះគ្រីស្ទ.
៧៨ *ក* ស.ប. ព្រះគុណ.
*ខ* គ. និង ស. ៨៨:១១៨; ៩០:១៥; ៩៣:៥៣.
៧៩ *ក* ស.ប. ស្ថានសួគ៌.
*ខ* ស.ប. សង្គ្រាម.
៨១ *ក* ស.ប. ធ្វើបន្ទាល់.
*ខ* គ. និង ស. ៦៣:៥៨. ស.ប. ព្រមាន, ពាក្យព្រមាន.
៨៣ *ក* ចោទិ. ៤:២៩–៣១; យេរេ. ២៩:១២–១៤; គ. និង ស. ៥៤:១០.
*ខ* អាលម៉ា ៣៧:៣៥.
៨៤ *ក* យ.ស. — ប្រវត្តិ ១:៤១.
*ខ* អេសាយ ៨:១៦–១៧.
៨៥ *ក* ម៉ាថាយ ២៤:១៥.
*ខ* គ. និង ស. ១១:១៥.
៨៥ *គ* ១ នីហ្វៃ ១២:១០–១១; យ៉ាកុប ១:១៩; ២:២; គ. និង ស. ១១២:៣៣. ស.ប. សុទ្ធ, សុទ្ធសាធ.
៨៦ *ក* ម៉ូសាយ ៥:៨. ស.ប. ឥស្សរភាព.
*ខ* យ៉ូហាន ៨:៣៦. ស.ប. សិទ្ធិជ្រើសរើស; សេរី, សេរីភាព.
*គ* កាឡាទី ៥:១.
*ឃ* ស.ប. អំពើបាប.

ចូរទុកដៃ របស់អ្នកឲ្យបានជ្រះស្អាត រហូតដល់ព្រះអម្ចាស់ទ្រង់យាងមក ។

៨៧ ត្បិតនៅមិនយូរថ្ងៃប៉ុន្មានទេ ហើយផែនដីនឹងញ័ររន្ធត់ ហើយទ្រេតទ្រោត ដូចជាមនុស្សស្រវឹង; ហើយព្រះអាទិត្យនឹងលាក់ភ័ក្ត្រា ហើយនឹងមិនព្រមឲ្យពន្លឺទេ; ហើយព្រះច័ន្ទនឹងជោគជាំទៅដោយឈាម; ហើយតារាទាំងឡាយនឹងត្រឡប់ទៅជាខឹងយ៉ាងខ្លាំង ហើយនឹងទំលាក់ខ្លួនធ្លាក់ចុះ ដូចជាផ្លែល្វាជ្រុះពីដើមល្វាដូច្នោះដែរ ។

៨៨ ហើយបន្ទាប់ពីទីបន្ទាល់របស់អ្នក នោះសេចក្ដីក្រោធនិងសេចក្ដីក្ដៅក្រហាយនឹងមានមកលើប្រជាជន ។

៨៩ ត្បិតបន្ទាប់ពីទីបន្ទាល់របស់អ្នក នោះទីបន្ទាល់អំពីផែនដីរំជួលនឹងមកដល់ ដែលនឹងបណ្ដាលឲ្យមានការថ្ងូរនៅកណ្ដាលផែនដី ហើយមនុស្សលោកនឹងដួលទៅលើដី ហើយនឹងមិនអាចក្រោកឈរបានឡើយ ។

៩០ ហើយទីបន្ទាល់អំពីសូរផ្គរលាន់ និងសូររន្ទះបាញ់ និងសូរខ្យល់ព្យុះ និងសូររលកទឹកសមុទ្របោកហួសណាហួសណី ។

៩១ ហើយគ្រប់ទាំងអស់នឹងនៅក្នុងស្ថានភាពចលាចល; ហើយប្រាកដមែន មនុស្សលោកនឹងស្រយុតចិត្ត; ព្រោះសេចក្ដីភ័យខ្លាចនឹង មានមកលើអស់ទាំងមនុស្ស ។

៩២ ហើយពួកទេវតានឹងហោះកាត់កណ្ដាលមេឃ ដោយបន្លឺសម្លេងយ៉ាងខ្លាំង ដោយបន្លឺត្រែនៃព្រះថា៖ ចូររៀបចំ ចូររៀបចំឱបណ្ដាជននៅលើផែនដីអើយ ត្បិតសេចក្ដីជំនុំជំរះនៃព្រះរបស់យើងមកដល់ហើយ ។ មើលចុះ និងមើលន៏ ប្ដីថ្មោងថ្មីមកហើយ; ចូរចេញទៅជួបលោកចុះ ។

៩៣ ហើយមួយរំពេចនោះ ស្រាប់តែឃើញមានទីសំគាល់ដ៏ធំលេចមកនៅលើមេឃ ហើយគ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា ។

៩៤ ហើយទេវតាមួយទៀតនឹងបន្លឺត្រែរបស់លោកថា៖ សាសនាចក្រដ៏ធំនោះ ជាមាតានៃសេចក្ដីគួរខ្ពើមឆ្អើមទាំងឡាយ ដែលបានធ្វើ ឲ្យអស់ទាំងសាសន៍ផឹកស្រាទំពាំងបាយជូរនៃសេចក្ដីក្រោធនៃសេចក្ដីកំផិតរបស់នាង ដែលបៀតបៀនពួកបរិសុទ្ធនៃព្រះ ដែលកំចាយ ឈាម — នាងនោះហើយ ដែលអង្គុយនៅលើទឹកច្រើន និងនៅលើកោះទាំងឡាយក្នុងសមុទ្រ — មើលចុះ នាងជាស្រងែនៅលើ ផែនដី; នាងត្រូវបានចងជាកណ្ដាប់; ចំណងរបស់នាងមាំមួនណាស់ ដែលគ្មាននរណាអាចស្រាយបានឡើយ; ហេតុដូច្នេះហើយ នាងល្មមនឹងបានឆេះហើយ ។ ហើយទេវតានោះនឹងបន្លឺត្រែរបស់លោកកាន់តែរន្ថើនខ្លាំងឡើងៗ ហើយអស់ទាំងសាសន៍នឹងបានឮសូរ ។

៩៥ ហើយនឹងមានភាពស្ងប់ស្ងាត់នៅលើមេឃ អស់រយៈពេលកន្លះម៉ោង; ហើយមួយរំពេចក្រោយមក នោះស្រាប់តែរនាំងស្ថានសួគ៌ នឹងបើកឡើង ដូចជាក្រាំងត្រូវបានលាតបន្ទាប់ពីបានមូរទុក ហើយព្រះភ័ក្ត្រនៃព្រះអម្ចាស់នឹងត្រូវបានបើកឲ្យឃើញ;

៩៦ ហើយពួកបរិសុទ្ធដែលនៅលើផែនដី ដែលរស់នៅ នោះនឹងបានប្រោសឲ្យមានជីវិត ហើយលើកឡើងទៅជួបទ្រង់ ។

៩៧ ហើយពួកអ្នកដែលដេកលក់នៅក្នុងផ្នូររបស់ខ្លួន នោះនឹងចេញមក ព្រោះផ្នូររបស់ពួកគេនឹងបានបើកឡើង; ហើយពួកគេក៏នឹង បានលើកឡើងទៅជួបទ្រង់ នៅកណ្ដាលសសរនៃផ្ទៃមេឃ —

៩៨ ពួកគេជារបស់ផងព្រះគ្រីស្ទ ជាផលដំបូង ពួក

---

៨៦ *ង* យ៉ូប ១៧:៩; ទំនុក. ២៤:៤; អាលម៉ា ៥:១៩.
៨៧ *ក* អេសាយ ១៣:៤–១៣.
*ខ* គ. និង ស. ៤៣:១៨.
*គ* យ៉ូអែល ២:១០; គ. និង ស. ៤៥:៤២; ១៣៣:៤៩.
*ឃ* វិវរ. ៦:១២.
*ង* យ៉ូអែល ៣:១៥.
៨៩ *ក* គ. និង ស. ៤៥:៣៣.
៩០ *ក* វិវរ. ៨:៥; គ. និង ស. ៤៣:១៧–២៥.
៩១ *ក* គ. និង ស. ៤៥:២៦.
៩២ *ក* វិវរ. ៨:១៣; គ. និង ស. ១៣៣:១៧.
*ខ* ម៉ាថាយ ២៥:១–១៣; គ. និង ស. ៣៣:១៧; ១៣៣:១០, ១៩.
៩៣ *ក* ម៉ាថាយ ២៤:៣០; លូកា ២១:២៥–២៧. ស.ប. ទីសំគាល់អំពីពេលវេលា.
៩៤ *ក* ១ នីហ្វៃ ១៣:៤–៩.
*ខ* ស.ប. អារក្ស — សាសនាចក្រនៃអារក្ស.
*គ* វិវរ. ១៧:៥.
*ឃ* វិវរ. ១៤:៨.
*ង* ម៉ាថាយ ១៣:៣៨.
*ច* គ. និង ស. ៦៤:២៣–២៤; ១០១:២៣–២៥. ស.ប. ផែនដី — ការសំអាតផែនដី.
៩៥ *ក* គ. និង ស. ៣៨:១២.
*ខ* វិវរ. ៦:១៤.
*គ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៩៦ *ក* ១ ថែស្សា. ៤:១៦–១៧.
៩៧ *ក* គ. និង ស. ២៩:១៣; ៤៥:៤៥–៤៦; ១៣៣:៥៦. ស.ប. ដំណើររស់ឡើងវិញ.
៩៨ *ក* ១ កូរិន. ១៥:២៣.

គេនេះហើយដែលនឹងចុះមកជាមួយទ្រង់មុនដំបូង ហើយពួក
គេនេះហើយដែល នៅលើផែនដី និងនៅក្នុងផ្នូររបស់ខ្លួន ដែល
បានលើកឡើងទៅជួបទ្រង់មុនដំបូង; ហើយគ្រប់ការណ៍ទាំងនេះ
នឹងកើតឡើង ដោយ សារសូរសម្លេងត្រែរបស់ទេវតានៃព្រះ ។
៩៩ ហើយបន្ទាប់ពីនេះមក ទេវតាមួយទៀតនឹងបន្លឺសម្លេង
ដែលជាត្រែទីពីរ; ហើយខណៈនោះ សេចក្ដីប្រោសលោះនឹង
មានឡើងដល់ អស់អ្នកណា ដែលជារបស់ផងព្រះគ្រីស្ទ ក្នុង
កាលទ្រង់យាងមក; ជាពួកអ្នកដែលបានទទួលចំណែករបស់ខ្លួន
នៅក្នុងគុកនោះ ដែលបាន រៀបចំទុកសំរាប់ពួកគេ
ប្រយោជន៍ឲ្យពួកគេអាចបានទទួលដំណឹងល្អ ហើយបានទទួល
ការជំនុំជំរះ ស្របតាមមនុស្សក្នុងសាច់ឈាម ។
១០០ ហើយជាថ្មីទៀត សូរត្រែមួយទៀតនឹងបន្លឺឡើង ដែលជា
ត្រែទីបី; ហើយខណៈនោះ វិញ្ញាណនៃមនុស្សទាំងឡាយដែល
ត្រូវទទួល ការជំនុំជំរះនឹងចេញមក ហើយនឹងបាន
ឃើញថានៅក្រោមការដាក់ទោស;
១០១ ហើយពួកគេទាំងនេះហើយដែលជាមនុស្សស្លាប់ដែល
នៅសល់ទាំងប៉ុន្មាន ហើយពួកគេពុំរស់ទៀតឡើយ រហូតដល់
ចប់រយៈ ពេលមួយពាន់ឆ្នាំ ឬពុំរស់ទៀតទេ រហូតដល់ចុងបំផុត
ផែនដី ។
១០២ ហើយត្រែមួយទៀតនឹងបន្លឺឡើង ដែលជាត្រែទីបួន ថា៖
មានក្នុងចំណោមពួកអ្នកដែលនៅសល់ រហូតដល់ថ្ងៃដ៏ធំចុងក្រោយ
បង្អស់ គឺចុងបំផុត ដែលនឹងនៅតែស្មោកគ្រោកដដែល ។
១០៣ ហើយត្រែមួយទៀតនឹងបន្លឺឡើង ដែលជាត្រែទីប្រាំ
ជាទេវតាទីប្រាំដែលថ្លែងប្រាប់អំពីដំណឹងល្អដ៏អស់កល្បអស់កាល
ជានិច្ច — ដោយហោះកាត់កណ្ដាលមេឃ ប្រាប់ដល់គ្រប់
ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន;
១០៤ ហើយការណ៍នេះនឹងត្រូវទៅជាសូរនៃត្រែរបស់លោក
ដោយប្រាប់ដល់អស់ទាំងមនុស្ស ទាំងនៅលើស្ថានសួគ៌ និងនៅ
លើផែនដី និងដែលនៅក្រោមផែនដីផង — ព្រោះគ្រប់ទាំង
ត្រចៀកនឹងបានឮ ហើយគ្រប់ទាំងជង្គង់ត្រូវលុតចុះ ហើយគ្រប់
ទាំង អណ្ដាតត្រូវទទួលស្គាល់ ក្នុងកាលពួកគេឮសូរត្រែបន្លឺថា៖
ចូរកោតខ្លាចដល់ព្រះ ហើយថ្វាយសិរីល្អដល់ព្រះអង្គ ដែល
គង់នៅលើបល្ល័ង្ក ជារៀងដរាបតទៅ; ត្បិតម៉ោងនៃសេច
ក្ដីជំនុំជំរះរបស់ទ្រង់មកដល់ហើយ ។
១០៥ ហើយជាថ្មីទៀត ទេវតាមួយទៀតនឹងបន្លឺត្រែ
របស់លោក ដែលជាទេវតាទីប្រាំមួយ ដោយថា៖ នាង
បានរលំហើយ ដែល បានធ្វើឲ្យអស់ទាំងសាសន៍
ផឹកស្រាទំពាំងបាយជូរនៃសេចក្ដីក្រោធនៃសេចក្ដីកំផិតរបស់នាង;
នាងបានរលំហើយ បានរលំហើយ!
១០៦ ហើយជាថ្មីទៀត ទេវតាមួយទៀតនឹងបន្លឺត្រែ
របស់លោក ដែលជាទេវតាទីប្រាំពីរ ដោយថា៖ បាន
សំរេចហើយ បានសំរេច ហើយ! កូនចៀមនៃព្រះបានឈ្នះ
ហើយបានជាន់ក្នុងធុងទំពាំងបាយជូរតែម្នាក់ឯង គឺជាឃ្នាបធុង
នៃស្រាទំពាំងបាយជូរ ជាសេចក្ដី ឃោរឃៅរបស់សេចក្ដីខ្ញាល់
នៃព្រះដ៏មានឥទ្ធិឫទ្ធិ ។
១០៧ ហើយខណៈនោះ ពួកទេវតានឹងត្រូវបានពាក់សិរីល្អនៃ
ព្រះចេស្ដារបស់ទ្រង់ ទុកជាមកុដ ហើយពួកបរិសុទ្ធនឹងត្រូវ
បានពោរពេញ ទៅដោយសិរីល្អរបស់ទ្រង់ ហើយទទួល
កេរ្ដិ៍មរតករបស់ខ្លួន ហើយបានធ្វើឲ្យស្មើនឹងព្រះអង្គ ។
១០៨ ហើយខណៈនោះ ទេវតាទីមួយនឹងបន្លឺត្រែ
របស់លោកម្ដងទៀត ប្រាប់ដល់ត្រចៀកនៃមនុស្សដែលរស់នៅ
ទាំងអស់ ហើយបើក សំដែងនូវកិច្ចការសម្ងាត់នៃមនុស្ស
លោក និងកិច្ចការដ៏អស្ចារ្យទាំងឡាយនៃព្រះ នៅក្នុងរយៈ
ពេលមួយពាន់ឆ្នាំដំបូង ។
១០៩ ហើយខណៈនោះ ទេវតាទីពីរនឹងបន្លឺត្រែរបស់លោក
ហើយបើកសម្ដែងនូវកិច្ចការសម្ងាត់នៃមនុស្សលោក និងគំនិត

៩៩ *ក* គ. និង ស. ៧៦:៧៣; ១៣៨:៨.
ស.ប. សេចក្ដីសង្គ្រោះ
សំរាប់មនុស្សស្លាប់.
*ខ* ១ ពេត្រុស ៤:៦.
១០០ *ក* វិវរ. ២០:១២–១៣;
អាលម៉ា ១១:៤១;
គ. និង ស. ៤៣:១៨; ៧៦:៨៥.
*ខ* ស.ប. ដាក់ទោស, ការដាក់ទោស.
១០១ *ក* វិវរ. ២០:៥.
*ខ* ស.ប. សហស្សវត្សរ៍.
១០២ *ក* ស.ប. ស្មោកគ្រោក,
សេចក្ដីស្មោកគ្រោក.
១០៣ *ក* វិវរ. ១៤:៦–៧.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
១០៤ *ក* វិវរ. ៥:១៣.
*ខ* អេសាយ ៤៥:២៣;
ភីលីព ២:៩–១១.
*គ* ស.ប. សេចក្ដីកោតខ្លាច —
សេចក្ដីកោតខ្លាចដល់ព្រះ;
ការគោរពកោតក្រែង.
១០៥ *ក* វិវរ. ១៤:៨; គ. និង ស. ១:១៦.
១០៦ *ក* ស.ប. កូនចៀមនៃព្រះ.
*ខ* ១ កូរិន. ១៥:២៥.
*គ* អេសាយ ៦៣:៣–៤;
វិវរ. ១៩:១៥;
គ. និង ស. ៧៦:១០៧; ១៣៣:៥០.
១០៧ *ក* ស.ប. ជនបរិសុទ្ធ.
*ខ* ស.ប. សិរីល្អនៃសេឡេស្ទាល.
*គ* ស.ប. ភាពដំកើងឡើង.
*ឃ* គ. និង ស. ៧៦:៩៥.
១០៨ *ក* អាលម៉ា ៣៧:២៥;
គ. និង ស. ១:៣.
*ខ* គ. និង ស. ៧៧:៦–៧.

ដែលចិត្តគិត ហើយដែលសំរេចដែរ និងកិច្ចការដ៏អស្ចារ្យនៃព្រះនៅក្នុងរយៈពេលមួយពាន់ឆ្នាំទីពីរ —

១១០ ហើយតាមលំដាប់តទៅ រហូតដល់ទេវតាទីប្រាំពីរនឹងបន្លឺត្រែរបស់លោក; ហើយលោកនឹងឈរនៅលើដែនដី និងនៅលើសមុទ្រ ហើយស្បថដោយនូវព្រះនាមនៃទ្រង់ដែលគង់នៅលើបល្ល័ង្កថាគ្មានពេលបង្អង់ទៀតឡើយ; ហើយសាតាំងនឹងត្រូវចង គឺជាពស់ពីចាស់បុរាណ ដែលហៅថាអារក្ស ហើយនឹងមិនត្រូវស្រាយឡើយ ដល់ទៅអស់រយៈពេលមួយពាន់ឆ្នាំ ។

១១១ ហើយខណៈនោះ វានឹងត្រូវបានស្រាយមួយរដូវខ្លីប្រយោជន៍ឲ្យវាអាចប្រមូលពលទ័ពទាំងឡាយរបស់វា ។

១១២ ហើយមីកែល ជាទេវតាទីប្រាំពីរ គឺជាមហាទេវតា នឹងប្រមូលពលទ័ពទាំងឡាយរបស់លោក គឺជាពួកពលបរិវារស្ថានសួគ៌ ។

១១៣ ហើយអារក្សនឹងប្រមូលពលទ័ពទាំងឡាយរបស់វា; គឺជាពលស្ថាននរក ហើយនឹងឡើងមកច្បាំងនិងមីកែល និងពលទ័ពទាំង ឡាយរបស់លោក ។

១១៤ ហើយខណៈនោះ ចំបាំងនៃព្រះដ៏មហិមានឹងកើតឡើង; ហើយអារក្ស និងពលទ័ពទាំងឡាយរបស់វានឹងត្រូវបណ្ដេញចេញទៅក្នុងកន្លែងផ្ទាល់របស់ពួកវាវិញ ដើម្បីកុំឲ្យពួកវាមានអំណាចទៅលើពួកបរិសុទ្ធជាដាច់ខាតទៀតឡើយ ។

១១៥ ត្បិតមីកែលនឹងច្បាំងចំបាំងទាំងឡាយរបស់ពួកគេ ហើយនឹងឈ្នះលើអារក្ស ដែលស្វែងរកបល្ល័ង្ករបស់ទ្រង់ដែលគង់នៅលើ បល្ល័ង្ក គឺជាកូនចៀម ។

១១៦ នេះហើយជាសិរីល្អនៃព្រះ និងពួកអ្នកដែលបានញែកចេញជាបរិសុទ្ធ; ហើយពួកគេនឹងមិនឃើញសេចក្ដីស្លាប់ទៀតឡើយ ។

១១៧ ហេតុដូច្នេះហើយ យើងប្រាប់អ្នកជាប្រាកដថា ឱមិត្តទាំងឡាយរបស់យើងអើយ ចូរប្រកាសឲ្យមានជំនុំមុតមាំរបស់អ្នក ដូចដែល យើងបានបញ្ជាដល់អ្នកចុះ ។

១១៨ ហើយដូចជាមនុស្សពុំមានសេចក្ដីជំនឿទាំងអស់គ្នា នោះចូរអ្នករាល់គ្នាព្យាយាមស្វែងរក ហើយបង្រៀនគ្នាទៅវិញទៅមក នូវពាក្យសំដីនៃប្រាជ្ញាវាងវៃ; មែនហើយ ចូរអ្នករាល់គ្នាស្វែងរកពាក្យសំដីនៃប្រាជ្ញាវាងវៃ ចេញពីសៀវភៅដ៏ល្អៗបំផុត; ចូរស្វែងរក ការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្ដីជំនឿផង ។

១១៩ ចូររៀបចំខ្លួន; ចូររៀបចំអ្វីៗដែលត្រូវការគ្រប់មុខ; ហើយចូរតាំងគេហដ្ឋានមួយឡើង គឺគេហដ្ឋាននៃការអធិស្ឋាន គេហដ្ឋាន នៃការតមអាហារ គេហដ្ឋាននៃសេចក្ដីជំនឿ គេហដ្ឋាននៃការរៀនសូត្រ គេហដ្ឋាននៃសិរីល្អ គេហដ្ឋាននៃរបៀបរៀបរយ គេហដ្ឋាន នៃព្រះ;

១២០ ប្រយោជន៍ឲ្យការចូលរបស់អ្នកអាចបានធ្វើឡើងដោយនូវព្រះនាមនៃព្រះអម្ចាស់; ប្រយោជន៍ឲ្យការចេញរបស់អ្នកអាច បានធ្វើឡើង ដោយនូវព្រះនាមនៃព្រះអម្ចាស់; ប្រយោជន៍ឲ្យអស់ទាំងការជំរាបសួររបស់អ្នកអាចបានធ្វើឡើងដោយនូវព្រះនាម នៃព្រះអម្ចាស់ ដោយលើកដៃថ្វាយដល់ព្រះដ៏ខ្ពស់បំផុត ។

១២១ ហេតុដូច្នេះហើយ ចូរឈប់ពីសំដីអសារឥតការទាំងអស់របស់អ្នក ពីសំណើចទាំងអស់ ពីសេចក្ដីប៉ងប្រាថ្នាដ៏ស្រើបស្រាល ទាំងអស់របស់អ្នក ពីសេចក្ដីឆ្មើងឆ្មៃ និងគំនិតផ្ដេសផ្ដាសទាំងអស់របស់អ្នក និងពីអំពើទុច្ចរិតទាំងអស់របស់អ្នកចុះ ។

១២២ ចូរតាំងគ្រូបង្រៀនម្នាក់នៅក្នុងចំណោមអ្នករាល់គ្នា ហើយចូរកុំឲ្យទាំងអស់គ្នានិយាយព្រមគ្នាឡើយ; ប៉ុន្តែចូរឲ្យនិយាយម្នាក់ម្ដង ហើយចូរឲ្យទាំងអស់គ្នាស្ដាប់ពាក្យសំដីរបស់

១១០ *ក* គ. និង ស. ៨៤:១០០.
*ខ* វិវរ. ២០:១–៣;
១ នីហ្វៃ ២២:២៦;
គ. និង ស. ១០១:២៨.
ស.ប. អារក្ស.
*គ* ស.ប. សហស្សវត្សរ៍.
១១១ *ក* គ. និង ស. ២៩:២២;
៤៣:៣០–៣១.
១១២ *ក* ស.ប. មីកែល.
១១៤ *ក* វិវរ. ១៦:១៤.
១១៥ *ក* អេសាយ ១៤:១២–១៧;
ម៉ូសេ ៤:១–៤.
១១៦ *ក* ស.ប. ភាពដំកើងឡើង;
ការញែកជាបរិសុទ្ធ.
*ខ* វិវរ. ២១:៤;
អាលម៉ា ១១:៤៥; ១២:១៨;
គ. និង ស. ៦៣:៤៩.
ស.ប. អមតៈ, អមតភាព.
១១៧ *ក* គ. និង ស. ១០៩:៦.
១១៨ *ក* គ. និង ស. ៨៨:៧៦–៨០.
ស.ប. បង្រៀន, គ្រូបង្រៀន.
*ខ* ស.ប. ប្រាជ្ញា.
*គ* គ. និង ស. ៥៥:៤; ១០៩:៧, ១៤.
១១៩ *ក* គ. និង ស. ៩៥:៣;
៩៧:១០–១៧; ១០៩:២–៩;
១១៥:៨.
ស.ប. ព្រះវិហារបរិសុទ្ធ,
ដំណាក់នៃព្រះអម្ចាស់.
១២១ *ក* គ. និង ស. ៤៣:៣៤; ១០០:៧.
*ខ* គ. និង ស. ៥៩:១៥; ៨៨:៦៩.
*គ* ស.ប. ខាងរូបកាយ.
*ឃ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.

អ្នកនោះ ប្រយោជន៍កាលណាទាំងអស់គ្នានិយាយ នោះទើបឲ្យទាំងអស់បានស្អាងឡើង ទាំងអស់គ្នា ហើយប្រយោជន៍ឲ្យមនុស្សគ្រប់រូបអាចបានសិទ្ធិស្មើគ្នា ។

១២៣ ចូរមើលឲ្យឃើញថាអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក; ចូរឈប់មានចិត្តលោភ; ចូរចេះចែកគ្នាទៅវិញទៅមក ដូចដែលដំណឹងល្អតម្រូវ ។

១២៤ ចូរឈប់មានចិត្តខ្ជិលច្រអូស; ចូរឈប់មានចិត្តមិនស្អាត; ចូរឈប់រកកំហុសពីគ្នាទៅវិញទៅមក; ចូរឈប់ដេកយូរជាងដែល ត្រូវការ; ចូរឆាប់ចូលដំណេក ប្រយោជន៍កុំឲ្យអ្នករាល់គ្នាអស់កម្លាំង; ចូរឆាប់ក្រោក ប្រយោជន៍ឲ្យរូបកាយរបស់អ្នករាល់គ្នា និងគំនិត របស់អ្នករាល់គ្នាអាចមានកម្លាំងក្លៀវក្លា ។

១២៥ ហើយហួសពីអស់ទាំងអ្វីៗទៅទៀត ចូរបំពាក់ខ្លួនដោយចំណងនៃសេចក្ដីសប្បុរស ដូចជាដោយស្បៃ ដែលជាចំណងនៃសេចក្ដី ល្អឥតខ្ចោះ និងសេចក្ដីសុខសាន្ត ។

១២៦ ចូរអធិស្ឋានជានិច្ច ប្រយោជន៍កុំឲ្យអ្នករាល់គ្នាអាចរសាយចិត្ត រហូតដល់យើងនឹងយាងមក ។ មើលចុះ និងមើលនឹ៎ យើងនឹង យាងមកជាឆាប់ ហើយទទួលយកអ្នករាល់គ្នាមកឯយើងផ្ទាល់ ។ អាម៉ែន ។

១២៧ ហើយជាថ្មីទៀត របៀបនៃគេហដ្ឋានដែលបានរៀបចំឡើងសំរាប់គណៈប្រធាននៃសាលារបស់ពួកព្យាការី គឺបានតាំងឡើងសំរាប់ការបង្គាប់ដល់ពួកគេ ចំពោះគ្រប់ទាំងអស់ដែលជាការចាំបាច់សំរាប់ពួកគេ គឺសំរាប់ពួកអ្នកកាន់តំណែងទាំងអស់នៅក្នុងសាសនាចក្រ ឬម្យ៉ាងទៀតថា គឺអស់អ្នកណាដែលត្រូវបានហៅឲ្យបំរើនៅក្នុងសាសនាចក្រ ចាប់ផ្ដើមពីពួកសង្ឃជាន់ខ្ពស់ ចុះរហូតដល់ ពួកឌីកុន —

១២៨ ហើយនេះជារបៀបនៃគេហដ្ឋានរបស់គណៈប្រធាននៃសាលា គឺៈ អ្នកណាដែលត្រូវបានតាំងឲ្យធ្វើប្រធាន ឬគ្រូបង្រៀននោះត្រូវ ឲ្យឃើញថាកំពុងតែឈរនៅក្នុងកន្លែងរបស់ខ្លួន នៅក្នុងគេហដ្ឋាន ដែលត្រូវបានរៀបចំសំរាប់អ្នកនោះ ។

១២៩ ហេតុដូច្នេះហើយ អ្នកនោះត្រូវទៅក្នុងគេហដ្ឋាននៃព្រះមុនគេ នៅកន្លែងណាដែលពួកជំនុំនៅក្នុងគេហដ្ឋានអាចស្ដាប់ឮពាក្យ សំដីរបស់អ្នកនោះ ដោយក្បោះក្បាយជាក់លាក់ គឺពុំមែនដោយពាក្យសំដីខ្លាំងទេ ។

១៣០ ហើយកាលណាអ្នកនោះចូលមកក្នុងគេហដ្ឋាននៃព្រះ ត្បិតអ្នកនោះត្រូវចូលក្នុងគេហដ្ឋានមុនគេ — មើលចុះ នេះហើយជាការ ប្រសើរ ដើម្បីឲ្យអ្នកនោះអាចបានទៅជាគំរូ —

១៣១ ចូរឲ្យអ្នកនោះថ្វាយបទអធិស្ឋានរបស់ខ្លួន ដោយលុតជង្គង់នៅចំពោះព្រះ ដោយនូវទីសំគាល់ ឬការចងចាំអំពីសេចក្ដីសញ្ញាដ៏ អស់កល្បអស់កាលជានិច្ច ។

១៣២ ហើយកាលណាមនុស្សណាមួយចូលមកពីក្រោយអ្នកនោះ ចូរឲ្យគ្រូបង្រៀនក្រោកឈរឡើង ហើយលើកដៃឡើងទៅរកមេឃ មែនហើយ គឺលើកឡើងលើ ជំរាបសួរបងប្អូន ឬបងប្អូនទាំងឡាយ ដោយពាក្យទាំងនេះថាៈ

១៣៣ តើអ្នកជាបងប្អូន ឬពួកបងប្អូនក្នុងសាសនាឬ ? ខ្ញុំសូមជំរាបសួរ ដោយនូវព្រះនាមនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយនូវ ទីសំគាល់ ឬការចងចាំអំពីសេចក្ដីសញ្ញាដ៏អស់កល្បអស់កាលជានិច្ច គឺខ្ញុំទទួលរាប់អានអ្នកនៅក្នុងសេចក្ដីសញ្ញាដោយការសំរេចចិត្ត ដែលជាប់ ឥតកំរើក ហើយឥតប្រែប្រួល ដើម្បីជាមិត្ត និងជាបងប្អូនអ្នក តាមរយៈព្រះគុណនៃព្រះ នៅក្នុងចំណងនៃសេចក្ដីស្រឡាញ់ ដើម្បីដើរតាមអស់ទាំងព្រះបញ្ញត្តិនៃព្រះ ដោយឥតទោស ដោយមានចិត្តអរគុណ ជារៀងដរាបតទៅ ។ អាម៉ែន ។

១៣៤ ហើយអ្នកណាដែលឃើញថាមិនសមទទួលការជំរាបសួរនេះ នោះពុំមានកន្លែងនៅក្នុងចំណោមអ្នកទេ; ត្បិតអ្នករាល់គ្នាពុំត្រូវ ទ្រាំឲ្យគេហដ្ឋានរបស់យើងកខ្វក់ដោយអ្នកនោះឡើយ ។

១៣៥ ហើយអ្នកណាដែលចូលមក ហើយមានចិត្តស្មោះត្រង់នៅចំពោះយើង ហើយជាបងប្អូន ឬបើសិនជាពួកគេជាពួកបងប្អូន ក្នុងសាសនា នោះពួកគេត្រូវជំរាបសួរប្រធាន ឬគ្រូបង្រៀនដោយលើកដៃឡើងទៅរកមេឃ ដោយពាក្យអធិស្ឋាន និងសេចក្ដីសញ្ញាដដែលនេះ ឬដោយថា អាម៉ែន ដោយនូវទីសំគាល់ដដែល ។

១២៣ *ក* ស.ប. សេចក្ដីស្រឡាញ់.
*ខ* ស.ប. លោភ.
១២៤ *ក* ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
*ខ* គ. និង ស. ៦៤:៧–១០. ស.ប. ការនិយាយអាក្រក់.
១២៥ *ក* ស.ប. សេចក្ដីសប្បុរស.
*ខ* ស.ប. សេចក្ដីសុខសាន្ត.
១២៦ *ក* ស.ប. ការអធិស្ឋាន.
*ខ* គ. និង ស. ១:១២.
១២៧ *ក* ស.ប. សាលានៃពួកព្យាការី.
*ខ* ស.ប. តំណែង, អ្នកកាន់តំណែង.
១៣១ *ក* ស.ប. ថ្វាយបង្គំ.
១៣៣ *ក* ស.ប. សេចក្ដីប្រកប.
*ខ* ស.ប. ពួកបងប្អូនប្រុស, បងប្អូនប្រុស; បងប្អូនស្រី.
១៣៤ *ក* គ. និង ស. ៩៧:១៥–១៧; ១១០:៧–៨.

១៣៦ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា នេះហើយជាគំរូដល់អ្នក សំរាប់ការជំរាបសួរគ្នាទៅវិញទៅមក នៅក្នុងគេហដ្ឋាននៃព្រះ គឺនៅក្នុងសាលានៃពួកព្យាការី ។

១៣៧ ហើយអ្នករាល់គ្នាត្រូវបានហៅឲ្យធ្វើការនេះ ដោយពាក្យអធិស្ឋាន និងអំណរគុណ ដូចជាព្រះវិញ្ញាណនឹងប្រទានពាក្យសំដី ចំពោះកិច្ចការទាំងអស់របស់អ្នក នៅក្នុងគេហដ្ឋាននៃព្រះអម្ចាស់ គឺនៅក្នុងសាលានៃពួកព្យាការី ប្រយោជន៍ឲ្យទីនោះអាចបានទៅជា ទីបរិសុទ្ធ ជារោងឧបោសថនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីការស្អាងដល់អ្នក ។

១៣៨ ហើយអ្នករាល់គ្នាមិនត្រូវទទួលនរណាមួយពីចំណោមអ្នករាល់គ្នា ឲ្យចូលក្នុងសាលានេះឡើយ លើកលែងតែអ្នកនោះបានជ្រះ ស្អាតពីឈាមនៃតំណមនុស្សនេះ;

១៣៩ ហើយអ្នកនោះត្រូវបានទទួល ដោយសារពិធីបរិសុទ្ធនៃការលាងជើង ព្រោះដោយហេតុនេះហើយ ទើបពិធីបរិសុទ្ធនៃការលាង ជើងត្រូវបានតាំងឡើង ។

១៤០ ហើយជាថ្មីទៀត ពិធីបរិសុទ្ធនៃការលាងជើង គឺត្រូវធ្វើឡើងដោយប្រធាន ឬដោយអែលឌើរដ៏ជាអធិបតីនៅក្នុងសាសនាចក្រ ។

១៤១ ពិធីនេះត្រូវចាប់ផ្ដើមដោយពាក្យអធិស្ឋាន; ហើយបន្ទាប់ពីបានទទួលទាននំប៉័ង និងស្រាទំពាំងបាយជូររួចហើយនោះលោកត្រូវ ក្រវាត់ខ្លួន តាមរបៀបដែលបានថ្លែងប្រាប់នៅក្នុងជំពូកទីដប់បី ក្នុងទីបន្ទាល់របស់យ៉ូហានអំពីយើង ។ អាម៉ែន ៕

កណ្ឌទី ៨៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៨៣៣ (*History of the Church, *១:៣២៧–៣២៩)* ។ *ព្រោះតែពួកបងប្អូនក្នុងសាសនាមុនដំបូងប្រើថ្នាំជក់នៅក្នុងការប្រជុំ របស់ពួកគេ ទើបធ្វើឲ្យព្យាការីពិចារណាពីរឿងនេះ ដោយហេតុនេះ ទើបលោកទូលសូមដល់ព្រះអម្ចាស់អំពីរឿងនេះ ។ វិវរណៈនេះ ត្រូវបានទទួលមក ដែលស្គាល់ថាជា* ពាក្យសំដីនៃប្រាជ្ញាវាងវៃ ។ *មុនដំបូង ខបីខាងមុខ គឺបានសរសេរឡើងជាការបង្គាប់ និងការអធិប្បាយដោយព្យាការី ។*

*១–៩, ការប្រើប្រាស់ស្រាទំពាំងបាយជូរ ភេសជ្ជៈខ្លាំង ថ្នាំជក់ និងភេសជ្ជៈក្ដៅត្រូវបានហាមប្រាម; ១០–១៧, រុក្ខជាតិ ផ្លែឈើ សាច់ និង ធញ្ញជាតិត្រូវបានតែងតាំងសំរាប់ការប្រើប្រាស់ដល់មនុស្ស និងដល់សត្វទាំងឡាយ; ១៨–២១, ការគោរពតាមក្រឹត្យវិន័យនៃដំណឹងល្អ ព្រមទាំង ពាក្យសំដីនៃប្រាជ្ញាវាងវៃ នោះផ្ដល់នូវព្រះពរទាំងឡាយ ខាងសាច់ឈាម និងខាងវិញ្ញាណ ។*

ពាក្យសំដីនៃប្រាជ្ញាវាងវៃ គឺសំរាប់ផលប្រយោជន៍ដល់ក្រុមប្រឹក្សានៃពួកសង្ឃជាន់ខ្ពស់ ដែលបានជួបជុំគ្នានៅក្រុងខឺតឡង់ និងដល់ សាសនាចក្រ ហើយព្រមទាំងដល់ពួកបរិសុទ្ធនៅក្រុងស៊ីយ៉ូនផង —

២ *ដើម្បីផ្ញើការសួរសុខទុក្ខ គឺពុំមែនដោយព្រះបញ្ញត្តិ ឬការបង្ខំទេ ប៉ុន្តែដោយវិវរណៈ និងពាក្យសំដីនៃប្រាជ្ញាវាងវៃវិញ គឺដោយ បង្ហាញនូវរបៀប* និងព្រះហឫទ័យនៃព្រះ ក្នុងសេចក្ដីសង្គ្រោះខាងសាច់ឈាម នៃពួកបរិសុទ្ធទាំងអស់ នៅថ្ងៃចុងក្រោយបង្អស់ —

៣ ដែលបានប្រទានសំរាប់គោលការណ៍ដោយសេចក្ដីសន្យា គឺដែលបានសម្រួលតាមសមត្ថភាពនៃពួកកំសោយ និងអស់ទាំងពួក បរិសុទ្ធ ដែលកំសោយជាងគេបំផុតផង ដែលជា ឬដែលអាចហៅថាជាពួកបរិសុទ្ធ ។

៤ មើលចុះ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នកដូច្នេះថា៖ ពីព្រោះតែអំពើអាក្រក់ទាំងឡាយ និងផែនការទាំងឡាយ ដែលមាន ហើយនឹងមាននៅក្នុងដួងចិត្តមនុស្ស ដែល

១៣៧ *ក* គ. និង ស. ៥០:២១–២៤.
១៣៨ *ក* គ. និង ស. ៨៨:៧៤–៧៥, ៨៤–៨៥.
១៣៩ *ក* ស.ប. លាង, បានលាង, ការលាង.
១៤១ *ក* ស.ប. បុណ្យរំឭក.
*ខ* យ៉ូហាន ១៣:៤–១៧.
**៨៩** ១ *ក* ស.ប. ពាក្យសំដីនៃប្រាជ្ញាវាងវៃ.
២ *ក* គ. និង ស. ២៩:៣៤.
ស.ប. ព្រះបញ្ញត្តិទាំងឡាយនៃព្រះ.
៣ *ក* គ. និង ស. ៨៩:១៨–២១.
*ខ* ស.ប. ជនបរិសុទ្ធ.
៤ *ក* ស.ប. ការបោក, បញ្ឆោត, សេចក្ដីបញ្ឆោត.

[ខ]រួមគំនិតប្រព្រឹត្តអំពើទុច្ចរិត នៅថ្ងៃចុងក្រោយបង្អស់ ទើបយើង
បាន[ក]ព្រមានដល់ អ្នក ហើយហាមអ្នកទុកជាមុន ដោយប្រទាន
ដល់អ្នក នូវពាក្យសំដីនៃប្រាជ្ញាវាងវៃនេះ តាមរយៈវិវរណៈ —
៥ ថាដរាបណាមនុស្សណាមួយផឹក[ក]ស្រាទំពាំងបាយជូរ ឬ
ភេសជ្ជៈខ្លាំងនៅក្នុងចំណោមអ្នករាល់គ្នា មើលចុះ គឺពុំមែនល្អទេ
ឬក៏មិនសម ចំពោះព្រះនេត្រនៃព្រះវរបិតារបស់អ្នកដែរ គឺគ្រាន់តែ
ជួបជុំគ្នា ដើម្បីថ្វាយសាក្រាម៉ង់ទាំងឡាយរបស់អ្នកដល់ព្រះអង្គ
បានហើយ ។
៦ ហើយមើលចុះ នេះគឺត្រូវជាស្រាទំពាំងបាយជូរ មែនហើយ
[ក]គឺស្រាទំពាំងបាយជូរសុទ្ធ ពីផ្លែទំពាំងបាយជូរដែលអ្នកធ្វើផ្ទាល់ ។
៧ ហើយជាថ្មីទៀត [ក]ភេសជ្ជៈខ្លាំង គឺពុំមែនសំរាប់ពោះទេ
ប៉ុន្តែសំរាប់ជូតខ្លួនអ្នករាល់គ្នាវិញ ។
៨ ហើយជាថ្មីទៀត ថ្នាំជក់ គឺពុំមែនសំរាប់[ក]រូបកាយ
ឬសំរាប់ពោះដែរ ហើយមិនមែនល្អសំរាប់មនុស្សឡើយ ប៉ុន្តែ
ជាថ្នាំសំរាប់ការជាំ និងអស់ទាំងគោក្របីឈឺ គឺដើម្បីយកមក
ប្រើប្រាស់ ដោយការវិនិច្ឆ័យ និងការប្រសប់ ។
៩ ហើយជាថ្មីទៀត ភេសជ្ជៈក្តៅ គឺពុំមែនសំរាប់រូបកាយ
ឬពោះឡើយ ។
១០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា [ក]រុក្ខជាតិ
ដែលល្អទាំងឡាយ នោះព្រះអង្គទ្រង់បានតែងតាំងទុកសំរាប់
សុខភាព ធម្មជាតិ និងការប្រើប្រាស់នៃមនុស្ស —
១១ គ្រប់រុក្ខជាតិតាមរដូវវា និងគ្រប់ផ្លែឈើតាមរដូវវា គឺគ្រប់
ទាំងអស់គឺដើម្បីយកមកប្រើប្រាស់ ដោយការប្រុងប្រយ័ត្ន និង
[ក]អំណរអរ ។
១២ មែនហើយ ព្រមទាំង[ក]សាច់[ខ]ពីសត្វជើងបួន និងពីសត្វហើរ
លើអាកាសផង នោះយើងជាព្រះអម្ចាស់បានតែងតាំងសំរាប់ឲ្យ
មនុស្ស យកមកប្រើប្រាស់ ដោយអំណរអរ; ទោះជាយ៉ាង
ណាក៏ដោយ គង់តែរបស់ទាំងឡាយនេះត្រូវយកមកប្រើប្រាស់
ដោយ[ក]សំចៃដែរ;
១៣ ហើយជាការសព្វព្រះហឫទ័យដល់យើង ដែលរបស់
ទាំងនេះមិនត្រូវយកមកប្រើប្រាស់ គឺគ្រាន់តែនៅរដូវរងា ឬគ្រាដាក់
ឬនៅ ពេលអំណត់ ។
១៤ [ក]គ្រប់ទាំងធញ្ញជាតិត្រូវបានតែងតាំងសំរាប់ការប្រើប្រាស់
របស់មនុស្ស និងសត្វ ដើម្បីទុកជាអាហារនៃជីវិត គឺពុំ
មែនគ្រាន់តែសំរាប់ មនុស្សទេ ប៉ុន្តែសំរាប់សត្វជើងបួននៅទីវាល
និងសត្វហើរលើអាកាស ព្រមទាំងអស់ទាំងសត្វព្រៃដែលរត់
ឬលូនវារនៅលើដីផងដែរ;
១៥ ហើយរបស់ទាំងនេះ ព្រះទ្រង់បានបង្កើតឡើង សំរាប់ការ
ប្រើប្រាស់របស់មនុស្ស គ្រាន់តែនៅពេលអំណត់ ឬពេល
អត់ឃ្លានជាខ្លាំង ។
១៦ គ្រប់ទាំងធញ្ញជាតិ គឺល្អសំរាប់ទុកជាអាហារដល់មនុស្ស
ព្រមទាំងផលពីដើមដែលវារ ដែលផ្តល់ផ្លែផ្កា ទោះជានៅក្នុងដី
ឬខ្ពស់ពីដីក៏ដោយ —
១៧ ទោះជាយ៉ាងណាក៏ដោយ គឺស្រូវសាលីសំរាប់មនុស្ស
ហើយពោតសំរាប់គោក្របី ហើយស្រូវអាវ៉ែនសំរាប់សេះ និង
ស្រូវអេប៊ូត សំរាប់សត្វស្លាបទាំងឡាយ និងសំរាប់ជ្រូក និង
សំរាប់សត្វទាំងអស់នៅទីវាល ហើយស្រូវឱកសំរាប់សត្វប្រើប្រាស់
ទាំងអស់ និងសំរាប់ ភេសជ្ជៈសាបៗ ព្រមទាំងធញ្ញជាតិ
ផ្សេងផងដែរ ។
១៨ ហើយពួកបរិសុទ្ធទាំងអស់ដែលនឹកចេះកាន់តាម ហើយ
ប្រព្រឹត្តតាមពាក្យសំដីទាំងនេះ ដោយដើរក្នុងការគោរពដល់ព្រះ
បញ្ញត្តិ ទាំងឡាយ នោះនឹងបានទទួល[ក]សេចក្តីសុខស្រួលដល់ផ្ចិត
ពួកគេ ហើយជាខួរដល់ឆ្អឹងពួកគេ;
១៩ ហើយនឹងរកឃើញ[ក]ប្រាជ្ញា និងផលថ្លៃវិសេសនៃ
[ខ]ចំណេះវិជ្ជា គឺជាសម្បត្តិដែលលាក់ទុក;
២០ ហើយនឹង[ក]រត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែល
ល្វើយឡើយ ។
២១ ហើយយើងជាព្រះអម្ចាស់ ប្រទានដល់ពួកគេ [ក]នូវសេច
ក្តីសន្យាមួយថា ទេវតាដែលបំផ្លាញនឹង[ខ]ឆ្លងហួសពួកគេ ដូចជាកូនចៅ
អ៊ីស្រាអែលដែរ ហើយមិនប្រហារពួកគេឡើយ ។ អាម៉ែន ៕

៤ ខ ស.ប. បក្សព័ន្ធសម្ងាត់.
ក ស.ប. ព្រមាន, ពាក្យព្រមាន.
៥ ក លេវី. ១០:៩–១១;
អេសាយ ៥:១១–១២;
១ កូរិន. ៦:១០.
៦ ក គ. និង ស. ២៧:១–៤.
៧ ក សុភា. ២០:១; ២៣:២៩–៣៥.
៨ ក ១ កូរិន. ៣:១៦–១៧.
ស.ប. រូបកាយ.
១០ ក ក.ន. រុក្ខជាតិ ។ លោកុប្បត្តិ ១:២៩;
គ. និង ស. ៥៩:១៧–២០.
១១ ក ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
១២ ក លោកុ. ៩:៣; លេវី. ១១:១–៨.
ខ ១ ធីម៉ូ. ៤:៣–៤;
គ. និង ស. ៤៩:១៨–២១.
ក គ. និង ស. ៥៩:២០.
១៤ ក ដានី. ១:៦–២០.
១៨ ក សុភា. ៣:៨.
១៩ ក ស.ប. ប្រាជ្ញា.
ខ ស.ប. ដំរិះ; ទីបន្ទាល់.
២០ ក អេសាយ ៤០:៣១.
២១ ក គ. និង ស. ៨៤:៨០.
ខ និក្ខ. ១២:២៣, ២៩.

## កណ្ឌទី ៩០

*វិវរណៈចំពោះ យ៉ូសែប ស៊្មីធ ជាព្យាការី ដែលបានប្រទាននៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៨៣៣* (History of the Church, *១:៣២៩–៣៣១)* ។ *វិវរណៈនេះជាជំហានតទៅទៀត អំពីការតាំងគណៈប្រធានទី១ (សូមមើលចំណងជើងនៃកណ្ឌទី ៨១); ជាការបន្ដនៃវិវរណៈនេះ ទីប្រឹក្សាទាំងឡាយដែលបានពោលដល់នោះត្រូវបានតែងតាំងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៨៣៣ ។*

*១–៥, កូនសោទាំងឡាយនៃនគរត្រូវបានប្រគល់ដល់ យ៉ូសែប ស៊្មីធ ហើយតាមរយៈលោក ទើបដល់សាសនាចក្រ; ៦–៧, ស៊ីឌនី រិកដុន និង ហ្វ្រេឌើរិក ជី វិលលាមស៍ ត្រូវបំរើក្នុងគណៈប្រធានទី១; ៨–១១, ដំណឹងល្អត្រូវបានផ្សាយដល់ពួកសាសន៍អ៊ីស្រាអែលទាំងឡាយ ដល់ពួកសាសន៍ដទៃ និងដល់ពួកសាសន៍យូដា គឺមនុស្សគ្រប់រូបត្រូវបានឮក្នុងភាសារបស់ខ្លួន; ១២–១៨, យ៉ូសែប ស៊្មីធ និង ទីប្រឹក្សា ទាំងឡាយរបស់លោកត្រូវចាត់ចែងសាសនាចក្រ តាមរបៀបរៀបរយ; ១៩–៣៧, អ្នកដទៃជាច្រើនត្រូវបានទូន្មានពីព្រះអម្ចាស់ ឲ្យដើរ ដោយទៀងត្រង់ ហើយបំរើនៅក្នុងនគររបស់ទ្រង់ ។*

ដូច្នេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា បុត្រយើងអើយ អំពើបាបទាំងឡាយរបស់អ្នក ត្រូវបាន[ក]អត់ទោសឲ្យហើយ ស្របតាមសំណូមពររបស់អ្នក ត្បិតការអធិស្ឋានទាំងឡាយរបស់អ្នក និងការអធិស្ឋាននៃបងប្អូនរបស់អ្នក ទាំងប៉ុន្មាន បានឡើងមកឯព្រះកាណ៌របស់យើងហើយ ។

២ ហេតុដូច្នេះហើយ អ្នកបានពរហើយ ពីពេលនេះតទៅ ដែល[ក]កាន់កូនសោទាំងឡាយនៃនគរ ដែលបានប្រទានដល់អ្នក; [ខ]រីឯនគរនោះ កំពុងតែចេញមកនៅលើកចុងក្រោយបង្អស់ ។

៣ យើងប្រាប់អ្នកជាប្រាកដថា កូនសោទាំងឡាយនៃនគរនេះ នឹងមិនត្រូវដកចេញពីអ្នកឡើយ នៅពេលអ្នកនៅក្នុងលោកិយ ឬនៅ នាបរលោកនាយក្ដី;

៤ ទោះជាយ៉ាងណាក៏ដោយ គង់តែតាមរយៈអ្នក នោះ[ក]ព្រះបន្ទូលទាំងឡាយនឹងត្រូវបានប្រទានដល់អ្នកផ្សេងទៀត មែនហើយ គឺដល់សាសនាចក្រ ។

៥ ហើយអស់អ្នកណាទទួលព្រះបន្ទូលនៃព្រះ នោះចូរឲ្យពួកគេ[ក]ប្រុងប្រយ័ត្នពីរបៀបពួកគេកាន់របស់ទាំងនោះចុះ ក្រែងលោពួកគេ រាប់ថាជាការឥតការ ហើយត្រូវបាននាំមកក្រោមការដាក់ទោសដោយហេតុនោះ ហើយជំពប់ ហើយ[ខ]ដួលក្នុងកាលខ្យល់ព្យុះបោកមក ហើយខ្យល់បក់បោក ហើយទឹកភ្លៀងធ្លាក់មក ហើយបោកមកលើផ្ទះរបស់ពួកគេ ។

៦ ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់ដល់បងប្អូនអ្នក គឺស៊ីឌនី រិកដុន និង ហ្វ្រេឌើរិក ជី វិលលាមស៍ថា អំពើបាបទាំងឡាយរបស់ ពួកគេត្រូវបានអត់ទោសឲ្យហើយដែរ ហើយពួកគេត្រូវបានរាប់ថាស្មើនឹងអ្នក ក្នុងការកាន់កូនសោទាំងឡាយនៃនគរ;

៧ ព្រមទាំងតាមរយៈការចាត់ចែងរបស់អ្នក នូវកូនសោទាំងឡាយនៃ[ក]សាលានៃពួកព្យាការីផង ដែលយើងបានបញ្ជាឲ្យរៀបចំនោះ;

៨ ប្រយោជន៍ថាតាមមាគ៌ានេះ ទើបពួកគេអាចបានល្អឥតខ្ចោះនៅក្នុងការងារបំរើរបស់ពួកគេ សំរាប់សេចក្ដីសង្គ្រោះនៃស៊ីយ៉ូន និងសាសន៍ទាំងឡាយនៃអ៊ីស្រាអែល និងពួកសាសន៍ដទៃ គឺមនុស្សជាច្រើនណាដែលនឹងជឿ;

៩ ប្រយោជន៍ថាតាមរយៈការចាត់ចែងរបស់អ្នក ទើបពួកគេអាចបានទទួលព្រះបន្ទូល និងតាមរយៈការចាត់ចែងរបស់ពួកគេ ទើប[ក]ព្រះបន្ទូលអាចបានចេញទៅដល់ទីបំផុតផែនដី គឺមុនដំបូង[ខ]ដល់ពួកសាសន៍ដទៃ ហើយខណៈនោះ មើលចុះ និងមើលន៏ ពួកគេនឹងបែរ ទៅរកពួកសាសន៍យូដា ។

១០ ហើយខណៈនោះ ថ្ងៃនោះនឹងមកដល់ ក្នុងកាល

៩០ ១*ក* ស.ប. អត់ទោស, អភ័យទោស.
២ *ក* គ. និង ស. ៦៥:២.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
៤ *ក* កិច្ចការ ៧:៣៨; រ៉ូម ៣:២; ហេព្រើរ ៥:១២;
គ. និង ស. ១២៤:៣៩, ១២៦.
ស.ប. ការព្យាករណ៍, ព្យាករ.
៥ *ក* គ. និង ស. ១:១៤.
*ខ* ម៉ាថាយ ៧:២៦–២៧.
៧ *ក* ស.ប. សាលានៃពួកព្យាការី.
៩ *ក* ម៉ាថាយ ១៩:៣០;
អេធើរ ១៣:១០–១២.
*ខ* ១ នីហ្វៃ ១៣:៤២;
គ. និង ស. ១០៧:៣៣; ១៣៣:៨.

ព្រះពាហុនៃព្រះអម្ចាស់នឹង[ក]សំដែងក្នុងព្រះចេស្ដា នូវការបរិវត្តន៍
ដល់ពួកសាសន៍ ទាំងឡាយ ពួកសាសន៍ដែលឥតសាសនា វង្ស
[ខ]យ៉ូសែប អំពីដំណឹងល្អនៃសេចក្ដីសង្គ្រោះរបស់ពួកគេ ។
១១ ត្បិតនៅថ្ងៃនោះ ហេតុការណ៍នឹងកើតឡើងថា មនុស្ស
គ្រប់រូប[ក]នឹងបានឮភាពពោរពេញនៃដំណឹងល្អ ដោយនូវពាក្យ
សំដីរបស់ខ្លួន និងដោយនូវភាសារបស់ខ្លួន តាមរយៈពួកអ្នក
ដែលត្រូវបាន[ខ]តែងតាំងចំពោះ[គ]អំណាចនេះ ដោយសារការចាត់
ចែងនៃ[ឃ]ព្រះដ៏ជាជំនួយ ដែលបានសណ្ឋិតមកលើពួកគេ សំរាប់
វិវរណៈនៃព្រះយេស៊ូវគ្រីស្ទ ។
១២ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា យើងប្រទាន
ដល់អ្នកនូវព្រះបញ្ញត្តិមួយថា អ្នកត្រូវបន្ត[ក]ក្នុងការងារបំរើ និង
គណៈ ប្រធានទី១ ។
១៣ ហើយកាលណាអ្នកបានបញ្ចប់ការបកប្រែគម្ពីររបស់ពួក
ព្យាការី នោះអ្នកនឹង[ក]ត្រួតពិនិត្យលើការងារនៃសាសនាចក្រ និង
[ខ]សាលា ពីពេលនេះតទៅ;
១៤ ហើយម្ដងម្កាល ដូចជាបានសំដែងដោយព្រះដ៏ជាជំនួយ
នោះនឹងបាន[ក]ទទួលវិវរណៈទាំងឡាយ ដើម្បីបើកបង្ហាញ
[ខ]សេចក្ដីអាថ៌ កំបាំងទាំងឡាយនៃនគរ ។
១៥ ហើយចូរតាំងសាសនាចក្រទាំងប៉ុន្មាន ឲ្យមានរបៀបរៀបរយ
ហើយ[ក]ចូរសិក្សា និង[ខ]រៀន ហើយស្គាល់ជិតស្និទ្ធនូវអស់ទាំងសៀវ
ភៅល្អៗ ហើយនិង[គ]ភាសាទាំងឡាយ និងអណ្ដាតទាំងឡាយ
និងប្រជាជន ។
១៦ ហើយនេះត្រូវជាធុរៈកិច្ច និងបេសកកម្មអស់មួយជីវិត
របស់អ្នក គឺដើម្បីត្រួតពិនិត្យក្នុងក្រុមប្រឹក្សា ហើយតាំងឲ្យ
មានរបៀបរៀបរយ នៅអស់ទាំងការងារនៃសាសនាចក្រ
និងនគរនេះ ។
១៧ ចូរ[ក]កុំខ្មាស់ ឬត្រូវជ្រប់មុខឡើយ; ប៉ុន្តែចូរទទួលការព្រមាន
ដាស់តឿន ចំពោះគំនិតខ្ពង់ខ្ពស់ និង[ខ]សេចក្ដីឆ្មើងឆ្មៃរបស់អ្នកចុះ
ត្បិតការ ទាំងនោះនាំ ឲ្យជាប់អន្ទាក់ដល់ព្រលឹងអ្នក ។
១៨ ចូរតាំងគេហដ្ឋានរបស់អ្នកឲ្យមានរបៀបរៀបរយចុះ;
ចូរទុក[ក]ការខ្ជិលច្រអូស និង[ខ]ការឥតស្អាតស្អំឲ្យឆ្ងាយពីអ្នកចេញ ។
១៩ ឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា ចូរទុកឲ្យមានកន្លែង
មួយ យ៉ាងឆាប់តាមដែលធ្វើទៅបាន សំរាប់ក្រុមគ្រួសារនៃទីប្រឹក្សា
និងស្មៀនរបស់អ្នក គឺហ្វ្រេដើរិក ជី វិលលាមស៍ ។
២០ ហើយចូរឲ្យ យ៉ូសែប ស្មីធ ស៊ីញ៉រ ដែល[ក]អ្នក
បំរើដ៏ចំណាស់របស់យើង នៅជាមួយគ្រួសាររបស់លោក នៅ
លើកន្លែងដែលលោក រស់នៅពេលនេះតទៅទៀតចុះ; ហើយ
ចូរកុំលក់កន្លែងនោះឡើយ រហូតដល់ព្រះឱស្ឋនៃព្រះអម្ចាស់
នឹងបញ្ជាក់ប្រាប់ ។
២១ ហើយចូរឲ្យទីប្រឹក្សារបស់យើងគឺ ស៊ីឌនី [ក]រិកដុន នៅ
កន្លែងដែលគាត់អាស្រ័យនៅឥឡូវនេះតទៅទៀតចុះ រហូតដល់
ព្រះឱស្ឋនៃ ព្រះអម្ចាស់នឹងបញ្ជាក់ប្រាប់ ។
២២ ហើយចូរឲ្យប៊ីស្សប «សូមមើល ពាក្យនេះទាំងអស់»
ព្យាយាមស្វែងរក ដើម្បីឲ្យបាន[ក]ភ្នាក់ងារម្នាក់ ហើយចូរឲ្យអ្នក
នោះជាអ្នកដែលមាន[ខ]ទ្រព្យសម្បត្តិ — ជាអ្នក សំណប់របស់
ព្រះ ហើយមានសេចក្ដីជំនឿខ្លាំង —
២៣ ដើម្បីដោយមាគ៌ានេះ ទើបគាត់អាចបង់បំណុលអស់
គ្រប់យ៉ាង; ប្រយោជន៍កុំឲ្យឃ្លាំងនៃព្រះអម្ចាស់ត្រូវបាននាំឲ្យមាន
ឈ្មោះខូច នៅចំពោះភ្នែកប្រជាជនឡើយ ។
២៤ ចូរ[ក]ព្យាយាមស្វែងរក ចូរ[ខ]អធិស្ឋានជានិច្ច ហើយចូរមាន
ជំនឿ ហើយគ្រប់[គ]ការណ៍ទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អដល់
អ្នក បើសិនជា អ្នករាល់គ្នាដើរដោយទៀងត្រង់ ហើយនឹកចាំពី
[ឃ]សេចក្ដីសញ្ញា ដែលអ្នករាល់គ្នាបានធ្វើសេចក្ដីសញ្ញាជាមួយគ្នា
ទៅវិញទៅមកនោះ ។

១០ *ក* គ. និង ស. ៤៣:២៣–២៧; ៨៨:៨៤, ៨៧–៩២.
*ខ* លោកុ. ៤៩:២២–២៦; ១ នីហ្វៃ ១៥:១៣–១៤.
១១ *ក* ស.ប. កិច្ចការផ្សាយសាសនា.
*ខ* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ; តែងតាំង, ការតែងតាំង.
*គ* ស.ប. បព្វជិតភាព.
*ឃ* ស.ប. ព្រះដ៏ជាជំនួយ.
១២ *ក* ស.ប. ធ្វើការងារបំរើ.
១៣ *ក* គ. និង ស. ១០៧:៩១–៩២.
*ខ* ស.ប. សាលានៃពួកព្យាការី.
១៤ *ក* ស.ប. វិវរណៈ.
*ខ* ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
១៥ *ក* គ. និង ស. ៨៨:៧៦–៨០, ១១៨; ៩៣:៥៣.
*ខ* គ. និង ស. ១០៧:៩៩–១០០; ១៣០:១៨–១៩.
*គ* ស.ប. ភាសា.
១៧ *ក* រ៉ូម ១:១៦; ២ នីហ្វៃ ៦:១៣.
*ខ* គ. និង ស. ៨៨:១២១. ស.ប. សេចក្ដីឆ្មើងឆ្មៃ.
១៨ *ក* គ. និង ស. ៥៨:២៦–២៩. ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
*ខ* គ. និង ស. ៣៨:៤២.
២០ *ក* ស.ប. ស្មីធ, យ៉ូសែប ស៊ីញ៉រ.
២១ *ក* ស.ប. រិកដុន, ស៊ីឌនី.
២២ *ក* គ. និង ស. ៨៤:១១២–១១៣.
*ខ* យ៉ាកុប ២:១៧–១៩.
២៤ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* ស.ប. ការអធិស្ឋាន.
*គ* អេសរ៉ា ៨:២២; រ៉ូម ៨:២៨; គ. និង ស. ១០០:១៥; ១២២:៧–៨.
២៤ *ឃ* ស.ប. សេចក្ដីសញ្ញា.

២៥ ចូរឲ្យក្រុមគ្រួសារអ្នកមានចំនួនតូច ជាពិសេស យ៉ូសែប ស្ម៊ីធ ស៊ីញ៉ រ ជាអ្នកបំរើចំណាស់របស់យើង ដូចជាអស់អ្នកដែលពុំមែន នៅក្នុងក្រុមគ្រួសាររបស់អ្នកចុះ;

២៦ ប្រយោជន៍កុំឲ្យការណ៍ទាំងនោះដែលបានផ្គត់ផ្គង់ដល់អ្នក ដើម្បីសំរេចកិច្ចការរបស់យើង ត្រូវដកចេញពីអ្នក ហើយ ផ្ដល់ដល់អស់ អ្នកដែលមិនសក្ដិសមឡើយ —

២៧ ហើយដោយហេតុនេះ ទើបអ្នកជាប់រារាំង ក្នុងការសំរេចការណ៍ទាំងនោះ ដែលយើងបានបញ្ជាដល់អ្នក ។

២៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា គឺជាព្រះហឫទ័យរបស់យើង ដែលនាងវីអែណា ចាកស៍ ជាអ្នកបំរើរបស់យើង គប្បី ទទួលប្រាក់កាស ដើម្បីបង់សោហ៊ុយរបស់នាង ហើយឡើងទៅឯដែនដីស៊ីយ៉ូនចុះ;

២៩ ហើយប្រាក់ដែលនៅសល់ទាំងប៉ុន្មាន នោះអាចថ្វាយដល់យើងចុះ ហើយនាងនឹងបានរង្វាន់ តាមពេលដែលយើងកំណត់ ។

៣០ យើងប្រាប់អ្នកជាប្រាកដថា សមចំពោះព្រះនេត្ររបស់យើងហើយ ដែលនាងគួរឡើងទៅឯដែនដីស៊ីយ៉ូន ហើយទទួលកេរ្ដិ៍មរតក ពីដៃប៊ីស្សព;

៣១ ប្រយោជន៍ឲ្យនាងអាចបានរស់នៅ ដោយសេចក្ដីសុខសាន្ត ដរាបណានាងមានចិត្តស្មោះត្រង់ ហើយមិនខ្ជិលច្រអូស អស់មួយ ជីវិតរបស់នាង ពីពេលនេះតទៅ ។

៣២ ហើយមើលចុះ យើងប្រាប់អ្នកជាប្រាកដថា អ្នករាល់គ្នានឹងត្រូវសរសេរព្រះបញ្ញត្តិនេះ ហើយប្រាប់ដល់ពួកបងប្អូនរបស់អ្នកក្នុង សាសនា ដែលនៅក្រុងស៊ីយ៉ូន ដោយនូវការជំរាបសួរដ៏ប្រកបដោយសេចក្ដីស្រឡាញ់ ថាយើងបានហៅអ្នក ឲ្យត្រួតពិនិត្យលើក្រុង ស៊ីយ៉ូនផង តាមពេលដែលយើងកំណត់ ។

៣៣ ហេតុដូច្នេះហើយ ចូរឲ្យពួកគេឈប់រំខានចិត្តយើងចំពោះរឿងនេះចុះ ។

៣៤ មើលចុះ យើងប្រាប់អ្នកថា ពួកបងប្អូនរបស់អ្នកក្នុងសាសនា ដែលនៅក្រុងស៊ីយ៉ូន ចាប់ផ្ដើមប្រែចិត្ត ហើយពួកទេវតាមានចិត្ត ត្រេកអរមកលើពួកគេ ។

៣៥ ទោះជាយ៉ាងណាក៏ដោយ គង់តែយើងមិនសព្វព្រះហឫទ័យចំពោះការណ៍ជាច្រើន; ហើយយើងមិនសព្វព្រះហឫទ័យជាមួយនឹង វិលលាម អ៊ី ម៉ុកឡេលិន ជាអ្នកបំរើរបស់យើងទេ ឬក៏ជាមួយនិង ស៊ីឌនី គិលបឺត ជាអ្នកបំរើរបស់យើងដែរ; ព្រមទាំងប៊ីស្សពផង ហើយពួកអ្នកផ្សេងៗទៀត ក៏មានការណ៍ជាច្រើន ដែលត្រូវប្រែចិត្តចេញ ។

៣៦ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា យើងជាព្រះអម្ចាស់ នឹងទាស់និងស៊ីយ៉ូន ហើយអង្វរនិងពួកអ្នកពូកែរបស់នាង ហើយវាយផ្ចាល នាង ទាល់តែនាងបានជ័យជំនះ ហើយបានស្អាតស្អំនៅចំពោះយើង ។

៣៧ ត្បិតនាងនឹងមិនត្រូវរង្គើចេញពីកន្លែងនាងឡើយ ។ យើងជាព្រះអម្ចាស់ បានមានព្រះបន្ទូលហើយ ។ អាម៉ែន ៕

## កណ្ឌទី ៩១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៩ ខែមីនា ឆ្នាំ១៨៣៣ (*History of the Church*, ១:៣៣១–៣៣២)* ។ *នៅពេលនេះ ព្យាការីបានរវល់និងការបកប្រែព្រះគម្ពីរសញ្ញាចាស់ ។ ដោយបានមកដល់ ផ្នែកនៃការសរសេរពីបុរាណ ដែលហៅថា អាប៉ូគ្រីផា នោះលោកបានទូលសូមដល់ព្រះអម្ចាស់ ហើយបានទទួលការបង្គាប់នេះ ។*

*១–៣, អាប៉ូគ្រីផា ភាគច្រើនបានបកប្រែត្រឹមត្រូវ ប៉ុន្តែមានពាក្យបញ្ចូលជាច្រើន ដោយ\ដៃមនុស្សដែលមិនពិត; ៤–៦, អាប៉ូគ្រីផាមាន ផលប្រយោជន៍ដល់អស់អ្នកដែលបានបំភ្លឺ ដោយព្រះវិញ្ញាណ ។*

២៥ *ក* ក.ន. ពួកមនុស្សក្រីក្រដែលយ៉ូសែប ស្ម៊ីធ ស៊ីញ៉ រ ថែរក្សា.
៣២ *ក* គ. និង ស. ១០៧:៩១–៩២.
៣៥ *ក* គ. និង ស. ៦៦:1; ៧៥:៦–៩.
៣៦ *ក* ស.ប. ស៊ីយ៉ូន.
*ខ* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*គ* ស.ប. សុទ្ធ, សុទ្ធសាធ.

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក អំពីអាប៉ូគ្រីផាដូច្នេះថា — មានរឿងដែលពិតជាច្រើននៅក្នុងអ័ប៉ូគ្រីផា ហើយភាគ ច្រើនបានបកប្រែត្រឹមត្រូវ;
២ មានរឿងជាច្រើនដែលមិនពិតនៅក្នុងនោះដែរ ដែលជាពាក្យបញ្ចូលដោយដៃមនុស្ស ។
៣ យើងប្រាប់អ្នកជាប្រាកដថា វាមិនចាំបាច់ត្រូវការបកប្រែអាប៉ូគ្រីផាទេ ។
៤ ហេតុដូច្នេះហើយ អស់អ្នកណាដែលអានអាប៉ូគ្រីផា ចូរឲ្យអ្នកនោះបានយល់ចុះ ត្បិតព្រះវិញ្ញាណសំដែងប្រាប់ពីសេចក្ដីពិត ។
៥ ហើយអស់អ្នកណាដែលបានបំភ្លឺដោយព្រះវិញ្ញាណ នោះនឹងបានផលប្រយោជន៍ពីអាប៉ូគ្រីផាដែរ;
៦ ហើយអស់អ្នកណាដែលមិនទទួលការបំភ្លឺពីព្រះវិញ្ញាណទេ នោះមិនអាចបានផលប្រយោជន៍ឡើយ ។ ហេតុដូច្នេះហើយ វាមិនចាំបាច់ត្រូវការបកប្រែអាប៉ូគ្រីផាទេ ។ អាម៉ែន ៕

## កណ្ឌទី ៩២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៨៣៣ (*History of the Church*, ១:៣៣៣) ។ វិវរណៈត្រូវបានផ្ដល់ដល់ ហ្វ្រេឌើរិក ជី វិលលាម្ស ជាអ្នកដែលទើបតែបានតាំងឲ្យ ធ្វើជាទីប្រឹក្សា នៅក្នុងគណៈប្រធានទីមួយ ។*

*១–២, ព្រះអម្ចាស់ទ្រង់ប្រទានព្រះបញ្ញត្តិមួយ អំពីការទទួលចូលសហសមាគម ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា យើងប្រទានដល់សហសមាគម ដែលបានរៀបចំឡើងស្របតាមព្រះបញ្ញត្តិដែល បានប្រទានមកលើកមុន គឺជាវិវរណៈនិងព្រះបញ្ញត្តិអំពីហ្វ្រេឌើរិក ជី វិលលាម្ស ជាអ្នកបំរើរបស់យើងថាអ្នករាល់គ្នានឹងទទួល គាត់ចូលក្នុងសមាគម ។ យើងមានព្រះបន្ទូលដល់ម្នាក់យ៉ាងណា នោះយើងមានព្រះបន្ទូលដល់មនុស្សទាំងអស់យ៉ាងនោះដែរ ។
២ ហើយជាថ្មីទៀត យើងប្រាប់ដល់ហ្វ្រេឌើរិក ជី វិលលាម្ស ជាអ្នកបំរើរបស់យើងថា អ្នកនឹងត្រូវទៅជាសមាជិកសកម្មម្នាក់នៅក្នុង សមាគម; ហើយដរាបណាអ្នកមានចិត្តស្មោះត្រង់ ក្នុងការកាន់តាមព្រះបញ្ញត្តិពីមុនៗទាំងអស់ នោះអ្នកនឹងបានពរជារៀងដរាបតទៅ ។ អាម៉ែន ៕

## កណ្ឌទី ៩៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៨៣៣ (*History of the Church*, ១:៣៤៣–៣៤៦) ។*

*១–៥, អស់អ្នកណាដែលមានចិត្តស្មោះត្រង់នឹងបានឃើញព្រះអម្ចាស់; ៦–១៨, យ៉ូហានបានធ្វើទីបន្ទាល់ថា ព្រះរាជបុត្រានៃព្រះ បានព្រះគុណថែមលើព្រះគុណ រហូតដល់ទ្រង់បានទទួលភាពពោរពេញនូវសិរីល្អនៃព្រះវរបិតា; ១៩–២០, ពួកមនុស្សស្មោះត្រង់ដែល បានព្រះគុណថែមលើព្រះគុណ នោះក៏នឹងបានទទួលភាពពោរពេញរបស់ព្រះអង្គយ៉ាងនោះដែរ; ២១–២២, អស់អ្នកណាដែលបានកើត មកតាមរយៈព្រះគ្រីស្ទ នោះជាសាសនាចក្រនៃកូនច្បង; ២៣–២៨, ព្រះគ្រីស្ទបានទទួលភាពពោរពេញនៃសេចក្ដីពិត ហើយដោយសារ ការគោរពតាមនោះមនុស្សលោកក៏អាចធ្វើដូច្នោះបានដែរ; ២៩–៣២, កាលដើមដំបូង មនុស្សលោកបាននៅជាមួយព្រះ; ៣៣–៣៥, វត្ថុធាតុទាំងឡាយសុទ្ធតែមាននៅអស់កល្បជានិច្ច ហើយមនុស្សលោកអាចបានទទួលនូវភាពពោរពេញនៃសេចក្ដីអំណរ នៅក្នុងដំណើររស់ឡើងវិញ; ៣៦–៣៧, សិរីល្អនៃព្រះគឺជាបញ្ញា; ៣៨–៤០, ពួកកូនក្មេងសុទ្ធតែបរិសុទ្ធនៅចំពោះព្រះ ពីព្រោះតែសេចក្ដី ប្រោសលោះនៃព្រះគ្រីស្ទ; ៤១–៥៣, ពួកបងប្អូនដែល*

៩១ ១*ក* ស.ប. អ័ប៉ូគ្រីផា.
៤*ក* ស.ប. យោបល់.
៥*ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ; ការបំផុសគំនិត, បំផុសគំនិត.
៩២ ១*ក* គ. និង ស. ៨២:១១, ១៥–២១. ស.ប. សហសមាគម.

*ដឹកនាំគេត្រូវបានបញ្ជាឲ្យតាំងក្រុមគ្រួសាររបស់ខ្លួនឲ្យមានរបៀបរៀបរយ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ហេតុការណ៍
នឹងកើតឡើងថា មនុស្សគ្រប់រូបដែល[ក]លះបង់ចោលអំពើ
បាបទាំង ឡាយរបស់ខ្លួន ហើយមករកយើង ហើយ[ខ]អំពាវនាវ
ដល់ព្រះនាមរបស់យើង ហើយ[គ]គោរពតាមសម្លេងរបស់យើង
ហើយកាន់តាម ព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះនឹង[ឃ]បាន
ឃើញ[ង]ព្រះភក្ត្ររបស់យើង ហើយស្គាល់ថាយើងជាព្រះ;
២ ហើយថាយើងជា[ក]ពន្លឺពិត ដែលបំភ្លឺដល់មនុស្សទាំងអស់
ដែលកើតមកក្នុងលោកិយ;
៣ ហើយថាយើង[ក]គង់នៅក្នុងព្រះវរបិតា ហើយព្រះវរបិតា
គង់នៅក្នុងយើង ហើយឯព្រះវរបិតា និងយើង គឺតែមួយ —
៤ ជាព្រះវរបិតា [ក]ពីព្រោះព្រះអង្គ[ខ]បានប្រទានដល់យើងនូវ
ភាពពោរពេញរបស់ទ្រង់ ហើយជាព្រះរាជបុត្រា ពីព្រោះយើង
បានគង់នៅក្នុង លោកិយ ហើយបានធ្វើរោងឧបោសថរបស់យើង
ទៅ[គ]ជាសាច់ឈាម ហើយបានគង់នៅក្នុងចំណោមពួកកូន
មនុស្ស ។
៥ យើងបានគង់នៅក្នុងលោកិយ ហើយបានទទួលពីព្រះវរបិតា
និង[ក]កិច្ចការទាំងឡាយរបស់ទ្រង់ ត្រូវបានសំដែងប្រាប់យ៉ាងច្បាស់
លាស់ ។
៦ ហើយ[ក]យ៉ូហានបានឃើញ ហើយបានធ្វើទីបន្ទាល់អំពី
ភាពពោរពេញនៃ[ខ]សិរីល្អរបស់យើង ហើយភាពពោរពេញនៃ
[គ]បញ្ជីរបស់យ៉ូហាន នឹងត្រូវបានបើកសំដែងពីពេលនេះ ។
៧ ហើយលោកបានធ្វើទីបន្ទាល់ថា៖ ខ្ញុំបានឃើញសិរីល្អរបស់
ទ្រង់ គឺកាល[ក]ដើមដំបូងមានព្រះអង្គ មុនមានលោកិយមកម្ល៉េះ;
៨ ហេតុដូច្នេះហើយ កាលដើមដំបូងមានព្រះបន្ទូល ត្បិត
ព្រះអង្គនោះហើយជា[ក]ព្រះបន្ទូល គឺជាសារទូតអំពីសេចក្ដី
សង្គ្រោះ —
៩ ជា[ក]ពន្លឺ និងជា[ខ]ព្រះដ៏ប្រោសលោះនៃពិភពលោក; ជា
ព្រះវិញ្ញាណនៃសេចក្ដីពិត ដែលបានយាងមកក្នុងពិភពលោក
ពីព្រោះពិភពលោក ត្រូវបានកើតមកដោយសារទ្រង់ ហើយនៅ
ក្នុងទ្រង់ គឺជាជីវិតនៃមនុស្សលោក និងជាពន្លឺនៃមនុស្សលោក ។
១០ ពិភពទាំងឡាយ[ក]ត្រូវបានកើតមកដោយសារទ្រង់; មនុស្ស
លោកត្រូវបានកើតមកដោយសារទ្រង់; គ្រប់ទាំងអស់ត្រូវបានកើត
មក ដោយសារទ្រង់ និងតាមរយៈទ្រង់ និងមកពីទ្រង់ ។
១១ ហើយខ្ញុំ យ៉ូហាន ធ្វើទីបន្ទាល់ថា ខ្ញុំបានឃើញសិរីល្អរបស់
ទ្រង់ ដូចជាសិរីល្អនៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា ពោរ
ពេញទៅដោយព្រះគុណ និងសេចក្ដីពិត គឺជាព្រះវិញ្ញាណនៃ
សេចក្ដីពិត ដែលយាងមក ហើយគង់នៅក្នុងសាច់ឈាម ហើយ
គង់នៅ ក្នុងចំណោមពួកយើងរាល់គ្នា ។
១២ ហើយខ្ញុំ យ៉ូហាន បានឃើញថា មុនដំបូង ទ្រង់ពុំបានទទួល
[ក]នូវភាពពោរពេញទេ ប៉ុន្តែបានទទួលព្រះគុណ[ខ]ថែមលើព្រះគុណ;
១៣ ហើយមុនដំបូង ទ្រង់ពុំបានទទួលនូវភាពពោរពេញ ប៉ុន្តែ
បាន[ក]ព្រះគុណថែមលើព្រះគុណជាបន្តបន្ទាប់មក រហូតដល់ទ្រង់
បាន ទទួលនូវភាពពោរពេញ;
១៤ ដូច្នោះហើយ ទើបទ្រង់ត្រូវបានហៅថាជា[ក]ព្រះរាជបុត្រានៃ
ព្រះ ពីព្រោះមុនដំបូង ទ្រង់ពុំបានទទួលនូវភាពពោរពេញឡើយ ។

**៩៣** ១*ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត; សក្តិសម, ភាពសក្តិសម.
*ខ* យ៉ូអែល ២:៣២.
*គ* ស.ប. ការគោរព, ដែលគោរព, គោរព.
*ឃ* និក្ខ. ៣៣:១១; គ. និង ស. ៣៨:៧–៨; ៦៧:១០–១២; ៨៨:៦៨; ១០១:២៣; ១៣០:៣. ស.ប. ព្រះដ៏ជាជំនួយ.
*ង* ក.យ.ស., ១ យ៉ូហាន ៤:១២.
២ *ក* យ៉ូហាន ១:៤–៩; គ. និង ស. ១៤:៩; ៨៤:៤៥–៤៧; ៨៨:៦–៧. ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៣ *ក* យ៉ូហាន ១០:២៥–៣៨; ១៧:២០–២៣; គ. និង ស. ៥០:៤៣–៤៥.
៤ *ក* ម៉ូសាយ ១៥:១–៧.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិទ្ធិអំណាច.
*គ* លូកា ១:២៦–៣៥; ២:៤–១៤; ៣ នីហ្វៃ ១:១២–១៤; អេធើរ ៣:១៤–១៦.
៥ *ក* យ៉ូហាន ៥:៣៦; ១០:២៥; ១៤:១០–១២.
៦ *ក* យ៉ូហាន ១:៣៤.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.
*គ* យ៉ូហាន ២០:៣០–៣១.
៧ *ក* យ៉ូហាន ១:១–៣, ១៤; ១៧:៥; គ. និង ស. ៧៦:៣៩.
៨ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ; ព្រះយេហូវ៉ា.
៩ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* ស.ប. ព្រះដ៏ប្រោសលោះ.
១០ *ក* ហេព្រើរ ១:១–៣; គ. និង ស. ៧៦:២៤; ម៉ូសេ ១:៣១–៣៣.
១២ *ក* ភីលីព ២:៦–១១.
*ខ* យ៉ូហាន ១:១៦–១៧.
១៣ *ក* លូកា ២:៥២.
១៤ *ក* លូកា ១:៣១–៣៥; គ. និង ស. ៦:២១. ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះរាជបុត្រា.

១៥ ហើយខ្ញុំ [ក]យ៉ូហាន ធ្វើទីបន្ទាល់ថា ហើយមើលនឹ៍ផ្ទៃមេឃត្រូវបានបើកចំហ ហើយ[ខ]ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកសណ្ឋិត លើទ្រង់ ក្នុងរូបជា[គ]ព្រាប ហើយបានគង់នៅលើទ្រង់ ហើយមានឮសម្លេងចេញពីស្ថានសួគ៌ថា៖ [ឃ]នេះជាកូនស្ងួនភ្ជារបស់យើង;

១៦ ហើយខ្ញុំ យ៉ូហាន ធ្វើទីបន្ទាល់ថា ទ្រង់បានទទួលភាពពោរពេញនៃសិរីល្អរបស់ព្រះវរបិតា;

១៧ ហើយទ្រង់បានទទួលគ្រប់[ក]ព្រះចេស្តា[ខ]ទាំងអស់ ទាំងនៅលើស្ថានសួគ៌ និងនៅលើផែនដីផង ហើយសិរីល្អនៃ[គ]ព្រះវរបិតាបានស្ថិតនៅ ជាមួយនឹងព្រះអង្គ ត្បិតទ្រង់គង់នៅក្នុងព្រះអង្គ ។

១៨ ហើយហេតុការណ៍នឹងកើតថា បើសិនជាអ្នកមានចិត្តស្មោះត្រង់ នោះអ្នកនឹងបានទទួលភាពពោរពេញអំពីបញ្ជីរបស់យ៉ូហានដែរ ។

១៩ យើងប្រទានដល់អ្នកនូវពាក្យទាំងនេះ ដើម្បីឲ្យអ្នកអាចយល់ ហើយចេះ[ក]ថ្វាយបង្គំ ហើយស្គាល់នូវអ្វីដែលខ្លួនថ្វាយបង្គំប្រយោជន៍ ឲ្យអ្នកអាចចូលមកឯព្រះវរបិតា ដោយនូវព្រះនាមរបស់យើង ហើយនៅវេលាកំណត់ ឲ្យបានទទួលនូវភាពពោរពេញរបស់ទ្រង់ ។

២០ ត្បិតបើសិនជាអ្នកកាន់តាម[ក]ព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នកនឹងបានទទួលនូវ[ខ]ភាពពោរពេញរបស់ទ្រង់ ហើយបាន[គ]ដំកើង ក្នុងយើង ដូចជាយើងនៅក្នុងព្រះវរបិតាដែរ; ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា អ្នកនឹងបានទទួល[ឃ]ព្រះគុណថែមលើព្រះគុណ ។

២១ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា [ក]កាលដើមដំបូង យើងបានគង់នៅជាមួយព្រះវរបិតា ហើយយើងជា[ខ]កូនច្បង;

២២ ហើយអស់អ្នកណាដែលបានកើតមកដោយសារយើង សុទ្ធតែជា[ក]ពួកអ្នកដែលទទួលនូវ[ខ]សិរីល្អដូចគ្នា ហើយសុទ្ធ តែជាសាសនាចក្រ នៃកូនច្បង ។

២៣ កាលដើមដំបូង អ្នករាល់គ្នា[ក]ក៏បាននៅជាមួយព្រះវរបិតាដែរ; ជាអ្វីដែលជាព្រះវិញ្ញាណ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត;

២៤ ហើយ[ក]សេចក្តីពិតគឺជា[ខ]ការចេះដឹង អំពីការណ៍ទាំងឡាយដែលមាននៅពេលនេះ និងការណ៍ទាំងឡាយដែលមានមកហើយ ហើយនឹងការណ៍ទាំងឡាយដែលនឹងមានខាងមុខ;

២៥ ហើយការណ៍ណា[ក]ដែលលើស ឬតិចជាងនេះ គឺជាវិញ្ញាណនៃអាកំណាច ដែលជា[ខ]អ្នកកុហកចាប់តាំងពីដើមដំបូងមកម្ល៉េះ ។

២៦ [ក]ព្រះវិញ្ញាណនៃសេចក្តីពិត គឺមកពីព្រះ ។ យើងជាព្រះវិញ្ញាណនៃសេចក្តីពិត ហើយយ៉ូហានបានធ្វើទីបន្ទាល់អំពីយើងដោយថា៖ ទ្រង់បានទទួលនូវភាពពោរពេញនៃសេចក្តីពិត មែនហើយ គឺជាគ្រប់សេចក្តីពិតទាំងអស់ ។

២៧ ហើយគ្មាននរណាទទួលនូវ[ក]ភាពពោរពេញបានឡើយ លើកលែងតែអ្នកនោះកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

២៨ អ្នកណាដែល[ក]កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះបានទទួលសេចក្តីពិត និង[ខ]ពន្លឺ រហូតដល់អ្នកនោះបានដំកើងឡើង នៅក្នុងសេចក្តីពិត ហើយ[គ]ស្គាល់ការណ៍គ្រប់យ៉ាង ។

២៩ [ក]កាលដើមដំបូង មនុស្សក៏បាននៅជាមួយនឹងព្រះដែរ

១៥ ក យ៉ូហាន ១:២៩–៣៤.
ខ ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
គ ស.ប. ព្រាប, ទីសំគាល់ជា.
ឃ ម៉ាថាយ ៣:១៦–១៧.
១៧ ក ម៉ាថាយ ២៨:១៨; យ៉ូហាន ១៧:២; ១ ពេត្រុស ៣:២២.
ខ ស.ប. ព្រះយេស៊ូវគ្រីស្ទ — សិទ្ធិអំណាច; អំណាច.
គ ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
១៩ ក យ៉ូហាន ៤:២១–២៦; ១៧:៣; កិច្ចការ ១៧:២២–២៥. ស.ប. ថ្វាយបង្គំ.
២០ ក គ. និង ស. ៥០:២៨.
ខ យ៉ូហាន ១:១៦; គ. និង ស. ៨៤:៣៦–៣៩.
គ យ៉ូហាន ១៧:៤–៥, ២២. ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
ឃ ស.ប. ព្រះគុណ.
២១ ក យ៉ូហាន ១:១–២; ១ ពេត្រុស ១:១៩–២០; ម៉ូសេ ៤:២.
ខ ស.ប. កូនច្បង.
២២ ក ១ ពេត្រុស ៥:១; គ. និង ស. ១៣៣:៥៧.
ខ ស.ប. សិរីល្អនៃសេឡេស្ទាល.
២៣ ក ស.ប. មនុស្ស, មនុស្សលោក — មនុស្សជាកូនវិញ្ញាណនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
២៤ ក ស.ប. សេចក្តីពិត.
ខ ស.ប. ដំរិះ.
២៥ ក គ. និង ស. ២០:៣៥.
ខ យ៉ូហាន ៨:៤៤; ២ នីហ្វៃ ២:១៨; ម៉ូសេ ៤:៤.
២៦ ក យ៉ូហាន ១៤:៦.
២៧ ក ស.ប. ល្អឥតខ្ចោះ.
២៨ ក ស.ប. ការគោរព, ដែលគោរព, គោរព.
ខ គ. និង ស. ៥០:២៤; ៨៤:៤៥. ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
គ យ៉ូហាន ១៧:៣; គ. និង ស. ៨៨:៤៩, ៦៧.
២៩ ក អ័ប្រា. ៣:១៨. ស.ប. ជីវិតមុនផែនដី; មនុស្ស, មនុស្សលោក.

[ខ]បញ្ញា ឬពន្លឺនៃសេចក្ដីពិត ក៏ពុំបានបង្កើត ឬធ្វើឡើង ឬអាចបង្កើត ឬធ្វើឡើង ឡើយ ។

៣០ គ្រប់សេចក្ដីពិតទាំងអស់គឺមានសេរីនៅក្នុងវិស័យដែលព្រះទ្រង់បានដាក់វាទុក ដើម្បី[ក]ឲ្យប្រព្រឹត្តដោយខ្លួនឯង ដូចជាគ្រប់បញ្ញាទាំង អស់ដែរ បើពុំនោះសោតទេ គ្មានការរស់នៅឡើយ ។

៣១ មើលចុះ នេះហើយជា[ក]សិទ្ធជ្រើសរើសនៃមនុស្ស និងនេះហើយជាការដាក់ទោសនៃមនុស្ស; ពីព្រោះអ្វីដែលមានមកពីដើមដំបូង នោះ [ខ]ត្រូវបានសំដែងយ៉ាងច្បាស់ដល់ពួកគេ ហើយពួកគេពុំបានទទួលពន្លឺទេ ។

៣២ ហើយមនុស្សគ្រប់រូបដែលវិញ្ញាណរបស់ខ្លួន ពុំបានទទួល[ក]ពន្លឺទេនោះ គឺនៅក្រោមការដាក់ទោសហើយ ។

៣៣ ត្បិតមនុស្សជា[ក]វិញ្ញាណ ។ [ខ]វត្ថុធាតុទាំងឡាយសុទ្ធតែមាននៅអស់កល្បជានិច្ច ហើយវិញ្ញាណ និងវត្ថុធាតុនៅជាប់គ្នា ដោយឥត បែកបាក់ឡើយ គឺបានទទួលនូវភាពពោរពេញនៃសេចក្ដីអំណរ;

៣៤ ហើយកាលណា[ក]បែកបាក់ពីគ្នា នោះមនុស្សពុំអាចទទួលនូវភាពពោរពេញ នៃ[ខ]សេចក្ដីអំណរបានឡើយ ។

៣៥ [ក]វត្ថុធាតុទាំងឡាយសុទ្ធតែជា[ខ]រោងឧបោសថនៃព្រះ មែនហើយ មនុស្សជារោងឧបោសថនៃព្រះ គឺជាព្រះវិហារទាំងឡាយ; ហើយ ព្រះវិហារណាក៏ដោយដែលខូច នោះព្រះទ្រង់នឹងបំផ្លាញព្រះវិហារនោះចោល ។

៣៦ [ក]សិរីល្អនៃព្រះ គឺជា[ខ]បញ្ញា ឬក៏ម្យ៉ាងទៀត ជា[គ]ពន្លឺ និងសេចក្ដីពិត ។

៣៧ ពន្លឺ និងសេចក្ដីពិតបោះបង់ចោល[ក]អាកំណាចនោះ ។

៣៨ កាលដើមដំបូង វិញ្ញាណនៃមនុស្សគ្រប់រូបសុទ្ធតែ[ក]ឥតមានទោស; ហើយព្រះ ដោយបាន[ខ]ប្រោសលោះមនុស្សពី[គ]ការធ្លាក់ នោះមនុស្សបានត្រឡប់ទៅក្នុងស្ថានភាព[ឃ]ទារកវិញ គឺឥតមានទោសនៅចំពោះព្រះ ។

៣៩ ហើយអាកំណាចនេះមក ហើយ[ក]យកពន្លឺ និងសេចក្ដីពិតដោយសារការមិនគោរពតាម ចេញពីកូនចៅមនុស្ស និងពីព្រោះតែ[ខ]សណ្ដាប់ធ្នាប់នៃពួកអយ្យកោរបស់ពួកគេ ។

៤០ ប៉ុន្តែយើងបានបញ្ជាដល់អ្នក ឲ្យ[ក]ចិញ្ចឹមកូនចៅរបស់ខ្លួននៅក្នុងពន្លឺ និងសេចក្ដីពិត ។

៤១ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា ហ្វ្រេឌើរិក ជី វិលលាម្សជាអ្នកបំរើរបស់យើងអើយ អ្នកនៅក្រោមការដាក់ទោសនេះរហូតមក;

៤២ អ្នកពុំបាន[ក]បង្រៀនកូនចៅរបស់ខ្លួន ពីពន្លឺ និងសេចក្ដីពិតតាមព្រះបញ្ញត្តិទាំងឡាយនោះឡើយ; ហើយអាកំណាចនោះវាមានអំ ណាចនៅលើអ្នកនៅឡើយ និងនេះហើយជាហេតុនៃសេចក្ដីវេទនារបស់អ្នក ។

៤៣ ហើយឥឡូវនេះ យើងប្រទានព្រះបញ្ញត្តិមួយដល់អ្នក — បើសិនជាអ្នកនឹងត្រូវបានរំដោះឲ្យរួច នោះអ្នកនឹងត្រូវតាំងគេហដ្ឋាន របស់ខ្លួន ឲ្យមាន[ក]របៀបរៀបរយ ត្បិតមានការណ៍ជាច្រើន ដែលពុំទាន់បានត្រឹមត្រូវនៅក្នុងគេហដ្ឋានរបស់អ្នកនៅឡើយទេ ។

៤៤ ប្រាកដមែន យើងប្រាប់ដល់ ស៊ីឌនី រិកដុន ជាអ្នកបំរើយើងថា នៅក្នុងរឿងខ្លះៗ នោះគាត់ពុំបានកាន់តាមព្រះបញ្ញត្តិ

២៩ ខ ស.ប. បញ្ញា, បញ្ញាទាំងឡាយ.
៣០ ក ២ នីហ្វៃ ២:១៣–២៧.
៣១ ក ស.ប. សិទ្ធិជ្រើសរើស.
ខ ចោទិ. ៣០:១១–១៤;
គ. និង ស. ៨៤:២៣–២៤.
៣២ ក ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ;
សេចក្ដីពិត.
៣៣ ក គ. និង ស. ៧៧:២;
អេប្រា. ៥:៧–៨.
ស.ប. មនុស្ស, មនុស្សលោក —
មនុស្សជាកូនវិញ្ញាណនៃ
ព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
ខ គ. និង ស. ១៣១:៧–៨;
១៣៨:១៧.
ស.ប. ដំណើររស់ឡើងវិញ.
៣៤ ក ២ នីហ្វៃ ៩:៨–១០.
ខ ស.ប. សេចក្ដីអំណរ.
៣៥ ក គ. និង ស. ១៣០:២២.
ខ ១ កូរិន. ៣:១៦–១៧.
៣៦ ក ស.ប. សិរីល្អ; ព្រះយេស៊ូវគ្រីស្ទ —
សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ.
ខ គ. និង ស. ១៣០:១៨–១៩;
អ័ប្រា. ៣:១៩.
ស.ប. បញ្ញា, បញ្ញាទាំងឡាយ.
គ គ. និង ស. ៨៨:៦–១៣.
៣៧ ក ម៉ូសេ ១:១២–១៦
ស.ប. អារក្ស.
៣៨ ក ស.ប. ភាពឥតទោស, ឥតទោស.
ខ ម៉ូសាយ ២៧:២៤–២៦;
ម៉ូសេ ៥:៩; ម. នៃ ស. ១:៣.
ស.ប. ប្រោសលោះ, បានប្រោសលោះ,
សេចក្ដីប្រោសលោះ.
គ ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
ឃ មរ៉ូណៃ ៨:៨, ១២, ២២;
គ. និង ស. ២៩:៤៦–៤៧.
ស.ប. សេចក្ដីសង្គ្រោះ —
សេចក្ដីសង្គ្រោះដល់កូនក្មេង.
៣៩ ក ម៉ាថាយ ១៣:១៨–១៩;
២ កូរិន. ៤:៣–៤;
អាលម៉ា ១២:៩–១១.
ខ អេសេ. ២០:១៨–១៩;
អាលម៉ា ៣:៨. ស.ប. សណ្ដាប់.
៤០ ក ស.ប. គ្រួសារ —
កាតព្វកិច្ចរបស់ឪពុកម្ដាយ.
៤២ ក ១ សាំយូ. ៣:១១–១៣;
គ. និង ស. ៦៨:២៥–៣១.
៤៣ ក ១ ធីម៉ូ. ៣:៤–៥.

ទាំងឡាយ អំពីកូនចៅគាត់ទេ; ហេតុដូច្នេះហើយ ទីមួយ
ចូរតាំងគេហដ្ឋានរបស់អ្នក ឲ្យមានរបៀបរៀបរយចុះ ។
៤៥ ប្រាកដមែន យើងប្រាប់ដល់ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ
ជាអ្នកបំរើរបស់យើង ឬម្យ៉ាងទៀតថា យើងនឹងហៅអ្នកថាជា
មិត្ត[ក] ត្បិតអ្នកជាមិត្ត របស់យើង ហើយអ្នករាល់គ្នាមានកេរ្ដិ៍មរតក
នៅជាមួយនិងយើងដែរ —
៤៦ យើងបានហៅអ្នកជាពួក[ក]អ្នកបំរើ ដោយយល់ដល់ពិភព
លោកប៉ុណ្ណោះ ហើយអ្នករាល់គ្នាសុទ្ធតែជាអ្នកបំរើដល់ពួកគេ
ដោយយល់ ដល់យើង —
៤៧ ហើយឥឡូវនេះ យើងប្រាប់ដល់យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជា
ប្រាកដថា — អ្នកពុំបានកាន់តាមព្រះបញ្ញត្តិទាំងឡាយទេ
ហើយត្រូវតែបាន [ក]បន្ទោសនៅចំពោះព្រះអម្ចាស់;
៤៨ [ក]ក្រុមគ្រួសាររបស់អ្នកត្រូវតែប្រែចិត្ត ហើយលះបង់
ចោលការណ៍ខ្លះៗ ហើយប្រុងស្ដាប់តាមពាក្យសំដីរបស់ខ្លួន
បើពុំនោះសោតទេ នឹងត្រូវដកចេញពីកន្លែងរបស់ពួកគេ ។
៤៩ អ្វីៗដែលយើងប្រាប់ដល់មនុស្សម្នាក់យ៉ាងណា នោះយើង
ប្រាប់ដល់មនុស្សទាំងអស់យ៉ាងនោះដែរ; ចូរ[ក]អធិស្ឋានជានិច្ច ក្រែង
លោ អាកំណាចនោះមានអំណាចមកលើអ្នក ហើយដកអ្នក
ចេញពីកន្លែងរបស់អ្នក ។
៥០ ព្រមទាំង នូវល ខេ វិតនី ជាប៊ីស្សពនៃសាសនាចក្រ
របស់យើង ក៏ត្រូវវាយផ្ចាលផងដែរ ហើយត្រូវរៀបចំគ្រួសារ
របស់ខ្លួនឲ្យមាន របៀបរៀបរយ ហើយត្រូវមើលឲ្យឃើញថា
ពួកគេមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង
ហើយត្រូវអធិស្ឋានជានិច្ច បើពុំនោះសោតទេ ពួកគេនឹងត្រូវ
ដកចេញពីកន្លែងរបស់ពួកគេ ។
៥១ ឥឡូវនេះ យើងប្រាប់អ្នក ជាមិត្តទាំងឡាយរបស់យើងថា
ចូរឲ្យស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង ចេញដំណើររបស់
គាត់ទៅ ហើយទៅជាបន្ទាន់ ហើយឲ្យប្រកាសប្រាប់ពីឆ្នាំ ដែល
ព្រះអម្ចាស់ទ្រង់[ក]សព្វព្រះហឫទ័យ និងពីដំណឹងល្អនៃសេចក្ដីសង្គ្រោះ
ដូចដែលយើង នឹងប្រទានពាក្យសំដីដល់គាត់; ហើយដោយ
ពាក្យអធិស្ឋាននៃសេចក្ដីជំនឿរបស់អ្នក តាមការយល់ព្រមតែ
មួយ នោះយើងនឹងលើក គាត់ឡើង ។
៥២ ហើយចូរឲ្យ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និង ហ្វ្រេឌើរិក ជី
វិលលាម្ស ជាពួកអ្នកបំរើរបស់យើង បន្ទាន់ផងចុះ ហើយអ្វីៗនឹង
ត្រូវបាន ប្រទានដល់ពួកគេ ស្របតាមពាក្យអធិស្ឋាននៃសេច
ក្ដីជំនឿ ហើយដរាបណាអ្នកកាន់តាមព្រះបន្ទូលទាំងឡាយ
របស់យើង នោះអ្នកនឹង មិនត្រូវធ្វើឲ្យខ្មាស់ នៅលោកិយនេះ
ឬនៅបរលោកឡើយ ។
៥៣ ហើយយើងប្រាប់អ្នកជាប្រាកដថា គឺជាព្រះហឫទ័យ
របស់យើង ដែលអ្នកត្រូវប្រញាប់[ក]បកប្រែព្រះគម្ពីររបស់យើង
និងដើម្បីឲ្យ[ខ]បាន [គ]ការចេះដឹងអំពីប្រវត្តិសាស្ត្រ និងអំពីប្រទេសទាំង
ឡាយ និងអំពីនគរទាំងឡាយ និងអំពីក្រិត្យវិន័យទាំងឡាយនៃ
ព្រះ និងមនុស្ស និងគ្រប់ ការណ៍ទាំងអស់នេះ សំរាប់សេច
ក្ដីសង្គ្រោះដល់ស៊ីយ៉ូន ។ អាម៉ែន ៕

## កណ្ឌទី ៩៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៨៣៣ (*History of the Church*, ១:៣៤៦–៣៤៧)* ។ *ហៃរុម ស្ម៊ីធ, រេយណូល្ស ខាហ៊ូន, និង យ៉ារេឌ ខារតើរ ត្រូវបានតែងតាំង ឲ្យធ្វើជាគណៈកម្មាធិការខាងការស្ថាបនាអាគារនៃសាសនាចក្រ ។*

*១–៩, ព្រះអម្ចាស់ទ្រង់ប្រទានព្រះបញ្ញត្តិមួយ ដែលទាក់ទងទៅនិងសំណង់សាលាមួយ សំរាប់កិច្ចការនៃគណៈប្រធាន; ១០–១២, រោង បោះពុម្ពត្រូវសង់ឡើង; ១៣–១៧, កេរ្ដិ៍មរតកខ្លះៗត្រូវបានចែក ។*

៤៥ *ក* គ. និង ស. ៨៤:៦៣; ៨៨:៦២.
៤៦ *ក* លេវី. ២៥:៥៥;
១ នីហ្វៃ ២១:៣–៨.
ស.ប. ការបំរើ.
៤៧ *ក* គ. និង ស. ៩៥:១–២.
ស.ប. វាយផ្ចាល, ការវាយផ្ចាល.
៤៨ *ក* ស.ប. គ្រួសារ — កាតព្វកិច្ចរបស់កូន.
៤៩ *ក* ៣ នីហ្វៃ ១៨:១៥–២១.
៥០ *ក* គ. និង ស. ៦៤:៤០.
៥១ *ក* លូកា ៤:១៩.
៥៣ *ក* ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.).
*ខ* គ. និង ស. ៨៨:៧៦–៨០, ១១៨.
*គ* ស.ប. ដំរិះ.

ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់អ្នក ជាមិត្ត*ក*ទាំងឡាយរបស់យើងថា យើងប្រទានព្រះបញ្ញត្តិមួយដល់អ្នក ថាអ្នករាល់គ្នានឹងត្រូវ ចាប់ផ្ដើមគ្រោងការ និងរៀបចំសំណង់ និងគ្រឹះនៃទីក្រុងក្នុងស្ដេក*ខ*របស់ស៊ីយ៉ូន នៅទីនេះ នៅក្នុងដែនដីខឺតឡង់ ចាប់ផ្ដើមនឹងដំណាក់ របស់យើង ។

២ ហើយមើលចុះ គឺត្រូវធ្វើតាមគំរូ*ក* ដែលយើងបានប្រទានដល់អ្នក ។

៣ ហើយចូរថ្វាយកន្លែងដីទីមួយនៅទិសខាងត្បូង ទុកជាអាគារនៃសាលាសំរាប់គណៈប្រធាន សំរាប់កិច្ចការនៃគណៈប្រធាន ក្នុងការ ទទួលវិវរណៈទាំងឡាយ; និងសំរាប់កិច្ចការខាងការងារបំរើនៃគណៈប្រធាន នៅគ្រប់ទាំងអស់ ដែលទាក់ទងទៅនិងសាសនាចក្រ និងនគរ ។

៤ យើងប្រាប់អ្នកជាប្រាកដថា គឺត្រូវសង់ទទឹង ១៧ ម៉ែត្រ និងបណ្ដោយ ២០ ម៉ែត្រ នៅទីលានខាងក្នុង ។

៥ ហើយត្រូវមានទីលានខាងក្រោម និងទីលានខាងលើ តាមគំរូដែលនឹងបានប្រទានដល់អ្នក ពីពេលនេះតទៅ ។

៦ ហើយគឺត្រូវធ្វើពិធីឆ្លងថ្វាយដល់ព្រះអម្ចាស់ ចាប់តាំងពីគ្រឹះ តាមរបៀបនៃបព្វជិតភាព តាមគំរូដែលនឹងបានប្រទានដល់អ្នក ពីពេលនេះតទៅ ។

៧ ហើយនឹងត្រូវបានធ្វើពិធីឆ្លងថ្វាយដល់ព្រះអម្ចាស់ ទុកសំរាប់កិច្ចការនៃគណៈប្រធាន ។

៨ ហើយអ្នករាល់គ្នាមិនត្រូវឲ្យរបស់មិនស្អាត*ក*ចូលក្នុងទីនោះឡើយ ហើយសិរីល្អរបស់យើងនឹងនៅទីនោះ ហើយវត្តមានរបស់យើង នឹងនៅទីនោះ ។

៩ ប៉ុន្តែបើសិនជាមានរបស់មិនស្អាត*ក*ណាមួយចូលក្នុងទីនោះ នោះសិរីល្អរបស់យើងនឹងមិននៅទីនោះទេ ហើយវត្តមានរបស់យើងក៏ នឹងមិនចូលមកទីនោះដែរ ។

១០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា កន្លែងដីទីពីរនៅទិសខាងត្បូង នឹងត្រូវធ្វើពិធីឆ្លងថ្វាយដល់យើង ទុកជាអាគារ នៃគេហដ្ឋានរបស់យើង ទុកសំរាប់កិច្ចការខាងការបោះពុម្ពនៃការបកប្រែ*ក*នូវព្រះគម្ពីរ*ខ*របស់យើង និងគ្រប់អ្វីៗទាំងអស់ ដែលយើង នឹងបញ្ជាដល់អ្នក ។

១១ ហើយទទឹងត្រូវជា ១៧ ម៉ែត្រ និងបណ្ដោយត្រូវជា ២០ ម៉ែត្រ នៅទីលានខាងក្នុង; ហើយត្រូវមានទីលានខាងក្រោម និងទីលានខាងលើ ។

១២ ហើយគេហដ្ឋាននេះនឹងត្រូវថ្វាយដល់ព្រះអម្ចាស់ទាំងមូល ចាប់តាំងពីគ្រឹះផ្ទះ ទុកសំរាប់កិច្ចការនៃការបោះពុម្ព ដោយនូវគ្រប់ការណ៍ទាំងអស់ ដែលយើងនឹងបញ្ជាដល់អ្នក ដើម្បីឲ្យបានបរិសុទ្ធដោយឥតខ្ចោះឡើយ ស្របតាមគំរូនៅគ្រប់ការណ៍ទាំងអស់ ដូចដែល នឹងបានប្រទានដល់អ្នក ។

១៣ ហើយនៅកន្លែងដីទីបី នោះហៃរុម ស្ម៊ីធ ជាអ្នកបំរើរបស់យើង នឹងបានទទួលកេរ្ដិ៍មរតករបស់គាត់ ។

១៤ ហើយនៅកន្លែងដីទីមួយ និងទីពីរនៅទិសខាងជើង នោះរេយណុល្ឌ ខាហ៊ូន និង យ៉ារេឌ ខារតើរ ជាពួកអ្នកបំរើរបស់យើង នឹងបានទទួលកេរ្ដិ៍មរតករបស់ពួកគេ —

១៥ ប្រយោជន៍ឲ្យពួកគេអាចធ្វើកិច្ចការ ដែលយើងបានតាំងដល់ពួកគេ គឺធ្វើជាគណៈកម្មាធិការ ដើម្បីកសាងគេហដ្ឋានទាំងឡាយ របស់យើង ស្របតាមព្រះបញ្ញត្តិ ដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានប្រទានដល់អ្នក —

១៦ គេហដ្ឋានទាំងពីរនេះ មិនត្រូវកសាងទេ ទាល់តែយើងប្រទានដល់អ្នក នូវព្រះបញ្ញត្តិមួយ អំពីគេហដ្ឋាននោះសិន ។

១៧ ហើយឥឡូវនេះ យើងមិនប្រទានអ្វីទៅដល់អ្នកទៀតឡើយ នៅពេលនេះ ។ អាម៉ែន ៕

## កណ្ឌទី ៩៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៨៣៣ (*History of the Church*, ១:៣៥០–៣៥២) ។ វិវរណៈនេះគឺជាការបន្តពីការដឹកនាំពីព្រះ ដើម្បីកសាងគេហដ្ឋានទាំងឡាយ សំរាប់ថ្វាយបង្គំ និងការបង្គាប់ ជាពិសេស គឺដំណាក់នៃព្រះអម្ចាស់ (សូមមើល កណ្ឌទី ៨៨:១១៩–១៣៦ និងកណ្ឌទី ៩៤) ។*

៩៤ ១*ក* គ. និង ស. ៩៣:៤៥.
*ខ* ស.ប. ចំរឹង, ស្ដេក.
២ *ក* គ. និង ស. ៥២:១៤–១៥.
៣ *ក* គ. និង ស. ១០៧:៩, ២២.
៨ *ក* លូកា ១៩:៤៥–៤៦;
គ. និង ស. ១០៩:១៦–២០.
*ខ* ១ពង្សាវ. ៨:១០–១១.
ស.ប. សិរីល្អ.
៩ *ក* គ. និង ស. ៩៧:១៥–១៧.
១០ *ក* គ. និង ស. ១០៤:៥៨–៥៩.
*ខ* ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.).

*១–៦, ពួកបរិសុទ្ធត្រូវបានវាយផ្ចាល ព្រោះតែការខកខានមិនបានកសាងដំណាក់នៃព្រះអម្ចាស់; ៧–១០, ព្រះអម្ចាស់ទ្រង់សព្វព្រះ ហឫទ័យចង់ប្រើប្រាស់គេហដ្ឋានរបស់ទ្រង់ ដើម្បីប្រទានអំណោយទានដល់ប្រជារាស្ត្ររបស់ទ្រង់ នូវអំណាចមកពីស្ថានលើ; ១១–១៧, គេហដ្ឋាននោះត្រូវតាំងជាកន្លែងនៃការថ្វាយបង្គំ ហើយទុកសំរាប់ជាសាលានៃពួកសាវក ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះដល់អ្នកដែល
យើងស្រឡាញ់ និងដល់អ្នកណាដែលយើងស្រឡាញ់
នោះយើង[ក]វាយ ផ្ចាល ដើម្បីឲ្យអំពើបាបទាំងឡាយរបស់ពួកគេ
[ខ]អាចបានអត់ទោស ត្បិតដោយសារការវាយផ្ចាលនេះហើយ
ដែលយើងរៀបចំផ្លូវឡើង សំរាប់[គ]ការរំដោះដល់ពួកគេ
នៅគ្រប់ការណ៍ទាំងអស់ ឲ្យរួចពី[ឃ]ការល្បួង ហើយយើង
បានស្រឡាញ់អ្នក —
២ ហេតុដូច្នោះហើយ អ្នករាល់គ្នាត្រូវតែបានវាយផ្ចាល
ហើយបន្ទោសនៅចំពោះព្រះភ័ក្ត្ររបស់យើង;
៣ ត្បិតអ្នករាល់គ្នាបានធ្វើបាបទាស់និងយើង នូវអំពើ
បាបដ៏ធ្ងន់ណាស់ ពីព្រោះអ្នករាល់គ្នាពុំបានគិតពិចារណាពីព្រះ
បញ្ញត្តិដ៏ធំគ្រប់ជំពូក ដែលយើងបានប្រទានដល់អ្នក អំពីការ
កសាង[ក]គេហដ្ឋានរបស់យើងឡើយ;
៤ ត្បិតការរៀបចំដែលយើងគ្រោង ដើម្បីត្រៀមពួកសាវក
របស់យើង [ក]ឲ្យកាត់មែកចំការទំពាំងបាយជូររបស់យើង នៅលើក
ចុងក្រោយ បង្អស់ ប្រយោជន៍ឲ្យយើងអាចសំរេចកិច្ចការ
[ខ]ប្លែកៗរបស់យើងបាន គឺប្រយោជន៍ឲ្យយើងអាច[គ]ចាក់ព្រះ
វិញ្ញាណរបស់យើង ទៅលើ គ្រប់ទាំងមនុស្ស —
៥ ប៉ុន្តែមើលចុះ យើងប្រាប់អ្នកជាប្រាកដថា មានមនុស្ស
ជាច្រើនដែលត្រូវបានតែងតាំងឡើងនៅក្នុងចំណោមអ្នក ដែល
យើងបានហៅ ប៉ុន្តែមានពួកគេតែបន្តិចទេ ដែល[ក]ត្រូវបាន
រើសឡើង ។
៦ ពួកអ្នកណាដែលពុំបានរើសឡើង នោះបានធ្វើបាបដ៏ធ្ងន់ណាស់
ពីព្រោះពួកគេកំពុងតែដើរ[ក]ក្នុងសេចក្ដីងងឹត នៅពេលថ្ងៃត្រង់ ។
៧ ហើយពីហេតុនេះ ទើបយើងបានប្រទានដល់អ្នកនូវព្រះបញ្ញត្តិ
មួយថា អ្នកគប្បីប្រកាសឲ្យមាន[ក]ជំនុំមុតមាំរបស់អ្នក ប្រយោជន៍ឲ្យ
ការ [ខ]តមអាហារទាំងឡាយរបស់អ្នក និងការទួញសោករបស់អ្នក
អាចបានឮឡើងទៅដល់ព្រះកាណ៌របស់ព្រះអម្ចាស់[គ]នៃសាបោត
ដែល តាមការបកស្រាយថា ព្រះ[ឃ]ដ៏បង្កបង្កើតនៃថ្ងៃទីមួយ
គឺជាដើម ហើយជាចុង ។
៨ មែនហើយ យើងប្រាប់អ្នកជាប្រាកដថា យើងបានប្រទាន
ដល់អ្នកនូវព្រះបញ្ញត្តិមួយថា អ្នកគប្បីកសាងគេហដ្ឋានមួយ
គឺនៅក្នុង គេហដ្ឋាននោះហើយ ដែលយើងគ្រោងនឹង[ក]ប្រទាន
អំណោយទានដល់អស់អ្នកណា ដែលយើងបានរើស ដោយ
ព្រះចេស្ដាពីស្ថានលើ;
៩ ត្បិតនេះហើយជា[ក]សេចក្ដីសន្យាពីព្រះវរបិតាដល់អ្នក; ហេតុ
ដូច្នេះហើយ យើងបញ្ជាឲ្យអ្នកនៅ ដូចជាពួកសាវករបស់យើង
នៅ ក្រុងយេរូសាឡិមដែរ ។
១០ ទោះជាយ៉ាងណាក៏ដោយ ក៏គង់តែពួកអ្នកបំរើ
របស់យើងបានធ្វើបាបដ៏ធ្ងន់ណាស់; ហើយ[ក]ការទាស់ទែងគ្នា
បានកើតឡើង នៅក្នុង[ខ]សាលានៃពួកព្យាការី; ដែលជាការ
ដ៏ធ្ងន់ធ្ងរដល់យើងណាស់ ព្រះអម្ចាស់របស់អ្នកបានមានព្រះ
បន្ទូលថាដូច្នោះហើយ; ហេតុដូច្នេះហើយ យើងបានចាត់
ពួកគេឲ្យចេញទៅ ដើម្បីបានត្រូវវាយផ្ចាល ។
១១ យើងប្រាប់អ្នកជាប្រាកដថា គឺជាព្រះហឫទ័យរបស់យើង

**៩៥** ១*ក* ចោទិ. ១១:១–៨;
សុភា. ១៣:១៨;
ហេព្រើរ ១២:៥–១១;
ហេលេ. ១៥:៣;
គ. និង ស. ១០១:៤–៥; ១០៥:៦.
ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. អត់ទោស, អភ័យទោស.
*គ* ១ កូរិន. ១០:១៣.
*ឃ* ស.ប. ល្បួង, សេចក្ដីល្បួង.
៣ *ក* ហាកាយ ១:៧–១១;
គ. និង ស. ៨៨:១១៩.
ស.ប. ព្រះវិហារបរិសុទ្ធ,
ដំណាក់នៃព្រះអម្ចាស់.
៤ *ក* យ៉ាកុប ៥:៦១–៧៥;
គ. និង ស. ២៤:១៩; ៣៣:៣–៤.
ស.ប. ចំការទំពាំងបាយជូរនៃ
ព្រះអម្ចាស់.
*ខ* អេសាយ ២៨:២១;
គ. និង ស. ១០១:៩៥.
*គ* សុភា. ១:២៣; យ៉ូអែល ២:២៨;
គ. និង ស. ១៩:៣៨.
ស.ប. អំណោយទានទាំងឡាយនៃព្រះ
វិញ្ញាណ; ព្រះវិញ្ញាណបរិសុទ្ធ.
៥ *ក* ម៉ាថាយ ២០:១៦;
គ. និង ស. ១០៥:៣៥–៣៧;
១២១:៣៤–៤០.
ស.ប. ការរើសតាំង.
៦ *ក* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
៧ *ក* គ. និង ស. ៨៨:៧០, ៧៤–៨២,
១១៧–១២០.
*ខ* ស.ប. តម, តំណម.
*គ* ស.ប. ព្រះយេហូវ៉ា.
*ឃ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
៨ *ក* គ. និង ស. ៣៨:៣២; ៣៩:១៥;
៤៣:១៦; ១១០:៩–១០.
ស.ប. អំណោយទានពិសិដ្ឋ.
៩ *ក* លូកា ២៤:៤៩.
១០ *ក* ស.ប. ការទាស់ទែង.
*ខ* ស.ប. សាលានៃពួកព្យាការី.

ដែលអ្នកគប្បីកសាងគេហដ្ឋានមួយ ។ បើសិនជាអ្នកកាន់តាមព្រះបញ្ញត្តិ ទាំងឡាយរបស់យើង នោះអ្នកនឹងមានអំណាច ដើម្បីកសាងគេហដ្ឋាននោះ ។

១២ បើសិនជាអ្នកមិន[ក]កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងទេ នោះ[ខ]សេចក្ដីស្រឡាញ់នៃព្រះវរបិតា នឹងមិននៅជាមួយអ្នកឡើយ ហេតុដូច្នេះហើយ អ្នកនឹងត្រូវដើរក្នុងសេចក្ដីងងឹត ។

១៣ ឥឡូវនេះហើយគឺជាប្រាជ្ញា និងព្រះហឫទ័យនៃព្រះអម្ចាស់ — ចូរកសាងគេហដ្ឋានមួយចុះ ពុំមែនតាមរបៀបនៃពិភពលោកទេ ត្បិតយើងពុំបានប្រទានដល់អ្នកថា អ្នករាល់គ្នានឹងត្រូវរស់នៅតាមរបៀបនៃពិភពលោកឡើយ;

១៤ ហេតុដូច្នេះហើយ ចូរកសាងគេហដ្ឋាននោះតាមរបៀបដែលយើងនឹងបង្ហាញដល់អ្នកទាំងបីនាក់ចុះ ដែលអ្នករាល់គ្នានឹងតាំង ហើយតែងតាំងចំពោះអំណាចនេះ ។

១៥ ហើយទំហំនៃដំណាក់នោះគឺ ទទឹង ១៧ ម៉ែត្រ ហើយចូរឲ្យបណ្ដោយមាន ២០ ម៉ែត្រ នៅទីលានខាងក្នុងចុះ ។

១៦ ហើយចូរឲ្យផ្នែកខាងក្រោមទីលានខាងក្នុងបានថ្វាយដល់យើង សំរាប់ជាដង្វាយសាក្រាម៉ង់ ហើយសំរាប់ការផ្សាយរបស់អ្នក និងការតមអាហាររបស់អ្នក និងការអធិស្ឋានរបស់អ្នក និង[ក]ការថ្វាយនូវសេចក្ដីប៉ងប្រាថ្នាដ៏ខ្ពង់ខ្ពស់បំផុតរបស់អ្នកឡើងមកដល់យើង គឺព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថាដូច្នោះហើយ ។

១៧ ហើយចូរឲ្យផ្នែកខាងលើទីលានខាងក្នុងបានថ្វាយដល់យើងសំរាប់ជាសាលានៃពួកសាវករបស់យើងចុះ គឺព្រះរាជបុត្រា[ក]អាម៉ាន ទ្រង់មានព្រះបន្ទូលថាដូច្នោះហើយ; ឬម៉្យាងទៀតថា គឺអាលផា; ឬម៉្យាងទៀតថា គឺអូមេកា; គឺជាព្រះយេស៊ូវគ្រីស្ទជា[ខ]ព្រះអម្ចាស់ របស់អ្នក ។ អាម៉ែន ៕

## កណ្ឌទី ៩៦

*វិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី ដោយបង្ហាញនូវរបៀបរៀបចំទីក្រុង ឬស្ដេកនៃស៊ីយ៉ូន នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៨៣៣ ទុកជាគំរូដល់ពួកបរិសុទ្ធនៅក្រុងខឺតឡង់ (*History of the Church, *១:៣៥២–៣៥៣) ។ ជាពេលវេលានៅឯសន្និសីទនៃពួកសង្ឃជាន់ខ្ពស់ ហើយកម្មវត្ថុដ៏សំខាន់នៃការពិចារណានោះ គឺអំពីការចែកដីធ្លីនានា ដែលស្គាល់ថាជា ស្រែអ្នកប្រេញ ដែលជាកម្មសិទ្ធិរបស់សាសនាចក្រ នៅក្បែរក្រុងខឺតឡង់ ។ ចាប់តាំងពីសន្និសីទមក នោះពុំអាច យល់ព្រមគ្នាថានរណាត្រូវថែរក្សាស្រែនោះឡើយ គ្រប់មនុស្សទាំងអស់បានយល់ព្រមគ្នាថាត្រូវសូមដល់ព្រះអម្ចាស់ អំពីរឿងនេះ ។*

*១, ស្ដេកខឺតឡង់នៃក្រុងស៊ីយ៉ូនត្រូវធ្វើឲ្យបានមាំមួន; ២–៥, ប៊ីស្សពត្រូវចែកកេរ្តិ៍មរតកដល់ពួកបរិសុទ្ធ; ៦–៩, យ៉ូហាន ចនសុន ត្រូវធ្វើជា សមាជិកនៃសហសមាគម ។*

មើលចុះ យើងប្រាប់អ្នកថា នេះហើយជាប្រាជ្ញា ដែលអ្នករាល់គ្នាអាចចេះប្រព្រឹត្តអំពីរឿងនេះ ត្បិតជាការចាំបាច់ដល់យើងថា [ក]ស្ដេកនេះ ដែលយើងបានតាំងឡើង ត្បិតកម្លាំងនៃស៊ីយ៉ូនត្រូវតែធ្វើឲ្យបានមាំមួន ។

២ ហេតុដូច្នេះហើយ ចូរឲ្យ នូវល ខេ វិតនី ជាអ្នកបំរើរបស់យើង កាន់កាប់កន្លែងដែលបានពោលដល់ នៅក្នុងចំណោមអ្នករាល់គ្នា ដែលយើងគ្រោងនឹងកសាងដំណាក់ដ៏បរិសុទ្ធរបស់យើងនៅលើនោះ ។

៣ ហើយជាថ្មីទៀត ចូរចែកទីនោះចេញជាទីដីនានាស្របតាមប្រាជ្ញា សំរាប់ផលប្រយោជន៍ដល់អស់អ្នកណា ដែលស្វែងរក កេរ្តិ៍មរតកទាំងឡាយ ដូចជានឹងបានសំរេចនៅក្នុងការប្រឹក្សា នៅក្នុងចំណោមអ្នករាល់គ្នាចុះ ។

៤ ហេតុដូច្នេះហើយ ចូរស្ដាប់ ដើម្បីឲ្យអ្នករាល់គ្នាឃើញថារឿងនេះ ហើយនិងចំណែកនោះ ដែលជាការចាំបាច់ដើម្បីផ្ដល់ប្រយោជន៍ ដល់[ក]សមាគមរបស់យើង ចំពោះគោលបំណងនៃការនាំព្រះបន្ទូលរបស់យើងទៅដល់កូនចៅមនុស្ស ។

១២ *ក* យ៉ូហាន ១៥:១០.
*ខ* ១ យ៉ូហាន ២:១០, ១៥.
១៦ *ក* គ. និង ស. ៥៩:៩–១៤.
១៧ *ក* គ. និង ស. ៧៨:២០.
*ខ* ស.ប. ព្រះអម្ចាស់.
៩៦ ១*ក* អេសាយ ៣៣:២០; ៥៤:២.
ស.ប. ចំរីង, ស្ដេក.
៤ *ក* គ. និង ស. ៧៨:៣–៤.
ស.ប. សហសមាគម.

៥ ត្បិតមើលចុះ យើងប្រាប់អ្នកជាប្រាកដថា នេះហើយជាការចាំបាច់បំផុតដល់យើង គឺថាព្រះបន្ទូលរបស់យើងនឹងត្រូវបានចេញទៅ ដល់កូនចៅមនុស្ស ចំពោះគោលបំណងនៃការបន្ទន់ចិត្តនៃកូនចៅមនុស្ស សំរាប់ការល្អ របស់អ្នក ។ គឺដូច្នោះមែន ។ អាម៉ែន ។

៦ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា គឺជាប្រាជ្ញា ហើយជាការចាំបាច់បំផុតដល់យើងថា យ៉ូហាន ចនសុន ជាអ្នកបំរើរបស់ យើង ដែលយើងបានទទួលដង្វាយរបស់គាត់ ហើយដែលយើងបានឮការអធិស្ឋានរបស់គាត់ ជាអ្នកនោះហើយដែលយើងប្រទាននូវ សេចក្ដីសន្យានៃជីវិតដ៏អស់កល្បជានិច្ច ដរាបណាគាត់កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ចាប់ពីពេលនេះតទៅ —

៧ ត្បិតគាត់ជាពូជពង្សនៃយ៉ូសែប ហើយជាអ្នកទទួលនូវព្រះពរទាំងឡាយនៃសេចក្ដីសន្យា ដែលបានធ្វើដល់ពួកអយ្យកោរបស់គាត់ —

៨ យើងប្រាប់អ្នកជាប្រាកដថា ជាការចាំបាច់បំផុតដល់យើងដែលគាត់ត្រូវក្លាយជាសមាជិកនៃសមាគម ប្រយោជន៍ឲ្យគាត់អាចជួយ ក្នុងការនាំព្រះបន្ទូលរបស់យើងទៅដល់កូនចៅមនុស្ស ។

៩ ហេតុដូច្នេះហើយ អ្នករាល់គ្នានឹងត្រូវតែងតាំងគាត់ ចំពោះព្រះពរនេះចុះ ហើយគាត់ត្រូវព្យាយាមស្វែងរក ដើម្បីដកបំណុលដែលមានមកលើគេហដ្ឋាន ដែលបានពោលដល់នៅក្នុងចំណោមអ្នករាល់គ្នា ប្រយោជន៍ឲ្យគាត់អាចរស់នៅទីនោះបាន ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ៩៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២ ខែសីហា ឆ្នាំ១៨៣៣ (*History of the Church, *១:៤០០–៤០២)* ។ *ជាពិសេស វិវរណៈនេះទាក់ទងតែនិងកិច្ចការរបស់ពួកបរិសុទ្ធនៅស៊ីយ៉ូន ឃុំចាកសុន រដ្ឋមិសសួរី ក្នុងការឆ្លើយចំពោះសំណូមពររបស់ព្យាការីចង់បានពត៌មានពីព្រះអម្ចាស់ ។ នៅពេលនេះ ពួកសមាជិកនៃ សាសនាចក្រនៅរដ្ឋមិសសួរី កំពុងតែនៅក្រោមការបៀតបៀនដ៏ធ្ងន់ធ្ងរ ហើយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៨៣៣ ត្រូវបានបង្ខំឲ្យ ចុះឈ្មោះយល់ព្រមចេញពីឃុំចាកសុន ។*

*១–២, ពួកបរិសុទ្ធជាច្រើននៅក្រុងស៊ីយ៉ូន (ឃុំចាកសុន រដ្ឋមិសសួរី) ត្រូវបានពរចំពោះការស្មោះត្រង់របស់ពួកគេ; ៣–៥, ប៉ាលី ភី ប្រាត្ត ត្រូវបានសរសើរចំពោះកិច្ចការរបស់គាត់នៅក្នុងសាលានៅក្រុងស៊ីយ៉ូន; ៦–៩, អស់អ្នកណាដែលគោរពតាមសេចក្ដីសញ្ញារបស់ខ្លួន នោះត្រូវបានទទួលដោយព្រះអម្ចាស់; ១០–១៧, ដំណាក់មួយត្រូវបានកសាងឡើងនៅស៊ីយ៉ូន ដើម្បីឲ្យអ្នកដែលមានចិត្តបរិសុទ្ធ អាចបានឃើញព្រះនៅទីនោះ; ១៨–២១, ស៊ីយ៉ូនគឺជាអ្នកដែលមានចិត្តបរិសុទ្ធ; ២២–២៨, ស៊ីយ៉ូននឹងបានរួចផុតពីពាក់របស់ ព្រះអម្ចាស់ បើសិនជានាងមានចិត្តស្មោះត្រង់ ។*

មិត្តទាំងឡាយរបស់យើងអើយ យើងប្រាប់អ្នកជាប្រាកដថា យើងមានព្រះបន្ទូលដល់អ្នកដោយសម្លេងរបស់យើង គឺជាសម្លេងនៃព្រះ វិញ្ញាណរបស់យើង ប្រយោជន៍ឲ្យយើងអាចបង្ហាញដល់អ្នក នូវព្រះហឫទ័យរបស់យើង អំពីបងប្អូនក្នុងសាសនារបស់អ្នក នៅក្នុង ដែនដីស៊ីយ៉ូន គឺពួកគេជាច្រើនបានបន្ទាបខ្លួនយ៉ាងពិត ហើយកំពុងព្យាយាមស្វែងរក ដើម្បីបានប្រាជ្ញា និងដើម្បីរកសេចក្ដីពិត ។

២ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា អស់អ្នកនោះមានពរហើយ ត្បិតពួកគេនឹងបានមែន; ត្បិតយើងជាព្រះអម្ចាស់បង្ហាញសេច ក្ដីមេត្តាករុណាដល់អស់ទាំងពួកស្លូតបូត និងមកលើអស់អ្នកណាដែលយើងអាចរាប់ថាសុចរិត ក្នុងកាលយើងនឹងនាំពួកគេមកជំនុំជំរះ ។

៣ មើលចុះ យើងប្រាប់អ្នកអំពីសាលានៅស៊ីយ៉ូនថា យើងជាព្រះអម្ចាស់ សព្វព្រះហឫទ័យជាខ្លាំង ដែលមានសាលានៅស៊ីយ៉ូន ហើយសព្វព្រះហឫទ័យនិង ប៉ាលី ភី ប្រាត្ត ជាអ្នកបំរើរបស់យើងជាខ្លាំង ត្បិតគាត់នៅជាប់និងយើង ។

៤ ហើយដរាបណាគាត់នៅជាប់និងយើងរហូត នោះគាត់នឹងត្រូវត្រួតត្រាលើសាលាតទៅទៀត នៅក្នុងដែនដី

៧ *ក* ស.ប. យ៉ូសែប, កូនប្រុសរបស់យ៉ាកុប.

៩៧ ១*ក* ស.ប. ស៊ីយ៉ូន.
២ *ក* ម៉ាថាយ ៥:៥; ម៉ូសាយ ៣:១៩.

៣ *ក* ស.ប. សាលានៃពួកព្យាការី.
*ខ* ស.ប. ប្រាត្ត, ប៉ាលី ប៉ាកើរ.

ស៊ីយ៉ូន រហូតដល់យើង នឹងប្រទានដល់គាត់ នូវព្រះបញ្ញត្តិផ្សេងទៀត ។

៥ ហើយយើងនឹងប្រទានពរដល់គាត់ ដោយព្រះពរដ៏ច្រើនអនេក ក្នុងការពន្យល់ប្រាប់ពីអស់ទាំងបទគម្ពីរ និងការអាថ៌កំបាំងទាំងឡាយ ដើម្បីការស្អាងដល់សាលា និងដល់សាសនាចក្រនៅស៊ីយ៉ូន ។

៦ ហើយចំពោះពួកអ្នកដែលនៅសល់ទាំងប៉ុន្មាននៅក្នុងសាលានោះយើងជាព្រះអម្ចាស់ សព្វព្រះហឫទ័យនឹងបង្ហាញសេចក្ដីមេត្តា ករុណា; ទោះជាយ៉ាងណាក៏ដោយ គង់តែមានពួកអ្នកដែលត្រូវការ[ក]វាយផ្ចាល ហើយកិច្ចការរបស់ពួកគេនឹងត្រូវបានធ្វើឲ្យស្គាល់ ។

៧ [ក]ពូថៅបានដាក់នៅឫសដើមឈើហើយ; ហើយអស់ទាំងដើមណាដែលកើត[ខ]ផ្លែមិនល្អ នោះត្រូវកាប់ហើយបោះចោលទៅក្នុងភ្លើង ។ យើងជាព្រះអម្ចាស់ បានមានព្រះបន្ទូលហើយ ។

៨ យើងប្រាប់អ្នកជាប្រាកដថា អស់ទាំងមនុស្សនៅក្នុងចំណោមពួកគេណាដែលដឹងថាខ្លួនមាន[ក]ចិត្ត[ខ]ទៀងត្រង់ ហើយមានចិត្តសង្រេង ហើយវិញ្ញាណរបស់ខ្លួនទន់ទាប ហើយយល់[គ]ព្រមគោរពតាមសេចក្ដីសញ្ញារបស់ខ្លួន ដោយការ[ឃ]បូជា — មែនហើយ គឺគ្រប់ការបូជា[ង] ដែលយើងជាព្រះអម្ចាស់នឹងបញ្ជា — នោះពួកគេត្រូវបានទទួលដោយយើងហើយ ។

៩ ត្បិតយើងជាព្រះអម្ចាស់នឹងបណ្ដាលឲ្យពួកគេបង្កើតឡើងនូវគ្រប់ដើមឈើដែលមានផ្លែណា ដែលបានដាំនៅលើដីល្អ គឺនៅក្បែរ ស្ទឹងសុទ្ធសាធ ដើម្បីឲ្យបង្កើតបានផ្លែវិសេសជាច្រើន ។

១០ យើងប្រាប់អ្នកជាប្រាកដថា ជាព្រះហឫទ័យរបស់យើងដែល[ក]ដំណាក់មួយត្រូវបានកសាងឡើងដល់យើង នៅដែនដីស៊ីយ៉ូនតាម[ខ]គំរូ ដែលយើងបានប្រទានដល់អ្នក ។

១១ មែនហើយ ចូរកសាងដំណាក់នោះយ៉ាងឆាប់ដោយដង្វាយ១ភាគ១០ ពីប្រជារាស្ត្ររបស់យើងចុះ ។

១២ មើលចុះ នេះជា[ក]ដង្វាយ១ភាគ១០ និងការបូជាដែលយើងដ៏ជាព្រះអម្ចាស់ តម្រូវពីដៃរបស់ពួកគេ ប្រយោជន៍ឲ្យអាចមាន [ខ]ដំណាក់មួយបានកសាងឡើងដល់យើង សំរាប់សេចក្ដីសង្គ្រោះនៃស៊ីយ៉ូន ។

១៣ សំរាប់ជាកន្លែងនៃ[ក]សេចក្ដីអំណរគុណ ចំពោះពួកបរិសុទ្ធទាំងអស់ និងសំរាប់ជាកន្លែងនៃការបង្ហាប់ដល់អស់អ្នកណាដែលត្រូវ បានហៅចំពោះកិច្ចការនៃការងារបំរើ នៅគ្រប់ការហៅ និងតំណែងរបស់ពួកគេផ្សេងៗគ្នា ។

១៤ ប្រយោជន៍ឲ្យពួកគេអាចបានល្អឥតខ្ចោះ ក្នុង[ក]ការយល់អំពីការងារបំរើ ក្នុងទ្រឹស្ដី ក្នុងគោលការណ៍ និងក្នុងគោលលទ្ធិ ក្នុងគ្រប់ ទាំងអស់ដែលទាក់ទងទៅនិង[ខ]នគរព្រះនៅលើផែនដី [គ]គឺកូនសោទាំងឡាយនៃនគរនេះត្រូវបានប្រទានមកលើអ្នកហើយ ។

១៥ ហើយដរាបណាប្រជារាស្ត្ររបស់យើងកសាងដំណាក់មួយដល់យើង ដោយនូវព្រះនាមនៃព្រះអម្ចាស់ ហើយមិនទ្រាំឲ្យរបស់[ក]មិន ស្អាតចូលមកក្នុងទីនោះឡើយ ដើម្បីកុំឲ្យដំណាក់ស្មោកគ្រោក នោះ[ខ]សិរីល្អរបស់យើងនឹងសណ្ឋិតមកលើដំណាក់នោះ;

១៦ មែនហើយ [ក]វត្តមានរបស់យើងនឹងនៅទីនោះ ព្រោះយើងនឹងចូលមកទីនោះ ហើយគ្រប់អ្នកដែលមាន[ខ]ចិត្តបរិសុទ្ធដែលនឹងចូល មកទីនោះ នោះនឹងបានឃើញព្រះ ។

១៧ ប៉ុន្តែបើសិនជាដំណាក់នោះស្មោកគ្រោក នោះយើងនឹងមិនចូលមកទីនោះទេ ហើយសិរីល្អរបស់យើងក៏នឹងមិននៅទីនោះដែរ; ព្រោះយើងនឹងមិនចូលក្នុងព្រះវិហារទាំងឡាយណា ដែលមិនបរិសុទ្ធឡើយ ។

៦ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
៧ *ក* ម៉ាថាយ ៣:១០.
*ខ* លូកា ៦:៤៣–៤៥; អាលម៉ា ៥:៣៦, ៥២; ៣ នីហ្វៃ ១៤:១៥–២០.
៨ *ក* ស.ប. ចិត្តសង្រេង.
*ខ* ស.ប. ទៀងត្រង់, ចិត្តទៀងត្រង់.
*គ* គ. និង ស. ៦៤:៣៤.
*ឃ* ស.ប. បូជា, យញ្ញបូជា.
*ង* គ. និង ស. ៥២:១៥; ១៣២:៥០.
១០ *ក* គ. និង ស. ៥៧:៣; ៨៨:១១៩; ១២៤:៥១.
*ខ* គ. និង ស. ១១៥:១៤–១៦.
១២ *ក* ស.ប. ដង្វាយ១ភាគក្នុង១០, ការថ្វាយដង្វាយ១ភាគក្នុង១០.
*ខ* ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់.
១៣ *ក* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
១៤ *ក* ស.ប. យោបល់.
*ខ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*គ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
១៥ *ក* គ. និង ស. ៩៤:៩; ១០៩:២០–២១.
*ខ* ហាកាយ ២:៧; គ. និង ស. ៨៤:៥.
១៦ *ក* គ. និង ស. ១១០:១–១០.
*ខ* ម៉ាថាយ ៥:៨; គ. និង ស. ៦៧:១០–១៣; ៨៨:៦៨. ស.ប. សុទ្ធ, សុទ្ធសាធ.

១៨ ហើយឥឡូវនេះ មើលចុះ បើសិនជាស៊ីយ៉ូនធ្វើការ
ទាំងនេះ នោះនាងនឹងបានលូតលាស់ ហើយលាតខ្លួន ហើយ
ត្រឡប់ជារុងរឿង មហិមា និងគួរឲ្យស្ញែងខ្លាចណាស់ ។
១៩ ហើយសាសន៍ទាំងឡាយនៅលើផែនដី នឹងឲ្យកិត្តិយ
សដល់នាង ហើយនឹងនិយាយថា៖ ពិតមែនហើយ ស៊ីយ៉ូន
គឺជាទីក្រុងនៃព្រះ របស់យើង ហើយពិតមែនហើយ ស៊ីយ៉ូនពុំ
អាចរលំបានឡើយ ឬក៏ដកចេញពីកន្លែងនាងឡើយ ត្បិតព្រះ
ទ្រង់គង់នៅទីនោះ ហើយព្រះ ហស្តនៃព្រះអម្ចាស់ក៏នៅ
ទីនោះដែរ;
២០ ហើយទ្រង់បានស្បថដោយព្រះចេស្ដានៃកម្លាំងរបស់ទ្រង់
ដើម្បីធ្វើជាសេចក្ដីសង្គ្រោះរបស់នាង និងប៉មដ៏ខ្ពស់របស់នាង ។
២១ ហេតុដូច្នេះហើយ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលដូច្នេះថា ចូរឲ្យស៊ីយ៉ូនអរសប្បាយចុះ ត្បិតនេះហើយ
ជាស៊ីយ៉ូន — ជាអ្នកដែលមានចិត្តល្អស្អុទ្ធសាធ; ហេតុ
ដូច្នេះហើយ ចូរឲ្យស៊ីយ៉ូនអរសប្បាយចុះ ក្នុងកាលគ្រប់ពួក
ទុច្ចរិតនឹងត្រូវទួញសោក ។
២២ ត្បិតមើលចុះ ហើយមើលន៏ សេចក្ដីសងសឹកនឹងឆាប់មក
លើពួកទមិឡ «សូមមើល ទាំងអស់» ល្ហើស ដូចជាព្យុះសង្ឃ
រា; ហើយតើនរណានឹងរួចបាន?
២៣ រំពាត់របស់ព្រះអម្ចាស់នឹងហួរកាត់ទាំងយប់ទាំងថ្ងៃ
ហើយការឮដំណឹងអំពីរំពាត់ នោះនឹងធ្វើឲ្យអស់ទាំងមនុស្ស
ស្ញែងខ្លាច; មែនហើយ រំពាត់នោះនឹងមិនឈប់ឈរឡើយ រហូត
ដល់ព្រះអម្ចាស់ទ្រង់យាងមក;
២៤ ត្បិតសេចក្ដីក្ដៅក្រហាយនៃព្រះអម្ចាស់ ត្រូវបាន
ឆួលឡើងទាស់នឹងអំពើគួរខ្ពើមឆ្អើមរបស់ពួកគេ និងអស់ទាំង
កិច្ចការទុច្ចរិតរបស់ ពួកគេផង ។
២៥ ទោះជាយ៉ាងណាក៏ដោយ គង់តែស៊ីយ៉ូននឹងបានរួច បើ
សិនជានាងគោរពតាម ដើម្បីប្រព្រឹត្តនូវគ្រប់ទាំងអស់ ដែល
យើងបាន បញ្ជាដល់នាង ។
២៦ ប៉ុន្តែបើសិនជានាងមិនគោរពតាម ដើម្បីប្រព្រឹត្តនូវអ្វី
ៗដែលយើងបានបញ្ជាដល់នាងទេ នោះយើងនឹងពិនិត្យពិច័យនាង
ស្របតាមកិច្ចការនាងទាំងអស់ គឺដោយសេចក្ដីទុក្ខវេទនាដ៏ធ្ងន់
ដោយអាសន្នរោគ ដោយសេចក្ដីវេទនា ដោយដាវ ដោយ
សេចក្ដីសងសឹក ដោយភ្លើងឆេះ ។
២៧ ទោះជាយ៉ាងណាក៏ដោយ ចូរអានឃ្លានេះតែម្ដងគត់ឲ្យ
ត្រចៀកនាងឮ ថាយើងជាព្រះអម្ចាស់ បានទទួលដង្វាយ
របស់នាងហើយ; ហើយបើសិនជានាងមិនធ្វើបាបទៀតទេ នោះ
គ្មានអ្វីណាមួយពីសេចក្ដីទាំងនេះនឹងកើតមកលើនាងឡើយ;
២៨ ហើយយើងនឹងប្រទានពរដល់នាង នូវព្រះពរទាំងឡាយ
ហើយចំរើនពរដ៏ច្រើនអនេកមកលើនាង និងមកលើតំណទាំង
ឡាយ របស់នាង ជារៀងដរាបតទៅ ព្រះអម្ចាស់ដ៏ជាព្រះរបស់
អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ អាម៉ែន ៕

## កណ្ឌទី ៩៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៦ ខែសីហា ឆ្នាំ១៨៣៣ (*History of the Church*, ១:៤០៣–៤០៦) ។ វិវរណៈនេះបានមក ព្រោះតែមានការបៀតបៀនមកលើពួកបរិសុទ្ធនៅ រដ្ឋមិសសួរី ។ ដោយបានរងទុក្ខខាងរូបកាយ ហើយព្រមទាំងបានបាត់បង់ទ្រព្យសម្បត្តិ វាជាធម្មតាទេ ដែលពួកបរិសុទ្ធនៅរដ្ឋមិសសួរី មានអារម្មណ៍ឆ្ពោះទៅរកការតបសងសឹក ។ ហេតុដូច្នេះហើយ ទើបព្រះអម្ចាស់ទ្រង់បានប្រទានវិវរណៈនេះ ។ ទោះជាដំណឹងខ្លះអំពី បញ្ហាទាំងឡាយនៅរដ្ឋមិសសួរី ពិតជាបានឮដល់ព្យាការីនៅក្រុងខឺតឡង់ក៏ដោយ (ចម្ងាយ ១៤៤០ គ.ម.) គង់តែទម្រង់អំពីបញ្ហានោះ អាចបានឮដល់លោកនៅថ្ងៃនេះបាន ដោយសារតែវិវរណៈប៉ុណ្ណោះ ។*

១៨ *ក* គ. និង ស. ៩០:២៤; ១០០:១៥.
១៩ *ក* អេសាយ ៦០:១៤;
សាការី ២:១០–១២;
គ. និង ស. ៤៥:៦៦–៧០;
៤៩:១០.
*ខ* ស.ប. ក្រុងយេរូសាឡិមថ្មី.
២០ *ក* ២ សាំយូ. ២២:៣.
២១ *ក* ម៉ូសេ ៧:១៨.
ស.ប. សុទ្ធ, សុទ្ធសាធ; ស៊ីយ៉ូន.
២២ *ក* ស.ប. ការសងសឹក.
២៣ *ក* អេសាយ ២៨:១៤–១៩;
គ. និង ស. ៤៥:៣១.
២៥ *ក* ២ នីហ្វៃ ៦:១៣–១៨;
គ. និង ស. ៦៣:៣៤;
យ.ស. — ម៉ាថាយ ១:២០.
២៦ *ក* គ. និង ស. ៨៤:៥៤–៥៩.
*ខ* លូកា ២១:១០–១៣.
*គ* ម៉ាឡាគី ៤:១–៣;
៣ នីហ្វៃ ២១:២០–២១.
*ឃ* យ៉ូអែល ១:១៥–២០.
២៧ *ក* អេសេ. ១៨:២៧.
២៨ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.

*១–៣, សេចក្ដីទុក្ខវេទនាទាំងឡាយនៃពួកបរិសុទ្ធ នឹងបានទៅជាការល្អដល់ពួកគេ; ៤–៨, ពួកបរិសុទ្ធត្រូវគាំទ្រក្រិត្យវិន័យត្រឹមត្រូវនៃ ដែនដី; ៩–១០, មនុស្សណាទៀងត្រង់ មានគំនិត ហើយល្អនោះគួរគាំទ្រក្នុងតំណែងរដ្ឋការផ្នែកស៊ីវិល; ១១–១៥, អស់អ្នកណាដែល បូជជីវិតរបស់ខ្លួន ដើម្បីគតិរបស់ព្រះអម្ចាស់ នោះនឹងមានជីវិតដ៏អស់កល្បជានិច្ច; ១៦–១៨, ចូរលះបង់ចោលសង្គ្រាម ហើយប្រកាស ប្រាប់ពីសេចក្ដីសុខសាន្តវិញ; ១៩–២២, ពួកបរិសុទ្ធនៅក្រុងខឺតឡង់ត្រូវបានបន្ទោស ហើយបញ្ជាឲ្យប្រែចិត្ត; ២៣–៣២, ព្រះអម្ចាស់ទ្រង់បើកសំដែងប្រាប់ពីក្រិត្យវិន័យទាំងឡាយរបស់ទ្រង់ ដែលទាក់ទងទៅនិងសេចក្ដីបៀតបៀន និងសេចក្ដីទុក្ខវេទនាទាំងឡាយ ដែលបាន ដាក់មកលើប្រជារាស្ត្ររបស់ទ្រង់; ៣៣–៣៨, សង្គ្រាមត្រូវបានរាប់ថាជាយុត្តិធម៌ ក្នុងកាលតែព្រះអម្ចាស់ទ្រង់បញ្ជាឲ្យមានសង្គ្រាម ប៉ុណ្ណោះ; ៣៩–៤៨, ពួកបរិសុទ្ធត្រូវអត់ទោសដល់ពួកខ្មាំងសត្រូវរបស់ខ្លួន បើសិនជាពួកគេប្រែចិត្ត នោះពួកគេក៏នឹងបានរួចផុតពីសេចក្ដី សងសឹករបស់ព្រះអម្ចាស់ដែរ ។*

មិត្តទាំងឡាយរបស់យើងអើយ យើងប្រាប់អ្នកជាប្រាកដថា កុំខ្លាចឡើយ ចូរមានចិត្តក្សាន្តចុះ; មែនហើយ ចូរអរសប្បាយជានិច្ច ហើយនូវគ្រប់អ្វីៗទាំងអស់ ចូរថ្លែងអំណរគុណ;

២ ដោយអត់ឱនរង់ចាំព្រះអម្ចាស់ ត្បិតការអធិស្ឋានរបស់អ្នកបានចូលក្នុងព្រះកាណ៌របស់ព្រះអម្ចាស់នៃសាបោតហើយ ហើយត្រូវបាន កត់ទុកដោយតម្រា និងទីបន្ទាល់នេះ — គឺព្រះអម្ចាស់ទ្រង់បានស្បថ ហើយបានចេញបញ្ញត្តិថា ពួកគេនឹងត្រូវបានអនុញ្ញាតហើយ ។

៣ ហេតុដូច្នេះហើយ ព្រះអង្គប្រទានសេចក្ដីសន្យានេះដល់អ្នក ដោយសេចក្ដីសញ្ញាដ៏មិនចេះប្រែប្រួលថា ការអធិស្ឋានទាំងឡាយនឹង ត្រូវបានសំរេច; ហើយគ្រប់ការណ៍ទាំងអស់ដែលអ្នកត្រូវបានរងទុក្ខ នោះនឹងផ្សំគ្នាសំរាប់សេចក្ដីល្អដល់អ្នក និងដល់សិរីល្អរបស់ព្រះនាម យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៤ ហើយឥឡូវនេះ ប្រាកដមែន យើងប្រាប់អ្នកអំពីក្រិត្យវិន័យទាំងឡាយនៃដែនដីថា គឺជាព្រះហឫទ័យរបស់យើង ដែលប្រជារាស្ត្រ របស់យើងត្រូវគោរពតាម ដើម្បីប្រព្រឹត្តនូវគ្រប់អ្វីៗទាំងអស់ ដែលយើងបានបញ្ជាដល់ពួកគេ ។

៥ ហើយថាក្រិត្យវិន័យនៃដែនដី ដែលអនុញ្ញាត ដោយគាំទ្រគោលការណ៍នៃសេរីភាពនោះ ក្នុងការទ្រទ្រង់សិទ្ធិ និងឯកសិទ្ធិទាំងឡាយ នោះគឺសំរាប់មនុស្សទាំងអស់ ហើយរាប់ថាត្រឹមត្រូវនៅចំពោះយើង ។

៦ ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ រាប់អ្នក និងពួកបងប្អូនអ្នកក្នុងសាសនាថាសុចរិតហើយ ក្នុងការគាំទ្រក្រិត្យវិន័យនោះ ដែលជា ក្រិត្យវិន័យត្រឹមត្រូវនៃដែនដី;

៧ ហើយរីឯក្រិត្យវិន័យនៃមនុស្សវិញ អ្វីៗក៏ដោយដែលលើសឬតិចជាងនេះ គឺមកតែពីអាកំណាចទេ ។

៨ យើងជាព្រះអម្ចាស់ដ៏ជាព្រះ ធ្វើឲ្យអ្នកមានសេរី ហេតុដូច្នេះហើយ អ្នករាល់គ្នាច្បាស់ជាមានសេរីមែន; ហើយក្រិត្យវិន័យក៏ធ្វើឲ្យអ្នក មានសេរីដែរ ។

៩ ទោះជាយ៉ាងណាក៏ដោយ កាលណាមនុស្សទុច្ចរិតគ្រប់គ្រង នោះប្រជាជនទូញសោក ។

១០ ហេតុដូច្នោះហើយ មនុស្សណាទៀងត្រង់ និងមនុស្សណាមានគំនិត នោះគួរព្យាយាមស្វែងរក ហើយមនុស្សណាល្អ និងមនុស្ស ណាមានគំនិត នោះអ្នករាល់គ្នាគួរគោរព ដើម្បីលើកឡើង; បើពុំនោះសោតទេ អ្វីៗក៏ដោយដែលតិចជាងនេះ គឺមកតែពីអាកំណាច ទេ ។

១១ ហើយយើងប្រទានដល់អ្នកនូវព្រះបញ្ញត្តិមួយថា អ្នករាល់គ្នាត្រូវលះបង់ចោលអស់ទាំងសេចក្ដីអាក្រក់ ហើយកាន់ខ្ជាប់ខាង សេចក្ដីល្អវិញ គឺថាអ្នករាល់គ្នាត្រូវរស់នៅ ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋនៃព្រះ ។

១២ ត្បិតព្រះអង្គទ្រង់នឹងប្រទានដល់ពួកស្មោះត្រង់

៩៨ ១*ក* គ. និង ស. ៦៨:៦.
*ខ* ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
២ *ក* ទំនុក. ២៧:១៤; អេសាយ ៣០:១៨–១៩; គ. និង ស. ១៣៣:៤៥.
៣ *ក* គ. និង ស. ១២២:៧. ស.ប. សេចក្ដីទំនាស់.
៥ *ក* ១ ពេត្រុស ២:១៣–១៤; គ. និង ស. ៥៨:២១; ១៣៤:៥.
*ខ* គ. និង ស. ១០១:៧៧–៨០; ១០៩:៥៤. ស.ប. រដ្ឋធម្មនុញ្ញ; ឥស្សរភាព.
៨ *ក* យ៉ូហាន ៨:៣២; ២ កូរិន. ៣:១៧. ស.ប. សិទ្ធិជ្រើសរើស; សេរី, សេរីភាព.
៩ *ក* សុភា. ២៩:២.
១០ *ក* ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់.
១១ *ក* ចោទិ. ៨:៣; ម៉ាថាយ ៤:៤; គ. និង ស. ៨៤:៤៣–៤៤.
១២ *ក* អេសាយ ២៨:១០; គ. និង ស. ៤២:៦១.

មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ; ហើយយើងនឹងសាកល្បង
អ្នក ហើយល្បងល អ្នក ដោយសារមាគ៌ានេះ ។
១៣ ហើយអស់អ្នកណាដែលប្ដូរជីវិតរបស់ខ្លួន ដើម្បីគតិ
របស់យើង ដោយយល់ដល់ព្រះនាមរបស់យើង នោះនឹង
បានវិញ គឺជាជីវិតដ៏ នៅអស់កល្បជានិច្ច ។
១៤ ហេតុដូច្នេះហើយ ចូរកុំខ្លាចពួកខ្មាំងសត្រូវរបស់អ្នកឡើយ
ត្បិតយើងបានចេញបញ្ញត្តក្នុងព្រះហឫទ័យរបស់យើងហើយ គឺព្រះ
អម្ចាស់ទ្រង់បានមានព្រះបន្ទូលថា យើងនឹងល្បងលអ្នកនូវគ្រប់ទាំង
អស់ ថាតើអ្នកនឹងនៅជាប់ក្នុងសេចក្ដីសញ្ញារបស់យើង រហូត
ដល់ ស្លាប់ឬទេ ប្រយោជន៍ឲ្យអ្នកអាចបានឃើញថាសក្តិសម ។
១៥ ត្បិតបើសិនជាអ្នករាល់គ្នាមិននៅជាប់ក្នុងសេចក្ដីសញ្ញា
របស់យើងទេ នោះអ្នករាល់គ្នាមិនសមនិងយើងឡើយ ។
១៦ ហេតុដូច្នេះហើយ ចូរលះបង់សង្គ្រាម ហើយប្រកាស
ប្រាប់ពីសេចក្ដីសុខសាន្តវិញ ហើយចូរព្យាយាមស្វែងរក ដើម្បី
បង្វែរចិត្តកូន មកឯឪពុករបស់ខ្លួន និងចិត្តឪពុកមកឯកូនវិញ;
១៧ ហើយជាថ្មីទៀត គឺចិត្តនៃពួកសាសន៍យូដាមកឯពួកព្យាការី
និងពួកព្យាការីមកឯពួកសាសន៍យូដាវិញ; ក្រែងយើងយាងមក
ហើយវាយផែនដីទាំងមូលដោយសេចក្ដីបណ្ដាសា ហើយក្រែង
មនុស្សទាំងអស់ត្រូវឆេះនៅចំពោះយើង ។
១៨ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ; ត្បិតនៅក្នុង
ដំណាក់របស់ព្រះវរបិតារបស់យើង នោះមានវិមានជាច្រើន
ហើយយើងបាន រៀបចំកន្លែងទុកឲ្យអ្នក; ហើយកន្លែងណាដែល
ព្រះវរបិតា និងយើងគង់នៅ នោះអ្នករាល់គ្នាក៏នឹងនៅដែរ ។
១៩ មើលចុះ យើងជាព្រះអម្ចាស់ មិនសព្វព្រះហឫទ័យនិង
មនុស្សជាច្រើន ដែលនៅក្នុងសាសនាចក្រនៅក្រុងខឺតឡង់ឡើយ;
២០ ព្រោះពួកគេមិនលះបង់ចោលអំពើបាបទាំងឡាយរបស់
ពួកគេ និងផ្លូវដ៏ទុច្ចរិតទាំងឡាយរបស់ពួកគេ សេចក្ដីឆ្មើងឆ្មៃនៃ
ចិត្តរបស់ ពួកគេ និងសេចក្ដីលោភលន់របស់ពួកគេ និងគ្រប់ទាំង
របស់គួរស្អប់ខ្ពើមរបស់ពួកគេ ហើយគោរពតាមពាក្យសំដីនៃ
ប្រាជ្ញាវាងវៃ និងជីវិតដ៏នៅអស់កល្បជានិច្ច ដែលយើងបាន
ប្រទានដល់ពួកគេឡើយ ។
២១ យើងប្រាប់អ្នកជាប្រាកដថា យើងជាព្រះអម្ចាស់ នឹងវាយ
ផ្ចាលពួកគេ ហើយនឹងធ្វើនូវអ្វីៗដែលយើងសព្វព្រះហឫទ័យ បើ
សិនជា ពួកគេមិនប្រែចិត្ត ហើយគោរពតាមអ្វីៗគ្រប់ទាំងអស់
ដែលយើងបានមានព្រះបន្ទូលទៅកាន់ពួកគេទេនោះ ។
២២ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា បើសិនជាអ្នករាល់
គ្នាគោរព ដើម្បីប្រព្រឹត្តនូវអ្វីៗដែលយើងបញ្ជាដល់អ្នក នោះយើង
ជា ព្រះអម្ចាស់នឹងបង្វែរអស់ទាំងសេចក្ដីក្រោធ និងសេច
ក្ដីក្ដៅក្រហាយចេញពីអ្នក ហើយទ្វារស្ថាននរកនឹងពុំដែលឈ្នះ
អ្នកឡើយ ។
២៣ ឥឡូវនេះ យើងមានព្រះបន្ទូលទៅកាន់អ្នក អំពីក្រុម
គ្រួសារនៃអ្នករាល់គ្នាថា — បើសិនជាមនុស្សលោកនឹង
វាយអ្នក ឬក្រុម គ្រួសារអ្នកម្ដង ហើយអ្នករាល់គ្នាអត់ទ្រាំ ហើយ
មិនជេរប្រមាថពួកគេ ឬរកការសងសឹកទេ នោះអ្នករាល់គ្នានឹង
បានរង្វាន់;
២៤ ប៉ុន្តែបើសិនជាអ្នករាល់គ្នាមិនអត់ទ្រាំទេ ការវាយនោះនឹង
ត្រូវបានចាត់ដល់អ្នកថា ដូចជាបានវាល់ដល់អ្នក តាមរង្វាល់
ត្រឹមត្រូវ ហើយ ។
២៥ ហើយជាថ្មីទៀត បើសិនជាខ្មាំងសត្រូវរបស់អ្នកនឹងវាយ
អ្នកលើកទីពីរ ហើយអ្នកមិនជេរប្រមាថខ្មាំងសត្រូវរបស់ខ្លួនទេ
ហើយអត់ទ្រាំ នោះរង្វាន់របស់អ្នកនឹងត្រូវបានឡើងមួយរយដង ។
២៦ ហើយជាថ្មីទៀត បើសិនជាអ្នកនោះវាយអ្នកលើកទីបី
ហើយអ្នករាល់គ្នាអត់ទ្រាំ នោះរង្វាន់របស់អ្នកនឹងត្រូវបានឡើងដល់
អ្នក បួនដង;

---

១២ *ខ* អ័ប្រា. ៣:២៥–២៦.
១៣ *ក* លូកា ៩:២៤;
គ. និង ស. ១០១:៣៥–៣៨;
១០៣:២៧–២៨.
ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
១៤ *ក* នេហេ. ៤:១៤;
គ. និង ស. ១២២:៩.
*ខ* គ. និង ស. ១២៤:៥៥.
*គ* វិវរ. ២:១០;
គ. និង ស. ១៣៦:៣១, ៣៩.
១៦ *ក* អាលម៉ា ៤៨:១៤.
ស.ប. អ្នកផ្សះផ្សា.
*ខ* ស.ប. សង្គ្រាម.
*គ* ស.ប. សេចក្ដីសុខសាន្ត.
*ឃ* ម៉ាឡាគី ៤:៥–៦;
គ. និង ស. ២:១–២.
១៧ *ក* ស.ប. ពួកសាសន៍យូដា.
១៨ *ក* យ៉ូហាន ១៤:២;
គ. និង ស. ៥៩:២;
៧៦:១១១; ៨១:៦.
២១ *ក* ម៉ូសាយ ២៣:២១;
ហេលេ. ១២:៣.
ស.ប. វាយផ្ចាល, ការវាយផ្ចាល.
២២ *ក* ស.ប. ការគោរព, ដែលគោរព,
គោរព.
*ខ* ម៉ាថាយ ១៦:១៧–១៨;
គ. និង ស. ៣៣:១២–១៣.
២៣ *ក* លូកា ៦:២៩;
អាលម៉ា ៤៣:៤៦–៤៧.
ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
២៤ *ក* ម៉ាថាយ ៧:១–២.

២៧ ហើយទីបន្ទាល់ទាំងបីនេះ នឹងត្រូវបានឈរទាស់និងខ្មាំងសត្រូវរបស់អ្នក បើសិនជាអ្នកនោះមិនប្រែចិត្តទេ ហើយនឹងមិនត្រូវបាន លុបចោលឡើយ ។

២៨ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា បើសិនជាខ្មាំងសត្រូវនោះនឹងបានរួចគេចផុតពីការសងសឹករបស់យើង ដែលអ្នកនោះ មិនត្រូវបាននាំមកជំនុំជំរះ នៅចំពោះយើងទេ ខណៈនោះអ្នករាល់គ្នាត្រូវមើលឲ្យឃើញថា អ្នករាល់គ្នា[ក]ព្រមានអ្នកនោះដោយនូវព្រះ នាមរបស់យើង ដើម្បីកុំឲ្យអ្នកនោះមកលើអ្នកទៀត ឬមកលើក្រុមគ្រួសារអ្នក គឺកូនចៅរបស់កូនអ្នក រហូតដល់តំណទីបីទីបួន ។

២៩ ហើយខណៈនោះ បើសិនជាអ្នកនោះនឹងមកលើអ្នក ឬកូនចៅអ្នក ឬកូនចៅរបស់កូនអ្នក លុះដល់តំណទីបីទីបួន នោះយើងបាន បញ្ជូនខ្មាំងសត្រូវរបស់អ្នក មកក្នុងកណ្ដាប់ដៃអ្នកហើយ;

៣០ ហើយខណៈនោះ បើសិនជាអ្នកនឹងប្រណីដល់អ្នកនោះ នោះអ្នកនឹងត្រូវបានរង្វាន់ ចំពោះសេចក្ដីសុចរិតរបស់អ្នក; ហើយដល់កូន ចៅអ្នក និងកូនចៅរបស់កូនអ្នកដែរ លុះដល់តំណទីបីទីបួន ។

៣១ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្មាំងសត្រូវរបស់អ្នកនៅក្នុងកណ្ដាប់ដៃអ្នកដែរ; ហើយបើសិនជាអ្នកសងអ្នកនោះ តាមការទាំង ឡាយដែលគាត់ធ្វើ នោះអ្នកត្រូវបានរាប់ថាសុចរិតហើយ; បើសិនជាអ្នកនោះបានស្វែងរកផ្ដាច់ជីវិត ហើយជីវិតអ្នកត្រូវមានគ្រោះថ្នាក់ ដោយសារអ្នកនោះ នោះខ្មាំងសត្រូវអ្នក នៅក្នុងកណ្ដាប់ដៃរបស់អ្នកហើយ ហើយអ្នកត្រូវបានរាប់ថាជាសុចរិតវិញ ។

៣២ មើលចុះ នេះហើយជាក្រិត្យវិន័យ ដែលយើងបានប្រទានដល់នីហ្វៃ ជាអ្នកបំរើរបស់យើង និងដល់[ក]ពួកអយ្យកោរបស់អ្នក គឺយ៉ូសែប និងយ៉ាកុប និងអ៊ីសាក និងអាប្រាហាំ និងអស់ទាំងពួកព្យាការី និងពួកសាវករបស់យើងពីបុរាណ ។

៣៣ ហើយជាថ្មីទៀត នេះហើយជា[ក]ក្រិត្យវិន័យ ដែលយើងបានប្រទានដល់រាស្ត្រយើងពីបុរាណ ដើម្បីកុំឲ្យពួកគេចេញទៅច្បាំងទាស់ និងសាសន៍ ពូជមនុស្ស ភាសា ឬប្រជាជនណាមួយឡើយ លើកលែងតែយើងជាព្រះអម្ចាស់បានបញ្ជាដល់ពួកគេប៉ុណ្ណោះ ។

៣៤ ហើយបើសិនជាមានសាសន៍ណា ភាសាណា ឬប្រជាជនណា[ក]ប្រកាសសង្គ្រាមទាស់នឹងពួកគេ នោះពួកគេត្រូវលើកទង់នៃ សន្តិភាពជាមុន ដល់ប្រជាជន សាសន៍ ឬភាសានោះ;

៣៥ ហើយបើសិនជាប្រជាជននោះមិនទទួលដង្វាយនៃសន្តិភាពទេ ឬលើកទីពីរឬទីបី នោះពួកគេត្រូវយកទីបន្ទាល់ទាំងនេះ មកចំពោះព្រះអម្ចាស់;

៣៦ ខណៈនោះ យើងជាព្រះអម្ចាស់នឹងប្រទានដល់ពួកគេ នូវព្រះបញ្ញត្តិមួយ ហើយរាប់ពួកគេថាសុចរិត ក្នុងការចេញទៅច្បាំងទាស់ និងសាសន៍ ភាសា ឬប្រជាជននោះ ។

៣៧ ហើយយើងជាព្រះអម្ចាស់នឹង[ក]ច្បាំងចំបាំងរបស់ពួកគេ និងចំបាំងរបស់កូនចៅរបស់ពួកគេ និងរបស់កូនចៅរបស់ពួកគេដែរ រហូតដល់ពួកគេត្រូវបានសងសឹកដល់អស់ទាំងពួកខ្មាំងសត្រូវរបស់ពួកគេ លុះដល់តំណទីបីទីបួន ។

៣៨ មើលចុះ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថា នេះហើយជាគំរូដល់គ្រប់ប្រជាជន សំរាប់ការរាប់ជាសុចរិតនៅ ចំពោះយើង ។

៣៩ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា បើសិនជាបន្ទាប់ពីខ្មាំងសត្រូវរបស់អ្នកបានមកលើអ្នកលើកទីមួយរួចគេប្រែចិត្ត ហើយមករកអ្នកសូមក្ដីអភ័យទោសពីអ្នក នោះអ្នកត្រូវអត់ទោសដល់គេ ហើយមិនត្រូវកាន់ទីបន្ទាល់ទាស់នឹងខ្មាំងសត្រូវរបស់អ្នក ឡើយ —

៤០ ហើយដល់លើកទីពីរ និងទីបីជាដើម ហើយជារាល់ៗដងណាខ្មាំងសត្រូវរបស់អ្នកប្រែចិត្តពីការរំលង ដែលគេបានប្រព្រឹត្តរំលងលើ អ្នក គឺអ្នកត្រូវ[ក]អត់ទោសដល់គេ រហូតដល់ប្រាំពីរចិតសិបដងទៅទៀត ។

៤១ ហើយបើសិនជាគេប្រព្រឹត្តរំលងលើអ្នក ហើយមិនប្រែចិត្តនៅលើកទីមួយទេ ទោះជាយ៉ាងណាក៏ដោយ គង់តែអ្នកត្រូវអត់ទោស ដល់គេដែរ ។

៤២ ហើយបើសិនជាគេប្រព្រឹត្តរំលងលើអ្នកនៅលើកទីពីរ ហើយមិនប្រែចិត្តសោះ ទោះជាយ៉ាងណាក៏ដោយ គង់តែអ្នកត្រូវអត់ទោស ដល់គេដែរ ។

៤៣ ហើយបើសិនជាគេប្រព្រឹត្តរំលងលើអ្នកនៅលើកទីបី ហើយមិនប្រែចិត្តសោះ នោះអ្នកត្រូវតែអត់ទោសដល់គេដែរ ។

២៨ *ក* ស.ប. ព្រមាន, ពាក្យព្រមាន.
៣២ *ក* គ. និង ស. ២៧:១០.
៣៣ *ក* ចោទិ. ២០:១០; អាលម៉ា ៤៨:១៤–១៦.
៣៤ *ក* គ. និង ស. ១០៥:៣៨–៤១.
៣៧ *ក* យ៉ូស្វេ ២៣:១០; អេសាយ ៤៩:២៥.
៤០ *ក* ម៉ាថាយ ១៨:២១–២២; គ. និង ស. ៦៤:៩–១១. ស.ប. អត់ទោស, អភ័យទោស.

៤៤ ប៉ុន្តែប្រសិនបើជាគេប្រព្រឹត្តរំលងលើអ្នកនៅលើកទីបួន នោះអ្នកមិនត្រូវអត់ទោសដល់គេឡើយ ប៉ុន្តែត្រូវយកទីបន្ទាល់ទាំងនេះ ទៅចំពោះព្រះអម្ចាស់វិញ; ហើយទីបន្ទាល់ទាំងនេះនឹងមិនត្រូវបានលុបចេញឡើយ រហូតដល់អ្នកនោះប្រែចិត្ត ហើយសងដល់អ្នកបួនដង នូវអ្វីៗទាំងអស់ ដែលគេបានប្រព្រឹត្តរំលងនិងអ្នក ។

៤៥ ហើយបើសិនជាអ្នកនោះធ្វើបែបនេះ នោះអ្នកត្រូវអត់ទោសដល់គេឲ្យអស់ពីចិត្ត; ហើយបើសិនជាអ្នកនោះមិនធ្វើបែបនេះទេ នោះយើងជាព្រះអម្ចាស់នឹង[ក]សងសឹកជំនួសអ្នក ដល់ខ្មាំងសត្រូវអ្នក ដល់ទៅមួយភាគរយដងទៅទៀត;

៤៦ និងទៅលើកូនចៅរបស់គេ និងទៅលើកូនចៅនៃកូនរបស់គេទាំងអស់គ្នាដែលស្អប់យើង គឺរហូតដល់[ក]តំណទីបី និងទីបួនផង;

៤៧ ប៉ុន្តែបើសិនជាកូនចៅនឹងប្រែចិត្ត ឬក៏កូនចៅនៃកូនផង ហើយ[ក]បែរមករកព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេ ដោយអស់ពីចិត្តរបស់ ពួកគេ ហើយដោយអស់ពីពលំ គំនិត និងកម្លាំងរបស់ពួកគេ ហើយសងឡើងវិញនូវការរំលងទាំងអស់ ដែលពួកគេបានប្រព្រឹត្តរំលង ឬដែលឪពុកនៃឪពុកពួកគេ ដល់ទៅបួនដង ខណៈនោះ ទើបសេចក្ដីក្ដៅក្រហាយរបស់អ្នកនឹងបានបែរចេញ;

៤៨ ហើយ[ក]ការសងសឹកនឹងមិនត្រូវមានមកលើពួកគេទៀតឡើយ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយការរំលងរបស់ពួកគេនឹងមិនត្រូវបានយកមកធ្វើជាទីបន្ទាល់ទាស់និងពួកគេ នៅចំពោះព្រះអម្ចាស់ឡើយ ។ អាម៉ែន ៕

## កណ្ឌទី ៩៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី ចំពោះយ៉ូហាន មើដក់ នៅខែសីហា ឆ្នាំ១៨៣២ នៅភូមិហៃរាំ រដ្ឋអូហៃអូ ។ ទោះជាគោលលទ្ធិ និងសេចក្ដីសញ្ញា ដែលបានបោះពុម្ពផ្សាយចាប់ផ្ដើមពីឆ្នាំ១៨៧៦តមក បានកត់ថាវិវរណៈនេះ នៅក្រុងខឺតឡង់ ខែសីហា ឆ្នាំ១៨៣៣ក៏ដោយ គង់តែការបោះពុម្ពមុន និងបញ្ជីប្រវត្តិទាំងឡាយបញ្ជាក់ប្រាប់ពីដំណឹងពិតប្រាកដដែរ ។*

*១–៨, យ៉ូហាន មើដក់ ត្រូវបានហៅឲ្យទៅប្រកាសប្រាប់ដំណឹងល្អ ហើយអស់អ្នកណាដែលទទួលគាត់ នោះឈ្មោះថាទទួលព្រះអម្ចាស់ ដែរ ហើយនឹងបានទទួលសេចក្ដីមេត្តាករុណា ។*

មើលចុះ ដូច្នេះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់យ៉ូហាន មើដក់ ជាអ្នកបំរើយើងថា — អ្នកត្រូវបានហៅឲ្យទៅឯស្រុកទាំងឡាយ នៅទិសខាងកើត ពីផ្ទះមួយទៅផ្ទះមួយ ពីភូមិមួយទៅភូមិមួយ និងពីទីក្រុងមួយទៅទីក្រុងមួយ ដើម្បីទៅប្រកាសប្រាប់ពីដំណឹងល្អ ដ៏នៅអស់កល្បអស់កាលជានិច្ចរបស់យើង ដល់បណ្ដាជននៅទីនោះ នៅកណ្ដាល[ក]សេចក្ដីបៀតបៀន និងអំពើទុច្ចរិតក្ដី ។

២ ហើយអ្នកណាដែល[ក]ទទួលអ្នក នោះឈ្មោះថាទទួលយើងដែរ ហើយអ្នកនឹងត្រូវបានអំណាច ដើម្បីប្រកាសព្រះបន្ទូលរបស់យើង ដោយ[ខ]ការសំដែងនៃព្រះវិញ្ញាណបរិសុទ្ធរបស់យើង ។

៣ ហើយអ្នកណាដែលទទួលអ្នក [ក]ដូចជាកូនក្មេងមួយ នោះឈ្មោះថាបានទទួល[ខ]នគររបស់យើងហើយ; ហើយពួកគេមានពរហើយ ព្រោះពួកគេនឹងបានទទួល[គ]សេចក្ដីមេត្តាករុណា ។

៤ ហើយអស់អ្នកណាដែល[ក]បដិសេធអ្នក នោះនឹងត្រូវបានបដិសេធដោយព្រះវរបិតារបស់យើង និងវង្សារបស់ទ្រង់ដែរ; ហើយអ្នកត្រូវ [ខ]លាងជើងរបស់អ្នកនៅទីសម្ងាត់ ទុកជាទីបន្ទាល់ទាស់និងពួកគេ ។

៥ ហើយមើលចុះ និងមើលន៏ យើង[ក]យាងមកយ៉ាងឆាប់ ដើម្បី[ខ]ជំនុំជំរះ ដើម្បីបរិវត្តមនុស្សទាំងអស់ អំពីអំពើអាក្រក់ទាំងឡាយ

៤៥ *ក* មរមន ៨:២០.
៤៦ *ក* ចោទិ. ៥:៩–១០.
៤៧ *ក* ម៉ូសាយ ៧:៣៣; មរមន ៩:៦.
៤៨ *ក* អេសេ. ១៨:១៩–២៣.
៩៩ ១*ក* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
២ *ក* ម៉ាថាយ ១០:៤០.
*ខ* ១ កូរិន. ២:៤–៥.
៣ *ក* ម៉ាថាយ ១៨:១–៦.
*ខ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*គ* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៤ *ក* យ៉ូហាន ១២:៤៤–៥០.
*ខ* គ. និង ស. ៧៥:១៩–២២.
៥ *ក* គ. និង ស. ១:១១–១៤.
*ខ* យូដាស ១:១៤–១៥.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.

ដែលពួក គេបានប្រព្រឹត្តទាស់និងយើង ដូចដែលបានសរសេរ ទុកអំពីយើង នៅក្នុងកណ្ឌនៃព្រះគម្ពីរនេះ ។

៦ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា គឺមិនចាំបាច់ឲ្យ អ្នកត្រូវទៅទេ ទាល់តែកូនចៅរបស់អ្នកត្រូវបានផ្គត់ផ្គង់ ហើយ បញ្ជូនដោយស្រួលបួល ឡើងទៅឯបីស្សពនៃស៊ីយ៉ូនសិន ។

៧ ហើយមិនយូរឆ្នាំក្រោយមក បើសិនជាអ្នកមានចិត្តប្រាថ្នា ពីយើង នោះអ្នកអាចឡើងទៅឯដែនដីដ៏ល្អ ដើម្បីទទួលកេរ្តិ៍មរតក របស់ អ្នកចុះ;

៨ បើពុំនោះសោតទេ អ្នកត្រូវប្រកាសប្រាប់ពីដំណឹងល្អរបស់យើង តទៅទៀត រហូតដល់អ្នកត្រូវបានដកយកទៅ ។ អាម៉ែន ៕

## កណ្ឌទី ១០០

*វិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ស៊ីឌនី រិកដុន នៅភូមិផែរីស្ប៊ើក រដ្ឋនូវយ៉ោក ថ្ងៃទី១២ ខែតុលា ឆ្នាំ១៨៣៣ (*History of the Church*, ១:៤១៦, ៤១៩–៤២១)* ។ *បងប្រុសទាំងពីរ ដោយបានបាត់ពីគ្រួសាររបស់ខ្លួនអស់ជាច្រើនថ្ងៃ នោះបានព្រួយបារម្ភពីពួកគេ ។*

*១–៤, យ៉ូសែប និង ស៊ីឌនី ត្រូវផ្សាយដំណឹងល្អសំរាប់សេចក្ដីសង្គ្រោះនៃព្រលឹងទាំងឡាយ; ៥–៨, សេចក្ដីដែលពួកគេត្រូវនិយាយ នោះនឹងបានប្រទានដល់ពួកគេនៅម៉ោងនោះឯង; ៩–១២, ស៊ីឌនី ត្រូវធ្វើជាអ្នកនិយាយ ហើយ យ៉ូសែប ត្រូវធ្វើជាអ្នកទទួលវិវរណៈ ហើយខ្លាំងក្លាខាងថ្លែងទីបន្ទាល់; ១៣–១៧, ព្រះអម្ចាស់ទ្រង់នឹងបង្កើតប្រជារាស្ត្របរិសុទ្ធឡើង ហើយពួកដែលគោរពធ្វើតាម នឹងបានសង្គ្រោះ ។*

ប្រាកដមែន ដូច្នេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក គឺ ស៊ីឌនី និង យ៉ូសែប ជាមិត្តទាំងឡាយរបស់យើង ព្រមទាំងក្រុមគ្រួសារ របស់អ្នកផងដែរ; ពួកគេនៅក្នុងព្រះហស្ត របស់យើងហើយ ហើយយើងនឹងប្រព្រឹត្តដល់ពួកគេ តាមតែយើងឃើញថាល្អ; ត្បិតនៅក្នុង យើង គឺសុទ្ធតែអំណាចទាំងអស់ ។

២ ហេតុដូច្នេះហើយ ចូរមកតាមយើង ហើយស្ដាប់តាមពាក្យទូន្មាន ដែលយើងនឹងប្រទានដល់អ្នកចុះ ។

៣ មើលចុះ និងមើលន៏ យើងមានមនុស្សជាច្រើននៅកន្លែងនេះ គឺនៅភូមិភាគជុំវិញ; ហើយទ្វារដ៏មានផលប្រយោជន៍ នឹងត្រូវ បានបើកចំហ នៅភូមិភាគជុំវិញ នៅដែនដីនៃទិសខាងកើតនេះ ។

៤ ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ បានទុកឲ្យអ្នកមកឯទីនេះ; ត្បិតដោយហេតុនេះហើយ ទើបបានចាំបាច់ សំរាប់សេចក្ដី សង្គ្រោះនៃព្រលឹងទាំងឡាយ ។

៥ ហេតុដូច្នេះហើយ យើងប្រាប់អ្នកជាប្រាកដថា ចូរបន្លឺសម្លេងរបស់អ្នកឡើងដល់ប្រជាជននេះចុះ; ចូរប្រាប់គំនិតទាំងឡាយដែលយើង នឹងដាក់ក្នុងចិត្តរបស់អ្នករាល់គ្នាចុះ ហើយអ្នកនឹងមិនត្រូវបានធ្វើឲ្យខ្មាស់ នៅចំពោះមនុស្សលោកឡើយ ។

៦ ត្បិតសេចក្ដីដែលអ្នកត្រូវនិយាយ នោះនឹងបានប្រទានដល់អ្នក នៅម៉ោងនោះ គឺនៅវេលានោះឯង ។

៧ ប៉ុន្តែយើងប្រទានព្រះបញ្ញត្តិមួយដល់អ្នកថា អ្នករាល់គ្នាត្រូវប្រកាសពីអ្វីក៏ដោយដែលអ្នកប្រកាស ដោយនូវព្រះនាមរបស់យើង ដោយនូវចិត្តម៉ឺងម៉ាត់ ដោយនូវវិញ្ញាណស្លូតបូត នៅគ្រប់ទាំងអស់ ។

៨ ហើយយើងប្រទានដល់អ្នក នូវសេចក្ដីសន្យានេះថា ដរាបណាអ្នករាល់គ្នាធ្វើបែបនេះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងត្រូវចាត់ឲ្យមក ដើម្បីថ្លែងទីបន្ទាល់អំពីអ្វីៗទាំងអស់ ដែលអ្នករាល់គ្នាត្រូវនិយាយ ។

៩ ហើយជាការចាំបាច់ដល់យើងថា អ្នកស៊ីឌនី ជាអ្នកបំរើរបស់យើង គួរធ្វើជាអ្នកនិយាយដល់ប្រជាជននេះ; មែនហើយ ប្រាកដមែន យើងនឹងតែងតាំងអ្នកចំពោះតំណែងនេះ គឺធ្វើជាអ្នកនិយាយជំនួសយ៉ូសែប ជាអ្នកបំរើរបស់យើង ។

៨ *ក* ម៉ាថាយ ១៩:២៩.
**១០០** ១ *ក* ស.ប. រិកដុន, ស៊ីឌនី.
*ខ* ស.ប. ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ
៤ *ក* ស.ប. សេចក្ដីសង្គ្រោះ.
៥ *ក* ហេលេ. ៥:១៨;
គ. និង ស. ៦៨:៣–៤.
៦ *ក* ម៉ាថាយ ១០:១៩–២០;
គ. និង ស. ៨៤:៨៥.
៧ *ក* គ. និង ស. ៨៤:៦១.
*ខ* ស.ប. ស្លូតបូត, ភាពស្លូតបូត.
៨ *ក* ២ នីហ្វៃ ៣៣:១–៤.
៩ *ក* និក្ខ. ៤:១៤–១៦;
២ នីហ្វៃ ៣:១៧–១៨;
គ. និង ស. ១២៤:១០៣–១០៤.

១០ ហើយយើងនឹងប្រទានដល់លោក នូវអំណាចដើម្បីឲ្យបាន
ខ្លាំងក្លា [ក]ក្នុងការថ្លែងទីបន្ទាល់ ។
១១ ហើយយើងនឹងប្រទានដល់អ្នក នូវ[ក]អំណាចដើម្បីឲ្យបាន
ខ្លាំងក្លា ក្នុងការពន្យល់អស់ទាំងបទគម្ពីរ ប្រយោជន៍ឲ្យអ្នក
អាចធ្វើជាអ្នក និយាយជំនួសលោក ហើយលោកនឹងត្រូវធ្វើជា
[ខ]អ្នកបើកសម្ដែងដល់អ្នក ប្រយោជន៍ឲ្យអ្នកអាចដឹងយ៉ាងពិត អំពី
គ្រប់ការណ៍ទាំងអស់ ដែលទាក់ទងទៅនិងការណ៍ទាំងឡាយ នៃ
នគររបស់យើងនៅលើផែនដី ។
១២ ហេតុដូច្នេះហើយ ចូរបន្ដដំណើររបស់អ្នក ហើយចូរឲ្យ
ចិត្តអ្នកបានសប្បាយរីករាយចុះ; ត្បិតមើលចុះ និងមើលន៏
យើងគង់នៅជា មួយអ្នករហូតដល់ចុងបំផុត ។
១៣ ហើយឥឡូវនេះ យើងប្រទានដល់អ្នក នូវព្រះបន្ទូលមួយ
អំពី[ក]ស៊ីយ៉ូន ។ ស៊ីយ៉ូននឹងត្រូវបាន[ខ]ប្រោសលោះ ទោះជានាងត្រូវ
បានវាយ ផ្ចាល អស់មួយរដូវខ្លីក៏ដោយ ។
១៤ បងប្អូនរបស់អ្នក គឺអួរសុន [ក]ហៃឌ និង យ៉ូហាន គូឌ
ជាពួកអ្នកបំរើរបស់យើង កំពុងតែនៅក្នុងព្រះហស្ដរបស់យើង
ហើយ; ហើយ ដរាបណាពួកគេកាន់តាមព្រះបញ្ញត្តិទាំងឡាយ
របស់យើង នោះពួកគេនឹងបានសង្គ្រោះ ។
១៥ ហេតុដូច្នេះហើយ ចូរឲ្យចិត្តអ្នកបានក្សាន្តចុះ; ត្បិត
គ្រប់ការណ៍[ក]ទាំងអស់នឹងបានផ្សំគ្នា សំរាប់សេចក្ដីល្អដល់ពួកគេ
ដែលដើរដោយ ទៀងត្រង់ ហើយដើម្បីសេចក្ដីញែកចេញជា
បរិសុទ្ធនៃសាសនាចក្រ ។
១៦ ត្បិតយើងនឹងបង្កើតឡើងនូវប្រជាជន[ក]បរិសុទ្ធមួយដល់យើង
ដែលនឹងបំរើយើង ដោយនូវសេចក្ដីសុចរិត;
១៧ ហើយគ្រប់មនុស្សទាំងអស់ដែល[ក]អំពាវនាវដល់ព្រះនាមនៃ
ព្រះអម្ចាស់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់
នោះនឹងបានសង្គ្រោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១០១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៨៣៣ (*History of the Church*, ១:៤៥៨–៤៦៤) ។ នៅពេលនេះ ពួកបរិសុទ្ធដែលបានប្រមូលគ្នាទៅរដ្ឋមិសសួរី កំពុងតែរងទុក្ខវេទនានូវការ បៀតបៀនដ៏ធំ ។ ពួកមនុស្សកំណាចបានដេញពួកគេចេញពីផ្ទះសំបែងគេ នៅឃុំចាកសុន ហើយ ពួកបរិសុទ្ធខ្លះបានខំតាំងខ្លួននៅ ឃុំវ៉ាន់ បួរិន ប៉ុន្ដែសេចក្ដីបៀតបៀនបានទៅតាមពួកគេទៀត ។ នៅពេលនោះ មានក្រុមពួក បរិសុទ្ធដ៏ធំកំពុងនៅឃុំឃ្លេ រដ្ឋមិសសួរី ។ មានការគំរាមកំហែងជាច្រើនចង់រកសម្លាប់សមាជិកសាសនាចក្រចោល ។ ប្រជាជនបានបាត់បង់គ្រឿង សំលៀកបំពាក់ គោក្របី និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផ្សេងៗទៀតផង; ហើយដំណាំដ៏ច្រើនរបស់ពួកគេ ត្រូវបានបំផ្លាញចោល ។*

*១–៨, ពួកបរិសុទ្ធត្រូវបានវាយផ្ចាល ហើយរងទុក្ខ ព្រោះតែការរំលងទាំងឡាយរបស់ពួកគេ; ៩–១៥, សេចក្ដីគ្នាន់ក្នាញ់របស់ព្រះ អម្ចាស់នឹងធ្លាក់មកលើសាសន៍ទាំងឡាយ ប៉ុន្ដែរាស្ត្ររបស់ទ្រង់នឹងបានប្រមូលគ្នា ហើយនឹងបានកំសាន្តចិត្ត; ១៦–២១, ស៊ីយ៉ូន និងស្ដេកទាំងឡាយរបស់នាង នឹងត្រូវបានតាំងឡើង; ២២–៣១, ស្ថានភាពនៃជីវិតរស់នៅក្នុងពេលសហស្សវត្សរ៍ត្រូវបានថែងប្រាប់; ៣២–៤២, ខណៈនោះ ពួកបរិសុទ្ធនឹងបានពរហើយបានរង្វាន់; ៤៣–៦២, ពាក្យប្រៀបប្រដូចអំពីបុរសត្រកូលខ្ពស់ម្នាក់ និងដើមអូលីវ បញ្ជាក់ប្រាប់ពីទុក្ខកង្វល់ទាំងឡាយ និងសេចក្ដីប្រោសលោះដែលជាយថាហេតុនៃស៊ីយ៉ូន; ៦៣–៧៥, ពួកបរិសុទ្ធត្រូវតែប្រមូលគ្នាតទៅ ទៀត; ៧៦–៨០, ព្រះអម្ចាស់ទ្រង់បានតាំងរដ្ឋធម្មនុញ្ញនៃសហរដ្ឋ; ៨១–១០១, ពួកបរិសុទ្ធត្រូវតវ៉ាសូមឲ្យកែសាទុក្ខ តាមពាក្យប្រៀបប្រដូច អំពីស្ត្រី និងចៅក្រមដ៏ឥតយុត្តិធម៌ម្នាក់ ។*

១០ *ក* ស.ប. ធ្វើបន្ទាល់.
១១ *ក* អាលម៉ា ១៧:២–៣.
*ខ* គ. និង ស. ១២៤:១២៥.
១៣ *ក* ស.ប. ស៊ីយ៉ូន.
*ខ* គ. និង ស. ៨៤:៩៩;
១០៥:៩–១០, ៣១, ៣៧.
១៤ *ក* ស.ប. ហៃឌ, អួរសុន.
១៥ *ក* រ៉ូម ៨:២៨;
គ. និង ស. ៩០:២៤; ១០៥:៤០.
១៦ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
១៧ *ក* យ៉ូអែល ២:៣២;
អាលម៉ា ៣៨:៤–៥.

ប្រាកដមែន យើងប្រាប់អ្នកអំពីពួកបងប្អូនអ្នកក្នុងសាសនា ដែលត្រូវបានរងទុក្ខ បៀតបៀន និងដេញចេញពីដែនដីនៃកេរ្ដិ៍មរតករបស់ពួក គេថា —

២ យើងជាព្រះអម្ចាស់បានអនុញ្ញាតឲ្យមានសេចក្ដីវេទនាមកលើពួកគេ ដែលពួកគេមានសេចក្ដីទុក្ខវេទនានោះ ក៏ព្រោះតែអំពើរំលង ទាំងឡាយរបស់ពួកគេ;

៣ ប៉ុន្តែយើងនឹងបានពួកគេ ហើយនៅថ្ងៃនោះ ពួកគេនឹងបានជារបស់យើង ក្នុងកាលយើងនឹងយាងមករើសគ្រឿងអលង្ការទាំងឡាយ របស់យើង ។

៤ ហេតុដូច្នេះហើយ ពួកគេត្រូវការបានវាយផ្ចាល និងសាកល្បង ដូចជាលោកអ័ប្រាហាំដែរ ដែលត្រូវបានបញ្ជាឲ្យបូជាកូនប្រុស តែមួយ របស់លោក ។

៥ ត្បិតអស់អ្នកណាដែលមិនព្រមទ្រាំទ្រក្នុងសេចក្ដីវាយផ្ចាល តែមិនទទួលស្គាល់យើង នោះមិនអាចញែកចេញជាបរិសុទ្ធបានឡើយ ។

៦ មើលចុះ យើងប្រាប់អ្នកថា មានការរង្កៀសចិត្ត និងការទាស់ទែងគ្នា និងការច្រណែនគ្នា និងការប្រឆាំងគ្នា និងការប៉ងប្រាថ្នាខាង តណ្ហា និងខាងលោភលន់ នៅក្នុងចំណោមពួកគេទាំងឡាយ; ហេតុដូច្នេះហើយ ដោយសាររបស់ទាំងនេះទើបពួកគេបានបង្ខូចកេរ្ដិ៍ មរតកទាំងឡាយរបស់ខ្លួនចោល ។

៧ ពួកគេកម្រនឹងស្ដាប់តាមសម្លេងនៃព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេ; ហេតុដូច្នេះហើយ ព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេក៏ក្រនឹងឮបទ អធិស្ឋានទាំងឡាយរបស់ពួកគេ ដើម្បីឆ្លើយតបបទអធិស្ឋានទាំងនោះ នៅថ្ងៃដែលពួកគេមានទុក្ខខ្វល់ខ្វាយដែរ ។

៨ នៅថ្ងៃដែលពួកគេមានសេចក្ដីសុខសាន្ត នោះពួកគេរាប់ពាក្យដំបូន្មានរបស់យើងថាមានប្រយោជន៍បន្តិចបន្តួច; ប៉ុន្តែនៅថ្ងៃដែលពួក គេមានទុក្ខខ្វល់ខ្វាយ នោះពួកគេខំរាវរកយើង មកពីការចាំបាច់ ។

៩ យើងប្រាប់អ្នកជាប្រាកដថា ទោះជាពួកគេមានបាបក៏ដោយគង់តែចិត្តយើងពោរពេញទៅដោយសេចក្ដីអាណិតមេត្តាដល់ពួកគេដែរ ។ យើងនឹងមិនបណ្ដេញពួកគេចេញអស់រលីងឡើយ; ហើយនៅថ្ងៃនៃសេចក្ដីក្រោធ នោះយើងនឹងនឹកចាំដល់សេចក្ដីមេត្តាករុណា ។

១០ យើងបានស្បថ ហើយព្រះរាជឱង្ការបានចេញទៅ ដោយសារព្រះបញ្ញត្តិដើម ដែលយើងបានប្រទានដល់អ្នក ប្រយោជន៍ឲ្យយើង បានទំលាក់ដាវនៃព្រះពិរោធរបស់យើង ជំនួសប្រជារាស្ត្ររបស់យើងវិញ; ហើយដូចជាយើងបានមានព្រះបន្ទូលមកហើយ នោះហេតុ ការណ៍នឹងបានកន្លងផុត ។

១១ ព្រះពិរោធរបស់យើងនឹងឆាប់បង្ហូរមកលើគ្រប់អស់ទាំងសាសន៍ ដោយគ្មានកំរិតឡើយ; ហើយយើងនឹងធ្វើការនេះក្នុងកាលពេង នៃសេចក្ដីទុច្ចរិតរបស់ពួកគេកំពុងតែពេញ ។

១២ ហើយនៅថ្ងៃនោះ អស់អ្នកណាដែលបានឃើញនៅលើប៉មចាំយាម ឬម្យ៉ាងទៀតថា គឺអស់ទាំងពួកសាសន៍អ៊ីស្រាអែលរបស់យើង នឹងបានសង្គ្រោះ ។

១៣ ហើយពួកអ្នកដែលត្រូវបានខ្ចាត់ព្រាត់ នោះនឹងបានប្រមូលមកវិញ ។

១៤ ហើយអស់អ្នកណាដែលយំសោក នោះនឹងបានសេចក្ដីកំសាន្ដចិត្ត ។

១០១ ១*ក* ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
*ខ* គ. និង ស. ១០៣:១–២, ១១;
១០៩:៤៧.
២ *ក* គ. និង ស. ៥៨:៣–៤.
*ខ* ម៉ូសាយ ៧:២៩–៣០;
គ. និង ស. ១០៣:៤;
១០៥:២–១០.
៣ *ក* អេសាយ ៦២:៣;
ម៉ាឡាគី ៣:១៧;
គ. និង ស. ៦០:៤.
៤ *ក* គ. និង ស. ៩៥:១–២;
១៣៦:៣១.
ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* លោកុ. ២២:១–១៤;
យ៉ាកុប ៤:៥.
ស.ប. អ័ប្រាហាំ.
៥ *ក* ម៉ាថាយ ១០:៣២–៣៣;
រ៉ូម ១:១៦; ២ នីហ្វៃ ៣១:១៤.
*ខ* ស.ប. ការញែកជាបរិសុទ្ធ.
៦ *ក* ស.ប. ការទាស់ទែង.
*ខ* ស.ប. ច្រណែន.
*គ* ស.ប. សំរេកស្រើប.
៧ *ក* អេសាយ ៥៩:២;
ម៉ូសាយ ១១:២២–២៥; ២១:១៥;
អាលម៉ា ៥:៣៨.
៨ *ក* ហេលេ. ១២:៣.
*ខ* កិច្ចការ ១៧:២៧;
អាលម៉ា ៣២:៥–១៦.
៩ *ក* ស.ប. អាណិត;
សេចក្ដីមេត្តាករុណា, មេត្តាករុណា.
*ខ* យេរេ. ៣០:១១.
*គ* គ. និង ស. ៩៨:២១–២២.
១០ *ក* គ. និង ស. ១:១៣–១៤.
១១ *ក* ហេលេ. ១៣:១៤;
អេធើរ ២:៩–១១.
១២ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
១៣ *ក* ចោទិ. ៣០:៣–៦;
១ នីហ្វៃ ១០:១៤.
ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
១៤ *ក* ម៉ាថាយ ៥:៤.

១៥ ហើយអស់អ្នកណាដែលប្តូរ[ក]ជីវិតរបស់ខ្លួន សំរាប់ព្រះនាមរបស់យើង នោះនឹងបានពាក់មកុដ ។

១៦ ហេតុដូច្នេះហើយ ចូរឲ្យចិត្តអ្នកបានក្សាន្តអំពីស៊ីយ៉ូនចុះ; ក្បិតសាច់ឈាមទាំងអស់នៅក្នុង[ក]ព្រះហស្តរបស់យើងហើយ; ចូរបង្អង់សិន [ខ]ឲ្យបានដឹងថា យើងជាព្រះ ។

១៧ [ក]ស៊ីយ៉ូននឹងមិនត្រូវបានរើចេញពីកន្លែងនាងឡើយ ទោះជាកូនចៅនាងត្រូវខ្ចាត់ព្រាត់ក៏ដោយ ។

១៨ ពួកអ្នកដែលនៅ ហើយមានចិត្តបរិសុទ្ធ នោះនឹង[ក]វិលមករកកេរ្តិ៍មរតកទាំងឡាយរបស់ពួកគេវិញ គឺពួកគេ និងកូនចៅរបស់ពួកគេ ផង ដោយ[ខ]ចំរៀងទាំងឡាយអំពីសេចក្តី[គ]អំណរដ៏អស់កល្បអស់កាលជានិច្ច ដើម្បីសង់ទីចាស់នៃស៊ីយ៉ូនដែលខូចបង់ឡើងជាថ្មី —

១៩ ហើយគ្រប់ការណ៍ទាំងនេះ ដើម្បីឲ្យបានសំរេចតាមពួកព្យាការី ។

២០ ហើយមើលចុះ គ្មាន[ក]កន្លែងណាមួយទៀតឡើយដែលបានតាំងឡើង ក្រៅពីកន្លែងដែលយើងបានតាំងនោះ; ហើយគ្មានកន្លែងណា ទៀតឡើយដែលបានតាំងឡើង ក្រៅពីកន្លែងដែលយើងបានតាំងនោះ សំរាប់កិច្ចការនៃការប្រមូលពួកបរិសុទ្ធរបស់យើង —

២១ រហូតដល់ថ្ងៃនោះមកដល់ ក្នុងកាលគ្មានបន្ទប់សំរាប់ពួកគេទៀតឡើយ; ហើយនៅខណៈនោះ យើងមានកន្លែងផ្សេងៗទៀតដែលយើងនឹងតាំងដល់ពួកគេ ហើយទីនោះនឹងត្រូវបានហៅថា [ក]ស្តេក សំរាប់ជារនាំង ឬជាកម្លាំងនៃស៊ីយ៉ូន ។

២២ មើលចុះ នេះហើយជាព្រះហឫទ័យរបស់យើង ថាអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមយើង ហើយថ្វាយបង្គំយើងតាមដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ចរបស់យើង នោះត្រូវ[ក]ប្រមូលគ្នា ហើយ[ខ]ឈរនៅទីបរិសុទ្ធនានា;

២៣ ហើយរៀបចំសំរាប់វិវរណៈដែលនឹងមកដល់ ក្នុងកាល[ក]វាំងននគ្រប់ព្រះវិហាររបស់យើង នៅក្នុងរោងឧបោសថរបស់យើងដែលលាក់ផែនដី នោះនឹងត្រូវបានបើកឡើង ហើយអស់ទាំងមនុស្សនឹង[ខ]បានឃើញយើងគ្រប់គ្នា ។

២៤ ហើយអ្វីៗដែល[ក]ពុករលួយគ្រប់យ៉ាង ទាំងមនុស្ស ឬសត្វនៅវាល ឬសត្វស្លាបហើរលើមេឃ ឬត្រីនៅសមុទ្រក៏ដោយ ដែលរស់នៅ លើអស់ទាំងផ្ទៃផែនដី នោះនឹង[ខ]ត្រូវបានបំផ្លាញបង់;

២៥ ហើយព្រមទាំងធាតុសារពើក៏នឹង[ក]រលាយទៅ ដោយកំដៅដ៏ក្រៃលែង ហើយគ្រប់ទាំងអស់នឹងត្រឡប់ជា[ខ]ថ្មី ប្រយោជន៍ឲ្យដំរិះ និង[គ]សិរីល្អរបស់យើង អាចមាននៅលើអស់ទាំងផែនដី ។

២៦ ហើយនៅថ្ងៃនោះ សេចក្តី[ក]ខ្មាំងនៃមនុស្ស និងសេចក្តីខ្មាំងនៃសត្វទាំងឡាយ មែនហើយ គឺសេចក្តីខ្មាំងនៃអស់ទាំងសាច់ឈាមនឹងឈប់មាននៅចំពោះព្រះភ័ក្ត្ររបស់យើង ។

២៧ ហើយនៅថ្ងៃនោះ អ្វីក៏ដោយដែលមនុស្សណាម្នាក់សូម នោះនឹងត្រូវបានប្រទានដល់អ្នកនោះ ។

២៨ ហើយនៅថ្ងៃនោះ [ក]អារក្សសាតាំងនឹងពុំមានអំណាចដើម្បីល្បួងមនុស្សណាឡើយ ។

២៩ ហើយនឹងពុំមាន[ក]សេចក្តីទុក្ខព្រួយឡើយ ពីព្រោះពុំមានសេចក្តីស្លាប់ទេ ។

៣០ នៅថ្ងៃនោះ [ក]ទារកនឹងមិនស្លាប់ឡើយ ទាល់តែវាមានអាយុច្រើន; ហើយជីវិតវានឹងបានយឺនយូរដូចជាអាយុដើមឈើ;

៣១ ហើយកាលវាស្លាប់ទៅ នោះវានឹងមិនដេកលក់ គឺនៅ

១៥ *ក* ម៉ាថាយ ១០:៣៩.
ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
១៦ *ក* ម៉ូសេ ៦:៣២.
*ខ* និក្ខ. ១៤:១៣–១៤;
ទំនុក. ៤៦:១០.
១៧ *ក* ស.ប. ស៊ីយ៉ូន.
១៨ *ក* គ. និង ស. ១០៣:១១–១៤.
*ខ* អេសាយ ៣៥:១០;
គ. និង ស. ៤៥:៧១.
ស.ប. ច្រៀង.
*គ* អេម៉ុស ៩:១៣–១៥;
គ. និង ស. ៨៤:២–៥;
១០៣:១១.
២០ *ក* គ. និង ស. ៥៧:១–៤.
២១ *ក* គ. និង ស. ៨២:១៣–១៤;
១១៥:៦, ១៧–១៨.
ស.ប. ចំរឹង, ស្តេក.
២២ *ក* ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* ម៉ាថាយ ២៤:១៥;
គ. និង ស. ៤៥:៣២; ១១៥:៦.
២៣ *ក* ស.ប. វាំងនន.
*ខ* អេសាយ ៤០:៥;
គ. និង ស. ៣៨:៨; ៩៣:១.
ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
២៤ *ក* គ. និង ស. ២៩:២៤.
*ខ* សេផា. ១:២–៣; ម៉ាឡាគី ៤:១;
គ. និង ស. ៨៨:៩៤;
យ.ស. — ប្រវត្តិ ១:៣៧.
២៥ *ក* អេម៉ុស ៩:៥;
២ ពេត្រុស ៣:១០–១៤.
ស.ប. ផែនដី —
ការសំអាតផែនដី.
*ខ* វិវរ. ២១:៥.
*គ* ស.ប. សហស្សវត្សរ៍.
២៦ *ក* អេសាយ ១១:៦–៩.
ស.ប. សេចក្តីខ្មាំង.
*ខ* ស.ប. សេចក្តីសុខសាន្ត.
២៨ *ក* វិវរ. ២០:២–៣;
១ នីហ្វៃ ២២:២៦;
គ. និង ស. ៨៨:១១០.
២៩ *ក* វិវរ. ២១:៤.
៣០ *ក* អេសាយ ៦៥:២០–២២;
គ. និង ស. ៦៣:៥១.

ក្នុងដីទេ ប៉ុន្តែនឹង[ក]ផ្លាស់ប្រែមួយប៉ប្រិចភ្នែក ហើយនឹង[ខ]បានលើកឡើង
ហើយសេចក្ដីសំរាករបស់វានឹងបានជាទីរុងរឿងឧត្ដម ។
៣២ មែនហើយ យើងប្រាប់អ្នកជាប្រាកដថា នៅ[ក]ថ្ងៃនោះ ក្នុង
កាលព្រះអម្ចាស់នឹងយាងមក នោះព្រះអង្គនឹង[ខ]បើកសំដែងគ្រប់
ទាំងអស់ —
៣៣ របស់របរដែលបានកន្លងផុតទៅ ហើយរបស់របរ
ដែល[ក]អាថិកំបាំង ដែលគ្មានមនុស្សណាស្គាល់ របស់របរពីផែនដី
ដែលត្រូវបាន បង្កើតឡើង និងគោលបំណង និងចុងបង្ហើយ
នៃផែនដី —
៣៤ របស់របរដែលវិសេសវិសាល របស់របរដែលនៅខាងលើ
និងរបស់របរដែលនៅខាងក្រោម របស់របរនៅក្នុងផែនដី និងនៅ
លើផែនដី និងនៅលើស្ថានសួគ៌ ។
៣៥ ហើយអស់អ្នកណាដែលស៊ូទ្រាំ[ក]សេចក្ដីបៀតបៀន ដោយ
ព្រោះព្រះនាមរបស់យើង ហើយកាន់ខ្ជាប់ក្នុងសេចក្ដី[ខ]ជំនឿ ទោះ
ជា ពួកគេត្រូវបានហៅឲ្យប្ដូរជីវិតរបស់ខ្លួនដោយព្រោះយើងក្ដី
គង់តែពួកគេនឹងបានទទួលនៅអស់ទាំងសិរីល្អទាំងនេះដែរ ។
៣៦ ហេតុដូច្នោះហើយ ចូរកុំខ្លាចទោះជាដល់[ក]ការ
ស្លាប់ក៏ដោយ ត្បិតនៅក្នុងពិភពលោកនេះ សេចក្ដី[ខ]អំណររបស់
អ្នកពុំបានពោរ ពេញទេ ប៉ុន្តែនៅក្នុងយើង ទើបសេចក្ដីអំណរ
របស់អ្នកបានពោរពេញ ។
៣៧ ហេតុដូច្នេះហើយ ចូរកុំគិតពីរូបកាយ ឬពីជីវិត
នៃរូបកាយឡើយ; ប៉ុន្តែចូរគិតពី[ក]ព្រលឹង និងពីជីវិតនៃព្រលឹងវិញ ។
៣៨ ហើយចូរ[ក]ស្វែងរកព្រះភក្ត្រនៃព្រះអម្ចាស់ជានិច្ច ប្រយោជន៍
ឲ្យអ្នករាល់គ្នាអាចបានព្រលឹងរបស់ខ្លួន ដោយមាន[ខ]ចិត្តអត់ធន់
ហើយអ្នករាល់គ្នានឹងបានជីវិតដ៏នៅអស់កល្បជានិច្ច ។
៣៩ កាលណាមនុស្សត្រូវបានហៅចំពោះ[ក]ដំណឹងល្អដ៏អស់កល្ប
អស់កាលរបស់យើង និងសេចក្ដីសញ្ញា ដោយសេចក្ដីសញ្ញា
ដ៏អស់កល្បអស់កាលជានិច្ច នោះពួកគេត្រូវបានរាប់ដូចជា[ខ]អំបិល
នៃផែនដី និងជាជាតិប្រៃនៃមនុស្ស;
៤០ ពួកគេត្រូវបានហៅឲ្យធ្វើជាតិប្រៃនៃមនុស្ស; ហេតុ
ដូច្នេះហើយ បើសិនជាអំបិលនៃផែនដីបាត់ជាតិប្រៃហើយ មើលចុះ
វាគ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ
ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ ។
៤១ មើលចុះ នេះហើយជាប្រាជ្ញាអំពីកូនចៅនៃស៊ីយ៉ូន
គឺមនុស្សជាច្រើន ប៉ុន្តែពុំមែនទាំងអស់គ្នាទេ; ពួកគេត្រូវបាន
ឃើញថាជា អ្នករំលងច្បាប់ ហេតុដូច្នេះហើយ ពួកគេត្រូវ
[ក]ការវាយផ្ចាល —
៤២ អ្នកណាដែល[ក]ដំកើងខ្លួន នោះនឹងត្រូវបន្ទាបចុះ ហើយអ្នក
ណាដែល[ខ]បន្ទាបខ្លួន នោះនឹងត្រូវដំកើងឡើងវិញ ។
៤៣ ហើយឥឡូវនេះ យើងនឹងបង្ហាញដល់អ្នក នូវពាក្យ
ប្រៀបប្រដូចមួយ ប្រយោជន៍ឲ្យអ្នកអាចដឹងពីព្រះហឫទ័យ
របស់យើង ដែលយើងមានអំពីសេចក្ដីប្រោសលោះនៃ
ស៊ីយ៉ូន ។
៤៤ មាន[ក]បុរសត្រកូលខ្ពស់ម្នាក់ លោកមានដីធ្លីមួយកន្លែង
ដ៏ជំរើសណាស់; ហើយលោកបានមានប្រសាសន៍ទៅកាន់ពួក
អ្នកបំរើ របស់លោកថា៖ ចូរអ្នករាល់គ្នាទៅ[ខ]ចំការរបស់យើង
គឺនៅលើដីធ្លីដ៏ជំរើសនេះ ហើយដាំដើមអូលីវ១២ដើមចុះ;
៤៥ ហើយចូរដាក់[ក]អ្នកយាមជុំវិញដើមទាំងនោះ ហើយសង់
ប៉មមួយ ប្រយោជន៍ឲ្យនរណាមួយអាចសម្លឹងមើលជុំវិញដែនដី
ដើម្បីឲ្យ ធ្វើជាអ្នកយាមនៅលើប៉ម ប្រយោជន៍កុំឲ្យដើមអូលីវទាំង
ឡាយរបស់យើងត្រូវបាក់ចុះ ក្នុងកាលខ្មាំងសត្រូវមកបង្ខូច
ហើយបេះយក ដល់ខ្លួន នូវផ្លែនៃចំការរបស់យើងឡើយ ។
៤៦ ឥឡូវនេះ ពួកអ្នកបំរើនៃបុរសត្រកូលខ្ពស់ក៏បានទៅ ហើយ
ប្រព្រឹត្តតាមអ្វីដែលចៅហ្វាយរបស់ខ្លួនបានបញ្ជាដល់ពួកគេ ហើយ

៣១ *ក* ១ កូរិន. ១៥:៥២;
គ. និង ស. ៤៣:៣២.
*ខ* ១ ថែស្សា. ៤:១៦–១៧.
៣២ *ក* គ. និង ស. ២៩:១១.
ស.ប. សហស្សវត្សរ៍.
*ខ* គ. និង ស. ១២១:២៦–២៨.
៣៣ *ក* ស.ប. សេចក្ដីអាថិកំបាំងទាំងឡាយនៃ
ព្រះ.
៣៥ *ក* គ. និង ស. ៦៣:២០.
ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
*ខ* គ. និង ស. ៩៨:១៣.
៣៦ *ក* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
*ខ* ស.ប. សេចក្ដីអំណរ.
៣៧ *ក* ស.ប. ព្រលឹង.
៣៨ *ក* ២ របា. ៧:១៤;
គ. និង ស. ៩៣:១.
*ខ* ស.ប. សេចក្ដីអត់ធន់.
៣៩ *ក* ស.ប. សេចក្ដីសញ្ញាថ្មី
ហើយអស់កល្បជានិច្ច.
*ខ* ម៉ាថាយ ៥:១៣;
គ. និង ស. ១០៣:១០.
៤១ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
៤២ *ក* អូបា. ១:៣–៤; លូកា ១៤:១១;
ហេលេ. ៤:១២–១៣.
*ខ* លូកា ១៨:១៤.
ស.ប. បន្ទាបខ្លួន,
ចិត្តសុភាពរាបសា.
៤៤ *ក* គ. និង ស. ១០៣:២១–២២.
*ខ* ស.ប. ចំការទំពាំងបាយជូរនៃព្រះ
អម្ចាស់.
៤៥ *ក* អេសេ. ៣៣:២, ៧;
៣ នីហ្វៃ ១៦:១៨.
ស.ប. ចាំយាម, ពួកអ្នកចាំយាម.

ដាំ ដើមអូលីវទាំងឡាយ ហើយសង់របងជុំវិញ ហើយដាក់អ្នកយាម ហើយចាប់ផ្ដើមសង់ប៉មមួយ ។

៤៧ ហើយនៅពេលពួកគេកំពុងតែចាក់គ្រឹះប៉មនោះ ស្រាប់តែពួកគេបាននិយាយគ្នាថា៖ ហើយតើចៅហ្វាយរបស់យើងត្រូវការ អ្វីនឹងប៉មនេះ ?

៤៨ ហើយបានពិគ្រោះគ្នាជាយូរ ដោយនិយាយគ្នាថា៖ តើចៅហ្វាយរបស់យើងត្រូវការអ្វីនឹងប៉មនេះ ដោយឃើញថា នេះជា ពេលសុខសាន្តត្រាន ?

៤៩ តើមិនគួរយកប្រាក់នេះទៅផ្ញើទុកនឹងអ្នកចងការទេឬអី ? ត្បិតមិនត្រូវការរបស់ទាំងនេះឡើយ ។

៥០ ហើយនៅពេលពួកគេកំពុងតែជជែកគ្នាទៅវិញទៅមក ស្រាប់តែពួកគេត្រឡប់ទៅជាខ្ជិលច្រអូស ហើយពួកគេមិនបានស្ដាប់ តាមបញ្ជាទាំងឡាយរបស់ចៅហ្វាយខ្លួនឡើយ ។

៥១ ហើយខ្មាំងសត្រូវបានមកពេលយប់ ហើយបំបាក់[ក]របង; ហើយពួកអ្នកបំរើនៃបុរសត្រកូលខ្ពស់បានក្រោកឡើង ហើយបានភ័យញ័រ ហើយបានរត់ចេញ; ហើយខ្មាំងសត្រូវបានបំផ្លាញកិច្ចការទាំងឡាយរបស់ពួកគេចោល ហើយបានរំលំដើមអូលីវទាំងឡាយចុះ ។

៥២ ឥឡូវនេះ មើលចុះ បុរសត្រកូលខ្ពស់ ជាចៅហ្វាយនៃចំការ លោកបានហៅពួកអ្នកបំរើរបស់លោក ហើយបានមានប្រសាសន៍ ទៅកាន់ពួកគេថា៖ ហេតុអ្វី! ដែលបណ្ដាលឲ្យការអាក្រក់នេះកើតឡើង?

៥៣ ម្ដេចក៏អ្នករាល់គ្នាមិនបានប្រព្រឹត្តតាមអ្វីដែលយើងបានបញ្ជាដល់អ្នក ហើយ — បន្ទាប់ពីអ្នករាល់គ្នាបានដាំដំណាំក្នុងចំការ ហើយសង់របងជុំវិញ ហើយដាក់អ្នកយាមនៅលើកំផែងរបងទាំងឡាយរួចហើយ — សង់ប៉មមួយដែរ ហើយបានដាក់អ្នកយាម នៅលើប៉ម ហើយបានមើលចំការរបស់យើង ហើយពុំបានដេកឡើយ ក្រែងខ្មាំងសត្រូវនឹងមកលើអ្នក ?

៥៤ ហើយមើលចុះ អ្នកយាមនៅលើប៉មនឹងអាចមើលឃើញខ្មាំងសត្រូវ នៅពេលវានៅឆ្ងាយម្លេះ; ហើយខណៈនោះ អ្នករាល់គ្នានឹង អាចបានប្រុងប្រៀបខ្លួន ហើយរារាំងខ្មាំងសត្រូវកុំឲ្យបំបាក់របងចំការចុះ ហើយអ្នកនឹងអាចជួយសង្គ្រោះចំការរបស់យើង ពីកណ្ដាប់ដៃ នៃមេបំផ្លាញ ។

៥៥ ហើយចៅហ្វាយនៃចំការបានមានប្រសាសន៍ទៅកាន់ពួកអ្នកបំរើរបស់លោកថា៖ ចូរទៅ ហើយប្រមូល[ក]ពួកអ្នកបំរើរបស់យើងដែល នៅសល់ទាំងប៉ុន្មាន ហើយយកកម្លាំងទាំងអស់ពីវង្សារបស់យើង ដែលមានពលទ័ពរបស់យើង ពួកកំឡោះរបស់យើង និងពួកអ្នក ដែលមានវ័យកណ្ដាល ព្រមទាំងក្នុងចំណោមអស់ទាំងអ្នកបំរើរបស់យើងផង ដែលជាកម្លាំងនៃវង្សាយើង លើកលែងតែពួកអ្នកដែល យើងបានចាត់ឲ្យនៅប៉ុណ្ណោះ;

៥៦ ហើយចូរអ្នករាល់គ្នាប្រញាប់ទៅឯដែនដីនៃចំការរបស់យើង ហើយរំដោះចំការយើងមកវិញ ត្បិតវាជារបស់យើង; យើងបានទិញ វាដោយប្រាក់ ។

៥៧ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាប្រញាប់ទៅឯដែនដីរបស់យើង; ចូរបំបាក់កំផែងនៃពួកខ្មាំងសត្រូវរបស់យើង; ចូររំលំប៉មរបស់គេចុះ ហើយបំបែកពួកអ្នកយាមរបស់គេចេញខ្ចាត់ខ្ចាយ ។

៥៨ ហើយដរាបណាពួកគេប្រមូលគ្នាមកទាស់នឹងអ្នក នោះចូរ[ក]សងសឹកពួកខ្មាំងសត្រូវឲ្យយើង ប្រយោជន៍ឲ្យបន្តិចទៀតយើងអាចមកជាមួយនឹងវង្សាយើង ដែលនៅសល់ទាំងប៉ុន្មាន ហើយយកដែនដីវិញ ។

៥៩ ហើយអ្នកបំរើបានទូលដល់ចៅហ្វាយខ្លួនថា៖ តើការទាំងនេះនឹងកើតឡើងនៅពេលណា ?

៦០ ហើយលោកបានមានប្រសាសន៍ទៅកាន់អ្នកបំរើរបស់លោកថា៖ កាលដែលយើងប្រាថ្នា; ចូរអ្នករាល់គ្នាប្រញាប់ទៅ ហើយ ប្រព្រឹត្តនូវអ្វីៗគ្រប់យ៉ាង ដែលយើងបានបញ្ជាដល់អ្នកចុះ;

៦១ ហើយនេះនឹងទៅជាត្រា និងពររបស់យើងមកលើអ្នក — ជានាយតម្រួតការដ៏ស្មោះ[ខ]ត្រង់ ហើយ[ក]ឈ្លាសវៃនៅកណ្ដាលវង្សា របស់យើង ជាអ្នកត្រួតត្រានៅក្នុងនគររបស់យើង ។

៦២ ហើយអ្នកបំរើរបស់លោកក៏ប្រញាប់ទៅ ហើយបានប្រព្រឹត្តនូវអ្វីៗគ្រប់យ៉ាង ដែលចៅហ្វាយខ្លួនបានបញ្ជាដល់គេ; ហើយជាច្រើន [ក]ថ្ងៃក្រោយមក អ្វីៗគ្រប់យ៉ាងត្រូវបានសំរេចជាស្រេច ។

៦៣ ជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា យើងនឹងបង្ហាញដល់អ្នក នូវប្រាជ្ញាដែលមាននៅក្នុងយើង អំពីអស់ទាំងសាសនា

៥១ *ក* អេសាយ ៥:១–៧.
៥៥ *ក* គ. និង ស. ១០៣:២២, ២៩–៣០; ១០៥:១៦, ២៩–៣០.
៥៨ *ក* គ. និង ស. ៩៧:២២–២៤; ១០៥:១៥.
៦១ *ក* គ. និង ស. ៧៨:២២.
៦១ *ខ* ម៉ាថាយ ២៥:២០–២៣.
៦២ *ក* គ. និង ស. ១០៥:៣៧.

ចក្រ ដរាបណាពួកគេយល់ព្រមឲ្យណែនាំ ក្នុងផ្លូវត្រឹមត្រូវ សំរាប់សេចក្ដីសង្គ្រោះរបស់ពួកគេ —

៦៤ ប្រយោជន៍ឲ្យកិច្ចការខាងការប្រមូលពួកបរិសុទ្ធរបស់យើងអាចបានបន្តទៅ ប្រយោជន៍ឲ្យយើងអាចតាំងពួកគេឡើង ដល់ព្រះនាម របស់យើង នៅលើទីបរិសុទ្ធនានា; ត្បិតពេលច្រូតកាត់មកដល់ហើយ ហើយព្រះបន្ទូលរបស់យើងត្រូវតែបានសំរេច ។

៦៥ ហេតុដូច្នេះហើយ យើងត្រូវប្រមូលរាស្ត្ររបស់យើងជុំគ្នា តាមពាក្យប្រៀបប្រដូចអំពីស្រូវសាលី និងស្រងែ ប្រយោជន៍ឲ្យស្រូវសាលីអាចបានទៅក្នុងជង្រុក ដើម្បីឲ្យបានជីវិតដ៏នៅអស់កល្បជានិច្ច ហើយបានបំពាក់សិរីល្អខាងសេឡេស្ទាលទុកជាមកុដ ក្នុងកាល យើងនឹងយាងមកក្នុងនគរនៃព្រះវរបិតារបស់យើង ដើម្បីចែកឲ្យមនុស្សគ្រប់គ្នា តាមការប្រព្រឹត្តរបស់គេរៀងខ្លួន;

៦៦ នៅពេលស្រងែនឹងត្រូវចងជាកណ្ដាប់ ហើយចំណងរបស់វាមាំមួនណាស់ ប្រយោជន៍ឲ្យវាអាចបានដុតដោយភ្លើងដែលពន្លត់ មិនបាន ។

៦៧ ហេតុដូច្នេះហើយ យើងប្រទានបញ្ញត្តិមួយដល់អស់ទាំងសាសនាចក្រថា ពួកគេត្រូវប្រមូលគ្នាបន្តនៅកន្លែងនានាដែលយើងបាន ចាត់ទុក ។

៦៨ ទោះជាយ៉ាងណាក៏ដោយ ដូចជាយើងបានប្រាប់ដល់អ្នកហើយ នៅបញ្ញត្តិពីដើមថា ចូរកុំឲ្យការប្រមូលរបស់អ្នកធ្វើទៅដោយ ប្រញាប់ប្រញាល់ ឬដោយរត់ភៀសឡើយ; ប៉ុន្តែចូរឲ្យគ្រប់ទាំងអស់បានប្រុងប្រៀបចំពោះអ្នកជាស្រេច ។

៦៩ ហើយដើម្បីឲ្យគ្រប់ទាំងអស់បានប្រុងប្រៀបចំពោះអ្នកជាស្រេច នោះចូរគោរពតាមបញ្ញត្តិ ដែលយើងបានប្រទានឲ្យអំពីការណ៍ ទាំងនេះចុះ —

៧០ ដែលប្រាប់ ឬបង្រៀនឲ្យទិញដីធ្លីទាំងឡាយនិងប្រាក់ ដែលអាចទិញបានដោយប្រាក់ នៅក្នុងភូមិភាគជុំវិញដែនដី ដែលយើងបាន ចាត់ទុកជាដែនដីស៊ីយ៉ូន សំរាប់ការចាប់ផ្ដើមនៃការប្រមូលពួកបរិសុទ្ធរបស់យើង;

៧១ គ្រប់ដែនដីទាំងអស់ដែលអាចទិញបាន នៅក្នុងឃុំចាកសុន និងនៅឃុំជុំវិញទាំងឡាយ ហើយចូរទុកអ្វីដែលនៅសល់ទាំងប៉ុន្មាន នៅក្នុងព្រះហស្តរបស់យើងចុះ ។

៧២ ឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យគ្រប់សាសនាចក្រប្រមូលប្រាក់កាសរបស់ពួកគេទាំងអស់គ្នា; ចូរឲ្យការណ៍ទាំងនេះបាន សំរេចតាមពេលវេលារបស់ខ្លួន ប៉ុន្តែមិនមែនដោយប្រញាប់ប្រញាល់ទេ; ហើយចូរមើលឲ្យឃើញថាគ្រប់ទាំងអស់បានប្រុងប្រៀបចំពោះ អ្នកជាស្រេច ។

៧៣ ហើយចូរមនុស្សមានកិត្តិយសបានតាំងឡើង គឺពួកអ្នកប្រាជ្ញ ហើយចាត់ពួកគេឲ្យទៅទិញដីធ្លីទាំងនេះចុះ ។

៧៤ ហើយសាសនាចក្រទាំងឡាយនៅស្រុកនៃទិសខាងកើតៗ កាលណាពួកគេបានស្ថាបនាឡើង បើសិនជាពួកគេនឹងប្រុងស្ដាប់តាម ការទូន្មាននេះ នោះពួកគេអាចទិញដីធ្លីទាំងឡាយ ហើយប្រមូលគ្នាមកលើទីនោះ; ហើយដោយផ្លូវនេះ ទើបពួកគេអាចតាំងស៊ីយ៉ូន ឡើងបាន ។

៧៥ សូម្បីតែឥឡូវនេះ មានរបស់របរគ្រប់គ្រាន់ហើយ មែនហើយ គឺមានជាបរិបូរ ដើម្បីប្រោសលោះស៊ីយ៉ូន ហើយសង់ទីចាស់របស់ នាងដែលខូចបង់ឡើងជាថ្មី មិនត្រូវរលំទៀតឡើយ បើសិនជាសាសនាចក្រទាំងឡាយ ដែលហៅខ្លួនតាមព្រះនាមរបស់យើង យល់ព្រមស្ដាប់តាមសម្លេងរបស់យើង ។

៧៦ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា អស់អ្នកណាដែលត្រូវខ្ចាត់ព្រាត់ដោយពួកខ្មាំងសត្រូវរបស់ពួកគេ នោះគឺជាព្រះហឫទ័យរបស់យើង ថាពួកគេត្រូវតែបន្តតវ៉ាសូមឲ្យកែសាទុក្ខ និងការសង ដោយដៃនៃអស់អ្នកដែលត្រូវបានដាក់ឲ្យធ្វើជាពួកអ្នកត្រួតត្រា ហើយដែលមានសិទ្ធិអំណាចលើអ្នក —

៧៧ តាមក្រិត្យវិន័យទាំងឡាយ និងធម្មនុញ្ញនៃប្រជាជន ដែលយើងបានស៊ូទ្រាំឲ្យតាំងឡើង ហើយត្រូវឲ្យរក្សាទុក សំរាប់សិទ្ធិនានា និងសេចក្ដីការពារដល់គ្រប់សាច់ឈាមទាំងអស់ តាមគោលការណ៍ទាំងឡាយដែលយុត្តិធម៌ ហើយបរិសុទ្ធ;

៧៨ ថាមនុស្សគ្រប់រូបអាចប្រព្រឹត្តនូវគោលលទ្ធិ និងគោលការណ៍ ដែលទាក់ទងទៅនឹងពេលខាងមុខ តាមសិទ្ធិជ្រើសរើស

៦៤ *ក* គ. និង ស. ៨៧:៨.
*ខ* គ. និង ស. ៣៣:៣, ៧.
ស.ប. ចំរូត.
*គ* គ. និង ស. ១:៣៨.
៦៥ *ក* ម៉ាថាយ ១៣:៦–៤៣;
គ. និង ស. ៨៦:១–៧.
*ខ* ស.ប. សិរីល្អនៃសេឡេស្ទាល.
៦៦ *ក* ណាហ៊ុម ១:៥; ម៉ាថាយ ៣:១២;
គ. និង ស. ៣៨:១២;
៦៣:៣៣–៣៤.
៦៨ *ក* គ. និង ស. ៥៨:៥៦.
៧០ *ក* គ. និង ស. ៦៣:២៧–២៩.
៧២ *ក* អេសាយ ៥២:១០–១២.
៧៥ *ក* អាលម៉ា ៥:៣៧–៣៩.
៧៧ *ក* ស.ប. រដ្ឋាភិបាល.
*ខ* ស.ប. ឥស្សរភាព.
៧៨ *ក* ស.ប. សិទ្ធិជ្រើសរើស.

ខាង សិលធម៌ ដែលយើងបានប្រទានដល់គេ ប្រយោជន៍ឲ្យមនុស្សគ្រប់រូប អាចបាន[ខ]ទទួលការខុសត្រូវ ចំពោះអំពើបាបទាំងឡាយរបស់ខ្លួន នៅថ្ងៃ[គ]ជំនុំជំរះ ។

៧៩ ហេតុដូច្នេះហើយ គឺមិនត្រូវឲ្យមនុស្សណាមួយ ត្រូវជាប់ជាបាវបំរើដល់អ្នកណាមួយឡើយ ។

៨០ ហើយដោយហេតុនេះ ទើបយើងបានតាំង[ក]ធម្មនុញ្ញនៃដែនដីនេះឡើង ដោយដៃនៃពួកអ្នកប្រាជ្ញ ដែលយើងបានបង្កើតឡើង ចំពោះ គោលបំណងនេះឯង ហើយបានប្រោសលោះដែនដី ដោយសារការ[ខ]ខ្ចាយឈាម ។

៨១ ឥឡូវនេះ តើយើងនឹងប្រៀបធៀបកូនចៅស៊ីយ៉ូនទៅនិងអ្វីហ្ន៎ ? យើងនឹងប្រៀបធៀបពួកគេទៅនិង[ក]ពាក្យប្រៀបប្រដូចអំពីស្ត្រី និង ចៅក្រមដ៏ឥតយុត្តិធម៌ម្នាក់ ត្បិតមនុស្សលោកត្រូវតែ[ខ]អធិស្ឋានជានិច្ច ហើយឥតត្រូវរសាយចិត្តឡើយ ដែលថា —

៨២ នៅក្នុងក្រុងមួយ មានចៅក្រមម្នាក់ ដែលមិនកោតខ្លាចដល់ព្រះ ក៏មិនញញើតមនុស្សផង ។

៨៣ ហើយមានស្ត្រីមេម៉ាយម្នាក់ នៅក្នុងក្រុងនោះដែរ ហើយនាងចេះតែមកនិយាយនិងលោកថា សូមលោកកាត់ទោសដល់ខ្មាំង សត្រូវឲ្យខ្ញុំផង ។

៨៤ ហើយលោកមិនទទួលព្រមជាយូរក្រែលហើយ លុះក្រោយមកក៏គិតក្នុងចិត្តថា ទោះបើខ្ញុំមិនកោតខ្លាចដល់ព្រះ ឬញញើតចំពោះ មនុស្សណាក៏ដោយ គង់តែខ្ញុំនឹងជំនុំជំរះឲ្យស្ត្រីមេម៉ាយនេះជាមិនខាន ដោយព្រោះនាងនាំឲ្យរំខានចិត្តខ្ញុំខ្លាំងណាស់ ក្រែងនាងចេះ តែមករំអុកជានិច្ចដូច្នេះទៅ នឹងនាំឲ្យខ្ញុំពិបាកចិត្តទៅទៀត ។

៨៥ យើងនឹងប្រៀបធៀបកូនចៅស៊ីយ៉ូនយ៉ាងដូច្នេះហើយ ។

៨៦ ចូរឲ្យពួកគេសូមក្ដីនៅបាតជើងចៅក្រមចុះ;

៨៧ ហើយបើសិនជាលោកមិនស្ដាប់តាមពួកគេទេ នោះចូរឲ្យពួកគេសូមក្ដីនៅបាតជើងចៅហ្វាយខេត្ត;

៨៨ ហើយបើសិនជាចៅហ្វាយខេត្តមិនព្រមស្ដាប់តាមពួកគេទេ នោះចូរឲ្យពួកគេសូមក្ដីនៅបាតជើងប្រធានាធិបតី;

៨៩ ហើយបើសិនជាប្រធានាធិបតីមិនព្រមស្ដាប់តាមពួកគេទេ ខណៈនោះ ព្រះអម្ចាស់នឹងតើនឡើង ហើយយាងចេញមកពី[ក]ទីកំបាំង របស់ទ្រង់ ហើយនៅក្នុងសេចក្ដីខ្ញាល់របស់ទ្រង់ នឹងធ្វើទុក្ខដល់ប្រទេស;

៩០ ហើយនៅក្នុងព្រះហឫទ័យខ្ញាល់របស់ទ្រង់ និងនៅក្នុងព្រះពិរោធដ៏ខ្លាំង នៅក្នុងពេលវេលារបស់ទ្រង់ នោះនឹងកាត់[ក]ពួកនាយ តម្រួតការដែលទុច្ចរិត មិនស្មោះត្រង់ និងមិនយុត្តិធម៌ចេញ ហើយឲ្យពួកគេមានចំណែកជាមួយនិងពួកមនុស្សមានពុត និង[ខ]ពួកមនុស្ស មិនជឿ;

៩១ គឺនៅក្នុងទីងងឹតខាងក្រៅ នៅទីនោះនឹងយំ ហើយ[ក]ទួញសោក ហើយសង្កៀតធ្មេញ ។

៩២ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាអធិស្ឋាន សូមឲ្យត្រចៀកពួកគេអាចបានបើកឮសំរែករបស់អ្នកចុះ ប្រយោជន៍ឲ្យយើងអាចមាន [ក]សេចក្ដីមេត្តាករុណាដល់ពួកគេ ដើម្បីកុំឲ្យការណ៍ទាំងនេះ មានមកលើពួកគេឡើយ ។

៩៣ អ្វីៗដែលយើងបានមានព្រះបន្ទូលដល់អ្នក នោះត្រូវតែមកដល់ ប្រយោជន៍ឲ្យមនុស្សទាំងអស់អាចបានទុកថា[ក]ឥតដំណោះសារ ។

៩៤ ប្រយោជន៍ពួកអ្នកប្រាជ្ញ និងពួកអ្នកត្រួតត្រាអាចបានឮ ហើយដឹងនូវអ្វីដែលពួកគេមិនបាន[ក]ពិចារណាគិតដល់;

៩៥ ប្រយោជន៍ឲ្យយើងអាចចាប់ផ្ដើម ដើម្បីសំរេចកិច្ចការរបស់យើង គឺកិច្ចការ[ក]ចំឡែករបស់យើង ហើយអនុវត្តកិច្ចការរបស់យើង គឺ កិច្ចការចំឡែករបស់យើង ដើម្បីឲ្យមនុស្សលោកអាចចេះ[ខ]វែកញែកចេញរវាងពួកសុចរិតនឹងពួកទុច្ចរិត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ថាដូច្នោះ ។

៩៦ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា គឺផ្ទុយទៅនិង

៧៨ *ខ* ស.ប. ទទួលខុសត្រូវ,
ចេះទទួលខុសត្រូវ,
ការទទួលខុសត្រូវ.
*គ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
៨០ *ក* ២ នីហ្វៃ ១:៧–៩;
គ. និង ស. ៩៨:៥–៦.
ស.ប. រដ្ឋធម្មនុញ្ញ.
*ខ* ១ នីហ្វៃ ១៣:១៣–១៩.
៨១ *ក* លូកា ១៨:១–៨.
*ខ* ស.ប. ការអធិស្ឋាន.
៨៩ *ក* អេសាយ ៤៥:១៥;
គ. និង ស. ១២១:១, ៤;
១២៣:៦.
៩០ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
*ខ* វិវរ. ២១:៨.
ស.ប. ការឥតជំនឿ.
៩១ *ក* ម៉ាថាយ ២៥:៣០;
គ. និង ស. ១៩:៥;
២៩:១៥–១៧; ១២៤:៨.
៩២ *ក* ស.ប. សេចក្ដីមេត្តាករុណា,
មេត្តាករុណា.
៩៣ *ក* រ៉ូម ១:១៨–២១.
៩៤ *ក* អេសាយ ៥២:១៥;
៣ នីហ្វៃ ២០:៤៥; ២១:៨.
៩៥ *ក* អេសាយ ២៨:២១;
គ. និង ស. ៩៥:៤.
*ខ* ម៉ាឡាគី ៣:១៨.
ស.ប. ការសង្កេតស្គាល់,
អំណោយទាបខាង.

ព្រះបញ្ញត្តិរបស់យើង និងព្រះហឫទ័យរបស់យើង ដែល ស៊ីឌនី គីលបឺត ជាអ្នកបំរើរបស់យើង ត្រូវលក់[ក]ឃ្លាំងរបស់យើង ដែលយើងបានតាំងដល់ប្រជារាស្ត្រយើង ទៅក្នុងកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវ របស់យើង ។

៩៧ ចូរកុំឲ្យអ្វីដែលយើងបានតាំងឡើង ត្រូវបានបង្ខូចដោយពួកខ្មាំងសត្រូវរបស់យើង ដោយការអនុមតិពីអស់អ្នកដែលហៅខ្លួនតាម ព្រះនាមយើងឡើយ;

៩៨ ត្បិតនេះហើយជាអំពើបាបដ៏ធ្ងន់ធ្ងរទាស់និងយើង ហើយទាស់និងរាស្ត្ររបស់យើង ព្រោះតែការណ៍ទាំងនោះ ដែលយើងបាន ចេញបញ្ញត្តិ ហើយដែលនឹងកើតឡើងដល់សាសន៍ទាំងឡាយជាឆាប់ៗ ។

៩៩ ហេតុដូច្នេះហើយ គឺជាព្រះហឫទ័យរបស់យើង ថារាស្ត្ររបស់យើងត្រូវទាមទារ ហើយទាមទារទៅលើអ្វី ដែលយើងបានតាំងដល់ពួកគេ ទោះបើពួកគេមិនត្រូវបានអនុម័តឲ្យអាស្រ័យនៅលើទីនោះក្ដី ។

១០០ ទោះជាយ៉ាងណាក៏ដោយ គង់តែយើងពុំបានថាពួកគេមិនអាចអាស្រ័យនៅលើទីនោះដែរ; ត្បិតដរាបណាពួកគេបង្កើតផល និងកិច្ចការ ដែលសំណាំនិងនគររបស់យើង នោះពួកគេនឹងបានអាស្រ័យនៅលើទីនោះ ។

១០១ ពួក[ក]គេនឹងសង់ផ្ទះ ហើយអ្នកផ្សេងនឹងពុំគ្រងទីនោះទុកជាមរតកឡើយ; ពួកគេនឹងដាំចំការទំពាំងបាយជូរ ហើយពួកគេនឹង បរិភោគផលនៃចំការនោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១០២

*កំណត់ហេតុអំពីការរៀបចំក្រុមប្រឹក្សាជាន់ខ្ពស់លើកទីមួយនៃសាសនាចក្រ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៣៤ (*History of the Church*, ២:២៨–៣១) ។ កំណត់ហេតុដើមត្រូវបានកត់ដោយអែលឌើរអូលីវើរ ខៅឌើរ និងអែលឌើរអ៊ួរសុន ហៃឌ ។ ពីរថ្ងៃក្រោយមក កំណត់ហេតុត្រូវបានកែប្រែដោយព្យាការី អានឲ្យក្រុមប្រឹក្សាស្ដាប់ ហើយទទួលស្គាល់ដោយ ក្រុមប្រឹក្សា ។ ខ៣០ទៅ៣២ ដែលទាក់ទងទៅនឹងក្រុមប្រឹក្សានៃពួកសាវក១២នាក់ នោះត្រូវបានបញ្ចូលដោយព្យាការីយ៉ូសែប ស្ម៊ីធ នៅឆ្នាំ ១៨៣៥ កាលលោកបានរៀបចំកណ្ឌនេះសំរាប់បោះពុម្ព នៅក្នុងគោលលទ្ធិនិងសេចក្ដីសញ្ញា ។*

*១–៨, ក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវបានតាំងឡើងឲ្យដោះស្រាយបញ្ហាសំខាន់ៗទាំងឡាយ ដែលមានឡើងក្នុងសាសនាចក្រ; ៩–១៨, បែបបទត្រូវបានប្រទានឲ្យសំរាប់កាត់សេចក្ដីទាំងឡាយ; ១៩–២៣, ប្រធាននៃក្រុមប្រឹក្សាធ្វើការសំរេចចិត្ត ២៤–៣៤, បែបបទខាង ការប្ដឹងឧទ្ធរណ៍ ត្រូវបានចែងប្រាប់ ។*

ថ្ងៃនេះ ក្រុមប្រឹក្សាទូទៅនៃពួកសង្ឃជាន់ខ្ពស់២៤នាក់ បានប្រជុំគ្នានៅផ្ទះរបស់ យ៉ូសែប[ក] ស្ម៊ីធ ជុញ្ញ័រ ដោយវិវរណៈ ហើយបាន ចាប់ផ្ដើមរៀបចំក្រុមប្រឹក្សាជាន់ខ្ពស់ នៃសាសនាចក្រនៃព្រះគ្រីស្ទ ដែលមានពួកសង្ឃជាន់ខ្ពស់១២នាក់ និងប្រធានមួយ ឬបីនាក់ តាមដែលករណីតម្រូវការ ។

២ ក្រុមប្រឹក្សាជាន់ខ្ពស់ត្រូវបានតាំងឡើងដោយវិវរណៈ សំរាប់គោលបំណងខាងការដោះស្រាយបញ្ហាសំខាន់ៗទាំងឡាយ ដែលអាចមានឡើង នៅក្នុងសាសនាចក្រ ដែលពុំអាចដោះស្រាយបានដោយសាសនាចក្រ ឬដោយក្រុមប្រឹក្សានៃប៊ីស្សព ដើម្បី ផ្សះផ្សាក្រុមទាំងឡាយ ។

៣ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ, ស៊ីឌនី រិកដុន, និងហ្វ្រេឌើរិក ជី វិលលាម្ស ត្រូវបានទទួលស្គាល់ថាជាប្រធាន ដោយសម្លេងនៃក្រុមប្រឹក្សា; ហើយ យ៉ូសែប ស្ម៊ីធ ស៊ីញ្ញ័រ, យ៉ូហាន ស្ម៊ីធ, យ៉ូសែប ខូ, យ៉ូហាន ចនសុន, ម៉ាទិន ហារិស, យ៉ូហាន អែស ខារតើរ, យ៉ារេឌ ខារតើរ, អូលីវើ ខៅឌើរ, សាំយ៉ូអែល អេច ស្ម៊ីធ, អ៊ួរសុន ហៃឌ, សិលវ៉េស្ទើរ ស្ម៊ីធ, និង លូកា ចនសុន, ដែលជាពួកសង្ឃជាន់ខ្ពស់ ត្រូវបានរើសឲ្យធ្វើជាក្រុមប្រឹក្សាដែលនៅអចិន្ត្រៃយ៍សំរាប់សាសនាចក្រ ដោយសម្លេងនៃក្រុមប្រឹក្សាជាឯកច្ឆន្ទ ។

៤ ពួកទីប្រឹក្សាដែលមានឈ្មោះខាងលើ ត្រូវបានសួរថាតើពួកគេព្រមទទួលការតែងតាំងរបស់ខ្លួន ហើយថាតើពួកគេព្រមធ្វើការ

៩៦ *ក* ស.ប. ឃ្លាំង.
៩៧ *ក* គ. និង ស. ១០៣:៤; ១១២:២៥–២៦; ១២៥:២.
១០១ *ក* អេសាយ ៦៥:២១–២២. ស.ប. សហស្សវត្សរ៍.
**១០២** ១*ក* ស.ប. ក្រុមប្រឹក្សាជាន់ខ្ពស់.
២ *ក* គ. និង ស. ១០៧:៧២–៧៤.

ក្នុង តំណែងនោះ តាមក្រិត្យវិន័យនៃស្ថានសួគ៌ឬទេ ចំពោះសំណួរទាំងនេះ ពួកគេទាំងអស់គ្នាបានឆ្លើយថាពួកគេព្រមទទួលការតែងតាំង របស់ពួកគេ ហើយព្រមបំពេញតំណែងរបស់ពួកគេ តាមព្រះគុណនៃព្រះ ដែលបានប្រទានមកលើពួកគេ ។

៥ ចំនួនមនុស្សដែលធ្វើជាក្រុមប្រឹក្សា ដែលបានបោះឆ្នោត នៅក្នុងនាម និងសំរាប់សាសនាចក្រ ក្នុងការតែងតាំងពួកទីប្រឹក្សាដែលមានឈ្មោះខាងលើនេះ គឺ៤៣នាក់ ដូចជាមានដូចតទៅនេះ គឺៈ ពួកសង្ឃជាន់ខ្ពស់៩នាក់, ពួកអែលឌើរ១៧នាក់, ពួកសង្ឃ៤នាក់, និងសមាជិក១៣នាក់ ។

៦ បានបោះឆ្នោតថាៈ ក្រុមប្រឹក្សាជាន់ខ្ពស់ពុំអាចមានអំណាចដើម្បីធ្វើការបានឡើយ លើកលែងតែពួកទីប្រឹក្សា៧នាក់ដែលមានឈ្មោះខាងលើ ឬពួកអ្នកដែលបានតាំងជំនួសពួកគេនៅទីនោះ ។

៧ ពួក៧នាក់នេះត្រូវមានអំណាច ដើម្បីតាំងពួកសង្ឃជាន់ខ្ពស់ផ្សេងទៀត ដែលពួកគេគិតថាសម ហើយមានសមត្ថភាពដើម្បីធ្វើការ ជំនួសពួកទីប្រឹក្សាដែលមិននៅទីនោះ ។

៨ បានបោះឆ្នោតថាៈ កាលណាមានតំណែងណានៅទំនេរដោយសារមរណភាព ការដកចេញពីតំណែងព្រោះការរំលង ឬការដក ចេញពីព្រំដែននៃការត្រួតត្រាក្នុងសាសនាចក្រនេះ នោះតំណែងដែលនៅទំនេរពីទីប្រឹក្សាដែលមានឈ្មោះខាងលើ ត្រូវបំពេញដោយ អ្នក ដែលប្រធាន ឬប្រធានទាំងឡាយឲ្យឈ្មោះ ហើយត្រូវអនុម័តដោយសម្លេងនៃក្រុមប្រឹក្សាទូទៅនៃពួកសង្ឃជាន់ខ្ពស់ ដែលបាន ប្រជុំគ្នាសំរាប់គោលបំណងនោះ ដើម្បីធ្វើការនៅក្នុងនាមនៃសាសនាចក្រ ។

៩ ប្រធាននៃសាសនាចក្រ ដែលជាប្រធាននៃក្រុមប្រឹក្សាផងត្រូវបានតាំងឡើងដោយវិវរណៈ ហើយទទួលស្គាល់នូវការចាត់ចែងរបស់ លោក ដោយសម្លេងនៃសាសនាចក្រ ។

១០ ហើយនេះគឺតាមភាពថ្លៃថ្នូរនៃតំណែងរបស់លោក ដែលលោកត្រូវត្រួតលើក្រុមប្រឹក្សានៃសាសនាចក្រ; ហើយគឺជាឯកសិទ្ធិរបស់ លោក ដែលត្រូវបានជួយដោយប្រធានពីរនាក់ទៀត ដែលបានតាំងឡើងតាមរបៀបដដែល ដែលលោកត្រូវបានតាំងឡើងនោះ ។

១១ ហើយបើសិនជាអ្នកដែលត្រូវបានតាំងឡើង ឲ្យជួយលោក ម្នាក់ឬទាំងពីរនាក់មិននៅទេ នោះលោកមានអំណាច ដើម្បីត្រួតលើ ក្រុមប្រឹក្សា ដោយមិនចាំបាច់មានអ្នកជំនួយឡើយ; ហើយបើសិនជាលោកមិននៅ នោះប្រធានផ្សេងទៀតមានអំណាច ដើម្បីត្រួតជំនួស លោក ទាំងពីរនាក់ ឬពួកគេណាមួយក៏បាន ។

១២ កាលណាក្រុមប្រឹក្សានៃសាសនាចក្រនៃព្រះគ្រីស្ទត្រូវបានរៀបចំដោយត្រឹមត្រូវ តាមគំរូដែលបានប្រាប់មកហើយនោះ នោះគឺជាធុរៈ នៃពួកទីប្រឹក្សា១២នាក់ ដើម្បីធ្វើការចាប់ឆ្នោតដោយលេខ ហើយដោយមាគ៌ានោះ ទើបបញ្ជាក់ថាពួក១២នាក់ណាមួយដែលត្រូវ និយាយមុនគេ ចាប់ផ្ដើមនិងលេខមួយរហូតដល់លេខ១២ ។

១៣ កាលណាក្រុមប្រឹក្សានេះប្រជុំគ្នា ដើម្បីកាត់ក្ដីណាមួយ នោះពួកទីប្រឹក្សា១២នាក់ត្រូវពិចារណាថាតើមានបញ្ហាធំ ឬអត់; បើសិនជាទេ នោះពួកទីប្រឹក្សាតែពីរនាក់ទេត្រូវនិយាយ តាមគំរូដែលបានសរសេរទុកខាងលើនេះ ។

១៤ ប៉ុន្តែបើសិនជាគិតថាមានបញ្ហាធំ នោះបួននាក់ត្រូវបានតាំងឡើង; ហើយបើសិនជាមានបញ្ហាធំជាងនេះ នោះប្រាំមួយនាក់; ប៉ុន្តែគ្មានករណីណាមួយ ត្រូវមានជាងប្រាំមួយនាក់តាំងឡើងឲ្យនិយាយនោះឡើយ ។

១៥ នៅគ្រប់ករណីទាំងអស់ នោះអ្នកជាប់ចោទមានសិទ្ធិបានក្រុមប្រឹក្សាពាក់កណ្ដាល ដើម្បីការពារកុំឲ្យមានការមើលងាយ ឬការ អយុត្តិធម៌ ។

១៦ ហើយពួកទីប្រឹក្សាដែលបានតាំងឡើងឲ្យនិយាយនៅចំពោះក្រុមប្រឹក្សា នោះត្រូវប្រាប់ករណី បន្ទាប់ពីបានពិនិត្យមើលភស្តុតាងតាមភាពពិតប្រាកដនៅចំពោះក្រុមប្រឹក្សា; ហើយមនុស្សគ្រប់រូបត្រូវនិយាយ តាមអ្វីៗដែលពិត ហើយយុត្តិធម៌ ។

១៧ ពួកទីប្រឹក្សាទាំងនោះដែលបានរើសលេខ ដូចជាលេខ ២, ៤, ៦, ៨, ១០, និង ១២ គឺជាមនុស្សដែលត្រូវឈរឡើងនិយាយជំនួស អ្នកជាប់ចោទ ហើយការពារកុំឲ្យមានការមើលងាយ និងការអយុត្តិធម៌ ។

១៨ នៅគ្រប់ករណីទាំងអស់ អ្នកចោទ និងអ្នកជាប់ចោទ ត្រូវមានសិទ្ធិឱកាសនិយាយជំនួសខ្លួន នៅចំពោះក្រុមប្រឹក្សា បន្ទាប់ពីបានឮ ភស្តុតាងទាំងឡាយ និងបន្ទាប់ពីពួកទីប្រឹក្សា ដែលបានតាំងឡើងឲ្យនិយាយអំពីករណី បាននិយាយចប់ស្រេចបាច់ ។

១៩ បន្ទាប់ពីបានឮភស្តុតាងទាំងឡាយ កាលពួកទីប្រឹក្សា អ្នកចោទ និងអ្នកជាប់ចោទបាននិយាយហើយ នោះប្រធានត្រូវកាត់ក្ដី តាមយោបល់ដែលលោកមានអំពីរឿងក្ដី ហើយសូមឲ្យទីប្រឹក្សា១២នាក់អនុម័តការកាត់ក្ដីនោះ ដោយពួកគេបោះឆ្នោត ។

៩ *ក* ស.ប. វិវរណៈ.
*ខ* ស.ប. ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ.
១៦ *ក* ស.ប. សេចក្ដីយុត្តិធម៌.

២០ ប៉ុន្តែបន្ទាប់ពីបានឮភស្តុតាង និងពាក្យដោះសារទាំងឡាយស្រេចបាច់ហើយ បើសិនជាពួកទីប្រឹក្សាដែលនៅសល់ទាំងប៉ុន្មានដែលពុំបាននិយាយ ឬពួកគេណាមួយ រកឃើញកំហុសក្នុងការកាត់ក្ដីរបស់ប្រធាន នោះពួកគេអាចសំដែងប្រាប់កំហុសនោះ ហើយបណ្ដឹងក្ដីនឹងត្រូវបានកាត់ក្ដីម្ដងទៀត ។

២១ ហើយបើសិនជាបន្ទាប់ពីបានកាត់ក្ដីម្ដងទៀត ឃើញមានពត៌មានថែមទៀតអំពីរឿងនេះ នោះការកាត់ក្ដីត្រូវប្រែប្រួលឲ្យស្រប ទៅតាមពត៌មាននោះ ។

២២ ប៉ុន្តែក្នុងករណីដែលគ្មានពត៌មានបន្ថែមទៀតទេ នោះការកាត់ក្ដីលើកទីមួយត្រូវនៅជាស្ថាបពរ ហើយក្រុមប្រឹក្សាភាគច្រើនមានអំណាច ដើម្បីសំរេចចិត្តដដែល ។

២៣ នៅករណីណាមួយដែលមានបញ្ហាខាង[ក]គោលលទ្ធិ ឬគោលការណ៍ បើសិនជាពុំមានការសរសេរគ្រប់គ្រាន់ ដើម្បីបង្ហាញ រឿងឲ្យបានច្បាស់លាស់ ដល់គំនិតនៃក្រុមប្រឹក្សាទេ នោះប្រធានអាចសូម ហើយបានព្រះហឫទ័យនៃព្រះអម្ចាស់ដោយ[ខ]វិវរណៈ ។

២៤ ពួកសង្ឃជាន់ខ្ពស់ កាលនៅឆ្ងាយ មានអំណាចឲ្យហៅ ហើយរៀបចំក្រុមប្រឹក្សាមួយ តាមបែបដែលបានអធិប្បាយប្រាប់ខាង លើនេះ ដើម្បីដោះស្រាយបញ្ហានានា នៅពេលក្រុមទាំងឡាយ ឬពួកគេណាមួយសូម ។

២៥ ហើយក្រុមប្រឹក្សានៃពួកសង្ឃជាន់ខ្ពស់ដែលបានពោលដល់នោះ នឹងមានអំណាចដើម្បីតាំងគ្នាគេម្នាក់ ឲ្យត្រួតលើក្រុមប្រឹក្សាបែប នេះបណ្ដោះអាសន្ន ។

២៦ គឺត្រូវជាធុរៈនៃក្រុមប្រឹក្សាដែលបានពោលដល់នោះ ដើម្បីបញ្ជូនជាប្រញាប់ នូវបញ្ជីការរបស់ពួកគេមួយច្បាប់ ព្រមទាំងការ ថ្លែងទីបន្ទាល់ និងការសំរេចចិត្តរបស់ពួកគេផង ទៅឲ្យក្រុមប្រឹក្សាជាន់ខ្ពស់ នៃវេទិការបស់គណៈប្រធានទីមួយ នៃសាសនាចក្រ ។

២៧ បើសិនជាក្រុមទាំងឡាយ ឬពួកគេណាមួយមិនពេញចិត្តនិងការសំរេចចិត្ត របស់ក្រុមប្រឹក្សាដែលបានពោលដល់នោះទេ នោះពួកគេអាចសុំឧទ្ធរណ៍ដល់ក្រុមប្រឹក្សាជាន់ខ្ពស់ នៃវេទិការបស់គណៈប្រធានទីមួយ នៃសាសនាចក្រ ហើយកាត់ក្ដីម្ដងទៀត ជាករណីដែលត្រូវបានឮ តាមគំរូដែលបានសរសេរទុកខាងលើ ហាក់ដូចជាគ្មានបានសំរេចចិត្ត រួចមកហើយទេ ។

២៨ ក្រុមប្រឹក្សានៃពួកសង្ឃជាន់ខ្ពស់នេះ ដែលនៅឆ្ងាយ នោះគ្រាន់តែត្រូវហៅ កាលណាមានរឿង[ក]ដ៏ធំបំផុតនៅក្នុងសាសនាចក្រ ប៉ុណ្ណោះ; ហើយគ្មានរឿងធម្មតា ឬទូទៅណាសមនឹងហៅក្រុមប្រឹក្សាបែបនេះឡើយ ។

២៩ ពួកសង្ឃជាន់ខ្ពស់ដែលធ្វើដំណើរ ឬនៅឆ្ងាយ គេមានអំណាចនិយាយថាតើជាការចាំបាច់ហៅក្រុមប្រឹក្សាបែបនេះ ឬអត់ ។

៣០ មានការវែកញែករវាងក្រុមប្រឹក្សាជាន់ខ្ពស់ ឬពួកសង្ឃជាន់ខ្ពស់ដែលធ្វើដំណើរនៅឆ្ងាយ នឹងក្រុមប្រឹក្សាជាន់ខ្ពស់ដែល[ក]ធ្វើដំណើរ ដែលមានពួក[ខ]សាវក១២នាក់ អំពីការសំរេចចិត្តរបស់ពួកគេ ។

៣១ ចំពោះការសំរេចចិត្តនៃពួកអ្នកដែលបានពោលដល់មុននោះអាចសុំឧទ្ធរណ៍បាន ប៉ុន្តែចំពោះការសំរេចចិត្តនៃពួកអ្នកក្រោយ នោះពុំអាចធ្វើបានឡើយ ។

៣២ ពួកអ្នកក្រោយ គឺគ្រាន់តែអាចបានហៅសួរ ដោយពួកអ្នកមានសិទ្ធិអំណាចទូទៅនៃសាសនាចក្រ ក្នុងកាលមានការរំលង ប៉ុណ្ណោះ ។

៣៣ បានដោះស្រាយថាៈ ប្រធាន ឬពួកប្រធានពីវេទិការបស់គណៈប្រធានទីមួយ នៃសាសនាចក្រ ត្រូវមានអំណាចនឹងសំរេចចិត្តថា តើរឿងបែបនេះ ដែលត្រូវបានសុំឧទ្ធរណ៍ នោះគិតថាត្រឹមត្រូវនឹងបានកាត់ក្ដីម្ដងទៀតឬអី បន្ទាប់ពីបានពិនិត្យមើលក្ដីឧទ្ធរណ៍ និង ភស្តុតាងទាំងឡាយ ព្រមទាំងបទអធិប្បាយផង ។

៣៤ ខណៈនោះ ពួកទីប្រឹក្សា១២នាក់ បានចាប់ផ្ដើមធ្វើការចាប់ឆ្នោត ឬបោះឆ្នោត ដើម្បីបញ្ជាក់ឲ្យដឹងថានរណាត្រូវនិយាយមុនគេ ហើយមានឈ្មោះដូតតទៅនេះ គឺៈ ១) អូលីវើរ ខៅឌើរី; ២) យ៉ូសែប ខូ; ៣) សាំយូអែល អេច ស្ម៊ីធ; ៤) លូកា ចនសុន; ៥) យ៉ូហាន អែស ខារតើរ; ៦) ស៊ិលវែស្ទើរ ស្ម៊ីធ; ៧) យ៉ូហាន ចនសុន; ៨) អូរសុន ហៃឌ; ៩) យ៉ារេឌ ខារតើរ; ១០) យ៉ូសែប ស្ម៊ីធ ស៊ីញ៉ូរ, ១១) យ៉ូហាន ស្ម៊ីធ; ១២) ម៉ាទិន ហារិស ។ បន្ទាប់ពីការអធិស្ឋាន នោះសន្និសីទក៏ចប់ទៅ ។

អូលីវើរ ខៅឌើរី
អូរសុន ហៃឌ
ស្មៀន

២៣ *ក* ជនគ. ៩:៨.
*ខ* ស.ប. វិវរណៈ.
២៨ *ក* គ. និង ស. ១០៧:៧៨.
៣០ *ក* គ. និង ស. ១០៧:២៣–២៤, ៣៥–៣៨.
*ខ* ស.ប. សាវក.

## កណ្ឌទី ១០៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៨៣៤ (*History of the Church, *២:៣៦–៣៩)* ។ *វិវរណៈនេះត្រូវបានទទួល បន្ទាប់ពី ប៉ាលី ភី ប្រាត្ត និង ឡៃម៉ាន វ៉ៃត បានមកដល់ ក្រុងខឺតឡង់ រដ្ឋអូហៃអូ ដែលបានមកពីរដ្ឋមិសសួរី ដើម្បីមកប្រឹក្សាជាមួយនិងព្យាការី អំពីការរំដោះ និងការវិលទៅដីធ្លីនៃពួកបរិសុទ្ធ វិញ នៅឃុំចាកសុន ។*

*១–៤, ដើមហេតុដែលព្រះអម្ចាស់ទ្រង់បណ្ដោយឲ្យពួកបរិសុទ្ធនៅឃុំចាកសុន ត្រូវគេបៀតបៀន; ៥–១០, ពួកបរិសុទ្ធនឹងបានឈ្នះ បើសិនជាពួកគេកាន់តាមព្រះបញ្ញត្តិទាំងឡាយ; ១១–២០, សេចក្ដីប្រោសលោះនៃស៊ីយ៉ូននឹងមានឡើងដោយអំណាច ហើយព្រះ អម្ចាស់ទ្រង់នឹងយាងទៅខាងមុខរាស្ត្ររបស់ទ្រង់; ២១–២៨, ពួកបរិសុទ្ធត្រូវប្រមូលគ្នានៅស៊ីយ៉ូន ហើយអស់អ្នកណាដែលប្ដូរជីវិតខ្លួន នោះនឹងបានវិញ; ២៩–៤០, ពួកបងប្អូនប្រុសនានាក្នុងសាសនាត្រូវបានហៅឲ្យរៀបចំជំរំស៊ីយ៉ូន ហើយទៅឯក្រុងស៊ីយ៉ូន; ពួកគេត្រូវ បានសន្យាថាបានជ័យជំនះ បើសិនជាពួកគេមានចិត្តស្មោះត្រង់ ។*

១ យើងប្រាប់អ្នកជាប្រាកដថា ឱមិត្តទាំងឡាយរបស់យើងអើយ មើលចុះ យើងនឹងប្រទានដល់អ្នក នូវវិវរណៈ និងបញ្ញត្តិមួយ ប្រយោជន៍ឲ្យ អ្នកអាចបានដឹងពីរបៀប ដើម្បី[ក]ធ្វើកិច្ចការខាងការបំពេញធុរកិច្ចទាំងឡាយរបស់អ្នក អំពី[ខ]ការសង្គ្រោះ និងការប្រោសលោះដល់ពួកបង ប្អូនអ្នកក្នុងសាសនា ដែលត្រូវបានខ្ចាត់ព្រាត់នៅឯដែនដីស៊ីយ៉ូន;

២ ដោយបាន[ក]បណ្ដេញចេញ ហើយវាយដោយដៃនៃពួកខ្មាំងសត្រូវរបស់យើង ដែលយើងនឹងចាក់សេចក្ដីក្រោធរបស់យើងមកលើ ដោយគ្មានកំរិត ក្នុងពេលរបស់យើង ។

៣ ត្បិតយើងបានស៊ូទ្រាំឲ្យពួកគេដល់ពេលនេះ ប្រយោជន៍ឲ្យពួកគេអាចបាន[ក]បំពេញកំរិតនៃសេចក្ដីទុច្ចរិតទាំងឡាយរបស់ពួកគេ ប្រយោជន៍ឲ្យពែងរបស់ពួកគេអាចបានពេញ;

៤ ហើយប្រយោជន៍ឲ្យអស់អ្នកណា ដែលហៅខ្លួនតាមនាមរបស់យើង អាចបានវាយផ្ចាលដោយ[ក]ការវាយផ្ចាលដ៏ធ្ងន់ធ្ងរអស់មួយរដូវខ្លី ពីព្រោះពួកគេពុំបាន[ខ]ស្ដាប់តាមសិក្ខាបទ និងបញ្ញត្តិទាំងឡាយ ដែលយើងបានប្រទានដល់ពួកគេ ដោយពេញលេញឡើយ ។

៥ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា យើងបានចេញបញ្ញត្តិមួយ ដែលរាស្ត្រយើងត្រូវយល់ថា ដរាបណាពួកគេស្ដាប់តាម ចាប់ពីម៉ោង នេះទៅ នូវ[ក]ការទូន្មានដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេ នឹងប្រទានដល់ពួកគេនោះ ។

៦ មើលចុះ ពួកគេនឹងត្រូវចាប់ផ្ដើមឈ្នះលើពួកខ្មាំងសត្រូវរបស់យើង ចាប់ពីម៉ោងនេះទៅ ត្បិតយើងបានចេញបញ្ញត្តហើយ ។

៧ ហើយដោយ[ក]ប្រុងគោរពតាមអស់ទាំងព្រះបន្ទូល ដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេ នឹងមានបន្ទូលដល់ពួកគេ នោះពួក គេនឹងមិនត្រូវចាញ់ឡើយ រហូតដល់[ខ]នគរទាំងឡាយនៃពិភពលោកនៅក្រោមជើងយើង ហើយផែនដី[គ]ត្រូវបានប្រទានដល់[ឃ]ពួកបរិសុទ្ធ ដើម្បីគ្រងយកជា[ង]មរតក ជារៀងរាបដរាបតទៅ ។

៨ ប៉ុន្តែដរាបណាពួកគេមិន[ក]កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយមិនប្រុងគោរពតាមអស់ទាំងព្រះបន្ទូលរបស់យើងទេ នោះនគរទាំងឡាយនៃពិភពលោកនឹងឈ្នះលើពួកគេ ។

៩ ត្បិតពួកគេត្រូវបានតាំងឲ្យធ្វើជា[ក]ពន្លឺដល់ពិភពលោក ហើយឲ្យធ្វើជាអ្នកសង្គ្រោះនៃមនុស្សលោក;

១០ ហើយដរាបណាពួកគេមិនធ្វើជាអ្នកសង្គ្រោះនៃមនុស្សលោកទេ នោះពួកគេទៅដូចជា[ក]អំបិលដែលបាត់ជាតិប្រៃ

**១០៣** ១*ក* គ. និង ស. ៤៣:៨.
*ខ* គ. និង ស. ១០១:៤៣–៦២.
២ *ក* គ. និង ស. ១០១:១; ១០៩:៤៧.
៣ *ក* អាលម៉ា ១៤:១០–១១; ៦០:១៣.
៤ *ក* គ. និង ស. ៩៥:១.
ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* គ. និង ស. ១០១:២; ១០៥:២–៦.
៥ *ក* ស.ប. ពាក្យទូន្មាន (ន.).
៧ *ក* គ. និង ស. ៣៥:២៤.
ស.ប. ការគោរព, ដែលគោរព, គោរព.
*ខ* ដានី. ២:៤៤.
*គ* ដានី. ៧:២៧.
*ឃ* ស.ប. ជនបរិសុទ្ធ.
*ង* គ. និង ស. ៣៨:២០.
៨ *ក* ម៉ូសាយ ១:១៣;
គ. និង ស. ៨២:១០.
៩ *ក* ១ នីហ្វៃ ២១:៦.
១០ *ក* ម៉ាថាយ ៥:១៣–១៦;
គ. និង ស. ១០១:៣៩–៤០.

ម្ល៉ោះហើយគ្មាន ប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ ។

១១ ប៉ុន្ដែយើងប្រាប់អ្នកជាប្រាកដថា យើងបានចេញបញ្ញត្តិថា ពួកបងប្អូនអ្នកក្នុងសាសនា ដែលត្រូវបានខ្ចាត់ព្រាត់នោះនឹងត្រូវបានវិល ទៅឯដែនដីនៃកេរ្តិ៍មរតករបស់ពួកគេវិញ ហើយនឹងសង់ទីចាស់នៃស៊ីយ៉ូនដែលខូចបង់ឡើងជាថ្មី ។

១២ ត្បិតបន្ទាប់ពីមានការវេទនាដ៏ច្រើន នោះទើបបានព្រះពរ ដូចជាយើងបានប្រាប់អ្នកនៅក្នុងព្រះបញ្ញត្តិពីមុនហើយ ។

១៣ មើលចុះ នេះហើយជាព្រះពរដែលយើងបានសន្យាឲ្យ បន្ទាប់ពីមានការវេទនាទាំងឡាយ ព្រមទាំងការវេនាទាំងឡាយរបស់ពួក បងប្អូនអ្នកក្នុងសាសនាផង — ជាការប្រោសលោះដល់អ្នក និងការប្រោសលោះដល់ពួកបងប្អូនអ្នកក្នុងសាសនា ព្រមទាំងការត្រឡប់ របស់គេ ទៅឯដែនដីស៊ីយ៉ូនវិញ ដើម្បីតាំងឡើង គឺមិនត្រូវទំលាក់ចុះទៀតឡើយ ។

១៤ ទោះជាយ៉ាងណាក៏ដោយ បើសិនជាពួកគេបង្ខូចកេរ្តិ៍មរតកទាំងឡាយរបស់គេចោល នោះពួកគេនឹងត្រូវទំលាក់ចុះ; ត្បិតយើងនឹងមិនប្រណីពួកគេឡើយ បើសិនជាពួកគេបង្ខូចកេរ្តិ៍មរតកទាំងឡាយរបស់គេចោល ។

១៥ មើលចុះ យើងប្រាប់អ្នកថា ការប្រោសលោះស៊ីយ៉ូនត្រូវតែមានឡើងដោយអំណាច ។

១៦ ហេតុដូច្នេះហើយ យើងនឹងបណ្ដាលឲ្យមានមនុស្សម្នាក់កើតឡើងដល់រាស្ដ្ររបស់យើង ដែលនឹងដឹកនាំពួកគេ ដូចជាលោក ម៉ូសេបានដឹកនាំកូនចៅអ៊ីស្រាអែលដូច្នោះហើយ ។

១៧ ត្បិតអ្នករាល់គ្នាជាកូនចៅអ៊ីស្រាអែល ហើយជាពូជលោកអ័ប្រាហាំ ហើយអ្នករាល់គ្នាត្រូវតែបាននាំចេញឲ្យរួចពីសេវកភាព ដោយអំណាច និងដោយដៃសណ្ដឹង ។

១៨ ហើយដូចជាពួកអយ្យកោរបស់អ្នក ត្រូវបាននាំជាមុនដំបូងយ៉ាងណា នោះការប្រោសលោះនៃស៊ីយ៉ូនក៏នឹងបានជាយ៉ាងនោះដែរ ។

១៩ ហេតុដូច្នេះហើយ កុំឲ្យមានចិត្តតក់ស្លុតឡើយ ត្បិតតើយើងពុំបានប្រាប់ដល់អ្នក ដូចជាយើងបានប្រាប់ដល់ពួកអយ្យកោរបស់អ្នកទេ ឬអីថា៖ ទេវតារបស់យើងនឹងទៅមុខអ្នក ប៉ុន្ដែពុំមែនវត្តមានរបស់យើងទេ ។

២០ ប៉ុន្ដែយើងប្រាប់ដល់អ្នកថា៖ ពួកទេវតារបស់យើងនឹងទៅមុខអ្នក ព្រមទាំងវត្តមានរបស់យើងផង ហើយនៅបន្តិចទៀតនោះអ្នក រាល់គ្នានឹងបានដែនដីដ៏ល្អ ។

២១ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង គឺជាបុរសដែលយើងបានប្រៀបធៀបទៅនឹង អ្នកបំរើ ដែលចៅហ្វាយនៃចំការទំពាំងបាយជូរបាននិយាយដល់ នៅក្នុងពាក្យប្រៀបប្រដូច ដែលយើងបានប្រទានដល់អ្នក ។

២២ ហេតុដូច្នេះហើយ ចូរឲ្យ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ប្រាប់ដល់កម្លាំងនៃវង្សាយើង ពួកកំឡោះ និងពួកអ្នកមាន វ័យកណ្ដាលរបស់យើងថា — ចូរប្រមូលគ្នាមកជុំឯដែនដីស៊ីយ៉ូន គឺនៅលើដែនដីដែលយើងបានទិញនិងប្រាក់ដែលបានថ្វាយ ដល់យើងចុះ ។

២៣ ហើយចូរឲ្យសាសនាចក្រទាំងអស់បញ្ជូនពួកអ្នកប្រាជ្ញ ព្រមទាំងប្រាក់កាសរបស់គេ ហើយឲ្យឡើងមកទិញដែនដីទាំងឡាយ ដូចជាយើងបានបញ្ជាដល់ពួកគេចុះ ។

២៤ ហើយដរាបណាពួកខ្មាំងសត្រូវរបស់យើងមកទាស់នឹងអ្នក ដើម្បីបណ្ដេញអ្នកចេញពីដែនដីដ៏ល្អរបស់យើង ដែលយើងបានតាំងទុក ជាដែនដីស៊ីយ៉ូន គឺជាដែនដីទាំងឡាយរបស់អ្នក ស្របតាមទីបន្ទាល់ទាំងនេះ ដែលអ្នករាល់គ្នាបានទិញនៅចំពោះយើងទាស់នឹងពួកគេ នោះអ្នករាល់ត្រូវដាក់បណ្ដាសាពួកគេចុះ;

២៥ ហើយអ្នកណាក៏ដោយដែលអ្នករាល់គ្នាដាក់បណ្ដាសា នោះយើងនឹងដាក់បណ្ដាសាដែរ ហើយអ្នករាល់គ្នាត្រូវសងសឹកដល់ពួក ខ្មាំងសត្រូវរបស់យើងឲ្យយើង ។

១១ *ក* គ. និង ស. ១០១:១៨.
១២ *ក* វិវរ. ៧:១៣–១៤;
គ. និង ស. ៥៨:៤; ១១២:១៣.
១៦ *ក* និក្ខ. ៣:២–១០;
គ. និង ស. ១០៧:៩១–៩២.
ស.ប. ម៉ូសេ.
១៧ *ក* ស.ប. អ័ប្រាហាំ —
ពូជរបស់អ័ប្រាហាំ;
សេចក្ដីសញ្ញាអ័ប្រាហាំ.
១៩ *ក* ស.ប. ពួកទេវតា.
*ខ* គ. និង ស. ៨៤:១៨–២៤.
២០ *ក* និក្ខ. ១៤:១៩–២០.
*ខ* គ. និង ស. ១០០:១៣.
២១ *ក* គ. និង ស. ១០១:៥៥–៥៨.
*ខ* ស.ប. ចំការទំពាំងបាយជូរនៃព្រះអម្ចាស់.
២២ *ក* គ. និង ស. ៣៥:១៣–១៤;
១០៥:១៦, ២៩–៣០.
២៣ *ក* គ. និង ស. ៤២:៣៥–៣៦;
៥៧:៥–៧; ៥៨:៤៩–៥១;
១០១:៦៨–៧៤.
២៤ *ក* គ. និង ស. ២៩:៧–៨;
៤៥:៦៤–៦៦; ៥៧:១–២.

២៦ ហើយវត្តមានរបស់យើងនឹងគង់នៅជាមួយអ្នក សូម្បីតែ[ក]ក្នុងការសងសឹកដល់ពួកខ្មាំងសត្រូវរបស់យើងឲ្យយើង ដល់ទៅតំណទីបី និងតំណទីបួននៃពួកអ្នកដែលស្អប់យើងដែរ ។

២៧ ចូរកុំឲ្យមនុស្សណាខ្លាចនឹងប្ដូរជីវិតរបស់ខ្លួន ដោយយល់ដល់ព្រះនាមរបស់យើងឡើយ អ្នកណាដែលប្ដូរ[ក]ជីវិតរបស់ខ្លួន ដោយយល់ ដល់ព្រះនាមរបស់យើង នោះនឹងបានវិញ ។

២៨ ហើយអស់អ្នកណាដែលមិនព្រមប្ដូរជីវិតរបស់ខ្លួន ដោយយល់ដល់ព្រះនាមរបស់យើង នោះពុំមែនជាសិស្សរបស់យើងទេ ។

២៩ គឺជាព្រះហឫទ័យរបស់យើង ដែល [ក]ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង ត្រូវបន្លឺសម្លេងរបស់គាត់ឡើង នៅក្នុងសាលាប្រជុំនានា នៅស្រុកខាងកើតទាំងឡាយ ក្នុងការរៀបចំសាសនាចក្រនានា ឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយដែលយើងបានប្រទានដល់ពួកគេ អំពីការសាងឡើងវិញ និងការប្រោសលោះនៃស៊ីយ៉ូន ។

៣០ គឺជាព្រះហឫទ័យរបស់យើងថា [ក]ប៉ាលី ភី ប្រាត្ត ជាអ្នកបំរើរបស់យើង និង ឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើង មិនត្រូវវិលទៅឯ ដែនដីនៃពួកបងប្អូនរបស់គេក្នុងសាសនាឡើយ រហូតដល់ពួកគេបានបក្សពួក ដើម្បីឡើងទៅឯដែនដីស៊ីយ៉ូន តាមក្រុម ១០នាក់ ឬ២០នាក់ ឬ៥០នាក់ ឬមួយ[ខ]រយនាក់ គឺរហូតដល់ពួកគេបានគ្នាដល់ទៅ៥០០នាក់ នូវកម្លាំងពីវង្សារបស់យើងសិន ។

៣១ មើលចុះ នេះហើយជាព្រះហឫទ័យរបស់យើង; ចូរសូម នោះអ្នកនឹងបានទទួល; ប៉ុន្តែមនុស្សលោក[ក]ពុំដែលប្រព្រឹត្តតាមព្រះហឫទ័យរបស់យើងគ្រប់ពេលវេលាឡើយ ។

៣២ ហេតុដូច្នេះហើយ បើសិនជាអ្នកពុំអាចបានគ្នាប្រាំរយនាក់ទេ នោះចូរព្យាយាមស្វែងរក ក្រែងលោអ្នកអាចស្វែងរកបានបីរយ នាក់ ។

៣៣ ហើយបើសិនជាអ្នករាល់គ្នាពុំអាចស្វែងរកបានបីរយនាក់ទេ នោះចូរព្យាយាមស្វែងរក ក្រែងលោអ្នករាល់គ្នាអាចបានមួយរយ នាក់ ។

៣៤ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា យើងប្រទានបញ្ញត្តិមួយដល់អ្នកថា អ្នករាល់គ្នាមិនត្រូវឡើងទៅឯដែនដីស៊ីយ៉ូនឡើយ រហូតដល់ អ្នកបានគ្នាមួយរយនាក់ នូវកម្លាំងពីវង្សារបស់យើងដើម្បីឡើងទៅឯដែនដីស៊ីយ៉ូនជាមួយអ្នក ។

៣៥ ហេតុដូច្នេះហើយ ដូចជាយើងបានប្រាប់អ្នកហើយថា ចូរសូម នោះអ្នករាល់គ្នានឹងបានទទួល; ចូរអធិស្ឋានដោយអស់ពីចិត្ត ក្រែង លោយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង អាចទៅជាមួយអ្នក ហើយត្រួតនៅកណ្ដាលរាស្ត្ររបស់យើង ហើយរៀបចំនគររបស់ យើង នៅលើ[ក]ដែនដីដែលបានញែកទុក ហើយតាំងកូនចៅស៊ីយ៉ូន តាមក្រិត្យវិន័យ និងព្រះបញ្ញត្តិទាំងឡាយ ដែលមានមកហើយ ហើយដែលនឹងត្រូវបានប្រទានដល់អ្នក ។

៣៦ អស់ទាំងជ័យជំនះ និងសិរីល្អត្រូវ[ក]បានធ្វើឲ្យ[ខ]សំរេចដល់អ្នកតាមរយៈសេចក្ដីឧស្សាហ៍ សេចក្ដីស្មោះត្រង់ និងពាក្យអធិស្ឋានទាំង ឡាយនៃសេចក្ដីជំនឿ ។

៣៧ ចូរឲ្យ ប៉ាលី ភី ប្រាត្ត ជាអ្នកបំរើរបស់យើង ធ្វើដំណើរជាមួយ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើងចុះ ។

៣៨ ចូរឲ្យ ឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើង ធ្វើដំណើរជាមួយ ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើងចុះ ។

៣៩ ចូរឲ្យ ហៃរុម ស្ម៊ីធ ជាអ្នកបំរើរបស់យើង ធ្វើដំណើរជាមួយ ហ្វ្រេឌើរិក ជី វិលលាម្ស ជាអ្នកបំរើរបស់យើងចុះ ។

៤០ ចូរឲ្យ អ៊ួរសុន ហៃឌ ជាអ្នកបំរើរបស់យើង ធ្វើដំណើរជាមួយ អ៊ួរសុន ប្រាត្ត ជាអ្នកបំរើរបស់យើងចុះ គឺទៅកន្លែងណាក៏ដោយ ដែល យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើងនឹងទូន្មានដល់ពួកគេ ក្នុងការបំពេញព្រះបញ្ញត្តិទាំងឡាយ ដែលយើងបានប្រទាន ដល់អ្នកចុះ ហើយចូរទុកពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន ឲ្យនៅក្នុងព្រះហស្តរបស់យើងចុះ ។ គឺដូច្នោះមែន ។ អាម៉ែន៕

## កណ្ឌទី ១០៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៨៣៤ អំពីសហសមាគម ឬសមាគមនៃសាសនាចក្រ សំរាប់ផលប្រយោជន៍ដល់មនុស្សទាល់ក្រ (*History of the Church, *២:៥៤–៦០)* ។ *នេះជា*

២៦ *ក* គ. និង ស. ៩៧:២២.
២៧ *ក* ម៉ាថាយ ១០:៣៩; លូកា ៩:២៤; គ. និង ស. ៩៨:១៣–១៥; ១២៤:៥៤.
២៩ *ក* ស.ប. រិកដុន, ស៊ីឌនី.
៣០ *ក* ស.ប. ប្រាត្ត, ប៉ាលី ប៉ាកើរ.
*ខ* គ. និង ស. ១០១:៥៥.
៣១ *ក* គ. និង ស. ៨២:១០.
៣៥ *ក* គ. និង ស. ៨៤:៣១.
៣៦ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* គ. និង ស. ១០៤:៧៩–៨២.

*គ្រានៃការប្រជុំប្រឹក្សារបស់គណៈប្រធានទីមួយ និងពួកសង្ឃជាន់ខ្ពស់ ក្នុងការគិតពិចារណាអំពីសេចក្ដីត្រូវការខាងសាច់ឈាមយ៉ាង ឆាប់ៗនៃប្រជាជន ។ សហសមាគមនៅក្រុងខឺតឡង់ត្រូវបានរំលាយបន្ដិចសិន ហើយរៀបចំឡើងវិញ ហើយទ្រព្យសម្បត្តិទាំងឡាយ ត្រូវចែកជាការកាន់កាប់ត្រួតត្រា នៅក្នុងចំណោមសមាជិកនៃសមាគម ។*

*១–១០, ពួកបរិសុទ្ធណាដែលប្រព្រឹត្តរំលងទាស់និងសហសមាគមនោះនឹងត្រូវបណ្ដាសា; ១១–១៦, ព្រះអម្ចាស់ទ្រង់ផ្គត់ផ្គង់ដល់ពួក បរិសុទ្ធរបស់ទ្រង់ តាមមាគ៌ារបស់ទ្រង់ផ្ទាល់; ១៧–១៨, ក្រឹត្យវិន័យខាងដំណឹងល្អចាត់ចែងខាងការរក្សាមនុស្សទាល់ក្រ; ១៩–៤៦, ការកាន់កាប់ត្រួតត្រា និងព្រះពរទាំងឡាយ នៃពួកបងប្អូននានាត្រូវបានចាត់តាំង; ៤៧–៥៣, សហសមាគមនៅក្រុងខឺតឡង់ និងសមាគមនៅក្រុងស៊ីយ៉ូន ត្រូវឲ្យប្រតិបត្តិផ្សេងគ្នា; ៥៤–៦៦, ឃ្លាំងដ៏ពិសិដ្ឋនៃព្រះអម្ចាស់ គឺត្រូវបានតាំងឡើងសំរាប់បោះពុម្ព ព្រះគម្ពីរ; ៦៧–៧៧, ឃ្លាំងទូទៅនៃសហសមាគមត្រូវប្រតិបត្តិតាមការយល់ព្រមទូទៅ; ៧៨–៨៦, អស់អ្នកដែលនៅក្នុងសហសមាគម ត្រូវសងបំណុលរបស់គេទាំងអស់ ហើយព្រះអម្ចាស់ទ្រង់នឹងរំដោះពួកគេ ឲ្យរួចពីសេវកភាពខាងលុយកាក់ ។*

មិត្តទាំងឡាយរបស់យើងអើយ យើងប្រាប់អ្នកជាប្រាកដថា យើងប្រទានដល់អ្នកនូវពាក្យដំបូន្មាន និងព្រះបញ្ញត្តិមួយអំពីទ្រព្យសម្បត្តិ ទាំងអស់ ដែលជារបស់ផងសមាគម ដែលយើងបានបញ្ជាឲ្យរៀបចំ ហើយតាំងឡើងធ្វើ[ក]ជាសហសមាគម និងជាសមាគមដ៏នៅ អស់កល្បអស់កាលជានិច្ច សំរាប់ផលប្រយោជន៍ដល់សាសនាចក្ររបស់យើង និងសំរាប់សេចក្ដីសង្គ្រោះដល់មនុស្សលោក រហូត ដល់យើងយាងមក —

២ ដោយសេចក្ដីសន្យាដែលមិនចេះផ្លាស់ប្ដូរ និងមិនចេះប្រែប្រួលថាដរាបណាអស់អ្នកដែលយើងបានបញ្ជា មានចិត្តស្មោះត្រង់ នោះពួកគេនឹងត្រូវបានព្រះពរ ដោយព្រះពរដ៏ច្រើនអនេក;

៣ ប៉ុន្តែដរាបណាពួកគេមិនមានចិត្តស្មោះត្រង់ទេ នោះពួកគេជិតនឹងត្រូវបណ្ដាសាហើយ ។

៤ ហេតុដូច្នេះហើយ ដរាបណាពួកអ្នកបំរើរបស់យើងខ្លះ មិនបានកាន់តាមព្រះបញ្ញត្តិ ប៉ុន្តែបានបំបាក់សេចក្ដីសញ្ញា តាមរយៈ[ក]ការលោភលន់ និងដោយពាក្យបោកបញ្ឆោត នោះយើងដាក់បណ្ដាសាដល់ពួកគេ ដោយពាក្យបណ្ដាសាដ៏ធ្ងន់ធ្ងរឈឺចាប់ជាអតិបរមា ។

៥ ត្បិតយើងជាព្រះអម្ចាស់ បានចេញបញ្ញត្តនៅក្នុងព្រះហឫទ័យរបស់យើងថា ដរាបណាមានមនុស្សណាមួយដែលជាសមាជិកនៃ សមាគមបានឃើញថាជាអ្នករំលងច្បាប់ ឬម្យ៉ាងទៀតថា បានបំបាក់សេចក្ដីសញ្ញា ដែលអ្នករាល់គ្នាជាប់នៅ អ្នកនោះហើយ នឹងត្រូវ បណ្ដាសាក្នុងជីវិតរបស់ខ្លួន ហើយនឹងត្រូវជាន់ឈ្លីនៅក្រោមជើងអ្នកណាក៏ដោយដែលយើងសព្វព្រះហឫទ័យ ។

៦ ត្បិតយើងជាព្រះអម្ចាស់ នឹងមិនត្រូវ[ក]គេមើលងាយចំពោះការណ៍ទាំងនេះឡើយ ។

៧ ហើយគ្រប់ការណ៍ទាំងនេះ ដើម្បីកុំឲ្យពួកអ្នកឥតទោសដែលនៅក្នុងចំណោមអ្នក អាចបានជាប់ទោស ជាមួយនឹងពួកឥតសុចរិត ឡើយ; ហើយដើម្បីកុំឲ្យអ្នកមានទោសនៅក្នុងចំណោមអ្នក អាចបានរួចផុតឡើយ; ពីព្រោះយើងជាព្រះអម្ចាស់ បានសន្យាដល់អ្នក នូវ[ក]មកុដនៃសិរីល្អ នៅខាងស្ដាំយើង ។

៨ ហេតុដូច្នេះហើយ ដរាបណាអ្នកបានឃើញថាជាអ្នករំលងច្បាប់ នោះអ្នកពុំអាចបានរួចផុតពីសេចក្ដីក្រោធរបស់យើង ក្នុងជីវិត អ្នកឡើយ ។

៩ ដរាបណាអ្នករាល់គ្នាបាន[ក]កាត់ចេញ ដោយព្រោះអំពើរំលង នោះអ្នករាល់គ្នាពុំអាចបានរួចផុតពីការធ្វើ[ខ]ទុក្ខនៃ[គ]អារក្សសាតាំងឡើយ រហូតដល់ថ្ងៃប្រោសលោះ ។

១០ ហើយឥឡូវនេះ យើងប្រទានអំណាចដល់អ្នកចាប់តាំងពីម៉ោងនេះទៅ ថាបើសិនជាមានមនុស្សណាមួយ ក្នុងចំណោមអ្នករាល់គ្នា ក្នុងសមាគម បានឃើញថាជាអ្នករំលងច្បាប់ ហើយមិនប្រែចិត្តពីអំពើអាក្រក់សោះ នោះអ្នករាល់គ្នាត្រូវបញ្ជូនអ្នកនោះទៅរកការធ្វើទុក្ខ របស់អារក្សសាតាំងចុះ ហើយអ្នកនោះនឹងពុំមានអំណាច ដើម្បី[ក]នាំឲ្យមានអំពើអាក្រក់មកលើអ្នកឡើយ ។

១១ នេះហើយជាប្រាជ្ញានៅក្នុងយើង; ហេតុដូច្នេះហើយ

**១០៤** ១*ក* គ. និង ស. ៧៨:៣–១៥.
ស.ប. សហសមាគម.
៤ *ក* ស.ប. លោភ.
៦ *ក* កាឡាទី ៦:៧–៩.
៧ *ក* អេសាយ ៦២:៣;
គ. និង ស. ៧៦:៥៦.
ស.ប. សិរីល្អ.
៩ *ក* ស.ប. ការកាត់ចេញពីសាសនា.
*ខ* គ. និង ស. ៨២:២១.
*គ* ស.ប. អារក្ស.
១០ *ក* គ. និង ស. ១០៩:២៥–២៧.

យើងប្រទានបញ្ញត្តិមួយដល់អ្នកថា អ្នករាល់គ្នាត្រូវរៀបចំខ្លួន
ហើយតាំង ឲ្យមនុស្សមាន[ក]ការកាន់កាប់ត្រួតត្រារៀងៗខ្លួន;
១២ ប្រយោជន៍ឲ្យមនុស្សគ្រប់រូប អាចបានទទួលការខុសត្រូវ
ចំពោះយើង នូវការកាន់កាប់ត្រួតត្រា ដែលបានតាំងដល់ខ្លួន ។
១៣ ត្បិតជាការចាំបាច់ថា យើងជាព្រះអម្ចាស់ត្រូវរាប់
មនុស្សគ្រប់រូប ឲ្យ[ក]ទទួលការខុសត្រូវ ជា[ខ]នាយតម្រួតការ
លើព្រះពរទាំងឡាយ ខាងផែនដី ដែលយើងបានបង្កើត ហើយ
បានរៀបចំឡើង សំរាប់សត្វលោកទាំងឡាយរបស់យើង ។
១៤ យើងជាព្រះអម្ចាស់ [ក]បានលាតផ្ទៃមេឃ ហើយ[ខ]បាន
ស្ថាបនាផែនដី គឺជាការដែលព្រះហស្តយើងធ្វើ; ហើយគ្រប់ទាំង
អស់ នៅទីនោះសុទ្ធតែជារបស់ផងយើង ។
១៥ ហើយនេះជាគោលបំណងរបស់យើង ដើម្បីផ្គត់ផ្គង់ដល់
ពួកបរិសុទ្ធរបស់យើង ត្បិតគ្រប់ទាំងអស់សុទ្ធតែជារបស់ផង
យើង ។
១៦ ប៉ុន្តែការនេះត្រូវបានសំរេចតាម[ក]មាគ៌ារបស់យើង; ហើយ
មើលចុះ នេះជាមាគ៌ារបស់យើង ថាយើងជាព្រះអម្ចាស់បាន
ចេញបញ្ញត្តិ [ខ]ដើម្បីផ្គត់ផ្គង់ដល់ពួកបរិសុទ្ធរបស់យើង
ប្រយោជន៍ឲ្យមនុស្សទ័លក្រត្រូវបានដំកើងឡើង ក្នុងកាលមនុស្ស
មានត្រូវបានបន្ទាបចុះ ។
១៧ [ក]ត្បិតផែនដីបានពោរពេញ ហើយមានបរិបូរគ្រប់គ្រាន់
និងនៅសល់ទៀតផង; មែនហើយ យើងបានរៀបចំគ្រប់ទាំងអស់
ហើយបានប្រទានដល់កូនចៅមនុស្ស ឲ្យធ្វើជា[ខ]ភ្នាក់ងារដល់ខ្លួន ។
១៨ ហេតុដូច្នេះហើយ បើសិនជាមានមនុស្សណាមួយយកពី
[ក]របស់បរិបូរដែលយើងបានបង្កើតមក ហើយពុំចែកចំណែករបស់ខ្លួន
តាម [ខ]ក្រិត្យវិន័យនៃដំណឹងល្អរបស់យើង ដល់[គ]មនុស្សទាល់ក្រ
និងមនុស្សកំសត់ទុគ៌តទេ អ្នកនោះនឹងសម្លឹងភ្នែកឡើងនៅក្នុង
[ឃ]ស្ថាននរក ជាមួយ មនុស្សទុច្ចរិត នៅក្នុងការរងទុក្ខវេទនា ។
១៩ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដ អំពី
ទ្រព្យសម្បត្តិទាំងឡាយនៃ[ក]សមាគម —

២០ ចូរឲ្យ ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង បាន
តាំងឡើងដល់កន្លែងរបស់គាត់ ដែលគាត់កំពុងអាស្រ័យនៅ
ពេលនេះចុះ ហើយកន្លែងសម្លាប់ស្បែក ទុកសំរាប់ជាការកាន់
កាប់ត្រួតត្រារបស់គាត់ សំរាប់ការគាំទ្រដល់គាត់ នៅពេល
គាត់ធ្វើការនៅក្នុងចំការ ទំពាំងបាយជូររបស់យើង គឺស្របតាម
ព្រះហឫទ័យរបស់យើង កាលយើងនឹងបញ្ជាដល់គាត់ ។
២១ ហើយចូរឲ្យបានសំរេចសព្វគ្រប់ តាមពាក្យដំបូន្មាន
នៃសមាគម និងតាមការយល់ព្រមព្រៀងគ្នា ឬតាមសម្លេង
នៃសមាគម ដែលនៅក្នុងដែនដីខឺតឡង់ ។
២២ ហើយការកាន់កាប់ត្រួតត្រា និងព្រះពរនេះ យើងជាព្រះ
អម្ចាស់ ប្រទានមកលើ ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង
ទុកជាព្រះ ពរមកលើគាត់ និងពូជពង្សរបស់គាត់បន្តបន្ទាប់គ្នាទៅ;
២៣ ហើយយើងនឹងបង្កើនព្រះពរមកលើគាត់កាន់តែច្រើនឡើង
ដរាបណាគាត់បន្ទាបខ្លួននៅចំពោះយើង ។
២៤ ហើយជាថ្មីទៀត ចូរឲ្យ ម៉ាទិន ហារិស ជាអ្នកបំរើ
របស់យើង បានតាំងដល់គាត់ សំរាប់ជាការកាន់កាប់ត្រួតត្រា
របស់គាត់ នូវកន្លែងដីដែល យ៉ូហាន ចនសុន ជាអ្នកបំរើ
របស់យើងបានមក ដោយដូរកេរ្តិ៍មរតករបស់គាត់ពីមុន ទុកសំរាប់
គាត់ និងពូជពង្សរបស់ គាត់បន្តបន្ទាប់គ្នាទៅ;
២៥ ហើយដរាបណាគាត់មានចិត្តស្មោះត្រង់ នោះយើងនឹង
បង្កើនព្រះពរកាន់តែច្រើនឡើងមកលើគាត់ និងពូជពង្សរបស់
គាត់ បន្តបន្ទាប់គ្នាទៅ ។
២៦ ហើយចូរឲ្យ ម៉ាទិន ហារិស ជាអ្នកបំរើរបស់យើង
ទុកប្រាក់កាសរបស់គាត់ សំរាប់ការប្រកាសព្រះបន្ទូលទាំង
ឡាយរបស់យើង តាមដែល យ៉ូសែប ស៊្មីធ ជុញ្ញ័រ ជាអ្នកបំរើ
របស់យើង នឹងដឹកនាំចុះ ។
២៧ ហើយជាថ្មីទៀត ចូរឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស ជាអ្នក
បំរើរបស់យើង បានកន្លែងដែលគាត់កំពុងអាស្រ័យនៅលើឥឡូ
វនេះចុះ ។

១១ ក គ. និង ស. ៤២:៣២.
ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
១៣ ក ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
ខ គ. និង ស. ៧២:៣–៥, ១៦–២២.
១៤ ក អេសាយ ៤២:៥; ៤៥:១២.
ស.ប. បង្កបង្កើត, ការបង្កបង្កើត.
ខ ទំនុក. ១៩:១; ២៤:១.
១៦ ក គ. និង ស. ១០៥:៥.
ស.ប. សុខុមាលភាព.
ខ ១ សាំយូ. ២:៧–៨; លូកា ១:៥១–៥៣; គ. និង ស. ៨៨:១៧.
១៧ ក គ. និង ស. ៥៩:១៦–២០.
ស.ប. ផែនដី.
ខ ស.ប. សិទ្ធិជ្រើសរើស.
១៨ ក លូកា ៣:១១; យ៉ាកុប (ព.ស.ថ.) ២:១៥–១៦.
ខ គ. និង ស. ៤២:៣០.
គ សុភា. ១៤:២១; ម៉ូសាយ ៤:២៦; គ. និង ស. ៥២:៤០.
ឃ លូកា ១៦:២០–៣១.
១៩ ក ស.ប. សហសមាគម.

២៨ ហើយចូរឲ្យ អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង បានដីធ្លីនៅជាប់ផ្ទះ ដែលជាកន្លែងទុកសំរាប់ធ្វើរោងបោះពុម្ព ដែលជា ដីធ្លីទីមួយ ហើយជាដីធ្លីដែលឪពុករបស់គាត់កំពុងអាស្រ័យនៅលើ ។

២៩ ហើយចូរឲ្យ ហ្វ្រេឌើរិក ជី វិលលាម្ស និង អូលីវើរ ខៅឌើរី ជាពួកអ្នកបំរើរបស់យើង បានរោងបោះពុម្ព និងរបស់របរទាំងអស់ខាង ការនោះចុះ ។

៣០ ហើយនេះនឹងទៅជាការកាន់កាប់ត្រួតត្រារបស់ពួកគេ ដែលនឹងត្រូវបានតាំងមកលើពួកគេ ។

៣១ ហើយដរាបណាពួកគេមានចិត្តស្មោះត្រង់ មើលចុះ យើងនឹងប្រទានពរ ហើយបង្កើនព្រះពរមកលើពួកគេកាន់តែច្រើនឡើង ។

៣២ ហើយនេះគឺជាការចាប់ផ្ដើមនៃការកាន់កាន់ត្រួតត្រា ដែលយើងបានតាំងដល់ពួកគេ សំរាប់ពួកគេ និងពូជពង្សរបស់ពួកគេ បន្តបន្ទាប់គ្នាទៅ ។

៣៣ ហើយដរាបណាពួកគេមានចិត្តស្មោះត្រង់ នោះយើងនឹងបង្កើនព្រះពរកាន់តែច្រើនឡើង មកលើពួកគេ និងពូជពង្សរបស់ពួកគេ បន្តបន្ទាប់គ្នាទៅ គឺដោយព្រះពរដ៏ច្រើនអនេក;

៣៤ ហើយជាថ្មីទៀត ចូរឲ្យ យ៉ូហាន ចនសុន ជាអ្នកបំរើរបស់យើង បានផ្ទះសំបែងដែលគាត់កំពុងអាស្រ័យនៅ និងកេរ្តិ៍មរតកទាំង អស់ លើកលែងតែដីដែលបានទុកសំរាប់ធ្វើអាគារនៃគេហដ្ឋានទាំងឡាយរបស់យើង ដែលទាក់ទងទៅនិងកេរ្តិ៍មរតកនោះ និងដីធ្លីទាំង នោះ ដែលបានឲ្យដល់ អូលីវើរ ខៅឌើរី ជាអ្នកបំរើរបស់យើង ។

៣៥ ហើយដរាបណាគាត់មានចិត្តស្មោះត្រង់ នោះយើងនឹងបង្កើនព្រះពរមកលើគាត់កាន់តែច្រើនឡើង ។

៣៦ ហើយនេះគឺជាព្រះហឫទ័យរបស់យើង ថាគាត់ត្រូវលក់ដីធ្លីទាំងឡាយ ដែលទុកសំរាប់ការសាងឡើង នូវទីក្រុងនៃពួកបរិសុទ្ធ របស់យើង ដរាបណាដែលបានធ្វើឲ្យគាត់ដឹងដោយសម្លេងនៃព្រះវិញ្ញាណរបស់យើង ហើយស្របតាមពាក្យដំបូន្មាននៃសមាគម និងដោយសម្លេងនៃសមាគម ។

៣៧ ហើយនេះគឺជាការចាប់ផ្ដើមនៃការកាន់កាប់ត្រួតត្រា ដែលយើងបានតាំងដល់គាត់ ទុកសំរាប់ជាព្រះពរដល់គាត់ និងពូជពង្ស របស់គាត់បន្តបន្ទាប់គ្នាទៅ ។

៣៨ ហើយដរាបណាគាត់មានចិត្តស្មោះត្រង់ នោះយើងនឹងចំរើនពរដ៏ច្រើនអនេកមកលើគាត់ ។

៣៩ ហើយជាថ្មីទៀត ចូរឲ្យ នូវល ខេ វិតនី ជាអ្នកបំរើរបស់យើង បានតាំងដល់គាត់ នូវផ្ទះសំបែង និងដីធ្លីដែលគាត់អាស្រ័យនៅឥឡូវ នេះ និងដីធ្លី និងអាគារដែលមានហាងលក់ដូរ ព្រមទាំងដីធ្លី ដែលនៅជ្រុងខាងត្បូងហាងលក់ដូរ ហើយព្រមទាំងដីធ្លីដែលមានរោងផេះ ផង ។

៤០ ហើយការណ៍អស់ទាំងនេះយើងបានតាំងដល់ នូវល ខេ វិតនី ជាអ្នកបំរើរបស់យើង សំរាប់ជាការកាន់កាប់ត្រួតត្រារបស់គាត់ ទុកសំរាប់ជាព្រះពរមកលើគាត់ និងពូជពង្សរបស់គាត់បន្តបន្ទាប់គ្នាទៅ សំរាប់ជាផលប្រយោជន៍ដល់ហាងលក់ដូរនៃសមាគម របស់យើង ដែលយើងបានតាំងឡើងសំរាប់ស្ដេករបស់យើង នៅដែនដីខឺតឡង់ ។

៤១ មែនហើយ ប្រាកដមែន នេះគឺជាការកាន់កាប់ត្រួតត្រា ដែលយើងបានចាត់តាំងដល់ អែន ខេ វិតនី ជាអ្នកបំរើរបស់យើង គឺហាង លក់ដូរទាំងមូលនេះ គឺដល់គាត់ និងភ្នាក់ងាររបស់គាត់ និងពូជពង្សរបស់គាត់បន្តបន្ទាប់គ្នាទៅ ។

៤២ ហើយដរាបណាគាត់មានចិត្តស្មោះត្រង់ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ដែលយើងបានប្រទានដល់គាត់ នោះយើងនឹងបង្កើនព្រះពរមកលើគាត់ និងពូជពង្សរបស់គាត់ បន្តបន្ទាប់គ្នាទៅ គឺដោយព្រះពរដ៏ច្រើនអនេក ។

៤៣ ហើយជាថ្មីទៀត ចូរឲ្យ យ៉ូសែប ស្ម៊ីធ ជុញ៉ែរ ជាអ្នកបំរើរបស់យើង បានចាត់តាំងដល់លោក នូវដីធ្លីដែលបានទុកសំរាប់កសាង គេហដ្ឋានរបស់យើង ដែលមានបណ្ដោយ ២០០ ម៉ែត្រ និងទទឹង ៦០ ម៉ែត្រ និងព្រមទាំងកេរ្តិ៍មរតក ដែលឪពុកលោកអាស្រ័យនៅ ពេលឥឡូវនេះផង;

៤៤ ហើយនេះគឺជាការចាប់ផ្ដើមនៃការកាន់កាប់ត្រួតត្រា ដែលយើងបានចាត់តាំងដល់លោក ទុកសំរាប់ជាព្រះពរមកលើលោក និងមកលើឪពុកលោក ។

៤៥ ត្បិតមើលចុះ យើងបានទុកកេរ្តិ៍មរតកមួយសំរាប់ឪពុកលោក ទុកសំរាប់ជាការគាំទ្រដល់គាត់; ហេតុដូច្នេះហើយ គាត់ត្រូវរាប់ នៅក្នុងវង្សារបស់ យ៉ូសែប ស្ម៊ីធ ជុញ៉ែរ ជាអ្នកបំរើរបស់យើង ។

៤៦ ហើយយើងនឹងបង្កើនព្រះពរមកលើវង្សារបស់ យ៉ូសែប ស្ម៊ីធ ជុញ៉ែរ ជាអ្នកបំរើរបស់យើង ដរាបណាលោកមានចិត្តស្មោះត្រង់ គឺដោយព្រះពរដ៏ច្រើនអនេក ។

៤៧ ហើយឥឡូវនេះ យើងប្រទានបញ្ញត្តិមួយដល់អ្នក

៣៤ *ក* គ. និង ស. ៩៤:៣, ១០.
៣៦ *ក* ស.ប. វិវរណៈ.
៣៩ *ក* ស.ប. វិតនី, នូវល ខេ.
៤១ *ក* គ. និង ស. ៨៤:១១២–១១៣.
៤៥ *ក* គ. និង ស. ៩០:២០.
ស.ប. ស្ម៊ីធ, យ៉ូសែប ស៊ីញ៉ែរ.

អំពីស៊ីយ៉ូនថា អ្នកមិនត្រូវនៅជាប់ចំណងជាសហសមាគមនិង
ពួកបងប្អូនអ្នក នៅក្នុងសាសនា នៅក្រុងស៊ីយ៉ូនទៀតឡើយ
លើកលែងតែតាមបែបនេះគឺ —
៤៨ បន្ទាប់ពីអ្នកត្រូវបានរៀបចំឡើង នោះអ្នកត្រូវបានហៅ
ថាជា សហសមាគមរបស់ស្ដេកនៃស៊ីយ៉ូន នៅទីក្រុងខឺតឡង់ ។
ហើយបន្ទាប់ពីពួកគេត្រូវបានរៀបចំឡើង នោះពួកបងប្អូនអ្នកនៅ
ក្នុងសាសនានឹងត្រូវបានហៅថាជា សហសមាគមនៃទីក្រុងស៊ីយ៉ូន ។
៤៩ ហើយពួកគេនឹងត្រូវបានរៀបចំឡើង នៅក្នុងនាមទាំង
ឡាយរបស់ពួកគេផ្ទាល់ និងនៅក្នុងនាមរបស់ពួកគេផ្ទាល់;
ហើយពួកគេត្រូវ ប្រព្រឹត្តកិច្ចការរបស់ពួកគេ នៅក្នុងនាមរបស់
ពួកគេផ្ទាល់ និងនៅក្នុងនាមទាំងឡាយរបស់ពួកគេផ្ទាល់;
៥០ ហើយអ្នកត្រូវប្រព្រឹត្តកិច្ចការរបស់អ្នក នៅក្នុងនាមរបស់
អ្នកផ្ទាល់ និងនៅក្នុងនាមទាំងឡាយរបស់អ្នកផ្ទាល់ ។
៥១ ហើយការណ៍នេះយើងបានបញ្ជាឲ្យសំរេច សំរាប់សេច
ក្ដីសង្គ្រោះដល់អ្នក និងសំរាប់សេចក្ដីសង្គ្រោះដល់ពួកគេ មក
ពីពួកគេត្រូវ បានបណ្ដេញចេញ និងពីអ្វីដែលនឹងកើតឡើង ។
៥២ សេចក្ដីសញ្ញាទាំងឡាយដែលបានបំពាក់តាមរយៈការ
រំលង ដោយសារការលោភលន់ និងពាក្យបោកបញ្ឆោត —
៥៣ ហេតុដូច្នេះហើយ អ្នកត្រូវបានរំលាយជាសហសមាគម
ដោយសារពួកបងប្អូនរបស់អ្នកក្នុងសាសនា ដើម្បីកុំឲ្យអ្នកជាប់
ចំណងនិង ពួកគេ លើកលែងតែនៅម៉ោងនេះ លើកលែងតែតាម
បែបនេះ ដូចជាយើងបានមានព្រះបន្ទូល គឺដោយសារការខ្ចីប្រាក់
ដូចដែល បានយល់ព្រមដោយសមាគមនេះ នៅក្រុមប្រឹក្សា
តាមតែកាលៈទេសៈនឹងបណ្ដោយ និងតាមតែសម្លេងនៃក្រុម
ប្រឹក្សាដឹកនាំ ។
៥៤ ហើយជាថ្មីទៀត យើងប្រទានបញ្ញត្តិមួយដល់អ្នក អំពីការ
កាន់កាប់ត្រួតត្រារបស់អ្នក ដែលយើងបានចាត់តាំងដល់អ្នក ។
៥៥ មើលចុះ គ្រប់ទ្រព្យសម្បត្តិទាំងអស់សុទ្ធតែរបស់ផងយើង
បើពុំនោះសោតទេ សេចក្ដីជំនឿរបស់អ្នកសុទ្ធតែឥតអំពើហើយ
ហើយ អ្នករាល់គ្នាត្រូវបានឃើញថាជាមនុស្សមានពុត ហើយសេច
ក្ដីសញ្ញាទាំងឡាយដែលអ្នករាល់គ្នាបានធ្វើដល់យើង នោះបាន
បែកបាក់;
៥៦ ហើយបើសិនជាទ្រព្យសម្បត្តិទាំងឡាយជារបស់ផងយើង
ខណៈនោះ អ្នករាល់គ្នាជានាយតម្រួតការហើយ; បើពុំនោះសោត
ទេ អ្នករាល់គ្នាពុំមែនជានាយតម្រួតការឡើយ ។
៥៧ ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា យើងបានចាត់ដល់អ្នក
ឲ្យធ្វើជានាយតម្រួតការលើវង្សារបស់យើង គឺពិតជានាយតម្រួត
ការទាំង ឡាយមែន ។
៥៨ ហើយដោយសារគោលបំណងនេះ ទើបយើងបាន
បញ្ជាឲ្យអ្នករៀបចំខ្លួនឡើង គឺដើម្បីបោះពុម្ពព្រះបន្ទូលទាំងឡាយ
របស់យើង ជាភាពពោរពេញនៃព្រះគម្ពីររបស់យើង
ជាវិវរណៈទាំងឡាយដែលយើងបានប្រទានដល់អ្នក ហើយដែល
យើងនឹងប្រទានដល់អ្នក ម្ដងម្កាលៗ ពីពេលនេះតទៅ —
៥៩ សំរាប់គោលបំណងនៃការកសាងសាសនាចក្រ និងនគរ
របស់យើងឡើង នៅលើផែនដី ហើយដើម្បីរៀបចំរាស្ត្រ
របស់យើងចាំ ពេលដែលយើងនឹងគង់នៅជាមួយពួកគេ ដែល
នៅជិតដៃបង្កើយ ។
៦០ ហើយអ្នករាល់គ្នាត្រូវរៀបចំកន្លែងមួយដល់ខ្លួន ទុកសំរាប់
ជាឃ្លាំង ហើយថ្វាយទីនោះដល់ព្រះនាមរបស់យើង ។
៦១ ហើយអ្នករាល់គ្នាត្រូវចាត់នរណាមួយ ក្នុងចំណោមអ្នក
រាល់គ្នា ឲ្យរក្សាឃ្លាំង ហើយអ្នកនោះត្រូវបានតែងតាំងចំពោះ
ព្រះពរនេះ ។
៦២ ហើយត្រូវមានត្រានៅលើឃ្លាំង និងគ្រប់ទាំង
របស់ពិសិដ្ឋៗ ដែលត្រូវបានដាក់ក្នុងឃ្លាំងផង; ហើយគ្មាន
នរណាមួយ ក្នុងចំណោម អ្នករាល់គ្នា ត្រូវហៅទីនោះ
ឬចំណែកណាមួយថាជារបស់ខ្លួនឡើយ ត្បិតទីនោះត្រូវទៅជា
របស់អ្នកទាំងអស់គ្នា ។
៦៣ ហើយយើងប្រទានឃ្លាំងដល់អ្នក ចាប់ពីម៉ោងនេះ
តទៅ ហើយឥឡូវនេះ ចូរមើលឲ្យឃើញថា អ្នករាល់គ្នាទៅ
ហើយប្រើ ប្រាស់ការកាន់កាប់ត្រួតត្រា ដែលយើងបាន
ចាត់ដល់អ្នកចុះ លើកលែងតែរបស់ពិសិដ្ឋទាំងឡាយ
ទុកសំរាប់ការបោះពុម្ពរបស់ពិសិដ្ឋ ទាំងនេះ តាមដែល
យើងមានបន្ទូលមកប៉ុណ្ណោះ ។
៦៤ ហើយអ្វីដែលបានមកពីរបស់ពិសិដ្ឋទាំងឡាយ នោះនឹង

---

៤៨ *ក* គ. និង ស. ៨២:១៣; ៩៤:១; ១០៩:៥៩.
ស.ប. ចំរឹង, ស្ដេក.
៥១ *ក* គ. និង ស. ១០៩:៤៧.
៥២ *ក* ស.ប. សេចក្ដីសញ្ញា.
*ខ* ស.ប. លោភ.
៥៦ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា.
៥៨ *ក* ស.ប. ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.).
៥៩ *ក* ស.ប. សហស្សវត្សរ៍.
*ខ* គ. និង ស. ១:៣៥–៣៦; ២៩:៩–១១.
៦៤ *ក* ក.ន. កម្រៃ ឬចំណូល.

ត្រូវមាននៅក្នុងឃ្លាំង ហើយត្រាមួយនឹងត្រូវបិទពីលើ; ហើយមិនត្រូវ ប្រើប្រាស់ ឬយកចេញពីឃ្លាំង ឬក៏ស្រាយត្រាដែលបានបិទពីលើ ដោយអ្នកណាមួយឡើយ លើកលែងតែដោយសម្លេងនៃសមាគម ឬដោយព្រះបញ្ញត្តិប៉ុណ្ណោះ ។

៦៥ ហើយដោយបែបនេះ អ្នករាល់គ្នាត្រូវរក្សាទុក នូវអ្វីៗដែលបានពីរបស់ពិសិដ្ឋទាំងឡាយនៅក្នុងឃ្លាំង ទុកសំរាប់គោលបំណងដ៏ពិសិដ្ឋ និងបរិសុទ្ធទាំងឡាយ ។

៦៦ ហើយរបស់នេះនឹងត្រូវបានហៅថាជាឃ្លាំងពិសិដ្ឋនៃព្រះអម្ចាស់; ហើយត្រាមួយនឹងត្រូវបានដាក់ពីលើ ប្រយោជន៍ឲ្យវាអាច បានបរិសុទ្ធ ហើយបានថ្វាយដល់ព្រះអម្ចាស់ ។

៦៧ ហើយជាថ្មីទៀត ត្រូវមានឃ្លាំងមួយទៀតរៀបចំឡើង ហើយត្រូវមានហិរញ្ញិកមួយចាត់ឲ្យរក្សាឃ្លាំង និងត្រូវមានត្រាមួយ ដាក់ពីលើ;

៦៨ ហើយប្រាក់កាសទាំងអស់ ដែលអ្នកបានមកពីការកាន់កាប់ត្រួតត្រាទាំងឡាយរបស់អ្នក ដោយសារការតម្លើងតម្លៃទៅលើទ្រព្យសម្បត្តិទាំងឡាយ ដែលយើងបានចាត់ដល់អ្នក ចំពោះផ្ទះសំបែង ឬចំពោះដីធ្លី ឬចំពោះគោក្របី ឬចំពោះរបស់គ្រប់យ៉ាង លើកលែងតែការសរសេរដ៏បរិសុទ្ធ និងពិសិដ្ឋទាំងឡាយ ដែលយើងបានរក្សាទុកចំពោះខ្លួនយើងផ្ទាល់ ទុកសំរាប់គោលបំណងដ៏បរិសុទ្ធ និងពិសិដ្ឋទាំងឡាយ នោះត្រូវបោះទៅក្នុងឃ្លាំងភ្លាមៗ តាមដែលអ្នកបានទទួលប្រាក់ រាប់រយ ឬរាប់ហាសិប ឬរាប់ម្ភៃ ឬរាប់ដប់ ឬរាប់ប្រាំ ។

៦៩ ឬម៉្យាងទៀតថា បើសិនជាមានមនុស្សណាមួយ ក្នុងចំណោមអ្នកបានប្រាំដុល្លា នោះចូរឲ្យគាត់បោះទៅក្នុងឃ្លាំងចុះ; ឬបើសិន ជាគាត់មានដប់ ឬម្ភៃ ឬហាសិប ឬមួយរយ នោះចូរឲ្យគាត់ធ្វើយ៉ាងដូច្នោះដែរ;

៧០ ហើយចូរកុំឲ្យអ្នកណាមួយ ក្នុងចំណោមអ្នកនិយាយថាប្រាក់នោះជារបស់គាត់ផ្ទាល់ឡើយ; ត្បិតប្រាក់នោះមិនត្រូវហៅថាជារបស់ គាត់ ឬចំណែកណាមួយឡើយ ។

៧១ ហើយមិនត្រូវប្រើប្រាស់ចំណែកណាមួយ ឬយកចេញពីឃ្លាំងឡើយ លើកលែងតែដោយសម្លេង និងការយល់ព្រមទូទៅនៃ សមាគមប៉ុណ្ណោះ ។

៧២ ហើយនេះត្រូវទៅជាសម្លេង និងការយល់ព្រមទូទៅនៃសមាគម — គឺមនុស្សណាមួយ ក្នុងចំណោមអ្នកនិយាយទៅហេរញ្ញិកថា៖ ខ្ញុំត្រូវការចំនួននេះ ដើម្បីជួយខ្ញុំក្នុងការកាន់កាប់ត្រួតត្រារបស់ខ្ញុំ —

៧៣ បើសិនជាត្រូវប្រាំដុល្លា ឬបើសិនជាត្រូវដប់ដុល្លា ឬម្ភៃ ឬហាសិប ឬមួយរយក្ដី នោះហេរញ្ញិកត្រូវឲ្យដល់គាត់ នូវចំនួនដែលគាត់ ត្រូវការ ដើម្បីជួយក្នុងការកាន់កាប់ត្រួតត្រារបស់គាត់ —

៧៤ រហូតដល់ឃើញថាគាត់ជាអ្នករំលងច្បាប់ ហើយបានសំដែងចំពោះក្រុមប្រឹក្សានៃសមាគមយ៉ាងច្បាស់ថា គាត់ជានាយ[ក]ត្រួតការដ៏ មានចិត្តមិនស្មោះត្រង់ ហើយមានមារយាទមិនល្អ ។

៧៥ ប៉ុន្តែកាលណាគាត់ជាសមាជិកពេញទី ហើយស្មោះត្រង់ ហើយមានមារយាទល្អចំពោះការកាន់កាប់ត្រួតត្រារបស់គាត់នេះហើយ ជាសំគាល់របស់គាត់ដល់ហេរញ្ញិក ថាហេរញ្ញិកមិនត្រូវបង្ខាំងឡើយ ។

៧៦ ប៉ុន្តែចំពោះករណីរំលងច្បាប់វិញ នោះហិរញ្ញិកត្រូវនៅក្រោមក្រុមប្រឹក្សា និងសម្លេងនៃសមាគម ។

៧៧ ហើយនៅករណីណាឃើញថាហេរញ្ញិក ជានាយត្រួតការដ៏មិនស្មោះត្រង់ ហើយមានមារយាទមិនល្អ នោះគាត់ត្រូវនៅក្រោម ក្រុមប្រឹក្សា និង[ក]សម្លេងនៃសមាគម ហើយត្រូវដកចេញពីកន្លែងគាត់ ហើយម្នាក់ទៀតត្រូវបានតាំងឡើងជំនួសគាត់ ។

៧៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដ អំពីបំណុលទាំងឡាយរបស់អ្នកថា — មើលចុះ គឺជាព្រះហឫទ័យរបស់យើង ដែលអ្នក[ក]ត្រូវ[ខ]បង់បំណុលរបស់អ្នកឲ្យអស់ ។

៧៩ ហើយគឺជាព្រះហឫទ័យរបស់យើង ដែលអ្នករាល់គ្នាត្រូវ[ក]បន្ទាបខ្លួននៅចំពោះយើង ហើយត្រូវបានព្រះពរនេះ ដោយសារការ [ខ]ឧស្សាហ៍ និងភាពរាបសា និងការអធិស្ឋានដោយសេចក្ដីជំនឿរបស់អ្នក ។

៨០ ហើយដរាបណាអ្នកមានចិត្តឧស្សាហ៍ និងរាបទាប ហើយអនុវត្ត[ក]ការអធិស្ឋានដោយសេចក្ដីជំនឿ មើលចុះ យើងនឹងបន្ទន់ចិត្តរបស់ ម្ចាស់បំណុល ដែលអ្នកជំពាក់ រហូតដល់យើងបញ្ជូនផ្លូវនានាដល់អ្នក សំរាប់ការរំដោះរបស់អ្នក ។

៨១ ហេតុដូច្នេះហើយ ចូរប្រញាប់សរសេរទៅ[ក]រដ្ឋនូវយ៉ោក ហើយសរសេរតាមអ្វីដែលព្រះវិញ្ញាណរបស់យើងដឹកនាំ; ហើយយើងនឹង បន្ទន់ចិត្តរបស់ម្ចាស់បំណុល

៧៤ *ក* លូកា ១៦:១–១២.
៧៧ *ក* គ. និង ស. ១០៧:៩៩–១០០.
៧៨ *ក* គ. និង ស. ៤២:៥៤.
*ខ* ស.ប. បំណុល.
៧៩ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
៨០ *ក* យ៉ាកុប (ពស.ថ.) ៥:១៥.

ដែលអ្នកជំពាក់ ដើម្បីឲ្យបានយកចេញពីគំនិតរបស់ពួកគេនូវការធ្វើទុក្ខដល់អ្នក ។

៨២ ហើយដរាបណាអ្នករាល់គ្នាមានចិត្តរាបសា ហើយស្មោះត្រង់ ហើយអំពាវនាវដល់ព្រះនាមយើង មើលចុះ យើងនឹងប្រទានឲ្យ អ្នកមានជ័យជំនះ ។

៨៣ យើងប្រទានដល់អ្នកនូវសេចក្ដីសន្យាមួយថា អ្នកត្រូវបានរំដោះឲ្យរួចផុតពីសេវកភាពរបស់អ្នក តែម្ដងនេះគត់ ។

៨៤ ដរាបណាអ្នកមានឱកាសខ្ចីប្រាក់រាប់រយ ឬរាប់ពាន់ គឺរហូតដល់អ្នកខ្ចីបានល្មមនិងរំដោះខ្លួនឲ្យរួចពីសេវកភាព នោះជាឯកសិទ្ធិរបស់អ្នកហើយ ។

៨៥ ហើយចូរបញ្ចាំទ្រព្យសម្បត្តិទាំងឡាយ ដែលយើងបានដាក់ទៅក្នុងកណ្ដាប់ដៃរបស់អ្នករាល់គ្នាតែម្ដងនេះគត់ ដោយផ្ដល់ឈ្មោះរបស់អ្នករាល់គ្នា ដោយការយល់ព្រមទូទៅ ឬម៉្យាងទៀត ដូចជាឃើញថាល្អចំពោះអ្នក ។

៨៦ យើងប្រទានឯកសិទ្ធិនេះចំពោះអ្នក តែម្ដងនេះគត់; ហើយមើលចុះ បើសិនជាចាប់ផ្ដើមប្រព្រឹត្តនូវអ្វីៗទាំងឡាយ ដែលយើងបានលាតត្រដាងនៅចំពោះអ្នក ស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះគ្រប់អ្វីៗទាំងអស់សុទ្ធតែរបស់យើង ហើយអ្នករាល់គ្នាជានាយតម្រួតការរបស់យើង ហើយចៅហ្វាយមិនដែលស៊ូទ្រាំឲ្យវង្សារបស់ លោកត្រូវបែកបាក់ឡើយ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១០៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅទន្លេហ្វិស៊ីង រដ្ឋមិសសួរី ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៨៣៤* (History of the Church, *២:១០៨–១១១)* ។ *អំពើឃោរឃៅរបស់ហ្វូងមនុស្សកំណាចទាស់និងពួកបរិសុទ្ធ នៅរដ្ឋមិសសួរី មានកាន់តែខ្លាំងឡើង ហើយក្រុមមនុស្សជាច្រើនពីឃុំមួយចំនួនបានប្រកាសប្រាប់បំណងចិត្តរបស់ពួកគេ ថានិងបំផ្លាញប្រជារាស្ត្រ ចោល ។ ព្យាការីបានមកពីក្រុងខឺតឡង់ ដើរខាងមុខក្រុមដែលស្គាល់ថាជា ជំរំស៊ីយ៉ូន ដោយយកសំលៀកបំពាក់និងស្បៀងអាហារ មកផង ។ កាលក្រុមនេះកំពុងតែបោះជំរំនៅទន្លេហ្វិស៊ីង នោះព្យាការីបានទទួលវិវរណៈនេះ ។*

*១–៥, ស៊ីយ៉ូននឹងត្រូវបានស្ថាបនាឡើង ដោយការអនុលោមទៅតាមក្រិត្យវិន័យខាងសេឡេស្ទាល; ៦–១៣, សេចក្ដីប្រោសលោះនៃ ស៊ីយ៉ូនត្រូវបានបង្អង់មួយរដូវខ្លីសិន; ១៤–១៩, ព្រះអម្ចាស់ទ្រង់នឹងច្បាំងចំបាំងទាំងឡាយនៃស៊ីយ៉ូន; ២០–២៦, ពួកបរិសុទ្ធត្រូវមានគំនិត ហើយមិនត្រូវអួតអាងក្នុងកិច្ចការដ៏ខ្លាំងក្លាទាំងឡាយ នៅពេលពួកគេប្រមូលគ្នាឡើយ; ២៧–៣០, ដែនដីទាំងឡាយនៅឃុំចាកសុន និងឃុំជិតខាងនោះត្រូវទិញយក; ៣១–៣៤, ពួកអែលឌើរត្រូវទទួលអំណោយទានពិសិដ្ឋ នៅក្នុងដំណាក់នៃព្រះអម្ចាស់ នៅក្រុង ខឺតឡង់; ៣៥–៣៧, ពួកបរិសុទ្ធណាដែលត្រូវបានហៅ ហើយរើស នោះនឹងបានញែកចេញជាបរិសុទ្ធ; ៣៨–៤១, ពួកបរិសុទ្ធត្រូវ លើកទង់ជ័យនៃសន្តិភាពដល់ពិភពលោក ។*

ប្រាកដមែន យើងប្រាប់ដល់អ្នក ដែលបានជួបជុំគ្នា ដើម្បីរៀនពីព្រះហឫទ័យរបស់យើង អំពីសេចក្ដីប្រោសលោះរាស្ត្ររបស់យើងដែល មានទុក្ខលំបាកថា —

២ មើលចុះ យើងប្រាប់ដល់អ្នកថា បើសិនជាពុំមែនដោយសារការរំលងទាំងឡាយ នៃរាស្ត្ររបស់យើងទេនោះ ដោយនិយាយអំពី សាសនាចក្រ ហើយពុំមែនអំពីមនុស្សម្នាក់ៗទេ នោះពួកគេអាចបានប្រោសលោះឲ្យរួចផុតទៅហើយនៅពេលឥឡូវនេះ ។

៣ ប៉ុន្តែមើលចុះ ពួកគេពុំបានរៀន ដើម្បីគោរពតាមអ្វីៗ ដែលយើងតម្រូវពីដៃរបស់ពួកគេទេ ប៉ុន្តែបានពោរពេញទៅដោយអំពើអាក្រក់ ហើយមិនរំលែកនូវទ្រព្យរបស់ខ្លួន តាមបែបដែលគួរឲ្យពួកបរិសុទ្ធធ្វើ ដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌ត នៅក្នុងចំណោមពួកគេ;

៤ ហើយមិនបានសាមគ្គីគ្នា តាមការរួបរួមគ្នា ដែលតម្រូវដោយក្រិត្យវិន័យនៃនគរសេឡេស្ទាលឡើយ;

៨១ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៨២ *ក* លូកា ១៤:១១;
គ. និង ស. ៦៧:១០.
*ខ* គ. និង ស. ១០៣:៣៦.

**១០៥** ១*ក* គ. និង ស. ១០០:១៣.
២ *ក* គ. និង ស. ១០៤:៤–៥, ៥២.
៣ *ក* កិច្ចការ ៥:១–១១;
គ. និង ស. ៤២:៣០.
ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ.
៤ *ក* គ. និង ស. ៧៨:៣–៧.

៥ ហើយ[ក]ស៊ីយ៉ូនមិនអាចបានស្ថាបនាឡើង [ខ]លើកលែងតែដោយសារគោលការណ៍ទាំងឡាយ នៃ[គ]ក្រឹត្យវិន័យនៃនគរសេឡេស្ទាល; បើពុំនោះសោតទេ យើងមិនអាចទទួលនាងមកឯយើងបានឡើយ ។

៦ ហើយរាស្ត្រយើងត្រូវតែ[ក]បានវាយផ្ចាល រហូតដល់ពួកគេចេះ[ខ]គោរពតាម បើសិនជាចាំបាច់ ដោយសារអ្វីៗដែលពួកគេរងទុក្ខ ។

៧ យើងពុំមានព្រះបន្ទូលអំពីអស់អ្នកដែលបានតាំងឡើងឲ្យដឹកនាំរាស្ត្រយើង ដែលជា[ក]ពួកអែលឌើរទីមួយនៃសាសនាចក្ររបស់យើង នោះទេ ត្បិតពួកគេពុំមែននៅក្រោមការដាក់ទោសនេះឡើយ;

៨ ប៉ុន្តែយើងមានព្រះបន្ទូលអំពីសាសនាចក្រទាំងឡាយរបស់យើងដែលនៅឆ្ងាយ — មានមនុស្សជាច្រើនដែលនិយាយថា៖ តើព្រះ របស់ពួកគេនៅឯណា ? មើលចុះ ព្រះអង្គនឹងរំដោះពួកគេឲ្យរួច នៅគ្រាមានទុក្ខខ្វល់ខ្វាយ បើពុំនោះសោតទេ យើងនឹងមិនឡើង ទៅស៊ីយ៉ូនឡើយ ហើយនឹងទុកប្រាក់របស់យើងវិញ ។

៩ ហេតុដូច្នេះហើយ មកពី[ក]ការរំលងច្បាប់ទាំងឡាយនៃរាស្ត្ររបស់យើង គឺជាការចាំបាច់ដល់យើង ដែលពួកអែលឌើររបស់យើងត្រូវ រង់ចាំមួយរដូវខ្លីសិន ចំពោះសេចក្ដីប្រោសលោះនៃស៊ីយ៉ូន —

១០ ដើម្បីឲ្យខ្លួនគេអាចបានរៀបចំជាស្រេច ហើយដើម្បីឲ្យរាស្ត្រយើងអាចបានបង្រៀនឲ្យបានល្អឥតខ្ចោះទៅទៀត ហើយមានការ ពិសោធន៍ ហើយចេះឲ្យបានល្អឥតខ្ចោះទៅទៀត អំពី[ក]កាតព្វកិច្ចរបស់ពួកគេ និងអ្វីៗដែលយើងតម្រូវពីដៃរបស់ពួកគេ ។

១១ ហើយការណ៍នេះពុំអាចបានកន្លងផុតទៅឡើយ រហូតដល់[ក]ពួកអែលឌើររបស់យើង បាន[ខ]ទទួលអំណាច ពីស្ថានខ្ពស់ ។

១២ ត្បិតមើលចុះ យើងបានរៀបចំអំណោយទានពិសិដ្ឋ និងព្រះពរដ៏មហិមាមួយទុក ដើម្បី[ក]ចាក់មកលើពួកគេ ដរាបណាពួកគេមាន ចិត្តស្មោះត្រង់ ហើយនៅក្នុងភាពរាបសានៅចំពោះយើងតទៅ ។

១៣ ហេតុដូច្នេះហើយ គឺជាការចាំបាច់ដល់យើងថា ពួកអែលឌើររបស់យើងត្រូវរង់ចាំមួយរដូវខ្លីសិន ចំពោះសេចក្ដីប្រោសលោះ នៃស៊ីយ៉ូន ។

១៤ ត្បិតមើលចុះ យើងពុំបានតម្រូវពីដៃរបស់ពួកគេ ឲ្យច្បាំងចំបាំងទាំងឡាយនៃស៊ីយ៉ូនឡើយ; ត្បិតដូចជាយើងបានប្រាប់ក្នុងព្រះបញ្ញត្តិពី មុនយ៉ាងណា នោះយើងក៏នឹងសំរេចយ៉ាងនោះដែរ — គឺយើងនឹង [ក]ច្បាំងចំបាំងទាំងឡាយរបស់អ្នក ។

១៥ មើលចុះ យើងបានចាត់[ក]មេបំផ្លាញឲ្យទៅបំផ្លាញ ហើយកំទេចចោលពួកខ្មាំងសត្រូវរបស់យើង; ហើយមិនជាច្រើនឆ្នាំក្រោយមក នោះពួកគេនឹងមិនត្រូវនៅសល់ ដើម្បីបង្អូចកេរ្តិ៍មរតករបស់យើង ហើយដើម្បី[ខ]ប្រមាថដល់ព្រះនាមរបស់យើងនៅលើដែនដីទាំងឡាយ ដែលយើងបាន[គ]តាំងសំរាប់ការប្រមូលនៃពួកបរិសុទ្ធរបស់យើងឡើយ ។

១៦ មើលចុះ យើងបានបញ្ជាដល់ យ៉ូសែប ស្ម៊ីធ ជុញ៉័រ ជាអ្នកបំរើរបស់យើង ឲ្យនិយាយទៅកាន់[ក]កម្លាំងនៃវង្សារបស់យើង គឺពលទ័ព របស់យើង ពួកកំឡោះរបស់យើង និងមនុស្សវ័យកណ្ដាល ដើម្បីឲ្យប្រមូលគ្នាសំរាប់សេចក្ដីប្រោសលោះរាស្ត្ររបស់យើង ហើយ រំលំប៉មទាំងឡាយនៃពួកខ្មាំងសត្រូវរបស់យើង ហើយបំបែក[ខ]ពួកអ្នកយាមរបស់គេចេញខ្ចាត់ខ្ចាយ;

១៧ ប៉ុន្តែកម្លាំងនៃវង្សារបស់យើងពុំបានស្ដាប់តាមព្រះបន្ទូលទាំងឡាយរបស់យើងឡើយ ។

១៨ ប៉ុន្តែដរាបណាមានពួកអ្នកដែលស្ដាប់តាមព្រះបន្ទូលទាំងឡាយរបស់យើង នោះយើងបានរៀបចំ[ក]ព្រះពរ និងអំណោយទានពិសិដ្ឋ ទុកសំរាប់ពួកគេ បើសិនជាពួកគេមានចិត្តស្មោះត្រង់តទៅ ។

---

៥ *ក* ស.ប. ស៊ីយ៉ូន.
*ខ* គ. និង ស. ១០៤:១៥–១៦.
*គ* គ. និង ស. ៨៨:២២.
៦ *ក* គ. និង ស. ៩៥:១–២. ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. ការគោរព, ដែលគោរព, គោរព.
៧ *ក* គ. និង ស. ២០:២–៣.
៩ *ក* គ. និង ស. ១០៣:៤.
១០ *ក* ស.ប. កាតព្វកិច្ច.
១១ *ក* ស.ប. អែលឌើរ.
*ខ* គ. និង ស. ៣៨:៣២; ៩៥:៨. ស.ប. អំណោយទានពិសិដ្ឋ.
១២ *ក* គ. និង ស. ១១០.
១៤ *ក* យ៉ូស្វេ ១០:១២–១៤; អេសាយ ៤៩:២៥; គ. និង ស. ៩៨:៣៧.
១៥ *ក* គ. និង ស. ១:១៣–១៤.
*ខ* គ. និង ស. ១១២:២៤–២៦. ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.
*គ* គ. និង ស. ៨៤:៣–៤; ១០៣:៣៥.
១៦ *ក* គ. និង ស. ១០១:៥៥; ១០៣:២២, ៣០.
*ខ* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
១៨ *ក* គ. និង ស. ១១០:៨–១០.

១៩ យើងបានឮបទអធិស្ឋានទាំងឡាយរបស់ពួកគេហើយ ហើយព្រមទទួលដង្វាយរបស់ពួកគេ; ហើយគឺជាការចាំបាច់ដល់យើង ដែលពួកគេត្រូវបាននាំមកដល់ទីនេះ សំរាប់ការសាកល្បងសេចក្ដីជំនឿនៃពួកគេ ។

២០ ហើយឥឡូវនេះ យើងប្រាប់អ្នកជាប្រាកដថា យើងប្រទានព្រះបញ្ញត្តិមួយដល់អ្នកថា ដរាបណាមានមនុស្សជាច្រើនឡើងមកទីនេះ ដែលអាចនៅក្នុងភូមិភាគជុំវិញបាន នោះចូរឲ្យពួកគេនៅចុះ;

២១ ហើយអស់អ្នកណាដែលពុំអាចនៅបានទេ ដែលមានគ្រួសារនៅទិសខាងកើត ចូរឲ្យពួកគេនៅមួយរដូវខ្លីសិនចុះ តាមដែល យ៉ូសែប ជាអ្នកបំរើរបស់យើង បានដឹកនាំពួកគេ;

២២ ត្បិតយើងនឹងទូន្មានដល់លោកអំពីរឿងនេះ និងគ្រប់អ្វីក៏ដោយ ដែលលោកបានតាំងដល់ពួកគេ នោះនឹងត្រូវបានសំរេច ។

២៣ ហើយចូរឲ្យរាស្ត្រយើងទាំងអស់ ដែលអាស្រ័យនៅក្នុងភូមិភាគជុំវិញ មានចិត្តស្មោះត្រង់ និងប្រកបដោយពាក្យអធិស្ឋាន និងរាបសាជាខ្លាំងនៅចំពោះយើង ហើយចូរកុំបើកសំដែងនូវអ្វីៗដែលយើងបានបើកសំដែងដល់ពួកគេឡើយ ទាល់តែមានប្រាជ្ញាក្នុង យើង ថាពួកគេត្រូវបើកសំដែង ។

២៤ ចូរកុំនិយាយពីការជំនុំជំរះ ឬអួតអាងពីសេចក្ដីជំនឿ ឬពីកិច្ចការដ៏ខ្លាំងក្លាឡើយ ប៉ុន្តែចូរប្រមូលគ្នាដោយប្រុងប្រយ័ត្ន ឲ្យបានច្រើន ដែលអាចធ្វើទៅបាននៅក្នុងភូមិភាគមួយ ស្របតាមអារម្មណ៍របស់ប្រជាជនចុះ;

២៥ ហើយមើលចុះ យើងនឹងប្រទានដល់អ្នក នូវការគាប់ចិត្ត និងបុណ្យគុណដល់ភ្នែករបស់ពួកគេ ប្រយោជន៍ឲ្យអ្នកអាចបានសំរាក ដោយសុខសាន្ត និងសន្តិសុខ ក្នុងកាលអ្នកនិយាយទៅកាន់ប្រជាជនថា៖ ចូរអនុវត្តសេចក្ដីជំនុំជំរះ និងសេចក្ដីយុត្តិធម៌ជំនួសយើង តាមក្រិត្យវិន័យ ហើយចូរតវ៉ាកែតំរូវកំហុសដែលបានធ្វើខុសនិងយើងផង ។

២៦ ឥឡូវនេះ មើលចុះ មិត្តទាំងឡាយរបស់យើងអើយ យើងប្រាប់អ្នកថា ដោយនូវផ្លូវនេះ ទើបអ្នកអាចបានការគាប់ចិត្តនៅក្នុងភ្នែក នៃប្រជាជន រហូតដល់កងទ័ពអ៊ីស្រាអែលបានត្រឡប់ជាធំមហិមា ។

២៧ ហើយយើងនឹងបន្ទន់ចិត្តនៃប្រជាជន ដូចដែលយើងបានបន្ទន់ចិត្តនៃផារ៉ោនម្ដងម្កាលៗដែរ រហូតដល់ យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជា អ្នកបំរើរបស់យើង និងពួកអែលឌើររបស់យើង ដែលយើងបានតាំងឡើង គេនឹងមានពេល ដើម្បីប្រមូលកម្លាំងនៃវង្សារបស់យើង ។

២៨ ហើយដើម្បីចាត់ពួកអ្នកប្រាជ្ញ ឲ្យទៅបំពេញនូវអ្វីដែលយើងបានបញ្ជា អំពីការទិញអស់ទាំងដែនដីនៅឃុំចាកសុនណា ដែលអាច ទិញបាន ហើយនិងនៅឃុំជុំវិញផង ។

២៩ ត្បិតគឺជាព្រះហឫទ័យរបស់យើង ដែលដែនដីទាំងនេះត្រូវតែបានទិញ; ហើយបន្ទាប់ពីបានទិញដែនដីទាំងនេះហើយនោះពួកបរិសុទ្ធរបស់យើងត្រូវយកដែនដីទាំងនេះ តាមក្រិត្យវិន័យនៃការថ្វាយ ដែលយើងបានប្រទានឲ្យ ។

៣០ ហើយបន្ទាប់ពីដែនដីទាំងនេះត្រូវបានទិញហើយ នោះយើងនឹងចាត់ពលទ័ពអ៊ីស្រាអែលថាឥតទោស ក្នុងការយកដែនដីរបស់ ខ្លួនផ្ទាល់ ដែលពួកគេបានទិញនិងប្រាក់របស់ពួកគេរួចមកហើយនោះ និងអំពីការរំលំប៉មទាំងឡាយនៃពួកខ្មាំងសត្រូវរបស់យើងចុះ ដើម្បីឲ្យបានមកលើពួកគេ និងការបំបែកពួកអ្នកយាមរបស់ពួកគេឲ្យខ្ចាត់ខ្ចាយ ហើយនិងការសងសឹកដល់ពួកខ្មាំងសត្រូវរបស់យើង ជំនួសយើង រហូតដល់តំណទីបី និងទីបួននៃពួកអ្នកដែលស្អប់យើង ។

៣១ ប៉ុន្តែទីមួយ ចូរឲ្យទ័ពរបស់យើងបានត្រឡប់ជាធំមហិមា ហើយចូរឲ្យទ័ពនោះបានញែកចេញជាបរិសុទ្ធនៅចំពោះយើងចុះ ប្រយោជន៍ឲ្យគេបានត្រឡប់ជាស្រស់ដូចជាព្រះអាទិត្យ ហើយភ្លឺត្រចះដូចជាព្រះច័ន្ទ ហើយប្រយោជន៍ឲ្យទង់ជ័យនាងអាចបានស្ញែងខ្លាច ដល់អស់ទាំងសាសន៍;

៣២ ដើម្បីឲ្យនគរទាំងឡាយនៃពិភពលោកនេះ អាចបានបង្ខំឲ្យទទួលស្គាល់ថា នគរស៊ីយ៉ូន គឺពិតជានគរនៃព្រះរបស់យើង និងព្រះគ្រីស្ទ របស់ទ្រង់; ហេតុដូច្នេះហើយ ចូរយើងបាននៅក្រោមក្រិត្យវិន័យទាំងឡាយរបស់នាងចុះ ។

១៩ *ក* ស.ប. សេចក្ដីជំនឿ.
២៤ *ក* គ. និង ស. ៨៤:៧៣.
ស.ប. សេចក្ដីឆ្មើងឆ្មៃ.
២៥ *ក* ស.ប. សេចក្ដីសុខសាន្ត.
២៦ *ក* យ៉ូអែល ២:១១.
២៧ *ក* លោកុ. ៤៧:១–១២.
២៨ *ក* គ. និង ស. ១០១:៧៣.
*ខ* គ. និង ស. ៤២:៣៥–៣៦.
២៩ *ក* គ. និង ស. ៤២:៣០.
ស.ប. ថ្វាយ,
ក្រិត្យវិន័យនៃការថ្វាយ;
សហសមាគម.
៣០ *ក* គ. និង ស. ៣៥:១៣–១៤;
១០១:៥៥; ១០៣:២២, ២៦.
*ខ* គ. និង ស. ៩៧:២២.
៣១ *ក* ស.ប. ការញែកជាបរិសុទ្ធ.
*ខ* បទចំរៀង. ៦:១០;
គ. និង ស. ៥:១៤; ១០៩:៧៣.
៣២ *ក* វិវ. ១១:១៥.
ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*ខ* ស.ប. រដ្ឋាភិបាល.

៣៣ យើងប្រាប់អ្នកជាប្រាកដថា គឺជាការចាំបាច់ដល់យើង ដែលពួកអែលឌើរមុនដំបូងនៃសាសនាចក្ររបស់យើង ត្រូវទទួល [ក]អំណោយ ទានពិសិដ្ឋពីស្ថានខ្ពស់ នៅក្នុងដំណាក់របស់យើង ដែលយើងបានបញ្ជាឲ្យស្ថាបនាដល់ព្រះនាមរបស់យើង នៅក្នុងដែនដីខឺតឡង់ ។

៣៤ ហើយចូរឲ្យព្រះបញ្ញត្តិទាំងឡាយ ដែលយើងបានប្រទានដល់ស៊ីយ៉ូន និង[ក]ក្រិត្យវិន័យរបស់នាង បានអនុវត្ត និងបំពេញបន្ទាប់ពីការ ប្រោសលោះរបស់នាងចុះ ។

៣៥ ធ្លាប់មានថ្ងៃមួយសំរាប់[ក]ការហៅ ប៉ុន្តែពេលនោះបានមកដល់ហើយសំរាប់ការរើស; ហើយចូរឲ្យអស់អ្នកណាដែល[ខ]សក្ដិសម ត្រូវបានរើសចុះ ។

៣៦ ហើយនឹងបានសំដែងដល់អ្នកបំរើរបស់យើង ដោយសម្លេងនៃព្រះវិញ្ញាណរបស់យើង ប្រាប់ពីពួកអ្នកដែល[ក]ត្រូវបានរើស; ហើយពួក គេនឹងត្រូវបាន[ខ]ញែកចេញជាបរិសុទ្ធ;

៣៧ ហើយដរាបណាពួកគេដើរតាម[ក]ដំបូន្មានដែលពួកគេបានទទួល នោះជាច្រើនថ្ងៃក្រោយមក ពួកគេនឹងបានអំណាចដើម្បីសំរេច គ្រប់ការណ៍ទាំងអស់ ដែលទាក់ទងទៅនិងស៊ីយ៉ូន ។

៣៨ ហើយជាថ្មីម្ដងទៀត យើងប្រាប់អ្នកថា ចូរតវ៉ាសូមសេចក្ដីសុខសាន្ត មិនគ្រាន់តែចំពោះប្រជាជនដែលវាយអ្នកប៉ុណ្ណោះទេ តែដល់ គ្រប់មនុស្សទាំងអស់ផង;

៣៩ ហើយចូរលើក[ក]ទង់ជ័យនៃ[ខ]សន្តិភាព ហើយធ្វើការប្រកាសប្រាប់ពីសេចក្ដីសុខសាន្ត ដល់ទីបំផុតនៃផែនដី;

៤០ ហើយធ្វើសំណូមពរសូមសេចក្ដីសុខសាន្ត ចំពោះពួកអ្នកដែលវាយអ្នក ស្របតាមសម្លេងនៃព្រះវិញ្ញាណ ដែលនៅក្នុងអ្នក ហើយគ្រប់[ក]ការណ៍ទាំងអស់នឹងផ្សំគ្នា សំរាប់សេចក្ដីល្អដល់អ្នក ។

៤១ ហេតុដូច្នេះហើយ ចូរមានចិត្តស្មោះត្រង់ចុះ; ហើយមើលចុះ និងមើលន៏ យើង[ក]គង់នៅជាមួយអ្នក រហូតដល់ចុងបំផុត ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១០៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៨៣៤ (*History of the Church, *២:១៧០–១៧១)* ។ *វិវរណៈនេះត្រូវបានតម្រង់ទៅរក វ៉ារិន អេ ខៅឌើរី ជាបងប្រុសរបស់ អូលីវើរ ខៅឌើរី ។*

*១–៣, វ៉ារិន អេ ខៅឌើរី ត្រូវបានហៅឲ្យធ្វើជាមេដឹកនាំត្រួតត្រានៅកន្លែងរបស់គាត់; ៤–៥, ការយាងមកលើកទីពីរនឹងមិនមកដល់ កូនចៅនៃពន្លឺដូចជាចោរឡើយ; ៦–៨, ព្រះពរដ៏មហិមាទាំងឡាយ មកតាមក្រោយការបំរើដ៏ស្មោះត្រង់ នៅក្នុងសាសនាចក្រ ។*

ក៏ជាព្រះហឫទ័យរបស់យើង ដែល វ៉ារិន អេ ខៅឌើរី ជាអ្នកបំរើរបស់យើង ត្រូវបានតាំងហើយតែងតាំង ឲ្យធ្វើជាសង្ឃជាន់ខ្ពស់ ត្រួតត្រាលើសាសនាចក្ររបស់យើង នៅក្នុងដែនដី[ក]ប្រ៊ីដុម និងនៅភូមិភាគទាំងឡាយជុំវិញ;

២ ហើយត្រូវផ្សាយដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ចរបស់យើង ហើយបន្លឺសម្លេងរបស់គាត់ឡើង ហើយព្រមានប្រជាជន មិនគ្រាន់ តែនៅកន្លែងគាត់ផ្ទាល់តែប៉ុណ្ណោះទេ តែនៅឃុំទាំងឡាយជុំវិញផង;

៣ ហើយត្រូវថ្វាយពេលទាំងមូលចំពោះការងារដ៏ខ្ពង់ខ្ពស់ និងបរិសុទ្ធនេះ ដែលយើងប្រទានដល់គាត់នៅពេលឥឡូវនេះ

៣៣ *ក* គ. និង ស. ៩៥:៨–៩.
ស.ប. អំណោយទានពិសិដ្ឋ.
៣៤ *ក* ក.ន. គ. និង ស. ៤២ ត្រូវបានស្គាល់ថា «ក្រិត្យវិន័យ».
៣៥ *ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
*ខ* ស.ប. សក្ដិសម, ភាពសក្ដិសម.
៣៦ *ក* គ. និង ស. ៩៥:៥.
ស.ប. រើស, បានរើស, ដែលបានរើស (កិ.).
*ខ* ស.ប. ការញែកជាបរិសុទ្ធ.
៣៧ *ក* ស.ប. ពាក្យទូន្មាន (ន.).
៣៩ *ក* ស.ប. ទង់.
*ខ* ស.ប. សេចក្ដីសុខសាន្ត.
៤០ *ក* រ៉ូម ៨:២៨; គ. និង ស. ៩០:២៤; ១០០:១៥.
៤១ *ក* ម៉ាថាយ ២៨:១៩–២០.
**១០៦** ១*ក* ក.ន. ទីក្រុងប្រ៊ីដុំ រដ្ឋនូវយ៉ោក និងនៅក្រវល់ជុំវិញ.

ដោយការ ព្យាយាម[ក]ស្វែងរក[ខ]នគរស្ថានសួគ៌ និងសេចក្ដីសុចរិតទាំងឡាយនៃនគរនោះ ហើយគ្រប់របស់ដែលចាំបាច់ទាំងអស់ នឹងបានប្រទានមក លើថែមទៀត; ក្បិត[គ]អ្នកដែលធ្វើការ នោះសមនិងឈ្នួលរបស់ខ្លួនហើយ ។

៤ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា [ក]ការយាងមកនៃព្រះអម្ចាស់[ខ]ជិតដល់ហើយ ហើយនឹងមកដល់ពិភពលោក[គ]ដូចជាចោរ មកនៅពេលយប់ —

៥ ហេតុដូច្នេះហើយ ចូរក្រវាត់ចង្កេះ ប្រយោជន៍ឲ្យអ្នកអាចបានទៅជាកូនចៅនៃ[ក]ពន្លឺ ហើយដើម្បីកុំឲ្យ[ខ]ថ្ងៃនោះមកដល់អ្នកដូចជាចោរ ឡើយ ។

៦ ហើយជាថ្មីម្ដងទៀត យើងប្រាប់អ្នកជាប្រាកដថា មានសេចក្ដីអំណរនៅលើស្ថានសួគ៌ កាល វ៉ារិន ជាអ្នកបំរើរបស់យើង ក្រាបចំពោះ ដំបងពេជ្ររបស់យើង ហើយបំបែកខ្លួនចេញពីកលល្បិចនៃមនុស្ស;

៧ ហេតុដូច្នេះហើយ វ៉ារិន ជាអ្នកបំរើរបស់យើង មានពរហើយ ព្រោះយើងនឹងមានសេចក្ដីមេត្តាករុណាដល់គាត់; ហើយទោះជាភាព[ក]អសារឥតការនៃចិត្តគាត់ក៏ដោយ គង់តែយើងនឹងលើកគាត់ឡើងដែរ ដរាបណាគាត់បន្ទាបខ្លួននៅចំពោះយើង ។

៨ ហើយយើងនឹងប្រទាន[ក]ព្រះគុណ និងការបញ្ជាក់ដល់គាត់ ដើម្បីឲ្យគាត់អាចឈរមាំមួនបាន; ហើយបើសិនជាគាត់ធ្វើជាសាក្សីដ៏ ស្មោះត្រង់ និងពន្លឺដល់សាសនាចក្រតទៅ នោះយើងបានរៀបចំមកុដមួយទុកសំរាប់គាត់ នៅក្នុង[ខ]វិមានទាំងឡាយនៃព្រះវរបិតា របស់យើង ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១០៧

*វិវរណៈអំពីបព្វជិតភាព ដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៨៣៥ (*History of the Church, *២:២០៩–២១៧)* ។ *នៅថ្ងៃដែលបានពោលដល់នេះ ពួក១២នាក់បានជួបជុំគ្នាក្នុងក្រុមប្រឹក្សាមួយ ហើយបានសារភាពអំពីការកំសោយនិងការខ្វះខាតរៀងៗខ្លួន ដោយថ្លែងសូមការអភ័យទោស ហើយដោយស្វែងរកការណែនាំពីព្រះអម្ចាស់តទៅទៀត ។ ពួកគេកំពុងតែនឹងបែកគ្នាទៅបំរើបេសកកម្មតាមស្រុករៀងៗខ្លួន ។ ទោះជាចំណែក ទាំងឡាយនៃកណ្ឌនេះ ត្រូវបានទទួលនៅថ្ងៃដែលបានពោលដល់នេះក៏ដោយ គង់តែបញ្ជីប្រវត្តិទាំងឡាយបញ្ជាក់ថា ផ្នែកនានានោះត្រូវបានទទួលនៅពេលផ្សេងៗពីគ្នា ខ្លះនៅខែវិច្ឆិកា ឆ្នាំ១៨៣១ម្ល៉េះ ។*

*១–៦, មានបព្វជិតភាពពីរយ៉ាងគឺ៖ មិលគីស្សាដែក និងអើរ៉ុន; ៧–១២, អស់អ្នកដែលកាន់បព្វជិតភាពមិលគីស្សាដែក មានអំណាចនឹង ធ្វើការក្នុងតំណែងទាំងឡាយ នៅក្នុងសាសនាចក្របាន; ១៣–១៧, គណៈប៊ីស្សពត្រួតត្រាលើបព្វជិតភាពអើរ៉ុន ដែលបំរើចាត់ចែងខាង ការប្រព្រឹត្តខាងក្រៅទាំងឡាយ; ១៨–២០, បព្វជិតភាពមិលគីស្សាដែកកាន់កូនសោទាំងឡាយខាងអស់ទាំងព្រះពរនៃវិញ្ញាណ; បព្វជិតភាពអើរ៉ុនកាន់កូនសោខាងការងារបំរើនៃពួកទេវតា; ២១–៣៨, គណៈប្រធានទីមួយ ពួក១២នាក់ និងពួក៧០នាក់ រួមគ្នាធ្វើ ជាក្រុមទាំងឡាយ ដែលសំរេចចិត្ត នៅក្នុងសេចក្ដីសាមគ្គី និងសេចក្ដីសុចរិត; ៣៩–៥២, របៀបនៃអយ្យកោត្រូវបានតាំងឡើង មកពីលោកអ័ដាមដល់លោកណូអេ; ៥៣–៥៧, ពួកបរិសុទ្ធពីបុរាណបានជួបជុំគ្នានៅអ័ដាម-អុនដៃ-អាម៉ាន ហើយព្រះអម្ចាស់ទ្រង់ បានលេចមកឯពួកគេ; ៥៨–៦៧, ពួក១២នាក់ត្រូវចាត់ចែង អ្នកដឹកនាំនៃសាសនាចក្រឲ្យមានរបៀបរៀបរយ; ៦៨–៧៦, ពួកប៊ីស្សពបំរើជាចៅក្រម ទូទៅនៅក្នុងអ៊ីស្រាអែល; ៧៧–៨៤, គណៈប្រធានទីមួយ និងពួក១២នាក់ រួមគ្នាជាតុលាការដ៏ខ្ពស់បំផុត នៅក្នុងសាសនាចក្រ; ៨៥–១០០, ពួកប្រធាននៃបព្វជិតភាពត្រួតត្រាលើក្រុមរបស់ខ្លួន រៀងៗខ្លួន ។*

៣ *ក* ម៉ាថាយ ៦:៣៣.
*ខ* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
*គ* ម៉ាថាយ ១០:១០;
គ. និង ស. ៣១:៥.
៤ *ក* យ៉ាកុប (ព.ស.ថ.) ៥:៨.
*ខ* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
*គ* ១ ថែស្សា. ៥:២.
៥ *ក* ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* វិវរ. ១៦:១៥.
៧ *ក* ស.ប. ឥតប្រយោជន៍, ការឥតប្រយោជន៍.
៨ *ក* ស.ប. ព្រះគុណ.
*ខ* យ៉ូហាន ១៤:២;
អេធើរ ១២:៣២–៣៤;
គ. និង ស. ៥៩:២; ៧៦:១១១;
៨១:៦; ៩៨:១៨.

នៅក្នុងសាសនាចក្រ មានបព្វជិតភាពពីរយ៉ាង ដែលមានឈ្មោះថា បព្វជិតភាពមិលគីស្សាដែក និងអើរ៉ុន ព្រមទាំងបព្វជិតភាពលេវី ។

២ ហេតុអ្វីបានជាទីមួយត្រូវបានហៅថាបព្វជិតភាពមិលគីស្សាដែក គឺពីព្រោះលោកមិលគីស្សាដែក ជាសង្ឃជាន់ខ្ពស់ដ៏ធំបែបនេះម្នាក់ ។

៣ មុនសម័យលោក បព្វជិតភាពនោះត្រូវបានហៅថា *បព្វជិតភាពដ៏បរិសុទ្ធតាមរបៀបនៃព្រះរាជបុត្រានៃព្រះ ។*

៤ ប៉ុន្តែមកពីការគោរពកោតក្រែង ឬភក្តីភាពដល់ព្រះនាមនៃព្រះដ៏ខ្ពស់បំផុត គឺដើម្បីកុំឲ្យប្រើព្រះនាមរបស់ព្រះអង្គជាញឹកញាប់ពេក ទើបសាសនាចក្រពីសម័យបុរាណ បានហៅបព្វជិតភាពតាមលោកមិលគីស្សាដែក ឬបព្វជិតភាពមិលគីស្សាដែក ។

៥ គ្រប់ទាំងសិទ្ធិអំណាច ឬតំណែងផ្សេងៗទៀត នៅក្នុងសាសនាចក្រ សុទ្ធតែជាការបន្ថោងបញ្ជាប់ទៅនិងបព្វជិតភាពនេះ ។

៦ ប៉ុន្តែមានចំណែក ឬមេចំណែកពីរយ៉ាងគឺ — ទីមួយជាបព្វជិតភាពមិលគីស្សាដែក ហើយមួយទៀតជាបព្វជិតភាពអើរ៉ុន ឬលេវី ។

៧ តំណែងនៃអែលឌើរនៅក្រោមបព្វជិតភាពមិលគីស្សាដែក ។

៨ បព្វជិតភាពមិលគីស្សាដែក មានសិទ្ធិខាងគណៈប្រធាន ហើយមានអំណាច និងសិទ្ធិអំណាចលើអស់ទាំងតំណែងនៅក្នុងសាសនាចក្រ នៅគ្រប់សម័យនានាក្នុងពិភពលោក ដើម្បីចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ ។

៩ គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ តាមរបៀបលោកមិលគីស្សាដែក មានសិទ្ធិដើម្បីធ្វើការក្នុងគ្រប់តំណែងទាំងអស់នៅក្នុង សាសនាចក្រ ។

១០ ពួកសង្ឃជាន់ខ្ពស់ តាមរបៀបបព្វជិតភាពមិលគីស្សាដែក មានសិទ្ធិដើម្បីធ្វើការនៅក្នុងតំណែងរបស់ខ្លួន គឺនៅក្រោមការដឹកនាំនៃ គណៈប្រធាន ក្នុងការចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ ហើយព្រមទាំងនៅក្នុងតំណែងនៃអែលឌើរ សង្ឃ (តាមរបៀបលេវី) គ្រូ ឌីកុន និងសមាជិក ។

១១ អែលឌើរមានសិទ្ធិដើម្បីធ្វើការជំនួសសង្ឃជាន់ខ្ពស់ កាលណាសង្ឃជាន់ខ្ពស់មិននៅ ។

១២ សង្ឃជាន់ខ្ពស់ និងអែលឌើរត្រូវចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ យល់ព្រមតាមសេចក្ដីសញ្ញា និងព្រះបញ្ញត្តិទាំងឡាយនៃ សាសនាចក្រ; ហើយពួកគេមានសិទ្ធិដើម្បីធ្វើការនៅក្នុងតំណែងទាំងនេះនៃសាសនាចក្រ កាលណាគ្មានអ្នកកាន់សិទ្ធិអំណាចខ្ពស់ ជាងនៅទីនោះ ។

១៣ បព្វជិតភាពទីពីរត្រូវបានហៅថា បព្វជិតភាពអើរ៉ុន ពីព្រោះបព្វជិតភាពនេះត្រូវបានប្រទានមកលើលោកអើរ៉ុន និងពូជពង្សលោក គឺរហូតអស់ទាំងតំណពួកគេ ។

១៤ ហេតុអ្វីបានជាបព្វជិតភាពអើរ៉ុនត្រូវបានហៅថាបព្វជិតភាពតូចជាង គឺពីព្រោះបព្វជិតភាពនេះជាការបន្ថោងបញ្ជាប់ទៅនឹង របស់ធំជាង ឬបព្វជិតភាពមិលគីស្សាដែក ហើយមានអំណាច ក្នុងការចាត់ចែងពិធីការទាំងឡាយខាងក្រៅ ។

១៥ គណៈប៊ីស្សពគឺជាគណៈប្រធាននៃបព្វជិតភាពនេះ ហើយកាន់កូនសោទាំងឡាយ ឬសិទ្ធិអំណាចនៃរបស់ដដែល ។

១៦ គ្មាននរណាមានសិទ្ធិចំពោះតំណែងនេះ ដើម្បីកាន់កូនសោទាំងឡាយនៃបព្វជិតភាពនេះឡើយ លើកលែងតែអ្នកនោះចំជាពូជ ពង្សលោកអើរ៉ុនពិត ។

១៧ ប៉ុន្តែសង្ឃជាន់ខ្ពស់ក្នុងបព្វជិតភាពមិលគីស្សាដែក មានសិទ្ធិអំណាចដើម្បីធ្វើការនៅក្នុងអស់ទាំងតំណែងតូចជាង គឺគាត់អាច ធ្វើការនៅក្នុងតំណែងប៊ីស្សព កាលណាពុំអាចរកពូជពង្សលោកអើរ៉ុនពិតបាន សូមឲ្យតែគាត់បានហៅ ហើយញែកចេញ ហើយតែង តាំងចំពោះអំណាចនេះ ដោយដៃរបស់គណៈប្រធាននៃបព្វជិតភាពមិលគីស្សាដែក ។

១៨ អំណាច និងសិទ្ធិអំណាចនៃរបស់ខ្ពស់ជាង ឬបព្វជិតភាព

១០៧ ១*ក* ស.ប. បព្វជិតភាពមិលគីស្សាដែក.
*ខ* ស.ប. បព្វជិតភាពអើរ៉ុន.
២ *ក* ក.យ.ស., លោកុ. ១៤:២៥–៤០;
គ. និង ស. ៨៤:១៤.
ស.ប. មិលគីស្សាដែក.
៣ *ក* អាលម៉ា ១៣:៣–១៩;
គ. និង ស. ៧៦:៥៧.
៤ *ក* ស.ប. ការគោរពកោតក្រែង.
៥ *ក* គ. និង ស. ៨៤:២៩; ១០៧:១៤.
៦ *ក* ចោទិ. ១០:៨–៩.
៧ *ក* ស.ប. អែលឌើរ.
៨ *ក* ស.ប. សិទ្ធិអំណាច.
៩ *ក* គ. និង ស. ៨១:២; ១០៧:២២,
៦៥–៦៧, ៩១–៩២.
១០ *ក* ស.ប. សង្ឃជាន់ខ្ពស់.
*ខ* គ. និង ស. ១២១:៣៤–៣៧.
១៣ *ក* ស.ប. បព្វជិតភាពអើរ៉ុន.
*ខ* ស.ប. អើរ៉ុន, បងប្រុសរបស់ម៉ូសេ.
១៤ *ក* គ. និង ស. ២០:៥២; ១០៧:៥.
១៥ *ក* ស.ប. ប៊ីស្សព.
១៦ *ក* គ. និង ស. ៦៨:១៤–២១;
១០៧:៦៨–៧៦.
១៧ *ក* ស.ប. តែងតាំង, ការតែងតាំង.
*ខ* គ. និង ស. ៦៨:១៥.

មិលគីស្សាដែក គឺត្រូវកាន់កូនសោទាំងឡាយនៃអស់ទាំងព្រះពរខាងវិញ្ញាណ នៅក្នុងសាសនាចក្រ —

១៩ ដើម្បីមានឯកសិទ្ធិក្នុងការទទួលសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរស្ថានសួគ៌ ដើម្បីឲ្យស្ថានសួគ៌បានបើកចំហចំពោះពួកគេ ដើម្បីទាក់ទងជាមួយនឹងជំនុំទូទៅ និងសាសនាចក្រនៃកូនច្បង ហើយដើម្បីត្រេកអរចំពោះសេចក្ដីប្រួបរួមគ្នា និងវត្តមាននៃព្រះដ៏ជា ព្រះវរបិតា និងព្រះយេស៊ូវ ដ៏ជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មី ។

២០ អំណាច និងសិទ្ធិអំណាចនៃរបស់តូចជាង ឬបព្វជិតភាពអើរ៉ុន គឺត្រូវកាន់កូនសោទាំងឡាយនៃការងារបំរើរបស់ពួកទេវតា ហើយដើម្បីចាត់ចែងការប្រព្រឹត្តិខាងក្រៅទាំងឡាយ នៃយពាក្យខាងដំណឹងល្អ បុណ្យជ្រមុជទឹកខាងការប្រែចិត្ត សំរាប់ការផ្ដាច់បាប ទាំងឡាយ យល់ព្រមតាមសេចក្ដីសញ្ញា និងព្រះបញ្ញត្តិទាំងឡាយ ។

២១ មកពីការចាំបាច់ទើបមានពួកប្រធាន ឬពួកអ្នកកាន់តំណែងត្រួតត្រា ដែលកើតមានឡើង ឬបានតាំងឡើង ឬមកពីចំណោមពួកអ្នក ដែលបានតែងតាំងចំពោះតំណែងនានា នៅក្នុងបព្វជិតភាពទាំងពីរនេះ ។

២២ មកពីបព្វជិតភាពមិលគីស្សាដែក គឺមានពួកសង្ឃជាន់ខ្ពស់ត្រួតត្រាបីនាក់ ដែលបានរើសឡើងដោយក្រុម គឺបានតាំងហើយតែង តាំងឡើងចំពោះតំណែងនោះ ហើយគាំទ្រដោយសេចក្ដីទុកចិត្ត សេចក្ដីជំនឿ និងសេចក្ដីអធិស្ឋាននៃសាសនាចក្រ ឲ្យធ្វើជាក្រុមក្នុង គណៈ ប្រធាននៃសាសនាចក្រ ។

២៣ ពួកអ្នកប្រឹក្សា១២នាក់ដែលធ្វើដំណើរ ត្រូវបានហៅឲ្យធ្វើជាពួកសាវក១២នាក់ ឬជាពួកសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទ នៅពេញសព្វក្នុងពិភពលោក — ម្ល៉ោះហើយ ខុសពីពួកអ្នកកាន់តំណែងផ្សេងៗទៀតនៅក្នុងសាសនាចក្រ ក្នុងភារកិច្ចនៃការងារ របស់ពួកគេ ។

២៤ ហើយពួកគេរួមគ្នាធ្វើជាក្រុម ដោយមានសិទ្ធិអំណាចនិងអំណាចស្មើគ្នានឹងប្រធានបីនាក់ ដែលបានពោលដល់មកហើយនោះ ។

២៥ ពួក៧០នាក់ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ហើយឲ្យធ្វើជាពួកសាក្សីពិសេស ដល់ពួកសាសន៍ដទៃ និងនៅពេញសព្វក្នុងពិភព លោក — ម្ល៉ោះហើយ ខុសពីពួកអ្នកកាន់តំណែងផ្សេងៗទៀតនៅក្នុងសាសនាចក្រ ក្នុងភារកិច្ចនៃការងាររបស់ពួកគេ ។

២៦ ហើយពួកគេរួមគ្នាធ្វើជាក្រុម ដោយមានសិទ្ធិអំណាចស្មើគ្នានិងពួកសាក្សី១២នាក់ ឬពួកសាវកពិសេសដែលបានពោលប្រាប់មក ហើយនោះ ។

២៧ ហើយការសំរេចចិត្តណាមួយដែលបានធ្វើឡើងដោយក្រុមទាំងនេះ ត្រូវតែបានធ្វើឡើង ដោយសម្លេងនៃក្រុមទាំងនោះជាឯកច្ឆន្ទ; គឺថា សមាជិកគ្រប់រូបនៅក្នុងក្រុមនីមួយៗ ត្រូវយល់ព្រមនិងការសំរេចចិត្តទាំងឡាយនៃក្រុមរបស់ខ្លួន ដើម្បីធ្វើការសំរេចចិត្តទាំងឡាយ របស់ពួកគេ ដោយមានអំណាច ឬសុពលភាពនិងគ្នាទៅវិញទៅមក —

២៨ សមាជិកភាគច្រើនអាចរួមគ្នាធ្វើជាក្រុម ជួនណាកាលៈទេសៈពុំអាចធ្វើឲ្យសមាជិកជួបជុំទាំងអស់គ្នាបាន —

២៩ លើកលែងតែករណីនេះ បើពុំនោះសោតទេ ការសំរេចចិត្តរបស់ពួកគេពុំអាចបានព្រះពរទាំងឡាយ ដូចជាការសំរេចចិត្តទាំង ឡាយនៃក្រុមរបស់ប្រធានទាំងបីពីបុរាណ ដែលបានតែងតាំងតាមរបៀបលោកមិលគីស្សាដែក ហើយដែលជាពួកបុរសសុចរិត និងបរិសុទ្ធនោះឡើយ ។

៣០ ការសំរេចចិត្តទាំងឡាយនៃក្រុមទាំងនេះ ឬពីក្រុមណាមួយ នោះត្រូវបានធ្វើឡើង ដោយសេចក្ដីសុចរិត ដោយបរិសុទ្ធភាព និងចិត្តសុភាពរាបសារ ស្លូតបូត និងសេចក្ដីអត់ធ្មត់ និងដោយសេចក្ដីជំនឿ និងគុណធម៌ និងដំរិះ សេចក្ដីអត់សង្កត់ សេចក្ដីអត់ធន់ សេចក្ដីកោតខ្លាចដល់ព្រះ សេចក្ដីរាប់អានគ្នា និងសេចក្ដីសប្បុរស;

១៨ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
១៩ *ក* អាលម៉ា ១២:៩–១១; គ. និង ស. ៦៣:២៣; ៨៤:១៩–២២. ស.ប. សេចក្ដីអាថ៌កំបាំងទាំងឡាយនៃព្រះ.
*ខ* ហេព្រើរ ១២:២២–២៤.
*គ* ស.ប. អ្នកសង្គ្រោះ.
២០ *ក* គ. និង ស. ១៣:១; ៨៤:២៦–២៧.
*ខ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*គ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ឃ* ស.ប. ការផ្ដាច់បាប.
២២ *ក* ស.ប. បព្វជិតភាពមិលគីស្សាដែក.
*ខ* គ. និង ស. ៩០:៣, ៦; ១០៧:៩, ៦៥–៦៧, ៧៨–៨៤, ៩១–៩២.
*គ* ស.ប. ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ.
២៣ *ក* គ. និង ស. ១០៧:៣៣–៣៥.
*ខ* ស.ប. សាវក.
២៥ *ក* ស.ប. ពួក៧០នាក់.
៣០ *ក* គ. និង ស. ១២១:៣៦. ស.ប. សុចរិត, សេចក្ដីសុចរិត.
*ខ* គ. និង ស. ១២១:៤១. ស.ប. គុណធម៌.

៣១ ពីព្រោះសេចក្ដីសន្យាថា បើសិនជាសេចក្ដីទាំងឡាយនេះចំរើនឡើង ក្នុងចិត្តពួកគេហើយ នោះពួកគេនឹងមិនដែលនៅ[ក]ឥតផល ខាងដំណើរស្គាល់ព្រះអម្ចាស់ឡើយ ។

៣២ ហើយនៅករណីណាដែលការសំរេចចិត្តរបស់ក្រុមទាំងនេះត្រូវបានធ្វើឡើង ដោយសេចក្ដីមិនសុចរិត ការសំរេចចិត្តនោះ នឹងត្រូវ នាំមកចំពោះជំនុំទូទៅ នៃក្រុមនានា ដែលធ្វើឡើងជាអ្នកមានសិទ្ធិអំណាចក្នុងសាសនាចក្រលើការណ៍ទាំងឡាយខាងវិញ្ញាណ; បើពុំ នោះសោតទេ នឹងគ្មាននរណាអាចប្ដឹងឧទ្ធរណ៍ពីការសំរេចចិត្តរបស់ពួកគេបានឡើយ ។

៣៣ ពួក១២នាក់គឺជាក្រុមប្រឹក្សាត្រួតត្រាជាន់ខ្ពស់ដែលធ្វើដំណើរ ដើម្បីធ្វើការដោយនូវព្រះនាមនៃព្រះអម្ចាស់ នៅក្រោមការដឹកនាំ របស់គណៈប្រធាននៃសាសនាចក្រ យល់ព្រមតាមការតែងតាំងនៃស្ថានសួគ៌; ដើម្បីសាងសាសនាចក្រឡើង ហើយកាន់កាប់គ្រប់ទាំង កិច្ចការនៃសាសនាចក្រ នៅគ្រប់សាសន៍ មុនដំបូង [ក]ដល់ពួកសាសន៍ដទៃ ហើយទីពីរ ដល់ពួកសាសន៍យូដា ។

៣៤ ពួក៧០នាក់ត្រូវប្រព្រឹត្តដោយនូវព្រះនាមនៃព្រះអម្ចាស់ នៅក្រោមការដឹកនាំរបស់[ក]ពួក១២នាក់ ឬក្រុមប្រឹក្សាជាន់ខ្ពស់ដែលធ្វើ ដំណើរ ក្នុងការសាងសាសនាចក្រឡើង និងការកាន់កាប់គ្រប់ទាំងកិច្ចការនៃសាសនាចក្រ នៅគ្រប់សាសន៍ គឺមុនដំបូង ដល់ពួក សាសន៍ដទៃ ហើយបន្ទាប់មក ដល់ពួកសាសន៍យូដា —

៣៥ ពួក១២នាក់ដែលត្រូវបានចាត់ឲ្យទៅ ដោយកាន់កូនសោទាំងឡាយ ដើម្បីទៅបើកទ្វារ ដោយការប្រកាសប្រាប់ពីដំណឹងល្អនៃ ព្រះយេស៊ូវគ្រីស្ទ ហើយមុនដំបូង ដល់ពួកសាសន៍ដទៃ ហើយបន្ទាប់មក ដល់ពួកសាសន៍យូដា ។

៣៦ [ក]ក្រុមប្រឹក្សាជាន់ខ្ពស់ដែលនៅជាអចិន្ត្រៃយ៍ នៅឯស្តេកទាំងឡាយនៃស៊ីយ៉ូន ធ្វើជាក្រុមមួយដែលមានសិទ្ធិអំណាចស្មើគ្នានិងក្រុម ប្រធាន ឬក្រុមប្រឹក្សាដែលធ្វើដំណើរ ក្នុងកិច្ចការទាំងឡាយនៃសាសនាចក្រ ក្នុងគ្រប់ទាំងការសំរេចចិត្តទាំងឡាយរបស់ពួកគេ ។

៣៧ ក្រុមប្រឹក្សាជាន់ខ្ពស់នៅស៊ីយ៉ូន ធ្វើជាក្រុមមួយដែលមានសិទ្ធិអំណាចស្មើគ្នានឹងក្រុមប្រឹក្សាទាំងឡាយនៃពួក១២នាក់នៅឯស្តេក ទាំងឡាយនៃស៊ីយ៉ូន ក្នុងកិច្ចការទាំងឡាយ នៃសាសនាចក្រ ក្នុងគ្រប់ទាំងការសំរេចចិត្តទាំងឡាយរបស់ពួកគេ ។

៣៨ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាដែលធ្វើដំណើរ ឲ្យស្មើដល់[ក]ពួក៧០នាក់ កាលណាពួកគេត្រូវការជំនួយ ដើម្បីបំពេញការងារនានា ខាងការផ្សាយ និងការចាត់ចែងដំណឹងល្អ ជាជាងអ្នកណាផ្សេងៗទៀត ។

៣៩ គឺជាភារកិច្ចរបសពួក១២នាក់ នៅក្នុងសាខាធំៗក្នុងសាសនាចក្រ ឲ្យតែងតាំងពួកអ្នកធ្វើការងារ[ក]បំរើខាងការផ្សាយដំណឹងល្អ ដូចដែលពួកគេ ត្រូវបានចាត់ដល់ពួកគេ ដោយវិវរណៈ —

៤០ របៀបនៃបព្វជិតភាពនេះត្រូវបានបញ្ជាក់ថាបានបន្តចុះមកពីឪពុកដល់កូន ហើយជារបស់ផងពូជពង្សពិតពីពូជជំរើសដែលសេចក្ដី សន្យាទាំងឡាយត្រូវបានធ្វើឡើងនោះ ។

៤១ របៀបនេះត្រូវបានតាំងឡើង នៅសម័យលោក[ក]អ័ដាម [ខ]ហើយបានចុះមកតាមពូជអំបូរ តាមរបៀបដែលមានដូចតទៅនេះគឺ៖

៤២ ពីលោកអ័ដាមទៅ[ក]សេត ដែលត្រូវបានតែងតាំងដោយលោកអ័ដាម កាលមានអាយុ៦៩ឆ្នាំ ហើយបានឲ្យពរដល់គាត់បីឆ្នាំមុន ការមរណភាពរបស់លោក (អ័ដាម) ហើយបានទទួលសេចក្ដីសន្យាពីព្រះ ដោយឪពុករបស់គាត់ ថាពូជពង្សរបស់គាត់ត្រូវបានជ្រើស រើស ដោយព្រះអម្ចាស់ ហើយថាពួកគេត្រូវបានរក្សាទុកឲ្យគង់វង់ រហូតដល់ទីបំផុតនៃផែនដី;

៤៣ ពីព្រោះគាត់ (សេត) ជាមនុស្សដ៏[ក]ល្អឥតខ្ចោះ ហើយ[ខ]រូបភាពគាត់ គឺជារូបភាពរបស់ឪពុករបស់គាត់បេះបិទ ដែលគាត់មើល ទៅដូច ជាឪពុករបស់គាត់ទាំងស្រុង ហើយអាចបានស្គាល់គាត់ថាខុសពីឪពុក ដោយសារអាយុគាត់ប៉ុណ្ណោះ ។

៤៤ អេណុសត្រូវបានតែងតាំងកាលមានអាយុ១៣៤ឆ្នាំ និងបួនខែ ដោយដៃរបស់លោកអ័ដាម ។

៤៥ ព្រះបានហៅកៃណាននៅក្នុងទីរហោស្ថាន កាលគាត់មានអាយុ៤០ឆ្នាំ; ហើយគាត់បានជួបលោកអ័ដាម ក្នុងកាលធ្វើដំណើរទៅ កន្លែងសេដូឡាម៉ាក់ ។ គាត់មានអាយុ៨៧ឆ្នាំ កាលគាត់បានទទួលការតែងតាំងរបស់គាត់ ។

៣១ *ក* ២ ពេត្រុស ១:៥–៨.
៣៣ *ក* ១ នីហ្វៃ ១៣:៤២;
៣ នីហ្វៃ ១៦:៤–១៣;
គ. និង ស. ៩០:៨–៩.
៣៤ *ក* គ. និង ស. ១១២:២១.
៣៦ *ក* ស.ប. ក្រុមប្រឹក្សាជាន់ខ្ពស់.
៣៨ *ក* ស.ប. ពួក៧០នាក់.
៣៩ *ក* ស.ប. គ្រូផ្សាយដំណឹងល្អ;
អយ្យកោ, ខាងអយ្យកោ.
៤១ *ក* ស.ប. អ័ដាម.
*ខ* លោកុ. ៥;
គ. និង ស. ៨៤:៦–១៦;
ម៉ូសេ ៦:១០–២៥.
៤២ *ក* ស.ប. សេត.
៤៣ *ក* ស.ប. ល្អឥតខ្ចោះ.
*ខ* លោកុ. ៥:៣.

៤៦ ម៉ាលេលាលមានអាយុ៤៩៦ឆ្នាំ និង៧ថ្ងៃ កាលគាត់បានតែងតាំង ដោយដៃរបស់លោកអ័ដាម ដែលជាអ្នកឲ្យពរដល់គាត់ផង ។

៤៧ យ៉ារេឌមានអាយុ២០០ឆ្នាំ កាលគាត់បានតែងតាំងនៅក្រោមដៃរបស់លោកអ័ដាម ជាអ្នកដែលឲ្យពរដល់គាត់ផង ។

៤៨ [ក]ហេណុកមានអាយុ២៥ឆ្នាំ កាលគាត់បានតែងតាំងនៅក្រោមដៃរបស់លោកអ័ដាម; ហើយគាត់មានអាយុ ៦៥ ឆ្នាំ ហើយលោកអ័ដាមបានឲ្យពរដល់គាត់ ។

៤៩ ហើយគាត់បានឃើញព្រះអម្ចាស់ ហើយគាត់បាន[ក]ដើរជាមួយទ្រង់ ហើយបាននៅចំពោះព្រះភ័ក្ត្ររបស់ទ្រង់រហូត; ហើយគាត់បានដើរជាមួយព្រះអស់៣៦៥ឆ្នាំ ដែលមានន័យថា គាត់មានអាយុ៤៣០ឆ្នាំ កាលគាត់បាន[ខ]ប្រែរូប ។

៥០ [ក]មធូសាឡាមានអាយុ១០០ឆ្នាំ កាលគាត់បានតែងតាំងនៅក្រោមដៃរបស់លោកអ័ដាម ។

៥១ ឡាមេកមានអាយុ៣២ឆ្នាំ កាលគាត់បានតែងតាំងនៅក្រោមដៃរបស់សេត ។

៥២ [ក]ណូអេមានអាយុ១០ឆ្នាំ កាលគាត់បានតែងតាំងនៅក្រោមដៃរបស់ មធូសាឡា ។

៥៣ បីឆ្នាំមុនមរណភាពរបស់លោកអ័ដាម នោះលោកបានហៅសេត អេណុស កៃណាន ម៉ាលេលាល យ៉ារេឌ ហេណុក និងមធូសាឡា ដែលសុទ្ធតែជាពួក[ក]សង្ឃជាន់ខ្ពស់ទាំងអស់ ព្រមទាំងពូជពង្សលោកដែលនៅសល់ទាំងប៉ុន្មាន ដែលសុចរិតឲ្យទៅ ក្នុងច្រក[ខ]ភ្នំអ័ដាម-អុនដៃ-អាម៉ាន ហើយនៅទីនោះ បានប្រទានមកលើពួកគេ នូវពរចុងក្រោយបង្អស់របស់លោក ។

៥៤ ហើយព្រះអម្ចាស់ ទ្រង់បានលេចមកឯពួកគេ ហើយពួកគេបានក្រោកឡើង ហើយឲ្យពរដល់លោក[ក]អ័ដាម ហើយហៅលោកថា [ខ]មីកែល ជាស្ដេច ជាមហាទេវតា ។

៥៥ ហើយព្រះអម្ចាស់បានកំសាន្ដចិត្តដល់លោកអ័ដាម ហើយមានព្រះបន្ទូលទៅកាន់លោកថា៖ យើងបានដាក់អ្នកឲ្យនៅខាងមុខ; សាសន៍ដ៏ច្រើននឹងមកពីអ្នក ហើយអ្នកជា[ក]ស្ដេចលើពួកគេជារៀងរហូតទៅ ។

៥៦ ហើយលោកអ័ដាមបានក្រោកឈរឡើង នៅកណ្ដាលក្រុមជំនុំ ទោះជាលោកកោងខ្នងដោយសារអាយុក្ដី ដោយបានពោរពេញ ទៅដោយ[ក]ព្រះវិញ្ញាណបរិសុទ្ធ ហើយបានទាយប្រាប់ពីអ្វីៗដែលនឹងកើតឡើងដល់ពូជពង្សរបស់លោកដល់ទៅតំណចុងក្រោយបង្អស់ ។

៥៧ ការណ៍ទាំងនេះត្រូវបានសរសេរទុក នៅក្នុងគម្ពីរហេណុក ហើយនឹងត្រូវធ្វើទីបន្ទាល់ នៅពេលកំណត់ ។

៥៨ គឺជាភារកិច្ចរបស់[ក]ពួក១២នាក់ដែរ ឲ្យ[ខ]តែងតាំង ហើយរៀបចំអស់ទាំងពួកអ្នកកាន់តំណែងផ្សេងៗទៀតនៅក្នុងសាសនាចក្រ ឲ្យមានរបៀបរៀបរយ យល់ព្រមតាមវិវរណៈដែលថា៖

៥៩ ចំពោះសាសនាចក្រនៃព្រះគ្រីស្ទ នៅក្នុងដែនដីស៊ីយ៉ូន ជាការបន្ថែមទៅនិង[ក]ក្រិត្យវិន័យទាំងឡាយនៃសាសនាចក្រ អំពីធុរកិច្ចនៃសាសនាចក្រ —

៦០ យើងប្រាប់អ្នកជាប្រាកដថា ព្រះអម្ចាស់នៃពួកពលបរិវារទ្រង់មានព្រះបន្ទូលថា ជាការចាំបាច់ ត្រូវតែមាន[ក]ពួកអែលឌើរត្រួតត្រា ដើម្បីត្រួតត្រាលើពួកអ្នក ដែលមានតំណែងជាអែលឌើរ;

៦១ ហើយពួកសង្ឃ [ក]ដើម្បីត្រួតត្រាលើពួកអ្នក ដែលមានតំណែងជាសង្ឃផង;

៦២ ហើយពួកគ្រូ [ក]ដើម្បីត្រួតត្រាលើពួកអ្នក ដែលមានតំណែងជាគ្រូផង តាមរបៀបដូចគ្នា ព្រមទាំងពួកឌីកុនផងដែរ —

៦៣ ហេតុដូច្នោះហើយ ពីឌីកុនទៅគ្រូ ហើយពីគ្រូទៅសង្ឃ ហើយពីសង្ឃទៅអែលឌើរ រៀងៗខ្លួនតាមដែលពួកគេបានកំណត់ស្រប តាមសេចក្ដីសញ្ញា និងព្រះបញ្ញត្តិទាំងឡាយនៃសាសនាចក្រ ។

៦៤ ខណៈនោះ ទើបមានបព្វជិតភាពជាន់ខ្ពស់ ដែលជាធំបំផុតលើអ្វីៗទាំងអស់ ។

៦៥ ហេតុដូច្នោះហើយ ជាការចាំបាច់ ត្រូវតែមាននរណាម្នាក់តាំងឡើងពីបព្វជិតភាពជាន់ខ្ពស់ ឲ្យត្រួតត្រាលើបព្វជិតភាព ហើយអ្នកនោះនឹងត្រូវហៅថាជា ប្រធាននៃបព្វជិតភាពជាន់ខ្ពស់ នៃសាសនាចក្រ;

៤៨ *ក* ស.ប. ហេណុក.
៤៩ *ក* លោកុ. ៥:២២; ហេព្រើរ ១១:៥; ម៉ូសេ ៧:៦៩.
*ខ* ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.
៥០ *ក* ស.ប. មធូសាឡា.
៥២ *ក* ស.ប. ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប.
៥៣ *ក* ស.ប. សង្ឃជាន់ខ្ពស់.
*ខ* គ. និង ស. ៧៨:១៥; ១១៦:១. ស.ប. អ័ដាម-អុនដៃ-អាម៉ាន.
៥៤ *ក* គ. និង ស. ១២៨:២១. ស.ប. អ័ដាម.
*ខ* ស.ប. មីកែល.
៥៥ *ក* គ. និង ស. ៧៨:១៦.
៥៦ *ក* ម៉ូសេ ៥:១០.
៥៨ *ក* ស.ប. សាវក.
*ខ* ស.ប. តែងតាំង, ការតែងតាំង.
៥៩ *ក* គ. និង ស. ៤៣:២–៩.
៦០ *ក* គ. និង ស. ១០៧:៨៩–៩០.
៦១ *ក* គ. និង ស. ១០៧:៨៧.
៦២ *ក* គ. និង ស. ១០៧:៨៥–៨៦.

៦៦ ឬម៉្យាងទៀតថា [ក]សង្ឃជាន់ខ្ពស់ដែលត្រួតត្រាលើបព្វជិតភាពជាន់ខ្ពស់ នៃសាសនាចក្រ ។

៦៧ ពីសង្ឃជាន់ខ្ពស់ដែលត្រួតត្រា ទើបមានការចាត់ចែងការប្រព្រឹត្តិទាំងឡាយ និងពរទាំងឡាយមកលើសាសនាចក្រ ដោយ[ក]ការដាក់ដៃលើ ។

៦៨ ហេតុដូច្នោះហើយ តំណែងនៃប៊ីស្សពគឺពុំស្មើ[ក]តំណែងនៃសង្ឃជាន់ខ្ពស់ដែលត្រួតត្រាទេ; ត្បិតតំណែងនៃប៊ីស្សពគឺជាការចាត់ចែង គ្រប់អស់ទាំងការណ៍ខាងសាច់ឈាម ។

៦៩ ទោះជាយ៉ាងណាក៏ដោយ គង់តែប៊ីស្សពត្រូវបានរើសពី[ក]បព្វជិតភាពជាន់ខ្ពស់ដែរ លើកលែងតែលោកជាពូជពង្សលោកអេរ៉ុន[ខ]ពិត ប៉ុណ្ណោះ ។

៧០ ត្បិតលើកលែងតែអ្នកនោះជាពូជពង្សលោកអេរ៉ុនពិត នោះគាត់ពុំអាចកាន់កូនសោទាំងឡាយនៃបព្វជិតភាពនោះបានឡើយ ។

៧១ ទោះជាយ៉ាងណាក៏ដោយ គង់តែសង្ឃជាន់ខ្ពស់ គឺថាតាមរបៀបលោកមិលគីស្សាដែក អាចបានញែកចេញ ចំពោះការងារ បំរើខាង ការណ៍ទាំងឡាយនៃសាច់ឈាមដែរ ដោយបានដំរិះពីការណ៍ទាំងឡាយខាងសាច់ឈាម ដោយសារព្រះវិញ្ញាណនៃ សេចក្ដីពិត;

៧២ ហើយឲ្យធ្វើជាចៅក្រមនៅអ៊ីស្រាអែលដែរ គឺដើម្បីប្រតិបត្តិធុរកិច្ចនៃសាសនាចក្រ ដើម្បីអង្គុយជំនុំជំរះលើពួកអ្នករំលងច្បាប់ស្របតាមទីបន្ទាល់ ដូចដែលបានលាតត្រដាងនៅចំពោះគាត់ស្របតាមក្រិត្យវិន័យទាំងឡាយ ដោយការជំនួយពីទីប្រឹក្សាទាំងឡាយ របស់គាត់ ដែលគាត់បានរើស ឬដែលនឹងរើសនៅក្នុងចំណោមពួកអែលឌើរនៃសាសនាចក្រ ។

៧៣ នេះគឺជាភារកិច្ចរបស់ប៊ីស្សព ដែលពុំមែនជាពូជពង្សលោកអេរ៉ុនពិត ប៉ុន្តែដែលបានតែងតាំងចំពោះបព្វជិតភាពជាន់ខ្ពស់ តាមរបៀបលោកមិលគីស្សាដែក ។

៧៤ ដូច្នោះ ទើបគាត់បានធ្វើជាចៅក្រម គឺជាចៅក្រមទូទៅនៅក្នុងចំណោមបណ្ដាជននៃស៊ីយ៉ូន ឬនៅក្នុងស្តេកនៃស៊ីយ៉ូន ឬនៅក្នុង សាខាណាមួយក្នុងសាសនាចក្រ ដែលគាត់នឹងត្រូវបានញែកចេញ ចំពោះការងារបំរើនេះ រហូតដល់ព្រំដែនស៊ីយ៉ូនបានពង្រីកឡើង ហើយចាំបាច់ត្រូវមានប៊ីស្សព ឬចៅក្រមផ្សេងៗទៀតនៅក្នុងស៊ីយ៉ូន ឬកន្លែងណាផ្សេងទៀត ។

៧៥ ហើយដរាបណាមានប៊ីស្សពផ្សេងៗទៀតបានតាំងឡើង នោះពួកគេត្រូវប្រតិបត្តិក្នុងតំណែងដដែល ។

៧៦ ប៉ុន្តែពូជពង្សលោកអេរ៉ុនពិត មានសិទ្ធិពេញច្បាប់ ចំពោះគណៈប្រធាននៃបព្វជិតភាពនេះ ចំពោះ[ក]កូនសោទាំងឡាយនៃការងារ បំរើនេះ ដើម្បីប្រតិបត្តិក្នុងតំណែងនៃប៊ីស្សពដោយឡែក ដោយពុំចាំបាច់ទីប្រឹក្សាទាំងឡាយឡើយ លើកលែងតែក្នុងករណី ដែលមាន ប្រធាននៃបព្វជិតភាពជាន់ខ្ពស់ តាមរបៀបលោកមិលគីស្សាដែក ត្រូវកាត់ក្ដីប៉ុណ្ណោះ ដើម្បីអង្គុយជាចៅក្រមនៅអ៊ីស្រាអែល ។

៧៧ ហើយការសំរេចចិត្តពីក្រុមណាមួយនៃក្រុមទាំងនេះយល់ព្រមតាមព្រះបញ្ញត្តិដែលថា៖

៧៨ ជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ធុរកិច្ចដ៏សំខាន់បំផុតនៃសាសនាចក្រ និងករណីដ៏[ក]ពិបាកបំផុតនៃសាសនាចក្រដរាបណា គ្មានការពេញចិត្តចំពោះការសំរេចចិត្តនៃប៊ីស្សពឬពួកចៅក្រម នោះនឹងត្រូវប្រគល់ ហើយ[ខ]បញ្ជូនឡើងទៅដល់ក្រុមប្រឹក្សានៃ សាសនាចក្រ នៅចំពោះគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ។

៧៩ ហើយគណៈប្រធាននៃក្រុមប្រឹក្សាក្នុងបព្វជិតភាពជាន់ខ្ពស់ត្រូវមានអំណាច ដើម្បីហៅពួកសង្ឃជាន់ខ្ពស់ផ្សេងៗទៀតគឺ១២នាក់ ឲ្យជួយធ្វើជាទីប្រឹក្សាទាំងឡាយ; ហើយដូច្នេះទើបគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ និងទីប្រឹក្សាទាំងឡាយរបស់គេ មានអំណាច ដើម្បីសំរេចចិត្តចំពោះទីបន្ទាល់ ស្របតាមក្រិត្យវិន័យទាំងឡាយនៃសាសនាចក្រ ។

៨០ ហើយបន្ទាប់ពីការសំរេចចិត្តនេះ នឹងពុំបាននឹកចាំនៅចំពោះព្រះអម្ចាស់ទៀតទេ; ត្បិតនេះគឺជាក្រុមប្រឹក្សាជាន់ខ្ពស់បំផុតនៃ សាសនាចក្ររបស់ព្រះ ហើយជាការសំរេចចិត្តចុងក្រោយបង្អស់ ចំពោះការទាស់ទែងខាងការណ៍ទាំងឡាយនៃវិញ្ញាណ ។

៨១ គ្មាននរណាមួយដែលជាសមាជិកនៃសាសនាចក្រត្រូវបានលើកលែងពីក្រុមប្រឹក្សានេះ នៅក្នុងសាសនាចក្រឡើយ ។

៨២ ហើយដរាបណាប្រធាននៃបព្វជិតភាពបានប្រព្រឹត្តរំលង នោះគាត់នឹងត្រូវបាននឹកចាំ នៅចំពោះក្រុមប្រឹក្សាទូទៅ

---

៦៦ *ក* គ. និង ស. ១០៧:៩, ៩១–៩២.
ស.ប. ប្រធាន.
៦៧ *ក* ស.ប. ដៃ, ការដាក់.
៦៨ *ក* ស.ប. ប៊ីស្សព.
៦៩ *ក* ស.ប. បព្វជិតភាពមិលគីស្សាដែក.
*ខ* គ. និង ស. ៦៨:១៤–២៤; ៨៤:១៨; ១០៧:១៣–១៧.
៧២ *ក* គ. និង ស. ៥៨:១៧–១៨.
៧៦ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
៧៨ *ក* គ. និង ស. ១០២:១៣, ២៨.
*ខ* គ. និង ស. ៦៨:២២.

នៃសាសនាចក្រ ដែលនឹងត្រូវជួយដោយទីប្រឹក្សា១២នាក់នៃ
បព្វជិតភាពជាន់ខ្ពស់ ។
៨៣ ហើយការសំរេចចិត្តរបស់ពួកគេមកលើអ្នកនោះ នឹងត្រូវ
បញ្ចប់រឿងទាស់ទែងអំពីគាត់ ។
៨៤ ដូច្នេះ ទើបគ្មាននរណាត្រូវបានលើកលែងពី[ក]សេចក្ដីយុត្តិធម៌
និងក្រិត្យវិន័យទាំងឡាយនៃព្រះឡើយ ប្រយោជន៍ឲ្យគ្រប់ទាំង
អស់អាច បានសំរេចតាមរបៀបរៀបរយ និងតាមការម៉ឺង
ម៉ាត់នៅចំពោះទ្រង់ ស្របតាមសេចក្ដីពិត និងសេចក្ដីសុចរិត ។
៨៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ភារកិច្ច
របស់ប្រធាននៅលើតំណែងនៃ[ក]ឌីកុន គឺត្រូវត្រួតត្រាលើពួកឌីកុន
១២នាក់ ត្រូវអង្គុយជាមួយពួកគេក្នុងក្រុមប្រឹក្សា ហើយត្រូវ
[ខ]បង្រៀនពួកគេអំពីភារកិច្ចរបស់គេ ដោយស្អាងគ្នាទៅវិញទៅមក
ដូចដែលបាន ប្រទានឲ្យមក ស្របតាមសេចក្ដីសញ្ញាទាំង
ឡាយ ។
៨៦ ហើយព្រមទាំងភារកិច្ចរបស់ប្រធាននៅលើតំណែងនៃ[ក]ពួក
គ្រូដែរ គឺត្រូវត្រួតត្រាលើគ្រូ២៤នាក់ ហើយត្រូវអង្គុយជាមួយ
ពួកគេ ក្នុងក្រុមប្រឹក្សា ដោយបង្រៀនពួកគេអំពីភារកិច្ច
នៃតំណែងរបស់ពួកគេ ដូចដែលបានប្រទានឲ្យមក ក្នុងសេច
ក្ដីសញ្ញាទាំងឡាយ ។
៨៧ ព្រមទាំងភារកិច្ចរបស់ប្រធានលើបព្វជិតភាពអើរ៉ុនដែរ គឺត្រូវ
ត្រួតត្រាលើ[ក]ពួកសង្ឃ៤៨នាក់ ហើយអង្គុយជាមួយពួកគេ ក្នុង
ក្រុមប្រឹក្សា ដើម្បីបង្រៀនពួកគេអំពីភារកិច្ចនៃតំណែងរបស់ពួក
គេ ដូចដែលបានប្រទានឲ្យមកក្នុងសេចក្ដីសញ្ញាទាំងឡាយ —
៨៨ ប្រធាននេះត្រូវធ្វើជាប៊ីស្សព; ត្បិតនេះហើយជាភារកិច្ច
មួយនៃបព្វជិតភាពនេះ ។
៨៩ ជាថ្មីទៀត ភារកិច្ចរបស់ប្រធាននៅលើតំណែងនៃ[ក]ពួក
អែលឌើរ គឺត្រូវត្រួតត្រាលើពួកអែលឌើរ៩៦នាក់ ហើយ
ត្រូវអង្គុយជាមួយ ពួកគេក្នុងក្រុមប្រឹក្សា ហើយត្រូវបង្រៀនពួក
គេ ស្របតាមសេចក្ដីសញ្ញាទាំងឡាយ ។
៩០ គណៈប្រធាននេះខុសពីគណៈប្រធាននៃពួក៧០នាក់ ហើយ
ត្រូវបានបង្កើតឡើងសំរាប់ពួកអ្នក ដែលមិន[ក]ធ្វើដំណើរ
ទៅពេញសព្វក្នុង ពិភពលោក ។
៩១ ហើយជាថ្មីទៀត ភារកិច្ចរបស់ប្រធាននៃតំណែងរបស់
បព្វជិតភាព[ក]ជាន់ខ្ពស់[ខ] គឺត្រូវត្រួតត្រាលើសាសនាចក្រទាំងមូល
ហើយត្រូវធ្វើ ដូចជាលោកម៉ូសេ —
៩២ មើលចុះ នេះហើយជាប្រាជ្ញា; មែនហើយ គឺត្រូវធ្វើជា[ក]អ្នក
មើលឆុត ជា[ខ]អ្នកបើកសម្ដែង ជាអ្នកបកប្រែ ហើយជា[គ]ព្យាការី
ដោយ មានគ្រប់[ឃ]អំណោយទានទាំងអស់នៃព្រះ ដែលទ្រង់ប្រទាន
មកលើមេដឹកនាំសាសនាចក្រ ។
៩៣ ហើយគឺស្របតាមការនិមិត្ត ដែលបង្ហាញអំពីរបៀប
នៃ[ក]ពួក៧០នាក់ ថាពួកគេត្រូវមានប្រធានប្រាំពីរនាក់ ដើម្បីត្រួត
ត្រាលើពួកគេ ដែលត្រូវបានរើសចេញពីចំនួនពួក៧០នាក់;
៩៤ ហើយប្រធានទីប្រាំពីរក្នុងប្រធានទាំងនេះ ត្រូវត្រួត
ត្រាលើប្រធានទាំងប្រាំមួយនាក់;
៩៥ ហើយប្រធានទាំងប្រាំពីរនាក់នេះ ត្រូវរើសពួក៧០
នាក់ផ្សេងទៀត ក្រៅពីពួក៧០នាក់លើកមុន ដែលពួកគេ
ជាសមាជិក ហើយត្រូវ ត្រួតត្រាលើពួកគេ;
៩៦ ហើយនិងពួក៧០នាក់ផ្សេងទៀត រហូតដល់ប្រាំពីរ៧០ដង
បើសិនជាកិច្ចការក្នុងចំការទំពាំងបាយជូរតម្រូវដោយមក
ពីការចាំបាច់ ។
៩៧ ហើយពួក៧០ទាំងនេះត្រូវធ្វើជាអ្នកធ្វើការងារបំរើដែល
[ក]ធ្វើដំណើរ ដល់ពួកសាសន៍ដទៃមុនដំបូង ហើយដល់ពួកសាសន៍
យូដាផង ។
៩៨ រីឯពួកអ្នកកាន់តំណែងផ្សេងៗទៀតនៅក្នុងសាសនាចក្រ
ដែលមិនមែនជាសមាជិកនៃពួក១២នាក់ ឬពួក៧០នាក់ទេ នោះ
មិនត្រូវ នៅក្រោមកាតព្វកិច្ច ដើម្បីធ្វើដំណើរក្នុងចំណោម
សាសន៍ទាំងអស់ឡើយ ប៉ុន្តែត្រូវធ្វើដំណើរតាមដែលកាលៈទេសៈ
អនុញ្ញាត ទោះជា ពួកគេអាចកាន់តំណែងខ្ពង់ខ្ពស់ និងសំខាន់ៗនៅ
ក្នុងសាសនាចក្រក្ដី ។
៩៩ ហេតុដូច្នោះហើយ នៅពេលឥឡូវនេះ ចូរឲ្យមនុស្ស

៨៤ *ក* ស.ប. សេចក្ដីយុត្តិធម៌.
៨៥ *ក* ស.ប. ឌីកុន.
*ខ* គ. និង ស. ៣៨:២៣;
៨៨:៧៧–៧៩, ១១៨.
៨៦ *ក* គ. និង ស. ២០:៥៣–៦០.
ស.ប. គ្រូ, បព្វជិតភាពអើរ៉ុន.
៨៧ *ក* ស.ប. សង្ឃ, បព្វជិតភាពអើរ៉ុន.
៨៨ *ក* ស.ប. ប៊ីស្សព.
៨៩ *ក* ស.ប. អែលឌើរ.
៩០ *ក* គ. និង ស. ១២៤:១៣៧.
៩១ *ក* គ. និង ស. ១០៧:៩, ៦៥–៦៧.
*ខ* គ. និង ស. ២៨:២;
១០៣:១៦–២១.
៩២ *ក* ម៉ូសាយ ៨:១៣–១៨.
ស.ប. អ្នកមើលឆុត.
*ខ* ស.ប. វិវរណៈ.
*គ* គ. និង ស. ២១:១.
ស.ប. ព្យាការី.
*ឃ* ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
៩៣ *ក* គ. និង ស. ១០៧:៣៨.
ស.ប. ពួក៧០នាក់.
៩៧ *ក* គ. និង ស. ១២៤:១៣៨–១៣៩.

គ្រប់រូបរៀនពីភារកិច្ចរបស់ខ្លួន ហើយឲ្យប្រតិបត្តិក្នុងតំណែង
ដែលខ្លួនត្រូវ បានតាំងឡើង ដោយសេចក្ដីឧស្សាហ៍គ្រប់ជំពូក ។
១០០ អ្នកណាដែលខ្ជិលច្រអូសមិនត្រូវបានរាប់ថាសមនឹង
ឈរឡើយ ហើយអ្នកណាដែលមិនរៀនពីកាតព្វកិច្ចរបស់ខ្លួន ហើយបង្ហាញខ្លួន ថាពុំបានទទួលការអនុមតិទេ នោះមិនត្រូវបាន រាប់ថាសមនឹងឈរឡើយ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១០៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៨៣៥ (*History of the Church, *២:៣៤៥) ។ កណ្ឌនេះត្រូវបានទទួលតាមសំណូមពររបស់ ឡៃម៉ាន ស៊ើម៉ាន ដែលទើបបានតែងតាំងឡើងឲ្យ ធ្វើជាសង្ឃជាន់ខ្ពស់ និងជាពួក៧០នាក់រួចមកហើយ ហើយដែលជាអ្នកបានមករកព្យាការីសូមវិវរណៈ ចង់ដឹងពីភារកិច្ចរបស់គាត់ ។*

*១–៣, ឡៃម៉ាន ស៊ើម៉ាន ត្រូវបានអត់ទោសចំពោះអំពើបាបរបស់គាត់ហើយ; ៤–៥, គាត់នឹងត្រូវបានរាប់ចូលជាមួយនិងពួកអែលឌើរ ដែលដឹកនាំសាសនាចក្រ; ៦–៨, គាត់ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ហើយឲ្យចំរើនកម្លាំងដល់បងប្អូនគាត់នៅក្នុងសាសនា ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក គឺឡៃម៉ាន ជាអ្នកបំរើរបស់យើងដូច្នេះថា ៖ អំពើបាបទាំងឡាយរបស់អ្នក ត្រូវបានអត់ទោសឲ្យហើយ ពីព្រោះអ្នកបានគោរពតាមសម្លេងរបស់យើង ក្នុងការឡើងមកទីនេះ នៅពេលព្រលឹមនេះ ដើម្បីមក ទទួលការទូន្មានពីអ្នកដែលយើងបានតាំងឡើង ។

២ ហេតុដូច្នេះហើយ ចូរឲ្យព្រលឹងអ្នកបានស្ងប់ស្ងៀមអំពីជំហរខាងវិញ្ញាណរបស់អ្នកចុះ ហើយចូរកុំប្រឆាំងនិងសម្លេងរបស់យើងទៀតឡើយ ។

៣ ហើយចូរក្រោកឈរឡើង ហើយចូរប្រយ័ត្នពីពេលនេះតទៅ ក្នុងការគោរពតាមសម្បថទាំងឡាយរបស់អ្នក ដែលអ្នកបានធ្វើ ហើយនឹងធ្វើ ហើយអ្នកនឹងបានពរ ដោយព្រះពរដ៏ធំអតិបរមា ។

៤ ចូរព្យាយាមរង់ចាំ ទាល់តែត្រូវបានប្រកាសឲ្យមានជំនុំមុតមាំមួយ ដោយពួកអ្នកបំរើរបស់យើង ខណៈនោះ អ្នកនឹងបានចំណាំទុក ជាមួយពួកអែលឌើរទីមួយរបស់យើង ហើយទទួលសិទ្ធិ ដោយការតែងតាំងជាមួយនិងពួកអែលឌើររបស់យើង ដែលយើងបានរើស នោះ ។

៥ មើលចុះ នេះគឺជាសេចក្ដីសន្យានៃព្រះវរបិតាដល់អ្នក បើសិនជាអ្នកមានចិត្តស្មោះត្រង់រហូតតទៅ ។

៦ ហើយនឹងបានបំពេញដល់អ្នកនៅថ្ងៃនោះ ថាអ្នកនឹងបានសិទ្ធិដើម្បីផ្សាយដំណឹងល្អរបស់យើង នៅទីណាក៏ដោយ ដែលយើងនឹងចាត់ ឲ្យអ្នកទៅ ពីពេលនេះរៀងរហូតតទៅ ។

៧ ហេតុដូច្នេះហើយ ចូរចំរើនកម្លាំងដល់បងប្អូនអ្នកនៅក្នុងសាសនា ដោយគ្រប់វាចារបស់អ្នក ដោយគ្រប់សេចក្ដីអធិស្ឋានរបស់អ្នក ដោយគ្រប់សេចក្ដីដាស់តឿនរបស់អ្នក និងដោយគ្រប់ការប្រព្រឹត្តិរបស់អ្នក ។

៨ ហើយមើលចុះ និងមើលន៏ យើងគង់នៅជាមួយអ្នក ដើម្បីប្រទានពរដល់អ្នក ហើយរំដោះអ្នកជារៀងដរាបតទៅ ។ អាម៉ែន ៕

## កណ្ឌទី ១០៩

*បទអធិស្ឋានដែលបានថ្វាយនៅពិធីឆ្លងព្រះវិហារនៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៧ ខែមីនា ឆ្នាំ១៨៣៦ (*History of the Church, *២:៤២០–៤២៦) ។ ស្របតាមកំណត់របស់ព្យាការី បទអធិស្ឋាននេះត្រូវបានប្រទានដល់លោក ដោយវិវរណៈ ។*

៩៩ *ក* ស.ប. កាតព្វកិច្ច.
*ខ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
១០០ *ក* គ. និង ស. ៥៨:២៦–២៩.
ស.ប. ខ្ជិលច្រអូស, ការខ្ជិលច្រអូស.
*ខ* ស.ប. សក្តិសម, ភាពសក្តិសម.
**១០៨** ២ *ក* ស.ប. សេចក្ដីសំរាក.
៤ *ក* គ. និង ស. ១០៩:៦–១០.
៥ *ក* គ. និង ស. ៨២:១០.
៦ *ក* ស.ប. កិច្ចការផ្សាយសាសនា.
៧ *ក* លូកា ២២:៣១–៣២.
៨ *ក* ២ នីហ្វៃ ៩:១៩.

*១–៥, ព្រះវិហារខឺតឡង់ត្រូវបានសង់ឡើងជាទីសំរាប់ឲ្យកូនមនុស្សមកទស្សនកិច្ច; ៦–២១, គឺជាដំណាក់នៃការអធិស្ឋាន ការតម អាហារ សេចក្ដីជំនឿ ការរៀនសូត្រ សិរីល្អ និង របៀបរៀបរយ ហើយជាដំណាក់នៃព្រះ; ២២–៣៣, សូមឲ្យពួកអ្នកមិនប្រែចិត្តណា ដែលជំទាស់និងរាស្ត្ររបស់ព្រះត្រូវបានធ្វើឲ្យខ្មាស; ៣៤–៤២, សូមឲ្យពួកបរិសុទ្ធចេញទៅ ក្នុងអំណាចដើម្បីប្រមូលពួកសុចរិតទៅ ឯស៊ីយ៉ូន; ៤៣–៥៣, សូមឲ្យពួកបរិសុទ្ធបានរំដោះរួចពីអំពើដ៏គួរស្ញែងខ្លាច ដែលនឹងត្រូវចាក់ទៅលើពួកទុច្ចរិត នៅថ្ងៃចុងក្រោយបង្អស់; ៥៤–៥៨, សូមឲ្យសាសន៍ ប្រជាជន និងសាសនាចក្រទាំងឡាយបានរៀបចំសំរាប់ដំណឹងល្អ; ៥៩–៦៧, សូមឲ្យពួកសាសន៍យូដា ពួកសាសន៍លេមិន និងអស់ទាំងសាសន៍អ៊ីស្រាអែលបានប្រោសលោះ; ៦៨–៨០, សូមឲ្យពួកបរិសុទ្ធបានពាក់សិរីល្អ និងកិត្តិយសជាមកុដ ហើយបានសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច ។*

សូមថ្វាយ[ក]ព្រះគុណដល់ព្រះនាមព្រះអង្គ ឱព្រះអម្ចាស់[ខ]ដ៏ជាព្រះនៃសាសន៍អ៊ីស្រាអែលអើយ ដែលកាន់តាមសេចក្ដីសញ្ញា ហើយបង្ហាញ សេចក្ដីមេត្តាករុណាដល់ពួកអ្នកបំរើរបស់ទ្រង់ ដែលដំដើរដោយទៀងត្រង់នៅចំពោះទ្រង់អស់ពីចិត្តរបស់ពួកគេ —

២ ព្រះអង្គបានបញ្ជាពួកអ្នកបំរើរបស់ទ្រង់ ឲ្យសង់[ក]ដំណាក់មួយនៅទីនេះ [ខឺតឡង់] ។

៣ ហើយឥឡូវនេះ សូមព្រះអង្គទតមើលចុះ ឱព្រះអម្ចាស់អើយ ថាពួកអ្នកបំរើរបស់ទ្រង់បានសំរេចតាមព្រះបញ្ញត្តិរបស់ទ្រង់ហើយ ។

៤ ហើយឥឡូវនេះ ទូលបង្គំសូមដល់ព្រះអង្គ ជាព្រះវរបិតាដ៏បរិសុទ្ធ ដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាពីឱរា របស់ទ្រង់ មានតែព្រះនាមមួយគត់ ដែលសេចក្ដីសង្គ្រោះអាចបានប្រទានដល់កូនចៅមនុស្ស នោះទូលបង្គំសូមដល់[ខ]ព្រះអង្គ ឱព្រះ អម្ចាស់អើយ សូមទទួល[ក]ដំណាក់នេះ ដែលជាស្នាដៃរបស់ទូលបង្គំទាំងអស់គ្នា ជាពួកអ្នកបំរើរបស់ទ្រង់ ដែលទ្រង់បានបញ្ជាឲ្យទូលបង្គំ ទាំងអស់គ្នាសង់ ។

៥ ត្បិតព្រះអង្គជ្រាបថាទូលបង្គំទាំងអស់គ្នាបានសំរេចកិច្ចការនេះតាមរយៈការវេទនាដ៏ខ្លាំង; ហើយចេញពីភាពក្រខ្សត់របស់ទូលបង្គំទាំងអស់គ្នា នោះទូលបង្គំទាំងអស់គ្នាបានថ្វាយរបស់របរនៃទូលបង្គំទាំងអស់គ្នា ដើម្បីសង់[ក]ដំណាក់មួយដល់ព្រះនាមរបស់ទ្រង់ ប្រយោជន៍ឲ្យកូនមនុស្សអាចមានកន្លែងមួយ ដើម្បីសំដែងអង្គទ្រង់ដល់រាស្ត្ររបស់ទ្រង់ ។

៦ ហើយដូចដែលព្រះអង្គបានមានព្រះបន្ទូលនៅក្នុង[ក]វិវរណៈដែលបានប្រទានដល់ទូលបង្គំទាំងអស់គ្នា ដោយហៅទូលបង្គំទាំងអស់គ្នា ថាជាមិត្តទាំងឡាយរបស់ទ្រង់ថា — ចូរប្រកាសឲ្យមានជំនុំមុតមាំរបស់អ្នក ដូចដែលយើងបានបញ្ជាដល់អ្នកចុះ;

៧ ហើយដូចជាមនុស្សពុំមានសេចក្ដីជំនឿទាំងអស់គ្នា នោះចូរអ្នករាល់គ្នាព្យាយាមស្វែងរក ហើយបង្រៀនគ្នាទៅវិញទៅមក នូវពាក្យសំដីនៃប្រាជ្ញាវាងវៃ; មែនហើយ ចូរអ្នករាល់គ្នាស្វែងរកពាក្យសំដីនៃប្រាជ្ញាវាងវៃ ចេញពីសៀវភៅដ៏ល្អៗបំផុត; ចូរស្វែងរក ការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្ដីជំនឿផង;

៨ ចូររៀបចំខ្លួន; ចូររៀបចំអ្វីៗដែលត្រូវការគ្រប់មុខ; ហើយចូរតាំងដំណាក់មួយឡើង គឺដំណាក់នៃការអធិស្ឋាន ដំណាក់នៃការតមអាហារ ដំណាក់នៃសេចក្ដីជំនឿ ដំណាក់នៃការរៀនសូត្រ ដំណាក់នៃសិរីល្អ ដំណាក់នៃរបៀបរៀបរយ ដំណាក់នៃព្រះ;

៩ ប្រយោជន៍ឲ្យការចូលរបស់អ្នកអាចបានធ្វើឡើង ដោយនូវព្រះនាមនៃព្រះអម្ចាស់; ប្រយោជន៍ឲ្យការចេញរបស់អ្នកអាចបានធ្វើឡើង ដោយនូវព្រះនាមនៃព្រះអម្ចាស់; ប្រយោជន៍ឲ្យអស់ទាំងការជំរាបសួររបស់អ្នកអាចបានធ្វើឡើង ដោយនូវព្រះនាមនៃព្រះអម្ចាស់ ដោយ លើកដៃថ្វាយដល់ព្រះដ៏ខ្ពស់បំផុត —

១០ ហើយឥឡូវនេះ ឱព្រះវរបិតាដ៏បរិសុទ្ធអើយ ទូលបង្គំទាំងអស់គ្នាសូមព្រះអង្គជួយទូលបង្គំទាំងអស់គ្នា ជារាស្ត្ររបស់ទ្រង់ ដោយព្រះគុណរបស់ទ្រង់ ក្នុងការប្រកាសឲ្យមានជំនុំមុតមាំរបស់យើង ប្រយោជន៍ឲ្យការនេះអាចបានសំរេច ដើម្បីកិត្តិយសព្រះអង្គ និងដល់ការទទួលដ៏ឧត្តុងឧត្តម របស់ទ្រង់;

១១ ហើយនៅក្នុងរបៀបមួយ ប្រយោជន៍ឲ្យទូលបង្គំទាំងអស់គ្នាអាចបានឃើញថាសក្តិសម ចំពោះព្រះនេត្ររបស់ទ្រង់ ដើម្បី

**១០៩** ១*ក* អាលម៉ា ៣៧:៣៧;
គ. និង ស. ៤៦:៣២.
ស.ប. ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ.
*ខ* ដានី. ៩:៤.
ស.ប. សេចក្ដីសញ្ញា.
២ *ក* គ. និង ស. ៨៨:១១៩.
៤ *ក* ១ ពង្សាវ. ៩:៣.
ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់.
*ខ* ២ នីហ្វៃ ៥:១៦.
៥ *ក* គ. និង ស. ១២៤:២៧–២៨.
៦ *ក* គ. និង ស. ៨៨:១១៧–១២០.

បានភាព ពោរពេញនៃ[ក]សេចក្ដីសន្យាទាំងឡាយ ដែលព្រះអង្គបាន
ធ្វើដល់ទូលបង្គំទាំងអស់គ្នា ជារាស្ត្ររបស់ទ្រង់ នៅ
ក្នុងវិវរណៈដែលបានប្រទាន ដល់ទូលបង្គំនោះ;
១២ សូមឲ្យ[ក]សិរីល្អរបស់ទ្រង់អាចបានសណ្ឋិតមកលើរាស្ត្រ
របស់ទ្រង់ និងមកលើដំណាក់របស់ទ្រង់នេះ ដែលទូលបង្គំទាំង
អស់គ្នា ថ្វាយដល់ព្រះអង្គនៅពេលឥឡូវនេះ សូមឲ្យដំណាក់នេះ
អាចបានញែកចេញជាបរិសុទ្ធ ហើយតាំងជាបរិសុទ្ធ ហើយ
សូមឲ្យវត្តមាន ដ៏បរិសុទ្ធរបស់ទ្រង់នេះ អាចគង់នៅក្នុង
ដំណាក់នេះរហូតតទៅ;
១៣ ហើយសូមឲ្យមនុស្សទាំងអស់ ដែលនឹងចូលមកលើ
ធរណីទ្វារ នៃដំណាក់នៃព្រះអម្ចាស់ អាចបានជ្រាបយល់នូវព្រះ
ចេស្ដា របស់ទ្រង់ ហើយអាចបានបង្ខំឲ្យទទួលស្គាល់ថា ព្រះអង្គ
បានញែកដំណាក់នេះចេញជាបរិសុទ្ធ ហើយថាដំណាក់នេះជា
ដំណាក់ របស់ទ្រង់ គឺជាទីនៃបរិសុទ្ធភាពរបស់ទ្រង់ ។
១៤ ហើយព្រះវរបិតាដ៏បរិសុទ្ធអើយ សូមព្រះអង្គអនុញ្ញាតឲ្យ
អស់អ្នកណា ដែលនឹងថ្វាយបង្គំនៅក្នុងដំណាក់នេះ អាចបាន
ទទួលការ បង្រៀនពីពាក្យសំដីនៃប្រាជ្ញាវាងវៃ ចេញពីសៀវភៅ
ដ៏ល្អៗបំផុត; ហើយសូមឲ្យពួកគេអាចបានការរៀនសូត្រ គឺដោយ
សារការសិក្សា និងដោយសារសេចក្ដីជំនឿផង ដូចដែល
ព្រះអង្គបានមានព្រះបន្ទូលលើកមុនចុះ;
១៥ ហើយសូមឲ្យពួកគេអាចបានធំឡើងក្នុងទ្រង់ ហើយទទួល
នូវភាពពោរពេញនៃព្រះវិញ្ញាណបរិសុទ្ធ ហើយបានរៀបចំ
តាមក្រិត្យ វិន័យទាំងឡាយ ហើយបានរៀបចំដើម្បីបានអ្វីៗដែល
ត្រូវការគ្រប់មុខ;
១៦ ហើយសូមឲ្យដំណាក់នេះ អាចបានទៅជាដំណាក់
នៃការអធិស្ឋាន ដំណាក់នៃការតមអាហារ ដំណាក់នៃសេចក្ដី
ជំនឿ ដំណាក់នៃសិរីល្អ និងនៃព្រះ គឺជាដំណាក់របស់
ព្រះអង្គ;
១៧ សូមឲ្យអស់ទាំងការចូលនៃរាស្ត្ររបស់ទ្រង់ ទៅក្នុង
ដំណាក់នេះ អាចបានធ្វើឡើង ដោយនូវព្រះនាមនៃព្រះអម្ចាស់;
១៨ សូមឲ្យអស់ទាំងការចេញរបស់ពួកគេ ពីដំណាក់នេះ
អាចបានធ្វើឡើង ដោយនូវព្រះនាមនៃព្រះអម្ចាស់;
១៩ ឲ្យអស់ទាំងការជំរាបសួររបស់ពួកគេ អាចបានធ្វើឡើង
ដោយនូវព្រះនាមនៃព្រះអម្ចាស់ ដោយដៃបរិសុទ្ធ លើកឡើងថ្វាយ
ដល់ព្រះដ៏ខ្ពស់បំផុត;
២០ ហើយសូមកុំឲ្យរបស់[ក]មិនស្អាត បានអនុញ្ញាតចូលក្នុង
ដំណាក់ទ្រង់ ដើម្បីបង្ខូចដំណាក់ទ្រង់ឡើយ;
២១ ហើយកាលណារាស្ត្ររបស់ទ្រង់ប្រព្រឹត្តរំលង គឺពួកគេ
ណាមួយក៏ដោយ នោះសូមពួកគេឆាប់ប្រែចិត្ត ហើយវិលមក
រកទ្រង់វិញ ហើយសូមឲ្យបានប្រកបដោយគុណ ចំពោះព្រះនេត្រ
របស់ទ្រង់ ហើយបានសាងឡើងវិញ ចំពោះព្រះពរទាំងឡាយ
ដែលព្រះអង្គបាន តែងតាំងឡើង ដើម្បីចាក់មកលើពួកអ្នក ដែល
នឹង[ក]គោរពកោតក្រែងដល់ព្រះអង្គ នៅក្នុងដំណាក់ទ្រង់ ។
២២ ហើយទូលបង្គំទាំងអស់គ្នាសូមដល់ព្រះអង្គ ឱព្រះវរបិតា
ដ៏បរិសុទ្ធអើយ សូមឲ្យពួកអ្នកបំរើរបស់ទ្រង់ អាចបានចេញពី
ដំណាក់ នេះទៅប្រដាប់ ដោយព្រះចេស្ដារបស់ទ្រង់ ហើយ
សូមឲ្យព្រះនាមរបស់ទ្រង់អាចបាននៅក្នុងពួកគេ ហើយសូមឲ្យ
សិរីល្អរបស់ទ្រង់ នៅជុំវិញពួកគេ ហើយ[ក]ពួកទេវតារបស់ទ្រង់
ថែរក្សាពួកគេ;
២៣ ហើយចេញពីទីនេះទៅ សូមឲ្យពួកគេអាចបាន
ថ្លែងពីដំណឹងធំ និងរុងរឿងអស្ចារ្យ តាមសេចក្ដីពិត
ប្រាប់ដល់[ក]ទីបំផុតនៃផែនដី ប្រយោជន៍ឲ្យពួកគេអាចបាន
ដឹងថា នេះគឺជាកិច្ចការរបស់ទ្រង់ ហើយថាព្រះអង្គបាន
ដាក់ព្រះហស្ដរបស់ទ្រង់ ដើម្បីបំពេញនូវអ្វីៗ ដែលព្រះអង្គ
បានមានព្រះបន្ទូលប្រាប់ ដោយសារមាត់នៃពួកព្យាការីទាំង
ឡាយ ពីគ្រាចុងក្រោយបង្អស់ ។
២៤ ទូលបង្គំទាំងអស់គ្នាសូមដល់ព្រះអង្គ ឱព្រះវរបិតាដ៏បរិសុទ្ធ
អើយ សូមតាំងប្រជាជនដែលនឹងថ្វាយបង្គំ ហើយមានឈ្មោះ
និងជំហរដ៏ប្រសើរ នៅក្នុងដំណាក់ទ្រង់នេះ ដល់អស់តំណ
មនុស្ស និងដល់អស់កល្បជានិច្ច;
២៥ សូមកុំឲ្យគ្រឿងសស្ត្រាវុធបាន[ក]ធ្វើឡើង[ខ]ទាស់និងពួកគេបាន
លូតលាស់ឡើយ; សូមឲ្យនរណាដែលជីករណ្ដៅសំរាប់ពួកគេ
បានធ្លាក់ទៅក្នុងរណ្ដៅនោះខ្លួនឯងចុះ;
២៦ សូមកុំឲ្យប័ក្សពួកមនុស្សទុច្ចរិតមានអំណាច ផ្ទុះកើតឡើង

១១ *ក* គ. និង ស. ៣៨:៣២;
១០៥:១១–១២, ១៨, ៣៣.
១២ *ក* ស.ប. សិរីល្អ.
២០ *ក* គ. និង ស. ៩៤:៨–៩;
៩៧:១៥–១៧.
២១ *ក* ស.ប. ការគោរពកោតក្រែង.
២២ *ក* ស.ប. ពួកទេវតា.
២៣ *ក* គ. និង ស. ១:២.
២៥ *ក* អេសាយ ៥៤:១៧.
*ខ* សុភា. ២៦:២៧; ១ នីហ្វៃ ១៤:៣;
២២:១៤.

ហើយ[ក]ឈ្មោះលើរាស្ត្ររបស់ទ្រង់ ដែល[ខ]ព្រះនាមរបស់ទ្រង់នឹងបានដាក់លើពួកគេ នៅក្នុងដំណាក់នេះឡើយ ។

២៧ ហើយបើសិនជាមានប្រជាជនណាមួយនឹងក្រោកឡើងទាស់និងប្រជារាស្ត្រនេះ សូមឲ្យសេចក្ដីខ្ញាល់របស់ទ្រង់ឆួលឡើងទាស់និង ពួកគេ;

២៨ ហើយបើសិនជាពួកគេនឹងវាយប្រជារាស្ត្រនេះ សូមឲ្យព្រះអង្គវាយពួកគេវិញ; សូមព្រះអង្គច្បាំងជំនួសរាស្ត្ររបស់ទ្រង់ ដូចជា ទ្រង់បានធ្វើនៅថ្ងៃសង្គ្រាម ប្រយោជន៍ឲ្យពួកគេអាចបានដោះលែង រួចពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវរបស់ពួកគេ ។

២៩ ទូលបង្គំទាំងអស់គ្នាសូមដល់ព្រះអង្គ ឱព្រះវរបិតាដ៏បរិសុទ្ធអើយ សូមបំភាន់ និងបង្អើល ហើយធ្វើឲ្យមានការអាម៉ាស និងការច្រឡំ ដល់អស់ អ្នកណាដែលបានរាយការណ៍កុហកនៅប្រទេសក្រៅ ពាសពេញលើពិភពលោក ទាស់នឹងអ្នកបំរើ ឬពួកអ្នកបំរើរបស់ទ្រង់ បើសិនជាពួកគេមិនប្រែចិត្ត នៅពេលដំណឹងល្អដ៏នៅអស់កល្បអស់កាលជានិច្ច ត្រូវបានប្រកាសប្រាប់ដល់ត្រចៀកពួកគេនោះ;

៣០ ហើយសូមឲ្យកិច្ចការទាំងឡាយរបស់ពួកគេ អាចបានទៅជាឥតប្រយោជន៍ ហើយត្រូវបោសចេញដោយ[ក]ព្រិល និងដោយសេចក្ដី ជំនុំជំរះទាំងឡាយ ដែលព្រះអង្គបានចាត់មកលើពួកគេ ដោយនូវសេចក្ដីខ្ញាល់របស់ទ្រង់ សូមឲ្យឈប់មានការ[ខ]កុហក និងការ បង្កាច់ទាស់និងរាស្ត្ររបស់ទ្រង់ ។

៣១ ត្បិតព្រះអង្គជ្រាប ឱព្រះអម្ចាស់អើយ ថាពួកអ្នកបំរើរបស់ទ្រង់ឥតមានទោស នៅចំពោះទ្រង់ ក្នុងការថ្លែងទីបន្ទាល់អំពីព្រះនាម របស់ទ្រង់ ដែលពួកគេបានស៊ូទ្រាំការណ៍ទាំងនេះ ។

៣២ ហេតុដូច្នេះហើយ ទូលបង្គំទាំងអស់គ្នាអង្វរដល់ព្រះអង្គសូមសេចក្ដីរំដោះពី[ក]នឹមនេះ ឲ្យបានរួចពេញលេញ និងពេញទី;

៣៣ សូមបំបាក់នឹមនោះចេញ ឱព្រះអម្ចាស់អើយ សូមបំបាក់នឹមនោះចេញពីកនៃពួកអ្នកបំរើរបស់ទ្រង់ ដោយព្រះចេស្ដា ប្រយោជន៍ឲ្យទូលបង្គំទាំងអស់គ្នា អាចបានក្រោកឡើងនៅកណ្ដាលតំណមនុស្សនេះ ហើយធ្វើកិច្ចការរបស់ទ្រង់ ។

៣៤ ឱព្រះយេហូវ៉ាអើយ សូមមានសេចក្ដីមេត្តាករុណាមកលើប្រជារាស្ត្រនេះ ហើយដោយព្រោះគ្រប់មនុស្សទាំងអស់[ក]ធ្វើបាប សូមអភ័យទោសចំពោះការរំលងច្បាប់ទាំងឡាយនៃរាស្ត្ររបស់ទ្រង់ផង ហើយសូមអំពើទាំងនោះបានលុបចេញជារៀងរហូតទៅ។

៣៥ សូមឲ្យការ[ក]លាបនៃពួកអ្នកបំរើរបស់ទ្រង់ បានបិទភ្ជាប់មកលើពួកគេ ដោយអំណាចពីស្ថានខ្ពស់ ។

៣៦ សូមឲ្យបានបំពេញមកលើពួកគេ ដូចជាមកលើពួកអ្នកទាំងនោះ កាលបុណ្យថ្ងៃ៥០; សូមឲ្យអំណោយទានខាង[ក]ភាសាបាន ចាក់មកលើរាស្ត្ររបស់ទ្រង់ ដូចជា[ខ]អណ្ដាតភ្លើង និងការបកប្រែភាសានោះ។

៣៧ ហើយសូមឲ្យដំណាក់ទ្រង់បានពោរពេញទៅដោយ[ក]សិរីល្អរបស់ទ្រង់ ហាក់ដូចជាដោយខ្យល់បក់គំហុកយ៉ាងខ្លាំង ។

៣៨ សូមដាក់មកលើពួកអ្នកបំរើរបស់ទ្រង់ នូវ[ក]ទីបន្ទាល់អំពីសេចក្ដីសញ្ញា ដើម្បីកាលណាពួកគេចេញទៅ ហើយប្រកាសប្រាប់ពីព្រះបន្ទូលរបស់ទ្រង់ នោះសូមឲ្យពួកគេអាច[ខ]បិទត្រាក្រិត្យវិន័យ ហើយរៀបចំចិត្តនៃពួកបរិសុទ្ធរបស់ទ្រង់ សំរាប់អស់ទាំងសេចក្ដីជំនុំជំរះ ដែលព្រះអង្គនឹងចាត់មក ដោយនូវសេចក្ដីក្រោធរបស់ទ្រង់ ឲ្យមានមកលើបណ្ដាជននៅលើ[គ]ផែនដី ព្រោះតែអំពើរំលងទាំងឡាយរបស់ ពួកគេ សូមកុំឲ្យរាស្ត្ររបស់ទ្រង់រសាយចិត្តនៅថ្ងៃមានទុក្ខខ្វល់ខ្វាយឡើយ ។

៣៩ ហើយទីក្រុងណាដែលពួកអ្នកបំរើរបស់ទ្រង់ចូលទៅ ហើយប្រជាជននៅក្នុងទីក្រុងនោះទទួលទីបន្ទាល់របស់ពួកគេ នោះសូមឲ្យសេចក្ដីសុខសាន្តរបស់ទ្រង់ និងសេចក្ដីសង្គ្រោះរបស់ទ្រង់មានមកលើទីក្រុងនោះ; ប្រយោជន៍ឲ្យពួកគេអាចបានប្រមូលពួកសុចរិត ចេញពីទីក្រុងនោះ ដើម្បីឲ្យពួកគេអាចបានចេញមក[ក]ឯស៊ីយ៉ូន ឬមកឯស្តេកទាំងឡាយរបស់នាង ជាកន្លែងទាំងឡាយនៃការកំណត់ របស់ទ្រង់ ដោយចំរៀងទាំងឡាយអំពីសេចក្ដីអំណរដ៏នៅអស់កល្បអស់កាលជានិច្ច;

៤០ ហើយទាល់តែការណ៍នេះបានសំរេច សូមកុំឲ្យសេចក្ដីជំនុំជំរះរបស់ទ្រង់ធ្លាក់មកលើទីក្រុងនោះឡើយ ។

៤១ ហើយទីក្រុងណាដែលពួកអ្នកបំរើរបស់ទ្រង់ចូលទៅ ហើយប្រជាជននៅក្នុងទីក្រុងនោះមិនទទួលទីបន្ទាល់របស់ពួកគេទេ ហើយ

២៦ *ក* គ. និង ស. ៩៨:២២.
*ខ* ១ ពង្សាវ. ៨:២៩.
៣០ *ក* អេសាយ ២៨:១៧; ម៉ូសាយ ១២:៦; គ. និង ស. ២៩:១៦.
*ខ* ៣ នីហ្វៃ ២១:១៩–២១.
៣២ *ក* ស.ប. នឹម.
៣៤ *ក* រ៉ូម ៣:២៣; ៥:១២. ស.ប. អំពើបាប.
៣៥ *ក* ស.ប. ចាក់ប្រេង.
៣៦ *ក* ស.ប. អំណោយទានខាងភាសា.
*ខ* កិច្ចការ ២:១–៣.
៣៧ *ក* គ. និង ស. ៨៤:៥; ១០៩:១២. ស.ប. សិរីល្អ.
៣៨ *ក* ស.ប. ទីបន្ទាល់.
*ខ* អេសាយ ៨:១៦; គ. និង ស. ១:៨.
*គ* ស.ប. ផែនដី — ការសំអាតផែនដី.
៣៩ *ក* អេសាយ ៣៥:១០.

ពួកអ្នកបំរើរបស់ទ្រង់ព្រមានដល់ពួកគេ ដើម្បីសង្គ្រោះពួកគេឲ្យរួចពីពួជតំណវៀចនេះ នោះសូមឲ្យបានធ្លាក់មកលើទីក្រុងនោះតាមអ្វីដែលបានពោល ដោយសារមាត់នៃពួកព្យាការីទាំងឡាយរបស់ទ្រង់ចុះ ។

៤២ ប៉ុន្តែឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមអង្វរដល់ព្រះអង្គ សូមព្រះអង្គរំដោះពួកអ្នកបំរើរបស់ទ្រង់ឲ្យរួចពីកណ្ដាប់ដៃ របស់ពួកគេ ហើយជំរះពួកគេឲ្យបានស្អាតពីឈាមរបស់ពួកនោះផងចុះ ។

៤៣ ឱព្រះអម្ចាស់អើយ ទូលបង្គំទាំងអស់គ្នាមិនត្រេកអរដោយសារការបំផ្លិចបំផ្លាញដល់មនុស្សទូទៅទាំងឡាយទេ; [ក]ព្រលឹងរបស់ពួកគេ សុទ្ធតែមានតម្លៃនៅចំពោះព្រះអង្គ;

៤៤ ប៉ុន្តែព្រះបន្ទូលរបស់ទ្រង់ត្រូវតែបានសំរេច ។ សូមជួយពួកអ្នកបំរើរបស់ទ្រង់ ដោយ[ក]ព្រះគុណរបស់ទ្រង់ ដើម្បីជួយពួកគេឲ្យនិយាយ ថា៖ ឱព្រះអម្ចាស់អើយ សូមឲ្យបានសំរេចតាមតែព្រះហឫទ័យរបស់ទ្រង់ចុះ ហើយពុំមែនតាមចិត្តទូលបង្គំឡើយ ។

៤៥ ទូលបង្គំដឹងថាព្រះអង្គបានមានព្រះបន្ទូល ដោយសារមាត់នៃពួកព្យាការីទាំងឡាយរបស់ទ្រង់ នូវការគួរស្ញែងខ្លាចទាំងឡាយ អំពី ពួកទុច្ចរិតនៅ[ក]ថ្ងៃចុងក្រោយបង្អស់ — ថាព្រះអង្គនឹងចាក់សេចក្ដីជំនំជំរះរបស់ទ្រង់ ដោយគ្មានកំរិតឡើយ;

៤៦ ហេតុដូច្នេះហើយ ឱព្រះអម្ចាស់អើយ សូមរំដោះរាស្ត្ររបស់ទ្រង់ឲ្យរួចផុតពីការអន្តរាយនៃពួកទុច្ចរិតផងចុះ; សូមបណ្ដាលឲ្យពួកអ្នក បំរើរបស់ទ្រង់អាចបិទត្រាក្រិត្យវិន័យ ហើយចងសេចក្ដីបន្ទាល់ ដើម្បីឲ្យពួកគេអាចបានរៀបចំសំរាប់ថ្ងៃនៃការឆេះឆាប ។

៤៧ ព្រះវរបិតាដ៏បរិសុទ្ធអើយ ទូលបង្គំសូមព្រះអង្គនឹកចាំដល់ពួកអ្នក ដែលត្រូវបានដេញដោយបណ្ដាជននៃឃុំចាកសុន រដ្ឋមិសសួរី ចេញពីដែនដីនៃកេរ្តិ៍មរតករបស់ពួកគេ ហើយសូមបំបាក់ ឱព្រះអម្ចាស់អើយ នូវនឹមនៃសេចក្ដីទុក្ខវេទនានេះដែលបានដាក់មកលើពួកគេ ផង ។

៤៨ ឱព្រះអម្ចាស់អើយ ព្រះអង្គជ្រាបហើយថាពួកគេត្រូវបានសង្កត់សង្កិន ហើយធ្វើទុក្ខយ៉ាងខ្លាំង ដោយពួកមនុស្សទុច្ចរិត; ហើយដួង ចិត្តរបស់ទូលបង្គំទាំងអស់គ្នា[ក]ហូរហៀរដោយក្ដីសោកសៅ ព្រោះតែបន្ទុកដ៏ធ្ងន់ធ្ងរទាំងឡាយរបស់ពួកគេ ។

៤៩ ឱព្រះអម្ចាស់អើយ តើដល់[ក]ពេលណាទៅ ដែលទ្រង់នឹងស៊ូទ្រាំឲ្យរាស្ត្រនេះរងទុក្ខវេទនានេះ ហើយសំរែកទាំងឡាយនៃពួកឥត ទោសរបស់[ខ]ពួកគេ នឹងបន្លឺឡើងទៅដល់ព្រះកាណ៌របស់ទ្រង់ ហើយឈាមរបស់ពួកគេនឹងឡើងទៅជាទីបន្ទាល់នៅចំពោះទ្រង់ ហើយព្រះអង្គមិនសំដែងទីបន្ទាល់របស់ទ្រង់ដើម្បីពួកគេ ?

៥០ ឱព្រះអម្ចាស់អើយ សូមមាន[ក]សេចក្ដីមេត្តាករុណា មកលើពួកមនុស្សកំណាចដែលទុច្ចរិត ដែលបានដេញរាស្ត្ររបស់ទ្រង់ចេញ ប្រយោជន៍ឲ្យពួកគេអាចបានឈប់បង្ហិនបង្ហោច ប្រយោជន៍ឲ្យពួកគេអាចបានប្រែចិត្តពីអំពើបាបរបស់ពួកគេ បើសិនជាអាចមានការ ប្រែចិត្ត ។

៥១ ប៉ុន្តែបើសិនជាពួកគេមិនព្រមទេ ឱព្រះអង្គអើយ សូមលាតព្រះពាហុរបស់ព្រះអង្គ ហើយ[ក]ប្រោសលោះនូវអ្វីដែលទ្រង់បានតាំងជា ស៊ីយ៉ូន ដល់រាស្ត្ររបស់ព្រះអង្គ ។

៥២ ហើយបើសិនជាពុំអាចធ្វើបានទេ សូមកុំឲ្យគតិនៃរាស្ត្ររបស់ទ្រង់អាចបានបរាជ័យនៅចំពោះទ្រង់ឡើយ សូមឲ្យសេចក្ដីខ្ញាល់របស់ ទ្រង់ឆួលឡើង ហើយសេចក្ដីគ្នាន់ក្នាញ់របស់ទ្រង់ធ្លាក់មកលើពួកគេ ប្រយោជន៍ពួកគេអាចបានហិនហោចទាំងឫសទាំងមែក ចេញអស់ ក្រោមមេឃ;

៥៣ ប៉ុន្តែដរាបណាពួកគេព្រមប្រែចិត្ត ព្រះអង្គប្រកបដោយសេចក្ដីមេត្តាករុណា និងសេចក្ដីអាណិតអាសូរ សូមទ្រង់បំបែរសេចក្ដី ក្រោធរបស់ទ្រង់ នៅពេលព្រះអង្គទតទៅលើព្រះភ័ក្ត្រនៃអ្នកដែលទ្រង់បានចាក់ប្រេងតាំង ។

៥៤ ឱព្រះអម្ចាស់អើយ សូមមានសេចក្ដីមេត្តាករុណាទៅលើអស់ទាំងសាសន៍នៅលើផែនដី; សូមមានសេចក្ដីមេត្តាករុណាទៅលើ ពួកអ្នកត្រួតត្រានៃដែនដីរបស់ទូលបង្គំទាំងអស់គ្នា; សូមឲ្យគោលការណ៍ទាំងនោះ ដែលត្រូវបានការពារដោយកិត្តិយស និងកិត្តិនាម គឺ[ក]ធម្មនុញ្ញនៃ ដែនដី ដោយអយ្យកោទាំងឡាយរបស់ទូលបង្គំទាំងអស់គ្នា បានតាំងឡើងជារៀងរាបតទៅ ។

៥៥ សូមនឹកចាំដល់ពួកមហាក្សត្រ ពួកស្ដេច ពួកមានត្រកូលខ្ពស់ និងពួកអ្នកធំនៅលើផែនដី និងអស់ទាំងប្រជាជន និង

៤៣ *ក* ស.ប. ព្រលឹង.
៤៤ *ក* ស.ប. ព្រះគុណ.
៤៥ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
៤៨ *ក* ស.ប. អាណិត.
៤៩ *ក* ទំនុក. ១៣:១–២.
*ខ* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
៥០ *ក* ស.ប. សេចក្ដីមេត្តាករុណា, មេត្តាករុណា.
៥១ *ក* គ. និង ស. ១០០:១៣; ១០៥:២.
៥៤ *ក* ១ ពេត្រុស ២:១៣–១៥; គ. និង ស. ៩៨:៥–៧; ១០១:៧៧, ៨០. ស.ប. រដ្ឋធម្មនុញ្ញ.

សាសនាចក្រ ទាំងឡាយ និងអស់ទាំងមនុស្សក្រីក្រ មនុស្ស
កំសត់ទុគិត និងមនុស្សមានទុក្ខលំបាកនៃផែនដី;
៥៦ សូមឲ្យដួងចិត្តរបស់ពួកគេបានបន្ទន់ នៅពេលពួកអ្នកបំរើ
របស់ទ្រង់នឹងចេញពីដំណាក់ទ្រង់ ឱព្រះយេហូវ៉ាអើយ ដើម្បីទៅ
ថ្លែងទីបន្ទាល់ពីព្រះនាមរបស់ទ្រង់; សូមឲ្យការប្រកាន់របស់ពួក
គេអាចបានរសាត់បាត់ទៅនៅចំពោះសេចក្ដីពិត ហើយសូមឲ្យ
រាស្ត្រ របស់ទ្រង់អាចបានទទួលការគាប់ចិត្តចំពោះភ្នែកនៃមនុស្ស
ទាំងអស់;
៥៧ សូមឲ្យអស់ទាំងចុងបំផុតផែនដីអាចបានដឹងថាទូលបង្គំ
ទាំងអស់គ្នា ជាពួកអ្នកបំរើរបស់ទ្រង់ បានឮសម្លេងរបស់ទ្រង់
ហើយថាទ្រង់ បានចាត់ឲ្យទូលបង្គំទាំងអស់គ្នាទៅ;
៥៨ សូមឲ្យពួកអ្នកបំរើរបស់ទ្រង់ គឺកូនចៅនៃយ៉ាកុប អាចបាន
ប្រមូលពួកសុចរិតចេញពីចំណោមចុងផែនដីអស់ទាំងនេះ
ដើម្បីកសាង ទីក្រុងមួយដ៏បរិសុទ្ធថ្វាយដល់ព្រះនាមទ្រង់ ដូច
ដែលព្រះអង្គបានបញ្ជាដល់ពួកគេ ។
៥៩ ទូលបង្គំទាំងអស់គ្នាសូមឲ្យព្រះអង្គតាំងដល់ស៊ីយ៉ូន នូវ
ស្តេកផ្សេងៗទៀត ក្រៅពីស្តេកនេះ ដែលព្រះអង្គបានតាំង
ប្រយោជន៍ឲ្យ ការប្រមូលនៃរាស្ត្ររបស់ទ្រង់អាចបានរមៀលតទៅ
ដោយអំណាច និងឫទ្ធានុភាពដ៏អស្ចារ្យ សូមឲ្យកិច្ចការរបស់
ទ្រង់អាចបានកាត់យ៉ាងខ្លី ដោយសេចក្ដីសុចរិត ។
៦០ ឥឡូវនេះ ឱព្រះអម្ចាស់អើយ ពាក្យទាំងនេះ ទូលបង្គំទាំង
អស់គ្នាបានទូលនៅចំពោះព្រះអង្គ អំពីវិវរណៈ និងព្រះបញ្ញត្តិទាំង
ឡាយ ដែលព្រះអង្គបានប្រទានដល់ទូលបង្គំទាំងអស់គ្នា ជាពួក
អ្នកដែលរាប់ជាមួយពួកសាសន៍ដទៃ ។
៦១ ប៉ុន្តែព្រះអង្គជ្រាបថា ទ្រង់មានសេចក្ដីស្រឡាញ់ដ៏ខ្លាំង
សំរាប់កូនចៅនៃយ៉ាកុប ដែលត្រូវបានខ្ចាត់ខ្ចាយនៅលើភ្នំទាំង
ឡាយ អស់ជាយូរយារមកហើយ នៅថ្ងៃដែលមេឃមីរស្រទំ
ហើយងងឹត ។
៦២ ហេតុដូច្នេះហើយ ទូលបង្គំទាំងអស់គ្នាសូមឲ្យទ្រង់មាន
សេចក្ដីមេត្តាករុណាមកលើកូនចៅនៃយ៉ាកុប គឺចាប់ពីម៉ោងនេះទៅ
សូមឲ្យក្រុងយេរូសាឡិមអាចបានចាប់ផ្ដើមប្រោសលោះ;
៦៣ ហើយសូមឲ្យនឹមនៃសេវកភាពអាចបានចាប់ផ្ដើមបាក់
ចេញពីវង្សនៃហ្លួងដាវីឌ;
៦៤ ហើយសូមឲ្យកូនចៅនៃយូដាអាចចាប់ផ្ដើមវិលទៅរក
ដែនដីទាំងឡាយ ដែលព្រះអង្គបានប្រទានដល់លោកអ័ប្រាហាំ
ជាអយ្យកោរបស់ ពួកគេ ។
៦៥ ហើយសូមបណ្ដាលសំណល់ទាំងឡាយនៃយ៉ាកុប ដែល
ត្រូវបណ្ដាសា ហើយវាយ ពីព្រោះតែសេចក្ដីរំលងរបស់ពួកគេ
បានប្រែពីភាពព្រៃផ្សៃ និងសាហាវរបស់ពួកគេ ទៅរកភាពពោរពេញ
នៃដំណឹងល្អដ៏នៅអស់កល្បអស់កាលជានិច្ច;
៦៦ សូមឲ្យពួកគេអាចបានដាក់គ្រឿងសស្ត្រាវុធនៃការកំចាយ
ឈាមចុះ ហើយឈប់មានការបះបោរទាំងឡាយរបស់ពួកគេ ។
៦៧ ហើយសូមឲ្យអស់ទាំងសំណល់នៃអ៊ីស្រាអែលដែល
ខ្ចាត់ខ្ចាយទាំងប៉ុន្មាន ដែលត្រូវបានបណ្ដេញទៅដល់ចុងបំផុត
ផែនដី បានស្គាល់ សេចក្ដីពិត ជឿដល់ព្រះមែស៊ី ហើយបាន
ប្រោសលោះពីសេចក្ដីសង្កត់សង្កិន ហើយបានអរសប្បាយនៅ
ចំពោះព្រះអង្គ ។
៦៨ ឱព្រះអម្ចាស់អើយ សូមនឹកចាំដល់ យ៉ូសែប ស៊្មីធ ជុញ៉រ
ជាអ្នកបំរើរបស់ទ្រង់ និងអស់ទាំងសេចក្ដីទុក្ខវេទនា និងសេច
ក្ដីបៀតបៀន ទាំងឡាយរបស់លោក — ពីអ្វីដែលលោកបាន
ធ្វើសេចក្ដីសញ្ញាជាមួយព្រះយេហូវ៉ា ហើយសច្ចាដល់ព្រះអង្គ
ជាព្រះដ៏មហិទ្ធិឫទ្ធិ នៃយ៉ាកុប — និងព្រះបញ្ញត្តិទាំងឡាយ
ដែលទ្រង់បានប្រទានដល់លោក ហើយថាលោកបានខំខ្នះខ្នែង
ដើម្បីប្រព្រឹត្តតាមព្រះហឫទ័យ របស់ទ្រង់ ។
៦៩ ឱព្រះអម្ចាស់អើយ សូមមានសេចក្ដីមេត្តាករុណាដល់
ភរិយា និងកូនចៅរបស់លោកផង ប្រយោជន៍ឲ្យពួកគេអាចបាន

៥៦ *ក* ស.ប. សេចក្ដីពិត.
៥៧ *ក* គ. និង ស. ២០:១៦;
៧៦:២២–២៤.
៥៩ *ក* អេសាយ ៥៤:២.
*ខ* ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*គ* ម៉ាថាយ ២៤:២២.
៦០ *ក* ១ នីហ្វៃ ១៣:១–៣២;
១៥:១៣–១៨.
៦២ *ក* ៣ នីហ្វៃ ២០:២៩.
ស.ប. ក្រុងយេរូសាឡិម.
៦៣ *ក* ស.ប. ដាវីឌ.
៦៤ *ក* សាការី ១២:៦–៩;
ម៉ាឡាគី ៣:៤;
គ. និង ស. ១៣៣:១៣, ៣៥.
ស.ប. យូដា.
*ខ* លោកុ. ១៧:១–៨.
ស.ប. ដែនដីសន្យា.
៦៥ *ក* ២ នីហ្វៃ ៣០:៣;
អាលម៉ា ៤៦:២៣–២៤;
៣ នីហ្វៃ ២០:១៥–២១;
គ. និង ស. ១៩:២៧.
*ខ* ២ នីហ្វៃ ៣០:៦;
៣ នីហ្វៃ ២១:២០–២២.
ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
៦៧ *ក* ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
៦៨ *ក* ស.ប. សេចក្ដីសញ្ញា.
*ខ* ស.ប. ព្រះយេហូវ៉ា.

ដំកើងឡើង នៅក្នុងវត្តមានរបស់ទ្រង់ ហើយបានរក្សាទុក ដោយព្រះហស្ដរបស់ទ្រង់ដែលរក្សាបីបាច់ ។

៧០ សូមមានសេចក្ដីមេត្តាករុណាមកលើ[ក]បងប្អូនជិតស្និទរបស់ពួកគេ ប្រយោជន៍ឲ្យការប្រកាន់ទាំងឡាយរបស់ពួកគេអាចបានបំបាក់ ចោល ហើយបានបង្ហូរយកទៅដូចជាទឹកជន់ ប្រយោជន៍ឲ្យពួកគេអាចបានប្រែចិត្តជឿ ហើយបានប្រោសលោះជាមួយនិងពួកអ៊ីស្រាអែល ហើយដឹងថាព្រះអង្គជាព្រះ ។

៧១ ឱព្រះអម្ចាស់អើយ សូមនឹកចាំដល់ពួកប្រធាន គឺអស់ទាំងពួកប្រធាននៃសាសនាចក្ររបស់ទ្រង់ ប្រយោជន៍ឲ្យព្រះហស្ដស្ដាំរបស់ទ្រង់ អាចដំកើងពួកគេឡើង ជាមួយនិងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងបងប្អូនជិតស្និទរបស់ពួកគេផង ប្រយោជន៍ឲ្យឈ្មោះពួកគេ អាចបានចងចាំ និងនឹកចាំរហូតដល់អស់កល្បអស់កាលជានិច្ច ពីតំណមួយទៅតំណមួយទៀត ។

៧២ ឱព្រះអម្ចាស់អើយ សូមនឹកចាំដល់អស់ទាំងសាសនាចក្ររបស់ទ្រង់ ជាមួយនិងក្រុមគ្រួសាររបស់ពួកគេ ហើយនិងអស់ទាំងបងប្អូន ជិតស្និទរបស់ពួកគេ ជាមួយនិងពួកអ្នកឈឺ និងពួកអ្នកមានទុក្ខលំបាករបស់ពួកគេ ជាមួយនិងអស់ទាំងមនុស្សក្រីក្រ និងពួកស្លូតបូតនៅ លើផែនដីផង; ប្រយោជន៍ឲ្យនគរ ដែលព្រះអង្គបានតាំងឡើង ដោយឥតមានដៃអ្នកណាធ្វើ អាចបានត្រឡប់ទៅជាភ្នំដ៏ធំមួយ ហើយបាន ពេញផែនដីទាំងមូល;

៧៣ ប្រយោជន៍ឲ្យសាសនាចក្ររបស់ទ្រង់អាចបានចេញមកពីទីរហោស្ថាននៃសេចក្ដីងងឹត ហើយភ្លឺឡើងស្រស់ដូច[ក]ជាព្រះច័ន្ទភ្លឺត្រចះ ដូចជាព្រះអាទិត្យ ហើយគួរស្ញែងខ្លាចដូចជាពលទ័ពមានទាំងទង់ជ័យផង;

៧៤ ហើយបានតែងខ្លួនដូចជាប្រពន្ធថ្មោងថ្មីសំរាប់ថ្ងៃនោះ នៅពេលព្រះអង្គនឹងបើកបង្ហាញផ្ទៃមេឃ ហើយបណ្ដាលឲ្យភ្នំទាំងឡាយ [ក]ហូរចុះមកពីវត្តមានរបស់ទ្រង់ ហើយ[ខ]ច្រកភ្នំទាំងឡាយនឹងបានលើកឡើង កន្លែងរដិបរដុបនឹងបានរាបស្មើ ដើម្បីឲ្យសិរីល្អរបស់ទ្រង់បាន ពេញសព្វផែនដី;

៧៥ កាលត្រែនឹងបន្លឺសូរសំរាប់ពួកអ្នកស្លាប់ សូមឲ្យទូលបង្គំទាំងអស់គ្នា[ក]បានលើកឡើងទៅក្នុងពពក ទៅជួបព្រះអង្គ ប្រយោជន៍ឲ្យទូលបង្គំទាំងអស់គ្នា អាចបាននៅជុំព្រះអម្ចាស់;

៧៦ សូមឲ្យសំលៀកបំពាក់របស់ទូលបង្គំទាំងអស់គ្នាអាចបានជ្រះស្អាត សូមឲ្យទូលបង្គំទាំងអស់គ្នាអាចបានពាក់ដោយ[ក]សំលៀកបំពាក់ នៃសេចក្ដីសុចរិត ទាំងកាន់ធាងចាកនៅដៃរបស់ទូលបង្គំទាំងអស់គ្នា ហើយ[ខ]មកុដនៃសិរីល្អ[គ]នៅលើក្បាលរបស់ទូលបង្គំទាំងអស់គ្នា ហើយ[ឃ]ត្រូវបានសេចក្ដីអំណរដ៏នៅអស់កល្បជានិច្ច សំរាប់អស់ទាំងសេចក្ដីទុក្ខលំបាកទាំងឡាយរបស់ទូលបង្គំទាំងអស់គ្នា ។

៧៧ ឱព្រះអម្ចាស់ជាព្រះដ៏មហិទ្ធិឫទ្ធិអើយ សូមឮសំណូមពរទាំងឡាយរបស់ទូលបង្គំទាំងអស់គ្នាផង ហើយឆ្លើយតបទូលបង្គំទាំងអស់គ្នា ពីស្ថានសួគ៌ ជាទីលំនៅដ៏បរិសុទ្ធរបស់ទ្រង់ ជាកន្លែងដែលទ្រង់គង់លើបល្ល័ង្ក ដោយ[ក]សិរីល្អ កិត្តិនាម ចេស្ដាឫទ្ធានុភាព កម្លាំង អំណាច សេចក្ដីពិត សេចក្ដីយុត្តិធម៌ សេចក្ដីជំនុំជំរះ សេចក្ដីមេត្តាករុណា និងការនិរន្តនៃភាពពោរពេញពីភាពអស់កល្បអស់កាលជានិច្ច ទៅភាពអស់កល្ប អស់កាលជានិច្ច ។

៧៨ ឱសូមឮ ឱសូមឮ ឱសូមឮទូលបង្គំទាំងអស់គ្នា ឱព្រះអម្ចាស់អើយ! ហើយឆ្លើយតបនូវសំណូមពរទាំងនេះ ហើយទទួលការថ្វាយ ដំណាក់នេះដល់ព្រះអង្គ ជាស្នាដៃរបស់ទូលបង្គំដែលទូលបង្គំទាំងអស់គ្នាបានសង់ថ្វាយដល់ព្រះនាមរបស់ទ្រង់;

៧៩ ហើយព្រមទាំងសាសនាចក្រនេះផង ដើម្បីដាក់ព្រះនាមរបស់ទ្រង់ខាងលើ ។ ហើយសូមជួយទូលបង្គំទាំងអស់គ្នា ដោយព្រះចេស្ដា នៃព្រះវិញ្ញាណរបស់ទ្រង់ ដើម្បីឲ្យទូលបង្គំទាំងអស់គ្នា អាចពង្រួមសម្លេងរបស់ទូលបង្គំទាំងអស់គ្នា ជាមួយ[ក]នឹងពួកសេរាភីមដ៏ភ្លឺថ្លានៅ ជុំវិញបល្ល័ង្ករបស់ទ្រង់ ដោយការប្រកាសនូវពាក្យសរសើរដំកើង ដោយច្រៀងហូសាណាដល់ព្រះ និង[ខ]កូនចៀម!

៨០ ហើយសូមឲ្យពួកអ្នកទាំងឡាយដែលទ្រង់បានតាំង [ក]បានបំពាក់ដោយសេចក្ដីសង្គ្រោះ ហើយសូមឲ្យពួកបរិសុទ្ធរបស់ទ្រង់ស្រែក ឡើងដោយអំណរ ។ អាម៉ែន និងអាម៉ែន ៕

៧០ *ក* ក.ន. ញាតិសន្តានជិតស្និទ.
៧២ *ក* ដានី. ២:៤៤–៤៥;
គ. និង ស. ៦៥:២.
៧៣ *ក* បទចំរៀង. ៦:១០;
គ. និង ស. ៥:១៤; ១០៥:៣១.
៧៤ *ក* គ. និង ស. ១៣៣:២១–២២, ៤០.
*ខ* អេសាយ ៤០:៤; លូកា ៣:៥;
គ. និង ស. ៤៩:២៣.
៧៥ *ក* ១ ថែស្សា. ៤:១៧.
៧៦ *ក* វិវរ. ៧:១៣–១៥;
២ នីហ្វៃ ៩:១៤.
*ខ* ស.ប. មកុដ; ភាពដំកើងឡើង.
*គ* ស.ប. សេចក្ដីអំណរ.
*ឃ* ហេព្រើរ ១២:១–១១;
គ. និង ស. ៥៨:៤.
៧៧ *ក* ស.ប. សិរីល្អ.
៧៩ *ក* អេសាយ ៦:១–២.
*ខ* ស.ប. កូនចៀមនៃព្រះ.
៨០ *ក* ទំនុក. ១៣២:១៦.

## កណ្ឌទី ១១០

*ការនិមិត្តទាំងឡាយដែលបានសម្ដែងដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី និង អូលីវើរ ខៅឌើរី នៅក្នុងព្រះវិហារឯក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី៣ ខែមេសា ឆ្នាំ១៨៣៦ (*History of the Church*, ២:៤៣៥–៤៣៦)* ។ *នេះជាគ្រានៃការប្រជុំនៅថ្ងៃឈប់សំរាក ។ ព្យាការីកត់បុព្វកថាចំពោះបញ្ជីរបស់លោក អំពីការសំដែងទាំងឡាយ ដោយពាក្យទាំងនេះថា៖ «នៅពេលរសៀល ខ្ញុំបានជួយពួកប្រធានឯទៀត ក្នុងការចែកអាហាររបស់ព្រះអម្ចាស់ ដល់សាសនាចក្រ ដោយបានទទួលអាហារពីពួក១២នាក់ ដែលមានឯកសិទ្ធិធ្វើការ នៅឯតុដ៏ពិសិដ្ឋថ្ងៃនេះ ។ បន្ទាប់ពីបានប្រតិបត្តិកិច្ចការនេះដល់ពួកបងប្អូនរបស់ខ្ញុំក្នុងសាសនារួចហើយ នោះខ្ញុំបានទៅឯវេទិកា ដោយមានវាំងននបិទ ហើយក្រាបចុះជាមួយអូលីវើរ ក្នុងការអធិស្ឋានដ៏មុតមាំ និងស្ងាត់ ។ បន្ទាប់ពីបានក្រោកពីអធិស្ឋាននោះស្រាប់ តែមានការនិមិត្តមួយបើកឲ្យយើងទាំងពីរនាក់ឃើញ» (*History of the Church*, ២:៤៣៥*) ។

*១–១០, ព្រះអម្ចាស់យេហូវ៉ាលេចមកក្នុងសិរីល្អ ហើយទទួលព្រះវិហារខឺតឡង់ជាដំណាក់របស់ទ្រង់; ១១–១២, លោកម៉ូសេ និងលោក អេលីយ៉ាសលេចមករៀងៗខ្លួន ហើយប្រគល់កូនសោ និងគ្រាកាន់កាប់ត្រួតត្រាទាំងឡាយរបស់ពួកគេ; ១៣–១៦, លោកអេលីយ៉ា វិលមកវិញ ហើយប្រគល់កូនសោទាំងឡាយ និងគ្រាកាន់កាប់ត្រួតត្រារបស់លោក ដូចជាបានសន្យាទុក ដោយលោកម៉ាឡាគី ។*

[ក]វស្បូត្រូវបានបើកពីគំនិតរបស់ពួកយើង ហើយ[ខ]ភ្នែកនៃយោបល់របស់ពួកយើងត្រូវបានបើកឡើង ។

២ យើងបានឃើញព្រះអម្ចាស់ ទ្រង់ឈរនៅលើរបាំងផ្នែកវេទិកា នៅចំពោះយើង; ហើយនៅក្រោមព្រះបាទរបស់ទ្រង់ មានកំរាលធ្វើពី មាសសុទ្ធ មានពណ៌ដូចជាត្បូងឃ្មុំ ។

៣ [ក]ព្រះនេត្ររបស់ទ្រង់ដូចជាអណ្ដាតភ្លើង; ព្រះកេសារបស់ទ្រង់ស ដូចជាហិមៈសុទ្ធ; [ខ]ព្រះភ័ក្ត្ររបស់ទ្រង់ភ្លឺជាងពន្លឺថ្ងៃ; ហើយ[គ]សំឡេង របស់ទ្រង់ ដូចជាសូរនៃទឹកច្រើន គឺជាសម្លេងនៃ[ឃ]ព្រះយេហូវ៉ាមានព្រះបន្ទូលថា៖

៤ យើងជា[ក]ដើម ហើយជាចុង; យើងជាអង្គដែលមាន[ខ]ព្រះជន្មរស់នៅ យើងជាអង្គដែលត្រូវបានស្លាប់; យើងជា[គ]ព្រះគាំទ្ររបស់អ្នក ជាមួយ ព្រះវរបិតា ។

៥ មើលចុះ អំពើបាបទាំងឡាយរបស់អ្នកត្រូវបាន[ក]អត់ទោសឲ្យហើយ; អ្នកត្រូវបានជ្រះស្អាតនៅចំពោះយើង; ហេតុដូច្នេះហើយ ចូរងើបមុខឡើង ហើយអរសប្បាយរីករាយចុះ ។

៦ ចូរឲ្យចិត្តនៃបងប្អូនអ្នកក្នុងសាសនាបានអរសប្បាយរីករាយចុះ ហើយចូរឲ្យចិត្តនៃអស់ទាំងរាស្ត្ររបស់យើងបានអរសប្បាយរីករាយ ដែលបាន[ក]សង់ដំណាក់នេះថ្វាយដល់ព្រះនាមរបស់យើង ដោយអស់ពីកម្លាំងរបស់ពួកគេ ។

៧ ត្បិតមើលចុះ យើងបាន[ក]ទទួល[ខ]ដំណាក់នេះហើយ ហើយព្រះនាមរបស់យើងនឹងស្ថិតនៅទីនេះ; ហើយយើងនឹងសំដែងកាយយើង ដល់រាស្ត្ររបស់យើង នៅក្នុងដំណាក់នេះ ដោយសេចក្ដីមេត្តាករុណា ។

៨ មែនហើយ យើងនឹង[ក]លេចមកឯពួកអ្នកបំរើរបស់យើង ហើយមានបន្ទូលទៅកាន់ពួកគេ ដោយសម្លេងរបស់យើងផ្ទាល់ បើសិនជា រាស្ត្រយើងនឹងកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង ហើយមិន[ខ]បង្ខូចដំណាក់[គ]ដ៏បរិសុទ្ធនេះ ។

៩ មែនហើយ គឺចិត្តនៃមនុស្ស[ក]រាប់ពាន់រាប់ម៉ឺននាក់នឹងបានអរសប្បាយរីករាយ ដោយព្រោះតែព្រះពរទាំងឡាយ ដែលនឹងបានចាក់ ចេញមក ព្រមទាំង[ខ]អំណោយទានពិសិដ្ឋ ដែលពួកអ្នកបំរើរបស់យើងបានទទួលនៅក្នុងដំណាក់នេះ ។

១០ ហើយការល្បីល្បាញអំពីដំណាក់នេះនឹងរាលដាលទៅ

---

**១១០** ១*ក* ស.ប. វាំងនន.
*ខ* គ. និង ស. ៧៦:១២, ១៩; ១៣៦:៣២; ១៣៨:១១.
៣ *ក* វិវរ. ១:១៤.
*ខ* វិវរ. ១:១៦; យ.ស. — ប្រវត្តិ ១:១៧.
*គ* អេសេ. ៤៣:២; វិវរ. ១:១៥; គ. និង ស. ១៣៣:២១–២២.
*ឃ* ស.ប. ព្រះយេហូវ៉ា.
៤ *ក* ស.ប. កូនច្បង.
*ខ* ចោទិ. ៥:២៤.
*គ* ស.ប. ព្រះដ៏គាំទ្រ.
៥ *ក* ស.ប. អត់ទោស, អភ័យទោស.
៦ *ក* គ. និង ស. ១០៩:៤–៥.
៧ *ក* ២ របា. ៧:១៦.
*ខ* ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់.
៨ *ក* គ. និង ស. ៥០:៤៥.
*ខ* គ. និង ស. ៩៧:១៥–១៧.
*គ* ស.ប. បរិសុទ្ធ.
៩ *ក* លោកុ. ១២:១–៣; គ. និង ស. ៣៩:១៥; អ័ប្រា. ២:៨–១១.
*ខ* គ. និង ស. ៩៥:៨. ស.ប. អំណោយទានពិសិដ្ឋ.

ដល់ដែនដីឆ្ងាយៗ; ហើយនេះគឺជាការចាប់ផ្ដើមនូវព្រះពរ ដែលនឹង បានចាក់មកលើក្បាលនៃរាស្ត្ររបស់យើង ។ គឺដូច្នោះមែន ។ អាម៉ែន ។

១១ បន្ទាប់ពីការនិមិត្តនេះបិទទៅ នោះស្រាប់តែផ្ទៃមេឃបានបើកដល់យើងម្ដងទៀត; ហើយលោកម៉ូសេបានលេចមកចំពោះយើង ហើយបានប្រគល់ដល់យើងនូវកូនសោទាំងឡាយនៃការប្រមូលសាសន៍អ៊ីស្រាអែល ពីទិសទាំងបួននៃផែនដី ហើយនិងការនាំពូជដប់ អំបូរចេញពីដែនដីខាងជើងមក ។

១២ បន្ទាប់មក លោកអេលីយ៉ាសបានលេចមក ហើយបានប្រគល់គ្រាកាន់កាប់ត្រួតត្រា នៃដំណឹងល្អរបស់លោកអ័ប្រាហាំ ដោយប្រាប់ថា នៅក្នុងយើង និងពូជរបស់យើង នោះអស់ទាំងតំណមនុស្សបន្ទាប់ពីយើងមក នឹងបានពរ ។

១៣ បន្ទាប់ពីការនិមិត្តបានបិទទៅ នោះមានការនិមិត្តដ៏ធំ និងរុងរឿងមួយទៀត បានបើកមកលើយើង; ព្រោះលោកអេលីយ៉ាជាព្យាការី ដែលបានយកទៅស្ថានសួគ៌ ដោយមិនបានភ្លក់សេចក្ដីស្លាប់ បានឈរនៅចំពោះយើង ហើយបាននិយាយថា៖

១៤ មើលចុះ ពេលវេលាបានមកដល់ពេញលេញហើយ ដែលបានពោលដោយមាត់នៃលោកម៉ាឡាគី — ដោយធ្វើទីបន្ទាល់ថា លោក [អេលីយ៉ា] នឹងត្រូវបានចាត់ឲ្យមកមុនថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចនៃព្រះអម្ចាស់នឹងមកដល់ —

១៥ ដើម្បីបង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុក ក្រែងផែនដីទាំងមូលនឹងត្រូវវាយដោយសេចក្ដីបណ្ដាសា —

១៦ ហេតុដូច្នេះហើយ កូនសោទាំងឡាយនៃគ្រាកាន់កាប់ត្រួតត្រានេះ ត្រូវបានប្រគល់ទៅក្នុងដៃរបស់អ្នក; ហើយដោយសារការណ៍ នេះ ទើបអ្នករាល់គ្នាអាចបានដឹងថាថ្ងៃដ៏ធំ និងគួរស្ញែងខ្លាចនៃព្រះអម្ចាស់ជិតមកដល់ហើយ គឺនៅមាត់ទ្វារ ។

## កណ្ឌទី ១១១

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងសាឡិម រដ្ឋម៉ាស្សាជូសសែត្ស ថ្ងៃទី៦ ខែសីហា ឆ្នាំ១៨៣៦ (*History of the Church*, ២:៤៦៥–៤៦៦)* ។ *នៅគ្រានេះ ពួកមេដឹកនាំសាសនាចក្រត្រូវជាប់បំណុលជាច្រើន ដោយព្រោះ តែការងារបំរើរបស់ពួកគេ ។ ដោយបានឮថាមានប្រាក់ចំនួនច្រើននៅក្រុងសាឡិម រដ្ឋម៉ាស្សាជូសសែត្ស ដែលពួកគេអាចយកបាន ទើប ព្យាការី, ស៊ីឌនី រិកដុន, ហៃរុម ស្ម៊ីធ, និង អូលីវើរ ខៅឌើរី បានធ្វើដំណើរពីក្រុងខឺតឡង់ រដ្ឋអូហៃអូ ដើម្បីទៅស៊ើបមើលការរាយ ការណ៍នេះ ព្រមទាំងទៅផ្សាយដំណឹងល្អផង ។ ពួកបងប្អូនក្នុងសាសនាបានសំរេចកិច្ចការនៃសាសនាចក្រ ហើយបានផ្សាយសាសនា ខ្លះៗ ។ នៅពេលបានឃើញថាគ្មានប្រាក់ឯណាដល់ពួកគេ ទើបពួកគេវិលទៅក្រុងខឺតឡង់វិញ ។ ប្រការសំខាន់ៗដ៏ក្រៃល អំពីព្រឹត្តិ ការណ៍ ត្រូវបានថ្លែងប្រាប់ នៅក្នុងពាក្យពេចន៍នៃវិវរណៈនេះ ។*

*១–៥, ព្រះអម្ចាស់ទ្រង់ថែរក្សានូវសេចក្ដីត្រូវការខាងសាច់ឈាមរបស់ពួកអ្នកបំរើរបស់ទ្រង់; ៦–១១, ទ្រង់នឹងបង្ហាញសេចក្ដីមេត្តា ករុណាដល់ស៊ីយ៉ូន ហើយរៀបចំគ្រប់អ្វីៗទាំងអស់ សំរាប់សេចក្ដីល្អដល់ពួកអ្នកបំរើរបស់ទ្រង់ ។*

១ យើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក មិនមែនមិនសព្វព្រះហឫទ័យប៉ុន្មានទេក្នុងការធ្វើដំណើរនេះ សូម្បីតែការចំកួតរបស់អ្នកក៏ដោយ ។

២ យើងមានទ្រព្យសម្បត្តិជាច្រើននៅក្នុងទីក្រុងនេះសំរាប់អ្នក សំរាប់ផលប្រយោជន៍ដល់ស៊ីយ៉ូន និងមនុស្សជាច្រើន នៅក្នុង

១០ *ក* គ. និង ស. ១០៥:១២.
១១ *ក* ស.ប. ការនិមិត្ត.
*ខ* ម៉ាថាយ ១៧:៣.
*គ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ឃ* យ៉ាកុប ៦:២; គ. និង ស. ២៩:៧.
ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ង* គ. និង ស. ១៣៣:២៦–៣២.
ស.ប. អ៊ីស្រាអែល — ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់.
១២ *ក* ស.ប. អេលីយ៉ាស.
*ខ* ស.ប. គ្រាកាន់កាប់ត្រួតត្រា.
*គ* កាឡាទី ៣:៦–២៩.
ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.
១៣ *ក* ស.ប. អេលីយ៉ា.
*ខ* ស.ប. ពួកអ្នកដែលបានផ្លាស់ប្រែរូប.
១៥ *ក* យ.ស. — ប្រវត្តិ ១:៣៨–៣៩.
ស.ប. ពង្សាវតារ;
សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់.
១៦ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.

ទីក្រុងនេះ ដែលយើងនឹងប្រមូលនៅពេលកំណត់ សំរាប់ផលប្រយោជន៍ដល់ស៊ីយ៉ូន តាមរយៈគ្រឿងឧបករណ៍របស់អ្នក ។

៣ ហេតុដូច្នេះហើយ ជាការចាំបាច់ ដែលអ្នកត្រូវរាក់ទាក់ជាមួយមនុស្សនៅក្នុងទីក្រុងនេះ តាមដែលអ្នកនឹងត្រូវបានណែនាំ ហើយតាម ដែលនឹងបានប្រទានដល់អ្នក ។

៤ ហើយហេតុការណ៍នឹងកើតឡើង នៅពេលកំណត់ថា យើងនឹងប្រទានទីក្រុងនេះទៅក្នុងកណ្ដាប់ដៃអ្នក ទើបអ្នកនឹងមានអំណាចលើ ទីក្រុង ដរាបណាដែលពួកគេនឹងមិនរកឃើញផ្នែកសម្ងាត់ទាំងឡាយរបស់អ្នក; ហើយទ្រព្យនៃទីក្រុង ជាមាស និងប្រាក់ នឹងទៅជា របស់ផងអ្នក ។

៥ ចូរកុំអំពល់ខ្លួនអំពីបំណុលទាំងឡាយរបស់អ្នកឡើយ ព្រោះយើងនឹងប្រទានអំណាចដល់អ្នកឲ្យសងបំណុលទាំងឡាយ ។

៦ ចូរកុំអំពល់ខ្លួនអំពីស៊ីយ៉ូនឡើយ ព្រោះយើងនឹងមានសេចក្ដីមេត្តាករុណាដល់នាង ។

៧ ចូរនៅទីនេះ និងនៅភូមិភាគជុំវិញនេះចុះ;

៨ ហើយនៅកន្លែងណាដែលយើងសព្វព្រះហឫទ័យឲ្យអ្នកនៅភាគច្រើន នោះនឹងត្រូវបានប្រាប់ដល់អ្នក ដោយសេចក្ដីសុខសាន្ត និងព្រះចេស្ដានៃព្រះវិញ្ញាណរបស់យើង ដែលនឹងហូរទៅរកអ្នក ។

៩ នៅកន្លែងនេះ អ្នកអាចបានដោយជួល ។ ហើយចូរខំសាកសួរពីបណ្ដាជនពីបុរាណកាល និងពួកអ្នកដែលរកឃើញទីក្រុងនេះ;

១០ ត្បិតនៅក្នុងទីក្រុងនេះ មានទ្រព្យសម្បត្តិលើសទៅទៀតសំរាប់អ្នក ។

១១ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាមានប្រាជ្ញាដូចជាពស់ តែឥតបាប; ហើយយើងនឹងរៀបចំគ្រប់អ្វីៗទាំងអស់ សំរាប់សេចក្ដីល្អដល់ អ្នក យ៉ាងលឿនតាមដែលអ្នកអាចទទួលរបស់ទាំងនោះបាន ។ អាម៉ែន ៕

## កណ្ឌទី ១១២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី ចំពោះ ថូម៉ាស ប៊ី ម៉ាស នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៨៣៧ (*History of the Church*, ២:៤៩៩–៥០១) ។ វិវរណៈនេះមានព្រះបន្ទូលដែលព្រះអម្ចាស់មានចំពោះ ថូម៉ាស ប៊ី ម៉ាស ស្ដីអំពីពួកសាវក១២នាក់នៃកូនចៀម ។ ព្យាការីកត់ថាវិវរណៈនេះត្រូវបានទទួល នៅថ្ងៃដែលដំណឹងល្អបានផ្សាយ មុនដំបូង នៅប្រទេសអង់គ្លេស ។ នៅគ្រានោះ ថូម៉ាស ប៊ី ម៉ាស ត្រូវជាប្រធាននៃក្រុមសាវក១២នាក់ ។*

*១–១០, ពួក១២នាក់ត្រូវបញ្ជូនដំណឹងល្អ ហើយបន្លឺសម្លេងព្រមានដល់អស់ទាំងសាសន៍ និងប្រជាជន; ១១–១៥, ពួកគេត្រូវផ្ទុកឈើឆ្កាង របស់ខ្លួន ដើរតាមព្រះយេស៊ូវ ហើយឲ្យចំណីដល់ចៀមរបស់ទ្រង់; ១៦–២០, អស់អ្នកណាដែលទទួលគណៈប្រធានទីមួយ នោះទទួល ព្រះអម្ចាស់ដែរ; ២១–២៩, សេចក្ដីងងឹតគ្របដណ្ដប់ផែនដី ហើយមានតែពួកអ្នកដែលជឿ ហើយទទួលបុណ្យជ្រមុជទឹកទេ ដែលនឹង បានសង្គ្រោះ; ៣០–៣៤, គណៈប្រធានទីមួយ និងពួក១២នាក់ កាន់កូនសោទាំងឡាយនៃគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក ថូម៉ាស ជាអ្នកបំរើរបស់យើងដូច្នេះថា៖ យើងបានឮបទអធិស្ឋានទាំងឡាយ របស់អ្នកហើយ ហើយការដាក់ទានទាំងឡាយរបស់អ្នក បានឡើងមកជាការរំឭកនៅចំពោះយើង ជំនួសពួកអ្នកទាំងនោះ ដែលជាបង ប្អូនរបស់អ្នកក្នុងសាសនា ដែលត្រូវបានរើស ដើម្បីថ្លែងទីបន្ទាល់ពីព្រះនាមរបស់យើង ហើយដើម្បីចាត់ទីបន្ទាល់របស់យើងឲ្យទៅទី ឆ្ងាយ ក្នុងចំណោមគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន ហើយត្រូវបានតែងតាំង តាមរយៈឧបករណ៍នៃពួកអ្នកបំរើរបស់យើង ។

២ យើងប្រាប់អ្នកជាប្រាកដថា មានការណ៍បន្តិចបន្តួចនៅក្នុងចិត្តរបស់អ្នក ហើយនៅនឹងអ្នក ដែលយើងជាព្រះអម្ចាស់មិនសព្វព្រះ ហឫទ័យ ។

៣ ទោះជាយ៉ាងណាក៏ដោយ ដរាបណាអ្នកបានបន្ទាបខ្លួន

១១១ ៥*ក* គ. និង ស. ៦៤:២៧–២៩.
៨ *ក* គ. និង ស. ២៧:១៦.
ស.ប. សេចក្ដីសុខសាន្ត.
១១ *ក* ម៉ាថាយ ១០:១៦.
*ខ* រ៉ូម ៨:២៨;
គ. និង ស. ៩០:២៤; ១០០:១៥.
១១២ ១*ក* កិច្ចការ ១០:៤.
*ខ* គ. និង ស. ១៨:២៨.
៣ *ក* ម៉ាថាយ ២៣:១២;
លូកា ១៤:១១.

នោះអ្នកនឹងបានដំកើងឡើង; ហេតុដូច្នេះហើយ អំពើបាបទាំង
អស់របស់អ្នក ត្រូវបានអត់ទោសឲ្យហើយ ។
៤ ចូរឲ្យមានសង្ឃឹមនៅចំពោះព្រះភ័ក្ត្ររបស់យើងចុះ; ហើយ
អ្នកនឹងត្រូវថ្លែងទីបន្ទាល់ពីព្រះនាមរបស់យើង មិនគ្រាន់តែដល់
ពួកសាសន៍ដទៃប៉ុណ្ណោះទេ ប៉ុន្តែដល់ពួកសាសន៍យូដាផង; ហើយ
អ្នកនឹងត្រូវបញ្ជូនព្រះបន្ទូលរបស់យើងទៅដល់ចុងបំផុតផែនដី ។
៥ ហេតុដូច្នេះហើយ ចូរខំប្រយុទ្ធ ចាប់តាំងពីព្រលឹមទៅដល់
ព្រលឹម; ហើយជារៀងរាល់ថ្ងៃ ចូរបន្លឺសម្លេងព្រមានរបស់
អ្នកចេញទៅ ហើយកាលពេលយប់មកដល់ ចូរកុំបណ្ដោយឲ្យ
បណ្ដាជននៅលើផែនដីលង់លក់ឡើយ ព្រោះតែពាក្យពេចន៍
របស់អ្នក ។
៦ ចូរឲ្យទីលំនៅរបស់អ្នកបានស្គាល់នៅក្នុងស៊ីយ៉ូន ហើយចូរកុំ
ដូរផ្ទះឡើយ; ត្បិតយើងជាព្រះអម្ចាស់ មានកិច្ចការដ៏ធំសំរាប់ឲ្យ
អ្នក ប្រតិបត្តិ ក្នុងការផ្សាយព្រះនាមរបស់យើង នៅក្នុង
ចំណោមកូនចៅមនុស្ស ។
៧ ហេតុដូច្នេះហើយ ចូរក្រវាត់ចង្កេះសំរាប់កិច្ចការចុះ ។
ចូរឲ្យជើងអ្នកបានពាក់ស្បែកជើងផង ព្រោះអ្នកត្រូវបានរើសហើយ
ហើយផ្លូវរបស់អ្នកនៅចំណោមភ្នំទាំងឡាយ និងនៅចំណោម
សាសន៍ជាច្រើន ។
៨ ហើយដោយសារពាក្យសំដីរបស់អ្នក ទើបពួកអ្នក
ខ្ពង់ខ្ពស់ជាច្រើនត្រូវបានបន្ទាបចុះ ហើយដោយសារពាក្យសំដី
របស់អ្នក ទើបពួក អ្នកទាបត្រូវបានដំកើងឡើង ។
៩ សម្លេងរបស់អ្នកនឹងទៅជាការបន្ទោសដល់អ្នករំលងច្បាប់
ហើយដោយសារការបន្ទោសរបស់អ្នក ចូរឲ្យអណ្ដាតនៃពួកអ្នក
និយាយ ដើមគេឈប់ពីការខូចអាក្រក់ចុះ ។
១០ ចូរមានចិត្តរាបសា; ហើយព្រះអម្ចាស់ជាព្រះរបស់អ្នកនឹង
ដឹកដៃអ្នក ហើយប្រទានចម្លើយដល់បទអធិស្ឋានទាំងឡាយ
របស់អ្នក ។
១១ យើងជ្រាបនូវចិត្តរបស់អ្នកហើយ ហើយបានឮបទអធិស្ឋាន
ទាំងឡាយដែលអ្នកមានអំពីបងប្អូនរបស់អ្នកក្នុងសាសនា ។ ចូរកុំ
បង្ហាញសេចក្ដីស្រឡាញ់ដល់ពួកគេលើសជាងមនុស្សឯទៀតឡើយ
ប៉ុន្តែចូរឲ្យអ្នកមានសេចក្ដីស្រឡាញ់ដល់ពួកគេ ដូចជាដល់ខ្លួន
ហើយចូរមានសេចក្ដីស្រឡាញ់ដ៏បរិបូរដល់មនុស្សលោកទាំងអស់
ហើយដល់អស់អ្នកណាដែលស្រឡាញ់ព្រះនាមរបស់យើង ។
១២ ហើយចូរអធិស្ឋានឲ្យពួកបងប្អូនរបស់អ្នកក្នុងពួក១២នាក់ ។
ចូរព្រមានដាស់តឿនដល់ពួកគេដោយតឹងរឹង ដោយយល់ដល់
ព្រះនាមរបស់យើង ហើយចូរឲ្យពួកគេទទួលការព្រមានដាស់តឿន
ចំពោះអំពើបាបទាំងអស់របស់ពួកគេ ហើយចូរអ្នករាល់គ្នាមាន
ចិត្ត ស្មោះត្រង់ ចំពោះព្រះនាមរបស់យើង នៅចំពោះយើងចុះ ។
១៣ ហើយបន្ទាប់ពីសេចក្ដីល្បួង និងសេចក្ដីវេទនាជាច្រើនរបស់
ពួកគេ មើលចុះ យើងជាព្រះអម្ចាស់ នឹងរាវរកពួកគេ ហើយបើ
សិនជាពួកគេមិនពង្រឹងចិត្តរបស់ពួកគេ ហើយធ្វើក្បាលរឹងរូសទាស់
និងយើងទេ នោះពួកគេនឹងត្រូវបានប្រែចិត្តជឿ ហើយយើងនឹង
ប្រោសពួកគេឲ្យបានជា ។
១៤ ឥឡូវនេះ យើងប្រាប់ដល់អ្នក ហើយអ្វីៗដែលយើង
ប្រាប់ដល់អ្នក គឺយើងប្រាប់ដល់គ្រប់ពួក១២នាក់ថា៖ ចូរក្រោក
ឡើង ហើយ ក្រវាត់ចង្កេះ ផ្ទុកឈើឆ្កាងរបស់ខ្លួន ដើរតាម
យើង ហើយឲ្យចំណីដល់ចៀមយើងចុះ ។
១៥ ចូរកុំដំកើងខ្លួន; ចូរកុំបះបោរទាស់នឹងយ៉ូសែប ជាអ្នកបំរើ
របស់យើងឡើយ; ត្បិតយើងប្រាប់អ្នកជាប្រាកដថា យើងគង់នៅជា
មួយ លោក ហើយព្រះហស្តរបស់យើងនឹងនៅលើលោក; ហើយ
កូនសោទាំងឡាយដែលយើងបានប្រទានដល់លោក ព្រមទាំង
ដល់អ្នកផង នោះនឹងមិនត្រូវបានដកចេញពីលោកឡើយ រហូត
ដល់យើងយាងមក ។
១៦ ប្រាកដមែន យើងប្រាប់អ្នក ថូម៉ាស ជាអ្នកបំរើ
របស់យើងថា អ្នកជាបុរសដែលយើងបានរើសឲ្យកាន់កូនសោ

៤ *ក* ម៉ាថាយ ៩:២; យ៉ូហាន ១៦:៣៣.
*ខ* គ. និង ស. ១៨:៦; ៩០:៨–៩.
*គ* គ. និង ស. ១៩:២៧.
៥ *ក* យូដាស ១:៣.
*ខ* គ. និង ស. ១:៤–៥.
៦ *ក* ទំនុក. ១២៥:១.
៧ *ក* អេភេ. ៦:១៣–១៧.
៨ *ក* ស.ប. បន្ទាបខ្លួន,
ចិត្តសុភាពរាបសា.
១០ *ក* សុភា. ១៨:១២.
១១ *ក* ម៉ាថាយ ៥:៤៣–៤៨.
ស.ប. សេចក្ដីសប្បុរស;
សេចក្ដីស្រឡាញ់.
១២ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
១៣ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* យ៉ូហាន ១៦:៣៣;
វិវរ. ៧:១៣–១៤;
គ. និង ស. ៥៨:៣–៤.
*គ* ៣ នីហ្វៃ ១៨:៣២.
ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
១៤ *ក* ម៉ាថាយ ១៦:២៤. ក.យ.ស.,
ម៉ាថាយ ១៦:២៥–២៦;
លូកា ៩:២៣.
*ខ* យ៉ូហាន ២១:១៥–១៧.
១៥ *ក* ស.ប. ការបះបោរ.
*ខ* គ. និង ស. ២៨:៧.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.

ទាំងឡាយនៃនគរ របស់យើង ដូចជាពួក១២នាក់ នៅក្នុង
ចំណោមសាសន៍ទាំងអស់ —
១៧ ប្រយោជន៍ឲ្យអ្នកអាចធ្វើជាអ្នកបំរើរបស់យើង ដើម្បីបើក
ទ្វារនគរ នៅគ្រប់កន្លែងនានា ដែលយ៉ូសែប ជាអ្នកបំរើរបស់
យើង និងស៊ីឌនី ជាអ្នកបំរើរបស់យើង និងហៃរុម ជាអ្នកបំរើ
របស់យើង ពុំអាចមកបាន;
១៨ ត្បិតនៅលើពួកគេ នោះយើងបានដាក់បន្ទុកនៃអស់
ទាំងសាសនាចក្រ មួយរដូវខ្លី ។
១៩ ហេតុដូច្នេះហើយ ទីណាក៏ដោយដែលពួកគេនឹងចាត់ឲ្យ
អ្នកទៅ នោះអ្នករាល់គ្នាទៅចុះ ហើយយើងនឹងគង់នៅជាមួយអ្នក;
ហើយនៅកន្លែងណាក៏ដោយ ដែលអ្នករាល់គ្នានឹងប្រកាសប្រាប់ពី
ព្រះនាមរបស់យើង នោះទ្វារដ៏មានផលប្រយោជន៍នឹងត្រូវបាន
បើកចំហ ប្រយោជន៍ឲ្យពួកគេអាចបានទទួលព្រះបន្ទូលរបស់យើង ។
២០ អស់អ្នកណាដែលទទួលព្រះបន្ទូលរបស់យើង នោះ
ទទួលយើង ហើយអស់អ្នកណាដែលទទួលយើង នោះទទួលពួក
អ្នកទាំងនោះ គឺគណៈប្រធានទីមួយ ដែលយើងបានចាត់ឲ្យទៅ
ដែលយើងបានធ្វើជាទីប្រឹក្សាទាំងឡាយដល់អ្នក ដោយយល់ដល់
ព្រះនាមរបស់យើង ។
២១ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា នរណាក៏ដោយដែល
អ្នករាល់គ្នានឹងចាត់ឲ្យទៅ ដោយនូវព្រះនាមរបស់យើង ដោយ
សម្លេងនៃ ពួកបងប្អូនរបស់អ្នកក្នុងសាសនា គឺពួក១២នាក់ គឺបាន
រ៉ាប់រង និងអនុញ្ញាតដោយអ្នកពេញច្បាប់ នោះនឹងមានអំណាច
ដើម្បីបើកទ្វារ នគររបស់យើង ដល់សាសន៍ណាមួយក៏ដោយ
ដែលអ្នករាល់គ្នានឹងចាត់ឲ្យពួកគេទៅ —
២២ ដរាបណាពួកគេបន្ទាបខ្លួននៅចំពោះយើង ហើយនៅជាប់
ក្នុងព្រះបន្ទូលរបស់យើង ហើយប្រុងស្ដាប់តាមសម្លេងនៃ
ព្រះវិញ្ញាណ របស់យើង ។
២៣ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា សេចក្ដីងងឹត
គ្របដណ្ដប់លើផែនដី ហើយសេចក្ដីងងឹតដ៏ធំគ្របលើគំនិត
នៃប្រជាជន ហើយសាច់ឈាមទាំងអស់ត្រឡប់ជាពុករលួយ
នៅចំពោះព្រះភ័ក្ត្ររបស់យើង ។
២៤ មើលចុះ សេចក្ដីសងសឹកនឹងឆាប់មកលើបណ្ដាជន
នៅលើផែនដី គឺជាថ្ងៃនៃសេចក្ដីក្រោធ ជាថ្ងៃនៃការឆេះឆាប
ជាថ្ងៃនៃសេចក្ដី ហិនហោច នៃការយំ នៃការទួញសោក
និងនៃទំនួញ; ហើយដូចជាព្យុះសង្ឃរានឹងមកលើផ្ទៃផែនដីទាំង
អស់ ព្រះអម្ចាស់ទ្រង់មានព្រះ បន្ទូលថាដូច្នោះ ។
២៥ ហើយមកលើដំណាក់របស់យើង នោះវានឹងចាប់ផ្ដើម
ហើយចេញពីដំណាក់របស់យើងទៅ នោះវានឹងចេញទៅ ព្រះ
អម្ចាស់ទ្រង់ មានព្រះបន្ទូលថាដូច្នោះ ។
២៦ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា មុនដំបូង គឺនៅចំណោម
ពួកគេដែលនៅក្នុងចំណោមអ្នក ដែលបានរាប់ខ្លួនថាស្គាល់ព្រះនាម
របស់យើង ហើយពុំបានស្គាល់ព្រះនាមរបស់យើងឡើយ ហើយ
បានពោលពាក្យប្រមាថដំទាស់ដល់យើង នៅកណ្ដាលវង្សា
របស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
២៧ ហេតុដូច្នេះហើយ ចូរមើលឲ្យឃើញថា អ្នករាល់គ្នាមិន
បាច់ខ្វល់ខ្វាយចិត្តអំពីកិច្ចការនៃសាសនាចក្ររបស់យើង នៅទីនេះ
ឡើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
២៨ ប៉ុន្តែចូរជំរះចិត្តរបស់អ្នកឲ្យបានបរិសុទ្ធ នៅចំពោះយើងចុះ;
រួចហើយ ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងពិភពលោក ហើយ
ផ្សាយ ដំណឹងល្អរបស់យើង ដល់សត្វលោកគ្រប់រូបណា ដែល
ពុំទាន់បានទទួលនៅឡើយនោះ;
២៩ ហើយអ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក
នោះនឹងបានសង្គ្រោះ ហើយអ្នកណាដែលមិនជឿ ហើយមិន
ទទួលបុណ្យ ជ្រមុជទឹកទេ នោះនឹងជាប់ទោស ។

---

១៧ *ក* ស.ប. រិកដុន, ស៊ីឌនី.
*ខ* ស.ប. ស៊្មីធ, ហៃរុម.
១៩ *ក* ១ កូរិន. ១៦:៩;
គ. និង ស. ១១៨:៣.
២០ *ក* គ. និង ស. ៨៤:៣៥–៣៨.
២១ *ក* គ. និង ស. ១០៧:៣៤–៣៥.
*ខ* ស.ប. សិទ្ធិអំណាច.
២២ *ក* ស.ប. ប្រុងស្ដាប់; ការគោរព,
ដែលគោរព, គោរព.
២៣ *ក* អេសាយ ៦០:២; មីកា ៣:៦;
គ. និង ស. ៣៨:១១.
ស.ប. សេចក្ដីក្បត់សាសនា —
សេចក្ដីក្បត់
សាសនានៃសាសនាចក្រគ្រីស្ទានដើម.
*ខ* គ. និង ស. ១០:២០–២៣.
២៤ *ក* ស.ប. ការសងសឹក.
*ខ* គ. និង ស. ១២៤:៨.
២៥ *ក* ១ ពេត្រុស ៤:១៧–១៨.
២៦ *ក* ម៉ាថាយ ៧:២១–២៣;
គ. និង ស. ៤១:១; ៥៦:១.
*ខ* លូកា ៦:៤៦;
ម៉ូសាយ ២៦:២៤–២៧;
៣ នីហ្វៃ ១៤:២១–២៣.
*គ* ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ.
២៨ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
*ខ* ម៉ាកុស ១៦:១៥–១៦.
២៩ *ក* មរមន ៩:២២–២៣;
គ. និង ស. ២០:២៥–២៦.
*ខ* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
២៩ *គ* ស.ប. សេចក្ដីជាប់ទោស.

៣០ ត្បិតចំពោះអ្នក គឺ[ក]ពួក១២នាក់ និងពួកអ្នកទាំងនោះ គឺ[ខ]គណៈប្រធានទីមួយ ដែលត្រូវបានតាំងជាមួយអ្នក ឲ្យធ្វើជាទីប្រឹក្សារបស់អ្នក និងជាមេដឹកនាំរបស់អ្នក នោះនឹងត្រូវប្រទានអំណាចនៃបព្វជិតភាពនេះឲ្យ សំរាប់ថ្ងៃ[គ]ចុងក្រោយបង្អស់ និងសំរាប់ពេលចុងក្រោយ បង្អស់ ដែលជាគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។

៣១ ជាអំណាចដែលអ្នកកាន់ ជាមួយអ្នកអស់ទាំងនោះ ដែលបានទទួលគ្រាកាន់កាប់ត្រួតត្រា នៅគ្រាណាមួយក៏ដោយ ចាប់តាំងពី ដើមកំណើតមនុស្សមកម្ល៉េះ;

៣២ ត្បិតយើងប្រាប់អ្នកជាប្រាកដថា [ក]កូនសោទាំងឡាយនៃគ្រាកាន់កាប់ត្រួតត្រា ដែលអ្នករាល់គ្នាបានទទួល បាន[ខ]ចុះមកពីពួក អយ្យកោ ហើយនៅចុងក្រោយបំផុត ត្រូវបានបញ្ជូនមកពីស្ថានសួគ៌ដល់អ្នក ។

៣៣ យើងប្រាប់អ្នកជាប្រាកដថា មើលចុះ ការងាររបស់អ្នកធំណាស់ហ្ន៎ ។ ចូរ[ក]សំអាតចិត្តអ្នក និងសំលៀកបំពាក់អ្នកចុះ ក្រែងឈាម នៃតំណមនុស្សនេះ[ខ]តំរូវពីដៃអ្នក ។

៣៤ ចូរមានចិត្តស្មោះត្រង់ រហូតដល់យើង[ក]យាងមក ត្បិតយើងយាងមកជាឆាប់; ទាំងនាំយករង្វាន់មកជាមួយផង ដើម្បីសងដល់មនុស្សគ្រប់គ្នា តាម[ខ]ការដែលខ្លួនបានធ្វើ ។ យើងជាអាលផា និងអូមេកា ។ អាម៉ែន ៕

កណ្ឌទី ១១៣

*ចម្លើយចំពោះសំណួរខ្លះៗអំពីការសរសេររបស់លោកអេសាយ ដែលបានឲ្យដោយ យ៉ូសែប ស្ម៊ីធ ជាព្យាការី ខែមីនា ឆ្នាំ១៨៣៨ (*History of the Church, *៣:៩–១០)* ។

*១–៦, គល់របស់អ៊ីសាយ ដែលមានលំពង់ចេញមក ហើយឫសរបស់អ៊ីសាយត្រូវបានប្រាប់; ៧–១០, ពួកសំណល់នៃស៊ីយ៉ូនដែលបាន ខ្ចាត់ខ្ចាយ មានសិទ្ធិចំពោះបព្វជិតភាព ហើយត្រូវបានហៅឲ្យវិលទៅរកព្រះអម្ចាស់វិញ ។*

តើអ្នកណាទៅជាគល់របស់[ក]អ៊ីសាយ ដែលបានពោលដល់នៅក្នុងខទី១ ទី២ ទី៣ ទី៤ និងទី៥ នៅក្នុងជំពូកទី១១ នៃគម្ពីរអេសាយ ?

២ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះ៖ គឺជាព្រះគ្រីស្ទ ។

៣ តើអ្វីជាលំពង់ ដែលបានពោលដល់នៅក្នុងខទី១ នៅក្នុងជំពូកទី១១ នៃគម្ពីរអេសាយ ដែលត្រូវចេញមកពីគល់របស់អ៊ីសាយ ?

៤ មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ គឺជាអ្នកបំរើនៅក្នុងព្រះហស្តនៃព្រះគ្រីស្ទ ដែលជាពូជពង្សរបស់អ៊ីសាយខ្លះ និងពូជពង្សរបស់អេប្រាអិមខ្លះ ឬជាវង្សនៃយ៉ូសែប ដែលមាន[ខ]អំណាចដ៏ខ្លាំង ដាក់មកលើអ្នកបំរើនោះ ។

៥ តើអ្វីជាឫសរបស់អ៊ីសាយ ដែលបានពោលដល់នៅក្នុងខទី១០ នៅក្នុងជំពូកទី១១ ?

៦ មើលចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ គឺជាពូជពង្សរបស់អ៊ីសាយ ព្រមទាំងយ៉ូសែប ជាអ្នកដែលត្រូវមានបព្វជិតភាព និង[ក]កូនសោទាំងឡាយនៃនគរ សំរាប់ជា[ខ]ទង់ជ័យ និងសំរាប់[គ]ការប្រមូលរាស្ត្ររបស់យើង នៅថ្ងៃចុងក្រោយបង្អស់ ។

៧ សំណួរទាំងឡាយដោយ អេលីយ៉ាស ហ៊ិកប៊ី សួរថា៖ តើបញ្ហានៅក្នុងគម្ពីរអេសាយ ជំពូកទី៥២ ខទី១ មានន័យថាដូចម្តេច ដែលថា៖ ឱក្រុងស៊ីយ៉ូនអើយ ចូរពាក់កម្លាំងរបស់ឯង — ហើយតើអេសាយនិយាយពីអ្នកណា ?

៣០ *ក* ស.ប. សាវក.
*ខ* ស.ប. គណៈប្រធានទី១.
*គ* អេភេ. ១:១០;
គ. និង ស. ២៧:១៣;
១២៤:៤០–៤២.
ស.ប. គ្រាកាន់កាប់ត្រួតត្រា.
៣២ *ក* គ. និង ស. ១១០:១១–១៦.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* អេប្រា. ១:២–៣.
៣៣ *ក* យ៉ាកុប ១:១៩.
*ខ* គ. និង ស. ៧២:៣.
៣៤ *ក* វិវរ. ២២:៧, ១២;
គ. និង ស. ៤៩:២៨; ៥៤:១០.
*ខ* ស.ប. កិច្ចការ.
**១១៣** ១*ក* ស.ប. អ៊ីសាយ.
៤ *ក* លោកុ. ៤១:៥០–៥២;
គ. និង ស. ១៣៣:៣០–៣៤.
ស.ប. អេប្រាអិម.
*ខ* ស.ប. អំណាច.
៦ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* គ. និង ស. ៤៥:៩.
ស.ប. ទង់.
*គ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.

៨ លោកបាននិយាយពីពួកអ្នកដែលព្រះទ្រង់នឹងហៅនៅថ្ងៃចុងក្រោយបង្អស់ ដែលត្រូវកាន់អំណាចនៃបព្វជិតភាព ដើម្បីនាំ[ក]ក្រុងស៊ីយ៉ូន មកម្ដងទៀត ហើយនិងសេចក្ដីប្រោសលោះដល់សាសន៍អ៊ីស្រាអែល; ហើយដើម្បី[ខ]ពាក់កម្លាំងរបស់នាងនោះ គឺដើម្បីពាក់សិទ្ធិអំណាច នៃបព្វជិតភាព ដែលនាង គឺស៊ីយ៉ូន មាន[គ]សិទ្ធិមានតាមវង្សត្រកូល; ព្រមទាំងវិលទៅរកអំណាចនោះ ដែលនាងបានបាត់បង់ ។

៩ តើយើងត្រូវយល់យ៉ាងណា ដោយថាក្រុងស៊ីយ៉ូនដោះចំណងពីកនាងចេញ ?

១០ យើងត្រូវយល់ថា ពួកសំណល់ដែល[ក]បានខ្ចាត់ខ្ចាយ ត្រូវបានទូន្មានឲ្យវិលពីទីដែលពួកគេបានរលំ [ខ]ទៅរកព្រះអម្ចាស់វិញ; ហើយបើ សិនជាពួកគេវិលវិញ នោះសេចក្ដីសន្យានៃព្រះអម្ចាស់ គឺថាទ្រង់នឹងមានព្រះបន្ទូលទៅរកពួកគេ ឬប្រទានដល់ពួកគេនូវវិវរណៈ ។ សូមមើលខទី៦ ទី៧ និងទី៨ ។ ចំណងទាំងឡាយនៅកនាង គឺជាសេចក្ដីបណ្ដាសានៃព្រះមកលើនាង ឬពួកសំណល់នៃអ៊ីស្រាអែល នៅក្នុងស្ថានភាពខ្ចាត់ខ្ចាយរបស់ពួកគេក្នុងចំណោមពួកសាសន៍ដទៃ ៕

## កណ្ឌទី ១១៤

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងហ្វារ់វែស្ត រដ្ឋមិសសួរី ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៨៣៨ (*History of the Church*, ៣:២៣)* ។

*១–២, តំណែងទាំងឡាយក្នុងសាសនាចក្រ ដែលកាន់ដោយពួកអ្នកមិនស្មោះត្រង់ នោះនឹងត្រូវប្រគល់ឲ្យអ្នកផ្សេង ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថាៈ គឺជាប្រាជ្ញាចំពោះ ដាវីឌ ដ័បបុលយូ ប៉ាទិ្តន ជាអ្នកបំរើរបស់យើង របស់យើង ថាគាត់ត្រូវ ចាត់ចែងធុរកិច្ចទាំងអស់របស់គាត់ជាបន្ទាន់តាមដែលគាត់ធ្វើទៅបាន ហើយកំចាត់នូវរបស់របរគាត់ចេញប្រយោជន៍ ឲ្យគាត់អាចទៅធ្វើបេសកកម្មដល់យើង នៅនិទាយរដូវឆ្នាំក្រោយ ទៅជុំអ្នកផ្សេងៗទៀត គឺមាន១២នាក់រួមទាំងខ្លួនអ្នកផង ដើម្បី ទៅធ្វើទីបន្ទាល់ពីព្រះនាមរបស់យើង ហើយប្រកាសប្រាប់ពីដំណឹងដ៏រីករាយ ដល់ពេញសព្វក្នុងពិភពលោក ។

២ ត្បិតប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា ដរាបណាមានមនុស្សក្នុងចំណោមអ្នករាល់គ្នាណា ដែលមិនទទួលស្គាល់ ព្រះនាមរបស់យើង នោះអ្នកផ្សេងទៀតនឹងត្រូវ[ក]ដាក់[ខ]ជំនួសពួកគេ ហើយទទួលគណៈប៊ីស្សពរបស់ខ្លួន ។ អាម៉ែន ៕

## កណ្ឌទី ១១៥

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងហ្វារ់វែស្ត រដ្ឋមិសសួរី ថ្ងៃទី២៦ ខែមេសា ឆ្នាំ១៨៣៨ ដោយបានប្រាប់ឲ្យដឹងពីព្រះហឫទ័យនៃព្រះ អំពីការកសាងទីនោះ និងដំណាក់នៃព្រះអម្ចាស់ (*History of the Church*, ៣:២៣–២៥)* ។ *វិវរណៈនេះត្រូវបានតម្រង់ទៅរកពួកមេដឹកនាំដែលត្រួតត្រាលើសាសនាចក្រ ។*

*១–៤, ព្រះអម្ចាស់ទ្រង់ឲ្យនាមដល់សាសនាចក្ររបស់ទ្រង់ថាជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ; ៥–៦, ស៊ីយ៉ូន និងស្តេកទាំងឡាយរបស់នាងសុទ្ធតែជាទីការពារ និងទីជ្រកកោនសំរាប់ពួកបរិសុទ្ធ; ៧–១៦, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យសង់ ដំណាក់នៃព្រះអម្ចាស់នៅក្រុងហ្វារ់វែស្ត; ១៧–១៩, យ៉ូសែប ស្ម៊ីធ កាន់កូនសោទាំងឡាយនៃនគររបស់ព្រះនៅលើផែនដី ។*

៨ *ក* ស.ប. ស៊ីយ៉ូន.
*ខ* គ. និង ស. ៨២:១៤.
*គ* ស.ប. សិទ្ធិកូនច្បង.

១០ *ក* ស.ប. អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកអ៊ីស្រាអែល.
*ខ* ហូសេ ៣:៤–៥; ២ នីហ្វៃ ៦:១១.

**១១៤** ២ *ក* គ. និង ស. ១១៨:១, ៦.
*ខ* គ. និង ស. ៦៤:៤០.

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះដល់អ្នក [ក]យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាអ្នកបំរើរបស់យើង ព្រមទាំង [ខ]ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង និងព្រមទាំង [គ]ហៃរុម ស្ម៊ីធ ជាអ្នកបំរើ របស់យើង ហើយជាទីប្រឹក្សារបស់អ្នក ដែលត្រូវបានតាំងឡើង នៅពេលនេះ និងពីពេលនេះតទៅ;

២ ហើយព្រមទាំងដល់អ្នក [ក]អែតរីត ប៉ាទ្រិច ជាអ្នកបំរើ របស់យើង និងទីប្រឹក្សាទាំងឡាយរបស់គាត់ផងដែរ;

៣ ហើយព្រមទាំងដល់ពួកអ្នកបំរើដ៏ស្មោះត្រង់របស់យើង ដែលនៅក្នុងក្រុមប្រឹក្សាជាន់ខ្ពស់ នៃសាសនាចក្ររបស់យើង នៅក្រុងស៊ីយ៉ូន ត្បិតពួកនោះនឹងត្រូវបានហៅថាដូច្នោះ ហើយ ព្រមទាំងដល់អស់ទាំងពួកអែលឌើរ និងប្រជារាស្ត្រនៅក្នុងសាសនាចក្រ នៃព្រះយេស៊ូវ គ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយរបស់យើង ដែលបានខ្ចាត់ខ្ចាយពាសពេញលើពិភពលោក;

៤ [ក]ត្បិតសាសនាចក្ររបស់យើងនឹងត្រូវបានហៅថាដូច្នោះ ហើយនៅគ្រាចុងក្រោយបង្អស់ គឺជា[ខ]សាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទ នៃពួក បរិសុទ្ធថ្ងៃចុងក្រោយ ។

៥ ប្រាកដមែន យើងប្រាប់អ្នកទាំងអស់គ្នាដូច្នេះថា៖ ចូរ [ក]ក្រោកឡើង ហើយបញ្ចាំង[ខ]ពន្លឺចេញទៅ ប្រយោជន៍ឲ្យពន្លឺរបស់អ្នកអាចបាន ទៅជាបមាណីយដល់សាសន៍នានា;

៦ ហើយប្រយោជន៍ឲ្យ[ក]ការប្រមូលគ្នាមកលើដែនដី[ខ]ស៊ីយ៉ូន និង មកលើ[គ]ស្តេកទាំងឡាយរបស់នាង អាចបានទៅជាទីការពារ និង ជាទី [ឃ]ជ្រកកោនពីព្យុះសង្ឃរា និងពីសេចក្ដីក្រោធដែលឥតលាយ [ង]ក្នុងកាលបានចាក់មកលើផែនដីទាំងមូល ។

៧ ចូរឲ្យទីក្រុងហ្វាវែស្ត ទៅជាដែនដីបរិសុទ្ធ ហើយថ្វាយ ដល់យើងចុះ; ហើយទីនោះនឹងត្រូវបានហៅថា បរិសុទ្ធបំផុត ត្បិតដីធ្លីដែល អ្នកឈរលើគឺ[ក]បរិសុទ្ធ ។

៨ ហេតុដូច្នេះហើយ យើងបញ្ជាដល់អ្នកឲ្យ[ក]សង់ដំណាក់ មួយថ្វាយដល់យើង សំរាប់ការប្រមូលនៃពួកបរិសុទ្ធរបស់យើង ប្រយោជន៍ ឲ្យពួកគេអាចថ្វាយ[ខ]បង្គំយើង ។

៩ ហើយចូរចាប់ផ្ដើមកិច្ចការនេះ និងគ្រឹះស្ថាន និងការរៀបចំ ផង នៅរដូវក្ដៅខាងមុខនេះ;

១០ ហើយចូរចាប់ផ្ដើមនៅថ្ងៃទី៤ ខែកក្កដាខាងមុខចុះ; ហើយ ចាប់ពីពេលនោះតមក ចូរឲ្យរាស្ត្ររបស់យើងខំព្យាយាមធ្វើការ ដើម្បី សង់ដំណាក់មួយថ្វាយដល់ព្រះនាមរបស់យើងចុះ;

១១ ហើយ[ក]មួយឆ្នាំបន្ទាប់ពីថ្ងៃនេះទៅ ចូរឲ្យពួកគេចាប់ផ្ដើម សង់[ខ]គ្រឹះនៃដំណាក់របស់យើងម្ដងទៀត ។

១២ ដូច្នេះ ចាប់តាំងពីពេលនោះទៅ ចូរឲ្យពួកគេខំព្យាយាម ធ្វើការ ទាល់តែបានធ្វើព្រះវិហាររួច ចាប់ពីថ្មជ្រុងព្រះវិហារទៅដល់ ដំបូលព្រះវិហារ ទាល់តែគ្មានអ្វីនៅសល់ដែលមិនទាន់ធ្វើរួចឡើយ។

១៣ យើងប្រាប់អ្នកជាប្រាកដថា ចូរកុំឲ្យ យ៉ូសែប ជាអ្នកបំរើ របស់យើង ឬក៏ ស៊ីឌនី ជាអ្នកបំរើរបស់យើង ឬក៏ ហៃរុម ជាអ្នក បំរើ របស់យើង ជាប់ជំពាក់តទៅទៀតឡើយ ចំពោះការកសាង ដំណាក់មួយថ្វាយដល់ព្រះនាមរបស់យើង;

១៤ ប៉ុន្តែចូរឲ្យមានដំណាក់មួយសង់ឡើងថ្វាយដល់ព្រះនាម របស់យើង តាម[ក]គំរូដែលយើងនឹងបង្ហាញដល់ពួកគេ។

១៥ ហើយបើសិនជារាស្ត្ររបស់យើងមិនសង់ដំណាក់នោះ តាមគំរូដែលយើងនឹងបង្ហាញដល់គណៈប្រធានរបស់ពួកគេទេ នោះយើង នឹងមិនទទួលដំណាក់នោះ ពីដៃរបស់ពួកគេឡើយ ។

១៦ ប៉ុន្តែបើសិនជារាស្ត្ររបស់យើងសង់ដំណាក់នោះ តាមគំរូដែលយើងនឹងបង្ហាញដល់គណៈប្រធានរបស់ពួកគេ គឺ យ៉ូសែប ជាអ្នកបំរើរបស់យើង និងពួកទីប្រឹក្សារបស់លោក ខណៈនោះ យើងនឹងទទួលដំណាក់នោះ ពីដៃនៃរាស្ត្រយើង ។

១៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា គឺជា ព្រះហឫទ័យរបស់យើង ដែលទីក្រុង ហ្វាវែស្ត ត្រូវបានសង់ឡើងជា ប្រញាប់ ដោយការប្រមូលនៃពួកបរិសុទ្ធរបស់យើង;

១៨ ហើយកន្លែងផ្សេងៗទៀតត្រូវបានតាំងឡើង សំរាប់[ក]ស្តេក ទាំងឡាយ នៅក្នុងភូមិភាគជុំវិញ នៅពេលណាកន្លែងទាំងនោះត្រូវ បាន សំដែងប្រាប់ដល់យ៉ូសែប ជាអ្នកបំរើរបស់យើង ម្ដងម្កាលៗ ។

---

**១១៥** ១*ក* ស.ប. ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ
*ខ* ស.ប. រិកដុន, ស៊ីឌនី.
*គ* ស.ប. ស្ម៊ីធ, ហៃរុម.
២ *ក* ស.ប. ប៉ាទ្រិច, អែតរីត.
៤ *ក* ៣ នីហ្វៃ ២៧:៤–៨.
*ខ* ស.ប. សាសនាចក្រនៃព្រះ យេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ.
៥ *ក* អេសាយ ៦០:១–៣.
*ខ* អេសាយ ១១:១២.
ស.ប. ទង់.
៦ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ខ* ស.ប. ស៊ីយ៉ូន.
*គ* គ. និង ស. ១០១:២១.
ស.ប. ចំរឹង, ស្តេក.
*ឃ* អេសាយ ២៥:១, ៤;
គ. និង ស. ៤៥:៦៦–៧១.
*ង* វិវរ. ១៤:១០;
គ. និង ស. ១:១៣–១៤.
៧ *ក* ស.ប. បរិសុទ្ធ.
៨ *ក* គ. និង ស. ៨៨:១១៩; ៩៥:៨.
*ខ* ស.ប. ថ្វាយបង្គំ.
១១ *ក* គ. និង ស. ១១៨:៥.
*ខ* គ. និង ស. ១២៤:៤៥–៥៤.
១៤ *ក* ហេព្រើរ ៨:៥;
គ. និង ស. ៩៧:១០.
១៨ *ក* គ. និង ស. ១០១:២១.
ស.ប. ចំរឹង, ស្តេក.

១៩ ត្បិតមើលចុះ យើងនឹងគង់នៅជាមួយលោក ហើយយើង
នឹងញែកលោកចេញជាបរិសុទ្ធ នៅចំពោះប្រជាជន; ត្បិត
ដល់លោក នេះហើយ ដែលយើងបានប្រទានកូនសោទាំងឡាយ
នៃនគរ និងការងារបំរើនេះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១១៦

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្បែរវែត្ស ហ្វែរី នៅកន្លែងមួយដែលហៅថា ស្ព្រីង ហិល នៅឃុំដាវីស រដ្ឋមិសសួរី ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៨៣៨ (*History of the Church, *៣:៣៥)* ។

ស្ព្រីង ហិល ត្រូវបានឲ្យឈ្មោះដោយព្រះអម្ចាស់ថាជា អ័ដាម-អុនដៃ-អាម៉ាន តាមដែលលោកមានប្រសាសន៍ ពីព្រោះជាកន្លែងដែល លោកអ័ដាមនឹងមកទស្សនកិច្ចប្រជាជនរបស់លោក ឬអ្នកពីចាស់បុរាណនឹងអង្គុយ ដូចដែលបានពោលដល់ដោយលោកដានីយ៉ែល ជាព្យាការី ។

## កណ្ឌទី ១១៧

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងហ្វារវែស្ត រដ្ឋមិសសួរី ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៨៣៨ អំពីភារកិច្ចជាបន្ទាន់របស់ វិលលាម ម៉ាក្ស, នូវល ខេ វិតនី, និង អូលីវើរ គ្រែនតើរ (*History of the Church, *៣:៤៥–៤៦)* ។

*១–៩, ពួកអ្នកបំរើរបស់ព្រះអម្ចាស់មិនត្រូវលោភចង់បានរបស់របរខាងសាច់ឈាមឡើយ ត្បិត «តើអ្វីទៅជារបស់របរដល់ព្រះ អម្ចាស់?»; ១០–១៦, ពួកគេត្រូវលះបង់ចោលព្រលឹងតូចតាច ហើយការបូជាទាំងឡាយរបស់ពួកគេ នឹងបានទៅជាពិសិដ្ឋ ចំពោះព្រះអម្ចាស់ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់ វិលលាម ម៉ាក្ស ជាអ្នកបំរើរបស់យើង ហើយព្រមទាំងដល់ នូវល ខេ វិតនី ជាអ្នក បំរើរបស់យើងដូច្នេះថា ចូរឲ្យពួកគេចាត់ចែងធុរកិច្ចរបស់ពួកគេជាបន្ទាន់ ហើយធ្វើដំណើរពីដែនដីខឺតឡង់ មុនយើងដ៏ជាព្រះអម្ចាស់ ចាត់ឲ្យទឹកកកធ្លាក់នៅលើផែនដីម្ដងទៀត ។
២ ចូរឲ្យពួកគេភ្ញាក់ ហើយក្រោកឡើង ហើយចេញមក ហើយកុំនៅឡើយ ត្បិតយើងជាព្រះអម្ចាស់ បញ្ជាហើយ ។
៣ ហេតុដូច្នេះហើយ បើសិនជាពួកគេនៅ នោះនឹងពុំបានស្រួលដល់ពួកគេទេ ។
៤ ចូរឲ្យពួកគេប្រែចិត្តពីអស់ទាំងអំពើបាបរបស់ពួកគេ និងអស់ទាំងសេចក្ដីប៉ងប្រាថ្នាដ៏លោភលន់របស់ពួកគេ នៅចំពោះយើងចុះ ព្រះ អម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ; ត្បិតតើអ្វីទៅជារបស់របរដល់យើង ? ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៥ ចូរឲ្យរបស់របរទាំងឡាយនៃក្រុងខឺតឡង់បានចេញមកបង់បំណុល ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ ព្រះអម្ចាស់ទ្រង់មាន ព្រះបន្ទូលថា ចូរឲ្យពួកគេទៅចុះ ហើយអ្វីក៏ដោយដែលនៅសល់ ចូរឲ្យរបស់ទាំងនោះនៅក្នុងកណ្ដាប់ដៃរបស់អ្នក ព្រះអម្ចាស់ទ្រង់មាន ព្រះបន្ទូលថាដូច្នោះ ។
៦ ត្បិតតើយើងមិនមានសត្វហើរលើអាកាស ព្រមទាំងត្រីនៅសមុទ្រ ហើយនិងសត្វជើងបួននៅលើភ្នំទាំងឡាយទេឬអី ? តើយើងមិន បានបង្កើតផែនដីទេឬអី ? តើយើងមិនមានអំណាចលើវាសនានៃអស់ទាំងពលទ័ពរបស់សាសន៍ទាំងឡាយនៅលើផែនដីទេឬអី ?
៧ ហេតុដូច្នេះហើយ តើយើងនឹងមិនធ្វើឲ្យកន្លែងស្ងាត់ឈឹងលាស់ទង ហើយរីក ហើយឲ្យផលិតបានផលជាបរិបូរទេឬអី ? ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៩ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
១១៦ ១*ក* គ. និង ស. ៧៨:១៥.
ស.ប. អ័ដាម-អុនដៃ-អាម៉ាន.
*ខ* ស.ប. អ័ដាម.
*គ* ដានី. ៧:១៣–១៤, ២២.
១១៧ ៤*ក* គ. និង ស. ១០៤:១៤.
៥ *ក* គ. និង ស. ១០៤:៧៨.
៦ *ក* កិច្ចការ ១៧:២៦;
១ នីហ្វៃ ១៧:៣៦–៣៩.
៧ *ក* អេសាយ ៣៥:១;
គ. និង ស. ៤៩:២៤–២៥.

៨ តើមិនមានកន្លែងគ្រប់គ្រាន់ទេឬអី នៅលើភ្នំទាំងឡាយនៅ[ក]អ័ដាម-អុនដៃ-អាម៉ាន និងនៅលើប្រេកភ្នំទាំងឡាយនៅអូឡាហា[ខ]ស៊ីនេហា ឬក៏[គ]ដែនដីដែលលោកអ័ដាម បានអាស្រ័យនៅ ដែលគួរឲ្យអ្នកលោភចង់បានគ្រាន់តែមួយតំណក់ ហើយចោលសេចក្ដីដែល មានទម្ងន់ជាងឬ ?

៩ ហេតុដូច្នេះហើយ ចូរឡើងមកទីនេះ មកឯដែនដីនៃរាស្ត្ររបស់យើង គឺស៊ីយ៉ូន ។

១០ ចូរឲ្យ វិលលាម ម៉ាក្ស ជាអ្នកបំរើរបស់យើង មាន[ក]ចិត្តស្មោះលើរបស់របរបន្តិចបន្តួច ហើយគាត់នឹងបានធ្វើជាអ្នកត្រួតត្រាលើរបស់ ជាច្រើន ។ ចូរឲ្យគាត់ត្រួតត្រានៅកណ្ដាលរាស្ត្ររបស់យើង នៅទីក្រុងហ្វាវែស្ថ ហើយចូរឲ្យគាត់បានពរដោយព្រះពរទាំងឡាយ នៃរាស្ត្ររបស់យើង ។

១១ ចូរឲ្យ នូវល ខេ វិតនី ជាអ្នកបំរើរបស់យើង មានចិត្តអាម៉ាសខ្មាស់អំពី[ក]ពួកនីកូឡា និងអំពីគ្រប់ទាំងអំពើគួរខ្ពើមឆ្អើមដ៏[ខ]សម្ងាត់របស់ ពួកគេ និងអំពីគ្រប់ទាំងព្រលឹងតូចតាចរបស់គាត់នៅចំពោះយើងចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយចូឡើងមកឯដែន ដីអ័ដាម-អុនដៃ-អាម៉ាន ហើយធ្វើជា[គ]ប៊ីស្សពដល់រាស្ត្ររបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ គឺពុំមែននៅក្នុងនាមទេ ប៉ុន្តែនៅក្នុងការប្រព្រឹត្តវិញ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១២ ហើយជាថ្មីទៀត យើងប្រាប់ដល់អ្នកថា យើងនឹកចាំដល់[ក]អូលីវើរ គ្រែងគើរ ជាអ្នកបំរើរបស់យើង; មើលចុះ យើងប្រាប់គាត់ជា ប្រាកដថា ឈ្មោះគាត់នឹងត្រូវបានរំឭកថាពិសិដ្ឋ ពីតំណមួយទៅតំណមួយទៀត ជារៀងដរាបរហូតតទៅ ព្រះអម្ចាស់មានព្រះបន្ទូល ថាដូច្នោះ ។

១៣ ហេតុដូច្នេះហើយ ចូរឲ្យគាត់ឧស្សាហ៍ធ្វើការ ដើម្បីសេចក្ដីប្រោសលោះនៃគណៈប្រធានទីមួយ ក្នុងសាសនាចក្ររបស់យើងចុះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ; ហើយកាលណាគាត់ដួល នោះគាត់នឹងក្រោកឡើងវិញ [ក]ត្បិតការបូជារបស់គាត់នឹងបានរាប់ ថាពិសិដ្ឋដល់យើង ជាងការតម្លើងរបស់គាត់ទៅទៀត ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៤ ហេតុដូច្នេះហើយ ចូរឲ្យគាត់ឡើងមកទីនេះជាប្រញាប់ គឺមកឯដែនដីស៊ីយ៉ូន; ហើយនៅពេលកំណត់ នោះគាត់នឹងបានធ្វើជាអ្នក ជំនួញ នៅក្នុងនាមរបស់យើង សំរាប់ផលប្រយោជន៍ដល់រាស្ត្ររបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៥ ហេតុដូច្នេះហើយ ចូរកុំឲ្យនរណាមើលងាយ អូលីវើរ គ្រែងគើរ ជាអ្នកបំរើរបស់យើងឡើយ ប៉ុន្តែចូរឲ្យព្រះពរទាំងឡាយនៃ រាស្ត្ររបស់យើងបានមកលើគាត់ជារៀងដរាបរហូតតទៅ ។

១៦ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យពួកអ្នកបំរើរបស់យើងទាំងអស់ នៅដែនដីខឺតឡង់ នឹកចាំដល់ព្រះអម្ចាស់ជាព្រះ របស់ពួកគេ ព្រមទាំងដំណាក់របស់យើងផង ដើម្បីថែរក្សាទីនោះទុកជាបរិសុទ្ធ ហើយដើម្បីគ្រវែងចោលពួកអ្នកដូរប្រាក់ នៅពេល កំណត់របស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១១៨

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងហ្វាវែស្ថ រដ្ឋមិសសួរី ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៨៣៨ ជាចម្លើយចំពោះពាក្យអំពាវនាវថា «ឱព្រះអម្ចាស់អើយ សូមបង្ហាញដល់ទូលបង្គំអំពីពួក១២នាក់» (*History of the Church, *៣:៤៦)* ។

*១–៣, ព្រះអម្ចាស់ទ្រង់នឹងផ្គត់ផ្គង់ដល់ក្រុមគ្រួសារនៃពួក១២នាក់; ៤–៦, តំណែងទំនេរទាំងឡាយក្នុងពួក១២នាក់ត្រូវបានបំពេញ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ចូរឲ្យមានសន្និសីទភ្លាម; ចូរឲ្យពួក១២នាក់បានរៀបចំឡើង; ហើយចូរតាំងមនុស្ស ទាំងឡាយ ឲ្យ[ក]បំពេញកន្លែងនៃពួកអ្នកដែលបានធ្លាក់ ។

៨ *ក* គ. និង ស. ១១៦:១.
ស.ប. អ័ដាម-អុនដៃ-អាម៉ាន.
*ខ* អ័ប្រា. ៣:១៣.
*គ* ស.ប. អេដែន.
១០ *ក* ម៉ាថាយ ២៥:២៣.
១១ *ក* វិវរ. ២:៦, ១៥.
*ខ* ស.ប. បក្សព័ន្ធសម្ងាត់.
*គ* ស.ប. ប៊ីស្សព.
១២ *ក* ក.ន. ភ្នាក់ងារដែលព្យាការីបានទុកឲ្យចាត់ចែងការងាររបស់លោកនៅក្រុងខឺតឡង់.
១៣ *ក* ស.ប. បូជា, យញ្ញបូជា.
**១១៨** ១*ក* កិច្ចការ ១:១៣, ១៦–១៧, ២២–២៦.

២ ចូរឲ្យ [ក]ថូម៉ាស ជាអ្នកបំរើរបស់យើង នៅមួយរដូវសិន នៅដែនដីស៊ីយ៉ូន ដើម្បីបោះពុម្ពផ្សាយព្រះបន្ទូលរបស់យើង ។
៣ ចូរឲ្យពួកអ្នកដែលនៅសល់ទាំងប៉ុន្មាន ផ្សាយពីម៉ោងនេះតទៅ ហើយបើសិនជាពួក[ក]គេប្រព្រឹត្ត[ខ]ការនេះ ដោយចិត្តសុភាពរាបសា ស្លូតបូត និងទន់ទាប និងអត់ធ្មត់ នោះយើងជាព្រះអម្ចាស់ ប្រទានដល់ពួកគេនូវសេចក្ដីសន្យាមួយថា យើងនឹងផ្គត់ផ្គង់ដល់ក្រុមគ្រួសារ របស់ពួកគេ; ហើយទ្វារដ៏មានផលប្រយោជន៍នឹងត្រូវបានបើកចំហដល់ពួកគេ ចាប់ពីពេលនេះតទៅ ។
៤ ហើយនៅនិទាឃរដូវឆ្នាំក្រោយ ចូរឲ្យពួកគេចេញទៅលើទឹកដ៏ធំធេង ហើយនៅទីនោះ ចូរប្រកាសប្រាប់ពីដំណឹងល្អរបស់យើង គឺពីភាពពោរពេញនៃដំណឹងល្អរបស់យើង ហើយថ្លែងទីបន្ទាល់អំពីព្រះនាមរបស់យើងចុះ ។
៥ ចូរឲ្យពួកគេចេញពីពួកបរិសុទ្ធរបស់យើង នៅទីក្រុងហ្វាវែស្ត នៅថ្ងៃទី២៦ នៃខែមេសាឆ្នាំក្រោយ នៅចំកន្លែងសង់ដំណាក់របស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៦ ចូរឲ្យ យ៉ូហាន ថេល័រ ជាអ្នកបំរើរបស់យើង ហើយព្រមទាំង យ៉ូហាន អ៊ី ភេច ជាអ្នកបំរើរបស់យើង និង វិលហ្វឺដ វូឌ្រុហ្វ ជាអ្នកបំរើរបស់យើង ហើយព្រមទាំង វិលឡឺដ រិឆើដ្ស ជាអ្នកបំរើរបស់យើង បានតាំងឡើង ដើម្បីបំពេញតំណែងទាំងឡាយ នៃពួកអ្នកដែលបានធ្លាក់ ហើយបានប្រាប់តាមត្រូវការអំពីការតែងតាំងរបស់ពួកគេចុះ ៕

## កណ្ឌទី ១១៩

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស៊្មីធ ជាព្យាការី នៅក្រុងហ្វាវែស្ត រដ្ឋមិសសួរី ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៨៣៨ ជាចម្លើយចំពោះពាក្យអំពាវនាវរបស់លោកដែលថា «ឱព្រះអម្ចាស់អើយ សូមបង្ហាញដល់អ្នកបំរើរបស់ទ្រង់ ថាព្រះអង្គតម្រូវដង្វាយ១ភាគ១០ប៉ុណ្ណា ពីទ្រព្យសម្បត្តិនៃរាស្ត្ររបស់ទ្រង់» (*History of the Church*, ៣:៤៤) ។ ក្រិត្យវិន័យនៃដង្វាយ ១ភាគ១០ តាមដែលយល់នៅសព្វថ្ងៃនេះ ពុំបានប្រទានដល់សាសនាចក្រមុនវិវរណៈនេះឡើយ ។ ពាក្យថាដង្វាយ១ភាគ១០ នៅក្នុងបទអធិស្ឋានដែល ទើបស្រង់មកនេះ ហើយនៅក្នុងវិវរណៈដែលបានប្រទានមុនវិវរណៈនេះ (៦៤:២៣; ៨៥:៣; ៩៧:១១) ពុំមែនមានន័យថា១ភាគ១០ប៉ុណ្ណោះទេ ប៉ុន្តែជាដង្វាយ ឬវិភាគទានតាមចិត្តដល់មូលនិធិនៃសាសនាចក្រ ។ លើកមុន ព្រះអម្ចាស់ទ្រង់បានប្រទានដល់សាសនាចក្រ នូវក្រិត្យវិន័យនៃការថ្វាយ និងការត្រួតត្រាទ្រព្យសម្បត្តិ ដែលសមាជិក (ជាពិសេស ពួកអែលឌើរដឹកនាំ) បានចូលក្នុងសេចក្ដីសញ្ញាដែលត្រូវជាអស់កល្បអស់កាលជានិច្ច ។ មកពីមនុស្សជាច្រើនមិនបាន កាន់តាមសេចក្ដីសញ្ញានេះ ទើបព្រះអម្ចាស់ទ្រង់ដកក្រិត្យវិន័យនេះចេញមួយរយៈសិន ហើយបានប្រទានក្រិត្យវិន័យនៃដង្វាយ១ភាគ១០ ដល់សាសនាចក្រទាំងមូលជំនួសវិញ ។ ព្យាការីបានសួរដល់ព្រះអម្ចាស់ ថាតើទ្រង់តម្រូវទ្រព្យសម្បត្តិប៉ុណ្ណា សំរាប់គោលបំណង ពិសិដ្ឋៗ ។ ចម្លើយនោះគឺជាវិវរណៈនេះ ។*

*១–៥, ពួកបរិសុទ្ធត្រូវថ្វាយទ្រព្យសម្បត្តិដែលមានលើសច្រើន ហើយថ្វាយជាដង្វាយ១ភាគ១០ គឺ១ភាគ១០នូវប្រាក់ប្រចាំឆ្នាំ; ៦–៧ ដំណើរបែបនេះនឹងញែកដែនដីស៊ីយ៉ូនចេញជាបរិសុទ្ធ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា យើងតម្រូវទ្រព្យសម្បត្តិទាំងអស់ ដែលពួកគេមាន[ក]លើសដើម្បីដាក់នៅក្នុងដៃ របស់ប៊ីស្សព នៃសាសនាចក្ររបស់យើង នៅក្រុងស៊ីយ៉ូន ។
២ សំរាប់ការកសាង[ក]ដំណាក់របស់យើង និងសំរាប់ការសង់គ្រឹះនៃស៊ីយ៉ូន និងសំរាប់បព្វជិតភាព និងសំរាប់បំណុលទាំងឡាយ របស់គណៈប្រធាន នៃសាសនាចក្ររបស់យើង ។
៣ ហើយនេះនឹងទៅជាការចាប់ផ្ដើមដង្វាយ[ក]១ភាគ១០នៃរាស្ត្ររបស់យើង ។
៤ ហើយបន្ទាប់មក អស់អ្នកណាដែលថ្វាយដង្វាយ១ភាគ ១០ ត្រូវថ្វាយ១ភាគ១០នូវធនធានបួក្នុងមួយឆ្នាំដែលគេបាន; ហើយនេះនឹងត្រូវ ទៅជាក្រិត្យវិន័យដែលនៅអចិន្ត្រៃយ ចំពោះពួកគេជារៀងដរាបតទៅ សំរាប់បព្វជិតភាពដ៏បរិសុទ្ធរបស់យើង ព្រះអម្ចាស់ទ្រង់មាន ព្រះបន្ទូលថាដូច្នោះ ។

២ *ក* ស.ប. ម៉ាស, ថូម៉ាស ប៊ី.
៣ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ស.ប. កាន់ខ្ជាប់.
**១១៩** ១ *ក* គ. និង ស. ៤២:៣៣–៣៤, ៥៥; ៥១:១៣; ៨២:១៧–១៩.
២ *ក* គ. និង ស. ១១៥:៨.
៣ *ក* គ. និង ស. ៦៤:២៣; ម៉ាឡាគី ៣:៨–១២. ស.ប. ដង្វាយ១ភាគក្នុង១០, ការថ្វាយដង្វាយ១ភាគ ក្នុង១០.

៥ យើងប្រាប់អ្នកជាប្រាកដថា ហេតុការណ៍នឹងបានកើតឡើងថា អស់អ្នកណាដែលប្រមូលគ្នាមកឯដែនដីស៊ីយ៉ូន នឹងត្រូវថ្វាយដង្វាយ ១ភាគ១០ នូវទ្រព្យសម្បត្តិដែលគេមានលើស ហើយត្រូវគោរពតាមក្រិត្យវិន័យនេះ បើពុំនោះសោតទេ ពួកគេនឹងមិនត្រូវបានឃើញ ថាសមនិងនៅជាប់ក្នុងចំណោមអ្នករាល់គ្នាឡើយ ។

៦ ហើយយើងប្រាប់អ្នកថា បើសិនជារាស្ត្ររបស់យើងមិនគោរពតាមក្រិត្យវិន័យនេះ ដើម្បីញែកក្រិត្យវិន័យនេះទុកជាបរិសុទ្ធ ហើយដោយសារក្រិត្យវិន័យនេះ ញែកដែនដីស៊ីយ៉ូនចេញជាបរិសុទ្ធដល់យើង ប្រយោជន៍ឲ្យក្រិត្យក្រមទាំងឡាយរបស់យើង និងសេចក្ដីជំនុំជំរះទាំងឡាយរបស់យើង អាចបានរក្សាទុកនៅទីនោះ គឺដើម្បីឲ្យដែនដីនេះបានទៅជាទីដ៏បរិសុទ្ធបំផុត មើលចុះ យើងប្រាប់អ្នកជាប្រាកដថា ទីនោះនឹងមិនត្រូវបានទៅជាស៊ីយ៉ូនដល់អ្នកឡើយ ។

៧ ហើយនេះនឹងត្រូវទៅជាគំរូដល់គ្រប់ស្តេកនៃស៊ីយ៉ូន ។ គឺដូច្នោះមែន ។ អាម៉ែន៕

កណ្ឌទី ១២០

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងហ្វារ៉េស្ត រដ្ឋមិសសួរី ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៨៣៨ ដោយប្រាប់ឲ្យបានដឹងពីរបៀបប្រើប្រាស់ទ្រព្យសម្បត្តិទាំងឡាយ ដែលបានទទួលជាដង្វាយ១ភាគ១០ ដូចដែលបានប្រាប់នៅក្នុងវិវរណៈខាងលើនេះ គឺកណ្ឌទី ១១៩ (*History of the Church*, ៣:៤៤)* ។

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នោះថា ឥឡូវនេះពេលវេលាបានមកដល់ហើយ ដែលត្រូវប្រើប្រាស់ទ្រព្យសម្បត្តិដោយក្រុមប្រឹក្សាមួយ គឺមានគណៈប្រធានទីមួយនៃសាសនាចក្ររបស់យើង ព្រមទាំងប៊ីស្សព និងក្រុមប្រឹក្សារបស់គាត់ ហើយដោយ ក្រុមប្រឹក្សាជាន់ខ្ពស់របស់យើង; ហើយដោយសម្លេងយើងផ្ទាល់ដល់ពួកគេ ព្រះអម្ចាស់មានព្រះបន្ទូលថាដូច្នោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

កណ្ឌទី ១២១

*បទអធិស្ឋាន និងបទព្យាករណ៍ទាំងឡាយ ដែលបានសរសេរដោយ យ៉ូសែប ស្ម៊ីធ ជាព្យាការី កាលលោកជាប់នៅក្នុងគុក នៅក្រុងលិបើទី រដ្ឋមិសសួរី នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៣៩ (*History of the Church*, ៣:២៨៩–៣០០) ។ ព្យាការី និងគូកនទាំង ឡាយត្រូវបានជាប់គុកអស់ជាច្រើនខែ ។ សំណូមពរ និងការអំពាវនាវទាំងឡាយរបស់ពួកគេ ដែលបានសុំដល់ក្រសួងរដ្ឋការ និងក្រ សួងតុលាការ នោះពុំឃើញផ្តល់ការរំដោះសោះ ។*

*១–៦, ព្យាការីសូមអង្វរដល់ព្រះអម្ចាស់ឲ្យជួយរំដោះទុក្ខដល់ពួកបរិសុទ្ធ; ៧–១០, ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលនូវសេចក្ដីសុខសាន្តដល់ លោក; ១១–១៧, មានបណ្តាសាហើយដល់អស់អ្នកណាដែលបន្លឺសម្លេងក្លែងក្លាយ ប្រាប់អំពីការរំលងទាស់នឹងរាស្ត្ររបស់ព្រះអម្ចាស់; ១៨–២៥, ពួកគេនឹងពុំមានសិទ្ធិបានបព្វជិតភាពឡើយ ហើយនឹងជាប់ទោស; ២៦–៣២, វិវរណៈដ៏រុងរឿងទាំងឡាយត្រូវបានសន្យាដល់ អស់អ្នកណាដែលស៊ូទ្រាំដោយក្លាហាន; ៣៣–៤០, ហេតុអ្វីបានជាមានមនុស្ស ជាច្រើនត្រូវបានហៅ ហើយមានតែបន្តិចបន្តួចទេដែលត្រូវបានរើស; ៤១–៤៦, បព្វជិតភាពគប្បីប្រើប្រាស់នៅក្នុងសេចក្ដីសុចរិតតែប៉ុណ្ណោះ ។*

ឱព្រះអង្គអើយ តើព្រះអង្គគង់នៅទីណា ? ហើយតើព្រះពន្លាដែលគ្របបាំងទីបំពួនទ្រង់នៅទីណា ?

២ តើព្រះហស្តទ្រង់នឹងទប់ទុក ហើយព្រះនេត្រទ្រង់ មែនហើយ ព្រះនេត្រដ៏សុទ្ធសាធរបស់ទ្រង់ ដែលទតមើលមកពីស្ថានសួគ៌

៥ *ក* គ. និង ស. ៥៧:២–៣.
៦ *ក* ស.ប. ស៊ីយ៉ូន.
៧ *ក* ស.ប. ចំរឹង, ស្តេក.
**១២០** ១*ក* ក.ន. ដង្វាយ១ភាគក្នុង១០.
**១២១** ១*ក* ទំនុក. ១៣:១–២; ១០២:១–២.

ដ៏នៅ អស់កល្បជានិច្ច នូវកំហុសទាំងឡាយនៃរាស្ត្ររបស់ទ្រង់
និងពួកអ្នកបំរើរបស់ទ្រង់ ហើយនិងព្រះកាណ៌ទ្រង់ ដែល
[ក]ឮសំរែករបស់ពួកគេ ដល់ណាទៅ ?
៣ មែនហើយ ឱព្រះអម្ចាស់អើយ តើពួកគេត្រូវរង[ក]ទុក្ខ
ចំពោះកំហុស និងការសង្កត់សង្កិនដ៏ខុសច្បាប់ទាំងនេះដល់
ណាទៅ មុនព្រះ ហឫទ័យរបស់ទ្រង់នឹងបានទន់ទៅរកពួកគេ
ហើយមុនព្រះអង្គមានចិត្តក្ដួលដោយសេចក្ដីមេត្តាករុណាដល់
ពួកគេ ?
៤ ឱព្រះអម្ចាស់អើយ ជាព្រះ[ក]ដ៏មានមហិទ្ធិឫទ្ធិ ជាព្រះបង្កើត
ផ្ទៃមេឃ ផែនដី និងសមុទ្រទាំងឡាយ ព្រមទាំងអ្វីៗទាំងអស់នៅ
ក្នុងទីនោះ ផង ហើយជាអ្នកកាន់កាប់ និងបង្ក្រាបអារក្ស
និងអំណាចងងឹតងងល់នៃសេយ៉ូល — សូមសន្ធឹង
ព្រះហស្តទ្រង់ផង; សូមឲ្យព្រះនេត្រទ្រង់ បានទតមើលធ្លុះ; សូមឲ្យ
ព្រះពន្លាទ្រង់បានលើកឡើង; សូមកុំឲ្យ[ខ]ទីបំពួនទ្រង់បានគ្របបាំង
ឡើយ; សូមឲ្យព្រះកាណ៌ទ្រង់ផ្ទៀងស្ដាប់; សូមឲ្យព្រះហឫទ័យ
ទ្រង់បានទន់ ហើយសូមឲ្យទ្រង់មានចិត្តក្ដួល ដោយសេចក្ដីមេត្តា
ករុណាដល់ទូលបង្គំទាំងឡាយផងចុះ ។
៥ សូមឲ្យសេចក្ដីខ្ញាល់របស់ទ្រង់ឆួលឡើងទាស់នឹងពួកខ្មាំង
សត្រូវរបស់ពួកទូលបង្គំ; ហើយនៅក្នុងសេចក្ដីឃោរឃៅនៃ
ព្រះហឫទ័យ របស់ទ្រង់ សូមព្រះអង្គ[ក]សងសឹកដោយដាវរបស់
ទ្រង់ ពីការអយុត្តិធម៌ទាំងឡាយឲ្យពួកទូលបង្គំផងចុះ ។
៦ សូមនឹកដល់ពួកបរិសុទ្ធរបស់ទ្រង់ដែលមានទុក្ខលំបាក ឱព្រះ
របស់ទូលបង្គំអើយ; ហើយពួកអ្នកបំរើរបស់ទ្រង់នឹងត្រេកអរ
ចំពោះព្រះនាមរបស់ទ្រង់ ជារៀងដរាបតទៅ ។
៧ បុត្រយើងអើយ ចូរមានសេចក្ដីសុខសាន្តដល់ព្រលឹងបុត្រចុះ;
[ក]សេចក្ដីទំនាស់ និងសេចក្ដីទុក្ខលំបាករបស់អ្នក នោះគ្រាន់តែមួយ
ភ្លែត ប៉ុណ្ណោះទេ;
៨ ហើយខណៈនោះ បើសិនជាអ្នក[ក]ស៊ូទ្រាំការណ៍នោះដោយ
ហ្មត់ចត់ នោះព្រះទ្រង់នឹងដំកើងអ្នកឡើងនៅស្ថានខ្ពស់; អ្នកនឹង
បានជ័យ ជំនះ លើពួកខ្មាំងសត្រូវរបស់អ្នកទាំងអស់ ។
៩ [ក]មិត្តភក្តិទាំងឡាយរបស់អ្នកកំពុងឈរគាំទ្រអ្នក ហើយពួកគេ
នឹងជំរាបសួរអ្នក ដោយចិត្តសាទរ និងដៃសោមនស្សទៀត ។
១០ អ្នកពុំទាន់បានដូច[ក]យ៉ូបទេ; មិត្តភក្តិទាំងឡាយរបស់អ្នក ពុំ
បានទាស់នឹងអ្នក ឬចោទប្រកាន់ថាអ្នកប្រព្រឹត្តអំពើរំលង ដូចជា
ពួកគេ បានធ្វើដល់យ៉ូបនោះទេ ។
១១ ហើយពួកអ្នកដែលចោទប្រកាន់ថាអ្នកប្រព្រឹត្តអំពើរំលង
នោះសេចក្ដីសង្ឃឹមរបស់ពួកគេនឹងត្រូវបានបែកខ្ទេចខ្ទី ហើយសេច
ក្ដីប្រាថ្នា របស់ពួកគេនឹងត្រូវបានរលាយបាត់ទៅ ដូចជា[ក]ទឹកស
ន្សើមកករលាយ នៅពេលព្រះអាទិត្យរះរស្មីចែងចាំងមក;
១២ ហើយព្រះទ្រង់ព្រមទាំងដាក់ព្រះហស្តទ្រង់ និងត្រា
ដើម្បី[ក]ប្ដូរពេលវេលា និងរដូវទាំងឡាយ ហើយដើម្បីបំបាំងគំនិត
របស់ពួកគេ ប្រយោជន៍កុំឲ្យពួកគេអាចយល់នូវកិច្ចការដ៏អស្ចារ្យ
ទាំងឡាយរបស់ទ្រង់; ប្រយោជន៍ឲ្យទ្រង់ពិសោធពួកគេផងដែរ
ហើយចាប់ពួកគេ នៅក្នុងឧបាយកលរបស់ខ្លួនគេផ្ទាល់;
១៣ មកពីដួងចិត្តពួកគេពុករលួយ ព្រមទាំងអ្វីៗទាំងឡាយ
ដែលពួកគេយល់ព្រមធ្វើដល់អ្នកដទៃ ហើយចូលចិត្តធ្វើឲ្យអ្នក
ផ្សេងរងទុក្ខ នោះសូមឲ្យកើតដល់[ក]ខ្លួនគេដោយពេញទំហឹងចុះ;
១៤ ប្រយោជន៍ឲ្យពួកគេអាចបានខកចិត្តដែរ ហើយឲ្យពួកគេ
អស់សង្ឃឹម;
១៥ ហើយមិនយូរប៉ុន្មានឆ្នាំពីនេះទៅ សូមឲ្យពួកគេ និងពូជពង្ស
របស់ពួកគេត្រូវបានកំចាត់ចេញពីក្រោមមេឃ ព្រះទ្រង់មានព្រះ
បន្ទូល ថាដូច្នោះ ប្រយោជន៍កុំឲ្យមានពួកគេណាមួយ
នៅសល់ ដើម្បីឈរនៅក្បែរកំផែងឡើយ ។
១៦ មានបណ្ដាសាហើយដល់អស់អ្នកណាដែលនឹងលើក
កែងជើង ទាស់នឹងអ្នកដែលបាន[ក]ចាក់ប្រេងតាំងរបស់យើង ព្រះ
អម្ចាស់ទ្រង់ មានព្រះបន្ទូលថាដូច្នោះ ហើយស្រែក[ខ]ប្រាប់ថា
ពួកគេបានប្រព្រឹត្តអំពើបាប ក្នុងកាលពួកគេពុំបានប្រព្រឹត្តអំពើបាប
នៅចំពោះយើងផង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ
ប៉ុន្តែបានប្រព្រឹត្តនូវអ្វីៗដែលសមនឹងភ្នែកយើង និងអ្វីដែលយើង
បានបញ្ជាដល់ពួកគេ ។
១៧ ប៉ុន្តែអស់អ្នកណាដែលស្រែកប្រាប់ពីអំពើរំលង នោះបាន
ធ្វើឡើង មកពីពួកគេសុទ្ធតែជាពួកអ្នកបំរើនៃអំពើបាប ហើយជា
[ក]កូនចៅនៃការមិនគោរពប្រតិបត្តិតាមខ្លួនឯងនោះហើយ ។
១៨ ហើយអស់អ្នកណាដែលស្បថក្លែងក្លាយ ទាស់នឹងពួកអ្នក

២ *ក* ហាបា. ១:២.
៣ *ក* គ. និង ស. ១០៩:៤៩.
៤ *ក* ស.ប. ព្រះដ៏មានគ្រប់ព្រះចេស្ដា.
*ខ* គ. និង ស. ១២៣:៦.
៥ *ក* លូកា ១៨:៧–៨.
៧ *ក* ស.ប. សេចក្ដីទំនាស់.
៨ *ក* ១ ពេត្រុស ២:១៩–២៣.
ស.ប. កាន់ខ្ជាប់.
៩ *ក* គ. និង ស. ១២២:៣.
១០ *ក* ស.ប. យ៉ូប.
១១ *ក* និក្ខ. ១៦:១៤.
១២ *ក* ដានី. ២:២១.
១៣ *ក* សុភា. ២៨:១០; ១ នីហ្វៃ ១៤:៣.
១៦ *ក* ១ សាំយូ. ២៦:៩;
ទំនុក. ១០៥:១៥.
*ខ* ២ នីហ្វៃ ១៥:២០;
ម៉ូរ៉ូណៃ ៧:១៤, ១៨.
១៧ *ក* អេភេ. ៥:៦.

បំរើរបស់យើង ប្រយោជន៍ឲ្យពួកគេអាចនាំពួកអ្នកបំរើរបស់យើង
ចូលក្នុងសេវកភាព និងសេចក្ដីស្លាប់ —
១៩ វេទនាដល់ពួកនោះ; ពីព្រោះពួកគេបានជំទាស់កូនតូច
ៗរបស់យើង នោះពួកគេនឹងត្រូវបានកាត់ចេញពីពិធីបរិសុទ្ធទាំង
ឡាយនៃ ដំណាក់របស់យើង ។
២០ កញ្ជើរបស់ពួកគេនឹងមិនបានពេញឡើយ ផ្ទះសំបែងរបស់
ពួកគេ និងជង្រុករបស់ពួកគេនឹងត្រូវវិនាស ហើយរីឯខ្លួនគេនោះ
នឹងត្រូវ គេមើលងាយ ដោយពួកអ្នកដែលបញ្ជោរខ្លួន ។
២១ ពួកគេនឹងពុំមានសិទ្ធិបានបព្វជិតភាពឡើយ ព្រមទាំងពូជពង្ស
របស់ពួកគេបន្តបន្ទាប់មកពីតំណមួយទៅតំណមួយដែរ ។
២២ គ្រាន់បើដល់ពួកគេហើយ បើសិនជាយកថ្មត្បាល់កិន
យ៉ាងធំចងកពួកគេ ហើយពួកគេលង់ទៅក្នុងជំរៅនៃសមុទ្រ ។
២៣ វេទនាដល់អស់អ្នកណាដែលធ្វើទុក្ខរាស្ត្រយើង
ហើយបណ្ដេញ និងធ្វើឃាត និងថ្លែងទីបន្ទាល់ទាស់នឹងពួកគេ ព្រះ
អម្ចាស់នៃពួក ពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ; ពូជពស់វែក
នឹងមិនដែលរួចផុតពីសេចក្ដីផ្ដាច់ទោសនៃស្ថាននរកឡើយ ។
២៤ មើលចុះ ភ្នែកយើងទតមើលឃើញ ហើយស្គាល់អស់
ទាំងកិច្ចការរបស់ពួកគេ ហើយយើងទុកសេចក្ដីជំនុំជំរះឲ្យមកជា
ឆាប់ តាមរដូវកាលវា គឺសំរាប់ពួកគេទាំងអស់;
២៥ ត្បិតមានពេលវេលាកំណត់ទុកសំរាប់មនុស្សគ្រប់រូប
ស្របតាមកិច្ចការរបស់ខ្លួន ។
២៦ ព្រះទ្រង់នឹងប្រទានដំរិះដល់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ
របស់ទ្រង់ មែនហើយ ដោយអំណោយទានជាព្រះវិញ្ញាណ
បរិសុទ្ធ ដែលពុំអាចប្រាប់បាន ដែលពុំទាន់បានបើកសម្ដែងប្រាប់
ចាប់តាំងពីកំណើតលោកិយ រហូតមកដល់ពេលឥឡូវនេះ;
២៧ ដែលពួកដូនតារបស់យើងបានទន្ទឹងចាំដោយអន្ទះសារ
សូមឲ្យបានបើកសម្ដែងប្រាប់ នៅគ្រាចុងក្រោយបង្អស់ ដែលចិត្ត
គំនិតរបស់ ពួកគេបានតម្រង់ទៅរក ដោយពួកទេវតា ដូចជាបាន
រក្សាទុក សំរាប់ភាពពោរពេញនៃសិរីល្អរបស់ពួកគេ;
២៨ ជាពេលវេលាដែលនឹងមកដល់ ដោយគ្មានអ្វីណាមួយ
ដែលត្រូវរក្សាទុកនោះឡើយ ទោះជាមានព្រះតែមួយអង្គ ឬ
ច្រើនអង្គក្ដី គង់តែពួកគេនឹងបានសម្ដែងដែរ ។
២៩ គ្រប់ទាំងបល្ល័ង្ក និងអំណាចគ្រប់គ្រង ក្សត្របុរី និង
អំណាចទាំងឡាយ នឹងត្រូវបានបើកសម្ដែង ហើយប្រទានមកលើ
អស់អ្នកណា ដែលស៊ូទ្រាំដោយក្លាហាន ដើម្បីដំណឹងល្អនៃ
ព្រះយេស៊ូវគ្រីស្ទ ។
៣០ ហើយបន្ថែមទៀត បើសិនជាមានកំរិតដល់ផ្ទៃមេឃ
ឬដល់សមុទ្រទាំងឡាយ ឬដល់ដីគោក ឬដល់ព្រះអាទិត្យ
ព្រះច័ន្ទ ឬតារាទាំងឡាយ —
៣១ គ្រប់ពេលវេលានៃការវិលនៃរបស់ទាំងនោះ គ្រប់កំណត់ថ្ងៃ
ខែ និងឆ្នាំទាំងឡាយ និងគ្រប់ទាំងថ្ងៃនៃថ្ងៃ ខែ និងឆ្នាំនៃរបស់
ទាំងនោះ និងគ្រប់ទាំងសិរីល្អ ច្បាប់ និងពេលកំណត់នៃរបស់
ទាំងនោះ នោះនឹងត្រូវបានបើកសម្ដែង នៅក្នុងថ្ងៃនៃការកាន់កាប់
ត្រួតត្រា នៃពេលពេញកំណត់ —
៣២ ស្របតាមអ្វីដែលបានតែងតាំងឡើង នៅចំកណ្ដាល
ក្រុមប្រឹក្សា នៃព្រះដ៏គង់នៅអស់កល្បជានិច្ច លើព្រះនានាទាំង
អស់ មុនកំណើតលោកិយនេះម៉្លេះ ដែលត្រូវបានរក្សាទុកចំពោះការ
បង្ហើយ និងការបញ្ចប់លោកិយ ក្នុងកាលមនុស្សគ្រប់រូប នឹងបាន
ចូលទៅ ក្នុងវត្តមានដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ និងទៅក្នុង
សេចក្ដីសំរាកដ៏អមតៈរបស់ទ្រង់ ។
៣៣ តើទឹកហូរនឹងនៅកខ្វក់យូរប៉ុណ្ណាទៅ ? តើអំណាចអ្វី
ដែលនឹងបញ្ឈប់ស្ថគ៌ាបាន? ដូចជាមនុស្សណាម្នាក់លាតដៃខ្សោយ

១៩ *ក* ម៉ាថាយ ១៨:៦.
ស.ប. ជំទាស់ចិត្ត.
*ខ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
២០ *ក* ចោទិ. ២៨:១៥–២០.
២១ *ក* ស.ប. បព្វជិតភាព.
២២ *ក* ម៉ាថាយ ១៨:៦;
គ. និង ស. ៥៤:៥.
២៣ *ក* ម៉ាថាយ ១២:៣៤.
២៤ *ក* ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
*ខ* ហេពេ. ៨:២៥.
ស.ប. ជំនុំជំរះ, សេចក្ដីជំនុំជំរះ.
២៥ *ក* យ៉ូប ៧:១; គ. និង ស. ១២២:៩.
*ខ* ស.ប. កិច្ចការ.
២៦ *ក* ដានី. ២:២០–២២;
ម. នៃ ស. ១:៩.
ស.ប. វិវរណៈ.
*ខ* គ. និង ស. ៨:២–៣.
*គ* ស.ប. អំណោយទានជាព្រះ
វិញ្ញាណបរិសុទ្ធ.
២៨ *ក* គ. និង ស. ៤២:៦១;
៧៦:៧–៨; ៩៨:១២.
*ខ* ទំនុក. ៨២:១, ៦;
យ៉ូហាន ១០:៣៤–៣៦;
១ កូរិន. ៨:៥–៦;
គ. និង ស. ៧៦:៥៨; ១៣២:២០;
អ័ប្រា. ៤:១; ៥:១–២.
២៩ *ក* គ. និង ស. ១០១:៣២.
៣០ *ក* យ៉ូប ២៦:៧–១៤;
ទំនុក. ១០៤:៥–៩;
កិច្ចការ ១៧:២៦.
៣១ *ក* ស.ប. គ្រាកាន់កាប់ត្រួតត្រា.
៣២ *ក* ស.ប. ក្រុមប្រឹក្សានៅស្ថានសួគ៌.
*ខ* ចោទិ. ១០:១៧.
*គ* ស.ប. មនុស្ស, មនុស្សលោក —
មនុស្សមានលទ្ធភាពនឹងក្លាយទៅ
ដូចជាព្រះវរបិតា ដែលគង់នៅ
ស្ថានសួគ៌.
*ឃ* ស.ប. សេចក្ដីសំរាក.

ទៅបញ្ឈប់ទន្លេមិសសួរី នៅក្នុងដំណើរវាដែលបានសំរេចទុក ឬបង្វែទឹកហូរបញ្ច្រាសយ៉ាងណា នោះក៏ដូចជាបង្អាក់ព្រះដ៏មានមហិទ្ធិឫទ្ធិ ពីការចាក់ដំរិះពីស្ថានសួគ៌ មកលើក្បាលនៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយយ៉ាងនោះដែរ ។

៣៤ មើលចុះ មានមនុស្សជាច្រើនដែលត្រូវបានហៅ ប៉ុន្តែមានមនុស្សតែបន្តិចទេដែលត្រូវបានរើស ។ ហើយតើហេតុអ្វីបានជាពួកគេ មិនត្រូវបានរើស ?

៣៥ ពីព្រោះចិត្តរបស់ពួកគេត្រូវបានភ្ជាប់ជាខ្លាំងទៅលើអ្វីៗទាំងឡាយនៃលោកនេះ ហើយប្រាថ្នាចង់បានកិត្តិយសនៃមនុស្សលោក ដែលពួកគេពុំបានរៀននូវមេរៀននេះមួយ —

៣៦ ថាសិទ្ធិទាំងឡាយនៃបព្វជិតភាព គឺជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌ ដែលមិនអាចបំបែកបានឡើយ ហើយថាអំ ណាចនៃស្ថានសួគ៌ពុំអាចត្រួតត្រា ឬកាន់កាប់បានឡើយ លើកលែងតែដោយគោលការណ៍នៃសេចក្ដីសុចរិតប៉ុណ្ណោះ ។

៣៧ ឯសិទ្ធិទាំងឡាយអាចបានប្រទានមកលើយើង នោះពិតមែនហើយ; ប៉ុន្តែនៅពេលយើងខំស្វែងរកផ្លូវ ដើម្បីលាក់អំពើបាបទាំងឡាយរបស់យើង ឬដើម្បីបំពេញសេចក្ដីឆ្មើងឆ្មៃរបស់យើង, សេចក្ដីប៉ងប្រាថ្នាដ៏ឥតប្រយោជន៍របស់យើង, ឬដើម្បីអនុវត្តការត្រួតត្រា ឬការគ្រប់គ្រង ឬការបង្ខិតបង្ខំទៅលើព្រលឹងនៃកូនចៅមនុស្ស ដោយនូវសេចក្ដីដ៏ឥតសុចរិតណាមួយ មើលចុះ ស្ថានសួគ៌ដកខ្លួនចេញ; ព្រះវិញ្ញាណនៃព្រះអម្ចាស់ថប់បារម្ភ; ហើយកាលណាព្រះវិញ្ញាណថយចេញ បព្វជិតភាព ឬសិទ្ធិអំណាចនៃមនុស្សនោះត្រូវបានបញ្ចប់ ។

៣៨ មើលចុះ មុនអ្នកនោះដឹងខ្លួន នោះគេនៅតែម្នាក់ឯង ដើម្បីធាក់ជល់នឹងជន្លួញ ដើម្បីបៀតបៀនពួកបរិសុទ្ធ និងដើម្បីប្រឆាំងនឹង ព្រះ ។

៣៩ យើងបានរៀនដោយការពិសោធន៍ដ៏សោហ្មង ថាជាធម្មជាតិ និងនិស្ស័យនៃមនុស្សស្ទើរគ្រប់រូប រំពេចណាពួកគេមានសិទ្ធិ អំណាចបន្តិចបន្តួច តាមដែលពួកគេស្មាន នោះពួកគេនឹងចាប់ផ្ដើមអនុវត្តអំណាចគ្រប់គ្រងដោយឥតសុចរិតភ្លាម ។

៤០ ម្ល៉ោះហើយ បានជាមានមនុស្សជាច្រើនដែលត្រូវបានហៅ ប៉ុន្តែមានមនុស្សតែបន្តិចទេដែលត្រូវបានរើស ។

៤១ គ្មានអំណាច ឬឥទ្ធិពលណាអាច ឬគប្បីកាន់កាប់ ដោយសារបព្វជិតភាពបានឡើយ លើកលែងតែដោយការលួងលោម ដោយការអត់ធ្មត់ ដោយការទន់ភ្លន់ និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ប៉ុណ្ណោះ;

៤២ ដោយចិត្តល្អ និងដោយការចេះដឹងពេញទី ដែលនឹងពង្រីកព្រលឹងឲ្យធំទូលំទូលាយ ដោយឥតលាក់ពុត និងដោយឥតមានឧបាយ កលឡើយ —

៤៣ ដោយស្ដីបន្ទោសសមពេលសមហេតុ ដោយការតឹងរឹង កាលណាបានបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ; ហើយបន្ទាប់មក ដោយបង្ហាញនូវសេចក្ដីស្រឡាញ់ដ៏ច្រើនឡើង ចំពោះអ្នកនោះដែលអ្នកបានស្ដីបន្ទោស ក្រែងអ្នកនោះរាប់អ្នកថាជាខ្មាំងសត្រូវរបស់គេ;

៤៤ ប្រយោជន៍ឲ្យគេអាចដឹងថាសេចក្ដីស្មោះស្ម័គ្ររបស់អ្នក គឺខ្លាំងជាងចំណងនៃសេចក្ដីស្លាប់ ។

៤៥ ក៏សូមឲ្យចិត្តអ្នកពេញទៅដោយសេចក្ដីសប្បុរសដល់មនុស្សទាំងអស់ និងដល់ពួកអ្នកជឿផង ហើយសូមឲ្យគុណធម៌តុបតែងគំនិត អ្នក ដោយឥតឈប់ឈរឡើយ; ខណៈនោះអ្នកនឹងមានចិត្តក្លាហានឡើង នៅចំពោះវត្តមាននៃព្រះ ហើយគោលលទ្ធិអំពីបព្វជិតភាព នឹងចុះមកលើព្រលឹងរបស់អ្នក ដូចជាទឹកសន្សើមចុះពីលើមេឃ ។

៤៦ ព្រះវិញ្ញាណបរិសុទ្ធនឹងទៅជាគូកនអ្នកជានិច្ច ហើយដំបងពេជ្ររបស់អ្នក ជាដំបងពេជ្រនៃសេចក្ដីសុចរិត និងសេចក្ដី

៣៣ *ក* គ. និង ស. ១២៨:១៩.
ស.ប. ដំរិះ.
៣៤ *ក* ម៉ាថាយ ២០:១៦; ២២:១–១៤;
គ. និង ស. ៩៥:៥–៦.
ស.ប. ហៅ, បានហៅពីព្រះ,
ការហៅ.
*ខ* ស.ប. ជំរើស (គ. ឬ ន.).
៣៥ *ក* ស.ប. សេចក្ដីប្រកបដោយលោកិយ.
*ខ* ម៉ាថាយ ៦:២; ២ នីហ្វៃ ២៦:២៩.
៣៦ *ក* ស.ប. បព្វជិតភាព; សិទ្ធិអំណាច.
*ខ* ស.ប. អំណាច.
*គ* ស.ប. សុចរិត, សេចក្ដីសុចរិត.
៣៧ *ក* សុភា. ២៨:១៣.
*ខ* ស.ប. អំពើបាប.
*គ* ស.ប. សេចក្ដីឆ្មើងឆ្មៃ.
*ឃ* គ. និង ស. ១:៣៣.
៣៨ *ក* កិច្ចការ ៩:៥.
*ខ* ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
៣៩ *ក* ស.ប. មនុស្សខាងសាច់ឈាម.
៤១ *ក* ១ ពេត្រុស ៥:១–៣.
*ខ* ២ កូរិន. ៦:៤–៦.
៤២ *ក* យ៉ាកុប ៣:១៧.
*ខ* ស.ប. ឧបាយកល.
៤៣ *ក* ស.ប. វាយផ្ចាល, ការវាយផ្ចាល.
*ខ* ស.ប. សេចក្ដីសប្បុរស;
សេចក្ដីស្រឡាញ់.
៤៥ *ក* ស.ប. គុណធម៌.
*ខ* ស.ប. គំនិត.
*គ* ចោទិ. ៣២:១–២;
គ. និង ស. ១២៨:១៩.
៤៦ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.

ពិត ដែលមិនចេះប្រែប្រួល; ហើយ[ខ]អំណាចគ្រប់គ្រងរបស់អ្នកនឹងទៅជាអំណាចគ្រប់គ្រងដ៏នៅអស់កល្បអស់កាលជានិច្ច ហើយដោយឥត ការបង្ខិតបង្ខំ នោះវានឹងហូរមកលើអ្នកជារៀងដរាបតទៅ ៕

## កណ្ឌទី ១២២

*ព្រះបន្ទូលនៃព្រះអម្ចាស់ទៅកាន់ យ៉ូសែប ស្ម៊ីធ ជាព្យាការី កាលលោកជាប់នៅក្នុងគុក នៅក្រុងលិបើទី រដ្ឋមិសសួរី ខែមីនា ឆ្នាំ១៨៣៩ (*History of the Church*, ៣:៣០០–៣០១)* ។

*១–៤, នៅគ្រប់ចុងផែនដីនឹងសាកសួរអំពីឈ្មោះនៃ យ៉ូសែប ស្ម៊ីធ; ៥–៧, អស់ទាំងគ្រោះ និងការលំបាកទាំងឡាយរបស់លោក នោះនឹងផ្ដល់ការពិសោធន៍ដល់លោក ហើយទៅជាសេចក្ដីល្អដល់លោកទៅវិញ; ៨–៩, កូនមនុស្សបានចុះទាបជាងការណ៍ទាំងនោះ ។*

នៅគ្រប់ចុងផែនដីនឹងសាកសួរអំពី[ក]ឈ្មោះរបស់អ្នក ហើយពួកល្ងង់ខ្លៅនឹងសើចចំអកអ្នក ហើយស្ថាននរកខ្ញាល់ទាស់នឹងអ្នក;

២ ក្នុងកាលអ្នកមានចិត្តបរិសុទ្ធ និងអ្នកមានប្រាជ្ញា និងអ្នកដែលមានត្រកូលខ្ពស់ និងអ្នកដែលមានគុណធម៌ នោះនឹងស្វែងរក[ក]ដំបូន្មាន និងសិទ្ធិអំណាច និងព្រះពរទាំងឡាយជារៀងរហូតពីក្រោមដៃអ្នក ។

៣ ហើយប្រជាជនរបស់អ្នកនឹងមិនដែលបែរទៅជាទាស់នឹងអ្នក ដោយសារទីបន្ទាល់នៃពួកក្បត់ឡើយ ។

៤ ហើយទោះបីឥទ្ធិពលរបស់ពួកគេនឹងបោះបង់អ្នកទៅក្នុងចលាចល និងទៅក្នុងរបង និងកំផែង[ក]គុកក៏ដោយ គង់តែអ្នកនឹងបានកិត្តិយស ដែរ; ហើយគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ ហើយសម្លេងអ្នកនឹងទៅជាស្ទែងខ្លាចជាង[ខ]សិង្ហសាហាវទៅទៀត នៅកណ្ដាលពួកខ្មាំងសត្រូវ នៃអ្នក ពីព្រោះតែសេចក្ដីសុចរិតរបស់អ្នក; ហើយព្រះរបស់អ្នកនឹងឈរនៅក្បែរអ្នក ជារៀងដរាបតទៅ ។

៥ បើសិនជាអ្នកត្រូវបានហៅឲ្យឆ្លងកាត់សេចក្ដីវេទនា; បើសិនជាអ្នកមានគ្រោះ នៅក្នុងចំណោមពួកបងប្អូនអ្នកក្នុងសាសនា; បើសិនជាអ្នកមានគ្រោះ នៅក្នុងចំណោមពួកចោរប្លន់; បើសិនជាអ្នកមានគ្រោះ ដោយដី ឬដោយទឹក;

៦ បើសិនជាអ្នកត្រូវគេចោទដោយការចោទក្លែងក្លាយគ្រប់បែបយ៉ាង; បើសិនជាពួកខ្មាំងសត្រូវរបស់អ្នកសង្កត់មកលើអ្នក; បើសិនជា ពួកគេបំបាក់បំបែកអ្នកចេញពីសមាគមនៃឪពុក និងម្ដាយ និងបងប្អូនប្រុសស្រីរបស់អ្នក; ហើយបើសិនជាពួកខ្មាំងសត្រូវរបស់អ្នកបំបាក់ បំបែកអ្នកដោយដាវចេញពីឱរានៃប្រពន្ធអ្នក និងពីកូនចៅអ្នក ហើយពីកូនច្បងបង្អស់របស់អ្នក ទោះជាមានអាយុតែប្រាំមួយឆ្នាំគត់ក្ដី គឺវានឹងតោង ខោអាវអ្នកជាប់ ហើយនឹងវាចាថា៖ លោកឪពុក លោកឪពុក ម៉េចក៏ពុកមិននៅជាមួយយើង ? ឱលោកឪពុកអើយ តើមនុស្សទាំង ឡាយគេនឹងធ្វើអ្វីដល់ពុក ? ហើយបើសិនជាវាត្រូវគេគ្រវែងចេញពីអ្នកដោយដាវ ហើយអ្នកត្រូវគេអូសទៅដាក់គុក ហើយពួកខ្មាំង សត្រូវរបស់អ្នកដើរក្រវែលជុំវិញអ្នក ដូចជា[ក]ចចកធុំឈាមនៃកូនចៀមក្ដី;

៧ ហើយបើសិនជាអ្នកត្រូវបានបោះទៅក្នុងរណ្ដៅ ឬទៅក្នុងកណ្ដាប់ដៃនៃពួកឃាតករ ហើយអ្នកត្រូវគេកាត់ទោសដល់ស្លាប់; បើសិនជា អ្នកបោះទៅក្នុង[ក]ជំរៅ; បើសិនជាទឹករលកបោកបាចទាស់នឹងអ្នក; បើសិនជាខ្យល់កួចគ្រឡប់ជាខ្មាំងសត្រូវដល់អ្នក; បើសិនជាផ្ទៃមេឃ ទៅជាងងឹតឈឹង ហើយអស់ទាំងធនធាតុប្រមូលគ្នារារាំងផ្លូវ; ហើយទោះបីលើសជាងអ្វីៗទាំងអស់ បើសិនជាចង្កោមមាត់នៃ[ខ]ស្ថាននរក នឹងហារត្របាក់អ្នកក្ដី ឱ្យត្រូវឬ បុត្រយើងអើយ ចូរអ្នកដឹងថា គ្រប់ការណ៍ទាំងនេះ នឹងផ្ដល់ការ[គ]ពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នក ទៅវិញ ។

៤៦ *ខ* ដានី. ៧:១៣–១៤.
**១២២** ១*ក* យ.ស. — ប្រវត្តិ ១:៣៣.
២ *ក* ស.ប. ពាក្យទូន្មាន (ន.).
៤ *ក* គ. និង ស. ១២១:៧–៨.
*ខ* ៣ នីហ្វៃ ២០:១៦–២១; ២១:១២.
៦ *ក* លូកា ១០:៣.
៧ *ក* យ៉ូណាស ២:៣–៦.
*ខ* ២ សាំយូ. ២២:៥–៧; យ.ស. — ប្រវត្តិ ១:១៥–១៦.
*គ* ២ កូរិន. ៤:១៧; ហេព្រើរ ១២:១០–១១; ២ នីហ្វៃ ២:១១.

៨ [ក]កូនមនុស្សបាន[ខ]ចុះទាបជាងការណ៍ទាំងនោះទៅទៀត ។
តើអ្នកធំជាងទ្រង់ឬអី ?
៩ ហេតុដូច្នេះហើយ កូនកាន់ផ្លូវឲ្យខ្ជាប់ ហើយបព្វជិតភាពនឹង
[ក]នៅជាមួយអ្នក; ត្បិត[ខ]ក៏រិតទាំងឡាយរបស់ពួកគេត្រូវបានចាត់ទុក
ពួកគេពុំអាច បង្ហួសបានឡើយ ។ [គ]ថ្ងៃរបស់អ្នកត្រូវបានរាប់ទុក
ហើយឆ្នាំរបស់អ្នក[ឃ]មិនត្រូវបានរាប់ទុកជាតិចឡើយ; ហេតុ
ដូច្នេះហើយ ចូរកុំខ្លាចនូវអ្វី ដែលមនុស្សអាចប្រព្រឹត្តនោះឡើយ
ត្បិតព្រះទ្រង់នឹងគង់នៅជាមួយអ្នក ជារៀងដរាបតទៅ ៕

## កណ្ឌទី ១២៣

*កាតព្វកិច្ចនៃពួកបរិសុទ្ធដែលទាក់ទងទៅនឹងពួកអ្នកបៀតបៀនរបស់ខ្លួន នោះត្រូវបានថែងឡើងដោយ យ៉ូសែប ស្ម៊ីធ ជាព្យាការីកាល លោកជាប់នៅក្នុងគុក នៅក្រុងលិបើទី រដ្ឋមិសសួរី ខែមីនា ឆ្នាំ១៨៣៩ (*History of the Church, *៣:៣០២–៣០៣)* ។

*១–៦, ពួកបរិសុទ្ធគប្បីប្រមូល ហើយបោះពុម្ពនូវដំណើររឿងអំពីការទុក្ខលំបាក និងការបៀតបៀនទាំងឡាយរបស់ពួកគេ; ៧–១០, វិញ្ញាណដដែលនោះ ដែលតាំងជំនឿក្លែងក្លាយ ក៏បាននាំឲ្យមានការបៀតបៀនដល់ពួកបរិសុទ្ធដែរ; ១១–១៧, មនុស្សជាច្រើន នៅក្នុងចំណោមក្រុមសាសនាទាំងអស់ នោះនឹងនៅតែបានទទួលសេចក្ដីពិត ។*

ហើយជាថ្មីទៀត យើងខ្ញុំសូមឲ្យអ្នកពិចារណាពីភាពសមបែបសម
បទ នូវគ្រប់ទាំងអ្វីៗដែលពួកបរិសុទ្ធប្រមូលទុកជាសំគាល់
អំពីការពិត ការទុក្ខវេទនា និងការទុក្ខទោសទាំងអស់ ដែល
ប្រជាជននៃរដ្ឋនេះបានដាក់មកលើពួកគេ;
២ ហើយព្រមអស់ទាំងរបស់របរ និងចំនួនខូចខាតទាំងប៉ុន្មាន
ដែលពួកគេបានទទួល ទាំងខាងខូចនាមខូចប្រាណ និងខាងខូច
របស់របរ ពិតប្រាកដផង;
៣ ហើយព្រមទាំងឈ្មោះនៃជនគ្រប់រូប ដែលមានចំណែកក្នុង
ការសង្កត់សង្កិនពួកគេ តាមដែលពួកគេអាចរកបានឈ្មោះ
ទាំងនោះ ហើយស្វែងរកឈ្មោះទាំងនោះបាន ។
៤ ហើយប្រហែលជាអាចតាំងគណៈកម្មាធិការមួយឡើង
ដើម្បីស្វែងរកការណ៍ទាំងនេះ និងដើម្បីកត់នូវដំណើររឿង និង
សំបុត្រ ភស្តុតាងទាំងឡាយ; ហើយព្រមទាំងប្រមូលនូវការ
បោះពុម្ពផ្សាយបង្ខូចកេរ្តិ៍ទាំងឡាយ ដែលសុសសាយ;
៥ និងការណ៍ទាំងអស់ដែលនៅក្នុងទស្សនាវដ្ដីទាំង
ឡាយ និងនៅក្នុងសព្វវចនាធិប្បាយទាំងឡាយ និងគ្រប់ទាំង
ប្រវត្តិបង្ខូចកេរ្តិ៍ទាំង ឡាយ ដែលបានបោះពុម្ពផ្សាយ ហើយ
កំពុងកត់ទុក និងដោយអ្នកណា ហើយបង្ហាញប្រាប់ពីប្រជុំអំពើ
ទុច្ចរិត និងការបង្ខំដ៏អាក្រក់អាស្រូវ និងឃាតកម្មទាំងឡាយ
ដែលបានប្រព្រឹត្តមកលើប្រជាជននេះ —
៦ គឺមិនគ្រាន់តែឲ្យយើងអាចបោះពុម្ពផ្សាយប្រាប់ដល់អស់
ទាំងពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែអាចបង្ហាញប្រាប់ពីរឿងនោះ
ដល់ក្រសួង រាជការទាំងឡាយ នូវគ្រប់ទាំងសម្បុររបស់ពួក
គេដែលងងឹតងងល់ និងដូចជានរក ទុកជាការប្រឹងប្រែងចុង
ក្រោយបង្អស់ ដែលតម្រូវពី យើង ដោយព្រះវរបិតាសួគ៌
មុនយើងអាចទាមទារយកសេចក្ដីសន្យានោះបានដោយពេញ
លេញ ដែលនឹងទូលសូមទ្រង់ឲ្យយាងចេញ មកពី[ក]ទីកំបាំងរបស់
ទ្រង់; ហើយក៏ដើម្បីកុំឲ្យសាសន៍ទាំងមូលអាចបាននៅដោយការ
ដោះសា មុនទ្រង់អាចចាត់ព្រះចេស្ដានៃព្រះពាហុដ៏ ខ្លាំងក្លា
របស់ទ្រង់ចេញមក ។
៧ គឺជាកាតព្វកិច្ចដ៏ចាំបាច់ ដែលយើងមានចំពោះព្រះ ចំពោះ
ពួកទេវតា ដែលពួកយើងនឹងត្រូវបាននាំមកឈរជាមួយ ហើយ
ចំពោះខ្លួន យើងផ្ទាល់ ចំពោះប្រពន្ធកូនយើង ដែលត្រូវបាន
ធ្វើឲ្យឱនចុះ ដោយការទុក្ខព្រួយសោកសៅ និងទុក្ខសង្រេង
នៅក្រោមកណ្ដាប់ដៃដ៏អា ស្រូវបំផុតនៃឃាតករ អំណាចផ្ដាច់ការ
និងការសង្កត់សង្កិន ដែលបានគាំទ្រ និងទ្រទ្រង់ដោយឥទ្ធិពល
នៃវិញ្ញាណនោះ ដែលបានបញ្ចុះ ជំនឿទាំងឡាយដល់ពួក

៨ *ក* ស.ប. កូនមនុស្ស.
*ខ* ហេព្រើរ ២:៩, ១៧–១៨;
គ. និង ស. ៧៦:១០៧; ៨៨:៦.
៩ *ក* គ. និង ស. ៩០:៣.
*ខ* កិច្ចការ. ១៧:២៦.
*គ* គ. និង ស. ១២១:២៥.
*ឃ* នេហេ. ៤:១៤;
ទំនុក. ៥៦:៤; ១១៨:៦;
សុភា. ៣:៥–៦; អេសាយ ៥១:៧;
លូកា ១២:៤–៥; ២ នីហ្វៃ ៨:៧;
គ. និង ស. ៣:៧; ៩៨:១៤.
**១២៣** ៦ *ក* គ. និង ស. ១០១:៨៩;
១២១:១, ៤.

អយ្យកោ ដែលបានអំពើកុហកទាំងឡាយ តមកក្នុងដួងចិត្តនៃកូនចៅ ហើយបានបំពេញពិភពលោក ដោយ ចលាចល ហើយបានរីកកាន់តែធំឡើងៗ ហើយឥឡូវនេះ ទៅជាប្រភពដ៏ពេញទំហឹង នៃការពុករលួយទាំងអស់ ហើយផែនដីទាំងមូលថ្ងូរនៅក្រោមទម្ងន់នៃសេចក្ដីទុច្ចរិតរបស់វា ។

៨ គឺជានឹមដែក គឺជាចំណងដ៏មាំ; របស់ទាំងនោះសុទ្ធតែជាខ្នោះដៃ និងច្រវាក់ និងខ្នោះជើង និងគំនាបពីស្ថាននរក ។

៩ ហេតុដូច្នេះហើយ គឺជាកាតព្វកិច្ចដ៏ចាំបាច់ ដែលយើងមាន មិនគ្រាន់តែចំពោះប្រពន្ធកូនយើងផ្ទាល់ទេ ប៉ុន្តែចំពោះពួកស្រីមេម៉ាយ និងកូនកំព្រាដែរ ដែលប្ដី និងឪពុកត្រូវគេធ្វើឃាតនៅក្រោមដៃដែករបស់វា;

១០ ដែលជាអំពើដ៏ងងឹតងងល់ទាំងឡាយ ល្មមធ្វើឲ្យស្ថាននរកញ័ររន្ធត់ ហើយឈរតក់ស្លុត និងស្លាំងស្លក់ ហើយដៃទាំងឡាយនៃអារក្ស ផ្ទាល់ក៏ញញាក់ញញ័រដែរ ។

១១ ហើយក៏ជាកាតព្វកិច្ចដ៏ចាំបាច់ ដែលយើងមាន ចំពោះជំនាន់ក្រោយ និងចំពោះពួកអ្នកមានចិត្តបរិសុទ្ធ —

១២ ត្បិតមានមនុស្សជាច្រើននៅលើផែនដីនៅឡើយ នៅក្នុងចំណោមក្រុម ប័ក្ស និកាយទាំងឡាយ ដែលបានខ្វាក់ដោយសារ ឧបាយកលដ៏ប្រសប់នៃមនុស្ស ម្ល៉ោះហើយ ទើបពួកគេពួនចាំបញ្ឆោត ហើយជាពួកអ្នកដែលលាក់ពីសេចក្ដីពិត ពីព្រោះពួកគេមិន ដឹងជាទៅរកសេចក្ដីពិតឯណាទេ —

១៣ ហេតុដូច្នេះហើយ គឺថាយើងគួរចំណាយ និងបង្ហិនជីវិតរបស់យើង ក្នុងការនាំពន្លឺមករកការណ៍កំបាំងទាំងឡាយនៃសេចក្ដីងងឹត ណា ដែលយើងស្គាល់; ហើយការណ៍ទាំងនោះសុទ្ធតែបានសម្ដែងប្រាប់មកពីស្ថានសួគ៌ —

១៤ ខណៈនោះ កិច្ចការទាំងនេះគួរតែប្រព្រឹត្តដោយការព្យាយាមដ៏ខ្នះខ្នែង ។

១៥ ចូរកុំឲ្យមនុស្សណាមួយរាប់ថាការណ៍នោះជាតូចឡើយ; ត្បិតមានការណ៍ជាច្រើននៅអនាគត ដោយមានទំនាក់ទំនងទៅនឹងពួក បរិសុទ្ធ ដែលពឹងពាក់ទៅលើការណ៍ទាំងនេះដែរ ។

១៦ បងប្អូនអើយ អ្នកដឹងហើយថាសំពៅដ៏ធំ បានទទួលជំនួយពីចង្កូតដ៏តូច ក្នុងកាលមានខ្យល់ព្យុះ ដោយសារដំណើរ ប្រក្រតីនឹងខ្យល់ និងរលក ។

១៧ ហេតុដូច្នេះហើយ បងប្អូនដ៏សូនភ្ងាអើយ ចូរយើងប្រព្រឹត្តការណ៍ទាំងនេះ ដែលនៅក្នុងអំណាចយើង ដោយមានចិត្តរីករាយចុះ; ហើយលំដាប់នោះ យើងអាចឈរនៅស្ងៀមដោយជឿជាក់ថានឹងបានឃើញសេចក្ដីសង្គ្រោះពីព្រះ និងបានព្រះពាហុទ្រង់បើកសម្ដែង មកឲ្យឃើញ ៕

## កណ្ឌទី ១២៤

*វិវរណៈដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងណៅវូ រដ្ឋអិលលីណោយ ថ្ងៃទី១៩ ខែមករា ឆ្នាំ១៨៤១ (*History of the Church, *៤:២៧៤–២៨៦)* ។ *មកពីការបៀតបៀន និងទម្រង់ការខុសច្បាប់មានចេះតែច្រើនឡើងទាស់នឹងពួកគេ ពីពួករដ្ឋការ បានជាពួកបរិសុទ្ធត្រូវគេបង្ខំឲ្យចេញពីរដ្ឋមិសសួរី ។ បញ្ញត្តិឲ្យកំចាត់ចោល ដែលបានចេញដោយលោកលិលបឺន ដ័បបុលយូ បកស៍ ជាអភិបាលរដ្ឋមិសសួរី ចុះនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៨៣៨ នោះពុំបានទុកឲ្យពួកគេមានផ្លូវណាទៀតឡើយ (*History of the Church, *៣:១៧៥)* ។ *នៅឆ្នាំ១៨៤១ កាលវិវរណៈនេះត្រូវបានប្រទានមក នោះទីក្រុងណៅវូ ដែលនៅចំ កន្លែងភូមិដើម នៃភូមិខមមើស រដ្ឋអិលលីណោយ ត្រូវបានសង់ឡើងដោយពួកបរិសុទ្ធ ហើយនៅទីនេះហើយ ទីស្នាក់ការនៃ សាសនាចក្រត្រូវបានតាំងឡើង ។*

*១–១៤, យ៉ូសែប ស្ម៊ីធ ត្រូវបានបញ្ជាឲ្យអនុវត្តការប្រកាសដ៏ម៉ឺងម៉ាត់ ប្រាប់អំពីដំណឹងល្អ ដល់ប្រធានាធិបតីនៃសហរដ្ឋ ដល់អភិបាលរដ្ឋ ទាំងឡាយ និងដល់ពួកអ្នកគ្រប់គ្រងអស់ទាំងសាសន៍; ១៥–២១, ហៃរុម ស្ម៊ីធ, ដាវីឌ ដ័បបុលយូ ប៉ាទិន, យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ, និងពួកអ្នកផ្សេងៗទៀត ដែលនៅក្នុងចំណោមពួកអ្នករស់ និងពួកអ្នកស្លាប់ នោះត្រូវបានទទួលព្រះពរ ដោយសារសេចក្ដីទៀងត្រង់ និងសេចក្ដីស្មោះរបស់ពួកគេ; ២២–២៨, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យស្ថាបនាទីសំណាក់សំរាប់ជាទីកំសាន្ត*

៧ *ក* ម៉ូសេ ៧:៤៨–៤៩.
៨ *ក* ស.ប. នឹម.
៩ *ក* គ. និង ស. ៩៨:១៣; ១២៤:៥៤.
១២ *ក* កូល៉ុស ២:៨; គ. និង ស. ៧៦:៧៥.
*ខ* ១ នីហ្វៃ ៨:២១–២៣.
១៣ *ក* ១ កូរិន. ៤:៥.
១៦ *ក* យ៉ាកុប (ព.ស.ថ.) ៣:៤; អាលម៉ា ៣៧:៦–៧; គ. និង ស. ៦៤:៣៣.
១៧ *ក* គ. និង ស. ៥៩:១៥.
*ខ* និក្ខ. ១៤:១៣.

*ដល់មនុស្សដទៃ និងព្រះវិហារមួយ នៅក្រុងណៅវូ; ២៩–៣៦, បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ត្រូវបានប្រព្រឹត្តឡើងនៅក្នុងព្រះវិហារ; ៣៧–៤៤, រាស្ត្ររបស់ព្រះអម្ចាស់ ស្ថាបនាព្រះវិហាររហូត សំរាប់ការប្រព្រឹត្តិនូវពិធីបរិសុទ្ធទាំងឡាយ; ៤៥–៥៥, ពួកបរិសុទ្ធត្រូវបានរួចពីការស្ថាបនាព្រះវិហារនៅឃុំចាកសុន មកពីការសង្កត់សង្កិននៃពួកខ្មាំងសត្រូវរបស់ពួកគេ; ៥៦–៨៣, ការបង្គាប់ទាំងឡាយត្រូវបានប្រទាន សំរាប់ការស្ថាបនា ណៅវូហោស; ៨៤–៩៦, ហៃរុម ស្ម៊ីធ ត្រូវបានហៅឲ្យធ្វើជាលោកអយ្យកោ ដើម្បីទទួលកូនសោទាំងឡាយ និងដើម្បីឈរជំនួស អូលីវើ ខៅឌើរី; ៩៧–១២២, វិលលាម ឡាវ៍ និងពួកអ្នកផ្សេងៗទៀតត្រូវបានទូន្មានអំពីការងារ របស់ពួកគេ; ១២៣–១៤៥, ពួកអ្នកដឹកនាំទូទៅ និងពួកអ្នកដឹកនាំនៅប្រចាំភូមិត្រូវបានប្រាប់ឈ្មោះ ព្រមទាំងភារកិច្ច និងក្រុមដែលពួកគេចូលរួម ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដល់អ្នក គឺ យ៉ូសែប ស្ម៊ីធ ជាអ្នកបំរើរបស់យើងថា យើងពេញចិត្តនឹងដង្វាយ និងការទទួល ស្គាល់របស់អ្នក ដែលអ្នកបានធ្វើ; ត្បិតចំពោះការណ៍នេះហើយ ដែលយើងបានលើកអ្នកឡើង ប្រយោជន៍ឲ្យយើងអាចបង្ហាញនូវប្រាជ្ញា របស់យើង តាមរយៈ[ក]ពួកកំសោយនៃផែនដី ។

២ ការអធិស្ឋានទាំងឡាយរបស់អ្នក នោះយើងទទួលស្គាល់ហើយ រីឯចម្លើយដល់ការណ៍ទាំងនោះ នោះយើងប្រាប់អ្នកថា ពេលនេះ អ្នកត្រូវបានហៅយ៉ាងឆាប់ឲ្យអនុវត្តការប្រកាសដ៏ម៉ឺងម៉ាត់ ប្រាប់អំពីដំណឹងល្អ និងប្រាប់អំពី[ក]ស្តេកនេះ ដែលយើងបានតាំងឡើងជាថ្មសីមា នៃស៊ីយ៉ូន ដែលនឹងត្រូវបានដាប់ដោយក្បាច់ក្បូរតាមរបៀបព្រះរាជវាំង ។

៣ ការប្រកាសនេះ នឹងត្រូវបានធ្វើឡើងដល់អស់ទាំង[ក]មហាក្សត្រនៃពិភពលោក ដល់ជ្រុងទាំងបួននៃផែនដី ដល់ប្រធានាធិបតីដែលបាន រើសតាំងឡើងដោយកិត្តិយស និងដល់ពួកអភិបាលរដ្ឋដ៏ឧត្តមនៃប្រទេសដែលអ្នករស់នៅ និងដល់អស់ទាំងសាសន៍ក្នុងផែនដី ដែលខ្ចាត់ខ្ចាយពាសពេញទូទៅផង ។

៤ ចូរសរសេរការប្រកាសនោះដោយវិញ្ញាណនៃ[ក]ភាពស្លូតបូត និងដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងស្ថិតនៅក្នុងអ្នក នៅពេលសរសេរការប្រកាសនោះ;

៥ ត្បិតការណ៍នោះនឹងត្រូវបានប្រទានដល់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ ឲ្យដឹងនូវព្រះហឫទ័យរបស់យើង អំពីមហាក្សត្រ និងពួកអ្នក មានសិទ្ធិអំណាចទាំងនោះ ព្រមទាំងអ្វីៗដែលនឹងធ្លាក់មកលើពួកគេ នៅពេលខាងមុខផង ។

៦ ត្បិតមើលចុះ យើងកំពុងតែនឹងហៅពួកគេ ឲ្យស្ដាប់តាមពន្លឺ និងសិរីល្អនៃស៊ីយ៉ូន ត្បិតពេលកំណត់បានមកដល់នាងហើយ ។

៧ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាស្រែកប្រាប់ពួកគេ ដោយការប្រកាសដ៏ខ្លាំង និងដោយទីបន្ទាល់របស់អ្នកចុះ ចូរកុំខ្លាចពួកគេឡើយ ត្បិតពួកគេជា[ក]ស្មៅ ហើយសិរីល្អរបស់ពួកគេដូចជាផ្កានៃស្មៅនោះ ដែលនឹងរោយចុះជាឆាប់ៗ ប្រយោជន៍កុំឲ្យពួកគេអាចដោះសារបាន —

៨ ហើយប្រយោជន៍ឲ្យយើងអាចមករកពួកគេនៅថ្ងៃនៃការពិនិត្យពិច័យ កាលដែលយើងនឹងបើកស្បៃចេញពីមុខយើង ដើម្បីចាត់ ចំណែកនៃពួកសង្កត់សង្កិន ទុកក្នុងចំណោមពួកអ្នកមានពុត ជាទីដែលមាន[ក]សង្កៀតធ្មេញ បើសិនជាពួកគេមិនទទួលស្គាល់ពួកអ្នកបំរើ របស់យើង និងទីបន្ទាល់របស់យើង ដែលយើងបានបើកសម្ដែងដល់ពួកគេនោះ ។

៩ ហើយជាថ្មីទៀត យើងនឹងមករក ហើយបន្ទន់ចិត្តពួកគេ គឺពួកគេជាច្រើនដើម្បីជាការល្អដល់អ្នក ប្រយោជន៍ឲ្យអ្នកអាចបានគុណធម៌ នៅក្នុងភ្នែកគេ ប្រយោជន៍ឲ្យពួកគេអាចមករក[ក]ពន្លឺនៃសេចក្ដីពិត និងឲ្យពួកសាសន៍ដទៃទៅរកភាពដំកើងឡើង ឬភាពលើកឡើងនៃ ស៊ីយ៉ូន ។

១០ ត្បិតថ្ងៃនៃការពិនិត្យពិច័យរបស់យើងនឹងមកជាប្រញាប់ គឺនៅ[ក]វេលាដែលអ្នករាល់គ្នាមិនគិត ហើយតើទីណាទៅ ជាទីសន្តិសុខនៃ រាស្ត្រយើង និងជាទីពឹងជ្រក សំរាប់ពួកអ្នកដែលនៅសល់ ?

**១២៤** ១*ក* ១ កូរិន. ១:២៦–២៨;
គ. និង ស. ១:១៩; ៣៥:១៣.
២ *ក* ស.ប. ចំរឹង, ស្តេក.
៣ *ក* ទំនុក. ១១៩:៤៦;
ម៉ាថាយ ១០:១៨;
គ. និង ស. ១:២៣.
៤ *ក* ស.ប. ស្លូតបូត, ភាពស្លូតបូត.
៧ *ក* ទំនុក. ១០៣:១៥–១៦;
អេសាយ ៤០:៦–៨;
១ ពេត្រុស ១:២៤–២៥.
៨ *ក* ម៉ាថាយ ៨:១២;
អាលម៉ា ៤០:១៣;
គ. និង ស. ១០១:៩១; ១១២:២៤.
៩ *ក* អេសាយ ៦០:១–៤.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
១០ *ក* ម៉ាថាយ ២៤:៤៤;
យ.ស. — ម៉ាថាយ ១:៤៨.

១១ ចូរភ្ញាក់ឡើង ឱពួកមហាក្សត្រនៃផែនដីអើយ! ចូរមក ឱ
ចូរមកជាមួយមាសរបស់អ្នក និងប្រាក់របស់អ្នក ដើម្បីរ
ទាជួយរាស្ត្រយើង គឺទោឯគេហដ្ឋាននៃពួកស្រីៗនៃក្រុងស៊ីយ៉ូន ។
១២ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យ រ៉ូបឺត
ប៊ី ថមសុន ជាអ្នកបំរើរបស់យើង ជួយអ្នកសរសេរការ
ប្រកាសនេះ ត្បិតយើងពេញចិត្តនឹងគាត់ណាស់ ហើយដើម្បីឲ្យ
គាត់អាចបាននៅជាមួយអ្នក;
១៣ ហេតុដូច្នេះហើយ ចូរឲ្យគាត់ប្រុងស្ដាប់តាមការទូន្មាន
របស់អ្នក ហើយយើងនឹងប្រទានពរដល់គាត់ ដោយព្រះពរ
ដ៏ច្រើនអនេក; ចូរ ឲ្យគាត់មានចិត្តស្មោះ និងពិតត្រង់ក្នុងការណ៍
ទាំងអស់ ចាប់តាំងពីអំណិះតទៅ ហើយគាត់នឹងបានធំ នៅក្នុង
ព្រះនេត្ររបស់យើង;
១៤ ប៉ុន្តែចូរឲ្យគាត់នឹកចាំពី[ក]ការកាន់កាប់ត្រួតត្រារបស់គាត់
ដែលយើងតម្រូវពីដៃរបស់គាត់ចុះ ។
១៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា មាន
ពរហើយ [ក]ហៃរុម ស្ម៊ីធ ជាអ្នកបំរើរបស់យើង; ត្បិតយើងជាព្រះ
អម្ចាស់ ស្រឡាញ់ គាត់ មកពី[ខ]សេចក្ដីស្មោះនៃចិត្តរបស់គាត់ និង
មកពីគាត់បានស្រឡាញ់នូវអ្វីដែលត្រឹមត្រូវចំពោះយើង ព្រះ
អម្ចាស់ទ្រង់មានព្រះបន្ទូល ថាដូច្នោះ ។
១៦ ជាថ្មីទៀត ចូរឲ្យ យ៉ូហាន ស៊ី បិនណែត ជាអ្នកបំរើ
របស់យើង ជួយអ្នកក្នុងការងាររបស់អ្នក នូវការផ្ញើព្រះបន្ទូល
របស់យើងទៅពួក មហាក្សត្រ និងប្រជាជននៃផែនដី
ហើយឈរនៅក្បែរអ្នក គឺ យ៉ូសែប ស្ម៊ីធ ជាអ្នកបំរើរបស់យើង
នៅក្នុងម៉ោងនៃសេចក្ដីទុក្ខវេទនា ហើយរង្វាន់របស់គាត់នឹង
ពុំបាត់បង់ឡើយ បើសិនជាគាត់ទទួល[ក]ការទូន្មាន ។
១៧ ហើយមកពីសេចក្ដីស្រឡាញ់របស់គាត់ នោះគាត់នឹងបាន
ទៅជាធំ ត្បិតគាត់នឹងបានទៅជារបស់ផងយើង បើសិនជាគាត់
ប្រព្រឹត្ត ការណ៍នេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
យើងបានឃើញកិច្ចការដែលគាត់បានប្រព្រឹត្ត ដែលយើងទទួល
បើសិនជាគាត់ ធ្វើតទៅ ហើយនឹងបំពាក់គាត់ដោយព្រះពរទាំង
ឡាយ និងសិរីល្អដ៏ធំ ទុកជាមកុដ ។
១៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា ជាព្រះហឫទ័យ
របស់យើង ដែល ឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើង គួរផ្សាយ
តទៅទៀត ដើម្បីក្រុងស៊ីយ៉ូន នៅក្នុងវិញ្ញាណនៃភាពស្លូតបូត
ដោយទទួលថ្លែងប្រាប់ពីយើង នៅមុខមនុស្សលោក; ហើយយើង
នឹងទ្រគាត់លើស្លាប [ក]ឥន្ទ្រី; ហើយគាត់នឹងបង្កើតសិរីល្អ និងកិត្តិយ
សចំពោះខ្លួន និងចំពោះព្រះនាមរបស់យើងដែរ ។
១៩ គឺកាលណាគាត់បញ្ចប់កិច្ចការរបស់គាត់ នោះយើងអាច
ទទួលគាត់មកចំពោះខ្លួនយើងផ្ទាល់ ដូចជាយើងបានធ្វើដល់ [ក]ដាវីឌ
ប៉ាទិ្តន ជាអ្នកបំរើរបស់យើងដែរ គឺជាអ្នកដែលនៅជាមួយ
យើងនៅពេលនេះ និងព្រមទាំង [ខ]អែតរីត ប៉ាទ្រិច ជាអ្នកបំរើ
របស់យើង និងព្រមទាំង [គ]យ៉ូសែប ស្ម៊ីធ ស៊ីញ៉ែរ ជាអ្នក
បំរើដ៏ចំណាស់របស់យើងផងដែរ ដែលអង្គុយជាមួយលោក
អ័ប្រាហាំ នៅខាងស្ដាំដៃរបស់លោក ហើយ លោកមានពរ
ហើយបរិសុទ្ធផង ព្រោះលោកជារបស់ផងយើង ។
២០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ជួច
មិលលើ ជាអ្នកបំរើរបស់យើង គាត់គ្មាន[ក]ឧបាយកលឡើយ;
គាត់ជាអ្នកដែលអាច ទុកចិត្តបាន មកពីសេចក្ដីទៀងត្រង់នៃចិត្ត
គាត់; ហើយមកពីសេចក្ដីស្រឡាញ់ ដែលគាត់មាន ចំពោះ
ទីបន្ទាល់អំពី យើង នោះយើងជាព្រះ អម្ចាស់ស្រឡាញ់គាត់ ។
២១ ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា យើងបិទត្រាមក
លើក្បាលគាត់ នូវតំណែងខាង[ក]គណៈប៊ីស្សព ដូចជាចំពោះ
អែតរីត ប៉ាទ្រិច ជាអ្នកបំរើរបស់យើងដែរ ប្រយោជន៍ឲ្យគាត់
អាចទទួលការថ្វាយពីគេហដ្ឋានរបស់យើង ប្រយោជន៍ឲ្យគាត់
អាចប្រគល់ពរមកលើ ក្បាលនៃពួកក្រីក្រនៃរាស្ត្ររបស់យើង ព្រះ
អម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ចូរកុំឲ្យនរណាមើលងាយ
ជួច ជាអ្នកបំរើរបស់យើង ឡើយ ត្បិតគាត់នឹងដំកើងកិត្តិយស
ដល់យើង ។
២២ ចូរឲ្យ ជួច ជាអ្នកបំរើរបស់យើង និង ឡៃម៉ាន ជាអ្នកបំរើ
របស់យើង និង យ៉ូហាន ស្នែឌើ ជាអ្នកបំរើរបស់យើង និងពួក
អ្នកផ្សេងៗ ទៀត [ក]ស្ថាបនាគេហដ្ឋានមួយ ថ្វាយដល់ព្រះនាម
របស់យើង ជាគេហដ្ឋានមួយដែល យ៉ូសែប ជាអ្នកបំរើរបស់
យើង នឹងបង្ហាញដល់ពួក គេ គឺនៅលើកន្លែងដែលលោកនឹង
បង្ហាញដល់ពួកគេផងដែរ ។

១៤ *ក* ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
១៥ *ក* ស.ប. ស្ម៊ីធ, ហៃរុម.
*ខ* ស.ប. សេចក្ដីស្មោះ.
១៦ *ក* ស.ប. ពាក្យទូន្មាន (ន.).
១៨ *ក* និក្ខ. ១៩:៤; អេសាយ ៤០:៣១.
១៩ *ក* គ. និង ស. ១២៤:១៣០.
ស.ប. ប៉ាទិ្តន, ដាវីឌ ដ័បបុលយូ.
*ខ* ស.ប. ប៉ាទ្រិច, អែតរីត.
*គ* ស.ប. ស្ម៊ីធ, យ៉ូសែប ស៊ីញ៉ែរ.
*ឃ* គ. និង ស. ១៣៧:៥.
២០ *ក* ស.ប. ឧបាយកល.
២១ *ក* គ. និង ស. ៤១:៩.
ស.ប. ប៊ីស្សព.
២២ *ក* គ. និង ស. ១២៤:៥៦–៦០.

២៣ ហើយទីនោះនឹងទៅជាទីសំណាក់ ជាគេហដ្ឋានដែលពួកអ្នកមកពីចម្ងាយអាចមកស្នាក់នៅ; ហេតុដូច្នេះហើយ ចូរធ្វើទីនោះ ឲ្យទៅជាគេហដ្ឋានដ៏ល្អមួយ គួរសមការទទួលគ្រប់យ៉ាង ប្រយោជន៍ឲ្យ[ក]អ្នកធ្វើដំណើរដ៏នឿយហត់ អាចបានសុខ[ខ]ស្រួល ក្នុងកាលគាត់ ពិចារណាពីព្រះបន្ទូលនៃព្រះអម្ចាស់; និងពីថ្មសីមា ដែលយើងបានតាំងឡើងសំរាប់ក្រុងស៊ីយ៉ូន ។

២៤ គេហដ្ឋាននេះនឹងត្រូវទៅជាទីអាស្រ័យដ៏ស្រួលមួយ បើសិនជាស្ថាបនាចំពោះព្រះនាមរបស់យើង ហើយបើសិនជាអ្នកត្រួតត្រា ដែលនឹងត្រូវបានតាំងឡើងឲ្យត្រួតត្រា មិនទ្រាំឲ្យមានភាពកខ្វក់ណាមួយចូលមកក្នុងទីនោះឡើយ ។ ទីនោះនឹងទៅជាបរិសុទ្ធ បើពុំនោះសោតទេ ព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នកទ្រង់នឹងពុំគង់នៅទីនោះឡើយ ។

២៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យពួកបរិសុទ្ធរបស់យើងមកពីទីចំងាយចុះ ។

២៦ ហើយចូរអ្នករាល់គ្នាចាត់ពួកទូតដែលលឿន មែនហើយ ចូររើសពួកទូត ហើយប្រាប់ដល់ពួកគេថា៖ ចូរមក យកមាសអ្នកមកផង និងប្រាក់អ្នក និងត្បូងដ៏វិសេសរបស់អ្នក និងគ្រប់របស់របរកេរ្តិ៍អាករចាស់ៗរបស់អ្នក ហើយព្រមទាំងអស់អ្នកដែលមានចំណេះវិជ្ជាធ្វើ របស់របរទាំងឡាយណាដែលចង់មកអាចមក ហើយចូរយកឈើស្រឡៅ និងឈើស្រល់ និងឈើកកោះព្រមទាំងអស់ទាំងឈើ វិសេសៗទាំងឡាយនៃផែនដីផង;

២៧ ហើយចូរយកដែក និងទង់ដែង និងលង្ហិន និងស័ង្កសីហើយព្រមទាំងវត្ថុវិសេសៗទាំងឡាយនៃផែនដីផង; ហើយចូរស្ថាបនា [ក]គេហដ្ឋានមួយដល់ព្រះនាមរបស់យើង ដើម្បីឲ្យព្រះដ៏ខ្ពស់បំផុត [ខ]គង់នៅទីនោះ ។

២៨ ត្បិតពុំឃើញមានទីណាមួយឡើយនៅលើផែនដី ដែលទ្រង់អាចយាងមក ហើយ[ក]សាងឡើងវិញ នូវអ្វីដែលបានបាត់បង់ចំពោះអ្នក ឬក៏អ្វីដែល ទ្រង់បានយកចេញពីអ្នកទៅ គឺភាពពោរពេញនៃបព្វជិតភាព ។

២៩ ត្បិតអាង[ក]សំរាប់បុណ្យជ្រមុជទឹក នោះពុំមាននៅលើផែនដីដែលពួកគេ គឺពួកបរិសុទ្ធរបស់យើងអាច[ខ]ធ្វើបុណ្យជ្រមុជទឹកជំនួសពួកអ្នកស្លាប់នោះទេ —

៣០ ត្បិតពិធីនេះត្រូវធ្វើនៅក្នុងដំណាក់របស់យើង ហើយពុំអាចបានទទួលស្គាល់ចំពោះយើងឡើយ លើកលែងតែនៅគ្រាក្រតោក យ៉ាករបស់អ្នក គឺជាពេលដែលអ្នកពុំអាចស្ថាបនាដំណាក់ដល់យើងប៉ុណ្ណោះ ។

៣១ ប៉ុន្តែយើងបានបញ្ជាអ្នក គឺអ្នករាល់គ្នាដែលជាពួកបរិសុទ្ធរបស់យើង ឲ្យ[ក]ស្ថាបនាដំណាក់មួយដល់យើង; ហើយយើងនឹងអនុញ្ញាត ដល់អ្នក នូវពេលវេលាគ្រប់គ្រាន់ ដើម្បីស្ថាបនាដំណាក់ដល់យើង; ហើយនៅពេលនេះ បុណ្យជ្រមុជទឹករបស់អ្នក នឹងបានទទួល ស្គាល់ចំពោះយើង ។

៣២ ប៉ុន្តែមើលចុះ នៅចុងពេលកំណត់នេះ បុណ្យជ្រមុជទឹកជំនួសពួកអ្នកស្លាប់របស់អ្នក នោះនឹងពុំបានទទួលស្គាល់ចំពោះយើងឡើយ; ហើយបើសិនជាអ្នកមិនប្រព្រឹត្តការណ៍ទាំងនេះនៅចុងពេលកំណត់ទេ នោះអ្នករាល់គ្នានឹងត្រូវបដិសេធជាសាសនាចក្រ ជាមួយនឹង ពួកអ្នកស្លាប់របស់អ្នកផង ព្រះអម្ចាស់ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៣៣ ត្បិតយើងប្រាប់អ្នកជាប្រាកដថា បន្ទាប់ពីអ្នកមានពេលគ្រប់គ្រាន់ ដើម្បីស្ថាបនាដំណាក់ដល់យើង ដែលមានពិធីបុណ្យជ្រមុជទឹក ជំនួសពួកអ្នកស្លាប់ ហើយដែលមានពិធីនេះតាំងពីកំណើតលោកិយមកម្ល៉េះ នោះបុណ្យជ្រមុជទឹកជំនួសពួកអ្នកស្លាប់របស់អ្នក នឹងពុំត្រូវ បានទទួលស្គាល់ចំពោះយើងឡើយ;

៣៤ ត្បិតនៅក្នុងនោះគឺជា[ក]កូនសោទាំងឡាយ នៃបព្វជិតភាពដ៏បរិសុទ្ធដែលបានតែងតាំងឡើង ប្រយោជន៍ឲ្យអ្នកអាចបានទទួល កិត្តិយស និងសិរីល្អ ។

៣៥ ហើយបន្ទាប់ពីពេលនេះតទៅ បុណ្យជ្រមុជទឹកជំនួសពួកអ្នកស្លាប់របស់អ្នក ដោយពួកអ្នកដែលនៅឆ្ងាយៗ នោះមិនត្រូវទទួល ស្គាល់ចំពោះយើងឡើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៣៦ ត្បិតត្រូវបានតែងតាំងថានៅក្រុងស៊ីយ៉ូន និងនៅក្នុងស្តេក

២៣ *ក* ចោទិ. ៣១:១២;
ម៉ាថាយ ២៥:៣៥, ៣៨.
*ខ* គ. និង ស. ១២៤:២.
២៧ *ក* គ. និង ស. ១០៩:៥.
ស.ប. ព្រះវិហារបរិសុទ្ធ,
ដំណាក់នៃព្រះអម្ចាស់.
*ខ* និក្ខ. ២៥:៨;
គ. និង ស. ៩៧:១៥–១៧.
២៨ *ក* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
២៩ *ក* គ. និង ស. ១២៨:១៣.
*ខ* ១ កូរិន. ១៥:២៩;
គ. និង ស. ១២៧:៦; ១៣៨:៣៣.
ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក —
បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់;
សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់.
៣១ *ក* គ. និង ស. ៩៧:១០.
៣៤ *ក* គ. និង ស. ១១០:១៤–១៦.
ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.

របស់នាង និងនៅក្រុងយេរូសាឡិម គឺជាកន្លែងទាំងនោះដែល
យើងបាន តាំងឡើងសំរាប់[ក]ជាទីពឹងជ្រក នោះនឹងទៅជាកន្លែង
ទាំងឡាយ សំរាប់បុណ្យជ្រមុជទឹកជំនួសពួកអ្នកស្លាប់របស់អ្នក ។
៣៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា តើ[ក]ការ
លាងទាំងឡាយរបស់អ្នកនឹងបានទទួលស្គាល់ចំពោះយើងទៅ
ម្ដេចបាន លើក លែងតែអ្នកប្រព្រឹត្តពិធីទាំងនោះ នៅក្នុងដំណាក់
ដែលអ្នកបានស្ថាបនាដល់ព្រះនាមរបស់យើង ?
៣៨ ត្បិតដោយហេតុនេះហើយ ទើបយើងបានបញ្ជា
ដល់លោកម៉ូសេថា លោកត្រូវស្ថាបនា[ក]រោងឧបោសថមួយ ថា
ពួកគេគប្បីទ្ររោង នោះទៅជាមួយពួកគេនៅក្នុងទីរហោស្ថាន
ហើយឲ្យស្ថាបនា[ខ]ដំណាក់មួយ នៅក្នុងដែនដីសន្យា ប្រយោជន៍ឲ្យ
ពីធីទាំងនោះអាចបាន បើកសម្ដែងឲ្យឃើញ នូវអ្វីដែលបាន
លាក់ទុកពីមុនកំណើតលោកិយមកម្ល៉េះ ។
៣៩ ហេតុដូច្នេះហើយ យើងប្រាប់អ្នកជាប្រាកដថា ការលាប
ទាំងឡាយរបស់អ្នក និង[ក]ការលាងទាំងឡាយរបស់អ្នក និង[ខ]បុណ្យ
ជ្រមុជទឹក ទាំងឡាយរបស់អ្នកជំនួសពួកអ្នកស្លាប់ និង[គ]ជំនុំមុំតមាំ
ទាំងឡាយរបស់អ្នក និងបុណ្យរំឭកទាំងឡាយរបស់អ្នក សំរាប់
[ឃ]ជាយញ្ញបូជា ទាំងឡាយរបស់អ្នក ដោយបុត្រារបស់លេវី និង
សំរាប់ព្រះបន្ទូល នៅក្នុង[ង]ទីបរិសុទ្ធបំផុតរបស់អ្នក ដែលអ្នកទទួល
ការសន្ទនាទាំង ឡាយ និងក្រិត្យក្រម និងសេចក្ដីជំនុំជំរះ
ទាំងឡាយរបស់អ្នក សំរាប់ការចាប់ផ្ដើមនៃវិវរណៈទាំងឡាយ
និងគ្រឹះនៃក្រុងស៊ីយ៉ូន និងសំរាប់ សិរីល្អ កិត្តិយស និងអំណោយ
ទានពិសិដ្ឋនៃប្រជារាស្ត្ររបស់នាង នោះត្រូវបានតែងតាំងឡើង
ដោយពិធីនៃដំណាក់ដ៏បរិសុទ្ធរបស់ យើង ដែលរាស្ត្រយើងត្រូវ
បានបញ្ជារហូត ឲ្យស្ថាបនាដល់ព្រះនាមដ៏បរិសុទ្ធរបស់យើង ។
៤០ ហើយយើងប្រាប់អ្នកជាប្រាកដថា ចូរស្ថាបនាដំណាក់នេះ
ដល់ព្រះនាមរបស់យើង ប្រយោជន៍ឲ្យយើងអាចបើកសម្ដែង
ប្រាប់ពី ពិធីទាំងឡាយរបស់យើង ដល់រាស្ត្រយើង;
៤១ ត្បិតយើងគិតថាសមនឹង[ក]បើកសម្ដែងដល់សាសនាចក្រ
របស់យើង នូវការណ៍ទាំងឡាយ ដែលបាន[ខ]លាក់ទុកមុន
កំណើតលោកិយ មកម្ល៉េះ គឺជាការណ៍ទាំងឡាយ ដែល
ទាក់ទងទៅនឹង[គ]គ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ។
៤២ ហើយយើងនឹង[ក]បង្ហាញដល់ យ៉ូសែប ជាអ្នកបំរើ
របស់យើង នូវការណ៍ទាំងអស់ ដែលទាក់ទងទៅនឹងដំណាក់នេះ
និងបព្វជិតភាពនៃដំណាក់នេះ និងកន្លែងនៃដំណាក់នេះ ដែលនឹង
ត្រូវបានស្ថាបនាឡើង ។
៤៣ ហើយអ្នករាល់គ្នាត្រូវស្ថាបនាដំណាក់នេះ នៅកន្លែង
ដែលអ្នកបានគិតពិចារណាថានឹងស្ថាបនា ត្បិតគឺជាទី ដែល
យើងបាន រើសសំរាប់ឲ្យអ្នកស្ថាបនាដំណាក់នេះ ។
៤៤ បើសិនជាអ្នករាល់គ្នាធ្វើការ ដោយអស់ពីកម្លាំងរបស់
អ្នក នោះយើងនឹងចាត់ទីនោះ ដើម្បីឲ្យវាបានទៅជា[ក]បរិសុទ្ធ ។
៤៥ ហើយបើសិនជារាស្ត្រយើងនឹងប្រុងស្ដាប់តាមសម្លេងយើង
និងតាមសម្លេងនៃ[ក]ពួកអ្នកបំរើរបស់យើង ដែលយើងបាន
តែងតាំងឡើង ឲ្យដឹកនាំរាស្ត្រយើង មើលចុះ យើងប្រាប់អ្នកជា
ប្រាកដថា ពួកគេនឹងមិនត្រូវបានរើចេញពីកន្លែងគេឡើយ ។
៤៦ ប៉ុន្តែបើសិនជាពួកគេមិនប្រុងស្ដាប់តាមសម្លេងយើង
ឬតាមសម្លេងនៃមនុស្សទាំងនេះ ដែលយើងបានតែងតាំងឡើងទេ
នោះពួកគេនឹងមិនត្រូវបានពរឡើយ ពីព្រោះពួកគេបង្ខូចដីធ្លីដ៏បរិសុទ្ធ
ទាំងឡាយរបស់យើង និងពិធីដ៏បរិសុទ្ធទាំងឡាយរបស់យើង
និងធម្មន្ញទាំងឡាយ និងព្រះបន្ទូលដ៏បរិសុទ្ធទាំងឡាយរបស់យើង
ដែលយើងបានប្រទានដល់ពួកគេ ។
៤៧ ហើយហេតុការណ៍នឹងកើតឡើងថា បើសិនជាអ្នក
ស្ថាបនាដំណាក់មួយដល់ព្រះនាមយើង ហើយមិនប្រព្រឹត្តនូវអ្វី
ៗដែលយើង មានបន្ទូល នោះយើងនឹងមិនអនុវត្ត[ក]សម្បថ ដែល
យើងបានធ្វើដល់អ្នក ឬនឹងមិនបំពេញសេចក្ដីសន្យាទាំងឡាយ
ដែលអ្នករាល់គ្នាតម្រូវ ពីដៃយើងឡើយ ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលថាដូច្នោះ ។
៤៨ ត្បិត[ក]ជាជាងបានព្រះពរ នោះអ្នករាល់គ្នា ដោយសារ

៣៦ ក អេសាយ ៤:៥–៦.
៣៧ ក ស.ប. លាង, បានលាង, ការលាង.
៣៨ ក និក្ខ. ២៥:១–៩; ៣៣:៧.
ស.ប. រោងឧបោសថ.
ខ ស.ប. ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់.
៣៩ ក និក្ខ. ២៩:៧.
ស.ប. ចាក់ប្រេង.
ខ ស.ប. ពិធីបរិសុទ្ធទាំងឡាយ — ពិធីបរិសុទ្ធជំនួស.
គ គ. និង ស. ៨៨:១១៧.
ឃ គ. និង ស. ១៣:១; ៨៤:៣១; ១២៨:២៤;
យ.ស. — ប្រវត្តិ ១:៦៩.
ង អេសេ. ៤១:៤;
គ. និង ស. ៤៥:៣២; ៨៧:៨; ១០១:២២.
៤១ ក ម. នៃ ស. ១:៩.
ខ គ. និង ស. ១២១:២៦–៣២.
គ អេភេ. ១:៩–១០;
គ. និង ស. ២៧:១៣; ១១២:៣០.
៤២ ក គ. និង ស. ៩៥:១៤–១៧.
៤៤ ក ស.ប. បរិសុទ្ធ.
៤៥ ក គ. និង ស. ១:៣៨.
ស.ប. ព្យាការី.
៤៧ ក ស.ប. សម្បថ.
៤៨ ក ចោទិ. ២៨:១៥.

កិច្ចការទាំងឡាយរបស់អ្នកផ្ទាល់ នាំសេចក្ដីបណ្ដាសាទាំង
ឡាយ សេចក្ដីក្រោធ សេចក្ដីគ្នាន់ក្នាញ់ និងសេចក្ដីជំនុំជំរះទាំង
ឡាយ មកលើក្បាលរបស់ខ្លួនទៅវិញ ដោយសារការចំកួតទាំង
ឡាយរបស់អ្នក និងដោយសារអស់ទាំងអំពើគួរខ្ពើមឆ្អើមរបស់
អ្នក ដែលអ្នកប្រព្រឹត្តនៅចំពោះយើង ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលថាដូច្នោះ ។
៤៩ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា កាលយើង
ប្រទានព្រះបញ្ញត្តិណាមួយឲ្យពួកកូនមនុស្សធ្វើកិច្ចការដល់ព្រះ
នាមយើង ហើយពួកកូនមនុស្សទាំងនោះ ចេញទៅដោយ
អស់ពីកម្លាំងរបស់ពួកគេ និងដោយអស់ពីសមត្ថភាពដែល
ពួកគេមាន ដើម្បីប្រព្រឹត្ត កិច្ចការនោះ ហើយព្យាយាម
ដោយមិនឈប់ឈរ ហើយពួកខ្មាំងសត្រូវរបស់គេមកលើ
ពួកគេ ហើយបង្អែបង្អាំងពួកគេមិនឲ្យធ្វើកិច្ចការ នោះឡើយ
មើលចុះ គឺជាការចាំបាច់ដល់យើង នឹងតម្រូវកិច្ចការនោះ
ពីដៃនៃពួកកូនមនុស្សទាំងនោះទៀតឡើយ ប៉ុន្តែត្រូវទទួលនូវ
ដង្វាយទាំងឡាយរបស់ពួកគេវិញ ។
៥០ ហើយសេចក្ដីទុច្ចរិត និងអំពើរំលងនូវក្រិត្យវិន័យ និង
ព្រះបញ្ញត្តិទាំងឡាយដ៏បរិសុទ្ធរបស់យើង នោះយើងនឹងពិនិត្យ
ពិច័យលើក្បាល នៃអស់អ្នកណាដែលបង្អែបង្អាំងកិច្ចការរបស់
យើង រហូតដល់តំណទីបី និងទីបួន ជាដរាបណាដែលពួកគេមិន
ប្រែចិត្ត ហើយស្អប់យើង ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះ
បន្ទូលថាដូច្នោះ ។
៥១ ហេតុដូច្នេះហើយ ដោយសារហេតុនេះ ទើបយើងទទួល
ដង្វាយទាំងឡាយពីអស់អ្នក ដែលយើងបានបញ្ជាឲ្យស្ថាបនា
ទីក្រុងមួយ និងដំណាក់មួយឡើងដល់ព្រះនាមរបស់យើង នៅឃុំ
ចាកសុន រដ្ឋមិសស្សួរី ហើយត្រូវបានបង្អែបង្អាំងដោយសារពួក
ខ្មាំងសត្រូវរបស់ ពួកគេ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មាន
ព្រះបន្ទូលថាដូច្នោះ ។
៥២ ហើយយើងតបស្នងសងគុណដោយនូវសេចក្ដីជំនុំជំរះ សេច
ក្ដីក្រោធ និងសេចក្ដីគ្នាញ់ក្នាន់ ការយំសោក ការទុក្ខព្រួយ និង
ការសង្កៀត ធ្មេញ មកលើក្បាលពួកគេវិញ រហូតដល់តំណទីបី
និងទីបួន ដរាបណាដែលពួកគេមិនប្រែចិត្ត ហើយស្អប់យើង
ព្រះអម្ចាស់ដ៏ជាព្រះ របស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៥៣ ហើយការណ៍នេះ យើងធ្វើទុកជាគំរូដល់អ្នក សំរាប់ការ
លួងលោមដល់អ្នក អំពីអស់អ្នកដែលត្រូវបានបញ្ជាឲ្យធ្វើកិច្ចការ
មួយ ហើយត្រូវបានបង្អែបង្អាំង ដោយសារកណ្ដាប់ដៃនៃពួកខ្មាំង
សត្រូវរបស់ពួកគេ និងដោយសារការសង្កត់សង្កិន ព្រះអម្ចាស់ដ៏ជា
ព្រះ របស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៥៤ ត្បិតយើងជាព្រះអម្ចាស់ជាព្រះរបស់អ្នក ហើយនឹង
ជួយសង្គ្រោះអស់ពួកអ្នកដែលជាបងប្អូនរបស់អ្នកក្នុងសាសនា
ដែលមានចិត្ត បរិសុទ្ធ ហើយដែលត្រូវគេប្រហារ នៅដែនដី
មិសស្សួរី ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៥៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា យើងបញ្ជា
ដល់អ្នកជាថ្មីទៀត ឲ្យស្ថាបនាដំណាក់មួយដល់ព្រះនាមរបស់យើង
គឺនៅ កន្លែងនេះ ប្រយោជន៍ឲ្យអ្នកអាចបញ្ជាក់ដល់យើងថា អ្នក
រាល់គ្នាមានចិត្តស្មោះត្រង់ចំពោះគ្រប់ការណ៍ទាំងអស់ ដែល
យើងបានបញ្ជា ដល់ ប្រយោជន៍យើងអាចប្រទានពរដល់អ្នក
ហើយបំពាក់កិត្តិយស អមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច
ទុកជាមកុដដល់អ្នក ។
៥៦ ហើយឥឡូវនេះ យើងប្រាប់អ្នកថា អំពីផ្ទះសំណាក់ ដែល
យើងបានបញ្ជាឲ្យអ្នកសង់ សំរាប់មនុស្សដទៃស្នាក់ នោះចូរសង់ដល់
ព្រះ នាមយើងចុះ ហើយចូរដាក់តាមព្រះនាមរបស់យើង ហើយ
ចូរឲ្យយ៉ូសែប ជាអ្នកបំរើរបស់យើង និងវង្សត្រកូលរបស់លោក
មានកន្លែង នៅក្នុងទីនោះផង គឺពីតំណមួយទៅតំណមួយផង ។
៥៧ ត្បិតការលាបតាំងនេះហើយ ដែលយើងបានដាក់មក
លើក្បាលរបស់លោក ដើម្បីឲ្យពររបស់លោកបានដាក់មក
លើក្បាល នៃពូជពង្សរបស់លោកបន្តបន្ទាប់ទៅ ។
៥៨ ហើយដូចជាយើងមានព្រះបន្ទូលដល់លោកអ័ប្រាហាំ អំពី
ពូជមនុស្សទាំងឡាយនៅផែនដីយ៉ាងណា នោះយើងក៏មាន
បន្ទូលដល់ យ៉ូសែប ជាអ្នកបំរើរបស់យើងយ៉ាងនោះដែរថា៖
ដោយសារអ្នក និងដោយសារពូជអ្នក នោះគ្រួសារមនុស្ស
នៅផែនដីនឹងបានពរ ។

៤៩ *ក* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*ខ* គ. និង ស. ៥៦:៤; ១៣៧:៩.
៥០ *ក* ម៉ូសាយ ១២:១.
*ខ* ចោទិ. ៥:៩;
គ. និង ស. ៩៨:៤៦–៤៧.
*គ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
៥១ *ក* គ. និង ស. ១១៥:១១.
*ខ* ស.ប. ឃុំចាកសុន, រដ្ឋមិសស្សួរី (សហរដ្ឋ).
៥២ *ក* គ. និង ស. ១២១:១១–២៣.
៥៤ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
*ខ* គ. និង ស. ៩៨:១៣; ១០៣:២៧–២៨.
៥៥ *ក* គ. និង ស. ១២៧:៤.
*ខ* អ័ប្រា. ៣:២៥.
៥៦ *ក* គ. និង ស. ១២៤:២២–២៤.
៥៨ *ក* លោកុ. ១២:៣; ២២:១៨;
អ័ប្រា. ២:១១.
ស.ប. អ័ប្រាហាំ.
*ខ* គ. និង ស. ១១០:១២.
ស.ប. សេចក្ដីសញ្ញាអ័ប្រាហាំ.

៥៩ ហេតុដូច្នេះហើយ ចូរឲ្យយ៉ូសែប ជាអ្នកបំរើរបស់យើង និងពូជលោកបន្តបន្ទាប់ទៅ មានកន្លែងនៅក្នុងគេហដ្ឋាននោះ ពីតំណមួយ ទៅតំណមួយផង ជារៀងរាបដរាបតទៅ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៦០ ហើយចូរឲ្យឈ្មោះគេហដ្ឋាននោះថា ណៅវូហោស ហើយចូរឲ្យទីនោះបានទៅជាទីអាស្រ័យដ៏រីករាយសំរាប់មនុស្ស ហើយជា ទីសំរាក សំរាប់អ្នកដំណើរនឿយហត់ ប្រយោជន៍ឲ្យគេអាចបានពិចារណាពីសិរីល្អនៃស៊ីយ៉ូន និងពីសិរីល្អនៃទីនេះ គឺជាថ្មសិមានៃ ស៊ីយ៉ូន;

៦១ ប្រយោជន៍ឲ្យគេអាចបានទទួលការទូន្មានពីពួកអ្នក ដែលយើងបានចាត់ដូចជា[ក]ដំណាំដ៏ល្អ និងជាពួកអ្នកចាំយាម[ខ] នៅលើកំផែង ទាំងឡាយរបស់នាងផង ។

៦២ មើលចុះ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យ ជូច មិលលើ ជាអ្នកបំរើរបស់យើង និង ឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើង និង យ៉ូហាន ស្នេឌើរ ជាអ្នកបំរើរបស់យើង និង ពេត្រុស ហារ្វ ជាអ្នកបំរើរបស់យើង រៀបចំខ្លួន ហើយតាំងពួកគេម្នាក់ឲ្យធ្វើជាប្រធានលើ ក្រុមរបស់ខ្លួន ចំពោះផលប្រយោជន៍ខាងការកសាងគេហដ្ឋាននោះ ។

៦៣ ហើយពួកគេត្រូវបង្កើតធម្មនុញ្ញមួយ ដែលពួកគេអាចទទួលហ៊ុនសំរាប់កសាងគេហដ្ឋាននោះ ។

៦៤ ហើយពួកគេមិនអាចទទួលមួយហ៊ុនក្នុងគេហដ្ឋាននោះ តិចជាងហាសិបដុល្លាឡើយ ហើយពួកគេត្រូវបានអនុញ្ញាតឲ្យទទួលចំនួន មួយម៉ឺនប្រាំពាន់ដុល្លា ពីមនុស្សម្នាក់ សំរាប់ជាហ៊ុនក្នុងគេហដ្ឋាននោះ ។

៦៥ ប៉ុន្តែពួកគេពុំត្រូវអនុញ្ញាតឲ្យទទួលលើសជាងមួយម៉ឺនប្រាំពាន់ដុល្លា ពីនរណាម្នាក់ សំរាប់ជាហ៊ុននៃគេហដ្ឋាននោះឡើយ ។

៦៦ ហើយពួកគេពុំត្រូវបានអនុញ្ញាតឲ្យទទួលមួយហ៊ុនក្នុងគេហដ្ឋាននោះ ពីនរណាម្នាក់ តិចជាងហាសិបដុល្លាឡើយ ។

៦៧ ហើយពួកគេពុំត្រូវបានអនុញ្ញាតឲ្យទទួលមនុស្សណាមួយជាអ្នកចូលហ៊ុនក្នុងគេហដ្ឋាននេះឡើយ លើកលែងតែអ្នកនោះបង់ហ៊ុន ទៅក្នុងដៃពួកគេ នៅពេលគេទិញនោះ;

៦៨ ហើយនៅចំនួនហ៊ុនណាដែលគេបង់ដល់ដៃពួកគេ នោះគេនឹងបានហ៊ុនចំនួននោះក្នុងគេហដ្ឋាន; ប៉ុន្តែបើសិនជាគេមិនបានបង់អ្វី ដល់ដៃពួកគេទេ នោះគេនឹងពុំបានហ៊ុនអ្វីក្នុងគេហដ្ឋាននោះឡើយ ។

៦៩ ហើយបើសិនជានរណាមួយបង់ហ៊ុនដល់ដៃពួកគេ នោះនឹងមានហ៊ុនក្នុងគេហដ្ឋាននោះ សំរាប់សាមីខ្លួនគេ និងសំរាប់តំណគេបន្ត បន្ទាប់ទៅ ពីតំណមួយទៅតំណមួយ ដរាបណាដែលគេ និងពូជពង្សគេមានហ៊ុននោះ ហើយពុំបានលក់ ឬដកហ៊ុនចេញពីដៃពួកគេ តាមអំពើចិត្តគេ នោះគឺបើសិនជាអ្នកនឹងធ្វើតាមព្រហឫទ័យរបស់យើង ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នកទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៧០ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា បើសិនជា ជូច មិលលើ ជាអ្នកបំរើរបស់យើង និង ឡៃម៉ាន វ៉ៃត ជាអ្នកបំរើរបស់យើង និង យ៉ូហាន ស្នេឌើរ ជាអ្នកបំរើរបស់យើង និង ពេត្រុស ហារ្វ ជាអ្នកបំរើរបស់យើង ទទួលហ៊ុនណាមួយនៅក្នុងដៃពួកគេ ជាប្រាក់ ឬជាទ្រព្យសម្បត្តិដែលពួកគេទទួលជាតម្លៃប្រាក់ នោះពួកគេមិនត្រូវចាយភាគណាមួយនៃហ៊ុននោះចំពោះផលប្រយោជន៍ណាផ្សេង ឡើយ លើកលែងតែសំរាប់គេហដ្ឋាននោះប៉ុណ្ណោះ ។

៧១ ហើយបើសិនជាពួកគេចាយចំណែកណាមួយនៃហ៊ុននោះនៅកន្លែងណាផ្សេងទៀត លើកលែងតែនៅក្នុងគេហដ្ឋាននោះ ដោយ គ្មានការអនុញ្ញាតិពីអ្នកចូលហ៊ុនទេ ហើយពុំបានសងមួយភាគបួនដល់ហ៊ុននោះ ដែលពួកគេបានចាយនៅកន្លែងផ្សេងទៀតទេ លើក លែងតែនៅគេហដ្ឋាននោះ នោះពួកគេត្រូវបណ្ដាសា ហើយនឹងត្រូវដកចេញពីកន្លែងពួកគេ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូល ថាដូច្នោះ; ត្បិតយើងជាព្រះអម្ចាស់ គឺជាព្រះ ហើយពុំត្រូវ[ក]មើលងាយ ក្នុងការណ៍ណាមួយ នៃការណ៍ទាំងនេះឡើយ ។

៧២ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យ យ៉ូសែប ជាអ្នកបំរើរបស់យើង ចូលហ៊ុនក្នុងដៃពួកគេ សំរាប់ការកសាងនៃគេហដ្ឋាននេះ ដូចជា ឃើញថាល្អដល់លោកចុះ; ប៉ុន្តែយ៉ូសែប ជាអ្នកបំរើរបស់យើង មិនអាចចូលហ៊ុនលើសជាងមួយម៉ឺនប្រាំពាន់ដុល្លាក្នុងគេហដ្ឋាននោះ ឬតិចជាងហាសិបដុល្លាឡើយ; ឬក៏នរណាមួយឡើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៧៣ ហើយមានមនុស្សឯទៀតដែរ ដែលចង់ដឹងពីព្រះហឫទ័យរបស់យើង អំពីពួកគេ ព្រោះពួកគេបានទូលសូមពីព្រះហស្តយើង ។

៦១ *ក* អេសាយ ៦១:៣; អេសេ. ៣៤:២៩.
*ខ* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
៧១ *ក* កាឡាទី ៦:៧.

៧៤ ហេតុដូច្នេះហើយ យើងប្រាប់អ្នក អំពី វិនសុន ណៃត ជាអ្នកបំរើរបស់យើង បើសិនជាគាត់នឹងប្រព្រឹត្តតាមព្រះហឫទ័យរបស់យើង នោះចូរឲ្យគាត់ចូលហ៊ុនក្នុងគេហដ្ឋាននេះ សំរាប់រូបគាត់ និងសំរាប់ពូជពង្សគាត់បន្តបន្ទាប់ទៅ ពីតំណមួយតំណមួយផងចុះ ។

៧៥ ហើយចូរឲ្យគាត់បន្លឺសម្លេងគាត់ឮសូរកាន់តែតន្ថើន ខ្លាំងឡើង នៅចំកណ្ដាលបណ្ដាជន ដើម្បី[ក]អង្វរប្រាប់ពីគតិនៃពួកអ្នកទាល់ក្រ និងពួកអ្នកកំសត់ទុគ៌ត; ហើយចូរកុំឲ្យគាត់ខកខាន ឬមានចិត្តតក់ស្លុតឡើយ; ហើយយើងនឹងទទួល[ខ]ដង្វាយទាំងឡាយរបស់គាត់ ត្បិតដង្វាយរបស់គាត់ពុំមែនថ្វាយដល់យើង ដូចជាដង្វាយរបស់កាអ៊ីនឡើយ ព្រោះគាត់នឹងទៅជារបស់ផងយើង ព្រះអម្ចាស់ទ្រង់មាន ព្រះបន្ទូលថាដូច្នោះ ។

៧៦ ចូរឲ្យគ្រួសារគាត់សប្បាយរីករាយ ហើយ បែរចិត្តចេញពីសេចក្ដីទុក្ខវេទនាចុះ; ត្បិតយើងបានរើសគាត់ ហើយបានលាបគាត់ហើយ ហើយគាត់នឹងបានកិត្តិយសនៅកណ្ដាលវង្សត្រកូលគាត់ ព្រោះយើងនឹងអភ័យទោសចំពោះអំពើបាបទាំងអស់របស់គាត់ ព្រះអម្ចាស់ទ្រង់ មានព្រះបន្ទូលថាដូច្នោះ ។ អាម៉ែន ។

៧៧ យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យ ហៃរុម ជាអ្នកបំរើរបស់យើង ចូលហ៊ុនទៅក្នុងគេហដ្ឋាននោះ ដូចដែលឃើញថាល្អដល់គាត់ គឺសំរាប់រូបគាត់ និងពូជពង្សគាត់បន្តបន្ទាប់ទៅ ពីតំណមួយទៅតំណមួយផងចុះ ។

៧៨ ចូរឲ្យ អ៊ីសាក កាលឡង់ ជាអ្នកបំរើរបស់យើង ចូលហ៊ុនទៅក្នុងគេហដ្ឋាននោះ ព្រោះយើងជាព្រះអម្ចាស់ស្រឡាញ់គាត់ ចំពោះ កិច្ចការដែលគាត់បានធ្វើ ហើយនឹងអភ័យទោសចំពោះអំពើបាបទាំងអស់របស់គាត់ ហេតុដូច្នេះហើយ ចូរត្រូវចងចាំដល់គាត់ ចំពោះ ការប្រាក់នៃគេហដ្ឋាននោះ ពីតំណមួយទៅតំណមួយផង ។

៧៩ ចូរឲ្យ អ៊ីសាក កាលឡង់ ជាអ្នកបំរើរបស់យើង បានតាំងឡើងនៅក្នុងចំណោមពួកអ្នករាល់គ្នា ហើយតែងតាំងឡើងដោយ វិលលាម ម៉ាក្ស ជាអ្នកបំរើរបស់យើង ហើយបាន ពរដោយសារគាត់ចុះ គឺទៅជាមួយ ហៃរុម ជាអ្នកបំរើរបស់យើង ដើម្បីសំរេចនូវ កិច្ចការដែល យ៉ូសែប ជាអ្នកបំរើរបស់យើង នឹងបញ្ជាក់ប្រាប់ដល់ពួកគេ ហើយពួកគេនឹងត្រូវបានពរដ៏ធំ ។

៨០ ចូរឲ្យ វិលលាម ម៉ាក្ស ជាអ្នកបំរើរបស់យើង ចូលហ៊ុនទៅក្នុងគេហដ្ឋាននោះ ដូចដែលឃើញថាល្អដល់គាត់ គឺសំរាប់រូបគាត់ និងពូជពង្សគាត់ ពីតំណមួយទៅតំណមួយផងចុះ ។

៨១ ចូរឲ្យ ហែនរី ជី ស៊ើរូឌ ជាអ្នកបំរើរបស់យើង ចូលហ៊ុនទៅក្នុងគេហដ្ឋាននោះ ដូចដែលឃើញថាល្អដល់គាត់ គឺសំរាប់រូបគាត់ និងពូជគាត់បន្តបន្ទាប់ទៅ ពីតំណមួយទៅតំណមួយផងចុះ ។

៨២ ចូរឲ្យ វិលលាម ឡរ៍ ជាអ្នកបំរើរបស់យើង ចូលហ៊ុនទៅក្នុងគេហដ្ឋាននោះ សំរាប់រូបគាត់ និងពូជគាត់បន្តបន្ទាប់ទៅ ពីតំណមួយទៅតំណមួយផងចុះ ។

៨៣ បើសិនជាគាត់នឹងធ្វើតាមព្រះហឫទ័យរបស់យើង ចូរកុំឲ្យគាត់នាំគ្រួសារគាត់ទៅដែនដីនៃទិសខាងកើត សូម្បីតែទៅក្រុងខឺតឡង់ ក្ដី; ទោះជាយ៉ាងណាក៏ដោយ យើងជាព្រះអម្ចាស់ នឹងកសាងក្រុងខឺតឡង់ឡើង ប៉ុន្តែយើងជាព្រះអម្ចាស់ មានរំពាត់ដែលបាន រៀបចំទុក សំរាប់បណ្ដាជនទីនោះ ។

៨៤ ហើយអំពី អាលម៉ុន បាបបិត ជាអ្នកបំរើរបស់យើង នោះមានរឿងជាច្រើនដែលយើងមិនសព្វព្រះហឫទ័យ; មើលចុះ គាត់គិត ចង់តាំងដំបូន្មានរបស់ខ្លួន ជំនួសដំបូន្មានដែលយើងបានតែងតាំង សូម្បីតែដំបូន្មានពីគណៈប្រធាននៃសាសនាចក្ររបស់យើងដែរ; ហើយគាត់តាំងរូបកូន[ក]គោមាសឡើង សំរាប់ជាការថ្វាយបង្គំនៃរាស្ត្ររបស់យើង ។

៨៥ ចូរកុំឲ្យនរណាមួយ[ក]ចេញពីកន្លែងនេះ ដែលបានមកទីនេះ ប្រុងនឹងកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងឡើយ ។

៨៦ បើសិនជាពួកគេរស់នៅទីនេះ ចូរឲ្យពួកគេរស់នៅចំពោះយើង; ហើយបើសិនជាពួកគេស្លាប់ ចូរឲ្យពួកគេស្លាប់ចំពោះយើង; ត្បិតពួកគេនឹងបាន [ក]សំរាកពីការងារទាំងអស់របស់ពួកគេនៅទីនេះ ហើយនឹងធ្វើកិច្ចការរបស់ពួកគេតទៅទៀត ។

៨៧ ហេតុដូច្នេះហើយ ចូរឲ្យ វិលលាម ជាអ្នកបំរើរបស់យើង ដាក់ទីទុកចិត្តរបស់គាត់មកលើយើង ហើយឈប់ភិតភ័យអំពីគ្រួសារគាត់ មកពី ជម្ងឺនៅដែនដីចុះ ។ បើសិនជាអ្នករាល់គ្នា [ក]ស្រឡាញ់យើង ចូរកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងចុះ; ហើយជម្ងឺនៅ ដែនដីនឹង [ខ]បែរទៅជាសិរីល្អដល់អ្នកទៅវិញ ។

៧៥ *ក* សុភា. ៣១:៩.
*ខ* នេហ្វីទី២. ៤:៤–៥;

៧៥ *ក* សុភា. ៣១:៩.
   *ខ* លោកុ. ៤:៤–៥;
   ម៉ូសេ ៥:១៨–២៨.
៨៤ *ក* និក្ខ. ៣២:២–៤.
៨៥ *ក* លូកា ៩:៦២.
៨៦ *ក* វិវ. ១៤:១៣.
   ស.ប. ស្ថានបរមសុខ;
   សេចក្ដីសំរាក.
៨៧ *ក* យ៉ូហាន ១៤:១៥.
   *ខ* គ. និង ស. ១២១:៨; ១២២:៧.

៨៨ ចូរឲ្យ វិលលាម ជាអ្នកបំរើរបស់យើង ទៅហើយប្រកាសប្រាប់ពីដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ចរបស់យើង ដោយសម្លេងយ៉ាងខ្លាំង និងដោយសេចក្ដីអំណរដ៏ធំ ដូចដែលបានបណ្ដាលដោយព្រះវិញ្ញាណរបស់យើង ដល់បណ្ដាជននៅក្រុងវ៉ូរសាវ និងដល់បណ្ដាជននៅក្រុងកាតធេចផង និងដល់បណ្ដាជននៅក្រុងប៊ើរលីងតោនផង និងដល់បណ្ដាជននៅក្រុងម៉ាឌិសុនផង ហើយចូរឲ្យរង់ចាំដោយមានចិត្តអត់ធន់ និងចិត្តព្យាយាមចាំការបង្គាប់តទៅទៀត ពីសន្និសីទទូទៅរបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៨៩ បើសិនជាគាត់នឹងធ្វើតាមព្រះហឫទ័យរបស់យើង នោះពីអំណឹះតទៅ ចូរឲ្យគាត់ប្រុងស្ដាប់តាមដំបូន្មាននៃយ៉ូសែប ជាអ្នកបំរើ របស់យើងចុះ ហើយដោយសារប្រាក់កាសរបស់ខ្លួនគាត់ ចូរគាំទ្រគតិនៃពួកអ្នកទ័លក្រ ហើយបោះពុម្ពការបកប្រែថ្មីនៃព្រះបន្ទូល ដ៏បរិសុទ្ធរបស់យើង ផ្សាយដល់បណ្ដាជននៅលើផែនដីចុះ ។

៩០ ហើយបើសិនជាគាត់ធ្វើបែបនេះ នោះយើងនឹងប្រទានពរដល់គាត់ ដោយព្រះពរដ៏ច្រើនអនេក ដើម្បីកុំឲ្យគាត់ត្រូវបោះបង់ចោល ឬ ឃើញថាពូជគាត់ត្រូវសុំទានអាហារឡើយ ។

៩១ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យវិលលាម ជាអ្នកបំរើរបស់យើង បានតាំង, តែងតាំង, និងលាបឲ្យធ្វើជាទីប្រឹក្សា ដល់យ៉ូសែប ជាអ្នកបំរើរបស់យើង នៅកន្លែងហៃរុម ជាអ្នកបំរើរបស់យើង ដើម្បីឲ្យហៃរុម ជាអ្នកបំរើរបស់យើង អាចយកតំណែងនៃ បព្វជិតភាព និងអយ្យកោ ដែលត្រូវបានតាំងដល់គាត់ ដោយឪពុកគាត់ តាមរយៈការឲ្យពរ និងដោយសិទ្ធផង;

៩២ គឺចាប់ពីអំណឹះតទៅ គាត់នឹងកាន់កូនសោទាំងឡាយនៃពររបស់លោកអយ្យកោ មកលើក្បាលនៃរាស្ត្រយើងទាំងអស់,

៩៣ គឺនរណាក៏ដោយដែលគាត់ឲ្យពរ នោះនឹងបានពរ ហើយនរណាក៏ដោយដែលគាត់ដាក់បណ្ដាសា នោះនឹងត្រូវបណ្ដាសា; គឺអ្វីក៏ ដោយដែលគាត់នឹងចងនៅលើផែនដី នោះនឹងត្រូវបានចងនៅលើស្ថានសួគ៌ដែរ; ហើយអ្វីក៏ដោយដែលគាត់នឹងស្រាយនៅលើផែនដី នោះនឹងត្រូវបានស្រាយនៅលើស្ថានសួគ៌ដែរ ។

៩៤ ហើយចាប់ពីពេលនេះតទៅ យើងតាំងដល់គាត់ ថាគាត់អាចបានទៅជាព្យាការី និងជាអ្នកមើលឆុត និងជាអ្នកបើកសម្ដែងចំពោះសាសនាចក្ររបស់យើង ដូចជាយ៉ូសែប ជាអ្នកបំរើរបស់យើងដែរ;

៩៥ ប្រយោជន៍ឲ្យគាត់អាចប្រព្រឹត្តព្រមព្រៀងគ្នាជាមួយនឹងយ៉ូសែប ជាអ្នកបំរើរបស់យើង; ហើយថាគាត់ត្រូវទទួលដំបូន្មានពីយ៉ូសែប ជាអ្នកបំរើរបស់យើង ដែលនឹងបង្ហាញដល់គាត់ នូវកូនសោទាំងឡាយ ដែលគាត់អាចសូម និងអាចទទួល ហើយបានពាក់មកុដ ដោយ ព្រះពរ និងសិរីល្អ និងកិត្តិយស និងបព្វជិតភាព និងអំណោយទានទាំងឡាយនៃបព្វជិតភាពដដែល ដែលបានពាក់លើអ្នកនោះម្ដង គឺ អូលីវើរ ខៅឌើរី ដែលធ្លាប់ជាអ្នកបំរើរបស់យើង;

៩៦ ប្រយោជន៍ឲ្យហៃរុម ជាអ្នកបំរើរបស់យើង អាចធ្វើទីបន្ទាល់អំពីការណ៍ទាំងឡាយ ដែលយើងនឹងបង្ហាញដល់គាត់ ប្រយោជន៍ឲ្យ ឈ្មោះគាត់អាចបានរំឭកដល់ដោយកិត្តិយស ពីតំណមួយទៅតំណមួយផង ជារៀងដរាបតទៅ ។

៩៧ ចូរឲ្យ វិលលាម ឡូវ៍ ជាអ្នកបំរើរបស់យើង បានទទួលកូនសោទាំងឡាយដែរ ដើម្បីឲ្យគាត់អាចសូម ហើយអាចបានទទួលព្រះពរ ទាំងឡាយ; ចូរឲ្យគាត់បន្ទាបខ្លួននៅចំពោះយើង ហើយដោយគ្មានឧបាយកលឡើយ ហើយគាត់នឹងបានទទួលព្រះវិញ្ញាណរបស់យើង គឺជាព្រះដ៏ជាជំនួយ ដែលនឹងសម្ដែងប្រាប់គាត់ នូវសេចក្ដីពិតនៃការណ៍គ្រប់ទាំងអស់ ហើយនឹងប្រទានដល់គាត់ នូវអ្វីដែលគាត់ត្រូវ និយាយ នៅម៉ោងនោះឯង ។

៩៨ ហើយទីសំគាល់ទាំងនេះនឹងជាប់តាមគាត់ — គឺគាត់នឹងប្រោសមនុស្សឈឺ គាត់នឹងបណ្ដេញអារក្សចេញ ហើយនឹងត្រូវបានរួចពី ពួកអ្នកដែលដាក់បំពុលគាត់;

៩៩ ហើយគាត់នឹងត្រូវបាននាំទៅតាមផ្លូវទាំងឡាយណា

---

៨៨ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ.
៨៩ *ក* គ. និង ស. ៧៨:៣.
*ខ* ក.ន. ការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស្ម៊ីធ.
៩០ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
*ខ* ទំនុក. ៣៧:២៥.
៩១ *ក* គ. និង ស. ១០៧:៣៩–៤០. ស.ប. អយ្យកោ, ខាងអយ្យកោ.
៩២ *ក* ស.ប. ពរនៃអយ្យកោ.
៩៣ *ក* គ. និង ស. ១៣២:៤៥–៤៧.
*ខ* ម៉ាថាយ ១៦:១៩. ស.ប. ភ្ជាប់, ការភ្ជាប់.
៩៤ *ក* គ. និង ស. ១០៧:៩១–៩២. ស.ប. អ្នកមើលឆុត.
៩៥ *ក* គ. និង ស. ៦:២៨.
*ខ* ស.ប. ខៅឌើរី, អូលីវើរ.
៩៧ *ក* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
*ខ* ស.ប. ឧបាយកល.
*គ* ស.ប. ព្រះដ៏ជាជំនួយ.
៩៨ *ក* ម៉ាកុស ១៦:១៧–១៨. ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
*ខ* ស.ប. ប្រោស, ការប្រោស.

ដែលពស់មាន[ក]ពិសពុំអាចចឹកកែងជើងគាត់បានឡើយ ហើយគាត់នឹងហោះ ហើរលើស្លាប[ខ]ឥន្ទ្រី នៅក្នុងមនោគតិនៃគំនិតរបស់គាត់ ។

១០០ ហើយបើសិនជាយើងមានព្រះហឫទ័យចង់ឲ្យគាត់ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ នោះចូរកុំឲ្យទប់សម្លេងគាត់ឡើយ ។

១០១ ហេតុដូច្នេះហើយ ចូរឲ្យ វិលលាម ជាអ្នកបំរើរបស់យើង ស្រែកឲ្យពេញបំពង់ក ហើយកុំសំចៃឡើយ ដោយសេចក្ដីអំណរ និងសេចក្ដីអរសប្បាយ និងដោយហូសាណាដល់ទ្រង់ ដែលគង់នៅលើបល្ល័ង្ក ជារៀងរាបដរាបតទៅ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១០២ មើលចុះ យើងប្រាប់អ្នកថា យើងមានបេសកកម្មមួយទុកសំរាប់ វិលលាម ជាអ្នកបំរើរបស់យើង និងហៃរុម ជាអ្នកបំរើរបស់យើង និងសំរាប់ពួកគេប៉ុណ្ណោះ; ហើយចូរឲ្យយ៉ូសែប ជាអ្នកបំរើរបស់យើង នៅផ្ទះចុះ ត្បិតគេត្រូវការលោក ។ អ្វីដែលនៅសល់ទាំងប៉ុន្មាន នោះយើងនឹងបង្ហាញដល់អ្នកនៅពេលក្រោយ ។ គឺដូច្នោះមែន ។ អាម៉ែន ។

១០៣ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា បើសិនជា [ក]ស៊ីឌនី ជាអ្នកបំរើរបស់យើង នឹងបំរើយើង ហើយធ្វើជាទីប្រឹក្សាដល់យ៉ូសែប ជាអ្នកបំរើរបស់យើង នោះចូរឲ្យគាត់ក្រោកហើយឡើងមក ហើយឈរនៅក្នុងតំណែងរបស់គាត់ ហើយបន្ទាបខ្លួននៅ ចំពោះយើងចុះ ។

១០៤ ហើយបើសិនជាគាត់នឹងថ្វាយដល់យើង នូវដង្វាយដ៏គួរសម ហើយដោយការទទួលស្គាល់ទាំងឡាយ ហើយនៅជាមួយរាស្ត្រ យើង មើលចុះ យើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក នឹងប្រោសគាត់ឲ្យគាត់បានជា; ហើយគាត់នឹងត្រូវបន្លឺ[ក]សម្លេងរបស់គាត់ទៀត នៅលើភ្នំទាំងឡាយ ហើយធ្វើជាអ្នកនិយាយនៅចំពោះព្រះភ័ក្ត្រយើង ។

១០៥ ចូរឲ្យគាត់មក ហើយទុកគ្រួសារគាត់នៅក្នុងសង្កាត់ដែលយ៉ូសែប ជាអ្នកបំរើរបស់យើង អាស្រ័យនៅ ។

១០៦ នៅក្នុងដំណើរទាំងអស់របស់គាត់ ចូរឲ្យគាត់បន្លឺសម្លេងគាត់ឡើង ហាក់ដូចជាដោយសម្លេងត្រែ ហើយព្រមានប្រាប់ដល់បណ្ដា ជននៅលើផែនដី ឲ្យរត់ចេញពីសេចក្ដីក្រោធដែលត្រូវមក ។

១០៧ ចូរឲ្យគាត់ជួយយ៉ូសែប ជាអ្នកបំរើរបស់យើង ហើយចូរឲ្យ វិលលាម ឡ [ក]រ៍ ជាអ្នកបំរើរបស់យើង ជួយយ៉ូសែប ជាអ្នកបំរើរបស់ យើងដែរ ក្នុងការធ្វើ[ក]ការប្រកាសដ៏ម៉ឺងម៉ាត់មួយ ដល់ពួកមហាក្សត្រនៅលើផែនដី ដូចដែលយើងបានប្រាប់អ្នករួចមកហើយនោះ ។

១០៨ បើសិនជា ស៊ីឌនី ជាអ្នកបំរើរបស់យើង នឹងធ្វើតាមព្រះហឫទ័យរបស់យើង ចូរកុំឲ្យគាត់ដកគ្រួសារគាត់ចេញពីដែនដីនៅ[ក]ទិស ខាងកើតឡើយ ប៉ុន្តែចូរឲ្យគាត់ប្ដូរទីលំនៅរបស់គាត់ ដូចដែលយើងបានប្រាប់រួចមកហើយនោះ ។

១០៩ មើលចុះ គឺពុំមែនជាព្រះហឫទ័យយើងទេ ដែលគាត់ត្រូវស្វែងរកសន្តិសុខ និងទីពឹងជ្រក ចេញពីទីក្រុង ដែលយើងបានតាំងដល់ អ្នក គឺជាទី[ក]ក្រុងណៅវូនោះ ។

១១០ យើងប្រាប់អ្នកជាប្រាកដថា សូម្បីតែឥឡូវនេះ បើសិនជាគាត់ប្រុងស្ដាប់តាមសម្លេងយើង នោះនឹងបានស្រួលដល់គាត់ហើយ ។ គឺដូច្នោះមែន ។ អាម៉ែន ។

១១១ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យអេម៉ុស ដាវីស ជាអ្នកបំរើរបស់យើង ចូលដៃជាមួយពួកអ្នកដែលយើងបាន តាំងឡើងឲ្យកសាងផ្ទះសំណាក់ គឺណៅវូហោស ។

១១២ ចូរឲ្យគាត់ធ្វើការណ៍នេះ បើសិនជាគាត់នឹងមានការប្រាក់; ហើយចូរឲ្យគាត់ប្រុងស្ដាប់តាមដំបូន្មាននៃយ៉ូសែប ជាអ្នកបំរើ របស់យើង ហើយធ្វើការងារដោយដៃរបស់ខ្លួន ប្រយោជន៍ឲ្យគាត់អាចបានទីទុកចិត្តពីមនុស្ស ។

១១៣ ហើយកាលណាគាត់បានបញ្ជាក់ថា ខ្លួនមានចិត្តស្មោះត្រង់ ក្នុងគ្រប់ការណ៍ទាំងអស់ ដែលបានផ្ទុកផ្ដាក់ឲ្យគាត់ថែរក្សា មែនហើយ សូម្បីតែការណ៍តូចតាចក៏ដោយ គង់តែគាត់នឹងត្រូវបានធ្វើជាអ្នក[ក]ត្រួតត្រាលើរបស់ជាច្រើនដែរ;

១១៤ ហេតុដូច្នេះហើយ ចូរឲ្យគាត់[ក]បន្ទាបខ្លួនចុះ ប្រយោជន៍ឲ្យគាត់អាចបានដំកើងឡើង ។ គឺដូច្នោះមែន ។ អាម៉ែន ។

១១៥ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា បើសិនជា

៩៩ *ក* គ. និង ស. ៨៤:៧១–៧៣.
*ខ* និក្ខ. ១៩:៤; អេសាយ ៤០:៣១.
១០៣ *ក* ស.ប. រិកដុន, ស៊ីឌនី.
១០៤ *ក* និក្ខ. ៤:១៤–១៦;
២ នីហ្វៃ ៣:១៧–១៨;
គ. និង ស. ១០០:៩–១១.
១០៧ *ក* គ. និង ស. ១២៤:២–៤.
១០៨ *ក* គ. និង ស. ១២៤:៨២–៨៣.
១០៩ *ក* ស.ប. ក្រុងណៅវូ,
រដ្ឋអិលលីណោយ (សហរដ្ឋ).
១១៣ *ក* ម៉ាថាយ ២៥:១៤–៣០.
១១៤ *ក* ម៉ាថាយ ២៣:១២;
គ. និង ស. ១០១:៤២.

វ៉ូបឺត ឌី ហ្វូស្ទើរ ជាអ្នកបំរើរបស់យើង នឹងគោរពតាមសម្លេងយើង នោះចូរឲ្យគាត់កសាងគេហដ្ឋានមួយ សំរាប់យ៉ូសែប ជាអ្នកបំរើរបស់យើង ស្របតាមកិច្ចព្រមព្រៀង ដែលគាត់បានធ្វើជាមួយលោក ហាក់ដូចជាទ្វារនឹងបានបើកឲ្យគាត់ តាមកាលវេលា ។

១១៦ ហើយចូរឲ្យគាត់[ក]ប្រែចិត្តពីអស់ទាំងសេចក្ដីចំកួតរបស់ខ្លួន ហើយបំពាក់គាត់ដោយសេចក្ដីសប្បុរស ហើយឲ្យឈប់ប្រព្រឹត្តអំពើ អាក្រក់ ហើយឲ្យបោះបង់ចោលអស់ទាំងពាក្យរឹងទទឹងរបស់គាត់ចុះ;

១១៧ ហើយឲ្យចូលហ៊ុនចូលដៃជាមួយក្រុមណៅវូហោស សំរាប់រូបគាត់ និងសំរាប់តំណគាត់បន្តបន្ទាប់ទៅ ពីតំណមួយទៅ តំណមួយផងចុះ;

១១៨ ហើយចូរប្រុងស្ដាប់តាមដំបូន្មាននៃយ៉ូសែប និង ហៃរុម និង វិលលាម ឡូវ៍ ជាពួកអ្នកបំរើរបស់យើង និងតាមពួកអ្នកដែលមាន សិទ្ធិអំណាច ដែលយើងបានហៅឲ្យសង់គ្រឹះនៃស៊ីយ៉ូន; ហើយនឹងបានស្រួលដល់គាត់ ជារៀងដរាបតទៅ ។ គឺដូច្នោះមែន ។ អាម៉ែន ។

១១៩ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរកុំឲ្យនរណាចូលហ៊ុនជាមួយក្រុមណៅវូហោសឡើយ លើកលែងតែអ្នកនោះ ជឿដល់ព្រះគម្ពីរមរមន និងវិវរណៈទាំងឡាយ ដែលបានប្រទានដល់អ្នក ព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ;

១២០ ត្បិតអ្វីដែល[ក]លើស ឬតិចជាងនេះ គឺមកតែពីអាកំណាចទេ ហើយនឹងបានជាប់ដោយបណ្ដាសាទាំងឡាយ ហើយពុំមែនដោយ ព្រះពរឡើយ ព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ គឺដូច្នោះមែន ។ អាម៉ែន ។

១២១ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យក្រុមណៅវូហោស មានថ្លៃឈ្នួលត្រឹមត្រូវ សំរាប់ការងារទាំងអស់របស់ ពួកគេ ដែលពួកគេបានធ្វើ ក្នុងការកសាងណៅវូហោសចុះ; ហើយចូរឲ្យថ្លៃឈ្នួលរបស់ពួកគេ បានយល់ដោយព្រមព្រៀងគ្នា ក្នុងចំណោមពួកគេ ដូចជាសមស្របតាមតម្លៃនោះ ។

១២២ ហើយចូរឲ្យមនុស្សរាល់គ្នាណាដែលចូលហ៊ុន កាន់បង្គាន់ដៃនូវចំណែកប្រាក់របស់ខ្លួន បើសិនជាត្រូវការ សំរាប់ការគាំទ្រដល់ ពួកគេ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ; បើពុំនោះសោតទេ ការងារទាំងឡាយរបស់ពួកគេនឹងត្រូវបានរាប់ជាហ៊ុនដល់ពួកគេ នៅក្នុងគេហដ្ឋាននោះ ។ គឺដូច្នោះមែន ។ អាម៉ែន ។

១២៣ យើងប្រាប់អ្នកជាប្រាកដថា ឥឡូវនេះ យើងប្រទានដល់អ្នករាល់គ្នា នូវ[ក]ពួកអ្នកកាន់តំណែង ដែលជាសមាជិកនៃបព្វជិតភាព របស់យើង ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចកាន់[ខ]កូនសោទាំងឡាយនៃបព្វជិតភាពនោះ គឺជាបព្វជិតភាព ដែលធ្វើតាមរបៀបនៃ [គ]លោកមិលគីស្សាដែក ដែលធ្វើតាមរបៀបនៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើង ។

១២៤ មុនដំបូង យើងប្រទានដល់អ្នករាល់គ្នា ហៃរុម ស្ម៊ីធ ឲ្យធ្វើជា[ក]លោកអយ្យកោចំពោះអ្នក ដើម្បីកាន់នូវព្រះពរទាំងឡាយខាង[ខ]ការភ្ជាប់ នៃសាសនាចក្ររបស់យើង [ឃ]គឺជាព្រះវិញ្ញាណបរិសុទ្ធនៃ[គ]សេចក្ដីសន្យា ដើម្បីឲ្យអ្នករាល់គ្នាបានភ្ជាប់ទុក ចំពោះថ្ងៃនៃ សេចក្ដីប្រោសលោះ ប្រយោជន៍កុំឲ្យអ្នករាល់គ្នាអាចបានធ្លាក់ ទោះជា[ង]ម៉ោងនៃសេចក្ដីល្បួង ដែលអាចមានមកលើអ្នកក៏ដោយ ។

១២៥ យើងប្រទានដល់អ្នករាល់គ្នា យ៉ូសែប ជាអ្នកបំរើរបស់យើង ឲ្យធ្វើជាអែលឌើរពិនិត្យត្រួតត្រាលើអស់ទាំងសាសនាចក្រ របស់យើង ឲ្យធ្វើជាអ្នកបកប្រែ ជាអ្នកទទួលវិវរណៈ ជា[ក]អ្នកមើលឆុត និងជាព្យាការី ។

១២៦ យើងប្រទានដល់លោក ឲ្យធ្វើជាទីប្រឹក្សាគឺ ស៊ីឌនី រិកដុន ជាអ្នកបំរើរបស់យើង និង វិលលាម ឡូវ៍ ជាអ្នកបំរើរបស់យើង ប្រយោជន៍ឲ្យពួកអ្នកទាំងនេះអាចរួមទៅជាក្រុម និងជា[ក]គណៈប្រធានទីមួយ ដើម្បីទទួលព្រះបន្ទូលទាំងឡាយ សំរាប់សាសនាចក្រទាំង មូល ។

១២៧ យើងប្រទានដល់អ្នករាល់គ្នា [ក]ព្រិកហាំ យ៉ង់ ជាអ្នកបំរើរបស់យើង ឲ្យធ្វើជាប្រធានលើក្រុម១២នាក់ដែលធ្វើដំណើរ;

១២៨ ជា[ក]ពួក១២នាក់ដែលកាន់កូនសោទាំងឡាយ ដើម្បីបើកសិទ្ធិអំណាចនៃនគររបស់យើង នៅលើជ្រុងទាំងបួននៃផែនដី

---

១១៦ *ក* កូល៉ុស ៣:១៤.
ស.ប. សេចកីសប្បុរស.
១២០ *ក* ម៉ាថាយ ៥:៣៧;
គ. និង ស. ៩៨:៧.
១២៣ *ក* ស.ប. តំណែង, អ្នកកាន់តំណែង.
*ខ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*គ* ស.ប. បព្វជិតភាពមិលគីស្សាដែក.
១២៤ *ក* ស.ប. អយ្យកោ, ខាងអយ្យកោ.
*ខ* ស.ប. ភ្ជាប់, ការភ្ជាប់.
*គ* គ. និង ស. ៧៦:៥៣; ៨៨:៣–៤.
ស.ប. ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា.
*ឃ* អេភេ. ៤:៣០.
*ង* វិវរ. ៣:១០.
១២៥ *ក* គ. និង ស. ២១:១.
ស.ប. អ្នកមើលឆុត.
១២៦ *ក* គ. និង ស. ៩០:៤–៥.
១២៧ *ក* ស.ប. យ៉ង់, ព្រិកហាំ.
១២៨ *ក* ស.ប. សាវក.

ហើយ បន្ទាប់ពីនោះ ឲ្យ[ខ]បញ្ជូនព្រះបន្ទូលរបស់យើងទៅដល់សត្វលោកគ្រប់រូប ។

១២៩ ពួកគេគឺ ហ៊ីបឺរ ស៊ី គិមបុល, បាលី ភី ប្រាត្ត, អ័រសុន ប្រាត្ត, អ័រសុន ហៃឌ, វិលលាម ស្ម៊ីធ, យ៉ូហាន ថេលើរ, យ៉ូហាន អ៊ី ភេច, វិលហ្វូឌ វូឌរ្រុភ្វ, វិលឡឺឌ រិចឺឌ្ស, ជួច អេ ស្ម៊ីធ;

១៣០ រីឯ [ក]ដាវីឌ [ខ]ប៉ាទ្តិន នោះយើងបានយកមកឯយើងហើយ; មើលចុះ បព្វជិតភាពរបស់គាត់ នោះគ្មាននរណាអាចយកពីគាត់បាន ឡើយ; ប៉ុន្តែយើងប្រាប់អ្នកជាប្រាកដថា អ្នកផ្សេងទៀតអាចបានតែងតាំងឡើង ចំពោះតំណែងដដែលនោះ ។

១៣១ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា យើងប្រទានដល់អ្នកនូវ[ក]ក្រុមប្រឹក្សាជាន់ខ្ពស់មួយ សំរាប់ថ្មសិមានៃស៊ីយ៉ូន —

១៣២ ដោយមានឈ្មោះថា សាំយូអែល បិន្ត, ហៃនរី ជីស៊ើរូឌ, ជួច ដ័បបុលយូ ហារិស, ឆាល្ស ស៊ី រិច, ថូម៉ាស ក្រូវើរ, នូវល ណៃត, ដាវីឌ ដត់, ដាន់បើរ វិលសុន — រីឯ ស៊ីប្លូរ ព្រុនសុន នោះយើងបានយកមកឯយើងហើយ; គ្មាននរណាអាចយកបព្វជិតភាពពីគាត់បាន ឡើយ ប៉ុន្តែអ្នកផ្សេងទៀតអាចបានតែងតាំងឡើង ចំពោះតំណែងដដែលនោះជំនួសគាត់; ហើយយើងប្រាប់អ្នកជាប្រាកដថា ចូរឲ្យអ៊ើរ៉ុន ចនសុន បានតែងតាំងឡើង ចំពោះតំណែងនេះជំនួសគាត់ចុះ — ដាវីឌ ហ្វូលមើរ, អាលភ្វូស កាត់ឡើរ, វិលលាម ហាន់ទិងតោន ។

១៣៣ ហើយជាថ្មីទៀត យើងប្រទានដល់អ្នករាល់គ្នា ជន ស៊ី ស្ម៊ីធ ឲ្យធ្វើជាប្រធានលើក្រុមនៃពួកសង្ឃជាន់ខ្ពស់;

១៣៤ ពិធីការត្រូវបានអនុវត្តឡើង សំរាប់គោលបំណងនៃការរៀបចំពួកអ្នក ដែលត្រូវបានតែងតាំងឡើងជាពួកប្រធាន ឬពួកអ្នកបំរើ ដែលនៅអចិន្ត្រៃយ លើ[ក]ស្តេកផ្សេងៗ ដែលមានពាសពេញទូទៅ;

១៣៥ ហើយពួកគេក៏អាចធ្វើដំណើរបានដែរ បើសិនជាពួកគេប្រាថ្នា ប៉ុន្តែសុខចិត្តទទួលការតែងតាំងជាប្រធានដែលនៅអចិន្ត្រៃយវិញ; នេះគឺជាតំណែងនៃការហៅរបស់ពួកគេ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៣៦ យើងប្រទានដល់គាត់ អាម៉ាសា ឡៃម៉ាន និង ណូអេ ប៉ាកឹត ទុកជាទីប្រឹក្សាទាំងឡាយ ប្រយោជន៍ឲ្យពួកគេអាចពិនិត្យត្រួតត្រា លើក្រុមនៃពួកសង្ឃជាន់ខ្ពស់ ក្នុងសាសនាចក្ររបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៣៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា យើងប្រទានដល់អ្នករាល់គ្នា យ៉ូហាន អេ ហ៊ិក្ស, សាំយូអែល វិលលាម្ស, និង អ៊ីសាយ បេកើរ ជាអ្នកកាន់បព្វជិតភាព ដើម្បីពិនិត្យត្រួតត្រាលើ[ក]ក្រុមនៃពួកអែលឌើរ ជាក្រុមដែលត្រូវបានអនុវត្តឡើង សំរាប់ពួកអ្នកធ្វើការងារបំរើដែល នៅប្រចាំជាអចិន្ត្រៃយ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេអាចធ្វើដំណើរបានដែរ ប៉ុន្តែពួកគេត្រូវបានតែងតាំងឡើង ឲ្យធ្វើជា ពួកអ្នកធ្វើការងារបំរើដែលនៅអចិន្ត្រៃយ ចំពោះសាសនាចក្ររបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៣៨ ហើយជាថ្មីទៀត យើងប្រទានដល់អ្នករាល់គ្នា យ៉ូសែប យ៉ង់, យ៉ូសាយ បាត់តើហ្វៀល, ដានីយ៉ែល ម៉ៃល្ស, ហៃនរី ហើរម៉ាន, សេរ៉ា ប៉ុលសៃហ្វើរ, លេវី ហែនខក់, យ៉េម្ស ហ្វូស្ទើរ, ឲ្យពិនិត្យត្រួតត្រាលើ[ក]ក្រុមនៃពួក៧០នាក់;

១៣៩ ជាក្រុមដែលបានអនុវត្តឡើង សំរាប់ពួកអែលឌើរដែលធ្វើដំណើរ ដើម្បីធ្វើទីបន្ទាល់ប្រាប់ពីព្រះនាមរបស់យើង នៅក្នុងពិភព លោកទាំងអស់ រីឯកន្លែងណាដែលមានក្រុមប្រឹក្សាជាន់ខ្ពស់ដែលធ្វើដំណើរ គឺជាពួកសាវករបស់យើង នោះនឹងត្រូវបញ្ជូនពួកគេឲ្យ ទៅរៀបចំផ្លូវ នៅចំពោះព្រះភ័ក្ត្រយើង ។

១៤០ ការខុសគ្នារវាងក្រុមនេះនឹងក្រុមនៃពួកអែលឌើរ គឺថាក្រុមមួយត្រូវធ្វើដំណើររហូត ហើយក្រុមមួយទៀត ត្រូវពិនិត្យត្រួតត្រាលើ សាសនាចក្រទាំងឡាយ តាមកាលវេលា; មួយមានភារកិច្ចខាងការពិនិត្យត្រួតត្រា តាមកាលវេលា ហើយមួយទៀត ពុំមានភារកិច្ច ខាងការពិនិត្យត្រួតត្រាលើទេ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៤១ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា យើងប្រទានដល់អ្នករាល់គ្នា វិនសុន ណៃត, សាំយូអែល អេច ស្ម៊ីធ, និង សាដ្រាក់ រ៉ោនឌី បើសិនជាគាត់យល់ព្រម ឲ្យពិនិត្យត្រួតត្រាលើ[ក]គណៈប៊ីស្សព; ដំណឹងអំពីគណៈប៊ីស្សពដែលបានពោលដល់នេះ ត្រូវបានប្រទានដល់អ្នក នៅក្នុងព្រះ[ខ]គម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ។

១៤២ ហើយជាថ្មីទៀត យើងប្រាប់អ្នកថា សាំយូអែល រ៉ូហ្វ និងទីប្រឹក្សាទាំងឡាយរបស់គាត់ សំរាប់ពួកសង្ឃ និងប្រធាននៃ

---

១២៨ *ខ* ម៉ាកុស ១៦:១៥.
១៣០ *ក* ស.ប. ប៉ាទ្តិន, ដាវីឌ ដ័បបុលយូ.
*ខ* គ. និង ស. ១២៤:១៩.
១៣១ *ក* ស.ប. ក្រុមប្រឹក្សាជាន់ខ្ពស់.
១៣៤ *ក* ស.ប. ចំរឹង, ស្តេក.
១៣៧ *ក* គ. និង ស. ១០៧:១១–១២, ៨៩–៩០.
ស.ប. អែលឌើរ; ក្រុម.
១៣៨ *ក* ស.ប. ពួក៧០នាក់.
១៤១ *ក* គ. និង ស. ៦៨:១៤; ១០៧:១៥.
*ខ* ស.ប. គោលលទ្ធិ និងសេចក្ដីសញ្ញា.

ពួកគ្រូ ហើយនិងទីប្រឹក្សាទាំងឡាយរបស់គាត់ ហើយព្រមទាំងប្រធាននៃពួកឌីកុន និងទីប្រឹក្សាទាំងឡាយរបស់គាត់ ហើយព្រមទាំងប្រធាននៃ ស្តេក និងទីប្រឹក្សាទាំងឡាយរបស់គាត់ផង ។

១៤៣ តំណែងទាំងឡាយខាងលើនេះ យើងបានប្រទានដល់អ្នក ហើយកូនសោទាំងឡាយនៃតំណែងនោះ សំរាប់ជាជំនួយ និងការ ត្រួតត្រា សំរាប់កិច្ចការខាងការងារបំរើ និងការធ្វើឲ្យពួកបរិសុទ្ធបាន[ក]ល្អឥតខ្ចោះ ។

១៤៤ ហើយយើងប្រទានបញ្ញត្តិមួយដល់អ្នកថា អ្នកគួរបំពេញតំណែងទាំងនេះ ហើយ[ក]អនុម័តឈ្មោះទាំងនោះ ដែលយើងបានពោល ប្រាប់ បើពុំនោះសោតទេ ចូរកុំអនុម័តពួកគេ នៅឯសន្និសីទទូទៅរបស់យើងឡើយ;

១៤៥ ហើយថាអ្នករាល់គ្នាគួររៀបចំបន្ទប់ទាំងឡាយទុកសំរាប់តំណែងទាំងនេះ នៅក្នុងគេហដ្ឋានរបស់យើង នៅពេលអ្នកកសាង គេហដ្ឋាននោះដល់ព្រះនាមរបស់យើង ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ គឺដូច្នោះមែន ។ អាម៉ែន ៕

## កណ្ឌទី ១២៥

*វិវរណៈដែលបានប្រទានមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងណៅវូ រដ្ឋអិលលីណោយ ខែមីនា ឆ្នាំ១៨៤១ អំពីពួកបរិសុទ្ធនៅក្នុងភូមិភាគអៃអូវ៉ា (*History of the Church*, ៤:៣១១–៣១២)* ។

*១–៤; ពួកបរិសុទ្ធត្រូវស្ថាបនាទីក្រុងទាំងឡាយ ហើយត្រូវប្រមូលគ្នាទៅឯស្ដេកទាំងឡាយនៃក្រុងស៊ីយ៉ូន ។*

តើព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យយ៉ាងណា អំពីពួកបរិសុទ្ធនៅក្នុងភូមិភាគអៃអូវ៉ា ?

២ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា យើងប្រាប់ដល់អ្នក បើសិនអស់អ្នកដែល[ក]ហៅខ្លួនតាមព្រះនាមយើង ហើយប្រុង នឹងធ្វើជាពួកបរិសុទ្ធរបស់យើង បើសិនជាពួកគេធ្វើតាមព្រះហឫទ័យរបស់យើង ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយ ដែលយើងមាន អំពីពួកគេ នោះចូរឲ្យពួកគេប្រមូលគ្នាមករកកន្លែងទាំងឡាយ ដែលយើងនឹងតាំងដល់ពួកគេ ដោយយ៉ូសែប ជាអ្នកបំរើរបស់យើងចុះ ហើយស្ថាបនាទីក្រុងទាំងឡាយឡើងដល់ព្រះនាមរបស់យើង ប្រយោជន៍ឲ្យពួកគេអាចបានរៀបចំទុកជាស្រេច សំរាប់អ្វីដែលនឹងមក នៅពេលអនាគត ។

៣ ចូរឲ្យពួកគេស្ថាបនាទីក្រុងមួយឡើងដល់ព្រះនាមរបស់យើង នៅលើដែនដីបណ្ដោយនឹងទីក្រុងណៅវូ ហើយចូរហៅឈ្មោះ [ក]សារ៉ាហិមឡា ជាឈ្មោះទីក្រុងនោះចុះ ។

៤ ហើយចូរឲ្យអស់អ្នកដែលមកពីទិសខាងកើត និងខាងលិច និងខាងជើង និងខាងត្បូងណាដែលមានសេចក្ដីប្រាថ្នាចង់អាស្រ័យនៅ [ក]ទីនេះ ចូរឲ្យយកទីកេរ្តិ៍អាករនៅទីដដែលនោះ ព្រមទាំងនៅក្នុងទីក្រុង[ខ]ណាស្វិល ឬក៏នៅក្នុងទីក្រុងណៅវូ និងនៅក្នុងស្តេកទាំងឡាយ ដែលយើងបានតាំងឡើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

## កណ្ឌទី ១២៦

*វិវរណៈដែលបានប្រទានមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្នុងផ្ទះនៃព្រិកហាំ យ៉ង់ នៅទីក្រុងណៅវូ រដ្ឋអិលលីណោយ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ១៨៤១ (*History of the Church*, ៤:៣៨២)* ។ *នៅពេលនេះ ព្រិកហាំ យ៉ង់ ត្រូវជាប្រធានលើក្រុមនៃពួកសាវក១២នាក់* ។

១៤៣ *ក* អេភេ. ៤:១១–១៤.
១៤៤ *ក* គ. និង ស. ២៦:២.
ស.ប. ការយល់ព្រមទូទៅ.
**១២៥** ២ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើង.
៣ *ក* ស.ប. សារ៉ាហិមឡា.
៤ *ក* ក.ន. ក្រុងណាស្វិលនៅឃុំលីរដ្ឋអៃអូវ៉ា.
*ខ* ស.ប. ចំរឹង, ស្តេក.

*១–៣, ព្រិកហាំ យ៉ង់ ត្រូវបានទទួលការសរសើរចំពោះកិច្ចការទាំងឡាយរបស់គាត់ ហើយត្រូវបានដកចេញពីការធ្វើដំណើរឆ្ងាយ នៅថ្ងៃក្រោយ ។*

មកដល់បងប្រុស[ក]ព្រិកហាំ យ៉ង់ ជាទីស្រឡាញ់អើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា៖ ព្រិកហាំ ជាអ្នកបំរើរបស់យើងអើយ យើងមិនតម្រូវពីដៃអ្នក ឲ្យចាកចេញពីគ្រួសារអ្នក ដូចនៅពេលមុនៗទៀតឡើយ ត្បិតដង្វាយរបស់អ្នកសមដល់យើងហើយ ។

២ យើងបានឃើញការងារ និង[ក]កិច្ចការរបស់អ្នក ក្នុងការធ្វើដំណើរដើម្បីព្រះនាមរបស់យើង ។

៣ ហេតុដូច្នេះហើយ យើងបញ្ជាដល់អ្នក ឲ្យបញ្ជូនព្រះបន្ទូលរបស់យើងទៅទីឆ្ងាយ ហើយថែទាំ[ក]គ្រួសាររបស់អ្នកឲ្យបានស្រួលបួល ចាប់ពីពេលនេះ គឺពីអំណិះ និងរៀងដរាបតទៅ ។ អាម៉ែន ៕

## កណ្ឌទី ១២៧

*សំបុត្រពី យ៉ូសែប ស្ម៊ីធ ជាព្យាការី ទៅកាន់ពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅទីក្រុងណៅវូ រដ្ឋអិលលីណោយ មាននូវការដឹកនាំអំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ចេញពីទីក្រុងណៅវូ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៤២ (*History of the Church, *៥:១៤២–១៤៤)* ។

*១–៤, យ៉ូសែប ស្ម៊ីធ សរសើរដំកើងនៅក្នុងសេចក្ដីបៀតបៀន និងសេចក្ដីវេទនា; ៥–១២, បញ្ជីទាំងឡាយត្រូវបានកត់ទុកដែលទាក់ទង ទៅនឹងបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ។*

ពីព្រោះព្រះអម្ចាស់ទ្រង់បានបើកសំដែងប្រាប់ដល់ខ្ញុំ ថាពួកខ្មាំងសត្រូវរបស់ខ្ញុំ នៅរដ្ឋមិសសួរី ព្រមទាំងនៅរដ្ឋនេះ កំពុងតែតាមរកខ្ញុំ ទៀត; ហើយពីព្រោះពួកគេតាមរកខ្ញុំ ដោយគ្មាន[ក]ហេតុ ហើយដោយគ្មានសេចក្ដីយុត្តិធម៌ ឬសិទ្ធិសូម្បីតែស្រមោល ឬពណ៌តូចតាចណា មួយឡើយ នៅការគាំទ្រខាងពួកគេ ក្នុងការញុះញង់ឡើងនូវការចោទទោសដល់ខ្ញុំ; ហើយពីព្រោះការចោទរបស់ពួកគេដែលគ្មាន ភស្តុតាង គឺសុទ្ធតែទាក់ទងទៅនឹងពាក្យកុហកដ៏ខ្មៅបំផុត នោះខ្ញុំគិតថាជាការចាំបាច់ ហើយប្រកបដោយប្រាជ្ញាវាងវៃក្នុងខ្លួនខ្ញុំត្រូវចេញពីទីកន្លែងមួយរដូវខ្លីសិនចុះ សំរាប់សន្តិសុខដល់ខ្លួនខ្ញុំផ្ទាល់ និងសន្តិសុខដល់ប្រជារាស្ត្រនេះ ។ ខ្ញុំសូមប្រាប់ដល់អស់អ្នកណា ដែលខ្ញុំមានធុរកិច្ចជាមួយថា ខ្ញុំបានទុកកិច្ចការទាំងឡាយរបស់ខ្ញុំជាមួយភ្នាក់ងារ និងស្មៀនទាំងឡាយ ដែលនឹងធ្វើកិច្ចការទាំងអស់ ដោយរបៀបរៀបរយ និងទាន់ពេលវេលា ហើយនឹងមើលគន់ថាបំណុលខ្ញុំទាំងអស់ ត្រូវបានសងទាន់ពេល ដោយលក់ដូរទ្រព្យសម្បត្តិ ឬតាមរបៀបណាផ្សេងទៀត តាមការតម្រូវ ឬតាមកាលៈទេសៈបណ្ដោយ ។ នៅពេលខ្ញុំដឹងថាខ្យល់ព្យុះបានបោកផុតកាលណា នោះខ្ញុំនឹងវិលមករកអ្នកវិញ ។

២ ហើយរីង[ក]គ្រោះដែលខ្ញុំត្រូវបានហៅឲ្យឆ្លងកាត់[ខ] នោះហាក់ដូចជាការតូចតាចចំពោះខ្ញុំ ពីព្រោះសេចក្ដីប្រណែន និងសេចក្ដីក្រោធនៃ មនុស្ស នោះសុទ្ធតែជាការធម្មតា អស់មួយជីវិតរបស់ខ្ញុំ; ហើយដោយមកពីហេតុអ្វីនោះឃើញថាពិបាកយល់ដែរ លើកលែងតែខ្ញុំត្រូវ [គ]បានតែងតាំងពីកំណើតលោកិយមក សំរាប់គោលបំណងល្អ ឬអាក្រក់ណាមួយ តាមតែអ្នកពិចារណាគិតចុះ ។ ចូរអ្នករាល់គ្នាវិនិច្ឆ័យ ដោយខ្លួនឯងចុះ ។ ព្រះទ្រង់ជ្រាបសព្វគ្រប់ ទោះជាការល្អ ឬការអាក្រក់ក្ដី ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គង់តែទឹកជ្រៅនេះ ហើយដែលខ្ញុំធ្លាប់ហែលកាត់ ។ ការណ៍ទាំងអស់នេះក្លាយទៅជាការធម្មតាចំពោះ[ឃ]ខ្ញុំ; ហើយខ្ញុំគិតដូចប៉ុលថាត្រូវសរសើរដំកើងក្នុង សេចក្ដីវេទនា; ត្បិតរហូតដល់ថ្ងៃនេះហើយ ដែលព្រះនៃអយ្យកោទាំងឡាយរបស់ខ្ញុំបានរំដោះខ្ញុំឲ្យរួចពីការណ៍ទាំងអស់ ហើយនឹង រំដោះខ្ញុំឲ្យរួចពីអំណិះតទៅ; ត្បិតមើលចុះ និងមើលន៏ ខ្ញុំនឹងមានជ័យជំនះលើ

---

**១២៦** ១*ក* ស.ប. យ៉ង់, ព្រិកហាំ.
២ *ក* ស.ប. កិច្ចការ.
៣ *ក* ស.ប. គ្រួសារ.
**១២៧** ១*ក* យ៉ូប ២:៣;
ម៉ាថាយ ៥:១០–១២;
១ ពេត្រុស ២:២០–២៣.
២ *ក* ទំនុក. ២៣:១–៦.
ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
*ខ* ស.ប. ប្រណែន.
*គ* ស.ប. ការតែងតាំងមុនកំណើតលោកិយ.
*ឃ* ២ កូរិន. ៦:៤–៥.

អស់ទាំងពួកខ្មាំងសត្រូវរបស់ខ្ញុំ ព្រោះព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់
មានព្រះបន្ទូលថាដូច្នោះ ។
៣ ហេតុដូច្នេះហើយ ចូរឲ្យពួកបរិសុទ្ធទាំងអស់គ្នាមាន
ចិត្តអរសប្បាយ ហើយមានចិត្តត្រេកអរជាអនេកចុះ; ព្រោះព្រះ
របស់អ៊ីស្រាអែល គឺជាព្រះរបស់ពួកគេ ហើយទ្រង់នឹងវាល់
សំណងដ៏ត្រឹមត្រូវទុកជារង្វាន់មកលើក្បាលនៃអស់ទាំងពួកអ្នក
ដែលសង្កត់សង្កិនគេ ។
៤ ហើយជាថ្មីទៀត ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល
ដូច្នេះថា៖ ចូរឲ្យកិច្ចការនៃព្រះវិហាររបស់យើង និងកិច្ចការទាំង
អស់ ដែលយើងបានចាត់ដល់អ្នក មានតទៅ ហើយ
កុំឈប់ឈរឡើយ; ហើយចូរឲ្យសេចក្ដីព្យាយាមរបស់អ្នក និងសេច
ក្ដីខ្ជាប់ខ្ជួន និងសេច ក្ដីអត់ធន់របស់អ្នក និងកិច្ចការរបស់អ្នកកើន
ទៅជាពីរ ហើយអ្នកក៏នឹងពុំត្រូវបាត់បង់រង្វាន់របស់ខ្លួនដែរ ព្រះ
អម្ចាស់នៃពួកពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។ ហើយបើ
សិនជាពួកគេបៀតបៀនអ្នក ក៏ពួកគេបានបៀតបៀនពួកព្យាការី
និងពួកមនុស្សសុចរិត ពីមុនអ្នកដែរ ។ ត្បិតដោយការណ៍ទាំង
អស់នេះហើយ ទើបមានរង្វាន់នៅស្ថានសួគ៌ ។
៥ ហើយជាថ្មីទៀត យើងប្រទានដល់អ្នក នូវព្រះបន្ទូល
អំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ។
៦ ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះ ដល់អ្នក
អំពីមនុស្សស្លាប់របស់អ្នក ថា៖ កាលណាអ្នកណាមួយទទួល
បុណ្យជ្រមុជទឹក ជំនួសមនុស្សស្លាប់របស់អ្នក នោះចូរឲ្យមានអ្នក
កត់បញ្ជីទុក ហើយចូរគាត់ធ្វើសាក្សីអំពីបុណ្យជ្រមុជទឹកទាំង
ឡាយរបស់អ្នក; ចូរឲ្យគាត់ឮ ដោយត្រចៀកគាត់ ប្រយោជន៍ឲ្យ
គាត់អាចធ្វើទីបន្ទាល់អំពីសេចក្ដីពិត ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលថាដូច្នោះ;
៧ ប្រយោជន៍ឲ្យគ្រប់ការកត់ត្រារបស់អ្នកទាំងអស់ អាចបាន
កត់ត្រាទុកនៅស្ថានសួគ៌ដែរ; អ្វីក៏ដោយដែលអ្នកចងនៅផែនដី
នោះអាចបានចងនៅស្ថានសួគ៌ដែរ; អ្វីក៏ដោយដែលអ្នកស្រាយ
នៅផែនដី នោះអាចបានស្រាយនៅស្ថានសួគ៌ដែរ;
៨ ព្រោះយើងបំរុងនឹងសាងឡើងវិញ នូវការណ៍ជាច្រើន
ដល់ផែនដី ដែលទាក់ទងទៅនឹងបព្វជិតភាព ព្រះអម្ចាស់នៃពួក
ពលបរិវារ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៩ ហើយជាថ្មីទៀត ចូរទុកគ្រប់បញ្ជីទាំងអស់ឲ្យមាន
របៀបរៀបរយ ប្រយោជន៍ឲ្យរបស់ទាំងនោះអាចបានទុកនៅ
ក្នុងប័ណ្ណសារនៃ ព្រះវិហារបរិសុទ្ធរបស់យើង ដើម្បីទុកជាទីរឭក
ពីតំណមួយទៅតំណមួយ ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់មាន
ព្រះបន្ទូលថាដូច្នោះ ។
១០ ខ្ញុំនឹងប្រាប់ដល់ពួកបរិសុទ្ធទាំងអស់គ្នាថា ខ្ញុំមានសេច
ក្ដីប្រាថ្នា ដោយសេចក្ដីប្រាថ្នាដ៏ធំបំផុត ចង់មានវាចាទៅកាន់ពួក
គេ ពីវេទិកា នូវកម្មវត្ថុអំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ នៅ
ថ្ងៃឈប់សំរាកខាងមុខ ។ ប៉ុន្តែពីព្រោះវាហួសពីអំណាចខ្ញុំ
ដើម្បីធ្វើការនេះ ទើបខ្ញុំនឹងសរសេរនូវព្រះបន្ទូលនៃព្រះអម្ចាស់
តាមកាលវេលា អំពីកម្មវត្ថុនោះ ហើយផ្ញើទៅឲ្យអ្នក ព្រមទាំង
ការណ៍ផ្សេងៗទៀតជា ច្រើនផង ។
១១ ឥឡូវនេះ ខ្ញុំសូមបញ្ចប់សំបុត្រខ្ញុំនៅពេលនេះសិនចុះ
ព្រោះត្រូវការពេលទៀត ត្បិតខ្មាំងសត្រូវកំពុងតែរង់ចាំ
ហើយក៏ដូចជាព្រះ អង្គសង្គ្រោះទ្រង់បានមានព្រះបន្ទូលដែរ
ថា ចៅហ្វាយរបស់លោកីយនេះជិតមកដល់ហើយ តែវា
គ្មានអ្វីនៅក្នុងខ្ញុំទេ ។
១២ មើលចុះ ការអធិស្ឋានរបស់ខ្ញុំដល់ព្រះ សូមឲ្យអ្នកទាំង
អស់គ្នាបានសង្គ្រោះ ។ ហើយខ្ញុំចុះឈ្មោះខ្លួនថា ជាអ្នកបំរើ
របស់អ្នក នៅក្នុងព្រះអម្ចាស់ គឺជាព្យាការី និងអ្នកមើលឆុត
នៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួបរិសុទ្ធថ្ងៃចុងក្រោយ ។

យ៉ូសែប ស្ម៊ីធ ។

៣ *ក* ៣ នីហ្វៃ ១១:១២–១៤.
ស.ប. សេចក្ដីទំនាស់.
៤ *ក* គ. និង ស. ១២៤:៥៥.
*ខ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*គ* ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
៥ *ក* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក —
បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់.
*ខ* ស.ប. សេចក្ដីសង្គ្រោះ
សំរាប់មនុស្សស្លាប់.
៦ *ក* ១ កូរិន. ១៥:២៩;
គ. និង ស. ១២៨:១៣, ១៨.
*ខ* គ. និង ស. ១២៨:២–៤, ៧.
៧ *ក* ស.ប. សៀវភៅជីវិត.
*ខ* ស.ប. ភ្ជាប់, ការភ្ជាប់.
៨ *ក* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ស.ប. បព្វជិតភាពមិលគីស្សាដែក.
៩ *ក* គ. និង ស. ១២៨:២៤.
១១ *ក* យ៉ូហាន ១៤:៣០;
ក.យ.ស., យ៉ូហាន ១៤:៣០.
ស.ប. អារក្ស.
១២ *ក* គ. និង ស. ១២៤:១២៥.
ស.ប. អ្នកមើលឆុត.

## កណ្ឌទី ១២៨

*សំបុត្រពី យ៉ូសែប ស្ម៊ីធ ជាព្យាការី ទៅកាន់សាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលមាននូវការដឹកនាំបន្តទៅទៀត អំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ចេញពីទីក្រុងណៅវូ រដ្ឋអិលលីណោយ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៨៤២ (*History of the Church, *៥:១៤៨–១៥៣)* ។

*១–៥, ពួកអ្នកកត់បញ្ជីទូទៅ និងប្រចាំភូមិ ត្រូវបញ្ជាក់នូវការពិតប្រាកដ អំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់; ៦–៩, បញ្ជីទាំងឡាយ របស់ពួកគេ ត្រូវបានចង ហើយកត់ត្រាទុកនៅផែនដី និងនៅស្ថានសួគ៌; ១០–១៤, អាងសំរាប់បុណ្យជ្រមុជទឹក គឺជានិមិត្តរូបអំពីផ្នូរ; ១៥–១៧, លោកអេលីយ៉ាបានសាងឡើងវិញ នូវអំណាចដែលទាក់ទងទៅនឹងបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់; ១៨–២១, គ្រប់ទាំង កូនសោអំណាច និងសិទ្ធិអំណាចនៃគ្រាកាន់កាប់ត្រួតត្រាមុនៗទាំងប៉ុន្មាន នោះត្រូវបានសាងឡើងវិញ; ២២–២៥, ដំណឹងដ៏រីក រាយ និងដ៏រុងរឿង ត្រូវបានប្រកាសប្រាប់ដល់មនុស្សនៅរស់ និងមនុស្សស្លាប់ ។*

ដូចជាខ្ញុំបានប្រាប់អ្នក ក្នុងសំបុត្រខ្ញុំ មុនខ្ញុំបានចាកចេញពីកន្លែងខ្ញុំហើយថា ខ្ញុំចង់សរសេរមកអ្នក តាមកាលវេលាម្ដងៗ ហើយឲ្យពត៌[ក]មានដល់អ្នក អំពីកម្មវត្ថុជាច្រើន ឥឡូវនេះ ខ្ញុំនិយាយពីកម្មវត្ថុអំពីបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ទៀត ព្រោះកម្មវត្ថុនោះហាក់ដូចជា ជាប់នៅក្នុងសតិខ្ញុំ ហើយជ្រួតជ្រាបមកក្នុងអារម្មណ៍ខ្ញុំយ៉ាងខ្លាំង ចាប់តាំងពីខ្ញុំបានត្រូវពួកខ្មាំងសត្រូវរបស់ខ្ញុំតាមរកម្ល៉េះ ។

២ ខ្ញុំបានសរសេរនូវពាក្យខ្លះនៃវិវរណៈដល់អ្នក អំពីអ្នកកាន់បញ្ជី ។ ខ្ញុំមានគំនិតថែមបន្តិចបន្តួចទៀត ដែលទាក់ទងអំពីការណ៍នេះ ដែលខ្ញុំបញ្ជាក់ប្រាប់នៅពេលឥឡូវនេះ ។ គឺថាបានប្រកាសប្រាប់នៅក្នុងសំបុត្រពីមុនហើយថា គួរមាន[ក]អ្នកកត់បញ្ជីម្នាក់ ដែលគួរធ្វើជា សាក្សី ហើយក៏ត្រូវឮដោយត្រចៀកគាត់ផ្ទាល់ ប្រយោជន៍ឲ្យគាត់អាចកត់បញ្ជីអំពីសេចក្ដីពិត នៅចំពោះព្រះអម្ចាស់ ។

៣ ឥឡូវទំនាក់ទំនងអំពីការណ៍នេះ គឺជាការពិបាកដល់អ្នកកត់បញ្ជីម្នាក់ណាស់ ដែលត្រូវមានវត្តមាននៅគ្រប់ពេលវេលា ហើយត្រូវ ធ្វើការគ្រប់យ៉ាង ។ ដើម្បីដោះស្រាយបញ្ហានេះ នោះអាចមានអ្នកកត់បញ្ជីម្នាក់ប្រចាំសង្កាត់នីមួយៗក្នុងទីក្រុង ដែលសមបំផុត សំរាប់កត់កំណត់ហេតុឲ្យបានត្រឹមត្រូវ; ហើយចូរឲ្យគាត់ធ្វើដោយម៉ឺងម៉ាត់ និងច្បាស់លាស់ ក្នុងការកត់ហេតុការណ៍ទាំងមូល ដោយបញ្ជាក់ក្នុង បញ្ជីគាត់ថា គាត់បានឃើញដោយភ្នែកគាត់ ហើយបានឮដោយត្រចៀកគាត់ ដោយប្រាប់ថ្ងៃ និងឈ្មោះជាដើម និងប្រវត្តិនៃកម្មវិធី ទាំងមូល; ដោយប្រាប់នូវឈ្មោះបុគ្គលចំនួនបីនាក់ដែលមានវត្តមាន បើសិនជាមាននរណាម្នាក់នៅទីនោះ ដែលអាចហៅនៅពេលណាមួយឲ្យបញ្ជាក់ពីការណ៍ដដែល គឺថាដោយមាត់នៃ[ក]សាក្សីពីរឬបីនាក់ នោះគ្រប់ពាក្យអាចបានបញ្ជាក់ ។

៤ បន្ទាប់មក ចូរឲ្យមានអ្នកកត់បញ្ជីទូទៅម្នាក់ ដែលអាចជូនបញ្ជីឯទៀតៗទៅឲ្យ ដោយមាននូវប័ណ្ណទាំងឡាយដែលចុះហត្ថលេខារបស់ពួកគេផ្ទាល់ ដោយបញ្ជាក់ថាបញ្ជីដែលពួកគេបានធ្វើនោះគឺពិត ។ ខណៈនោះ អ្នកកត់បញ្ជីប្រចាំសាសនាចក្រទូទៅអាចបញ្ចូល បញ្ជីទៅក្នុងបញ្ជីនៃសាសនាចក្រទូទៅ ជាមួយនឹងប័ណ្ណទាំងឡាយ និងអស់ទាំងពួកសាក្សីដែលនៅទីនោះ ជាមួយនឹងការថ្លែងរបស់ គាត់ផ្ទាល់ថា គាត់ជឿជាក់ថាការថ្លែងខាងលើនិងបញ្ជីទាំងឡាយនោះពិត តាមការចេះដឹងរបស់គាត់ អំពីចរិតនិងតំណែងទូទៅ នៃមនុស្សទាំងនោះនៅក្នុងសាសនាចក្រ ។ ហើយកាលណាការណ៍នោះត្រូវបានសំរេចនៅក្នុងសៀវភៅនៃសាសនាចក្រទូទៅ នោះបញ្ជីនឹងបានទៅជាបរិសុទ្ធ ហើយនឹងបញ្ជាក់អំពីពិធី ហាក់ដូចជាគាត់បានឃើញនឹងភ្នែកគាត់ ហើយបានឮនឹងត្រចៀកគាត់ដែរ ហើយបានធ្វើបញ្ជីអំពីការណ៍ដដែលនៅក្នុងសៀវភៅនៃសាសនាចក្រទូទៅ ។

៥ អ្នកអាចគិតថារបៀបនៃការណ៍ទាំងឡាយជាការល្អិតល្អន់ណាស់ ប៉ុន្តែចូរឲ្យខ្ញុំប្រាប់អ្នកថា នេះគឺគ្រាន់តែជាការធ្វើតាមព្រះហឫទ័យ នៃព្រះប៉ុណ្ណោះ ដោយធ្វើតាមពិធី និងការ

**១២៨** ១*ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់.
២ *ក* គ. និង ស. ១២៧:៦.
៣ *ក* ស.ប. សាក្សី.

រៀបចំ ដែលព្រះអម្ចាស់ទ្រង់បានតែងតាំង និងរៀបចំឡើង មុនកំណើតលោកិយមកម្ល៉េះ សំរាប់សេចក្ដីសង្គ្រោះដល់ពួក មនុស្សស្លាប់ ដែលត្រូវស្លាប់ ដោយគ្មានការចេះដឹង អំពីដំណឹងល្អ ។

៦ ហើយថែមទៀត ខ្ញុំចង់ឲ្យអ្នកចាំថា យ៉ូហាន ជាអ្នក ទទួលវិវរណៈ កំពុងតែពិចារណាអំពីកម្មវត្ថុនេះដែរ ដែល ទាក់ទងទៅនឹងមនុស្ស ស្លាប់ ក្នុងកាលលោកបានប្រកាស ដូចអ្នកអាចឃើញកត់ទុក នៅក្នុងគម្ពីរវិវរណៈ ២០:១២ ហើយ ថា — *នោះខ្ញុំឃើញមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច គេឈរនៅចំពោះព្រះ បញ្ជីក៏បានបើកឡើង ហើយបញ្ជី១ទៀត គឺជាបញ្ជីជីវិតបានបើកឡើងដែរ រួចមនុស្សស្លាប់ ទាំងអស់ត្រូវ ជំនុំជំរះ ពីសេចក្ដីដែលកត់ទុកក្នុងបញ្ជីទាំងនោះ តាមអំពើដែល គេបានប្រព្រឹត្តរៀងខ្លួន ។*

៧ អ្នកនឹងឃើញថា ក្នុងពាក្យស្រង់នេះ ដែលបញ្ជីក៏បាន បើកឡើង ហើយបញ្ជី១ទៀត គឺជាបញ្ជីជីវិតបានបើកឡើងដែរ រួចមនុស្សស្លាប់ ទាំងអស់ត្រូវជំនុំជំរះ ពីសេចក្ដីដែលកត់ទុកក្នុង បញ្ជីទាំងនោះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន; ម្ល៉ោះ ហើយ បញ្ជីទាំងឡាយដែល បានពោលដល់នោះច្បាស់ជាបញ្ជី ដែលមានបញ្ជីអំពីអំពើដែលគេប្រព្រឹត្តរៀងខ្លួន ហើយមាន ន័យដល់បញ្ជីទាំងឡាយ ដែលបានទុកនៅ លើផែនដី ។ ហើយបញ្ជីដែលជាបញ្ជីជីវិតនោះជាបញ្ជី ដែលបាន ទុកនៅស្ថានសួគ៌; គោលការណ៍នោះពិតជាព្រមព្រៀងគ្នា នឹង គោលលទ្ធិ ដែលបានបញ្ជាដល់អ្នក នៅក្នុងវិវរណៈ ដែលមាននៅក្នុងសំបុត្រ ដែលខ្ញុំបានសរសេរទៅអ្នក មុនខ្ញុំ ចាកចេញពីកន្លែងខ្ញុំ នោះ — ប្រយោជន៍ឲ្យគ្រប់ការកត់ ត្រារបស់អ្នកទាំងអស់ អាចបានកត់ទុកនៅស្ថានសួគ៌ដែរ ។

៨ ឥឡូវនេះ សារៈនៃពិធីនេះ គឺមាននៅក្នុងអំណាចនៃបព្វជិតភាព ដោយសារវិវរណៈនៃព្រះយេស៊ូវគ្រីស្ទ ដែលបានអនុញ្ញាតថាអ្វី ក៏ដោយដែលអ្នកចងនៅផែនដី នោះនឹងត្រូវបានចងនៅស្ថានសួគ៌ដែរ ហើយអ្វីក៏ដោយដែលអ្នកស្រាយនៅផែនដី នោះនឹងត្រូវ បាន ស្រាយនៅស្ថានសួគ៌ដែរ ។ ឬក៏ម្យ៉ាងទៀត ដោយគិតពីការ បកប្រែផ្សេងទៀតថា អ្វីក៏ដោយដែលអ្នកកត់ត្រានៅផែនដី នោះ នឹង ត្រូវបានកត់ទុកនៅស្ថានសួគ៌ដែរ ហើយអ្វីក៏ដោយដែល អ្នកមិនកត់ត្រានៅផែនដី នោះនឹងមិនត្រូវបានកត់ត្រា ទុកនៅស្ថានសួគ៌ដែរ; ត្បិត ចេញពីបញ្ជីទាំងឡាយ នោះមនុស្ស ស្លាប់នឹងត្រូវជំនុំជំរះ តាមអំពើដែលខ្លួនបានប្រព្រឹត្តរៀងខ្លួន ទោះ ជាពួកគេបានធ្វើពិធីទាំងឡាយ ដោយខ្លួនគេផ្ទាល់ ឬក៏ដោយ ភ្នាក់ងាររបស់គេផ្ទាល់ ស្របតាមពិធីដែលព្រះទ្រង់បានរៀបចំទុក សំរាប់សេចក្ដីសង្គ្រោះដល់ពួកគេ តាំងពីមុនកំណើតលោកិយ មកម្ល៉េះ ស្របតាមបញ្ជីទាំងឡាយ ដែលពួកគេបានកត់ទុក អំពី ពួកមនុស្សស្លាប់របស់ពួកគេ ។

៩ ការណ៍នេះអាចមើលទៅថាជាគោលលទ្ធិមួយដ៏ធំដុំណាស់ ដែលយើងយកមកនិយាយថា — អំណាចដែលកត់ ឬចងនៅផែនដី ហើយចងទុកនៅស្ថានសួគ៌ដែរ ។ ទោះជាយ៉ាង ណាក៏ដោយ គង់តែនៅគ្រប់សម័យលោក កាលណាព្រះអម្ចាស់ ទ្រង់បានប្រទាន នូវការកាន់កាប់ត្រួតត្រានៃបព្វជិតភាព ដល់ មនុស្សណាម្នាក់ ឬមនុស្សមួយក្រុម ដោយវិវរណៈប្រាកដ នោះ អំណាចនេះក៏ត្រូវបានប្រទាន ឲ្យជាដរាបដែរ ។ ម្ល៉ោះហើយ អ្វីក៏ដោយដែលពួកអ្នកមានសិទ្ធិអំណាចបានប្រព្រឹត្ត ដោយនូវ ព្រះនាមនៃព្រះអម្ចាស់ ហើយបានប្រព្រឹត្ត ដោយពិតស្មោះត្រង់ ហើយបានកត់បញ្ជីត្រឹមត្រូវ និងស្មោះត្រង់នូវអ្វីទាំងនោះ ការណ៍ នោះបានក្លាយទៅជាក្រិត្យវិន័យនៅផែនដី និងនៅស្ថានសួគ៌ដែរ ហើយមិនអាចបំបាត់បានឡើយ ស្របតាមបញ្ញត្តិទាំងឡាយរបស់ ព្រះយេហូវ៉ាដ៏ធំ ។ ពាក្យនេះគួរជឿជាក់ ។ តើអ្នកណាអាច យល់ឮ ?

១០ ហើយជាថ្មីទៀត ចំពោះអ្វីដែលកើតឡើងមកហើយ គឺក្នុងគម្ពីរម៉ាថាយ ១៦:១៨, ១៩ ដែលថា៖ *ខ្ញុំប្រាប់អ្នកថា អ្នក ឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វា រស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។ ហើយខ្ញុំនឹងឲ្យកូនសោនៃ នគរស្ថានសួគ៌ដល់អ្នក៖ ហើយបើអ្នក នឹងចងអ្វីៗនៅផែនដី នោះនឹងត្រូវចងទុកនៅស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែន ដី នោះនឹងត្រូវស្រាយ នៅស្ថានសួគ៌ដែរ ។*

១១ ឥឡូវនេះ ការអាថិកំបាំងដ៏ធំ និងមហិមាអំពីការណ៍

---

៥ *ក* ស.ប. សេចក្ដីសង្គ្រោះ សំរាប់មនុស្សស្លាប់.
*ខ* ១ ពេត្រុស ៤:៦.
៧ *ក* វិវរ. ២០:១២; គ. និង ស. ១២៧:៦–៧.
ស.ប. សៀវភៅជីវិត.
*ខ* គ. និង ស. ២១:១.
៨ *ក* ស.ប. អំណាច; បព្វជិតភាព.
*ខ* ស.ប. ភ្ជាប់, ការភ្ជាប់.
*គ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*ឃ* ស.ប. សេចក្ដីសង្គ្រោះ សំរាប់មនុស្សស្លាប់.
៩ *ក* ស.ប. គ្រាកាន់កាប់ត្រួតត្រា.
*ខ* ស.ប. សិទ្ធិអំណាច.
*គ* ស.ប. ព្រះយេហូវ៉ា.

ទាំងមូល និង*ការធំបំផុត* អំពីកម្មវត្ថុទាំងមូល ដែលនៅចំពោះយើង គឺមាននូវ ការបានអំណាចទាំងឡាយនៃបព្វជិតភាពដ៏បរិសុទ្ធ ។ ត្បិតអ្នកណាដែលត្រូវបានប្រទាន[ក]កូនសោទាំងនេះ នោះមិនមែនជាពិបាកនឹង បានការចេះដឹងនូវការពិត អំពី[ខ]សេចក្ដីសង្គ្រោះនៃកូនចៅមនុស្ស ទាំងសំរាប់មនុស្សស្លាប់ និងមនុស្សរស់ផង ។

១២ នៅក្នុងការណ៍នេះហើយជា[ក]សិរីល្អ និង[ខ]កិត្តិយស និង[គ]អមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច — ពិធីនៃបុណ្យជ្រមុជដោយទឹក គឺត្រូវ[ឃ]ពន្លិចទៅក្នុងទឹក ដើម្បីធ្វើជាតំណាងអំពីសេចក្ដីស្លាប់ ប្រយោជន៍ឲ្យគោលការណ៍មួយអាចបានសមស្របនឹងគ្នា; ត្រូវពន្លិចទៅ ក្នុងទឹក ហើយងើបចេញពីទឹកមកវិញ គឺជាតំណាងអំពីដំណើររស់ឡើងវិញនៃមនុស្សស្លាប់ ក្នុងការងើបចេញពីផ្នូរមកវិញ; ម្ល៉ោះហើយ ពិធីនេះត្រូវបានតាំងឡើង ដើម្បីរួមទំនាក់ទំនងជាមួយនឹងពិធីនៃបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ ដោយមានតំណាងអំពីសេចក្ដីស្លាប់ ។

១៣ ដោយហេតុនេះ ទើបមាន[ក]អាងនៃបុណ្យជ្រមុជទឹកតាំងឡើង ទុកជា[ខ]និមិត្តរូបអំពីផ្នូរ ហើយត្រូវបានបញ្ជាឲ្យដាក់នៅខាងក្រោម កន្លែងដែលមនុស្សរស់ធ្លាប់ជួបជុំគ្នា ដើម្បីបង្ហាញពីមនុស្សរស់ និងមនុស្សស្លាប់ ហើយប្រយោជន៍ឲ្យគ្រប់ការណ៍ទាំងអស់អាចមាន តំណាងរបស់វា ហើយប្រយោជន៍ឲ្យគ្រប់ការណ៍ទាំងអស់អាចបានសមស្របនឹងគ្នា — គឺអ្វីដែលជារបស់ផងផែនដី ទៅនឹងអ្វីដែលជា របស់ផងស្ថានសួគ៌ ដូចដែលប៉ុលបានប្រកាសប្រាប់ នៅក្នុងគម្ពីរកូរិនថូស ទី១ ១៥:៤៦, ៤៧, និង៤៨ ថា៖

១៤ *ឯវិញ្ញាណ មិនមែនកើតមុនទេ គឺរូបសាច់ទេតើ រួចទើបមានវិញ្ញាណជាខាងក្រោយ ។ មនុស្សមុនដំបូងកើតមកពីដី គឺធ្វើតាមពី ធូលីដី តែមនុស្សទី២ ជាព្រះអម្ចាស់ដែលចេញមកពីស្ថានសួគ៌វិញ ។ ឯមនុស្សដែលកើតពីធូលីដីមកជាយ៉ាងណា នោះអស់អ្នកដែល កើតពីធូលីដី ក៏យ៉ាងនោះដែរ; ហើយព្រះអម្ចាស់ ដែលយាងមកពីស្ថានសួគ៌ ជាយ៉ាងណា ពួកស្ថានសួគ៌ក៏យ៉ាងនោះដែរ* ។ ហើយដូចជាបានកត់នៅផែនដី អំពីពួកមនុស្សស្លាប់របស់អ្នក ដែលច្បាស់ជាបានកត់ទុក ជាយ៉ាងណា នោះក៏បានកត់ទុកនៅស្ថានសួគ៌ ជាយ៉ាងនោះដែរ ។ ហេតុដូច្នេះហើយ នេះគឺជាអំណាចនៃ[ក]ការភ្ជាប់ និងការចង ហើយបើនិយាយតាមពាក្យពិត គឺជា[ខ]កូនសោទាំង ឡាយ ដែលមាននូវ[គ]កូនសោខាងការចេះដឹង ។

១៥ ហើយឥឡូវនេះ បងប្អូនប្រុសស្រីជាទីស្ងួនភ្ងារបស់ខ្ញុំអើយ ចូរឲ្យខ្ញុំបញ្ជាក់ប្រាប់អ្នកថា នេះគឺជាគោលការណ៍ទាំងឡាយ ដែលទាក់ ទងទៅនឹងមនុស្សស្លាប់ និងមនុស្សរស់ ដែលមិនអាចបង្ហួសចោលដោយគ្មានគិតពិចារណានោះឡើយ គឺជាការទាក់ទងទៅនឹង សេចក្ដីសង្គ្រោះរបស់យើង ។ ត្បិត[ក]សេចក្ដីសង្គ្រោះរបស់ពួកគេ គឺជាការចាំបាច់ និងសំខាន់បំផុត ចំពោះសេចក្ដីសង្គ្រោះរបស់យើង ដូចជាប៉ុលមានប្រសាសន៍អំពីពួកអយ្យកោ — ថាពួកគេពុំអាចបានល្អឥតខ្ចោះក្រៅពីយើងឡើយ — រីឯយើងក៏ពុំអាចបាន[ខ]ល្អឥតខ្ចោះក្រៅពីមនុស្សស្លាប់របស់យើងដែរ ។

១៦ ហើយឥឡូវនេះ ចំពោះការទាក់ទងទៅនឹងបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ នោះខ្ញុំនឹងប្រាប់អ្នកនូវពាក្យស្រង់របស់ប៉ុលមួយទៀត គឺគម្ពីរកូរិនថូស ទី១ ១៥:២៩ ដែលថា៖ *ពុំនោះ ពួកអ្នកដែលទទួលបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ នឹងធ្វើដូចម្ដេច បើសិនជាពួក ស្លាប់មិនរស់ឡើងវិញទេ ? នោះតើហេតុអ្វីបានជាពួកគេទទួលបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ធ្វើអី ?*

១៧ ហើយជាថ្មីទៀត ចំពោះទំនាក់ទំនងនឹងពាក្យស្រង់នេះ ខ្ញុំនឹងផ្ដល់ដល់អ្នក នូវពាក្យស្រង់ពីព្យាការីមួយទៀត ដែលបានតម្រង់ នេត្រារបស់លោកទៅរក[ក]ការសាងឡើងវិញនៃបព្វជិតភាព, សិរីល្អទាំងឡាយដែលនឹងបានបើកសំដែងប្រាប់នៅថ្ងៃចុងក្រោយបំផុត, និងពីរបៀបដ៏ពិសេស អំពីកម្មវត្ថុដ៏រុងរឿងបំផុត ដែលជារបស់នៃដំណឹងល្អដ៏នៅអស់កល្បអស់កាលជានិច្ច ដោយមានឈ្មោះថា បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់; ត្បិតលោកម៉ាឡាគីមានប្រសាសន៍ នៅក្នុងជំពូកចុងក្រោយបង្អស់ ខទី៥ និងទី៦ ថា៖ *មើល មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាច*

១១ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* ស.ប. សេចក្ដីសង្គ្រោះ.
១២ *ក* ស.ប. សិរីល្អ.
*ខ* ស.ប. គោរពប្រតិបត្តិ.
*គ* ស.ប. អមតៈ, អមតភាព.
*ឃ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកដោយការពន្លិច.
១៣ *ក* គ. និង ស. ១២៤:២៩.
*ខ* ស.ប. ការនិមិត្តរូប.
១៤ *ក* ស.ប. ភ្ជាប់, ការភ្ជាប់.
*ខ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*គ* ក.យ.ស., លូកា ១១:៥៣.
១៥ *ក* ស.ប. សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់.
*ខ* ហេព្រើរ ១១:៤០. ស.ប. ល្អឥតខ្ចោះ.
១៧ *ក* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.

*របស់ព្រះអម្ចាស់បានមកដល់ នោះអញនឹងចាត់អេលីយ៉ា ឲ្យមក ឯឯងរាល់គ្នា ។ លោកនឹងបង្វែរ ចិត្តពួកឪពុក មកឯកូន និងចិត្ត កូនមកឯឪពុកវិញ ក្រែងអញមកវាយផែនដីដោយសេចក្ដីបណ្ដាសា* ។

១៨ ខ្ញុំអាចធ្វើការបកប្រែបទគម្ពីរនេះឲ្យបានច្បាស់លាស់ទៅទៀត ប៉ុន្តែតាមដើម បទនេះច្បាស់គ្រាន់បើចំពោះគោលបំណងរបស់ខ្ញុំ ហើយ ។ ក្នុងករណីនេះ គឺល្មមគ្រាន់តែឲ្យដឹងថា ផែនដីនឹងត្រូវ បានវាយដោយសេចក្ដីបណ្ដាសា លើកលែងតែមានចំណងភ្ជាប់ យ៉ាង ណាមួយ រវាងពួកឪពុកនឹងកូនៗ គឺចំពោះកម្មវត្ថុអ្វីណា មួយ — ហើយមើលចុះ តើកម្មវត្ថុនោះជាអ្វីទៅ ? គឺជាបុណ្យជ្រមុជទឹកជំនួស មនុស្សស្លាប់ ។ ត្បិតយើងរាល់គ្នា មិនអាចបានល្អឥតខ្ចោះ ក្រៅពីពួកគេឡើយ រីឯពួកគេក៏មិនអាច បានល្អឥតខ្ចោះ ក្រៅពីយើងដែរ ។ ទាំងពួកគេ និងពួកយើង មិន អាចបានល្អឥតខ្ចោះ ក្រៅពីអស់អ្នកដែលស្លាប់ នៅក្នុង ដំណឹងល្អឡើយ; ត្បិតជាការចាំបាច់ ក្នុងការ ចាប់ផ្ដើមនូវគ្រា កាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ជាគ្រាកាន់កាប់ត្រួតត្រា ដែលកំពុងតែចាប់ផ្ដើមនៅពេលឥឡូវនេះ ប្រយោជន៍ ឲ្យការរួបរួម និងការភ្ជាប់គ្នាទាំងមូល និងពេញលេញ និងល្អឥតខ្ចោះ នៃការកាន់កាប់ត្រួតត្រា និងកូនសោ និងអំណាច និងសិរីល្អទាំង ឡាយ បានកើតឡើង ហើយបានបើកសំដែងប្រាប់ តាំងពីសម័យលោកអ័ដាម រហូតមកដល់ពេលនេះ ។ ហើយមិន តែប៉ុណ្ណេះសោត ប៉ុន្តែពីការណ៍ទាំងនោះផង ដែលពុំដែលបាន បើកសំដែងប្រាប់ តាំងពីកំណើតលោកិយមកម្ល៉េះ ប៉ុន្តែបាន លាក់ទុកពីពួកអ្នកប្រាជ្ញ និងពួក អ្នកឈ្លាសវៃ នោះនឹងត្រូវបាន បើកសំដែងដល់ពួកកូនក្មេង និងកូនដែលបៅ នៅក្នុងសម័យនេះ គឺជាការកាន់កាប់ត្រួតត្រានៃពេលពេញ កំណត់ ។

១៩ ឥឡូវនេះ តើយើងឮអ្វីនៅក្នុងដំណឹងល្អ ដែលយើងបាន ទទួលនោះ ? គឺសម្លេងរីករាយ ! គឺសម្លេងនៃសេចក្ដីមេត្ដាករុណា ពីស្ថាន សួគ៌; ហើយជាសម្លេងនៃសេចក្ដីពិត ចេញពីផែនដី; ជា ដំណឹងដ៏រីករាយសំរាប់ពួកអ្នកស្លាប់; ជាសម្លេងនៃសេចក្ដីរីករាយ សំរាប់ពួកអ្នក រស់ និងពួកអ្នកស្លាប់; ជាដំណឹងដ៏រីករាយ អំពីសេចក្ដីអំណរដ៏ធំ ។ ល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះ ដែល ដើរលើភ្នំ ដែលនាំដំណឹង ដ៏រីករាយ ពីការណ៍ប្រសើរល្អ ហើយ ដែលប្រាប់ដល់ក្រុងស៊ីយ៉ូនថា៖ ព្រះនៃអ្នក ទ្រង់សោយរាជ្យ ! ដូចជាទឹកសន្សើមពីភ្នំកើមែល ដើម្បីឲ្យការចេះដឹងនៃព្រះ ចុះមកលើពួកគេ !

២០ ហើយជាថ្មីទៀត តើយើងឮអ្វី ? គឺដំណឹងដ៏រីករាយពីភ្នំ គូម៉ូរ៉ា ! ម៉ូរ៉ូណៃ ជាទេវតាពីស្ថានសួគ៌ ដែលប្រកាសប្រាប់ពីការ បំពេញនៃ ពួកព្យាការីថា — គម្ពីរនឹងត្រូវបានបើកសម្ដែងឲ្យ ឃើញ ។ គឺសម្លេងនៃព្រះអម្ចាស់ នៅក្នុងទីរហោស្ថាននៃក្រុង ហ្វាយែត្ត ឃុំសេនេកា ដែលប្រកាសប្រាប់ពីសាក្សីបីនាក់ ដើម្បី ធ្វើទីបន្ទាល់អំពីគម្ពីរ ! គឺសម្លេងនៃមីកែល នៅលើច្រាំងទន្លេសុសគ្វីហាណា ដែលដឹងថាជា អារក្ស ក្នុងកាលវាលេចមកជាទេវតា នៃពន្លឺ ! គឺសម្លេងនៃពេត្រុស យ៉ាកុប និងយ៉ូហាន នៅក្នុង ទីរហោស្ថាន រវាងភូមិហារម៉ូនី ឃុំសុសគ្វីហាណា នឹងភូមិខូលស្វិល ឃុំព្រូម នៅលើទន្លេសុសគ្វីហាណា ដែលប្រកាស ប្រាប់ថាខ្លួនជាអ្នក មានកូនសោទាំងឡាយ នៃនគរ ហើយ នៃគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ !

២១ ហើយជាថ្មីទៀត គឺសម្លេងនៃព្រះនៅក្នុងបន្ទប់នៃលោកវិតមើរ ជាឪពុកចាស់ នៅភូមិហ្វាយែត្ត ឃុំសេនេកា ហើយនៅពេល ផ្សេងៗ និងកន្លែងផ្សេងៗ តាមដំណើរ និងសេចក្ដីទុក្ខវេទនាទាំង អស់ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃ

១៧ *ខ* ៣ នីហ្វៃ ២៥:៥–៦; គ. និង ស. ២:១–៣; ១១០:១៣–១៦. ស.ប. អេលីយ៉ា.
១៨ *ក* យ.ស. — ប្រវត្តិ ១:៣៦–៣៩.
*ខ* ស.ប. ពង្សាវតារ; ពិធីបរិសុទ្ធទាំងឡាយ — ពិធីបរិសុទ្ធជំនួស.
*គ* គ. និង ស. ១២៤:២៨–៣០; ១២៧:៦–៧.
*ឃ* ស.ប. គ្រាកាន់កាប់ត្រួតត្រា.
*ង* គ. និង ស. ៣៥:១៨.
*ច* ម៉ាថាយ ១១:២៥; លូកា ១០:២១; អាលម៉ា ៣២:២៣.
១៩ *ក* ទំនុក. ៨៥:១០–១១.
*ខ* លូកា ២:១០.
*គ* អេសាយ ៥២:៧–១០; ម៉ូសាយ ១៥:១៣–១៨; ៣ នីហ្វៃ ២០:៤០.
*ឃ* ចោទិ. ៣២:២; គ. និង ស. ១២១:៤៥.
២០ *ក* យ.ស. — ប្រវត្តិ ១:៥១–៥២. ស.ប. គូម៉ូរ៉ា, ភ្នំ.
*ខ* ស.ប. ម៉ូរ៉ូណៃ, កូនប្រុសរបស់មរមន.
*គ* អេសាយ ២៩:៤, ១១–១៤; ២ នីហ្វៃ ២៧:៦–២៩. ស.ប. ព្រះគម្ពីរមរមន.
*ឃ* ស.ប. ហ្វាយែត, រដ្ឋនូវយ៉ោក (សហរដ្ឋ).
*ង* គ. និង ស. ១៧:១–៣.
*ច* គ. និង ស. ២៧:១១. ស.ប. អ័ដាម.
*ឆ* ២ កូរិន. ១១:១៤.
*ជ* គ. និង ស. ២៧:១២.
*ឈ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
២១ *ក* ក.ន. ពេត្រុស វិតមើរ ស៊ីញ៉ែរ.

ចុងក្រោយ នេះ ! ហើយគឺសម្លេងនៃមីកែល ជាមហាទេវតា; គឺសម្លេងនៃ[ខ]កាព្រីយ៉ែល និងនៃ[គ]រ៉ាហ្វាយ៉ែល និងនៃ[ឃ]ពួកទេវតាផ្សេងៗទៀត ពីមីកែល ឬ[ង]អ័ដាម ចុះមកដល់ពេលសព្វថ្ងៃនេះ ទាំងអស់គ្នាប្រកាសប្រាប់ពី[ច]ការកាន់កាប់ក្ដួតត្រារបស់ខ្លួន សិទ្ធិរបស់ខ្លួន កូនសោរបស់ខ្លួន កិត្តិយសរបស់ខ្លួន ឫទ្ធានុភាព និងសិរីល្អរបស់ខ្លួន និងអំណាចនៃបព្វជិតភាពរបស់ខ្លួន; ដែលប្រាប់មួយបន្ទាត់ម្ដងៗ [ឆ]មួយសិក្ខាបទម្ដងៗ ឯណេះបន្តិច ឯណោះបន្តិច; ដែលផ្ដល់ការលួងលោមដល់យើង ដោយប្រកាសប្រាប់ពីអ្វី ដែលនឹងកើតឡើង ដែលបញ្ជាក់នូវ[ជ]សេចក្ដី សង្ឃឹមរបស់យើង !

២២ បងប្អូនអើយ តើយើងនឹងមិនទៅមុខ ដោយសារចលនាដ៏ធំមហិមានេះឬ ? ចូរទៅមុខ ហើយកុំថយក្រោយឡើយ ។ បងប្អូន អើយ ចូរមានចិត្តក្លាហានចុះ; ហើយចូរទៅ ចូរទៅទៅរកជ័យជំនះ ! ចូរឲ្យចិត្តអ្នកបានអរសប្បាយ ហើយ[ក]រីករាយជាអតិបរមាចុះ ។ ចូរឲ្យផែនដីទំលាយសម្លេងច្រៀងចេញមក ។ ចូរឲ្យពួកអ្នកស្លាប់បន្លឺសម្លេងច្រៀង អំពីការសរសើរដំកើងដ៏អស់កល្បជានិច្ច ដល់ក្សត្រា [ខ]អេម៉ាញូអែល ដែលបានតែងតាំងឡើង មុនកំណើតលោកិយមកម្ល៉េះ ដែលនឹងធ្វើឲ្យយើងអាច[គ]ប្រោសលោះពួកគេ ឲ្យរួចពី [ឃ]គុករបស់ពួក គេ; ព្រោះពួកអ្នកជាប់គុកនឹងបានរួច ។

២៣ ចូរឲ្យ[ក]ភ្នំបន្លឺឡើង ដោយអំណរ ហើយឲ្យច្រកភ្នំទាំងអស់បន្លឺឡើងជាខ្លាំង; ហើយឲ្យសមុទ្រ និងដីគោកទាំងអស់ ប្រាប់ពីការអស្ចារ្យ នៃស្ដេចដ៏នៅអស់កល្បជានិច្ចរបស់អ្នក ! ហើយឲ្យទន្លេ និងស្ទឹង និងអូទាំងឡាយ ហូរដោយរីករាយ ។ ចូរឲ្យព្រៃប្រឹក្សា និងអស់ទាំង ឈើនៅពេញវាល សរសើរដំកើងដល់ព្រះអម្ចាស់; ហើយឲ្យ[ខ]ថ្មដាយំ ដោយអំណរចុះ ! ហើយចូរឲ្យព្រះអាទិត្យ ព្រះច័ន្ទ និង[គ]ផ្កាយព្រឹក ច្រៀងជាមួយគ្នា ហើយចូរឲ្យអស់ទាំងកូនព្រះស្រែកអរសាទរចុះ ! ហើយចូរឲ្យរបស់របរដ៏អស់កល្បជានិច្ចដែលបានបង្កើតឡើង ប្រកាសប្រាប់ពីព្រះនាមរបស់ទ្រង់ ជារៀងដរាបតទៅ ! ហើយជាថ្មីទៀត រុងរឿងណាស់ហ្ន៎ គឺជាសម្លេងដែលយើងបានឮពីស្ថានសួគ៌ ដែលប្រកាសប្រាប់ដល់ត្រចៀកយើង អំពីសិរីល្អ និងសេចក្ដីសង្គ្រោះ និងកិត្តិយស និង[ឃ]អមតភាព និង[ង]ជីវិតដ៏នៅអស់កល្បជានិច្ច; អំពីនគរ ក្សត្របុរី និងអំណាចទាំងឡាយ !

២៤ មើលចុះ [ក]ថ្ងៃដ៏ធំនៃព្រះអម្ចាស់នៅជិតដែបង្កើយ; ហើយ[ខ]អ្នកឯណានឹងធន់នៅបាន ក្នុងកាលដែលទ្រង់យាងមកនោះ ហើយតើអ្នក ណានឹងឈរនៅ ក្នុងកាលដែលទ្រង់លេចមក ? ត្បិតទ្រង់ប្រៀបដូចជា[គ]ភ្លើងរបស់ជាងសំរង ហើយដូចជាក្បុងរបស់ជាងប្រមោក; ហើយទ្រង់នឹងគង់ចុះ ដូចជាជាង[ឃ]សំរងហើយនឹងដេញអាចម៍ប្រាក់ ហើយទ្រង់សំអាតពួក[ង]កូនចៅលេវី ហើយសំរង[ច]ពួកគេដូចមាស ហើយនិងប្រាក់ ដើម្បីឲ្យពួកគេអាចថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយសេចក្ដីសុចរិត ។ ហេតុដូច្នេះហើយ ចូរយើង ជាសាសនាចក្រ ហើយប្រជារាស្ត្រ ហើយជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយសេចក្ដីសុចរិតចុះ; ហើយចូរយើងថ្វាយ នៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់ នៅពេលណាដែលធ្វើរួចស្រេចបាច់នូវបញ្ជីមួយដែលមាន[ឆ]បញ្ជីនៃពួកអ្នកស្លាប់របស់យើង ដែលគួរសម ទទួលការគ្រប់យ៉ាង ។

២៥ បងប្អូនអើយ ខ្ញុំមានការណ៍ជាច្រើន ដែលចង់ប្រាប់អ្នក អំពីកម្មវត្ថុនេះ; ប៉ុន្តែឥឡូវត្រូវបិទសិនហើយ ហើយនឹងបន្តនូវកម្មវត្ថុនេះ នៅពេលផ្សេងទៀត ។ ខ្ញុំជាអ្នកបំរើដ៏ស្លូតបូតរបស់អ្នក ហើយជាមិត្តអ្នកដ៏មិនដែលផ្លាស់ប្ដូរឡើយ,

យ៉ូសែប ស្ម៊ីធ ។

២១ ខ ស.ប. កាព្រីយ៉ែល.
គ ស.ប. រ៉ាហ្វាយ៉ែល.
ឃ ស.ប. ពួកទេវតា.
ង គ. និង ស. ១០៧:៥៣–៥៦.
ច ស.ប. គ្រាកាន់កាប់ក្ដួតត្រា.
ឆ អេសាយ ២៨:១០.
ជ ស.ប. សេចក្ដីសង្ឃឹម.
២២ ក អេសាយ ៤៩:១៣.
ខ អេសាយ ៧:១៤; អាលម៉ា ៥:៥០.
ស.ប. អេម៉ាញូអែល.
គ ស.ប. ប្រោសលោះ,
បានប្រោសលោះ,
សេចក្ដីប្រោសលោះ.
ឃ អេសាយ ២៤:២២;
គ. និង ស. ៧៦:៧២–៧៤.
២៣ ក អេសាយ ៤៤:២៣.
ខ លូកា ១៩:៤០.
គ យ៉ូប ៣៨:៧.
ឃ ស.ប. អមតៈ, អមតភាព.
ង ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
២៤ ក ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.
ខ ម៉ាឡាគី ៣:១–៣.
គ ៣ នីហ្វៃ ២៤:២–៣.
ស.ប. ផែនដី —
ការសំអាតផែនដី.
ឃ សាការី ១៣:៩.
ង ចោទិ. ១០:៨;
គ. និង ស. ១៣:១; ១២៤:៣៩.
ច គ. និង ស. ៨៤:៣១.
ស.ប. ដង្វាយ.
ឆ គ. និង ស. ១២៧:៩.
ស.ប. ពង្សាវតារ.

## កណ្ឌទី ១២៩

*ការបង្គាប់ទាំងឡាយដែលត្រូវបានឲ្យមកដោយ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅទីក្រុងណេវ៉ូ រដ្ឋអិលលីណោយ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៨៤៣ ដោយបានប្រាប់ឲ្យដឹង អំពីកូនសោដ៏ធំបី ដែលអាចស្គាល់នូវលក្ខណៈ ត្រឹមត្រូវនៃពួកទេវតាដែលបំរើ និងវិញ្ញាណ ទាំងឡាយ (*History of the Church*, ៥:២៦៧)* ។

*១–៣, នៅស្ថានសួគ៌ មានទាំងរូបកាយដែលបានរស់ឡើងវិញ និងរូបកាយដែលជាវិញ្ញាណ; ៤–៩, កូនសោទាំងឡាយត្រូវបានប្រទាន ឲ្យមក ដើម្បីឲ្យអាចបានស្គាល់ពួកសារទូតនៅម្ខាងវាំងនន ។*

១ នៅស្ថានសួគ៌ មានតួពីរយ៉ាង គឺៈ ពួកទេវតា ដែលជាអង្គដែលបានរស់ឡើងវិញ ដោយមានរូបកាយជាសាច់ និងឆ្អឹង —

២ ឧបមាដូចជាកាលព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថាៈ *ចូរពាល់ខ្ញុំមើល ត្បិតខ្មោចគ្មានសាច់ឬឆ្អឹង ដូចជាឃើញខ្ញុំនេះទេ* ។

៣ ទីពីរគឺ វិញ្ញាណនៃពួកអ្នកសុចរិតដែលត្រូវបានធ្វើឲ្យល្អឥតខ្ចោះ ពួកគេនេះហើយដែលពុំបានរស់ឡើងវិញទេ ប៉ុន្តែគ្រងសិរីល្អដូចគ្នា ទុកជាមរតក ។

៤ កាលណាមានសារទូតមកប្រាប់ថា គាត់មានសារមកពីព្រះ នោះចូរហុចដៃអ្នក ហើយសូមឲ្យគេចាប់ដៃនឹងអ្នក ។

៥ បើគេជាទេវតាមែន គេនឹងធ្វើតាម ហើយអ្នកនឹងចាប់ដៃគេ ។

៦ បើគេជាវិញ្ញាណនៃមនុស្សសុចរិត ដែលបានធ្វើឲ្យល្អឥតខ្ចោះ នោះគេនឹងមកក្នុងសិរីល្អរបស់គេ; ត្បិតតាមតែផ្លូវនេះម៉្យាងគត់ ដែលគេអាចលេចមកបាន —

៧ ចូរសូមឲ្យគេចាប់ដៃនឹងអ្នក ប៉ុន្តែគេនឹងមិនកំរើកឡើយ ពីព្រោះជាការផ្ទុយទៅនឹងរបៀបនៃស្ថានសួគ៌ ដែលមនុស្សសុចរិតចេះបញ្ឆោត; ប៉ុន្តែគេនៅតែប្រគល់សាររបស់គេដដែល ។

៨ បើវាជាអារក្ស ក្លែងជាទេវតានៃពន្លឺវិញ កាលណាអ្នកសូមចាប់ដៃ នោះវានឹងហុចដៃវា ហើយអ្នកនឹងមិនបានប៉ះដៃវាសោះ; ហេតុដូច្នេះហើយ ទើបអ្នកអាចស្គាល់វា ។

៩ នេះហើយជាកូនសោបីយ៉ាង ដែលអ្នកអាចស្គាល់ពីការចាត់ចែងណាមួយមកពីព្រះ ។

## កណ្ឌទី ១៣០

*ការបង្គាប់អំពីកម្មវត្ថុផ្សេងៗដែលបានបង្គាប់ដោយ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិរេមុស រដ្ឋអិលលីណោយ ថ្ងៃទី២ ខែមេសា ឆ្នាំ១៨៤៣ (*History of the Church*, ៥:៣២៣–៣២៥)* ។

*១–៣ ព្រះវរបិតា និងព្រះរាជបុត្រា អាចលេចមកឲ្យមនុស្សឃើញផ្ទាល់; ៤–៧, ពួកទេវតារស់នៅក្នុងគោលខាងសេឡេស្ទាល; ៨–៩, ផែនដីខាងសេឡេស្ទាលនឹងទៅជាយូរីម និងធូមីមដ៏ធំ; ១០–១១, គ្រួសសម្ពួយត្រូវបានប្រទានដល់អស់អ្នកណាដែលចូលក្នុងពិភពសេឡេស្ទាល; ១២–១៧, គ្រានៃការយាងមកលើកទីពីរ នោះត្រូវបានលាក់ពីព្យាការី; ១៨–១៩, បញ្ញាដែលបាននៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើង ក្នុងដំណើររស់ឡើងវិញ; ២០–២១, ព្រះពរទាំងអស់សុទ្ធតែបានមក ដោយសារការគោរពតាមក្រឹត្យវិន័យ; ២២–២៣, ព្រះវរបិតា និងព្រះរាជបុត្រា មានព្រះកាយជាសាច់ និងឆ្អឹង ។*

១ កាលព្រះអង្គសង្គ្រោះ ទ្រង់លេចមក នោះយើងនឹងឃើញទ្រង់ដូចជាទ្រង់យ៉ាងនេះឯង ។ យើងនឹងឃើញថាព្រះអង្គ ជាមនុស្សដូច រូបយើងរាល់គ្នា ។

២ ហើយទំនាក់ទំនងដែលមាននៅក្នុងចំណោមពួក

១២៩ ១ *ក* ស.ប. ស្ថានសួគ៌.
*ខ* ស.ប. ពួកទេវតា.
*គ* ស.ប. ដំណើររស់ឡើងវិញ.
២ *ក* លូកា ២៤:៣៩.
៣ *ក* ស.ប. វិញ្ញាណ.
*ខ* ហេព្រើរ ១២:២៣;
គ. និង ស. ៧៦:៦៩.
៨ *ក* ២ កូរិន. ១១:១៤; ២ នីហ្វៃ ៩:៩.
១៣០ ១ *ក* ១ យ៉ូហាន ៣:២;
មរ៉ូណៃ ៧:៤៨.
ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* លូកា ២៤:៣៦–៤០.

យើងនៅទីនេះយ៉ាងណា នោះក៏នឹងមាននៅក្នុងចំណោមយើងនៅទីនោះយ៉ាង នោះដែរ គ្រាន់តែរួបរួមដោយសិរីល្អដ៏នៅអស់កល្បជានិច្ច គឺជាសិរីល្អដែលយើងពុំមានការពិសោធន៍នៅពេលឥឡូវនេះប៉ុណ្ណោះ ។

៣ គម្ពីរយ៉ូហាន ១៤:២៣ — ការលេចមកនៃព្រះវរបិតា និងព្រះរាជបុត្រា នៅក្នុងខនោះ គឺជាការលេចមកផ្ទាល់; រីឯជំនឿ ដែលថាព្រះវរបិតាគង់នៅក្នុងចិត្តមនុស្ស នោះគឺជាជំនឿខាងក្រុមសាសនាផ្សេងៗ ហើយគឺជាការខុស ។

៤ ជាចម្លើយដល់សំនួរថា — តើការរាប់ពេលវេលានៃព្រះ ពេលវេលារបស់ទេវតា ពេលវេលារបស់ព្យាការី និងពេលវេលារបស់មនុស្ស នោះតើពុំមែនរាប់តាមពិភពដែលពួកគេរស់នៅទេឬអី ?

៥ ខ្ញុំឆ្លើយថា បាទ ។ ប៉ុន្តែគ្មានទេវតាណាដែលបំរើនៅលើផែនដីនេះឡើយ លើកលែងតែពួកអ្នកដែលនៅឬធ្លាប់នៅទីនេះ ។

៦ ពួកទេវតាពុំរស់នៅក្នុងពិភព ដូចជាផែនដីនេះឡើយ;

៧ ប៉ុន្តែពួកគេរស់នៅក្នុងវត្តមាននៃព្រះ គឺនៅក្នុងគោលដូចជាសមុទ្រកែវ និងភ្លើង ជាទីដែលគ្រប់ទាំងអស់ ត្រូវបានសំដែងពីសិរីល្អរបស់ខ្លួន នៅអតីតកាល នៅបច្ចុប្បន្នកាល និងនៅអនាគតកាល ហើយមានតទៅរហូត នៅចំពោះព្រះអម្ចាស់ ។

៨ កន្លែងដែលព្រះទ្រង់គង់នៅ គឺជាយូរីម និងធូមីមដ៏ធំ ។

៩ ផែនដីនេះ នៅក្នុងសណ្ឋានញែកចេញជាបរិសុទ្ធ និងអមតភាព នោះនឹងក្លាយទៅដូចជាកែវចរណៃ ហើយនឹងទៅជាយូរីម និងធូមីម ចំពោះអស់អ្នកណាដែលអាស្រ័យនៅទីនោះ រីឯគ្រប់ទាំងអស់ ដែលទាក់ទងទៅនឹងនគរទាប ឬគ្រប់អស់ទាំងនគរនៃរបបទាប នោះនឹងសំដែងដល់អស់អ្នកណាដែលអាស្រ័យនៅទីនោះ ហើយផែនដីនេះនឹងទៅជារបស់ផងព្រះគ្រីស្ទ ។

១០ ខណៈនោះ គ្រួសសដែលបានពោលដល់នៅក្នុងគម្ពីរវិវរណៈ ២:១៧ នោះនឹងក្លាយទៅជាយូរីម និងធូមីម ចំពោះអស់អ្នកណា ដែលបានទទួលគ្រួសនោះ គឺដោយសារគ្រួសនោះនោះអ្វីៗទាំងឡាយដែលទាក់ទងទៅនឹងរបៀបជាន់ខ្ពស់នៃនគរ នឹងបានបង្ហាញ ឲ្យដឹង ។

១១ ខណៈនោះ គ្រួសសមួយត្រូវបានប្រទានដល់អស់អ្នកណាដែលចូលមកក្នុងនគរសេឡេស្ទាល ដែលនឹងមានឈ្មោះថ្មីខាងលើ ដែលគ្មានអ្នកណាស្គាល់ឡើយ លើកលែងតែអ្នកដែលបានទទួលប៉ុណ្ណោះ ។ ឈ្មោះថ្មីនោះគឺជាពាក្យសំគាល់ ។

១២ ខ្ញុំព្យាករ ដោយនូវព្រះនាមនៃព្រះអម្ចាស់ដ៏ជាព្រះ ថាការចាប់ផ្ដើមនៃការពិបាកទាំងឡាយ ដែលនឹងបណ្ដាលឲ្យមានការកំចាយ ឈាមដ៏ច្រើន មុនពេលកូនមនុស្សនឹងយាងមកជាលើកទីពីរ នោះនឹងកើតឡើងនៅរដ្ឋសៅខារ៉ូឡាញណា ។

១៣ ការនេះអាចកើតឡើង ដោយសារបញ្ហាខាងទាសភាព ។ នេះគឺជាសម្លេងដែលបានប្រកាសប្រាប់មកខ្ញុំ ក្នុងកាលខ្ញុំកំពុងតែអធិស្ឋានដោយមានចិត្តព្យាយាម អំពីកម្មវត្ថុនោះ នៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៨៣២ ។

១៤ គ្រានោះ ខ្ញុំកំពុងតែអធិស្ឋានដោយមានចិត្តព្យាយាមចង់ដឹងនូវពេលវេលានៃការយាងមករបស់កូនមនុស្ស កាលខ្ញុំបានឮសម្លេង ប្រាប់ពាក្យដូចតទៅនេះថា៖

១៥ យ៉ូសែប ជាបុត្រយើងអើយ បើសិនជាអ្នករស់នៅដល់អាយុប៉ែតសិបប្រាំឆ្នាំ នោះអ្នកនឹងបានឃើញព្រះភ័ក្ត្រានៃកូនមនុស្ស; ហេតុដូច្នេះហើយ ការណ៍នេះគ្រប់គ្រាន់ហើយ ហើយចូរកុំរំខានយើងពីការណ៍នេះទៀតឡើយ ។

១៦ ខ្ញុំក៏ទុកឲ្យនៅបែបនេះ ដោយពុំអាចសំរេចចិត្តថា ទោះជាការយាងមកនេះនិយាយពីការចាប់ផ្ដើមសហស្សវត្សរ៍ ឬពីការលេច មកមុននោះ ឬក៏ខ្ញុំត្រូវស្លាប់ ហើយទើបឃើញព្រះភ័ក្ត្ររបស់ទ្រង់នោះឡើយ ។

១៧ ខ្ញុំជឿថាការយាងមកនៃកូនមនុស្ស នឹងមិនមកមុនពេលនោះឡើយ ។

---

២ *ក* ស.ប. សិរីល្អនៃសេឡេស្ទាល.
៣ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*ខ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះរាជបុត្រា.
*គ* គ. និង ស. ៩៣:១.
*ឃ* គ. និង ស. ១៣០:២២. ស.ប. ព្រះ, ក្រុមព្រះ.
៤ *ក* ២ ពេត្រុស ៣:៨; អ័ប្រា. ៣:៤–១០; សូមមើលផងដែរ វត្ថុចម្លងតាមលេខ ២, រូបទី ១, នៅក្នុងគម្ពីរអ័ប្រាហាំ.
៥ *ក* ស.ប. ពួកទេវតា.
៧ *ក* វិវរ. ៤:៦; ១៥:២.
*ខ* អេសាយ ៣៣:១៤; គ. និង ស. ១៣២:១–៣.
៨ *ក* ស.ប. យូរីម និងធូមីម.
៩ *ក* គ. និង ស. ៧៧:១. ស.ប. ផែនដី — ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
១១ *ក* វិវរ. ២:១៧.
*ខ* អេសាយ ៦២:២.
១២ *ក* គ. និង ស. ៣៨:២៩; ៤៥:៦៣.
*ខ* គ. និង ស. ៨៧:១–៥.
១៤ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.

១៨ គោលការណ៍នៃប្រាជ្ញាណាក៏ដោយ ដែលយើងបាននៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើង ក្នុងដំណើររស់ឡើងវិញ ។

១៩ ហើយបើសិនជាអ្នកណាមួយ បានចំណេះវិជ្ជា និងបញ្ញាច្រើនជាងអ្នកផ្សេង នៅក្នុងជីវិតនេះ ដោយសារការព្យាយាម និងការ គោរពរបស់ខ្លួន អ្នកនោះនឹងបានប្រៀបច្រើន នៅពិភពខាងមុខ ។

២០ មានក្រឹត្យវិន័យមួយដ៏ពុំអាចដកចេញបាន ដែលបានធ្វើនៅស្ថានសួគ៌ មុនកំណើតលោកិយមកម្ល៉េះ ដែលគ្រប់ព្រះពរទាំងអស់ ផ្អែកទៅលើ —

២១ ហើយកាលណាយើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រឹត្យវិន័យនោះ ដែលព្រះពរនោះផ្អែកទៅលើ ។

២២ ព្រះវរបិតា ទ្រង់មានព្រះកាយជាសាច់ និងឆ្អឹង ដែលជាក់ស្ដែងដូចជារូបកាយមនុស្ស; ព្រះរាជបុត្រាក៏ដូច្នោះដែរ; ប៉ុន្តែព្រះ វិញ្ញាណបរិសុទ្ធ ពុំមានព្រះកាយជាសាច់ និងឆ្អឹងឡើយ តែមានរូបជាព្រះវិញ្ញាណវិញ ។ បើពុំនោះសោតទេ ព្រះវិញ្ញាណបរិសុទ្ធពុំអាចសណ្ឋិត នៅក្នុងយើងបានឡើយ ។

២៣ មនុស្សអាចទទួលព្រះវិញ្ញាណបរិសុទ្ធបាន ហើយព្រះវិញ្ញាណបរិសុទ្ធអាចយាងចុះមកសណ្ឋិតលើគេបាន ហើយមិនសណ្ឋិតនៅជា មួយគេក៏បានដែរ ។

កណ្ឌទី ១៣១

*ការបង្គាប់ទាំងឡាយដោយ យ៉ូសែប ស្ម៊ីធ ជាព្យាការី ដែលបានប្រាប់នៅភូមិរ៉េមុស រដ្ឋអិលលីណោយ ថ្ងៃទី១៦ និង១៧ ខែឧសភា ឆ្នាំ១៨៤៣ (*History of the Church, *៥:៣៩២–៣៩៣)* ។

*១–៤, អាពាហ៍ពិពាហ៍ខាងសេឡេស្ទាល គឺជាការសំខាន់បំផុត ចំពោះភាពលើកដំកើងឡើង នៅស្ថានសួគ៌ដ៏ខ្ពស់បំផុត; ៥–៦, របៀប ដែលមនុស្សអាចបានភ្ជាប់ទុក ចំពោះជីវិតដ៏នៅអស់កល្បជានិច្ច នោះត្រូវបានអធិប្បាយប្រាប់; ៧–៨, គ្រប់អស់ទាំងវិញ្ញាណសុទ្ធតែជា ធាតុ ។*

នៅក្នុងសិរីល្អខាងសេឡេស្ទាលនោះមានស្ថានសួគ៌ បួលំដាប់បី;

២ ហើយដើម្បីឲ្យបានលំដាប់ខ្ពស់បំផុត នោះមនុស្សត្រូវចូលក្នុងរបៀបនៃបព្វជិតភាពនេះ [មានន័យដល់សេចក្ដីសញ្ញាថ្មី ហើយអស់កល្ប អស់កាលជានិច្ច ខាងអាពាហ៍ពិពាហ៍];

៣ ហើយបើសិនជាគេពុំចូលទេ នោះគេពុំអាចបានលំដាប់នោះឡើយ ។

៤ គេអាចចូលលំដាប់ផ្សេងទៀតបាន ប៉ុន្តែនោះហើយជាទីបញ្ចប់នៃនគររបស់គេ; គេពុំអាចបានកំណើនឡើយ ។

៥ (១៧ ឧសភា ១៨៤៣) ។ ពាក្យព្យាករណ៍ដ៏ពិតជាងមានន័យពីមនុស្សដែលដឹងថាខ្លួនបានភ្ជាប់ទុក ចំពោះជីវិតដ៏នៅអស់កល្បជានិច្ច ដោយវិវរណៈ និងវិញ្ញាណនៃការព្យាករណ៍ តាមរយៈអំណាចនៃបព្វជិតភាពបរិសុទ្ធ ។

៦ គឺគ្មានផ្លូវទេ សំរាប់ឲ្យមនុស្សបានសង្គ្រោះ ក្នុងការល្ងង់ខ្លៅ ។

៧ គ្មានអ្វីដែលជាអរូបធាតុនោះឡើយ ។ គ្រប់អស់

១៨ *ក* ស.ប. បញ្ញា, បញ្ញាទាំងឡាយ.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
១៩ *ក* ស.ប. ដំរិះ.
*ខ* ស.ប. ព្រះដ៏ប្រោសឲ្យរួច.
*គ* ស.ប. ការគោរព, ដែលគោរព, គោរព.
*ឃ* អាលម៉ា ១២:៩–១១.
២០ *ក* គ. និង ស. ៨២:១០.
*ខ* ស.ប. ជីវិតមុនផែនដី.
*គ* ចោទិ. ១១:២៦–២៨; គ. និង ស. ១៣២:៥.
ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
២២ *ក* ស.ប. ព្រះ, ក្រុមព្រះ.
*ខ* កិច្ចការ ១៧:២៩.
*គ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២៣ *ក* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
**១៣១** ១*ក* គ. និង ស. ៧៦:៧០.
ស.ប. សិរីល្អនៃសេឡេស្ទាល.
២ *ក* គ. និង ស. ១៣២:៥–២១.
ស.ប. ភាពដំកើងឡើង.
*ខ* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍ — សេចក្ដីសញ្ញាថ្មី និងអស់កល្បជានិច្ចនៃអាពាហ៍ពិពាហ៍.
៤ *ក* គ. និង ស. ១៣២:១៦–១៧.
៥ *ក* ២ ពេត្រុស ១:១៩.
ស.ប. ការហៅ និងការរើសតាំង.
*ខ* គ. និង ស. ៦៨:១២; ៨៨:៤.
ស.ប. ភ្ជាប់, ការភ្ជាប់.
៥ *គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៦ *ក* ស.ប. សេចក្ដីសង្គ្រោះ.
*ខ* គ. និង ស. ១០៧:៩៩–១០០.

ទាំង[ក]វិញ្ញាណសុទ្ធតែជាធាតុ ប៉ុន្តែវា[ខ]ហ្មត់ ឬសុទ្ធសាធជាង ហើយអាចសំគាល់ ឃើញដោយភ្នែកបរិសុទ្ធប៉ុណ្ណោះ;

៨ យើងពុំអាចមើលឃើញទេ; ប៉ុន្តែកាលណារូបកាយយើងត្រូវបានធ្វើឲ្យបរិសុទ្ធ នោះយើងអាចមើលឃើញថា វាសុទ្ធតែជាធាតុទាំង អស់ ។

## កណ្ឌទី ១៣២

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្រុងណៅវូ រដ្ឋអិលលីណោយ ត្រូវបានកត់ទុកនៅថ្ងៃទី១២ ខែកក្កដា ១៨៤៣ គឺទាក់ទងទៅនឹងសេចក្ដីសញ្ញាថ្មី និងអស់កល្បអស់កាលជានិច្ច ដែលមាននូវភាពអស់កល្បជានិច្ច នៃសេចក្ដីសញ្ញាខាងអាពាហ៍ពិពាហ៍ ព្រមទាំងការមានប្រពន្ធច្រើន (*History of the Church*, ៥:៥០១–៥០៧) ។ ទោះជាវិវរណៈនេះត្រូវបាន កត់ទុកនៅឆ្នាំ១៨៤៣ក៏ដោយ គង់តែមានភស្តុតាងពីបញ្ជីប្រវត្តិទាំងឡាយ ថាគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលមាន នៅក្នុងវិវរណៈនេះ គឺបានដឹងដោយព្យាការីតាំងពីឆ្នាំ១៨៣១ម្ល៉េះ ។*

*១–៦, ភាពលើកដំកើងឡើងត្រូវបានមក តាមរយៈសេចក្ដីសញ្ញាថ្មី និងអស់កល្បអស់កាលជានិច្ច; ៧–១៤, ខនិងល័ក្ខខ័ណ្ឌទាំងឡាយ នៃសេចក្ដីសញ្ញានោះត្រូវបានថែងប្រាប់; ១៥–២០, អាពាហ៍ពិពាហ៍ខាងសេឡេស្ទាល និងការមានក្រុមគ្រួសារតទៅបណ្ដាលឲ្យមនុស្ស ក្លាយទៅជាព្រះបាន; ២១–២៥, ផ្លូវតូចហើយចង្អៀតនាំទៅរកជីវិតទាំងឡាយដ៏នៅអស់កល្បជានិច្ច; ២៦–២៧, ក្រិត្យវិន័យត្រូវបាន ប្រទានមក ដែលទាក់ទងទៅនឹងការពោលពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ; ២៨–៣៩, សេចក្ដីសន្យាទាំងឡាយ អំពីភាពចំរើន ឡើងដ៏នៅ អស់កល្បជានិច្ច និងភាពដំកើងឡើង នោះត្រូវបានសន្យាដល់ពួកព្យាការី និងពួកបរិសុទ្ធ នៅគ្រប់សម័យ; ៤០–៤៧, យ៉ូសែប ស្ម៊ីធ ត្រូវបានទទួលអំណាច ឲ្យចង និងភ្ជាប់នៅផែនដី និងនៅស្ថានសួគ៌ដែរ; ៤៨–៥០, ព្រះអម្ចាស់ទ្រង់ភ្ជាប់មកលើលោក នូវភាពដំកើងឡើងរបស់លោក; ៥១–៥៧, អិមម៉ា ស្ម៊ីធ ត្រូវបានទូន្មានឲ្យមានចិត្តស្មោះ ហើយពិតត្រង់; ៥៨–៦៦, ក្រិត្យវិន័យទាំងឡាយដែលចាត់ចែងខាងការមានប្រពន្ធច្រើន នោះត្រូវបានថែងប្រាប់ ។*

ប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះដល់អ្នក គឺយ៉ូសែប ជាអ្នកបំរើរបស់យើង ថាដរាបណាអ្នកបានទូលសូមពីព្រះហស្ដយើង ចង់ដឹង ហើយយល់អំពីរបៀប ដែលយើងជាព្រះអម្ចាស់ បានរាប់ថាសុចរិតចំពោះអ័ប្រាហាំ, អ៊ីសាក, និងយ៉ាកុប ជាពួកអ្នកបំរើរបស់ យើង ព្រមទាំងម៉ូសេ, ដាវីឌ, និងសាឡូម៉ូន ជាពួកអ្នកបំរើរបស់យើង អំពីគោលការណ៍ និងគោលលទ្ធិខាងការមាន[ក]ប្រពន្ធ និងស្រីស្នំ ច្រើននោះ —

២ មើលចុះ និងមើលន៏ យើងជាព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក ហើយនឹងឆ្លើយតបដល់អ្នកអំពីរឿងនេះ ។

៣ ហេតុដូច្នេះហើយ ចូរ[ក]ត្រៀមចិត្ត ដើម្បីទទួល ហើយគោរពតាមការបង្គាប់ទាំងឡាយ ដែលយើងកំពុងតែនឹងប្រាប់ដល់អ្នក; ចំពោះអស់អ្នកណាដែលក្រិត្យវិន័យនេះបានបើកសំដែងដល់ពួកគេ នោះត្រូវគោរពតាមក្រិត្យវិន័យនេះដូចគ្នា ។

៤ ត្បិតមើលចុះ យើងបើកសំដែងប្រាប់ដល់អ្នក ពីសេចក្ដីសញ្ញាថ្មី និងអស់កល្បអស់កាលជានិច្ច; ហើយបើសិនជាអ្នកមិនកាន់[ក]សេចក្ដី សញ្ញានោះ[ខ]ផាប់ទេ ខណៈនោះ អ្នកផាប់ទោស; ត្បិតគ្មានអ្នកណាមួយអាច[គ]បដិសេធសេចក្ដីសញ្ញានេះ ហើយអនុញ្ញាតឲ្យចូលក្នុងសិរីល្អ របស់យើងបានឡើយ ។

៥ ត្បិតអស់អ្នកណាដែលនឹងបាន[ក]ព្រះពរពីព្រះហស្ដរបស់យើង នោះនឹងនៅផាប់នឹង[ខ]ក្រិត្យវិន័យ ដែលបានតាំងសំរាប់ព្រះពរនោះ និងល័ក្ខខ័ណ្ឌនៃក្រិត្យវិន័យនោះ ដូចដែលបានបង្កើតឡើងតាំងពីមុនកំណើតលោកិយមកម្ល៉េះ ។

៧ *ក* ស.ប. វិញ្ញាណ.
*ខ* គ. និង ស. ៧៦:១២; ៩៧:១៦; ម៉ូសេ ១:១១.
**១៣២** ១*ក* គ. និង ស. ១៣២:៣៤, ៣៧–៣៩.
ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន.
៣ *ក* គ. និង ស. ២៩:៨; ៥៨:៦; ៧៨:៧.
៤ *ក* ស.ប. សេចក្ដីសញ្ញា.
*ខ* ស.ប. សេចក្ដីផាប់ទោស.
៤ *គ* គ. និង ស. ១៣១:១–៤.
៥ *ក* គ. និង ស. ១៣០:២០–២១.
*ខ* ស.ប. ក្រិត្យវិន័យ.

៦ ហើយដូចជាទាក់ទងទៅនឹង[ក]សេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច នោះត្រូវបានបង្កើតឡើង សំរាប់ភាពពោរពេញនៃ [ខ]សិរីល្អរបស់យើង; ហើយអ្នកណាដែលទទួលនូវភាពពោរពេញនៃសិរីល្អនោះ នោះត្រូវ ហើយគួរនៅជាប់នឹងក្រិត្យវិន័យ បើពុំនោះ សោតទេ អ្នកនោះនឹងជាប់ទោស ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៧ ហើយយើងប្រាប់អ្នកជាប្រាកដថា [ក]លក្ខខណ្ឌទាំងឡាយនៃក្រិត្យវិន័យនេះ គឺថា៖ គ្រប់ទាំងសេចក្ដីសញ្ញា កិច្ចសន្យា សំបុត្រធានា កាតព្វកិច្ច [ខ]សម្បថ ការសច្ចា ការប្រព្រឹត្តិ ការរួបរួម ការចូលរួម ឬការសង្ឃឹម ដែលពុំបានធ្វើ ហើយចូល ហើយ[គ]ភ្ជាប់ ដោយ[ឃ]ព្រះវិញ្ញាណ បរិសុទ្ធនៃសេចក្ដីសន្យា ដោយអ្នកដែលបានលាប ចំពោះវេលាកាល និងចំពោះអស់ទាំងភាពអស់កល្បជានិច្ចផង ដែរ ហើយការណ៍ នោះក៏បរិសុទ្ធបំផុតដែរ គឺដោយ[ង]វិវរណៈ និងព្រះបញ្ញត្តិ តាមរយៈមាត៌ានៃអ្នកចាក់ប្រេងតាំងរបស់យើង ដែលយើងបានតែងតាំងនៅលើផែនដី ដើម្បីឲ្យកាន់អំណាចនេះ (ហើយយើងបានតែងតាំងដល់យ៉ូសែប ជាអ្នកបំរើរបស់យើង ឲ្យកាន់អំណាចនេះ នៅថ្ងៃចុង ក្រោយបង្អស់ ហើយពុំដែលមានច្រើនជាងមួយនៅលើផែនដី នៅគ្រាណាមួយ ដែលអំណាចនេះ និង[ច]កូនសោទាំងឡាយនៃបព្វជិត ភាពនេះត្រូវបានប្រទានឲ្យនោះឡើយ) នោះសុទ្ធតែគ្មានប្រសិទ្ធិភាព អំណាច ឬអានុភាព នៅក្នុង និងក្រោយពីដំណើររស់ពីស្លាប់ឡើង វិញឡើយ; ត្បិតគ្រប់ទាំងកិច្ចសន្យាណាដែលពុំបានធ្វើចំពោះគោលបំណងនេះ នោះក៏ឈប់ដែរ នៅពេលមនុស្សស្លាប់ទៅ ។

៨ មើលចុះ ដំណាក់យើង គឺជាដំណាក់នៃរបៀបរៀបរយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយពុំមែនជាដំណាក់ នៃចលាចលឡើយ ។

៩ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា តើយើងនឹងទទួល[ក]ដង្វាយដែលពុំបានធ្វើដោយនូវព្រះនាមយើងឬ ?

១០ ឬតើយើងនឹងទទួលពីដៃអ្នក នូវអ្វីដែលយើងពុំបាន[ក]តាំងឬ ?

១១ ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា តើយើងនឹងតាំងដល់អ្នក លើកលែងតែតាមក្រិត្យវិន័យ ដូចដែលយើង និងព្រះវរបិតា របស់យើង [ក]បានតែងតាំងដល់អ្នក តាំងពីមុនកំណើតលោកិយមកម្ល៉េះឬ ?

១២ យើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក; ហើយយើងប្រទានដល់អ្នក នូវព្រះបញ្ញត្តិនេះ — ថាគ្មានអ្នកណា[ក]ទៅឯព្រះបានឡើយ លើក លែងតែដោយយើង ឬដោយព្រះបន្ទូលយើង ដែលជាក្រិត្យវិន័យរបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៣ ហើយរបស់សព្វសារពើដែលនៅក្នុងលោកិយ ទោះជាបានតែងតាំងឡើងដោយមនុស្សលោក ដោយបល្ល័ង្កទាំងឡាយ ឬក្សត្របុរី ទាំងឡាយ ឬអំណាចទាំងឡាយ ឬរបស់នានាក្នុងនាមអ្វីក៏ដោយ គង់តែពុំមែនដោយយើង ឬដោយព្រះបន្ទូលនៃយើងដែរ ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថាដូច្នោះ គឺនឹងត្រូវបោះចោល ហើយនឹង[ក]មិនត្រូវមាននៅឡើយ បន្ទាប់ពីមនុស្សលោកស្លាប់ទៅ ឬនៅក្នុង ឬក្រោយពីដំណើររស់ឡើងវិញឡើយ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

១៤ ត្បិតអ្វីៗក៏ដោយដែលនៅ នោះគឺដោយយើង ហើយអ្វីៗក៏ដោយ ដែលពុំមែនដោយយើងទេ នោះនឹងត្រូវញាប់ញ័រ ហើយបំផ្លាញចោល ។

១៥ ហេតុដូច្នេះហើយ បើសិនជាបុរសណាមួយ[ក]រៀបការយកប្រពន្ធ នៅក្នុងលោកិយ ហើយអ្នកនោះពុំមែនរៀបការយកនាងដោយយើង ឬដោយព្រះបន្ទូលយើងទេ ហើយអ្នកនោះធ្វើសេចក្ដីសញ្ញាជាមួយនាង ថាដរាបណាគាត់នៅក្នុងលោក ហើយនាងនៅ ជាមួយគាត់ នោះសេចក្ដីសញ្ញា និងអាពាហ៍ពិពាហ៍របស់ពួកគេ គ្មានប្រសិទ្ធិភាពឡើយ កាលណាពួកគេស្លាប់ទៅ ហើយកាលពួក គេចាកចេញពីលោកិយទៅ; ហេតុដូច្នេះហើយ ពួកគេពុំនៅជាប់គ្នា ដោយសារក្រិត្យវិន័យណាឡើយ កាលពួកគេចាកចេញពី លោកិយទៅនោះ ។

១៦ ហេតុដូច្នេះហើយ កាលពួកគេចាកចេញពីលោកិយទៅ

៦ *ក* គ. និង ស. ៦៦:២.
ស.ប. សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច.
*ខ* គ. និង ស. ៧៦:៧០, ៩២–៩៦.
ស.ប. សិរីល្អនៃសេឡេស្ទាល.
៧ *ក* គ. និង ស. ៨៨:៣៨–៣៩.
*ខ* ស.ប. សម្បថ.
*គ* ស.ប. ភ្ជាប់, ការភ្ជាប់.
*ឃ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា.
*ង* ស.ប. វិវរណៈ.
*ច* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
៩ *ក* ម៉ូរ៉ូណៃ ៧:៥–៦.
ស.ប. បូជា, យញ្ញបូជា.
១០ *ក* លេវី. ២២:២០–២៥; ម៉ូសេ ៥:១៩–២៣.
១១ *ក* គ. និង ស. ១៣២:៥.
១២ *ក* យ៉ូហាន ១៤:៦.
១៣ *ក* ៣ នីហ្វៃ ២៧:១០–១១.
១៥ *ក* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍.

នោះពួកគេពុំមែនរៀបការយកគ្នាជាប្ដីប្រពន្ធទៀតទេ; ប៉ុន្តែត្រូវ
បានតែង តាំងឡើងជាពួកទេវតានៅស្ថានសួគ៌វិញ គឺជាពួក
ទេវតាដែលជាអ្នកបំរើខាងការបំរើ ដើម្បីបំរើដល់អស់អ្នកណា
ដែលសំណំ នឹងទម្ងន់នៃសិរីល្អ ដ៏ធំជាង និងដ៏លើសលប់ និង
ដ៏នៅអស់កល្បជានិច្ច ។
១៧ ត្បិតពួកទេវតាទាំងនេះពុំបាននៅជាប់នឹងក្រិត្យវិន័យ
របស់យើងឡើយ; ហេតុដូច្នេះហើយ ពួកគេពុំអាចបាន
ចំរើនឡើងឡើយ ប៉ុន្តែ នៅបែកគ្នា ហើយនៅតែឯង ដោយ
គ្មានភាពដំកើងឡើងឡើយ នៅក្នុងសភាពរបស់ពួកគេដែលបាន
សង្គ្រោះរួច រហូតដល់ភាពអស់ កល្បជានិច្ច; ហើយ
ចាប់ពីអំណិះតទៅ ពុំមែនជាព្រះទេ ប៉ុន្តែជាពួកទេវតានៃព្រះ
ជារៀងដរាបតទៅ ។
១៨ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា បើ
សិនជាបុរសណាមួយរៀបការប្រពន្ធ ហើយធ្វើសេចក្ដីសញ្ញាជា
មួយនាង ចំពោះវេលាកាល និងចំពោះអស់ទាំងភាព
អស់កល្បជានិច្ចផងដែរ បើសិនជាសេចក្ដីសញ្ញាពុំមែនដោយ
យើង ឬដោយព្រះបន្ទូល យើង ដែលជាក្រិត្យវិន័យរបស់យើង
ហើយពុំបានភ្ជាប់ ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា
តាមរយៈអ្នកណាដែលយើងបានលាប និង តែងតាំងឡើង
ចំពោះអំណាចនេះទេនោះ សេចក្ដីសញ្ញានោះគ្មានការ
ឬប្រសិទ្ធិភាពឡើយ កាលពួកគេចាកចេញពីលោកិយទៅ ពី
ព្រោះពួកគេពុំផ្សំផ្គុំដោយយើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល
ថាដូច្នោះ ឬដោយព្រះបន្ទូលយើងដែរ; កាលណាពួកគេ
ចាកចេញ ពីលោកិយទៅ សេចក្ដីសញ្ញានោះពុំបានទទួល
ស្គាល់នៅទីនោះឡើយ ពីព្រោះទេវតា និងព្រះទាំងឡាយត្រូវ
បានតែងតាំងនៅទីនោះ ជាពួកអ្នកដែលគេពុំអាចបង្ហួសបានឡើយ;
ហេតុដូច្នេះហើយ ពួកគេពុំអាចគ្រងសិរីល្អរបស់យើងទុកជាមរតក
បានឡើយ; ត្បិតដំ ណាក់យើង គឺជាដំណាក់នៃរបៀបរៀបរយ
ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
១៩ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា បើ
សិនជាបុរសណាមួយរៀបការប្រពន្ធ ដោយព្រះបន្ទូលយើង
ដែលជាក្រិត្យវិន័យ របស់យើង និងដោយសេចក្ដីសញ្ញាថ្មី និង
ដ៏នៅអស់កល្បអស់កាលជានិច្ច ហើយសេចក្ដីសញ្ញានោះបាន
ភ្ជាប់ដល់ពួកគេ ដោយព្រះ វិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា
ដោយអ្នកណាដែលត្រូវបានលាប ដែលយើងបានតែងតាំងឡើ
ងចំពោះអំណាចនេះ និងកូនសោទាំង ឡាយនៃបព្វជិតភាពនេះ;
ហើយនឹងត្រូវបានប្រាប់ដល់ពួកគេថា — អ្នករាល់គ្នានឹងត្រូវ
បានក្រោកឡើង នៅក្នុងដំណើររស់ឡើងវិញ លើកទីមួយ;
ហើយបើសិនជាបន្ទាប់ពីដំណើររស់ឡើងលើកទីមួយ នោះ
គឺនៅក្នុងដំណើររស់ឡើងវិញ បន្ទាប់មក; ហើយនឹងបានគ្រង
បល្ល័ង្កទាំងឡាយ នគរទាំងឡាយ ក្សត្របុរីទាំងឡាយ និង
អំណាចទាំងឡាយ អំណាចគ្រប់គ្រងទាំងឡាយ គ្រប់ទីកំពស់
និងជំរៅ ទាំងអស់ — ខណៈនោះ ទើបនឹងបានកត់ទុកនៅក្នុង
បញ្ជីជីវិតរបស់កូនចៀម ថាអ្នកនោះមិនត្រូវប្រព្រឹត្តឃាតកម្ម
ដោយការកំចាយ ឈាម ដែលគ្មានទោសឡើយ ហើយបើ
សិនជាអ្នករាល់គ្នានៅជាប់ក្នុងសេចក្ដីសញ្ញារបស់យើង ហើយ
មិនប្រព្រឹត្តឃាតកម្ម ដោយការកំចាយឈាម ដែលគ្មានទោសនោះ
នោះនឹងបានសំរេចដល់ពួកគេ ចំពោះគ្រប់ការណ៍ទាំងអស់ ដែល
អ្នកបំរើរបស់យើង បានភ្ជាប់ទៅលើពួកគេ ក្នុង កាលវេលា
និងរហូតដល់អស់ទាំងភាពអស់កល្បជានិច្ចផង; ហើយនឹងមាន
ប្រសិទ្ធិភាពពេញលេញ កាល ពួកគេចាកចេញពីលោកិយ ទៅ;
ហើយពួកគេនឹងបង្ហួសទេវតាទាំងឡាយ និងព្រះទាំងឡាយ
ដែលបានចាត់ឲ្យនៅទីនោះ ដើម្បីទៅ រកភាពដំកើងឡើង និង
សិរីល្អរបស់ពួកគេ ក្នុងអ្វីៗគ្រប់ទាំងអស់ ដូចដែលបាន
ភ្ជាប់លើក្បាលពួកគេ គឺជាសិរីល្អដែលនឹងបាន ពូជដ៏បរិបូរ និង
បន្តបន្ទាប់ ជារៀងដរាបតទៅ ។
២០ ខណៈនោះ ពួកគេនឹងទៅជាព្រះ ពីព្រោះពួកគេគ្មាន
ទីអវសានឡើយ; ហេតុដូច្នេះហើយ ពួកគេនឹងទៅពីភាព
អស់កល្ប អស់កាល ជានិច្ច ទៅភាពអស់កល្បអស់កាលជានិច្ច
ពីព្រោះពួកគេមានបន្តទៅ; ខណៈនោះ ពួកគេនឹងទៅលើអ្វីៗទាំង

១៦ ក ម៉ាថាយ ២២:២៣–៣៣;
ម៉ាកុស ១២:១៨–២៥;
លូកា ២០:២៧–៣៦.
ខ ស.ប. ពួកទេវតា.
១៩ ក ស.ប. អាពាហ៍ពិពាហ៍,
រៀបអាពាហ៍ពិពាហ៍ —
សេចក្ដីសញ្ញាថ្មី
និងអស់កល្បជានិច្ចនៃអាពាហ៍ពិពាហ៍.
ខ ស.ប. ភ្ជាប់, ការភ្ជាប់.
គ គ. និង ស. ៧៦:៥២–៥៣;
៨៨:៣–៤.
ឃ ស.ប. កូនសោទាំងឡាយនៃបព្វជិត
ភាព.
ង និក្ខ. ១៩:៥–៦;
វិវរ. ៥:១០; ២០:៦;
គ. និង ស. ៧៦:៥៦;
៧៨:១៥, ១៨.
ច ស.ប. សៀវភៅជីវិត.
ឆ ស.ប. ភាពដំកើងឡើង.

អស់ ពីព្រោះ គ្រប់ការណ៍ ទាំងអស់សុទ្ធតែនៅក្រោម
អំណាចខ្លួន ។ ខណៈនោះ ពួកគេនឹងទៅជាព្រះ ពីព្រោះពួក
គេនឹងមានអំណាចគ្រប់យ៉ាង ហើយពួកទេវតា ត្រូវនៅក្រោម
អំណាចពួកគេ ។
២១ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា លើកលែងតែអ្នក
រាល់គ្នានៅជាប់នឹងក្រិត្យវិន័យរបស់យើង នោះអ្នករាល់គ្នាពុំ
អាចបាន សិរីល្អនេះឡើយ ។
២២ ត្បិតទ្វារនោះតូច ហើយផ្លូវដែលនាំទៅឯភាព
ដំកើងឡើង និងភាពបន្តជីវិតទាំងឡាយក៏ចង្អៀតផង ហើយមាន
មនុស្ស តិចណាស់ ដែលរកផ្លូវនោះឃើញ ពីព្រោះអ្នករាល់គ្នាពុំ
បានទទួលយើងនៅក្នុងលោកនេះ ឬក៏ស្គាល់យើងឡើយ ។
២៣ ប៉ុន្តែបើសិនជាអ្នករាល់គ្នាទទួលយើងនៅក្នុងលោកនេះ
ខណៈនោះ អ្នករាល់គ្នាក៏នឹងបានស្គាល់យើងដែរ ហើយនឹងបាន
ទទួល ភាពដំកើងឡើងរបស់អ្នក; ប្រយោជន៍ឲ្យអ្នករាល់គ្នា
បាននៅកន្លែង ដែលយើងនៅនោះដែរ ។
២៤ នេះហើយជាជីវិតដ៏នៅអស់កល្បជានិច្ច —
គឺដើម្បីស្គាល់ព្រះដ៏ប្រកបដោយប្រាជ្ញា ហើយពិតតែមួយអង្គ
និងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់មក ។ យើងនេះហើយ
ដែលជាព្រះអង្គ ។ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាទទួល
ក្រិត្យវិន័យរបស់យើងចុះ ។
២៥ ទ្វារនោះធំ ហើយផ្លូវដែលនាំទៅឯសេចក្ដីស្លាប់ក៏ទូលាយ
ផង; ហើយមានមនុស្សជាច្រើន ដែលចូលតាមទ្វារនោះ ពីព្រោះ
ពួកគេ ពុំបានទទួលយើង ឬក៏ពួកគេពុំនៅជាប់ក្នុងក្រិត្យវិន័យ
របស់យើងឡើយ ។
២៦ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា បើសិនជាមាន
បុរសណាមួយរៀបការប្រពន្ធ ស្របតាមព្រះបន្ទូលរបស់យើង
ហើយពួកគេ ត្រូវបានភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេច
ក្ដីសន្យា ស្របតាមការតែងតាំងរបស់យើង ហើយបើបុរស
ឬនាងនោះបានប្រព្រឹត្តអំពើ បាប ឬការរំលងណាមួយ នៅ
ក្នុងសេចក្ដីសញ្ញាថ្មី និងដ៏នៅអស់កល្បអស់កាលជានិច្ច និងការ
ពោលពាក្យមើលងាយគ្រប់បែបបទក៏ ដោយ ហើយបើសិនជា
ពួកគេពុំបានប្រព្រឹត្តអំពើឃាតកម្ម ដែលពួកគេបានកំចាយ
ឈាមដែលគ្មានទោសទេ នោះគង់តែពួកគេនឹង ត្រូវបានក្រោក
ឡើង នៅក្នុងដំណើររស់ឡើងវិញលើកទីមួយ ហើយចូលទៅ
ក្នុងភាពដំកើងឡើងរបស់ពួកគេដែរ; ប៉ុន្តែពួកគេនឹង ត្រូវ
បំផ្លាញចោល នៅក្នុងសាច់ឈាម ហើយនឹងត្រូវបាន
ប្រគល់ទៅឯការធ្វើទុក្ខពីអារក្សសាតាំង ទំរាំដល់ថ្ងៃប្រោសលោះ
ព្រះអម្ចាស់ដ៏ ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
២៧ ការពោលពាក្យប្រមាថទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ ដែល
នឹងអត់ទោសឲ្យពុំបានទេ ទោះនៅលោកិយនេះ ឬនៅបរលោកក្ដី
ព្រមទាំងថា អ្នករាល់គ្នាប្រព្រឹត្តអំពើឃាតកម្ម ដែលអ្នករាល់គ្នា
បានកំចាយឈាមដែលគ្មានទោស ហើយអ្នករាល់គ្នាយល់ព្រម
ចំពោះ សេចក្ដីសុគតរបស់យើង បន្ទាប់ពីអ្នករាល់គ្នាបានទទួល
សេចក្ដីសញ្ញាថ្មី និងដ៏នៅអស់កល្បអស់កាលជានិច្ចរបស់យើង
ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថា ដូច្នោះ; ហើយអ្នក
ណាដែលមិននៅជាប់នឹងក្រិត្យវិន័យនេះ នោះពុំអាចចូលក្នុង
សិរីល្អរបស់យើងបានឡើយ ប៉ុន្តែនឹងត្រូវជាប់ទោសវិញ ព្រះ
អម្ចាស់ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
២៨ យើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ហើយនឹងប្រទាន
ដល់អ្នក នូវព្រះបញ្ញត្តិមួយ អំពីបព្វជិតភាពបរិសុទ្ធរបស់យើង
ដូចដែលបានតែងតាំងដោយយើង និងព្រះវរបិតារបស់យើង
ចាប់តាំងពីមុនកំណើតលោកិយមកម្ល៉េះ ។

---

២០ *ក* ម៉ាថាយ ២៥:២១; គ. និង ស. ២៩:១២–១៣; ១៣២:៣៧. ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
*ខ* គ. និង ស. ៥០:២៦–២៩; ៧៦:៩៤–៩៥; ៨៤:៣៥–៣៩.
២១ *ក* ស.ប. ក្រិត្យវិន័យ.
២២ *ក* លូកា ១៣:២៤; ២ នីហ្វៃ ៣៣:៩; ហេលេ. ៣:២៩–៣០.
*ខ* ម៉ាថាយ ៧:១៣–១៤, ២៣; ២ នីហ្វៃ ៩:៤១; ៣១:១៧–២១.
*គ* គ. និង ស. ១៣២:៣០–៣១.
២៣ *ក* យ៉ូហាន ១៤:២–៣.
២៤ *ក* យ៉ូហាន ១៧:៣. ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
*ខ* យ៉ូហាន ៣:១៦–១៧; គ. និង ស. ៤៩:៥.
២៥ *ក* ម៉ាថាយ ៧:១៣–១៤; ៣ នីហ្វៃ ១៤:១៣–១៥.
*ខ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
*គ* យ៉ូហាន ៥:៤៣.
២៦ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា.
*ខ* អាលម៉ា ៣៩:៥–៦.
*គ* គ. និង ស. ៨២:២១; ១០៤:៩–១០.
*ឃ* ស.ប. អារក្ស.
២៧ *ក* ស.ប. ប្រមាថព្រះ, ការប្រមាថព្រះ; អំពើបាបដ៏អត់ឱនមិនបាន.
*ខ* ម៉ាថាយ ១២:៣១–៣២; ហេព្រើរ ៦:៤–៦; គ. និង ស. ៧៦:៣១–៣៥. ស.ប. ពួកកូនអន្តរធាន.
២៧ *គ* ស.ប. សេចក្ដីជាប់ទោស.

២៩ [ក]លោកអ័ប្រាហាំបានទទួលការណ៍គ្រប់យ៉ាង អ្វីៗក៏ដោយ ដែលលោកបានទទួល ដោយវិវរណៈ និងបញ្ញា នោះគឺដោយព្រះបន្ទូលរបស់យើង ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយបានទទួលក្នុងភាពដំកើងឡើងរបស់លោក ហើយអង្គុយនៅលើបល្ល័ង្ករបស់លោកហើយ ។

៣០ លោកអ័ប្រាហាំបានទទួល[ក]សេចក្ដីសន្យា អំពីពូជរបស់លោក និងអំពីផលនៃពោះរបស់លោក — គឺអ្នករាល់គ្នាចេញពី[ខ]ពោះ អ្នកនោះហើយ គឺឈ្មោះថា យ៉ូសែប ជាអ្នកបំរើរបស់យើង — ដែលត្រូវមានបន្តទៅ ដរាបណាពួកគេនៅក្នុងលោកិយនេះ; ហើយអំពី លោកអ័ប្រាហាំ និងពូជលោកនោះពួកគេនឹងមានបន្តទៅ នៅបរលោក; ទាំងនៅលោកិយនេះ និងនៅបរលោកក្ដី ក៏ពួកគេនឹងមាន ច្រើនឥតគណនាដូចជា[គ]ផ្កាយដែរ; ឬម្យ៉ាងទៀត បើសិនជាអ្នករាល់គ្នាអាចរាប់ខ្សាច់នៅលើឆ្នេរសមុទ្របាន ក៏អ្នកពុំអាចរាប់ពួកគេអស់ ដែរ ។

៣១ សេចក្ដីសន្យានេះក៏ជាសេចក្ដីសន្យាដល់អ្នកដែរ ពីព្រោះអ្នករាល់គ្នាជា[ក]ពូជពីលោកអ័ប្រាហាំ ហើយសេចក្ដីសន្យាបានធ្វើដល់ លោកអ័ប្រាហាំ; ហើយដោយសារក្រិត្យវិន័យនេះហើយ ជាការបន្តកិច្ចការនៃព្រះវរបិតារបស់យើង ដែលព្រះអង្គលើកដំកើងព្រះអង្គ ទ្រង់ ។

៣២ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាទៅ ហើយធ្វើ[ក]កិច្ចការទាំងឡាយរបស់លោកអ័ប្រាហាំចុះ; ចូរចូលក្នុងក្រិត្យវិន័យរបស់យើង ហើយអ្នករាល់គ្នានឹងបានសង្គ្រោះ ។

៣៣ ប៉ុន្តែបើសិនជាអ្នករាល់គ្នាមិនចូលក្នុងក្រិត្យវិន័យរបស់យើងទេ នោះអ្នករាល់គ្នាពុំអាចបានទទួលសេចក្ដីសន្យានៃព្រះវរបិតា ដែលព្រះអង្គបានធ្វើដល់លោកអ័ប្រាហាំនោះឡើយ ។

៣៤ ព្រះទ្រង់បាន[ក]បញ្ជាលោកអ័ប្រាហាំ ហើយនាង[ខ]សារ៉ាបានប្រគល់នាង[គ]ហាការដល់លោកអ័ប្រាហាំឲ្យធ្វើជាប្រពន្ធ ។ ហើយតើហេតុ អ្វីបានជានាងធ្វើដូច្នោះ ? ពីព្រោះការណ៍នេះគឺជាក្រិត្យវិន័យ; ហើយចេញពីនាងហាការ នោះមានមនុស្សជាច្រើនកើតមក ។ ហេតុដូច្នេះហើយ ការណ៍នេះត្រូវបានសំរេចសេចក្ដីសន្យា ព្រមទាំងការណ៍ផ្សេងៗទៀត ។

៣៥ ហេតុដូច្នេះហើយ តើលោកអ័ប្រាហាំ នៅក្រោមការដាក់ទោសឬ ? យើងប្រាប់អ្នកជាប្រាកដថា ទេ; ត្បិតយើង ជាព្រះអម្ចាស់ បាន[ក]បញ្ជាការណ៍នោះ ។

៣៦ លោកអ័ប្រាហាំ[ក]ត្រូវបានបញ្ជាឲ្យថ្វាយដង្វាយនូវ[ខ]អ៊ីសាកជាកូនរបស់លោក; ទោះជាយ៉ាងណាក៏ដោយ គង់តែបានសរសេរទុកមក ដែរថា កុំ[គ]ឲ្យសំឡាប់មនុស្សឲ្យសោះ ។ ក៏ប៉ុន្តែលោកអ័ប្រាហាំពុំបានជំទាស់ដែរ ហើយការណ៍នោះត្រូវបានរាប់ជា[ឃ]សេចក្ដីសុចរិត ដល់លោកវិញ ។

៣៧ លោកអ័ប្រាហាំបានទទួលយក[ក]ពួកស្រីស្នំ ហើយពួកគេបានបង្កើតកូនជូនលោក; ហើយការណ៍នោះត្រូវបានរាប់ជាសេចក្ដីសុចរិត ដល់លោក គឺពីព្រោះពួកគេត្រូវបានប្រគល់ដល់លោក ហើយលោកបាននៅជាប់នឹងក្រិត្យវិន័យរបស់យើង; ដូចជាអ៊ីសាក និង[ខ]យ៉ាកុប ដែរ ពួកគេពុំបានប្រព្រឹត្តអ្វីផ្សេងពីការណ៍ ដែលពួកគេត្រូវបានបញ្ជាឲ្យធ្វើនោះឡើយ; ហើយពីព្រោះពួកគេពុំបានប្រព្រឹត្តអ្វីផ្សេងពីការណ៍ ដែលពួកគេ ត្រូវបានបញ្ជាឲ្យធ្វើនោះ ទើបពួកគេបានចូល[គ]ក្នុងភាពដំកើងឡើងរបស់ពួកគេ ស្របតាមសេចក្ដីសន្យាទាំងឡាយ ហើយ អង្គុយលើបល្ល័ង្កទាំងឡាយ ហើយពុំមែនជាពួកទេវតាទេ តែជាព្រះវិញ ។

៣៨ [ក]ហ្លួងដាវីឌក៏បានទទួលយកភរិយា និងស្រី[ខ]ស្នំជាច្រើន ហើយព្រមទាំងហ្លួងសាឡូម៉ូន និងលោកម៉ូសេ ជាពួកអ្នកបំរើរបស់យើងដែរ ព្រមទាំងអ្នកផ្សេងជាច្រើនទៀត ដែលជាពួកអ្នកបំរើរបស់យើងផង ចាប់តាំងពីដើមកំណើត រហូតមកដល់ពេលនេះ; ហើយពួកគេពុំ បានប្រព្រឹត្តអំពើបាបណា

២៩ *ក* ស.ប. អ័ប្រាហាំ.
៣០ *ក* លោកុ. ១២:១–៣; ១៣:១៦.
ស.ប. អ័ប្រាហាំ — ពូជរបស់អ័ប្រាហាំ; សេចក្ដីសញ្ញាអ័ប្រាហាំ.
*ខ* ២ នីហ្វៃ ៣:៦–១៦.
*គ* លោកុ. ១៥:៥; ២២:១៧.
៣១ *ក* គ. និង ស. ៨៦:៨–១១; ១១០:១២.
៣២ *ក* យ៉ូហាន ៨:៣៩; អាលម៉ា ៥:២២–២៤.
៣៤ *ក* លោកុ. ១៦:១–៣.
*ខ* ស.ប. សារ៉ា.
*គ* លោកុ. ២៥:១២–១៨.
ស.ប. នាងហាការ.
៣៥ *ក* យ៉ាកុប ២:២៤–៣០.
៣៦ *ក* លោកុ. ២២:២–១២.
*ខ* ស.ប. អ៊ីសាក.
*គ* និក្ខ. ២០:១៣.
*ឃ* យ៉ាកុប ៤:៥.
ស.ប. សុចរិត, សេចក្ដីសុចរិត.
៣៧ *ក* ក.ន. ប្រពន្ធផ្សេងៗទៀត ។ លោកុ. ២៥:៥–៦.
*ខ* លោកុ. ៣០:១–៤; គ. និង ស. ១៣៣:៥៥.
ស.ប. យ៉ាកុប, កូនប្រុសរបស់អ៊ីសាក.
*គ* ស.ប. ភាពដំកើងឡើង; មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតា ដែលគង់នៅស្ថានសួគ៌.
៣៨ *ក* ស.ប. ដាវីឌ.
*ខ* ១ សាំយូ. ២៥:៤២–៤៣; ២ សាំយូ. ៥:១៣; ១ពង្សាវ. ១១:១–៣.

មួយឡើយ លើកលែងតែការណ៍ទាំងនោះ ដែលពួកគេពុំបាន
ទទួលពីយើងប៉ុណ្ណោះ ។
៣៩ ភរិយា និងស្រីស្នំទាំងឡាយរបស់ហ្លួងដាវីឌ ត្រូវ
បានប្រទានដល់ទ្រង់ពីយើង ដោយដៃរបស់ណាថាន់ ជាអ្នកបំរើ
របស់យើង ហើយ អ្នកផ្សេងៗទៀត ដោយពួកព្យាការី ដែល
មានកូនសោអំពីអំណាចនេះ; ហើយទ្រង់ពុំបានប្រព្រឹត្តអំពើបាបណា
មួយទាស់នឹង យើងឡើយ លើកលែងតែក្នុងករណីនៃអូរី និង
ប្រពន្ធគាត់ប៉ុណ្ណោះ; ហើយដោយហេតុនេះហើយ ទើបទ្រង់បាន
ធ្លាក់ពីភាពដំកើងឡើង របស់ទ្រង់ ហើយបានទទួលចំណែករបស់
ទ្រង់; ហើយទ្រង់នឹងពុំបានគ្រងពួកគេទុកជាមរតកនៅបរលោក
ឡើយ ត្បិតយើងបានប្រទាន ពួកគេ ដល់អ្នកផ្សេងទៀតហើយ
ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។
៤០ យើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ហើយយើងប្រទាន
ដល់អ្នក គឺយ៉ូសែប ជាអ្នកបំរើរបស់យើង នូវតំណែងមួយ ហើយ
សាង ឡើងវិញនូវការណ៍គ្រប់យ៉ាង ។ ចូរអ្នករាល់គ្នាទូលសូម
អ្វីក៏ដោយ នោះនឹងត្រូវបានប្រទានដល់អ្នក ស្របតាមព្រះបន្ទូល
របស់យើង ។
៤១ ហើយដូចជាអ្នករាល់គ្នាបានទូលសូមចង់ដឹងអំពីការកំផិត
ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា បើសិនជាមានបុរស
ណាម្នាក់ បានទទួលប្រពន្ធ នៅក្នុងសេចក្ដីសញ្ញាថ្មី និងអស់កល្ប
អស់កាលជានិច្ច ហើយបើសិនជានាងនៅជាមួយបុរសណាផ្សេង
ទៀត ដែល យើងពុំបានតាំងដល់នាង ដោយការលាបដ៏
បរិសុទ្ធនោះទេ នោះនាងបានប្រព្រឹត្តអំពើកំផិតហើយ ហើយ
នឹងត្រូវបំផ្លាញចោល ។
៤២ បើសិនជានាងពុំនៅក្នុងសេចក្ដីសញ្ញាថ្មី និងអស់កល្ប
អស់កាលជានិច្ចទេ ហើយនាងនៅជាមួយបុរសណាផ្សេងទៀត
នោះនាង បានប្រព្រឹត្តអំពើកំផិតហើយ ។
៤៣ ហើយបើសិនជាប្ដីនាងនៅជាមួយស្រីណាផ្សេងទៀត
ហើយគាត់នៅក្នុងកិច្ចសច្ចា នោះគាត់បានបំបាក់កិច្ចសច្ចា
របស់ខ្លួន ហើយ បានប្រព្រឹត្តអំពើកំផិតហើយ ។
៤៤ ហើយបើសិនជានាងពុំបានប្រព្រឹត្តអំពើកំផិតទេ ប៉ុន្តែនៅ
គ្មានទោស ហើយពុំបានបំបាក់កិច្ចសច្ចារបស់ខ្លួនឡើយ ហើយនាង
ដឹង ផាក់ ហើយយើងបើកសំដែងប្រាប់ដល់អ្នក គឺយ៉ូសែប
ជាអ្នកបំរើរបស់យើង ខណៈនោះទើបអ្នកមានអំណាច ដោយ
អំណាចនៃ បព្វជិតភាពបរិសុទ្ធរបស់យើង ដើម្បីយកនាង ហើយ
ប្រគល់នាងទៅឲ្យអ្នកណា ដែលពុំបានប្រព្រឹត្តអំពើកំផិត ប៉ុន្តែ
មានចិត្តស្មោះវិញ; ត្បិតអ្នកនោះនឹងត្រូវបានតាំងឲ្យធ្វើជាអ្នកត្រួត
លើរបស់ជាច្រើន ។
៤៥ ត្បិតយើងបានដាក់មកលើអ្នក នូវកូនសោទាំងឡាយ និង
អំណាចនៃបព្វជិតភាព ដែលយើងសាងឡើងវិញនូវការណ៍គ្រប់
យ៉ាង ហើយធ្វើឲ្យអ្នកដឹង នូវការណ៍គ្រប់យ៉ាង តាមពេល
កំណត់ ។
៤៦ ហើយប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា
អ្វីក៏ដោយដែលអ្នកភ្ជាប់នៅផែនដី នោះនឹងត្រូវបានភ្ជាប់ទុក
នៅស្ថានសួគ៌ដែរ; ហើយអ្វីក៏ដោយដែលអ្នកចងនៅផែនដី
ដោយនូវព្រះនាមរបស់យើង និងដោយព្រះបន្ទូលរបស់យើង
ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ដូច្នោះ នោះនឹងត្រូវបាន
ចងទុកអស់កល្បជានិច្ចនៅស្ថានសួគ៌ដែរ ហើយបាបទាំងឡាយ
របស់អ្នកណាក៏ដោយ ដែលអ្នកអត់ទោសឲ្យ នៅផែនដី នោះ
នឹងត្រូវបានអត់ទោសឲ្យនៅស្ថានសួគ៌ដែរ; ហើយបាបទាំងឡាយ
របស់អ្នកណាក៏ដោយ ដែលអ្នកប្រកាន់នៅផែនដី នោះនឹងត្រូវ
ប្រកាន់ជាប់នៅស្ថានសួគ៌ដែរ ។
៤៧ ហើយជាថ្មីទៀត យើងប្រាប់អ្នកជាប្រាកដថា អ្នក
ណាក៏ដោយដែលអ្នកឲ្យពរ នោះយើងនឹងប្រទានពរឲ្យដែរ
ហើយអ្នកណាក៏ ដោយដែលអ្នកដាក់បណ្ដាសា នោះយើងនឹង
ដាក់បណ្ដាសាដែរ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ;
ត្បិតយើងជាព្រះអម្ចាស់ គឺជាព្រះរបស់អ្នក ។
៤៨ ហើយជាថ្មីទៀត យើងប្រាប់អ្នក គឺយ៉ូសែប ជាអ្នកបំរើ
របស់យើង ជាប្រាកដថា អ្វីក៏ដោយដែលអ្នកប្រគល់នៅផែនដី
ហើយដល់អ្នក ណាក៏ដោយ ដែលអ្នកប្រគល់ឲ្យនៅផែនដី ដោយ

៣៩ *ក* ២ សាំយូ. ១២:៧–៨.
*ខ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*គ* ២ សាំយូ. ១១:៤, ២៧; ១២:៩; ១ ពង្សាវ. ១៥:៥.
ស.ប. អំពើកំផិត; ឃាតកម្ម.
*ឃ* យេរេ. ៨:១០.
៤០ *ក* យ.ស. — ប្រវត្តិ ១:៣៣.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៤២ *ក* គ. និង ស. ៤២:២២–២៦.
៤៣ *ក* ស.ប. សេចក្ដីសញ្ញា; អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍.
៤៤ *ក* ស.ប. ព្រហ្មចារីភាព.
៤៥ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ខ* កិច្ចការ ៣:២១; គ. និង ស. ៨៦:១០.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៤៦ *ក* ស.ប. ភ្ជាប់, ការភ្ជាប់.
*ខ* ស.ប. ការផ្ដាច់បាប.
៤៧ *ក* លោកុ. ១២:១–៣; គ. និង ស. ១២៤:៩៣.

ព្រះបន្ទូលរបស់យើង ហើយស្របតាមក្រិត្យវិន័យរបស់យើង នោះនឹងត្រូវបានផ្ដល់ ដោយព្រះពរទាំងឡាយ និងដោយព្រះចេស្ដារបស់យើង ហើយពុំមែនដោយបណ្ដាសាឡើយ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយនឹងគ្មានការដាក់ទោសនៅផែនដីនិងនៅស្ថានសួគ៌ឡើយ ។

៤៩ ត្បិតយើងជាព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក ហើយនឹងបានដល់អ្នក ដរាបដល់បំផុតលោក និងរហូតដល់អស់ភាពអស់កល្បជានិច្ចផង; ត្បិតយើងប្រាកដជាភ្ជាប់មកលើអ្នក នូវភាពដំកើងឡើងរបស់អ្នក ហើយរៀបចំបល្ល័ង្កមួយសំរាប់អ្នក នៅនគរនៃ ព្រះវរបិតារបស់ យើង ជាមួយលោកអ័ប្រាហាំ ជាអយ្យកោរបស់អ្នក ។

៥០ មើលចុះ យើងបានទតឃើញការបូជាទាំងឡាយរបស់អ្នក ហើយនឹងអត់ទោសដល់អស់ទាំងអំពើបាបរបស់អ្នក; យើងបានទត ឃើញការបូជាទាំងឡាយរបស់អ្នក ចំពោះការគោរពតាមអ្វីដែលយើងបានប្រាប់ដល់អ្នកហើយ ។ ហេតុដូច្នេះហើយ ចូរទៅហើយ យើងនឹងរៀបចំផ្លូវសំរាប់ឲ្យអ្នកចៀសរួចចុះ ដូចជាយើងបានទទួលដង្វាយរបស់លោកអ័ប្រាហាំ គឺអ៊ីសាក ជាកូនលោកនោះ ។

៥១ យើងប្រាប់អ្នកជាប្រាកដថា៖ យើងប្រទានព្រះបញ្ញត្តិមួយដល់ អិមម៉ា ស្ម៊ីធ ជាអ្នកបំរើរបស់យើង ដែលជាប្រពន្ធរបស់អ្នកដែលយើងបាន ប្រទានដល់អ្នកថា នាងទប់ខ្លួន ហើយកុំទទួលទាននូវអ្វីដែលយើងបញ្ជាដល់អ្នក ឲ្យប្រគល់ដល់នាងឡើយ; ត្បិតយើងធ្វើការណ៍នេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថាដូច្នោះ ដើម្បីពិសោធដល់អ្នកទាំងអស់គ្នា ដូចជាយើងបានពិសោធលោកអ័ប្រាហាំដែរ ហើយ ប្រយោជន៍ឲ្យយើងអាចតម្រូវដង្វាយពីដៃអ្នក ដោយសេចក្ដីសញ្ញា និងការបូជា ។

៥២ ហើយចូរឲ្យ អិមម៉ា ស្ម៊ីធ ជាអ្នកបំរើរបស់យើង ទទួលអស់អ្នកណាដែលត្រូវបានប្រទានដល់យ៉ូសែប ជាអ្នកបំរើរបស់យើង ហើយដែល ល្អស្អុទ្ធសាធ និងបរិសុទ្ធនៅចំពោះយើង; ហើយអស់អ្នកណាដែលមិនបរិសុទ្ធ ហើយថាខ្លួនបរិសុទ្ធ នោះនឹងត្រូវបំផ្លាញចោល ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៥៣ ត្បិតយើងជាព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក ហើយអ្នករាល់គ្នាត្រូវគោរពតាមសម្លេងរបស់យើង; ហើយយើងប្រទានដល់យ៉ូសែប ជាអ្នកបំរើរបស់យើង ប្រយោជន៍ឲ្យលោកអាចបានធ្វើជាអ្នកត្រួតលើរបស់ជាច្រើន; ត្បិតលោកមានចិត្តស្មោះលើរបស់បន្តិចបន្តួច ហើយចាប់ពីអំណិះតទៅ យើងនឹងចំរើនកម្លាំងដល់លោក ។

៥៤ ហើយយើងបញ្ជាដល់ អិមម៉ា ស្ម៊ីធ ជាអ្នកបំរើរបស់យើង ឲ្យនៅ និងនៅជាប់នឹងយ៉ូសែប ជាអ្នកបំរើរបស់យើង ហើយគ្មាន នរណាទៀតសោះ ។ ប៉ុន្តែបើសិនជានាងមិននៅជាប់នឹងព្រះបញ្ញត្តិនេះទេ នោះនាងនឹងត្រូវបំផ្លាញចោល ព្រះអម្ចាស់ទ្រង់មានព្រះ បន្ទូលថាដូច្នោះ; ត្បិតយើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ហើយនឹងបំផ្លាញនាងចោល បើសិនជានាងមិននៅជាប់ក្នុងក្រិត្យវិន័យ របស់យើងទេ ។

៥៥ ប៉ុន្តែបើសិនជានាងមិននៅជាប់នឹងព្រះបញ្ញត្តិនេះទេ ខណៈនោះ យ៉ូសែប ជាអ្នកបំរើរបស់យើង ត្រូវធ្វើអ្វីគ្រប់យ៉ាងសំរាប់នាង ដូចដែលលោកបានប្រាប់មកហើយ; ហើយយើងនឹងប្រទានពរដល់លោក ហើយបង្កើនលោកឲ្យបានច្រើនជាអនេក ហើយប្រទានដល់ លោកមួយរយដង នៅក្នុងលោកិយនេះ គឺជាឪពុកនិងម្ដាយ, បងប្អូនប្រុសស្រី, ផ្ទះសំបែង និងដែនដី, ប្រពន្ធ និងកូនចៅ, ហើយនឹង មកុដនៃជីវិតទាំងឡាយដ៏នៅអស់កល្បជានិច្ច នៅក្នុងពិភពទាំងឡាយដ៏នៅអស់កល្បជានិច្ច ។

៥៦ ហើយជាថ្មីទៀត យើងប្រាប់ជាប្រាកដថា ចូរឲ្យអ្នកបំរើរបស់យើងអត់ទោសដល់យ៉ូសែប ជាអ្នកបំរើរបស់យើង នូវការរំលងទាំង ឡាយរបស់លោកចុះ; ហើយខណៈនោះ ទើបនាងត្រូវបានអត់ទោសចំពោះការរំលងទាំងឡាយរបស់នាង ដែលនាងបានធ្វើរំលងទាស់ នឹងយើង; ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក នឹងប្រទានពរដល់នាង ហើយបង្កើននាងឲ្យបានច្រើនជាអនេក ហើយធ្វើឲ្យចិត្ត នាងបានអរសប្បាយ ។

៥៧ ហើយជាថ្មីទៀត យើងប្រាប់ថា ចូរកុំឲ្យយ៉ូសែប ជាអ្នកបំរើរបស់យើង ដករបស់របរលោកចេញពីដៃលោកឡើយ ក្រែងលមាន ខ្មាំងសត្រូវមក ហើយបំផ្លាញលោកចោល;

៤៩ *ក* ម៉ាថាយ ២៨:២០.
*ខ* គ. និង ស. ៦៨:១២.
*គ* គ. និង ស. ៥:២២.
ស.ប. ការហៅ និងការរើសតាំង.
*ឃ* លោកុ. ១៧:១–៨; ២ នីហ្វៃ ៨:២.
៥០ *ក* ស.ប. បូជា, យញ្ញបូជា.
*ខ* លោកុ. ២២:១០–១៤;
គ. និង ស. ៩៧:៨.
៥២ *ក* ស.ប. ស្ម៊ីធ, អិមម៉ា ហេល.
៥៣ *ក* ម៉ាថាយ ២៥:២១;
គ. និង ស. ៥២:១៣.
៥៥ *ក* ម៉ាកុស ១០:២៨–៣១.
*ខ* ស.ប. គ្រួសារ — គ្រួសារដ៏នៅអស់កល្បជានិច្ច;
ជីវិតដ៏នៅអស់កល្បជានិច្ច.
៥៦ *ក* ស.ប. អត់ទោស, អភ័យទោស.

ត្បិតអារក្សសាតាំងស្វែងរកបំផ្លាញលោកចោល; ត្បិតយើងជាព្រះអម្ចាស់ដ៏ជាព្រះ របស់អ្នក ហើយលោកគឺជាអ្នកបំរើរបស់យើង; ហើយមើលចុះ និងមើលន៏ យើងគង់នៅជាមួយលោក ដូចជាយើងបានគង់នៅ ជាមួយលោក អ័ប្រាហាំ ជាអយ្យកោរបស់អ្នក ដរាបដល់ភាពដំកើងឡើង និងសិរីល្អរបស់លោក ។

៥៨ ឥឡូវនេះ អំពីក្រិត្យវិន័យនៃបព្វជិតភាព នោះមានការណ៍ជាច្រើន ដែលទាក់ទងទៅនឹងរឿងនោះ ។

៥៩ ប្រាកដមែន បើសិនជាមានបុរសណាមួយ ដែលត្រូវបានហៅពីព្រះវរបិតាយើង ដូចជាលោកអើរ៉ុន ដោយសម្លេងយើងផ្ទាល់ និងដោយសម្លេងរបស់ព្រះអង្គដែលចាត់យើង ហើយយើងបានប្រទានដល់អ្នកនោះ នូវកូនសោទាំងឡាយ និងអំណាចនៃបព្វជិតភាព នេះ បើសិនជាអ្នកនោះប្រព្រឹត្តអ្វីក៏ដោយ ដោយនូវព្រះនាមរបស់យើង និងស្របតាមក្រិត្យវិន័យរបស់យើង និងតាមព្រះបន្ទូលរបស់ យើង អ្នកនោះនឹងពុំបានប្រព្រឹត្តអំពើបាបឡើយ ហើយយើងនឹងរាប់គាត់ថាជាសុចរិត ។

៦០ ហេតុដូច្នេះហើយ ចូរកុំឲ្យអ្នកណានិន្ទាលើយ៉ូសែប ជាអ្នកបំរើរបស់យើងឡើយ; ត្បិតយើងនឹងរាប់លោកថាជាសុចរិត; ត្បិតលោក នឹងធ្វើការបូជាអ្វីដែលយើងតម្រូវពីដៃលោក ចំពោះការរំលងទាំងឡាយរបស់លោក ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូល ថាដូច្នោះ ។

៦១ ហើយជាថ្មីទៀត អំពីក្រិត្យវិន័យនៃបព្វជិតភាព បើសិនជាមានបុរសណាមួយ យកស្រីព្រហ្មចារីធ្វើជាប្រពន្ធ ហើយមានប្រាថ្នា ចង់បានមួយទៀត ហើយប្រពន្ធទីមួយយល់ព្រម ហើយបើសិនជាគាត់យកប្រពន្ធទីពីរ ហើយពួកគេជាស្រីព្រហ្មចារី ហើយពុំបានសច្ចា ដល់បុរសផ្សេងទេ ខណៈនោះ រាប់គាត់ថាជាសុចរិត; គាត់មិនអាចប្រព្រឹត្តអំពើកំផិតបានឡើយ ព្រោះពួកគេត្រូវបានប្រគល់ដល់ គាត់ហើយ; ត្បិតអ្នកនោះពុំអាចប្រព្រឹត្តអំពើកំផិតចំពោះអ្វីដែលបានប្រគល់ដល់គាត់ ហើយដែលមិនមែនដល់អ្នកណាផ្សេងនោះឡើយ ។

៦២ ហើយបើសិនជាអ្នកនោះមានស្រីព្រហ្មចារីដប់នាក់ ដែលបានប្រគល់ដល់គាត់ដោយក្រិត្យវិន័យនេះ នោះគាត់ពុំអាចប្រព្រឹត្ត អំពើកំផិតបានឡើយ ត្បិតពួកគេជាប្រពន្ធគាត់ ហើយពួកគេត្រូវបានប្រគល់ដល់គាត់; ហេតុដូច្នេះហើយ អ្នកនោះត្រូវបានរាប់ថា ជាសុចរិត ។

៦៣ ប៉ុន្តែបើសិនជាស្រីព្រហ្មចារីណាមួយក្នុងចំណោមដប់នាក់ បន្ទាប់ពីនាងរៀបការហើយ នៅជាមួយបុរសផ្សេងទៀត នោះនាងបានប្រព្រឹត្តអំពើកំផិត ហើយនឹងត្រូវបំផ្លាញចោល; ត្បិតពួកគេត្រូវបានប្រគល់ដល់អ្នកនោះ ដើម្បីបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដី ស្របតាមព្រះបញ្ញត្តិរបស់យើង និងដើម្បីបំពេញសេចក្ដីសន្យា ដែលបានធ្វើដោយព្រះវរបិតារបស់យើង ចាប់តាំងពីមុនកំណើតលោកិយមកម្ល៉េះ និងសំរាប់ភាពដំកើងឡើងរបស់ពួកគេ នៅក្នុងពិភពទាំងឡាយដ៏នៅអស់កល្បជានិច្ច ប្រយោជន៍ឲ្យពួកគេអាច បានព្រលឹងនៃមនុស្សលោក ត្បិតការណ៍នេះហើយ ទើបកិច្ចការនៃព្រះវរបិតារបស់យើងបានបន្តទៅ ប្រយោជន៍ឲ្យទ្រង់អាចបានដំកើងឡើង ។

៦៤ ហើយជាថ្មីទៀត ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា បើសិនជាមានបុរសណាមួយ ដែលកាន់កូនសោទាំងឡាយនៃអំណាច នេះ បើគេមានប្រពន្ធ ហើយអ្នកនោះបង្រៀនដល់នាង អំពីក្រិត្យវិន័យនៃបព្វជិតភាព ដូចដែលទាក់ទងទៅនឹងការណ៍ទាំងនេះ ខណៈនោះ ទើបនាងនឹងជឿ ហើយនឹងបំរើគាត់ បើពុំនោះសោតទេ នាងនឹងត្រូវបំផ្លាញចោល ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូល ថាដូច្នោះ; ត្បិតយើងនឹងបំផ្លាញនាងចោល; ព្រោះយើងនឹងដំកើងព្រះនាមយើង នៅលើអស់អ្នកណាដែលទទួល ហើយនៅក្នុងក្រិត្យ វិន័យរបស់យើង ។

៦៥ ហេតុដូច្នេះហើយ ការណ៍នោះនឹងទៅជាក្រិត្យវិន័យចំពោះយើង បើសិនជានាងមិនទទួលក្រិត្យវិន័យនេះទេ ត្បិតដើម្បីឲ្យគាត់បាន ទទួលនូវការណ៍គ្រប់យ៉ាង ដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់គាត់ នឹងប្រទានដល់គាត់ ពីព្រោះនាងមិនបានជឿ ហើយបំរើគាត់ តាមព្រះបន្ទូលយើងទេ; ហើយខណៈនោះ នាងនឹងក្លាយទៅជាអ្នករំលង; ហើយអ្នកនោះត្រូវបានលើកលែងពីក្រិត្យវិន័យរបស់នាង សារ៉ា ដែលបានបំរើលោកអ័ប្រាហាំ

៥៧ *ក* ម៉ាថាយ ១០:២៨.
*ខ* ស.ប. ភាពដំកើងឡើង.
៥៨ *ក* គ. និង ស. ៨៤:១៩–២៦.
ស.ប. បព្វជិតភាព.
៥៩ *ក* ហេព្រើរ ៥:៤.
ស.ប. អើរ៉ុន, បងប្រុសរបស់ម៉ូសេ.
*ខ* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
៦១ *ក* ស.ប. ព្រហ្មចារី.
*ខ* សេចក្ដីប្រកាស — ១.
ស.ប. អាពាហ៍ពិពាហ៍,
រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន.
៦៣ *ក* លោកុ. ១:២៦–២៨;
យ៉ាកុប ២:៣០.
*ខ* ម៉ូសេ ១:៣៩.

តាមក្រិត្យវិន័យ ក្នុងកាលយើងបញ្ជាលោកអ័ប្រាហាំ ឲ្យយកនាងហាការធ្វើជាប្រពន្ធ ។
៦៦ ហើយឥឡូវនេះ អំពីក្រិត្យវិន័យនេះ ប្រាកដមែន យើងប្រាប់អ្នកជាប្រាកដថា យើងនឹងបើកសំដែងប្រាប់ដល់អ្នក ពីអំណិះតទៅ; ហេតុដូច្នេះហើយ ចូររាប់ការណ៍នេះថាល្មមនៅពេលនេះសិនចុះ ។ មើលចុះ យើងជាអាលផា និងអូមេកា ។ អាម៉ែន ៕

## កណ្ឌទី ១៣៣

*វិវរណៈដែលបានប្រទានឲ្យមកតាមរយៈ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅភូមិហៃរាំ រដ្ឋអូហៃអូ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៨៣១ (*History of the Church, *១:២២៩–២៣៤)* ។ *សំរាប់បុព្វកថានៃវិវរណៈនេះ ព្យាការីបានសរសេរថា៖ «នៅពេលនេះ មានការណ៍ ជាច្រើន ដែលពួកអែលឌើរប្រាថ្នាចង់ដឹង អំពីការផ្សាយដំណឹងល្អ ដល់បណ្ដាជននៅលើផែនដី និងអំពីការប្រមូលគ្នា ហើយដើម្បីដើរ តាមពន្លឺនៃសេចក្ដីពិត ហើយត្រូវបានបង្គាប់មកពីស្ថានខ្ពស់ នោះទើបនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៨៣១ ខ្ញុំបានទូលសូមដល់ព្រះអម្ចាស់ ហើយបានទទួលវិវរណៈដ៏សំខាន់ ដែលមានដូចតទៅនេះ» (*History of the Church, *១:២២៩)* ។ *មុនដំបូង កណ្ឌនេះ ត្រូវបានបញ្ចូលក្នុងព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ជាបរិសិដ្ឋ ហើយបន្ទាប់មក ទើបបានដាក់លេខតាមកណ្ឌ* ។

*១–៦, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យរៀបចំសំរាប់ការយាងមកលើកទីពីរ; ៧–១៦, មនុស្សលោកទាំងអស់ត្រូវបានបញ្ជាឲ្យរត់ចេញពីក្រុង បាប៊ីឡូន មកឯក្រុងស៊ីយ៉ូន ហើយរៀបចំសំរាប់ថ្ងៃដ៏ធំនៃព្រះអម្ចាស់; ១៧–៣៥, ទ្រង់នឹងឈរលើភ្នំស៊ីយ៉ូន ទ្វីបទាំងឡាយនឹងក្លាយទៅ ជាដែនដីតែមួយ ហើយពួកពូជអំបូរនៃអ៊ីស្រាអែលដែលបាត់នោះនឹងវិលមកវិញ; ៣៦–៤០, ដំណឹងល្អត្រូវបានសាងឡើងវិញ តាមរយៈ យ៉ូសែប ស្ម៊ីធ ដើម្បីឲ្យបានផ្សាយប្រាប់ដល់អស់ទាំងពិភពលោក; ៤១–៥១, ព្រះអម្ចាស់ទ្រង់នឹងយាងចុះមក ក្នុងសេចក្ដីសងសឹកមកលើ ពួកទុច្ចរិត; ៥២–៥៦, គឺនឹងទៅជាឆ្នាំនៃពួកប្រោសលោះរបស់ទ្រង់; ៥៧–៧៤, ដំណឹងល្អនឹងត្រូវបានចាត់ឲ្យចេញទៅ ដើម្បីជួយសង្គ្រោះ ពួកបរិសុទ្ធ និងសំរាប់ជាសេចក្ដីបំផ្លិចបំផ្លាញដល់ពួកទុច្ចរិត* ។

ប្រុងស្ដាប់ចុះ ឱអ្នករាល់គ្នាជារាស្ត្រនៃសាសនាចក្រយើងអើយ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់មានព្រះបន្ទូលថាដូច្នោះ ហើយចូរ ស្ដាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ដែលមានអំពីអ្នកចុះ —
២ ព្រះអម្ចាស់ដែលនឹងយាងមកឯព្រះវិហាររបស់ទ្រង់ក្នុងមួយរំពេច; ព្រះអម្ចាស់ដែលនឹងយាងចុះមកលើពិភពលោក ដោយសេចក្ដី បណ្ដាសា ដើម្បីជំនុំជំរះ; មែនហើយ មកលើអស់ទាំងសាសន៍ ដែលភ្លេចព្រះ និងមកលើអស់ទាំងពួកមនុស្សអាក្រក់ ដែលនៅក្នុងចំ ណោមពួកអ្នក ។
៣ ត្បិតទ្រង់នឹងលាតព្រះពាហុបរិសុទ្ធរបស់ទ្រង់ នៅភ្នែកនៃគ្រប់ទាំងសាសន៍ ហើយអស់ទាំងចុងផែនដី នឹងបានឃើញសេចក្ដីសង្គ្រោះ នៃព្រះរបស់ពួកគេ ។
៤ ហេតុដូច្នោះហើយ ចូររៀបចំ ចូររៀបចំ ឱរាស្ត្រយើងអើយ; ចូរញែកខ្លួនចេញជាបរិសុទ្ធ; ចូរប្រមូលគ្នីគ្នា ឱអ្នករាល់គ្នាជារាស្ត្រនៃ សាសនាចក្រយើង ដែលនៅលើដែនដីស៊ីយ៉ូនអើយ គឺអ្នកទាំងអស់ដែលពុំបានបញ្ជាឲ្យនៅនោះ ។
៥ ចូរចេញពីក្រុងបាប៊ីឡូន ។ ចូរអ្នករាល់គ្នាដែលកាន់ប្រដាប់ទាំងឡាយ នៃព្រះអម្ចាស់បានជ្រះស្អាតចុះ ។
៦ ចូរប្រកាសឲ្យមានជំនុំមុតមាំទាំងឡាយរបស់អ្នក ហើយនិយាយរកគ្នាទៅវិញទៅមកឲ្យបានញឹកញាប់ចុះ ។ ហើយចូរឲ្យមនុស្ស គ្រប់រូបអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ចុះ ។
៧ មែនហើយ យើងប្រាប់អ្នកម្ដងទៀតជាប្រាកដថា

**១៣៣** ២*ក* ម៉ាឡាគី ៣:១;
គ. និង ស. ៣៦:៨.
*ខ* គ. និង ស. ១:៣៦.
ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម.
៣ *ក* អេសាយ ៥២:១០.
*ខ* អេសាយ ១២:២; ៥២:១០.
ស.ប. ផែនការនៃសេចក្ដីប្រោសលោះ; សេចក្ដីសង្គ្រោះ.
៥ *ក* អាលម៉ា ៥:៥៧;
គ. និង ស. ១:១៦.
ស.ប. បាបិល, បាប៊ីឡូន; សេចក្ដីប្រកបដោយលោកិយ.
*ខ* ២ ធីម៉ូ. ២:២១;
៣ នីហ្វៃ ២០:៤១;
គ. និង ស. ៣៨:៤២.
ស.ប. សុទ្ធ, សុទ្ធសាធ.
៦ *ក* ម៉ាឡាគី ៣:១៦–១៨.

ពេលវេលាបានមកដល់ហើយ ក្នុងកាលសម្លេងនៃព្រះអម្ចាស់
ប្រាប់ដល់អ្នកថា៖ ចូរចេញពីក្រុង[ក]បាប៊ីឡូន; ចូរប្រមូលគ្នា
ពីចំណោមសាសន៍នានា ពីទិស[ខ]ទាំងបួន ចាប់តាំងពីជើងមេឃ
ម្ខាង រហូតដល់ជើងមេឃម្ខាង ។
៨ ចូរចាត់[ក]ពួកអែលឌើរនៃសាសនាចក្ររបស់យើង ឲ្យទៅឯ
សាសន៍ទាំងឡាយ ដែលនៅឆ្ងាយអង្វែង គឺទៅដល់[ខ]កោះទាំង
ឡាយក្នុង សមុទ្រ; ចូរចាត់ឲ្យទៅឯដែនដីចំឡែកៗ; ចូរប្រកាស
ប្រាប់សាសន៍ទាំងអស់ គឺមុនដំបូង ដល់[គ]ពួកសាសន៍ដទៃ
ហើយបន្ទាប់មក ដល់[ឃ]ពួកសាសន៍យូដា ។
៩ ហើយមើលចុះ និងមើលន៏ នេះគឺជាសំរែករបស់ពួកគេ
និងសម្លេងនៃព្រះអម្ចាស់ ដល់ប្រជាជនទាំងអស់ ថា៖ ចូរអ្នក
រាល់គ្នាចេញ ទៅឯដែនដីស៊ីយ៉ូន ប្រយោជន៍ឲ្យព្រំដែនទាំង
ឡាយនៃរាស្ត្ររបស់យើងអាចបានរីក ហើយប្រយោជន៍ឲ្យ[ក]ស្តេក
ទាំងឡាយរបស់នាងអាច បានចំរើនកម្លាំង ហើយប្រយោជន៍ឲ្យ
[ខ]ស៊ីយ៉ូនអាចបានចេញទៅភូមិភាគជុំវិញ ។
១០ មែនហើយ ចូរឲ្យសំរែកចេញទៅក្នុងចំណោមប្រជាជន
ទាំងអស់ ថា៖ ចូរភ្ញាក់ហើយក្រោកឡើង ហើយចេញទៅទទួល
[ក]ប្តីថ្មោង ថ្មីចុះ; មើលចុះ ហើយមើលន៏ ប្តីថ្មោងថ្មីកំពុងតែមក;
ចូរអ្នករាល់គ្នាចេញទៅទទួលលោកចុះ ។ ចូររៀបចំខ្លួនសំរា
ប់[ខ]ថ្ងៃដ៏ធំនៃព្រះ អម្ចាស់ចុះ ។
១១ ហេតុដូច្នេះហើយ ចូរ[ក]ចាំយាមចុះ ត្បិតអ្នករាល់គ្នាមិន[ខ]ដឹង
ជាថ្ងៃណា ឬម៉ោងណាឡើយ ។
១២ ហេតុដូច្នេះហើយ ចូរឲ្យពួកអ្នកដែលនៅក្នុង[ក]ចំណោមពួក
សាសន៍ដទៃ រត់ទៅឯ[ខ]ក្រុងស៊ីយ៉ូនចុះ ។
១៣ ហើយចូរឲ្យពួកអ្នកដែលជាពូជពង្ស[ក]យូដា រត់ទៅ
[ខ]ក្រុងយេរូសាឡិម គឺទៅឯ[គ]ភ្នំទាំងឡាយនៃដំណាក់របស់ព្រះ
អម្ចាស់ ។
១៤ ចូរអ្នករាល់គ្នាចេញពីចំណោមពួកសាសន៍នានា
គឺចេញពីក្រុងបាប៊ីឡូន ចេញពីកណ្តាលអំពើទុច្ចរិត ដែលជាក្រុង
បាប៊ីឡូនខាង វិញ្ញាណ ។
១៥ ប៉ុន្តែប្រាកដមែន ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលដូច្នេះថា
ចូរកុំឲ្យការរត់ភៀសរបស់អ្នក ធ្វើទៅដោយ[ក]ប្រញាប់ប្រញាលឡើយ
ប៉ុន្តែចូរឲ្យគ្រប់ទាំងអស់បានប្រុងប្រៀបចំពោះអ្នកជាស្រេច; ហើយ
អ្នកណាដែលទៅ នោះចូរកុំឲ្យគេងាកមើលក្រោយឡើយ
ក្រែងលោ សេចក្តីបំផ្លិចបំផ្លាញនឹងមានមកលើគេមួយរំពេចនោះ ។
១៦ ឱអ្នករាល់គ្នាជាបណ្តាជននៅលើផែនដីអើយ ចូរប្រុង
[ក]ស្តាប់ចុះ ហើយឱអ្នករាល់គ្នាជាពួកអែលឌើរ នៃសាសនាចក្រ
យើងអើយ ចូរញជុំគ្នា ហើយឮសម្លេងនៃព្រះអម្ចាស់ចុះ;
ត្បិតទ្រង់បានហៅដល់មនុស្សទាំងអស់ ហើយទ្រង់បានបញ្ជា ដល់
មនុស្សទាំងអស់ នៅគ្រប់ទិសទី ឲ្យ[ខ]ប្រែចិត្ត ។
១៧ ត្បិតមើលចុះ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់[ក]បានចាត់ទេវតា
មួយដែលកំពុងហោះកាត់កណ្តាលមេឃ ឲ្យស្រែកប្រាប់ថា៖
ហើយចូរអ្នក រាល់គ្នារៀបចំ[គ]ផ្លូវទទួលព្រះអម្ចាស់ ហើយ[ខ]តម្រង់
ផ្លូវថ្វាយទ្រង់ចុះ ត្បិតម៉ោងនៃការយាងមករបស់ទ្រង់នៅជិត
បង្កើយ —
១៨ កាល[ក]កូនចៀមនឹងឈរនៅលើ[ខ]ភ្នំស៊ីយ៉ូន ហើយមានមនុស្ស
[គ]មួយសែនបួនម៉ឺនបួនពាន់នាក់ ដែលមានព្រះនាមព្រះវរបិតា
ទ្រង់កត់លើ ថ្ងាស គេបានឈរជាមួយដែរ ។

៧ ក គ. និង ស. ២៩:៨.
ស.ប. អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
ខ សាការី ២:៦–៧;
ម៉ាកុស ១៣:២៧.
៨ ក ស.ប. កិច្ចការផ្សាយសាសនា.
ខ អេសាយ ១១:១១;
១ នីហ្វៃ ២២:៤;
២ នីហ្វៃ ១០:៨, ២០.
គ ស.ប. ពួកសាសន៍ដទៃ.
ឃ ស.ប. ពួកសាសន៍យូដា.
៩ ក អេសាយ ៥៤:២.
ស.ប. ចំរឹង, ស្តេក.
ខ ស.ប. ស៊ីយ៉ូន.
១០ ក ម៉ាថាយ ២៥:៦;
គ. និង ស. ៣៣:១៧–១៨;
៤៥:៥៤–៥៩.
ស.ប. ប្តីថ្មោងថ្មី.
ខ គ. និង ស. ១:១២–១៤.
១១ ក ម៉ាកុស ១៣:៣២–៣៧;
យ.ស. — ម៉ាថាយ ១:៤៦, ៤៨.
ខ គ. និង ស. ៤៩:៧.
១២ ក គ. និង ស. ៣៨:៣១, ៤២.
ខ ស.ប. ស៊ីយ៉ូន.
១៣ ក ស.ប. យូដា.
ខ ស.ប. ក្រុងយេរូសាឡិម.
គ អេសាយ ២:១–៣;
អេសេ. ៣៨:៨.
ឃ ទំនុក. ១២២:១–៩.
១៥ ក អេសាយ ៥២:១០–១២;
គ. និង ស. ៥៨:៥៦.
ខ លោកុ. ១៩:១៧, ២៦;
លូកា ៩:៦២.
១៦ ក គ. និង ស. ១:១–៦.
ខ ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
១៧ ក គ. និង ស. ១៣:១;
២៧:៧–៨; ៨៨:៩២.
ខ អេសាយ ៤០:៣–៥.
គ ម៉ាឡាគី ៣:១.
១៨ ក វិវរ. ១៤:១.
ស.ប. កូនចៀមនៃព្រះ.
ខ គ. និង ស. ៨៤:២.
គ វិវរ. ៧:១–៤.

១៩ ហេតុដូច្នោះហើយ ចូររៀបចំសំរាប់ការយាងមកនៃ
ប្ដីថ្មោងថ្មីចុះ; ចូរទៅ ចូរចេញទៅទទួលលោកចុះ ។
២០ ត្បិតមើលចុះ ទ្រង់នឹងឈរនៅលើភ្នំដើមអូលីវ
និងនៅលើមហាសាគរដ៏ខ្លាំងក្លា គឺជាទីជំរៅដ៏ធំ និងនៅលើកោះ
ទាំងឡាយក្នុង សមុទ្រ និងនៅលើដែនដីស៊ីយ៉ូន ។
២១ ហើយទ្រង់នឹងបន្លឺសម្លេងទ្រង់ចេញពីក្រុងស៊ីយ៉ូន ហើយ
ទ្រង់នឹងមានព្រះបន្ទូលពីក្រុងយេរូសាឡិម ហើយសម្លេងទ្រង់នឹង
បានឮក្នុង ចំណោមប្រជាជនទាំងអស់;
២២ ហើយសម្លេងនោះនឹងទៅដូចជាសូរទឹកច្រើន ហើយដូច
ផ្គរលាន់យ៉ាងខ្លាំង ដែលនឹងកំទេចភ្នំទាំងឡាយ ហើយច្រកភ្នំ
ទាំងឡាយ នឹងគ្មានឃើញឡើយ ។
២៣ ទ្រង់នឹងបញ្ជាដល់ទីជំរៅដ៏ធំ ហើយទីជំរៅនោះនឹងត្រូវ
បានបង្ហូរទៅឯស្រុកទាំងឡាយដែលនៅទិសខាងជើង ហើយ
កោះទាំង ឡាយនឹងក្លាយទៅជាដែនដីតែមួយ;
២៤ ហើយដែនដីយេរូសាឡិម និងដែនដីស៊ីយ៉ូន នឹង
ត្រឡប់ទៅកន្លែងវាវិញ ហើយផែនដីនឹងបានដូចកាលពីដើម
មុនផែនដីត្រូវបាន បែកចេញពីគ្នា ។
២៥ ហើយព្រះអម្ចាស់ គឺជាព្រះអង្គសង្គ្រោះ ទ្រង់នឹង
ឈរនៅកណ្ដាលរាស្ត្រទ្រង់ ហើយនឹងសោយរាជ្យលើ
សាច់ឈាមទាំងអស់ ។
២៦ ហើយពួកអ្នកដែលនៅស្រុកទាំងឡាយនៅទិសខាងជើង
នឹងត្រូវបាននឹកចាំនៅចំពោះព្រះអម្ចាស់; ហើយពួកព្យាការីរបស់
ពួកគេ នឹងបានឮសម្លេងរបស់ទ្រង់ ហើយនឹងមិនទប់ខ្លួនទៀតឡើយ;
ហើយពួកគេនឹងវាយថ្មដាទាំងឡាយ ហើយទឹកកកនឹងហូរចុះមក
នៅ ចំពោះវត្តមានរបស់ពួកអ្នកនោះ ។
២៧ ហើយថ្នល់ខ្ពស់មួយនឹងត្រូវបានបោះឡើង នៅកណ្ដាល
ទីជំរៅដ៏ធំ,
២៨ ពួកខ្មាំងសត្រូវរបស់ពួកគេនឹងក្លាយទៅជារបឹបចំពោះខ្លួន ។
២៩ ហើយនៅទីរហោស្ថានដ៏ឥតជីជាតិនឹងផុសឡើងជា
ត្រពាំងទឹករស់ ហើយខ្សាច់ដែលក្ដៅព្រាចៗនឹងពុំនៅជាដី
ហួតហែងទៀត ឡើយ ។
៣០ ហើយពួកគេនឹងផលិតចេញមក នូវទ្រព្យសម្បត្តិរបស់ពួក
គេ ជូនកូនចៅនៃអេប្រាអិម ជាពួកអ្នកបំរើរបស់យើង ។
៣១ ហើយព្រំដែនទាំងឡាយនៃភ្នំដ៏នៅអស់កល្បអស់កាល
ជានិច្ចនឹងញ័ររន្ធត់ នៅចំពោះវត្តមានរបស់ពួកគេ ។
៣២ ហើយនៅទីនោះ ពួកគេនឹងដួលចុះ ហើយនឹងត្រូវបាន
បំពាក់ដោយសិរីល្អជាមកុដ គឺនៅក្រុងស៊ីយ៉ូន ដោយដៃនៃពួក
អ្នកបំរើ របស់ព្រះអម្ចាស់ គឺជាកូនចៅនៃអេប្រាអិម ។
៣៣ ហើយពួកគេនឹងបានពោរពេញទៅដោយចំរៀងទាំងឡាយ
នៃសេចក្ដីអំណរដ៏នៅអស់កល្បអស់កាលជានិច្ច ។
៣៤ មើលចុះ នេះគឺជាព្រះពរនៃព្រះដ៏គង់នៅអស់កល្ប
អស់កាលជានិច្ច មកលើពួកពូជអំបូរអ៊ីស្រាអែល និងព្រះពរ
ដ៏ធំជាង មកលើ ក្បាលអេប្រាអិម និងពួកអ្នកដែលដើរជាមួយ
លោក ។
៣៥ ហើយពួកគេក៏មកពីពូជអំបូរយូដាដែរ គឺបន្ទាប់ពីការឈឺ
ចាប់របស់ពួកគេ នោះនឹងត្រូវបានញែកចេញជាបរិសុទ្ធ

១៩ *ក* ម៉ាថាយ ២៥:១–១៣;
គ. និង ស. ៣៣:១៧–១៨;
៨៨:៩២.
ស.ប. ការយាងមកលើកទីពីរនៃ
ព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. ប្ដីថ្មោងថ្មី.
២០ *ក* សាការី ១៤:៤;
គ. និង ស. ៤៥:៤៨–៥៣.
២១ *ក* យ៉ូអែល ៣:១៦; អេម៉ុស ១:២.
*ខ* អេសាយ ២:២–៤.
២២ *ក* អេសេ. ៤៣:២; វិវរ. ១:១៥;
គ. និង ស. ១១០:៣.
*ខ* ទំនុក. ៧៧:១៨; វិវរ. ១៤:២.
*គ* ពួកចៅ. ៥:៥; អេសាយ ៤០:៤;
៦៤:១; វិវរ. ១៦:២០;
គ. និង ស. ៤៩:២៣; ១០៩:៧៤.
២៣ *ក* វិវរ. ៦:១៤.
២៤ *ក* ស.ប. ក្រុងយេរូសាឡិម.
*ខ* លោកុ. ១០:២៥.
ស.ប. ផែនដី —
ការបំបែកផែនដី.
២៥ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ —
រជ្ជកាលនៃព្រះ
គ្រីស្ទនៅសហស្សវត្សរ៍.
២៦ *ក* យេរេ. ១៦:១៤–១៥;
គ. និង ស. ១១០:១១.
ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែលទាំង១០អំបូរ
ដែលបាត់.
២៧ *ក* អេសាយ ១១:១៥–១៦;
២ នីហ្វៃ ២១:១៦.
២៩ *ក* អេសាយ ៣៥:៦–៧.
៣០ *ក* សាការី ១០:៧–១២.
ស.ប. អេប្រាអិម —
ពូជអំបូររបស់អេប្រាអិម.
៣១ *ក* លោកុ. ៤៩:២៦.
៣៣ *ក* អេសាយ ៣៥:១០; ៥១:១១;
គ. និង ស. ៦៦:១១.
៣៤ *ក* ស.ប. អ៊ីស្រាអែល —
ពូជអ៊ីស្រាអែលទាំង១២អំបូរ.
*ខ* លោកុ. ៤៨:១៤–២០;
១ របា. ៥:១–២;
អេធើរ ១៣:៧–១០.
៣៥ *ក* ស.ប. យូដា —
ពូជអំបូររបស់យូដា.

ក្នុង[ខ]ភាពបរិសុទ្ធ នៅចំពោះព្រះអម្ចាស់ ដើម្បីឲ្យរស់នៅ
ក្នុងវត្តមានរបស់ទ្រង់ ទាំងថ្ងៃទាំងយប់ ជារៀងដរាប
តទៅ ។
៣៦ ហើយឥឡូវនេះ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលជាប្រាកដ
ថា ការណ៍ទាំងនេះអាចបានដឹងនៅក្នុងចំណោមអ្នករាល់គ្នា
ឱបណ្ដាជន នៅលើផែនដីអើយ យើងបានចាត់ឲ្យ[ក]ទេវតារបស់យើង
ហោះកាត់កណ្ដាលមេឃ ទាំងមាន[ខ]ដំណឹងល្អដ៏នៅអស់កល្ប
អស់កាលជានិច្ច ដែលបានលេចមកឲ្យមនុស្សខ្លះឃើញ ហើយ
បានថ្លែងប្រាប់ដល់មនុស្ស ដែលនឹងលេចមកឯមនុស្សជាច្រើន
ដែលរស់នៅលើផែនដី ។
៣៧ ហើយ[ក]ដំណឹងល្អនេះនឹងត្រូវបាន[ខ]ផ្សាយដល់[គ]គ្រប់អស់
ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ប្រជាជន ។
៣៨ ហើយពួកអ្នកបំរើនៃព្រះនឹងចេញទៅ ដោយបន្លឺសម្លេង
យ៉ាងខ្លាំងថា៖ ចូរកោតខ្លាចដល់ព្រះ ហើយសរសើរសិរីល្អ
របស់ទ្រង់ចុះ ត្បិតម៉ោងដែលទ្រង់ត្រូវជំនុំជំរះ នោះបានមក
ដល់ហើយ;
៣៩ ហើយចូរ[ក]ក្រាបថ្វាយបង្គំដល់ព្រះដ៏បង្កើតផ្ទៃមេឃ និង
ផែនដី និងសមុទ្រ និងរន្ធទឹកទាំងប៉ុន្មាន —
៤០ ដោយអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ ទាំងថ្ងៃ
ទាំងយប់ ដោយទូលថា៖ ឱបើសិនជាទ្រង់នឹង[ក]វែកផ្ទៃមេឃ ហើយ
យាងចុះមក ទៅអេះ ដើម្បីឲ្យភ្នំទាំងប៉ុន្មាន បានញាប់ញ័រនៅ
ចំពោះទ្រង់ ។
៤១ ហើយនោះនឹងត្រូវបានឆ្លើយមកលើក្បាលពួកគេ;
ព្រោះវត្តមាននៃព្រះអម្ចាស់នឹងបានទៅដូចជាភ្លើងរាលឆេះគំនរ
ស្នាប់ ហើយដូចជាភ្លើងធ្វើឲ្យ[ក]ពុះខ្ទោលឡើង ។
៤២ ឱព្រះអម្ចាស់អើយ ព្រះអង្គទ្រង់នឹងយាងចុះមក
ដើម្បីធ្វើឲ្យពួកខ្មាំងសត្រូវទ្រង់បានស្គាល់ព្រះនាមទ្រង់ ហើយឲ្យ
សាសន៍ទាំងប៉ុន្មាន បានញាប់ញ័រនៅចំពោះទ្រង់ —
៤៣ នៅគ្រាដែលទ្រង់បានធ្វើការគួរស្ញែងខ្លាច ដែលពួកគេពុំ
បានម៉ែចិត្តសោះ;
៤៤ មែនហើយ កាលទ្រង់យាងចុះមក ហើយភ្នំទាំងប៉ុន្មាន
បានកក្រើកញ័រនៅចំពោះទ្រង់ គឺទ្រង់តែងតែ[ក]ប្រោសដល់អ្នកណា
ដែលមាន ចិត្តរីករាយ ហើយប្រព្រឹត្តដោយសុចរិត គឺដល់ពួក
អ្នកដែលនឹកចាំពីទ្រង់ ក្នុងអស់ទាំងផ្លូវរបស់ទ្រង់ ។
៤៥ ត្បិតចាប់តាំងពីកំណើតលោកិយមក មនុស្សលោកមិន
ដែលឮ ក៏មិនដែលដឹងដោយសារត្រចៀក ហើយភ្នែកមិនដែល
ឃើញព្រះ ឯណា ឱព្រះអង្គអើយ ក្រៅពីទ្រង់ នូវការណ៍ដ៏ធំ
ដែល[ក]ទ្រង់បានរៀបចំសំរាប់អ្នកដែល[ខ]សង្ឃឹមដល់ទ្រង់ឡើយ ។
៤៦ ហើយនឹងបានពោលថា៖ តើ[ក]អ្នកណាហ្ន៎ ដែល[ខ]ចុះមក
ពីព្រះដែលគង់នៅលើស្ថានសួគ៌ ស្លៀកពាក់ដោយសំពត់ពណ៌;
មែនហើយ គឺមកពីតំបន់ទាំងឡាយដែលពុំដែលស្គាល់គឺ
ស្លៀកពាក់ដោយរុងរឿង ហើយក៏ដើរដោយឫទ្ធិយ៉ាងខ្លាំង
របស់គេនោះ ?
៤៧ ហើយទ្រង់នឹងមានព្រះបន្ទូលថា៖ យើងនេះហើយជាអ្នក
ដែលមានព្រះបន្ទូលដោយសេចក្ដីសុចរិត ជាអ្នកពូកែនឹងសង្គ្រោះ ។
៤៨ ហើយព្រះអម្ចាស់ទ្រង់នឹង[ក]ពាក់ព្រះពស្ត្រពណ៌ក្រហម
ហើយព្រះភូសាដ៏ដូចជាអ្នកដែលជាន់ក្នុងផុងទំពាំងបាយជូរ ។
៤៩ ហើយសិរីល្អនៃវត្តមានរបស់ទ្រង់នឹងទៅជាធំអស្ចារ្យ
ដែល[ក]ព្រះអាទិត្យនឹងលាក់ភក្ត្រដោយក្ដីខ្មាស់ ហើយព្រះច័ន្ទនឹង
មិនព្រមឲ្យ ពន្លឺទេ ហើយតារាទាំងឡាយនឹងត្រូវគ្រវាត់ចេញពីកន្លែង
របស់ខ្លួន ។
៥០ ហើយសម្លេងទ្រង់នឹងបានឮថា៖ យើងបាន[ក]ជាន់ក្នុងផុង
ទំពាំងបាយជូរតែម្នាក់ឯង ហើយបាននាំសេចក្ដីជំនុំជំរះមកលើ
ប្រជាជន ទាំងអស់; ហើយឥតមានអ្នកណានៅជាមួយនឹង
យើងឡើយ;
៥១ ហើយយើងបានឈ្លីគេដោយសេចក្ដីឃោរឃៅរបស់យើង

៣៥ ខ ស.ប. បរិសុទ្ធភាព.
៣៦ ក វិវរ. ១៤:៦–៧; គ. និង ស. ២០:៥–១២.
ខ ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៣៧ ក ស.ប. ដំណឹងល្អ.
ខ ស.ប. កិច្ចការផ្សាយសាសនា; ផ្សាយ.
គ គ. និង ស. ៤២:៥៨.
៣៩ ក ស.ប. ថ្វាយបង្គំ.
៤០ ក អេសាយ ៦៤:១–២.
៤១ ក យ៉ូប ៤១:៣១.
៤៤ ក ១ ថែស្សា. ៤:១៥–១៨.
៤៥ ក អេសាយ ៦៤:៤; ១ កូរិន. ២:៩.
ខ បរិទេវ ៣:២៥; ២ នីហ្វៃ ៦:៧, ១៣.
៤៦ ក អេសាយ ៦៣:១–២.
ខ ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៤៨ ក លោកុ. ៤៩:១១–១២; លូកា ២២:៤៤; វិវរ. ១៩:១១–១៥; គ.យ.ស., វិវរ. ១៩:១៥; ម៉ូសាយ ៣:៧; គ. និង ស. ១៩:១៨.
៤៩ ក អេសាយ ១៣:១០; ២៤:២៣; គ. និង ស. ៤៥:៤២; ៨៨:៨៧.
៥០ ក អេសាយ ៦៣:២–៣; គ. និង ស. ៧៦:១០៧; ៨៨:១០៦.

ហើយបានជាន់គេដោយសេចក្ដីកំហឹងរបស់យើង ហើយឈាមគេ
នោះយើងបានសំរក់មកលើសំលៀកបំពាក់របស់យើង ហើយធ្វើឲ្យ
ប្រឡាក់សំលៀកបំពាក់របស់យើងអស់ហើយ ត្បិតនេះគឺជាថ្ងៃ
សង សឹក ដែលនៅក្នុងចិត្តយើង ។
៥២ ហើយឥឡូវនេះ ឆ្នាំកំណត់នៃពួកប្រោសលោះរបស់យើង
ក៏បានមកដល់; ហើយពួកគេនឹងថ្លែងប្រាប់ពីសេចក្ដីសប្បុរសរបស់
ព្រះអម្ចាស់របស់គេ និងគ្រប់ទាំងអស់ដែលទ្រង់បានប្រោសមក
លើពួកគេ តាមសេចក្ដីសប្បុរសរបស់ទ្រង់ និងតាមសេច
ក្ដីសប្បុរស ដ៏បរិបូររបស់ទ្រង់ ជារៀងដរាបតទៅ ។
៥៣ ក្នុងគ្រប់ទាំងសេចក្ដីទុក្ខវេទនារបស់គេ នោះទ្រង់ក៏រង
ទុក្ខដែរ ។ ហើយទេវតាដែលនៅចំពោះទ្រង់បានសង្គ្រោះគេ;
ហើយដោយ សេចក្ដីស្រឡាញ់របស់ទ្រង់ និងដោយសេច
ក្ដីមេត្តាករុណារបស់ទ្រង់ នោះទ្រង់បានប្រោសលោះគេ ហើយ
កាលពីចាស់បុរាណ ទ្រង់បានលើកគេបីទៅជាដរាប;
៥៤ មែនហើយ ព្រមទាំងលោកហេណុក និងពួកអ្នកដែល
នៅជាមួយនឹងលោកផង; ពួកព្យាការីដែលនៅមុនលោក; ហើយ
ព្រមទាំង លោកណូអេ និងពួកអ្នកដែលនៅមុនលោកដែរ;
ហើយព្រមទាំងលោកម៉ូសេ និងពួកអ្នកដែលនៅមុនលោកដែរ;
៥៥ ហើយពីលោកម៉ូសេ ទៅលោកអេលីយ៉ា ហើយ
ពីលោកអេលីយ៉ា ទៅលោកយ៉ូហាន ដែលបាននៅជាមួយនឹង
ព្រះគ្រីស្ទ កាលទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយព្រមទាំងពួក
សាវកបរិសុទ្ធ ជាមួយនឹងលោកអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប
គេនឹងបាននៅក្នុង វត្តមាននៃកូនចៀម ។
៥៦ ហើយផ្នូរនៃពួកបរិសុទ្ធនឹងត្រូវបានបើក; ហើយពួកគេ
នឹងចេញមក ហើយឈរនៅខាងស្ដាំដៃនៃកូនចៀម ក្នុងកាល
ទ្រង់ឈរនៅ លើភ្នំស៊ីយ៉ូន និងនៅលើទីក្រុងបរិសុទ្ធ គឺក្រុងយេរូ
សាឡិមថ្មី; ហើយពួកគេនឹងច្រៀងទំនុករបស់កូនចៀម ទាំងថ្ងៃ
ទាំងយប់ ជារៀងដរាបតទៅ ។
៥៧ ហើយដោយហេតុនេះ ទើបមនុស្សអាចបានធ្វើទៅជាពួក
អ្នកមានចំណែកក្នុងសិរីល្អទាំងឡាយ ដែលនឹងត្រូវបានបើកសំដែង
នោះព្រះអម្ចាស់ទ្រង់បានចាត់ភាពពោរពេញនៃដំណឹងល្អរបស់
ទ្រង់ គឺជាសេចក្ដីសញ្ញាដ៏នៅអស់កល្បអស់កាលជានិច្ចរបស់
ទ្រង់ ដោយ ពិភាក្សាយ៉ាងច្បាស់លាស់ និងក្បោះក្បាយ —
៥៨ ដើម្បីឲ្យរៀបចំពួកកំសោយ ឲ្យទន្ទឹងចាំការណ៍ទាំងនោះ
ដែលត្រូវមកលើផែនដី ហើយទន្ទឹងចាំការងាររបស់ព្រះអម្ចាស់
ក្នុង ថ្ងៃកាលពួកកំសោយនឹងបំភាន់ពួកអ្នកប្រាជ្ញ ហើយពួកតូចនឹង
ត្រឡប់ជាសាសន៍មួយយ៉ាងពូកែ ហើយពីរនាក់នឹងធ្វើឲ្យរាប់
ម៉ឺននាក់រត់ ។
៥៩ ហើយតាមរយៈពួកកំសោយនៅលើផែនដី នោះព្រះ
អម្ចាស់ទ្រង់នឹងបញ្ចាន់សាសន៍ទាំងឡាយ ដោយសារព្រះចេស្ដា
នៃ ព្រះវិញ្ញាណរបស់ទ្រង់ ។
៦០ ហើយដោយសារហេតុនេះ ទើបព្រះបញ្ញត្តិទាំងនេះ
ត្រូវបានប្រទានមក; ការណ៍ទាំងនេះត្រូវបានបញ្ជាឲ្យទុក កុំឲ្យ
ពិភពលោកដឹង អំពីថ្ងៃដែលការណ៍ទាំងនោះនឹងត្រូវបានប្រទាន
មក ប៉ុន្តែឥឡូវនេះ ត្រូវចេញទៅដល់សាច់ឈាមទាំងអស់ —
៦១ ហើយនេះគឺស្របតាមគំនិត និងព្រះហឫទ័យនៃព្រះអម្ចាស់
ដែលត្រួតត្រាលើសាច់ឈាមទាំងអស់ ។
៦២ ហើយចំពោះអ្នកណាដែលប្រែចិត្ត ហើយញែក
ខ្លួនចេញជាបរិសុទ្ធនៅចំពោះព្រះអម្ចាស់ នោះនឹងត្រូវបាន
ប្រទានឲ្យមាន ជីវិតដ៏នៅអស់កល្បជានិច្ច ។

៥១ *ក* លេវី. ៨:៣០.
៥៣ *ក* អេសាយ ៦៣:៨–៩.
*ខ* ស.ប. សេចក្ដីសប្បុរស.
*គ* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
៥៤ *ក* ស.ប. ហេណុក.
*ខ* ស.ប. ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប.
*គ* ស.ប. ម៉ូសេ.
៥៥ *ក* ស.ប. ដំណើររស់ឡើងវិញ.
៥៦ *ក* គ. និង ស. ២៩:១៣.
*ខ* ស.ប. ជនបរិសុទ្ធ.
*គ* គ. និង ស. ៤៥:៤៥–៤៦; ៨៨:៩៦–៩៧.
*ឃ* ម៉ាថាយ ២៥:៣៣–៣៤.
*ង* អេសាយ ២៤:២៣; វិវ. ១៤:១; គ. និង ស. ៧៦:៦៦; ៨៤:២, ៩៨–១០២.
*ច* ស.ប. ក្រុងយេរូសាឡិមថ្មី.
*ឆ* វិវ. ១៥:៣; គ. និង ស. ៨៤:៩៨–១០២.
*ជ* ស.ប. កូនចៀមនៃព្រះ.
៥៧ *ក* ស.ប. លំដាប់នៃសិរីល្អ.
*ខ* ស.ប. ដំណឹងល្អ.
៥៨ *ក* ម៉ាថាយ ១១:២៥; ១ កូរិន. ១:២៧; អាលម៉ា ៣២:២៣; ៣៧:៦–៧.
*ខ* អេសាយ ៦០:២២.
៥៨ *គ* ចោទិ. ៣២:២៩–៣០.
៥៩ *ក* មីកា ៤:១១–១៣.
៦០ *ក* គ. និង ស. ១០៤:៥៨–៥៩.
*ខ* គ. និង ស. ១:២.
៦២ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* គ. និង ស. ៨៨:៧៤. ស.ប. ការញែកជាបរិសុទ្ធ.
*គ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.

៦៣ ហើយចំពោះអស់អ្នកណាដែលមិន[ក]ព្រមស្ដាប់តាមសម្លេងនៃព្រះអម្ចាស់ នោះនឹងត្រូវបានពោរពេញទៅដោយអ្វី ដែលបានសរសេរ ទុកដោយព្យាការីម៉ូសេ គឺថាពួកគេនឹង[ខ]ត្រូវកាត់ចេញពីចំណោមប្រជាជន ។

៦៤ ហើយព្រមទាំងអ្វីដែលបានសរសេរទុក ដោយព្យាការី[ក]ម៉ាឡាគីថា៖ ត្បិតមើល ថ្ងៃនោះកំពុងតែមកដល់ [ខ]ថ្ងៃនោះ[គ]ឆេះឆ្លោ ដូចជា គុកភ្លើង នោះអស់ពួកអ្នកឆ្មើងឆ្មៃ ហើយនិងអស់ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាជញ្ជ្រាំង ហើយថ្ងៃដែលត្រូវមកដល់នោះ នឹងឆេះបន្សុសគេទាំងអស់ទៅ ឥតទុកឲ្យគេមានឫស ឬមែកនៅសល់ឡើយ នេះហើយ ជាព្រះបន្ទូលរបស់ព្រះអម្ចាស់ នៃពួកពល បរិវារ ។

៦៥ ហេតុដូច្នោះហើយ នេះគឺនឹងត្រូវទៅជាចម្លើយពីព្រះអម្ចាស់ ដល់ពួកគេថា៖

៦៦ នៅថ្ងៃនោះ កាលយើងបានយាងមករករាស្ត្ររបស់យើង នោះគ្មានមនុស្សណាមួយក្នុងចំណោមអ្នក[ក]បានទទួលយើងឡើយ ហើយអ្នកត្រូវបានដេញចេញ ។

៦៧ កាលយើងបានហៅជាថ្មីទៀត នោះគ្មានអ្នកណាឆ្លើយតបឡើយ; ទោះជាយ៉ាងណាក៏ដោយ គង់តែ[ក]ព្រះពាហុរបស់យើងពុំបាន រួញខ្លីនឹងជួយលោះ [ខ]ឬព្រះចេស្ដាយើងនឹងដោះឲ្យរួចដែរ ។

៦៨ មើលចុះ កាលណាយើងស្ដីឲ្យ នោះសមុទ្រក៏រីង[ក]ស្ងួតទៅ ។ យើងធ្វើឲ្យទន្លេទៅជាទីហួតហែង; ឯត្រីធុំស្អុយ ហើយស្លាប់ទៅ ដោយស្រេក ។

៦៩ យើងបំពាក់ផ្ទៃមេឃដោយពពកខ្មៅ ហើយក៏ដណ្ដប់ទៅដោយសំពត់ធ្មៃផង ។

៧០ ហើយអ្នកនឹងបានតែ[ក]ប៉ុណ្ណោះពីព្រះហស្តយើង — អ្នករាល់គ្នានឹងត្រូវដេកទៅដោយទុក្ខវេទនា ។

៧១ មើលចុះ និងមើលន៏ គ្មានអ្នកណានឹងជួយដោះអ្នកឡើយ; ត្បិតអ្នករាល់គ្នាពុំបានគោរពតាមសម្លេងរបស់យើងសោះ កាលយើង បានហៅអ្នកពីលើមេឃ; អ្នករាល់គ្នាពុំបានជឿដល់ពួកអ្នកបំរើរបស់យើងឡើយ ហើយកាលពួកគេត្រូវបាន[ក]ចាត់ឲ្យមករកអ្នក នោះអ្នក រាល់គ្នាពុំបានទទួលពួកគេសោះ ។

៧២ ហេតុដូច្នោះហើយ ពួកគេបាន[ក]ភ្ជាប់ទីបន្ទាល់ ហើយបានចងក្រិត្យវិន័យ ហើយអ្នករាល់គ្នាត្រូវបានប្រគល់ទៅឯសេចក្ដីងងឹត ។

៧៣ ពួកអ្នកទាំងនេះនឹងចេញទៅក្នុងសេចក្ដីងងឹតខាងក្រៅ នៅទីនោះនឹងមាន[ក]យំ និងទួញសោក ហើយសង្កៀតធ្មេញ ។

៧៤ មើលចុះ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ទ្រង់បានមានព្រះបន្ទូលហើយ ។ អាម៉ែន ៕

កណ្ឌទី ១៣៤

*សេចក្ដីថ្លែងប្រាប់អំពីជំនឿ អំពីការត្រួតត្រា និងក្រិត្យវិន័យទូទៅ ត្រូវបានទទួលស្គាល់ ដោយការចេញសម្លេងជាឯកច្ឆន្ទ នៅឯសន្និបាត ទូទៅនៃសាសនាចក្រ ដែលបានធ្វើឡើង នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៨៣៥ (*History of the Church, *២:២៤៧–២៤៩)* ។ *គ្រានោះជាការប្រជុំនៃពួកមេដឹកនាំក្នុងសាសនាចក្រ ដែលបានជួបជុំដើម្បីពិចារណាអំពីការណ៍ទាំងឡាយដែល បានស្នើឲ្យមាននៅក្នុងច្បាប់ទីមួយ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ នៅពេលនោះ សេចក្ដីប្រកាសត្រូវបានផ្ដល់នូវបុព្វកថា ដូចត ទៅនេះ៖ «ដើម្បីកុំឲ្យជំនឿរបស់យើងដែលទាក់ទងទៅនឹង*

៦៣ *ក* ស.ប. ប្រុងស្ដាប់.
*ខ* កិច្ចការ ៣:២២–២៣;
១ នីហ្វៃ ២២:២០–២១;
៣ នីហ្វៃ ២០:២៣; ២១:១១;
គ. និង ស. ១:១៤;
យ.ស. — ប្រវត្តិ ១:៤០.
៦៤ *ក* ម៉ាឡាគី ៤:១.
ស.ប. ម៉ាឡាគី.
*ខ* យ.ស. — ប្រវត្តិ ១:៣៦–៣៧.
*គ* អេសាយ ៦៦:១៥–១៦;
១ នីហ្វៃ ២២:១៥;
៣ នីហ្វៃ ២៥:១;
គ. និង ស. ២៩:៩; ៦៤:២៤.
ស.ប. ផែនដី — ការសំអាតផែនដី.
៦៦ *ក* យ៉ូហាន ១:១១.
៦៧ *ក* ២ នីហ្វៃ ២៨:៣២.
*ខ* អេសាយ ៥០:២; ២ នីហ្វៃ ៧:២.
៦៨ *ក* និក្ខ. ១៤:២១;
យ៉ូស្វេ ៣:១៤–១៧.
៧០ *ក* អេសាយ ៥០:១១.
៧១ *ក* ២ របា. ៣៦:១៥–១៦;
យេរេ. ៤៤:៤–៥.
៧២ *ក* អេសាយ ៨:១៦–២០.
៧៣ *ក* ម៉ាថាយ ៨:១១–១២;
លូកា ១៣:២៨;
គ. និង ស. ១៩:៥.
ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ; ស្ថាននរក.

*រដ្ឋាភិបាលទាំងឡាយនៅលើផែនដី និងក្រិត្យវិន័យទូទៅ អាចបានបក ស្រាយខុស ឬយល់ខុស នោះយើងបានគិតថាសមនឹងសំដែងប្រាប់ពីយោបល់របស់យើងអំពីការណ៍នោះ នៅចុងគម្ពីរនេះ» (*History of the Church, *២:២៤៧)* ។

*១–៤, រដ្ឋាភិបាលទាំងឡាយគប្បីរក្សានូវសេរីភាពខាងសតិសម្បជញ្ញៈ និងខាងការថ្វាយបង្គំ; ៥–៨, មនុស្សទាំងអស់គប្បីគាំទ្ររដ្ឋាភិបាល របស់ខ្លួន ហើយមានការគោរព និងការព្រមធ្វើតាមក្រិត្យវិន័យ; ៩–១០, សមាគមទាំងឡាយខាងសាសនាមិនគួរអនុវត្តអំណាចខាង ស៊ីវិលទេ; ១១–១២, មនុស្សលោកត្រូវបានរាប់ថាសុចរិត ក្នុងសេចក្ដីការពារខ្លួន និងទ្រព្យសម្បត្តិរបស់ខ្លួន ។*

យើងខ្ញុំជឿថា [ក]រដ្ឋាភិបាលទាំងឡាយត្រូវបានបង្កើតឡើងពីព្រះ សំរាប់ផលប្រយោជន៍ដល់មនុស្ស; ហើយថាទ្រង់ធ្វើឲ្យមនុស្ស [ខ]ទទួលការ ខុសត្រូវ ចំពោះកិច្ចការទាំងឡាយរបស់ខ្លួន ដែលទាក់ទងទៅនឹងរដ្ឋាភិបាលនោះ ទាំងការចែងច្បាប់ទាំងឡាយ និងការអនុវត្តច្បាប់ ទាំងនោះផង សំរាប់ការល្អ និងសន្តិសុខដល់សង្គម ។

២ យើងខ្ញុំជឿថា គ្មានរដ្ឋាភិបាលណាអាចនៅក្នុងសេចក្ដីសុខសាន្តបានឡើយ លើកលែងតែច្បាប់ទាំងឡាយត្រូវបានបង្កើតឡើង ហើយទ្រទ្រង់ដែលនឹងធានាដល់បុគ្គលនិមួយៗ នូវ[ក]សេរីភាពខាង[ខ]សតិសម្បជញ្ញៈខាងសិទ្ធិ និងការកាន់កាប់ទ្រព្យសម្បត្តិ និងខាង ការការពារជីវិត ។

៣ យើងខ្ញុំជឿថា រដ្ឋាភិបាលទាំងអស់ចាំបាច់តម្រូវ[ក]ពួកអ្នកកាន់តំណែងរាជការ និងពួកចៅក្រម ដើម្បីអនុវត្តច្បាប់នៃរដ្ឋាភិបាលនោះ; ហើយអ្នកទាំងនោះដែលនឹងចាត់ចែងច្បាប់ដោយត្រឹមត្រូវ និងយុត្តិធម៌ នោះគួរឲ្យស្វែងរក ហើយទ្រទ្រង់ដោយសម្លេងនៃប្រជាជន បើនៅក្នុងសាធារណៈរដ្ឋ ឬដោយព្រះហឫទ័យនៃមហាក្សត្រ ។

៤ យើងខ្ញុំជឿថា សាសនាត្រូវបានបង្កើតឡើងពីព្រះ; ហើយថាមនុស្សលោកត្រូវទទួលខុសត្រូវចំពោះទ្រង់ ហើយចំពោះព្រះអង្គតែមួយ ប៉ុណ្ណោះ ដើម្បីឲ្យអនុវត្តខាងសាសនា លើកលែងតែគំនិតខាងសាសនារបស់ពួកគេ បណ្ដាលឲ្យពួកគេរំលោភទៅលើសិទ្ធិ និងសេរី ភាពទាំងឡាយនៃមនុស្សផ្សេងៗផង; ប៉ុន្តែយើងខ្ញុំមិនជឿឡើយថា ច្បាប់របស់មនុស្សមានសិទ្ធិនឹងជ្រៀតជ្រែក ក្នុងការដាក់ច្បាប់ ខាងការថ្វាយបង្គំ ដើម្បីដាក់កំរិតដល់សតិសម្បជញ្ញៈមនុស្ស ឬដាក់បញ្ជានូវរបៀបការថ្វាយភក្តីភាពសាធារណៈ ឬដោយឡែក; គឺថាចៅក្រមខាងរដ្ឋការគប្បីបង្ខបង្ខាំងកុំឲ្យមានទោសឧក្រិដ្ឋ ប៉ុន្តែមិនត្រូវឲ្យត្រួតត្រាលើសម្បជញ្ញៈឡើយ; គប្បីដាក់ទោស ប៉ុន្តែមិន ត្រូវហាមប្រាមខាងសេរីភាពនៃព្រលឹងឲ្យសោះ ។

៥ យើងខ្ញុំជឿថា មនុស្សទាំងអស់មានកាតព្វកិច្ច ដើម្បីគាំទ្រ និងទ្រទ្រង់រដ្ឋាភិបាល ដែលពួកគេអាស្រ័យនៅរៀងៗខ្លួន ក្នុងពេលការ ពារសិទ្ធិកំណើត និងដ៏ឥតដកចេញបាន ដោយច្បាប់នៃរដ្ឋាភិបាលទាំងឡាយ; ហើយថាការចាក់រុក និង[ក]ការបះបោរ គឺជាការមិនគួរសម សំរាប់ឲ្យពលរដ្ឋគ្រប់រូបបានការពារឡើយ ហើយគួរដាក់ទោសតាមច្បាប់; ហើយថារដ្ឋាភិបាលទាំងអស់មានសិទ្ធិនឹងចែងច្បាប់ តាមការវិនិច្ឆ័យរបស់ខ្លួន ដែលគិតថាសមបំផុត ដើម្បីធានាប្រយោជន៍នៃពលរដ្ឋ; ប៉ុន្តែនៅពេលដដែលនោះ រាប់ថាសេរីភាព ខាងសតិសម្បជញ្ញៈគឺជាការដ៏ពិសិដ្ឋមួយ ។

៦ យើងខ្ញុំជឿថា មនុស្សគ្រប់រូបត្រូវបានកិត្តិយសក្នុងតំណែងរបស់ខ្លួន ដូចជាពួកអ្នកត្រួតត្រា និងពួកចៅក្រមជាដើម ដោយបានរើស តាំងសំរាប់ការពារអ្នកឥតទោស ហើយដាក់ទោសដល់អ្នកមានទោសវិញ; ហើយថាចំពោះ[ក]ច្បាប់ទាំងឡាយនោះ មនុស្សត្រូវគោរព ហើយព្រមធ្វើតាម ពីព្រោះបើគ្មានច្បាប់ទាំងឡាយនោះទេ នោះសេចក្ដីសុខសាន្ត និងការស្រុះស្រួលគ្នានឹងត្រូវបានជំនួសដោយ អនាធិបតេយ្យ និងការភិតភ័យជាខ្លាំង; ច្បាប់នៃមនុស្សជាតិទាំងឡាយត្រូវបានបង្កើតឡើង សំរាប់គោលបំណងដ៏ជាក់លាក់នៃការ ចាត់ចែងផលប្រយោជន៍របស់យើង ដោយឡែក និងដោយប្រទេស រវាងមនុស្សមួយនឹងមនុស្សមួយទៀត; រីឯក្រិត្យវិន័យទាំងឡាយ ខាងវិញ្ញាណ ដែលបានប្រទាន

**១៣៤** ១ *ក* គ. និង ស. ៩៨:៤–៧;
ម. នៃ ស. ១:១២.
*ខ* ស.ប. ទទួលខុសត្រូវ,
ចេះទទួលខុសត្រូវ,
ការទទួលខុសត្រូវ.
២ *ក* ស.ប. សិទ្ធិជ្រើសរើស.
*ខ* ស.ប. បញ្ញាចិត្ត.
*គ* គ. និង ស. ៤២:១៨–១៩.
៣ *ក* គ. និង ស. ៩៨:៨–១០.
៤ *ក* អាលម៉ា ២១:២១–២២;
ម. នៃ ស. ១:១១.
ស.ប. ថ្វាយបង្គំ.
៥ *ក* ម. នៃ ស. ១:១២.
ស.ប. ការបះបោរ.
៦ *ក* គ. និង ស. ៥៨:២១; ៨៨:៣៤.

មកពីស្ថានសួគ៌ ដែលតាំងច្បាប់អំពីកិច្ចការខាងវិញ្ញាណ សំរាប់សេចក្ដីជំនឿ និងការថ្វាយបង្គំ ក្រិត្យវិន័យ ទាំងពីរនោះ ត្រូវបានឆ្លើយតបដោយមនុស្ស ចំពោះព្រះដ៏បង្កើតរបស់ខ្លួន ។

៧ យើងខ្ញុំជឿថា ពួកអ្នកត្រួតត្រាប្រទេស និងរដ្ឋាភិបាលទាំងឡាយមានសិទ្ធិ ហើយមានកាតព្វកិច្ចដើម្បីបង្កើតច្បាប់ទាំងឡាយឡើង សំរាប់ការពារពលរដ្ឋទាំងអស់ ក្នុងការអនុវត្តជំនឿខាងសាសនារបស់ពួកគេ ដោយសេរី; ប៉ុន្តែតាមសេចក្ដីយុត្តិធម៌ យើងខ្ញុំមិនជឿថា ពួកគេមានសិទ្ធិនឹងដកហូតឯកសិទ្ធិនេះពីពលរដ្ឋ ឬហាមប្រាមពួកគេកុំឲ្យមានគំនិតនោះឡើយ ដរាបណាមានការគោរព និងគរុការភាព ដល់ច្បាប់ទាំងឡាយ ហើយមតិខាងសាសនា មិនរាប់ការនាំបំបះបំបោរ និងការរួមគំនិតធ្វើអំពើទុច្ចរិត ថាជាការយុត្តិធម៌ ។

៨ យើងខ្ញុំជឿថា ការប្រព្រឹត្តទោសឧក្រិដ្ឋ នោះត្រូវ*ក*ដាក់ទោសតាមទោសដែលបានប្រព្រឹត្ត; ថាអំពើឃាតកម្ម អំពើក្បត់ជាតិ អំពើលួចប្លន់ អំពើលួច និងអំពើបំបែកបំបាក់សេចក្ដីសុខសាន្តទូទៅ តាមរបៀបណាក៏ដោយ នោះត្រូវដាក់ទោស តាមទោសឧក្រិដ្ឋ របស់ខ្លួន និងតាមការទោរទន់របស់ពួកគេទៅរកអំពើអាក្រក់ ក្នុងចំណោមមនុស្ស ដោយច្បាប់ទាំងឡាយនៃរដ្ឋាភិបាលនោះ ដែលបានប្រព្រឹត្តការរំលោភ; ហើយសំរាប់សេចក្ដីសុខសាន្ត និងសេចក្ដីស្ងប់ស្ងាត់នៃប្រជាជនទូទៅ នោះមនុស្សទាំងអស់ត្រូវឈាន ជើងទៅមុខ ហើយប្រើប្រាស់សមត្ថភាពរបស់ពួកគេ ក្នុងការនាំអ្នកមានទោសទាស់នឹងច្បាប់ល្អ មកដាក់ទោស ។

៩ យើងខ្ញុំមិនជឿថាយុត្តិធម៌ ដើម្បីលាយឡំឥទ្ធិពលខាងសាសនាជាមួយនឹងការគ្រប់គ្រងខាងរដ្ឋាភិបាល ដែលធ្វើឲ្យសមាគមខាង សាសនា មួយត្រូវបានចំរើនឡើង ហើយមួយទៀតត្រូវបានហាមប្រាមចំពោះឯកសិទ្ធិខាងសាសនារបស់គេ ហើយត្រូវបដិសេធសិទ្ធិនៃ បុគ្គលនីមួយៗ នៃសមាជិករបស់គេជាពលរដ្ឋនោះឡើយ ។

១០ យើងខ្ញុំជឿថា សមាគមខាងសាសនាទាំងអស់មានសិទ្ធិដើម្បីដោះស្រាយចរិយាមិនត្រឹមត្រូវនៃសមាជិករបស់គេ តាមច្បាប់ និង បទបញ្ញាទាំងឡាយនៃសមាគមនានា; ដរាបណាការដោះស្រាយនោះប្រព្រឹត្តឡើងដោយគោរពដល់មិត្តភាព និងជំហរល្អ; ប៉ុន្តែយើងខ្ញុំមិនជឿថា សមាគមខាងសាសនាណាមួយ មានសិទ្ធិអំណាចនឹងកាត់ទោសមនុស្សទាំងឡាយ ចំពោះសិទ្ធិខាងទ្រព្យសម្បត្តិ ឬជីវិត ដើម្បីដកយកពីពួកគេ នូវទ្រព្យសម្បត្តិខាងលោកិយ ឬដើម្បីធ្វើឲ្យពួកគេមានការគ្រោះថ្នាក់ដល់ជីវិត ឬរាងកាយ ឬដើម្បីធ្វើទុក្ខ ទោសមកលើសាច់ឈាមគេឡើយ ។ ពួកគេគ្រាន់តែអាច*ក*កាត់កាលពួកគេចេញពីសាសនា ចេញពីសមាគមគេ ហើយដកគេចេញពី ការរាប់អានប៉ុណ្ណោះ ។

១១ យើងខ្ញុំជឿថា មនុស្សទាំងឡាយត្រូវតវ៉ាទៅច្បាប់ស៊ីវិលសូមឲ្យកែកំហុស និងសាទុក្ខទាំងអស់ ដែលបានប្រព្រឹត្តខុសឆ្គងមកលើខ្លួន ឬដែលបាន រំលោភមកលើសិទ្ធិខាងទ្រព្យសម្បត្តិ និងខាងចរិយា ដែលមានច្បាប់បែបនេះការពារសិទ្ធិនោះ; ប៉ុន្តែយើងខ្ញុំជឿថា មនុស្សទាំងអស់ ត្រូវបានរាប់ថាសុចរិត ក្នុងការការពារខ្លួន មិត្តភក្តិ និងទ្រព្យសម្បត្តិ និងរដ្ឋាភិបាលរបស់គេ ពីការរំលោភ និងការបំពានល្មើសច្បាប់ នៃជនទាំងអស់ នៅពេលមានគ្រោះអាសន្ន នៅពេលពុំអាចធ្វើការតវ៉ាដល់ច្បាប់ ហើយពុំអាចបានការរំដោះបាន ឆាប់ៗ ។

១២ យើងខ្ញុំជឿថា ជាការសុចរិត ដើម្បី*ក*ផ្សាយដំណឹងល្អដល់សាសន៍នានានៅលើផែនដី ហើយព្រមានពួកសុចរិតឲ្យសង្គ្រោះខ្លួនឲ្យរួច ពីការពុករលួយនៃលោកិយ ប៉ុន្តែយើងមិនជឿថា ជាការត្រឹមត្រូវ ដើម្បីជ្រៀតជ្រែកនឹងពួកទាសករ ឬផ្សាយដំណឹងល្អដល់គេ ឬធ្វើបុណ្យជ្រមុជទឹកឲ្យពួកគេ ដែលទាស់នឹងបំណង និងការប៉ងប្រាថ្នារបស់ចៅហ្វាយរបស់គេ ឬក៏រំខាន ឬមានអានុភាពលើពួកគេ តិចតួចយ៉ាងណាក៏ដោយ ដែលនឹងបណ្ដាលឲ្យពួកគេខកចិត្តចំពោះស្ថានការណ៍របស់ខ្លួនក្នុងជីវិតនេះ ទើបធ្វើឲ្យមានគ្រោះថ្នាក់ដល់ ជីវិតនៃមនុស្សទាំងឡាយ; ការជ្រៀតជ្រែកបែបនេះ យើងខ្ញុំជឿថា ជាការល្មើសច្បាប់ ហើយមិនយុត្តិធម៌ ហើយមានគ្រោះថ្នាក់ដល់ សេចក្ដីសុខសាន្តនៃគ្រប់រដ្ឋាភិបាល ដែលបណ្ដោយឲ្យមនុស្សជាតិជាប់ក្នុងទាសភាព ។

---

៨ *ក* អាលម៉ា ៣០:៧–១១; គ. និង ស. ៤២:៨៤–៨៧.

១០ *ក* ស.ប. ការកាត់ចេញពីសាសនា.

១២ *ក* ស.ប. កិច្ចការផ្សាយសាសនា; ផ្សាយ.

## កណ្ឌទី ១៣៥

*ទុក្ករកម្មនៃ យ៉ូសែប ស្ម៊ីធ ជាព្យាការី និងបងប្រុសរបស់លោក គឺ ហៃរុម ស្ម៊ីធ ជាអយ្យកោ នៅក្រុងកាតធេច រដ្ឋអិលលីណោយ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៨៤៤ (*History of the Church, *៦:៦២៩–៦៣១)* ។ *ឯកសារនេះត្រូវបានសរសេរដោយអែលឌើរ យ៉ូហាន ថេលើរ ក្នុងក្រុមប្រឹក្សានៃពួក១២នាក់ ដែលជាសាក្សីចំពោះហេតុការណ៍នោះ ។*

*១–២, យ៉ូសែប និង ហៃរុម ត្រូវគេធ្វើទុក្ករកម្មនៅគុកកាតធេច; ៣, តំណែងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្យាការីត្រូវបានប្រកាសប្រាប់; ៤–៧, លោហិតដ៏ឥតទោសរបស់គេធ្វើទីបន្ទាល់អំពីសេចក្ដីពិត និងទេវភាពនៃកិច្ចការនេះ ។*

ដើម្បីបិទទីបន្ទាល់អំពីព្រះគម្ពីរនេះ និងព្រះគម្ពីរមរមន នោះយើងខ្ញុំប្រកាសប្រាប់ពី[ក]ទុក្ករកម្មនៃ [ខ]យ៉ូសែប ស្ម៊ីធ ជាព្យាការី និង ហៃរុម ស្ម៊ីធ ជាអយ្យកោ ។ អ្នកទាំងពីរនាក់ត្រូវបានបាញ់នៅក្នុង[គ]គុកកាតធេច នៅថ្ងៃទី២៧ នៃខែមិថុនា ឆ្នាំ១៨៤៤ ប្រមាណជាម៉ោង ប្រាំរសៀល ដោយពួកហ្វូងមនុស្សកំណាចមានអាវុធ — លាបមុខខ្មៅ — ក្នុងចំនួន ១៥០ ទៅ ២០០ នាក់ ។ [ឃ]ហៃរុមត្រូវបាន បាញ់មុន ហើយដួល ទៅស្ងប់ៗ ដោយប្រកាសថា៖ *ខ្ញុំស្លាប់ហើយ !* យ៉ូសែបបានលោតពីបង្អួច ហើយត្រូវគេបាញ់ស្លាប់ ក្នុងពេលខំប្រឹងលោត ដោយប្រកាសថា៖ *ឱព្រះអម្ចាស់ដ៏ជាព្រះខ្ញុំអើយ !* គេទាំងពីរនាក់ត្រូវគេបាញ់បន្ទាប់ពីបានស្លាប់ទៅហើយ ក្នុងបែបដ៏ឃោរឃៅមួយ ហើយទាំងពីរនាក់បានទទួលបួនគ្រាប់ ។

២ [ក]យ៉ូហាន ថេលើរ និង វិលឡឺដ រិចឆឺត្ស ជាសាវ័កពីរនាក់គត់ដែលបាននៅក្នុងបន្ទប់នោះនៅពេលនោះ; អ្នកទីមួយត្រូវបានរបួសក្នុងបែបដ៏សាហាវដោយត្រូវបួនគ្រាប់ ប៉ុន្តែឥឡូវបានជាហើយ; រីឯអ្នកទីពីរ គឺតាមរយៈទិព្វញ្ញាណនៃព្រះ នោះបានរួចផុត ដោយគ្មានប្រ ហោងក្នុងអាវគាត់ឡើយ ។

៣ យ៉ូសែប ស្ម៊ីធ ជា[ក]ព្យាការី និង[ខ]អ្នកមើលឆុតនៃព្រះអម្ចាស់ បានសំរេចច្រើនជាងគេ លើកលែងតែព្រះយេស៊ូវប៉ុណ្ណោះ សំរាប់សេចក្ដី សង្គ្រោះដល់មនុស្សក្នុងលោកនេះ ជាងមនុស្សផ្សេងៗទៀត ដែលធ្លាប់រស់នៅលោកនេះ ។ នៅរយៈពេលម្ភៃឆ្នាំយ៉ាងខ្លី លោកបាន នាំមកនូវព្រះគម្ពីរមរមន ដែលលោកបានបកប្រែដោយអំណោយទាន និងអំណាចនៃព្រះ ហើយបានធ្វើជា[គ]មាគ៌ាក្នុងការបោះពុម្ពផ្សាយ គម្ពីរនោះលើទ្វីបពីរ; បានបញ្ជូលភាពពោរពេញនៃដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ច ដែលមានក្នុងគម្ពីរនោះ ដល់ទៅទិសទាំងបួន នៃផែនដី; បាននាំមកនូវវិវរណៈទាំងឡាយ និងព្រះបញ្ញត្តិទាំងឡាយ ដែលចងក្រងធ្វើព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញានេះ និងឯកសារ និងការបង្គាប់ដ៏ប្រកបដោយប្រាជ្ញាវាងវៃជាច្រើនទៀត សំរាប់ផលប្រយោជន៍ដល់កូនចៅមនុស្ស; បានប្រមូលពួកបរិសុទ្ធ នៅថ្ងៃចុងក្រោយជាច្រើនពាន់នាក់ បានតាំង[ឃ]ទីក្រុងដ៏ធំមួយ ហើយទុកឈ្មោះល្បីល្បាញ ដែលពុំអាចប្រហារចោលបានឡើយ ។ លោកបានរស់ដោយអស្ចារ្យ ហើយលោកបានស្លាប់ដោយអស្ចារ្យ ចំពោះព្រះនេត្រនៃព្រះ និងចំពោះប្រជារាស្ត្រលោក; ហើយដូចជាអ្នកចាក់ប្រេងតាំងរបស់ព្រះអម្ចាស់ នៅជំនាន់បុរាណដែរ ក៏បានបិទត្រាបេសកកម្មរបស់លោក និងកិច្ចការរបស់លោក ដោយ[ង]លោហិតរបស់លោកផ្ទាល់; ហើយព្រមទាំង ហៃរុម ជាបងប្រុសលោកផង ។ ក្នុងជីវិត ពួកគេពុំបានបែកបាក់ ហើយក្នុងសេចក្ដីស្លាប់ ក៏ពួកគេពុំ បានបែកបាក់ដែរ !

៤ កាល យ៉ូសែប ទៅក្រុងកាតធេច ដើម្បីប្រគល់ខ្លួនចំពោះការតម្រូវក្លែងក្លាយដោយច្បាប់ គឺពីរបីថ្ងៃមុនការធ្វើឃាតកម្មរបស់លោក នោះ លោកបានមានប្រសាសន៍ថា៖ «ខ្ញុំទៅដូចជា[ក]ចៀមដឹកទៅសំឡាប់; ប៉ុន្តែខ្ញុំស្ងប់ចិត្តដូចជាព្រឹកព្រលឹមនារដូវក្ដៅ; ខ្ញុំគ្មានសតិ ទាស់ចំពោះព្រះ និងចំពោះមនុស្សគ្រប់រូបឡើយ ។ ខ្ញុំនឹងស្លាប់ទៅដោយឥតទោស ហើយនៅតែនឹងមានពាក្យពោលពីខ្ញុំថា — លោកត្រូវគេធ្វើឃាត ដោយចេតនា» ។ — នៅព្រលឹមដដែលនោះ

**១៣៥** ១*ក* គ. និង ស. ៥:២២; ៦:៣០.
ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
*ខ* ស.ប. ស្ម៊ីធ, យ៉ូសែប ជុញ៉ែរ
*គ* ស.ប. គុកកាតធេច (សហរដ្ឋ).
*ឃ* ស.ប. ស្ម៊ីធ, ហៃរុម.
២ *ក* ស.ប. ថេលើរ, យ៉ូហាន.
៣ *ក* ស.ប. ព្យាការី.
*ខ* ស.ប. អ្នកមើលឆុត.
*គ* គ. និង ស. ៣៥:១៧; ៤២:១២.
ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ឃ* ស.ប. ក្រុងណៅវូ,
រដ្ឋអិលលីណោយ (សហរដ្ឋ).
*ង* ហេព្រើរ ៩:១៦–១៧;
គ. និង ស. ១៣៦:៣៩.
៤ *ក* អេសាយ ៥៣:៧.

គឺបន្ទាប់ពី ហៃរុម បានត្រៀមស្រេចនឹងទៅ — តើនឹងថាពាក្យដឹកទៅសំឡាប់ឬអី ? មែនហើយ ត្បិតពិតជាដឹកទៅសំឡាប់មែន — នោះលោកបានអានឃ្លា នៅចុងជំពូកទី១២ ក្នុងគម្ពីរអេធើរ នៅក្នុងព្រះគម្ពីរមរមន ហើយបានបត់ចុងសន្លឹកទុក ថា៖

៥ *ហេតុការណ៍បានកើតឡើងថា ខ្ញុំបានអំពាវនាវចំពោះព្រះអម្ចាស់ សូមឲ្យទ្រង់ប្រទានដល់ពួកសាសន៍ដទៃនូវព្រះគុណ ដើម្បីឲ្យពួក គេអាចមានសេចក្ដីសប្បុរស ។ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ បើពួកគេគ្មានសេចក្ដី សប្បុរសទេ វាមិនជាសំខាន់អីទេចំពោះអ្នក អ្នកបានស្មោះត្រង់ ហេតុដូច្នេះ អាវរបស់អ្នកនឹងត្រូវធ្វើឲ្យ[ក]ជ្រះស្អាត ហើយដោយសារអ្នក បានឃើញភាពទន់ខ្សោយរបស់អ្នក នោះអ្នកនឹងបានធ្វើឲ្យខ្លាំងពូកែ រហូតដល់បានអង្គុយឯទីកន្លែងដែលយើងបានរៀបចំទុក នៅក្នុងទីលំនៅទាំងឡាយ របស់ព្រះវរបិតាយើង ។ ហើយឥឡូវនេះ ខ្ញុំ . . . សូមលាពួកសាសន៍ដទៃសិនហើយ មែនហើយ ហើយដល់ បងប្អូនទាំងឡាយរបស់ខ្ញុំផង ដែលខ្ញុំស្រឡាញ់ លុះត្រាយើងនឹងជួបគ្នា នៅខាងមុខ[ខ]វេទិកាជំនុំជំរះនៃព្រះគ្រីស្ទ នៅទីនោះ មនុស្ស ទាំងអស់នឹងដឹងថា អាវរបស់ខ្ញុំគ្មានប្រឡាក់ដោយឈាមរបស់អ្នកឡើយ ។* ឥឡូវនេះ ពួកអ្នកដែល[គ]ធ្វើទីបន្ទាល់បានស្លាប់ទៅហើយ ហើយទីបន្ទាល់របស់ពួកគេនៅតែមានឥទ្ធិពល ។

៦ ហៃរុម ស្ម៊ីធ មានអាយុ៤៤ឆ្នាំ នៅខែកុម្ភៈ ឆ្នាំ១៨៤៤ ហើយ យ៉ូសែប ស្ម៊ីធ មានអាយុ៣៨ នៅខែធ្នូ ឆ្នាំ១៨៤៣; ហើយពីអំណេះ តទៅ ឈ្មោះពួកគេត្រូវបានរាប់ក្នុងចំណោមពួកទុក្ករបុគ្គលសំរាប់សាសនា; ហើយអ្នកអាននៅគ្រប់សាសន៍នឹងត្រូវបានរំឭកឲ្យបាន ដឹងថា ព្រះគម្ពីរមរមន និងព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញានេះ ជារបស់សាសនាចក្រ ត្រូវអស់តម្លៃឈាមដ៏វិសេសបំផុតនៃសតវត្ស ទី១៩ ដើម្បីនាំរបស់ទាំងនោះចេញមក សំរាប់សេចក្ដីសង្គ្រោះដល់ពិភពលោកដ៏ហិនហោច; ហើយថាបើដូចជាភ្លើងអាចឆេះឆាបដល់ [ក]ឈើស្រស់ ដើម្បីសិរីល្អនៃព្រះជាយ៉ាងណា នោះតើមិនស្រួលទេឬអីដែលនឹងឆេះឈើស្ងួត ដើម្បីសំអាតចំការទំពាំងបាយជូរពីសេចក្ដីពុករលួយចេញ ។ ពួកគេបានរស់ដើម្បីសិរីល្អ; ពួកគេបានស្លាប់ដើម្បីសិរីល្អ; ហើយសិរីល្អគឺជារង្វាន់ដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ ។ ពីជំនាន់មួយទៅជំនាន់ នោះឈ្មោះរបស់ពួកគេនឹងបន្តទៅដល់កូនចៅ ដូចជាត្បូងសំរាប់ពួកអ្នកដែលបានញែកចេញជាបរិសុទ្ធ ។

៧ ពួកគេឥតមានទោសឧក្រិដ្ឋអ្វីសោះ ដូចជាពួកគេធ្លាប់បានសាកល្បងពីមុនមកហើយនោះ ហើយគ្រាន់តែជាប់នៅក្នុងគុកដោយសារ ការរួមគំនិតចោទប្រកាន់ពីពួកក្បត់ និងពួកមនុស្សទុច្ចរិតប៉ុណ្ណោះ; ហើយ*លោហិតដ៏ឥតទោស*របស់ពួកគេនៅលើក្ដារគុកកាតធេច នោះគឺជាត្រាបិទភ្ជាប់ទៅនឹង «សាសនាមរមន» ដែលពុំអាចបដិសេធ ដោយតុលាការណាមួយនៅលើផែនដីបានឡើយ ហើយ *លោហិតដ៏ឥតទោស*របស់ពួកគេ នៅលើស្លាកស្នាមទុយិសនៃរដ្ឋអិលលីណោយ ព្រមទាំងសេចក្ដីសន្យានៃរដ្ឋដែលបំភ្លេចចោល ដែលបានធានាដោយអភិបាលរដ្ឋ នោះសុទ្ធតែជាសាក្សីចំពោះសេចក្ដីពិតនៃដំណឹងល្អដ៏នៅអស់កល្បអស់កាលជានិច្ច ថាពិភពលោកទាំងមូល ពុំអាចចោទបានឡើយ; ហើយ*លោហិតដ៏ឥតទោស*របស់ពួកគេ នៅលើទង់សេរីភាព និងនៅលើ ម៉ាកណា ចារតានៃសហរដ្ឋ គឺជាអ្នកទូតសំរាប់សាសនានៃព្រះយេស៊ូវគ្រីស្ទ ដែលនឹងចាប់ដល់ចិត្តមនុស្សទៀងត្រង់ នៅក្នុងចំណោមគ្រប់អស់ទាំងសាសន៍; ហើយ*លោហិតដ៏ឥតទោស*របស់ពួកគេ ព្រមទាំងលោហិតនៃអស់ទាំងពួកទុក្ករបុគ្គល នៅ[ក]ក្រោមអាសនាដែលលោក យ៉ូហានបានឃើញ នឹងស្រែកទៅដល់ព្រះអម្ចាស់នៃពួកពលបរិវារ ទាល់តែទ្រង់សងសឹកលោហិតនោះ នៅលើផែនដី ។ អាម៉ែន ៕

## កណ្ឌទី ១៣៦

*ព្រះបន្ទូល និងព្រះហឫទ័យនៃព្រះអម្ចាស់ ដែលបានប្រទានតាមរយៈប្រធាន ព្រិកហាំ យ៉ង់ នៅវិនទើរ ខ្វរទើរ្ស នៅឯជំរុំអ៊ីស្រាអែលជាដែនដីនៃពួកអូម៉ាហា នៅច្រាំងខាងលិចនៃទន្លេមិសសួរី នៅក្បែរភូមិ ខោនសិល ប្លើហ្វ រដ្ឋអៃអូវ៉ា (*Journal History of the Church, *ថ្ងៃទី១៤ ខែមករា ឆ្នាំ១៨៤៧)* ។

៥ *ក* គ. និង ស. ៨៨:៧៤–៧៥.
*ខ* អេធើរ ១២:៣៦–៣៨.
*គ* ហេព្រើរ ៩:១៦–១៧.
៦ *ក* លូកា ២៣:៣១.
៧ *ក* វិវរ. ៦:៩.

*១–១៦, របៀបដែលជំរុំអ៊ីស្រាអែលត្រូវរៀបចំឡើង សំរាប់ការធ្វើដំណើរទៅទិសខាងលិច នោះត្រូវបានអធិប្បាយប្រាប់; ១៧–២៧, ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យរស់នៅដោយបមាណីយខាងដំណើងល្អជាច្រើន; ២៨–៣៣, ពួកបរិសុទ្ធគួរច្រៀង រាំ អធិស្ឋាន ហើយចេះ មានប្រាជ្ញា; ៣៤–៤២, ពួកព្យាការីត្រូវបានប្រហារ ដើម្បីឲ្យគេអាចបានទទួលកិត្តិយស ហើយឲ្យពួកទុច្ចរិតអាចបានដាក់ទោស ។*

ព្រះបន្ទូល និងព្រះហឫទ័យនៃព្រះអម្ចាស់ អំពីជំរុំអ៊ីស្រាអែលចំពោះដំណើររបស់ពួកគេទៅទិសខាងលិច គឺៈ

២ ចូរឲ្យប្រជាជនទាំងអស់នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ព្រមទាំងអស់អ្នកដែលធ្វើដំណើរជាមួយ ពួកគេផង ឲ្យរៀបចំជាក្រុមៗ ដោយធ្វើសេចក្ដីសញ្ញា និងសេចក្ដីសន្យា ដើម្បីកាន់តាមអស់ទាំងព្រះបញ្ញត្តិ និងក្រិត្យក្រមទាំងឡាយនៃ ព្រះអម្ចាស់ដ៏ជាព្រះរបស់យើងចុះ ។

៣ ចូរឲ្យក្រុមនីមួយៗដែលបានរៀបចំនោះមានមេដឹកនាំលើមនុស្ស១០០នាក់ មេដឹកនាំលើមនុស្ស៥០នាក់ និងមេដឹកនាំលើមនុស្ស១០នាក់ ដោយមានប្រធាន ព្រមទាំងទីប្រឹក្សារបស់គាត់ពីរនាក់លើពួកគេ គឺនៅក្រោមការដឹកនាំនៃពួកសាវក ១២នាក់ ។

៤ ហើយនេះត្រូវជាសេចក្ដីសញ្ញារបស់យើង — ថាយើងនឹងដើរតាមរបៀបទាំងអស់នៃព្រះអម្ចាស់ ។

៥ ចូរឲ្យក្រុមនីមួយៗមានសំរាប់ខ្លួន នូវអស់ទាំងគោ រទេះ ស្បៀងអាហារ សំលៀកបំពាក់ និងរបស់របរដែលត្រូវការផ្សេងៗទៀត សំរាប់ដំណើរ ដែលពួកគេអាចធ្វើទៅបាន ។

៦ កាលបានរៀបចំក្រុមទាំងឡាយរួចហើយ នោះចូរឲ្យពួកគេទៅដោយកម្លាំងរបស់ពួកគេ ដើម្បីជួយរៀបចំអស់អ្នកណាដែលត្រូវ នៅ ។

៧ ចូរឲ្យក្រុមនីមួយៗ ព្រមទាំងមេដឹកនាំ និងប្រធានគេផង សំរេចចិត្តនូវចំនួនមនុស្សប៉ុន្មានដែលអាចទៅបាននៅរដូវផ្ការីកខាងមុខនេះ; រួចហើយ ចូររើសចំនួនមនុស្សឲ្យបានគ្រប់គ្រាន់ដែលអាចទៅបាន និងដែលប៉ិនប្រសប់ ឲ្យបររទេះដឹកគ្រាប់ពូជ និងឧបករណ៍ធ្វើស្រែ ចំការ គឺឲ្យទៅជាពួកអ្នកត្រួសត្រាយ ដើម្បីរៀបចំដាំដំណាំ ។

៨ ចូរឲ្យក្រុមនីមួយៗ មានរបស់របរស្មើគ្នា ស្របតាមចំណែកនៃទ្រព្យសម្បត្តិដែលពួកគេមាន ចំពោះការយកមនុស្សក្រីក្រ ពួកស្រី មេម៉ាយ ពួកកូនកំព្រា និងក្រុមគ្រួសារនៃអស់អ្នកដែលបានចូលទាហាន ដើម្បីកុំឲ្យសំរែកទាំងឡាយនៃស្រីមេម៉ាយ និងកូនកំព្រា បានឡើងទៅដល់ព្រះកាណ៌នៃព្រះអម្ចាស់ ទាស់នឹងប្រជាជននេះឡើយ ។

៩ ចូរឲ្យក្រុមនីមួយៗរៀបចំផ្ទះសំបែង និងស្រែចំការសំរាប់ដាំស្រូវ សំរាប់អស់អ្នកដែលនៅចាំដល់រដូវក្រោយ; ហើយនេះគឺជាព្រះ ហឫទ័យនៃព្រះអម្ចាស់ ដែលទ្រង់មានអំពីរាស្ត្ររបស់ទ្រង់ ។

១០ ចូរឲ្យមនុស្សម្នាក់ៗប្រើប្រាស់នូវអស់ទាំងឥទ្ធិពល និងទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីដកប្រជាជននេះទៅឯកន្លែងដែលព្រះអម្ចាស់ ទ្រង់នឹងតាំងស្តេកនៃស៊ីយ៉ូន ។

១១ ហើយបើសិនជាអ្នករាល់គ្នាប្រព្រឹត្តការណ៍នេះ ដោយចិត្តបរិសុទ្ធ ដោយនូវអស់ទាំងសេចក្ដីស្មោះត្រង់ នោះអ្នករាល់គ្នានឹងបានព្រះ ពរ; អ្នកនឹងបានព្រះពរ ក្នុងហ្វូងចៀមអ្នក និងគោក្របីអ្នក និងក្នុងស្រែចំការអ្នក និងក្នុងផ្ទះសំបែងអ្នក និងនៅក្នុងក្រុមគ្រួសារអ្នក ។

១២ ចូរឲ្យ អែសរ៉ា ធី បេនសុន និង អ៊ីរ៉ាស្តុស ស្នូវ ជាពួកអ្នកបំរើរបស់យើង រៀបចំក្រុមមួយចុះ ។

១៣ ហើយចូរឲ្យ អ៊ួរសុន ប្រាត្ត និង វិលហ្វឺឌ វូឌដ្រុព្វ ជាពួកអ្នកបំរើរបស់យើង រៀបចំក្រុមមួយចុះ ។

១៤ ព្រមទាំងចូរឲ្យ អាម៉ាសា ឡៃម៉ាន និង ជួច អេ ស្មីធ ជាពួកអ្នកបំរើរបស់យើង រៀបចំក្រុមមួយចុះ ។

១៥ ហើយចូរតាំងពួកប្រធាន និងពួកមេដឹកនាំលើមនុស្ស១០០នាក់ និង៥០នាក់ និង១០នាក់ចុះ ។

១៦ ហើយចូរពួកអ្នកបំរើរបស់យើង ដែលបានតាំងឡើងឲ្យទៅហើយបង្រៀនការណ៍នេះ ដែលជាព្រះហឫទ័យរបស់យើងដល់ពួកបរិសុទ្ធ ប្រយោជន៍ឲ្យពួកគេអាចប្រុងប្រៀបទៅឯដែនដីនៃសេចក្ដីសុខសាន្ត ។

---

**១៣៦** ២*ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ.
៣ *ក* និក្ខ. ១៨:២១–២៦.
*ខ* ស.ប. សាវក.
៤ *ក* ស.ប. សេចក្ដីសញ្ញា.
*ខ* ស.ប. ដើរ, ដើរជាមួយព្រះ.
*គ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
៨ *ក* ស.ប. មនុស្សក្រីក្រ.
*ខ* ស.ប. ស្រីមេម៉ាយ.
*គ* យ៉ាកុប (ព.ស.ថ.) ១:២៧; ៣ នីហ្វៃ ២៤:៥.
១០ *ក* ស.ប. ចំរឹង, ស្តេក.
១១ *ក* ចោទិ. ២៨:១–១៤. ស.ប. ប្រទានពរ, មានពរ, ព្រះពរ.

១៧ ចូរទៅចុះ ហើយប្រព្រឹត្តដូចដែលយើងបានប្រាប់ដល់អ្នកចុះ ហើយចូរកុំខ្លាចពួកខ្មាំងសត្រូវរបស់អ្នកឡើយ; ត្បិតពួកគេនឹងពុំ មានអំណាចនឹងបញ្ឈប់កិច្ចការយើងបានឡើយ ។

១៨ ស៊ីយ៉ូននឹង[ក]ត្រូវបានប្រោសលោះ នៅពេលកំណត់របស់យើង ។

១៩ ហើយបើសិនជាមានមនុស្សណាមួយស្វែងរក ដើម្បីដំកើងខ្លួន ហើយពុំស្វែងរក[ក]ពាក្យដំបូន្មានរបស់យើងទេ អ្នកនោះនឹងពុំមាន អំណាចឡើយ ហើយសេចក្ដីចំកួតរបស់គេនឹងត្រូវបានសំដែងឲ្យឃើញ ។

២០ ចូរស្វែងរក; ហើយ[ក]កាន់តាមអស់ទាំងពាក្យសច្ចាអ្នកដែលបានធ្វើជាមួយគ្នានិងគ្នា ហើយចូរកុំ[ខ]លោភចង់បានអ្វីដែលជារបស់ផង បងប្អូនអ្នកឡើយ ។

២១ ចូរ[ក]ញែកខ្លួនចេញពីការអាក្រក់ ក្នុងការចេញព្រះនាមនៃព្រះអម្ចាស់ ជាអសារឥតការ ត្បិតយើងជាព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក គឺ [ខ]ជាព្រះនៃអយ្យកោរបស់អ្នក ជាព្រះនៃអ័ប្រាហាំ និងអ៊ីសាក និងយ៉ាកុប ។

២២ [ក]យើងជាអ្នកដែលបាននាំកូនចៅអ៊ីស្រាអែលចេញពីដែនដីអេស៊ីព្ទ ហើយព្រះពាហុរបស់យើងកំពុងលើកសន្ធឹងឡើង នៅថ្ងៃចុង ក្រោយបង្អស់ ដើម្បី[ខ]ជួយសង្គ្រោះសាសន៍អ៊ីស្រាអែលជារាស្ត្ររបស់យើង ។

២៣ ចូរឈប់[ក]ទាស់ទែងនឹងគ្នា ចូរឈប់[ខ]និយាយអាក្រក់ពីគ្នាទៅវិញទៅមក ។

២៤ ចូរឈប់[ក]ការផឹកប្រមឹក; ហើយចូរឲ្យកិច្ចការទាំងឡាយរបស់អ្នកបាន[ខ]ស្អាងគ្នាទៅវិញទៅមកចុះ ។

២៥ បើសិនជាអ្នកខ្ចីអ្វីពីអ្នកជិតខាងរបស់ខ្លួន នោះអ្នកត្រូវសងនូវអ្វីដែលអ្នកបាន[ក]ខ្ចីនោះវិញ; ហើយបើសិនជាអ្នកមិនអាចសងបានទេ នោះចូរទៅជាប្រញាប់ ហើយប្រាប់អ្នកជិតខាងរបស់ខ្លួនចុះ ក្រែងលោគេដាក់ទោសដល់អ្នក ។

២៦ បើសិនជាអ្នករកឃើញរបស់ដែលអ្នកជិតខាងរបស់ខ្លួន[ក]បានបាត់ នោះអ្នកត្រូវខំព្យាយាមស្វែងរកម្ចាស់ ទាល់តែអ្នកបានប្រគល់របស់ នោះទៅគេវិញ ។

២៧ អ្នកត្រូវ[ក]ខំព្យាយាមរក្សាអ្វីដែលអ្នកមាន ប្រយោជន៍ឲ្យអ្នកអាចបានទៅជា[ខ]អ្នកកាន់កាប់ត្រួតត្រាដ៏ឈ្លាសវៃ; ត្បិតរបស់ទាំងនោះ សុទ្ធតែជាអំណោយទានដោយឥតគិតថ្លៃ ពីព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ហើយអ្នកត្រូវជាអ្នកកាន់កាប់ត្រួតត្រារបស់ទ្រង់ ។

២៨ បើសិនជាអ្នកសប្បាយរីករាយ ចូរ[ក]សរសើរដំកើងដល់ព្រះអម្ចាស់ ដោយការច្រៀង ដោយការលេងភ្លេង ដោយការរាំ និងដោយ [ខ]ការអធិស្ឋាន អំពីការសរសើរ និង[គ]អំណរគុណ ។

២៩ បើសិនជាអ្នកមាន[ក]ចិត្តទុក្ខព្រួយ ចូរអំពាវនាវដល់ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក ដោយការអង្វរករ សូមឲ្យដួងព្រលឹងអ្នកអាចមាន [ខ]អំណរអរផង ។

៣០ ចូរកុំខ្លាចពួកខ្មាំងសត្រូវរបស់អ្នកឡើយ ត្បិតពួកគេនៅក្នុងកណ្ដាប់ដៃរបស់យើងហើយ ហើយយើងនឹងប្រព្រឹត្តដល់ពួកគេតាម បំណងព្រះហឫទ័យរបស់យើង ។

៣១ រាស្ត្ររបស់យើងត្រូវតែបាន[ក]សាកល្បងនូវគ្រប់ការណ៍ទាំងអស់ ប្រយោជន៍ឲ្យពួកគេអាចបានរៀបចំ ដើម្បីទទួលនូវ[ខ]សិរីល្អដែល យើងមានសំរាប់ពួកគេ គឺជាសិរីល្អនៃស៊ីយ៉ូន; ហើយអ្នកណាដែលមិនទ្រាំ[គ]ការវាយផ្ចាល នោះមិនសមនឹងនគររបស់យើងឡើយ ។

១៨ ក គ. និង ស. ១០០:១៣.
១៩ ក ស.ប. ពាក្យទូន្មាន (ន.).
២០ ក ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់.
ខ ស.ប. លោភ.
២១ ក ស.ប. សេចក្ដីមើលងាយ.
ខ និក្ខ. ៣:៦; ១ នីហ្វៃ ១៩:១០.
២២ ក និក្ខ. ១៣:១៨; យេរេ. ២:៥–៧;
១ នីហ្វៃ ៥:១៥;
អាលម៉ា ៣៦:២៨.
ស.ប. ព្រះយេហូវ៉ា.
ខ យេរេ. ៣០:១០;
អេសេ. ២០:៣៣–៣៤;
គ. និង ស. ៣៨:៣៣.
២៣ ក ៣ នីហ្វៃ ១១:២៩–៣០.
ស.ប. ការទាស់ទែង.
ខ គ. និង ស. ២០:៥៤.
ស.ប. ការនិយាយអាក្រក់.
២៤ ក ស.ប. ពាក្យសំដីនៃប្រាជ្ញាវាងវៃ.
ខ គ. និង ស. ១០៨:៧.
២៥ ក ទំនុក. ៣៧:២១; ម៉ូសាយ ៤:២៨.
ស.ប. បំណុល; ទៀងត្រង់,
ចិត្តទៀតត្រង់.
២៦ ក លេវី. ៦:៤; ចោទិ. ២២:៣.
២៧ ក ស.ប. ព្រះដ៏ប្រោសឲ្យរួច.
ខ ស.ប. អ្នកកាន់កាប់ត្រួតត្រា,
ការកាន់កាប់ត្រួតត្រា.
២៨ ក ស.ប. ច្រៀង.
ខ ស.ប. ការអធិស្ឋាន.
គ ២ របា. ៥:១៣;
គ. និង ស. ៥៩:១៥–១៦.
ស.ប. ដ៏អរគុណ, អរគុណ,
ការថ្លែងអំណរគុណ.
២៩ ក ២ សាំយូ. ២២:៧.
ខ ស.ប. សេចក្ដីអំណរ.
៣១ ក គ. និង ស. ១០១:៤.
ស.ប. សេចក្ដីទំនាស់.
ខ រ៉ូម ៨:១៨;
គ. និង ស. ៥៨:៣–៤.
ស.ប. សិរីល្អ.
គ ស.ប. វាយផ្ចាល, ការវាយផ្ចាល.

៣២ ចូរឲ្យអ្នកណាដែលល្ងង់ ចេះមាន[ក]ប្រាជ្ញា ដោយ[ខ]ការបន្ទាបខ្លួន និងដោយការអំពាវនាវដល់ព្រះអម្ចាស់ដ៏ជាព្រះរបស់ខ្លួន ប្រយោជន៍ឲ្យភ្នែកគេអាចបានបើកឡើង ដើម្បីឲ្យគេអាចមើលឃើញ ហើយត្រចៀកបានបើក ដើម្បីឲ្យគេអាចបានស្ដាប់ឮ;

៣៣ ត្បិត[ក]ព្រះវិញ្ញាណរបស់យើង កំពុងតែបានចាត់ទៅក្នុងពិភពលោក ដើម្បីទៅបំភ្លឺដល់ពួករាបសា និងពួកទន់ទាប ហើយដើម្បីទៅ ដាក់ទោសដល់ពួកអាក្រក់ ។

៣៤ ពួកបងប្អូនអ្នកបានបដិសេធអ្នក និងទីបន្ទាល់របស់អ្នក គឺជាសាសន៍ដែលបាន[ក]ដេញអ្នកចេញ;

៣៥ ហើយឥឡូវនេះ ថ្ងៃអន្តរាយរបស់គេមកដល់ហើយ គឺជាថ្ងៃទុក្ខវេទនា ដូចជាស្រីដែលឈឺនឹងសំរាលកូន; ហើយសេចក្ដីទុក្ខសោក របស់គេនឹងទៅជាធំ លើកលែងតែពួកគេប្រែចិត្តឲ្យបានឆាប់រហ័ស មែនហើយ គឺឲ្យបានឆាប់រហ័សបំផុត ។

៣៦ ត្បិតពួកគេបានសំឡាប់ពួកព្យាការី ហើយពួកអ្នកដែលត្រូវបានចាត់ឲ្យទៅឯពួកគេ; ហើយពួកគេបានកំចាយឈាមដែលគ្មានទោស ដែលស្រែកចេញពីដីទាស់នឹងពួកគេ ។

៣៧ ហេតុដូច្នេះហើយ ចូរកុំឆ្ងល់ពីការណ៍ទាំងនេះឡើយ ព្រោះអ្នករាល់គ្នាពុំទាន់បាន[ក]ស្អាតបាតនៅឡើយទេ; អ្នករាល់គ្នាពុំអាចទ្រាំសិរីល្អរបស់យើងបាននៅឡើយទេ; ប៉ុន្តែអ្នករាល់គ្នានឹងបានឃើញសិរីល្អរបស់យើង បើសិនជាអ្នករាល់គ្នាមានចិត្តស្មោះត្រង់ ក្នុងការកាន់ តាមគ្រប់អស់ទាំងព្រះបន្ទូលរបស់យើង ដែលយើងបានប្រទានដល់អ្នក ចាប់តាំងពីសម័យលោកអ័ដាមទៅលោកអ័ប្រាហាំ ពីលោក អ័ប្រាហាំទៅលោកម៉ូសេ ពីលោកម៉ូសេទៅព្រះយេស៊ូវ និងពួកសាវករបស់ទ្រង់ ហើយពីព្រះយេស៊ូវ និងពួកសាវករបស់ទ្រង់ទៅ យ៉ូសែប ស៊្មីធ ជាអ្នកដែលយើងបានហៅ ដោយសារ[គ]ពួកទេវតារបស់យើង គឺជាពួកអ្នកបំរើរបស់យើងខាងការងារបំរើ និងដោយ សម្លេងរបស់យើងផ្ទាល់ ចេញពីស្ថានសួគ៌ ដើម្បីឲ្យនាំចេញមកនូវកិច្ចការរបស់យើង;

៣៨ គឺលោកបានតាំងគ្រឹះស្ថាន ហើយបានមានចិត្តស្មោះត្រង់; ហើយយើងបានយកលោកមកឯខ្លួនយើង ។

៣៩ មានមនុស្សជាច្រើនបានឆ្ងល់ ពីព្រោះតែមរណភាពរបស់លោក; ប៉ុន្តែជាការចាំបាច់ដែលលោកត្រូវ[ក]បិទត្រា[ខ]ទីបន្ទាល់របស់លោក ដោយ[គ]លោហិតរបស់លោក ប្រយោជន៍ឲ្យលោកអាចបានទទួលកិត្តិយស ហើយឲ្យពួកទុច្ចរិតអាចបានផាប់ទោស ។

៤០ តើយើងមិនបានដោះលែងអ្នកឲ្យរួចពី[ក]ពួកខ្មាំងសត្រូវអ្នក ដោយគ្រាន់តែយើងបានទុកសាក្សីមួយ អំពីព្រះនាមរបស់យើងទេឬ ?

៤១ ឥឡូវនេះ ហេតុដូច្នេះហើយ ឱអ្នករាល់គ្នាជារាស្ត្រ[ក]នៃសាសនាចក្រយើងអើយ ចូរប្រុងស្ដាប់ចុះ; ហើយឱអ្នករាល់គ្នាជាពួក អែលឌើរអើយ ចូរឮជុំគ្នាចុះ; អ្នកបានទទួល[ខ]នគររបស់យើងហើយ ។

៤២ ហើយចូរមានចិត្តព្យាយាម ក្នុងការកាន់តាមគ្រប់អស់ទាំងព្រះបញ្ញត្តិរបស់យើងចុះ ក្រែងមានសេចក្ដីជំនុំជំរះមកលើអ្នក ហើយ ក្រែងសេចក្ដីជំនឿរបស់អ្នកវិនាសបាត់ ហើយក្រែងពួកខ្មាំងសត្រូវរបស់អ្នកមានជ័យជំនះមកលើអ្នក ។ ម្ល៉ោះហើយ គ្មានអ្វីទៀត ទេនៅពេលនេះ ។ អាម៉ែន និង អាម៉ែន ៕

---

៣២ *ក* ស.ប. ប្រាជ្ញា.
*ខ* ស.ប. បន្ទាបខ្លួន, ចិត្តសុភាពរាបសា.
៣៣ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៣៤ *ក* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
៣៧ *ក* ស.ប. សុទ្ធ, សុទ្ធសាធ.
*ខ* ហេលេ. ៨:១៨.
*គ* វិវរ. ១៤:៦; គ. និង ស. ១១០:១១–១៦; ១២៨:១៩–២១; យ.ស. — ប្រវត្តិ ១:៣០–៤៧.
៣៩ *ក* ម៉ូសាយ ១៧:២០; គ. និង ស. ១៣៥:៣.
*ខ* ស.ប. ទីបន្ទាល់.
*គ* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
៤០ *ក* និក្ខ. ២៣:២២; គ. និង ស. ៨:៤; ១០៥:១៥.
៤១ *ក* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ដានី. ៧:២៧.

## កណ្ឌទី ១៣៧

*ការនិមិត្តមួយដែលបានប្រទានដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅក្នុងព្រះវិហារខឺតឡង់ រដ្ឋអូហៃអូ ថ្ងៃទី២១ ខែមករា ឆ្នាំ១៨៣៦* (History of the Church, *២:៣៨០–៣៨១)* ។ *នៅគ្រានៃការចាត់ចែងពិធីទាំងឡាយនៃអំណោយទានពិសិដ្ឋ ដូចដែល បានបើកសំដែងប្រាប់មកនៅពេលនោះ ។*

*១–៦, ព្យាការីឃើញ អាលវិន ជាបងប្រុសលោក នៅក្នុងនគរសេឡេស្ទាល; ៧–៩, គោលលទ្ធិអំពីសេចក្ដីសង្គ្រោះសំរាប់មនុស្ស ស្លាប់ត្រូវបានបើកសំដែងប្រាប់; ១០, កូនក្មេងទាំងអស់ត្រូវបានសង្គ្រោះ នៅក្នុងនគរសេឡេស្ទាល ។*

[ក]ផ្ទៃមេឃបានបើកដល់យើង ហើយខ្ញុំបានឃើញ[ខ]នគរសេឡេស្ទាលនៃព្រះ និងសិរីល្អនៅទីនោះផង ទោះបើ[គ]ក្នុងរូបកាយ ឬក្រៅពីរូបកាយ នោះខ្ញុំមិនដឹងទេ ។

២ ខ្ញុំបានឃើញលំអរដ៏ល្អអស្ចារ្យនៃ[ក]ខ្លោងទ្វារ ដែលពួកអ្នកគ្រងនគរនោះទុកជាមរតកនឹងចូល ដែលប្រៀបដូចជាខ្លោងមូលពី[ខ]អណ្ដាត ភ្លើង;

៣ ព្រមទាំង[ក]បល្ល័ង្កដ៏ឆេះឆាបនៃព្រះ ដែល[ខ]ព្រះវរបិតា និង[គ]ព្រះរាជបុត្រាគង់លើ ។

៤ ខ្ញុំបានឃើញ[ក]ថ្នល់ដ៏ល្អៗនៃនគរ ដែលមានរូបរាងដូចជាក្រាលដោយមាស ។

៥ ខ្ញុំបានឃើញលោកអយ្យកោ[ក]អ័ដាម និង[ខ]លោកអ័ប្រាហាំ; និង[គ]បិតាខ្ញុំ និង[ឃ]មាតាខ្ញុំ; និង[ង]អាលវិន ជាបងប្រុសខ្ញុំ ដែលបានដេកលក់យូរលង់ ណាស់មកហើយ;

៦ ហើយបានមានចិត្តអស្ចារ្យថា តើគាត់បាន[ក]ក៏ទទួលមរតកនៅក្នុងនគរនោះយ៉ាងម៉េចទៅ ដោយឃើញថាគាត់បានលាចាកជីវិតនេះតាំងពីមុនព្រះអម្ចាស់ទ្រង់បានលូកព្រះហស្តទ្រង់ ទៅ[ខ]ប្រមូលពួកសាសន៍អ៊ីស្រាអែលលើកទីពីរ ហើយពុំទាំងបានទទួល[គ]បុណ្យជ្រមុជទឹក សំរាប់ការផ្ដាច់បាបនៅឡើយផង ។

៧ ស្រាប់តែឮសម្លេងនៃព្រះអម្ចាស់បន្លឺមកខ្ញុំថាៈ មនុស្សទាំងអស់ដែលបាន[ក]ស្លាប់ទៅ ដោយគ្មាន[ខ]ការចេះដឹងអំពីដំណឹងល្អនេះ គឺជាពួក អ្នកដែលនឹងទទួលដំណឹងល្អ បើសិនជាពួកគេត្រូវបាន[គ]អនុញ្ញាតឲ្យនៅ នោះនឹងទៅជាពួកអ្នកគ្រងនគរ[ឃ]សេឡេស្ទាលនៃព្រះទុកជាមតរក;

៨ ព្រមទាំងមនុស្សទាំងអស់ដែលនឹងស្លាប់ពីអំណិះតទៅដោយគ្មានការចេះដឹងអំពីដំណឹងល្អ គឺជាពួកអ្នកដែលប្រាកដជា[ក]នឹងទទួល ដំណឹងល្អដោយអស់ពីចិត្ត នោះនឹងទៅជាពួកអ្នកគ្រងនគរនោះទុកជាមរតកដែរ;

**១៣៧** ១ *ក* កិច្ចការ ៧:៥៥–៥៦;
១ នីហ្វៃ ១:៨;
ហេលេ. ៥:៤៥–៤៩;
យ.ស. — ប្រវត្តិ ១:៤៣.
*ខ* ស.ប. សិរីល្អនៃសេឡេស្ទាល.
*គ* ២ កូរិន. ១២:២–៤;
១ នីហ្វៃ ១១:១; ម៉ូសេ ១:១១.
២ *ក* ២ នីហ្វៃ ៩:៤១; ៣១:១៧.
*ខ* និក្ខ. ២៤:១៧;
អេសាយ ៣៣:១៤–១៥;
ហេលេ. ៥:២៣;
គ. និង ស. ១៣០:៧.
៣ *ក* អេសាយ ៦:១;
អេសេ. ១:២៦–២៨.
*ខ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*គ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះរាជបុត្រា.
៤ *ក* វិវរ. ២១:២១;
គ. និង ស. ១១០:២.
៥ *ក* ស.ប. អ័ដាម.
*ខ* គ. និង ស. ១៣២:២៩.
ស.ប. អ័ប្រាហាំ.
*គ* គ. និង ស. ១២៤:១៩.
ស.ប. ស្ម៊ីធ, យ៉ូសែប ស៊ីញ៉័រ.
*ឃ* ស.ប. ស្ម៊ីធ, លូស៊ី ម៉ាក.
*ង* យ.ស. — ប្រវត្តិ ១:៤.
៦ *ក* ស.ប. សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់.
*ខ* អេសាយ ១១:១១;
១ នីហ្វៃ ២២:១០–១២;
យ៉ាកុប ៦:២.
ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*គ* យ៉ូហាន ៣:៣–៥;
២ នីហ្វៃ ៩:២៣;
អេធើរ ៤:១៨–១៩;
គ. និង ស. ៧៦:៥០–៥២;
៨៤:៧៤.
ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.
៧ *ក* ហេលេ. ៥:៣០.
ស.ប. វិវរណៈ.
*ខ* ក.យ.ស., ១ ពេត្រុស ៤:៦;
២ នីហ្វៃ ៩:២៥–២៦;
ម៉ូសាយ ១៥:២៤.
*គ* គ. និង ស. ៧៦:៥០–៧០.
*ឃ* ស.ប. សិរីល្អនៃសេឡេស្ទាល.
៨ *ក* អាលម៉ា ១៨:៣២;
គ. និង ស. ៦:១៦.

៩ ត្បិតយើងជាព្រះអម្ចាស់ នឹងជំនុំជំរះមនុស្សលោកទាំងអស់
ស្របតាមកិច្ចការរបស់ពួកគេ គឺស្របតាមសេចក្ដីប៉ងប្រាថ្នា នៃ
ដួងចិត្តរបស់ ពួកគេ ។

១០ ហើយខ្ញុំក៏បានឃើញកូនក្មេងទាំងអស់ ដែលបាន
ស្លាប់មុនគ្រប់អាយុទទួលខុសត្រូវ នោះត្រូវបានសង្គ្រោះនៅក្នុង
នគរសេឡេស្ទាល នៅស្ថានសួគ៌ដែរ ៕

## កណ្ឌទី ១៣៨

*ការនិមិត្តមួយដែលបានប្រទានដល់ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ នៅទីក្រុងសលលេក រដ្ឋយូថាហ៍ ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩១៨ ។ នៅក្នុងសុន្ទរកថាបើករបស់លោក នៅឯសន្និសីទទូទៅនៃសាសនាចក្រ លើកទី៨៩ ប្រចាំឆ្នាំលើកទីពីរ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩១៨ នោះប្រធានស្ម៊ីធបានប្រកាសប្រាប់ថា លោកបានទទួលដំណឹងដ៏ឧត្ដមទាំងឡាយ នៅខែមុនៗ ។ ដំណឹងមួយនោះស្ដីអំពីទស្សនកិច្ច របស់ព្រះអង្គសង្គ្រោះទៅជួបពួកវិញ្ញាណនៃមនុស្សស្លាប់ ក្នុងកាលព្រះកាយទ្រង់បញ្ចុះនៅក្នុងផ្នូរ នោះប្រធានស្ម៊ីធបានទទួលកាលពីថ្ងៃ ម្សិលមិញ ។ ការនិមិត្តនោះត្រូវបានកត់ទុកជាប្រញាប់ បន្ទាប់ពីចប់សន្និសីទ ។ នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩១៨ ការនិមិត្តនោះត្រូវ បានប្រគល់ដល់ពួកទីប្រឹក្សាក្នុងគណៈប្រធានទីមួយ ក្រុមប្រឹក្សានៃពួក១២នាក់ និងលោកអយ្យកោ ហើយការនិមិត្តនោះត្រូវបានទទួល ដោយពួកគេជាឯកច្ឆន្ទ ។*

*១–១០, ប្រធាន យ៉ូសែប អែហ្វ ស្ម៊ីធ ពិចារណាពីការនិពន្ធនៃពេត្រុស និងពីទស្សនកិច្ចរបស់ព្រះអម្ចាស់របស់យើងទៅឯស្ថានឃុំព្រលឹង មនុស្សស្លាប់; ១១–២៤, ប្រធានស្ម៊ីធឃើញមនុស្សស្លាប់ដែលសុចរិតប្រជុំគ្នានៅស្ថានបរមសុខ និងការងារបំរើរបស់ព្រះគ្រីស្ទ នៅក្នុង ចំណោមពួកគេ; ២៥–៣៧, លោកឃើញនូវការរៀបចំដើម្បីផ្សាយដំណឹងល្អនៅក្នុងចំណោមព្រលឹងវិញ្ញាណ; ៣៨–៥២, លោកឃើញលោកអ័ដាម នាងអេវ៉ា និងពួកព្យាការីបរិសុទ្ធជាច្រើនផងនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ដែលគិតថាស្ថានភាពខាងព្រលឹងរបស់គេ មុនដំណើររស់ឡើងវិញរបស់គេនោះជាសេវកភាព; ៥៣–៦០, ពួកអ្នកស្លាប់ដែលសុចរិតនៅថ្ងៃនេះ បន្តការងាររបស់ខ្លួន នៅស្ថានឃុំ ព្រលឹងមនុស្សស្លាប់ ។*

នៅថ្ងៃទី៣នៃខែតុលានេះ ក្នុងឆ្នាំមួយពាន់ប្រាំបួនរយដប់ប្រាំបី
នោះខ្ញុំបានអង្គុយនៅក្នុងបន្ទប់ខ្ញុំ ពិចារណាពីបទគម្ពីរ;
២ ហើយសញ្ជឹងគិតពីការបូជាដ៏ធំដែលធ្វើឲ្យធួននឹងបាប
ដែលបានប្រព្រឹត្តដោយព្រះរាជបុត្រានៃព្រះ សំរាប់សេច
ក្ដីប្រោសលោះដល់ ពិភពលោក;
៣ និងពីសេចក្ដីស្រឡាញ់ដ៏ធំ និងអស្ចារ្យ ដែលបាន
សំដែងដោយព្រះវរបិតា និងព្រះរាជបុត្រា តាមរយៈការយាង
មកនៃព្រះដ៏ប្រោស លោះនៃពិភពលោក;
៤ គឺថាតាមរយៈដង្វាយធួនរបស់ទ្រង់ និងដោយសារការ
គោរពដល់គោលការណ៍ទាំងឡាយនៃដំណឹងល្អ ទើបមនុស្ស
លោកអាចបាន សង្គ្រោះ ។
៥ កាលខ្ញុំកំពុងតែគិតរឿងនេះ នោះគំនិតខ្ញុំបែរទៅគិត
ពីការនិពន្ធនៃសាវកពេត្រុស សរសេរទៅពួកបរិសុទ្ធដើម ដែល
ខ្ចាត់ខ្ចាយទូទៅ ទាំងស្រុកប៉ុនតុស ស្រុកកាឡាទី ស្រុក
កាប៉ាដូគា និងនៅផ្នែកផ្សេងៗនៃស្រុកអាស៊ី ជាទីដែលដំណឹងល្អ
បានផ្សាយ បន្ទាប់ពីការឆ្កាងព្រះ អម្ចាស់ ។
៦ ខ្ញុំបានបើកព្រះគម្ពីរប៊ីប ហើយអានជំពូកទីបី និងទីបួន នៅក្នុង
សំបុត្រទីមួយរបស់ពេត្រុស ហើយកាលខ្ញុំអាន នោះខ្ញុំមានចិត្ត
ស្ញើបជា ខ្លាំង គឺជាងពេលមុនៗ ចំពោះវគ្គដែលមានដូចតទៅ
នេះ គឺៈ

៩ *ក* វិវរ. ២០:១២–១៣.
ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
*ខ* ស.ប. កិច្ចការ.
*គ* គ. និង ស. ៦៤:៣៤.
ស.ប. ចិត្ត.
១០ *ក* ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ.
*ខ* ស.ប. សេចក្ដីសង្គ្រោះ — សេចក្ដីសង្គ្រោះដល់កូនក្មេង.
**១៣៨** ១ *ក* ស.ប. រំពឹងគិត.
២ *ក* ម៉ាថាយ ២០:២៨.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
៣ *ក* យ៉ូហាន ៣:១៦.
ស.ប. សេចក្ដីស្រឡាញ់.
*ខ* ស.ប. ព្រះដ៏ប្រោសលោះ.
៤ *ក* ម. នៃ ស. ១:៣.
*ខ* ម៉ាថាយ ៧:២១.
ស.ប. ការគោរព, ដែលគោរព, គោរព.
៥ *ក* ក.ន. ពួកបរិសុទ្ធជំនាន់មុន.
*ខ* ១ ពេត្រុស ១:១.

៧ «ព្រោះព្រះគ្រីស្ទទ្រង់បានរងទុក្ខម្ដង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នា ទៅឯព្រះ ដោយទ្រង់ត្រូវគេធ្វើគុតខាងសាច់ឈាម តែបានព្រះវិញ្ញាណប្រោសឲ្យរស់វិញ៖

៨ «ហើយដោយនូវព្រះវិញ្ញាណនោះឯង ទ្រង់បានយាងទៅប្រដៅដល់ពួកវិញ្ញាណដែលជាប់ឃុំ;

៩ «ជាពួកអ្នកដែលពីដើមមិនព្រមជឿ គឺក្នុងខណៈដែលសេចក្ដីអត់ធ្មត់របស់ព្រះ បានរង់ចាំនៅជំនាន់លោកណូអេ កាលលោកកំពុងតែ ធ្វើទូកធំ ហើយនៅក្នុងទូកនោះមានមនុស្សតែបន្តិច គឺប្រាំបីនាក់ប៉ុណ្ណោះ ដែលបានរួចដោយសារទឹក» (ពេត្រុស ទី១ ៣:១៨–២០) ។

១០ «ហេតុនោះបានជាបានផ្សាយដំណឹងល្អទៅមនុស្ស ដែលស្លាប់ហើយដែរ ដើម្បីឲ្យគេត្រូវជាប់ជំនុំជំរះខាងសាច់ឈាមតាមបែប មនុស្ស តែឲ្យគេបានរស់ខាងវិញ្ញាណតាមព្រះវិញ» (ពេត្រុស ទី១ ៤:៦) ។

១១ នៅពេលខ្ញុំកំពុងតែពិចារណាពីការណ៍ទាំងនេះ ដែលបានសរសេរទុក នោះស្រាប់តែភ្នែកនៃយោបល់ខ្ញុំត្រូវបានបើក ហើយព្រះ វិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើខ្ញុំ ហើយខ្ញុំបានឃើញពួកពលបរិវារនៃមនុស្សស្លាប់ ទាំងអ្នកតូច ទាំងអ្នកធំ ។

១២ ហើយមានការប្រមូលផ្ដុំគ្នានៅកន្លែងមួយ នូវក្រុមវិញ្ញាណនៃមនុស្សសុចរិតដ៏ឥតគណនា ដែលមានចិត្តស្មោះត្រង់ចំពោះទីបន្ទាល់ អំពីព្រះគ្រីស្ទ កាលគេមានជីវិតរស់ជាមនុស្ស;

១៣ ហើយជាពួកអ្នកដែលបានថ្វាយយញ្ញបូជា ក្នុងនិមិត្តរូបអំពីការបូជាដ៏ធំនៃព្រះរាជបុត្រានៃព្រះ ហើយបានរងទុក្ខវេទនាព្រោះតែព្រះ នាមនៃព្រះដ៏ប្រោសលោះរបស់គេ ។

១៤ ពួកគេទាំងអស់នេះបានលាចាកពីជីវិតលោកទៅ ដោយមានសេចក្ដីសង្ឃឹមដ៏មុតមាំ អំពីដំណើររស់ឡើងវិញដ៏រុងរឿងតាមរយៈ ព្រះគុណនៃព្រះ ដ៏ជាព្រះវរបិតា និងព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។

១៥ ខ្ញុំបានឃើញថា ពួកគេពោរពេញទៅដោយសេចក្ដីអំណរ និងសេចក្ដីរីករាយ ហើយអរសប្បាយជុំគ្នា ពីព្រោះថ្ងៃនៃសេចក្ដីរំដោះ របស់គេ នៅជិតដៃបង្កើយ ។

១៦ ពួកគេបានជួបជុំគ្នាចាំការយាងមកនៃព្រះរាជបុត្រានៃព្រះមកឯស្ថានឃុំព្រលឹងមនុស្សស្លាប់ ដើម្បីមកប្រកាសប្រាប់ពីសេចក្ដីប្រោស លោះរបស់គេឲ្យរួចពីចំណងទាំងឡាយនៃសេចក្ដីស្លាប់ ។

១៧ ធូលីដីរបស់គេដែលលង់លក់ទៅនោះត្រូវបានសាងឡើងជារូបរៀងពេញខ្នាតវិញ គឺឆ្អឹងទៅជាឆ្អឹងគេវិញ ហើយសរសៃ និងសាច់ ទៅលើឆ្អឹង វិញ្ញាណ និងរូបកាយត្រូវរួបរួមគ្នា ដោយមិនបែកបាក់ទៀតឡើយ ប្រយោជន៍ឲ្យពួកគេអាចបានទទួលភាពពោរពេញនៃ សេចក្ដីអំណរ ។

១៨ កាលហ្វូងមនុស្សដ៏ក្រៃលក្រៃនេះកំពុងតែរង់ចាំ ហើយចរចាដោយមានចិត្តអរសប្បាយចំពោះម៉ោងនៃសេចក្ដីរំដោះរបស់គេ ឲ្យរួចពីច្រវាក់ទាំងឡាយនៃសេចក្ដីស្លាប់ នោះស្រាប់តែព្រះរាជបុត្រានៃព្រះបានលេចមកប្រកាសប្រាប់ពីការដោះលែងដល់ពួកជាប់ឃុំឃាំងទាំងឡាយដែលមានចិត្តស្មោះត្រង់;

១៩ ហើយនៅទីនោះ ទ្រង់បានផ្សាយប្រាប់ពួកគេពីដំណឹងល្អដ៏នៅអស់កល្បអស់កាលជានិច្ច គឺពីគោលលទ្ធិអំពីដំណើររស់ឡើងវិញ និងសេចក្ដីប្រោសលោះមនុស្សលោកពីការធ្លាក់ និងពីអំបាបរៀងៗខ្លួន អាស្រ័យទៅលើករណីនៃការប្រែចិត្ត ។

៨ ក អេសាយ ៦១:១; លូកា ៤:១៨; គ. និង ស. ៧៦:៧៣–៧៤; ៨៨:៩៩.
១១ ក ស.ប. បទព្រះគម្ពីរ — តម្លៃនៃព្រះគម្ពីរ.
ខ អេភេ. ១:១៨; គ. និង ស. ៧៦:១០, ១២, ១៩.
គ អេសាយ ១១:២.
ឃ ស.ប. វិញ្ញាណ.
១២ ក គ. និង ស. ៧៦:៦៩–៧០.
ខ គ. និង ស. ៦:១៣; ៥១:១៩; ៧៦:៥១–៥៣.
១៣ ក ស.ប. បូជា, យញ្ញបូជា.
ខ ម៉ាថាយ ៥:១០–១២.
១៤ ក អេធើរ ១២:៤; ម៉ូរ៉ូណៃ ៧:៣, ៤០–៤៤. ស.ប. សេចក្ដីសង្ឃឹម.
ខ ស.ប. ដំណើររស់ឡើងវិញ.
គ ស.ប. ព្រះគុណ.
ឃ ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
ង ស.ប. បង្កើតតែមួយ.
១៥ ក អេសាយ ៥១:១១; អាលម៉ា ៤០:១២.
១៦ ក លូកា ២៣:៤៣; អាលម៉ា ៤០:១១–១២. ស.ប. ស្ថានបរមសុខ.
ខ មរមន ៩:១៣.
១៧ ក ២ នីហ្វៃ ៩:១០–១៣.
ខ អេសេ. ៣៧:១–១៤.
គ គ. និង ស. ៩៣:៣៣–៣៤.
ឃ ស.ប. សេចក្ដីអំណរ.
១៨ ក អេសាយ ៦១:១. ស.ប. សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់.
១៩ ក គ. និង ស. ៧៦:៧២–៧៤.
ខ ស.ប. ដំណឹងល្អ.
គ ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
ឃ ស.ប. ប្រែចិត្ត, ការប្រែចិត្ត.

២០ ប៉ុន្តែចំពោះពួកទុច្ចរិតវិញ នោះទ្រង់ពុំបានយាងទៅជួបទេ ហើយនៅក្នុងចំណោមពួកទមិលល្មើស និងពួកដែលមិនប្រែចិត្ត ដែលបាន បង្ខូចខ្លួនកាលនៅក្នុងសាច់ឈាម នោះសម្លេងរបស់ទ្រង់ពុំបានបន្លឺឡើងឡើយ;

២១ រីឯពួកបះបោរដែលបដិសេធទីបន្ទាល់ និងពាក្យព្រមានទាំងឡាយ នៃពួកព្យាការីពីបុរាណ ក៏ពុំបានឃើញវត្តមានរបស់ទ្រង់ ឬ សម្លឹងមើលព្រះភ័ក្ត្ររបស់ទ្រង់ដែរ ។

២២ កន្លែងដែលពួកគេនៅនោះសេចក្ដីងងឹតសោយរាជ្យ ប៉ុន្តែនៅក្នុងចំណោមពួកសុចរិតវិញ នោះមានសេចក្ដីសុខសាន្ត;

២៣ ហើយពួកបរិសុទ្ធមានចិត្តអរសប្បាយចំពោះសេចក្ដីប្រោសលោះរបស់គេ ហើយលុតជង្គង់ចុះ ហើយទទួលស្គាល់ព្រះរាជបុត្រា នៃព្រះថា ជាព្រះដ៏ប្រោសលោះ និងជាព្រះដ៏ប្រោសគេឲ្យរួចពីសេចក្ដីស្លាប់ និងពីច្រវាក់ទាំងឡាយនៃស្ថាននរក ។

២៤ មុខមាត់គេភ្លឺចែងចាំង ហើយរស្មីពីវត្តមាននៃព្រះអម្ចាស់បានសណ្ឋិតលើពួកគេ ហើយពួកគេបានច្រៀងសរសើរដំកើងដល់ព្រះ នាមដ៏បរិសុទ្ធរបស់ទ្រង់ ។

២៥ ខ្ញុំមានចិត្តអស្ចារ្យ ព្រោះខ្ញុំបានយល់ថាព្រះអង្គសង្គ្រោះទ្រង់បានចំណាយពេលអស់បីឆ្នាំ ក្នុងការងារបំរើរបស់ទ្រង់ ក្នុងចំណោម ពួកសាសន៍យូដា និងអស់អ្នកដែលនៅក្នុងវង្សអ៊ីស្រាអែល ដោយបានខ្នះខ្នែងព្យាយាមបង្រៀនគេ ពីដំណឹងល្អដ៏នៅអស់កល្បអស់កាល ជានិច្ច ហើយហៅគេឲ្យមានការប្រែចិត្ត;

២៦ ហើយទោះជាទ្រង់បានធ្វើកិច្ចការដ៏អស្ចារ្យទាំងឡាយ និងអព្ភូតហេតុទាំងឡាយ និងការប្រកាសប្រាប់ពីសេចក្ដីពិតក៏ដោយគង់តែ មានតែបន្តិចទេ ដែលបានស្ដាប់តាមសម្លេងទ្រង់ ហើយបានអរសប្បាយចំពោះវត្តមានរបស់ទ្រង់ ហើយបានទទួលសេចក្ដីសង្គ្រោះ ពីព្រះហស្តរបស់ទ្រង់ ។

២៧ ប៉ុន្តែការងារបំរើរបស់ទ្រង់នៅក្នុងចំណោមអស់អ្នកដែលស្លាប់វិញ នោះមានកំណត់ពេលដ៏ខ្លី រវាងការឆ្កាងនឹងដំណើរដែលទ្រង់ មានព្រះជន្មរស់ឡើងវិញ;

២៨ ខ្ញុំបានគិតពិចារណាពីពាក្យសំដីរបស់ពេត្រុស ដែលលោកបាននិយាយថា ព្រះរាជបុត្រានៃព្រះបានផ្សាយដល់ពួកវិញ្ញាណ ដែល ជាប់ឃុំ ជាពួកអ្នកដែលពីដើមមិនព្រមជឿ គឺក្នុងខណៈដែលសេចក្ដីអត់ធ្មត់របស់ព្រះ បានរង់ចាំនៅជំនាន់លោកណូអេ — ហើយម្ដេចក៏ ទ្រង់អាចផ្សាយដល់ពួកវិញ្ញាណ ហើយប្រព្រឹត្តការងារដែលចាំបាច់ នៅចំណោមពួកគេបាន ក្នុងវេលាដ៏ខ្លីនោះ ។

២៩ ហើយនៅពេលខ្ញុំកំពុងតែគិតពិចារណា នោះស្រាប់តែភ្នែកខ្ញុំបានបើក ហើយយោបល់ខ្ញុំបានភ្ញាក់ឡើង ហើយខ្ញុំបានយល់ថាព្រះ អម្ចាស់ទ្រង់ពុំបានយាងទៅជួបពួកទុច្ចរិត និងពួកអ្នកដែលមិនព្រមជឿ ដែលបានបដិសេធសេចក្ដីពិត ដើម្បីទៅបង្រៀនគេ ដោយអង្គ ទ្រង់នោះឡើយ;

៣០ ប៉ុន្តែមើលចុះ ពីចំណោមពួកសុចរិត នោះទ្រង់បានរៀបចំពលរបស់ទ្រង់ ហើយបានតាំងសារទូតទាំងឡាយ គឺបំពាក់ដោយ អំណាច និងសិទ្ធិអំណាច ហើយបានអនុញ្ញាតឲ្យពួកគេចេញទៅ ហើយនាំពន្លឺនៃដំណឹងល្អទៅឲ្យពួកគេ ដែលនៅក្នុងសេចក្ដីងងឹត គឺទៅដល់គ្រប់ អស់ទាំងវិញ្ញាណនៃមនុស្សលោក; ហើយដំណឹងល្អត្រូវបានផ្សាយដល់ពួកអ្នកស្លាប់ តាមបែបដូច្នោះហើយ ។

៣១ ហើយពួកសារទូតដែលបានរើសឡើងនោះ បានចេញទៅប្រកាសប្រាប់ពីថ្ងៃ ដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ ហើយប្រកាស ប្រាប់ពីឥស្សរភាពដល់ពួកជាប់ឃុំឃាំង ដែលជាប់ចំណង គឺដល់អស់អ្នកណាដែលព្រមប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន ហើយទទួលយកដំណឹងល្អ ។

៣២ ដំណឹងល្អត្រូវបានផ្សាយតាមបែបដូច្នោះហើយ ដល់ពួកអ្នកដែលស្លាប់ ក្នុងអំពើបាបទាំងឡាយរបស់ខ្លួន ដោយគ្មាន

២០ *ក* អាលម៉ា ៤០:១៣–១៤.
ស.ប. ស្ថាននរក; ទុច្ចរិត, អំពើទុច្ចរិត.
*ខ* ១ នីហ្វៃ ១០:២១.
២២ *ក* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
*ខ* ស.ប. សេចក្ដីសុខសាន្ត.
២៣ *ក* ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
*ខ* រ៉ូម ១៤:១១; ម៉ូសាយ ២៧:៣១.
*គ* ២ នីហ្វៃ ១:១៣; អាលម៉ា ១២:១១.
២៤ *ក* ទំនុក. ១០៤:១–២; អេសាយ ៦០:១៩; វិវរ. ២២:៥; យ.ស. — ប្រវត្តិ ១:១៧.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
*ខ* ស.ប. ច្រៀង.
២៦ *ក* ១ នីហ្វៃ ១១:២៨.
២៧ *ក* ម៉ាកុស ៨:៣១.
២៩ *ក* គ. និង ស. ៧៦:១២.
៣០ *ក* លូកា ២៤:៤៩.
*ខ* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ.
*គ* គ. និង ស. ១:២.
៣១ *ក* អេសាយ ៦១:២; លូកា ៤:១៧–១៩.
*ខ* ស.ប. ឥស្សរភាព.
៣២ *ក* យ៉ូហាន ៨:២១–២៤.

[ខ]ការចេះដឹងពី សេចក្ដីពិត ឬនៅក្នុងការរំលង ដោយបានបដិសេធពួកព្យាការី ។

៣៣ ពួកគេត្រូវបានបង្រៀនឲ្យមាន[ក]សេចក្ដីជំនឿជឿដល់ព្រះ, ការប្រែចិត្តពីអំពើបាប, [ខ]បុណ្យជ្រមុជទឹកជំនួស សំរាប់[គ]ការផ្ដាច់បាប, [ឃ]អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ,

៣៤ ហើយគ្រប់ទាំងគោលការណ៍ផ្សេងៗទៀតនៃដំណឹងល្អ ដែលជាចាំបាច់សំរាប់ឲ្យគេដឹង ដើម្បីឲ្យខ្លួនគេមានលក្ខណៈគ្រប់គ្រាន់ ប្រយោជន៍ឲ្យពួកគេអាចបានទទួល[ក]ការជំនុំជំរះ តាមមនុស្សក្នុងសាច់ឈាម ប៉ុន្តែរស់តាមព្រះ ក្នុងវិញ្ញាណវិញ ។

៣៥ ហើយហេតុនោះ ទើបបានធ្វើឲ្យដឹងក្នុងចំណោមមនុស្សស្លាប់ ទាំងអ្នកតូច ទាំងអ្នកធំ ទាំងពួកអ្នកឥតសុចរិតព្រម ទាំងពួកអ្នក ស្មោះត្រង់ដែរ ថាសេចក្ដីប្រោសលោះត្រូវបាននាំមក តាមរយៈ[ក]ការបូជានៃព្រះរាជបុត្រានៃព្រះនៅលើ[ខ]ឈើឆ្កាង ។

៣៦ ដូច្នោះហើយ ទើបបានធ្វើឲ្យដឹងថា ព្រះដ៏ប្រោសលោះរបស់យើង ទ្រង់បានចំណាយពេល ក្នុងកាលទ្រង់ធ្វើដំណើរទៅស្ថានឃុំ [ក]ព្រលឹងមនុស្សស្លាប់ ដោយបង្គាប់ និងរៀបចំវិញ្ញាណនៃពួកព្យាការីដែលស្មោះត្រង់ ដែលបានធ្វើទីបន្ទាល់អំពីព្រះអង្គ កាលនៅក្នុង សាច់ឈាម;

៣៧ ប្រយោជន៍ឲ្យពួកគេអាចនាំសារអំពីសេចក្ដីប្រោសលោះទៅដល់ពួកអ្នកស្លាប់ទាំងអស់ ដែលទ្រង់ពុំអាចទៅជួប ដោយព្រះអង្គ ផ្ទាល់បាន ពីព្រោះមកពី[ក]ការបះបោរ និងការរំលងរបស់ពួកគេ ថាដោយសារការងារបំរើនៃពួកអ្នកបំរើរបស់ទ្រង់ នោះពួកគេអាចបានឮ ព្រះបន្ទូលរបស់ទ្រង់ដែរ ។

៣៨ នៅក្នុងចំណោមអ្នកធំ និងអ្នកពូកែទាំងឡាយ ដែលប្រជុំគ្នានៅក្នុងជំនុំនៃពួកសុចរិតដ៏ធំក្រៃ នោះមានលោក[ក]អ័ដាម ជាបិតាគឺជាអ្នកពីចាស់បុរាណ ហើយជាបិតានៃមនុស្សទាំងអស់ ។

៣៩ ហើយនាង[ក]អេវ៉ាដ៏ឧត្ដម ជាមាតារបស់យើង ព្រមទាំងបុត្ររបស់នាងជាច្រើន ដែលមានចិត្តស្មោះត្រង់ ដែលបានរស់នៅក្នុងជំនាន់ នានា ហើយបានថ្វាយបង្គំព្រះដ៏ពិត ហើយមានព្រះជន្មរស់នៅ ។

៤០ [ក]អេបិល គឺជា[ខ]ទុក្ករបុគ្គលទីមួយ ក៏នៅទីនោះដែរ ព្រមទាំង[គ]សេតផង ជាប្អូនប្រុសលោក ជាអ្នកពូកែម្នាក់ ដែលមាន[ឃ]រូបដូចឪពុក របស់ គាត់បេះបិទ គឺលោកអ័ដាម ។

៤១ [ក]ណូអេ ដែលបានព្រមានប្រាប់ពីទឹកជន់; [ខ]សេម ជា[គ]សង្ឃជាន់ខ្ពស់ដ៏ធំ; [ឃ]អ័ប្រាហាំ ជាបិតានៃពួកស្មោះត្រង់; [ង]អ៊ីសាក [ច]យ៉ាកុប និង[ឆ]ម៉ូសេ ជាអ្នកចែងច្បាប់ដ៏ធំ ដល់សាសន៍អ៊ីស្រាអែល;

៤២ និង[ក]អេសាយ ដែលបានប្រកាសប្រាប់ដោយពាក្យព្យាករណ៍ថា ព្រះដ៏ប្រោសលោះត្រូវបានចាក់ប្រេងតាំង ដើម្បីនឹងប្រោសមនុស្ស ដែលមានចិត្តសង្រេង ហើយប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់ពួកជាប់[ខ]ឃុំឃាំង ហើយពីការបើក[គ]គុកដោះលែងដល់អ្នកដែលជាប់ ចំណង គឺលោកក៏នៅទីនោះដែរ ។

៤៣ មានថែមទៀត គឺ[ក]អេសេគាល ដែលត្រូវបានបង្ហាញឲ្យឃើញក្នុងការនិមិត្ត នូវច្រកភ្នំទាំងឡាយ ដែលពេញដោយ[ខ]ឆ្អឹងខ្មោច ដែល នឹងត្រូវបំពាក់ពីលើដោយសាច់ ដើម្បីឲ្យចេញមកម្ដងទៀត ក្នុង[គ]ដំណើររស់ឡើងវិញនៃមនុស្សស្លាប់ ទៅជាមនុស្សរស់;

៣២ *ខ* គ. និង ស. ១២៨:៥.
ស.ប. ជំរិះ.
៣៣ *ក* ម. នៃ ស. ១:៤.
ស.ប. សេចក្ដីជំនឿ.
*ខ* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក —
បុណ្យជ្រមុជ ទឹកជំនួសមនុស្សស្លាប់;
ពិធីបរិសុទ្ធទាំងឡាយ —
ពិធីបរិសុទ្ធជំនួស.
*គ* ស.ប. ការផ្ដាច់បាប.
*ឃ* ស.ប. អំណោយទានជាព្រះ
វិញ្ញាណបរិសុទ្ធ.
៣៤ *ក* ស.ប. សេចក្ដីជំនុំជំរះ
ចុងក្រោយបំផុត.
៣៥ *ក* អាលម៉ា ៣៤:៩–១៦.
ស.ប. ធ្វើឲ្យធួន, ដង្វាយធួន;
បូជា, យញ្ញបូជា.
*ខ* ស.ប. ឈើឆ្កាង; ការឆ្កាង.
៣៦ *ក* គ. និង ស. ១៣៨:៥៧.
៣៧ *ក* គ. និង ស. ១៣៨:២០.
ស.ប. ការបះបោរ.
៣៨ *ក* ស.ប. អ័ដាម.
៣៩ *ក* ម៉ូសេ ៤:២៦.
ស.ប. នាងអេវ៉ា.
៤០ *ក* ស.ប. អេបិល.
*ខ* ស.ប. ធ្វើទុក្ករកម្ម, ទុក្ករកម្ម.
*គ* ស.ប. សេត.
*ឃ* លោកុ. ៥:៣; ម៉ូសេ ៦:១០.
៤១ *ក* ស.ប. ណូអេ,
អយ្យកោក្នុងព្រះគម្ពីរប៊ីប.
*ខ* ស.ប. សិម.
*គ* ស.ប. សង្ឃជាន់ខ្ពស់.
៤១ *ឃ* លោកុ. ១៧:១–៨.
ស.ប. អ័ប្រាហាំ.
*ង* លោកុ. ២១:១–៥.
ស.ប. អ៊ីសាក.
*ច* លោកុ. ៣៥:៩–១៥.
ស.ប. យ៉ាកុប,
កូនប្រុសរបស់អ៊ីសាក.
*ឆ* ស.ប. ម៉ូសេ.
៤២ *ក* ស.ប. អេសាយ.
*ខ* អេសាយ ៦១:១–២.
*គ* ស.ប. ស្ថាននរក.
៤៣ *ក* ស.ប. អេសេគាល.
*ខ* អេសេ. ៣៧:១–១៤.
*គ* ស.ប. ដំណើររស់ឡើងវិញ.

៤៤ [ក]ដានីយ៉ែល ដែលបានឃើញ ហើយប្រាប់ទុកជាមុន
អំពីការតាំងឡើង[ខ]នូវនគរនៃព្រះ នៅថ្ងៃចុងក្រោយ ដែលមិនត្រូវ
បំផ្លាញចោល ឬឲ្យទៅរាស្ត្រផ្សេងឡើយ;
៤៥ [ក]អេលីយ៉ាស ដែលបាននៅជាមួយលោកម៉ូសេ
នៅលើភ្នំនៃ[ខ]ការប្រែរូប;
៤៦ ហើយ[ក]ម៉ាឡាគី ជាព្យាការីដែលបានធ្វើទីបន្ទាល់អំពីការ
មករបស់លោក[ខ]អេលីយ៉ា — អំពីអ្នកដែលម៉ូរ៉ូណៃបាននិយាយ
ទៅកាន់ ព្យាការី យ៉ូសែប ស្ម៊ីធ ដោយប្រកាស
ប្រាប់ថាលោកនឹងមកមុនការចាប់ផ្ដើមនៅ[គ]ថ្ងៃដ៏ធំហើយស្ញែ
ងខ្លាចរបស់ព្រះអម្ចាស់ — លោកក៏ នៅទីនោះដែរ ។
៤៧ ព្យាការីអេលីយ៉ាត្រូវដាក់នៅក្នុង[ក]ចិត្តនៃកូនចៅ នូវសេច
ក្ដីសន្យា ដែលបានធ្វើដល់ពួកឪពុករបស់ពួកគេ,
៤៨ ដោយប្រាប់ពីមុននូវ[ក]កិច្ចការដ៏ធំដែលត្រូវធ្វើ នៅក្នុង
[ខ]ព្រះវិហារទាំងឡាយនៃព្រះអម្ចាស់ នៅ[គ]គ្រាកាន់កាប់ត្រួតត្រា
នៃពេលពេញកំ ណត់ គឺសំរាប់សេចក្ដីប្រោសលោះដល់ពួកអ្នក
ស្លាប់ និងការ[ឃ]ភ្ជាប់កូនចៅទៅឯមាតាបិតាគេ ក្រែងលោផែនដី
ទាំងមូលនឹងត្រូវកំទេច សូន្យឈឹង ក្នុងកាលទ្រង់យាងមក ។
៤៩ គ្រប់អ្នកទាំងនេះ ព្រមទាំងមនុស្សជាច្រើនទៀត គឺ[ក]ពួក
ព្យាការី ដែលបានរស់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ហើយ
បានធ្វើទី បន្ទាល់អំពីការយាងមកនៃព្រះរាជបុត្រានៃព្រះ គេបាន
ជួបជុំគ្នាក្នុងជំនុំដ៏ធំទូលំទូលាយ ហើយបានរង់ចាំសេចក្ដីដោះលែង
របស់ពួកគេ,
៥០ ត្បិតពួកអ្នកស្លាប់បានគិតថា ការបាត់[ក]វិញ្ញាណគេដ៏យូរលង់
ពីរូបកាយ[ខ]គេនោះជាសេវកភាព ។

៥១ ពួកអ្នកទាំងនេះហើយដែលព្រះអម្ចាស់បានបង្រៀន ហើយ
បានប្រទានដល់ពួកគេ ឲ្យមាន[ក]អំណាចចេញមក បន្ទាប់ដែលទ្រង់
មាន ព្រះជន្មរស់ពីស្លាប់ឡើងវិញ ដើម្បីឲ្យចូលទៅក្នុងនគររបស់
ព្រះវរបិតាទ្រង់ គឺនៅទីនោះ នឹងបានពាក់ដោយ[ខ]អមតភាព
និង[គ]ជីវិតដ៏នៅ អស់កល្បជានិច្ច ទុកជាមកុដ,
៥២ ហើយចាប់តាំងពីពេលនោះទៅ នឹងបន្តការងាររបស់គេ
ដែលបានសន្យាដោយព្រះអម្ចាស់ ហើយទៅជាអ្នកទទួលទាននូវគ្រប់
អស់ទាំង[ក]ព្រះពរ ដែលបានទុកសំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់ ។
៥៣ ព្យាការីយ៉ូសែប ស្ម៊ីធ និង ហៃរុម ស្ម៊ីធ ជាឪពុកខ្ញុំ,
ព្រិកហាំ យ៉ង់, យ៉ូហាន ថេលើរ, វិលហ្វូឌ វូឌរុហ្វ, និង
ពួកវិញ្ញាណជំរើសៗឯ ទៀត ដែលបាន[ក]រក្សាទុក ឲ្យមក
នៅពេលពេញកំណត់ ដើម្បីចូលរួមក្នុងការដាក់[ខ]គ្រឹះនៃកិច្ចការ
ដ៏ធំ នៅថ្ងៃចុងក្រោយ,
៥៤ ព្រមទាំងការកសាងព្រះវិហារទាំងឡាយ និងការ
ប្រព្រឹត្តិនៃពិធីទាំងឡាយនៅទីនោះ សំរាប់សេចក្ដីប្រោសលោះ
ដល់[ក]ពួកអ្នកស្លាប់ នោះក៏នៅឯស្ថានវិញ្ញាណ ។
៥៥ ខ្ញុំបានសង្កេតឃើញថា ពួកគេនៅក្នុងចំណោម[ក]ពួកឧត្តុង
ឧត្ដម និងពួកអ្នកដ៏ដែលបាន[ខ]រើសតាំងពីដើមដំបូងមក ឲ្យធ្វើជា
អ្នកត្រួតត្រា ក្នុងសាសនាចក្រនៃព្រះ ។
៥៦ ចាប់តាំងពីមុនគេចាប់កំណើត នោះពួកគេ ជាមួយនឹងពួក
អ្នកផ្សេងទៀត បានទទួលមេរៀនមុនដំបូងនានា នៅពិភពនៃ
ពួកវិញ្ញាណ ហើយត្រូវ[ក]បានរៀបចំឲ្យមក [ខ]នៅពេលកំណត់នៃព្រះ
ដើម្បីធ្វើការងារនៅក្នុង[គ]ចំការទំពាំងបាយជូររបស់ទ្រង់ សំរាប់សេច
ក្ដីសង្គ្រោះ ដល់ព្រលឹងនៃមនុស្សលោក ។

៤៤ ក ស.ប. ដានីយ៉ែល.
ខ ដានី. ២:៤៤–៤៥.
ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
៤៥ ក ស.ប. អេលីយ៉ាស.
ខ ស.ប. ការប្រែរូប.
៤៦ ក ម៉ាឡាគី ៤:៥–៦;
យ.ស. — ប្រវត្តិ ១:៣៦–៣៩.
ស.ប. ម៉ាឡាគី.
ខ គ. និង ស. ១១០:១៣–១៥.
ស.ប. អេលីយ៉ា.
គ ស.ប. ការយាងមកលើកទីពីរនៃព្រះ
យេស៊ូវគ្រីស្ទ.
៤៧ ក គ. និង ស. ១២៨:១៧.
៤៨ ក ស.ប. សេចក្ដីសង្គ្រោះ
សំរាប់មនុស្សស្លាប់.
ខ ស.ប. ព្រះវិហារបរិសុទ្ធ,
ដំណាក់នៃព្រះអម្ចាស់.
គ ស.ប. គ្រាកាន់កាប់ត្រួតត្រា.
ឃ ស.ប. ត្រួសារ —
ត្រួសារដ៏នៅអស់កល្បជានិច្ច; ភ្ជាប់,
ការភ្ជាប់.
៤៩ ក ហេលេ. ៨:១៩–២២.
៥០ ក ស.ប. វិញ្ញាណ.
ខ គ. និង ស. ៤៥:១៧.
៥១ ក ១ កូរិន. ៦:១៤;
អាលម៉ា ៤០:១៩–២១.
ខ ស.ប. អមតៈ, អមតភាព.
គ គ. និង ស. ២៩:៤៣.
ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៥២ ក អេសាយ ៦៤:៤; ១ កូរិន. ២:៩;
គ. និង ស. ១៤:៧.
៥៣ ក ស.ប. ការតែងតាំងមុនកំណើតលោ
កិយ.
ខ គ. និង ស. ៦៤:៣៣.
៥៤ ក ស.ប. ពិធីបរិសុទ្ធទាំងឡាយ —
ពិធីបរិសុទ្ធជំនួស.
៥៥ ក អ័ប្រា. ៣:២២–២៤.
ខ ស.ប. ការតែងតាំងមុនកំណើតលោ
កិយ.
៥៦ ក យ៉ូប ៣៨:៤–៧;
អាលម៉ា ១៣:៣–៧.
ខ កិច្ចការ ១៧:២៤–២៧.
គ យ៉ាកុប ៦:២–៣.
ស.ប. ចំការទំពាំងបាយជូរនៃព្រះ
អម្ចាស់.

៥៧ ខ្ញុំបានឃើញថា [ក]ពួកអែលឌើរដែលស្មោះត្រង់នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ គឺកាលពួកគេចាកចេញពីជីវិតនេះទៅនោះគេ នៅតែបន្តការងារគេ ក្នុងការផ្សាយដំណឹងល្អអំពីការប្រែចិត្ត និងសេចក្ដីប្រោសលោះ តាមរយៈដង្វាយធួននៃព្រះរាជបុត្រាបង្កើតតែមួយ នៃព្រះ នៅក្នុងចំណោមអស់អ្នកដែលនៅក្នុង[ខ]សេចក្ដីងងឹត និងនៅក្រោមចំណងនៃអំពើបាប នៅស្ថានឃុំព្រលឹងមនុស្សស្លាប់ដ៏ធំ ។

៥៨ ពួកអ្នកស្លាប់ណាដែលប្រែចិត្ត នោះនឹង[ក]បានប្រោសលោះ តាមរយៈការគោរពតាម[ខ]ពិធីទាំងឡាយនៃដំណាក់របស់ព្រះ ។

៥៩ ហើយបន្ទាប់ពីពួកគេបានសងទោសនៃអំពើរំលងទាំងឡាយរបស់ពួកគេ ហើយត្រូវបាន[ក]សំអាត[ខ]ឲ្យបានស្អាត នោះនឹងបានទទួល រង្វាន់តាមការដែលគេបានប្រព្រឹត្ត ព្រោះពួកគេជាអ្នកគ្រងសេចក្ដីសង្គ្រោះទុកជាមរតក ។

៦០ ការនិមិត្តអំពីសេចក្ដីប្រោសលោះដល់មនុស្សស្លាប់ត្រូវបានបើកសំដែងដល់ខ្ញុំយ៉ាងដូច្នោះហើយ ហើយខ្ញុំថ្លែងទីបន្ទាល់ ហើយខ្ញុំដឹងថា ទីបន្ទាល់នេះ[ក]ពិត តាមរយៈព្រះពរនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ គឺដូច្នោះមែន។ អាម៉ែន ៕

# សេចក្ដីប្រកាសជាផ្លូវការ ទី១

*ជូនចំពោះលោកអ្នកទូទៅសូមជ្រាបៈ*

ការឃោសនាពត៌មានត្រូវបានបញ្ជូនទៅ សំរាប់គោលបំណងខាងនយោបាយ ពីទីក្រុងសលត៍លេក ដែលបានផ្សាយទូទៅ ដោយថ្លែងថា គណៈកម្មការនៃរដ្ឋយូថាហ៍ ក្នុងសេចក្ដីរាយការណ៍ថ្មីៗរបស់គេទៅកាន់លេខាធិការនៃក្រសួងមហាផ្ទៃ រាយការណ៍ថាអាពាហ៍ពិពាហ៍ ខាងប្រពន្ធច្រើន នៅតែប្រព្រឹត្តនៅឡើយ ហើយថាអាពាហ៍ពិពាហ៍បែបនេះមានដល់ទៅ៤០ ឬច្រើនជាងនេះ ដែលបានចូលពិធីធ្វើនៅ រដ្ឋយូថាហ៍ ចាប់តាំងពីខែមិថុនា ឬកំឡុងឆ្នាំនេះ ហើយថានៅក្នុងការនិយាយទូទៅ នោះពួកអ្នកដឹកនាំនៃ សាសនាចក្របានបង្រៀន លើកទឹកចិត្ត ហើយជំរុញឲ្យមានការប្រព្រឹត្តពហុពន្ធភាពតទៅ —

ហេតុដូច្នេះហើយ ខ្ញុំ ជាប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ សូមប្រកាសប្រាប់តាមមាត៌ានេះ គឺតាម បែបបទដ៏មុតមាំបំផុត ថាការចោទទាំងប៉ុន្មាននោះសុទ្ធតែមិនពិត ។ យើងខ្ញុំពុំបានបង្រៀនអំពីពហុពន្ធភាព ឬអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន ឬក៏អនុញ្ញាតិឲ្យមនុស្សណាមួយចូលក្នុងពិធីនោះឡើយ ហើយខ្ញុំបដិសេធថា ពុំមានអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើនដល់ទៅចំនួន៤០ ឬក៏ក្នុងចំនួនណាក្ដីនៅគ្រានោះ បានរៀបពិធីនៅក្នុងព្រះវិហារទាំងឡាយរបស់យើង ឬនៅក្នុងកន្លែងណាក្ដី នៅក្នុងទឹកដីយូថាហ៍ឡើយ ។

មានរឿងមួយដែលបានរាយការណ៍ ក្នុងកាលមនុស្សចោទថា អាពាហ៍ពិពាហ៍នោះត្រូវបានចូលធ្វើពិធីឡើង នៅក្នុងគេហដ្ឋានខាងអំណោយទានពិសិដ្ឋ នៅទីក្រុងសលត៍លេក នៅនិទាឃរដូវក្នុងឆ្នាំ១៨៨៩ ប៉ុន្តែខ្ញុំពុំអាចរកឃើញថានរណាមួយបានប្រព្រឹត្តពិធីនោះឡើយ; អ្វីដែលបានសំរេចតាមរបៀបនោះ នោះខ្ញុំពុំបានដឹងទេ ។ មកពីការចោទនេះដែលថាបានកើតឡើង គឺតាមការបង្គាប់របស់ខ្ញុំ នោះគេហដ្ឋានខាងអំណោយទានពិសិដ្ឋត្រូវបានរើចេញដោយឥតបង្អង់ ។

ដរាបណាដែលមានច្បាប់ចែងឡើងដោយសភា ហាមប្រាមមិនឲ្យមានអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន គឺជាច្បាប់ដែលបានប្រកាសថា ជាច្បាប់ពេញលេញ ដោយតុលាការខ្ពស់បំផុត នោះខ្ញុំសូមប្រកាសប្រាប់ពីបំណងចិត្តខ្ញុំ ក្នុងការយល់ព្រមគោរពតាមច្បាប់ទាំងនោះ ហើយនឹងប្រើឥទ្ធិពលដែលខ្ញុំមាននឹងសមាជិកនៃសាសនាចក្រ ដែលខ្ញុំត្រួតត្រាលើ ដើម្បីឲ្យពួកគេប្រព្រឹត្តតាមបែបនោះដែរ ។

គ្មានអ្វីនៅក្នុងការបង្រៀនរបស់ខ្ញុំទៅកាន់សាសនាចក្រ ឬនៅក្នុងការបង្រៀនរបស់សហការីរបស់ខ្ញុំ នៅគ្រាដែលបានពោលដល់នោះ ដែលអាចបកស្រាយថាបានបង្ខំ ឬលើកទឹកចិត្តឲ្យប្រព្រឹត្តពហុពន្ធភាពនោះឡើយ; ហើយកាលណាមានអែលឌើរក្នុងសាសនាចក្រ

៥៧ *ក* ស.ប. អែលឌើរ.
*ខ* ស.ប. ស្ថាននរក.
៥៨ *ក* ស.ប. ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.
*ខ* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
៥៩ *ក* អាលម៉ា ៥:១៧–២២. ស.ប. អត់ទោស, អភ័យទោស.
*ខ* ស.ប. កិច្ចការ.
៦០ *ក* ស.ប. សេចក្ដីពិត.

ណាម្នាក់ បានប្រើសំដីក្នុងការបង្រៀនដែលឃើញថាឲ្យន័យបែបនេះ អ្នកនោះត្រូវស្ដីបន្ទោសមួយរំពេច ។ ហើយឥឡូវនេះ ខ្ញុំប្រកាសទូទៅថាពាក្យទូន្មានរបស់ខ្ញុំទៅកាន់ពួកបរិសុទ្ធ គឺសូមឲ្យឈប់ចូលពិធីអាពាហ៍ពិពាហ៍ណា ដែលបានហាមប្រាមដោយច្បាប់នៃដែនដី ។

វិលហ្វឺឌ វូឌដ្រុព្វ
ប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

ប្រធាន ឡូរិនសូ ស្នូវ បានថ្លែងដូចដែលមានតទៅនេះថា៖

«ខ្ញុំសូមស្នើ ដោយទទួលស្គាល់ថា វិលហ្វឺឌ វូឌដ្រុព្វ ជាប្រធាននៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយ ជាបុរសមួយគត់នៅលើផែនដីនៅពេលនេះ ដែលកាន់កូនសោទាំងឡាយនៃពិធីភ្ជាប់ទាំងឡាយ នោះយើងគិតថាលោកមានសិទ្ធិអំណាចត្រឹមត្រូវ ដោយសារគុណធម៌នៃតំណែងរបស់លោក ដើម្បីចេញសេចក្ដីប្រកាសដែលបានអានឲ្យអ្នកស្ដាប់នោះ ហើយដែលចុះនៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៨៩០ ហើយថា ដោយសារសាសនាចក្រដែលបានប្រជុំក្នុងសន្និសីទទូទៅ នោះយើងសូមទទួលសេចក្ដីប្រកាសរបស់លោក ស្ដីអំពីអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើនទុកថាជាមានសិទ្ធិអំណាច ហើយមានអានុភាព» ។

ការបញ្ចេញមតិសូមឲ្យគាំទ្រការណ៍ដែលបានពោលដល់នោះ គឺជាឯកច្ឆន្ទ ។

ទីក្រុងសលត៍លេក រដ្ឋយូថាហ៍ ៦ តុលា ១៨៩០

ដំរីសចេញពីសុន្ទរកថាបីដោយ
ប្រធាន វិលហ្វឺឌ វូឌដ្រុព្វ
អំពីសេចក្ដីប្រកាសនេះ

ព្រះអម្ចាស់ទ្រង់នឹងមិនអនុញ្ញាតឲ្យខ្ញុំ ឬនរណាផ្សេងទៀត ដែលឈរជាប្រធាននៃសាសនាចក្រនេះ ដឹកនាំអ្នកឲ្យវង្វេងចេញឡើយ ។ គឺពុំមែននៅក្នុងកម្មវិធីឡើយ ។ គឺមិនមែននៅក្នុងព្រះហឫទ័យនៃព្រះឡើយ ។ បើសិនជាខ្ញុំខំធ្វើដូច្នោះ នោះព្រះអម្ចាស់ទ្រង់នឹងដក ខ្ញុំចេញពីកន្លែងខ្ញុំទៅហើយ ហើយទ្រង់ក៏នឹងប្រព្រឹត្តយ៉ាងដូច្នោះ ដល់អ្នកណាដែលខំដឹកនាំកូនចៅមនុស្សចេញពីព្រះបន្ទូលទាំងឡាយ នៃព្រះ និងចេញពីភារកិច្ចរបស់គេដែរ ។ (សន្និសីទទូទៅនៃសាសនាចក្រប្រចាំឆ្នាំទី៦១, នៅថ្ងៃច័ន្ទ ទី៦ ខែតុលា ឆ្នាំ១៨៩០, ទីក្រុង សលត៍លេក រដ្ឋយូថាហ៍ ។ បានរាយការណ៍នៅក្នុង *Deseret Evening News,* ថ្ងៃទី១១ ខែតុលា ឆ្នាំ១៨៩០, ទំព័រលេខ ២) ។

មិនសំខាន់ទេដែលអ្នកណាត្រូវរស់ ឬអ្នកណាត្រូវស្លាប់ ឬអ្នកណាត្រូវបានហៅឲ្យដឹកនាំសាសនាចក្រនេះ គឺពួកគេគ្រាន់តែត្រូវដឹកនាំ ដោយការបំផុសគំនិតពីព្រះដ៏មានមហិទ្ធិឫទ្ធិប៉ុណ្ណោះ ។ បើសិនជាពួកគេមិនធ្វើដូច្នោះទេ នោះពួកគេមិនអាចធ្វើបានឡើយ . . .។

នៅពេលឆាប់ៗនេះ ខ្ញុំបានទទួលវិវរណៈខ្លះៗ ហើយខ្លះៗទៀតសំខាន់ដល់ខ្ញុំ ហើយខ្ញុំនឹងប្រាប់អ្នក នូវអ្វីដែលព្រះអម្ចាស់ទ្រង់បាន មានព្រះបន្ទូលមកកាន់ខ្ញុំ ។ ខ្ញុំសូមរំឭកប្រាប់អ្នកពីអ្វីដែលហៅថាសេចក្ដីប្រកាស . . .។

ព្រះអម្ចាស់ទ្រង់បានប្រាប់ខ្ញុំឲ្យសួរពួកបរិសុទ្ធនូវសំណួរមួយ ហើយទ្រង់ក៏បានប្រាប់ខ្ញុំថា បើសិនជាពួកគេព្រមស្ដាប់តាមអ្វីដែលខ្ញុំប្រាប់ដល់ ពួកគេ ហើយឲ្យឆ្លើយសំណួរដែលខ្ញុំសួរគេ ដោយព្រះវិញ្ញាណ និងព្រះចេស្ដានៃព្រះ នោះពួកគេទាំងអស់គ្នានឹងឆ្លើយដូចគ្នា ហើយពួកគេ ទាំងអស់គ្នានឹងជឿដូចគ្នា ចំពោះការណ៍នេះ ។

នេះគឺជាសំណួរថា៖ តើអ្វីជាផ្លូវដ៏វាងវៃបំផុតសំរាប់ឲ្យពួកបរិសុទ្ធធ្វើ — តើត្រូវបន្តការប្រព្រឹត្តអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន ដោយ មាន

ការជំទាស់ពីច្បាប់នៃប្រទេស និងការជំទាស់ពីមនុស្សដល់ទៅ៦០លាននាក់, និងដោយត្រូវទទួលការរឹបអូស និងការបាត់ បង់ព្រះវិហារទាំងអស់, និងការបញ្ឈប់នូវពិធីទាំងអស់ដែលប្រព្រឹត្តនៅទីនោះផង, ទាំងសំរាប់ពួកអ្នកនៅរស់ និងសំរាប់ពួកអ្នកស្លាប់ផង ដែរ, និងការដាក់គុកនូវគណៈប្រធានទីមួយ និងពួក១២នាក់ និងមេគ្រួសារទាំងឡាយនៅក្នុងសាសនាចក្រ, និងការរឹបអូសទ្រព្យសម្បត្តិ ផ្ទាល់ខ្លួនរបស់ប្រជាជន (គ្រប់ការណ៍ទាំងអស់នេះនឹងបញ្ឈប់ការប្រព្រឹត្តអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន); ឬក៏បន្ទាប់ពីអ្វីៗដែលយើង បានប្រព្រឹត្ត ហើយរងទុក្ខ តាមរយៈការស្មោះចិត្តគោរពតាមគោលការណ៍នេះ យើងត្រូវឈប់ប្រព្រឹត្ត ហើយយល់ព្រមស្តាប់តាមច្បាប់ ហើយដោយការប្រព្រឹត្តនេះ ទើបអាចទុកឲ្យពួកព្យាការី ពួកសាវក និងពួកឪពុកនៅផ្ទះបាន ដើម្បីឲ្យពួកគេអាចបង្គាប់ប្រជាជន ហើយប្រព្រឹត្តការងារទាំងឡាយនៃ សាសនាចក្របាន ហើយព្រមទាំងទុកព្រះវិហារទាំងឡាយឲ្យនៅក្នុងកណ្តាប់ដៃនៃពួកបរិសុទ្ធ ដើម្បីឲ្យពួកគេអាចប្រព្រឹត្តពិធីទាំងឡាយ នៃដំណឹងល្អ ទាំងសំរាប់ពួកអ្នកនៅរស់ និងសំរាប់ពួកអ្នកស្លាប់ផងដែរឬ ?

ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ខ្ញុំ ដោយការនិមិត្ត និងវិវរណៈ នូវអ្វីដែលនឹងកើតឡើងជាពិតប្រាកដ បើសិនជាយើងមិនឈប់ប្រព្រឹត្តនេះ ។ បើសិនជាយើងមិនបានឈប់ទេ នោះអ្នកក៏មិនចាំបាច់ត្រូវការ . . . អ្នកណាមួយនៅក្នុងព្រះវិហារឡូកាន់ឡើយ; ព្រោះពិធីទាំងអស់នឹង ត្រូវឈប់ឈឹងពេញដែនដីស៊ីយ៉ូន ។ ចលាចលនឹងសោយរាជ្យពេញស្រុកអ៊ីស្រាអែល ហើយពួកបុរសជាច្រើននឹងត្រូវជាប់គុក ។ បញ្ហានេះនឹងមានមកលើសាសនាចក្រទាំងមូល ហើយយើងក៏នឹងត្រូវបង្ខំឲ្យឈប់ប្រព្រឹត្តជាមិនខានឡើយ ។ ឥឡូវនេះ នេះគឺជាសំណួរ ថាតើការប្រព្រឹត្តនោះត្រូវឈប់ដោយបែបនោះ ឬក៏តាមផ្លូវដែលព្រះអម្ចាស់ទ្រង់បានសំដែងប្រាប់ដល់យើង ហើយទុកពួកព្យាការី និងពួកសាវក និងពួកឪពុករបស់យើង ឲ្យនៅជាមនុស្សសេរី ហើយទុកព្រះវិហារទាំងឡាយឲ្យនៅក្នុងកណ្តាប់ដៃនៃប្រជាជន ដើម្បីឲ្យ ពួកអ្នកស្លាប់អាចបានប្រោសលោះ ។ មានមនុស្សមួយចំនួនធំហើយដែលត្រូវបានដោះលែងឲ្យរួចពីគុកនៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ដោយប្រជាជននេះ ហើយតើត្រូវឲ្យកិច្ចការ នោះមានតទៅ ឬឈប់មាន ? នេះគឺជាសំណួរដែលខ្ញុំសូមដាក់ខាងមុខពួកបរិសុទ្ធថ្ងៃចុង ក្រោយ ។ អ្នកត្រូវវិនិច្ឆ័យដោយខ្លួនឯងផ្ទាល់ ។ ខ្ញុំចង់ឲ្យអ្នកឆ្លើយសំណួរនោះសំរាប់ខ្លួនឯងផ្ទាល់ ។ ខ្ញុំនឹងមិនឆ្លើយទេ; ប៉ុន្តែខ្ញុំសូមប្រាប់អ្នកថា នោះច្បាស់លក្ខខ័ណ្ឌដែលយើងជា ប្រជាជនត្រូវប្រទះ បើសិនជាយើងពុំបានរើសផ្លូវដែលយើងបានរើសនោះ ។

. . . ខ្ញុំច្បាស់ជាបានឃើញអ្វីដែលនឹងកន្លងផុតទៅ បើសិនជាពុំបានសំរេចអ្វីមួយ ។ ខ្ញុំមានវិញ្ញាណនេះស្ថិតលើខ្ញុំជាយូរយារណាស់ មកហើយ ។ ប៉ុន្តែខ្ញុំចង់និយាយយ៉ាងនេះទៅវិញថា៖ ខ្ញុំគប្បីបណ្តោយឲ្យគេយកព្រះវិហារទាំងអស់ចេញពីកណ្តាប់ដៃយើងទៅ; ខ្ញុំគប្បី ទៅចូលគុកដោយខ្លួនឯង ហើយបណ្តោយឲ្យមនុស្សផ្សេងៗទៅដែរ បើសិនជាព្រះនៃស្ថានសួគ៌ទ្រង់បានបញ្ជាដល់ខ្ញុំ ឲ្យខ្ញុំប្រព្រឹត្តនូវអ្វីៗ ដែលខ្ញុំបានប្រព្រឹត្តនោះ; ហើយកាលពេលនោះមកដល់ នោះខ្ញុំត្រូវបានបញ្ជាឲ្យប្រព្រឹត្តបែបនោះ ការណ៍នោះគឺច្បាស់លាស់ដល់ខ្ញុំ ។ ខ្ញុំបានទៅចំពោះព្រះអម្ចាស់ ហើយខ្ញុំបានសរសេរនូវអ្វីដែលព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យឲ្យខ្ញុំសរសេរ . . .។

ខ្ញុំសូមផ្ញើការណ៍ទុកជាមួយនឹងអ្នក សំរាប់ឲ្យអ្នកសញ្ជឹងគិត ហើយពិចារណា ។ ព្រះអម្ចាស់ទ្រង់កំពុងធ្វើការជាមួយពួកយើង ។ (សន្និសីទប្រចាំស្តេកខែស, ក្រុងឡូកាន់ រដ្ឋយូថាហ៍, ថ្ងៃអាទិត្យ ទី១ ខែវិច្ឆិកា ឆ្នាំ១៨៩១, បានរាយការណ៍នៅក្នុង *Deseret Weekly,* ១៤ វិច្ឆិកា ១៨៩១) ។

ឥឡូវនេះ ខ្ញុំសូមប្រាប់អ្នកនូវអ្វីដែលបានសំដែងដល់ខ្ញុំ និងពីអ្វីដែលព្រះរាជបុត្រានៃព្រះបានធ្វើចំពោះការណ៍នេះ . . .។ ប្រាកដដូចជា ព្រះដ៏មានមហិទ្ធិឫទ្ធិទ្រង់មានព្រះជន្មរស់នៅ គឺគ្រប់ការណ៍ទាំងអស់នឹងកើតឡើងមែន បើសិនជាពុំបានប្រទានសេចក្តីប្រកាសនោះ មកទេ ។ ហេតុដូច្នេះហើយទើបព្រះរាជបុត្រានៃព្រះ ទ្រង់សព្វព្រះហឫទ័យឲ្យមានការណ៍នេះសំដែងដល់សាសនាចក្រ និងដល់ ពិភពលោក សំរាប់គោលបំណងទាំងឡាយ ដែលនៅក្នុងព្រះហឫទ័យរបស់ទ្រង់ ។ ព្រះអម្ចាស់ទ្រង់បានចេញបញ្ញត្តឲ្យតាំងក្រុងស៊ីយ៉ូន ។ ទ្រង់បានចេញបញ្ញត្តឲ្យធ្វើព្រះវិហារនេះឲ្យរួច ។ ទ្រង់បានចេញបញ្ញត្តថាសេចក្តីសង្គ្រោះដល់ពួកអ្នកនៅរស់ និងពួកអ្នកស្លាប់ ត្រូវបានប្រទានមក នៅក្នុងច្រកភ្នំទាំងឡាយ ។ ហើយព្រះដ៏មានមហិទ្ធិឫទ្ធិបានចេញបញ្ញត្តថា អារក្សនឹងមិនដែលបង្អាក់ការណ៍នោះ បានឡើយ ។ បើសិនជាអ្នកអាចយល់នូវការណ៍នោះ នោះហើយជាកូនសោចំពោះការណ៍នោះ ។ (ចេញពីសេចក្តីថ្លែងប្រចាំពិធី ឧទ្ទិសទី៦ នៃព្រះវិហារសល្តលេក, ខែមេសា ឆ្នាំ១៨៩៣ ។ ឯកសារបោះពុម្ពនូវពិធីឧទ្ទិស, ចេញពីប័ណ្ណសារនៃផ្នែកប្រវត្តិរបស់ សាសនាចក្រ, ទីក្រុងសល្តលេក រដ្ឋយូថាហ៍) ៕

---

# សេចក្តីប្រកាសជាផ្លូវការ ទី២

*ជូនចំពោះលោកអ្នកទូទៅសូមជ្រាប៖*

*នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨ សន្និសីទទូទៅប្រចាំឆ្នាំលើកទី១៤៨ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ការណ៍ដែលមានដូចតទៅនេះ ត្រូវបានថ្លែងដោយប្រធាន អែន អែលដុន ថែនណើរ ជាទីប្រឹក្សាទីមួយ ក្នុងគណៈប្រធានទីមួយ នៃសាសនាចក្រ ថា៖*

នៅដើមខែមិថុនាឆ្នាំនេះ គណៈប្រធានទីមួយបានប្រកាសប្រាប់ថា មានវិវរណៈមួយ ដែលបានទទួលដោយប្រធានស្ពែនសើរ ដ័បបុលយូ គីមបុល ដែលពន្យារព្រះពរទាំងឡាយខាងបព្វជិតភាព និងព្រះវិហារទៅដល់គ្រប់សមាជិកប្រុសៗទាំងអស់ ក្នុងសាសនាចក្រដែល

សក្ដិសម ។ ប្រធានគិមបុលបានសូមឲ្យខ្ញុំប្រាប់សន្និសីទថា បន្ទាប់ពីលោកបានទទួលវិវរណៈនេះ ដែលបានមកដល់លោក បន្ទាប់ពីបានភាវនា និងអធិស្ឋានជាយូរលង់ នៅក្នុងបន្ទប់ដ៏ពិសិដ្ឋទាំងឡាយក្នុងព្រះវិហារបរិសុទ្ធ នោះលោកបានថ្លែងប្រាប់ពីវិវរណៈនេះដល់ពួកទីប្រឹក្សា ដែលបានទទួលស្គាល់ ហើយអនុម័ត ។ ខណៈនោះ ទើបបានថ្លែងប្រាប់ដល់ក្រុមនៃពួកសាវក១២នាក់ ដែលបានអនុម័តដោយឯកច្ឆន្ទ ហើយបន្ទាប់មក ទើបបានថ្លែងប្រាប់ដល់គ្រប់ពួកអ្នកមានសិទ្ធិអំណាចទូទៅ ដែលបានអនុម័តដោយឯកច្ឆន្ទដូច្នោះដែរ ។

ប្រធានគិមបុលបានសូមឲ្យខ្ញុំអានសំបុត្រនេះនៅពេលឥឡូវនេះថាៈ

ថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៨
ជូនចំពោះអស់ទាំងពួកអ្នកកាន់តំណែងក្នុងបព្វជិតភាពទូទៅ និងប្រចាំភូមិនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពាសពេញពិភពលោក សូមជ្រាបៈ

ជូនចំពោះបងប្អូនប្រុសទាំងឡាយៈ

ប្រាកដដូចជាយើងបានធ្វើសាក្សីអំពីការពង្រីកកិច្ចការនៃព្រះអម្ចាស់នៅលើផែនដី នោះយើងមានចិត្តកតញ្ញូចំពោះប្រជាជនពី សាសន៍ជាច្រើន ដែលបានទទួលសារអំពីដំណឹងល្អដែលបានសាងឡើងវិញ ហើយបានចូលសាសនាចក្រក្នុងចំនួនដ៏ច្រើនឡើងៗ ។ ម្ល៉ោះហើយ ទើបការណ៍នេះបានបណ្ដាលឲ្យយើងមានសេចក្ដីប៉ងប្រាថ្នាចង់ពន្យារដល់សមាជិកគ្រប់រូបដែលសក្ដិសម នៅក្នុង សាសនាចក្រ ឲ្យមានឯកសិទ្ធិ និងព្រះពរទាំងឡាយ ដែលដំណឹងល្អផ្ដល់ ។

ដោយយល់ពីសេចក្ដីសន្យាទាំងឡាយ ដែលបានធ្វើដោយពួកព្យាការី និងពួកប្រធាននៃសាសនាចក្រពីមុនយើង ថានៅគ្រាណាមួយតាមផែនការដ៏អស់កល្បជានិច្ចរបស់ព្រះ នោះគ្រប់អស់ទាំងបងប្អូនប្រុសៗរបស់យើង ដែលសក្ដិសមអាចបានទទួលបព្វជិតភាព ហើយដោយបានឃើញនូវសេចក្ដីស្មោះត្រង់របស់អស់អ្នក ដែលបព្វជិតភាពត្រូវបានបដិសេធ នោះយើងបានទូលអង្វរយ៉ាងយូរលង់ និងដោយអស់ពីចិត្ត ជំនួសពួកគេទាំងនេះ ដែលជាបងប្អូនប្រុសរបស់យើងដែលស្មោះត្រង់ គឺបានចំណាយពេលជាច្រើនម៉ោង ក្នុង បន្ទប់ព្រះវិហារខាងលើ អំពាវនាវដល់ព្រះអម្ចាស់ សូមការណែនាំពីព្រះ ។

ទ្រង់បានឮពាក្យអធិស្ឋានទាំងឡាយរបស់យើង ហើយដោយវិវរណៈ ទើបបានបញ្ជាក់ថាថ្ងៃសន្យាដ៏យូរលង់ បានមកដល់ហើយ ក្នុងកាលបុរសដែលស្មោះត្រង់គ្រប់រូប និងសក្ដិសមនៅក្នុងសាសនាចក្រ អាចបានទទួលបព្វជិតភាព ព្រមទាំងអំណាចដើម្បីអនុវត្ត សិទ្ធិអំណាចពីព្រះ ហើយអាចមានចិត្តអរជាមួយពួកស្និទ្ធស្នាលរបស់ខ្លួន ចំពោះព្រះពរនានាដែលបានហូរមកពីបព្វជិតភាពនោះ ព្រមទាំងព្រះពរទាំងឡាយនៃព្រះវិហារផង ។ ហេតុដូច្នោះហើយ គ្រប់អស់ទាំងសមាជិកប្រុសៗក្នុងសាសនាចក្រ អាចបានតែងតាំងឲ្យកាន់បព្វជិតភាពបាន ដោយគ្មានគិតដល់សញ្ជាតិ ឬសម្បុរឡើយ ។ ពួកអ្នកដឹកនាំខាងបព្វជិតភាពត្រូវបានបង្គាប់ឲ្យដើរតាមច្បាប់នៃការសម្ភាសយ៉ាងល្អិតល្អន់ នូវបេក្ខជនទាំងអស់សំរាប់ការតែងតាំងឲ្យកាន់បព្វជិតភាពអើរ៉ុន ឬបព្វជិតភាពម៉ិលគីស្សាដែក ដើម្បីបញ្ជាក់ថាពួកគេសមនឹង បមាណិយ សំរាប់ភាពសក្ដិសម ។

យើងសូមប្រកាសដោយភាពម៉ឺងមាត់ថា ឥឡូវនេះ ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យដឹងនូវព្រះហឫទ័យដែលទ្រង់មាន ចំពោះការប្រទានពរដល់កូនចៅទាំងអស់របស់ទ្រង់ពាសពេញលើផែនដី ដែលស្ដាប់តាមសម្លេងនៃពួកអ្នកបំរើរបស់ទ្រង់ ដែលមានសិទ្ធិអំណាច ហើយ ត្រៀមខ្លួនដើម្បីទទួលព្រះពរគ្រប់ប្រការនៃដំណឹងល្អ ៕

ដោយស្មោះស្ម័គ្រ,

ស្ពែនសើរ ដ័បបុលយូ គិមបុល
អែន អែលដុន ថែនណើរ
ម៉ារីយ៉ុន ជី រ៉មនីយ

គណៈប្រធានទីមួយ

ដោយទទួលស្គាល់ថាស្ពែនសើរ ដ័បបុលយូ គិមបុល ជាព្យាការី អ្នកមើលឆុត និងជាអ្នកទទួលវិវរណៈ ហើយជាប្រធាននៃ

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះត្រូវបានស្នើថាយើង ដែលជាពួកជំនុំ សូមទទួលស្គាល់វិវរណៈនេះថាជាព្រះបន្ទូល និងព្រះហឫទ័យនៃព្រះអម្ចាស់ ។ ទាំងអស់គ្នាដែលយល់ព្រម សូមលើកដៃស្ដាំ ។ បើមានអ្នកណាជំទាស់ សូមឲ្យសំគាល់ដូច្នោះផង ។

*ការបញ្ចេញមតិសូមឲ្យគាំទ្រការណ៍ដែលបានពោលដល់នោះ គឺជាឯកច្ឆន្ទ ក្នុងការយល់ព្រម ។*

ទីក្រុងសលត៍លេក រដ្ឋយូថាហ៍ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៨ ៕

# មុក្តាដ៏មានតម្លៃមហិមា

ការជ្រើសរើសពីវិវរណៈ

ពីការបកប្រែ និងពីការនិពន្ធទាំងឡាយដោយ

យ៉ូសែប ស៊្មីធ

ជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈទីមួយចំពោះ

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃ

ពួកបរិសុទ្ធថ្ងៃចុងក្រោយ

# បុព្វកថា

មុក្ដាដ៏មានតម្លៃមហិមា គឺជាការជ្រើសរើសនូវឯកសារដ៏សំខាន់ទាំងឡាយ ដែលទាក់ទងទៅនឹងចំណុចសំខាន់ៗជាច្រើន អំពីសេចក្ដីជំនឿ និងគោលលទ្ធិនៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ វត្ថុទាំងនេះត្រូវបានផលិតដោយព្យាការី យ៉ូសែបស្ម៊ីធ ហើយបានបោះពុម្ពនៅក្នុងកាសែតទៀងទាត់ប្រចាំសាសនាចក្រ នៅសម័យលោក ។

ប្រជុំឯកសារទាំងឡាយលើកទីមួយ មានចំណងជើងថា មុក្ដាដ៏មានតម្លៃមហិមា ត្រូវបានធ្វើឡើងនៅឆ្នាំ ១៨៥១ ដោយអែលឌើរ ហ្វ្រាំងក្លិន ឌី រិចឺត្ស កាលនោះត្រូវជាសមាជិកក្នុងក្រុមប្រឹក្សានៃពួក១២នាក់ ហើយជាប្រធានលើបេសកកម្មប្រចាំប្រទេសអង់គ្លេស ។ គោលបំណងនោះ គឺដើម្បីធ្វើឲ្យស្រួលបានអត្ថបសំខាន់ៗ ដែលពុំសូវមានបោះពុម្ពផ្សាយ នៅគ្រា យ៉ូសែប ស្ម៊ីធ ។ កាលសមាជិកនៃសាសនាចក្រមានកាន់តែច្រើនឡើង ពាសពេញទ្វីបអឺរ៉ុប និងទ្វីបអាមេរិក នោះមានការតម្រូវឲ្យមានវត្ថុទាំងនេះ ។ មុក្ដាដ៏មានតម្លៃមហិមា ត្រូវបានទទួលប្រើប្រាស់ទូទៅ ហើយក្រោយមក ក្លាយទៅជាគម្ពីរបមាណីយ នៃសាសនាចក្រ តាមការសំរេចរបស់គណៈ ប្រធានទីមួយ និងសន្និសីទទូទៅ នៅទីក្រុងសល្ដលេក នៅថ្ងៃទី១០ ខែតុលា ឆ្នាំ ១៨៨០ ។

ការបន្ថែមបន្ថយជាច្រើនត្រូវបានកែប្រែនៅក្នុងមាតិការ តាមតែសេចក្ដីត្រូវការរបស់សាសនាចក្រ ។ នៅឆ្នាំ១៨៧៨ ផ្នែកនានានៃគម្ពីរម៉ូសេ ដែលពុំនៅក្នុងច្បាប់ទីមួយ នោះត្រូវបានបញ្ចូល ។ នៅឆ្នាំ១៩០២ ភាគខ្លះនៃមុក្ដាដ៏មានតម្លៃមហិមា ដែលជាសម្ភារៈដូចគ្នាដែលបានបោះពុម្ពផ្សាយនៅក្នុង គោលលទ្ធិនិងសេចក្ដីសញ្ញា នោះត្រូវបានដកចេញ ។ ការរៀបចំចេញជាជំពូក និងខ ព្រមទាំងជាលេខយោងទាំងឡាយ នោះត្រូវបានធ្វើឡើងនៅឆ្នាំ១៩០២ ។ ការបោះពុម្ពផ្សាយលើកទីមួយដែលមានជួរពីរ ព្រមទាំងមានលិបិក្រមនោះគឺនៅឆ្នាំ១៩២១ ។ ពុំមានការកែប្រែណាទៀតឡើយ រហូតដល់ខែមេសា ឆ្នាំ១៩៧៦ កាលមានវត្ថុនៃវិវរណៈពីរចំណុចត្រូវបានបន្ថែម ។ នៅឆ្នាំ១៩៧៩ វត្ថុទាំងពីរនេះត្រូវបានដកចេញពី មុក្ដាដ៏មានតម្លៃមហិមា ហើយបានដាក់ក្នុង គោលលទ្ធិនិងសេចក្ដីសញ្ញា ដែលឥឡូវនេះឃើញថាជា កណ្ឌទី១៣៧ និង១៣៨ ។ ការបោះពុម្ពផ្សាយសព្វថ្ងៃនេះ មានការកែប្រែខ្លះ ដែលត្រូវបានធ្វើឡើង ដើម្បីធ្វើឲ្យឯកសារនោះស្រុះគ្នានឹងឯកសារមុនៗ ។

ដែលមានដូចតទៅនេះ គឺជាបុព្វកថាចំពោះមាតិការនៅសព្វថ្ងៃនេះ គឺៈ

*ការជ្រើសរើសចេញពីគម្ពីរម៉ូសេ* ៖ ការដកស្រង់ចេញពីគម្ពីរលោកុប្បត្តិ ដែលជាការបកប្រែព្រះគម្ពីរប៊ីប ដោយយ៉ូសែប ស្ម៊ីធ កាលលោកបានចាប់ផ្ដើមធ្វើនៅខែមិថុនា ១៨៣០ (*History of the Church*, *[ប្រវត្តិនៃសាសនាចក្រ] ១:៩៨–១០១, ១៣១–១៣៩* ) ។

*គម្ពីរអ័ប្រាហាំ* — ជាការបកប្រែចេញពីក្រាំងប្របុសទាំងឡាយនៃពួកអេស៊ីព្ទ ដែលបានមកក្នុងកណ្ដាប់ដៃយ៉ូសែប ស្ម៊ីធ នៅឆ្នាំ ១៨៣៥ ដែលមានការនិពន្ធទាំងឡាយ របស់អយ្យកោអ័ប្រាហាំ ។ ការបកប្រែនេះត្រូវបានបោះពុម្ពផ្សាយបន្តិចម្ដងៗ នៅក្នុងកាសែត *Times and Seasons* ចាប់ផ្ដើមពីថ្ងៃទី១ ខែមីនា ឆ្នាំ១៨៤២ នៅក្រុងណេវ៉ូ រដ្ឋអិលលីណោយ (*History of the Church*, *៤:៥១៩–៥៣៤* ) ។

*យ៉ូសែប ស្ម៊ីធ — ម៉ាថាយ* — ជាការស្រង់ចេញពីទីបន្ទាល់របស់ម៉ាថាយ នៅក្នុងការបកប្រែព្រះគម្ពីរប៊ីប ដោយ យ៉ូសែប ស្ម៊ីធ (សូមមើល គោលលទ្ធិនិងសេចក្ដីសញ្ញា ៤៥:៦០–៦១ សំរាប់ព្រះបញ្ញត្តិពីព្រះ ឲ្យចាប់ផ្ដើមការបកប្រែព្រះគម្ពីរសញ្ញាថ្មី) ។

*យ៉ូសែប ស្ម៊ីធ — ប្រវត្តិ* — ជាការសង្ខេបចេញពីទីបន្ទាល់ និងប្រវត្តិរបស់ យ៉ូសែប ស្ម៊ីធ តាមផ្លូវការ ដែលលោកបានរៀបចំឡើងនៅ ឆ្នាំ១៨៣៨ ហើយដែលបានបោះពុម្ពផ្សាយបន្តិចម្ដងៗ នៅក្នុងកាសែត *Times and Seasons* នៅក្រុងណេវ៉ូ រដ្ឋអិលលីណោយ ចាប់ផ្ដើមពីថ្ងៃទី១៥ ខែមីនា ឆ្នាំ ១៨៤២ (*History of the Church*, *១:១–៤៤* ) ។

*មាត្រានៃសេចក្ដីជំនឿរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* ៖ ជាសេចក្ដីថ្លែងប្រាប់ដោយ យ៉ូសែប ស្ម៊ីធ ដែលបានបោះពុម្ពផ្សាយនៅក្នុងកាសែត *Times and Seasons* នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៨៤២ ជាមួយនឹងប្រវត្តិដ៏ខ្លី អំពីសាសនាចក្រ ដែលស្គាល់ទូទៅថា សំបុត្រជូនលោកវ៉េនត្វើធ (*History of the Church*, *៤:៥៣៥–៥៤១* ) ។

## ឈ្មោះនិងលេខរៀងនៃគម្ពីរទាំងឡាយនៅក្នុង

# មុក្ដាដ៏មានតម្លៃមហិមា


| | ទំព័រ |
|---|---|
| ការជ្រើសរើសពីគម្ពីរម៉ូសេ | ១ |
| គម្ពីរអ័ប្រាហាំ | ២៩ |
| វត្ថុចម្លងតាម លេខទី ១ | ៣០ |
| វត្ថុចម្លងតាម លេខទី ២ | ៣៦ |
| វត្ថុចម្លងតាម លេខទី ៣ | ៤១ |
| យ៉ូសែប ស្ម៊ីធ — ម៉ាថាយ | ៤៤ |
| យ៉ូសែប ស្ម៊ីធ — ប្រវត្តិ | ៤៨ |
| មាត្រានៃសេចក្ដីជំនឿ | ៦១ |

# ការជ្រើសរើសចេញពីគម្ពីរម៉ូសេ

ជាការស្រង់ចេញពីការបកប្រែព្រះគម្ពីរប៊ីប ដែលបានបើកសម្ដែងដល់ យ៉ូសែប ស្ម៊ីធ ជាព្យាការី នៅខែមិថុនា ឆ្នាំ១៨៣០–ខែកុម្ភៈ ឆ្នាំ១៨៣១ ។

## ជំពូកទី ១

*(មិថុនា ១៨៣០)*

*ព្រះទ្រង់បានសម្ដែងអង្គទ្រង់ដល់លោកម៉ូសេ — ម៉ូសេត្រូវបានប្រែរូប — គាត់ត្រូវប្រឈមមុខនឹងអារក្សសាតាំង — ម៉ូសេឃើញ ពិភពលោកជាច្រើនដែលមានមនុស្សអាស្រ័យនៅ — ពិភពលោកដ៏ឥតគណនាត្រូវបានបង្កើតឡើងដោយព្រះរាជបុត្រា — កិច្ចការ និងសិរីល្អរបស់ព្រះ គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស ។*

ព្រះបន្ទូលទាំងឡាយនៃព្រះ ដែលទ្រង់មានព្រះបន្ទូលទៅម៉ូសេ ក្នុងកាលម៉ូសេត្រូវបាននាំឡើងទៅលើភ្នំដ៏ខ្ពស់បំផុត,
២ ហើយគាត់បានឃើញព្រះនៅប្រទល់មុខ ហើយគាត់បានទូលជាមួយនឹងទ្រង់ ហើយសិរីល្អនៃព្រះត្រូវបានចាំងមកលើម៉ូសេ; ហេតុដូច្នេះហើយ ទើបម៉ូសេអាចទ្រាំចំពោះវត្តមានរបស់ទ្រង់បាន ។
៣ ហើយព្រះទ្រង់បានមានព្រះបន្ទូលទៅម៉ូសេថា៖ មើលចុះ យើងជាព្រះអម្ចាស់ដ៏ជាព្រះមានមហិទ្ធិឫទ្ធិ ហើយគ្មានទីបញ្ចប់ គឺជាព្រះនាមរបស់យើង; ត្បិតយើងគ្មានថ្ងៃចាប់ផ្ដើម ឬឆ្នាំបញ្ចប់ឡើយ; ហើយតើនេះពុំមែនជាគ្មានទីបញ្ចប់ទេឬអី ?
៤ ហើយមើលចុះ អ្នកជាបុត្ររបស់យើង; ហេតុដូច្នេះហើយ ចូរមើល ហើយយើងនឹងបង្ហាញដល់អ្នក នូវផលនៃដៃរបស់យើង; ប៉ុន្តែពុំ មែនទាំងអស់ទេ ព្រោះកិច្ចការយើងនោះគ្មានទីបញ្ចប់ឡើយ ព្រមទាំងព្រះបន្ទូលរបស់យើងផងដែរ ព្រោះការណ៍ទាំងនោះពុំដែល ឈប់ឈរឡើយ ។
៥ ហេតុដូច្នោះហើយ គ្មានមនុស្សណាម្នាក់អាចមើលឃើញគ្រប់អស់ទាំងការណ៍របស់យើងបានឡើយ លើកលែងតែអ្នកនោះបាន ឃើញគ្រប់អស់ទាំងសិរីល្អរបស់យើង; ហើយគ្មានមនុស្សណាម្នាក់អាចមើលឃើញសិរីល្អរបស់យើង ហើយបន្ទាប់មក រស់នៅលើផែនដី ក្នុងសាច់ឈាមទៀតឡើយ ។
៦ ហើយយើងមានកិច្ចការសំរាប់អ្នក ម៉ូសេ ជាបុត្រយើង; ហើយអ្នកនៅក្នុងរូបដូចជាព្រះរាជបុត្រាបង្កើតតែមួយរបស់យើង; ហើយព្រះ រាជបុត្រាបង្កើតតែមួយរបស់យើង គឺជា ហើយនឹងទៅជាព្រះអង្គសង្គ្រោះ ព្រោះទ្រង់ពោរពេញទៅដោយព្រះគុណ និងសេចក្ដីពិត; ប៉ុន្តែគ្មានព្រះឯណាក្រៅពីយើងឡើយ ហើយគ្រប់ទាំងអស់គឺនៅចំពោះយើង ព្រោះយើងស្គាល់គ្រប់អ្វីៗទាំងអស់ ។
៧ ហើយឥឡូវនេះ មើលចុះ យើងបង្ហាញការណ៍មួយនេះដល់អ្នក ម៉ូសេ ជាបុត្រយើង ព្រោះអ្នកនៅក្នុងលោកិយ ហើយឥឡូវនេះ យើងបង្ហាញការណ៍នោះដល់អ្នក ។
៨ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសេបានសម្លឹងមើល ហើយបានឃើញពិភពលោកដែលគាត់កើតមក; ហើយម៉ូសេបាន

---

១ ១ក អាលម៉ា ១២:៣០; ម៉ូសេ ១:៤២.
ខ ស.ប. ម៉ូសេ.
២ ក និក្ខ. ៣:៦; ៣៣:១១;
យ៉ូហាន ១:១៨; ៦:៤៦;
អេធើរ ៣:៦–១៦; ម៉ូសេ ១:១១.
ក.យ.ស., និក្ខ. ៣៣:២០, ២៣.
ខ ជនគ. ១២:៦–៨; ចោទិ. ៣៤:១០;
គ. និង ស. ១៧:១.
គ ចោទិ. ៥:២៤;
ម៉ូសេ ១:១៣–១៤, ២៥.
ស.ប. សិរីល្អ.
ឃ ស.ប. ការប្រែរូប.
៣ ក វិវរ. ១១:១៧; ១៩:៦;
១ នីហ្វៃ ១:១៤; ១២១:៤.
ស.ប. ព្រះ, ក្រុមព្រះ.
ខ អេសាយ ៦៣:១៦;
គ. និង ស. ១៩:៩–១២;
ម៉ូសេ ៧:៣៥.
ស.ប. មិនចេះចប់មិនហើយ.
៤ ក ម៉ូសេ ៧:៤.
ខ ម៉ូសេ ៧:៣២, ៣៥–៣៧.
គ ទំនុក. ៤០:៥;
គ. និង ស. ៧៦:១១៤.
ឃ ទំនុក. ១១១:៧–៨; ម៉ូសេ ១:៣៨.
ង ២ នីហ្វៃ ៩:១៦;
គ. និង ស. ១:៣៧–៣៩.
ស.ប. ព្រះបន្ទូលនៃព្រះ.
៦ ក លោកុ. ១:២៦;
អេធើរ ៣:១៤–១៥;
ម៉ូសេ ១:១៣–១៦.
ខ ស.ប. បង្កើតតែមួយ.
គ ស.ប. ព្រះអង្គសង្គ្រោះ.
ឃ យ៉ូហាន ១:១៤, ១៧;
អាលម៉ា ១៣:៩.
ស.ប. ព្រះគុណ.
ង ម៉ូសេ ៥:៧.
ច ១ ពង្សាវ. ៨:៦០;
អេសាយ ៤៥:៥–១៨,
២១–២២.
ឆ ១ នីហ្វៃ ៩:៦; ២ នីហ្វៃ ៩:២០;
អាលម៉ា ១៨:៣២;
គ. និង ស. ៣៨:១–២.
ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
៨ ក ម៉ូសេ ២:១.
ខ ម៉ូសេ ១:២៧.

ឃើញ ពិភពលោក និងទីបញ្ចប់ផងដែរ ព្រមទាំងកូនចៅមនុស្សលោកទាំងអស់ ដែលមាននៅពេលនោះ និងដែលបានបង្កើតឡើងមក; អំពីការណ៍នោះ នោះគាត់មានចិត្តអស្ចារ្យ និងឆ្ងល់ជាអនេក ។

៩ ហើយវត្តមាននៃព្រះថយចេញពីម៉ូសេទៅ ដើម្បីកុំឲ្យសិរីល្អរបស់ទ្រង់ស្ថិតនៅជាមួយនឹងម៉ូសេទៀត; ហើយម៉ូសេត្រូវបានទុកឲ្យនៅតែ ម្នាក់ឯង ។ ហើយកាលគាត់ត្រូវបានទុកឲ្យនៅតែម្នាក់ឯងនោះ គាត់ក៏ដួលទៅលើដី ។

១០ ហើយហេតុការណ៍បានកើតឡើងថា អស់រយៈជាច្រើនម៉ោងមុនម៉ូសេបានទទួលកម្លាំងគាត់ដូចដើមវិញ; ហើយគាត់ពោលទៅ ខ្លួនថា៖ ឥឡូវនេះ ព្រោះហេតុនេះហើយទើបខ្ញុំដឹងថាមនុស្សគឺគ្មានជាអ្វីសោះ ជាការណ៍ដែលខ្ញុំពុំដែលគិតពីមុនមកឡើយ ។

១១ ប៉ុន្តែឥឡូវនេះ ភ្នែកខ្ញុំផ្ទាល់បានមើលឃើញព្រះ; ប៉ុន្តែពុំមែនដោយភ្នែកខ្ញុំធម្មតាទេ តែជាភ្នែកខាងវិញ្ញាណរបស់ខ្ញុំវិញ ព្រោះភ្នែក ធម្មតារបស់ខ្ញុំពុំអាចមើលឃើញទេ; ព្រោះខ្ញុំនឹងត្រូវស្វិត ហើយស្លាប់ចំពោះវត្តមានរបស់ទ្រង់ជាមិនខានឡើយ; ប៉ុន្តែសិរីល្អរបស់ ទ្រង់បានមកលើខ្ញុំ; ហើយខ្ញុំបានមើលឃើញព្រះភ័ក្ត្រទ្រង់ ព្រោះខ្ញុំត្រូវបានប្រែរូបនៅចំពោះទ្រង់ ។

១២ ហើយហេតុការណ៍បានកើតឡើងថា កាលម៉ូសេបានពោលនូវពាក្យពេចន៍ទាំងនេះ មើលចុះ អារក្សសាតាំងបានមកដោយល្បួង គាត់ថា៖ ម៉ូសេ ជាកូនមនុស្សអើយ ចូរថ្វាយបង្គំយើង ។

១៣ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសេបានងើបមើលទៅអារក្សសាតាំង ហើយនិយាយថា៖ តើអ្នកជានរណា ? ត្បិតមើលចុះ ខ្ញុំជាបុត្រនៃព្រះ នៅក្នុងរូបដូចជាព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់; ហើយចុះតើសិរីល្អរបស់អ្នកនៅឯណាដែលគួរឲ្យខ្ញុំថ្វាយបង្គំ ?

១៤ ត្បិតមើលចុះ ខ្ញុំពុំអាចមើលទៅលើព្រះបានទេ លើកលែងតែសិរីល្អរបស់ទ្រង់បានស្ថិតមកលើខ្ញុំ ហើយខ្ញុំបានប្រែរូបនៅចំពោះទ្រង់ ។ ប៉ុន្តែខ្ញុំអាចមើលទៅលើអ្នក ក្នុងភាពមនុស្សធម្មតា ។ តើការណ៍នេះពិតជាពុំមែនទេឬអី ?

១៥ សូមព្រះនាមនៃព្រះរបស់ខ្ញុំបានប្រកបដោយព្រះពរ ព្រោះព្រះវិញ្ញាណទ្រង់មិនទាន់ថយចេញពីខ្ញុំអស់ទេ បើពុំនោះសោតទេ តើសិរីល្អ របស់អ្នកនៅឯណា ត្បិតវាជាសេចក្ដីងងឹតចំពោះខ្ញុំ ? ហើយខ្ញុំអាចវិនិច្ឆ័យរវាងអ្នកនឹងព្រះបាន; ព្រោះព្រះទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ ចូរថ្វាយបង្គំដល់ព្រះ ព្រោះអ្នកត្រូវបំរើទ្រង់តែមួយព្រះអង្គប៉ុណ្ណោះ ។

១៦ នែសាតាំង ចូរឯងថយចេញទៅ; ចូរកុំបញ្ឆោតខ្ញុំអី; ព្រោះព្រះទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ អ្នកមានរូបដូចជាព្រះរាជបុត្រា បង្កើតតែមួយរបស់យើង ។

១៧ ហើយទ្រង់ក៏បានប្រទានព្រះបញ្ញត្តិទាំងឡាយដល់ខ្ញុំផងដែរ កាលទ្រង់បានហៅខ្ញុំចេញពីគុម្ពបន្លា ដែលមានភ្លើងឆេះថា៖ ចូរអំពាវ នាវដល់ព្រះ ដោយនូវព្រះនាមនៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើង ហើយថ្វាយបង្គំយើងចុះ ។

១៨ ហើយម៉ូសេបាននិយាយជាថ្មីទៀតថា៖ ខ្ញុំនឹងមិនឈប់អំពាវនាវដល់ព្រះឡើយ ព្រោះខ្ញុំមានការណ៍ផ្សេងៗទៀតដែលខ្ញុំត្រូវទូលនឹង ទ្រង់៖ ត្បិតសិរីល្អរបស់ទ្រង់បានស្ថិតមកលើខ្ញុំ ហេតុដូច្នោះហើយ ទើបខ្ញុំអាចវិនិច្ឆ័យរវាងទ្រង់និងអ្នកបាន ។ នែសាតាំង ចូរថយ ចេញទៅ ។

១៩ ហើយឥឡូវនេះ កាលម៉ូសេបានពោលពាក្យទាំងនេះហើយ នោះអារក្សសាតាំងក៏ស្រែកដោយសម្លេងខ្លាំង ហើយទន្ទ្រានលើដី ហើយបញ្ជាថា៖ យើងជាព្រះរាជបុត្រាបង្កើត ចូរថ្វាយបង្គំយើងមក ។

២០ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសេចាប់ផ្ដើមភ័យជាអតិបរមា; ហើយនៅពេលគាត់ចាប់ផ្ដើមភ័យ នោះគាត់

---

៨ *គ* ទំនុក. ៨:៣–៤.

១០ *ក* ដានី. ១០:៨, ១៧; ១ នីហ្វៃ ១៧:៤៧; អាលម៉ា ២៧:១៧; យ.ស. – ប្រវត្តិ ១:២០.
*ខ* ដានី. ៤:៣៥; ហេលេ. ១២:៧.

១១ *ក* ស.ប. ព្រះ, ក្រុមព្រះ.
*ខ* ម៉ូសេ ៦:៣៦; គ. និង ស. ៦៧:១០–១៣.
*គ* និក្ខ. ១៩:២១.
*ឃ* និក្ខ. ២០:១៩.
*ង* លោកុ. ៣២:៣០; ម៉ូសេ ៧:៤.
*ច* ម៉ាថាយ ១៧:១–៨. ស.ប. ការប្រែរូប.

១២ *ក* ម៉ូសេ ៤:១–៤. ស.ប. អារក្ស.
*ខ* ម៉ូសេ ៦:៤៩. ស.ប. ល្បួង, សេចក្ដីល្បួង.

១៣ *ក* ទំនុក. ៨២:៦; ១ យ៉ូហាន ៣:២; ហេព្រើរ ១២:៩.

១៤ *ក* ស.ប. ការប្រែរូប.

១៥ *ក* ម៉ាថាយ ៤:១០. ស.ប. ថ្វាយបង្គំ.
*ខ* ១ សាំយូ. ៧:៣; ៣ នីហ្វៃ ១៣:២៤.

១៦ *ក* ម៉ូសេ ១:៦.

១៧ *ក* និក្ខ. ៣:២.
*ខ* ម៉ូសេ ៥:៨.

១៩ *ក* ម៉ាថាយ ២៤:៤–៥.

បានឃើញ ភាពល្វីងជូរចត់នៃស្ថាននរក[ក] ។ ទោះជាយ៉ាង
ណាក៏ដោយ ដោយបានអំពាវនាវ[ខ]ដល់ព្រះ នោះគាត់បានទទួល
កម្លាំង ហើយគាត់បាន បញ្ជាថា៖ នែសាតាំង ចូរថយចេញពីខ្ញុំទៅ
ត្បិតខ្ញុំនឹងថ្វាយបង្គំដល់ព្រះតែមួយអង្គប៉ុណ្ណោះ គឺជាព្រះនៃសិរីល្អ ។
២១ ហើយឥឡូវនេះ អារក្ស[ក]សាតាំងចាប់ផ្ដើមញ័ររន្ធត់
ហើយផែនដីរញ្ជួយ; ហើយម៉ូសេបានទទួលកម្លាំង ហើយបាន
អំពាវនាវដល់ព្រះ ថា៖ ដោយនូវព្រះនាមនៃព្រះរាជបុត្រាបង្កើត
តែមួយ ចូរថយចេញទៅ សាតាំង ។
២២ ហើយហេតុការណ៍បានកើតឡើងថា អារក្សសាតាំងបាន
ស្រែកដោយសម្លេងខ្លាំង ទាំងយំ និងទួញសោក និង
សង្កៀត[ក]ធ្មេញ; រួចហើយ ទើបវាថយចេញទៅ គឺចេញពីវត្តមាន
នៃម៉ូសេ ដែលគាត់មើលវាមិនឃើញឡើយ ។
២៣ ហើយឥឡូវនេះ ម៉ូសេបានធ្វើបន្ទាល់អំពីការណ៍នេះ;
ប៉ុន្តែពីព្រោះមកពីអំពើទុច្ចរិត ទើបពុំមានការណ៍នេះ នៅក្នុង
ចំណោម កូនចៅមនុស្សឡើយ ។
២៤ ហើយហេតុការណ៍បានកើតឡើងថា កាលអារក្សសាតាំង
បានថយចេញពីវត្តមាននៃម៉ូសេទៅ នោះម៉ូសេបានបើកភ្នែកឡើង
ទៅស្ថានសួគ៌ ដោយបានពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ[ក]
ដែលធ្វើទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា;
២៥ ហើយដោយបានអំពាវនាវដល់ព្រះនាមនៃព្រះ នោះគាត់
បានឃើញសិរីល្អរបស់ទ្រង់ម្ដងទៀត ត្បិតសិរីល្អនោះបានបិតមក
លើគាត់; ហើយគាត់បានឮសម្លេងថា៖ ម៉ូសេអើយ អ្នកមាន
ពរហើយ ត្បិតយើងជាព្រះដ៏មានមហិទ្ធិឫទ្ធិ បានរើសអ្នក ហើយ
អ្នកនឹងត្រូវធ្វើឲ្យបាន ខ្លាំងពូកែជាងទឹក[ក]ជាច្រើន; ព្រោះរបស់
ទាំងនោះនឹងគោរព[ខ]តាមបញ្ជាអ្នក ហាក់បីដូចអ្នកជាព្រះ[គ] ។
២៦ ហើយមើលន៏ យើងគង់នៅជាមួយនឹងអ្នក គឺរហូតដល់
អស់មួយជីវិតរបស់អ្នក; ព្រោះអ្នកនឹងដោះលែង[ក]រាស្ត្រយើងឲ្យ
រួច[ខ]ពី សេវកភាព គឺពួក[គ]អ៊ីស្រាអែល ជាពួកជំរើស[ឃ]របស់យើង ។
២៧ ហើយហេតុការណ៍បានកើតឡើងថា នៅពេល
សម្លេងនោះកំពុងតែមានបន្ទូលមក នោះម៉ូសេចោលភ្នែកគាត់
ហើយមើល[ក] ឃើញផែនដី មែនហើយ គឺនូវអ្វីៗទាំងអស់ដែល
នៅទីនោះ; ហើយគ្មានចំណុចណាមួយឡើយដែលគាត់មើលមិន
ឃើញ គឺស្គាល់ ដោយសារព្រះវិញ្ញាណនៃព្រះ ។
២៨ ហើយគាត់ក៏ឃើញបណ្ដាជននៅលើទីនោះ ហើយ
គ្មានព្រលឹងណាមួយដែលគាត់មើលមិនឃើញឡើយ; ហើយ
គាត់ស្គាល់ពួកគេ ដោយសារព្រះវិញ្ញាណនៃព្រះ; ហើយពួកគេ
មានចំនួនសន្ធឹក គឺឥតគណនា ហាក់បីដូចជាខ្សាច់នៅឆ្នេរសមុទ្រ ។
២៩ ហើយគាត់បានឃើញដែនដីជាច្រើន; ហើយដែនដីនីមួយ
ៗត្រូវបានហៅថា ផែនដី[ក] ហើយមានបណ្ដាជនអាស្រ័យនៅ
លើផ្ទៃទីនោះ ។
៣០ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសេបានអំពាវនាវ
ដល់ព្រះថា៖ ព្រះករុណាវិសេស សូមប្រាប់ទូលបង្គំថា ម្ដេច
ក៏មាន ការណ៍ទាំងនេះ ហើយថាតើព្រះអង្គបានបង្កើតរបស់
ទាំងនេះតាមរបៀបណា ?
៣១ ហើយមើលចុះ សិរីល្អនៃព្រះអម្ចាស់បានមកលើម៉ូសេ
ដើម្បីឲ្យម៉ូសេបានឈរក្នុងវត្តមាននៃព្រះ ហើយទូលនឹងទ្រង់ប្រទល់[ក]
មុខ ។ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលទៅ
ម៉ូសេថា៖ គឺសំរាប់គោលបំណង[ខ]របស់យើងផ្ទាល់ ដែលយើង
បានបង្កើតរបស់ទាំងនេះ មក ។ នេះហើយជាប្រាជ្ញា ហើយ
ប្រាជ្ញានោះនៅក្នុងយើង ។
៣២ ហើយដោយសារព្រះបន្ទូល[ក]នៃព្រះចេស្ដារបស់យើង នោះ
យើងបានបង្កើតរបស់ទាំងនោះ គឺជាព្រះរាជបុត្រាបង្កើតតែមួយ
របស់ យើង ដែលពោរពេញទៅដោយព្រះគុណ[ខ] និងសេចក្ដីពិត[គ] ។
៣៣ ហើយពិភព[ក]លោកដ៏ច្រើនឥតគណនា នោះយើងបាន
បង្កើត[ខ]ឡើង; ហើយយើងបានបង្កើតរបស់ទាំងនោះឡើង សំរាប់
គោលបំណងរបស់យើងផ្ទាល់; ហើយដោយសារព្រះរាជបុត្រា

២០ *ក* ស.ប. ស្ថាននរក.
*ខ* យ.ស.—ប្រវត្តិ ១:១៥–១៦.
ស.ប. ការអធិស្ឋាន.
២១ *ក* ស.ប. អារក្ស.
២២ *ក* ម៉ាថាយ ១៣:៤១–៤២;
ម៉ូសាយ ១៦:១–៣.
២៤ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
២៥ *ក* និក្ខ. ១៤:២១–២២.
*ខ* ស.ប. អំណាច; បព្វជិតភាព.
*គ* និក្ខ. ៤:១៦.
២៦ *ក* និក្ខ. ៣:៧–១២.
*ខ* ១ នីហ្វៃ ១៧:២៣–២៥.
*គ* ១ ពង្សាវ. ៨:៥១–៥៣.
ស.ប. អ៊ីស្រាអែល.
*ឃ* ស.ប. ជំរើស (គ. ឬ ន.).
២៧ *ក* គ. និង ស. ៨៨:៤៧; ម៉ូសេ ១:៨.
ស.ប. ការនិមិត្ត.
២៩ *ក* ស.ប. ផែនដី.
៣១ *ក* ចោទិ. ៥:៤; ម៉ូសេ ១:១១.
*ខ* អេសាយ ៤៥:១៧–១៨;
២ នីហ្វៃ ២:១៤–១៥.
៣២ *ក* យ៉ូហាន ១:១–៤, ១៤;
ហេព្រើរ ១:១–៣; វិវរ. ១៩:១៣;
យ៉ាកុប ៤:៩; ម៉ូសេ ២:១, ៥.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ទំនុក. ១៩:១; ម៉ូសេ ៥:៧–៨.
ស.ប. ព្រះគុណ.
*គ* ស.ប. សេចក្ដីពិត.
៣៣ *ក* ទំនុក. ៨:៣–៤;
គ. និង ស. ៧៦:២៤;
ម៉ូសេ ៧:២៩–៣០.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.

នោះយើងបានបង្កើតរបស់ទាំងនោះមក [គ]គឺជាព្រះរាជបុត្រាបង្កើ
តតែមួយ របស់យើង ។
៣៤ ហើយមនុស្ស[ក]ទីមួយបង្អស់នៃមនុស្សលោក នោះយើងបាន
ហៅថា [ខ]អ័ដាម ដែល[គ]ជាច្រើន ។
៣៥ ប៉ុន្តែមានតែដំណើររឿងអំពីផែនដីនេះ និងអំពី
បណ្ដាជននៅទីនេះប៉ុណ្ណោះ ដែលយើងប្រាប់ដល់អ្នក ។ ត្បិត
មើលចុះ មានពិភព ជាច្រើនដែលបានកន្លងផុតទៅ ដោយ
សារព្រះបន្ទូលនៃព្រះចេស្ដារបស់យើង ។ ហើយឥឡូវនេះ
មានពិភពជាច្រើនដែលឈរ ហើយ មានចំនួនដ៏ឥតគណនា
ចំពោះមនុស្ស; ប៉ុន្តែគ្រប់ការណ៍ទាំងអស់សុទ្ធតែបានរាប់
ចំពោះយើង ត្បិតរបស់ទាំងនោះជារបស់ផងយើង ហើយយើង
[ក]ស្គាល់របស់ទាំងនោះ ។
៣៦ ហើយហេតុការណ៍បានកើតឡើងថា ម៉ូសេបានទូលទៅព្រះ
អម្ចាស់ថា៖ ឱព្រះអង្គអើយ សូមមានសេចក្ដីមេត្តាករុណា
ដល់បាវបំរើ របស់ទ្រង់ផងចុះ ហើយសូមប្រាប់ទូលបង្គំអំពីផែនដីនេះ
និងអំពីបណ្ដាជនដែលអាស្រ័យនៅលើទីនោះ និងអំពីផ្ទៃមេឃ
ហើយនៅ ពេលនោះ ទើបទូលបង្គំបានស្កប់ចិត្ត ។
៣៧ ហើយព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់មានព្រះបន្ទូលទៅ
ម៉ូសេថា៖ [ក]ផ្ទៃមេឃនោះមានដ៏ច្រើន ហើយពុំអាចរាប់បានអស់
ចំពោះមនុស្ស ឡើយ; ប៉ុន្តែត្រូវបានរាប់ចំពោះយើង ត្បិតរបស់
ទាំងនោះជារបស់ផងយើង ។
៣៨ ហើយដូចជាផែនដីមួយបានកន្លងផុតទៅជាយ៉ាងណា
ហើយផ្ទៃមេឃនៃទីនោះក៏នឹងមកជាយ៉ាងនោះដែរ; ហើយគ្មាន
[ក]ទីបញ្ចប់ ចំពោះកិច្ចការទាំងឡាយរបស់យើងឡើយ ឬក៏ចំពោះ
ព្រះបន្ទូលទាំងឡាយរបស់យើងដែរ ។
៣៩ ត្បិតមើលចុះ នេះហើយជា[ក]កិច្ចការរបស់យើង និង[ខ]សិរីល្អ
របស់យើង — គឺដើម្បីនាំឲ្យមាន[គ]អមតភាព និង[ឃ]ជីវិតដ៏នៅ
អស់កល្បជានិច្ច ដល់មនុស្ស ។
៤០ ហើយឥឡូវនេះ ម៉ូសេជាបុត្រយើងអើយ យើងនឹងមាន
ព្រះបន្ទូលដល់អ្នក អំពីផែនដីនេះ ដែលអ្នកឈរលើ; ហើយអ្នក
[ក]នឹងសរសេរ ពីការណ៍ទាំងប៉ុន្មាន ដែលយើងនឹងមានព្រះបន្ទូល
ប្រាប់ ។
៤១ ហើយនៅថ្ងៃណាដែលកូនចៅមនុស្សនឹងគិតថាព្រះបន្ទូល
ទាំងឡាយរបស់យើងឥតតម្លៃ ហើយ[ក]ដកអ្វីជាច្រើនចេញពីគម្ពីរ
ដែលអ្នក នឹងសរសេរ មើលចុះ យើងនឹងបង្កើតម្នាក់ទៀត ឲ្យ
[ខ]ដូចអ្នក; ហើយ[គ]ព្រះបន្ទូលទាំងឡាយនឹងមាននៅក្នុងចំណោម
កូនចៅមនុស្សម្ដងទៀត — គឺនៅក្នុងចំណោមមនុស្សជាច្រើន
ណាដែលនឹងជឿ ។
៤២ (ព្រះបន្ទូលទាំងនេះត្រូវបាន[ក]ពោលប្រាប់ដល់លោកម៉ូសេ
នៅលើភ្នំ រីឯឈ្មោះភ្នំនោះនឹងពុំដែលបានស្គាល់ក្នុងចំណោម
កូនចៅ មនុស្សឡើយ ។ ហើយឥឡូវនេះ ព្រះបន្ទូលទាំងឡាយ
នេះត្រូវបានពោលប្រាប់ដល់អ្នក ។ ចូរកុំបង្ហាញព្រះបន្ទូលទាំង
ឡាយនេះដល់ នរណាឲ្យសោះ លើកលែងតែពួកអ្នកដែលជឿ
ប៉ុណ្ណោះ ។ គឺពិតយ៉ាងដូច្នោះមែន ។ អាម៉ែន ៕)

## ជំពូកទី ២

*(មិថុនា–តុលា ១៨៣០)*

*ព្រះទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី — គឺជីវិតគ្រប់ប្រភេទត្រូវបានបង្កើតឡើង — ព្រះទ្រង់បង្កើតមនុស្ស ហើយប្រទានឲ្យគេមានអំ ណាចត្រួតត្រាលើគ្រប់ការណ៍ទាំងអស់ ។*

ហើយហេតុការណ៍បានកើតឡើងថា [ក]ព្រះអម្ចាស់ទ្រង់មានព្រះ
បន្ទូលទៅម៉ូសេថា៖ មើលចុះ យើងបើកសម្ដែងដល់អ្នកអំពី
[ខ]ផ្ទៃមេឃនេះ និង[គ]ផែនដីនេះ; ចូរកត់នូវព្រះបន្ទូលដែលយើងមាន
បន្ទូលចុះ ។ [ង]យើងជាដើម និងជាចុង ជា[ឃ]ព្រះដ៏មានមហិទ្ធិឫទ្ធិ;
ដោយសារព្រះរាជ បុត្រាបង្កើតតែមួយរបស់យើង ទើបយើង[ច]បាន

៣៣ *គ* ម៉ូសេ ១:៦.
៣៤ *ក* ម៉ូសេ ៣:៧.
*ខ* អ័ប្រា. ១:៣.
ស.ប. អ័ដាម.
*គ* ម៉ូសេ ៤:២៦; ៦:៩.
៣៥ *ក* ម៉ូសេ ១:៦; ៧:៣៦.
ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
៣៧ *ក* អ័ប្រា. ៤:១.
ស.ប. ស្ថានសួគ៌.
៣៨ *ក* ម៉ូសេ ១:៤.
៣៩ *ក* រ៉ូម ៨:១៦–១៧;
២ នីហ្វៃ ២:១៤–១៥.
ស.ប. ផែនការនៃសេចក្ដីប្រោសលោះ.
*ខ* ស.ប. សិរីល្អ.
*គ* ស.ប. អមតៈ, អមតភាព.
*ឃ* ស.ប. ជីវិតដ៏នៅអស់កល្បជានិច្ច.
៤០ *ក* ២ នីហ្វៃ ២៩:១១–១២.
៤១ *ក* ១ នីហ្វៃ ១៣:២៣–៣២;
ម៉ូសេ ១:២៣.
*ខ* ២ នីហ្វៃ ៣:៧–១៩.
*គ* ១ នីហ្វៃ ១៣:៣២, ៣៩–៤០;
គ. និង ស. ៩:២.
៤២ *ក* ម៉ូសេ ១:១.
២ ១*ក* ម៉ូសេ ១:៣០, ៣៦.
*ខ* ស.ប. ស្ថានសួគ៌.
*គ* ម៉ូសេ ១:៨.
*ឃ* ស.ប. ព្រះ, ក្រុមព្រះ —
ព្រះដ៏ជាព្រះវរបិតា.
*ង* ស.ប. បង្កើតតែមួយ.
*ច* ស.ប. បង្កបង្កើត, ការបង្កបង្កើត.

បង្កើតរបស់ទាំងនេះមក; មែនហើយ គឺនៅដើមដំបូងឡើយ
យើងបានបង្កើតផ្ទៃមេឃ និងផែនដីដែលអ្នកឈរលើ ។
២ ហើយ[ក]ផែនដីគ្មានរូបរាង ហើយនៅទទេ; ហើយយើងបាន
បណ្ដាលឲ្យមានសេចក្ដីងងឹតគ្របលើផ្ទៃនៃជំរៅទឹក; ហើយព្រះ
វិញ្ញាណរបស់យើងរេរានៅពីលើផ្ទៃទឹក; ត្បិតយើងជា[ក]ព្រះ ។
៣ ហើយយើងជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យមានពន្លឺឡើង;
ហើយក៏មានពន្លឺឡើង ។
៤ ហើយយើងជាព្រះ បានឃើញពន្លឺនោះ; ហើយពន្លឺនោះ[ក]ល្អ ។
ហើយយើងជាព្រះ បានញែកពន្លឺចេញពីងងឹត ។
៥ ហើយយើងជាព្រះ បានហៅពន្លឺថាជាថ្ងៃ; ហើយងងឹត យើង
បានហៅថាជាយប់; ហើយការណ៍នេះយើងធ្វើឡើង ដោយសារ
[ក]ព្រះបន្ទូលនៃព្រះចេស្ដារបស់យើង[ខ] ហើយការណ៍នោះក៏មាន
ដូច្នោះ ដូចដែលយើងបានមានបន្ទូលមក; ហើយក៏មានល្ងាច
មានព្រឹកឡើង ជា[គ]ថ្ងៃទី ១ ។
៦ [ក]ហើយជាថ្មីទៀត យើងជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យ
មាន[ក]ប្រឡោះនៅកណ្ដាលទឹក ហើយក៏មានដូច្នោះ ដូចដែល
យើងបាន មានបន្ទូលមក; ហើយយើងបានមានបន្ទូលថា៖ ចូរឲ្យវា
ញែកទឹកចេញពីគ្នា; ហើយក៏មានដូច្នោះ ។
៧ ហើយយើងជាព្រះ ក៏ធ្វើប្រឡោះ ទាំងញែក[ក]ទឹកដែល
នៅក្រោមប្រឡោះចេញពីទឹកដែលនៅលើប្រឡោះ ហើយក៏មាន
ដូច្នោះ ដូច ដែលយើងបានមានបន្ទូលមក ។
៨ ហើយយើងជាព្រះ បានហៅប្រឡោះនោះថាជា[ក]មេឃ;
ហើយក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី ២ ។
៩ ហើយយើងជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យ
ទឹកនៅក្រោមមេឃប្រមូលគ្នានៅ[ក]កន្លែងតែមួយ ហើយក៏មាន
ដូច្នោះ; ហើយយើង ជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យមាន
ដីគោកឡើង; ហើយក៏មានដូច្នោះ ។
១០ ហើយយើងជាព្រះ បានហៅដីគោកនោះថាជា[ក]ផែនដី;
ហើយទីទឹកដែលប្រមូលគ្នានោះយើងហៅថាជាសមុទ្រ; ហើយ
យើងជាព្រះ បានឃើញថារបស់គ្រប់យ៉ាងដែលយើងបានធ្វើ
ឡើងសុទ្ធតែល្អ ។

១១ ហើយយើងជា[ក]ព្រះ បានមានបន្ទូលថា៖ ចូរឲ្យផែនដីដុះតិណ
ជាតិឡើង គឺជាពួកស្មៅ និងរុក្ខជាតិដែលមានគ្រាប់
និងដើមឈើ ដែលមានផ្លែតាមពូជ និងដើមឈើដែលមានផ្លែ
គឺមានគ្រាប់ក្នុងផ្លែនៅលើផែនដី ហើយក៏មានដូច្នោះ ដូចដែល
យើងបានមាន បន្ទូលមក ។
១២ ហើយផែនដីក៏ដុះតិណជាតិឡើង ជាពួកស្មៅ និងរុក្ខជាតិ
គ្រប់មុខដែលមានគ្រាប់តាមពូជវា និងដើមឈើដែលមានផ្លែ គឺមាន
គ្រាប់ក្នុងផ្លែតាមពូជវា; ហើយយើងជាព្រះ បានឃើញថារបស់
គ្រប់យ៉ាងដែលយើងបានធ្វើឡើងនោះសុទ្ធតែល្អ;
១៣ ហើយក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី ៣ ។
១៤ ហើយយើងជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យមានតួពន្លឺនៅនា
ផ្ទៃមេឃ ដើម្បីនឹងញែកថ្ងៃចេញពីយប់ ហើយសំរាប់ទុកជា
ទីសំគាល់ និងសំរាប់ជារដូវ និងសំរាប់ជាថ្ងៃ និងសំរាប់ជាឆ្នាំ;
១៥ ហើយចូរឲ្យមានតួពន្លឺនៅនាផ្ទៃមេឃ ដើម្បីបំភ្លឺមកផែនដី
ហើយក៏មានដូច្នោះ ។
១៦ ហើយយើងជាព្រះ បានធ្វើ[ក]ពន្លឺធំជាពីរតួ មួយដែលធំជាង
នោះសំរាប់ត្រួតក្នុងពេលថ្ងៃ ហើយមួយដែលតូចជាង សំរាប់
ត្រួតក្នុង ពេលយប់ ហើយពន្លឺដែលធំជាងនោះគឺជាព្រះអាទិត្យ
ហើយពន្លឺដែលតូចជាងនោះគឺជាព្រះច័ន្ទ; ហើយព្រមទាំងតារា
ទាំងឡាយ ក៏បានធ្វើឡើង តាមព្រះបន្ទូលរបស់យើងដែរ ។
១៧ ហើយយើងជាព្រះ បានដាក់តួពន្លឺទាំងនោះនៅឯផ្ទៃមេឃ
ដើម្បីនឹងបំភ្លឺមកលើផែនដី,
១៨ ហើយព្រះអាទិត្យត្រួតក្នុងពេលថ្ងៃ ហើយព្រះច័ន្ទត្រួត
ក្នុងពេលយប់ ហើយដើម្បីញែកពន្លឺចេញពីងងឹត; ហើយយើងជា
ព្រះ បានឃើញថារបស់គ្រប់យ៉ាងដែលយើងបានធ្វើឡើងនោះ
សុទ្ធតែល្អ;
១៩ ហើយក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី ៤ ។
២០ ហើយយើងជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យទឹកមាន
ពោរពេញទៅដោយមច្ឆាជាតិរវើកជាបរិបូរ និងបក្សីជាតិ
ហើរ លើដីនៅនាអាកាស ។
២១ ហើយយើងជាព្រះ បានបង្កើត[ក]ត្រីបាឡែនដ៏សំបើមៗ និង

២ *ក* លោកុ. ១:២; អេប្រា. ៤:២.
៣ *ក* គ. និង ស. ៨៨:៦–១៣.
ស.ប. ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ.
៤ *ក* លោកុ. ១:៤; អ័ប្រា. ៤:៤.
៥ *ក* ម៉ូសេ ១:៣២.
*ខ* ២ កូរិន. ៤:៦.
*គ* លោកុ. ១:៥.
៦ *ក* លោកុ. ១:៦–៨.
៧ *ក* អ័ប្រា. ៤:៩–១០.
៨ *ក* ស.ប. ស្ថានសួគ៌.
៩ *ក* លោកុ. ១:៩; អ័ប្រា. ៤:៩.
១០ *ក* ស.ប. ផែនដី.
១១ *ក* លោកុ. ១:១១–១២;
អ័ប្រា. ៤:១១–១២.
១៦ *ក* លោកុ. ១:១៦.
២១ *ក* លោកុ. ១:២១; អ័ប្រា. ៤:២១.

ជីវិតទាំងឡាយដែលកំរើក ដែលទឹកទាំងឡាយបាននាំមកជាបរិបូរ តាមពូជ ហើយអស់ទាំងសត្វស្លាបគ្រប់មុខតាមពូជដែរ; ហើយយើងជាព្រះ បានឃើញថារបស់គ្រប់យ៉ាង ដែលយើងបានបង្កើតឡើង នោះសុទ្ធតែល្អ ។

២២ ហើយយើងជាព្រះ បានប្រទាន[ក]ពរដល់សត្វទាំងឡាយនោះថា៖ ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសនៅក្នុង ទឹកសមុទ្រ ហើយឲ្យសត្វស្លាបចំរើនឡើងនៅផែនដីដែរ;

២៣ ហើយក៏មានល្ងាច មានព្រឹកឡើង ជាថ្ងៃទី ៥ ។

២៤ ហើយយើងជាព្រះ បានមានបន្ទូលថា៖ ចូរឲ្យផែនដីមានពោរពេញទៅដោយចតុប្បាទជាតិតាមពូជ គឺជាសត្វស្រុក សត្វលូនវារ និងសត្វព្រៃនៅផែនដីតាមពូជ ហើយក៏មានដូច្នោះ;

២៥ ហើយយើងជាព្រះ បានធ្វើសត្វព្រៃនៅផែនដីតាមពូជ សត្វស្រុកតាមពូជ ហើយគ្រប់ទាំងសត្វដែលលូនវារនៅដីគោកតាមពូជដែរ; ហើយយើងជាព្រះ បានឃើញថាគ្រប់របស់ទាំងនេះសុទ្ធតែល្អ ។

២៦ ហើយយើងជាព្រះ បានមានបន្ទូលទៅ[ក]ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង ដែលបានគង់នៅជាមួយនឹងយើងចាប់តាំងពីដើម ដំបូងមកថា៖ ចូរយើង[ខ]ធ្វើមនុស្សឲ្យដូចជា[គ]រូបយើង ឲ្យមានភាពដូចយើង; ហើយក៏មានដូច្នោះ ។ ហើយយើងជាព្រះ បានមាន បន្ទូលថា៖ ចូរឲ្យពួកគេមាន[ឃ]អំណាចត្រួតត្រាលើត្រីសមុទ្រ និងលើសត្វហើរលើអាកាស និងលើសត្វជើងបួន និងលើផែនដីទាំងមូល ព្រមទាំងលើសត្វលូនវារ ដែលវារនៅផែនដីផង ។

២៧ ហើយយើងជា[ក]ព្រះ បានបង្កើតមនុស្សឲ្យដូចរូបយើង គឺដូចជារូបនៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើង នោះយើងបានបង្កើតគេ មក; គឺជាប្រុសជាស្រី យើងបានបង្កើតពួកគេឡើង ។

២៨ ហើយយើងជាព្រះ បានប្រទានពរដល់ពួកគេ ហើយបានមានបន្ទូលទៅពួកគេថា៖ ចូរបង្កើតកូនឲ្យ[ក]ចំរើនជាច្រើនឡើង ឲ្យមាន ពេញពាសលើផែនដីចុះ ហើយបង្ក្រាបផែនដី ហើយមានអំណាចត្រួតត្រាលើត្រីសមុទ្រ និងលើសត្វហើរលើអាកាស និងលើជីវិតផង ទាំងឡាយដែលកំរើកនៅផែនដីផង ។

២៩ ហើយយើងជាព្រះ បានមានបន្ទូលទៅបុរសថា៖ មើលចុះ យើងបានប្រទានដល់អ្នក នូវគ្រប់ទាំងតិណជាតិមានគ្រាប់ពូជដែលដុះនៅផែនដី និងគ្រប់ទាំងដើមឈើទាំងឡាយ ដែលកើតផ្លែមានគ្រាប់ពូជ; របស់ទាំងនោះនឹងទៅជា[ក]អាហារដល់អ្នក ។

៣០ ហើយចំពោះអស់ទាំងសត្វនៅលើផែនដី និងចំពោះសត្វហើរលើអាកាស និងចំពោះគ្រប់សត្វទាំងឡាយ ដែលលូនវារនៅលើ ផែនដី ដែលយើងបានឲ្យមានជីវិតទាំងប៉ុន្មាន នោះនឹងត្រូវប្រទានគ្រប់តិណជាតិល្អៗឲ្យធ្វើជាអាហារ; ហើយក៏មានដូច្នោះ គឺដូចដែល យើងបានមានបន្ទូលមក ។

៣១ ហើយយើងជាព្រះ បានទតគ្រប់ទាំងរបស់ដែលយើងបានធ្វើនោះ ហើយមើលចុះ របស់ទាំងអស់ដែលយើងបានធ្វើនោះសុទ្ធតែ [ក]ល្អប្រពៃ; ហើយក៏មានល្ងាច មានព្រឹកឡើង ជា[ខ]ថ្ងៃទី ៦ ៕

## ជំពូកទី ៣

*(មិថុនា–តុលា ១៨៣០)*

*ព្រះទ្រង់បានបង្កើតរបស់ទាំងអស់ខាងវិញ្ញាណ មុនមានរបស់ទាំងនោះនៅលើផែនដីតាមធម្មជាតិ — ទ្រង់បានបង្កើតបុរសគឺជាសាច់ទី មួយនៅលើផែនដី — ស្ត្រីគឺជាជំនួយមួយដ៏សមចំពោះបុរស ។*

ដូច្នេះផ្ទៃមេឃ និងផែនដីក៏បាន[ក]ធ្វើរួចជាស្រេច ព្រមទាំងរបស់សព្វសារពើផង ។

២ ហើយនៅថ្ងៃទី ៧ នោះយើងជាព្រះ បានបង្ហើយកិច្ចការរបស់យើង ព្រមទាំងរបស់ទាំងប៉ុន្មានដែលយើងបានធ្វើផង; ហើយយើងក៏ ឈប់ផ្អាក[ក]សំរាកនៅ[ខ]ថ្ងៃទី ៧ នោះ ពីគ្រប់ទាំងកិច្ចការរបស់យើង ហើយគ្រប់របស់ទាំងអស់ដែលយើងបានធ្វើនោះរួចជាស្រេច ហើយយើងជាព្រះ បានឃើញថារបស់ទាំងនោះសុទ្ធតែល្អ;

២២ *ក* លោកុ. ១:២២–២៥;
អ័ប្រា. ៤:២២–២៥.
២៦ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*គ* លោកុ. ១:២៦–២៧;
ម៉ូសេ ៦:៨–១០;
អ័ប្រា. ៤:២៦–២៧.
*ឃ* លោកុ. ១:២៨; ម៉ូសេ ៥:១;
អ័ប្រា. ៤:២៨.
២៧ *ក* ស.ប. ព្រះ, ក្រុមព្រះ.
២៨ *ក* ម៉ូសេ ៥:២.
២៩ *ក* លោកុ. ១:២៩–៣០;
អ័ប្រា. ៤:២៩–៣០.
៣១ *ក* លោកុ. ១:៣១;
គ. និង ស. ៥៩:១៦–២០.
*ខ* និក្ខ. ២០:១១; អ័ប្រា. ៤:៣១.
៣ ១ *ក* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
*ខ* លោកុ. ២:១; អ័ប្រា. ៥:១.
២ *ក* លោកុ. ២:២–៣;
អ័ប្រា. ៥:២–៣.
ស.ប. សេចក្ដីសំរាក.
*ខ* ស.ប. ថ្ងៃឈប់សំរាក.

៣ ហើយយើងជាព្រះ [ក]បានប្រទានពរដល់ថ្ងៃទី ៧ ហើយញែកថ្ងៃនោះទុកជាថ្ងៃបរិសុទ្ធ ពីព្រោះនៅថ្ងៃនោះ យើងបានឈប់សំរាកពីគ្រប់ ទាំង[ខ]កិច្ចការរបស់យើង ដែលយើងជាព្រះបានបង្កើត និងបានធ្វើមក ។

៤ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា នេះហើយជាដើមកំណើតនៃផ្ទៃមេឃ និងផែនដី ក្នុងកាលដែលបានកើតមក គឺនៅវេលា ដែលយើង ជាព្រះអម្ចាស់ដ៏ជាព្រះបានធ្វើផ្ទៃមេឃ និងផែនដី,

៥ និងតិណជាតិគ្រប់យ៉ាងនៅវាល [ក]មុនមាននៅលើផែនដី ព្រមទាំងរុក្ខជាតិគ្រប់យ៉ាងនៅវាល មុនដែលដុះមកផង ។ ត្បិតយើងជាព្រះ អម្ចាស់ដ៏ជាព្រះ [ខ]បានបង្កើតគ្រប់របស់ទាំងអស់ ដែលយើងបានពោលដល់នោះ[គ]ខាងវិញ្ញាណ មុនមានរបស់ទាំងនោះនៅលើផែនដី តាមធម្មជាតិ ។ ត្បិតយើងជាព្រះអម្ចាស់ដ៏ជាព្រះ មិនបានបង្អុរភ្លៀងមកលើ[ឃ]ផ្ទៃផែនដីទេ ។ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានបង្កើតអស់ទាំងកូនចៅមនុស្ស; ក៏ប៉ុន្តែពុំទាន់មានមនុស្សណានឹង[ង]ភ្ជួរដីសោះ; ត្បិតយើងបានបង្កើតពួកគេនៅ[ច]ស្ថានសួគ៌; ហើយពុំ ទាន់មាន[ឆ]សាច់នៅលើផែនដីនៅឡើយទេ ឬក៏នៅក្នុងទឹក ឬនៅលើអាកាសដែរ;

៦ ប៉ុន្តែយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូល ហើយក៏មាន[ក]ចំហាយឡើងពីដីមក ហើយស្រោចស្រប់គ្រប់លើផ្ទៃដី ។

៧ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានសូនមនុស្សពី[ក]ធូលីដី ហើយផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ ហើយ[ខ]មនុស្សក្លាយ ជាមាន[គ]ព្រលឹងរស់ឡើង គឺជាសាច់ទី[ឃ]មួយនៅលើផែនដី ព្រមទាំងជាមនុស្សទីមួយផង; ទោះជាយ៉ាងណាក៏ដោយ គង់តែមានគ្រប់របស់ ទាំងអស់ មុនដែលបានបង្កើតមក; ប៉ុន្តែរបស់ទាំងនោះត្រូវបានបង្កើត និងធ្វើឡើងខាងវិញ្ញាណ ស្របតាមបន្ទូលរបស់យើង ។

៨ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានធ្វើសួនច្បារមួយនៅ[ក]ស្រុកអេដែនទិសខាងកើត ហើយយើងបានដាក់មនុស្សដែលយើងបាន សូនឡើងឲ្យនៅទីនោះ ។

៩ ហើយចេញពីដី នោះយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានធ្វើឲ្យដុះគ្រប់អស់ទាំងដើមឈើតាមធម្មជាតិ ដែលគួរជាទីគាប់ដល់ចក្ខុនៃ មនុស្ស ហើយមនុស្សក៏អាចមើលឃើញដើមទាំងនោះដែរ ។ ហើយដើមទាំងនោះក៏ក្លាយជាមានជីវិតរស់នៅ ។ ត្បិតដើមទាំងនោះ សុទ្ធតែជាវិញ្ញាណ ក្នុងកាលដែលយើងបានបង្កើតដើមឈើទាំងនោះឡើង; ត្បិតដើមឈើទាំងនោះបាននៅក្នុងវិស័យ ដែលយើង ជាព្រះបានបង្កើតដើមឈើទាំងនោះមកមែនហើយ គឺគ្រប់របស់ទាំងអស់ដែលយើងបានរៀបចំឡើងសំរាប់ទុកជាការប្រើប្រាស់ដល់ មនុស្ស; ហើយមនុស្សបានឃើញថាល្អសំរាប់ធ្វើជាអាហារ ។ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ ក៏ដាំ[ក]ដើមជីវិតនៅកណ្ដាលសួនច្បារ ព្រមទាំង[ខ]ដើមសំរាប់ដឹងខុសត្រូវផង ។

១០ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានបណ្ដាលឲ្យមានទន្លេមួយហូរចេញពីស្រុកអេដែន មក[ក]ស្រោចសួនច្បារនោះ; ហើយហូរបែក ពីនោះ ហើយក្លាយទៅជាបួនមុខ ។

១១ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានហៅឈ្មោះទន្លេទី១ថា ពិសុន ហើយទន្លេនោះហូរព័ទ្ធស្រុកហាវិឡាយទាំងមូល ដែល យើងជាព្រះអម្ចាស់ដ៏ជាព្រះ បានបង្កើតឲ្យមានមាសជាច្រើន;

១២ ហើយមាសដែលមកស្រុកនោះជាមាសយ៉ាងល្អ ហើយក៏មានទាំងបេ្តល្លាម និងត្បូងអូនីក្សផង ។

១៣ ហើយឈ្មោះទន្លេទី២ នោះត្រូវបានហៅថា គីហុន; គឺជាទន្លេដែលហូរព័ទ្ធស្រុកគូស ។

១៤ ហើយឈ្មោះទន្លេទី៣ គឺហ៊ីដេកែល ជាទន្លេដែលហូរចាក់ទៅខាងកើតស្រុកអាសស៊ើរ ។ ហើយទន្លេទី៤ គឺអ៊ើប្រាត ។

១៥ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានយកមនុស្សទៅ ហើយដាក់គេនៅក្នុងសួនច្បារអេដែន ឲ្យធ្វើការហើយថែរក្សាសួនច្បារ នោះ ។

៣ *ក* ម៉ូសាយ ១៣:១៩.
*ខ* និក្ខ. ៣១:១៤–១៥.
៥ *ក* លោកុ. ២:៤–៥; អ័ប្រា. ៥:៤–៥.
*ខ* ម៉ូសេ ៦:៥១.
*គ* អ័ប្រា. ៣:២៣;
គ. និង ស. ២៩:៣១–៣៤.
ស.ប. ការបង្កបង្កើតខាងវិញ្ញាណ.
*ឃ* ស.ប. វិញ្ញាណ.
*ង* លោកុ. ២:៥.
*ច* ស.ប. ស្ថានសួគ៌.
*ឆ* ស.ប. មនុស្ស, មនុស្សលោក — មនុស្សជាកូនវិញ្ញាណនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
៦ *ក* លោកុ. ២:៦.
៧ *ក* លោកុ. ២:៧; ម៉ូសេ ៤:២៥; ៦:៥៩; អ័ប្រា. ៥:៧.
*ខ* ស.ប. អ័ដាម.
*គ* ស.ប. ព្រលឹង.
*ឃ* ម៉ូសេ ១:៣៤.
៨ *ក* ស.ប. អេដែន.
៩ *ក* ស.ប. ដើមជីវិត.
*ខ* លោកុ. ២:៩.
១០ *ក* លោកុ. ២:១០.

១៦ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានបញ្ជាដល់បុរសថា៖ ផ្លែឈើទាំងអស់នៅក្នុងសួនច្បារ នោះអ្នកអាចបរិភោគបានតាមចិត្ត,

១៧ ប៉ុន្តែផលពីដើមដឹងខុសត្រូវ នោះអ្នកមិនត្រូវបរិភោគឡើយ ទោះជាយ៉ាងណាក៏ដោយ អ្នកអាចជ្រើសរើសសំរាប់ខ្លួនផ្ទាល់ ត្បិត ការណ៍នោះត្រូវបានប្រទានដល់អ្នកហើយ; ប៉ុន្តែចូរចងចាំថា យើងបានហាមឃាត់ ត្បិតនៅថ្ងៃណាដែលអ្នកបរិភោគ នោះអ្នកនឹងត្រូវ ស្លាប់ជាមិនខានឡើយ ។

១៨ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលទៅព្រះរាជបុត្រាបង្កើតតែមួយរបស់យើងថា វាមិនល្អទេដែលបុរសនេះត្រូវ នៅតែម្នាក់ឯង; ហេតុដូច្នោះហើយ យើងនឹងធ្វើឲ្យមានជំនួយមួយដ៏សមចំពោះគាត់ ។

១៩ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានយកដីមកសូននូវគ្រប់ទាំងសត្វជើងបួននៅវាល និងគ្រប់ទាំងសត្វហើរលើអាកាសផង; ហើយបានបញ្ជាដល់សត្វទាំងនោះឲ្យមកឯអ័ដាម ដើម្បីឲ្យដឹងថាគាត់នឹងហៅដូចម្ដេច; ហើយសត្វទាំងនោះក៏មានព្រលឹងរស់ដែរ; ត្បិត យើងជាព្រះ បានផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងសត្វទាំងនោះ ហើយបានបញ្ជាថា ឈ្មោះណាក៏ដោយដែលអ័ដាមបានដាក់ឲ្យដល់ជីវិតផងទាំងឡាយ នោះបានសំរេចជាឈ្មោះរបស់សត្វនោះឯង ។

២០ ហើយអ័ដាមបានដាក់ឈ្មោះឲ្យដល់គ្រប់ទាំងសត្វស្រុក សត្វព្រៃ និងសត្វហើរលើអាកាសទាំងប៉ុន្មានជាស្រេច; ប៉ុន្តែចំពោះអ័ដាម វិញ នោះមិនឃើញមានជំនួយណាមួយដ៏សមចំពោះគាត់សោះ ។

២១ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានធ្វើឲ្យអ័ដាមដេកលង់លក់ទៅ ហើយគាត់ក៏ដេកលក់ ហើយយើងបានយកឆ្អឹងជំនីរគាត់មួយ ហើយភ្ជិតសាច់ទៅវិញ;

២២ ហើយរីឯឆ្អឹងជំនីរដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានយកពីបុរសមក នោះយើងបានធ្វើជាស្ត្រីមួយ ហើយនាំនាងទៅឯបុរស ។

២៣ ហើយអ័ដាមក៏ថា៖ ឥឡូវនេះ ខ្ញុំដឹងហើយថានេះជាឆ្អឹងពីឆ្អឹងខ្ញុំ ហើយជាសាច់ពីសាច់ខ្ញុំ; នាងនឹងត្រូវបានហៅថា «ស្ត្រី» ពីព្រោះ នាងត្រូវបានយកចេញពីបុរសមក ។

២៤ ហេតុដូច្នេះហើយ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្ដាយខ្លួន ហើយទៅនៅជាប់នឹងប្រពន្ធ; ហើយអ្នកទាំងពីរ នោះនឹងត្រូវជា សាច់តែមួយសុទ្ធ ។

២៥ ហើយគេទាំងពីរនាក់នៅខ្លួនអាក្រាតទទេ គឺបុរសនិងប្រពន្ធគាត់ ហើយឥតមានសេចក្ដីខ្មាសអៀនឡើយ ៕

---

## ជំពូកទី ៤

*(មិថុនា–តុលា ១៨៣០)*

*របៀបដែលសាតាំងក្លាយទៅជាអារក្ស — វាល្បួងនាងអេវ៉ា — លោកអ័ដាម ហើយនាងអេវ៉ាបានធ្លាក់ ហើយសេចក្ដីស្លាប់ចូល មកក្នុងពិភពលោក ។*

ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលទៅម៉ូសេថា៖ សាតាំងនោះដែលអ្នកបានបញ្ជា ដោយនូវព្រះនាមនៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើង គឺជាអ្នកដដែល ដែលមានតាំងពីដើមដំបូងមក ហើយវាបានមកចំពោះយើង ដោយទូលថា — មើលចុះ ទូលបង្គំនៅឯណេះហើយ សូមចាត់ទូលបង្គំចុះ ទូលបង្គំនឹងធ្វើជាព្រះរាជបុត្រារបស់ព្រះអង្គ ហើយទូលបង្គំនឹងប្រោសលោះមនុស្សលោក ទាំងអស់ ប្រយោជន៍កុំឲ្យព្រលឹងណាមួយត្រូវបាត់ឡើយ ហើយទូលបង្គំនឹងប្រព្រឹត្តការនោះជាមិនខាន; ហេតុដូច្នោះហើយ សូមប្រទាន ដល់ទូលបង្គំនូវកិត្តិយសរបស់ព្រះអង្គចុះ ។

២ ប៉ុន្តែមើលចុះ ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង ដែលជាទីស្ងួនភ្ងា និងជាទីជំរើសរបស់យើងចាប់តាំងពីដើមដំបូងមក

---

១៧ *ក* ម៉ូសេ ៧:៣២.
ស.ប. សិទ្ធិជ្រើសរើស.
*ខ* អ័ប្រា. ៥:១៣.
*គ* លោកុ. ២:១៧.
ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម; ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់.
១៨ *ក* ស.ប. បង្កើតតែមួយ.
*ខ* លោកុ. ២:១៨; អ័ប្រា. ៥:១៤.
២២ *ក* ស.ប. នាងអេវ៉ា; ស្ត្រី, ពួកស្ត្រី.
២៣ *ក* លោកុ. ២:២៣; អ័ប្រា. ៥:១៧.
២៤ *ក* លោកុ. ២:២៤; គ. និង ស. ៤២:២២; ៤៩:១៥–១៦; អ័ប្រា. ៥:១៧–១៨.
*ខ* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍.
៤ ១*ក* ស.ប. អារក្ស.
*ខ* គ. និង ស. ២៩:៣៦–៣៧.
*គ* អេសាយ ១៤:១២–១៥.
២ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ម៉ូសេ ៧:៣៩; អ័ប្រា. ៣:២៧.
ស.ប. ការតែងតាំងមុនកំណើតរលោកិយ.

បានទូល ដល់យើងថា — [គ]ព្រះវរបិតាអើយ សូមឲ្យ
[ឃ]ព្រះហឫទ័យរបស់ព្រះអង្គបានសំរេច ហើយសូមឲ្យ[ង]សិរីល្អរបស់
ព្រះអង្គបានជារបស់ផង ព្រះអង្គរហូត ។
៣ ហេតុដូច្នោះហើយ មកពីសាតាំងបាន[ក]បះបោរទាស់នឹងយើង
ហើយបានខំរកបំផ្លាញ[ខ]សិទ្ធិជ្រើសរើសរបស់មនុស្ស ដែលយើងជា
ព្រះអម្ចាស់ដ៏ជាព្រះ បានប្រទានដល់មនុស្ស ហើយក៏មកពីវាបាន
ចង់ឲ្យយើងប្រទានដល់វា នូវព្រះចេស្ដារបស់យើងផ្ទាល់; គឺដោយ
សារ ព្រះចេស្ដានៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើង នោះ
យើងបានបណ្ដាលឲ្យវា[គ]ត្រូវបណ្ដេញចុះ ។
៤ ហើយវាក្លាយទៅជាសាតាំង មែនហើយ គឺជាអារក្ស
ជាបិតានៃអស់ទាំង[ក]ការកុហក ដើម្បីបញ្ឆោត ហើយដើម្បីធ្វើឲ្យ
មនុស្សខ្វាក់ ហើយដើម្បីដឹក ពួកគេយកទៅជាឈ្លើយ តាមចិត្ត
របស់វា គឺមនុស្សជាច្រើនណាដែលមិនព្រមស្ដាប់តាមសម្លេង
របស់យើងនោះ ហើយ ។
៥ ហើយឥឡូវនេះ ពស់ជាសត្វមាន[ក]ឧបាយកលលើសជាង
អស់ទាំងសត្វព្រៃ ដែលយើងជាព្រះអម្ចាស់ដ៏ជាព្រះ បាន
ធ្វើឡើង ។
៦ ហើយសាតាំងបានដាក់ទៅក្នុងចិត្តពស់ (ត្បិតវាបាន
ទាញមនុស្សជាច្រើនឲ្យទៅតាមវា) ហើយវាក៏ខំល្បួងបញ្ឆោត
[ក]នាងអេវ៉ា ត្បិតវា មិនស្គាល់គំនិតនៃព្រះទេ ហេតុដូច្នោះហើយ
បានជាវាខំរកបំផ្លាញពិភពលោកចោល ។
៧ ហើយវានិយាយទៅស្ត្រីថា៖ មែនហើយ តើព្រះទ្រង់បាន
មានព្រះបន្ទូលថា — អ្នកមិនត្រូវបរិភោគផ្លែឈើគ្រប់មុខនៅ
[ក]ក្នុងសួនច្បារ មែនឬ ? (ហើយវាបាននិយាយតាមមាត់ពស់) ។
៨ ហើយស្ត្រីបាននិយាយទៅពស់ថា៖ យើងអាចបរិភោគអស់
ទាំងផ្លែឈើនៅក្នុងសួនច្បារបាន;
៩ ប៉ុន្តែចំពោះផ្លែដើមឈើមួយ ដែលអ្នកឃើញនៅ
កណ្ដាលសួនច្បារ នោះព្រះទ្រង់បានមានព្រះបន្ទូលថា —
អ្នកមិនត្រូវបរិភោគផ្លែនោះ ឡើយ ថែមទាំងមិនត្រូវពាល់ប៉ះផង
ក្រែងលោអ្នកត្រូវស្លាប់ ។
១០ ហើយពស់បាននិយាយទៅស្ត្រីថា៖ អ្នកប្រាកដជាមិន
ស្លាប់ទេ;
១១ ត្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគផ្លែ
ឈើនោះ នោះ[ក]ភ្នែកអ្នកនឹងបានភ្លឺឡើង ហើយអ្នកនឹងបានដូចជា
ពួកព្រះដែរ ដោយ[ខ]ដឹងខុសត្រូវ ។
១២ ហើយកាលស្ត្រីបានឃើញថា ផ្លែឈើនោះ
ជាផ្លែល្អសំរាប់ធ្វើជាអាហារ ហើយថាផ្លែនោះក្លាយទៅជា
ទីគាប់ដល់ភ្នែក ហើយជា ដើមដែលល្មមគួរ[ក]នឹងចង់បាន
ដើម្បីឲ្យនាងបានប្រាជ្ញា នាងក៏យកផ្លែ[ខ]បរិភោគ ហើយព្រម
ទាំងចែកឲ្យដល់ប្ដីនាងដែលនៅជាមួយ នាងដែរ ហើយ
គាត់ក៏បរិភោគតាម ។
១៣ ហើយស្រាប់តែភ្នែករបស់អ្នកទាំងពីរបានភ្លឺឡើង
ហើយគេដឹងថាខ្លួននៅ[ក]អាក្រាត ។ ហើយគេក៏យកស្លឹកល្វាមក
ក្លាស់ធ្វើជា ប្រដាប់បាំង ។
១៤ ហើយគេបានឮសម្លេងនៃព្រះអម្ចាស់ដ៏ជាព្រះ កាល
គេ[ក]កំពុងតែដើរក្នុងសួនច្បារ នៅពេលថ្ងៃល្ងើយ; ហើយអ័ដាមនិង
ប្រពន្ធគាត់ ក៏ទៅពួនពីវត្តមាននៃព្រះអម្ចាស់ដ៏ជាព្រះ នៅកណ្ដាល
ដើមឈើក្នុងសួនច្បារ ។
១៥ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានហៅទៅអ័ដាម
ដោយមានបន្ទូលទៅគាត់ថា៖ [ក]អ្នកទៅឯណា ?
១៦ ហើយគាត់បានទូលថា៖ ទូលបង្គំបានឮសម្លេងទ្រង់នៅ
ក្នុងសួនច្បារ ហើយទូលបង្គំនឹកភ័យខ្លាច ពីព្រោះ
ទូលបង្គំឃើញថាទូលបង្គំ នៅខ្លួនអាក្រាតទទេ ហើយ
ទូលបង្គំក៏រត់ទៅពួន ។
១៧ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលទៅ
អ័ដាមថា៖ តើអ្នកណាប្រាប់ឲ្យអ្នកដឹងថា អ្នកនៅខ្លួនអាក្រាតទទេ
ដូច្នេះ ? តើអ្នកបានបរិភោគផ្លែឈើដែលយើងបញ្ជាដល់អ្នកថា
អ្នកមិនត្រូវបរិភោគ[ក]ផ្លែនោះ បើសិនជាអ្នកបរិភោគ នោះអ្នក
ច្បាស់ជា នឹងត្រូវស្លាប់ជាមិនខានឡើយនោះឬអី ?
១៨ ហើយបុរសទូលឆ្លើយថា៖ ស្ត្រីដែលទ្រង់បានប្រទានដល់

២ *គ* ស.ប. ព្រះ, ក្រុមព្រះ —
ព្រះដ៏ជាព្រះវរបិតា.
*ឃ* លូកា ២២:៤២.
*ង* ស.ប. សិរីល្អ.
៣ *ក* ស.ប. ក្រុមប្រឹក្សានៅស្ថានសួគ៌.
*ខ* ស.ប. សិទ្ធិជ្រើសរើស.
*គ* គ. និង ស. ៧៦:២៥–២៧.
៤ *ក* ២ នីហ្វៃ ២:១៨;
គ. និង ស. ១០:២៥.
ស.ប. ការបោក, បញ្ឆោត,
សេចក្ដីបញ្ឆោត; សេចក្ដីកុហក.
៥ *ក* លោកុ. ៣:១; ម៉ូសាយ ១៦:៣;
អាលម៉ា ១២:៤.
៦ *ក* ស.ប. នាងអេវ៉ា.
៧ *ក* ស.ប. អេដែន.
១១ *ក* លោកុ. ៣:៣–៦; ម៉ូសេ ៥:១០.
*ខ* អាលម៉ា ១២:៣១.
១២ *ក* លោកុ. ៣:៦.
*ខ* ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
១៣ *ក* លោកុ. ២:២៥.
១៤ *ក* លោកុ. ៣:៨.
១៥ *ក* លោកុ. ៣:៩.
១៧ *ក* ម៉ូសេ ៣:១៧.

ទូលបង្គំ ហើយបានបញ្ជាថា នាងត្រូវនៅជាមួយនឹងទូលបង្គំ នាងឲ្យផ្លែឈើ នោះមកទូលបង្គំ ហើយទូលបង្គំក៏ទទួលទានទៅ ។

១៩ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលទៅស្ត្រីថា៖ តើនេះជាអ្វីទៅដែលនាងបានប្រព្រឹត្ត ? ហើយស្ត្រីបានទូលឆ្លើយថា៖ ពស់វារមកល្បួងបញ្ឆោតខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់បានទទួលទានទៅ ។

២០ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលទៅពស់ថា៖ ដោយព្រោះឯងបានធ្វើដូច្នេះ ឯងនឹងត្រូវបណ្ដាសាធ្ងន់ជាងអស់ ទាំងពួកសត្វស្រុក សត្វព្រៃ; គឺឯងត្រូវលូនតែនឹងពោះ ហើយត្រូវស៊ីធូលីដីអស់១ជីវិត;

២១ ហើយយើងនឹងដាក់សេចក្ដីខ្មាំងរវាងឯងនិងស្ត្រី គឺរវាងពូជឯងនិងពូជនាង; ហើយគេនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែង ជើងគេ ។

២២ ទៅស្ត្រី នោះយើងជាព្រះអម្ចាស់ដ៏ជាព្រះបានមានបន្ទូលថា៖ យើងនឹងចំរើនឲ្យនាងមានសេចក្ដីព្រួយលំបាកជាច្រើនឡើងក្នុងវេលាដែលមានផ្ទៃពោះ ។ នាងនឹងបង្កើតកូនដោយឈឺចាប់ ហើយចិត្តនាងនឹងប្រាថ្នាខាងឯប្ដីនាង ហើយគាត់នឹងត្រួតត្រាលើនាង ។

២៣ ហើយទៅអ័ដាម នោះយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលថា៖ ដោយព្រោះអ្នកបានស្ដាប់តាមសម្លេងនៃប្រពន្ធអ្នក ហើយ បានបរិភោគផ្លែនៃដើមឈើនោះ ដែលយើងបានបញ្ជាដល់អ្នកថា — អ្នកមិនត្រូវបរិភោគផ្លែនោះឡើយ នោះដីត្រូវបណ្ដាសាដោយ ព្រោះអ្នក; អ្នកត្រូវរកស៊ីពីដីដោយនឿយហត់អស់១ជីវិត ។

២៤ ដីនឹងដុះជាបន្លា ហើយនិងអញ្ចាញឲ្យអ្នក ហើយអ្នកត្រូវបរិភោគអស់ទាំងតិណជាតិដែលដុះនៅស្រែចំការ ។

២៥ អ្នកនឹងបានអាហារបរិភោគដោយការបែកញើស ដរាបដល់អ្នកត្រឡប់ទៅជាដីវិញ — ត្បិតច្បាស់ជានឹងស្លាប់ជាមិនខានឡើយ — ពីព្រោះអ្នកត្រូវបានយកចេញពីដីមក ត្បិតអ្នកជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ ។

២៦ ហើយអ័ដាមបានឲ្យឈ្មោះប្រពន្ធគាត់ថា «អេវ៉ា» ពីព្រោះនាងជាម្ដាយនៃជីវិតទាំងអស់; ត្បិតយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានហៅស្ត្រីទី១ថាដូច្នោះហើយ ដែលមានជាច្រើន ។

២៧ ចំពោះអ័ដាម ហើយព្រមទាំងប្រពន្ធគាត់ផង នោះយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានធ្វើអាវពីស្បែកឲ្យពាក់បិទបាំងកាយ ។

២៨ ហើយយើងជាព្រះអម្ចាស់ដ៏ជាព្រះ បានមានបន្ទូលទៅព្រះរាជបុត្រាបង្កើតតែមួយរបស់យើងថា៖ មើលចុះ មនុស្សបានត្រឡប់ដូចជា យើងមួយដែរ ទាំងដឹងខុសត្រូវផង; ហើយឥឡូវនេះខ្លាចក្រែងគេលូកដៃគេទៅ ហើយបេះផ្លែពីដើមជីវិតផង ហើយបរិភោគ ហើយរស់ ជារៀងដរាបទៅ,

២៩ ហេតុដូច្នេះហើយ យើងជាព្រះអម្ចាស់ដ៏ជាព្រះ នឹងបណ្ដេញគាត់ចេញពីសួនច្បារអេដែន ឲ្យទៅភ្ជួររាស់ដីដែលបានយកគាត់ចេញ មក;

៣០ ព្រោះដរាបណាយើងជាព្រះអម្ចាស់ដ៏ជាព្រះ មានព្រះជន្មរស់នៅ នោះព្រះបន្ទូលទាំងឡាយរបស់យើងក៏នឹងមិនផ្ដល់ផលដែល ឥតប្រយោជន៍ដែរ ត្បិតកាលណាព្រះបន្ទូលយើងចេញពីព្រះឱសយើងទៅ នោះនឹងបានសំរេច ។

៣១ ម្ល៉ោះហើយ យើងក៏បណ្ដេញមនុស្សចេញ ហើយយើងបានដាក់ ចេរូប៊ីននៅខាងកើតសួនច្បារអេដែន និងដាវដែលជាអណ្ដាតភ្លើង វេបែរគ្រប់ទិស ដើម្បីនឹងរក្សាផ្លូវទៅឯដើមជីវិត ។

៣២ (នេះហើយជាព្រះបន្ទូលដែលយើងបានមានបន្ទូលទៅម៉ូសេ ជាអ្នកបំរើរបស់យើង ហើយព្រះបន្ទូលទាំងនោះសុទ្ធតែពិតដូចដែល យើងសព្វព្រះហឫទ័យ; ហើយយើងបានមានបន្ទូលទៅអ្នក ។ ចូរមើលឲ្យឃើញថាអ្នកមិនបង្ហាញព្រះបន្ទូលទាំងនោះដល់អ្នកណាឡើយ វៀតដល់យើងបញ្ជាអ្នក គឺលើកលែងតែចំពោះពួកអ្នកដែលជឿប៉ុណ្ណោះ ។ អាម៉ែន ៕)

១៩ *ក* លោកុ. ៣:១៣; ម៉ូសាយ ១៦:៣.
២០ *ក* លោកុ. ៣:១៣–១៥.
២២ *ក* លោកុ. ៣:១៦.
២៥ *ក* លោកុ. ៣:១៧–១៩.
ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
*ខ* លោកុ. ២:៧; ម៉ូសេ ៦:៥៩; អ័ប្រា. ៥:៧.
២៦ *ក* ម៉ូសេ ១:៣៤; ៦:៩.
២៧ *ក* ស.ប. ភាពរម្យទម.
២៨ *ក* លោកុ. ៣:២២.
ស.ប. មនុស្ស, មនុស្សលោក — មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌.
*ខ* ស.ប. ជំរិះ.
*គ* អាលម៉ា ៤២:៤–៥.
*ឃ* លោកុ. ២:៩; ១ នីហ្វៃ ១១:២៥; ម៉ូសេ ៣:៩.
ស.ប. ដើមជីវិត.
២៩ *ក* ស.ប. អេដែន.
៣០ *ក* ១ ពង្សាវ. ៨:៥៦; គ. និង ស. ១:៣៨.
៣១ *ក* អាលម៉ា ៤២:៣.
ស.ប. ចេរ៉ូប៊ីន.

## ជំពូកទី ៥

*(មិថុនា–តុលា ១៨៣០)*

*លោកអ័ដាម និងនាងអេវ៉ាបង្កើតបានកូនចៅ — អ័ដាមថ្វាយយញ្ញបូជាទាំងឡាយ ហើយបំរើព្រះ — កាអ៊ីន និងអេបិលបានកើតមក — កាអ៊ីនបះបោរ ស្រឡាញ់អារក្សសាតាំងជាងព្រះ ហើយក្លាយទៅជាអន្តរធាន — អំពើឃាតកម្ម និងអំពើទុច្ចរិតរាលដាល — ដំណឹងល្អ ត្រូវបានផ្សាយចាប់តាំងពីដើមដំបូងមក ។*

ហើយហេតុការណ៍បានកើតឡើងថា បន្ទាប់ពីយើងជាព្រះ
អម្ចាស់ដ៏ជាព្រះ បានបណ្ដេញគេចេញទៅ នោះអ័ដាមបាន
ចាប់ផ្ដើមភ្ជួររាស់ដី ហើយមាន[ក]អំណាចត្រួតត្រាលើគ្រប់ទាំង
សត្វស្រុក សត្វព្រៃ ហើយបរិភោគអាហារ ដោយសារការ
បែកញើស ដូចដែលយើងជាព្រះ អម្ចាស់ បានបញ្ជាដល់គាត់ ។
ហើយព្រមទាំងនាងអេវ៉ា ជាប្រពន្ធគាត់ ក៏បានធ្វើការជាមួយ
គាត់ដែរ ។
២ ហើយអ័ដាមក៏ស្គាល់ប្រពន្ធគាត់ ហើយនាង[ក]បង្កើតបាន
[ខ]កូនប្រុសកូនស្រីទាំងឡាយ ហើយពួកគេបានចាប់ផ្ដើមបង្កើតកូន
[គ]ជាច្រើនឡើង ហើយមានពេញពាសលើផែនដី ។
៣ ហើយចាប់តាំងពីពេលនោះមក នោះ[ក]ពួកកូនប្រុសកូនស្រី
របស់អ័ដាមបានចាប់ផ្ដើមបែកចេញជាគូៗ នៅលើដែនដី ហើយ
ភ្ជួររាស់ដី ហើយចញ្ចឹមហ្វូងចៀម ហើយពួកគេក៏បង្កើតបាន
កូនប្រុសកូនស្រីទាំងឡាយ ។
៤ ហើយអ័ដាមនិងនាងអេវ៉ា ជាប្រពន្ធគាត់បានអំពាវនាវដល់
ព្រះនាមនៃព្រះអម្ចាស់ ហើយពួកគេបានឮសម្លេងនៃព្រះអម្ចាស់
ចេញពីផ្លូវ ឆ្ពោះទៅសួនច្បារ[ក]អេដែន មានព្រះបន្ទូលមកពួកគេ
ហើយពួកគេមើលមិនឃើញទ្រង់សោះ ត្បិតពួកគេត្រូវបាន
បិទចេញពី[ខ]វត្តមាន របស់ទ្រង់ ។
៥ ហើយទ្រង់បានប្រទានដល់ពួកគេ នូវព្រះបញ្ញត្តិទាំងឡាយ
ថាពួកគេគប្បី[ក]ថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់ពួកគេ ហើយ
គប្បីយក[ខ]កូន សត្វច្បង នៃហ្វូងចៀមរបស់គេ មកថ្វាយ
ជាយញ្ញបូជាទាំងឡាយដល់ព្រះអម្ចាស់ ។ ហើយអ័ដាមបាន
[គ]គោរពតាមព្រះបញ្ញត្តិទាំង ឡាយនៃព្រះអម្ចាស់ ។
៦ ហើយជាច្រើនថ្ងៃកន្លងមក នោះមាន[ក]ទេវតាមួយពីព្រះ
អម្ចាស់បានលេចមកឲ្យអ័ដាមឃើញ ដោយសួរថា៖ ហេតុអ្វីបាន
ជាអ្នកថ្វាយ [ខ]យញ្ញបូជាទាំងឡាយដល់ព្រះអម្ចាស់ ? ហើយ
អ័ដាមបានទូលតបទៅលោកថា៖ ខ្ញុំមិនដឹងទេ លើកលែងតែព្រះ
អម្ចាស់ទ្រង់បញ្ជាខ្ញុំ ប៉ុណ្ណោះ ។
៧ ហើយខណៈនោះ ទេវតាប្រាប់ថា៖ ការណ៍នេះ
គឺជា[ក]និមិត្តរូបអំពី[ខ]ការបូជានៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះ
វរបិតា ដែលពោរ ពេញទៅដោយ[គ]ព្រះគុណ និងសេចក្ដីពិត ។
៨ ហេតុដូច្នោះហើយ អ្នកនឹងត្រូវធ្វើអ្វីៗទាំងអស់ដែលអ្នកធ្វើ
ដោយ[ក]នូវព្រះនាមនៃព្រះរាជបុត្រា ហើយអ្នកត្រូវ[ខ]ប្រែចិត្ត ហើយ
[គ]អំពាវ នាវដល់ព្រះ ដោយនូវព្រះនាមនៃព្រះរាជបុត្រា ជារៀង
ដរាបរហូតតទៅ ។
៩ ហើយនៅថ្ងៃនោះ [ក]ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមក
សណ្ឋិតលើអ័ដាម ដែលថ្លែងទីបន្ទាល់អំពីព្រះវរបិតា និងអំពី
ព្រះរាជបុត្រា ថា៖ យើងជា[ខ]ព្រះរាជបុត្រាបង្កើតតែមួយនៃ
ព្រះវរបិតា ចាប់តាំងពីដើមដំបូងមក គឺចាប់តាំងពីពេលនោះ
និងជារៀងដរាបតទៅ គឺដោយ ព្រោះអ្នកបាន[គ]ធ្លាក់ នោះអ្នកនឹង
អាចបាន[ឃ]ប្រោសលោះ និងព្រមទាំងមនុស្សជាតិទាំងអស់ផង
គឺមនុស្សជាច្រើនណាដែលសុខចិត្ត ។

---

**៥** ១*ក* ម៉ូសេ ២:២៦.
២ *ក* លោកុ. ៥:៤.
*ខ* គ. និង ស. ១៣៨:៣៩.
*គ* លោកុ. ១:២៨; ម៉ូសេ ២:២៨.
៣ *ក* ម៉ូសេ ៥:២៨.
៤ *ក* ស.ប. អេដែន.
*ខ* អាលម៉ា ៤២:៩.
៥ *ក* ស.ប. ថ្វាយបង្គំ.
*ខ* និក្ខ. ១៣:១២–១៣; ជនគ. ១៨:១៧; ម៉ូសាយ ២:៣. ស.ប. កូនច្បង.
*គ* ស.ប. ការគោរព, ដែលគោរព, គោរព.
៦ *ក* ស.ប. ពួកទេវតា.
*ខ* ស.ប. បូជា, យញ្ញបូជា.
៧ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ — គំរូ និងនិមិត្តរូបទាំងឡាយអំពីព្រះគ្រីស្ទ.
*ខ* អាលម៉ា ៣៤:១០–១៥. ស.ប. លោហិត.
*គ* ម៉ូសេ ១:៦, ៣២. ស.ប. ព្រះគុណ.
៨ *ក* ២ នីហ្វៃ ៣១:២១.
*ខ* ម៉ូសេ ៦:៥៧. ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*គ* ស.ប. ការអធិស្ឋាន.
៩ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ; បង្កើតតែមួយ.
*គ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ; ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
*ឃ* ម៉ូសាយ ២៧:២៤–២៦; គ. និង ស. ៩៣:៣៨; ម. នៃ ស. ៣. ស.ប. ផែនកានៃសេចក្ដីប្រោសលោះ; ប្រោសលោះ, បានប្រោសលោះ, សេចក្ដីប្រោសលោះ.

១០ ហើយនៅថ្ងៃនោះ អ័ដាមបានថ្វាយពរដល់ព្រះ ហើយបាន
ពោរពេញ ហើយបានចាប់ផ្ដើមព្យាករអំពីក្រុមគ្រួសារទាំង
អស់នៅលើ ផែនដី ថា៖ សូមឲ្យព្រះនាមនៃព្រះបានប្រកបដោយ
ព្រះពរ ត្បិតព្រោះតែការរំលងរបស់ខ្ញុំ នោះភ្នែកខ្ញុំបានភ្លឺឡើង
ហើយនៅក្នុងជីវិត នេះ ខ្ញុំនឹងមានសេចក្ដីអំណរ ហើយនៅក្នុង
សាច់ឈាម នោះខ្ញុំនឹងឃើញព្រះទៀត ។
១១ ហើយនាងអេវ៉ា ជាប្រពន្ធគាត់ បានឮគ្រប់ការណ៍ទាំងនេះ
ហើយមានចិត្តរីករាយ ដោយពោលថា៖ បើសិនជា
ពុំមែនដោយសារ ការរំលងរបស់យើងទេ នោះយើងក៏នឹងមិន
មានពូជសោះ ហើយនឹងមិនដឹងខុសត្រូវ និងសេចក្ដីអំណរអំពីសេច
ក្ដីប្រោសលោះរបស់ យើង និងជីវិតដ៏នៅអស់កល្បជានិច្ច ដែល
ព្រះទ្រង់បានប្រទានដល់មនុស្សទាំងអស់ដែលគោរពតាមដែរ ។
១២ ហើយអ័ដាមនិងនាងអេវ៉ាបានថ្វាយពរដល់ព្រះនាមនៃព្រះ
ហើយពួកគេបានប្រាប់គ្រប់ការណ៍ទាំងអស់ដល់ពួកកូនប្រុស
កូនស្រី របស់គេ ។
១៣ ហើយអារក្សសាតាំងបានមកក្នុងចំណោមពួកគេ ដោយ
ថា៖ យើងក៏ជាព្រះរាជបុត្រានៃព្រះដែរ; ហើយវាបានបញ្ជាពួក
គេថា៖ ចូរកុំជឿការណ៍នោះឡើយ; ហើយពួកគេក៏មិនជឿការណ៍
នោះទេ ហើយពួកគេស្រឡាញ់អារក្សសាតាំងជាងព្រះ ។ ហើយ
ចាប់តាំងពី ពេលនោះមក មនុស្សលោកបានចាប់ផ្ដើមក្លាយ
ទៅជាមានវិស័យខាងរូបកាយ ខាងកាមរាគ និងខាងអារក្ស ។
១៤ ហើយព្រះអម្ចាស់ដ៏ជាព្រះ បានហៅមនុស្សដោយ
សារព្រះវិញ្ញាណបរិសុទ្ធនៅគ្រប់ទិសទី ហើយបញ្ជាពួកគេថា
ពួកគេគួរប្រែចិត្ត;
១៥ ហើយមនុស្សជាច្រើនណាដែលជឿដល់ព្រះរាជបុត្រា
ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេ នោះនឹងបានសង្គ្រោះ;
ហើយ មនុស្សជាច្រើនណាដែលមិនជឿ ហើយមិនប្រែចិត្តទេ នោះ
នឹងត្រូវជាប់ទោស; ហើយព្រះបន្ទូលទាំងឡាយបានចេញពីព្រះ
ឱស្ឋនៃព្រះ ក្នុងច្បាប់មួយដ៏តឹងរឹង ហេតុដូច្នោះហើយ ព្រះបន្ទូល
ទាំងនោះត្រូវតែបានសំរេច ។
១៦ ហើយអ័ដាមនិងនាងអេវ៉ា ជាប្រពន្ធគាត់ ពុំដែល
ឈប់អំពាវនាវដល់ព្រះឡើយ ។ ហើយអ័ដាមក៏ស្គាល់នាងអេវ៉ា
ជាប្រពន្ធខ្លួន ហើយនាងមានផ្ទៃពោះបង្កើតបានកាអ៊ីន ហើយ
និយាយថា៖ ខ្ញុំបានកូនប្រុសមួយពីព្រះអម្ចាស់; ហេតុដូច្នោះហើយ
វាមិនអាចបដិសេធ ព្រះបន្ទូលរបស់ព្រះបានឡើយ ។ ប៉ុន្តែមើលចុះ
កាអ៊ីនពុំបានស្ដាប់តាមព្រះអម្ចាស់ទេ ដោយនិយាយថា៖ តើព្រះ
អម្ចាស់ទ្រង់ជានរណា ទៅ ដែលគួរឲ្យខ្ញុំស្គាល់ទ្រង់ ?
១៧ ហើយនាងក៏មានផ្ទៃពោះ ហើយបង្កើតបានអេបិល
ជាប្អូនទៀត ។ ហើយអេបិលបានស្ដាប់តាមសំឡេងនៃព្រះ
អម្ចាស់ ។ ហើយ អេបិលជាអ្នកគង្វាលចៀម ប៉ុន្តែកាអ៊ីនជា
អ្នកភ្ជួររាស់ដីវិញ ។
១៨ ហើយកាអ៊ីនបានស្រឡាញ់អារក្សសាតាំងជាងព្រះ ។
ហើយអារក្សសាតាំងបានបញ្ជាគាត់ ដោយថា៖ ចូរថ្វាយដង្វាយ
ដល់ ព្រះអម្ចាស់ទៅ ។
១៩ ហើយក្រោយមក ហេតុការណ៍បានកើតឡើងថា កាអ៊ីន
បានយកផលដែលកើតពីដី មកថ្វាយជាដង្វាយដល់ព្រះអម្ចាស់ ។
២០ ហើយអេបិល គាត់ក៏យកកូនជាដំបូងពីហ្វូងចៀម
មកថ្វាយ ព្រមទាំងខ្លាញ់វាផង ។ ហើយព្រះអម្ចាស់ទ្រង់បាន
សព្វព្រះហឫទ័យ ចំពោះអេបិល និងចំពោះដង្វាយរបស់គាត់;
២១ ប៉ុន្តែចំពោះកាអ៊ីន និងចំពោះដង្វាយគាត់វិញ នោះទ្រង់
មិនសព្វព្រះហឫទ័យទេ ។ ឥឡូវនេះ អារក្សសាតាំងបាន
ដឹងពីការណ៍នេះ ហើយការណ៍នេះធ្វើឲ្យវាពេញចិត្ត ។ ហើយ
កាអ៊ីនក៏ក្ដៅក្រហាយ ហើយឡើងទឹកមុខក្រញូវ ។
២២ ហើយព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាអ៊ីនថា៖
ហេតុអ្វីបានជាអ្នកខឹង ? ហេតុអ្វីបានជាអ្នកធ្វើមុខក្រញូវដូច្នេះ ?
២៣ បើសិនជាអ្នកធ្វើល្អ នោះអ្នកនឹងត្រូវបានរើស ។

---

១០ *ក* ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ខ* គ. និង ស. ១០៧:៤១–៥៦.
ស.ប. ការព្យាករណ៍, ព្យាករ.
*គ* ស.ប. សេចក្ដីអំណរ.
*ឃ* យ៉ូប ១៩:២៦; ២ នីហ្វៃ ៩:៤.
១១ *ក* ស.ប. នាងអេវ៉ា.
*ខ* ២ នីហ្វៃ ២:២២–២៣.
១២ *ក* ចោទិ. ៤:៩.
១៣ *ក* ស.ប. អារក្ស.
*ខ* ស.ប. ការឥតជំនឿ.
*គ* ម៉ូសេ ៦:១៥.
*ឃ* ស.ប. ខាងរូបកាយ;
មនុស្សខាងសាច់ឈាម.
១៤ *ក* យ៉ូហាន ១៤:១៦–១៨, ២៦.
១៥ *ក* ស.ប. ជំនឿ, ជឿ.
*ខ* ស.ប. សេចក្ដីសង្គ្រោះ.
*គ* គ. និង ស. ៤២:៦០.
ស.ប. សេចក្ដីជាប់ទោស.
១៦ *ក* លោកុ. ៤:១–២.
ស.ប. កាអ៊ីន.
១៧ *ក* ស.ប. អេបិល.
*ខ* ហេព្រើរ ១១:៤.
១៨ *ក* គ. និង ស. ១០:២០–២១.
*ខ* គ. និង ស. ១៣២:៨–១១.
២០ *ក* ស.ប. ដង្វាយ; បូជា, យញ្ញបូជា.
២១ *ក* លោកុ. ៤:៣–៧.
២៣ *ក* លោកុ. ៤:៧;
គ. និង ស. ៥២:១៥; ៩៧:៨.

ហើយបើសិនជាអ្នកមិនធ្វើល្អទេ នោះអំពើបាបដេកនៅមាត់ទ្វារ ហើយអារក្ស សាតាំងប្រាថ្នាចង់បានអ្នក; ហើយលើកលែងតែអ្នកប្រុងស្ដាប់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះយើងនឹងប្រគល់អ្នកទៅ ហើយនឹងកើតដល់អ្នកតាមសេចក្ដីប៉ងប្រាថ្នារបស់វា ។ ហើយអ្នកនឹងត្រួតត្រាលើវាដែរ;

២៤ ត្បិតចាប់តាំងពីពេលនេះទៅ អ្នកនឹងទៅជាបិតានៃសេចក្ដីកុហករបស់វា; អ្នកនឹងត្រូវបានហៅថា[ក]អាអន្តរធាន ព្រោះអ្នកក៏បាន នៅមុនកំណើតលោកិយដែរ ។

២៥ ហើយនៅពេលក្រោយនឹងមានគេពោលថា — [ក]អំពើគួរខ្ពើមឆ្អើមទាំងប៉ុន្មាននេះសុទ្ធតែបានមកពីកាអ៊ីន; ព្រោះគាត់បានបដិសេធ ដំបូន្មានដ៏សំខាន់ជាង ដែលគាត់បានទទួលពីព្រះ ហើយនេះគឺជាបណ្ដាសា ដែលយើងនឹងដាក់លើអ្នក លើកលែងតែអ្នកប្រែចិត្ត ។

២៦ ហើយកាអ៊ីនក៏ក្ដៅក្រហាយ ហើយមិនព្រមស្ដាប់តាមសម្លេងនៃព្រះអម្ចាស់ទៀតទេ ឬក៏ដល់អេបិល ជាប្អូនគាត់ ដែលបានដើរក្នុង បរិសុទ្ធភាព នៅចំពោះព្រះអម្ចាស់ ។

២៧ ហើយអ័ដាមនិងប្រពន្ធគាត់បានមានទុក្ខនៅចំពោះព្រះអម្ចាស់ ពីព្រោះតែកាអ៊ីននិងបងប្អូនគាត់ ។

២៨ ហើយហេតុការណ៍បានកើតឡើងថា កាអ៊ីនបានយកកូនស្រីមួយរបស់បងប្រុសគាត់ធ្វើជាប្រពន្ធ ហើយ[ក]ពួកគេស្រឡាញ់អារក្ស សាតាំងជាងព្រះ ។

២៩ ហើយអារក្សសាតាំងបាននិយាយទៅកាអ៊ីនថា៖ ចូរស្បថដល់យើង គឺដោយកអ្នក ហើយបើសិនជាអ្នកប្រាប់ពីការណ៍នេះ នោះអ្នកនឹងត្រូវស្លាប់; ហើយចូរឲ្យពួកបងប្អូនអ្នកស្បថ ដោយក្បាលគេផង និងដោយព្រះដ៏មានព្រះជន្មរស់នៅ ថាពួកគេនឹងមិនប្រាប់ ឡើយ; ត្បិតបើសិនជាពួកគេប្រាប់ពីការណ៍នេះ នោះពួកគេច្បាស់ជានឹងត្រូវស្លាប់ដែរ; ហើយការណ៍នេះគឺដើម្បីកុំឲ្យឪពុកអ្នកដឹងពី ការណ៍នោះ; ហើយនៅថ្ងៃនេះ យើងនឹងប្រគល់អេបិលមកក្នុងកណ្ដាប់ដៃអ្នក ។

៣០ ហើយអារក្សសាតាំងបានស្បថដល់កាអ៊ីនថា វានឹងធ្វើអ្វីតាមការបញ្ជាទាំងឡាយរបស់គាត់ ។ ហើយគ្រប់ការណ៍ទាំងអស់នេះ ត្រូវ បានប្រព្រឹត្តឡើងដោយសម្ងាត់ ។

៣១ ហើយកាអ៊ីនបាននិយាយថា៖ ខ្ញុំពិតជាម៉ាហាន ជាមេនៃអំពើសម្ងាត់ដ៏ធំ ប្រយោជន៍ឲ្យខ្ញុំ[ក]អាចធ្វើឃាត ហើយបានកំរៃ ។ ហេតុដូច្នោះហើយ បានជាកាអ៊ីនត្រូវបានហៅថា [ខ]មេម៉ាហាន ហើយគាត់បានអួតសរសើរក្នុងអំពើទុច្ចរិតរបស់គាត់ ។

៣២ ហើយកាអ៊ីនបានទៅឯវាល ហើយកាអ៊ីនបាននិយាយជាមួយនឹងអេបិល ជាប្អូនគាត់ ។ ហើយហេតុការណ៍បានកើតឡើងថា ក្នុងកាលពួកគេកំពុងតែនៅឯវាល នោះស្រាប់តែកាអ៊ីនក្រោកឡើងទាស់នឹងអេបិល ជាប្អូនគាត់ ហើយសម្លាប់គាត់ចោល ។

៣៣ ហើយកាអ៊ីន[ក]បានអួតសរសើរចំពោះអ្វីដែលគាត់បានប្រព្រឹត្ត ដោយថា៖ ខ្ញុំមានសេរីភាពហើយ; ហ្វូងចៀមទាំងឡាយរបស់ប្អូនខ្ញុំ ច្បាស់ជានឹងធ្លាក់មកក្នុងកណ្ដាប់ដៃខ្ញុំហើយ ។

៣៤ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅកាអ៊ីនថា៖ តើអេបិលជាប្អូនអ្នកនៅឯណា ? ហើយគាត់ទូលឆ្លើយថា៖ ទូលបង្គំមិន ដឹងទេ ។ តើទូលបង្គំជា[ក]អ្នកថែរក្សាប្អូនឬអី ?

៣៥ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ តើអ្នកបានប្រព្រឹត្តអ្វីទៅ ? សូរសំរែកនៃឈាមរបស់ប្អូនអ្នកពីដីបានឡើងទៅដល់យើង ។

៣៦ ហើយឥឡូវនេះ អ្នកនឹងត្រូវបណ្ដាសា ដោយព្រោះផែនដី ដែលបានហារមាត់ទទួលឈាមប្អូនរបស់អ្នកពីដៃអ្នក ។

៣៧ កាលណាអ្នកភ្ជួររាស់ដី នោះដីនឹងមិនបង្កើតផលឲ្យអ្នកដ៏ពេញកម្លាំងទេ ។ អ្នក[ក]ត្រូវរសាត់ព្រាត់ ហើយអណ្ដែតទៅមកលើផែនដី វិញ ។

៣៨ ហើយកាអ៊ីនបានទូលទៅព្រះអម្ចាស់ថា៖ អារក្សសាតាំង[ក]បានល្បួងទូលបង្គំ ពីព្រោះមកពីហ្វូងចៀមទាំងឡាយរបស់ប្អូនទូលបង្គំ ។ ហើយទូលបង្គំក៏ក្ដៅក្រហាយផង; ត្បិតដង្វាយរបស់វានោះទ្រង់បានទទួល ហើយមិនទទួលដង្វាយទូលបង្គំ; ទោសរបស់ទូលបង្គំធ្ងន់ ហួសជាងទូលបង្គំអាចទ្រាំទៅបាន ។

៣៩ មើលចុះ នៅថ្ងៃនេះ ទ្រង់បានបណ្ដេញទូលបង្គំចេញពីព្រះភ័ក្ត្រនៃព្រះអម្ចាស់ហើយ ហើយចេញពីព្រះភ័ក្ត្ររបស់ទ្រង់ទៅនោះទូល បង្គំនឹងពួន ហើយទូលបង្គំនឹងរសាត់ព្រាត់ ហើយអណ្ដែតទៅមកលើផែនដី; ហើយហេតុការណ៍នឹងកើតឡើងថា

២៤ *ក* ស.ប. ពួកកូនអន្តរធាន.
២៥ *ក* ហេលេ. ៦:២៦–២៨.
២៨ *ក* ម៉ូសេ ៥:១៣.
៣១ *ក* ស.ប. ឃាតកម្ម.
*ខ* ក.ន. «គំនិត», «អ្នកបំផ្លាញ», និង «អ្នកធំ» ប្រដែលជាអត្ថន័យបានមកពីមូលស័ព្ទ ដែលមាននៅក្នុងពាក្យ «ម៉ាហាន».
៣៣ *ក* ស.ប. សេចក្ដីឆ្មើងឆ្មៃ; សេចក្ដីប្រកបដោយលោកិយ.
៣៤ *ក* លោកុ. ៤:៩.
៣៧ *ក* លោកុ. ៤:១១–១២.
៣៨ *ក* ស.ប. លោភ; ល្បួង, សេចក្ដីល្បួង.

អស់អ្នកណាដែល ឃើញទូលបង្គំ គេនឹងសម្លាប់ប្រហារ
ទូលបង្គំដែរ ពីព្រោះតែសេចក្ដីទុច្ចរិតទាំងឡាយរបស់ទូលបង្គំ
ត្បិតការណ៍ទាំងប៉ុន្មាននេះពុំអាច បិទបាំងពីព្រះអម្ចាស់បានឡើយ ។
៤០ ហើយយើងជាព្រះអម្ចាស់បានមានបន្ទូលទៅគាត់ថា៖
អស់អ្នកណាដែលប្រហារអ្នក នោះការសងសឹក[ក]នឹងធ្វើដល់
គេ១ជា៧ស្ទួន ។ ហើយយើងជាព្រះអម្ចាស់បានដៅចំណាំ
កាអ៊ីន ក្រែងលោអ្នកណាដែលឃើញគាត់ នឹងសម្លាប់
គាត់ចោល ។
៤១ ហើយកាអ៊ីនត្រូវបានបិទចេញពីវត្ត[ក]មាននៃព្រះអម្ចាស់
ហើយជាមួយនឹងប្រពន្ធគាត់ ព្រមទាំងបងប្អូនគាត់ជាច្រើនបាន
ទៅរស់នៅ ស្រុកណូឌ ខាងកើតអេដែន ។
៤២ ហើយកាអ៊ីនបានស្គាល់ប្រពន្ធគាត់ ហើយនាងមានផ្ទៃពោះ
ហើយបង្កើតបានអេណុក ហើយគាត់ក៏បង្កើតបានកូនប្រុសកូនស្រី
ជាច្រើន ។ ហើយគាត់បានសង់ទីក្រុងមួយ ហើយគាត់ដាក់ឈ្មោះ
ទីក្រុងនោះតាមឈ្មោះអេណុក ជាកូនខ្លួន ។
៤៣ ហើយអេណុកបង្កើតបានអ៊ីរ៉ាឌ និងព្រមទាំងកូនប្រុស
កូនស្រីឯទៀតផង ។ ហើយអ៊ីរ៉ាឌបង្កើតបានមហ៊ូយ៉ែល និងព្រម
ទាំងកូនប្រុស កូនស្រីឯទៀតផង ។ ហើយមហ៊ូយ៉ែលបង្កើត
បានមធូសែល និងព្រមទាំងកូនប្រុសកូនស្រីឯទៀតផង ។ ហើយម
ធូសែលបង្កើតបាន ឡាមេក ។
៤៤ ហើយឡាមេកបានប្រពន្ធពីរ; មួយឈ្មោះអ័ដា ហើយមួយ
ទៀតឈ្មោះស៊ីឡា ។
៤៥ ហើយនាងអ័ដាបង្កើតបានយ៉ាបាល; គាត់ជាឪពុកនៃអស់
ពួកអ្នកដែលនៅក្នុងត្រសាល ហើយមានហ្វូងសត្វ; ហើយប្អូន
គាត់ឈ្មោះ យូបាល ដែលជាឪពុកនៃពួកអ្នកលេងស៊ុងនិងខ្លុយ ។
៤៦ ហើយរីឯនាងស៊ីឡា នាងក៏បង្កើតបានទូបាល-កាអ៊ីន
ជាមេបង្រៀនពួកជាងលង្ហិន និងជាងដែក ។ ហើយប្អូនស្រី
ទូបាលកាអ៊ីន ត្រូវបានហៅថា នាងន៉ាអាម៉ា ។
៤៧ ហើយឡាមេកបាននិយាយទៅនាងអ័ដា និងនាងស៊ីឡា
ជាប្រពន្ធខ្លួនថា៖ ចូរស្ដាប់ពាក្យបង ឱប្រពន្ធឡាមេករាល់
គ្នាអើយ ចូរប្រុង ស្ដាប់ពាក្យបងចុះ ត្បិតបងបានប្រហារមនុស្ស
ម្នាក់ ពីព្រោះវាបានធ្វើឲ្យបងមានរបួស គឺជាមនុស្សកំឡោះម្នាក់
ដោយហេតុវាបានវាយ បងឲ្យជាំ ។
៤៨ បើសិនជាត្រូវសងសឹក[ក]ជួសកាអ៊ីន១ជា៧ដង នោះក៏ត្រូវ
សងសឹកជួសឡាមេក១ជា៧៧ដងវិញ;
៤៩ ត្បិតឡាមេកបានចូលក្នុងសេចក្ដី[ក]សញ្ញាជាមួយនឹង
អាររក្សាសាតាំង តាមរបៀបកាអ៊ីន ដូច្នេះហើយ ទើបគាត់បាន
ក្លាយទៅជា មេម៉ាហាន ជាមេនៃអំពើសម្ងាត់ដ៏ធំនោះ ដែលបាន
ធ្វើដល់កាអ៊ីន ពីអាររក្សាសាតាំង; ហើយអ៊ីរ៉ាឌ ជាកូន
របស់អេណុក ដោយបានដឹង អំពីអំពើសម្ងាត់របស់ពួកគេ ក៏បាន
បើកសម្ដែងប្រាប់ដល់កូនប្រុសទាំងឡាយនៃអ័ដាម;
៥០ ហេតុដូច្នោះហើយ ដោយខឹងក្រៃ នោះឡាមេកក៏ប្រហារ
គាត់បង់ គឺមិនដូចជាកាអ៊ីនចំពោះអេបិល ជាប្អូនខ្លួន ដោយ
ព្រោះចង់បាន កំរៃនោះទេ ប៉ុន្តែគាត់បានប្រហារអ៊ីរ៉ាឌ ដោយ
ព្រោះពាក្យសំបថវិញ ។
៥១ ត្បិតចាប់តាំងពីសម័យកាអ៊ីនមក នោះក៏[ក]មានបក្សព័ន្ធសម្ងាត់
ហើយកិច្ចការរបស់ពួកគេ គឺនៅក្នុងសេចក្ដីងងឹត ហើយគេរាប់
មនុស្សគ្រប់រូបថាជាបងប្អូនគេ ។
៥២ ហេតុដូច្នោះហើយ បានជាព្រះអម្ចាស់ទ្រង់ដាក់បណ្ដាសា
ដល់ឡាមេក និងគ្រួរបស់គាត់ ហើយព្រមអស់អ្នកណាដែលបាន
ធ្វើសេចក្ដី សញ្ញាជាមួយនឹងអាររក្សាសាតាំងផង; ត្បិតពួកគេពុំ
បានកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះឡើយ ហើយការណ៍
នេះបានធ្វើឲ្យព្រះទ្រង់ ថប់ព្រះហឫទ័យ ហើយទ្រង់ពុំបានបំរើពួក
គេទេ ហើយកិច្ចការទាំងឡាយរបស់ពួកគេសុទ្ធតែជាអំពើ
គួរខ្ពើមឆ្អើម ហើយបានចាប់ផ្ដើម រាលដាលក្នុងចំណោមពួក[ក]
កូនប្រុសនៃមនុស្ស ។ ហើយការណ៍នោះមាននៅក្នុងចំណោម
ពួកកូនប្រុសនៃមនុស្ស ។
៥៣ ហើយរីឯនៅក្នុងចំណោមពួកកូនស្រីនៃមនុស្សវិញ
នោះការណ៍ទាំងនេះពុំបាននិយាយដល់ឡើយ ពីព្រោះកាល
ឡាមេកបាន ប្រាប់អំពើសម្ងាត់ដល់ពួកប្រពន្ធគាត់ នោះពួកគេ
បានបះបោរទាស់នឹងគាត់ ហើយបានប្រកាសប្រាប់ពីការណ៍
ទាំងនេះពាសពេញទូទៅ ហើយគ្មានសេចក្ដីមេត្តាករុណា
ឡើយ;
៥៤ ហេតុដូច្នោះហើយ ទើបឡាមេកត្រូវគេស្អប់ ហើយ
បណ្ដេញចេញ ហើយមិនមកក្នុងចំណោមពួកកូនប្រុសនៃ
មនុស្សឡើយ ក្រែងលោគាត់ត្រូវស្លាប់ ។

៤០ ក លោកុ. ៤:១៥.
៤១ ក ម៉ូសេ ៦:៤៩.
៤៨ ក លោកុ. ៤:២៤ ។ ក.ន. ឡាមេកបានអួតអាងថាសាតាំងនឹងរធ្វើដល់គាត់លើសជាងដែលវាធ្វើដល់កាអ៊ីន ។ ហេតុដែលគាត់ស្មានបែបនេះ គឺត្រូវបានរាយរាប់ប្រាប់នៅក្នុងខ ៤៩ និង ៥០.
៤៩ ក ស.ប. សម្បថ.
៥១ ក ស.ប. បក្សព័ន្ធសម្ងាត់.
៥២ ក ម៉ូសេ ៨:១៤–១៥.

៥៥ ហើយដូច្នេះ ទើបកិច្ចការទាំងឡាយនៃ[ក]សេចក្ដីងងឹតបាន
ចាប់ផ្ដើមមានជ័យជំនះក្នុងចំណោមពួកកូនប្រុសនៃមនុស្ស ។
៥៦ ហើយព្រះទ្រង់បានដាក់បណ្ដាសាដល់ផែនដី ដោយពាក្យ
បណ្ដាសាដ៏ធ្ងន់ធ្ងរ ហើយបានខ្ញាល់នឹងពួកទុច្ចរិត គឺគ្រប់កូនប្រុស
ទាំងអស់ នៃមនុស្សដែលទ្រង់បានបង្កើតមក;
៥៧ ត្បិតពួកគេមិនព្រមស្ដាប់តាមសម្លេងរបស់ទ្រង់ឡើយ ឬក៏
ជឿដល់[ក]ព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ដែរ គឺជាព្រះ
អង្គដែលទ្រង់ បានប្រកាសប្រាប់ថានឹងយាងមកនៅវេលាដ៏ខ្ពង់ខ្ពស់
បំផុត ជាអ្នកដែលបានត្រៀមទុក តាំងពីមុនកំណើតលោកិយមក
ម្ល៉េះ ។
៥៨ ហើយដូច្នេះ ទើប[ក]ដំណឹងល្អបានចាប់ផ្ដើម[ខ]ផ្សាយ
ចាប់តាំងពីដើមដំបូងមក គឺបានប្រកាសប្រាប់ដោយពួកទេវតា
បរិសុទ្ធ ដែលបាន ចាត់ឲ្យមកពីវត្តមាននៃព្រះ និងដោយ
សម្លេងរបស់ទ្រង់ផ្ទាល់ និងដោយ[គ]អំណោយទានជាព្រះវិញ្ញាណ
បរិសុទ្ធ ។
៥៩ ហើយដូច្នេះ ទើបគ្រប់ការណ៍ទាំងអស់ ត្រូវបាន
បញ្ជាក់ប្រាប់ដល់អ័ដាម ដោយពិធីបរិសុទ្ធ ហើយដំណឹងល្អត្រូវ
បានផ្សាយ និងបញ្ញត្តិ មួយត្រូវបានចេញទៅ ដើម្បីឲ្យមាន
ដំណឹងល្អនៅក្នុងលោកិយ គឺរហូតដល់ចុងបំផុតលោកិយ;
ហើយគឺដូច្នោះមែន ។ អាម៉ែន ។៕

## ជំពូកទី ៦

*(វិច្ឆិកា–ធ្នូ ១៨៣០)*

*ពូជអ័ដាមកត់សៀវភៅរំឭក — ពូជពង្សរបស់លោកដែលសុចរិត គេផ្សាយពីការប្រែចិត្ត — ព្រះទ្រង់សម្ដែងអង្គទ្រង់ដល់ហេណុក — ហេណុកផ្សាយដំណឹងល្អ — ផែនការនៃសេចក្ដីសង្គ្រោះត្រូវបានបើកសម្ដែងដល់លោកអ័ដាម — លោកបានទទួលបុណ្យជ្រមុជទឹក និងបព្វជិតភាព ។*

ហើយ[ក]អ័ដាមបានប្រុងស្ដាប់តាមសម្លេងនៃព្រះ ហើយបានហៅ
ដល់ពួកកូនប្រុសរបស់លោកឲ្យប្រែចិត្ត ។
២ ហើយអ័ដាមបានស្គាល់ប្រពន្ធគាត់ម្ដងទៀត[ក] ហើយនាង
បង្កើតបានកូនប្រុសមួយ ហើយគាត់ឲ្យឈ្មោះថា សេត ។ ហើយ
អ័ដាមបាន សរសើរដំកើងដល់ព្រះនាមនៃព្រះ; ត្បិតគាត់
បាននិយាយថា៖ ព្រះទ្រង់បានប្រទានពូជមួយទៀតមកខ្ញុំជំនួសអេបិល
ដែលកាអ៊ីនបាន ប្រហារទៅនោះ ។
៣ ហើយព្រះទ្រង់បានសម្ដែងអង្គទ្រង់ឲ្យសេតឃើញ ហើយ
គាត់ពុំបានបះបោរឡើយ ប៉ុន្តែបាន[ក]ថ្វាយដង្វាយដ៏សមរម្យ
ដូចអេបិល ជាបងខ្លួន។ ហើយគាត់ក៏បង្កើតបានកូនប្រុសមួយដែរ
ហើយគាត់ឲ្យឈ្មោះថា អេណុស ។
៤ ហើយនៅពេលនោះ ពួកគេទាំងប៉ុន្មាននេះបានចាប់ផ្ដើម
[ក]អំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ ហើយព្រះអម្ចាស់ ទ្រង់បាន
ប្រទានពរ ដល់ពួកគេ;
៥ ហើយ[ក]សៀវភៅរំឭកមួយត្រូវបានកត់ទុក ដែលកត់នៅក្នុង
ភាសាអ័ដាម ត្បិតត្រូវបានប្រទានដល់មនុស្សជាច្រើនណាដែល
អំពាវនាវ ដល់ព្រះ ឲ្យសរសេរដោយវិញ្ញាណនៃការ[ខ]បំផុសគំនិត;
៦ ហើយដោយសារពួកគេ ទើបពួកកូនចៅគេត្រូវបាន
បង្រៀនឲ្យចេះអាន និងចេះសរសេរ ដោយមានភាសាដែល
សុទ្ធសាធ និងមិន ខូចខាត ។
៧ ឥឡូវនេះ ឯ[ក]បព្វជិតភាពដែលនេះ ដែលមានតាំងពីដើមដំបូង
មក នោះក៏ត្រូវមានរហូតដល់ចុងបំផុតលោកិយដែរ ។
៨ ឥឡូវនេះ អ័ដាមបានពោលពាក្យព្យាករណ៍នេះ ក្នុងកាល
គាត់ត្រូវ[ក]បណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ ហើយ[ខ]ពង្សាវតារ
មួយ ត្រូវបានកត់ទុកអំពី[គ]កូនចៅនៃព្រះ ។ ហើយនេះហើយគឺជា
[ឃ]បញ្ជីពង្សាវតារនៃពូជអ័ដាម ដោយនិយាយថា៖ នៅថ្ងៃដែលព្រះ
បាន បង្កើតមនុស្សមក នោះទ្រង់បានធ្វើឲ្យមានភាពមើលទៅដូច
ជាអង្គទ្រង់;
៩ តាម[ក]រូបដូចព្រះអង្គផ្ទាល់ នោះទ្រង់បានបង្កើត[ខ]គេជា

៥៥ *ក* ស.ប. សេចក្ដីងងឹតខាងវិញ្ញាណ; ទុច្ចរិត, អំពើទុច្ចរិត.
៥៧ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
៥៨ *ក* ស.ប. ដំណឹងល្អ.
*ខ* អាលម៉ា ១២:២៨–៣០; ម៉ូរ៉ូណៃ ៧:២៥, ២៩–៣១. ស.ប. ពួកទេវតា.
*គ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
៦ ១ *ក* ស.ប. អ័ដាម.
២ *ក* លោកុ. ៤:២៥. ស.ប. សេត.
៣ *ក* ស.ប. បូជា, យញ្ញបូជា.
៤ *ក* លោកុ. ៤:២៦. ស.ប. ការអធិស្ឋាន.
៥ *ក* អ័ព្រា. ១:២៨, ៣១. ស.ប. សៀវភៅរំឭក.
*ខ* ស.ប. ការបំផុសគំនិត, បំផុសគំនិត.
៧ *ក* ស.ប. បព្វជិតភាព.
៨ *ក* ២ ពេត្រុស ១:២១.
*ខ* ស.ប. ពង្សាវតារ.
*គ* ស.ប. បុត្រាបុត្រីនៃព្រះ.
*ឃ* លោកុ. ៥:១.
៩ *ក* លោកុ. ១:២៦–២៨; ម៉ូសេ ២:២៦–២៩; អ័ព្រា. ៤:២៦–៣១.
*ខ* ស.ប. មនុស្ស, មនុស្សលោក.

ប្រុសជាស្រី ហើយបានប្រទានពរដល់ពួកគេ ហើយបាន[គ]ហៅពួក
គេថា «អ័ដាម» ក្នុងថ្ងៃដែលពួកគេត្រូវបានបង្កើតមក ហើយ
ដែលបានក្លាយទៅជា[ឃ]ព្រលឹងរស់នៅលើដី ដែលជា[ង]កំណល់កល់
ព្រះបាទនៃព្រះ ។
១០ ហើយ[ក]អ័ដាមអាយុបាន១៣០ឆ្នាំ ហើយបង្កើតបាន
កូនប្រុសមួយតាម[ខ]រូបភាពគាត់ ហើយមើលទៅដូចជាគាត់
ហើយក៏ឲ្យឈ្មោះជា សេត ។
១១ ហើយក្រោយពីគាត់បង្កើតបានសេតមក នោះអ័ដាមរស់នៅ
បាន៨០០ឆ្នាំ ហើយគាត់បង្កើតបានកូនប្រុសកូនស្រីជាច្រើនទៀត;
១២ ហើយអាយុអ័ដាមទាំងអស់បាន៩៣០ឆ្នាំ ហើយ
គាត់ក៏ស្លាប់ទៅ ។
១៣ សេតអាយុបាន១០៥ឆ្នាំ ហើយបង្កើតបានអេណុស
ហើយបានព្យាករអស់មួយជីវិតគាត់ ហើយបានបង្រៀនអេណុស
ជាកូនប្រុស តាមផ្លូវទាំងឡាយនៃព្រះ; ហេតុដូច្នោះហើយ
ទើបអេណុសព្យាករដែរ ។
១៤ ហើយក្រោយពីគាត់បង្កើតបានអេណុសមក នោះសេត
រស់នៅបាន៨០៧ឆ្នាំ ហើយបង្កើតបានកូនប្រុសកូនស្រីជាច្រើន
ទៀត ។
១៥ ហើយមានកូនចៅមនុស្សជាច្រើនឥតគណនានៅលើដែនដី ។
នៅសម័យនោះ អារក្សសាតាំងមាន[ក]អំណាចត្រួតត្រាដ៏ធំទៅ
លើមនុស្ស ហើយបានញាំញីក្នុងចិត្តពួកគេ; ហើយចាប់
តាំងពីពេលនោះមក ក៏មានសង្គ្រាម និងការកំចាយឈាមទាំង
ឡាយ; ហើយមនុស្សលើកដៃ ទាស់នឹងបងប្អូនខ្លួន ក្នុងការ
ប្រព្រឹត្តអំពើស្លាប់ ដោយស្វែងរកអំណាច ពីព្រោះមកពីកិច្ចការ
[ខ]សម្ងាត់ទាំងឡាយ ។
១៦ អាយុសេតទាំងអស់បាន៩១២ឆ្នាំ ហើយគាត់ក៏ស្លាប់ទៅ ។
១៧ ហើយអេណុសអាយុបាន៩០ឆ្នាំ ហើយបង្កើតបាន[ក]កៃ
ណាន ។ ហើយអេណុស និងប្រជារាស្ត្រនៃព្រះដែលនៅសល់
ទាំងប៉ុន្មាន បានចេញមកពីដែនដី ដែលហៅថា ស៊ូឡុន ហើយ
បានអាស្រ័យនៅក្នុងដែនដីសន្យា ដែលបានហៅតាមឈ្មោះ
កូនប្រុសគាត់ផ្ទាល់ ដែលគាត់ឲ្យឈ្មោះជា កៃណាន ។
១៨ ហើយក្រោយពីគាត់បង្កើតបានកៃណានមក នោះ
អេណុសរស់នៅបាន៨១៥ឆ្នាំ ហើយបង្កើតបានកូនប្រុសកូនស្រី
ជាច្រើនទៀត ។ ហើយអាយុអេណុសទាំងអស់បាន៩០៥ឆ្នាំ ហើយ
គាត់ក៏ស្លាប់ទៅ ។
១៩ ហើយកៃណានអាយុបាន៧០ឆ្នាំ ហើយបង្កើតបាន
ម៉ាលេលាល; ហើយក្រោយពីគាត់បង្កើតបានម៉ាលេលាល
នោះកៃណានរស់នៅ បាន៨៤០ឆ្នាំ ហើយបង្កើតបានកូនប្រុស
កូនស្រីទៀត ។ ហើយអាយុកៃណានទាំងអស់បាន៩១០ឆ្នាំ
ហើយគាត់ក៏ស្លាប់ទៅ ។
២០ ហើយម៉ាលេលាលអាយុបាន៦៥ឆ្នាំ ហើយបង្កើតបាន
យ៉ារេឌ; ហើយក្រោយពីគាត់បង្កើតបានយ៉ារេឌមក នោះ
ម៉ាលេលាលរស់ នៅបាន៨៣០ឆ្នាំ ហើយបង្កើតបានកូនប្រុស
កូនស្រីទៀត ។ ហើយអាយុម៉ាលេលាលទាំងអស់បាន៨៩៥ឆ្នាំ
ហើយគាត់ក៏ស្លាប់ទៅ ។
២១ ហើយយ៉ារេឌអាយុបាន១៦២ឆ្នាំ ហើយបង្កើតបាន[ក]ហេណុក;
ហើយក្រោយពីគាត់បង្កើតបានហេណុកមក នោះយ៉ារេឌរស់នៅ
បាន៨០០ឆ្នាំ ហើយបង្កើតបានកូនប្រុសកូនស្រីទៀត ។ ហើយ
យ៉ារេឌបានបង្រៀនហេណុកតាមផ្លូវទាំងឡាយនៃព្រះ ។
២២ ហើយនេះហើយគឺជាពង្សាវតារនៃពួកកូនប្រុសរបស់
អ័ដាម ដែលជា[ក]បុត្រានៃព្រះ ដែលព្រះអង្គទ្រង់ផ្ទាល់បានមានព្រះ
បន្ទូលជាមួយ ។
២៣ ហើយពួកគេសុទ្ធតែជា[ក]អ្នកផ្សាយអំពីសេចក្ដីសុចរិត
ហើយបាននិយាយ ហើយ[ខ]ព្យាករ ហើយបានហៅមនុស្សទាំងអស់
នៅគ្រប់ ទិសទី ឲ្យ[គ]ប្រែចិត្ត; ហើយ[ឃ]សេចក្ដីជំនឿក៏ត្រូវបានបង្រៀន
ដល់កូនចៅមនុស្ស ។
២៤ ហើយហេតុការណ៍បានកើតឡើងថា អាយុយ៉ារេឌទាំង
អស់បាន៩៦២ឆ្នាំ ហើយគាត់ក៏ស្លាប់ទៅ ។
២៥ ហើយហេណុកអាយុបាន៦៥ឆ្នាំ ហើយបង្កើតបាន
[ក]មធូសាឡា ។
២៦ ហើយហេតុការណ៍បានកើតឡើងថា ហេណុកបាន
ធ្វើដំណើរនៅលើដែនដី ក្នុងចំណោមប្រជាជន; ហើយកាល

៩ *គ* ម៉ូសេ ១:៣៤; ៤:២៦.
*ឃ* ស.ប. ព្រលឹង.
*ង* អ័ប្រា. ២:៧.
១០ *ក* គ. និង ស. ១០៧:៤១–៥៦.
*ខ* លោកុ. ៥:៣;
គ. និង ស. ១០៧:៤២–៤៣;
១៣៨:៤០.
១៥ *ក* ម៉ូសេ ៥:១៣.
*ខ* ស.ប. បក្សព័ន្ធសម្ងាត់.
១៧ *ក* លោកុ. ៥:១០–១៤;
គ. និង ស. ១០៧:៤៥, ៥៣.
២១ *ក* លោកុ. ៥:១៨–២៤;
ម៉ូសេ ៧:៦៩; ៨:១–២.
ស.ប. ហេណុក.
២២ *ក* លូកា ៣:៣៨.
២៣ *ក* ស.ប. ព្យាការី.
*ខ* ស.ប. ការព្យាករណ៍, ព្យាករ.
*គ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ឃ* ស.ប. សេចក្ដីជំនឿ.
២៥ *ក* ស.ប. មធូសាឡា.

គាត់កំពុងតែ ធ្វើដំណើរ នោះស្រាប់តែព្រះវិញ្ញាណនៃព្រះ បាន យាងចុះមកពីស្ថានសួគ៌ ហើយមកសណ្ឋិតលើគាត់ ។

២៧ ហើយគាត់បានឮសម្លេងចេញពីស្ថានសួគ៌មកថា៖ ហេណុក បុត្រយើងអើយ ចូរទៅព្យាករដល់ប្រជាជននេះ ហើយ ប្រាប់ទៅ ពួកគេថា — ចូរប្រែចិត្តចុះ ត្បិតព្រះអម្ចាស់ទ្រង់មាន ព្រះបន្ទូលដូច្នេះថា៖ យើងមានសេចក្ដីខ្ញាល់នឹងប្រជាជននេះ ហើយសេចក្ដីខ្ញាល់ របស់យើង បានឆេះឡើងទាស់នឹងពួកគេ ត្បិតចិត្តរបស់ពួកគេបានរឹងរូស ហើយត្រចៀករបស់ពួកគេបាន ស្ពឹកលែងឮ ហើយភ្នែករបស់ ពួកគេពុំអាចមើលឃើញឆ្ងាយឡើយ;

២៨ ហើយត្បិតចាប់តាំងពីថ្ងៃដែលយើងបានបង្កើតពួកគេមក នោះតំណទាំងប៉ុន្មាននេះ គេបានបែរចេញ ហើយបានបដិសេធ យើង ហើយបានស្វែងរកការទូន្មានរបស់ខ្លួន ក្នុងសេចក្ដីងងឹត; ហើយដោយអំពើគួរខ្ពើមឆ្អើមទាំងឡាយរបស់ខ្លួន នោះគេបាន គិតបង្កើត នូវអំពើឃាតកម្ម ហើយពុំបានកាន់តាមព្រះបញ្ញត្តិទាំង ឡាយ ដែលយើងបានប្រទានដល់អ័ដាម ជាឪពុកពួក គេនោះឡើយ ។

២៩ ហេតុដូច្នោះហើយ បានជាពួកគេស្បថកុហកដោយខ្លួន ហើយដោយសារសំបថទាំងឡាយរបស់ពួកគេ នោះពួកគេ បាននាំសេចក្ដី ស្លាប់មកលើខ្លួន; ហើយមានស្ថាននរកមួយ ដែល យើងបានរៀបចំសំរាប់ពួកគេ បើសិនជាពួកគេមិនព្រមប្រែចិត្ត សោះ;

៣០ ហើយនេះហើយគឺជាបញ្ញត្តិមួយ ដែលយើងបានចាត់ទៅ នៅដើមកំណើតលោកិយ គឺចេញពីព្រះឱស្ឋយើងទៅ ចាប់តាំងពី កំណើតលោកិយមក និងដោយមាត់នៃពួកអ្នកបំរើ របស់យើង ជាពួកអយ្យកោរបស់អ្នក នោះយើងបានចេញ បញ្ញត្តិហើយ គឺដូចជា បញ្ញត្តិនោះនឹងបានចេញទៅក្នុងលោកិយ រហូតដល់ចុងផែនដីផង ។

៣១ ហើយកាលហេណុកបានឮព្រះបន្ទូលទាំងនេះ នោះ គាត់ក៏ក្រាបខ្លួនទៅដល់ដី នៅចំពោះព្រះអម្ចាស់ ហើយទូល ចំពោះព្រះ អម្ចាស់ថា៖ ហេតុអ្វីបានជាទូលបង្គំទទួលការប្រណី ចំពោះព្រះនេត្ររបស់ព្រះអង្គ ហើយទូលបង្គំគ្រាន់តែជាក្មេងតូច មួយ ហើយប្រជាជន ទាំងអស់គ្នាស្អប់ទូលបង្គំ; ត្បិតទូលបង្គំមាន មាត់រឹង; ម្ដេចឡើយក៏ទូលបង្គំជាអ្នកបំរើទ្រង់ ?

៣២ ហើយព្រះអម្ចាស់មានព្រះបន្ទូលទៅហេណុកថា៖ ចូរទៅ ហើយធ្វើដូចដែលយើងបានបញ្ជាដល់អ្នកចុះ ហើយគ្មាន នរណានឹង ចាក់ទំលុះអ្នកឡើយ ។ ចូរបើកមាត់អ្នក ហើយ មាត់នោះនឹងបានពោរពេញ ហើយយើងនឹងប្រទានសំដីដល់អ្នក ត្បិតគ្រប់សាច់ ទាំងអស់នៅក្នុងកណ្ដាប់ដៃរបស់យើងហើយ ហើយយើងនឹងប្រព្រឹត្តនូវអ្វីដែលឃើញថាល្អដល់យើង ។

៣៣ ចូរប្រាប់ទៅប្រជាជននេះថា៖ ចូរអ្នករាល់គ្នារើសនៅ ថ្ងៃនេះចុះ ថានឹងបំរើព្រះអម្ចាស់ដ៏ជាព្រះដែលបានបង្កើតអ្នកមក ។

៣៤ មើលចុះ ព្រះវិញ្ញាណរបស់យើងកំពុងតែស្ថិតនៅលើ អ្នក ហេតុដូច្នោះហើយ គ្រប់អស់ទាំងពាក្យសំដីរបស់អ្នក យើង នឹងរាប់ ជាសុចរិត; ហើយភ្នំទាំងឡាយនឹងគេចចេញពីមុខអ្នក ហើយទន្លេទាំងឡាយនឹងបែរចេញពីដំណើរវា ហើយអ្នកនឹងនៅ ក្នុងយើង ហើយយើងក្នុងអ្នក; ហេតុដូច្នេះហើយ ចូរដើរជាមួយ នឹងយើងចុះ ។

៣៥ ហើយព្រះអម្ចាស់ទ្រង់មានបន្ទូលទៅហេណុក ហើយ ប្រាប់គាត់ថា៖ ចូរលាបភ្នែកអ្នកនឹងដីឥដ្ឋ ហើយលាងចេញ ហើយអ្នកនឹង បានឃើញ ។ ហើយគាត់ក៏ធ្វើដូច្នោះ ។

៣៦ ហើយគាត់បានឃើញវិញ្ញាណទាំងប៉ុន្មានដែលព្រះទ្រង់ បានបង្កើតមក; ហើយគាត់ក៏ឃើញគ្រប់អ្វីទាំងអស់ដែលពុំអាច មើលឃើញ ដោយភ្នែកធម្មតា; ហើយចាប់តាំងពីពេលនោះមក មានឮគេនិយាយទូទៅទាំងដែនដីថា៖ មានអ្នកមើលឆុតម្នាក់ ដែលព្រះអម្ចាស់ទ្រង់ បានបង្កើតឡើងដល់រាស្ត្រទ្រង់ ។

៣៧ ហើយហេតុការណ៍បានកើតឡើងថា ហេណុក បានចេញទៅលើដែនដី ក្នុងចំណោមប្រជាជន ដោយឈរលើភ្នំ និងទីខ្ពស់ទាំង ឡាយ ហើយស្រែកដោយសម្លេងខ្លាំង ដោយ ធ្វើទីបន្ទាល់ទាស់នឹងកិច្ចការទាំងឡាយរបស់ពួកគេ; ហើយគ្រប់ មនុស្សទាំងអស់ក៏អាក់ អន់ចិត្ត ដោយព្រោះតែគាត់ ។

៣៨ ហើយពួកគេដែលបានចេញមកស្ដាប់គាត់ នៅលើទីខ្ពស់ ទាំងឡាយ ក៏និយាយទៅអ្នកថែរក្សាត្រសាលថា៖ ចូរអ្នករាល់

២៧ ក គ. និង ស. ៦៣:៣២.
ខ ម៉ាថាយ ១៣:១៥;
២ នីហ្វៃ ៩:៣១;
ម៉ូសាយ ២៦:២៨;
គ. និង ស. ១:២, ១១, ១៤.
គ អាលម៉ា ១០:២៥; ១៤:៦.
២៨ ក ស.ប. ការបះបោរ.
២៩ ក ស.ប. សម្បថ.
ខ ស.ប. ស្ថាននរក.
៣១ ក និក្ខ. ៤:១០–១៦; យេរេ. ១:៦–៩.
៣២ ក គ. និង ស. ២៤:៥–៦; ៦០:២.
៣៣ ក ស.ប. សិទ្ធិជ្រើសរើស.
៣៤ ក ម៉ាថាយ ១៧:២០.
ខ ម៉ូសេ ៧:១៣.
គ លោកុ. ៥:២៤; ម៉ូសេ ៧:៦៩.
ស.ប. ដើរ, ដើរជាមួយព្រះ.
៣៦ ក ស.ប. ការបង្កបង្កើតខាងវិញ្ញាណ.
ខ ម៉ូសេ ១:១១.
គ ស.ប. អ្នកមើលឆុត.
៣៧ ក ១ នីហ្វៃ ១៦:១–៣.

គ្នា នៅទីនេះសិនចុះ ហើយថែរក្សាត្រសាលទាំងឡាយផង
កាលយើងទៅឯនាយ ដើម្បីទៅមើលអ្នកមើលឆុតម្នាក់ ត្បិត
គាត់ព្យាករ ហើយមានការណ៍ចំឡែកមួយនៅលើផែនដី; មាន
មនុស្សព្រៃផ្សៃម្នាក់បានមកក្នុងចំណោមយើងរាល់គ្នា ។
៣៩ ហើយហេតុការណ៍បានកើតឡើងថា កាលពួកគេបាន
ឃើញគាត់ នោះគ្មាននរណាមួយហានលើកដៃទាស់នឹងគាត់ឡើយ;
ត្បិតអស់អ្នកណាដែលបានឮគាត់ ក៏កើតមានការភ័យខ្លាចឡើង;
ព្រោះគាត់បានដើរជាមួយនឹងព្រះ ។
៤០ ហើយមានមនុស្សម្នាក់បានមកឯគាត់ ដែលមានឈ្មោះថា
ម៉ាហ៊ីយ៉ា ហើយបាននិយាយទៅគាត់ថា៖ សូមប្រាប់យើងខ្ញុំ
ដោយច្បាស់ ថាអ្នកជាអ្នកណា ហើយមកពីណាដែរ ?
៤១ ហើយគាត់បានប្រាប់ពួកគេថា៖ ខ្ញុំបានមកពីដែនដីកៃណាន
ជាដែនដីនៃពួកអយ្យកោខ្ញុំ ជាដែនដីនៃសេចក្ដីសុចរិតរហូតដល់
សព្វថ្ងៃនេះ ។ ហើយឪពុកខ្ញុំបានបង្រៀនខ្ញុំនូវគ្រប់ការណ៍ទាំង
អស់ តាមផ្លូវទាំងឡាយនៃព្រះ ។
៤២ ហើយហេតុការណ៍បានកើតឡើងថា ក្នុងកាលខ្ញុំ
កំពុងតែធ្វើដំណើរពីដែនដីកៃណាន តាមឆ្នេរសមុទ្រខាងកើត នោះ
ខ្ញុំបានឃើញ ការនិមិត្តមួយ; ហើយមើលន៏ ខ្ញុំបានឃើញស្ថានសួគ៌
ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំ ហើយប្រទាន
ព្រះបញ្ញត្តិដល់ខ្ញុំ; ដូច្នោះ ដោយសារហេតុនេះហើយ បានជា
ខ្ញុំប្រាប់ពាក្យទាំងនេះ ដើម្បីកាន់តាមព្រះបញ្ញត្តិនោះ ។
៤៣ ហើយហេណុកបានមានប្រសាសន៍តទៅទៀតថា៖
ព្រះអម្ចាស់ដែលមានព្រះបន្ទូលមកខ្ញុំ គឺទ្រង់ជាព្រះ
នៃស្ថានសួគ៌ ហើយទ្រង់ជា ព្រះរបស់ខ្ញុំ ហើយជាព្រះរបស់អ្នក
ហើយអ្នករាល់គ្នាជាបងប្អូនរបស់ខ្ញុំ ហើយម្ដេចក៏អ្នករាល់គ្នា
[ក]មានសេចក្ដីទូន្មានក្នុងខ្លួនដូច្នេះ ហើយ បដិសេធព្រះ
នៃស្ថានសួគ៌ទៅវិញ ?
៤៤ ទ្រង់បានធ្វើផ្ទៃមេឃ; ហើយ[ក]ផែនដីជា[ខ]កំណល់កល់ព្រះបាទ
ទ្រង់; ហើយឫសផែនដីគឺជារបស់ផងទ្រង់ ។ មើលចុះ ទ្រង់បាន
ដាក់ឫស ផែនដី ព្រមទាំងពួកពលបរិវារមនុស្សផង ក៏ទ្រង់បាន
ធ្វើឲ្យមានមកលើផ្ទៃផែនដីដែរ ។
៤៥ ហើយសេចក្ដីស្លាប់ក៏មានមកលើពួកអយ្យកោរបស់យើង;
ទោះជាយ៉ាងណាក៏ដោយ គង់តែយើងស្គាល់ពួកគេដែរ ហើយ
មិនអាច បដិសេធបានឡើយ ហើយសូម្បីតែមនុស្សទីមួយបំផុត
គឺអ័ដាម ក៏យើងស្គាល់ដែរ ។
៤៦ ត្បិតមានសៀវភៅ[ក]រំឮកមួយដែលបានកត់ទុក ក្នុងចំណោម
ពួកយើងរាល់គ្នា ស្របតាមគំរូដែលបានប្រទានដោយព្រះអង្គុលីនៃ
ព្រះ; ហើយគឺត្រូវបានប្រទានឲ្យមក ក្នុងភាសារបស់យើងផ្ទាល់ ។
៤៧ ហើយពេលហេណុកកំពុងតែប្រាប់ពីព្រះបន្ទូលនៃព្រះ
នោះប្រជាជនញ័ររន្ធត់ ហើយពុំអាចឈរនៅក្នុងវត្តមានរបស់
គាត់បានឡើយ ។
៤៨ ហើយគាត់មានប្រសាសន៍ទៅពួកគេថា៖ ពីព្រោះតែ
អ័ដាម[ក]ធ្លាក់ ទើបមានពួកយើងមក; ហើយដោយសារការ
ធ្លាក់របស់គាត់ [ខ]ទើបមានសេចក្ដីស្លាប់; ហើយយើងរាល់គ្នាត្រូវ
បានធ្វើឲ្យទៅជាអ្នកទទួលនូវសេចក្ដីទុក្ខលំបាក និងទុក្ខវេទនា ។
៤៩ មើលចុះ អារក្សសាតាំងបានមកក្នុងចំណោមកូនចៅ
មនុស្ស ហើយ[ក]បានល្បួងពួកគេឲ្យថ្វាយបង្គំវា; ហើយមនុស្សលោក
បានក្លាយទៅ [ខ]ខាងលោកិយ [គ]កាមរាគ និងអាក្រក់ ហើយ[ឃ]ត្រូវបាន
បិទបាំងចេញពីវត្តមាននៃព្រះ ។
៥០ ប៉ុន្តែព្រះទ្រង់បានធ្វើឲ្យដឹងដល់ពួកអយ្យកោរបស់យើងថា
គ្រប់មនុស្សទាំងអស់ត្រូវតែប្រែចិត្ត ។
៥១ ហើយទ្រង់បានហៅអ័ដាម ជាឪពុកយើង ដោយសម្លេង
ទ្រង់ផ្ទាល់ថា៖ យើងជាព្រះ; យើងបានបង្កើតលោកិយ និង
[ក]មនុស្សលោក មក [ខ]មុនមានពួកគេនៅក្នុងសាច់ឈាមម្ល៉េះ ។
៥២ ហើយទ្រង់ក៏មានព្រះបន្ទូលទៅគាត់ថា៖ បើសិនជាអ្នក
បែរមករកយើង ហើយប្រុងស្ដាប់តាមសម្លេងយើង ហើយជឿ
ហើយប្រែចិត្ត ពីអស់ទាំងអំពើរំលងរបស់អ្នក ហើយ[ក]ទទួលបុណ្យ
ជ្រមុជ គឺដោយទឹក ដោយនូវព្រះនាមនៃព្រះរាជបុត្រាបង្កើតតែ

៤៣ *ក* សុភា. ១:២៤–៣៣;
គ. និង ស. ៥៦:១៤–១៥.
៤៤ *ក* ចោទិ. ១០:១៤.
*ខ* អ័ប្រា. ២:៧.
៤៦ *ក* ស.ប. សៀវភៅរំឮក.
៤៨ *ក* ២ នីហ្វៃ ២:២៥.
ស.ប. ការធ្លាក់នៃលោកអ័ដាម
និងនាងអេវ៉ា.
*ខ* ស.ប. សេចក្ដីស្លាប់ខាងសាច់ឈាម.
៤៩ *ក* ម៉ូសេ ១:១២.
ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* ម៉ូសាយ ១៦:៣–៤;
ម៉ូសេ ៥:១៣.
ស.ប. ខាងរូបកាយ.
*គ* ស.ប. ខាងកាមរាគ, កាមរាគ.
*ឃ* ស.ប. សេចក្ដីស្លាប់ខាងវិញ្ញាណ.
៥១ *ក* ស.ប. មនុស្ស, មនុស្សលោក —
មនុស្ស
ជាកូនវិញ្ញាណនៃព្រះវរបិតាដែល
គង់នៅស្ថានសួគ៌.
*ខ* ស.ប. ការបង្កបង្កើតខាងវិញ្ញាណ.
៥២ *ក* ៣ នីហ្វៃ ១១:២៣–២៦.
ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក.

មួយរបស់យើង ដែល ពោរពេញទៅដោយ[ខ]ព្រះគុណ និងសេចក្ដីពិត ដែលជា[គ]ព្រះយេស៊ូវគ្រីស្ទ ជា[ឃ]ព្រះនាមតែមួយគត់ដែលនឹងបានប្រទានមកក្រោមមេឃ ដែលនឹងមាន[ង]សេចក្ដីសង្គ្រោះមកដល់កូនចៅមនុស្ស នោះអ្នកនឹងបានទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសូមអ្វីៗទាំង ដោយនូវព្រះនាមទ្រង់ ហើយអ្វីៗក៏ដោយដែលអ្នករាល់គ្នាសូម នោះនឹងបានប្រទានដល់អ្នក ។

៥៣ ហើយអ័ដាម ជាឪពុករបស់យើង បានទូលទៅព្រះអម្ចាស់ ហើយទូលថា៖ ហេតុអ្វីបានជាមនុស្សត្រូវប្រែចិត្ត ហើយទទួលបុណ្យ ជ្រមុជដោយទឹក ? ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅអ័ដាមថា៖ មើលចុះ យើងបាន[ក]អភ័យទោសដល់អ្នកចំពោះអំពើរំលង របស់អ្នកនៅក្នុងសួនច្បារអេដែនហើយ ។

៥៤ មកពីការណ៍នេះហើយ ទើបមានគេនិយាយទូទៅក្នុងចំណោមប្រជាជនថា [ក]ព្រះរាជបុត្រានៃព្រះ បាន[ខ]ធ្វើឲ្យធួននឹងទោសដើម ម្ល៉ោះ ហើយបានជាអំពើបាបទាំងឡាយនៃឪពុកម្ដាយ ពុំអាចធ្លាក់ទៅលើក្បាលនៃ[គ]កូនចៅបានឡើយ ត្បិតពួកគេនៅសុទ្ធសាធ ចាប់តាំងពី កំណើតលោកិយមកម្លេះ ។

៥៥ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅអ័ដាមថា៖ ដរាបណាកូនចៅអ្នកត្រូវបានចាប់កំណើតមកក្នុងអំពើបាប ម្ល៉ោះ ហើយ កាលណាគេចាប់ផ្ដើមធំឡើង នោះ[ក]អំពើបាបក៏កើតមានក្នុងចិត្តគេដែរ ហើយពួកគេភ្លក់នូវ[ខ]សេចក្ដីល្វីងជូរចត់ ប្រយោជន៍ឲ្យពួកគេអាច ចេះឲ្យតម្លៃដល់របស់ល្អ ។

៥៦ ហើយគឺត្រូវបានប្រទានដល់ពួកគេ ឲ្យចេះដឹងខុសត្រូវ; ហេតុដូច្នោះហើយ ទើបពួកគេជា[ក]ភ្នាក់ងារចំពោះខ្លួនផ្ទាល់ ហើយយើងបាន ប្រទានដល់អ្នក នូវក្រិត្យវិន័យ និងបញ្ញត្តិមួយទៀត ។

៥៧ ហេតុដូច្នោះហើយ ចូរបង្រៀនកូនចៅអ្នក ថាមនុស្សទាំងអស់នៅគ្រប់ទិសទី[ក]ត្រូវតែប្រែចិត្ត បើពុំនោះសោតទេ ពួកគេពុំអាចគ្រង នគរព្រះទុកជាមរតកបានឡើយ ត្បិតគ្មានអ្វីដែល[ខ]មិនស្អាតអាច[គ]អាស្រ័យនៅទីនោះ ឬនៅក្នុងវត្តមានរបស់ទ្រង់បានឡើយ; ត្បិតនៅ ក្នុងភាសាអ័ដាម [ឃ]មនុស្សនៃបរិសុទ្ធភាព គឺជាព្រះនាមរបស់ទ្រង់ ហើយព្រះនាមនៃព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ គឺ[ង]កូនមនុស្ស គឺព្រះយេស៊ូវគ្រីស្ទ ជា[ច]ចៅក្រមសុចរិត ដែលនឹងយាងមកក្នុងពេលដ៏ខ្ពង់ខ្ពស់បំផុត ។

៥៨ ហេតុដូច្នេះហើយ យើងប្រទានដល់អ្នក នូវបញ្ញត្តិមួយ ឲ្យបង្រៀនការណ៍ទាំងនេះដោយសេរី ដល់[ក]កូនចៅអ្នកថា៖

៥៩ គឺដោយសារការរំលង នោះទើបមានការធ្លាក់ ឯការធ្លាក់នោះនាំឲ្យមានការស្លាប់ ហើយដរាបណាអ្នករាល់គ្នាបានកើតមកក្នុង លោកិយដោយសារទឹក និងឈាម និង[ក]វិញ្ញាណដែលយើងបានធ្វើ ហើយទើបបានក្លាយជា[ខ]ធូលីដីមានព្រលឹងរស់ឡើងជាយ៉ាងណា នោះអ្នករាល់គ្នាក៏ត្រូវតែបាន[គ]កើតម្ដងទៀតទៅក្នុងនគរស្ថានសួគ៌ ដោយសារ[ឃ]ទឹក និងដោយសារព្រះវិញ្ញាណ ហើយត្រូវបានសំអាត ដោយសារឈាម គឺជាព្រះលោហិតនៃព្រះរាជបុត្រាបង្កើតតែមួយរបស់យើងយ៉ាងនោះដែរ; ប្រយោជន៍ឲ្យអ្នកអាចបានញែកជាបរិសុទ្ធ ចេញពីអស់ទាំងអំពើបាប ហើយ[ង]មានសេចក្ដីអំណរចំពោះ[ច]ព្រះបន្ទូល អំពីជីវិតដ៏នៅអស់កល្បជានិច្ចនៅនាលោកិយនេះ និងជីវិតដ៏នៅ អស់កល្បជានិច្ចនៅឯនាបរលោក គឺជា[ឆ]សិរីល្អដ៏នៅអមតៈ;

៦០ ត្បិតដោយសារ[ក]ទឹក នោះអ្នករាល់គ្នាកាន់តាមព្រះបញ្ញត្តិទាំងឡាយ; ដោយសារព្រះវិញ្ញាណ នោះអ្នករាល់គ្នាត្រូវបាន

៥២ *ខ* ស.ប. ព្រះគុណ.
*គ* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ឃ* កិច្ចការ ៤:១២; ២ នីហ្វៃ ៣១:២១.
*ង* ស.ប. សេចក្ដីសង្គ្រោះ.
៥៣ *ក* ស.ប. អត់ទោស, អភ័យទោស.
៥៤ *ក* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*ខ* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*គ* ម៉ូសាយ ៣:១៦.
៥៥ *ក* ស.ប. អំពើបាប.
*ខ* គ. និង ស. ២៩:៣៩. ស.ប. សេចក្ដីទំនាស់.
៥៦ *ក* ២ នីហ្វៃ ២:២៦–២៧; ហេលេ. ១៤:២៩–៣០. ស.ប. សិទ្ធិជ្រើសរើស.
៥៧ *ក* ១ កូរិន. ៦:៩–១០. ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ខ* ១ នីហ្វៃ ១០:២១. ស.ប. ស្អាត និងឥតស្អាត.
*គ* ទំនុក. ២៤:៣–៤; ១ នីហ្វៃ ១៥:៣៣–៣៦; មរមន ៧:៧; គ. និង ស. ៧៦:៥០–៦២.
*ឃ* ម៉ូសេ ៧:៣៥. ស.ប. មនុស្សនៃបរិសុទ្ធភាព.
*ង* ស.ប. កូនមនុស្ស.
*ច* ស.ប. ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម; សេចក្ដីយុត្តិធម៌.
៥៨ *ក* ស.ប. កូនក្មេង, ពួកកូនក្មេង.
៥៩ *ក* ១ យ៉ូហាន ៥:៨.
*ខ* លោកុ. ២:៧; ម៉ូសេ ៤:២៥; អ័ប្រា. ៥:៧.
*គ* ស.ប. កើតម្ដងទៀត, កើតពីព្រះ.
*ឃ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ង* ២ នីហ្វៃ ៤:១៥–១៦; អាលម៉ា ៣២:២៨.
*ច* យ៉ូហាន ៦:៦៨.
*ឆ* ស.ប. សិរីល្អនៃសេឡេស្ទាល.
៦០ *ក* ម៉ូរ៉ូណៃ ៨:២៥.

រាប់ថា [ខ]សុចរិត ហើយដោយសារ[គ]ព្រះលោហិត នោះអ្នករាល់
គ្នាត្រូវបាន[ឃ]ញែកចេញជាបរិសុទ្ធ;
៦១ ហេតុដូច្នេះហើយ ទើបបានប្រទានឲ្យនៅជាប់នឹងអ្នក; ជា
ទីបន្ទាល់ពីស្ថានសួគ៌; ជា[ក]ព្រះដ៏ជាជំនួយ ជាការណ៍ទាំងឡាយ
ដ៏ប្រកប ដោយសេចក្ដីសុខសាន្ត អំពីសិរីល្អដ៏នៅអមតៈ; ជាសេច
ក្ដីពិតអំពីគ្រប់ការណ៍ទាំងអស់; ដែលប្រោសគ្រប់អ្វីទាំងអស់
ដែលធ្វើឲ្យគ្រប់ អ្វីទាំងអស់មានជីវិត; ដែលជ្រាបគ្រប់ការណ៍
ទាំងអស់ ហើយមានព្រះចេស្ដាគ្រប់យ៉ាង ស្របតាមប្រាជ្ញា
សេចក្ដីមេត្តាករុណា សេចក្ដីពិត សេចក្ដីយុត្តិធម៌ និងសេច
ក្ដីជំនុំជំរះ ។
៦២ ហើយឥឡូវនេះ មើលចុះ យើងប្រាប់អ្នកថា៖ នេះហើយ
ជា[ក]ផែនការនៃសេចក្ដីសង្គ្រោះដល់មនុស្សទាំងអស់ គឺតាមរយៈ
ព្រះ លោហិត នៃព្រះរាជបុត្រា[ខ]បង្កើតតែមួយរបស់យើង ដែល
នឹងយាងមកក្នុងពេលដ៏ខ្ពង់ខ្ពស់បំផុត ។
៦៣ ហើយមើលចុះ គ្រប់អ្វីទាំងអស់មានរូបភាពដូចគ្នា ហើយ
គ្រប់អ្វីទាំងអស់ត្រូវបានបង្កើត ហើយធ្វើឡើងមក ដើម្បី [ក]ធ្វើទីប
ន្ទាល់អំពី យើង ទាំងរបស់ខាងសាច់ឈាម និងទាំងរបស់
ខាងវិញ្ញាណផង; របស់ទាំងឡាយដែលនៅស្ថានសួគ៌ពីលើ និង
របស់ទាំងឡាយ ដែលនៅលើផែនដី និងរបស់ទាំងឡាយដែល
នៅក្នុងផែនដី និងរបស់ទាំងឡាយដែលនៅខាងក្រោមផែនដី
ទាំងខាងលើ និងទាំង ខាងក្រោមផង៖ គឺគ្រប់ការណ៍ទាំង
អស់ធ្វើទីបន្ទាល់អំពីយើង ។
៦៤ ហើយហេតុការណ៍បានកើតឡើងថា កាលព្រះអម្ចាស់
ទ្រង់មានព្រះបន្ទូលជាមួយនឹងអ័ដាម ជាឪពុករបស់យើង
រួចហើយ នោះស្រាប់ តែអ័ដាមបានអំពាវនាវទៅព្រះ
អម្ចាស់ ហើយគាត់ត្រូវបាននាំទៅដោយ[ក]ព្រះវិញ្ញាណនៃព្រះ
អម្ចាស់ ហើយបាននាំចុះទៅក្នុង[ខ]ទឹក ហើយបានកប់នៅក្នុងទឹក
ហើយបាននាំចេញមកពីទឹកវិញ ។
៦៥ ហើយគាត់បានទទួលបុណ្យជ្រមុជទឹកយ៉ាងដូច្នោះហើយ
ហើយព្រះវិញ្ញាណនៃព្រះបានយាងចុះមកសណ្ឋិតលើគាត់ ហើយ
គាត់ បាន[ក]កើតពីព្រះវិញ្ញាណយ៉ាង[ខ]ដូច្នោះហើយ ហើយបានក្លាយ
ទៅជាមនុស្សដែលបានប្រោសខាងក្នុង ។
៦៦ ហើយគាត់បានឮចេញពីស្ថានសួគ៌ថា៖ អ្នកបាន[ក]ទទួល
បុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធហើយ ។
នេះហើយជា[ខ]ទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា ចាប់ពី
អំណរិះ និងរៀងដរាបតទៅ;
៦៧ ហើយអ្នកនៅតាម[ក]របៀបនៃទ្រង់ដែលគ្មានថ្ងៃចាប់ផ្ដើម
ឬឆ្នាំបញ្ចប់ឡើយ គឺពីអស់ទាំងភាពអស់កល្បទៅអស់ទាំងភាព
អស់កល្ប ជានិច្ច ។
៦៨ មើលចុះ អ្នក[ក]ក្លាយទៅតែមួយក្នុងយើង គឺជា[ខ]កូននៃព្រះ;
ហើយដូច្នេះ ទើបមនុស្សទាំងអស់អាចក្លាយទៅជាកូនរបស់យើង
បាន ។ អាម៉ែន ៕

## ជំពូកទី ៧

*(ធ្នូ ១៨៣០)*

*ហេណុកបង្រៀន ដឹកនាំប្រជាជន ហើយរើភ្នំទាំងឡាយ — ទីក្រុងស៊ីយ៉ូនត្រូវបានតាំងឡើង — ហេណុកមើលឃើញជាមុន អំពីការ យាងមកនៃកូនមនុស្ស ការបូជាដ៏ធួនរបស់ទ្រង់ និងដំណើររស់ឡើងវិញនៃពួកបរិសុទ្ធ — គាត់មើលឃើញជាមុន អំពីការសាងឡើងវិញ ការប្រមូល ការយាងមកជាលើកទីពីរ និងការវិលមកវិញនៃក្រុងស៊ីយ៉ូន ។*

ហើយហេតុការណ៍បានកើតឡើងថា ហេណុកបានវាចា
តទៅទៀតថា៖ មើលចុះ អ័ដាម ជាឪពុករបស់យើង គាត់បាន
បង្រៀនពីការណ៍ ទាំងនេះ ហើយមនុស្សជាច្រើនបានជឿ ហើយ
បាន[ក]ក្លាយជាកូននៃព្រះ ហើយមនុស្សជាច្រើនពុំបានជឿទេ ហើយ
បានវិនាសទៅ ក្នុងអំពើបាបទាំងឡាយរបស់ខ្លួន ហើយកំពុងតែ

៦០ ខ ស.ប. ការរាប់ជាសុចរិត, រាប់ជាសុចរិត.
គ ស.ប. លោហិត.
ឃ ស.ប. ការញែកជាបរិសុទ្ធ.
៦១ ក ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
៦២ ក ស.ប. ផែនកានៃសេចក្ដីប្រោសលោះ.
ខ ស.ប. បង្កើតតែមួយ.
៦៣ ក អាលម៉ា ៣០:៤៤; គ. និង ស. ៨៨:៤៥–៤៧.
៦៤ ក ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
ខ ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
៦៥ ក ស.ប. កើតម្ដងទៀត, កើតពីព្រះ.
ខ ម៉ូសាយ ២៧:២៥; អាលម៉ា ៥:១២–១៥.
៦៦ ក គ. និង ស. ១៩:៣១. ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
ខ ២ នីហ្វៃ ៣១:១៧–១៨; ៣ នីហ្វៃ ២៨:១១.
៦៧ ក ស.ប. បព្វជិតភាពមិលគីស្សាដែក.
៦៨ ក ១ យ៉ូហាន ៣:១–៣; គ. និង ស. ៣៥:២.
ខ យ៉ូហាន ១:១២; គ. និង ស. ៣៤:៣. ស.ប. បុត្រាបុត្រីនៃព្រះ.
៧ ១ក ស.ប. បុត្រាបុត្រីនៃព្រះ.

រង់ចាំដោយ[ខ]ភ័យខ្លាចក្នុងការវេទនា ចំពោះសេចក្ដីគ្នាន់ក្នាញ់ដ៏ឆួលឆាបនៃការពិរោធ របស់ព្រះ ដែលនឹងចាក់មកលើពួកគេ ។

២ ហើយចាប់ពីពេលនោះមក ហេណុកបានចាប់ផ្ដើមព្យាករ ដោយប្រាប់ទៅប្រជាជនថា៖ កាលខ្ញុំកំពុងតែធ្វើដំណើរ ហើយបានឈរ នៅលើកន្លែងម៉ាហ៊ូយ៉ា ហើយអំពាវនាវទៅព្រះអម្ចាស់ នោះស្រាប់តែមានសម្លេងមួយចេញមកពីស្ថានសួគ៌ថា — ចូរអ្នកបែរ ហើយចូរ អ្នកទៅលើភ្នំស៊ីម្មានចុះ ។

៣ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំក៏បែរ ហើយទៅលើភ្នំ; ហើយកាលខ្ញុំកំពុងតែនៅលើភ្នំ នោះស្រាប់តែខ្ញុំឃើញផ្ទៃមេឃបើក ចំហ ហើយខ្ញុំ[ក]ត្រូវបានបំពាក់ដោយសិរីល្អ;

៤ ហើយខ្ញុំមើលឃើញព្រះអម្ចាស់; ហើយទ្រង់បានឈរនៅចំពោះមុខខ្ញុំ ហើយទ្រង់បានមានព្រះបន្ទូលជាមួយខ្ញុំ ដូចជាមនុស្សនិយាយ [ក]ប្រទល់មុខគ្នា; ហើយទ្រង់បានមានព្រះបន្ទូលមក[ខ]ខ្ញុំថា៖ ចូរមើល ហើយយើងនឹងបង្ហាញដល់អ្នក នូវលោកិយអស់រយៈតំណដ៏ច្រើន ។

៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំបានឃើញនៅក្នុងច្រកភ្នំស៊ុម ហើយមើលន៏ មានប្រជាជនដ៏ច្រើនដែលអាស្រ័យនៅក្នុង ត្រសាលទាំងឡាយ ដែលជាប្រជាជនស៊ុម ។

៦ ហើយជាថ្មីទៀត ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ ចូរមើល; ហើយខ្ញុំក៏មើលទៅទិសខាងជើង ហើយខ្ញុំបានឃើញប្រជាជន កាណាន ដែលអាស្រ័យនៅក្នុងត្រសាលទាំងឡាយ ។

៧ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ ចូរព្យាករ; ហើយខ្ញុំក៏ព្យាករថា៖ មើលចុះ ប្រជាជនកាណាន ដែលមានចំនួនដ៏ ច្រើនឥតគណនា គេនឹងចេញទៅដោយប្រុងចូលច្បាំងនឹងប្រជាជនស៊ុម ហើយនឹងប្រហារពួកគេបង់ ប្រយោជន៍ឲ្យពួកគេត្រូវបានបំផ្លាញ សូន្យបង់; ហើយប្រជាជនកាណាននឹងបំបែកគ្នានៅលើដែនដី ហើយដែនដីនឹងទៅជាស្ងួតហួតហែង ហើយនឹងមិនឲ្យផលឡើយ ហើយគ្មាន មនុស្សផ្សេងទៀតអាចអាស្រ័យនៅទីនោះ ក្រៅពីប្រជាជនកាណានឡើយ;

៨ ត្បិតមើលចុះ ព្រះអម្ចាស់ទ្រង់នឹងដាក់បណ្ដាសាដល់ដែនដីដោយកំដៅដ៏ខ្លាំង ហើយការស្ងួតហួតហែងនៃទីនោះនឹងមានជារៀង ដរាបតទៅ; ហើយ[ក]សម្បុរក្រម៉ៅបានមានមកលើអស់ទាំងកូនចៅកាណាន ប្រយោជន៍ឲ្យពួកគេត្រូវមនុស្សស្អប់ក្នុងចំណោមប្រជាជន ទាំងអស់ ។

៩ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់បានមានព្រះបន្ទូលមកខ្ញុំថា៖ ចូរមើល; ហើយខ្ញុំក៏មើល ហើយខ្ញុំបានឃើញដែនដី សារុន និងដែនដីហេណុក និងដែនដីអោមណើរ និងដែនដីហេណៃ និងដែនដីសេម និងដែនដីហាណើរ និងដែនដីហាណាណៃហា និងអស់ទាំងបណ្ដាជននៅទីនោះផង;

១០ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ ចូរទៅរកប្រជាជននេះចុះ ហើយប្រាប់ទៅគេថា — ចូរ[ក]ប្រែចិត្តចុះ ក្រែងយើង ចេញមក ហើយវាយពួកគេដោយសេចក្ដីបណ្ដាសា ហើយពួកគេស្លាប់ទៅ ។

១១ ហើយទ្រង់បានប្រទានដល់ខ្ញុំ នូវព្រះបញ្ញត្តិមួយថា ខ្ញុំត្រូវ[ក]ទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមនៃព្រះវរបិតា និងនៃព្រះរាជបុត្រា ដែលពោរពេញទៅដោយ[ខ]ព្រះគុណ និងសេចក្ដីពិត និងនៃ[គ]ព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា ។

១២ ហើយហេតុការណ៍បានកើតឡើងថា ហេណុកចេះតែហៅអស់ទាំងប្រជាជនតទៅទៀត ឲ្យប្រែចិត្ត លើកលែងតែប្រជាជន កាណានប៉ុណ្ណោះ ។

១៣ ហើយ[ក]សេចក្ដីជំនឿរបស់ហេណុកគឺធំណាស់ហ្ន៎ ដែលគាត់បានដឹកនាំប្រជាជននៃព្រះ ហើយពួកខ្មាំងសត្រូវរបស់គេបានមកធ្វើចំបាំង ប្រឆាំងនឹងពួកគេ; ហើយគាត់បានពោលព្រះបន្ទូលនៃព្រះអម្ចាស់ ហើយផែនដីក៏កក្រើក ហើយ[ខ]ភ្នំទាំងឡាយរត់ចេញ គឺស្របតាមបញ្ជា របស់គាត់; ហើយ[គ]ទន្លេដែលមានទឹកទាំងប៉ុន្មានត្រូវបានបែរចេញពីដំណើរវា; ហើយសូរសិង្ហគ្រហឹមបានឮចេញពីទីរហោស្ថាន; ហើយ សាសន៍ទាំងអស់បានភ័យខ្លាចជាខ្លាំង ព្រោះពាក្យសំដីរបស់ហេណុកមានអានុភាពណាស់ ហើយ[ឃ]អំណាចខាងភាសាដែលព្រះទ្រង់បាន ប្រទានដល់គាត់ នោះធំដ៏ក្រៃលែង ។

១៤ ក៏មានដីផុសឡើងចេញពីជំរៅសមុទ្រមក ហើយការភ័យខ្លាចរបស់ពួកខ្មាំងសត្រូវនៃប្រជាជននៃព្រះ នោះធំដ៏ក្រៃលែង

១ *ខ* អាលម៉ា ៤០:១១–១៤.
៣ *ក* ស.ប. ការប្រែរូប.
៤ *ក* លោកុ. ៣២:៣០; ចោទិ. ៥:៤; ម៉ូសេ ១:២, ១១, ៣១.
*ខ* ម៉ូសេ ១:៤.
៨ *ក* ២ នីហ្វៃ ២៦:៣៣.
១០ *ក* ម៉ូសេ ៦:៥៧.
ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
១១ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. ព្រះគុណ.
*គ* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
១៣ *ក* ស.ប. សេចក្ដីជំនឿ.
*ខ* ម៉ាថាយ ១៧:២០.
*គ* ម៉ូសេ ៦:៣៤.
*ឃ* ស.ប. អំណាច; បព្វជិតភាព.

ដែលពួកគេ បានរត់ ហើយឈរពីចម្ងាយ ហើយ
បានឡើងទៅលើដែនដី ដែលបានផុសឡើងមកពីជំរៅសមុទ្រ ។
១៥ ហើយពួក[ក]មនុស្សរូបធំសំបើមនៃដែនដី គេក៏ឈរពីចម្ងាយ;
ហើយមានសេចក្ដីបណ្ដាសាមួយបានចេញទៅលើប្រជាជនទាំង
អស់ ដែលបានប្រឆាំងនឹងព្រះ;
១៦ ហើយចាប់ពីពេលនោះមក ក៏មានសង្គ្រាម និងការកំចា
យឈាមទាំងឡាយនៅក្នុងចំណោមពួកគេ; ប៉ុន្តែព្រះអម្ចាស់
ទ្រង់បាន យាងមក ហើយគង់នៅជាមួយនឹងរាស្ត្រទ្រង់ ហើយពួក
គេបានរស់នៅក្នុងសេចក្ដីសុចរិត ។
១៧ ហើយ[ក]សេចក្ដីស្ញែងខ្លាចពីព្រះអម្ចាស់នោះមានមកលើ
អស់ទាំងសាសន៍ សិរីល្អរបស់ព្រះអម្ចាស់គឺធំដ៏អស្ចារ្យ ដែល
មានមកលើ រាស្ត្រទ្រង់ ។ ហើយព្រះអម្ចាស់ទ្រង់[ខ]បានប្រទានពរ
ដល់ដែនដី ហើយពួកគេបានពរនៅលើភ្នំទាំងឡាយ និងនៅលើ
ទីខ្ពស់ទាំងឡាយ ហើយបានលូតលាស់ ។
១៨ ហើយព្រះអម្ចាស់ទ្រង់បានហៅរាស្ត្រទ្រង់ថា «[ក]ស៊ីយ៉ូន»
ពីព្រោះពួកគេមានចិត្ត[ខ]តែមួយ និងគំនិតតែមួយ ហើយបានរស់នៅ
ក្នុង សេចក្ដីសុចរិត; ហើយគ្មានមនុស្សក្រីក្រនៅក្នុងចំណោមពួក
គេឡើយ ។
១៩ ហើយហេណុកបានបន្តការផ្សាយរបស់គាត់ដល់រាស្ត្រនៃ
ព្រះ ក្នុងសេចក្ដីសុចរិត ។ ហើយហេតុការណ៍បានកើតឡើងថា
នៅជំនាន់គាត់ នោះគាត់បានសង់ទីក្រុងមួយ ដែលបានហៅថា
ទីក្រុងនៃបរិសុទ្ធភាព គឺក្រុងស៊ីយ៉ូន ។
២០ ហើយហេតុការណ៍បានកើតឡើងថា ហេណុកបានទូលជា
មួយព្រះអម្ចាស់ ហើយគាត់បានទូលទៅព្រះអម្ចាស់ថា៖ [ក]ស៊ីយ៉ូន
ច្បាស់ជានឹងបានរស់នៅដោយសុខជារៀងរាបតទៅ ។ ប៉ុន្តែ
ព្រះអម្ចាស់បានមានព្រះបន្ទូលទៅហេណុកថា៖ យើងនឹងប្រទាន
ពរដល់ស៊ីយ៉ូន ប៉ុន្តែយើងបានដាក់បណ្ដាសាដល់មនុស្សដែល
សល់ទាំងប៉ុន្មានវិញ ។
២១ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បាន
បង្ហាញដល់ហេណុក នូវអស់ទាំងបណ្ដាជននៃផែនដី; ហើយគាត់
បាន ឃើញ ហើយមើលន៏ ក្រោយមក ក្រុងស៊ីយ៉ូនត្រូវបាន[ក]យក
ទៅលើស្ថានសួគ៌ ។ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះ
បន្ទូលទៅហេណុក ថា៖ មើលចុះ គឺជាទីលំនៅរបស់យើងជានិច្ច ។
២២ ហើយហេណុកក៏បានឃើញមនុស្ស ដែលនៅសល់
ទាំងប៉ុន្មាន ដែលជាពួកកូនប្រុសនៃអ័ដាម; ហើយពួកគេគឺជា
ពូជលាយឡំគ្នា ពីពូជអ័ដាមទាំងអស់ ក្រៅពីពូជកាអ៊ីន ត្បិត
ពូជកាអ៊ីនមាន[ក]សម្បុរខ្មៅ ហើយគ្មានកន្លែងនៅក្នុងចំណោមពួក
គេឡើយ ។
២៣ ហើយបន្ទាប់ពីក្រុងស៊ីយ៉ូនត្រូវបានយកទៅលើ[ក]ស្ថានសួគ៌
នោះហេណុក[ខ]បានឃើញ ហើយមើលន៏ [គ]គ្រប់អស់
ទាំងសាសន៍នៅលើ ផែនដីក៏នៅចំពោះគាត់;
២៤ ហើយក៏មានតំណមនុស្សតាមតំណមនុស្ស; ហើយហេណុក
នៅទីខ្ពស់ ហើយ[ក]បានលើកឡើង គឺទៅក្នុងព្រះឱរានៃព្រះវរបិតា
និងកូន មនុស្ស; ហើយមើលចុះ អំណាចនៃអារក្សសាតាំង
មាននៅពាសពេញលើផ្ទៃផែនដី ។
២៥ ហើយគាត់បានឃើញពួកទេវតាកំពុងតែចុះពីស្ថានសួគ៌
មក; ហើយគាត់បានឮសម្លេងដ៏ខ្លាំងពោលថា៖ វេទនា វេទនា
ដល់ បណ្ដាជននៅលើផែនដី ។
២៦ ហើយគាត់ក៏បានឃើញអារក្សសាតាំង; ហើយវា
មាន[ក]ច្រវាក់ដ៏ធំនៅដៃវា ហើយវាគ្របដណ្ដប់ផ្ទៃផែនដីទាំងមូល
ដោយ[ខ]សេចក្ដីងងឹត; ហើយវាបានងើបមុខឡើង ហើយសើច
ហើយ[គ]ពួកទេវតារបស់វាក៏អរសប្បាយ ។
២៧ ហើយហេណុកបានឃើញពួក[ក]ទេវតាកំពុងតែចុះពីស្ថានសួគ៌
មក ដោយធ្វើ[ខ]ទីបន្ទាល់ពីព្រះវរបិតា និងព្រះរាជបុត្រា; ហើយ
ព្រះ វិញ្ញាណបរិសុទ្ធបានសណ្ឋិតលើមនុស្សជាច្រើន ហើយពួក
គេត្រូវបាននាំឡើងទៅក្រុងស៊ីយ៉ូន ដោយព្រះចេស្ដាទាំងឡាយ
នៃស្ថាន សួគ៌ ។
២៨ ហើយហេតុការណ៍បានកើតឡើងថា ព្រះនៃស្ថានសួគ៌
ទ្រង់បានទតមើលមកលើមនុស្ស ដែលនៅសល់ទាំងប៉ុន្មាន ហើយ
ទ្រង់ព្រះ កន្សែង; ហើយហេណុកបានធ្វើទីបន្ទាល់អំពីការណ៍នោះ

១៥ ក លោកុ. ៦:៤; ម៉ូសេ ៨:១៨.
១៧ ក និក្ខ. ២៣:២៧.
ខ ១ របា. ២៨:៧–៨;
១ នីហ្វៃ ១៧:៣៥.
១៨ ក ស.ប. ស៊ីយ៉ូន.
ខ កិច្ចការ ៤:៣២; ភីលីព ២:១–៤.
ស.ប. ការរួបរួមតែមួយ.
២០ ក ម៉ូសេ ៧:៦២–៦៣.
ស.ប. ក្រុងយេរូសាឡិមថ្មី.
២១ ក ម៉ូសេ ៧:៦៩.
២២ ក ២ នីហ្វៃ ២៦:៣៣.
២៣ ក ស.ប. ស្ថានសួគ៌.
ខ ស.ប. ការនិមិត្ត.
គ គ. និង ស. ៨៨:៤៧;
ម៉ូសេ ១:២៧–២៩.
២៤ ក ២ កូរិន. ១២:១–៤.
២៦ ក អាលម៉ា ១២:១០–១១.
ខ អេសាយ ៦០:១–២.
គ យូដាស ១:៦;
គ. និង ស. ២៩:៣៦–៣៧.
២៧ ក ស.ប. ពួកទេវតា.
ខ ស.ប. ទីបន្ទាល់.

ដោយពោលថា៖ ម្ដេចឡើយក៏ស្ថានសួគ៌យំ
ហើយស្រក់ទឹកភ្នែកដូចជាទឹក ភ្លៀង ស្រក់លើភ្នំទាំងឡាយ
ដូច្នោះ ?
២៩ ហើយហេណុកបានទូលទៅព្រះអម្ចាស់ថា៖ ម្ដេច
ឡើយក៏ទ្រង់ព្រះកន្សែង ដោយឃើញថាព្រះអង្គបរិសុទ្ធ
ហើយពីអស់ទាំងភាពអស់ កល្បទៅអស់ទាំងភាពអស់កល្ប
ជានិច្ចដូច្នោះ ?
៣០ ហើយទោះបីជាមនុស្សអាចរាប់ចុណ្ណភាគទាំងឡាយ
នៃផែនដី មែនហើយ គឺផែនដីរាប់លានដូចផែនដីនេះ គង់តែពុំ
មែនជាការ ចាប់ផ្ដើមនូវចំនួននៃការបង្កបង្កើតរបស់ទ្រង់ដែរ
ហើយវាំងនននរបស់ទ្រង់នៅតែលាតទៅទៀត; ហើយទោះ
ជាយ៉ាងនោះក្ដី គង់តែទ្រង់ គង់នៅទីនោះ ហើយឧ
រាព្រះអង្គក៏គង់នៅទីនោះដែរ; ហើយព្រះអង្គទ្រង់ក៏យុត្តិធម៌;
ព្រះអង្គទ្រង់មានសេចក្ដីមេត្តាករុណា ហើយ សប្បុរសជានិច្ច;
៣១ ហើយព្រះអង្គទ្រង់បានយកក្រុងស៊ីយ៉ូនទៅឧរារបស់ទ្រង់
ផ្ទាល់ ចេញពីអស់ទាំងការបង្កបង្កើតរបស់ទ្រង់ ចេញពីអស់ទាំង
ភាព អស់កល្បទៅអស់ទាំងភាពអស់កល្បជានិច្ច; ហើយគ្មាន
អ្វីឡើយ ក្រៅពីសេចក្ដីសុខសាន្ត សេចក្ដីយុត្តិធម៌ និងសេច
ក្ដីពិតដែលជាទីលំ នៅនៃបល្ល័ង្កទ្រង់; ហើយសេចក្ដីមេត្តាករុណា
នឹងចេញទៅ នៅចំពោះព្រះភ័ក្ត្រទ្រង់ ហើយគ្មានចុងបំផុតឡើយ;
ម្ដេចឡើយក៏ទ្រង់ព្រះ កន្សែងដូច្នោះ ?
៣២ ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅហេណុកថា៖ មើលចុះ
នេះគឺជាពួកបងប្អូនរបស់អ្នក; ពួកគេជាផលនៃដៃយើងផ្ទាល់
ហើយយើងបានប្រទានដល់ពួកគេ នូវចំណេះវិជ្ជាដែលគេមាន
នៅថ្ងៃដែលយើងបានបង្កើតគេមក; ហើយនៅក្នុងសួនច្បារអេដែន
នោះយើងបានប្រទានសិទ្ធិជ្រើសរើសដល់មនុស្ស;
៣៣ ហើយដល់ពួកបងប្អូនរបស់អ្នក នោះយើងបានមានបន្ទូល
ហើយទាំងប្រទានបញ្ញត្តិមួយថា ពួកគេត្រូវស្រឡាញ់គ្នាទៅវិញទៅ
មក ហើយថាពួកគេត្រូវរើសយើងជាព្រះវរបិតារបស់គេ; ប៉ុន្តែ
មើលចុះ ពួកគេគ្មានសេចក្ដីស្រឡាញ់ទេ ហើយពួកគេស្អប់ឈាម
ខ្លួនឯង ទៅវិញ;
៣៤ ហើយ ភ្លើងនៃសេចក្ដីគ្នាន់ក្នាញ់របស់យើងក៏ឆួលឆាប
ឡើងទាស់នឹងពួកគេ; ហើយដោយសេចក្ដីក្ដៅក្រហាយ
របស់យើង នោះ យើងនឹងចាត់ឲ្យ ទឹកជន់មកលើគេ ត្បិត
សេចក្ដីខ្ញាល់ដ៏ក្ដៅរបស់យើងបានឆេះឡើងទាស់នឹងពួកគេ
ហើយ ។
៣៥ មើលចុះ យើងជាព្រះ; មនុស្សនៃបរិសុទ្ធភាព គឺជា
ព្រះនាមរបស់យើង; មនុស្សនៃដំបូន្មាន គឺជាព្រះនាមរបស់យើង;
ហើយគ្មានទី បញ្ចប់ និងអស់កល្បជានិច្ច គឺជាព្រះនាម
របស់យើងដែរ ។
៣៦ ហេតុដូច្នោះហើយ យើងអាចលាតព្រះហស្តយើង ហើយ
កាន់អស់ទាំងការបង្កបង្កើតដែលយើងបានធ្វើមក; ហើយព្រះនេត្រ
របស់ យើងក៏អាចទំលុះរបស់ទាំងនោះបានដែរ ហើយនៅក្នុង
ចំណោមអស់ទាំងផលនៃដៃរបស់យើង នោះពុំដែលមានអំពើ
ទុច្ចរិតដ៏ធំម្លេះ ឡើយ នៅក្នុងចំណោមបងប្អូនរបស់អ្នក ។
៣៧ ប៉ុន្តែមើលចុះ អំពើបាបទាំងឡាយរបស់គេនឹងត្រូវមក
លើក្បាលនៃពួកឪពុកគេ; អារក្សសាតាំងនឹងទៅជាឪពុករបស់គេ
ហើយ សេចក្ដីទុក្ខវេទនានឹងទៅជាទោសរបស់គេ; ហើយ
ស្ថានសួគ៌ទាំងមូលនឹងយំដោយព្រោះពួកគេ គឺចំពោះអស់
ទាំងផលនៃដៃរបស់ យើងផង; ហេតុដូច្នោះហើយ តើមិនឲ្យ
ស្ថានសួគ៌យំទេឬអី ដោយឃើញថាមនុស្សទាំងនេះនឹងរងទុក្ខ ?
៣៨ ប៉ុន្តែមើលចុះ មនុស្សទាំងនេះដែលព្រះនេត្រយើងទតមក
លើ នោះនឹងវិនាសបង់នៅក្នុងទឹកជំនន់; ហើយមើលចុះ យើង
នឹងបិទគេ ចេញ; ហើយមានគុកមួយដែលយើងបានរៀបចំ
សំរាប់ពួកគេ ។
៣៩ ហើយរឹងអ្នកដែលយើងបានរើស នោះបានអង្វរចំពោះព្រះ
ភ័ក្ត្រយើង ។ ហេតុដូច្នោះហើយ អ្នកនោះនឹងរងទុក្ខជំនួសអំពើ
បាបទាំង ឡាយរបស់ពួកគេ; ដរាបណាពួកគេប្រែចិត្ត នៅថ្ងៃ

២៩ *ក* អេសាយ ៦៣:៧–១០.
៣០ *ក* គ. និង ស. ៧៦:២៤; ម៉ូសេ ១:៣៣.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
៣១ *ក* ស.ប. សេចក្ដីសុខសាន្ត.
*ខ* ស.ប. សេចក្ដីយុត្តិធម៌.
*គ* ស.ប. សេចក្ដីពិត.
៣២ *ក* ម៉ូសេ ១:៤.
*ខ* ស.ប. ដំរិះ.
*គ* ស.ប. សិទ្ធិជ្រើសរើស.
៣៣ *ក* ស.ប. សេចក្ដីស្រឡាញ់.
៣៤ *ក* អេសាយ ៣០:២៧; ណាហ៊ុម ១:៦; គ. និង ស. ៣៥:១៤.
*ខ* លោកុ. ៧:៤, ១០; ម៉ូសេ ៨:១៧, ២៤. ស.ប. ទឹកជំនន់នៅសម័យណូអេ.
៣៥ *ក* ម៉ូសេ ៦:៥៧.
*ខ* ម៉ូសេ ១:៣.
៣៦ *ក* គ. និង ស. ៣៨:២; ៨៨:៤១; ម៉ូសេ ១:៣៥–៣៧.
*ខ* លោកុ. ៦:៥–៦; ម៉ូសេ ៨:២២, ២៨–៣០.
៣៨ *ក* ១ ពេត្រុស ៣:១៨–២០. ស.ប. ស្ថាននរក.
៣៩ *ក* ក.ន. ព្រះអង្គសង្គ្រោះ.

ដែលអ្នកជំរើសរបស់យើងនឹងវិលមកយើងវិញ ហើយរហូតដល់ថ្ងៃនោះ នោះពួកគេ នឹងរងទោស;

៤០ ហេតុដូច្នោះហើយ ដោយព្រោះហេតុនេះហើយ បានជាស្ថានសួគ៌យំ មែនហើយ និងចំពោះអស់ទាំងផលនៃដៃរបស់យើងផង ។

៤១ ហើយហេតុការណ៍បានកើតឡើងថា ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅហេណុក ហើយប្រាប់ហេណុកពីកិច្ចការទាំងអស់នៃ កូនចៅមនុស្ស; ហេតុដូច្នោះហើយ ទើបហេណុកបានដឹងហើយសម្លឹងមើលអំពើទុច្ចរិតរបស់គេ និងសេចក្ដីទុក្ខវេទនារបស់គេហើយយំ ហើយលាតសន្ធឹងដៃគាត់ ហើយដួងចិត្តគាត់រីកទូលំទូលាយដូចជាភាពដ៏អស់កល្បជានិច្ច; ហើយគាត់មានចិត្តក្ដួលអាណិត; ហើយគ្រប់ ភាពអស់កល្បជានិច្ចបានកក្រើក ។

៤២ ហើយហេណុកក៏បានឃើញណូអេ និងគ្រួសាររបស់គាត់ផង; ថាពូជពង្សនៃកូនប្រុសណូអេទាំងអស់នឹងត្រូវបានសង្គ្រោះដោយ សេចក្ដីសង្គ្រោះខាងសាច់ឈាម ។

៤៣ ហេតុដូច្នោះហើយ ហេណុកបានឃើញថាណូអេសង់ទូកធំមួយ; ហើយថាព្រះអម្ចាស់ទ្រង់បានញញឹមចំពោះទូកធំនោះ ហើយបាន កាន់ដោយព្រះហស្តរបស់ទ្រង់ផ្ទាល់; ប៉ុន្តែចំពោះមនុស្សទុច្ចរិតដែលនៅសល់ទាំងប៉ុន្មាន នោះទឹកជន់មក ហើយលេបពួកគេបាត់ទៅ ។

៤៤ ហើយកាលហេណុកបានឃើញការណ៍នេះ នោះគាត់មានសេចក្ដីល្វីងជូរចត់នៅក្នុងព្រលឹង ហើយយំដោយព្រោះបងប្អូនរបស់គាត់ ហើយទូលទៅស្ថានសួគ៌ថា៖ ទូលបង្គំនឹង មិនព្រមល្ហើយចិត្តឡើយ; ប៉ុន្តែព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅហេណុកថា៖ ចូរលើក ចិត្តអ្នកឡើង ហើយរីករាយចុះ; ហើយចូរមើល ។

៤៥ ហើយហេតុការណ៍បានកើតឡើងថា ហេណុកបានមើល; ហើយចាប់តាំងពីណូអេមក នោះគាត់បានឃើញអស់ទាំងគ្រួសារនៅលើ ផែនដី; ហើយគាត់អំពាវនាវទៅព្រះអម្ចាស់ថា៖ តើថ្ងៃនៃព្រះអម្ចាស់នឹងមកនៅពេលណា ? តើលោហិតនៃអ្នកសុចរិតនឹងបានច្រូចនៅ ពេលណា ប្រយោជន៍ឲ្យអស់អ្នកណាដែលទូញសោក អាចបានញែកជាបរិសុទ្ធ ហើយបានជីវិតដ៏នៅអស់កល្បជានិច្ច ?

៤៦ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ គឺនឹងកើតឡើងនៅពេលដ៏ខ្ពង់ខ្ពស់បំផុត គឺនៅថ្ងៃនៃអំពើទុច្ចរិត និងការសងសឹក ។

៤៧ ហើយមើលចុះ ហេណុកបានឃើញថ្ងៃនៃការយាងមករបស់កូនមនុស្ស គឺនៅក្នុងសាច់ឈាម; ហើយព្រលឹងគាត់បានអរសប្បាយ ដោយពោលថា៖ អ្នកសុចរិតត្រូវបានលើកឡើងហើយកូនចៀមត្រូវបានប្រហារ តាំងពីកំណើតលោកិយមកម្ល៉េះ; ហើយតាមរយៈសេចក្ដី ជំនឿ នោះខ្ញុំនៅក្នុងឧរានៃព្រះវរបិតាហើយមើលចុះ ស៊ីយ៉ូននៅជាមួយខ្ញុំ ។

៤៨ ហើយហេតុការណ៍បានកើតឡើងថា ហេណុកបានមើលមកលើផែនដី; ហើយគាត់បានឮសម្លេងចេញពីពោះផែនដីថា៖ វេទនា វេទនាដល់ខ្ញុំ ជាមាតាមនុស្សលោក; ខ្ញុំឈឺចាប់ ខ្ញុំអស់កម្លាំង ពីព្រោះតែអំពើទុច្ចរិតនៃកូនចៅរបស់ខ្ញុំ ។ តើដល់ពេលណាខ្ញុំនឹងបាន សំរាក ហើយបានសំអាតឲ្យជ្រះពីអំពើ ស្មោកគ្រោក ដែលបានចេញពីខ្ញុំទៅ ? តើពេលណាព្រះដ៏បង្កបង្កើតខ្ញុំនឹងមកញែកខ្ញុំចេញ ជាបរិសុទ្ធដើម្បីឲ្យខ្ញុំអាចបានសំរាក ហើយឲ្យសេចក្ដីសុចរិតនៅលើមុខខ្ញុំបានមួយរដូវ ?

៤៩ ហើយកាលហេណុកបានឮផែនដីថ្ងូរ នោះគាត់ក៏យំ ហើយអំពាវនាវទៅព្រះអម្ចាស់ថា៖ ឱព្រះអម្ចាស់អើយ ម្ដេចក៏ទ្រង់មិន មានសេចក្ដីមេត្តាករុណាដល់ផែនដីផង ? តើទ្រង់នឹងមិនប្រទានពរដល់កូនចៅណូអេទេឬអី ?

៥០ ហើយហេតុការណ៍បានកើតឡើងថា ហេណុកនៅតែអំពាវនាវទៅព្រះអម្ចាស់ថា៖ ទូលបង្គំសូមដល់ព្រះអង្គ ឱព្រះអម្ចាស់អើយ ដោយនូវព្រះនាមនៃព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ សូមព្រះអង្គមានសេចក្ដីមេត្តាករុណា ដល់ណូអេ និងពូជគាត់ផង សូមកុំឲ្យផែនដីត្រូវទឹកលិចលើទៀតឡើយ ។

៥១ ហើយព្រះអម្ចាស់ទ្រង់ពុំអាចទប់បានឡើយ; ហើយទ្រង់

---

៣៩ *ខ* ម៉ូសេ ៤:២; អេប្រា. ៣:២៧.
ស.ប. ព្រះយេស៊ូវគ្រីស្ទ.
*គ* ស.ប. សេចក្ដីជាប់ទោស.
៤១ *ក* ម៉ូសាយ ២៨:៣.
ស.ប. អាណិត.
៤២ *ក* ស.ប. ណូអេ,
អយ្យកោក្នុងព្រះគម្ពីរប៊ីប.
*ខ* ម៉ូសេ ៨:១២.
៤៣ *ក* លោកុ. ៦:១៤–១៦; អេធើរ ៦:៧.
៤៤ *ក* ទំនុក. ៧៧:២; អេធើរ ១៥:៣.
៤៥ *ក* ស.ប. ការញែកជាបរិសុទ្ធ.
៤៦ *ក* ម៉ូសេ ៥:៥៧.
៤៧ *ក* ស.ប. កូនចៀមនៃព្រះ.
*ខ* ម៉ូសេ ៧:២១.
៤៨ *ក* ស.ប. ផែនដី —
ការសំអាតផែនដី.
*ខ* ម៉ូសេ ៧:៥៤, ៥៨, ៦៤.
*គ* ស.ប. ស្មោកគ្រោក,
សេចក្ដីស្មោកគ្រោក.

បានធ្វើសេចក្ដីសញ្ញាជាមួយនឹងហេណុក ហើយបានស្បថដល់
គាត់ ដោយពាក្យសំបថមួយថា ទ្រង់នឹងទប់ទឹកជំនន់ទុក; ថាទ្រង់
នឹងមានព្រះបន្ទូលទៅកូនចៅណូអេ;
៥២ ហើយទ្រង់បានចេញបញ្ញត្តិមួយដ៏ឥតប្រែប្រួលបានថា
សំណល់នៃពូជរបស់គាត់នោះនឹងឃើញមាននៅក្នុងអស់ទាំងសាសន៍
កាលណាផែនដីនៅគង់វង់;
៥៣ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ មានពរហើយ
ដល់អ្នកណា ដែលព្រះមែស៊ីនឹងចេញពីពូជគេមក; ត្បិតទ្រង់មាន
ព្រះ បន្ទូលថា — យើងជាព្រះមែស៊ី ជាស្ដេចនៃស៊ីយ៉ូន គឺជា
ថ្មដានៃស្ថានសួគ៌ ដែលធំអង្វែងដូចជាភាពអស់កល្បជានិច្ច;
អស់អ្នកណា ដែល ចូលតាមទ្វារ ហើយលើកដោយសារយើង
នោះនឹងមិនដែលធ្លាក់ឡើយ; ហេតុដូច្នោះហើយ មានពរហើយ
ដល់អស់អ្នកណា ដែល យើងបានពោលដល់ ត្បិតពួកគេនឹងចេញ
មក ដោយចំរៀងនៃសេចក្ដីអំណរដ៏អស់កាលអស់កល្បជានិច្ច ។
៥៤ ហើយហេតុការណ៍បានកើតឡើងថា ហេណុកបាន
អំពាវនាវទៅព្រះអម្ចាស់ថា៖ កាលកូនមនុស្សយាងមកក្នុង
សាច់ឈាម នោះតើផែនដីនឹងបានសំរាកឬ ? ទូលបង្គំសូមដល់
ព្រះអង្គ សូមបង្ហាញការណ៍ទាំងនេះដល់ទូលបង្គំផង ។
៥៥ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅហេណុកថា៖
ចូរមើល ហើយគាត់ក៏មើល ហើយបានឃើញកូនមនុស្សត្រូវ
បានលើក ឡើងលើឈើឆ្កាង តាមរបៀបមនុស្សលោក ។
៥៦ ហើយគាត់បានឮសម្លេងដ៏ខ្លាំង; ហើយស្ថានសួគ៌បិទ
មុខ; ហើយរបស់ទាំងអស់ដែលព្រះទ្រង់បានបង្កើតមកក៏
ទួញសោក; ហើយ ផែនដីថ្ងូរ; ហើយថ្មទាំងប៉ុន្មានក៏បែក;
ហើយពួកបរិសុទ្ធបានក្រោកឡើង ហើយត្រូវបានបំពាក់សិរីល្អ
ជាមកុដ នៅខាងស្ដាំដៃនៃកូន មនុស្ស;
៥៧ ហើយវិញ្ញាណជាច្រើនដែលនៅក្នុងគុកក៏ចេញមកដែរ
ហើយឈរនៅខាងស្ដាំដៃនៃព្រះ; ហើយពួកអ្នកដែលនៅសល់
ទាំងប៉ុន្មាន នោះត្រូវជាប់ច្រវាក់ទាំងឡាយនៃសេចក្ដីងងឹត រហូត
ដល់សេចក្ដីជំនុំជំរះនៅថ្ងៃដ៏ធំនោះ ។
៥៨ ហើយជាថ្មីទៀត ហេណុកបានយំ ហើយអំពាវនាវទៅព្រះ
អម្ចាស់ថា៖ តើដល់ពេលណាទៅផែនដីនឹងបានសំរាក ?
៥៩ ហើយហេណុកបានឃើញកូនមនុស្សយាងឡើងទៅឯព្រះ
វរបិតា; ហើយគាត់បានទូលទៅព្រះអម្ចាស់ថា៖ តើព្រះអង្គនឹងមិន
យាង មកផែនដីទៀតទេឬអី ? ដរាបណាព្រះអង្គទ្រង់ជាព្រះ
ហើយទូលបង្គំស្គាល់ព្រះអង្គ នោះព្រះអង្គបានស្បថនឹងទូលបង្គំ
ហើយបានបញ្ជា ដល់ទូលបង្គំថា ទូលបង្គំត្រូវសូមដោយនូវព្រះនាម
នៃព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់; ព្រះអង្គទ្រង់បានបង្កើត
ទូលបង្គំមក ហើយបាន ប្រទានដល់ទូលបង្គំ ឲ្យមានសិទ្ធិចំពោះ
បល្ល័ង្កទ្រង់ ហើយពុំមែនដោយសារខ្លួនទូលបង្គំទេ ប៉ុន្តែតាមរយៈ
ព្រះគុណរបស់ព្រះអង្គវិញ; ហេតុដូច្នោះហើយ ទូលបង្គំសូម
សួរដល់ព្រះអង្គថា តើទ្រង់នឹងមិនយាងមកផែនដីទៀតទេឬអី ។
៦០ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅហេណុកថា៖
ដរាបណាយើងមានព្រះជន្មរស់នៅ នោះយើងក៏នឹងយាងមក នៅ
គ្រា ចុងក្រោយបង្អស់ គឺនៅថ្ងៃនៃអំពើទុច្ចរិត និងការសងសឹក
ដើម្បីបំពេញសម្បថដែលយើងបានធ្វើដល់អ្នក អំពីកូនចៅណូអេ;
៦១ ហើយថ្ងៃនោះនឹងមកដល់ កាលផែនដីនឹងបានសំរាក
ប៉ុន្តែមុនថ្ងៃនោះមកដល់ នោះផ្ទៃមេឃនឹងទៅជាងងឹត ហើយ
វាំងនននៃសេចក្ដីងងឹតនឹងគ្របដណ្ដប់លើផែនដី; ហើយផ្ទៃមេឃ
នឹងញាប់ញ័រ ហើយព្រមទាំងផែនដីផងដែរ; ហើយនឹងមានសេច
ក្ដីវេទនាដ៏ធំនៅក្នុងចំ ណោមកូនចៅមនុស្ស ប៉ុន្តែរីឯរាស្ត្រ
យើងវិញ នោះយើងនឹងរក្សាទុក;
៦២ ហើយរីឯសេចក្ដីសុចរិត នោះយើងនឹងចាត់ឲ្យចុះមក
ពីស្ថានសួគ៌; ហើយឯសេចក្ដីពិត នោះយើងនឹង

៥១ *ក* ទំនុក. ១០៤:៦–៩.
៥២ *ក* ម៉ូសេ ៨:២.
៥៣ *ក* ស.ប. ព្រះមែស៊ី.
*ខ* ម៉ាថាយ ២:២; ២ នីហ្វៃ ១០:១៤; អាលម៉ា ៥:៥០; គ. និង ស. ១២៨:២២.
*គ* ទំនុក. ៧១:៣; ៧៨:៣៥; ហេលេ. ៥:១២. ស.ប. ថ្ម.
*ឃ* ២ នីហ្វៃ ៣១:១៩–២០.
*ង* ស.ប. ភ្លេង.
៥៥ *ក* ស.ប. កូនមនុស្ស.
*ខ* ៣ នីហ្វៃ ២៧:១៤. ស.ប. ការឆ្កាង.
៥៦ *ក* ម៉ាថាយ ២៧:៤៥, ៥០–៥១.
*ខ* ស.ប. ដំណើររស់ឡើងវិញ.
*គ* ស.ប. មកុដ; ភាពដំកើងឡើង.
*ឃ* ម៉ាថាយ ២៥:៣៤.
៥៧ *ក* ស.ប. វិញ្ញាណ.
*ខ* គ. និង ស. ៧៦:៧១–៧៤; ៨៨:៩៩.
៦០ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
៦១ *ក* ស.ប. ផែនដី — ស្ថានភាពចុងក្រោយបង្អស់នៃផែនដី.
*ខ* គ. និង ស. ៣៨:១១–១២; ១១២:២៣.
*គ* ស.ប. វាំងនន.
*ឃ* ១ នីហ្វៃ ២២:១៥–២២; ២ នីហ្វៃ ៣០:១០.
៦២ *ក* ទំនុក. ៨៥:១១. ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ស.ប. ព្រះគម្ពីរមរមន.

ចាត់ឲ្យចេញពី[គ]ផែនដីទៅ ដើម្បី ទៅ[ឃ]ធ្វើបន្ទាល់ពីព្រះរាជបុត្រា
បង្កើតតែមួយរបស់យើង; [ង]ពីដំណើរដែលទ្រង់រស់ពីស្លាប់
ឡើងវិញ; មែនហើយ គឺពីដំណើររស់ឡើងវិញនៃ មនុស្ស
លោកទាំងអស់; ហើយសេចក្ដីសុចរិត និងសេចក្ដីពិត
នោះយើងនឹងបណ្ដាលឲ្យបោសផែនដី ដូចជាទឹកជំនន់ ដើម្បី
[ច]ប្រមូល ពួកអ្នកជំរើសរបស់យើង ពីទិសទាំងបួននៃផែនដី ឲ្យមក
ឯកន្លែងដែលយើងនឹងរៀបចំទុក គឺជាទីក្រុងបរិសុទ្ធ ប្រយោជន៍ឲ្យ
រាស្ត្រយើង អាចក្រវាត់ចង្កេះគេ ហើយរង់ចាំពេលនៃការយាង
មករបស់យើង; ត្បិតទីក្រុងនោះ នឹងទៅជារោង ឧបោសថ
របស់យើង ហើយនឹងត្រូវ បានហៅថា «ស៊ីយ៉ូន» ជា[ឆ]ក្រុងយេរូ
សាឡិមថ្មី ។
៦៣ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅហេណុកថា៖
ខណ:នោះ អ្នកហើយនិង[ក]ទីក្រុងរបស់អ្នក នឹងទៅជួបពួក
គេនៅទីនោះ ហើយយើងនឹងទទួលយកពួកគេមកឯឱរារបស់យើង
ហើយពួកគេនឹងបានឃើញយើង; ហើយយើងនឹងដួលទៅលើ-
កគេ ហើយពួកគេ នឹងដួលមកលើ-កយើង ហើយយើងនឹងថើប
គ្នាទៅវិញទៅមក;
៦៤ ហើយនោះនឹងទៅជាទីលំនៅរបស់យើង ហើយនឹងត្រូវបាន
ហៅថា «ស៊ីយ៉ូន» ដែលនឹងចេញមកពីការបង្កបង្កើតទាំង
អស់ ដែល យើងបាន[ក]ធ្វើមក; ហើយអស់រយៈពេលមួយពាន់ឆ្នាំ
នោះផែនដីនឹងបាន[ខ]សំរាក ។
៦៥ ហើយហេតុការណ៍បានកើតឡើងថា ហេណុកបានឃើញ
[ក]ថ្ងៃនៃការយាងមករបស់កូនមនុស្ស គឺនៅថ្ងៃចុងក្រោយបង្អស់
ដើម្បីមក គង់នៅលើផែនដី ក្នុងសេចក្ដីសុចរិត អស់រយៈ
ពេល១ពាន់ឆ្នាំ;
៦៦ ប៉ុន្តែមុនថ្ងៃនោះមកដល់ នោះគាត់បានឃើញមានសេច
ក្ដីវេទនាដ៏ធំនៅក្នុងចំណោមពួកទុច្ចរិត; ហើយគាត់ក៏បានឃើញ
សមុទ្រ ហើយសមុទ្រមានចលាចល [ក]ហើយមនុស្សស្រយុតចិត្ត
ដោយសម្លឹងមើលទាំងខ្លាច ចំពោះ [ខ]សេចក្ដីជំនុំជំរះនៃព្រះដ៏មាន
មហិទ្ធិឫទ្ធិ ដែលនឹងមានមកលើពួកទុច្ចរិត ។
៦៧ ហើយព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ហេណុក នូវគ្រប់
ការណ៍ទាំងអស់ សូម្បីតែចុងបំផុតនៃផែនដីផងដែរ; ហើយ
គាត់បានឃើញ ថ្ងៃនៃពួកសុចរិត គឺជាម៉ោងនៃសេច
ក្ដីប្រោសលោះរបស់ពួកគេ ហើយក៏បានទទួលនូវភាពពោរេ
ពញនៃ[ក]សេចក្ដីអំណរ;
៦៨ ហើយអាយុ[ក]ស៊ីយ៉ូនទាំងអស់ គឺជីវិតរបស់ហេណុក នោះ
បាន៣៦៥ឆ្នាំ ។
៦៩ ហើយហេណុក និងប្រជាជនគាត់ [ក]បានដើរជាមួយនឹង
ព្រះ ហើយទ្រង់បានគង់នៅក្នុងកណ្ដាលក្រុងស៊ីយ៉ូន; ហើយ
ហេតុការណ៍បាន កើតឡើងថា ក្រុងស៊ីយ៉ូនមិននៅទៀតទេ
ពីព្រោះព្រះទ្រង់បានទទួលយកទៅឯព្រះឱរារបស់ទ្រង់; ហើយ
ចាប់តាំងពីពេលនោះមក ឮពាក្យពោលថា ក្រុងស៊ីយ៉ូនបាន
ទៅបាត់ហើយ ៕

---

## ជំពូកទី ៨

*(កុម្ភៈ ១៨៣១)*

*មធូសាឡាព្យាករ — ណូអេនិងពួកកូនប្រុសគាត់ផ្សាយដំណឹងល្អ — អំពើទុច្ចរិតដ៏ធំមានជ័យជំនះ — ការហៅឲ្យប្រែចិត្តគ្មាន នរណាស្ដាប់តាម — ព្រះទ្រង់ចេញបញ្ញត្តិឲ្យមានសេចក្ដីបំផ្លិចបំផ្លាញដល់អស់ទាំងសាច់ ដោយសារទឹកជំនន់ ។*

ហើយអាយុហេណុកទាំងអស់បាន៤៣០ឆ្នាំ ។
២ ហើយហេតុការណ៍បានកើតឡើងថា [ក]មធូសាឡា ជា
កូនហេណុក ពុំបានយកទៅទេ ប្រយោជន៍ឲ្យសេចក្ដីសញ្ញាទាំង
ឡាយនៃ ព្រះអម្ចាស់អាចបានសំរេច ដែលទ្រង់បានធ្វើដល់ហេណុក;
ត្បិតទ្រង់ពិតជាបានធ្វើសេចក្ដីសញ្ញាជាមួយហេណុកថា ណូអេ
នឹងត្រូវជាផល ពីពោះគាត់ ។
៣ ហើយហេតុការណ៍បានកើតឡើងថា មធូសាឡាបានព្យាករ
ថា ចេញពីពោះគាត់ នោះនឹងផុសឡើងនូវនគរទាំងអស់នៃផែនដី
(តាម រយៈណូអេ) ហើយគាត់បានយកសិរីល្អដល់ខ្លួន ។
៤ ហើយក៏កើតមានការអំណត់មួយដ៏ធំនៅលើផែនដី

---

៦២ *គ* អេសាយ ២៩:៤.
*ឃ* ស.ប. ទីបន្ទាល់.
*ង* ស.ប. ដំណើររស់ឡើងវិញ.
*ច* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
*ឆ* ស.ប. ក្រុងយេរូសាឡិមថ្មី.
៦៣ *ក* វិវរ. ២១:៩–១១; គ. និង ស. ៤៥:១១–១២; ម៉ូសេ ៧:១៩–២១.
៦៤ *ក* ស.ប. សហស្សវត្សរ៍.
*ខ* ម៉ូសេ ៧:៤៨.
៦៥ *ក* យូដាស ១:១៤. ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៦៦ *ក* អេសាយ ១៣:៦–៧.
*ខ* ស.ប. សេចក្ដីជំនុំជំរះចុងក្រោយបំផុត.
៦៧ *ក* ស.ប. សេចក្ដីអំណរ.
៦៨ *ក* លោកុ. ៥:២៣; ម៉ូសេ ៨:១.
៦៩ *ក* លោកុ. ៥:២៤; ម៉ូសេ ៦:៣៤. ស.ប. ដើរ, ដើរជាមួយព្រះ.
៨ ២ *ក* ស.ប. មធូសាឡា.

ហើយព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដល់ផែនដី ដោយ
ពាក្យបណ្ដាសា ដ៏ធ្ងន់ធ្ងរ ហើយបណ្ដាជនជាច្រើននៅទីនោះ
បានស្លាប់ទៅ ។
៥ ហើយហេតុការណ៍បានកើតឡើងថា មធូសាឡា
អាយុបាន១៨៧ឆ្នាំ ហើយក៏បង្កើតបានឡាមេក;
៦ ហើយក្រោយពីគាត់បង្កើតបានឡាមេកមក នោះមធូសាឡារ
ស់នៅបាន៧៨២ឆ្នាំ ហើយបង្កើតបានកូនប្រុសកូនស្រីទៀត;
៧ ហើយអាយុមធូសាឡាទាំងអស់បាន៩៦៩ឆ្នាំ ហើយ
គាត់ក៏ស្លាប់ទៅ ។
៨ ហើយឡាមេកអាយុបាន១៨២ឆ្នាំ ហើយបង្កើតបាន
កូនប្រុសមួយ,
៩ ហើយគាត់ឲ្យឈ្មោះថា ណូអេ ដោយនិយាយថា៖ កូននេះ
នឹងកំសាន្តចិត្តយើង ក្នុងការដែលយើងធ្វើ ហើយនិងសេច
ក្ដីនឿយហត់ នៃដៃយើង ដោយព្រោះដីដែលព្រះអម្ចាស់ទ្រង់បាន
ដាក់បណ្ដាសា ។
១០ ហើយក្រោយពីគាត់បង្កើតបានណូអេមក នោះឡាមេក
រស់នៅបាន៥៩៥ឆ្នាំ ហើយបង្កើតបានកូនប្រុសកូនស្រីទៀត;
១១ ហើយអាយុឡាមេកទាំងអស់បាន៧៧៧ឆ្នាំ ហើយ
គាត់ក៏ស្លាប់ទៅ ។
១២ ហើយណូអេអាយុបាន៤៥០ឆ្នាំ ហើយក៏បង្កើតបានយ៉ាផែត;
ហើយ៤២ឆ្នាំក្រោយមក នោះគាត់បង្កើតបានសិម ពីនាងដែល
ជា ម្ដាយរបស់យ៉ាផែត ហើយកាលគាត់អាយុបាន៥០០ឆ្នាំ
នោះគាត់បង្កើតបានហាំ ។
១៣ ហើយណូអេ និងពួកកូនប្រុសគាត់បានប្រុងស្ដាប់តាមព្រះ
អម្ចាស់ ហើយបានឮ ហើយពួកគេត្រូវបានហៅថាជា ពួកកូនប្រុស
នៃព្រះ ។
១៤ ហើយកាលពួកបុរសទាំងនេះបានចាប់ផ្ដើមបង្កើតកូ
នជាច្រើននៅលើផ្ទៃផែនដី ហើយកូនស្រីៗបានកើតមក នោះពួក
កូនប្រុស នៃមនុស្សបានឃើញពួកកូនស្រីទាំងនោះថាជាស្រស់ល្អ
ហើយពួកគេក៏យកពួកកូនស្រីធ្វើជាប្រពន្ធ តាមតែចិត្តគេរើស ។
១៥ ហើយព្រះអម្ចាស់បានមានព្រះបន្ទូលទៅណូអេថា៖ ពួក
កូនស្រីនៃកូនប្រុសៗរបស់អ្នកបានលក់ខ្លួនហើយ; ត្បិតមើលចុះ
សេចក្ដី ខ្ញាល់របស់យើងឆួលឡើងទាស់នឹងពួកកូនប្រុសនៃមនុស្ស
ព្រោះពួកគេមិនព្រមស្ដាប់តាមសម្លេងរបស់យើងឡើយ ។
១៦ ហើយហេតុការណ៍បានកើតឡើងថា ណូអេបានព្យាករ
ហើយបានបង្រៀនពីការណ៍ទាំងឡាយនៃព្រះ គឺដូចជាបានធ្វើមក
តាំងពីដើម ដំបូងម្លេះ ។
១៧ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅណូអេថា៖ ព្រះ
វិញ្ញាណយើងនឹងពុំតស៊ូគង់នៅជាមួយនឹងមនុស្សជានិច្ចទេ ត្បិតគេ
នឹង ដឹងថាសាច់ឈាមទាំងអស់នឹងត្រូវស្លាប់; ប៉ុន្តែអាយុគេនឹង
បានត្រឹមតែ១២០ឆ្នាំ; ហើយបើសិនជាមនុស្សលោកមិនប្រែចិត្តទេ
នោះយើង នឹងចាត់ឲ្យទឹកជន់មកលើពួកគេ ។
១៨ ហើយនៅជំនាន់នោះ មានមនុស្សរូបធំសំបើមនៅលើផែនដី
ហើយពួកគេបានព្យាយាមតាមយកជីវិតណូអេ ដើម្បីផ្ដាច់ចោល;
ប៉ុន្តែព្រះអម្ចាស់ទ្រង់បានគង់នៅជាមួយនឹងណូអេ ហើយព្រះ
ចេស្ដានៃព្រះអម្ចាស់បានស្ថិតនៅលើគាត់ ។
១៩ ហើយព្រះអម្ចាស់ទ្រង់បានតែងតាំងណូអេ តាមរបៀបរបស់
ទ្រង់ ហើយបានបញ្ជាគាត់ថា គាត់ត្រូវចេញទៅ ហើយប្រកាស
ប្រាប់ ពី ដំណឹងល្អរបស់ទ្រង់ ដល់កូនចៅមនុស្ស គឺដូចដែលបាន
ប្រទានដល់ហេណុកនោះ ។
២០ ហើយហេតុការណ៍បានកើតឡើងថា ណូអេបានហៅ
ដល់កូនចៅមនុស្សថា ពួកគេត្រូវតែប្រែចិត្ត; ប៉ុន្តែពួកគេមិនព្រម
ស្ដាប់តាម ពាក្យសំដីគាត់ឡើយ;
២១ ហើយបន្ទាប់ពីពួកគេបានឮគាត់ នោះពួកគេក៏ឡើងមក
ចំពោះគាត់ ដោយនិយាយថា៖ មើលចុះ ពួកយើងជាកូនប្រុស
នៃព្រះ; តើពួកយើងពុំបានយកកូនស្រីមនុស្សធ្វើជាប្រពន្ធទេឬអី ?

---

៩ *ក* ស.ប. ណូអេ,
អយ្យកោក្នុងព្រះគម្ពីរប៊ីប.
*ខ* ម៉ូសេ ៤:២៣.
១២ *ក* លោកុ. ៥:៣២.
ស.ប. យ៉ាផែត.
*ខ* ស.ប. សិម.
*គ* ស.ប. ហាំ.
១៣ *ក* គ. និង ស. ១៣៨:៤១.
ស.ប. កាព្រីយ៉ែល.
*ខ* ស.ប. ការគោរព, ដែលគោរព,
គោរព.
*គ* ស.ប. បុត្រាបុត្រីនៃព្រះ.
១៤ *ក* ម៉ូសេ ៥:៥២.
១៥ *ក* ស.ប. អាពាហ៍ពិពាហ៍,
រៀបអាពាហ៍ពិពាហ៍ — អាពាហ៍
ពិពាហ៍រវាងសេចក្ដីជំនឿ.
១៧ *ក* លោកុ. ៦:៣; ២ នីហ្វៃ ២៦:១១;
អេធើរ ២:១៥;
គ. និង ស. ១:៣៣.
*ខ* ២ នីហ្វៃ ៩:៤.
ស.ប. សាច់.
*គ* លោកុ. ៧:៤, ១០; ម៉ូសេ ៧:៣៤.
១៨ *ក* លោកុ. ៦:៤; ជនគ. ១៣:៣៣;
យ៉ូស្វេ ១៧:១៥.
*ខ* ស.ប. អំណាច.
១៩ *ក* គ. និង ស. ១០៧:៥២.
ស.ប. តែងតាំង, ការតែងតាំង.
*ខ* អ័ប្រា. ១:១៩.
*គ* ស.ប. បព្វជិតភាពមិលគីស្សាដែក.
*ឃ* ស.ប. កិច្ចការផ្សាយសាសនា.
២០ *ក* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.

ហើយតើពួកយើងពុំបានស៊ីផឹក ហើយរៀបការយកគ្នាទេឬអី ?
ហើយប្រពន្ធ យើងបានបង្កើតកូនឲ្យយើង ហើយពួកគេ
ទាំងនោះសុទ្ធតែជាមនុស្សខ្លាំងពូកែ ដែលដូចជាមនុស្សពីបុរាណ
ជាមនុស្សមានល្បីឈ្មោះដ៏ ធំ ។ ហើយពួកគេពុំបានស្ដាប់តាម
ពាក្យសំដីរបស់ណូអេឡើយ ។
២២ ហើយព្រះទ្រង់បានទតឃើញថា អំពើទុច្ចរិតនៃមនុស្សបាន
ក្លាយទៅកាន់តែធំឡើងនៅលើផែនដី; ហើយមនុស្សគ្រប់រូបបាន
ដំកើង ក្នុងគំនិតដែលមាននៅក្នុងចិត្តរបស់ពួកគេ ដែលសុទ្ធតែ
អាក្រក់ជានិច្ច ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ណូអេចេះតែផ្សាយ
ប្រាប់មនុស្សតទៅថា៖ ចូរប្រុងស្ដាប់ ហើយឮពាក្យសំដីខ្ញុំចុះ;
២៤ ចូរជឿ ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក ហើយ
ទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ជា
ព្រះរាជបុត្រានៃព្រះ គឺដូចជាពួកអយ្យកោរបស់យើងចុះ ហើយ
អ្នករាល់គ្នានឹងបានទទួលព្រះវិញ្ញាណបរិសុទ្ធ ប្រយោជន៍ឲ្យអ្នករាល់
គ្នា អាចបានគ្រប់ការណ៍ទាំងអស់ ដែលបានសំម្ដែងមក; ហើយបើ
សិនជាអ្នករាល់គ្នាមិនធ្វើដូច្នេះទេ នោះទឹកជន់នឹងមកលើអ្នក; ទោះ
ជា យ៉ាងណាក៏ដោយ ក៏ពួកគេមិនព្រមស្ដាប់តាមដែរ ។
២៥ ហើយណូអេស្ដាយ ហើយចិត្តគាត់ឈឺចាប់ ដែលព្រះ
អម្ចាស់បានធ្វើមនុស្សនៅលើផែនដី ហើយចិត្តគាត់សោកសៅជា
ខ្លាំង ។
២៦ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ យើងនឹង
បំផ្លាញមនុស្សដែលយើងបានបង្កើតមក ឲ្យបាត់សូន្យចេញពីផែនដី
ទាំងមនុស្ស ទាំងសត្វជើងបួន និងទាំងសត្វលូនវារ និងទាំងសត្វ
ហើរលើអាកាសផង; ត្បិតណូអេស្ដាយចិត្ត ដែលយើងបានបង្កើត
របស់ ទាំងនោះ ហើយដែលយើងបានធ្វើរបស់ទាំងនោះមក;
ហើយគាត់បានទូលដល់យើង; ត្បិតពួកគេបានព្យាយាមតាមយក
ជីវិតគាត់ ។
២៧ ហើយណូអេបានប្រកបដោយគុណ ចំពោះព្រះនេត្រនៃ
ព្រះអម្ចាស់យ៉ាងដូច្នោះហើយ; ព្រោះណូអេជាមនុស្សសុចរិត
ហើយ ល្អឥត ខ្ចោះម្នាក់ នៅក្នុងតំណវង្សគាត់; ហើយគាត់បាន
ដើរជាមួយនឹងព្រះ ដូចជាកូនប្រុសគាត់បីនាក់ដែរ គឺសិម ហាំ
និងយ៉ាផែត ។
២៨ ហើយផែនដីបានពុករលួយនៅចំពោះព្រះ ហើយបាន
ពោរពេញទៅដោយសេចក្ដីកាចសហ័ស ។
២៩ ហើយព្រះទ្រង់បានទតមកលើផែនដី ហើយមើលចុះ ផែនដី
បានពុករលួយ ត្បិតគ្រប់ទាំងសាច់បានបង្ខូចផ្លូវរបស់ខ្លួននៅលើផែនដី
ទៅហើយ ។
៣០ ហើយព្រះទ្រង់បានមានព្រះបន្ទូលទៅណូអេថា៖ អស់
ទាំងសាច់ត្រូវផុតពីមុខយើងទៅ ត្បិតផែនដីបានពោរពេញទៅដោយ
សេចក្ដី កាចសហ័ស ហើយមើលចុះ យើងនឹងបំផ្លាញគ្រប់
ទាំងសាច់ឲ្យបាត់សូន្យចេញពីផែនដី ៕: ៚

២១ *ក* ម៉ាថាយ ២៤:៣៨–៣៩;
យ.ស. — ម៉ាថាយ ១:៤១.
២២ *ក* លោកុ. ៦:៥; ម៉ូសេ ៧:៣៦–៣៧.
*ខ* ម៉ូសាយ ៤:៣០;
អាលម៉ា ១២:១៤.
ស.ប. គំនិត.
២៣ *ក* ស.ប. ផ្សាយ.
២៤ *ក* ស.ប. ជំនឿ, ជឿ.
*ខ* ស.ប. បុណ្យជ្រមុជទឹក,
ធ្វើបុណ្យជ្រមុជទឹក —
ការតម្រូវការទាំងឡាយសំរា
ប់បុណ្យជ្រមុជទឹក.
*គ* ២ នីហ្វៃ ៣២:២–៥.
២៦ *ក* ស.ប. ផែនដី —
ការសំអាតផែនដី.
២៧ *ក* ស.ប. ព្រះគុណ.
*ខ* លោកុ. ៦:៩.
*គ* ស.ប. ដើរ, ដើរជាមួយព្រះ.
២៨ *ក* លោកុ. ៦:១១–១៣.
៣០ *ក* គ. និង ស. ៥៦:៣.

# គម្ពីរអ័ប្រាហាំ

បានបកប្រែចេញពីឯកសារប្របុស ដោយយ៉ូសែប ស្ម៊ីធ

*ជាការបកប្រែពីបញ្ជីបុរាណមួយ ដែលបានធ្លាក់មកក្នុងកណ្ដាប់ដៃរបស់យើង ចេញពីផ្នូរក្រោមដីនៅស្រុកអេស៊ីព្ទ ។ ជាការនិពន្ធរបស់អ័ប្រាហាំ កាលលោកនៅស្រុកអេស៊ីព្ទ ហៅថាគម្ពីរអ័ប្រាហាំ គឺបានសរសេរដោយដៃរបស់លោកផ្ទាល់ នៅលើក្រាំងប្របុស ។ (History of the Church, ២:២៣៥–២៣៦, ៣៤៨–៣៥១) ។*

## ជំពូកទី ១

*លោកអ័ប្រាហាំស្វែងរកព្រះពរទាំងឡាយខាងរបៀបអយ្យកោ — លោកត្រូវពួកសង្ឃក្លែងក្លាយនៅស្រុកខាល់ដេបៀតបៀន — ព្រះយេហូវ៉ាជួយសង្គ្រោះលោក — ដើមកំណើត និងរដ្ឋាភិបាលនៅស្រុកអេស៊ីព្ទត្រូវបានរៀបរាប់សារឡើងវិញ ។*

នៅក្នុងដែនដីនៃពួកសាសន៍ខាល់ដេ គឺនៅឯទីលំនៅនៃពួកអយ្យកោរបស់ខ្ញុំ នោះខ្ញុំ អ័ប្រាហាំ បានឃើញថាជាការចាំបាច់ឲ្យខ្ញុំរកទីលំនៅផ្សេងទៀត;

២ ហើយដោយឃើញថាមានសុភមង្គល និងសេចក្ដីសុខសាន្ត និងសេចក្ដីសំរាកដ៏ធំជាងចំពោះខ្ញុំ ទើបខ្ញុំស្វែងរកព្រះពរទាំងឡាយ ខាងពួកអយ្យកោ និងសិទ្ធិដែលគួរឲ្យខ្ញុំបានតែងតាំងឡើង ដើម្បីចាត់ចែងពរនោះ; ដោយខ្លួនខ្ញុំធ្លាប់ធ្វើជាអ្នកដើរតាមសេចក្ដីសុចរិត ដោយ ព្រមទាំងមានប្រាថ្នាចង់ធ្វើជាអ្នកដែលមានចំណេះដ៏ធំ ហើយចង់ធ្វើជាអ្នកដើរតាមសេចក្ដីសុចរិតកាន់តែខ្លាំងឡើង ហើយចង់ បានចំណេះដ៏ធំឡើងទៅទៀត ហើយចង់ធ្វើជាឪពុកលើសាសន៍ជាច្រើន ជាម្ចាស់នៃសេចក្ដីសុខសាន្ត ហើយមានប្រាថ្នាចង់ទទួលការ បង្គាប់ទាំងឡាយ ហើយចង់កាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះទើបខ្ញុំបានក្លាយទៅជាអ្នកគ្រងមរតកដ៏ត្រឹមត្រូវ គឺជាសង្ឃ ជាន់ខ្ពស់ ដោយកាន់នូវសិទ្ធិដែលជារបស់ផងពួកអយ្យកោ ។

៣ សិទ្ធិនោះត្រូវបានប្រគល់មកលើខ្ញុំ ពីពួកអយ្យកោ; សិទ្ធិនោះបានចុះមកពីពួកអយ្យកោ គឺចាប់តាំងពីដើមដំបូងនៃពេលវេលាមែនហើយ គឺចាប់តាំងពីដើមដំបូងមក ឬមុនកំណើតផែនដី ចុះមកដល់ពេលបច្ចុប្បន្ននេះ គឺជាសិទ្ធិនៃកូនច្បង ឬមនុស្សទីមួយដែលជា អ័ដាម ឬឪពុកទីមួយ គឺតាមរយៈពួកអយ្យកោរហូតមកដល់ខ្ញុំ ។

៤ ខ្ញុំបានស្វែងរកការតែងតាំងរបស់ខ្ញុំចំពោះបព្វជិតភាពស្របតាមការតែងតាំងនៃព្រះ ចំពោះពួកអយ្យកោ ដែលទាក់ទងទៅនឹងពូជ ។

៥ ដោយពួកអយ្យកោរបស់ខ្ញុំបានបែរចេញពីសេចក្ដីសុចរិតរបស់ពួកគេ ហើយចេញពីព្រះបញ្ញត្តិដ៏បរិសុទ្ធទាំងឡាយ ដែលព្រះអម្ចាស់ ដ៏ជាព្រះរបស់ពួកគេបានប្រទានដល់ពួកគេ ចំពោះការថ្វាយបង្គំដល់ព្រះទាំងឡាយ នៃពួកអ្នកឥតសាសនា គឺមិនព្រមស្ដាប់តាមសម្លេង របស់ខ្ញុំសោះឡើយ;

៦ ត្បិតចិត្តរបស់ពួកគេបានតាំងធ្វើអំពើអាក្រក់ ហើយបានបែរចេញទាំងស្រុងទៅរកព្រះនៃអេលកេណា និងព្រះនៃលិបណា និងព្រះនៃ ម៉ាម៉ាក់រ៉ា និងព្រះនៃកូរ៉ាស និងព្រះនៃផារ៉ោន ជាស្ដេចនៃស្រុកអេស៊ីព្ទ;

៧ ហេតុដូច្នេះហើយ បានជាពួកគេបែរចិត្តគេទៅឯយញ្ញបូជានៃពួកអ្នកឥតសាសនា ក្នុងការយកកូនចៅគេបូជាថ្វាយដល់រូបព្រះគទាំង ឡាយ ហើយមិនព្រមស្ដាប់តាមសម្លេងរបស់ខ្ញុំឡើយ ប៉ុន្តែខំព្យាយាមផ្ដាច់ជីវិតខ្ញុំ ដោយដៃសង្ឃនៃអេលកេណាវិញ ។ សង្ឃនៃ អេលកេណា ក៏ជាសង្ឃនៃផារ៉ោនដែរ ។

៨ ឥឡូវ នៅពេលនេះគឺជាទំនៀមទំលាប់របស់សង្ឃនៃផារ៉ោនគឺជាស្ដេចនៃស្រុកអេស៊ីព្ទ ដើម្បីយកពួកមនុស្សប្រុស ពួកមនុស្សស្រីនិងកូនក្មេងទៅបូជានៅលើអាសនា ដែលបានសង់ឡើងនៅដែនដីខាល់ដេ ទុកជាដង្វាយថ្វាយដល់ព្រះចំឡែកៗទាំងនេះ ។

១ ១*ក* ស.ប. អេីរ.
*ខ* ស.ប. អ័ប្រាហាំ.
*គ* កិច្ចការ ៧:២–៤.
២ *ក* ស.ប. សេចក្ដីអំណរ.
*ខ* ស.ប. សេចក្ដីសំរាក.
*គ* ស.ប. សុចរិត, សេចក្ដីសុចរិត.
*ឃ* គ. និង ស. ៤២:៦១.
ស.ប. ដំរិះ.
*ង* ស.ប. សង្ឃជាន់ខ្ពស់.
*ច* ស.ប. បព្វជិតភាពមិលគីស្សាដែក.
៣ *ក* គ. និង ស. ៨៤:១៤.
*ខ* គ. និង ស. ៦៨:១៧.
ស.ប. កូនច្បង.
*គ* ម៉ូសេ ១:៣៤.
ស.ប. អ័ដាម.
៤ *ក* ស.ប. សិទ្ធិកូនច្បង.
៥ *ក* លោកុ. ១២:១.
*ខ* ស.ប. ការថ្វាយបង្គំរូបព្រះ.
៦ *ក* ក.ន. ព្រះក្លែងក្លាយទាំងឡាយ ដែលបានគូសប្រាប់នៅក្នុងវត្ថុចម្លង តាមលេខ ១ នៅក្នុងគម្ពីរអ័ប្រាហាំ.

# វត្ថុចម្លងតាមចេញពីគម្ពីរអ័ប្រាហាំ

លេខ ១




## ការពន្យល់

រូបទី ១ : ទេវតានៃព្រះអម្ចាស់

រូបទី ២ : អ័ប្រាហាំជាប់ចំណងនៅលើអាសនា

រូបទី ៣ : សង្ឃនៃអែលកេណាដែលថ្វាយបង្គំរូបព្រះ ខំយកអ័ប្រាហាំធ្វើជាយញ្ញបូជា

រូបទី ៤ : អាសនាសំរាប់ធ្វើយញ្ញបូជា ដោយពួកសង្ឃដែលថ្វាយបង្គំរូបព្រះ ឈរពីមុខព្រះទាំងឡាយនៃអែលកេណា, លិបណា, ម៉ាម៉ាក់រ៉ា, កូរ៉ាស, និងផារ៉ោន ។

រូបទី ៥ : រូបចម្លាក់ព្រះនៃអែលកេណា

រូបទី ៦ : រូបចម្លាក់ព្រះនៃលិបណា

រូបទី ៧ : រូបចម្លាក់ព្រះនៃម៉ាម៉ាក់រ៉ា

រូបទី ៨ : រូបចម្លាក់ព្រះនៃកូរ៉ាស

រូបទី ៩ : រូបចម្លាក់ព្រះនៃផារ៉ោន

រូបទី ១០ : លោកអ័ប្រាហាំនៅស្រុកអេស៊ីព្ទ

រូបទី ១១ : គូសជាតំណាងសសរនៃផ្ទៃមេឃ ដូចដែលបានយល់ដោយពួកសាសន៍អេស៊ីព្ទ

រូបទី ១២ : រ៉ារគីយ៉ាង មានន័យថា ប្រឡោះ ឬផ្ទៃមេឃខាងលើក្បាលយើង; ប៉ុន្តែក្នុងករណីនេះ ដែលទាក់ទងទៅនឹងកម្មវត្ថុនេះ នោះពួកសាសន៍អេស៊ីព្ទឲ្យន័យថា សារម៉ាវ ជាទីខ្ពស់ ឬផ្ទៃមេឃ ដែលមានន័យដូចគ្នានឹងពាក្យហេព្រើរថា សារម៉ាយីម ។

៩ ហើយហេតុការណ៍បានកើតឡើងថា សង្ឃបានថ្វាយដង្វាយដល់ព្រះនៃផារ៉ោន និងព្រមទាំងដល់ព្រះនៃសាក្រេអែល គឺស្រប តាម របៀបនៃពួកសាសន៍អេស៊ីព្ទ ។ ឥឡូវនេះ ព្រះនៃសាក្រេអែល គឺជាព្រះអាទិត្យ ។

១០ គឺជាអំណរគុណជាកូនក្មេង ដែលសង្ឃនៃផារ៉ោនបានបូជាលើអាសនា ដែលឈរនៅក្បែរភ្នំមួយហៅថា ភ្នំប៉ូទីផារ ដែលនៅ ទួលវាលអូលីសេម ។

១១ ឥឡូវនេះ សង្ឃនេះបានបូជាលើអាសនានេះ នូវស្រីព្រហ្មចារីបីនាក់ នៅគ្រាមួយនោះ ពួកគេជាកូនស្រីរបស់អូណៃតា ដែលជា វង្សាពិតពីពោះនៃហាំ ។ ពួកស្រីព្រហ្មចារីទាំងនេះត្រូវបានបូជាថ្វាយ ដោយព្រោះតែគុណធម៌របស់ពួកគេ; ពួកគេមិនព្រមក្រាបថ្វាយ បង្គំព្រះធ្វើពីឈើ ឬធ្វើពីថ្មទាំងឡាយនោះទេ ហេតុដូច្នេះហើយ បានជាពួកគេត្រូវយកមកសម្លាប់នៅលើអាសនានេះ ហើយត្រូវបានធ្វើ តាមរបៀបពួកសាសន៍អេស៊ីព្ទ ។

១២ ហើយហេតុការណ៍បានកើតឡើងថា ពួកសង្ឃបានចាប់ខ្ញុំយ៉ាងរឹងតឹង ដើម្បីពួកគេអាចប្រហារខ្ញុំ ដូចជាគេបានធ្វើដល់ពួកស្រី ព្រហ្មចារីនៅលើអាសនានេះដែរ; ហើយដើម្បីឲ្យអ្នកអាចដឹងអំពីអាសនានេះ នោះខ្ញុំនឹងអធិប្បាយប្រាប់អ្នក អំពីរូបគំនូរដែលនៅ ដើមបញ្ជីនេះ ។

១៣ អាសនានោះត្រូវបានធ្វើឡើងដូចជារូបគ្រែ ដែលដូចជាមាននៅក្នុងចំណោមពួកខាល់ដេ ហើយអាសនានោះឈរនៅខាងមុខ ព្រះទាំងឡាយនៃអែលកេណា លិបណា ម៉ាម៉ាក់រ៉ាកូរ៉ាស និងព្រមទាំងព្រះមួយអង្គ ដែលមានរូបរាងដូចជាផារ៉ោនជាស្ដេចនៃស្រុក អេស៊ីព្ទ ។

១៤ ដើម្បីឲ្យអ្នកអាចយល់អំពីព្រះទាំងឡាយនេះ នោះខ្ញុំបានគូសគំនូរប្រាប់នៅដើមបញ្ជី គឺរូបបែបនេះហៅដោយពួកខាល់ដេថា រ៉ាលីណូស ដែលបញ្ជាក់ថាជាវត្ថុលេខនា ។

១៥ ហើយនៅពេលណាពួកគេលើកដៃមកលើខ្ញុំ ដើម្បីគេអាចបូជាខ្ញុំ ហើយផ្ដាច់ជីវិតខ្ញុំ មើលចុះ ខ្ញុំបានបន្លឺសម្លេងខ្ញុំឡើងដល់ព្រះអម្ចាស់ ដ៏ជាព្រះរបស់ខ្ញុំ ហើយព្រះអម្ចាស់បានស្ដាប់ ហើយឮ ហើយទ្រង់បានបំពេញទៅដោយការនិមិត្តអំពីព្រះដ៏មានមហិទ្ធិឫទ្ធិ ហើយទេវតា មួយរូបមកពីវត្តមានរបស់ទ្រង់បានឈរនៅក្បែរខ្ញុំ ហើយបានស្រាយដៃខ្ញុំភ្លាម;

១៦ ហើយសម្លេងលោកបានបន្លឺមកខ្ញុំថា៖ អ័ប្រាហាំ អ័ប្រាហាំ អើយ មើលចុះ ឈ្មោះយើងគឺជាព្រះយេហូវ៉ា ហើយយើងបានឮអ្នក ហើយ ហើយបានចុះមកដោះលែងអ្នក ហើយនាំអ្នកចេញទៅឆ្ងាយពីផ្ទះឪពុកអ្នក ហើយចេញពីញាតិសន្ដានអ្នកទៅនៅឯដែនដី ចំឡែកមួយ ដែលអ្នកមិនដែលស្គាល់;

១៧ ហើយការណ៍នេះក៏ដោយព្រោះពួកគេបានបែរចិត្តគេចេញពីយើង ទៅថ្វាយបង្គំដល់ព្រះនៃអែលកេណា និងព្រះនៃលិបណា និងព្រះនៃម៉ាម៉ាក់រ៉ា និងព្រះនៃកូរ៉ាស និងព្រះនៃផារ៉ោនជាស្ដេចនៃស្រុកអេស៊ីព្ទ; ហេតុដូច្នេះហើយ បានជាយើងចុះមកពិនិត្យពិច័យពួក គេ ហើយមកបំផ្លាញអ្នកណាដែលបានលើកដៃទាស់នឹងអ្នក គឺអ័ប្រាហាំ ជាបុត្ររបស់យើង ដើម្បីនឹងផ្ដាច់ជីវិតអ្នកបង់ ។

១៨ មើលចុះ យើងនឹងដឹកអ្នកដោយដៃយើង ហើយយើងនឹងយកអ្នកទៅ ដើម្បីដាក់ព្រះនាមយើងមកលើអ្នក គឺជាបព្វជិតភាពនៃឪពុក របស់អ្នក ហើយព្រះចេស្ដារបស់យើងនឹងស្ថិតនៅលើអ្នក ។

១៩ ដូចជាមួយណូអេយ៉ាងណា នោះក៏នឹងនៅជាមួយអ្នកយ៉ាងនោះដែរ; ប៉ុន្តែតាមរយៈការងារបំរើរបស់អ្នក នោះព្រះនាមរបស់ យើងនឹងបានស្គាល់នៅលើផែនដីជារៀងដរាបតទៅ ត្បិតយើងជាព្រះរបស់អ្នក ។

២០ មើលចុះ ភ្នំប៉ូទីផារ នៅក្នុងដែនដីអ៊ើរ នៃស្រុកខាល់ដេ ។ ហើយព្រះអម្ចាស់ទ្រង់បានបំបាក់អាសនានៃអែលកេណា និងអាសនានៃ ព្រះទាំងឡាយនៃដែនដី ហើយបានបំផ្លាញគេចោលអស់រលីង ហើយបានវាយសង្ឃ នោះគាត់ក៏ស្លាប់ទៅ; ហើយមានការទួញសោកជា ខ្លាំងនៅស្រុកខាល់ដេ ហើយព្រមទាំងនៅក្នុងវាំងនៃផារ៉ោនដែរ; ឈ្មោះថាផារ៉ោន បញ្ជាក់ថាជាស្ដេចដោយលោហិតក្សត្រ ។

២១ ឥឡូវ ស្ដេចនៃស្រុកអេស៊ីព្ទនេះ ត្រូវជាវង្សាពីពោះនៃហាំ ហើយជាពូជពីឈាមនៃពួកកាណានដោយកំណើត ។

២២ ចេញពីពូជនេះមកផុសឡើងនូវពួកសាសន៍អេស៊ីព្ទទាំងអស់ ហើយឈាមនៃពួកកាណានត្រូវបានរក្សាទុកនៅដែនដីយ៉ាង ដូច្នេះហើយ ។

២៣ ដែនដីអេស៊ីព្ទត្រូវបានរកឃើញដោយស្ត្រីម្នាក់ ដែលជាកូនស្រីនៃហាំ ហើយជាកូនស្រីនៃអេស៊ីព្ទុស ដែលនៅក្នុងភាសា

១១ *ក* ស.ប. ហាំ.
*ខ* ដានី. ៣:១៣–១៨.
១៥ *ក* ម៉ូសាយ ៩:១៧–១៨.
*ខ* អ័ប្រា. ២:១៣.
១៦ *ក* ស.ប. ព្រះយេហូវ៉ា.
*ខ* ស.ប. ដែនដីសន្យា.
១៨ *ក* ស.ប. បព្វជិតភាព.
១៩ *ក* លោកុ. ១២:១–៣.
២០ *ក* លោកុ. ១១:២៨; អ័ប្រា. ២:៤.
២១ *ក* លោកុ. ១០:៦; ទំនុក. ៧៨:៥១; ម៉ូសេ ៨:១២.
*ខ* ម៉ូសេ ៧:៦–៨. ស.ប. កាណាន, សាសន៍កាណាន.
២៣ *ក* ស.ប. អេស៊ីព្ទ.

ខាល់ដេ បញ្ជាក់ថាជាអេស៊ីព្ទ ដែលបញ្ជាក់ពីអ្វីដែលត្រូវបានហាមឃាត់;

២៤ កាលស្ត្រីនេះបានរកឃើញដែនដី ដែនដីនោះនៅក្រោមទឹកក្រោយមក នាងបានដាក់ពួកកូនប្រុសនាងឲ្យនៅទីនោះ; ហើយដូច្នេះ ចេញពីហាំមក ទើបមានពូជនោះដែលរក្សាបណ្ដាសាទុកនៅលើដែនដី ។

២៥ ឥឡូវនេះ រដ្ឋាភិបាលទីមួយនៃស្រុកអេស៊ីព្ទត្រូវបានតាំងឡើងដោយផារ៉ោន ជាកូនច្បងនៃនាងអេស៊ីពុស ដែលជាកូនស្រីរបស់ហាំ ហើយជារដ្ឋាភិបាលតាមរបៀបរដ្ឋាភិបាលរបស់ហាំ ដែលរាប់តាមអយ្យកោ ។

២៦ ផារ៉ោនជាមនុស្សសុចរិតម្នាក់ បានតាំងនគរទ្រង់ឡើង ហើយបានវិនិច្ឆ័យរាស្ត្រទ្រង់ដោយប្រាជ្ញាវាងវៃ និងដោយយុត្តិធម៌អស់មួយ ជីវិតទ្រង់ ដោយខំព្យាយាមធ្វើតាមរបៀបដែលបានតាំងឡើងដោយពួកអយ្យកោ នៅតំណទីមួយ នៅថ្ងៃនៃរជ្ជកាលរបស់អយ្យកោ ទីមួយ គឺនៅក្នុងរជ្ជកាលនៃអ័ដាម និងនៅក្នុងរជ្ជកាលនៃណូអេ ជាឪពុកទ្រង់ផង ដែលបានប្រទានពរដល់ទ្រង់ នូវព្រះពរទាំងឡាយ នៃផែនដី និងព្រះពរទាំងឡាយខាងប្រាជ្ញា ប៉ុន្តែបានដាក់បណ្ដាសាដល់ទ្រង់ ដែលទាក់ទងទៅខាងបព្វជិតភាពវិញ ។

២៧ ឥឡូវនេះ ដោយព្រោះផារ៉ោនជាពូជពង្សដែលទ្រង់ពុំអាចមានសិទ្ធិចំពោះបព្វជិតភាព ទោះជាយ៉ាងណាក៏ដោយ គង់តែផារ៉ោន អាចទាមទារពីលោកណូអេ តាមរយៈហាំ ហេតុដូច្នេះហើយ បានជាឪពុកខ្ញុំត្រូវបានទាញចេញ ដោយសារការថ្វាយរូបព្រះរបស់ពួកគេ;

២៨ ប៉ុន្តែខ្ញុំនឹងខំព្យាយាមចាប់តាំងពីពេលនេះទៅ ដើម្បីអធិប្បាយប្រាប់ពីតំណចាប់ពីខ្ញុំរៀងទៅដល់ដើមការបង្កបង្កើតវិញ ត្បិតបញ្ជី ទាំងឡាយត្រូវបានធ្លាក់មកក្នុងកណ្ដាប់ដៃខ្ញុំ ដែលខ្ញុំកាន់រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

២៩ ឥឡូវនេះ បន្ទាប់ពីសង្ឃនៃអេលកេណាត្រូវបានវាយ ហើយគាត់ក៏ស្លាប់ទៅ នោះមានការសំរេចនូវការណ៍ទាំងនោះ ដែលបាន ប្រាប់ដល់ខ្ញុំ អំពីដែនដីខាល់ដេ ថានឹងមានអំណត់អត់នៅលើដែនដី ។

៣០ ម្ល៉ោះហើយ អំណត់អត់ក៏មានពាសពេញលើដែនដីខាល់ដេទាំងអស់ ហើយឪពុកខ្ញុំបានរងទុក្ខវេទនាជាខ្លាំង ដោយព្រោះតែ អំណត់អត់នោះ ហើយគាត់បានប្រែចិត្តពីការអាក្រក់ដែលគាត់បានសំរេចនឹងធ្វើទាស់នឹងខ្ញុំ គឺផ្ដាច់ជីវិតខ្ញុំបង់ ។

៣១ ប៉ុន្តែបញ្ជីទាំងឡាយនៃពួកដូនតា គឺពួកអយ្យកោ ស្ដីអំពីសិទ្ធិចំពោះបព្វជិតភាព នោះព្រះអម្ចាស់ដ៏ជាព្រះរបស់ខ្ញុំ ទ្រង់បានរក្សាទុក នៅក្នុងកណ្ដាប់ដៃខ្ញុំ; ហេតុដូច្នេះហើយ ការចេះដឹងអំពីដើមការបង្កបង្កើត ហើយព្រមទាំងអំពីពិភពទាំងឡាយ និងពីតារាទាំងឡាយ ដូចជាបានស្គាល់ដល់ពួកអយ្យកោ នោះខ្ញុំបានទុករហូតមកដល់សព្វថ្ងៃនេះ ហើយខ្ញុំនឹងខំសរសេរអំពីការណ៍ទាំងឡាយនេះខ្លះៗ ទុកនៅលើបញ្ជីនេះ សំរាប់ជាផលប្រយោជន៍ដល់ពូជពង្សរបស់ខ្ញុំ ដែលនឹងមកតាមក្រោយខ្ញុំ ៕

## ជំពូកទី ២

*លោកអ័ប្រាហាំចេញពីអ៊ើរ ទៅឯស្រុកកាណាន — ព្រះយេហូវ៉ាទ្រង់លេចមកឲ្យលោកឃើញនៅត្រង់ហារ៉ាន — ព្រះពរទាំងឡាយ អំពីដំណឹងល្អត្រូវបានសន្យាដល់ពូជលោក និងតាមរយៈពូជលោកទៅដល់មនុស្សទាំងអស់ — លោកទៅស្រុកកាណាន ហើយរហូត ទៅស្រុកអេស៊ីព្ទ ។*

ឥឡូវនេះ ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានបណ្ដាលឲ្យមានអំណត់អត់ដ៏ធ្ងន់ធ្ងរនៅលើដែនដីអ៊ើរ រហូតដល់ហារ៉ាន ជាប្អូនប្រុសខ្ញុំ ស្លាប់ទៅ; ប៉ុន្តែថេរ៉ា ជាឪពុកខ្ញុំ នៅតែរស់នៅលើដែនដីអ៊ើរ ស្រុកខាល់ដេ ។

២ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ អ័ប្រាហាំ បានយកសារ៉ាយ ធ្វើជាប្រពន្ធ ហើយណាឃរ ជាប្អូនប្រុសខ្ញុំ បានយកមីលកា ធ្វើជាប្រពន្ធ ដែលជាកូនស្រីរបស់ហារ៉ាន ។

៣ ឥឡូវនេះ ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ អ័ប្រាហាំអើយ ចូរអ្នកចេញពីស្រុកអ្នក ហើយចេញពីញាតិសន្ដានអ្នក ហើយចេញពីផ្ទះឪពុកអ្នក ទៅនៅឯដែនដីដែលយើងនឹងបង្ហាញអ្នកចុះ ។

៤ ហេតុដូច្នេះហើយ បានជាខ្ញុំចេញពីដែនដីអ៊ើរ ស្រុកខាល់ដេ

២៦ *ក* ស.ប. ប្រទានពរ, មានពរ, ព្រះពរ.
២៧ *ក* គ. និង ស. សេចក្ដីប្រកាស — ២.
ស.ប. បព្វជិតភាព.
២៨ *ក* ម៉ូសេ ៦:៥.
ស.ប. សៀវភៅរំឭក.

៣០ *ក* អ័ប្រា. ១:៧.
៣១ *ក* អ័ប្រា. ៣:១–១៨.
២ ១*ក* លោកុ. ១១:២៨.
*ខ* លោកុ. ១១:២៤–២៦;
១ របា. ១:២៦.

២ *ក* លោកុ. ១១:២៩.
ស.ប. សារ៉ា.
*ខ* លោកុ. ១១:២៧; ២២:២០–២៤.
៣ *ក* លោកុ. ១២:១; កិច្ចការ ៧:១–៣.
៤ *ក* នេហេ. ៩:៧.

ទៅឯដែនដីកាណាន; ហើយខ្ញុំបានយកឡុត ជាកូនប្រុសរបស់ប្អូនខ្ញុំ
និងប្រពន្ធឡុត និងសារ៉ាយ ជាប្រពន្ធខ្ញុំទៅផង; ហើយឪពុកខ្ញុំក៏
ទៅតាមខ្ញុំដែរ ទៅឯដែនដីដែលយើងដាក់ឈ្មោះថា ហារ៉ាន ។
៥ ហើយអំណត់អត់ក៏ធូរស្បើយ; ហើយឪពុកខ្ញុំបាននៅឯហារ៉ាន
ហើយបានអាស្រ័យនៅទីនោះ ដោយព្រោះមានហ្វូងចៀម
ជាច្រើននៅ ហារ៉ាន; ហើយឪពុកខ្ញុំបានបែរទៅថ្វាយរូបព្រះ
របស់គាត់ទៀត ហេតុដូច្នេះហើយ បានជាគាត់រស់នៅឯហារ៉ាន
តទៅ ។
៦ ប៉ុន្តែខ្ញុំ អ័ប្រាហាំ និងឡុត ជាកូនប្រុសរបស់ប្អូនខ្ញុំ បាន
អធិស្ឋានទៅព្រះអម្ចាស់ ហើយព្រះអម្ចាស់ទ្រង់បានលេចមកឲ្យខ្ញុំ
ឃើញ ហើយបានមានព្រះបន្ទូលមកខ្ញុំថា៖ ចូរក្រោកឡើង ហើយ
យកឡុតទៅជាមួយអ្នកចុះ; ត្បិតយើងមានគោលបំណងនឹងយក
អ្នកចេញពី ហារ៉ាន ហើយនឹងធ្វើឲ្យអ្នកទៅជាអ្នកបំរើ ដើម្បី
នាំនាមយើងទៅឯដែនដីចំឡែក ដែលយើងនឹងប្រទានដល់ពូជអ្នក
បន្តបន្ទាប់ពីអ្នកទៅ ទុកជាកេរ្តិ៍អាករដ៏អស់កល្បអស់កាលជានិច្ច
កាលណាពួកគេប្រុងស្តាប់តាមសម្លេងរបស់យើងនោះ ។
៧ ត្បិតយើងជាព្រះអម្ចាស់ ដ៏ជាព្រះរបស់អ្នក;
យើងគង់នៅលើស្ថានសួគ៌; ផែនដីជាកំណល់កល់ព្រះបាទយើង;
យើងលាត ដៃលើសមុទ្រ ហើយសមុទ្រគោរពតាមសម្លេងយើង;
យើងបណ្តាលឲ្យខ្យល់ និងភ្លើងទៅជារាជរថរបស់យើង; យើង
មាន បន្ទូលទៅភ្នំទាំងឡាយថា — ចូរចេញទៅ —
ហើយមើលចុះ ភ្នំទាំងនោះត្រូវបានយកទៅឆ្ងាយដោយខ្យល់ព្យុះ
ក្នុងមួយរំពេចភ្លាមៗ ។
៨ ព្រះនាមយើង គឺព្រះយេហូវ៉ា ហើយយើងដឹងពីដើមដំបូង
មកចុងបំផុត; ហេតុដូច្នេះហើយ ព្រះហស្តយើងនឹងនៅលើអ្នក ។
៩ ហើយយើងនឹងបង្កើតសាសន៍មួយយ៉ាងធំពីអ្នក ហើយយើង
នឹងប្រទានពរដល់អ្នកហួសកំរិត ហើយធ្វើឲ្យឈ្មោះអ្នកបានធំក្នុង
ចំណោម អស់ទាំងសាសន៍ ហើយអ្នកនឹងទៅជាពរដល់
ពូជអ្នកជាបន្តបន្ទាប់ទៅ ដើម្បីឲ្យពួកគេបានកាន់ការងារបំរើ និង
បព្វជិតភាពនេះដល់អស់ ទាំងសាសន៍ ដោយដៃរបស់ពួកគេ;
១០ ហើយយើងនឹងប្រទានពរដល់ពួកគេតាមរយៈឈ្មោះអ្នក;
ចំពោះមនុស្សជាច្រើនដែលទទួលដំណឹងល្អនេះ នោះនឹងត្រូវបាន
ហៅ តាមឈ្មោះអ្នក ហើយនឹងត្រូវបានរាប់ថាជាពូជអ្នក ហើយ
នឹងក្រោកឡើង ហើយជូនពរដល់អ្នក ជាឪពុករបស់គេ;
១១ ហើយយើងនឹងប្រទានពរដល់ពួកអ្នកណាដែលឲ្យពរដល់
អ្នក ហើយនឹងដាក់បណ្តាសាដល់ពួកអ្នកណាដែលផ្តាសាអ្នក;
ហើយ ដោយសារអ្នក (គឺថាដោយសារបព្វជិតភាពរបស់អ្នក)
និងដោយសារពូជអ្នក (គឺថាដោយសារបព្វជិតភាពរបស់អ្នក)
ត្បិតយើង បានប្រទានដល់អ្នក នូវសេចក្តីសន្យាមួយថា សិទ្ធិនេះ
នឹងនៅជាប់នឹងអ្នករហូត ហើយនៅជាប់នឹងពូជអ្នកជាបន្តបន្ទាប់ទៅ
(គឺនិយាយ ថា ពូជអ្នកពិត ឬពូជចេញពីរូបកាយអ្នក) នោះ
ទើបអស់ទាំងគ្រួសារនៅលើផែនដីនឹងបានពរ គឺដោយព្រះពរ
ទាំងឡាយនៃដំណឹងល្អ ដែល ជាព្រះពរទាំងឡាយខាងសេច
ក្តីសង្គ្រោះ គឺខាងជីវិតដ៏នៅអស់កល្បជានិច្ច ។
១២ ឥឡូវនេះ បន្ទាប់ពីព្រះអម្ចាស់ទ្រង់បានថយចេញពីមាន
ព្រះបន្ទូលជាមួយនឹងខ្ញុំ ហើយបានដកព្រះភ័ក្ត្ររបស់ទ្រង់ចេញពីខ្ញុំទៅ
នោះខ្ញុំក៏និយាយក្នុងចិត្តថា៖ អ្នកបំរើរបស់ទ្រង់បានខំស្វែងរកទ្រង់
ឥឡូវនេះ ទូលបង្គំបានរកឃើញព្រះអង្គហើយ;
១៣ ព្រះអង្គបានចាត់ទេវតារបស់ទ្រង់ឲ្យមក ដោះលែង
ទូលបង្គំពីព្រះទាំងឡាយនៃអែលកេណា ហើយល្អហើយដែល
ទូលបង្គំនឹងស្តាប់ តាមសម្លេងព្រះអង្គ ហេតុដូច្នេះហើយ
សូមឲ្យអ្នកបំរើរបស់ទ្រង់ក្រោកឡើង ហើយចេញទៅដោយ
សេចក្តីសុខសាន្តចុះ ។
១៤ ម៉្លោះហើយខ្ញុំ អ័ប្រាហាំ បានចេញតាមដែលព្រះអម្ចាស់

៤ *ខ* លោកុ. ១១:៣១–៣២.
៥ *ក* យ៉ូស្វេ ២៤:២.
៦ *ក* ស.ប. ឡុត.
*ខ* លោកុ. ១៧:១.
ស.ប. ព្រះយេស៊ូវគ្រីស្ទ – ព្រះគ្រីស្ទមានព្រះជន្មរស់នៅមុនផែនដី.
*គ* លោកុ. ១២:២–៣; អ័ប្រា. ១:១៩.
*ឃ* លោកុ. ១៣:១៤–១៥; ១៧:៨; និក្ខ. ៣៣:១.
ស.ប. ដែនដីសន្យា.
៧ *ក* ១ នីហ្វៃ ១៧:៣៩; គ. និង ស. ៣៨:១៧.
*ខ* អេសាយ ៦៦:១៥–១៦.
៨ *ក* ស.ប. ព្រះយេហូវ៉ា.
*ខ* ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
៩ *ក* ១ នីហ្វៃ ១៧:៤០; ២ នីហ្វៃ ២៩:១៤; ៣ នីហ្វៃ ២០:២៧; មរមន ៥:២០.
ស.ប. អ័ប្រាហាំ — ពូជរបស់អ័ប្រាហាំ.
*ខ* គ. និង ស. ៨៤:១៧–១៩; ម៉ូសេ ៦:៧.
ស.ប. បព្វជិតភាពមិលគីស្សាដែក.
១០ *ក* កាឡាទី ៣:៧–៩.
*ខ* លោកុ. ១៣:១៦; កាឡាទី ៣:២៩; ២ នីហ្វៃ ៣០:២.
*គ* ស.ប. អយ្យកោ, ខាងអយ្យកោ.
១១ *ក* ស.ប. សេចក្តីសញ្ញាអ័ប្រាហាំ.
*ខ* អេសាយ ៦១:៩.
*គ* ស.ប. សិទ្ធិកូនច្បង; អ៊ីស្រាអែល; បព្វជិតភាព.
១២ *ក* គ. និង ស. ៨៨:៦៣.
១៣ *ក* អ័ប្រា. ១:១៥–១៧.

ទ្រង់មានព្រះបន្ទូលដល់ខ្ញុំ ហើយឡុតនៅជាមួយនឹងខ្ញុំ; ហើយខ្ញុំ
អ័ប្រាហាំ មានអាយុ៦២ឆ្នាំ កាលខ្ញុំចេញពីហារ៉ាន ។
១៥ ហើយខ្ញុំបានយកសារ៉ាយ ដែលខ្ញុំបានយកជាប្រពន្ធ កាល
ខ្ញុំនៅអ៊ើរ ស្រុកខាល់ដេ ហើយឡុត ជាកូនប្រុសរបស់ប្អូនខ្ញុំ ព្រម
ទាំង របស់របរយើងទាំងអស់ ដែលយើងបានប្រមូលបានមក ហើយ
ទាំងជនទាំងឡាយដែលយើងឈ្នះបានមកនៅហារ៉ានផង ហើយ
បាន ចេញមកតាមផ្លូវទៅដែនដីកាណាន ហើយបានរស់នៅ
ក្នុងត្រសាលទាំងឡាយ ក្នុងកាលយើងធ្វើដំណើរមក;
១៦ ហេតុដូច្នេះហើយ ភាពអស់កល្បជានិច្ច គឺជាជម្រក
របស់យើង ហើយជាថ្មដារបស់យើង ហើយជាសេចក្ដីសង្គ្រោះ
របស់យើង ក្នុង កាលយើងធ្វើដំណើរពីហារ៉ាន តាមផ្លូវស្រុក
យេរិសុន ដើម្បីមកឯដែនដីកាណាន ។
១៧ ឥឡូវនេះ ខ្ញុំ អ័ប្រាហាំ បានសង់អាសនាមួយ
នៅដែនដីយេរិសុន ហើយបានថ្វាយដង្វាយដល់ព្រះអម្ចាស់ ហើយ
បានអធិស្ឋានសូម ឲ្យអំណត់អត់បានបែរចេញពីផ្ទះឪពុករបស់ខ្ញុំ
ដើម្បីកុំឲ្យពួកគេអាចត្រូវវិនាសបង់ ។
១៨ ហើយបន្ទាប់មក យើងបានដើរកាត់ស្រុក
ពីយេរិសុនទៅកន្លែងមួយឈ្មោះថា ស៊ីគែម; កន្លែងនោះនៅ
ក្នុងវាលម៉ូរេ ហើយយើង បានចូលមកដល់ព្រំដែនស្រុកកាណាន
ហើយ ហើយខ្ញុំបានថ្វាយយញ្ញបូជានៅទីនោះ នៅក្នុងវាលម៉ូរេ
ហើយបានអំពាវនាវដល់ព្រះ អម្ចាស់អស់ពីចិត្ត ពីព្រោះយើងបាន
ចូលមកដល់ដែនដីនៃពួកសាសន៍ដែលថ្វាយបង្គំរូបព្រះនេះ ។
១៩ ហើយព្រះអម្ចាស់ទ្រង់បានលេចមកឲ្យខ្ញុំឃើញ ក្នុង
ការឆ្លើយតបដល់ការអធិស្ឋានរបស់ខ្ញុំ ហើយបានមានព្រះបន្ទូល
មកខ្ញុំថា៖ យើងនឹងប្រទានដែនដីនេះដល់ពូជអ្នក ។
២០ ហើយខ្ញុំ អ័ប្រាហាំ បានក្រោកពីកន្លែងអាសនា ដែលខ្ញុំ
បានសង់ថ្វាយដល់ព្រះអម្ចាស់ ហើយរើចេញពីទីនោះ ទៅឯភ្នំនៅ
ខាងកើត បេត-អែល ហើយបានបោះត្រសាលនៅទីនោះ គឺបេត-
អែលនៅខាងលិច និងហៃយនៅខាងកើត; ហើយនៅទីនោះ
ខ្ញុំបានសង់ អាសនាមួយទៀតថ្វាយដល់ព្រះអម្ចាស់ ហើយបាន
អំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ម្ដងទៀត ។
២១ ហើយខ្ញុំ អ័ប្រាហាំ បានធ្វើដំណើរ ដោយចេះតែទៅខាង
ត្បូងទៀត; ហើយនៅទីនោះ នៅតែមានអំណត់អត់នៅលើដែនដី;
ហើយខ្ញុំ អ័ប្រាហាំ ប្ដេជ្ញាចិត្តចុះទៅស្រុកអេស៊ីព្ទ ដើម្បីទៅ
ស្នាក់នៅទីនោះ ព្រោះអំណត់អត់បានកើតមានកាន់តែខ្លាំង
ឡើង ។
២២ ហើយហេតុការណ៍បានកើតឡើងថា កាលខ្ញុំជិតចូល
ក្នុងស្រុកអេស៊ីព្ទ នោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលមកខ្ញុំថា៖
មើលចុះ សារ៉ាយ ជាប្រពន្ធអ្នក នាងជាស្ត្រីមានរូបស្រស់
ល្អណាស់;
២៣ ហេតុដូច្នេះហើយ ហេតុការណ៍នឹងកើតឡើងថា កាល
ណាពួកសាសន៍អេស៊ីព្ទសម្លឹងមើលឃើញនាង នោះពួកគេនឹង
និយាយថា — នាងជាប្រពន្ធគាត់; ហើយពួកគេនឹងសំឡាប់
អ្នកចោល ប៉ុន្តែពួកគេនឹងទុកនាងឲ្យរស់; ហេតុដូច្នេះហើយ
ចូរមើលឲ្យឃើញថា អ្នកប្រព្រឹត្តបែបនេះចុះ គឺ៖
២៤ ចូរឲ្យនាងនិយាយប្រាប់ពួកសាសន៍អេស៊ីព្ទថា នាង
ជាប្អូនស្រីរបស់អ្នក ហើយអ្នកនឹងមានជីវិតរស់នៅ ។
២៥ ហើយហេតុការណ៍បានកើតឡើងថា ខ្ញុំ អ័ប្រាហាំ បាន
ប្រាប់សារ៉ាយ ជាប្រពន្ធខ្ញុំ ពីគ្រប់ការណ៍ទាំងអស់ដែលព្រះ
អម្ចាស់ទ្រង់បាន ប្រាប់ដល់ខ្ញុំ — ហេតុដូច្នេះហើយ ខ្ញុំសូម
ដល់នាង សូមនិយាយប្រាប់ពួកគេថា នាងជាប្អូនស្រីខ្ញុំ ដើម្បីឲ្យ
បានល្អដល់ខ្ញុំ ដោយព្រោះនាង ហើយឲ្យខ្ញុំមានជីវិតរស់ ដោយ
សារនាងផងចុះ ៕

## ជំពូកទី ៣

*លោកអ័ប្រាហាំចេះដឹងអំពីព្រះអាទិត្យ ព្រះច័ន្ទ និងតារាទាំងឡាយ ដោយសារយូរីមនិងធូមីម — ព្រះអម្ចាស់ទ្រង់បើកសម្ដែងដល់លោក អំពីស្ថានភាពដ៏នៅអស់កល្បជានិច្ចនៃវិញ្ញាណទាំងឡាយ — លោកចេះដឹងអំពីជីវិតមុនផែនដី ការតែងតាំងទុកជាមុន ការបង្កបង្កើត ការរើសព្រះដ៏ប្រោសលោះ និងស្ថានភាពទី ២ របស់មនុស្ស ។*

១៤ *ក* លោកុ. ១២:៤–៥.
១៥ *ក* ស.ប. សារ៉ា.
*ខ* ស.ប. អ៊ើរ.
*គ* ស.ប. ការប្រែចិត្តជឿ, ប្រែចិត្តជឿ.
*ឃ* ស.ប. កាណាន, សាសន៍កាណាន.
១៦ *ក* ស.ប. ថ្ម.
១៧ *ក* ស.ប. អាសនា.
*ខ* អ័ប្រា. ១:២៩.
១៨ *ក* លោកុ. ១២:៦.
*ខ* ស.ប. បូជា, យញ្ញបូជា.
១៩ *ក* លោកុ. ១៣:១២–១៥; ១៧:៨; និក្ខ. ៣:១–១០; ជនគ. ៣៤:២.
ស.ប. ដែនដីសន្យា.
២០ *ក* ស.ប. បេត–អែល.
*ខ* លោកុ. ១៣:៣–៤.
*គ* លោកុ. ១២:៨.
២២ *ក* លោកុ. ១២:១១–១៣.

ហើយខ្ញុំ អ័ប្រាហាំ បាន[ក]យូរីម និងធូមីម ដែលព្រះអម្ចាស់ដ៏ជាព្រះ
របស់ខ្ញុំ បានប្រទានដល់ខ្ញុំនៅអើរ ស្រុកខាល់ដេ;
២ ហើយខ្ញុំបានមើលឃើញ[ក]តារាទាំងឡាយ គឺតារា
ទាំងនោះសុទ្ធតែធំៗណាស់ ហើយតារាមួយនោះនៅយ៉ាងជិត
នឹងបល្ល័ង្កនៃព្រះ ជាងគេ; ហើយមានតារាដ៏ធំៗជាច្រើន ដែល
នៅជិតនោះ;
៣ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ តារា
ទាំងនេះសុទ្ធតែជាតារាត្រួតត្រា; ហើយឈ្មោះតារាដ៏ធំមួយនោះ
គឺ [ក]កូឡុប ពីព្រោះវានៅជិតយើង ត្បិតយើងជាព្រះអម្ចាស់ដ៏ជា
ព្រះរបស់អ្នក៖ គឺយើងបានចាត់ឲ្យតារាមួយនេះត្រួតត្រាលើអស់
ទាំងតារាទាំងនោះ ដែលនៅក្នុងលំដាប់ដូចគ្នាដែលអ្នកឈរលើ ។
៤ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំ ដោយយូរីម
និងធូមីម ថាកូឡុបនៅតាមរបៀបនៃព្រះអម្ចាស់ ស្របតាម
ពេលវេលា និង រដូវកាលរបស់វា តាមការវិលជុំវិញនៃទីនោះ;
រីឯការវិលជុំវិញម្តង គឺមានមួយ[ក]ថ្ងៃចំពោះព្រះអម្ចាស់[ខ] ស្របតាម
របៀបរៀបរាប់ពេល វេលារបស់ទ្រង់ គឺមួយពាន់ឆ្នាំស្របតាម
ពេលវេលាដែលកំណត់ទុកចំពោះទីនោះដែលអ្នកឈរលើ ។ នេះ
ហើយជារបៀបរៀបរាប់ ពេលវេលារបស់ព្រះអម្ចាស់ ស្របតាម
របៀបរៀបរាប់នៃកូឡុប ។
៥ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ ភពដែល
មានពន្លឺតូចជាង គឺតូចជាងភពដែលត្រួតក្នុងពេលថ្ងៃ ដែលសំរាប់
ត្រួតក្នុងពេលយប់ នោះខ្ពស់ ឬធំជាងភពដែលអ្នកឈរលើ តាម
ការរៀបរាប់ពេលវេលារបស់វា ត្បិតវាដើរតាមរបៀបយឺតយូរ;
គឺនៅក្នុងរបៀបនេះ ពីព្រោះវាឈរនៅលើផែនដីដែលអ្នកឈរលើ
ហេតុដូច្នេះហើយ ការរៀបរាប់ពេលវេលារបស់វា គឺពុំមែនរាប់
តាមថ្ងៃ និងខែ និងឆ្នាំឡើយ ។
៦ ហើយព្រះអម្ចាស់ទ្រង់[ក]មានព្រះបន្ទូលមកខ្ញុំថា៖ ឥឡូវនេះ
អ័ប្រាហាំអើយ មានការពិតទាំងពីរនេះហើយ មើលចុះ ភ្នែករបស់
អ្នកក៏ មើលឃើញដែរ; ព្រោះបានប្រទានដល់អ្នក ឲ្យស្គាល់
របៀបរៀបរាប់ពេលវេលា និងពេលប្រក្រតីផង មែនហើយ
គឺពេលប្រក្រតីនៃ ផែនដីដែលអ្នកឈរលើ និងពេលប្រ
ក្រតីនៃពន្លឺដ៏ធំជាង ដែលចាត់ឲ្យត្រួតក្នុងពេលថ្ងៃ និងពេលប្រ
ក្រតីនៃពន្លឺដ៏តូចជាង ដែលចាត់ឲ្យត្រួតក្នុងពេលយប់ ។
៧ ឥឡូវនេះ ពេលប្រក្រតីនៃពន្លឺដ៏តូចជាង បើរាប់តាម
របៀបរៀបរាប់ពេលវេលារបស់វា នោះយូរជាងរបៀបរៀប
រាប់ពេលវេលានៃ ផែនដី ដែលអ្នកឈរលើ ។
៨ ហើយកាលណាមានការពិតទាំងពីរនេះ នោះក៏គួរមាន
ការពិតខ្ពស់ជាងនេះដែរ គឺថា មានភពមួយទៀតដែលមាន
របៀបរៀបរាប់ ពេលវេលាកាន់តែយូរទៅទៀត;
៩ ហើយដូច្នេះ ទើបមានរបៀបរៀបរាប់ពេលវេលានៃភពមួយ
ខ្ពស់ជាងមួយទៀត រហូតដល់អ្នកជិតមកដល់កូឡុប ជាកូឡុបនោះ
ហើយដែលរាប់តាមរបៀបរៀបរាប់ពេលវេលារបស់ព្រះអម្ចាស់;
ជាកូឡុបនោះហើយដែលចាត់ឲ្យនៅជិតបល្ល័ង្កនៃព្រះ ដើម្បីត្រួតលើ
អស់ទាំងភព ដែលនៅក្នុង[ក]របៀបដូចនៅទីនោះដែលអ្នកឈរលើ ។
១០ ហើយត្រូវបានប្រទានដល់អ្នក ឲ្យស្គាល់ពេលប្រ
ក្រតីនៃអស់ទាំងតារា ដែលចាត់ឲ្យបំភ្លឺ រហូតដល់អ្នកជិតមក
ដល់បល្ល័ង្កនៃព្រះ ។
១១ ដូច្នេះ ខ្ញុំ អ័ប្រាហាំ[ក]បានទូលជាមួយនឹងព្រះអម្ចាស់ ទល់មុខ
គ្នា ដូចជាមនុស្សនិយាយគ្នា; ហើយទ្រង់បានប្រាប់ខ្ញុំអំពីកិច្ចការ
ទាំងឡាយ ដែលព្រះហស្តទ្រង់បានធ្វើមក;
១២ ហើយទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ បុត្រយើង
បុត្រយើងអើយ (ហើយព្រះហស្តរបស់ទ្រង់បានលាតសន្ធឹងមក)
មើលចុះ យើងនឹងបង្ហាញដល់អ្នក នូវរបស់ទាំងឡាយនេះ ។
ហើយទ្រង់បានដាក់ព្រះហស្តទ្រង់មកលើភ្នែកខ្ញុំ ហើយខ្ញុំបានឃើញ
របស់ទាំង ឡាយនោះ ដែលព្រះហស្តទ្រង់បានធ្វើមក ដែលមាន
ជាច្រើន; ហើយរបស់ទាំងនោះបានកើនជាច្រើនឡើង នៅចំពោះ
ភ្នែកខ្ញុំ; ហើយខ្ញុំ ពុំអាចមើលឃើញទីបញ្ចប់នៃរបស់ទាំងនោះ
ឡើយ ។
១៣ ហើយទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ នេះគឺជាស៊ីនេហា
ដែលជាព្រះអាទិត្យ ។ ហើយទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖
កូកុបគី ជាតារា ។ ហើយទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖
អូលេអា គឺជាព្រះច័ន្ទ ។ ហើយទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖
កូការប៊ីម ដែល បញ្ជាក់ថាជាតារាទាំងឡាយ ឬគ្រប់ពន្លឺដ៏ធំ
ៗទាំងអស់ ដែលនៅលើផ្ទៃមេឃ ។
១៤ ហើយគឺនៅពេលយប់ដែលព្រះអម្ចាស់ទ្រង់បានមានព្រះ
បន្ទូលប្រាប់ខ្ញុំពីពាក្យទាំងឡាយនេះថា៖ យើងនឹងចំរើនអ្នកឲ្យ[ក]កើន

៣ ១ *ក* និក្ខ. ២៨:៣០; ម៉ូសាយ ៨:១៣; ២៨:១៣–១៦; យ.ស.—ប្រវត្តិ ១:៣៥. ស.ប. យូរីម និងធូមីម.
២ *ក* អ័ប្រា. ១:៣១.
៣ *ក* ក.ន. សូមមើល វត្ថុចម្លងតាម លេខ ២, រូបទី ១–៥. ស.ប. កូឡុប.
៤ *ក* អ័ប្រា. ៥:១៣.
*ខ* ទំនុក. ៩០:៤; ២ ពេត្រុស ៣:៨.
៦ *ក* អ័ប្រា. ៣:១៦–១៩.
៩ *ក* គ. និង ស. ៨៨:៣៧–៤៤.
១១ *ក* លោកុ. ១៧:១; ជនគ.១២:៥–៨.
១៤ *ក* អ័ប្រា. ២:៩.

## វត្ថុចម្លងតាមចេញពីគម្ពីរអ័ប្រាហាំ

លេខ ២



## ការពន្យល់

រូបទី ១ : កូឡុប ជាការបង្កបង្កើតទីមួយ គឺនៅជិតសេឡេស្ទាល ឬទីលំនៅនៃព្រះជាងគេ ។ ជាទីដំបូងក្នុងការគ្រប់គ្រងចុងក្រោយ បង្អស់ចំពោះការរាប់ពេលវេលា ។ ការរាប់ពេលវេលាស្របតាមពេលវេលានៃសេឡេស្ទាល ជាពេលវេលានៃសេឡេស្ទាល ដែល មានន័យថា មួយថ្ងៃស្មើមួយហត្ថ ។ មួយថ្ងៃនៅកូឡុប គឺស្មើនឹងមួយពាន់ឆ្នាំ ស្របតាមការរាប់ពេលវេលានៃផែនដីនេះ ដែលត្រូវបាន ហៅដោយពួកសាសន៍អេស៊ីព្ទថា យ៉ា-អូ-អេ ។

រូបទី ២ : ឈរនៅក្បែរកូឡុប ត្រូវបានហៅដោយពួកសាសន៍អេស៊ីព្ទថា អូលិបលិស ដែលជាការបង្កបង្កើតដ៏មហិមាសំរាប់គ្រប់គ្រង តមកដែលនៅជិតសេឡេស្ទាល ឬកន្លែងដែលព្រះទ្រង់គង់នៅ; ដោយកាន់នូវកូនសោនៃអំណាច ព្រមទាំងទាក់ទងទៅនឹងភពផ្សេងៗ ទៀតផង; ដូចដែលបានបើកសម្តែងប្រាប់ពីព្រះដល់អ័ប្រាហាំ ក្នុងកាលលោកបានថ្វាយយញ្ញបូជានៅលើអាសនា ដែលលោកបានសង់ ថ្វាយព្រះអម្ចាស់ ។

រូបទី ៣ : ធ្វើឡើងជាតំណាងព្រះ គង់នៅលើបល្ល័ង្កទ្រង់ បំពាក់ដោយព្រះចេស្តា និងសិទ្ធិអំណាច ជាមួយនឹងមកុដនៃពន្លឺដ៏នៅអស់ កល្បជានិច្ចនៅលើព្រះសិរទ្រង់; ក៏ជាតំណាងនូវពាក្យសំគាល់ដ៏ធំទាំងឡាយនៃបព្វជិតភាពបរិសុទ្ធ ដូចដែលបានបើកសម្តែងប្រាប់ លោកអ័ដាម នៅក្នុងសួនច្បារអេដែន ព្រមទាំងសេត ណូអេ មិុលគិស្សាដែក អ័ប្រាហាំ និងអស់ទាំងពួកអ្នកដែលត្រូវបានបើកសម្តែង ប្រាប់ពីបព្វជិតភាព ។

រូបទី ៤ : ជាចម្លើយទាំងឡាយចំពោះពាក្យហេព្រើរថា រ៉ាវគីយ៉ាង គឺមានន័យថា ប្រឡោះ ឬផ្ទៃមេឃ; ហើយជារូបដែលបានរាប់ទុក នៅក្នុងភាសាអេស៊ីព្ទ មានន័យថា មួយពាន់; ជាចម្លើយចំពោះន័យអំពីពេលវេលានៅអូលិពលិស ដែលស្មើនឹងកូឡុប ចំពោះការវិល របស់វា និងការរៀបរាប់ពេលវេលានៅទីនោះ ។

រូបទី ៥ : បានហៅក្នុងភាសាអេស៊ីព្ទថា អេនិស-កូ-អូន-ដូស; នេះគឺជាភពមួយដែលត្រួតត្រា ហើយដែលហៅដោយពួកអេស៊ីព្ទថា ជាព្រះអាទិត្យ ហើយដើម្បីសុំពន្លឺខ្លួនពីកូឡុប តាមរយៈវត្ថុ កា-អេ-វ័នរ៉ាស ដែលជាកូនសោធំ ឬក៏ម្យ៉ាងទៀត គឺជាអំណាចត្រួតត្រា ដែលត្រួតត្រាភព ឬតារា១៥ដួង ដែលនៅនឹងនរ ដូចជា ផ្លូអេសេ ឬព្រះច័ន្ទ ផែនដី និងព្រះអាទិត្យផង នៅក្នុងការវិលរបស់ដួងទាំង នេះរាល់ឆ្នាំ ។ ភពនេះទទួលអំណាចរបស់ខ្លួនតាមរយៈវត្ថុ គ្លី-ផ្លូ-អ៊ិស-អេស ឬ ហា-កូ-កាវ-ប៊ីម រីឯតារាទាំងឡាយដែលតំណាង ដោយលេខ ២២ និង លេខ ២៣ នោះទទួលពន្លឺរបស់ខ្លួនពីការវិលនៃកូឡុប ។

រូប៉ទី ៦ : ជាតំណាងផែនដីនេះ តាមទិសទាំងបួន ។

រូបទី ៧ : ជាតំណាងព្រះគង់នៅលើបល្ល័ង្កទ្រង់ ដោយបើកសម្តែងតាមផ្ទៃមេឃប្រាប់ពីពាក្យសំគាល់ទាំងឡាយនៃបព្វជិតភាព; ដូចជាសំ គាល់ពីព្រះវិញ្ញាណបរិសុទ្ធ ដល់លោកអ័ប្រាហាំ ក្នុងរូបដូចជាព្រាប ។

រូបទី ៨ : មានការនិពន្ធទាំងឡាយ ដែលពុំអាចបើកសម្តែងប្រាប់ដល់ពិភពលោកបានឡើយ; ប៉ុន្តែសំរាប់មាននៅក្នុងព្រះវិហារ បរិសុទ្ធនៃព្រះ ។

រូបទី ៩ : ពុំចាំបាច់បើកសម្តែងប្រាប់នៅពេលបច្ចុប្បន្ននេះទេ ។

រូបទី ១០ : ក៏ដូច្នោះដែរ ។

រូបទី ១១ : ក៏ដូច្នោះដែរ ។ បើសិនជាពិភពលោកអាចរកឃើញន័យនៃលេខទាំងនេះ ក៏សូមធ្វើទៅចុះ ។ អាម៉ែន ។

រូបទី ១២, ១៣, ១៤, ១៥, ១៦, ១៧, ១៨, ១៩, ២០, និង ២១ នោះនឹងត្រូវបានប្រទាននៅពេលកំណត់នៃព្រះអម្ចាស់ ។

ការបកប្រែខាងលើនេះត្រូវបានធ្វើឡើង តាមតែដែលយើងមានសិទ្ធិបកប្រែនៅពេលបច្ចុប្បន្ននេះប៉ុណ្ណោះ ។

ច្រើន ឡើង ហើយពូជអ្នកជាបន្តបន្ទាប់ទៅ ឲ្យមានដូចជារបស់
ទាំងនេះដែរ; ហើយបើសិនជាអ្នកអាចរាប់ខ្សាច់បាន នោះហើយ
ជាចំនួននៃ ពូជទាំងឡាយរបស់អ្នក ។
១៥ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ អ័ប្រាហាំ
អើយ យើងបង្ហាញរបស់ទាំងនេះដល់អ្នក មុនអ្នករាល់គ្នាទៅក្នុង
ស្រុកអេស៊ីព្ទ ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចបានប្រកាសប្រាប់
ពាក្យទាំងអស់នេះ ។
១៦ បើសិនជាមានវត្ថុពីរ ហើយមួយខ្ពស់ជាងមួយទៀត នោះ
ច្បាស់ជានឹងមានរបស់របរដ៏ធំជាង ខ្ពស់លើសនោះទៅទៀត;
ហេតុដូច្នេះហើយ កូឡុបគឺធំជាងកូការប៊ីមទាំងអស់ ដែលអ្នក
បានឃើញ ពីព្រោះកូឡុបនៅជិតយើងជាងគេ ។
១៧ ឥឡូវនេះ បើសិនជាមានរបស់ពីរ គឺមួយខ្ពស់ជាងមួយ
ទៀត ហើយព្រះច័ន្ទខ្ពស់ជាងផែនដី ម្ល៉ោះហើយ ច្បាស់ជាអាច
មានភព ឬតារាខ្ពស់ជាងព្រះច័ន្ទទៅទៀត; ហើយគ្មានអ្វីដែល
ព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យនឹងធ្វើទេ លើកលែងតែអ្វីនោះ
ដែលទ្រង់នឹង សំរេចប៉ុណ្ណោះ ។
១៨ ម្តេចឡើយក៏ទ្រង់បានធ្វើតារាដ៏ធំជាងនោះ; ក៏ដូចគ្នាដែរ
បើសិនជាមានវិញ្ញាណពីរ ហើយមួយមានបញ្ញាជាងមួយទៀត
តែ រីឯវិញ្ញាណទាំងពីរនេះ ទោះជាមួយមានបញ្ញាជាងមួយ
ទៀតក៏ដោយ ក៏គង់តែពុំមានដើមដំបូងដែរ; ពួកវិញ្ញាណ
ទាំងនេះមានតាំងពី ដើមមកម្ល៉េះ ពួកគេគ្មានទីបញ្ចប់ឡើយ គឺពួក
គេនឹងមានរហូតតទៅទៀត ព្រោះពួកគេជាណូឡោម ឬនៅ
អស់កល្បជានិច្ច ។
១៩ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ មាន
ការពិតទាំងពីរនេះហើយថា មានវិញ្ញាណពីរ គឺមួយមានបញ្ញា
ជាងមួយ ទៀត; ក៏នឹងមានមួយទៀតដែលមានបញ្ញាជាងនោះទៅ
ទៀត; យើងជាព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នក យើងមានបញ្ញា
ជាងពួកគេទាំង អស់ ។
២០ ព្រះអម្ចាស់ដ៏ជាព្រះរបស់អ្នកបានចាត់ទេវតារបស់ទ្រង់
ឲ្យទៅដោះលែងអ្នកពីកណ្តាប់ដៃរបស់សង្ឃនៃអែលកេណា ។
២១ យើងគង់នៅកណ្តាលពួកគេទាំងអស់; ហេតុ
ដូច្នេះហើយ បានជាឥឡូវនេះ យើងចុះមកឯអ្នក ដើម្បីប្រកាស
ប្រាប់ដល់អ្នក អំពីកិច្ចការទាំងឡាយដែលព្រះហស្តរបស់យើង
បានធ្វើមក ម្ល៉ោះហើយ បញ្ញាយើងលើសជាងពួកគេទាំងអស់
ត្បិតយើងគ្រប់គ្រងស្ថានសួគ៌ ខាងលើ និងផែនដីខាងក្រោម
ដោយប្រាជ្ញា និងការឈ្លាសវៃគ្រប់យ៉ាង គឺលើអស់ទាំងបញ្ញា
ទាំងឡាយដែលភ្នែកអ្នកបានឃើញ តាំងពីដើមដំបូងមកម្ល៉េះ;
នៅដើមដំបូងឡើយ យើងបានចុះមកកណ្តាលអស់ទាំងបញ្ញា
ដែលអ្នកបានឃើញនោះ ។
២២ ឥឡូវនេះ ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ខ្ញុំ អ័ប្រាហាំ
នូវបញ្ញាទាំងឡាយដែលត្រូវបានបង្កើតឡើង មុនកំណើតលោកិយ
មកម្ល៉េះ; ហើយនៅក្នុងចំណោមពួកគេទាំងអស់ នោះមានអ្នក
ដែលមានត្រកូលខ្ពស់ និងធំៗជាច្រើន;
២៣ ហើយព្រះទ្រង់បានទតឃើញព្រលឹងទាំងឡាយនេះថា
សុទ្ធតែល្អ ហើយទ្រង់បានឈរនៅកណ្តាលពួកគេ ហើយទ្រង់មាន
ព្រះបន្ទូល ថា៖ ពួកអ្នកទាំងនេះ យើងនឹងធ្វើទៅជាពួកអ្នកគ្រប់
គ្រងរបស់យើង; ត្បិតទ្រង់បានឈរក្នុងចំណោមអស់អ្នកដែល
ជាវិញ្ញាណ ហើយទ្រង់ បានទតឃើញថាពួកគេសុទ្ធតែល្អ; ហើយ
ទ្រង់បានមានព្រះបន្ទូលមកខ្ញុំថា៖ អ័ប្រាហាំអើយ អ្នកនៅក្នុងពួក
គេដែរ; អ្នកត្រូវបានរើសតាំងពី មុនអ្នកចាប់កំណើតមកម្ល៉េះ ។
២៤ ហើយក៏មានម្នាក់ឈរក្នុងចំណោមពួកគេ ដែល
មើលទៅដូចជាព្រះ ហើយទ្រង់បានមានព្រះបន្ទូលទៅកាន់អស់
អ្នកដែលនៅជា មួយទ្រង់ថា៖ យើងនឹងចុះទៅ ត្បិតមានកន្លែង
ទំនេរនៅទីនោះ ហើយយើងនឹងយកវត្ថុទាំងឡាយនេះទៅ ហើយ
យើងនឹងធ្វើផែនដី ដើម្បីឲ្យពួកគេទាំងនេះអាចរស់នៅលើ;
២៥ ហើយយើងនឹងសាកល្បងពួកគេមើលបើសិនជាពួកគេ

១៤ ខ លោកុ. ១៣:១៦;
គ. និង ស. ១៣២:៣០.
គ លោកុ. ២២:១៧; ហូសេ ១:១០.
១៦ ក អ័ប្រា. ៣:៣.
១៧ ក យ៉ូប ៩:៤–១២.
១៨ ក ណូឡោម
គឺជាពាក្យថាតាមពាក្យហេព្រើរ
ដែលមានន័យថា អស់កល្បជានិច្ច.
១៩ ក អេសាយ ៥៥:៨–៩.
ស.ប. ព្រះដ៏ជ្រាបសព្វសារពើ.
២០ ក អ័ប្រា. ១:១៥.
២១ ក គ. និង ស. ៨៨:៤៥–៤៧;
ម៉ូសេ ១:២៧–២៩.
ខ ស.ប. ប្រាជ្ញា.
២២ ក ស.ប. បញ្ញា, បញ្ញាទាំងឡាយ.
ខ ស.ប. ក្រុមប្រឹក្សានៅស្ថានសួគ៌;
ជីវិតមុនផែនដី.
គ គ. និង ស. ១៣៨:៥៥.
២៣ ក អេសាយ ៤៩:១–៥; យេរេ. ១:៥.
ស.ប. រើស, បានរើស,
ដែលបានរើស (កិ.);
ការតែងតាំងមុនកំណើតលោកិយ.
២៤ ក ស.ប. កូនច្បង.
ខ ស.ប. បង្កបង្កើត, ការបង្កបង្កើត.
គ ស.ប. ផែនដី —
បង្កើតសំរាប់មនុស្ស.
២៥ ក គ. និង ស. ៩៨:១២–១៤;
១២៤:៥៥.
ស.ប. សិទ្ធិជ្រើសរើស;
ផែនការនៃសេចក្តីប្រោសលោះ.

នឹងប្រព្រឹត្តនូវអ្វីៗគ្រប់យ៉ាង ដែលព្រះអម្ចាស់ដ៏ជាព្រះរបស់ពួក
គេ នឹងបញ្ជា ដល់ពួកគេ;
២៦ ហើយអស់អ្នកណាដែលរក្សាសណ្ឋានទីមួយរបស់ខ្លួន នោះ
នឹងត្រូវបានបន្ថែមឡើង; ហើយអស់អ្នកណាដែលមិនរក្សាសណ្ឋានទី
មួយរបស់ខ្លួនទេ នោះនឹងពុំបានសិរីល្អនៅក្នុងនគរជាមួយគ្នានឹង
អស់អ្នកណា ដែលរក្សាសណ្ឋានទីមួយរបស់គេនោះឡើយ;
ហើយអស់ អ្នកណាដែលរក្សាសណ្ឋានទីពីររបស់ខ្លួន នោះនឹង
បានសិរីល្អបន្ថែមទៅលើក្បាលគេជារៀងដរាបរហូតតទៅ ។
២៧ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ តើយើងនឹង
ចាត់អ្នកណា ? ហើយម្នាក់ដូចជាកូនមនុស្សបានឆ្លើយថា៖
ទូលបង្គំនៅឯ ណេះហើយ សូមចាត់ទូលបង្គំចុះ ។ ហើយ
ម្នាក់ទៀតបានឆ្លើយហើយនិយាយថា៖ ទូលបង្គំនៅឯណេះហើយ
សូមចាត់ទូលបង្គំចុះ ។ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូល
ថា៖ យើងនឹងចាត់អ្នកទីមួយ ។
២៨ ហើយអ្នកទីពីរក៏ខឹង ហើយពុំបានរក្សាសណ្ឋានទីមួយ
របស់ខ្លួនឡើយ ហើយនៅថ្ងៃនោះ មានមនុស្សជាច្រើនបាន
ដើរតាមគាត់ ៕

## ជំពូកទី ៤

*ក្រុមព្រះគ្រោងការបង្កបង្កើតផែនដី និងអ្វីៗទាំងអស់ដែលមានជីវិតនៅលើផែនដី — គំរោងការចំនួនប្រាំមួយថ្ងៃនៃការបង្កបង្កើតរបស់ព្រះត្រូវបានថ្លែងប្រាប់ ។*

ហើយខណៈនោះ ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ តោះ
ចូរយើងចុះទៅ ។ ហើយព្រះទាំងឡាយទ្រង់បានយាងចុះទៅនៅ
ដើម ដំបូង ហើយព្រះទាំងនោះ គឺថាក្រុមព្រះ បានរៀបចំ ហើយ
សូននូវផ្ទៃមេឃ និងផែនដី ។
២ ហើយផែនដី គឺបន្ទាប់ពីបានសូនរួចហើយ នោះគ្មានរូបរាងទេ
ហើយនៅទទេ ពីព្រោះព្រះទាំងឡាយទ្រង់ពុំទាន់បានសូននូវអ្វីឡើយ
ក្រៅពីផែនដីប៉ុណ្ណោះ; ហើយសេចក្ដីងងឹតគ្របលើផ្ទៃនៃជំរៅទឹក
ហើយព្រះវិញ្ញាណនៃក្រុមព្រះរេរានៅពីលើផ្ទៃទឹក ។
៣ ហើយព្រះទាំងឡាយទ្រង់ (ក្រុមព្រះ) បានមានព្រះបន្ទូល
ថា៖ ចូរឲ្យមានពន្លឺឡើង; ហើយក៏មានពន្លឺឡើង ។
៤ ហើយព្រះទាំងឡាយទ្រង់ (ក្រុមព្រះ) បានយល់ឃើញពន្លឺ
ត្បិតពន្លឺនោះភ្លឺចែងចាំង; ហើយព្រះទាំងឡាយទ្រង់បានញែកពន្លឺ
ឬបណ្ដាលពន្លឺ ឲ្យញែកចេញពីងងឹត ។
៥ ហើយក្រុមព្រះបានហៅពន្លឺថា ថ្ងៃ ហើយងងឹត ព្រះទាំង
ឡាយទ្រង់បានហៅថា យប់ ។ ហើយហេតុការណ៍បានកើតឡើងថា
ពីល្ងាច ទៅដល់ព្រឹក នោះព្រះទាំងឡាយទ្រង់បានហៅថា យប់;
ហើយពីព្រឹកទៅដល់ល្ងាច នោះព្រះទាំងឡាយទ្រង់បានហៅថា
ថ្ងៃ; ហើយនេះគឺ ជាទីមួយ ឬដើមដំបូង អំពីអ្វីដែលព្រះទាំង
ឡាយទ្រង់បានហៅថា ថ្ងៃ និងយប់ ។
៦ ហើយក្រុមព្រះក៏មានព្រះបន្ទូលថា៖ ចូរឲ្យមានប្រឡោះ
នៅកណ្ដាលទឹក ហើយវានឹងញែកទឹកចេញពីគ្នា ។
៧ ហើយក្រុមព្រះបានបញ្ជាប្រឡោះ ដើម្បីឲ្យវាញែកទឹកដែល
នៅក្រោមប្រឡោះ ចេញពីទឹកដែលនៅលើប្រឡោះ; ហើយ
ក៏មានដូច្នោះ ដូចដែលព្រះទាំងឡាយទ្រង់បានបញ្ជាមែន ។
៨ ហើយក្រុមព្រះបានហៅប្រឡោះនោះថា មេឃ ។
ហើយហេតុការណ៍បានកើតឡើងថា ពីល្ងាចទៅដល់ព្រឹក នោះព្រះ
ទាំង ឡាយទ្រង់ ហៅថា យប់; ហើយហេតុការណ៍
បានកើតឡើងថា ពីព្រឹកទៅដល់ល្ងាច នោះព្រះទាំងឡាយ
ទ្រង់ហៅថា ថ្ងៃ; ហើយនេះគឺជាលើកទីពីរ ដែលព្រះទាំងឡាយ
ទ្រង់បានហៅថា ថ្ងៃ និងយប់ ។
៩ ហើយក្រុមព្រះបានបញ្ជា ដោយមានព្រះបន្ទូលថា៖ ចូរឲ្យ
ទឹកនៅក្រោមមេឃប្រមូលគ្នានៅកន្លែងតែមួយ ហើយចូរឲ្យមាន
ដីគោក ឡើង; ហើយក៏មានដូច្នោះ ដូចដែលព្រះទាំងឡាយទ្រង់
បានបញ្ជាមែន;
១០ ហើយក្រុមព្រះបានឲ្យឈ្មោះដីគោកនោះថា ផែនដី;
ហើយទីទឹកដែលប្រមូលគ្នា នោះព្រះទាំងឡាយទ្រង់ឲ្យឈ្មោះ
ថា ទឹកធំ; ហើយ ក្រុមព្រះបានទតឃើញថា របស់ទាំង
នោះគោរពធ្វើតាម ។
១១ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ តោះ

២៥ *ខ* ស.ប. ការគោរព, ដែលគោរព, គោរព.
២៦ *ក* យូដាស ១:៦.
*ខ* ស.ប. ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់.
*គ* ទិតុស ១:២. ស.ប. សិរីល្អ.
២៧ *ក* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*ខ* ស.ប. ព្រះយេស៊ូវគ្រីស្ទ; កូនមនុស្ស.
*គ* ម៉ូសេ ៤:១–២.
២៨ *ក* ស.ប. អារក្ស.
*ខ* ស.ប. ពួកកូនអន្ធការ.
៤ ១ *ក* លោកុ. ១:១; ម៉ូសេ ២:១.
*ខ* ស.ប. បង្កបង្កើត, ការបង្កបង្កើត.
២ *ក* លោកុ. ១:២; ម៉ូសេ ២:២.
៦ *ក* លោកុ. ១:៤–៦; ម៉ូសេ ២:៤.
៨ *ក* ស.ប. ស្ថានសួគ៌.
*ខ* លោកុ. ១:៨.
៩ *ក* អេម៉ុស ៩:៦; ម៉ូសេ ២:៧.
*ខ* លោកុ. ១:៩.
១០ *ក* លោកុ. ១:១០; អ័ប្រា. ៤:២២.

ចូរយើងរៀបចំផែនដីឲ្យដុះតិណជាតិឡើង; ជា[ក]ពួកស្មៅ និងរុក្ខ
ជាតិដែលមានគ្រាប់ និងដើមឈើ ដែលមានផ្លែតាមពូជ
គឺមានគ្រាប់ក្នុងផ្លែដែលបង្កើតដើមដូចរូបវានៅលើផែនដី; ហើយ
ក៏មានដូច្នោះ គឺដូចដែលក្រុមព្រះ អង្គទ្រង់បានបញ្ជារមែន ។
១២ ហើយក្រុមព្រះបានរៀបចំផែនដីឲ្យដុះតិណជាតិឡើង ពួក
ស្មៅដែលមានគ្រាប់តាមពូជវា និងរុក្ខជាតិឲ្យដុះរុក្ខជាតិពីគ្រាប់វា
ដែលមានគ្រាប់តាមពូជវា; ហើយឲ្យផែនដីដុះដើមឈើពីគ្រាប់តាម
ពូជវា ដែលមានផ្លែ រីឯគ្រាប់វាអាចបង្កើតបានតែដើមវាប៉ុណ្ណោះ
គឺតាមពូជវា; ហើយក្រុមព្រះបានទតឃើញថា របស់ទាំងនោះ
គោរពធ្វើតាម ។
១៣ ហើយហេតុការណ៍បានកើតឡើងថា ព្រះទាំងឡាយទ្រង់
បានរាប់ថ្ងៃទាំងឡាយ; ពីល្ងាចទៅដល់ព្រឹក នោះព្រះទាំងឡាយ
ទ្រង់បានហៅថា យប់; ហើយហេតុការណ៍បានកើតឡើងថា
ពីព្រឹកទៅដល់ល្ងាច នោះព្រះទាំងឡាយទ្រង់បានហៅថា ថ្ងៃ;
ហើយនេះគឺជាលើកទីបី ។
១៤ ហើយក្រុមព្រះបានរៀបចំ [ក]ពន្លឺទាំងឡាយនៅនាផ្ទៃមេឃ
ហើយបានបណ្ដាលឲ្យពន្លឺទាំងនោះញែកថ្ងៃចេញពីយប់; ហើយ
បាន រៀបចំពន្លឺទាំងនោះសំរាប់ទុកជាទីសំគាល់ និងសំរាប់ជារដូវ
និងសំរាប់ជាថ្ងៃ និងសំរាប់ជាឆ្នាំ;
១៥ ហើយបានរៀបចំពន្លឺទាំងនោះឲ្យទៅជាតួពន្លឺនៅនាផ្ទៃមេឃ
ដើម្បីនឹងញែកថ្ងៃចេញពីយប់; ហើយក៏មានដូច្នោះ ។
១៦ ហើយក្រុមព្រះបានរៀបចំធ្វើពន្លឺធំជាពីរតួ មួយដែល
[ក]ធំជាង នោះសំរាប់ត្រួតក្នុងពេលថ្ងៃ ហើយមួយដែលតូចជាង
សំរាប់ត្រួតក្នុង ពេលយប់; ជាមួយនឹងពន្លឺតូចជាង នោះព្រះទាំង
ឡាយទ្រង់បានដាក់តារាទាំងឡាយផងដែរ;
១៧ ហើយក្រុមព្រះបានដាក់តួពន្លឺទាំងនោះនៅនាផ្ទៃមេឃ
ដើម្បីនឹងបំភ្លឺមកលើផែនដី, ហើយដើម្បីនឹងត្រួតក្នុងពេលថ្ងៃ និងក្នុង
ពេលយប់ ហើយដើម្បីនឹងបណ្ដាលឲ្យញែកពន្លឺចេញពីងងឹត ។
១៨ ហើយក្រុមព្រះបានទតរបស់ទាំងនោះដែលព្រះទាំងឡាយ
ទ្រង់បានបញ្ជា ទាល់តែរបស់ទាំងនោះគោរពធ្វើតាម ។
១៩ ហើយហេតុការណ៍បានកើតឡើងថា ពីល្ងាចទៅដល់ព្រឹក
នោះជាយប់; ហើយហេតុការណ៍បានកើតឡើងថា ពីព្រឹកទៅ
ដល់ល្ងាច នោះជាថ្ងៃ; ហើយនេះគឺជាលើកទីបួន ។
២០ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ តោះ
ចូរយើងរៀបចំទឹកឲ្យមានពោរពេញទៅដោយមច្ឆាជាតិរវើកជាប
រិបូរ; និងបក្សីជាតិ ដើម្បីឲ្យវាអាចហើរលើដីនៅនាអាកាស ។
២១ ហើយក្រុមព្រះបានរៀបចំទឹក ដើម្បីឲ្យទឹកអាចបង្កើត
[ក]ត្រីបាឡែនដ៏សំបើមៗ និងជីវិតទាំងឡាយដែលកំរើក ដែល
ទឹកទាំងឡាយ បានបង្កើតមកជាបរិបូរតាមពូជ; ហើយអស់ទាំង
សត្វស្លាបគ្រប់មុខតាមពូជ ។ ហើយក្រុមព្រះបានទតឃើញថា
របស់ទាំងនោះគោរព ធ្វើតាម ហើយថាគំរោងការរបស់ព្រះ
ទ្រង់នោះល្អ ។
២២ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ យើងនឹងប្រទានពរ
ដល់សត្វទាំងឡាយនោះ ហើយបណ្ដាលឲ្យសត្វទាំងឡាយនោះ
បង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពោសពេញនៅក្នុងទឹកសមុទ្រ
[ក]ឬទឹកធំ; ហើយបណ្ដាលឲ្យសត្វស្លាបចំរើនឡើងនៅផែនដីដែរ ។
២៣ ហើយហេតុការណ៍បានកើតឡើងថា ពីល្ងាចទៅដល់
ព្រឹក នោះព្រះទាំងឡាយទ្រង់ហៅថា យប់; ហើយហេតុការណ៍
បានកើតឡើងថា ពីព្រឹកទៅដល់ល្ងាច នោះព្រះទាំងឡាយ
ទ្រង់ហៅថា ថ្ងៃ; ហើយនេះគឺជាលើកទីប្រាំ ។
២៤ ហើយ[ក]ក្រុមព្រះបានរៀបចំឲ្យផែនដីមានពោរពេញទៅដោយ
ចតុប្បាទជាតិតាមពូជ គឺជាសត្វស្រុក សត្វលូនវារ និងសត្វព្រៃ
នៅផែនដីតាមពូជ; ហើយក៏មានដូច្នោះ ដូចដែលព្រះទាំងឡាយ
ទ្រង់បានមានព្រះបន្ទូលមែន ។
២៥ ហើយក្រុមព្រះបានរៀបចំផែនដីឲ្យមានសត្វព្រៃតាមពូជ
និងសត្វស្រុកតាមពូជ ហើយគ្រប់ទាំងសត្វដែលលូនវារនៅដី
គោកតាម ពូជដែរ; ហើយក្រុមព្រះបានទតឃើញថារបស់ទាំង
នោះនឹងគោរពធ្វើតាម ។
២៦ ហើយក្រុមព្រះបាន[ក]ប្រឹក្សាជាមួយ[ខ]គ្នា ហើយមានព្រះ[គ]បន្ទូល
ថា៖ តោះ ចូរយើងចុះទៅ ហើយសូនមនុស្សឲ្យដូចជារូបយើង
ឲ្យមាន ភាពដូចយើង; ហើយយើងនឹងឲ្យពួកគេមានអំណាច
ត្រួតត្រាលើត្រីសមុទ្រ និងលើសត្វហើរលើអាកាស និងលើ
សត្វជើងបួន និងលើផែនដីទាំងមូល ព្រមទាំងលើសត្វលូនវារ
ដែលវារនៅផែនដីផង ។
២៧ ម្ល៉ោះហើយ [ក]ក្រុមព្រះក៏យាងចុះទៅបង្កើតមនុស្សឲ្យដូច
រូបព្រះទាំងឡាយ គឺដូចជារូបនៃព្រះ នោះព្រះទាំងឡាយទ្រង់

---

១១ *ក* លោកុ. ១:១១–១២;
ម៉ូសេ ២:១១–១២.
១៤ *ក* គ. និង ស. ៨៨:៧–១១.
១៦ *ក* លោកុ. ១:១៦.
២១ *ក* លោកុ. ១:២១; ម៉ូសេ ២:២១.
២២ *ក* អ័ប្រា. ៤:១០.
២៤ *ក* ស.ប. ព្រះ, ក្រុមព្រះ.
២៦ *ក* ស.ប. ពាក្យទូន្មាន (ន.).
*ខ* ស.ប. មនុស្ស, មនុស្សលោក.
*គ* ម៉ូសេ ៦:៨–១០.
២៧ *ក* លោកុ. ១:២៦–២៧; អ័ប្រា. ៥:៧.

# វត្ថុចម្លងតាមចេញពីគម្ពីរអ័ប្រាហាំ

លេខ ៣




## ការពន្យល់

រូបទី ១ : លោកអ័ប្រាហាំអង្គុយនៅលើបល្ល័ង្ករបស់ផារ៉ោន ដោយសារសំណូមពររបស់ស្ដេច ដោយមានមកុដនៅលើក្បាលលោក ដែលជាតំណាងបព្វជិតភាព គឺជានិមិត្តរូបអំពីគណៈប្រធាននៅស្ថានសួគ៌; ទាំងមានដំបងពេជ្រនៃសេចក្ដីយុត្តិធម៌ និងសេចក្ដីជំនុំជំរះនៅ ដៃលោកផង ។

រូបទី ២ : ស្ដេចផារ៉ោន ជានាមដែលបានប្រទានឲ្យ ដោយតួអក្សរនៅខាងលើព្រះសិរទ្រង់ ។

រូបទី ៣ : ជាលោកអ័ប្រាហាំនៅស្រុកអេស៊ីព្ទ ដូចជាបានប្រាប់នៅក្នុងរូបទី ១០ នៃវត្ថុចម្លងតាមលេខទី ១ ។

រូបទី ៤ : ស្ដេចផារ៉ោន ជាស្ដេចនៃស្រុកអេស៊ីព្ទ ដូចដែលបានសរសេរទុកនៅខាងលើដៃ ។

រូបទី ៥ : ស៊ូឡិម ជាខ្ញុំកំដរឯករបស់ស្ដេច ដូចជាតំណាងដោយតួអក្សរនៅខាងលើដៃគាត់ ។

រូបទី ៦ : អូលិមឡា ជាខ្ញុំបំរើរបស់ស្ដេច ។

លោកអ័ប្រាហាំកំពុងតែអធិប្បាយប្រាប់ពីគោលការណ៍អំពីតារាសាស្ត្រ នៅក្នុងវាំងស្ដេច ។

បានបង្កើតគេមក គឺជាប្រុសជាស្រី ព្រះទាំងឡាយទ្រង់បាន
បង្កើតគេឡើង ។
២៨ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ យើងនឹងប្រទានពរ
ដល់ពួកគេ ។ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ យើងនឹង
បណ្ដាល ឲ្យពួកគេបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមាន
ពាសពេញលើផែនដី ហើយបង្ក្រាបផែនដី ហើយមានអំណាច
ត្រួតត្រាលើ ត្រីសមុទ្រ និងលើសត្វហើរលើអាកាស និងលើ
ជីវិតផងទាំងឡាយដែលកំរើកនៅផែនដីផង ។
២៩ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ មើលចុះ យើងបាន
ប្រទានដល់ពួកគេ នូវគ្រប់ទាំងតិណជាតិមានគ្រាប់ពូជ ដែលនឹង
ដុះនៅ លើផ្ទៃផែនដី និងគ្រប់ទាំងដើមឈើទាំងឡាយដែល
នឹងកើតផ្លែ; មែនហើយ គឺផ្លែឈើដែលមានគ្រាប់តាមពូជវា
នោះយើងនឹងប្រទាន ដល់ពួកគេ; របស់ទាំងនោះនឹងទៅជា
[ក]អាហារដល់ពួកគេ ។
៣០ ហើយចំពោះអស់ទាំងសត្វនៅលើផែនដី និងចំពោះសត្វ
ហើរលើអាកាស និងចំពោះគ្រប់សត្វទាំងឡាយ ដែលលូនវារ
នៅលើ ផែនដីផង មើលចុះ យើងនឹងប្រទានឲ្យមានជីវិត
ហើយយើងក៏នឹងប្រទានគ្រប់តិណជាតិខ្ចីៗឲ្យធ្វើជាអាហារ; ហើយ
អស់ទាំងរបស់ ទាំងនេះ នឹងត្រូវបានរៀបចំយ៉ាងដូច្នោះហើយ ។
៣១ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ យើងនឹងធ្វើអ្វីៗគ្រប់
យ៉ាងដែលយើងបានមានបន្ទូល ហើយរៀបចំរបស់ទាំងនោះឡើង;
ហើយមើលចុះ របស់ទាំងនោះនឹងគោរពតាមណាស់ ។ ហើយ
ហេតុការណ៍បានកើតឡើងថា ពីល្ងាចទៅដល់ព្រឹក នោះព្រះទាំង
ឡាយ ទ្រង់ហៅថា យប់; ហើយហេតុការណ៍បានកើតឡើងថា
ពីព្រឹកទៅដល់ល្ងាច នោះព្រះទាំងឡាយទ្រង់ហៅថា ថ្ងៃ;
ហើយព្រះទាំងឡាយទ្រង់បាន រាប់លើក[ក]ទីប្រាំមួយ ៕

## ជំពូកទី ៥

*ក្រុមព្រះបញ្ចប់គំរោងការរបស់ព្រះទាំងឡាយខាងការបង្កបង្កើតរបស់របរគ្រប់យ៉ាង — ព្រះទាំងឡាយទ្រង់សំរេចការបង្កបង្កើត ស្របតាមគំរោងការរបស់ព្រះទាំងឡាយ — លោកអ័ដាមឲ្យឈ្មោះដល់គ្រប់ទាំងសត្វដែលមានជីវិត។*

ហើយដូច្នេះ យើងនឹងសំរេចផ្ទៃមេឃ និងផែនដី និង
អ្វីៗសព្វសារពើនៅលើទីនោះផង ។
២ ហើយក្រុមព្រះបានមានព្រះបន្ទូលជាមួយគ្នាថា៖ នៅគ្រា
[ក]ទីប្រាំពីរ នោះយើងនឹងបញ្ចប់កិច្ចការរបស់យើង ដែលយើងបាន
ប្រឹក្សាគ្នា; ហើយយើងនឹងសំរាកនៅគ្រាទីប្រាំពីរ ពីគ្រប់ទាំង
កិច្ចការដែលយើងបានប្រឹក្សាគ្នា ។
៣ ហើយក្រុមព្រះបានបញ្ចប់នៅគ្រាទីប្រាំពីរ ពីព្រោះនៅគ្រា
ទីប្រាំពីរ ព្រះទាំងឡាយនឹង[ក]សំរាកពីគ្រប់ទាំងកិច្ចការដែលព្រះ
ទាំងឡាយ[ខ]ទ្រង់ (ក្រុមព្រះ) បានប្រឹក្សាគ្នា ដើម្បីនឹងសូនឡើង;
ហើយបានញែកគ្រានោះចេញជាបរិសុទ្ធ ។ ហើយការសំរេចចិត្ត
របស់ព្រះទាំងឡាយ គឺយ៉ាង ដូច្នោះហើយ នៅពេលព្រះទាំង
ឡាយទ្រង់បានប្រឹក្សាគ្នា ដើម្បីនឹងសូននូវផ្ទៃមេឃ និងផែនដី ។
៤ ហើយក្រុមព្រះបានយាងចុះមក ហើយបានសូននូវរបស់
ទាំងនេះ ដែលជាដើមកំណើតនៃផ្ទៃមេឃ និងផែនដី ក្នុងកាល
ដែលបានសូន មក គឺនៅវេលា ដែលព្រះទាំងឡាយទ្រង់
បានសូននូវផែនដី និងផ្ទៃមេឃ,
៥ ស្របតាមអ្វីៗទាំងអស់ដែលព្រះទាំងឡាយទ្រង់បានមានព្រះ
បន្ទូល អំពីតិណជាតិគ្រប់យ៉ាងនៅវាល [ក]មុនមាននៅលើផែនដី
ព្រមទាំង រុក្ខជាតិគ្រប់យ៉ាងនៅវាល មុនដែលដុះមកផង; ត្បិត
ក្រុមព្រះពុំទាន់បានបង្អុរភ្លៀងមកលើផ្ទៃផែនដីទេ កាលព្រះទាំងឡាយ
ទ្រង់ប្រឹក្សាគ្នា ហើយពុំទាន់បានសូនមនុស្ស ឲ្យភ្ជួរដីនៅឡើយទេ ។
៦ ប៉ុន្តែស្រាប់តែមានចំហាយឡើងពីដីមក ហើយស្រោចស្រប់
គ្រប់លើផ្ទៃដី ។
៧ ហើយ[ក]ក្រុមព្រះបានសូនមនុស្សពី[ខ]ធូលីដី ហើយយក[គ]វិញ្ញាណ
គាត់ (គឺថា វិញ្ញាណរបស់មនុស្ស) ហើយដាក់ទៅក្នុងរូបគាត់;
ហើយក៏ផ្លុំខ្យល់ដង្ហើម[ឃ]ជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះគាត់ ហើយ
មនុស្សក្លាយទៅជាមានព្រលឹងរស់ឡើង ។
៨ ហើយក្រុមព្រះបានធ្វើសួនច្បារមួយនៅ[ក]ស្រុកអេដែនទិស
ខាងកើត ហើយព្រះទាំងឡាយទ្រង់បានដាក់មនុស្សឲ្យនៅទីនោះ
គឺជាវិញ្ញាណ ដែលព្រះទាំងឡាយទ្រង់បានដាក់ទៅក្នុងរូបដែល
ព្រះទាំងឡាយទ្រង់បានសូនមកនោះ ។
៩ ហើយចេញពីដី នោះក្រុមព្រះបានធ្វើឲ្យដុះគ្រប់អស់
ទាំងដើមឈើ ដែលគួរជាទីគាប់ដល់ចក្ខុ ល្អសំរាប់ធ្វើ

២៩ *ក* លោកុ. ១:២៩–៣០.
៣១ *ក* និក្ខ. ៣១:១៧.
**៥** ២ *ក* ស.ប. ថ្ងៃឈប់សំរាក.
៣ *ក* និក្ខ. ២០:៨–១១;
ម៉ូសាយ ១៣:១៦–១៩.
*ខ* គ. និង ស. ៧៧:១២.
៥ *ក* ស.ប. ការបង្កបង្កើតខាងវិញ្ញាណ.
៧ *ក* អ័ប្រា. ៤:២៦–៣១.
*ខ* ម៉ូសេ ៤:២៥; ៦:៥៩.
*គ* លោកុ. ២:៧;
គ. និង ស. ៩៣:៣៣.
ស.ប. ជីវិតមុនផែនដី; វិញ្ញាណ.
*ឃ* ស.ប. ព្រលឹង.
៨ *ក* ស.ប. អេដែន.

ជាអាហារ; ទាំង[ក]ដើមជីវិតនៅកណ្ដាលសួនច្បារ ព្រមទាំងដើម
សំរាប់ដឹងខុសត្រូវផង ។
១០ មានទន្លេមួយហូរចេញពីស្រុកអេដែន មកស្រោច
សួនច្បារនោះ; ហើយហូរបែកពីនោះ ហើយក្លាយទៅជាបួនមុខ ។
១១ ហើយក្រុមព្រះបានយកមនុស្សទៅ ហើយដាក់គាត់នៅ
ក្នុងសួនច្បារអេដែន ឲ្យធ្វើការហើយថែរក្សាសួនច្បារនោះ ។
១២ ហើយក្រុមព្រះបានបញ្ជាដល់បុរសថា៖ ផ្លែឈើទាំង
អស់នៅក្នុងសួនច្បារ នោះអ្នកអាចបរិភោគបានតាមចិត្ត,
១៣ ប៉ុន្តែផលពីដើមដឹងខុសត្រូវ នោះអ្នកមិនត្រូវបរិភោគឡើយ
ត្បិតនៅពេលណាដែលអ្នកបរិភោគ នោះអ្នកនឹងត្រូវស្លាប់ជា
មិនខានឡើយ ។ ឥឡូវនេះ ខ្ញុំ អ័ប្រាហាំ បានឃើញថា ពេលនោះ
គឺរាប់តាម[ក]ពេលវេលារបស់ព្រះអម្ចាស់ ដែលរាប់តាមពេលវេលា
នៅ[ខ]កូឡុប; ត្បិតក្រុមព្រះពុំទាន់បានកំណត់ដល់លោកអ័ដាម តាម
របៀបរៀបរាប់របស់លោកនៅឡើយទេ ។
១៤ ហើយក្រុមព្រះបានមានព្រះបន្ទូលថា៖ តោះ ចូរយើងធ្វើឲ្យ
មានជំនួយម្នាក់សមសំរាប់ជួយគាត់ ត្បិតមិនល្អទេដែលបុរសគួរនៅ
ម្នាក់ឯង ហេតុដូច្នេះហើយ យើងនឹងសូនជាជំនួយមួយដ៏សម
ចំពោះគាត់ ។
១៥ ហើយក្រុមព្រះបានធ្វើឲ្យ[ក]អ័ដាមដេកលង់លក់ទៅ ហើយ
គាត់ក៏ដេកលក់ ហើយព្រះទាំងឡាយទ្រង់បានយកឆ្អឹកជំនីរគាត់
មួយ ហើយភ្ជិត សាច់ទៅវិញ;
១៦ ហើយរីឯឆ្អឹងជំនីរដែលក្រុមព្រះបានយកពីបុរសមក នោះ
ព្រះទាំងឡាយទ្រង់បានសូនជា[ក]ស្ត្រីមួយ ហើយនាំនាងទៅឯបុរស ។
១៧ ហើយអ័ដាមក៏ថា៖ នេះគឺជាឆ្អឹងពីឆ្អឹងខ្ញុំ ហើយជាសាច់ពី
សាច់ខ្ញុំ; ឥឡូវនេះ នាងនឹងត្រូវបានហៅថា «ស្ត្រី» ពីព្រោះ
នាងត្រូវបានយកចេញពីបុរសមក ។
១៨ ហេតុដូច្នេះហើយ[ក] បានជាមនុស្សប្រុសនឹងលាចេញពីឪពុក
ម្ដាយខ្លួន ហើយទៅនៅជាប់[ខ]នឹងប្រពន្ធរបស់ខ្លួន ហើយអ្នក
ទាំងពីរ នោះនឹងត្រូវជាសាច់តែមួយសុទ្ធ ។
១៩ ហើយគេទាំងពីរនាក់នៅខ្លួនអាក្រាតទទេ គឺបុរសនិង
ប្រពន្ធគាត់ ហើយឥតមានសេចក្ដីខ្មាសអៀនឡើយ ។
២០ ហើយក្រុមព្រះបានយកដីមកសូននូវគ្រប់ទាំងសត្វជើងបួន
នៅវាល និងគ្រប់ទាំងសត្វហើរលើអាកាសផង; ហើយបាននាំ
សត្វ ទាំងនោះមកឯអ័ដាម ដើម្បីឲ្យដឹងជាគាត់នឹងហៅដូចម្ដេច;
ហើយឈ្មោះណាក៏ដោយដែលអ័ដាមបានដាក់ឲ្យដល់គ្រប់ទាំ
ងជីវិតផង ទាំងឡាយ នោះបានសំរេចជាឈ្មោះរបស់
សត្វនោះឯង ។
២១ ហើយអ័ដាមបានដាក់ឈ្មោះឲ្យដល់គ្រប់ទាំងសត្វស្រុក
សត្វព្រៃ និងសត្វហើរលើអាកាសទាំងប៉ុន្មានជាស្រេច; ហើយ
ចំពោះអ័ដាម វិញ នោះឃើញថាមានជំនួយមួយដ៏សមចំពោះ
គាត់ ៕

៩ *ក* ស.ប. ដើមជីវិត.
១៣ *ក* ២ ពេត្រុស ៣:៨.
*ខ* អ័ប្រា. ៣:២–៤. ស.ប. កូឡុប.
១៥ *ក* ស.ប. អ័ដាម.
១៦ *ក* ស.ប. នាងអេវ៉ា.
១៨ *ក* គ. និង ស. ៤២:២២; ៤៩:១៥–១៦.
*ខ* ស.ប. អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍.

# យ៉ូសែប ស៊្មីធ — ម៉ាថាយ

*ជាការដកស្រង់ចេញពីការបកប្រែព្រះគម្ពីរប៊ីប ដូចដែលបានបើកសម្ដែងប្រាប់ដល់ យ៉ូសែប ស៊្មីធ នៅឆ្នាំ ១៨៣១៖ ម៉ាថាយ ២៣:៣៩ និងជំពូកទី ២៤ ។*

*ព្រះយេស៊ូវទ្រង់ប្រាប់ទុកជាមុន អំពីការបំផ្លិចបំផ្លាញដែលនឹងកើតឡើងដល់ក្រុងយេរូសាឡិម — ទ្រង់ព្រមទាំងបរិយាយប្រាប់ពីការយាង មកលើកទីពីររបស់កូនមនុស្ស និងការបំផ្លិចបំផ្លាញពួកទុច្ចរិត ។*

ត្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា អ្នករាល់គ្នានឹងលែងឃើញខ្ញុំ
ទៀតហើយពីនេះទៅមុខ ហើយនឹងដឹងថា ខ្ញុំនេះហើយជា
អ្នកនោះ ដែលត្រូវ សរសេរទុកដោយព្យាការី ដរាបដល់
អ្នករាល់គ្នានឹងនិយាយថា៖ សូមមានព្រះពរ ដល់
ព្រះអង្គដែល[ក]យាងមក ដោយនូវព្រះនាម ព្រះអម្ចាស់ មកលើ
ពពកនៅលើមេឃ មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា
មកជាមួយ ទ្រង់ផង ។ ខណៈនោះ ស្រាប់តែពួកសិស្ស ទ្រង់
យល់ថា ព្រះអង្គនឹងយាងមកលើផែនដីម្ដងទៀត បន្ទាប់ពីទ្រង់
បានទទួលការរុងរឿង ហើយបានពាក់មកុដនៅខាងស្ដាំព្រះ
ហស្ត [ខ]នៃព្រះ ។
២ ហើយព្រះយេស៊ូវបានយាងចេញពីព្រះវិហារទៅ; ហើយ
ពួកសិស្សទ្រង់បានមករកទ្រង់ដើម្បីស្ដាប់ទ្រង់ ដោយទូលថា៖
លោកគ្រូ សូមបង្ហាញដល់យើងខ្ញុំ ពីការសាងព្រះវិហារ ដូច
ដែលព្រះអង្គបានមានព្រះបន្ទូលថា — របស់ទាំងនោះនឹងត្រូវ
ទំលាក់ចុះ ហើយចោល ស្ងាត់ទុកឲ្យអ្នក ។
៣ ហើយព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅគេថា៖ តើអ្នក
រាល់គ្នាមើលមិនឃើញការណ៍ទាំងអស់នេះឬទេ ហើយតើអ្នក
រាល់គ្នាមិន យល់ទេឬអី ? ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា
នៅទីនេះ គឺនៅលើព្រះវិហារនេះ [ក]នឹងគ្មានថ្មនៅត្រួតលើថ្ម ដែល
មិនត្រូវទំលាក់ចុះ នោះទេ ។
៤ ហើយព្រះយេស៊ូវបានចេញពីពួកគេ ហើយទៅលើ[ក]ភ្នំដើម
អូលីវ។ ហើយកាលទ្រង់គង់នៅលើភ្នំដើមអូលីវ នោះពួកសិស្ស
បានមកឯ ទ្រង់ដោយឡែក ដោយទូលថា៖ សូមប្រាប់យើងខ្ញុំ
តើកាលណាការណ៍ទាំងនេះដែលព្រះអង្គបានមានព្រះបន្ទូល
ពីការបំផ្លិចបំផ្លាញ ព្រះវិហារ និងពួកសាសន៍យូដា នឹងមកដល់;
ហើយតើមាន[ខ]ទីសំគាល់ណាប្រាប់ពី[គ]ការយាងមករបស់ទ្រង់ និងពី
[ឃ]ចុងបំផុតនៃពិភពលោក ឬការបំផ្លិចបំផ្លាញនៃ[ង]ពួកទុច្ចរិត ដែលជា
ចុងបំផុតនៃពិភពលោកនោះ ?
៥ ហើយព្រះយេស៊ូវទ្រង់ឆ្លើយ ហើយមានព្រះបន្ទូលទៅពួក
គេថា៖ ចូរប្រយ័ត្ន ដើម្បីកុំឲ្យអ្នកណាបញ្ឆោតអ្នកឡើយ;
៦ ត្បិតនឹងមានមនុស្សជាច្រើនមក ដោយនូវឈ្មោះខ្ញុំ ដោយ
និយាយថា — ខ្ញុំជាព្រះគ្រីស្ទ — ហើយនឹងបញ្ឆោតមនុស្ស
ជាច្រើន;
៧ គ្រានោះ គេនឹងបញ្ជូនអ្នករាល់គ្នាទៅឲ្យមាន[ក]សេចក្ដីវេទនា
ហើយព្រមទាំងសំឡាប់អ្នករាល់គ្នា ហើយអ្នករាល់គ្នានឹងត្រូវគ្រប់
ទាំង សាសន៍[ខ]ស្អប់ ដោយព្រោះឈ្មោះខ្ញុំ;
៨ ហើយនៅគ្រានោះ មនុស្សជាច្រើននឹងរវាតចិត្តចេញ ហើយ
នឹងក្បត់គ្នាទៅវិញទៅមក ហើយនឹងស្អប់គ្នាទៅវិញទៅមក;
៩ ហើយនឹងមានព្យាការីក្លែងក្លាយជាច្រើនកើតឡើង ហើយ
នឹងបញ្ឆោតមនុស្សជាច្រើនដែរ;
១០ ហើយពីព្រោះសេចក្ដីទុច្ចរិតនឹងចំរើនជាច្រើនឡើង បាន
[ក]ជាសេចក្ដីស្រឡាញ់នៃមនុស្សជាច្រើននឹងរសាយអស់ទៅ;
១១ ប៉ុន្តែអ្នកណាដែលកាន់ខ្ជាប់ ហើយមិនព្រមចុះចាញ់ទេ
អ្នកនោះនឹងបានសង្គ្រោះ ។
១២ ហេតុដូច្នេះហើយ កាលណាអ្នករាល់គ្នាឃើញ[ក]សេច
ក្ដីខែមឆ្អើមនៃការបង្ខូចបំផ្លាញ ដែលបានពោលដល់[ខ]ដោយ
ព្យាការីដានីយ៉ែល អំពីសេចក្ដីបំផ្លិចបំផ្លាញ[គ]ក្រុងយេរូសាឡិម

១ ១*ក* ម៉ាថាយ ២៦:៦៤; កិច្ចការ ១:១១.
*ខ* ស.ប. ព្រះ, ក្រុមព្រះ.
៣ *ក* លូកា ១៩:៤៤.
៤ *ក* ស.ប. ដើមអូលីវ, ភ្នំ.
*ខ* លូកា ២១:៧–៣៦;
គ. និង ស. ៤៥:១៦–៧៥.
ស.ប. គ្រាចុងក្រោយបង្អស់,
គ្រាចុងក្រោយ;
ទីសំគាល់អំពីពេលវេលា.
*គ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ឃ* ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.
*ង* ម៉ាឡាគី ៤:១;
គ. និង ស. ១៣៣:៦៤–៧៤.
ស.ប. ទុច្ចរិត, អំពើទុច្ចរិត.
៧ *ក* ១ ពេត្រុស ៤:១២–១៤.
*ខ* ស.ប. បៀតបៀន, សេចក្ដីបៀតបៀន.
១០ *ក* គ. និង ស. ៤៥:២៧.
១២ *ក* ដានី. ១២:១១.
*ខ* ស.ប. ដានីយ៉ែល.
*គ* ស.ប. ក្រុងយេរូសាឡិម.

គ្រានោះ អ្នករាល់គ្នានឹងឈរនៅក្នុង[ឃ]ទីបរិសុទ្ធ; អ្នកណាដែលអានមើល សូមយល់ចុះ ។

១៣ គ្រានោះ ចូរឲ្យពួកអ្នកដែលនៅស្រុកយូដា រត់ចេញទៅឯ[ក]ភ្នំទាំងឡាយចុះ;

១៤ ចូរឲ្យអ្នកណាដែលនៅលើដំបូលផ្ទះរត់ចេញទៅ ហើយចូរកុំឲ្យត្រឡប់ទៅយករបស់អ្វីពីផ្ទះរបស់ខ្លួនឡើយ;

១៥ ឬមិនឲ្យអ្នកណាដែលនៅស្រែចំការ ត្រឡប់មកវិញ ដើម្បីនឹងយកសំលៀកបំពាក់របស់ខ្លួនឡើយ;

១៦ ហើយនៅគ្រានោះ វេទនាហើយ ដល់អស់អ្នកណាដែលមាន[ក]ផ្ទៃពោះ ហើយដល់អស់អ្នកណាដែលបំបៅកូន;

១៧ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាអធិស្ឋានដល់ព្រះអម្ចាស់ សូមកុំឲ្យអ្នកត្រូវរត់នៅរដូវរងា ឬនៅថ្ងៃឈប់សំរាកឡើយ;

១៨ ត្បិតនៅគ្រានោះ នឹងមានសេចក្ដីវេទនាជាខ្លាំងណាស់ដល់[ក]ពួកសាសន៍យូដា និងមកលើបណ្ដាជននៅ[ខ]ក្រុងយេរូសាឡិម ដូចដែល មិនដែលបានចាត់ពីព្រះ មកលើសាសន៍អ៊ីស្រាអែលដល់ម្ល៉េះឡើយ តាំងពីដើមកំណើតនគររបស់ពួកគេ រហូតមកដល់សព្វថ្ងៃនេះ; ទេ មិនដែលមានយ៉ាងដូច្នោះឡើយ ហើយនឹងមិនចាត់មកលើសាសន៍អ៊ីស្រាអែលទៀតដែរ ។

១៩ គ្រប់ការណ៍ទាំងអស់ដែលធ្លាក់លើពួកគេ នោះគ្រាន់តែជាការចាប់ផ្ដើមនៃសេចក្ដីទុក្ខសោក ដែលនឹងធ្លាក់មកលើគេ ។

២០ ហើយលើកលែងតែបន្ថយគ្រានោះឲ្យខ្លីចុះ នោះគ្មានមនុស្សណានឹងបានសង្គ្រោះនៅក្នុងសាច់ឈាមឡើយ; ប៉ុន្តែដោយព្រោះ យល់ដល់ពួករើសតាំង ស្របតាមសេចក្ដីសញ្ញា ទើបថ្ងៃនោះនឹងបានបន្ថយឲ្យខ្លីចុះ ។

២១ មើលចុះ ការណ៍ទាំងនេះខ្ញុំបានប្រាប់ដល់អ្នករាល់គ្នា អំពីពួកសាសន៍យូដា; ហើយជាថ្មីទៀត បន្ទាប់ពីសេចក្ដីវេទនានៅគ្រានោះ នឹងកើតមកលើក្រុងយេរូសាឡិម បើសិនជាមានអ្នកណាមួយប្រាប់អ្នករាល់គ្នាថា មើល ព្រះគ្រីស្ទគង់នៅទីនេះ ឬនៅទីនោះ នោះកុំឲ្យ ជឿគេឡើយ;

២២ ត្បិតនៅគ្រានោះ នឹងមានព្រះគ្រីស្ទក្លែងក្លាយ ហើយព្យាការីក្លែងក្លាយកើតឡើង ហើយនឹងបង្ហាញទីសំគាល់យ៉ាងធំនិងការ អស្ចារ្យ ដរាបដល់ពួកគេអាចបញ្ឆោតទាំងពួករើសតាំងដែលជាពួករើសតាំង ស្របតាមសេចក្ដីសញ្ញា បើសិនជាធ្វើទៅបាន ។

២៣ មើលចុះ ខ្ញុំនិយាយពីការណ៍ទាំងនេះប្រាប់ដល់អ្នករាល់គ្នា ដោយព្រោះយល់ដល់[ក]ពួករើសតាំង; ហើយអ្នករាល់គ្នាក៏នឹងឮអំពី [ខ]សង្គ្រាម និងពាក្យចចាមអារាមអំពីសង្គ្រាមទាំងឡាយ; ចូរមើលឲ្យឃើញថាអ្នករាល់គ្នាកុំខ្វល់ឡើយ ត្បិតគ្រប់អ្វីៗទាំងអស់ដែលខ្ញុំ និយាយប្រាប់អ្នករាល់គ្នា នោះច្បាស់ជានឹងបានសំរេច; ប៉ុន្តែពុំទាន់ដល់ចុងបំផុតនៅឡើយទេ ។

២៤ មើលចុះ ខ្ញុំបានប្រាប់អ្នករាល់គ្នាទុកជាមុន;

២៥ ហេតុដូច្នោះហើយ បើពួកគេនឹងប្រាប់អ្នករាល់គ្នាថា៖ មើលចុះ ទ្រង់គង់នៅទីរហោស្ថាន; ចូរកុំឲ្យទៅឡើយ៖ មើលចុះ ទ្រង់គង់នៅ ក្នុងបន្ទប់សម្ងាត់; ចូរកុំឲ្យជឿឡើយ;

២៦ ត្បិតដូចជាពន្លឺនៅពេលព្រលឹមស្រាង កំពុងតែរះឡើងពីទិស[ក]ខាងកើត ហើយភ្លឺដល់ទិសខាងលិច ហើយគ្របដណ្ដប់មកលើផែនដី ទាំងមូលជាយ៉ាងណា នោះការយាងមកនៃកូនមនុស្សក៏នឹងទៅជាយ៉ាងដូច្នោះដែរ ។

២៧ ហើយឥឡូវនេះ ខ្ញុំបង្ហាញដល់អ្នករាល់គ្នានូវពាក្យប្រៀបប្រដូចមួយ ។ មើលចុះ នៅកន្លែងណាដែលមានខ្មោចនោះឥន្ទ្រីនឹង [ក]ប្រជុំគ្នានៅកន្លែងនោះឯង; ដំណើរនេះក៏បែបដូច្នោះដែរ គឺពួករើសតាំងរបស់យើងនឹងប្រជុំគ្នាពីទិសទាំងបួននៃផែនដី ។

២៨ ហើយពួកគេនឹងឮពីសង្គ្រាម និងពាក្យចចាមអារាមអំពីសង្គ្រាមទាំងឡាយ ។

២៩ មើលចុះ ខ្ញុំនិយាយដោយយល់ដល់ពួករើសតាំងរបស់ខ្ញុំ; ពីព្រោះសាសន៍មួយនឹងលើកគ្នាទាស់នឹងសាសន៍មួយ នគរមួយនឹង ទាស់នឹងនគរមួយ; នឹងមាន[ក]អំណត់ និងជំងឺអាសន្នរោគ និងផែនដីកក្រើកនៅកន្លែងផ្សេងៗ ។

៣០ ហើយជាថ្មីទៀត ពីព្រោះសេចក្ដីទុច្ចរិតនឹងចំរើនជាច្រើនឡើង បានជាសេចក្ដីស្រឡាញ់នៃមនុស្សនឹងរសាយអស់ទៅ; ប៉ុន្តែអ្នកណា ដែលនឹងមិនព្រមចុះចាញ់ទេ អ្នកនោះនឹងបានសង្គ្រោះ ។

៣១ ហើយជាថ្មីទៀត ដំណឹងល្អនៃនគរនេះនឹងត្រូវបានផ្សាយនៅពាសពេញ[ក]ពិភពលោក ទុកជាទីបន្ទាល់ដល់គ្រប់ទាំងសាសន៍

១២ *ឃ* គ. និង ស. ១០១:២២–២៥.
១៣ *ក* គ. និង ស. ១៣៣:១៣.
១៦ *ក* លូកា ២៣:២៩–៣០.
១៨ *ក* ស.ប. ពួកសាសន៍យូដា.
*ខ* សាការី ១២; ១៤:១–៥.
២៣ *ក* ស.ប. ពួករើសតាំង.
*ខ* គ. និង ស. ៤៥:២៦.
២៦ *ក* អេសេ. ៤៣:២.
២៧ *ក* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
២៩ *ក* គ. និង ស. ៤៣:២៤–២៥.
៣១ *ក* ម៉ាថាយ ២៨:១៩–២០.

ហើយនៅគ្រានោះ ទើបចុងបំផុតមកដល់ ឬសេចក្ដីបំផ្លិចបំផ្លាញដល់ពួកទុច្ចរិត;

៣២ ហើយជាថ្មីទៀត សេចក្ដីខេមឆ្អើមនៃការបង្ខូចបំផ្លាញ ដែលបានពោលដល់ដោយព្យាការីដានីយ៉ែល នឹងបានសំរេច ។

៣៣ ហើយក្រោយសេចក្ដីវេទនារបស់ថ្ងៃនោះមក ស្រាប់តែព្រះអាទិត្យនឹងទៅជាងងឹត ហើយព្រះច័ន្ទនឹងលែងភ្លឺ ហើយអស់ទាំងតារា នឹងធ្លាក់ចុះពីលើមេឃ ហើយអំណាចទាំងឡាយនៅលើមេឃនឹងត្រូវកក្រើកកំរើក ។

៣៤ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្សតំណនេះ ដែលការណ៍ទាំងនេះនឹងត្រូវបានបង្ហាញមក នោះនឹងមិនកន្លងហួសបាត់ទៅឡើយ ទាល់តែគ្រប់ទាំងអស់ដែលខ្ញុំបានប្រាប់អ្នករាល់គ្នានឹងបានសំរេចសិន ។

៣៥ ទោះជាគ្រានោះនឹងមកដល់ក៏ដោយ កាលផ្ទៃមេឃ ហើយផែនដីនឹងកន្លងបាត់ទៅ; គង់តែពាក្យខ្ញុំមិនដែលបាត់ឡើយ ប៉ុន្តែគ្រប់ទាំងអស់នឹងបានសំរេចវិញ ។

៣៦ ហើយដូចជាខ្ញុំបានប្រាប់អ្នករាល់គ្នាពីមុនមកហើយថា ក្រោយសេចក្ដីវេទនារបស់គ្រានោះមក ហើយអំណាចទាំងឡាយនៅលើ មេឃនឹងត្រូវកក្រើកកំរើក គ្រានោះ ទើបទីសំគាល់របស់កូនមនុស្ស នឹងលេចមកនៅលើមេឃ ហើយនៅគ្រានោះ គ្រប់ពូជអំបូរមនុស្ស នៅផែនដីនឹងគក់ទ្រូងយំ; ហើយពួកគេនឹងឃើញកូនមនុស្សមកលើពពកនៅលើមេឃ មានទាំងព្រះចេស្ដា និងសិរីល្អផងខ្លាំង;

៣៧ ហើយអស់អ្នកណាដែលរក្សាពាក្យខ្ញុំទុក នោះនឹងមិនត្រូវបញ្ឆោតឡើយ ពីព្រោះកូនមនុស្សនឹងមក ហើយលោកនឹងចាត់ពួកទេវតា របស់លោក ឲ្យមកមុនលោក ដោយសូរផ្លុំត្រែជាខ្លាំង ហើយពួកគេនឹងប្រមូលពួករើសតាំងរបស់លោក ដែលនៅសល់ទាំងប៉ុន្មាន ពីទិសទាំងបួន ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង ។

៣៨ ឥឡូវនេះ ចូររៀនសេចក្ដីប្រៀបប្រដូចអំពីដើមល្វាថា — កាលណាមែកវានៅទន់នៅឡើយ ហើយវាចាប់ផ្ដើមដុះស្លឹកឡើង នោះអ្នករាល់គ្នាដឹងថា រដូវក្ដៅនៅជិតដែរបង្កើយ;

៣៩ ដំណើរនេះក៏បែបដូច្នោះដែរ គឺពួករើសតាំងរបស់ខ្ញុំ កាលណាពួកគេនឹងឃើញគ្រប់ការណ៍ទាំងនេះ នោះពួកគេក៏នឹងដឹងថា លោកជិតមកដល់ហើយ ក៏នៅមាត់ទ្វារផង;

៤០ ប៉ុន្តែត្រង់ថ្ងៃនោះ និងម៉ោង នោះគ្មានអ្នកណាដឹងទេ; ទោះទាំងពួកទេវតានៃព្រះដែលនៅលើស្ថានសួគ៌ក៏មិនដឹងដែរ ប៉ុន្តែមានតែព្រះវរបិតារបស់ខ្ញុំប៉ុណ្ណោះ ។

៤១ ប៉ុន្តែដូចជានៅជំនាន់លោកណូអេយ៉ាងណា នោះកូនមនុស្សក៏នឹងមកជាយ៉ាងដូច្នោះដែរ;

៤២ ត្បិតនឹងកើតដល់ពួកគេដូចជានៅគ្រាមុនទឹកលិចដែរ; ត្បិតដរាបដល់ថ្ងៃដែលលោកណូអេចូលទៅក្នុងទូកធំ នោះពួកគេកំពុងតែ ស៊ីផឹក ហើយរៀបការប្ដីប្រពន្ធ;

៤៣ ហើយឥតបានដឹងខ្លួនឡើយ ទាល់តែទឹកជន់ឡើង ហើយយកគេទៅទាំងអស់គ្នា; នោះដល់កាលកូនមនុស្សមក ក៏នឹងមានដូច្នោះ ដែរ ។

៤៤ នៅគ្រានោះ អ្វីៗដែលបានសរសេរទុកនឹងបានសំរេច គឺនៅថ្ងៃចុងក្រោយបង្អស់ នឹងមានមនុស្សពីរនាក់នៅចំការ ម្នាក់នឹងបាន យកទៅ ហើយម្នាក់ទុកនៅ;

៤៥ មនុស្សពីរនាក់កំពុងតែកិនម៉្សៅ ម្នាក់នឹងបានយកទៅ ហើយម្នាក់ទុកនៅ;

៤៦ ហើយអ្វីក៏ដោយដែលខ្ញុំប្រាប់ដល់មនុស្សម្នាក់ នោះខ្ញុំប្រាប់ដល់មនុស្សទាំងអស់; ដូច្នេះហើយ ឲ្យចាំយាម ត្បិតអ្នករាល់គ្នាមិនដឹង ជាពេលណា ដែលព្រះអម្ចាស់នៃអ្នករាល់គ្នានឹងយាងមកទេ ។

៤៧ ប៉ុន្តែចូរដឹងសេចក្ដីនេះចុះ បើសិនជាម្ចាស់ផ្ទះដែលល្អបានដឹងថាចោរនឹងមកនៅយាមណា នោះគាត់នឹងបានចាំយាម ហើយមិនទ្រាំ ឲ្យចោរទំលុះចូលផ្ទះគាត់បានទេ ប៉ុន្តែច្បាស់ជាបានរង់ចាំជាស្រេច ។

៤៨ ហេតុដូច្នេះហើយ ឲ្យអ្នករាល់គ្នាប្រុងប្រៀបខ្លួនជាស្រេចដែរ ត្បិតកូនមនុស្សនឹងមកនៅវេលាដែលអ្នករាល់គ្នាមិនគិត ។

៤៩ ខណៈនោះ តើអ្នកណាជាអ្នកបំរើស្មោះត្រង់ ហើយមាន

៣៣ *ក* យ៉ូអែល ២:១០;
គ. និង ស. ២៩:១៤.
៣៥ *ក* គ. និង ស. ១:៣៨.
៣៦ *ក* យ.ស. — ម៉ាថាយ ១:១៨.
*ខ* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
៣៧ *ក* ស.ប. បទព្រះគម្ពីរ.
*ខ* គ. និង ស. ២៩:១១–១៥.
*គ* ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
៣៨ *ក* គ. និង ស. ៣៥:១៦.
៤០ *ក* គ. និង ស. ៣៩:២០–២១; ៤៩:៧.
៤១ *ក* លោកុ. ៦:៥.
៤២ *ក* ស.ប. ទឹកជំនន់នៅសម័យណូអេ.
៤៤ *ក* ស.ប. គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ.
*ខ* សាការី ១៣:៨.
៤៦ *ក* ស.ប. ចាំយាម, ពួកអ្នកចាំយាម.
៤៩ *ក* ស.ប. ទុកចិត្ត.

មារយាទ ដែលចៅហ្វាយបានតាំងឲ្យត្រួតលើពួកផ្ទះលោក និងឲ្យអាហារ គេបរិភោគ តាមត្រូវពេល ?

៥០ មានពរហើយ ដល់អ្នកបំរើនោះ ដែលចៅហ្វាយខ្លួនឃើញថាកំពុងតែធ្វើការ ក្នុងកាលលោកមកដល់; ហើយខ្ញុំប្រាប់អ្នករាល់គ្នាជា ប្រាកដថា លោកនឹងតាំងអ្នកនោះឡើងឲ្យត្រួតលើរបស់ទ្រព្យលោកទាំងអស់ ។

៥១ [ក]ប៉ុន្តែបើសិនជាអ្នកបំរើអាក្រក់នោះនឹងគិតក្នុងចិត្តថា ចៅហ្វាយអញក្រមក,

៥២ ហើយក៏តាំងវាយដំពួកគូកន្លួខន ហើយព្រមទាំងស៊ីផឹកជាមួយនឹងពួកមនុស្សប្រមឹកផង,

៥៣ ចៅហ្វាយនៃអ្នកបំរើនោះនឹងមកដល់ នៅថ្ងៃណាដែលវាមិននៅចាំ ជាវេលាណាដែលវាមិនដឹង,

៥៤ ហើយនឹងកាត់វាជាដុំៗ ហើយនឹងឲ្យវាមានចំណែកជាមួយនឹងពួកមនុស្សមានពុតផង; នៅទីនោះនឹងយំ ហើយ[ក]សង្កៀតធ្មេញ ។

៥៥ ហើយទើប[ក]ចុងបំផុតនៃពួកទុច្ចរិតមកដល់ ស្របតាមពាក្យព្យាករណ៍នៃលោកម៉ូសេ ដែលថា៖ ពួកគេនឹងត្រូវកាត់កាល់ចេញពីចំ ណោមមនុស្ស; ប៉ុន្តែពុំទាន់ដល់ចុងបំផុតនៃផែនដីនៅឡើយទេ ប៉ុន្តែជាឆាប់ៗ ៕

៥១ *ក* គ. និង ស. ៤៥:២៦.
៥៤ *ក* ម៉ាថាយ ៨:១២.
៥៥ *ក* ២ នីហ្វៃ ៣០:១០; គ. និង ស. ១:៩–១០; ២៩:១៧.
ស.ប. ពិភពលោក — ចុងបំផុតនៃផែនដី.

# យ៉ូសែប ស៊្មីធ — ប្រវត្តិ

ជាសេចក្ដីដកស្រង់ចេញពីប្រវត្តិនៃយ៉ូសែប ស៊្មីធ ជាព្យាការី

*History of the Church,* Vol. 1, ជំពូកទី ១ ដល់ ទី ៥

*យ៉ូសែប ស៊្មីធ ប្រាប់ពីដូនតារបស់លោក សមាជិកក្នុងគ្រួសារ និងពីទីលំនៅគេមុនៗ — ការរំភើបុខសប្រក្រតីអំពីសាសនា ដែលមាន នៅរដ្ឋនូវយ៉ោកខាងលិច — លោកសំរេចចិត្ត នឹងស្វែងរកប្រាជ្ញា ដូចដែលយ៉ាកុបបានដឹកនាំ — ព្រះវរបិតា និងព្រះរាជបុត្រាលេចមក ហើយ យ៉ូសែបត្រូវបានហៅឲ្យ ធ្វើការងារបំរើរបស់លោកជាព្យាការី (ខ ១–២០) ។*

មកពីមានការរាយការណ៍ជាច្រើន ដែលបានបោះពុម្ពផ្សាយ ដោយពួកជនដែលប្រកបដោយការអាក្រក់ និងឧបាយកល ដែលទាក់ទង ទៅនឹងកំណើត[ក] និងការជឿនលឿនរបស់សាសនា[ខ]ចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ អ្វីៗទាំងអស់សុទ្ធតែបានចែង ឡើង ដោយពួកអ្នកនិពន្ធការរាយការណ៍នោះ ដើម្បីប្រយុទ្ធប្រឆាំងនឹងកេរ្តិ៍ឈ្មោះសាសនាចក្រ និងការជឿនលឿននៃសាសនាចក្រ នៅក្នុងពិភពលោក — នោះខ្ញុំត្រូវបានអន្ទោកអន្ទោងឲ្យសរសេរប្រវត្តិនេះ ដើម្បីកែខៃគំនិតមនុស្ស ហើយតម្រង់មនុស្សទាំងអស់ដែល ស្វែងរកសេចក្ដីពិតចំពោះការពិតត្រង់ តាមដែលការនោះបានកើតឡើង ដែលទាក់ទងទៅនឹងរូបខ្ញុំ និងសាសនាចក្រ ស្របតាមការពិត ដែលខ្ញុំមាន ។

២ នៅក្នុងប្រវត្តិនេះ ខ្ញុំនឹងថ្លែងប្រាប់ពីហេតុការណ៍នានា ដែលទាក់ទងទៅនឹងសាសនាចក្រនេះ ដោយនូវសេចក្ដីពិត និងសេចក្ដី សុចរិត តាមដែលការណ៍នោះបានកើតឡើង ឬដូចដែលមាននៅសព្វថ្ងៃនេះ ឥឡូវនេះ [១៨៣៨] ប្រាំបីឆ្នាំមកហើយ ចាប់តាំងពី [ក]បានរៀបចំសាសនាចក្រដែលបានពោលនោះមក ។

៣ [ក]ខ្ញុំកើតនៅឆ្នាំនៃព្រះអម្ចាស់របស់យើង គឺមួយពាន់ប្រាំបីរយប្រាំ នៅថ្ងៃទី ២៣ ក្នុងខែធ្នូ នៅភូមិសារុន ឃុំវិនសើរ រដ្ឋវ័រម៉ុន្ត ។ … ឪពុកខ្ញុំ ជា[ខ]យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ បានចាកចេញពីរដ្ឋវ័រម៉ុន្ត ហើយរើទៅនៅភូមិប៉ាលម៉ៃរ៉ា ឃុំអុនតារីយ៉ូ (ឥឡូវនេះ វេញ) នៅរដ្ឋ នូវយ៉ោក កាលខ្ញុំមានអាយុ ១០ ឆ្នាំ ឬប្រហែលប៉ុណ្ណោះ ។ ប្រហែលជាបួនឆ្នាំបន្ទាប់ពីឪពុកខ្ញុំមកនៅភូមិប៉ាលម៉ៃរ៉ា នោះគាត់រើជាមួយ គ្រួសារគាត់ ទៅនៅភូមិម៉ែនឆែសស្ទើរ នៅឃុំអុនតារីយ៉ូដដែល —

៤ [ក]គ្រួសារគាត់មានមនុស្ស១១នាក់ រាប់តាមឈ្មោះគឺ ឪពុកខ្ញុំ គឺ យ៉ូសែប ស៊្មីធ; [ខ]ម្ដាយខ្ញុំ គឺ លូស៊ី ស៊្មីធ (នាមត្រកូលនាងកាលមុនរៀប ការ គឺ ម៉ាក ជាកូនស្រីរបស់ សាឡូម៉ូន ម៉ាក); ពួកបងប្អូនប្រុសខ្ញុំ គឺ [គ]អាលវិន (ដែលស្លាប់នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ១៨២៣ ស្លាប់កាលគាត់មានអាយុ២៦ឆ្នាំ), [ឃ]ហៃរុម, រូបខ្ញុំ, [ង]សាំយូអែល ហារីសុន, វិលលាម, ដន ខារឡូស; និងពួកបងប្អូនស្រីខ្ញុំ គឺ សូផ្រូនា, កាទេរិន, និង លូស៊ី ។

៥ រវាងឆ្នាំទីពីរបន្ទាប់ពីពួកយើងផ្លាស់ទីលំនៅទៅនៅភូមិម៉ែនឆែសស្ទើរ នៅកន្លែងដែលយើងរស់នៅ នោះមានការរំភើបុខសប្រក្រតី អំពីវិស័យសាសនា ។ ការរំភើបនោះបានចាប់ផ្ដើមឡើង នៅក្នុងបក្សពួកមែថូឌីស្ទ ប៉ុន្តែមិនយូរប៉ុន្មានក៏ក្លាយជាការរំភើបទូទៅ រវាង បក្សពួកទាំងអស់នៅតំបន់ស្រុកនោះ ។ ពិតមែនហើយ តំបន់ស្រុកទាំងមូលហាក់ដូចជាមានការរំភើប ហើយហ្វូងមនុស្សដ៏ធំបាន រួមគ្នាចូលបក្សពួកសាសនាផ្សេងៗពីគ្នា ដែលបណ្ដាលឲ្យមានការរំជួល និងការបែកបាក់ដ៏មិនតូចទេ នៅក្នុងចំណោមប្រជាជនខ្លះ ស្រែកថា៖ «[ក]មើលន៏ នៅទីនេះ !» ហើយខ្លះទៀតថា៖ «មើលន៏ នៅទីនោះ !» ខ្លះកំពុងតែប្រជែងគ្នាយកសេចក្ដីជំនឿខាង ពួកមែថូឌីស្ទ ខ្លះយកខាងពួកប្រែសប៊ីធារាន ហើយខ្លះយកខាង ពួកបាទីស្ទ ។

៦ ត្បិតទោះជាពួកអ្នកប្រែចិត្តជឿផ្សេងៗទាំងនេះបានសម្ដែងសេចក្ដីស្រឡាញ់ដ៏ធំ នៅពេលពួកគេបានប្រែចិត្តជឿក្ដី ហើយទោះជាពួកអាចារ្យនានាបានសម្ដែងសេចក្ដីឧស្សាហ៍ដ៏ធំ ដោយខំប្រឹងប្រែងខាងការញុំាង និងការផ្សាយអំពីស្ថានការណ៍ដ៏អស្ចារ្យខាង វិស័យសាសនា ដើម្បីចង់ឲ្យមនុស្សគ្រប់រូបប្រែចិត្តជឿ ដូចជាពួកគេចូលចិត្តហៅមនុស្សដែលចូលរួម ដោយបណ្ដោយឲ្យគេចូលរួមនឹង បក្សពួកណាតាមតែចិត្តគេក្ដី; គង់តែកាលណាពួកអ្នកប្រែចិត្តជឿបានចាប់ផ្ដើមបែកចេញ ខ្លះទៅបក្សមួយ ខ្លះ

១ *ក* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
*ខ* ស.ប. សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ.
២ *ក* គ. និង ស. ២០:១.
៣ *ក* ស.ប. ស៊្មីធ, យ៉ូសែប ជុញ៉័រ
*ខ* ២ នីហ្វៃ ៣:១៥.
៤ *ក* ស.ប. ស៊្មីធ, យ៉ូសែប ស៊ីញ៉័រ.
*ខ* ស.ប. ស៊្មីធ, លូស៊ី ម៉ាក.
*គ* គ. និង ស. ១៣៧:៥–៦.
*ឃ* ស.ប. ស៊្មីធ, ហៃរុម.
*ង* ស.ប. ស៊្មីធ, សាំយូអែល អេច.
៥ *ក* ម៉ាថាយ ២៤:២៣.

ទៅមួយទៀត នោះឃើញ ថាពួកអាចារ្យ និងពួកអ្នកប្រែចិត្តជឿធ្វើពុតជារាក់ទាក់នឹងគ្នា ជាជាងរាប់អានគ្នាពិតប្រាកដវិញ; ត្បិតចេះតែមានការរំជួល និងការអាក់ អន់ចិត្តជាខ្លាំងឡើង — អាចារ្យម្នាក់ទាស់នឹងអាចារ្យម្នាក់ទៀត ហើយអ្នកប្រែចិត្តជឿម្នាក់ទាស់នឹងអ្នកប្រែចិត្តជឿម្នាក់ទៀត ទោះបីជា ពួកគេធ្លាប់មានការរាប់អាននឹងគ្នាក៏ដោយ គង់តែការរាប់អាននោះលែងមានអស់រលីង ដោយសារតែពាក្យឈ្លោះប្រកែក និងការ ប្រកួតប្រជែងគ្នាខាងគំនិតជឿ ។

៧ ពេលនេះ ខ្ញុំនៅក្នុងវ័យ១៥ឆ្នាំ ។ គ្រួសាររបស់ឪពុកខ្ញុំកំពុងតែប្រែចិត្តជឿតាមជំនឿខាងពួកប្រែសប៊ីធារាន ហើយមានបួននាក់ ដែលបានចូលរួមនឹងសាសនាចក្រនោះ រាប់តាមឈ្មោះគឺ ម្ដាយខ្ញុំ គឺ លូស៊ី; បងប្រុសខ្ញុំ គឺ ហៃរុម និងប្អូនប្រុសខ្ញុំ គឺ សាំយូអែល ហារីសុន; និងបងស្រីខ្ញុំ គឺ សូហ្វ្រូនា ។

៨ នៅក្នុងគ្រាដែលមានសេចក្ដីរំភើបដ៏ធំនេះហើយ ដែលខ្ញុំមានគំនិតគិតពិចារណាដ៏ជ្រាលជ្រៅ ហើយមានចិត្តខ្វល់ខ្វាយជាខ្លាំង; ប៉ុន្ដែ ទោះជាខ្ញុំមានគំនិតគិតដ៏ជ្រាលជ្រៅ ហើយជួនកាលដ៏ខ្លាំងក្លាក្ដី គង់តែខ្ញុំទុកខ្លួនឲ្យឆ្ងាយពីបក្សពួកទាំងឡាយនេះដែរ ទោះបីខ្ញុំបានទៅ ប្រជុំជាមួយគេច្រើនដងច្រើនគ្រាតាមតែឱកាសដែលអាចធ្វើទៅបាន ។ កំឡុងពេលតមក នោះគំនិតខ្ញុំក្លាយទៅមានអារម្មណ៍ទៅ ខាងបក្សពួកមែថូឌីស្ទ ហើយខ្ញុំមានសេចក្ដីប៉ងប្រាថ្នាចង់ចូលរួមនឹងពួកគេ; ប៉ុន្ដែមានការរំជួល និងការឈ្លោះប្រកែកគ្នាជាខ្លាំង ក្នុងចំណោមបក្សពួកផ្សេងៗ ដល់ម្ល៉េះបានជាពិបាកដល់ជនដូចរូបខ្ញុំ ដែលនៅវ័យក្មេង ហើយមិនសូវស្គាល់មនុស្ស និងដឹងក្ដី ឲ្យចេះសំ រេចចិត្តថានរណាមួយត្រូវ ហើយនរណាមួយខុសនោះឡើយ ។

៩ ចិត្តរបស់ខ្ញុំនៅពេលនោះរំភើបជាខ្លាំង ដោយព្រោះមានសំរែក និងការជ្រួលច្របល់ដ៏ធំ ហើយឥតឈប់ឈរ ។ ពួកប្រែសប៊ីធារាន បានសំរេចចិត្តទាស់នឹងពួកបាទីស្ទ និងពួកមែថូឌីស្ទជាខ្លាំង ហើយបានប្រើអំណាចគ្រប់យ៉ាង ទាំងខាងវិចារណញ្ញាណ និងខាងកលល្បិចផង ដើម្បីបង្ហាញកំហុសរបស់បក្សពួកទាំងនោះ ឬយ៉ាងហោច ដើម្បីធ្វើឲ្យប្រជាជនគិតថាខ្លួនខុស ។ ផ្ទុយទៅវិញ ពួកបាទីស្ទ និងពួក មែថូឌីស្ទក៏ខប្រឹងប្រែងដែរ ក្នុងការឧស្សាហ៍តាំងលទ្ធិខ្លួន ហើយបង្ហាញថាពួកអ្នកផ្សេងសុទ្ធតែខុស ។

១០ នៅកណ្ដាលចំបាំងខាងពាក្យសំដី និងការជ្រួលច្របល់ខាងគំនិតជឿនេះ ខ្ញុំតែងតែគិតក្នុងចិត្តខ្ញុំថា៖ តើត្រូវធ្វើអ្វីហ្ន៎ ? តើបក្សពួកមួយ ណាទៅដែលត្រូវ ឬក៏គេសុទ្ធតែខុសទាំងអស់គ្នា ? បើសិនជាមានបក្សពួកណាមួយដែលត្រូវ នោះតើណាមួយទៅ ហើយតើខ្ញុំនឹង ស្គាល់តាមរបៀបណាបាន ?

១១ នៅពេលដែលខ្ញុំកំពុងតែគិតពិចារណា នៅក្រោមការពិបាកដ៏សែនធ្ងន់ធ្ងរ ដែលបានបណ្ដាលឡើង មកពីការប្រកួតប្រជែងនៃពួក សាសនា នោះថ្ងៃមួយ ខ្ញុំកំពុងតែអាននៅក្នុងសំបុត្រយ៉ាកុប ជំពូកទី១ ខទី៥ ដែលអានថា៖ *«តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ»* ។

១២ ពុំដែលមានបទគម្ពីរណាមួយ ដែលមានប្រសិទ្ធភាពទៅលើចិត្តមនុស្ស ដូចជាបទគម្ពីរនេះមានប្រសិទ្ធភាពមកលើចិត្តខ្ញុំឡើយ ។ មើលទៅហាក់បីដូចជាចូលមកពេញដួងចិត្តដោយឥទ្ធិពលដ៏មហិមា ។ ខ្ញុំតែងតែពិចារណាគិតអំពីរឿងនេះម្ដងហើយម្ដងទៀត ដោយ ដឹងថា បើមានអ្នកណាមួយដែលត្រូវការប្រាជ្ញាពីព្រះ គឺខ្លួនខ្ញុំនេះហើយ តែនឹងធ្វើយ៉ាងណា នោះខ្ញុំមិនដឹងទេ ហើយលើកលែងតែខ្ញុំ អាចបានប្រាជ្ញាលើសជាងដែលខ្ញុំមាន នោះខ្ញុំនឹងមិនដឹងសោះ ត្បិតពួកគ្រូបង្រៀនសាសនាពីបក្សពួកផ្សេងៗ គេយល់បទគម្ពីរតែមួយ ខុសឆ្ងាយពីគ្នា ធ្វើយ៉ាងនេះដូចជាបំផ្លាញនូវការទុកចិត្តទាំងអស់ បើចង់បានការដោះស្រាយនូវសំណួរនេះ ដោយពឹងផ្អែកទៅលើ ព្រះគម្ពីរប៊ីប ។

១៣ ជាយូរយារក្រែលមក ខ្ញុំបានសំរេចចិត្តថា ខ្ញុំត្រូវនៅក្នុងសេចក្ដីងងឹតងងល់តទៅ ឬក៏ខ្ញុំត្រូវធ្វើតាមពាក្យដែលយ៉ាកុបបានដឹកនាំ គឺថា ត្រូវសូមដល់ព្រះ ។ ជាយូរយារក្រែលមក ខ្ញុំបានប្ដេជ្ញាចិត្តថានឹង «សូមដល់ព្រះ» ដោយសំរេចចិត្តថា បើទ្រង់ប្រទានប្រាជ្ញាដល់ពួកអ្នក ដែលខ្វះប្រាជ្ញា ហើយនឹងប្រទានឲ្យដោយសទ្ធាឥតបន្ទោសផង នោះខ្ញុំនឹងប្រថុយចិត្តចុះ ។

១៤ ម្ល៉ោះហើយ ស្របតាមបែបនេះ គឺតាមការប្ដេជ្ញាចិត្តរបស់ខ្ញុំថានឹងសូមដល់ព្រះ ខ្ញុំបានចូលទៅក្នុងព្រៃ ដើម្បីនឹងបំរុងសូម នៅពេល ព្រលឹមនៃថ្ងៃដ៏ល្អភ្លឺស្វាង គឺនៅដើមនិទាឃរដូវ ក្នុងឆ្នាំមួយពាន់ប្រាំបីរយម្ភៃ គឺជាពេលដំបូងបំផុតនៅក្នុងជីវិតខ្ញុំ ដែលខ្ញុំបានបំរុងធ្វើយ៉ាង នេះ ត្បិតនៅកណ្ដាលការថប់បារម្ភរបស់ខ្ញុំទាំងអស់ នោះខ្ញុំពុំដែលបំរុងនឹងអធិស្ឋានចេញសម្លេងឡើយ ។

១៥ បន្ទាប់ពីខ្ញុំបានទៅដល់កន្លែងដែលខ្ញុំសំរេចថានឹងទៅ ព្រមទាំងបានសម្លឹងមើលជុំវិញខ្លួន ហើយដោយបានឃើញថា

៦ *ក* ស.ប. ការទាស់ទែង.
១០ *ក* ស.ប. សេចក្ដីពិត.
១២ *ក* ១ កូរិន. ២:១០–១៦.
*ខ* ស.ប. ព្រះគម្ពីរប៊ីប.
១៣ *ក* ស.ប. ការអធិស្ឋាន.
១៤ *ក* ស.ប. ការអធិស្ឋាន.

ខ្ញុំនៅម្នាក់ឯង នោះខ្ញុំក៏លុតជង្គង់ចុះ ហើយបានចាប់ផ្ដើមបួងសួងដល់ព្រះប្រាប់ពីបំណងនៃដួងចិត្តរបស់ខ្ញុំ ។ ខ្ញុំទើបតែចាប់ផ្ដើមធ្វើនៅមួយរំពេចនោះ ស្រាប់តែខ្ញុំត្រូវបានគ្របសង្កត់ដោយអំណាចណាមួយ ដែលមានជំនះមកលើរូបខ្ញុំទាំងស្រុង ហើយមានឥទ្ធិពលមកលើរូបខ្ញុំយ៉ាង អស្ចារ្យ ដែលចងអណ្ដាតខ្ញុំទុកធ្វើឲ្យខ្ញុំមិនអាចនិយាយបានឡើយ ក៏មានភាពងងឹតហ៊ុំព័ទ្ធខ្ញុំជុំវិញ ហើយនៅពេលនោះ មើលទៅហាក់ បីដូចជាខ្ញុំកំពុងតែស្ថិតនៅក្នុងការបំផ្លិចបំផ្លាញយ៉ាងឆាប់ៗ ។

១៦ ប៉ុន្ដែ ដោយខំប្រឹងប្រែងអស់ពីសមត្ថភាពដែលខ្ញុំមានដើម្បីអំពាវនាវដល់ព្រះ សូមឲ្យដោះលែងខ្ញុំឲ្យរួចពីអំណាចនៃខ្មាំងសត្រូវនេះ ដែលគ្របសង្កត់មកលើខ្ញុំ ហើយនៅខណៈនោះកាលខ្ញុំហៀបនឹងលិចលង់ទៅក្នុងការអស់សង្ឃឹម ហើយបោះបង់ខ្លួនទៅក្នុងការបំផ្លិច បំផ្លាញ — ពុំមែនទៅក្នុងការហិនហោចដែលស្រមៃគិតឃើញនោះទេ តែទៅក្នុងអំណាចនៃអ្នកណាមួយពិត ដែលមកពីពិភពមើល មិនឃើញ ដែលមានអំណាចដ៏សែនអស្ចារ្យ ដូចដែលខ្ញុំពុំដែលធ្លាប់ឃើញអ្នកណាមួយមានពីមុនមកឡើយ — នៅខណៈការភ្ញាក់ផ្អើល ដ៏មហិមានេះ ស្រាប់តែខ្ញុំបានឃើញបង្គោលពន្លឺមួយនៅចំលើក្បាលខ្ញុំ មានរស្មីចែងចាំងលើសជាងសុរិយាទៅទៀត ដែលចុះសន្សឹមៗមកចំលើរូបខ្ញុំ ។

១៧ នៅពេលរស្មីនោះលេចមកមិនយូរប៉ុន្មាន ស្រាប់តែខ្ញុំបានឃើញថា ខ្ញុំបានរួចពីខ្មាំងសត្រូវដែលបានចងខ្ញុំទុក ។ កាលពន្លឺនោះស្ថិត ចំលើរូបខ្ញុំ ខ្ញុំបានឃើញតួអង្គពីរ ដែលមានរស្មី និងសិរីរុងរឿងដែលពុំអាចពណ៌នាបានឡើយ ឈរនៅលើអាកាសពីលើរូបខ្ញុំ ។ តួអង្គ មួយមានព្រះបន្ទូលមកខ្ញុំ ដោយហៅខ្ញុំតាមឈ្មោះ ហើយចង្អុលទៅតួអង្គមួយទៀត ដោយមានព្រះបន្ទូលថា — *« នេះជា ព្រះរាជបុត្រា ដ៏ស្ងួនភ្ងារបស់យើងចូរស្ដាប់តាមទ្រង់ចុះ ! »*

១៨ គោលបំណងរបស់ខ្ញុំ ក្នុងការទៅទូលដល់ព្រះអម្ចាស់គឺចង់ដឹងថាបក្សពួកណាមួយទៅដែលត្រូវ ដើម្បីឲ្យខ្ញុំបានដឹងថាខ្ញុំត្រូវចូលរួម នឹងបក្សណាមួយ ។ ហេតុដូច្នេះហើយ គឺមិនយូរប៉ុន្មានដែលខ្ញុំបានដឹងខ្លួនវិញ ដែលអាចនិយាយបាន ខ្ញុំបានទូលដល់តួអង្គពីរនោះ ដែល ឈរនៅក្នុងពន្លឺចំពីលើរូបខ្ញុំថាតើបក្សពួកទាំងអស់ណាមួយត្រូវ (ត្បិតនៅពេលនោះ ខ្ញុំមិនដែលបានគិតក្នុងចិត្តថា បក្សពួកទាំងនោះ សុទ្ធតែខុសទាំងអស់គ្នាឡើយ) — ហើយថាតើខ្ញុំគប្បីចូលរួមមួយណា ។

១៩ ខ្ញុំបានទទួលចម្លើយថា ខ្ញុំមិនត្រូវចូលរួមនឹងបក្សពួកណាមួយឡើយ ត្បិតគេសុទ្ធតែខុសទាំងអស់គ្នា ហើយតួអង្គដែលមានព្រះបន្ទូល មកខ្ញុំ ក៏មានព្រះបន្ទូលថា អស់ទាំងគោលជំនឿរបស់គេសុទ្ធតែអំពើគួរខ្ពើមឆ្អើមចំពោះព្រះនេត្ររបស់ទ្រង់ ថាពួកអ្នកកាន់សាសនា ទាំងនោះ សុទ្ធតែពុករលួយ ថា៖ « គេគោរពប្រតិបត្តិដល់យើងតែបបូរមាត់ទេ ឯចិត្តគេ នោះនៅឆ្ងាយពីយើងណាស់ គេបង្រៀន សេចក្ដីដែលជាបញ្ញត្តិរបស់មនុស្សវិញ ដោយមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្ដែមិនព្រមទទួលស្គាល់ព្រះចេស្ដា ដែលមកដោយការគោរពប្រតិបត្តិនោះទេ » ។

២០ សារជាថ្មីទៀត ទ្រង់បានហាមមិនឲ្យខ្ញុំចូលរួមនឹងពួកគេណាមួយឡើយ ហើយទ្រង់បានមានព្រះបន្ទូលជាច្រើនការណ៍ទៀតប្រាប់ខ្ញុំ ដែលខ្ញុំពុំអាចយកមកសរសេរនៅពេលនេះបានឡើយ ។ កាលខ្ញុំបានដឹងខ្លួនទៀត នោះខ្ញុំបានឃើញថា ខ្ញុំដេកផ្ងារកំពុងសម្លឹង មើលទៅលើមេឃ ។ កាលពន្លឺនោះបានចេញផុតទៅខ្ញុំគ្មានកម្លាំងសោះ តែមិនយូរប៉ុន្មាន ខ្ញុំមានកម្លាំងបន្តិចបន្តួចមកវិញ ខ្ញុំក៏ទៅផ្ទះ ។ ហើយកាលខ្ញុំផ្អែកទៅនឹងជើងក្រានកំដៅផ្ទះម្ដាយខ្ញុំបានសួរថាកើតអី ។ ខ្ញុំបានឆ្លើយថា៖ « កុំភ័យអីស្រួលទេតើ — ខ្ញុំស្រួលខ្លួន » ។ រួចខ្ញុំនិយាយប្រាប់ម្ដាយខ្ញុំថា៖ « ខ្ញុំបានចេះដឹងដោយខ្លួនខ្ញុំថា ពួកប្រែសបិធាវានមិនពិតទេ » ។ មើលទៅហាក់បី ដូចជាមារសត្រូវ វាដឹងខ្លួនគឺចាប់តាំងពីពេលដំបូងក្នុងជីវិតខ្ញុំមក នោះខ្ញុំត្រូវបានរាប់ថាជាអ្នកឆាឆៅ និងជាអ្នករំខាននគររបស់វា; បើពុំនោះសោតទេហេតុអ្វីបានជាអំណាចទាំងឡាយនៃសេចក្ដីងងឹតរួបរួមគ្នាប្រឆាំង

១៦ *ក* ម៉ូសេ ១:២០.
*ខ* កិច្ចការ ២៦:១៣.
*គ* វិវរ. ១:១៦.
១៧ *ក* ស.ប. ការនិមិត្ត.
*ខ* កិច្ចការ ៧:៥៥–៥៦;
កូល៉ុស ៣:១.
ស.ប. ព្រះ, ក្រុមព្រះ.
*គ* ស.ប. សិរីល្អ.
*ឃ* ម៉ាថាយ ៣:១៧; ១៧:៥;
៣ នីហ្វៃ ១១:៧.
*ង* ស.ប. ព្រះយេស៊ូវគ្រីស្ទ.
១៨ *ក* គ. និង ស. ៦:១១; ៤៦:៧.
១៩ *ក* ទំនុក. ១៤.
ស.ប. សេចក្ដីក្បត់សាសនា —
សេចក្ដីក្បត់សាសនានៃសាសនាចក្រគ្រីស្ទានដើម.
*ខ* អេសាយ ២៩:១៣–១៤;
អេសេ. ៣៣:៣០–៣១.
*គ* ស.ប. សេចក្ដីក្បត់សាសនា —
សេចក្ដីក្បត់សាសនាទូទៅ.
*ឃ* ទីតុស ១:១៤;
គ. និង ស. ៤៥:២៩.
*ង* ២ ធីម៉ូ. ៣:៥.
២០ *ក* ស.ប. អារក្ស.

នឹងខ្ញុំ ? ហេតុអ្វីបានជាមាន[ខ]ការជំទាស់ និងការបៀតបៀនកើតឡើង ទាស់នឹងខ្ញុំ តាំងពីខ្ញុំនៅវ័យទារកម្ល៉េះ ?

*ពួកអាចារ្យខ្លះ និងពួកអ្នកកាន់សាសនាផ្សេងៗទៀត បដិសេធមិនទទួលស្គាល់ការនិមិត្តទីមួយ — ការបៀតបៀនគរមកលើ យ៉ូសែប ស៊្មីធ — លោកធ្វើទីបន្ទាល់អំពីការជាក់ស្ដែងនៃការនិមិត្តនោះ (ខ ២១–២៦) ។*

២១ ពីរបីថ្ងៃកន្លងមក បន្ទាប់ពីខ្ញុំបានឃើញ[ក]ការនិមិត្តនេះ នោះខ្ញុំ
បានជួបអាចារ្យម្នាក់ពីពួកមែថូឌីស្ទ ដែលជាអ្នកសកម្មម្នាក់ ក្នុង
ការ រំភើបខាងវិស័យសាសនា ដែលបានរៀបរាប់មកហើយនោះ;
ហើយដោយបាននិយាយជាមួយគាត់អំពីរឿងសាសនា នោះខ្ញុំក៏
ឆ្លៀត យកឱកាសប្រាប់គាត់ពីដំណើររឿង អំពីការនិមិត្តដែលខ្ញុំ
បានឃើញ ។ ខ្ញុំបានភ្ញាក់ផ្អើលជាខ្លាំងចំពោះអាកប្បកិរិយារបស់
គាត់; គាត់មិន គ្រាន់តែរាប់ថាពាក្យសំដីដែលខ្ញុំជំរាបគាត់នោះថា
មិនសំខាន់តែប៉ុណ្ណោះទេ តែថែមទាំងដោយពាក្យមើលងាយជា
ខ្លាំងថា ការនិមិត្ត នោះគឺសុទ្ធតែមកពីអារក្សទាំងអស់ ថា
សព្វថ្ងៃនេះ លែងមានការណ៍អ្វីជា[ខ]ការនិមិត្ត ឬ[ក]វិវរណៈហើយ; ថា
ការណ៍អស់ទាំងនោះ ព្រមទាំង ពួកសាវកផង នោះលែងមាន
ហើយ ហើយថានឹងពុំមានការណ៍អស់ទាំងនោះទៀតឡើយ ។
២២ ប៉ុន្តែមិនយូរប៉ុន្មាន ខ្ញុំបានឃើញថា ក្នុងការប្រាប់រឿងនោះ
បាននាំផ្ដល់ឲ្យមានការចោទប្រកាន់មកលើរូបខ្ញុំជា[ក]ខ្លាំង ក្នុងចំណោម
ពួក កាន់សាសនា ហើយជាបុព្វហេតុនៃការបៀតបៀនដ៏មហិមា
ដែលចេះតែមានកាន់តែច្រើនឡើងៗ; ហើយទោះជាខ្ញុំជាក្មេង
ម្នាក់ដែល[ខ] មិនសូវមានគេឯងស្គាល់ គឺមានវ័យតែ ១៤ និង ១៥
ឆ្នាំប៉ុណ្ណោះ ហើយទោះជាកាលៈទេសៈក្នុងជីវិតខ្ញុំ ដែលបាន
ធ្វើឲ្យយុវវ័យម្នាក់មិន ជាអ្វីក្នុងពិភពលោកអើពើក៏ដោយ គង់តែ
មានមនុស្សពីឋានខ្ពង់ខ្ពស់បានអើពើ ល្មមនឹងចាក់រុកមនុស្សឲ្យមាន
គំនិតទាស់នឹងខ្ញុំ ហើយ បង្កើតឲ្យមានការបៀតបៀនដ៏
ល្វីងជូរចត់ដែរ; ហើយការណ៍នេះ គឺមានទូទៅក្នុងបក្សពួកទាំង
អស់ — គេទាំងអស់គ្នាបានរួបរួមដៃគ្នា បៀតបៀនលើរូបខ្ញុំ ។
២៣ នៅពេលនោះ ការណ៍នេះធ្វើឲ្យខ្ញុំគិតពិចារណាជាខ្លាំង
និងជាញឹកញាប់ចាប់តាំងពីពេលនោះមក ថាចំឡែកម្ល៉េះ
ហេតុអ្វីក៏ក្មេង ប្រុសម្នាក់ដែលមិនសូវមានគេឯងស្គាល់ អាយុ១៤
ឆ្នាំជាង ហើយក៏ជាមនុស្សម្នាក់ដែលត្រូវទ្រាំធ្វើការជារៀងរាល់
ថ្ងៃ ដើម្បីទ្រទ្រង់ជីវិតតិចតួច ម្ដេចឡើយក៏គេថាខ្ញុំជាមនុស្ស
គ្រាន់បើ ដល់ទៅធ្វើឲ្យមនុស្សធំដុំពីបក្សពួកដ៏ល្បីល្បាញនៅគ្រា
នោះអើពើ ហើយនៅតាម របៀបណាមួយ ដែលធ្វើឲ្យគេមាន
ចិត្តបៀតបៀន និងប្រទេចផ្ដាសាដ៏ល្វីងជូរចត់ទៅវិញ ។ ប៉ុន្តែ
ទោះជាការណ៍នេះចំឡែក ឬអត់ក៏ ដោយ គង់តែនេះហើយជា
ស្ថានការណ៍ដែលបានកើតឡើង ហើយការណ៍នេះតែងតែជា
បុព្វហេតុ ដែលធ្វើឲ្យខ្ញុំមានចិត្តសោកសៅ ជាអនេក ។
២៤ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គង់តែជាការពិតមែន
ដែលខ្ញុំបានឃើញការនិមិត្តនោះ ។ ខ្ញុំបានគិតតាំងពីពេលនោះ
មក ថាខ្ញុំ មានអារម្មណ៍ដូច[ក]លោកប៉ុលដែរ ក្នុងកាលលោកបាន
[ខ]ដោះសា នៅខាងមុខព្រះរាជាអ័គ្រីប៉ា ហើយបានប្រាប់ពីដំណើរ
រឿងនៃការនិមិត្ត ដែលលោកបានឃើញ កាលលោកបានឃើញពន្លឺ
ហើយបានឮសម្លេង; ប៉ុន្តែគង់តែមានមនុស្សតែបន្តិចបន្តួចប៉ុណ្ណោះ
ដែលបានជឿ លោក; រីឯមនុស្សខ្លះបានថាលោកជាមនុស្សមិន
ទៀងត្រង់ ឯមនុស្សផ្សេងទៀតថាលោកជាមនុស្សឆ្កួត; ហើយ
លោកត្រូវគេមើលងាយ ហើយត្រូវគេជេរប្រទេចផ្ដាសា ។
ប៉ុន្តែការណ៍អស់ទាំងនេះពុំបានបំផ្លាញនូវការពិត អំពីការនិមិត្ត
ដែលលោកបានឃើញនោះឡើយ ។ លោកបានឃើញការនិមិត្ត
លោកដឹងថាលោកបានឃើញមែន ហើយអស់ទាំងការ
បៀតបៀននៅក្រោមមេឃទាំងឡាយ ក៏មិនអាច
ប្រែការណ៍នោះបានដែរ; ហើយទោះជាគេនឹងបៀតបៀន
លោកដល់ស្លាប់ក៏ដោយ គង់តែលោកដឹង ហើយនឹងដឹង
រហូតដល់ដង្ហើម ចុងក្រោយបង្អស់ ថាលោកបានទាំងឃើញ
ហើយឮសម្លេងនិយាយមកកាន់លោក ហើយអស់
ទាំងពិភពលោកក៏មិនអាចធ្វើឲ្យលោក គិត ឬជឿនូវ
អ្វីផ្សេងទៀតឡើយ ។
២៥ ម្ល៉ោះហើយ រឿងនោះក៏ដូចជារឿងខ្ញុំដែរ ។ ខ្ញុំពិតជាបាន
ឃើញពន្លឺមែន ហើយនៅកណ្ដាលពន្លឺនោះ ខ្ញុំបានឃើញ[ក]តួអង្គពីរ
ហើយតួអង្គនោះបានមានព្រះបន្ទូលមកខ្ញុំជាពិតប្រាកដ ហើយទោះ
ជាខ្ញុំត្រូវគេស្អប់ ហើយបៀតបៀន មកពីថាខ្ញុំបានឃើញការនិមិត្តក្ដី

២០ *ខ* ២ នីហ្វៃ ២:១១;
គ. និង ស. ៥៨:២–៤.
ស.ប. សេចក្ដីទំនាស់.
២១ *ក* ស.ប. ការនិមិត្តទីមួយ.
*ខ* ស.ប. ការនិមិត្ត.
*គ* ស.ប. វិវរណៈ.
២២ *ក* យ៉ាកុប (ព.ស.ថ.) ៥:១០–១១.
ស.ប. បៀតបៀន,
សេចក្ដីបៀតបៀន.
*ខ* ១ សាំយូ. ១៦:៧;
អាលម៉ា ៣៧:៣៥.
២៤ *ក* ស.ប. ប៉ុល.
*ខ* កិច្ចការ ២៦:១–៣២.
២៥ *ក* យ.ស.—ប្រវត្តិ ១:១៧.

គង់តែការណ៍នោះពិត ហើយនៅពេលគេកំពុងតែបៀតបៀនខ្ញុំ ជេរប្រទេចផ្ដាសាដល់ខ្ញុំ ហើយនិយាយបង្កុសនូវពាក្យអាក្រក់គ្រប់បែបយ៉ាងទាស់នឹងខ្ញុំ មកពីខ្ញុំបានថាដូច្នោះក្ដី គង់តែការណ៍នោះធ្វើឲ្យខ្ញុំគិតក្នុងចិត្តថា៖ ហេតុដូចម្ដេចក៏បៀតបៀនខ្ញុំ ព្រោះតែខ្ញុំបានប្រាប់ពីការពិត ? ខ្ញុំពិតជាបានឃើញការនិមិត្តមែន ហើយតើខ្ញុំជាអ្វីទៅ ដែលអាចទាស់នឹងព្រះបាន ហើយចុះតើហេតុអ្វី បានជាពិភពលោកគិតចង់ឲ្យខ្ញុំបដិសេធអ្វីដែលខ្ញុំពិតជាបានឃើញនោះ ? ត្បិតខ្ញុំបានឃើញការនិមិត្ត ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំដឹងថា ព្រះទ្រង់ក៏ដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាច [ខ]បដិសេធរឿងនេះ ឬក៏ហ៊ានធ្វើយ៉ាងដូច្នោះបានឡើយ យ៉ាងហោចខ្ញុំបានដឹង ថាបើ ខ្ញុំធ្វើដូច្នោះ នោះខ្ញុំនឹងជំទាស់ព្រះ ហើយនឹងនៅក្រោមការដាក់ទោសជាមិនខានឡើយ ។

២៦ ឥឡូវនេះ ខ្ញុំបានស្កប់ចិត្តចំពោះពិភពលោក អំពីបក្សពួកទាំងឡាយហើយ — ថាពុំមែនជាមុខងាររបស់ខ្ញុំ ក្នុងការចូលរួមនឹងពួកគេ ណាមួយឡើយ តែត្រូវរង់ចាំដរាបដល់ខ្ញុំបានទទួលការដឹកនាំតទៅទៀត ។ ខ្ញុំបានឃើញថា[ក]ទីបន្ទាល់របស់ខ្ញុំ អំពីយ៉ាកុបនោះពិតមែន — ថាមនុស្សណាមួយដែលខ្វះប្រាជ្ញា នោះអាចសូមដល់ព្រះ ហើយនឹងបានទទួល ដោយឥតបន្ទោសផង ។

*ម៉ូរ៉ូណៃលេចមកឲ្យ យ៉ូសែប ស្ម៊ីធ ឃើញ — ឈ្មោះរបស់យ៉ូសែបនឹងត្រូវបានស្គាល់សំរាប់សេចក្ដីល្អ និងសេចក្ដីអាក្រក់ ក្នុងចំណោម គ្រប់សាសន៍ទាំងអស់ — ម៉ូរ៉ូណៃប្រាប់លោកអំពីព្រះគម្ពីរមរមន និងអំពីសេចក្ដីជំនុំជំរះរបស់ព្រះអម្ចាស់ដែលនឹងកើតឡើង ហើយស្រង់បទគម្ពីរ ជាច្រើន — កន្លែងលាក់ផ្ទាំងមាសត្រូវបានបើកសម្ដែងប្រាប់ — ម៉ូរ៉ូណៃបង្គាប់ព្យាការីតទៅ (ខទី ២៧–៥៤) ។*

២៧ ខ្ញុំចេះតែធ្វើការតាមធម្មតាទៅក្នុងជីវិត រហូតដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៨២៣ ហើយនៅគ្រប់ពេលវេលាខ្ញុំបានរងទុក្ខនូវការ បៀតបៀនដ៏ធ្ងន់ធ្ងរ ពីដៃនៃមនុស្សគ្រប់ជាន់ថ្នាក់ ទាំងសាសនិកជន និងអសាសនិកជនផង ព្រោះតែខ្ញុំនៅតែបញ្ជាក់ថាខ្ញុំបានឃើញ ការនិមិត្តនោះ ។

២៨ ក្នុងចន្លោះពេលដែលខ្ញុំបានឃើញការនិមិត្ត ទៅទល់នឹងឆ្នាំ ១៨២៣ — ដោយបានហាមប្រាមមិនឲ្យចូលរួមនឹងបក្សពួកសាសនា ណាមួយឡើយ ហើយដោយមានវ័យក្មេងពេក ហើយបានទទួលការបៀតបៀនពីអស់អ្នកទាំងឡាយដែលគួរណាតែរាប់អានខ្ញុំជាមិត្ត និងរាក់ទាក់នឹងខ្ញុំដោយស្រួលបួល ហើយបើសិនជាពួកគេបានសន្និដ្ឋានថាខ្ញុំមានការភាន់ច្រឡំ គួរណាតែខំព្យាយាមទាញខ្ញុំមកវិញ ដោយមធ្យោបាយដ៏សមរម្យ និងដោយមេត្រីភាព — នោះខ្ញុំត្រូវបានទុកឲ្យប្រទះ[ក]ការល្បួងគ្រប់បែបយ៉ាង; ហើយសេពគបនឹងមនុស្សគ្រប់ ប្រភេទក្នុងសង្គម ខ្ញុំតែងតែធ្លាក់ទៅក្នុងការខុសឆ្គងជាច្រើន ហើយបានសម្ដែងនូវការទន់ខ្សោយនៃយុវវ័យ និងការឆ្កួតលីលានៃមនុស្ស លោក; ដែលខ្ញុំតូចចិត្តនឹងនិយាយថា ការណ៍ទាំងនោះហើយដែលបាននាំខ្ញុំឲ្យធ្លាក់ទៅក្នុងការល្បួងផ្សេងៗ ដែលគួរខ្ពើមឆ្អើមចំពោះ ព្រះនេត្រនៃព្រះ ។ នៅពេលខ្ញុំលន់តួសារភាពនេះ ចូរកុំឲ្យអ្នកណាមួយសន្និដ្ឋានថាខ្ញុំមានទោសដ៏ធំ ឬមានបាបដ៏ធ្ងន់នោះឡើយ ។ ការប្រព្រឹត្តបាបបែបនេះ ពុំដែលមាននៅក្នុងចិត្តខ្ញុំឡើយ ។ ប៉ុន្តែខ្ញុំមានទោសខាងការនិយាយលេងសើចមិនត្រឹមត្រូវ ហើយជួនកាល បានសេពគបនឹងគ្នីគ្នាដែលលេងសើចមិនត្រឹមត្រូវ ជាដើម ដែលមិនសមរម្យនឹងចរិយានៃអ្នកដែលបាន[ខ]ហៅដោយព្រះ ដូចជារូបខ្ញុំនោះ ឡើយ ។ ប៉ុន្តែការណ៍នេះមិនជាចំឡែកទេ ចំពោះអ្នកផងទាំងឡាយណាដែលនឹកចាំពីយុវវ័យរបស់ខ្ញុំ ហើយដែលបានស្គាល់ចរិយារួសរាយរបស់ខ្ញុំ ។

២៩ ដោយសារការណ៍ទាំងនេះហើយ ដែលខ្ញុំតែងតែគិតថាខ្លួនមានទោស ដោយព្រោះតែភាពទន់ខ្សោយ និងភាពមិនល្អឥតខ្ចោះរបស់ខ្ញុំ; នៅពេលវេលារាត្រីនៃពេលដែលបានពោលខាងលើនេះ គឺថ្ងៃទី២១ ខែកញ្ញា បន្ទាប់ពីខ្ញុំបានចូលទៅកាន់ដំណេកខ្ញុំនៅយប់នោះ នោះខ្ញុំបានចាប់ផ្ដើម[ក]អធិស្ឋាន ហើយទូលអង្វរដល់ព្រះដ៏មានមហិទ្ធិឫទ្ធិ សូមក្ដីអភ័យទោស ចំពោះអស់ទាំងអំពើបាប និង អំពើឆ្កួតលីលារបស់ខ្ញុំ ហើយសូមការសម្ដែងប្រាប់ដល់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចដឹងអំពីស្ថានភាព និងជំហររបស់ខ្ញុំចំពោះទ្រង់; ត្បិតខ្ញុំជឿជាក់ ថា នឹងបានទទួលការសម្ដែងពីព្រះ ដូចខ្ញុំបានទទួលកាលពីលើកមុននោះ ។

៣០ នៅពេលដែលខ្ញុំកំពុងតែអំពាវនាវដល់ព្រះ នោះស្រាប់តែខ្ញុំប្រទះឃើញមានពន្លឺមួយរះឡើងនៅក្នុងបន្ទប់ខ្ញុំ ឯពន្លឺនោះចេះតែភ្លឺខ្លាំងឡើងៗ រហូតដល់បន្ទប់ទាំងមូលភ្លឺជាង

២៥ *ខ* ស.ប. សេចក្ដីក្លាហាន, ដ៏ក្លាហាន; សេចក្ដីស្មោះ.
២៦ *ក* យ៉ាកុប (ព.ស.ថ.) ១:៥–៧.
២៨ *ក* ស.ប. ល្បួង, សេចក្ដីល្បួង.
*ខ* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
២៩ *ក* ស.ប. ការអធិស្ឋាន.

ពន្លឺថ្ងៃត្រង់ទៅទៀត នៅមួយរំពេចនោះ មាន[ក]រូបមនុស្សមួយ បានលេចមកនៅក្បែរគ្រែខ្ញុំ ឈរនៅ លើអាកាស ពីព្រោះជើងលោកពុំបានប៉ះក្តារឡើយ ។

៣១ លោកពាក់អាវរលុង ដែលមាន[ក]ពណ៌ដ៏សអស្ចារ្យ គឺជាភាពសជាងអ្វីៗនៅលើលោកិយ ដែលខ្ញុំធ្លាប់ប្រទះឃើញមក ហើយខ្ញុំ ថែមទាំងមិនជឿថា មានអ្វីមួយនៅក្នុងលោកិយនេះ នឹងត្រូវធ្វើឲ្យឃើញសក្រៃលែង ហើយចែងចាំងដូច្នោះឡើយ ដៃរបស់លោកនៅ ទទេត្រឹមខាងលើកដៃបន្តិច ក៏ដូចជាជើងលោកនៅទទេ ត្រឹមខាងលើកជើងបន្តិច ឯក្បាលនិងកលោកក៏នៅទទេដែរ ខ្ញុំបានឃើញថា លោកមិនបានស្លៀក ពាក់អ្វីក្រៅពីអាវនោះឡើយ នៅពេលអាវនោះចំហ ធ្វើឲ្យខ្ញុំឃើញទ្រូងលោក ។

៣២ មិនត្រឹមតែអាវលោកដែលជាសក្រៃលែងប៉ុណ្ណោះឡើយ តែថែមទាំងរូបកាយលោក [ក]ក៏ឧត្តមរុងរឿង[ខ]ជាងដែលអាចអធិប្បាយបាន ឯមុខរបស់លោក នោះពិតជាដូចផ្លេកបន្ទោរ បន្ទប់ខ្ញុំភ្លឺក្រៃលែង តែភ្លឺមិនជាប៉ុន្មាន ដូចជានៅជុំវិញរាងកាយលោកទេ កាលខ្ញុំបាន មើលឃើញលោកមុនដំបូងបង្អស់នោះ ខ្ញុំខ្លាច ប៉ុន្តែមិនយូរប៉ុន្មាន សេចក្តី[គ]ខ្លាចក៏បាត់ពីខ្ញុំទៅ ។

៣៣ លោកបានហៅខ្ញុំដោយ[ក]ឈ្មោះ ហើយពោលមកកាន់ខ្ញុំថាលោកជាទូត ដែលបានចាត់មកពីវត្តមាននៃព្រះ ឲ្យមករកខ្ញុំ ហើយថា ឈ្មោះលោក គឺមរ៉ូណៃ ថាព្រះទ្រង់មានកិច្ចការឲ្យខ្ញុំធ្វើ ហើយថាឈ្មោះរបស់ខ្ញុំ[ខ] នឹងមានដើម្បីសេចក្តីល្អ និងសេចក្តីអាក្រក់ ក្នុងគ្រប់ទាំង សាសន៍ គ្រប់ពូជមនុស្ស ហើយគ្រប់ទាំងភាសា ឬថាឈ្មោះខ្ញុំនឹងត្រូវនិយាយដល់ទាំងសេចក្តីល្អ និងសេចក្តីអាក្រក់ នៅក្នុងចំណោម បណ្តាជនទាំងអស់ ។

៣៤ លោកមានប្រសាសន៍ថា មាន[ក]គម្ពីរមួយកប់ទុក ដែលឆ្លាក់នៅលើ[ខ]ផ្ទាំងមាស ដែលចែងអំពីប្រវត្តិរបស់ប្រជាជន ដែលបានរស់ នៅលើ ទ្វីបនេះ កាលពីជំនាន់ដើម ហើយអំពីទីកំណើតដែលពួកគេលេចមក លោកមានប្រសាសន៍ទៀតថា [គ]ភាពពោរពេញនៃដំណឹង ល្អដ៏អស់កល្បជានិច្ច មាននៅក្នុងគម្ពីរនេះ ដូចជាព្រះអង្គសង្គ្រោះទ្រង់បានប្រទានឲ្យប្រជាជនជំនាន់ដើម ។

៣៥ លោកប្រាប់ទៀតថា មាន[ក]ត្បូងពីរដុំនៅក្នុងស៊ុមប្រាក់ ហើយត្បូងទាំងពីរនេះភ្ជាប់ជាមួយនឹងប្រដាប់បាំងទ្រូង ជារបស់ដែលហៅថា [ខ]យូរីមនិង ធូមីម កប់នៅជាមួយនឹងផ្ទាំងទាំងឡាយ ហើយការធ្វើជាម្ចាស់ និងការប្រើត្បូងទាំងនេះ គឺការដែលធ្វើឲ្យអ្នកនោះជា[គ]អ្នកមើលឆុត នៅជំនាន់បុរាណ ឬជំនាន់ដើម ហើយថាព្រះទ្រង់បានរៀបត្បូងនោះទុក ដើម្បីជាប្រយោជន៍នៃការបកប្រែគម្ពីរនេះឯង ។

៣៦ បន្ទាប់ពីបានប្រាប់ខ្ញុំពីការណ៍ទាំងនេះហើយ នោះលោកបានចាប់ផ្តើមស្រង់ពាក្យព្យាករណ៍ទាំងឡាយ ចេញពី[ក]ព្រះគម្ពីរសញ្ញាចាស់ ។ មុនដំបូង លោកបានស្រង់ភាគខ្លះចេញពីជំពូកទី៣ ក្នុង[ខ]គម្ពីរម៉ាឡាគី; ហើយលោកក៏ស្រង់ជំពូកទី៤ ឬជំពូកចុងក្រោយបង្អស់ នូវពាក្យព្យាករណ៍ដដែល តែខុសគ្នាតែបន្តិចបន្តួច ពីពាក្យដែលបានសរសេរទុកនៅក្នុងព្រះគម្ពីរប៊ីបរបស់យើង ។ ជំនួសការដកស្រង់ ខទី១ ដូចដែលបានសរសេរទុកនៅក្នុងគម្ពីរយើង នោះលោកបានស្រង់តាមបែបនេះថា៖

៣៧ *ត្បិតមើលចុះ [ក]ថ្ងៃនោះកំពុងតែមកដល់ ថ្ងៃនោះ[ខ]ឆេះឆ្លោដូចជាគុកភ្លើង នោះអស់ពួកអ្នកឆ្មើងឆ្មៃ មែនហើយ ហើយនិងអស់អ្នកដែល ប្រព្រឹត្តអំពើទុច្ចរិត គេនឹងឆេះដូចជា[គ]ជញ្ជ្រាំង; ត្បិតពួកគេដែលមក គេនឹងបញ្ឆេះបន្សុសពួកគេទៅ ឥតទុកឲ្យគេមានឫស ឬមែកនៅសល់ ឡើយ នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់នៃពួកពលបរិវារ* ។

៣៨ ហើយម្តងទៀត លោកបានស្រង់ពាក្យពីខទី៥ផង ដែលថា៖ *មើលចុះ យើងនឹងបើកសម្តែងដល់អ្នករាល់គ្នា [ក]នូវបព្វជិតភាព*

៣០ *ក* ស.ប. ពួកទេវតា; មរ៉ូណៃ, កូនប្រុសរបស់មរមន.
៣១ *ក* កិច្ចការ ១០:៣០; ១ នីហ្វៃ ៨:៥; ៣ នីហ្វៃ ១១:៨.
៣២ *ក* ៣ នីហ្វៃ ១៩:២៥. ស.ប. សិរីល្អ.
*ខ* និក្ខ. ៣៤:២៩–៣៥; ហេលេ. ៥:៣៦; គ. និង ស. ១១០:៣.
*គ* និក្ខ. ៣:៦; អេធើរ ៣:៦–៨, ១៩.
៣៣ *ក* និក្ខ. ៣៣:១២, ១៧; អេសាយ ៤៥:៣–៤.
៣៤ *ក* ស.ប. ព្រះគម្ពីរមរមន.
*ខ* ស.ប. ផ្ទាំងមាស.
*គ* ស.ប. ការសាងឡើងវិញនៃដំណឹងល្អ.
៣៥ *ក* លេវី. ៨:៨. ស.ប. ប្រដាប់បាំងទ្រូង.
*ខ* និក្ខ. ២៨:៣០. ស.ប. យូរីម និងធូមីម.
*គ* ស.ប. អ្នកមើលឆុត.
៣៦ *ក* ស.ប. ព្រះគម្ពីរសញ្ញាចាស់.
*ខ* ស.ប. ម៉ាឡាគី.
៣៧ *ក* ស.ប. ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ.
*ខ* ៣ នីហ្វៃ ២៥:១–៦; គ. និង ស. ៦៤:២៣–២៤. ស.ប. ផែនដី — ការសំអាតផែនដី; ពិភពលោក — ចុងបំផុតនៃផែនដី.
*គ* ណាហ៊ុម ១:៨–១០; ១ នីហ្វៃ ២២:១៥, ២៣; ២ នីហ្វៃ ២៦:៤–៦; គ. និង ស. ២៩:៩.
៣៨ *ក* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព; បព្វជិតភាព.

*ដោយដៃនៃ[ខ]អេលីយ៉ា ដែលជាព្យាការី មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចនៃព្រះអម្ចាស់បានមកដល់* ។

៣៩ លោកក៏ស្រង់ពាក្យពីខបន្ទាប់នោះផ្សេងគ្នាដែរ ដែលថា៖ *ហើយលោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅ នូវ[ក]សេចក្តីសន្យាដែលបាន ធ្វើដល់ពួកឪពុក ហើយចិត្តនៃកូនចៅនឹងបាន[ខ]វិលមករកពួកឪពុករបស់ពួកគេវិញ ។ បើសិនជាមិនមែនដូច្នោះទេ នោះផែនដីទាំងមូល នឹងត្រូវកំទេចចោលស្ងួនឡឹង ក្នុងកាលទ្រង់យាងមក* ។

៤០ បន្ថែមទៅនឹងពាក្យព្យាករណ៍ទាំងនេះ លោកបានស្រង់ពាក្យពីជំពូកទី១១ ក្នុងគម្ពីរអេសាយ ថាពាក្យព្យាករណ៍នេះជិតនឹងបាន សំរេចហើយ ។ លោកក៏ស្រង់ពាក្យពីជំពូកទី៣ ក្នុងគម្ពីរកិច្ចការ ខទី២២ និង២៣ ដូចដែលមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីរបស់យើង បេះបិត ។ លោកបានប្រាប់ថា[ក]ព្យាការីនោះ គឺជាព្រះគ្រីស្ទ; ប៉ុន្តែថ្ងៃនោះមិនទាន់មកដល់ទេ ក្នុងកាល «អស់អ្នកណាដែលមិនព្រម ស្តាប់តាមព្យាការីនោះទេ នោះនឹង[ខ]ត្រូវកាត់កាល់ចេញ ពីចំណោមមនុស្ស» ប៉ុន្តែនឹងមកដល់ជាយ៉ាងឆាប់ៗ ។

៤១ លោកក៏ស្រង់ពាក្យពីជំពូកទី២ ក្នុង[ក]គម្ពីរយ៉ូអែល ពីខទី២៨ ដល់ចប់ ។ លោកបានប្រាប់ដែរថា ពាក្យព្យាករណ៍នេះពុំទាន់បានសំរេចនៅឡើយទេ ប៉ុន្តែនឹងបានសំរេចនៅពេលឆាប់ៗ ។ ហើយលោកបានថ្លែងប្រាប់តទៅទៀតថា ភាពពោរពេញនៃ[ខ]ពួកសាសន៍ដទៃនឹងកើតឡើងជាឆាប់ៗ ។ លោកបានស្រង់វគ្គគម្ពីរផ្សេងៗជាច្រើន ហើយបានផ្តល់ពាក្យពន្យល់ជាច្រើន ដែលពុំអាចយកមកប្រាប់ បាននៅទីនេះ ។

៤២ ម្តងទៀត លោកបានប្រាប់ខ្ញុំថា កាលណាខ្ញុំបានទទួលយកផ្ទាំងទាំងឡាយ ដែលលោកបានថ្លែងដល់នោះ — ត្បិតមិនទាន់ដល់ ពេលដែលខ្ញុំត្រូវទទួលផ្ទាំងទាំងនោះទេ — ខ្ញុំមិនត្រូវបង្ហាញដល់អ្នកណាទេ; សូម្បីតែប្រដាប់បាំងទ្រូង ព្រមទាំងយូរីម និងធូមីមផង; ខ្ញុំអាចបង្ហាញតែត្រឹមជនណា ដែលព្រះទ្រង់បញ្ជាឲ្យបង្ហាញដល់ប៉ុណ្ណោះ; បើខ្ញុំបង្ហាញឲ្យអ្នកផ្សេងឃើញនោះខ្ញុំនឹងត្រូវបំផ្លាញ ចោល ។ នៅពេលដែលលោកកំពុងតែសន្ទនាជាមួយនឹងខ្ញុំអំពីផ្ទាំងចារិកនោះ ការនិមិត្តបានបើកសម្តែងនៅក្នុង[ក]គំនិតខ្ញុំ លុះត្រាខ្ញុំបានមើលឃើញ ទីកន្លែង ដែលមានផ្ទាំងទាំងនោះកប់ទុក ហើយការនិមិត្តនោះច្បាស់លាស់ រហូតដល់ខ្ញុំស្គាល់កន្លែងនោះបាន នៅពេល ដែលខ្ញុំទៅកាន់កន្លែងនោះក្រោយមក ។

៤៣ ក្រោយពីការសន្ទនានេះហើយ ខ្ញុំឃើញថាពន្លឺនៅក្នុងបន្ទប់ចាប់ផ្តើមប្រមូលរួមជុំវិញកាយ លោកដែលមានបន្ទូលមកកាន់ខ្ញុំ ហើយ នៅដូច្នោះតទៅ លុះត្រាបន្ទប់ត្រឡប់ទៅជាងងឹតម្តងទៀត លើកលែងតែនៅជុំវិញលោកប៉ុណ្ណោះ; មួយរំពេចនោះ ខ្ញុំឃើញហាក់ដូច ជាមានផ្លូវមួយចំហត្រង់ឡើងទៅដល់ស្ថានសួគ៌ ហើយលោកក៏ត្រឡប់ឡើងទៅ រហូតដល់មើលលែងឃើញ ក្រោយមក បន្ទប់ខ្ញុំក៏ ត្រឡប់ទៅក្នុងសភាពដើមវិញ ដូចកាលមុនដែលពន្លឺនៃស្ថានសួគ៌នេះបានលេចមក ។

៤៤ ខ្ញុំដេកសញ្ជឹងគិតដល់សេចក្តីប្លែកនៃហេតុការណ៍ ហើយនឹកឆ្ងល់ជាខ្លាំង ដល់រឿងដែលទូតដ៏ពិសេសនេះបានប្រាប់ខ្ញុំ; នៅពេល ដែលខ្ញុំកំពុងតែ[ក]គិតនោះ ខ្ញុំក៏ឃើញថាបន្ទប់ខ្ញុំ ចាប់ផ្តើមភ្លឺឡើងម្តងទៀត ហើយនៅមួយរំពេចនោះ ទូតពីស្ថានសួគ៌ដដែលនោះក៏មក ឈរនៅក្បែរគ្រែខ្ញុំម្តងទៀត ។

៤៥ លោកក៏ចាប់ផ្តើម ហើយនិយាយពីរឿងដដែលនោះទៀត ដែលលោកបានធ្វើហើយកាលលោកបានមកមុនដំបូង ដោយមិនប្រែ ប្រួលឡើយ; នៅពេលចប់ហើយ នោះលោកបានប្រាប់ខ្ញុំអំពីសេចក្តីជំនុំជំរះដ៏មហិមា ដែលនឹងកើតឡើងនៅលើផែនដីនេះ ព្រមទាំង សេចក្តីហិនវិនាសដ៏ខ្លាំង ដោយអំណត់អត់ ដាវ និងជម្ងឺអាសន្នរោគ; ហើយថាសេចក្តីជំនុំជំរះដ៏គួរធ្ងន់ធ្ងរទាំងឡាយនេះនឹងកើតមាន នៅលើផែនដីក្នុងជំនាន់នេះឯង ។ កាលបានថ្លែងពីរឿងទាំងអស់នេះហើយ នោះលោកក៏ត្រឡប់ឡើងទៅវិញម្តងទៀត ដូចដែល លោកបានធ្វើពេលមុនដែរ ។

៤៦ នៅវេលានេះ ហេតុការណ៍ដែលបានយល់នៅក្នុងចិត្តរបស់ខ្ញុំគឺជ្រាលជ្រៅណាស់ ដែលពុំអាចដេកបាន ហើយខ្ញុំដេកស្លឹកស្លាំងនៅក្នុងការណ៍អស្ចារ្យ ដែលខ្ញុំបានទាំងឃើញ ហើយបានឮមក ។ ប៉ុន្តែជាសេចក្តីប្លែកចិត្តរបស់ខ្ញុំអ្វីម្លេះ កាលឃើញទូតដដែលនៅក្បែរគ្រែ ខ្ញុំម្តងទៀត ហើយបានឮទូតរៀបរាប់ ឬថ្លែងមក

៣៨ *ខ* គ. និង ស. ២៧:៩;
១១០:១៣–១៦.
ស.ប. អេលីយ៉ា.
៣៩ *ក* កាឡាទី ៣:៨, ១៩.
*ខ* ស.ប. ពង្សាវតារ;
សេចក្តីសង្គ្រោះសំរាប់មនុស្សស្លាប់.
៤០ *ក* ចោទិ. ១៨:១៥–១៩.
*ខ* ៣ នីហ្វៃ ២០:២៣; ២១:២០.
៤១ *ក* កិច្ចការ ២:១៦–២១.
*ខ* រ៉ូម ១១:១១–២៥;
គ. និង ស. ៨៨:៨៤.
ស.ប. ពួកសាសន៍ដទៃ.
៤២ *ក* ស.ប. គំនិត.
៤៤ *ក* ស.ប. រំពឹងគិត.

ខ្ញុំម្ដងទៀត ពីរឿងដដែលដូចពេលមុននោះ; [ក]ហើយព្រមទាំងឲ្យ
ពាក្យដាស់[ខ]តឿនដល់ខ្ញុំ ដោយប្រាប់ខ្ញុំថាអារក្សសាតាំងនឹង
ព្យាយាមល្បួងខ្ញុំ (ពីព្រោះមកពីសភាពក្រខ្សត់របស់គ្រួសារ
ឪពុកខ្ញុំ) ឲ្យទៅយកផ្ទាំងទាំងឡាយ ដើម្បីនឹងកសាងខ្លួនជាអ្នក
មាន ។ រឿងនេះលោកឃាត់ខ្ញុំ ដោយមានប្រសាសន៍ថា ខ្ញុំមិន
ត្រូវមានគោលបំណងផ្សេងទៀតក្នុងសេចក្ដី នឹកគិត ក្នុងការបាន
ផ្ទាំងទាំងឡាយមក ក្រៅពី[គ]ដើម្បីសរសើរដំកើងព្រះ ហើយមិន
ត្រូវធ្លាក់ទៅក្នុងឥទ្ធិពលនៃមូលហេតុអ្វីផ្សេងទៀត ឡើយ
ក្រៅពីការកសាងនគរនៃព្រះប៉ុណ្ណោះ; មិនដូច្នោះសោតទេ ខ្ញុំមិន
អាចនឹងយកផ្ទាំងទាំងឡាយមកបានឡើយ ។
៤៧ ក្រោយពីបានមកជួបខ្ញុំជាលើកទីបី នោះលោកក៏
ត្រឡប់ឡើងទៅស្ថានសួគ៌វិញ ដូចលើកមុន ហើយខ្ញុំត្រូវទុកឲ្យ
រំពឹងគិតទៀត ចំពោះសេចក្ដីប្លែកនៃហេតុការណ៍ ដែល
ខ្ញុំទើបតែបានជួបប្រទះមក; នៅមួយរំពេចក្រោយមក
ដែលទូតស្ថានសួគ៌បានត្រឡប់ឡើង ចេញពីខ្ញុំទៅវិញជាលើកទីបី
នោះមាន់ក៏រងាវ ហើយខ្ញុំក៏ដឹងថា ជិតភ្លឺហើយ ដូច្នោះការ
សន្ទនារបស់យើងច្បាស់ជាបានប្រព្រឹត្តទៅ អស់ពេលពេញ
មួយយប់តែម្ដង ។
៤៨ មួយសន្ទុះក្រោយមក ខ្ញុំក្រោកពីដំណេក ហើយទៅធ្វើ
ការដូចដែលត្រូវធ្វើតាមធម្មតារាល់ៗថ្ងៃ; ប៉ុន្តែក្នុងការព្យាយាម
ធ្វើការដូច ពេលផ្សេងៗ ខ្ញុំហាក់បីដូចជាអស់កម្លាំងជ្លួខាំង
រហូតដល់ធ្វើអ្វីលែងកើត; ឪពុកខ្ញុំដែលកំពុងតែធ្វើការនៅក្បែ
រខ្ញុំនោះ ឃើញថាមានអ្វីខុសពីធម្មតាចំពោះខ្ញុំ ហើយបាន
ប្រាប់ឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញ ។ ខ្ញុំចេញទៅដោយសេចក្ដីតាំងចិត្ត
ថានឹងត្រឡប់ទៅផ្ទះ; ប៉ុន្តែក្នុងការ ព្យាយាមឆ្លងរបងចេញពីចំការ
នោះខ្ញុំអស់កម្លាំងរលីងពីខ្លួន ហើយខ្ញុំដួលស្ដូកស្ដឹងនៅលើដី
ហើយសន្លប់អស់មួយសន្ទុះទៅ ។
៤៩ រឿងដំបូងដែលខ្ញុំចាំបាន គឺសម្លេងមួយនិយាយមកកាន់ខ្ញុំ
ហៅខ្ញុំដោយឈ្មោះ ។ ខ្ញុំមើលទៅលើ ហើយឃើញទូតដដែល
ឈរនៅ លើក្បាលខ្ញុំ ហ៊ុំព័ទ្ធជុំវិញដោយរស្មីដូចពីលើកមុនដែរ ។
ហើយលោកថ្លែងពីរឿងទាំងអស់មកខ្ញុំម្ដងទៀត ដែលលោកបាន
ប្រាប់ខ្ញុំ កាល ពីយប់មិញ ហើយលោកបញ្ជាខ្ញុំឲ្យទៅរក[ក]ឪពុកខ្ញុំ
ហើយប្រាប់គាត់ពីការនិមិត្ត និងបញ្ញត្តិទាំងឡាយដែលខ្ញុំបានទទួល ។
៥០ ខ្ញុំធ្វើតាម; ខ្ញុំត្រឡប់ទៅរកឪពុកខ្ញុំនៅក្នុងចំការ ហើយបាន
រៀបរាប់រឿងសព្វគ្រប់ជំរាបគាត់ ។ គាត់ឆ្លើយតបមកខ្ញុំថា
ជារឿងមក ពីព្រះ ហើយគាត់បានប្រាប់ឲ្យខ្ញុំទៅ ហើយធ្វើដូច
ដែលទូតបានបញ្ជាចុះ ។ ខ្ញុំបានចេញពីចំការ ហើយទៅកាន់ទីកន្លែង
ដែលទូតបាន ប្រាប់ខ្ញុំថា មានផ្ទាំងទាំងឡាយកប់ទុក; ហើយមក
ពីសេចក្ដីច្បាស់លាស់នៃការនិមិត្តដែលខ្ញុំបានឃើញមក នោះខ្ញុំ
ស្គាល់កន្លែងនោះភ្លាម នៅពេលខ្ញុំទៅដល់ទីនោះ ។
៥១ នៅជិតភូមិម៉ានឆេស្ទើរ ស្រុកអុនតារីយ៉ូ រដ្ឋនូវយ៉ោក
មាន[ក]ភ្នំមួយធំ ហើយខ្ពស់បំផុតនៅក្នុងតំបន់ ។ នៅខាងលិចភ្នំនេះ
មិនជា ឆ្ងាយប៉ុន្មានពីកំពូល ហើយនៅក្រោមដុំថ្មមួយដ៏ធំ មាន
ផ្ទាំងទាំងឡាយដាក់ទុកនៅក្នុងហិបថ្ម ។ ដុំថ្មនេះក្រាស់ ហើយ
នៅចំកណ្ដាល ប៉ែកខាងលើមានរាងមូល ហើយស្ដើងបន្តិច
ខាងជ្រុងៗ ហើយចំកណ្ដាលវាផុសចេញពីដី ប៉ុន្តែជ្រុង
ជុំវិញត្រូវដីកប់ជិតអស់ ។
៥២ កាលបានកាយដីចេញហើយ ខ្ញុំបានដងគំនាស់មួយ ដែល
ខ្ញុំបញ្ចូលក្រោមជ្រុងថ្ម ហើយដោយកម្លាំងបន្តិចបន្តួច ក៏គាស់ថ្មនោះ
របើកឡើងបាន ។ ខ្ញុំមើលទៅខាងក្នុងហើយពិតជាទីនោះមែន ខ្ញុំ
ឃើញទាំង[ក]ផ្ទាំងទាំងឡាយ [ខ]យូរីមនិងធូមីម ហើយព្រមទាំង[គ]ប្រដាប់
បាំងទ្រូង ដូចដែលទូតមានប្រសាសន៍មក ។ ហិបដែលដាក់របស់
ទាំងនេះ បានធ្វើឡើងដោយការដាក់ថ្មភ្ជាប់គ្នាពីជាតិស៊ីម៉ង់ត៍
ម្យ៉ាង ។ នៅបាតហិប មានថ្មពីរដុំដាក់ទុកទទឹងហិប
ហើយនៅពីលើថ្មពីរដុំនេះ មានផ្ទាំងទាំងឡាយ ព្រមទាំងវត្ថុ
ផ្សេងៗដាក់ទុកជាមួយគ្នាផង ។
៥៣ ខ្ញុំព្យាយាមយករបស់ទាំងនោះចេញមក ប៉ុន្តែ
ត្រូវទូតហាមឃាត់ ហើយប្រាប់ម្ដងទៀតថា ពេលដែលត្រូវនាំយក
របស់ទាំងនោះ ចេញមក ពុំទាន់មកដល់នៅឡើយ គឺមិន
ទាន់ដល់ពេលទេ ។ លុះត្រាគម្រប់បួនឆ្នាំចាប់ពីឆ្នាំនេះទៅ; ប៉ុន្តែ
លោកមានប្រសាសន៍ប្រាប់ខ្ញុំថា ចាប់ពីថ្ងៃនេះ ទៅរហូត
ដល់កំណត់មួយឆ្នាំ ខ្ញុំត្រូវត្រឡប់មកកាន់កន្លែងនេះវិញ ហើយ
លោកនឹងមកជួបខ្ញុំនៅទីនោះ ហើយថា ខ្ញុំត្រូវ ធ្វើដូច្នោះ
តទៅ លុះត្រាដល់ពេលដែលនឹងបានទទួលផ្ទាំងទាំងឡាយ
នោះមក ។
៥៤ ម្ល៉ោះហើយ ដូចដែលខ្ញុំត្រូវបានបញ្ជាមក ខ្ញុំក៏ទៅនៅពេល
គ្រប់កំណត់មួយឆ្នាំម្ដងៗ ហើយជារៀងរាល់ដង ខ្ញុំបានជួបទូត
ដដែល នៅទីនោះ ហើយបានទទួលការបង្គាប់ និងប្រាជ្ញាពីលោក

៤៦ *ក* ស.ប. អារក្ស.
*ខ* ស.ប. ល្បួង, សេចក្ដីល្បួង.
*គ* គ. និង ស. ១២១:៣៧.

៤៩ *ក* ស.ប. ស៊្មីធ, យ៉ូសែប ស៊ីញ៉ែរ.

៥១ *ក* ស.ប. គូម៉ូរ៉ា, ភ្នំ.

៥២ *ក* មរមន ៦:៦.
ស.ប. ផ្ទាំងមាស.
*ខ* ស.ប. យូរីម និងធូមីម.
*គ* ស.ប. ប្រដាប់បាំងទ្រូង.

គ្រប់ពេលដែលយើងសន្ទនាគ្នា អំពីរឿងដែលព្រះអម្ចាស់[ក]ទ្រង់នឹងធ្វើ ហើយ តើដោយរបៀបណា និងដោយនូវអ្វីដែលនគរព្រះនឹងត្រូវចាត់ចែងនៅគ្រាក្រោយបង្អស់ ។

*យ៉ូសែប ស៊្មីធ រៀបការនឹងនាង អិមម៉ា ហេល — លោកទទួលផ្ទាំងមាសពីមូរ៉ូណៃ ហើយបកប្រែអក្សរខ្លះៗ — ម៉ាទិន ហារីស បង្ហាញ អក្សរទាំងឡាយ និងការបកប្រែទៅសាស្ត្រាចារ្យ អ័នថុន ដែលថា៖ «ខ្ញុំមិនអាចអានគម្ពីរដែលបិទបានទេ» (ខទី៥៥–៦៥) ។*

៥៥ ពីព្រោះតែស្ថានភាពខាងសេដ្ឋកិច្ចរបស់ឪពុកខ្ញុំមិនសូវបរិបូរ នោះយើងត្រូវធ្វើការដោយដៃរបស់យើង ស៊ីឈ្នួលគេនៅពេលថ្ងៃ និងការផ្សេងៗទៀត ដែលយើងអាចមានឱកាសធ្វើបាន ។ ជួនកាល យើងនៅផ្ទះ ហើយជួនកាល យើងនៅឆ្ងាយពីផ្ទះ ហើយដោយ ធ្វើការងារជារៀងរហូតទៅ ទើបអាចទ្រទ្រង់ជីវិតឲ្យបានគ្រាន់បើ ។

៥៦ នៅឆ្នាំ ១៨២៣ គ្រួសារឪពុកខ្ញុំបានជួបប្រទះការទុក្ខលំបាកមួយដ៏ធំ ដោយការស្លាប់របស់បងប្រុសបង្អស់របស់ខ្ញុំ គឺ[ក]អាលវិន ។ នៅខែតុលា ឆ្នាំ ១៨២៥ ខ្ញុំបានស៊ីឈ្នួលតាចាស់ម្នាក់ឈ្មោះ យ៉ូសៀស ស្តោល ដែលរស់នៅឃុំឈីណាំងកូ រដ្ឋនូវយ៉ោក ។ គាត់បានឮពាក្យចចាមអារាមពីអណ្តូងប្រាក់ ដែលបានជីកដោយពួកអេស្ប៉ាញលនៅភូមិហារម៉ូនី ឃុំសុសគ្វីហាណា រដ្ឋផែនសិលវេញ៉ា; ហើយមុនគាត់ជួលខ្ញុំ នោះគាត់ធ្លាប់បានជីក បើសិនជាអាចធ្វើបាន ដើម្បីរកអណ្តូងប្រាក់នោះដែរ ។ បន្ទាប់ពីខ្ញុំបានទៅស្នាក់នៅជា មួយគាត់ នោះគាត់បាននាំខ្ញុំ និងកូនឈ្នួលគាត់ផ្សេងៗទៀត ទៅជីករកអណ្តូងប្រាក់ ដែលខ្ញុំបានធ្វើការតទៅអស់រយៈពេលជិតមួយខែ ដោយគ្មានបាន ការជោគជ័យអ្វីសោះ ចំពោះការព្យាយាមរបស់យើង ហើយនៅទីបញ្ចប់ ខ្ញុំបានបបួលតាចាស់ឲ្យឈប់ជីករកអណ្តូងប្រាក់ ។ ម្ល៉ោះហើយ ទើបមាន រឿងប្រឌិតឡើងទូទៅថា ខ្ញុំជាអ្នកជីករកប្រាក់ ។

៥៧ ក្នុងរយៈពេលខ្ញុំធ្វើការនោះ ខ្ញុំត្រូវបានដាក់ឲ្យស្នាក់នៅជាមួយលោក អ៊ីសាក ហេល នៅភូមិហារម៉ូនី ។ នៅទីនោះហើយដែល ខ្ញុំបានឃើញប្រពន្ធខ្ញុំ គឺ[ក]អិមម៉ា ហេល (កូនស្រីលោក) មុនដំបូងបង្អស់ ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៨២៧ យើងបានរៀបការគ្នា កាលខ្ញុំនៅធ្វើការជូនលោកស្តោល ។

៥៨ មកពីខ្ញុំចេះតែនិយាយថាខ្ញុំបានឃើញការនិមិត្ត នោះ[ក]ការបៀតបៀនចេះតែមកតាមខ្ញុំ ហើយគ្រួសាររបស់ឪពុកខាងប្រពន្ធខ្ញុំ បានជំទាស់នឹងអាពាហ៍ពិពាហ៍របស់យើង ។ ហេតុដូច្នេះហើយ ខ្ញុំត្រូវនាំនាងទៅកន្លែងផ្សេង; ម្ល៉ោះហើយ យើងបានទៅរៀបការនៅ ផ្ទះរបស់ចៅក្រម តារបិល នៅភូមិបេនប្រ៊ិចខាងត្បូង ឃុំឈីណាំងកូ រដ្ឋនូវយ៉ោក ។ បន្ទាប់ពីអាពាហ៍ពិពាហ៍ភ្លាមនោះខ្ញុំបានចេញពី មុខងារស៊ីឈ្នួលលោកស្តោល ហើយបានទៅផ្ទះឪពុកខ្ញុំ ហើយបានធ្វើស្រែជាមួយគាត់នៅរដូវនោះ ។

៥៩ នៅទីបញ្ចប់ ក៏ដល់ពេលដែលនឹងបានទទួលទាំងផ្ទាំងទាំងឡាយ យូរីមនិងធូមីម ហើយព្រមទាំងប្រដាប់បាំងទ្រូងផង ។ នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៨២៧ ខ្ញុំបានត្រឡប់ទៅកាន់កន្លែងដែលមានវត្ថុទាំងនេះ កប់ទុកតាមធម្មតា នៅពេលគ្រប់កំណត់មួយឆ្នាំទៀត ទូតស្ថានសួគ៌ដដែលក៏បានប្រគល់វត្ថុទាំងនោះដល់ខ្ញុំ ទាំងថា៖ ខ្ញុំត្រូវទទួលការខុសត្រូវចំពោះវត្ថុទាំងនោះ; ហើយថាបើខ្ញុំបណ្តោយ ឲ្យរបស់[ក]ទាំងនោះខូចខាតទៅ ដោយមិនយកចិត្តទុកដាក់ ឬក៏ដោយការធ្វេសប្រហែសណាមួយរបស់ខ្ញុំ នោះខ្ញុំនឹងត្រូវកាត់[ខ]ចេញ; ប៉ុន្តែបើខ្ញុំខប្រើសេចក្តីព្យាយាមដ៏អស់ពីចិត្តខ្ញុំ ដែលនឹងរក្សាវត្ថុទាំងនោះទុក លុះត្រាដល់លោក ជាទូតនឹងហៅយករបស់ទាំងនោះវិញ នោះវត្ថុទាំងនោះនឹងបានទទួលការពារឲ្យគង់វង្សនៅ ។

៦០ នៅមិនយូរប៉ុន្មាន ខ្ញុំក៏ដឹងហេតុផលដែលខ្ញុំត្រូវបានទទួលបំរាមយ៉ាងតឹងរឹងដូច្នោះ ដើម្បីឲ្យថែរក្សា របស់ទាំងនោះទុកឲ្យផុត អន្តរាយ ហើយហេតុដែលទូតបានពោលទុកថា កាលណាខ្ញុំបានសំរេចនូវអ្វីដែលត្រូវការពីដៃរបស់ខ្ញុំហើយ នោះលោកនឹងហៅ យករបស់ទាំងនោះវិញ ។ ត្បិតនៅមិនយូរប៉ុន្មាន ដែលអ្នកផ្សេងទាំងពួងដឹងថាខ្ញុំមានរបស់ទាំងនោះ នោះគេបានខិតខំព្យាយាមធ្វើ អំពើអាស្រូវបំផុត ដើម្បីនឹងដណ្តើមយករបស់ទាំងនោះពីខ្ញុំទៅ ។ មធ្យោបាយគ្រប់បែប ដែលអាចគិតឃើញបានមក ក៏ធ្វើដើម្បីប្រយោជន៍នោះ ។ សេចក្តីបៀតបៀនមកលើរូបខ្ញុំ មានទម្ងន់ធ្ងន់ល្វីងជូរចត់ជាងពេលណាៗទាំងអស់ ហើយមនុស្សទាំងហ្វូងយាមចាំ គ្រប់ពេលវេលា ដើម្បីនឹងដណ្តើមយករបស់ទាំងនោះពីខ្ញុំទៅ ប្រសិនបើធ្វើបាន ។ ប៉ុន្តែដោយសារប្រាជ្ញារបស់ព្រះ របស់ទាំងនោះបាន នៅក្នុងកណ្តាប់ដៃរបស់ខ្ញុំ

---

៥៤ *ក* ស.ប. នគរព្រះ ឬនគរស្ថានសួគ៌.
៥៦ *ក* គ. និង ស. ១៣៧:៥–៨.
៥៧ *ក* ស.ប. ស៊្មីធ, អិមម៉ា ហេល.
៥៨ *ក* ស.ប. បៀតបៀន, សេចក្តីបៀតបៀន.
៥៩ *ក* យ.ស.—ប្រវត្តិ ១:៤២.
*ខ* ស.ប. បទព្រះគម្ពីរ — ព្រះគម្ពីរដែលត្រូវរក្សាទុក.

ដោយផុតអន្តរាយ លុះត្រាខ្ញុំបានសំរេចភារកិច្ច ដោយវត្ថុនោះ
ដែលត្រូវការធ្វើពីដៃរបស់ខ្ញុំ ។ នៅពេល ដែលទូតតម្រូវយកវ
ត្ថុទាំងនោះវិញ ដូចដែលបានគ្រោងទុក នោះខ្ញុំបាន
ប្រគល់វត្ថុទាំងនោះទៅលោកវិញ ហើយលោកមានវត្ថុទាំង
នោះ នៅក្នុងសេចក្ដីថែរក្សានៃលោករហូតដល់ថ្ងៃនេះ គឺថ្ងៃទី២
ខែឧសភា ឆ្នាំ១៨៣៨ ។
៦១ ប៉ុន្តែការរំភើបចេះតែមានតទៅ ហើយពាក្យចចាមអារាម
ព្រមទាំងអណ្ដាតវារាប់ពាន់នោះធ្វើការគ្រប់ពេលវេលា ក្នុងការ
និយាយផ្សាយមួលបង្កាច់អំពីគ្រួសាររបស់ឪពុកខ្ញុំ និងអំពីរូបខ្ញុំ ។
បើសិនជាខ្ញុំយកពាក្យទាំងនោះមកប្រាប់តែ១ភាគ១០០០ នោះនឹង
បានទៅជាសៀវភៅរាប់ក្បាល ។ ប៉ុន្តែការបៀតបៀនបានក្លាយ
ទៅខ្លាំងពេក ដែលខ្ញុំពុំអាចទ្រាំបានឡើយ បានជាខ្ញុំត្រូវចាកចេញពី
ភូមិម៉ែនឆេសស្ទើរ ហើយខ្ញុំនិងប្រពន្ធខ្ញុំទៅឃុំសុសគ្វិហាណា
នៅរដ្ឋផែនសិលវេញ៉ា ។ កាលកំពុងតែត្រៀមនឹងចេញទៅ —
ដោយមក ពីក្រពន់ពេក ហើយការបៀតបៀនមានសភាពធ្ងន់ធ្ងរជា
ខ្លាំងមកលើពួកយើង យើងប្រហែលជាពុំទៅជាអ្នកណាផ្សេងទៀត
ក្រៅពីភាពក្រីក្រឡើយ — នៅកណ្ដាលការទុក្ខវេទនា
របស់យើង យើងបានជួបបុរសជាសំឡាញ់ ឈ្មោះថា ម៉ាទិន
ហារីស ដែលបានមក រកយើង ហើយឲ្យខ្ញុំ ៥០ ដុល្លា
ដើម្បីជួយយើងធ្វើដំណើរ ។ លោកហារីសជាអ្នកស្រុក
ពីភូមិប៉ាលម៉ៃរ៉ា ឃុំវេញ នៅរដ្ឋនូវយ៉ោក ហើយជាកសិករ
ម្នាក់ដែលមានកេរ្តិ៍ឈ្មោះ ។
៦២ ដោយសារជំនួយដែលបានទទួលទាន់ពេលវេលា ខ្ញុំអាចទៅ
ដល់ទីដៅរបស់ខ្ញុំ នៅរដ្ឋផែនសិលវេញ៉ា; ហើយបន្ទាប់ពីខ្ញុំបាន
ទៅដល់ទីនោះភ្លាម ខ្ញុំក៏ចាប់ផ្ដើមចម្លងអក្សរចេញពីផ្ទាំងទាំង
ឡាយ ។ ខ្ញុំបានចម្លងអក្សរភាគច្រើនដែរ ហើយដោយសារ
យូរីមនិងធូមីម ខ្ញុំបានបកប្រែពាក្យខ្លះៗ ដែលខ្ញុំបានធ្វើការនោះ
នៅចន្លោះខែធ្នូ និងខែកុម្ភៈ បន្ទាប់ពីខ្ញុំបានមកដល់ផ្ទះនៃឪពុកខាង
ប្រពន្ធខ្ញុំ ។
៦៣ នៅក្នុងខែកុម្ភៈនេះ លោកម៉ាទិន ហារីស ដែលបាន
ពោលប្រាប់ពីមុននេះ នោះលោកបានមកឯកន្លែងយើង យកអក្សរ
ទាំងឡាយ ដែលខ្ញុំបានចម្លងចេញពីផ្ទាំងទាំងឡាយ ហើយបាន
យកអក្សរទាំងនោះទៅតាមខ្លួន ទៅទីក្រុងនូវយ៉ោក ។ រីឯអ្វី
ដែលបានកើតឡើង ដល់គាត់ និងអក្សរទាំងនោះ នោះខ្ញុំ
សូមប្រាប់ពីដំណើររឿងគាត់ផ្ទាល់ អំពីហេតុការណ៍នោះ ដូច
ដែលគាត់បានរៀបរាប់ប្រាប់ខ្ញុំបន្ទាប់ ពីគាត់បានវិលមកវិញ ដែល
មានដូចតទៅះ
៦៤ «ខ្ញុំបានទៅដល់ទីក្រុងនូវយ៉ោក ហើយបានបង្ហាញអក្សរ
ដែលបានចម្លង ព្រមទាំងពាក្យដែលបានបកប្រែមក ដល់
សាស្ត្រាចារ្យ ឆាល្ស អ័នថុន ជាបុរសម្នាក់ដែលមាន
ឈ្មោះល្បីល្បាញខាងអក្សរសាស្ត្រ ។ សាស្ត្រាចារ្យ អ័នថុន បាន
មានប្រសាសន៍ថា សេចក្ដីបក ប្រែនោះត្រូវហើយ គឺត្រូវ
ជាងសេចក្ដីបកប្រែពីភាសាអេស៊ីព្ទទាំងអស់ ដែលគាត់ធ្លាប់បាន
ឃើញពីមុនមក ។ បន្ទាប់មក ខ្ញុំបានបង្ហាញ គាត់ នូវអក្សរទាំង
ឡាយនោះ ដែលពុំទាន់បានបកប្រែនៅឡើយ ហើយគាត់មាន
ប្រសាសន៍ថា អក្សរទាំងនោះគឺជាអក្សរអេស៊ីព្ទ អក្សរ ខាល់ដេ
អក្សរអាសសើរ និងអក្សរអារ៉ាប់; ហើយគាត់មានប្រសាសន៍ថា
អក្សរទាំងនោះជាតួអក្សរពិត ។ លោកបានចេញលិខិត
បញ្ជាក់ឲ្យខ្ញុំ ដោយបញ្ជាក់ប្រាប់ប្រជាជននៅប៉ាលម៉ៃរ៉ាថា អក្សរ
ទាំងឡាយនោះគឺជាតួអក្សរពិត ហើយថាសេចក្ដីបកប្រែ
ទាំងនោះ ក៏បានបកប្រែត្រឹមត្រូវដែរ ។ ខ្ញុំក៏យកលិខិតនោះ
ហើយដាក់ក្នុងហោប៉ៅខ្ញុំ ហើយកាលខ្ញុំរៀបចំនឹងចេញពីផ្ទះទៅ
នោះលោកអ័នថុន បានហៅខ្ញុំមកវិញ ហើយបានសួរខ្ញុំថា
ម្ដេចក៏យុវជននោះដឹងថាមានផ្ទាំងមាសកប់នៅកន្លែង ដែលគាត់
រកឃើញ ។ ខ្ញុំបានឆ្លើយថា មានទេវតារបស់ព្រះមួយរូបបាន
បើកសម្ដែងប្រាប់កន្លែងនោះដល់គាត់ ។
៦៥ «រួចគាត់មានប្រសាសន៍ថាះ “ខ្ញុំសូមមើលលិ
ខិតបញ្ជាក់នោះសិន” ។ ខ្ញុំក៏ដកយកលិខិតចេញពីហោប៉ៅខ្ញុំ
ហើយហុចទៅគាត់ កាលគាត់ឈោងយកទៅហើយក៏ហែក
ចោល ដោយមានប្រសាសន៍ថា សព្វថ្ងៃនេះ វាគ្មានរឿង
ខាងការបំរើរបស់ពួកទេវតាទៀតទេ ហើយថាបើសិនជា
ខ្ញុំយកផ្ទាំងទាំងឡាយមកឲ្យគាត់ នោះគាត់នឹងបកប្រែ ។
ខ្ញុំបានជំរាបគាត់ថា ផ្ទាំងភាគខ្លះត្រូវបិទ ហើយថាខ្ញុំ ត្រូវបាន
ហាមប្រាមមិនឲ្យយកមកទេ ។ គាត់ក៏ឆ្លើយថាះ “ខ្ញុំមិនអាចអាន
គម្ពីរដែលបិទបានទេ” ។ ខ្ញុំបានចាកចេញពីគាត់ទៅ ហើយបាន
ទៅជួបបណ្ឌិត មិចឆែល ដែលបញ្ជាក់ប្រាប់នូវអ្វីៗ ដូចជា
សាស្ត្រចារ្យ អ័នថុន បានប្រាប់ពីតួអក្សរ និងពីសេច
ក្ដីបកប្រែដែរ» ។

៦១ *ក* គ. និង ស. ៥:១.
ស.ប. ហារិស, ម៉ាទិន.
៦២ *ក* ស.ប. យូរីម និងធូមីម.
៦៥ *ក* ស.ប. ពួកទេវតា.
*ខ* អេសាយ ២៩:១១–១២;
២ នីហ្វៃ ២៧:១០;
អេធើរ ៤:៤–៧.

• • • •

*អូលីវើរ ខៅឌើរីធ្វើការបំរើជាស្មៀន ក្នុងការបកប្រែព្រះគម្ពីរមរមន — យ៉ូសែប និង អូលីវើរ ទទួលបព្វជិតភាពអើរ៉ុនពីយ៉ូហានបាទីស្ទ — ពួកគេបានទទួលបុណ្យជ្រមុជទឹក បុណ្យតែងតាំង ហើយបានទទួលវិញ្ញាណខាងការព្យាករណ៍ ។ (ខទី ៦៦–៧៥) ។*

៦៦ នៅថ្ងៃទី ៥ ខែមេសា ឆ្នាំ១៨២៩ នោះ[ក]អូលីវើរ ខៅដើរីបានមកឯផ្ទះខ្ញុំ ខ្ញុំមិនដែលឃើញគាត់សោះ លុះដល់ពេលនោះ ។ គាត់បានថ្លែងប្រាប់ខ្ញុំថា គាត់បានបង្រៀនឯសាលារៀននៅក្បែរភូមិ ដែលឪពុកខ្ញុំអាស្រ័យនៅ ហើយមកពីឪពុកខ្ញុំបានបញ្ជូនកូនចៅទៅសាលារៀននោះ ម្ល៉ោះហើយ បានជាគាត់ទៅស្នាក់នៅផ្ទះរបស់ឪពុកខ្ញុំអស់មួយរដូវ ហើយកាលនៅទីនោះ នោះគ្រួសារឪពុកខ្ញុំ បានប្រាប់គាត់ពីរឿងដែលខ្ញុំបានទទួលផ្ទាំងទាំងឡាយ ម្ល៉ោះហើយ បានជាគាត់មកស៊ើបសួររកខ្ញុំ ។

៦៧ កាលលោកខៅឌើរីមកដល់បានពីរថ្ងៃ (គឺថ្ងៃទី៧ ក្នុងខែមេសា) នោះខ្ញុំបានចាប់ផ្តើមបកប្រែព្រះគម្ពីរមរមន ហើយគាត់បានចាប់ ផ្តើមកត់ឲ្យខ្ញុំ ។

• • • •

៦៨ យើងចេះតែបន្តការបកប្រែរហូតដល់ខែក្រោយ (ខែឧសភា ឆ្នាំ១៨២៩) កាលនៅថ្ងៃមួយ យើងបានចូលទៅក្នុងព្រៃ ទៅអធិស្ឋាន ហើយសូមដល់ព្រះអម្ចាស់ [ក]អំពីបុណ្យជ្រមុជទឹក សំរាប់[ខ]ការផ្តាច់បាប ដែលយើងបានឃើញពោលដល់នៅក្នុងការបកប្រែផ្ទាំងទាំងឡាយ នោះ ។ នៅពេលយើងកំពុងតែធ្វើការអធិស្ឋាន និងអំពាវនាវដល់ព្រះអម្ចាស់ ស្រាប់តែមាន[គ]ទូតម្នាក់មកពីស្ថានសួគ៌ចុះមក នៅលើ [ឃ]ពពកនៃពន្លឺ ហើយកាលបានដាក់[ង]ដៃលើយើង នោះ[ច]លោកបានតែងតាំងយើង ដោយនិយាយថា៖

៦៩ *នៅលើអ្នក ជាពួកអ្នកបំរើដូចរូបខ្ញុំអើយ ដោយនូវព្រះនាមនៃព្រះមែស៊ី ខ្ញុំសូមប្រគល់[ក]បព្វជិតភាពអើរ៉ុន ដែលកាន់កូនសោទាំង ឡាយ អំពីការបំរើនៃពួកទេវតា និងអំពីដំណឹងល្អនៃការប្រែចិត្ត និងអំពីបុណ្យជ្រមុជទឹក ដោយការពន្លិច សំរាប់ការផ្តាច់បាប ហើយ បព្វជិតភាពនេះ នឹងមិនត្រូវបានដកចេញពីផែនដីទៀតឡើយ រហូតដល់ពេលកូនប្រុសទាំងឡាយនៃលោក[ខ]លេវី ថ្វាយដង្វាយម្តងទៀត ដល់ព្រះអម្ចាស់ ដោយសេចក្តីសុចរិត ។*

៧០ លោកបានប្រាប់ថា បព្វជិតភាពអើរ៉ុន ពុំមានអំណាចខាងការដាក់ដៃលើ សំរាប់[ក]អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធទេ ប៉ុន្តែ ថាបព្វជិតភាពនោះ នឹងត្រូវបានប្រទានដល់យើងនៅពេលក្រោយ ហើយលោកបានបញ្ជាឲ្យយើងទៅ ហើយទទួលបុណ្យជ្រមុជទឹក ហើយបានបង្គាប់យើង ថាខ្ញុំត្រូវធ្វើបុណ្យជ្រមុជទឹកជូនអូលីវើរ ខៅដើរី ហើយបន្ទាប់មក អូលីវើរត្រូវធ្វើបុណ្យជ្រមុជទឹកជូនខ្ញុំវិញ ។

៧១ ម្ល៉ោះហើយ យើងបានទៅ ហើយបានទទួលបុណ្យជ្រមុជទឹក ។ មុនដំបូង ខ្ញុំបានធ្វើបុណ្យជ្រមុជទឹកជូនអូលីវើរ ហើយបន្ទាប់មក អូលីវើរបានធ្វើបុណ្យជ្រមុជទឹកជូនខ្ញុំវិញ — ក្រោយមក ខ្ញុំបានដាក់ដៃលើក្បាលគាត់ ហើយបានតែងតាំងគាត់ចំពោះបព្វជិតភាពអើរ៉ុន ហើយបន្ទាប់មក គាត់បានដាក់ដៃលើក្បាលខ្ញុំ ហើយបានតែងតាំងខ្ញុំចំពោះបព្វជិតភាពនោះដែរ — ព្រោះយើងត្រូវបានបញ្ជាឲ្យធ្វើការ នោះ ។*

៧២ ទូតដែលមកឯយើងពេលនោះ ហើយដែលបាន

* អូលីវើរ ខៅឌើរី អធិប្បាយប្រាប់ពីហេតុការណ៍ទាំងឡាយនេះយ៉ាងដូច្នេះថា៖ «នេះគឺជាថ្ងៃដែលពុំអាចបំភ្លេចបានឡើយ — ដើម្បីអង្គុយស្តាប់សម្លេងដែលចេញមក ដោយសារការបំផុសពីស្ថានសួគ៌ ដែលដាស់តឿននូវសេចក្តីកតញ្ញូតាដ៏ជ្រាលជ្រៅ ដែល មាននៅក្នុងឱរានេះ ! ពីមួយថ្ងៃទៅមួយថ្ងៃ ដែលខ្ញុំបានសរសេរដោយគ្មានការរអាក់រអួល តាមពាក្យដែលចេញពីមាត់គាត់ ក្នុងកាល គាត់បកប្រែដោយយូរីមនិងធូមីម ឬតាមដែលពួកសាសន៍នីហ្វៃនិយាយថា ប្រដាប់បកប្រែ នូវប្រវត្តិ ឬបញ្ជីដែលហៅថា ‹ព្រះគម្ពីរមរមន› ។

« សូម្បីតែប្រាប់បន្តិចបន្តួច ពីដំណើររឿងដ៏ជាប់ចិត្ត ដែលបានថ្លែងដោយមរមន និងម៉ូរ៉ូណៃ ជាកូនដ៏ស្មោះត្រង់របស់លោក ប្រាប់អំពីប្រជាជនដែលស្ថានសួគ៌ធ្លាប់ស្រឡាញ់ ហើយសព្វព្រះហឫទ័យ នោះហួសកំរិតដែលខ្ញុំចង់សរសេរទៅទៀត; ហេតុដូច្នេះហើយ ខ្ញុំនឹងផ្អាកការនេះសិនទុកសំរាប់ពេលក្រោយ ហើយដូចជាខ្ញុំបានប្រាប់នៅក្នុងបុព្វកថាហើយថា គ្រាន់តែសរសេរពីហេតុការណ៍បន្តិច បន្តួច ដែលទាក់ទងដ៏ជិតដិតទៅនឹងការលូតលាស់នៃសាសនាចក្រនេះប៉ុណ្ណោះ ដែលអាចចាប់ចិត្តដល់មនុស្សរាប់ពាន់នាក់ ដែលបាន ឈានជើងទៅមុខ ហើយឱបក្រសោបយកដំណឹងល្អនៃព្រះគ្រីស្ទ ទោះជានៅកណ្តាលការទទឹងពីពួកថ្កើងខ្លួន និងការមួលបង្កាច់ពីពួក មនុស្សមានពុតត្តិ ។

៦៦ *ក* ស.ប. ខៅឌើរី, អូលីវើរ.
៦៨ *ក* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ខ* ស.ប. ការផ្តាច់បាប.
*គ* ស.ប. យ៉ូហាន-បាទីស្ទ.
*ឃ* ជនគ. ១១:២៥; អេធើរ ២:៤–៥, ១៤; គ. និង ស. ៣៤:៧.
*ង* ម. នៃ ស. ៥. ស.ប. ដៃ, ការដាក់.
*ច* ស.ប. សិទ្ធិអំណាច; តែងតាំង, ការតែងតាំង.
៦៩ *ក* ស.ប. បព្វជិតភាពអើរ៉ុន.
*ខ* ចោទិ. ១០:៨; គ. និង ស. ១៣; ១២៤:៣៩. ស.ប. លេវី — ពូជអំបូររបស់លេវី.
៧០ *ក* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.

ប្រគល់បព្វជិតភាពដល់យើង បានប្រាប់ថាឈ្មោះលោកគឺ យ៉ូហាន ជាបុគ្គល ដដែលដែលហៅថា [ក]យ៉ូហានបាទីស្ទ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយថាលោកបានធ្វើការនៅក្រោមការដឹកនាំពី[ខ]ពេត្រុស [គ]យ៉ាកុប និង[ឃ]យ៉ូហាន ដែលកាន់[ង]កូនសោទាំងឡាយនៃបព្វជិតភាព[ច]មិលគីស្សាដែក គឺជាបព្វជិតភាព ដែលលោកប្រាប់ថា នឹងបានប្រគល់ដល់យើង នៅពេលកំណត់ទុក ហើយថាខ្ញុំនឹងត្រូវហៅថាជា[ឆ]អែលឌើរទីមួយ ក្នុងសាសនាចក្រ ហើយគាត់ (អូលីវើរ ខៅឌើរ) ជាទីពីរ ។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៨២៩ នោះយើងត្រូវបានតែងតាំងឡើង នៅក្រោមដៃនៃទូតនេះ ហើយបានទទួលបុណ្យជ្រមុជទឹកផង ។

៧៣ កាលយើងងើបឡើងពីទឹកមកភ្លាម បន្ទាប់ពីយើងបានទទួលបុណ្យជ្រមុជទឹកហើយ នោះយើងបានស្គាល់នូវព្រះពរដ៏មហិមា និងរុង រឿងពីព្រះវរបិតាសួគ៌របស់យើង ។ មិនយូរប៉ុន្មាន បន្ទាប់ពីខ្ញុំធ្វើបុណ្យជ្រមុជទឹកជូនអូលីវើរ ខៅឌើរ ហើយ ស្រាប់តែ[ក]ព្រះវិញ្ញាណ បរិសុទ្ធបានយាងមកសណ្ឋិតលើគាត់ ហើយគាត់ក្រោកឈរឡើង ហើយបាន[ខ]ព្យាករអំពីការណ៍ជាច្រើន ដែលនឹងកើតឡើងនៅពេល ឆាប់ៗនេះ ។ ហើយជាថ្មីទៀត មិនយូរប៉ុន្មាន បន្ទាប់ពីខ្ញុំបានទទួលបុណ្យជ្រមុជទឹកពីគាត់ហើយ នោះខ្ញុំក៏មានវិញ្ញាណខាងការព្យាករណ៍ដែរ គឺកាលកំពុងតែក្រោកឈរឡើង នោះខ្ញុំបានព្យាករអំពីការលូតលាស់ឡើងនៃសាសនាចក្រនេះ ព្រមទាំងការណ៍ផ្សេងៗ ទៀត ដែលទាក់ទងទៅនឹងសាសនាចក្រ និងកូនចៅមនុស្សនៅតំណនេះ ។ យើងបានពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ហើយត្រេកអរនៅក្នុងព្រះ នៃសេចក្ដីសង្គ្រោះរបស់យើង ។

៧៤ ឥឡូវនេះ មកពីគំនិតយើងបានទទួលការបំភ្លឺ នោះយើងចាប់ផ្ដើម[ក]យល់នូវបទគម្ពីរទាំងឡាយ [ខ]ដែលបានលាតត្រដាងនៅចំពោះ យើង ហើយអត្ថន័យ និងគោលបំណងនៃវគ្គដ៏អាថ៌កំបាំងទាំងឡាយនោះ ក៏បានបើកសម្ដែងដល់យើងតាមរបៀបដែលយើងពុំដែលបាន ទទួលពីមុន ឬគិតពីមុនមកសោះ ។ ក្នុងពេលនោះ យើងត្រូវបានហាមប្រាមឲ្យទុកដោយសម្ងាត់អំពីការដែលបានទទួលបព្វជិតភាព និងបុណ្យជ្រមុជទឹកដែលយើងបានទទួលមកនោះ ដោយព្រោះវិញ្ញាណខាងការបៀតបៀនដែលកើតឡើងពាសពេញភូមិទៅហើយ នោះ ។

៧៥ យើងបានទទួលការគំរាមកំហែងពីពួកមនុស្សកំណាចជាច្រើនលើកច្រើនគ្រា ហើយពួកនេះក៏ជាពួកកាន់សាសនាដែរ ។ ហើយ គោលបំណងរបស់ពួកមនុស្សកំណាចដែលចង់ធ្វើទុក្ខដល់យើង នោះត្រូវបានរារាំងដោយសារតែឥទ្ធិពលពីគ្រួសារនៃឪពុកខាងប្រពន្ធ ខ្ញុំទេ (នៅក្រោមទិព្វញ្ញាណនៃព្រះ) គ្រួសារនេះបានក្លាយជាស្និទស្នាលនឹងខ្ញុំណាស់ ហើយបានប្រឆាំងនឹងពួកមនុស្សកំណាច ហើយ ថែមទាំងយល់ព្រមឲ្យខ្ញុំធ្វើការបកប្រែតទៅដោយគ្មានការរអាក់រអួល; ហើយដូច្នេះ ទើបបានធានា ហើយសន្យាថានឹងការពារយើង ពីអំពើទទឹងច្បាប់គ្រប់យ៉ាង ដែលពួកគេអាចធ្វើទៅបាន ៕

« គ្មានមនុស្សណាមួយ ទោះជានៅក្នុងស្មារតីរឹងប៉ឹងក្ដី អាចបកប្រែ ហើយសរសេរតាមការដឹកនាំ ដែលបានប្រាប់ដល់ពួក សាសន៍នីហ្វៃចេញពីព្រះឱស្ឋនៃព្រះអង្គសង្គ្រោះបានឡើយ ដែលស្ដីអំពីរបៀបជាក់លាក់ ដែលមនុស្សត្រូវកសាងសាសនាចក្ររបស់ ទ្រង់ឡើង ហើយជាពិសេសក្នុងកាលការពុករលួយរាលដាលឥតទីទៃ លើគ្រប់សណ្ដាប់បែបបទ ដែលបានប្រព្រឹត្តនៅក្នុងចំណោម មនុស្សលោក ដោយគ្មានក្ដីប្រាថ្នាចង់បានសិទ្ធិក្នុងការបង្ហាញចិត្តព្រមព្រៀង ដោយកប់នៅក្នុងផ្នូរទឹក ដើម្បីជាសេចក្ដីសន្មត់របស់បញ្ញា ចិត្តជ្រះថ្លា ដោយសារដំណើររស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទនោះឡើយ ។

« បន្ទាប់ពីបានសរសេរពីដំណើររឿង ដែលបានប្រាប់អំពីការងារបំរើរបស់ព្រះអង្គសង្គ្រោះ ចំពោះពួកសំណល់នៃពូជរបស់ យ៉ាកុប នៅលើទ្វីបនេះហើយ នោះអាចបានឃើញយ៉ាងជាក់ ដូចជាព្យាការីបានពោលថានឹងកើតឡើង គឺថាសេចក្ដីងងឹតនឹងគ្របលើ ផែនដី ហើយសេចក្ដីសូន្យសុងនឹងគ្របលើគំនិតនៃប្រជាជន ។ កាលបានពិចារណាគិតទៅ នោះដូចជាងាយឃើញថា នៅកណ្ដាល ការខ្វះខ្នែង និងសម្លេងអ៊ូអរអំពីសាសនា នោះគ្មាននរណាមានសិទ្ធិអំណាចពីព្រះ ដើម្បីប្រព្រឹត្តពិធីការទាំងឡាយនៃដំណឹងល្អឡើយ ។ ត្បិតគេអាចសួរថា តើមនុស្សលោកមានសិទ្ធិអំណាច ដើម្បីប្រព្រឹត្តការងារដោយនូវព្រះនាមនៃព្រះគ្រីស្ទ ដែលមិនទទួលស្គាល់វិវរណៈ ទាំងឡាយ កាលទីបន្ទាល់អំពីព្រះអង្គ មិនជាតូចតាចជាងវិញ្ញាណខាងការព្យាករណ៍ ហើយសាសនារបស់ព្រះអង្គក៏បានពឹងផ្អែក ស្ថាបនា និងគាំទ្រដោយសារវិវរណៈផ្ទាល់ នៅគ្រប់ជំនាន់នៃលោកិយ ដែលទ្រង់មានមនុស្សនៅលើផែនដីដែរឬទេ ? បើសិនជា ការពិតទាំងឡាយនេះត្រូវបានបង្កប់ទុក ហើយលាក់យ៉ាងជិតដោយមនុស្សលោក នោះនឹងឃើញថាមានគ្រោះថ្នាក់

៧២ *ក* ស.ប. យ៉ូហាន-បាទីស្ទ.
*ខ* គ. និង ស. ២៧:១២–១៣.
ស.ប. ពេត្រុស.
*គ* ស.ប. យ៉ាកុប, កូនប្រុសរបស់សេបេដេ.
*ឃ* ស.ប. យ៉ូហាន, កូនប្រុសរបស់សេបេដេ.
*ង* ស.ប. កូនសោទាំងឡាយនៃបព្វជិតភាព.
*ច* ស.ប. បព្វជិតភាពមិលគីស្សាដែក.
*ឆ* ស.ប. អែលឌើរ.
៧៣ *ក* ស.ប. ព្រះវិញ្ញាណបរិសុទ្ធ.
*ខ* ស.ប. ការព្យាករណ៍, ព្យាករ.
៧៤ *ក* ស.ប. យោបល់.
*ខ* យ៉ូហាន ១៦:១៣.

បើសិនជា បញ្ចេញឧបាយកលរបស់គេ ឲ្យភ្លឺថែងចាំងនៅចំពោះមុខមនុស្ស ឯរបស់ទាំងនោះមិននៅចំពោះយើងទៀតទេ ហើយយើងត្រូវរង់ចាំព្រះបញ្ញត្តិ ដែលនឹងប្រាប់ថា <ចូរក្រោកឡើង ហើយទទួលបុណ្យជ្រមុជទឹកចុះ> ។

« ការណ៍នេះពុំបានប៉ងដ៏យូរយា មុននឹងបានយល់ឡើយ ។ ព្រះអម្ចាស់ដែលបរិបូរទៅដោយសេចក្ដីមេត្តាករុណា ហើយសព្វ ព្រះហឫទ័យចង់ឆ្លើយតបនូវសេចក្ដីអធិស្ឋានដ៏ញឹកញាប់របស់ពួករាបសាជានិច្ច បន្ទាប់ពីយើងបានអំពាវនាវដល់ទ្រង់ ដោយចិត្តក្លៀវក្លា ដែលគង់នៅឆ្ងាយពីទីលំនៅរបស់មនុស្ស នោះទ្រង់ចុះមកសម្ដែងប្រាប់ដល់យើងអំពីព្រះហឫទ័យរបស់ទ្រង់ ។ មួយរំពេចនោះ ហាក់ដូចជាពីកណ្ដាលភាពអស់កល្បជានិច្ច នោះស្រាប់តែសម្លេងនៃព្រះដ៏ប្រោសលោះ ទ្រង់មានព្រះបន្ទូលប្រាប់ពី សេចក្ដីសុខសាន្តដល់យើង កាលវាំងននបើកចេញទៅ ហើយមានទេវតាពីព្រះបានចុះមក ពាក់ដោយសិរីល្អ ហើយបានប្រាប់នូវសារ ដែលបានទន្ទឹងចាំ និងកូនសោទាំងឡាយនៃដំណឹងល្អខាងការប្រែចិត្ត ។ សេចក្ដីអំណរអ្វីហ្ន៎ ! សេចក្ដីអស្ចារ្យអ្វីហ្ន៎ ! សេចក្ដីចំឡែកអ្វីហ្ន៎ ! កាលលោកិយកំពុងតែមានទុក្ខកង្វល់ និងវឹកវរ — កាលមនុស្សរាប់ លាននាក់កំពុងតែស្រវាំរាវរកកំផែងដូចជាមនុស្សខ្វាក់ ហើយកាលអស់ទាំងមនុស្សកំពុងតែពឹងផ្អែកទៅលើការមិនទៀងទាត់ ទាំងពួងទូទៅ គឺភ្នែកយើងបានមើលឃើញ ត្រចៀកយើងបានឮ ដូចជានៅពេលថ្ងៃភ្លឺស្រាង; មែនហើយ លើសទៅទៀត — គឺលើស ជាងភាពថែងចាំងនៃរស្មីសុរិយានៅខែឧសភា ដែលបំភ្លឺរស្មីទៅលើផ្ទៃព្រឹក្សាទៅទៀត ! ខណៈនោះ សម្លេងរបស់លោកប្រកបដោយភាពទន់ភ្លន់ បានចាក់ទំលុះទៅក្នុងខ្លួនប្រាណដែរ ហើយពាក្យពេចន៍ទាំងឡាយរបស់លោក ដែលថា <ខ្ញុំជាបាវបំរើជាមួយនឹងអ្នក> នោះបានកំចាត់សេចក្ដីខ្លាចបាត់អស់ទៅ ។

យើងបានស្ដាប់ យើងបានសម្លឹងមើល យើងបានស្ងែងកោត ! គឺជាសម្លេងនៃទេវតាពីសិរីល្អ គឺជាសារពីព្រះដ៏ខ្ពស់បំផុត ! ហើយកាល យើងបានឮ នោះយើងបានអរសប្បាយ ក្នុងកាលសេចក្ដីស្រឡាញ់របស់ទ្រង់បានឆួលឆាបមកលើដួងព្រលឹងរបស់យើង ហើយយើងបាន ហ៊ុំទៅដោយការនិមិត្តអំពីព្រះដ៏មានមហិទ្ធិឫទ្ធិ ! តើមានកន្លែងសង្ស័យនៅទីណា ? គ្មាននៅទីណាទេ; ការមិនទៀងទាត់បានរសាត់ បាត់ទៅ ការសង្ស័យបានលិចលង់បាត់ទៅ ដោយគ្មានងើបមកវិញទេ ក្នុងកាលការនឹកឡើង និងការបោកបញ្ឆោតបានរសាត់បាត់អស់ រលីងរហូតទៅ !

« ប៉ុន្តែ ឱបងអើយ ចូរគិតមើលសិន ចូរគិតមើលតទៅទៀតចុះថា តើដួងចិត្តយើងពោរពេញទៅដោយសេចក្ដីអំណរអ្វីហ្ន៎ ហើយតើយើងត្រូវក្រាបចុះចំពោះការដ៏អស្ចារ្យអ្វីហ្ន៎ (ត្បិតតើនរណាមួយដែលនឹងមិនលុតជង្គង់ចុះចំពោះព្រះពរបែបនេះ ?) នៅពេលយើងបានទទួលពីដៃលោក នូវបព្វជិតភាពបរិសុទ្ធ កាលលោកមានប្រសាសន៍ថា៖ <នៅលើអ្នក ជាពួកអ្នកបំរើដូចរូបខ្ញុំអើយ ដោយនូវព្រះនាមនៃព្រះមែស៊ី ខ្ញុំសូមប្រគល់បព្វជិតភាពនេះ និងសិទ្ធិអំណាចនេះដែលនឹងនៅលើផែនដី ប្រយោជន៍ឲ្យកូនប្រុសទាំង ឡាយនៃលោកលេវី អាចថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយសេចក្ដីសុចរិត !>

« ខ្ញុំនឹងមិនព្យាយាមចង្អុលប្រាប់អ្នក ពីអារម្មណ៍ក្នុងចិត្តនេះ ឬពីលំអដ៏ប្រកបដោយឫទ្ធានុភាព និងសិរីល្អដែលលោមព័ទ្ធជុំវិញយើងនៅគ្រានេះឡើយ; ប៉ុន្តែអ្នកនឹងជឿខ្ញុំ កាលខ្ញុំប្រាប់ថា គ្មានផែនដី ឬមនុស្សណាដែលប្រកបដោយវោហារដែលបានមក តាមកាលវេលា ក៏ពុំអាចចាប់ផ្ដើមនឹងតែងភាសាតាមសណ្ដាប់ដ៏ចាប់ចិត្ត និងដ៏ប្រសើរដូចជាតួបរិសុទ្ធនេះបានឡើយ ។ ពុំបានឡើយ; ឬក៏ផែនដីនេះមានអំណាចនឹងផ្ដល់សេចក្ដីអំណរ និងប្រគល់សេចក្ដីសុខសាន្ត ឬយល់នូវប្រាជ្ញាដែលមាននៅក្នុងមួយឃ្លាៗ ដែលបានប្រគល់មក ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធបានឡើយ ! មនុស្សអាចបោកបញ្ឆោតមនុស្សទូទៅ រីឯការបោកបញ្ឆោតចេះតែមានការបោកបញ្ឆោតតទៅ ហើយកូនចៅនៃពួកទុច្ចរិតអាចមានអំណាចបញ្ចុះបញ្ចូលពួកមនុស្សឆោត និងពួកគ្មានការរៀនសូត្រ រហូតដល់គ្មានប្រយោជន៍ ប៉ុន្តែការនឹកឡើងឲ្យចំណីដល់មនុស្សជា ច្រើន ហើយផលនៃការកុហកអណ្ដែតមនុស្សឥតគំនិតនៅលើរលកទៅរកផ្នូរ; ប៉ុន្តែគ្រាន់តែពាល់ដោយព្រះអង្គុលីនៃសេចក្ដីស្រឡាញ់របស់ទ្រង់ មែនហើយ គ្រាន់តែរស្មីមួយនៃសិរីល្អពីស្ថានលើ ឬព្រះបន្ទូលមួយមាត់ ពីព្រះឱស្ឋនៃព្រះអង្គសង្គ្រោះ ពីឱរានៃភាពអស់កល្បជានិច្ច នោះប្រែទៅជាឥតប្រយោជន៍ទាំងអស់ ហើយលុបការណ៍ទាំងនោះចេញ ពីគំនិតរៀងរហូតតទៅ ។ សេចក្ដីជាក់ស្ដែងដែលយើងបាននៅក្នុងវត្តមាននៃទេវតា សេចក្ដីពិតប្រាកដដែលយើងបានឮសម្លេងនៃព្រះយេស៊ូវ និងសេចក្ដីពិតដែល មិនខូចខាត ដូចជាបានហូរចេញមកពីតួដ៏សុទ្ធសាធ ដែលបានវាចាតាមព្រះហឫទ័យនៃព្រះ នោះខ្ញុំពុំអាចពណ៌នាបានឡើយ, ហើយខ្ញុំនឹងសម្លឹងមើលការសម្ដែងនូវសេចក្ដីល្អសប្បុរសរបស់ព្រះអង្គសង្គ្រោះនេះ ដោយសេចក្ដីអស្ចារ្យ និងដោយអំណរគុណ ក្នុងកាលខ្ញុំបានអនុញ្ញាតឲ្យរស់នៅ; ហើយនៅក្នុងវិមានទាំងឡាយនោះ ដែលមានភាពល្អឥតខ្ចោះ ហើយដែលអំពើបាបពុំ ដែលចូលបាន នោះខ្ញុំសង្ឃឹមថានឹងសរសើរដំកើងទ្រង់នៅថ្ងៃនោះ ដោយមិនឈប់ឈរឡើយ» ។ *Messenger and Advocate,* vol. 1 (តុលា ១៨៣៤), ទំព័រ ១៤–១៦ ។

# មាត្រានៃសេចក្ដីជំនឿ

នៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

*History of the Church,* Vol. 4, ទំព័រ ៥៣៥–៥៤១

១ យើងខ្ញុំ[ក]ជឿដល់ព្រះ គឺ[ខ]ព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច និងដល់[គ]ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយដល់[ឃ]ព្រះវិញ្ញាណបរិសុទ្ធ ។

២ យើងខ្ញុំជឿថា មនុស្សទាំងអស់នឹងត្រូវទទួលទោស ចំពោះអំពើបាបរបស់[ក]ខ្លួនផ្ទាល់ គឺមិនមែនចំពោះ[ខ]អំពើរំលងរបស់លោកអ័ដាមទេ ។

៣ យើងខ្ញុំជឿថា តាមរយៈ[ក]ដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបាន[ខ]សង្គ្រោះ ដោយសារ[គ]ការគោរពតាម[ឃ]ក្រិត្យវិន័យ និង[ង]ពិធីការទាំងឡាយនៃដំណឹងល្អ ។

៤ យើងខ្ញុំជឿថា គោលការណ៍ទីមួយ និង[ក]ពិធីការទាំងឡាយនៃដំណឹងល្អគឺ៖ ទីមួយ [ខ]សេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ; ទីពីរ [គ]ការប្រែចិត្ត; ទីបី [ឃ]បុណ្យជ្រមុជទឹក ដោយ[ង]ការពន្លិចសំរាប់ការផ្ដាច់បាប; ទីបួន ការដាក់[ច]ដៃលើ សំរាប់[ឆ]អំណោយទានជាព្រះវិញ្ញាណ បរិសុទ្ធ ។

៥ យើងខ្ញុំជឿថា មនុស្សត្រូវតែបាន[ក]ហៅពីព្រះ ដោយ[ខ]ការព្យាករណ៍ និងដោយការដាក់[គ]ដៃលើ ដោយអស់អ្នកណាដែលមាន[ឃ]សិទ្ធិ អំណាច ដើម្បីនឹង[ង]ផ្សាយដំណឹងល្អ ហើយប្រព្រឹត្ត[ច]ពិធីការទាំងឡាយនៃដំណឹងល្អ ។

៦ យើងខ្ញុំជឿចំពោះ[ក]ការរៀបចំដូចគ្នា ដូចដែលមាននៅក្នុងសាសនាចក្រពីអតីតកាល ដូចជា ពួក[ខ]សាវក ពួក[គ]ព្យាការី ពួក[ឃ]គ្រូគង្វាល ពួកគ្រូ ពួក[ង]គ្រូផ្សាយដំណឹងល្អ ជាដើម ។

៧ យើងខ្ញុំជឿដល់[ក]អំណោយទាន[ខ]ខាងភាសា [គ]ការព្យាករណ៍ [ឃ]វិវរណៈ [ង]ការនិមិត្ត [ច]ការប្រោសឲ្យជា [ឆ]ការបកប្រែភាសា ជាដើម ។

៨ យើងខ្ញុំជឿថា [ក]ព្រះគម្ពីរប៊ីប គឺជា[ខ]ព្រះបន្ទូលនៃព្រះ បើសិនជា

១ *ក* ស.ប. ជំនឿ, ជឿ.
*ខ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវរបិតា.
*គ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះរាជបុត្រា; ព្រះយេស៊ូវគ្រីស្ទ.
*ឃ* ស.ប. ព្រះ, ក្រុមព្រះ — ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ; ព្រះវិញ្ញាណបរិសុទ្ធ.
២ *ក* ចោទិ. ២៤:១៦; អេសេ. ១៨:១៩–២០. ស.ប. ទទួលខុសត្រូវ, ចេះទទួលខុសត្រូវ, ការទទួលខុសត្រូវ; សិទ្ធិជ្រើសរើស.
*ខ* ស.ប. ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា.
៣ *ក* ស.ប. ធ្វើឲ្យធួន, ដង្វាយធួន.
*ខ* ម៉ូសាយ ២៧:២៤–២៦; ម៉ូសេ ៥:៩. ស.ប. សេចក្ដីសង្គ្រោះ.
*គ* ស.ប. ការគោរព, ដែលគោរព, គោរព.
*ឃ* ស.ប. ក្រិត្យវិន័យ.
*ង* ស.ប. ដំណឹងល្អ.
៤ *ក* ស.ប. ពិធីបរិសុទ្ធទាំងឡាយ.
*ខ* ស.ប. សេចក្ដីជំនឿ.
*គ* ស.ប. ប្រែចិត្ត, ការប្រែចិត្ត.
*ឃ* ស.ប. បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក.
*ង* ស.ប. ការផ្ដាច់បាប.
*ច* ស.ប. ដៃ, ការដាក់.
*ឆ* ស.ប. អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ.
៥ *ក* ស.ប. ហៅ, បានហៅពីព្រះ, ការហៅ.
*ខ* ស.ប. ការព្យាករណ៍, ព្យាករ.
*គ* ស.ប. ដៃ, ការដាក់.
*ឃ* ស.ប. សិទ្ធិអំណាច; បព្វជិតភាព.
*ង* ស.ប. ផ្សាយ.
*ច* អាលម៉ា ១៣:៨–១៦.
៦ *ក* ស.ប. សាសនាចក្រពិត, ទីសំគាល់នៃ — ការកសាងសាសនាចក្រ.
*ខ* ស.ប. សាវក.
*គ* ស.ប. ព្យាការី.
*ឃ* ស.ប. ប៊ីស្សព.
*ង* ស.ប. គ្រូផ្សាយដំណឹងល្អ; អយ្យកោ, ខាងអយ្យកោ.
៧ *ក* ស.ប. អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ.
*ខ* ស.ប. អំណោយទានខាងភាសា.
*គ* ស.ប. ការព្យាករណ៍, ព្យាករ.
*ឃ* ស.ប. វិវរណៈ.
*ង* ស.ប. ការនិមិត្ត.
*ច* ស.ប. ប្រោស, ការប្រោស.
*ឆ* ១ កូរិន. ១២:១០; មរមន ៩:៧–៨.
៨ *ក* ស.ប. ព្រះគម្ពីរប៊ីប.
*ខ* ស.ប. ព្រះបន្ទូលនៃព្រះ.

បានបកប្រែ[គ]ត្រឹមត្រូវ; យើងខ្ញុំក៏ជឿដែរថា [ឃ]ព្រះគម្ពីរមរមន ជាព្រះបន្ទូល នៃព្រះ ។

៩ យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ ដែលទ្រង់បាន[ក]បើកសម្ដែងមក និងការណ៍ទាំងអស់ ដែលទ្រង់បើកសម្ដែងនៅពេលឥឡូវនេះ ហើយយើងខ្ញុំជឿថា ទ្រង់នឹង[ខ]បើកសម្ដែងនូវការណ៍ដ៏ធំ និងសំខាន់ៗជាច្រើន ដែលទាក់ទងទៅនឹងនគរនៃព្រះ ។

១០ យើងខ្ញុំជឿចំពោះ[ក]ការប្រមូលដ៏ពិតប្រាកដនៃសាសន៍អ៊ីស្រាអែល និងចំពោះការសាងឡើងវិញ នូវពូជ[ខ]ទាំង១០អំបូរ; ថា[គ]ក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក; ថាព្រះគ្រីស្ទនឹង[ឃ]សោយរាជ្យនៅលើផែនដីផ្ទាល់ ហើយថាផែនដីនឹងបាន [ង]ផ្លាស់ប្ដូរសារជាថ្មី ហើយនឹងទទួល[ឆ]សិរីល្អដ៏ប្រកបដោយភាពបរមសុខ ។

១១ យើងខ្ញុំសូមអះអាងយក[ក]សិទ្ធិក្នុងការថ្វាយបង្គំព្រះដ៏មានមហិទ្ធិឫទ្ធិ ស្របតាម[ខ]ការណែនាំនៃ[គ]សម្បជញ្ញៈរបស់យើងខ្ញុំ ហើយសូម បណ្ដោយឲ្យមនុស្សទាំងអស់មានសិទ្ធិដូចគ្នា ចូរឲ្យគេ[ឃ]ថ្វាយបង្គំតាមរបៀបណា នៅទីណា ឬអ្វីក៏ដោយ ដែលគេប្រាថ្នា ។

១២ យើងខ្ញុំជឿចំពោះការនៅក្រោមអំណាចស្ដេច ប្រធានាធិបតី អ្នកគ្រប់គ្រង និងចៅក្រមទាំងឡាយ ក្នុងការគោរពប្រតិបត្តិ និងការគាំទ្រ[ក]ច្បាប់ ។

១៣ យើងខ្ញុំជឿលើការប្រព្រឹត្តដោយ[ក]ទៀងត្រង់ ត្រឹមត្រូវ [ខ]បរិសុទ្ធ សប្បុរស គុណធម៌ ហើយលើការ[គ]ធ្វើល្អដល់មនុស្សទាំងអស់; ពិតមែនហើយ យើងខ្ញុំអាចនិយាយបានថា យើងខ្ញុំដើរតាម[ឃ]សេចក្ដីដាស់តឿនរបស់ប៉ុល — យើងខ្ញុំជឿដល់អ្វីៗទាំងអស់ យើងខ្ញុំ [ង]សង្ឃឹមដល់អ្វីៗទាំងអស់ យើងខ្ញុំបាន[ច]ទ្រាំទ្រអ្វីៗជាច្រើន ហើយសង្ឃឹមថានឹងអាចទ្រាំទ្រអ្វីៗទាំងអស់បានដែរ ។ ហើយបើសិនជាមានអ្វីណាមួយ ដែលប្រកប ដោយ[ឆ]គុណធម៌ គួរស្រឡាញ់ ឬឈ្មោះល្អ ឬក៏គួរឲ្យសរសើរ នោះយើងខ្ញុំស្វែងរករបស់ផងទាំងនេះហើយ ។

យ៉ូសែប ស៊្មីធ

៨ គ ១ នីហ្វៃ ១៣:២០–៤០; ១៤:២០–២៦.
ឃ ស.ប. ព្រះគម្ពីរមរមន.
៩ ក ស.ប. វិវរណៈ.
ខ អេម៉ុស ៣:៧; គ. និង ស. ១២១:២៦–៣៣. ស.ប. បទព្រះគម្ពីរ — គម្ពីរដែលបានព្យាករថានឹងចេញមក.
១០ ក អេសាយ ៤៩:២០–២២; ៦០:៤; ១ នីហ្វៃ ១៩:១៦–១៧. ស.ប. អ៊ីស្រាអែល — ការប្រមូលនៃសាសន៍អ៊ីស្រាអែល.
ខ ស.ប. អ៊ីស្រាអែល — ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់.
គ អេធើរ ១៣:២–១១; គ. និង ស. ៤៥:៦៦–៦៧; ៨៤:២–៥; ម៉ូសេ ៧:១៨. ស.ប. ក្រុងយេរូសាឡិមថ្មី; ស៊ីយ៉ូន.
ឃ ស.ប. សហស្សវត្សរ៍.
ង ស.ប. ផែនដី — ការសំអាតផែនដី.
ច ក.ន. ជាស្ថានភាពដូចជាសួនច្បារអេដែន; អេសាយ ១១:៦–៩; ៣៥:១–១០; ៥១:១–៣; ៦៥:១៧–២៥; អេសេ. ៣៦:៣៥. ស.ប. ស្ថានបរមសុខ.
ឆ ស.ប. សិរីល្អ.
១១ ក គ. និង ស. ១៣៤:១–១១.
ខ ស.ប. សិទ្ធិជ្រើសរើស.
គ ស.ប. បញ្ញាចិត្ត.
ឃ ស.ប. ថ្វាយបង្គំ.
១២ ក គ. និង ស. ៥៨:២១–២៣. ស.ប. ក្រិត្យវិន័យ.
១៣ ក ស.ប. ទៀងត្រង់, ចិត្តទៀតត្រង់; សេចក្ដីស្មោះ.
ខ ស.ប. ព្រហ្មចារីភាព.
គ ស.ប. ការបំរើ.
ឃ ភីលីព ៤:៨.
ង ស.ប. សេចក្ដីសង្ឃឹម.
ច ស.ប. កាន់ខ្ជាប់.
ឆ ស.ប. ភាពរម្យទម; គុណធម៌.

# សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ

បុព្វកថា

តារាងប្រធានបទទាំងឡាយតាមលំដាប់អក្ខរក្រម

បទជំរើសនានាចេញពីការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស្ម៊ីធ

ប្រវត្តិសាសនាចក្រតាមលំដាប់ពេលកើតឡើង, ផែនទី, និងរូបថតទាំងឡាយ

ផែនទី និងរូបថតទាំងឡាយអំពីព្រះគម្ពីរប៊ីប

# បុព្វកថា

សេចក្ដីណែនាំដល់បទព្រះគម្ពីរឲ្យន័យចំពោះគោលលទ្ធិ, គោលការណ៍, ប្រជាជន, និងកន្លែងខ្លះៗដែលឃើញមាននៅក្នុងព្រះគម្ពីរប៊ីប, ព្រះគម្ពីរមរមន, គោលលទ្ធិ និងសេចក្ដីសញ្ញា, និងមុក្ដាដ៏មានតម្លៃមហិមា ។ សេចក្ដីណែនាំដល់បទព្រះគម្ពីរព្រមទាំងផ្ដល់នូវសេចក្ដី យោងខាងបទព្រះគម្ពីរសំខាន់ៗ សំរាប់ឲ្យអ្នកសិក្សាប្រធានបទនីមួយៗ ។ សេចក្ដីណែនាំនេះអាចជួយអ្នក ក្នុងការសិក្សាព្រះគម្ពីរ ដោយខ្លួនឯង និងដោយគ្រួសារ ។ វាអាចជួយអ្នកឆ្លើយនូវចម្លើយអំពីដំណឹងល្អ, សិក្សានូវប្រធានបទទាំងឡាយក្នុងបទព្រះគម្ពីរ, តែងបាឋកថា និងមេរៀននានា, ហើយបង្កើនការចេះដឹង និងទីបន្ទាល់របស់អ្នកអំពីដំណឹងល្អ ។

សេចក្ដីណែនាំនេះមានបីភាគគឺ: (១) តារាងប្រធានបទទាំងឡាយតាមលំដាប់អក្ខរក្រម, (២) បទជំរើសនានាចេញពីការបកប្រែព្រះ គម្ពីរប៊ីបដោយយ៉ូសែប ស៊្មីធ (ក.យ.ស.), (៣) ប្រវត្តិសាសនាចក្រតាមលំដាប់ពេលកើតឡើង, ផែនទី, និងរូបថតទាំងឡាយ; ហើយនិងផែនទី និងរូបថតទាំងឡាយអំពីព្រះគម្ពីរប៊ីប ។

១. *តារាងប្រធានបទទាំងឡាយតាមលំដាប់អក្ខរក្រម* - ភាគនេះឲ្យន័យខ្លីៗដល់ប្រធានបទនីមួយៗ ហើយរាយនូវសេចក្ដីយោង សំខាន់ៗ ខាងបទព្រះគម្ពីរ ដែលស្ដីអំពីប្រធានបទនោះ ។ នៅពីមុខសេចក្ដីយោងនីមួយៗមានពាក្យស្រង់ ឬពាក្យសង្ខេបខ្លីៗអំពីបទ ព្រះគម្ពីរនោះ ។ សេចក្ដីយោងខាងបទព្រះគម្ពីរទាំងឡាយមានតាមលំដាប់ដូចតទៅនេះគឺ៖ ព្រះគម្ពីរសញ្ញាចាស់, ព្រះគម្ពីរសញ្ញាថ្មី, ព្រះគម្ពីរមរមន, គោលលទ្ធិ និងសេចក្ដីសញ្ញា, និងមុក្ដាដ៏មានតម្លៃមហិមា ។

២. *បទជំរើសនានាចេញពីការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស៊្មីធ* - នៅឆ្នាំ១៨៣០ ព្រះអម្ចាស់ទ្រង់បានបង្គាប់ព្យាការីយ៉ូសែប ស៊្មីធ ឲ្យចាប់ផ្ដើមធ្វើការកែសំរួល ឬបកប្រែព្រះគម្ពីរប៊ីបច្បាប់ស្ដេចយេម្ស ។ គោលបំណងរបស់ព្យាការីគឺដើម្បីសាងឡើងវិញនូវការ ពិតដ៏ច្បាស់ និងពិសេសទាំងឡាយ ដែលបានបាត់ពីព្រះគម្ពីរប៊ីបច្បាប់ដើម ។ លោកបានសំរេចកិច្ចការភាគច្រើននោះក្នុងខែកក្កដា ឆ្នាំ១៨៣៣ ។ ក៏ប៉ុន្ដែរហូតដល់មរណភាពរបស់លោកនៅឆ្នាំ ១៨៤៤ នោះលោកនៅតែធ្វើការកែសម្រួលរហូត ក្នុងការរៀបចំ អត្ថបទសរសេរសំរាប់បោះពុម្ព ។ ទោះបីគម្ពីរទាំងមូលនោះពុំទាន់បានសំរេច ឬបានទទួលស្គាល់តាមផ្លូវការ ដោយសាសនាចក្រក្ដី គង់តែការបកប្រែដោយយ៉ូសែប ស៊្មីធ មាននូវការយល់ធ្លុះជ្រៅអំពីន័យបទព្រះគម្ពីរ ហើយជាជំនួយដ៏សំខាន់មួយ ក្នុងការយល់ព្រះគម្ពីរ ប៊ីបដែរ ។ ការកែសម្រួលខ្លះៗដែលមានសារៈសំខាន់ នោះមាននៅក្នុងសេចក្ដីណែនាំដល់បទព្រះគម្ពីរ ។ (បើសិនជាចង់បាន ពត៌មានថែមទៀត សូមមើលប្រធានបទ «ការបកប្រែដោយយ៉ូសែប ស៊្មីធ» នៅក្នុងសេចក្ដីណែនាំ) ។

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យកការបកប្រែចេញជាភាសាអង់គ្លេស នូវព្រះគម្ពីរប៊ីបច្បាប់ស្ដេចយេម្ស មកប្រើជាផ្លូវការ ។ ព្រះគម្ពីរច្បាប់នេះមានសារៈសំខាន់ក្នុងការសាងឡើងវិញនៃដំណឹងល្អ ហើយចេះតែមានឥទ្ធិពលតទៅទៀត ចំពោះសាសន៍ជាច្រើននៅក្នុងពិភពលោកទូទៅ ។

៣. *ប្រវត្តិសាសនាចក្រតាមលំដាប់ពេលកើតឡើង, ផែនទី, និងរូបថតទាំងឡាយ; ហើយនិងផែនទី និងរូបថតទាំងឡាយ អំពីព្រះគម្ពីរប៊ីប* - ដោយការស្គាល់នូវភូមិសាស្ត្រនៃដែនដី ដែលបានពោលដល់នៅក្នុងបទព្រះគម្ពីរ នោះអ្នកអាចយល់អំពីហេតុ ការណ៍នានាក្នុងគម្ពីរកាន់តែច្រើនឡើង ។ សេចក្ដីណែនាំនេះមានរួមនូវផែនទី៩ផែន អំពីតំបន់សំខាន់ៗក្នុងប្រវត្តិសាសនាចក្រ, ១៤ផែន អំពីដែនដីក្នុងព្រះគម្ពីរប៊ីប, និង១ផែន អំពីពិភពលោក ។ ដើម្បីរកទីកន្លែងណាមួយ សូមមើលលិបិក្រមសំរាប់ផ្នែកផែនទី ដែលអ្នកចង់ដឹង ។ លិបិក្រមនោះនឹងប្រាប់អ្នកនូវ ផែនទីណាដែលសម និងក្រឡានៃទីកន្លែងនោះនៅលើផែនទី ។ រីឯរូបថត១៨ សន្លឹកអំពីប្រវត្តិសាសនាចក្រ និងអំពីព្រះគម្ពីរប៊ីប នោះក៏មានពិពណ៌នាទាំងឡាយ ដែលនឹងជួយឲ្យអ្នកយល់អំពីហេតុការណ៍ ក្នុងគម្ពីរ កាន់តែច្រើនឡើងដែរ ។

ប្រវត្តិសាសនាចក្រតាមលំដាប់ពេលនោះរាយប្រាប់ពីថ្ងៃទីអំពីហេតុការណ៍សំខាន់ៗ ដែលកើតឡើងចំពោះការសាងឡើងវិញ និងការលូតលាស់របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ដើម្បីជួយអ្នកថែមទៀត ក្នុងការសិក្សាព្រះគម្ពីររបស់អ្នក នោះសេចក្ដីណែនាំនេះមាននូវជំនួយពិសេសផ្សេងៗទៀត ។ ជាឧទាហរណ៍ បើសិនជាអ្នកបើកមើល «ព្រះយេស៊ូវគ្រីស្ទ» នោះអ្នកនឹងឃើញថាមានបញ្ជីដ៏ទូលំទូលាយអំពីប្រធានបទនីមួយៗ នៅក្នុងសេចក្ដីណែនាំដែលផ្ដល់ពត៌មានដែលទាក់ទងទៅនឹងព្រះអម្ចាស់ និងការងារបំរើរបស់ទ្រង់ផ្ទាល់ ។ ប្រធានបទនេះគឺជាប្រធានបទតែមួយគត់នៅ ក្នុងសេចក្ដីណែនាំ ដែលមានបញ្ជីដ៏វែងឆ្ងាយ ដែលបញ្ជាក់ប្រាប់សារៈសំខាន់អំពីព្រះគ្រីស្ទចំពោះមនុស្សលោកទាំងអស់ ។ បន្ថែមលើ នេះទៀត នៅក្រោមប្រធានបទ «លំដាប់ពេល» នោះរាយប្រាប់អំពីហេតុការណ៍សំខាន់ៗបំផុត ដែលកើតឡើងនៅសម័យព្រះគម្ពីរ ប៊ីប និងព្រះគម្ពីរមរមន ព្រមទាំងថ្ងៃទីដែលប្រហាក់ប្រហែលផង ។ ប្រធានបទ «ដំណឹងល្អទាំងឡាយ» រួមទាំងមានតារាងសមស្របគ្នា អំពីដំណឹងល្អទាំងឡាយ ។ តារាងនេះប្រៀបផ្ទឹមនូវសេចក្ដីបង្រៀននៃព្រះអង្គសង្គ្រោះ ដូចដែលឃើញមាននៅក្នុងគម្ពីរម៉ាថាយ, ម៉ាកុស, លូកា, យ៉ូហាន, និងវិវរណៈប្រចាំថ្ងៃចុងក្រោយ ។

ខាងក្រោមនេះគឺជាអក្សរកាត់ឈ្មោះគម្ពីរទាំងឡាយដែលយកមកប្រើក្នុងសេចក្ដីណែនាំនេះ៖

ព្រះគម្ពីរសញ្ញាចាស់

| | |
|---|---|
| លោកុប្បត្តិ | លោកុ. |
| និក្ខមនំ | និក្ខ. |
| លេវីវិន័យ | លេវី. |
| ជនគណនា | ជនគ. |
| ចោទិយកថា | ចោទិ. |
| យ៉ូស្វេ | យ៉ូស្វេ |
| ពួកចៅហ្វាយ | ពួកចៅ. |
| នាងរស់ | នាងរស់ |
| សាំយូអែល ទី ១ | ១ សាំយូ. |
| សាំយូអែល ទី ២ | ២ សាំយូ. |
| ពង្សាវតារក្សត្រ ទី ១ | ១ ពង្សាវ. |
| ពង្សាវតារក្សត្រ ទី ២ | ២ ពង្សាវ. |
| របាក្សត្រ ទី ១ | ១ របា. |
| របាក្សត្រ ទី ២ | ២ របា. |
| អែសរ៉ា | អែសរ៉ា |
| នេហេមា | នេហេ. |
| នាងអេសធើរ | នាងអេស |
| យ៉ូប | យ៉ូប |
| ទំនុកដំកើង | ទំនុក. |
| សុភាសិត | សុភា. |
| សាស្ដា | សាស្ដា |
| បទចំរៀងសាឡូម៉ូន | បទចំរៀង. |
| អេសាយ | អេសាយ |
| យេរេមា | យេរេ. |
| បរិទេវ | បរិទេវ |
| អេសេគាល | អេសេ. |
| ដានីយ៉ែល | ដានី. |
| ហូសេ | ហូសេ |
| យ៉ូអែល | យ៉ូអែល |
| អេម៉ុស | អេម៉ុស |
| អូបាឌា | អូបា. |
| យ៉ូណាស | យ៉ូណាស |
| មីកា | មីកា |
| ណាហ៊ុម | ណាហ៊ុម |
| ហាបាគុក | ហាបា. |
| សេផានា | សេផា. |
| ហាកាយ | ហាកាយ |
| សាការី | សាការី |
| ម៉ាឡាគី | ម៉ាឡាគី |

ព្រះគម្ពីរសញ្ញាថ្មី (ព.ស.ថ.)

| | |
|---|---|
| ម៉ាថាយ | ម៉ាថាយ |
| ម៉ាកុស | ម៉ាកុស |
| លូកា | លូកា |
| យ៉ូហាន | យ៉ូហាន |
| កិច្ចការពួកសាវក | កិច្ចការ |
| រ៉ូម | រ៉ូម |
| កូរិនថូស ទី ១ | ១ កូរិន. |
| កូរិនថូស ទី ២ | ២ កូរិន. |
| កាឡាទី | កាឡាទី |
| អេភេសូ | រអេភេ. |
| ភីលីព | ភីលីព |
| កូល៉ុស | កូល៉ុស |
| ថែស្សាឡូនិច ទី ១ | ១ ថែស្សា. |
| ថែស្សាឡូនិច ទី ២ | ២ ថែស្សា. |
| ធីម៉ូថេ ទី ១ | ១ ធីម៉ូ. |
| ធីម៉ូថេ ទី ២ | ២ ធីម៉ូ. |
| ទីតុស | ទីតុស |
| ភីលេម៉ូន | ភីលេ. |
| ហេព្រើរ | ហេព្រើរ |
| យ៉ាកុប (ព្រះគម្ពីរសញ្ញាថ្មី) | យ៉ាកុប (ព.ស.ថ.) |
| ពេត្រុស ទី ១ | ១ ពេត្រុស |
| ពេត្រុស ទី ២ | ២ ពេត្រុស |
| យ៉ូហាន ទី ១ | ១ យ៉ូហាន |
| យ៉ូហាន ទី ២ | ២ យ៉ូហាន |
| យ៉ូហាន ទី ៣ | ៣ យ៉ូហាន |
| យូដាស | យូដាស |
| វិវរណៈ | វិវរ. |

ព្រះគម្ពីរមរមន

| | |
|---|---|
| នីហ្វៃ ទី ១ | ១ នីហ្វៃ |
| នីហ្វៃ ទី ២ | ២ នីហ្វៃ |
| យ៉ាកុប | យ៉ាកុប |
| អេណុស | អេណុស |
| យ៉ារ៉ុម | យ៉ារ៉ុម |
| អោមណៃ | អោមណៃ |
| ពាក្យសំដីនៃមរមន | ព. នៃ ម. |
| ម៉ូសាយ | ម៉ូសាយ |
| អាលម៉ា | អាលម៉ា |
| ហេលេមិន | ហេលេ. |

| | |
|---|---|
| នីហ្វៃ ទី ៣ | ៣ នីហ្វៃ |
| នីហ្វៃ ទី ៤ | ៤ នីហ្វៃ |
| មរមន | មរមន |
| អេធើរ | អេធើរ |
| មរ៉ូណៃ | មរ៉ូណៃ |
| | |
| គោលលទ្ធិ និងសេចក្ដីសញ្ញា | គ. និង ស. |
| សេចក្ដីប្រកាសជាផ្លូវការ ទី ១ | សេចក្ដីប្រកាស – ១ |
| សេចក្ដីប្រកាសជាផ្លូវការ ទី ២ | សេចក្ដីប្រកាស – ២ |

| | |
|---|---|
| មុក្ដាដ៏មានតម្លៃមហិមា | |
| ម៉ូសេ | ម៉ូសេ |
| អ័ប្រាហាំ | អ័ប្រា. |
| យ៉ូសែប ស៊្មីធ—ម៉ាថាយ | យ.ស.—ម៉ាថាយ |
| យ៉ូសែប ស៊្មីធ—ប្រវត្តិ | យ.ស.—ប្រវត្តិ |
| មាត្រានៃសេចក្ដីជំនឿ | ម. នៃ ស. |
| | |
| ការបកប្រែដោយយ៉ូសែប ស៊្មីធ | ក.យ.ស. |

# តារាងប្រធានបទទាំងឡាយតាមលំដាប់អក្ខរក្រម

របៀបប្រើ— សេចក្ដីណែនាំដល់បទព្រះគម្ពីរ គឺជាតារាងប្រធានបទតាមលំដាប់អក្ខរក្រម ។ សេចក្ដីណែនាំនេះឲ្យន័យខ្លីៗដល់មុខ ប្រធានវិមួយៗ ហើយរាយនូវសេចក្ដីយោងសំខាន់ៗ ខាងបទព្រះគម្ពីរ ដែលស្ដីអំពីប្រធានបទនោះ ។ នៅពីមុខសេចក្ដីយោងនីមួយៗ មានពាក្យស្រង់ និងពាក្យសង្ខេបខ្លីៗអំពីបទព្រះគម្ពីរនោះ ។ សេចក្ដីយោងខាងបទព្រះគម្ពីរទាំងឡាយមានតាមលំដាប់ដូចតទៅនេះគឺៈ ព្រះគម្ពីរសញ្ញាចាស់, ព្រះគម្ពីរសញ្ញាថ្មី, ព្រះគម្ពីរមរមន, គោលលទ្ធិ និងសេចក្ដីសញ្ញា, និងមុក្ដាដ៏មានតម្លៃមហិមា ។ ឧីយ៉ាក្រោម ខាងក្រោមនេះពន្យល់ពីប្រធានបទមួយជាឧទាហរណ៍ ៖

ប្រធានបទនានា គឺសរសេរជាអក្សរធំ ។

**ផែនដី** *សូមមើលផង* បង្កើត, ការបង្កបង្កើត; ពិភពលោក, លោកិយ, មនុស្សលោក

ជូនកាល ប្រធានបទផ្សេងទៀតនៅក្នុងសេចក្ដីណែនាំ មានពត៌មានដែលទាក់ទងទៅនឹងប្រធានបទដែលអ្នកកំពុងសិក្សា ។ ពាក្យផ្ដែក*សូមមើលផង* ប្រាប់អ្នកឲ្យមើលប្រធានបទទាំងឡាយនេះដែលទាក់ទងនឹងគ្នាដែរ ។

មានអត្ថន័យខ្លីៗ អំពីប្រធានបទនីមួយៗ ។

ជាពិភពដែលយើងរស់នៅ គឺព្រះបានបង្កើតដោយព្រះយេស៊ូវគ្រីស្ទ ដើម្បីទុកឲ្យមនុស្សប្រើនៅគ្រាពិសោធន៍ខាងសាច់ឈាមរបស់គេ ។ អនាគតចុងក្រោយបង្អស់នៃផែនដី គឺឲ្យបានសិរីល្អ ហើយថ្កើងថ្កានឡើង (គ. និង ស. ៧៧:១–២; ១៣០:៨–៩) ។ ផែនដីនឹងបាន ក្លាយទៅជាកេរ្ដិ៍មរតកដ៏នៅអស់កល្បជានិច្ច ដល់ពួកអ្នកដែលបានរស់នៅសុខសាន្តនឹងសិរីល្អខាងសេឡេស្ទាល (គ. និង ស. ៨៨:១៤:២៦) ។ ពួកគេនឹងមានសេចក្ដីអំណរចំពោះវត្តមាននៃព្រះវរបិតា និងព្រះរាជបុត្រា (គ. និង ស. ៧៦:៦២) ។

សេចក្ដីយោងខាងបទព្រះគម្ពីរដែលទាក់ទងនឹងគ្នា នោះដាក់នៅក្នុងវង់ក្រចក ។

សេចក្ដីយោងនានាខាងបទព្រះគម្ពីរ ដែលជួយអ្នកឲ្យយល់អត្ថន័យ នោះមាននៅក្នុងវង់ក្រចក ។

*បង្កើតសំរាប់មនុស្ស ៖* ព្រះទ្រង់ប្រទានឲ្យមនុស្សមានអំណាចលើផែនដី, **លោកុ.** ១:២៨ (ម៉ូសេ ២:២៨) ។ ផែនដីជារបស់ផង ព្រះអម្ចាស់, **និក្ខ.** ៩:២៩ (ទំនុក. ២៤:១) ។ ព្រះអម្ចាស់ទ្រង់បានប្រគល់ផែនដីដល់កូនចៅមនុស្ស, **ទំនុក.** ១១៥:១៦ ។ ដោយព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ នោះមានមនុស្សរស់នៅ លើផែនដី, **យ៉ាកុប** ៤:៩ ។ មនុស្សក្រីក្រ និងមនុស្សស្លូតបូតនៅលើផែនដី នឹងបានគ្រងផែនដីទុកជាមរតក, **គ. និង ស.** ៨៨:១៧ (ម៉ាថាយ ៥:៥; ៣ នីហ្វៃ ១២:៥) ។ យើងនឹងធ្វើផែនដី ហើយយើងនឹងសាក ល្បងពួកគេ, **អ័ប្រា.** ៣:២៤–២៥ ។

នៅពីមុខសេចក្ដីយោងខាងបទព្រះគម្ពីរនីមួយៗមានពាក្យស្រង់ពីបទព្រះគម្ពីរ ឬពាក្យសង្ខេបខ្លីៗអំពីបទព្រះគម្ពីរនោះ ។

ប្រធានបទខ្លះៗ មានប្រធានបទរង ។ ប្រធានបទរងនោះសរសេរជាអក្សរផ្ដេក ។

ជូនកាល ពត៌មានស្ដីអំពីមុខប្រធានមួយពុំមាននៅក្រោមប្រធានបទដែលអ្នកមើលនោះទេ ។ ពាក្យផ្ដេក*សូមមើល* ប្រាប់អ្នកឲ្យ មើលប្រធានបទដែលមានពត៌មាននោះ ។

**បុណ្យអ៊ីស្ទើរ***សូមមើល* ព្រះយេស៊ូវគ្រីស្ទ; ដំណើររស់ឡើងវិញ

**ចុងបំផុតផែនដី***សូមមើល* ពិភពលោក— ចុងបំផុតផែនដី

ពាក្យផ្ដេក*សូមមើល* (ឬ*សូមមើលផង* ) តទៅដោយរដ្ឋសញ្ញា (-) ប្រាប់អ្នកថាពត៌មាននោះរកឃើញក្នុងប្រធានបទរង («ចុងបំផុតផែនដី») នៃប្រធានបទធំ («ពិភពលោក») ។

**កាឌ់, កូនប្រុសរបស់យ៉ាកុប** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាកូនប្រុសរបស់យ៉ាកុប និងនាងស៊ីលផា (លោកុ. ៣០:១០–១១) ។ ពូជពង្សរបស់លោកបានក្លាយទៅ ជាពូជអំបូរនៃអ៊ីស្រាអែលមួយ ។

*ពូជអំបូររបស់កាឌ់៖* ចំពោះពររបស់យ៉ាកុបដល់កាឌ់ ជាកូនលោក សូមមើលគម្ពីរលោកុប្បត្តិ ៤៩:១៩ ។ ចំពោះពររបស់ម៉ូសេ ដល់ពូជអំបូររបស់កាឌ់ សូមមើលគម្ពីរចោទិយកថា ៣៣:២០–២១ ។ តាមពរទាំងនេះ ពូជពង្សកាឌ់ត្រូវបានជាជាតិចូលចិត្តខាង ចម្បាំង ។ ដែនដីទាំងឡាយ ដែលបានចែកទុកដល់ពួកគេ នៅស្រុកកាណាន គឺនៅខាងកើតទន្លេយ័រដាន់ ហើយមានវាលស្មៅល្អ ព្រមទាំងមានទឹកបរិបូរផង ។

**កាឌ់ ជាអ្នកមើលឆុត** *សូមមើលផង* បទព្រះគម្ពីរ — គម្ពីរដែលបាត់

ជាព្យាការី ហើយជាមិត្ត និងជាអ្នកប្រឹក្សាដ៏ស្មោះត្រង់ម្នាក់នៃស្ដេចដាវីឌ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (១ សាំយូ. ២២:៥; ២ សាំយូ. ២៤:១១–១៩) ។ លោកបានសរសេរគម្ពីរកិច្ចការទាំងឡាយនៃស្ដេចដាវីឌ ដែលបានក្លាយទៅជាគម្ពីរដែលបាត់ (១ របា. ២៩:២៩) ។

**កាណាន, សាសន៍កាណាន**

នៅសម័យព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសទី៤ នៃហាំ (លោកុ. ៩:២២; ១០:១, ៦) ហើយជាចៅរបស់លោកណូអេ ។ សាសន៍កាណាន សំដៅទៅពួកអ្នកណា ដែលមកពីស្រុកដែលកាណានបានរស់នៅមុនដំបូង ហើយក៏សំដៅទៅពូជពង្សលោក ។ សាសន៍កាណាន ក៏ជាឈ្មោះសំរាប់ប្រជាជនដែលនៅតាមដីទំនាប ជាប់នឹងឆ្នេរសមុទ្រមេឌីទេរេណេ នៅស្រុកភីលីស្ទីន ។ ជួនកាល ឈ្មោះនេះបានយកមកហៅ អស់អ្នកណា ដែលមិនមែនជាសាសន៍អ៊ីស្រាអែល ដែលនៅស្រុកខាងលិចយ័រដាន់ គឺដែលពួកក្រេក ហៅថា សាសន៍ភីនីស៊ី ។

**កាណុង** *សូមមើលផង* គោលលទ្ធិ និងសេចក្ដីសញ្ញា; បទព្រះគម្ពីរ; ព្រះគម្ពីរប៊ីប; ព្រះគម្ពីរមរមន, មុក្ដាដ៏មានតម្លៃមហិមា

ជាប្រជុំគម្ពីរដ៏ពិសិដ្ឋៗ ដែលបានទទួលស្គាល់ ហើយមានសិទ្ធិអំណាច ។ នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយនោះ គម្ពីរកាណុងទាំងប៉ុន្មាន ហៅថា គម្ពីរបមាណិយ ហើយមានទាំងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី, ព្រះគម្ពីរមរមន, គោលលទ្ធិ និងសេចក្ដីសញ្ញា, ព្រមទាំងមុក្ដាដ៏មានតម្លៃមហិមា ។

**កាតព្វកិច្ច** *សូមមើលផង* ការគោរពតាម, គោរពតាម, ដែលគោរពតាម

នៅក្នុងគម្ពីរ គឺជាការងារ មុខងារ ឬកាតព្វកិច្ច ដែលតែងតែបានប្រទានឲ្យមក ដោយព្រះអម្ចាស់ ឬដោយពួកអ្នកបំរើរបស់ទ្រង់ ។

ចូរកាន់តាមបញ្ញត្តិទ្រង់ចុះ ត្បិតប៉ុណ្ណេះឯងជាកិច្ចទាំងមូលនៃមនុស្ស, **សាស្ដា** ១២:១៣ ។ តើព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកប្រព្រឹត្តដូចម្ដេច បើមិនមែនឲ្យប្រព្រឹត្តដោយសុចរិត, **មីកា** ៦:៨ ។ យើងត្រូវតែស្ដាប់បង្គាប់របស់ព្រះ ជាជាងមនុស្ស, **កិច្ចការ** ៥:២៩ ។ ពួកគេត្រូវវាយ ដោយសេចក្ដីទុក្ខវេទនា ដើម្បីដាស់រំឭលគេ ឲ្យនឹកចាំដល់ករណីយកិច្ចរបស់គេ, **ម៉ូសាយ** ១:១៧ ។ ភារកិច្ចទាំងឡាយនៃពួកអែលឌើរ ពួកសង្ឃ ពួកគ្រូ និងពួកឌីកុនត្រូវបានអធិប្បាយប្រាប់, **គ. និង ស.** ២០:៣៨–៦៧ ។ ពួកអ្នកកាន់បព្វជិតភាពត្រូវធ្វើ កាតព្វកិច្ចគ្រួសារគ្រប់យ៉ាង, **គ. និង ស.** ២០:៤៧, ៥១ ។ កាតព្វកិច្ចទាំងឡាយនៃសមាជិក បន្ទាប់ពីបានទទួលបុណ្យជ្រមុជទឹក ត្រូវបានអធិប្បាយប្រាប់, **គ. និង ស.** ២០:៦៨–៦៩ ។ ពួកអែលឌើររបស់យើងត្រូវរង់ចាំមួយរដូវដ៏ខ្លីសិន ដើម្បីឲ្យរាស្ត្រយើងអាចចេះឲ្យបាន ល្អឥតខ្ចោះអំពីកាតព្វកិច្ចរបស់គេ, **គ. និង ស.** ១០៥:១០ ។ ចូរឲ្យមនុស្សរាល់គ្នារៀនពីកាតព្វកិច្ចរបស់ខ្លួន, **គ. និង ស.** ១០៧:៩៩–១០០ ។

**កាត់ទោស, ការកាត់ទោស** *សូមមើលផង* ជំនុំជំរះ, សេចក្ដីជំនុំជំរះ; សេចក្ដីជំនុជំរះចុងក្រោយបំផុត

គឺដើម្បីជំនុំជំរះ ឬសំរេចកំហុសដោយព្រះ ។

ព្រះទ្រង់នឹងកាត់ទោសដល់មនុស្សណា ដែលគិតគូរបង្កើតការអាក្រក់, **សុភា.** ១២:២ ។ ព្រះអម្ចាស់ទ្រង់វាយផ្ចាលយើង ដើម្បីកុំឲ្យយើងជាប់ទោសជាមួយនឹងលោកិយ, **១ កូរិន.** ១១:៣២ ។ ពាក្យសំដី កិច្ចការ និងគំនិតយើងទាំងឡាយនឹងកាត់ទោសយើង, **អាលម៉ា** ១២:១៤ ។ ដោយដឹងនូវរឿងទាំងឡាយ តែពុំបានធ្វើតាម នោះមនុស្សលោកនៅក្រោមការកាត់ទោសហើយ, **ហេលេ.** ១៤:១៩ ។ បើយើងរាល់គ្នាឈប់ធ្វើការ នោះយើងនឹងត្រូវនៅក្រោមការកាត់ទោសហើយ, **មរ៉ូណៃ** ៩:៦ ។ អ្នកណាដែលមិនអត់ទោសដល់បង ប្អូនរបស់ខ្លួន នោះជាប់ទោសនៅចំពោះព្រះអម្ចាស់; **គ. និង ស.** ៦៤:៩ ។ អ្នកណាដែលធ្វើបាបទាស់នឹងពន្លឺដ៏ធំជាង នោះនឹងត្រូវទទួលការជាប់ទោសដ៏ធំជាងដែរ, **គ. និង ស.** ៨២:៣ ។ សាសនាចក្រទាំងមូលនឹងត្រូវនៅក្រោមការដាក់ទោស រហូតដល់ ពួកគេប្រែចិត្ត ហើយនឹកចាំដល់ព្រះគម្ពីរមរមន, **គ. និង ស.** ៨៤:៥៤–៥៧ ។

**កាន់ខ្ជាប់** *សូមមើលផង* ល្បួង, សេចក្ដីទំនាស់; សេចក្ដីល្បួង, សេចក្ដីអត់ធន់

ដើម្បីនៅស្ថិតស្ថេរក្នុងកិច្ចសន្យា ដើម្បីឲ្យបានពិតចំពោះព្រះបញ្ញត្តិទាំងឡាយនៃព្រះ ទោះជាមានសេចក្ដីល្បួង សេចក្ដីប្រឆាំង និងសេចក្ដីទំនាស់ក៏ដោយ ។

អ្នកណាដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុត អ្នកនោះនឹងបានសង្គ្រោះ, **ម៉ាថាយ** ១០:២២ (ម៉ាកុស ១៣:១៣) ។ គេគ្មានឫស ហើយក៏នៅជាប់តែបន្តិចទេ, **ម៉ាកុស** ៤:១៧ ។ សេចក្ដីសប្បុរសទ្រាំទ្រអ្វីៗទាំងអស់, **១ កូរិន.** ១៣:៧ ។ បន្ទាប់ពីអ័ប្រាហាំមានសេចក្ដីអត់ធន់ជាយូរ នោះលោកបានទទួលសេចក្ដីសន្យា, **ហេព្រើរ** ៦:១៥ ។ បើអ្នកនោះកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះគេនឹងត្រូវបានលើក ឡើងនៅថ្ងៃចុងក្រោយបង្អស់, **១ នីហ្វៃ** ១៣:៣៧ ។ បើបងរាល់គ្នានឹងគោរពតាមព្រះបញ្ញត្តិទាំងប៉ុន្មាន ហើយកាន់ខ្ជាប់ ដរាបដល់ ចុងបំផុត នោះបងៗនឹងបានសង្គ្រោះ, **១ នីហ្វៃ** ២២:៣១ (អាលម៉ា ៥:១៣) ។ បើអ្នករាល់គ្នាខិតខំជឿនទៅមុខ ដោយទទួលទាន នូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះអ្នករាល់គ្នានឹងមានជីវិតដ៏នៅអស់កល្បជានិច្ច, **២ នីហ្វៃ** ៣១:២០ (៣ នីហ្វៃ ១៥:៩; គ. និង ស. ១៤:៧) ។ អស់អ្នកណាដែលដាក់ឈ្មោះយើងលើខ្លួន ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត អ្នកនោះនឹង បានសង្គ្រោះ, **៣ នីហ្វៃ** ២៧:៦ ។ អស់អ្នកណាដែលកាន់ខ្ជាប់នៅក្នុង សាសនាចក្ររបស់យើង ដរាបដល់ចុងបំផុត អ្នកនោះហើយ ដែលយើងនឹងតាំងឡើងលើថ្មដារបស់យើង, **គ. និង ស.** ១០:៦៩ ។ អ្នកណាដែលកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿ នោះនឹងបានឈ្នះ លើលោកិយ, **គ. និង ស.** ៦៣:២០, ៤៧ ។ គ្រប់ទាំងបល្ល័ង្ក និងអំណាច គ្រប់គ្រងទាំងឡាយនឹងត្រូវបានប្រទានមកលើអស់អ្នកណា ដែលស៊ូទ្រាំដោយក្លាហានដើម្បីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ១២១:២៩ ។

**កាព្រីយ៉ែល***សូមមើលផង* ណូអេ, នាងម៉ារា, ពួកទេវតា; មាតារបស់ព្រះយេស៊ូវ; អយ្យកោក្នុងព្រះគម្ពីរប៊ីប

ជាទេវតាដែលបានចាត់ឲ្យទៅឯដានីយ៉ែល (ដានី. ៨:១៦; ៩:២១) ទៅឯសាការី (លូកា ១:១១–១៩; គ. និង ស. ២៧:៧) ទៅឯនាងម៉ារា (លូកា ១:២៦–៣៨) ហើយទៅឯអ្នកផ្សេងៗទៀត (គ. និងស. ១២៨:២១) ។ ព្យាការីយ៉ូសែប ស្ម៊ីធបានបញ្ជាក់ថា កាព្រីយ៉ែលគឺជាព្យាការីណូអេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

**កាម៉ាលាល***សូមមើលផង* ពួកផារិស៊ី

ជាពួកផារិស៊ីម្នាក់ដែលស្គាល់ទូទៅនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាអ្នកដែលចេះ ហើយបង្រៀនក្រិត្យសាសន៍យូដា ។ សាវកប៉ុល ជាសិស្សរបស់លោកម្នាក់ (កិច្ចការ ២២:៣) ។ លោកមានអំណាចច្រើននៅក្នុងក្រុមជំនុំសានហេទ្រិន (កិច្ចការ ៥:៣៤–៤០) ។

**ការកាត់ចេញពីសាសនា***សូមមើលផង* ការបះបោរ, សេចក្ដីក្បត់សាសនា

ជាដំណើរខាងការបដិសេធមនុស្សណាម្នាក់ ចេញពីសាសនាចក្រ ហើយដកយកអស់ទាំងសិទ្ធិ និងឯកសិទ្ធិនៃសមាជិកចេញ ។ ពួកមេដឹកនាំសាសនាចក្រកាត់មនុស្សចេញពីសាសនាចក្រ នៅពេលអ្នកនោះបានរើសការរស់នៅដែលផ្ទុយទៅនឹងព្រះបញ្ញត្តិទាំង ឡាយរបស់ព្រះអម្ចាស់ប៉ុណ្ណោះ ហើយបានធ្វើឲ្យខ្លួនមិនសមជាសមាជិកតទៅទៀតនៅក្នុងសាសនាចក្រឡើយ ។

មនុស្សជាច្រើនបានធ្វើចិត្តរឹងរូស ហើយឈ្មោះរបស់គេត្រូវបានលុបចេញ, **អាលម៉ា** ១:២៤ (អាលម៉ា ៦:៣) ។ បើអ្នកនោះពុំប្រែចិត្តទេ អ្នកនោះពុំត្រូវរាប់ចូលក្នុងចំណោមរាស្ត្រយើងឡើយ, **៣ នីហ្វៃ** ១៨:៣១ (ម៉ូសាយ ២៦) ។ ពួកអ្នកដែលផិតគ្នា ហើយមិនប្រែចិត្តទេ នោះនឹងត្រូវបណ្ដេញចេញ, **គ. និង ស.** ៤២:២៤ ។ អ្នកណាដែលធ្វើបាប ហើយមិនប្រែចិត្តទេ នោះនឹងត្រូវបណ្ដេញចេញ, **គ. និង ស.** ៤២:២៨ ។ របៀបទាំងឡាយត្រូវបានរៀបរាប់ប្រាប់ សំរាប់កាត់ក្ដីនូវបញ្ហាសំខាន់ៗ នៅក្នុងសាសនាចក្រ, **គ. និង ស.** ១០២ (គ. និង ស. ៤២:៨០–៩៣) ។ ប៊ីស្សពត្រូវបានតាំងឲ្យធ្វើជាចៅក្រមនៅអ៊ីស្រាអែល, **គ. និង ស.** ១០៧:៧២ ។ សមាគមខាងសាសនាទាំង ឡាយមានសិទ្ធិ ដើម្បីដោះស្រាយចរិយាមិនត្រឹមត្រូវនៃសមាជិក, **គ. និង ស.** ១៣៤:១០ ។

**ការកាត់ស្បែក** *សូមមើលផង* សេចក្ដីសញ្ញាអ័ប្រាហាំ

ជាទីសំគាល់ក្នុងសេចក្ដីសញ្ញាអ័ប្រាហាំ ចំពោះពួកសាសន៍អ៊ីស្រាអែលប្រុសៗ នៅគ្រាកាន់កាប់ត្រួតត្រាសម័យព្រះគម្ពីរសញ្ញាចាស់ (លោកុ. ១៧:១០–១១; ២៣–២៧; ក.យ.ស., លោកុ. ១៧:១១) ។ ការកាត់ស្បែក គឺធ្វើដោយកាត់ « ស្បែកស្រោមចុងស្វាស » ពីទារក និងមនុស្សពេញវ័យ ប្រុសៗ ។ អស់អ្នកណាដែលបានទទួលកាត់ស្បែក នោះគេមានអំណរចំពោះឯកសិទ្ធិ ហើយបានទទួល ការខុសត្រូវនៃសេចក្ដីសញ្ញា ។ ការ កាត់ស្បែកដែលជាទីសំគាល់អំពីសេចក្ដីសញ្ញា នោះបានឈប់ធ្វើដោយសារបេសកកម្មនៃ ព្រះគ្រីស្ទ (ម៉ូរ៉ូណៃ ៨:៨; គ. និង ស. ៧៤:៣–៧) ។

**ការកំណត់កំណើត** *សូមមើលផង* គ្រួសារ; រៀបអាពាហ៍ពិពាហ៍, អាពាហ៍ពិពាហ៍

ជាការកំណត់ចំនួនកូនចៅដែលភរិយានិងស្វាមីចង់បាន ឬការឃុំកំណើត ។

ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដី, **លោកុ.** ១:២៨ (ម៉ូសេ ២:២៨) ។ កូនចៅជាមរតកមកពីព្រះ អម្ចាស់, **ទំនុក.** ១២៧:៣–៥ ។ គ្រួសារលោកលីហៃត្រូវបង្កើតពូជថ្វាយព្រះអម្ចាស់, **១ នីហ្វៃ** ៧:១ ។ អាពាហ៍ពិពាហ៍ត្រូវបានតែងតាំងមកពីព្រះដល់មនុស្ស, **គ. និង ស.** ៤៩:១៥–១៧ ។ ពួកអ្នកថ្កើងថ្កាននឹងបានទទួលភាពពោរពេញ និងការបន្តពូជពង្សជារៀង ដរាបតទៅ, **គ. និង ស.** ១៣២:១៩, ៦៣ ។

**ការខ្ចាត់ខ្ចាយនៃពួកសាសន៍អ៊ីស្រាអែល** *សូមមើល* អ៊ីស្រាអែល — ការខ្ចាត់ខ្ចាយនៃពួកសាសន៍អ៊ីស្រាអែល

**ការគោរពកោតក្រែង** *សូមមើលផង* កិត្តិយស, គោរពប្រតិបត្តិ, សេចក្ដីកោតខ្លាច

ជាការគោរពដ៏ខ្លាំងចំពោះអ្វីៗដែលពិសិដ្ឋ; ការអស្ចារ្យ ។

ព្រះអម្ចាស់ទ្រង់បានបង្គាប់ឲ្យលោកម៉ូសេដោះស្បែកជើង ព្រោះលោកកំពុងឈរនៅលើដីដ៏បរិសុទ្ធ, **និក្ខ.** ៣:៤–៥ ។ ព្រះគឺគួរឲ្យស្ញែង ខ្លាច និងកោតខ្លាចដល់, **ទំនុក.** ៨៩:៧ ។ ចូរបំរើព្រះបែបឲ្យទ្រង់សព្វព្រះហឫទ័យទាំងមានចិត្តគោរពប្រតិបត្តិ ហើយកោតខ្លាចដល់ ទ្រង់, **ហេព្រើរ** ១២:២៨ ។ ម៉ូរ៉ូណៃបានក្រាបខ្លួនចុះទៅលើដី ហើយបានអធិស្ឋានយ៉ាងខ្លាំង, **អាលម៉ា** ៤៦:១៣ ។ ហ្វូងមនុស្សបានដួលទៅលើដី ហើយថ្វាយបង្គំព្រះគ្រីស្ទ, **៣ នីហ្វៃ** ១១:១២–១៩ ។ ចូរក្រាបចុះនៅចំពោះយើង, **គ. និង ស.** ៥:២៤ ។ គ្រប់ទាំងអស់ក្រាបចុះ ដោយការគោរពកោតក្រែងដ៏ទន់ទាបរាបសា នៅចំពោះបល្ល័ង្កនៃព្រះ, **គ. និង ស.** ៧៦:៩៣ ។ គំនិតរបស់អ្នកត្រូវបានងងឹតពីព្រោះអ្នកបានរាប់ការណ៍ទាំងឡាយ ដែលអ្នកបានទទួលមក ទុកជាគ្មានផលប្រយោជន៍វិញ, **គ. និង ស.** ៨៤:៥៤–៥៧ ។ គ្រប់ទាំងជង្គង់ត្រូវលុតចុះ ហើយគ្រប់ទាំងអណ្ដាតត្រូវទទួលស្គាល់, **គ. និង ស.** ៨៨:១០៤ ។ មកពីការគោរពកោតក្រែង ឬភក្ដីភាពដល់ព្រះ នាមនៃព្រះដ៏ខ្ពស់បំផុត ទើបសាសនាចក្របានហៅបព្វជិតភាពនោះតាមលោកមិលគីស្សាដែក, **គ. និង ស.** ១០៧:៤ ។ ព្រះពរទាំង ឡាយនឹងបានចាក់មកលើអស់អ្នកណាដែលនឹងគោរពកោតក្រែងដល់ព្រះអង្គនៅក្នុងដំណាក់ទ្រង់, **គ. និង ស.** ១០៩:២១ ។

**ការគោរពតាម, ដែលគោរពតាម, គោរពតាម** *សូមមើលផង* ក្រិត្យវិន័យ; ដើរ, ដើរជាមួយនឹងព្រះ, ប្រទានពរ, ប្រុងស្ដាប់; ព្រះបញ្ញត្តិទាំងឡាយនៃព្រះ; ព្រះពរ; មានពរ, សេចក្ដីអំណរ

តាមន័យខាងវិញ្ញាណ ការគោរពតាម គឺជាការប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះ ។

ណូអេក៏ធ្វើដូច្នោះ តាមគ្រប់ទាំងសេចក្ដី ដែលព្រះបានបង្គាប់, **លោកុ,** ៦:២២ ។ អ័ប្រាហាំបានគោរពតាមព្រះអម្ចាស់, **លោកុ.** ២២:១៥–១៨ ។ យើងខ្ញុំរាល់គ្នានឹងធ្វើតាម គ្រប់អស់ទាំងសេចក្ដី ដែលព្រះអម្ចាស់បានមានបន្ទូលមក, **និក្ខ.** ២៤:៧ ។ ឱពួក អ៊ីស្រាអែលអើយ ចូរស្ដាប់ ហើយប្រយ័ត្ននឹងប្រព្រឹត្តតាមចុះ, **ចោទិ.** ៦:១–៣ ។ ចូរស្រឡាញ់ដល់ព្រះអម្ចាស់ ហើយស្ដាប់តាមបន្ទូល ទ្រង់ចុះ, **ចោទិ.** ៣០:២០ ។ ដែលស្ដាប់បង្គាប់ នោះវិសេសជាងយញ្ញបូជា, **១ សាំយូ.** ១៥:២២ ។ ចូរកោតខ្លាចដល់ព្រះ ហើយកាន់ តាមបញ្ញត្តិទ្រង់ចុះ, **សាស្ដា** ១២:១៣–១៤ ។ មនុស្សមិនអាចនឹងចូលទៅក្នុងនគរស្ថានសួគ៌គ្រប់រូបបានឡើយ លើកលែងតែអស់អ្នក ដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតាតែប៉ុណ្ណោះ, **ម៉ាថាយ** ៧:២១ (៣ នីហ្វៃ ១៤:២១) ។ បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងថា សេចក្ដី បង្រៀននេះមកពីព្រះ, **យ៉ូហាន** ៧:១៧ ។ យើងរាល់គ្នាគួរតែស្ដាប់បង្គាប់របស់ព្រះជាជាងមនុស្ស, **កិច្ចការ** ៥:២៩ ។ ក្មេងរាល់គ្នា អើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនចុះ, **អេភេ.** ៦:១ (កូល៉ុស ៣:២០) ។ ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗ ដែលព្រះ អម្ចាស់ទ្រង់បានបញ្ជា, **១ នីហ្វៃ** ៣:៧ ។ ខ្ញុំបានគោរពតាមសម្លេងនៃព្រះវិញ្ញាណ, **១ នីហ្វៃ** ៤:៦–១៨ ។ បើសិនជាកូនចៅមនុស្សកាន់ តាមព្រះបញ្ញត្តិទាំងឡាយ នៃព្រះ នោះទ្រង់នឹងចិញ្ចឹមគេ, **១ នីហ្វៃ** ១៧:៣ ។ សូមប្រយ័ត្នប្រយែង ក្រែងអ្នករាល់គ្នាគោរពតាមវិញ្ញាណអាក្រក់, **ម៉ូសាយ** ២:៣២–៣៣, ៣៧ (គ. និង ស. ២៩:៤៥) ។ មនុស្សលោកប្រូតនូវរង្វាន់គេ តាមវិញ្ញាណដែលគេគោរពតាម, **អាលម៉ា** ៣:២៦–២៧ ។ មនុស្សលោកគួរប្រព្រឹត្តអ្វីៗជាច្រើន តាមបំណងចិត្តរបស់ខ្លួន, **គ. និង ស.** ៥៨:២៦–២៩ ។ មនុស្សមិនដែលជំទាស់ព្រះ ក្នុងការ ណាមួយឡើយ លើកលែងតែអស់អ្នកណាដែលមិនទទួលស្គាល់ព្រះហស្ដ របស់ទ្រង់ ហើយមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ ទ្រង់ប៉ុណ្ណោះ **គ. និង ស.** ៥៩:២១ ។ យើងជាព្រះអម្ចាស់ជាប់សន្យា កាលណាអ្នករាល់គ្នាប្រព្រឹត្តតាមអ្វី ដែលយើងមានព្រះបន្ទូល, **គ. និង ស.** ៨២:១០ ។ មនុស្សគ្រប់រូបណាដែលគោរពតាមសម្លេង របស់យើង នោះនឹងបានឃើញព្រះភ័ក្ត្ររបស់យើង ហើយដឹងថា យើងជាព្រះ, **គ. និង ស.** ៩៣:១ ។ មនុស្សត្រូវតែបានវាយផ្ចាល រហូតដល់ពួកគេចេះគោរពតាម, **គ. និង ស.** ១០៥:៦ ។ កាលណា យើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរព ដល់ក្រិត្យវិន័យនោះ ដែលព្រះពរនោះផ្អែកទៅលើ, **គ. និង ស.** ១៣០:២១ ។ អ័ដាមបានគោរពតាម, **ម៉ូសេ** ៥:៥ ។ យើងនឹង សាកល្បងពួកគេមើលតើពួកគេនឹងប្រព្រឹត្តនូវអ្វីៗគ្រប់យ៉ាង ដែលព្រះអម្ចាស់ដ៏ជាព្រះនឹងបញ្ជា, **អ័ប្រា.** ៣:២៥ ។

**ការគាំទ្រពួកអ្នកដឹកនាំសាសនាចក្រ** *សូមមើលផង* ការយល់ព្រមទូទៅ

គឺស្ម័គ្រចិត្តគាំទ្រអស់អ្នកណា ដែលបំរើក្នុងមុខងារដឹកនាំនៃសាសនាចក្រទូទៅ និងប្រចាំតំបន់ ។

ចូរដាក់យ៉ូស្វេ នៅចំពោះមុខពួកជំនុំទាំងអស់ រួចប្រគល់សេចក្ដីបង្គាប់ដល់លោក នៅមុខគេ, **ជនគ.** ២៧:១៨–១៩ ។ បណ្ដាជនទាំង ឡាយ ក៏បន្លឺវាចាឡើងថា ជយោព្រះករុណា, **១ សាំយូ.** ១០:២៤ ។ ចូរជឿតាមពួកហោរារបស់ទ្រង់ ទើបអ្នករាល់គ្នានឹងប្រកបដោយសេចក្ដីចំរើន, **២ របា.** ២០:២០ ។ ចូរស្ដាប់តាមពួកអ្នកដែលនាំមុខអ្នករាល់គ្នាចុះ, **ហេព្រើរ** ១៣:១៧ ។ កូននឹងបានគាប់ ព្រះហឫទ័យពីព្រះអម្ចាស់ ពីព្រោះកូនមិនបានរអ៊ូរទាំ, **១ នីហ្វៃ** ៣:៦ ។ ពួកអ្នកណាដែលទទួលពួកព្យាការី នោះត្រូវទុកឲ្យមានជីវិត រស់, **៣ នីហ្វៃ** ១០:១២–១៣ ។ ចូរស្ដាប់បង្គាប់តាមពាក្យសំដីនៃមនុស្ស១២នាក់នេះចុះ, **៣ នីហ្វៃ** ១២:១ ។ ដោយសម្លេងរបស់ យើងផ្ទាល់ ឬក៏ដោយសម្លេងនៃពួកអ្នកបំរើរបស់យើងក្ដី គឺដូចតែគ្នា, **គ. និង ស.** ១:៣៨ ។ ពាក្យសំដីរបស់លោកនោះហើយ អ្នកនឹង បានទទួល ហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់, **គ. និង ស.** ២១:៥ ។ អ្នកណាដែលទទួលពួកអ្នកបំរើរបស់យើង ឈ្មោះថា ទទួលយើងដែរ, **គ. និង ស.** ៨៤:៣៥–៣៨ ។ អស់អ្នកណាដែលទទួលយើង នោះទទួលពួកអ្នកទាំងនោះ ដែលយើងបានចាត់ឲ្យទៅ, **គ. និង ស.** ១១២:២០ ។

បើសិនជារាស្ត្រយើងមិនប្រុងស្តាប់សម្លេងនៃមនុស្សទាំងនេះ ដែលយើងបានតែងតាំងឡើងទេ នោះពួកគេ នឹងមិនត្រូវបានពរឡើយ, **គ. និង ស.** ១២៤:៤៥–៤៦ ។

**ការងារបំរើនៃពួកទេវតា** *សូមមើល* ពួកទេវតា

**ការឆ្កាង** *សូមមើលផង* គាល់កូថា; ដង្វាយធួន; ឈើឆ្កាង; ធ្វើឲ្យធួន, ព្រះយេស៊ូវគ្រីស្ទ

ជារបៀបសម្លាប់របស់ពួករ៉ូមម៉្យាង ដែលមានទូទៅនៅសម័យព្រះគម្ពីរសញ្ញាថ្មី គឺសម្លាប់មនុស្ស ដោយចង ឬក៏បោះដែកគោលដៃ និងជើងអ្នកនោះទៅលើឈើឆ្កាង ។ តាមធម្មតា របៀបនេះ គឺធ្វើដល់តែពួកអ្នកបំរើ និងពួកអ្នកទោសទាបបំផុតប៉ុណ្ណោះ ។ តាមធម្មតា មានការវាយដំមុនការឆ្កាង (ម៉ាកុស ១៥:១៥) ។ អ្នកដែលត្រូវគេឆ្កាងតាមធម្មតា ត្រូវលីឈើឆ្កាងដោយខ្លួនឯងទៅទីសម្លាប់ (យ៉ូហាន ១៩:១៦–១៧) ។ តាមធម្មតា ពួកទាហានដែលធ្វើការសម្លាប់ ក៏យកខោអាវអ្នកនេះ (ម៉ាថាយ ២៧:៣៥) ។ គេដោតឈើ ឆ្កាងទៅក្នុងដី ដើម្បីឲ្យជើងអ្នកនោះខ្ពស់ពីដីប្រមាណ ១ ទៅ ២ ហត្ថប៉ុណ្ណោះ ។ ពួកទាហានចាំយាមឈើឆ្កាង រហូតដល់អ្នកនៅលើ ឈើឆ្កាងស្លាប់ គឺជួនកាល មានដល់ទៅ ៣ ថ្ងៃ (យ៉ូហាន ១៩:៣១–៣៧) ។

ព្រះយេស៊ូវគ្រីស្ទត្រូវគេឆ្កាង ពីព្រោះមានពួកអ្នកមិនជឿមួយក្រុមបានចោទបង្កុសដល់ទ្រង់ ថាបាននាំការបះបោរទាស់នឹងសេសារ ហើយបានប្រមាថដល់ព្រះ ពីព្រោះទ្រង់បានមានព្រះបន្ទូលថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ ។ គេបានបំពាក់លើទ្រង់នូវអាវពណ៌ស្វាយ (យ៉ូហាន ១៩:២) និងភួងបន្លា ហើយបានជេរប្រមាថព្រះយេស៊ូវ នូវប្រការផ្សេងៗ (ម៉ាថាយ ២៦:៦៧; ម៉ាកុស ១៤:៦៥) ។

ពួកមនុស្សអាក្រក់នឹងចាក់ទំលុះព្រះហស្ត និងបាទានៃព្រះមែស៊ី, **ទំនុក.** ២២:១១–១៨ ។ ព្រះគ្រីស្ទនឹងទៅដូចកូនចៀម ដែលគេដឹកទៅសម្លាប់, **អេសាយ** ៥៣:៧ ។ ព្រះយេស៊ូវទ្រង់ប្រាប់ពីការឆ្កាងរបស់ទ្រង់ទុកជាមុន, **ម៉ាថាយ** ២០:១៨–១៩ ។ ការឆ្កាងព្រះគ្រីស្ទត្រូវបានអធិប្បាយប្រាប់, **ម៉ាថាយ** ២៧:២២–៥០ (ម៉ាកុស ១៥:២២–៣៧; លូកា ២៣:២៦–៤៦; យ៉ូហាន ១៩:១៧–៣០) ។ នីហ្វៃបានឃើញនៅក្នុងការនិមិត្ត នូវការឆ្កាងកូនចៀមនៃព្រះ, **១ នីហ្វៃ** ១១:៣៣ ។ នីហ្វៃប្រាប់អំពីការរងទុក្ខ និងការឆ្កាងព្រះគ្រីស្ទ, **១ នីហ្វៃ** ១៩:៩–១៤ ។ យ៉ាកុបប្រាប់អំពីការបង្រៀន និងការឆ្កាងព្រះបរិសុទ្ធតែមួយ នៃពួកអ៊ីស្រាអែល, **២ នីហ្វៃ** ៦:៩ ។ ព្យុះសង្ឃរា ដីកក្រើក ភ្លើង និងខ្យល់កួចនៅទ្វីបអាមេរិក បញ្ជាក់ប្រាប់ពីការឆ្កាងព្រះគ្រីស្ទនៅក្រុងយេរូសាឡិម, **៣ នីហ្វៃ** ៨ ។ យើងជាព្រះយេស៊ូវដែលត្រូវគេឆ្កាង, **គ. និង ស.** ៤៥:៥១–៥២ ។ ការងារបំរើរបស់ព្រះគ្រីស្ទនៅក្នុងចំណោមព្រលឹងវិញ្ញាណនៅស្ថានឃុំព្រលឹង នោះមានកំណត់ ពេលដ៏ខ្លី រវាងការឆ្កាងនឹងដំណើរដែលទ្រង់មានព្រះជន្មរស់ឡើងវិញ, **គ. និង ស.** ១៣៨:២៧ ។

**ការជាប់ឃុំឃាំង** *សូមមើលផង* សេរី, សេរីភាព

គឺជាប់ឃុំខ្លួន ឬវិញ្ញាណ ។

ពួកវង្សអ៊ីស្រាអែលបានត្រូវដឹកនាំទៅជាឈ្លើយ ដោយព្រោះអំពើទុច្ចរិតរបស់ខ្លួន, **អេសេ.** ៣៩:២៣ ។ បើអ្នកណាដឹកនាំគេឲ្យទៅជាឈ្លើយ អ្នកនោះឯងនឹងត្រូវគេដឹកនាំខ្លួនទៅជាឈ្លើយដែរ, **វិវរ.** ១៣:១០ ។ ពួកទុច្ចរិតនឹងត្រូវធ្លាក់ទៅក្នុងការជាប់ឃុំឃាំងនៃអារក្ស, **១ នីហ្វៃ** ១៤:៤, ៧ ។ មនុស្សលោកមានសិទ្ធិនឹងរើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច ឬក៏ការជាប់ឃុំឃាំង និងការ ស្លាប់, **២ នីហ្វៃ** ២:២៧ ។ ចំណង់របស់សាច់ឈាមផ្តល់អំណាចដល់វិញ្ញាណអារក្សឲ្យចាប់ឃុំឃាំង, **២ នីហ្វៃ** ២:២៩ ។ ចុះតើអ្នក រាល់គ្នាចាំបានខ្លះឬទេ នូវការជាប់ឃុំឃាំងនៃពួកអយ្យកោរបស់អ្នក ? **អាលម៉ា** ៥:៥–៦ ។ ពួកជនទាំងឡាយណាដែលធ្វើចិត្តរឹងរូស ជនទាំងនោះនឹងត្រូវអារក្សចាប់ឃុំឃាំង, **អាលម៉ា** ១២:១១ ។ អ្នករាល់គ្នាត្រូវចាំយាម ហើយអធិស្ឋានជានិច្ច ខ្លាចក្រែងអារក្សល្បួង អ្នក ហើយអ្នករាល់គ្នានឹងត្រូវវាចាប់នាំយកទៅឃុំឃាំង, **៣ នីហ្វៃ** ១៨:១៥ ។

**ការជ្រើសរើស** *សូមមើល* ដែលបានរើស, បានរើស, រើស, សិទ្ធិជ្រើសរើស

**ការឈ្លោះគ្នា** *សូមមើល* ការទាស់ទែងគ្នា

**ការញែកជាបរិសុទ្ធ** *សូមមើលផង* ធ្វើឲ្យធួន, ដង្វាយធួន; ព្រះយេស៊ូវគ្រីស្ទ; ការរាប់ជាសុចរិត, រាប់ជាសុចរិត

ជាដំណើរឲ្យបានផុតពីអំពើបាប ឲ្យបានសុទ្ធសាធ ស្អាតបាត និងបរិសុទ្ធតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ (ម៉ូសេ ៦:៥៩–៦០) ។

ព្រះទ្រង់បានរើសអ្នករាល់គ្នា ដើម្បីឲ្យបានសង្គ្រោះ ដោយព្រះវិញ្ញាណទ្រង់ញែកចេញជាបរិសុទ្ធ, **២ ធី.** ២:១៣ ។ យើងរាល់គ្នាបានញែកជាបរិសុទ្ធ ដោយសារដង្វាយថ្វាយរូបអង្គព្រះយេស៊ូវ, **ហេព្រើរ** ១០:១០ ។ ព្រះយេស៊ូវទ្រង់ក៏បានរងទុក្ខ ដើម្បីនឹងញែកប្រជាជនឲ្យបរិសុទ្ធ ដោយសារព្រះលោហិតនៃអង្គទ្រង់, **ហេព្រើរ** ១៣:១២ ។ ពួកសង្ឃជាន់ខ្ពស់បានញែកជាបរិសុទ្ធ ហើយសំលៀកបំពាក់ របស់គេបានលាងឲ្យស ដោយឈាមនៃកូនចៀម, **អាលម៉ា** ១៣:១០–១២ ។ ការញែកជាបរិសុទ្ធ មានមកដល់អស់អ្នកណាដែលថ្វាយ ចិត្តដល់ព្រះ, **ហេលេ.** ៣:៣៣–៣៥ ។ ចូរប្រែចិត្តចុះ ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចបានញែកជាបរិសុទ្ធ ដោយការទទួលនូវព្រះ វិញ្ញាណបរិសុទ្ធ, **៣ នីហ្វៃ** ២៧:២០ ។ ការ ញែកជាបរិសុទ្ធតាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ នោះគឺយុត្តិធម៌ និងត្រឹមត្រូវ, **គ. និង ស.** ២០:៣១ ។ ព្រះយេស៊ូវបានយាងមក ក្នុងពិភពលោក ដើម្បីញែកពិភពលោកចេញជាបរិសុទ្ធ, **គ. និង ស.** ៧៦:៤១ ។ ចូរញែកខ្លួនអ្នករាល់គ្នាចេញជាបរិសុទ្ធចុះ ប្រយោជន៍ ឲ្យគំនិតរបស់អ្នកស្មោះស្ម័គ្រទាំងស្រុងទៅរកព្រះ, **គ. និង ស.** ៨៨:៦៨ ។

**ការញែកចេញ** *សូមមើលផង* ការដាក់ដៃលើ, ការហៅ; ហៅ, បានហៅពីព្រះ

ដើម្បីជ្រើសរើស ហើយញែកទុកសំរាប់ពិធីបរិសុទ្ធទាំងឡាយ ។ ការតែងតាំងនេះ គឺចំពោះការបំរើណាមួយ នៅក្នុងអង្គការនៃ សាសនាចក្រ ដោយការដាក់ដៃលើ ដោយអ្នកណាម្នាក់ ដែលមានសិទ្ធិអំណាចត្រឹមត្រូវ ។ មានតែអស់អ្នកណាដែលត្រួតត្រាលើក្រុម ទាំងឡាយនៃបព្វជិតភាពប៉ុណ្ណោះ ដែលអាចទទួលកូនសោទាំងឡាយ នៅពេលពួកគេបានញែកចេញ ។ មនុស្សដែលត្រូវញែកចេញ ចំពោះមុខងារឯទៀត ក្រៅពីពួកប្រធាននៃក្រុមទាំងឡាយក្នុងបព្វជិតភាព នោះអាចបានពរខាងបព្វជិតភាព ប៉ុន្តែមិនបានទទួលកូនសោ ទាំងឡាយជាមួយនឹងពរនោះឡើយ ។

ចូរញែកបាណាបាស និងសុលចេញឲ្យខ្ញុំ សំរាប់ការងារ, **កិច្ចការ** ១៣:២–៣ ។ ត្រូវមានប៊ីស្សពផ្សេងៗទៀត ដែលត្រូវញែកចេញ, **គ. និង ស.** ៦៨:១៤ ។ ប៊ីស្សព គឺជាចៅក្រមទូទៅ នឹងត្រូវបានញែកចេញ ចំពោះការងារបំរើនេះ, **គ. និង ស.** ១០៧:១៧–៧៤ ។ មនុស្សត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍ និងដោយការដាក់ដៃលើ, **ម. នៃ ស.** ១:៥ ។

**ការដាក់ដៃលើ** *សូមមើល* ការដាក់លើ, ដៃ

**ការដាក់ទោសដល់ជីវិត** *សូមមើលផង* ឃាតកម្ម

ជាការដាក់ទោសដោយសម្លាប់ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តជាពិសេស គឺទាក់ទងទៅនឹងការដាក់ទោសចំពោះអំពើឃាតកម្ម ។

អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ, **លោកុ.** ៩:៦ (ក.យ.ស., លោកុ. ៩:១២–១៣) ។ អ្នកណាដែលសម្លាប់គេ នោះត្រូវតែសម្លាប់វិញជាមិនខាន, **ជនគ.** ៣៥:១៦ ។ ពួកឃាតករដែលសម្លាប់គេដោយចេតនា នោះនឹងត្រូវស្លាប់, **២ នីហ្វៃ** ៩:៣៥ ។ ត្រូវកាត់ទោសអ្នកដល់ជីវិតតាមច្បាប់, **អាលម៉ា** ១:១៣–១៤ ។ អ្នកណាដែលសម្លាប់មនុស្សនឹងត្រូវទទួលទោសដល់ជីវិត, **អាលម៉ា** ១:១៨ ។ ច្បាប់បានទាមទារនូវជីវិតនៃជន ដែលជាឃាតករ, **អាលម៉ា** ៣៤:១២ ។ អ្នកណាដែលសម្លាប់គេ នោះនឹងត្រូវស្លាប់, **គ. និង ស.** ៤២:១៩ ។

**ការតែងតាំងមុនកំណើតលោកិយ***សូមមើលផង* ជីវិតមុនផែនដី

ជាការតែងតាំងមុនផែនដីដល់កូនចៅវិញ្ញាណដ៏ក្លាហានរបស់ព្រះ ដើម្បីបំពេញបេសកកម្មណាមួយ កាលពួកគេមានជីវិតដែលរមែង ស្លាប់ ។

ព្រះទ្រង់បានដាក់ព្រំប្រទល់ឲ្យប្រជាជន, **ចោទិ.** ៣២:៨ ។ មុនយើងបានជបបង្កើតអ្នកនៅក្នុងពោះម្តាយ នោះយើងបានតាំងអ្នកឡើង ជាព្យាការី, **យេរេ.** ១:៥ ។ ព្រះទ្រង់បានសំរេចកំណត់ពេលវេលា ដែលបានតាំងជាមុន, **កិច្ចការ** ១៧:២៦ ។ ត្បិតអ្នកណាដែលទ្រង់ បានស្គាល់ជាមុន នោះទ្រង់ក៏តម្រូវទុកជាមុន, **រ៉ូម** ៨:២៨–៣០ ។ ទ្រង់បានរើសយើងរាល់គ្នាក្នុងទ្រង់ តាំងពីមុនកំណើតលោកិយមក, **អេភេ.** ១:៣–៤ ។ ព្រះយេស៊ូវគ្រីស្ទត្រូវបានតែងតាំងមុនកំណើតលោកិយមកដើម្បីធ្វើជាព្រះប្រោសលោះ, **១ ពេត្រុស** ១:១៩–២០ (វិវរ. ១៣:៨) ។ ពួកគេត្រូវបានហៅ ហើយបានរៀបចំឡើង តាំងពីមុនកំណើតលោកិយ **អាលម៉ា** ១៣:១–៩ ។ ខ្ញុំបានសង្កេត ឃើញថា ពួកឧត្តុងឧត្តម និងពួកអ្នកធំនោះបានរើសតាំងពីដើមដំបូងមក, **គ. និង ស.** ១៣៨:៥៥–៥៦ ។ ព្រះរាជបុត្រាបង្កើតដ៏ជាទី ស្ងួនភ្ងារបស់យើង ត្រូវបានរើសតាំងចាប់តាំងពីដើមដំបូងមក, **ម៉ូសេ** ៤:២ ។ អ័ប្រាហាំត្រូវបានរើសតាំងពីមុនលោកចាប់កំណើត មកម្ល៉េះ, **អ័ប្រា.** ៣:២៣ ។

**ការតាំងឡើងវិញ, ការសាងឡើងវិញ** *សូមមើលផង* ការសាងឡើងវិញនៃដំណឹងល្អ

ជាការសាងឡើងវិញនៃវត្ថុ ឬស្ថានភាពដែលបានដកយកចេញ ឬដែលបានបាត់បង់ទៅ ។

វិញ្ញាណ និងរូបកាយនឹងផ្គុំគ្នាជាថ្មី នៅក្នុងប្រាណដ៏ល្អឥតខ្ចោះ, **អាលម៉ា** ១១:៤៣–៤៤ ។ ការសាងឡើងវិញ គឺធ្វើជាថ្មីឡើងវិញ អាក្រក់ទៅជាអាក្រក់វិញ ហើយសុចរិតទៅជាសុចរិតវិញ, **អាលម៉ា** ៤១:១០–១៥ ។ យើងខ្ញុំជឿចំពោះការសាងឡើងវិញនូវពូជទាំង១០អំបូរ ហើយថាផែនដីនឹងបានផ្លាស់ប្តូរសារជាថ្មី ទៅរកសិរីល្អដ៏ប្រកបដោយភាពបរមសុខរបស់វា, **ម. នៃ ស.** ១:១០ (គ. និង ស. ១៣៣:២៣–២៤) ។

**ការថ្វាយបង្គំ រូបព្រះ**

ជាការថ្វាយបង្គំដល់រូបព្រះ ឬក៏ការជាប់ចិត្តយ៉ាងខ្លាំង ឬក៏ការថ្វាយភក្តីភាពដល់អ្វីមួយ ។

កុំឲ្យមានព្រះឯណាទៀតនៅចំពោះយើងឲ្យសោះ, **និក្ខ.** ២០:៣ (ម៉ូសាយ ១២:៣៥; ១៣:១២–១៣) ។ បើអ្នកទៅប្រព្រឹត្តតាមព្រះដទៃ នោះអ្នករាល់គ្នានឹងត្រូវវិនាសទៅអស់រលីង, **ចោទិ.** ៨:១៩ ។ សេចក្តីចចេសសោត ក៏ដូចជាអំពើអាក្រក់ណាមួយ ហើយនិងការថ្វាយបង្គំដល់រូបព្រះ, **១ សាំយូ.** ១៥:២៣ ។ អ្នកបានបើកខ្លួនឲ្យដល់អ្នកដទៃទៀតក្រៅពីយើង, **អេសាយ** ៥៧:៨ ។ អ្នកបានសរសើរ ដល់អស់ទាំងព្រះ ដែលធ្វើពីប្រាក់ និងមាស, **ដានី.** ៥:២៣ ។ អ្នករាល់គ្នាពុំអាចនឹងគោរពដល់ព្រះ និងទ្រព្យសម្បត្តិផងបានទេ, **ម៉ាថាយ** ៦:២៤ ។ សេចក្តីលោភ គឺជាការថ្វាយបង្គំរូបព្រះ, **កូល៉ុស** ៣:៥ ។ កូនតូចៗរាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះ ចេញ, **១ យ៉ូហាន** ៥:២១ ។ វេទនាដល់អស់អ្នកណាដែលថ្វាយបង្គំរូបព្រះ, **២ នីហ្វៃ** ៩:៣៧ ។ ការថ្វាយបង្គំរូបព្រះរបស់ប្រជាជន នីហ្វៃ បាននាំមកលើគេនូវសង្គ្រាម និងការបំផ្លិចបំផ្លាញទាំងឡាយរបស់គេ, **អាលម៉ា** ៥០:២១ ។ មនុស្សគ្រប់រូប ដើរតាមរូបភាពនៃ ព្រះរបស់ខ្លួនគេផ្ទាល់, **គ. និង ស.** ១:១៦ ។ ចូរឲ្យពួកគេធ្វើការដោយដៃរបស់ខ្លួន ប្រយោជន៍កុំឲ្យត្រូវប្រព្រឹត្តនូវការថ្វាយបង្គំរូបព្រះ ឡើយ, **គ. និង ស.** ៥២:៣៩ ។ ឪពុករបស់អ័ប្រាហាំត្រូវបានទាញចេញ ដោយសារការថ្វាយរូបព្រះ, **អ័ប្រា.** ១:២៧ ។

**ការថ្វាយបង្គំ** *សូមមើលផង* ក្រុមព្រះ, ព្រះ

ជាសេចក្ដីស្រឡាញ់ ការគោរពកោតក្រែង ការបំរើ និងភក្ដីភាពដល់ព្រះ (គ. និង ស. ២០:១៩) ។ ការថ្វាយបង្គំមានរួមនូវការអធិស្ឋាន ការតមអាហារ ការបំរើក្នុងសាសនាចក្រ ការចូលរួមក្នុងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ និងការប្រព្រឹត្តផ្សេងៗទៀត ដែលបង្ហាញនូវភក្ដីភាព និងសេចក្ដីស្រឡាញ់ដល់ព្រះ ។

កុំឲ្យមានព្រះឯណាទៀត នៅចំពោះអញឲ្យសោះ, **និក្ខ.** ២០:៣ (និក្ខ. ៣២:១–៨, ១៩–៣៥; ទំនុក. ៨១:៩) ។ ថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្ដីពិត, **យ៉ូហាន** ៤:២៣ ។ ចូរថ្វាយបង្គំដល់ទ្រង់ ដែលបង្កើតផ្ទៃមេឃ និងផែនដី, **វិវរ.** ១៤:៧ (គ. និង ស. ១៣៣:៣៨–៣៩) ។ ចូរថ្វាយបង្គំទ្រង់ ឲ្យចិត្ត អស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នក, **២ នីហ្វៃ** ២៥:២៩ ។ ពួកគេបានជឿដល់ព្រះគ្រីស្ទ ហើយថ្វាយបង្គំព្រះវរបិតា ដោយនូវព្រះនាមទ្រង់, **យ៉ាកុប** ៤:៥ ។ ស៊ីណូសបានបង្រៀនថា មនុស្សលោកគួរអធិស្ឋាន ហើយថ្វាយបង្គំនៅគ្រប់ទីកន្លែង, **អាលម៉ា** ៣៣:៣–១១ ។ ចូរថ្វាយបង្គំព្រះ ទោះនៅទីណាដែលអ្នកនៅក្ដី នៅក្នុងវិញ្ញាណ និងនៅ ក្នុងការពិត, **អាលម៉ា** ៣៤:៣៨ ។ ប្រជាជនបានក្រាបចុះទៅនឹងព្រះបាទានៃព្រះយេស៊ូវ ហើយបានថ្វាយបង្គំព្រះអង្គ, **៣ នីហ្វៃ** ១១:១៧ ។ មនុស្សទាំងអស់ត្រូវតែប្រែចិត្ត ជឿដល់ព្រះយេស៊ូវគ្រីស្ទ ហើយថ្វាយបង្គំដល់ព្រះវរបិតា ដោយនូវព្រះនាមរបស់ទ្រង់, **គ. និង ស.** ២០:២៩ ។ យើងប្រទានដល់អ្នកនូវពាក្យទាំងនេះ ដើម្បីឲ្យអ្នកអាចយល់ ហើយចេះថ្វាយបង្គំ ហើយស្គាល់នូវអ្វីដែលខ្លួន ថ្វាយបង្គំ, **គ. និង ស.** ៩៣:១៩ ។ ខ្ញុំនឹងថ្វាយបង្គំដល់ព្រះតែមួយអង្គប៉ុណ្ណោះ, **ម៉ូសេ** ១:១២–២០ ។ យើងខ្ញុំសូមអះអាងយកសិទ្ធិក្នុង ការថ្វាយបង្គំព្រះដ៏មានមហិទ្ធិឫទ្ធិ, **ម. នៃ ស.** ១:១១ ។

**ការទាស់ទែង** *សូមមើលផង* ការបះបោរ

ជាជម្លោះ ការប្រកែកគ្នា និងសេចក្ដីដេញដោលគ្នា ។ ការទាស់ទែងជាពិសេស រវាងសមាជិកក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ឬក៏រវាងសមាជិកក្នុងក្រុមគ្រួសារ នោះមិនសព្វព្រះហឫទ័យដល់ព្រះអម្ចាស់ឡើយ ។

សូមកុំឲ្យឯងហើយនឹងអញមានរឿងទាស់ទែងគ្នាឡើយ, **លោកុ.** ១៣:៨ ។ សេចក្ដីឆ្មើងឆ្មៃ ផ្ដល់នូវការទាស់ទែងគ្នា, **សុភា.** ១៣:១០ ។ បើអ្នកណាមានហេតុទាស់នឹងអ្នកណា នោះចូរអត់ទោសឲ្យគេចុះ ដូចជាព្រះគ្រីស្ទបានអត់ទោសឲ្យអ្នករាល់គ្នាដែរ, **កូល៉ុស** ៣:១៣ ។ ចូរចៀសវាងពីសេចក្ដីដេញដោលយ៉ាងល្ងីល្ងើ និងពីសេចក្ដីឈ្លោះប្រកែក, **ទីតុស** ៣:៩ ។ ព្រះអម្ចាស់ទ្រង់បញ្ជាមិនឲ្យមនុស្សទាស់ គ្នាទៅវិញទៅមកឡើយ, **២ នីហ្វៃ** ២៦:៣២ ។ ចូរកុំទ្រាំឲ្យកូនចៅអ្នកឈ្លោះប្រកែកគ្នាឡើយ, **ម៉ូសាយ** ៤:១៤ ។ អាលម៉ាបញ្ជាមិន ឲ្យមានការទាស់ទែងគ្នាឡើយ ក្នុងចំណោមសមាជិកនៃសាសនាចក្រ, **ម៉ូសាយ** ១៨:២១ ។ សាតាំងផ្សាយនូវពាក្យចចាមអារាម និងការទាស់ទែងគ្នា, **ហេលេ.** ១៦:២២ ។ អារក្សជាបិតានៃការទាស់ទែងគ្នា ហើយចាក់រុកឲ្យមនុស្សទាស់គ្នា, **៣ នីហ្វៃ** ១១:២៩ (ម៉ូសាយ ២៣:១៥) ។ ចូរតាំងដំណឹងល្អរបស់យើង ដើម្បីកុំឲ្យមានការទាស់ទែងគ្នាច្រើនពេក, **គ. និង ស.** ១០:៦២–៦៤ ។ ចូរឈប់ ទាស់ទែងនឹងគ្នាទៅ, **គ. និង ស.** ១៣៦:២៣ ។

**ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា***សូមមើលផង* ដង្វាយធួន;
ដែលរមែងស្លាប់,ធ្វើឲ្យធួន, នាងអេវ៉ា; ប្រោសលោះ;
ប្រោសលោះ, បានប្រោសលោះ, ផែនការនៃសេចក្ដី,
ព្រះយេស៊ូវគ្រីស្ទ; ភាពដែលរមែងស្លាប់;
មនុស្សខាងសាច់ឈាម; សេចក្ដីស្លាប់ខាងសាច់ឈាម;
សេចក្ដីស្លាប់ខាងវិញ្ញាណ; សេចក្ដីប្រោសលោះ, អ័ដាម

ជាដំណើរដែលមនុស្សលោកក្លាយទៅជាមនុស្សដែលរមែងស្លាប់នៅលើផែនដីនេះ ។ កាលលោកអ័ដាម និងនាងអេវ៉ាបានបរិភោគ ផ្លែឈើហាមឃាត់ នោះពួកគេបានក្លាយទៅជាមនុស្សដែលរមែងស្លាប់ គឺថាគេនៅក្រោមអំណាចអំពើបាប និងសេចក្ដីស្លាប់ ។ លោកអ័ដាមក្លាយទៅជា « សាច់ទីមួយ » នៅលើផែនដី (ម៉ូសេ ៣:៧) ។ វិវរណៈនៅថ្ងៃចុងក្រោយ បង្ហាញយ៉ាងច្បាស់ថា ការធ្លាក់ គឺជាព្រះពរ ហើយថា លោកអ័ដាម និងនាងអេវ៉ា គួរតែបានទទួលការគោរពជាឪពុកម្ដាយទីមួយ នៃមនុស្សលោកទាំងអស់ ។

ការធ្លាក់ជាដំណើរចាំបាច់មួយ ក្នុងការជឿនលឿនរបស់មនុស្ស ។ ពីព្រោះព្រះទ្រង់បានជ្រាបថា ការធ្លាក់នឹងមានកើតឡើង នោះទ្រង់ បានរៀបចំនូវព្រះអង្គសង្គ្រោះមួយទុក នៅជីវិតមុនផែនដី ។ ព្រះយេស៊ូវគ្រីស្ទបានយាងមកនៅពេលដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីធ្វើឲ្យធួន នឹងការធ្លាក់នៃលោកអ័ដាម និងអំពើបាបទាំងឡាយនៃមនុស្សម្នាក់ៗ តាមលក្ខណៈនៃការប្រែចិត្តរបស់មនុស្ស ។

នៅថ្ងៃណាដែលអ្នកបរិភោគ នោះនឹងត្រូវស្លាប់ជាមិនខាន, **លោកុ.** ២:១៧ (ម៉ូសេ ៣:១៧) ។ នាងក៏យកផ្លែមកបរិភោគ, **លោកុ.** ៣:៦ (ម៉ូសេ ៤:១២) ។ ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ, **១ កូរិន.** ១៥:២២ ។ មនុស្សលោកទាំងអស់រស់នៅក្នុងស្ថានភាពវង្វេង និងស្ថានភាពធ្លាក់, **១ នីហ្វៃ** ១០:៦ ។ ផ្លូវត្រូវបានរៀបចំជាស្រេច ចាប់តាំងពីការធ្លាក់នៃមនុស្សមក, **២ នីហ្វៃ** ២:៤ ។ បន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ាបាន ទទួលទានផ្លែឈើហាមឃាត់ហើយ នោះពួកគេត្រូវបានបណ្ដេញចេញពីសួនច្បារអេដែន, **២ នីហ្វៃ** ២:១៩ ។ លោកអ័ដាមបានធ្លាក់ ខ្លួន ដើម្បីឲ្យមានមនុស្សលោក, **២ នីហ្វៃ** ២:១៥–២៦ ។ មនុស្សខាងសាច់ឈាមជាសត្រូវដល់ព្រះ ហើយមានមកតាំងពីការធ្លាក់នៃ លោកអ័ដាមម្ល៉េះ, **ម៉ូសាយ** ៣:១៩ ។ អេរ៉ុនបានបង្រៀនបិតារបស់ឡាម៉ូណៃអំពីការធ្លាក់, **អាលម៉ា** ២២:១២–១៤ ។ ត្រូវតែមាន ដង្វាយធួនកើតឡើង បើពុំនោះសោតទេ មនុស្សលោកទាំងអស់នឹងត្រូវធ្លាក់ ហើយវង្វេង, **អាលម៉ា** ៣៤:៩ ។ ឪពុកម្ដាយទីមួយរបស់ យើងត្រូវបានកាត់ចេញពីវត្តមាននៃព្រះអម្ចាស់ ទាំងខាងសាច់ឈាម និង

ខាងវិញ្ញាណផង, **អាលម៉ា** ៤២:២–១៥ (ហេលេ. ១៤:១៦) ។ ដោយសារការធ្លាក់ នោះធម្មជាតិនៃយើងខ្ញុំ បានក្លាយទៅជាអាក្រក់, **អេធើរ** ៣:២ ។ ដោយសារការរំលងនៃក្រឹត្យវិន័យដ៏បរិសុទ្ធ ទាំងនេះ នោះមនុស្សបានក្លាយទៅជាមនុស្សធ្លាក់, **គ. និង ស.** ២០:២០ (គ. និង ស. ២៩:៣៤–៤៤) ។ ព្រោះអ្នកបានធ្លាក់ នោះអ្នក នឹងអាចបានប្រោសលោះ, **ម៉ូសេ** ៥:៩–១២ ។ ដោយសារការរំលង នោះទើបមានការធ្លាក់, **ម៉ូសេ** ៦:៥៩ ។ មនុស្សទាំងឡាយ នឹងត្រូវទទួលទោស ចំពោះអំពើបាបរបស់ខ្លួនផ្ទាល់, **ម. នៃ ស.** ១:២ ។

**ការនិមិត្ត** *សូមមើលផង* ការនិមិត្តទីមួយ; សប្តិ, សុបិន; វិវរណៈ

ជាវិវរណៈ ដែលបើកសម្តែងឲ្យឃើញ អំពីព្រឹត្តិការណ៍ មនុស្ស ឬអ្វីណាមួយ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

ឧទាហរណ៍ទាំងឡាយអំពីការនិមិត្តសំខាន់ៗ មានដូចតទៅនេះ៖ ការនិមិត្តរបស់អេសេគាល អំពីជំនាន់ចុងក្រោយបង្អស់ (អេសេ. ៣៧–៣៩), ការនិមិត្តរបស់ស្ទេផាន អំពីព្រះយេស៊ូវឈរនៅខាងស្តាំព្រះហស្តនៃព្រះ (កិច្ចការ ៧:៥៥–៥៦), វិវរណៈរបស់យ៉ូហាន ទាក់ទងទៅនឹងជំនាន់ចុងក្រោយបង្អស់ (វិវរ. ៤–២១), ការនិមិត្តរបស់លីហៃ និងនីហ្វៃ អំពីដើមជីវិត (១ នីហ្វៃ ៨, ១០–១៤), ការនិមិត្ត របស់អាលម៉ា ជាកូន អំពីទេវតានៃព្រះអម្ចាស់ (ម៉ូសាយ ២៧), ការនិមិត្តរបស់បងប្រុសរបស់យ៉ារេឌ អំពីបណ្តាជនទាំងអស់នៅលើ ផែនដី (អេធើរ ៣:២៥), ការនិមិត្តអំពីសិរីល្អទាំងឡាយ (គ. និង ស. ៧៦), ការនិមិត្តទាំងឡាយ ដែលបានប្រទានដល់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី នៅក្នុងព្រះវិហារខឺតឡង់ (គ. និង ស. ១១០), ការនិមិត្តរបស់យ៉ូសែប អែហ្វ ស្ម៊ីធ អំពីសេចក្តីប្រោសលោះនៃ មនុស្សស្លាប់ (គ. និង ស. ១៣៨), ការនិមិត្តរបស់ម៉ូសេ អំពីព្រះ និងការបង្កបង្កើតទាំងឡាយរបស់ទ្រង់ (ម៉ូសេ ១), ការនិមិត្តរបស់ហេណុក អំពីព្រះ (ម៉ូសេ ៦–៧), ការនិមិត្តទីមួយ របស់យ៉ូសែប ស្ម៊ីធ (យ.ស.–ប្រវត្តិ ១) ។

គ្រាណាដែលឥតមានការបើកសម្តែង នោះបណ្តាជនវិនាស, **សុភា.** ២៩:១៨ ។ ពួកកំឡោះៗនឹងឃើញការជាក់ស្តែង, **យ៉ូអែល** ២:២៨ (កិច្ចការ ២:១៧) ។ ទ្រង់បានប្រទានការចេះដឹងដល់ខ្ញុំ ដោយការនិមិត្ត, **២ នីហ្វៃ** ៤:២៣ ។ លោកជាទូត ដែលបានចាត់មក ពីវត្តមាននៃព្រះ, **យ.ស. — ប្រវត្តិ** ១:៣៣ ។ យើងខ្ញុំជឿដល់ការព្យាករណ៍ វិវរណៈ ការនិមិត្ត, **ម. នៃ ស.** ១:៧ ។

**ការនិមិត្តទីមួយ** *សូមមើលផង* ការសាងឡើងវិញនៃដំណឹងល្អ; ស្ម៊ីធ យ៉ូសែប ជុញ៉រ

ជាការលេចមកនៃព្រះដ៏ជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ដល់ព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងព្រៃឈើ ។

នៅនិទាឃរដូវឆ្នាំ ១៨២០ យ៉ូសែប ស្ម៊ីធ ជុញ៉រ មានអាយុ ១៥ ឆ្នាំ ។ លោកបានរស់នៅជាមួយគ្រួសារលោក នៅក្នុងភូមិប៉ាល់ម៉ៃរ៉ា រដ្ឋនូវយ៉ោក ។ នៅខាងលិចផ្ទះ មិនជាឆ្ងាយប៉ុន្មាន គឺមានព្រៃឈើធំៗ ។ យ៉ូសែបបានទៅទីនេះ ដើម្បីអធិស្ឋានទៅព្រះ ចង់ដឹងថាតើ សាសនាចក្រណាមួយដែលត្រឹមត្រូវ ។ លោកបានមានអារម្មណ៍កាលអានព្រះគម្ពីរប៊ីបថា លោកត្រូវស្វែងរកចម្លើយនោះពីព្រះ (យ៉ាកុប ១:៥–៦) ។ ក្នុងការឆ្លើយតបពាក្យអធិស្ឋានរបស់លោក នោះព្រះវរបិតា និងព្រះរាជបុត្រាបានលេចមកឲ្យលោកឃើញ ហើយបានប្រាប់ លោកមិនឲ្យចូលសាសនាចក្រនានា នៅលើផែនដីឡើយ ត្បិតគេទាំងអស់សុទ្ធតែខុស (យ៉ូសែប ស្ម៊ីធ — ប្រវត្តិ ១:១៥–២០) ។ ការពិសោធន៍ដ៏ពិសិដ្ឋនេះបានចាប់ផ្តើមនូវហេតុការណ៍ជាច្រើន ដែលនឹងនាំមកនូវការសាងឡើងវិញនៃដំណឹងល្អ និងសាសនាចក្រ ដ៏ពិតនៃព្រះគ្រីស្ទ ។

**ការនិយាយអាក្រក់** *សូមមើលផង* ការទាស់ទែងគ្នា; និយាយដើម, ពាក្យចចាមអារាម, សេចក្តីកុហក

ជាការនិយាយពីអ្វីៗដែលខុស ដែលធ្វើឲ្យមានចិត្តឈឺចាប់ និងទុច្ចរិត ។ នៅក្នុងគម្ពីរ ការនិយាយបែបនេះតែងតែជា ការនិយាយ អំពីមនុស្សម្នាក់ ដោយមានបំណងនឹងធ្វើឲ្យមានចិត្តឈឺគ្រាំគ្រា ។

ចូររក្សាអណ្តាត ឲ្យរួចពីសេចក្តីអាក្រក់, **ទំនុក.** ៣៤:១៣ (១ ពេត្រុស ៣:១០) ។ មនុស្សចោលម្សៀត គេគិតគូរបង្កើតការអាក្រក់, **សុភា.** ១៦:២៧ ។ អ្នករាល់គ្នាមានពរក្នុងកាលដែលគេនិយាយបង្ខុសគ្រប់ទាំងសេចក្តីអាក្រក់ពីអ្នករាល់គ្នា, **ម៉ាថាយ** ៥:១១ (៣ នីហ្វៃ ១២:១១) ។ ពីក្នុងចិត្តនោះឯង ដែលចេញអស់ទាំងគំនិតអាក្រក់, **ម៉ាថាយ** ១៥:១៩ (ម៉ាកុស ៧:២១) ។ អ្នកមិនត្រូវនិយាយអាក្រក់ពីចៅហ្វាយឡើយ, **កិច្ចការ** ២៣:៥ ។ ចូរខំដកការនិយាយអាក្រក់ចេញពីពួកអ្នករាល់គ្នាទៅ, **អេភេ.** ៤:៣១ ។ កុំឲ្យនិន្ទាគ្នាឡើយ, **យ៉ាកុប** (ព.ស.ថ.) ៤:១១ ។ មើលឲ្យឃើញថា គ្មានការពោលបង្កាច់ ឬក៏មានការនិយាយអាក្រក់ឡើយ, **គ. និង ស.** ២០:៥៤ ។

**ការបកប្រែដោយយ៉ូសែបស្ម៊ីធ (ក.យ.ស.)** *សូមមើលផង* យ៉ូសែប ជុញ៉រ, ស្ម៊ីធ

ជាការកែសំរួល ឬការបកប្រែព្រះគម្ពីរប៊ីបរបស់ស្តេចយេម្ស ក្នុងភាសាអង់គ្លេស ដែលព្យាការីយ៉ូសែប ស្ម៊ីធ បានចាប់ផ្តើមកែ នៅខែមិថុនា ឆ្នាំ ១៨៣០ ។ ព្រះអង្គទ្រង់បានបញ្ជាលោកឲ្យបកប្រែ ហើយរាប់ទុកជាផ្នែកនៃតំណែងរបស់លោកជាព្យាការី ។

ទោះបីយ៉ូសែបបានបញ្ចប់ការបកប្រែភាគច្រើននៅខែកក្កដា ឆ្នាំ ១៨៣៣ហើយក៏ដោយ គង់តែលោកនៅតែធ្វើការកែប្រែតទៅ រហូតដល់ពេលលោកស្លាប់នៅឆ្នាំ ១៨៤៤ កាលរៀបចំឯកសារសំរាប់បោះពុម្ព ។ លោកបានបោះពុម្ពការបកប្រែភាគខ្លះ នៅក្នុងជីវិត លោកប្រហែលជាលោកអាចបានកែប្រែបន្ថែមទៀតដែរ បើសិនជាលោកនៅរស់ ដើម្បីបោះពុម្ពការបកប្រែទាំងអស់ ។ *សាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដែលរៀបចំឡើងវិញ* បានបោះពុម្ពលើកទី ១ នូវការបកប្រែដ៏ប្រសើរ ដោយយ៉ូសែប ស្ម៊ីធ នៅឆ្នាំ ១៨៦៩ ។ គេបានបោះពុម្ពជាច្រើនលើក ចាប់តាំងពីពេលនោះមក ។

ព្យាការីបានដឹងអំពីការណ៍ជាច្រើន នៅពេលធ្វើការបកប្រែនោះ ។ កណ្ឌជាច្រើននៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា នោះបានទទួលមកដោយសារការបកប្រែរបស់លោក (ដូចជា គ. និង ស. ៧៦,

៧៧, ៩១ និង ១៣២) ។ ហើយព្រះអម្ចាស់ទ្រង់ក៏បានប្រទានដល់យ៉ូសែបនូវការបង្គាប់ដ៏ជាក់លាក់ សំរាប់ការបកប្រែនោះ ដែលបានកត់ទុកនៅក្នុង គោលលទ្ធិ និងសេចក្តីសញ្ញា (គ. និង ស. ៣៧:១; ៤៥:៦០–៦១; ៧៦:១៥–១៨; ៩០:១៣; ៩១; ៩៤:១០; ១០៤:៥៨; ១២៤:៨៩) ។ ឥឡូវនេះ មានគម្ពីរម៉ូសេ និងយ៉ូសែប ស្ម៊ីធ — ម៉ាថាយ បានបញ្ចូលជាមួយ មុក្តាដ៏មានតម្លៃមហិមា គឺបានដកស្រង់ចេញពីការបកប្រែដោយយ៉ូសែប ស្ម៊ីធ ផ្ទាល់ ។

ការបកប្រែដោយយ៉ូសែប ស្ម៊ីធបានសាងឡើងវិញ នូវសេចក្តីដ៏ច្បាស់ និងវិសេសខ្លះៗ ដែលបានបាត់ពីព្រះគម្ពីរប៊ីប (១ នីហ្វៃ ១៣) ។ ទោះបីជាវាមិនមែនជាគម្ពីរតាមផ្លូវការរបស់សាសនាចក្រក៏ដោយ គង់តែការបកប្រែនេះផ្តល់នូវការយល់ដ៏ជ្រាលជ្រៅជាច្រើន ហើយ ដ៏មានប្រយោជន៍ខ្លាំងក្នុងការយល់ព្រះគម្ពីរប៊ីបដែរ ។ វាក៏ជាសាក្សីមួយចំពោះតំណែង និងការងារបំរើដ៏ឧត្តមនៃព្យាការីយ៉ូសែប ស្ម៊ីធ ។

**ការបែកខ្ញែក** *សូមមើល* អ៊ីស្រាអែល —
ការបាក់បែកនៃពួកសាសន៍អ៊ីស្រាអែល

**ការបង្កបង្កើតខាងវិញ្ញាណ** *សូមមើលផង* ការបង្កបង្កើត; បង្កើត, មនុស្ស, មនុស្សលោក

ព្រះអម្ចាស់ទ្រង់បានបង្កើតអស់ទាំងអ្វីៗខាងវិញ្ញាណ មុនទ្រង់បានបង្កើតរបស់ទាំងនោះខាងសាច់ឈាម (ម៉ូសេ ៣:៥) ។

ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យមានតិណជាតិគ្រប់មុខ មុនមាននៅលើផែនដី, **លោកុ.** ២:៤–៦ (អ័ប្រា. ៥:៥) ។ ដោយសារព្រះចេស្តានៃ ព្រះវិញ្ញាណរបស់យើង នោះយើងបានបង្កើតរបស់គ្រប់ទាំងអស់ — ទីមួយខាងវិញ្ញាណ រួចទីពីរ ខាងសាច់ឈាម, **គ. និង ស.** ២៩:៣១–៣២ ។ អ្វីដែលជាសាច់ឈាម មានរូបភាពដូចជាអ្វីខាងវិញ្ញាណ, **គ. និង ស.** ៧៧:២ ។ យើងបានបង្កើតលោកិយ និងមនុស្សលោកមកមុនមានពួកគេនៅក្នុងសាច់ឈាមម្លេះ, **ម៉ូសេ** ៦:៥១ ។

**ការប្រតិព័ទ្ធភេទដូចគ្នា** *សូមមើលផង* កាមរាគ, ខាងកាមរាគ, អំពើសហាយស្មន់

ជាការរួមដំណេកនៃបុគ្គលនីមួយៗដែលមានភេទដូចគ្នា ។ ព្រះទ្រង់ហាមប្រាមមិនឲ្យមានការរួមដំណេកបែបនេះទេ ។

ចូរអ្នកនាំវាចេញមកឯយើង ឲ្យយើងបានស្គាល់ផង, **លោកុ.** ១៩:១–១១ (ម៉ូសេ ៥:៥១–៥៣) ។ កុំឲ្យរួមដំណេកនឹងប្រុស ដូចជារួមនឹងស្រីឡើយ ត្បិតនោះជាអំពើគួរខ្ពើមឆ្អើម, **លេវី.** ១៨:២២ (លេវី ២០:១៣) ។ មិនត្រូវមានប្រុសណាមួយធ្វើជាកូនជឹង នៅក្នុងពួកកូនប្រុសសាសន៍អ៊ីស្រាអែលឡើយ, **ចោទិ.** ២៣:១៧ ។ គេបើកបង្ហាញអំពើបាបរបស់គេចេញ ដូចជាក្រុងសូដុំម គេមិនខំបិទបាំងទេ, **អេសាយ** ៣:៩ (២ នីហ្វៃ ១៣:៩) ។ ពួកប្រុសៗបង្កើតឲ្យមានសេចក្តីសំរេបរោលរាល ដល់គ្នាទៅវិញទៅមក, **រ៉ូម** ១:២៧ ។ ពួកលេងកូនជឹងនឹងមិនបានគ្រងនគរព្រះទុកជាមរតកឡើយ, **១ កូរិន.** ៦:៩–១០ ។ ក្រិត្យវិន័យមិនមែនតាំងសំរាប់មនុស្សសុចរិតទេ ប៉ុន្តែសំរាប់ពួកគេដែលលេងកូនជឹងវិញ, ១ ធីម៉ូ. ១:៩–១០ ។ ពួកអ្នកដែលទៅតាមសាច់ឈាមដទៃ នោះត្រូវបានតាំងទុកជាក្បួន ឲ្យរងទុក្ខទោសក្នុងភ្លើងដ៏ឆេះអស់កល្បជានិច្ច, **យូដាស** ១:៧ ។

**ការប្រមូលនៃសាសន៍អ៊ីស្រាអែល** *សូមមើល* អ៊ីស្រាអែល —
ការប្រមូលនៃសាសន៍អ៊ីស្រាអែល

**ការប្រសិទ្ធិពរដល់មនុស្សឈឺ** *សូមមើលផង* ការដាក់; ការប្រោស; ចាក់ប្រេង; ដៃ, បព្វជិតភាព, ប្រេង; ប្រោស

ជាការប្រសិទ្ធិពរដល់មនុស្សឈឺ ដោយពួកបុរសដែលកាន់បព្វជិតភាពមិលគីស្សាដែក គឺដោយប្រើប្រេងដែលបានញែកទុក ។

សូមដាក់ព្រះហស្តលើវា, **ម៉ាថាយ** ៩:១៨ ។ ព្រះយេស៊ូវបានដាក់ព្រះហស្តលើមនុស្សពិការខ្លះ ហើយបានប្រោសពួកគេឲ្យជា, **ម៉ាកុស** ៦:៥ ។ ពួកសាវកនៃព្រះគ្រីស្ទបានចាក់ប្រេងលាបមនុស្សឈឺជាច្រើនឲ្យគេបានជា, **ម៉ាកុស** ៦:១៣ ។ ពួកអែលឌើរត្រូវចាក់ប្រេងលាបហើយប្រោសមនុស្សឈឺ, **យ៉ាកុប (ព.ស.ថ.)** ៥:១៤–១៥ ។ អ្នករាល់គ្នាមិនត្រូវប្រោសមនុស្សឈឺឲ្យបានជាឡើយ លើកលែងតែតម្រូវពី អ្នក ដោយពួកអ្នកដែលមានសេចក្តីប្រាថ្នាប៉ុណ្ណោះ, **គ. និង ស.** ២៤:១៣–១៤ ។ ពួកអែលឌើរត្រូវដាក់ដៃលើមនុស្សឈឺ, **គ. និង ស.** ៤២:៤៤ ។ ចូរដាក់ដៃអ្នកលើមនុស្សដែលមានជំងឺ ហើយពួកគេនឹងបានជាស្បើយ, **គ. និង ស.** ៦៦:៩ ។

**ការប្រើជានិមិត្តរូប**

ការប្រើអ្វីមួយ ដូចជារូប ឬរូបភាពអំពីរបស់ផ្សេងទៀត ។ ការប្រើជានិមិត្តរូបនៅក្នុងព្រះគម្ពីរ ដូចជាយកវត្ថុ ព្រឹត្តិការណ៍ ឬកាលៈទេសៈ ដើម្បីធ្វើជាតំណាងគោលការណ៍ ឬការបង្រៀនដំណឹងល្អ ។ ជាឧទាហរណ៍ នៅក្នុងព្រះគម្ពីរមរមន ព្យាការីអាលម៉ាបានយកគ្រាប់ពូជមកធ្វើជាតំណាងព្រះបន្ទូលនៃព្រះ (អាលម៉ា ៣២) ។

ពួកព្យាការីទាំងអស់ក្នុងព្រះគម្ពីរ បានប្រើនិមិត្តរូប ដើម្បីបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ និមិត្តរូបខ្លះ មាននៅក្នុងបុណ្យ និងពិធីបរិសុទ្ធ (ម៉ូសេ ៦:៦៣), យញ្ញបូជា (ហេព្រើរ ៩:១១–១៥; ម៉ូសេ ៥:៧–៨), បុណ្យរំលង (លូកា ២២:១៣–២០; ក.យ.ស., ម៉ាកុស ១៤:២០–២៤), និងបុណ្យជ្រមុជទឹក (រ៉ូម ៦:១–៦; គ. និង ស. ១២៨:១២–១៣) ។ ឈ្មោះជាច្រើននៅក្នុងព្រះគម្ពីរប៊ីប គឺជានិមិត្តរូប ។ បុណ្យរោងឧបោសថ និងក្រិត្យវិន័យលោកម៉ូសេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់បានធ្វើជាតំណាងអំពីសេចក្តីពិតដ៏នៅអស់កល្បជានិច្ច (ហេព្រើរ ៨–១០; ម៉ូសាយ ១៣:២៩–៣២; អាលម៉ា ២៥:១៥; ហេលេ. ៨:១៤–១៥) ។ សំរាប់ឧទាហរណ៍ផ្សេងទៀត សូមមើល ម៉ាថាយ ៥:១៣–១៦; យ៉ូហាន ៣:១៤–១៥; យ៉ាកុប ៤:៥; អាលម៉ា ៣៧:៣៨–៤៥ ។

**ការប្រែចិត្តជឿ, អ្នកប្រែចិត្តជឿ** *សូមមើលផង* កើតពីព្រះ; កើតម្តងទៀត, សិស្ស

ជាការប្រែជំនឿ ចិត្ត និងជីវិតរបស់មនុស្សម្នាក់ ដើម្បីទទួលយក ហើយធ្វើឲ្យបានស្របតាមព្រះហឫទ័យនៃព្រះ (កិច្ចការ ៣:១៩) ។

ការប្រែចិត្តជឿមានរួមនូវសេចក្តីសំរេចចិត្តដោយចេតនា ដើម្បីបោះបង់ចោលផ្លូវចាស់របស់មនុស្សម្នាក់ ហើយប្រែឲ្យបានទៅជាសិស្សនៃព្រះគ្រីស្ទ ។ ការប្រែចិត្ត បុណ្យជ្រមុជទឹកសំរាប់ការផ្តាច់បាប ការទទួលយកព្រះវិញ្ញាណបរិសុទ្ធ ដោយការដាក់ដៃលើ ហើយមានសេចក្តីជំនឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទតទៅ នោះហើយដែលសំរេចការប្រែចិត្តជឿ ។ មនុស្សខាងសាច់ឈាមនឹងបានប្រែទៅជា មនុស្សថ្មីមួយ ដែលបានញែកចេញជាបរិសុទ្ធ ហើយស្អាតបាត គឺបានកើតម្តងទៀតក្នុងព្រះគ្រីស្ទយេស៊ូវ (២ កូរិន. ៥:១៧; ម៉ូសាយ ៣:១៩) ។

មនុស្សត្រូវតែផ្លាស់គំនិត ហើយត្រឡប់ដូចជាកូនក្មេងតូចៗ, **ម៉ាថាយ** ១៨:៣ (ម៉ូសាយ ៣:១៩) ។ កាលណាអ្នកបានប្រែចិត្តវិលមក វិញ នោះចូរចំរើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង, **លូកា** ២២:៣២ ។ ពួកអ្នកដែលទទួលពាក្យរបស់គាត់ដោយអំណរ ក៏បានទទួល បុណ្យជ្រមុជទឹក, **កិច្ចការ** ២:៤១ (៣៧–៤១) ។ ចូរនាំមនុស្សបាបឲ្យត្រឡប់ពីផ្លូវវង្វេងមកវិញចុះ, **យ៉ាកុប** (ព.ស.ថ.) ៥:២០ ។ អេណុសបានប្រែចិត្តជឿ, **អេណុស** ១:២–៥ ។ ព្រះបន្ទូលនៃស្តេចបេនយ៉ាមីនបាននាំមកនូវការផ្លាស់ប្តូរយ៉ាងធំក្នុងប្រជាជន, **ម៉ូសាយ** ៥:២ (អាលម៉ា ៥:១២–១៤) ។ មនុស្សទាំងអស់ត្រូវតែកើតម្តងទៀត មែនហើយ គឺកើតពីព្រះ, **ម៉ូសាយ** ២៧:២៥ ។ អាលម៉ា និងពួក បុត្រារបស់ម៉ូសាយបានប្រែចិត្តជឿ, **ម៉ូសាយ** ២៧:៣៣–៣៥ ។ បិតារបស់ឡាម៉ូណៃបានប្រែចិត្តជឿ, **អាលម៉ា** ២២:១៥–១៨ ។ ដោយ ព្រះចេស្តា និងព្រះបន្ទូលនៃព្រះ នោះពួកគេបានប្រែចិត្តជឿទៅដល់ព្រះអម្ចាស់, **អាលម៉ា** ៥៣:១០ ។ ការប្រែចិត្តនាំមកនូវការផ្លាស់ប្តូរ ក្នុងចិត្ត, **ហេលេ.** ១៥:៧ ។ មនុស្សជាច្រើនណាដែលបានប្រែចិត្តជឿ នោះបានសម្តែងយ៉ាងពិតថា ពួកគេបានត្រូវពិនិត្យពិច័យ ដោយ ព្រះចេស្តា និងព្រះវិញ្ញាណនៃព្រះ, **៣ នីហ្វៃ** ៧:២១ ។ ពីព្រោះតែសេចក្តីជំនឿរបស់គេដល់ព្រះគ្រីស្ទ នៅគ្រាគេប្រែចិត្តជឿ នោះពួកគេបានទទួលបុណ្យជ្រមុជដោយភ្លើង ហើយដោយព្រះវិញ្ញាណបរិសុទ្ធ, **៣ នីហ្វៃ** ៩:២០ ។ ពួកគេនឹងចេញទៅ ហើយផ្សាយ ប្រាប់ពីការប្រែចិត្ត ហើយមនុស្សជាច្រើននឹងបានប្រែចិត្តជឿ, **គ. និង ស.** ៤៤:៣–៤ ។

**ការប្រែរូប** *សូមមើលផង* កូនសោទាំងឡាយនៃបព្វជិតភាព, ព្រះយេស៊ូវគ្រីស្ទ

ជាលក្ខណៈនៃជនទាំងឡាយណា ដែលបានប្រែប្រួលរាងកាយ និងសភាពមួយរយៈ — គឺថា បានលើកឡើងទៅឯស្ថានភាពខាងវិញ្ញាណដែលខ្ពស់ជាង — ដើម្បីឲ្យពួកគេអាចទ្រាំទ្រវត្តមាន និងសិរីល្អនៃពួកពលស្ថគ៌ាទាំងឡាយបាន ។

*ការប្រែរូបនៃព្រះគ្រីស្ទ៖* ពេត្រុស យ៉ាកុប និងយ៉ូហានបានឃើញព្រះអម្ចាស់ទទួលភាពរុងរឿង ហើយប្រែរូប នៅចំពោះពួកគេ ។ ព្រះអង្គសង្គ្រោះបានសន្យាពីមុនថា ពេត្រុសនឹងបានទទួលកូនសោទាំងឡាយនៃនគរស្ថានសួគ៌ (ម៉ាថាយ ១៦:១៣–១៩; ១៧:១–៩; ម៉ាកុស ៩:២–១០; លូកា ៩:២៨–៣៦; ២ ពេត្រុស ១:១៦–១៨) ។ នៅព្រឹត្តការណ៍ដ៏សំខាន់នេះ ព្រះអង្គសង្គ្រោះ ម៉ូសេ និងអេលីយ៉ា បានប្រគល់កូនសោទាំងឡាយនៃបព្វជិតភាព ដែលបានសន្យាទុកឲ្យទៅពេត្រុស យ៉ាកុប និងយ៉ូហាន ។ ដោយសារកូនសោទាំង ឡាយនៃបព្វជិតភាពនេះ ពួកសាវកបានអំណាច ដើម្បីបន្តកិច្ចការនៃនគរបន្ទាប់ពីព្រះយេស៊ូវទ្រង់យាងឡើងទៅលើ ។

យ៉ូសែប ស្ម៊ីធបានបង្រៀនថា នៅលើភ្នំនៃការប្រែរូប ពេត្រុស យ៉ាកុប និងយ៉ូហាន ក៏បានប្រែរូបដែរ ។ ពួកគេបានឃើញការនិមិត្តមួយ អំពីផែនដីដែលនឹងមានរូបរាងដ៏ប្រកបដោយភាពដ៏រុងរឿង នៅអនាគតកាល (គ. និង ស. ៦៣:២០–២១) ។ ពួកគេបានឃើញលោក ម៉ូសេ និងលោកអេលីយ៉ា ជាពួកអ្នកដែលបានប្រែរូប ហើយបានឮសម្លេងនៃព្រះវរបិតា ។ ព្រះវរបិតាមានព្រះបន្ទូលថា « នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់; ចូរស្តាប់តាមចុះ » (ម៉ាថាយ ១៧:៥) ។

*ពួកអ្នកដែលបានប្រែរូប៖* គេក៏បានឃើញព្រះនៃអ៊ីស្រាអែល, **និក្ខ.** ២៤:៩–១១ ។ ស្បែកមុខលោកភ្លឺ ក្នុងកាលលោកទូលនឹងព្រះ, **និក្ខ.** ៣៤:២៩ (ម៉ាកុស ៩:២–៣) ។ ព្រះភ័ក្ត្រព្រះយេស៊ូវបានភ្លឺ, **ម៉ាថាយ** ១៧:២ (ម៉ាកុស ៩:២–៣) ។ ពួកជនជាតិអ៊ីស្រាអែល មិនអាចនឹងសម្លឹងមើលមុខលោកម៉ូសេបានទេ ដោយព្រោះសិរីល្អ, **២ កូរិន.** ៣:៧ ។ មុខអ័ប៊ីណាដៃបានភ្លឺចែងចាំងយ៉ាងក្រៃលែង, **ម៉ូសាយ** ១៣:៥–៩ ។ ពួកគេត្រូវបានហ៊ុំព័ទ្ធជុំវិញ ហាក់បីដូចជាភ្លើង, **ហេលេ.** ៥:២៣, ៣៦, ៤៣–៤៥ (៣ នីហ្វៃ ១៧:២៤; ១៩:១៤) ។ ពួកគេមានពណ៌ស ដូចជាព្រះភ័ក្ត្ររបស់ព្រះយេស៊ូវ, **៣ នីហ្វៃ** ១៩:២៥ ។ មើលទៅដូចជាពួកគេមានការប្រែរូប, **៣ នីហ្វៃ** ២៨:១៥ ។ គ្មានមនុស្សណាមួយបានឃើញព្រះនៅក្នុងសាច់ឈាមនៅពេលណាមួយឡើយ លើកលែងតែបានប្រោសឡើង ដោយ ព្រះវិញ្ញាណប៉ុណ្ណោះ, **គ. និង ស.** ៦៧:១០–១២ ។ ដោយសារព្រះចេស្តានៃព្រះវិញ្ញាណ នោះភ្នែករបស់យើងខ្ញុំបានបើក, **គ. និង ស.** ៧៦:១២ ។ សិរីល្អនៃព្រះត្រូវបានចាំងមកលើម៉ូសេ, **ម៉ូសេ** ១:២ ។ សិរីល្អរបស់ទ្រង់បានមកលើខ្ញុំ; ហើយខ្ញុំបានមើលឃើញព្រះភ័ក្ត្រទ្រង់ ព្រោះខ្ញុំត្រូវបានប្រែរូប, **ម៉ូសេ** ១:១១ ។ ខ្ញុំឃើញផ្ទៃមេឃបើកចំហ ហើយខ្ញុំត្រូវបានបំពាក់ដោយសិរីល្អ, **ម៉ូសេ** ៧:៣–៤ ។

**ការបោក, បញ្ឆោត, សេចក្តីបញ្ឆោត***សូមមើលផង* សេចក្តីកុហក, ឧបាយកល

នៅក្នុងគម្ពីរ បញ្ឆោត គឺធ្វើឲ្យអ្នកណាមួយជឿដល់អ្វីៗ ដែលមិនពិត ។

អ្នកណាដែលមិនបានស្បថប្រវ័ញ្ចគេ អ្នកនោះនឹងឡើងទៅឯភ្នំនៃព្រះអម្ចាស់, **ទំនុក.** ២៤:៤ ។ សូមជួយទូលបង្គំឲ្យរួចពីមនុស្សកំភូត, **ទំនុក.** ៤៣:១ ។ វេទនាដល់ពួកអ្នក ដែលរាប់សេចក្តីអាក្រក់ថាជាល្អ ហើយសេចក្តីល្អថាជាអាក្រក់វិញ, **អេសាយ** ៥:២០ (២ នីហ្វៃ

១៥:២០) ។ ចូរកុំឲ្យអ្នកណាបញ្ឆោតខ្លួនឡើយ, **១ កូរិន.** ៣:១៨ ។ កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នា ដោយពាក្យសំដីឥតប្រយោជន៍ ឡើយ, **អេភេ.** ៥:៦ ។ ពួកអាក្រក់នឹងបញ្ឆោត ហើយនឹងត្រូវបញ្ឆោត,២ ធីម៉ូ. ៣:១៣ ។ សាតាំង ជាអ្នកដែលបញ្ឆោតលោកិយ ទាំងមូលត្រូវបោះចេញ, **វិវរ.** ១២:៩ ។ សាតាំងត្រូវចងទុក ដើម្បីកុំឲ្យវាបញ្ឆោតសាសន៍ទាំងឡាយទៀតឡើយ, **វិវរ.** ២០:១–៣ ។ ព្រះអម្ចាស់ទ្រង់មិនអាចបញ្ឆោតបានឡើយ, **២ នីហ្វៃ** ៩:៤១ ។ បើអ្នករាល់គ្នាដើរតាមព្រះរាជបុត្រា ដោយពុំបោកបញ្ឆោតចំពោះព្រះ នោះអ្នករាល់គ្នានឹងបានទទួលព្រះវិញ្ញាណបរិសុទ្ធ, **២ នីហ្វៃ** ៣១:១៣ ។ សេរេមបានសារភាពថាខ្លួនត្រូវបានបញ្ឆោត ដោយអំណាច នៃអារក្ស, **យ៉ាកុប** ៧:១៨ ។ ប្រជារាស្ត្រស្ដេចណូអេត្រូវបានបញ្ឆោតដោយពាក្យបញ្ចើចបញ្ចើ, **ម៉ូសាយ** ១១:៧ ។ ពួកអ្នកណាដែល មានប្រាជ្ញាបានទទួលយកព្រះវិញ្ញាណបរិសុទ្ធ ទុកជាអ្នកណែនាំរបស់ខ្លួន ហើយដែលពុំត្រូវគេបញ្ឆោត, **គ. និង ស.** ៤៥:៥៧ ។ វេទនា ដល់ពួកអ្នកណាដែលជាមនុស្សឆបោក, **គ. និង ស.** ៥០:៦ ។ វាបានក្លាយទៅជាសាតាំង ជាបិតានៃអស់ទាំងការកុហក ដើម្បីបញ្ឆោត ហើយដើម្បីធ្វើឲ្យមនុស្សខ្វាក់, **ម៉ូសេ** ៤:៤ ។

**ការបំផុសគំនិត, បំផុសគំនិត** *សូមមើលផង* ព្រះវិញ្ញាណបរិសុទ្ធ; វិវរណៈ

ជាការណែនាំដ៏ឧត្ដមដែលបានប្រទានឲ្យមនុស្សដោយព្រះ ។ ការបំផុសគំនិតតែងតែមានមកដោយព្រះវិញ្ញាណ ដល់គំនិត និងចិត្តនៃ ជនណាមួយ តាមមាគ៌ាផ្សេងៗ ។

ក្រោយពីភ្លើងនោះមក មានឮសម្លេងតូចរហៀងៗ, **១ពង្សាវ.** ១៩:១២ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដី ទាំងអស់ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី, **យ៉ូហាន** ១៤:២៦ ។ ព្រះវិញ្ញាណនៃសេចក្ដីពិត នឹងដឹកនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្ដី ពិត, **យ៉ូហាន** ១៦:១៣ ។ ព្រះវិញ្ញាណបាននាំខ្ញុំ ដោយខ្ញុំមិនដឹងជាមុនសោះឡើយថាខ្ញុំនឹងត្រូវធ្វើអ្វីខ្លះ, **១ នីហ្វៃ** ៤:៦ ។ សម្លេងនៃ ព្រះអម្ចាស់បានចូលមកក្នុងគំនិតខ្ញុំ, **អេណុស** ១:១០ ។ អ្វីក៏ដោយដែលអញ្ជើញ ហើយញុះញង់ឲ្យធ្វើល្អ គឺបំផុសគំនិតមកពីព្រះ, **មរ៉ូណៃ** ៧:១៣–១៦ ។ តើយើងពុំបាននិយាយដោយស្កប់ស្កល់ដល់គំនិតរបស់អ្នកទេឬអី ?, **គ. និង ស.** ៦:២៣ ។ យើងនឹង ប្រាប់អ្នកនៅក្នុង គំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នក, **គ. និង ស.** ៨:២ ។ ព្រះវិញ្ញាណរបស់យើងនឹងបំភ្លឺគំនិតរបស់អ្នក ដែលនឹងបំពេញព្រលឹង របស់អ្នកដោយសេចក្ដីអំណរ, **គ. និង ស.** ១១:១៣ ។ នឹងបានប្រទានឲ្យអ្នក នូវអ្វីដែលអ្នកត្រូវនិយាយ និងកត់ នៅវេលានោះឯង, **គ. និង ស.** ២៤:៦ (គ. និង ស. ៨៤:៨៥) ។ សម្លេងតូចរហៀងៗដែលខ្សឹប ហើយទំលុះគ្រប់ទាំងអស់, **គ. និង ស.** ៨៥:៦ ។

**ការបំរើ** *សូមមើលផង* សុខុមាលភាព, សេចក្ដីស្រឡាញ់

ជាការថែរក្សា ឬការងារដែលធ្វើដើម្បីប្រយោជន៍ដល់ព្រះ និងដល់អ្នកឯទៀត ។ នៅពេលយើងបំរើអ្នកដទៃ យើងក៏បំរើព្រះដែរ ។ ចូរឯងរាល់គ្នារើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាម នៅថ្ងៃនេះចុះ, **យ៉ូស្វេ** ២៤:១៥ ។ ដាដរាបណា ដែលអ្នករាល់គ្នា បានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកទាំងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ, **ម៉ាថាយ** ២៥:៣៥–៤៥ ។ ចូរថ្វាយរូបកាយទុកជាយញ្ញបូជារស់ ជាការគោរពនៃអ្នករាល់គ្នា, **រ៉ូម** ១២:១ ។ ត្រូវឲ្យបំរើគ្នាទៅវិញទៅមក ដោយសេចក្ដីស្រឡាញ់, **កាឡាទី** ៥:១៣ ។ ត្រូវចំណាយជីវិតរបស់ខ្លួនក្នុងការបំរើដល់ព្រះរបស់កូន, **២ នីហ្វៃ** ២:៣ ។ កាលណាអ្នករាល់គ្នានៅក្នុងការបំរើ ដល់មនុស្សទូទៅ នោះគឺអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបំរើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ, **ម៉ូសាយ** ២:១៧ ។ អស់អ្នកណាដែលយក បានដែនដីសន្យា នោះត្រូវបំរើព្រះ បើពុំនោះទេ ពួកគេនឹងត្រូវបោសចោល, **អេធើរ** ២:៨–១២ ។ អស់អ្នកណាដែលចាប់ផ្ដើមធ្វើ ការបំរើព្រះអើយ នោះត្រូវបំរើទ្រង់ឲ្យអស់ពីចិត្ត, **គ. និង ស.** ៤:២ ។ ព្រះអម្ចាស់ទ្រង់បានប្រទានព្រះបញ្ញត្តិទាំងឡាយ ដើម្បីឲ្យ មនុស្សលោកស្រឡាញ់ ហើយបំរើទ្រង់, **គ. និង ស.** ២០:១៨–១៩ ។ ដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នោះអ្នកត្រូវបំរើព្រះ, **គ. និង ស.** ៥៩:៥ ។ យើងជាព្រះអម្ចាស់ សព្វព្រះហឫទ័យនឹងឲ្យកិត្តិយសដល់អស់អ្នកណាដែលបំរើយើង, **គ. និង ស.** ៧៦:៥ ។ ចូរថ្វាយបង្គំដល់ព្រះ ព្រោះអ្នកត្រូវបំរើទ្រង់តែមួយព្រះអង្គប៉ុណ្ណោះ, **ម៉ូសេ** ១:១៥ ។

**ការបះបោរ** *សូមមើលផង* អ៊្សីរទាំ; សេចក្ដីក្បត់សាសនា; អារក្ស; អំពើបាប

ជាការបំពាន ឬការជំទាស់ព្រះអម្ចាស់ ដោយមិនដើរតាមពួកមេដឹកនាំដ៏ជ្រើសរបស់ទ្រង់ ហើយមិនព្រមគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

កុំឲ្យបះបោរនឹងព្រះអម្ចាស់ឡើយ, **ជនគ.** ១៤:៩ ។ មនុស្សខូចអាក្រក់គេរកតែបះបោរម៉្យាងប៉ុណ្ណោះ, **សុភា.** ១៧:១១ ។ វេទនាដល់ ពួកកូនចៅដែលរឹងចចេស, **អេសាយ** ៣០:១ ។ ព្រះអម្ចាស់ទ្រង់ពុំប្រោសលោះអ្នកណាមួយ ដែលបះបោរទាស់នឹងទ្រង់ ហើយស្លាប់ ក្នុងអំពើបាបរបស់គេឡើយ, **ម៉ូសាយ** ១៥:២៦ ។ ពួកសាសន៍អាំលិស៊ីបានបះបោរចេញមុខមកទាស់នឹងព្រះ, **អាលម៉ា** ៣:១៨–១៩ ។ ពួកអ្នកបះបោរនឹងត្រូវចាក់ទំលុះ ដោយសេចក្ដីទុក្ខសោកដ៏រីងរៃ, **គ. និង ស.** ១:៣ ។ សេចក្ដីខ្ញាល់របស់ព្រះអម្ចាស់បានឆួលឡើងទាស់នឹងពួកបះបោរ, **គ. និង ស.** ៥៦:១ (គ. និង ស. ៦៣:១–៦) ។ សាតាំងបានបះបោរទាស់នឹងព្រះ, **ម៉ូសេ** ៤:៣ ។

**ការផ្ដាច់បាប** *សូមមើលផង* ការប្រែចិត្ត, ដង្វាយធួន; ធ្វើឲ្យធួន, ប្រែចិត្ត, ព្រះយេស៊ូវគ្រីស្ទ; អភ័យទោស; អត់ទោស

ជាការអត់ទោសដល់កំហុសទាំងប៉ុន្មាន ដោយពឹងផ្អែកទៅលើលក្ខខ័ណ្ឌនៃការប្រែចិត្ត ។ ការផ្ដាច់បាបត្រូវបានធ្វើឡើង ដោយ សារដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ជនម្នាក់ៗបានទទួលការផ្ដាច់បាបទាំងឡាយរបស់ខ្លួន បើសិនជននោះមានសេចក្ដីជំនឿជឿ ដល់ព្រះគ្រីស្ទ, លន់តួបាបរបស់ខ្លួន, ទទួលពិធីបរិសុទ្ធទាំងឡាយនៃបុណ្យជ្រមុជទឹក, និងការ

ដាក់ដៃលើ សំរាប់អំណោយទានជា ព្រះវិញ្ញាណបរិសុទ្ធ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ (ម. នៃ ស. ១:៣–៤) ។

ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមក៏ដោយ គង់តែនឹងបានសដូចហិមៈ, **អេសាយ** ១:១៦–១៨ ។ នេះជាឈាមខ្ញុំដែលបានច្រូចចេញ សំរាប់ការផ្ដាច់បាប, **ម៉ាថាយ** ២៦:២៨ (ហេព្រើរ ៩:២២–២៨; គ. និង ស. ២៧:២) ។ ចូរប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ប្រយោជន៍ឲ្យបានរួចពីបាប, **កិច្ចការ** ២:៣៨ (លូកា ៣:៣; គ.និង ស. ១០៧:២០) ។ អស់អ្នកណាដែលជឿលើទ្រង់ នោះនឹងបានរួចពីបាប, **កិច្ចការ** ១០:៤៣ (ម៉ូសាយ ៣:១៣) ។ ព្រះគ្រីស្ទជាប្រភពមួយដែលគេអាចស្វែងរក ដើម្បីឲ្យបានផ្ដាច់បាប, **២ នីហ្វៃ** ២៥:២៦ ។ ដើម្បីឲ្យបានការផ្ដាច់បាប នោះយើងរាល់គ្នាត្រូវចេះថែរក្សាមនុស្សក្រីក្រ និងមនុស្សកំសត់ទុគិត, **ម៉ូសាយ** ៤:១១–១២, ២៦ ។ ជនណាដែលប្រែចិត្ត នោះនឹងបានទទួលសេចក្ដីមេត្តាករុណា ចំពោះការផ្ដាច់បាបរបស់ខ្លួន, **អាលម៉ា** ១២:៣៤ ។ ការបំពេញនូវបញ្ញត្តិទាំងឡាយ នោះនាំមកនូវការផ្ដាច់បាប, **ម៉ូរ៉ូណៃ** ៨:២៥ ។ បព្វជិតភាពអើរ៉ុនកាន់កូនសោទាំងឡាយ អំពីបុណ្យ ជ្រមុជទឹកដោយការពន្លិច សំរាប់ការផ្ដាច់បាប, **គ. និង ស.** ១៣:១ (គ. និង ស. ៨៤:៦៤, ៧៤; ម. នៃ ស. ១:៤) ។ យើងជា ព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ, **គ. និង ស.** ៥៨:៤២–៤៣ (អេសេ. ១៨:២១–២២) ។ ពួកអ្នកទាំងនេះត្រូវបាន បង្រៀនអំពីបុណ្យជ្រមុជទឹកជំនួស សំរាប់ការផ្ដាច់បាប, **គ. និង ស.** ១៣៨:៣៣ ។

**ការពន្លិច** *សូមមើល* ធ្វើបុណ្យជ្រមុជទឹក — ដោយការពន្លិច, បុណ្យជ្រមុជទឹក

**ការព្យាករណ៍, ព្យាករ** *សូមមើលផង* ព្យាការី; ព្យាការីស្រី; វិវរណៈ; អ្នកមើលឆុត

ការព្យាករណ៍មាននូវពាក្យ ឬការសរសេរដ៏បំផុសគំនិតពីព្រះ ដែលជនណាម្នាក់ទទួល តាមរយៈវិវរណៈពីព្រះវិញ្ញាណបរិសុទ្ធ ។ ទីបន្ទាល់អំពីព្រះយេស៊ូវ គឺជាវិញ្ញាណខាងការព្យាករណ៍ (វិវរ. ១៩:១០) ។ ការព្យាករណ៍អាចស្ដីពីពេលកន្លងទៅហើយ បច្ចុប្បន្ននេះ ឬពេលខាងអានាគត ។ កាលណាជនណាម្នាក់ព្យាករ អ្នកនោះស្ដី ឬសរសេរនូវអ្វីដែលព្រះទ្រង់ចង់ឲ្យគាត់ដឹង សំរាប់ផលប្រយោជន៍ ដល់គាត់ ឬដល់អ្នកឯទៀត ។ មនុស្សម្នាក់ៗអាចទទួលការព្យាករណ៍ ឬវិវរណៈ សំរាប់ផលប្រយោជន៍ដល់ខ្លួនផ្ទាល់ ។

តើព្រះសុខចិត្តឲ្យបណ្ដាជនទាំងអស់របស់ព្រះអម្ចាស់ធ្វើជាព្យាការីឬអី, **ជនគ.** ១១:២៩ ។ កូនប្រុសស្រីរបស់ឯងនឹងទាយ, **យ៉ូអែល** ២:២៨ (កិច្ចការ ២:១៧–១៨) ។ ទ្រង់សំដែងគំនិតលាក់កំបាំងរបស់ទ្រង់ដល់ពួកហោរា ជាអ្នកបំរើទ្រង់, **អេម៉ុស** ៣:៧ ។ គ្មានពាក្យ ទំនាយណាក្នុងគម្ពីរ ដែលស្រាយបានតាមតែចិត្តនោះឡើយ, **២ ពេត្រុស** ១:២០ ។ ពួកសាសន៍នីហ្វៃមានវិវរណៈ និងវិញ្ញាណនៃការ ព្យាករណ៍ជាច្រើន, **យ៉ាកុប** ៤:៦, ១៣ ។ អាលម៉ា និងអាមូលេកបានដឹងនូវបំណងនៃចិត្តស៊ីអែស្រុម ដោយសារវិញ្ញាណនៃការ ព្យាករណ៍, **អាលម៉ា** ១២:៧ ។ វេទនាដល់អ្នកណាដែលនិយាយថា ព្រះអម្ចាស់ទ្រង់ឈប់ធ្វើកិច្ចការ ដោយការព្យាករណ៍ទៀតហើយ, **៣ នីហ្វៃ** ២៩:៦ ។ ចូរពិចារណាមើលពាក្យព្យាករណ៍របស់អេសាយចុះ, **មរមន** ៨:២៣ ។ សេចក្ដីព្យាករណ៍ទាំងប៉ុន្មាននោះនឹងបាន សំរេចទាំងអស់, **គ. និង ស.** ១:៣៧–៣៨ ។ មនុស្សត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍, **ម. នៃ ស.** ១:៥ ។

**ការពោលបង្កាច់** *សូមមើល* ការនិយាយអាក្រក់

**ការយកមកចិញ្ចឹមជាកូន** *សូមមើលផង* កូនចៅព្រះគ្រីស្ទ; បុត្រាបុត្រីនៃព្រះ, អ័ប្រាហាំ-ពូជរបស់អ័ប្រាហាំ; អ៊ីស្រាអែល;

គម្ពីរពោលដល់ការយកមកចិញ្ចឹមជាកូនពីរយ៉ាង ។

១) ជនដែលមិនមែនជាពូជអ៊ីស្រាអែល ក្លាយទៅជាសមាជិកក្នុងគ្រួសាររបស់អ័ប្រាហាំ និងក្នុងវង្សអ៊ីស្រាអែល ដោយមានសេចក្ដីជំនឿជឿលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹកដោយការពន្លិច និងដោយទទួលព្រះវិញ្ញាណបរិសុទ្ធ (២ នីហ្វៃ ៣១:១៧–១៨; គ. និង ស. ៨៤:៧៣–៧៤; អ័ប្រា. ២:៦, ១១) ។

២) អស់អ្នកណាដែលបានទទួលពិធីបរិសុទ្ធសំរាប់សង្គ្រោះនៃដំណឹងល្អ ក្លាយទៅជាបុត្រាបុត្រីនៃព្រះយេស៊ូវគ្រីស្ទ ដោយគោរពតាម បញ្ញត្តិទាំងឡាយរបស់ទ្រង់រហូតតទៅ (រ៉ូម ៨:១៥–១៧; កាឡាទី ៣:២៤–២៩; ៤:៥–៧; ម៉ូសាយ ៥:៧–៨) ។

**ការយល់ព្រមទូទៅ** *សូមមើលផង* ការគាំទ្រពួកអ្នកដឹកនាំក្នុងសាសនាចក្រ, សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ

ជាគោលការណ៍មួយ សំរាប់ឲ្យពួកសមាជិកក្នុងសាសនា គាំទ្រដល់អស់អ្នកណាដែលបានហៅឲ្យបំរើក្នុងសាសនាចក្រ ព្រមទាំងការ សំរេចចិត្តនានា ក្នុងសាសនាចក្រ ដែលតម្រូវការគាំទ្ររបស់គេ គឺតាមធម្មតាធ្វើឡើងដោយលើកដៃស្ដាំ ។

ព្រះយេស៊ូវគ្រីស្ទទ្រង់ឈរជាសិរសានៃសាសនាចក្ររបស់ទ្រង់ ។ តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នោះទ្រង់ណែនាំពួកអ្នកដឹកនាំ ក្នុងសាសនាចក្រ ចំពោះកិច្ចការ និងសេចក្ដីសំរេចសំខាន់ៗ ។ ប៉ុន្តែសមាជិកក្នុងសាសនាចក្រទាំងអស់គ្នាមានសិទ្ធិ និងឯកសិទ្ធក្នុងការគាំទ្រ ឬក៏មិនគាំទ្រនូវសកម្មភាព និងការសំរេចចិត្តនៃពួកអ្នកដឹកនាំរបស់គេ ។

ពួកជនទាំងអស់គ្នាក៏ទទួលព្រម, **និក្ខ.** ២៤:៣ (ជនគ. ២៧:១៨–១៩) ។ ពួកសាវក និងពួកអែលឌើរបានជួបជុំព្រមព្រៀងគ្នា, **កិច្ចការ** ១៥:២៥ ។ គ្មាននរណាអាចបានតែងតាំងឡើង ដោយគ្មានការអនុមតិពីសាសនាចក្រនោះឡើយ, **គ. និង ស.** ២០:៦៥–៦៦ ។ របស់ ទាំងអស់នឹងត្រូវបានសំរេច ដោយសារការយល់ព្រមទូទៅ, **គ. និង ស.** ២៦:២ (គ. និង ស. ២៨:១៣) ។ ចូរឲ្យបានសំរេចសព្វគ្រប់ តាមការយល់ព្រមព្រៀងគ្នា, **គ. និង ស.** ១០៤:២១ ។

**ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ** *សូមមើលផង* កុក; ទីសំគាល់អំពីពេលវេលា, ព្រះយេស៊ូវគ្រីស្ទ; ម៉ាកុក; អើម៉ាគេដូន

នៅដើមយុគសហស្សវត្សរ៍ ព្រះយេស៊ូវទ្រង់នឹងយាងមកលើផែនដី ។ ព្រឹត្តិការណ៍នេះនឹងគូសសំគាល់អំពីទីបញ្ចប់នៃការពិសោធន៍ មនុស្ស នៅលើផែនដីនេះ ។ ពួកទុច្ចរិតនឹងត្រូវបានដកចេញពីផែនដី ហើយពួក សុចរិតនឹងត្រូវបានលើកឡើងទៅលើពពក ក្នុងកាល ផែនដីត្រូវសំអាត ។ ទោះជាគ្មាននរណាដឹងដោយពិតប្រាកដថា ព្រះគ្រីស្ទនឹងយាងមក លើកទីពីរ នៅវេលាណាក្តី គង់តែទ្រង់បាន ប្រទានដល់យើងនូវ ទីសំគាល់ទាំងឡាយ ឲ្យមើលនូវអ្វីដែលប្រាប់ពីពេលវេលាដែលជិត មកដល់ដែរ (ម៉ាថាយ ២៤; យ.ស. — ម៉ាថាយ ១) ។

ខ្ញុំដឹងថាអ្នកដែលលោះខ្ញុំ ទ្រង់នឹងមកឈរនៅលើផែនដី នៅជំនាន់ក្រោយ, **យ៉ូប** ១៩:២៥ ។ គ្រប់ទាំងជង្គង់នឹងលុតចុះ ហើយគ្រប់ ទាំងអណ្តាត នឹងស្បថនៅមុខអញ, **អេសាយ** ៤៥:២៣ (គ. និង ស. ៨៨:១០៤) ។ កូនមនុស្សទ្រង់យាងមកក្នុង ពពកឰដ៏អាកាស, **ដានី.** ៧:១៣ (ម៉ាថាយ ២៦:៦៤; លូកា ២១:២៥–២៨) ។ គេនឹងគន់មើលអញ ដែលពួកគេបានចាក់, **សាការី** ១២:១០ ។ ម្នាក់នឹង សួរថា ចុះតើរបួសអ្វីនុះនៅដៃអ្នក? **សាការី** ១៣:៦ (គ. និង ស. ៤៥:៥១) ។ តើមានអ្នកឯណាធន់នៅបាន ក្នុងកាលដែលទ្រង់យាង មក? ត្បិតទ្រង់ប្រៀបដូចជាភ្លើងរបស់ជាងសំរង, **ម៉ាឡាគី** ៣:២ (៣ នីហ្វៃ ២៤:២; គ. និង ស. ១២៨:២៤) ។ កូនមនុស្សនឹងមកក្នុង សិរីល្អនៃ ព្រះវរបិតារបស់លោក, **ម៉ាថាយ** ១៦:២៧ (ម៉ាថាយ ២៥:៣១) ។ ឯត្រង់ថ្ងៃ និងពេលកំណត់ នោះគ្មានអ្នកណាដឹងទេ ជ្រាបតែព្រះវរបិតា នៃខ្ញុំប៉ុណ្ណោះ, **ម៉ាថាយ** ២៤:៣៦ (គ. និង ស. ៤៩:៧; យ.ស. — ម៉ាថាយ ១:៣៨–៤៨) ។ ព្រះយេស៊ូវនេះឯង ទ្រង់នឹងយាងមកវិញ តាមបែបដដែល ដូចអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ, **កិច្ចការ** ១:១១ ។ ព្រះអម្ចាស់ ទ្រង់នឹងយាងចុះ ពីស្ថានសួគ៌មក, **១ ធីម៉ូ.** ៤:១៦ ។ រីឯថ្ងៃនៃព្រះអម្ចាស់ នោះនឹងមកដូចជាចោរប្លន់ នៅពេលយប់, **២ ពេត្រុស** ៣:១០ ។ ព្រះអម្ចាស់ ទ្រង់យាងមក ជាមួយនឹងពួក បរិសុទ្ធទ្រង់ទាំងសល់សែន, **យូដាស** ១:១៤ ។ ទ្រង់យាងមកតាម ពពក នោះគ្រប់ទាំងភ្នែកនឹងឃើញទ្រង់, **វិវ.** ១:៧ ។ ព្រះយេស៊ូវទ្រង់ នឹងឈរ ដើម្បីជំនុំជំរះមនុស្សលោក, **៣ នីហ្វៃ** ២៧:១៤–១៨ ។ ចូររៀបចំ ចូររៀបចំ ត្បិតព្រះអម្ចាស់ នៅជិតបង្កើយ, **គ. និង ស.** ១:១២ ។ យើងនឹងសម្តែងខ្លួនឲ្យឃើញពីស្ថានសួគ៌ ដោយព្រះចេស្តា ហើយនឹងស្ថិតនៅលើផែនដីអស់មួយ ពាន់ឆ្នាំ, **គ. និង ស.** ២៩:៩–១២ ។ ចូរបន្លឺសម្លេងរបស់អ្នកឡើង ហើយស្រែកប្រាប់ពីការប្រែចិត្ត ដោយរៀបចំផ្លូវទទួលព្រះអម្ចាស់ សំរាប់ការយាងមកលើកទីពីររបស់ ទ្រង់, **គ. និង ស.** ៣៤:៥–១២ ។ យើងជាព្រះយេស៊ូវគ្រីស្ទ ហើយយើងនឹងមកឯព្រះវិហារបរិសុទ្ធ របស់យើងភ្លាម, **គ. និង ស.** ៣៦:៨ (គ. និង ស. ១៣៣:២) ។ ថ្ងៃនោះមកដល់យ៉ាងឆាប់ៗ ដែលអ្នករាល់គ្នានឹងមើលឃើញយើង ហើយនឹងស្គាល់ថាយើងជា ព្រះ, **គ. និង ស.** ៣៨:៨ ។ អ្នកណាដែលកោតខ្លាចដល់យើង នោះ នឹងទន្ទឹងចាំដល់ទីសំគាល់ទាំងឡាយ ពីការ យាងមកនៃកូនមនុស្ស, **គ. និង ស.** ៤៥:៣៩ ។ ព្រះភក្ត្រនៃព្រះអម្ចាស់នឹងត្រូវបានបើកឲ្យ ឃើញ, **គ. និង ស.** ៨៨:៩៥ ។ ថ្ងៃដ៏ធំ និងគួរ ស្ញែងខ្លាចនៃព្រះ អម្ចាស់ជិតមកដល់ហើយ, **គ. និង ស.** ១១០:១៦ ។ កាលព្រះ អង្គសង្គ្រោះ ទ្រង់លេចមក នោះយើងនឹងឃើញទ្រង់ ដូចជាទ្រង់ យ៉ាងនេះឯង, **គ. និង ស.** ១៣០:១ ។ ព្រះអង្គសង្គ្រោះ ទ្រង់នឹង ឈរនៅកណ្តាលរាស្ត្រទ្រង់ ហើយនឹងសោយរាជ្យ, **គ. និង ស.** ១៣៣:២៥ ។ តើអ្នកណាហ្ន៎ ដែលចុះមកពីព្រះដែល គង់នៅលើស្ថានសួគ៌ ស្លៀកពាក់ដោយសំពត់ពណ៌, **គ. និង ស.** ១៣៣:៤៦ (អេសាយ ៦៣:១) ។

**ការយាងឡើង** *សូមមើលផង* ការយាងមកលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ, ព្រះយេស៊ូវគ្រីស្ទ

ជាការចាកចេញជាផ្លូវការ របស់ព្រះអង្គសង្គ្រោះពីផែនដីនេះ ៤០ ថ្ងៃ ក្រោយពីដំណើររស់ឡើងវិញរបស់ទ្រង់ ។ ការយាងឡើងទៅ ចាប់ផ្តើម នឹងកន្លែងលើភ្នំដើមអូលីវ ក្នុងវត្តមានរបស់ពួកសិស្ស (ម៉ាកុស ១៦:១៩; លូកា ២៤:៥១) ។ នៅគ្រានោះ មានទេវតាពីររូប ពីស្ថានសួគ៌ បាន មកធ្វើទីបន្ទាល់ថា នៅពេលខាងមុខ ព្រះអម្ចាស់ទ្រង់នឹងយាងមកវិញ « តាមបែបដដែល » (កិច្ចការ ១:៩–១២) ។

**ការរាប់ជាសុចរិត, រាប់ជាសុចរិត** *សូមមើលផង* ការញែកចេញជាបរិសុទ្ធ, ដង្វាយធួន; ធ្វើឲ្យធួន

ដើម្បីឲ្យបានលើកលែងពីការដាក់ទោសចំពោះអំពើបាប ហើយរាប់ថា ឥតមានទោស ។ ជនម្នាក់ៗត្រូវបានរាប់ជាសុចរិត ដោយសារ ព្រះ គុណនៃព្រះអង្គសង្គ្រោះ តាមរយៈសេចក្តីជំនឿជឿដល់ទ្រង់ ។ សេចក្តី ជំនឿនេះ គឺបានបង្ហាញដោយសារការប្រែចិត្ត និងការគោរព តាមក្រិត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ ។ ដង្វាយ ធួននៃព្រះយេស៊ូវគ្រីស្ទ អាចនាំឲ្យមនុស្សលោកប្រែចិត្ត ហើយបានរាប់ ជាសុចរិត ឬលើកលែងពីការដាក់ទោស ដែលគេនឹងត្រូវទទួល ។

អស់ទាំងពួកអ៊ីស្រាអែលនឹងបានសុចរិតក្នុងព្រះអម្ចាស់, **អេសាយ** ៤៥:២៥ ។ មិនមែនពួកអ្នកដែលគ្រាន់តែស្តាប់ទេ ប៉ុន្តែគឺជាពួកអ្នក ដែលប្រព្រឹត្តតាមក្រិត្យវិន័យវិញ នឹងបានរាប់ជាសុចរិត, **រ៉ូម** ២:១៣ ។ មនុស្សបានរាប់ជាសុចរិត ដោយសារព្រះលោហិតនៃព្រះគ្រីស្ទ, **រ៉ូម** ៥:១–២, ៩ ។ អ្នករាល់គ្នាបានរាប់ជាសុចរិត ដោយនូវព្រះនាមនៃ ព្រះអម្ចាស់យេស៊ូវ, **១ កូរិន.** ៦:១១ ។ កាលបានយើងបានរាប់ ជា សុចរិត ដោយសារព្រះគុណទ្រង់ នោះឲ្យយើងបានត្រឡប់ជាអ្នក គ្រងមរតក, **ទីតុស** ៣:៧ ។ ចុះលោកអ័ប្រាហាំ ជាអយ្យកោយើង តើមិនបានរាប់ជាសុចរិតដោយការលោកប្រព្រឹត្តទេឬអី ? **យ៉ាកុប** (ព.ស.ថ.) ២:២១ ។ មនុស្សបានរាប់ជាសុចរិត ដោយសារការ ប្រព្រឹត្ត គឺមិនមែនដោយសារសេចក្តីជំនឿតែប៉ុណ្ណោះទេ, **យ៉ាកុប** (ព.ស.ថ.) ២:១៤–២៦ ។ តាមក្រិត្យវិន័យ នោះពុំមានសាច់ឈាម ណាបាន រាប់ជាសុចរិតឡើយ, **២ នីហ្វៃ** ២:៥ ។ អ្នកបំរើដ៏សុចរិតរបស់យើង នឹងរាប់មនុស្សជាច្រើនសុចរិត ត្បិតទ្រង់នឹងរងទោស ចំពោះអំពើ

ទុច្ចរិតរបស់គេ, **ម៉ូសាយ** ១៤:១១ (អេសាយ ៥៣:១១) ។ តើអ្នកអាចនិយាយបានទេថា សំលៀកបំពាក់របស់អ្នកបាន សំអាត ដោយសារព្រះគ្រីស្ទ ? **អាលម៉ា** ៥:២៧ ។ ការរាប់ជាសុចរិតតាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ នោះគឺត្រឹមត្រូវ, **គ. និង ស.** ២០:៣០–៣១ (គ. និង ស. ៨៨:៣៩) ។ ដោយសារព្រះវិញ្ញាណ នោះអ្នករាល់គ្នាត្រូវបានរាប់ថាសុចរិត, **ម៉ូសេ** ៦:៦០ ។

**ការរួបរួមតែមួយ** *សូមមើលផង* ក្រុមព្រះ, ព្រះ

ដើម្បីឲ្យមានគំនិត សេចក្ដីប៉ងប្រាថ្នា និងគោលដៅតែមួយ ជាមួយនឹងព្រះវរបិតារបស់យើង ដែលគង់នៅលើស្ថានសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ជាមុនសិន រួចសឹមរួមគ្នាជាមួយនឹងពួកបរិសុទ្ធផ្សេងៗទៀត ។

ដែលបងប្អូននៅមូលជាមួយគ្នា ដោយចិត្តព្រមព្រៀង នោះជាការល្អ, **ទំនុក.** ១៣៣:១ ។ ខ្ញុំហើយនិងព្រះវរបិតា គឺតែមួយព្រះអង្គទេ, **យ៉ូហាន** ១០:៣០ (គ. និង ស. ៥០:៤៣) ។ ព្រះយេស៊ូវទ្រង់បានអធិស្ឋាន ដើម្បីឲ្យមនុស្សទាំងអស់បានរួមគ្នាតែមួយ ដូចជាទ្រង់ និងព្រះវរបិតាទ្រង់ រួមតែមួយដែរ, **យ៉ូហាន** ១៧:១១–២៣ (៣ នីហ្វៃ ១៩:២៣) ។ ខ្ញុំទូន្មានដល់អ្នករាល់គ្នាថា កុំឲ្យមានសេចក្ដីបាក់បែកក្នុងពួកអ្នករាល់គ្នាឡើយ តែត្រូវឲ្យបានរួបរួមគ្នាយ៉ាងខ្ជាប់ខ្ជួនវិញ, **១ កូរិន.** ១:១០ ។ ចូរតាំងគំនិត និងចិត្តឲ្យបានម៉ឺងម៉ាត់ជាមួយគ្នាតែមួយ ត្រូវសាមគ្គីក្នុងកិច្ចការគ្រប់មុខ, **២ នីហ្វៃ** ១:២១ ។ ពួកបរិសុទ្ធគួរតែមានចិត្តចងក្រងរួមគ្នាដោយសាមគ្គី, **ម៉ូសាយ** ១៨:២១ ។ ព្រះយេស៊ូវទ្រង់បានអធិស្ឋានសូមការសាមគ្គី នៅក្នុងចំណោមពួកសិស្សរបស់ទ្រង់ដែលជាសាសន៍នីហ្វៃ, **៣ នីហ្វៃ** ១៩:២៣ ។ ពួក សិស្ស បានរួមគ្នាក្នុងការអធិស្ឋាន និងការតមអាហារយ៉ាងខ្លាំង, **៣ នីហ្វៃ** ២៧:១ ។ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះតែមួយ, **គ. និង ស.** ២០:២៧–២៨ (គ. និង ស. ៣៥:២; ៥០:៤៣) ។ គឺជាកាតព្វកិច្ចរបស់អ្នក ដើម្បីចូលរួមជាមួយ សាសនាចក្រដ៏ពិត, **គ. និង ស.** ២៣:៧ ។ អ្វីក៏ដោយដែលអ្នកសូម ដោយនូវសេចក្ដីជំនឿ ដោយរួមប្រជុំគ្នាអធិស្ឋាន នោះអ្នករាល់ គ្នានឹងបានទទួល, **គ. និង ស.** ២៩:៦ ។ បើសិនជាអ្នករាល់គ្នាមិនរួមគ្នាតែមួយទេ ឈ្មោះថាអ្នករាល់គ្នាពុំមែនជារបស់ផងយើងឡើយ, **គ. និង ស.** ៣៨:២៧ ។ ព្រះអម្ចាស់ទ្រង់បានហៅរាស្ត្រទ្រង់ថា ស៊ីយ៉ូន ពីព្រោះពួកគេមានចិត្តតែមួយ និងគំនិតតែមួយ, **ម៉ូសេ** ៧:១៨ ។

**ការរើសតាំង***សូមមើលផង* ការហៅ និងការរើសតាំង

ផ្អែកទៅតាមភាពសក្ដិសមមុនផែនដី នោះព្រះទ្រង់បានរើសអស់អ្នកណាដែលនឹងទៅជាពូជនៃអ័ប្រាហាំ និងវង្សអ៊ីស្រាអែល ហើយដែលនឹងក្លាយទៅជារាស្ត្រក្នុងសេចក្ដីសញ្ញា (ចោទិ. ៣២:៧–៩; អ័ប្រា. ២:៩–១១) ។ ប្រជាជនទាំងនេះបានទទួលព្រះពរ និងកាតព្វកិច្ចវិសេសៗ ដើម្បីឲ្យគេអាចផ្ដល់ពរដល់អស់ទាំងសាសន៍ក្នុងលោក (រ៉ូម ១១:៥–៧; ១ ពេត្រុស ១:២; អាលម៉ា ១៣:១–៥; គ. និង ស. ៨៤:៩៩) ។ ប៉ុន្តែ សូម្បីតែពួកអ្នកជំរើសទាំងនេះ ក៏ត្រូវតែបានហៅ ហើយរើសតាំងនៅក្នុងជីវិតនេះ ដើម្បីឲ្យបានទទួលសេចក្ដី សង្គ្រោះដែរ ។

**ការលះលែងគ្នា***សូមមើលផង* រៀបអាពាហ៍ពិពាហ៍, អាពាហ៍ពិពាហ៍

ជាការបណ្ដាច់អាពាហ៍ពិពាហ៍ដោយអំណាចច្បាប់ ខាងស៊ីវិល ឬខាងសាសនា ។ ស្របតាមព្រះគម្ពីរសញ្ញាថ្មី នោះព្រះទ្រង់អនុញ្ញាតឲ្យមានការលះលែងគ្នា ក្រោមល័ក្ខខណ្ឌខ្លះៗ ពីព្រោះតែអំពើរឹងរូសនៃចិត្តមនុស្ស ប៉ុន្តែដូចដែលព្រះយេស៊ូវទ្រង់បានពន្យល់ប្រាប់ថា « ពីដើមមកមិនមែនដូច្នោះទេ » (ម៉ាថាយ ១៩:៣–១២) ។ គម្ពីរឲ្យដំបូន្មានទាស់នឹងការលះលែងគ្នាទូទៅ ហើយបង្គាប់ឲ្យប្ដីប្រពន្ធស្រឡាញ់គ្នា ដោយសេចក្ដីសុចរិត (១ កូរិន. ៧:១០–១២; គ. និង ស. ៤២:២២) ។

**ការសងសឹក** *សូមមើលផង* សេចក្ដីខ្នាំង

ជាការសងសឹក ឬការតបស្នង ចំពោះរបួស ឬកំហុសអ្វីមួយ ។

ព្រះនៃអ្នករាល់គ្នា ទ្រង់នឹងយាងមកសងសឹក, **អេសាយ** ៣៥:៤ ។ ការសងសឹក នោះស្រេចនឹងអញ អញនឹងសងសឹកដល់គេ, **រ៉ូម** ១២:១៩ (មរមន ៣:១៥; ៨:២០) ។ ដាវនៃការសងសឹកព្យួរនៅលើពួកអ្នករាល់គ្នា, **មរមន** ៨:៤០–៤១ ។ យើងនឹងដាក់ការសងសឹកមកលើពួកទុច្ចរិត ព្រោះពួកគេមិនព្រមប្រែចិត្តសោះ, **គ. និង ស.** ២៩:១៧ ។ ព្រះអង្គសង្គ្រោះបានយាងមក នៅថ្ងៃនៃអំពើទុច្ចរិត និងការសងសឹក, **ម៉ូសេ** ៧:៤៥–៤៦ ។

**ការសង្កេតស្គាល់, អំណោយទានខាង***សូមមើលផង* អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ

គឺដើម្បីឲ្យយល់ ហើយដឹងនូវអ្វីៗ តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណ ។ អំណោយទានខាងការសង្កេតស្គាល់ ជាអំណោយទានមួយនៃព្រះវិញ្ញាណ ។ គឺមានទាំងការស្គាល់យ៉ាងជ្រាលជ្រៅអំពីចរិតនៃមនុស្ស និងប្រភព និងន័យនៃសេចក្ដីសម្ដែងខាងវិញ្ញាណផង ។

មនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះអម្ចាស់ ទ្រង់ទតចំពោះក្នុងចិត្តវិញ, **១ សាំយូ.** ១៦:៧ ។ វេទនាដល់ពួកអ្នក ដែលរាប់សេចក្ដីអាក្រក់ថាជាល្អ, **អេសាយ** ៥:២០ (២ នីហ្វៃ ១៥:២០) ។ សេចក្ដីខាងឯព្រះ ត្រូវពិចារណាខាងវិញ្ញាណវិញ, **១ កូរិន.** ២:១៤ ។ ឲ្យមនុស្សខ្លះនូវអំណោយទាននៃការសង្កេតស្គាល់អស់ទាំងវិញ្ញាណ, **១ កូរិន.** ១២:១០ ។ អាំម៉ុនអាចយល់គំនិតរបស់ទ្រង់, **អាលម៉ា** ១៨:១៨, ៣២ ។ សម្លេងតូចបានចាក់ទំលុះពួកអ្នកដែលបានឮ, **៣ នីហ្វៃ** ១១:៣ ។ ប្រយោជន៍កុំឲ្យអ្នករាល់គ្នាត្រូវគេ បញ្ឆោត នោះអ្នករាល់ត្រូវព្យាយាមស្វែងរកអំណោយទាននានាដែលវិសេសបំផុតចុះ, **គ. និង ស.** ៤៦:៨, ២៣ ។ ពួកមេដឹកនាំក្នុង សាសនាចក្រត្រូវបាន ប្រទានឲ្យចេះសង្កេតស្គាល់អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ, **គ. និង ស.** ៤៦:២៧ ។ រូបកាយនោះដែល បានពោរពេញទៅដោយពន្លឺ យល់គ្រប់ការណ៍ទាំងអស់, **គ. និង ស.** ៨៨:៦៧ ។ ម៉ូសេបានឃើញផែនដី គឺស្គាល់ដោយសារព្រះ វិញ្ញាណបរិសុទ្ធនៃព្រះ, **ម៉ូសេ** ១:២៧ ។

**ការសាងឡើងវិញនៃដំណឹងល្អ***សូមមើលផង* គ្រាកាន់កាប់ត្រួតត្រា; យ៉ូសែប ជុញ៉រ, សេចក្ដីក្បត់សាសនា; ស្ម៊ីធ

ជាការតាំងឡើងវិញរបស់ព្រះនូវសេចក្ដីពិត និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ នៅក្នុងចំណោមមនុស្សលោកនៅលើផែនដី ។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទត្រូវបានបាត់បង់ពីផែនដី តាមរយៈសេចក្ដីក្បត់សាសនា ដែលបានកើតឡើង បន្ទាប់ពីការងារបំរើនៃពួក សាវករបស់ព្រះគ្រីស្ទនៅលើផែនដី ។ សេចក្ដីក្បត់សាសនានោះចាំបាច់ធ្វើឲ្យមានការសាងឡើងវិញនៃដំណឹងល្អ ។ តាមរយៈការ និមិត្ត ការងារបំរើនៃពួកទេវតា និងវិវរណៈទាំងឡាយដល់មនុស្សលោកនៅលើផែនដី នោះព្រះទ្រង់បានសាងដំណឹងល្អឡើងវិញ ។ ការសាងឡើងវិញបានចាប់ផ្ដើមនឹងព្យាការីយ៉ូសែស្ម៊ីធ (យ.ស. — ប្រវត្តិ ១:១–៧៥; គ. និង ស. ១២៨:២០–២១) ហើយបានបន្តមក សព្វថ្ងៃនេះ តាមរយៈកិច្ចការនៃពួកព្យាការីដែលមានជីវិតនៅរស់របស់ព្រះអម្ចាស់ ។

ព្រះដំណាក់របស់ព្រះអម្ចាស់នឹងបានតាំងឡើងខ្ពស់លើភ្នំទាំងឡាយ, **អេសាយ** ២:២ (មីកា ៤:២; ២ នីហ្វៃ ១២:២) ។ ព្រះទ្រង់នឹងធ្វើការមួយយ៉ាងអស្ចារ្យ និងចំឡែក, **អេសាយ** ២៩:១៤ (២ នីហ្វៃ ២៥:១៧–១៨; គ. និង ស. ៤:១) ។ ព្រះទ្រង់នឹងតាំងនគរមួយឡើងដែលមិនត្រូវបំផ្លាញឡើយ, **ដានី.** ២:៤៤ ។ លោកអេលីយ៉ានឹងមក ហើយនឹងតាំងការទាំងអស់ឡើងវិញ, **ម៉ាថាយ** ១៧:១១ (ម៉ាកុស ៩:១២; គ. និង ស. ៧៧:១៤) ។ នឹងមានគ្រាតាំងរបស់ទាំងអស់ឡើងវិញ, **កិច្ចការ** ៣:២១ (គ. និង ស. ២៧:៦) ។ នៅក្នុងកាល ដែលពេលពេញកំណត់បានមកដល់ នោះព្រះទ្រង់នឹងបំព្រួមគ្រប់ការទាំងអស់, **អេភេ.** ១:១០ ។ ខ្ញុំក៏ឃើញទេវតាមួយទៀត ទាំងមានដំណឹងល្អដ៏នៅអស់កល្បជានិច្ច សំរាប់ថ្លែងប្រាប់, **វិវរ.** ១៤:៦ ។ ភាពពោរពេញនៃដំណឹងល្អនឹងបានមកដល់ពួកសាសន៍ដទៃ, **១ នីហ្វៃ** ១៥:១៣–១៨ ។ ពួកសាសន៍យូដានឹងត្រូវបានសាងឡើងវិញ នៅក្នុងសាសនាចក្រដ៏ពិត, **២ នីហ្វៃ** ៩:២ ។ សេចក្ដីពិតនឹងចេញមកនៅថ្ងៃចុងក្រោយ, **៣ នីហ្វៃ** ១៦:៧ ។ នៅលើអ្នកខ្ញុំសូមប្រគល់បព្វជិតភាពអើរ៉ុន, **គ. និង ស.** ១៣:១ (យ.ស. — ប្រវត្តិ ១:៦៩) ។ យើងបានប្រគល់កូនសោទាំងឡាយនៃនគរ នៅថ្ងៃចុងក្រោយបង្អស់; **គ. និង ស.** ២៧:៦, ១៣–១៤ (គ. និង ស. ១២៨:១៩–២១) ។ ចូរប្រមូល ពូជអំបូរអ៊ីស្រាអែលទាំងឡាយ ហើយសាងឡើងវិញនូវគ្រប់ទាំងអស់, **គ. និង ស.** ៧៧:៩ ។ កូនសោទាំងឡាយនៃគ្រាកាន់ កាប់ត្រួតត្រានេះ ត្រូវបានប្រគល់ឲ្យ, **គ. និង ស.** ១១០:១៦ (គ. និង ស. ៦៥:២) ។ បព្វជិតភាពត្រូវបានប្រទានឲ្យនៅគ្រាកាន់កាប់ត្រួតត្រានៃ ពេលពេញកំណត់, **គ. និង ស.** ១១២:៣០ ។ ខ្ញុំក៏ឃើញតួអង្គពីរ, **យ.ស. — ប្រវត្តិ** ១:១៧ ។ យើងនឹងបើកសំដែងដល់អ្នករាល់គ្នា នូវបព្វជិតភាព ដោយដៃនៃអេលីយ៉ា, **យ.ស. — ប្រវត្តិ** ១:៣៨ (ម៉ាឡាគី ៤:៥–៦) ។

**ការហៅ និងការរើសតាំង** *សូមមើលផង* ការរើសតាំង

ពួកអ្នកដើរតាមព្រះគ្រីស្ទដ៏សុចរិត អាចបានរាប់ចូលក្នុងចំណោមពួករើសតាំង ដែលបានទទួលការធានានូវភាពថ្កើងថ្កាន ។ ការហៅ និងការរើសតាំងនេះចាប់ផ្ដើមនឹងការប្រែចិត្ត និងបុណ្យជ្រមុជទឹក ។ គឺក្លាយជាពោរពេញ ក្នុងកាលពួកគេ « ខិតខំជឿនទៅមុខ ដោយ ទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត » (២ នីហ្វៃ ៣១:១៩–២០) ។ គម្ពីរហៅដំណើរនេះថា ធ្វើឲ្យការហៅ និងការរើសតាំងរបស់យើង បានពិតប្រាកដ (២ ពេត្រុស ១:៤–១១; គ. និង ស. ១៣១:៥–៦) ។

អ្នករាល់គ្នានឹងបានធ្វើជានគរដល់យើង ដែលសុទ្ធតែជាសង្ឃ, **និក្ខ.** ១៩:៥–៦ (វិវរ. ១:៦) ។ ព្រះទ្រង់បានរើសអ្នករាល់គ្នា តាំងពីដើមដំបូងមក ដើម្បីឲ្យបានសង្គ្រោះ, ២ ថែស្ស. ២:១៣ ។ ចូរឲ្យអ្នករាល់គ្នាមានចិត្តឧស្សាហ៍ ដើម្បីនឹងធ្វើឲ្យការហៅ ហើយរើសតាំងបានពិតប្រាកដ, **២ ពេត្រុស** ១:១០ ។ ព្រះអម្ចាស់ទ្រង់អាចភ្ជាប់អ្នកជារបស់ផងទ្រង់, **ម៉ូសាយ** ៥:១៥ ។ យើងធ្វើសេចក្ដីសញ្ញាជាមួយនឹងអ្នកថា អ្នកនឹងបានជីវិតដ៏នៅអស់កល្បជានិច្ច, **ម៉ូសាយ** ២៦:២០ ។ ពួកអ្នកដែលកាន់បព្វជិតភាពដ៏ស្មោះត្រង់ ពួកគេត្រឡប់ជា សាសនាចក្រ និងនគរ និងជាពួករើសតាំងនៃព្រះ, **គ. និង ស.** ៨៤:៣៣–៣៤ ។ ពាក្យព្យាករណ៍ដ៏ពិតជាង មានន័យពីមនុស្សដែល ដឹងថាខ្លួនបានភ្ជាប់ទុក ចំពោះជីវិតដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ១៣១:៥–៦ ។ យើងភ្ជាប់មកលើអ្នក នូវភាពថ្កើងថ្កានរបស់អ្នក, **គ. និង ស.** ១៣២:៤៩ ។

**ការអធិស្ឋាន** *សូមមើលផង* ថ្វាយបង្គំ, រំពឹងគិត; សូម; អាម៉ែន

ជាការទាក់ទងដោយគោរពជាមួយនឹងព្រះ នៅពេលជនណាម្នាក់ថ្លែងអំណរគុណ ហើយសូមព្រះពរទាំងឡាយ ។ ការអធិស្ឋានទាំង ឡាយត្រូវទូលទៅរកព្រះវរបិតារបស់យើង ដែលគង់នៅលើស្ថានសួគ៌ ដោយនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ បទអធិស្ឋានទាំង ឡាយអាចចេញសំដីឲ្យឮ ឬក៏ធ្វើនៅក្នុងចិត្ត ។ គំនិតទាំងឡាយនៃជនម្នាក់ៗ ក៏អាចរាប់ថាជាបទអធិស្ឋានបានដែរ បើសិនជាគេគិតសំដៅ ទៅរកព្រះ ។ បទចំរៀងនៃពួកសុចរិតក៏អាចរាប់ថាជាបទអធិស្ឋានថ្វាយព្រះដែរ (គ. និង ស. ២៥:១២) ។

គោលបំណងនៃការអធិស្ឋាន គឺមិនមែនដើម្បីប្រែប្រួលព្រះហឫទ័យនៃព្រះទេ ប៉ុន្តែដើម្បីសូមនូវព្រះពរទាំងឡាយដែលព្រះទ្រង់ប្រណី នឹងប្រទានឲ្យដល់យើង និងដល់អ្នកឯទៀត ប៉ុន្តែគឺយើងត្រូវតែសូមដើម្បីឲ្យបានទទួល ។

យើងរាល់គ្នាអធិស្ឋានទៅព្រះវរបិតា ដោយនូវព្រះនាមនៃព្រះគ្រីស្ទ (យ៉ូហាន ១៤:១៣–១៤; ១៦:២៣–២៤) ។ យើងពិតជាអាចអធិស្ឋាន ដោយនូវព្រះនាមនៃព្រះគ្រីស្ទ កាលណាការប្រាថ្នាយើងទាំងប៉ុន្មាន គឺជារបស់ផងព្រះគ្រីស្ទ (យ៉ូហាន ១៤:៧; គ. និង ស. ៤៦:៣០) ។ បន្ទាប់មក យើងសូមនូវអ្វីៗដែលត្រឹមត្រូវ នោះព្រះទ្រង់នឹងប្រទានឲ្យ (៣ នីហ្វៃ ១៨:២០) ។ ពាក្យអធិស្ឋានខ្លះមិនឆ្លើយតបទេ ពីព្រោះពាក្យទាំងនោះមិនមែនជាតំណាងខាងការប្រាថ្នានៃព្រះគ្រីស្ទឡើយ តែផុសឡើងពីសេចក្ដីលោភលន់នៃមនុស្សវិញ (យ៉ាកុប (ព.ស.ថ.) ៤:៣; គ. និង ស. ៤៦:៩) ។ ម្ល៉ោះហើយ

បើសិនជាយើងរាល់គ្នាសូមព្រះនូវអ្វីៗដែលមិនសុចរិត នោះនឹងត្រឡប់ទៅជាទោសដល់យើងវិញ (គ. និង ស. ៨៨:៦៥) ។

ហើយនៅជាន់នោះ មនុស្សទាំងឡាយចាប់តាំងអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់, **លោកុ.** ៤:២៦ ។ នៅទីអាសនានោះ អ័ប្រាហាំក៏អំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់, **លោកុ.** ១៣:៤ ។ អ្នកបំរើរបស់អ័ប្រាហាំបានអធិស្ឋានសូម ក្នុងការរកប្រពន្ធឲ្យអ៊ីសាក, **លោកុ.** ២៤:១០–១៩ ។ ព្រះទ្រង់បានហាមថា ខ្ញុំនឹងធ្វើបាបចំពោះព្រះអម្ចាស់ ដោយលែងអធិស្ឋានឲ្យអ្នករាល់គ្នា, **១ សាំយូ.** ១២:២៣ ។ ព្រះអម្ចាស់ទ្រង់ស្ដាប់សេចក្ដីអធិស្ឋានរបស់មនុស្សសុចរិត, **សុភា.** ១៥:២៩ ។ ឯងនឹងឃើញអញ កាលណាឯងស្វែងរកអញ ឲ្យអស់អំពីចិត្ត, **យេរេ.** ២៩:១២–១៣ ។ ចូរអធិស្ឋានឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នា, **ម៉ាថាយ** ៥:៤៤ (លូកា ៦:២៨; ៣ នីហ្វៃ ១២:៤៤) ។ ចូរអធិស្ឋានដល់ព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅទីលាក់កំបាំងចុះ, **ម៉ាថាយ** ៦:៥–៨ (៣ នីហ្វៃ ១៣:៥–៨) ។ ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះ, **ម៉ាថាយ** ៦:៩–១៣ (លូកា ១១:២; ៣ នីហ្វៃ ១៣:៩) ។ ចូរសូម នោះតែងនឹងឲ្យមកអ្នក, **ម៉ាថាយ** ៧:៧ (៣ នីហ្វៃ ១៤:៧; គ. និង ស. ៤:៧; ៦:៥; ៦៦:៩) ។ ព្រះយេស៊ូវយាងឡើងលើភ្នំដោយឡែក ដើម្បីនឹងអធិស្ឋាន, **ម៉ាថាយ** ១៤:២៣ ។ ចូរចាំយាម ហើយអធិស្ឋានចុះ ដើម្បីមិនឲ្យកើតសេចក្ដីល្បួងនាំចិត្តឡើយ, **ម៉ាថាយ** ២៦:៤១ (ម៉ាកុស ១៤:៣៨; ៣ នីហ្វៃ ១៨:១៥–១៨; គ. និង ស. ៣១:១២) ។ ត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ, **យ៉ាកុប** (ព.ស.ថ.) ១:៥–៦ (គ. និង ស. ៤២:៦៨; ៤៦:៧) ។ សេចក្ដីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់, **យ៉ាកុប** (ព.ស.ថ.) ៥:១៦ ។ ចូរស្ដាប់តាមព្រះវិញ្ញាណ ដែលបង្រៀនមនុស្សឲ្យអធិស្ឋាន, **២ នីហ្វៃ** ៣២:៨–៩ ។ ខ្ញុំបានអំពាវនាវដល់ព្រះអង្គ ដោយការអធិស្ឋានដ៏ខ្លាំង, **អេណុស** ១:៤ ។ ខ្ញុំបានតមអាហារ ហើយអធិស្ឋានជាច្រើនថ្ងៃ, **អាលម៉ា** ៥:៤៥–៤៦ (អាលម៉ា ២៦:២២) ។ គេបានអធិស្ឋានជា ច្រើនដង ហើយតមអាហារទៀត, **អាលម៉ា** ១៧:៣ ។ តើអ្នកចាំបានទេថា លោកស៊ីណូសបាននិយាយអំពីការអធិស្ឋាន ឬការថ្វាយបង្គំ ? **អាលម៉ា** ៣៣:៣ ។ ចូរបន្ទាបខ្លួន ហើយអធិស្ឋានជានិច្ច, **អាលម៉ា** ៣៤:១៨–២៧ ។ ចូរប្រឹក្សាជាមួយនឹងព្រះអម្ចាស់ នូវគ្រប់កិច្ច ការរបស់កូន, **អាលម៉ា** ៣៧:៣៧ ។ អ្នករាល់គ្នាត្រូវអធិស្ឋានដល់ព្រះវរបិតា ដោយនូវឈ្មោះយើងជានិច្ច, **៣ នីហ្វៃ** ១៨:១៩–២០ ។ ចូរអធិស្ឋានជាមួយគ្រួសាររបស់អ្នករាល់គ្នា, **៣ នីហ្វៃ** ១៨:២១ ។ ព្រះយេស៊ូវទ្រង់បានអធិស្ឋានដល់ព្រះវរបិតា, **៣ នីហ្វៃ** ១៩:៣១–៣៤ (៣ នីហ្វៃ ១៨:១៦; យ៉ូហាន ១៧) ។ ទ្រង់បានបញ្ជាពួកគេថា ពុំត្រូវឈប់អធិស្ឋាននៅក្នុងចិត្តរបស់គេឡើយ, **៣ នីហ្វៃ** ២០:១ ។ បើអ្នកនោះអធិស្ឋាន តែពុំបានធ្វើដោយចិត្តស្មោះត្រង់ទេ ការនោះនឹងពុំនាំផលប្រយោជន៍អ្វីដល់អ្នកនោះឡើយ, **មរ៉ូណៃ** ៧:៦–៩ ។ ចូរកុំសូមអ្វីដែលអ្នកមិនគួរសូមនោះឡើយ, **គ. និង ស.** ៨:១០ ។ ចូរអធិស្ឋានជានិច្ច ប្រយោជន៍ឲ្យអ្នកអាចក្លាយទៅជា អ្នកជំនះបាន, **គ. និង ស.** ១០:៥ ។ យើងបញ្ជាអ្នកថា ចូរអធិស្ឋានឲ្យឮ ព្រមទាំងនៅក្នុងចិត្ត, **គ. និង ស.** ១៩:២៨ ។ ព្រះវិញ្ញាណ ត្រូវបានប្រទានដល់អ្នក ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ0, **គ. និង ស.** ៤២:១៤ ។ អ្នកត្រូវទៅជំណាក់នៃការអធិស្ឋាន ហើយថ្វាយ បុណ្យរំឭករបស់អ្នកឡើង, **គ. និង ស.** ៥៩:៩ (ម៉ាថាយ ២១:១៣) ។ ឪពុកម្ដាយត្រូវបង្រៀនកូនចៅរបស់ខ្លួនឲ្យអធិស្ឋាន, **គ. និង ស.** ៦៨:២៨ ។ ព្រះអម្ចាស់ដ៏ជាព្រះរបស់ពួកគេ ក៏ក្រនឹងឮបទអធិស្ឋានទាំងឡាយរបស់ពួកគេ, **គ. និង ស.** ១០១:៧–៨ (ម៉ូសាយ ២១:១៥) ។ ចូរមានចិត្តរាបសា; ហើយព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងប្រទានចម្លើយដល់បទអធិស្ឋានទាំងឡាយរបស់អ្នក, **គ. និង ស.** ១១២:១០ ។ អ័ដាមត្រូវបានបញ្ជាឲ្យអំពាវនាវដល់ព្រះ ដោយនូវព្រះនាមនៃព្រះរាជបុត្រា, **ម៉ូសេ** ៥:៨ ។ ព្រះវរបិតា និងព្រះរាជបុត្រា បានលេចមកឯយ៉ូសែប ស្ម៊ីធ ចំពោះចម្លើយដល់ការអធិស្ឋានរបស់លោក, **យ.ស. —— ប្រវត្តិ** ១:១១–២០ ។

**ការឥតជំនឿ** *សូមមើលផង* ជំនឿ, ជឿ

ការខ្វះខាតខាងសេចក្ដីជំនឿជឿដល់ព្រះ និងដល់ដំណឹងល្អរបស់ទ្រង់ ។

ទ្រង់មិនបានធ្វើការឫទ្ធិបារមីជាច្រើននៅទីនោះទេ ពីព្រោះគេមិនជឿ, **ម៉ាថាយ** ១៣:៥៨ ។ ពីព្រោះតែការឥតជំនឿរបស់គេ ពួក សិស្សព្រះយេស៊ូវ ពុំអាចបណ្ដេញអារក្សចេញបានឡើយ, **ម៉ាថាយ** ១៧:១៤–២១ ។ សូមជួយចំពោះសេចក្ដីណា ដែលខ្ញុំមិនជឿ, **ម៉ាកុស** ៩:២៣–២៤ ។ ព្រះយេស៊ូវទ្រង់ក៏បន្ទោសពួកសិស្សរបស់ទ្រង់ ចំពោះការឥតជំនឿ និងចិត្តរឹងរូសរបស់គេ, **ម៉ាកុស** ១៦:១៤ ។ ដូចម្ដេចទៅសេចក្ដីដែលឥតជំនឿ តើនឹងធ្វើឲ្យសេចក្ដីជំនឿជឿដល់ព្រះ ទៅជាមិនកើតការឬអី ? **រ៉ូម** ៣:៣ ។ មនុស្សម្នាក់វិនាសទៅ គឺប្រសើរជាងសាសន៍ទាំងមូលត្រូវចុះអន់ថយ ហើយវិនាសក្នុងការឥតជំនឿ, **១ នីហ្វៃ** ៤:១៣ ។ លុះដល់ពេលពួកគេចុះអន់ថយ ក្នុង ការឥតជំនឿ នោះទ្រង់នឹងបណ្ដាលឲ្យគេត្រូវខ្ចាត់ខ្ចាយ ហើយត្រូវវាយ, **២ នីហ្វៃ** ១:១០–១១ (គ. និង ស. ៣:១៨) ។ ពីព្រោះតែការ ឥតជំនឿរបស់គេ នោះពួកគេពុំអាចយល់ព្រះបន្ទូលនៃព្រះបានឡើយ, **ម៉ូសាយ** ២៦:១–៥ ។ យើងពុំអាចបង្ហាញដល់ពួកសាសន៍យូដា នូវអព្ភូតហេតុដ៏មហិមាយ៉ាងនេះទេ ពីព្រោះតែការឥតជំនឿនៃពួកគេ, **៣ នីហ្វៃ** ១៩:៣៥ ។ ពេលកន្លងមកហើយ នោះគំនិតរបស់អ្នក ត្រូវបានងងឹត ពីព្រោះតែការឥតជំនឿ, **គ. និង ស.** ៨៤:៥៤–៥៨ ។

**កាលីឡេ**

នៅសម័យបុរាណ និងសម័យបច្ចុប្បន្ន គឺជាស្រុកខាងជើងបំផុតនៃអ៊ីស្រាអែល គឺនៅខាងលិចទន្លេយ័រដាន់ និងសមុទ្រកាលីឡេ ។ ស្រុកកាលីឡេមានចម្ងាយ ៩៧ គ.ម. ហើយមានទទឹង ៤៨ គ.ម. ។ កាលពីបុរាណ ស្រុកកាលីឡេមានដីដ៏ល្អៗ និងភូមិដ៏ណែន ណាប់នៅអ៊ីស្រាអែល ។ ផ្លូវធំៗដ៏សំខាន់ទាំងប៉ុន្មានដែលនាំទៅឯដាម៉ាសទៅឯស្រុកអេស៊ីព្ទ និងទៅឯភូមិភាគខាងកើតអ៊ីស្រាអែល នោះរត់កាត់ស្រុកកាលីឡេ ។ ធាតុអាកាសដ៏ល្អ និងដីដ៏មានជីជាតិបានផ្ដល់នូវដំណាំ ដូចជាអូលីវ ស្រូវសាលី ស្រូវឱក និងទំពាំង បាយជូរ ។ ការនេសាទនៅតាមសមុទ្រកាលីឡេផ្ដល់នូវទំនិញលក់ចេញ និងប្រភព

ខាងសម្បត្តិទ្រព្យជាច្រើន ។ ព្រះអង្គសង្គ្រោះ ទ្រង់បានចំណាយពេលជាយូរនៅស្រុកកាលីឡេ ។

ពន្លឺយ៉ាងធំនឹងភ្លឺឡើងក្នុងស្រុកកាលីឡេ, **អេសាយ** ៩:១–៣ (២ នីហ្វៃ ១៩:១–៣) ។ ព្រះយេស៊ូវទ្រង់យាងគ្រប់សព្វក្នុងស្រុកកាលីឡេ ទ្រង់ប្រកាស បង្រៀន និងប្រោសឲ្យជា, **ម៉ាថាយ** ៤:២៣ ។ ក្រោយពីព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ឡើងវិញ នោះទ្រង់បានលេចមក ឯស្រុកកាលីឡេ, **ម៉ាកុស** ១៤:២៨ (យ៉ូហាន ២១:១–១៤) ។ ល្បីអំពីព្រះយេស៊ូវសុសសាយទូទៅក្នុងស្រុកកាលីឡេ, **លូកា** ៤:១៤ ។ ព្រះយេស៊ូវទ្រង់បានចាប់ផ្ដើមសម្ដែងអព្ភូតហេតុនៅភូមិកាណា ក្នុងស្រុកកាលីឡេ, **យ៉ូហាន** ២:១១ ។

*សមុទ្រកាលីឡេ៖* សមុទ្រកាលីឡេស្ថិតនៅក្នុងភូមិភាគខាងជើង អ៊ីស្រាអែល ។ បានហៅថា សមុទ្រគេនេសារ៉ែត នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយជាបឹងគេនេសារ៉ែត ឬក៏សមុទ្រទីបេរាស នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ព្រះយេស៊ូវទ្រង់បានបង្រៀនបទបង្រៀនជាច្រើននៅទីនោះ (ម៉ាថាយ ១៣:២) ។ សមុទ្រមានរូបរាងដូចជាផ្លែជំពូ បណ្ដោយ ២០ គ.ម. និងទទឹង ១២ គ.ម. នៅកន្លែងធំបំផុត ។ វាស្ថិតនៅ ២០៧ ម. ទាបជាងផ្ទៃសមុទ្រ ដែលជួនកាលបណ្ដាលឲ្យអាកាសជុំវិញទៅជាក្ដៅក្រៃលែង ។ ខ្យល់ត្រជាក់បក់ចុះមកពីលើភ្នំ ហើយជួបនឹងខ្យល់ក្ដៅនៅលើទឹក តែងតែធ្វើឲ្យមានខ្យល់ព្យុះយ៉ាងឆាប់ៗ (លូកា ៨:២២–២៤) ។

**កាលែប**

ជាមនុស្សម្នាក់ក្នុងក្រុមដែលលោកម៉ូសេបានចាត់ឲ្យទៅរកស្រុកកាណាន ក្នុងឆ្នាំទី២ក្រោយពីនិក្ខមនំ ។ គាត់ និងយ៉ូស្វេប៉ុណ្ណោះ ដែលនាំមករបាយការណ៍ដំណឹងពិតអំពីស្រុក (ជនគ. ១៣:៦, ៣០; ១៤:៦–៣៨) ។ ពួកគេប៉ុណ្ណោះក្នុងអ្នកទាំងអស់ ដែលបានចេញពីស្រុកអេស៊ីព្ទ ដែលនៅរស់អស់រយៈពេល ៤០ ឆ្នាំ ក្នុងទីរហោស្ថាន (ជនគ. ២៦:៦៥; ៣២:១២; ចោទិ. ១:៣៦) ហើយបានចូលស្រុកកាណាន (យ៉ូស្វេ ១៤:៦–១៤; ១៥:១៣–១៩) ។

**កាល់វ៉ារី** *សូមមើល* គាល់កូថា

**កាសឡាទី, សំបុត្រដល់ពួក** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ មុនដំបូង គឺជាសំបុត្រមួយច្បាប់ដែលសាវកប៉ុលបានសរសេរទៅពួកបរិសុទ្ធ នៅស្រុកកាឡាទី ។ សេចក្ដីនៃសំបុត្រនេះ គឺថាសេរីភាពដ៏ពិតអាចរកបាន ដោយសារការរស់តាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ។ បើសិន ជាពួកបរិសុទ្ធទទួលយកការបង្រៀនទាំងឡាយនៃពួកគ្រីស្ទានសាសន៍យូដាដែលចេះតែគោរពតាមក្រិត្យវិន័យលោកម៉ូសេ នោះពួកគេ នឹងដាក់កំរិត ឬកំចាត់សេរីភាពដែលពួកគេរកបានក្នុងព្រះគ្រីស្ទចោល ។ នៅក្នុងសំបុត្រ ប៉ុលបានតាំងតំណែងរបស់លោកជាសាវក បានពន្យល់ប្រាប់អំពីគោលលទ្ធិនៃសេចក្ដីសុចរិត ដោយសេចក្ដីជំនឿ ហើយបានបញ្ជាក់នូវតម្លៃនៃសាសនាខាងវិញ្ញាណ ។

នៅជំពូកទី ១ និងទី ២ ប៉ុលបានថ្លែងពីការស្ដាយចំពោះដំណឹងដែលលោកបានទទួលអំពីសេចក្ដីក្បត់សាសនា នៅក្នុងចំណោមពួក កាឡាទី ហើយបានបញ្ជាក់ប្រាប់ពីតំណែងរបស់លោកនៅក្នុងចំណោមពួកសាវក ។ ជំពូកទី ៣ និងទី ៤ ពិគ្រោះអំពីគោលលទ្ធិនៃ សេចក្ដីជំនឿ និងកិច្ចការទាំងឡាយ ។ ជំពូកទី ៥និងទី ៦ មានការបង្រៀនអំពីផលប្រយោជន៍ទូទៅ អំពីគោលលទ្ធិនៃសេចក្ដីជំនឿ ។

**កាអ៊ីន** *សូមមើលផង* ធ្វើឃាតកម្ម; បក្សព័ន្ធសម្ងាត់, អ័ដាម; អេបិល

ជាកូនប្រុសរបស់លោកអ័ដាម និងនាងអេវ៉ា ដែលបានសម្លាប់អេបិលជាប្អូនប្រុស (លោកុ. ៤:១–១៦) ។

ដង្វាយរបស់គាត់ត្រូវព្រះអម្ចាស់ទ្រង់មិនទទួលស្គាល់, **លោកុ.** ៤:៣–៧ (ម៉ូសេ ៥:៥–៨; ១៨–២៦) ។ បានសម្លាប់អេបិល ជាប្អូន, **លោកុ.** ៤:៨–១៤ (ម៉ូសេ ៥:៣២–៣៧) ។ ព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសា និងគំនូសលើគាត់, **លោកុ.** ៤:១៥ (ម៉ូសេ ៥:៣៧–៤១) ។ លោកអ័ដាម និងនាងអេវ៉ា មានកូនប្រុសស្រីជាច្រើនមុនកាអ៊ីនកើត, **ម៉ូសេ** ៥:១–៣, ១៦–១៧ ។ បានស្រឡាញ់អារក្សសាតាំង ជាងស្រឡាញ់ព្រះ, **ម៉ូសេ** ៥:១៣, ១៨ ។ បានចូលក្នុងសេចក្ដីសញ្ញាដ៏ឥតបរិសុទ្ធជាមួយនឹងសាតាំង, **ម៉ូសេ** ៥:២៩–៣១ ។

**កិច្ចការ, ការប្រព្រឹត្ត**

ជាកិច្ចការរបស់ជនម្នាក់ ទោះជាល្អ ឬអាក្រក់ក្ដី ។ ជនគ្រប់រូបនឹងត្រូវបានជំនុំជំរះ តាមការប្រព្រឹត្តទាំងឡាយរបស់ខ្លួន ។

ព្រះអម្ចាស់ទ្រង់នឹងសងដល់មនុស្សទាំងឡាយ តាមការដែលគេប្រព្រឹត្ត, **សុភា.** ២៤:១២ ។ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខ មនុស្សលោក ដើម្បីឲ្យគេឃើញការល្អ ដែលអ្នកប្រព្រឹត្ត, **ម៉ាថាយ** ៥:១៦ (៣ នីហ្វៃ ១២:១៦) ។ អ្នកដែលធ្វើតាមព្រះហឫទ័យនៃព្រះ វរបិតារបស់ខ្ញុំ នោះនឹងចូលទៅក្នុងនគរស្ថានសួគ៌, **ម៉ាថាយ** ៧:២១ ។ សេចក្ដីជំនឿ បើគ្មានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ ហើយ, **យ៉ាកុប** (ព.ស.ថ.) ២:១៤–២៦ ។ ពួកគេនឹងត្រូវបានជំនុំជំរះចំពោះកិច្ចការទាំងឡាយរបស់ពួកគេ, **១ នីហ្វៃ** ១៥:៣២ (ម៉ូសាយ ៣:២៤) ។ យើងដឹងថា មានតែព្រះគុណទេ ទើបយើងបានសង្គ្រោះ បន្ទាប់ពីអ្វីៗទាំងអស់ ដែលយើងអាចធ្វើបាន, **២ នីហ្វៃ** ២៥:២៣ ។ ចូរបង្រៀនពួកគេ កុំឲ្យនឿយហត់ឲ្យសោះ នៅក្នុងកិច្ចការល្អ, **អាលម៉ា** ៣៧:៣៤ ។ គឺជាការចាំបាច់ថា មនុស្សនឹងបាន ទទួលការជំនុំជំរះតាមកិច្ចការរបស់ខ្លួន, **អាលម៉ា** ៤១:៣ ។ ដោយសារកិច្ចការរបស់គេ នោះអ្នករាល់គ្នានឹងស្គាល់ពួកគេ, **ម៉ូរ៉ូណៃ** ៧:៥ (គ. និង ស. ១៨:៣៨) ។ យើងជាព្រះអម្ចាស់ នឹងជំនុំជំរះមនុស្សលោកទាំងអស់ស្របតាមកិច្ចការរបស់ពួកគេ, **គ. និង ស.** ១៣៧:៩ ។

**កិច្ចការផ្សាយសាសនា** *សូមមើលផង* ដំណឹងល្អទាំងឡាយ; ផ្សាយ

ដើម្បីប្រាប់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដោយវាចា និងដោយគំរូ ។

ល្អណាស់ហ្ន៎ គឺជើងនៃអ្នកនោះ ដែលដើរលើភ្នំ ថ្លែងប្រាប់ពីសេចក្ដីសង្គ្រោះ, **អេសាយ** ៥២:៧ ។ អញនឹងស្វែងរកចៀមរបស់អញទាំងស៊ើបសួររកទាល់តែឃើញផង, **អេសេ.** ៣៤:១១ ។ ចូរផ្សាយដំណឹងទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ, **ម៉ាកុស** ១៦:១៥ (មរមន ៩:២២) ។ ស្រែបានក្រហមល្មមច្រូតហើយ, **យ៉ូហាន** ៤:៣៥ ។ ធ្វើដូចម្ដេចឲ្យមានអ្នកណាប្រាប់បាន លើកតែមានអ្នកណាចាត់ឲ្យគេទៅ, **រ៉ូម** ១០:១៥ ។ ចូរបង្រៀនគេនូវព្រះបន្ទូលនៃព្រះ ឲ្យអស់ពីសេចក្ដីព្យាយាម, **យ៉ាកុប** ១:១៩ ។ ព្រះអម្ចាស់ទ្រង់អនុញ្ញាតឲ្យអស់ទាំងសាសន៍បង្រៀនព្រះបន្ទូលរបស់ទ្រង់, **អាលម៉ា** ២៩:៨ ។ ដើម្បីឲ្យដំណឹងល្អអាចបានប្រកាសប្រាប់ ដោយពួកកំសោយ និងពួករាបទាប, **គ. និង ស.** ១:២៣ ។ កិច្ចការដ៏អស្ចារ្យនឹងចេញមកហើយ, **គ. និង ស.** ៤:១ ។ បើសិនជាអ្នកត្រូវធ្វើការអស់មួយជីវិតអ្នក ហើយបាននាំព្រលឹងតែមួយគត់មករកយើង នោះតើអ្នកនឹងមានសេចក្ដីអំណរដ៏មហិមាដល់ណាទៅ, **គ. និង ស.** ១៨:១៥ ។ ពួកដែលយើងបានរើសតាំង ឮសម្លេងរបស់យើង ហើយមិនពង្រឹងចិត្តរបស់ពួកគេឡើយ, **គ. និង ស.** ២៩:៧ ។ ចូរចេញទៅផ្សាយដំណឹងល្អរបស់យើងពីរនាក់ៗ, **គ. និង ស.** ៤២:៦ ។ សម្លេងត្រូវចេញពីកន្លែងនេះទៅ, **គ. និង ស.** ៥៨:៦៤ ។ ត្រូវបើកមាត់របស់អ្នក ក្នុងការ ប្រកាសប្រាប់ពីដំណឹងល្អរបស់យើង, **គ. និង ស.** ៧១:១ ។ ចូរប្រកាសប្រាប់សេចក្ដីពិត តាមវិវរណៈ និងព្រះបញ្ញត្តិទាំងឡាយ, **គ. និង ស.** ៧៥:៤ ។ មនុស្សណាដែលបានព្រមាន នោះត្រូវព្រមានអ្នកជិតខាងរបស់ខ្លួន, **គ. និង ស.** ៨៨:៨១ (គ. និង ស. ៣៨:៤០–៤១) ។ ព្រះអម្ចាស់ទ្រង់នឹងផ្គត់ផ្គង់ដល់ក្រុមគ្រួសារនៃអស់អ្នក7ណា ដែលផ្សាយដំណឹងល្អ, **គ. និង ស.** ១១៨:៣ ។ ពួកអ្នកបំរើនៃព្រះនឹងចេញទៅ, **គ. និង ស.** ១៣៣:៣៨ ។ ពួកអែលឌើរដែលស្មោះត្រង់ គឺកាលពួកគេចាកចេញពីជីវិតនេះទៅ នោះគេនៅតែបន្តការងាររបស់គេ, **គ. និង ស.** ១៣៨:៥៧ ។

**កិច្ចការរបស់ពួកសាវក** *សូមមើលផង* លូកា

គម្ពីរនេះគឺជាភាគទី ២ ក្នុងឯកសារពីរ ដែលលូកាបានសរសេរទៅដល់ថេវភីល ។ ភាគទី ១ នោះស្គាល់ថា ដំណឹងល្អតាមលោកលូកា ។ ជំពូកទី ១–១២ កត់ត្រាអំពីកិច្ចការសំខាន់ៗខាងការផ្សាយសាសនាខ្លះៗ របស់ពួកសាវក ១២ នាក់ នៅក្រោមការដឹកនាំ របស់ពេត្រុស បន្ទាប់ពីការសុគត និងដំណើររស់ឡើងវិញនៃព្រះអង្គសង្គ្រោះ ។ ជំពូកទី ១៣–២៨ បង្ហាញពីការធ្វើដំណើរ និងកិច្ចការ ខាងការផ្សាយសាសនាខ្លះៗរបស់សាវកប៉ុល ។

**កុក** *សូមមើលផង* ការយាងមកលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ, ម៉ាកុក

ជាស្ដេចនៃម៉ាកុក ។ អេសេគាលបានព្យាករថា កុកនឹងរុករានយកអ៊ីស្រាអែលនៅសម័យការយាងមកលើកទីពីរនៃព្រះអម្ចាស់ (អេសេ. ៣៨–៣៩) ។ ចម្បាំងមួយទៀតហៅថា ចម្បាំងនៃកុក និងម៉ាកុកនឹងកើតឡើងនៅចុងឆ្នាំសហស្សវត្សរ៍ (វិវរ. ២០:៧–៩; គ. និង ស. ៨៨:១១១–១១៦) ។

**កូនក្មេង, ពួកកូនក្មេង** *សូមមើលផង* ការទទួលខុសត្រូវ; គ្រួសារ; ចេះទទួលការខុសត្រូវ, ដង្វាយធួន; ទទួលការខុសត្រូវ, ធ្វើឲ្យធួន, ប្រទានពរ, បុណ្យជ្រមុជទឹកឲ្យទារក; ព្រះពរ — ការប្រទានពរដល់កូនក្មេង; មានពរ, សេចក្ដីសង្គ្រោះ — សេចក្ដីសង្គ្រោះនៃ កូនក្មេង

ជាជនមានវ័យក្មេង ដែលមិនទាន់ដល់ភាពគ្រប់ការនៅឡើយ ។ ពួកឪពុកម្ដាយត្រូវបង្ហាត់បង្រៀនកូនចៅរបស់ខ្លួន ឲ្យគោរពតាម ព្រះហឫទ័យរបស់ព្រះ ។ កូនក្មេងពុំមានបាបទេ រហូតដល់វាដល់អាយុចេះទទួលការខុសត្រូវ (មរ៉ូណៃ ៨:២២; គ. និង ស. ៦៨:២៧) ។

កូនចៅជាមរដកមកពីព្រះអម្ចាស់, **ទំនុក.** ១២៧:៣–៥ ។ ចូរបង្ហាត់កូនក្មេងឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្ត, **សុភា.** ២២:៦ ។ ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ, **ម៉ាថាយ** ១៩:១៤ ។ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួន, **អេភេ.** ៦:១–៣ (កូល៉ុស ៣:២០) ។ បើឥតមានការធ្លាក់ នោះលោកអ័ដាម និងនាងអេវ៉ានឹងពុំ អាចមានកូនចៅឡើយ, **២ នីហ្វៃ** ២:២២–២៣ ។ ចូរបង្រៀនកូនចៅឲ្យ ដើរតាមផ្លូវត្រឹមត្រូវ និងស្អាតស្អំ, **ម៉ូសាយ** ៤:១៤–១៥ ។ កូនក្មេងតូចៗ ក៏មានជីវិតដ៏នៅអស់កល្បជានិច្ច, **ម៉ូសាយ** ១៥:២៥ ។ ព្រះយេស៊ូវបានយកកូនក្មេងតូចៗ ហើយបានប្រទានពរដល់ពួកវា, **៣ នីហ្វៃ** ១៧:២១ ។ កូនចៅទាំងប៉ុន្មានរបស់អ្នកនឹងបានទទួល ការបង្រៀនពីព្រះអម្ចាស់ ហើយវារាល់គ្នានឹងមានសន្តិសុខជាបរិបូរ, **៣ នីហ្វៃ** ២២:១៣ (អេសាយ ៥៤:១៣) ។ កូនក្មេងតូចៗមិន បាច់មានការប្រែចិត្ត ឬបុណ្យជ្រមុជទឹកឡើយ, **មរ៉ូណៃ** ៨:៨–២៤ ។ កូនក្មេងតូចៗត្រូវបានប្រោសលោះ ចាប់តាំងពីកំណើតលោកិយ មកម្ល៉េះតាមរយៈបុត្រាបង្កើតតែមួយរបស់យើង, **គ. និង ស.** ២៩:៤៦–៤៧ ។ ឪពុកម្ដាយគួរតែបង្រៀនកូនចៅនូវគោលការណ៍ និង ការប្រតិបត្តិនៃដំណឹងល្អ, **គ. និង ស.** ៦៨:២៥, ២៧–២៨ ។ កូនក្មេងសុទ្ធតែបរិសុទ្ធតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទហើយ, **គ. និង ស.** ៧៤:៧ ។ ឪពុកម្ដាយបានត្រូវបញ្ជាឲ្យចញ្ចឹមកូនចៅរបស់ខ្លួន នៅក្នុងពន្លឺ និងសេចក្ដីពិត, **គ. និង ស.** ៩៣:៤០ ។ កូនក្មេង ទាំងអស់ដែលបានស្លាប់មុនគ្រប់អាយុទទួលខុសត្រូវ នោះត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល, **គ. និង ស.** ១៣៧:១០ ។

**កូនច្បង** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ, សិទ្ធិកូនច្បង

នៅសម័យពួកអយ្យកោពីចាស់បុរាណ កូនច្បងប្រុសបានទទួលសិទ្ធិកូនច្បង (លោកុ. ៤៣:៣៣) ហើយក៏បានទទួលការគ្រប់គ្រងគ្រួសារនៅពេលឪពុកស្លាប់ទៅ ។ កូនច្បងត្រូវមានភាពសក្ដិសមដើម្បីទទួលភារកិច្ចនេះ (១ របា ៥:១–២) ហើយអាច បាត់សិទ្ធិកូនច្បង ដោយសារសេចក្ដីឥតសុចរិត ។

នៅក្រោមក្រិត្យវិន័យលោកម៉ូសេ កូនច្បងប្រុសរាប់ទុកជាកូនរបស់ព្រះ ។ កូនច្បងបានទទួលរបស់របររបស់ឪពុកពីរភាគ (ចោទិ.

(២១:១៧) ។ បន្ទាប់ពីឪពុកគេស្លាប់ទៅ នោះគេត្រូវរក្សាម្ដាយ និងបងប្អូនស្រីៗរបស់គេ ។

កូនសត្វឈ្មោលបងគេក៏រាប់ទុកជារបស់ផងព្រះដែរ ។ សត្វស្អាតៗបានយកមកធ្វើយញ្ញបូជា រីឯសត្វមិនស្អាតៗវិញ នោះអាចយកមកសំអាត ឬលក់ ឬក៏សម្លាប់ចោល (និក្ខ. ១៣:២, ១១–១៣; ៣៤:១៩–២០; លេវី. ២៧:១១–១៣, ២៦–២៧) ។

កូនច្បងបានធ្វើជាតំណាងព្រះយេស៊ូវគ្រីស្ទ និងការងារបំរើរបស់ទ្រង់នៅលើផែនដី ដោយរំឭកដល់ប្រជាជនថា ព្រះមែស៊ីដ៏ធំ នឹងយាងមក (ម៉ូសេ ៥:៤–៨; ៦:៦៣) ។

ព្រះយេស៊ូវជាកូនច្បងក្នុងកូនចៅវិញ្ញាណទាំងឡាយរបស់ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា នៅក្នុងសាច់ឈាម ហើយជាអ្នកទីមួយ ដែលមានព្រះជន្មរស់ពីស្លាប់ ក្នុងដំណើររស់ឡើងវិញ (កូល៉ុស ១:១៣–១៨) ។ ពួកបរិសុទ្ធដែលស្មោះត្រង់នឹងក្លាយទៅជាសមាជិកក្នុងសាសនាចក្រនៃកូនច្បង នៅភាពអស់កល្បជានិច្ច (គ. និង ស. ៩៣:២១–២២) ។

កូនប្រុសៗរបស់អ្នកដែលកើតជាដំបូង នោះត្រូវថ្វាយដល់យើង, **និក្ខ.** ២២:២៩ ។ យើងបានញែកអស់ទាំងកូនច្បងក្នុងសាសន៍ អ៊ីស្រាអែលចេញទុកសំរាប់យើង, **ជនគ.** ៣:១៣ ។ ដើម្បីឲ្យទ្រង់បានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន, **រ៉ូម** ៨:២៩ ។ ទ្រង់ឲ្យ ព្រះរាជបុត្រាមកក្នុងលោកិយ, **ហេព្រើរ** ១:៦ ។ ពួកគេនេះហើយដែលជាសាសនាចក្រនៃកូនច្បង, **គ. និង ស.** ៧៦:៥៤, ៩៤ ។ សិទ្ធិនោះត្រូវបានប្រគល់មកលើខ្ញុំ ពីពួកអយ្យកោ គឺជាសិទ្ធិនៃកូនច្បង, **អ័ប្រា.** ១:៣ ។

**កូនចៀមនៃព្រះ** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, បុណ្យរំលង, ព្រះយេស៊ូវគ្រីស្ទ

ជាព្រះនាមមួយថ្វាយដល់ព្រះអង្គសង្គ្រោះ ដែលសំដៅដល់ព្រះយេស៊ូវជាដង្វាយបូជាជំនួសយើងទាំងអស់គ្នា ។

ទ្រង់ត្រូវគេនាំមកដូចជាកូនចៀមដឹកទៅសម្លាប់, **អេសាយ** ៥៣:៧ (ម៉ូសាយ ១៤:៧) ។ នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក, **យ៉ូហាន** ១:២៩ (អាលម៉ា ៧:១៤) ។ អ្នករាល់គ្នាត្រូវបានលោះដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទ ទុកដូចជាឈាមនៃកូនចៀមឥតខ្ចោះ, **១ ពេត្រុស** ១:១៨–២០ ។ កូនចៀមដែលគេបានសម្លាប់ នោះគួរសម, **វិវ.** ៥:១២ ។ យើងរាល់គ្នាឈ្នះសាតាំង ដោយសារឈាមនៃកូនចៀម, **វិវ.** ១២:១១ ។ សំលៀកបំពាក់ទាំងនេះបានលាងជំរះឲ្យស ដោយឈាមនៃកូនចៀម ដោយ សារសេចក្ដីជំនឿរបស់គេចំពោះទ្រង់, **១ នីហ្វៃ** ១២:១១ ។ កូនចៀមនៃព្រះ គឺជាព្រះរាជបុត្រានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ហើយគឺជា ព្រះអង្គសង្គ្រោះនៃមនុស្សលោក, **១ នីហ្វៃ** ១៣:៤០ (១ នីហ្វៃ ១១:២១) ។ ចូរអំពាវនាវយ៉ាងព្យាយាមដល់ព្រះវរបិតា ដោយនូវ ព្រះនាមនៃព្រះយេស៊ូវ ក្រែងអ្នករាល់គ្នាអាចបានលាងជំរះដោយឈាមនៃកូនចៀម, **មរមន** ៩:៦ (វិវ. ៧:១៤; អាលម៉ា ៣៤:៣៦) ។ កូនមនុស្ស កូនចៀមដែលត្រូវបានប្រហារតាំងពីកំណើតលោកិយមកម្ល េះ, **ម៉ូសេ** ៧:៤៧ ។

**កូនចៅព្រះគ្រីស្ទ** *សូមមើលផង* កើតពីព្រះ; កើតម្ដងទៀត, បង្កើត; បុត្រាបុត្រីនៃព្រះ, ព្រះយេស៊ូវគ្រីស្ទ

អស់អ្នកណាដែលទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

អ្នកណាដែលនឹងបន្ទាបខ្លួន ឲ្យបានដូចកូនតូចនេះ អ្នកនោះឯងឈ្មោះថាធំជាងគេបំផុត, **ម៉ាថាយ** ១៨:១–៤ ។ ចូរអ្នករាល់គ្នាជឿ ដល់ពន្លឺ ដើម្បីឲ្យបានធ្វើជាកូនពន្លឺ, **យ៉ូហាន** ១២:៣៦ ។ សម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយទៅដូចជាកូនក្មេង, **ម៉ូសាយ** ៣:១៩; ២៧:២៥–២៦ ។ មកពីសេចក្ដីសញ្ញា អ្នករាល់គ្នានឹងត្រូវបានហៅថាជាកូនចៅនៃព្រះគ្រីស្ទ, **ម៉ូសាយ** ៥:៧ ។ បើអ្នករាល់ គ្នាក្ដាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ នោះអ្នកប្រាកដជាកូននៃព្រះគ្រីស្ទ, **មរ៉ូណៃ** ៧:១៩ ។ យើងក៏នឹងប្រទានដល់អស់មនុស្សជាច្រើន ណាដែលនឹងទទួលយើង នូវអំណាចដើម្បីត្រឡប់ទៅជាកូនរបស់យើង, **គ. និង ស.** ៣៩:៤ ។ កុំឲ្យខ្លាចឡើយ កូនក្មេងតូចៗអើយ ត្បិតអ្នក រាល់គ្នាជារបស់ផងយើង, **គ. និង ស.** ៥០:៤០–៤១ ។ អ្នកក្លាយទៅតែមួយក្នុងយើង គឺជាកូននៃព្រះ, **ម៉ូសេ** ៦:៦៨ ។

**កូនចៅនៃព្រះ** *សូមមើល* បុត្រាបុត្រីនៃព្រះ, មនុស្ស, មនុស្សលោក

**កូនចៅអ៊ីស្រាអែល** *សូមមើល* អ៊ីស្រាអែល

**កូនេលាស** *សូមមើលផង* ពេត្រុស, មេទ័ព; សាសន៍ដទៃ

ជាមេទ័ពម្នាក់ពីសេសារា ដែលពេត្រុសបានធ្វើបុណ្យជ្រមុជទឹកឲ្យ (កិច្ចការ ១០) ។ លោកប្រហែលជាសាសន៍ដទៃទីមួយ ដែលចូលសាសនាចក្រ ដោយមិនចាំបាច់ប្រែចូលសាសនាយូដាជាមុនសិន ។ បុណ្យជ្រមុជទឹករបស់កូនេលាស និងគ្រួសារលោកបានធ្វើជាសញ្ញាបើកផ្លូវឲ្យដំណឹងល្អបានផ្សាយដល់ពួកសាសន៍ដទៃ ។ ពេត្រុសជាមេសាវក ដែលកាន់កូនសោនៃនគរព្រះ នៅលើផែនដីនៅគ្រានោះ ក៏បានដឹកនាំការផ្សាយសាសនានេះ ។

**កូនមនុស្ស** *សូមមើលផង* ក្រុមព្រះ; ព្រះ; ព្រះយេស៊ូវគ្រីស្ទ

ជាព្រះនាម ដែលព្រះយេស៊ូវគ្រីស្ទប្រើ នៅពេលមានព្រះបន្ទូលអំពីព្រះអង្គទ្រង់ (លូកា ៩:២២; លូកា ២១:៣៦) ។ កូនមនុស្សមាន ន័យថាកូនមនុស្សនៃបរិសុទ្ធភាព ។ មនុស្សនៃបរិសុទ្ធភាព គឺជាព្រះនាមមួយនៃព្រះដ៏ជាព្រះវរបិតា ។ នៅពេលព្រះយេស៊ូវទ្រង់ហៅ ព្រះអង្គទ្រង់ថាកូនមនុស្ស នោះគឺជាការថ្លែងបើកមុខ អំពីការទាក់ទងដ៏ឧត្ដមរបស់ទ្រង់ ជាមួយនឹងព្រះវរបិតា ។ ព្រះនាមនេះប្រទះ ឃើញជាញឹកញាប់នៅក្នុងដំណឹងល្អទាំងឡាយ ។ វិវរណៈនៅថ្ងៃចុងក្រោយ បញ្ជាក់ប្រាប់អំពីន័យដ៏ពិសេស និងពិសិដ្ឋភាពអំពីព្រះនាម នៃព្រះអង្គសង្គ្រោះនេះ (គ. និង ស. ៤៥:៣៩; ៤៩:៦; ២២; ៥៨:៦៥; ម៉ូសេ ៦:៥៧) ។

***កូនសោទាំងឡាយនៃបព្វជិតភាព*** *សូមមើលផង*
ការកាន់កាប់ត្រួតត្រា; គណៈប្រធានទីមួយ; បព្វជិតភាព

កូនសោទាំងឡាយ គឺជាសិទ្ធរបស់គណៈប្រធាន ឬជាអំណាចដែលព្រះទ្រង់បានប្រទានដល់មនុស្សឲ្យដឹកនាំ ត្រួតត្រា ហើយគ្រប់គ្រងបព្វជិតភាពនៃព្រះនៅលើផែនដី ។ ពួកអ្នកកាន់បព្វជិតភាព ដែលបានហៅឲ្យកាន់មុខងារនៃគណៈប្រធាន នោះទទួលកូនសោទាំង ឡាយពីពួកអ្នកដែលមានសិទ្ធិអំណាចនៅលើគេ ។ ពួកអ្នកកាន់បព្វជិតភាពត្រូវប្រើប្រាស់បព្វជិតភាព នៅក្នុងកំរិត ដែលបានអនុញ្ញាត ដោយ ពួកអ្នកដែលកាន់កូនសោទាំងឡាយ ។ ប្រធាននៃសាសនាចក្រកាន់កូនសោទាំងអស់នៃបព្វជិតភាព (គ. និង ស. ១០៧:៦៥–៦៧, ៩១–៩២; ១៣២:៧) ។

ពេត្រុសបានទទួលកូនសោទាំងឡាយនៃនគរ, **ម៉ាថាយ** ១៦:១៩ ។ មីកែល (អ័ដាម) បានទទួលកូនសោទាំងឡាយនៃសេចក្ដីសង្គ្រោះនៅក្រោមការដឹកនាំពីព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ៧៨:១៦ ។ កូនសោទាំងឡាយនៃនគរ ត្រូវជារបស់ផងគណៈប្រធានទីមួយរហូត, **គ. និង ស.** ៨១:២ ។ បព្វជិតភាពមិលគីស្សាដែកកាន់កូនសោនៃសេចក្ដីអាថ៌កំបាំងទាំងឡាយនៃចំណេះវិជ្ជាពីព្រះ, **គ. និង ស.** ៨៤:១៩ ។ យ៉ូសែប ស៊្មីធ និងអូលីវើរ ខៅឌើរីបានទទួលកូនសោទាំងឡាយអំពីការប្រមូលសាសន៍អ៊ីស្រាអែល, អំពីដំណឹងល្អនៃលោកអ័ប្រាហាំ និងអំពីអំណាចនៃការបិទភ្ជាប់, **គ. និង ស.** ១១០:១១–១៦ ។ កូនសោពិសេសៗត្រូវបានកាន់ដោយពួកសាវក១២នាក់, **គ. និង ស.** ១១២:១៦ ។ គណៈប្រធានទីមួយ និងពួក១២នាក់ កាន់កូនសោទាំងឡាយនៃគ្រាកាន់កាប់ត្រួតត្រានៅពេលពេញកំណត់, **គ. និង ស.** ១១២:៣០–៣៤ ។ ពួកអ្នកកាន់តំណែងក្នុងបព្វជិតភាព គេកាន់កូនសោទាំងឡាយ, **គ. និង ស.** ១២៤:១២៣ ។ អ្នកណាដែលមាន កូនសោទាំងឡាយ នោះអាចបានការចេះដឹង, **គ. និង ស.** ១២៨:១១ ។ បព្វជិតភាពអើរ៉ុនកាន់កូនសោទាំងឡាយ ខាងការបំរើរបស់ ពួកទេវតា និងដំណឹងល្អខាងការប្រែចិត្ត និងបុណ្យជ្រមុជទឹក, **យ.ស. — ប្រវត្តិ** ១:៦៩ (គ. និង ស. ១៣) ។

***កូម៉ូរ៉ា*** *សូមមើលផង* សូដុំម

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាទីក្រុងដ៏ទុច្ចរិតមួយ ដែលព្រះអម្ចាស់ទ្រង់បានបំផ្លាញចោល, លោកុ. ១៩:១២–២៩ ។

***កូរិនថូស, សំបុត្រដល់ពួក*** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាគម្ពីរពីរក្បាលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ មុនដំបូង គ្រាន់តែជាសំបុត្រដែលប៉ុលបានសរសេរទៅពួកបរិសុទ្ធ នៅឯកូរិនថូស ដើម្បីកែទម្រង់ ការឥតរបៀបនៅចំណោមពួកគេ ។ ពួកកូរិនថូសបានរស់នៅក្នុងសង្គមមួយ ដែលទុច្ចរិតខាងសីលធម៌ ។

*កូរិនថូសទី១៖* ជំពូកទី ១ មានពាក្យសួរសុខទុក្ខ និងពាក្យអរគុណពីប៉ុល ។ ជំពូកទី ២–៦ ជាការប្រដៅរបស់ប៉ុល អំពីកំហុសរបស់ពួកបរិសុទ្ធនៅកូរិនថូស ។ ជំពូកទី ៧–១២ ជាចម្លើយរបស់ប៉ុលចំពោះសំណួរខ្លះៗ ។ ជំពូកទី ១៣–១៥ ស្ដីអំពីសេចក្ដីសប្បុរស អំណោយទានខាងវិញ្ញាណ និងដំណើររស់ឡើងវិញ ។ ជំពូកទី ១៦ ជាការទូន្មានរបស់ប៉ុល ឲ្យឈរយ៉ាងមាំមួនក្នុងសេចក្ដីជំនឿ ។

*កូរិនថូសទី២៖* ជំពូកទី ១ មានពាក្យសួរសុខទុក្ខ និងពាក្យអរគុណពីប៉ុល ។ ជំពូកទី ២ មានពាក្យទូន្មានផ្ទាល់ដល់ទីតុស ។ ជំពូកទី ៣–៧ ថែងអំពីព្រះចេស្ដានៃដំណឹងល្អ ក្នុងជីវិតនៃពួកបរិសុទ្ធ និងពួកមេដឹកនាំគេ ។ ជំពូកទី ៨–៩ ទូន្មានពួកបរិសុទ្ធឲ្យដាក់ទានទៅ អ្នកក្រីក្រ ដោយមានចិត្តរីករាយ ។ ជំពូកទី ១០–១២ ជាការអះអាងខាងមុខងាររបស់ប៉ុល ជាសាវកម្នាក់ ។ ជំពូកទី ១៣ ជាពាក្យទូន្មានឲ្យបានល្អឥតខ្ចោះ ។

***កូរិអានតុន*** *សូមមើលផង* កូនប្រុសរបស់អាលម៉ា, អាលម៉ា

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសរបស់អាលម៉ា ដែលជាកូនប្រុសរបស់អាលម៉ា ។

បានទៅឯពួកសាសន៍សូរ៉ាំ, **អាលម៉ា** ៣១:៧ ។ បោះបង់ចោលការបង្រៀន ដើម្បីទៅតាមស្រីខូចម្នាក់, **អាលម៉ា** ៣៩:៣ ។ អាលម៉ា បានបង្រៀនគាត់ អំពីស្ថានភាពរស់នៅក្រោយពីសេចក្ដីស្លាប់ ដំណើររស់ឡើងវិញ និងដង្វាយធួន, **អាលម៉ា** ៣៩–៤២ ។ ត្រូវបានហៅឲ្យទៅផ្សាយសាសនាជាថ្មីទៀត, **អាលម៉ា** ៤២:៣១ ។ បានចុះសំពៅទៅដែនដីខាងជើង, **អាលម៉ា** ៦៣:១០ ។

***កូរិអានទុមើរ*** *សូមមើលផង* ពួកសាសន៍យ៉ារេឌ

នៅក្នុងព្រះគម្ពីរមរមន ជាស្ដេចនៃសាសន៍យ៉ារេឌ ហើយជាសាសន៍យ៉ារេឌតែមួយគត់ដែលបាននៅរស់ ។

ត្រូវបានជួបដោយប្រជាជនសារ៉ាហិមឡា, **អោមណៃ** ១:២១ ។ ជាស្ដេចលើដែនដីទាំងមូល, **អេធើរ** ១២:១–២ ។ ត្រូវបានចាប់យកទៅដោយសារេឌ ហើយត្រូវបានរំដោះដោយពួកបុត្រារបស់ទ្រង់, **អេធើរ** ១៣:២៣–២៤ ។ បានច្បាំងនឹងសត្រូវជាច្រើន, **អេធើរ** ១៣:២៨–១៤:៣១ ។ បានប្រែចិត្ត, **អេធើរ** ១៥:៣ ។ បានច្បាំងចម្បាំងចុងក្រោយបង្អស់ជាមួយនឹងស៊ិស, **អេធើរ** ១៥:១៥–៣២ ។

***កូរីហូរ*** *សូមមើលផង* អ្នកទទឹងនឹងព្រះគ្រីស្ទ

ជាអ្នកទទឹងនឹងព្រះគ្រីស្ទម្នាក់ នៅក្នុងព្រះគម្ពីរមរមន ដែលបានតវ៉ារកភស្តុតាងទីសំគាល់អំពីព្រះចេស្ដានៃព្រះ; ព្រះអម្ចាស់ទ្រង់ បានបណ្ដាលឲ្យកូរីហូរទៅជាគ (អាលម៉ា ៣០:៦–៦០) ។

***កូល៉ុស, សំបុត្រដល់ពួក*** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាគម្ពីរមួយក្នុងព្រះគម្ពីរសញ្ញាថ្មី ។ មុនដំបូង គឺជាសំបុត្រមួយច្បាប់ដែលសាវកប៉ុល បានសរសេរដល់ពួកកូល៉ុស ក្រោយពីលោក អេប៉ាប្រាស ជាអ្នកផ្សាយដំណឹងល្អ នៃសាសនាចក្រនៅកូស៊ុស បានមក

ជួបនឹងលោក (កូល៉ុស ១:៧–៨) ។ អេប៉ាប្រាសប្រាប់ប៉ុលថា ពួកកូល៉ុស កំពុងតែធ្លាក់ទៅក្នុងកំហុសដ៏ធ្ងន់ — គេគិតថាខ្លួនគេគ្រាន់បើជាងមនុស្សឯទៀត ពីព្រោះគេកាន់តាមពិធីបរិសុទ្ធខាងក្រៅខ្លះៗយ៉ាងប្រយ័ត្នប្រយែង (កូល៉ុស ២:១៦) គឺដោយអត់នូវសេចក្ដីប្រាថ្នាខាងសាច់ឈាមខ្លះ ហើយថ្វាយបង្គំពួកទេវតា (កូល៉ុស ២:១៨) ។ អំពើទាំងនេះ ធ្វើឲ្យពួកកូល៉ុស គិតថាខ្លួនគេបានញែកចេញជាបរិសុទ្ធ ។ គេក៏គិតថា គេយល់នូវការអាថ៌កំបាំងនៃ សាកលលោក ជាងសមាជិកដទៃទៀតក្នុងសាសនាចក្រ ។ នៅក្នុងសំបុត្រលោក នោះ ប៉ុលបានកែតម្រូវគេ ដោយបង្រៀនគេថា សេចក្ដីប្រោសលោះបានមកតាមរយៈព្រះគ្រីស្ទប៉ុណ្ណោះ ហើយពួកយើងត្រូវមានប្រាជ្ញាវាងវៃ ហើយបំរើទ្រង់ ។

ជំពូកទី១ គឺជាការសួរសុខទុក្ខរបស់ប៉ុលដល់ពួកកូល៉ុស ។ ជំពូកទី ២–៣ ស្ដីអំពីគោលលទ្ធិ ហើយមានពាក្យសម្ដែងខ្លះ អំពីព្រះគ្រីស្ទថា ជាព្រះដ៏ប្រោសលោះ ការអន្តរាយនៃការថ្វាយបង្គំក្លែងក្លាយ ហើយនិងសារៈសំខាន់អំពីដំណើររស់ឡើងវិញ ។ ជំពូកទី ៤ បង្រៀនថា ពួកបរិសុទ្ធត្រូវមានប្រាជ្ញាវាងវៃគ្រប់ជំពូក ។

**កូលិយ៉ាត** *សូមមើលផង* ដាវីឌ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាមនុស្សមាឌធំម្នាក់នៃសាសន៍ភីលីស្ទីន ដែលបបួលប្រជែងនឹងពួកទាហានសាសន៍អ៊ីស្រាអែល ។ ដាវីឌបានទទួលការប្រជែង ហើយបានសម្លាប់វា ដោយជំនួយពីព្រះអម្ចាស់ (១ សាំយូ. ១៧) ។

**កូឡុប**

ជាតារាមួយដែលនៅជិតបល្ល័ង្កព្រះជាងគេ (អ័ប្រា. ៣:២–៣, ៩) ។

អ័ប្រាហាំបានឃើញកូឡុប និងតារាទាំងឡាយ, **អ័ប្រា.** ៣:២–១៨ ។ របៀបរៀបរាប់ពេលវេលារបស់ព្រះអម្ចាស់ស្របតាម របៀបរៀបរាប់នៃកូឡុប, **អ័ប្រា.** ៣:៤, ៩ (អ័ប្រា. ៥:១៣) ។

**កើតម្ដងទៀត, កើតពីព្រះ** *សូមមើលផង* ការប្រែចិត្តជឿ, កូនចៅព្រះគ្រីស្ទ; ធ្វើបុណ្យជ្រមុជ; បង្កើត; បុណ្យជ្រមុជទឹក, បុត្រាបុត្រីនៃព្រះ, ប្រែចិត្តជឿ; មនុស្សខាងសាច់ឈាម

មានព្រះវិញ្ញាណនៃព្រះអម្ចាស់ ញាំងឲ្យមានការប្រែប្រួលដ៏ធំដល់ចិត្តនៃជនណាមួយ ដើម្បីឲ្យអ្នកនោះឈប់មានបំណងនឹង ធ្វើអំពើ អាក្រក់ តែមានសេចក្ដីប្រាថ្នា ដើម្បីស្វែងរកអ្វីផងព្រះវិញ ។

យើងនឹងដាក់វិញ្ញាណថ្មី នៅក្នុងអ្នករាល់គ្នា, **អេសេ.** ១១:១៩ (អេសេ ១៨:៣១; ៣៦:២៦) ។ អស់អ្នកណាដែលជឿដល់ព្រះនាម ព្រះគ្រីស្ទ មិនមែនកើតពីឈាមទេ តែកើតអំពីព្រះវិញ, **យ៉ូហាន** ១:១២–១៣ ។ លើកលែងតែមនុស្សបានកើតអំពីទឹក ហើយអំពីព្រះ វិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ, **យ៉ូហាន** ៣:៣–៧ ។ យើងអាចកើតម្ដងទៀត ដោយព្រះបន្ទូលនៃព្រះ, **១ ពេត្រុស** ១:២៣ (៣–២៣) ។ អស់អ្នកណាដែលបានកើតពីព្រះ នឹងមិនធ្វើអំពើបាបទៀតឡើយ, **ក.យ.ស., ១ យ៉ូហាន** ៣:៩ ។ ត្បិតអស់អ្នកណាដែលបានកើតអំពីព្រះ នោះបានឈ្នះលើលោកិយហើយ, **១ យ៉ូហាន** ៥:៤ ។ អស់អ្នកណាដែលបានកើតពីព្រះគ្រីស្ទ នោះបានធ្វើសេចក្ដីសញ្ញានឹងព្រះហើយ, **ម៉ូសាយ** ៣:១៩; ៥:២–៧ ។ គ្រប់មនុស្សទាំងអស់ត្រូវតែកើតម្ដងទៀត មែនហើយ គឺកើត ពីព្រះ, **ម៉ូសាយ** ២៧:២៥–២៦ (អាលម៉ា ៥:៤៩) ។ តើអ្នករាល់គ្នាបានកើតមកពីព្រះក្នុងវិញ្ញាណហើយឬនៅ ? **អាលម៉ា** ៥:១២–១៩ ។ បើអ្នករាល់គ្នាមិនបានកើតម្ដងទៀតទេ នោះអ្នករាល់គ្នាមិនអាចគ្រងនគរស្ថានសួគ៌ទុកជាមរតកបានឡើយ, **អាលម៉ា** ៧:១៤ ។ អស់អ្នកណាដែលជឿតាមព្រះបន្ទូលរបស់យើង នោះនឹងបានកើតពីយើង គឺពីទឹក និងពីព្រះវិញ្ញាណ, **គ. និង ស.** ៥:១៦ ។ អ្នករាល់គ្នា ក៏ត្រូវតែបានកើតម្ដងទៀត ទៅក្នុងនគរស្ថានសួគ៌, **ម៉ូសេ** ៦:៥៩ ។

**កៃផា** *សូមមើលផង* ពួកសាឌូស៊ី, អាណា

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសង្ឃជាន់ខ្ពស់ម្នាក់ ហើយជាកូនប្រសារបស់លោកអាណា ។ កៃផាមានផ្នែកយ៉ាងសកម្មក្នុងការប្រឆាំង នឹងព្រះយេស៊ូវ និងពួកសិស្សទ្រង់ (ម៉ាថាយ ២៦:៣–៤; យ៉ូហាន ១១:៤៧–៥១; ១៨:១៣–១៤) ។

**កំហឹង** *សូមមើលផង* សេចក្ដីស្រឡាញ់; ស្អប់, ការស្អប់

កំហឹង គឺសម្ដែងដោយចិត្តឆាប់ខឹង ។ ព្រះអម្ចាស់ទ្រង់ព្រមានពួកបរិសុទ្ធឲ្យទប់កំហឹងរបស់ខ្លួន (ម៉ាថាយ ៥:២២) ។ ទោះជាឪពុកម្ដាយ ឬកូនចៅក្ដី គេមិនគួរធ្វើទុក្ខគ្នានៅក្នុងគ្រួសារឡើយ ។ នៅក្នុងគម្ពីរ កំហឹងតែងតែមាននិមិត្តរូបជាភ្លើង (២ នីហ្វៃ ១៥:២៥; គ. និង ស. ១:១៣) ។

ហើយការអឺនក៏ក្ដៅក្រហាយ ហើយឡើងទឹកមុខក្រញូវ, **លោកុ.** ៤:៥ ។ ព្រះអម្ចាស់ទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្ដីសប្បុរសដ៏ធំទូលាយ, **ទំនុក.** ១៤៥:៨ ។ ពាក្យតបឆ្លើយដោយស្រទន់ នោះរមែងរំងាប់សេចក្ដីក្រោធទៅ, **សុភា.** ១៥:១ ។ មនុស្សគំរោះគំរើយ រមែងបណ្ដាលឲ្យមានសេចក្ដីទាស់ទែងគ្នា តែអ្នកណាដែលយឺតនឹងខឹង នោះរំងាប់សេចក្ដីជម្លោះវិញ, **សុភា.** ១៥:១៨ (សុភា. ១៤:២៩) ។ យើងនឹងផ្អាកកំហឹងយើង ដោយយល់ដល់ឈ្មោះយើង, **អេសាយ** ៤៨:៩ ។ យើងបានហុចដៃទៅពួកអ្នកដែល បណ្ដាល ឲ្យយើងខឹងជានិច្ច, **អេសាយ** ៦៥:២–៣ ។ បើអ្នកណាទះកំផ្លៀងស្ដាំនៃអ្នក នោះត្រូវតែបែរកំផ្លៀងម្ខាងទៅឲ្យទៀត, **ម៉ាថាយ** ៥:៣៩ ។ ឪពុករាល់គ្នាអើយ កុំឲ្យចាក់រុកកូនរបស់ខ្លួនឲ្យក្រោធឡើយ, **អេភេ.** ៦:៤ ។ ដោយមកពីខ្ញុំបានប្រាប់ការពិតដល់អ្នក ទើបអ្នកខឹងនឹង ខ្ញុំ, **ម៉ូសាយ** ១៣:៤ ។ យើងនឹងមកពិនិត្យពិច័យប្រជាជននេះ ដោយសេចក្ដីពិរោធរបស់យើង, **អាលម៉ា** ៨:២៩ ។ សេចក្ដីក្រោធរបស់ ទ្រង់មិនទាស់នឹងនរណាមួយទេ លើកលែងតែអស់អ្នកណាដែលមិនទទួលស្គាល់ព្រះហស្តរបស់ទ្រង់ក្នុងគ្រប់ទាំងអស់, **គ. និង ស.** ៥៩:២១ ។ យើងជាព្រះអម្ចាស់កំពុងតែខ្ញាល់នឹងពួកទុច្ចរិត, **គ. និង ស.** ៦៣:៣២ ។

**កំហឹង** *សូមមើល* សេចក្ដីខ្ញាល់

**ក្រិត្យវិន័យ** *សូមមើលផង* ការគោរពតាម, ក្រិត្យវិន័យលោកម៉ូសេ; គោរពតាម, ដែលគោរពតាម, ប្រទានពរ, ព្រះបញ្ញត្តិទាំងឡាយនៃព្រះ; ព្រះពរ; មានពរ

ជាបញ្ញត្តិ ឬច្បាប់ទាំងឡាយនៃព្រះ ដែលព្រះពរ និងទោសទាំងអស់ផ្អែកទៅលើ នៅលើស្ថានសួគ៌ ព្រមទាំងនៅលើផែនដីផង ។ អស់អ្នកណាដែលគោរពតាមក្រិត្យវិន័យទាំងឡាយនៃព្រះ នោះនឹងបានទទួលព្រះពរ ដែលបានសន្យាទុក ។ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា មនុស្សក៏ត្រូវគោរព ប្រតិបត្តិ និងគាំទ្រច្បាប់ទាំងឡាយនៃផែនដី (ម. នៃ ស. ១:១២) ។

ក្រិត្យវិន័យលោកម៉ូសេ គឺជាក្រិត្យវិន័យដែលបានរៀបចំទុក ដើម្បីនាំមនុស្សប្រុសស្រីមកឯព្រះគ្រីស្ទ ។ គឺក្រិត្យវិន័យអំពីការហាមឃាត់ អំពីការបញ្ជា និងអំពីពិធីបរិសុទ្ធ ។ សព្វថ្ងៃនេះ ក្រិត្យវិន័យនៃព្រះគ្រីស្ទដែលបានបំពេញក្រិត្យវិន័យលោកម៉ូសេ គឺជាដំណឹងល្អដ៏ពោរ ពេញ ឬ « ក្រិត្យវិន័យដ៏ឥតខ្ចោះខាងឯសេរីភាព » (យ៉ាកុប (ព.ស.ថ.) ១:២៥) ។

ព្រះទ្រង់ឲ្យបញ្ញត្តិដល់អ័ដាម, **លោកុ** ១:២៨; ២:១៦–១៧ ។ ព្រះទ្រង់ឲ្យក្រិត្យវិន័យដល់ណូអេ, **លោកុ** ៩:១ ។ ក្រិត្យវិន័យនៃ ព្រះអម្ចាស់នោះឥតខ្ចោះ ក៏កែព្រលឹងឡើង, **ទំនុក**. ១៩:៧ ។ ព្រះអម្ចាស់ទ្រង់ជាចៅក្រមនៃយើងរាល់គ្នា, **អេសាយ** ៣៣:២២ ។ មានអ្នកដែលតែងក្រិត្យវិន័យតែមួយទេ, **យ៉ាកុប** (ព.ស.ថ.) ៤:១២ ។ នៅទីណាដែលគ្មានក្រិត្យវិន័យ ទីនោះក៏គ្មានការដាក់ ទោសដែរ, **២ នីហ្វៃ** ៩:២៥ ។ មានក្រិត្យវិន័យមួយ ដែលបានប្រទានឲ្យ, **អាលម៉ា** ៤២:១៧–២២ ។ មនុស្សលោកនឹងត្រូវជំនុំជំរះ ស្របតាមក្រិត្យវិន័យ, **អាលម៉ា** ៤២:២៣ ។ ព្រះគ្រីស្ទជាក្រិត្យវិន័យ, **៣ នីហ្វៃ** ១៥:៩ ។ គ្រប់ក្រិត្យវិន័យទាំងអស់គឺក្រិត្យវិន័យខាង វិញ្ញាណ, **គ. និង ស.** ២៩:៣៤ ។ យ៉ូសែប ស្ម៊ីធបានទទួលក្រិត្យវិន័យនៃសាសនាចក្រ ដោយវិវរណៈ, **គ. និង ស.** ៤២ ។ អ្នកណា ដែលកាន់តាមក្រិត្យ វិន័យទាំងឡាយនៃព្រះ នោះមិនត្រូវបំពាក់ក្រិត្យវិន័យទាំងឡាយនៃផែនដីទេ, **គ. និង ស.** ៥៨:២១ ។ ពន្លឺនៃ ព្រះគ្រីស្ទ គឺជាក្រិត្យវិន័យ តាមរយៈអ្វីគ្រប់ទាំងអស់ត្រូវបានគ្រប់គ្រង, **គ. និង ស.** ៨៨:៧–១៣ ។ ព្រះអង្គបានប្រទានក្រិត្យវិន័យដល់គ្រប់ទាំងអស់, **គ. និង ស.** ៨៨:៤២–៤៣ ។ ប្រជារាស្ត្រត្រូវគោរពតាមក្រិត្យវិន័យនៃផែនដី, **គ. និង ស.** ៩៨:៤–៥ ។ កាលណាយើងបាន ព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រិត្យវិន័យ, **គ. និង ស.** ១៣០:២០–២១ ។ សាសនាចក្របានថ្លែងប្រាប់អំពី ជំនឿរបស់គេ ដែលទាក់ទងនឹងក្រិត្យវិន័យទាំងឡាយខាងស៊ីវិល, **គ. និង ស.** ១៣៤ ។ មនុស្សលោកទាំងអស់អាចបានសង្គ្រោះ ដោយសារការគោរពតាម ក្រិត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ, **ម. នៃ ស.** ១:៣ ។

**ក្រិត្យវិន័យលោកម៉ូសេ** *សូមមើលផង* ក្រិត្យវិន័យ; បព្វជិតភាពអើរ៉ុន; ម៉ូសេ, ស្អាត និងឥតស្អាត

ព្រះទ្រង់បានប្រទានក្រិត្យវិន័យតាមរយៈលោកម៉ូសេ ដល់វង្សអ៊ីស្រាអែល ដើម្បីជំនួសក្រិត្យវិន័យដែលខ្ពង់ខ្ពស់ជាង ដែលពួកគេមិនអាចគោរពតាមបាន (និក្ខ. ៣៤; ក.យ.ស., និក្ខ. ៣៤:១–២; ក.យ.ស., ចោទិ. ១០:២) ។ ក្រិត្យវិន័យលោកម៉ូសេមានគោលការណ៍ ច្បាប់ បុណ្យ ពិធី និងគំនូសជាច្រើន ដើម្បីរំឭកប្រជាជនអំពីភារកិច្ច និងកាតព្វកិច្ចរបស់គេ ។ គឺមានទាំងក្រិត្យវិន័យខាងសីលធម៌ ខាងចរិយាមាយាទ ខាងសាសនា និងខាងបញ្ញត្តិ និងការប្រព្រឹត្តខាងសាច់ឈាម — ព្រមទាំងខាងការបូជា (លេវី. ១–៧) — ដែលមាន ទុកសំរាប់រំឭកគេឲ្យនឹកដល់ព្រះ និងភារកិច្ចដែលគេមានចំពោះទ្រង់ (ម៉ូសាយ ១៣:៣០) ។ សេចក្ដីជំនឿ ការប្រែចិត្ត បុណ្យជ្រមុជ ដោយទឹក និងការផ្ដាច់បាប គឺជាផ្នែកនៃក្រិត្យវិន័យ ដូចជាព្រះបញ្ញត្តិ ១០ ប្រការ និងព្រះបញ្ញត្តិផ្សេងៗជាច្រើនទៀតដែលមានតម្លៃ ដូចជាចរិយាមាយាទ និងសីលធម៌ដ៏ខ្ពង់ខ្ពស់ ។ ក្រិត្យវិន័យខាងបុណ្យជាច្រើន ត្រូវបានសំរេចដោយការសុគត និងដំណើររស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ ដែលបានបញ្ចប់នូវយញ្ញបូជា ដោយការបង្ហូរឈាម (អាលម៉ា ៣៤:១៣–១៤) ។ ក្រិត្យវិន័យត្រូវបានចាត់ចែង នៅក្រោមអំណាច បព្វជិតភាពអើរ៉ុន ហើយជាដំណឹងល្អដែលបានរៀបចំទុក ដើម្បីនាំពួកអ្នកកាន់តាមមករកព្រះគ្រីស្ទ ។

យើងនឹងឲ្យក្រិត្យវិន័យដល់គេដូចជាមុន ប៉ុន្តែនឹងត្រូវរាប់តាមក្រិត្យវិន័យនៃបញ្ញត្តិខាងសាច់ឈាម, **ក.យ.ស., និក្ខ.** ៣៤:១–២ ។ ក្រិត្យវិន័យធ្វើជាអ្នកដឹកនាំយើងរាល់គ្នាទៅដល់ព្រះគ្រីស្ទ, **កាឡាទី** ៣:១៩–២៤ ។ យើងនៅតែកាន់តាមក្រិត្យវិន័យលោកម៉ូសេ ហើយ ទន្ទឹងចាំព្រះគ្រីស្ទយ៉ាងខ្ជាប់ខ្ជួន, **២ នីហ្វៃ** ២៥:២៤–៣០ ។ សេចក្ដីសង្គ្រោះពុំមែនបានមកដោយសារក្រិត្យវិន័យលោកម៉ូសេតែ ប៉ុណ្ណោះទេ, **ម៉ូសាយ** ១២:២៧–១៣:៣២ ។ នៅក្នុងយើង នោះក្រិត្យវិន័យលោកម៉ូសេត្រូវបានបំពេញ, **៣ នីហ្វៃ** ៩:១៧ ។ ក្រិត្យ វិន័យដែលបានប្រទានដល់លោកម៉ូសេ បានចប់ហើយនៅក្នុងយើង, **៣ នីហ្វៃ** ១៥:១–១០ ។ មកពីការមិនគោរពតាម នោះព្រះអម្ចាស់ ទ្រង់បានយកម៉ូសេ និងបព្វជិតភាពបរិសុទ្ធចេញពីកូនចៅអ៊ីស្រាអែល ដោយទុកក្រិត្យវិន័យនៃព្រះបញ្ញត្តិទាំងឡាយខាងសាច់ឈាម ឲ្យវិញ, **គ. និង ស.** ៨៤:២៣–២៧ ។

**ក្រុងណោវូ, រដ្ឋអិលលីណោយ (សហរដ្ឋ)**

ជាទីក្រុងមួយដែលបានតាំងឡើង ដោយពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅឆ្នាំ ១៨៣៩ នៅរដ្ឋអិលលីណោយ ។ ក្រុងនេះស្ថិតនៅឯទន្លេ មិស៊ីស៊ីបពីមានចម្ងាយប្រហែល ៣២០ គ.ម. ផ្នែកខាងលើទន្លេពីក្រុងសង្គលូវី ។

មកពីមានការបៀតបៀនទាំងឡាយនៅរដ្ឋមិសសួរី ទើបពួកបរិសុទ្ធ បានផ្លាស់កន្លែងប្រមាណ ៣២០ គ.ម. ទៅខាងទិសឦសានគឺឆ្លងកាត់ទន្លេមិស៊ីស៊ីបពី ហើយចូលទៅក្នុងរដ្ឋអិលលីណោយ ជាកន្លែង ដែលគេរកឃើញថាមានស្ថានភាពដ៏គួរគាប់ចិត្តជាង ។

បន្ទាប់មក ពួកបរិសុទ្ធបានទិញដីនៅក្បែរទីក្រុងខមម៉ើស ដែលមិនទាន់លូត លាស់នៅឡើយ ។ ដីនេះគឺស្ទើរជាវាលភក់ល្បប់ទាំងស្រុង ក្រៅពីអាគារតូចតាចប៉ុណ្ណោះ ។ ពួកបរិសុទ្ធបានបង្ហូរទឹកចេញពីដែនដី ហើយបានតាំងផ្ទះសំបែងនៅ ។ យ៉ូសែប ស៊្មីធ បាននាំគ្រួសារទៅនៅក្នុងផ្ទះឈើតូចមួយ ។ ឈ្មោះទីក្រុងខមម៉ើស ក៏បានដូរទៅជា ណៅវូ តាមពាក្យហេព្រើរ មានន័យថា « ស្អាតស្អំ » ។

មានកណ្ឌជាច្រើននៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាដែលបានកត់នៅក្រុងណៅវូ (គ. និង ស. ១២៤–១២៩, ១៣២, ១៣៥) ។ ពួកបរិសុទ្ធត្រូវបានប្រាប់ឲ្យសង់ព្រះវិហារមួយនៅក្រុងណៅវូ (គ. និង ស. ១២៤:២៦–២៧) ។ ពួកគេបានសង់ព្រះវិហារមួយ ហើយបានរៀបចំធ្វើស្ដេកទាំងឡាយនៃស៊ីយ៉ូន មុនត្រូវបានបណ្ដេញចេញពីផ្ទះសំបែងគេនៅឆ្នាំ ១៨៤៦ ។ ដោយសារតែការបៀតបៀននេះ ទើបពួកបរិសុទ្ធបានចេញពីទីកន្លែង ហើយបានធ្វើដំណើរទៅទិសខាងលិច ។

## ក្រុងយេរូសាឡិមថ្មី

ជាកន្លែងដែលពួកបរិសុទ្ធនឹងជួបជុំគ្នា ហើយព្រះគ្រីស្ទ ទ្រង់នឹងសោយរាជ្យផ្ទាល់ នៅជាមួយនឹងពួកគេ នៅគ្រាសហស្សវត្សរ៍ ។ ក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នឹងត្រូវបានសង់ឡើងនៅលើទ្វីបអាមេរិក ហើយផែនដីនឹងបានសាងឡើងជាថ្មី ហើយនឹងទទួលភាពរុងរឿងដ៏បរមសុខ (ម. នៃ ស. ១:១០) ។ ក្រុងយេរូសាឡិមគឺសំដៅលើទីក្រុងដ៏បរិសុទ្ធ ដែលនឹងចុះមកពីលើស្ថានសួគ៌នៅដើមសហស្សវត្សរ៍ ។

ក្រិត្យវិន័យនឹងផ្សាយចេញពីក្រុងស៊ីយ៉ូន, **មីកា** ៤:២ ។ ឈ្មោះនៃទីក្រុងរបស់ព្រះអញ គឺជាឈ្មោះក្រុងយេរូសាឡិមថ្មី, **វិវ.** ៣:១២ ។ យ៉ូហានបានឃើញទីក្រុងដ៏បរិសុទ្ធ គឺក្រុងយេរូសាឡិមថ្មី, **វិវ.** ២១:១–៥ ។ យើងនឹងតាំងរាស្ត្រនេះឡើង នៅលើដែនដីនេះ ហើយ ដែនដីនេះនឹងបានទៅជាក្រុងយេរូសាឡិមថ្មី, **៣ នីហ្វៃ** ២០:២២ ។ ក្រុងយេរូសាឡិមថ្មីនឹងបានស្ថាបនានៅលើទ្វីបអាមេរិក, **អេធើរ** ១៣:៣–៦, ១០ ។ ទីក្រុងយេរូសាឡិមថ្មីនឹងត្រូវបានរៀបចំ, **គ. និង ស.** ៤២:៩, ៣៥, ៦២–៦៩ ។ ពួកបរិសុទ្ធត្រូវប្រមូលគ្នា ហើយ ស្ថាបនាក្រុងយេរូសាឡិមថ្មី, **គ. និង ស.** ៤៥:៦៣–៧៥ ។ ក្រុងយេរូសាឡិមថ្មីត្រូវសង់ឡើងនៅរដ្ឋមិសសួរី, **គ. និង ស.** ៨៤:១–៥ (គ. និង ស. ៥៧:១–៣) ។ កូនចៀមនឹងឈរនៅលើភ្នំស៊ីយ៉ូន និងនៅលើទីក្រុងបរិសុទ្ធ គឺក្រុងយេរូសាឡិមថ្មី, **គ. និង ស.** ១៣៣:៥៦ ។ រោងឧបោសថរបស់ យើងនឹងត្រូវបានហៅថា ស៊ីយ៉ូន ជាក្រុងយេរូសាឡិមថ្មី, **ម៉ូសេ** ៧:៦២ ។

## ក្រុម *សូមមើលផង* បព្វជិតភាព

ពាក្យថា*ក្រុម* អាចយកមកប្រើបានពីរយ៉ាងគឺ ទី (១) ជាក្រុមបុរសនីមួយៗ ដែលកាន់តំណែងនៃបព្វជិតភាពដូចគ្នា ។ ទី (២) ជាសមាជិកចំនួនតូច ឬធំនៅក្នុងក្រុមបព្វជិតភាព ដែលត្រូវទៅប្រជុំដើម្បីចាត់ចែងធុរកិច្ចនៃសាសនាចក្រ (គ. និង ស. ១០៧:២៨) ។ ក្រុមទាំងឡាយនៃគណៈប្រធានទីមួយ ក្នុងពួក ១២ នាក់ និងក្នុងពួក ៧០ នាក់ និងទំនាក់ទំនងរបស់ពួកគេត្រូវបានអធិប្បាយប្រាប់, **គ. និង ស.** ១០៧:២២–២៦, ៣៣–៣៤ (គ. និង ស. ១២៤:១២៦–១២៨) ។ ការសំរេចចិត្តនៃក្រុមទាំងនេះ ត្រូវតែបានធ្វើឡើង ដោយឯកច្ឆន្ទ, **គ. និង ស.** ១០៧:២៧ ។ ការសំរេចចិត្តនៃក្រុមណាមួយ ត្រូវឲ្យធ្វើឡើង ដោយសេចក្ដីសុចរិតគ្រប់យ៉ាង, **គ. និង ស.** ១០៧:៣០–៣២ ។ កាតព្វកិច្ចទាំងឡាយនៃពួកប្រធាននៅក្នុងក្រុមបព្វជិតភាពត្រូវបានអធិប្បាយប្រាប់, **គ. និង ស.** ១០៧:៨៥–៩៦ ។ ក្រុមនៃពួកអែលឌើរត្រូវបានអនុវត្តឡើង សំរាប់ពួកអ្នកធ្វើការងារបំរើដែលនៅប្រចាំជាអចិន្ត្រៃយ, **គ. និង ស.** ១២៤:១៣៧ ។

## ក្រុមនៃពួក ១២ នាក់ *សូមមើល* សាវក

## ក្រុមប្រឹក្សាជាន់ខ្ពស់

ជាក្រុមនៃពួកសង្ឃជាន់ខ្ពស់ ១២ នាក់ ។

កាលសាសនាចក្របានសាងឡើងថ្មីៗ ពាក្យថា*ក្រុមប្រឹក្សជាន់ខ្ពស់* សំដៅដល់អង្គការត្រួតត្រាពីរយ៉ាង គឺៈ (១) ក្រុមនៃពួកសាវក ១២ នាក់ ក្នុងសាសនាចក្រ (គ. និង ស. ១០៧:៣៣, ៣៨); និង (២) ក្រុមប្រឹក្សាជាន់ខ្ពស់ដែលបំរើនៅក្នុងស្ដេកនីមួយៗ (គ. និង ស. ១០២; ១០៧:៣៦) ។

## ក្រុមប្រឹក្សានៃពួក ១២ នាក់ *សូមមើល* សាវក

## ក្រុមប្រឹក្សានៅស្ថានសួគ៌ *សូមមើលផង*

ផែនការនៃសេចក្ដីប្រោសលោះ; ជីវិតមុនផែនដី;
សង្គ្រាមនៅលើស្ថានសួគ៌

ជាគ្រានៃជីវិតមុនផែនដី កាលព្រះវរបិតាបានបង្ហាញផែនការរបស់ទ្រង់ដល់ពួកកូនចៅទ្រង់ជាវិញ្ញាណដែលនឹងចុះមកលើផែនដីនេះ ។

អស់ទាំងកូនព្រះបានស្រែកអរសាទរ, **យ៉ូប** ៣៨:៧ ។ ដំកើងបល្ល័ង្កខ្ញុំឲ្យខ្ពស់ជាងអស់ទាំងផ្កាយរបស់ព្រះ, **អេសាយ** ១៤:១២–១៣ ។ មានសង្គ្រាមមួយនៅលើស្ថានសួគ៌, **វិវ.** ១២:៧–១១ ។ មុនគេចាប់កំណើតនោះពួកគេបានទទួលមេរៀនមុនដំបូងនានា នៅពិភពនៃ ពួកវិញ្ញាណ, **គ. និង ស.** ១៣៨:៥៦ ។ សាតាំងបានបះបោរនៅជីវិតមុនផែនដី, **ម៉ូសេ** ៤:១–៤ ។ បញ្ញាទាំងឡាយដែលត្រូវបានបង្កើត ឡើងមុនកំណើតលោកិយមកម្ល៉េះ, **អ័ប្រា.** ៣:២២ ។ ក្រុមព្រះបានប្រឹក្សាជាមួយគ្នា, **អ័ប្រា.** ៤:២៦ ។ ក្រុមព្រះបានបញ្ចប់កិច្ចការ ដែលពួកព្រះអង្គបានប្រឹក្សាគ្នាថានឹងធ្វើ, **អ័ប្រា.** ៥:២ ។

## ខ្ជិលច្រអូស, ការខ្ជិលច្រអូស

មិនសកម្ម ហើយមិនចូលរួមក្នុងកិច្ចការទាំងឡាយដែលសុចរិតឡើយ ។

បើអ្នកណាមិនចង់ធ្វើការ មិនត្រូវទាំងឲ្យអ្នកបរិភោគផង, **២ ថែស្ស.** ៣:១០ ។ ពួកគេក្លាយទៅជាប្រជារាស្ត្រដ៏ខ្ជិលច្រអូស ប្រកប ដោយល្បិចកិច្ចកល, **២ នីហ្វៃ** ៥:២៤ ។ ចូរគេចចេញពីការខ្ជិលច្រអូស,

**អាលម៉ា** ៣៨:១២ ។ អ្នកណាដែលខ្ជិលច្រអូស នោះនឹងមិន ត្រូវបរិភោគអាហារនៃអ្នកដែលធ្វើការនោះឡើយ, **គ. និង ស.** ៤២:៤២ ។ វេទនាដល់អ្នកដែលមិនព្រមធ្វើការដោយដៃរបស់ខ្លួន សោះ!, **គ. និង ស.** ៥៦:១៧ ។ ត្រូវឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ, **គ. និង ស.** ៥៨:២៧ ។ ចូរឈប់មានចិត្តខ្ជិលច្រអូស, **គ. និង ស.** ៨៨:១២៤ ។

**ខាងកាមរាគ, កាមរាគ** *សូមមើលផង* អំពើកំផិត; ព្រហ្មចារីភាព; អំពើសហាយស្មន់; សេចក្ដីសំរើប; អំពើកាមរាគខុសច្បាប់

ជាការចូលចិត្ត ឬសេចក្ដីប៉ងប្រាថ្នាចំពោះការស្រើបស្រាលខាងសាច់ឈាម ដែលមិនសុចរិត ជាពិសេស អំពើកាមរាគ ។

ប្រពន្ធរបស់ចៅហ្វាយគាត់ ដេញភ្នែកជាប់តាមមើលយ៉ូសែប, **លោកុ.** ៣៩:៧ ។ អ្នកណាដែលក្រឡេកឃើញស្ត្រី ហើយមានដំរេក សំរើបចង់បាន នោះបានប្រព្រឹត្តសេចក្ដីកំផិតហើយ, **ម៉ាថាយ** ៥:២៨ (៣ នីហ្វៃ ១២:២៨) ។ ចូរចៀសចេញពីសេចក្ដីប៉ងប្រាថ្នាខាង សាច់ឈាម ដែលតយុទ្ធនឹងព្រលឹងវិញ្ញាណ, **១ ពេត្រុស** ២:១១ ។ សេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្ដីប៉ងប្រាថ្នារបស់ភ្នែក នោះមិនកើតមកពីព្រះវរបិតាទេ, **១ យ៉ូហាន** ២:១៦ ។ ចូរកុំទៅតាមសេចក្ដីសំរើបនៃភ្នែករបស់ខ្លួនទៀតឡើយ, **អាលម៉ា** ៣៩:៩ ។ ដោយសារការរំលងក្រិត្យវិន័យដ៏បរិសុទ្ធទាំងឡាយ នោះមនុស្សបានក្លាយទៅជាមានវិស័យខាងកាមរាគ, **គ. និង ស.** ២០:២០ ។ បើសិនជាអ្នកណាមួយប្រព្រឹត្តអំពើកំផិតនៅក្នុងចិត្តរបស់ខ្លួន នោះនឹងមិនមានព្រះវិញ្ញាណឡើយ, **គ. និង ស.** ៦៣:១៦ ។ ចូរឈប់ ពីសេចក្ដីប៉ងប្រាថ្នាដ៏ស្រើបស្រាលទាំងអស់របស់អ្នកចុះ, **គ. និង ស.** ៨៨:១២១ ។ មនុស្សលោកបានចាប់ផ្ដើមក្លាយទៅជាមានវិស័យ ខាងរូបកាយ ខាងកាមរាគ និងខាងអារក្ស, **ម៉ូសេ** ៥:១៣ (ម៉ូសាយ ១៦:៣; ម៉ូសេ ៦:៤៩) ។

**ខាងរូបកាយ** *សូមមើលផង* កាមរាគ, ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; ខាងកាមរាគ, មនុស្សខាងសាច់ឈាម

ជាអ្វីៗដែលមិនមែនជាខាងវិញ្ញាណ; បើនិយាយចំទៅ ពាក្យនេះអាចយកមកប្រើដើម្បីឲ្យន័យដល់អ្វីដែលរមែងស្លាប់ ឬខាងសាច់ឈាម (គ. និង ស. ៦៧:១០) ឬខាងលោកិយ ខាងសាច់ឈាម និងខាងកាមរាគ (ម៉ូសាយ ១៦:១០–១២) ។

គំនិតដែលជាប់ទៅខាងរូបកាយ គឺជាសេចក្ដីស្លាប់, **២ នីហ្វៃ** ៩:៣៩ ។ អារក្សបំពេមនុស្សលោកឲ្យបានសុខខាងរូបកាយ, **២ នីហ្វៃ** ២៨:២១ ។ ពួកគេសម្លឹងមើលថា ខ្លួនគេនៅក្នុងស្ថានភាពខាងរូបកាយ, **ម៉ូសាយ** ៤:២ ។ ជនណាដែលស្ថិតនៅក្នុងស្ថានភាពខាងរូបកាយ ជននោះនឹងនៅស្ថានភាពធ្លាក់តទៅទៀត, **ម៉ូសាយ** ១៦:៥ ។ មនុស្សទាំងអស់ត្រូវតែកើតមកពីព្រះ គឺផ្លាស់ពីស្ថានភាពខាងរូបកាយ និងខាងការធ្លាក់របស់គេ, **ម៉ូសាយ** ២៧:២៥ ។ មនុស្សលោកបានក្លាយទៅជាមនុស្សខាងរូបកាយ ខាងកាមរាគ និងខាងអារក្ស, **អាលម៉ា** ៤២:១០ ។ អស់អ្នកណាដែលដើរតាមសេចក្ដីបំណង និងសេចក្ដីប៉ងប្រាថ្នាខាងរូបកាយរបស់ខ្លួន អ្នកនោះត្រូវតែ ដួលចុះ, **គ. និង ស.** ៣:៤ ។ មនុស្សពុំអាចមើលឃើញព្រះ ដោយគំនិតខាងរូបកាយបានឡើយ, **គ. និង ស.** ៦៧:១០–១២ ។ មនុស្ស លោកបានចាប់ផ្ដើមក្លាយទៅជាមនុស្សខាងរូបកាយ ខាងកាមរាគ និងខាងអារក្ស, **ម៉ូសេ** ៥:១៣; ៦:៤៩ ។

**ខៅឌើរី, អូលីវើរ**

ជាអែលឌើរទីពីរ ក្នុងសាសនាចក្រដែលបានសាងឡើងវិញ ហើយជាសាក្សីម្នាក់ក្នុងពួកសាក្សីបីនាក់ ចំពោះកំណើត និងភាពពិតប្រាកដពីព្រះ អំពីព្រះគម្ពីរមរមន ។ លោកធ្វើជាស្មៀន នៅពេលយ៉ូសែប ស្ម៊ីធបកប្រែព្រះគម្ពីរមរមនចេញពីផ្ទាំង មាស (យ.ស. — ប្រវត្តិ ១:៦៦–៦៨) ។

បានទទួលទីបន្ទាល់អំពីសេចក្ដីពិតនៃការបកប្រែព្រះគម្ពីរមរមន, **គ. និង ស.** ៦:១៧, ២២–២៤ ។ ត្រូវបានតែងតាំងឡើងដោយ យ៉ូហាន-បាទីស្ទ, **គ. និង ស.** ១៣ (គ. និង ស. ២៧:៨; យ.ស. — ប្រវត្តិ ១:៦៨–៧៣, សូមមើល កំណត់ដល់ឃ្លា ៧១) ។ បន្ទាប់ពីអ្នករាល់គ្នាបានសេចក្ដីជំនឿ ហើយបានឃើញរបស់ទាំងឡាយ ដោយភ្នែករបស់អ្នកហើយ នោះអ្នករាល់គ្នាត្រូវធ្វើទីបន្ទាល់អំពីរបស់ទាំងនោះ, **គ. និង ស.** ១៧:៣, ៥ ។ យើងបានសម្ដែងដល់អ្នក ដោយសារព្រះវិញ្ញាណរបស់យើង ថាការណ៍ទាំងឡាយដែលអ្នកបាន សរសេរនោះគឺពិត, **គ. និង ស.** ១៨:២ ។ ត្រូវចាត់ ហើយតែងតាំងឲ្យធ្វើជាអ្នកត្រួតត្រាលើវិវរណៈទាំងឡាយ, **គ. និង ស.** ៧០:៣ ។ បានទទួលកូនសោទាំងឡាយនៃបព្វជិតភាព ជាមួយនឹងយ៉ូសែប ស្ម៊ីធ, **គ. និង ស.** ១១០ ។

**គណៈប្រធាន** *សូមមើល* គណៈប្រធានទីមួយ

**គណៈប្រធានទីមួយ** *សូមមើលផង* កូនសោទាំងឡាយនៃបព្វជិតភាព; ប្រធាន; វិវរណៈ

ជាប្រធាននៃសាសនាចក្រ និងពួកអ្នកប្រឹក្សារបស់លោក ។ ពួកគេជាក្រុមនៃពួកសង្ឃជាន់ខ្ពស់បីនាក់ ហើយត្រួតត្រាលើសាសនាចក្រទាំងមូល ។ គណៈប្រធានទីមួយ កាន់គ្រប់ទាំងកូនសោនៃបព្វជិតភាព ។

កូនសោទាំងឡាយនៃនគរត្រូវជារបស់ផងគណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់រហូត, **គ. និង ស.** ៨១:២ ។ គណៈប្រធាននៃបព្វជិតភាពជាន់ខ្ពស់ មានសិទ្ធិដើម្បីធ្វើការក្នុងគ្រប់តំណែងទាំងអស់, **គ. និង ស.** ១០៧:៩, ២២ ។ អស់អ្នកណាដែលទទួលយើង នោះទទួលគណៈប្រធានទីមួយ, **គ. និង ស.** ១១២:២០, ៣០ ។ គណៈប្រធានទីមួយគឺដើម្បីទទួលព្រះបន្ទូលទាំងឡាយ [វិវរណៈ] សំរាប់សាសនាចក្រទាំងមូល, **គ. និង ស.** ១២៤:១២៦ ។

**គម្ពីរ៥ច្បាប់** *សូមមើលផង* ចោទិយកថា; ជនគណនា; និក្ខមនំ; ព្រះគម្ពីរសញ្ញាចាស់, ម៉ូសេ; លេវីវិន័យ; លោកុប្បត្តិ

ជាឈ្មោះដាក់ឲ្យគម្ពីរដំបូង ទាំង៥ច្បាប់នៅក្នុងព្រះគម្ពីរ

សញ្ញាចាស់ — លោកុប្បត្តិ, និក្ខមនំ, លេវីវិន័យ, ជនគណនា និង ចោទិយកថា ។ ពួកសាសន៍យូដាស្គាល់គម្ពីរទាំងនេះថា តូរា ឬក្រិត្យវិន័យនៃអ៊ីស្រាអែល ។ គម្ពីរទាំងនេះ បានសរសេរ ដោយលោកម៉ូសេ (១ នីហ្វៃ ៥:១០–១១) ។

**គម្ពីរដ៏ជាបមាណិយ** *សូមមើល* កាណុង

**គាល់កូថា** *សូមមើលផង* ការឆ្កាង; ព្រះយេស៊ូវគ្រីស្ទ

*គាល់កូថា* មានន័យថា « រលាក្បាល » នៅក្នុងភាសាអើរ៉ាម ។ គឺជាឈ្មោះកន្លែងដែលគេឆ្កាងព្រះគ្រីស្ទ (ម៉ាថាយ ២៧:៣៣; ម៉ាកុស ១៥:២២; យ៉ូហាន ១៩:១៧) ។ ឈ្មោះកន្លែងនេះក្នុង ភាសាឡាតាំងហៅថា*កាល់វ៉ារី* (លូកា ២៣:៣៣) ។

**គិមបុល, ស្ពែនសើរ វ៉េបបុលយូ** *សូមមើលផង* សេចក្ដីប្រកាសជាផ្លូវការទី ២

ជាប្រធានទី១២ ក្នុងសាសនាចក្រ ចាប់តាំងពីបានតាំងឡើង នៅឆ្នាំ ១៨៣០ ។ ស្ពែនសើរ វ៉េបបុលយូ គិមបុល បានបំរើជាប្រធាន ពីខែធ្នូ ឆ្នាំ ១៩៧៣ ទៅដល់ខែវិច្ឆិកា ឆ្នាំ ១៩៨៥ ។ លោកបានកើតនៅឆ្នាំ ១៨៩៥ ហើយស្លាប់នៅឆ្នាំ ១៩៨៥ កាលមាន អាយុ ៩០ ឆ្នាំ ។

នៅខែមិថុនា ១៩៧៨ នោះគណៈប្រធានទីមួយ បានប្រកាសថា វិវរណៈដែលបានទទួលដោយប្រធានគិមបុល អំពីការអនុញ្ញាតឲ្យ បព្វជិតភាព និងព្រះពរទាំងឡាយ ក្នុងព្រះវិហារបរិសុទ្ធ ដល់សមាជិកបុរសៗទាំងអស់ណា ដែលសក្ដិសម, **គ. និង ស.** សេចក្ដីប្រកាសជាផ្លូវការ ទី ២ ។

**គិសគូមេន** *សូមមើលផង* ពួកចោរកាឌីអានតុន

នៅក្នុងព្រះគម្ពីរមរមន គឺជាអ្នកដឹកនាំក្រុមមនុស្សទុច្ចរិតម្នាក់ ដែលក្រោយមកស្គាល់ថាជាពួកចោរកាឌីអានតុន (ហេលេ. ១:៩–១២; ២) ។

**គុកកាតធេច (សហរដ្ឋ)** *សូមមើលផង* យ៉ូសែប ជុញ្ញ័រ, ស្ម៊ីធ, ស្ម៊ីធ, ហៃរំ

យ៉ូសែប និងហៃរុម ស្ម៊ីធត្រូវហ្វូងមនុស្សកំណាចសម្លាប់ នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៨៤៤ នៅក្នុងគុកនៅកាតធេច រដ្ឋអិលលីណោយ សហរដ្ឋអាមេរិក (គ. និង ស. ១៣៥) ។

**គុកលីប៊ឺទី រដ្ឋមិសសួរី (សហរដ្ឋ)** *សូមមើលផង* យ៉ូសែប ជុញ្ញ័, ស្ម៊ីធ

ជាគុកតូចមួយដែលព្យាការីយ៉ូសែប ស្ម៊ីធ និងអ្នកឯទៀតត្រូវ គេដាក់ដោយអយុត្តិធម៌ ពីខែវិច្ឆិកា ១៨៣៨ ទៅខែមេសា ១៨៣៩ ។ កាលនៅក្នុងលក្ខណៈដ៏ពិបាកទាំងនេះ នោះយ៉ូសែបបាន ទទួលវិវរណៈដ៏ប្រាកដខ្លះ បានព្យាករ ហើយបានទទួលការបំផុស គំនិតឲ្យ សរសេរសំបុត្រដ៏សំខាន់មួយច្បាប់ទៅពួកបរិសុទ្ធ គឺជាបទ ដកស្រង់ទាំងឡាយ ដែលមាននៅក្នុង គ. និង ស. ១២១–១២៣ ។

**គុណធម៌** *សូមមើល* ព្រហ្មចារីភាព; អំពើកំផិត; អំពើរាគកាម, អំពើសហាយស្មន់

**គុណធម៌** *សូមមើលផង* ព្រហ្មចារីភាព; សេចក្ដីស្មោះ; អំណាច

ជាសេចក្ដីស្មោះ និងឧត្ដមភាព ជាឫទ្ធិ និងកម្លាំង (លូកា ៨:៤៦) ឬបរិសុទ្ធពីកាមគុណ (ម៉ូរ៉ូណៃ ៩:៩) ។

នាងជាស្ត្រីល្អត្រឹមត្រូវណាស់, **នាងរស់** ៣:១១ ។ អ្នកណាដែលមាន ដៃស្អាត និងចិត្តបរិសុទ្ធ នោះនឹងឈរនៅក្នុងទីបរិសុទ្ធរបស់ ព្រះអម្ចាស់, **ទំនុក.** ២៤:៣–៤ ។ ស្ត្រីមានចិត្តបរិសុទ្ធ នោះជាមកុដ ដល់ប្ដីខ្លួន, **សុភា.** ១២:៤ ។ ស្ត្រីគ្រប់លក្ខណ៍ នោះមានតម្លៃជា ជាងត្បូងទទឹមទៅទៀត, **សុភា.** ៣១:១០–៣១ ។ ចូរបន្ថែមឲ្យសេចក្ដីជំនឿបានទៀងត្រង់, **២ ពេត្រុស** ១:៥ (គ. និង ស. ៤:៦) ។ ត្រូវតែពិសោធគុណធម៌នៃព្រះបន្ទូលនៃព្រះ, **អាលម៉ា** ៣១:៥ ។ សូមឲ្យគុណធម៌តុបតែងគំនិតអ្នក ដោយឥតឈប់ឈរចុះ, **គ. និង ស.** ១២១:៤៥ ។ យើងខ្ញុំជឿលើការប្រព្រឹត្តដោយគុណធម៌, **ម. នៃ ស.** ១:១៣ (ភីលីព ៤:៨) ។

**គូម៉ូរ៉ា, ភ្នំ** *សូមមើលផង* កូនប្រុសរបស់មរមន; ព្រះគម្ពីរមរមន; ម៉ូរ៉ូណៃ, យ៉ូសែប ជុញ្ញ័រ, ស្ម៊ីធ

ជាភ្នំតូចមួយនៅទិសខាងលិចរដ្ឋនូវយ៉ោក សហរដ្ឋអាមេរិក ។ នៅទីនេះ ព្យាការីពីបុរាណម្នាក់ ឈ្មោះម៉ូរ៉ូណៃ បានលាក់ផ្ទាំងមាស ទាំងឡាយ ដែលមានកំណត់ខ្លះរបស់ពួកសាសន៍នីហ្វៃ និងយ៉ារេឌ ។ យ៉ូសែប ស្ម៊ីធបានត្រូវម៉ូរ៉ូណៃ ដែលបានរស់ឡើងវិញ ចាត់ឲ្យទៅ ឯភ្នំនេះ នៅឆ្នាំ ១៨២៧ ដើម្បីទៅយកផ្ទាំងទាំងនេះ ហើយបកប្រែភាគខ្លះ ។ សេចក្ដីបកប្រែនេះ គឺជាព្រះគម្ពីរមរមន ។

ពួកសាសន៍នីហ្វៃបានប្រមូលគ្នានៅឯភ្នំគូម៉ូរ៉ា, **មរមន** ៦:២–៤ ។ ភ្នំគូម៉ូរ៉ានៅក្នុងដែនដីដែលមានទឹកច្រើន, **មរមន** ៦:៤ ។ មរមនបាន លាក់បញ្ជីនៅក្នុងភ្នំគូម៉ូរ៉ា, **មរមិន** ៦:៦ ។ ពួកសាសន៍នីហ្វៃទាំងអស់ ត្រូវស្លាប់នៅលើភ្នំគូម៉ូរ៉ា លើកលែងតែ ២៤ នាក់ប៉ុណ្ណោះ, **មរមន** ៦:១១ ។ យើងឮដំណឹងដ៏រីករាយពីភ្នំគូម៉ូរ៉ា, **គ. និង ស.** ១២៨:២០ ។ យ៉ូសែប ស្ម៊ីធបានយកផ្ទាំងពីភ្នំគូម៉ូរ៉ា, **យ.ស. — ប្រវត្តិ** ១:៤២, ៥០–៥៤, ៥៩ ។

**គួរខ្ពើមឆ្អើម, អំពើគួរខ្ពើមឆ្អើម** *សូមមើលផង* បាប

នៅក្នុងគម្ពីរ អ្វីៗដែលបណ្ដាលឲ្យពួកសុចរិត ឬពួកដែលមានចិត្តបរិសុទ្ធ ខ្ពើមឆ្អើម ឬស្អប់ ។

បបូរមាត់ដែលពោលពាក្យភូតភរ ជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់, **សុភា.** ១២:២២ ។ សេចក្ដីឆ្មើងឆ្មៃ គឺជាសេចក្ដីគួរខ្ពើមឆ្អើម នៅ ចំពោះព្រះនេត្រនៃព្រះអម្ចាស់, **យ៉ាកុប** ២:១៣–២២ ។ ពួកទុច្ចរិត នឹងត្រូវដាក់ឲ្យមើលឃើញសេចក្ដីខ្ពើមឆ្អើមរបស់ខ្លួន, **ម៉ូសាយ** ៣:២៥ ។ ភាពអព្រហ្មចារី គឺជាអំពើគួរខ្ពើមឆ្អើមជាងអំពើបាបទាំងអស់ លើកលែងតែអំពើឃាតកម្ម និងការបដិសេធព្រះវិញ្ញាណ បរិសុទ្ធ,

**អាលម៉ា** ៣៩:៣–៥ ។ សេចក្ដីក្ដៅក្រហាយនៃព្រះអម្ចាស់ ត្រូវបានឆួលឡើងទាស់នឹងអំពើគួរខ្ពើមឆ្អើមរបស់ពួកគេ, **គ. និង ស.** ៩៧:២៤ ។

**គេឌាន (ព្រះគម្ពីរមរមន)**

ជាអ្នកដឹកនាំសាសន៍នីហ្វៃដ៏ស្មោះត្រង់ម្នាក់ ។

ជាមនុស្សខ្លាំងពូកែមួយរូប ហើយជាសត្រូវដល់ស្ដេចណូអេ, **ម៉ូសាយ** ១៩:៤–៨ ។ បានប្រឹក្សាជាមួយនឹងស្ដេចលិមហៃ, **ម៉ូសាយ** ២០:១៧–២២ ។ បានគ្រោងផែនការ ដើម្បីរត់ចេញពីសេវកភាពនៃពួកសាសន៍លេមិន, **ម៉ូសាយ** ២២:៣–៩ ។ ត្រូវបានសម្លាប់ដោយ នីហូរ, **អាលម៉ា** ១:៨–១០ ។

**គែតសេម៉ានី***សូមមើលផង* ដង្វាយធួន; ដើមអូលីវ, ធ្វើឲ្យធួន, ភ្នំ

ជាសួនច្បារមួយដែលបាននិយាយដល់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ថានៅក្បែរភ្នំអូលីវក្នុងភាសាអើរ៉ាមពាក្យ*គែតសេម៉ានី* មានន័យ ថា « ត្បាល់គាបផ្លែអូលីវ » ។ ព្រះយេស៊ូវទ្រង់បានយាងទៅឯសួនច្បារនៅពេលយប់ដែលយូដាសបានក្បត់ទ្រង់ ។ នៅទីនោះទ្រង់បានអធិស្ឋាន ហើយបានរងទុក្ខនៅក្នុងច្បារគែតសេម៉ានី ជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក (ម៉ាថាយ ២៦:៣៦, ៣៩; ម៉ាកុស ១៤:៣២; យ៉ូហាន ១៨:១; អាលម៉ា ២១:៩; គ. និង ស. ១៩:១៥–១៩) ។

**គោរពប្រតិបត្តិ** *សូមមើលផង* ការកោតក្រែង, រាប់អាន

ដូចដែលប្រើនៅក្នុងគម្ពីរទូទៅ គឺដើម្បីបង្ហាញការគោរព និងការកោតក្រែងដល់អ្នកណាម្នាក់ ឬដល់អ្វីមួយ ។

ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយអ្នក, **និក្ខ.** ២០:១២ (១ នីហ្វៃ ១៧:៥៥; ម៉ូសាយ ១៣:២០) ។ ចូរថ្វាយកិត្តិនាមដល់ព្រះអម្ចាស់ ដោយ ទ្រព្យសម្បត្តិ, **សុភា.** ៣:៩ ។ បើអ្នកណាបំរើខ្ញុំ ព្រះវរបិតានឹងលើកមុខអ្នកនោះ, **យ៉ូហាន** ១២:២៦ ។ ពួកប្ដីៗគួរតែរាប់អានប្រពន្ធខ្លួន, **១ ពេត្រុស** ៣:៧ ។ គេថ្វាយកិត្តិនាមដល់ព្រះអម្ចាស់តែនឹងបបូរមាត់គេប៉ុណ្ណោះ, **២ នីហ្វៃ** ២៧:២៥ (អេសាយ ២៩:១៣) ។ ខ្ញុំមិនបានស្វែងរកកិត្តិយសនៃលោកិយទេ, **អាលម៉ា** ៦០:៣៦ ។ អារក្សបានបះបោរទាស់នឹងយើង ដោយទូលថា៖ សូមប្រទានដល់ ទូលបង្គំនូវភាពរុងរឿងរបស់ព្រះអង្គ ដែលជាព្រះចេស្ដារបស់យើង, **គ. និង ស.** ២៩:៣៦ ។ ពួកស្មោះត្រង់នឹងបានពាក់មកុដដោយ កិត្តិយស, **គ. និង ស.** ៧៥:៥ (គ. និង ស. ១២៤:៥៥) ។ ព្រះអម្ចាស់ទ្រង់ចូលចិត្តឲ្យកិត្តិយសដល់អស់អ្នកណាដែលបំរើទ្រង់, **គ. និង ស.** ៧៦:៥ ។ ពួកគេមិនត្រូវបានរើស ពីព្រោះពួកគេប្រាថ្នាចង់បានកិត្តិយសនៃមនុស្សលោក, **គ. និង ស.** ១២១:៣៤–៣៥ ។ យើងខ្ញុំជឿចំពោះគោរពប្រតិបត្តិ និងការគាំទ្រច្បាប់, **ម. នៃ ស.** ១:១២ (គ. និង ស. ១៣៤:៦) ។

**គោលការណ៍***សូមមើលផង* ដំណឹងល្អ

ជាគោលលទ្ធិ សេចក្ដីពិត ឬក្រិត្យវិន័យដ៏សំខាន់ ។ គោលការណ៍ទីមួយនៃដំណឹងល្អ គឺសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងការប្រែចិត្ត (ម. នៃ ស. ១:៤) ។

ដោយមិនឈប់ខាងឯសេចក្ដីបឋមសិក្សានៃព្រះបន្ទូលព្រះគ្រីស្ទ ហើយខំឲ្យបានជឿនទៅមុខ ដរាបដល់ពេញខ្នាតចុះ, **ហេព្រើរ** ៦:១–៣ ។ ពួកអែលឌើរ ពួកសង្ឃ និងពួកគ្រូត្រូវបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរ, **គ. និង ស.** ៤២:១២ ។ បង្គាប់ឲ្យបានល្អទៅទៀត អំពីគោលការណ៍ អំពីគោលលទ្ធិ អំពីគ្រប់ការណ៍ទាំងអស់, **គ. និង ស.** ៨៨:៧៨ (គ. និង ស. ៩៧:១៤) ។ មនុស្សគ្រប់រូបអាចប្រព្រឹត្តនូវគោលលទ្ធិ និងគោលការណ៍ ដែលទាក់ទងទៅតាមសិទ្ធិជ្រើសរើសខាងសិលធម៌ ដែលយើងបានប្រទានដល់គេ, **គ. និង ស.** ១០១:៧៨ ។ គោលការណ៍នៃបញ្ញាណាក៏ដោយ ដែលយើងបាននៅក្នុងជីវិតនេះ នោះនឹងនៅ ជាប់នឹងយើង ក្នុងដំណើររស់ឡើងវិញ, **គ. និង ស.** ១៣០:១៨–១៩ ។

**គោលការណ៍ទីមួយនៃដំណឹងល្អ***សូមមើល* ការប្រែចិត្ត,
បុណ្យជ្រមុជទឹក, ប្រែចិត្ត, ធ្វើបុណ្យជ្រមុជទឹក;
ព្រះវិញ្ញាណបរិសុទ្ធ; សេចក្ដីជំនឿ

**គោលលទ្ធិ និងសេចក្ដីសញ្ញា***សូមមើលផង* កាណុង;
ព្រះគម្ពីរនៃព្រះបញ្ញត្តិ; បទព្រះគម្ពីរ; យ៉ូសែប ជុញ្ញ័រ, ស្ម៊ីធ

ជាការប្រជុំវិវរណៈពីព្រះ និងសេចក្ដីប្រកាសដែលបំផុសគំនិតនៅថ្ងៃចុងក្រោយ ។ ព្រះអម្ចាស់ទ្រង់ប្រទានរបស់ទាំងនេះដល់យ៉ូសែប ស្ម៊ីធ និងដល់ពួកអ្នកខ្លះក្រោយពីលោកទៅ សំរាប់ការតាំង ហើយចាត់ចែងនគរព្រះនៅលើផែនដីនៅថ្ងៃចុងក្រោយបង្អស់ ។ គោលលទ្ធិ និងសេចក្ដីសញ្ញា ជាគម្ពីរបមាណីយមួយក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាមួយនឹងព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមន និងមុក្ដាដ៏មានតម្លៃមហិមា ។ គោលលទ្ធិ និងសេចក្ដីសញ្ញា ជារបស់ចំឡែកមួយ ពីព្រោះមិនមែនជាការបកប្រែចេញ ពីបញ្ជីបុរាណទេ ។ ព្រះអម្ចាស់ទ្រង់ប្រទានវិវរណៈទាំងនេះដល់ពួកព្យាការីដ៏ជំរើសរបស់ទ្រង់នៅបច្ចុប្បន្ននេះ ដើម្បីសាងនគរទ្រង់ ឡើងវិញ ។ នៅក្នុងវិវរណៈទាំងប៉ុន្មាននោះ ជននីមួយៗឮនូវសម្លេងដ៏ទន់ភ្លន់ និងមុតមាំនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ (គ. និង ស. ១៨:៣៥–៣៦) ។

ព្យាការីយ៉ូសែប ស្ម៊ីធ មានប្រសាសន៍ថា គោលលទ្ធិ និងសេចក្ដីសញ្ញា ជាមូលដ្ឋាននៃសាសនាចក្រនៅគ្រាចុងក្រោយបង្អស់ ហើយជាផលប្រយោជន៍ដល់ពិភពលោក (គ. និង ស. ៧០:ចំណងជើង) ។ វិវរណៈទាំងឡាយដែលនៅក្នុងនោះ ចាប់ផ្ដើមការរៀបចំផ្លូវចាំការយាងមកលើកទីពីរ នៃព្រះអម្ចាស់ ក្នុងការសំរេចនូវគ្រប់ទាំងពាក្យដែលបានពោលដោយពួកព្យាការី ចាប់តាំងពីកំណើតលោកិយមក ។

**គោលលទ្ធិនៃព្រះគ្រីស្ទ** *សូមមើលផង* ដំណឹងល្អ;
ផែនការនៃសេចក្ដីប្រោសលោះ

ជាគោលការណ៍ និងការបង្រៀនទាំងឡាយ អំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

គោលលទ្ធិរបស់ខ្ញុំនឹងធ្លាក់មកដូចជាភ្លៀង, **ចោទិ.** ៣២:២ ។ មនុស្ស ដែលរអ៊ូរទាំនឹងទទួលសេចក្ដីប្រៀនប្រដៅ, **អេសាយ** ២៩:២៤ ។ បណ្ដា មនុស្សក៏នឹកប្លែក ពីសេចក្ដីដែលទ្រង់បង្រៀន, **ម៉ាថាយ** ៧:២៨ ។ គោលលទ្ធិនេះមិនមែនជារបស់ខ្ញុំទេ តែជារបស់ផងទ្រង់ដែល ចាត់ឲ្យ ខ្ញុំមកនោះវិញ, **យ៉ូហាន** ៧:១៦ ។ គ្រប់ទាំងគម្ពីរ គឺមានប្រយោជន៍ សំរាប់ការបង្រៀន,២ ធីម៉ូ. ៣:១៦ ។ នេះគឺជាគោលលទ្ធិ នៃព្រះ គ្រីស្ទ ហើយគឺជាគោលលទ្ធិតែមួយ ហើយពិតនៃព្រះវរបិតា, **២ នីហ្វៃ** ៣១:២១ (២ នីហ្វៃ ៣២:៦) ។ ហើយក៏ពុំត្រូវមានការប្រ កែកគ្នានៅក្នុងចំណោមអ្នករាល់គ្នា អំពីចំណុចទាំងឡាយ នៃគោលលទ្ធិ របស់យើង, **៣ នីហ្វៃ** ១១:២៨, ៣២, ៣៥, ៣៩–៤០ ។ អារក្ស សាតាំងចាក់រុកដួងចិត្តនៃមនុស្សទាំងឡាយ ឲ្យមានការទាស់ទែងគ្នា អំពីចំណុចទាំងឡាយ នៃគោលលទ្ធិរបស់យើង, **គ. និង ស.** ១០:៦២–៦៣, ៦៧ ។ ចូរបង្រៀនកូនចៅនូវគោលលទ្ធិអំពីការប្រែ ចិត្ត សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ អំពីបុណ្យជ្រមុជទឹក និងអំពីអំ ណោយទានជាព្រះវិញ្ញាណបរិសុទ្ធ, **គ. និង ស.** ៦៨:២៥ ។ ត្រូវ បង្រៀនគ្នាទៅវិញទៅមក នូវគោលលទ្ធិនៃនគរ, **គ. និង ស.** ៨៨:៧៧–៧៨ ។ គោលលទ្ធិអំពីបព្វជិតភាពនឹងចុះមកលើព្រលឹង របស់អ្នក, **គ. និង ស.** ១២១:៤៥ ។

**គំនិត**

ជាញាណសតិ; ជាអានុភាពដោយចេតនានៃគំនិត ។

ចូរបំរើទ្រង់ដោយអស់ពីចិត្ត ហើយស្ម័គ្រស្មោះផង, **១ របា.** ២៨:៩ ។ ចូរស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់ពីគំនិត, **ម៉ាថាយ** ២២:៣៧ ។ គំនិតដែលជាប់ទៅខាងសាច់ឈាម គឺជាសេចក្ដីស្លាប់ ឯគំនិតដែលជាប់ទៅខាងវិញ្ញាណ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច វិញ, **២ នីហ្វៃ** ៩:៣៩ ។ សម្លេងនៃព្រះអម្ចាស់បានចូលមកក្នុងគំនិតខ្ញុំ, **អេណុស** ១:១០ ។ ព្រះបន្ទូលមានប្រសិទ្ធិភាពទៅលើគំនិត មនុស្ស ច្រើនជាងផ្លែដាវទៅទៀត, **អាលម៉ា** ៣១:៥ ។ យើងនឹងប្រាប់អ្នកនៅ ក្នុងគំនិតរបស់អ្នក, **គ. និង ស.** ៨:២ ។ អ្នកត្រូវសិក្សា ក្នុងគំនិតរបស់ អ្នក, **គ. និង ស.** ៩:៨ ។ ចូរឲ្យការម៉ឺងម៉ាត់ អំពីភាពអស់កល្បជានិច្ច ស្ថិតនៅក្នុងគំនិតរបស់ អ្នករាល់គ្នាចុះ, **គ. និង ស.** ៤៣:៣៤ ។ ពេលកន្លងមកហើយ នោះគំនិតរបស់អ្នកត្រូវបានងងឹត, **គ. និង ស.** ៨៤:៥៤ ។ ចូរឆាប់ចូលដំណេក ចូរឆាប់ក្រោក ប្រយោជន៍ឲ្យ រូបកាយ និងគំនិតរបស់អ្នករាល់គ្នាអាចមានកម្លាំងភ្លៀវក្លា, **គ. និង ស.** ៨៨:១២៤ ។ អារក្សសាតាំងមិនស្គាល់គំនិតនៃ ព្រះទេ, **ម៉ូសេ** ៤:៦ ។ ព្រះអម្ចាស់ទ្រង់បានហៅរាស្ត្រទ្រង់ថា ស៊ីយ៉ូន ពីព្រោះពួកគេ មានចិត្តតែមួយ និងគំនិតតែមួយ, **ម៉ូសេ** ៧:១៨ ។

**គំនិត** *សូមមើលផង* រំពឹងគិត, សិទ្ធិជ្រើសរើស

ជាគតិ ដំណើរ និងរូបភាព នៅក្នុងខួរក្បាលនៃមនុស្សម្នាក់ៗ ។ អំណាច ដែលអាចគិត គឺជាអំណោយទានមកពីព្រះ ហើយយើងមាន សេរីភាព ក្នុងការប្រើអំណាចរបស់យើង ដើម្បីគិតតាមចិត្ត ។ របៀបដែលយើងគិត នោះមានឥទ្ធិពលយ៉ាងខ្លាំង ដល់អាកប្បកិរិយា ព្រមទាំងឋានៈយើង នៅជីវិតបន្ទាប់ពីនេះទៅ ។ គំនិតដែលសុចរិត នាំទៅរកសេច ក្ដីសង្គ្រោះ រីឯគំនិតដែលទុច្ចរិត នាំទៅរកសេចក្ដី ផាប់ទោសវិញ ។

ព្រះអម្ចាស់ទ្រង់យល់អស់ទាំងសេចក្ដីដែលយើងគិត, **១ របា.** ២៨:៩ ។ ដូចជាគេគិតក្នុងចិត្តយ៉ាងណា នោះគេក៏យ៉ាងនោះដែរ, **សុភា.** ២៣:៧ ។ គំនិតអញមិនមែនដូចជាគំនិតឯងរាល់គ្នាទេ, **អេសាយ** ៥៥:៧–៩ ។ ព្រះយេស៊ូវទ្រង់ជ្រាបគំនិតគេ, **ម៉ាថាយ** ១២:២៥ (លូកា ៥:២២; ៦:៨) ។ នៅពីខាងក្នុង ពីក្នុងចិត្តរបស់មនុស្ស មានចេញអស់ ទាំងគំនិតអាក្រក់, **ម៉ាកុស** ៧:២០–២៣ ។ ចូរនាំអស់ ទាំងគំនិត ឲ្យចុះចូលស្ដាប់បង្គាប់ព្រះគ្រីស្ទ, **២ កូរិន.** ១០:៥ ។ ឯសេចក្ដីឯណា ដែលពិត ដែលសុចរិត ដែលបរិសុទ្ធ ឬដែលគួរឲ្យ ស្រឡាញ់ ចូរពិចារណាពីសេចក្ដីទាំងនេះចុះ, **ភីលិព** ៤:៨ ។ សូមនឹកចាំថា គំនិតដែលជាប់ទៅខាងសាច់ឈាម គឺជាសេចក្ដីស្លាប់ រីឯគំនិតដែល ជាប់ទៅខាងវិញ្ញាណ គឺជាជីវិតដ៏នៅអស់កល្បជានិច្ចវិញ, **២ នីហ្វៃ** ៩:៣៩ ។ បើអ្នករាល់គ្នាពុំប្រយ័ត្នខ្លួនឯង ទាំងគំនិត ខ្លួនទេ នោះអ្នក នឹងត្រូវវិនាស, **ម៉ូសាយ** ៤:៣០ ។ គំនិតរបស់យើងនឹងកាត់ទោសយើង, **អាលម៉ា** ១២:១៤ ។ មានតែព្រះទេ ដែល ជ្រាបនូវគំនិតរបស់អ្នក និងបំណងដែលនៅក្នុងចិត្តរបស់អ្នក, **គ. និង ស.** ៦:១៦ (គ. និង ស. ៣៣:១) ។ ចូរមើលមកឯយើង ដោយ នូវគ្រប់ទាំងគំនិត, **គ. និង ស.** ៦:៣៦ ។ ចូររក្សាទុកក្នុងគំនិតរបស់អ្នករាល់គ្នា នូវព្រះបន្ទូលទាំង ឡាយខាងជីវិត, **គ. និង ស.** ៨៤:៨៥ ។ ចូរបោះបង់ចោល នូវអស់ ទាំងគំនិតដ៏ឥតប្រយោជន៍របស់អ្នកចុះ, **គ. និង ស.** ៨៨:៦៩ ។ គំនិត នៃចិត្តមនុស្សលោក នឹងត្រូវបានបើក សម្ដែងឲ្យឃើញ, **គ. និង ស.** ៨៨:១០៩ ។ សូមឲ្យគុណធម៌តុបតែងគំនិតអ្នក ដោយឥតឈប់ឈរឡើយ, **គ. និង ស.** ១២១:៤៥ ។ គំនិតដែលមាននៅក្នុងចិត្តរបស់មនុស្ស សុទ្ធតែអាក្រក់ជានិច្ច, **ម៉ូសេ** ៨:២២ ។

**គំនិតផ្ដេសផ្ដាស** *សូមមើលផង* ការនិយាយអាក្រក់

គឺការឲ្យតម្លៃដល់របស់ពិសិដ្ឋទុកជារបស់ផ្ដេសផ្ដាស (គ. និង ស. ៨៤:៥៤) ។

ពួកបរិសុទ្ធមិនត្រូវមានគំនិតអសារឥតការទាំងឡាយ ឬមាន សំណើចសើចហួសហេតុឡើយ, **គ. និង ស.** ៨៨:៦៩ ។ ចូរឈប់ពី សេចក្ដីឆ្មើងឆ្មៃ និងគំនិតផ្ដេសផ្ដាសទាំងអស់របស់អ្នកចុះ, **គ. និង ស.** ៨៨:១២១ ។

**គំរូ**

ជាបែបបទដែលជនណាមួយអាចធ្វើតាម ដើម្បីឲ្យបានផលអ្វីមួយ ។ នៅក្នុងព្រះគម្ពីរ តាមធម្មតា ពាក្យថា គំរូ មានន័យថា ជំរាប់ សំរាប់ការរស់នៅតាមរបៀបណាមួយ ក៏សំរាប់សង់អ្វីមួយ ។

ព្រះអម្ចាស់ ទ្រង់បានបញ្ជាពួកអ៊ីស្រាអែលឲ្យសង់រោងឧបោសថ តាមគំរូដែលទ្រង់បានបង្ហាញដល់លោកម៉ូសេ, **និក្ខ.** ២៥ ។ ដាវីឌបាន ប្រគល់គំរូដល់សាឡូម៉ូនសំរាប់សង់ព្រះវិហារ, **១ របា.** ២៨:១១–

១៣ ។ នៅក្នុងខ្លួនខ្ញុំនោះព្រះយេស៊ូវបានសម្ដែងធ្វើជាក្បួនដល់ពួកអ្នកដែលនឹងជឿដល់ទ្រង់, ១ ធីម៉ូ. ១:១៦ ។ យើងនឹងប្រទានគំរូដល់អ្នក អំពីគ្រប់ទាំងអស់ ដើម្បីកុំឲ្យអ្នករាល់គ្នាអាចត្រូវគេបញ្ឆោត បាន, **គ. និង ស.** ៥២:១៤ ។

**គ្រាកាន់កាប់ត្រួតត្រា***សូមមើលផង* ការសាងឡើងវិញនៃដំណឹងល្អ, កូនសោទាំងឡាយនៃបព្វជិតភាព; ដំណឹងល្អ; បព្វជិតភាព

គ្រាកាន់កាប់ត្រួតត្រាខាងដំណឹងល្អ គឺជារយៈកាល ដែលព្រះអម្ចាស់ទ្រង់មានអ្នកបំរើ ដែលមានសិទ្ធិអំណាចយ៉ាងតិចម្នាក់ នៅលើ ផែនដី ដែលកាន់កូនសោទាំងឡាយនៃបព្វជិតភាពបរិសុទ្ធ ។

អ័ដាម, ហេណុក, ណូអេ, អ័ប្រាហាំ, ម៉ូសេ, ព្រះយេស៊ូវគ្រីស្ទ, យ៉ូសែប ស៊្មីធ, និងអ្នកផ្សេងៗទៀត បានចាប់ផ្ដើមគ្រាកាន់កាប់ត្រួតត្រា នៃដំណឹងល្អថ្មី ។ កាលព្រះអម្ចាស់ទ្រង់រៀបចំគ្រាកាន់កាប់ត្រួតត្រា នោះដំណឹងល្អត្រូវបានបង្ហាញម្ដងទៀត ដើម្បីកុំឲ្យបណ្ដាជនក្នុងគ្រាកាន់កាប់ត្រួតត្រានោះ ត្រូវពឹងផ្អែកទៅលើគ្រាកាន់កាប់ត្រួតត្រាមុនសំរាប់ការចេះដឹងអំពីផែនការនៃសេចក្ដីសង្គ្រោះ ។ គ្រាកាន់ កាប់ត្រួតត្រាដែលចាប់ផ្ដើមដោយយ៉ូសែប ស៊្មីធ គឺស្គាល់ថាជា « គ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ » ។

ព្រះនៃស្ថានសួគ៌ ទ្រង់នឹងតាំងនគរមួយឡើង, **ដានី** ២:៤៤ (គ. និង ស. ៦៥) ។ ដល់ថ្ងៃចុងក្រោយបង្អស់ យើងនឹងចាក់ព្រះវិញ្ញាណ យើងទៅលើគ្រប់ទាំងមនុស្ស, **កិច្ចការ** ២:១៧ (យ៉ូអែល ២:២៨) ។ ស្ថានសួគ៌ត្រូវទទួលព្រះគ្រីស្ទ ដរាបដល់គ្រាតាំងរបស់ទាំងអស់ ឡើងវិញ, **កិច្ចការ** ៣:២១ ។ ក្នុងការកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ នោះព្រះទ្រង់នឹងបង្រួបបង្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ, **អេភេ.** ១:១០ ។ យើងនឹងតាំងសាសនាចក្ររបស់យើងឡើង ក្នុងចំណោមពួកគេ, **៣ នីហ្វៃ** ២១:២២ ។ ព្រះអម្ចាស់ទ្រង់បានប្រគល់ កូនសោទាំងឡាយនៃនគររបស់ទ្រង់ និងនៃការកាន់កាប់ត្រួតត្រានៃដំណឹងល្អសំរាប់ពេលចុងក្រោយបង្អស់, **គ. និង ស.** ២៧:១៣ ។ កូនសោទាំងឡាយនៃការកាន់កាប់ត្រួតត្រានេះ ត្រូវបានប្រគល់ទៅក្នុងដៃរបស់អ្នក, **គ. និង ស.** ១១០:១២–១៦ ។ អស់ទាំងកូនសោ នៃគ្រាកាន់កាប់ត្រួតត្រាមុនទាំងប៉ុន្មានត្រូវបានសាងឡើងវិញ ក្នុងការកាន់កាប់ត្រួតត្រានៃពេលពេញកំណត់, **គ. និង ស.** ១២៨:១៨–២១ ។

**គ្រាចុងក្រោយបង្អស់, គ្រាចុងក្រោយ** *សូមមើលផង* ការយាងមកលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ; ទីសំគាល់អំពីពេលវេលា

ជាពេលវេលាដែលយើងរស់នៅឥឡូវនេះ ។ ជាបច្ចុប្បន្នកាល (ឬគ្រាកាន់កាប់ត្រួតត្រានៅពេលវេលា) មុនការយាងមកលើកទីពីរ នៃព្រះអម្ចាស់ ។

យើងនឹងប្រាប់អ្នកឲ្យដឹងពីការដែលនឹងកើតដល់អ្នករាល់គ្នានៅជាន់ក្រោយ, **លោកុ.** ៤៩:១ ។ ព្រះដ៏ប្រោសលោះទ្រង់នឹងមកឈរ នៅលើផែនដីជាន់ក្រោយ, **យ៉ូប** ១៩:២៥ ។ នៅជាន់ក្រោយបង្អស់ នោះដំណាក់នៃព្រះអម្ចាស់នឹងបានតាំងឡើង, **អេសាយ** ២:២ ។ នៅជាន់ក្រោយបង្អស់នឹងមានគ្រាលំបាកណាស់,២ ធីម៉ូ. ៣:១–៧ ។ នៅជាន់ក្រោយនឹងមានមនុស្សចំអកមិនទទួលស្គាល់ការយាង មកលើកទីពីរ, **២ ពេត្រុស** ៣:៣–៧ ។ ខ្ញុំព្យាករប្រាប់អ្នករាល់គ្នាអំពីគ្រាក្រោយបង្អស់, **២ នីហ្វៃ** ២៦:១៤–៣០ ។ សាសនាចក្ររបស់ យើងនឹងត្រូវបានហៅថាដូច្នោះហើយនៅគ្រាចុងក្រោយបង្អស់ គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.** ១១៥:៤ ។ ព្រះគ្រីស្ទនឹងយាងមកនៅគ្រាចុងក្រោយបង្អស់, **ម៉ូសេ** ៧:៦០ ។

**គ្រូផ្សាយដំណឹងល្អ***សូមមើលផង* ខាងអយ្យកោ; ពរនៃអយ្យកោ, អយ្យកោ

ជាអ្នកដែលផ្ដល់ ឬផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ យ៉ូសែប ស៊្មីធ បានបង្រៀនថា គ្រូផ្សាយដំណឹងល្អ គឺជាអយ្យកោ ។ ពួកអយ្យកោ ត្រូវបានហៅ ហើយតែងតាំងនៅក្រោមការដឹកនាំនៃពួកសាវក ១២ នាក់ ដើម្បីឲ្យប្រទានព្រះពរវិសេស ហៅថា ពរនៃអយ្យកា ។

ព្រះអម្ចាស់ទ្រង់ហៅមនុស្សខ្លះឲ្យធ្វើជាសាវក ខ្លះជាព្យាការី ហើយខ្លះជាគ្រូផ្សាយដំណឹងល្អ, **អេភេ.** ៤:១១ ។ ចូរធ្វើការជាគ្រូផ្សាយដំណឹងល្អចុះ,២ ធីម៉ូ. ៤:៥ ។ ពួកយើងខ្ញុំជឿដល់ពួកសាវក ពួកព្យាការី ពួកគ្រូគង្វាល ពួកគ្រូ ពួកគ្រូផ្សាយដំណឹងល្អ, **ម. នៃ ស.** ១:៦ ។

**គ្រូ, បព្វជិតភាពអើរ៉ុន** *សូមមើលផង* បព្វជិតភាពអើរ៉ុន

ជាតំណែងមួយ ក្នុងបព្វជិតភាពអើរ៉ុន ។

កាតព្វកិច្ចរបស់គ្រូ គឺដើម្បីមើលការខុសត្រូវលើសាសនាចក្រ, **គ. និង ស.** ២០:៥៣–៦០ ។ តំណែងនៃគ្រូ គឺជាការបន្ថែមបញ្ជាប់ ចាំបាច់ ទៅនឹងបព្វជិតភាពតូចជាង, **គ. និង ស.** ៨៤:៣០, ១១១ ។ ប្រធាននៅលើក្រុមនៃពួកគ្រូ គឺត្រូវត្រួតត្រាលើគ្រូ២៤នាក់, **គ. និង ស.** ១០៧:៨៦ ។

**គ្រួសារ***សូមមើលផង* កូនក្មេង, ពួកកូនក្មេង; ម្ដាយ, រៀបអាពាហ៍ពិពាហ៍; អាពាហ៍ពិពាហ៍, ឪពុកខាងសាច់ឈាម

ដូចដែលប្រើនៅក្នុងគម្ពីរ គ្រួសារមានប្ដីប្រពន្ធ និងកូនចៅ ហើយជួនកាល មានញាតិសន្ដានរស់នៅក្នុងផ្ទះតែមួយ ឬនៅក្រោម មេគ្រួសារតែមួយ ។ គ្រួសារក៏អាចមានតែឪពុក ឬម្ដាយ និងកូនចៅ, ប្ដីនិងប្រពន្ធឥតមានកូនចៅ, ឬក៏មនុស្សដែលនៅលីវរស់នៅ ម្នាក់ឯង ។

*ទូទៅ៖* គ្រប់ទាំងគ្រួសារនៅផែនដីនឹងបានពរដោយសារឯង, **លោកុ.** ១២:៣ (លោកុ. ២៨:១៤; អ័ប្រា. ២:១១) ។ យើងនឹងធ្វើជា ព្រះដល់គ្រប់ទាំងគ្រួសារនៃសាសន៍អ៊ីស្រាអែល, **យេរេ.** ៣១:១ ។ គ្រប់ទាំងគ្រួសារនៅស្ថានសួគ៌ ហើយនៅផែនដី មាននាមត្រកូលពីព្រះវរបិតាមក, **អេភេ.** ៣:១៤–១៥ ។ លោកអ័ដាម និងនាងអេវ៉ាបានបង្កើតគ្រួសារទាំងឡាយនៃអស់ទាំងផែនដី, **២ នីហ្វៃ** ២:២០ ។ សិរីល្អរបស់អ្នក គឺនឹងបានពូជបន្តបន្ទាប់ ជារៀងដរាបតទៅ, **គ. និង ស.**

១៣២:១៩ ។ យើងនឹងប្រទានឲ្យលោកនូវមកុដនៃជីវិតទាំង ឡាយដ៏នៅអស់កល្បជានិច្ច នៅក្នុងពិភពទាំងឡាយដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ១៣២:៥៥ ។ ការភ្ជាប់កូនចៅទៅឯមាតាបិតា គឺជាភាគមួយនៃកិច្ចការដ៏មហិមានៅពេលពេញកំណត់, **គ. និង ស.** ១៣៨:៤៨ ។ ជាប្រុសជាស្រី យើងបានបង្កើតពួកគេឡើង ហើយយើងបានមានបន្ទូលទៅពួកគេថា៖ ចូរបង្កើតកូនឲ្យចំរើនជាច្រើនឡើង, **ម៉ូសេ** ២:២៧–២៨ ។ វាមិនល្អទេដែលបុរសនេះត្រូវ នៅតែម្នាក់ឯង, **ម៉ូសេ** ៣:១៨ ។ លោកអ័ដាម និងនាងអេវ៉ាបានធ្វើការជាមួយគ្នា, **ម៉ូសេ** ៥:១ ។

*កាតព្វកិច្ចរបស់ពួកឪពុកម្ដាយ៖* អ័ប្រាហាំនឹងបង្គាប់កូនចៅលោក ហើយពួកគេនឹងកាន់ខ្ជាប់តាមផ្លូវនៃព្រះអម្ចាស់, **លោកុ.** ១៨:១៧–១៩ ។ អ្នកត្រូវបង្រៀនពាក្យទាំងនេះដល់កូនចៅអ្នកដោយប្រិតប្រៀន, **ចោទិ.** ៦:៧ (ចោទិ. ១១:១៩) ។ អ្នកណាដែល ស្រឡាញ់កូន នោះវាយផ្ចាលវា, **សុភា.** ១៣:២៤ (សុភា. ២៣:១៣) ។ ចូរបង្ហាត់កូនក្មេង ឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្ត, **សុភា.** ២២:៦ ។ រស់នៅដោយអំណរ ជាមួយនឹងប្រពន្ធជាទីស្រឡាញ់របស់អ្នក, **សាស្ដា** ៩:៩ ។ កូនចៅទាំងប៉ុន្មានរបស់អ្នក នឹងធ្វើជាសិស្ស របស់ព្រះអម្ចាស់, **អេសាយ** ៥៤:១៣ (៣ នីហ្វៃ ២២:១៣) ។ ចូរបង្រៀននាទៅតាមដំបូន្មានរបស់ព្រះអម្ចាស់, **អេភេ.** ៦:១–៤ (អេណុស ១:១) ។ បើមានអ្នកណា ដែលមិនផ្គត់ផ្គង់ឲ្យពួកញាតិសន្តានខ្លួន អ្នកនោះឈ្មោះថា បានបោះបង់ចោលសេចក្ដីជំនឿ ហើយ, ១ ធីម៉ូ. ៥:៨ ។ លោកបានទូន្មានពួកគេដោយអស់ទាំងអារម្មណ៍របស់មេបាដ៏ទន់ភ្លន់ម្នាក់, **១ នីហ្វៃ** ៨:៣៧ ។ ពួកយើងនិយាយអំពីព្រះគ្រីស្ទ ដើម្បីឲ្យកូនចៅយើង អាចដឹងនូវប្រភពអ្វីដែលគេអាចមើលទៅ, **២ នីហ្វៃ** ២៥:២៦ ។ ប្ដីប្រពន្ធរបស់គេស្រឡាញ់កូនៗរបស់ខ្លួន, **យ៉ាកុប** ៣:៧ ។ ចូរបង្រៀនកូនចៅឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយបំរើគ្នាទៅវិញទៅមក, **ម៉ូសាយ** ៤:១៤–១៥ ។ អ្នកត្រូវ ការពារគ្រួសាររបស់អ្នក ទោះជាត្រូវកំចាយឈាមក៏ដោយ, **អាលម៉ា** ៤៣:៤៧ ។ ចូរអធិស្ឋានជាមួយគ្រួសាររបស់អ្នក ដើម្បីឲ្យប្រពន្ធ កូនអ្នកអាចបានទទួលពរ, **៣ នីហ្វៃ** ១៨:២១ ។ ពួកឪពុកម្ដាយត្រូវបង្រៀនដំណឹងល្អដល់កូនចៅរបស់ខ្លួន, **គ. និង ស.** ៦៨:២៥ ។ មនុស្សគ្រប់រូបតម្រូវឲ្យផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួនផ្ទាល់, **គ. និង ស.** ៧៥:២៨ ។ គ្រប់កូនក្មេងទាំងអស់មានសិទ្ធិពឹងពាក់ទៅលើ ឪពុកម្ដាយរបស់ខ្លួន, **គ. និង ស.** ៨៣: ៤ ។ ចូរចញ្ចឹមកូនចៅរបស់ខ្លួន នៅក្នុងពន្លឺ និងសេចក្ដីពិត, **គ. និង ស.** ៩៣:៤០ ។ តាំងគេហដ្ឋានរបស់ខ្លួនឲ្យមានរបៀបរៀបរយ, **គ. និង ស.** ៩៣:៤៣–៤៤, ៥០ ។ ពួកអ្នកកាន់បព្វជិតភាពត្រូវបញ្ចុះបញ្ចូលអ្នកផ្សេង ដោយការ ស្រឡាញ់ស្មោះត្រង់ប៉ុណ្ណោះ, **គ. និង ស.** ១២១:៤១ ។ លោកអ័ដាម និងនាងអេវ៉ាពួកគេបានប្រាប់គ្រប់ការណ៍ទាំង អស់ដល់កូនចៅរបស់គេ, **ម៉ូសេ** ៥:១២ ។

*កាតព្វកិច្ចរបស់កូន៖* ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយខ្លួន, **និក្ខ.** ២០:១២ ។ កូនអើយ ចូរស្ដាប់ពាក្យប្រៀនប្រដៅរបស់ឪពុកចុះ, **សុភា.** ១:៨ (សុភា. ១៣:១; ២៣:២២) ។ ព្រះយេស៊ូវនៅក្នុងឱវាទរបស់មាតាបិតារបស់ទ្រង់, **លូកា** ២:៥១ ។ ព្រះយេស៊ូវទ្រង់បាន ធ្វើតាមបំណងព្រះហឫទ័យនៃព្រះវរបិតារបស់ទ្រង់, **យ៉ូហាន** ៦:៣៨ (៣ នីហ្វៃ ២៧:១៣) ។ ចូរស្ដាប់បង្គាប់មាតាបិតាក្នុងព្រះអម្ចាស់, **អេភេ.** ៦:១ (កូល៉ុស ៣:២០) ។ បើសិនជាកូនចៅប្រែចិត្ត នោះសេចក្ដីក្ដៅក្រហាយរបស់អ្នកនឹងបានបែរចេញ, **គ. និង ស.** ៩៨:៤៥–៤៨ ។ បុត្រីទាំងឡាយរបស់នាងអេវ៉ា ដែលមានចិត្តស្មោះត្រង់បានថ្វាយបង្គំព្រះដ៏ពិត ហើយមានព្រះជន្មរស់នៅ, **គ. និង ស.** ១៣៨:៣៨–៣៩ ។

*គ្រួសារដ៏នៅអស់កល្បជានិច្ច៖* គោលលទ្ធិ និងសេចក្ដីសញ្ញាតាំងឡើងនូវធម្មភាពដ៏នៅអស់កល្បជានិច្ចនៃការទាក់ទងខាង អាពាហ៍ពិពាហ៍ និងខាងគ្រួសារ ។ អាពាហ៍ពិពាហ៍ខាងសេឡេស្ទាល និងការបន្តក្រុមគ្រួសារនោះធ្វើឲ្យប្ដីប្រពន្ធក្លាយទៅជាព្រះ (គ. និង ស. ១៣២:១៥–២០) ។

## គ្រឿងការពារ

ជាប្រដាប់ពាក់ដើម្បីការពារខ្លួនពីការវាយសំពង ឬពីការចាក់ដោយអាវុធ ។ ពាក្យនេះក៏បានយកមកប្រើក្នុងន័យថា លក្ខណៈខាង វិញ្ញាណដែរ ដែលការពារជនណាមួយពីសេចក្ដីល្បួង ឬពីអំពើអាក្រក់ ។

ចូរពាក់គ្រប់គ្រឿងការពាររបស់ព្រះ, **អេភេ.** ៦:១០–១៨ (គ. និង ស. ២៧:១៥–១៨) ។

## គេឌាន (ព្រះគម្ពីរសញ្ញាចាស់)

ជាអ្នកដឹកនាំម្នាក់ ដែលបានរំដោះពួកអ៊ីស្រាអែល ពីពួកសាសន៍ម៉ាឌាន (ចៅហ្វាយ ៦:១១–៤០; ៧–៨) ។

## ឃ្លង់

ជារោគដ៏ជាប់រាលដាលមួយ ដែលបាននិយាយដល់ជាញយៗ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ។ មនុស្ស ដែលគេស្គាល់ជាច្រើននៅព្រះគម្ពីរប៊ីបនៅពេលណាមួយមានរោគនេះ ព្រមទាំងលោកម៉ូសេផង (និក្ខ. ៤:៦–៧), នាងម៉ារាម ជាបងស្រីលោក (ជនគ. ១២:១០), ណាម៉ាន់ (២ ពង្សា. ៥), និងស្ដេចអូសៀស (២ របា. ២៦:១៩–២១) ។

ព្រះយេស៊ូវទ្រង់បានប្រោសឲ្យមនុស្សជាច្រើនឲ្យជាពីឃ្លង់, **ម៉ាថាយ** ៨:២–៤ (ម៉ាកុស ១:៤០–៤៥; លូកា ៥:១២–១៥; ៣ នីហ្វៃ ១៧:៧–៩) ។ ព្រះយេស៊ូវទ្រង់បានប្រោសមនុស្សឃ្លង់ ១០ នាក់ឲ្យជា, **លូកា** ១៧:១១–១៩ ។

## ឃាតកម្ម *សូមមើលផង* កាអ៊ីន; ទោសដល់ជីវិត

គឺសម្លាប់មនុស្សដោយខុសច្បាប់ និងដោយចេតនា ។ ឃាតកម្មគឺជាអំពើបាបដែលត្រូវដាក់ទោស ចាប់ពីពេលដំបូងបង្អស់មក (លោកុ. ៤:១–១២; ម៉ូសេ ៥:១៨–៤១) ។

អ្នកណាដែលកំចាយឈាមរបស់មនុស្ស នោះឈាមអ្នកនោះឯងនឹងត្រូវខ្ចាយដោយសារមនុស្សដែរ, **លោកុ.** ៩:៦ (ក.យ.ស., លោកុ. ៩:១២–១៣; និក្ខ. ២១:១២; អាលម៉ា ៣៤:១២) ។ កុំឲ្យសម្លាប់

មនុស្សឲ្យសោះ, **និក្ខ.** ២០:១៣ (ចោទិ. ៥:១៧; ម៉ាថាយ ៥:២១–២២; ម៉ូសាយ ១៣:២១; គ. និង ស. ៥៩:៦) ។ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា «កុំឲ្យសម្លាប់មនុស្សឲ្យសោះ», **ម៉ាថាយ** ១៩:១៨ ។ ពួកកាប់សម្លាប់គេនឹងមានចំណែកក្នុងសេចក្តីស្លាប់ទីពីរ, **វិវ.** ២១:៨ ។ បងរាល់គ្នាជាពួកឃាតករនៅក្នុងដួងចិត្ត, **១ នីហ្វៃ** ១៧:៤៤ ។ វេទនាដល់ឃាតករ ដែលសម្លាប់គេដោយចេតនា, **២ នីហ្វៃ** ៩:៣៥ ។ ព្រះទ្រង់បានបញ្ជាថា មនុស្សមិនត្រូវធ្វើ ឃាតកម្មឡើយ, **២ នីហ្វៃ** ២៦:៣២ ។ អំពើឃាតកម្ម គឺជាអំពើគួរខ្ពើមឆ្អើមដល់ព្រះអម្ចាស់, **អាលម៉ា** ៣៩:៥–៦ ។ អ្នកណាដែល សម្លាប់ នោះនឹងពុំបានការអត់ទោសឡើយ, **គ. និង ស.** ៤២:១៨ ។ នរណាមួយដែលសម្លាប់គេ នោះនឹងត្រូវបញ្ជូនឡើងទៅរកច្បាប់ ទាំងឡាយនៃប្រទេស, **គ. និង ស.** ៤២:៧៩ ។

**ឃុំចាកសុន រដ្ឋមិសសួរី (សហរដ្ឋ)** *សូមមើលផង* ក្រុងយេរូសាឡិមថ្មី

ជាទីកន្លែងជួបជុំគ្នានៃពួកបរិសុទ្ធ នៅថ្ងៃចុងក្រោយបង្អស់ គឺជាទីប្រជុំដែលពួកគេនឹងតាំងក្រុងយេរូសាឡិមថ្មី (គ. និង ស. ៥៧–៥៨; ៨២; ១០១:៦៩–៧១; ១០៥:២៨) ។

**ឃ្លាំង** *សូមមើលផង* សុខុមាលភាព

ជាទីកន្លែងមួយដែលប៊ីស្សពទទួល, កាន់កាប់, ហើយចែកចាយដល់មនុស្សក្រីក្រ នូវដង្វាយដែលថ្វាយដោយពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ឃ្លាំងនីមួយៗ អាចមានទំហំធំ ឬតូច តាមតែកាលៈទេសៈត្រូវការ ។ ពួកបរិសុទ្ធដ៏ស្មោះត្រង់ ប្រគល់នូវការប៉ិនប្រសប់, ជំនាញការ, របស់របរ, និងប្រាក់កាសដល់ប៊ីស្សព ដើម្បីឲ្យថែរក្សាពួកមនុស្សក្រីក្រ ក្នុងពេលត្រូវការ ។ ហេតុដូច្នេះហើយ ឃ្លាំងនីមួយៗ អាចមាន រួមនូវការបំរើ, ប្រាក់កាស, ម្ហូបអាហារ, ឬរបស់របរផ្សេងៗ ។ ប៊ីស្សព គឺជាភ្នាក់ងារនៃឃ្លាំង ហើយចែកចាយរបស់របរ និងការបំរើ ទាំងឡាយតាមសេចក្តីត្រូវការ និងតាមការដឹកនាំពីព្រះវិញ្ញាណនៃព្រះអម្ចាស់ (គ. និង ស. ៤២:២៩–៣៦; ៨២:១៤–១៩) ។

ចូរឲ្យគេប្រមូលស្បៀងអាហារបំរុងទុក សំរាប់អំណត់ទាំង ៧ ឆ្នាំ, **លោកុ.** ៤១:៣៤–៣៦, ៤៦–៥៧ ។ ចូរនាំយកដង្វាយ១ភាគក្នុង១០ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ, **ម៉ាឡាគី** ៣:១០ (៣ នីហ្វៃ ២៤:១០) ។ ចូរឲ្យប៊ីស្សពតាំងឃ្លាំងមួយឡើងចំពោះសាសនាចក្រនេះ, **គ. និង ស.** ៥១:១៣ ។ របស់របរដែលមានច្រើនលើស នោះត្រូវឲ្យទៅឃ្លាំងរបស់យើង, **គ. និង ស.** ៧០:៧–៨ ។ ពួកបរិសុទ្ធត្រូវចាត់ចែង ហើយតាំងឃ្លាំងមួយឡើង, **គ. និង ស.** ៧៨:១–៤ ។ ពួកកូនក្មេងមានសិទ្ធិពឹងពាក់ទៅលើឃ្លាំងរបស់ព្រះអម្ចាស់ បើឪពុកម្តាយ គេគ្មានអ្វី, **គ. និង ស.** ៨៣:៥ ។

**ចាក់ប្រេង, លាបប្រេង***សូមមើលផង* ការប្រសិទ្ធិពរដល់មនុស្សឈឺ; ប្រេង

នៅសម័យបុរាណ ពួកព្យាការីរបស់ព្រះអម្ចាស់ បានចាក់ប្រេងតាំងអ្នកណាដែលនឹងធ្វើការពិសេសៗ ដូចជាលោកអើរ៉ុន ឬពួកសង្ឃ ឬស្តេចទាំងឡាយណាដែលនឹងគ្រប់គ្រងលើពួកអ៊ីស្រាអែល ។ នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ចាក់ប្រេងលាប គឺបន្តក់ប្រេងដែលបានឧទ្ទិសទុកមួយ ឬពីរតំណក់ ទៅលើក្បាលជនណាមួយ ទុកជាផ្នែកនៃពរដ៏វិសេសមួយ ។ ការនេះអាចប្រព្រឹត្តទៅបាន នៅក្រោមសិទ្ធិ អំណាច និងអំណាចនៃបព្វជិតភាពមិលគីស្សាដែកតែប៉ុណ្ណោះ ។ កាលបានចាក់ប្រេងរួចហើយ នោះអ្នកដែលមានសិទ្ធិអំណាចនៃ បព្វជិតភាពដដែលនោះ អាចភ្ជាប់ការចាក់ប្រេង ហើយឲ្យពរពិសេសដល់អ្នកដែលគេលាបប្រេងឲ្យ ។

ចូរចាក់ប្រេងតាំងគេឡើង ហើយញែកចេញជាបរិសុទ្ធ ដើម្បីឲ្យបានធ្វើការងារបំរើដល់យើង, **និក្ខ.** ២៨:៤១ (លេវី. ៨:៦–១២, ៣០) ។ ចូរចាក់ប្រេងតាំងអ្នកនោះឲ្យគ្រប់គ្រងលើពួកអ៊ីស្រាអែល ជារាស្ត្រយើងចុះ, **១ សាំយូ.** ៩:១៦; ១០:១ ។ ពួកអែលឌើរត្រូវចាក់ប្រេងលាប ហើយឲ្យពរដល់មនុស្សឈឺ, **យ៉ាកុប (ព.ស.ថ.)** ៥:១៤–១៥ (គ. និង ស. ៤២:៤៤) ។

**ចិត្តទន់ទាប** *មើល* ចិត្តសង្រេង

**ចិត្តសង្រេង** *សូមមើលផង* ការប្រែចិត្ត; ចិត្ត; ចិត្តសុភាពរាបសា; បន្ទាបខ្លួន, បូជា, ប្រែចិត្ត, ភាពស្លូតបូត; ស្លូតបូត

មានចិត្តសង្រេង គឺត្រូវបន្ទាបខ្លួន មានចិត្តទន់ទាប ប្រែចិត្ត ហើយស្លូតបូត — គឺត្រូវស្តាប់តាមព្រះហឫទ័យនៃព្រះ ។

យើងនៅជាមួយនឹងអ្នកណាដែលមានចិត្តសង្រេង ហើយវិញ្ញាណទន់ទាប, **អេសាយ** ៥៧:១៥ ។ ព្រះគ្រីស្ទថ្វាយព្រះអង្គទ្រង់ ជំនួសអស់អ្នកណា ដែលមានចិត្តសង្រេង ហើយវិញ្ញាណទន់ទាប, **២ នីហ្វៃ** ២:៧ ។ ចូរថ្វាយដល់ព្រះអម្ចាស់ នូវចិត្តសង្រេង និងវិញ្ញាណទន់ទាបចុះ, **៣ នីហ្វៃ** ៩:២០ (គ. និង ស. ៥៩:៨) ។ លើកលែងតែអស់អ្នកណាដែលមានចិត្តសង្រេង និងវិញ្ញាណទន់ទាបប៉ុណ្ណោះទេ ដែលបានទទួល ចំពោះបុណ្យជ្រមុជទឹក, **មរ៉ូណៃ** ៦:២ ។ ព្រះយេស៊ូវត្រូវគេឆ្កាង ដើម្បីសេចក្តីផ្តាច់បាបទាំងឡាយ ចំពោះពួកអ្នក មានចិត្តសង្រេង, **គ. និង ស.** ២១:៩ ។ អ្នកណាដែលមានវិញ្ញាណទន់ទាប អ្នកនោះឈ្មោះថា ត្រូវបានទទួលហើយ, **គ. និង ស.** ៥២:១៥ ។ ព្រះវិញ្ញាណបរិសុទ្ធបានត្រូវសន្យាឲ្យដល់អស់អ្នកណាដែលមានចិត្តសង្រេង, **គ. និង ស.** ៥៥:៣ ។ ព្រះវិញ្ញាណរបស់យើង ត្រូវបានចាត់ឲ្យទៅបំភ្លឺ ដល់ពួករាបសា និងពួកទន់ទាប, **គ. និង ស.** ១៣៦:៣៣ ។

**ចិត្ត***សូមមើលផង* កើតពីព្រះ; កើតម្តងទៀត, ចិត្តសង្រេង

គឺជានិមិត្តរូបអំពីគំនិត និងចំណង់នៃមនុស្ស ហើយជាប្រភពដែលជាគំរូអំពីគ្រប់ទាំងអារម្មណ៍ និងទឹកចិត្ត ។

ចូរស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃអ្នកឲ្យអស់ពីចិត្ត, **ចោទិ.** ៦:៥ (ចោទិ. ៦:៣–៧; ម៉ាថាយ ២២:៣៧; លូកា ១០:២៧; គ. និង ស.

៥៩:៥) ។ ព្រះអម្ចាស់ទ្រង់រកបានមនុស្សមួយ ដែលត្រូវនឹងព្រះហឫទ័យទ្រង់, **១ សាំយូ.** ១៣:១៤ ។ មនុស្សមើលតែឫកពាខាង ក្រៅ តែព្រះអម្ចាស់ ទ្រង់ទតចំពោះក្នុងចិត្តវិញ, **១ សាំយូ.** ១៦:៧ ។ អ្នកដែលមានដៃស្អាត និងចិត្តបរិសុទ្ធ នឹងឡើងទៅឯភ្នំនៃ ព្រះអម្ចាស់ ហើយនឹងបានពរ, **ទំនុក.** ២៤:៣–៥ (២ នីហ្វៃ ២៥:១៦) ។ ដូចជាមនុស្សគិតក្នុងចិត្តយ៉ាងណា គេក៏យ៉ាងនោះដែរ, **សុភា.** ២៣:៧ ។ អេលីយ៉ានឹងបង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុកវិញ, **ម៉ាឡាគី** ៤:៥–៦ (លូកា ១:១៧; គ. និង ស. ២:២; ១១០:១៤–១៥; ១៣៨:៤៧; យ.ស. — ប្រវត្តិ ១:៣៩) ។ មានពរហើយ អ្នកដែលមានចិត្តបរិសុទ្ធ, **ម៉ាថាយ** ៥:៨ (៣ នីហ្វៃ ១២:៨) ។ មនុស្សនិយាយអំពីសេចក្ដីល្អ ឬសេចក្ដីអាក្រក់ ដែលនៅក្នុងចិត្ត, **លូកា** ៦:៤៥ ។ ចូរដើរតាមព្រះរាជបុត្រាដោយពេញចិត្តប្រាថ្នា, **២ នីហ្វៃ** ៣១:១៣ ។ តើអ្នករាល់គ្នាបានកើតពីព្រះក្នុងវិញ្ញាណ ហើយបានស្គាល់ការផ្លាស់ប្ដូរដ៏ធំនេះ នៅក្នុងដួងចិត្តអ្នកហើយឬអី ?, **អាលម៉ា** ៥:១៤ ។ ចូរថ្វាយដល់ព្រះអម្ចាស់ នូវចិត្តសង្រេង និងវិញ្ញាណទន់ទាបចុះ, **៣ នីហ្វៃ** ៩:២០ (៣ នីហ្វៃ ១២:១៩; អេធើរ ៤:១៥; មរ៉ូណៃ ៦:២) ។យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នក ដោយព្រះវិញ្ញាណបរិសុទ្ធ, **គ. និង ស.** ៨:២ ។

**ចិត្តឧស្សាហ៍**

ជាសេចក្ដីខិតខំយ៉ាងនឹងនរ និងយ៉ាងខ្លាំងក្លា ជាវិសេស នៅក្នុងការបំរើព្រះអម្ចាស់ និងគោរពតាមព្រះបន្ទូលរបស់ទ្រង់ ។

ចូរប្រុងស្ដាប់តាមយើងឲ្យអស់ពីចិត្តចុះ, **អេសាយ** ៥៥:២ ។ ព្រះទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលព្យាយាមស្វែងរកទ្រង់, **ហេព្រើរ** ១១:៦ ។ ចូរឲ្យមានសេចក្ដីឧស្សាហ៍គ្រប់យ៉ាង គឺបន្ថែមដំរិះទៅសេចក្ដីជំនឿរបស់អ្នក, **២ ពេត្រុស** ១:៥ ។ ចូរបង្រៀនព្រះបន្ទូលនៃ ព្រះឲ្យអស់ពីសេចក្ដីព្យាយាម, **យ៉ាកុប** ១:១៩ ។ ពួកគេបានពិចារណាមើលបទព្រះគម្ពីរយ៉ាងព្យាយាម, **អាលម៉ា** ១៧:២ ។ ពួកគេធ្វើ ការព្យាយាមគ្រប់យ៉ាង ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយ, **៣ នីហ្វៃ** ៦:១៤ ។ ចូរយើងព្យាយាមធ្វើការដោយខិតខំ, **មរ៉ូណៃ** ៩:៦ ។ ត្រូវឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ, **គ. និង ស.** ៥៨:២៩ ។ ចូរកុំខ្ជិលច្រអូសឡើយ ប៉ុន្ដែធ្វើការដោយកម្លាំងរបស់អ្នកចុះ, **គ. និង ស.** ៧៥:៣ ។ ចូរព្យាយាមស្ដាប់តាមព្រះបន្ទូលទាំងឡាយអំពីជីវិតដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ៨៤:៤៣ ។ ចូរឲ្យមនុស្សគ្រប់រូប រៀនពីភារកិច្ចរបស់ខ្លួន ហើយឲ្យប្រតិបត្តិដោយសេចក្ដីឧស្សាហ៍គ្រប់ជំពូក, **គ. និង ស.** ១០៧:៩៩ ។

**ចុងបំផុតផែនដី***សូមមើល* ពិភពលោក — ចុងបំផុតផែនដី

**ចេរ៉ូប៊ីន**

ជារូបតំណាងសត្វពីស្ថានសួគ៌ រីឯរូបពិតប្រាកដយ៉ាងណា នោះគ្មាននរណាដឹងទេ ។ ចេរ៉ូប៊ីនបានត្រូវហៅឲ្យចាំយាមកន្លែងពិសិដ្ឋ ទាំងឡាយ ។

ព្រះអម្ចាស់ ទ្រង់ដាក់ចេរ៉ូប៊ីនឲ្យរក្សាផ្លូវទៅឯដើមជីវិត, **លោកុ.** ៣:២៤ (អាលម៉ា ១២:២១–២៩; ៤២:២–៣; ម៉ូសេ ៤:៣១) ។ គំរូតំណាងនៃរូបចេរ៉ូប៊ីន បានត្រូវដាក់នៅលើទីសន្ដោស, **និក្ខ.** ២៥:១៨, ២២ (១ពង្សា. ៦:២៣–២៨; ហេព្រើរ ៩:៥) ។ ចេរ៉ូប៊ីន បានត្រូវពោលដល់ នៅក្នុងការនិមិត្តរបស់អេសេគាល, **អេសេ.** ១០; ១១:២២ ។

**ចោទិយកថា***សូមមើលផង* គម្ពីរ៥ច្បាប់

មានន័យថា « ការតម្រួតច្បាប់ » ហើយជាគម្ពីរទី ៥ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

ចោទិយកថាមានសេចក្ដីថ្លែងទីបីចុងក្រោយបង្អស់នៃម៉ូសេ ដែលលោកបាននិយាយក្នុងវាលម៉ូអាប់ មុនលោកត្រូវបានប្រែរូប ។ សេចក្ដីថ្លែងទី ១ (ជំពូកទី ១–៤) ជាពាក្យណែនាំ ។ សេចក្ដីថ្លែងទី ២ (ជំពូកទី៥–២៦) មានពីរភាគ គឺៈ (១) ជំពូកទី ៥–១១ — ជាព្រះបញ្ញត្តិ ១០ ប្រការ ហើយជាការអធិប្បាយដ៏មានប្រយោជន៍ប្រាប់អំពីព្រះបញ្ញត្តិទាំងនោះ ហើយ (២) ជំពូកទី ១២–២៦ — ជាវិន័យនៃច្បាប់ ដែលរួមធ្វើជាមូលដ្ឋាននៃគម្ពីរទាំងមូល ។ សេចក្ដីថ្លែងទី ៣ (ជំពូកទី ២៧–៣០) មានការសាងឡើងវិញដ៏ហ្មតចត់នូវសេចក្ដីសញ្ញារវាងពួកអ៊ីស្រាអែលនិងព្រះ ហើយជាសេចក្ដីប្រទានព្រះពរ ដែលបានមកពីការគោរព និងបណ្ដាសា ដែលបានមកពីការឥតគោរព ។ ជំពូកទី ៣១–៣៤ រៀបរាប់អំពីការរំដោះច្បាប់ចំពោះពួកលេវី អំពីចំរៀងម៉ូសេ និងព្រះពរចុងក្រោយបង្អស់ ហើយនិងអំពីការឃ្លាតចេញរបស់ម៉ូសេ ។

**ចំការទំពាំងបាយជូរនៃព្រះអម្ចាស់** *សូមមើលផង* វាល; ស្រែ, អ៊ីស្រាអែល

ជានិមិត្តរូបមួយ អំពីវាលស្រែនៃកិច្ចការខាងវិញ្ញាណ ។ តាមធម្មតា នៅក្នុងព្រះគម្ពីរ ចំការទំពាំងបាយជូរនៃព្រះអម្ចាស់ សំដៅដល់វង្សអ៊ីស្រអែល ឬនគរព្រះនៅលើផែនដី ។ ជួនកាល ចំការទំពាំងបាយជូរសំដៅដល់បណ្ដាជនទូទៅ ដែលនៅលើពិភពលោក ។

ចំការទំពាំងបាយជូររបស់ព្រះអម្ចាស់នៃពួកពលបរិវារ នោះគឺជាពូជពង្សរបស់អ៊ីស្រាអែល, **អេសាយ** ៥:៧ (២ នីហ្វៃ ១៥:៧) ។ ព្រះយេស៊ូវទ្រង់បានប្រាប់នូវពាក្យប្រៀបប្រដូចអំពីពួកអ្នកធ្វើការ នៅក្នុងចំការទំពាំងបាយជូរ, **ម៉ាថាយ** ២០:១–១៦ ។ ពួកអ៊ីស្រាអែលគឺប្រៀបដូចជាដើមអូលីវស្រុក ដែលបានថែរក្សា នៅក្នុងចំការរបស់ព្រះអម្ចាស់, **យ៉ាកុប** ៥ ។ ពួកអ្នកបំរើនៃព្រះអម្ចាស់ នឹងកាត់ត្រួសចំការរបស់ទ្រង់ ជាលើកចុងក្រោយបង្អស់, **យ៉ាកុប** ៦ ។ ព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់អស់អ្នកណា ដែលធ្វើការនៅក្នុងចំការទំពាំងបាយជូររបស់ទ្រង់, **គ. និង ស.** ២១:៩ (អាលម៉ា ២៨:១៤) ។ ចូរអ្នករាល់គ្នាធ្វើការ នៅក្នុងចំការទំពាំងបាយជូររបស់យើងជាលើកចុងក្រោយបង្អស់ចុះ, **គ. និង ស.** ៤៣:២៨ ។

**ចំរឹង, ស្តេក**

ជាក្រុមនៃអង្គការ និងទីចាត់ការមួយក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ស្តេករួមមានវួដ ឬសាខាទាំងឡាយ ។ តាមធម្មតា ស្តេកមានព្រំដែនប្រចាំភូមិភាគ ហើយយកលំនាំតាមគំរូត្រសាល ដែលបានអធិប្បាយប្រាប់ នៅក្នុង គម្ពីរអេសាយ ៥៤:២ ថា៖ « ចូរបន្តខ្សែឲ្យវែង និងបោះចំរឹងឲ្យមាំឡើង » ។ ស្តេកនីមួយៗ នៃក្រុងស៊ីយ៉ូន គាំទ្រ ហើយជួយដើម្បី លើកសាសនាចក្រឡើង ដូចជាត្រសាល ឬរោងឧបោសថ ដំកើងឡើងដោយចំរឹង ។ ស្តេក គឺជាទីប្រជុំមួយ សំរាប់ពួកសំណល់នៃ អ៊ីស្រាអែលដែលរសាត់ព្រាត់ទាំងឡាយ (គ. និង ស. ៨២:១៣–១៤; ១០១:១៧–២១) ។

ចូរពង្រឹងចំរឹង ហើយចូរពង្រីកនូវព្រំដែនរបស់ខ្លួន, **ម៉ូរ៉ូណៃ** ១០:៣១ (គ. និង ស. ៨២:១៤) ។ សូមតាំងដល់ស៊ីយ៉ូន នូវស្តេកផ្សេងៗទៀត ក្រៅពីស្តេកនេះ, **គ. និង ស.** ១០៩:៥៩ ។ ការប្រមូលគ្នាមកលើដែនដីស៊ីយ៉ូន និងមកលើស្តេកទាំងឡាយរបស់នាង អាចបានទៅជាទីការពារ, **គ. និង ស.** ១១៥:៦ (គ. និង ស. ១០១:២១) ។ កន្លែងផ្សេងៗទៀតត្រូវបានតាំងឡើង សំរាប់ស្តេកទាំងឡាយ, **គ. និង ស.** ១១៥:១៨ ។ ប្រធានលើក្រុមនៃពួកសង្ឃជាន់ខ្ពស់បានតែងតាំងឡើងដើម្បីរើសអស់អ្នកណា ដែលនឹងបានតាំងឡើងជាពួក ប្រធានលើស្តេក, **គ. និង ស.** ១២៤:១៣៣–១៣៤ ។ ចូរអ្នករាល់គ្នាចេញទៅឯដែនដីស៊ីយ៉ូន ប្រយោជន៍ឲ្យស្តេកទាំងឡាយរបស់នាងអាចបានចំរើនកម្លាំង, **គ. និង ស.** ១៣៣:៩ ។

**ចំរូត**

ជួនកាល បទគម្ពីរយកពាក្យ *ចំរូត* មកប្រើជាគំរូ ដើម្បីនិយាយពីការនាំមនុស្សចូលសាសនាចក្រ ដែលជានគរព្រះនៅលើផែនដី ឬពីគ្រាជំនុំជំរះ ដូចជាការយាងមកលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ ។

រដូវច្រូតកាត់បានកន្លងហើយ រដូវក្តៅក៏ផុតទៅ តែយើងរាល់គ្នាមិនទាន់បានសង្គ្រោះនៅឡើយ, **យេរេ.** ៨:២០ (គ. និង ស. ៥៦:១៦) ។ ចំរូតធំណាស់ តែមានអ្នកច្រូតតិចទេ, **ម៉ាថាយ** ៩:៣៧ ។ ចំរូតគឺជាបំផុតកល្ប, **ម៉ាថាយ** ១៣:៣៩ ។ ពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ, **កាឡាទី** ៦:៧–៩ (គ. និង ស. ៦:៣៣) ។ ស្រែសស់ព្រោះល្មមច្រូតហើយ, **គ. និង ស.** ៤:៤ ។ រដូវច្រូតកាត់បានផុតទៅ ហើយព្រលឹងរបស់អ្នករាល់គ្នាមិនទាន់បានសង្គ្រោះឡើយ, **គ. និង ស.** ៤៥:២ ។ ពេលច្រូតកាត់មកដល់ហើយ ហើយព្រះបន្ទូលរបស់យើងត្រូវតែបានសំរេច, **គ. និង ស.** ១០១:៦៤ ។

**ចាំយាម, ពួកអ្នកចាំយាម** *សូមមើលផង* ការព្រមាន, ព្រមាន

ប្រុងប្រយ័ត្ន ចាំយាម ។ ជនណាម្នាក់ដែលចាំយាម ហើយគោរពតាម នោះសុទ្ធតែបានរៀបចំជាស្រេច ។ ពួកអ្នកចាំយាម គឺជាពួក អ្នកដឹកនាំ ដែលបានហៅដោយពួកអ្នកដែលតំណាងព្រះអម្ចាស់ ដើម្បីឲ្យមានមុខងារណាមួយ ដើម្បីសុខុមាលភាព ដល់ពួកអ្នកឯទៀត ។ អស់អ្នកណាដែលបានហៅឲ្យធ្វើជាមេអ្នកដឹកនាំ នោះមានមុខងារយ៉ាងពិសេស ដើម្បីធ្វើជាពួកអ្នកចាំយាម ចំពោះពិភពលោក ទាំងមូល ។

អញបានតាំងឯងឲ្យធ្វើជាអ្នកចាំយាម, **អេសេ.** ៣:១៧–២១ ។ ពួកអ្នកចាំយាមដែលបន្លឺសម្លេងព្រមាន នោះបានដោះព្រលឹងខ្លួនឲ្យរួច, **អេសេ.** ៣៣:៧–៩ ។ ដូច្នេះ ឲ្យចាំយាម ត្បិតអ្នករាល់គ្នាមិនដឹងជាពេលណា ដែលព្រះអម្ចាស់នៃអ្នករាល់គ្នានឹងយាងមកទេ, **ម៉ាថាយ** ២៤:៤២–៤៣ (ម៉ាថាយ ២៥:១៣; ម៉ាកុស ១៣:៣៥–៣៧; គ. និង ស. ១៣៣:១០–១១) ។ ចូរចាំយាម ហើយអធិស្ឋានចុះ ដើម្បី មិនឲ្យកើតសេចក្តីល្បួងនាំចិត្តឡើយ, **ម៉ាថាយ** ២៦:៤១ (៣ នីហ្វៃ ១៨:១៥, ១៨) ។ បើអ្នករាល់គ្នាពុំប្រយ័ត្នខ្លួនឯង គំនិតរបស់ខ្លួន ពាក្យសំដីរបស់ខ្លួន កិច្ចការរបស់ខ្លួនទេ នោះអ្នកនឹងត្រូវវិនាស, **ម៉ូសាយ** ៤:៣០ ។ អាលម៉ាបានតែងតាំងពួកសង្ឃ និងពួកអែលឌើរ ដើម្បីឲ្យត្រួតត្រា ហើយមើលគន់លើសាសនាចក្រ, **អាលម៉ា** ៦:១ ។ អ្នកណាដែលពុំបានចាំមើលព្រះអម្ចាស់ នោះនឹងត្រូវកាត់ចេញ, **គ. និង ស.** ៤៥:៤៤ ។ ប៊ីស្សព និងពួកអ្នកផ្សេងៗត្រូវបានហៅ ហើយតែងតាំងឡើងពីព្រះ ដើម្បីឲ្យមើលគន់លើសាសនាចក្រ, **គ. និង ស.** ៤៦:២៧ ។ ព្រះអម្ចាស់ទ្រង់បានដាក់ពួកអ្នកចាំយាមឲ្យមើលគន់លើចំការ, **គ. និង ស.** ១០១:៤៤–៥៨ ។

**ច្បាប់បងច្បង** *សូមមើល* សិទ្ធិកូនច្បង

**ច្រណែន** *សូមមើលផង* ប្រច័ណ្ឌ, លោភ; សេចក្តីប្រច័ណ្ឌ

តាមបទគម្ពីរ ប្រាថ្នាចង់បានអ្វីដែលជារបស់អ្នកផ្សេង គឺជាការខុស ។

ពួកអយ្យកោក៏លក់យ៉ូសែបឲ្យទៅឯស្រុកអេស៊ីព្ទ ដោយមានចិត្តឈ្នានីស, **កិច្ចការ** ៧:៩ ។ សេចក្តីសប្បុរសមិនចេះឈ្នានីសឡើយ, **១ កូរិន.** ១៣:៤ (ម៉ូរ៉ូណៃ ៧:៤៥) ។ សេចក្តីឈ្នានីសនាំឲ្យកើតចិត្តធំ, ១ ធីម៉ូ. ៦:៤ ។ កន្លែងណាដែលមានសេចក្តីច្រណែន នោះក៏មានវឹកវរ និងសេចក្តីអាក្រក់គ្រប់យ៉ាង, **យ៉ាកុប** (ព.ស.ថ.) ៣:១៦ ។ ព្រះអម្ចាស់ទ្រង់បញ្ជាដល់មនុស្សថា ពួកគេមិនត្រូវឈ្នានីសឡើយ, **២ នីហ្វៃ** ២៦:៣២ ។ ពុំមានការឈ្នានីសនៅចំណោមប្រជាជននីហ្វៃឡើយ, **៤ នីហ្វៃ** ១:១៥–១៨ ។ សេចក្តីច្រណែន និងសេចក្តីក្រោធ នៃមនុស្ស នោះសុទ្ធតែជាការធម្មតា អស់មួយជីវិតរបស់ខ្ញុំ, **គ. និង ស.** ១២៧:២ ។

**ច្រៀង** *សូមមើលផង* ភ្លេង, ទំនុកសរសើរដំកើង

ដើម្បីថ្វាយបង្គំ និងសរសើរដំកើងដល់ព្រះ ដោយចំរៀង និងទំនុកភ្លេង ។

ចូរច្រៀងថ្វាយព្រះអម្ចាស់ចុះ, **១ របា.** ១៦:២៣–៣៦ (ទំនុក. ៩៦) ។ ចូរច្រៀងសរសើរដល់ព្រះអម្ចាស់ចុះ ចូរអរព្រះគុណ, **ទំនុក.** ៣០:៤ ។ ចូរឡើងសម្លេង ដោយអំណរថ្វាយព្រះអម្ចាស់, **ទំនុក.** ១០០:១ ។ រួចកាលបានច្រៀងទំនុកមួយហើយ នោះក៏នាំគ្នាចេញ ទៅឯភ្នំដើមអូលីវ, **ម៉ាថាយ** ២៦:៣០ ។ ព្រះវិញ្ញាណបរិសុទ្ធបានបណ្តាលឲ្យគេច្រៀងសរសើរ, **ម៉ូរ៉ូណៃ** ៦:៩ ។ បទចំរៀងនៃពួក សុចរិត គឺជាបទ

អធិស្ឋានដល់យើង, **គ. និង ស.** ២៥:១២ ។ បើសិនជាអ្នកសប្បាយរីករាយ ចូរសរសើរដំកើងដល់ព្រះអម្ចាស់ ដោយ ការច្រៀង, **គ. និង ស.** ១៣៦:២៨ ។

**ឆ្នោត**

ជារបៀបជ្រើសរើស ឬកំចាត់ចោលនូវអ្វីជាច្រើនចេញ គឺតែងតែធ្វើឡើងដោយរើសសន្លឹកក្រដាស ឬបន្ទះឈើមួយពីចំណោមច្រើន ។ ការនេះគឺហៅថា បោះឆ្នោត ។

គេបានធ្វើឆ្នោត ចាប់ចែកព្រះពស្ត្រទ្រង់, **ម៉ាថាយ** ២៧:៣៥ (ទំនុក. ២២:១៨; ម៉ាកុស ១៥:២៤; លូកា ២៣:៣៤; យ៉ូហាន ១៩:២៤) ។ គេបានចាប់ឆ្នោត ហើយឆ្នោតត្រូវលើរូបម៉ាត់ធាស, **កិច្ចការ** ១:២៣–២៦ ។ ពួកយើងចាប់ឆ្នោត — រកនរណាម្នាក់ក្នុងចំណោម ពួកយើង ដែលត្រូវចូលទៅផ្ទះឡាបាន់, **១ នីហ្វៃ** ៣:១១ ។

**ជនគណនា** *សូមមើលផង* គម្ពីរ៥ច្បាប់

ជាគម្ពីរទីបួននៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ លោកម៉ូសេបានសរសេរគម្ពីរជនគណនា ។ គម្ពីរជនគណនាប្រាប់អំពីរឿងនៃពួកសាសន៍អ៊ីស្រាអែល ធ្វើដំណើរពីភ្នំស៊ីណាយ ទៅឯវាលទំនាបនៅស្រុកម៉ូអាប់ នៅព្រំដែនស្រុកកាណាន ។ មេរៀនដ៏សំខាន់មួយ ដែលគម្ពីរនេះបង្រៀន គឺថា រាស្ត្ររបស់ព្រះត្រូវដើរដោយសេចក្តីជំនឿ ដោយទុកចិត្តលើសេចក្តីសន្យារបស់ទ្រង់ បើសិនជាពួកគេនឹងបន្តទៅ ដោយជោគជ័យ ។ គម្ពីរនេះរៀបរាប់អំពីការកាត់ទោសរបស់ព្រះ ដល់ពួកអ៊ីស្រាអែល ចំពោះការមិនគោរពតាម ហើយផ្តល់នូវដំណឹងអំពីក្រិត្យវិន័យនៃសាសន៍អ៊ីស្រាអែល ។ ឈ្មោះគម្ពីរគឺបានដកចេញមកពីភាពដ៏ធំនៃការស្រង់ចំនួនប្រជាជន (ជនគ. ១–២, ២៦) ។

ជំពូកទី ១–១០ ប្រាប់អំពីការរៀបចំនៃពួកអ៊ីស្រាអែល ដើម្បីធ្វើដំណើរចេញពីភ្នំស៊ីណាយ ។ ជំពូកទី ១១–១៤ អធិប្បាយប្រាប់អំពីដំណើរ, អំពីការចាត់ឲ្យមនុស្សទៅសង្កេតមើលស្រុកកាណាន, និងអំពីការដែលពួកអ៊ីស្រាអែលមិនព្រមចូលដែនដីសន្យា ។ ជំពូកទី ១៥–១៩ កត់នូវក្រិត្យវិន័យផ្សេងៗ និងព្រឹត្តិការណ៍ខាងប្រវត្តិ ។ ជំពូកទី ២០–៣៦ គឺជាប្រវត្តិនៃឆ្នាំចុងក្រោយបង្អស់ ដែលបណ្តាជនស្ថិតនៅក្នុងទីរហោស្ថាន ។

**ជ័រពិដោរពីស្រុកកាឡាត**

ជាជ័រ ឬគ្រឿងក្រអូបសំរាប់ផ្សះរបួស (លោកុ. ៤៣:១១; យេរេ. ៨:២២; ៤៦:១១; ៥១:៨) ។ ជាដើមប្រទាលមុខសេះដែលមានជ័រ ដែលគេយកមកធ្វើជា ជ័រពិដោរ ដែលដុះជាច្រើននៅស្រុកកាឡាត នៅសម័យព្រះគម្ពីរសញ្ញាចាស់ ម្លោះហើយ ជ័រនោះគេស្គាល់ ថាជា «ជ័រពិដោរពីស្រុកកាឡាត» (លោកុ. ៣៧:២៥; អេសេ. ២៧:១៧) ។

**ជាតិស្រា** *សូមមើល* ពាក្យសំដីនៃប្រាជ្ញាវាងវៃ

**ជីវិត** *សូមមើលផង* ជីវិតដ៏នៅអស់កល្បជានិច្ច; ពន្លឺនៃព្រះគ្រីស្ទ

ជាការរស់នៅខាងសាច់ឈាម និងខាងវិញ្ញាណ ដែលបានធ្វើឲ្យកើតឡើងដោយសារព្រះចេស្តានៃព្រះ ។

នៅថ្ងៃនេះ អញបានដាក់សំពៀងជីវិត និងសេចក្តីល្អនៅមុខឯង, **ចោទិ.** ៣០:១៥–២០ ។ ទ្រង់នឹងបង្ហាញឲ្យទូលបង្គំឃើញផ្លូវជីវិត, **ទំនុក.** ១៦:១១ ។ អ្នកណាដែលប្រព្រឹត្តតាមសេចក្តីសុចរិតនោះរមែងបានជីវិត, **សុភា.** ២១:២១ ។ អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ, **ម៉ាថាយ** ១០:៣៩ (១៦:២៥; ម៉ាកុស ៨:៣៥; លូកា ៩:២៤; ១៧:៣៣) ។ កូនមនុស្សមិនមែនមក ប៉ងនឹងបំផ្លាញជីវិតមនុស្សទេ គឺមក ដើម្បីនឹងជួយសង្គ្រោះវិញ, **លូកា** ៩:៥៦ ។ នៅក្នុងទ្រង់មានជីវិត ហើយជីវិតនោះជាពន្លឺនៃមនុស្សលោក, **យ៉ូហាន** ១:៤ ។ អ្នកណាដែលជឿដល់ព្រះអង្គ ដែលចាត់ឲ្យ ខ្ញុំមក អ្នកនោះបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ, **យ៉ូហាន** ៥:២៤ ។ ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត, **យ៉ូហាន** ១៤:៦ ។ បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា, **១ កូរិន.** ១៥:១៩–២២ ។ សេចក្តី គោរពប្រតិបត្តិដល់ព្រះ មានសេចក្តីសន្យាឲ្យបានជីវិត នៅជាន់ឥឡូវនេះ ហើយទៅខាងនាយផង, ១ ធីម៉ូ. ៤:៨ ។ កូនចៅយើងអាច ទន្ទឹងចាំដល់ជីវិតនោះដែលនៅក្នុងព្រះគ្រីស្ទ, **២ នីហ្វៃ** ២៥:២៣–២៧ ។ ជីវិតនេះគឺពេលសំរាប់ឲ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹង ព្រះ, **អាលម៉ា** ៣៤:៣២ (អាលម៉ា ១២:២៤) ។ យើងជាពន្លឺ និងជាជីវិតនៃពិភពលោក, ៣ នីហ្វៃ ៩:១៨ (ម៉ូសាយ ១៦:៩; ៣ នីហ្វៃ ១១:១១; អេធើរ ៤:១២) ។ មានពរហើយ ដល់ពួកអ្នកដែលមានចិត្តស្មោះត្រង់ ទោះបីក្នុងជីវិត ឬក្នុងសេចក្តីស្លាប់ក្តី, **គ. និង ស.** ៥០:៥ ។ នេះគឺជាជីវិតដ៏នៅអស់កល្បជានិច្ច — គឺដើម្បីឲ្យបានស្គាល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ១៣២:២៤ ។ នេះហើយជា កិច្ចការរបស់យើង និងសិរីល្អរបស់យើង — គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។

**ជីវិតដ៏នៅអស់កល្បជានិច្ច** *សូមមើលផង* ដង្វាយធួន; ជីវិត, ធ្វើឲ្យធួន, ភាពថ្កើងថ្កានឡើង; មកុដ; សិរីល្អខាងសេឡេស្ទាល

គឺដើម្បីរស់នៅជាគ្រួសារជាដរាបនៅក្នុងវត្តមានរបស់ព្រះ (គ. និង ស. ១៣២:១៩–២០, ២៤, ៥៥) ។ ជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមាបំផុតរបស់ព្រះដល់មនុស្ស ។

ទ្រង់មានព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច, **យ៉ូហាន** ៦:៦៨ ។ នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឲ្យគេបានស្គាល់ដល់ទ្រង់ ដ៏ជាព្រះពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទ, **យ៉ូហាន** ១៧:៣ (គ. និង ស. ១៣២:២៤) ។ ចូរខំប្រឹងតស៊ូ ដោយការតស៊ូយ៉ាងល្អនៃ សេចក្តីជំនឿ ចូរតោងចាប់ជីវិតអស់កល្បជានិច្ចឲ្យខ្ជាប់, ១ ធីម៉ូ. ៦:១២ ។ មនុស្សមានសិទ្ធនឹងរើសយកឥស្សរភាព និងជីវិតដ៏នៅអស់ កល្បជានិច្ច, **២ នីហ្វៃ** ២:២៧ (ហេលេ. ១៤:៣១) ។ គំនិតដែលជាប់ទៅ

ខាងវិញ្ញាណ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច, **២ នីហ្វៃ** ៩:៣៩ ។ បន្ទាប់មក តើអ្នករាល់គ្នានឹងនៅលើផ្លូវចង្អៀត ដែលនាំទៅឯជីវិតដ៏នៅអស់កល្បជានិច្ច, **២ នីហ្វៃ** ៣១:១៧–២០ ។ ដើម្បីជឿដល់ព្រះ គ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះគឺជាជីវិតដ៏នៅអស់កល្បជានិច្ច, **២ នីហ្វៃ** ៣៣:៤ (៣ នីហ្វៃ ១៥:៩) ។ អ្នកណាដែល មានជីវិតដ៏នៅអស់កល្បជានិច្ច ឈ្មោះថាជាអ្នកមានហើយ, **គ. និង ស.** ៦:៧ (គ. និង ស. ១១:៧) ។ ជីវិតដ៏នៅ អស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមាបំផុត នូវគ្រប់អំណោយទានទាំងឡាយនៃព្រះ, **គ. និង ស.** ១៤:៧ (រ៉ូម ៦:២៣) ។ ពួកសុចរិតនឹងបាន ទទួលសេចក្ដីសុខសាន្ត នៅនាលោកិយនេះ និងជីវិតដ៏នៅអស់កល្បជានិច្ច នៅបរលោក, **គ. និង ស.** ៥៩:២៣ ។ អស់អ្នក ណាដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុត នឹងបានជីវិតដ៏នៅអស់កល្បជានិច្ចជាមកុដ, **គ. និង ស.** ៦៦:១២ (គ. និង ស. ៧៥:៥) ។ មនុស្សទាំងអស់ដែលបានស្លាប់ទៅ ដោយគ្មានដំណឹងល្អជាពួកអ្នកដែលនឹងទទួលដំណឹងល្អ បើសិនជាពួកគេត្រូវបានអនុញ្ញាតឲ្យនៅ នោះនឹងទៅជាពួកអ្នកគ្រងនគរសេឡេស្ទាលទុកជាមរតក, **គ. និង ស.** ១៣៧:៧–៩ ។ កិច្ចការ និងសិរីល្អរបស់ព្រះ គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។ ព្រះទ្រង់ប្រទានជីវិតដ៏នៅអស់កល្បជានិច្ច ដល់ពួកអ្នកដែល គោរពតាម, **ម៉ូសេ** ៥:១១ ។

**ជីវិតដ៏អស់កល្បជានិច្ច** *សូមមើល* ជីវិតដ៏នៅអស់កល្បជានិច្ច

**ជីវិតមុនផែនដី** *សូមមើលផង* ក្រុមប្រឹក្សានៅស្ថានសួគ៌; ដើមដំបូង; មនុស្ស, មនុស្សលោក; សង្គ្រាមនៅស្ថានសួគ៌

ជាជីវិតនៅមុនជីវិតផែនដី ។ មនុស្សប្រុសស្រីទាំងអស់បានរស់នៅជាមួយនឹងព្រះ ជាកូនវិញ្ញាណរបស់ទ្រង់ មុនមកឯផែនដីក្នុង សាច់ឈាម ។ ជួកកាល ជីវិតនេះហៅថា សណ្ឋានទីមួយ (អ័ប្រា. ៣:២៦) ។

ក្នុងកាលព្រះទ្រង់ចាប់តាំងបង្កផែនដីឡើង នោះអស់ទាំងកូនព្រះបានស្រែកអរសាទរ, **យ៉ូប** ៣៨:៤–៧ ។ វិញ្ញាណនឹងត្រឡប់ទៅឯព្រះ ដែលទ្រង់បានប្រទានមកនោះ, **សាស្ដា** ១២:៧ ។ មុនដែលអញបានជបបង្កើតឯងនៅក្នុងពោះម្ដាយ នោះអញស្គាល់ឯងហើយ, **យេរេ.** ១:៤–៥ ។ មនុស្សយើងជាពូជព្រះ, **កិច្ចការ** ១៧:២៨ ។ ព្រះទ្រង់បានរើសយើងតាំងពីមុនកំណើតលោកិយមក, **អេភេ.** ១:៣–៤ ។ យើងរាល់គ្នាត្រូវចុះចូល ចំពោះព្រះវរបិតាខាងវិញ្ញាណ, **ហេព្រើរ** ១២:៩ ។ ពួកទេវតាដែលមិនបានរក្សាសណ្ឋានដើមរបស់ខ្លួន នោះទ្រង់បានឃុំទុកក្នុងចំណងអស់កល្បជានិច្ច, **យូដាស** ១:៦ (អ័ប្រា. ៣:២៦) ។ អារក្ស និងពួកទេវតារបស់វាត្រូវបានបោះចេញ, **វិវ.** ១២:៩ ។ ពួកគេត្រូវបានហៅ ហើយរៀបចំទុក ចាប់តាំងពីកំណើតលោកិយមក, **អាលម៉ា** ១៣:៣ ។ ព្រះគ្រីស្ទបានទតមើលមកលើ ផ្ទៃមេឃនៃភាពអស់កល្បជានិច្ច និងអស់ទាំងពួកពលបរិវារនៃស្ថានសួគ៌មុនកំណើតលោកិយមកម្ល៉េះ, **គ. និង ស.** ៣៨:១ ។ កាលដើម ដំបូងមនុស្សក៏បាននៅជាមួយនឹងព្រះដែរ, **គ. និង ស.** ៩៣:២៩ (ហេលេ. ១៤:១៧; គ. និង ស. ៤៩:១៧) ។ វិញ្ញាណនៃពួកឧត្ដុងឧត្ដម ត្រូវបានរើសតាំងពីដើមដំបូងមក ឲ្យធ្វើជាអ្នកត្រួតត្រាក្នុងសាសនាចក្រ, **គ. និង ស.** ១៣៨:៥៣–៥៥ ។ មនុស្សជាច្រើនបានទទួល មេរៀននានាមុនដំបូង នៅពិភពនៃពួកវិញ្ញាណ, **គ. និង ស.** ១៣៨:៥៦ ។ គ្រប់របស់ទាំងអស់ត្រូវបានបង្កើតឡើងខាងវិញ្ញាណ មុនមានរបស់ទាំងនោះនៅលើផែនដី, **ម៉ូសេ** ៣:៥ ។ យើងបានបង្កើតលោកិយ និងមនុស្សលោកមក មុនមានពួកគេនៅក្នុងសាច់ ឈាមម្ល៉េះ, **ម៉ូសេ** ៦:៥១ ។ អ័ប្រាហាំបានឃើញបញ្ញាទាំងឡាយដែលត្រូវបានបង្កើតឡើងមុនកំណើតលោកិយមកម្ល៉េះ, **អ័ប្រា.** ៣:២១–២៤ ។

**ជេរប្រមាថផ្ដាសសា** *សូមមើល* ការប្រមាថ; ប្រមាថ, សម្បថ; សេចក្ដីមើលងាយ

**ជំទាស់ចិត្ត**

គឺបំពាក់ក្រិត្យវិន័យនៃព្រះ ធ្វើបាប ឬធ្វើឲ្យមានទុក្ខ ឬរបួស ហើយក៏ធ្វើឲ្យអាក់អន់ចិត្ត ឬរំខានចិត្ត ។

បងប្អូនណាដែលបានអន់ចិត្តហើយ នោះពិបាកបង្រាបជាងទីក្រុងយ៉ាងមាំមួន, **សុភា.** ១៨:១៩ ។ បើភ្នែកស្ដាំអ្នកនាំឲ្យរវាតចិត្ត នោះចូរខ្វេះចេញបោះចោលទៅ, **ម៉ាថាយ** ៥:២៩ ។ បើអ្នកណាធ្វើឲ្យកូនតូចណាមួយនេះ ដែលជឿដល់ខ្ញុំ រវាតចិត្តចេញនោះស៊ូឲ្យគេពន្លង់ទៅក្នុងសមុទ្រទីជ្រៅវិញ, **ម៉ាថាយ** ១៨:៦ (គ. និង ស. ១២១:១៩–២២) ។ បើសិនជាបងប្អូនប្រុស ឬស្រីរបស់ខ្លួនណាម្នាក់មានហេតុទាស់នឹងអ្នក ហើយសារភាព នោះអ្នកត្រូវរាប់រកគ្នាវិញ, **គ. និង ស.** ៤២:៨៨ ។ មនុស្សមិនដែលជំទាស់ព្រះ ក្នុងការណ៍ណាមួយឡើយ លើកលែងតែអស់អ្នកណាដែលមិនទទួលស្គាល់ព្រះហស្តរបស់ទ្រង់ ហើយមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ប៉ុណ្ណោះ **គ. និង ស.** ៥៩:២១ ។

**ជំនួស** *សូមមើល* ពិធីបរិសុទ្ធ — ពិធីបរិសុទ្ធជំនួស; សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់

**ជំនឿ, ជឿ** *សូមមើលផង* ការតតជំនឿ, ទុកចិត្ត; ព្រះយេស៊ូវគ្រីស្ទ; សេចក្ដីជំនឿ

គឺមានសេចក្ដីជំនឿជឿដល់អ្នកណាមួយ ឬក៏ទទួលស្គាល់អ្វីមួយថាពិត ។ ជនម្នាក់ៗត្រូវតែប្រែចិត្ត ហើយជឿដល់ព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យបានសង្គ្រោះ នៅក្នុងនគរព្រះ (គ. និង ស. ២០:២៩) ។

ចូរជឿដល់ព្រះអម្ចាស់ ជាព្រះនៃអ្នករាល់គ្នា ចូរជឿតាមពួកព្យាការីរបស់ទ្រង់, **២ របា.** ២០:២០ ។ ដានីយ៉ែលមិនបានរបួសនៅក្នុងរូងសិង្ហឡើយ ពីព្រោះលោកបានជឿដល់ព្រះ, **ដានី.** ៦:២៣ ។ ឲ្យបានដូចជំនឿរបស់អ្នកចុះ, **ម៉ាថាយ** ៨:១៣ ។ គ្រប់ទាំងសេចក្ដីអ្វីដែលអ្នករាល់គ្នានឹងអធិស្ឋានសូម ដោយមានចិត្តជឿ នោះនឹងបានសំរេចទាំងអស់, **ម៉ាថាយ** ២១:២២ ។ កុំខ្លាចអី ឲ្យគ្រាន់តែជឿប៉ុណ្ណោះ, **ម៉ាកុស** ៥:៣៦ ។ ការទាំងអស់នឹងសំរេចបានដល់អ្នកណា

ដែលជឿ, **ម៉ាកុស** ៩:២៣–២៤ ។ អ្នកណា ដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ, **ម៉ាកុស** ១៦:១៦ (២ នីហ្វៃ ២:៩; ៣ នីហ្វៃ ១១:៣៣–៣៥) ។ អ្នកណាដែលជឿដល់ ព្រះរាជបុត្រា នោះនឹងមានជីវិតដ៏អស់កល្បជានិច្ច, **យ៉ូហាន** ៣:១៦, ១៨, ៣៦ (យ៉ូហាន ៥:២៤; គ. និង ស. ១០:៥០) ។ យើងខ្ញុំក៏បានជឿ ហើយដឹងថា ទ្រង់ជាព្រះគ្រីស្ទ, **យ៉ូហាន** ៦:៦៩ ។ អ្នកណាដែលជឿដល់ខ្ញុំ ទោះបីបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញ ដែរ, **យ៉ូហាន** ១១:២៥–២៦ ។ យើងរាល់គ្នាដែលជឿ យើងចូលក្នុងសេចក្តីសំរាក, **ហេព្រើរ** ៤:៣ ។ ចូរជឿដល់ព្រះយេស៊ូវគ្រីស្ទ ហើយស្រឡាញ់គ្នាទៅវិញទៅមក, **១ យ៉ូហាន** ៣:២៣ ។ ព្រះមែស៊ីទ្រង់នឹងមិនបំផ្លាញអ្នកណា ដែលជឿដល់ទ្រង់ឡើយ, **២ នីហ្វៃ** ៦:១៤ ។ ពួកសាសន៍យូដានឹងត្រូវគេបៀតបៀន ទាល់តែពួកគេត្រូវបានបញ្ចុះបញ្ចូលឲ្យជឿដល់ព្រះគ្រីស្ទ, **២ នីហ្វៃ** ២៥:១៦ ។ បើអ្នករាល់គ្នាជឿនូវការណ៍ទាំងអស់នេះ នោះសូមឲ្យអ្នកអ្នករាល់គ្នាចាប់ផ្តើមប្រព្រឹត្តទៅ, **ម៉ូសាយ** ៤:១០ ។ ព្រះរាជបុត្រានឹងដាក់លើព្រះអង្គ នូវអំពើរលងនៃជនទាំងឡាយណា ដែលជឿដល់ព្រះនាមទ្រង់, **អាលម៉ា** ១១:៤០ ។ មានពរហើយដល់អស់អ្នកណា ដែល ជឿដល់ព្រះបន្ទូលនៃព្រះ ដោយពុំបាច់ឲ្យគេបង្ខំ, **អាលម៉ា** ៣២:១៦ ។ សូម្បីបើអ្នករាល់គ្នាពុំអាចធ្វើអ្វីក្រៅពីការចង់ជឿ នោះសូមឲ្យ បំណងនេះមាននៅក្នុងខ្លួនអ្នកចុះ, **អាលម៉ា** ៣២:២៧ ។ បើអ្នករាល់គ្នាជឿដល់ព្រះនាមទ្រង់ នោះអ្នករាល់គ្នានឹងប្រែចិត្ត, **ហេលេ.** ១៤:១៣ ។ ជនណាដែលជឿដល់យើង ក៏ជឿដល់ព្រះវរបិតាផង, ៣ នីហ្វៃ ១១:៣៥ ។ មិនដែលអ្នកណាដែលជឿដល់ព្រះអម្ចាស់ ដូចជាបងរបស់យ៉ារេឌឡើយ, **អេធើរ** ៣:១៥ ។ គ្រប់ទាំងអ្វីៗដែលបញ្ចុះបញ្ចូលឲ្យជឿដល់ព្រះគ្រីស្ទ នោះគឺបានចាត់មកពីព្រះចេស្តា នៃព្រះគ្រីស្ទ, **មរ៉ូណៃ** ៧:១៦–១៧ ។ អស់អ្នកណាដែលជឿតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះនឹងបានប្រទានឲ្យឃើញការសម្តែងនៃ ព្រះវិញ្ញាណ, គ. និង ស. ៥:១៦ ។ អស់អ្នកណាដែលជឿដល់ព្រះនាមរបស់ព្រះអម្ចាស់ នោះនឹងត្រឡប់ទៅជាកូនព្រះ, **គ. និង ស.** ១១:៣០ (យ៉ូហាន ១:១២) ។ ចំពោះមនុស្សខ្លះទៀត ត្រូវបានប្រទានឲ្យជឿដល់ពាក្យពេចន៍នៃអ្នកផ្សេង, **គ. និង ស.** ៤៦:១៤ ។ ទីសំគាល់ទាំងឡាយជាប់តាមអស់អ្នកដែលជឿ, **គ. និង ស.** ៥៨:៦៤ (គ. និង ស. ៦៣:៧–១២) ។ អស់អ្នកណាដែលជឿ ប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ, **ម៉ូសេ** ៦:៥២ ។

**ជំនុំជំរះ, សេចក្តីជំនុំជំរះ** *សូមមើលផង* ការដាក់ទោស; ដាក់ទោស, ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម; សេចក្តីជំនុំជំរះចុងក្រោយបំផុត

គឺដើម្បីកាត់ក្តីអំពីចរិយាដែលទាក់ទងនឹងគោលការណ៍នៃដំណឹងល្អ; ដើម្បីសំរេចចិត្ត; ហើយដើម្បីពិចារណាមើលខុសត្រូវ ។

ម៉ូសេអង្គុយជំនុំជំរះរឿងឲ្យបណ្តាជនទាំងឡាយ, **និក្ខ.** ១៨:១៣ ។ ត្រូវឲ្យជំនុំជំរះអ្នកជិតខាងអ្នកដោយសុចរិត, **លេវី.** ១៩:១៥ ។ កុំឲ្យថ្កោលទោសគេឡើយ ដើម្បីមិនឲ្យអ្នកបានត្រូវថ្កោលទោសវិញ, **ម៉ាថាយ** ៧:១ (ក.យ.ស., ម៉ាថាយ ៧:១–២; លូកា ៦:៣៧; ៣ នីហ្វៃ ១៤:១) ។ ក្បិតអស់អ្នកណាដែលបានធ្វើបាបក្នុងបន្ទុកក្រិត្យវិន័យ នោះនឹងត្រូវក្រិត្យវិន័យជំនុំជំរះវិញ, **រ៉ូម** ២:១២ ។ ពួកបរិសុទ្ធនឹងជំនុំជំរះលោកិយ, **១ កូរិន.** ៦:២–៣ ។ ព្រះរាជបុត្រានៃព្រះដ៏នៅអស់កល្បជានិច្ចត្រូវមនុស្សលោកជំនុំជំរះ, **១ នីហ្វៃ** ១១:៣២ ។ ពួកសាវក១២នាក់នៃកូនចៀមនឹងជំនុំជំរះ ពូជអ៊ីស្រាអែលទាំង ១២ អំបូរ, **១ នីហ្វៃ** ១២:៩ (គ. និង ស. ២៩:១២) ។ សេចក្តីស្លាប់ ស្ថាននរក និងអារក្ស និងអ្នកទាំងអស់ដែលត្រូវចាប់ទៅនោះ គេនឹងទទួលការជំនុំជំរះ, **២ នីហ្វៃ** ២៨:២៣ (១ នីហ្វៃ ១៥:៣៣) ។ បើអ្នករាល់គ្នាថ្កោលទោសជន ដែលមកសុំទានអ្នក តើការកាត់ទោសអ្នកយុត្តិធម៌ជាងនេះទៅឬអី ដែលអ្នកឱប ក្រសោបទ្រព្យរបស់ខ្លួនទុក, **ម៉ូសាយ** ៤:២២ ។ មនុស្សនឹងបានទទួលការជំនុំជំរះ តាមកិច្ចការរបស់ខ្លួន, **អាលម៉ា** ៤១:៣ ។ ចូរវិនិច្ឆ័យដោយសុចរិត នោះកូននឹងបានសេចក្តីយុត្តិធម៌សាងឡើងដល់កូន, **អាលម៉ា** ៤១:១៤ ។ មនុស្សលោកនឹងបានទទួល ការជំនុំជំរះ តាមគម្ពីរទាំងឡាយ ដែលនឹងបានសរសេរទុក, ៣ នីហ្វៃ ២៧:២៣–២៦ (វិវរ. ២០:១២) ។ សំណល់នៃប្រជាជននេះ នឹងបានទទួលការជំនុំជំរះពីពួក១២នាក់ ដែលព្រះយេស៊ូវបានរើសនៅក្នុងដែនដីនេះ, **មរមន** ៣:១៨–២០ ។ មរមនបានពន្យល់ប្រាប់ពី របៀបឲ្យចេះវិនិច្ឆ័យខុសនិងត្រូវ, **មរ៉ូណៃ** ៧:១៤–១៨ ។ ចូរដាក់ទីពឹងរបស់អ្នកទៅនឹងព្រះវិញ្ញាណនោះ ដែលនាំឲ្យវិនិច្ឆ័យដោយសុចរិត, **គ. និង ស.** ១១:១២ ។ អ្នករាល់គ្នាត្រូវនិយាយនៅក្នុងចិត្តថា — *សូមឲ្យព្រះទ្រង់ជំនុំជំរះរវាងអ្នកនឹងខ្ញុំចុះ*, **គ. និង ស.** ៦៤:១១ ។ សាសនាចក្ររបស់ព្រះអម្ចាស់នឹងជំនុំជំរះសាសន៍ទាំងឡាយ, **គ. និង ស.** ៦៤:៣៧–៣៨ ។ ព្រះរាជបុត្រាបានយាងទៅជួបពួកវិញ្ញាណនៅស្ថានឃុំព្រលឹង ដើម្បីឲ្យគេអាចបានទទួលការជំនុំជំរះតាមបែបមនុស្សក្នុងសាច់ឈាម, **គ. និង ស.** ៧៦:៧៣ (១ ពេត្រុស ៤:៦) ។ ប៊ីស្សពនឹងធ្វើជាចៅក្រមទូទៅ, **គ. និង ស.** ១០៧:៧២–៧៤ ។ ព្រះអម្ចាស់ ទ្រង់នឹងជំនុំជំរះមនុស្សលោកទាំងអស់ ស្របតាមកិច្ចការរបស់ពួកគេ គឺស្របតាមសេចក្តីប៉ងប្រាថ្នានៃដួងចិត្តរបស់ពួកគេ, **គ. និង ស.** ១៣៧:៩ ។

**ជំរើស** (គ. ឬ ន.) *សូមមើលផង* ការហៅ, បានហៅពីព្រះ, ហៅ

ជាពួកអ្នកដែលព្រះទ្រង់បានរើសតាំង ឲ្យកាន់មុខងារពិសេស ។

យើងបានតាំងសញ្ញានឹងអ្នកដែលយើងបានរើសតាំង, **ទំនុក** ៨៩:៣ ។ បានហៅមនុស្សជាច្រើន តែរើសបានតិចទេ, **ម៉ាថាយ** ២២:១៤ (ម៉ាថាយ ២០:១៦; គ. និង ស. ៩៥:៥; ១២១:៣៤, ៤០) ។ ពួកបរិសុទ្ធជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង, **១ ពេត្រុស** ២:៩ ។ ព្រះគ្រីស្ទជាទីស្ងួនភ្ងា និងជាទីជំរើសរបស់ព្រះ ចាប់តាំងពីដើមដំបូងមក, **ម៉ូសេ** ៤:២ ។

**ឈឺ, ជម្ងឺ**

មានជម្ងឺ ឬរោគាអ្វីមួយ ។ នៅក្នុងព្រះគម្ពីរ ជម្ងឺខាងសាច់ឈាម

ជូនកាល រាប់ទុកជានិមិត្តរូប អំពីការខ្វះខាតខាងការស្រុះស្រួលខាងវិញ្ញាណ (អេសាយ ១:៤–៧; ៣៣:២៤) ។

អញបានឮពាក្យអធិស្ឋានរបស់ឯង ក៏បានឃើញទឹកភ្នែកឯងហើយ មើលអញនឹងប្រោសឲ្យឯងបានជា, **២ ពង្សាវ.** ២០:១–៥ (២ របា. ៣២:២៤; អេសាយ ៣៨:១–៥) ។ ព្រះយេស៊ូវយាងទៅប្រោសជម្ងឺគ្រប់មុខ និងអស់ទាំងជរាពិការឲ្យបានជា, **ម៉ាថាយ** ៤:២៣–២៤ (១ នីហ្វៃ ១១:៣១; ម៉ូសាយ ៣:៥–៦) ។ ពួកអ្នកដែលសុខសប្បាយ មិនត្រូវការនឹងគ្រូពេទ្យទេ គឺជាពួកដែលមានជម្ងឺវិញទេតើ, **ម៉ាថាយ** ៩:១០–១៣ (ម៉ាកុស ២:១៤–១៧; លូកា ៥:២៧–៣២) ។ តើមានពួកអ្នករាល់គ្នាណាឈឺឬទេ? ត្រូវឲ្យអ្នកនោះហៅពួក ចាស់ទុំ, **យ៉ាកុប** (ព.ស.ថ.) ៥:១៤–១៥ ។ ព្រះគ្រីស្ទទ្រង់នឹងលើកដាក់លើខ្លួនទ្រង់ នូវការឈឺចាប់ និងជម្ងឺទាំងឡាយរបស់រាស្ត្រទ្រង់, **អាលម៉ា** ៧:១០–១២ ។ ព្រះយេស៊ូវទ្រង់បានប្រោសគ្រប់ទាំងមនុស្សឈឺ នៅចំណោមពួកសាសន៍នីហ្វៃឲ្យបានជា, ៣ នីហ្វៃ ២៦:១៥ ។ ត្រូវថែទាំឲ្យចំណីដោយអស់ពីភាពទន់ភ្លន់ ដោយរុក្ខជាតិ និងអាហារសាបៗ, **គ. និង ស.** ៤២:៤៣ (អាលម៉ា ៤៦:៤០) ។ ចូរនឹកចាំ ក្នុងគ្រប់ការណ៍ទាំងអស់ ពីមនុស្សឈឺ និងមនុស្សមានទុក្ខវេទនា, **គ. និង ស.** ៥២:៤០ ។ ចូរដាក់ដៃអ្នកលើមនុស្សដែលមានជម្ងឺ ហើយពួកគេនឹងបានជាសះស្បើយ, **គ. និង ស.** ៦៦:៩ ។

**ឈើឆ្កាង** *សូមមើលផង* ការឆ្កាង; គាល់កូថា; ដង្វាយធួន;
ធ្វើឲ្យធួន, បុណ្យរំឭក, ព្រះយេស៊ូវគ្រីស្ទ

ជាឈើដែលគេឆ្កាងព្រះយេស៊ូវគ្រីស្ទនៅពីលើ (ម៉ាកុស ១៥:២០–២៦) ។ សព្វថ្ងៃនេះ មានមនុស្សជាច្រើននៅក្នុងលោកិយគិតថា ឈើឆ្កាង គឺជាតំណាងនៃការឆ្កាងព្រះគ្រីស្ទ ហើយជាការបូជាដ៏ធួន ប៉ុន្តែព្រះអម្ចាស់ទ្រង់បានតាំងនិមិត្តរូបរបស់ទ្រង់ផ្ទាល់ ចំពោះការ ឆ្កាង និងការបូជារបស់ទ្រង់ — គឺនំប៉័ង និងទឹកនៃបុណ្យរំឭក (ម៉ាថាយ ២៦:២៦–២៨; គ. និង ស. ២០:៤០; ៧៥–៧៩) ។ នៅក្នុង គម្ពីរ អស់អ្នកណាដែលផ្ទុកឈើឆ្កាងរបស់ខ្លួន គឺជាអ្នកដែលស្រឡាញ់ព្រះយេស៊ូវគ្រីស្ទជាខ្លាំង ដែលពួកគេលះកាត់ចិត្តពី អំពើទុច្ចរិត និងសេចក្តីសំរើបខាងលោកិយ ហើយកាន់តាមបញ្ញត្តិរបស់ទ្រង់ (ក.យ.ស., ម៉ាថាយ ១៦:២៥–២៦) ។

ចូរផ្ទុកឈើឆ្កាងមកតាមខ្ញុំចុះ, **ម៉ាកុស** ១០:២១ (៣ នីហ្វៃ ១២:៣០; គ. និង ស. ២៣:៦) ។ ព្រះយេស៊ូវទ្រង់បានរងទ្រាំនៅលើឈើ ឆ្កាង រួចទ្រង់ក៏គង់ខាងស្តាំបល្ល័ង្កនៃព្រះ, **ហេព្រើរ** ១២:២ ។ ទ្រង់ត្រូវគេលើកឡើងលើឈើឆ្កាង ហើយធ្វើគតជំនួសអំពើបាបទាំង ឡាយនៃមនុស្សលោក, **១ នីហ្វៃ** ១១:៣៣ ។ ពួកអ្នកណាដែលស៊ូទ្រាំនូវឈើឆ្កាងទាំងឡាយនៃពិភពលោក អ្នកនោះនឹងគ្រងនគរព្រះ ទុកជាមរដក, **២ នីហ្វៃ** ៩:១៨ ។ ព្រះវរបិតារបស់យើង ទ្រង់បានចាត់ឲ្យយើងមក ដើម្បីយើងនឹងត្រូវលើកឡើងលើឈើឆ្កាង, ៣ នីហ្វៃ ២៧:១៤–១៥ ។ អ្នកណាដែលមិនព្រមផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយដើរតាមយើង ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើងទេ អ្នកនោះនឹងមិនត្រូវបានសង្គ្រោះឡើយ, **គ. និង ស.** ៥៦:២ ។ ចូរមើលកូនមនុស្សត្រូវបានលើកឡើងលើឈើឆ្កាង, **ម៉ូសេ** ៧:៥៥ ។

**ដង្វាយ** *សូមមើលផង* ការដាក់ទាន; ការសង្គ្រោះ, តម, តំណម;
ដង្វាយ១ភាគ១០; ថ្វាយដង្វាយ១ភាគ១០, ទាន, បូជា

ជាអំណោយថ្វាយទៅព្រះអម្ចាស់ ។ ព្រះគម្ពីរសញ្ញាចាស់តែងតែប្រើពាក្យនេះ ដើម្បីស្តីអំពីយញ្ញបូជា ឬដង្វាយដុតទាំងឡាយ ។ សព្វថ្ងៃនេះ សាសនាចក្រប្រើដង្វាយតម និងដង្វាយថ្វាយដោយស្ម័គ្រពីចិត្ត (ព្រមទាំងពេលវេលា ការប៉ិនប្រសប់ និងទ្រព្យសម្បត្តិ) ដើម្បីជួយមនុស្សក្រីក្រ និងសំរាប់ប្រយោជន៍សំខាន់ផ្សេងៗទៀត ។

ឯងរាល់គ្នាបានកោងយករបស់អញ ក្នុងដង្វាយ១ភាគក្នុង១០ និងក្នុងដង្វាយលើកចុះឡើងនោះឯង, **ម៉ាឡាគី** ៣:៨–១០ ។ ចូរទៅរកជានឹងបងប្អូនជាមុនសិន រួចសឹមមកថ្វាយដង្វាយអ្នកចុះ, **ម៉ាថាយ** ៥:២៣–២៤ ។ ចូរថ្វាយ ព្រលឹងទាំងមូលរបស់អ្នក ជាដង្វាយថ្វាយព្រះគ្រីស្ទ, **អោមណៃ** ១:២៦ ។ បើអ្នកណាថ្វាយដង្វាយដោយចិត្តមិនស្មោះ នោះគ្មាន ប្រយោជន៍អ្វីដល់អ្នកនោះឡើយ, **មរ៉ូណៃ** ៧:៦ ។ កូនសោទាំងឡាយនៃបព្វជិតភាពនឹងមិនត្រូវបានដកចេញពីផែនដីទៀតឡើយរហូតដល់ពេលកូនប្រុសទាំងឡាយនៃលោកលេវីថ្វាយដង្វាយម្តងទៀតដល់ព្រះអម្ចាស់ ដោយសេចក្តីសុចរិត, **គ. និង ស.** ១៣:១ ។ នៅថ្ងៃនេះ ជាថ្ងៃរបស់ព្រះអម្ចាស់ អ្នកត្រូវថ្វាយដង្វាយទាំងឡាយរបស់អ្នក និងបុណ្យរំឭកទាំងឡាយរបស់អ្នក ដល់ព្រះដ៏ខ្ពស់បំផុត, **គ. និង ស.** ៥៩:១២ ។ ចូរយើង ជាសាសនាចក្រ ហើយប្រជារាស្ត្រថ្វាយដង្វាយដល់ព្រះអម្ចាស់ ដោយសេចក្តីសុចរិតចុះ, **គ. និង ស.** ១២៨:២៤ ។

**ដង្វាយ១ភាគក្នុង១០, ការថ្វាយដង្វាយ១ភាគក្នុង១០**
*សូមមើលផង* ដង្វាយ, ប្រាក់

ជាផ្នែក១ភាគក្នុង១០ នូវប្រាក់ប្រចាំឆ្នាំនៃជនណាម្នាក់ ដែលថ្វាយដល់ព្រះអម្ចាស់ តាមរយៈសាសនាចក្រ ។ មូលនិធិពីដង្វាយ១ភាគក្នុង១០ត្រូវយកទៅប្រើ ដើម្បីកសាងសាលាប្រជុំ និងព្រះវិហារទាំងឡាយ ដើម្បីទ្រទ្រង់កិច្ចការផ្សាយសាសនា ហើយដើម្បី កសាងនគរព្រះនៅលើផែនដី ។

អ័ប្រាហាំបានថ្វាយដង្វាយ១ភាគក្នុង១០ ពីគ្រប់របស់ទាំងអស់ដែលលោកមាន ដល់មិលគីស្សាដែក, **លោកុ.** ១៤:១៨–២០ (ហេព្រើរ ៧:១–២, ៩; អាលម៉ា ១៣:១៥) ។ អស់ទាំងដង្វាយ១ភាគក្នុង១០ គឺជារបស់ផងព្រះអម្ចាស់ ទុកជាបរិសុទ្ធសំរាប់ព្រះអម្ចាស់, **លេវី.** ២៧:៣០–៣៤ ។ ត្រូវឲ្យឯងហូតយក១ភាគក្នុង១០ ពីអស់ទាំងផលដែលកើន, **ចោទិ.** ១៤:២២, ២៨ ។ គេក៏យក១ភាគក្នុង១០ ពីរបស់ទាំងអស់ មកជាបរិបូរ, ២ របា. ៣១:៥ ។ ចុះតើមនុស្សនឹងកោងយករបស់ព្រះឬ? តើយើងបានកោងយករបស់ទ្រង់ឯណា ? គឺក្នុងដង្វាយ១ភាគក្នុង១០ ហើយក្នុងដង្វាយទាំងប៉ុន្មាននោះឯង, **ម៉ាឡាគី** ៣:៨–១១ (៣ នីហ្វៃ ២៤:៨–១១) ។ អ្នកណាដែលបាន

ថ្វាយដង្វាយ១ភាគ១០ នោះនឹងមិនត្រូវឆេះឡើយ នៅការយាងមករបស់ទ្រង់, **គ. និង ស.** ៦៤:២៣ (គ. និង ស. ៨៥:៣) ។ ព្រះដំណាក់របស់ព្រះនឹងត្រូវបានសាងឡើង ដោយដង្វាយ១ភាគ១០ពីប្រជារាស្ត្ររបស់ទ្រង់, **គ. និង ស.** ៩៧:១១–១២ ។ ព្រះអម្ចាស់ទ្រង់បានបើកសម្តែងប្រាប់ក្រិត្យវិន័យនៃដង្វាយ១ភាគក្នុង១០, **គ. និង ស.** ១១៩ ។ ដង្វាយ១ភាគក្នុង១០នឹងត្រូវចាត់ចែង ដោយក្រុម ប្រឹក្សាមួយ, **គ. និង ស.** ១២០ ។

**ដ៏អរគុណ, អរគុណ, ការថ្លែងអំណរគុណ** *សូមមើលផង*
ថ្វាយបង្គំ, ប្រទានពរ, ព្រះពរ; មានពរ

ជាអំណរចំពោះព្រះពរទាំងឡាយ ដែលបានមកពីព្រះ ។ ការថ្លែងអំណរគុណ គឺជាការដ៏គាប់ព្រះហឫទ័យដល់ព្រះ ហើយការថ្វាយបង្គំដ៏ពិត មានរួមនូវការថ្លែងអំណរគុណដល់ទ្រង់ ។ យើងរាល់គ្នាគួរតែថ្វាយអំណរគុណដល់ព្រះអម្ចាស់ ចំពោះគ្រប់អ្វីៗទាំងអស់ ។

នេះជាការល្អហើយ ដែលអរព្រះគុណដល់ព្រះអម្ចាស់, **ទំនុក.** ៩២:១ ។ចូរយើងចូលទៅចំពោះទ្រង់ ដោយអរព្រះគុណ, **ទំនុក.** ៩៥:១–២ ។ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ, **ទំនុក.** ១០០:១–៥ ។ ចូរកុំលែងអរព្រះគុណឡើយ, **អេភេ.** ១:១៥–១៦ ។ ចូរឲ្យដឹងគុណ, **កូល៉ុស** ៣:១៥ ។ សូមថ្វាយព្រះពរ សិរីល្អ ពាក្យអរគុណកិត្តិនាម ដល់ព្រះនៃយើងរាល់គ្នាចុះ, **វិវរ.** ៧:១២ ។ ឱចុះតើអ្នករាល់គ្នាត្រូវថ្លែងអំណរគុណដល់ព្រះរាជាសួគ៌របស់អ្នកយ៉ាងដូចម្តេចទៅ, **ម៉ូសាយ** ២:១៩–២១ ។ សូមអ្នករាល់ គ្នារស់នៅ ក្នុងអំណរគុណជារៀងរាល់ថ្ងៃ, **អាលម៉ា** ៣៤:៣៨ ។ នៅពេលអ្នកក្រោកឡើងនៅពេលព្រឹក ចូរឲ្យចិត្តកូនពោរពេញ ទៅដោយអំណរគុណដល់ព្រះ, **អាលម៉ា** ៣៧:៣៧ ។ អ្នករាល់គ្នាគួរធ្វើនូវអ្វីគ្រប់ទាំងអស់ដោយការអធិស្ឋាន និងអំណរគុណ, **គ. និង ស.** ៤៦:៧ ។ អ្នករាល់គ្នាត្រូវថ្លែងអំណរគុណដល់ព្រះ, **គ. និង ស.** ៤៦:៣២ ។ ចូរប្រព្រឹត្តការទាំងនេះ ដោយអំណរគុណ, **គ. និង ស.** ៥៩:១៥–២១ ។ចូរទទួលព្រះពរនេះពីព្រះហស្តនៃព្រះអម្ចាស់ ដោយមានចិត្តអំណរ, **គ. និង ស.** ៦២:៧ ។ អ្នកណាដែលទទួលគ្រប់ ទាំងអស់ ដោយអំណរអរគុណ នោះនឹងត្រូវបានធ្វើឲ្យរុងរឿង, **គ. និង ស.** ៧៨:១៩ ។គ្រប់អ្វីៗទាំងអស់ ចូរថ្លែងអំណរគុណ, **គ. និង ស.** ៩៨:១ (១ ថែស្ស. ៥:១៨) ។ ចូរសរសើរដំកើងដល់ព្រះអម្ចាស់ ដោយការអធិស្ឋានអំពីការសរសើរ និងអំណរគុណ, **គ. និង ស.** ១៣៦:២៨ ។

**ដាន់***សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់យ៉ាកុប និងនាងប៊ីលហាដែលជាបាវស្រីរបស់នាងរ៉ាជែល (លោកុ. ៣០:៥–៦) ។

*ពូជអំបូររបស់ដាន់៖* ចំពោះការប្រទានពរដែលយ៉ាកុបឲ្យដល់ដាន់ចូរមើលគម្ពីរលោកុប្បត្តិ ៤៩:១៦–១៨ ។ ចំពោះការប្រទានពរ ដែលម៉ូសេឲ្យដល់ពូជអំបូររបស់ដាន់ ចូរមើលគម្ពីរចោទិយកថា ៣៣:២២ ។ក្រោយពីពួកគេបានមករស់នៅស្រុកកាណាន នោះពូជអំបូររបស់ដាន់បានទទួលដែនដីតូចមួយ ប៉ុន្តែមានដីជាតិល្អបំផុត (យ៉ូស្វេ ១៩:៤០–៤៨) ។ ពួកគេមានការលំបាកជាខ្លាំង ក្នុងការការពារដែនដីពីពួកសាសន៍អាម៉ូរី (ចៅហ្វាយ ១:៣៤) និងពីពួកសាសន៍ភីលីស្ទីន (ចៅហ្វាយ ១៣:២, ២៥; ១៨:១) ។ ដោយហេតុនេះ ពួកសាសន៍ដាន់ បានផ្លាស់ទៅនៅទិខាងជើងស្រុកភីលីស្ទីន (ចៅហ្វាយ ១៨) គឺនៅជុំវិញក្រុងឡាអ៊ីស ហើយដាក់ ឈ្មោះថ្មីថា ទីក្រុងដាន់ ។ភូមិនេះ គឺស្គាល់ទូទៅថា ជាទិខាងជើងស្រុកភីលីស្ទីន គឺចាប់តាំង« ពីក្រុងដាន់ រហូតដល់បៀរ-សេបា » ។

**ដានីយ៉ែល**

ជាតួសំខាន់ក្នុងគម្ពីរដានីយ៉ែល នៅក្នុងព្រះគម្ពីរសញ្ញាចាស់; ជាព្យាការីនៃព្រះ ហើយជាបុរសដែលមានសេចក្តីជំនឿដ៏ខ្លាំងបំផុត ។

គ្មានដំណឹងអ្វីអំពីឪពុកម្តាយលោកទេ តែលោកដូចជាមកពីពូជស្តេច (ដានី. ១:៣) ។ លោកត្រូវគេចាប់យកទៅជាឈ្លើយ នៅក្រុង បាប៊ីឡូន ជាទីដែលលោកបានទទួលឈ្មោះជា បេលថិស្សាសារ (ដានី. ១:៦–៧) ។ ដានីយ៉ែល និងពួកឈ្លើយបីនាក់ទៀត មិនព្រម បរិភោគអាហារស្តេច ដោយព្រោះសាសនា (ដានី. ១:៨–១៦) ។

ដានីយ៉ែលត្រូវស្តេចនេប៊ូក្នេសា និងស្តេចដារីយុសសព្វព្រះទ័យ ដោយសារអំណាចលោកដែលលោកមាន ក្នុងការបកស្រាយន័យសុបិន (ដានី. ២; ៤) ។ លោកបានអាន ហើយបកស្រាយន័យអក្សរនៅលើជញ្ជាំង (ដានី. ៥) ។ ពួកខ្មាំងសត្រូវរបស់លោកបានរកផ្លូវទាស់នឹងលោក ហើយលោកត្រូវគេបោះចុះទៅក្នុងរូងសិង្ហ ប៉ុន្តែព្រះអម្ចាស់ ទ្រង់ជួយរក្សាជីវិតលោកទុក (ដានី. ៦) ។

*គម្ពីរដានីយ៉ែល៖* គម្ពីរនេះមានពីរភាគ គឺ៖ ជំពូកទី ១–៦ជារឿងអំពីដានីយ៉ែល និងមិត្តលោកបីនាក់ ។ ជំពូកទី ៧–១២ ជាការ និមិត្តដ៏ប្រកបដោយការព្យាករណ៍ ដែលដានីយ៉ែលបានឃើញ ។គម្ពីរនេះបង្រៀននូវសារៈសំខាន់អំពីការនៅស្មោះចំពោះព្រះ ហើយអធិប្បាយប្រាប់ថា ព្រះអម្ចាស់ទ្រង់ប្រទានពរដល់ពួកស្មោះត្រង់ ។

ការផ្តល់ដ៏សំខាន់ក្នុងគម្ពីរ គឺការបកស្រាយន័យសុបិននៃស្តេចនេប៊ូក្នេសា ។ ក្នុងសុបិននោះមាននគរព្រះនៅថ្ងៃចុងក្រោយបង្អស់បាន ត្រូវយកមកធ្វើជាតំណាងថ្មមួយ ដែលកាត់ចេញពីភ្នំ ។ ថ្មនឹងរមៀលទៅរហូតដល់ពេញផែនដីទាំងមូល (ដានី. ២; សូមមើលផងគ. និង ស. ៦៥:២) ។

**ដាម៉ាស**

ជាទីក្រុងបុរាណមួយនៅស្រុកស៊ីរី ។

ដាម៉ាសស្ថិតនៅលើវាលមួយដ៏មានដីជាតិ នៅជាប់ព្រំដែនទីរហោស្ថាន ហើយបានទឹកស្រោចស្រប់ដោយទន្លេបារាដា ។ គឺបានពោល ដល់ជាញឹកញាប់នៅក្នុងគម្ពីរ (ចាប់ផ្តើមពីគម្ពីរលោកុប្បត្តិ ១៥:២) ។ ប៉ុលកំពុងតែធ្វើដំណើរទៅក្រុងដាម៉ាស កាលព្រះយេស៊ូវដែលមានព្រះជន្មរស់ឡើងវិញ បានលេចមកឯលោក (កិច្ចការ ៩:១–២៧; ២២:៥–១៦; ២៦:១២–២០; ២ កូរិន ១១:៣២–៣៣) ។

**ដារីយុស** *សូមមើលផង* បាបិល, បាប៊ីឡូន

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាស្ដេចនៃសាសន៍មេឌី ដែលសោយរាជ្យនៅស្រុកបាប៊ីឡូន ក្រោយពីស្ដេចបេលសាសារសុគតទៅ (ដានី. ៥:៣១; ៦:៩, ២៥–២៨; ៩:១; ១១:១) ។

**ដាវីឌ** *សូមមើលផង* នាងបាតសេបា; ទំនុកដំកើង

ជាស្ដេចម្នាក់នៅស្រុកអ៊ីស្រាអែលពីបុរាណ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

ដាវីឌជាកូនប្រុសរបស់អ៊ីសាយ ពីពូជអំបូររបស់យូដា ។ លោកជាកំឡោះក្លាហានម្នាក់ ដែលបានប្រហារសិង្ហ ខ្លាឃ្មុំ និងកូលីយ៉ាត ជា សាសន៍ភីលីស្ទីន មាឌធំម្នាក់ (១ សាំយូ. ១៧) ។ ដាវីឌត្រូវបានរើស ហើយចាក់ប្រេងតាំងឡើងជាស្ដេចអ៊ីស្រាអែល ។ ដូចជាសូលដែរ ទ្រង់ក៏មានទោសយ៉ាងធ្ងន់ កាលមានព្រះជន្មធំឡើង ប៉ុន្តែមិនដូចសូលទេ ទ្រង់អាចមានសេចក្ដីទន់ទាបដ៏ពិត ។ ហេតុដូច្នេះ ហើយទ្រង់អាចទទួលការអត់ទោសឲ្យ លើកលែងតែក្នុងការប្រហារអ៊ូរី (គ.ស. ១៣២:៣៩) ។ ជីវិតទ្រង់អាចចែកចេញជាបួនភាគ គឺៈ (១) នៅភូមិបេថ្លេហិម ជាទីដែលទ្រង់ជាអ្នកគង្វាល (១ សាំយូ. ១៦–១៧); (២) នៅក្នុងវាំងនៃស្ដេចសូល (១ សាំយូ. ១៨–១៩:១៨); (៣) ជាអ្នករសាត់ព្រាត់ (១ សាំយូ. ១៩:១៨–២ សាំយូ. ១:២៧); (៤) ជាស្ដេចលើយូដា នៅឯហេប្រុន (២ សាំយូ. ២–៤) ហើយបន្ទាប់មក ជាស្ដេចលើអ៊ីស្រាអែលទាំងអស់ (២ សាំយូ. ៥–១ ពង្សាវ. ២:១១) ។

អំពើបាបរបស់ដាវីឌចំពោះការសហាយស្មន់នឹងនាងបាតសេបា នោះមានការឥតផលជាច្រើនតតាមមក ដែលធ្វើឲ្យខូចខាតដល់ជីវិតទ្រង់អស់រយៈពេល ២០ ឆ្នាំចុងក្រោយ ។ នៅក្នុងរាជ្យទ្រង់ ប្រទេសទាំងមូលបានចំរើនលូតលាស់ ប៉ុន្តែចំពោះដាវីឌ ទ្រង់រងទុក្ខមកពី ផលនៃអំពើបាបរបស់ទ្រង់ ។ មានការមិនស្រុះស្រួលក្នុងគ្រួសារជានិច្ច គឺក្នុងរឿងអាប់សាឡុម និងអ័ដូនីយ៉ា ដែលចប់ក្នុងការបះបោរ ពេញខ្នាត ។ ហេតុការណ៍ទាំងនេះ ជាការសំរេចនៃពាក្យបន្ទុករបស់ណាថាន់ជាព្យាការី មកលើដាវីឌ ពីព្រោះតែអំពើបាបរបស់ទ្រង់ (២ សាំយូ. ១២:៧–១៣) ។

សូម្បីតែមានវិបត្តិទាំងនេះក៏ដោយ គង់តែរាជ្យដាវីឌក៏ជារាជ្យដ៏ប្រសើរបំផុតមួយ ក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ពីព្រោះ (១) ទ្រង់បាន រួបរួមពួកពូជអំបូរទៅជាប្រទេសមួយ (២) ទ្រង់រក្សាទុកនូវរបស់របរសាធារណៈនៃប្រទេស (៣) ទ្រង់ដំកល់រដ្ឋាភិបាលលើសាសនាពិត ដើម្បីទុកព្រះហឫទ័យរបស់ព្រះជាច្បាប់នៃអ៊ីស្រាអែល ។ ដោយហេតុទាំងនេះហើយ ទើបរាជ្យដាវីឌត្រូវបានរាប់ទុកថា ជាយុគដ៏ឧត្ដម មួយក្នុងប្រទេស ហើយជាគំរូអំពីយុគដ៏រុងរឿងទៅទៀត កាលព្រះមែស៊ីនឹងយាងមក (អេសាយ ១៦:៥; យេរេ. ២៣:៥; អេសេ. ៣៧:២៤–២៨) ។

ជីវិតរបស់ដាវីឌអធិប្បាយប្រាប់អំពីសេចក្ដីត្រូវការនៃជនគ្រប់រូបដើម្បីកាន់ខ្ជាប់ក្នុងសេចក្ដីសុចរិតដរាបដល់ចុងបំផុត ។ កាលនៅវ័យក្មេង នោះទ្រង់ត្រូវគេរាប់ថា ជាមនុស្សត្រូវនឹង « ព្រះហឫទ័យ » របស់ព្រះអម្ចាស់ (១ សាំយូ. ១៣:១៤) ។ កាលធំពេញវ័យ ទ្រង់មានបន្ទូលដោយព្រះវិញ្ញាណ ហើយមានវិវរណៈជាច្រើន ។ ប៉ុន្តែទ្រង់បង់តម្លៃដ៏ធ្ងន់ ចំពោះការមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយ នៃព្រះ (គ. និង ស. ១៣២:៣៩) ។

**ដើមជីវិត** *សូមមើលផង* អេដែន

ជាដើមឈើមួយ នៅក្នុងសួនច្បារអេដែន ហើយនៅឯស្ថានបរមសុខនៃព្រះ (លោកុ. ២:៩; វិវរ. ២:៧) ។ នៅក្នុងសុបិនរបស់លីហៃ នោះដើមជីវិត គឺជាតំណាងអំពីសេចក្ដីស្រឡាញ់របស់ព្រះ ហើយដែលបានសំដៅដល់អំណោយទានដ៏ធំបំផុត ក្នុងអស់ទាំងអំណោយទាននៃព្រះ (១ នីហ្វៃ ៨; ១១:២១–២២, ២៥; ១៥:៣៦) ។

ចេរូប៊ីន និងដាវ ដែលជាអណ្ដាតភ្លើង រក្សាផ្លូវទៅឯដើមជីវិត, **លោកុ.** ៣:២៤ (អាលម៉ា ១២:២១–២៣; ៤២:២–៦) ។ យ៉ូហានបានឃើញដើមជីវិត ហើយស្លឹកឈើនោះ មានអំណាចសំរាប់នឹងមើលអស់ទាំងសាសន៍ឲ្យជា, **វិវរ.** ២២:២ ។ លីហៃបានឃើញដើមជីវិត, **១ នីហ្វៃ** ៨:១០–៣៥ ។ នីហ្វៃបានឃើញដើមឈើ ដែលឪពុកលោកបានឃើញ, **១ នីហ្វៃ** ១១:៨–៩ ។ ដំបងដែកនាំផ្លូវទៅឯដើមជីវិត, **១ នីហ្វៃ** ១១:២៥ (១ នីហ្វៃ ១៥:២២–២៤) ។ ឈូងសមុទ្រមួយដ៏គួរឲ្យស្អប់ស្អែងបំបែកពួកទុច្ចរិតឲ្យចេញពីដើមជីវិត, **១ នីហ្វៃ** ១៥:២៨, ៣៦ ។ គឺជាការចាំបាច់ថាត្រូវមានផ្លែដែលហាមឃាត់ ផ្ទុយទៅនឹងដើមជីវិត, **២ នីហ្វៃ** ២:១៥ ។ ចូរមករកព្រះអម្ចាស់ ហើយទទួលទាន នូវផ្លែនៃដើមជីវិតចុះ, **អាលម៉ា** ៥:៣៤, ៦២ ។ ប្រសិនបើឪពុកម្ដាយដើមរបស់យើងបានទទួលទាននូវផ្លែនៃដើមជីវិត នោះពួកគេនឹង ត្រូវវេទនារហូត, **អាលម៉ា** ១២:២៦ ។ បើអ្នករាល់គ្នាពុំថែទាំព្រះបន្ទូលទេ នោះអ្នករាល់គ្នានឹងពុំអាចបេះផ្លែនៃដើម ជីវិតបានឡើយ, **អាលម៉ា** ៣២:៤០ ។ ព្រះអម្ចាស់ទ្រង់បានដាំដើមជីវិតនៅកណ្ដាលសួនច្បារ, **ម៉ូសេ** ៣:៩ (អ័ប្រា. ៥:៩) ។ ព្រះទ្រង់បានបណ្ដេញអ័ដាមចេញពីសួនច្បារអេដែន ខ្លាចក្រែងគាត់ទទួលទានផ្លែនៃដើមជីវិត ហើយរស់ជារៀងដរាបទៅ, **ម៉ូសេ** ៤:២៨–៣១ ។

**ដើមដំបូង** *សូមមើលផង* ការបង្កបង្កើត; ជីវិតមុនផែនដី, បង្កើត, ព្រះយេស៊ូវគ្រីស្ទ

តាមធម្មតា គឺនិយាយពីគ្រាមុនជីវិតមនុស្សលោក — គឺជាជីវិតមុនផែនដី ។ ជួនកាល ព្រះយេស៊ូវគ្រីស្ទត្រូវគេថ្វាយព្រះនាមថា ជាដើម ។

កាលដើមដំបូងឡើយ ព្រះទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី, **លោកុ.** ១:១ (ម៉ូសេ ២:១) ។ កាលដើមដំបូងមានព្រះបន្ទូល, **យ៉ូហាន** ១:១ ។ យើងគឺជាអាលផា និងអូមេកា គឺជាដើម ហើយជាចុង, **៣ នីហ្វៃ** ៩:១៨ ។ ព្រះគ្រីស្ទទ្រង់ជាដើម ហើយជាចុង, **គ. និង ស.** ១៩:១ ។ សេចក្ដីសញ្ញាថ្មី និងអស់កល្បជានិច្ច គឺមានតាំងពីដើមដំបូងមកម៉្លេះ, **គ. និង ស.** ២២:១ ។ មានមនុស្សនៅជាមួយនឹងព្រះ តាំងពីដើមដំបូងមកម៉្លេះ, **គ. និង ស.** ៩៣:២៣, ២៩ ។ វិញ្ញាណនៃពួកឧត្តុងឧត្ដម

និងពួកអ្នកធំ នោះត្រូវបានរើសតាំងពីដើមដំបូងមក, **គ. និង ស.** ១៣៨:៥៥ ។ ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង បានគង់នៅជាមួយនឹងយើង ចាប់តាំងពីដើមដំបូងមក, **ម៉ូសេ** ២:២៦ ។

**ដើមអូលីវ** *សូមមើលផង* ប្រេង, អ៊ីស្រាអែល

ជាដើមឈើមួយ ដែលមានទូទៅនៅស្រុកអ៊ីស្រាអែល ហើយជាធនធានកសិកម្មដ៏សំខាន់មួយ នៅដែនដីទាំងប៉ុន្មានក្នុងព្រះគម្ពីរប៊ីប ។ ដើមនេះគេដាំយកដើម ផ្លែ និងប្រេង ។ ដើមអូលីវ គេតែងតែប្រើនៅក្នុងគម្ពីរ ដើម្បីធ្វើជានិមិត្តរូបអំពីវង្សអ៊ីស្រាអែល ។

វង្សអ៊ីស្រាអែលត្រូវបានប្រៀបធៀបនឹងដើមអូលីវ ដែលមែកទាំងឡាយត្រូវកាត់ចេញ ហើយត្រូវខ្ចាត់ខ្ចាយ, **១ នីហ្វៃ** ១០:១២ (១ នីហ្វៃ ១៥:១២) ។ ព្រះអម្ចាស់ទ្រង់បានប្រៀបធៀបវង្សអ៊ីស្រាអែលទៅនឹងដើមអូលីវស្រុក, **យ៉ាកុប** ៥–៦ ។ យ៉ូសែប ស៊្មីធ បានហៅវិវរណៈក្នុងកណ្ឌទី ៨៨ ថា ស្លឹកអូលីវ, **គ. និង ស.** ៨៨:ចំណងជើង ។ បុរសត្រកូលខ្ពស់ម្នាក់បានប្រាប់ពួកអ្នកបំរើរបស់លោកឲ្យទៅចំការ ហើយដាំដើមអូលីវ១២ដើម, **គ. និង ស.** ១០១:៤៣–៦២ ។

**ដើមអូលីវ, ភ្នំ** *សូមមើលផង* គេតសេម៉ានី

ជាភ្នំនៅខាងកើតច្រកភ្នំកេដ្រុន គឺនៅខាងកើតក្រុងយេរូសាឡិម ។ នៅលើជំរាលភ្នំខាងលិច នៅជិតជើងភ្នំ គឺជាសួនច្បារគេត សេម៉ានី ។ ភូមិបេតផាសេ និងភូមិបេថានី គឺនៅលើជំរាលភ្នំខាងកើត ។ ភ្នំនេះគឺជាទីកន្លែងនៃព្រឹត្តិការណ៍ជាច្រើនក្នុងព្រះគម្ពីរប៊ីប (ម៉ាថាយ ២៤:៣) ។ ហើយក៏នឹងទៅជាទីកន្លែងដ៏សំខាន់មួយដែរ ក្នុងព្រឹត្តិការណ៍នៅគ្រាចុងក្រោយ (សាការី ១៤:៣–៥; គ. និង ស. ៤៥:៤៨–៥៤; ១៣៣:២០) ។

**ដើរ, ដើរជាមួយនឹងព្រះ** *សូមមើលផង* ការគោរពតាម, គោរពតាម; ដែលគោរពតាម, ផ្លូវ, សុចរិត, សេចក្ដីសុចរិត

នៅឲ្យបានស្រុះស្រួលនឹងការបង្រៀនទាំងឡាយរបស់ព្រះ ហើយរស់នៅតាមដែលព្រះទ្រង់ មានព្រះហឫទ័យចង់ឲ្យរាស្ត្ររបស់ ទ្រង់រស់នៅ; ស្ដាប់តាម ហើយគោរពតាមការបណ្ដាលពីព្រះវិញ្ញាណបរិសុទ្ធ ។

ដើម្បីឲ្យអញបានល្បងគេមើល តើគេនឹងដើរតាមច្បាប់របស់អញឬទេ, **និក្ខ.** ១៦:៤ ។ គ្មានរបស់ល្អណានឹងសំចៃទុក ពីពួកអ្នកដែលដើរដោយទៀងត្រង់ឡើយ, **ទំនុក.** ៨៤:១១ ។ អស់អ្នកណា ដែលដើរតាមក្រិត្យក្រមរបស់អញ ហើយរក្សាបញ្ញត្តិច្បាប់របស់អញ នោះនឹង បានទៅជារាស្ត្ររបស់អញ, **អេសេ.** ១១:២០–២១ (ចោទិ. ៨:៦) ។ តើព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យឯងប្រព្រឹត្តដូចម្ដេច បើមិនមែន ឲ្យឯងដើរជាមួយនឹងព្រះ ដោយសុភាពរាបទាប ? **មីកា** ៦:៨ (គ. និង ស. ១១:១២) ។ ចូរដើរក្នុងពន្លឺ ដូចជាព្រះគង់ក្នុងពន្លឺ, **១ យ៉ូហាន** ១:៧ (២ យ៉ូហាន ១:៦; ៤ នីហ្វៃ ១:១២;៣ យ៉ូហាន ១:៤) ។ ចូរដើរតាមផ្លូវតូច ដែលនាំទៅឯជីវិតចុះ, **២ នីហ្វៃ** ៣៣:៩ ។ ស្ដេចបេនយ៉ាមីនបានដើរ ដោយសតិសម្បជញ្ញៈដ៏ជ្រះថ្លាចំពោះព្រះ, **ម៉ូសាយ** ២:២៧ ។ កាតព្វកិច្ចរបស់អ្នក គឺដើម្បីដើរដោយគ្មានទោសតាមរបៀបដ៏បរិសុទ្ធ នៃព្រះ, **អាលម៉ា** ៧:២២ ។ ពួកសមាជិកក្នុងសាសនាចក្រត្រូវសម្ដែង ដោយដំណើរ និងវាចាដ៏សុចរិត, **គ. និង ស.** ២០:៦៩ ។ ត្រូវស្ដាប់តាមព្យាការី ហើយដើរក្នុងបរិសុទ្ធភាពទាំងអស់ នៅចំពោះព្រះអម្ចាស់, **គ. និង ស.** ២១:៤ ។ ត្រូវបង្រៀនកូនចៅឲ្យ អធិស្ឋាន និងឲ្យដើរ ដោយទៀងត្រង់ នៅចំពោះព្រះអម្ចាស់, **គ. និង ស.** ៦៨:២៨ ។ ចូរនៅក្នុងយើង ហើយយើងក្នុងអ្នក; ហេតុដូច្នេះហើយ ចូរដើរជាមួយនឹងយើងចុះ, **ម៉ូសេ** ៦:៣៤ ។

**ដេក**

ជាស្ថានភាពនៃការឈប់សំរាក ក្នុងពេលមនុស្សម្នាក់ មិនធ្វើអ្វី ហើយភ្លឹក ។ ព្រះអម្ចាស់ទ្រង់បានទូន្មានដល់ពួកបរិសុទ្ធទ្រង់ កុំឲ្យដេក យូរជាងសេចក្ដីត្រូវការឡើយ (គ. និង ស. ៨៨:១២៤) ។ ការដេក ក៏អាចរាប់ទុកជានិមិត្តរូបអំពីសេចក្ដីស្លាប់ខាងវិញ្ញាណ (១ កូរិន. ១១:៣០; ២ នីហ្វៃ ១:១៣) ឬអំពីសេចក្ដីស្លាប់ ខាងសាច់ឈាម (មរមន ៩:១៣) ។

**ដែនដីសន្យា**

ជាដែនដីទាំងឡាយដែលព្រះអម្ចាស់ទ្រង់បានសន្យាទុក ជាកេរ្ដិ៍អាករដល់ពួកអ្នកដែលដើរតាមទ្រង់ដោយស្មោះត្រង់ ហើយតែងតែ សន្យាដល់ពូជពង្សគេដែរ ។ មានដែនដីសន្យាជាច្រើន ។ នៅក្នុងព្រះគម្ពីរមរមនដែនដីសន្យាដែលតែងតែពោលដល់ គឺជាទ្វីប អាមេរិក ។

អញនឹងឲ្យស្រុកនេះដល់ពូជឯង, **លោកុ.** ១២:៧ (អ័ប្រា. ២:១៩) ។ អញនឹងឲ្យស្រុកកាណានដល់ឯង និងពូជឯង, **លោកុ.** ១៧:៨ (លោកុ. ២៨:១៣) ។ ម៉ូសេបានប្រាប់ព្រំដែននៃស្រុកសំរាប់ពួកអ៊ីស្រាអែលនៅស្រុកកាណាន, **ជនគ.** ៣៤:១–១២ (ជនគ. ២៧:១២) ។ អ្នករាល់គ្នានឹងបាននាំទៅកាន់ដែនដីសន្យា, **១ នីហ្វៃ** ២:២០ (១ នីហ្វៃ ៥:៥) ។ ព្រះអម្ចាស់ទ្រង់នាំជនសុចរិត ទៅដែនដីដ៏ល្អ, **១ នីហ្វៃ** ១៧:៣៨ ។ បើសិនជាពូជពង្សរបស់លីហៃកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះពួកគេនឹងចំរើនឡើងនៅលើដែនដីសន្យា, **២ នីហ្វៃ** ១:៥–៩ ។ ពួកអ៊ីស្រាអែលនឹងបានត្រឡប់ទៅឯដែនដីសន្យារបស់គេវិញ, **២ នីហ្វៃ** ២៤:១–២ (អេសាយ ១៤:១–២) ។ សាសន៍ណាក៏ដោយដែលនឹងយកបានដែនដីនេះ គឺត្រូវបំរើព្រះ បើពុំនោះទេ ពួកគេនឹងត្រូវបោសចេញ, **អេធើរ** ២:៩–១២ ។ នេះជាដែនដីសន្យា ហើយជាកន្លែងសំរាប់ទីក្រុងស៊ីយ៉ូន, **គ. និង ស.** ៥៧:២ ។ ពួកយូដាអាចចាប់ផ្ដើមវិលទៅរកដែនដីទាំងឡាយ នៃលោកអ័ប្រាហាំ, **គ. និង ស.** ១០៩:៦៤ ។ ក្រុងយេរូសាឡិមថ្មីនឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក, **ម. នៃ ស.** ១:១០ ។

**ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់** *សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; ពិភពលោក, រូបកាយ; សេចក្ដីស្លាប់ខាងសាច់ឈាម

ជាវេលាចាប់ពីកំណើត រហូតដល់សេចក្ដីស្លាប់ខាងសាច់ឈាម ។ ជួនកាល វេលានេះត្រូវបានហៅថា សណ្ឋានទីពីរ ។

នៅថ្ងៃណាដែលឯងស៊ីផលនៃដើមនោះ នោះនឹងត្រូវស្លាប់ជាមិនខាន, **លោកុ.** ២:១៦–១៧ (ម៉ូសេ ៣:១៦–១៧) ។ នៅពេល ស្លាប់ទៅ នោះវិញ្ញាណត្រឡប់ទៅឯព្រះ ហើយរូបកាយត្រឡប់ទៅឯធូលីដីវិញ, **សាស្តា** ១២:៧ (លោកុ, ៣:១៩; ម៉ូសេ ៤:២៥) ។ កុំឲ្យបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នា ដែលតែងតែស្លាប់, **រ៉ូម** ៦:១២ ។ រូបកាយដែលរមែងស្លាប់នេះ ត្រូវប្រដាប់ដោយ សេចក្តីមិនចេះស្លាប់វិញ, **១ កូរិន.** ១៥:៥៣ (អេណុស ១:២៧; ម៉ូសាយ ១៦:១០; មរមន ៦:២១) ។ ស្ថានភាពរបស់មនុស្សបានក្លាយ ទៅជាស្ថានភាពពិសោធន៍, **២ នីហ្វៃ** ២:២១ (អាលម៉ា ១២:២៤; ៤២:១០) ។ លោកអ័ដាមបានធ្លាក់ខ្លួន ដើម្បីឲ្យមាន មនុស្សលោក, **២ នីហ្វៃ** ២:២៥ ។ តើអ្នករាល់គ្នាមើលទៅមុខ ហើយមើលមករូបកាយដែលរមែងស្លាប់នេះថានឹងបានប្រោសឲ្យទៅជាអមតៈទេ ? **អាលម៉ា** ៥:១៥ ។ ជីវិតនេះគឺជាពេលសំរាប់ប្រុងប្រៀបទៅជួបព្រះ, **អាលម៉ា** ៣៤:៣២ ។ ចូរកុំខ្លាចការស្លាប់ ត្បិត សេចក្តីអំណររបស់អ្នកពុំបានពោរពេញនៅក្នុងពិភពលោកនេះទេ, **គ. និង ស.** ១០១:៣៦ ។ អស់អ្នកណាដែលរក្សាសណ្ឋានទីពីរ របស់ខ្លួន នោះនឹងបានសិរីល្អ, **អ័ប្រា.** ៣:២៦ ។

**ដៃសេរីវេត** *សូមមើលផង* ពួកសាសន៍យ៉ារេឌ

នៅក្នុងព្រះគម្ពីរមរមន ពាក្យយ៉ារេឌ មានន័យថា « ឃ្មុំ » (អេធើរ ២:៣) ។

**ដៃ, ការដាក់** *សូមមើលផង* ការញែកចេញ,
ការប្រសិទ្ធពរដល់មនុស្សឈឺ; ពិធីតែងតាំង; តែងតាំង,
អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ

ជាការដាក់ដៃលើក្បាលមនុស្ស ក្នុងកម្មពិធីបព្វជិតភាព ។ ពិធីបរិសុទ្ធនៃបព្វជិតភាពជាច្រើនបានធ្វើដោយការដាក់ដៃលើ ដូចជា ពិធីតែងតាំង ការប្រទានពរ ការប្រសិទ្ធពរដល់មនុស្សឈឺ ពិធីបញ្ជាក់សមាជិកសាសនាចក្រ និងការប្រទានព្រះវិញ្ញាណបរិសុទ្ធ ។

ម៉ូសេបានដាក់ដៃលើក្បាលយ៉ូស្វេ តាមព្រះអម្ចាស់បានបង្គាប់, **ជនគ.** ២៧:១៨, ២២–២៣ (ចោទិ. ៣៤:៩) ។ ព្រះយេស៊ូវដាក់ព្រះហស្តលើមនុស្សឈឺចំនួនតិចតួច ហើយបានប្រោសឲ្យគេបានជា, **ម៉ាកុស** ៦:៥ (មរមន ៩:២៤) ។ ពួកសាវកបានដាក់ដៃលើពួក ៧ នាក់ដែលនឹងជួយពួកគេ, **កិច្ចការ** ៦:៥–៦ ។ ព្រះវិញ្ញាណបរិសុទ្ធបានត្រូវប្រទានឲ្យដោយការដាក់ដៃលើ, **កិច្ចការ** ៨:១៤–២៧ ។ អាន៉ានាសបានដាក់ដៃលើសុល ហើយបានធ្វើឲ្យភ្នែកលោកភ្លឺវិញ, **កិច្ចការ** ៩:១២, ១៧–១៨ ។ ប៉ុលបានដាក់ដៃលើគាត់ ហើយបានធ្វើឲ្យគាត់ជា, **កិច្ចការ** ២៨:៨ ។ ប៉ុលបានបង្រៀនពីបុណ្យជ្រមុជទឹក និងការដាក់ដៃលើ, **ហេព្រើរ** ៦:២ ។ អាលម៉ាបានតែងតាំង ពួកសង្ឃ និងពួកអែលឌើរឡើង ដោយការដាក់ដៃលើ, **អាលម៉ា** ៦:១ ។ ព្រះយេស៊ូវទ្រង់ប្រទានអំណាចដល់ពួកសិស្សទ្រង់ ឲ្យប្រគល់ ព្រះវិញ្ញាណបរិសុទ្ធ ដោយការដាក់ដៃលើ, ៣ នីហ្វៃ ១៨:៣៦–៣៧ ។ ដល់ជនណាដែលអ្នកដាក់ដៃលើ នោះអ្នកត្រូវឲ្យព្រះវិញ្ញាណ បរិសុទ្ធ, **មរ៉ូណៃ** ២:២ ។ ពួកអែលឌើរត្រូវដាក់ដៃលើកូនក្មេង សំរាប់ឲ្យពរ, **គ. និង ស.** ២០:៧០ ។ ពួកគេនឹងបានទទួលព្រះវិញ្ញាណ បរិសុទ្ធដោយសារការដាក់ដៃលើ, **គ. និង ស.** ៣៥:៦ (ម. នៃ ស. ១:៤) ។ ពួកអែលឌើរត្រូវដាក់ដៃលើពួកមនុស្សឈឺ, **គ. និង ស.** ៤២:៤៤ (គ. និង ស. ៦៦:៩) ។ ពួកកូនក្មេងត្រូវទទួលការដាក់ដៃលើ បន្ទាប់ពីបុណ្យជ្រមុជទឹក, **គ. និង ស.** ៦៨:២៧ ។ បព្វជិតភាព ត្រូវបានទទួលដោយការដាក់ដៃលើ, **គ. និង ស.** ៨៤:៦–១៦ ។

**ដំណាក់នៃព្រះអម្ចាស់** *សូមមើល* ដំណាក់នៃព្រះអម្ចាស់,
ព្រះវិហារបរិសុទ្ធ

**ដំណឹងល្អ** *សូមមើលផង* គ្រាកាន់កាប់ត្រួតត្រា;
គោលលទ្ធិនៃព្រះគ្រីស្ទ; ផែនការនៃសេចក្តីប្រោសលោះ

ជាផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះ ដែលធ្វើទៅបានតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ដំណឹងល្អមានរួមទាំងសេចក្តីពិតដ៏នៅអស់កល្បជានិច្ច ឬក្រិត្យ សេចក្តីសញ្ញា និងពិធីបរិសុទ្ធទាំងប៉ុន្មានដែលត្រូវការ ដើម្បីឲ្យមនុស្សលោកចូលទៅឯវត្តមានព្រះវិញ ។ ព្រះទ្រង់បានសាងឡើងវិញ នូវភាពពោរពេញនៃដំណឹងល្អដល់ផែនដី នៅសតវត្សទី ១៩ ដោយព្យាការីយ៉ូសែប ស្ម៊ីធ ។

ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកិយទាំងមូល ហើយផ្សាយដំណឹងល្អ, **ម៉ាកុស** ១៦:១៥ ។ ភាគដ៏ច្បាស់ និងពិសេសៗទាំងប៉ុន្មាន នៃដំណឹងល្អរបស់កូនចៀមត្រូវបានរក្សាទុក, **១ នីហ្វៃ** ១៣:៣២ ។ នេះគឺជាដំណឹងល្អរបស់យើង, ៣ នីហ្វៃ ២៧:១៣–២១ (គ. និង ស. ៣៩:៦) ។ ព្រះគម្ពីរមរមនមានភាពពោរពេញនៃដំណឹងល្អ, **គ. និង ស.** ២០:៨–៩ (គ. និង ស. ៤២:១២) ។ នេះគឺជាដំណឹងល្អ, **គ. និង ស.** ៧៦:៤០–៤៣ ។ បព្វជិតភាពមិលគីស្សាដែកចាត់ចែងដំណឹងល្អ, **គ. និង ស.** ៨៤:១៩ ។ មនុស្សគ្រប់រូបនឹងបានឮភាពពោរពេញនៃដំណឹងល្អ ដោយនូវអណ្តាតរបស់ខ្លួន, **គ. និង ស.** ៩០:១១ ។ ព្រះរាជបុត្រាបានផ្សាយដំណឹងល្អដល់វិញ្ញាណទាំងឡាយនៃ មនុស្សស្លាប់, **គ. និង ស.** ១៣៨:១៨–២១, ២៨–៣៧ ។ ដំណឹងល្អបានផ្សាយ ចាប់តាំងពីដើមដំបូងមក, **ម៉ូសេ** ៥:៥៨ ។ គោលការណ៍ និងពិធីបរិសុទ្ធទីមួយ នៃដំណឹងល្អត្រូវបានអធិប្បាយប្រាប់, **ម. នៃ ស.** ១:៤ ។

**ដំណឹងល្អ, ការសាងឡើងវិញនៃ** *មើល*
ការសាងឡើងវិញនៃដំណឹងល្អ

**ដំណឹងល្អទាំងឡាយ** *សូមមើលផង* កូនប្រុសរបស់សេបេដេ;
ម៉ាថាយ, ម៉ាកុស; យ៉ូហាន, លូកា

ជាបញ្ជីរឿង ឬទីបន្ទាល់បួនច្បាប់អំពីព្រះជន្មនៃព្រះយេស៊ូវនៅលើផែនដី និងហេតុការណ៍ដែលទាក់ទងទៅនឹងការបង្រៀនរបស់ទ្រង់ នៅក្នុងគម្ពីរបួនច្បាប់មុនដំបូងក្នុងព្រះគម្ពីរសញ្ញាថ្មី ។ បានសរសេរដោយម៉ាថាយ

ម៉ាកុស លូកា និងយ៉ូហាន គឺជាទីបន្ទាល់ដែល បានកត់ទុក អំពីព្រះជន្មនៃព្រះគ្រីស្ទ ។ គម្ពីរនីហ្វៃទី ៣ នៅក្នុងព្រះគម្ពីរមរមន តាមបែបបទជាច្រើន គឺដូចជាដំណឹងល្អទាំងបួនច្បាប់ នេះ ដែលមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែរ ។

គម្ពីរទាំងឡាយនៅក្នុងព្រះគម្ពីរសញ្ញាថ្មីមុនដំបូងបានសរសេរជាភាសាក្រេក ។ ដំណឹងល្អដែលព្រះយេស៊ូវគ្រីស្ទបានធ្វើដង្វាយធួន ដែលនឹងប្រោសលោះមនុស្សលោកទាំងអស់ពីសេចក្ដីស្លាប់ ហើយប្រទានរង្វាន់ដល់បុគ្គលនីមួយៗ តាមកិច្ចការរបស់គេ (យ៉ូហាន ៣:១៦; រ៉ូម ៥:១០–១១; ២ នីហ្វៃ ៩:២៦; អាលម៉ា ៣៤:៩; គ. និង ស. ៧៦:៦៩) ។

*ភាពស្របគ្នានូវដំណឹងល្អទាំងឡាយ៖* សេចក្ដីបង្រៀននៃព្រះអង្គសង្គ្រោះនៅក្នុងគម្ពីរម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន អាចយកមកប្រៀបធៀបគ្នានឹងវិវរណៈនៅថ្ងៃចុងក្រោយ តាមបែបខាងក្រោមនេះ គឺ៖

**ភាពស្របគ្នានូវដំណឹងល្អទាំងឡាយ**

| ព្រឹត្តិការណ៍ | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន | វិវរណៈនៅថ្ងៃចុងក្រោយ |
|---|---|---|---|---|---|
| ពង្សាវតារនៃព្រះយេស៊ូវ | ១:២–១៧ | | ៣:២៣–៣៨ | | |
| កំណើតនៃយ៉ូហាន–បាទីស្ទ | | | ១:៥–២៥, ៥៧–៥៨ | | |
| កំណើតនៃព្រះយេស៊ូវ | ២:១–១៥ | | ២:៦–៧ | | ១ នីហ្វៃ ១១:១៨–២០; ២ នីហ្វៃ ១៧:១៤; ម៉ូសាយ ៣:៥–៨; អាលម៉ា ៧:១០; ហេលេ. ១៤:៥–១២; ៣ នីហ្វៃ ១:៤–២២ |
| ពាក្យព្យាករណ៍ទាំងឡាយនៃស៊ីម្មាន និងនាងអាណា | | | ២:២៥–៣៩ | | |
| ទៅព្រះវិហារ(បុណ្យរំលង) | | | ២:៤១–៥០ | | |
| ការចាប់ផ្ដើមនៃការបង្រៀនរបស់យ៉ូហាន | ៣:១, ៥–៦ | ១:៤ | ៣:១–៣ | ១:៦–១៤ | |
| បុណ្យជ្រមុជទឹកនៃព្រះយេស៊ូវ | ៣:១៣–១៧ | ១:៩–១១ | ៣:២១–២២ | ១:៣២–៣៤ | ១ នីហ្វៃ ១០:៧–១០; ២ នីហ្វៃ ៣១:៤–២១ |
| សេចក្ដីល្បួងទាំងឡាយមកលើព្រះយេស៊ូវ | ៤:១–១១ | | ៤:១–១៣ | | |
| ទីបន្ទាល់នៃយ៉ូហាន-បាទីស្ទ | | | | ១:១៩–៣៦ | គ. និង ស. ៩៣:៦–១៨, ២៦ |

| ព្រឹត្តិការណ៍ | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន | វិវរណៈនៅថ្ងៃចុងក្រោយ |
|---|---|---|---|---|---|
| ការជុបលៀងការនៅភូមិកាណា (អព្ភូតហេតុ ទីមួយ១នៃព្រះយេស៊ូវ) | | | | ២:១–១១ | |
| ការលាងសំអាតទីមួយ នៃ ព្រះវិហារ | | | | ២:១៤–១៧ | |
| ការជួបនឹងនីកូដេម | | | | ៣:១–១០ | |
| ស្ត្រីសាសន៍សាម៉ារីនៅឯអណ្តូង ទឹក | | | | ៤:១–៤២ | |
| ព្រះយេស៊ូវត្រូវគេមិនទទួល ស្គាល់នៅឯណាសារ៉ែត | ៤:១៣–១៦ | | ៤:១៦–៣០ | | |
| ពួកអ្នកនេសាទត្រូវបានហៅ ឲ្យធ្វើជាអ្នកនេសាទមនុស្ស | ៤:១៨–២២ | ១:១៦–២០ | | | |
| ការពេញអួនយ៉ាងអស្ចារ្យ | | | ៥:១–១១ | | |
| ការប្រោសកូនស្រីនៃយ៉ៃរ៉ុស ឲ្យរស់ | ៩:១៨–១៩, ២៣–២៦ | ៥:២១–២៤, ៣៥–៤៣ | ៨:៤១–៤២, ៤៩–៥៦ | | |
| ការប្រោសស្ត្រីធ្លាក់ឈាមឲ្យជា | ៩:២០–២២ | ៥:២៥–៣៤ | ៨:៤៣–៤៨ | | |
| ការហៅពួក១២នាក់ | ១០:១–៤២ | ៣:១៣–១៩; ៦:៧–១៣ | ៦:១២–១៦; ៩:១–២; ១២:២–១២, ៤៩–៥៣ | | ១ នីហ្វៃ ១៣:២៤–២៦, ៣៩–៤១; គ. និង ស. ៩៥:៤ |
| ការប្រោសកូននៃស្រីមេម៉ាយឲ្យ រស់ | | | ៧:១១–១៥ | | |
| ការលាបប្រេងព្រះ បាទព្រះយេស៊ូវ | | | ៧:៣៦–៥០ | ១២:២–៨ | |
| ការបញ្ឈប់ខ្យល់ព្យុះឲ្យស្ងប់ស្ងាត់ | | ៤:៣៦–៤១ | ៨:២២–២៥ | | |

| ព្រឹត្តិការណ៍ | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន | វិវរណៈនៅថ្ងៃចុងក្រោយ |
|---|---|---|---|---|---|
| ការហៅពួក៧០នាក់ | | | ១០:១ | | គ. និង ស. ១០៧:២៥, ៣៤, ៩៣–៩៧ |
| ការបណ្ដេញកងទ័ពអារក្សឲ្យចូលក្នុងជ្រូក | | ៥:១–២០ | | | |
| បទបង្រៀននៅលើភ្នំ | ៥–៧ | | ៦:១៧–៤៩ | | ៣ នីហ្វៃ ១២–១៤ |

ពាក្យប្រៀបប្រដូចទាំងឡាយនៃព្រះយេស៊ូវ គឺជារឿងខ្លីៗ ដែលប្រៀបធៀបរបស់របរ និងព្រឹត្តិការណ៍ធម្មតាទៅនឹងសេចក្ដីពិត ។ ព្រះយេស៊ូវទ្រង់តែងតែប្រើពាក្យទាំងនេះដើម្បីបង្រៀនសេចក្ដីពិតខាងវិញ្ញាណ ។

| | | | | | |
|---|---|---|---|---|---|
| អ្នកព្រោះគ្រាប់ពូជ | ១៣:៣–៩, ១៨–២៣ | ៤:៣–៩, ១៤–២០ | ៨:៤–៨, ១១–១៥ | | |
| ស្រងែ | ១៣:២៤–៣០, ៣៦–៤៣ | | | | គ. និង ស. ៨៦:១–៧ |
| គ្រាប់ពូជល្ហុត | ១៣:៣១–៣២ | ៤:៣០–៣២ | ១៣:១៨–១៩ | | |
| ដំបែ | ១៣:៣៣ | | ១៣:២០–២១ | | |
| កំណប់កប់ទុកក្នុងចំការ | ១៣:៤៤ | | | | |
| មុក្ដាដ៏មានតម្លៃបំផុត | ១៣:៤៥–៤៦ | | | | |
| អួននៃអ្នកនេសាទ | ១៣:៤៧–៥០ | | | | |
| ថៅកែ | ១៣:៥១–៥២ | | | | |
| ចៀមដែលវង្វេងបាត់ | ១៨:១២–១៤ | | ១៥:១–៧ | | |
| ប្រាក់ដែលបាត់ | | | ១៥:៨–១០ | | |
| កូនដែលខ្ជះខ្ជាយ | | | ១៥:៨ — ៣២ | | |
| អ្នកបំរើដែលឥតក្ដីមេត្តាករុណា | ១៨:២៣–៣៥ | | | | |

| ព្រឹត្តិការណ៍ | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន | វិវរណៈនៅថ្ងៃចុងក្រោយ |
|---|---|---|---|---|---|
| ជនសាម៉ារីដែលល្អ | | | ១០:២៥–៣៧ | | |
| អ្នកត្រួតត្រាដែលមិនយុត្តិធម៌ | | | ១៦:១–៨ | | |
| ឡាសារ និងបុរសដែលមានទ្រព្យ | | | ១៦:១៩–១៥, ១៩–៣១ | | |
| ចៅក្រមដែលមិនយុត្តិធម៌ | | | ១៨:១–៨ | | |
| អ្នកគង្វាលល្អ | | | | ១០:១–២១ | ៣ នីហ្វៃ ១៥:១៧–២៤ |
| ពួកអ្នកធ្វើការក្នុងចំការទំពាំងបាយជូរ | ២០:១–១៦ | ១០:៣១ | | | |
| ប្រាក់ណែន | | | ១៩:១១–២៧ | | |
| កូនប្រុសពីរនាក់ | ២១:២៨–៣២ | | | | |
| អ្នកធ្វើចំការដ៏ទុច្ចរិត | ២១:៣៣–៤៦ | ១២:១–១២ | ២០:៩–២០ | | |
| ពិធីរៀបការនៃបុត្រស្តេច | ២២:១–១៤ | | ១៤:១–២៤ | | |
| នាងព្រហ្មចារី១០នាក់ | ២៥:១–១៣ | | ១២:៣៥–៣៦ | | គ. និង ស. ៤៥:៥៦–៥៩ |
| ប្រាក់រាប់ពាន់ | ២៥:១៤–៣០ | | | | |
| ចៀម, ពពែ | ២៥:៣១–៤៦ | | | | |
| ប្រទានអាហារដល់មនុស្ស ៥០០០ នាក់ | ១៤:១៦–២១ | ៦:៣៣–៤៤ | ៩:១១–១៧ | ៦:៥–១៤ | |
| ព្រះយេស៊ូវយាងលើទឹក | ១៤:២២–៣៣ | ៦:៤៥–៥២ | | ៦:១៦–២១ | |
| ទីបន្ទាល់នៃពេត្រុសអំពីព្រះគ្រីស្ទ | ១៦:១៣–១៦ | ៨:២៧–២៩ | ៩:១៨–២០ | | |

| ព្រឹត្តិការណ៍ | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន | វិវរណៈនៅថ្ងៃចុងក្រោយ |
|---|---|---|---|---|---|
| ពេត្រុសត្រូវបានសន្យាថានឹងបាន កូនសោទាំងឡាយនៃនគរ | ១៦:៩ | | | | |
| បទបង្រៀនអំពីនំប៉ុងជីវិត | | | | ៦:២២–៧១ | |
| ប្រោសមនុស្សខ្វាក់ឲ្យមើលឃើញ នៅថ្ងៃឈប់សំរាក | | | | ៩:១–៤១ | |
| ការប្រែរូប; បានប្រគល់កូនសោ ទាំងឡាយនៃបព្វជិតភាព | ១៧:១–១៣ | ៩:២–១៣ | ៩:២៨–៣៦; | | គ. និង ស. ៦៣:២០–២១; ១១០:១១–១៣ |
| ការប្រទានពរដល់ពួកកូនក្មេង | ១៩:១៣–១៥ | ១០:១៣–១៦ | ១៨:១៥–១៧ | | |
| ការអធិស្ឋាននៃព្រះអម្ចាស់ | ៦:៥–១៥ | | ១១:១–៤ | | |
| ឡាសារបានរស់ឡើងវិញ | | | | ១១:១–៤៥ | |
| ការយាងចូលដ៏ថ្កុំថ្កើង | ២១:៦–១១ | ១១:៧–១១ | ១៩:៣៥–៣៨ | ១២:១២–១៨ | |
| ពួកអ្នកដូរប្រាក់ត្រូវបាន បណ្តេញចេញពីព្រះវិហារ | ២១:១២–១៦ | ១១:១៥–១៩ | ១៩:៤៥–៤៨ | | |
| ស្លឹងនៃស្រីមេម៉ាយ | | ១២:៤១–៤៤ | ២១:១–៤ | | |
| សេចក្តីថ្លែងអំពីការយាងមក លើកទីពីរ | ២៤:១–៥១ | ១៣:១–៣៧ | ១២:៣៧–៤៨; ១៧:២០–៣៧; ២១:៥–៣៨ | | គ. និង ស. ៤៥:១៦–៦០; យ.ស.—— ម៉ាថាយ ១:១–៥៥ |
| ការប្រោសឲ្យមនុស្សឃ្លង់១០នាក់ | | | ១៧:១២–១៤ | | |
| បុណ្យរំលងចុងក្រោយបង្អស់នៃ ព្រះយេស៊ូវ; បុណ្យរំឭកត្រូវបាន តែងតាំងឡើង; ការបង្គាប់ដល់ ពួក១២នាក់; ការលាងជើង ពួក សិស្ស | ២៦:១៤–៣២ | ១៤:១០–២៧ | ២២:១–២០ | ១៣–១៧ | |

| ព្រឹត្តិការណ៍ | ម៉ាថាយ | ម៉ាកុស | លូកា | យ៉ូហាន | វិវរណៈនៅថ្ងៃចុងក្រោយ |
|---|---|---|---|---|---|
| ការរងទុក្ខនៃព្រះយេស៊ូវនៅក្នុងសួនច្បារគេតសេម៉ានី | ២៦:៣៦–៤៦ | ១៤:៣២–៤២ | ២២:៤០–៤៦ | | ២ នីហ្វៃ ៩:២១–២២; ម៉ូសាយ ៣:៥–១២; គ. និង ស. ១៩:១–២៤ |
| ព្រះយេស៊ូវជាដើមទំពាំងបាយជូរ | | | | ១៥:១–៨ | |
| ការក្បត់នៃយូដាស | ២៦:៤៧–៥០ | ១៤:៤៣–៤៦ | ២២:៤៧–៤៨ | ១៨:២–៣ | |
| ការចោទឆ្លើយនៅចំពោះលោកកៃផា | ២៦:៥៧ | ១៤:៥៣ | ២២:៥៤, ៦៦–៧១ | ១៨:២៤, ២៨ | |
| ការចោទឆ្លើយនៅចំពោះលោកពីឡាត់ | ២៧:២, ១១–១៤ | ១៥:១–៥ | ២៣:១–៦ | ១៨:២៨–៣៨ | |
| ការចោទឆ្លើយនៅចំពោះស្ដេចហេរ៉ូឌ | | | ២៣:៧–១០ | | |
| ព្រះយេស៊ូវត្រូវគេវាយហើយចំអកឡកឡឺយ | ២៧:២៧–៣១ | ១៥:១៥–២០ | | ១៩:១–១២ | |
| ការឆ្កាង | ២៧:៣៥–៤៤ | ១៥:២៤–៣៣ | ២៣:៣២–៤៣ | ១៩:១៨–២២ | ហេលេ. ១៤:២០–២៧; ៣ នីហ្វៃ ៨:៥–២២; ១០:៩ |
| ដំណើររស់ឡើងវិញ | ២៨:២–៨ | ១៦:៥–៨ | ២៤:៤–៨ | | |
| ការព្រះយេស៊ូវលេចមកឯពួកសិស្ស | | ១៦:១៤ | ២៤:១៣–៣២, ៣៦–៥១ | ២០:១៩–២៣ | |
| ការព្រះយេស៊ូវលេចមកឯថូម៉ាស | | | | ២០:២៤–២៩ | |
| ការយាងឡើង | | ១៦:១៩–២០ | ២៤:៥០–៥៣ | | |

**ដំណើររស់ឡើងវិញ** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, រូបកាយ; ព្រះយេស៊ូវគ្រីស្ទ; វិញ្ញាណ, សេចក្ដីស្លាប់ខាងសាច់ឈាម; អមតៈ, អមតភាព

ជាការរួបរួមជាថ្មីនូវរូបកាយខាងវិញ្ញាណទៅនឹងរូបកាយខាងសាច់ឈាម ដែលមានសាច់ និងឆ្អឹង បន្ទាប់ពីបានស្លាប់ទៅហើយ ។ ក្រោយពីដំណើររស់ឡើងវិញ វិញ្ញាណ និងរូបកាយនឹងមិនត្រូវបែកចេញពីគ្នាទៀតឡើយ ហើយជននោះនឹងបានក្លាយទៅជាជន ដ៏មានជីវិតអមតៈ ។ ជនរាល់រូបដែលបានកើតនៅផែនដីនឹងបានរស់ឡើងវិញ ពីព្រោះព្រះយេស៊ូវគ្រីស្ទទ្រង់បានមានជ័យជំនះលើ សេចក្ដីស្លាប់ហើយ (១ កូរិន. ១៥:២០–២២) ។

ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាអ្នកមុនដំបូង ដែលបានមានព្រះជន្មរស់ឡើងវិញនៅលើផែនដីនេះ (កិច្ចការ ២៦:២៣; កូល៉ុស ១:១៨; វិវរ. ១:៥) ។ ព្រះគម្ពីរសញ្ញាថ្មីផ្ដល់នូវភស្ដុតាងជាច្រើនថា ព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ឡើងវិញទាំងព្រះកាយខាងសាច់ឈាមរបស់ ទ្រង់ៈ ផ្នូររបស់ទ្រង់នៅទទេ, ទ្រង់សោយត្រី និងទឹកឃ្មុំ, ទ្រង់មានព្រះកាយជាសាច់ និងឆ្អឹង, បណ្ដាជនបានពាល់ទ្រង់ ហើយពួក ទេវតាបានថាទ្រង់មានព្រះជន្មរស់ឡើងវិញហើយ (ម៉ាកុស ១៦:១–៦; លូកា ២៤:១–១២, ៣៦–៤៣; យ៉ូហាន ២០:១–១៨) ។ វិវរណៈនៅថ្ងៃចុងក្រោយបញ្ជាក់នូវហេតុការណ៍ដែលមានពិតប្រាកដ អំពីដំណើររស់ឡើងវិញនៃព្រះគ្រីស្ទ និងមនុស្សលោកទាំងអស់ (អាលម៉ា ១១:៤០–៤៥; ៤០; ៣ នីហ្វៃ ១១:១–១៧; គ. និង ស. ៧៦; ម៉ូសេ ៧:៦២) ។

មនុស្សទាំងអស់នឹងមិនបានរស់ឡើងវិញដល់សិរីល្អដូចគ្នាទេ (១ កូរិន. ១៥:៣៩–៤២; គ. និង ស. ៧៦:៨៩–៩៨), ក៏នឹងមិនបានរស់ឡើងវិញដំណាលគ្នាដែរ (១ កូរិន. ១៥:២២–២៣; អាលម៉ា ៤០:៨; គ. និង ស. ៧៦:៦៤–៦៥, ៨៥) ។ ពួកបរិសុទ្ធជាច្រើនបានរស់ ឡើងវិញ បន្ទាប់ពីព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ (ម៉ាថាយ ២៧:៥២) ។ ពួកមនុស្សសុចរិតនឹងបានរស់ឡើងវិញមុនពួកមនុស្ស ទុច្ចរិត ហើយនឹងចេញមកនៅក្នុងដំណើររស់ឡើងវិញទីមួយ (១ ថែស្ស. ៤:១៦); ពួកមនុស្សបាបដែលពុំបានប្រែចិត្ត នោះនឹងបានចេញ នៅក្នុងដំណើររស់ឡើងវិញចុងក្រោយបង្អស់ (វិវរ. ២០:៥–១៣; គ. និង ស. ៧៦:៨៥) ។

ទោះជារូបនេះត្រូវរលាយទៅ តែនៅក្នុងរាងកាយនេះ ខ្ញុំនឹងបានឃើញព្រះ, **យ៉ូប** ១៩:២៦ (ម៉ូសេ ៥:១០) ។ អញនឹងបើកផ្នូរខ្មោចរបស់ឯងរាល់គ្នា ហើយនឹងធ្វើឲ្យឯងរាល់គ្នាឡើងចេញមក, **អេសេ.** ៣៧:១២ ។ អស់ទាំងផ្នូរខ្មោចក៏របើកឡើង ឯរូបកាយជាច្រើន បានរស់ឡើងវិញ, **ម៉ាថាយ** ២៧:៥២–៥៣ (៣ នីហ្វៃ ២៣:៩) ។ ព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់ឡើងវិញមែន, **លូកា** ២៤:៣៤ ។ វិញ្ញាណគ្មានសាច់ ឬឆ្អឹង ដូចជាអ្នករាល់គ្នាឃើញខ្ញុំនេះទេ, **លូកា** ២៤:៣៩ ។ ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត, **យ៉ូហាន** ១១:២៥ ។ ពួកសាវក ១២ នាក់បានបង្រៀនថា ព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ឡើងវិញ, **កិច្ចការ** ១:២១–២២ (កិច្ចការ ២:៣២; ៣:១៥; ៤:៣៣) ។ មនុស្សគ្រប់គ្នានឹងបានប្រោសឲ្យរស់ក្នុងព្រះគ្រីស្ទ, **១ កូរិន.** ១៥:១–២២ ។ ពួកស្លាប់ក្នុងព្រះគ្រីស្ទ នឹងរស់ឡើងវិញជាមុនបង្អស់, **១ ថែស្ស.** ៤:១៦ ។ មានពរហើយ ក៏បរិសុទ្ធផង អស់អ្នកណាដែលមានចំណែកក្នុងខណៈរស់ឡើងវិញជាន់មុនដំបូង, **វិវរ.** ២០:៦ ។ ព្រះគ្រីស្ទទ្រង់បានលះបង់ជីវិតទ្រង់ ហើយយកវិញ ដើម្បីទ្រង់អាចបណ្ដាលឲ្យមានដំណើររស់ឡើងវិញ ដល់មនុស្សស្លាប់, **២ នីហ្វៃ** ២:៨ (ម៉ូសាយ ១៣:៣៥; ១៥:២០; អាលម៉ា ៣៣:២២; ៤០:៣; ហេលេ. ១៤:១៥) ។ បើគ្មានដំណើររស់ឡើងវិញទេ នោះពួកយើងនឹងបានទៅនៅក្រោមអំណាចនៃអារក្សសាតាំង, **២ នីហ្វៃ** ៩:៦–៩ ។ ដំណើររស់ឡើងវិញនឹងបានដល់មនុស្សលោក ទាំងអស់, **២ នីហ្វៃ** ៩:២២ ។ លោកអ័ប៊ីណាដៃបានបង្រៀនអំពីដំណើររស់ឡើងវិញលើកទីមួយ, **ម៉ូសាយ** ១៥:២១–២៦ ។ ពួកទុច្ចរិត នឹងនៅដូច្នេះហាក់ដូចជាគ្មានការប្រោសលោះបានកើតឡើង លើកលែងតែការបន្ធូរនូវចំណងទាំងឡាយនៃសេចក្ដីស្លាប់, **អាលម៉ា** ១១:៤១–៤៥ ។ អាលម៉ាបានពន្យល់ប្រាប់អំពីស្ថានភាពនៃព្រលឹងទាំងឡាយរវាងសេចក្ដីស្លាប់នឹងដំណើររស់ឡើងវិញ, **អាលម៉ា** ៤០:៦, ១១–២៤ ។ នៅពេលព្រះអម្ចាស់ទ្រង់យាងមក នោះពួកមនុស្សស្លាប់ ដែលបានស្លាប់ក្នុងព្រះគ្រីស្ទ នឹងបានចេញមក, **គ. និង ស.** ២៩:១៣ (គ. និង ស. ៤៥:៤៥–៤៦; ៨៨:៩៧–៩៨; ១៣៣:៥៦) ។ ត្រូវយំសោក ជាពិសេស ចំពោះអស់អ្នកណាដែលគ្មានសេចក្ដីសង្ឃឹមដល់ដំណើររស់ឡើងវិញដ៏រុងរឿង, **គ. និង ស.** ៤២:៤៥ ។ ពួកគេដែលមិនស្គាល់ច្បាប់ នោះនឹងមានចំណែកក្នុងដំណើររស់ ឡើងវិញទីមួយនេះ, **គ. និង ស.** ៤៥:៥៤ ។ ពួកគេនឹងរស់ពីស្លាប់ឡើងវិញ ហើយនឹងមិនត្រូវស្លាប់ទៀតឡើយ, **គ. និង ស.** ៦៣:៤៩ ។ ដំណើររស់ពីស្លាប់ឡើងវិញ គឺជាសេចក្ដីប្រោសលោះនៃព្រលឹង, **គ. និង ស.** ៨៨:១៤–១៦ ។ វិញ្ញាណ និងវត្ថុធាតុនៅជាប់គ្នា ដោយឥតបែកបាក់ឡើយ គឺបានទទួលនូវភាពពោរពេញនៃសេចក្ដីអំណរ, **គ. និង ស.** ៩៣:៣៣ ។ ពួកទេវតា ដែលជាអង្គដែលបានរស់ឡើងវិញ ដោយមានរូបកាយជាសាច់ និងឆ្អឹង, **គ. និង ស.** ១២៩:១ ។ បញ្ញាណាក៏ដោយ ដែលយើងបាននៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើង ក្នុងដំណើររស់ឡើងវិញ **គ. និង ស.** ១៣០:១៨–១៩ ។

**ដំរិះ, ការចេះដឹង** *សូមមើលផង* ប្រាជ្ញា, យោបល់; សេចក្ដីពិត

ជាយោបល់ និងការយល់ ជាពិសេស អំពីសេចក្ដីពិត នៅពេលបង្រៀន ឬបញ្ជាក់ដោយព្រះវិញ្ញាណ ។

ព្រះអម្ចាស់ ទ្រង់ជាព្រះដែលជ្រាបទាំងអស់, **១ សាំយូ.** ២:៣ ។ ព្រះអម្ចាស់មានដំរិះសព្វគ្រប់, **យ៉ូប** ៣៧:១៦ ។ សេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់ នោះជាដើមចមនៃដំរិះ, **សុភា.** ១:៧ ។ អ្នកណាដែលមានដំរិះ រមែងសំចៃទុកនូវពាក្យសំដី, **សុភា.** ១៧:២៧ ។ ផែនដីនឹងបានពោរពេញទៅដោយដំរិះអំពីព្រះអម្ចាស់ **អេសាយ** ១១:៩ (២ នីហ្វៃ ២១:៩; ៣០:១៥) ។ អ្នករាល់គ្នាបានដកកូនសោនៃចំណេះ ចេញទៅហើយ, **លូកា** ១១:៥២ ។ សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់, **អេភេ.** ៣:១៩ ។ បន្ថែមឲ្យសេចក្ដីជំនឿ

បាន ទៀងត្រង់ ឲ្យសេចក្ដីទៀងត្រង់បានដំរិះ, **២ ពេត្រុស** ១:៥ ។ នីហ្វៃមានដំរិះដ៏ជ្រាលជ្រៅអំពីសេចក្ដីសប្បុរសរបស់ព្រះ, **១ នីហ្វៃ** ១:១ ។ ពួកគេនឹងបានការចេះដឹងអំពីព្រះដ៏ប្រោសលោះរបស់ពួកគេ, **២ នីហ្វៃ** ៦:១១ ។ ពួកសុចរិតនឹងមានដំរិះដ៏ឥតខ្ចោះពីសេចក្ដីសុចរិតរបស់គេ, **២ នីហ្វៃ** ៩:១៤ ។ ព្រះវិញ្ញាណប្រទានដំរិះ, **អាលម៉ា** ១៨:៣៥ ។ ដំរិះរបស់អ្នកបានឥតខ្ចោះចំពោះរឿងនេះ, **អាលម៉ា** ៣២:៣៤ ។ ពួកសាសន៍លេមិននឹងត្រូវបាននាំទៅដល់ការចេះដឹងដ៏ពិតពីព្រះដ៏ប្រោសលោះរបស់គេ, **ហេលេ.** ១៥:១៣ ។ អ្នករាល់គ្នាអាចដឹងដោយដំរិះដ៏ឥតខ្ចោះថា មកពីព្រះ, **មរ៉ូណៃ** ៧:១៥–១៧ ។ ពួកបរិសុទ្ធនឹងរកឃើញផលថ្លៃវិសេសនៃការចេះដឹង, ***គ. និង ស.*** ៨៩:១៩ ។ ការចេះដឹងពេញទី ដែលនឹងពង្រីកព្រលឹងឲ្យធំទូលំទូលាយ, ***គ. និង ស.*** ១២១:៤២ ។ អ្នកណាដែលត្រូវបាន ប្រទានកូនសោទាំងនេះ នោះមិនមែនជាពិបាកនឹងបានការចេះដឹងពីការពិត, ***គ. និង ស.*** ១២៨:១១ ។ បើសិនជា អ្នកណាមួយ បានដំរិះនៅក្នុងជីវិតនេះ អ្នកនោះនឹងបានប្រៀបច្រើននៅពិភពខាងមុខ, ***គ. និង ស.*** ១៣០:១៩ ។ គឺគ្មានផ្លូវទេ សំរាប់ឲ្យមនុស្សបាន សង្គ្រោះ ក្នុងការល្ងង់ខ្លៅ, ***គ. និង ស.*** ១៣១:៦ ។

**ឌីកុន** *សូមមើលផង* បព្វជិតភាពអើរ៉ុន

ជាការហៅមួយ ក្នុងសាសនាចក្រ នៅសម័យសាវកប៉ុល (ភីលិព ១:១; ១ ធីម៉ូ. ៣:៨–១៣) ហើយជាតំណែងមួយ ក្នុងបព្វជិតភាព អើរ៉ុន (គ. និង ស. ២០:៣៨, ៥៧–៥៩; ៨៤:៣០, ១១១; ១០៧:៨៥) ។

**ណាថាណែល** *សូមមើលផង* បារថូលូមេ

ជាសាវកម្នាក់របស់ព្រះគ្រីស្ទ ហើយជាមិត្តរបស់ភីលីព នៅក្នុងព្រះគម្ពីរសញ្ញាថ្មី (យ៉ូហាន ១:៤៥–៥១) ។ លោកមកពីភូមិកាណា ស្រុកកាលីឡេ (យ៉ូហាន ២១:២) ។ ព្រះគ្រីស្ទទ្រង់មានបន្ទូលថា ណាថាណែល ជាសាសន៍អ៊ីស្រាអែលម្នាក់ ដែលឥតមានចិត្តឧបាយ (យ៉ូហាន ១:៤៧) ។ ជាទូទៅ មនុស្សបានសន្និដ្ឋានថា លោក និង បារថូលូមេ ជាមនុស្សតែមួយ (ម៉ាថាយ ១០:៣; ម៉ាកុស ៣:១៨; លូកា ៦:១៤; យ៉ូហាន ១:៤៣–៤៥) ។

**ណាថាន់** *សូមមើលផង* ដាវីឌ

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ នៅសម័យស្ដេចដាវីឌ ។ កាលដាវីឌបានអំពាវនាវថានឹងសង់ព្រះវិហារមួយថ្វាយ ព្រះអម្ចាស់ នោះព្រះអម្ចាស់ទ្រង់បានបង្គាប់ឲ្យណាថាន់ទៅប្រាប់ដាវីឌថា ទ្រង់មិនត្រូវសង់ឡើយ ។ ណាថាន់ក៏បានបន្ទោសដាវីឌដែរ ដោយបានបណ្ដាលឲ្យអ៊ូរីស្លាប់ ដែលជាអ្នកចំបាំងរបស់លោក ហើយដោយបានយកនាងបាតសេបា ជាប្រពន្ធអ៊ូរី មកធ្វើជាភរិយា (២ សាំយូ. ១២:១–១៥; គ. និង ស. ១៣២:៣៨–៣៩) ។ សាដុក ជាមួយនឹងណាថាន់ បានចាក់ប្រេងលាបសាឡូម៉ូន ជាបុត្ររបស់ដាវីឌ ឲ្យធ្វើជាស្ដេច (១ ពង្សាវ. ១:៣៨–៣៩, ៤៥) ។

**ណាម៉ាន់** *សូមមើលផង* អេលីសេ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាមេទ័ពនៃពលទ័ពរបស់ស្ដេចស៊ីរី ។ លោកក៏ជាមនុស្សឃ្លង់ម្នាក់ដែរ ។ តាមរយៈសេចក្ដីជំនឿនៃបាវបំរើដែលជាសាសន៍អ៊ីស្រាអែល នោះលោកបានទៅឯស្រុកអ៊ីស្រាអែល ដើម្បីទៅរកព្យាការីអេលីសេ ។ លោកបានជាពីរោគឃ្លង់ ដោយសារការបន្ទាបខ្លួន ហើយដោយការមុជទឹក ៧ ដង នៅក្នុងទន្លេយ័រដាន់ ដូចដែលព្យាការីអេលីសេបានបង្គាប់ (២ ពង្សាវ. ៥:១–១៩; លូកា ៤:២៧) ។

**ណាសារ៉ែត** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ជាភូមិមួយនៅក្នុងចំណោមភ្នំតូចៗខាងលិចទន្លេកាលីឡេ ។ ភូមិណាសារ៉ែត គឺជាទីលំនៅមុនដំបូងរបស់ព្រះយេស៊ូវ (ម៉ាថាយ ២:២៣) ។ ព្រះយេស៊ូវ ទ្រង់បានបង្រៀននៅក្នុងសាលាប្រជុំ នៅភូមិណាសារ៉ែត ហើយបានថ្លែងប្រាប់ថា ទ្រង់បានបំពេញពាក្យព្យាករណ៍ នៅក្នុងគម្ពីរអេសាយ ៦១:១–២ (ម៉ាថាយ ១៣:៥៤–៥៨; ម៉ាកុស ៦:១–៦; លូកា ៤:១៦–៣០) ។

**ណាហ៊ុម**

ជាព្យាការីម្នាក់ពីស្រុកកាលីឡេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានកត់ពាក្យព្យាករណ៍របស់លោក រវាងឆ្នាំ ៦៤២ និង ឆ្នាំ ៦០៦ ម.គ.ស. ។

*គម្ពីរណាហ៊ុម៖* ជំពូកទី ១ ស្ដីអំពីផែនដីឆេះនៅគ្រាការយាងមកលើកទីពីរ និងអំពីសេចក្ដីមេត្តាករុណា និងព្រះចេស្ដារបស់ ព្រះអម្ចាស់ ។ ជំពូកទី ២ ប្រាប់អំពីការបំផ្លាញក្រុងនីនីវេ គឺជាជំរាប់ទុកជាមុនអំពីអ្វីដែលនឹងកើតឡើងនៅគ្រាចុងក្រោយ ។ ជំពូកទី ៣ បន្តការប្រាប់ទុកជាមុន អំពីការបំផ្លិចបំផ្លាញក្រុងនីនីវេដ៏គួរឲ្យវេទនា ។

**ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប** *សូមមើលផង* កាព្រីយ៉ែល; ទូកធំ; ទឹកជំនន់នៅសម័យណូអេ; ឥន្ទធនូ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់ឡាមេក ហើយជាអយ្យកោទី១០ មកពីលោកអ័ដាម (លោកុ. ៥:២៩–៣២) ។ លោកបានធ្វើបន្ទាល់អំពីព្រះគ្រីស្ទ ហើយបានផ្សាយពីការប្រែចិត្តដល់តំណមនុស្សទុច្ចរិត ។ កាលប្រជាជនមិនទទួលពាក្យរបស់លោក នោះព្រះទ្រង់បញ្ជាឲ្យលោកសង់ទូកធំមួយ ដើម្បីធ្វើជាទីអាស្រ័យដល់គ្រួសារលោក និងដល់អស់ទាំងសត្វគ្រប់ប្រភេទ កាលផែនដីត្រូវទឹកលិច ដើម្បីបំផ្លាញពួកទុច្ចរិតចោល (លោកុ. ៦:១៣–២២; ម៉ូសេ ៨:១៦–៣០) ។ ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា ណូអេ គឺជា ទេវតាកាព្រីយ៉ែល ហើយឈរបន្ទាប់ពីលោកអ័ដាម ក្នុងការកាន់កូនសោទាំងឡាយនៃសេចក្ដីសង្គ្រោះ ។

លោក និងយ៉ាផែត សិម និងហាំ ជាកូនប្រុសៗលោក ហើយនិងពួកប្រពន្ធគេត្រូវបានសង្គ្រោះ នៅពេលគេបានសង់ទូកធំមួយ តាមបញ្ជានៃព្រះ, **លោកុ.** ៦–៨ (ហេព្រើរ ១១:៧; ១ ពេត្រុស ៣:២០) ។

ព្រះអម្ចាស់ទ្រង់បានធ្វើសេចក្ដីសញ្ញាជាថ្មី ជាមួយនឹងណូអេ ដែលទ្រង់បានធ្វើជាមួយនឹងហេណុក, **លោកុ.** ៩:១–១៧ (ម៉ូសេ ៧:៤៩–៥២; ក.យ.ស., លោកុ. ៩:១៥, ២១–២៥) ។ ណូអេត្រូវបានតែងតាំងឡើងចំពោះបព្វជិតភាព កាលគាត់មានអាយុ១០ឆ្នាំ ដោយមធូសាឡា, **គ. និង ស.** ១០៧:៥២ ។ មនុស្សបានព្យាយាមតាមផ្ដាច់ជីវិតណូអេ ប៉ុន្ដែព្រះចេស្ដានៃព្រះបានជួយគាត់, **ម៉ូសេ** ៨:១៨ ។ លោកបានក្លាយទៅជាអ្នកផ្សាយខាងសេចក្ដីសុចរិត ហើយបានបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ, **ម៉ូសេ** ៨:១៩, ២៣–២៤ (២ ពេត្រុស ២:៥) ។

**ណូអេ, បុត្ររបស់ស៊ីនិព្វ**

ជាស្ដេចដ៏ទុច្ចរិតម្នាក់ នៅក្នុងព្រះគម្ពីរមរមន ។ ទ្រង់បានគ្រប់គ្រងលើសាសន៍នីហ្វៃមួយក្រុម នៅដែនដីនីហ្វៃ ។

ណូអេបានប្រព្រឹត្តអំពើបាបជាច្រើន, **ម៉ូសាយ** ១១:១–១៥ ។ ទ្រង់បានបញ្ជាឲ្យគេប្រហារព្យាការីអ័ប៊ីណាដៃចោល, **ម៉ូសាយ** ១៣:១ (ម៉ូសាយ ១៧:១, ៥–២០) ។ ណូអេត្រូវគេដុតរហូតដល់សុគត, **ម៉ូសាយ** ១៩:២០ ។

**ណែបថាលី** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

ជាកូនប្រុសទីប្រាំ ក្នុងកូន ១២ នាក់របស់យ៉ាកុប ហើយជាកូនប្រុសទីពីរ របស់នាងប៊ីលហា ដែលជាបាវបំរើស្រីរបស់នាងរ៉ាជែល (លោកុ. ៣០:៧–៨) ។ ណែបថាលីមានកូនប្រុសបួននាក់ (១ របា. ៧:១៣) ។

*ពូជអំបូរនៃណែបថាលី៖* ពរដែលយ៉ាកុបឲ្យដល់ណែបថាលី នោះបានកត់នៅក្នុងគម្ពីរលោកុប្បត្តិ ៤៩:២១ ។ ពរដែលម៉ូសេឲ្យ ដល់ពូជអំបូរនោះបានកត់នៅក្នុងគម្ពីរចោទិយកថា ៣៣:២៣ ។

**តម, តំណម** *សូមមើលផង* ការដាក់ទាន; ដង្វាយ; ទាន, មនុស្សក្រីក្រ; សុខុមាលភាព

គឺស្ម័គ្រចិត្តមិនព្រមទទួលទានអាហារ និងទឹក ប្រយោជន៍ដើម្បីខិតទៅជិតព្រះអម្ចាស់ និងការសូមព្រះពរទ្រង់ ។ នៅពេលបុគ្គល នីមួយៗ ឬជាក្រុមតម នោះគេគួរតែអធិស្ឋានសូមឲ្យបានយល់នូវព្រះហឫទ័យរបស់ព្រះ ហើយសូមឲ្យចំរើនកម្លាំងខាងវិញ្ញាណ ។ តំណមធ្លាប់បានប្រព្រឹត្តដោយពួកអ្នកជឿពិតជាដរាប ។

នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ថ្ងៃឈប់សំរាកក្នុងមួយខែម្ដង ត្រូវបានចាត់ទុកសំរាប់គោលបំណងខាងតំណម ។ នៅគ្រានេះ សមាជិកក្នុងសាសនាចក្រអត់អាហារ អត់ទឹក អស់រយៈ ២៤ ម៉ោង ។ បន្ទាប់មក ពួកគេថ្វាយប្រាក់ដែលគេតែងតែចំណាយលើម្ហូបអាហារទាំងនោះទៅសាសនាចក្រ ។ ប្រាក់នេះហៅថា ដង្វាយតម ។ សាសនាចក្រប្រើដង្វាយតម ដើម្បីជួយមនុស្សក្រីក្រ និងមនុស្ស កំសត់ទុគ៌ត ។

យើងរាល់គ្នាបានតម ហើយសូមអង្វរដល់ព្រះនៃយើង, **អែសរ៉ា** ៨:២១–២៣, ៣១ ។ ខ្ញុំក៏តម ហើយអធិស្ឋាន នៅចំពោះព្រះនៃស្ថានសួគ៌, **នេហេ.** ១:៤ ។ សូមអ្នករាល់គ្នាតមឲ្យខ្ញុំកុំឲ្យបរិភោគអ្វីអស់រវាងបីថ្ងៃ, **នាងអេសធើរ.** ៤:១៦ ។ ទូលបង្គំបានបន្ទាបព្រលឹង ទូលបង្គំ ដោយតមអត់អាហារ, **ទំនុក.** ៣៥:១៣ ។ តើមិនមែននេះជាតំណមដែលយើងបានរើស ? **អេសាយ** ៥៨:៣–១២ ។ ខ្ញុំបានតាំងចិត្តចំពោះព្រះអម្ចាស់ដ៏ជាព្រះ ដើម្បីរកអធិស្ឋានដោយតំណម, **ដានី.** ៩:៣ ។ ចូរឲ្យអ្នករាល់គ្នាវិលមកឯយើងឲ្យអស់អំពីចិត្ត និងដោយតមអត់, **យ៉ូអែល** ២:១២ ។ ពួកបណ្ដាជននៅក្រុងនីនីវេ គេក៏ជឿព្រះអង្គ ហើយបានប្រកាសឲ្យមានពេលតមអត់, **យ៉ូណាស** ៣:៥ ។ ព្រះយេស៊ូវទ្រង់តម ៤០ ថ្ងៃ, **ម៉ាថាយ** ៤:២ (និក្ខ. ៣៤:២៨; ១ ពង្សាវ. ១៩:៨; លូកា ៤:១–២) ។ ចូរកុំឲ្យមនុស្សលោក ឃើញថា អ្នកតមឡើយ, **ម៉ាថាយ** ៦:១៣ (៣ នីហ្វៃ ១៣:១៦) ។ អារក្សបែបយ៉ាងនេះ វាចេញទៅដោយសារតែអធិស្ឋានហើយនិង តមអត់ប៉ុណ្ណោះ, **ម៉ាថាយ** ១៧:២១ ។ ចូរបន្ដការតមអាហារ និងការអធិស្ឋាន, **អោមណៃ** ១:២៦ (៤ នីហ្វៃ ១:១២) ។ ពួកគេបានចាប់ផ្ដើមតម ហើយអធិស្ឋានទៅព្រះអម្ចាស់ ជាព្រះរបស់គេ, **ម៉ូសាយ** ២៧:២២ ។ ខ្ញុំបានតមអាហារ ហើយអធិស្ឋានជាច្រើនថ្ងៃ ដើម្បីឲ្យខ្ញុំអាចដឹងនូវការណ៍ទាំងនេះ, **អាលម៉ា** ៥:៤៦ ។ កូនចៅនៃព្រះបានរួមគ្នាតមអាហារ ហើយអធិស្ឋានឲ្យអស់ពីចិត្ត, **អាលម៉ា** ៦:៦ ។ ពួកបុត្រានៃម៉ូសាយបានប្រគល់ខ្លួនតមអាហារ ហើយអធិស្ឋានជាខ្លាំង, **អាលម៉ា** ១៧:៣, ៩ ។ មានពេលសំរាប់តមអាហារ និងអធិស្ឋានបន្ទាប់ពីពួកសាសន៍នីហ្វៃជាច្រើនបានស្លាប់, **អាលម៉ា** ២៨:៥–៦ ។ គេបានតមអាហារជាច្រើន ហើយអធិស្ឋានជាច្រើន, **អាលម៉ា** ៤៥:១ (ហេលេ. ៣:៣៥) ។ ចូររៀបចំអាហាររបស់អ្នក ដោយចិត្តស្មោះស្ម័គ្រ ប្រយោជន៍ឲ្យការតមរបស់អ្នកអាចបានល្អ ឥតខ្ចោះ, **គ. និង ស.** ៥៩:១៣–១៤ ។ អ្នករាល់គ្នាត្រូវបន្ដការអធិស្ឋាន និងការតមអាហារ, **គ. និង ស.** ៨៨:៧៦

**តែងតាំង, ការតែងតាំង** *សូមមើលផង* ការដាក់; ការហៅ; ដៃ, តំណែង, បព្វជិតភាព, បានហៅពីព្រះ, សិទ្ធិអំណាច; ហៅ, អ្នកកាន់តំណែង

ដើម្បីតាំង ឬប្រទានសិទ្ធិអំណាច ឬតំណែង ។ ដើម្បីប្រើសិទ្ធិអំណាចនៅក្នុងសាសនាចក្រនៃព្រះអម្ចាស់ ជននោះត្រូវតែបានហៅពីព្រះ ដោយការព្យាករណ៍ និងដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាច (ម. នៃ ស. ១:៥) ។ ទោះជានរណាមួយ អាចបានទទួលសិទ្ធិអំណាច ដោយការតែងតាំងក៏ដោយ គង់តែអ្នកនោះប្រើសិទ្ធិអំណាចនោះនៅក្រោមការណែនាំពីអស់អ្នកណា ដែលកាន់កូនសោទាំងឡាយចំពោះសិទ្ធិអំណាចនោះ ។

អញបានតាំងឯងឡើងជាហោរា ដល់អស់ទាំងសាសន៍, **យេរេ.** ១:៥ ។ មិនមែនអ្នករាល់គ្នា ដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលបាន តាំងអ្នករាល់គ្នាវិញ, **យ៉ូហាន** ១៥:១៦ ។ ដោយបានទទួលសិទ្ធិអំណាចពីព្រះនោះអាលម៉ាបានតាំងពួកសង្ឃឡើង, **ម៉ូសាយ** ១៨:១៨ ។ មនុស្ស

ទាំងឡាយត្រូវបានតែងតាំងចំពោះបព្វជិតភាពជាន់ខ្ពស់ ដោយពិធីបរិសុទ្ធ, **អាលម៉ា** ១៣:១–៩ ។ ព្រះយេស៊ូវទ្រង់បានហៅ ហើយបានតែងតាំងពួកសិស្ស ១២ នាក់, ៣ នីហ្វៃ ១២:១ ។ ពួកអែលឌើរបានតែងតាំងពួកសង្ឃ និងពួកគ្រូ ដោយការដាក់ដៃលើ, **ម៉ូរ៉ូណៃ** ៣:១–៤ ។ អ្នកត្រូវចាំបន្តិចទៀត ត្បិតអ្នកមិនទាន់បានតែងតាំងនៅឡើយទេ, **គ. និង ស.** ៥:១៧ ។ យ៉ូសែប ស្ម៊ីធ ត្រូវបាន តែងតាំងជាសាវកនៃព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ២០:២ (គ. និង ស. ២៧:១២) ។ គ្មាននរណាអាចបានតែងតាំងឡើង ដោយគ្មាន ការអនុមតិពីសាសនាចក្រនោះឡើយ, **គ. និង ស.** ២០:៦៥ ។ មិនបានអនុញ្ញាតដល់អ្នកណាមួយទៅផ្សាយដំណឹងល្អរបស់យើងឡើយ លើកលែង តែអ្នកនោះបានតែងតាំងឡើង ដោយនរណាម្នាក់ដែលមានសិទ្ធិអំណាច, **គ. និង ស.** ៤២:១១ ។ ពួកអែលឌើរត្រូវបាន តែងតាំងឡើង ឲ្យទៅផ្សាយដំណឹងល្អរបស់យើង, **គ. និង ស.** ៥០:១៣–១៨ ។ គឺជាភារកិច្ចរបស់ពួក១២នាក់ ឲ្យតែងតាំង ហើយ រៀបចំអស់ទាំង ពួកអ្នកកាន់តំណែងផ្សេងៗទៀតនៅក្នុងសាសនាចក្រ ឲ្យមានរបៀបរៀបរយ, **គ. និង ស.** ១០៧:៥៨ ។ ខ្ញុំស្វែងរក ព្រះពរទាំងឡាយ ខាងពួកអយ្យកោ និងសិទ្ធិដែលគួរឲ្យខ្ញុំបានតែងតាំងឡើង, **អ័ប្រា.** ១:២ ។ យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរ បាន តែងតាំងគ្នាទៅវិញ ទៅមកចំពោះបព្វជិតភាពអើរ៉ុន, **យ.ស. — ប្រវត្តិ** ១:៦៨–៧២ ។

**តំណែង, អ្នកកាន់តំណែង** *សូមមើលផង* ការតែងតាំង; តែងតាំង, បព្វជិតភាព

ជាមុខងារដែលមានសិទ្ធិអំណាច ឬការទទួលខុសត្រូវនៅក្នុងអង្គការណាមួយ គឺតែងតែប្រើនៅក្នុងព្រះគម្ពីរ ដើម្បីសំដៅអំពីមុខងារណា មួយដែលមានសិទ្ធិអំណាចខាងបព្វជិតភាព; ក៏អាចមានន័យដល់ភារកិច្ចដែលចាត់ទុកសំរាប់តំណែងណាមួយ ឬសំរាប់មនុស្សណាម្នាក់ដែលកាន់តំណែងនោះ ។

សមាជិកទាំងអស់មិនមានការងារដូចគ្នាទេ, **រ៉ូម** ១២:៤ ។ យើងបានដំកើងការងាររបស់យើងថ្វាយព្រះអម្ចាស់, **យ៉ាកុប** ១:១៩ ។ មិលគីស្សាដែកបានទទួលមុខងារនៃបព្វជិតភាពជាន់ខ្ពស់, **អាលម៉ា** ១៣:១៨ ។ មុខងារនៃការងារបំរើរបស់ពួកទេវតា គឺហៅមនុស្សឲ្យប្រែចិត្ត, **ម៉ូរ៉ូណៃ** ៧:៣១ ។ គ្មាននរណាអាចបានតែងតាំងឡើងឲ្យកាន់តំណែងណាមួយ នៅក្នុងសាសនាចក្រនេះ ដោយគ្មានការអនុមតិពីសាសនាចក្រនោះឡើយ, **គ. និង ស.** ២០:៦៥ ។ ចូរឲ្យមនុស្សគ្រប់រូបឈរនៅក្នុងតំណែងរបស់ខ្លួន, **គ. និង ស.** ៨៤:១០៩ ។ មានពួកប្រធាន ឬពួកអ្នកត្រួតត្រា ដែលបានតាំងឡើងក្នុងចំណោមពួកអ្នកដែលបានតែងតាំងចំពោះតំណែងនានា នៅក្នុងបព្វជិតភាពទាំងពីរនេះ, **គ. និង ស.** ១០៧:២១ ។ ភារកិច្ចទាំងឡាយនៃពួកអ្នកដែលត្រួតត្រាលើតំណែងក្នុងក្រុមទាំងឡាយនៃបព្វជិតភាពត្រូវបានរៀបរាប់ប្រាប់, **គ. និង ស.** ១០៧:៨៥–៩៨ ។ ចូរឲ្យមនុស្សគ្រប់រូបរៀនពីភារកិច្ចរបស់ខ្លួន ហើយឲ្យប្រតិបត្តិក្នុងតំណែង ដែលខ្លួនត្រូវ បានតាំងឡើង, **គ. និង ស.** ១០៧:៩៩–១០០ ។ យើងប្រទានដល់អ្នករាល់គ្នា នូវពួកអ្នកកាន់តំណែង ដែលជាសមាជិកនៃបព្វជិតភាពរបស់យើង, **គ. និង ស.** ១២៤:១២៣ ។

**ត្រចៀក** *សូមមើលផង* ប្រុងស្តាប់

នៅក្នុងគម្ពីរ ត្រចៀកតែងតែយកមកប្រើជានិមិត្តរូប អំពីសមត្ថភាពរបស់មនុស្ស ដើម្បីស្តាប់ឮ ហើយយល់នូវការណ៍ទាំងឡាយនៃព្រះ ។

ពួកគេមានត្រចៀក តែស្តាប់មិនឮ, **ទំនុក.** ១១៥:៦ ។ ព្រះអម្ចាស់ទ្រង់ដាស់ត្រចៀកខ្ញុំ ដើម្បីឲ្យខ្ញុំស្តាប់, **អេសាយ** ៥០:៤–៥ (២ នីហ្វៃ ៧:៤–៥) ។ អ្នកណាដែលមានត្រចៀកសំរាប់ស្តាប់ ឲ្យស្តាប់ចុះ, **ម៉ាថាយ** ១១:១៥ ។ គេឮដោយត្រចៀកធ្ងន់, **ម៉ាថាយ** ១៣:១៥ (ម៉ូសេ ៦:២៧) ។ ភ្នែកមើលមិនដែលឃើញ ត្រចៀកមិនដែលឮនូវសេចក្តីដែលបានរៀបចំទុកសំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់, **១ កូរិន.** ២:៩ (គ. និង ស. ៧៦:១០) ។ អារក្សខ្ទប់ដាក់ត្រចៀកគេ, **២ នីហ្វៃ** ២៨:២២ ។ ចូរបើកត្រចៀកឲ្យបានឮ, **ម៉ូសាយ** ២:៩ (៣ នីហ្វៃ ១១:៥) ។ ខ្ញុំត្រូវបានហៅជាច្រើនដង តែខ្ញុំធ្វើជាមិនឮ, **អាលម៉ា** ១០:៦ ។ ចូរផ្ទៀងត្រចៀកស្តាប់ពាក្យសំដីរបស់ឪពុក, **អាលម៉ា** ៣៦:១ (អាលម៉ា ៣៨:១; គ. និង ស. ៥៨:១) ។ គ្មានត្រចៀកណាដែលនឹងមិនបានឮឡើយ, **គ. និង ស.** ១:២ ។ ត្រចៀកបានបើក ដោយសារសេចក្តីទន់ទាប និងដោយសារសេចក្តីអធិស្ឋាន, **គ. និង ស.** ១៣៦:៣២ ។

**ថូម៉ាស**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសាវកម្នាក់ ក្នុងពួកសាវក ១២ នាក់ដើម ដែលព្រះអង្គសង្គ្រោះទ្រង់បានរើស កាលទ្រង់ធ្វើការងារបំរើនៅលើផែនដី ។ តាមភាសាក្រេក ឈ្មោះលោកគឺ ឌីឌីម (ម៉ាថាយ ១០:២–៣; យ៉ូហាន ១៤:៥; ២០:២៤–២៩; ២១:២) ។ ទោះជាថូម៉ាសបានសង្ស័យ អំពីដំណើរដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ទាល់តែលោកបានឃើញព្រះអង្គសង្គ្រោះ ដោយភ្នែកលោកផ្ទាល់ក្តី គង់តែមារយាទដ៏នឹងនឹងរបស់លោក ធ្វើឲ្យលោកសុខចិត្តតស៊ូសេចក្តីបៀតបៀន និងសេចក្តីស្លាប់ ជាមួយនឹងព្រះអម្ចាស់របស់លោកដែរ (យ៉ូហាន ១១:១៦; ២០:១៩–២៥) ។

**ថេលើរ, យ៉ូហាន**

ជាប្រធានទីបីក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

ត្រូវបានហៅឲ្យចូលរួមក្នុងក្រុមប្រឹក្សានៃពួក ១២ នាក់, **គ. និង ស.** ១១៨:៦ (គ. និង ស. ១២៤:១២៨–១២៩) ។ បានសរសេរអំពីទុក្ករកម្មនៃយ៉ូសែប និងហៃរុម ស្ម៊ីធ, **គ. និង ស.** ១៣៥ ។ ត្រូវរបួសកាលគេធ្វើទុក្ករកម្ម, **គ. និង ស.** ១៣៥:២ ។ បាននៅក្នុងចំណោមពួកអ្នកខ្លាំងពូកែ ដែលយ៉ូសែប អែហ្វ ស្ម៊ីធបានឃើញនៅឯស្ថានវិញ្ញាណ, **គ. និង ស.** ១៣៨:៥៣–៥៦ ។

**ថៃស្សាឡូនិច, សំបុត្រដល់ពួក** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាគម្ពីរពីរក្បាលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ពីប្រភពដើម គម្ពីរទាំងពីរនេះគឺជាសំបុត្រ ដែលប៉ុលបានសរសេរទៅពួកថៃស្សាឡូនិច នៅពេលលោកនៅស្រុកកូរិនថូស កាលលោកទៅឯអឺរ៉ុប រវាងឆ្នាំ ៥០ គ.ស. ។ កិច្ចការរបស់លោកនៅស្រុកថៃស្សាឡូនិចត្រូវបានរៀបរាប់ប្រាប់នៅក្នុងគម្ពីរកិច្ចការ ១៧ ។ ប៉ុលចង់វិលទៅស្រុកថៃស្សាឡូនិចវិញ ប៉ុន្តែមិនអាចទៅបាន (១ ថែស្ស. ២:១៨) ។ ហេតុដូច្នេះហើយ ទើបលោកចាត់ឲ្យធីម៉ូថេ ទៅកំសាន្តចិត្តដល់ពួកអ្នកដែលប្រែចិត្តជឿ ហើយត្រូវនាំពាក្យមកប្រាប់លោកអំពីពួកគេវិញ ។ ប៉ុលបានសរសេរសំបុត្រទីមួយ មកពីអំណរគុណរបស់លោក ដែលធីម៉ូថេបានវិលមកវិញ ។

*ថៃស្សាឡូនិចទី ១៖* ជំពូកទី ១–២ ជាការសួរសុខទុក្ខ និងការអធិស្ឋានរបស់ប៉ុល សំរាប់ពួកបរិសុទ្ធ ។ ជំពូកទី ៣–៥ ជាការបង្គាប់អំពីការចំរើនខាងវិញ្ញាណ អំពីសេចក្ដីស្រឡាញ់ អំពីសេចក្ដីសប្បុរស អំពីការមានចិត្តឧស្សាហ៍ និងអំពីការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។

*ថៃស្សាឡូនិចទី ២៖* ជំពូកទី ១ ជាការអធិស្ឋាន សំរាប់ពួកបរិសុទ្ធ ។ ជំពូកទី ២ ស្ដីអំពីសេចក្ដីក្បត់សាសនា ដែលនឹងកើតឡើង ។ ជំពូកទី ៣ ជាការអធិស្ឋានរបស់ប៉ុល ចំពោះការជោគជ័យ ដែលដំណឹងល្អត្រូវបានធ្វើឲ្យមានឡើង ។

**ថ្ងៃឈប់សំរាក** *សូមមើលផង* ការបង្កបង្កើត; បង្កើត, សេចក្ដីសំរាក

ជាថ្ងៃបរិសុទ្ធមួយ ដែលញែកចេញរាល់អាទិត្យទុកសំរាប់សំរាក និងថ្វាយបង្គំ ។ បន្ទាប់ពីព្រះទ្រង់បានបង្កើតនូវគ្រប់អ្វីៗទាំងអស់ នោះទ្រង់បានឈប់សំរាកនៅថ្ងៃទីប្រាំពីរ ហើយបានបង្គាប់ថា ទុកមួយថ្ងៃរាល់ៗអាទិត្យជាថ្ងៃឈប់សំរាក ដើម្បីជួយឲ្យមនុស្ស រំឭកចាំដល់ទ្រង់ (និក្ខ. ២០:៨–១១) ។

មុនព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ សមាជិកនៃសាសនាចក្របានថ្វាយថ្ងៃចុងក្រោយបង្អស់ក្នុងសប្ដាហ៍ទុកជាថ្ងៃឈប់សំរាក ដូចជាពួកសាសន៍យូដាដែរ ។ បន្ទាប់ពីដំណើររស់ឡើងវិញ សមាជិកនៃសាសនាចក្រ ទោះបីជាពួកសាសន៍យូដា ឬសាសន៍ដទៃក្ដី បានថ្វាយថ្ងៃទីមួយក្នុងសប្ដាហ៍ (ថ្ងៃរបស់ព្រះអម្ចាស់) ដើម្បីរំឭកចាំដល់ការរស់ឡើងវិញនៃព្រះអម្ចាស់ ។ សព្វថ្ងៃនេះ សាសនាចក្រនៅតែ ថ្វាយមួយថ្ងៃរាល់អាទិត្យ ទុកជាថ្ងៃឈប់សំរាកដ៏បរិសុទ្ធ ដើម្បីថ្វាយបង្គំព្រះ ហើយឈប់សំរាកពីការងារទាំងឡាយនៃលោកិយ ។

ថ្ងៃឈប់សំរាករំឭកដល់មនុស្សទាំងឡាយ អំពីសេចក្ដីត្រូវការអាហារផ្នែកខាងវិញ្ញាណ និងអំពីការងាររបស់គេ ដើម្បីគោរពតាមព្រះ ។ នៅពេលសាសន៍ណាមួយមិនយកចិត្តទុកដាក់ក្នុងកាលកាន់នូវថ្ងៃឈប់សំរាកទេ នោះស្ថានភាពនៃជីវិតគ្រប់យ៉ាងក៏ប្រែប្រួលស្របទៅតាម ហើយជីវិតជីវ៉ាខាងសាសនា ក៏ក្លាយទៅជាចុះអាប់ឱន (នេហេ. ១៣:១៥–១៨; យេរេ. ១៧:២១–២៧) ។

ព្រះទ្រង់បានឈប់សំរាកនៅថ្ងៃទីប្រាំពីរ, **លោកុ.** ២:១–៣ ។ ពួកកូនចៅអ៊ីស្រាអែលមិនបានរើសនំម៉ាន៉ា នៅថ្ងៃឈប់សំរាកទេ, **និក្ខ.** ១៦:២២–៣០ ។ ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះទុកជាថ្ងៃបរិសុទ្ធ, **និក្ខ.** ២០:៨–១១ (ម៉ូសាយ ១៣:១៦–១៩) ។ ថ្ងៃឈប់សំរាកត្រូវបានប្រទានមកទុកជាទីសំគាល់ រវាងព្រះនឹងមនុស្ស, **និក្ខ.** ៣១:១២–១៧ (អេសេ. ២០:១២; ២០) ។ ពួកយើងមិនត្រូវទិញឬលក់អ្វីនៅថ្ងៃឈប់សំរាកឡើយ, **នេហេ.** ១០:៣១ ។ ចូររាប់ថ្ងៃឈប់សំរាកទុកជាទីរីករាយចិត្ត ដោយប្រតិបត្តិតាម ព្រះអម្ចាស់ ឥតធ្វើតាមអំពើចិត្តរបស់ខ្លួនឡើយ, **អេសាយ** ៥៨:១៣–១៤ ។ ថ្ងៃឈប់សំរាកបានតាំងសំរាប់មនុស្ស មិនមែនជាមនុស្ស សំរាប់ថ្ងៃឈប់សំរាកទេ, **ម៉ាកុស** ២:២៣–២៨ ។ កូនមនុស្ស គឺជាព្រះអម្ចាស់នៃថ្ងៃឈប់សំរាក, **លូកា** ៦:១–១០ ។ ព្រះយេស៊ូវទ្រង់ បានបង្រៀននៅក្នុងសាលាប្រជុំ ហើយបានប្រោសឲ្យជា នៅថ្ងៃឈប់សំរាក, **លូកា** ១៣:១០–១៤ ។ ពួកសាសន៍នីហ្វៃបានញែកថ្ងៃឈប់ សំរាកទុកជាថ្ងៃបរិសុទ្ធ, **យ៉ារុម** ១:៥ ។ ចូរញែកថ្ងៃឈប់សំរាកទុកថ្ងៃបរិសុទ្ធចុះ, **ម៉ូសាយ** ១៨:២៣ ។ ថ្វាយបុណ្យរំឭករបស់អ្នក ឡើង នៅថ្ងៃបរិសុទ្ធរបស់យើងចុះ, **គ. និង ស.** ៥៩:៩–១៣ ។ បណ្ដាជននៃក្រុងស៊ីយ៉ូនត្រូវគោរពថ្ងៃឈប់សំរាក, **គ. និង ស.** ៦៨:២៩ ។ យើងជាព្រះ បានឈប់សំរាកនៅថ្ងៃទីប្រាំពីរ ពីគ្រប់ទាំងកិច្ចការរបស់យើង, **ម៉ូសេ** ៣:១–៣ (លោកុ. ២:១–៣; អ័ប្រា. ៥:១–៣) ។

**ថ្ងៃនៃព្រះអម្ចាស់** *សូមមើល* ថ្ងៃឈប់សំរាក

**ថ្ងៃនៃព្រះអម្ចាស់***សូមមើល* ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ, ថ្ងៃឈប់សំរាក; សេចក្ដីជំនុំជំរះចុងក្រោយបង្អស់

**ថ្ងៃអាទិត្យ** *សូមមើល* ថ្ងៃឈប់សំរាក

**ថ្នាំជក់** *សូមមើល* ពាក្យសំដីនៃប្រាជ្ញាវាងវៃ

**ថ្ម** *សូមមើលផង* ដំណឹងល្អ; ព្រះយេស៊ូវគ្រីស្ទ; វិវរណៈ

បើនិយាយតាមនិមិត្តរូប ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អ គឺជាគ្រឹះ និងជាការទ្រទ្រង់ដ៏រឹងប៉ឹង (គ. និង ស. ១១:២៤; ៣៣:១២–១៣) ។ ថ្មក៏អាចសំដៅដល់វិវរណៈដែរ ដែលព្រះទ្រង់ប្រើសំរាប់បង្ហាញដំណឹងល្អរបស់ទ្រង់ដល់មនុស្ស (ម៉ាថាយ ១៦:១៥–១៨) ។

ទ្រង់ជាថ្ម ការរបស់ទ្រង់សុទ្ធតែគ្រប់ល័ក្ខណ៍, **ចោទិ.** ៣២:៤ ។ ព្រះអម្ចាស់ទ្រង់ជាថ្មនៃទូលបង្គំៗនឹងយកទ្រង់ជាទីពឹង, **២ សាំយូ.** ២២:២–៣ ។ មានថ្មមួយដាប់ផ្ដាច់ចេញ ឥតដៃអ្នកណាធ្វើ, **ដានី.** ២:៣៤–៣៥ ។ គឺបានរកឃើញនៅលើថ្ម, **ម៉ាថាយ** ៧:២៥ (៣ នីហ្វៃ ១៤:២៥) ។ ព្រះយេស៊ូវគ្រីស្ទ ទ្រង់ជាថ្ម ដែលបានចាត់ទុកជា

ឥតប្រយោជន៍, **កិច្ចការ** ៤:១០–១១ ។ ថ្មនោះហើយ គឺជាព្រះ គ្រីស្ទ, **១ កូរិន.** ១០:១–៤ (និក្ខ. ១៧:៦) ។ អ្នកណាដែលសង់នៅលើថ្ម នោះនឹងទទួលយកសេចក្ដីពិត, **២ នីហ្វៃ** ២៨:២៨ ។ ពួក សាសន៍យូដានឹងមិនទទួលស្គាល់ថ្ម (ព្រះគ្រីស្ទ) ដែលពួកគេអាចបានសង់លើឡើយ, **យ៉ាកុប** ៤:១៥–១៧ ។ គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង ដែលយើងត្រូវសង់គ្រឹះរបស់យើង, **ហេលេ.** ៥:១២ ។ អស់អ្នកណាដែលសង់នៅលើគោលលទ្ធិទាំងឡាយ របស់ព្រះគ្រីស្ទ នោះបានសង់នៅលើថ្មរបស់ទ្រង់ហើយ ហើយនឹងមិនរលំឡើយ កាលទឹកជន់មក, ៣ នីហ្វៃ ១១:៣៩–៤០ (ម៉ាថាយ ៧:២៤–២៧; ៣ នីហ្វៃ ១៨:១២–១៣) ។ មនុស្សមានគំនិតបានសង់ផ្ទះរបស់ខ្លួននៅលើថ្ម, ៣ នីហ្វៃ ១៤:២៤ ។ បើសិនជាអ្នករាល់គ្នា បានសង់នៅលើថ្មដារបស់យើង នោះផែនដី និងស្ថាននរកពុំអាចយកឈ្នះបានឡើយ, **គ. និង ស.** ៦:៣៤ ។ អ្នកណាដែលសង់នៅលើថ្មដានេះ នឹងមិនត្រូវរលំឡើយ, **គ. និង ស.** ៥០:៤៤ ។ យើងជាព្រះមែស៊ី ជាស្ដេចនៃស៊ីយ៉ូន គឺជាថ្មដានៃស្ថានសួគ៌, **ម៉ូសេ** ៧:៥៣ ។

### ថ្មជ្រុង *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ជាថ្មសំខាន់មួយដែលដាក់នៅជ្រុងជើងជញ្ជាំងរបស់អាគារ ។ ព្រះយេស៊ូវគ្រីស្ទត្រូវបានថ្វាយព្រះនាមថាជាថ្មជ្រុងយ៉ាងឯក (អេភេ. ២:២០)។

ថ្មដែលពួកជាងផ្ទះបានចោលចេញ នោះបានត្រឡប់ជាថ្មជ្រុងយ៉ាងឯកហើយ, **ទំនុក.** ១១៨:២២ (ម៉ាថាយ ២១:៤២–៤៤; ម៉ាកុស ១២:១០; លូកា ២០:១៧; កិច្ចការ ៤:១០–១២) ។ ពួកសាសន៍យូដាមិនទទួលស្គាល់ថ្មជ្រុងឡើយ, **យ៉ាកុប** ៤:១៥–១៧ ។

### ថ្វាយ, ក្រិត្យវិន័យនៃការថ្វាយ *សូមមើលផង* នគរព្រះ ឬនគរស្ថានសួគ៌; សហសមាគម

គឺថ្វាយ ធ្វើឲ្យបរិសុទ្ធ ឬឲ្យបានទៅជាសុចរិត ។ ក្រិត្យវិន័យនៃការថ្វាយ គឺជាគោលការណ៍មួយពីព្រះ ដែលមនុស្សប្រុសស្រីស្ម័គ្រចិត្តថ្វាយពេលវេលា ការប៉ិនប្រសប់ និងទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីតាំង និងសាងឡើងនូវនគរនៃព្រះ ។

ចូរអ្នករាល់គ្នាថ្វាយខ្លួនដល់ព្រះអម្ចាស់នៅថ្ងៃនេះចុះ, **និក្ខ.** ៣២:២៩ ។ ពួកអ្នកដែលជឿទាំងអស់មានរបស់ទាំងអស់នៅមូលព្រមគ្នា, **កិច្ចការ** ២:៤៤–៤៥ ។ ពួកគេមានវត្ថុសព្វសារពើនៅមូលព្រមគ្នាក្នុងចំណោមគេ ហេតុដូច្នេះហើយ គ្មានអ្នកមាន ឬអ្នកក្រឡើយ, **៤ នីហ្វៃ** ១:៣ ។ ព្រះអម្ចាស់ទ្រង់ពន្យល់ប្រាប់ពីគោលការណ៍នៃការថ្វាយ, **គ. និង ស.** ៤២:៣០–៣៩ (គ. និង ស. ៥១:២–១៩; ៥៨:៣៥–៣៦) ។ មនុស្សម្នាក់មិនត្រូវមានលើសជាងអ្នកផ្សេងឡើយ, **គ. និង ស.** ៤៩:២០ ។ មនុស្សគ្រប់រូបត្រូវបានដូចគ្នា តាម គ្រួសាររបស់ខ្លួន, **គ. និង ស.** ៥១:៣ ។ មានរបៀបមួយបានត្រូវតាំងឡើង ប្រយោជន៍ឲ្យពួកបរិសុទ្ធអាចបានស្មើគ្នា ក្នុងចំណងទាំងឡាយពីការខាងស្ថានសួគ៌ ព្រមទាំងការខាងផែនដីផង, **គ. និង ស.** ៧៨:៤–៥ ។ មនុស្សរាល់គ្នាត្រូវបានស្មើគ្នា តាមសេចក្ដីចំណង់ របស់ខ្លួន និងសេចក្ដីត្រូវការរបស់ខ្លួន, **គ. និង ស.** ៨២:១៧–១៩ ។ ស៊ីយ៉ូនអាចបានស្ថាបនាឡើងដោយសារគោលការណ៍ទាំងឡាយនៃនគរសេឡេស្ទាលប៉ុណ្ណោះ, **គ. និង ស.** ១០៥:៥ ។ ប្រជាជនរបស់ហេណុកមានចិត្តតែមួយ និងគំនិតតែមួយ ហើយបានរស់នៅក្នុងសេចក្ដីសុចរិត ហើយគ្មានមនុស្សក្រីក្រនៅក្នុងចំណោមពួកគេឡើយ, **ម៉ូសេ** ៧:១៨ ។

### ទង់

នៅក្នុងគម្ពីរ គឺជាទង់ ឬទង់ជ័យមួយ ដែលប្រជាជនប្រមូលគ្នាមករួមជុំវិញជាក្រុម ចំពោះគោលបំណង ឬទីសំគាល់មួយ ។ នៅសម័យបុរាណ ទង់ត្រូវបានប្រើជាទីរួបរួមទាហានក្នុងចម្បាំង ។ ព្រះគម្ពីរមរមន និងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ គឺជាទង់សំគាល់ដល់អស់ទាំងសាសន៍នៅលើផែនដី ។

ទ្រង់នឹងលើកទង់ជ័យសំរាប់សាសន៍ទាំងឡាយ, **អេសាយ** ៥:២៦ (២ នីហ្វៃ ១៥:២៦) ។ ឫសនៃអ៊ីសាយនឹងបានតាំងឡើង ទុកជាទង់, **អេសាយ** ១១:១០ (២ នីហ្វៃ ២១:១០; គ. និង ស. ១១៣:៦) ។ ចូរលើកទង់ជ័យនៃសន្តិភាព, **គ. និង ស.** ១០៥:៣៩ ។

### ទង់ឥស្សរភាព *សូមមើលផង* មរ៉ូណៃ, មេទ័ព

ជាទង់ដែលបានដំឡើង ដោយមរ៉ូណៃជាមេទ័ពឯកនៃកងទ័ពនីហ្វៃ នៅក្នុងព្រះគម្ពីរមរមន ។ មរ៉ូណៃបានធ្វើទង់ ដើម្បីលើកទឹកចិត្ត ប្រជាជននីហ្វៃឲ្យការពារសាសនា ឥស្សរភាព សេចក្ដីសុខសាន្ត និងក្រុមគ្រួសាររបស់ពួកគេ ។

មរ៉ូណៃបានធ្វើទង់ឥស្សរភាពពីក្រណាត់អាវរបស់លោក, **អាលម៉ា** ៤៦:១២–១៣ ។ អស់អ្នកណាដែលចង់រក្សាទង់ នោះបានចូលក្នុងសេចក្ដីសញ្ញា, **អាលម៉ា** ៤៦:២០–២២ ។ មរ៉ូណៃបានបង្គាប់ឲ្យដោតទង់នៅលើប៉មទាំងអស់, **អាលម៉ា** ៤៦:៣៦ (អាលម៉ា ៥១:២០) ។

### ទន្លេយ័រដាន់

ទន្លេយ័រដាន់ហូរពីសមុទ្រកាលីឡេ ទៅសមុទ្រស្លាប់ ។ ទន្លេនេះមានបណ្ដោយ ១៦០ គ.ម. ហើយបានកើតឡើង ដោយមានស្ទឹងជាច្រើនហូរពីភ្នំហើម៉ុនមករួមគ្នា ។ ទន្លេយ័រដាន់ជាទន្លេដ៏សំខាន់បំផុតនៅក្នុងអ៊ីស្រាអែល ។

មានព្រឹត្តិការណ៍ពីរដ៏សំខាន់ដែលទាក់ទងនឹងទន្លេនេះ គឺព្រះអម្ចាស់ទ្រង់បានញែកទឹកទន្លេ សំរាប់ឲ្យពួកអ៊ីស្រាអែលឆ្លង (យ៉ូស្វេ ៣:១៤–១៧), និងបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ៣:១៣–១៧; ១ នីហ្វៃ ១០:៩) ។

### ទទួលការខុសត្រូវ, ចេះទទួលការខុសត្រូវ, ការទទួលខុសត្រូវ *សូមមើលផង* សិទ្ធិជ្រើសរើស

ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា មនុស្សគ្រប់រូបទទួលខុសត្រូវចំពោះសេចក្ដីប្រថ្នា អាកប្បកិរិយា សេចក្ដីប៉ងប្រាថ្នា និងសកម្មភាពទាំងឡាយរបស់ខ្លួន ។

អាយុដែលចេះទទួលការខុសត្រូវ គឺជាអាយុកូនក្មេងកាលដែលរាប់ថា ចេះទទួលខុសត្រូវ ចំពោះសកម្មភាពរបស់ខ្លួន ហើយមានសមត្ថភាពនឹងប្រព្រឹត្តអំពើបាប ហើយប្រែចិត្ត ។

យើងនឹងជំនុំជំរះមនុស្សគ្រប់គ្នាតាមអំពើប្រព្រឹត្តិរៀងខ្លួន, **អេសេ.** ១៨:៣០ ។ ពួកគេនឹងត្រូវរៀបរាប់ប្រាប់ពីអស់ទាំងហេតុនៃពាក្យឥតប្រយោជន៍, **ម៉ាថាយ** ១២:៣៦ ។ ចូររៀបរាប់ប្រាប់ពីការអ្នកត្រួតត្រានោះមកមើល, **លូកា** ១៦:២ ។ យើងទាំងអស់គ្នានឹងត្រូវរៀបរាប់ទូលថ្វាយព្រះ ពីដំណើររបស់ខ្លួនយើងជាមិនខាន, **រ៉ូម** ១៤:១២ ។ ពួកមនុស្សស្លាប់នឹងត្រូវជំនុំជំរះ តាមអំពើដែលគេបានប្រព្រឹត្ត រៀងខ្លួន, **វិវរ.** ២០:១២ ។ ពាក្យសំដី កិច្ចការ និងគំនិតរបស់យើងនឹងកាត់ទោសយើង, **អាលម៉ា** ១២:១៤ ។ ពួកយើង ជាចៅក្រមជំនុំជំរះខ្លួនផ្ទាល់ នៅក្នុងការធ្វើល្អ ឬធ្វើអាក្រក់, **អាលម៉ា** ៤១:៧ ។ អ្នកត្រូវបានអនុញ្ញាតឲ្យធ្វើអ្វីៗដើម្បីខ្លួនឯង, **ហេលេ.** ១៤:២៩–៣១ ។ ការណ៍នេះដែលអ្នករាល់គ្នាត្រូវបង្រៀន — គឺការប្រែចិត្ត និងបុណ្យជ្រមុជទឹក ដល់ជនទាំងឡាយណាដែលដឹងខុសត្រូវ, **ម៉ូរ៉ូណៃ** ៨:១០ ។ មនុស្សគ្រប់រូបត្រូវតែប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក នៅពេលមានអាយុចេះទទួលការខុសត្រូវ, **គ. និង ស.** ១៨:៤២ ។ អារក្សសាតាំងពុំអាចល្បួងកូនក្មេងតូចៗបានទេ លុះត្រាពួកគេចាប់ផ្ដើមទទួលការខុសត្រូវ នៅចំពោះយើងសិន, **គ. និង ស.** ២៩:៤៦–៤៧ ។ កូនក្មេងត្រូវទទួលបុណ្យជ្រមុជទឹក កាលមានអាយុប្រាំបីឆ្នាំ, **គ. និង ស.** ៦៨:២៧ ។ មនុស្សគ្រប់រូបអាចបានទទួល ការខុសត្រូវចំពោះអំពើបាបទាំងឡាយរបស់ខ្លួន នៅថ្ងៃជំនុំជំរះ, **គ. និង ស.** ១០១:៧៨ ។ គឺត្រូវបានប្រទានដល់មនុស្សលោក ឲ្យចេះដឹងខុសត្រូវ; ហេតុដូច្នោះហើយ ទើបពួកគេជាភ្នាក់ងារចំពោះខ្លួនផ្ទាល់, **ម៉ូសេ** ៦:៥៦ ។ មនុស្សទាំងឡាយនឹងត្រូវទទួលទោស ចំពោះអំពើបាបរបស់ខ្លួនផ្ទាល់, **ម. នៃ ស.** ១:២ ។

**ទទួលសារភាព, ការទទួលសារភាព, ទទួលថ្លែងប្រាប់, ការទទួលថ្លែងប្រាប់** *សូមមើលផង* ការប្រែចិត្ត, ប្រែចិត្ត, អត់ទោស

គម្ពីរប្រើយ៉ាងតិចពាក្យ*ការទទួលសារភាព* និង*ការទទួលថ្លែងប្រាប់* ។ ទីមួយ ទទួលថ្លែងប្រាប់ គឺថ្លែងនូវសេចក្ដីជំនឿរបស់ខ្លួន ដល់អ្វីមួយ ដូចជាទទួលថ្លែងប្រាប់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ (ម៉ាថាយ ១០:៣២; រ៉ូម ១០:៩; ១ យ៉ូហាន ៤:១–៣; គ. និង ស. ៨៨:១០៤) ។

ន័យម៉្យាងទៀត ទទួលសារភាព គឺទទួលកំហុសរបស់ខ្លួន ដូចជាក្នុងការទទួលសារភាពចំពោះអំពើបាបទាំងឡាយ ។ គឺជាកាតព្វកិច្ចរបស់មនុស្សគ្រប់រូប ឲ្យទទួលសារភាពចំពោះអស់ទាំងអំពើបាបដល់ព្រះអម្ចាស់ ហើយសូមក្ដីអត់ទោសពីទ្រង់ (គ. និង ស. ៥៨:៤២–៤៣) ។ កាលណាចាំបាច់ នោះត្រូវទទួលសារភាពនូវអំពើបាបទាំងឡាយដល់អ្នកផ្សេង ឬដល់ពួកអ្នកផ្សេងដែលបានធ្វើ អំពើបាបទៅលើ ។ រីឯអំពើបាបធ្ងន់ៗ ត្រូវទទួលសារភាពដល់អ្នកកាន់តំណែងក្នុងសាសនាចក្រ (ក្នុងករណីភាគច្រើន គឺប៊ីស្សព) ។

អ្នកនោះត្រូវលន់តួចំពោះអំពើបាបដែលខ្លួនបានប្រព្រឹត្ត, **លេវី.** ៥:៥ ។ គេនឹងលន់តួសេចក្ដីទុច្ចរិតរបស់គេ, **លេវី.** ២៦:៤០–៤២ ។ ចូរសរសើរដល់ព្រះអម្ចាស់ ជាព្រះនៃសាសន៍អ៊ីស្រាអែល ហើយលន់តួនឹងទ្រង់ទៅ, **យ៉ូស្វេ** ៧:១៩ ។ មនុស្សក៏ទទួលបុណ្យជ្រមុជទឹក ពីគាត់ ក្នុងទន្លេយ័រដាន់ ហើយលន់តួបាប, **ម៉ាថាយ** ៣:៥–៦ ។ អ្នកណាលងច្បាប់ណាដែលទទួលសារភាពនូវអំពើបាបទាំងឡាយ របស់ខ្លួន នោះនឹងត្រូវបានអត់ទោសឲ្យ, **ម៉ូសាយ** ២៦:២៩ ។ ចូរអ្នកទទួលសារភាពនូវអំពើបាបទាំងឡាយរបស់អ្នកចុះ ក្រែងលោអ្នក នឹងរងទុក្ខទោសទាំងឡាយ, **គ. និង ស.** ១៩:២០ ។ ពួកប្រែចិត្តនឹងទទួលសារភាពនូវអំពើបាបទាំងឡាយ ហើយលះបង់ចោលអំពើ បាបទាំងនោះ, **គ. និង ស.** ៥៨:៤៣ ។ ព្រះអម្ចាស់ទ្រង់មានចិត្តមេត្តាករុណាដល់អស់អ្នកណាដែលទទួលសារភាពនូវអំពើបាបទាំង ឡាយរបស់ខ្លួន ដោយចិត្តរាបសា, **គ. និង ស.** ៦១:២ ។ ព្រះអម្ចាស់ទ្រង់អភ័យទោសនូវអំពើបាបទាំងឡាយ នៃអស់អ្នកណាដែល ទទួលសារភាព ហើយសូមក្ដីអភ័យទោស, **គ. និង ស.** ៦៤:៧ ។

**ទាន, ការដាក់ទាន** *សូមមើលផង* ដង្វាយ; តម, តំណម; មនុស្សក្រីក្រ; សុខុមាលភាព

ជាដង្វាយទាំងឡាយ ដើម្បីជួយមនុស្សក្រីក្រ ។

កុំឲ្យអ្នករាល់គ្នាធ្វើទាននៅមុខមនុស្ស, **ម៉ាថាយ** ៦:១–៤ (៣ នីហ្វៃ ១៣:១–៤) ។ ស្រីមេម៉ាយនេះបានថ្វាយលើសជាងអ្នកទាំងអស់, **ម៉ាកុស** ១២:៤១–៤៤ ។ ដែលឲ្យ នោះបានពរជាជាងទទួល, **កិច្ចការ** ២០:៣៣–៣៥ ។ ខ្ញុំចង់ឲ្យអ្នករាល់គ្នាចែករំលែកនូវទ្រព្យរបស់ ខ្លួន ដល់អ្នកទាល់ក្រ, **ម៉ូសាយ** ៤:២៦ ។ បណ្ដាជននៃសាសនាចក្រគប្បីចែករំលែកនូវទ្រព្យសម្បត្តិរបស់ខ្លួន មនុស្សម្នាក់ៗទៅតាមអ្វីដែលគេមាន, **ម៉ូសាយ** ១៨:២៧ ។

**ទីតុស, សំបុត្រដល់** *សូមមើលផង* ទីតុស, ប៉ុល; សំបុត្ររបស់ប៉ុល

កាលប៉ុលបានរួចពីការដាក់គុករបស់ពួករ៉ូមមួយរយៈ នោះលោកបានសរសេរសំបុត្រទៅទីតុស ដែលនៅឯកោះក្រេត ។ សំបុត្រថ្លែងពីសំនួរដែលទាក់ទងទៅនឹងផ្នែកខាងការអប់រំ និងអង្គការនៃសាសនាចក្រ ។

ជំពូកទី ១ មានការសួរសុខទុក្ខពីប៉ុល ព្រមទាំងការបង្រៀន និងលក្ខណៈទូទៅ សំរាប់ពួកប៊ីស្សព ។ ជំពូកទី ២–៣ មានការបង្រៀនទូទៅ និងបណ្ដាំលោកទៅទីតុស អំពីការថែទាំពួកក្រុមផ្សេងៗ នៅក្នុងសាសនាចក្រ នៃពួកក្រេត ។ ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យមានជ័យជំនះលើអំពើខ្ជិលឆ្អើម គឺឲ្យបានប្រកបដោយចិត្តស្រគត់ស្រគំ និងស្មោះត្រង់ ហើយរក្សាកិច្ចការល្អទាំងឡាយ ។

**ទីតុស** *សូមមើលផង* ទីតុស, ប៉ុល; សំបុត្រដល់, សំបុត្ររបស់ប៉ុល

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសាសន៍ក្រេកដែលប្រែចិត្តជឿម្នាក់ដ៏គួរទុកចិត្ត ដែលបានធ្វើដំណើរទៅក្រុងយេរូសាឡិម ជាមួយនឹងប៉ុល ហើយក្រោយមក បានត្រឡប់ទៅជាអ្នកផ្សាយសាសនា (កាឡាទី

២:១–៤; ២ ធីម៉ូ. ៤:១០) ។ ទីតុសបានយកសំបុត្រទីមួយរបស់ប៉ុល ទៅឲ្យពួកបរិសុទ្ធ នៅស្រុកកូរិនថូស (២ កូរិន. ៧:៥–៨, ១៣–១៥) ។

**ទីបន្ទាល់** *សូមមើលផង* ធ្វើបន្ទាល់; ព្រះវិញ្ញាណបរិសុទ្ធ; សាក្សី

ជាគំរិះ និងសាក្សីខាងវិញ្ញាណ ដែលព្រះវិញ្ញាណបរិសុទ្ធប្រទានឲ្យ ។ ទីបន្ទាល់ក៏អាចទៅជាសេចក្ដីថ្លែងជាផ្លូវការ ឬតាមច្បាប់ ដែលជនណាម្នាក់យល់ថា ជាសេចក្ដីពិត (គ. និង ស. ១០២:២៦) ។

ខ្ញុំដឹងថា អ្នកដែលលោះខ្ញុំ ទ្រង់មានព្រះជន្មរស់នៅ, **យ៉ូប** ១៩:២៥–២៦ ។ មិនត្រូវឲ្យអ្នកមានសេចក្ដីខ្មាស់ ចំពោះការធ្វើបន្ទាល់ពី ព្រះអម្ចាស់នៃយើងឡើយ, **២ ធីម៉ូ.** ១:៨ ។ ការធ្វើបន្ទាល់ពីព្រះយេស៊ូវ នោះហើយជាវិញ្ញាណនៃសេចក្ដីទំនាយ, **វិវ.** ១៩:១០ ។ ចូរឈរជាសាក្សីដល់ព្រះ នៅគ្រប់ពេលវេលា, **ម៉ូសាយ** ១៨:៩ ។ ពុំមានផ្លូវណាមួយ ដើម្បីទាមទារយកមនុស្សមកវិញទេ ក្រៅពីការ ធ្វើបន្ទាល់យ៉ាងម៉ឺងម៉ាត់ទាស់នឹងពួកគេប៉ុណ្ណោះ, **អាលម៉ា** ៤:១៩–២០ ។ ខ្ញុំមាននូវគ្រប់អ្វីៗទាំងអស់ ដែលជាទីបន្ទាល់ថា ការណ៍ទាំង នេះពិត, **អាលម៉ា** ៣០:៤១–៤៤ ។ អ្នករាល់គ្នាពុំទទួលសាក្សីឡើយ រហូតដល់ពេលក្រោយពីការសាកល្បងនៃសេចក្ដីជំនឿរបស់អ្នក សិន, **អេធើរ** ១២:៦ ។ តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នកទេឬអី? តើអ្នកអាចមានសាក្សីណាដែល អស្ចារ្យជាងសាក្សីមកពីព្រះ? **គ. និង ស.** ៦:២២–២៣ ។ ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់ នេះគឺ ជាទីបន្ទាល់ដែលយើងខ្ញុំសូមថ្លែងអំពីទ្រង់, **គ. និង ស.** ៧៦:២២–២៤ ។ យើងចាត់ឲ្យអ្នកទៅធ្វើបន្ទាល់ ហើយ ព្រមានប្រជាជន, **គ. និង ស.** ៨៨:៨១–៨២ ។ ឥឡូវនេះ ពួកអ្នកដែលធ្វើទីបន្ទាល់បានស្លាប់ទៅហើយ ហើយទីបន្ទាល់របស់ពួកគេ នៅតែមានឥទ្ធិពល, **គ. និង ស.** ១៣៥:៤–៥ ។ ហេណុកបានឃើញពួកទេវតាកំពុងតែធ្វើទីបន្ទាល់ពីព្រះវរបិតា និងព្រះរាជបុត្រា, **ម៉ូសេ** ៧:២៧ ។ ទោះជាខ្ញុំត្រូវគេស្អប់ ហើយបៀតបៀន មកពីថាខ្ញុំបានឃើញការនិមិត្តក្ដី គង់តែការណ៍នោះពិត, **យ.ស. — ប្រវត្តិ** ១:២៤–២៥ ។

**ទីសំគាល់** *សូមមើលផង* ទីសំគាល់នៃ; ទីសំគាល់អំពីពេលវេលា, សាសនាចក្រពិត, អព្ភូតហេតុ

ជាព្រឹត្តិការណ៍ ឬការពិសោធន៍ណាមួយ ដែលមនុស្សយល់ថា ជាភស្តុតាង ឬជាទីសំគាល់អំពីអ្វីមួយ ។ តាមធម្មតា ទីសំគាល់ គឺជាការសម្ដែងដ៏អស្ចារ្យដែលមកពីព្រះ ។ សាតាំងក៏មានអំណាចនឹងបង្ហាញនូវទីសំគាល់ទាំងឡាយ នៅក្រោមលក្ខខ័ណ្ឌខ្លះ ។ ពួក បរិសុទ្ធគួរតែស្វែងរកអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ ប៉ុន្តែមិនគួរស្វែងរកទីសំគាល់ ដើម្បីឲ្យបានស្កប់ស្កល់ចិត្ត ឬឲ្យបានសេចក្ដីជំនឿនោះឡើយ ។ តែផ្ទុយទៅវិញ គឺព្រះអម្ចាស់ទ្រង់ទេ ដែលនឹងប្រទាននូវទីសំគាល់ទាំងឡាយ ក្នុងកាលទ្រង់ទតឃើញថា សមដល់អស់អ្នកណាដែលជឿ (គ. និង ស. ៥៨:៦៤) ។

ព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់មួយ មកអ្នករាល់គ្នា ដោយព្រះអង្គទ្រង់, **អេសាយ** ៧:១៤ (២ នីហ្វៃ ១៧:១៤) ។ ព្រះទ្រង់ធ្វើទីសំគាល់ និងការអស្ចារ្យនៅស្ថានសួគ៌ ហើយនៅផែនដី, **ដានី.** ៦:២៧ ។ តំណមនុស្សអាក្រក់ ហើយកំផិត គេចេះតែចង់ឃើញទីសំគាល់, **ម៉ាថាយ** ១២:៣៩ (ម៉ាថាយ ១៦:៤; លូកា ១១:២៩) ។ ទីសំគាល់ទាំងនេះ នឹងជាប់តាមអស់អ្នកដែលជឿ, **ម៉ាកុស** ១៦:១៧ (មរមន ៩:២៤; អេធើរ ៤:១៨; គ. និង ស. ៨៤:៦៥) ។ សេរេមបានទាមទាររកទីសំគាល់, **យ៉ាកុប** ៧:១៣–២០ ។ កូរីហ័របានទាមទាររកទីសំគាល់, **អាលម៉ា** ៣០:៤៨–៦០ ។ ចូរបង្ហាញដល់ពួកយើងនូវទីសំគាល់មួយ ទើបពួកយើងនឹងជឿ, **អាលម៉ា** ៣២:១៧ ។ មនុស្សភាគច្រើនបានជឿតាមទីសំគាល់ និងការអស្ចារ្យទាំងឡាយ, ៣ នីហ្វៃ ១:២២ ។ ប្រជាជនបានភ្លេចពីទីសំគាល់ និងការអស្ចារ្យទាំងឡាយ, ៣ នីហ្វៃ ២:១ ។ អ្នករាល់គ្នាពុំទទួលសាក្សីឡើយ រហូតដល់ពេលក្រោយពីការសាកល្បងនៃសេចក្ដីជំនឿរបស់អ្នកសិន, **អេធើរ** ១២:៦ ។ ចូរកុំសូមអព្ភូតហេតុឡើយ លើកលែងតែយើងនឹងបញ្ជា, **គ. និង ស.** ២៤:១៣ ។ សេចក្ដីជំនឿពុំមែនមានឡើង ដោយសារទីសំគាល់ទាំងឡាយឡើយ ប៉ុន្តែទីសំគាល់ទាំងឡាយមកតាមក្រោយអស់អ្នកដែលជឿវិញ, **គ. និង ស.** ៦៣:៧–១១ ។ នៅគ្រានោះ នឹងមានព្រះគ្រីស្ទក្លែងក្លាយ ហើយព្យាការីក្លែងក្លាយកើតឡើង ហើយនឹងបង្ហាញទីសំគាល់យ៉ាងធំ និងការអស្ចារ្យ, **យ.ស. — ម៉ាថាយ** ១:២២ ។

**ទីសំគាល់ទាំងឡាយអំពីកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ជាព្រឹត្តិការណ៍ទាំងឡាយ ដែលដង្ហែកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ ។

*កំណើត៖* នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រាមួយ, **អេសាយ** ៧:១៤ ។ នឹងមានអ្នកគ្រប់គ្រងលើអ៊ីស្រាអែលម្នាក់កើតចេញ ពីបេថ្លេហិម, **មីកា** ៥:២ ។ សាំយូអែល ជាសាសន៍លេមិន បានព្យាករអំពីមួយថ្ងៃ មួយយប់ និងអំពីថ្ងៃដែលភ្លឺមួយ; អំពីផ្កាយថ្មីមួយ; និងអំពីទីសំគាល់ផ្សេងៗទៀត, **ហេលេ.** ១៤:២–៦ ។ ទីសំគាល់ទាំងឡាយត្រូវបានសំរេច, ៣ នីហ្វៃ ១:១៥–២១ ។

*ការសុគត៖* សាំយូអែល ជាសាសន៍លេមិន បានព្យាករអំពីការងងឹតអំពីផ្គរលាន់ និងផ្លេកបន្ទោរ និងអំពីផែនដីរញ្ជួយ, **ហេលេ.** ១៤:២០–២៧ ។ ទីសំគាល់ទាំងឡាយត្រូវបានបំពេញ, ៣ នីហ្វៃ ៨:៥–២៣ ។

**ទីសំគាល់អំពីពេលវេលា** *សូមមើលផង* ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ; ថ្ងៃចុងក្រោយ; ថ្ងៃចុងក្រោយបង្អស់, ទីសំគាល់

ជាព្រឹត្តិការណ៍ ឬការពិសោធន៍ទាំងឡាយ ដែលព្រះទ្រង់ប្រទានដល់មនុស្ស ដើម្បីបង្ហាញប្រាប់ថា សារៈសំខាន់នៃកិច្ចការទ្រង់បាន កើតឡើងឬនឹងកើតឡើងយ៉ាងឆាប់ៗ ។ នៅថ្ងៃចុងក្រោយ មានទីសំគាល់ជាច្រើនដែលបានព្យាករប្រាប់ទុក អំពីការយាងមកលើក ទីពីរនៃព្រះអង្គសង្គ្រោះ ។

ទីសំគាល់ទាំងនេះ បណ្តាលឲ្យពួកមនុស្សស្មោះត្រង់ បានស្គាល់នូវផែនការរបស់ព្រះ បានព្រមានទុកជាមុន ហើយបានរៀបចំ ។

ភ្នំជាទីស្នាងព្រះវិហារនៃព្រះអម្ចាស់ នឹងបានតាំងឡើងខ្ពស់ នៅលើភ្នំធំៗ, **អេសាយ** ២:២–៣ ។ ព្រះអម្ចាស់ទ្រង់នឹងលើកទង់ជ័យ ហើយនឹងប្រមូលពួកអ៊ីស្រាអែល, **អេសាយ** ៥:២៦ (២ នីហ្វៃ ១៥:២៦–៣០) ។ ព្រះអាទិត្យនឹងងងឹត ហើយព្រះច័ន្ទនឹងអាប់រស្មី, **អេសាយ** ១៣:១០ (យ៉ូអែល ៣:១៥; គ. និង ស. ២៩:១៤) ។ ពួកមនុស្សនឹងរំលងក្រិត្យក្រម ហើយផ្តាច់សេចក្តីសញ្ញាដ៏នៅអស់កល្ប ជានិច្ចចេញ, **អេសាយ** ២៤:៥ ។ ពួកសាសន៍នីហ្វៃនឹងនិយាយប្រាប់ ហាក់ដូចជាសំដីចេញពីធូលីដី, **អេសាយ** ២៩:៤ (២ នីហ្វៃ ២៧) ។ ពួកអ៊ីស្រាអែលនឹងត្រូវបានប្រមូល ដោយព្រះចេស្តា, **អេសាយ** ៤៩:២២–២៣ (១ នីហ្វៃ ២១:២២–២៣; ៣ នីហ្វៃ ២០–២១) ។ ព្រះទ្រង់នឹងតាំងនគរមួយឡើង ដែលមិនត្រូវបំផ្លាញឡើយ, **ដានី.** ២:៤៤ (គ. និង ស. ៦៥:២) ។ សង្គ្រាម សុបិន និងការនិមិត្តទាំងឡាយនឹងមានឡើងមុនការយាងមកលើកទីពីរ, **យ៉ូអែល** ២ ។ អស់ទាំងសាសន៍នឹងប្រមូលគ្នាទៅច្បាំងនឹងក្រុងយេរូសាឡិម, **សាការី** ១៤:២ (អេសេ. ៣៨–៣៩) ។ ថ្ងៃនោះនឹងមកដល់ ថ្ងៃនោះឆេះធ្លោ ដូចជាគុកភ្លើង, **ម៉ាឡាគី** ៤:១ (៣ នីហ្វៃ ២៥:១; គ. និង ស. ១៣៣:៦៤; យ.ស. — ប្រវត្តិ ១:៣៧) ។ ការអន្តរាយដ៏ធំៗនឹងមានឡើងមុនការយាងមកលើកទីពីរ, **ម៉ាថាយ** ២៤ (យ.ស. — ម៉ាថាយ ១) ។ ប៉ុលបានអធិប្បាយប្រាប់អំពីការក្បត់សាសនា និងពេលដ៏អន្តរាយនៃជាន់ក្រោយបង្អស់, **២ ធីម៉ូ.** ៣–៤ ។ ព្យាការីពីរនាក់នឹង ត្រូវគេប្រហារ ហើយនឹងរស់ឡើងវិញនៅក្រុងយេរូសាឡិម, **វិវរ.** ១១ (គ. និង ស. ៧៧:១៥) ។ ដំណឹងល្អនឹងត្រូវបានសាងឡើងវិញ នៅថ្ងៃចុងក្រោយបង្អស់ ដោយការងារបំរើនៃទេវតា, **វិវរ.** ១៤:៦–៧ (គ. និង ស. ១៣; ២៧; ១១០:១១–១៦; ១២៨:៨–២៤) ។ ក្រុងបាប៊ីឡូននឹងបានតាំងឡើង ហើយរលំចុះ, **វិវរ.** ១៧–១៨ ។ ពួកអ៊ីស្រាអែលនឹងត្រូវបានប្រមូល ដោយព្រះចេស្តា, **១ នីហ្វៃ** ២១:១៣–២៦ (អេសាយ ៤៩:១៣–២៦; ៣ នីហ្វៃ ២០–២១) ។ នេះគឺជាទីសំគាល់ដើម្បីឲ្យអ្នកអាចដឹងអំពីពេលវេលា, ៣ នីហ្វៃ ២១:១ ។ ព្រះគម្ពីរមរមននឹងត្រូវបានចេញមកដោយព្រះចេស្តានៃព្រះ, **មរមន** ៨ ។ ពួកសាសន៍លេមិននឹងត្រូវរីកឡើងដូចជាផ្កា កូឡាប, **គ. និង ស.** ៤៩:២៤–២៥ ។ ពួកមនុស្សទុច្ចរិតនឹងប្រហារពួកមនុស្សទុច្ចរិត, **គ. និង ស.** ៦៣:៣២–៣៥ (វិវរ. ៩) ។ សង្គ្រាមនឹងចាក់មកលើអស់ ទាំងសាសន៍, **គ. និង ស.** ៨៧:២ ។ ទីសំគាល់ទាំងឡាយ ការប្រែប្រួលវត្ថុធាតុ និងពួកទេវតារៀបចំសំរាប់ការយាងមកនៃព្រះអម្ចាស់, **គ. និង ស.** ៨៨:៨៦–៩៤ ។ សេចក្តីងងឹតនឹងគ្របដណ្តប់ផែនដី, **គ. និង ស.** ១១២:២៣–២៤ ។ ព្រះអម្ចាស់ទ្រង់បង្គាប់ពួកបរិសុទ្ធ ឲ្យរៀបចំសំរាប់ការយាងមកលើកទីពីរ, **គ. និង ស.** ១៣៣ ។

**ទីសំគាល់អំពីសាសនាចក្រពិត** *សូមមើល* ទីសំគាល់អំពី, សាសនាចក្រពិត

**ទីអានគុម**

ជាមេទ័ពសាសន៍នីហ្វៃដ៏មហិមាម្នាក់ នៅក្នុងព្រះគម្ពីរមរមន (អាលម៉ា ៥០:៣៥; ៥១–៥២; ៦១–៦២) ។

**ទឹកជំនន់នៅសម័យណូអេ** *សូមមើលផង* ទូកធំ; ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប; ឥន្ធធនូ

នៅសម័យណូអេ នោះផែនដីត្រូវគ្របដណ្តប់ដោយទឹកទាំងស្រុង ។ នេះគឺជាបុណ្យជ្រមុជទឹកឲ្យផែនដី ហើយជាតំណាងអំពីការ លាងសំអាត (១ ពេត្រុស ៣:២០–២១) ។

យើងនឹងធ្វើឲ្យមានជំនន់លើផែនដី ដើម្បីនឹងបំផ្លាញគ្រប់ទាំងសាច់, **លោកុ.** ៦:១៧ (ម៉ូសេ ៧:៣៤, ៤៣, ៥០–៥២; ៨:១៧, ៣០) ។ ជំនន់ក៏ឡើងលើផែនដី, **លោកុ.** ៧:១០ ។ ព្រះទ្រង់បានដាក់ធ្នូនៅនាពពក ទុកជាទីសំគាល់នៃសេចក្តីសញ្ញា, **លោកុ.** ៩:៩–១៧ ។ ក្រោយពីទឹកបានស្រកទៅ នោះផែនដីអាមេរិកបានក្លាយទៅជាផែនដីជំរើសមួយ, **អេធើរ** ១៣:២ ។ ពួកទុច្ចរិតនឹងវិនាសបង់ក្នុងទឹក ជំនន់, **ម៉ូសេ** ៧:៣៨; ៨:២៤ ។

**ទឹករស់** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ជានិមិត្តរូបមួយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងសេចក្តីបង្រៀនរបស់ទ្រង់ ។ ដូចជាទឹកជារបស់សំខាន់មួយ សំរាប់ទ្រទ្រង់ជីវិតខាងសាច់ឈាមយ៉ាងណា នោះព្រះអង្គសង្គ្រោះ និងសេចក្តីបង្រៀនរបស់ទ្រង់ (ទឹករស់) ក៏ជារបស់សំខាន់មួយ សំរាប់ជីវិតដ៏នៅអស់កល្បជានិច្ចយ៉ាងនោះដែរ ។

ឯងរាល់គ្នានឹងដងទឹកពីអណ្តូងនៃសេចក្តីសង្គ្រោះដោយអំណរ, **អេសាយ** ១២:៣ ។ គេបានបោះបង់ចោលអញ ដែលជាក្បាលទឹករស់, **យេរេ.** ២:១៣ ។ អស់អ្នកណាដែលផឹកទឹកដែលខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ, **យ៉ូហាន** ៤:៦–១៥ ។ បើអ្នកណាស្រេក ចូរឲ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ, **យ៉ូហាន** ៧:៣៧ ។ ដំបងដែកនាំទៅឯប្រភពនៃទឹករស់, **១ នីហ្វៃ** ១១:២៥ ។ ចូរទទួលទានទឹកនៃជីវិតដោយសេរីចុះ, **គ. និង ស.** ១០:៦៦ ។ ព្រះបញ្ញត្តិទាំងឡាយរបស់យើងនឹងត្រូវទៅដូចជាអណ្តូងនៃទឹករស់, **គ. និង ស.** ៦៣:២៣ ។

**ទុកចិត្ត** *សូមមើលផង* សេចក្តីជំនឿ, សេចក្តីទុកចិត្ត

គឺពឹងពាក់ ឬទុកចិត្តដល់អ្នកណាម្នាក់ ឬដល់អ្វីមួយ ។ តាមការណ៍ខាងវិញ្ញាណ ទុកចិត្តមានរួមទាំងការពឹងពាក់ទៅលើព្រះ និងព្រះវិញ្ញាណទ្រង់ ។

ទោះបើទ្រង់សម្លាប់ខ្ញុំក៏ដោយ គង់តែខ្ញុំនឹងទុកចិត្តដល់ទ្រង់ដែរ, **យ៉ូប** ១៣:១៥ ។ ចូរពឹងដល់ព្រះអម្ចាស់ ឲ្យអស់អំពីចិត្តរបស់ឯង, **សុភា.** ៣:៥ ។ ព្រះទ្រង់ប្រោសពួកបំរើទ្រង់ ដែលទុកចិត្តដល់ទ្រង់, **ដានី.** ៣:១៩–២៨ ។ ទូលបង្គំនឹងទុកចិត្តដល់ព្រះអង្គជារៀងរាប, **២ នីហ្វៃ** ៤:៣៤ ។ ចូរអរសប្បាយរីករាយ ហើយដាក់ទីទុកចិត្តរបស់អ្នកទៅលើព្រះចុះ, **ម៉ូសាយ** ៧:១៩ ។ នរណាដែលដាក់ទីទុកចិត្ត របស់ខ្លួនទៅលើព្រះ

នោះនឹងបានលើកឡើង នៅថ្ងៃចុងក្រោយបង្អស់, **ម៉ូសាយ** ២៣:២២ ។ នរណាដែលនឹងដាក់ទីទុកចិត្តរបស់ ខ្លួនទៅលើព្រះ នោះនឹងបានគាំទ្រ ក្នុងកាលគេមានការពិសោធន៍, **អាលម៉ា** ៣៦:៣, ២៧ ។ ចូរកុំទុកចិត្តទៅលើដៃនៃមនុស្សឡើយ, **គ. និង ស.** ១:១៩ ។ ចូរដាក់ទីទុកចិត្តរបស់អ្នកទៅនឹងព្រះវិញ្ញាណនោះ ដែលនាំឲ្យធ្វើល្អ, **គ. និង ស.** ១១:១២ ។ ចូរឲ្យគាត់ទុកចិត្ត ដល់យើង ហើយគាត់នឹងមិនត្រូវបានធ្វើឲ្យខ្មាសឡើយ, **គ. និង ស.** ៨៤:១១៦ ។

**ទុក្ករបុគ្គល, ទុក្ករកម្ម**

ជាមនុស្សដែលប្ដូរជីវិតខ្លួន ជាជាងចោលព្រះគ្រីស្ទ ដំណឹងល្អ ឬក៏ជំនឿ ឬគោលការណ៍ដ៏សុចរិតរបស់ខ្លួន ។

អស់ទាំងឈាមរបស់មនុស្សសុចរិត ពីអេបិល រហូតដល់សាការីនឹងធ្វើទីបន្ទាល់ទាស់នឹងពួកមនុស្សទុច្ចរិត, **ម៉ាថាយ** ២៣:៣៥ (លូកា ១១:៥០) ។ អ្នកណាដែលបាត់ជីវិត ដោយព្រោះយល់ដល់ខ្ញុំ ហើយនឹងដំណឹងល្អ នោះនឹងបានជីវិតវិញ, **ម៉ាកុស** ៨:៣៥ (គ. និង ស. ៩៨:១៣) ។ គេចោលស្ទេផានទីងថ្ម, **កិច្ចការ** ៧:៥៩ (កិច្ចការ ២២:២០) ។ កាលណាមានសំបុត្រសញ្ញា នោះត្រូវតែមានការស្លាប់ដល់ម្ចាស់សំបុត្រ, **ហេព្រើរ** ៩:១៦–១៧ ។ អ័ប៊ីណាដៃក៏ដួលចុះ ដោយរងទុក្ខដល់ស្លាប់ដោយភ្លើង, **ម៉ូសាយ** ១៧:២០ ។ ពួកសាសន៍អាំម៉ូណៃហា ដែលបានប្រែចិត្តជឿ ត្រូវបានបោះចោលទៅក្នុងភ្លើង, **អាលម៉ា** ១៤:៨–១១ ។ មនុស្សជាច្រើនត្រូវគេប្រហារ ពីព្រោះគេបានធ្វើបន្ទាល់ចំពោះការណ៍ទាំងនេះ, ៣ **នីហ្វៃ** ១០:១៥ ។ អស់អ្នកណាដែលប្ដូរជីវិតរបស់ខ្លួន ដើម្បីគតិរបស់យើង នោះនឹងរកឃើញជីវិតដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ៩៨:១៣–១៤ ។ យ៉ូសែប ស្ម៊ីធ និង ហៃរុម ស្ម៊ីធ គឺជាទុក្ករបុគ្គលចំពោះការសាងឡើងវិញនៃដំណឹងល្អ, **គ. និង ស.** ១៣៥ ។ យ៉ូសែប ស្ម៊ីធបានបិទទីបន្ទាល់របស់លោក ដោយលោហិតរបស់លោក, **គ. និង ស.** ១៣៦:៣៩ ។

**ទុច្ចរិត, សេចក្ដីទុច្ចរិត** *សូមមើលផង* ពួកទមិលល្មើស, បរិសុទ្ធ; បាប; សេចក្ដីងងឹតខាងវិញ្ញាណ; សេចក្ដីស្មោកគ្រោក; ស្មោកគ្រោក, សេចក្ដីឥតសុចរិត, អំពើដ៏ឥត តសុចរិត

ជាការអាក្រក់ ការទុច្ចរិត; ដោយមិនគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

ធ្វើដូចម្ដេចឲ្យខ្ញុំប្រព្រឹត្តការ ដែលអាក្រក់យ៉ាងធំនេះទៅបាន ហើយធ្វើអំពើបាបទាស់នឹងព្រះ? **លោកុ.** ៣៩:៧–៩ ។ ព្រះអម្ចាស់ទ្រង់គង់នៅឆ្ងាយពីមនុស្សអាក្រក់ តែទ្រង់ស្ដាប់សេចក្ដីអធិស្ឋាន របស់មនុស្សសុចរិតវិញ, **សុភា.** ១៥:២៩ ។ កាលណាមនុស្សអាក្រក់គ្រប់គ្រង នោះបណ្ដាជនស្រែកថ្ងូរឡើង, **សុភា.** ២៩:២ (គ. និង ស. ៩៨:៩) ។ ចូរបណ្ដេញមនុស្សអាក្រក់នោះ ពីចំណោមពួកអ្នករាល់គ្នាចេញ, **១ កូរិន.** ៥:១៣ ។ ពួកយើងទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅស្ថានដ៏ខ្ពស់, **អេភេ.** ៦:១២ ។ ចូរអ្នករាល់គ្នាចេញពីពួកទុច្ចរិតមក ហើយចូរកុំប៉ះពាល់ដល់វត្ថុទាំងឡាយដែលឥតស្អាតរបស់ពួកនោះឡើយ, **អាលម៉ា** ៥:៥៦–៥៧ (គ. និង ស. ៣៨:៤២) ។ នេះគឺជាស្ថានភាពចុងក្រោយបំផុតនៃពួកទុច្ចរិត, **អាលម៉ា** ៣៤:៣៥ (អាលម៉ា ៤០:១៣–១៤) ។ សេចក្ដីទុច្ចរិតមិនដែលជាសុភមង្គលឡើយ, **អាលម៉ា** ៤១:១០ ។ ពួកទុច្ចរិតនឹងត្រូវធ្វើទោសដោយពួកទុច្ចរិត, **មរមន** ៤:៥ (គ. និង ស. ៦៣:៣៣) ។ នៅម៉ោងនោះ នឹងមានការបំបែកពួកសុចរិត និងពួកទុច្ចរិតពីគ្នាទាំងស្រុង, **គ. និង ស.** ៦៣:៥៤ ។ ទីបចុងបំផុត នៃពួកទុច្ចរិតមកដល់, **យ.ស. — ម៉ាថាយ** ១:៥៥ ។

**ទូកធំ** *សូមមើលផង* ទឹកជំនន់នៅសម័យណូអេ; ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប; ឥន្ទធនូ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាទូកដែលលោកណូអេបានធ្វើ ដើម្បីរក្សាជីវិតទុកនៅគ្រាទឹកជន់ធំ ។

ចូរអ្នកយកឈើម៉ៃសាក់ធ្វើជាទូក, **លោកុ.** ៦:១៤ ។ ទូកធំបានកឿងនៅលើភ្នំអារ៉ារ៉ាត, **លោកុ.** ៨:៤ ។ ភេគ្រោរបស់ពួកយ៉ារេឌ គឺជិតដូចទូកធំរបស់លោកណូអេ, **អេធើរ** ៦:៧ ។

**ទូន្មាន (កិ.)**

ដូចដែលប្រើនៅក្នុងគម្ពីរ ទូន្មានមានន័យថា ណែនាំ ឬក៏បង្គាប់ ។

យើងបានទូន្មានឲ្យអ្នកទិញមាសដែលសំរងក្នុងភ្លើង, **វិវ.** ៣:១៨ ។ ចូរកុំចង់ទូន្មានដល់ព្រះអម្ចាស់ឡើយ, **យ៉ាកុប** ៤:១០ ។ ទ្រង់ ឲ្យដំបូន្មាននៅក្នុងប្រាជ្ញា ទៅលើគ្រប់ទាំងកិច្ចការរបស់ទ្រង់, **អាលម៉ា** ៣៧:១២ ។ អំពើបាបទាំងឡាយរបស់អ្នកបានឡើងមកដល់ យើង ពីព្រោះអ្នកស្វែងរកដំបូន្មាន តាមអំពើចិត្តរបស់ខ្លួន, **គ. និង ស.** ៥៦:១៤ ។

**ទៀងត្រង់, ចិត្តទៀងត្រង់** *សូមមើលផង* សេចក្ដីស្មោះ

គឺមានចិត្តស្មោះ ពិតត្រង់ ហើយគ្មានចិត្តឆបោកឡើយ ។

ពួកអ្នកដែលប្រព្រឹត្តដោយពិតត្រង់ នោះជាទីគាប់ដល់ព្រះហឫទ័យរបស់ព្រះអម្ចាស់វិញ, **សុភា.** ១២:២២ ។ ចូរសងតាមដែលអ្នកបានបន់ចុះ, **សាស្ដា** ៥:៤–៥ ។ យើងខ្ញុំនេះចោលអស់ទាំងការលាក់កំបាំងនៃសេចក្ដីឥតទៀងត្រង់, **២ កូរិន.** ៤:១–២ ។ ចូរនិយាយដោយទៀងត្រង់, **១ ពេត្រុស** ២:១២ ។ វេទនាដល់ពួកដែលកុហក ព្រោះអ្នកនោះនឹងត្រូវបោះចោលទៅក្នុងស្ថាននរក, **២ នីហ្វៃ** ៩:៣៤ ។ ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលតែការពិត ហើយមិនកុហកឡើយ, **យ៉ាកុប** ៤:១៣ ។ អស់អ្នកណាដែលខ្ចីអ្វីពីអ្នកជិតខាង ត្រូវតែសងរបស់ដែលខ្លួនខ្ចីទៅវិញ, **ម៉ូសាយ** ៤:២៨ (គ. និង ស. ១៣៦:២៥) ។ ចូរមើលឲ្យឃើញថា អ្នកប្រព្រឹត្តដោយយុត្តិធម៌ វិនិច្ឆ័យដោយ សុចរិត ហើយធ្វើល្អចុះ, **អាលម៉ា** ៤១:១៤ ។ ចូរឲ្យមនុស្សគ្រប់រូបប្រព្រឹត្តដោយទៀងត្រង់, **គ. និង ស.** ៥១:៩ ។ មនុស្សទាំងអស់ណា ដែលដឹងថាខ្លួនមានចិត្តទៀងត្រង់ នោះពួកគេត្រូវបានទទួលដោយយើងហើយ, **គ. និង ស.** ៩៧:៨ ។ មនុស្សណាទៀងត្រង់ មនុស្សណាមានគំនិត

និងមនុស្សណាល្អ នោះគួរព្យាយាមស្វែងរក ដើម្បីកាន់តំណែងខាងនយោបាយ, **គ. និង ស.** ៩៨:៤–១០ ។ ចូរព្យាយាម រកអ្វីដែលអ្នកជិតខាងបានធ្វើបាត់ ដើម្បីប្រគល់ទៅវិញ, **គ. និង ស.** ១៣៦:២៨ ។ យើងខ្ញុំជឿលើការប្រព្រឹត្តដោយទៀងត្រង់, **ម. នៃ ស.** ១:១៣ ។

**ទោស** *សូមមើលផង* ការប្រែចិត្ត, ប្រែចិត្ត

ជាស្ថានភាពអំពីការធ្វើអ្វីខុស ឬក៏ចិត្តសោកស្តាយ ដែលគួរមានចំពោះអំពើបាប ។

គាត់បានធ្វើបាប ហើយមានទោស, **លេវី** ៦:១–៦ ។ អស់អ្នកណាដែលនឹងទទួលទានបុណ្យរំឭកដោយមិនត្រឹមត្រូវ នោះគឺមានទោសចំពោះរូបកាយ និងលោហិតនៃព្រះយេស៊ូវ, **១ កូរិន.** ១១:២៧ ។ អ្នកណាដែលមានទោស រាប់សេចក្តីពិតទុកជាការពិបាក, **១ នីហ្វៃ** ១៦:២ ។ យើងនឹងមានការចេះដឹងដ៏ឥតខ្ចោះអំពីអស់ទាំងកំហុសរបស់យើង, **២ នីហ្វៃ** ៩:១៤ ។ ទោសរបស់ខ្ញុំបានបំបាត់ចោលទៅ, **អេណុស** ១:៦ ។ មានទោសដែលបានភ្ជាប់ទុក ដែលបាននាំមកនូវការសោកស្តាយក្នុងស្មារតី, **អាលម៉ា** ៤២:១៨ ។ ចូរទុកឲ្យអំពើបាបរបស់កូន បារម្ភដល់កូនចុះ៖ គឺការបារម្ភនោះហើយ ដែលអាចញាំងឲ្យកូនប្រែចិត្ត, **អាលម៉ា** ៤២:២៩ ។ អ្នកខ្លះក្នុងចំណោមអ្នក រាល់គ្នាមាន ទោសនៅចំពោះយើង ប៉ុន្តែយើងនឹងមានចិត្តអាណិតអាសូរ, **គ. និង ស.** ៣៨:១៤ ។ ព្រះរាជបុត្រានៃព្រះ បានធ្វើឲ្យធួន នឹងទោសដើម, **ម៉ូសេ** ៦:៥៤ ។

**ទំនុកដំកើង** *សូមមើលផង* ដាវីឌ; ភ្លេង

ជាពាក្យកំណាព្យ ឬទំនុកសរសើរដំកើងដែលបានបំផុសគំនិត ។

*គម្ពីរទំនុកដំកើង៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមាននូវការប្រជុំនៃទំនុកដំកើង ឯទំនុកទាំងនោះជាច្រើន គឺអំពីព្រះគ្រីស្ទ ។ គម្ពីរទំនុកដំកើង ត្រូវបានស្រង់ជាញឹកញាប់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

ហ្លួងដាវីឌបានសរសេរភាគច្រើននៃទំនុកដំកើង ។ ទំនុកដំកើង គឺបានសរសេរទុកជាការសរសើរដំកើងព្រះ ។ ទំនុកជាច្រើនត្រូវបានចងក្រងជាចំរៀង ។

**ទំនុកសរសើរដំកើង***សូមមើលផង* ច្រៀង, ភ្លេង

ជាចំរៀងសរសើរដល់ព្រះ ។

ពួកសាវក ១២ នាក់បានច្រៀងទំនុកមួយ មុនព្រះអម្ចាស់យាងទៅសួនច្បារគែតសេម៉ានី, **ម៉ាថាយ** ២៦:៣០ ។ ព្រះអម្ចាស់ទ្រង់បាន ហៅ អិមម៉ា ស៊្មិធ ឲ្យធ្វើការជ្រើសរើសយកទំនុកសរសើរដំកើងព្រះដ៏ពិសិដ្ឋទាំងឡាយ, **គ. និង ស.** ២៥:១១ ។ បទចំរៀងនៃពួកសុចរិត គឺជាបទអធិស្ឋានដល់យើង ហើយនឹងបានឆ្លើយតប ដោយនូវព្រះពរ មកលើក្បាលរបស់ពួកគេ, **គ. និង ស.** ២៥:១២ ។ ចូរសរសើរដំកើងដល់ព្រះអម្ចាស់ ដោយការច្រៀង ដោយការលេងភ្លេង, **គ. និង ស.** ១៣៦:២៨ ។

**ទ្រព្យសម្បត្តិ***សូមមើលផង* ប្រាក់; សេចក្តីឆ្មើងឆ្មៃ

ជាទ្រព្យ ឬរបស់របរដែលមានបរិបូរ ។ ព្រះអម្ចាស់ទ្រង់ទូន្មានកុំឲ្យពួកបរិសុទ្ធស្វែងរកទ្រព្យសម្បត្តិខាងលោកិយ លើកលែងតែ ដើម្បីធ្វើអំពើល្អ ។ ពួកបរិសុទ្ធមិនត្រូវស្វែងរកទ្រព្យសម្បត្តិខាងលោកិយ មុននឹងស្វែងរកនគរព្រះ ដែលកាន់នូវទ្រព្យសម្បត្តិទាំង ឡាយនៃភាពដ៏នៅអស់កល្បជានិច្ច (យ៉ាកុប ២:១៨–១៩) ។

បើកាលណាមានទ្រព្យសម្បត្តិចំរើនឡើង នោះកុំឲ្យទុកចិត្តនឹងរបស់ទាំងនោះឲ្យសោះ, **ទំនុក.** ៦២:១០ ។ ទ្រព្យសម្បត្តិគ្មាន ប្រយោជន៍ក្នុងថ្ងៃពិរោធឡើយ, **សុភា.** ១១:៤ ។ អ្នកណាដែលពឹងចំពោះទ្រព្យសម្បត្តិខ្លួន នោះនឹងត្រូវដួលចុះ, **សុភា.** ១១:២៨ ។ នាមឈ្មោះល្អ នោះគួររើសយក ជាជាងទ្រព្យសម្បត្តិយ៉ាងច្រើន, **សុភា.** ២២:១ ។ មនុស្សអ្នកមានចូលទៅក្នុងនគរព្រះ នោះពិបាកណាស់, **ម៉ាកុស** ១០:២៣ (លូកា ១៨:២៤–២៥) ។ ការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង, **១ ធីម៉ូ.** ៦:១០ ។ ទេវនាដល់អ្នកមាន ដែលមើលងាយដល់មនុស្សក្រីក្រ ហើយទ្រព្យសម្បត្តិរបស់គេ គឺជាព្រះរបស់គេ, **២ នីហ្វៃ** ៩:៣០ ។ ពួកមនុស្សសុចរិតមិនបានដាក់ចិត្តទៅលើទ្រព្យសម្បត្តិទេ តែបានចែកដល់គ្រប់ទាំងមនុស្ស, **អាលម៉ា** ១:៣០ ។ ប្រជាជនបានចាប់ផ្តើម វាយឫកក្រអឺត ដោយសារទ្រព្យសម្បត្តិ, **អាលម៉ា** ៤:៦–៨ ។ ប្រជជនបានញែកចេញតាមឋានៈ គឺតាមទ្រព្យសម្បិត្តរបស់គេ, ៣ នីហ្វៃ ៦:១២ ។ ចូរកុំស្វែងរកទ្រព្យសម្បត្តិឡើយ ប៉ុន្តែរកប្រាជ្ញាវិញ, **គ. និង ស.** ៦:៧ (អាលម៉ា ៣៩:១៤; គ. និង ស. ១១:៧) ។ ទ្រព្យ សម្បត្តិទាំងឡាយនៃផែនដី គឺជារបស់ផងព្រះ ទុកសំរាប់ប្រទានឲ្យ; ប៉ុន្តែចូរប្រយ័ត្នពីសេចក្តីឆ្មើងឆ្មៃ, **គ. និង ស.** ៣៨:៣៩ ។

*ទ្រព្យសម្បត្តិនៃភាពអស់កល្បជានិច្ច៖* ចូរប្រមូលទ្រព្យសម្បត្តិទុកនៅឯស្ថានសួគ៌, **ម៉ាថាយ** ៦:១៩–២១ ។ គេប៉ុន្មានដងហើយដែលយើង បានហៅអ្នក ដោយទ្រព្យសម្បត្តិខាងជីវិតដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ៤៣:២៥ ។ ទ្រព្យសម្បត្តិទាំងឡាយនៃភាព អស់កល្បជានិច្ច គឺជារបស់ផងយើង ទុកសំរាប់ប្រទានឲ្យ, **គ. និង ស.** ៦៧:២ (គ. និង ស. ៧៨:១៨) ។

**ធីម៉ូថេ, សំបុត្រដល់** *សូមមើលផង* ធីម៉ូថេ, ប៉ុល;
សំបុត្ររបស់ប៉ុល

ជាគម្ពីរពីរក្បាលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ពីប្រភពដើម គម្ពីរទាំងពីរនេះ គឺជាសំបុត្រដែលប៉ុលបានសរសេរទៅធីម៉ូថេ ។

*ធីម៉ូថេទី ១៖* ប៉ុលបានសរសេរសំបុត្រទីមួយ បន្ទាប់ពីលោកត្រូវជាប់គុកមុនដំបូង ។ លោកបានទុកឲ្យធីម៉ូថេ នៅស្រុកអេភេសូរ ដោយគិតថានឹងវិលមកវិញ (១ ធីម៉ូ. ៣:១៤) ។ ប៉ុន្តែប៉ុលគិតថាលោកត្រូវបង្អង់នៅ ម្លេះហើយ ទើបលោកសរសេរសំបុត្រទៅ ធីម៉ូថេ មើលទៅប្រហែលជាបានសរសេរចេញពីស្រុកម៉ាសេដូន (១ ធីម៉ូ. ១:៣) ដើម្បីឲ្យសេចក្តីទូន្មាន និងសេចក្តីលើកទឹកចិត្ត ដើម្បីបំពេញកិច្ចការរបស់លោក ។

ជំពូកទី ១ ជាការសួរសុខទុក្ខ មកពីប៉ុល និងការបង្រៀនរបស់លោក អំពីការស្កប់ស្កល់ដ៏ឥតប្រយោជន៍ ដែលឃើញមាននៅក្នុង សាសនាចក្រ ។ ជំពូកទី ២–៣ ប្រាប់ពីរបៀបថ្វាយបង្គំរបស់បណ្ដាជន និងពីលក្ខណៈ និងចរិតនៃពួកអ្នកបង្រៀន ។ ជំពូកទី ៤–៥ មាននូវការអធិប្បាយប្រាប់ អំពីសេចក្ដីក្បត់សាសនា នៅថ្ងៃចុងក្រោយ និងសេចក្ដីទូន្មានដល់ធីម៉ូថេនូវរបៀបរៀបចំដល់អ្នកដែលលោក ដឹកនាំ ។ ជំពូកទី ៦ ជាសេចក្ដីដាស់តឿន ឲ្យឃើញថាស្មោះត្រង់ ហើយឲ្យចៀសវាងពីទ្រព្យសម្បត្តិខាងលោកិយ ។

ធី*ម៉ូថេទី ២៖* ប៉ុលបានសរសេរសំបុត្រទីពីរ កាលលោកជាប់គុកលើកទីពីរ គឺមុនពីទុក្ករកម្មលោកបន្តិច ។ គម្ពីរនេះមាននូវពាក្យចុងក្រោយបង្អស់របស់ប៉ុល ហើយបង្ហាញនូវសេចក្ដីក្លាហានដ៏អស្ចារ្យ និងសេចក្ដីទុកចិត្ត ដែលលោកមាន កាលលោកប្រឈមមុខនឹងសេចក្ដីស្លាប់ ។

ជំពូកទី ១ មាននូវការសួរសុខទុក្ខពីប៉ុល និងបន្ទុកដល់ធីម៉ូថេ ។ ជំពូកទី ២–៣ ប្រាប់នូវការព្រមាន និងការដឹកនាំទាំងឡាយ ព្រមទាំងការប្រឹងប្រែង ឲ្យតស៊ូនឹងគ្រោះថ្នាក់ខាងមុខ ។ ជំពូកទី ៤ ជាបណ្ដាំដល់មិត្តទាំងឡាយរបស់ប៉ុល គឺមាននូវពាក្យណែនាំឲ្យធ្វើដូចម្ដេចចំពោះអ្នកក្បត់សាសនា ។

**ធីម៉ូថេ** *សូមមើលផង* ប៉ុល

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាអ្នកកំឡោះគូកនផ្សាយសាសនារបស់ប៉ុល កាលប៉ុលធ្វើការងារបំរើ (កិច្ចការ ១៦:១–៣; ២ ធីម៉ូ. ១:១–៥) ។ ឪពុកលោកជាសាសន៍ក្រេក រីឯម្ដាយលោកជាសាសន៍យូដា; លោក និងឪពុកម្ដាយលោក បានរស់នៅស្រុកលីស្រ្ដា ។

ប៉ុលបាននិយាយអំពីធីម៉ូថេ ថាជា « កូនពិតក្នុងសេចក្ដីជំនឿ » របស់លោក (១ ធីម៉ូ. ១:២, ១៨; ២ ធីម៉ូ. ១:២) ។ មើលទៅធីម៉ូថេប្រហែលជាអ្នកជំនួយដ៏គួរទុកចិត្ត និងចំណានម្នាក់របស់ប៉ុល (ភីលិព ២:១៩–២៣) ។

**ធ្វើការងារបំរើ, អ្នកធ្វើការងារបំរើ** *សូមមើលផង* ការបំរើ, បព្វជិតភាព

ដើម្បីធ្វើកិច្ចការនៃព្រះអម្ចាស់នៅលើផែនដី ។ ពួកអ្នកបំរើដ៏ជំរើសរបស់ព្រះ ត្រូវបានហៅអំពីព្រះ ដើម្បីឲ្យធ្វើការងារបំរើនូវកិច្ចការរបស់ទ្រង់ ។ កាលណាពួកអ្នកធ្វើការងារបំរើដ៏ពិតធ្វើតាមព្រះហឫទ័យនៃព្រះអម្ចាស់ នោះគេធ្វើជាតំណាងព្រះអម្ចាស់ ក្នុងការងារ ដ៏សំខាន់ ហើយធ្វើជាភ្នាក់ងារទាំងឡាយរបស់ទ្រង់ (គ. និង ស. ៦៤:២៩), ហេតុដូច្នោះហើយ ការធ្វើការងារបំរើនូវកិច្ចការដ៏ចាំបាច់ សំរាប់សេចក្ដីសង្គ្រោះដល់មនុស្សលោក ។ ព្រះអម្ចាស់ទ្រង់បានប្រទានដល់ពួកសាវក, ពួកព្យាការី, ពួកអ្នកផ្សាយដំណឹងល្អ, ពួកសង្ឃ ជាន់ខ្ពស់, ពួក ៧០ នាក់, ពួកអែលឌើរ, ពួកប៊ីស្សព, ពួកសង្ឃ, ពួកគ្រូ, ពួកឌីកុន, នូវជំនួយ និងការគ្រប់គ្រង សំរាប់ការធ្វើឲ្យពួក បរិសុទ្ធបានល្អឥតខ្ចោះ និងសំរាប់កិច្ចការខាងការងារបំរើ (អេភេ. ៤:១១–១៦; ១ កូរិន. ១២:១២–២៨; គ. និង ស. ២០; ១០៧) ។

ព្រះអម្ចាស់ ទ្រង់បានរើសលោកឲ្យឈរធ្វើការងារ នៅក្នុងព្រះនាមនៃព្រះអម្ចាស់, **ចោទិ.** ១៨:៥ ។ មនុស្សទាំងឡាយនឹងហៅឯង រាល់គ្នាជាអ្នកគោរពដល់ព្រះនៃយើងរាល់គ្នា, **អេសាយ** ៦១:៦ ។ កូនមនុស្សបានមក មិនមែនឲ្យគេបំរើលោកទេ គឺនឹងបំរើគេវិញ, **ម៉ាថាយ** ២០:២៦–២៨ ។ ខ្ញុំបានលេចមក ដើម្បីនឹងតាំងអ្នក ឲ្យធ្វើជាអ្នកបំរើ ហើយជាទីបន្ទាល់, **កិច្ចការ** ២៦:១៦–១៨ ។ ព្រះទ្រង់ មិនមែនជាអ្នករមិលគុណ ដែលទ្រង់នឹងភ្លេចការងារនៃសេចក្ដីស្រឡាញ់ ដែលអ្នករាល់គ្នាបានសម្ដែងដល់ពួកបរិសុទ្ធ, **ហេព្រើរ** ៦:១០ ។ បើអ្នកណាបំរើ នោះត្រូវបំរើដោយកម្លាំងដែលព្រះប្រទានឲ្យ, **១ ពេត្រុស** ៤:១០–១១ ។ គេបានបង្រៀន ហើយបានធ្វើការងារ បំរើគ្នាទៅវិញទៅមក, ៣ នីហ្វៃ ២៦:១៩ ។ គឺជាភារកិច្ចរបស់ពួក១២នាក់ ឲ្យតែងតាំងពួកអ្នកធ្វើការងារបំរើខាងការផ្សាយដំណឹងល្អ, **គ. និង ស.** ១០៧:៣៩–៤០ ។ សង្ឃជាន់ខ្ពស់ម្នាក់អាចបានញែកចេញ ចំពោះការងារបំរើខាងការណ៍ទាំងឡាយនៃសាច់ឈាម, **គ. និង ស.** ១០៧:៧១–៧២ ។ ពួក៧០នាក់ត្រូវធ្វើជាអ្នកធ្វើការងារបំរើដែលធ្វើដំណើរ, **គ. និង ស.** ១០៧:៩៣–៩៧ ។ ពួកអែលឌើរត្រូវបានតែងតាំងឡើង ឲ្យធ្វើជាពួកអ្នកធ្វើការងារបំរើ ដែលនៅប្រចាំអចិន្ត្រៃយ៍ ចំពោះសាសនាចក្ររបស់យើង, **គ. និង ស.** ១២៤:១៣៧ ។

**ធ្វើតាម** *សូមមើល* ការគោរពតាម, គោរពតាម, ដែលគោរពតាម

**ធ្វើបន្ទាល់** *សូមមើលផង* ទីបន្ទាល់

ធ្វើសាក្សីដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ; ធ្វើសេចក្ដីថ្លែងដោយម៉ឺងម៉ាត់ពីសេចក្ដីពិត ដោយសំអាងទៅលើជំរិះ ឬជំនឿរបស់ខ្លួនផ្ទាល់ ។

ព្រះដ៏ជាជំនួយ ទ្រង់នឹងធ្វើបន្ទាល់ពីខ្ញុំ, **យ៉ូហាន** ១៥:២៦ ។ ទ្រង់បានផ្ដាំឲ្យយើងរាល់គ្នាប្រកាស និងធ្វើបន្ទាល់, **កិច្ចការ** ១០:៤២ ។ ពួកសាក្សីបីនាក់នឹងធ្វើបន្ទាល់អំពីសេចក្ដីពិត, **២ នីហ្វៃ** ២៧:១២ ។ ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនឹងនាំពាក្យទាំងនោះចូលទៅក្នុងចិត្តនៃកូនចៅមនុស្ស, **២ នីហ្វៃ** ៣៣:១ ។ បទព្រះគម្ពីរធ្វើបន្ទាល់អំពីព្រះគ្រីស្ទ, **យ៉ាកុប** ៧:១០–១១ (យ៉ូហាន ៥:៣៩) ។ ខ្ញុំសូមធ្វើបន្ទាល់ដល់អ្នករាល់គ្នាថា ខ្ញុំដឹងនូវរឿងដែលខ្ញុំបាននិយាយទាំងអម្បាលម៉ាននេះ ថាជារឿងពិត, **អាលម៉ា** ៥:៤៥ (អាលម៉ា ៣៤:៨) ។ អ្នករាល់គ្នាត្រូវធ្វើបន្ទាល់អំពីរបស់ទាំងនោះ ដោយព្រះចេស្ដានៃព្រះ, **គ. និង ស.** ១៧:៣–៥ ។ អ្វីដែលព្រះវិញ្ញាណធ្វើបន្ទាល់ដល់អ្នករាល់គ្នា នោះអ្នករាល់គ្នាគប្បីធ្វើដូច្នោះ, **គ. និង ស.** ៤៦:៧ ។ យើងចាត់ឲ្យអ្នកទៅធ្វើបន្ទាល់ ហើយព្រមាន, **គ. និង ស.** ៨៨:៨១ ។

**ធ្វើឲ្យធួន, ដង្វាយធួន** *សូមមើលផង* ការឆ្កាង; ការញែកចេញជាបរិសុទ្ធ; ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា, ការប្រែចិត្ត; ការផ្ដាច់បាប; ការរាប់ជាសុចរិត, កូនចៅព្រះគ្រីស្ទ; គែតសេម៉ានី; ដំណើររស់ឡើងវិញ;

ឈើឆ្កាង; បានប្រោសលោះ, បុណ្យរំលងរំលង; បុត្រាបុត្រីនៃព្រះ, បូជា, ប្រែចិត្ត, ប្រោសលោះ, ផែនការនៃសេចក្ដីប្រោសលោះ; ព្រះគុណ; ព្រះយេស៊ូវគ្រីស្ទ; មានចិត្តមេត្តាករុណា, យញ្ញបូជា; រាប់ជាសុចរិត; លោហិត; សេចក្ដីប្រោសលោះ; សេចក្ដីមេត្តាករុណា; សេចក្ដីសង្គ្រោះ; អមតៈ, អមតភាព; អត់ទោស

ដើម្បីធ្វើឲ្យមនុស្សបានធួននឹងព្រះ ។

គឺដូចដែលបានប្រើក្នុងគម្ពីរ ដើម្បីធ្វើឲ្យធួន គឺដើម្បីរងទណ្ឌកម្មចំពោះអំពើបាបណាមួយ ដើម្បីដោះបាបចេញពីអ្នកមានបាបណា ដែល បានប្រែចិត្ត ហើយអនុញ្ញាតឲ្យគេបានធួននឹងព្រះ ។ ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះតែមួយអង្គដែលមានសមត្ថភាពនឹងថ្វាយដង្វាយធួនដ៏ល្អ ឥតខ្ចោះជំនួសមនុស្សគ្រប់រូប ។ ទ្រង់អាចធ្វើដូច្នោះបាន ដោយសារការជ្រើសរើស និងការតែងតាំងទុកជាមុនរបស់ព្រះអង្គ នៅក្នុងមហាក្រុមប្រឹក្សា មុនកំណើតលោកិយម្ល៉េះ (អេធើរ ៣:១៤; ម៉ូសេ ៤:១–២; អ័ប្រា. ៣:២៧), ដោយសារបុត្រភាពជាព្រះ និងព្រះជន្មរបស់ទ្រង់ដ៏ប្រកបដោយគ្មានបាប ។ ដង្វាយធួនរបស់ទ្រង់មានរួមនូវការរងទុក្ខ ជំនួសអំពើបាបនៃមនុស្សលោក នៅក្នុងសួនច្បារ គែតសេម៉ានី ការច្រួចព្រះលោហិតរបស់ទ្រង់ និងការសុគតរបស់ទ្រង់ និងដំណើរដែលទ្រង់មានព្រះជន្មរស់ឡើងពីផ្នូរមកវិញ បន្តបន្ទាប់ មក (អេសាយ ៥៣:៣–១២; ម៉ូសាយ ៣:៥–១១; អាលម៉ា ៧:១០–១៣) ។ ពីព្រោះតែដង្វាយធួន ទើបមនុស្សគ្រប់រូបនឹងបានរស់ពី ស្លាប់ឡើងវិញដោយមានរូបកាយអមតៈ (១ កូរិន. ១៥:២២) ។ ដង្វាយធួនក៏ផ្ដល់ដល់យើងនូវផ្លូវមួយ សំរាប់ឲ្យយើងអាចបានអត់ ទោសចំពោះអំពើបាបរបស់យើង ហើយអាចបានរស់នៅជាមួយនឹងព្រះជារៀងដរាប ។ ប៉ុន្តែមនុស្សគ្រប់រូប ដែលដល់អាយុចេះទទួល ការខុសត្រូវ ហើយបានទទួលក្រិត្យវិន័យ នោះគេអាចបានព្រះពរទាំងនេះបានបើសិនជាគេមានសេចក្ដីជំនឿដល់ព្រះយេស៊ូវគ្រីស្ទ ប្រែចិត្តពីអំពើបាបទទួលពិធីបរិសុទ្ធខាងសេចក្ដីសង្គ្រោះ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះប៉ុណ្ណោះ ។ អស់អ្នកណាដែល មិនទាន់ដល់អាយុចេះទទួលការខុសត្រូវ និងអស់អ្នកណាដែលគ្មានក្រិត្យវិន័យទេ នោះគេនឹងបានសង្គ្រោះ ដោយសារដង្វាយធួន (ម៉ូសាយ ១៥:២៤–២៥; ម៉ូរ៉ូណៃ ៨:២២) ។ គម្ពីរបានបង្រៀនយ៉ាងច្បាស់លាស់ថា បើសិនជាព្រះគ្រីស្ទពុំបានធ្វើឲ្យធួននឹងបាបយើងទេ នោះគ្មានក្រិត្យវិន័យពិធីបរិសុទ្ធ ឬយញ្ញបូជាណាអាចធ្វើឲ្យស្កប់ស្កល់នឹងការទាមទារនៃសេចក្ដីយុត្តិធម៌បានឡើយ ហើយមនុស្សលោក ក៏នឹងពុំអាចវិលទៅឯវត្តមាននៃព្រះបានដែរ (២ នីហ្វៃ ២:៩) ។

នេះជាឈាមខ្ញុំ ដែលបានច្រួចចេញ សំរាប់មនុស្សជាច្រើន ប្រយោជន៍នឹងផ្ដាច់បាប, **ម៉ាថាយ** ២៦:២៨ ។ ញើសទ្រង់ក៏ត្រឡប់ដូចជាដំណក់ឈាមដ៏ធំៗ, **លូកា** ២២:៣៩–៤៤ ។ ខ្ញុំនឹងឲ្យសាច់ខ្ញុំជំនួសជីវិតមនុស្សលោក, **យ៉ូហាន** ៦:៥១ ។ ខ្ញុំជាសេចក្ដីរស់ឡើងវិញហើយជាជីវិត, **យ៉ូហាន** ១១:២៥ ។ ព្រះគ្រីស្ទជាមេបង្កើតនៃសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច ដល់អស់អ្នកណាដែលស្ដាប់បង្គាប់ទ្រង់, **ហេព្រើរ** ៥:៩ ។ ពួកយើងត្រូវបានញែកចេញជាបរិសុទ្ធ ដោយសារការច្រួចព្រះលោហិតនៃព្រះគ្រីស្ទ, **ហេព្រើរ** ៩; ១០:១–១០ ។ ព្រះគ្រីស្ទទ្រង់បានរងទុក្ខម្ដង ដោយព្រោះបាបដែរ, **១ ពេត្រុស** ៣:១៨ ។ ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទសំអាតយើងរាល់គ្នា ពីគ្រប់ អំពើបាបទាំងអស់, **១ យ៉ូហាន** ១:៧ ។ ទ្រង់ត្រូវគេលើកឡើងលើឈើឆ្កាង ហើយធ្វើគតជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក, **១ នីហ្វៃ** ១១:៣២–៣៣ ។ សេចក្ដីប្រោសលោះនឹងមកដល់អស់អ្នកណាដែលមានចិត្តសង្រេង និងវិញ្ញាណទន់ទាប, **២ នីហ្វៃ** ២:៣–១០, ២៥–២៧ ។ ទ្រង់បានថ្វាយរូបអង្គទ្រង់ជាយញ្ញបូជាជំនួសអំពើបាប, **២ នីហ្វៃ** ២:៧ ។ ដង្វាយធួនលោះមនុស្សលោកពីសេចក្ដីធ្លាក់ ហើយជួយសង្គ្រោះគេពីសេចក្ដីស្លាប់ និងពីស្ថាននរក, **២ នីហ្វៃ** ៩:៥–២៤ ។ ត្រូវតែមានដង្វាយធួនដ៏និរន្តរ៍មួយ, **២ នីហ្វៃ** ៩:៧ ។ ចូរស្រុះស្រួលនឹងព្រះ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ, **យ៉ាកុប** ៤:១១ ។ លោហិតរបស់ព្រះអង្គ ក៏នឹងធ្វើឲ្យធួននឹងបាបនៃជនណាដែល បានធ្វើបាបដោយសារល្ងង់ខ្លៅ, **ម៉ូសាយ** ៣:១១:១៨ ។ មនុស្សលោកបានទទួលសេចក្ដីសង្គ្រោះ ដោយសារដង្វាយធួន, **ម៉ូសាយ** ៤:៦–៨ ។ បើគ្មានដង្វាយធួនទេ នោះពួកគេនឹងចៀសពុំផុតពីសេចក្ដីវិនាសបានឡើយ, **ម៉ូសាយ** ១៣:២៧–៣២ ។ ទ្រង់នឹងធ្វើឲ្យធួន នឹងអំពើបាបទាំងឡាយនៃពិភពលោក, **អាលម៉ា** ៣៤:៨–១៦ ។ ព្រះអង្គទ្រង់ផ្ទាល់ បានធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃពិភពលោក ដើម្បីនាំមកនូវផែនការនៃសេចក្ដីយុត្តិធម៌, **អាលម៉ា** ៤២:១១–៣០ ។ យើងជាព្រះនៃផែនដីទាំងមូល ហើយត្រូវគេធ្វើគត ជំនួសអំពើ បាបទាំងឡាយនៃពិភពលោក, ៣ នីហ្វៃ ១១:១៤ ។ យើងជាព្រះ បានរងទុក្ខនូវការណ៍ទាំងនេះ ជំនួសមនុស្សទាំងអស់, **គ. និង ស.** ១៩:១៦ ។ កូនក្មេងតូចៗត្រូវបានប្រោសលោះ តាមរយៈបុត្រាបង្កើតតែមួយរបស់យើង, **គ. និង ស.** ២៩:៤៦–៤៧ ។ សូមទតមើល ការរងទុក្ខទាំងឡាយ និងការសុគតរបស់អ្នក ដែលពុំបានធ្វើបាបឡើយ, **គ. និង ស.** ៤៥:៣–៥ ។ ការណ៍នេះ គឺជានិមិត្តរូបអំពីការ បូជានៃព្រះរាជបុត្រាបង្កើតតែមួយ, **ម៉ូសេ** ៥:៧ ។ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះ, **ម. នៃ ស.** ១:៣ ។

**នគរព្រះ ឬនគរស្ថានសួគ៌** *សូមមើលផង*

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ, សិរីល្អនៃសេឡេស្ទាល

នគរព្រះនៅលើផែនដី គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ (គ. និង ស. ៦៥) ។ គោលបំណងនៃសាសនាចក្រ គឺដើម្បីរៀបចំសមាជិកឲ្យរស់នៅរៀងដរាបតទៅ នៅក្នុងនគរសេឡេស្ទាល ឬនគរស្ថានសួគ៌ ។ ប៉ុន្តែ ជួនកាលគម្ពីរហៅសាសនាចក្រថា ជានគរស្ថានសួគ៌ ដោយឲ្យន័យថាសាសនាចក្រជានគរស្ថានសួគ៌នៅលើផែនដី ។

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជានគរព្រះនៅលើផែនដី ប៉ុន្តែបច្ចុប្បន្ននេះ គឺគ្រាន់តែនគរខាងសាសនាប៉ុណ្ណោះ ។ នៅសហស្សវត្សរ៍ នោះនគរព្រះនឹងទៅជានគរទាំងខាងនយោបាយ និងខាងសាសនាផង ។

ព្រះអម្ចាស់ទ្រង់ជាមហាក្សត្រដ៏គង់នៅអស់កល្បជានិច្ច, **ទំនុក.** ១០:១៦ (ទំនុក. ១១:៤) ។ ព្រះនៃស្ថានសួគ៌ ទ្រង់នឹងតាំងនគរមួយឡើង ដែលមិនត្រូវបំផ្លាញឡើយ, **ដានី.** ២:៤៤ (គ. និង ស. ១៣៨:៤៤) ។ ចូរប្រែចិត្តឡើង ត្បិតនគរស្ថានសួគ៌ជិតដល់ហើយ, **ម៉ាថាយ** ៣:២ (ម៉ាថាយ ៤:១៧) ។ សូមឲ្យរាជ្យទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី, **ម៉ាថាយ** ៦:១០ ។ ចូរស្វែងរកនគរព្រះជាមុនសិន, **ម៉ាថាយ** ៦:៣៣ (៣ នីហ្វៃ ១៣:៣៣) ។ ខ្ញុំនឹងឲ្យកូនសោនៃនគរដល់អ្នក, **ម៉ាថាយ** ១៦:១៩ ។ ចូរមកទទួលមរតកចុះ គឺជានគរដែលបានរៀបចំទុកសំរាប់អ្នករាល់គ្នា, **ម៉ាថាយ** ២៥:៣៤ ។ កាលខ្ញុំនឹងទទួលទានសាក្រម៉ង់ជាមួយនឹងអ្នករាល់គ្នានៅក្នុងនគរព្រះវរបិតានៃខ្ញុំ, **ម៉ាថាយ** ២៦:២៦–២៩ ។ អ្នករាល់គ្នានឹងឃើញអស់ទាំងព្យាការីនៅក្នុងនគរព្រះ, **លូកា** ១៣:២៨ ។ ពួកមនុស្សទុច្ចរិតមិនដែលបានគ្រងនគរព្រះទុកជាមរតកឡើយ, **១ កូរិន.** ៦:៩ ។ សាច់ឈាមពុំអាចនឹងគ្រងនគរព្រះជាមរតកបានឡើយ, **១ កូរិន.** ១៥:៥០ ។ មុននឹងអ្នកស្វែងរកទ្រព្យសម្បត្តិ ចូរអ្នកស្វែងរកនគរនៃព្រះសិន, **យ៉ាកុប** ២:១៨ ។ គ្មានអ្វីដែលមិនស្អាតអាច គ្រងនគរស្ថានសួគ៌ទុកជាមរតកបានឡើយ, **អាលម៉ា** ១១:៣៧ ។ អ្នកអាចសំរាកជាមួយពួកគេ នៅក្នុងនគរនៃព្រះវរបិតារបស់យើង, **គ. និង ស.** ១៥:៦ ។ ចំពោះអ្នកនោះនគរ ឬកូនសោទាំងឡាយនៃសាសនាចក្រត្រូវបានប្រទានឲ្យហើយ, **គ. និង ស.** ៤២:៦៩ (គ. និង ស. ៦៥:២) ។ សូមឲ្យនគរព្រះបានចេញទៅ ប្រយោជន៍ឲ្យនគរស្ថានសួគ៌អាចបានមកដល់, **គ. និង ស.** ៦៥:៥–៦ ។ កូនសោទាំង ឡាយនៃនគរនេះ នឹងមិនត្រូវដកចេញពីអ្នកឡើយ, **គ. និង ស.** ៩០:៣ ។ អ្នកណាដែលទទួលអ្នក ដូចជាកូនក្មេងមួយ នោះឈ្មោះថា បានទទួលនគររបស់យើងហើយ, **គ. និង ស.** ៩៩:៣ ។ សាសនាចក្ររបស់យើងនឹងត្រូវបានហៅថាដូច្នោះហើយ នៅថ្ងៃចុងក្រោយ បង្អស់ គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.** ១១៥:៤ ។ ផ្ទៃមេឃបានបើក ហើយខ្ញុំបានឃើញ នគរសេឡេស្ទាលនៃព្រះ, **គ. និង ស.** ១៣៧:១–៤ ។

**នាងដេបូរ៉ា**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាព្យាការីស្រីម្នាក់ ដែលបានវិនិច្ឆ័យសាសន៍អ៊ីស្រាអែល ហើយឲ្យបារ៉ាកទៅទាស់នឹងពួកសាសន៍ កាណាន (ចៅហ្វាយ ៤) ។ ចំរៀងរបស់នាងដេបូរ៉ា និងបារ៉ាកច្រៀងសរសើរនូវការរំដោះរបស់ពួកអ៊ីស្រាអែលចេញពីការជាប់ សេវកភាព (ចៅហ្វាយ ៥) ។

**នាងដេលីឡា** *សូមមើលផង* ភីលីស្ទីន

ជាស្ត្រីសាសន៍ភីលីស្ទីនម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានបញ្ឆោត ហើយក្បត់សាំសុន (ចៅហ្វាយ ១៦) ។

**នាងន៉ាអូមី** *សូមមើលផង* នាងរស់

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាស្ត្រីដ៏សុចរិតម្នាក់ ហើយជាប្រពន្ធរបស់អេលីម៉ាលេច (នាងរស់ ១–៤) ។ អេលីម៉ាលេច និងនាងន៉ាអូមីបាននាំគ្រួសារគេ ទៅស្រុកម៉ូអាប់ ដើម្បីឲ្យបានរួចផុតពីការអំណត់អត់ ។ បន្ទាប់ពីអេលីម៉ាលេច និងកូនប្រុសពីរនាក់របស់នាងស្លាប់ទៅ នោះនាងន៉ាអូមីបានវិលទៅភូមិបេថ្លេហិមវិញ ជាមួយនឹងនាងរស់ ជាកូនប្រសា ។

**នាងព្រហ្មចារីម៉ារា** *សូមមើល* នាងម៉ារា, មាតារបស់ព្រះយេស៊ូវ

**នាងម៉ាថា** *សូមមើលផង* នាងម៉ារា, ពីភូមិបេថានី, ឡាសារ

ជាបងស្រីរបស់ឡាសារ និងនាងម៉ារា នៅក្នុងព្រះគម្ពីរសញ្ញាថ្មី (លូកា ១០:៣៨–៤២; យ៉ូហាន ១១:១–៤៦; ១២:២) ។

**នាងម៉ារា ពីភូមិបេថានី** *សូមមើលផង* នាងម៉ាថា, ឡាសារ

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាបងស្រីរបស់ឡាសារ ហើយជាប្អូនស្រីរបស់នាងម៉ាថា ។

នាងម៉ារាបានអង្គុយស្តាប់ នៅទៀបព្រះបាទព្រះយេស៊ូវ, **លូកា** ១០:៣៩, ៤២ ។ នាងម៉ារា និងនាងម៉ាថា ជាបងប្អូន បានចាត់ឲ្យគេទៅហៅព្រះយេស៊ូវ, **យ៉ូហាន** ១១:១–៤៥ ។ នាងបានចាក់ប្រេងលាបព្រះបាទាព្រះយេស៊ូវ, **យ៉ូហាន** ១២:៣–៨ ។

**នាងម៉ារា ពីម៉ាក់ដាឡា**

ជាស្ត្រីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលកើតជាសិស្សដ៏ស្មោះស្ម័គ្ររបស់ព្រះយេស៊ូវគ្រីស្ទ ។ ម៉ាក់ដាឡាជាទីកន្លែងដែលនាង ម៉ារាអាស្រ័យនៅ គឺនៅត្រើយខាងលិចសមុទ្រកាលីឡេ ។

នាងបាននៅក្បែរឈើឆ្កាង, **ម៉ាថាយ** ២៧:៥៦ (ម៉ាកុស ១៥:៤០; យ៉ូហាន ១៩:២៥) ។ នាងបានទៅមើលគេបញ្ចុះព្រះគ្រីស្ទ, **ម៉ូថាយ** ២៧:៦១ (ម៉ាកុស ១៥:៤៧) ។ នាងបាននៅឯផ្នូរ នៅព្រលឹមនៃដំណើររស់ឡើងវិញ, **ម៉ូថាយ** ២៨:១ (ម៉ាកុស ១៦:១; លូកា ២៤:១០; យ៉ូហាន ២០:១, ១១) ។ ព្រះយេស៊ូវទ្រង់បានលេចមកឯនាងមុនគេបង្អស់ បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ, **ម៉ាកុស** ១៦:៩ (យ៉ូហាន ២០:១៤–១៨) ។ អារក្សប្រាំពីរបានចេញពីនាង, **លូកា** ៨:២ ។

**នាងម៉ារា, មាតារបស់ព្រះយេស៊ូវ** *សូមមើលផង* ប្តីរបស់នាងម៉ារា, ព្រះយេស៊ូវគ្រីស្ទ; យ៉ូសែប

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជានាងព្រហ្មចារី ដែលព្រះដ៏ជាព្រះវរបិតាបានរើសឲ្យធ្វើជាមាតានៃព្រះរាជបុត្រាទ្រង់ នៅក្នុងសាច់ឈាម ។ បន្ទាប់ពីកំណើតព្រះយេស៊ូវ នោះនាងម៉ារាមានកូនទៀត (ម៉ាកុស ៦:៣) ។

នាងត្រូវជាគូដណ្តឹងរបស់យ៉ូសែប, **ម៉ាថាយ** ១:១៨ (លូកា ១:២៧) ។ យ៉ូសែបត្រូវបានហាមមិនឲ្យលែងនាងម៉ារា ឬបណ្តាច់នាង ចេញឡើយ, **ម៉ាថាយ** ១:១៨–២៥ ។ ពួកអ្នកប្រាជ្ញបានទៅមើលនាងម៉ារា, **ម៉ាថាយ** ២:១១ ។ នាងម៉ារា និងយ៉ូសែបបានរត់គៀសខ្លួន ទៅស្រុកអេស៊ីព្ទ

ជាមួយនឹងកុមារយេស៊ូវ, **ម៉ាថាយ** ២:១៣–១៤ ។ បន្ទាប់ពីហេរ៉ូឌបានសុគតទៅ នោះទាំងគ្រួសារក៏ត្រឡប់មកឯ ភូមិណាសារ៉ែតវិញ, **ម៉ាថាយ** ២:១៩–២៣ ។ ទេវតាកាព្រីយ៉ែលបានមករកនាង, **លូកា** ១:២៦–៣៨ ។ នាងបានទៅលេងនឹង អេលីសាបិត ជាបងប្អូនជីដូនមួយនឹងនាង, **លូកា** ១:៣៦, ៤០–៤៥ ។ នាងម៉ារាបានថ្វាយទំនុកសរសើរដំកើងដល់ព្រះអម្ចាស់, **លូកា** ១:៤៦–៥៥ ។ នាងម៉ារាបានទៅឯភូមិបេថ្លេហិមជាមួយនឹងយ៉ូសែប, **លូកា** ២:៤–៥ ។ នាងម៉ារាប្រសូតបានព្រះយេស៊ូវ ហើយផ្ដេក ទ្រង់ក្នុងស្នូក, **លូកា** ២:៧ ។ ពួកអ្នកគង្វាលសត្វចៀមបានទៅឯភូមិបេថ្លេហិម ដើម្បីទៅមើលទារកដែលជាព្រះគ្រីស្ទ, **លូកា** ២:១៦–២០ ។ នាងម៉ារា និងយ៉ូសែបបាននាំព្រះយេស៊ូវទៅឯព្រះវិហារបរិសុទ្ធ នៅក្រុងយេរូសាឡិម, **លូកា** ២:២១–៣៨ ។ នាងម៉ារា និងយ៉ូសែបបាននាំព្រះយេស៊ូវទៅបុណ្យរំលង, **លូកា** ២:៤១–៥២ ។ នាងម៉ារាទៅការគេនៅភូមិកាណា, **យ៉ូហាន** ២:២–៥ ។ កាលព្រះអង្គសង្គ្រោះកំពុងនៅលើឈើឆ្កាង នោះទ្រង់បានប្រាប់ឲ្យយ៉ូហានមើលថែរក្សាមាតាទ្រង់, **យ៉ូហាន** ១៩:២៥–២៧ ។ នាងម៉ារាបាននៅជាមួយនឹងពួកសាវកបន្ទាប់ពីព្រះគ្រីស្ទបានលើកឡើងទៅលើស្ថានសួគ៌, **កិច្ចការ** ១:១៤ ។ នាងម៉ារាជានាងព្រហ្មចារីម្នាក់ ស្រស់ ហើយស្អាតបំផុត ជាងនាងព្រហ្មចារីនានាទាំងអស់, **១ នីហ្វៃ** ១១:១៣–២០ ។ មាតានៃព្រះគ្រីស្ទត្រូវឲ្យហៅថា នាងម៉ារា, **ម៉ូសាយ** ៣:៨ ។ នាងម៉ារាជាស្ត្រីព្រហ្មចារី គឺជាប្រដាប់ដ៏វិសេស និងជំរើសមួយ, **អាលម៉ា** ៧:១០ ។

**នាងម៉ារា, ម្ដាយម៉ាកុស** *សូមមើលផង* ម៉ាកុស

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាម្ដាយរបស់យ៉ូហាន-ម៉ាកុស ដែលជាអ្នកនិពន្ធដំណឹងល្អតាមលោកម៉ាកុស (កិច្ចការ ១២:១២) ។

**នាងម៉ារាម** *សូមមើលផង* ម៉ូសេ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាបងស្រីរបស់ម៉ូសេ (ជនគ. ២៦:៥៩) ។

បានមើលថែកូនទូក ធ្វើពីដើមបបុស, **និក្ខ.** ២:១–៨ ។ បាននាំបណ្ដាស្ត្រីរាំក្រាប់, **និក្ខ.** ១៥:២០–២១ ។ បានរអ៊ូរទាំទាស់នឹងម៉ូសេ ហើយត្រូវវាយដោយរោគឃ្លង់ រួចបានជា, **ជនគ.** ១២:១–១៥ (ចោទិ. ២៤:៩) ។

**នាងយេសិបិល** *សូមមើលផង* អ័ហាប់

ជាស្ត្រីទុច្ចរិតម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មកពីស្រុកភីនីស៊ី ។ ព្រះនាងជាភរិយានៃអ័ហាប់ (១ ពង្សាវ. ១៦:៣០–៣១), ជាស្ដេចនៃអ៊ីស្រាអែល ដែលបានសោយរាជ្យកាលអេលីយ៉ាធ្វើជាព្យាការី ។

អាពាហ៍ពិពាហ៍នៃព្រះនាងយេសិបិលទៅនឹងអ័ហាប់ គឺជាហេតុការណ៍តែមួយគត់ ដែលបណ្ដាលឲ្យមានការរលំនគរអ៊ីស្រាអែលខាងជើង ។ ព្រះនាងយេសិបិលបានណែនាំឲ្យមានការថ្វាយបង្គំរូបព្រះដ៏អាក្រក់បំផុតមកពីស្រុកនាង ចូលស្រុកអ៊ីស្រាអែល មកជួសការថ្វាយបង្គំព្រះ យេហូវ៉ា (១ ពង្សាវ. ១៨:១៣, ១៩) ។

ព្រះនាងយេសិបិលបានសម្លាប់ពួកព្យាការីនៃព្រះជាច្រើន, **១ ពង្សាវ.** ១៨:៤ ។ ព្រះនាងយេសិបិលរកសម្លាប់អេលីយ៉ា, **១ ពង្សាវ.** ១៩:១–៣ ។ អំពើទុច្ចរិតរបស់ព្រះនាងយេសិបិលក៏ចប់នឹងការសុគតដ៏អាក្រក់របស់នាង, **២ ពង្សាវ.** ៩:៣០–៣៧ ។

**នាងរស់** *សូមមើលផង* បូអូស

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាកូនប្រសាសាសន៍ម៉ូអាប់ របស់នាងន៉ាអូមី និងអេលីម៉ាលេច ដែលជាសាសន៍អ៊ីស្រាអែល ។ បន្ទាប់ពីប្ដីនាងស្លាប់ទៅ នាងរស់បានរៀបការនឹងបូអូស ជាសាច់ញាតិនឹងនាងន៉ាអូមី ។ អូបិឌ ជាកូនប្រុសរបស់គេ គឺជាដូនតានៃហ្លួងដាវីឌ និងព្រះគ្រីស្ទ ។ រឿងនាងរស់អធិប្បាយប្រាប់យ៉ាងក្បោះក្បាយអំពីការប្រែចិត្តជឿនៃអ្នកក្រៅសាសន៍អ៊ីស្រាអែល ចូលទៅក្នុងវង្សអ៊ីស្រាអែល ។ នាងរស់បានបោះបង់ចោលព្រះរបស់នាងពីមុន និងជីវភាពពីដើម ដើម្បីទៅរួបរួមនឹងវង្សានៃសេចក្ដីជំនឿ ក្នុងការបំរើព្រះនៃអ៊ីស្រាអែល (នាងរស់ ១:១៦) ។

*គម្ពីរនាងរស់៖* ជំពូកទី ១ រៀបរាប់អំពីជីវិតរបស់អេលីម៉ាលេច និងគ្រួសារគាត់ នៅស្រុកម៉ូអាប់ ។ បន្ទាប់ពីពួកប្ដីៗបាន ស្លាប់ទៅ នោះនាងន៉ាអូមី និងនាងរស់បានទៅក្រុងយេរូសាឡិម ។ ជំពូកទី ២ ពន្យល់ប្រាប់អំពីនាងរស់រើសសន្សំស្រូវនៅស្រែបូអូស ។ ជំពូកទី ៣ ប្រាប់អំពីរបៀបនាងន៉ាអូមីបង្គាប់នាងរស់ឲ្យទៅឯទីលាន ហើយចូលទៅដេកខាងចុងជើងបូអូស ។ ជំពូកទី ៤ គឺជារឿងនាងរស់រៀបការនឹងបូអូស ។ គេមានកូនប្រុសម្នាក់ ឈ្មោះអូបិឌ ជាវង្សារបស់ហ្លួងដាវីឌ និងព្រះគ្រីស្ទ ។

**នាងរ៉ាជែល** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាប្រពន្ធរបស់យ៉ាកុប (លោកុ. ២៩–៣១, ៣៥) ។ នាងជាម្ដាយរបស់យ៉ូសែប និងបេនយ៉ាមីន ។

**នាងរេបេកា** *សូមមើលផង* អ៊ីសាក

ជាប្រពន្ធរបស់អ៊ីសាក ដែលជាអយ្យកោ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (លោកុ. ២៤–២៧) ។ នាងរេបេកាជាម្ដាយរបស់អេសាវ និងយ៉ាកុប (លោកុ. ២៥:២៣–២៦) ។

**នាងលេអា** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក;
បងប្រុសរបស់នាងរេបិកា, យ៉ាកុប, ឡាបាន់

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនស្រីច្បងបង្អស់របស់ឡាបាន់ ហើយជាប្រពន្ធម្នាក់របស់យ៉ាកុប (លោកុ. ២៩) ។ នាងលេអាបាន ក្លាយទៅជាម្ដាយរបស់កូនប្រុសប្រាំមួយនាក់ និងកូនស្រីម្នាក់ (លោកុ. ២៩:៣១–៣៥; ៣០:១៧–២១) ។

**នាងសារ៉ា** *សូមមើលផង* អ័ប្រាហាំ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាប្រពន្ធទី១របស់អ័ប្រាហាំ ។ កាលនាងមានអាយុចាស់ណាស់ទៅហើយ នោះនាងបង្កើតបានអ៊ីសាក (លោកុ. ១៨:៩–១៥; ២១:២) ។

**នាងហាណា** *សូមមើលផង* ព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់, សាំយូអែល

ជាម្ដាយរបស់សាំយូអែល ដែលជាព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ព្រះអម្ចាស់ទ្រង់បានប្រទានសាំយូអែលដល់នាងហាណា ក្នុងចម្លើយតបដល់ពាក្យអធិស្ឋានរបស់នាង (១ សាំយូ. ១:១១, ២០–២៨) ។ នាងហាណាបានថ្វាយសាំយូអែលដល់ព្រះអម្ចាស់ ។ ចំរៀងអំពីការថ្លែងអំណរគុណរបស់នាង អាចយកមកប្រៀបផ្ទឹមនឹងចំរៀងរបស់នាងម៉ារា ជាមាតារបស់ព្រះយេស៊ូវ (១ សាំយូ. ២:១–១០; លូកា ១:៤៦–៥៥) ។

**នាងហាការ** *សូមមើលផង* កូនប្រុសរបស់អ័ប្រាហាំ, អ័ប្រាហាំ; អ៊ីសម៉ាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាបាវស្រីសាសន៍អេស៊ីព្ទរបស់នាងសារ៉ា ។ នាងត្រឡប់ទៅជាប្រពន្ធរបស់អ័ប្រាហាំ ហើយជាម្ដាយរបស់ អ៊ីសម៉ាអែល (លោកុ. ១៦:១–១៦; ២៥:១២; គ. និង ស. ១៣២:៣៤, ៦៥) ។ ព្រះអម្ចាស់ទ្រង់បានសន្យានឹងនាងហាការថា សាសន៍ដ៏ធំមួយនឹងបានចេញមកពីកូនប្រុសនាង (លោកុ. ២១:៩–២១) ។

**នាងអាណ**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាព្យាការីស្រីម្នាក់ពីពូជអំបូររបស់អេសើរ ។ នៅកំណើតព្រះយេស៊ូវ នោះនាងជាស្រីមេម៉ាយចំណាស់ទៅ ហើយ ។ នាងបានឃើញព្រះទារកយេស៊ូវ កាលយកទ្រង់ទៅព្រះវិហារបរិសុទ្ធ ហើយក៏ស្គាល់ថា ទ្រង់ជាព្រះដ៏ប្រោសលោះ (លូកា ២:៣៦–៣៨) ។

**នាងអេលីសាបិត***សូមមើលផង* យ៉ូហាន-បាទីស្ទ

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាប្រពន្ធរបស់សាការី ជាម្ដាយរបស់យ៉ូហាន-បាទីស្ទ ហើយជាញាតិរបស់នាងម៉ារា (លូកា ១:៥–៦០) ។

**នាងអេវ៉ា***សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា, អ័ដាម; អេដែន

ជាស្ត្រីទីមួយ ដែលរស់នៅលើផែនដីនេះ (លោកុ. ២:២១–២៥; ៣:២០) ។ នាងជាប្រពន្ធរបស់លោកអ័ដាម ។ ក្នុងភាសាហេព្រើរ ឈ្មោះនេះមានន័យថា « ជីវិត » ហើយបញ្ជាក់ថា នាងអេវ៉ា គឺជាម្ដាយទីមួយ នៅលើផែនដី (ម៉ូសេ ៤:២៦) ។ នាង ព្រមទាំងលោក អ័ដាម ជាបុរសទីមួយ នឹងបានទទួលនូវចំណែកសិរីល្អដ៏នៅអស់កល្បជានិច្ច ចំពោះមុខងារគេក្នុងការធ្វើឲ្យមាននូវការជឿនលឿនដ៏ នៅអស់កល្បជានិច្ចនៃមនុស្សលោកទាំងអស់ ។

នាងអេវ៉ាត្រូវបានល្បួង ហើយបានទទួលទានផ្លែហាមឃាត់, **លោកុ.** ៣ (២ នីហ្វៃ ២:១៥–២០; ម៉ូសេ ៤) ។ នាងអេវ៉ាយល់នូវការចាំបាច់នៃការធ្លាក់ និងសេចក្ដីអំណរអំពីសេចក្ដីប្រោសលោះ, **ម៉ូសេ** ៥:១១–១២ ។ ប្រធានយ៉ូសែប អែហ្វ ស្ម៊ីធ បានឃើញនាងអេវ៉ានៅក្នុងការនិមិត្តរបស់លោក អំពីស្ថានវិញ្ញាណ, **គ. និង ស.** ១៣៨:៣៩ ។

**នាងអេសធើរ**

ជាស្ត្រីម្នាក់ដែលមានសេចក្ដីជំនឿដ៏ធំ ហើយជាតួសំខាន់នៅក្នុងគម្ពីរនាងអេសធើរ ។

*គម្ពីរនាងអេសធើរ៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមានរឿងអំពីសេចក្ដីក្លាហានដ៏ខ្លាំង របស់ព្រះនាងអេសធើរ ក្នុងការសង្គ្រោះរាស្ត្ររបស់ព្រះនាង ពីសេចក្ដីបំផ្លិចបំផ្លាញ ។

ជំពូកទី ១–២ ប្រាប់អំពីនាងអេសធើរ ជាស្ត្រីសាសន៍យូដាម្នាក់ ហើយជាកូនស្រីចិញ្ចឹមរបស់បុរសសាសន៍យូដាម្នាក់ ឈ្មោះម៉ាដេកាយ គឺនាងត្រូវបានរើសឲ្យធ្វើជាមហាក្សត្រីលើស្រុកពើស៊ី ពីព្រោះមកពីសម្រស់របស់នាង ។ ជំពូកទី ៣ ពន្យល់ប្រាប់អំពីហាម៉ាន ជាប្រធាន នៅក្នុងវាំងស្ដេច លោកបានស្អប់ម៉ាដេកាយ ហើយបានទទួលក្រិត្យមួយ ដើម្បីសម្លាប់ប្រជារាស្ត្រយូដាទាំងអស់បង់ ។ ជំពូកទី ៤–១០ ប្រាប់អំពីនាងអេសធើរ ដោយមានគ្រោះធំដល់ខ្លួន បានប្រាប់ស្ដេចអំពីជាតិនាង ហើយបានទទួលក្រិត្យក្រមផ្ទុយទៅវិញ ។

**នាមនៃសាសនាចក្រ** *សូមមើល* នាមនៃ; សាសនាចក្រ, សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**និក្ខមនំ***សូមមើលផង* គម្ពីរ៥ច្បាប់

ជាគម្ពីរមួយសរសេរដោយលោកម៉ូសេ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលអធិប្បាយប្រាប់អំពីការចាកចេញនៃពួកសាសន៍អ៊ីស្រាអែល ពីស្រុកអេស៊ីព្ទ ។ ប្រវត្តិសាស្ត្រអ៊ីស្រាអែលមុនដំបូង ដូចដែលបានកត់ទុកនៅក្នុងគម្ពីរនិក្ខមនំ អាចចែកចេញជាបីភាគគឺ៖ (១) ទាសភាព នៃប្រជាជនទៅស្រុកអេស៊ីព្ទ (២) ការដែលគេចេញដំណើរពីស្រុកអេស៊ីព្ទនៅក្រោមការដឹកនាំនៃលោកម៉ូសេ និង (៣) ការដែលគេឧទ្ទិសកិច្ចការព្រះក្នុងជីវភាពខាងសាសនារបស់គេ និងជីវភាពខាងរដ្ឋាភិបាលរបស់គេ ។

ភាគទី ១ គឺជំពូកទី ១–១៥ ពន្យល់ប្រាប់អំពីការសង្កត់សង្កិនពួកសាសន៍អ៊ីស្រាអែលនៅស្រុកអេស៊ីព្ទ; អំពីប្រវត្តិមុនដំបូង និងការហៅរបស់ម៉ូសេ; អំពីនិក្ខមនំ និងបានស្ថាបនាបុណ្យរំលង; និងអំពីដំណើរទៅសមុទ្រក្រហម ការបំផ្លាញទ័ពផារ៉ោន និងចំរៀងរបស់ម៉ូសេអំពីជ័យជំនះ ។

ភាគទី ២ គឺជំពូកទី ១៥–១៨ ប្រាប់អំពីសេចក្ដីប្រោសលោះនៃពួកសាសន៍អ៊ីស្រាអែល និងហេតុការណ៍ក្នុងដំណើរពីសមុទ្រក្រហមទៅភ្នំស៊ីណាយ; អំពីទឹកម៉ារ៉ាល្វីង ការប្រទាននូវសត្វក្រួច និងនំម៉ាន៉ា ការគោរពថ្ងៃឈប់សំរាក អំណោយទាននូវទឹក នៅរេផេឌីម យ៉ាងអស្ចារ្យ និងចម្បាំងនៅទីនោះជាមួយនឹងពួកសាសន៍អាម៉ាលេក; អំពីការមកនៃលោកយេត្រូនៅក្នុងជំរំ និងពាក្យទូន្មានរបស់ លោកអំពីរដ្ឋាភិបាលរបស់ប្រជាជន ។

ភាគទី ៣ គឺជំពូកទី ១៩–៤០ ទាក់ទងនឹងការដែលពួកសាសន៍អ៊ីស្រាអែលថ្វាយខ្លួនចំពោះកិច្ចការរបស់ព្រះ ចំពោះហេតុការណ៍

ដ៏មុឹងម៉ាត់នៅភ្នំស៊ីណាយ ។ ព្រះអម្ចាស់ទ្រង់ញែកប្រជាជនចេញជានគរនៃពួកសង្ឃ និងជាសាសន៍បរិសុទ្ធ; ទ្រង់បានប្រទានព្រះបញ្ញត្តិ ១០ ប្រការ ហើយទ្រង់បានបង្គាប់អំពីរោងឧបោសថ គ្រឿងគុបតែង និងការថ្វាយបង្គំនៅខាងក្នុង ។ បន្ទាប់មក មានដំណើររឿងអំពី អំពើបាបរបស់ប្រជាជន ចំពោះការថ្វាយបង្គំកូនគោមាស ហើយចុងក្រោយបង្អស់ អំពីដំណើររឿងនៃការសង់រោងឧបោសថ និងគ្រឿងសំរាប់កិច្ចការ ។

**និយាយដើម** *សូមមើលផង* ការនិយាយអាក្រក់;
ពាក្យចចាមអារាម

គឺប្រាប់រឿង ឬដំណឹងផ្ទាល់ខ្លួនអំពីអ្នកដទៃទៅអ្នកផ្សេង ដោយគ្មានបានទទួលការអនុញ្ញាតពីអ្នកនោះឡើយ ។

មនុស្សលោកនឹងត្រូវរៀបរាប់ប្រាប់ពីអស់ទាំងហេតុនៃពាក្យឥតប្រយោជន៍, **ម៉ាថាយ** ១២:៣៦ ។ ពួកបរិសុទ្ធបានត្រូវទូន្មាន កុំឲ្យមាន មាត់ប៉ប៉ាច់ប៉ប៉ោច ហើយបេះបួយ, ១ ធីម៉ូ. ៥:១១–១៤ ។ កុំឲ្យនិយាយអាក្រក់ពីអ្នកជិតខាងខ្លួនឲ្យសោះ, **គ. និង ស.** ៤២:២៧ ។ ចូរចំរើនកម្លាំងដល់បងប្អូនអ្នក ដោយគ្រប់វាចារបស់អ្នក, **គ. និង ស.** ១០៨:៧ ។

**នីកូដេម** *សូមមើលផង* ពួកផារិស៊ី

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាអ្នកត្រួតត្រានៃពួកសាសន៍យូដាដ៏សុចរិតម្នាក់ (ប្រហែលជាពីក្រុមជំនុំសានហេទ្រិន) ហើយជាផារិស៊ីម្នាក់ (យ៉ូហាន ៣:១) ។

លោកបាននិយាយជាមួយនឹងព្រះយេស៊ូវ នៅពេលយប់, **យ៉ូហាន** ៣:១–២១ ។ លោកបានដោះសារជួសព្រះគ្រីស្ទចំពោះពួកផារិស៊ី, **យ៉ូហាន** ៧:៥០–៥៣ ។ លោកបានយកគ្រឿងក្រអូបមកឯការបញ្ចុះព្រះយេស៊ូវ, **យ៉ូហាន** ១៩:៣៩–៤០ ។

**នីនីវេ** *សូមមើលផង* យ៉ូណាស, អាសស៊ើរ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជារាជធានីនៃស្រុកអាសស៊ើរ ហើយដល់ទៅជាង ២០០ ឆ្នាំ គឺជាមជ្ឈមណ្ឌលខាងជំនួញ នៅត្រើយខាងកើតទន្លេទីគ្រីស ។ ក្រុងនីនីវេបានរលំនៅពេលអាណាចក្រអាសស៊ើរធ្លាក់ នៅឆ្នាំ ៦០៦ ម.គ.ស. ។

សានហេរីប ជាស្តេចស្រុកអាសស៊ើរ បានអាស្រ័យនៅឯក្រុងនីនីវេ, **២ ពង្សាវ.** ១៩:៣៦ ។ យ៉ូណាសត្រូវបានចាត់ទៅប្រកាសដល់ មនុស្សនៅទីក្រុងនោះឲ្យប្រែចិត្ត, **យ៉ូណាស** ១:១–២ (យ៉ូណាស ៣:១–៤) ។ ប្រជាជននៅក្រុងនីនីវេបានប្រែចិត្ត, **យ៉ូណាស** ៣:៥–១០ ។ ព្រះគ្រីស្ទបានយកក្រុងនីនីវេទុកជាជំរាប់អំពីការប្រែចិត្ត ចំពោះពួកសាសន៍យូដា, **ម៉ាថាយ** ១២:៤១ ។

**នីហ៊ូរ** *សូមមើលផង* អ្នកទទឹងនឹងព្រះគ្រីស្ទ; ឧបាយកលផ្ទៃកសង្ឃ

ជាមនុស្សអាក្រក់ម្នាក់នៅក្នុងព្រះគម្ពីរមរមន ។ នីហ៊ូរគឺជាមនុស្សមុនដំបូងបង្អស់ នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ដែលប្រព្រឹត្ត ឧបាយកលផ្ទៃកសង្ឃ ។ បន្ទាប់ពីបានបង្រៀនលទ្ធិក្លែងក្លាយ ហើយបានសម្លាប់គេឌាន នោះនីហ៊ូរត្រូវគេប្រហារជីវិត ចំពោះទោស គាត់ (អាលម៉ា ១) ។ ពួកអ្នកដើរតាមនីហ៊ូរបានបន្តការប្រព្រឹត្ត និងការបង្រៀនដ៏អាក្រក់របស់គាត់ជាយូរ ក្រោយពេលដែលនីហ៊ូរ ស្លាប់ទៅ ។

អាលម៉ា និងអាមូលេកត្រូវគេដាក់គុក ដោយចៅក្រមម្នាក់ ដែលដើរតាមរបៀបនីហ៊ូរ, **អាលម៉ា** ១៤:១៤–១៨ ។ ពួកគេជាអ្នកកាន់តាមជំនឿនៃនីហ៊ូរ ដែលត្រូវគេប្រហារចោល, **អាលម៉ា** ១៦:១១ ។ មនុស្សជាច្រើនបានដើរតាមរបៀបនៃពួកនីហ៊ូរ, **អាលម៉ា** ២១:៤ ។ ភាគច្រើននៃពួកអ្នកដែលប្រហារបងប្អូនរបស់គេ គឺជាពួកអ្នកដើរតាមរបៀបនៃពួកនីហ៊ូរ, **អាលម៉ា** ២៤:២៨ ។

**នីហ្វៃ, កូនប្រុសរបស់ហេលេមិន** *សូមមើលផង*
កូនប្រុសរបស់ហេលេមិន; លីហៃ, ហេលេមិន,
អ្នកផ្សាយសាសនាសាសន៍នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន ជាព្យាការី ហើយជាអ្នកផ្សាយសាសនាដ៏ឆ្នើមម្នាក់នៃសាសន៍នីហ្វៃ ។

ជាកូនប្រុសច្បងរបស់ហេលេមិន, **ហេលេ.** ៣:២១ ។ ត្រូវបានតាំងឡើងឲ្យធ្វើជាមេចៅក្រម, **ហេលេ.** ៣:៣៧ ។ លោក និងលីហៃ ជាប្អូនប្រុសរបស់លោក បានធ្វើឲ្យពួកសាសន៍លេមិនជាច្រើនប្រែចិត្តជឿដំណឹងល្អ, **ហេលេ.** ៥:១៨–១៩ ។ ត្រូវបានព័ទ្ធជុំវិញដោយ ភ្លើង ហើយបានដោះលែងពីគុក, **ហេលេ.** ៥:២០–៥២ ។ បានអធិស្ឋានលើប៉មនៅក្នុងសួនច្បាររបស់លោក, **ហេលេ.** ៧:៦–១០ ។ បានប្រាប់ អំពីអ្នកដែលសម្លាប់មេចៅក្រម, **ហេលេ.** ៨:២៥–២៨; ៩:១–៣៨ ។ ត្រូវបានប្រទានអំណាចដ៏ធំពីព្រះអម្ចាស់, **ហេលេ.** ១០:៣–១១ ។ បានសូមដល់ព្រះអម្ចាស់នូវអំណត់អត់ និងការបញ្ចប់អំណត់អត់, **ហេលេ.** ១១:៣–១៨ ។

**នីហ្វៃ, កូនប្រុសរបស់នីហ្វៃ ដែលជាកូនប្រុសរបស់ហេលេមិន**
*សូមមើលផង* សិស្ស; នីហ្វៃ, កូនប្រុសរបស់ហេលេមិន

ជាសិស្សម្នាក់ក្នុងសិស្ស ១២ នាក់នៃសាសន៍នីហ្វៃ ដែលបានរើសដោយព្រះយេស៊ូវគ្រីស្ទ ដែលមានព្រះជន្មរស់ឡើងវិញ នៅក្នុងព្រះគម្ពីរមរមន (៣ នីហ្វៃ ១:២–៣; ១៩:៤) ។ ព្យាការីនេះបានអធិស្ឋានយ៉ាងខ្លាំងដល់ព្រះអម្ចាស់ជំនួសប្រជាជនលោក ។ នីហ្វៃបានឮសម្លេងនៃព្រះអម្ចាស់ (៣ នីហ្វៃ ១:១១–១៤) ។ នីហ្វៃត្រូវបានពួកទេវតាមកជួប, បានបណ្តេញអារក្សអសោចិ៍ចេញ, បានប្រោសឲ្យប្អូនប្រុសលោករស់ឡើងវិញ, ហើយបានថ្លែងទីបន្ទាល់មួយ ដែលពុំអាចបដិសេធបានឡើយ (៣ នីហ្វៃ ៧:១៥–១៩; ១៩:៤) ។ នីហ្វៃបានកត់បញ្ជីខាងបទគម្ពីរ (៣ នីហ្វៃ ១:២–៣) ។

*គម្ពីរនីហ្វៃទី ៣៖* ជាគម្ពីរមួយដែលបានសរសេរដោយនីហ្វៃ ជាកូនប្រុសរបស់នីហ្វៃ នៅក្នុងព្រះគម្ពីរមរមន ។ ជំពូកទី ១–១០ បង្ហាញនូវការសំរេចនៃពាក្យព្យាករណ៍ អំពីការយាងមកនៃព្រះអម្ចាស់ ។ ទីសំគាល់

អំពីកំណើតនៃព្រះគ្រីស្ទត្រូវបានរៀបរាប់ប្រាប់; ប្រជាជនបានប្រែចិត្ត ប៉ុន្តែពួកគេបានត្រឡប់ទៅរកអំពើទុច្ចរិតវិញ ។ នៅទីបញ្ចប់ ព្យុះសង្ឃរា ផែនដីរញ្ជួយ ខ្យល់ព្យុះដ៏កាចសាហាវ និងសេចក្ដីបំផ្លិចបំផ្លាញដ៏ធំ បានឲ្យទីសំគាល់អំពីការសុគតនៃព្រះគ្រីស្ទ ។ ជំពូកទី ១១–២៨ កត់អំពីការយាងមកឯទ្វីបអាមេរិករបស់ព្រះ គ្រីស្ទ ។ នេះគឺជាភាគកណ្ដាលនៃគម្ពីរនីហ្វៃទី ៣ ។ ព្រះបន្ទូលនៃព្រះគ័ស្ទជាច្រើន គឺដូចជាបទបង្រៀនរបស់ទ្រង់ដែលបានកត់ទុក នៅក្នុងព្រះគម្ពីរប៊ីប (ជាឧទាហរណ៍, ម៉ាថាយ ៥–៧ និង ៣ នីហ្វៃ ១២–១៤) ។ ជំពូកទី ២៩–៣០ គឺជាពាក្យសំដីរបស់មរមនដល់ សាសន៍ទាំងឡាយនៅថ្ងៃចុងក្រោយ ។

*គម្ពីរនីហ្វៃទី ៤៖* គម្ពីរនេះមានតែ ៤៩ ខ ប៉ុណ្ណោះ, ខទាំងអស់នៅក្នុងជំពូកតែមួយ ប៉ុន្តែគម្ពីរនេះរៀបរាប់ប្រវត្តិនៃពួកសាសន៍នីហ្វៃ ជិតដល់ទៅ៣០០ ឆ្នាំ (ឆ្នាំ ៣៤–៣២១ គ.ស.) ។ មានអ្នកសរសេរជាច្រើនតំណ ព្រមទាំងនីហ្វៃ ក៏បានដាក់ពាក្យទុកក្នុងបញ្ជីដែរ ។ ខ ១–១៩ ប្រាប់ថា បន្ទាប់ពីការយាងមកនៃព្រះគ្រីស្ទ ដែលមានព្រះជន្មរស់ឡើងវិញ នោះពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនបាន ប្រែចិត្តជឿដល់ដំណឹងល្អ ។ សេចក្ដីសុខសាន្ត សេចក្ដីស្រឡាញ់ និងសេចក្ដីស្រុះស្រួលគ្នាបានសោយរាជ្យលើផែនដី ។ ពួកសិស្សសាសន៍នីហ្វៃបីនាក់ ដែលព្រះគ្រីស្ទបានអនុញ្ញាតឲ្យអាស្រ័យនៅលើផែនដីដរាបដល់ការយាងមកលើកទីពីររបស់ទ្រង់ (៣ នីហ្វៃ ២៨:៤–៩) បានធ្វើការងារបំរើប្រជាជន ។ នីហ្វៃបានទុកបញ្ជីប្រវត្តិឲ្យអេម៉ុស ជាកូនប្រុសរបស់លោក ។ ខ ១៩–៤៧ គឺជាបញ្ជី អំពីការងារបំរើរបស់អេម៉ុស (៨៤ ឆ្នាំ) និងអំពីការងារបំរើរបស់អេម៉ុស ជាកូនប្រុសរបស់លោក (១១២ ឆ្នាំ) ។ នៅឆ្នាំ ២០១ គ.ស. សេចក្ដីឆ្មើងឆ្មៃក៏ចាប់ផ្ដើមបណ្ដាលឲ្យមានបញ្ហា នៅក្នុងចំណោមប្រជាជនដែលបានបំបែកខ្លួនចេញតាមវណ្ណៈ ហើយបានចាប់ផ្ដើម បង្កើតសាសនាចក្រក្លែងក្លាយ ដើម្បីរកកម្រៃដល់ខ្លួន (៤ នីហ្វៃ ១:២៤–៣៤) ។

ខចុងក្រោយបង្អស់នៃគម្ពីរនីហ្វៃទី ៤ បង្ហាញថា ប្រជាជនបានវិលទៅរកអំពើទុច្ចរិតវិញ (៤ នីហ្វៃ ១:៣៥–៤៩) ។ នៅឆ្នាំ ៣០៥ គ.ស. អេម៉ុស ជាកូនប្រុសរបស់អេម៉ុស ក៏ស្លាប់ទៅ ហើយអាំម៉ារ៉ុនជាប្អូនប្រុសរបស់លោក បានលាក់អស់ទាំងបញ្ជីប្រវត្តិដ៏ពិសិដ្ឋទុកដើម្បីឲ្យបានគង់វង់ ។ ក្រោយមក អាំម៉ារ៉ុនបានប្រគល់បញ្ជីប្រវត្តិទាំងឡាយឲ្យទៅមរមន ដែលបានកត់ហេតុការណ៍ជាច្រើន អំពីសម័យលោក រួចហើយ ក៏បានសង្ខេបចូលគ្នា (មរមន ១:២–៤) ។

**នីហ្វៃ, កូនប្រុសរបស់លីហៃ** *សូមមើលផង* ពួកសាសន៍នីហ្វៃ, លីហៃ, ឪពុករបស់នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសដ៏សុចរិតម្នាក់របស់លីហៃ និងនាងសារាយ (១ នីហ្វៃ ១:១–៤; ២:៥) ។ នីហ្វៃមានសេចក្ដីជំនឿជឿដ៏ខ្លាំងដល់ព្រះបន្ទូលនៃព្រះ (១ នីហ្វៃ ៣:៧) ។ ហើយបានកើតទៅជាព្យាការីវិសេស អ្នកកត់បញ្ជីប្រវត្តិ និងជាមេដឹកនាំដ៏ឆ្នើមម្នាក់ លើប្រជាជនរបស់លោក ។

បានគោរពធ្វើតាម ហើយបានអធិស្ឋានដោយមានសេចក្ដីជំនឿ, **១ នីហ្វៃ** ២:១៦ ។ បានវិលទៅក្រុងយេរូសាឡិមវិញ ដើម្បីទៅយក ផ្ទាំងលង្ហិន, **១ នីហ្វៃ** ៣–៤ ។ បានវិលទៅក្រុងយេរូសាឡិមវិញ ដើម្បីទៅនាំគ្រួសារអ៊ីសម៉ាអែលចូលទីរហោស្ថាន, **១ នីហ្វៃ** ៧ ។ បានឃើញការនិមិត្តមួយដូចដែលលីហៃបានឃើញ, **១ នីហ្វៃ** ១០:១៧–២២; ១១ ។ បានឃើញក្នុងការនិមិត្តមួយ អំពីអនាគតនៃប្រជា ជនរបស់លោក និងការសាងឡើងវិញនៃដំណឹងល្អ, **១ នីហ្វៃ** ១២–១៣ ។ បានស្រាយន័យនូវការនិមិត្តអំពីដើមជីវិត, **១ នីហ្វៃ** ១៥:២១–៣៦ ។ បានធ្វើធ្នូលោកបាក់ ប៉ុន្តែដោយសារសេចក្ដីជំនឿ នោះលោកអាចរកអាហារបាន, **១ នីហ្វៃ** ១៦:១៨–៣២ ។ បាន សង់សំពៅមួយ ហើយបានបើកសំពៅទៅឯដែនដីសន្យា, **១ នីហ្វៃ** ១៧–១៨ ។ ពួកសាសន៍នីហ្វៃ និងសាសន៍លេមិនបានបាក់បែកពីគ្នា, **២ នីហ្វៃ** ៥ ។ បានថ្លែងទីបន្ទាល់ចុងក្រោយបង្អស់, **២ នីហ្វៃ** ៣៣ ។

*គម្ពីរនីហ្វៃទី ១៖* ជំពូកទី ១ ទៅ ១៨:៨ ភាគច្រើនទាក់ទងទៅនឹងព្យាការីលីហៃ និងគ្រួសាររបស់លោក ចេញពីក្រុងយេរូសាឡិម ។ គេបានធ្វើដំណើរតាមទីរហោស្ថានដ៏ក្រៀមក្រោះ រហូតដល់បានទៅដល់សមុទ្រ ។ ១ នីហ្វៃ ១៨:៩–២៣ ប្រាប់អំពីដំណើរតាមផ្លូវទឹករបស់ពួកគេ ទៅដែនដីសន្យា តាមដែលបានដឹកនាំដោយព្រះអម្ចាស់ ទោះបីជាមានការបះបោរពីលេមិន និងលេមយ្យូលក៏ដោយ ។ ជំពូកទី ១៩–២២ ប្រាប់អំពីគោលបំណងរបស់នីហ្វៃចំពោះការកត់បញ្ជីប្រវត្តិ (១ នីហ្វៃ ៦:១–៦: ១៩:១៨) — គឺដើម្បីបញ្ចុះបញ្ចូល មនុស្សទាំងអស់ឲ្យនឹកចាំដល់ព្រះអម្ចាស់ ជាព្រះដ៏ប្រោសលោះរបស់គេ ។ លោកបានស្រង់ពាក្យអេសាយ (១ នីហ្វៃ ២០–២១) ហើយបានបកស្រាយ ពាក្យបណ្ដាំរបស់អេសាយ ដោយមានសេចក្ដីសង្ឃឹមថាមនុស្សទាំងអស់នឹងអាចបានស្គាល់ថា ព្រះយេស៊ូវ គ្រីស្ទជាព្រះអង្គសង្គ្រោះ ហើយជាព្រះដ៏ប្រោសលោះរបស់គេ (១ នីហ្វៃ ២២:១២) ។

*គម្ពីរនីហ្វៃទី ២៖* ជំពូកទី ១–៤ មាននូវការបង្រៀន និងការព្យាករណ៍ចុងក្រោយបង្អស់របស់លោក មុនលោកស្លាប់ទៅ គឺព្រមទាំង មាននូវការឲ្យពរទាំងឡាយដល់កូនៗលោក និងដល់ពូជពង្សគេ ។ ជំពូកទី ៥ ពន្យល់ប្រាប់ពីហេតុអ្វីបានជាពួកសាសន៍នីហ្វៃបែកខ្លួន ចេញពីពួកសាសន៍លេមិន ។ ពួកសាសន៍នីហ្វៃបានសង់ព្រះវិហារមួយ បានបង្រៀនអំពីក្រិត្យវិន័យលោកម៉ូសេ ហើយបានកត់បញ្ជីប្រវត្តិ ទុក ។ ជំពូកទី ៦–១០ មាននូវពាក្យទាំងឡាយនៃយ៉ាកុប គឺជាប្អូនប្រុសរបស់នីហ្វៃ ។ យ៉ាកុបបានរៀបរាប់សារឡើងវិញ អំពីប្រវត្តិនៃ ស្រុកយូដា ហើយបានព្យាករអំពីព្រះមែស៊ី ពាក្យខ្លះបានដកស្រង់ចេញពីការសរសេរនៃព្យាការីអេសាយ ។ នៅក្នុងជំពូកទី ១១–៣៣ នោះ នីហ្វៃបានកត់នូវទីបន្ទាល់របស់លោកអំពីព្រះគ្រីស្ទ ទីបន្ទាល់របស់យ៉ាកុប ការព្យាករណ៍អំពីគ្រាចុងក្រោយបង្អស់ និងជំពូកជាច្រើនចេញពីគម្ពីរអេសាយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

*ផ្ទាំងនីហ្វៃ៖* សូមមើល ផ្ទាំង

**នឹម** *សូមមើលផង* សិស្ស

ជាប្រដាប់មួយ សំរាប់ដាក់ជុំវិញកសត្វ ឬមនុស្សទាំងឡាយ

ដើម្បីទឹមជាប់គ្នា ។ នឹមនៃព្រះគ្រីស្ទ គឺជានិមិត្តរូបអំពីការងារជាសិស្ស រីឯនឹមនៃការជាប់ចំណង នោះជានិមិត្តរូបអំពីការសង្កត់សង្កិន ។

នឹមខ្ញុំងាយ ហើយបន្ទុកខ្ញុំក៏ស្រាល, **ម៉ាថាយ** ១១:២៩–៣០ ។ ចូរអ្នករាល់គ្នាកុំទឹមនឹម ជាមួយនឹងមនុស្សមិនជឿឡើយ, **២ កូរិន.** ៦:១៤ ។ ចូរកុំឲ្យត្រូវជាប់ចំណង ជាបាវបំរើទៀតឡើយ, **កាឡាទី** ៥:១ ។ យើងក៏មិនចង់យកអ្នកណាម្នាក់ទៅដាក់ក្នុងនឹមនៃសេវកភាព ឡើយ, **អាលម៉ា** ៤៤:២ ។ ទុក្ខវេទនានៃពួកបរិសុទ្ធ គឺជានឹមដែក ជាចំណងដ៏មាំ និងជាច្រវាក់នៃស្ថាននរក, **គ. និង ស.** ១២៣:១–៣, ៧–៨ ។

**នេប៊ូក្នេសា** *សូមមើលផង* ដានីយ៉ែល, បាបិល, បាប៊ីឡូន

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាស្ដេចក្រុងបាប៊ីឡូន (ឆ្នាំ ៦០៤–៥៦១ ម.គ.ស.) ដែលបានបង្ក្រាបស្រុកយូដា (២ ពង្សាវ. ២៤:១–៤) ។ ហើយបានព័ទ្ធជុំវិញក្រុងយេរូសាឡិម (២ ពង្សាវ. ២៤:១០–១១) ។ ព្យាការីលីហៃត្រូវព្រះទ្រង់បញ្ជាឲ្យរត់ចេញពីក្រុងយេរូសាឡិម នៅឆ្នាំ ៦០០ ម.គ.ស. ដើម្បីចៀសវាងការចាប់យកទៅជាឈ្លើយឯក្រុងបាប៊ីឡូន (១ នីហ្វៃ ១:៤–១៣) កាលស្ដេចនេប៊ូក្នេសាចាប់យកស្ដេចសេដេគា និងប្រជាជនទៅ (២ ពង្សាវ. ២៥:១, ៨–១៦, ២០–២២) ។ ដានីយ៉ែលបានបកស្រាយន័យសប្ដិថ្វាយស្ដេចនេប៊ូក្នេសា (ដានី. ២; ៤) ។

**នេហេមា**

ជាអ្នកឧត្ដុង្គឧត្ដមម្នាក់នៃសាសន៍អ៊ីស្រាអែលនៅក្រុងបាប៊ីឡូន នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (ប្រហែលជាពូជលេវី ឬជាពូជអំបូរនៃយូដា) ដែលបានកាន់តំណែងជាអ្នកថ្វាយពែង នៅឯរាជ្យវាំងនៃអើថាស៊ើកសេស ដែលលោកបានទទួលរាជ្យទាន អនុញ្ញាតឲ្យលោកសង់ កំផែងក្រុងយេរូសាឡិមឡើងវិញ ។

*គម្ពីរនេហេមា៖* គម្ពីរនេះជាការបន្តពីគម្ពីរអែសរ៉ា ។ គឺមាននូវដំណើររឿងអំពីការចំរើន និងការលំបាកនៃកិច្ចការ នៅក្រុង យេរូសាឡិម ក្រោយពីសាសន៍យូដាបានត្រឡប់ មកពីការឃុំឃាំងរបស់សាសន៍បាប៊ីឡូនវិញ ។ ជំពូកទី ១–៧ ប្រាប់អំពីដំណើរមួយនៃនេហេមាទៅក្រុងយេរូសាឡិមលើកដំបូង និងការសង់កំផែងទីក្រុងឡើងវិញ ទោះជាមានការជំទាស់ដ៏ធំក្ដី ។ ជំពូកទី ៨–១០ អធិប្បាយប្រាប់អំពីការអប់រំខាងសាសនា និងខាងសង្គម ដែលនេហេមាខំធ្វើឡើង ។ ជំពូកទី ១១–១៣ រាយនាមប្រាប់ពីពួកអ្នក ដែលសក្ដិសម ហើយប្រាប់អំពីដំណើររឿងអំពីពិធីឆ្លងកំផែង ។ ខ ៤–៣១ នៃជំពូកទី ១៣ កត់អំពីដំណើរទីពីរនៃនេហេមា ទៅក្រុងយេរូសាឡិម បន្ទាប់ពីបានឃ្លាតចេញអស់រយៈពេល ១២ ឆ្នាំ ។

**នំបុ័ងជីវិត** *សូមមើលផង* បុណ្យរំឭក, ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទជានំបុ័ងជីវិត ។ នំបុ័ងនៃបុណ្យរំឭក គឺជានិមិត្តរូបអំពីព្រះកាយរបស់ព្រះគ្រីស្ទ ។

ខ្ញុំជានំបុ័ងជីវិត, **យ៉ូហាន** ៦:៣៣–៥៨ ។ ចូរទទួលទាននំបុ័ង និងទឹកនៃជីវិតចុះ, **អាលម៉ា** ៥:៣៤ ។ នំបុ័ង គឺជាការចងចាំអំពីព្រះកាយ ព្រះគ្រីស្ទ, **៣ នីហ្វៃ** ១៨:៥–៧ ។ នំបុ័ង គឺជានិមិត្តរូបអំពីសាច់ព្រះគ្រីស្ទ, **គ. និង ស.** ២០:៤០, ៧៧ (ម៉ូរ៉ូណៃ ៤:១–៣) ។

**បកប្រែ**

ដើម្បីថ្លែងអត្ថន័យ អំពីគតិណាមួយ ពីភាសាមួយ ទៅភាសាមួយទៀត តាមពាក្យដូចគ្នា (ម៉ូសាយ ៨:៨–១៣; ម. នៃ ស. ១:៨) ។ នៅ ក្នុងព្រះគម្ពីរ គេតែងតែពោលថា ការបកប្រែ គឺជាអំណោយទានមកពីព្រះ (អាលម៉ា ៩:២១; គ. និង ស. ៨; ៩:៧–៩) ។ ជួនកាល វាអាចមានន័យថា ដើម្បីផ្លែ ឬកែនូវការបកប្រែ ដែលមានមកហើយ ពីភាសាណាមួយ ឬធ្វើឲ្យមានឡើងវិញ នូវឯកសារដែលបានបាត់ បង់ទៅ (គ. និង ស. ៤៥:៦០–៦១) ។ យ៉ូសែប ស៊្មីធត្រូវបានបញ្ជាឲ្យធ្វើការបកប្រែព្រះគម្ពីរប៊ីបនៃស្ដេចយេម្សដ៏ប្រកបដោយការបំផុស គំនិត (គ. និង ស. ៤២:៥៦; ៧៦:១៥) ។

យ៉ូសែប ស៊្មីធ មានអំណាចដើម្បីបកប្រែ តាមរយៈសេចក្ដីមេត្តាករុណានៃព្រះ គឺដោយព្រះចេស្ដានៃព្រះ, **គ. និង ស.** ១:២៩ ។ អ្នកមាន អំណោយទានឲ្យបកប្រែ, **គ. និង ស.** ៥:៤ ។ យើងប្រទានអំណោយទានមួយដល់អ្នក បើសិនជាអ្នកមានបំណងចង់បានពីយើង ដើម្បី បកប្រែ, **គ. និង ស.** ៦:២៥ ។ ព្រះទ្រង់បានប្រទានដល់យ៉ូសែប ស៊្មីធ នូវអំណាចពីស្ថានដ៏ខ្ពស់ ដើម្បីបកប្រែព្រះគម្ពីរមរមន, **គ. និង ស.** ២០:៨ ។ ដោយសារយូរីម និងធូមីម ខ្ញុំបានបកប្រែពាក្យខ្លះៗ, **យ.ស. — ប្រវត្តិ** ១:៦២ (ម៉ូសាយ ៨:១៣; ២៨:១៣) ។

**បក្សព័ន្ធ** *សូមមើល* បក្សព័ន្ធសម្ងាត់

**បក្សព័ន្ធសម្ងាត់** *សូមមើលផង* កាអ៊ីន; ពួកចោរកាឌីអានតុន

ជាអង្គការមួយដែលមនុស្សរួមគំនិតគ្នាដោយសម្បថ ដើម្បីធ្វើអំពើអាក្រក់ទាំងឡាយរបស់គេ ។

បិតានៃសេចក្ដីកុហកចាក់រុកកូនចៅមនុស្សឲ្យធ្វើបក្សព័ន្ធសម្ងាត់, **២ នីហ្វៃ** ៩:៩ ។ យើងត្រូវបំផ្លាញទាំងកិច្ចការសម្ងាត់ទាំងឡាយនៃ សេចក្ដីងងឹត, **២ នីហ្វៃ** ១០:១៥ ។ សេចក្ដីជំនុំជំរះនៃព្រះបានធ្លាក់មកលើពួកជននៃបក្សព័ន្ធសម្ងាត់, **អាលម៉ា** ៣៧:៣០ ។ កាឌីអានតុន គឺជាមូលហេតុនៃការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងនៃប្រជាជននីហ្វៃ, **ហេលេ.** ២:៤–១៣ ។ សាតាំងបានដាក់ទៅក្នុងចិត្តមនុស្សឲ្យ បង្កើតសម្បថ និងសេចក្ដីសញ្ញាសម្ងាត់ៗទាំងឡាយ, **ហេលេ.** ៦:២១–៣១ ។ ព្រះអម្ចាស់ទ្រង់មិនធ្វើការដោយបក្សព័ន្ធសម្ងាត់ទេ, **អេធើរ** ៨:១៩ ។ សាសន៍ណាដែលគាំទ្របក្សព័ន្ធសម្ងាត់ នោះនឹងត្រូវបំផ្លាញចោល, **អេធើរ** ៨:២២–២៣ ។ ពួកគេបានបដិសេធ ពាក្យទាំងអស់នៃពួកព្យាការីពីព្រោះមកពីសង្គមសម្ងាត់របស់គេ, **អេធើរ** ១១:២២ ។ ចាប់តាំងពីសម័យកាអ៊ីនមក នោះក៏មានបក្សព័ន្ធ សម្ងាត់, **ម៉ូសេ** ៥:៥១ ។

**បងប្រុសរបស់យ៉ារេឌ** *សូមមើលផង* ពួកសាសន៍យ៉ារេឌ, យ៉ារេឌ

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរមរមន ។ លោក និងប្អូនប្រុសលោកបានបង្កើតសាសន៍យ៉ារេឌ កាលគេបាននាំប្រជាជនមួយក្រុមចេញ ពីប៉មបាបិលទៅកាន់ដែនដីសន្យា នៅអឌ្ឍគោលខាងលិច (អេធើរ ១–៦) ។ លោកជាមនុស្សដ៏មានសេចក្ដីជំនឿដ៏ធំក្រៃលែង ទើបលោកបានទូលជាមួយនឹងព្រះអម្ចាស់ទល់នឹងមុខ (គ. និង ស. ១៧:១) ។ រឿងរបស់លោកបានកត់ទុកនៅក្នុងគម្ពីរអេធើរ ។

បងរបស់យ៉ារេឌ ជាបុរសម្នាក់មានមាឌធំ ហើយខ្លាំងក្លា ហើយគាប់ព្រះហឫទ័យនៃព្រះអម្ចាស់ជាខ្លាំង, **អេធើរ** ១:៣៤ ។ មកពីសេចក្ដីជំនឿរបស់លោក នោះបងរបស់យ៉ារេឌបានឃើញព្រះអង្គុលីនៃព្រះអម្ចាស់, **អេធើរ** ៣:៦–៩ (១២:២០) ។ ព្រះគ្រីស្ទបានបង្ហាញព្រះកាយខាងវិញ្ញាណរបស់ទ្រង់ដល់បងប្រុសរបស់យ៉ារេឌ, **អេធើរ** ៣:១៣–២០ ។ ពុំដែលមានការណ៍អ្វីធំជាងការណ៍ដែលបានសម្ដែងដល់បងរបស់យ៉ារេឌឡើយ, **អេធើរ** ៤:៤ ។ បងប្រុសរបស់យ៉ារេឌបានព្រមានប្រជាជនលោកជំទាស់នឹងរាជាធិបតេយ្យ, **អេធើរ** ៦:២២–២៣ ។ ព្រះអម្ចាស់ទ្រង់បានបង្ហាញនូវអ្វីៗទាំងអស់ដល់បងប្រុសរបស់យ៉ារេឌ, **អេធើរ** ១២:២១ ។ បងប្រុសរបស់យ៉ារេឌជា មនុស្សខ្លាំងពូកែខាងការសរសេរ, **អេធើរ** ១២:២៤ ។ តាមរយៈសេចក្ដីជំនឿនោះបងរបស់យ៉ារេឌបានរើភ្នំសេរិន, **អេធើរ** ១២:៣០ ។

**បងប្អូនស្រី** *សូមមើលផង* បងប្អូនប្រុស; ពួកបងប្អូនប្រុស; មនុស្ស, មនុស្សលោក

ជាកូនចៅនៃព្រះវរបិតារបស់យើង ដែលគង់នៅលើស្ថានសួគ៌ ម្ល៉ោះហើយ គ្រប់ទាំងពួកបុរស និងពួកស្ត្រី គឺជាបងប្អូននឹងគ្នា ខាងឯវិញ្ញាណ ។ នៅក្នុងសាសនាចក្រ សមាជិក និងមិត្តស្រីៗក្នុងសាសនាចក្រត្រូវហៅថា បងស្រី ។

អ្នកណាដែលធ្វើតាមព្រះហឫទ័យនៃព្រះវរបិតាខ្ញុំ គឺអ្នកនោះហើយជាប្អូនប្រុសប្អូនស្រីខ្ញុំ, **ម៉ាថាយ** ១២:៥០ (ម៉ាកុស ៣:៣៥) ។ ក្រិត្យវិន័យទាំងឡាយ ដែលចែងអំពីការសារភាពអំពើបាបទាំងឡាយ រវាងបងប្អូនប្រុសស្រី នៅក្នុងសាសនាចក្រ នោះត្រូវបាន រៀបរាប់ប្រាប់, **គ. និង ស.** ៤២:៨៨–៩៣ ។

**បង្កើត** *សូមមើលផង* កូនចៅព្រះគ្រីស្ទ; កើតពីព្រះ; កើតម្ដងទៀត, បង្កើតតែមួយ; បុត្រាបុត្រីនៃព្រះ

គឺកើត ។ បង្កើត គឺកើតកូន ធ្វើឲ្យមានជាតិកម្ម ឬឲ្យមានជីវិត ។ នៅក្នុងគម្ពីរ ពាក្យនេះតែងតែយកមកប្រើថាជា កើតពីព្រះ ។ ទោះជាព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតាក្នុងសាច់ឈាមក៏ដោយ គង់តែមនុស្សគ្រប់រូបអាចត្រឡប់ជា បុត្រាបុត្រីនៃព្រះគ្រីស្ទខាងវិញ្ញាណបានដែរ ដោយទទួលស្គាល់ព្រះអង្គ ដោយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយ ដោយក្លាយទៅជាមនុស្សថ្មី តាមរយៈព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។

យើងបានបង្កើតអ្នកនៅថ្ងៃនេះ, **ទំនុក.** ២:៧ (កិច្ចការ ១៣:៣៣; ហេព្រើរ ១:៥–៦; ៥:៥) ។ សិរីល្អនៃទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាបង្កើតតែមួយ ដែលមកពីព្រះវរបិតា, **យ៉ូហាន** ១:១៤ (២ នីហ្វៃ ២៥:១២; អាលម៉ា ១២:៣៣–៣៤; គ. និង ស. ៧៦:២៣) ។ ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាបង្កើតរបស់ទ្រង់តែមួយ, **យ៉ូហាន** ៣:១៦ (គ. និង ស. ២០:២១ ។ ព្រះគ្រីស្ទទ្រង់បានបង្កើតរាស្ត្រទ្រង់ដោយវិញ្ញាណ, **ម៉ូសាយ** ៥:៧ ។ អស់អ្នកណាដែលបានកើតមកដោយសារព្រះអម្ចាស់ សុទ្ធតែជាសាសនាចក្រនៃកូនច្បង, **គ. និង ស.** ៩៣:២២ ។

**បង្កើត, ការបង្កបង្កើត** *សូមមើលផង* ការបង្កបង្កើតខាងវិញ្ញាណ, ដើមដំបូង; ថ្ងៃឈប់សំរាក; ផែនដី; ព្រះយេស៊ូវគ្រីស្ទ

រៀបចំឡើង ។ ដោយបានធ្វើតាមរយៈព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រារបស់ទ្រង់ នោះព្រះទ្រង់បានរៀបចំវត្ថុធាតុក្នុងធម្មជាតិ ដើម្បីបង្កើតផែនដីឡើង ។ ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវបានធ្វើមនុស្សឲ្យដូចជារូបទ្រង់ (ម៉ូសេ ២:២៦–២៧) ។

កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី, **លោកុ.** ១:១ ។ ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង, **លោកុ.** ១:២៦ (ម៉ូសេ ២:២៦–២៧; អ័ប្រា. ៤:២៦) ។ គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់, **យ៉ូហាន** ១:៣, ១០ ។ គឺទ្រង់នេះហើយ ដែលបង្កើត គ្រប់ទាំងអស់ទាំងរបស់នៅស្ថានសួគ៌, **កូល៉ុស** ១:១៦ (ម៉ូសាយ ៣:៨; ហេលេ. ១៤:១២) ។ ព្រះទ្រង់បានបង្កើតពិភពលោកទាំង ឡាយ ដោយសារព្រះរាជបុត្រា, **ហេព្រើរ** ១:២ ។ មនុស្សបានត្រូវបង្កើតពីដំបូង, **ម៉ូសាយ** ៧:២៧ ។ យើងបានបង្កើតផ្ទៃមេឃ និងផែន ដី និងអស់ទាំងអ្វីៗ, ៣ នីហ្វៃ ៩:១៥ (មរមន ៩:១១, ១៧) ។ មនុស្សទាំងអស់បានត្រូវបង្កើតឡើង កាលពីដំបូង តាមរូបយើងផ្ទាល់, **អេធើរ** ៣:១៥ ។ ព្រះយេស៊ូវគ្រីស្ទបានបង្កើតផ្ទៃមេឃ និងផែនដី, **គ. និង ស.** ១៤:៩ ។ ទ្រង់បានបង្កើតមនុស្ស ជាប្រុសជាស្រី ឲ្យដូចជារូបរបស់ទ្រង់, **គ. និង ស.** ២០:១៨ ។ យើងបាន បង្កើតពិភពលោកដ៏ច្រើនឥតគណនា, **ម៉ូសេ** ១:៣៣ ។ ដោយសារ ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង នោះយើងបានបង្កើត ផ្ទៃមេឃ, **ម៉ូសេ** ២:១ ។ យើងជាព្រះអម្ចាស់ដ៏ជាព្រះ បានបង្កើតគ្រប់ របស់ទាំងអស់ខាងវិញ្ញាណ មុនមានរបស់ទាំងនោះនៅលើផែនដី តាមធម្មជាតិ, **ម៉ូសេ** ៣:៥ ។ ផែនដីរាប់លានដូចផែនដីនេះពុំមែន ជាការចាប់ផ្ដើមនូវចំនួននៃការបង្កបង្កើតរបស់ទ្រង់ដែរ, **ម៉ូសេ** ៧:៣០ ។ ពួកព្រះបានរៀបចំ ហើយសូននូវផ្ទៃមេឃ, **អ័ប្រា.** ៤:១ ។

**បង្កើតតែមួយ** *សូមមើលផង* បង្កើត; ព្រះយេស៊ូវគ្រីស្ទ

ជាព្រះនាមមួយទៀតសំរាប់ព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់ជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា (លូកា ១:២៦–៣៥; យ៉ូហាន

១:១៤; ៣:១៦; ១ នីហ្វៃ ១១:១៨–២០; ២ នីហ្វៃ ២៥:១២; អាលម៉ា ៧:១០; ១២:៣៣; ម៉ូសេ ៧:៦២) ។

**បង្ខំ, ការបង្ខិតបង្ខំ** *សូមមើលផង* ព្រះវិញ្ញាណបរិសុទ្ធ

គឺជម្រុញយ៉ាងខ្លាំងឲ្យធ្វើ ឬមិនឲ្យធ្វើអ្វីមួយ ជាពិសេស គឺដោយឥទ្ធិពល និងអំណាចពីព្រះវិញ្ញាណបរិសុទ្ធ ។

វិញ្ញាណដែលសណ្ឋិតនៅនឹងខ្ញុំ ក៏បណ្ដាលខ្ញុំ, **យ៉ូប** ៣២:១៨ ។ សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទបង្ខំយើងខ្ញុំ, **២ កូរិន.** ៥:១៤ ។ ខ្ញុំបាន ត្រូវបង្ខំដោយព្រះវិញ្ញាណ ថាខ្ញុំគួរតែសម្លាប់ឡាបាន់, **១ នីហ្វៃ** ៤:១០ ។ ព្រះវិញ្ញាណរារាំងខ្ញុំ, **អាលម៉ា** ១៤:១១ ។ ខ្ញុំត្រូវបានបង្ខំតាមសេចក្ដីសញ្ញា, **អាលម៉ា** ៦០:៣៤ ។ អាំម៉ារុនបានលាក់បញ្ជីទុកដោយព្រះវិញ្ញាណបរិសុទ្ធបានបង្ខិតបង្ខំ, **៤ នីហ្វៃ** ១:៤៨ ។ អ្វីដែលមកពីលើ ត្រូវតែមកដោយការទប់ពីព្រះវិញ្ញាណ, **គ. និង ស.** ៦៣:៦៤ ។

**បង្រៀន, គ្រូបង្រៀន** *សូមមើលផង* ព្រះវិញ្ញាណបរិសុទ្ធ

ផ្ដល់ចំណេះដល់អ្នកឯទៀត ជាពិសេស អំពីសេចក្ដីពិតនៃដំណឹងល្អ ហើយណែនាំពួកគេឲ្យទៅរកសេចក្ដីសុចរិត ។ ពួកអ្នកណា ដែលបង្រៀនដំណឹងល្អ ត្រូវបានដឹកនាំដោយព្រះវិញ្ញាណ ។ ឪពុកម្ដាយទាំងអស់ គឺជាគ្រូបង្រៀន នៅក្នុងគ្រួសាររបស់ខ្លួន ។ ពួកបរិសុទ្ធត្រូវស្វែងរក ហើយយល់ព្រមទទួលនូវការបង្គាប់ទាំងឡាយពីព្រះអម្ចាស់ និងពីពួកអ្នកដឹកនាំរបស់ទ្រង់ ។

ត្រូវឲ្យឯងប្រាប់ពីការណ៍ទាំងនោះដល់កូនចៅឯង, **ចោទិ.** ៤:៨–៩ ។ ត្រូវឲ្យប្រិតប្រៀនសេចក្ដីទាំងនេះ ដល់កូនចៅឯង, **ចោទិ.** ៦:៧ (ចោទិ. ១១:១៨–១៩) ។ ចូរបង្ហាត់កូនក្មេង ឲ្យប្រព្រឹត្តតាមផ្លូវ ដែលគួរប្រព្រឹត្ត, **សុភា.** ២២:៦ ។ កូនចៅទាំងប៉ុន្មានរបស់ឯង នឹងធ្វើ ជាសិស្សរបស់ព្រះអម្ចាស់, **អេសាយ** ៥៤:១៣ (៣ នីហ្វៃ ២២:១៣) ។ យើងខ្ញុំដឹងថា លោកជាគ្រូមកពីព្រះពិត, **យ៉ូហាន** ៣:២ ។ អ្នកឯងដែលបង្រៀនគេ តើមិនបង្រៀនខ្លួនឯងទេឬអី ? **រ៉ូម** ២:២១ ។ ខ្ញុំបានទទួលការបង្រៀនខ្លះៗ នូវចំណេះវិជ្ជាទាំងអស់របស់ ឪពុកខ្ញុំ, **១ នីហ្វៃ** ១:១ (អេណុស ១:១) ។ ពួកសង្ឃ និងពួកគ្រូត្រូវព្យាយាមបង្រៀន ឬក៏ត្រូវទទួលអំពើបាបទាំងឡាយរបស់មនុស្ស មកលើក្បាលរបស់ខ្លួន, **យ៉ាកុប** ១:១៨–១៩ ។ សូមប្រុងស្ដាប់តាមយើង ហើយសូមបើកត្រចៀករបស់អ្នករាល់គ្នាចុះ, **ម៉ូសាយ** ២:៩ ។ អ្នករាល់គ្នាត្រូវបង្រៀនកូនចៅអ្នក ឲ្យស្រឡាញ់ ហើយបំរើគ្នាទៅវិញទៅមក, **ម៉ូសាយ** ៤:១៥ ។ ចូរកុំទុកចិត្តលើនរណាម្នាក់ ឲ្យធ្វើ ជាគ្រូអ្នកឡើយ លើកលែងតែអ្នកនោះជាមនុស្សមកពីព្រះ, **ម៉ូសាយ** ២៣:១៤ ។ ព្រះអម្ចាស់ទ្រង់បានស្រោចព្រះវិញ្ញាណទ្រង់ មកលើ អស់ទាំងដែនដី ដើម្បីរៀបចំចិត្តគំនិតគេ ឲ្យទទួលព្រះបន្ទូល, **អាលម៉ា** ១៦:១៦ ។ ពួកគេបានបង្រៀនដោយអានុភាព និងសិទ្ធិអំណាច ពីព្រះ, **អាលម៉ា** ១៧:២–៣ ។ ពួកគេត្រូវបានបង្រៀនដោយម្ដាយគេ, **អាលម៉ា** ៥៦:៤៧ (អាលម៉ា ៥៧:២១) ។ ដរាបណាពួកគេ ស្វែងរកប្រាជ្ញា នោះពួកគេអាចបានទទួលការបង្គាប់, **គ. និង ស.** ១:២៦ ។ ចូរបង្រៀនគ្នាទៅវិញទៅមក ស្របតាមតំណែងដែល យើងបានតែងដល់អ្នកចុះ, **គ. និង ស.** ៣៨:២៣ ។ ត្រូវបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុង ព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន, **គ. និង ស.** ៤២:១២ ។ អ្នករាល់គ្នាត្រូវបានទទួលការបង្រៀនមកពីស្ថានលើ, **គ. និង ស.** ៤៣:១៥–១៦ ។ ឪពុកម្ដាយទាំងឡាយត្រូវបង្រៀនកូនចៅរបស់ខ្លួន, **គ. និង ស.** ៦៨:២៥–២៨ ។ ត្រូវបង្រៀនគ្នាទៅវិញទៅមក នូវគោលលទ្ធិនៃនគរ, **គ. និង ស.** ៨៨:៧៧–៧៨, ១១៨ ។ ចូរតាំងគ្រូមួយនៅក្នុងចំណោមអ្នករាល់គ្នា, **គ. និង ស.** ៨៨:១២២ ។ អ្នកពុំបានបង្រៀនកូនចៅរបស់ខ្លួនពីពន្លឺ និងសេចក្ដីពិត និងនេះហើយជាហេតុនៃសេចក្ដីវេទនារបស់អ្នក, **គ. និង ស.** ៩៣:៣៩–៤២ ។ ចូរបង្រៀនការណ៍ទាំងនេះដោយសេរី ដល់កូនចៅអ្នកចុះ, **ម៉ូសេ** ៦:៥៧–៦១ ។

*ការបង្រៀនដោយនូវព្រះវិញ្ញាណ៖* មិនមែនជាអ្នករាល់គ្នាត្រូវនិយាយទេ គឺជាព្រះវិញ្ញាណទេតើ ដែលទ្រង់មានបន្ទូលក្នុងខ្លួនអ្នក, **ម៉ាថាយ** ១០:១៩–២០ ។ តើយើងមិនមានសេចក្ដីខ្នះខ្នាញ់នៅក្នុងចិត្ត ក្នុងពេលដែលទ្រង់បានសម្ដែងពីគម្ពីរនឹងយើងទេឬអី ? **លូកា** ២៤:៣២ ។ ដំណឹងល្អគឺបានប្រកាសប្រាប់ ដោយព្រះចេស្ដានៃព្រះវិញ្ញាណ, **១ កូរិន.** ២:១–១៤ ។ លោកបាននិយាយដោយអានុភាព ព្រះចេស្ដា និងសិទ្ធិអំណាចពីព្រះ, **ម៉ូសាយ** ១៣:៥–៩ (អាលម៉ា ១៧:៣; ហេលេ. ៥:១៧) ។ អ្នកនឹងបានព្រះវិញ្ញាណរបស់យើង ដើម្បី បញ្ចុះបញ្ចូលមនុស្សលោក, **គ. និង ស.** ១១:២១ ។ នឹងបានឮពីអ្នក នូវអ្វីៗគ្រប់យ៉ាង ដែលអ្នកនឹងបង្រៀនពួកគេ ដោយសារព្រះដ៏ជា ជំនួយ, **គ. និង ស.** ២៨:១ (គ. និង ស. ៥២:៩) ។ បើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវ បង្រៀនឡើយ, **គ. និង ស.** ៤២:១៤ (គ. និង ស. ៤២:៦) ។ ចូរបង្រៀនកូនចៅមនុស្សពីអ្វីៗ ដោយព្រះចេស្ដានៃព្រះវិញ្ញាណរបស់ យើង, **គ. និង ស.** ៤៣:១៥ ។ ពួកអែលឌើរត្រូវផ្សាយដំណឹងល្អ ដោយព្រះវិញ្ញាណ, **គ. និង ស.** ៥០:១៣–២២ ។ សេចក្ដីដែលត្រូវ និយាយ នឹងបានប្រទានដល់អ្នករាល់គ្នានៅចំពេលនោះឯង, **គ. និង ស.** ៨៤:៨៥ (គ.និង ស. ១០០:៥–៨) ។

**បញ្ញា, បញ្ញាទាំងឡាយ** *សូមមើលផង* ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ; ព្រះវិញ្ញាណ; សេចក្ដីពិត

បញ្ញាមានន័យច្រើនយ៉ាង រីឯន័យបីយ៉ាង គឺ៖ (១) គឺជាពន្លឺនៃសេចក្ដីពិត ដែលបង្កើតជីវិត និងពន្លឺដល់គ្រប់អ្វីៗទាំងអស់នៅក្នុង សាកលលោក ។ បញ្ញាមានមករហូត ។ (២) ពាក្យថា*បញ្ញាទាំងឡាយ* ក៏អាចស្ដីអំពីកូនចៅវិញ្ញាណនៃព្រះ ។ (៣) គម្ពីរក៏បាន ថែងអំពីបញ្ញាជាធាតុវិញ្ញាណ ដែលមានមកមុនយើងកើតជាកូនចៅវិញ្ញាណ ។

បញ្ញានៅជាប់នឹងបញ្ញា, **គ. និង ស.** ៨៨:៤០ ។ បញ្ញាពុំបានបង្កើត ឬធ្វើឡើងឡើយ, **គ. និង ស.** ៩៣:២៩ ។ បញ្ញាទាំងអស់គឺមានសេរីនៅក្នុងវិស័យដែលព្រះទ្រង់បានដាក់វាទុក, **គ. និង ស.** ៩៣:៣០ ។ សិរីល្អនៃព្រះ គឺជាបញ្ញា, **គ. និង ស.** ៩៣:៣៦–៣៧ ។ បញ្ញា

ណាដែលបាននៅក្នុងជីវិតនេះ នោះនឹងនៅជាប់នឹងយើង ក្នុងដំណើររស់ឡើងវិញ, **គ. និង ស.** ១៣០:១៨–១៩ ។ ព្រះអម្ចាស់ទ្រង់គ្រប់គ្រងលើបញ្ញាទាំងអស់, **អ័ប្រា.** ៣:២១ ។ ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់អ័ប្រាហាំ នូវបញ្ញាទាំងឡាយដែលត្រូវបានបង្កើតឡើង មុនកំណើតលោកិយមកម្ល៉េះ, **អ័ប្រា.** ៣:២២ ។

**បញ្ញាចិត្ត, សតិ, សតិសម្បជញ្ញៈ** *សូមមើលផង* ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ

ជាការចាប់អារម្មណ៍នៅក្នុងចិត្តអំពីការដឹងខុសត្រូវ គឺមានមកពីពន្លឺនៃព្រះគ្រីស្ទដែលនៅក្នុងមនុស្សទាំងអស់(មរ៉ូណៃ ៧:១៦) ។ ពួកយើងកើតមកដោយមានសមត្ថភាពតាមធម្មជាតិ ដើម្បីដឹងការខុសត្រូវ ដោយសារពន្លឺនៃព្រះគ្រីស្ទ ដែលបានប្រទានដល់មនុស្សគ្រប់រូប (គ. និង ស. ៨៤:៤៦) ។ ញាណនេះហៅថា សតិសម្បជញ្ញៈ ។ ការដែលមានសតិសម្បជញ្ញៈ នោះធ្វើឲ្យយើងទៅជាអ្នកដឹងខុសត្រូវ ។ ដូចជាញាណផ្សេងៗទៀត ឯសតិសម្បជញ្ញៈរបស់យើងអាចស្លាប់ ដោយសារអំពើបាប ឬដោយសារការប្រើខុសបែបបទ ។

ពួកអាចារ្យ និងពួកផារិស៊ីបានចោទប្រកាន់ទោសខ្លួន ដោយបញ្ញាចិត្តគេ, **យ៉ូហាន** ៨:៩ ។ បញ្ញាចិត្តគេក៏ធ្វើបន្ទាល់ឲ្យ, **រ៉ូម** ២:១៤–១៥ ។ ពួកក្បត់សាសនាមានបញ្ញាចិត្តរបស់គេរលាកនឹងដែកភ្លើង, ១ ធីម៉ូ. ៤:២ ។ មនុស្សលោកបានប្រៀនប្រដៅគ្រប់គ្រាន់ ឲ្យដឹងខុស និងត្រូវ, **២ នីហ្វៃ** ២:៥ ។ ស្ដេចបេនយ៉ាមីនមានសតិសម្បជញ្ញៈដ៏ជ្រះថ្លាចំពោះព្រះ, **ម៉ូសាយ** ២:១៥ ។ ពួកសាសន៍នីហ្វៃពោរពេញទៅដោយសេចក្ដីអំណរ ដោយបានស្ងប់ស្ងាត់ក្នុងសតិសម្បជញ្ញៈ, **ម៉ូសាយ** ៤:៣ ។ ស៊ីអែសរ៉ុមបានកើតទុក្ខ ដោយដឹងនូវ កំហុសរបស់ខ្លួន, **អាលម៉ា** ១៤:៦ ។ យើងបានត្រូវប្រទានសេចក្ដីអំណរ ឬសេចក្ដីសោកស្ដាយនៃសតិសម្បជញ្ញៈ ស្របតាមតែសេចក្ដីប៉ងប្រាថ្នារបស់យើង, **អាលម៉ា** ២៩:៥ ។ ការធ្វើទោស និងច្បាប់ដ៏យុត្តិធមិមួយនាំមកនូវការសោកស្ដាយនៅក្នុងស្មារតី, **អាលម៉ា** ៤២:១៨ ។ ព្រះវិញ្ញាណនៃព្រះគ្រីស្ទត្រូវបានប្រទានដល់មនុស្សរាល់គ្នា ដើម្បីឲ្យគេអាចដឹងខុស និងត្រូវ, **មរ៉ូណៃ** ៧:១៦ ។ បុគ្គល និមួយៗ គួរមានសេរីភាពខាងសតិសម្បជញ្ញៈ, **គ. និង ស.** ១៣៤:២ ។ ខ្ញុំគ្មានសតិទាស់ឡើយ, **គ. និង ស** ១៣៥:៤ ។ យើងខ្ញុំសូមអះ អាងយកសិទ្ធិក្នុងការថ្វាយបង្គំព្រះ ស្របតាមការណែនាំនៃសម្បជញ្ញៈរបស់យើងខ្ញុំ, **ម. នៃ ស.** ១:១១ ។

**បណ្ដាសា, បណ្ដាសាទាំងឡាយ** *សូមមើលផង* សេចក្ដីផាប់ទោស; សេចក្ដីមើលងាយ

នៅក្នុងគម្ពីរ បណ្ដាសា គឺជាការប្រើក្រិត្យវិន័យពីព្រះ ដែលបណ្ដោយ ឬនាំឲ្យមានការជំនុំជំរះ និងវិបាកពីការជំនុំជំរះទាំងឡាយមកលើ អ្វី ជន ឬរាស្ត្រណាមួយ ដោយព្រោះតែអំពើគតសុចរិតជាហេតុទីមួយ ។ បណ្ដាសាទាំងឡាយ គឺជាការសម្ដែងនូវសេចក្ដីស្រឡាញ់ និងសេចក្ដីយុត្តិធមិដ៏ឧត្ដមពីព្រះ ។ បណ្ដាសាទាំងនោះអាចបានដាក់ដោយព្រះពិត ឬដាក់ដោយពួកអ្នកបំរើរបស់ទ្រង់ ដែលមានសិទ្ធិអំណាច ។ ជួនកាល ហេតុផលពេញទីនៃបណ្ដាសា នោះមានតែព្រះទេដែលជ្រាប ។ ថែមទៀត បណ្ដាសាដែល បានដាក់មកគឺជា ការពិសោធន៏នៃអស់អ្នកណាដែលមិនគោរពព្រះដោយចេតនាម្ល៉ោះហើយ ទើបពួកគេថយចេញពីព្រះវិញ្ញាណ នៃព្រះអម្ចាស់ ។

ព្រះអម្ចាស់ទ្រង់អាចដកបណ្ដាសាទាំងឡាយចេញ មកពីសេចក្ដីជំនឿរបស់បុគ្គលនិមួយៗ ឬរបស់ប្រជាជន ដែលជឿដល់ព្រះយេស៊ូវគ្រីស្ទ និងការគោរពដល់ក្រិត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ (អាលម៉ា ២៣:១៦–១៨, ៣ នីហ្វៃ ២:១៤–១៦; ម. នៃ ស. ១:៣) ។

ព្រះទ្រង់បានដាក់បណ្ដាសាដល់ពស់ ដោយបានល្បួងបញ្ឆោតលោកអ័ដាម និងនាងអេវ៉ា, **លោកុ.** ៣:១៣–១៥ (ម៉ូសេ ៤:១៩–២១) ។ ដីត្រូវបណ្ដាសា ដោយយល់ដល់លោកអ័ដាម និងនាងអេវ៉ា, **លោកុ.** ៣:១៧–១៩ (ម៉ូសេ ៤:២៣–២៥) ។ ព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដល់កាអ៊ីន ដោយបានសម្លាប់អេបិល, **លោកុ.** ៤:១១–១៦ (ម៉ូសេ ៥:២២–៤១) ។ ព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដល់កាណាន និងពូជពង្សគាត់, **លោកុ.** ៩:២៥–២៧ (ម៉ូសេ ៧:៦–៨; អ័ប្រា. ១:២១–២៧) ។ ពួកអ៊ីស្រាអែលនឹងត្រូវបានព្រះពរ បើសិនជាគោរពតាមព្រះ ហើយត្រូវបណ្ដាសា បើសិនជាមិនគោរពវិញ, **ចោទិ.** ២៨:១–៦៨ (ចោទិ. ២៩:១៨–២៨) ។ គេហាស៊ី និងពូជពង្សគាត់ត្រូវបណ្ដាសាកើតឃ្លង់នៃណាម៉ាន់, **២ ពង្សាវ.** ៥:២០–២៧ ។ ព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដល់ពួកសាសន៍អ៊ីស្រាអែល ពីបុរាណដែលមិនបានថ្វាយដង្វាយ១ភាគ១០ និងដង្វាយនានា, **ម៉ាឡាគី** ៣:៦–១០ ។ ព្រះយេស៊ូវបានដាក់បណ្ដាសាដល់ដើមល្វា ហើយដើមល្វានោះក៏ងាប់ទៅ, **ម៉ាកុស** ១១:១១–១៤, ២០–២១ ។ ព្រះយេស៊ូវបានដាក់បណ្ដាសាដល់ក្រុងខូរ៉ាស៊ីន ក្រុងបេតសៃដា និងក្រុងកាពើណិម, **លូកា** ១០:១០–១៥ ។ ពីព្រោះពួកសាសន៍លេមិនមិនព្រមស្ដាប់តាមព្រះអម្ចាស់ នោះពួកគេត្រូវបានបែកចេញពី វត្តមាននៃព្រះអម្ចាស់ ហើយត្រូវបណ្ដាសា, **២ នីហ្វៃ** ៥:២០–២៤ ។ មនុស្សទាំងអស់ត្រូវបានអញ្ជើញឲ្យមករកព្រះ, **២ នីហ្វៃ** ២៦:៣៣ ។ ព្រះអម្ចាស់ទ្រង់នឹងដាក់បណ្ដាសាដល់អស់អ្នកណាដែលប្រព្រឹត្តអំពើសហាយស្មន់, **យ៉ាកុប** ២:៣១–៣៣ ។ ពួកសាសន៍នីហ្វៃនឹង ត្រូវបណ្ដាសាធំធ្ងន់ ជាងពួកសាសន៍លេមិន លើកលែងតែពួកគេប្រែចិត្ត, **យ៉ាកុប** ៣:៣–៥ ។ ប្រជាជនដែលបះបោរ គេយកបណ្ដាសា មកលើខ្លួនផ្ទាល់, **អាលម៉ា** ៣:១៨–១៩ (ចោទិ. ១១:២៦–២៨) ។ កូរីហ៊ូរត្រូវបណ្ដាសា ដោយបានដឹកនាំប្រជាជនចេញពីព្រះ, **អាលម៉ា** ៣០:៤៣–៦០ ។ ព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដល់ដែនដី និងទ្រព្យសម្បត្តិរបស់ពួកសាសន៍នីហ្វៃ ដោយព្រោះតែសេចក្ដី ទុច្ចរិតរបស់ប្រជាជន, **ហេលេ.** ១៣:២២–២៣ (២ នីហ្វៃ ១:៧; អាលម៉ា ៣៧:៣១) ។ ព្រះអម្ចាស់ទ្រង់បានដាក់បណ្ដាសាដល់ពួក សាសន៍យ៉ារេឌដែលទុច្ចរិត, **អេធើរ** ៩:២៨–៣៥ ។ ដង្វាយធួនរបស់ព្រះគ្រីស្ទដកបណ្ដាសានៃលោកអ័ដាមចេញពីកូនក្មេងតូចៗ, **មរ៉ូណៃ** ៨:៨–១២ ។ អស់អ្នកណាដែលបែរចេញពីព្រះអម្ចាស់ នោះត្រូវបណ្ដាសា, **គ. និង ស.** ៤១:១ ។ ផែនដីនឹងត្រូវបានវាយ ដោយសេចក្ដីបណ្ដាសា

លើកលែងតែមានចំណងភ្ជាប់មួយ រវាងពួកឪពុកនឹងកូនៗ, **គ. និង ស.** ១២៨:១៨ (ម៉ាឡាគី ៤:៥–៦) ។

*សេចក្ដីមើលងាយ៖* ការជេរប្រទេចផ្ដាសាក៏ជាការប្រើពាក្យដែលមើលងាយ ប្រមាថ ឬចំអក ។

ប្រជាជនមិនត្រូវប្រទេចផ្ដាសាឪពុក ឬម្ដាយឡើយ, **និក្ខ.** ២១:១៧ (ម៉ាថាយ ១៥:៤) ។ កុំឲ្យជេរប្រទេចដល់អស់អ្នកណាដែលត្រួតត្រាលើអ្នកឡើយ, **និក្ខ.** ២២:២៨ (សាស្ដា ១០:២០) ។ មនុស្សប្រុសស្រីមិនត្រូវជេរប្រទេចដល់ព្រះឡើយ, **លេវី.** ២៤:១៣–១៦ ។ ពេត្រុសបានជេរប្រមាថ កាលគាត់បានបដិសេធថាមិនស្គាល់ព្រះយេស៊ូវ, **ម៉ាថាយ** ២៦:៦៩–៧៤ ។ ពួកសាសន៍នីហ្វៃដែលទុច្ចរិតបានប្រទេចផ្ដាសាដល់ព្រះ ហើយចង់ស្លាប់, **មរមន** ២:១៤ ។

**បទចំរៀងសាឡូម៉ូន**

ជាគម្ពីរមួយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា បទចំរៀងសាឡូម៉ូន គឺមិនមែនជាការនិពន្ធ ដែលប្រកបដោយការបំផុសគំនិតទេ ។

**បទបង្រៀននៅលើភ្នំ** *សូមមើលផង* បទប្រទានពរ;
ព្រះយេស៊ូវគ្រីស្ទ

ជាសេចក្ដីថ្លែងដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទ ចំពោះពួកសិស្សទ្រង់ដែលនឹងត្រូវចាត់ឲ្យទៅធ្វើបេសកកម្ម (ម៉ាថាយ ៥–៧; លូកា ៦:២០–៤៩) ។ ព្រះអម្ចាស់ទ្រង់បានបង្រៀនបទនេះបន្ទាប់ពីបានហៅពួក១២នាក់ភ្លាម ។

បទបង្រៀននេះត្រូវបានបញ្ជាក់ដោយការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស្ម៊ីធ និងដោយបទបង្រៀនប្រហែលគ្នា ដែលបានកត់ទុក នៅក្នុងគម្ពីរនីហ្វៃ ទី៣ ជំពូកទី ១២–១៤ ដែលបង្ហាញថា វគ្គសំខាន់ទាំងឡាយនៅក្នុងបទបង្រៀននោះដែលបានបាត់ពីដំណើររឿង នៅក្នុងគម្ពីរម៉ាថាយ ។

**បទប្រទានពរ** *សូមមើលផង* បទបង្រៀននៅលើភ្នំ

ជាសេចក្ដីបង្រៀនទាំងឡាយដែលព្រះយេស៊ូវបានប្រទាននៅក្នុងបទបង្រៀននៅលើភ្នំ ដែលអធិប្បាយប្រាប់អំពីចរិតដ៏ល្អ និងខាង វិញ្ញាណ (ម៉ាថាយ ៥:៣–១២; លូកា ៦:២០–២៣) ។ បទប្រទានពរត្រូវបានចងក្រងតាមរបៀបណាមួយ ដែលធ្វើឲ្យបទថ្លែងនីមួយៗ លំនាំទៅលើបទថ្លែងពីមុន ។ បញ្ជីដែលផ្ដល់យោបល់ ហើយឲ្យន័យច្បាស់ជាង នោះរកឃើញនៅក្នុងគម្ពីរនីហ្វៃទី ៣ ជំពូកទី ១២ ។

**បទព្រះគម្ពីរ** *សូមមើលផង* កាណុង; គោលលទ្ធិ
និងសេចក្ដីសញ្ញា; ព្រះគម្ពីរប៊ីប; ព្រះគម្ពីរមរមន;
ព្រះបន្ទូលនៃព្រះ, មុក្ដាដ៏មានតម្លៃមហិមា; លំដាប់ពេល

ជាពាក្យពេចន៍ ព្រមទាំងពាក្យសរសេរ និងពាក្យនិយាយ ដោយពួកបុរសបរិសុទ្ធនៃព្រះ កាលបានសណ្ឋិតដោយព្រះវិញ្ញាណបរិសុទ្ធ ។ សព្វថ្ងៃ បទព្រះគម្ពីរកាណុងមាន ព្រះគម្ពីរប៊ីប, ព្រះគម្ពីរមរមន, គោលលទ្ធិ និងសេចក្ដីសញ្ញា, និងមុក្ដាដ៏មានតម្លៃមហិមា ។ ព្រះយេស៊ូវ និងពួកអ្នកសរសេរទាំងប៉ុន្មាន នៅក្នុងព្រះគម្ពីរសញ្ញាថ្មី បានរាប់គម្ពីរទាំងប៉ុន្មាននៅក្នុងព្រះគម្ពីរសញ្ញាចាស់ថា ជាបទគម្ពីរ (ម៉ាថាយ ២២:២៩; យ៉ូហាន ៥:៣៩; ២ ធីម៉ូ. ៣:១៥; ២ ពេត្រុស ១:២០–២១) ។

តើយើងមិនមានសេចក្ដីខ្វល់ខ្វាញ់នៅក្នុងចិត្ត នៅពេលដែលទ្រង់បើកសម្ដែងពីគម្ពីរដល់យើង, **លូកា** ២៤:៣២ ។ ស្ទង់មើលគម្ពីរដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ច អំពីគម្ពីរនោះមក គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ, **យ៉ូហាន** ៥:៣៩ ។ ព្រះបន្ទូលនៃព្រះគ្រីស្ទនឹងប្រាប់ដល់អ្នក នូវគ្រប់អ្វីៗទាំងអស់ ដែលអ្នកត្រូវធ្វើ, **២ នីហ្វៃ** ៣២:៣ ។ មនុស្សជាច្រើនណា ដែលបានដឹកនាំមកឲ្យជឿដល់ព្រះគម្ពីរបរិសុទ្ធទាំងឡាយ គឺជាជនរឹងប៉ឹង និងខ្ជាប់ខ្ជួន ក្នុងសេចក្ដីជំនឿ, **ហេលេ.** ១៥:៧–៨ ។ មនុស្សលោកធ្វើខុស ក្នុងការ បង្វែរបទគម្ពីរទាំងឡាយ ហើយមិនយល់បទគម្ពីរទាំងនោះទេ, **គ. និង ស.** ១០:៦៣ ។ ព្រះបន្ទូលទាំងនេះ ពុំមែនជាពាក្យនៃមនុស្ស លោក ឬនៃមនុស្សទេ ប៉ុន្តែជាព្រះបន្ទូលរបស់យើង, **គ. និង ស.** ១៨:៣៤–៣៦ ។ ការចេញមកនៃព្រះគម្ពីរមរមន បញ្ជាក់ដល់ពិភព លោកថា បទគម្ពីរដ៏បរិសុទ្ធទាំងឡាយ គឺត្រឹមត្រូវ, **គ. និង ស.** ២០:២; ៨–១២ ។ អ្នកត្រូវចំណាយពេលវេលារបស់អ្នក ដើម្បីការ សិក្សាព្រះគម្ពីរ, **គ. និង ស.** ២៦:១ ។ ព្រះគម្ពីរត្រូវបានប្រទានមក សំរាប់ការបង្គាប់ដល់ពួកបរិសុទ្ធ, **គ. និង ស.** ៣៣:១៦ ។ បទគម្ពីរ ទាំងឡាយនឹងត្រូវបានប្រទានឲ្យ ដើម្បីសេចក្ដីសង្គ្រោះដល់ពួកដែលយើងរើសតាំង, **គ. និង ស.** ៣៥:២០ ។ ត្រូវបង្រៀនគោល ការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន, **គ. និង ស.** ៤២:១២ ។ ក្រិត្យវិន័យ ទាំងឡាយរបស់យើង ដែលស្ដីអំពីការណ៍ទាំងនេះ ត្រូវបានប្រទានឲ្យនៅក្នុងព្រះគម្ពីររបស់យើងហើយ, **គ. និង ស.** ៤២:២៨ ។ អ្វីក៏ដោយដែលនិយាយ កាលណាបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះគឺជាបទគម្ពី, **គ. និង ស.** ៦៨:៤ ។

*ព្រះគម្ពីរដែលបាត់៖* មានការសរសេរដ៏ពិសិដ្ឋជាច្រើន ដែលបានពោលដល់នៅក្នុងព្រះគម្ពីរ ដែលពួកយើងពុំមាននៅសព្វថ្ងៃនេះ ក្នុងចំណោមការសរសេរពិសិដ្ឋទាំងនោះ គឺគម្ពីរ និងពួកអ្នកនិពន្ធទាំងឡាយ៖ សេចក្ដីសញ្ញា (និក្ខ. ២៤:៧), សង្គ្រាមទាំងឡាយនៃ ព្រះអម្ចាស់ (ជនគ. ២១:១៤), យ៉ាសើរ (យ៉ូស្វេ ១០:១៣; ២ សាំយូ. ១:១៨), កិច្ចការរបស់សាឡូម៉ូន (១ ពង្សាវ. ១១:៤១), សាំយូអែលជាអ្នកមើលឆុត (១ របា. ២៩:២៩), ណាថាន់ ជាព្យាការី (២ របា. ៩:២៩), សេម៉ាយ៉ា ជាព្យាការី (២ របា. ១២:១៥), អ៊ីដោ ជាព្យាការី (២ របា. ១៣:២២), យេហ៊ូវ (២ របា. ២០:៣៤), ពាក្យសំដីនៃពួកអ្នកមើលឆុត (២ របា. ៣៣:១៩), ហេណុក (យូដាស ១:១៤), និងពាក្យសំដីនៃស៊ីណុក, ពាក្យសំដីនៃនីអ៊ុម និងពាក្យសំដីនៃស៊ីណូស (១ នីហ្វៃ ១៩:១០), ស៊ីណូស (យ៉ាកុប ៥:១), ស៊ីណុក និងអេសាយ៉ាស (ហេលេ. ៨:២០), និងសៀវភៅពួក

(ម៉ូសេ ៦:៥), និងសំបុត្រទាំងឡាយទៅដល់ពួកកូរិនថូស (១ កូរិន. ៥:៩), ទៅដល់ពួកអេភេសូរ (អេភេ. ៣:៣) និងសំបុត្រមកពីពួកឡៅឌីសេ (កូល៉ុស ៤:១៦) ។

*ព្រះគម្ពីរដែលត្រូវរក្សាទុក៖* យើងត្រូវតែយកបញ្ជីប្រវត្តិទាំងនេះ ដើម្បីឲ្យយើងអាចរក្សា នូវពាក្យពេចន៍ទាំងឡាយ ដែលបានពោល ដោយពួកព្យាការី, **១ នីហ្វៃ** ៣:១៩–២០ ។ ខ្ញុំត្រូវរក្សាផ្ទាំងទាំងនេះទុកឲ្យបានគង់វង់, **យ៉ាកុប** ១:៣ ។ វត្ថុទាំងនេះត្រូវបានរក្សាទុក ដោយព្រះហស្តនៃព្រះ, **ម៉ូសាយ** ១:៥ ។ ចូរថែរក្សាវត្ថុពិសិដ្ឋទាំងនេះទុក, **អាលម៉ា** ៣៧:៤៧ ។ បទព្រះគម្ពីរនឹងត្រូវបានរក្សាទុកឲ្យ បានគង់វង់, **គ. និង ស.** ៤២:៥៦ ។ ត្រូវខំប្រើសេចក្ដីព្យាយាមដ៏អស់ពីចិត្ត ដើម្បីរក្សាវត្ថុទាំងនោះទុក, **យ.ស. — ប្រវត្តិ** ១:៥៩ ។

*តម្លៃនៃព្រះគម្ពីរ៖* ត្រូវឲ្យមើលក្រិត្យវិន័យនេះ នៅចំពោះមុខពួកអ៊ីស្រាអែលទាំងអស់, **ចោទិ.** ៣១:១០–១៣ ។ កុំឲ្យគម្ពីរក្រិត្យវិន័យនេះភ្លេចបាត់ពីមាត់ឯងឡើយ, **យ៉ូស្វេ** ១:៨ ។ ក្រិត្យវិន័យរបស់ព្រះអម្ចាស់ នោះគ្រប់លក្ខណ៍ ក៏កែព្រលឹងឡើងវិញ, **ទំនុក.** ១៩:៧ ។ ព្រះបន្ទូលនៃទ្រង់ ជាចង្កៀងដល់ជើងទូលបង្គំ, **ទំនុក.** ១១៩:១០៥ ។ គម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ, **យ៉ូហាន** ៥:៣៩ ។ គ្រប់ទាំងបទគម្ពីរ បានប្រទានមក ដោយការសណ្ឋិតឲ្យតែងពីព្រះ ហើយក៏មានប្រយោជន៍សំរាប់ការបង្រៀន និងការបង្ហាត់, **២ ធីម៉ូ.** ៣:១៥–១៦ ។ ខ្ញុំបានប្រៀបធៀបបទគម្ពីរទាំងអស់ ទៅនឹងខ្លួនយើង ដើម្បីទុកជាប្រយោជន៍ និងការចេះដឹងដល់យើង, **១ នីហ្វៃ** ១៩:២៣ ។ ព្រលឹងខ្ញុំរីករាយ នៅក្នុងបទគម្ពីរទាំងឡាយ, **២ នីហ្វៃ** ៤:១៥–១៦ ។ យើងបានព្យាយាមខំសរសេរ ដើម្បីបញ្ចុះបញ្ចូល កូនចៅយើង និងបងប្អូនយើងផង ដើម្បីឲ្យជឿដល់ព្រះគ្រីស្ទ, **២ នីហ្វៃ** ២៥:២៣ ។ ពួកគេបានពិចារណាមើលបទព្រះគម្ពីរ ហើយ ឈប់ស្ដាប់តាមពាក្យរបស់មនុស្សទុច្ចរិតនេះទៅ, **យ៉ាកុប** ៧:២៣ (អាលម៉ា ១៤:១) ។ បើពុំដោយសារផ្ទាំងទាំងនេះទេ យើងច្បាស់ ជាត្រូវរងទុក្ខ នៅក្នុងភាពល្ងង់ខ្លៅ, **ម៉ូសាយ** ១:២–៧ ។ ពួកគេបានពិចារណាមើលបទព្រះគម្ពីរ យ៉ាងព្យាយាម ដើម្បីគេអាចស្គាល់ ព្រះបន្ទូលនៃព្រះ, **អាលម៉ា** ១៧:២–៣ ។ បទគម្ពីរទាំងឡាយត្រូវបានរក្សាទុក ដើម្បីនាំព្រលឹងទាំងឡាយ ទៅរកសេចក្ដីសង្គ្រោះ, **អាលម៉ា** ៣៧:១–១៩ (២ នីហ្វៃ ៣:១៥) ។ ព្រះបន្ទូលនៃព្រះនឹងដឹកនាំមនុស្សរបស់ព្រះគ្រីស្ទ, **ហេលេ.** ៣:២៩ ។ អ្វីក៏ដោយដែល ពួកគេនឹងនិយាយ កាលណាបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាបទគម្ពីរ ហើយជាព្រះចេស្ដានៃព្រះ ចំពោះសេចក្ដី សង្គ្រោះ, **គ. និង ស.** ៦៨:៤ ។ ចូរបោះពុម្ពនូវភាពពោរពេញនៃព្រះគម្ពីររបស់យើង សំរាប់គោលបំណងនៃការកសាងសាសនាចក្រ របស់យើងឡើង និងដើម្បីរៀបចំរាស្ត្ររបស់យើង, **គ. និង ស.** ១០៤:៥៨–៥៩ ។ អស់អ្នកណាដែលរក្សាពាក្យខ្ញុំទុក នោះនឹងមិនត្រូវ បញ្ឆោតឡើយ, **យ.ស. — ម៉ាថាយ** ១:៣៧ ។

*គម្ពីរដែលបានព្យាករថានឹងចេញមក៖* អេសាយបានប្រាប់ទុកជាមុនស្រេចអំពីការចេញមកនៃព្រះគម្ពីរមរមន, **អេសាយ** ២៩:១១–១៤ ។ ចូរយកបន្ទះឈើមួយ ហើយសរសេរលើបន្ទះឈើនោះ សំរាប់យូដា, **អេសេ.** ៣៧:១៥–២០ ។ គម្ពីរផ្សេងៗទៀត នឹងចេញមក, **១ នីហ្វៃ** ១៣:៣៩ ។ ចូរអ្នកកុំគិតស្មានថា ព្រះគម្ពីរប៊ីបមានពាក្យរបស់យើងទាំងអស់ឡើយ, **២ នីហ្វៃ** ២៩:១០–១៤ ។ ចូរកាន់ខ្ជាប់នូវដំណឹងល្អនៃព្រះគ្រីស្ទ ដែលនឹងត្រូវបានបង្ហាញនៅចំពោះមុខអ្នក នៅក្នុងបញ្ជីដែលនឹងចេញមក, **មរមន** ៧:៨–៩ ។ មានពរដល់អ្នកណា ដែលនាំការណ៍នេះមកឯពន្លឺ, **មរមន** ៨:១៦ ។ ចូរសរសេរការណ៍ទាំងនេះ នោះយើងនឹងបង្ហាញវា លុះដល់ ពេលកំណត់របស់យើង, **អេធើរ** ៣:២៧ (អេធើរ ៤:៧) ។ ពួកយើងខ្ញុំជឿថា ទ្រង់នឹងបើកសម្ដែងការណ៍ជាច្រើនទៀត, **ម. នៃ ស.** ១:៩ ។

**បទអធិស្ឋាននៃព្រះអម្ចាស់** *សូមមើលផង* បទអធិស្ឋាន

ជាបទអធិស្ឋានដែលព្រះអង្គសង្គ្រោះបានឧទ្ទិស្ត សំរាប់ពួកសិស្សទ្រង់ ដែលទុកជាគំរូសំរាប់បទអធិស្ឋានទាំងអស់ (ម៉ាថាយ ៦:៩–១៣; ៣ នីហ្វៃ ១៣:៩–១៣) ។

**បន្ទាបខ្លួន, ចិត្តសុភាពរាបសា** *សូមមើលផង* ចិត្តសង្រេង; ភាពទន់ខ្សោយ, ភាពស្លូតបូត; មនុស្សក្រីក្រ; ស្លូតបូត, សេចក្ដីឆ្មើងឆ្មៃ

ដើម្បីធ្វើឲ្យបានស្លូតបូត ហើយចេះស្ដាប់បង្គាប់ ឬក៏លក្ខណៈអំពីភាពស្លូតបូត និងការចេះស្ដាប់បង្គាប់ ។ ការបន្ទាបខ្លួន មានទាំងការយល់នូវការផ្ដេកផ្ដួលរបស់យើងទៅលើព្រះ និងការប៉ង់ប្រាថ្នាចង់ធ្វើតាមព្រះហឫទ័យទ្រង់ ។

ព្រះទ្រង់បាននាំឯងនៅក្នុងទីរហោស្ថាន ក្នុងរវាង ៤០ ឆ្នាំ ដើម្បីនឹងបន្ទាបចិត្តអ្នក, **ចោទិ.** ៨:២ ។ ទូលបង្គំបានបន្ទាបចិត្ត ដោយតមអត់អាហារ, **ទំនុក.** ៣៥:១៣ ។ ក្មេងដែលទាល់ក្រ តែមានប្រាជ្ញា នោះវិសេសជាងស្ដេច ដែលចាស់ជរា ហើយល្ងីល្ងើ, **សាស្ដា** ៤:១៣ ។ ព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងអ្នកណា ដែលមានចិត្តទន់ទាប, **អេសាយ** ៥៧:១៥ ។ អ្នកណាដែលបន្ទាបខ្លួន ឲ្យបាន ដូចកូនតូចនេះ អ្នកនោះឈ្មោះថា ធំជាងគេក្នុងនគរស្ថានសួគ៌, **ម៉ាថាយ** ១៨:៤ ។ អ្នកណាដែលបន្ទាបខ្លួន នោះនឹងបានដំកើងឡើង, **ម៉ាថាយ** ២៣:១២ (លូកា ១៤:១១; ១៨:១៤) ។ ព្រះយេស៊ូវបានបន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្ដាប់បង្គាប់ រហូតដល់ទីមរណៈ, **ភីលីព** ២:៨ (លូកា ២២:៤២; ២៣:៤៦) ។ ព្រះទ្រង់តតាំងនឹងមនុស្សអួរអាង តែផ្ដល់ព្រះគុណដល់ពួករាបសាវិញ, **១ ពេត្រុស** ៥:៥–៦ (២ នីហ្វៃ ៩:៤២) ។ ចូរបន្ទាបខ្លួនដល់កំរិតនៃភាពរាបសាចុះ, **ម៉ូសាយ** ៤:១១ (២ នីហ្វៃ ៩:៤២; ៣ នីហ្វៃ ១២:២) ។ តើអ្នកបាន បន្ទាបខ្លួនគ្រប់គ្រាន់ហើយឬនៅ ? **អាលម៉ា** ៥:២៧–២៨ ។ មនុស្សភាគច្រើនដែលមានភាពរាបសាជាង នោះបានក្លាយជាមុតមាំខ្លាំង ឡើងៗក្នុងភាពរាបសារបស់គេ, **ហេលេ.** ៣:៣៣–៣៥ ។ យើងឲ្យភាពទន់ខ្សោយទៅមនុស្ស ដើម្បីឲ្យពួកគេរាបសា, **អេធើរ** ១២:២៧ ។ ភាពរាបសា គឺជាគុណសម្បត្តិសំរាប់បុណ្យជ្រមុជទឹក, **គ. និង ស.** ២០:៣៧ ។ ចូរបន្ទាបខ្លួននៅចំពោះយើង នោះអ្នក នឹងបានឃើញយើង ហើយដឹងថា យើងជាព្រះ, **គ. និង ស.** ៦៧:១០ ។ ចូរមានចិត្ត

រាបសា; ហើយព្រះអម្ចាស់ជាព្រះរបស់អ្នកនឹង ប្រទានចម្លើយដល់បទអធិស្ឋានទាំងឡាយរបស់អ្នក, **គ. និង ស.** ១១២:១០ ។ ចូរឲ្យអ្នកណាដែលល្ងង់ ចេះមានប្រាជ្ញា ដោយការ បន្ទាបខ្លួន, **គ. និង ស.** ១៣៦:៣២ ។ ព្រះវិញ្ញាណត្រូវបានចាត់ទៅបំភ្លឺដល់ពួករាបសា, **គ. និង ស.** ១៣៦:៣៣ ។

**បន្ទះឈើនៃយូដា** *សូមមើល* យូដា — បន្ទះឈើនៃយូដា

**បន្ទះឈើនៃយ៉ូសែប** *សូមមើល* អេប្រាអិម — បន្ទះឈើនៃអេប្រាអិម ឬយ៉ូសែប

**បន្ទះឈើនៃអេប្រាអិម** *សូមមើល* អេប្រាអិម — បន្ទះឈើនៃអេប្រាអិម ឬយ៉ូសែប

**បព្វជិតភាព***សូមមើលផង* ការតែងតាំង; កូនសោទាំងឡាយនៃបព្វជិតភាព; បព្វជិតភាពមិលគីស្សាដែក; បព្វជិតភាពអើរ៉ុន; តែងតាំង, សម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព; សិទ្ធិអំណាច; អំណាច

ជាសិទ្ធិអំណាច និងអំណាចដែលព្រះទ្រង់ប្រទានដល់មនុស្សឲ្យប្រព្រឹត្តនូវគ្រប់ការណ៍ទាំងអស់ សំរាប់សេចក្ដីសង្គ្រោះនៃមនុស្ស (គ. និង ស. ៥០:២៦–២៧) ។ សមាជិកប្រុសៗក្នុងសាសនាចក្រ ដែលកាន់បព្វជិតភាព នោះបានរៀបចំជាក្រុមៗ ហើយមានសិទ្ធិអំណាច ដើម្បីធ្វើពិធីបរិសុទ្ធ និងការងារខាងការត្រួតត្រាខ្លះៗនៅក្នុងសាសនាចក្រ ។

បុណ្យចាក់លាបប្រេងរបស់គេនឹងបានសំរាប់ការងារជាសង្ឃអស់កល្បជានិច្ច, **និក្ខ.** ៤០:១៥ (ជនគ. ២៥:១៣) ។ ខ្ញុំបានតាំងអ្នក, **យ៉ូហាន** ១៥:១៦ ។ អ្នករាល់គ្នាបានធ្វើផ្ទះខាងឯវិញ្ញាណ ជាពួកសង្ឃបរិសុទ្ធ, **១ ពេត្រុស** ២:៥ ។ អ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង, **១ ពេត្រុស** ២:៩ (និក្ខ. ១៩:៦) ។ ពួកមនុស្សត្រូវបានហៅឲ្យធ្វើជាសង្ឃជាន់ខ្ពស់ ដោយសារសេចក្ដីជំនឿដ៏ខ្លាំង និងកិច្ចការដ៏ល្អទាំងឡាយរបស់គេ, **អាលម៉ា** ១៣:១–១២ ។ យើងប្រទានអំណាចដល់អ្នក ដើម្បីឲ្យធ្វើបុណ្យជ្រមុជទឹក, ៣ នីហ្វៃ ១១:២១ ។ អ្នករាល់គ្នានឹងមានអំណាច ដើម្បីឲ្យមានព្រះវិញ្ញាណបរិសុទ្ធ, **ម៉ូរ៉ូណៃ** ២:២ ។ យើងនឹងបើកសម្ដែងដល់អ្នករាល់គ្នានូវ បព្វជិតភាព ដោយដៃនៃលោកអេលីយ៉ា, **គ. និង ស.** ២:១ (យ.ស. — ប្រវត្តិ ១:៣៨) ។ ព្រះអម្ចាស់ទ្រង់បានបញ្ជាក់បព្វជិតភាពមកលើ លោកអើរ៉ុន និងពូជពង្សលោកដែរ, **គ. និង ស.** ៨៤:១៨ ។ បព្វជិតភាពដ៏ធំជាងនេះចាត់ចែងផ្សាយដំណឹងល្អ, **គ. និង ស.** ៨៤:១៩ ។ ព្រះអង្គបានយកលោកម៉ូសេចេញពីកណ្ដាលពួកគេ ព្រមទាំងបព្វជិតភាពដ៏បរិសុទ្ធផងដែរ, **គ. និង ស.** ៨៤:២៥ ។ សម្បថ និងសេចក្ដី សញ្ញានៃបព្វជិតភាពបានរៀបរាប់ប្រាប់, **គ. និង ស.** ៨៤:៣៣–៤២ ។ បព្វជិតភាពបានបន្តមក តាមរយៈពូជពង្សនៃពួកអយ្យកោរបស់ អ្នក, **គ. និង ស.** ៨៦:៨ ។ នៅក្នុងសាសនាចក្រ មានបព្វជិតភាពពីរយ៉ាង, **គ. និង ស.** ១០៧:១ ។ បព្វជិតភាពទីមួយ ត្រូវបានហៅថា បព្វជិតភាពដ៏បរិសុទ្ធ តាមរបៀបនៃព្រះរាជបុត្រានៃព្រះ, **គ. និង ស.** ១០៧:២–៤ ។ សិទ្ធិទាំងឡាយនៃបព្វជិតភាព គឺជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌, **គ. និង ស.** ១២១:៣៦ ។ គ្មានអំណាច ឬឥទ្ធិពលណាអាច ឬគប្បីកាន់កាប់ ដោយសារបព្វជិតភាពបានឡើយ លើកលែងតែដោយគុណធម៌នៃបព្វជិតភាព, **គ. និង ស.** ១២១:៤១ ។ សមាជិកប្រុសៗណាដែលស្មោះត្រង់ ហើយសក្ដិសមក្នុងសាសនាចក្រ អាចទទួលបព្វជិតភាពបាន, **គ. និង ស.** — ប្រកាសទី២ ។ យើងខ្ញុំជឿថា មនុស្សត្រូវតែបានហៅពីព្រះ, **ម. នៃ ស.** ១:៥ ។

**បព្វជិតភាព, ការតែងតាំង** *សូមមើល* ការតែងតាំង, តែងតាំង

**បព្វជិតភាព, កូនសោទាំងឡាយនៃ** *សូមមើល* កូនសោទាំងឡាយនៃបព្វជិតភាព

**បព្វជិតភាព, មិលគីស្សាដែក** *សូមមើល* បព្វជិតភាពមិលគីស្សាដែក

**បព្វជិតភាព, អើរ៉ុន** *សូមមើល* បព្វជិតភាពអើរ៉ុន

**បព្វជិតភាពលេវី** *សូមមើល* បព្វជិតភាពអើរ៉ុន

**បព្វជិតភាពជាន់ខ្ពស់** *សូមមើល* បព្វជិតភាពមិលគីស្សាដែក

**បព្វជិតភាពមិលគីស្សាដែក** *សូមមើលផង* បព្វជិតភាព, មិលគីស្សាដែក; អែលឌើរ

បព្វជិតភាពមិលគីស្សាដែក គឺជាបព្វជិតភាពដ៏ខ្ពស់ ឬធំជាង ។ បព្វជិតភាពអើរ៉ុន គឺជាបព្វជិតភាពទាបជាង ។ បព្វជិតភាពមិលគីស្សាដែក មានរួមទាំងកូនសោនៃព្រះពរទាំងឡាយខាងវិញ្ញាណនៅក្នុងសាសនាចក្រ ។ ដោយសារពិធីបរិសុទ្ធនៃបព្វជិតភាពដ៏ខ្ពស់ជាង នោះអំណាចនៃការងារខាងព្រះត្រូវបានបង្ហាញដល់មនុស្ស (គ. និង ស. ៨៤:១៨–២៥; ១០៧:១៨–២១) ។

មុនដំបូង ព្រះទ្រង់បានបង្ហាញបព្វជិតភាពដ៏ខ្ពស់ជាងនេះដល់លោកអ័ដាម ។ ពួកអយ្យកោ និងពួកព្យាការីនៅគ្រប់ការកាន់កាប់ ត្រួតត្រា គេមានអំណាចនេះ (គ. និង ស. ៨៤:៦–១៧) ។ មុនដំបូង បព្វជិតភាពនេះត្រូវបានហៅថា បព្វជិតភាពដ៏បរិសុទ្ធ តាមរបៀបនៃព្រះរាជបុត្រានៃព្រះ ។ ក្រោយមក បានស្គាល់ថា បព្វជិតភាពមិលគីស្សាដែក (គ. និង ស. ១០៧:២–៤) ។

កាលពួកកូនចៅអ៊ីស្រាអែលមិនបានរស់នៅតាមឯកសិទ្ធិ និងសេចក្ដីសញ្ញាទាំងឡាយ នៃបព្វជិតភាពមិលគីស្សាដែក នោះព្រះអម្ចាស់ទ្រង់បានដកយកក្រិត្យវិន័យដ៏ខ្ពស់ជាង ហើយបានប្រទានឲ្យគេ នូវបព្វជិតភាពទាបជាង និងក្រិត្យវិន័យទាបជាង (គ. និង ស. ៨៤:២៣–២៦) ។ គឺបានហៅថា បព្វជិតភាពអើរ៉ុន និងក្រិត្យវិន័យលោកម៉ូសេ ។ កាលព្រះយេស៊ូវទ្រង់បានយាងមកផែនដី នោះ ទ្រង់បានសាងឡើងវិញនូវបព្វជិតភាពមិលគីស្សាដែក ដល់ពួកសាសន៍យូដា ហើយបានចាប់ផ្ដើមសាងសាសនាចក្រ នៅក្នុងចំណោម ពួកគេ ។ ប៉ុន្តែបព្វជិតភាព និង

សាសនាចក្រក៏បានបាត់ម្ដងទៀត ដោយសារការក្បត់សាសនា ។ ក្រោយមក គឺបានសាងឡើងវិញ ដោយយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ (គ. និង ស. ២៧:១២–១៣; ១២៨:២០; យ.ស. — ប្រវត្តិ ១:៧៣) ។

នៅក្នុងបព្វជិតភាពមិលគីស្សាដែក គឺមានតំណែងទាំងឡាយ នៃអែលឌើរ នៃសង្ឃជាន់ខ្ពស់ នៃអយ្យកោ នៃពួកចិតសិបនាក់ និងនៃសាវក (គ. និង ស. ១០៧)។ បព្វជិតភាពមិលគីស្សាដែកនឹងទៅជា ផ្នែកនៃនគរព្រះ នៅលើផែនដីជានិច្ច ។

ប្រធានលើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាប្រធាននៃបព្វជិតភាពជាន់ខ្ពស់ ឬបព្វជិតភាពមិលគីស្សាដែក ហើយលោកកាន់អស់ទាំងកូនសោដែលទាក់ទងទៅនឹងនគរព្រះ នៅលើផែនដី ។ តំណែងជាប្រធាន គឺកាន់ដោយបុរសម្នាក់ ប៉ុណ្ណោះ នៅសម័យមួយៗ ហើយលោកជាមនុស្សតែមួយគត់នៅលើផែនដី ដែលមានសិទ្ធិអំណាចដើម្បីអនុវត្តនូវគ្រប់អស់ទាំងកូនសោ នៃបព្វជិតភាព (គ. និង ស. ១០៧:៦៤–៦៧; គ. និង ស. ១៣២:៧) ។

ព្រះគ្រីស្ទនឹងត្រូវធ្វើជាសង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោកមិលគីស្សាដែក, **ទំនុក.** ១១០:៤ (ហេព្រើរ ៥:៦, ១០; ហេព្រើរ ៧:១១) ។ បព្វជិតភាពមិលគីស្សាដែកចាត់ចែងដំណឹងល្អ, **ហេព្រើរ** ៧ (គ.ស. ៨៤:១៨–២៥) ។ លោកមិលគីស្សាដែកបានអនុវត្តសេចក្ដីជំនឿដ៏ខ្លាំង ហើយបានទទួលមុខងារនៃបព្វជិតភាពជាន់ខ្ពស់, **អាលម៉ា** ១៣:១៨ ។ បព្វជិតភាពមិលគីស្សាដែកត្រូវបានប្រគល់ មកលើយ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី, **គ. និង ស.** ២៧:១២–១៣ (យ.ស. — ប្រវត្តិ ១:៧២) ។ បព្វជិតភាពនេះត្រូវបានទទួល ដោយសម្បថ និងសេចក្ដីសញ្ញា, **គ. និង ស.** ៨៤:៣៣–៤២ ។ មានចំណែក ឬមេចំណែកពីរយ៉ាងគឺ — បព្វជិតភាពមិលគីស្សាដែក និងអើរ៉ុន, **គ. និង ស.** ១០៧:៦ ។ បព្វជិតភាពមិលគីស្សាដែកកាន់សិទ្ធិ ដើម្បីចាត់ចែងគ្រប់ទាំងព្រះពរខាងវិញ្ញាណ, **គ. និង ស.** ១០៧:៨–១៨ ។ ម៉ូសេ អេលីយ៉ាស និងអេលីយ៉ាបានប្រគល់ដល់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី នូវកូនសោទាំងឡាយនៃបព្វជិតភាព **គ. និង ស.** ១១០:១១–១៦ ។ ឥឡូវនេះ យើងប្រទានដល់អ្នករាល់គ្នា នូវពួកមេដឹកនាំដែលជាសមាជិកនៃបព្វជិតភាពរបស់យើង ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចកាន់កូនសោទាំងឡាយនៃបព្វជិតភាពនោះ, **គ. និង ស.** ១២៤:១២៣ ។

**បព្វជិតភាពអើរ៉ុន** *សូមមើលផង* ក្រិត្យវិន័យលោកម៉ូសេ; បងប្រុសរបស់ម៉ូសេ; បព្វជិតភាព, អើរ៉ុន

ជាបព្វជិតភាពតូចជាង (ហេព្រើរ ៧:១១–១២; គ. និង ស. ១០៧:១៣–១៤) ។ តំណែងខាងបព្វជិតភាពនេះ គឺប៊ីស្សព, សង្ឃ, គ្រូ, និងឌីកុន (គ. និង ស. ៨៤:៣០; ១០៧:១០, ១៤–១៥, ៨៧–៨៨) ។ ពីសម័យបុរាណ នៅក្រោមក្រិត្យវិន័យលោកម៉ូសេ នោះមាន ពួកសង្ឃជាន់ខ្ពស់, ពួកសង្ឃ, និងពួកលេវី ។ បព្វជិតភាពអើរ៉ុនត្រូវបានបើកសម្ដែងប្រាប់ដល់លោកម៉ូសេ ពីព្រោះពួកសាសន៍អ៊ីស្រាអែល ពីសម័យបុរាណ បានបះបោរទាស់នឹងព្រះ ។ ពួកគេមិនព្រមទទួលការញែកចេញជាបរិសុទ្ធ និងបព្វជិតភាពមិលគីស្សាដែក និងពិធីបរិសុទ្ធទាំងឡាយឡើយ (គ. និង ស. ៨៤:២៣–២៥) ។ បព្វជិតភាពអើរ៉ុនទាក់ទងទៅនឹងពិធីទាំងឡាយខាងសាច់ឈាម និងខាងក្រៅ ដែលមាននៅ ក្នុងក្រិត្យវិន័យ និងដំណឹងល្អ ។ (១ របា. ២៣:២៧–៣២; គ. និង ស. ៨៤:២៦–២៧; ១០៧:២០) ។ បព្វជិតភាពនេះកាន់កូនសោទាំង ឡាយខាងការបំរើនៃពួកទេវតា, ខាងដំណឹងល្អនៃការប្រែចិត្ត, និងខាងបុណ្យជ្រមុជទឹក (គ. និង ស. ១៣) ។ បព្វជិតភាពអើរ៉ុនត្រូវបានសាងឡើងវិញលើផែនដី នៅក្នុងការកាន់កាប់គ្រួតគ្រានេះ នៅថ្ងៃទី ១៥ ខែឧសភា ១៨២៩ ។ យ៉ូហាន-បាទីស្ទបានប្រគល់ បព្វជិតភាពនេះមកលើយ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី នៅលើច្រាំងទន្លេសុសគ្វីហាណា នៅក្បែរភូមិ ហារម៉ូនី រដ្ឋផែនស៊ិលវេញ៉ា (គ. និង ស. ១៣; យ.ស. — ប្រវត្តិ ១:៦៨–៧៣) ។

ហើយលោកនឹងបានសេចក្ដីសញ្ញា ឲ្យបានការងារជាសង្ឃ នៅជរាបតទៅ, **ជនគ.** ២៥:១៣ ។ ព្រះអម្ចាស់ទ្រង់នឹងសំអាតពួកកូន ចៅលេវី ហើយនឹងសំរងពួកគេ, **ម៉ាឡាគី** ៣:៣ (៣ នីហ្វៃ ២៤:៣) ។ គ្មានអ្នកណាលើកខ្លួនដល់ងារដ៏ប្រសើរនេះឡើយ, **ហេព្រើរ** ៥:៤ ។ ភាពល្អឥតខ្ចោះមិនមែនមក ដោយសារបព្វជិតភាពលេវីទេ, **ហេព្រើរ** ៧:១១ ។ បព្វជិតភាពនេះនឹងមិនត្រូវបានដកចេញពី ផែនដីទៀតឡើយ រហូតដល់ពេលកូនប្រុសទាំងឡាយនៃលោកលេវីថ្វាយដង្វាយ, **គ. និង ស.** ១៣:១ ។ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ត្រូវបានតែងតាំងឡើងចំពោះបព្វជិតភាពអើរ៉ុន, **គ. និង ស.** ២៧:៨ ។ បព្វជិតភាពដែលតូចជាងនោះ កាន់កូនសោខាងការ បំរើនៃពួកទេវតា, **គ. និង ស.** ៨៤:២៦ (គ. និង ស. ១៣:១) ។ មានបព្វជិតភាពពីរយ៉ាងដែលមានឈ្មោះថា បព្វជិតភាពមិលគីស្សា ដែក និងអើរ៉ុន, **គ. និង ស.** ១០៧:១ ។ បព្វជិតភាពទីពីរត្រូវបានហៅថា បព្វជិតភាពអើរ៉ុន, **គ. និង ស.** ១០៧:១៣ ។

**បរិទេវ, គម្ពីរ**

ជាគម្ពីរមួយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ បានសរសេរដោយយេរេមា ។ គឺជាប្រជុំកំណាព្យ ឬចំរៀងអំពីសេចក្ដីទុក្ខ ពីព្រោះមកពីការ រលំនៃក្រុងយេរូសាឡិម និងសាសន៍អ៊ីស្រាអែល ។ គម្ពីរនេះត្រូវបានសរសេរបន្ទាប់ពីទីក្រុងរលំ ប្រហែលជាឆ្នាំ ៥៨៦ ម.គ.ស. ។

**បរិសុទ្ធ** *សូមមើលផង* ការញែកចេញជាបរិសុទ្ធ, បរិសុទ្ធភាព; ភាពសុទ្ធសាធ; សុទ្ធសាធ

ជាពិសិដ្ឋ ដោយមានលក្ខណៈដ៏ល្អ ឬសុទ្ធសាធទាំងខាងវិញ្ញាណ និងខាងចិត្តធម៌ ។ ពាក្យផ្ទុយនឹងពាក្យបរិសុទ្ធ គឺពាក្យធម្មតា ឬ ពាក្យប្រមាថ ។

អ្នករាល់គ្នានឹងបានធ្វើជានគរដល់យើង ដែលសុទ្ធតែជាសង្ឃ ហើយជាសាសន៍បរិសុទ្ធឲ្យយើងដែរ, **និក្ខ.** ១៩:៥–៦ (១ ពេត្រុស. ២:៩) ។ ព្រះអម្ចាស់ទ្រង់បានបញ្ជាអ៊ីស្រាអែលថា៖ ចូរឲ្យអ្នកបានបរិសុទ្ធចុះ ត្បិតយើងបរិសុទ្ធ, **លេវី.** ១១:៤៤–៤៥ ។ ពួកអ្នកដែលមានដៃ ស្អាត និងចិត្តបរិសុទ្ធ នឹងឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់, **ទំនុក.** ២៤:៣–៤ ។

ចូរបង្រៀនរាស្ត្រយើងឲ្យចេះសំគាល់របស់បរិសុទ្ធ និងរបស់ ធម្មតា, **អេសេ.** ៤៤:២៣ ។ ព្រះទ្រង់បានហៅយើងមកក្នុងការងារបរិសុទ្ធ,២ ធីម៉ូ. ១:៨–៩ ។ តាំងពីក្មេងតូចមក អ្នកបានស្គាល់បទ គម្ពីរបរិសុទ្ធ,២ ធីម៉ូ. ៣:១៥ ។ មនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយដោយសារព្រះវិញ្ញាណបរិសុទ្ធ, **២ ពេត្រុស.** ១:២១ ។ មនុស្សទាំងអស់នឹងត្រូវជំនុំជំរះតាមសេចក្ដីពិត និងតាមសេចក្ដីបរិសុទ្ធ ដែលនៅក្នុងព្រះ, **២ នីហ្វៃ** ២:១០ ។ មនុស្សខាង សាច់ឈាមក្លាយទៅជាអ្នកបរិសុទ្ធ ដោយសារដង្វាយធួនរបស់ព្រះគ្រីស្ទ, **ម៉ូសាយ ៣:១៩ ។** ចូរដើរតាមរបៀបបរិសុទ្ធនៃព្រះ, **អាលម៉ា** ៧:២២ (អាលម៉ា ១៣:១១–១២) ។ ពួកសិស្សបីនាក់ត្រូវបានញែកចេញជាបរិសុទ្ធក្នុងសាច់ឈាម ហើយបានធ្វើឲ្យបរិសុទ្ធ, ៣ នីហ្វៃ ២៨:១–៩, ៣៦–៣៩ ។ ចូរកុំប្រហែសនឹងការណ៍ដ៏ពិសិដ្ឋទាំងឡាយឡើយ, **គ. និង ស.** ៦:១២ ។ អ្នកមិនអាចសរសេរ អ្វីដែលពិសិដ្ឋបានឡើយ លើកលែងតែបានប្រទានឲ្យមកពីយើង, **គ. និង ស.** ៩:៩ ។ អ្នករាល់គ្នានឹងត្រូវចងខ្លួន ដើម្បីប្រព្រឹត្តក្នុង បរិសុទ្ធភាពគ្រប់យ៉ាង, **គ. និង ស.** ៤៣:៩ ។ ពួកសិស្សរបស់យើងនឹងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ, **គ. និង ស.** ៤៥:៣២ ។ អ្វីដែលមកពីលើ គឺជាពិសិដ្ឋ, **គ. និង ស.** ៦៣:៦៤ ។ កូនក្មេងសុទ្ធតែបរិសុទ្ធ, **គ. និង ស.** ៧៤:៧ ។ ចាត់ទីនោះ ដើម្បីឲ្យវាបានទៅ ជាបរិសុទ្ធ, **គ. និង ស.** ១២៤:៤៤ ។ ព្រះអម្ចាស់ទ្រង់នឹងប្រមូលពួកអ្នកជំរើសរបស់ទ្រង់មកឯទីក្រុងបរិសុទ្ធ, **ម៉ូសេ ៧:៦២ ។**

**បរិសុទ្ធភាព** *សូមមើលផង* ការញែកចេញជាបរិសុទ្ធ, បរិសុទ្ធ; ភាពសុទ្ធសាធ; សុទ្ធសាធ

ជាភាពល្អឥតខ្ចោះខាងវិញ្ញាណ និងខាងចិត្តល្អសុទ្ធសាធ ។ បរិសុទ្ធភាពបង្ហាញនូវភាពបរិសុទ្ធនៃចិត្ត និងបំណងនៃមនុស្ស ។

សមាជិកទាំងឡាយនឹងសម្ដែងថាខ្លួនសក្តិសមចំពោះសាសនាចក្រ ដោយដើរក្នុងបរិសុទ្ធភាព នៅចំពោះព្រះអម្ចាស់, **គ. និង ស.** ២០:៦៩ ។ ដំណាក់របស់ទ្រង់ គឺជាទីនៃបរិសុទ្ធភាព, **គ. និង ស.** ១០៩:១៣ ។មនុស្សនៃបរិសុទ្ធភាព គឺព្រះនាមរបស់ព្រះ, **ម៉ូសេ** ៦:៥៧ (ម៉ូសេ៧:៣៥) ។

**បរិសុទ្ធលើអស់ទាំងបរិសុទ្ធ** *សូមមើលផង* ដំណាក់នៃព្រះអម្ចាស់, ព្រះវិហារ, រោងឧបោសថ

ជាបន្ទប់ដ៏ពិសិដ្ឋបំផុតនៅក្នុងរោងឧបោសថរបស់ម៉ូសេ ហើយក្រោយមកនៅក្នុងព្រះវិហារ ។ បរិសុទ្ធលើអស់ទាំងបរិសុទ្ធ ក៏បាន ហៅថា « ទីបរិសុទ្ធបំផុត » (និក្ខ. ២៦:៣៣–៣៤) ។

**បាណាបាស**

ជាឈ្មោះឲ្យទៅយ៉ូសែប (ក៏ហៅថា យ៉ូសេ) លោកជាពួកលេវីពីកោះគីប្រុស ដែលបានលក់ដីធ្លីរបស់ខ្លួន ហើយបានឲ្យប្រាក់ទៅពួក សាវក (កិច្ចការ ៤:៣៦–៣៧) ។ ទោះជាលោកមិនមែនជាពួកសាវក ១២ នាក់មុនដំបូងក៏ដោយ គង់តែលោកបានក្លាយទៅជា សាវកម្នាក់ដែរ (កិច្ចការ ១៤:៤, ១៤) ហើយបានបំរើក្នុងការធ្វើដំណើរជាច្រើនទៅផ្សាយសាសនា (កិច្ចការ ១១:២២–៣០; ១២:២៥; ១៣–១៥; ១ កូរិន. ៩:៦; កាឡាទី ២:១, ៩; កូល៉ុស ៤:១០) ។

**បាតសេបា** *សូមមើលផង* ដាវីឌ

ជាប្រពន្ធអ៊ូរី ។ ក្រោយមក នាងជាភរិយាស្ដេចដាវីឌ ហើយជាមាតារបស់សាឡូម៉ូន ។ ស្ដេចដាវីឌបានប្រព្រឹត្តអំពើកំផិតជាមួយនឹង នាង ។ ទ្រង់ក៏បានរៀបចំឲ្យប្ដីនាងស្លាប់ក្នុងចម្បាំង (២ សាំយូ. ១១) អំពើបាបនេះមានវិបាកដ៏នៅអស់កល្បជានិច្ចចំពោះដាវីឌ (គ. និង ស. ១៣២:៣៩) ។

**បាទិស្ទ** *សូមមើល* យ៉ូហាន-បាទិស្ទ

**ប៉ាទិន, ដាវីឌ ដ័បបុលយូ**

ជាសមាជិកក្នុងក្រុមពួកសាវក ១២ នាក់លើកទីមួយ ដែលត្រូវបានរើសនៅគ្រាកាន់កាប់ត្រួតត្រាថ្ងៃចុងក្រោយ ។ ដាវីឌ ប៉ាទិន គឺជា ទុក្ខរបុគ្គលមុនដំបូងនៃសាសនាចក្រដែលបានសាងឡើងវិញ ដោយត្រូវស្លាប់ក្នុងចំបាំងឯ ឃ្រុកិត រីវ័រ នៅរដ្ឋមិសសួរី ក្នុងឆ្នាំ ១៨៣៨ ។

ត្រូវបានហៅតាំងធុរកិច្ច ហើយធ្វើបេសកកម្ម, **គ. និង ស.** ១១៤:១ ។ ត្រូវបាននាំទៅឯព្រះអម្ចាស់, **គ. និង ស.** ១២៤:១៩, ១៣០ ។

**ប៉ាទ្រិច, អែតវឺត**

ជាសមាជិក ហើយជាមេដឹកនាំមុនដំបូងនៃសាសនាចក្រ បន្ទាប់ពីការសាងឡើងវិញ នៅសម័យទំនើបនេះ ។ អែតវឺត ប៉ាទ្រិច បានបំរើ ជាប៊ីស្សពទីមួយនៃសាសនាចក្រ (គ. និង ស. ៣៦; ៤១:៩–១១; ៤២:១០; ៥១:១–១៨; ១១៥; ១២៤:១៩) ។

**បាប** *សូមមើលផង* ការបះបោរ; គួរខ្ពើមឆ្អើម, ជំទាស់ចិត្ត; ទុច្ចរិត, ពួកទមិលល្មើស, សេចក្ដីស្មោកគ្រោក; សេចក្ដីឥតសុចរិត; ស្មោកគ្រោក, អំពើគួរខ្ពើមឆ្អើម; អំពើដ៏ឥតបរិសុទ្ធ; អំពើទុច្ចរិត, ឥតសុចរិត

ជាការមិនព្រមគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ដោយចេតនា ។

អ្នកណាដែលគ្របបាំងការរំលងរបស់ខ្លួន នោះនឹងមិនចំរើនឡើងទេ, **សុភា.** ២៨:១៣ ។ ទោះបើអំពើបាបរបស់ឯង ដូចជាពណ៌ក្រហម ក៏ដោយ គង់តែនឹងបានសដូចហិមៈ, **អេសាយ** ១:១៨ ។ ពួកមនុស្សបាបនឹងស្លាប់ រីឯពួកមនុស្សសុចរិតនឹងបានសង្គ្រោះ, **អេសេ.** ១៨ ។ កូនចៀមនៃព្រះដោះបាបមនុស្សលោក, **យ៉ូហាន** ១:២៩ ។ ចូរទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ, **កិច្ចការ** ២២:១៦ ។ ឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់, **រ៉ូម** ៦:២៣ ។ ឯអ្នកណាដែលចេះធ្វើល្អ តែមិនធ្វើសោះ នោះរាប់ជាបាបដល់អ្នកនោះ វិញ, **យ៉ាកុប** (ព.ស.ថ.) ៤:១៧ ។ តើព្រះអង្គនឹងធ្វើឲ្យទូលបង្គំញ័រ នៅចំពោះអំពើបាបឬទេ, **២ នីហ្វៃ** ៤:៣១ ។ វេទនាដល់អស់អ្នក ណាដែលស្លាប់ក្នុងបាប

របស់ខ្លួន, **២ នីហ្វ** ៩:៣៨ ។ គេពុំអាចសម្លឹងមើលអំពើបាបទៀតឡើយ លើកលែងតែមើលដោយស្អប់ខ្ពើម នោះប៉ុណ្ណោះ, **អាលម៉ា** ១៣:១២ ។ ចូរកូនកុំគិតថា កូននឹងបានសាងពីបាបឡើងវិញ ទៅកាន់សុភមង្គលនោះទេ, **អាលម៉ា** ៤១:៩–១០ ។ ព្រះអម្ចាស់ទ្រង់មិនអាចទតមើលអំពើបាបសូម្បីតែបន្តិចបន្តួចក៏មិនបានឡើយ, **អាលម៉ា** ៤៥:១៦ (គ. និង ស. ១:៣១) ។ ពួកកូន ក្មេងតូចៗ ពុំអាចប្រព្រឹត្តអំពើបាបឡើយ, **មរ៉ូណៃ** ៨:៨ ។ ដើម្បីប្រែចិត្ត នោះមនុស្សលោកត្រូវតែសារភាព ហើយលះបង់ចោល អំពើបាបទាំងឡាយរបស់ខ្លួន, **គ. និង ស.** ៥៨:៤២–៤៣ ។ បាបដ៏ធំជាង គឺនៅជាប់នឹងអ្នកណាដែលមិនអត់ទោស, **គ. និង ស.** ៦៤:៩ ។ អ្នកណាដែលធ្វើបាបទាស់នឹងពន្លឺដ៏ធំជាង នោះនឹងត្រូវទទួលការដាក់ទោសដ៏ធំជាងដែរ, **គ. និង ស.** ៨២:៣ ។ ចំពោះអ្នកនោះ ដែលធ្វើបាប នោះអំពើបាបពីដើមនឹងវិលមកវិញ, **គ. និង ស.** ៨២:៧ ។ នៅពេលយើងខំស្វែងរកផ្លូវ ដើម្បីលាក់អំពើបាបទាំងឡាយរបស់យើង នោះស្ថានសួគ៌ដកខ្លួនចេញ, **គ. និង ស.** ១២១:៣៧ ។

**បាបិល, បាប៊ីឡូន** *សូមមើលផង* នេប៊ូក្នេសា; ពិភពលោក

ជារាជធានីនៃបាប៊ីឡូនី ។

ក្រុងបាបិលត្រូវបានកសាងឡើងដោយនីមរ៉ុឌ ហើយជាទីក្រុងចាស់បំផុតមួយ នៅស្រុកមេសូប៉ូតាមី ឬស្រុកស៊ីណើរ (លោកុ. ១០:៨–១០) ។ ព្រះអម្ចាស់ទ្រង់បានបំភាន់ភាសាទាំងឡាយ នៅសម័យបណ្ដាជនសង់ប៉មនៅក្រុងបាបិល (លោកុ. ១១:១–៩; អេធើរ ១:៣–៥, ៣៣–៣៥) ។ ក្រោយមក ក្រុងបាប៊ីឡូនក្លាយទៅជារាជធានីរបស់ស្ដេចនេប៊ូក្នេសា ។ ទ្រង់បានសង់ទីក្រុងយ៉ាងធំមួយ ដែលនៅ មានសំណង់បាក់បែកនៅឡើយ ។ ក្រុងបាប៊ីឡូនបានក្លាយទៅជាទីក្រុងមួយដ៏អាក្រក់ ហើយចាប់តាំងពីពេលនោះមក ក្លាយទៅជា និមិត្តរូបអំពីសេចក្ដីទុច្ចរិតនៃពិភពលោក ។

ចូរឲ្យរត់ចេញពីកណ្ដាលក្រុងបាប៊ីឡូន, **យេរេ.** ៥១:៦ ។ ក្រុងបាប៊ីឡូននឹងបានតាំងឡើង ហើយនឹងរលំចុះ, **វិវរ.** ១៧–១៨ ។ ក្រុង បាប៊ីឡូននឹងត្រូវបំផ្លាញ, **២ នីហ្វ** ២៥:១៥ ។ ក្រុងបាប៊ីឡូននឹងរលំ, **គ. និង ស.** ១:១៦ ។ យើងនឹងមិនប្រណីនរណាមួយ ដែលនៅក្នុង ក្រុងបាប៊ីឡូនឡើយ, **គ. និង ស.** ៦៤:២៤ ។ ចូរចេញពីក្រុងបាប៊ីឡូន, **គ. និង ស.** ១៣៣:៥, ៧, ១៤ ។

**បារថូល៉ូមេ** *សូមមើលផង* ណាថាណែល

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសាវកម្នាក់ក្នុងពួកសាវក ១២ នាក់មុនដំបូង របស់ព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ១០:២–៤) ។

**បារ៉ាបាស**

ជាឈ្មោះបុរសម្នាក់ ដែលគេបានដោះលែងជួសព្រះយេស៊ូវ កាលនៅគ្រាឆ្កាង ។ បារ៉ាបាសជាមនុស្សបះបោរ ជាឃាតករ ហើយជា ចោរប្លន់ម្នាក់ (ម៉ាថាយ ២៧:១៦–២៦; ម៉ាកុស ១៥:៦–១៥; លូកា ២៣:១៨–២៥; យ៉ូហាន ១៨:៤០) ។

**បាឡាម**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលចង់ដាក់បណ្ដាសាដល់ពួកអ៊ីស្រាអែលយកប្រាក់ ។ លោកត្រូវព្រះអម្ចាស់បញ្ជាមិនឲ្យដាក់បណ្ដាសាដល់ពួកអ៊ីស្រាអែលឡើយ (ជនគ. ២២–២៤) ។

លារបស់បាឡាមមិនព្រមទៅមុខសោះ ពីព្រោះមានទេវតាមួយឈរនៅចំផ្លូវវា, **ជនគ.** ២២:២២–៣៥ ។

**ប៊ីស្សព** *សូមមើលផង* បព្វជិតភាពអើរ៉ុន

មានន័យថា « អ្នកមើលខុសត្រូវ » ជាតំណែង ឬមុខងារមួយខាងការទទួលខុសត្រូវ ។ ប៊ីស្សពជាតំណែងមួយនៅក្នុងបព្វជិតភាពអើរ៉ុន (គ. និង ស. ២០:៦៧; ១០៧:៨៧–៨៨) ហើយប៊ីស្សពក៏ជាចៅក្រមទូទៅម្នាក់នៅអ៊ីស្រាអែល (គ. និង ស. ១០៧:៧២, ៧៤) ។

ព្រះវិញ្ញាណបរិសុទ្ធបានតាំងអ្នករាល់គ្នា ឲ្យធ្វើជាអ្នកមើលខុសត្រូវ, **កិច្ចការ** ២០:២៨ ។ គុណសម្បត្តិទាំងឡាយត្រូវបានចែងទុកសំរាប់ ពួកប៊ីស្សព, **១ ធីម៉ូ.** ៣:១–៧ (ទីតុស ១:៧) ។ ប៊ីស្សពត្រូវបានតែងតាំងឡើង, **គ. និង ស.** ២០:៦៧ ។ អែតវើត ប៉ាទ្រិច ត្រូវបំរើធ្វើជាប៊ីស្សព ចំពោះសាសនាចក្រ, **គ. និង ស.** ៤១:៩ ។ ប៊ីស្សពត្រូវចេះសង្កេតស្គាល់អំណោយទានទាំងឡាយខាងវិញ្ញាណ, **គ. និង ស.** ៤៦:២៧, ២៩ ។ សង្ឃជាន់ខ្ពស់អាចធ្វើការក្នុងតំណែងជាប៊ីស្សពបាន, **គ. និង ស.** ៦៨:១៤, ១៩ (គ. និង ស. ១០៧:១៧) ។ ប៊ីស្សពត្រូវបានតាំងឡើងពីព្រះអម្ចាស់, **គ. និង ស.** ៧២:១–២៦ ។ ប៊ីស្សពត្រូវថែរក្សាមនុស្សទ័លក្រ, **គ. និង ស.** ៨៤:១១២ ។ ប៊ីស្សពត្រូវ ចាត់ចែងគ្រប់អស់ទាំងការណ៍ខាងសាច់ឈាម, **គ. និង ស.** ១០៧:៦៨ ។ ប៊ីស្សពជាប្រធានលើបព្វជិតភាពអើរ៉ុន, **គ. និង ស.** ១០៧:៨៧–៨៨ ។

**ប៊ីស្សពដ៏ជាអធិបតី**

ជាពួកអ្នកដឹកនាំដែលមានសិទ្ធិអំណាចម្នាក់ក្នុងសាសនាចក្រ ។ ជាទូទៅលោកមានភារកិច្ចលើសុខុមាលភាពខាងសាច់ឈាមនៃ សាសនាចក្រ (គ. និង ស. ១០៧:៦៨) ។ ប៊ីស្សពដ៏ជាអធិបតី និងពួកទីប្រឹក្សាលោក ដែលត្រូវជាពួកអ្នកដឹកនាំដែលមានសិទ្ធិអំណាច ដែរ ពួកគេត្រួតត្រាលើបព្វជិតភាពអើរ៉ុននៃសាសនាចក្រ (គ. និង ស. ៦៨:១៦–១៧; ១០៧:៧៦, ៨៧–៨៨) ។

អែតវើត ប៉ាទ្រិច ត្រូវបានតែងតាំងឡើងជាប៊ីស្សព, **គ. និង ស.** ៤១:៩ ។ ពួកប៊ីស្សពត្រូវបានហៅ ហើយញែកចេញ ដោយគណៈប្រធាន ទីមួយ, **គ. និង ស.** ៦៨:១៤–១៥ ។ ពូជពង្សនៃអើរ៉ុនពិត ដែលត្រូវជាកូនប្រុសច្បង នោះមានសិទ្ធិនឹងត្រួតត្រា បើសិនជាបានហៅ ញែកចេញ ហើយតែងតាំងដោយគណៈប្រធានទីមួយ, **គ. និង ស.** ៦៨:១៦, ១៨–២០ ។ អាចបានកាត់ក្ដីនៅចំពោះគណៈប្រធានទីមួយ ប៉ុណ្ណោះ, **គ. និង ស.** ៦៨:២២–២៤ (គ. និង ស. ១០៧:៨២) ។

**បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក** *សូមមើលផង* កើតពីព្រះ; កើតម្ដងទៀត, បុណ្យជ្រមុជទឹកឲ្យទារក; ពិធីបរិសុទ្ធ, ព្រះវិញ្ញាណបរិសុទ្ធ

គឺមកពីពាក្យក្រេក មានន័យថា « ជ្រលក់ » ឬ « ពន្លិច » ។ បុណ្យជ្រមុជទឹកដោយការពន្លិច ធ្វើដោយអ្នកណាមួយ ដែលមានសិទ្ធិអំណាច គឺជាពិធីបរិសុទ្ធទីមួយនៃដំណឹងល្អ ហើយជាពិធីចាំបាច់មួយ សំរាប់ចូលជាសមាជិកក្នុងសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួក បរិសុទ្ធថ្ងៃចុងក្រោយ ។ មុនពិធីនេះ គឺសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្ត ។ បន្ទាប់មក គឺការទទួលអំណោយ ទានជាព្រះវិញ្ញាណបរិសុទ្ធ ទើបបានសំរេច (២ នីហ្វៃ ៣១:១៣–១៤) ។ បុណ្យជ្រមុជដោយទឹក និងដោយព្រះវិញ្ញាណ គឺជាពិធី ចាំបាច់ មុនជនណាមួយអាចបានចូលក្នុងនគរសេឡេស្ទាល ។ លោកអ័ដាម គឺជាមនុស្សទីមួយដែលបានទទួលបុណ្យជ្រមុជទឹក (ម៉ូសេ ៦:៦៤–៦៥) ។ ព្រះយេស៊ូវក៏បានទទួលបុណ្យជ្រមុជទឹកដែរ ដើម្បីបំពេញគ្រប់ទាំងសេចក្ដីសុចរិត ហើយដើម្បីបង្ហាញផ្លូវដល់មនុស្ស លោកទាំងអស់ (ម៉ាថាយ ៣:១៣–១៧; ២ នីហ្វៃ ៣១:៥–១២) ។

ពីព្រោះមនុស្សគ្រប់រូបនៅលើផែនដី មិនមានឱកាសនឹងទទួលដំណឹងល្អកាលនៅក្នុងជីវិតនេះទេ នោះទើបព្រះអម្ចាស់ទ្រង់បានអនុញ្ញាតឲ្យមានបុណ្យជ្រមុជទឹក ដែលប្រព្រឹត្តឡើងដោយអ្នកជំនួសមនុស្សស្លាប់ ។ ហេតុដូច្នេះហើយ អស់អ្នកណាដែលទទួល ដំណឹងល្អនៅស្ថានវិញ្ញាណ នោះគេអាចនឹងចូលក្នុងនគរព្រះបាន ។

*ការចាំបាច់៖* ចូរធ្វើម្ដងនេះចុះ ដើម្បីឲ្យបានសំរេចតាមគ្រប់ទាំងសេចក្ដីសុចរិត, **ម៉ាថាយ** ៣:១៥ ។ ព្រះយេស៊ូវទ្រង់យាងមក ហើយ បានទទួលបុណ្យជ្រមុជទឹកពីយ៉ូហាន, **ម៉ាកុស** ១:៩ ។ ពួកផារិស៊ី និងពួកអ្នកប្រាជ្ញច្បាប់បានលើកគំនិះនៃព្រះចោល ដោយមិនទទួល បុណ្យជ្រមុជទឹក, **លូកា** ៧:៣០ ។ លើកលែងតែបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះ បានទេ, **យ៉ូហាន** ៣:៥ ។ ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា, **កិច្ចការ** ២:៣៨ ។ ទ្រង់បានបញ្ជាដល់ មនុស្សលោកទាំងអស់ថា គេត្រូវទទួលបុណ្យប្រមុជទឹក ដោយនូវព្រះនាមទ្រង់, **២ នីហ្វៃ** ៩:២៣–២៤ ។ មនុស្សលោកត្រូវដើរតាម ព្រះគ្រីស្ទ ទទួលបុណ្យជ្រមុជទឹក ទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត ទើបនឹងបានសង្គ្រោះ, **២ នីហ្វៃ** ៣១ ។ គោលលទ្ធិនៃព្រះគ្រីស្ទ គឺថា មនុស្សលោកគួរតែជឿ ហើយទទួលបុណ្យជ្រមុជទឹក, ៣ នីហ្វៃ ១១:២០–៤០ ។ ពួកអ្នកដែលមិនជឿដល់ ពាក្យសំដីរបស់អ្នក ហើយមិនបានទទួលបុណ្យជ្រមុជដោយទឹក ដោយនូវព្រះនាមរបស់យើងទេ នោះនឹងត្រូវជាប់ទោស, **គ. និង ស.** ៨៤:៧៤ ។ ព្រះទ្រង់បានពន្យល់ប្រាប់ដល់លោកអ័ដាមថា ហេតុអ្វីបានចាំបាច់មានការប្រែចិត្ត និងបុណ្យជ្រមុជទឹក, **ម៉ូសេ** ៦:៥២–៦០ ។

*បុណ្យជ្រមុជទឹកដោយការពន្លិច៖* កាលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជហើយ នោះទ្រង់ក៏យាងឡើងពីទឹកភ្លាម, **ម៉ាថាយ** ៣:១៦ (ម៉ាកុស ១:១០) ។ យ៉ូហានកំពុងតែធ្វើបុណ្យជ្រមុជ ពីព្រោះនៅទីនោះមានទឹកច្រើន, **យ៉ូហាន** ៣:២៣ ។ ភីលីព និងអ្នកកំរៀវ ក៏ចុះ ទៅក្នុងទឹក, **កិច្ចការ** ៨:៣៨ ។ យើងត្រូវបានកប់ជាមួយនឹងទ្រង់ ដោយទទួលបុណ្យជ្រមុជ, **រ៉ូម** ៦:៤ (កូល៉ុស ២:១២) ។ ចូរដើរតាម ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់អ្នក ចុះទៅក្នុងទឹក, **២ នីហ្វៃ** ៣១:១៣ ។ អាលម៉ា ហេឡាម និងពួកអ្នកផ្សេងៗ ទៀតត្រូវបាន កប់ទៅក្នុងទឹក, **ម៉ូសាយ** ១៨:១២–១៦ ។ ហើយបន្ទាប់មក អ្នកនឹងពន្លិចគេនៅក្នុងទឹក, ៣ នីហ្វៃ ១១:២៥–២៦ ។ របៀបធ្វើបុណ្យ ជ្រមុជទឹកតាមត្រឹមត្រូវនោះត្រូវបានរៀបរាប់ប្រាប់, **គ. និង ស.** ២០:៧២–៧៤ ។ ពួកគេបានទទួលបុណ្យជ្រមុជទឹក តាមបែបនៃការ បញ្ចុះរបស់ទ្រង់ ដោយបានកប់ក្នុងទឹក ដោយនូវព្រះនាមរបស់ទ្រង់, **គ. និង ស.** ៧៦:៥០–៥១ ។ លោកអ័ដាមត្រូវបានកប់នៅក្នុងទឹក ហើយបាននាំចេញមកពីទឹកវិញ, **ម៉ូសេ** ៦:៦៤ ។ បុណ្យជ្រមុជទឹក គឺដោយការពន្លិច សំរាប់ការផ្ដាច់បាប, **ម. នៃ ស.** ១:៤ ។

*បុណ្យជ្រមុជទឹកសំរាប់ការផ្ដាច់បាប៖* ចូរក្រោកឡើង ហើយទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ, **កិច្ចការ** ២២:១៦ ។ បន្ទាប់ពីបុណ្យជ្រមុជទឹក គឺជាការផ្ដាច់បាបរបស់អ្នក ដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ, **២ នីហ្វៃ** ៣១:១៧ ។ ចូរមកទទួលបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្តចុះ ដើម្បីអ្នកអាចបានលាងចេញពីអំពើបាបរបស់អ្នក, **អាលម៉ា** ៧:១៤ ។ មានពរហើយ ដល់អស់អ្នក ណាដែលនឹងជឿ ហើយទទួលបុណ្យជ្រមុជទឹក ត្បិតពួកគេនឹងបានទទួលការផ្ដាច់បាបរបស់គេ, ៣ នីហ្វៃ ១២:១–២ ។ ចូរប្រកាសប្រាប់អំពីការប្រែចិត្ត និងសេចក្ដីជំនឿជឿដល់ព្រះអង្គសង្គ្រោះ និងអំពីការផ្ដាច់បាប ដោយសារបុណ្យជ្រមុជទឹក, **គ. និង ស.** ១៩:៣១ ។ យើងខ្ញុំជឿដល់បុណ្យជ្រមុជទឹក ដោយការពន្លិច សំរាប់ការផ្ដាច់បាប, **ម. នៃ ស.** ១:៤ ។

*សិទ្ធិអំណាចត្រឹមត្រូវ៖* ចូរអ្នករាល់គ្នាទៅ ហើយបង្រៀនដល់គ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះ វរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ, **ម៉ាថាយ** ២៨:១៩ (គ. និង ស. ៦៨:៨) ។ ស្ដេចលិមហៃ និងរាស្ត្រទ្រង់ជាច្រើនចង់ ទទួលបុណ្យជ្រមុជទឹក តែគ្មានអ្នកណាម្នាក់សោះ នៅក្នុងដែនដី ដែលមានសិទ្ធិអំណាចពីព្រះឡើយ, **ម៉ូសាយ** ២១:៣៣ ។ យើងប្រ ទានអំណាចដល់អ្នក ដើម្បីឲ្យអ្នកធ្វើបុណ្យជ្រមុជទឹក, ៣ នីហ្វៃ ១១:១៩–២១ ។ បព្វជិតភាពអើរ៉ុនកាន់កូនសោទាំងឡាយ ខាងបុណ្យ ជ្រមុជទឹកដោយការពន្លិច សំរាប់ការផ្ដាច់បាប, **គ. និង ស.** ១៣:១ ។ ពួកគេនេះហើយ ដែលត្រូវបានតែងតាំងពីយើង ដើម្បីឲ្យធ្វើ បុណ្យជ្រមុជទឹក ដោយនូវនាមរបស់យើង, **គ. និង ស.** ១៨:២៩ ។ យ៉ូហាន-បាទីស្ទបានប្រគល់សិទ្ធិអំណាចដល់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរឲ្យធ្វើបុណ្យជ្រមុជទឹក, **យ.ស. — ប្រវត្តិ** ១:៦៨–៦៩ ។

*ការតម្រូវការទាំងឡាយសំរាប់បុណ្យជ្រមុជទឹក៖* ចូរអ្នកប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមនៃព្រះរាជបុត្រា ដ៏ជាទី សំឡាញ់របស់យើងចុះ, **២ នីហ្វៃ** ៣១:១១ ។ អ្នកត្រូវតែប្រែចិត្ត ហើយកើតជាថ្មី, **អាលម៉ា** ៧:១៤ ។ ចូរមើលថា អ្នកពុំទទួលបុណ្យ ជ្រមុជទឹកដោយមិន

សក្តិសមឡើយ, **មរមន** ៩:២៩ ។ ចូរបង្រៀនដល់ពួកមាតាបិតា ឲ្យប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ហើយ បន្ទាបខ្លួន, **ម៉ូរ៉ូណៃ** ៨:១០ ។ គុណសម្បត្តិនៃអស់អ្នក ណាដែលមានបំណងចង់ទទួលបុណ្យជ្រមុជទឹក ត្រូវបានថែងប្រាប់, **គ. និង ស.** ២០:៣៧ ។ កូនក្មេងត្រូវទទួលបុណ្យជ្រមុជទឹក សំរាប់ ការផ្តាច់បាបទាំងឡាយរបស់ខ្លួន កាលមានអាយុប្រាំបីឆ្នាំ, **គ. និង ស.** ៦៨:២៥, ២៧ ។

*សេចក្តីសញ្ញាទាំងឡាយដែលបានធ្វើតាមរយៈបុណ្យជ្រមុជទឹក៖* អ្នករាល់គ្នាបានចូលក្នុងសេចក្តីសញ្ញាជាមួយនឹងទ្រង់ថា អ្នករាល់គ្នា នឹងបំរើទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់, **ម៉ូសាយ** ១៨:៨–១០, ១៣ ។ អស់អ្នកណាដែលបានប្រែចិត្ត, លើកដាក់ មកលើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ ហើយប្តេជ្ញាថានឹងបំរើទ្រង់ នោះឈ្មោះថានឹងបានទទួលចូល ដោយបុណ្យជ្រមុជទឹក, **គ. និង ស.** ២០:៣៧ ។

*បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់៖* តើហេតុអ្វីបានគេទទួលបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ធ្វើអី, **១ កូរិន.** ១៥:២៩ ។ បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ គឺបានប្រព្រឹត្តឡើងសំរាប់ការផ្តាច់បាប, **គ. និង ស.** ១២៤:២៩; ១២៧:៥–៩; ១២៨:១; ១៣៨:៣៣ ។

*បុណ្យជ្រមុជទឹកមិនមែនសំរាប់ទារកទេ៖* ថាជាការចំអកឡុកឡឺយដ៏ខ្លាំងដល់ព្រះ ដែលអ្នករាល់គ្នាត្រូវធ្វើបុណ្យជ្រមុជទឹកឲ្យកូនក្មេង, **ម៉ូរ៉ូណៃ** ៨:៤–២៣ ។ កូនក្មេងត្រូវទទួលបុណ្យជ្រមុជទឹក កាលមានអាយុប្រាំបីឆ្នាំ, **គ. និង ស.** ៦៨:២៧ ។ កូនក្មេងទាំងអស់ ដែលបានស្លាប់មុនគ្រប់អាយុទទួលខុសត្រូវ នោះបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល, **គ. និង ស.** ១៣៧:១០ ។

**បុណ្យជ្រមុជទឹកឲ្យទារក** *សូមមើលផង* ការទទួលខុសត្រូវ;
កូនក្មេង,ចេះទទួលការខុសត្រូវ, ទទួលការខុសត្រូវ,
ធ្វើបុណ្យជ្រមុជទឹក — បុណ្យជ្រមុជទឹកពុំមែនសំរាប់ទារកទេ;
បុណ្យជ្រមុជទឹក, ពួកកូនក្មេង; សេចក្តីសង្គ្រោះ —
សេចក្តីសង្គ្រោះនៃពួកកូនក្មេង

ជាការប្រព្រឹត្តដោយធ្វើបុណ្យជ្រមុជទឹកដ៏មិនចាំបាច់ឲ្យទារក និងកូនក្មេងទាំងឡាយ ដែលមិនទាន់ដល់អាយុចេះទទួលការខុសត្រូវ គឺអាយុ ៨ ឆ្នាំ ។ព្រះអម្ចាស់ទ្រង់ដាក់ទោសដល់បុណ្យជ្រមុជទឹកឲ្យទារក (ម៉ូរ៉ូណៃ ៨:១០–២១) ។ ពួកកូនក្មេងកើតមកដោយឥតមាន ទោស ហើយឥតមានបាបទេ ។ សាតាំងគ្មានអំណាចនឹងល្បួងពួកកូនក្មេងបានទេ រហូតដល់ពួកគេក្លាយទៅជាអ្នកចេះទទួលការខុស ត្រូវ (គ. និង ស. ២៩:៤៦–៤៧) ។ ហេតុនោះហើយ ទើបពួកកូនក្មេងមិនត្រូវការប្រែចិត្ត ឬទទួលបុណ្យជ្រមុជទឹកឡើយ ។ ពួកកូនក្មេង ត្រូវទទួលបុណ្យជ្រមុជទឹកពេលមានអាយុ ៨ ឆ្នាំ (គ. និង ស. ៦៨:២៥–២៧) ។

**បុណ្យថ្ងៃទី ៥០** *សូមមើលផង* ក្រិត្យវិន័យលោកម៉ូសេ

ជាផ្នែកនៃក្រិត្យវិន័យលោកម៉ូសេ គឺការជប់លៀងនៃបុណ្យថ្ងៃទី ៥០ ឬការជប់លៀងនៃផលផ្លែមុនដំបូងប្រព្រឹត្តឡើង ៥០ ថ្ងៃបន្ទាប់ពីការជប់លៀងនៃបុណ្យរំលង (លេវី. ២៣:១៦) ។ បុណ្យថ្ងៃទី ៥០ គឺសំរាប់ធ្វើបុណ្យពិធីចម្រូត ហើយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺបានហៅថា ការជប់លៀងរដូវចម្រូត ឬការជប់លៀងនៃសប្តាហ៍ ។ គឺជាការជប់លៀងដែលកំពុងធ្វើ កាលពួកសាវកនៅក្រុងយេរូសាឡិម ត្រូវបាន ពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនិយាយភាសាទាំងឡាយ (កិច្ចការ ២; គ. និង ស. ១០៩:៣៦–៣៧) ។

**បុណ្យរំលង** *សូមមើលផង* កូនចៀមនៃព្រះ;
អាហារចុងក្រោយបង្អស់

ការជប់លៀងនៃបុណ្យរំលងត្រូវបានតាំងឡើង ដើម្បីជួយឲ្យកូនចៅអ៊ីស្រាអែលរំឭកចាំនៅពេលទេវតាមកបំផ្លាញ បានរំលងផ្ទះពួកគេ ហើយបានរំដោះគេចេញពីពួកសាសន៍អេស៊ីព្ទ (និក្ខ. ១២:២១–២៨; ១៣:១៤–១៥) ។ ឈាមកូនចៀមដែលឥតខ្ចោះទាំងប៉ុន្មានត្រូវ បានយកមកប្រើជាទីសំគាល់ សំរាប់ជួយសង្គ្រោះពួកអ៊ីស្រាអែលពីបុរាណ នោះគឺជានិមិត្តរូបអំពីព្រះយេស៊ូវគ្រីស្ទ ជាកូនចៀមនៃព្រះ រីឯការបូជារបស់ទ្រង់នោះបានប្រោសលោះមនុស្សលោកទាំងអស់ ។

នេះជាច្បាប់សំរាប់បុណ្យរំលង, **និក្ខ.** ១២:៤៣ ។ ព្រះយេស៊ូវ និងពួកសាវកទ្រង់បានកាន់តាមបុណ្យរំលង នៅគ្រាអាហារចុងក្រោយ បង្អស់, **ម៉ាថាយ** ២៦:១៧–២៩ (ម៉ាកុស ១៤:១២–២៥) ។ នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក, **យ៉ូហាន** ១:២៩, ៣៦ ។ ព្រះគ្រីស្ទដ៏ជាយញ្ញបូជានៃបុណ្យរំលង នោះបានត្រូវថ្វាយជំនួសយើងរាល់គ្នាហើយ, **១ កូរិន.** ៥:៧ ។ ពួកយើងរាល់គ្នាបានត្រូវ លោះ ដោយសារព្រះលោហិតនៃព្រះគ្រីស្ទ ទុកដូចជាឈាមនៃកូនចៀមឥតខ្ចោះ, **១ ពេត្រុស** ១:១៨–១៩ ។ ចូរមានសេចក្តីជំនឿជឿ ដល់កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក, **អាលម៉ា** ៧:១៤ ។ ពួកបរិសុទ្ធណាដែលរស់នៅតាមពាក្យសំដីនៃប្រាជ្ញាវាងវៃ នឹងបានជីវិតនៅគង់វង្ស ដូចជាកូនចៅអ៊ីស្រាអែលដែរ, **គ. និង ស.** ៨៩:២១ ។ កូនចៀមត្រូវបានប្រហារ តាំងពីកំណើតលោកិយ មកម្លេះ, **ម៉ូសេ** ៧:៤៧ ។

**បុណ្យរំឭក** *សូមមើលផង* ដង្វាយធួន; ឈើឆ្កាង;
ធ្វើបុណ្យជ្រមុជទឹក; ទឹករស់; ធ្វើឲ្យធួន, នំបុ័ងជីវិត;
បុណ្យជ្រមុជទឹក, បូជា, ព្រះយេស៊ូវគ្រីស្ទ;
អាហារចុងក្រោយបង្អស់

សំរាប់ពួកបរិសុទ្ធនៅថ្ងៃចុងក្រោយ *បុណ្យរំឭក* សំដៅដល់ពិធីនៃការទទួលទាននំបុ័ង និងទឹក ដើម្បីរំឭកចាំដល់ការបូជាដ៏ធួននៃព្រះ គ្រីស្ទ ។ ចំណិតនំបុ័ង គឺជាតំណាងអំពីព្រះកាយដ៏ខ្ទេចខ្ទាំរបស់ទ្រង់ រីឯទឹកគឺជាតំណាងអំពីព្រះលោហិត ដែលទ្រង់បានច្រួច ដើម្បី ធ្វើឲ្យធួននឹងបាបទាំងឡាយរបស់ពួកយើង (១ កូរិន. ១១:២៣–២៥; គ. និង ស. ២៧:២) ។ នៅពេលសមាជិកដែលសក្តិសមណា ម្នាក់នៃសាសនាចក្រទទួលទានបុណ្យរំឭក នោះគេសន្យាថានឹងលើកយកព្រះនាមនៃព្រះគ្រីស្ទមកដាក់លើខ្លួន ហើយនឹកចាំដល់ទ្រង់ ជានិច្ច ហើយនឹងកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ តាមបុណ្យនេះ សមាជិកនៃសាសនាចក្រធ្វើសេចក្តីសញ្ញានៃបុណ្យ ជ្រមុជទឹករបស់គេជាថ្មីម្តងទៀត ។

នៅគ្រាអាហារចុងក្រោយបង្អស់ ព្រះយេស៊ូវទ្រង់បានពន្យល់ប្រាប់អំពីបុណ្យរំលង កាលទ្រង់សោយជាមួយនឹងពួកសាវក១២នាក់ (ម៉ាថាយ ២៦:១៧–២៩; លូកា ២២:១–២០) ។

ព្រះយេស៊ូវទ្រង់បានយកនំបុ័ង ហើយក៏ប្រទានពរ ហើយទ្រង់ក៏យកពែងមកប្រទានពរ, **ម៉ាថាយ** ២៦:២៦–២៨ (ម៉ាកុស ១៤:២២–២៤; លូកា ២២:១៩–២០) ។ អ្នកណាដែលបរិភោគសាច់ និងឈាមរបស់ខ្ញុំ នោះមានជីវិតដ៏នៅអស់កល្បជានិច្ច, **យ៉ូហាន** ៦:៥៤ ។ អ្នកណាដែលបរិភោគបែបមិនគួរសម អ្នកនោះឈ្មោះថា បរិភោគជាសេចក្ដីជំនុំជំរះដល់ខ្លួនវិញ, **១ កូរិន.** ១១:២៩ (៣ នីហ្វៃ ១៨:២៩) ។ ព្រះយេស៊ូវទ្រង់បានបង្រៀនពួកសិស្សសាសន៍នីហ្វៃ ១២ នាក់ អំពីបុណ្យរំលង, ៣ នីហ្វៃ ១៨:១–១១ ។ ព្រះយេស៊ូវទ្រង់បានបង្រៀន ពួកសិស្សទាំងនេះថា ត្រូវហាមពួករាស្ត្រណាដែលមិនសក្តិសមមិនឲ្យបរិភោគបុណ្យរំលងឡើយ, ៣ នីហ្វៃ ១៨:២៨–២៩ (មរមន ៩:២៩) ។ បទអធិស្ឋានសំរាប់បុណ្យរំលងត្រូវបានរៀបរាប់ប្រាប់, **ម៉ូរ៉ូណៃ** ៤–៥ (គ. និង ស. ២០:៧៥–៧៩) ។ បុណ្យរំលងត្រូវបាន ចាត់ចែងដោយសង្ឃ ឬដោយអែលឌើរ, **គ. និង ស.** ២០:៤៦, ៧៦ ។ ពួកគ្រូ និងពួកឌីកុនពុំមានអំណាចនឹងប្រសិទ្ធិពរបុណ្យរំលងទេ, **គ. និង ស.** ២០: ៥៨ ។ អាចប្រើទឹកជំនួសស្រាទំពាំងបាយជូរបានសំរាប់បុណ្យរំលង, **គ. និង ស.** ២៧:១–៤ ។

**បុណ្យអ៊ីស្ទើរ** *សូមមើល* ដំណើររស់ឡើងវិញ, ព្រះយេស៊ូវគ្រីស្ទ

**បុត្រាបុត្រីនៃព្រះ** *សូមមើលផង* កូនចៅព្រះគ្រីស្ទ; កើតពីព្រះ; កើតម្ដងទៀត, ដង្វាយធួន; ធ្វើឲ្យធួន, បង្កើត; មនុស្ស, មនុស្សលោក

ព្រះគម្ពីរប្រើពាក្យនេះបានពីរយ៉ាង ។ ម៉្យាងគឺ យើងរាល់គ្នាជាកូនចៅវិញ្ញាណយ៉ាងពិតប្រាកដរបស់ព្រះវរបិតា ដែលគង់នៅលើស្ថានសួគ៌ ។ ម៉្យាងទៀត បុត្រាបុត្រីរបស់ព្រះ គឺអស់អ្នកណា ដែលបានកើតម្ដងទៀត តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ ។

*កូនចៅវិញ្ញាណនៃព្រះវរបិតា៖* ឯងរាល់គ្នាសុទ្ធតែជាអ្នកមានអំណាច ហើយជាកូននៃព្រះដ៏ខ្ពស់បំផុត, **ទំនុក.** ៨២:៦ ។ មនុស្សយើង ជាពូជព្រះ, **កិច្ចការ** ១៧:២៩ ។ ចូរចុះចូល ចំពោះព្រះវរបិតាខាងវិញ្ញាណ, **ហេព្រើរ** ១២:៩ ។ ខ្ញុំជាបុត្រនៃព្រះ, **ម៉ូសេ** ១:១៣ ។

*កូនចៅដែលកើតម្ដងទៀត តាមរយៈដង្វាយធួន៖* អស់អ្នកណាដែលទទួលទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូន ព្រះ, **យ៉ូហាន** ១:១២ (រ៉ូម ៨:១៤; ៣ នីហ្វៃ ៩:១៧; គ. និង ស. ១១:៣០) ។ ឥឡូវនេះ ដែលយើងបានហៅថាជាកូនរបស់ព្រះ, **១ យ៉ូហាន** ៣:១–២ ។ អ្នករាល់គ្នានឹងត្រូវបានហៅថាជាកូនចៅព្រះគ្រីស្ទ គឺបុត្រាបុត្រីរបស់ទ្រង់, **ម៉ូសាយ** ៥:៧ ។ មនុស្សគ្រប់រូប ត្រូវតែបានកើតម្ដងទៀត ដើម្បីឲ្យបានក្លាយទៅជាបុត្រាបុត្រីរបស់ទ្រង់, **ម៉ូសាយ** ២៧:២៥ ។ ពួកគេនឹងក្លាយទៅជាកូនប្រុស និងកូន ស្រីយើង, **អេធើរ** ៣:១៤ ។ អ្នកប្រាកដជានឹងក្លាយទៅជាកូននៃព្រះគ្រីស្ទ, **ម៉ូរ៉ូណៃ** ៧:១៩ ។ អស់អ្នកណាដែលទទួលដំណឹងល្អ របស់យើង នោះឈ្មោះថាជាបុត្រាបុត្រីរបស់យើង, **គ. និង ស.** ២៥:១ ។ ពួកគេសុទ្ធតែជាព្រះ គឺជាបុត្រានៃព្រះ, **គ. និង ស.** ៧៦:៥៨ ។ ដូច្នេះ ទើបមនុស្សទាំងអស់អាចក្លាយទៅជាកូនរបស់យើង, **ម៉ូសេ** ៦:៦៨ ។ មនុស្សជាច្រើនបានជឿ ហើយបានក្លាយជាកូននៃព្រះ, **ម៉ូសេ** ៧:១ ។

**ប៉ុល** *សូមមើលផង* សំបុត្ររបស់ប៉ុល

ជាសាវកម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ឈ្មោះប៉ុលក្នុងភាសាហេព្រើរ គឺសុល ហើយលោកត្រូវបានហៅតាមឈ្មោះនេះរហូតដល់ការចាប់ផ្ដើមបេសកកម្មរបស់លោកទៅដល់ពួកសាសន៍ដទៃ ។ ពីមុនលោកបានបៀតបៀនសាសនាចក្រ ប៉ុន្តែបានប្រែចិត្តជឿដល់ សេចក្ដីពិតបន្ទាប់ពីបានឃើញការនិមិត្តមួយអំពីព្រះយេស៊ូវគ្រីស្ទ ។ ប៉ុលបានធ្វើដំណើរទៅធ្វើបេសកកម្មសំខាន់ៗបីដង ហើយបាន សរសេរសំបុត្រជាច្រើនទៅកាន់ពួកបរិសុទ្ធ ។ សព្វថ្ងៃនេះ សំបុត្រទាំង១៤ច្បាប់នេះ រួមធ្វើជាផ្នែកមួយក្នុងព្រះគម្ពីរសញ្ញាថ្មី ។ នៅទី បញ្ចប់ លោកត្រូវគេយកទៅដាក់គុកនៅទីក្រុងរ៉ូម ហើយត្រូវគេសម្លាប់ ប្រហែលជានៅនិទាឃរដូវ ក្នុងឆ្នាំ ៦៥ គ.ស. ។

បានយល់ព្រមក្នុងការចោលស្ទេផាននឹងថ្ម, **កិច្ចការ** ៧:៥៧–៨:១ ។ បានធ្វើទុក្ខដល់ពួកបរិសុទ្ធ, **កិច្ចការ** ៨:៣ ។ កំពុងតែធ្វើដំណើរទៅ ក្រុងដាម៉ាស កាលព្រះយេស៊ូវលេចមកឲ្យលោកឃើញ, **កិច្ចការ** ៩:១–៩ ។ ត្រូវបានធ្វើបុណ្យជ្រមុជទឹកឲ្យដោយអាន៉ានាស, **កិច្ចការ** ៩:១០–១៨ ។ បន្ទាប់ពីបានសំរាកនៅឯស្រុកអារ៉ាបបៀ លោកបានត្រឡប់ទៅឯក្រុងដាម៉ាស ដើម្បីទៅផ្សាយ, **កិច្ចការ** ៩:១៩–២៥ (កាឡាទី ១:១៧) ។ បន្ទាប់ពីលោកបានប្រែចិត្តជឿបីឆ្នាំក្រោយមក លោកបានវិលទៅក្រុងយេរូសាឡិមវិញ, **កិច្ចការ** ៩:២៦–៣០ (កាឡាទី ១:១៨–១៩) ។ បានធ្វើដំណើរទៅធ្វើបេសកកម្មបីដង បានផ្សាយដំណឹងល្អ ហើយបានរៀបចំធ្វើសាខានៃសាសនាចក្រនៅ ភូមិភាគនៃរាជាណាចក្ររ៉ូមជាច្រើន, **កិច្ចការ** ១៣:១–១៤:២៦; ១៥:៣៦–១៨:២២; ១៨:២៣–២១:១៥ ។ កាលលោកបានវិលទៅ ក្រុងយេរូសាឡិមវិញ បន្ទាប់ពីបេសកកម្មទីបីរបស់លោក នោះលោកត្រូវគេចាប់ ហើយជូនទៅសេសារា, **កិច្ចការ** ២១:៧–២៣:៣៥ ។ បានជាប់គុកនៅឯសេសារាអស់រយៈពេលពីរឆ្នាំ, **កិច្ចការ** ២៤:១–២៦:៣២ ។ ត្រូវគេបញ្ជូនទៅក្រុងរ៉ូម ដើម្បីកាត់ក្តី ហើយត្រូវរង ទុក្ខដោយទូកលិចតាមផ្លូវ, **កិច្ចការ** ២៧:១–២៨:១១ ។

**បូជា, យញ្ញបូជា, លះបង់** *សូមមើលផង* ចិត្តសង្រេង; ដង្វាយធួន; ធ្វើឲ្យធួន, បុណ្យរំលង, ព្រះយេស៊ូវគ្រីស្ទ; លោហិត

កាលពីបុរាណ ពាក្យបូជាមានន័យថា ធ្វើឲ្យអ្វី ឬធ្វើឲ្យមនុស្សណាម្នាក់បានបរិសុទ្ធ ។ ឥឡូវនេះ ពាក្យនេះត្រឡប់ទៅជាមានន័យថា លះបង់ចោល ឬសុខចិត្តចោលរបស់ទ្រព្យខាងលោកិយ ដើម្បីព្រះអម្ចាស់ និងនគររបស់ទ្រង់ ។ សមាជិកនៃសាសនាចក្ររបស់ ព្រះអម្ចាស់ គួរតែយល់ព្រមបូជានូវអ្វីៗទាំងអស់ ដើម្បីព្រះអម្ចាស់ ។ យ៉ូសែប ស៊្មីធ បានមានបង្រៀនថា « សាសនាណាដែលមិន តម្រូវឲ្យបូជានូវគ្រប់អ្វីៗទាំង

អស់ នោះមិនដែលមានអំណាចគ្រប់គ្រាន់ ដើម្បីបណ្ដាលឲ្យមានសេចក្ដីជំនឿដ៏ចាំបាច់ដល់ជីវិត និង សេចក្ដីសង្គ្រោះឡើយ » ។ បើសិនជាគិតឲ្យបានវែងឆ្ងាយទៅ ព្រះពរទាំងឡាយដែលបានមក ដោយសារការបូជា នោះធំជាងអ្វីៗ ដែលបានលះបង់ទៅទៀត ។

ក្រោយពីលោកអ័ដាម និងនាងអេវ៉ាត្រូវបានដេញចេញពីសួនច្បារអេដែន ព្រះអម្ចាស់ទ្រង់បានប្រទានដល់គេ នូវក្រិត្យវិន័យនៃ យញ្ញបូជា ។ ក្រិត្យវិន័យនេះមានរួមនូវការបូជាកូនចៀមច្បងពីហ្វូងចៀមគេ។ យញ្ញបូជានេះ គឺជានិមិត្តរូបអំពីយញ្ញបូជា ដែលនឹងបាន ធ្វើដោយព្រះរាជបុត្រាបង្កើតតែមួយនៃព្រះ (ម៉ូសេ ៥:៤–៨) ។ ការបូជារបៀបនេះមានរៀងដរាបរហូតមកដល់ពេលព្រះយេស៊ូវគ្រីស្ទ សុគត ដែលជាទីបញ្ចប់នូវយញ្ញបូជាសត្វ ជាពិធីបរិសុទ្ធមួយនៃដំណឹងល្អ (អាលម៉ា ៣៤:១៣–១៤) ។ នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ សមាជិក ទទួលទានបុណ្យរំឭក ជានំប៉័ង និងទឹក ដើម្បីនឹកចាំដល់ការបូជានៃព្រះយេស៊ូវគ្រីស្ទ ។ សមាជិកនៃសាសនាចក្ររបស់ ព្រះគ្រីស្ទសព្វថ្ងៃនេះ ក៏សូមឲ្យបូជានូវចិត្តសង្រេង និងវិញ្ញាណទន់ទាប (៣ នីហ្វៃ ៩:១៩–២២) ។ ទាំងនេះ គឺមានន័យថា គេជា មនុស្សដែលមានចិត្តសុភាពរាបសា ដែលប្រែចិត្ត ហើយសុខចិត្តគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

អ័ប្រាហាំថងអ៊ីសាក ជាកូន ហើយដាក់វាលើអាសនា, **លោកុ.** ២២:១–១៨ (យ៉ាកុប ៤:៥) ។ ត្រូវឲ្យឯងថ្វាយដង្វាយដុត, **និក្ខ.** ២០:២៤ ។ ពួកសត្វទាំងឡាយដែលត្រូវថ្វាយជាយញ្ញបូជា មិនត្រូវមានខ្ចោះអាក្រក់ត្រង់ណាឡើយ, **ចោទិ.** ១៥:១៩–២១ ។ ដែល ស្ដាប់បង្គាប់តាមនោះវិសេសលើសជាងយញ្ញបូជា, **១ សាំយូ.** ១៥:២២ ។ ដែលស្រឡាញ់នោះវិសេសលើសជាងអស់ទាំងដង្វាយ ដុត និងយញ្ញបូជាទៅទៀត, **ម៉ាកុស** ១២:៣២–៣៣ ។ យើងរាល់គ្នាបានញែកជាបរិសុទ្ធ ដោយសារដង្វាយថ្វាយរូបអង្គព្រះគ្រីស្ទ, **ហេព្រើរ** ១០:១០–១៤ ។ ព្រះគ្រីស្ទបានថ្វាយព្រះអង្គទ្រង់ជាយញ្ញបូជាជំនួសអំពើបាប, **២ នីហ្វៃ** ២:៦–៧ ។ ការបូជាដ៏មហិមា និងចុង ក្រោយបំផុត គឺព្រះរាជបុត្រានៃព្រះ ដែលជាការបូជាដ៏និរន្តរ៍ និងអស់កល្បជានិច្ច, **អាលម៉ា** ៣៤:៨–១៤ ។ ចូរកុំថ្វាយដង្វាយដុត ទៀតឡើយ ចូរថ្វាយដល់ព្រះ នូវចិត្តសង្រេង និងវិញ្ញាណទន់ទាបវិញ, ៣ នីហ្វៃ ៩:១៩–២០ (ទំនុក. ៥១:១៦–១៧; គ. និង ស. ៥៩:៨) ។ ថ្ងៃនេះ គឺជាថ្ងៃនៃការបូជា, **គ. និង ស.** ៦៤:២៣ (គ. និង ស. ៩៧:១២) ។ មនុស្សទាំងអស់ដែលយល់ព្រមគោរពតាមសេចក្ដី សញ្ញារបស់ខ្លួន ដោយការបូជា នោះពួកគេត្រូវបានទទួលដោយព្រះអម្ចាស់ហើយ, **គ. និង ស.** ៩៧:៨ ។ យ៉ូសែប អេហ្វ ស្ម៊ីធបាន ឃើញវិញ្ញាណនៃមនុស្សទៀងត្រង់ ដែលបានថ្វាយយញ្ញបូជា ក្នុងនិមិត្តរូបអំពីការបូជារបស់ព្រះអង្គសង្គ្រោះ, **គ. និង ស.** ១៣៨:១៣ ។ សេចក្ដីប្រោសលោះត្រូវបាននាំមកតាមរយៈការបូជានៃព្រះរាជបុត្រានៃព្រះ នៅលើឈើឆ្កាង, **គ. និង ស.** ១៣៨:៣៥ ។

**បូអូស** *សូមមើលផង* នាងរស់

ជាប្ដីនាងរស់ (នាងរស់ ៤:៩–១០); ជាជីតាទួតរបស់ហ្លួងដាវីឌជាស្ដេចអ៊ីស្រាអែល (នាងរស់ ៤:១៣–១៧); ហើយជាអយ្យកោរបស់ ព្រះគ្រីស្ទ ជាស្ដេចលើអស់ទាំងស្ដេច (លូកា ៣:៣២) ។

**បៀតបៀន, សេចក្ដីបៀតបៀន** *សូមមើលផង* សេចក្ដីទំនាស់

គឺធ្វើឲ្យអ្នកផ្សេងមានទុក្ខកង្វល់ ឬការឈឺចាប់ ពីព្រោះមកពីជំនឿ ឬឋានៈរបស់គេក្នុងសង្គម; រំខាន ឬសង្កត់សង្កិន ។

មានពរហើយ អស់អ្នកណាដែលត្រូវគេបៀតបៀន ដោយព្រោះសេចក្ដីសុចរិត, **ម៉ាថាយ** ៥:១០ (៣ នីហ្វៃ ១២:១០) ។ ត្រូវអធិស្ឋាន ឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នា, **ម៉ាថាយ** ៥:៤៤ (៣ នីហ្វៃ ១២:៤៤) ។ មកពីពួកគេមាន បានជាគេបៀតបៀន មនុស្សស្លូតត្រង់, **២ នីហ្វៃ** ៩:៣០ (២ នីហ្វៃ ២៨:១២–១៣) ។ ពួកមនុស្សសុចរិតណា ដែលទន្ទឹងចាំព្រះគ្រីស្ទ ដោយរងគ្រប់ទាំងការ បៀតបៀន នោះនឹងពុំត្រូវវិនាសឡើយ, **២ នីហ្វៃ** ២៦:៨ ។ គ្រប់ការណ៍ទាំងនេះនឹងផ្ដល់ការពិសោធន៍ដល់អ្នក, **គ. និង ស.** ១២២:៧ ។

**បេត-អែល**

ជាភាសាហេព្រើរ មានន័យថា « ព្រះដំណាក់នៃព្រះ » ហើយជាកន្លែងមួយដ៏ពិសិដ្ឋបំផុតនៅអ៊ីស្រាអែល ។ មានចម្ងាយប្រហែលជា ១៦ គ.ម. ខាងជើងក្រុងយេរូសាឡិម ។ នៅទីនេះហើយដែលលោកអ័ប្រាហាំបានសាងអាសនារបស់លោក កាលលោកមកដល់ ស្រុកកាណានមុនដំបូង (លោកុ. ១២:៨; ១៣:៣) ។ នៅទីនេះហើយដែលយ៉ាកុបបានឃើញក្នុងការនិមិត្ត នូវជណ្ដើរទល់នឹងមេឃ (លោកុ. ២៨:១០–១៩)។ ទីនេះក៏ជាកន្លែងបរិសុទ្ធមួយ នៅសម័យលោកសាំយូអែលដែរ (១ សាំយូ. ៧:១៦; ១០:៣) ។

**បេថានី**

ជាភូមិមួយដែលព្រះយេស៊ូវគ្រីស្ទបានគង់នៅអាទិត្យចុងក្រោយបង្អស់នៃព្រះជន្មទ្រង់ជាមនុស្ស (ម៉ាថាយ ២១:១៧; ម៉ាកុស ១១:១១)។ ភូមិនេះស្ថិតនៅទិសអគ្នេយ៍ភ្នំដើមអូលីវ ។ ភូមិបេថានី គឺជាភូមិដែលឡាសារ នាងម៉ាថា និងនាងម៉ារាអាស្រ័យនៅ (យ៉ូហាន ១១:១–៤៦; ១២:១) ។

**បេថ្លេហិម**

ជាក្រុងដ៏តូចមួយ មានចម្ងាយ ៨ គ.ម. ខាងត្បូងក្រុងយេរូសាឡិម ។ ក្នុងភាសាហេព្រើរ បេថ្លេហិម មានន័យថា « ផ្ទះនំប៉័ង »; គេក៏ហៅថា អេប្រាតា ដែលមានន័យថា « មានផល » ។ ព្រះយេស៊ូវគ្រីស្ទបានប្រសូតនៅភូមិបេថ្លេហិម (មីកា ៥:២; ម៉ាថាយ ២:១–៨) ។ ជាទី បញ្ចុះនាងរ៉ាជែល (លោកុ. ៣៥:១៩; ៤៨:៧) ។

នាងរស់ និងបូអូសបានរស់នៅទីនោះ, **នាងរស់** ១:២២ ។ សាំយូអែលបានចាក់ប្រេងតាំងដាវីឌនៅទីនោះ, **១ សាំយូ.** ១៦:១–១៣; ១៧:១២, ១៥; ២០:៦, ២៨ ។ ស្ដេចហេរ៉ូឌបានប្រហារពួកកូនក្មេងនៅទីនោះ, **ម៉ាថាយ** ២:១៦ ។

**បេនយ៉ាមីន, បិតារបស់ម៉ូសាយ** *សូមមើលផង* 
បុត្ររបស់បេនយ៉ាមីន, ម៉ូសាយ

ជាព្យាការី ហើយជាស្ដេចនៅក្នុងព្រះគម្ពីរមរមន (ម៉ូសាយ ១–៦) ។

បានដោះស្រាយបញ្ហាដ៏ធំ ក្នុងការសាងសន្តិសុខក្នុងដែនដី, **អោមណៃ** ១:២៣–២៥ (ព. នៃ ម. ១:១២–១៨) ។ បានបង្រៀនបុត្រា របស់ទ្រង់, **ម៉ូសាយ** ១:១–៨ ។ បានប្រគល់នគរដល់ម៉ូសាយ ជាបុត្ររបស់ទ្រង់, **ម៉ូសាយ** ១:៩–១៨ ។ រាស្ត្រទ្រង់បានប្រមូលគ្នាមក ស្ដាប់ទ្រង់មានបន្ទូលចុងក្រោយបង្អស់, **ម៉ូសាយ** ២:១–៨ ។ បានមានបន្ទូលទៅកាន់រាស្ត្រទ្រង់, **ម៉ូសាយ** ២:៩–៤:៣០ ។ រាស្ត្រទ្រង់បានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់, **ម៉ូសាយ** ៥–៦ ។

**បេនយ៉ាមីន, កូនប្រុសរបស់យ៉ាកុប** *សូមមើលផង* 
កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាកូនប្រុសទីពីររបស់យ៉ាកុប និងនាងរ៉ាជែល (លោកុ. ៣៥:១៦–២០) ។

*ពូជអំបូររបស់បេនយ៉ាមីន៖* យ៉ាកុបបានឲ្យពរដល់បេនយ៉ាមីន (លោកុ. ៤៩:២៧) ។ ពូជពង្សរបស់បេនយ៉ាមីន ជាជនជាតិខាង សង្គ្រាម ។ សាសន៍បេនយ៉ាមីនពីរនាក់ដែលសំខាន់ គឺសូល ជាស្ដេចទីមួយនៃអ៊ីស្រាអែល (១ សាំយូ. ៩:១–២) និងប៉ុល ជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី (រ៉ូម ១១:១) ។

**បេលសាសារ** *សូមមើលផង* បាប៊ិល, បាប៊ីឡូន

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាស្ដេចចុងក្រោយបង្អស់នៅបាប៊ីឡូន ដែលបានសោយរាជ្យមុនស្ដេចស៊ីរូសចាប់យកក្រុងបាប៊ីឡូន ។ ទ្រង់ ត្រូវជាបុត្រ ហើយជាអ្នកសោយរាជ្យជួសស្ដេចនេប៊ូក្នេសា (ដានី. ៥:១–២) ។

**បំណុល***សូមមើលផង* អត់ទោស

ដូចដែលបានប្រើនៅក្នុងគម្ពីរ គឺជាប្រាក់ ឬរបស់របរដែលជំពាក់អ្នកផ្សេង ធ្វើឲ្យអ្នកខ្ចីនៅក្នុងស្ថានភាពឃុំឃាំង ។ ម៉្យាងទៀត ព្រះយេស៊ូវទ្រង់បង្រៀនថា យើងគួរសូមឲ្យព្រះវរបិតាអត់ទោសដល់យើង នូវបំណុលរបស់យើង ឬក៏ដោះយើងចេញពីការបង់ ថ្លៃអំពើបាបរបស់យើង — តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ — បន្ទាប់ពីយើងបានអត់ទោសឲ្យអ្នកដទៃ ចំពោះកំហុសរបស់គេ ទាស់នឹងយើង (ម៉ាថាយ ៦:១២; ៣ នីហ្វៃ ១៣:១១) ។

មនុស្សអាក្រក់គេខ្ចីឥតសងវិញឡើយ, **ទំនុក.** ៣៧; ២១ ។ អ្នកណាដែលខ្ចីគេ ជាបាវបំរើដល់អ្នកដែលឲ្យខ្ចីនោះ, **សុភា.** ២២:៧ ។ យើងបានលែងទារបំណុលអ្នកទាំងអស់ហើយតើ តើមិនគួរឲ្យអ្នកអាណិតមេត្តាដែរទេឬអី ? **ម៉ាថាយ** ១៨:២៣–៣៥ ។ កុំឲ្យជំពាក់អ្វីដល់អ្នកណាឡើយ ប៉ុន្តែចូរស្រឡាញ់គ្នាទៅវិញទៅមកចុះ, **រ៉ូម** ១៣:៨ ។ អ្នករាល់គ្នាជំពាក់ព្រះវរបិតាសួគ៌ឥតហួត, **ម៉ូសាយ** ២:២១–២៤, ៣៤ ។ អស់អ្នកណាដែលខ្ចីអ្វីពីអ្នកជិតខាងរបស់ខ្លួន ត្រូវតែសងរបស់ដែលខ្លួនបានខ្ចីទៅវិញ, **ម៉ូសាយ** ៤:២៨ ។ ចូរបង់ បំណុលហើយដោះខ្លួនឲ្យរួចពីសេវកភាពចុះ, **គ. និង ស.** ១៩:៣៥ ។ គឺជាបំរាមហាមឃាត់មិនឲ្យមានបំណុលពីពួកខ្មាំងសត្រូវរបស់ អ្នកឡើយ, **គ. និង ស.** ៦៤:២៧ ។ អ្នកត្រូវបង់បំណុលរបស់អ្នកឲ្យអស់, **គ. និង ស.** ១០៤:៧៨ ។ ចូរកុំជាប់ជំពាក់ ដើម្បីកសាងដំណាក់ នៃព្រះអម្ចាស់ឡើយ, **គ. និង ស.** ១១៥:១៣ ។

**បោះឆ្នោត** *សូមមើល* ការយល់ព្រមទូទៅ

**ប្ដី** *សូមមើល* គ្រួសារ; រៀបអាពាហ៍ពិពាហ៍, អាពាហ៍ពិពាហ៍,

**ប្ដីថ្មោងថ្មី** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទ គឺជានិមិត្តរូបនៅក្នុងព្រះគម្ពីរ អំពីប្ដីថ្មោងថ្មី ។ សាសនាចក្រ គឺជានិមិត្តរូបអំពីភរិយារបស់ទ្រង់ ។

ស្រីព្រហ្មចារី ១០ នាក់ចេញទៅជួបប្ដីថ្មោងថ្មី, **ម៉ាថាយ** ២៥:១–១៣ ។ អ្នកណាដែលយកប្រពន្ធ នោះឈ្មោះថាជាប្ដីហើយ, **យ៉ូហាន** ៣:២៧–៣០ ។ មានពរហើយ អស់អ្នកណាដែលព្រះបានហៅមកបរិភោគការកូនចៀម, **វិវរ.** ១៩:៥–១០ ។ ចូរប្រុងប្រៀបជាស្រេច ក្នុងកាលការយាងមកនៃប្ដីថ្មោងថ្មី, **គ. និង ស.** ៣៣:១៧ ។ ចូររៀបចំជាស្រេច ចាំប្ដីថ្មោងថ្មីចុះ, **គ. និង ស.** ៦៥:៣ ។

**ប្រច័ណ្ឌ, សេចក្ដីប្រច័ណ្ឌ** *សូមមើលផង* ច្រណែន

ដូចដែលប្រើនៅក្នុងគម្ពីរ ពាក្យ*ប្រច័ណ្ឌ* មានន័យពីរយ៉ាង គឺ៖ (១) មានចិត្តក្ដៅក្រហាយ ហើយមានអារម្មណ៍រំជួល និងជ្រាលជ្រៅ ចំពោះអ្នកណាមួយ ឬអ្វីមួយ, ហើយ (២) មានចិត្តច្រណែនចំពោះអ្វីដែលអ្នកដទៃមាន ឬមន្ទិលសង្ស័យថា អ្នកឯទៀតនឹងបានអ្វីមួយ លើស ។

*មានចិត្តក្ដៅក្រហាយ៖* អញជាព្រះអម្ចាស់ អញមានសេចក្ដីប្រច័ណ្ឌ, **និក្ខ.** ២០:៥ (ចោទិ. ៥:៩; ៦:១៥; ម៉ូសាយ ១១:២២) ។ អញនឹងមានសេចក្ដីប្រច័ណ្ឌ ដោយយល់ដល់ឈ្មោះបរិសុទ្ធរបស់អញ, **អេសេ.** ៣៩:២៥ ។ អញមានសេចក្ដីប្រច័ណ្ឌ ចំពោះក្រុងយេរូសាឡិម និងស៊ីយ៉ូន, **សាការី** ១:១៤ ។

*មានចិត្តច្រណែន ឬមន្ទិលសង្ស័យ៖* សេចក្ដីប្រច័ណ្ឌ ជាសេចក្ដីក្ដៅក្រហាយរបស់មនុស្ស, **សុភា.** ៦:៣២–៣៥ ។ អ័គីសបានចាប់ផ្ដើមច្រណែននឹងបុត្ររបស់ខ្លួន, **អេធើរ** ៩:៧ ។ ចូរកំចាត់ខ្លួនចេញពីសេចក្ដីច្រណែន និងសេចក្ដីខ្លាច, **គ. និង ស.** ៦៧:១០ ។

**ប្រដាប់បាំងទ្រូង** *សូមមើលផង* យូរីម និងធូមីម

គម្ពីរថែងអំពីប្រដាប់បាំងទ្រូងពីរយ៉ាង គឺ៖ (១) ជាផ្នែកខាងមុខអាវការពារ ឬអាវក្រោះ ។ ស្ដីតាមនិមិត្តរូប នោះពួកបរិសុទ្ធគួរតែពាក់ប្រដាប់បាំងទ្រូងនៃសេចក្ដីសុចរិត ដើម្បីការពារខ្លួនអំពីអំពើអាក្រក់ (អេសាយ ៥៩:១៧; អេភេ. ៦:១៤) ។ (២) ជាអាវពាក់ ដោយសង្ឃជាន់ខ្ពស់ នៅក្នុងក្រិត្យវិន័យលោកម៉ូសេ (និក្ខ. ២៨:១៣–៣០;

៣៩:៨–២១) ។ គឺធ្វើពីព្រៃ ហើយដាំត្បូងមានតម្លៃចំនួន ១២ ។ ជួនកាល សំដៅទៅនឹងការទាក់ទងនឹងយូរីម និងធូមីម (គ. និង ស. ១៧:១; យ.ស–ប្រវត្តិ ១:៣៥, ៤២, ៥២) ។

**ប្រទានពរ, មានពរ, ព្រះពរ** *សូមមើលផង* ការថ្លែងអំណរគុណ, ការប្រសិទ្ធិពរដល់មនុស្សឈឺ; ក្រិត្យវិន័យ; ដ៏អរគុណ, ពរនៃអយ្យកោ; ព្រះគុណ; អរគុណ

គឺដើម្បីប្រទានជំនួយពីព្រះមកលើអ្នកណាមួយ ។ អ្វីក៏ដោយដែលផ្តល់សុភមង្គលពិត សុខុមាលភាព ឬការចំរុងចំរើន នោះហើយជា ព្រះពរ ។

គ្រប់អស់ទាំងព្រះពរ គឺផ្អែកទៅលើក្រិត្យវិន័យដ៏នៅអស់កល្បជានិច្ច (គ. និង ស. ១៣០:២០–២១) ។ ពីព្រោះព្រះទ្រង់សព្វព្រះ ហឫទ័យចង់ឲ្យកូនចៅ របស់ទ្រង់មានសេចក្តីអំណរក្នុងជីវិត (២ នីហ្វៃ ២:២៥) នោះព្រះអង្គទ្រង់ប្រទានព្រះពរទាំងឡាយដល់ពួកគេ ជាលទ្ធផលពីការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ (គ. និង ស. ៨២:១០), ក្នុងការឆ្លើយតបការអធិស្ឋាន ឬពិធីបរិសុទ្ធនៃ បព្វជិតភាព (គ. និង ស. ១៩:៣៨; ១០៧:៦៥–៦៧), ឬតាមរយៈព្រះគុណរបស់ទ្រង់ (២ នីហ្វៃ ២៥:២៣) ។

បទថ្លែងដ៏ល្បីល្បាញអំពីព្រះពរ គឺ បទប្រទានពរ (ម៉ាថាយ ៥:១–១២; ៣ នីហ្វៃ ១២:១–១២) ។

*ទូទៅ៖* យើងនឹងបង្កើតនគរមួយយ៉ាងធំពីអ្នក យើងនឹងប្រទានពរដល់អ្នក, **លោកុ.** ១២:២–៣ (១ នីហ្វៃ ១៥:១៨; អ័ប្រា. ២:៩–១១) ។ អំណោយពររមែងស្ថិតលើក្បាលនៃមនុស្សសុចរិត, **សុភា.** ១០:៦ ។ មនុស្សស្មោះត្រង់នឹងបានពរជាបរិបូរ, **សុភា.** ២៨:២០ ។ ព្រះអម្ចាស់ទ្រង់នឹងបើកទ្វារស្ថានសួគ៌ ហើយចាក់ព្រះពរមកលើអ្នក, **ម៉ាឡាគី** ៣:១០ (៣ នីហ្វៃ ២៤:១០) ។ បទប្រទានពរសន្យានឹង ឲ្យពរ, **ម៉ាថាយ** ៥:១–១២ (៣ នីហ្វៃ ១២:១–១២) ។ មានពរហើយ អស់អ្នកណាដែលព្រះបានហៅមកបរិភោគការកូនចៀម, **វិវរ.** ១៩:៩ ។ អ្នកណាដែលជាមនុស្សសុចរិត អ្នកនោះសព្វព្រះហឫទ័យដល់ព្រះ, **១ នីហ្វៃ** ១៧:៣៥ (ម៉ូសាយ ១០:១៣) ។ ប្រសិនបើកូន ទាំងឡាយស្តាប់តាម នោះឪពុកនឹងប្រទានពរដល់កូន, **២ នីហ្វៃ** ១:២៨ ។ តានឹងឲ្យពរដល់ចៅដូចគ្នា, **២ នីហ្វៃ** ៤:៩ ។ ព្រះអង្គនឹង ប្រទានពរដល់អ្នកក្លាម, **ម៉ូសាយ** ២:២៤ ។ ព្រះអម្ចាស់ទ្រង់ប្រទានពរ ហើយធ្វើឲ្យចំរុងចំរើនដល់ជនទាំងឡាយណា ដែលដាក់សេចក្តី ទុកចិត្តរបស់គេលើទ្រង់, **ហេលេ.** ១២:១ ។ ជួយបញ្ចេញកិច្ចការរបស់យើងមក នោះអ្នកនឹងបានពរ, **គ. និង ស.** ៦:៩ ។ ចូរអធិស្ឋាន ជានិច្ច ហើយពររបស់អ្នកធំណាស់ហ្ន៎, **គ. និង ស.** ១៩:៣៨ ។ ចូរទទួលបុណ្យជ្រមុជទឹក ហើយអ្នកនឹងបានទទួលព្រះវិញ្ញាណរបស់ យើង និងព្រះពរដ៏មហិមា ដូចជាអ្នកពុំដែលបានស្គាល់មកសោះ, **គ. និង ស.** ៣៩:១០ ។ បន្ទាប់ពីមានការវេទនាដ៏ច្រើន នោះទើបបាន ព្រះពរ, **គ. និង ស.** ៥៨:៤ ។ មនុស្សលោកពុំគោរពតាមសោះ; យើងដកយកចេញ ហើយពួកគេពុំបានទទួលព្រះពរឡើយ, **គ. និង ស.** ៥៨:៣២ ។ អ្នករាល់គ្នាពុំទាន់យល់នៅឡើយទេ អំពីព្រះពរដ៏ធំណាស់ហ្ន៎ ដែលព្រះវរបិតាបានរៀបចំទុកសំរាប់អ្នក, **គ. និង ស.** ៧៨:១៧ ។ ពីបព្វជិតភាពជាន់ខ្ពស់ទើបមានការចាត់ចែងការប្រព្រឹត្តិទាំងឡាយ និងពរទាំងឡាយ មកលើសាសនាចក្រ, **គ. និង ស.** ១០៧:៦៥–៦៧ ។ មានក្រិត្យវិន័យ ដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ, **គ. និង ស.** ១៣០:២០ ។ មនុស្សទាំងអស់នឹងបានព្រះពរពី ព្រះហស្តរបស់យើង នោះនឹងនៅជាប់នឹងក្រិត្យវិន័យ, **គ. និង ស.** ១៣២:៥ ។ អស់ទាំងព្រះពរ ត្រូវបានទុកសំរាប់ពួកអ្នកដែល ស្រឡាញ់ព្រះអម្ចាស់, **គ. និង ស.** ១៣៨:៥២ ។ លោកអ័ប្រាហាំបានស្វែងរកព្រះពរទាំងឡាយខាងពួកអយ្យកោ និងសិទ្ធិដើម្បីចាត់ ចែងពរនោះ, **អ័ប្រា.** ១:២ ។

*ការប្រទានពរដល់កូនក្មេង៖* ឪពុកត្រូវឱបរាល់គ្នា ហើយប្រទានពរឲ្យផង, **ម៉ាកុស** ១០:១៦ ។ ទ្រង់បានយកកូនក្មេងរបស់ពួកគេ ម្តងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា, ៣ នីហ្វៃ ១៧:២១ ។ ពួកអែលឌើរត្រូវឲ្យពរដល់កូនក្មេង ដោយនូវព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ, **គ. និង ស.** ២០:៧០ ។

**ប្រធាន** *សូមមើលផង* គណៈប្រធានទីមួយ; ព្យាការី

ជានាមនៃអ្នកត្រួតត្រាលើអង្គការណាមួយ ។ ប្រធាននៃសាសនាចក្រ គឺជាព្យាការី, អ្នកមើលឆុត និងអ្នកទទួលវិវរណៈ (គ. និង ស. ២១:១; ១០៧:៩១–៩២) ។ ហើយពួកសមាជិកនៃសាសនាចក្រត្រូវហៅព្យាការីនៃសាសនាចក្រ តាមនាមថា « ប្រធាន » (គ. និង ស. ១០៧:៦៥) ។ លោកគឺជាជនតែម្នាក់គត់នៅលើផែនដី ដែលមានសិទ្ធិអំណាច ដើម្បីអនុវត្តកូនសោទាំងអស់នៃបព្វជិតភាព ។

អ្នកដឹកនាំទាំងឡាយនៃក្រុមបព្វជិតភាព និងអង្គការផ្សេងៗនៃសាសនាចក្រ ក៏អាចមាននាមថាជាប្រធានដែរ ។

ព្រះអម្ចាស់ ទ្រង់បានប្រទានកូនសោទាំងឡាយនៃនគរដល់យ៉ូសែប ស្ម៊ីធ, **គ. និង ស.** ៨១:១–២ ។ មានប្រធានបីនាក់រួមធ្វើជាក្រុម នៃគណៈប្រធាននៃសាសនាចក្រ, **គ. និង ស.** ១០៧:២១–២៤ ។ ពួកប្រធានត្រូវបានតែងតាំងឡើង តាមរបៀបនៃបព្វជិតភាព មិគីស្សាដែក, **គ. និង ស.** ១០៧:២៩ ។ ភារកិច្ចទាំងឡាយនៃពួកប្រធានលើពួកឌីកុន ពួកគ្រូ ពួកសង្ឃ និងពួកអែលឌើរត្រូវបានរៀបរាប់ប្រាប់, **គ. និង ស.** ១០៧:៨៥–៨៩ (គ. និង ស. ១២៤:១៣៦–៣៨, ១៤២) ។ មានពួកប្រធាន៧នាក់ ត្រួតលើគ្រប់ទាំងពួក ៧០ នាក់ឯទៀត, **គ. និង ស.** ១០៧:៩៣–៩៥ ។ ពួកប្រធាននៃស្តេកទាំងឡាយត្រូវបានតាំងឡើង, **គ. និង ស.** ១២៤:១៣៣–១៣៥ ។

**ប្រពន្ធ** *សូមមើល* គ្រួសារ; រៀបអាពាហ៍ពិពាហ៍, អាពាហ៍ពិពាហ៍

**ប្រមាថព្រះ, ការប្រមាថព្រះ** *សូមមើលផង* សេចក្តីមើលងាយ; អំពើបាបដ៏អត់ឱនមិនបាន

ជាការនិយាយដោយមិនគោរព ឬមិនកោតខ្លាចដល់ព្រះ ឬដល់របស់នានាដែលពិសិដ្ឋ ។

ព្រះយេស៊ូវទ្រង់ត្រូវពួកសាសន៍យូដាចោទជាច្រើនដងថា និយាយប្រមាថដល់ព្រះ ពីព្រោះព្រះអង្គបានមានព្រះបន្ទូល ថាទ្រង់មានសិទ្ធិ នឹងអត់ទោសដល់អំពើបាប (ម៉ាថាយ ៩:២–៣; លូកា ៥:២០–២១)

ពីព្រោះព្រះអង្គបានហៅអង្គទ្រង់ថា ជាព្រះរាជបុត្រានៃព្រះ (យ៉ូហាន ១០:២២–៣៦; ១៩:៧) ហើយពីព្រោះព្រះអង្គបានមានព្រះបន្ទូលថា ពួកគេនឹងឃើញទ្រង់អង្គុយនៅខាងស្តាំនៃព្រះចេស្តា ហើយនឹងយាងមកលើពពកនៅលើមេឃ (ម៉ាថាយ ២៦:៦៤–៦៥)។ ពាក្យចោទទាំងនេះច្បាស់ជាត្រូវពិតមែន បើសិនជាទ្រង់មិនជា ព្រះអង្គដែលទ្រង់មានព្រះបន្ទូលថានោះ។ មានពាក្យចោទទាស់នឹងទ្រង់ ដោយពួកសាក្សីក្លែងក្លាយ នៅពេលកាត់ក្តីខាងមុខក្រុមជំនុំ សាហេទ្រិន (ម៉ាថាយ ២៦:៥៩–៦១) គឺជាពាក្យប្រមាថទាស់នឹងព្រះវិហារបរិសុទ្ធនៃព្រះ។ ពាក្យប្រមាថទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ គឺមិនព្រមទទួលស្គាល់ព្រះគ្រីស្ទ ក្រោយពីបានទទួលការចេះដឹងដ៏ឥតខ្ចោះពីទ្រង់ហើយ នោះគឺជាអំពើបាបដ៏អត់ឱនមិនបាន (ម៉ាថាយ ១២:៣១–៣២; ម៉ាកុស ៣:២៨–២៩; គ. និង ស. ១៣២:២៧)។

អ្នកណាដែលប្រមាថដល់ព្រះនាមនៃព្រះអម្ចាស់ នឹងត្រូវសម្លាប់ជាមិនខាន, **លេវី.** ២៤:១១–១៦។ ពួកខ្មាំងសត្រូវនៃព្រះអម្ចាស់ នឹងមិនត្រូវទុកឲ្យនៅរស់ ដើម្បីប្រមាថដល់ព្រះនាមទ្រង់ឡើយ, **គ. និង ស.** ១០៥:១៥។ សេចក្តីសងសឹកនឹងមកលើអស់អ្នកណា ដែលប្រមាថទាស់នឹងព្រះអម្ចាស់, **គ. និង ស.** ១១២:២៤–២៦។

**ប្រវត្តិគ្រួសារ** *សូមមើល* ពង្សាវតារ; សេចក្តីសង្គ្រោះសំរាប់មនុស្សស្លាប់

**ប្រាក់** *សូមមើលផង* ការដាក់ទាន; ការថ្វាយដង្វាយ១ភាគ១០; ដង្វាយ១ភាគ១០, ទាន, ទ្រព្យសម្បត្តិ; សេចក្តីប្រកបដោយលោកិយ

ជាកាក់ ក្រដាស ប័ណ្ណ ឬជាអ្វីមួយ ដែលមនុស្សប្រើដើម្បីបង់ថ្លៃរបស់របរ ឬការបំរើផ្សេងៗ។ ជួនកាល ប្រាក់គឺជានិមិត្តរូបអំពីរបស់ទ្រព្យ។

ឯងរាល់គ្នាបានត្រូវលោះមកវិញ ដោយឥតបង់ប្រាក់, **អេសាយ** ៥២:៣។ ពួក ១២ ត្រូវបានហាមមិនឲ្យយកអ្វីសំរាប់គេតាមផ្លូវសោះ សូម្បីតែយាម នំបុ័ង ឬប្រាក់ក៏ដោយ, **ម៉ាកុស** ៦:៨។ ពេត្រុសប្រាប់ស៊ីម៉ូន ជាអ្នកធ្វើមន្តអាគមថា ប្រាក់គាត់នឹងវិនាសទៅជាមួយនឹងគាត់, **កិច្ចការ** ៨:២០។ ការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង, ១ ធីម៉ូ. ៦:១០។ សូមកុំចំណាយ ប្រាក់លើអ្វីដែលឥតប្រយោជន៍ឡើយ, **២ នីហ្វៃ** ៩:៥០–៥១ (អេសាយ ៥៥:១–២; ២ នីហ្វៃ ២៦:២៥–២៧)។ បើគេធ្វើការដើម្បីប្រាក់ គេនឹងត្រូវវិនាស, **២ នីហ្វៃ** ២៦:៣១។ មុននឹងអ្នកស្វែងរកទ្រព្យសម្បត្តិ ចូរអ្នកខំស្វែងរកនគរព្រះសិន, **យ៉ាកុប** ២:១៨–១៩។ សាសនាចក្រច្រើនដែលនឹងនិយាយថា ដើម្បីទឹកប្រាក់របស់អ្នក នោះអ្នកនឹងត្រូវបានអភ័យទោសដល់អំពើបាបរបស់អ្នក, **មរមន** ៨:៣២, ៣៧។ អ្នកណាដែលឲ្យប្រាក់កាសរបស់ខ្លួនសំរាប់គតិនៃស៊ីយ៉ូន នោះនឹងពុំត្រូវបាត់រង្វាន់របស់ខ្លួនឡើយ, **គ. និង ស.** ៨៤:៨៩–៩០។

**ប្រាជ្ញា** *សូមមើលផង* ការយល់, ដំរិះ; យោបល់, សេចក្តីពិត

ជាការប៉ិនប្រសប់ ឬអំណោយទានពីព្រះ ដើម្បីវិនិច្ឆ័យឲ្យបានត្រឹមត្រូវ។ មនុស្សម្នាក់ៗមានប្រាជ្ញា តាមរយៈការពិសោធន៍ និងការសិក្សា និងដោយការគោរពតាមការទូន្មានពីព្រះ។ បើគ្មានជំនួយពីព្រះទេ មនុស្សពុំមានប្រាជ្ញាដ៏ពិតឡើយ (២ នីហ្វៃ ៩:២៨; ២៧:២៦)។

ព្រះទ្រង់បានប្រទានឲ្យសាឡូម៉ូនមានប្រាជ្ញា, **១ ពង្សាវ.** ៤:២៩–៣០។ ប្រាជ្ញាជាសំខាន់លេខមួយ ដូច្នេះ ចូរខំឲ្យបានប្រាជ្ញាចុះ, **សុភា.** ៤:៧។ អ្នកណាដែលបានប្រាជ្ញា នោះស្រឡាញ់ព្រលឹងខ្លួន, **សុភា.** ១៩:៨។ ព្រះយេស៊ូវទ្រង់បានប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង, **លូកា** ២:៤០, ៥២។ បើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ, **យ៉ាកុប** (ព.ស.ថ.) ១:៥ (គ. និង ស. ៤២:៦៨; យ.ស. — ប្រវត្តិ ១:១១)។ ខ្ញុំសូមប្រាប់អ្នករាល់គ្នានូវរឿងទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាអាចមានប្រាជ្ញា, **ម៉ូសាយ** ២:១៧។ ឲ្យចេះមានប្រាជ្ញា នៅក្នុងវ័យក្មេងរបស់កូន, **អាលម៉ា** ៣៧:៣៥។ ពួកបរិសុទ្ធនឹងរកឃើញប្រាជ្ញា និងតម្លៃវិសេសនៃចំណេះវិជ្ជា, **គ. និង ស.** ៨៩:១៩។ ចូរឲ្យអ្នកណាដែលល្ងង់ ចេះមានប្រាជ្ញា ដោយការបន្ទាបខ្លួន និងដោយការអំពាវនាវដល់ព្រះអម្ចាស់, **គ. និង ស.** ១៣៦:៣២។

**ប្រាត្ត, ប៉ាលី ប៉ាកើរ**

ជាបងប្រុសរបស់អូរសុន ប្រាត្ត ហើយជាបុរសម្នាក់ក្នុងពួកសាវក ១២ នាក់មុនដំបូង ដែលបានហៅ បន្ទាប់ពីការសាងសាសនាចក្រ ឡើងវិញនៅសម័យទំនើបនេះ (គ. និង ស. ១២៤:១២៨–១២៩)។ ប៉ាលី ប្រាត្តត្រូវបានហៅលើកដំបូងក្នុងចំណោមការខិតខំខាងការផ្សាយសាសនាជាច្រើនផង កាលព្រះអម្ចាស់ទ្រង់បានប្រទានវិវរណៈមួយដល់លោក តាមរយៈយ៉ូសែប ស្ម៊ីធ នៅខែតុលា ឆ្នាំ ១៨៣០ (គ. និង ស. ៣២: ៥០:៣៧)។

**ប្រាត្ត, អូរសុន**

ជាបុរសម្នាក់ក្នុងពួកសាវក ១២ នាក់មុនដំបូង ដែលបានហៅ បន្ទាប់ពីការសាងសាសនាចក្រឡើងវិញ នៅសម័យទំនើបនេះ (គ. និង ស. ១២៤:១២៨–១២៩)។ លោកបានក្លាយជាសមាជិកនៃសាសនាចក្រតែ ៦ អាទិត្យប៉ុណ្ណោះ កាលព្រះអម្ចាស់ទ្រង់បានប្រទាន វិវរណៈមួយដល់លោក តាមរយៈយ៉ូសែប ស្ម៊ីធ (គ. និង ស. ៣៤)។ អូរសុន ប្រាត្តក៏បានធ្វើជាអ្នកផ្សាយសាសនាសំរាប់សាសនាចក្រ (គ. និង ស. ៥២:២៦; ៧៥:១៤) ហើយបានបំរើធ្វើជាអ្នកកត់ប្រវត្តិនៃសាសនាចក្រអស់ជាច្រើនឆ្នាំ។

**ប្រុងស្តាប់** *សូមមើលផង* ការគោរពតាម, គ្រូចៀក; គោរពតាម, ដែលគោរពតាម

គឺដើម្បីស្តាប់ ហើយគោរពតាមសម្លេង ឬការបង្រៀននៃព្រះអម្ចាស់។

ព្រះអម្ចាស់ទ្រង់នឹងបណ្តាលឲ្យមានព្យាការីមួយកើតឡើងឲ្យដូចជាលោក ហើយអ្នករាល់គ្នាត្រូវប្រុងស្តាប់តាមអ្នកនោះចុះ, **ចោទិ.** ១៨:១៥។ ប្រុងស្តាប់តាម គឺប្រសើរជាងចៀមធាត់ៗនៃយញ្ញបូជា, **១ សាំយូ.** ១៥:២០–២៣។ យើងរាល់គ្នាមិនបានប្រុងស្តាប់តាម ពួកអ្នកបំរើរបស់ព្រះ

អម្ចាស់ គឺជាពួកព្យាការី, **ដានី.** ៩:៦ ។ ពួកអ្នកសុចរិតណាដែលប្រុងស្តាប់តាមពាក្យរបស់ពួកព្យាការី នោះនឹង មិនត្រូវវិនាសឡើយ, **២ នីហ្វៃ** ២៦:៨ ។ ប្រសិនបើអ្នករាល់គ្នាពុំព្រមស្តាប់តាមសម្លេងនៃអ្នកគង្វាលល្អទេ នោះអ្នករាល់គ្នាពុំមែនជា កូនចៀមរបស់ទ្រង់ឡើយ, **អាលម៉ា** ៥:៣៨ (ហេលេ. ៧:១៨) ។ ចូរប្រុងស្តាប់ចុះ ឱប្រជារាស្ត្រនៃសាសនាចក្រយើងអើយ, **គ. និង ស.** ១:១ ។ អស់អ្នកណាដែលប្រុងស្តាប់តាមសម្លេងនៃព្រះវិញ្ញាណ នោះត្រូវបានបំភ្លឺ ហើយមករកព្រះវរបិតា, **គ. និង ស.** ៨៤:៤៦–៤៧ ។ ពួកគេកម្រនឹង ស្តាប់តាមសម្លេងនៃព្រះអម្ចាស់; ហេតុដូច្នេះហើយ ទ្រង់ក៏ក្រនឹងឮបទអធិស្ឋានទាំងឡាយរបស់ពួកគេដែរ, **គ. និង ស.** ១០១:៧–៩ ។ អស់អ្នកណាដែលមិនប្រុងស្តាប់តាមព្រះបញ្ញត្តិទាំងឡាយ នោះនឹងត្រូវវាយផ្ចាល, **គ. និង ស.** ១០៣:៤ (ម៉ូសេ ៤:៤) ។

**ប្រេង** *សូមមើលផង* ការប្រសិទ្ធិពរដល់មនុស្សឈឺ; ចាក់ប្រេង, ដើមអូលីវ, លាបប្រេង

តាមធម្មតា កាលណាគេនិយាយដល់ប្រេងទៅក្នុងគម្ពីរ គឺជាប្រេងអូលីវ ។ ចាប់តាំងពីសម័យព្រះគម្ពីរសញ្ញាចាស់មក ប្រេងអូលីវត្រូវបានប្រើសំរាប់ពិធីក្នុងព្រះវិហារ និងក្នុងរោងឧបោសថ សំរាប់ការចាក់ប្រេងលាប សំរាប់ដុតចង្កៀង និងសំរាប់ជាអាហារ ។ ជួនកាលប្រេងអូលីវ គឺនិមិត្តរូបអំពីការសុទ្ធសាធ និងអំពីព្រះវិញ្ញាណបរិសុទ្ធ និងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ (១ សាំយូ. ១០:១, ៦; ១៦:១៣; អេសាយ ៦១:១–៣) ។

សង្ឃយកប្រេងទៅលាបនៅទងត្រចៀកស្តាំ, **លេវី.** ១៤:២៨–២៩ ។ ព្រះអម្ចាស់ ទ្រង់បានចាត់ទូលបង្គំមកឲ្យចាក់ប្រេងតាំងទ្រង់ឡើងជាស្តេចលើរាស្ត្រទ្រង់, **១ សាំយូ.** ១៥:១ ។ ប្រេងក្នុងដបនៃស្រីមេម៉ាយ ក៏មិនចេះរលោះឡើយ, **១ ពង្សាវ.** ១៧:១០–១៦ ។ ព្រះអម្ចាស់ទ្រង់ចាក់ប្រេងលាបលើក្បាលទូលបង្គំ, **ទំនុក.** ២៣:៥ ។ ពួកគេបានលាបប្រេងឲ្យមនុស្សជំងឺជាច្រើនបានជា, **ម៉ាកុស** ៦:១៣ ។ ត្រូវឲ្យពួកចាស់ទុំមកអធិស្ឋានឲ្យអ្នកនោះ ព្រមទាំងលាបប្រេងឲ្យផង, **យ៉ាកុប (ព.ស.ថ.)** ៥:១៣–១៥ ។ ចូរមានចង្កៀងបង្កាត់ ហើយ ឆេះ ហើយមានប្រេងនៅជាមួយអ្នកផង, **គ. និង ស.** ៣៣:១៧ (ម៉ាថាយ ២៥:១–១៣) ។

**ប្រែចិត្ត, ការប្រែចិត្ត** *សូមមើលផង* ការឆ្លើយសារភាព; ការផ្តាច់បាប, ចិត្តសង្រេង; ឆ្លើយសារភាព, ដង្វាយធួន; ធ្វើឲ្យធួន, ព្រះយេស៊ូវគ្រីស្ទ; អត់ទោស, អភ័យទោស

ជាការផ្លាស់ប្រែគំនិត និងចិត្ត ដែលផ្តល់នូវអាកប្បកិរិយាដ៏ជ្រះថ្លាចំពោះព្រះ ចំពោះខ្លួន និងចំពោះជីវិតជាទូទៅ ។ ការប្រែចិត្ត មានន័យថា ជនម្នាក់បែរចេញពីអំពើអាក្រក់ ហើយបែរតម្រង់ចិត្ត និងបំណងរបស់ខ្លួន ទៅរកព្រះ ដោយចុះចូលតាមព្រះបញ្ញត្តិទាំងឡាយ និងព្រះហឫទ័យរបស់ព្រះ ហើយលះបង់ចោលអំពើបាប ។ ការប្រែចិត្តដ៏ពិតកើតឡើងពីសេចក្តីស្រឡាញ់ដល់ព្រះ និងការប៉ងប្រាថ្នាដ៏ស្មោះស្ម័គ្រ ដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ មនុស្សទាំងអស់ដែលចេះទទួលការខុសត្រូវ គេបានធ្វើ អំពើបាប ហើយត្រូវតែប្រែចិត្ត ដើម្បីឲ្យបានជឿនលឿនទៅរកសេចក្តីសង្គ្រោះ ។ មានតែតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប៉ុណ្ណោះ ដែលការប្រែចិត្តរបស់យើងអាចមានប្រសិទ្ធិភាព ហើយអាចបានទទួលស្គាល់ដោយព្រះ ។

ចូរលន់តួដល់ព្រះអម្ចាស់, **អែសរ៉ា** ១០:១១ ។ ចូរបំបាត់អំពើអាក្រក់របស់ឯងរាល់គ្នាចេញ ហើយលែងប្រព្រឹត្តអំពើអាក្រក់តទៅ, **អេសាយ** ១:១៦ ។ ចូរប្រែចិត្ត ហើយបែរចេញពីគ្រប់ទាំងអំពើរំលងរបស់ឯងទៅ, **អេសេ.** ១៨:៣០–៣១ ។ ចូរឲ្យប្រែចិត្តចុះ ត្បិត នគរស្ថានសួគ៌ជិតដល់ហើយ, **ម៉ាថាយ** ៣:២ ។ មានសេចក្តីអំណរនៅស្ថានសួគ៌ ដោយសារមនុស្សបាបតែមួយនាក់ ដែលប្រែចិត្ត, **លូកា** ១៥:៧ ។ ព្រះទ្រង់ត្រាសបង្គាប់ដល់មនុស្សទាំងអស់ នៅគ្រប់អន្លើឲ្យប្រែចិត្ត, **កិច្ចការ** ១៧:៣០ (២ នីហ្វៃ ៩:២៣; ៣ នីហ្វៃ ១១:៣១–៤០; គ. និង ស. ១៣៣:១៦) ។ សេចក្តីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះ នោះរមែងនាំឲ្យប្រែចិត្តឡើង ប្រយោជន៍ឲ្យ បានសង្គ្រោះ, **២ កូរិន.** ៧:១០ ។ ព្រះវិញ្ញាណនៃព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្តា បាននាំមកនូវការផ្លាស់ប្តូរយ៉ាងធំនៅក្នុងចិត្តយើង ដែលធ្វើឲ្យយើងពុំមានបំណងនឹងធ្វើអំពើទុច្ចរិតទៀតឡើយ, **ម៉ូសាយ** ៥:២ ។ បើគេសារភាពនូវអំពើបាបទាំងឡាយរបស់គេ ហើយប្រែចិត្ត អ្នកនោះហើយអ្នកត្រូវអត់ទោសឲ្យ, **ម៉ូសាយ** ២៦:២៩ ។ ក្រោយពីការផ្សាយរបស់អាលម៉ា នោះមានមនុស្សជាច្រើន បានចាប់ផ្តើមប្រែចិត្ត, **អាលម៉ា** ១៤:១ ។ ចូរអ្នកកុំបង្អង់នូវពេលវេលាចំពោះការប្រែចិត្តឡើយ, **អាលម៉ា** ៣៤:៣៣ ។ អាលម៉ាបាន បង្រៀនហេលេមិនអំពីការប្រែចិត្ត និងការប្រែចិត្តជឿរបស់លោក, **អាលម៉ា** ៣៦ (ម៉ូសាយ ២៧:៨–៣២) ។ ការប្រែចិត្តពុំអាចមាន ដល់មនុស្សទេ លើកលែងតែមានទោស, **អាលម៉ា** ៤២:១៦ ។ ចូរទុកឲ្យអំពើបាបរបស់កូនបារម្ភដល់កូន គឺការបារម្ភនេះហើយដែល អាចញ៉ាំងឲ្យកូនប្រែចិត្ត, **អាលម៉ា** ៤២:២៩ ។ អ្នករាល់គ្នាត្រូវថ្វាយដល់យើង នូវចិត្តសង្រេង និងវិញ្ញាណទន់ទាប; ៣ នីហ្វៃ ៩:២០ ។ អស់អ្នកណាដែលប្រែចិត្តហើយមករកយើង ដូចជាកូនក្មេងតូចម្នាក់ អ្នកនោះហើយដែលយើងនឹងទទួល, ៣ នីហ្វៃ ៩:២២ ។ ចូរប្រែ ចិត្តចុះ ឱអ្នករាល់គ្នា ដែលនៅចុងផែនដីអើយ, ៣ នីហ្វៃ ២៧:២០ ។ នៅពេលណាពួកគេបានប្រែចិត្តជាញយៗ នោះពួកគេត្រូវបាន ទទួលការអភ័យទោស, **ម៉ូរ៉ូណៃ** ៦:៨ ។ ចូរកុំថាអ្វីដល់តំណនេះឡើយ លើកលែងតែការប្រែចិត្ត, **គ. និង ស.** ៦:៩ (គ. និង ស. ១១:៩) ។ សេចក្តីអំណររបស់ទ្រង់មហិមាណាស់ណ៎ា ចំពោះព្រលឹងណាដែលប្រែចិត្ត!, **គ. និង ស.** ១៨:១៣ ។ មនុស្សគ្រប់រូបត្រូវតែប្រែចិត្ត បើពុំនោះសោតទេ ត្រូវរងទុក្ខ, **គ. និង ស.** ១៩:៤ ។ អ្នកណាដែលធ្វើបាប ហើយមិនប្រែចិត្តទេ នោះនឹងត្រូវបណ្តេញចេញ, **គ. និង ស.** ៤២:២៨ ។ អ្នកណាដែលប្រែចិត្ត ហើយលះបង់ចោលអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ, **គ. និង ស.** ៥៨:៤២–៤៣ ។ ពួកអ្នកស្លាប់ណាដែលប្រែចិត្ត នោះនឹងបានប្រោសលោះ, **គ. និង ស.** ១៣៨:៥៨ ។ យើងខ្ញុំជឿដល់ការប្រែចិត្ត, **ម. នៃ ស.** ១:៤ ។

**ប្រោស, ការប្រោស** *សូមមើលផង* ការប្រសិទ្ធពរដល់មនុស្សឈឺ; ចាក់ប្រេង

គឺដើម្បីធ្វើឲ្យជា ឬសុខស្រួលវិញ ទាំងខាងរាងកាយ និងខាងវិញ្ញាណ ។ បទគម្ពីរមាននូវគំរូនៃការប្រោសយ៉ាងអស្ចារ្យ ដោយព្រះអម្ចាស់ និងដោយពួកអ្នកបំរើរបស់ទ្រង់ ។

យើងជាព្រះអម្ចាស់ ដែលបានប្រោសអ្នករាល់គ្នាឲ្យជា, **និក្ខ.** ១៥:២៦ ។ ណាម៉ាន់បានមុជទឹកក្នុងទន្លេយ័រដាន់ប្រាំពីរដង ហើយបានជា, **២ ពង្សាវ.** ៥:១–១៤ ។ យើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់, **អេសាយ** ៥៣:៥ (ម៉ូសាយ ១៤:៣) ។ ព្រះអាទិត្យនៃសេចក្តីសុចរិតនឹងរះឡើង មានទាំងអំណាចប្រោសឲ្យជា នៅក្នុងចំអេងស្លាបទ្រង់, **ម៉ាឡាគី** ៤:២ ។ ព្រះយេស៊ូវទ្រង់ បានប្រោសជំងឺគ្រប់មុខឲ្យជា, **ម៉ាថាយ** ៤:២៣ (ម៉ាថាយ ៩:៣៥) ។ ទ្រង់ក៏ប្រទានគេឲ្យមានអំណាច ដើម្បីនឹងធ្វើឲ្យជំងឺគ្រប់មុខបានជា, **ម៉ាថាយ** ១០:១ ។ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្ស ដែលមានចិត្តសង្រេង, **លូកា** ៤:១៨ ។ ពួកគេត្រូវបានប្រោសឲ្យជា ដោយព្រះ ចេស្តានៃកូនចៀមនៃព្រះ, **១ នីហ្វៃ** ១១:៣១ ។ បើអ្នកជឿដល់សេចក្តីប្រោសលោះនៃព្រះគ្រីស្ទ នោះអ្នកនឹងអាចបានជា សះស្បើយ, **អាលម៉ា** ១៥:៨ ។ ទ្រង់បានប្រោសឲ្យជាសះស្បើយគ្រប់ៗគ្នា, ៣ នីហ្វៃ ១៧:៩ ។ អ្នកណាដែលមានសេចក្តីជំនឿជឿ ដល់យើង ដើម្បីឲ្យបានជាស្បើយ នោះនឹងត្រូវបានជាស្បើយហើយ, **គ. និង ស.** ៤២:៤៨ ។ ដោយនូវព្រះនាមរបស់យើង នោះពួកគេនឹងប្រោស មនុស្សឈឺឲ្យជា, **គ. និង ស.** ៨៤:៦៨ ។ យើងខ្ញុំជឿដល់អំណោយទានខាងការប្រោសឲ្យជា, **ម. នៃ ស.** ១:៧ ។

**ប្រោសលោះ, បានប្រោសលោះ, សេចក្តីប្រោសលោះ** *សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; ដង្វាយធួន; ធ្វើឲ្យធួន; ព្រះយេស៊ូវគ្រីស្ទ; សេចក្តីស្លាប់ខាងសាច់ឈាម; សេចក្តីស្លាប់ខាងវិញ្ញាណ; សេចក្តីសង្គ្រោះ

ដើម្បីដោះលែង ទិញ ឬលោះ ដូចជាធ្វើឲ្យមនុស្សរួចពីសេវកកម្មដោយបង់ថ្លៃ ។ *សេចក្តីប្រោសលោះ* សំដៅទៅលើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងពីការដោះលែងឲ្យរួចពីអំពើបាប ។ ដង្វាយធួនរបស់ព្រះយេស៊ូវប្រោសលោះមនុស្សគ្រប់រូបឲ្យរួចពីសេចក្តីស្លាប់ ខាងសាច់ឈាម ។ តាមរយៈដង្វាយធួនរបស់ទ្រង់ អស់អ្នកណាដែលមានសេចក្តីជំនឿជឿដល់ទ្រង់ ហើយដែលបានប្រែចិត្ត នោះនឹងបានប្រោសលោះឲ្យរួចពីសេចក្តីស្លាប់ខាងវិញ្ញាណដែរ ។

អញបានលោះឯងហើយ, **អេសាយ** ៤៤:២២ ។ អញនឹងលោះគេឲ្យរួចពីសេចក្តីស្លាប់, **ហូសេ** ១៣:១៤ (ទំនុក. ៤៩:១៥) ។ យើង បានសេចក្តីប្រោសលោះ ដោយសារព្រះលោហិតនៃព្រះគ្រីស្ទ, **អេភេ.** ១:៧, ១៤ (ហេព្រើរ ៩:១១–១៥; ១ ពេត្រុស ១:១៨–១៩; អាលម៉ា ៥:២១; ហេលេ. ៥:៩–១២) ។ ព្រះអម្ចាស់ទ្រង់បានប្រោសលោះព្រលឹងរបស់ឪពុក ឲ្យរួចពីស្ថាននរក, **២ នីហ្វៃ** ១:១៥ ។ សេចក្តីប្រោសលោះនឹងមកដោយ និងតាមរយៈព្រះមែស៊ីដ៏បរិសុទ្ធ, **២ នីហ្វៃ** ២:៦–៧, ២៦ (ម៉ូសាយ ១៥:២៦–២៧; ២៦:២៦) ។ គេបានច្រៀងនូវសេចក្តីស្រឡាញ់ដែលប្រោសលោះ, **អាលម៉ា** ៥:៩ (អាលម៉ា ៥:២៦; ២៦:១៣) ។ ពួកទុច្ចរិតនឹងនៅដូច្នេះ ហាក់ដូច ជាគ្មានការប្រោសលោះបានកើតឡើង, **អាលម៉ា** ១១:៤០–៤១ (អាលម៉ា ៣៤:១៦, ៤២:១៣; ហេលេ. ១៤:១៦–១៨) ។ ព្រះយេស៊ូវ គ្រីស្ទបាននាំមកនូវសេចក្តីប្រោសលោះដល់មនុស្សលោក, **មរមន** ៧:៥–៧ ។ ព្រះចេស្តានៃសេចក្តីប្រោសលោះ មានមកដល់អស់អ្នក ណាដែលគ្មានច្បាប់, **មរ៉ូណៃ** ៨:២២ (គ. និង ស. ៤៥:៥៤) ។ ពួកអ្នកណាដែលពុំជឿពុំអាចបានប្រោសលោះឲ្យរួចផុតពីការធ្លាក់ ខាងវិញ្ញាណរបស់ពួកគេបានឡើយ, **គ. និង ស.** ២៩:៤៤ ។ កូនក្មេងតូចៗត្រូវបានប្រោសលោះចាប់តាំងពីកំណើតលោកិយមកម៉្លេះ, **គ. និង ស.** ២៩:៤៦ ។ ព្រះអម្ចាស់ទ្រង់បានប្រោសលោះរាស្ត្ររបស់ទ្រង់, **គ. និង ស.** ៨៤:៩៩ ។ យ៉ូសែប អែហ្វ ស្ម៊ីធ បានឃើញក្នុង ការនិមិត្តមួយ អំពីការប្រោសលោះដល់មនុស្សស្លាប់, **គ. និង ស.** ១៣៨ ។ លោកអ័ដាម និងនាងអេវ៉ាបានរីករាយចំពោះសេចក្តី ប្រោសលោះរបស់គេ, **ម៉ូសេ** ៥:៩–១១ ។

**ប្រោសឲ្យមានជីវិតឡើងវិញ** *សូមមើលផង* ដំណើររស់ឡើងវិញ

គឺធ្វើឲ្យរស់, ឲ្យរស់ឡើងវិញ ឬក៏ប្រែប្រួលជនណាមួយ ដើម្បីឲ្យអ្នកនោះអាចនៅទីចំពោះវត្តមាននៃព្រះបាន ។

ព្រះទ្រង់បានប្រោសឲ្យយើងរាល់គ្នាបានរស់ ជាមួយនឹងព្រះគ្រីស្ទ, **អេភេ.** ២:៤–៥ (កូល៉ុស ២:៦, ១២–១៣) ។ ព្រះគ្រីស្ទត្រូវគេធ្វើគុត ខាងសាច់ឈាម តែបានព្រះវិញ្ញាណប្រោសឲ្យរស់វិញ, **១ ពេត្រុស** ៣:១៨ (គ. និង ស. ១៣៨:៧) ។ គ្មានមនុស្សណាមួយបានឃើញ ព្រះឡើយ លើកលែងតែបានប្រោសឡើង ដោយព្រះវិញ្ញាណ, **គ. និង ស.** ៦៧:១១ ។ សេចក្តីប្រោសលោះ គឺតាមរយៈព្រះអង្គដែល ប្រោសគ្រប់ទាំងអស់ឲ្យមានជីវិត, **គ. និង ស.** ៨៨:១៦–១៧ ។ ពួកបរិសុទ្ធនឹងត្រូវបានប្រោសឲ្យមានជីវិត ហើយបានលើកឡើងទៅ ជួបព្រះគ្រីស្ទ, **គ. និង ស.** ៨៨:៩៦ ។ លោកអ័ដាមបានក្លាយទៅជាមនុស្សដែលបានប្រោសខាងក្នុង, **ម៉ូសេ** ៦:៦៥ ។

**ផារ៉ោន** *សូមមើលផង* អេស៊ីព្ទ; អេស៊ីព្ទុស

ជាកូនប្រុសច្បងបង្អស់របស់នាងអេស៊ីព្ទុស ដែលជាកូនស្រីរបស់ហាំ (អ័ប្រា. ១:២៥) ។ ក៏ជានាមថ្វាយដល់ពួកស្តេចនៃសាសន៍អេស៊ីព្ទ (អ័ប្រា. ១:២៧) ។

**ផាលេក**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់ហេប៊ើរ ហើយជាចៅលួតរបស់សិម ។ នៅសម័យលោក ផែនដីត្រូវបានបាក់បែកពីគ្នា (លោកុ. ១០:២២–២៥) ។

**ផាហូរ៉ាន**

ជាមេចៅក្រមទីបីនៃសាសន៍នីហ្វៃ នៅក្នុងព្រះគម្ពីរមរមន (អាលម៉ា ៥០:៣៩–៤០; ៥១:១–៧; ៥៩–៦២) ។

**ផឹក, ស្រវឹង** *សូមមើល* ពាក្យសំដីនៃប្រាជ្ញាវាងវៃ

**ផែនការនៃសេចក្ដីប្រោសលោះ** *សូមមើលផង*
ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; ដង្វាយធួន; ដំណឹងល្អ; ធ្វើឲ្យធួន, ព្រះយេស៊ូវគ្រីស្ទ, សេចក្ដីសង្គ្រោះ

ជាភាពពោរពេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានរៀបចំឡើង ដើម្បីនាំឲ្យមាននូវអមតភាព និងជីវិតដ៏នៅអស់កល្បជា និច្ចដល់មនុស្ស ។ ផែនការនេះមានរួមទាំងការបង្កើត ការធ្លាក់ និងដង្វាយធួន ព្រមទាំងក្រិត្យក្រម និងគោលលទ្ធិទាំងអស់ ដែល ព្រះទ្រង់ប្រទានមក ។

ផែនការនេះធ្វើឲ្យមនុស្សទាំងអស់អាចបានថ្កើងថ្កានឡើង ហើយរស់នៅជាមួយនឹងព្រះជានិច្ច (២ នីហ្វៃ ២, ៩) ។ ព្រះគម្ពីរក៏ស្ដីអំពីផែនការនេះ ថាជាផែនការនៃសេចក្ដីសង្គ្រោះ ជាផែនការនៃសុភមង្គល និងជាផែនការនៃសេចក្ដីមេត្តាករុណា ។

ទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង, **អេសាយ** ៥៣:៥ (ម៉ូសាយ ១៤:៥) ។ គ្មាននាមណាទៀត នៅក្រោមមេឃ ដែលធ្វើឲ្យមនុស្សបានសង្គ្រោះឡើយ, **កិច្ចការ** ៤:១២ ។ ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ, **១ កូរិន.** ១៥:២២ ។ គឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ, **អេភេ.** ២:៨ (២ នីហ្វៃ ២៥:២៣) ។ ព្រះទ្រង់បានឲ្យជីវិតដ៏នៅអស់កល្បជានិច្ច មុនកំណើតលោកិយម្លេះ, **ទីតុស** ១:២ ។ ព្រះយេស៊ូវ ទ្រង់ជាមេបង្កើតនៃសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច, **ហេព្រើរ** ៥:៨–៩ ។ ផែនការនៃសេចក្ដីប្រោសលោះត្រូវបានពន្យាដល់ទៅពួកមនុស្សស្លាប់, **១ ពេត្រុស** ៣:១៨–២០; ៤:៦ (គ. និង ស. ១៣៨) ។ សេចក្ដីស្លាប់សំរេចនូវផែនការនៃការប្រោសប្រណីរបស់ព្រះបង្កបង្កើតដ៏ធំ, **២ នីហ្វៃ** ៩:៦ ។ ផែនការនៃព្រះរបស់យើងធំណាស់ហ្ន៎, **២ នីហ្វៃ** ៩:១៣ ។ ផែនការនៃសេចក្ដីប្រោសលោះនាំមកនូវដំណើររស់ឡើងវិញ និងការផ្ដាច់បាប, **អាលម៉ា** ១២:២៥–៣៤ ។ អើរ៉ុនបានបង្រៀនអំពីផែនការនៃសេចក្ដីប្រោសលោះ ដល់បិតារបស់ឡាម៉ូណៃ, **អាលម៉ា** ២២:១២–១៤ ។ អាមូលេកបានពន្យល់ប្រាប់អំពីផែនការនៃសេចក្ដីសង្គ្រោះ, **អាលម៉ា** ៣៤:៨–១៦ ។ អាលម៉ាបានពន្យល់ប្រាប់អំពីផែនការនៃសេចក្ដីសង្គ្រោះ **អាលម៉ា** ៤២:៥–២៦, ៣១ ។ គោលលទ្ធិទាំងឡាយ អំពីការបង្កបង្កើត អំពីការធ្លាក់ អំពីដង្វាយធួន និងអំពីបុណ្យជ្រមុជទឹកត្រូវបានបញ្ជាក់នៅក្នុងវិវរណៈសម័យទំនើប, **គ. និង ស.** ២០:១៧–២៩ ។ ផែនការត្រូវបានតែងតាំងឡើងមុនកំណើតលោកិយមកម្លេះ, **គ. និង ស.** ១២៨:២២ ។ កិច្ចការរបស់យើង និងសិរីល្អរបស់យើង គឺដើម្បីនាំឲ្យមាន អមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។ នេះហើយជា ផែនការនៃសេចក្ដីសង្គ្រោះដល់មនុស្សទាំងអស់, **ម៉ូសេ** ៦:៥២–៦២ ។ យើងនឹងសាកល្បងពួកគេ, **អ័ប្រា.** ៣:២២–២៦ ។

**ផែនការនៃសេចក្ដីសង្គ្រោះ** *សូមមើល*
ផែនការនៃសេចក្ដីប្រោសលោះ

**ផែនដី** *សូមមើលផង* ការបង្កបង្កើត; បង្កើត, ពិភពលោក

ជាពិភពដែលយើងរស់នៅ គឺព្រះបានបង្កើតដោយព្រះយេស៊ូវគ្រីស្ទ ដើម្បីទុកឲ្យមនុស្សប្រើនៅគ្រាពិសោធន៍ខាងសាច់ឈាមរបស់គេ ។ អនាគតចុងក្រោយបង្អស់នៃផែនដី គឺឲ្យបានសិរីល្អ ហើយថ្កើងថ្កានឡើង (គ. និង ស. ៧៧:១–២; ១៣០:៨–៩) ។ ផែនដីនឹងបាន ក្លាយទៅជានគរ៉ស្ថែដ៏នៅអស់កល្បជានិច្ច ដល់ពួកអ្នកដែលបានរស់នៅសំណាំនឹងសិរីល្អខាងសេឡេស្ទាល (គ. និង ស. ៨៨:១៤–២៦) ។ ពួកគេនឹងមានសេចក្ដីអំណរចំពោះវត្តមាននៃព្រះវរបិតា និងព្រះរាជបុត្រា (គ. និង ស. ៧៦:៦២) ។

*បង្កើតសំរាប់មនុស្ស៖* ព្រះទ្រង់ប្រទានឲ្យមនុស្សមានអំណាចលើផែនដី, **លោកុ.** ១:២៨ (ម៉ូសេ ២:២៨) ។ ផែនដីជារបស់ផង ព្រះអម្ចាស់, **និក្ខ.** ៩:២៩ (ទំនុក. ២៤:១) ។ ព្រះអម្ចាស់ទ្រង់បានប្រគល់ផែនដីដល់កូនចៅមនុស្ស, **ទំនុក.** ១១៥:១៦ ។ យើងបានរៀបចំផែនដី ហើយបង្កើតមនុស្សឲ្យអាស្រ័យនៅ, **អេសាយ** ៤៥:១២ ។ ដោយព្រះចេស្ដានៃព្រះបន្ទូលរបស់ទ្រង់ នោះមានមនុស្សរស់នៅលើផែនដី, **យ៉ាកុប** ៤:៩ ។ ផែនដីនឹងត្រូវបានប្រទានដល់អស់អ្នកណាដែលបានទទួលយកព្រះវិញ្ញាណបរិសុទ្ធ ទុកជាអ្នកណែនាំរបស់ ខ្លួន, **គ. និង ស.** ៤៥:៥៦–៥៨ (គ. និង ស. ១០៣:៧) ។ អស់អ្នកណាដែលបានគោរពតាមដំណឹងល្អ នោះនឹងបានទទួលរង្វាន់នូវ របស់ល្អៗនៃផែនដី, **គ. និង ស.** ៥៩:៣ ។ មនុស្សក្រីក្រ និងមនុស្សស្លូតបូតនៅលើផែនដី នឹងបានគ្រងផែនដីទុកជាមរតក, **គ. និង ស.** ៨៨:១៧ (ម៉ាថាយ ៥:៥; ៣ នីហ្វៃ ១២:៥) ។ យើងនឹងធ្វើផែនដី ហើយយើងនឹងសាកល្បងពួកគេ, **អ័ប្រា.** ៣:២៤–២៥ ។

*ជាភ្លូវរស់នោះ៖* ផែនដីស្ថិតស្ថេរនៅជាដរាប, **សាស្ដា** ១:៤ ។ សមុទ្រកែវគឺជាផែនដី នៅក្នុងស្ថានភាពដែលបានញែកចេញជា បរិសុទ្ធ ប្រកបដោយអមតភាព និងអស់កល្បជានិច្ច, **គ. និង ស.** ៧៧:១ ។ ផែនដីត្រូវតែបានញែកចេញជាបរិសុទ្ធ ប្រយោជន៍ឲ្យវាបាន រៀបចំសំរាប់សិរីល្អខាងសេឡេស្ទាល, **គ. និង ស.** ៨៨:១៨–១៩ ។ ផែនដីបានថ្ងូញសោកជាខ្លាំង, **ម៉ូសេ** ៧:៤៨ ។

*ការបំបែកផែនដី៖* ចូរឲ្យទឹកប្រមូលគ្នានៅកន្លែងមួយ, **លោកុ.** ១:៩ ។ នៅជាន់ផាលេក នោះផែនដីបានបែកគ្នា, **លោកុ.** ១០:២៥ ។ ក្រោយពីទឹកបានស្រកទៅ នោះផែនដីបានក្លាយទៅជាផែនដីដ៏វិសេសមួយ, **អេធើរ** ១៣:២ ។ ផែនដីនឹងបានដូចកាលពីដើម មុនផែនដី ត្រូវបានបែកចេញពីគ្នា, **គ. និង ស.** ១៣៣:២៤ ។

*ការសំអាតផែនដី៖* ភ្លៀងធ្លាក់មកលើផែនដី ៤០ ថ្ងៃ, **លោកុ.** ៧:៤ ។ ផែនដីត្រូវបានបំរុងទុកដល់ថ្ងៃជំនុំជំរះ សំរាប់ឲ្យភ្លើងឆេះ, **២ ពេត្រុស** ៣:៧ ។ បន្ទាប់ពីថ្ងៃនេះទៅនឹងមានការឆេះ, **គ. និង ស.** ៦៤:២៤ ។ ផែនដីមានសេចក្ដីប៉ងប្រាថ្នាចង់បានជ្រះស្អាតពីអំពើ ស្មោកគ្រោក, **ម៉ូសេ** ៧:៤៨ ។

*ស្ថានភាពចុងក្រោយបង្អស់នៃផែនដី៖* ផែនដីនឹងត្រូវរមូររួមគ្នាដូចរមូរក្រដាស ហើយកន្លងផុតទៅ, **៣ នីហ្វៃ** ២៦:៣ (គ. និង ស. ២៩:២៣) ។ នឹងមានផ្ទៃមេឃថ្មី និងផែនដីថ្មី, **អេធើរ** ១៣:៩ (គ. និង ស. ២៩:២៣) ។ សមុទ្រកែវ គឺជាផែនដី នៅក្នុងស្ថានភាពដែលបានញែកចេញជាបរិសុទ្ធ ប្រកបដោយអមតភាព និងអស់កល្បជានិច្ច, **គ. និង ស.** ៧៧:១ ។ ផែនដីត្រូវតែបានញែកចេញជាបរិសុទ្ធ ប្រយោជន៍ឲ្យវាបានរៀបចំសំរាប់សិរីល្អខាងសេឡេស្ទាល, **គ. និង ស.** ៨៨:១៨–១៩ ។ ផែនដីនេះ នឹងក្លាយទៅដូចជាកែវចរណៃ ហើយនឹងទៅជាយូរិម និងធូមីម, **គ. និង ស.** ១៣០:៨–៩ ។ ផែនដីនឹងសំរាកអស់រយៈពេលមួយពាន់ឆ្នាំ, **ម៉ូសេ** ៧:៦៤ ។ ផែនដីនឹងបានផ្លាស់ប្ដូរសារជាថ្មី, **ម. នៃ ស.** ១:១០ ។

**ផ្ទាំងមាស***សូមមើលផង* ផ្ទាំង, ព្រះគម្ពីរមរមន

ជាបញ្ជីដែលសរសេរទុកនៅលើផ្ទាំងមាស ។ បញ្ជីនេះប្រាប់អំពីរឿងនៃអារ្យធម៌ពីរ នៅលើទ្វីបអាមេរិក ។ យ៉ូសែប ស៊្មីធបានបកប្រែ ហើយបោះពុម្ពភាគខ្លះពីផ្ទាំងទាំងនេះ ។ ការបកប្រែនេះហៅថា ព្រះគម្ពីរមរមន ។ (សំរាប់ពត៌មានបន្ថែម សូមមើល « បុព្វកថា » និង « ទីបន្ទាល់នៃព្យាការីយ៉ូសែប ស៊្មីធ » នៅខាងមុខ ព្រះគម្ពីរមរមន) ។

**ផ្ទាំងលង្ហិន***សូមមើលផង* ផ្ទាំង

ជាបញ្ជីមួយរបស់ពួកសាសន៍យូដា ចាប់តាំងពីដើមដំបូង រហូតដល់ឆ្នាំ ៦០០ ម.គ.ស. ដែលមានការសរសេរជាច្រើននៃពួកព្យាការី ទាំងឡាយ (១ នីហ្វៃ ៥:១០–១៦) ។ បញ្ជីនេះបានរក្សាទុកដោយឡាបាន់ ជាពួកចាស់ទុំសាសន៍យូដាម្នាក់ នៅក្រុងយេរូសាឡិម ។ កាលលីហៃ និងគ្រួសារលោកនៅក្នុងទីរហោស្ថាន នោះលីហៃបានចាត់ឲ្យកូនប្រុសទាំងឡាយរបស់លោក ត្រឡប់ទៅក្រុងយេរូសាឡិមវិញ ដើម្បីទៅយកបញ្ជីនេះ (១ នីហ្វៃ ៣–៤) ។ (សំរាប់ពត៌មានបន្ថែមទៀត សូមមើល « ការអធិប្បាយដ៏ខ្លីអំពីព្រះគម្ពីរមរមន » ដែលមាននៅក្នុងព្រះគម្ពីរមរមន) ។

**ផ្ទាំងទាំងឡាយ** *សូមមើលផង* ផ្ទាំងមាស, ព្រះគម្ពីរមរមន

ពីសម័យបុរាណ មានវប្បធម៌ខ្លះបានសរសេរប្រវត្តិ និងបញ្ជីរបស់គេទុកនៅលើផ្ទាំងដែក ដូចជាករណីនៃព្រះគម្ពីរមរមន ។ សំរាប់ពត៌មានបន្ថែមទៀត សូមមើល « ការអធិប្បាយដ៏ខ្លីអំពីព្រះគម្ពីរមរមន » នៅទំព័រណែនាំនៃព្រះគម្ពីរមរមន ។

**ផ្ទះ** *សូមមើលផង* គ្រួសារ

ផ្ទះគួរតែធ្វើជាមជ្ឈមណ្ឌលខាងដំណឹងល្អ និងកិច្ចការប្រចាំគ្រួសារ ។

បុរសត្រូវឲ្យនៅទំនេរនៅឯផ្ទះ ដើម្បីនឹងបណ្ដាលឲ្យប្រពន្ធខ្លួនមានសេចក្ដីរីករាយឡើង, **ចោទិ.** ២៤:៥ ។ ទ្រង់ឲ្យគាត់ទៅផ្ទះវិញ, **ម៉ាកុស** ៨:២៦ ។ ត្រូវឲ្យកូនចៅនោះរៀនឲ្យចេះគោរពប្រតិបត្តិនៅឯផ្ទះ, **១ ធីម៉ូ.** ៥:៤ ។ ចូរមានចិត្តធ្ងន់ធ្ង ហើយបរិសុទ្ធ ជាអ្នករវល់ តែនឹងការនៅផ្ទះខ្លួន, **ទីតុស** ២:៥ ។ ចូរអ្នករាល់គ្នាត្រឡប់ទៅផ្ទះវិញ ហើយពិចារណាគិតពីរឿងទាំងឡាយ ដែលយើងបាននិយាយ, **៣ នីហ្វៃ** ១៧:២–៣ ។ ខ្ញុំបានដាស់តឿនឲ្យពួកគេទៅច្បាំង ដើម្បីការពារប្រពន្ធរបស់គេ និងកូនចៅរបស់គេ ហើយនិងផ្ទះសំបែង របស់គេ, **មរមន** ២:២៣ ។ ពួកឪពុកត្រូវមានចិត្តព្យាយាម ហើយគិតគូរពីគេហដ្ឋានខ្លាំងឡើង, **គ. និង ស.** ៩៣:៤៣–៤៤, ៤៨–៥០ ។

**ផ្នូរ** *សូមមើលផង* ដំណើររស់ឡើងវិញ

ជាកន្លែងកប់សពខាងសាច់ឈាម ។ ពីព្រោះព្រះដង្វាយធួន នោះមនុស្សរាល់គ្នានឹងបានរស់ឡើងពីផ្នូរវិញ ។

បន្ទាប់ពីដំណើររស់ឡើងវិញនៃព្រះគ្រីស្ទ នោះផ្នូរខ្មោចទាំងប៉ុន្មានក៏របើកឡើង ហើយរូបមនុស្សជាច្រើនបានរស់ឡើង, **ម៉ាថាយ** ២៧:៥២–៥៣ (៣ នីហ្វៃ ២៣:៩–១៣) ។ ឱសេចក្ដីស្លាប់អើយ ជ័យជំនះឯងនៅឯណា ? **១ កូរិន.** ១៥:៥៥ ។ ផ្នូរត្រូវប្រគល់ពួកមនុស្សស្លាប់ឡើង, **២ នីហ្វៃ** ៩:១១–១៣ ។ ពួកអ្នកដែលដេកលក់នៅក្នុងផ្នូររបស់ខ្លួន នោះនឹងចេញមក, **គ. និង ស.** ៨៨:៩៧–៩៨ ។ អាងនៃបុណ្យជ្រមុជទឹក គឺជានិមិត្តរូបអំពីផ្នូរ, **គ. និង ស.** ១២៨:១២–១៣ ។

**ផ្លូវ** *សូមមើលផង* ដើរ, ដើរជាមួយនឹងព្រះ, ព្រះយេស៊ូវគ្រីស្ទ

ជាផ្លូវ ឬដំណើរដែលមនុស្សដើរតាម ។ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា ទ្រង់ជាផ្លូវ (យ៉ូហាន ១៤:៤–៦) ។

ចូរកាន់តាមអស់ទាំងបញ្ញត្តិរបស់ព្រះអម្ចាស់ ដើម្បីនឹងដើរតាមអស់ទាំងផ្លូវរបស់ទ្រង់, **ចោទិ.** ៨:៦ ។ ចូរបង្ហាត់កូនក្មេង ឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្ត, **សុភា.** ២២:៦ (២ នីហ្វៃ ៤:៥) ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា អស់ទាំងផ្លូវរបស់អញ ខ្ពស់ជាងផ្លូវរបស់ឯង, **អេសាយ** ៥៥:៨–៩ ។ ឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀត, **ម៉ាថាយ** ៧:១៣–១៤ (៣ នីហ្វៃ ១៤:១៣–១៤; ៣ នីហ្វៃ ២៧:៣៣; គ. និង ស. ១៣២:២២, ២៥) ។ ព្រះទ្រង់នឹងរៀបផ្លូវ ឲ្យចៀសរួចពីសេចក្ដីល្បួង, **១ កូរិន.** ១០:១៣ ។ ព្រះអម្ចាស់ទ្រង់ មិនចេញបញ្ជាណាដែលទ្រង់នឹងមិនរៀបចំផ្លូវឲ្យកូនចៅទ្រង់កាន់តាមនោះឡើយ, **១ នីហ្វៃ** ៣:៧ (១ នីហ្វៃ ៩:៦; ១៧:៣, ១៣) ។ គ្មានផ្លូវឯណាផ្សេងទៀតទេ លើកលែងតែតាមទ្វារនោះ, **២ នីហ្វៃ** ៩:៤១ ។ អ្នករាល់គ្នាបានសេរីភាព ហើយធ្វើអ្វីសំរាប់ខ្លួនឯង — ដើម្បីរើសយកផ្លូវនៃសេចក្ដីស្លាប់ដ៏អស់កល្បជានិច្ច ឬក៏ផ្លូវនៃជីវិតដ៏នៅអស់កល្បជានិច្ចវិញ, **២ នីហ្វៃ** ១០:២៣ ។ នេះគឺជាផ្លូវ ហើយ គ្មានផ្លូវឯណាទៀតទេ ឬឈ្មោះណាទៀតឡើយ, **២ នីហ្វៃ** ៣១:២១ (ម៉ូសាយ ៣:១៧; អាលម៉ា ៣៨:៩; ហេលេ. ៥:៩) ។ ដោយ អំណោយនៃព្រះរាជបុត្រារបស់ទ្រង់ នោះព្រះទ្រង់បានរៀបចំផ្លូវមួយដ៏ប្រសើរលើសលែងទៅទៀត, **អេធើរ** ១២:១១ (១ កូរិន. ១២:៣១) ។ មនុស្សគ្រប់រូបដើរតាមផ្លូវរបស់ខ្លួនគេផ្ទាល់, **គ. និង ស.** ១:១៦ ។ ការនេះត្រូវបានសំរេចតាមមាគ៌ារបស់យើង, **គ. និង ស.** ១០៤:១៦ ។

**ផ្លែឈើហាមឃាត់** *សូមមើល* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា, អេដែន

**ផ្លែដំបូង**

គឺជាផលដំបូងដែលបានប្រមូលក្នុងរដូវមួយៗ ។ នៅសម័យព្រះគម្ពីរសញ្ញាចាស់ ផ្លែទាំងនោះត្រូវបានថ្វាយដល់ព្រះអម្ចាស់ (លេវី. ២៣:៩–២០) ។ អស់អ្នកណាដែលទទួលដំណឹងល្អ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត ក្នុងសេចក្ដីស្មោះត្រង់ នោះតាមខាង និមិត្តរូបវិញ គឺជាផ្លែដំបូងហើយ ពីព្រោះពួកគេជារបស់ផងព្រះ ។

ពួកអ្នកដែលតាមកូនចៀមទៅគ្រប់កន្លែងដែលទ្រង់យាងទៅ អ្នកទាំងនោះជាផ្លែដំបូងថ្វាយដល់ព្រះ, **វិវ.** ១៤:៤ ។ ពួកអ្នកណា ដែលនឹងចុះមកជាមួយទ្រង់មុនដំបូង គឺជាផលដំបូង, **គ. និង ស.** ៨៨:៩៨ ។

**ផ្សាយ** *សូមមើលផង* កិច្ចការផ្សាយសាសនា, ដំណឹងល្អ

ប្រាប់សារដែលផ្ដល់នូវយោបល់ដ៏ប្រសើរ អំពីគោលការណ៍ ឬគោលលទ្ធិនៃដំណឹងល្អ ។

ព្រះអម្ចាស់ទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សស្លូតបូត, **អេសាយ** ៦១:១ (លូកា ៤:១៦–២១) ។ ចូរក្រោកឡើង ទៅឯនីនីវេ ហើយស្រែកប្រកាសដល់ទីក្រុងនោះ, **យ៉ូណាស** ៣:២–១០ ។ តាំងពីគ្រានោះមក ព្រះយេស៊ូវក៏ចាប់តាំងប្រកាស, **ម៉ាថាយ** ៤:១៧ ។ ចូរអ្នករាល់គ្នាទៅពេញសព្វក្នុងលោកិយ ហើយផ្សាយដំណឹងល្អទូទៅដល់គ្រប់មនុស្សទាំងអស់ចុះ, **ម៉ាកុស** ១៦:១៥ ។ យើងប្រកាសប្រាប់ពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវឆ្កាង, **១ កូរិន.** ១:២២–២៤ ។ ទ្រង់បានយាងទៅប្រដៅដល់ពួកវិញ្ញាណ ដែលជាប់ឃុំ, **១ ពេត្រុស** ៣:១៩ ។ គឺគ្មានអ្វីក្រៅពីការប្រកាសប្រដៅ និងការរំឭកគេជាញយៗ ដើម្បីធ្វើឲ្យពួកគេកោតខ្លាចដល់ ព្រះអម្ចាស់, **អេណុស** ១:២៣ ។ លោកបានបញ្ជាពួកគេថា កុំឲ្យផ្សាយពីអ្វីឡើយ ក្រៅពីការប្រែចិត្ត និងសេចក្ដីជំនឿជឿដល់ព្រះ អម្ចាស់, **ម៉ូសាយ** ១៨:២០ ។ ការផ្សាយព្រះបន្ទូលមានបណ្ដាការដ៏ធំ ក្នុងការដឹកនាំប្រជាជន ឲ្យធ្វើនូវអ្វីៗដែលសុចរិត, **អាលម៉ា** ៣១:៥ ។ អ្នកមិនត្រូវសន្និដ្ឋានថា អ្នកត្រូវបានហៅឲ្យទៅផ្សាយ លុះត្រាអ្នកត្រូវបានហៅសិន, **គ. និង ស.** ១១:១៥ ។ ការណ៍នេះ មិនបានអនុញ្ញាតដល់អ្នកណាមួយ ដើម្បីឲ្យចេញទៅផ្សាយឡើយ លើកលែងតែអ្នកនោះបានតែងតាំងឡើង, **គ. និង ស.** ៤២:១១ ។ ដំណឹងល្អនេះនឹងត្រូវបានផ្សាយ ដល់គ្រប់អស់ទាំងសាសន៍, **គ. និង ស.** ១៣៣:៣៧ ។ ដំណឹងល្អបានចាប់ផ្ដើមផ្សាយ ចាប់តាំងពីដើមដំបូងមក, **ម៉ូសេ** ៥:៥៨ ។

**ពង្សាវតារ** *សូមមើលផង* គ្រួសារ; ធ្វើបុណ្យជ្រមុជទឹក — ជំនួសមនុស្សស្លាប់; បុណ្យជ្រមុជទឹក, ពិធីបរិសុទ្ធ — ពិធីបរិសុទ្ធជំនួស; សេចក្ដីសង្គ្រោះ, សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់, សៀវភៅរំឭក

ជាបញ្ជីកត់ខ្សែពូជពង្សនៃគ្រួសារ ។ នៅទីណាដែលមានតំណែងខាងបព្វជិតភាព ឬព្រះពរកំណត់ទុកចំពោះតែគ្រួសារណាមួយ នោះ ពង្សាវតារដែលមាននៅក្នុងគម្ពីរ គឺជាការសំខាន់ណាស់ (លោកុ. ៥; ១០; ២៥; ៤៦; ១ របា. ១–៩; អែសរ៉ា ២:៦១–៦២; នេហេ. ៧:៦៣–៦៤; ម៉ាថាយ ១:១–១៧; លូកា ៣:២៣–៣៨; ១ នីហ្វៃ ៣:១–៤; ៥:១៤–១៩; យ៉ារុម ១:១–២) ។ នៅក្នុងសាសនាចក្រដែលបានសាងឡើងវិញសព្វថ្ងៃនេះ សមាជិកក្នុងសាសនាចក្រនៅតែបន្តការស្វែងរកខ្សែពូជពង្សនៃគ្រួសារ ភាគខ្លះ គឺដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ពីពួកដូនតាដែលបានស្លាប់ទៅហើយ ដើម្បីឲ្យគេអាចធ្វើពិធីបរិសុទ្ធដ៏សង្គ្រោះជំនួសពួកដូនតារបស់គេ ។ ពិធីបរិសុទ្ធទាំងនេះរាប់ទុកជាមានសុពលភាព ចំពោះពួកអ្នកដែលបានស្លាប់ទៅហើយ ដែលបានទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នៅស្ថានវិញ្ញាណ (គ. និង ស. ១២៧, ១២៨) ។

**ពង្សាវតារក្សត្រ** *សូមមើលផង* លំដាប់ពេល

ជាគម្ពីរពីរក្បាល នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ គម្ពីរទាំងពីរនេះរៀបរាប់អំពីប្រវត្តិនៃសាសន៍អ៊ីស្រាអែល ចាប់តាំងពីការបះបោរនៃ អ័ដូនីយ៉ាជាបុត្រទីបួននៃស្ដេចដាវីឌ (ប្រមាណជាឆ្នាំ ១០១៥ ម.គ.ស.) រហូតដល់ការឃុំឃាំងស្រុកយូដា (ប្រមាណជាឆ្នាំ ៥៨៦ ម.គ.ស.) ។ គម្ពីរទាំងពីរនេះក៏មាននូវប្រវត្តិទាំងឡាយអំពីនគរខាងជើង (ពូជអ៊ីស្រាអែល ១០ អំបូរ) ចាប់តាំងពីការបែកបាក់គ្នា រហូត ដល់ពួកសាសន៍អាសស៊ើរចាប់គេយកទៅស្រុកខាងជើង ។

*ពង្សាវតារក្សត្រទី ១៖* ជំពូកទី ១ អធិប្បាយប្រាប់អំពីថ្ងៃចុងក្រោយបង្អស់នៅក្នុងជីវិតស្ដេចដាវីឌ ។ ជំពូកទី ២–១១ កត់អំពីជីវិតរបស់ សាឡូម៉ូន ។ ជំពូកទី ១២–១៦ ប្រាប់អំពីអ្នកគ្រងរាជ្យបន្ទាប់សាឡូម៉ូន គឺរេហូបោម និងយេរ៉ូបោម ។ យេរ៉ូបោមបានបណ្ដាលឲ្យមានការ បែកបាក់នគរអ៊ីស្រាអែល ។ ឯស្ដេចផ្សេងៗទៀតក៏បានពោលដល់ដែរ ។ ជំពូកទី ១៧–២១ កត់ភាគទាំងឡាយអំពីការងារបំរើរបស់អេលីយ៉ា កាលលោកទូន្មានដល់អ័ហាប់ ជាស្ដេចអ៊ីស្រាអែល ។ ជំពូកទី ២២ កត់អំពីសង្គ្រាមទាស់នឹងស្រុកស៊ីរី ដែលអ័ហាប់ និងយេហូសាផាត ជាស្ដេចយូដា បានចូលដៃគ្នា ។ ព្យាការីមីកាយ៉ាព្យាករជំទាស់នឹងពួកស្ដេច ។

*ពង្សាវតារក្សត្រទី ២៖* ជំពូកទី ១–២:១១ ប្រាប់អំពីជីវិតរបស់អេលីយ៉ាតមក ព្រមទាំងអំពីអេលីយ៉ាឡើងទៅស្ថានសួគ៌ ជិះរថជាភ្លើង ។ ជំពូកទី ២–៩ ប្រាប់អំពីការងារបំរើរបស់អេលីសេ អំពីសេចក្ដីជំនឿ និងអំណាចដ៏ធំ ។ ជំពូកទី ១០ ប្រាប់អំពីយេហ៊ូវ ជាស្ដេច ហើយអំពីរបៀបដែលទ្រង់បំផ្លាញដំណាក់អ័ហាប់ និងពួកសង្ឃនៃព្រះបាលយ៉ាងម៉េច ។ ជំពូកទី ១១–១៣ កត់អំពីរាជ្យដ៏សុចរិតរបស់យ៉ូអាស និង មរណភាពនៃអេលីសេ ។ ជំពូកទី ១៤–១៧ ប្រាប់អំពីស្ដេចផ្សេងៗទៀត ដែលបានសោយរាជ្យនៅស្រុកអ៊ីស្រាអែល និងស្រុកយូដា ភាគច្រើន គឺនៅក្នុងសេចក្ដីទុច្ចរិត ។ ជំពូកទី ១៥ កត់អំពីសាសន៍ស៊ីរីចាប់យកពូជអ៊ីស្រាអែលទាំង ១០ អំបូរ ។ ជំពូកទី ១៨–២០ កត់អំពីជីវិតដ៏សុចរិតនៃហេសេគា ជាស្ដេចយូដា និងអំពី

ព្យាការីអេសាយ ។ ជំពូកទី ២១–២៣ ប្រាប់អំពីស្ដេចម៉ាន៉ាសេ និងស្ដេច យ៉ូសៀស ។ តាមទំនាមទំលាប់ គឺម៉ាន៉ាសេបានទទួលខុសត្រូវ ចំពោះការធ្វើទុក្ករកម្មអេសាយ ។ យ៉ូសៀសជាស្ដេចដ៏សុចរិតម្នាក់ ដែលបានតាំងក្រិត្យវិន័យឡើង នៅចំណោមពួកសាសន៍យូដា ។ ជំពូកទី ២៤–២៥ កត់អំពីការឃុំឃាំងដោយសាសន៍បាប៊ីឡូន ។

**ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ** *សូមមើលផង* បញ្ញា, បញ្ញាចិត្ត, បញ្ញាទាំងឡាយ; ព្រះយេស៊ូវគ្រីស្ទ; ព្រះវិញ្ញាណបរិសុទ្ធ; សតិ, សតិសម្បជញ្ញៈ; សេចក្ដីពិត

ជាកម្លាំង អំណាច ឬឥទ្ធិពលដ៏ឧត្ដម ដែលចេញមកពីព្រះ ដោយសារព្រះគ្រីស្ទ ហើយផ្ដល់នូវជីវិត និងពន្លឺដល់គ្រប់អ្វីៗទាំងអស់ ។ គឺជាក្រិត្យវិន័យដែលត្រួតត្រាគ្រប់អ្វីៗទាំងអស់ នៅលើស្ថានសួគ៌ និងនៅលើផែនដី (គ. និង ស. ៨៨:៦–១៣) ។ ពន្លឺនេះក៏ជួយមនុស្សឲ្យស្គាល់សេចក្ដីពិត នៃដំណឹងល្អ ហើយជួយដាក់គេទៅលើផ្លូវនៃដំណឹងល្អនោះ ដែលនាំទៅឯសេចក្ដីសង្គ្រោះ (យ៉ូហាន ៣:១៩–២១; ១២:៤៦; អាលម៉ា ២៦:១៥; ៣២:៣៥; គ. និង ស. ៩៣:២៨–២៩, ៣១–៣២, ៤០, ៤២) ។

មិនត្រូវច្រឡំពន្លឺនៃព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធឡើយ ។ ពន្លឺនៃព្រះគ្រីស្ទ គឺមិនមែនជារូបទេ ។ គឺជាឥទ្ធិពលដែលមកពីព្រះ ហើយរៀបចំជនណាមួយឲ្យទទួលព្រះវិញ្ញាណបរិសុទ្ធវិញ ។ គឺជាឥទ្ធិពលចំពោះអំពើល្អ នៅក្នុងជីវិតនៃមនុស្សទាំងអស់ (យ៉ូហាន ១:៩; គ. និង ស. ៨៤:៤៦–៤៧) ។

សេចក្ដីសម្ដែងមួយអំពីពន្លឺនៃព្រះគ្រីស្ទ គឺសតិសម្បជញ្ញៈ ដែលជួយមនុស្សឲ្យរើសរវាងខុស និងត្រូវ (ម៉ូរ៉ូណៃ ៧:១៦) ។ នៅពេលណាមនុស្សចេះដឹងពីដំណឹងល្អច្រើនឡើង នោះសតិសម្បជញ្ញៈរបស់គេក្លាយទៅជាចាប់អារម្មណ៍ខ្លាំងឡើង (ម៉ូរ៉ូណៃ ៧:១២–១៩) ។ មនុស្សណាដែលប្រុងស្ដាប់តាមពន្លឺនៃព្រះគ្រីស្ទ នោះត្រូវបាននាំទៅរកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ (គ. និង ស. ៨៤:៤៦–៤៨) ។

ព្រះអម្ចាស់ទ្រង់ជាពន្លឺរបស់ខ្ញុំ, **ទំនុក.** ២៧:១ ។ ចូរយើងមកដើរក្នុងពន្លឺនៃព្រះអម្ចាស់, **អេសាយ** ២:៥ (២ នីហ្វៃ ១២:៥) ។ ព្រះ អម្ចាស់ទ្រង់នឹងទៅជាពន្លឺដ៏នៅអស់កល្បជានិច្ច, **អេសាយ** ៦០:១៩ ។ ពន្លឺពិតនោះបំភ្លឺមនុស្សរាល់គ្នា ដែលមកក្នុងលោកិយ, **យ៉ូហាន** ១:៤–៩ (យ៉ូហាន ៣:១៩; គ. និង ស. ៦:២១; ៣៤:១–៣) ។ ខ្ញុំជាពន្លឺនៃលោកិយ, **យ៉ូហាន** ៨:១២ (យ៉ូហាន ៩:៥; គ. និង ស. ១១:២៨) ។ អ្វីក៏ដោយដែលជាពន្លឺ គឺល្អ, **អាលម៉ា** ៣២:៣៥ ។ ព្រះគ្រីស្ទ គឺជាជីវិត និងជាពន្លឺនៃមនុស្សលោក, **អាលម៉ា** ៣៨:៩ (៣ នីហ្វៃ ៩:១៨; ១១:១១; អេធើរ ៤:១២) ។ ព្រះវិញ្ញាណនៃព្រះគ្រីស្ទ ត្រូវបានប្រទានឲ្យដល់មនុស្សគ្រប់រូប ដើម្បីឲ្យគេអាចដឹង ខុសត្រូវ, **ម៉ូរ៉ូណៃ** ៧:១៥–១៩ ។ អ្វីដែលមកពីព្រះ ជាពន្លឺភ្លឺកាន់តែខ្លាំងឡើងៗ រហូតដល់ថ្ងៃបានល្អឥតខ្ចោះ, **គ. និង ស.** ៥០:២៤ ។ ព្រះវិញ្ញាណប្រទានពន្លឺដល់មនុស្សគ្រប់រូប, **គ. និង ស.** ៨៤:៤៥–៤៨ (គ. និង ស. ៩៣:១–២) ។ អ្នកណាដែលកាន់តាមព្រះបញ្ញត្តិ ទាំងឡាយរបស់ទ្រង់ នោះបានទទួលពន្លឺ និងសេចក្ដីពិត, **គ. និង ស.** ៩៣:២៧–២៨ ។ ពន្លឺ និងសេចក្ដីពិតលះបង់ចោលអាកំណាច នោះ, **គ. និង ស.** ៩៣:៣៧ ។

**ពរនៃអយ្យកោ** *សូមមើលផង* ខាងអយ្យកោ, គ្រូផ្សាយដំណឹងល្អ; អយ្យកោ, ឪពុកខាងសាច់ឈាម

ជាព្រះពរដែលប្រទានដល់សមាជិកដ៏សក្ដិសមនៅក្នុងសាសនាចក្រ ដោយពួកអយ្យកោដែលបានតែងតាំងឡើង ។ ពរនៃអយ្យកោមាន នូវពាក្យទូន្មានពីព្រះអម្ចាស់ ចំពោះអ្នកដែលទទួលព្រះពរ ហើយថ្លែងប្រាប់ពូជរបស់អ្នកនោះនៅក្នុងវង្សអ៊ីស្រាអែល ។ ពួកឪពុកអាចឲ្យពរពិសេសៗ ទុកដូចជាអយ្យកោលើគ្រួសារគេ ប៉ុន្ដែព្រះពរទាំងនោះ មិនបានកត់ ឬរក្សាទុកដោយសាសនាចក្រ ឡើយ ។

អ៊ីស្រាអែលក៏លូកដៃស្ដាំទៅដាក់លើក្បាលអេប្រាអិម, **លោកុ.** ៤៨:១៤ ។ យ៉ាកុបបានប្រទានពរដល់ពួកកូនៗលោក និងពូជពួកគេ, **លោកុ.** ៤៩ ។ លីហៃបានប្រទានពរដល់ពូជពង្សលោក, **២ នីហ្វៃ** ៤:៣–១១ ។

**ពស់ធ្វើពីលង្ហិន** *សូមមើលផង* ម៉ូសេ, ព្រះយេស៊ូវគ្រីស្ទ

ជាពស់ធ្វើពីលង្ហិន ដែលព្រះទ្រង់បានបង្គាប់ឲ្យម៉ូសេធ្វើ ដើម្បីព្យាបាលពួកសាសន៍អ៊ីស្រាអែល ដែលត្រូវពស់ភ្លើងចឹក (ពស់ដ៏មានពិស) នៅឯទីរហោស្ថាន (ជនគ. ២១:៨–៩) ។ ពស់ធ្វើពីលង្ហិននេះ បានភ្ជាប់នៅលើបង្គោល ហើយ « បញ្ឈរឡើង ដើម្បីឲ្យអ្នកណាដែលនឹងសម្លឹងមើល នឹងអាចរស់នៅ » (អាលម៉ា ៣៣:១៩–២២) ។ ព្រះអម្ចាស់ទ្រង់ស្ដីពីការលើកពស់ឡើងនៅឯទីរហោស្ថាន ទុកជានិមិត្តរូបអំពីព្រះអង្គ ដែលត្រូវគេលើកឡើងលើឈើឆ្កាង (យ៉ូហាន ៣:១៤–១៥) ។ វិវរណៈនៅថ្ងៃចុងក្រោយបញ្ជាក់ពីរឿង ពស់ភ្លើងទាំងឡាយ និងពីរបៀបមនុស្សបានជាស្បើយ (១ នីហ្វៃ ១៧:៤១; ២ នីហ្វៃ ២៥:២០; ហេលេ. ៨:១៤–១៥) ។

**ពហុពន្ធភាព** *សូមមើល* រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន, អាពាហ៍ពិពាហ៍

**ពាក្យចចាមអារាម** *សូមមើលផង* ការនិយាយអាក្រក់; និយាយដើម

សាតាំងផ្សាយពាក្យចចាមអារាម និងការទាស់ទែងគ្នា — ជួនកាលផ្ដេកផ្ដួលទៅលើការពិតខ្លះៗ — ដើម្បីនឹងបំបែរមនុស្សឲ្យទាស់នឹងព្រះ ហើយនឹងការល្អទាំងអស់ (ហេលេ. ១៦:២២; យ.ស. — ប្រវត្តិ ១:១) ។ ទីសំគាល់មួយអំពីការយាងមកលើកទីពីរនៃព្រះយេស៊ូវ គ្រីស្ទ គឺថាមនុស្សនឹងនិយាយពីសង្គ្រាមទាំងឡាយ និងពាក្យចចាមអារាមពីសង្គ្រាមទាំងឡាយ (ម៉ាថាយ ២៤:៦; គ. និង ស. ៤៥:២៦; យ.ស. — ម៉ាថាយ ១:២៣) ។

**ពាក្យទូន្មាន (ន.)** *សូមមើលផង* ព្យាការី

ជាពាក្យដាស់តឿន ព្រមាន ណែនាំ និងពាក្យបង្គាប់មកពីព្រះអម្ចាស់ និងមេដឹកនាំទាំងឡាយរបស់ទ្រង់ដែលបានតែងតាំងឡើង ។

យើងនឹងទូន្មានអ្នកបន្តិច, **និក្ខ.** ១៨:១៩ ។ ព្រះទ្រង់នឹងនាំទូលបង្គំដោយដំបូន្មានរបស់ទ្រង់, **ទំនុក.** ៧៣:២៤ ។ គ្រាគ្មានពាក្យទូន្មាន នាំមុខ នោះប្រជាជនរមែងដួលទៅ, **សុភា.** ១១:១៤ ។ ពួកផារិស៊ី និងពួកអ្នកប្រាជ្ញច្បាប់ បានលើកព្រះដំរិះព្រះចោលចេញ, **លូកា** ៧:៣០ ។ ដែលបានរៀនសូត្រ គឺជាការល្អវិញ ប្រសិនបើគេស្ដាប់តាមដំបូន្មាននៃព្រះ, **២ នីហ្វៃ** ៩:២៩ ។ ចូរស្ដាប់តាមពាក្យទូន្មាន នៃទ្រង់ ដែលបានតែងតាំងអ្នកចុះ, **គ. និង ស.** ៧៨:២ ។ ចូរទទួលការទូន្មានពីអ្នកដែលយើងបានតាំងឡើង, **គ. និង ស.** ១០៨:១ ។ លោកគិតចង់តាំងដំបូន្មានរបស់ខ្លួន ជំនួសដំបូន្មានដែលយើងបានតែងតាំងឡើង, **គ. និង ស.** ១២៤:៨៤ ។ ចូរប្រុងស្ដាប់តាមដំបូន្មាន នៃយ៉ូសែប ជាអ្នកបំរើរបស់យើងចុះ, **គ. និង ស.** ១២៤:៨៩ ។ បើអ្នកណាមួយពុំស្វែងរកពាក្យដំបូន្មានរបស់យើងទេ អ្នកនោះនឹង ពុំមានអំណាចឡើយ, **គ. និង ស.** ១៣៦:១៩ ។

**ពាក្យប្រៀបប្រដូច** *សូមមើលផង* ដំណឹងល្អទាំងឡាយ — ភាពស្របគ្នានូវដំណឹងល្អទាំងឡាយ

ជារឿងខ្លីៗដែលបានយកមកប្រើ ដើម្បីពន្យល់ ហើយបង្រៀនពីសេចក្ដីពិត ឬពីគោលការណ៍ខាងវិញ្ញាណ ។ ពាក្យប្រៀបប្រដូច គឺសំអាងទៅលើការប្រៀបធៀបវត្ថុ ឬហេតុការណ៍ធម្មតា ទៅនឹងសេចក្ដីពិត ។ ជួនកាលន័យ ឬសារដ៏ជ្រាលជ្រៅ អំពីពាក្យប្រៀបប្រដូច លាក់កំបាំងពីពួកអ្នកស្ដាប់ ដែលមិនបានរៀបចំខាងវិញ្ញាណ ដើម្បីទទួល (ម៉ាថាយ ១៣:១០–១៧) ។

ព្រះយេស៊ូវទ្រង់តែងតែបង្រៀនដោយពាក្យប្រៀបប្រដូច ។ ចំពោះតារាងអំពីពាក្យប្រៀបប្រដូចដ៏សំខាន់ៗរបស់ទ្រង់ សូមមើល « ដំណឹងល្អទាំងឡាយ » ។

**ពាក្យសំដីនៃប្រាជ្ញាវាងវៃ**

ជាច្បាប់ខាងសុខភាព ដែលព្រះអម្ចាស់ទ្រង់បានបើកសម្ដែងប្រាប់ សំរាប់ប្រយោជន៍ខាងសាច់ឈាម ព្រមទាំងខាងវិញ្ញាណ ដល់ពួកបរិសុទ្ធ (គ. និង ស. ៨៩) ។ ច្បាប់នេះបានស្គាល់ទូទៅ ជាពាក្យសំដីនៃប្រាជ្ញាវាងវៃ ។ ព្រះអម្ចាស់បានបង្រៀនពួកអ្នកដែលដើរតាម ទ្រង់ជានិច្ច អំពីគោលការណ៍ខាងសុខភាព ។ ព្រះអម្ចាស់ទ្រង់បានបើកសម្ដែងប្រាប់យ៉ូសែប ស្ម៊ីធ អំពីអាហារណាដែលត្រូវបរិភោគ និងអាហារណាដែលមិនត្រូវបរិភោគ ព្រមទាំងពាក្យសន្យាចំពោះព្រះពរទាំងឡាយ ទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ចំពោះ ការគោរពតាមពាក្យសំដីនៃប្រាជ្ញាវាងវៃ ។

ចូរកុំផឹកស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹងណាឡើយ, **លេវី.** ១០:៩ ។ ស្រាទំពាំងបាយជូរ ជារបស់បញ្ឆោតមើលងាយ ហើយគ្រឿង ស្រវឹងបង្កើតការឡូឡា, **សុភា.** ២០:១ ។ គ្រឿងស្រវឹងនឹងទៅជាល្វីង ដល់អស់អ្នកដែលធ្លាប់ផឹក, **អេសាយ** ២៤:៩ ។ ដានីយ៉ែលមិន ព្រមឲ្យខ្លួនសៅហ្មង ដោយអាហារ និងស្រាទំពាំងបាយជូររបស់ស្ដេច, **ដានី.** ១:៨ ។ បើអ្នកណាបង្ខូចព្រះវិហារនៃព្រះ នោះព្រះនឹងធ្វើ ឲ្យអ្នកនោះត្រូវខូចដែរ, **១ កូរិន.** ៣:១៦–១៧ ។ ពួកប្រមឹក នោះមិនដែលបានគ្រងនគរព្រះទុកជាមរតកឡើយ, **១ កូរិន.** ៦:១០ (កាឡាទី ៥:២១) ។ អស់អ្នកណាដែលហាមប្រាមថា មនុស្សមិនត្រូវបរិភោគសាច់ឡើយនោះ ពុំមែនបានតែងតាំងពីព្រះទេ, **គ. និង ស.** ៤៩:១៨–២១ ។ របស់ទាំងអស់ត្រូវបានបង្កើតមក ដើម្បីឲ្យយកមកប្រើប្រាស់ ដោយការវិនិច្ឆ័យ គឺមិនឲ្យហួសហេតុឡើយ, **គ. និង ស.** ៥៩:២០ ។ ព្រះអម្ចាស់ទ្រង់បានទូន្មានដល់ពួកបរិសុទ្ធមិនឲ្យប្រើស្រាទំពាំងបាយជូរ ភេសជ្ជៈខ្លាំង ថ្នាំជក់ និងភេសជ្ជៈក្ដៅឡើយ, **គ. និង ស.** ៨៩:១–៩ ។ រុក្ខជាតិ ផ្លែឈើទាំងឡាយ សាច់ និងធញ្ញជាតិត្រូវបានតែងតាំងសំរាប់ការប្រើប្រាស់របស់មនុស្ស និងសត្វ, **គ. និង ស.** ៨៩:១០–១៧ ។ ការគោរពតាមពាក្យសំដីនៃប្រាជ្ញាវាងវៃនឹងបានទទួលព្រះពរទាំងឡាយ ទាំងខាងសាច់ឈាម និងខាងវិញ្ញាណ, **គ. និង ស.** ៨៩:១៨–២១ ។

**ពាន់**

ជារង្វាល់ម៉្យាងពីបុរាណសំរាប់វាស់ទម្ងន់ ឬអំពីចំនួនប្រាក់ ដែលមានតម្លៃមហិមា ។ ពាក្យថា ពាន់នេះ ក៏យកមកប្រើជានិមិត្តរូបអំពីអ្វី មួយដ៏មានតម្លៃមហិមា ដូចជាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ២៥:១៤–២៩; អេធើរ ១២:៣៥; គ. និង ស. ៦០:២, ១៣) ។

**ពិធីបញ្ចាក់** *មើល* ការដាក់, ដៃ

**ពិធីបរិសុទ្ធទាំងឡាយ** *សូមមើលផង* ការភ្ជាប់; ដំណាក់នៃព្រះអម្ចាស់, ពង្សាវតារ; ព្រះវិហារ, ភ្ជាប់, សេចក្ដីសង្គ្រោះ; សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់

ជាពិធី និងបុណ្យដ៏ពិសិដ្ឋទាំងឡាយ ។ ពិធីបរិសុទ្ធទាំងឡាយមាននូវកិច្ចការទាំងឡាយដែលមានន័យខាងវិញ្ញាណ ។ ពិធីបរិសុទ្ធ ទាំងឡាយក៏អាចមានន័យដល់ក្រិត្យវិន័យ និងក្រិត្យក្រមទាំងឡាយរបស់ព្រះដែរ ។

ពិធីបរិសុទ្ធទាំងឡាយនៅក្នុងសាសនាចក្រ មានរួមទាំងការប្រសិទ្ធពរដល់មនុស្សឈឺ (យ៉ាកុប (ព.ស.ថ.) ៥:១៤–១៥), ការប្រសិទ្ធពរបុណ្យរំឭក (គ. និង ស. ២០:៧៧, ៧៩), បុណ្យជ្រមុជទឹកដោយការពន្លិច (ម៉ាថាយ ៣:១៦; គ. និង ស. ២០:៧២–៧៤), ការប្រទានពរ ដល់ពួកកូនក្មេង (គ. និង ស. ២០:៧០), ការប្រទានព្រះវិញ្ញាណបរិសុទ្ធ (គ. និង ស. ២០:៦៨; ៣៣:១៥), ការប្រគល់ឲ្យបព្វជិតភាព (គ. និង ស. ៨៤:៦–១៦; ១០៧:៤១–៥២), ពិធីបរិសុទ្ធទាំងឡាយនៅ ក្នុងព្រះវិហារ (គ. និង ស. ១២៤:៣៩), និងអាពាហ៍ពិពាហ៍នៅ ក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច (គ. និង ស. ១៣២:១៩–២០) ។

ចូរបង្រៀនអស់ទាំងសេចក្ដីបញ្ញត្តិ និងច្បាប់ដល់គេ, **និក្ខ.** ១៨:២០ ។ ប្រព្រឹត្តតាមក្រិត្យក្រម ហើយរក្សាបញ្ញត្តិច្បាប់របស់អញ, **អេសេ.** ១១:២០ ។ ប្រជាជនតឹងរឹងនៅក្នុងការប្រតិបត្តិតាមពិធីបរិសុទ្ធទាំងឡាយនៃព្រះ, **អាលម៉ា** ៣០:៣ ។ តើមានប្រយោជន៍អ្វី ដែលយើងកាន់តាមក្រិត្យក្រមទាំងឡាយរបស់ទ្រង់ ? **៣ នីហ្វៃ** ២៤:១៣–១៤ ។ អ្នកណាដែលអធិស្ឋាន ដែលមានវិញ្ញាណទន់ទាប អ្នកនោះ ឈ្មោះថាត្រូវបានទទួលពីយើងហើយ បើសិនជាអ្នកនោះគោរពតាមពិធីបរិសុទ្ធ

ទាំងឡាយរបស់យើង, **គ. និង ស.** ៥២:១៤–១៩ ។ មនុស្សលោកទាំងអស់អាចបានសង្គ្រោះ ដោយសារការគោរពតាមក្រិត្យវិន័យ និងពិធីការទាំងឡាយនៃដំណឹងល្អ, **ម. នៃ ស.** ១:៣ ។

*ពិធីបរិសុទ្ធជំនួស៖* ជាពិធីបរិសុទ្ធខាងសាសនា ដែលមនុស្សរស់ធ្វើជំនួសជនដែលបានស្លាប់ទៅហើយ ។ ពិធីបរិសុទ្ធទាំងនេះមានប្រយោជន៍នៅពេលពួកអ្នកដែលគេបានធ្វើពិធីបរិសុទ្ធឲ្យ ទទួលការទាំងនេះ កាន់តាមសេចក្តីសញ្ញា ដែលទាក់ទងទៅនឹងការទាំងនេះ ហើយបានបិទភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យា ។ សព្វថ្ងៃនេះ ពិធីបរិសុទ្ធបែបនេះធ្វើនៅក្នុងព្រះវិហារ ។

តើពួកអ្នកដែលទទួលបុណ្យជ្រមុជទឹកជំនួសពួកមនុស្សស្លាប់នឹងធ្វើដូចម្តេច បើសិនជាពួកមនុស្សស្លាប់មិនរស់ឡើងវិញទេ ? **១ កូរិន.** ១៥:២៩ ។ បុណ្យជ្រមុជទឹកជំនួសពួកមនុស្សស្លាប់ ត្រូវធ្វើនៅក្នុងព្រះវិហារ, **គ. និង ស.** ១២៤:២៩–៣៦ ។ ពួកវិញ្ញាណនៅស្ថាន ឃុំព្រលឹងត្រូវបានគេបង្រៀន អំពីបុណ្យជ្រមុជទឹកជំនួស សំរាប់ការផ្តាច់បាប, **គ. និង ស.** ១៣៨:២៩–៣៤ ។

**ពិភពលោក, លោកិយ, មនុស្សលោក, ផែនដី** *សូមមើលផង*
ដែលរមែងស្លាប់, បាបិល, បាប៊ីឡូន; ផែនដី;
ភាពដែលរមែងស្លាប់

ជាផែនដី; ជាកន្លែងសំរាប់ពិសោធមនុស្សលោក ។ បើនិយាយតាមពាក្យប្រដូចវិញ គឺជាមនុស្សទាំងនោះ ដែលមិនគោរពតាមព្រះ បញ្ញត្តិទាំងឡាយរបស់ព្រះ ។

*ការរស់នៅរបស់មនុស្សលោក៖* នៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនា, **យ៉ូហាន** ១៦:៣៣ ។ ចូរកុំខ្លាចទោះជា ដល់ស្លាប់ក៏ដោយ ត្បិតនៅក្នុងពិភពលោកនេះ សេចក្តីអំណររបស់អ្នកពុំបានពោរពេញទេ, **គ. និង ស.** ១០១:៣៦ ។

*មនុស្សដែលមិនគោរពតាមព្រះបញ្ញត្តិ៖* អញនឹងធ្វើទោសដល់លោកិយដោយព្រោះអំពើអាក្រក់របស់គេ, **អេសាយ** ១៣:១១ (២ នីហ្វៃ ២៣:១១) ។ បើសិនជាលោកិយស្អប់អ្នករាល់គ្នា នោះអ្នករាល់គ្នាដឹងហើយ ថាគេបានស្អប់ខ្ញុំជាមុន, **យ៉ូហាន** ១៥:១៨–១៩ ។ អាគារដ៏ធំ ហើយទូលាយ នោះគឺជាសេចក្តីឆ្មើងឆ្មៃនៃមនុស្សលោក, **១ នីហ្វៃ** ១១:៣៦ ។ ពិភពលោកកំពុងតែទុំស្អុះនៅក្នុងសេចក្តី ទុច្ចរិត, **គ. និង ស.** ១៨:៦ ។ ចូររក្សាខ្លួនកុំឲ្យប្រឡាក់ពីលោកិយ, **គ. និង ស.** ៥៩:៩ ។ អ្នកណាដែលមានចិត្តស្មោះត្រង់ ហើយកាន់ ខ្ជាប់ នោះនឹងបានឈ្នះលើពិភពលោក, **គ. និង ស.** ៦៣:៤៧ ។ អ្នករាល់គ្នាមិនត្រូវរស់នៅតាមរបៀបនៃពិភពលោកឡើយ, **គ. និង ស.** ៩៥:១៣ ។

*ចុងបំផុតនៃផែនដី៖* អញបង្កើតផែនដីថ្មី ឯរបស់ពីមុន នោះនឹងមិនត្រូវនឹកចាំទៀតទេ, **អេសាយ** ៦៥:១៧ (វិវរ. ២១:១; ម. នៃ ស. ១:១០) ។ ដល់បំផុតកល្ប នោះស្រងែនឹងត្រូវបានច្រូត ហើយដុតបន្សុសក្នុងភ្លើង, **ម៉ាថាយ** ១៣:៤០, ៤៩ (ម៉ាឡាគី ៤:១; យ៉ាកុប ៦:៣) ។ ចំការទំពាំងបាយជូររបស់យើង នោះយើងនឹងបណ្តាលឲ្យដុតដោយភ្លើង, **យ៉ាកុប** ៥:៧៧ (គ. និង ស. ៦៤:២៣–២៤) ។ ព្រះអម្ចាស់ទ្រង់នឹងបំផ្លាញអារក្សសាតាំង និងកិច្ចការទាំងឡាយរបស់វា នៅចុងបំផុតនៃផែនដី, **គ. និង ស.** ១៩:៣ ។ ផែនដីត្រូវស្លាប់ ប៉ុន្តែនាងនឹងត្រូវបានប្រោសឲ្យមានជីវិតទៀត, **គ. និង ស.** ៨៨:២៥–២៦ ។ ព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ហេណុក នូវចុងបំផុតនៃ ផែនដី, **ម៉ូសេ** ៧:៦៧ ។

**ពិសិដ្ឋ** *សូមមើល* បរិសុទ្ធ, បរិសុទ្ធភាព

**ពីឡាត់, ប៉ុនទាស**

ជាអ្នកត្រួតត្រាសាសន៍រ៉ូមម្នាក់ ដែលនៅខេត្តយូដា ឆ្នាំ ២៦–៣៦ គ.ស. (លូកា ៣:១) ។ លោកស្អប់ប្រជាជនយូដា និងសាសនាគេ ហើយក៏បានឲ្យគេសម្លាប់ពួកកាលីឡេខ្លះចោល (លូកា ១៣:១) ។ ព្រះយេស៊ូវត្រូវគេចោទ ហើយកាត់ទោសឲ្យ ឆ្កាងនៅចំពោះលោកពីឡាត់ (ម៉ាថាយ ២៧:២, ១១–២៦, ៥៨–៦៦; ម៉ាកុស ១៥; លូកា ២៣; យ៉ូហាន ១៨:២៨–១៩:៣៨) ។

**ពូជទាំង ១០ អំបូរ** *សូមមើល* អ៊ីស្រាអែល

**ពូជរបស់អ័ប្រាហាំ** *សូមមើល* អ័ប្រាហាំ — ពូជរបស់អ័ប្រាហាំ

**ពូជអ៊ីស្រាអែលទាំង ១២ អំបូរ** *សូមមើល* អ៊ីស្រាអែល —
ពូជអ៊ីស្រាអែល ១២ អំបូរ

**ពួក៧០នាក់** *សូមមើលផង* បព្វជិតភាពមិលគីស្សាដែក, សាវក

ជាតំណែងមួយ ដែលពួកបុរសត្រូវបានតែងតាំង នៅក្នុងបព្វជិតភាពមិលគីស្សាដែក ។ សព្វថ្ងៃនេះ ក្រុមនៃពួក៧០នាក់ គឺពួកអ្នកដឹកនាំ ដែលមានសិទ្ធិអំណាចទូទៅនៅក្នុងសាសនាចក្រ ដែលបានទទួលសិទ្ធិអំណាចជាសាវក ប៉ុន្តែពុំបានតែងតាំងឲ្យធ្វើជាពួកសាវកទេ ។ ពួកគេចំណាយពេលវេលាគេពេញទី ចំពោះការងារបំរើ ។

ព្រះអម្ចាស់ទ្រង់បានតម្រូវ៧០នាក់ទៀត, **លូកា** ១០:១ ។ ពួក៧០នាក់ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ហើយឲ្យធ្វើជាពួកសាក្សីពិសេស អំពីព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ១០៧:២៥–២៦ ។ ពួក៧០នាក់ត្រូវប្រព្រឹត្តដោយនូវព្រះនាមនៃព្រះអម្ចាស់ នៅក្រោមការដឹកនាំរបស់ ពួក១២នាក់ ក្នុងការសាងសាសនាចក្រឡើង និងការកាន់កាប់គ្រប់ទាំងកិច្ចការនៃសាសនាចក្រ នៅគ្រប់សាសន៍, **គ. និង ស.** ១០៧:៣៤ ។ ចូររើសពួក៧០នាក់ផ្សេងទៀត រហូតដល់ប្រាំពីរ៧០ផង បើសិនជាកិច្ចការតម្រូវដោយមកពីការចាំបាច់, **គ. និង ស.** ១០៧:៩៣–៩៧ ។ ក្រុមនៃពួក៧០នាក់ត្រូវបានអនុវត្តឡើង សំរាប់ពួកអែលឌើរដែលធ្វើដំណើរ ដើម្បីធ្វើទីបន្ទាល់ប្រាប់ពីព្រះនាមរបស់ យើង នៅក្នុងពិភពលោកទាំងអស់, **គ. និង ស.** ១២៤:១៣៨–១៣៩ ។

**ពួកកូនប្រុសរបស់ហេលេមិន** *សូមមើល* ពួកកូនប្រុសរបស់លោក,
ហេលេមិន

**ពួកកូនអន្តរធាន** *សូមមើលផង* ស្ថាននរក; សេចក្ដីដាប់ទោស; សេចក្ដីស្លាប់ខាងវិញ្ញាណ; អារក្ស; អំពើបាបដ៏អត់ឱនមិនបាន

ជាពួកអ្នកដើរតាមអារក្សសាតាំង ដែលនឹងរងទុក្ខជាមួយនឹងវា នៅទីដ៏អស់កល្បជានិច្ច ។ ពួកកូនអន្តរធានមានរួមទាំង (១) ពួកអ្នកដែលដើរតាមអារក្សសាតាំង ហើយដែលត្រូវបានបណ្ដេញចេញពីស្ថានសួគ៌ មកពីបានបះបោរ នៅជីវិតមុនផែនដី ហើយ (២) ពួកអ្នកដែលបានអនុញ្ញាតឲ្យកើតមកក្នុងលោកនេះ ដើម្បីបានរូបកាយជាសាច់ឈាម ប៉ុន្តែក្រោយមក បានបំរើអារក្សសាតាំង ហើយបែរទៅជាទាស់នឹងព្រះទាំងស្រុង ។ ពួកអ្នកដែលនៅក្នុងក្រុមទីពីរនេះនឹងបានរស់ពីស្លាប់ឡើងវិញ ប៉ុន្តែនឹងមិនបានប្រោសលោះឲ្យរួច ពីការស្លាប់ទីពីរ (ខាងវិញ្ញាណ) ទេ ហើយពុំអាចរស់នៅក្នុងនគរនៃសិរីល្អបានឡើយ (គ. និង ស. ៨៨:៣២, ៣៥) ។

គ្មានអ្នកណាមួយត្រូវវិនាសឡើយ ក្រៅពីកូនអន្តរធាន, **យ៉ូហាន** ១៧:១២ ។ គឺគ្មានផ្លូវណានឹងនាំឲ្យគេប្រែចិត្តម្ដងទៀតទេ, **ហេព្រើរ** ៦:៤–៦ (ហេព្រើរ ១០:២៦–២៩) ។ សេចក្ដីមេត្តាករុណាពុំអាចជួយជននោះបានឡើយ ហើយទោសចុងក្រោយបង្អស់របស់ ជននោះគឺមិនចេះចប់មិនចេះហើយឡើយ, **ម៉ូសាយ** ២:៣៦–៣៩ ។ ជននោះហាក់បីដូចជាគ្មានការប្រោសលោះឡើយ, **ម៉ូសាយ** ១៦:៥ ។ អស់អ្នកណាដែលបដិសេធអព្ភូតហេតុទាំងឡាយរបស់ព្រះគ្រីស្ទ ដើម្បីរកប្រម្រៃដល់ខ្លួន នោះនឹងក្លាយទៅដូចជាកូនអន្តរធាន, **៣ នីហ្វៃ** ២៩:៧ ។ ពួកគេនឹងពុំបានទទួលការអត់ទោសនៅលោកិយនេះ ឬនៅបរលោកក្ដី, **គ. និង ស.** ៧៦:៣០–៣៤ (គ. និង ស. ៨៤:៤១; ១៣២:២៧) ។ គឺជាពួកនោះតែប៉ុណ្ណោះគត់ ដែលនឹងពុំបានប្រោសលោះឲ្យរួចពីសេចក្ដីស្លាប់ទីពីរ, **គ. និង ស.** ៧៦:៣៤–៤៨ ។ ពួកកូនអន្តរធានបានបដិសេធព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់ពីបានទទួលហើយនោះ, **គ. និង ស.** ៧៦:៣៥ ។ ពួកកូនអន្តរធានបានបដិសេធ ព្រះរាជបុត្រា បន្ទាប់ពីព្រះវរបិតាបានបើកសម្ដែងឲ្យស្គាល់ទ្រង់, **គ. និង ស.** ៧៦:៤៣ ។ កាអ៊ីននឹងត្រូវបានហៅ ថា អារអន្តរធាន, **ម៉ូសេ** ៥:២២–២៦ ។

**ពួកគ្រីស្ទាន** *សូមមើលផង* សិស្ស; អ្នកបរិសុទ្ធ

ជាឈ្មោះដាក់ឲ្យពួកអ្នកដែលជឿដល់ព្រះយេស៊ូវគ្រីស្ទ ។ ទោះជាពាក្យនេះត្រូវបានយកមកប្រើទូទៅនៅក្នុងពិភពលោកក៏ដោយ គង់ តែព្រះអម្ចាស់ទ្រង់ចាត់ពួកអ្នកដែលដើរតាមព្រះគ្រីស្ទដ៏ពិតថាជាពួកបរិសុទ្ធវិញ (កិច្ចការ ៩:១៣, ៣២, ៤១; ១ កូរិន. ១:២; គ. និង ស. ១១៥:៤) ។

ពួកសិស្សត្រូវគេហៅថាជាពួកគ្រីស្ទាន, **កិច្ចការ** ១១:២៦ ។ បើអ្នកណារងទុក្ខ ដោយព្រោះជាពួកគ្រីស្ទានវិញ នោះកុំឲ្យខ្មាស់ឲ្យ សោះ, **១ ពេត្រុស** ៤:១៦ ។ មកពីសេចក្ដីសញ្ញា អ្នករាល់គ្នានឹងត្រូវបានហៅថា ជាកូនចៅនៃព្រះគ្រីស្ទ, **ម៉ូសាយ** ៥:៧ ។ ពួកអ្នកដែល ជឿពិតត្រូវបានហៅថាជាពួកគ្រីស្ទាន ដោយពួកអ្នកដែលមិនមែនជាសមាជិកក្នុងសាសនាចក្រ, **អាលម៉ា** ៤៦:១៣–១៦ ។

**ពួកចោរកាឌីអានតុន** *សូមមើលផង* បក្សព័ន្ធសម្ងាត់

នៅក្នុងព្រះគម្ពីរមរមន ជាក្រុមចោរ ដែលបានបង្កើតឡើងដោយសាសន៍នីហ្វៃដ៏ទុច្ចរិតម្នាក់ឈ្មោះថា កាឌីអានតុន ។ អង្គការគេគឺផ្អែកទៅលើការសម្ងាត់ និងសម្បថផ្អែកខាងអារក្សសាតាំង ។

កាឌីអានតុនបានបណ្ដាលឲ្យមានការបំផ្លិចបំផ្លាញដល់សាសន៍នីហ្វៃ, **ហេលេ.** ២:១២–១៣ ។ អារក្សបានឲ្យសម្បថ និងសេចក្ដីសញ្ញាសម្ងាត់ដល់កាឌីអានតុន, **ហេលេ.** ៦:១៦–៣២ ។ បក្សព័ន្ធសម្ងាត់បានបណ្ដាលឲ្យមានការបំផ្លិចបំផ្លាញដល់សាសន៍យ៉ារេឌ, **អេធើរ** ៨:១៥–២៦ ។

**ពួកចៅហ្វាយ, គម្ពីរ**

ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ គម្ពីរពួកចៅហ្វាយទាក់ទងទៅនឹងពួកសាសន៍អ៊ីស្រាអែល ចាប់តាំងពីមរណភាពនៃយ៉ូស្វេ រហូតទៅដល់កំណើតនៃសាំយូអែល ។

ជំពូកទី ១–៣ ជាអារម្ភកថាចំពោះគម្ពីរចៅហ្វាយទាំងមូល ។ ជំពូកទាំងនេះពន្យល់ប្រាប់ថា ពីព្រោះពួកសាសន៍អ៊ីស្រាអែលមិនបានបណ្ដេញពួកខ្មាំងសត្រូវរបស់គេចេញ (ពួកចៅ. ១:១៦–៣៥), នោះពួកសាសន៍អ៊ីស្រាអែលត្រូវរងគ្រោះ — បាត់បង់សេចក្ដីជំនឿ រៀបការជាមួយនឹងពួកអ្នកដែលមិនជឿ និងការថ្វាយបង្គំរូបព្រះ ។ ជំពូកទី ៣–៥ រៀបរាប់អំពីការពិសោធន៍របស់ដេបូរ៉ា និងបារ៉ាក ជាអ្នកដែលបាននំដោះសាសន៍អ៊ីស្រាអែលពីពួកសាសន៍កាណាន ។ ជំពូកទី ៦–៨ ជាការពិសោធន៍ដ៏ផ្ដល់នូវសេចក្ដីជំនឿដល់គេឌាន ជាអ្នកដែលព្រះអម្ចាស់ទ្រង់បានប្រទានពរឲ្យទៅរំដោះសាសន៍អ៊ីស្រាអែលពីពួកសាសន៍ម៉ាឌាន ។ នៅជំពូកទី ៩–១២ មានមនុស្ស ផ្សេងៗជាច្រើនបានធ្វើជាចៅហ្វាយនៅស្រុកអ៊ីស្រាអែល ភាគច្រើននៅក្នុងសេចក្ដីក្បត់សាសនា និងនៅក្រោមការសង្កិតសង្កិន ។ ជំពូកទី ១៣–១៦ ប្រាប់អំពីការចំរើន និងការរលំនៃចៅហ្វាយចុងក្រោយបង្អស់ គឺសាំសុន ។ ជំពូកចុងក្រោយបង្អស់ គឺជំពូកទី ១៧–២១ អាចចាត់ទុកថាជាបរិសុទ្ធ ដែលបើកសម្ដែងប្រាប់អំពីជម្រៅនៃអំពើបាបរបស់ពួកអ៊ីស្រាអែល ។

**ពួកទមិលល្មើស, អំពើដ៏ឥតបរិសុទ្ធ** *សូមមើលផង* ទុច្ចរិត, សេចក្ដីស្មោកគ្រោក; សេចក្ដីឥតសុចរិត; ស្មោកគ្រោក, អំពើទុច្ចរិត អំពើបាប; ឥតសុចរិត

ជាមនុស្ស ឬអ្វីមួយដែលមិនស្របតាមព្រះហឫទ័យ ឬព្រះបញ្ញត្តិទាំងឡាយនៃព្រះ; គឺទុច្ចរិត ហើយឥតបរិសុទ្ធ ។

ផ្លូវរបស់មនុស្សអាក្រក់នឹងវិនាសទៅ, **ទំនុក.** ១:៦ ។ បើមនុស្សសុចរិតបានរួចដោយពិបាកផង នោះពួកទមិលល្មើស និងលេចមកនៅ ឯណា? **១ ពេត្រុស** ៤:១៨ ។ ចូរលះបង់ចោលនូវអស់ទាំងអំពើដ៏ឥតបរិសុទ្ធ, **ម៉ូរ៉ូណៃ** ១០:៣២ ។ សេចក្ដីសងសឹកនឹងឆាប់មកលើ ពួកទមិលល្មើស, **គ. និង ស.** ៩៧:២២ ។ នៅក្នុងចំណោមពួកទមិលល្មើស នោះសម្លេងរបស់ទ្រង់ពុំបានបន្លឺឡើងឡើយ, **គ. និង ស.** ១៣៨:២០ ។

**ពួកទេវតា**

នៅលើស្ថានសួគ៌មានតួអង្គពីរយ៉ាងដែលហៅថា ទេវតា គឺៈ តួអង្គដែលជាវិញ្ញាណ និងតួអង្គដែលមានរូបកាយជាសាច់ និងឆ្អឹង ។ ពួកទេវតាដែលជាវិញ្ញាណនោះពុំទាន់បានទទួលរូបកាយជាសាច់ និងឆ្អឹងទេ ឬពួកគេជាវិញ្ញាណ ដែលធ្លាប់មានរូបកាយជាសាច់ឈាម ម្តងហើយ ហើយកំពុងតែរង់ចាំទទួលដំណើររស់ឡើងវិញ ។ ពួកទេវតាដែលមានរូបកាយជាសាច់ និងឆ្អឹងនោះបានរស់ឡើងពីស្លាប់ វិញហើយ ឬក៏បានប្រែរូបហើយ ។

មានសេចក្តីយោងជាច្រើននៅក្នុងព្រះគម្ពីរ ស្តីពីកិច្ចការរបស់ពួកទេវតា ។ ជួនកាល ពួកទេវតាពោលដោយសម្លេងផ្គរ នៅពេល ប្រកាសប្រាប់សារពីព្រះ (ម៉ូសាយ ២៧:១១–១៦) ។ ពួកមនុស្សដែលសុចរិតក៏អាចហៅថាជាទេវតាបានផងដែរ (ក.យ.ស., លោកុ. ១៩:១៥) ។ ពួកទេវតាខ្លះបំរើនៅជុំវិញបល្ល័ង្កព្រះនៅលើស្ថានសួគ៌ (អាលម៉ា ៣៦:២២) ។

មានបទគម្ពីរខ្លះពោលអំពីពួកទេវតារបស់អារក្សដែរ ។ ពួកនេះគឺជាវិញ្ញាណដែលបានដើរតាមលូស៊ីហ្វើរ ហើយត្រូវបានបណ្តេញចេញពីវត្តមានរបស់ព្រះ មុនជីវិតនៅលើផែនដី ហើយត្រូវបានបោះចុះមកលើផែនដី (វិវរ. ១២:១–៩; ២ នីហ្វៃ ៩:៩, ១៦; គ. និង ស. ២៩:៣៦–៣៧) ។

យ៉ាកុបបានឃើញពួកទេវតានៃព្រះឡើងចុះ, **លោកុ.** ២៨:១២ ។ ពួកទេវតានៃព្រះបានមកជួបនឹងយ៉ាកុប, **លោកុ.** ៣២:១–២ ។ គេឌានបានឃើញទេវតានៃព្រះអម្ចាស់ប្រទល់មុខ, **ចៅហ្វាយ** ៦:២២ ។ ទេវតាមួយបានលើកដៃ ដើម្បីនឹងបំផ្លាញក្រុងយេរូសាឡិម, **២ សាំយូ.** ២៤:១៦ ។ ទេវតាមួយមកប៉ះអេលីយ៉ា ហើយប្រាប់លោកថា ចូរក្រោកឡើងបរិភោគសិន, **១ពង្សាវ.** ១៩:៥–៧ ។ ដានីយ៉ែលបានឃើញទេវតាកាព្រីយ៉ែលនៅក្នុងការនិមិត្ត, **ដានី.** ៨:១៥–១៦ ។ ទេវតាមីកែលបានជួយដានីយ៉ែល, **ដានី.** ១០:១៣ ។ ទេវតាកាព្រីយ៉ែលត្រូវបានចាត់ឲ្យមកពីព្រះ, **លូកា** ១:១៩, ២៦–២៧ ។ ពួកទេវតារបស់អារក្សត្រូវបានជាប់ច្រវាក់រហូតដល់សេចក្តី ជំនុំជំរះ, **យូដាស** ១:៦ (២ ពេត្រុស ២:៤) ។ ប្រជាជនបានឃើញពួកទេវតាហោះចុះមកពីស្ថានសួគ៌, **៣ នីហ្វៃ** ១៧:២៤ ។ ម៉ូរ៉ូណៃ បានសរសេរអំពីការបំរើនៃពួកទេវតា, **ម៉ូរ៉ូណៃ** ៧:២៥–៣២ ។ បព្វជិតភាពអើរ៉ុនកាន់កូនសោទាំងឡាយខាងការបំរើនៃពួកទេវតា, **គ. និង ស.** ១៣ ។ ម៉ូរ៉ូណៃ, យ៉ូហាន-បាទិស្ទ, ពេត្រុស, យ៉ាកុប, យ៉ូហាន, ម៉ូសេ, អេលីយ៉ា, និងអេលីយ៉ាស គេទាំងអស់គ្នាបានធ្វើការងារ បំរើដល់យ៉ូសែប ស្ម៊ីធ ក្នុងឋានៈជាទេវតា, **គ. និង ស.** ២៧:៥–១២ ។ អ្នករាល់គ្នាពុំអាចនៅក្នុងការងារបំរើនៃពួកទេវតាបានឡើយ, **គ. និង ស.** ៦៧:១៣ ។ មីកែលដែលជាមហាទេវតា គឺជាលោកអ័ដាម, **គ. និង ស.** ១០៧:៥៤ ។ ពួកទេវតា គឺជាអង្គដែលបានរស់ឡើង វិញ ដោយមានរូបកាយជាសាច់ និងឆ្អឹង, **គ. និង ស.** ១២៩ ។ គ្មានទេវតាណាដែលបំរើនៅលើផែនដីនេះឡើយ លើកលែងតែពួក អ្នកដែលនៅទីនេះ, **គ. និង ស.** ១៣០:៥ ។ មនុស្សលោកណាដែលពុំគោរពតាមក្រិត្យវិន័យរបស់ព្រះ ខាងអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច នោះពុំមែនរៀបការយកគ្នាជាប្តីប្រពន្ធទៀតទេ; ប៉ុន្តែត្រូវបានតែងតាំងឡើងជាពួកទេវតានៅស្ថានសួគ៌វិញ, **គ. និង ស.** ១៣២:១៦–១៧ ។

**ពួកបងប្អូនប្រុស, បងប្អូនប្រុស** *សូមមើលផង* បងប្អូនស្រី, មនុស្ស, មនុស្សលោក

ជាកូនចៅនៃព្រះវរបិតាសួគ៌, បុរស និងស្រ្តីទាំងអស់គ្នា គឺជាបងប្អូននឹងគ្នាខាងវិញ្ញាណ ។ នៅក្នុងសាសនាចក្រ សមាជិកប្រុស ឬមិត្តប្រុសក្នុងសាសនាចក្រតែងតែហៅគ្នាថា បងប្រុស ។

កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចំរើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង, **លូកា** ២២:៣២ ។ ឯអ្នកណាដែលមិនស្រឡាញ់បងប្អូន អ្នកនោះជាអ្នកនៅជាប់ក្នុងសេចក្តីស្លាប់នៅឡើយ, **១ យ៉ូហាន** ៣:១០–១៧ ។ ចូរអ្នកគិតដល់បងប្អូនអ្នក ដូចជាខ្លួនអ្នកដែរ, **យ៉ាកុប** ២:១៧ ។ ចូរបណ្តោយឲ្យមនុស្សគ្រប់រូប គោរពបងប្អូនខ្លួន ដូចជាខ្លួនឯងផ្ទាល់, **គ. និង ស.** ៣៨:២៤–២៥ ។ ចូរចំរើន កម្លាំងដល់បងប្អូនអ្នក ដោយគ្រប់វាចារបស់អ្នក, **គ. និង ស.** ១០៨:៧ ។

**ពួកបុត្រារបស់ម៉ូសាយ** *សូមមើល* ពួកបុត្រារបស់ទ្រង់, ម៉ូសាយ

**ពួកផារិស៊ី** *សូមមើលផង* ពួកសាសន៍យូដា

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាមនុស្សមួយក្រុមខាងសាសនា នៅក្នុងចំណោមពួកសាសន៍យូដា ដែលឈ្មោះមានន័យថា ញែក ឬបែកពីគ្នា ។ ពួកផារិស៊ីបានដំកើងខ្លួន ដោយសារការគោរពតាមក្រិត្យវិន័យលោកម៉ូសេយ៉ាងម៉ឺងម៉ាត់ និងការចៀសវាងចេញពីអ្វីៗដែល ទាក់ទងទៅនឹងពួកសាសន៍ដទៃ ។ ពួកគេបានជឿថាមានជីវិតក្រោយពីស្លាប់, ដំណើររស់ឡើងវិញ, និងការមានពួកទេវតា និងពួក វិញ្ញាណ ។ ពួកគេបានជឿថា ច្បាប់តាមមាត់ និងតាមសណ្តាប់ធ្នាប់នោះសំខាន់ដូចគ្នានឹងច្បាប់តាមតំរា ។ ការបង្រៀនរបស់គេ បានបន្ថែមបន្ថយសាសនាទៅត្រឹមនឹងការគោរពតាមច្បាប់ ហើយបានលើកទឹកចិត្តឲ្យមានការឆ្មើងឆ្មៃខាងវិញ្ញាណ ។ ពួកគេបាន បណ្តាលប្រជារាស្ត្រយូដាជាច្រើនឲ្យមានចិត្តសង្ស័យពីព្រះគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ។ ព្រះអម្ចាស់ ទ្រង់បានស្តីឲ្យពួកផារិស៊ី និងកិច្ចការទាំងឡាយរបស់ពួកគេនៅក្នុងគម្ពីរម៉ាថាយ ២៣; ម៉ាកុស ៧:១–២៣; និង លូកា ១១:៣៧–៤៤ ។

**ពួកពូជអំបូរដែលបាត់** *សូមមើល* អ៊ីស្រាអែល — ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់

**ពួកភីលីស្ទីន**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាពូជអំបូរមួយ ដែលពីដើមបានមកពីស្រុកកាប់ថោរ (អេម៉ុស ៩:៧) ហើយបានអាស្រ័យនៅដីទំនាបដ៏មានជីជាតិល្អ នៅលើឆ្នេរសមុទ្រមេឌីតេរ៉ាន ចាប់ពីក្រុងយ៉ូបប៉េ រហូតដល់ទីរហោស្ថាននៅស្រុកអេស៊ីព្ទ មុនសម័យលោកអ័ប្រាហាំ (លោកុ. ២១:៣២) ។ អស់រយៈជាច្រើនឆ្នាំមានការប្រយុទ្ធរវាងទាហានភីលីស្ទីន

នឹងទាហានអ៊ីស្រាអែល ។ ទីបំផុត ស្រុកភីលីស្ទីន ជាឈ្មោះដែនដីរបស់ពួកភីលីស្ទីន ក្លាយទៅជាឈ្មោះមួយដែលគេស្គាល់ទូទៅថាជាដែនដីបរិសុទ្ធទាំងអស់ ។

ពួកអ៊ីស្រាអែល បានត្រូវនៅក្រោមអំណាចនៃសាសន៍ភីលីស្ទីនអស់ ៤០ ឆ្នាំ, **ពួកចៅ.** ១៣:១ ។ សាំសុនបានច្បាំងនឹងពួកភីលីស្ទីន, **ពួកចៅ.** ១៣–១៦ ។ កូលីយ៉ាតជាសាសន៍ភីលីស្ទីនចេញពីក្រុងកាថ, **១ សាំយូ.** ១៧ ។ ដាវីឌបានឈ្នះលើពួកភីស្ទីន, **១ សាំយូ.** ១៩:៨ ។

**ពួកមរមន** *សូមមើលផង* សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ; សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

មរមន ជាឈ្មោះហៅលេង ដែលពួកមនុស្សក្រៅសាសនាចក្រហៅសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ឈ្មោះនេះបានមកពីព្រះគម្ពីរដ៏ពិសិដ្ឋមួយ ដែលបានចងក្រងដោយមរមន ជាព្យាការីពីបុរាណ ហើយដាក់ឈ្មោះថា ព្រះគម្ពីរមរមន ។ រីឯឈ្មោះដែលព្រះអម្ចាស់ទ្រង់ដាក់ឲ្យសមាជិកនៃសាសនាចក្រ គឺ « ពួកបរិសុទ្ធ » ។ ឈ្មោះត្រឹមត្រូវនៃ សាសនាចក្រគឺ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

**ពួករើសតាំង**

ពួករើសតាំង គឺជាពួកអ្នកដែលស្រឡាញ់ព្រះ ដោយអស់ពីចិត្តគេ ហើយរស់នៅតាមរបៀប ដែលសព្វព្រះហឫទ័យដល់ទ្រង់ ។ ពួកអ្នកដែលរស់នៅតាមរបៀបជាសិស្ស នៅថ្ងៃណាមួយ អ្នកនោះនឹងត្រូវបានរើសដោយព្រះអម្ចាស់ ឲ្យទៅនៅក្នុងចំណោមពួកកូនចៅ ជំរើសរបស់ទ្រង់ ។

បើសិនជាធ្វើបាន ពួកគេនឹងបញ្ឆោតទាំងពួកអ្នករើសតាំង, **ម៉ាថាយ** ២៤:២៤ ។ យ៉ូហានមានសេចក្ដីអំណរ ពីព្រោះពួកកូនចៅរបស់លោកស្រីរើសតាំងនៅក្នុងសេចក្ដីពិត និងស្មោះត្រង់, **២ យ៉ូហាន** ១ ។ បាបរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ ហើយអ្នកជាស្ត្រីរើស តាំង, **គ. និង ស.** ២៥:៣ ។ ពួកដែលយើងបានរើសតាំង ឮសម្លេងរបស់យើង ហើយមិនរាជ្រឹងចិត្តរបស់ពួកគេឡើយ, **គ. និង ស.** ២៩:៧ ។ ហើយទើបយើងប្រមូលពួកដែលយើងរើសតាំង ពីទិសទាំងបួននៃផែនដី, **គ. និង ស.** ៣៣:៦ ។ បទគម្ពីរទាំងឡាយនឹងត្រូវ បានប្រទានឲ្យដើម្បីសេចក្ដីសង្គ្រោះដល់ពួកដែលយើងរើសតាំង, **គ. និង ស.** ៣៥:២០–២១ ។ អស់អ្នកណាដែលដំកើងការហៅខាង បព្វជិតភាពរបស់ខ្លួន នោះនឹងក្លាយទៅជាពួករើសតាំងនៃព្រះ, **គ. និង ស.** ៨៤:៣៣–៣៤ ។ ដោយព្រោះយល់ដល់ពួករើសតាំង ទើបថ្ងៃនៃសេចក្ដីវេទនានឹងបានបន្ថយឲ្យខ្លីចុះ **យ.ស.– ម៉ាថាយ** ១:២០ ។

**ពួកវិញ្ញាណអារក្សអសោចិ៍** *មើល* វិញ្ញាណ — ពួកវិញ្ញាណអារក្សអសោចិ៍

**ពួកសាក្សីអំពីព្រះគម្ពីរមរមន** *សូមមើលផង* ព្រះគម្ពីរមរមន; សាក្សី

ព្រះអម្ចាស់ទ្រង់បានបញ្ជាពួកអ្នកឯទៀត ក្រៅពីព្យាការីយ៉ូសែប ស្ម៊ីធ ឲ្យធ្វើទីបន្ទាល់អំពីទេវភាពនៃព្រះគម្ពីរមរមន (គ. និង ស. ១៧, ១២៨:២០) ។ សូមមើល ទីបន្ទាល់នៃពួកសាក្សីទាំងនេះ នៅក្នុង « បុព្វកថា » ខាងមុខព្រះគម្ពីរមរមន ។

ដោយពាក្យនៃពួកទាំងបីនាក់ នោះយើងនឹងតាក់តែងពាក្យរបស់យើង, **២ នីហ្វៃ** ១១:៣ ។ មានពួកសាក្សី ដើម្បីធ្វើបន្ទាល់អំពីព្រះ បន្ទូលរបស់ទ្រង់ ដល់ពួកកូនចៅមនុស្ស, **២ នីហ្វៃ** ២៧:១២–១៣ ។ ដោយមាត់របស់ពួកសាក្សីបីនាក់ការណ៍ទាំងនេះនឹងត្រូវបាន បញ្ជាក់, **អេធើរ** ៥:៤ ។ ដោយសារសេចក្ដីជំនឿ នោះពួកសាក្សីបីនាក់នឹងបានឃើញផ្ទាំងទាំងឡាយ, **គ. និង ស.** ១៧ ។

**ពួកសាឌូស៊ី** *សូមមើលផង* ពួកសាសន៍យូដា

ជាបក្ស ឬក្រុមតូចមួយ តែមានអំណាចខាងការត្រួតត្រា នៅក្នុងចំណោមពួកសាសន៍យូដា ។ តាមមើលទៅ ពួកគេត្រូវបានគេឯងស្គាល់ជាច្រើន មកពីជំនឿដ៏តឹងរឹងរបស់គេក្នុងការកាន់តាមតួអក្សរនៃក្រិត្យវិន័យលោកម៉ូសេ និងការបដិសេធចំពោះវិញ្ញាណពិត និងពួកទេវតា និងអំពីលទ្ធិនៃដំណើររស់ឡើងវិញ និងជីវិតដ៏នៅអស់កល្បជានិច្ច (ម៉ាកុស ១២:១៨–២៧; កិច្ចការ ៤:១–៣; ២៣:៧–៨) ។

**ពួកសាសន៍ដទៃ**

ដូចដែលប្រើនៅក្នុងគម្ពីរ *ពួកសាសន៍ដទៃ* មានន័យច្រើនយ៉ាង ។ ជួនកាលមានន័យថា មនុស្សក្រៅពីពូជអ៊ីស្រាអែល ជួនកាល ជាមនុស្សក្រៅពីពូជយូដា ហើយជួនកាល ជាពួកសាសន៍ដែលឥតមានដំណឹងល្អ ទោះជាមានមនុស្សខ្លះអាចមានឈាមអ៊ីស្រាអែល នៅក្នុងចំណោមប្រជាជនក៏ដោយ ។ ពាក្យប្រើខាងក្រោយនេះ ជាពិសេស ជាលក្ខណៈអំពីពាក្យដែលប្រើនៅក្នុងព្រះគម្ពីរមរមន និងគោលលទ្ធិ និងសេចក្ដីសញ្ញា ។

ពួកសាសន៍អ៊ីស្រាអែលមិនត្រូវរៀបការនឹងពួកសាសន៍ក្រៅពីអ៊ីស្រាអែល ទេ (ពួកសាសន៍ដទៃ), **ចោទិ.** ៧:១–៣ ។ ព្រះអម្ចាស់ ទ្រង់នឹងយាងមកបំភ្លឺសាសន៍ដទៃ, **អេសាយ** ៤២:៦ ។ ពេត្រុសបានត្រូវបញ្ជាឲ្យយកដំណឹងល្អទៅឯពួកសាសន៍ដទៃ, **កិច្ចការ** ១០:៩–៤៨ ។ ព្រះទ្រង់ក៏បានប្រោសប្រទានការប្រែចិត្តដល់ពួកសាសន៍ដទៃ, **កិច្ចការ** ១១:១៨ ។ ពួកយើងរាល់គ្នាបានទទួលបុណ្យ ជ្រមុជទឹកចូលសាសនាចក្រតែមួយ ទោះជាយើងជាសាសន៍យូដា ឬសាសន៍ដទៃក្ដី, **១ កូរិន.** ១២:១៣ ។ ពួកសាសន៍ដទៃគួរតែបាន ទៅជាអ្នកគ្រងមរតក ជាមួយគ្នាក្នុងព្រះគ្រីស្ទ ដោយសារដំណឹងល្អ, **អេភេ.** ៣:៦ ។ ព្រះគម្ពីរមរមន គឺបានសរសេរទុកដល់ពួកសាសន៍ ដទៃ, **ទំព័រចំណងជើងព្រះគម្ពីរមរមន** (មរមន ៣:១៧) ។ បុរសម្នាក់ក្នុងចំណោមពួកសាសន៍ដទៃបានចេញដំណើរទៅលើផ្លូវទឹក, **១ នីហ្វៃ** ១៣:១២ ។ មានគម្ពីរផ្សេងៗទៀតបានចេញពីពួកសាសន៍ដទៃ, **១ នីហ្វៃ** ១៣:៣៩ ។ ភាពពោរពេញនៃដំណឹងល្អនឹងមកឯពួក សាសន៍ដទៃ, **១ នីហ្វៃ** ១៥:១៣ (៣ នីហ្វៃ ១៦:៧; គ. និង ស. ២០:៩) ។ ដែនដីនេះនឹងទៅជាដែនដីឥស្សរភាពមួយសំរាប់ពួក សាសន៍ដទៃ, **២ នីហ្វៃ** ១០:១១ ។ ពួកសាសន៍ដទៃប្រៀបដូចជាដើមអូលីវព្រៃ, **យ៉ាកុប** ៥ ។ ដំណឹងល្អនឹងបានចេញមកនៅពេល វេលារបស់ពួកសាសន៍ដទៃ, **គ. និង ស.** ៤៥:២៨

(គ. និង ស. ១៩:២៧) ។ ព្រះបន្ទូលនឹងចេញទៅដល់ទីបំផុតផែនដី គឺមុនដំបូង ទៅដល់ពួកសាសន៍ដទៃ ហើយបន្ទាប់មក ទៅដល់ពួកសាសន៍យូដា, **គ. និង ស.** ៩០:៨–១០ ។ ពួក៧០នាក់ត្រូវធ្វើជាពួកសាក្សីវិសេសចំពោះពួកសាសន៍ដទៃ, **គ. និង ស.** ១០៧;២៥ ។ ចូរចាត់ពួកអែលឌើរនៃសាសនាចក្ររបស់យើង ឲ្យទៅឯសាសន៍ទាំងអស់ គឺមុនដំបូង ដល់ពួកសាសន៍ដទៃ ហើយបន្ទាប់មក ដល់ពួកសាសន៍យូដា, **គ. និង ស.** ១៣៣:៨ ។

**ពួកសាសន៍នីហ្វៃ** *សូមមើលផង* កូនប្រុសរបស់លីហៃ, នីហ្វៃ, ពួកសាសន៍លេមិន; ព្រះគម្ពីរមរមន

ជាមនុស្សមួយក្រុមនៅក្នុងព្រះគម្ពីរមរមន ពួកគេជាច្រើនជាពូជពង្សនៃព្យាការីនីហ្វៃ ដែលជាកូនប្រុសរបស់លីហៃ ។ ពួកគេបានបែកចេញពីពួកសាសន៍លេមិន ហើយតាមធម្មតា ពួកគេជាមនុស្សសុចរិតជាងពួកសាសន៍លេមិន ។ ប៉ុន្តែបន្ទាប់មក ពួកគេត្រូវពួកសាសន៍ លេមិន បំផ្លាញចោល ពីព្រោះមកពីអំពើទុច្ចរិត ។

ពួកសាសន៍នីហ្វៃបានបែកចេញពួកសាសន៍លេមិន, **២ នីហ្វៃ** ៥:៥–១៧ ។ អស់អ្នកណាដែលមិនមែនជាសាសន៍លេមិន គឺជាសាសន៍ នីហ្វៃ, **យ៉ាកុប** ១:១៣ ។ ពួកសាសន៍នីហ្វៃត្រូវបានបំផុសគំនិតដោយព្រោះផលប្រយោជន៍ដ៏ប្រសើរជាង, **អាលម៉ា** ៤៣:៦–៩, ៤៥ ។ ពួកសាសន៍នីហ្វៃមិនដែលបានសប្បាយរីករាយជាងនៅសម័យម៉ូរ៉ូណៃឡើយ, **អាលម៉ា** ៥០:២៣ ។ ពួកសាសន៍នីហ្វៃត្រូវបានសង្គ្រោះ ពីព្រោះមកពីការអធិស្ឋាននៃពួកសុចរិត, **អាលម៉ា** ៦២:៤០ ។ ពួកសាសន៍នីហ្វៃបានចាប់ផ្ដើមចុះអន់ថយក្នុងការគេតជំនឿ, **ហេលេ.** ៦:៣៤–៣៥ ។ ព្រះយេស៊ូវ ទ្រង់បានបង្រៀន ហើយធ្វើការងារបំរើនៅក្នុងចំណោមពួកសាសន៍នីហ្វៃ, **៣ នីហ្វៃ** ១១:១–២៨:១២ ។ មនុស្សទាំងអស់បានប្រែចិត្តជឿដល់ព្រះអម្ចាស់ ហើយមានវត្ថុសព្វសារពើ នៅមូលព្រមគ្នា, **៤ នីហ្វៃ** ១:២–៣ ។ គ្មានសេចក្ដីទាស់ ទែងគ្នាឡើយ សេចក្ដីស្រឡាញ់នៃព្រះស្ថិតនៅក្នុងដួងចិត្តរបស់ពួកគេ ហើយពួកគេគឺជាប្រជាជនដ៏សប្បាយរីករាយបំផុត, **៤ នីហ្វៃ** ១:១៥–១៦ ។ ពួកសាសន៍នីហ្វៃបានចាប់ផ្ដើមមានចិត្តអួតអាង និងអសារឥតការ, **៤ នីហ្វៃ** ១:៤៣ ។ មានឈាមនិងសាកសព រាលពាសពេញលើអស់ទាំងផ្ទៃផែនដី, **មរមន** ២:៨ ។ ពួកសាសន៍នីហ្វៃបានចំរើនឡើងក្នុងអំពើទុច្ចរិត ហើយមរមន មិនព្រមដឹកនាំពួកគេឡើយ, **មរមន** ៣:៩–១១ ។ ពួកសាសន៍នីហ្វៃទាំងអស់ត្រូវបានប្រហារចោល លើកលែងតែមនុស្ស ២៤ នាក់ប៉ុណ្ណោះ, **មរមន** ៦:៧–១៥ ។ ពួកសាសន៍នីហ្វៃគ្រប់រូប ដែលមិនព្រមបដិសេធព្រះគ្រីស្ទនោះត្រូវគេប្រហារជីវិត, **ម៉ូរ៉ូណៃ** ១:២ ។ ពួកសាសន៍នីហ្វៃ ត្រូវបានបំផ្លាញចោល ពីព្រោះតែអំពើទុច្ចរិត និងអំពើបាបទាំងឡាយរបស់គេ, **គ. និង ស.** ៣:១៨ ។ ចូរប្រយ័ត្នពីសេចក្ដីឆ្មើងឆ្មៃ ក្រែងអ្នករាល់គ្នាក្លាយទៅដូចជាពួកសាសន៍នីហ្វៃ, **គ. និង ស.** ៣៨:៣៩ ។

**ពួកសាសន៍យ៉ារេឌ** *សូមមើលផង* បងប្រុសរបស់យ៉ារេឌ, ព្រះគម្ពីរមរមន; យ៉ារេឌ

ជាប្រជាជននៅក្នុងព្រះគម្ពីរមរមន ដែលជាពូជពង្សរបស់យ៉ារេឌ បងប្រុសរបស់លោក និងមិត្តរបស់គេទាំងប៉ុន្មាន (អេធើរ ១:៣៣–៤១) ។ ពួកគេត្រូវបានព្រះអង្គទ្រង់នាំចេញពីប៉មបាបិល ទៅកាន់ទ្វីបអាមេរិក ជាដែនដីសន្យា (អេធើរ ១:៤២–៤៣; ២–៣; ៦:១–១៨) ។ ទោះបីក្នុងគ្រាមួយ សាសន៍គេមានមនុស្សរាប់លាននាក់ក៏ដោយ គង់តែពួកគេត្រូវបំផ្លាញចោលអស់ ដោយសង្គ្រាមរវាងគ្នាឯង ដែលកើតមកពីអំពើទុច្ចរិត (អេធើរ ១៤–១៥) ។

**ពួកសាសន៍យូដា** *សូមមើលផង* អ៊ីស្រាអែល; យូដា

ពួកសាសន៍យូដាអាចជា (១) ពួជពង្សនៃយូដា ជាកូនប្រុសរបស់យ៉ាកុបម្នាក់ ក្នុងពួក ១២ នាក់ (២) ជាប្រជារាស្ត្រនៅនគរយូដា ខាងត្បូងកាលពីបុរាណ ឬ (៣) ជាប្រជារាស្ត្រដែលប្រព្រឹត្តតាមសាសនារបៀបរស់នៅ និងសណ្ដាប់នៃសាសនាយូដា ទោះជាមាន ឬមិនមានឈាមយូដាពីកំណើតក្ដី ។ មនុស្សទម្លាប់ហៅពាក្យ*សាសន៍យូដា* ថាជាពូជពង្សទាំងអស់របស់យ៉ាកុប ប៉ុន្តែនេះគឺមិនត្រូវទេ ។ គឺត្រូវដាក់កំណត់ដល់អស់អ្នកណាដែលនៅក្នុងនគរយូដា ឬជាពិសេសទៅទៀតនៅសព្វថ្ងៃនេះ គឺដល់អស់អ្នកណាដែលមកពី ពូជអំបូរនៃយូដា និងពួកអ្នកដែលលោករាប់អាន ។

ដំបងរាជ្យនឹងមិនដែលឃ្លាតពីយូដា ដរាបដល់ស៊ីឡូរបានមកដល់, **លោកុ.** ៤៩:១០ ។ ដំណឹងល្អនៃព្រះគ្រីស្ទ គឺជាព្រះចេស្ដានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់សាសន៍យូដាជាដើម, **រ៉ូម** ១:១៦ ។ ព្រះអម្ចាស់ទ្រង់នឹងលើកឡើងនូវព្យាការីម្នាក់ នៅក្នុងចំណោមពួក សាសន៍យូដា — គឺព្រះមែស៊ី, **១ នីហ្វៃ** ១០:៤ ។ នៅពេលណាដែលគម្ពីរនោះចេញពីមាត់នៃសាសន៍យូដា នោះគឺជារឿងច្បាស់ ហើយ បរិសុទ្ធ, **១ នីហ្វៃ** ១៤:២៣ ។ ពួកសាសន៍យូដានឹងត្រូវខ្ចាត់ខ្ចាយក្នុងចំណោមអស់ទាំងសាសន៍, **២ នីហ្វៃ** ២៥:១៥ ។ ពួកសាសន៍យូដា គឺជារាស្ត្រក្នុងសេចក្ដីសញ្ញារបស់យើង តាំងពីបុរាណមក, **២ នីហ្វៃ** ២៩:៤ ។ ពួកសាសន៍យូដា ដែលត្រូវខ្ចាត់ខ្ចាយ ក៏នឹងចាប់ ផ្ដើមជឿដល់ព្រះគ្រីស្ទ, **២ នីហ្វៃ** ៣០:៧ ។ ពួកសាសន៍យូដានឹងបដិសេធថ្ម ដែលពួកគេអាចសាងលើ, **យ៉ាកុប** ៤:១៤–១៦ ។ ពួកសាសន៍យូដានឹងមានសាក្សីផ្សេងទៀតថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទនោះហើយ, **មរមន** ៣:២០–២១ ។ ព្យាការីពីរនាក់នឹងត្រូវ បានលើកឡើងចំពោះសាសន៍យូដា នៅគ្រាចុងក្រោយបង្អស់, **គ. និង ស.** ៧៧:១៥ ។ ចូរហៅសាសន៍ទាំងអស់ គឺមុនដំបូង ដល់ពួក សាសន៍ដទៃ ហើយបន្ទាប់មក ដល់ពួកសាសន៍យូដា, **គ. និង ស.** ១៣៣:៨ ។ នៅគ្រានោះនឹងមានសេចក្ដីវេទនាជាខ្លាំងណាស់ដល់ ពួកសាសន៍យូដា, **យ.ស.** — **ម៉ាថាយ** ១:១៨ ។

**ពួកសាសន៍លេមិន** *សូមមើលផង* ពួកសាសន៍នីហ្វៃ, ព្រះគម្ពីរមរមន; លេមិន

ជាប្រជាជនមួយក្រុមនៅក្នុងព្រះគម្ពីរមរមន ពួកគេជាច្រើនត្រូវជាពូជពង្សលេមិន ដែលជាកូនប្រុសច្បងបង្អស់របស់លីហៃ ។ គេគិតថា នីហ្វៃ និងពូជពង្សលោក បានធ្វើខុសនឹងពួកគេ (ម៉ូសាយ ១០:១១–១៧) ។ ម្ល៉ោះហើយ ពួកគេបានបះបោរទាស់នឹងពួកសាសន៍នីហ្វៃ ហើយ

តែងតែមិនទទួលស្គាល់នូវការបង្រៀនទាំងឡាយអំពីដំណឹងល្អ ។ ប៉ុន្តែក្រោយពីកំណើតព្រះយេស៊ូវគ្រីស្ទបន្តិចមក នោះពួក សាសន៍លេមិនបានទទួលដំណឹងល្អ ហើយបានទៅជាសុចរិតជាងពួកសាសន៍នីហ្វៃទៅទៀត (ហេលេ. ៦:៣៤–៣៦) ។ ២០០ ឆ្នាំ ក្រោយពីព្រះគ្រីស្ទបានយាងមកឯទ្វីបអាមេរិក នោះទាំងពួកសាសន៍លេមិន និងពួកសាសន៍នីហ្វៃបានក្លាយទៅជាមនុស្សទុច្ចរិត ហើយ បានធ្វើសង្គ្រាមទាស់នឹងគ្នាទៅវិញទៅមក ។ ប្រមាណជាឆ្នាំ ៤០០ គ.ស. នោះពួកសាសន៍លេមិនបានបំផ្លាញសាសន៍នីហ្វៃចោល អស់រលីង ។

ពួកសាសន៍លេមិនបានឈ្នះលើពូជនីហ្វៃ, **១ នីហ្វៃ** ១២:១៩–២០ ។ ពួកសាសន៍លេមិន បានស្អប់ពួកសាសន៍នីហ្វៃ, **២ នីហ្វៃ** ៥:១៤ ។ ពួកសាសន៍លេមិននឹងទៅជារំពាត់ដល់ពួកសាសន៍នីហ្វៃ, **២ នីហ្វៃ** ៥:២៥ ។ ព្រះគម្ពីរមរមននឹងសាងដល់ពួកសាសន៍លេមិន នូវការ ចេះដឹងអំពីដូនតាគេទាំងប៉ុន្មាន និងអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ, **២ នីហ្វៃ** ៣០:៣–៦ (ទំព័រ ចំណងជើងនៃព្រះគម្ពីរមរមន) ។ ពួកសាសន៍លេមិនជាសំណល់នៃពួកសាសន៍យូដា, **គ. និង ស.** ១៩:២៧ ។ ពួកសាសន៍លេមិននឹងត្រូវផ្កាឡើងដូចជាកុឡាប មុនការ យាងមករបស់ព្រះអម្ចាស់, **គ. និង ស.** ៤៩:២៤ ។

**ពួកសាសន៍សាម៉ារី** *សូមមើលផង* សាម៉ារី

ជាប្រជាជននៅក្នុងព្រះគម្ពីរប៊ីប ដែលរស់នៅក្រុងសាម៉ារី បន្ទាប់ពីនគរអ៊ីស្រាអែលខាងជើង ត្រូវបានចាប់យកដោយពួកសាសន៍ អាសស៊ើរ ។ ពួកសាសន៍សាម៉ារី ជាមនុស្សមានសាច់ឈាមចម្រុះសាសន៍អ៊ីស្រាអែល និងជាសាសន៍ដទៃ ។ ឯសាសនារបស់គេ គឺជាសាសនាលាយឡំនឹងជំនឿកាន់តាមរបស់ពួកសាសន៍យូដា និងរបស់សាសន៍ដទៃ ។ ពាក្យប្រៀបប្រដូចអំពីសាសន៍សាម៉ារីដ៏ ល្អម្នាក់ នៅក្នុងគម្ពីរលូកា ១០:២៥–៣៧ បង្ហាញនូវការស្អប់ ដែលពួកសាសន៍យូដា មានឡើងចំពោះពួកសាសន៍សាម៉ារី មកពីពួកសាសន៍សាម៉ារី បានក្បត់ពីសាសនាអ៊ីស្រាអែល ។ ព្រះអម្ចាស់ទ្រង់បានបង្គាប់ឲ្យពួកសាវកទៅបង្រៀនដំណឹងល្អដល់ពួកសាសន៍សាម៉ារី (កិច្ចការ ១:៦–៨) ។ ភីលីពបានផ្សាយដំណឹងល្អនៃព្រះគ្រីស្ទ ប្រកបដោយជោគជ័យ ដល់ប្រជាជនសាម៉ារី ហើយបានសម្តែងអព្ភូតហេតុ ជាច្រើន នៅក្នុងចំណោមពួកគេ (កិច្ចការ ៨:៥–៣៩) ។

**ពួកសាសន៍អាម៉ាលេក** (ព្រះគម្ពីរសញ្ញាចាស់)

ជាពូជអំបូររបស់អារ៉ាបមួយ ដែលរស់នៅក្នុងទីរហោស្ថានប៉ារ៉ានៅចន្លោះ អារ៉ាបា និង មេឌីទែរ៉ាណេ ។ ពួកគេមានសង្គ្រាម មិនឈប់ឈរជាមួយនឹងពួកហេព្រើរ តាំងពីជំនាន់លោកម៉ូសេ (និក្ខ. ១៧:៨) ទៅជំនាន់ហ្លួងសូល និងហ្លួងដាវីឌ (១ សាំ. ១៥; ២៧:៨; ៣០; ២ សាំ. ៨:១១–១២) ។

**ពួកសាសន៍អាម៉ាលេកៃ** (ព្រះគម្ពីរមរមន)

ជាពួកសាសន៍នីហ្វៃមួយក្រុមដែលក្បត់សាសនា ជាពួកអ្នកដែលបាននាំពួកសាសន៍លេមិនទៅច្បាំងនឹងពួកសាសន៍នីហ្វៃ (អាលម៉ា ២១–២៤, ៤៣) ។

**ពួកសិស្សសាសន៍នីហ្វៃ** *សូមមើល* ពួកសិស្សសាសន៍នីហ្វៃបីនាក់

**ពួកសិស្សសាសន៍នីហ្វៃបីនាក់** *សូមមើលផង* ពួកសាសន៍នីហ្វៃ;
ពួកអ្នកដែលបានប្រែរូប, សិស្ស

ជាសិស្សសាសន៍នីហ្វៃបីនាក់ ដែលព្រះគ្រីស្ទបានរើស ដែលពោលដល់នៅក្នុងព្រះគម្ពីរមរមន ។

ព្រះអម្ចាស់ទ្រង់បានប្រទានឲ្យពួកសិស្សទាំងនេះ នូវព្រះពរដូចជាបានប្រទានឲ្យយ៉ូហាន ដ៏ជាទីស្រឡាញ់ — ដើម្បីឲ្យគេនៅលើផែនដីដើម្បីនាំព្រលឹងទាំងឡាយមករកព្រះគ្រីស្ទ រហូតដល់ព្រះអម្ចាស់ទ្រង់យាងមកម្តងទៀត ។ ពួកគេត្រូវបានផ្លាស់ប្រែរូប ដើម្បីកុំឲ្យគេមានការឈឺចាប់ ហើយមិនត្រូវស្លាប់ឡើយ (៣ នីហ្វៃ ២៨) ។

ព្រះគ្រីស្ទទ្រង់បានប្រទានដល់ពួកសិស្សបីនាក់តាមសេចក្តីប៉ងប្រាថ្នា ឲ្យនៅរស់រហូតដល់ទ្រង់យាងមកវិញ, **៣ នីហ្វៃ** ២៨:១–៩ ។ ពួកគេនឹងពុំត្រូវរងទុក្ខនូវការឈឺចាប់នៃសេចក្តីស្លាប់ ឬទុក្ខសោកណាឡើយ, **៣ នីហ្វៃ** ២៨:៧–៩ ។ ពួកគេនឹងបានសេចក្តីអំណរដ៏ពោរ ពេញ, **៣ នីហ្វៃ** ២៨:១០ ។ ពួកគេត្រូវបាននាំឡើងទៅលើស្ថានសួគ៌មួយភ្លែត, **៣ នីហ្វៃ** ២៨:១៣–១៧ ។ ពួកគេបានធ្វើការងារបំរើ ដល់ប្រជាជនហើយបានទាំទ្រសេចក្តីបៀតបៀន, **៣ នីហ្វៃ** ២៨:១៨–២៣ ។ ពួកគេបានធ្វើការងារបំរើដល់មរមន, **៣ នីហ្វៃ** ២៨:២៤–២៦ (មរមន ៨:១០–១១) ។ ពួកគេនឹងធ្វើការងារបំរើដល់សាសន៍ដទៃ ពួកសាសន៍យូដា ពួកពូជអំបូរដែលខ្ចាត់ខ្ចាយ និងអស់ទាំងសាសន៍, **៣ នីហ្វៃ** ២៨:២៧–២៩ ។ អារក្សសាតាំងពុំមានអំណាចលើពួកគេឡើយ, **៣ នីហ្វៃ** ២៨:៣៩ ។

**ពួកអ្នកដែលបានផ្លាស់ប្រែរូប**

ជាជនទាំងឡាយណា ដែលបានផ្លាស់ប្រែ ដើម្បីកុំឲ្យស្គាល់ការឈឺចាប់ ឬសេចក្តីស្លាប់ ដរាបដល់គេរស់ឡើងវិញ ទៅរកអមតភាព ។

ហេណុកបានដើរជាមួយនឹងព្រះ នោះគាត់មិននៅទៀតទេ ពីព្រោះព្រះទ្រង់បានទទួលយកគាត់ទៅ, **លោកុ.** ៥:២៤ (ហេព្រើរ ១១:៥; គ. និង ស. ១០៧:៤៨–៤៩) ។ លុះដល់សព្វថ្ងៃនេះ គ្មានអ្នកណាដឹងជាផ្នូរលោកម៉ូសេ នៅឯណាឡើយ, **ចោទិ.** ៣៤:៥–៦ (អាលម៉ា ៤៥:១៩) ។ អេលីយ៉ាក៏ឡើងទៅឯស្ថានសួគ៌ ដោយខ្យល់កួច, **២ពង្សាវ.** ២:១១ ។ បើសិនជាខ្ញុំចង់ឲ្យអ្នកនោះនៅ ទាល់តែខ្ញុំមក នោះតើអំពល់អ្វីដល់អ្នក ? **យ៉ូហាន** ២១:២២–២៣ (គ. និង ស. ៧:១–៣) ។ អ្នករាល់គ្នានឹងពុំត្រូវភ្លក់សេចក្តីស្លាប់ឡើយ, ៣ នីហ្វៃ ២៨:៧) ។ ដើម្បីកុំឲ្យគេភ្លក់សេចក្តីស្លាប់ នោះមានការប្រែប្រួលមួយ បាននាំមកដល់រូបកាយទាំងឡាយរបស់ពួកគេ, ៣ នីហ្វៃ ២៨:៣៨ (៤ នីហ្វៃ ១:១៤; មរមន ៨:១០–១១) ។ យ៉ូហាន ដ៏ជាទីស្រឡាញ់នឹងរស់នៅរហូតដល់ព្រះអម្ចាស់ទ្រង់យាងមក, **គ. និង ស.** ៧ ។ យើងបានយក

ក្រុងស៊ីយ៉ូននៃលោកហេណុក មកឯឋិវាររបស់យើង, **គ. និង ស.** ៣៨:៤ (ម៉ូសេ ៧:២១, ៣១, ៦៩) ។ ហេណុក និងបងប្អូនលោក គឺទីក្រុងមួយ ដែលត្រូវបានរក្សាទុក រហូតដល់ថ្ងៃនៃសេចក្ដីសុចរិតនឹងមកដល់, **គ. និង ស.** ៤៥:១២ ។ លោក អេលីយ៉ាត្រូវបានយកទៅស្ថានសួគ៌ ដោយមិនបានភ្លក់សេចក្ដីស្លាប់, **គ. និង ស.** ១១០:១៣ ។ ព្រះវិញ្ញាណ បរិសុទ្ធបានសណ្ឋិតលើមនុស្សជាច្រើន ហើយពួកគេត្រូវបាននាំ ឡើងទៅក្រុងស៊ីយ៉ូន, **ម៉ូសេ** ៧:២៧ ។

**ពួកអ្នកនិយមស្ដេច**

នៅក្នុងព្រះគម្ពីរមរមន គឺជាក្រុមមនុស្សដែលចង់រំលំរដ្ឋាភិបាលនៃពួក សាសន៍នីហ្វៃ (អាលម៉ា ៥១:១–៨) ។

**ពួកអ្នកមានសិទ្ធិអំណាចទូទៅ** *សូមមើល* គណៈប្រធានទីមួយ; ប៊ីស្សពដ៏ជាអធិបតី; ពួក ៧០ នាក់, សាវក

**ពេត្រុស**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពីដើមគេស្គាល់ពេត្រុសថាជាស៊ីម្មាន ឬស៊ីម៉ូន (២ ពេត្រុស ១:១), គឺជាអ្នកនេសាទពីស្រុកបេតសាយដា រស់នៅក្រុង កាពើណិមជាមួយនឹងប្រពន្ធលោក ។ ព្រះយេស៊ូវបានប្រោសឲ្យម្ដាយ នៃប្រពន្ធពេត្រុសបានជា (ម៉ាកុស ១:២៩–៣១) ។ ពេត្រុសត្រូវបាន ហៅជាមួយនឹងអនទ្រេ ជាប្អូនប្រុស ឲ្យធ្វើជាសិស្សនៃព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ៤:១៨–២២; ម៉ាកុស ១:១៦–១៨; លូកា ៥:១–១១) ។ ឈ្មោះលោកក្នុងភាសាអើរ៉ាមគឺ កេផាស មានន័យថា « អ្នកមើលឆុត » ឬ « ថ្ម » ដែលព្រះអម្ចាស់ទ្រង់បានដាក់ ឲ្យ (យ៉ូហាន ១:៤០–៤២; ក.យ.ស., យ៉ូហាន ១:៤២) ។ នៅក្នុងព្រះគម្ពីរ សញ្ញាថ្មី បានស្ដីអំពីការទន់ខ្សោយខាងសាច់ឈាមរបស់ ពេត្រុសខ្លះៗ តែក៏បានបង្ហាញថា លោកមានជ័យជំនះលើការទន់ខ្សោយទាំងនោះ ហើយត្រូវបានធ្វើឲ្យមានកម្លាំងមាំមួន ដោយសារ សេចក្ដីជំនឿដែល លោកមានដល់ព្រះយេស៊ូវគ្រីស្ទ ។

ពេត្រុសបានធ្វើបន្ទាល់ថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ហើយជាព្រះ រាជបុត្រានៃព្រះ (យ៉ូហាន ៦:៦៨–៦៩), ហើយព្រះអម្ចាស់ ទ្រង់បាន រើសតាំងលោកឲ្យកាន់កូនសោទាំងឡាយនៃនគរនៅលើផែនដី (ម៉ាថាយ ១៦:១៣–១៨) ។ នៅលើភ្នំនៃការប្រែរូប ពេត្រុសបាន ឃើញព្រះ អង្គសង្គ្រោះ ដែលបានប្រែរូប ព្រមទាំងលោកម៉ូសេ និងលោកអេលី យ៉ាផង (ម៉ាថាយ ១៧:១–៩) ។

ពេត្រុសជាមេសាវកនៅសម័យលោក ។ បន្ទាប់ពីការសុគត, ការ រស់ឡើងវិញ, និងការយាងឡើងនៃព្រះអង្គសង្គ្រោះ នោះលោកបាន ហៅសាសនាចក្រមកជុំគ្នា ហើយបានចាត់ចែងហៅសាវកម្នាក់ ឲ្យធ្វើ ជំនួស យូដាស-អ៊ីស្ការីយ៉ុត (កិច្ចការ ១:១៥–២៦) ។ ពេត្រុស និង យ៉ូហានបានប្រោសមនុស្សម្នាក់ ដែលខ្វិនពីកំណើតឲ្យជា (កិច្ចការ ៣:១–១៦) ហើយត្រូវបានលែងចេញពីគុកដោយអព្ភូតហេតុ (កិច្ចការ ៥:១១–២៩; ១២:១–១៩) ។ តាមរយៈការងារបំរើរបស់ពេត្រុស ទើបដំណឹងល្អ ត្រូវបានបើកផ្សាយជាលើកទីមួយដល់ពួក សាសន៍ដទៃ (កិច្ចការ ១០–១១) ។ នៅគ្រាចុងក្រោយ ពេត្រុស ជាមួយនឹងយ៉ាកុប និងយ៉ូហាន បានចុះមកពីស្ថានសួគ៌ ហើយបាន ប្រគល់បព្វជិតភាពមិលគីស្សាដែក និងកូនសោទាំងឡាយនៃបព្វជិតភាពនោះទៅលើ យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី (គ. និង ស. ២៧:១២–១៣; ១២៨:២០) ។

*សំបុត្រទី១របស់ពេត្រុស៖* គឺជាសំបុត្រទី ១ ដែលបានសរសេរពី « ក្រុងបាប៊ីឡូន » (ប្រហែលជាក្រុងរ៉ូម) ហើយបានផ្ញើ ទៅពួក បរិសុទ្ធ នៅកន្លែងដែលឥឡូវនេះហៅថា អាស៊ីតូច ក្រោយបន្តិចពីនេរ៉ូបានចាប់ផ្ដើមបៀតបៀនពួកគ្រីស្ទាន ។

ជំពូកទី ១ ស្ដីអំពីតំណែងរបស់ព្រះគ្រីស្ទ ដែលបាន តែងតាំងមុនផែនដី ឲ្យធ្វើជាព្រះដ៏ប្រោសលោះ ។ ជំពូកទី ២–៣ ពន្យល់ប្រាប់ថា ព្រះគ្រីស្ទ គឺជាថ្មជ្រុងយ៉ាងឯកនៃសាសនាចក្រ, ថាពួក បរិសុទ្ធកាន់នូវបព្វជិតភាពក្សត្រ, ហើយថា ព្រះគ្រីស្ទទ្រង់បានទៅផ្សាយ នៅឯ ស្ថានឃុំព្រលឹង ។ ជំពូកទី ៤–៥ ពន្យល់ប្រាប់អំពីមូលហេតុដែល ដំណឹងល្អត្រូវបានផ្សាយដល់ពួកមនុស្សស្លាប់ ហើយអំពីមូលហេតុដែល ពួកអែលឌើរត្រូវចិញ្ចឹមហ្វូងចៀម ។

*សំបុត្រទី២របស់ពេត្រុស៖* ជំពូកទី ១ ទូន្មានឲ្យពួកបរិសុទ្ធធ្វើការងារ និង ការរើសតាំងឲ្យបានពិតប្រាកដ ។ ជំពូកទី ២ ព្រមាន អំពីពួក គ្រូក្លែងក្លាយ ។ ជំពូកទី ៣ ស្ដីអំពីគ្រាចុងក្រោយ និងអំពីការយាងមក លើកទីពីរនៃព្រះគ្រីស្ទ ។

**ព្យាការី** *សូមមើលផង* ការព្យាករណ៍, ប្រធាន; ព្យាករ; វិវរណៈ; អ្នកមើលឆុត

ជាជនណាម្នាក់ដែលព្រះទ្រង់បានហៅ ហើយនិយាយជំនួសព្រះ ។ ជាទូតពីព្រះ ព្យាការីទទួលព្រះបញ្ញត្តិទាំងឡាយ, ការព្យាករណ៍ ទាំង ឡាយ, និងវិវរណៈទាំងឡាយពីព្រះ ។ ភារកិច្ចរបស់លោក គឺដើម្បីប្រាប់ មនុស្សលោកអំពីព្រះហឫទ័យ និងលក្ខណៈដ៏ពិតរបស់ព្រះ ហើយដើម្បី បង្ហាញអំពីអត្ថន័យនៃការទាក់ទងរបស់ទ្រង់ជាមួយនឹងពួកគេ ។ ព្យាការី ជំទាស់នឹងអំពើបាប ហើយទាយប្រាប់អំពីលទ្ធផល របស់វា ។ លោកគឺជា អ្នកផ្សាយអំពីសេចក្ដីសុចរិត ។ ជួនកាល ពួកព្យាការីអាចបានទទួល ការបំផុសគំនិតឲ្យទាយប្រាប់ពេលខាងមុខ សំរាប់ផលប្រយោជន៍ដល់ មនុស្សលោក ។ ប៉ុន្តែ ភារកិច្ចទីមួយរបស់លោក គឺដើម្បីធ្វើទីបន្ទាល់អំពី ព្រះគ្រីស្ទ ។ ប្រធាននៃ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធ ថ្ងៃចុងក្រោយ គឺជាព្យាការីរបស់ព្រះនៅលើផែនដីសព្វថ្ងៃនេះ ។ សមាជិកក្នុងគណៈ ប្រធានទីមួយ និងពួកសាវក ១២ នាក់ ត្រូវបាន គាំទ្រឲ្យធ្វើជាពួកព្យាការី ពួកអ្នកមើលឆុត និងពួកអ្នកទទួលវិវរណៈ ។

តើព្រះសុខចិត្តឲ្យបណ្ដាជនទាំងអស់របស់ព្រះអម្ចាស់ធ្វើជាព្យាការីឬអី, **ជនគ.** ១១:២៩ ។ បើមានហោរា នោះអញជាព្រះអម្ចាស់នឹងឲ្យ អ្នក នោះស្គាល់អញ ក្នុងការជាក់ស្ដែង, **ជនគ.** ១២:៦ ។ ព្រះអម្ចាស់ទ្រង់ បានធ្វើបន្ទាល់ទាស់នឹងពួកអ៊ីស្រាអែល ដោយសារគ្រប់ទាំង ពួកហោរា, **២ ពង្សាវ.** ១៧:១៣ (២ របា. ៣៦:១៥–១៦; យេរេ. ៧:២៥) ។ អញបានតាំងឯងជាហោរា ដល់សាសន៍ទាំងឡាយ, **យេរេ.** ១:៥, ៧ ។ ទ្រង់សំដែងគំនិតលាក់កំបាំងរបស់ទ្រង់ ដល់ពួកហោរា ជាអ្នកបំរើទ្រង់,

**អេម៉ុស** ៣:៧ ។ ទ្រង់មានបន្ទូលដោយមាត់ ពួកហោរាបរិសុទ្ធរបស់ទ្រង់, **លូកា** ១:៧០ (កិច្ចការ ៣:២១) ។ គ្រប់ទាំងពួកហោរាបានធ្វើបន្ទាល់អំពីព្រះគ្រីស្ទ, **កិច្ចការ** ១០:៤៣ ។ ព្រះទ្រង់បានតាំងពួកហោរាក្នុងសាសនាចក្រឡើង, **១ កូរិន.** ១២:២៨ (អេភេ. ៤:១១) ។ សាសនាចក្របានស្អាងឡើងលើជើង ជញ្ជាំងនៃពួកសាវក និងពួកហោរា, **អេភេ.** ២:១៩–២០ ។ ប្រជាជនបានបដិសេធពាក្យទាំងឡាយនៃពួកព្យាការី, **១ នីហ្វៃ** ៣:១៧–១៨ (២ នីហ្វៃ ២៦:៣) ។ រឿងគ្រប់យ៉ាងត្រូវបានធ្វើឲ្យពួកព្យាការីដឹង ដោយសារព្រះវិញ្ញាណ, **១ នីហ្វៃ** ២២:១–២ ។ ព្រះគ្រីស្ទទ្រង់បាន យាងមកឯពួកសាសន៍នីហ្វៃ ដើម្បីបំពេញនូវអ្វីៗទាំងអស់ ដែលទ្រង់មានបន្ទូលដោយមាត់របស់ពួកព្យាការីបរិសុទ្ធរបស់ទ្រង់, **៣ នីហ្វៃ** ១:១៣ (គ.ស. ៤២:៣៩) ។ អស់អ្នកណា ដែលមិនស្ដាប់តាមពាក្យទាំងឡាយរបស់ពួកព្យាការី នោះនឹងត្រូវកាត់ចេញ, **គ. និង ស.** ១:១៤ ។ អស់អ្នកណាដែលជឿដល់ពាក្យពេចន៍ទាំងឡាយរបស់ពួកព្យាការី នោះនឹងបានជីវិតដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ២០:២៦ ។ ពាក្យសំដីរបស់ព្យាការីនោះហើយ អ្នកនឹងបានទទួលហាក់ដូចជាបានមកពីព្រះឱស្ឋរបស់យើងផ្ទាល់, **គ. និង ស.** ២១:៤–៦ ។ វិវរណៈ និងព្រះបញ្ញត្តិទាំងឡាយសំរាប់សាសនាចក្រ គឺបានមកតាមរយៈជនតែម្នាក់ដែលបានតែងតាំងឡើង, **គ. និង ស.** ៤៣:១–៧ ។ ភារកិច្ច របស់ប្រធាន គឺត្រូវត្រួតត្រាលើសាសនាចក្រទាំងមូល ហើយត្រូវធ្វើដូចជាលោកម៉ូសេ គឺជាព្យាការី, **គ. និង ស.** ១០៧:៩១–៩២ ។ យើងខ្ញុំជឿដល់ពួកព្យាការ, **ម. នៃ ស.** ១:៦ ។

**ព្យាការីស្រី** *សូមមើលផង* ការព្យាករណ៍, ព្យាករ

ជាស្ត្រីដែលបានទទួលទីបន្ទាល់អំពីព្រះយេស៊ូវ ហើយគាប់ចិត្តនឹងវិញ្ញាណនៃវិវរណៈ ។ ព្យាការីស្រីមិនកាន់បព្វជិតភាព ឬកូនសោទាំងឡាយនៃបព្វជិតភាពទេ ។ ទោះជាមានស្ត្រីបន្តិចបន្តួចនៅក្នុងព្រះគម្ពីរដែលបានហៅថាព្យាការីស្រីក៏ដោយ គង់តែមានស្ត្រីជាច្រើន ដែលបានព្យាករ ដូចជានាងរេបេកា, នាងហាណា, នាងអេលីសាបិត និងនាងម៉ារាដែរ ។

នាងម៉ារាមត្រូវបានហៅថា ព្យាការីស្រី, **និក្ខ.** ១៥:២០ ។ នាងដេបូរ៉ាត្រូវបានហៅថា ព្យាការីស្រី, **ពួកចៅ.** ៤:៤ ។ នាងហ៊ុលដាត្រូវ បានហៅថា ព្យាការីស្រី, **២ ពង្សាវ.** ២២:១៤ (២ របា. ៣៤:២២) ។ នាងអាណាត្រូវបានហៅថា ព្យាការីស្រី, **លូកា** ២:៣៦ ។

**ព្រមាន, ពាក្យព្រមាន** *សូមមើលផង* ចាំយាម, ពួកអ្នកចាំយាម

ដើម្បីក្រាសប្រាប់ ឬហាមប្រាម ។ ពួកព្យាការី ពួកអ្នកដឹកនាំ និងពួកឪពុកម្ដាយព្រមាន ហើយបង្រៀនមនុស្សផ្សេងៗ ឲ្យគោរព តាមព្រះអម្ចាស់ និងតាមសេចក្ដីបង្រៀនទាំងឡាយរបស់ទ្រង់ ។

យ៉ាកុបបានព្រមានប្រជាជននីហ្វៃ ឲ្យទាស់នឹងអំពើបាបគ្រប់យ៉ាង, **យ៉ាកុប** ៣:១២ ។ សម្លេងនៃការព្រមាន នឹងត្រូវប្រាប់ដល់មនុស្សទាំងអស់, **គ. និង ស.** ១:៤ ។ ចូរបណ្ដោយឲ្យការផ្សាយរបស់អ្នក ទៅជាសម្លេងនៃការព្រមានចុះ, **គ. និង ស.** ៣៨:៤១ ។ នេះជាថ្ងៃនៃ ការព្រមាន, **គ. និង ស.** ៦៣:៥៨ ។ ជនណាម្នាក់ដែលបានព្រមាន នោះត្រូវព្រមានអ្នកជិតខាងរបស់ខ្លួន, **គ. និង ស.** ៨៨:៨១ ។ យើងបានព្រមានដល់អ្នក ហើយហាមអ្នកទុកជាមុនដោយប្រទានដល់អ្នកនូវពាក្យសំដីនៃប្រាជ្ញាវាងវៃនេះ, **គ. និង ស.** ៨៩:៤ ។

**ព្រលឹង** *សូមមើលផង* រូបកាយ; វិញ្ញាណ

ព្រះគម្ពីរស្ដីអំពីព្រលឹង បានបីយ៉ាង គឺ (១) ជារូបខាងវិញ្ញាណ ព្រមទាំងជីវិតមុន និងក្រោយផែនដី (អាលម៉ា ៤០:១១–១៤; អ័ប្រ. ៣:២៣); (២) ជាវិញ្ញាណ និងរូបកាយចូលរួមគ្នាជាមនុស្ស (អ័ប្រ. ៥:៧); និង (៣) ជាអ្នកដែលបានរស់ឡើងវិញ ដែលមិនចេះស្លាប់ គឺវិញ្ញាណ និងរូបកាយរបស់គេបាននៅជុំគ្នា ដោយមិនអាចបែកពីគ្នាបានឡើយ (អាលម៉ា ៤០:២៣; គ. និង ស. ៨៨:១៥–១៦) ។

ឈាមធ្វើឲ្យធួននឹងព្រលឹង, **លេវី.** ១៧:១១ ។ ទ្រង់កែព្រលឹងខ្ញុំឡើងវិញ, **ទំនុក.** ២៣:៣ ។ ត្រូវស្រឡាញ់ព្រះអម្ចាស់ ឲ្យអស់ពីព្រលឹង, **ម៉ាថាយ** ២២:៣៧ (ម៉ាកុស ១២:៣០) ។ អារក្សបានបញ្ឆោតព្រលឹងគេ, **២ នីហ្វៃ** ២៨:២១ ។ ចូរថ្វាយព្រលឹងទាំងមូលរបស់អ្នកជាដង្វាយថ្វាយទ្រង់, **អោមណៃ** ១:២៦ ។ ព្រះបន្ទូលចាប់ផ្ដើមពង្រីកព្រលឹងរបស់ខ្ញុំ, **អាលម៉ា** ៣២:២៨ ។ ព្រលឹងអ្នកនោះ នឹងពុំចេះស្រេកឃ្លានឡើយ, ៣ នីហ្វៃ ២០:៨ ។ នំបុ័ង និងទឹក នៃបុណ្យបុណ្យរំឭកត្រូវបានញែកចេញជាបរិសុទ្ធ ដល់ព្រលឹងនៃអស់អ្នកណា ដែលទទួលទាន, **មរ៉ូណៃ** ៤–៥ (គ. និង ស. ២០:៧៧–៧៩) ។ ពួកអ្នកធ្វើការនៅក្នុងនគរ នាំមកនូវសេចក្ដីសង្គ្រោះដល់ព្រលឹងខ្លួន តាមរយៈការបំរើរបស់គេ, **គ. និង ស.** ៤:២, ៤ ។ តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់, **គ. និង ស.** ១៨:១០ ។ អ្នករាល់គ្នា បានកើតមកក្នុងលោកិយដោយសារទឹក និងឈាម និងវិញ្ញាណ ហើយទើបបានក្លាយជាមានព្រលឹងរស់, **ម៉ូសេ** ៦:៥៩ ។

*តម្លៃនៃព្រលឹងទាំងឡាយ៖* មនុស្សគ្រប់រូប គឺជាកូនចៅវិញ្ញាណនៃព្រះ ។ ទ្រង់យកចិត្តទុកដាក់ ដល់កូនចៅទ្រង់គ្រប់គ្នា ហើយចាត់ថាកូនចៅទាំងអស់សុទ្ធតែសំខាន់ៗ ។ ពីព្រោះមកពីពួកគេជាកូនចៅទ្រង់ ទើបពួកគេអាចមានសិទ្ធិកើតទៅដូចទ្រង់បាន ។ ហេតុដូច្នេះហើយ ពួកគេមានតម្លៃណាស់ ។

មានសេចក្ដីអំណរ ដោយសារមនុស្សបាបតែ១នាក់ ដែលប្រែចិត្ត, **លូកា** ១៥:១០ ។ ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ, **យ៉ូហាន** ៣:១៦ ។ ពួកគេពុំអាចទ្រាំឲ្យព្រលឹងមនុស្សណាម្នាក់ត្រូវវិនាសឡើយ, **ម៉ូសាយ** ២៨:៣ ។ តើពុំមែនព្រលឹងដែលនៅក្នុងពេលនេះ មានតម្លៃចំពោះព្រះ ស្មើនឹងព្រលឹងដែលនៅពេលទ្រង់នឹងយាងមកទេឬអី ? **អាលម៉ា** ៣៩:១៧ ។ ការណ៍ដែលនឹងមានតម្លៃបំផុតចំពោះអ្នក គឺដើម្បីឲ្យអ្នកអាចនាំព្រលឹងទាំងឡាយមករកយើង, **គ. និង ស.** ១៥:៦ ។ ចូរចាំចុះថា តម្លៃនៃព្រលឹងទាំងឡាយ គឺមហិមាណាស់ ចំពោះព្រះនេត្រនៃព្រះ, **គ. និង ស.** ១៨:១០–១៥ ។ នេះហើយជាកិច្ចការ របស់យើង និងសិរីល្អរបស់យើង —

គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។

**ព្រហ្មចារី** *សូមមើលផង* នាងម៉ារា, មាតារបស់ព្រះយេស៊ូវ

ជាមនុស្សប្រុស ឬស្រី ដែលមានវ័យល្មមរៀបការ ហើយដែលមិនដែលបានរួមដំណេកជាមួយនឹងអ្នកណាឡើយ ។ នៅក្នុងព្រះគម្ពីរ ពាក្យថា ព្រហ្មចារី អាចធ្វើជាតំណាងមនុស្សណាម្នាក់ ដែលបរិសុទ្ធពីកាមគុណ (វិវរ. ១៤:៤) ។

នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រាមួយ, **អេសាយ** ៧:១៤ (ម៉ាថាយ ១:២៣; ២ នីហ្វៃ ១៧:១៤) ។ នគរស្ថានសួគ៌ គឺប្រៀបប្រដូចទៅនឹងស្រីព្រហ្មចារី ១០ នាក់, **ម៉ាថាយ** ២៥:១–១៣ ។ នៅភូមិណាសារ៉ែត ខ្ញុំបានឃើញនាងព្រហ្មចារីម្នាក់ ដែលជាមាតារបស់ព្រះរាជបុត្រានៃព្រះ, **១ នីហ្វៃ** ១១:១៣–១៨ ។ នាងម៉ារាជានាងព្រហ្មចារីម្នាក់ គឺជាប្រដាប់ដ៏ពិសេស ហើយជំរើសមួយ, **អាលម៉ា** ៧:១០ ។

**ព្រហ្មចារីភាព** *សូមមើលផង* កាមរាគ; កំផិត; ខាងកាមរាគ, គុណធម៌, អំពើសហាយស្មន់

ជាភាពបរិសុទ្ធខាងផ្លូវកាម នៃបុរស និងស្ត្រី ។

យ៉ូសែបមិនព្រមទៅដេកជាមួយនឹងប្រពន្ធប៉ូទីផារឡើយ, **លោកុ.** ៣៩:៧–២១ (គ. និង ស. ៤២:២៤; ៥៩:៦) ។ កុំឲ្យផិតគ្នាឲ្យសោះ, **និក្ខ.** ២០:១៤ ។ ស្ត្រីមានចិត្តបរិសុទ្ធ នោះជាមកុដដល់ប្តី, **សុភា.** ១២:៤ (សុភា. ៣១:១០) ។ តើមិនដឹងទេឬអីថា រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ, **១ កូរិន.** ៦:១៨–១៩ ។ ចូរធ្វើជាគំរូក្នុងសេចក្តីបរិសុទ្ធ, ១ ធីម៉ូ. ៤:១២ ។ គ្មានអ្វីដែលមិនស្អាតអាចអាស្រ័យនៅនឹងព្រះបានឡើយ, **១ នីហ្វៃ** ១០:២១ ។ ត្បិតយើងជាព្រះអម្ចាស់ ដ៏ជាព្រះ សព្វព្រះហឫទ័យចំពោះព្រហ្មចារីភាព នៃស្ត្រី, **យ៉ាកុប** ២:២៨ ។ អំពើបាបខាងផ្លូវកាម ជាអំពើដ៏គួរខ្ពើមឆ្អើម, **អាលម៉ា** ៣៩:១–១៣ ។ ព្រហ្មចារីភាព និងបរិសុទ្ធភាព គឺជា អ្វីដែលមានតម្លៃ និងវិសេសបំផុត លើអ្វីៗទាំងអស់, **មរ៉ូណៃ** ៩:៩ ។ យើងជឿលើការប្រព្រឹត្តិដោយបរិសុទ្ធ, **ម. នៃ ស.** ១:១៣ ។

**ព្រាប, ទីសំគាល់ជា** *សូមមើលផង* ព្រះវិញ្ញាណបរិសុទ្ធ

ជាទីសំគាល់មួយដែលរៀបចំទុកជាស្រេច ដែលធ្វើឲ្យយ៉ូហាន–បាទីស្ទ អាចស្គាល់ព្រះមែស៊ី (យ៉ូហាន ១:៣២–៣៤) ។ យ៉ូសែប ស៊្មីធ បានបង្រៀនថា ទីសំគាល់ជាព្រាបមានឡើង មុនកំណើតលោកិយមកម្លេះ ទុកជាទីបន្ទាល់ដល់ព្រះវិញ្ញាណបរិសុទ្ធ ។ ហេតុដូច្នេះហើយ អារក្សមិនអាចមកក្នុងទីសំគាល់ជាព្រាបបានឡើយ ។

ព្រះវិញ្ញាណនៃព្រះយាងចុះដូចជាសត្វព្រាប, **ម៉ាថាយ** ៣:១៦ ។ បន្ទាប់ពីព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក នោះព្រះវិញ្ញាណបរិសុទ្ធយាងចុះមក ក្នុងរូបជាព្រាប, **១ នីហ្វៃ** ១១:២៧ ។ ខ្ញុំ យ៉ូហាន ធ្វើទីបន្ទាល់ថា ហើយមើលន៏ ផ្ទៃមេឃត្រូវបានបើកចំហ ហើយព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកសណ្ឋិតលើទ្រង់ ក្នុងរូបជាព្រាប, **គ. និង ស.** ៩៣:១៥ ។

**ព្រៃពិសិដ្ឋ** *សូមមើល* ការនិមិត្តទីមួយ

**ព្រះ, ក្រុមព្រះ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ; ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ព្រះវិញ្ញាណបរិសុទ្ធ ព្រះអម្ចាស់

មានព្រះបីអង្គដាច់ឡែកពីគ្នា នៅក្នុងក្រុមព្រះ គឺៈ ព្រះ ជាព្រះវរបិតាដ៏អស់កល្បជានិច្ច និងព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ ហើយនិងព្រះវិញ្ញាណបរិសុទ្ធ ។ យើងរាល់គ្នាជឿដល់ព្រះនីមួយៗ (ម. នៃ ស. ១:១) ។ មកពីវិវរណៈនៅថ្ងៃចុងក្រោយ នោះយើងរាល់គ្នា ដឹងថា ព្រះវរបិតា និងព្រះរាជបុត្រាមានព្រះកាយជាសាច់ និងឆ្អឹងដែលចេះខូចខាត ហើយព្រះវិញ្ញាណបរិសុទ្ធជារូបវិញ្ញាណ គឺឥត មានសាច់ និងឆ្អឹងទេ (គ. និង ស. ១៣០:២២–២៣) ។ ព្រះទាំងបីអង្គនេះ រួមគ្នាតែមួយ ក្នុងការរួបរួមគ្នា និងភាពស្របគ្នា ដ៏ល្អឥត ខ្ចោះខាងគោលដៅ និងគោលលទ្ធិ (យ៉ូហាន ១៧:២១–២៣; ២ នីហ្វៃ ៣១:២១; ៣ នីហ្វៃ ១១:២៧, ៣៦) ។

*ព្រះដ៏ជាព្រះវរបិតាៈ* តាមធម្មតា គឺព្រះវរបិតា ឬព្រះអេឡូហិម ជាព្រះដែលថ្វាយព្រះនាមថា ព្រះ ។ ទ្រង់ត្រូវបានថ្វាយព្រះនាមថា ជាព្រះវរបិតា ពីព្រោះទ្រង់ជាបិតានៃវិញ្ញាណយើង (ម៉ាឡាគី ២:១០; ជនគ. ១៦:២២; ២៧:១៦; ម៉ាថាយ ៦:៩; អេភេ. ៤:៦; ហេព្រើរ ១២:៩) ។ ព្រះដ៏ជាព្រះវរបិតា គឺជាព្រះត្រួតត្រាដ៏មហិមានៃសាកលលោក ។ ទ្រង់មានគ្រប់ទាំងឥទ្ធិឫទ្ធិ (លោកុ. ១៨:១៤; អាលម៉ា ២៦:៣៥; គ. និង ស. ១៩:១–៣) ហើយជ្រាបគ្រប់ការណ៍ទាំងអស់ (ម៉ាថាយ ៦:៨; ២ នីហ្វៃ ២:២៤) ហើយនៅគ្រប់ទីកន្លែង ដោយសារព្រះវិញ្ញាណទ្រង់ (ទំនុក. ១៣៩:៧–១២; គ. និង ស. ៨៨:៧–១៣, ៤១) ។ មនុស្សលោកមានការទាក់ទងដ៏វិសេសជាមួយនឹងព្រះដែល ញែកមនុស្សចេញពីគ្រប់អ្វីៗទាំងអស់ដែលបានបង្កើតមក មនុស្សប្រុសស្រី គឺជាកូនចៅវិញ្ញាណនៃព្រះ (ទំនុក. ៨២:៦; ១ យ៉ូហាន ៣:១–៣; គ. និង ស. ២០:១៧–១៨) ។

មានបញ្ជីកត់តិចណាស់ អំពីព្រះដ៏ជាព្រះវរបិតា លេចមក ឬមានព្រះបន្ទូលនឹងមនុស្ស ។ បទគម្ពីរចែងថា ទ្រង់បានមានព្រះបន្ទូល នឹងលោកអ័ដាម និងនាងអេវ៉ា (ម៉ូសេ ៤:១៤–៣១) ហើយបានណែនាំឲ្យស្គាល់ព្រះយេស៊ូវជាច្រើនដង (ម៉ាថាយ ៣:១៧; ១៧:៥; យ៉ូហាន ១២:២៨–២៩; ៣ នីហ្វៃ ១១:៣–៧) ។ ទ្រង់បានលេចមកឯស្ទេផាន (កិច្ចការ ៧:៥៥–៥៦) ហើយមកឯយ៉ូសែប ស៊្មីធ (យ.ស. — ប្រវត្តិ ១:១៧) ។ ក្រោយមក ទ្រង់បានលេចឯយ៉ូសែប ស៊្មីធ ព្រមទាំង ស៊ីឌនី រិកដុន (គ. និង ស. ៧៦:២០, ២៣)។ ចំពោះអស់អ្នកណា ដែលស្រឡាញ់ព្រះ ហើយជំរះខ្លួននៅចំពោះទ្រង់ ជួនកាល ព្រះទ្រង់អនុញ្ញាតឲ្យមានឱកាសឃើញ ហើយដឹងក្នុងខ្លួនថា ទ្រង់ជាព្រះ (ម៉ាថាយ ៥:៨; ៣ នីហ្វៃ ១២:៨; គ. និង ស. ៧៦:១១៦–១១៨; ៩៣:១) ។

ព្រះអង្គនៃទូលបង្គំអើយ ឱព្រះអង្គនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់លះចោលទូលបង្គំ ? **ម៉ាកុស** ១៥:៣៤ ។ អ្នកទាំងនេះជាអ្នកបំរើ នៃ

ព្រះដ៏ខ្ពស់បំផុត, **កិច្ចការ** ១៦:១៧ ។ យើងជាពូជព្រះ, **កិច្ចការ** ១៧:២៨–២៩ ។ អ្នកត្រូវថ្វាយបុណ្យរំឭកទាំងឡាយរបស់អ្នក ដល់ព្រះដ៏ខ្ពស់បំផុត, **គ. និង ស.** ៥៩:១០–១២ ។ ហេណុកបានឃើញវិញ្ញាណទាំងប៉ុន្មានដែលព្រះទ្រង់បានបង្កើតមក, **ម៉ូសេ** ៦:៣៦ ។ មនុស្សនៃបរិសុទ្ធភាព គឺជាព្រះនាមរបស់ទ្រង់, **ម៉ូសេ** ៦:៥៧ ។

*ព្រះដ៏ជាព្រះរាជបុត្រា៖* ព្រះដែលយើងស្គាល់ថាជាព្រះយេហូវ៉ា គឺព្រះរាជបុត្រា ជាព្រះយេស៊ូវគ្រីស្ទ (អេសាយ ១២:២; ៤៣:១១; ៤៩:២៦; ១ កូរិន. ១០:១–៤; ១ ធីម៉ូ. ១:១; វិវរ. ១:៨; ២ នីហ្វៃ ២២:២) ។ ព្រះយេស៊ូវទ្រង់ធ្វើការនៅក្រោមការដឹកនាំនៃព្រះវរបិតា ហើយនៅក្នុងភាពស្របគ្នាទាំងស្រុងនឹងទ្រង់ ។ មនុស្សលោកទាំងអស់ជាប្អូនប្រុសស្រីរបស់ទ្រង់ ពីព្រោះទ្រង់ជាបុត្រច្បងក្នុងកូនចៅ វិញ្ញាណនៃព្រះអេឡូហិម ។ សេចក្តីយោងខ្លះខាងបទគម្ពីរ ពោលដល់ទ្រង់ ដោយពាក្យថា*ព្រះ* ។ ជាឧទាហរណ៍ បទគម្ពីរចែងថា « ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី » (លោកុ. ១:១) ប៉ុន្តែតាមពិត ព្រះយេស៊ូវ គឺជាព្រះដ៏បង្កបង្កើត នៅក្រោមការដឹកនាំនៃព្រះ ដ៏ជាព្រះវរបិតា (យ៉ូហាន ១:១–៣, ១០, ១៤; ហេព្រើរ ១:១–២) ។

ព្រះអម្ចាស់ ទ្រង់ហៅព្រះអង្គទ្រង់ថា យើងជាព្រះដ៏ជាព្រះ, **និក្ខ.** ៣:១៣–១៦ ។ យើងជាព្រះអម្ចាស់ (ព្រះយេហូវ៉ា) ហើយក្រៅពីយើង គ្មានអ្នកសង្គ្រោះណាទៀតឡើយ, **អេសាយ** ៤៣:១១ (អេសាយ ៤៥:២៣) ។ ខ្ញុំជាពន្លឺលោកិយ, **យ៉ូហាន** ៨:១២ ។ មុនដែលអ័ប្រាហាំកើតមក នោះមានខ្ញុំហើយ, **យ៉ូហាន** ៨:៥៨ ។ ព្រះអម្ចាស់ទ្រង់នឹងបង្រៀន នៅក្នុងចំណោមមនុស្ស ដោយនូវរោងឧបោសថ ឥដ្ឋ, **ម៉ូសាយ** ៣:៥–១០ ។ អ័ប៊ីណាដៃបានពន្យល់ប្រាប់ថាព្រះគ្រីស្ទ ជាព្រះវរបិតា ហើយជាព្រះរាជបុត្រា, **ម៉ូសាយ** ១៥:១–៤ (អេធើរ ៣:១៤) ។ ព្រះអម្ចាស់បានលេចមកឯបងរបស់យ៉ារេឌ, **អេធើរ** ៣ ។ ចូរស្តាប់តាមព្រះបន្ទូលនៃព្រះគ្រីស្ទ ដែលជាព្រះអម្ចាស់ និងព្រះ របស់អ្នកចុះ, **ម៉ូរ៉ូណៃ** ៨:៨ ។ ព្រះយេហូវ៉ាជាចៅក្រមនៃមនុស្សរស់ និងមនុស្សស្លាប់ផង, **ម៉ូរ៉ូណៃ** ១០:៣៤ ។ ព្រះយេស៊ូវទ្រង់បាន លេចមកឯយ៉ូសែប ស្ម៊ីធ និងស៊ីឌនី រីកដុន, **គ. និង ស.** ៧៦:២០, ២៣ ។ ព្រះអម្ចាស់យេហូវ៉ាបានលេចមកក្នុងព្រះវិហារខឺតឡង់, **គ. និង ស.** ១១០:១–៤ ។ ព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលនឹងអ័ប្រាហាំ, **អ័ប្រា.** ១:១៦–១៩ ។ ព្រះយេស៊ូវបានលេចមកឯយ៉ូសែប ស្ម៊ីធ, **យ.ស. — ប្រវត្តិ** ១:១៧ ។

*ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ៖* ព្រះវិញ្ញាណបរិសុទ្ធក៏ជាព្រះដែរ ហើយថ្វាយព្រះនាមថា ព្រះវិញ្ញាណបរិសុទ្ធ ជាព្រះវិញ្ញាណ ហើយជាព្រះវិញ្ញាណនៃព្រះ គឺនៅក្នុងចំណោមនាមដូចគ្នាទាំងឡាយ ។ ដោយជំនួយពីព្រះវិញ្ញាណបរិសុទ្ធ នោះមនុស្សអាចដឹងនូវ ព្រះហឫទ័យនៃព្រះដ៏ជាព្រះវរបិតា ហើយស្គាល់ថា ព្រះយេស៊ូវជាព្រះគ្រីស្ទ (១ កូរិន. ១២:៣) ។

ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់នឹងបង្រៀនសេចក្តីដែលអ្នករាល់គ្នាត្រូវនិយាយ, **លូកា** ១២:១២ ។ ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះដ៏ជាជំនួយ, **យ៉ូហាន** ១៤:២៦ (យ៉ូហាន ១៦:៧–១៥) ។ ព្រះយេស៊ូវបានបញ្ជាដល់ពួកសាវក ដោយនូវព្រះវិញ្ញាណបរិសុទ្ធ, **កិច្ចការ** ១:២ ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់អំពីព្រះ និងព្រះគ្រីស្ទ, **កិច្ចការ** ៥:២៩–៣២ (១ កូរិន. ១២:៣) ។ ព្រះវិញ្ញាណបរិសុទ្ធក៏ធ្វើបន្ទាល់ដល់ យើងដែរ, **ហេព្រើរ** ១០:១០–១៧ ។ ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នានឹងបានដឹង នូវសេចក្តីពិតនៃការណ៍ គ្រប់យ៉ាង, **ម៉ូរ៉ូណៃ** ១០:៥ ។ ព្រះវិញ្ញាណបរិសុទ្ធជាវិញ្ញាណនៃវិវរណៈ, **គ. និង ស.** ៨:២–៣ (គ. និង ស. ៦៨:៤) ។

**ព្រះគម្ពីរដែលបាត់** *សូមមើល* បទព្រះគម្ពីរ — ព្រះគម្ពីរដែលបាត់

**ព្រះគម្ពីរទាំងឡាយដែលបាត់** *សូមមើល* ព្រះគម្ពីរ — ព្រះគម្ពីរទាំងឡាយដែលបាត់

**ព្រះគម្ពីរនៃព្រះបញ្ញត្តិ***សូមមើលផង* គោលលទ្ធិ និងសេចក្តីសញ្ញា; វិវរណៈ

នៅឆ្នាំ ១៨៣៣ មានវិវរណៈមួយចំនួន ដែលព្យាការីយ៉ូសែប ស្ម៊ីធបានទទួល នោះត្រូវបានរៀបចំឡើង ដើម្បីបោះពុម្ពផ្សាយក្រោម ចំណងជើងថា A Book of Commandments for the Government of the Church of Christ (ព្រះគម្ពីរនៃព្រះបញ្ញត្តិសំរាប់ការ គ្រប់គ្រងសាសនាចក្រនៃព្រះគ្រីស្ទ) ។ ព្រះអម្ចាស់ ទ្រង់នៅតែបន្ត ការទាក់ទងនឹងពួកអ្នកបំរើរបស់ទ្រង់ ហើយការប្រជុំនៃវិវរណៈទាំងឡាយនោះត្រូវបានបោះពុម្ពផ្សាយពីរឆ្នាំ ក្រោយមកជាគោលលទ្ធិ និង សេចក្តីសញ្ញា ។

គ. និង ស. ១ គឺជាអារម្ភកថារបស់ព្រះអម្ចាស់ ចំពោះព្រះគម្ពីរនៃព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់, **គ. និង ស.** ១:៦ ។ ព្រះអម្ចាស់ទ្រង់បានឲ្យមនុស្សណាដែលមានប្រាជ្ញាបំផុត ឲ្យសរសេរឲ្យដូចវិវរណៈដ៏តូចបំផុតរបស់ទ្រង់ ដែលមាននៅក្នុងព្រះគម្ពីរនៃព្រះបញ្ញត្តិ, **គ. និង ស.** ៦៧:៤–៩ ។ ពួកអ្នកត្រួតត្រាត្រូវបានតែងតាំងឡើង ដើម្បីបោះពុម្ពវិវរណៈទាំងឡាយ, **គ. និង ស.** ៧០:១–៥ ។

**ព្រះគម្ពីរប៊ីប, ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.)** *សូមមើល* ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.)

**ព្រះគម្ពីរប៊ីប** *សូមមើលផង* កាណុង; បទព្រះគម្ពីរ, ព្រះគម្ពីរសញ្ញាចាស់; ព្រះគម្ពីរសញ្ញាថ្មី; យូដា — បន្ទះឈើនៃយូដា; អ័ប៉ូគ្រីផា; អេប្រាអិម — បន្ទះឈើនៃអេប្រាអិម ឬយ៉ូសែប

ជាការប្រជុំឯកសារនៃពួកហេព្រើរ និងពួកគ្រីស្ទាន ដែលមានវិវរណៈពីព្រះ ។ ពាក្យ*ប៊ីប* មានន័យថា « ព្រះគម្ពីរទាំងឡាយ » ។ ព្រះគម្ពីរប៊ីបជាស្នាដៃរបស់ពួកព្យាការី និងពួកអ្នកនិពន្ធជាច្រើន ដែលធ្វើតាមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ (២ ពេត្រុស ១:២១) ។

ព្រះគម្ពីរប៊ីបរបស់ពួកគ្រីស្ទានមានពីរភាគ គឺដែលគេស្គាល់ទូទៅថា

ព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ។ ព្រះគម្ពីរសញ្ញាចាស់មាន គម្ពីរទាំងឡាយ ដែលពួកសាសន៍យូដានៅស្រុកភីលីស្ទីនប្រើនៅសម័យព្រះអម្ចាស់ទ្រង់គង់នៅលើផែនដី ។ ព្រះគម្ពីរសញ្ញាថ្មីមាន ឯកសារនៅសម័យពួកសាវក ហើយរាប់ថា មានសន្តភាព និងសិទ្ធិអំណាច ដូចជាគម្ពីររបស់ពួកសាសន៍យូដាដែរ ។ គម្ពីរទាំងឡាយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺបានដកស្រង់យកមកពីអក្សរសាស្ត្រជាតិ ដែលមានតមកច្រើនសតវត្សមកហើយ ហើយបានសរសេរទុក ក្នុងភាសាហេព្រើរសឹងតែទាំងអស់ រីឯគម្ពីរទាំងឡាយនៅក្នុងព្រះគម្ពីរសញ្ញាថ្មីវិញ គឺជាឯកសារក្នុងជំនាន់តែមួយ ហើយភាគច្រើន បានសរសេរក្នុងភាសាក្រេក ។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យថា*សញ្ញា* ជាពាក្យតំណាងពាក្យហេព្រើរមួយ ដែលមានន័យថា « សេចក្ដីសញ្ញា » ។ សេចក្ដីសញ្ញាចាស់ គឺជាក្រិត្យវិន័យដែលបានប្រទានដល់លោកម៉ូសេ កាលពួកសាសន៍អ៊ីស្រាអែលមិនព្រមទទួលភាពពោរពេញនៃដំណឹងល្អ ដែលរាស្ត្រទ្រង់មានតាំងពីកំណើតមនុស្សលោកមកម្ល៉េះ ។ សេចក្ដីសញ្ញាថ្មី គឺជាដំណឹងល្អដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀន ។

នៅក្នុងព្រះគម្ពីរប៊ីបរបស់ពួកហេព្រើរ (ព្រះគម្ពីរសញ្ញាចាស់) គម្ពីរទាំងឡាយត្រូវបានចែកចេញជាបីក្រុម គឺ៖ ក្រិត្យវិន័យ, ពួកព្យាការី, និងឯកសារ ។ ព្រះគម្ពីរប៊ីបដែលពួកគ្រីស្ទានប្រើ នោះរៀបរាប់គម្ពីរទាំងឡាយតាមមុខប្រធាន ដូចជាខាងប្រវត្តិសាស្ត្រ ខាងកំណាព្យ និងខាងការព្យាករណ៍ ។

តាមធម្មតា គម្ពីរទាំងឡាយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី មានក្នុងលំដាប់នេះ គឺ៖ ដំណឹងល្អទាំងបួន និងកិច្ចការ; សំបុត្រប៉ុល; សំបុត្រទូទៅ របស់យាកុប យ៉ូហាន និងយូដាស; ហើយវិវរណៈយ៉ូហាន ។

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ឲ្យកិត្តិយស ហើយគោរពដល់ព្រះគម្ពីរប៊ីប ហើយក៏បញ្ជាក់ដែរថា ព្រះអម្ចាស់ទ្រង់នៅតែប្រទានវិវរណៈថែមទៀត តាមរយៈពួកព្យាការីទ្រង់នៅគ្រាចុងក្រោយ ដែលគាំទ្រ ហើយបញ្ជាក់ពីដំណើររឿងក្នុង ព្រះគម្ពីរប៊ីប អំពីទំនាក់ទំនងដែលព្រះទ្រង់មានជាមួយនឹងមនុស្សលោក ។

បន្ទះឈើនៃយូដា (ព្រះគម្ពីរប៊ីប) និងបន្ទះឈើនៃយ៉ូសែប (ព្រះគម្ពីរមរមន) នឹងក្លាយទៅតែមួយក្នុងព្រះហស្តរបស់ព្រះអម្ចាស់, **អេសេ.** ៣៧:១៥–២០ ។ សេចក្ដីពិតនៅក្នុងព្រះគម្ពីរប៊ីបនឹងបានតាំងឡើងដោយបទគម្ពីរនៅថ្ងៃចុងក្រោយ, **១ នីហ្វៃ** ១៣:៣៨–៤០ ។ ព្រះគម្ពីរប៊ីបនឹងរួមគ្នានឹងព្រះគម្ពីរមរមន ក្នុងការកំចាត់គោលលទ្ធិក្លែងក្លាយបង់, **២ នីហ្វៃ** ៣:១២ ។ ព្រះគម្ពីរ! ព្រះគម្ពីរ! យើងមាន ព្រះគម្ពីរមួយហើយ, **២ នីហ្វៃ** ២៩:៣–១០ ។ អស់អ្នកណាដែលជឿតាមព្រះគម្ពីរប៊ីប ក៏នឹងជឿតាមព្រះគម្ពីរមរមនដែរ, **មរមន** ៧:៨–១០ ។ ពួកអែលឌើរត្រូវបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន, **គ. និង ស.** ៤២:១២ ។ យើងខ្ញុំជឿថា ព្រះគម្ពីរប៊ីប គឺជាព្រះបន្ទូលនៃព្រះ បើសិនជាបានបកប្រែត្រឹមត្រូវ, **ម. នៃ ស.** ១:៨ ។

**ព្រះគម្ពីរមរមន** *សូមមើលផង* កាណុង; ជាព្យាការីសាសន៍នីហ្វៃ; បទគម្ពីរ; ផ្ទាំង; ផ្ទាំងមាស; ពួកសាក្សីអំពីព្រះគម្ពីរមរមន, មរមន, យ៉ូសែប ស៊្មីធ ជុញ្ញ័រ; អេប្រាអិម — បន្ទះឈើរបស់អេប្រាអិម ឬយ៉ូសែប

ជាព្រះគម្ពីរមួយក្នុងព្រះគម្ពីរទាំងបួនក្បាល ដែលបានទទួលស្គាល់ដោយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ គឺជាការសង្ខេប ដោយព្យាការីពីបុរាណម្នាក់ឈ្មោះ មរមន អំពីបញ្ជីទាំងឡាយរបស់បណ្ដាជនជំនាន់ដើមនៅទ្វីបអាមេរិក ។ គឺបាន សរសេរទុក ដើម្បីធ្វើបន្ទាល់ថា ព្រះយេស៊ូវជាព្រះគ្រីស្ទ ។ ស្ដីអំពីបញ្ជីនេះ ព្យាការីយ៉ូសែប ស៊្មីធ ដែលបានបកប្រែ ដោយអំណោយទាន និងព្រះចេស្ដានៃព្រះ ដោយមានប្រសាសន៍ថា៖ « ខ្ញុំបានប្រាប់បងប្អូនទាំងឡាយថា ព្រះគម្ពីរមរមន គឺជាគម្ពីរដ៏ត្រឹមត្រូវបំផុត ជាងគម្ពីរនានាទាំងអស់នៅលើផែនដីនេះ ហើយជាមូលដ្ឋាននៃសាសនារបស់យើង ហើយបុគ្គលម្នាក់ៗអាចចូលទៅជិតព្រះបាន ដោយ សារធ្វើតាមសិក្ខាបទទាំងឡាយនៃគម្ពីរនេះ ជាជាងគម្ពីរដទៃទាំងអស់ » (សូមមើលបុព្វកថា នៅខាងមុខព្រះគម្ពីរមរមន) ។

ព្រះគម្ពីរមរមន គឺជាបញ្ជីខាងសាសនានៃប្រជាជនបីក្រុម ដែលបានមកពីពិភពចាស់ មកកាន់ទ្វីបអាមេរិក ។ ពួកក្រុមទាំងនេះបានត្រូវដឹកនាំដោយពួកព្យាការី ដែលបានកត់ប្រវត្តិខាងសាសនា និងខាងការរស់នៅ ទុកនៅលើផ្ទាំងលោហធាតុ ។ ព្រះគម្ពីរមរមនកត់អំពី ទស្សនកិច្ចនៃព្រះយេស៊ូវគ្រីស្ទ កាលទ្រង់មកជួបប្រជាជននៅទ្វីបអាមេរិក បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ។ បន្ទាប់ពីទស្សនកិច្ច របស់ព្រះគ្រីស្ទ នោះមានរយៈពេល ២០០ ឆ្នាំ ដែលប្រកបទៅដោយសេចក្ដីសុខសាន្ត ។

ម៉ូរ៉ូណៃ ជាព្យាការី-ប្រវត្តិសាស្ត្រចុងក្រោយនៃពួកសាសន៍នីហ្វៃ លោកបានបិទបញ្ជីសង្ខេបនៃប្រជាជនទាំងនេះ ហើយបានលាក់ទុក នៅឆ្នាំ ៤២១ គ.ស. ។ នៅឆ្នាំ ១៨២៣ ម៉ូរ៉ូណៃដែលបានរស់ឡើងវិញ លោកបានមកជួបនឹងយ៉ូសែប ស៊្មីធ ហើយក្រោយមក បាន ប្រគល់បញ្ជីបុរាណ និងពិសិដ្ឋទាំងនេះដល់លោក ដើម្បីយកទៅបកប្រែ ហើយផ្សាយចេញដល់ពិភពលោក ទុកជាសក្ខីបទមួយទៀត អំពីព្រះយេស៊ូវគ្រីស្ទ ។

យ៉ូសែបជាមែកឈើមានផ្លែ ខ្នែងវានឹងវារពាក់លើកំផែង, **លោកុ.** ៤៩:២២–២៦ ។ សេចក្ដីពិតត្រូវបានពន្លកចេញពីដីមក, **ទំនុក.** ៨៥:១១ (មរមន ៨:១៦; ម៉ូសេ ៧:៦២) ។ ព្រះអម្ចាស់ ទ្រង់នឹងលើកទង់ជ័យសំរាប់ពួកសាសន៍ទាំងឡាយ ហើយនឹងហួចហៅពួកគេ, **អេសាយ** ៥:២៦ ។ សម្លេងនឹងឮចេញមកពីដី, **អេសាយ** ២៩:៤ (២ នីហ្វៃ ២៦:១៤–១៧) ។ ការជាក់ស្ដែងទាំងអស់បានត្រឡប់ដូចជាពាក្យក្នុងសៀវភៅ ដែលបិទត្រាហើយ, **អេសាយ** ២៩:១១ (អេសាយ ២៩:៩–១៨; ២ នីហ្វៃ ២៧:៦–២៦) ។ បន្ទះឈើនៃយ៉ូសែប និងនៃយូដានឹងបានទៅជាមួយ នៅក្នុងព្រះហស្តនៃព្រះអម្ចាស់, **អេសេ.** ៣៧:១៥–២០ ។ ខ្ញុំក៏មានចៀមឯទៀត ដែលមិនទាន់នៅក្នុងក្រោលនេះ, **យ៉ូហាន** ១០:១៦ (៣ នីហ្វៃ ១៥:១៦–២៤) ។ ព្រះគម្ពីរមរមន និងព្រះគម្ពីរប៊ីបនឹងដុះឡើងជុំគ្នា, **២ នីហ្វៃ** ៣:១២–២១ ។ ព្រះបន្ទូល នៃព្រះអម្ចាស់នឹងហួចហៅដល់ទៅចុងផែនដី, **២ នីហ្វៃ** ២៩:២ ។ ព្រះអម្ចាស់ទ្រង់បានធ្វើសេចក្ដីសញ្ញានឹងអេណុសថា នឹងនាំព្រះគម្ពីរ មរមនទៅដល់ពួកសាសន៍លេមិន, **អេណុស** ១:១៥–១៦ ។ ព្រះគម្ពីរមរមនបានត្រូវ

សរសេរឡើង ក្នុងគោលបំណង ដើម្បីឲ្យយើងជឿ ដល់ព្រះគម្ពីរប៊ីប, **មរមន** ៧:៩ ។ ព្រះគម្ពីរមរមននឹងឈរជាសាក្សីទាស់នឹងមនុស្សលោក, **អេធើរ** ៥:៤ ។ ចូរសូមដល់ព្រះ បើសិនជា ការណ៍ទាំងនេះមិនពិត, ម៉ូរ៉ូណៃ ១០:៤ ។ ព្រះគ្រីស្ទបានធ្វើបន្ទាល់ថា ព្រះគម្ពីរមរមនពិត, **គ. និង ស.** ១៧:៦ ។ ព្រះគម្ពីរមរមនមាន ភាពពោរពេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ២០:៩ (គ. និង ស. ២០:៨–១២; ៤២:១២) ។ យើងខ្ញុំក៏ជឿដែរថា ព្រះគម្ពីរមរមន ជាព្រះបន្ទូលនៃព្រះ, **ម. នៃ ស.** ១:៨ ។

**ព្រះគម្ពីរសញ្ញាចាស់** *សូមមើលផង* គម្ពីរ៥ច្បាប់; បទព្រះគម្ពីរ, ព្រះគម្ពីរប៊ីប

ជាការសរសេររបស់ពួកព្យាការីពីបុរាណ ដែលបានធ្វើនៅក្រោមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ហើយជាពួកអ្នកដែលបានធ្វើបន្ទាល់ ជាច្រើនសតវត្សមកហើយអំពីព្រះគ្រីស្ទ និងការងារបំរើរបស់ទ្រង់នៅពេលខាងមុខ ។ ព្រះគម្ពីរសញ្ញាចាស់ ក៏បានកត់នូវប្រវត្តិ អ័ប្រាហាំ និងពូជពង្សរបស់លោក ចាប់ផ្ដើមនឹងអ័ប្រាហាំ និងសេចក្ដីសញ្ញា ឬសញ្ញាដែលព្រះអម្ចាស់ទ្រង់បានធ្វើជាមួយនឹងអ័ប្រាហាំ និងពូជពង្សរបស់លោក ។

គម្ពីរ៥ច្បាប់ដំបូងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺបានសរសេរដោយលោកម៉ូសេ ។ គម្ពីរទាំងនេះ គឺ លោកុប្បត្តិ និក្ខមនំ លេវីវិន័យ ជនគណនា និង ចោទិយកថា ។ គម្ពីរលោកុប្បត្តិសំដៅចំពោះការបង្កបង្កើតនៃផែនដី, មនុស្សលោក, ភាសា, សាសន៍, និងដើម កំណើតនៃវង្សអ៊ីស្រាអែល ។

គម្ពីរខាងប្រវត្តិប្រាប់អំពីហេតុការណ៍នៃពួកអ៊ីស្រាអែល ។ គម្ពីរទាំងនេះគឺ យ៉ូស្វេ, ចៅហ្វាយ, នាងរស់, សាំយូអែលទី ១ និង ២, ពង្សាវតារក្សត្រទី ១ និង ២, របាក្សត្រទី ១ និង ២, អែសរ៉ា, នេហេមា, និងនាងអេសធើរ ។

គម្ពីរខាងកំណាព្យកត់នូវពាក្យដំបូន្មាន និងការនិពន្ធខ្លះៗ នៃពួកព្យាការី ។ គម្ពីរទាំងនេះគឺ យ៉ូប, ទំនុកដំកើង, សុភាសិត, សាស្ដា, បទចំរៀងសាឡូម៉ូន, និងបរិទេវ ។

ពួកព្យាការីបានព្រមានពួកសាសន៍អ៊ីស្រាអែល អំពីអំពើបាបរបស់ពួកគេ ហើយបានធ្វើបន្ទាល់អំពីព្រះពរ ដែលបានមកពីការគោរព ប្រតិបត្តិតាម ។ ពួកគេបានព្យាករអំពីការយាងមកនៃព្រះគ្រីស្ទ គឺជាអ្នកដែលនឹងធ្វើឲ្យធួននឹងបាបនៃអស់អ្នកណាដែលប្រែចិត្ត ទទួលពិធី បរិសុទ្ធ ហើយរស់នៅតាមដំណឹងល្អ ។ គម្ពីរទាំងឡាយនៃពួកព្យាការីគឺ អេសាយ, យេរេមា, អេសេគាល, ដានីយ៉ែល, ហូសេ, យ៉ូអែល, អេម៉ុស, អូបាឌា, យ៉ូណាស, មីកា, ណាហ៊ុម, ហាបាគុក, សេផានា, ហាកាយ, សាការី, និង ម៉ាឡាគី ។

ព្រះគម្ពីរសញ្ញាចាស់ភាគច្រើនត្រូវបានសរសេរក្នុងភាសាហេព្រើរ ។ មានការសរសេរបន្តិចបន្តួចដែរដែលជាភាសាអើរ៉ាម ជាភាសាប្រហែលគ្នា ។

**ព្រះគម្ពីរសញ្ញាថ្មី** *សូមមើលផង* បទព្រះគម្ពីរ, ព្រះគម្ពីរប៊ីប

ការប្រមូលផ្ដុំការសរសេរដ៏ប្រកបដោយការបំផុសគំនិត (ប្រភពដើមជាភាសាក្រេក) អំពីព្រះជន្ម និងការងារបំរើរបស់ព្រះយេស៊ូវគ្រីស្ទ អំពីពួកសាវក និងអំពីពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទផ្សេងៗទៀត ។ ព្រះគម្ពីរសញ្ញាថ្មី តាមធម្មតា ចែកចេញជា ដំណឹងល្អទាំងឡាយ កិច្ចការពួកសាវក សំបុត្រទាំងឡាយរបស់ប៉ុល សំបុត្រទូទៅ និងគម្ពីរវិវរណៈ ។

ដំណឹងល្អបួនភាគ — គម្ពីរម៉ាថាយ គម្ពីរម៉ាកុស គម្ពីរលូកា និងគម្ពីរយ៉ូហាន — គឺជាដំណើររឿងអំពីព្រះជន្មរបស់ព្រះគ្រីស្ទ ។ គម្ពីរ កិច្ចការកត់អំពីប្រវត្តិនៃសាសនាចក្រ និងពួកសាវក ជាពិសេសអំពីប្រវត្តិនៃដំណើររបស់ប៉ុលទៅផ្សាយសាសនា បន្ទាប់ពីព្រះគ្រីស្ទបានសុគតទៅ ។ សំបុត្ររបស់ប៉ុលផ្ដល់នូវការបង្គាប់ដល់ពួកអ្នកដឹកនាំក្នុងសាសនាចក្រ និងដល់សមាជិកទាំងឡាយ ។ ឯសំបុត្រឯទៀត គឺបានសរសេរដោយពួកសាវកផ្សេងៗ ហើយបានផ្ដល់នូវពាក្យទូន្មានបន្ថែមទៀតដល់ពួកបរិសុទ្ធដំបូង ។ គម្ពីរវិវរណៈ ដែលបាន សរសេរដោយសាវកយ៉ូហាន នោះភាគច្រើនមាននូវពាក្យព្យាករណ៍ ដែលទាក់ទងទៅនឹងគ្រាចុងក្រោយបង្អស់ ។

**ព្រះគុណ** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, ព្រះយេស៊ូវគ្រីស្ទ មានចិត្តមេត្តាករុណា, សេចក្ដីមេត្តាករុណា សេចក្ដីសង្គ្រោះ

ជាអំណាចផ្ដល់ពីព្រះ ដែលអនុញ្ញាតឲ្យមនុស្សប្រុសស្រីបានទទួលព្រះពរនៅក្នុងជីវិតនេះ ហើយបានទទួលជីវិតដ៏នៅអស់កល្បជានិច្ច និងភាពថ្កើងថ្កានឡើង បន្ទាប់ពីគេបានអនុវត្តសេចក្ដីជំនឿ ប្រែចិត្ត ហើយខិតខំអស់ពីសមត្ថភាព ដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ ជំនួយ និងកម្លាំងពីព្រះ បានត្រូវប្រទានឲ្យ ដោយសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់នៃព្រះ ។ មនុស្សលោកគ្រប់រូបត្រូវការ ព្រះគុណពីព្រះ ពីព្រោះការធ្លាក់នៃលោកអ័ដាម ហើយព្រមទាំងពីព្រោះសេចក្ដីទន់ខ្សោយរបស់មនុស្សដែរ ។

ព្រះគុណ និងសេចក្ដីពិត នោះបានមកដោយសារព្រះយេស៊ូវគ្រីស្ទ, **យ៉ូហាន** ១:១៧ ។ ដោយព្រះគុណនៃព្រះគ្រីស្ទ នោះយើងនឹងបានសង្គ្រោះ, **កិច្ចការ** ១៥:១១ (រ៉ូម ៣:២៣–២៤; គ. និង ស. ១៣៨:១៤) ។ យើងមានផ្លូវចូលក្នុងព្រះគុណ ដោយសេចក្ដីជំនឿ, **រ៉ូម** ៥:២ ។ ដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ, **អេភេ.** ២:៨ ។ ព្រះគុណនៃព្រះនាំសេចក្ដីសង្គ្រោះ មក, **ទីតុស** ២:១១ ។ ចូរមកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន, **ហេព្រើរ** ៤:១៦ ។ ព្រះទ្រង់ផ្ដល់ព្រះគុណដល់ពួករាបសា, **១ ពេត្រុស** ៥:៥ ។ គ្មានអ្នកណាអាចរស់នៅក្នុងវត្តមាននៃព្រះបានឡើយ លើកលែងតែដោយបុណ្យគុណ សេចក្ដីមេត្តាករុណា និងព្រះ គុណនៃព្រះមែស៊ីដ៏បរិសុទ្ធ, **២ នីហ្វៃ** ២:៨ ។ គឺមានតែដោយសារ និងតាមរយៈព្រះគុណនៃព្រះប៉ុណ្ណោះទើបមនុស្សបានសង្គ្រោះ, **២ នីហ្វៃ** ១០:២៤ ។ ពួកយើងរាល់គ្នានឹងបានសង្គ្រោះដោយសារព្រះគុណ បន្ទាប់ពីយើងធ្វើនូវអ្វីៗទាំងអស់, **២ នីហ្វៃ** ២៥:២៣ ។ គឺដោយសារព្រះគុណ ទើបយើងមានអំណាចធ្វើនូវកិច្ចការទាំងនេះបាន, **យ៉ាកុប** ៤:៧ ។ មនុស្សនឹងអាចបានសាងឡើងវិញពីគុណ មួយទៅគុណមួយ តាមកិច្ចការទាំងឡាយរបស់គេ, **ហេលេ.** ១២:២៤ ។ គុណរបស់យើងគ្រប់គ្រាន់សំរាប់អ្នកស្លូតបូត និងមនុស្សទាំងអស់ដែលបន្ទាបខ្លួន, **អេធើរ** ១២:២៦–២៧ ។ ម៉ូរ៉ូណៃបាន

អធិស្ឋានសូមឲ្យពួកសាសន៍ដទៃបានទទួលព្រះគុណ ដើម្បីឲ្យគេអាចមានសេចក្តីសប្បុរស, **អេធើរ** ១២:៣៦, ៤១ ។ ដោយសារព្រះគុណនៃព្រះដែលអ្នករាល់គ្នាបានល្អឥតខ្ចោះក្នុងព្រះគ្រីស្ទ, **ម៉ូរ៉ូណៃ** ១០:៣២–៣៣ ។ ព្រះយេស៊ូវទ្រង់បានព្រះគុណថែមលើព្រះគុណ, **គ. និង ស.** ៩៣:១២–១៣, ២០ ។

**ព្រះគ្រីស្ទ** *សូមមើល* ព្រះយេស៊ូវគ្រីស្ទ

**ព្រះដ៏គាំទ្រ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទជាព្រះដ៏គាំទ្ររបស់យើងចំពោះព្រះវរបិតា (ម៉ូរ៉ូណៃ ៧:២៨) ហើយអង្វរទ្រង់ជំនួសយើង ។

ព្រះយេស៊ូវគ្រីស្ទជាព្រះដ៏គាំទ្ររបស់យើងចំពោះព្រះវរបិតា, **១ យ៉ូហាន** ២:១ (គ. និង ស. ១១០:៤) ។ ព្រះយេស៊ូវនឹងអង្វរជំនួស មនុស្សគ្រប់រូប, **២ នីហ្វៃ** ២:៩ (ហេព្រើរ ៧:២៥) ។ ព្រះយេស៊ូវបានឈ្នះលើសេចក្តីស្លាប់ ដោយបានទទួលព្រះចេស្តារបស់ទ្រង់ សំរាប់អង្វរជំនួសកូនចៅមនុស្ស, **ម៉ូសាយ** ១៥:៨ ។ យើងជាព្រះដ៏គាំទ្រអ្នកនៅចំពោះព្រះវរបិតា, **គ. និង ស.** ២៩:៥ ។ ព្រះយេស៊ូវ គ្រីស្ទកំពុងតែអង្វរពីករណីអ្នករាល់គ្នា, **គ. និង ស.** ៤៥:៣–៥ ។

**ព្រះដ៏ជាជំនួយ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ, ព្រះវិញ្ញាណបរិសុទ្ធ

ព្រះគម្ពីរស្តីអំពីព្រះដ៏ជាជំនួយពីរអង្គ ។ ទីមួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ (យ៉ូហាន ១៤:២៦–២៧; ម៉ូរ៉ូណៃ ៨:២៦; គ. និង ស. ២១:៩; ៤២:១៧; ៩០:១១) ។ ព្រះដ៏ជាជំនួយទីពីរ គឺជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ (យ៉ូហាន ១៤:១៨, ២១, ២៣) ។ នៅពេលអ្នកណាមួយ ទទួលបានព្រះដ៏ជាជំនួយទីពីរ នោះព្រះយេស៊ូវគ្រីស្ទនឹងលេចមកឯអ្នកនោះម្តងម្កាល នឹងបើកសម្តែងឲ្យឃើញព្រះវរបិតា ហើយនឹង បង្រៀនអ្នកនោះប្រទល់មុខ (គ. និង ស. ១៣០:៣) ។

**ព្រះដ៏ជាជំនួយទីពីរ** *សូមមើល* ព្រះដ៏ជាជំនួយ

**ព្រះដ៏ជ្រាបសព្វសារពើ** *សូមមើលផង* ព្រះ, ក្រុមព្រះ

ជាលក្ខណៈនៃព្រះដែលមានគ្រប់ជំរិះទាំងអស់ (ម៉ាថាយ ៦:៨; ២ នីហ្វៃ ២:២៤) ។

**ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល** *សូមមើល* ព្រះយេស៊ូវគ្រីស្ទ

**ព្រះដ៏បង្កបង្កើត***សូមមើល* ការបង្កបង្កើត; បង្កើត, ព្រះយេស៊ូវគ្រីស្ទ

**ព្រះដ៏ប្រោសលោះ***សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ; ព្រះអង្គសង្គ្រោះ

ព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏ប្រោសលោះដ៏ធំនៃមនុស្សលោក ពីព្រោះទ្រង់បានបង់តម្លៃជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក ហើយ បានធ្វើឲ្យមាននូវដំណើររស់ឡើងវិញដល់មនុស្សទាំងអស់ តាមរយៈដង្វាយធួនរបស់ទ្រង់ ។

ខ្ញុំដឹងថា អ្នកដែលលោះខ្ញុំទ្រង់មានព្រះជន្មរស់នៅ, **យ៉ូប** ១៩:២៥ ។ ព្រះដ៏ប្រោសលោះឯង ជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា អញនឹងជួយឯង, **អេសាយ** ៤១:១៤ (អេសាយ ៤៣:១៤; ៤៨:១៧; ៥៤:៥; ៥៩:២០) ។ អញនេះ គឺព្រះអម្ចាស់ ជាព្រះអង្គសង្គ្រោះនៃឯង ហើយជាព្រះដ៏ប្រោសលោះឯង, **អេសាយ** ៤៩:២៦ (អេសាយ ៦០:១៦) ។ ត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះទ្រង់នឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប, **ម៉ាថាយ** ១:២១ ។ កូនមនុស្សបានមក ដើម្បីនឹងប្តូរជីវិតខ្លួន ទុកជា ថ្លៃលោះមនុស្ស ជាច្រើន, **ម៉ាថាយ** ២០:២៨ (១ ធីម៉ូ. ២:៥–៦) ។ ព្រះអម្ចាស់ទ្រង់ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់បានទតមើល ហើយប្រោសលោះ រាស្ត្រទ្រង់, **លូកា** ១:៦៨ ។ យើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត, **រ៉ូម** ៥:១០ ។ ព្រះយេស៊ូវគ្រីស្ទទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្តីទទឹងច្បាប់, **ទីតុស** ២:១៣–១៤ ។ ព្រះយេស៊ូវគ្រីស្ទបានលាងយើង ដោយព្រះលោហិតទ្រង់ឲ្យបានរួចពីបាប, **វិវ.** ១:៥ ។ សេចក្តីប្រោសលោះនឹងមក ដោយនិងតាមរយៈ ព្រះមែស៊ីដ៏បរិសុទ្ធ, **២ នីហ្វៃ** ២:៦–៧, ២៦ ។ ព្រះរាជបុត្រាបានយកដាក់លើអង្គទ្រង់នូវអំពើទុច្ចរិត និងអំពើរំលង របស់មនុស្សទាំង ឡាយ បានប្រោសលោះគេ ហើយក៏បានបំពេញការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌, **ម៉ូសាយ** ១៥:៦–៩, ១៨–២៧ ។ ព្រះគ្រីស្ទទ្រង់បានយាងមកប្រោសលោះអស់អ្នកណា ដែលនឹងទទួលបុណ្យជ្រមុជទឹកចំពោះការប្រែចិត្ត, **អាលម៉ា** ៩:២៦–២៧ ។ ព្រះអង្គនឹង យាងមកពិភពលោក ដើម្បីមកប្រោសលោះរាស្ត្ររបស់ទ្រង់, **អាលម៉ា** ១១:៤០–៤១ ។ សេចក្តីប្រោស លោះមានមកតាមរយៈការប្រែចិត្ត, **អាលម៉ា** ៤២:១៣–២៦ ។ ព្រះយេស៊ូវគ្រីស្ទទ្រង់បានយាងមកប្រោសលោះមនុស្សលោក, **ហេលេ.** ៥:៩–១២ ។ ព្រះគ្រីស្ទ បានប្រោសលោះមនុស្សលោកឲ្យបានរួចពីសេចក្តីស្លាប់ខាងសាច់ឈាម និងខាងវិញ្ញាណ, **ហេលេ.** ១៤:១២–១៧ ។ សេចក្តីប្រោសលោះមានមកតាមរយៈព្រះគ្រីស្ទ, ៣ នីហ្វៃ ៩:១៧ ។ យើងគឺជាតួអង្គដែលត្រូវបានរៀបចំ ចាប់តាំងពីកំណើតលោកិយមក ដើម្បីប្រោសលោះរាស្ត្រយើង, **អេធើរ** ៣:១៤ ។ ព្រះអម្ចាស់ដ៏ជាព្រះប្រោសលោះរបស់អ្នក ទ្រង់បានរងសេចក្តី ស្លាប់ នៅក្នុងសាច់ឈាម, **គ. និង ស.** ១៨:១១ ។ ព្រះគ្រីស្ទទ្រង់បានរងទុក្ខជំនួសមនុស្សទាំងអស់ បើសិនជាពួកគេប្រែចិត្ត, **គ. និង ស.** ១៩:១, ១៦–២០ ។ កូនក្មេងតូចៗ ត្រូវបានប្រោសលោះ តាមរយៈបុត្រាបង្កើតតែមួយ, **គ. និង ស.** ២៩:៤៦ ។ យើងបានចាត់ព្រះ រាជបុត្រាបង្កើតតែមួយរបស់យើង ឲ្យមក ឯពិភពលោក សំរាប់សេចក្តីប្រោសលោះពិភពលោក, **គ. និង ស.** ៤៩:៥ ។ ព្រះគ្រីស្ទទ្រង់ជា ពន្លឺ និងជាព្រះដ៏ប្រោសលោះនៃពិភពលោក, **គ. និង ស.** ៩៣:៨–៩ ។ យ៉ូសែប អែហ្វ. ស្ម៊ីធ បានឃើញក្នុងការនិមិត្តមួយ អំពីការប្រោស លោះដល់មនុស្សស្លាប់, **គ. និង ស.** ១៣៨ ។ យើងខ្ញុំជឿថា តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបាន សង្គ្រោះ, **ម. នៃ ស.** ១:៣ ។

**ព្រះដ៏ប្រោសឲ្យរួច***សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទជាព្រះជួយសង្គ្រោះមនុស្សលោក ពីព្រោះទ្រង់

ជួយមនុស្សទាំងអស់ឲ្យរួចផុតពីសេវកភាពនៃសេចក្ដីស្លាប់ និងពួកអ្នកដែលប្រែចិត្តឲ្យរួចផុតពីទោសនៃអំពើបាប ។

ព្រះអម្ចាស់ទ្រង់ជាថ្មដា ហើយជាអ្នកដ៏ប្រោសទូលបង្គំឲ្យរួច, **២ សាំយូ.** ២២:២ (ទំនុក. ១៨:២; ១៤៤:២) ។ ព្រះអង្គជាជំនួយ ហើយជាអ្នកដ៏ប្រោសទូលបង្គំឲ្យរួច, **ទំនុក.** ៤០:១៧ (ទំនុក. ៧០:៥) ។ ព្រះដ៏ប្រោសឲ្យរួច ទ្រង់នឹងចេញពីស៊ីយ៉ូនមក, **រ៉ូម** ១១:២៦ ។ ពួកបរិសុទ្ធទទួលស្គាល់ព្រះរាជបុត្រានៃព្រះ ជាព្រះដ៏ប្រោសលោះ ហើយជាព្រះដ៏ប្រោសគេឲ្យរួច, **គ. និង ស.** ១៣៨:២៣ ។

**ព្រះដ៏មានគ្រប់ព្រះចេស្ដា** *សូមមើលផង* ក្រុមព្រះ ព្រះ

ជាលក្ខណៈនៃព្រះដែលមានគ្រប់ព្រះចេស្ដាទាំងអស់ (លោកុ. ១៨:១៤; អាលម៉ា ២៦:៣៥; គ. និង ស. ១៩:១–៣) ។

**ព្រះដ៏សណ្ឋិតនៅគ្រប់ទិសទី** *សូមមើលផង* ក្រុមព្រះ ព្រះ

ជាអំណាចព្រះដែលមានក្នុងការសណ្ឋិតនៅគ្រប់ទិសទី តាមរយៈព្រះវិញ្ញាណរបស់ទ្រង់ (ទំនុក. ១៣៩:៧–១២; គ. និង ស. ៨៨:៧–១៣, ៤១) ។

**ព្រះដែលបានចាក់ប្រេងតាំង** *សូមមើលផង* ព្រះមែស៊ី
ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវត្រូវបានថ្វាយព្រះនាមថា ព្រះគ្រីស្ទ (ជាពាក្យក្រេក) ឬជាព្រះមែស៊ី (ជាពាក្យអារ៉ាប់) ។ ពាក្យទាំងពីរនេះមានន័យថា ព្រះ « ដែលបានចាក់ប្រេងតាំង » ។ ទ្រង់ជាអ្នកដែលព្រះវរបិតាបាន *ចាក់ប្រេងតាំង* ដើម្បីឲ្យធ្វើជាតំណាងព្រះវរបិតាផ្ទាល់ ចំពោះគ្រប់ការណ៍ទាំងអស់ ដែលទាក់ទងទៅនឹងសេចក្ដីសង្គ្រោះនៃមនុស្សលោក ។

ព្រះអម្ចាស់ទ្រង់បានចាក់ប្រេងតាំងខ្ញុំ, **អេសាយ** ៦១:១–៣ ។ ទ្រង់បានចាក់ប្រេងតាំងមនុស្សឲ្យផ្សាយដំណឹងល្អ, **លូកា** ៤:១៦–២២ ។ ព្រះយេស៊ូវត្រូវបានចាក់ប្រេងតាំងដោយព្រះដ៏ជាព្រះវរបិតា, **កិច្ចការ** ៤:២៧ ។ ព្រះទ្រង់បានចាក់ប្រេងតាំងព្រះយេស៊ូវពីស្រុក ណាសារ៉ែត, **កិច្ចការ** ១០:៣៨ ។

**ព្រះដំណាក់នៃព្រះអម្ចាស់** *សូមមើល* ដំណាក់នៃព្រះអម្ចាស់
ព្រះវិហារ

**ព្រះបញ្ញត្តិទាំងឡាយនៃព្រះ** *សូមមើលផង* ការគោរពតាម, ក្រិត្យវិន័យ; គោរពតាម; ដែលគោរពតាម, ព្រះបញ្ញត្តិ ១០ ប្រការ; ព្រះបន្ទូលនៃព្រះ, អំពើបាប

ជាក្រិត្យវិន័យ ហើយជាការតម្រូវដែលព្រះប្រទានដល់មនុស្សលោកជារៀងខ្លួន ឬជាក្រុមៗ ។ ការកាន់តាមព្រះបញ្ញត្តិនឹងនាំមកនូវ ព្រះពរពីព្រះអម្ចាស់ ដល់អ្នកដែលគោរពតាម (គ. និង ស. ១៣០:២១) ។

លោកណូអេធ្វើតាមគ្រប់ទាំងសេចក្ដីដែលព្រះបានបង្គាប់គាត់, **លោកុ.** ៦:២២ ។ ចូរដើរតាមច្បាប់ ហើយកាន់តាមបញ្ញត្តិយើងចុះ, **លេវី.** ២៦:៣ ។ ចូររក្សាបណ្ដាំរបស់យើង ដើម្បីឲ្យបានរស់នៅ, **សុភា.** ៤:៤ (សុភា. ៧:២) ។ បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់ តាមបញ្ញត្តិរបស់ខ្ញុំចុះ, **យ៉ូហាន** ១៤:១៥ (គ. និង ស. ៤២:២៩) ។ ទោះបើយើងសូមអ្វីពីទ្រង់ក៏ដោយ គង់តែនឹងបានសំរេច ពីព្រោះ យើងកាន់តាមព្រះបញ្ញត្តិទ្រង់, **១ យ៉ូហាន** ៣:២២ ។ ព្រះបញ្ញត្តិទ្រង់មិនមែនជាបន្ទុកដ៏ធ្ងន់ទេ, **១ យ៉ូហាន** ៥:៣ ។ ចូរកុំបែរចេញពី ការកាន់តាមបញ្ញត្តិទាំងឡាយឡើយ, **១ នីហ្វៃ** ២:១០ ។ ព្រះអម្ចាស់ទ្រង់មិនចេញបញ្ជាទាំងឡាយឡើយ លើកលែងតែទ្រង់នឹងរៀប ចំផ្លូវឲ្យ, **១ នីហ្វៃ** ៣:៧ ។ ខ្ញុំត្រូវតែធ្វើតាមព្រះបញ្ញត្តិដ៏តឹងរឹងនៃព្រះ, **យ៉ាកុប** ២:១០ ។ ដរាបណាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំង ឡាយរបស់យើង នោះអ្នករាល់គ្នានឹងបានចំរើននៅលើដែនដី, **យ៉ារ៉ុម** ១:៩ (អាលម៉ា ៩:១៣; ៥០:២០) ។ ចូររៀននៅក្នុងយុវវ័យ របស់កូនឲ្យចេះ កាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ, **អាលម៉ា** ៣៧:៣៥ ។ ព្រះបញ្ញត្តិទាំងប៉ុន្មាននេះសុទ្ធតែមកពីយើង, **គ. និង ស.** ១:២៤ ។ ចូរស្ទង់មើលព្រះបញ្ញត្តិទាំងនេះចុះ, **គ. និង ស.** ១:៣៧ ។ អស់អ្នកណាដែលមិនកាន់តាមបញ្ញត្តិទាំងឡាយទេ អ្នកនោះមិន អាចបានសង្គ្រោះឡើយ, **គ. និង ស.** ១៨:៤៦ (គ. និង ស. ២៥:១៥; ៥៦:២) ។ បញ្ញត្តិរបស់យើងទាំងឡាយ ជារបស់ខាងវិញ្ញាណ; បញ្ញត្តិទាំង នោះ ពុំមែនជារបស់ខាងធម្មជាតិ ឬខាងសាច់ឈាមទេ, **គ. និង ស.** ២៩:៣៥ ។ ព្រះបញ្ញត្តិទាំងឡាយបានត្រូវប្រទានមក ប្រយោជន៍ ឲ្យយើងអាចយល់ពីព្រះហឫទ័យរបស់ព្រះអម្ចាស់, **គ. និង ស.** ៨២:៨ ។ ខ្ញុំមិនដឹងទេ លើកលែងតែព្រះអម្ចាស់ទ្រង់បញ្ជាខ្ញុំ ប៉ុណ្ណោះ, **ម៉ូសេ** ៥:៦ ។ ព្រះអម្ចាស់ទ្រង់នឹងសាកល្បងពួកគេមើល បើសិនជាពួកគេនឹងប្រព្រឹត្តនូវអ្វីៗគ្រប់យ៉ាង ដែលទ្រង់បញ្ជាដល់ ពួកគេ, **អ័ប្រា.** ៣:២៥ ។

**ព្រះបញ្ញត្តិ ១០ ប្រការ** *សូមមើលផង* ព្រះបញ្ញត្តិទាំងឡាយនៃព្រះ
ម៉ូសេ

ជាក្រិត្យវិន័យ ១០ ប្រការ ដែលព្រះទ្រង់បានប្រទានឲ្យមកតាមរយៈព្យាការីម៉ូសេ ដើម្បីឲ្យគ្រប់គ្រងចរិយាធម៌ ។

ពួកហេព្រើរឲ្យឈ្មោះដល់ព្រះបញ្ញត្តិទាំងនេះថា « ព្រះបន្ទូល ១០ ប្រការ » ។ ក៏ហៅថាសេចក្ដីសញ្ញា (ចោទិ. ៩:៩) ឬក៏សេចក្ដីបន្ទាល់ (និក្ខ. ២៥:២១; ៣២:១៥) ។ ការដែលព្រះប្រទានព្រះបញ្ញត្តិ ១០ ប្រការទៅម៉ូសេ ហើយតាមរយៈលោកទៅដល់ពួកសាសន៍ អ៊ីស្រាអែលនោះត្រូវបានពណ៌នាប្រាប់ ក្នុង និក្ខ. ១៩:៩–២០:២៣; ៣២:១៥–១៩; ៣៤:១ ។ ព្រះបញ្ញត្តិទាំងនោះត្រូវបានឆ្លាក់នៅ លើបន្ទះថ្មពីរដែលដាក់ទុកនៅក្នុងហិប ដោយហេតុនោះ ទើបហិបនោះត្រូវបានហៅថា ហិបនៃសេចក្ដីសញ្ញា (ជនគ. ១០:៣៣) ។ ដោយស្រង់ចេញពី ចោទិ. ៦:៤–៥ និង លេវី. ១៩:១៨ នោះព្រះអម្ចាស់ទ្រង់បានសរុបព្រះបញ្ញត្តិ ១០ ប្រការទៅជា « ព្រះបញ្ញត្តិយ៉ាងធំ ពីរប្រការ » (ម៉ាថាយ ២២:៣៧–៣៩) ។

ព្រះបញ្ញត្តិ ១០ ប្រការបានត្រូវពោលដល់ឡើងវិញ នៅក្នុងវិវរណៈនៅថ្ងៃចុងក្រោយ (ម៉ូសាយ ១២:៣២–៣៧; ១៣:១២–២៤; គ. និង ស. ៤២:១៨–២៨; ៥៩:៥–១៣; ក.យ.ស., និក្ខ. ៣៤:១–២) ។

**ព្រះបន្ទូល** *សូមមើល* ព្រះយេស៊ូវគ្រីស្ទ — ព្រះគ្រីស្ទមានព្រះជន្មរស់នៅមុនផែនដី

**ព្រះបន្ទូលនៃព្រះ** *សូមមើលផង* បទព្រះគម្ពីរ ព្រះបញ្ញត្តិទាំងឡាយនៃព្រះ វិវរណៈ

ជាការបង្គាប់ ជាបញ្ញត្តិទាំងឡាយ ឬជាសារមកពីព្រះ ។ ពួកកូនចៅរបស់ព្រះ អាចបានព្រះបន្ទូលរបស់ទ្រង់ផ្ទាល់ ដោយវិវរណៈ តាមរយៈព្រះវិញ្ញាណ ឬពីពួកអ្នកបំរើដ៏ជំរើសរបស់ទ្រង់ (គ. និង ស. ១:៣៨) ។

មនុស្សរស់ ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋនៃព្រះអម្ចាស់, **ចោទិ.** ៨:៣ (ម៉ាថាយ ៤:៤; គ. និង ស. ៨៤:៤៣–៤៤) ។ ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ, **ទំនុក.** ១១៩:១០៥ ។ គេបានពេញ ជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា រួចក៏ផ្សាយព្រះបន្ទូលដោយចិត្តក្លាហាន, **កិច្ចការ** ៤:៣១–៣៣ ។ ដំបងដែក គឺជាព្រះបន្ទូលនៃព្រះ ដែលនាំទៅឯដើមជីវិត, **១ នីហ្វៃ** ១១:២៥ (១ នីហ្វៃ ១៥:២៣–២៥) ។ បងរាល់គ្នាមានចិត្តរឹងរូស ទើបមិនអាចចាប់អារម្មណ៍ពី ព្រះបន្ទូលរបស់ព្រះអង្គ, **១ នីហ្វៃ** ១៧:៤៥–៤៦ ។ វេទនាដល់អ្នកណា ដែលមិនទទួលស្គាល់ព្រះបន្ទូលនៃព្រះ, **២ នីហ្វៃ** ២៧:១៤ (២ នីហ្វៃ ២៨:២៩; អេធើរ ៤:៨) ។ ចូរខិតខំជឿនទៅមុខ ដោយទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ, **២ នីហ្វៃ** ៣១:២០ (២ នីហ្វៃ ៣២:៣) ។ ដោយ សារការតតធំនឿរបស់ពួកគេ នោះពួកគេពុំអាចយល់នូវព្រះបន្ទូលនៃព្រះបានឡើយ, **ម៉ូសាយ** ២៦:៣ (អាលម៉ា ១២:១០) ។ ពួកគេ បានពិចារណាមើលបទព្រះគម្ពីរ យ៉ាងព្យាយាម ដើម្បីឲ្យគេអាចស្គាល់ព្រះបន្ទូលនៃព្រះ, **អាលម៉ា** ១៧:២ ។ ត្រូវពិសោធគុណធម៌នៃ ព្រះបន្ទូលនៃព្រះ, **អាលម៉ា** ៣១:៥ ។ អាលម៉ាបានប្រៀបធៀបព្រះបន្ទូលនៃព្រះ ទៅនឹងគ្រាប់ពូជមួយ, **អាលម៉ា** ៣២:២៨–៤៣ ។ អ្វីក៏ដោយដែលពួកគេនឹងនិយាយកាលណាបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាព្រះបន្ទូលនៃ ព្រះអម្ចាស់, **គ. និង ស.** ៦៨:៤ ។ ត្រូវរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមក, **គ. និង ស.** ៨៤:៤៤–៤៥ ។ អស់អ្នកណាដែលរក្សា ពាក្យខ្ញុំទុក នោះនឹងមិនត្រូវបញ្ឆោតឡើយ, **យ.ស. — ម៉ាថាយ** ១:៣៧ ។

**ព្រះបាល** *សូមមើលផង* ការថ្វាយបង្គំរូបព្រះ

ជាព្រះអាទិត្យភេទបុរសមួយ ដែលគេថ្វាយបង្គំ ជាពិសេសនៅស្រុកភីនីស៊ី (១ ពង្សាវ. ១៦:៣១) តែបានថ្វាយបង្គំតាមរបៀបផ្សេងៗ នៅតាមកន្លែងឯទៀតគឺៈ ដោយពួកម៉ូអាប់ ជាព្រះបាល-ពេអរ (ជនគ. ២៥:១–៣) នៅឯស៊ីគែម ជាព្រះបាល-បេរិត (ចៅហ្វាយ ៨:៣៣; ៩:៤) នៅឯអេក្រុន ជាព្រះបាល-សេប៊ូប (២ ពង្សាវ. ១:២) ។ ព្រះបាលប្រហែលជាដូចគ្នានឹងព្រះបេល នៅបាប៊ីឡូន និង ព្រះសេអូស នៅក្រេក ។ ពាក្យ*បាល* ថ្លែងប្រាប់ពីទំនាក់ទំនងរវាងចៅហ្វាយនឹងបាវបំរើ ។ តាមធម្មតា រូបតំណាងព្រះបាល គឺជាគោឈ្មោល ។ ព្រះអាសថារ៉ូត ជាព្រះនាងដែលត្រូវថ្វាយជាមួយនឹងព្រះបាល ។

ជួនកាល ពាក្យ*បាល* ផ្សំនឹងឈ្មោះ ឬពាក្យមួយទៀត ដើម្បីបង្ហាញការទាក់ទងនឹងព្រះបាល ដូចជាកន្លែងដែលគេថ្វាយបង្គំ ឬក៏មនុស្សដែលមានលក្ខណៈដូចព្រះបាល ។ ក្រោយមក ពីព្រោះពាក្យ*បាល* ទៅជាអាក្រក់ពេក នោះបានជាគេដាក់ពាក្យ*បូសេត* ជំនួសក្នុងឈ្មោះផ្សំទាំងនោះ ។ *បូសេត* មានន័យថា « សេចក្ដីខ្មាស់ » ។

**ព្រះមែស៊ី** *សូមមើលផង* ព្រះដែលបានចាក់ប្រេងតាំង ព្រះយេស៊ូវគ្រីស្ទ

ជាពាក្យពីភាសាអើរ៉ាម និងភាសាហេព្រើរមានន័យថា « អ្នកដែលបានចាក់ប្រេងតាំង » ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីគេហៅព្រះ យេស៊ូវថាជាព្រះគ្រីស្ទ គឺជាភាសាក្រេក មានន័យដូច *ព្រះមែស៊ី* គឺមានន័យថាជាព្យាការី សង្ឃ ស្ដេច និងជាអ្នករំដោះដែលចាក់ប្រេងតាំង ដែលពួកសាសន៍យូដាទន្ទឹងចាំយ៉ាងអន្ទះអន្ទែងឲ្យយាងមក ។

ពួកសាសន៍យូដាជាច្រើនបានរង់ចាំអ្នករំដោះឲ្យរួចពីអំណាចពួករ៉ូម ហើយចំពោះការចំរើននៃប្រទេសកាន់តែច្រើនឡើង ហេតុនោះ ហើយបានជាកាលព្រះមែស៊ីទ្រង់យាងមក ពួកអ្នកដឹកនាំ និងមនុស្សជាច្រើនមិនព្រមទទួលស្គាល់ទ្រង់ឡើយ ។ មានតែពួកសុភាព រាបសា និងពួកស្មោះត្រង់ទេ ដែលអាចមើលឃើញថា ព្រះយេស៊ូវពីភូមិណាសារ៉ែតគឺជាព្រះគ្រីស្ទដ៏ពិតមែន (អេសាយ ៥៣; ម៉ាថាយ ១៦:១៦; យ៉ូហាន ៤:២៥–២៦) ។

ព្រះមែស៊ីនឹងឲ្យព្រះវិញ្ញាណផ្សាយដំណឹងល្អ ហើយប្រកាសប្រាប់ពីសេរីភាព, **អេសាយ** ៦១:១–៣ (លូកា ៤:១៨–២១) ។ យើងបាន ឃើញព្រះមែស៊ីហើយ គឺប្រែជាព្រះគ្រីស្ទ, **យ៉ូហាន** ១:៤១ (យ៉ូហាន ៤:២៥–២៦) ។ ព្រះទ្រង់បានលើកឡើងនៅក្នុងចំណោមពួកសាសន៍យូដា គឺព្រះមែស៊ី ឬពាក្យម៉្យាងទៀតថា ព្រះអង្គសង្គ្រោះ, **១ នីហ្វៃ** ១០:៤ ។ ព្រះរាជបុត្រានៃព្រះ គឺជាព្រះមែស៊ី ដែលនឹង យាងមក, **១ នីហ្វៃ** ១០:១៧ ។ សេចក្ដីប្រោសលោះនឹងមានមកដោយ និងតាមរយៈព្រះមែស៊ីដ៏បរិសុទ្ធ, **២ នីហ្វៃ** ២:៦ ។ ព្រះមែស៊ី យាងមកលុះដល់កាលដ៏ពេញកំណត់, **២ នីហ្វៃ** ២:២៦ ។ ព្រះមែស៊ីនឹងមានព្រះជន្មរស់ពីស្លាប់ឡើងវិញ, **២ នីហ្វៃ** ២៥:១៤ ។ ដោយនូវព្រះនាមនៃព្រះមែស៊ី ខ្ញុំសូមប្រគល់បព្វជិតភាពអើរ៉ុន, **គ. និង ស.** ១៣:១ ។ ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថា-យើងជា ព្រះមែស៊ី ជាស្ដេចនៃស៊ីយ៉ូន, **ម៉ូសេ** ៧:៥៣ ។

**ព្រះយេស៊ូវគ្រីស្ទ** *សូមមើលផង* ការបង្កបង្កើត; ការឆ្កាង; ការផ្ដាច់បាប; ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; ការយាងមកលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ; ការយាងឡើង; ការប្រែចិត្ត; ការប្រែរូប — ការប្រែរូបនៃព្រះគ្រីស្ទ; ក្រុមព្រះ; កូនច្បង; កូនចៀមនៃព្រះ; កូនមនុស្ស; គាល់កូតា; ឈើឆ្កាង; ដង្វាយធួន; ដើមដំបូង; ដំណឹងល្អទាំងឡាយ; ដំណើររស់ឡើងវិញ; ថ្ម; ថ្មជ្រុង; ទឹករស់; ធ្វើឲ្យធួន, សតិសម្បជញ្ញៈ; នាងម៉ារា, នំបុ័ងជីវិត; បង្កើត, បង្កើត; បទបង្រៀននៅលើភ្នំ; បានប្រោសលោះ, ប្ដីថ្មោងថ្មី;

បុណ្យរំឭក; បូជា; ប្រែចិត្ត, ប្រោសលោះ, ផ្លូវ,
ផែនការនៃសេចក្ដីប្រោសលោះ; ពស់, ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ;
ព្រះ, ព្រះគុណ; ព្រះដ៏គាំទ្រ; ព្រះដ៏ជាជំនួយ;
ព្រះដ៏ប្រោសលោះ; ព្រះដ៏ប្រោសឲ្យរួច;
ព្រះដែលបានចាក់ប្រេងតាំង; ព្រះមែស៊ី; ព្រះយេហូវ៉ា;
ព្រះអង្គសង្គ្រោះ; ព្រះអម្ចាស់; មាតារបស់ព្រះយេស៊ូវ;
មិនចេះចប់មិនចេះហើយ; យើងជាព្រះ; លង្ហិន; លោហិត;
សេចក្ដីជំនឿ; សេចក្ដីប្រោសលោះ; អ្នកគង្វាលល្អ;
អ្នកសង្រួបសង្រួម; អាលផា និងអូមេកា; អេម៉ាញូអែល

*ព្រះគ្រីស្ទ* (ជាពាក្យក្រេក) និង*ព្រះមែស៊ី* (ជាពាក្យហេព្រើរ) មានន័យថា « អ្នកដែលបានចាក់ប្រេងតាំង » ។ ព្រះយេស៊ូវគ្រីស្ទជាបុត្រច្បងនៃព្រះវរបិតា ក្នុងវិញ្ញាណ (ហេព្រើរ ១:៦; គ. និង ស. ៩៣:២១) ។ ទ្រង់ជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា ក្នុងសាច់ឈាម (យ៉ូហាន ១:១៤; ៣:១៦) ។ ទ្រង់ជាព្រះយេហូវ៉ា (គ. និង ស. ១១០:៣–៤) ហើយបានតែងតាំងចំពោះតំណែងដ៏ធំរបស់ទ្រង់ ចាប់តាំងមុនកំណើតលោកិយមក ។ នៅក្រោមការដឹកនាំនៃព្រះវរបិតា នោះព្រះយេស៊ូវទ្រង់បានបង្កើតផែនដី និងអ្វីៗសព្វសារពើនៅលើផែនដី (យ៉ូហាន ១:៣, ១៤; ម៉ូសេ ១:៣១–៣៣) ។ ទ្រង់បានប្រសូតមកពីនាងម៉ារា នៅភូមិបេថ្លេហិម មានព្រះជន្មរស់នៅដោយគ្មានបាប ហើយបានធ្វើដង្វាយធួនដ៏ឥតខ្ចោះ ជំនួសអំពើបាបទាំងឡាយរបស់មនុស្សលោកទាំងអស់ ដោយសារការ ហូរព្រះលោហិតរបស់ទ្រង់ និងការបូជាព្រះជន្មទ្រង់នៅលើឈើឆ្កាង (ម៉ាថាយ ២:១; ១ នីហ្វៃ ១១:១៣–៣៣; ៣ នីហ្វៃ ២៧:១៣–១៦; គ. និង ស. ៧៦:៤០–៤២) ។ ទ្រង់បានមានព្រះជន្មរស់ឡើងពីស្លាប់ ម្ល៉ោះហើយបានបញ្ជាក់នូវដំណើររស់ឡើងវិញ ដែលនឹងកើតមាន ដល់មនុស្សលោកទាំងអស់ ។ តាមរយៈដង្វាយធួន និងដំណើររស់ឡើងវិញរបស់ព្រះយេស៊ូវ នោះអស់អ្នកណាដែលប្រែចិត្តពីអំពើបាប ទាំងឡាយរបស់ខ្លួន ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះនឹងអាចបានរស់នៅអស់កល្បជានិច្ច ជាមួយនឹងព្រះយេស៊ូវ និងព្រះវរបិតា (២ នីហ្វៃ ៩:១០–១២; ២១–២២; គ. និង ស. ៧៦:៥០–៥៣, ៦២) ។

ព្រះយេស៊ូវគ្រីស្ទជាព្រះអង្គដ៏វិសេសបំផុតដែលបានកើតលើផែនដីនេះ ។ ព្រះជន្មរបស់ទ្រង់ជាគំរូដ៏ល្អឥតខ្ចោះអំពីរបៀបដែលមនុស្សទាំងអស់គួររស់នៅ ។ អស់ទាំងពាក្យអធិស្ឋាន ព្រះពរ និងពិធីបរិសុទ្ធនៃបព្វជិតភាពគួរតែធ្វើឡើង ដោយនូវព្រះនាមនៃព្រះអង្គ ។ ទ្រង់ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ជាស្ដេចលើអស់ទាំងស្ដេច ជាព្រះដ៏បង្កបង្កើត ជាព្រះអង្គសង្គ្រោះ ហើយជាព្រះនៃផែនដី ទាំងមូល ។

ព្រះយេស៊ូវគ្រីស្ទនឹងយាងមកក្នុងព្រះចេស្ដា និងសិរីល្អ ដើម្បីមកសោយរាជ្យនៅលើផែនដី នៅសហស្សវត្សរ៍ ។ នៅថ្ងៃចុងក្រោយបង្អស់ ទ្រង់នឹងជំនុំជំរះមនុស្សលោកទាំងអស់ (អាលម៉ា ១១:៤០–៤១; យ.ស. — ម៉ាថាយ ១) ។

*ការសរុបអំពីព្រះជន្មរបស់ទ្រង់ (តាមលំដាប់កាលរៀងមក)៖* កំណើត និងបេសកកម្មរបស់ព្រះយេស៊ូវត្រូវបានប្រាប់ទុកជាមុន, **លូកា** ១:២៦–៣៨ (អេសាយ ៧:១៤; ៩:៦–៧; ១ នីហ្វៃ ១១) ។ បានប្រសូតមក, **លូកា** ២:១–៧ (ម៉ាថាយ ១:១៨–២៥) ។ បានទទួល ការកាត់ស្បែក, **លូកា** ២:២១ ។ បានមកថ្វាយនៅព្រះវិហារ, **លូកា** ២:២២–៣៨ ។ បានមករកដោយពួកអ្នកប្រាជ្ញ, **ម៉ាថាយ** ២:១–១២ ។ យ៉ូសែប និងនាងម៉ារាបានភៀសខ្លួនជាមួយទ្រង់ទៅស្រុកអេស៊ីព្ទ, **ម៉ាថាយ** ២:១៣–១៨ ។ បាននាំមកឯណាសារ៉ែត, **ម៉ាថាយ** ២:១៩–២៣ ។ បានទៅព្រះវិហារ កាលមានព្រះជន្មាយុ ១២ ឆ្នាំ, **លូកា** ២:៤១–៥០ ។ មានប្អូនប្រុសស្រី, **ម៉ាថាយ** ១៣:៥៥–៥៦ (ម៉ាកុស ៦:៣) ។ បានទទួលបុណ្យជ្រមុជទឹក, **ម៉ាថាយ** ៣:១៣–១៧ (ម៉ាកុស ១:៩–១១; លូកា ៣:២១–២២) ។ ត្រូវអារក្សល្បួង, **ម៉ាថាយ** ៤:១–១១ (ម៉ាកុស ១:១២–១៣; លូកា ៤:១–១៣) ។ បានហៅពួកសិស្ស ១២ នាក់, **ម៉ាថាយ** ៤:១៨–២២ (ម៉ាថាយ ៩:៩; ម៉ាកុស ១:១៦–២០; ២:១៣–១៤; លូកា ៥:១–១១, ២៧–២៨; ៦:១២–១៦; យ៉ូហាន ១:៣៥–៥១) ។ បានអនុញ្ញាត ឲ្យពួក ១២ នាក់នាមសិទ្ធិអំណាច, **ម៉ាថាយ** ១០:១–៤ (ម៉ាកុស ៣:១៣–១៩; លូកា ៦:១២–១៦) ។ បានប្រទានបទបង្រៀននៅលើភ្នំ, **ម៉ាថាយ** ៥–៧ ។ បានប្រាប់អំពីការសុគត និងដំណើររស់ឡើងវិញរបស់ ទ្រង់ទុកជាមុន, **ម៉ាថាយ** ១៦:២១ (ម៉ាថាយ ១៧:២២–២៣; ២០:១៧–១៩; ម៉ាកុស ៨:៣១; ៩:៣០–៣២; ១០:៣២–៣៤; លូកា ៩:២២; ១៨:៣១–៣៤) ។ បានប្រែរូប, **ម៉ាថាយ** ១៧:១–៩ (ម៉ាកុស ៩:២–៨; លូកា ៩:២៨–៣៦) ។ បានចាត់ពួក ៧០ នាក់ឲ្យទៅ, **លូកា** ១០:១–២០ ។ បានចូលក្រុងយេរូសាឡិមដ៏ប្រកបដោយ ជោគជ័យ, **ម៉ាថាយ** ២១:១–១១ (ម៉ាកុស ១១:១–១១ លូកា ១៩:២៩–៤០; **យ៉ូហាន** ១២:១២–១៥) ។ បានតាំងបុណ្យរំឭកឡើង, **ម៉ាថាយ** ២៦:២៦–២៩ (ម៉ាកុស ១៤:២២–២៥; លូកា ២២:១៩–២០) ។ បានរងទុក្ខ ហើយអធិស្ឋាននៅក្នុងសួនច្បារគែតសេម៉ានី, **ម៉ាថាយ** ២៦:៣៦–៤៦ (ម៉ាកុស ១៤:៣២–៤២; លូកា ២២:៣៩–៤៦) ។ បានត្រូវគេក្បត់ ចាប់ និងបះបង់ចោល, **ម៉ាថាយ** ២៦:៤៧–៥៦ (ម៉ាកុស ១៤:៤៣–៥៣; លូកា ២២:៤៧–៥៤; យ៉ូហាន ១៨:២–១៣) ។ បានត្រូវគេឆ្កាង, **ម៉ាថាយ** ២៧:៣១–៥៤ (ម៉ាកុស ១៥:២០–៤១; លូកា ២៣:២៦–២៨, ៣២–៤៩; យ៉ូហាន ១៩:១៦–៣០) ។ មានព្រះ ជន្មរស់ឡើងវិញ, **ម៉ាថាយ** ២៨:១–៨ (ម៉ាកុស ១៦:១–៨; លូកា ២៤:១–១២; យ៉ូហាន ២០:១–១០) ។ បានលេចមក ក្រោយពីទ្រង់ មានព្រះជន្មរស់ឡើងវិញ, **ម៉ាថាយ** ២៨:៩–២០ (ម៉ាកុស ១៦:៩–១៨; លូកា ២៤:១៣–៤៨; យ៉ូហាន ២០:១១–៣១; កិច្ចការ ១:៣–៨; ១ កូរិន. ១៥:៥–៨) ។ បានយាងឡើងទៅលើស្ថានសួគ៌, **ម៉ាកុស** ១៦:១៩–២០ (លូកា ២៤:៥១–៥៣; កិច្ចការ ១:៩–១២) ។ បានលេចមកឯពួកសាសន៍នីហ្វៃ, ៣ នីហ្វៃ ១១:១–១៧ (៣ នីហ្វៃ ១១–២៦) ។ បានលេចមកឯយ៉ូសែប ស៊្មីធ, យ.ស. — ប្រវត្តិ ១:១៥–២០ ។

*សិទ្ធិអំណាច៖* ការគ្រប់គ្រងនឹងនៅលើស្មារបស់ទ្រង់, **អេសាយ** ៩:៦ (២ នីហ្វៃ ១៩:៦) ។ ព្រះយេស៊ូវទ្រង់បានបង្រៀនដូចជាមាន សិទ្ធិអំណាច, **ម៉ាថាយ** ៧:២៨–២៩ (ម៉ាកុស ១:២២) ។ កូនមនុស្សមាន

អំណាចនឹងអត់ទោសបាបនៅផែនដីបាន, **ម៉ាថាយ** ៩:៦ ។ ព្រះយេស៊ូវទ្រង់បង្គាប់ដល់អារក្សអសោចិ៍ដោយសិទ្ធិអំណាច ហើយវាក៏ស្ដាប់បង្គាប់ទ្រង់, **ម៉ាកុស** ១:២៧ (លូកា ៤:៣៣—៣៦) ។ ព្រះយេស៊ូវទ្រង់បានតែងតាំងពួក ១២ នាក់ឲ្យមានអំណាច, **ម៉ាកុស** ៣:១៤—១៥ ។ ទ្រង់មានព្រះបន្ទូលដោយអំណាច, **លូកា** ៤:៣២ ។ ព្រះវរបិតាបានប្រគល់គ្រប់ការជំនុំជំរះ ដល់ព្រះរាជបុត្រា, **យ៉ូហាន** ៥:២២, ២៧ ។ ព្រះទ្រង់បានចាក់ព្រះវិញ្ញាណបរិសុទ្ធ និងព្រះ ចេស្ដាឲ្យមកសណ្ឋិតលើព្រះយេស៊ូវ, **កិច្ចការ** ១០:៣៨ ។ ព្រះគ្រីស្ទត្រូវបានតែងតាំងពីមុនកំណើតលោកិយមក, **១ ពេត្រុស** ១:២០ (អេធើរ ៣:១៤) ។ ព្រះគ្រីស្ទមានកូនសោទាំងឡាយ នៃស្ថានឃុំព្រលឹងមនុស្សស្លាប់ និងសេចក្ដីស្លាប់, **វិវរ.** ១:១៨ ។ មនុស្សទាំង អស់ក្លាយជានៅក្រោមព្រះគ្រីស្ទ, **២ នីហ្វៃ** ៩:៥ ។ ព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ គឺជាបិតានៃស្ថានសួគ៌ និងផែនដី ជាអ្នកបង្កើតអ្វីៗសព្វសារពើចាប់ពីដំបូងមក, **ហេលេ.** ១៤:១២ ។ ព្រះយេស៊ូវគ្រីស្ទបានមកតាមបំណងព្រះហឫទ័យនៃព្រះវរបិតា ដើម្បីធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់, **គ. និង ស.** ១៩:២៤ ។ ព្រះយេស៊ូវបានទទួលភាពពោរពេញនៃសិរីល្អរបស់ព្រះវរបិតា ហើយទ្រង់បានទទួលអស់ទាំងព្រះចេស្ដា, **គ. និង ស.** ៩៣:៣—៤, ១៦—១៧ (យ៉ូហាន ៣:៣៥—៣៦) ។

*ដំរាប់នៃព្រះយេស៊ូវគ្រីស្ទ៖* ខ្ញុំបានធ្វើដំរាប់ទុកឲ្យអ្នករាល់គ្នា, **យ៉ូហាន** ១៣:១៥ ។ ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត, **យ៉ូហាន** ១៤:៦ ។ ព្រះគ្រីស្ទបានរងទុក្ខជំនួសយើង ទាំងទុកដំរាប់ ឲ្យយើងរាល់គ្នាដើរតាមលំអានដាននៃទ្រង់, **១ ពេត្រុស** ២:២១ ។ បើមនុស្សណាមួយមិនដើរតាមគំរូនៃព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅនោះទេ មនុស្សនោះនឹងមិនបានសង្គ្រោះឡើយ, **២ នីហ្វៃ** ៣១:១៦ ។ យើងចង់ឲ្យអ្នករាល់គ្នាបានល្អឥតខ្ចោះដូចជាយើងដែរ, ៣ នីហ្វៃ ១២:៤៨ ។ អ្នករាល់គ្នានឹងត្រូវធ្វើដូច្នេះជានិច្ច គឺឲ្យដូច ជាយើងបានធ្វើមក, ៣ នីហ្វៃ ១៨:៦ ។ យើងបានជាគំរូដល់អ្នករាល់គ្នា, ៣ នីហ្វៃ ១៨:១៦ ។ ការអ្វីដែលអ្នករាល់គ្នាបានឃើញយើង ធ្វើ ចូរអ្នកធ្វើយ៉ាងនោះដែរ, ៣ នីហ្វៃ ២៧:២១, ២៧ ។ ពួកអ្នកដើរតាមដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទនឹងបានដូចទ្រង់, **មរ៉ូណៃ** ៧:៤៨ ។

*សិរីល្អនៃព្រះយេស៊ូវគ្រីស្ទ៖* សិរីល្អនៃព្រះអម្ចាស់បានស្ថិតនៅពេញក្នុងរោងឧបោសថ, **និក្ខ.** ៤០:៣៤—៣៨ ។ ផែនដីទាំងមូលមាន ពេញដោយសិរីល្អនៃទ្រង់. **អេសាយ** ៦:៣ (២ នីហ្វៃ ១៦:៣) ។ សិរីល្អនៃព្រះអម្ចាស់ក៏បានរះឡើងដល់អ្នកដែរ, **អេសាយ** ៦០:១—២ ។ កូនមនុស្សនឹងមកក្នុងសិរីល្អនៃព្រះវរបិតា, **ម៉ាថាយ** ១៦:២៧ ។ សូមដំកើងទូលបង្គំឡើងជាមួយនឹងទ្រង់ផង ដោយសិរីល្អដែលទូលបង្គំ មានជាមួយនឹងទ្រង់ ក្នុងកាលដែលលោកិយមិនទាន់បានកើតនៅឡើយ, **យ៉ូហាន** ១៧:៥ ។ ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ទ្រង់ នឹងសោយរាជ្យដោយសិរីល្អដ៏ធំ, **១ នីហ្វៃ** ២២:២៤ ។ យើងបានសង្ឃឹមដល់សិរីល្អរបស់ទ្រង់, **យ៉ាកុប** ៤:៤ ។ ព្រះរាជបុត្រានៃព្រះ ទ្រង់នឹងយាងក្នុងសិរីល្អរបស់ទ្រង់, **អាលម៉ា** ៥:៥០ ។ ទ្រង់បានពន្យល់ប្រាប់ការណ៍ទាំងអស់តាំងពីដើមដំបូងរហូតដល់ពេល ដែល ទ្រង់នឹងយាងមកក្នុងសិរីល្អរបស់ទ្រង់, ៣ នីហ្វៃ ២៦:៣ ។ ពួកសាវករបស់យើងនឹងឈរប្រដាប់ក្នុងសិរីល្អដូចជាយើងដែរ, **គ. និង ស.** ២៩:១២ (គ. និង ស. ៤៥:៤៤) ។ យើងខ្ញុំបានមើលឃើញសិរីល្អនៃព្រះរាជបុត្រា គង់នៅខាងស្ដាំព្រះហស្តនៃព្រះវរបិតា, **គ. និង ស.** ៧៦:១៩—២៣ ។ យ៉ូហានបានឃើញ ហើយបានធ្វើទីបន្ទាល់អំពីភាពពោរពេញនៃសិរីល្អរបស់យើង, **គ. និង ស.** ៩៣:៦ (យ៉ូហាន ១:១៤) ។ ព្រះភ័ក្ត្ររបស់ទ្រង់ភ្លឺជាងពន្លឺថ្ងៃ, **គ. និង ស.** ១១០:៣ ។ សិរីល្អរបស់ទ្រង់បានមកលើខ្ញុំ ហើយខ្ញុំបានមើលឃើញព្រះភ័ក្ត្រ ទ្រង់, **ម៉ូសេ** ១:១—១១ ។ នេះហើយជាកិច្ចការរបស់យើង និងសិរីល្អរបស់យើង, **ម៉ូសេ** ១:៣៩ ។

*សិរសានៃសាសនាចក្រ៖* ព្រះគ្រីស្ទទ្រង់ជាសិរសានៃពួកជំនុំ, **អេភេ.** ៥:២៣ (អេភេ. ១:២២; ៤:១៥) ។ ទ្រង់ជាសិរសារបស់រូប កាយ គឺជាពួកជំនុំ, **កូល៉ុស** ១:១៨ ។ នេះជាសាសនាចក្ររបស់យើង, **ម៉ូសាយ** ២៦:២២ (ម៉ូសាយ ២៧:១៣) ។ ព្រះគ្រីស្ទទ្រង់ជា មេផ្ដើម ហើយជាមេសំរេចនូវសេចក្ដីជំនឿរបស់ពួកគេ, **មរ៉ូណៃ** ៦:១—៤ ។ សាសនាចក្រនេះយើងបានតាំងឡើង, **គ. និង ស.** ៣៣:៥ (៣ នីហ្វៃ ២៧:៣—៨) ។

*ចៅក្រម៖* ទ្រង់នឹងជំនុំជំរះមនុស្សលោក ដោយសេចក្ដីសុចរិត, **ទំនុក.** ៩:៨ (៣ នីហ្វៃ ២៧:១៦) ។ ទ្រង់យាងមក ដើម្បីជំនុំជំរះ ផែនដី, **ទំនុក.** ៩៦:១៣ ។ ព្រះទ្រង់នឹងជំនុំជំរះទាំងពួកអ្នកសុចរិត និងពួកទុច្ចរិតផង, **សាស្ដា** ៣:១៧ ។ ទ្រង់នឹងជំនុំជំរះរវាងអស់ទាំង នគរ, **អេសាយ** ២:៤ (មីកា ៤:៣; ២ នីហ្វៃ ១២:៤) ។ ទ្រង់នឹងជំនុំជំរះពួកទាល់ក្រ ដោយសេចក្ដីសុចរិត, **អេសាយ** ១១:២—៤ ។ ព្រះវរបិតាទ្រង់បានប្រគល់គ្រប់ការជំនុំជំរះ ដល់ព្រះរាជបុត្រា, **យ៉ូហាន** ៥:២២ ។ បើខ្ញុំជំនុំជំរះនោះសេចក្ដីជំនុំជំរះរបស់ខ្ញុំជាពិត, **យ៉ូហាន** ៨:១៦ ។ ព្រះទ្រង់បានតាំងទ្រង់ឡើងឲ្យជំនុំជំរះដល់ទាំងមនុស្សរស់ និងមនុស្សស្លាប់ផង, **កិច្ចការ** ១០:៤២ (២ ធីម៉ូ. ៤:១) ។ ព្រះទ្រង់នឹងជំនុំជំរះអស់ទាំងការលាក់កំបាំងរបស់មនុស្ស ដោយសារព្រះយេស៊ូវគ្រីស្ទ, **រ៉ូម** ២:១៦ ។ យើងទាំងអស់គ្នានឹងត្រូវឈរ នៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ, **រ៉ូម** ១៤:១០ (២ កូរិន. ៥:១០; អាលម៉ា ១២:១២; មរមន ៣:២០; ៧:៦; អេធើរ ១២:៣៨; គ. និង ស. ១៣៥:៥) ។ មនុស្សទាំងអស់មករកព្រះ ដើម្បីឲ្យទ្រង់ជំនុំជំរះ តាមសេចក្ដីពិត និងសេចក្ដីបរិសុទ្ធ ដែលនៅក្នុងទ្រង់, **២ នីហ្វៃ** ២:១០ ។ ឈរនៅចំពោះព្រះ ដើម្បីទទួលការជំនុំជំរះតាមអំពើទាំងឡាយដែលខ្លួនបានប្រព្រឹត្ត, **អាលម៉ា** ៥:១៥ (អាលម៉ា ១២:១៥; ៣៣:២២; ៣ នីហ្វៃ ២៧:១៤) ។ ព្រះ និងព្រះគ្រីស្ទជាចៅក្រមនៃមនុស្សទាំងអស់, **គ. និង ស.** ៧៦:៦៨ ។

*រជ្ជកាលនៃព្រះគ្រីស្ទនៅសហស្សវត្សរ៍៖* ការគ្រប់គ្រងនឹងនៅលើស្មាទ្រង់, **អេសាយ** ៩:៦ (២ នីហ្វៃ ១៩:៦) ។ ព្រះអម្ចាស់ទ្រង់មាន បន្ទូលថា យើងនឹងនៅកណ្ដាលអ្នករាល់គ្នា, **សាការី** ២:១០—១២ (សាការី ១៤:៩) ។ ព្រះទ្រង់នឹងប្រទានរាជ្យ នៃហ្លួងដាវីឌ ជា អយ្យកោទ្រង់ថ្វាយព្រះយេស៊ូវ, **លូកា** ១:៣០—៣៣ ។ ព្រះគ្រីស្ទនឹងសោយរាជ្យនៅអស់កល្បជានិច្ចរៀងរាបតទៅ, **វិវរ.** ១១:១៥ ។ ពួកបរិសុទ្ធនឹងសោយរាជ្យជាមួយនឹងព្រះគ្រីស្ទ មួយពាន់ឆ្នាំ, **វិវរ.** ២០:៤

(គ. និង ស. ៧៦:៦៣) ។ ដោយសារអំពើសុចរិតរបស់ ប្រជាជន នោះសាតាំងគ្មានអំណាចសោះ, **១ នីហ្វៃ** ២២:២៦ (វិវរ. ២០:១–៣) ។ យើងនឹងស្ថិតនៅក្នុងសេចក្ដីសុចរិត ជាមួយមនុស្ស លោក នៅលើផែនដីអស់មួយពាន់ឆ្នាំ, **គ. និង ស.** ២៩:១១ (គ. និង ស. ៤៣:២៩–៣០) ។ ចូរនៅក្រោមអំណាចទាំងឡាយដែល មានហើយចុះ រហូតដល់ទ្រង់សោយរាជ្យ ដែលមានសិទ្ធិសោយរាជ្យ, **គ. និង ស.** ៥៨:២២ (១ កូរិន. ១៥:២៥) ។ ព្រះគ្រីស្ទនឹង សោយរាជ្យនៅលើផែនដីផ្ទាល់, **ម. នៃ ស.** ១:១០ (អេសាយ ៣២:១) ។

*ការលេចមករបស់ព្រះគ្រីស្ទក្រោយពីសុគត៖* កាលព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ឡើងវិញ នោះទ្រង់ក៏លេចមកមុនដំបូង ឲ្យនាង ម៉ារាឃើញ, **ម៉ាកុស** ១៦:៩ (យ៉ូហាន ២០:១១–១៨) ។ ព្រះយេស៊ូវទ្រង់បានដើរហើយមានបន្ទូលនឹងពួកសិស្សពីរនាក់តាមផ្លូវទៅឯ ភូមិអេម៉ោស, **លូកា** ២៤:១៣–៣៤ ។ ព្រះយេស៊ូវទ្រង់បានលេចមកឯពួកសាវក ដែលបានពាល់ព្រះហស្ត និងព្រះបាទទ្រង់, **លូកា** ២៤:៣៦–៤៣ (យ៉ូហាន ២០:១៩–២០) ។ ព្រះយេស៊ូវទ្រង់បានលេចមកឯថូម៉ាស, **យ៉ូហាន** ២០:២៤–២៩ ។ ព្រះយេស៊ូវទ្រង់បាន លេចមកឯពួកសិស្សនៅឯសមុទ្រទីបេរាស, **យ៉ូហាន** ២១:១–១៤ ។ ព្រះយេស៊ូវទ្រង់បានបង្រៀនក្នុងរវាង ៤០ ថ្ងៃ ក្រោយពីទ្រង់មាន ព្រះជន្មរស់ឡើងវិញ, **កិច្ចការ** ១:២–៣ ។ ស្ទេផានបានឃើញព្រះយេស៊ូវឈរនៅខាងស្តាំព្រះហស្តនៃព្រះ, **កិច្ចការ** ៧:៥៥–៥៦ ។ ព្រះយេស៊ូវទ្រង់បានលេចមកឯសុល, **កិច្ចការ** ៩:១–៨ (ក.យ.ស., កិច្ចការ ៩:៧; កិច្ចការ ២៦:៩–១៧) ។ មនុស្សជាង ៥០០ នាក់ បានឃើញព្រះគ្រីស្ទ, **១ កូរិន.** ១៥:៣–៨ ។ ព្រះយេស៊ូវគ្រីស្ទបានសម្តែងអង្គទ្រង់ដល់ប្រជារាស្ត្រនីហ្វៃ, ៣ នីហ្វៃ ១១:១–១៧ ។ មនុស្ស ២៥០០ នាក់បានឃើញ ហើយបានឮព្រះយេស៊ូវ, ៣ នីហ្វៃ ១៧:១៦–២៥ ។ ព្រះអម្ចាស់ទ្រង់មកយាងរកមរមន, **មរមន** ១:១៥ ។ យ៉ូសែប ស្ម៊ីធ និង ស៊ីឌនី រិកដុន បានឃើញព្រះយេស៊ូវ, **គ. និង ស.** ៧៦:២២–២៣ ។ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរីបានឃើញ ព្រះអម្ចាស់នៅក្នុងព្រះវិហារខឺតឡង់, **គ. និង ស.** ១១០:១–៤ ។ យ៉ូសែប ស្ម៊ីធ បានឃើញព្រះយេស៊ូវ នៅខាងស្តាំព្រះហស្តនៃព្រះ, **យ.ស. — ប្រវត្តិ** ១:១៥–១៧ ។

*ព្រះគ្រីស្ទមានព្រះជន្មរស់នៅមុនផែនដី៖* ព្រះអម្ចាស់ទ្រង់បានលេចមកឯអាប់រ៉ាម, **លោកុ.** ១២:៧ (លោកុ. ១៧:១; ១៨:១; អ័ប្រា. ២:៦–៨) ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលប្រទល់មុខនឹងម៉ូសេ, **និក្ខ.** ៣៣:១១ (ចោទិ. ៣៤:១០; ម៉ូសេ ១:១–២) ។ ខ្ញុំក៏ឃើញព្រះ អម្ចាស់ទ្រង់ឈរក្បែរអាសនា, **អេម៉ុស** ៩:១ ។ កាលដើមដំបូង ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ។ ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា, **យ៉ូហាន** ១:១, ១៤ (១ យ៉ូហាន ១:១–៣) ។ មុនដែលលោកអ័ប្រាហាំកើតមក នោះមាន ខ្ញុំហើយ, **យ៉ូហាន** ៨:៥៨ ។ សូមដំកើងទូលបង្គំឡើង ដោយសិរីល្អដែលទូលបង្គំមានជាមួយនឹងទ្រង់ ក្នុងកាលដែលលោកិយមិនទាន់បានកើតនៅឡើយ, **យ៉ូហាន** ១៧:៥ ។ អេសាយពិតជាបានឃើញព្រះប្រោសលោះរបស់ខ្ញុំ ដូចជាខ្ញុំ និងយ៉ាកុប ដែលជាប្អូនខ្ញុំបាន ឃើញទ្រង់ដែរ, **២ នីហ្វៃ** ១១:២–៣ ។ ហើយថ្ងៃស្អែកឡើង យើងនឹងចុះមកឯលោកិយ, ៣ នីហ្វៃ ១:១២–១៤ ។ ព្រះគ្រីស្ទនៅមុន ពេលលោកិយចាប់ផ្ដើមម្ល៉េះ, ៣ នីហ្វៃ ២៦:៥ (យ៉ូហាន ៦:៦២) ។ ដូចជាយើងលេចមកឲ្យអ្នកឃើញយ៉ាងណា នោះយើងក៏នឹងលេច មកឲ្យរាស្ត្រយើងឃើញក្នុងសាច់ឈាមយ៉ាងនោះដែរ, **អេធើរ** ៣:១៤–១៧ ។ ហេណុកបានឃើញព្រះអម្ចាស់ ហើយបានដើរជាមួយ ទ្រង់, **គ. និង ស.** ១០៧:៤៨–៤៩ ។ ព្រះរាជបុត្រារបស់យើង ដែលជាទីស្ងួនភ្ងា និងជាទីជំរើសរបស់យើងចាប់តាំងពីដើមដំបូងមក, **ម៉ូសេ** ៤:២ ។ ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា៖ តើយើងនឹងចាត់អ្នកណា ? ហើយម្នាក់ដូចជាកូនមនុស្សបានឆ្លើយថា៖ ទូលបង្គំ នៅឯណេះហើយ សូមចាត់ទូលបង្គំចុះ, **អ័ប្រា.** ៣:២៧ ។

*ពាក្យព្យាករណ៍ទាំងឡាយអំពីកំណើត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ៖* នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រាមួយ, **អេសាយ** ៧:១៤ (១ នីហ្វៃ ១១:១៣–២០) ។ ចេញពីភូមិបេថ្លេហិមនឹងមានអ្នកគ្រប់គ្រងមួយ ចេញមកនៅក្នុងអ៊ីស្រាអែល, **មីកា** ៥:២ ។ សាំយូអែលជាសាសន៍លេមិន បានព្យាករអំពីមួយថ្ងៃ មួយយប់ និងមួយថ្ងៃដែលមានពន្លឺ; អំពីផ្កាយថ្មីមួយ និងទីសំគាល់ផ្សេងៗទៀត, **ហេលេ.** ១៤:២–៦ ។ សាំយូអែល ជាសាសន៍លេមិន បានព្យាករអំពីសេចក្ដីងងឹត ផ្គរលាន់ និងផ្លេកបន្ទោរ និងអំពីផែនដីញ័ររញ្ជួយ, **ហេលេ.** ១៤:២០–២៧ ។ ទីសំគាល់អំពីព្រះកំណើតរបស់ព្រះយេស៊ូវត្រូវបានសំរេច, ៣ នីហ្វៃ ១:១៥–២១ ។ ទីសំគាល់អំពីការសុគត របស់ព្រះយេស៊ូវត្រូវបានសំរេច, ៣ នីហ្វៃ ៨:៥–២៣ ។

*ការយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនយើងរាល់គ្នា៖* គ្មាននាមឈ្មោះណាទៀត ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះ ឡើយ, **កិច្ចការ** ៤:១២ (២ នីហ្វៃ ៣១:២១) ។ ពួកសាវកបានអរសប្បាយពីព្រោះព្រះបានរាប់ជាអ្នកគួរនឹងទ្រាំសេចក្ដីដំនៀល ដោយ ព្រោះព្រះនាមទ្រង់, **កិច្ចការ** ៥:៣៨–៤២ ។ នេះជាបញ្ញត្តិទ្រង់ គឺថា ត្រូវឲ្យយើងជឿដល់ព្រះនាមព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ, **១ យ៉ូហាន** ៣:២៣ ។ ចូរធ្វើបន្ទាល់ថា អ្នកយល់ព្រមទទួលយកព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួន ដោយទទួលបុណ្យជ្រមុជទឹក, **២ នីហ្វៃ** ៣១:១៣ ។ ខ្ញុំចង់ឲ្យអ្នករាល់គ្នាទទួលដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ, **ម៉ូសាយ** ៥:៦–១២ (ម៉ូសាយ ១:១១) ។ អ្នកណាក៏ដោយ ដែលប្រាថ្នាចង់លើកយកព្រះនាមនៃព្រះគ្រីស្ទមកដាក់លើខ្លួន នោះបានចូលរួមក្នុងសាសនាចក្រនៃព្រះ, **ម៉ូសាយ** ២៥:២៣ ។ អស់អ្នក ណាដែលជាពួកជឿពិតទៅលើព្រះគ្រីស្ទ គេបានលើកយកដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ, **អាលម៉ា** ៤៦:១៥ ។ ក្លោងទ្វារនៃ ស្ថានសួគ៌បានបើកចំហដល់អស់អ្នកណាដែលនឹងជឿដល់ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ, **ហេលេ.** ៣:២៨ ។ មានពរហើយ ដល់អ្នកណា ដែលឃើញថាមានចិត្តស្មោះត្រង់ចំពោះឈ្មោះយើង នៅថ្ងៃចុងក្រោយបង្អស់, **អេធើរ** ៤:១៩ ។ ពួកគេព្រមលើកដាក់លើខ្លួនគេនូវព្រះ នាមនៃព្រះរាជបុត្រា, **ម៉ូរ៉ូណៃ** ៤:៣ (គ. និង ស. ២០:៧៧) ។ ចូរយកព្រះនាមនៃព្រះគ្រីស្ទមកដាក់លើខ្លួន, **គ. និង ស.** ១៨:២១–២៥ ។

*ទីបន្ទាល់ដែលបានធ្វើអំពីព្រះយេស៊ូវគ្រីស្ទ៖* ប៉ុលបានធ្វើបន្ទាល់ថា ព្រះយេស៊ូវជាព្រះគ្រីស្ទ, **កិច្ចការ** ១៨:៥ ។ សូម្បីតែពួកអារក្សអសោចិ៍ក៏បានធ្វើបន្ទាល់ថា វាស្គាល់ព្រះយេស៊ូវហើយ, **កិច្ចការ** ១៩:១៥ ។ គ្មានអ្នកណាអាចនឹងថា ព្រះយេស៊ូវទ្រង់ជាព្រះអម្ចាស់ដែរ លើកលែងតែដោយនូវព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ, **១ កូរិន.** ១២:៣ ។ គ្រប់ទាំងជង្គង់នឹងលុតចុះ ហើយគ្រប់ទាំងអណ្ដាតនឹងថ្លែង ប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់, **ភីលីព** ២:១០–១១ ។ យើងនិយាយអំពីព្រះគ្រីស្ទ យើងរីករាយក្នុងព្រះគ្រីស្ទ យើងផ្សាយ អំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ, **២ នីហ្វៃ** ២៥:២៦ ។ ព្រះគម្ពីរមរមនគឺនឹងបញ្ជាក់ដល់ពួកយូដា និងពួកសាសន៍ដទៃថា ព្រះយេស៊ូវ ជាព្រះគ្រីស្ទ, **២ នីហ្វៃ** ២៦:១២ (ទំព័រចំណងជើងនៃព្រះគម្ពីរមរមន) ។ ពួកព្យាការី និងបទគម្ពីរធ្វើបន្ទាល់អំពីព្រះគ្រីស្ទ, **យ៉ាកុប** ៧:១១, ១៩ ។ ចូរស្វែង រកព្រះយេស៊ូវ ដែលពួកព្យាការី និងពួកសាវកបានសរសេរទុកនេះ, **អេធើរ** ១២:៤១ ។ យើងខ្ញុំបាន ឃើញទ្រង់ ហើយបានឮសម្លេង ដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយ, **គ. និង ស.** ៧៦:២០–២៤ ។ នេះហើយជាជីវិតដ៏ នៅអស់កល្បជានិច្ច — គឺដើម្បីស្គាល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ១៣២:២៤ ។ យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅ អស់កល្បជានិច្ច និងដល់ព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ, **ម. នៃ ស.** ១:១ ។ យើងខ្ញុំជឿថា ព្រះគ្រីស្ទនឹងសោយរាជ្យនៅលើផែនដី ផ្ទាល់, **ម. នៃ ស.** ១:១០ ។

*គំរូ និងនិមិត្តរូបទាំងឡាយអំពីព្រះគ្រីស្ទ៖* អេបិលក៏យកកូនជាដំបូងមួយពីហ្វូងសត្វមកថ្វាយ, **លោកុ.** ៤:៤ (ម៉ូសេ ៥:២០) ។ ចូរ យកអ៊ីសាកជាកូនអ្នកតែមួយ រួចថ្វាយវាជាដង្វាយដុតចុះ, **លោកុ.** ២២:១–១៣ (យ៉ាកុប ៤:៥) ។ ព្រះអម្ចាស់ទ្រង់បង្គាប់ឲ្យកូនចៅ អ៊ីស្រាអែលយកពួកកូនចៀមឥតខ្ចោះទៅថ្វាយបូជា, **និក្ខ.** ១២:៥, ២១, ៤៦ (ជនគ. ៩:១២; យ៉ូហាន ១:២៩; ១៩:៣៣; ១ ពេត្រុស ១:១៩; វិវរ. ៥:៦) ។ នេះគឺជានំបុ័ងដែលព្រះអម្ចាស់ ទ្រង់បានប្រទានឲ្យអ្នករាល់គ្នាបរិភោគ, **និក្ខ.** ១៦:២–១៥ (យ៉ូហាន ៦:៥១) ។ ចូរវាយថ្ម រួចនឹងមានទឹកចេញមកឲ្យមនុស្សផឹកហើយ, **និក្ខ.** ១៧:៦ (យ៉ូហាន ៤:៦–១៤; ១ កូរិន. ១០:១–៤) ។ ពពែនឹងផ្ទុកអស់ទាំង សេចក្ដីទុច្ចរិតរបស់គេលើខ្លួន, **លេវី.** ១៦:២០–២២ (អេសាយ ៥៣:១១; ម៉ូសាយ ១៤:១១; ១៥:៦–៩) ។ ម៉ូសេលើកពស់លង្ហិនឡើង ដើម្បីនឹងសង្គ្រោះពួកអ្នកណាដែលក្រឡេកមើលរូបពស់លង្ហិន, **ជនគ.** ២១:៨–៩ (យ៉ូហាន ៣:១៤–១៥; អាលម៉ា ៣៣:១៩; ហេលេ. ៨:១៤–១៥) ។ យ៉ូណាសបាននៅក្នុងពោះត្រីបីថ្ងៃ, **យ៉ូណាស** ១:១៧ (ម៉ាថាយ ១២:៤០) ។ ការណ៍នេះគឺជានិមិត្តរូបអំពីការបូជានៃ ព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា, **ម៉ូសេ** ៥:៤–៨ ។

**ព្រះយេហូវ៉ា** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ, យើងជាព្រះ

ជាសេចក្ដីសញ្ញា ឬព្រះនាមត្រឹមត្រូវរបស់ព្រះនៃអ៊ីស្រាអែល ។ គឺជាសញ្ញា « យើងជាព្រះដ៏នៅអស់កល្បជានិច្ច » (និក្ខ. ៣:១៤; យ៉ូហាន ៨:៥៨) ។ ព្រះយេហូវ៉ា ជាព្រះយេស៊ូវគ្រីស្ទមុនផែនដី ហើយបានយាងមកផែនដី ជាបុត្ររបស់នាងម៉ារា (ម៉ូសាយ ៣:៨; ១៥:១; ៣ នីហ្វៃ ១៥:១–៥) ។ តាមធម្មតា កាលណាមានពាក្យ*ព្រះអម្ចាស់* នៅក្នុងព្រះគម្ពីរសញ្ញាចាស់ នោះមានន័យដល់ ព្រះយេហូវ៉ា ។

*ព្រះយេហូវ៉ា ជាព្រះគ្រីស្ទ៖* ព្រះយេហូវ៉ាគឺជាព្រះនាមដែលបានស្គាល់ដោយពួកព្យាការីពីបុរាណ (និក្ខ. ៦:៣; អ័ប្រា. ១:១៦) ។ សាវកប៉ុលបានបង្រៀនថា ព្រះគ្រីស្ទ គឺជាព្រះយេហូវ៉ានៅក្នុងព្រះគម្ពីរសញ្ញាចាស់ (និក្ខ. ១៧:៦; ១ កូរិន. ១០:១–៤) ។ បងប្រុស របស់យ៉ារេឌ នៅក្នុងព្រះគម្ពីរមរមនបានឃើញព្រះគ្រីស្ទមុនផែនដី ហើយបានថ្វាយបង្គំទ្រង់ (អេធើរ ៣:១៣–១៥) ។ ម៉ូរ៉ូណៃក៏បានហៅព្រះគ្រីស្ទថា ព្រះយេហូវ៉ា (ម៉ូរ៉ូណៃ ១០:៣៤) ។ នៅព្រះវិហារខឺឡង់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី បានឃើញព្រះយេហូវ៉ាដែលមានព្រះជន្មរស់ឡើងវិញ (គ. និង ស. ១១០:៣–៤) ។

**ព្រះរាជបុត្រានៃព្រះ** *សូមមើល* ក្រុមព្រះ; ព្រះ; ព្រះយេស៊ូវគ្រីស្ទ

**ព្រះវរបិតាដ៏គង់នៅអស់កល្បជានិច្ច** *សូមមើល* ក្រុមព្រះ, ព្រះ, ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌

**ព្រះវរបិតាដែលគង់នៅស្ថានសួគ៌** *សូមមើលផង* ក្រុមព្រះ, ព្រះ

ជាព្រះវរបិតានៃវិញ្ញាណរបស់មនុស្សលោកទាំងអស់ (ទំនុក. ៨២:៦; ម៉ាថាយ ៥:៤៨; យ៉ូហាន ១០:៣៤; រ៉ូម ៨:១៦–១៧; កាឡាទី ៤:៧; ១ យ៉ូហាន ៣:២) ។ ព្រះយេស៊ូវជាព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់នៅក្នុងសាច់ឈាម ។ មនុស្សត្រូវបានបញ្ជាឲ្យគោរពហើយកោតខ្លាចដល់ព្រះវរបិតា ហើយឲ្យអធិស្ឋានទៅទ្រង់ ដោយនូវព្រះនាមនៃព្រះយេស៊ូវ ។

បើអ្នករាល់គ្នាអត់ទោសឲ្យមនុស្ស នោះព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងអត់ទោសឲ្យអ្នករាល់គ្នាដែរ, **ម៉ាថាយ** ៦:១៤ (ម៉ាថាយ ១៨:៣៥; ៣ នីហ្វៃ ១៣:១៤) ។ ព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយថា អ្នករាល់គ្នាត្រូវការនឹង របស់ទាំងនោះ, **ម៉ាថាយ** ៦:២៦–៣៣ (៣ នីហ្វៃ ១៣:២៦–៣៣) ។ ព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ តើទ្រង់នឹងប្រទាន ព្រះវិញ្ញាណបរិសុទ្ធមកអ្នកដែលសូម ជាជាងអម្បាលម៉ានទៅទៀត ? **លូកា** ១១:១១–១៣ ។ សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃ ព្រះអម្ចាស់របស់យើង គឺជាព្រះយេស៊ូវគ្រីស្ទ, **អេភេ.** ១:៣ ។ អ្នករាល់គ្នាជាប់ជំពាក់គុណ ដល់អស់កល្បជានិច្ច ដល់ព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌, **ម៉ូសាយ** ២:៣៤ ។ ព្រះគ្រីស្ទ ទ្រង់បានដំកើងព្រះនាមនៃព្រះវរបិតា, **អេធើរ** ១២:៨ ។ ពួកបរិសុទ្ធត្រូវធ្វើ បន្ទាល់អំពីការបៀតបៀនរបស់ពួកគេទាំងប៉ុន្មាន មុនព្រះវរបិតានឹងយាងចេញមកពីទីពួនរបស់ទ្រង់, **គ. និង ស.** ១២៣:១–៣, ៦ ។ យើងបានព្រះពរដ៏ធំ និងរុងរឿងពីព្រះវរបិតារបស់យើង ដែលគង់នៅស្ថានសួគ៌, **យ.ស.** — ប្រវត្តិ ១:៧៣ ។

**ព្រះវរបិតាសួគ៌** *សូមមើល* ក្រុមព្រះ, ព្រះ, ព្រះវរបិតា ដែលគង់នៅស្ថានសួគ៌

**ព្រះវិញ្ញាណដែលបរិសុទ្ធ** *សូមមើល* ព្រះវិញ្ញាណបរិសុទ្ធ

**ព្រះវិញ្ញាណបរិសុទ្ធ***សូមមើលផង* ការបំផុសគំនិត; ក្រុមព្រះ; ធ្វើបុណ្យជ្រមុជទឹក; ទីសំគាល់ជា; បាបដ៏អត់ឱនមិនបាន, បុណ្យជ្រមុជទឹក, បំផុសគំនិត, ព្រាប, ព្រះដ៏ជាជំនួយ; ព្រះ, ព្រះវិញ្ញាណបរិសុទ្ធ; ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា; វិវរណៈ; អំណោយទានជា

ជាសមាជិកទីបីក្នុងក្រុមព្រះ (១ យ៉ូហាន ៥:៧; គ. និង ស. ២០:២៨) ។ ទ្រង់ជាតួអង្គនៃព្រះវិញ្ញាណ គឺមិនមានព្រះកាយជាសាច់និងឆ្អឹងឡើយ (គ. និង ស. ១៣០:២២) ។ ជួនកាល ព្រះវិញ្ញាណបរិសុទ្ធត្រូវហៅថា ព្រះវិញ្ញាណ ឬព្រះវិញ្ញាណនៃព្រះ ។

ព្រះវិញ្ញាណបរិសុទ្ធធ្វើមុខងារសំខាន់ៗជាច្រើន នៅក្នុងផែនការនៃសេចក្ដីសង្គ្រោះ ។ (១) ទ្រង់ធ្វើទីបន្ទាល់អំពីព្រះវរបិតា និង ព្រះរាជបុត្រា (១ កូរិន. ១២:៣; ៣ នីហ្វៃ ២៨:១១; អេធើរ ១២:៤១) ។ (២) ទ្រង់បើកសម្ដែងសេចក្ដីពិតអំពីការណ៍ទាំងអស់ (យ៉ូហាន ១៤:២៦; ១៦:១៣; មរ៉ូណៃ ១០:៥; គ. និង ស. ៣៩:៦) ។ (៣) ទ្រង់ញែកពួកអ្នកទាំងឡាយណាដែលបានប្រែចិត្ត ហើយបានទទួលបុណ្យជ្រមុជទឹកចេញជាបរិសុទ្ធ (យ៉ូហាន ៣:៥; ៣ នីហ្វៃ ២៧:២០; ម៉ូសេ ៦:៦៤–៦៨) ។ (៤) ទ្រង់ជាព្រះ វិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា (គ. និង ស. ៧៦:៥០–៥៣; ១៣២:៧, ១៨–១៩, ២៦) ។

ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ អាចមកសណ្ឋិតលើមនុស្សណាមួយ មុនបុណ្យជ្រមុជទឹក ហើយធ្វើបន្ទាល់ថា ដំណឹងល្អនោះពិត ។ ប៉ុន្តែសិទ្ធិដើម្បីមានគុកនៃព្រះវិញ្ញាណបរិសុទ្ធជានិច្ច កាលណាមនុស្សសក្ដិសម នោះគឺជាអំណោយទានដែលអាចបានទទួល ដោយ ការដាក់ដៃលើ ដោយអ្នកកាន់បព្វជិតភាពមិលគីស្សាដែក ក្រោយពីបានទទួលបុណ្យជ្រមុជទឹកដោយត្រឹមត្រូវ ចូលសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទពិតប៉ុណ្ណោះ ។

ព្រះយេស៊ូវទ្រង់បានបង្រៀនថា គ្រប់អស់ទាំងអំពើបាបអាចបានអត់ឱនឲ្យ លើកលែងតែការប្រមាថជំទាស់ដល់ព្រះវិញ្ញាណបរិសុទ្ធ (ម៉ាថាយ ១២:៣១–៣២; ម៉ាកុស ៣:២៨–២៩; លូកា ១២:១០; ហេព្រើរ ៦:៤–៨; គ. និង ស. ៧៦:៣៤–៣៥) ។

ព្រះវិញ្ញាណបណ្ដាលឲ្យមនុស្សដើរតាមក្រិត្យក្រមរបស់ព្រះ, **អេសេ.** ៣៦:២៧ ។ ពួកសាវកត្រូវបានបញ្ជាឲ្យធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ, **ម៉ាថាយ** ២៨:១៩ ។ ព្រះវិញ្ញាណបរិសុទ្ធ ទ្រង់នឹងបង្រៀន អ្នករាល់គ្នាពីគ្រប់សេចក្ដីទាំងអស់, **យ៉ូហាន** ១៤:២៦ ។ មនុស្សបរិសុទ្ធ ដែលបានទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធបានបណ្ដាល, **២ ពេត្រុស** ១:២១ ។ នីហ្វៃត្រូវបានដឹកនាំដោយព្រះវិញ្ញាណ, **១ នីហ្វៃ** ៤:៦ ។ ការអាថ៌កំបាំងទាំងឡាយនៃព្រះនឹងបានបង្ហាញដល់គេ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ, **១ នីហ្វៃ** ១០:១៧–១៩ ។ ព្រះវិញ្ញាណបរិសុទ្ធបង្ហាញនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ, **២ នីហ្វៃ** ៣២:៥ ។ ដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នានឹងបានដឹងនូវសេចក្ដីពិតនៃការណ៍គ្រប់យ៉ាង, **មរ៉ូណៃ** ១០:៥ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងប្រាប់អ្នក នៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នក, **គ. និង ស.** ៨:២ ។ ព្រះវិញ្ញាណនឹងនាំឲ្យធ្វើល្អ, **គ. និង ស.** ១១:១២ ។ ព្រះវិញ្ញាណបរិសុទ្ធជ្រាបគ្រប់ទាំងអស់, **គ. និង ស.** ៣៥:១៩ ។ ព្រះវិញ្ញាណបរិសុទ្ធបង្រៀនអំពីការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តនៃនគរ, **គ. និង ស.** ៣៦:២ (គ. និង ស. ៣៩:៦) ។ បើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ, **គ. និង ស.** ៤២:១៤ ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើទីបន្ទាល់ពីព្រះវរបិតា និងពីព្រះរាជបុត្រា, **គ. និង ស.** ៤២:១៧ (១ កូរិន. ១២:៣; ៣ នីហ្វៃ ១១:៣២, ៣៥–៣៦) ។ ចំពោះមនុស្សខ្លះ ត្រូវបានប្រទាន ដោយព្រះវិញ្ញាណបរិសុទ្ធ ឲ្យដឹងថា ព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ, **គ. និង ស.** ៤៦:១៣ ។ អ្វីក៏ដោយដែលពួកគេ នឹងនិយាយ កាលណាបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាបទគម្ពីរ, **គ. និង ស.** ៦៨:៤ ។ ព្រះវិញ្ញាណបរិសុទ្ធនឹង ត្រូវចាត់ឲ្យមក ដើម្បីថ្លែងទីបន្ទាល់អំពីអ្វីៗ ទាំងអស់ ដែលអ្នករាល់គ្នាត្រូវនិយាយ, **គ. និង ស.** ១០០:៨ ។ ព្រះវិញ្ញាណបរិសុទ្ធនឹង ទៅជាគូកនអ្នកជានិច្ច, **គ. និង ស.** ១២១:៤៥–៤៦ ។

**ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា** *សូមមើលផង* ព្រះវិញ្ញាណបរិសុទ្ធ

ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា (កិច្ចការ ២:៣៣) ។ ទ្រង់បញ្ជាក់នូវសេចក្ដីសុចរិត ពិធីបរិសុទ្ធ និង សេចក្ដីសញ្ញានៃមនុស្ស ដែលរាប់ថាគួរសមដល់ព្រះ ។ ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ធ្វើទីបន្ទាល់ដល់ព្រះវរបិតា ថាពិធីបរិសុទ្ធ ទាំងឡាយខាងការសង្គ្រោះ នោះបានធ្វើដោយត្រឹមត្រូវ ហើយថា សេចក្ដីសញ្ញាដែលរួមនឹងពិធីទាំងនោះ នោះក៏បានកាន់តាម ។

ពួកគេនេះហើយដែលបានភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ហើយបានទទួលនូវគ្រប់ទាំងអ្វីៗដែលព្រះវរបិតាទ្រង់មាន, **គ. និង ស.** ៧៦:៥១–៦០ (អេភេ. ១:១៣–១៤) ។ គ្រប់ទាំងសេចក្ដីសញ្ញា និងការប្រព្រឹត្តិទាំងឡាយ ត្រូវតែបានភ្ជាប់ដោយព្រះវិញ្ញាណ បរិសុទ្ធនៃសេចក្ដីសន្យា ដើម្បីឲ្យមានប្រសិទ្ធិភាព បន្ទាប់ពីជីវិតនេះទៅ, **គ. និង ស.** ១៣២:៧, ១៨–១៩, ២៦ ។

**ព្រះវិហារបរិសុទ្ធ, ដំណាក់នៃព្រះអម្ចាស់** *សូមមើលផង* បរិសុទ្ធលើអស់ទាំងបរិសុទ្ធ; ពិធីបរិសុទ្ធទាំងឡាយ; រោងឧបោសថ, អំណោយបរិសុទ្ធ

គឺពិតជាដំណាក់នៃព្រះអម្ចាស់ ។ ព្រះអម្ចាស់ទ្រង់បានបង្គាប់រាស្ត្រទ្រង់ជាដរាបឲ្យសង់ព្រះវិហារបរិសុទ្ធទាំងឡាយ គឺជាអគារដ៏បរិសុទ្ធទាំងឡាយ សំរាប់ពួកបរិសុទ្ធដ៏សក្ដិសមធ្វើពិធីពិសិដ្ឋ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អសំរាប់ខ្លួន និងជំនួសមនុស្សស្លាប់ ។ ព្រះអម្ចាស់ ទ្រង់យាងមកឯព្រះវិហារបរិសុទ្ធទាំងឡាយរបស់ទ្រង់ ហើយព្រះវិហារបរិសុទ្ធទាំងប៉ុន្មានសុទ្ធតែបរិសុទ្ធបំផុត លើអស់ទាំងកន្លែងថ្វាយបង្គំ ។

រោងឧបោសថ ដែលលោកម៉ូសេ និងពួកកូនចៅអ៊ីស្រាអែលបាន

សង់ នោះគឺជាព្រះវិហារបរិសុទ្ធ ដែលរើចុះទៅណាបាន ។ ពួកសាសន៍អ៊ីស្រាអែលបានប្រើរោងឧបោសថ កាលពួកគេចេញពីស្រុកអេស៊ីព្ទ ។

ព្រះវិហារបរិសុទ្ធដែលមានគេឯងស្គាល់ជាងគេ ដែលពោលដល់នៅក្នុងព្រះគម្ពីរប៊ីប គឺជាព្រះវិហារបរិសុទ្ធដែលហ្លួងសាឡូម៉ូនបានសង់នៅក្រុងយេរូសាឡិម (២ របា. ២–៥) ។ ព្រះវិហារបរិសុទ្ធនោះត្រូវបានបំផ្លាញចោលនៅឆ្នាំ ៦០០ ម.គ.ស. ដោយពួកបាប៊ីឡូន ហើយបានសង់ឡើងវិញដោយសូរ៉ូបាបិល ជិតដល់ទៅ ១០០ ឆ្នាំក្រោយមក (អែសរ៉ា ១–៦) ។ ផ្នែកខ្លះនៃព្រះវិហារបរិសុទ្ធនេះ ត្រូវបានឆេះនៅឆ្នាំ ៣៧ ម.គ.ស. ហើយក្រោយមក ស្ដេចហេរ៉ូឌដ៏ធំបានសង់ឡើងវិញ ។ ពួកសាសន៍រ៉ូមបានបំផ្លាញព្រះវិហារបរិសុទ្ធ ចោលនៅឆ្នាំ ៧០ គ.ស. ។

នៅក្នុងព្រះគម្ពីរមរមន ពួកអ្នកដើរតាមដ៏សុចរិតរបស់ព្រះ ត្រូវបានដឹកនាំឲ្យសង់ ហើយថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធ (២ នីហ្វៃ ៥:១៦; ម៉ូសាយ ១:១៨; ៣ នីហ្វៃ ១១:១) ។ ការសង់ និងការប្រើព្រះវិហារបរិសុទ្ធតាមរបៀបត្រឹមត្រូវ គឺជាទីសំគាល់ទាំងឡាយ អំពីសាសនាចក្រពិត នៅគ្រាកាន់កាប់ត្រួតត្រាណាមួយ រួមទាំងសាសនាចក្រដែលសាងឡើងវិញនៅសម័យពួកយើង ។ ព្រះវិហារបរិសុទ្ធខឺតឡង់ គឺជាព្រះវិហារបរិសុទ្ធមុនដំបូងដែលបានសង់ឡើង ហើយថ្វាយដល់ព្រះអម្ចាស់ នៅគ្រាកាន់កាប់ត្រួតត្រានេះ ។ ចាប់តាំងពីពេលនោះមក មានព្រះវិហារបរិសុទ្ធទាំងឡាយដែលបានថ្វាយដល់ព្រះ នៅផែនដីជាច្រើន នៅលើផែនដី ។

តើអ្នកណានឹងឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់បាន ? **ទំនុក.** ២៤:៣–៥ ។ ចូរយើងឡើងទៅឯព្រះវិហារនៃព្រះរបស់យ៉ាកុបចុះ, **អេសាយ** ២:២–៣ (មីកា ៤:១–២; ២ នីហ្វៃ ១២:២–៣) ។ ព្រះអម្ចាស់ទ្រង់នឹងយាងមកដល់ព្រះវិហាររបស់ទ្រង់ភ្លាម, **ម៉ាឡាគី** ៣:១ (៣ នីហ្វៃ ២៤:១; គ. និង ស. ៣៦:៨; ៤២:៣៦) ។ ព្រះយេស៊ូវទ្រង់បានសំអាតព្រះវិហារ, **ម៉ាថាយ** ២១:១២–១៦ (ម៉ាកុស ១១:១៥–១៨; លូកា ១៩:៤៥–៤៨) ។ ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យសង់ព្រះវិហារបរិសុទ្ធមួយនៅរដ្ឋមិសសួរី, **គ. និង ស.** ៥៧:៣ (គ. និង ស. ៨៤:៣–៥) ។ ចូរតាំងដំណាក់មួយនៃព្រះឡើង, **គ. និង ស.** ៨៨:១១៩ (គ. និង ស. ១០៩:៨) ។ ព្រះអម្ចាស់ទ្រង់បានវាយ ផ្ចាលពួកបរិសុទ្ធ មកពីពុំបានសង់ព្រះវិហារបរិសុទ្ធ, **គ. និង ស.** ៩៥:១–១២ ។ យើងនឹងមិនចូលក្នុងព្រះវិហារបរិសុទ្ធទាំងឡាយណា ដែលមិនបរិសុទ្ធឡើយ, **គ. និង ស.** ៩៧:១៥–១៧ ។ យើងបានទទួលដំណាក់នេះហើយ ហើយព្រះនាមរបស់យើងនឹងស្ថិតនៅទីនេះ, **គ. និង ស.** ១១០:៧–៨ ។ រាស្ត្ររបស់ព្រះអម្ចាស់ត្រូវបានបញ្ជារហូត ឲ្យស្ថាបនាដំណាក់មួយដល់ព្រះនាមរបស់ទ្រង់, **គ. និង ស.** ១២៤:៣៩ ។ កិច្ចការដ៏ធំ ដែលត្រូវធ្វើនៅក្នុងព្រះវិហារបរិសុទ្ធទាំងឡាយនៃព្រះអម្ចាស់ មាននូវការភ្ជាប់កូនចៅទៅឯមាតាបិតាគេ, **គ. និង ស.** ១៣៨:៤៧–៤៨ ។ កិច្ចការដ៏ធំនៅថ្ងៃចុងក្រោយ មានរួមនូវការកសាងព្រះវិហារបរិសុទ្ធទាំងឡាយ, **គ. និង ស.** ១៣៨:៥៣–៥៤ ។

**ព្រះវិហារបរិសុទ្ធខឺតឡង់**

ជាព្រះវិហារបរិសុទ្ធមុនដំបូងដែលបានសាងឡើងដោយសាសនាចក្រនៅសម័យទំនើបនេះ ។ ពួកបរិសុទ្ធបានសង់ព្រះវិហារបរិសុទ្ធ នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ សហរដ្ឋអាមេរិក ស្របតាមបញ្ជារបស់ព្រះអម្ចាស់ (គ. និង ស. ៩៤:៣–៩) ។ គោលបំណងតែមួយគត់ គឺដើម្បីផ្ដល់នូវកន្លែងមួយ សំរាប់ឲ្យសមាជិកដ៏សក្ដិសមក្នុងសាសនាចក្រអាចទទួលអំណាច សិទ្ធិអំណាច និងការបំភ្លឺខាងវិញ្ញាណ (គ. និង ស. ១០៩; ១១០) ។ បានធ្វើពិធីឆ្លងព្រះវិហារបរិសុទ្ធនៅថ្ងៃទី ២៧ មីនា ឆ្នាំ ១៨៣៦ បទអធិស្ឋានឆ្លងត្រូវបានថ្វាយដោយព្យាការី យ៉ូសែប ស្ម៊ីធ ដោយ វិវរណៈ (គ. និង ស. ១០៩) ។ ព្រះអម្ចាស់ទ្រង់បានប្រទានវិវរណៈសំខាន់ៗជាច្រើន ហើយបានសាងឡើងវិញ នូវកូនសោទាំងឡាយនៃបព្វជិតភាពដែលត្រូវការនៅក្នុងព្រះវិហារបរិសុទ្ធនេះ (គ. និង ស. ១១០: ១៣៧) ។ ព្រះវិហារបរិសុទ្ធនេះ ពុំបានប្រើសំរាប់ពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធទាំងស្រុង ដូចដែលបានប្រទាននៅក្នុងព្រះវិហារបរិសុទ្ធសព្វថ្ងៃនេះទេ ។

**ព្រះអង្គ** *សូមមើល* ការរួបរួមតែមួយ, ក្រុមព្រះ; ព្រះ

**ព្រះអង្គសង្គ្រោះ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ជាព្រះដែលជួយសង្គ្រោះ ។ តាមរយៈដង្វាយធួនរបស់ទ្រង់ នោះព្រះយេស៊ូវគ្រីស្ទបានប្រទានឲ្យនូវសេចក្ដីប្រោសលោះ និងសេចក្ដី សង្គ្រោះដល់មនុស្សលោកទាំងអស់ ។ « ព្រះអង្គសង្គ្រោះ » គឺជាឈ្មោះ និងព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ ។

ព្រះអម្ចាស់ ទ្រង់ជាពន្លឺ ហើយជាសេចក្ដីសង្គ្រោះរបស់ខ្ញុំ, **ទំនុក.** ២៧:១ (និក្ខ. ១៥:១–២; ២សាំយូ. ២២:២–៣) ។ អញជាព្រះអម្ចាស់ ក្រៅពីអញ គ្មានអ្នកសង្គ្រោះណាទៀតឡើយ, **អេសាយ** ៤៣:១១ (គ. និង ស. ៧៦:១) ។ ចូរថ្វាយព្រះនាមថា យេស៊ូវ ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប, **ម៉ាថាយ** ១:២១ ។ នៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គ ប្រសូតដល់អ្នករាល់គ្នា គឺជាព្រះគ្រីស្ទ ដ៏ជាព្រះអម្ចាស់, **លូកា** ២:១១ ។ ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាព្រះរាជបុត្រាបង្កើតតែមួយយាងមកជួយ សង្គ្រោះមនុស្សលោក, **យ៉ូហាន** ៣:១៦–១៧ ។ គ្មាននាមឈ្មោះណាទៀតក្រៅពីព្រះនាមនៃព្រះគ្រីស្ទ ដែលឲ្យមនុស្សបានសង្គ្រោះ នោះឡើយ, **កិច្ចការ** ៤:១០–១២ (២ នីហ្វៃ ២៥:២០; ម៉ូសាយ ៣:១៧; ៥:៨; គ. និង ស. ១៨:២៣; ម៉ូសេ ៦:៥២) ។ យើងរាល់គ្នា នៅចាំព្រះអង្គសង្គ្រោះ ជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់យាងមកពីស្ថានសួគ៌, **ភីលីព** ៣:២០ ។ ព្រះវរបិតាបានចាត់ព្រះរាជបុត្រាមកធ្វើ ជាព្រះអង្គសង្គ្រោះនៃមនុស្សលោក, **១ យ៉ូហាន** ៤:១៤ ។ ព្រះអម្ចាស់ទ្រង់បានបង្កើតព្រះមែស៊ីឡើង គឺជាព្រះអង្គសង្គ្រោះនៃមនុស្ស លោក, **១ នីហ្វៃ** ១០:៤ ។ កូនចៀមនៃព្រះ គឺជាព្រះអង្គសង្គ្រោះនៃមនុស្សលោក, **១ នីហ្វៃ** ១៣:៤០ ។ ការចេះដឹងអំពីព្រះអង្គសង្គ្រោះ នឹងបានផ្សាយពេញគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន, **ម៉ូសាយ** ៣:២០ ។ ព្រះគ្រីស្ទទ្រង់បានសុគត ដើម្បីឲ្យសេចក្ដីសង្គ្រោះអាចកើតមានឡើង, **ហេលេ.** ១៤:១៥–១៦ ។ ការរាប់ជាសុចរិត និងការញែកជាបរិសុទ្ធ តាមរយៈព្រះ យេស៊ូវគ្រីស្ទ នោះ

គឺយុត្តិធម៌ និងត្រឹមត្រូវ, **គ. និង ស.** ២០:៣០–៣១ ។ យើងជាព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក, **គ. និង ស.** ៤៣:៣៤ ។ ព្រះរាជបុត្រាបង្កើតតែមួយរបស់យើង គឺជាព្រះអង្គសង្គ្រោះ, **ម៉ូសេ** ១:៦ ។ មនុស្សជាច្រើនណាដែលជឿដល់ ព្រះរាជបុត្រា ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេ នោះនឹងបានសង្គ្រោះ, **ម៉ូសេ** ៥:១៥ ។

**ព្រះអម្ចាស់** *សូមមើលផង* ក្រុមព្រះ; ព្រះ, ព្រះយេស៊ូវគ្រីស្ទ

ជាព្រះនាមមួយដែលមានការគោរពជ្រាលជ្រៅ និងកិត្តិយស សំរាប់ព្រះដ៏ជាព្រះវរបិតា និងព្រះអង្គសង្គ្រោះយេស៊ូវគ្រីស្ទ ។ ជាព្រះ នាមថ្វាយដល់មុខងារព្រះអាទិទេព ជាចៅហ្វាយដ៏ជាទីស្រឡាញ់លើរបស់របរដែលបានបង្កើតមក ។

ឥតមានការអ្វីដែលព្រះអម្ចាស់ទ្រង់ធ្វើមិនកើតឡើយ, **លោកុ.** ១៨:១៤ ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលប្រទល់មុខនឹងម៉ូសេ, **និក្ខ.** ៣៣:១១ ។ ត្រូវឲ្យឯងស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់ពីចិត្ត, **ចោទិ.** ៦:៥ (ម៉ាថាយ ២២:៣៧; ម៉ាកុស ១២:៣០) ។ ឯអញ និងពួក គ្រួអញ យើងរាល់គ្នានឹងគោរពប្រតិបត្តិដល់ព្រះអម្ចាស់តែមួយប៉ុណ្ណោះ, **យ៉ូស្វេ** ២៤:១៥ ។ ព្រះអម្ចាស់ទ្រង់ជាអ្នកគង្វាលខ្ញុំ, **ទំនុក.** ២៣:១ ។ ព្រះអម្ចាស់ ទ្រង់មានព្រះចេស្តា និងឥទ្ធិឫទ្ធិ ដ៏មានឥទ្ធិឫទ្ធិក្នុងចំបាំង, **ទំនុក.** ២៤:៨ ។ ព្រះអម្ចាស់ ដ៏ជាព្រះយេហូវ៉ា ទ្រង់ជា កំឡាំងរបស់ខ្ញុំ, **អេសាយ** ១២:២ (២ នីហ្វៃ ២២:២) ។ អញនេះគឺព្រះអម្ចាស់ ជាព្រះដ៏ជួយសង្គ្រោះឯង ហើយជាព្រះដ៏ប្រោសលោះ ឯង, **អេសាយ** ៦០:១៦ ។ ឯងត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃឯង, **ម៉ាថាយ** ៤:១០ (លូកា ៤:៨) ។ ការធំទាំងម្លេះ ដែលព្រះ អម្ចាស់បានមេត្តាប្រោស, **ម៉ាកុស** ៥:១៩ ។ ក៏មានព្រះអម្ចាស់តែមួយ គឺព្រះយេស៊ូវគ្រីស្ទ, **១ កូរិន.** ៨:៦ ។ មានព្រះអម្ចាស់តែមួយ សេចក្តីជំនឿតែមួយ បុណ្យជ្រមុជទឹកតែមួយ, **អេភេ.** ៤:៥ ។ ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក, **១ ថែស្ស.** ៤:១៦ ។ ខ្ញុំនឹង ទៅ ហើយធ្វើនូវអ្វីៗ ដែលព្រះអម្ចាស់ ទ្រង់បានបញ្ជា, **១ នីហ្វៃ** ៣:៧ ។ ព្រះអម្ចាស់ទ្រង់នឹងជំនុំជំរះអ្នកទាល់ក្រ ដោយសេចក្តីសុចរិត, **២ នីហ្វៃ** ៣០:៩ ។ ព្រះអម្ចាស់ដ៏ជាព្រះ គឺជាព្រះនៃអ័ប្រាហាំ បានដោះលែងពួកសាសន៍អ៊ីស្រាអែលឲ្យរួចផុតពីសេវកភាព, **អាលម៉ា** ២៩:១១ ។ គ្មានអ្វីអាចជួយសង្គ្រោះប្រជាជននេះបានឡើយ លើកលែងតែមានការប្រែចិត្ត និងសេចក្តីជំនឿជឿដល់ព្រះអម្ចាស់, **ហេលេ.** ១៣:៦ (ម៉ូសាយ ៣:១២) ។ ចូរស្តាប់តាមព្រះបន្ទូលទាំងឡាយនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់អ្នកចុះ, **គ. និង ស.** ១៥:១ ។ ចូរស្វែងរកព្រះភ័ក្ត្រនៃព្រះអម្ចាស់ជានិច្ច, **គ. និង ស.** ១០១:៣៨ ។ ព្រះអម្ចាស់ទ្រង់នឹងពាក់ព្រះពស្ត្រពណ៌ក្រហម នៅគ្រា យាងមកលើកទីពីរ, **គ. និង ស.** ១៣៣:៤៨ (អេសាយ ៦៣:១–៤) ។ អ័ប្រាហាំបានទូលជាមួយនឹងព្រះអម្ចាស់ ប្រទល់មុខគ្នា, **អ័ប្រា.** ៣:១១ ។ យើងខ្ញុំជឿថា គោលការណ៍ទីមួយនៃដំណឹងល្អ គឺសេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ, **ម. នៃ ស.** ១:៤ ។

**ព្រះអម្ចាស់នៃពួកពលបរិវារ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ជាព្រះនាមមួយទៀតសំរាប់ព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់សោយរាជ្យលើពួកពលបរិវារនៅលើស្ថានសួគ៌ និងនៅលើផែនដី ហើយនាំពួក សុចរិតទាស់នឹងអំពើអាក្រក់ (គ. និង ស. ២៩:៩; ១២១:២៣) ។

ព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់ជាមហាក្សត្រដ៏មានសិរីល្អ, **ទំនុក.** ២៤:១០ ។ ព្រះនៃសាសន៍អ៊ីស្រាអែល ដែលជាព្រះអម្ចាស់នៃ ពួកពលបរិវារ, **១ នីហ្វៃ** ២០:២ ។ វិញ្ញាណរបស់យើងនឹងពុំតស៊ូគង់នៅជាមួយនឹងមនុស្សជានិច្ចទេ ព្រះអម្ចាស់នៃពួកពលបរិវារមាន ព្រះបន្ទូលថាដូច្នោះ, **គ. និង ស.** ១:៣៣ ។

**ភាពជាព្រះ** *សូមមើល* ជីវិតដ៏នៅអស់កល្បជានិច្ច, បុរស,
បុរសទាំងឡាយ — បុរស, ភាពថ្កើងថ្កានឡើង;
សមត្ថភាពនឹងក្លាយទៅដូចជា ព្រះវរបិតាសួគ៌

**ភាពដំកើងឡើង** *សូមមើលផង* ជីវិតដ៏នៅអស់កល្បជានិច្ច;
ដង្វាយធួន; ធ្វើឲ្យធួន, បុរស, បុរសទាំង ឡាយ — បុរស,
មកុដ; សមត្ថភាពនឹងក្លាយទៅដូចជាព្រះវរបិតាសួគ៌,
សិរីល្អខាងសេឡេស្ទាល

ជាស្ថានភាពដ៏ខ្ពស់បំផុតនៃសុភមង្គល និងសិរីល្អ នៅក្នុងនគរសេឡេស្ទាល ។

នៅចំពោះទ្រង់មានសេចក្តីអំណរដ៏ពោរពេញ, **ទំនុក.** ១៦:១១ ។ ពួកគេសុទ្ធតែជាបណ្តាព្រះ គឺជាបុត្រានៃព្រះ — ហេតុដូច្នោះហើយ គ្រប់ទាំងអស់ជារបស់ផងពួកគេ, **គ. និង ស.** ៧៦:៥៨–៥៩ ។ ពួកបរិសុទ្ធនឹងត្រូវបានទទួលកេរ្តិ៍មរតករបស់ខ្លួន ហើយបានធ្វើឲ្យស្មើនឹង ព្រះអង្គ, **គ. និង ស.** ៨៨:១០៧ ។ ពួកទេវតាទាំងនេះពុំបាននៅជាប់នឹងក្រិត្យវិន័យរបស់យើងឡើយ; ហេតុដូច្នេះហើយ ពួកគេនៅ បែកគ្នាហើយនៅតែឯង ដោយគ្មានភាពដំកើងឡើងឡើយ, **គ. និង ស.** ១៣២:១៧ ។ មនុស្សប្រុសស្រីទាំងឡាយត្រូវតែរៀបការ តាមក្រិត្យវិន័យរបស់ព្រះ ដើម្បីឲ្យបានទទួលភាពដំកើងឡើង, **គ. និង ស.** ១៣២:១៩–២០ ។ ទ្វារនោះតូច ហើយផ្លូវក៏ចង្អៀតផង ដែលនាំទៅឯភាពដំកើងឡើង, **គ. និង ស.** ១៣២:២២–២៣ ។ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុបបានចូលទៅក្នុងភាពដំកើងឡើង របស់គេ, **គ. និង ស.** ១៣២:២៩, ៣៧ ។ យើងភ្ជាប់មកលើអ្នក នូវភាពដំកើងឡើងរបស់អ្នក, **គ. និង ស.** ១៣២:៤៩ ។

**ភាពតម្រូវទុកជាមុន** *សូមមើល* ការតែងតាំងមុនកំណើតលោកិយ

**ភាពទន់ខ្សោយ** *សូមមើលផង* ចិត្តសុភាពរាបសា, បន្ទាបខ្លួន

ជាលក្ខណៈនៃមនុស្ស និងការខ្វះខាតខាងការប៉ិនប្រសប់ កម្លាំង ឬក៏ការជំនាញ ។ ភាពទន់ខ្សោយ ជាស្ថានភាពនៃមនុស្ស ។ មនុស្សគ្រប់គ្នាសុទ្ធតែទន់ខ្សោយ ហើយមានតែតាមរយៈព្រះគុណនៃព្រះប៉ុណ្ណោះ ទើបពួកគេមានអំណាច ដើម្បីប្រព្រឹត្តអស់ទាំង កិច្ចការសុចរិតទាំងឡាយ

(យ៉ាកុប ៤:៦–៧) ។ ភាពទន់ខ្សោយនេះ គឺសម្ដែងនូវផ្នែកខាងភាពទន់ខ្សោយ ឬភាពទុរន់ទុរា ដែលជនម្នាក់ៗមាន ។

ចូរចំរើនកម្លាំងដៃដែលខ្សោយ, **អេសាយ** ៣៥:៣–៤ ។ វិញ្ញាណក៏ប្រុងជាស្រេចមែន តែសាច់ឈាមខ្សោយទេ, **ម៉ាថាយ** ២៦:៤១ (ម៉ាកុស ១៤:៣៨) ។ ដោយសារភាពទន់ខ្សោយ ដែលមាននៅក្នុងខ្លួនខ្ញុំស្របតាមសាច់ឈាមនោះទើបខ្ញុំបានដោះសាខ្លួនវិញ, **១ នីហ្វៃ** ១៩:៦ ។ ខ្ញុំត្រូវបានបញ្ជាឲ្យសរសេរការណ៍ទាំងនេះ ដោយមិនគិតដល់ភាពទន់ខ្សោយរបស់ខ្ញុំឡើយ, **២ នីហ្វៃ** ៣៣:១១ ។ សូមទ្រង់ កុំខ្វាល់នឹងអ្នកបំរើរបស់ទ្រង់ ដោយសារភាពទន់ខ្សោយរបស់គេឡើយ, **អេធើរ** ៣:២ ។ ពួកសាសន៍ដទៃនឹងចំអកឡកឡឺយដល់ ការណ៍ទាំងនេះដោយសារភាពទន់ខ្សោយរបស់យើងខ្ញុំ ខាងការសរសេរ, **អេធើរ** ១២:២៣–២៥, ៤០ ។ យើងនឹងបង្ហាញដល់ពួក សាសន៍ដទៃនូវភាពទន់ខ្សោយរបស់ពួកគេ, **អេធើរ** ១២:២៧–២៨ ។ ដោយសារអ្នកបានឃើញភាពទន់ខ្សោយរបស់អ្នក នោះអ្នកនឹង ត្រូវបានធ្វើឲ្យខ្លាំងក្លា, **អេធើរ** ១២:៣៧ ។ អ្នកណាដែលទន់ខ្សោយក្នុងចំណោមអ្នករាល់គ្នា នឹងត្រូវបានធ្វើឲ្យខ្លាំងក្លា ចាប់តាំងពីពេល នេះតទៅ, **គ. និង ស.** ៥០:១៦ ។ ព្រះយេស៊ូវគ្រីស្ទទ្រង់ជ្រាបនូវសេចក្ដីកំសោយនៃមនុស្ស, **គ. និង ស.** ៦២:១ ។

**ភាពនៃទឹកមុខ, សណ្ឋាន**

ភាពទូទៅនៃទឹកមុខរបស់ជននីមួយៗ ដែលតែងតែសម្ដែងនូវឥរិយាបថខាងវិញ្ញាណ និងស្ថានភាពនៃគំនិត ។

ភាពនៃទឹកមុខគេតែងធ្វើបន្ទាល់ទាស់នឹងគេ, **អេសាយ** ៣:៩ ។ ព្រះភ័ក្ត្របំព្រងនៃស្តេចក៏ផ្លាស់ប្រែទៅ ហើយគំនិតទ្រង់ក៏នាំឲ្យបារម្ភ ព្រួយវិញ, **ដានី.** ៥:៦ ។ សណ្ឋានរបស់ទេវតានោះ ដូចជាផ្លេកបន្ទោរ, **ម៉ាថាយ** ២៨:៣ ។ ព្រះភ័ក្ត្រទ្រង់ ដូចជាថ្ងៃភ្លឺពេញអំណាច, **វិវ.** ១:១៦ ។ តើអ្នករាល់គ្នាបានទទួលព្រះភ័ក្ត្ររបស់ព្រះ នៅក្នុងទឹកមុខអ្នករាល់គ្នាហើយឬនៅ, **អាលម៉ា** ៥:១៤, ១៩ ។ អាំម៉ូន បានឃើញទឹកមុខរបស់ស្ដេចផ្លាស់ប្ដូរ, **អាលម៉ា** ១៨:១២ ។ ចូរតមអាហារ ហើយអធិស្ឋាន ដោយអំណរគុណដោយទឹកចិត្ត និងទឹកមុខ រីករាយ, **គ. និង ស.** ៥៩:១៤–១៥ ។ ព្រះភ័ក្ត្ររបស់ទ្រង់ភ្លឺជាងពន្លឺថ្ងៃ, **គ. និង ស.** ១១០:៣ ។

**ភាពនៅលីវ** *សូមមើល* រៀបអាពាហ៍ពិពាហ៍, អាពាហ៍ពិពាហ៍

**ភាពរម្យទម** *សូមមើលផង* ចិត្តសុភាពរាបសា, បន្ទាបខ្លួន

ជាចរិយា ឬឫកពាដែលសុភាព រាបសា និងរម្យទម ។ មនុស្សរម្យទមចៀសវាងពីការហួសហេតុ និងការអួតអាង ។

ព្រះទ្រង់បានធ្វើអាវពីស្បែក ឲ្យអ័ដាម និងនាងអេវ៉ាពាក់បិទបាំងកាយ, **លោកុ.** ៣:២១ (ម៉ូសេ ៤:២៧) ។ ពួកស្ត្រីតែងខ្លួនតាមបែប គួរសម, ១ ធីម៉ូ. ២:៩ ។ ឲ្យមានចិត្តធ្ងន់ធ្ង ហើយបរិសុទ្ធ ជាអ្នករវល់តែនឹងការនៅផ្ទះខ្លួនចុះ, **ទីតុស** ២:៥ ។ មនុស្សជាច្រើនបាន លើកខ្លួនឡើង ក្នុងអំពើឆ្មើងឆ្មៃ ពីព្រោះមកតែសំលៀកបំពាក់របស់គេមានតម្លៃខ្ពស់, **យ៉ាកុប** ២:១៣ ។ ចូរឲ្យសំលៀកបំពាក់របស់អ្នក មានសម្បុរធម្មតា, **គ. និង ស.** ៤២:៤០ ។ យើងខ្ញុំជឿលើការប្រព្រឹត្តដោយបរិសុទ្ធ និងគុណធម៌, **ម.នៃ ស.** ១:១៣ ។

**ភាពអាសអាភាស** *សូមមើល* ព្រហ្មចារីភាព; អំពើកំផិត; អំពើសហាយស្មន់

**ភាពឥតទោស, ឥតទោស**

គឺគ្មានទោស ឬគ្មានបាប ។

មុនការធ្លាក់ នោះលោកអ័ដាម និងនាងអេវ៉ានៅក្នុងស្ថានភាពដ៏ឥតទោស, **២ នីហ្វៃ** ២:២៣ ។ ឈាមនៃពួកអ្នកឥតទោសនឹងឈរជាសាក្សី, **អាលម៉ា** ១៤:១១ ។ កាលដើមដំបូង វិញ្ញាណនៃមនុស្សគ្រប់រូបសុទ្ធតែឥតមានទោស, **គ. និង ស.** ៩៣:៣៨ ។ ពួកអ្នកឥតទោសមិនត្រូវជាប់ទោស ជាមួយនឹងពួកឥតសុចរិតឡើយ, **គ. និង ស.** ១០៤:៧ ។ យ៉ូសែប និងហៃរុម ស្ម៊ិធ ឥតមានទោសឧក្រិដ្ឋ អ្វីសោះ, **គ. និង ស.** ១៣៥:៦–៧ ។ ពួកកូនក្មេងនៅសុទ្ធសាធ ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ, **ម៉ូសេ** ៦:៥៤ ។

**ភាវនា** *សូមមើល* ពិចារណា

**ភាសា**

ជាពាក្យសរសេរ ឬនិយាយ ដែលផ្សំគ្នាតាមរបៀបណាមួយ ដើម្បីទាក់ទងគ្នាអំពីដំណឹង គំនិត និងយោបល់ ។ របៀបដែលយើងប្រើភាសាក៏បង្ហាញពីអារម្មណ៍ដែលយើងមានចំពោះព្រះ និងចំពោះមនុស្សដទៃយ៉ាងនោះដែរ ។ នៅពេលព្រះយេស៊ូវគ្រីស្ទយាងមកលើក ទីពីរនោះព្រះអម្ចាស់ទ្រង់នឹងប្រទានភាសាដ៏បរិសុទ្ធមួយ ដល់មនុស្សលោកទាំងអស់ (សេផា. ៣:៨–៩) ។

នៅផែនដីទាំងមូល នោះមានភាសាមានសំដីតែមួយ, **លោកុ.** ១១:១ ។ ព្រះអម្ចាស់ទ្រង់បានបំភាន់ភាសាលោកិយទាំងអស់, **លោកុ.** ១១:៤–៩ ។ គ្រប់គ្នាឮភាសាជាតិរបស់ខ្លួន, **កិច្ចការ** ២:១–៦ ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅមនុស្ស តាមភាសារបស់គេ, **២ នីហ្វៃ** ៣១:៣ (គ. និង ស. ១:២៤) ។ បេនយ៉ាមីនបានបង្រៀនបុត្រារបស់ទ្រង់ អំពីភាសារបស់ពួកអយ្យកោទ្រង់ ដើម្បីឲ្យគេអាចបានទៅជា មនុស្សប្រកបដោយយោបល់, **ម៉ូសាយ** ១:២–៥ ។ អ្នកណាដែលប្រើពាក្យសំដីសុភាពហើយស្អាងឡើង អ្នកនោះឈ្មោះថា មកពីព្រះ បើសិនជាអ្នកនោះគោរពតាមពិធីបរិសុទ្ធទាំងឡាយរបស់យើង, **គ. និង ស.** ៥២:១៦ ។ ចូរស្គាល់ជិតស្និទ្ធនូវភាសាទាំងឡាយ និងអណ្ដាតទាំងឡាយ និងប្រជាជន, **គ. និង ស.** ៩០:១៥ ។ អ័ដាម និងកូនចៅលោកមានភាសាដែលសុទ្ធសាធ និងមិនខូចខាត, **ម៉ូសេ** ៦:៥–៦, ៤៦ ។ ព្រះទ្រង់បានប្រទានឲ្យហេណុកមានអំណាចខាងភាសាដ៏ធំក្រៃលែង, **ម៉ូសេ** ៧:១៣ ។

**ភីលីព**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ភីលីព ពីស្រុកបេតសៃដា គឺជាសាវកម្នាក់ក្នុងពួក ១២ នាក់មុនលើកទីមួយនៃព្រះអង្គសង្គ្រោះ (ម៉ាថាយ ១០:២–៤; យ៉ូហាន ១:៤៣–៤៥) ។

មានភីលីពម្នាក់ទៀត គឺជាពួក ៧ នាក់ដែលបានរើសឲ្យជួយពួកសាវក ១២ នាក់ (កិច្ចការ ៦:២–៦) ។ លោកបានផ្សាយនៅស្រុកសាម៉ារី ហើយផ្សាយប្រាប់អ្នកកំរៀវសាសន៍អេធីយ៉ូពី (កិច្ចការ ៨) ។

**ភីលីព, សំបុត្រដល់ពួក** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាសំបុត្រមួយច្បាប់ ដែលប៉ុលបានសរសេរទៅពួកបរិសុទ្ធ នៅស្រុកភីលីព កាលលោកជាប់គុកលើកទីមួយនៅក្រុងរ៉ូម ។ ឥឡូវនេះ គឺជាគម្ពីរភីលីព នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

ជំពូកទី ១ មាននូវការសួរសុខទុក្ខ និងការបង្គាប់របស់ប៉ុល អំពីការសាមគ្គី ការបន្ទាបខ្លួន និងការស៊ូទ្រាំ ។ ជំពូកទី ២ បញ្ជាក់ថា មនុស្សទាំងអស់ នឹងត្រូវក្រាបថ្វាយព្រះគ្រីស្ទ ហើយថាមនុស្សគ្រប់រូបត្រូវបង្ហើយសេចក្ដីសង្គ្រោះរបស់ខ្លួន ។ នៅក្នុងជំពូកទី ៣ ប៉ុលបានពន្យល់ប្រាប់ថា លោកបានលះបង់ទាំងអស់ដើម្បីព្រះគ្រីស្ទ ។ នៅក្នុងជំពូកទី ៤ ប៉ុលបានអរគុណដល់ពួកបរិសុទ្ធនៅក្រុងភីលីព ចំពោះជំនួយរបស់ពួកគេ ។

**ភីលេម៉ូន** *សូមមើលផង* ប៉ុល

ជាអ្នកគ្រីស្ទានម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលមានបាវបំរើម្នាក់ឈ្មោះអូនេស៊ីម ដែលបានរត់ចេញ ទៅចូលរួមនឹងប៉ុល ។ ប៉ុលបានចាត់អូនេស៊ីមឲ្យទៅឯភីលេម៉ូនវិញ ព្រមទាំងផ្ញើសំបុត្រមួយច្បាប់ សូមឲ្យភីលេម៉ូនអត់ទោសឲ្យបាវបំរើរបស់ខ្លួនផង ។

**ភីលេម៉ូន, សំបុត្រដល់** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាគម្ពីរមួយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺបានដកយកមកពីសំបុត្រមួយច្បាប់ ដែលប៉ុលបានសរសេរ ។ សំបុត្ររបស់ប៉ុលដល់ភីលេម៉ូន គឺជាសំបុត្រផ្ទាល់ខ្លួន អំពីអូនេស៊ីម ជាបាវបំរើម្នាក់ ដែលបានប្លន់ភីលេម៉ូនជាចៅហ្វាយរបស់ខ្លួន ហើយបានរត់ទៅក្រុងរ៉ូម ។ ប៉ុលបាន ចាត់ឲ្យគាត់ទៅរកចៅហ្វាយរបស់ខ្លួន នៅស្រុកកូល៉ុសវិញ គឺទៅជាមួយនឹងទីឃីកុស ជាអ្នកកាន់សំបុត្រប៉ុលទៅពួកកូល៉ុស ។ ប៉ុលបាន សូមឲ្យលោកអត់ទោសឲ្យអូនេស៊ីម ហើយឲ្យទទួលគាត់យកវិញ ទុកដូចជាបងប្អូនគ្រីស្ទាន ។ ប៉ុលបានសរសេរសំបុត្រនេះ កាលលោកជាប់គុកលើកទីមួយនៅក្រុងរ៉ូម ។

**ភ្ជាប់, ការភ្ជាប់** *សូមមើលផង* បព្វជិតភាព, ពិធីបរិសុទ្ធទាំងឡាយ; អេលីយ៉ា

ដើម្បីធ្វើឲ្យមានសុពលភាពនៅលើស្ថានសួគ៌ អំពីពិធីបរិសុទ្ធទាំងឡាយ ដែលបានប្រព្រឹត្តដោយសិទ្ធិអំណាចនៃបព្វជិតភាព នៅលើផែនដី ។ ពិធីបរិសុទ្ធទាំងឡាយត្រូវបានភ្ជាប់ កាលណាពិធីទាំងនោះបានទទួលការអនុមតិពីព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា ដែលជា ព្រះវិញ្ញាណបរិសុទ្ធ ។

អ្វីៗដែលអ្នកនឹងចងទុកនៅផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ, **ម៉ាថាយ** ១៦:១៩ (ម៉ាថាយ ១៨:១៨; គ. និង ស. ១២៤:៩៣; ១៣២:៤៦) ។ អ្នករាល់គ្នាត្រូវបានដៅចំណាំ ដោយព្រះវិញ្ញាណបរិសុទ្ធដែលបានសន្យា, **អេភេ.** ១:១៣ ។ យើង ប្រទានឲ្យអ្នកនូវអំណាច ថា អ្វីក៏ដោយដែលអ្នកនឹងភ្ជាប់នៅលើផែនដី នោះនឹងត្រូវបានភ្ជាប់នៅលើស្ថានសួគ៌ដែរ, **ហេលេ.** ១០:៧ ។ ចំពោះពួកគេនេះហើយ ដែលបានទទួលអំណាច ដើម្បីភ្ជាប់នៅលើផែនដី ព្រមទាំងនៅលើស្ថានសួគ៌ផង, **គ. និង ស.** ១:៨ ។ អស់អ្នក ណាដែលនៅ ក្នុងសិរីល្អនៃសេឡេស្ទាល នោះត្រូវបានភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា, **គ.និង ស.** ៧៦:៥០–៧០ ។ អេលីយ៉ាប្រគល់កូនសោទាំងឡាយនូវអំណាចនៃការភ្ជាប់ដល់ដៃយ៉ូសែប ស៊្មីធ, **គ. និង ស.** ១១០:១៣–១៦ ។ នេះគឺជាអំណាចនៃការ ភ្ជាប់ និងការចង, **គ. និង ស.** ១២៨:១៤ ។ ពាក្យព្យាករណ៍ដ៏ពិតជាង មានន័យពីមនុស្សដែលដឹងខ្លួនថាបានភ្ជាប់ទុកចំពោះជីវិតដ៏នៅ អស់កល្បជានិច្ច, **គ. និង ស.** ១៣១:៥ ។ សេចក្ដីសញ្ញាទាំងអស់ណាដែលមិនបានភ្ជាប់ ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យា នោះកចប់ដែរ នៅពេលមនុស្សស្លាប់ទៅ, **គ. និង ស.** ១៣២:៧ ។ កិច្ចការដ៏ធំដែលត្រូវធ្វើនៅក្នុងព្រះវិហារបរិសុទ្ធទាំងឡាយមាន ទាំងការភ្ជាប់កូនចៅទៅឯមាតាបិតាគេ, **គ. និង ស.** ១៣៨:៤៧–៤៨ ។

**ភ្នែក, ភ្នែកទាំងឡាយ**

នៅក្នុងគម្ពីរ ភ្នែកតែងតែយកមកប្រើជានិមិត្តរូបអំពីសមត្ថភាពមនុស្ស ដើម្បីទទួលពន្លឺនៃព្រះ ។ តាមខាងនិមិត្តរូប ភ្នែកមនុស្សក៏បង្ហាញ នូវស្ថានភាពខាងវិញ្ញាណ និងយោបល់ខាងការណ៍ទាំងឡាយនៃព្រះ ។

ក្រិត្យក្រមនៃព្រះអម្ចាស់ជាសុទ្ធសាធ ក៏បំភ្លឺភ្នែក, **ទំនុក.** ១៩:៨ ។ ជនល្ងីល្ងើមានភ្នែក តែមើលមិនឃើញ, **យេរេ.** ៥:២១ (ម៉ាកុស ៨:១៨) ។ ចង្កៀងនៃរូបកាយ គឺជាភ្នែក, **ម៉ាថាយ** ៦:២២ (លូកា ១១:៣៤; ៣ នីហ្វៃ ១៣:២២; គ. និង ស. ៨៨:៦៧) ។ ភ្នែកអ្នក មានពរហើយ ត្បិតមើលឃើញ, **ម៉ាថាយ** ១៣:១៦ ។ ភ្នែកចិត្តរបស់អ្នករាល់គ្នានឹងបានភ្លឺឡើង, **អេភេ.** ១:១៧–១៨ ។ វេទនាដល់ពួក អ្នកដែលមានប្រាជ្ញានៅក្នុងភ្នែកខ្លួន, **២ នីហ្វៃ** ១៥:២១ (អេសាយ ៥:២១) ។ ពួកគេបានចាប់ផ្ដើមតមអាហារ ហើយអធិស្ឋាន សូមឲ្យ ភ្នែកមនុស្សបានបើក, **ម៉ូសាយ** ២៧:២២ ។ អារក្សសាតាំងបានធ្វើឲ្យភ្នែកគេខ្វាក់, ៣ នីហ្វៃ ២:២ ។ គ្មានអ្នកណាមានអំណាចនឹងនាំ ព្រះគម្ពីរមរមនចេញមកបានឡើយ លើកលែងតែដោយស្មោះស្ម័គ្រទាំងស្រុងចំពោះសិរីល្អរបស់ព្រះ, **មរមន** ៨:១៥ ។ ដោយសារ ព្រះចេស្ដានៃព្រះវិញ្ញាណ នោះភ្នែករបស់យើងខ្ញុំបានបើក ហើយយោបល់របស់យើងបានភ្លឺ, **គ. និង ស.** ៧៦:១២ ។ ពន្លឺដែលភ្លឺតាម រយៈព្រះអង្គដែលបំភ្លឺភ្នែកអ្នក, **គ. និង ស.** ៨៨:១១ ។ បើសិនជាភ្នែករបស់អ្នកស្មោះស្ម័គ្រទាំងស្រុងទៅចំពោះសិរីល្អរបស់យើង នោះរូបកាយអ្នកទាំងមូលនឹងបានពោរពេញទៅដោយពន្លឺ, **គ. និង ស.** ៨៨:៦៧ ។

**ភ្នំដើមអូលីវ** *សូមមើល* ដើមអូលីវ, ភ្នំ

**ភ្នំស៊ីណាយ** *សូមមើលផង* ក្រិត្យវិន័យលោកម៉ូសេ; ម៉ូសេ

ជាភ្នំមួយ នៅលើជ្រោយស៊ីណាយ នៅក្បែរកន្លែងដែលលោកម៉ូសេ និងពួកសាសន៍អ៊ីស្រាអែលបានបោះជំរុំ ក្រោយពីបានចេញពីស្រុក អ៊ីស៊ីព្ទ។ ភ្នំនេះក៏មានគេហៅថា ភ្នំហូរែប (និក្ខ. ៣:១) ។ នៅទីនេះហើយដែល ព្រះទ្រង់បានប្រទានក្រិត្យវិន័យទ្រង់ដល់លោកម៉ូសេ សំរាប់ជនអ៊ីស្រាអែល; នៅទីនេះ ក៏គេបានដំឡើងរោងឧបោសថដែរ (និក្ខ. ១៩:២; ២០:១៨; ២៤:១២; ៣២:១៥) ។

**ភ្លើង** *សូមមើលផង* ធ្វើបុណ្យជ្រមុជទឹក; បុណ្យជ្រមុជទឹក, ផែនដី — ការលាងសំអាតផែនដី; ព្រះវិញ្ញាណបរិសុទ្ធ, ស្ថាននរក

គឺជានិមិត្តរូបអំពីការលាង ការសំអាត ឬការញែកចេញជាបរិសុទ្ធ ។ ភ្លើងក៏អាចយកមកធ្វើជាគំរូអំពីវត្តមានរបស់ព្រះ ។

ព្រះនៃអ្នក ទ្រង់ជាភ្លើងឆេះបន្សុស, **ចោទិ.** ៤:២៤ ។ ព្រះអម្ចាស់ទ្រង់យកអណ្តាតភ្លើងធ្វើជាពួកបំរើទ្រង់, **ទំនុក.** ១០៤:៤ ។ ព្រះអម្ចាស់នៃពួកពលបរិវារនឹងធ្វើទោសពួកគេ ដោយអណ្តាតភ្លើងដែលឆេះបំផ្លាញ, **អេសាយ** ២៩:៦ (២ នីហ្វៃ ២៧:២) ។ ព្រះអម្ចាស់ទ្រង់នឹង យាងមកនាំទាំងភ្លើងមកជាមួយ, **អេសាយ** ៦៦:១៥ ។ ទ្រង់ប្រៀបដូចជាភ្លើងរបស់ជាងសំរង, **ម៉ាឡាគី** ៣:២ (៣ នីហ្វៃ ២៤:២; គ. និង ស. ១២៨:២៤) ។ ព្រះអង្គនឹងធ្វើបុណ្យជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនិងភ្លើងវិញ, **ម៉ាថាយ** ៣:១១ (លូកា ៣:១៦) ។ ពួកសុចរិតនឹងត្រូវបានទំនុកបំរុងទុកដោយភ្លើង, **១ នីហ្វៃ** ២២:១៧ ។ ពួកទុច្ចរិតនឹងត្រូវបំផ្លាញចោលដោយភ្លើង, **២ នីហ្វៃ** ៣០:១០ ។ នីហ្វៃបានពន្យល់ប្រាប់ពីរបៀបដែលយើងទទួលបុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ, **២ នីហ្វៃ** ៣១:១៣–១៤ (៣ នីហ្វៃ ៩:២០; ១២:១; ១៩:១៣; អេធើរ ១២:១៤; គ. និង ស. ៣៣:១១) ។ អ្នកត្រូវប្រកាសប្រាប់អំពីការផ្តាច់បាប ដោយសារបុណ្យជ្រមុជទឹក និងដោយសារភ្លើង, **គ. និង ស.** ១៩:៣១ ។ សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើមនឹងត្រូវរលំចុះដោយ ភ្លើងឆេះឆាប, **គ. និង ស.** ២៩:២១ ។ ផែនដីនឹងកន្លងផុតទៅ ដូចត្រូវភ្លើងឆេះ, **គ. និង ស.** ៤៣:៣២ ។ វត្តមាននៃព្រះអម្ចាស់នឹង បានទៅដូចជាភ្លើងរាលឆេះ, **គ. និង ស.** ១៣៣:៤១ ។ អ័ដាមបានទទួលបុណ្យជ្រមុជដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ, **ម៉ូសេ** ៦:៦៦ ។

**ភ្លេង** *សូមមើលផង* ច្រៀង, ទំនុកសរសើរដំកើង

ជាបទ និងទំនុកសរសើរដំកើងដែលមនុស្សច្រៀង ហើយលេងភ្លេងចាប់តាំងពីសម័យព្រះគម្ពីរប៊ីបដំបូងមក ដើម្បីសម្តែងសេចក្តីអំណរសរសើរដំកើង និងថ្វាយបង្គំ (២ សាំយូ. ៦:៥) ។ ភ្លេងអាចទៅជាបទអធិស្ឋាន ។ ទំនុកដំកើងប្រហែលជាបានច្រៀង ដោយបទ ងាយៗ ជាមួយនឹងប្រដាប់លេងភ្លេង ។

ម៉ារាម ជាបងស្រីរបស់អើរ៉ុន និងម៉ូសេ នាងក៏យកក្រាប់មកនៅដៃ ហើយនាងនិងពួកស្ត្រីរាំ, **និក្ខ.** ១៥:២០ ។ ពួកលេវីដែលជាអ្នក ច្រៀង គេកាន់ឈឹង និងស៊ុង ហើយមានពួកសង្ឃ ១២០ នាក់ផ្លុំត្រែ, **២ របា.** ៥:១២ ។ ព្រះយេស៊ូវ និងពួក ១២ នាក់បានច្រៀងទំនុក សរសើរដំកើងមួយ បន្ទាប់ពីអាហារចុងក្រោយបង្អស់, **ម៉ាថាយ** ២៦:៣០ ។ ចូរបង្រៀន ហើយទូន្មានគ្នា ដោយនូវទំនុកដំកើង ទំនុក បរិសុទ្ធ និងចំរៀងខាងវិញ្ញាណ, **កូល៉ុស** ៣:១៦ ។ តើអ្នករាល់គ្នាចាប់អារម្មណ៍ចង់ច្រៀងនូវចំរៀងនៃសេចក្តីស្រឡាញ់ដែលប្រោស លោះឬ ? **អាលម៉ា** ៥:២៦ ។ ព្រលឹងរបស់ព្រះគ្រេកអរចំពោះបទចំរៀងពីចិត្ត មែនហើយ បទចំរៀងនៃពួកសុចរិត គឺជាបទអធិស្ឋាន, **គ. និង ស.** ២៥:១២ ។ ចូរសរសើរដំកើងដល់ព្រះអម្ចាស់ ដោយការច្រៀង ដោយការលេងភ្លេង ដោយការរាំ, **គ. និង ស.** ១៣៦:២៨ ។

**មក** *សូមមើលផង* ការគោរពតាម, គោរពតាម, ដែលគោរពតាម, សិស្ស

នៅក្នុងគម្ពីរ ទោងិតអ្នកណាម្នាក់ ដោយដើរ ឬគោរពតាម ដូចជានៅក្នុងឃ្លាថា៖ « ចូរមកឯព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅ ក្នុងទ្រង់ចុះ » (ម៉ូរ៉ូណៃ ១០:៣២) ។

ចូរឱនត្រចៀក ហើយមកឯយើង, **អេសាយ** ៥៥:៣ ។ អស់អ្នកដែលនឿយព្រួយអើយ ចូរមកឯខ្ញុំ, **ម៉ាថាយ** ១១:២៨ ។ ទុកឲ្យកូនក្មេង មកឯខ្ញុំចុះ, **ម៉ាថាយ** ១៩:១៤ ។ បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង, **លូកា** ៩:២៣ ។ អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ, **យ៉ូហាន** ៦:៣៥ ។ ព្រះគ្រីស្ទអញ្ជើញគ្រប់ទាំងមនុស្សឲ្យមកឯទ្រង់, **២ នីហ្វៃ** ២៦:៣៣ ។ ចូរមករក យើងចុះ ហើយអ្នកនឹងបានសង្គ្រោះ, ៣ នីហ្វៃ ១២:២០ ។ ចូរមកឯព្រះគ្រីស្ទ, **ម៉ូរ៉ូណៃ** ១០:៣២ ។ អញ្ជើញមនុស្សទាំងអស់ ឲ្យមករក ព្រះគ្រីស្ទ, **គ. និង ស.** ២០:៥៩ ។ ចូរមករកយើង ហើយព្រលឹងរបស់អ្នករាល់គ្នានឹងរស់នៅ, **គ. និង ស.** ៤៥:៤៦ ។

**មកុដ** *សូមមើលផង* ជីវិតដ៏នៅអស់កល្បជានិច្ច

ជាគ្រឿងអលង្ការរាងមូលសំរាប់ពាក់លើក្បាលពួកអ្នកគ្រប់គ្រង ។ ក៏អាចយកមកប្រើជានិមិត្តរូបអំពីអានុភាព អំណាច និងក្រុមព្រះផ្ទៃកខាងសេឡេស្ទាល ។ អស់អ្នកណាដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុត ដោយកាន់តាមអស់ទាំងបញ្ញត្តិព្រះអ្នកនោះនឹងបានទទួល មកុដជាជីវិតដ៏នៅអស់កល្បជានិច្ច ។ (សូមមើល គ. និង ស. ២០:១៤; ម៉ូសេ ៧:៥៦; យ.ស— ម៉ាថាយ ១:១ ។)

មានមកុដនៃសេចក្តីសុចរិត បំរុងទុកឲ្យខ្ញុំ,២ ធីម៉ូ. ៤:៨ ។ អ្នករាល់គ្នានឹងទទួលភួងជ័យ ដែលមិនចេះស្រពោនឡើយ, **១ ពេត្រុស** ៥:៤ ។ ពួកមនុស្សស្លាប់ណាដែលស្លាប់ក្នុងព្រះអម្ចាស់ នោះនឹងទទួលមកុដនៃសេចក្តីសុចរិត, **គ. និង ស.** ២៩:១៣ ។ ពួកគេនឹងបានទទួល មកុដនៅក្នុងវិមានទាំងឡាយនៃព្រះវរបិតារបស់យើង, **គ. និង ស.** ៥៩:២ ។ ព្រះអម្ចាស់ទ្រង់រៀបចំពួកបរិសុទ្ធ ឲ្យឡើងទៅរកមកុដ ដែលបានរៀបចំទុកសំរាប់ពួកគេ, **គ. និង ស.** ៧៨:១៥ ។ ព្រះអម្ចាស់ទ្រង់បាន

សន្យាដល់ពួកបរិសុទ្ធរបស់ទ្រង់ នូវមកុដនៃសិរីល្អ នៅខាងស្តាំព្រះហស្តទ្រង់, **គ. និង ស.** ១០៤:៧ ។

**មធូសាឡា** *សូមមើលផង* ហេណុក

ជាកូនប្រុសរបស់ហេណុកនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ មធូសាឡារស់នៅបានអាយុ ៩៦៩ ឆ្នាំ (លោកុ. ៥:២១–២៧; លូកា ៣:៣៧; ម៉ូសេ ៨:៧) ។ លោកគឺជាព្យាការីដ៏សុចរិតម្នាក់ ដែលបានទុកនៅលើផែនដី កាលទីក្រុងរបស់ហេណុកត្រូវបានលើកឡើងទៅលើស្ថានសួគ៌ ។ លោកបាននៅលើផែនដី ដើម្បីផ្តល់នូវពូជពង្សមួយ តាមខ្សែរយៈដែលមានណូអេបន្តមក (ម៉ូសេ ៨:៣–៤) ។

**មនុស្សលោក** *សូមមើល* មនុស្ស, មនុស្សលោក

**មនុស្ស, មនុស្សលោក** *សូមមើលផង* ការបង្កបង្កើតខាងវិញ្ញាណ, ក្រុមព្រះ; ព្រះ, បុត្រាបុត្រីនៃព្រះ; វិញ្ញាណ

គឺសំដៅដល់មនុស្សលោកទាំងអស់ ទាំងប្រុសទាំងស្រី ។ មនុស្សប្រុសស្រីទាំងអស់ គឺជាកូនចៅវិញ្ញាណនៃព្រះវរបិតា ដែលគង់នៅ លើស្ថានសួគ៌ពិតប្រាកដ ។ កាលគេកើតមកក្នុងលោកនេះ គេបានទទួលរូបកាយ ដែលរមែងស្លាប់ ។ រូបកាយទាំងនេះ គឺបានបង្កើត តាមរូបអង្គព្រះ (លោកុ. ១:២៦–២៧) ។ មនុស្សប្រុសស្រីណា ដែលមានចិត្តស្មោះត្រង់ ក្នុងការទទួលពិធីបរិសុទ្ធដែលចាំបាច់ ក្នុងការ កាន់តាមសេចក្តីសញ្ញារបស់គេ និងក្នុងការគោរពតាមបញ្ញត្តិទាំងឡាយរបស់ព្រះ អ្នកទាំងនោះនឹងចូលក្នុងភាពថ្កើងថ្កានរបស់គេ ហើយក៏ក្លាយដូចជាព្រះ ។

ព្រះទ្រង់បានបង្កើតមនុស្សតាមរូបអង្គទ្រង់, **លោកុ.** ១:២៧ (ម៉ូសាយ ៧:២៧; គ. និង ស. ២០:១៧–១៨) ។ តើមនុស្សជាអ្វី ដែលទ្រង់នឹងរឭកដល់គេ ? **ទំនុក.** ៨:៤–៥ ។ ត្រូវបណ្តាសាហើយ អ្នកណាដែលទីពឹងដល់មនុស្ស ហើយយកសាច់ឈាមជាដៃរបស់ខ្លួន, **យេរេ.** ១៧:៥ (២ នីហ្វៃ ៤:៣៤; ២៨:២៦, ៣១) ។ កាលខ្ញុំធំឡើង នោះខ្ញុំបានលះចោលការរបស់កូនក្មេងចេញទៅ, **១ កូរិន.** ១៣:១១ ។ មានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្តីអំណរ, **២ នីហ្វៃ** ២:២៥ ។ មនុស្សខាងសាច់ឈាម គឺជាសត្រូវដល់ព្រះ, **ម៉ូសាយ** ៣:១៩ ។ តើអ្នករាល់គ្នាគួរធ្វើជាមនុស្សបែបណាទៅ ? ៣ នីហ្វៃ ២៧:២៧ ។ កិច្ចការនៃមនុស្សលោកស្មុគស្មាញ មិនមែនកិច្ចការ នៃព្រះទេ, **គ. និង ស.** ៣:៣ ។ អ្នកមិនត្រូវខ្លាចមនុស្សជាងព្រះឡើយ, **គ. និង ស.** ៣:៧ (គ. និង ស. ៣០:១១; ១២២:៩) ។ គ្រប់អ្វីៗ ទាំងអស់ត្រូវបានបង្កើតឡើងសំរាប់ផលប្រយោជន៍ និងការប្រើប្រាស់របស់មនុស្ស, **គ. និង ស.** ៥៩:១៨ ។ ខ្ញុំដឹងថាមនុស្សគឺគ្មានជា អ្វីសោះ, **ម៉ូសេ** ១:១០ ។ កិច្ចការ និងសិរីល្អរបស់ព្រះ គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្ប ជានិច្ចដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។

*មនុស្ស ជាកូនវិញ្ញាណនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌ៈ* គេក៏ទំលាក់ខ្លួនចុះក្រាបផ្កាប់មុខទូលថា ឱព្រះអង្គ ដ៏ជាព្រះនៃវិញ្ញាណគ្រប់ទាំងមនុស្សអើយ, **ជនគ.** ១៦:២២ (ជនគ. ២៧:១៦) ។ ឯងរាល់គ្នាជាកូនផងព្រះអម្ចាស់ ជាព្រះនៃឯង, **ចោទិ.** ១៤:១ ។ ឯងរាល់ គ្នាសុទ្ធតែជាអ្នកមានអំណាច ហើយជាកូននៃព្រះដ៏ខ្ពស់បំផុតទាំងអស់គ្នា, **ទំនុក.** ៨២:៦ ។ ឯងរាល់គ្នាជាកូននៃព្រះដ៏មានព្រះជន្មរស់ នៅ, **ហូសេ** ១:១០ ។ យើងទាំងអស់គ្នា តើមិនមានឪពុកតែមួយទេឬ ? តើមិនមែនជាព្រះតែមួយ ដែលបង្កើតយើងរាល់គ្នាមកទេឬអី ? **ម៉ាឡាគី** ២:១០ ។ យើងរាល់គ្នាជាពូជព្រះ, **កិច្ចការ** ១៧:២៩ ។ ព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ, **រ៉ូម** ៨:១៦ ។ ចូរចុះចូលចំពោះព្រះវរបិតាខាងវិញ្ញាណចុះ, **ហេព្រើរ** ១២:៩ ។ វិញ្ញាណរបស់មនុស្សទាំងអស់នឹងបាន ត្រឡប់ទៅផ្ទះវិញ គឺទៅជួបព្រះនោះ ដែលបានប្រទានជីវិតដល់គេ, **អាលម៉ា** ៤០:១១ ។ បណ្តាជននៅលើពិភពលោកទាំងឡាយ គឺជាបុត្រាបុត្រីបង្កើតនៃព្រះ, **គ. និង ស.** ៧៦:២៤ ។ កាលដើមដំបូង មនុស្សបាន នៅជាមួយនឹងព្រះវរបិតា, **គ. និង ស.** ៩៣:២៣, ២៩ ។ ព្រះទ្រង់បានបង្កើតមនុស្សទាំងអស់ខាងវិញ្ញាណ មុនមានពួកគេនៅលើផែនដី, **ម៉ូសេ** ៣:៥–៧ ។ យើងជាព្រះ; យើងបានបង្កើត លោកិយ និងមនុស្សលោកមក មុនមានពួកគេនៅក្នុងសាច់ឈាមម្លេះ, **ម៉ូសេ** ៦:៥១ ។

*មនុស្សមានលទ្ធភាពនឹងក្លាយទៅដូចជាព្រះវរបិតាដែលគង់នៅស្ថានសួគ៌ៈ* ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបានល្អឥតខ្ចោះ ដូចជាព្រះ វរបិតានៃអ្នក, **ម៉ាថាយ** ៥:៤៨ (៣ នីហ្វៃ ១២:៤៨) ។ តើគ្មានសេចក្តីចែងទុកមកក្នុងក្រិត្យវិន័យរបស់អ្នករាល់គ្នាថា អ្នករាល់គ្នា ជាព្រះទេឬអី, **យ៉ូហាន** ១០:៣៤ (គ. និង ស. ៧៦:៥៨) ។ យើងអាចទៅជាអ្នកគ្រងមរតកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង, **រ៉ូម** ៨:១៧ ។ អ្នករាល់គ្នាជាកូន ហើយបើជាកូន នោះនឹងបានទៅជាអ្នកគ្រងមរតកនៃព្រះ ដោយសារព្រះគ្រីស្ទ, **កាឡាទី** ៤:៧ ។ កាលណាទ្រង់ លេចមក នោះយើងនឹងបានដូចជាទ្រង់, **១ យ៉ូហាន** ៣:២ ។ ឯអ្នកណាដែលឈ្នះ នោះអញនឹងឲ្យអង្គុយលើបល្ល័ង្កជាមួយនឹងអញ, **វិវរ.** ៣:២១ ។ ចំពោះពួកគេទាំងនោះ យើងបានឲ្យក្លាយទៅជាបុត្រានៃព្រះ, ៣ នីហ្វៃ ៩:១៧ ។ អស់អ្នកណាដែលគ្រងនគរសេឡេស្ទាល ទុកជាមរតក ពួកគេសុទ្ធតែជាបណ្តាព្រះ គឺជាបុត្រានៃព្រះ, **គ. និង ស.** ៧៦:៥០, ៥៨ ។ ខណៈនោះ ពួកគេនឹងទៅជាព្រះ ពីព្រោះពួក គេនឹងមានអំណាចគ្រប់យ៉ាង, **គ. និង ស.** ១៣២:២០ ។

**មនុស្សក្រីក្រ** *សូមមើលផង* ការដាក់ទាន; ការសង្គ្រោះ, ចិត្តសុភាពរាបសា; ដង្វាយ; តម, តំណម; ទាន, បន្ទាបខ្លួន

នៅក្នុងព្រះគម្ពីរ ពាក្យថា មនុស្សក្រីក្រ អាចនិយាយដល់ (១) មនុស្សដែលខ្វះខាតរបស់របរ ដូចជាអាហារ សំលៀកបំពាក់ និងទីលំនៅ ឬ (២) មនុស្សដែលសុភាពរាបសា ហើយឥតមានចិត្តឆ្មើងឆ្មៃ ។

*ក្រខាងទ្រព្យសម្បត្តិៈ* មិនត្រូវឲ្យឯងក្តាប់ដៃនឹងបងប្អូនជាអ្នកក្រនោះឡើយ, **ចោទិ.** ១៥:៧ ។ មនុស្សអាក្រក់ គេបៀតបៀនដល់ មនុស្សក្រីក្រ ដោយសេចក្តីឆ្មើងឆ្មៃ, **ទំនុក.** ១០:២ ។ អ្នកណាដែលចែកចាយឲ្យដល់ពួកទាល់ក្រ អ្នកនោះនឹងមិនខ្វះខាតឡើយ, **សុភា.** ២៨:២៧ ។ ចូរនាំមនុស្សក្រមកឯផ្ទះឯងចុះ, **អេសាយ** ៥៨:៦–៧ ។ បើអ្នកចង់បាន

ជាគ្រប់លក្ខណ៍ ចូរចែកដល់ពួកអ្នកក្រីក្រចុះ, **ម៉ាថាយ** ១៩:២១ (ម៉ាកុស ១០:២១; លូកា ១៨:២២) ។ តើព្រះមិនបានរើសពួកអ្នកក្រនៅលោកិយនេះទេឬអី ? **យ៉ាកុប** (ព.ស.ថ.) ២:៥ ។ គ្មិតមកពីគេមាន គេមើលងាយមនុស្សក្រីក្រ, **២ នីហ្វៃ** ៩:៣០ ។ ដើម្បីឲ្យបានការផ្ដាច់បាបដល់អ្នក នោះចូរចែករំលែកទ្រព្យ របស់ខ្លួនដល់អ្នកទាល់ក្រចុះ, **ម៉ូសាយ** ៤:២៦ ។ ពួកគេបានចែករំលែកទ្រព្យរបស់ខ្លួនឲ្យអ្នកក្រីក្រ, **អាលម៉ា** ១:២៧ ។ បើអ្នកបែរចេញ ពីមនុស្សដែលខ្វះខាត នោះការអធិស្ឋានរបស់អ្នកគឺឥតប្រយោជន៍ទេ, **អាលម៉ា** ៣៤:២៨ ។ ពួកសាសន៍នីហ្វៃមានវត្ថុសព្វសារពើ នៅមូលព្រមគ្នា គឺគ្មានអ្នកមាន ឬអ្នកក្រឡើយ, **៤ នីហ្វៃ** ១:៣ ។ ចូរនឹកដល់មនុស្សទាល់ក្រ, **គ. និង ស.** ៤២:៣០ (គ. និង ស. ៥២:៤០) ។ វេទនាដល់អ្នកដែលទាល់ក្រដែលមានចិត្តឥតសង្រេង, **គ. និង ស.** ៥៦:១៧–១៨ ។ មនុស្សទាល់ក្រនឹងមករៀប អាពាហ៍ពិពាហ៍នៃកូនចៀម, **គ. និង ស.** ៥៨:៦–១១ ។ ប៊ីស្សពត្រូវស្វែងរកមនុស្សទាល់ក្រ, **គ. និង ស.** ៨៤:១១២ ។ ក្រិត្យវិន័យនៃ ដំណឹងល្អត្រួតត្រា លើការថែរក្សាមនុស្សទាល់ក្រ, **គ. និង ស.** ១០៤:១៧–១៨ ។ គ្មានមនុស្សក្រីក្រនៅក្នុងចំណោមពួកគេឡើយ, **ម៉ូសេ** ៧:១៨ ។

*កំសត់ខាងវិញ្ញាណៈ* មានពរច្រើនជាងដល់អស់អ្នកណា ដែលបន្ទាបខ្លួនដោយពុំបាច់គេបង្ខំ ពីព្រោះមកពីការក្រក្សត់, **អាលម៉ា** ៣២:៤–៦, ១២–១៦ ។ មានពរហើយ អស់អ្នកដែលមានសេចក្ដីកំសត់ខាងឯវិញ្ញាណ ដែលបានមករកខ្ញុំ, ៣ នីហ្វៃ ១២:៣ (ម៉ាថាយ ៥:៣) ។ ពួកទាល់ក្រ និងមនុស្សស្លូតត្រង់នឹងត្រូវបានដំណឹងល្អផ្សាយដល់ពួកគេ, **គ. និង ស.** ៣៥:១៥ ។

**មនុស្សខាងសាច់ឈាម** *សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា, កើតពីព្រះ; កើតម្ដងទៀត, ខាងរូបកាយ

គឺជនណាមួយដែលជ្រើសរើសដើម្បីនៅក្រោមឥទ្ធិពលនៃតណ្ហា សេចក្ដីប៉ងប្រាថ្នា សេចក្ដីស្រេកឃ្លាន និងវិស័យខាងសាច់ឈាម ជាជាងនៅក្រោមការដាស់តឿននៃព្រះវិញ្ញាណបរិសុទ្ធ ។ ជនបែបនេះអាចយល់សេចក្ដីខាងសាច់ឈាម ប៉ុន្តែមិនយល់សេចក្ដីខាងវិញ្ញាណឡើយ ។ មនុស្សទាំងអស់ គឺជាមនុស្សខាងសាច់ឈាម ឬជាសាច់ឈាមដែលរមែងស្លាប់ ពីព្រោះមកពីការធ្លាក់នៃលោក អ័ដាម និងនាងអេវ៉ា ។ មនុស្សគ្រប់រូបត្រូវតែកើតម្ដងទៀត តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ដើម្បីកុំឲ្យកើតជាមនុស្សខាង សាច់ឈាម ។

មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្ដីខាងឯព្រះវិញ្ញាណឡើយ, **១ កូរិន.** ២:១៤ ។ មនុស្សខាងសាច់ឈាមជាសត្រូវដល់ព្រះ ហើយគួរតែរលាស់ចេញ, **ម៉ូសាយ** ៣:១៩ ។ ជនណាដែលស្ថិតនៅក្នុងស្ថានភាពខាងរូបកាយរបស់ខ្លួន នោះស្ថិតនៅក្នុងស្ថានភាពធ្លាក់របស់ខ្លួនតទៅទៀត, **ម៉ូសាយ** ១៦:៥ (អាលម៉ា ៤២:៧–២៤; គ. និង ស. ២០:២០) ។ តើមានមនុស្សខាងសាច់ឈាមណាមួយដែលស្គាល់ការណ៍ទាំងនេះ ? **អាលម៉ា** ២៦:១៩–២២ ។ មនុស្សខាងសាច់ឈាម ឬខាងរូបកាយទាំងឡាយនៅក្នុងលោកិយ ដោយឥតមានព្រះ, **អាលម៉ា** ៤១:១១ ។ ពីព្រោះតែការរំលងរបស់លោក នោះមនុស្សបានក្លាយទៅជាស្លាប់ខាងវិញ្ញាណ, **គ. និង ស.** ២៩:៤១ ។ គ្មានមនុស្សខាងសាច់ឈាមណាមួយ អាចនៅក្នុងវត្តមាននៃព្រះបានទេ, **គ. និង ស.** ៦៧:១២ ។ ហើយមនុស្សលោក បានចាប់ផ្ដើមក្លាយទៅជាមនុស្សខាងរូបកាយ ខាងកាមរាគ និងខាងអារក្ស, **ម៉ូសេ** ៥:១៣ (ម៉ូសេ ៦:៤៩) ។

**មនុស្សនៃបរិសុទ្ធភាព** *សូមមើលផង* ក្រុមព្រះ, កូនមនុស្ស, ព្រះ, ព្រះវរបិតាដែលគង់នៅស្ថានសួគ៌

ជាព្រះនាមមួយទៀត សំរាប់ព្រះដ៏ជាព្រះវរបិតា (ម៉ូសេ ៦:៥៧) ។

**មនុស្សស្លាប់, សេចក្ដីសង្គ្រោះសំរាប់** *សូមមើល* សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់

**មរមន, ព្រះគម្ពីរ** *សូមមើល* ព្រះគម្ពីរមរមន

**មរមន, ព្យាការីសាសន៍នីហ្វៃ** *សូមមើលផង* ព្រះគម្ពីរមរមន

ជាព្យាការីសាសន៍នីហ្វៃ ជាឧត្ដមសេនីយ៍ ហើយជាអ្នកកត់បញ្ជីប្រវត្តិម្នាក់ នៅក្នុងព្រះគម្ពីរមរមន ។ មរមនបានរស់នៅប្រមាណជាឆ្នាំ ៣១១–៣៨៥ គ.ស. (មរមន ១:២, ៦; ៦:៥–៦; ៨:២–៣) ។ លោកជាមេទាហានស្ទើរតែអស់មួយជីវិតរបស់លោក គឺចាប់តាំងពីអាយុ ១៥ ឆ្នាំ (មរមន ២:១–២; ៣:៨–១២; ៥:១; ៨:២–៣) ។ អាំម៉ារ៉ុនបានបង្គាប់មរមនឲ្យត្រៀមខ្លួន ដើម្បីកាន់បញ្ជី និងការកត់បញ្ជីទុក (មរមន ១:២–៥; ២:១៧–១៨) ។ បន្ទាប់ពីបានកត់ប្រវត្តិអំពីសម័យលោក នោះមរមនបានសង្ខេបផ្ទាំងធំរបស់នីហ្វៃទៅលើផ្ទាំងមរមន ។ ក្រោយមក លោកបានប្រគល់បញ្ជីពិសិដ្ឋឲ្យទៅម៉ូរ៉ូណៃ ជាកូនប្រុសរបស់លោក ។ ផ្ទាំងទាំងនេះ គឺជាផ្នែកនៃបញ្ជីដែលយ៉ូសែប ស៊្មីធ បានបកប្រែជាព្រះគម្ពីរមរមន ។

*ពាក្យសំដីនៃមរមនៈ* ជាគម្ពីរតូចមួយ នៅក្នុងព្រះគម្ពីរមរមន ។ រវាងពាក្យចុងក្រោយបង្អស់របស់អាម៉ាលេគី នៅក្នុងគម្ពីរអោមណៃ នឹងពាក្យមុនបង្អស់ នៅក្នុងគម្ពីរម៉ូសាយ នោះមរមន ជាអ្នកពិនិត្យផ្ទៀងផ្ទាត់នូវអស់ទាំងបញ្ជី បានដាក់ពាក្យសង្ខេបដ៏ខ្លីនេះ ។ (សូមមើល « ការអធិប្បាយដ៏ខ្លីអំពីព្រះគម្ពីរមរមន » នៅខាងមុខព្រះគម្ពីរមរមន) ។

*គម្ពីរមរមនៈ* ជាគម្ពីរមួយទៀត នៅក្នុងកណ្ឌនៃបទគម្ពីរដែលស្គាល់ថាជាព្រះគម្ពីរមរមន ។ ជំពូកទី ១–២ ប្រាប់អំពីអាំម៉ារ៉ុន ជាព្យាការីសាសន៍នីហ្វៃម្នាក់ ដែលបានបង្គាប់មរមនអំពីពេលវេលា និងទីកន្លែងដើម្បីទៅយកផ្ទាំងទាំងឡាយ ។ ហើយនិងអំពី សង្គ្រាមដ៏ធំទាំងឡាយដែលបានចាប់ផ្ដើម និងអំពីសាសន៍នីហ្វៃបីនាក់ត្រូវបានដកចេញទៅ ពីព្រោះតែអំពើអាក្រក់របស់មនុស្ស ។ ជំពូកទី ៣–៤ ប្រាប់អំពីសំរែករបស់មរមន ដែលប្រាប់ឲ្យប្រជាជនប្រែចិត្ត ប៉ុន្តែពួកគេមានចិត្តរក់ទៅវិញ ហើយអំពើអាក្រក់ឈ្នះលើ អ៊ីស្រាអែលជាងពេលមុនៗមក ។

ជំពូកទី ៥–៦ កត់អំពីចំបាំងចុងក្រោយបង្អស់រវាងពួកសាសន៍នីហ្វៃនឹងពួកសាសន៍លេមិន ។ មរមនត្រូវគេប្រហារជាមួយនឹងសាសន៍នីហ្វៃភាគច្រើន ។ ក្នុងជំពូកទី ៧ មុនលោកស្លាប់ មរមនបានហៅប្រាប់ប្រជាជន — នៅពេល នោះ និងនៅពេលអនាគត — ឲ្យប្រែចិត្ត ។ ជំពូកទី ៨–៩ កត់ថា នៅទីបញ្ចប់ មានតែម៉ូរ៉ូណៃ ជាកូនប្រុសរបស់មរមន មួយគត់ដែលនៅសល់ ។ លោកបានកត់អំពីស្ថានភាពចុងក្រោយបង្អស់នៃសេចក្ដីស្លាប់ និងសព ព្រមទាំងទីបំផុតនៃប្រជាជននីហ្វៃ ហើយបានសរសេរពាក្យចំពោះតំណមនុស្សជំនាន់ក្រោយ និងពួកអ្នកអានបញ្ជីនេះ ។

**ម៉ូរ៉ូណៃ, កូនប្រុសរបស់មរមន** *សូមមើលផង* ព្យាការីសាសន៍នីហ្វៃ, ព្រះគម្ពីរមរមន; មរមន

ជាព្យាការីសាសន៍នីហ្វៃចុងក្រោយបង្អស់ នៅក្នុងព្រះគម្ពីរមរមន (ឆ្នាំ ៤២១ គ.ស.) ។ មុនលោកស្លាប់ មរមនបានប្រគល់បញ្ជីប្រវត្តិ ដែលហៅថា ផ្ទាំងមរមន ឲ្យទៅម៉ូរ៉ូណៃ ជាកូនប្រុសរបស់លោក (ព. នៃ ម. ១:១) ។ ម៉ូរ៉ូណៃបានបញ្ចប់ប្រមូលផ្ដុំផ្ទាំងមរមន ។ លោកបានបន្ថែមជំពូកទី៨ និង ៩ ទៅក្នុងព្រះគម្ពីរមរមន (មរមន ៨:១) ។ លោកបានសង្ខេប ហើយបានបញ្ចូលគម្ពីរអេធើរ (អេធើរ ១:១–២) ហើយបានបន្ថែមគម្ពីររបស់លោកដែលហៅថា គម្ពីរម៉ូរ៉ូណៃ (ម៉ូរ៉ូណៃ ១:១–៤) ។ ម៉ូរ៉ូណៃបានបិទផ្ទាំងទាំងឡាយ ហើយបាន លាក់ទុកនៅលើភ្នំគូម៉ូរ៉ា (មរមន ៨:១៤; ម៉ូរ៉ូណៃ ១០:២) ។ នៅឆ្នាំ ១៨២៣ ម៉ូរ៉ូណៃត្រូវបានចាត់ឲ្យមកក្នុងរូបដែលបានរស់ឡើងវិញ ដើម្បីបង្ហាញព្រះគម្ពីរមរមនដល់យ៉ូសែប ស្ម៊ីធ (យ.ស. — ប្រវត្តិ ១:៣០–៤២, ៤៥; គ. និង ស. ២៧:៥) ។ លោកបានបង្គាប់ព្យាការីវ័យក្មេងរូបនេះរាល់ឆ្នាំពីឆ្នាំ ១៨២៣ ទៅឆ្នាំ ១៨២៧ (យ.ស. — ប្រវត្តិ ១:៥៤) នៅទីបញ្ចប់ បានប្រគល់ផ្ទាំងទាំងឡាយដល់លោក នៅឆ្នាំ ១៨២៧ (យ.ស. — ប្រវត្តិ ១:៥៩) ។ បន្ទាប់ពីបានបញ្ចប់ការបកប្រែហើយ នោះយ៉ូសែប ស្ម៊ីធ បានប្រគល់ផ្ទាំងទាំងឡាយឲ្យទៅ ម៉ូរ៉ូណៃវិញ ។

*គម្ពីរម៉ូរ៉ូណៃ៖* ជាគម្ពីរចុងក្រោយបង្អស់ នៅក្នុងព្រះគម្ពីរមរមន ។ គឺបានសរសេរដោយម៉ូរ៉ូណៃ ជាព្យាការីសាសន៍នីហ្វៃចុង ក្រោយបង្អស់ ។ ជំពូកទី ១–៣ ប្រាប់អំពីការបំផ្លិចបំផ្លាញចុងក្រោយបង្អស់ដល់ពួកសាសន៍នីហ្វៃ ដោយបង្គាប់អំពីការប្រគល់ ព្រះវិញ្ញាណបរិសុទ្ធ និងបព្វជិតភាព ។ ជំពូកទី ៤–៥ អធិប្បាយប្រាប់អំពីរបៀបដ៏ត្រឹមត្រូវសំរាប់ចាត់ចែងបុណ្យរំឭក ។ ជំពូកទី ៦ ការសរុបអំពីកិច្ចការនៃសាសនាចក្រ ។ ជំពូកទី ៧–៨ គឺជាបទបង្រៀនអំពីគោលការណ៍ទីមួយនៃដំណឹងល្អ ព្រមទាំងការបង្រៀន ដោយមរមន អំពីសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ហើយនិងអំពីរបៀបដើម្បីវិនិច្ឆ័យរវាងអំពើល្អនឹងអំពើអាក្រក់ (ម៉ូរ៉ូណៃ ៧), ហើយនិងការអធិប្បាយរបស់មរមនប្រាប់ថា កូនក្មេងតូចៗ គឺរស់នៅក្នុងព្រះគ្រីស្ទ ហើយមិនត្រូវការបុណ្យជ្រមុជទឹកទេ (ម៉ូរ៉ូណៃ ៨) ។ ជំពូកទី ៩ រៀបរាប់អំពីសេចក្ដីហិនវិនាសនៃសាសន៍នីហ្វៃ ។ ជំពូកទី ១០ គឺជាពាក្យចុងក្រោយបង្អស់របស់ម៉ូរ៉ូណៃ ហើយព្រមទាំងមាតិកា ដើម្បីឲ្យបានដឹងការពិតអំពីព្រះគម្ពីរមរមន (ម៉ូរ៉ូណៃ ១០:៣–៥) ។

**ម៉ូរ៉ូណៃ, មេទ័ព** *សូមមើលផង* ទង់ឥស្សរភាព

នៅក្នុងព្រះគម្ពីរមរមន គឺជាមេទ័ពសាសន៍នីហ្វៃដ៏សុចរិតម្នាក់ ដែលបានរស់នៅប្រមាណជាឆ្នាំ ១០០ ម.គ.ស. ។

ម៉ូរ៉ូណៃត្រូវបានតែងតាំងឲ្យធ្វើជាមេបញ្ជាការលើពលទ័ពសាសន៍នីហ្វៃទាំងអស់, **អាលម៉ា** ៤៣:១៦–១៧ ។ បានលើកទឹកចិត្តឲ្យពួកទាហានសាសន៍នីហ្វៃច្បាំង ដើម្បីសេរីភាពរបស់គេ, **អាលម៉ា** ៤៣:៤៨–៥០ ។ បានធ្វើទង់ឥស្សរភាពពីក្រណាត់អាវលោក, **អាលម៉ា** ៤៦:១២–១៣ ។ ជាមនុស្សនៃព្រះ, **អាលម៉ា** ៤៨:១១–១៨ ។ បានខឹងនឹងរដ្ឋាភិបាល ដោយសារការមិនអើពើចំពោះសេរីភាព នៃដែនដី, **អាលម៉ា** ៥៩:១៣ ។

**ម៉ូរ៉ូណៃហា, កូនប្រុសរបស់មេទ័ពម៉ូរ៉ូណៃ**

ជាមេទ័ពសាសន៍នីហ្វៃដ៏សុចរិតម្នាក់ នៅក្នុងព្រះគម្ពីរមរមន (ប្រមាណជាឆ្នាំ ៦០ ម.គ.ស.) ។

ម៉ូរ៉ូណៃបានប្រគល់ពលទ័ពទៅឲ្យម៉ូរ៉ូណៃហា ជាកូនប្រុសរបស់លោក, **អាលម៉ា** ៦២:៤៣ ។ យកបានទីក្រុងសារ៉ាហិមឡាមកវិញ, **ហេលេ.** ១:៣៣ ។ បាននាំពួកសាសន៍លេមិនឲ្យប្រែចិត្ត ហើយបានទទួលការត្រួតត្រាលើដែនដីម្ដងទៀត, **ហេលេ.** ៤:១៤–២០ ។

**មហាទេវតា** *សូមមើលផង* មីកែល, អ័ដាម

មីកែល ឬអ័ដាម ជាមហាទេវតា ឬប្រធានទេវតា ។

ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់មួយព្រះឱស្ឋ ទាំងមានឮសម្លេងមហាទេវតា, **១ ថែស្ស.** ៤:១៦ ។ មីកែលជាមហាទេវតា, **យូដាស** ១:៩ (គ. និង ស. ២៩:២៦; ៨៨:១១២; ១២៨:២០–២១) ។

**មាតាបិតា, ឪពុកម្ដាយ** *សូមមើលផង* ម្ដាយ, ឪពុកខាងសាច់ឈាម

ជាឪពុក និងម្ដាយទាំងឡាយ ។ ប្ដីប្រពន្ធដ៏សក្តិសមទាំងឡាយណាដែលបានភ្ជាប់ក្នុងអាពាហ៍ពិពាហ៍តាមត្រឹមត្រូវ នៅក្នុងព្រះវិហារ នៃព្រះ នោះគេអាចបំពេញមុខងារគេជាមាតាបិតា រហូតដល់ភាពអស់កល្បជានិច្ច ។

ក្មេងរាល់គ្នាអើយ ចូរស្ដាប់បង្គាប់មាតាបិតាខ្លួនចុះ, **អេភេ.** ៦:១–៣ (កូល៉ុស ៣:២០) ។ លោកអ័ដាម និងនាងអេវ៉ាជាឪពុកម្ដាយដើមបង្អស់របស់យើងរាល់គ្នា, **១ នីហ្វៃ** ៥:១១ ។ បណ្ដាសាអាចធ្លាក់ទៅលើក្បាលនៃឪពុកម្ដាយរបស់ចៅ, **២ នីហ្វៃ** ៤:៦ ។ ចូរបង្រៀនដល់មាតាបិតាថា ពួកគេត្រូវប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក, **ម៉ូរ៉ូណៃ** ៨:១០ ។ ឪពុកម្ដាយត្រូវបានបញ្ជាឲ្យបង្រៀន ដំណឹងល្អដល់កូនចៅខ្លួន, **គ. និង ស.** ៦៨:២៥ ។ គ្រប់កូនក្មេងទាំងអស់មានសិទ្ធិពឹងពាក់ទៅលើឪពុកម្ដាយរបស់ខ្លួន, **គ. និង ស.** ៨៣:៤ ។ អំពើបាបទាំងឡាយនៃឪពុកម្ដាយ ពុំអាចធ្លាក់ទៅលើក្បាលនៃកូនចៅបានឡើយ, **ម៉ូសេ** ៦:៥៤ ។

**មាត្រានៃសេចក្តីជំនឿ** *សូមមើលផង* មុក្តាដ៏មានតម្លៃមហិមា; យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ

១៣ មាត្រាដ៏សំខាន់ៗ អំពីជំនឿដែលពួកសមាជិកក្នុងសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយជឿតាម ។

មុនដំបូង យ៉ូសែប ស្ម៊ីធបានសរសេរមាត្រាទាំងនេះនៅក្នុងសំបុត្រមួយទៅ យ៉ូហាន វែនត្វើធ ជាអ្នកពិនិត្យកាសែត *Chicago Democrat* ទុកជាចម្លើយតបដល់លោក អំពីអ្វីទៅដែលពួកសមាជិកក្នុងសាសនាចក្រជឿ ។ សំបុត្រនោះត្រូវបានស្គាល់ថាសំបុត្រជូនលោកវែនត្វើធ ហើយបានបោះពុម្ពផ្សាយមុនដំបូងនៅក្នុងកាសែត *Times and Seasons* នៅខែមិនា ១៨៤២ ។ នៅថ្ងៃទី ១០ ខែតុលា ១៨៨០ មាត្រានៃសេចក្តីជំនឿត្រូវបានទទួលស្គាល់ជាផ្លូវការថាជាបទគម្ពីរ ដោយសារការបោះឆ្នោតនៃពួក សមាជិកក្នុងសាសនាចក្រ ហើយបានបញ្ចូលជាភាគមួយក្នុង មុក្តាដ៏មានតម្លៃមហិមា ។

**មានចិត្តមេត្តាករុណា, សេចក្តីមេត្តាករុណា** *សូមមើលផង* ជង្វាយធួន; ធ្វើឲ្យធួន, ព្រះគុណ; ព្រះយេស៊ូវគ្រីស្ទ; សេចក្តីយុត្តិធម៌, អត់ទោស

ជាវិញ្ញាណនៃការអាណិត ការទន់ភ្លន់ និងការអត់ទោស ។ សេចក្តីមេត្តាករុណា គឺជាលក្ខណៈមួយនៃព្រះ ។ ព្រះយេស៊ូវគ្រីស្ទ ទ្រង់សំដែងសេចក្តីមេត្តាករុណា ដល់យើងរាល់គ្នា ដោយការបូជាដ៏ធួនរបស់ទ្រង់ ។

ព្រះអម្ចាស់ ទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស, **និក្ខ.** ៣៤:៦ (ចោទិ. ៤:៣១) ។ សេចក្តីសប្បុរសនៃទ្រង់នៅអស់ កល្បជានិច្ច, **១ របា.** ១៦:៣៤ ។ សេចក្តីសប្បុរស និងសេចក្តីមេត្តាករុណានឹងជាប់តាមខ្ញុំ, **ទំនុក.** ២៣:៦ ។ អ្នកណាដែលមានចិត្ត មេត្តាដល់មនុស្សទាល់ក្រ នោះរមែងសប្បាយវិញ, **សុភា.** ១៤:២១ ។ អញពេញចិត្តចំពោះសេចក្តីសប្បុរស មិនមែនចំពោះយញ្ញបូជា ទេ, **ហូសេ** ៦:៦ ។ មានពរហើយ អស់អ្នកណាដែលមានចិត្តមេត្តាករុណា ត្បិតអ្នកទាំងនោះនឹងបានសេចក្តីមេត្តាករុណាវិញ, **ម៉ាថាយ** ៥:៧ (៣ នីហ្វៃ ១២:៧) ។ វេទនានឹងមានដល់ពួកមនុស្សកំពុត ដែលថ្វាយដង្វាយ១ភាគ១០ តែបានចោលសេចក្តីសំខាន់ជាង នៅ ក្នុងក្រិត្យវិន័យវិញ ដូចជាសេចក្តីយុត្តិធម៌ សេចក្តីមេត្តាករុណា និងសេចក្តីជំនឿ, **ម៉ាថាយ** ២៣:២៣ ។ ចូរអ្នករាល់គ្នាមានចិត្តមេត្តា ករុណា ដូចជាព្រះវរបិតានៃអ្នក ទ្រង់មានព្រះហឫទ័យមេត្តាករុណាដែរ, **លូកា** ៦:៣៦ ។ ទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយ ការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ, **ទីតុស** ៣:៥ ។ សេចក្តីមេត្តាករុណាដ៏ទន់ ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ មានមកលើជនទាំងអស់, **១ នីហ្វៃ** ១:២០ ។ សេចក្តីមេត្តាករុណាគ្មានការទាមទារដល់ពួកមនុស្សមិន ប្រែចិត្តឡើយ, **ម៉ូសាយ** ២:៣៨–៣៩ ។ ព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណាដល់មនុស្សទាំងអស់ណា ដែលជឿដល់ព្រះនាមទ្រង់, **អាលម៉ា** ៣២:២២ ។ សេចក្តីមេត្តាករុណាអាចធ្វើឲ្យស្កប់ស្កល់ ដល់ការទាមទារនៃសេចក្តីយុត្តិធម៌, **អាលម៉ា** ៣៤:១៦ ។ តើកូន យល់ថា សេចក្តីមេត្តាករុណាអាចកោងសេចក្តីយុត្តិធម៌ឬ ? **អាលម៉ា** ៤២:២៥, (អាលម៉ា ៤២:១៣–២៥) ។ ពួកកូនក្មេងរស់នៅ ក្នុងព្រះគ្រីស្ទ ពីព្រោះតែសេចក្តីមេត្តាករុណារបស់ទ្រង់, **ម៉ូរ៉ូណៃ** ៨:១៩–២០ (គ. និង ស. ២៩:៤៦) ។ ពាហុនៃសេចក្តីមេត្តាករុណា របស់ព្រះយេស៊ូវគ្រីស្ទ បានធ្វើឲ្យធួននឹងបាបទាំងឡាយរបស់អ្នក, **គ. និង ស.** ២៩:១ ។ ដោយសារព្រះគុណធម៌នៃព្រះលោហិត ដែល យើងបានច្រួច នោះយើងបានអង្វរចំពោះព្រះវរបិតា ជំនួសអស់អ្នកណាដែលជឿដល់ព្រះនាមយើង, **គ. និង ស.** ៣៨:៤ ។ ពួកអ្នកណា ដែលបានកាន់តាមសេចក្តីសញ្ញានោះបានទទួលសេចក្តីមេត្តាករុណា, **គ. និង ស.** ៥៤:៦ ។ យើងជាព្រះអម្ចាស់ អត់ទោសដល់អំពើបាបទាំងឡាយ ហើយយើងមានចិត្តមេត្តាករុណាដល់អស់អ្នកណា ដែលសារភាពនូវអំពើបាបរបស់ខ្លួនដោយចិត្តរាបសា, **គ. និង ស.** ៦១:២ ។ យើងជាព្រះអម្ចាស់ បង្ហាញសេចក្តីមេត្តាករុណាដល់អស់ទាំងពួកស្លូតបូត, **គ. និង ស.** ៩៧:២ ។ ហើយអ្នកណាដែលទទួល អ្នក ដូចជាកូនក្មេងមួយ នោះឈ្មោះថាបានទទួលនគររបស់យើងហើយ ព្រោះពួកគេនឹងបានទទួលសេចក្តីមេត្តាករុណា, **គ. និង ស.** ៩៩:៣ ។ សេចក្តីមេត្តាករុណានឹងចេញទៅ នៅចំពោះព្រះភ័ក្ត្រទ្រង់, **ម៉ូសេ** ៧:៣១ ។

**មានអារម្មណ៍** *សូមមើលផង* ព្រះវិញ្ញាណបរិសុទ្ធ

គឺជ្រាបយល់នូវការដាស់តឿនពីព្រះវិញ្ញាណ ។

បងរាល់គ្នាមិនចាប់អារម្មណ៍ ទើបបងរាល់គ្នាមិនអាចដឹងនូវព្រះបន្ទូលរបស់ទ្រង់, **១ នីហ្វៃ** ១៧:៤៥ ។ នៅពេលអ្នកចាប់អារម្មណ៍ថា គ្រាប់នោះរីកឡើង នោះអ្នកនឹងនិយាយថា នេះច្បាស់ជាគ្រាប់ពូជល្អ, **អាលម៉ា** ៣២:២៨ ។ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះ ត្រឹមត្រូវ, **គ. និង ស.** ៩:៨ ។ មនុស្សទាំងអស់ ដែលនឹងចូលក្នុងដំណាក់នៃព្រះអម្ចាស់ អាចបានជ្រាបយល់នូវព្រះចេស្តារបស់ទ្រង់, **គ. និង ស.** ១០៩:១៣ ។

**មារសត្រូវ** *សូមមើល* អារក្ស

**ម៉ាកុក** *សូមមើលផង* ការយាងមកលើកទីពីរ នៃព្រះយេស៊ូវគ្រីស្ទ, កុក

នៅក្នុងព្រះគម្ពីរប៊ីប គឺជាស្រុក និងប្រជារាស្ត្រនៅក្បែរសមុទ្រខ្មៅ ។ កុក ជាស្តេចរបស់គេ នឹងនាំកងទ័ពម៉ាកុក នៅក្នុងចំបាំងមួយដ៏ធំចុងក្រោយបង្អស់ មុនការយាងមកលើកទីពីរនៃព្រះគ្រីស្ទ (អេសេ. ៣៨:២; ៣៩:៦) ។ ព្រះគម្ពីរទាំងឡាយពោលអំពីចំបាំងដ៏ធំ នៃកុក និងម៉ាកុក នៅទីបញ្ចប់នៃសហស្សវត្ស រវាងពលទ័ពព្រះ និងពលទ័ពអារក្ស (វិវ. ២០:៧–៩; គ. និង ស. ៨៨:១១១–១១៦) ។

**ម៉ាកុស** *សូមមើលផង* ដំណឹងល្អទាំងឡាយ

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យ៉ូហាន-ម៉ាកុស គឺជាកូនរបស់នាងម៉ារា ដែលនៅក្រុងយេរូសាឡិម (កិច្ចការ ១២:១២) ។ លោកក៏ប្រ ហែល

ជាបងប្អូនជីដូនមួយ (ឬក្មួយ) របស់បាណាបាស (កូល៉ុស ៤:១០) ។ លោកបានចេញពីក្រុងយេរូសាឡិម ទៅជាមួយនឹងប៉ុល និងបាណាបាស កាលធ្វើដំណើរទៅផ្សាយសាសនាដំបូង ហើយបានទុកពួកគេនៅឯពើកា (កិច្ចការ ១២:២៥; ១៣:៥, ១៣) ។ បន្ទាប់មក លោកបានទៅគីប្រុសជាមួយនឹងបាណាបាស (កិច្ចការ ១៥:៣៧–៣៩) ។ លោកបាននៅឯក្រុងរ៉ូមជាមួយនឹងប៉ុល (កូល៉ុស ៤:១០; ភីលេ ១:២៤) ។ ហើយលោកបាននៅជាមួយនឹងពេត្រុស នៅឯបាប៊ីឡូន (ប្រហែលជារ៉ូម) (១ ពេត្រុស ៥:១៣) ។ ចុងក្រោយបង្អស់ លោកបាននៅឯអេភេសូរ ជាមួយនឹងធីម៉ូថេ (២ ធីម៉ូ. ៤:១១) ។

*ដំណឹងល្អតាមលោកម៉ាកុស៖* ជាគម្ពីរទីពីរ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ដំណឹងល្អតាមលោកម៉ាកុស ប្រហែលជាបានសរសេរនៅ ក្រោមការដឹកនាំរបស់ពេត្រុស ។ គោលបំណងរបស់លោក គឺដើម្បីអធិប្បាយប្រាប់ថាព្រះអម្ចាស់ ជាព្រះរាជបុត្រានៃព្រះ ដែលមាន ព្រះជន្មរស់នៅ ហើយធ្វើកិច្ចការនៅក្នុងចំណោមមនុស្សលោក ។ ម៉ាកុសអធិប្បាយ ដោយកម្លាំង និងចិត្តស៊ុភាពរាបសា អំពីការ សរសើរដែលមនុស្សផ្សេងគិតដល់ព្រះយេស៊ូវ ។ ទំនៀមទំលាប់ចែងថា បន្ទាប់ពីពេត្រុសបានស្លាប់ទៅ នោះម៉ាកុសបានទៅឯស្រុក អេស៊ីព្ទ, បានរៀបកសាងសាសនាចក្រនៅឯស្រុកអ័លេក្សាន់ទ្រា ហើយបានស្លាប់ដោយទុក្ករកម្ម ។

ចំពោះជំពូកសង្ខេប សូមមើល *ដំណឹងល្អទាំងឡាយ* ។

**ម៉ាត់ធាស** *សូមមើលផង* សាវក — ការជ្រើសរើសពួកសាវក

ជាអ្នកដែលបានរើសឲ្យធ្វើជាសមាជិកនៃក្រុមសាវក ១២ នាក់ ជំនួសយូដាស-អ៊ីស្ការីយ៉ុត (កិច្ចការ ១:១៥–២៦) ។ លោកគឺជា សិស្សម្នាក់ នៅគ្រប់ពេលវេលា ដែលព្រះយេស៊ូវធ្វើការងារបំរើលើផែនដី (កិច្ចការ ១:២១–២២) ។

**ម៉ាថាយ** *សូមមើលផង* ដំណឹងល្អទាំងឡាយ

ជាសាវករបស់ព្រះយេស៊ូវគ្រីស្ទម្នាក់ ហើយជាអ្នកនិពន្ធគម្ពីរទីមួយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ម៉ាថាយជាសាសន៍យូដា ដែលជាអ្នក យកពន្ធឲ្យពួករ៉ូម នៅក្រុងកាពើណិម ប្រហែលជាធ្វើការឲ្យស្តេចហេរ៉ូឌអាន់ទីប៉ាស ។ មុនបានប្រែចិត្តជឿ នោះលោកត្រូវបានស្គាល់ ជា លេវី កូនរបស់អាល់ផាយ (ម៉ាកុស ២:១៤) ។ មិនយូរប៉ុន្មានក្រោយពីលោកត្រូវបានហៅឲ្យធ្វើជាសិស្សរបស់ព្រះយេស៊ូវ នោះលោកបានធ្វើបុណ្យជប់លៀងដែលព្រះអម្ចាស់ ទ្រង់បានយាងទៅ (ម៉ាថាយ ៩:៩–១៣; ម៉ាកុស ២:១៤–១៧; លូកា ៥:២៧–៣២) ។ ម៉ាថាយប្រហែលជាមានចំណេះអំពីព្រះគម្ពីរសញ្ញាចាស់យ៉ាងជ្រៅជ្រះ ហើយបានឃើញការសំរេចយ៉ាងល្អិតល្អន់ អំពីពាក្យ ព្យាករណ៍ នៅក្នុងព្រះជន្មរបស់ព្រះអម្ចាស់ ។ ជីវិតរបស់សាវកនេះបន្តមក នោះមិនសូវដឹងទេ ។ មានទំនៀមទំលាប់មួយចែងថា លោកបានស្លាប់ជា ទុក្ករបុគ្គល ។

*ដំណឹងល្អតាមលោកម៉ាថាយ៖* ជាគម្ពីរទីមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ដំណឹងល្អតាមលោកម៉ាថាយ ប្រហែលជាបានសរសេរ ដំបូងទុកសំរាប់ការប្រើប្រាសដល់ពួកសាសន៍យូដា នៅស្រុកភីលីស្ទីន ។ គម្ពីរនេះមានពាក្យស្រង់ជាច្រើនចេញពីព្រះគម្ពីរសញ្ញាចាស់ ។ បំណងដ៏ធំរបស់ម៉ាថាយ គឺដើម្បីបង្ហាញថា ព្រះយេស៊ូវ គឺជាព្រះមែស៊ី ដែលពួកព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់បានពោលទុក ។ លោកក៏បានបញ្ជាក់ថា ព្រះយេស៊ូវ គឺជាមហាក្សត្រ ហើយជាចៅក្រមនៃមនុស្សលោក ។

ចំពោះជំពូកសង្ខេប សូមមើល *ដំណឹងល្អទាំងឡាយ* ។

**ម៉ាន៉ា** *សូមមើលផង* និក្ខមនំ, នំប៉័ងជីវិត

ជាអាហារល្អិតៗ ដែលមានរសជាតិដូចនំធ្វើពីទឹកឃ្មុំ (និក្ខ. ១៦:១៤–៣១) ឬធ្វើពីប្រេងថ្មី (ជនគ. ១១:៨) ។ ព្រះអម្ចាស់ ទ្រង់បាន ប្រទាននំនោះ ដើម្បីចិញ្ចឹមពួកកូនចៅអ៊ីស្រាអែល កាលពួកគេនៅក្នុងទីរហោស្ថានអស់រយៈ ៤០ ឆ្នាំ (និក្ខ. ១៦:៤–៥, ១៤–៣០, ៣៥; យ៉ូស្វេ ៥:១២; ១ នីហ្វៃ ១៧:២៨) ។

ពួកកូនចៅអ៊ីស្រាអែលបានហៅនំនោះថា ម៉ាន៉ា (ឬ *ម៉ាន-ហ៊ូ* ជាពាក្យហេព្រើរ) — ដែលមានន័យថា « នេះជាអ្វី » ? — ពីព្រោះពួកគេ មិនស្គាល់ជានំអ្វីទេ (និក្ខ. ១៦:១៥) ។ ក៏បានហៅថាជា « អាហារទេវតា » និង « នំប៉័ងពីស្ថានសួគ៌ » (ទំនុក. ៧៨:២៤–២៥; យ៉ូហាន ៦:៣១) ។ គឺជានិមិត្តរូបសំរាប់ព្រះគ្រីស្ទ ដែលទ្រង់នឹងទៅជានំប៉័ងជីវិត (យ៉ូហាន ៦:៣១–៣៥) ។

**ម៉ាន៉ាសេ** *សូមមើលផង* កូនប្រុសរបស់យ៉ាកុប, យ៉ូសែប, អ៊ីស្រាអែល; អេប្រាអិម

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនច្បងបង្អស់របស់នាងអាសន៉ាត់ និងយ៉ូសែប ដែលបានលក់ទៅស្រុកអេស៊ីព្ទ (លោកុ. ៤១:៥០–៥១) ។ លោក និងអេប្រាអិម ជាប្អូនលោក គឺជាចៅរបស់យ៉ាកុប (អ៊ីស្រាអែល) ប៉ុន្តែយ៉ាកុបបានយកមកចិញ្ចឹមជាកូន ហើយបានឲ្យពរដល់ពួកគេទាំងពីរ ហាក់បីដូចជាកូនរបស់លោកបង្កើត (លោកុ. ៤៨:១–២០) ។

*ពូជអំបូររបស់ម៉ាន៉ាសេ៖* ពូជពង្សម៉ាន៉ាសេត្រូវបានរាប់ចូលក្នុងចំណោមពូជអំបូរនៃអ៊ីស្រាអែល (ជនគ. ១:៣៤–៣៥; យ៉ូស្វេ ១៣:២៩–៣១) ។ ពរនៃលោកម៉ូសេ ដែលឲ្យទៅពូជអំបូរនៃយ៉ូសែប ក៏បានឲ្យទៅអេប្រាអិម និងម៉ាន៉ាសេដែរ នោះបានកត់ទុកនៅ គម្ពីរចោទិយកថា ៣៣:១៣–១៧ ។ ដែនដីដែលបានចែកឲ្យពួកគេ នោះនៅខាងលិចយ័រដាន់បន្តិច ហើយនៅក្បែរដែនដីនៃពួក អេប្រាអិម ។ ពួកគេក៏មានរដ្ឋនៅខាងកើតយ័រដាន់ នៅក្នុងវាលស្មៅដ៏មានដីជាតិនៃស្រុកបាសាន និងស្រុកកាឡាត ។ នៅជាន់ ក្រោយបង្អស់ ពូជអំបូរម៉ាន៉ាសេនឹងជួយពូជអំបូរអេប្រាអិម ក្នុងការប្រមូលពួកសាសន៍អ៊ីស្រាអែលដែលបានខ្ចាត់ខ្ចាយទៅ (ចោទិ. ៣៣:១៣–១៧) ។ លីហៃ ជាព្យាការីនៅក្នុងព្រះគម្ពីរមរមន គឺជាពូជពង្សពីម៉ាន៉ាសេ (អាលម៉ា ១០:៣) ។

**ម៉ាស, ថូម៉ាស ប៊ី**

ជាប្រធានទីមួយនៃក្រុមពួកសាវក ១២ នាក់ បន្ទាប់ពីការសាងសាសនាចក្រឡើងវិញនៅឆ្នាំ ១៨៣០ ។ លោកបានកាន់កូនសោ ទាំងឡាយ

ចំពោះនគរដែលទាក់ទងទៅនឹងពួក ១២ នាក់ (គ. និង ស. ១១២:១៦) ហើយនៅឆ្នាំ ១៨៣៨ លោកត្រូវបានបញ្ជា ដោយវិវរណៈឲ្យបោះពុម្ពព្រះបន្ទូលរបស់ព្រះអម្ចាស់ (គ. និង ស. ១១៨:២) ។ កណ្ឌទី ៣១ នៃគោលលទ្ធិ និងសេចក្ដីសញ្ញា នោះបានបំរុងចំពោះលោក ។ លោកម៉ាសត្រូវបានកាត់ចេញពីសាសនានៅឆ្នាំ ១៨៣៩ ប៉ុន្តែបានទទួលបុណ្យជ្រមុជទឹកម្ដងទៀត នៅខែកក្កដា ឆ្នាំ ១៨៥៧ ។

**ម៉ាឡាគី**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានសរសេរ ហើយព្យាករ នៅប្រមាណឆ្នាំ ៤៣០ ម.គ.ស. ។

*គម្ពីរម៉ាឡាគី៖* គម្ពីរ ឬពាក្យព្យាករណ៍របស់ម៉ាឡាគី គឺជាគម្ពីរចុងក្រោយបង្អស់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ គឺដូចជាមានបទបួនប្រធានដ៏សំខាន់ៈ គឺ (១) អំពើបាបនៃពួកអ៊ីស្រាអែល — ម៉ាឡាគី ១:៦–២;១៧; ៣:៨–៩; (២) សេចក្ដីជំនុំជំរះនឹងមានមកលើ ពួកអ៊ីស្រាអែល ពីព្រោះមកពីការពុំគោរពតាមរបស់គេ — ម៉ាឡាគី ១:១៤: ២:២–៣, ១២; ៣:៥; (៣) សេចក្ដីសន្យាចំពោះពួក ដែលគោរពតាម — ម៉ាឡាគី ៣:១០–១២, ១៦–១៨; ៤:២–៣; និង (៤) ពាក្យព្យាករណ៍ដែលទាក់ទងនឹងអ៊ីស្រាអែល — ម៉ាឡាគី ៣:១–៥; ៤:១, ៥–៦ (គ. និង ស. ២; ១២៨:១៧; យ.ស. — ប្រវត្តិ ១:៣៧–៣៩) ។

នៅក្នុងពាក្យព្យាករណ៍របស់លោក នោះម៉ាឡាគីបានសរសេរអំពីយ៉ូហាន-បាទីស្ទ (ម៉ាឡាគី ៣:១; ម៉ាថាយ ១១:១០), អំពីក្រិត្យវិន័យខាងដង្វាយ១ភាគ១០ (ម៉ាឡាគី ៣:៧–១២), អំពីការយាងមកលើកទីពីរនៃព្រះអម្ចាស់ (ម៉ាឡាគី ៤:៥), និងអំពីការវិលមកវិញនៃអេលីយ៉ា (ម៉ាឡាគី ៤:៥–៦; គ. និង ស. ២; ១២៨: ១៧; យ.ស. — ប្រវត្តិ ១:៣៧–៣៩) ។ ព្រះអង្គសង្គ្រោះទ្រង់បានដកស្រង់ពាក្យពី គម្ពីរម៉ាឡាគី ជំពូកទី ៣ និងទី ៤ ទាំងស្រុង ប្រាប់ដល់ទៅពួកសាសន៍នីហ្វៃ (៣ នីហ្វៃ ២៤–២៥) ។

**មិនចេះចប់មិនចេះហើយ** *សូមមើលផង* ក្រុមព្រះ, ព្រះ

ជាព្រះនាមមួយនៃព្រះ គឺបញ្ជាក់ប្រាប់ពីស្ថានភាពដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ (គ. និង ស. ១៩:១០–១២: ម៉ូសេ ១:៣; ៧:៣៥) ។

**មិលគីស្សាដែក** *សូមមើលផង* បព្វជិតភាពមិលគីស្សាដែក; សាឡិម

ជាសង្ឃជាន់ខ្ពស់ ជាព្យាការី ហើយជាអ្នកដឹកនាំដ៏ធំម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានរស់នៅបន្ទាប់ពីទឹកជំនន់ និងនៅសម័យលោកអ័ប្រាហាំ ។ លោកបានត្រូវហៅថាជា ស្ដេចនៃក្រុងសាឡិម (យេរូសាឡិម) ជាស្ដេចនៃសេចក្ដីសុខសាន្ត ជាស្ដេចនៃសេចក្ដីសុចរិត (គឺជាន័យរបស់ពាក្យហេព្រើរ មិលគីស្សាដែក) ហើយជាសង្ឃនៃព្រះដ៏ខ្ពស់បំផុត ។

អ័ប្រាហាំបានថ្វាយដង្វាយ១ភាគ១០ ទៅមិលគីស្សាដែក, **លោកុ.** ១៤:១៨–២០ ។ រាស្ត្រមិលគីស្សាដែកបាននាំមកនូវសេចក្ដីសុចរិត ហើយបានស្ថានសួគ៌, **ក.យ.ស., លោកុ.** ១៤:២៥–៤០ ។ ព្រះគ្រីស្ទជាសម្ដេចសង្ឃ តាមរបៀបលោកមិលគីស្សាដែក, **ហេព្រើរ** ៥:៦ ។ លោកមិលគីស្សាដែក ជាស្ដេចក្រុងសាឡិម ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត, **ហេព្រើរ** ៧:១–៣ ។ គ្មាននរណាប្រសើរជាងលោកមិលគីស្សាដែកឡើយ, **អាលម៉ា** ១៣:១៤–១៩ ។ លោកអ័ប្រាហាំបានទទួលបព្វជិតភាពពីលោកមិលគីស្សាដែក, **គ. និង ស.** ៨៤:១៤ ។ មកពីការគោរពដល់ព្រះនាមនៃព្រះអម្ចាស់ ទើបសាសនាចក្រពីសម័យបុរាណ បានហៅបព្វជិតភាពជាន់ខ្ពស់ថា បព្វជិតភាពមិលគីស្សាដែក, **គ. និង ស.** ១០៧:១–៤ ។

**មិសស្សូរី** *សូមមើល* ក្រុងយេរូសាឡិមថ្មី

**មីកា**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ លោកជាអ្នកស្រុកម៉ូរ៉ាសិត កាត នៅក្នុងទំនាបស្រុកយូដា ហើយបានព្យាករ កាលហេសេគា ជាស្ដេច (មីកា ១:១–២) ។

*គម្ពីរមីកា៖* មីកាគឺជាគម្ពីរតែមួយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលឲ្យឈ្មោះថា ភូមិបេថ្លេហិម ជាទីកន្លែង ដែលព្រះមែស៊ី នឹងប្រសូតមក (មីកា ៥:២) ។ នៅក្នុងគម្ពីរនេះ ព្រះអម្ចាស់ទ្រង់បានទូន្មានដល់រាស្ត្រទ្រង់ ហើយបានជំណាលអំពីសេចក្ដីសប្បុរស របស់ទ្រង់ដល់ពួកគេ; ទ្រង់តម្រូវពីគេនូវសេចក្ដីយុត្តិធម៌ សេចក្ដីមេត្តាករុណា និងសេចក្ដីបន្ទាបរាបសា (មីកា ៦:៨) ។

**មីកែល** *សូមមើលផង* មហាទេវតា, អ័ដាម

ជាឈ្មោះដែលគេហៅលោកអ័ដាម នៅក្នុងជីវិតមុនផែនដី ។ លោកត្រូវគេហៅថា មហាទេវតា ។ នៅក្នុងភាសាហេព្រើរ ឈ្មោះ នេះមានន័យថា « ជាអ្នកដូចព្រះ » ។

មីកែល ជាមហាទេវតា ដែលបានមកជួយដានីយ៉ែល, **ដានី.** ១០:១៣, ២១ (គ. និង ស. ៧៨:១៦) ។ នៅជាន់ក្រោយបង្អស់ មីកែលជាម្ចាស់ដ៏ធំនឹងឈរឡើង, **ដានី.** ១២:១ ។ មីកែល ជាមហាទេវតាបានជជែកនឹងអារក្ស, **យូដាស** ១:៩ ។ មីកែល និងពួកទេវតារបស់លោកច្បាំងនឹងនាគ, **វិវរ.** ១២:៧ (ដានី. ៧) ។ មីកែលគឺជាលោកអ័ដាម, **គ. និង ស.** ២៧:១១ (គ. និង ស. ១០៧:៥៣–៥៧; គ. និង ស. ១២៨:២១) ។ មីកែល ជាមហាទេវតានៃព្រះអម្ចាស់នឹងបន្លឺត្រែរបស់លោក, **គ. និង ស.** ២៩:២៦ ។ មីកែលនឹងប្រមូលពលទ័ពទាំងឡាយរបស់លោក ហើយច្បាំងនឹងសាតាំង, **គ. និង ស.** ៨៨:១១២–១១៥ ។ សម្លេងនៃមីកែលនឹងបានឮបំរាមប្រាប់ ពីអារក្ស, **គ. និង ស.** ១២៨:២០ ។

**មុក្តាដ៏មានតម្លៃមហិមា** *សូមមើលផង* កាណុង; បទព្រះគម្ពីរ; យ៉ូសែប ស្ម៊ីធ, ស្ម៊ីធ

នគរព្រះនៅលើផែនដី គឺប្រៀបដូចជា « មុក្តាដ៏មានតម្លៃមហិមា » (ម៉ាថាយ ១៣:៤៥–៤៦) ។

មុក្តាដ៏មានតម្លៃមហិមា ក៏ជាឈ្មោះព្រះគម្ពីរមួយ ក្នុងព្រះគម្ពីរបួនច្បាប់ ដែលហៅថា « គម្ពីរដ៏ជាបមាណិយ » របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ច្បាប់ទី១ នៃមុក្តាដ៏មានតម្លៃមហិមាត្រូវបានបោះពុម្ពក្នុងឆ្នាំ ១៨៥១ ហើយមាននូវ ឯកសារដែលឥឡូវនេះ មាននៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា ។ ភាគជាច្រើនដែលបានបោះពុម្ពចាប់តាំងពីឆ្នាំ ១៩០២ មាននូវ (១) ការសង្ខេបពីការបកប្រែគម្ពីរលោកុប្បត្តិដោយយ៉ូសែប ស្ម៊ីធ បានហៅថា គម្ពីរម៉ូសេ និងការបកប្រែគម្ពីរម៉ាថាយ ជំពូកទី ២៤ បានហៅថា យ៉ូសែប ស្ម៊ីធ — ម៉ាថាយ; (២) ការបកប្រែដោយយ៉ូសែប ស្ម៊ីធ ចេញពីក្រាំងប្របុសនៃពួកអេស៊ីព្ទ ដែលលោកបានទទួល ក្នុងឆ្នាំ ១៨៣៥ បានហៅថា គម្ពីរអ័ប្រាហាំ; (៣) ការសង្ខេបពីប្រវត្តិនៃសាសនាចក្រ ដោយយ៉ូសែប ស្ម៊ីធ ដែលលោកបានសរសេរ ក្នុងឆ្នាំ ១៨៣៨ បានហៅថា យ៉ូសែប ស្ម៊ីធ — ប្រវត្តិ; និង (៤) មាត្រានៃសេចក្តីជំនឿ មានមាត្រា ១៣ បទ អំពីជំនឿ និងអំពីគោលលទ្ធិ ។

**មូលេក** *សូមមើលផង* សេដេគា

ជាបុត្ររបស់ស្តេចសេដេគា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (ប្រមាណជាឆ្នាំ ៥៨៩ ម.គ.ស.) ។ ព្រះគម្ពីរប៊ីបកត់ថា បុត្រាទាំងអស់របស់ស្តេចសេដេគាត្រូវគេប្រហារ (២ ពង្សាវ. ២៥:៧) ។ ប៉ុន្តែព្រះគម្ពីរមរមនបញ្ជាក់ថា មូលេកបាននៅរស់ (ហេលេ. ៨:២១) ។

សារ៉ាហិមឡាជាពូជពង្សនៃមូលេក, **ម៉ូសាយ** ២៥:២ ។ ប្រជារាស្ត្រនៃមូលេកបានចូលរួមនឹងពួកសាសន៍នីហ្វៃ, **ម៉ូសាយ** ២៥:១៣ ។ ព្រះអម្ចាស់ ទ្រង់បាននាំមូលេកចូលដែនដីខាងជើង, **ហេលេ.** ៦:១០ ។ បុត្រាទាំងអស់របស់ស្តេចសេដេគាត្រូវគេប្រហារចោល លើកលែងតែមូលេកប៉ុណ្ណោះ, **ហេលេ.** ៨:២១ ។

**ម៉ូសាយ, បិតារបស់បេនយ៉ាមីន** *សូមមើលផង* បិតារបស់ម៉ូសាយ; បេនយ៉ាមីន, សារ៉ាហិមឡា

នៅក្នុងព្រះគម្ពីរមរមន គឺជាព្យាការីសាសន៍នីហ្វៃម្នាក់ ដែលត្រូវបានធ្វើជាស្តេចលើប្រជារាស្ត្រ នៅក្រុងសារ៉ាហិមឡា ។

ម៉ូសាយត្រូវបានព្រមានឲ្យភៀសខ្លួនចេញពីដែនដីនីហ្វៃ, **អោមណៃ** ១:១២ ។ លោកបានជួបប្រទះប្រជារាស្ត្រនៅក្រុងសារ៉ាហិមឡា, **អោមណៃ** ១:១៤–១៥ ។ លោកបានបញ្ជាឲ្យប្រជារាស្ត្រនៅក្រុងសារ៉ាហិមឡារៀនភាសាលោក, **អោមណៃ** ១:១៨ ។ លោកត្រូវគេតែងតាំងឲ្យធ្វើជាស្តេចលើប្រជារាស្ត្រដែលបានចូលរួមគ្នា, **អោមណៃ** ១:១៩ ។ បេនយ៉ាមីន ជាបុត្ររបស់លោកបានសោយរាជ្យបន្ទាប់ពីលោកសុគតទៅ, **អោមណៃ** ១:២៣ ។

**ម៉ូសាយ, បុត្ររបស់បេនយ៉ាមីន** *សូមមើលផង* បិតារបស់ម៉ូសាយ; បេនយ៉ាមីន, ពួកបុត្រារបស់ទ្រង់, ម៉ូសាយ

ជាស្តេច ហើយជាព្យាការីសាសន៍នីហ្វៃដ៏សុចរិតម្នាក់ នៅក្នុងព្រះគម្ពីរមរមន ។ ម៉ូសាយបានដើរតាមដំរាប់ដ៏សុចរិតនៃបិតារបស់ទ្រង់ (ម៉ូសាយ ៦:៤–៧) ។ ទ្រង់បានបកប្រែផ្ទាំងមាស ២៤ បន្ទះ ដែលមាននូវបញ្ជីប្រវត្តិអំពីពួកសាសន៍យ៉ារេឌ (ម៉ូសាយ ២៨:១៧) ។

*គម្ពីរម៉ូសាយ៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរមរមន ។ ជំពូកទី ១–៦ មានអំពីបទបង្រៀនដ៏ប្រកបដោយអានុភាពនៃស្តេចបេនយ៉ាមីន ដល់រាស្ត្រទ្រង់ ។ ព្រះវិញ្ញាណនៃព្រះអម្ចាស់បានសណ្ឋិតលើចិត្តគេ ហើយប្រជារាស្ត្របានប្រែចិត្តជឿ ហើយគ្មានបំណងចង់ប្រព្រឹត្តអំពើអាក្រក់ទៀតឡើយ ។ ជំពូកទី ៧–៨ ប្រាប់អំពីសាសន៍នីហ្វៃមួយក្រុមដែលបានទៅអាស្រ័យនៅក្នុងចំណោមពួកសាសន៍លេមិន ។ មនុស្សមួយក្រុមត្រូវបានចាត់ឲ្យទៅរកពួកគេ ។ អាំម៉ូន ជាមេក្រុម បានរកពួកគេឃើញ ហើយបានដឹងពីរឿងនៃការវេទនារបស់គេ នៅ ក្រោមការសង្កត់សង្កិនរបស់ពួកសាសន៍លេមិន ។ ជំពូកទី ៩–២៤ រៀបរាប់អំពីការសង្កត់សង្កិននោះ និងអំពីរបៀបដែលពួកមេដឹកនាំ របស់គេ — គឺ សិនិព្វ ណូអេ និងលិមហៃ — បានរស់នៅក្រោមពួកសាសន៍លេមិនយ៉ាងណា ។ ទុក្ករកម្មនៃព្យាការីម្នាក់ហៅថា អ័ប៊ីណាដៃ ក៏បានកត់ទុកដែរ ។ អាលម៉ាបានប្រែចិត្តជឿកាលកាត់ក្តីអ័ប៊ីណាដៃ ។ ជំពូកទី ២៥–២៨ រៀបរាប់សារឡើងវិញនូវរឿងទាំងឡាយអំពី អាលម៉ាជាកូន និងពួកបុត្រា៤នាក់នៃស្តេចម៉ូសាយបានក្លាយជាអ្នកប្រែចិត្តជឿ ។ នៅក្នុងជំពូកទី ២៩ ស្តេចម៉ូសាយបានណែនាំនូវ របៀបគ្រប់គ្រងមួយដោយពួកចៅក្រម ជំនួសពួកស្តេច ។ អាលម៉ា កូនប្រុសរបស់អាលម៉ា ត្រូវបានរើសតាំងឲ្យធ្វើជាមេចៅក្រមទីមួយ ។

**ម៉ូសាយ, ពួកបុត្រារបស់ទ្រង់** *សូមមើលផង* បុត្ររបស់ បេនយ៉ាមីន; បុត្ររបស់ម៉ូសាយ; បុត្ររបស់ម៉ូសាយ; ម៉ូសាយ, ហិមណៃ; អើរ៉ុន, អាំម៉ូន, អោមណើរ

នៅក្នុងព្រះគម្ពីរមរមន គឺជាពួកបុត្រាបួននាក់របស់ស្តេចម៉ូសាយ ដែលបានប្រែចិត្តជឿ បន្ទាប់ពីមានទេវតាមួយបានលេចមកឯពួកគេ ហើយបានប្រាប់ពួកគេឲ្យប្រែចិត្ត ។ នាមពួកគេគឺ៖ អាំម៉ូន,អើរ៉ុន, អោមណើរ និង ហិមណៃ (ម៉ូសាយ ២៧:៣៤) ។ ពួកគេបាន ចំណាយពេលអស់១៤ឆ្នាំក្នុងការផ្សាយដំណឹងល្អដល់ពួកសាសន៍លេមិនបានដោយជោគជ័យ ។ បញ្ជីមួយអំពីការងារបំរើរបស់ពួកគេ នៅក្នុងចំណោមពួកសាសន៍លេមិននោះបានរៀបរាប់ប្រាប់នៅក្នុងគម្ពីរអាលម៉ា ជំពូកទី ១៧ ទៅ ២៦ ។

មុនដំបូង ពួកគេជាអ្នកមិនជឿ ដែលបានរកកំទេចសាសនាចក្រចោល, **ម៉ូសាយ** ២៧:៨–១០ (អាលម៉ា ៣៦:៦) ។ ពួកគេត្រូវទេវតាស្តីបន្ទោស ហើយបានប្រែចិត្ត, **ម៉ូសាយ** ២៧:១១–១២, ១៨–២០ ។ ពួកគេបានទទួលការអនុញ្ញាតឲ្យទៅផ្សាយដល់ពួកសាសន៍លេមិន, **ម៉ូសាយ** ២៨:១–៧ ។

**ម៉ូសេ** *សូមមើលផង* ការប្រែរូប — ការប្រែរូបនៃ ព្រះគ្រីស្ទ, ក្រិត្យវិន័យលោកម៉ូសេ; គម្ពីរ៥ច្បាប់; បងប្រុសរបស់ម៉ូសេ; បញ្ញត្តិ១០ប្រការ; អើរ៉ុន

ជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបាននាំពួកសាសន៍អ៊ីស្រាអែល ចេញពីការឃុំឃាំងរបស់ពួកសាសន៍អេស៊ីព្ទ ហើយ បាន

ផ្ដល់ដល់ពួកគេ នូវក្រិត្យវិន័យទាំងឡាយខាងសាសនា ខាងសង្គម និងខាងម្ហូបអាហារ ដែលបានបើកសម្ដែងប្រាប់ដោយព្រះ ។

ការងារបំរើរបស់ម៉ូសេបន្ដហួសកិរិតនៃជីវិតរបស់លោកនៅលើផែនដី ។ យ៉ូសែប ស្ម៊ីធបានបង្រៀនថា លោកបានមកជាមួយនឹង អេលីយ៉ា មកលើភ្នំនៃការប្រែរូប ហើយបានប្រគល់កូនសោទាំងឡាយនៃបព្វជិតភាពទាំងប៉ុន្មានមកលើពេត្រុស យ៉ាកុប និងយ៉ូហាន (ម៉ាថាយ ១៧:៣–៤; ម៉ាកុស ៩:៤–៩; លូកា ៩:៣០; គ. និង ស. ៦៣:២១) ។

ម៉ូសេបានលេចមកឯយ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី នៅថ្ងៃទី៣ ខែមេសា ឆ្នាំ ១៨៣៦ នៅក្នុងព្រះវិហារនៅក្រុងខើតឡង់ រដ្ឋអូហៃអូ ហើយបានប្រគល់ដល់គេ នូវកូនសោទាំងឡាយនៃការប្រមូលសាសន៍អ៊ីស្រាអែល (គ. និង ស. ១១០:១១) ។

វិវរណៈនៅថ្ងៃចុងក្រោយស្ដីជាច្រើនអំពីម៉ូសេ ។ លោកត្រូវបានពោលដល់ជាញឹកញាប់ នៅក្នុងព្រះគម្ពីរមរមន ហើយចេញពីគោល លទ្ធិ និងសេចក្ដីសញ្ញា យើងដឹងអំពីការងារបំរើរបស់លោក (គ. និង ស. ៨៤:២០–២៦) ហើយដឹងថាលោកបានទទួលបព្វជិតភាព ពីយេត្រូ ជាឪពុកក្មេករបស់លោក (គ. និង ស. ៨៤:៦) ។

វិវរណៈនៅថ្ងៃចុងក្រោយក៏បញ្ជាក់ប្រាប់ពីហេតុរឿងក្នុងព្រះគម្ពីរប៊ីប អំពីការងារបំរើរបស់លោក នៅក្នុងចំណោមពួកកូនចៅ អ៊ីស្រាអែល ហើយបញ្ជាក់ប្រាប់ថែមទៀតថា លោកគឺជាអ្នកនិពន្ធគម្ពីរ៥ច្បាប់ ដែលចាប់ផ្ដើមព្រះគម្ពីរសញ្ញាចាស់ (១ នីហ្វៃ ៥:១១; ម៉ូសេ ១:៤០–៤១) ។

ត្រូវបានជួយសង្គ្រោះដោយបុត្រីនៃផារ៉ោន, **និក្ខ.** ២:១–១០ ។ បានរត់ទៅឯស្រុកម៉ាឌាន, **និក្ខ.** ២:១១–២២ ។ ទេវតានៃព្រះអម្ចាស់ បានលេចមកឯលោក ក្នុងអណ្ដាតភ្លើងនៅកណ្ដាលគុម្ពបន្លា, **និក្ខ.** ៣:១–១៥ ។ បានប្រកាសប្រាប់អំពីគ្រោះ ដែលនឹងកើតឡើងដល់ពួក សាសន៍អេស៊ីព្ទ, **និក្ខ.** ៧–១១ ។ ព្រះអម្ចាស់ទ្រង់បានតាំងបុណ្យរំលងឡើង, **និក្ខ.** ១២:១–៣០ ។ បាននាំពួកកូនចៅអ៊ីស្រាអែលឆ្លងកាត់ សមុទ្រក្រហម, **និក្ខ.** ១៤:៥–៣១ ។ ព្រះអម្ចាស់ទ្រង់បានបណ្ដាលឲ្យមាននំម៉ាន៉ា នៅក្នុងទីរហោស្ថាន, **និក្ខ.** ១៦ ។ បានវាយថ្មដា នៅហូរែប ហើយទឹកក៏ចេញមក, **និក្ខ.** ១៧:១–៧ ។ អើរ៉ុន និងហើរបានលើកដៃគេឡើង ដើម្បីឲ្យយ៉ូស្វេឈ្នះលើអាម៉ាលេក, **និក្ខ.** ១៧:៨–១៦ ។ យេត្រូបានទូន្មានដល់លោក, **និក្ខ.** ១៨:១៣–២៦ ។ បានរៀបចំប្រជាជនសំរាប់ការលេចមកនៃព្រះអម្ចាស់ នៅលើភ្នំ ស៊ីណាយ, **និក្ខ.** ១៩ ។ ព្រះអម្ចាស់ទ្រង់បានបើកសម្ដែងបញ្ញត្តិ១០ប្រការដល់លោក, **និក្ខ.** ២០:១–១៧ ។ លោក និងពួកអែលឌើរ ៧០ នាក់បានឃើញព្រះ, **និក្ខ.** ២៤:៩–១១ ។ បានបំបែកបន្ទះថ្មនៃសេចក្ដីបន្ទាល់ ហើយបានបំផ្លាញរូបកូនគោមាសចោល, **និក្ខ.** ៣២:១៩–២០ ។ បានទូលប្រទល់មុខនឹងព្រះ, **និក្ខ.** ៣៣:៩–១១ ។ បានលេចមកកាលព្រះយេស៊ូវទ្រង់ប្រែរូប, **ម៉ាថាយ** ១៧:១–១៣ (ម៉ាកុស ៩:២–១៣; លូកា ៩:២៨–៣៦) ។ ចូរយើងមានកម្លាំងខ្លាំងដូចលោកម៉ូសេ, **១ នីហ្វៃ** ៤:២ ។ ព្រះគ្រីស្ទគឺជាព្យាការីម្នាក់ ដូចជាលោកម៉ូសេ ដែលព្រះអម្ចាស់ទ្រង់នឹងលើកឡើង, **១ នីហ្វៃ** ២២:២០–២១ (៣ នីហ្វៃ ២០:២៣; ចោទិ. ១៨:១៥) ។ បាននាំ សាសន៍អ៊ីស្រាអែលដោយវិវរណៈ, **គ. និង ស.** ៨:៣ ។ បានឃើញនៅក្នុងចំណោមពួកវិញ្ញាណដ៏ឧត្ដុង្គឧត្ដម, **គ. និង ស.** ១៣៨:៤១ ។ បានឃើញព្រះនៅប្រទល់មុខ, **ម៉ូសេ** ១:២, ៣១ ។ បាននៅក្នុងរូបដូចជាព្រះរាជ បុត្រាបង្កើតតែមួយ, **ម៉ូសេ**១:៦, ១៣ ។ ត្រូវសរសេរអំពីការណ៍ទាំងឡាយ ដែលបានបើកសម្ដែងដល់លោកអំពីការបង្កបង្កើត, **ម៉ូសេ** ២:១ ។

*គម្ពីរម៉ូសេ៖* ជាគម្ពីរមួយ នៅក្នុងមុក្ដាដ៏មានតម្លៃមហិមា ដែលមាននូវការបកប្រែដ៏ប្រសើរដោយយ៉ូសែប ស្ម៊ីធ គឺ ប្រាំពីរជំពូកដំបូងបង្អស់នៃគម្ពីរលោកុប្បត្តិ ។

ជំពូកទី ១ កត់អំពីការនិមិត្តមួយ ដែលម៉ូសេបានឃើញព្រះ ដែលបានបើកសម្ដែងដល់លោក អំពីផែនការនៃសេចក្ដីសង្គ្រោះទាំងមូល ។ ជំពូកទី ២–៥ គឺជាដំណើររឿងអំពីការបង្កបង្កើត និងការធ្លាក់នៃមនុស្ស ។ ជំពូកទី ៦–៧ មានការនិមិត្តមួយ អំពីលោកហេណុក និងការ ងារបំរើរបស់លោកនៅលើផែនដី ។ ជំពូកទី ៨ មានការនិមិត្តមួយ អំពីលោកណូអេ និងទឹកជំនន់ដ៏ធំ ។

*គម្ពីរ៥ច្បាប់នៃលោកម៉ូសេ៖* សូមមើល លោកុប្បត្តិ; និក្ខមនំ; លេវីវិន័យ; ជនគណនា; ចោទិយកថា

គម្ពីរ៥ច្បាប់ដំបូងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺបានស្គាល់ជាគម្ពីរទាំងឡាយនៃលោកម៉ូសេ ។ ផ្ទាំងលង្ហិនដែល នីហ្វៃបានយកពី ឡាបាន់នោះមានគម្ពីរទាំងឡាយនៃលោកម៉ូសេ (១ នីហ្វៃ ៥:១១) ។

នីហ្វៃបានអានរឿងជាច្រើន ដែលបានសរសេរទុកនៅក្នុងគម្ពីរទាំងឡាយនៃលោកម៉ូសេ, **១ នីហ្វៃ** ១៩:២៣ ។

**ម៉ូអាប់** *សូមមើលផង* ឡុត

ជាដែនដីមួយនៅសម័យព្រះគម្ពីរសញ្ញាចាស់ ដែលនៅឯកើតសមុទ្រស្លាប់ ។ ពួកសាសន៍ម៉ូអាប់ជាពូជពង្សពីឡុត ហើយជាញាតិសន្ដាននឹងពួកសាសន៍អ៊ីស្រាអែល ។ ពួកគេនិយាយភាសាប្រហែលគ្នានឹងភាសាហេព្រើរ ។ មានសង្គ្រាមជាញឹកញាប់រវាងពួក សាសន៍ម៉ូអាប់ នឹងពួកសាសន៍អ៊ីស្រាអែល (ពួកចៅ. ៣:១២–៣០; ១១:១៧; ២ សាំយូ. ៨:២; ២ ពង្សាវ. ៣:៦–២៧; ២ របា. ២០:១–២៥; អេសាយ ១៥) ។

**មេទ័ព**

ជាមេទ័ពម្នាក់ នៅក្នុងកងទ័ពរ៉ូម ដែលបញ្ជាកងទ័ព ៥០ ទៅ ១០០ នាក់ ។ កងទ័ពនេះជាមួយភាគហុកសិបក្នុងកងទ័ពរ៉ូម ។ (មើល ម៉ាថាយ ៨:៥; លូកា ២៣:៤៧; កិច្ចការ ១០:១–៨) ។

**មេបំផ្លាញ** *សូមមើលផង* អារក្ស

អារក្សសាតាំងជាមេបំផ្លាញ ។

ព្រះអម្ចាស់ទ្រង់មិនព្រមឲ្យមេបំផ្លាញចូលវាយ ក្នុងផ្ទះអ្នករាល់គ្នាទេ, **និក្ខ.** ១២:២៣ ។ មេបំផ្លាញជិះនៅលើផ្ទៃទឹកទាំងឡាយ, **គ. និង ស.** ៦១:១៩ ។ អ្នកចាំយាមអាចបានជួយសង្គ្រោះចំការយើងពីមេបំផ្លាញបាន, **គ. និង ស.** ១០១:៥១–៥៤ ។

**មែសាក់** *សូមមើលផង* ដានីយ៉ែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ គឺជាកំឡោះបីនាក់នៃសាសន៍អ៊ីស្រាអែល ជាមួយនឹងដានីយ៉ែល ដែលត្រូវបានចាប់យកទៅឯវាំងនៃនេប៊ូក្នេសា ជាស្ដេចស្រុកបាប៊ីឡូន ។ ឈ្មោះរបស់មែសាក់ក្នុងភាសាហេព្រើរ គឺ មីសែល ។ កំឡោះបួននាក់មិនព្រមធ្វើឲ្យខ្លួនស្មោកគ្រោក ដោយបរិភោគសាច់ និងស្រាទំពាំងបាយជូររបស់ស្ដេចឡើយ (ដានី. ១) ។ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ត្រូវស្ដេចបោះទៅក្នុងគុកភ្លើង តែបានព្រះរាជបុត្រានៃព្រះបានជួយរក្សាជីវិតទុក (ដានី. ៣) ។

**ម្ដាយ** *សូមមើលផង* គ្រួសារ; នាងអេវ៉ា; ឪពុកម្ដាយ

ជាឈ្មោះដ៏ពិសិដ្ឋមួយដែលឲ្យដល់ស្ត្រីណាម្នាក់ដែលមានកូន ឬបានកូនមកចិញ្ចឹម ។ ម្ដាយទាំងឡាយជួយក្នុងផែនការរបស់ព្រះ ដោយផ្ដល់នូវរូបកាយដែលរមែងស្លាប់ សំរាប់ពួកកូនចៅវិញ្ញាណរបស់ព្រះ ។

អ័ដាមបានឲ្យឈ្មោះប្រពន្ធគាត់ថា « អេវ៉ា » ពីព្រោះនាងជាម្ដាយនៃមនុស្សទាំងអស់, **លោកុ.** ៣:២០ (ម៉ូសេ ៤:២៦) ។ ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយឯង, **និក្ខ.** ២០:១២ (អេភេ. ៦:១–៣; ម៉ូសាយ ១៣:២០) ។ ចូរកុំបោះបង់ចោលសេចក្ដីដំបូន្មានរបស់ម្ដាយឯង ឡើយ, **សុភា.** ១:៨ ។ ឯមនុស្សល្ងីល្ងើ គេមើលងាយម្ដាយខ្លួនវិញ, **សុភា.** ១៥:២០ (សុភា. ១០:១) ។ ចូរកុំមើលងាយម្ដាយឯងក្នុង កាលដែលគាត់ចាស់ឡើយ, **សុភា.** ២៣:២២ ។ កូនៗ និងប្ដីនាងក្រោកឈរឡើងហៅនាងថាជាអ្នកមានពរ ហើយប្ដីនាងសរសើរ នាង, **សុភា.** ៣១:២៨ ។ មាតាព្រះយេស៊ូវ នាងឈរនៅជិតឈើឆ្កាង, **យ៉ូហាន** ១៩:២៥–២៧ ។ ពួកអ្នកចំបាំងសាសន៍លេមិនពីរ ពាន់នាក់ត្រូវ បានបង្រៀនដោយម្ដាយទាំងឡាយរបស់គេ, **អាលម៉ា** ៥៦:៤៧ (អាលម៉ា ៥៧:២១) ។ នាងអេវ៉ាដ៏ឧត្ដម ជាមាតា របស់យើង បាននៅក្នុងចំណោមមនុស្សធំ និងខ្លាំងពូកែ ដែលព្រះអម្ចាស់ទ្រង់បានបង្គាប់នៅស្ថានវិញ្ញាណ, **គ. និង ស.** ១៣៨:៣៨–៣៩ ។

**យ៉ង់, ព្រិកហាំ**

ជាសាវកដំបូងម្នាក់ នៅគ្រាកាន់កាប់ត្រួតត្រានេះ ហើយជាប្រធានទីពីរនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ ។ លោកបាននាំពួកបរិសុទ្ធចេញពីក្រុងណៅវូ រដ្ឋអិលលីណោយ ទៅកាន់ភូមិភាគខាងលិច គឺទៅឯច្រកភ្នំមួយ ដែលហៅថា សលត៍លេក វ៉ាលលី ហើយជាអ្នកធ្វើនិគមដ៏ធំម្នាក់ នៅភូមិភាគខាងលិចនៃសហរដ្ឋ ។

ព្រិកហាំ យ៉ង់ត្រូវបានហៅឲ្យធ្វើជាប្រធានលើពួកសាវក ១២ នាក់, **គ. និង ស.** ១២៤:១២៧ ។ ព្រិកហាំ យ៉ង់ត្រូវបានសរសើរ ចំពោះការងារទាំងឡាយរបស់លោក ហើយបានអនុញ្ញាតឲ្យឈប់ពីការធ្វើដំណើរទៅប្រទេសក្រៅ, **គ. និង ស.** ១២៦ ។ ព្រះអម្ចាស់ទ្រង់បានបង្គាប់ព្រិកហាំ យ៉ង់នូវរបៀបរៀបចំពួកបរិសុទ្ធ ឲ្យធ្វើដំណើរទៅកាន់ភូមិភាគខាងលិច, **គ. និង ស.** ១៣៦ ។ ព្រិកហាំ យ៉ង់បាននៅ ក្នុងចំណោមពួកអ្នកជំរើសទាំងឡាយ នៅឯស្ថានវិញ្ញាណ, **គ. និង ស.** ១៣៨:៥៣ ។

**យ៉ាកុប, កូនប្រុសរបស់លីហៃ** *សូមមើលផង* លីហៃ, ឪពុករបស់នីហ្វៃ

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរមរមន ហើយជាអ្នកនិពន្ធនូវបទបង្រៀនជាច្រើន នៅក្នុងគម្ពីរនីហ្វៃទី ២ និងគម្ពីរយ៉ាកុប (២ នីហ្វៃ ៦–១១; យ៉ាកុប ១–៧) ។

*គម្ពីរយ៉ាកុប៖* ជាគម្ពីរទីបីនៅក្នុងព្រះគម្ពីរមរមន ។ ជំពូកទី ១ ប្រាប់ពីនីហ្វៃបានប្រគល់បញ្ជីប្រវត្តិឲ្យយ៉ាកុប ហើយបន្ទាប់មក បានតាំង យ៉ាកុប និងយ៉ូសែប ជាប្អូនប្រុសលោកឲ្យធ្វើជាសង្ឃ ហើយជាគ្រូបង្រៀនដល់ប្រជារាស្ត្រ ។ ជំពូកទី ២–៤ ជាបទបង្រៀនដែលទូន្មានឲ្យប្រជាជននៅស្អាតបាត ។ យ៉ាកុបក៏បានបង្រៀនអំពីការយាងមកនៃព្រះមែស៊ីដ៏ប្រោសលោះ ហើយលោកបានប្រាប់អំពីមូលហេតុដែល ពួកមនុស្សខ្លះនៅអ៊ីស្រាអែលមិនព្រមទទួលស្គាល់ទ្រង់ កាលទ្រង់យាងមក ។ ជំពូកទី ៥–៦ មាននូវទីបន្ទាល់របស់យ៉ាកុប និងពាក្យ ប្រៀបធៀបដែលប្រកបដោយការព្យាករណ៍ អំពីប្រវត្តិ និងបេសកកម្មនៃប្រជាជនអ៊ីស្រាអែល ។ ជំពូកទី ៧ មាននូវដំណើររឿងនៃអ្នក បះបោរម្នាក់ ដែលបានរៀនសូត្រ ឈ្មោះសេរេម ដែលត្រូវបានចុះចាញ់ដោយទីបន្ទាល់ដ៏ឧត្ដមរបស់យ៉ាកុប ។

**យ៉ាកុប, កូនប្រុសរបស់សេបេដេ**

ជាសាវកម្នាក់ក្នុងពួក ១២ នាក់ ដែលបានរើសដោយព្រះយេស៊ូវ នៅសម័យការងារបំរើរបស់ទ្រង់នៅលើផែនដី ។ លោកត្រូវ ជាបងរបស់យ៉ូហាន ។ លោកជាសាវកម្នាក់ក្នុងពួក ៣ នាក់ ដែលបាននៅជាមួយនឹងព្រះយេស៊ូវ នៅគ្រាពិសេសៗ គឺៈ នៅគ្រា ប្រោសកូនស្រីនៃយ៉ៃរ៉ុស (ម៉ាកុស ៥:៣៧), នៅគ្រាប្រែរូប (ម៉ាថាយ ១៧:១; យ៉ាកុប ៩:២; លូកា ៩:២៨), និងកាលនៅឯសួនច្បារ គែតសេម៉ានី (ម៉ាថាយ ២៦:៣៧; ម៉ាកុស ១៤:៣៣) ។ ជាមួយនឹងពេត្រុស និងយ៉ូហាន នោះលោកបានសាងបព្វជិតភាព មិលគីស្សាដែកទៅផែនដីវិញ ដោយការតែងតាំងយ៉ូសែប ស្ម៊ីធ (គ. និង ស. ២៧:១២; ១២៨:២០; យ.ស. — ប្រវត្តិ ១:៧២) ។

**យ៉ាកុប, កូនប្រុសរបស់អាលផាយ**

ជាសាវកម្នាក់ក្នុងពួក ១២ នាក់ ដែលបានរើសដោយព្រះយេស៊ូវ នៅសម័យការងារបំរើរបស់ទ្រង់នៅលើផែនដី (ម៉ាថាយ ១០:៣; ម៉ាកុស ៣:១៨; លូកា ៦:១៥; កិច្ចការ ១:១៣) ។

**យ៉ាកុប, កូនប្រុសរបស់អ៊ីសាក** *សូមមើលផង* អ៊ីសាក; អ៊ីស្រាអែល, អេសាវ

ជាអយ្យកោ ហើយជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាកូនប្អូននៃកូនភ្លោះរបស់អ៊ីសាក និងនាងរេបិកា (លោកុ. ២៥:១៩–២៦) ។ យ៉ាកុបបានសិទ្ធិកូនច្បងជួសអេសាវ ជាបងលោក ។ នេះគឺមកពីភាពសក្ដិសម និងអាពាហ៍ពិពាហ៍ក្នុងសេចក្ដីសញ្ញា កាលអេសាវបោះបង់ចោលសិទ្ធិកូនច្បងរបស់ខ្លួន ហើយបានរៀបអាពាហ៍

ពិពាហ៍ក្រៅសេចក្ដីសញ្ញា (លោកុ. ២៥:៣០–៣៤; ២៦:៣៤–៣៥; ២៧; ២៨:៦–៩; ហេព្រើរ ១២:១៦) ។

នាងរេបិកាបានដឹងពីព្រះអម្ចាស់ថា អេសាវនឹងបំរើយ៉ាកុប, **លោកុ.** ២៥:២៣ ។ បានទិញសិទ្ធិកូនច្បងពីអេសាវ, **លោកុ.** ២៥:២៩–៣៤ ។ បានយល់សប្តិអំពីជណ្តើរមួយទល់នឹងផ្ទៃមេឃ, **លោកុ.** ២៨ ។ បានរៀបការនឹងនាងលេអា ហើយនឹងនាងរ៉ាជែល, **លោកុ.** ២៩:១–៣០ ។ បានកូនប្រុស ១២ នាក់ និងកូនស្រី ១, **លោកុ.** ២៩:៣១–៣០:២៤; ៣៥:១៦–២០ ។ បានរៀបការនឹងនាង ប៊ិលហា ហើយនឹងនាងស៊ីលផា, **លោកុ.** ៣០:៣–៤, ៩ ។ ឈ្មោះត្រូវបានដូរទៅជា អ៊ីស្រាអែល, **លោកុ.** ៣២:២៨ ។ បានឃើញ ព្រះទល់នឹងមុខ, **លោកុ.** ៣២:៣០ ។ គាប់ចិត្តនឹងយ៉ូសែប, **លោកុ.** ៣៧:៣ ។ បានទៅឯស្រុកអេស៊ីព្ទជាមួយនឹងគ្រួសារលោក, **លោកុ.** ៤៦:១–៧ ។ បានប្រទានពរឲ្យពួកកូនលោក និងពូជពង្សរបស់គេ, **លោកុ.** ៤៩ ។ បានស្លាប់, **លោកុ.** ៤៩:៣៣ ។ បានកាន់ តាមព្រះបញ្ញត្តិទាំងឡាយ ហើយសព្វថ្ងៃនេះ ត្រូវបានថ្កើងថ្កានឡើងលើបល្ល័ង្កនៅលើស្ថានសួគ៌ ជាមួយនឹងអ័ប្រាហាំ និងអ៊ីសាក, **គ. និង ស.** ១៣២:៣៧ ។

**យ៉ាកុប, ប្អូនប្រុសរបស់ព្រះអម្ចាស់**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាប្អូនប្រុសរបស់ព្រះអម្ចាស់ (កាឡាទី ១:១៩) ។ ហើយជាបងរបស់យ៉ូសេ ស៊ីម៉ូន យូដាស និងប្អូនស្រីខ្លះ (ម៉ាថាយ ១៣:៥៥–៥៦; ម៉ាកុស ៦:៣; យូដាស ១:១) ។ លោកក៏បានស្គាល់ថា យ៉ាកុប ជាអ្នកសុចរិត ហើយបានកាន់មុខងារសំខាន់មួយ នៅក្នុងសាសនាចក្រ នៅក្រុងយេរូសាឡិម (កិច្ចការ ១២:១៧; ១៥:១៣; ១ កូរិន. ១៥:៧; កាឡាទី ២:៩–១២) ។ ប្រហែលជាលោកនេះហើយ ដែលបានសរសេរសំបុត្ររបស់យ៉ាកុប ។

*សំបុត្ររបស់យ៉ាកុប៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ប្រភពដើម គឺជាសំបុត្រដែលបានសរសេរទៅពូជអ៊ីស្រាអែលទាំង ១២ អំបូរ ដែលបានខ្ចាត់ខ្ចាយពាសពេញ ហើយប្រហែលជាបានសរសេរចេញពីក្រុងយេរូសាឡិម ។ សំបុត្រនេះមាននូវសេចក្ដីចង ក្រងដ៏ក្បោះក្បាយ អំពីសាសនាកិច្ច ព្រមទាំងពាក្យទូន្មានដ៏សំខាន់នៅក្នុងជំពូកទី ១ ថាបើអ្នកណាមួយខ្វះប្រាជ្ញា មានតែសូមដល់ ព្រះឲ្យជួយ (យ៉ាកុប ១:៥–៦; យ.ស. — ប្រវត្តិ ១:៩–២០) ។ ជំពូកទី ២ ទាក់ទងទៅនឹងសេចក្ដីជំនឿ និងការងារ ។ ជំពូកទី ៣–៤ ស្ដីអំពីសេចក្ដីត្រូវការ ឲ្យទប់មាត់ និងការទូន្មានកុំឲ្យពួកបរិសុទ្ធនិយាយអាក្រក់ពីគ្នា ។ ជំពូកទី ៥ លើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យមាន ការអត់ធន់ ហើយឲ្យហៅ ពួកអែលឌើរឲ្យប្រទានពរឲ្យ កាលណាមានជម្ងឺ; ក៏បង្រៀនអំពីព្រះពរអំពីការជួយអ្នកដទៃឲ្យប្រែចិត្តជឿ ។

**យ៉ារ៉ែត** *សូមមើលផង* ណូអេ, អយ្យកោនៅក្នុងព្រះគម្ពីរប៊ីប

ជាកូនប្រុសច្បងបង្អស់របស់ណូអេ ដែលជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (ម៉ូសេ ៨:១២) ។ ណូអេបង្កើតបានយ៉ាផែត, **លោកុ.** ៥:៣២ (លោកុ. ៦:១០; ម៉ូសេ ៨:១២) ។ យ៉ាផែត និងប្រពន្ធគាត់បានចូលទូកធំរបស់ណូអេ, **លោកុ.** ៧:១៣ ។ យ៉ាផែតបានចេញពីទូកធំ, **លោកុ.** ៩:១៨ ។ ព្រះអង្គទ្រង់នឹងចំរើនយ៉ាផែត, **លោកុ.** ៩:២៧ ។

**យ៉ារ៉ុម**

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនរបស់អេណុស ហើយជាចៅទួតរបស់លីហៃ ។ លោកបានរក្សាបញ្ជីប្រវត្តិនៃសាសន៍នីហ្វៃ អស់រយៈ ពេល ៦០ ឆ្នាំ, គឺនៅឆ្នាំ ៤២០–៣៦១ ម.គ.ស. (អេណុស ១:២៥; យ៉ារ៉ុម ១:១៣) ។ លោកជាមនុស្សស្មោះត្រង់ម្នាក់ ហើយសំរេច មិនព្រមសរសេរច្រើននៅក្នុងបញ្ជីប្រវត្តិឡើយ (យ៉ារ៉ុម ១:២) ។

*គម្ពីរយ៉ារ៉ុម៖* មានតែ ១៥ ខ ប៉ុណ្ណោះនៅក្នុងគម្ពីរនេះ ដែលនៅក្នុងព្រះគម្ពីរមរមន ។ យ៉ារ៉ុមបានកត់ថា ពួកសាសន៍នីហ្វៃបានបន្ត ការរស់នៅតាមក្រិត្យវិន័យលោកម៉ូសេ ហើយទន្ទឹងចាំការយាងមកនៃព្រះគ្រីស្ទ ។ ពួកគេត្រូវបានដឹកនាំដោយពួកស្តេច ដែលជា មនុស្សដ៏មានសេចក្ដីជំនឿដ៏ធំក្រៃលែង ។ ពួកគេបានចំរើនឡើង កាលណាគេស្ដាប់តាមពួកព្យាការី ពួកសង្ឃ និងពួកគ្រូបង្រៀន របស់គេ ។

**យ៉ារេឌ** *សូមមើលផង* បងប្រុសរបស់យ៉ារេឌ; ពួកសាសន៍យ៉ារេឌ

ជាអ្នកដឹកនាំម្នាក់នៅក្នុងព្រះគម្ពីរមរមន ដែលបាននាំប្រជាជនមួយក្រុមពីប៉មបាបិល ជាមួយនឹងបងរបស់លោក ទៅកាន់ដែនដីសន្យា នៅអឌ្ឍគោលខាងលិច (អេធើរ ១:៣៣–២:១) ។

យ៉ារេឌបានសូមឲ្យបងប្រុសលោកអធិស្ឋាន សូមកុំឲ្យព្រះអម្ចាស់ទ្រង់បំភាន់ភាសារបស់គ្រួសារ និងមិត្តរបស់គេ, **អេធើរ** ១:៣៤–៣៧ ។ បានធ្វើដំណើរទៅឯសមុទ្រ ហើយបានអាស្រ័យនៅទីនោះអស់រយៈពេលបួនឆ្នាំ, **អេធើរ** ២:១៣ ។ បានចេញដំណើរតាមទូកទៅកាន់ដែនដីសន្យា, **អេធើរ** ៦:៤–១២ ។

**យូដា** *សូមមើលផង* ពួកសាសន៍យូដា, ព្រះគម្ពីរប៊ីប; អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនទីបួនរបស់យ៉ាកុប និងនាងលេអា (លោកុ. ២៩:៣៥; ៣៧:២៦–២៧; ៤៣:៣, ៨; ៤៤:១៦; ៤៩:៨) ។ យ៉ាកុបបានឲ្យពរដល់យូដា ថាលោកនឹងកើតជាអ្នកដឹកនាំពីកំណើតនៅក្នុងចំណោមពួកកូនរបស់យ៉ាកុបទាំងឡាយ ហើយថា ស៊ីឡូរ (ព្រះយេស៊ូវគ្រីស្ទ) នឹងមកពីពូជពង្សលោក (លោកុ. ៤៩:១០) ។

*ពូជអំបូររបស់យូដា៖* ពូជអំបូររបស់យូដាបានទៅអ្នកនាំមុខគេ ក្រោយពីបានតាំងទីលំនៅស្រុកកាណាន ។ មេប្រឆាំងរបស់គេ គឺពូជអំបូររបស់អេប្រាអិម ។ ម៉ូសេបានឲ្យពរដល់ពូជអំបូររបស់យូដា (ចោទិ. ៣៣:៧) ។ បន្ទាប់ពីការសោយរាជ្យរបស់សាឡូម៉ូន នោះពូជអំបូររបស់យូដាបានក្លាយទៅជានគរយូដា ។

*នគរយូដា៖* នៅរាជ្យនៃរេហូបោម ទីគ្រប់គ្រងរបស់សាឡូម៉ូនបានត្រូវបាក់បែកទៅជានគរពីរ មកពីការច្រណែនរវាងពូជអំបូរ អេប្រាអិម

និងពូជអំបូរយូដា ។ នគរខាងត្បូង ឬនគរយូដា មានរួមពូជអំបូរយូដា និងភាគច្រើនពីពូជអំបូរបេនយ៉ាមីន ។ ក្រុង យេរូសាឡិម គឺជារាជធានីរបស់គេ ។ សរុបទៅ នគរយូដានៅមានចិត្តស្មោះត្រង់ចំពោះការថ្វាយបង្គំព្រះយេហូវ៉ា ជាងនគរ ខាងជើង ។ ស្រុកយូដាមិនសូវបើកដៃដល់ការប្រយុទ្ធពីខាងជើង និងខាងកើត ហើយអំណាចនៃការគ្រប់គ្រងនៅក្នុងដៃនៃរាជវង្សា ដាវីឌ រហូតដល់ការឃុំឃាំងដោយពួកបាប៊ីឡូន ។ នគរយូដានៅតែកាន់កាប់បានអស់រយៈពេល ១៣៥ ឆ្នាំក្រោយពីការរលំនៃនគរ អ៊ីស្រាអែលដែលល្បីល្បាញ ហើយដែលមានអំណាចជាង ។

*បន្ទះឈើនៃយូដា៖* នេះគឺស្ដីដល់ព្រះគម្ពីរប៊ីប ជាបញ្ជីនៃវង្សយូដា (អេសេ. ៣៧:១៥–១៩) ។ នៅថ្ងៃចុងក្រោយបង្អស់ កាលមែកនៃវង្សអ៊ីស្រាអែលត្រូវបានប្រមូលមក នោះបញ្ជីដ៏ពិសិដ្ឋរបស់គេក៏នឹងបានប្រមូលរួមគ្នាដែរ ។ បញ្ជីខាងបទគម្ពីរទាំងនេះ បង្គ្រប់គ្នាទៅវិញ ទៅមក ហើយផ្សំគ្នាធ្វើជាទីបន្ទាល់តែមួយថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះនៃអ៊ីស្រាអែល ហើយជាព្រះនៃផែនដីទាំងមូល (២ នីហ្វៃ ៣; ២៩; គ.យ.ស., លោកុ. ៥០:២៤–៣៦) ។

## យូដាស

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាប្អូនប្រុសរបស់ព្រះយេស៊ូវ ហើយប្រហែលជាអ្នកនិពន្ធសំបុត្រយូដាស (ម៉ាថាយ ១៣:៥៥; យូដាស ១:១) ។

*សំបុត្ររបស់យូដាស៖* គម្ពីរនេះមានសំបុត្រពីយូដាស សរសេរដល់ពួកបរិសុទ្ធខ្លះ ដែលទន់ខ្សោយក្នុងសេចក្ដីជំនឿ ។ ពួកគេបានទន់ខ្សោយដោយសារពួកអ្នកដែលនៅក្នុងចំណោមពួកគេ ដែលចាត់ថាខ្លួនជាអ្នកគ្រីស្ទាន ប៉ុន្តែជាពួកអ្នកដែលថ្វាយបង្គំការស្មោកគ្រោក ឥតធម៌ ហើយលើកខ្លួនចេញពីការគោរពតាមច្បាប់ធម៌ ។ យូដាសបានចង់ដាស់តឿនពួកបរិសុទ្ធ ឲ្យប្រយ័ត្នគ្រោះថ្នាក់ខាងវិញ្ញាណ របស់គេ ហើយលើកទឹកចិត្តពួកគេ ឲ្យនៅក្នុងសេចក្ដីស្មោះត្រង់ ។

វគ្គដ៏សំខាន់ៗខ្លះនៅក្នុងគម្ពីរយូដាស គឺ ខទី ៦ ដែលប្រាប់សារឡើងវិញអំពីសង្គ្រាមលើស្ថានសួគ៌ និងការបណ្ដេញលូស៊ីហ្វើ និងពួក ទេវតាវាពីសណ្ឋានដើម (អ័ប្រា. ៣:២៦–២៨), និង ខ ១៤–១៥ ដែលស្រង់ពាក្យព្យាករណ៍ដែលហេណុកបានទាយ ។

## យូដាស, ប្អូនប្រុសរបស់យ៉ាកុប

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសាវកម្នាក់ក្នុងពួកសាវក ១២ នាក់ដំបូងរបស់ព្រះយេស៊ូវគ្រីស្ទ (លូកា ៦:១៣–១៦) ។ លោកប្រហែលជាម្នាក់នោះដែលស្គាល់ថា លេបេ ថាដេ (ម៉ាថាយ ១០:២–៤) ។

## យូដាស-អ៊ីស្ការីយ៉ុត

ជាសាវកម្នាក់ក្នុងពួកសាវក ១២ នាក់របស់ព្រះយេស៊ូវ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី (ម៉ាថាយ ១០:៤; ម៉ាកុស ១៤:១០; យ៉ូហាន ៦:៧១; ១២:៤) ។ នាមត្រកូលរបស់លោកមានន័យថា « មនុស្សពីកេរីយ៉ុត » ។ លោកមកពីពូជអំបូរយូដា ហើយជាសាវកតែមួយគត់ ដែល មិនមែនជាអ្នកស្រុកកាលីឡេ ។ យូដាសបានក្បត់ព្រះអម្ចាស់ ។

បានទទួលប្រាក់ ៣០ រៀល ដែលបានបញ្ជូនព្រះគ្រីស្ទដល់ពួកសង្គ្រាជ, **ម៉ាថាយ** ២៦:១៤–១៦ (សាការី ១១:១២–១៣) ។ បាន ក្បត់ព្រះអម្ចាស់ដោយថើប, **ម៉ាថាយ** ២៦:៤៧–៥០ (ម៉ាកុស ១៤:៤៣–៤៥; លូកា ២២:៤៧–៤៨; យ៉ូហាន ១៨:២–៥) ។ បានចងកសម្លាប់ខ្លួន, **ម៉ាថាយ** ២៧:៥ ។ អារក្សសាតាំងបានចូលយូដាស, **លូកា** ២២:៣ (យ៉ូហាន ១៣:២, ២៦–៣០) ។ ហ្លួងដាវីឌបានទាយអំពី យូដាសក្បត់ព្រះយេស៊ូវ, **កិច្ចការ** ១:១៦ (ទំនុក. ៤១:៩) ។

## យ៉ូណាថាន *សូមមើលផង* ដាវីឌ; សូល, ស្ដេចនៃអ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាបុត្ររបស់សូល ជាស្ដេចនៃអ៊ីស្រាអែល ។ យ៉ូណាថានជាមិត្តដ៏ស្និទ្ធស្នាលម្នាក់របស់ដាវីឌ (១ សាំយូ. ១៣–២៣, ៣១) ។

## យ៉ូណាស *សូមមើលផង* នីនីវេ

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលព្រះអម្ចាស់ ទ្រង់បានហៅឲ្យទៅផ្សាយអំពីការប្រែចិត្ត ដល់ទីក្រុងនីនីវេ (យ៉ូណាស ១:១–២) ។

*គម្ពីរយ៉ូណាស៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលប្រាប់អំពីការពិសោធន៍នៅក្នុងជីវិតយ៉ូណាស ។ ប្រហែលជា យ៉ូណាសពុំបានសរសេរគម្ពីរនេះដោយខ្លួនលោកទេ ។ គំនិតដ៏សំខាន់នៅក្នុងគម្ពីរយ៉ូណាស គឺថាព្រះយេហូវ៉ាសោយរាជ្យនៅគ្រប់ទិសទី ហើយមិនត្រឹមតែប្រទានសេចក្ដីស្រឡាញ់របស់ទ្រង់ដល់សាសន៍ ឬប្រជារាស្ត្រតែមួយប៉ុណ្ណោះទេ ។

នៅជំពូកទី ១ ព្រះអម្ចាស់ទ្រង់បានហៅឲ្យយ៉ូណាសទៅផ្សាយដល់ពួកនីនីវេ ។ ដោយមិនធ្វើតាមដែលព្រះអម្ចាស់បានបញ្ជា នោះស្រាប់តែយ៉ូណាសរត់ទៅទិសផ្សេងប្រឆើយ ដោយចុះទូក ហើយត្រូវត្រីធំលេប ។ ជំពូកទី ២ យ៉ូណាសបានអធិស្ឋានទៅព្រះអម្ចាស់ ហើយត្រីបានខ្ជាក់យ៉ូណាសចេញទៅលើដីគោក ។ ជំពូកទី ៣ កត់ថា យ៉ូណាសបានទៅក្រុងនីនីវេ ហើយបានព្យាករអំពីការរលំនៃទីក្រុងនោះ ។ ប៉ុន្តែប្រជាជនបានប្រែចិត្ត ។ ជំពូកទី ៤ ព្រះអម្ចាស់ទ្រង់បានបន្ទោសយ៉ូណាស ដែលបានខឹង ពីព្រោះព្រះអម្ចាស់ទ្រង់ បានទុកជីវិតឲ្យប្រជាជននៅរស់ ។

ព្រះយេស៊ូវទ្រង់បានបង្រៀនថា យ៉ូណាសត្រូវត្រីលេបនោះ ចាត់ទុកជាស្រមោលដែលនឹងកើតឡើង អំពីការសុគត និងដំណើររស់ឡើងវិញរបស់ព្រះយេស៊ូវផ្ទាល់ (ម៉ាថាយ ១២:៣៩–៤០; ១៦:៤; លូកា ១១:២៩–៣០) ។

## យ៉ូប

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាបុរសសុចរិតម្នាក់ ដែលបានរងទុក្ខនូវសេចក្ដីទុក្ខវេទនាជាច្រើន ប៉ុន្តែនៅតែមានចិត្ត ស្មោះត្រង់ចំពោះ

ជំនឿរបស់លោកដល់ព្រះ ។ រឿងលោក គឺបានរៀបរាប់ប្រាប់នៅក្នុងគម្ពីរយ៉ូប ។

*គម្ពីរយ៉ូប៖* ទោះបីជាគម្ពីរនេះស្ដីអំពីការរងទុក្ខរបស់យ៉ូបក៏ដោយ គង់តែមិនបានប្រាប់អំពីហេតុអ្វីបានជាយ៉ូប (ឬអ្នកឯទៀត) ត្រូវរងទុក្ខឈឺចាប់ ហើយបាត់បង់គ្រួសារ និងរបស់របរលោកដែរ ។ គម្ពីរនេះបញ្ជាក់ថា ការមានសេចក្ដីទុក្ខវេទនា គឺមិនចាំបាច់ថា មនុស្សនោះមានបាបឡើយ ។ ព្រះអម្ចាស់ទ្រង់អាចប្រើសេចក្ដីទុក្ខវេទនាសំរាប់ការពិសោធន៍ ការអប់រំ និងការប្រៀនប្រដៅ ព្រមទាំងសំរាប់ដាក់ទោស (គ. និង ស. ១២២) ។

គម្ពីរនេះអាចចែកចេញជាបួនភាគ ។ ជំពូកទី ១–២ ជាអារម្ភបទរឿង ។ ជំពូកទី ៣–៣១ រៀបរាប់អំពីការពិគ្រោះគ្នារវាងយ៉ូបនិង មិត្តបីនាក់ ។ ជំពូកទី ៣២–៣៧ មានពាក្យពេចន៍របស់អេលីហ៊ូវ ជាមិត្តទីបួន ដែលបានថ្កោលទោសយ៉ូប ចំពោះហេតុផ្សេងៗ ផ្សេងពីហេតុនៃពួកមិត្តបីនាក់មុន ។ ជំពូកទី ៣៨–៤២ បញ្ចប់គម្ពីរដោយពាក្យធានាជាថ្មីទៀតដល់យ៉ូបថា ដំណើរជីវិតលោក គឺជាដំណើរដ៏ល្អមួយ ចាប់តាំងពីដើមដំបូងមក ។

គម្ពីរយ៉ូបបង្រៀនថា បើអ្នកណាមានការចេះដឹងដ៏ពិតប្រាកដអំពីព្រះ ហើយរស់នៅតាមរបៀបដែលគួរសមចំពោះព្រះ អ្នកនោះនឹងអាចទ្រាំទ្រនូវការពិសោធន៍ ដែលមានមកលើខ្លួន បានកាន់តែប្រសើរឡើង ។ សេចក្ដីជំនឿដ៏ស្ថិតស្ថេររបស់យ៉ូបមានខ្លឹមសារ តាម បទបន្ទរថា៖ « ទោះបីទ្រង់សម្លាប់ខ្ញុំក៏ដោយ គង់តែខ្ញុំនឹងទុកចិត្តដល់ទ្រង់ដែរ » (យ៉ូប ១៣:១៥) ។ យ៉ូបក៏បានពោលដល់នៅក្នុងគម្ពីរ អេសេ. ១៤:១៤; យ៉ាកុប ៥:១១; គ. និង ស. ១២១:១០ ។

**យូរីម និងធូមីម** *សូមមើលផង* ប្រដាប់បាំងទ្រូង; អ្នកមើលឆុត

ជាឧបករណ៍ទាំងឡាយ ដែលព្រះទ្រង់បានរៀបចំឡើង ដើម្បីជួយមនុស្សលោក ក្នុងការទទួលវិវរណៈ និងក្នុងការបកប្រែភាសា ។ នៅក្នុងភាសាហេព្រើរ យូរីម និងធូមីម មានន័យថា « ពន្លឺ និងការល្អឥតខ្ចោះទាំងឡាយ » ។ យូរីម និងធូមីម គឺជាត្បូងពីរដុំ ភ្ជាប់ទៅនឹងបូរធ្វើពីប្រាក់ ហើយជួនកាល គេប្រើជាមួយនឹងប្រដាប់បាំងទ្រូង (គ. និង ស. ១៧:១; យ.ស. — ប្រវត្តិ ១:៣៥, ៤២, ៥២) ។ ផែនដីនេះនឹងត្រឡប់ទៅជាយូរីម និងធូមីមដ៏ធំ នៅក្នុងស្ថានភាពដែលបានញែកជាបរិសុទ្ធ និងអមតៈ (គ. និង ស. ១៣០:៦–៩) ។

ឯងត្រូវដាក់យូរីម និងធូមីម ភ្ជាប់នៅប្រដាប់បាំងទ្រូងនៃការវិនិច្ឆ័យ, **និក្ខ.** ២៨:៣០ ។ អ្នកណាដែលឈ្នះ នោះអញនឹងឲ្យគ្រួសសមួយ, **វិវរ.** ២:១៧ ។ លោកមានគ្រឿងប្រដាប់ម៉្យាង ដែលលោកយកមកក្ដុះមើល ហើយបកប្រែ, **ម៉ូសាយ** ៨:១៣ ។ ត្បូងពីរដុំនេះ យើងនឹង ឲ្យទៅអ្នក, **អេធើរ** ៣:២៣–២៤, ២៨ (អេធើរ ៤:៥) ។ យ៉ូសែប ស៊្មីធបានទទួលវិវរណៈទាំងឡាយ តាមរយៈយូរីម និងធូមីម, **គ. និង ស.** ចំណងជើងនៃកណ្ឌទី ៦, ១១, ១៤–១៦ ។ អ្នកបានទទួលអំណាចដើម្បីបកប្រែ ដោយនូវមធ្យោបាយនៃយូរីម និងធូមីម, **គ. និង ស.** ១០:១ ។ ពួកសាក្សីបីនាក់នឹងបានឃើញយូរីម និងធូមីម ដែលបានប្រទានដល់បងប្រុសរបស់យ៉ារេឌ នៅលើភ្នំ, **គ. និង ស.** ១៧:១ ។ កន្លែងដែលព្រះទ្រង់គង់នៅ គឺជាយូរីម និងធូមីមដ៏ធំ ។ គ្រួសសនឹងក្លាយទៅជាយូរីម និងធូមីម ចំពោះអស់អ្នកណា ដែលបានទទួលគ្រួសនោះ, **គ. និង ស.** ១៣០:៦–១១ ។ ខ្ញុំ អ័ប្រាហាំ បានយូរីម និងធូមីម, **អ័ប្រា.** ៣:១, ៤ ។

**យ៉ូសាផាត**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាស្ដេចដ៏ស្មោះត្រង់ម្នាក់ នៅស្រុកយូដា (១ ពង្សាវ. ១៥:២៤; ២២) ។

**យ៉ូសៀស**

ជាស្ដេចនៃស្រុកយូដាដ៏សុចរិតម្នាក់ ពីឆ្នាំ ៦៤១–៦១០ ម.គ.ស. (២ ពង្សាវ. ២២–២៤; ២ របា. ៣៤–៣៥) ។ នៅរាជ្យទ្រង់ បានប្រទះឃើញគម្ពីរក្រិត្យវិន័យនៅក្នុងព្រះដំណាក់នៃ ព្រះអម្ចាស់ (២ ពង្សាវ. ២២:៨–១៣) ។

**យ៉ូស្វេ** *សូមមើលផង* យេរីខូរ

ជាព្យាការី ហើយជាអ្នកដឹកនាំម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយជាអ្នកជំនួសម៉ូសេ ។ លោកបានកើតនៅស្រុកអេស៊ីព្ទ មុនពួកកូនចៅអ៊ីស្រាអែលបានរត់ចេញ (ជនគ. ១៤:២៦–៣១) ។ លោក និងកាលែប បាននៅក្នុងចំណោមពួកអ្នក ១២ នាក់ ដែលបានចាត់ឲ្យទៅសង្កេតមើលស្រុកកាណាន ។ ពួកគេពីរនាក់ប៉ុណ្ណោះដែលបានរាយការណ៍ល្អអំពីស្រុកនោះ (ជនគ. ១៣:៨, ១៧–១៤:១០) ។ លោកស្លាប់កាលមានអាយុ ១១០ ឆ្នាំ (យ៉ូស្វេ ២៤:២៩) ។ យ៉ូស្វេ ជាគំរាប់ដ៏ល្អមួយ អំពីព្យាការី-អ្នកចម្បាំង ដ៏បរិសុទ្ធម្នាក់ ។

*គម្ពីរយ៉ូស្វេ៖* គម្ពីរនេះដាក់ឈ្មោះតាមយ៉ូស្វេ ពីព្រោះលោកជាអ្នកសំខាន់នៅក្នុងគម្ពីរ ហើយគឺមិនមែនដោយព្រោះលោកជាអ្នកនិពន្ធនោះទេ ។ ជំពូកទី ១–១២ អធិប្បាយប្រាប់អំពីការច្បាំងយកស្រុកកាណាន ។ ជំពូកទី ១៣–២៤ ប្រាប់អំពីការចែកដីដល់ ពួកពូជអំបូរនៃអ៊ីស្រាអែល និងពាក្យទូន្មានចុងក្រោយបង្អស់របស់យ៉ូស្វេ ។

មានពីរខដែលពិសេសនៅក្នុងគម្ពីរយ៉ូស្វេ គឺព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដល់លោក ឲ្យនឹកជញ្ជឹងដល់បទគម្ពីរ (យ៉ូស្វេ ១:៨) និងការដែលយ៉ូស្វេហៅឲ្យបណ្ដាជនមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ (យ៉ូស្វេ ២៤:១៥) ។

**យ៉ូសែប, កូនប្រុសរបស់យ៉ាកុប** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក; យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនច្បងរបស់យ៉ាកុប និងនាងរ៉ាជែល (លោកុ. ៣០:២២–២៤; ៣៧:៣) ។

យ៉ូសែបបានទទួលសិទ្ធិកូនច្បង ពីព្រោះរូបេន ជាកូនច្បងរបស់ប្រពន្ធយ៉ាកុបទីមួយ បានបាត់សិទ្ធិ ដោយសារការរំលង (១ របា. ៥:១–២) ។ ពីព្រោះលោកមានចិត្តសក្ដិសម នោះយ៉ូសែប ជាកូនច្បងនៃប្រពន្ធ

យ៉ាកុបទីពីរ ជាអ្នកបន្ទាប់ដើម្បីបានពរនោះ ។ យ៉ូសែបក៏បានទទួលពរពីឪពុកលោក មុនយ៉ាកុបស្លាប់ (លោកុ. ៤៩:២២–២៦) ។

យ៉ូសែប ជាបុរសមានចរិតល្អណាស់ គឺជាបុគ្គល « មានជំរិះមានប្រាជ្ញា » (លោកុ. ៤១:៣៩) ។ ការមិនព្រមយកប្រពន្ធប៉ូទីផារ គឺជាដំរាប់អំពីសេចក្ដីជំនឿ ព្រហ្មចារីភាព និងសេចក្ដីស្មោះរបស់ខ្លួនលោក (លោកុ. ៣៩:៧–១២) ។ នៅស្រុកអេស៊ីព្ទ កាល យ៉ូសែបបានបើកសម្ដែងប្រាប់បងប្អូនលោកថាលោកជាអ្នកណាពិតមែន នោះលោកបានអរគុណគេ មិនបានបន្ទោសពួកគេ ចំពោះអ្វីៗដែលគេបាន ធ្វើដល់លោកឡើយ ។ លោកជឿថា ការដែលគេបានធ្វើ នោះបានជួយសំរេចនូវបំណងដ៏ឧត្ដមរបស់ព្រះ (លោកុ. ៤៥:៤–១៥) ។

វិវរណៈនៅថ្ងៃចុងក្រោយបើកសម្ដែងប្រាប់អំពីបេសកកម្មដ៏ធំជាងនោះទៅទៀត នៃគ្រួសាររបស់យ៉ូសែប នៅគ្រាចុងក្រោយបង្អស់ (២ នីហ្វៃ ៣:៣–២៤; ៣ នីហ្វៃ ២០:២៥–២៧; គ.យ.ស., លោកុ. ៥០) ។

យ៉ាកុបបានស្រឡាញ់យ៉ូសែបជាខ្លាំង ហើយបានឲ្យអាវមួយដ៏មានពណ៌ច្រើនដល់លោក, **លោកុ.** ៣៧:៣ ។ មកពីសេចក្ដីច្រណែន នោះពួកបងៗយ៉ូសែបក្លាយទៅជាស្អប់លោក ហើយបានរកឱកាសនឹងសំឡាប់លោកចោល ប៉ុន្តែបានលក់លោកឲ្យទៅពួកជំនួញ ដែលពួកគេកំពុងធ្វើដំណើរទៅស្រុកអេស៊ីព្ទ, **លោកុ.** ៣៧:៥–៣៦ ។ នៅស្រុកអេស៊ីព្ទ ព្រះអម្ចាស់ទ្រង់បានចំរើនយ៉ូសែប ហើយ លោកកើតទៅជាអ្នកកាន់កាប់ត្រួតត្រាផ្ទះប៉ូទីផារ, **លោកុ.** ៣៩:១–៤ ។ ប្រពន្ធប៉ូទីផារបានកុហក ដោយនិយាយថា យ៉ូសែបបានខំ ប្រលោមនាង យ៉ូសែបត្រូវគេកាត់ទោសទាំងបំពាន ហើយត្រូវគេដាក់គុក, **លោកុ.** ៣៩:៧–២០ ។ យ៉ូសែបបានស្រាយន័យសប្តិជូននាយពិសេសថ្វាយពែង និងមេពួកដុតនំរបស់ផារ៉ោន, **លោកុ.** ៤០ ។ ផារ៉ោនបានចាប់ផ្ដើមគាប់ចិត្តនឹងយ៉ូសែប ពីព្រោះយ៉ូសែបបាន ស្រាយន័យសប្តិមួយ ថ្វាយផារ៉ោន ទ្រង់បានឲ្យយ៉ូសែបធ្វើជាអ្នកកាន់កាប់ត្រួតត្រាលើស្រុកអេស៊ីព្ទ, **លោកុ.** ៤១:១៤–៤៥ ។ អេប្រាអិម និងម៉ាន៉ាសេបាន កើត, **លោកុ.** ៤១:៥០–៥២ ។ យ៉ូសែបបានជួបជុំនឹងឪពុក និងបងប្អូនលោកវិញ, **លោកុ.** ៤៥–៤៦ ។ យ៉ូសែបស្លាប់នៅស្រុកអេស៊ីព្ទ កាលគាត់មានអាយុ ១១០ ឆ្នាំ, **លោកុ.** ៥០:២២–២៦ ។

**យ៉ូសែប, ប្ដីរបស់នាងម៉ារា** *សូមមើលផង* នាងម៉ារា, មាតារបស់ព្រះយេស៊ូវ; ព្រះយេស៊ូវគ្រីស្ទ

ជាប្ដីនាងម៉ារា ដែលជាមាតារបស់ព្រះយេស៊ូវ ។ យ៉ូសែបជាពូជពង្សពីហ្លួងដាវីឌ (ម៉ាថាយ ១:១–១៦; លូកា ៣:២៣–៣៨) ហើយបានរស់នៅភូមិណាសារ៉ែត ។ លោកបានចូលដណ្ដឹងយកនាងម៉ារា ។ មុនថ្ងៃរៀបការ នាងម៉ារាត្រូវបានទេវតាកាព្រីយ៉ែលមកជួប ដែលបានប្រកាសប្រាប់ថា នាងម៉ារាត្រូវបានរើសឲ្យធ្វើជាមាតារបស់ព្រះអង្គសង្គ្រោះ (លូកា ១:២៦–៣៥) ។ យ៉ូសែបក៏បានទទួល វិវរណៈអំពីកំណើតដ៏ឧត្ដមនេះដែរ (ម៉ាថាយ ១:២០–២៥) ។

នាងម៉ារា គឺជាមាតារបស់ព្រះយេស៊ូវខាងសាច់ឈាម ពីព្រោះព្រះដ៏ជាព្រះវរបិតា គឺជាបិតារបស់ព្រះយេស៊ូវ ។ ប៉ុន្តែពួកសាសន៍យូដាគិតថា យ៉ូសែបជាបិតារបស់ព្រះយេស៊ូវ រីឯព្រះយេស៊ូវក៏គោរពលោកទុកដូចជាបិតាដែរ (លូកា ២:៤៨, ៥១) ។ មកពីបានទទួលការព្រមានដោយសប្តិពីស្ថានសួគ៌ នោះយ៉ូសែបបានការពារជីវិតនៃទារកយេស៊ូវទុក ដោយរត់ភៀសខ្លួនទៅស្រុកអេស៊ីព្ទ (ម៉ាថាយ ២:១៣–១៤) ។ បន្ទាប់ពីស្ដេចហេរ៉ូឌបានសុគតទៅ នោះមានទេវតាមួយមកបង្គាប់ឲ្យយ៉ូសែបនាំព្រះគ្រីស្ទជាកុមារទៅស្រុក អ៊ីស្រាអែលវិញ (ម៉ាថាយ ២:១៩–២៣) ។

**យ៉ូសែប, បន្ទះឈើ** *សូមមើល* ព្រះគម្ពីរមរមន; អេប្រាអិម — បន្ទះឈើរបស់អេប្រាអិម ឬយ៉ូសែប

**យ៉ូសែប ពីភូមិអើរីម៉ាថេ**

យ៉ូសែប ពីភូមិអើរីម៉ាថេ ជាសមាជិកម្នាក់ក្នុងក្រុមជំនុំសានហេទ្រិន ជាសិស្សរបស់ព្រះគ្រីស្ទម្នាក់ ជាអ្នកមាន ហើយជាសាសន៍ អ៊ីស្រាអែលដ៏ស្មោះត្រង់ម្នាក់ ដែលពុំបានចូលរួមក្នុងការថ្កោលទោសដល់ព្រះអម្ចាស់របស់យើង ។ បន្ទាប់ពីការឆ្កាង នោះយ៉ូសែប បានយកព្រះសពនៃព្រះអង្គសង្គ្រោះមករុំនឹងសំពត់ទេសឯងយ៉ាងស្អាត ហើយបញ្ចុះក្នុងផ្នូរដែលមានរូបរាងដូចជារូងរបស់យ៉ូសែបផ្ទាល់ (ម៉ាថាយ ២៧:៥៧–៦០; ម៉ាកុស ១៥:៤៣–៤៦; លូកា ២៣:៥០–៥៣; យ៉ូហាន ១៩:៣៨–៤២) ។

**យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ** *សូមមើល* យ៉ូសែប ជុញ្ញ័រ, ស្ម៊ីធ

**យ៉ូហាន-បាទីស្ទ** *សូមមើលផង* បព្វជិតភាពអើរ៉ុន; អេលីយ៉ាស

ជាកូនប្រុសរបស់សាការី និងនាងអេលីសាបិត នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ យ៉ូហានត្រូវបានចាត់ឲ្យទៅរៀបចំមនុស្សឲ្យទទួលព្រះមែស៊ី (យ៉ូហាន ១:១៩–២៧) ។ លោកបានកាន់កូនសោទាំងឡាយនៃបព្វជិតភាពអើរ៉ុន ហើយបានធ្វើបុណ្យជ្រមុជទឹកថ្វាយព្រះយេស៊ូវគ្រីស្ទ ។

អេសាយ និងពួកអ្នកផ្សេងៗទៀតបានព្យាករអំពីបេសកកម្មរបស់យ៉ូហាន, **អេសាយ** ៤០:៣ (ម៉ាឡាគី ៣:១; ១ នីហ្វៃ ១០:៧–១០; ២ នីហ្វៃ ៣១:៤) ។ ត្រូវគេដាក់គុក ហើយកាត់ក្បាល, **ម៉ាថាយ** ១៤:៣–១២ (ម៉ាកុស ៦:១៧–២៩) ។ កាព្រីយ៉ែលបានប្រាប់អំពីកំណើត និងការបង្រៀនរបស់យ៉ូហានដល់សាការី, **លូកា** ១:៥–២៥ ។ ព្រះយេស៊ូវទ្រង់បានបង្រៀនថា យ៉ូហាន-បាទីស្ទ ជាព្យាការីដ៏មហិមា ម្នាក់, **លូកា** ៧:២៤–២៨ ។ បានស្គាល់ថាព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ, **យ៉ូហាន** ១:២៩–៣៤ ។ ពួកសិស្សរបស់យ៉ូហានបាន ក្លាយទៅជាពួកសិស្សរបស់ព្រះយេស៊ូវ, **យ៉ូហាន** ១:២៥–២៩, ៣៥–៤២ (កិច្ចការ ១:២១–២២) ។ ពុំបានសម្ដែងអព្ភូតហេតុណា ឡើយ, **យ៉ូហាន** ១០:៤១ ។ ជាតួដែលបានរស់ឡើងវិញ គឺត្រូវបានចាត់ឲ្យទៅតែងតាំងយ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ឲ្យកាន់ បព្វជិតភាពអើរ៉ុន, **គ. និង ស.** ១៣ (គ. និង ស. ២៧:៧–៨; យ.ស. — ប្រវត្តិ ១:៦៨–៧២) ។ ទេវតាបានតែងតាំងលោក កាលលោក មានអាយុ ៨ ថ្ងៃ, **គ. និង ស.** ៨៤:២៨ ។

**យ៉ូហាន, កូនប្រុសរបស់សេបេដេ** *សូមមើលផង*
ដំណឹងល្អទាំងឡាយ; បច្ឆិតភាពមិលគីស្សាដែក;
ពួកអ្នកដែលបានប្រែរូប, សាវក; វិវរណៈរបស់យ៉ូហាន

ជាសាវកម្នាក់ក្នុងពួក ១២ នាក់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាកូនប្រុសរបស់សេបេដេ ហើយជាប្អូនប្រុសរបស់យ៉ាកុប ។ លោកជាអ្នក នេសាទមុនដំបូង (យ៉ាកុស ១:១៧–២០) ។ លោកប្រហែលជាសិស្សរបស់យ៉ូហាន-បាទិស្ទ ដែលមិនបានប្រាប់ឈ្មោះ ដែលបាន ពោលដល់នៅក្នុងគម្ពីរយ៉ូហាន ១:៤០ ។ ក្រោយមក លោកបានទទួលការងារជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ៤:២១–២២; លូកា ៥:១–១១) ។ លោកបានសរសេរដំណឹងល្អតាមលោកយ៉ូហាន សំបុត្របីច្បាប់ និងគម្ពីរវិវរណៈ ។ លោកជាសិស្សម្នាក់ក្នុងពួក បីនាក់ ដែលបាននៅជាមួយនឹងព្រះអម្ចាស់ នៅគ្រាប្រោសកូនស្រីរបស់យៃរ៉ុសឲ្យរស់ (ម៉ាកុស ៥:៣៥–៤២), នៅលើភ្នំនៃការប្រែរូប (ម៉ាថាយ ១៧:១–៩), ហើយនៅក្នុងសួនច្បារគេតសេម៉ានី (ម៉ាថាយ ២៦:៣៦–៤៦) ។ នៅក្នុងការសរសេររបស់លោក នោះលោក បានហៅខ្លួនថា ជាសិស្សដែលព្រះយេស៊ូវបានស្រឡាញ់ (យ៉ូហាន ១៣:២៣; ២១:២០) ហើយជា « សិស្សមួយនោះ » (យ៉ូហាន ២០:២–៨) ។ ព្រះយេស៊ូវទ្រង់ក៏បានហៅលោក និងបងប្រុសលោកថា បោនអើគេ គឺ « កូនផ្គរលាន់ » (យ៉ាកុស ៣:១៧) ។ មាន ពាក្យយោងអំពីលោកជាញឹកញាប់ នៅក្នុងដំណើររឿងនៃការឆ្កាង និងដំណើររស់ឡើងវិញ (លូកា ២២:៨; យ៉ូហាន ១៨:១៥; ១៩:២៦–២៧; ២០:២–៨; ២១:១–២) ។ ក្រោយមក លោកត្រូវប្រោសចាលទៅឯកោះប៉ាត់ម៉ុស ជាទីដែលលោកសរសេរ គម្ពីរវិវរណៈ (វិវ. ១:៩) ។

យ៉ូហានក៏បានពោលដល់ជាញឹកញាប់ នៅក្នុងវិវរណៈថ្ងៃចុងក្រោយ (១ នីហ្វៃ ១៤:១៨–២៧; ៣ នីហ្វៃ ២៨:៦; អេធើរ ៤:១៦; គ. និង ស. ៧; ២៧:១២; ៦១:១៤; ៧៧; ៨៨:១៤១) ។ វគ្គទាំងនេះបញ្ជាក់នូវបញ្ជីរបស់យ៉ូហាន ដែលមាននៅក្នុងព្រះគម្ពីរប៊ីប ហើយក៏ផ្ដល់នូវការយល់ដ៏ជ្រាលជ្រៅអំពីការធំសំបើម និងការសំខាន់ៗនៃកិច្ចការដែលព្រះអម្ចាស់ ទ្រង់បានប្រទានឲ្យលោកធ្វើនៅលើផែនដី នៅគ្រាព្រះគម្ពីរសញ្ញាថ្មី និងនៅគ្រាចុងក្រោយនេះ ។ បទគម្ពីរនៅថ្ងៃចុងក្រោយបញ្ជាក់ថា យ៉ូហានមិនបានស្លាប់ទេ ប៉ុន្តែបាន អនុញ្ញាតឲ្យនៅលើផែនដី ជាអ្នកបំរើខាងការងារបំរើ ដរាបដល់ពេលនៃការយាងមកលើកទីពីរ នៃព្រះអម្ចាស់ (យ៉ូហាន ២១:២០–២៣; ៣ នីហ្វៃ ២៨:៦–៧; គ. និង ស. ៧) ។

*សំបុត្ររបស់យ៉ូហាន៖* ទោះបីអ្នកសរសេរសំបុត្រទាំងបីច្បាប់នេះ មិនបានប្រាប់ឈ្មោះខ្លួនក៏ដោយ គង់តែពាក្យសំដីមានបែបបទ ជាខ្លាំងដូចជាពាក្យសំដីរបស់យ៉ូហាន ជាសាវក ម្លោះហើយ បានជាគេសន្និដ្ឋានថាលោកនេះហើយ ដែលបានសរសេរសំបុត្រទាំងបីច្បាប់នេះ ។

យ៉ូហានទី ១ ជំពូកទី ១ ទូន្មានឲ្យពួកបរិសុទ្ធបានសេចក្ដីប្រកបនឹងព្រះ ។ ជំពូកទី ២ បញ្ជាក់ថាពួកបរិសុទ្ធស្គាល់ព្រះ ដោយសារការគោរពតាម ហើយបង្គាប់កុំឲ្យគេស្រឡាញ់លោកិយ ។ ជំពូកទី ៣ ហៅឲ្យមនុស្សទាំងអស់ក្លាយទៅជាកូនចៅនៃព្រះ ហើយឲ្យ ស្រឡាញ់គ្នាទៅវិញទៅមក ។ ជំពូកទី ៤ ពន្យល់ប្រាប់ថា ព្រះជាសេចក្ដីស្រឡាញ់ ហើយគង់នៅក្នុងពួកអ្នកដែលស្រឡាញ់ទ្រង់ ។ ជំពូកទី ៥ ពន្យល់ប្រាប់ថាពួកបរិសុទ្ធកើតអំពីព្រះ ដោយសារជំនឿជឿដល់ព្រះគ្រីស្ទ ។

យ៉ូហានទី ២ ក៏ដូចជាយ៉ូហានទី ១ ដែរ ។ នៅក្នុងសំបុត្រនេះ យ៉ូហានអរសប្បាយ ពីព្រោះតែសេចក្ដីស្មោះត្រង់នៃកូនចៅរបស់ « លោកស្រីរើសតាំង » ។

យ៉ូហានទី ៣ សរសើរមនុស្សម្នាក់ឈ្មោះកៃយុស ចំពោះសេចក្ដីស្មោះត្រង់ និងជំនួយរបស់គាត់ ដែលបានផ្ដល់ដល់ពួកអ្នកដែល ស្រឡាញ់សេចក្ដីពិត ។

*ដំណឹងល្អតាមលោកយ៉ូហាន៖* នៅក្នុងគម្ពីរក្នុងព្រះគម្ពីរសញ្ញាថ្មីនេះ យ៉ូហានជាសាវក បានធ្វើបន្ទាល់ថា (១) ព្រះយេស៊ូវ គឺជា ព្រះគ្រីស្ទ ឬព្រះមែស៊ី ហើយ (២) ថាព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ (យ៉ូហាន ២០:៣១) ។ ភាពអំពីជីវិតរបស់ព្រះយេស៊ូវ ដែល លោកបានអធិប្បាយប្រាប់ គឺបានរើស ហើយរៀបយ៉ាងផ្ចិតផ្ចង់ ដោយព្រោះគោលបំណងនេះ ។ គម្ពីរនេះចាប់ផ្ដើមនឹងសេចក្ដីថ្លែង អំពីស្ថានភាពនៃព្រះគ្រីស្ទ កាលមានព្រះជន្មរស់នៅមុនផែនដី៖ ទ្រង់គង់នៅជាមួយនឹងព្រះ ទ្រង់ជាព្រះ ហើយទ្រង់ជាអ្នកបង្កើតនូវអ្វីៗទាំងអស់ ។ ទ្រង់បានកើតក្នុងសាច់ឈាម ជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា ។ យ៉ូហានរៀបរាប់អំពីដំណើរការងារបំរើរបស់ព្រះយេស៊ូវ គឺបញ្ជាក់យ៉ាងខ្លាំង អំពីទេវភាពរបស់ទ្រង់ និងដំណើររស់ពីស្លាប់ឡើងវិញរបស់ទ្រង់ ។ លោកបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ដែលបានសម្ដែងដោយឫទ្ធិបារមី ដោយទីបន្ទាល់ ដោយពួកព្យាការី និងដោយសម្លេងរបស់ព្រះ គ្រីស្ទផ្ទាល់ ។ យ៉ូហានបង្រៀន ដោយប្រើពាក្យផ្ទុយអំពីពន្លឺ និងងងឹត, ខុស និងត្រូវ, ល្អ និងអាក្រក់, ព្រះ និងអារក្ស ។ មើលទៅ ប្រហែលជាគ្មានបញ្ជីឯណាទៀត ដែលប្រកាសប្រាប់អំពីបរិសុទ្ធភាពនៃព្រះយេស៊ូវ និងភាពស្មោះត្រង់នៃពួកអ្នកត្រួតត្រាសាសន៍យូដា ដែលច្បាស់ជាងនេះឡើយ ។

យ៉ូហានបានសរសេរតែពីការងារបំរើរបស់ព្រះគ្រីស្ទនៅខេត្តយូដាជាពិសេស គឺអាទិត្យចុងក្រោយបង្អស់នៃការងារបំរើរបស់ទ្រង់នៅលើផែនដី រីឯម៉ាថាយ ម៉ាកុស និងលូកាបានសរសេរតែពីការងារបំរើរបស់ទ្រង់ នៅស្រុកកាលីឡេ ។ វគ្គជាច្រើនចេញពីដំណឹង ល្អនេះ ត្រូវបានបញ្ជាក់ដោយវិវរណៈនៅថ្ងៃចុងក្រោយ (គ. និង ស. ៧ និង គ. និង ស. ៨៨:១៣៨–១៤១) ។

ចំពោះជំពូកសង្ខេប សូមមើល *ដំណឹងល្អទាំងឡាយ* ។

*គម្ពីរវិវរណៈ៖ សូមមើល* វិវរណៈរបស់យ៉ូហាន ។

**យ៉ូអែល**

ជាព្យាការីម្នាក់នៅស្រុកយូដា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ថ្ងៃកំណើតលោក គឺមិនបានដឹងជាប្រាកដទេ — លោកប្រហែលជាបានរស់នៅរវាងរាជ្យយ៉ូអាស គឺមុនឆ្នាំ ៨៥០ ម.គ.ស. នឹងការវិលមកវិញនៃពួជអំបូរយូដា ពីការឃុំឃាំងនៅក្រុងបាប៊ីឡូន ។

*គម្ពីរយ៉ូអែលៈ* គម្ពីរនេះផ្ដិតផ្ដង់ទៅលើពាក្យព្យាករណ៍ដែលយ៉ូអែលបានទាយ បន្ទាប់ពីស្រុកយូដាត្រូវវាយ ដោយភាពរាំងស្ងួត ជាខ្លាំង និងដោយកណ្ដូប (យ៉ូអែល ១:៤–២០) ។ យ៉ូអែលបានបញ្ជាក់ដល់ប្រជាជនថា តាមរយៈការប្រែចិត្ត នោះគេនឹងបានទទួល ព្រះពរទាំងឡាយនៃព្រះទៀត (យ៉ាកុប ២:១២–១៤) ។

ជំពូកទី ១ ជាការហៅឲ្យមានជំនុំមុតមាំនៅក្នុងដំណាក់នៃព្រះអម្ចាស់ ។ ជំពូកទី ២ ប្រាប់អំពីសង្គ្រាម និងការស្ងាត់ស្ងៀមឈឹង ដែលនឹងកើតមុនសហស្សវត្សរ៍ ។ ជំពូកទី ៣ និយាយអំពីថ្ងៃចុងក្រោយ ហើយបញ្ជាក់ថា សាសន៍ទាំងអស់នឹងមានសង្គ្រាម ប៉ុន្តែថាព្រះអម្ចាស់ទ្រង់នឹងគង់នៅក្នុងក្រុងស៊ីយ៉ូនជាមិនខានឡើយ ។

ពេត្រុសបានស្រង់ពាក្យព្យាករណ៍របស់យ៉ូអែល អំពីការចាក់ព្រះវិញ្ញាណដូចបុណ្យថ្ងៃទី ៥០ (យ៉ូអែល ២:២៨–៣២; កិច្ចការ ២:១៦–២១) ។ ទេវតាម៉ូរ៉ូណៃក៏បានស្រង់វគ្គដដែលនេះដល់យ៉ូសែប ស្ម៊ីធ (យ.ស. — ប្រវត្តិ ១:៤១) ។

**យើងជាព្រះ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ, ព្រះយេហូវ៉ា

ជាព្រះនាមមួយនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។

ព្រះទ្រង់មានព្រះបន្ទូលទៅម៉ូសេថា « យើងជាព្រះដ៏ជាព្រះ », **និក្ខ.** ៣:១៤–១៥ ។ យើងជាព្រះអម្ចាស់, **និក្ខ.** ៦:២–៣ ។ មុនដែលលោកអ័ប្រាហាំកើតមក នោះមានខ្ញុំហើយ, **យ៉ូហាន** ៨:៥៦–៥៩ ។ ចូរស្ដាប់តាមសម្លេងនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏ជាព្រះដែល មហិមា, **គ. និង ស.** ២៩:១ (គ. និង ស. ៣៨:១; ៣៩:១) ។

**យេត្រូ** *សូមមើលផង* ម៉ូសេ

ជាស្ដេច ហើយជាសង្ឃនៅស្រុកម៉ាឌាន នៅក្នុងព្រះគម្ពីរសញ្ញាចាស់ម្នាក់ដែលបានឲ្យផ្ទះម៉ូសេស្នាក់នៅ ក្រោយពីម៉ូសេបាន រត់គៀសចេញពីស្រុកអេស៊ីព្ទ ។ លោកក៏បានហៅថា រេហួល (និក្ខ. ២:១៨) ។ បន្ទាប់មកម៉ូសេរៀបការយកនាងសេផូរ៉ា ជាកូនស្រីរបស់យេត្រូ, (និក្ខ. ៣:១; ៤:១៨; ១៨:១–១២) ។ យេត្រូបានបង្រៀនម៉ូសេឲ្យប្រគល់អំណាចទៅអ្នកផ្សេង (និក្ខ. ១៨:១៣–២៧) ។ ម៉ូសេបានទទួលបព្វជិតភាពមិលគីស្សាដែកពីយេត្រូ (គ. និង ស. ៨៤:៦–៧) ។

**យេរីខូរ**

ជាទីក្រុងមួយដែលព័ទ្ធដោយកំផែង នៅក្នុងច្រកភ្នំយ័រដាន់ ដែលមានកំរិត ២៤៥ ម. ទាបជាងផ្ទៃសមុទ្រ ។ ក្រុងយេរីខូរនៅក្បែរ កន្លែងដែលពួក សាសន៍អ៊ីស្រាអែលឆ្លងទន្លេ កាលពួកគេបានចូលដែនដីសន្យាលើកទីមួយ (យ៉ូស្វេ ២:១–៣; ៣:១៦; ៦) ។

ពួកសាសន៍អ៊ីស្រាអែលបានច្បាំងចម្បាំងនោះក្រុងយេរីខូរ, **យ៉ូស្វេ** ៦:១–២០ ។ យ៉ូស្វេបានដាក់បណ្ដាសាលើក្រុងយេរីខូរ, **យ៉ូស្វេ** ៦:២៦ (១ ពង្សាវ. ១៦:៣៤) ។ ក្រុងយេរីខូរ គឺនៅក្នុងភូមិភាគ ដែលបានចែកឲ្យទៅបេនយ៉ាមីន, **យ៉ូស្វេ** ១៨:១១–១២, ២១ ។ ព្រះអម្ចាស់ទ្រង់បានចូលទៅក្រុងយេរីខូរ កាលទ្រង់យាងទៅក្រុងយេរូសាឡិមចុងក្រោយបង្អស់, **ម៉ាកុស** ១០:៤៦ (លូកា ១៨:៣៥; ១៩:១) ។

**យេរូ-បាល** *សូមមើលផង* គេឌាន (ព្រះគម្ពីរសញ្ញាចាស់)

ជាឈ្មោះមួយដែលបានឲ្យទៅគេឌាន នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ក្រោយពីលោកបានបំផ្លាញអាសនារបស់ព្រះបាលចោល (ពួកចៅ. ៦:៣២; ៧;១; ៩; ១ សាំយូ. ១២:១១) ។

**យេរ៉ូបោម**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ យេរ៉ូបោមជាស្ដេចទីមួយ នៃស្រុកអ៊ីស្រាអែលខាងជើងដែលបានបំបែកចេញ ។ ទ្រង់ជាសមាជិកក្នុងពូជអំបូរអេប្រាអិម ។ យេរ៉ូបោមដ៏ទុច្ចរិតបាននាំការបះបោរទាស់នឹងវង្សយូដា និងវង្សានុវង្សរបស់ដាវីឌ ។

យេរ៉ូបោមបានតាំងរូបព្រះឡើងសំរាប់ឲ្យប្រជាជននៅក្នុងក្រុងដាន់ និងក្រុងបេត-អែល ថ្វាយបង្គំ, **១ ពង្សាវ.** ១២:២៨–២៩ ។ អ័ហ៊ីយ៉ាបានបន្ទោសយេរ៉ូបោម, **១ ពង្សាវ.** ១៤:៦–១៦ ។ យេរ៉ូបោមត្រូវបានចាំទុកថា បាននាំអំពើបាបដ៏គួរស្អែងខ្លាចមកឯស្រុកអ៊ីស្រាអែល, **១ ពង្សាវ.** ១៥:៣៤ (១ ពង្សាវ. ១២:៣០) ។

**យេរេមា** *សូមមើលផង* គម្ពីរបរិទេវ

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានកើតពីត្រកូលសង្ឃ ហើយបានព្យាករនៅស្រុកយូដា ពីឆ្នាំ ៦២៦–៥៨៦ ម.គ.ស. ។ លោកបានរស់នៅសម័យពួកព្យាការីដ៏មហិមា គឺៈ លីហៃ អេសេគាល ហូសេ និង ដានីយ៉ែល ។

យេរេមាបានត្រូវតែងតាំងឲ្យធ្វើជាព្យាការី តាំងពីជីវិតមុនផែនដីម្ល៉េះ (យេរេ. ១:៤–៥) ។ កំឡុងពេលប្រមាណជា ៤០ ឆ្នាំ ជាព្យាការីនោះលោកបានបង្រៀនជំទាស់នឹងការថ្វាយបង្គំរូបព្រះ និងអំពើកាមគុណនៅក្នុងចំណោមប្រជាជននៃសាសន៍យូដា (យេរេ. ៣:១–៥; ៧:៨–១០) ។ លោកត្រូវប្រឈមមុខទាស់នឹងការប្រឆាំង និងការមើលងាយរហូត (យេរេ. ២០:២; ៣៦:១៨–១៩; ៣៨:៤) ។ ក្រោយពីការរលំនៃក្រុងយេរូសាឡិម នោះពួកសាសន៍យូដា ដែលបានគៀសខ្លួនចូលទៅស្រុកអេស៊ីព្ទ ក៏បានយកយេរេមាទៅជាមួយពួកគេ (យេរេ. ៤៣:៥–៦), តាមទំនាមទំលាប់ គឺជាកន្លែងដែលពួកគេបានយកថ្មគប់សម្លាប់លោក ។

*គម្ពីរយេរេមាៈ* ជំពូកទី ១–៦ មានពាក្យព្យាករណ៍ទាំងឡាយនៅក្នុងរាជ្យនៃស្ដេចយ៉ូសៀស ។ ជំពូកទី ៧–២០ ជាពាក្យព្យាករណ៍ ទាំងឡាយនៅសម័យស្ដេចយេហូយ៉ាគីម ។ ជំពូកទី ២១–៣៨ ទាក់ទងនឹងរាជ្យនៃសេដេគា ។ ជំពូកទី ៣៩–៤៤ មានពាក្យព្យាករណ៍ ទាំងឡាយ ហើយបានអធិប្បាយប្រាប់ អំពីព្រឹត្តិការណ៍ខាងប្រវត្តិក្រោយពីការរលំនៃក្រុងយេរូសាឡិម ។ ជំពូកទី ៤៥ មានពាក្យសន្យាដល់បារូក ជាស្មៀនរបស់លោក ថាជីវិតនៃបារូកនឹងបានរក្សាទុក ។ ជាទីបញ្ចប់ ជំពូកទី ៤៦–៥១ ជាពាក្យព្យាករណ៍ជំទាស់នឹង

ប្រទេសក្រៅទាំងឡាយ ។ ជំពូកទី ៥២ ជាពាក្យបញ្ចប់ខាងប្រវត្តិ ។ ពាក្យព្យាករណ៍របស់យេរេមាខ្លះ មាននៅក្នុងផ្ទាំងលង្ហិនរបស់ ឡាបាន់ ដែលយកបានដោយនីហ្វៃ (១ នីហ្វៃ ៥:១០–១៣) ។ យេរេមាក៏ត្រូវបានពោលដល់ពីរដងទៀត នៅក្នុងព្រះគម្ពីរមរមន (១ នីហ្វៃ ៧:១៤; ហេលេ. ៨:២០) ។

គម្ពីរយេរេមាក៏មាននូវការទទួលស្គាល់អំពីការរស់នៅមុនផែនដីនៃមនុស្ស និងការតែងតាំងរបស់យេរេមា តាំងពីមុនកំណើតលោកិយ (យេរេ. ១:៤–៥); ពាក្យព្យាករណ៍មួយអំពីការវិលមកវិញនៃពួកអ៊ីស្រាអែល ពីស្ថានភាពខ្ចាត់ខ្ចាយរបស់ពួកគេ ដោយការប្រមូលម្នាក់ ពីក្រុងមួយ ហើយពីរនាក់ពីគ្រួសារមួយ នាំទៅក្រុងស៊ីយ៉ូនវិញ គឺជាដែនដីដ៏គាប់ចិត្ត ដែលពួកអ៊ីស្រាអែល និងពួកយូដានឹងអាស្រ័យនៅ ក្នុងសេចក្ដីសុខសាន្ត គ្រាន (យេរេ. ៣:១២–១៩); និងពាក្យព្យាករណ៍មួយ អំពីការដែលព្រះអម្ចាស់ទ្រង់ប្រមូលពួកអ៊ីស្រាអែលចេញពី ស្រុកខាងជើង ដោយចាត់ « ពួកនេសាទ » និង « ពួកបរបាញ់ » ជាច្រើនឲ្យទៅរកពួកគេ (យេរេ. ១៦:១៤–២១) ។ ព្រឹត្តិការណ៍នៅ ថ្ងៃចុងក្រោយនេះ គឺនឹងទៅជាការដ៏ធំជាង កាលម៉ូសេនាំពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទទៅទៀត (យេរេ. ១៦:១៣–១៥; ២៣:៨) ។

## យេរូសាឡិម

ជាទីក្រុងមួយនៅស្រុកអ៊ីស្រាអែលសព្វថ្ងៃនេះ ។ គឺជាទីក្រុងដ៏វិសេសបំផុតមួយនៅក្នុងប្រវត្តិគម្ពីរប៊ីប ។ ជាកន្លែងដ៏ពិសិដ្ឋបំផុតខ្លះ ចំពោះពួកគ្រីស្ទាន ពួកយូដា និងពួកអ៊ីស្លាម គឺនៅទីក្រុងនេះហើយ ដែលពួកអ្នកជឿដ៏ស្មោះត្រង់ជាច្រើនមកលេងជាទៀងទាត់ ។ ក្រុងយេរូសាឡិមតែងតែបានពោលថាជាទីក្រុងបរិសុទ្ធ ។

នៅគ្រាមួយ បានស្គាល់ថា សាឡិម (លោកុ. ១៤:១៨; ទំនុក. ៧៦:២), យេរូសាឡិម គឺជាទីក្រុងយេប៊ូស រហូតដល់ដាវីឌចាប់យកបាន (យ៉ូស្វេ ១០:១; ១៥:៨; ២ សាំយូ. ៥:៦–៧), ក៏បានតាំងធ្វើជារាជធានីរបស់ ទ្រង់ ។ រហូតដល់ពេលនោះ គឺធ្លាប់ប្រើជាបន្ទាយភ្នំ គឺ ប្រមាណជា ៨០០ ម. ខ្ពស់ជាងផ្ទៃសមុទ្រ ។ ក្រុងយេរូសាឡិមព័ទ្ធជុំវិញដោយច្រកភ្នំដ៏ខ្ពស់ នៅគ្រប់ទិស លើកលែងតែទិសខាងជើង ។

នៅក្នុងរាជ្យស្ដេចដាវីឌនៅក្រុងយេរូសាឡិម នោះទ្រង់សំណាក់នៅក្នុងវាំងធ្វើពីឈើ ។ ប៉ុន្តែនៅក្នុងរាជ្យសាឡូម៉ូន នោះប្រជាជន បានធ្វើអ្វីៗជាច្រើន ដើម្បីស្អាងទីក្រុងបានល្អ គឺមានទាំងការសាងវាំងស្ដេច និងព្រះវិហារ ។

បន្ទាប់ពីនគរអ៊ីស្រាអែល និងនគរយូដាបានបែកចេញ នោះក្រុងយេរូសាឡិមនៅជារាជធានីរបស់ស្រុកយូដា ។ គឺតែងតែបានវាយដោយពួកពលទ័ពលុកលុយ (១ពង្សាវ. ១៤:២៥; ២ ពង្សាវ. ១៤:១៣; ១៦:៥; ១៨–១៩; ២៤:១០; ២៥) ។ នៅក្រោមស្ដេច ហេសេគា នោះក្រុងយេរូសាឡិមបានក្លាយទៅមជ្ឈមណ្ឌលនៃការថ្វាយបង្គំខាងសាសនា ប៉ុន្តែភាគខ្លះត្រូវបានបំផ្លាញចោល នៅឆ្នាំ ៣២០ ម.គ.ស., ១៦៨ ម.គ.ស., និង ៦៥ ម.គ.ស. ។ ស្ដេចហេរ៉ូឌបានសាងកំផែង និងព្រះវិហារឡើងវិញ ប៉ុន្តែនៅឆ្នាំ ៧០ គ.ស. នោះពួករ៉ូមបានបំផ្លាញចោលអស់រលីង ។

មិលគីស្សាដែកជាស្ដេចក្រុងសាឡិម, **លោកុ**. ១៤:១៨ (ហេព្រើរ ៧:២) ។ អេសាយបានហៅឲ្យក្រុងយេរូសាឡិមប្រដាប់ដោយសំលៀកបំពាក់ដ៏រុងរឿង, **អេសាយ** ៥២:១ ។ ព្រះបន្ទូលនៃព្រះអម្ចាស់ចេញមកពីក្រុងយេរូសាឡិម, **មីកា** ៤:២ ។ ព្រះគ្រីស្ទបានទួញសោកស្ដាយចំពោះអនាគតនៃក្រុងយេរូសាឡិម, **ម៉ាថាយ** ២៣:៣៧–៣៩ (លូកា ១៣:៣៤) ។ យេរូសាឡិម គឺជាទីក្រុងនៃព្រះដ៏មាន ព្រះជន្មរស់, **ហេព្រើរ** ១២:២២ ។ ក្រុងយេរូសាឡិមនឹងត្រូវបំផ្លាញចោល បើមិនប្រែចិត្ត, **១ នីហ្វៃ** ១:៤, ១៣, ១៨ (២ នីហ្វៃ ១:៤; ហេព្រើរ ៨:២០) ។ ក្រុងយេរូសាឡិមនឹងត្រូវមានមនុស្សអាស្រ័យនៅទៀត ក្រោយពីការបំផ្លិចបំផ្លាញ, ៣ នីហ្វៃ ២០:៤៦ ។ ក្រុង យេរូសាឡិមនឹងត្រូវបានស្ថាបនាឡើងវិញ, **អេធើរ** ១៣:៥ ។ ព្រះគ្រីស្ទបានព្រមានដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយដូចដែលទ្រង់បាន ព្រមានប្រជាជននៅក្រុងយេរូសាឡិមដែរ, **គ. និង ស.** ៥:២០ ។ ចូរឲ្យពួកអ្នកដែលជាអ្នកស្រុកយូដា រត់ទៅក្រុងយេរូសាឡិម, **គ. និង ស.** ១៣៣:១៣ ។ ព្រះអម្ចាស់ ទ្រង់នឹងមានព្រះបន្ទូលពីក្រុងយេរូសាឡិម, **គ. និង ស.** ១៣៣:២១ ។

**យោបល់, ការយល់** *សូមមើលផង* ដំរិះ; ប្រាជ្ញា, សេចក្ដីពិត

ដើម្បីឲ្យបានដំរិះ ឬស្គាល់ន័យនៃសេចក្ដីពិតខ្លះៗ ព្រមទាំងអំពីការអនុវត្តន៍នៃជីវិត ។

កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ, **សុភា**. ៣:៥ ។ កំពុងដែលខំឲ្យបានរបស់ផ្សេងៗ នោះចូរខំឲ្យបានយោបល់ផង, **សុភា**. ៤:៧ ។ ព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូល ដោយពាក្យប្រៀបប្រដូចទាំងឡាយ ហើយមនុស្សខ្លះយល់មិនដល់ឡើយ, **ម៉ាថាយ** ១៣:១២–១៧ ។ ព្រះអម្ចាស់ទ្រង់ក៏បើកបំភ្លឺសតិស្មារតីគេឲ្យយល់, **លូកា** ២៤:៤៥ ។ បើអ្នករាល់គ្នាមិនអាចយល់ពាក្យទាំងនេះទេ គឺមកពីអ្នករាល់គ្នាមិនសូម, **២ នីហ្វៃ** ៣២:៤ (៣ នីហ្វៃ ១៧:៣) ។ បញ្ជីប្រវត្តិទាំងឡាយត្រូវបានរក្សាទុក ដើម្បីឲ្យអាចអាន ហើយ យល់, **ម៉ូសាយ** ១:២–៥ ។ ពីព្រោះតែការឥតជំនឿរបស់គេ នោះពួកគេពុំអាចយល់ព្រះបន្ទូលនៃព្រះបានឡើយ, **ម៉ូសាយ** ២៦:៣ ។ ពួកគេជាមនុស្ស ដែលមានយោបល់ដ៏ជ្រាលជ្រៅ, **អាលម៉ា** ១៧:២–៣ ។ ព្រះបន្ទូលចាប់ផ្ដើមបំភ្លឺយោបល់របស់ខ្ញុំ, **អាលម៉ា** ៣២:២៨ ។ មកចុះ យើងនឹងពិភាក្សាជាមួយគ្នា ដើម្បីឲ្យអ្នករាល់គ្នាអាចបានយល់, **គ. និង ស.** ៥០:១០–១២, ១៩–២៣ ។ ឪពុកម្ដាយត្រូវបង្រៀន កូនចៅឲ្យយល់, **គ. និង ស.** ៦៨:២៥ ។ កិច្ចការទាំងឡាយ និងការអាថ៌កំបាំងទាំងឡាយនៃព្រះ អាចបានយល់ដោយព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះ, **គ. និង ស.** ៧៦:១១៤–១១៦ ។ អារក្សសាតាំងស្វែងរកដើម្បីបំបែរចិត្តរបស់មនុស្សលោកចេញកុំឲ្យយល់, **គ. និង ស.** ៧៨:១០ ។ ពន្លឺនៃព្រះគ្រីស្ទប្រោសយោបល់ដល់យើង, **គ. និង ស.** ៨៨:១១ ។

**រដ្ឋធម្មនុញ្ញ** *សូមមើលផង* ក្រិត្យវិន័យ, រដ្ឋាភិបាល

នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ពាក្យថា « រដ្ឋធម្មនុញ្ញ »

គឺសំដៅទៅរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក ដែលបំផុសគំនិតពីព្រះ ដើម្បីរៀបចំផ្លូវសំរាប់ការសាងឡើងវិញនៃដំណឹងល្អ ។

ក្រិត្យវិន័យខាងធម្មនុញ្ញគួរតែបានគាំទ្រ, **គ. និង ស.** ៩៨:៥–៦ ។ ព្រះអម្ចាស់ទ្រង់បណ្ដាលឲ្យមានរដ្ឋធម្មនុញ្ញតាំងឡើង, **គ. និង ស.** ១០១:៧៧, ៨០ ។

**រដ្ឋាភិបាល***សូមមើលផង* រដ្ឋធម្មនុញ្ញ

នៅពេលព្រះយេស៊ូវយាងមកវិញ នោះទ្រង់នឹងតាំងរដ្ឋាភិបាលនៃសេចក្ដីសុចរិត ។

ការគ្រប់គ្រងនឹងនៅលើស្មារបស់ទ្រង់, **អេសាយ** ៩:៦ (២ នីហ្វៃ ១៩:៦) ។ ចូរថ្វាយរបស់សេសារ ទៅសេសារទៅ, **ម៉ាថាយ** ២២:២១ (គ. និង ស. ៦៣:២៦) ។ ចូរចុះចូលនឹងអំណាចខ្ពស់, **រ៉ូម** ១៣:១ ។ ចូរពោលពាក្យអធិស្ឋានឲ្យស្ដេច និងពួកនាម៉ឺនទាំង ប៉ុន្មានផង, ១ ធីម៉ូ. ២:១–២ ។ ចូរចុះចូលនឹងពួកនាម៉ឺន ហើយនិងពួកមានអំណាចទាំងអស់ ហើយព្រមទាំងស្ដាប់បង្គាប់តាមចៅក្រម, **ទីតុស** ៣:១ ។ ចូរចុះចូលនឹងគ្រប់ទាំងច្បាប់នៃមនុស្សលោក ដោយយល់ដល់ព្រះអម្ចាស់, **១ ពេត្រុស** ២:១៣–១៤ ។ ព្រះយេស៊ូវ គ្រីស្ទនឹងត្រឡប់ទៅជាអភិបាលដ៏ធំបំផុតនៃផែនដី, **វិវ.** ១១:១៥ ។ ចូររើសបុរសសុចរិតឲ្យធ្វើជាស្ដេចអ្នក, **ម៉ូសាយ** ២៣:៨ ។ ចូរធ្វើ កិច្ចការរបស់អ្នក តាមសម្លេងរបស់ប្រជាជន, **ម៉ូសាយ** ២៩:២៦ ។ ព្រះគ្រីស្ទទ្រង់នឹងធ្វើជាអ្នកត្រួតត្រារបស់អ្នក ក្នុងកាលទ្រង់យាងមក, **គ. និង ស.** ៤១:៤ ។ អ្នកណាដែលកាន់តាមក្រិត្យវិន័យទាំងឡាយនៃព្រះ នោះមិនត្រូវបំពាក់ក្រិត្យវិន័យទាំងឡាយនៃដែនដីទេ, **គ. និង ស.** ៥៨:២១ ។ កាលណាមនុស្សទុច្ចរិតគ្រប់គ្រង នោះប្រជាជនទ្រហួញសោក, **គ. និង ស.** ៩៨:៩–១០ ។ រដ្ឋាភិបាលទាំងឡាយត្រូវ បានបង្កើតឡើងពីព្រះ សំរាប់ផលប្រយោជន៍ដល់មនុស្ស, **គ. និង ស.** ១៣៤:១–៥ ។ មនុស្សទាំងឡាយមានកាតព្វកិច្ច ដើម្បីគាំទ្រ និងទ្រទ្រង់រដ្ឋាភិបាល, **គ. និង ស.** ១៣៤:៥ ។ យើងខ្ញុំជឿចំពោះការនៅក្រោមអំណាចស្ដេច ប្រធានាធិបតី អ្នកគ្រប់គ្រង និងចៅក្រម ទាំងឡាយ, **ម. នៃ ស.** ១:១២ ។

**របាក្សត្រ**

ជាគម្ពីរពីរក្បាលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ គម្ពីរទាំងនេះប្រាប់នូវប្រវត្តិដ៏ខ្លីៗ អំពីព្រឹត្តិការណ៍ទាំងឡាយ ចាប់តាំងពីការបង្កបង្កើត មកដល់ក្រិត្យនៃស្ដេចស៊ីរូស ដែលអនុញ្ញាតឲ្យពួកសាសន៍យូដាត្រឡប់ទៅក្រុងយេរូសាឡិមវិញ ។

*របាក្សត្រទី១៖* ជំពូកទី ១–៩ ចុះនូវពង្សាវតារ ចាប់ពីលោកអ័ដាម ទៅដល់ស្ដេចសូល ។ ជំពូកទី ១០ កត់អំពីការសុគតនៃស្ដេចសូល ។ ជំពូកទី ១១–២២ រាប់រៀបអំពីព្រឹត្តិការណ៍ទាំងឡាយ ដែលទាក់ទងទៅនឹងរាជ្យនៃស្ដេចដាវីឌ ។ ជំពូកទី ២៣–២៧ អធិប្បាយ ប្រាប់ពីសាឡូម៉ូនបានត្រូវតាំងឡើងជាស្ដេច ហើយពួកលេវីបានចាត់ឲ្យមានរបៀបរៀបរយ ។ ជំពូកទី ២៨ អធិប្បាយប្រាប់ពីស្ដេចដាវីឌ បញ្ជាសាឡូម៉ូនឲ្យសង់វិហារមួយ ។ ជំពូកទី ២៩ កត់អំពីការសុគតនៃស្ដេចដាវីឌ ។

*របាក្សត្រទី ២៖* ជំពូកទី ១–៩ រៀបរាប់អំពីព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទងទៅនឹងរាជ្យនៃស្ដេចសាឡូម៉ូន ។ ជំពូកទី ១០–១២ ប្រាប់អំពីរាជ្យនៃរេហូបោម ជាបុត្ររបស់សាឡូម៉ូន នៅពេលដែល សហនគរអ៊ីស្រាអែល បានបែកចេញជានគរខាងជើង និងនគរខាង ត្បូង ។ ជំពូកទី ១៣–៣៦ អធិប្បាយប្រាប់ពីរាជ្យនៃស្ដេចជាច្រើន ហូតដល់ការចាប់យកនគរយូដា ដោយស្ដេចនេប៊ូក្នេសារ ។ គម្ពីរ នេះចប់នឹងក្រិត្យនៃស្ដេចស៊ីរូស ដែលថាកូនចៅនៃសាសន៍យូដាដែលជាប់ឃុំឃាំង អាចត្រឡប់ទៅក្រុងយេរូសាឡិមវិញ ។

**រអ៊ូរទាំ** *សូមមើលផង* ការបះបោរ

គឺរទូរទាំ ហើយត្អូញត្អែរទាស់នឹងបំណង ផែនការ ឬពួកអ្នកបំរើរបស់ព្រះ ។

បណ្ដាជនត្អូញត្អែរដាក់ម៉ូសេ, **និក្ខ.** ១៥:២៣–១៦:៣ ។ ពួកសាសន៍យូដា គេខុកដាន់ទ្រង់, យ៉ូហាន ៦:៤១ ។ លេមិន និងលេមយួល បានរអ៊ូរទាំពីរឿងជាច្រើន, **១ នីហ្វៃ** ២:១១–១២ (១ នីហ្វៃ ៣:៣១; ១៧:១៧) ។ ចូរកុំរអ៊ូរទាំ ដោយសារតែអ្វីដែលអ្នកពុំបានឃើញ នោះឡើយ, **គ. និង ស.** ២៥:៤ ។

**រាប់អាន***សូមមើលផង* ការកោតក្រែង, កិត្តិយស

រាប់មនុស្ស ឬអ្វីមួយទុកជាមានតម្លៃ និងគុណសម្បត្តិ ជាពិសេស នៅក្នុងស្ថានការខាងដំណឹងល្អ ។

ទ្រង់ត្រូវគេមើលងាយ ហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ, **អេសាយ** ៥៣:៣–៤ ។ របស់ណាដែលមនុស្សគាប់ចិត្តរាប់អានជាច្រើន នោះជាទីស្អប់ខ្ពើមនៅចំពោះព្រះវិញ, **លូកា** ១៦:១៥ ។ ចូររាប់អានគេឲ្យលើសជាងខ្លួន, **ភីលីព** ២:៣ ។ ព្រះអម្ចាស់ទ្រង់យល់ថារូបកាយទាំងអស់ដូចគ្នា, **១ នីហ្វៃ** ១៧:៣៥ ។ មនុស្សរាល់គ្នាត្រូវគោរពអ្នកជិតខាង ដូចខ្លួនឯងផ្ទាល់, **ម៉ូសាយ** ២៧:៤ (គ. និង ស. ៣៨:២៤–២៥) ។ នៅថ្ងៃដែលពួកគេមានសេចក្ដីសុខសាន្ត នោះពួកគេរាប់ពាក្យដំបូន្មានរបស់យើងថា មានប្រយោជន៍បន្តិច បន្តួច, **គ. និង ស.** ១០១:៨ ។

**រ៉ាមីអុមតុម**

ជាកន្លែងឈរដ៏ខ្ពស់មួយ នៅក្នុងព្រះគម្ពីរមរមន ដែលពួកសាសន៍សូរាំជាពួកសាសន៍នីហ្វៃ ដែលបានក្បត់សាសនា ឈរលើ ដើម្បីអធិស្ឋាន (អាលម៉ា ៣១:៨–១៤) ។

**រ៉ាហ្វាអែល** *សូមមើលផង* ពួកទេវតា

ជាទេវតានៃព្រះអម្ចាស់ដែលបានចូលរួមក្នុងការសាងឡើងវិញនូវអ្វីៗគ្រប់យ៉ាង (គ. និង ស. ១២៨:២១) ។

**រិកដុន, ស៊ីឌនី**

ជាអ្នកដែលប្រែចិត្តជឿមុនដំបូង ហើយជាអ្នកដឹកនាំម្នាក់ នៅក្នុងសាសនាចក្រដែលបានសាងឡើងវិញ នៅឆ្នាំ ១៨៣០ ទៅដើមឆ្នាំ ១៨៤០ ។

នៅគ្រាមួយ ស៊ីឌនី រិកដុនបានធ្វើជាទីប្រឹក្សាទីមួយដល់យ៉ូសែប ស្ម៊ីធ នៅក្នុងគណៈប្រធានទីមួយនៃសាសនាចក្រ (គ. និង ស. ៣៥; ៥៨:៥០, ៥៧; ៦៣:៥៥–៥៦; ៧៦:១១–១២, ១៩–២៣; ៩០:៦; ៩៣:៤៤; ១០០:៩–១១; ១២៤:១២៦) ។ ក្រោយមក លោកបានបែរចេញ ហើយបានកាត់ចេញពីសាសនា នៅខែកញ្ញា ១៨៤៤ ។

**រូបេន***សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសច្បងបង្អស់របស់យ៉ាកុប និងនាងលេអា (លោកុ. ២៩:៣២; ៣៧:២១–២២, ២៩; ៤២:២២, ៣៧) ។ ទោះជារូបេនជាកូនប្រុសច្បងក៏ដោយ គង់តែលោកបានបាត់សិទ្ធិកូនច្បងដែរ ពីព្រោះមកពីអំពើបាប (លោកុ. ៣៥:២២; ៤៩:៣–៤) ។

*ពូជអំបូររបស់រូបេន៖* ពររបស់យ៉ាកុបដល់រូបេន នោះប្រទះឃើញនៅក្នុងគម្ពីរលោកុប្បត្តិ ៤៩:៣ និងគម្ពីរចោទិយកថា ៣៣:៦ ។ ចំនួនមនុស្សក្នុងពូជអំបូរនេះចេះតែមានតិចទៅៗ ហើយទោះជានៅមានពូជអំបូរនេះក៏ដោយ គង់តែបានក្លាយទៅជាមិនសូវសំខាន់អ្វី ខាងផ្លូវនយោបាយដែរ ។ សិទ្ធិកូនច្បងរបស់រូបេន នោះបានទៅយ៉ូសែប និងកូនប្រុសទាំងឡាយរបស់លោក ពីព្រោះយ៉ូសែប ជាកូន ច្បងបង្អស់របស់នាងរ៉ាជែល ជាប្រពន្ធទីពីររបស់យ៉ាកុប (១ របា. ៥:១–២) ។

**រូបកាយ** *សូមមើលផង* ដែលរមែងស្លាប់, ដំណើររស់ឡើងវិញ, ភាពដែលរមែងស្លាប់; ព្រលឹង, សេចក្ដីស្លាប់ខាងសាច់ឈាម

ជារូបរាងដែលប្រកបដោយសាច់ និងឆ្អឹង ដែលរមែងស្លាប់ ដែលត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះ ដែលត្រូវបានផ្សំនឹងវិញ្ញាណ ដើម្បីធ្វើជាមនុស្សមានជីវិតរស់ ។ រូបកាយខាងសាច់ឈាមនៃគ្រប់អស់ទាំងមនុស្សប្រុសស្រីនឹងបានរួមនឹងវិញ្ញាណរបស់គេវិញ ក្នុង ដំណើររស់ឡើងវិញ ។ ជួនកាល គម្ពីរហៅរូបកាយ និងវិញ្ញាណដែលបានរួមគ្នាថា ព្រលឹង (លោកុ. ២:៧; គ. និង ស. ៨៨:១៥; ម៉ូសេ ៣:៧, ៩, ១៩; អ័ប្រា. ៥:៧) ។

ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់សូនមនុស្សពីធូលីដី, **លោកុ.** ២:៧ (ម៉ូសេ ៣:៧) ។ ចូរពាល់ខ្ញុំមើល ត្បិតខ្មោចគ្មានសាច់ និងឆ្អឹងទេ, **លូកា** ២៤:៣៩ ។ ខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឲ្យចុះចូល, **១ កូរិន.** ៩:២៧ ។ មានរូបកាយខាងសាច់ឈាម នោះក៏មានរូបកាយខាង វិញ្ញាណ, **១ កូរិន.** ១៥:៤៤ ។ រូបកាយឥតមានព្រលឹងវិញ្ញាណ នោះក៏ស្លាប់ហើយ, **យ៉ាកុប** ២:២៦ (ព.គ.ថ.) ។ រូបកាយដែល រមែងស្លាប់នឹងបានប្រោសឡើងឲ្យទៅជារូបកាយអមតៈ, **អាលម៉ា** ១១:៤៣–៤៥ ។ ផ្នែកទាំងអស់នៃរាងកាយនឹងបានផ្គុំឡើងវិញ, **អាលម៉ា** ៤១:២ ។ ព្រះយេស៊ូវទ្រង់បានបង្ហាញព្រះកាយទ្រង់ដែលមានព្រះជន្មរស់ឡើងវិញដល់ពួកសាសន៍នីហ្វៃ, ៣ នីហ្វៃ ១០:១៨–១៩; ១១:១៣–១៥ ។ ព្រះវរបិតា ទ្រង់មានព្រះកាយជាសាច់ និងឆ្អឹង ដែលជាក់ស្ដែងដូចជារូបកាយមនុស្ស; ព្រះរាជបុត្រា ក៏ដូច្នោះ ដែរ, **គ. និង ស.** ១៣០:២២ ។ ព្រះទ្រង់បានបង្កើតមនុស្សប្រុសមនុស្សស្រី តាមរូបដូចព្រះអង្គផ្ទាល់, **ម៉ូសេ** ៦:៩ (លោកុ. ៩:៦) ។

**រ៉ូម** *សូមមើលផង* អាណាចក្ររ៉ូម

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជារាជធានីនៃអាណាចក្ររ៉ូម នៅត្រង់ទន្លេទីបេ នៅប្រទេសអ៊ីតាលី (កិច្ចការ ១៨:២; ១៩:២១; ២៣:១១) ។ ប៉ុលបានបង្រៀនដំណឹងល្អនៅក្រុងរ៉ូម កាលលោកជាប់ជាអ្នកទោសនៃរដ្ឋាភិបាលរ៉ូម (រ៉ូម ១:៧, ១៥–១៦; កិច្ចការ ២៨:១៤–៣១) ។

**រ៉ូម, សំបុត្រដល់ពួក** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសំបុត្រដែលប៉ុលបានសរសេរទៅពួកបរិសុទ្ធនៅក្រុងរ៉ូម ។ លោកកំពុងតែគិតចង់ទៅក្រុងយេរូសាឡិម ដែលច្បាស់ជានឹងមានការអន្តរាយ ។ បើសិនជាលោកបានរួចជីវិតបន្ទាប់មក លោកសង្ឃឹមថានឹងបានទៅក្រុងរ៉ូម ។ ភាគខ្លះក្នុង សំបុត្រនោះគឺសំរាប់រៀបចំសាសនាចក្រនៅទីនោះ ដើម្បីទទួលលោកនៅពេលលោកទៅ ។ សំបុត្រនោះក៏ចាត់ទុកជាមានពាក្យ ថ្លែងអំពីគោលលទ្ធិមួយ ដែលមិនស្រុះស្រួលគ្នា ហើយឥឡូវនេះ ប៉ុលបានចាត់ទុកថាបានសំរេចក្ដីហើយ ។

ជំពូកទី ១ មាននូវការសួរសុខទុក្ខពីប៉ុល ដល់ពួកសាសន៍រ៉ូម ។ ជំពូកទី ២–១១ មានសេចក្ដីថ្លែងខ្លះនូវគោលលទ្ធិ អំពីសេចក្ដីជំនឿ កិច្ចការ និងព្រះគុណ ។ ជំពូកទី ១២–១៦ មានការបង្រៀនច្បាស់លាស់ អំពីសេចក្ដីស្រឡាញ់ ភារៈកិច្ច និងសេចក្ដីបរិសុទ្ធ ។

**រើស, បានរើស, ដែលបានរើស (កិ.)** *សូមមើលផង* ការហៅ; បានហៅពីព្រះ, សិទ្ធិជ្រើសរើស; សេរី, សេរីភាព, ហៅ

កាលណាព្រះអម្ចាស់ទ្រង់ជ្រើស ឬរើសយកបុគ្គល ឬក្រុមណាមួយ នោះតាមធម្មតា ទ្រង់ក៏ហៅពួកគេឲ្យបំរើដែរ ។

ចូររើសយកព្រះណា ដែលអ្នកចង់គោរពប្រតិបត្តិតាមនៅថ្ងៃនេះចុះ, **យ៉ូស្វេ** ២៤:១៥ (អាលម៉ា ៣០:៨; ម៉ូសេ ៦:៣៣) ។ យើងបានរើសអ្នក ក្នុងឡនៃសេចក្ដីវេទនា, **អេសាយ** ៤៨:១០ (១ នីហ្វៃ ២០:១០) ។ មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ, **យ៉ូហាន** ១៥:១៦ ។ ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកិយនេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាស់វិញ, **១ កូរិន.** ១:២៧ ។ ទ្រង់បានរើសយើងរាល់គ្នា តាំងពីមុនកំណើតលោកិយមក, **អេភេ.** ១:៤ ។ យើងរាល់គ្នា មានសិទ្ធនឹងរើសយក ឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច ឬក៏យកការជាប់ឃុំឃាំង និងសេចក្ដីស្លាប់, **២ នីហ្វៃ** ២:២៧ ។ ពួកឧត្ដុងឧត្ដម និងពួកអ្នកធំ ដែលបានរើសតាំងពីដើមដំបូងមក, **គ. និង ស.** ១៣៨:៥៥–៥៦ ។ ពួកអ៊ីស្រាអែលត្រូវបានរើសដោយព្រះ, **ម៉ូសេ** ១:២៦ ។ លោក អ័ប្រាហាំត្រូវបានរើសតាំងពីមុនលោកចាប់កំណើតមកម្ល៉េះ, **អ័ប្រា.** ៣:២៣ ។

**រេហួល** *សូមមើល* យេត្រូ

**រេហូបោម***សូមមើលផង* សាឡូម៉ូន

ជាបុត្ររបស់ស្ដេចសាឡូម៉ូន នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ទ្រង់បានសោយរាជ្យជំនួសបិតារបស់ទ្រង់អស់រយៈពេល ១៧ ឆ្នាំនៅក្រុង

យេរូសាឡិម (១ ពង្សាវ. ១១:៤៣; ១៤:២១, ៣១) ។ នៅរាជ្យរបស់រេហូបោម នគរត្រូវបែកចែកជានគរអ៊ីស្រាអែល នៅទិសខាងជើង និងជានគរយូដា នៅទិសខាងត្បូង (១ ពង្សាវ. ១១:៣១–៣៦; ១២:១៩–២០) ។ រេហូបោមបានគ្រប់គ្រងលើនគរយូដា ។

**រោងឧបោសថ** *សូមមើលផង* ដំណាក់នៃព្រះអម្ចាស់, បរិសុទ្ធលើអស់ទាំងបរិសុទ្ធ; ព្រះវិហារ, ហឹបនៃសេចក្ដីសញ្ញា

ជាដំណាក់នៃព្រះអម្ចាស់ គឺជាកន្លែងដែលពួកអ៊ីស្រាអែលថ្វាយបង្គំកាលបានចេញមកពីស្រុកអេស៊ីព្ទ ។ តាមពិត រោងឧបោសថ គឺជាព្រះវិហារយកទៅណាបាន ហើយអាចរើជាបំណែក ហើយដំឡើងវិញបាន ។ ពួកកូនចៅអ៊ីស្រាអែល បានប្រើរោងឧបោសថ បែបនេះ រហូតដល់គេសង់ព្រះវិហារសាឡូម៉ូន (គ. និង ស. ១២៤:៣៨) ។

ព្រះទ្រង់បានបើកសម្ដែងប្រាប់គំរូនៃរោងឧបោសថ ដល់លោកម៉ូសេ (និក្ខ. ២៦–២៧) ហើយពួកកូនចៅអ៊ីស្រាអែល បានធ្វើតាមគំរូនោះ (និក្ខ. ៣៥–៤០) ។ កាលគេបានធ្វើរោងឧបោសថរួចស្រេចហើយ នោះមានពពកមកគ្របដណ្ដប់លើត្រសាល ហើយសិរីល្អនៃព្រះអម្ចាស់បានស្ថិតនៅពេញក្នុងរោងឧបោសថ (និក្ខ. ៤០:៣៣–៣៤) ។ ពពកគឺជាទីសំគាល់ថា ព្រះទ្រង់គង់នៅទីនោះ ។ នៅពេល យប់ មានរូបរាងដូចជាភ្លើង ។ កាលណាពពកស្ថិតនៅលើត្រសាល ពួកកូនចៅអ៊ីស្រាអែលក៏បោះជំរុំ ។ កាលណាពពកចេញទៅ ពួកគេក៏ចេញទៅតាម (និក្ខ. ៤០:៣៦–៣៨; ជនគ. ៩:១៧–១៨) ។ ពួកកូនចៅអ៊ីស្រាអែលបានសែងរោងឧបោសថ ទៅជាមួយពួកគេ កាលគេដើរវសាត់ព្រាត់ នៅក្នុងទីរហោស្ថាន ហើយកាលគេច្បាំងយកដែនដីកាណាន ។ បន្ទាប់ពីចំបាំងនោះមក រោងឧបោសថត្រូវបានទុកនៅស្រុកស៊ីឡូរ ជាកន្លែងដែលព្រះអម្ចាស់ទ្រង់បានរើស (យ៉ូស្វេ ១៨:១) ។ ក្រោយពីពួកកូនចៅអ៊ីស្រាអែលបានសង់ព្រះវិហារ សាឡូម៉ូនរួច នោះរោងឧបោសថក៏បាត់បង់អស់ពីប្រវត្តិសាស្ត្រទៅ ។

ព្រះអម្ចាស់ និងអេសាយបានយករោងឧបោសថ មកប្រើជានិមិត្តរូបអំពីទីក្រុងស៊ីយ៉ូនទាំងឡាយ និងជានិមិត្តរូបអំពីក្រុងយេរូសាឡិម កាលព្រះអម្ចាស់ទ្រង់នឹងយាងមកជាលើកទីពីរ (អេសាយ ៣៣:២០; ម៉ូសេ ៧:៦២) ។

**រំពឹងគិត** *សូមមើលផង* ការអធិស្ឋាន; វិវរណៈ

ភាវនាដ៏ជ្រាលជ្រៅ គឺតែងតែគិតអំពីបទគម្ពីរ ឬអំពីការណ៍នានានៃព្រះ ។ នៅពេលផ្ញើរួមនឹងការអធិស្ឋាន នោះការរំពឹងគិត អំពីការណ៍នានានៃព្រះនឹងអាចនាំមកនូវវិវរណៈ និងយោបល់យ៉ាងប្រចក្ស ។

នាងម៉ារាបានរំពឹងគិតរឿងទាំងនោះទុកតែក្នុងចិត្ត, **លូកា** ២:១៩ ។ កាលខ្ញុំអង្គុយរំពឹងគិតនៅក្នុងចិត្តខ្ញុំ នោះខ្ញុំត្រូវនាំទៅ, **១ នីហ្វៃ** ១១:១ ។ ចិត្តខ្ញុំរំពឹងគិតពីបទគម្ពីរ, **២ នីហ្វៃ** ៤:១៥ ។ នីហ្វៃបានដើរទៅ ដោយរំពឹងគិតដល់ការណ៍ទាំងឡាយ ដែលព្រះអម្ចាស់ទ្រង់ បានបង្ហាញដល់លោក, **ហេលេ** ១០:២–៣ ។ ចូរអ្នករាល់គ្នាត្រឡប់ទៅផ្ទះវិញ ហើយរំពឹងគិតអំពីរឿងទាំងឡាយ ដែលយើងបាន និយាយចុះ, **៣ នីហ្វៃ** ១៧:៣ ។ សូមនឹកចាំថាតើព្រះអម្ចាស់ទ្រង់មានសេចក្ដីមេត្តាករុណាយ៉ាងណា ហើយសូម រំពឹងគិតនៅក្នុងចិត្ត អ្នកចុះ, **ម៉ូរ៉ូណៃ** ១០:៣ ។ ចូររំពឹងគិតអំពីរបស់ទាំងឡាយដែលអ្នកបានទទួលចុះ, **គ. និង ស.** ៣០:៣ ។ ក្នុងកាលយើងខ្ញុំកំពុងតែរំពឹង គិតពីសេចក្ដីទាំងនេះ នោះព្រះអម្ចាស់ទ្រង់បានពាល់ភ្នែកនៃយោបល់របស់យើងខ្ញុំ, **គ. និង ស.** ៧៦:១៩ ។ ខ្ញុំបានអង្គុយនៅក្នុងបន្ទប់ខ្ញុំ រំពឹងគិតពីបទគម្ពីរ, **គ. និង ស.** ១៣៨:១–១១ ។ ខ្ញុំតែងតែរំពឹងគិតអំពីរឿងនេះម្ដងហើយ ម្ដងទៀត, **យ.ស. — ប្រវត្តិ** ១:១២ ។

**លាង, បានលាង, ការលាង** *សូមមើលផង* ដង្វាយធួន; ធ្វើបុណ្យជ្រមុជទឹក, ធ្វើឲ្យធួន, បុណ្យជ្រមុជទឹក

សំអាត ខាងសាច់ឈាម ឬខាងវិញ្ញាណ ។ បើនិយាយតាមនិមិត្តរូប ជនណាដែលបានប្រែចិត្ត អាចបានជ្រះស្អាតពីជីវិតដែលផ្ទុកទៅ ដោយអំពើបាប និងកម្មផល តាមរយៈការបូជាដ៏ធួននៃព្រះយេស៊ូវគ្រីស្ទ ។ ការលាងខ្លះ ដែលបានធ្វើនៅក្រោមសិទ្ធិអំណាច នៃបព្វជិតភាពដ៏ត្រឹមត្រូវនោះចាត់ទុកជាពិធីដ៏ពិសិដ្ឋទាំងឡាយ ។

សង្ឃត្រូវបោកសំលៀកបំពាក់ខ្លួន ហើយងូតទឹកចេញ, **ជនគ.** ១៩:៧ ។ សូមលាងទូលបង្គំឲ្យយ៉ាងស្អាតពីអំពើទុច្ចរិតរបស់ទូលបង្គំ, **ទំនុក.** ៥១:២, ៧ ។ ចូរលាងចេញ ចូរជំរះខ្លួនឲ្យស្អាតចុះ ចូរលែងប្រព្រឹត្តអំពើអាក្រក់តទៅ, **អេសាយ** ១:១៦–១៨ ។ ព្រះយេស៊ូវទ្រង់ បានលាងជើងរបស់ពួកសាវកទ្រង់, **យ៉ូហាន** ១៣:៤–១៥ (គ. និង ស. ៨៨:១៣៨–១៣៩) ។ ចូរទទួលបុណ្យជ្រមុជទឹក ហើយលាងបាបអ្នកចេញចុះ, **កិច្ចការ** ២២:១៦ (អាលម៉ា ៧:១៤; គ. និង ស. ៣៩:១០) ។ គ្មានអ្នកណាអាចបានសង្គ្រោះឡើយ លើកលែងតែសំលៀកបំពាក់របស់អ្នកនោះបានបោកឲ្យស, **អាលម៉ា** ៥:២១ (៣ នីហ្វៃ ២៧:១៩) ។ សំលៀកបំពាក់របស់ពួកគេក៏បានបោកឲ្យស តាមរយៈព្រះលោហិតនៃព្រះគ្រីស្ទ, **អាលម៉ា** ១៣:១១ (អេធើរ ១៣:១០) ។ ដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះពួកគេ អាចបានលាងហើយសំអាតឲ្យជ្រះចេញពីអស់ទាំងអំពើបាបរបស់ពួកគេ, **គ. និង ស.** ៧៦:៥២ ។ ការលាបទាំងឡាយរបស់អ្នក និង ការលាងទាំងឡាយរបស់អ្នក នោះត្រូវបានតែងតាំងឡើង ដោយពិធីនៃដំណាក់ដ៏បរិសុទ្ធរបស់យើង, **គ. និង ស.** ១២៤:៣៩–៤១ ។

**លិមហៃ** *សូមមើលផង* ណូអេ, បុត្ររបស់ស៊ីនិព្វ

នៅក្នុងព្រះគម្ពីរមរមន ជាស្ដេចដ៏សុចរិតម្នាក់នៃពួកសាសន៍នីហ្វៃ នៅដែនដីនីហ្វៃ លោកជាបុត្ររបស់ស្ដេចណូអេ (ម៉ូសាយ ៧:៧–៩) ។ ស្ដេចលិមហៃបានចូលក្នុងសេចក្ដីសញ្ញា ដើម្បីបំរើព្រះ(ម៉ូសាយ ២១:៣២) ។ ទ្រង់បាននាំរាស្ត្រទ្រង់ចេញពីសេវកភាព របស់ពួកសាសន៍លេមិន ហើយបានត្រឡប់ទៅដែនដីសារ៉ាហិមឡាវិញ (ម៉ូសាយ ២២) ។

**លីហៃ, មេទ័ពសាសន៍នីហ្វៃ**

នៅក្នុងព្រះគម្ពីរមរមន គឺជាមេទ័ពសាសន៍នីហ្វៃម្នាក់ (អាលម៉ា

៤៣:៣៥–៥៣; ៤៩:១៦–១៧; ៥២:២៧–៣៦; ៥៣:២; ៦១:១៥–២១) ។

**លីហៃ, សាសនទូតសាសន៍នីហ្វៃ** *សូមមើលផង* កូនប្រុសរបស់ហេលេមិន, ហេលេមិន

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសរបស់ហេលេមិន ហើយហេលេមិនជាកូនប្រុសរបស់ហេលេមិន ។ លីហៃជាអ្នកផ្សាយសាសនាដ៏ មហិមាម្នាក់ (ហេលេ. ៣:២១; ៤:១៤) ។

ត្រូវបានដាក់ឈ្មោះលីហៃ ដើម្បីឲ្យនឹកចាំដល់ដូនតារបស់លោក, **ហេលេ.** ៥:៤–៦ ។ លីហៃ និងនីហ្វៃបានធ្វើឲ្យមនុស្សជាច្រើនប្រែចិត្តជឿ, បានជាប់គុក, ត្រូវភ្លើងព័ទ្ធជុំវិញ, ហើយបាននិយាយជាមួយនឹងពួកទេវតា, **ហេលេ.** ៥:១៤–៤៨ ។ បានទទួលវិវរណៈជាច្រើន ជារៀងរាល់ថ្ងៃ, **ហេលេ.** ១១:២៣ ។

**លីហៃ, ឪពុករបស់នីហ្វៃ**

នៅក្នុងព្រះគម្ពីរមរមន គឺជាព្យាការីម្នាក់នៃពួកហេព្រើរ ដែលបាននាំគ្រួសារ និងពួកអ្នកដើរតាមលោកចេញពីក្រុងយេរូសាឡិម ទៅកាន់ដែនដីសន្យា នៅអឌ្ឍគោលខាងលិច ប្រមាណជាឆ្នាំ ៦០០ ម.គ.ស. ។ លីហៃ គឺជាព្យាការីទីមួយ នៅចំណោមរាស្ត្រលោក នៅក្នុងព្រះគម្ពីរមរមន ។

លីហៃបានភៀសខ្លួនចេញពីក្រុងយេរូសាឡិម ជាមួយនឹងគ្រួសារលោកតាមបញ្ជានៃព្រះអម្ចាស់ (១ នីហ្វៃ ២:១–៤) ។ លោកត្រូវជាពូជពង្សពីយ៉ូសែប ដែលត្រូវបានលក់ទៅស្រុកអេស៊ីព្ទ (១ នីហ្វៃ ៥:១៤) ។ ព្រះអម្ចាស់ទ្រង់បានប្រទានការនិមិត្តមួយអំពីដើមជីវិតដល់លោក (១ នីហ្វៃ ៨:២–៣៥) ។ លីហៃ និងកូនៗលោកបានធ្វើសំពៅមួយ ហើយបានបើកក្ដោងទៅកាន់អឌ្ឍគោលខាងលិច (១ នីហ្វៃ ១៧–១៨) ។ លោក និងពូជពង្សលោកបានតាំងទីលំនៅនៅដែនដីថ្មី (១ នីហ្វៃ ១៨:២៣–២៥) ។ មុនលោកស្លាប់ទៅ នោះលីហៃ បានឲ្យពរដល់កូនៗលោក ហើយបានបង្រៀនគេ អំពីព្រះគ្រីស្ទ និងអំពីការចេញមកនៃព្រះគម្ពីរមរមន នៅគ្រាចុងក្រោយ (២ នីហ្វៃ ១–៣, ៤:១–១២) ។

*គម្ពីរលីហៃ៖* យ៉ូសែប ស្ម៊ីធ បានចាប់ផ្ដើមពីគម្ពីរលីហៃ កាលលោកបកប្រែព្រះគម្ពីរមរមន ។ គឺជាបញ្ជីដែលមរមនបានសង្ខេប មកពីផ្ទាំងលីហៃ ។ បន្ទាប់ពីលោកបានបកប្រែគម្ពីរនេះបានឯកសារដល់ទៅ ១១៦ សន្លឹក នោះលោកបានប្រគល់ឯកសារទៅម៉ាទិន ហារិស ដែលជាស្មៀនរបស់យ៉ូសែបមួយរយៈខ្លី ក្នុងការបកប្រែព្រះគម្ពីរមរមន ។ ក្រោយមក សន្លឹកទាំងនោះក៏បាត់ទៅ ។ យ៉ូសែប មិនបានបកប្រែគម្ពីរលីហៃសាឡើងវិញ ដើម្បីជួសឯកសារដែលបាត់នោះទេ ប៉ុន្តែលោកបានបកប្រែដំណើររឿង ដែលទាក់ទងនឹងគ្នា ចេញពីផ្ទាំងមាសទៀត (សូមមើល បុព្វកថា គ. និង ស. ៣, ១០) ។ ឥឡូវនេះដំណើររឿងទាំងនេះផ្សេងៗទៀត គឺជាគម្ពីរលើកទីមួយទាំងគម្ពីរប្រាំមួយក្បាលនៃព្រះគម្ពីរមរមន ។

**លីអាហូណា**

នៅក្នុងព្រះគម្ពីរមរមន គឺជាដុំមូលមួយធ្វើពីលង្ហិន ដែលមានទ្រនិចពីរ ដែលចង្អុលប្រាប់ទិស — ដូចជាត្រីវិស័យ — ហើយក៏ជាការបង្ហាប់ខាងវិញ្ញាណដល់លីហៃ និងពួកអ្នកដែលដើរតាមលោក នៅពេលណាពួកគេសុចរិត ។ ព្រះអម្ចាស់ទ្រង់ប្រទានលីអាហូណាឲ្យ ហើយបានឲ្យបញ្ជាតាមដុំនេះ ។

លីហៃបានដុំមូលមួយធ្វើពីលង្ហិន ដែលមានទ្រនិចពីរដែលចង្អុលប្រាប់ផ្លូវដែលលីហៃ និងគ្រួសារលោកត្រូវទៅ, **១ នីហ្វៃ** ១៦:១០ ។ ដុំមូលដើរតាមសេចក្ដីជំនឿ និងចិត្តឧស្សាហ៍, **១ នីហ្វៃ** ១៦:២៨–២៩ (អាលម៉ា ៣៧:៤០) ។ បេនយ៉ាមីនបានឲ្យដុំមូលទៅម៉ូសាយ, **ម៉ូសាយ** ១:១៦ ។ ដុំមូល ឬវត្ថុដឹកនាំបានហៅថា លីអាហូណា, **អាលម៉ា** ៣៧:៣៨ ។ លីអាហូណា គឺបានប្រៀបធៀបទៅនឹងព្រះ បន្ទូលនៃព្រះគ្រីស្ទ, **អាលម៉ា** ៣៧:៤៣–៤៥ ។ ពួកសាក្សីបីនាក់អំពីព្រះគម្ពីរមរមន បានឃើញវត្ថុដឹកនាំ ដែលបានប្រទានឲ្យលីហៃ, **គ. និង ស.** ១៧:១ ។

**លូកា** *សូមមើលផង* កិច្ចការរបស់ពួកសាវក; ដំណឹងល្អទាំងឡាយ

ជាអ្នកនិពន្ធដំណឹងល្អតាមលោកលូកា និងគម្ពីរកិច្ចការនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយជាអ្នកផ្សាយសាសនា គូកនរបស់ប៉ុល ។ លោកបានកើតមកពីឪពុកម្ដាយសាសន៍ក្រេក ហើយបានធ្វើគ្រូពេទ្យ (កូល៉ុស ៤:១៤) ។ លូកាជាអ្នករៀនចេះដឹងណាស់ ។ លោកបានប្រាប់ ថាខ្លួនជាគូកនរបស់សាវកប៉ុល កាលលោកបានចូលរួមដំណើរនឹងប៉ុល នៅឯទ្រអាស (កិច្ចការ ១៦:១០–១១) ។ លូកាក៏បាននៅជា មួយនឹងប៉ុល នៅឯពីលីព កាលប៉ុលធ្វើដំណើរទៅក្រុងយេរូសាឡិមចុងក្រោយបង្អស់ (កិច្ចការ ២០:៦), ហើយអ្នកទាំងពីរបាននៅជា មួយគ្នា រហូតដល់ទៅដល់ក្រុងរ៉ូម ។ លូកាក៏បាននៅជាមួយនឹងប៉ុល នៅគ្រាប៉ុលត្រូវពួករ៉ូមដាក់គុកលើកទីពីរ (២ ធីម៉ូ. ៤:១១) ។ តាមទំនៀមទំលាប់ពោលថា លោកត្រូវស្លាប់ជាទុក្ករបុគ្គល ។

*ដំណឹងល្អតាមលោកលូកា៖* ជាដំណើររឿងមួយដែលលូកាបានសរសេរអំពីព្រះយេស៊ូវគ្រីស្ទ និងការងារបំរើកាលទ្រង់គង់នៅ លើផែនដី ។ គម្ពីរកិច្ចការរបស់ពួកសាវក គឺជាការបន្តនូវដំណឹងល្អតាមលោកលូកា ។ លូកាបានទុកដំណើររឿងដែលបានសរសេរ យ៉ាងក្បោះក្បាយអំពីការងារបំរើរបស់ព្រះយេស៊ូវ ដោយបង្ហាញថា ព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះនៃពួកសាសន៍យូដា ព្រមទាំងពួក សាសន៍ដទៃផង ។ លោកបានសរសេរជាច្រើន អំពីការបង្រៀនទាំងឡាយរបស់ព្រះយេស៊ូវ និងអំពីព្រឹត្តិការណ៍ទាំងឡាយរបស់ទ្រង់ ។ នៅក្នុងគម្ពីរលូកា យើងបានដឹងពីដំណើររឿងតែមួយអំពីកាព្រីយ៉ែលមកឯសាការី និងនាងម៉ារា (លូកា ១); ពីពួកអ្នកគង្វាលសត្វ ចៀមទៅមើលទារកយេស៊ូវ (លូកា ២:៨–១៨); ពីព្រះយេស៊ូវនៅឯព្រះវិហារបរិសុទ្ធ កាលទ្រង់មានព្រះជន្មាយុ១២ឆ្នាំ (លូកា ២:៤១–៥២); ពីការហៅ និងចាត់ពួក ៧០ នាក់ឲ្យទៅ (លូកា ១០:១–២៤); ពីព្រះយេស៊ូវបែកញើស ទៅជាដំណក់ឈាម (លូកា ២២:៤៤); ពីការ ពិភាក្សាដែលព្រះយេស៊ូវទ្រង់

បានមានព្រះបន្ទូលជាមួយនឹងពួកចោរ ដែលជាប់នៅលើឈើឆ្កាង (លូកា ២៣:៣៩–៤៣); និងពីព្រះ យេស៊ូវទ្រង់សោយត្រី និងទឹកឃ្មុំ បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ (លូកា ២៤:៤២–៤៣) ។
ចំពោះជំពូកសង្ខេប សូមមើល *ដំណឹងល្អទាំងឡាយ*

**លូស៊ីហ្វើរ** *សូមមើលផង* ពួកកូនអន្ទរធាន, មេបំផ្លាញ; ស្ថាននរក; អ្នកទទឹងនឹងព្រះគ្រីស្ទ; អារក្ស

ឈ្មោះនេះមានន័យថា អ្នកដ៏ភ្លឺចែងចាំង ឬអ្នកកាន់ពន្លឺ ។ លូស៊ីហ្វើរក៏គេស្គាល់ថាជាបុត្រានៃពេលព្រឹក ។ លូស៊ីហ្វើរជាបុត្រាវិញ្ញាណ នៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌ម្នាក់ ហើយបាននាំឲ្យមានការបះបោរនៅក្នុងជីវិតមុខផែនដី ។ វិវរណៈជាន់ក្រោយរៀបរាប់យ៉ាង ក្បោះក្បាយអំពីការធ្លាក់របស់លូស៊ីហ្វើរ (គ. និង ស. ៧៦:២៥–២៩) ។

លូស៊ីហ្វើរបានធ្លាក់កាលនៅរស់មុនជីវិតផែនដី, **អេសាយ** ១៤:១២ (លូកា ១០:១៨; ២ នីហ្វៃ ២៤:១២) ។ បន្ទាប់ពីវាបានធ្លាក់មក វាបានកើតទៅជាសាតាំង ហើយជាអារក្ស, **គ. និង ស.** ៧៦:២៥–២៩ (ម៉ូសេ ៤:១–៤) ។

**លួច, ការលួច**

យករបស់អ្វីៗ ពីអ្នកផ្សេង ដោយមិនស្មោះត្រង់ ឬខុសច្បាប់ ។ ព្រះយេស៊ូវទ្រង់បានបង្គាប់ មិនឲ្យកូនចៅទ្រង់លួចឲ្យសោះ (និក្ខ. ២០:១៥; ម៉ាថាយ ១៩:១៨; ២ នីហ្វៃ ២៦:៣២; ម៉ូសាយ ១៣:២២; គ. និង ស. ៥៩:៦) ។

ចូរប្រមូលទ្រព្យសម្បត្តិទុកសំរាប់ខ្លួន នៅឯស្ថានសួគ៌ ជាកន្លែងដែលចោរពុំទំលុះប្លន់យក, **ម៉ាថាយ** ៦:១៩–២១ ។ ការបរាជ័យរបស់ពួកសាសន៍នីហ្វៃកើតឡើង មកពីសេចក្ដីឆ្មើងឆ្មៃ ទ្រព្យសម្បត្តិ ការប្លន់ ការលួច, **ហេលេ.** ៤:១២ ។ អ្នកណាដែលលួចប្លន់ ហើយមិន ប្រែចិត្ត នោះនឹងត្រូវបណ្ដេញចេញ, **គ. និង ស.** ៤២:២០ ។ អស់អ្នកណាដែលលួច នោះនឹងត្រូវបញ្ជូនឡើងទៅរកច្បាប់នៃប្រទេស, **គ. និង ស.** ៤២:៨៤–៨៥ ។

**លេមិន** *សូមមើលផង* ពួកសាសន៍លេមិន; លីហៃ, ឪពុករបស់នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសច្បងបង្អស់របស់លីហៃ និងនាងសារាយ ហើយជាបងច្បងបង្អស់របស់នីហ្វៃ (១ នីហ្វៃ ២:៥) ។ តាមធម្មតា លេមិនបានជ្រើសរើសធ្វើអំពើអាក្រក់ ជាជាងអំពើល្អ ។

លេមិនបានរអ៊ូរទាំទាស់នឹងឪពុកលោក, **១ នីហ្វៃ** ២:១១–១២ ។ បានបះបោរទាស់នឹងនីហ្វៃ ជាប្អូនដ៏សុចរិតរបស់លោក, **១ នីហ្វៃ** ៧:៦ (១ នីហ្វៃ ៣:២៨–២៩) ។ មិនបានទទួលទានផ្លែនៃដើមជីវិត នៅក្នុងការនិមិត្តរបស់លីហៃឡើយ, **១ នីហ្វៃ** ៨:៣៥–៣៦ ។ បណ្ដាសាបានមក លើលេមិន និងពួកអ្នកដែលដើរតាមលោកទាំងប៉ុន្មាន, **២ នីហ្វៃ** ៥:២១ (អាលម៉ា ៣:៧) ។

**លេមយួល** *សូមមើលផង* ពួកសាសន៍លេមិន; លីហៃ, លេមិន; ឪពុករបស់នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសទីពីររបស់លីហៃ ហើយជាបងរបស់នីហ្វៃម្នាក់ ។ លោកចូលរួមនឹងលេមិន ជំទាស់នឹងនីហ្វៃ ។

លីហៃបានទូន្មានឲ្យលេមយួលនៅខ្ជាប់ខ្ជួនដូចជាច្រកភ្នំ, **១ នីហ្វៃ** ២:១០ ។ បានខឹងនឹងនីហ្វៃ ហើយក៏ស្ដាប់តាមលេមិន, **១ នីហ្វៃ** ៣:២៨ ។ ពួកសាសន៍លេមយួលបានចូលរួមក្នុងចំណោមពួកសាសន៍លេមិន, **យ៉ាកុប** ១:១៣–១៤ (អាលម៉ា ៤៧:៣៥) ។

**លេវី** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសទីបីរបស់យ៉ាកុប និងនាងលេអា (លោកុ. ២៩:៣៤; ៣៥:២៣) ។ លេវីក្លាយទៅជាឪពុកនៃពូជអំបូរមួយនៃពួកអ៊ីស្រាអែល ។

*ពូជអំបូររបស់លេវី៖* យ៉ាកុបបានឲ្យពរដល់លេវី និងពូជពង្សរបស់លោក (លោកុ. ៤៩:៥–៧) ។ ពួកពូជពង្សលេវីបានចាត់ចែងការ នៅក្នុងទីបរិសុទ្ធនៃសាសន៍អ៊ីស្រាអែល (ជនគ. ១:៤៧–៥៤) ។ លោកអើរ៉ុនជាសាសន៍លេវី ហើយពូជពង្សលោក គឺពួកសង្ឃ (និក្ខ. ៦:១៦–២០; ២៨:១–៤; ២៩) ។ ពួកលេវីបានជួយពួកសង្ឃ គឺជាពួកកូនប្រុសរបស់អើរ៉ុន (ជនគ. ៣:៥–១០; ១ ពង្សាវ. ៨:៤) ។ ជួនកាលពួកគេធ្វើជាអ្នកចំរៀង (១ របា. ១៥:១៦; នេហេ. ១១:២២); បានសម្លាប់សត្វសំរាប់បូជា (២ របា. ២៩:៣៤; អែសរ៉ា ៦:២០); ហើយតាមធម្មតាគឺជួយនៅក្នុងព្រះវិហារបរិសុទ្ធ (នេហេ. ១១:១៦) ។ ពួកលេវីបានថ្វាយខ្លួនចំពោះកិច្ចការនៃព្រះអម្ចាស់ ដើម្បី អនុវត្តពិធីបរិសុទ្ធជំនួសពួកកូនចៅអ៊ីស្រអែល ។ ពួកលេវីបានថ្វាយខ្លួនជំនួសពួកកូនចៅអ៊ីស្រាអែល (ជនគ. ៨:១១–២២); ទើបពួកគេ បានក្លាយទៅជារបស់ដ៏ពិសេសរបស់ព្រះ ដោយថ្វាយដល់ទ្រង់ជំនួសកូនច្បង (ជនគ. ៨:១៦) ។ ពួកគេពុំបានញែកចេញ ជាបរិសុទ្ធទេ ប៉ុន្តែត្រូវបានសំអាតសំរាប់ការងាររបស់គេ (ជនគ. ៨:៧–១៦) ។ ពួកគេមិនមានដីជាកេរ្ដិ៍មរតក នៅក្នុងស្រុកកាណាន ឡើយ (ជនគ. ១៨:២៣–២៤), ប៉ុន្តែពួកគេបានទទួលដង្វាយ១ភាគ១០ (ជនគ. ១៨:២១), ពីទីក្រុងទាំង ៤៨ (ជនគ. ៣៥:៦), ហើយមានសិទ្ធ នឹងទទួលនូវទានពីបណ្ដាជននៅពេលបុណ្យទាំងឡាយ (ចោទិ. ១២:១៨–១៩; ១៤:២៧–២៩) ។

**លេវីវិន័យ** *សូមមើលផង* គម្ពីរ៥ច្បាប់

ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលប្រាប់អំពីភារកិច្ចរបស់ពួកសង្ឃនៅក្នុងស្រុកអ៊ីស្រាអែល ។ គម្ពីរនេះបញ្ជាក់ប្រាប់អំពី បរិសុទ្ធភាពនៃព្រះ និងក្បួនដើម្បីឲ្យរាស្ត្រទ្រង់អាចរស់នៅដើម្បីឲ្យបានបរិសុទ្ធ ។ គោលបំណងនៃគម្ពីរនេះ គឺដើម្បីបង្រៀននូវសិក្ខាបទ ខាងសីលធម៌ និងសេចក្ដីពិតខាងសាសនានៃក្រិត្យវិន័យលោកម៉ូសេ ដោយពិធីទាំងឡាយ ។ លោកម៉ូសេបានសរសេរគម្ពីរលេវីវិន័យ ។

ជំពូកទី ១–៧ ពន្យល់ប្រាប់អំពីពិធីបរិសុទ្ធទាំងឡាយសំរាប់បូជា ។ ជំពូកទី ៨–១០ អធិប្បាយប្រាប់អំពីពិធីដែលគោរពតាម នៅក្នុងការ

តែងតាំងពួកសង្ឃ ។ ជំពូកទី ១១ ពន្យល់ប្រាប់អំពីអ្វីៗ ដែលអាច ឬមិនអាចបរិភោគ ហើយនិងអ្វីដែលស្អាត ឬមិនស្អាត ។ ជំពូកទី ១២ ពិគ្រោះ អំពីស្ត្រី ក្រោយពីបានសំរាលកូន ។ ជំពូកទី ១៣–១៥ ជាក្រិត្យវិន័យទាក់ទងនឹងពិធីនៃការមិនស្អាត ។ ជំពូកទី ១៦ មាននូវពិធីដែល ត្រូវគោរពតាមនៅថ្ងៃនៃដង្វាយធួន ។ ជំពូកទី ១៧–២៦ មានក្បួននៃច្បាប់ដែលទាក់ទងនឹងការគោរពតាមខាង សាសនា និងខាងសង្គម ។ ជំពូកទី ២៧ ពន្យល់ប្រាប់ថា ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យពួកអ៊ីស្រាអែលថ្វាយដំណាំ ហ្វូងចៀម និងហ្វូង សត្វដល់ព្រះអម្ចាស់ ។

**លោកុប្បត្តិ***សូមមើលផង* គម្ពីរ៥ច្បាប់

តាមពាក្យក្រេក មានន័យថា « កំណើត » ឬក៏ « ដើមដំបូង » ។ គម្ពីរលោកុប្បត្តិ គឺជាគម្ពីរទីមួយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយបានសរសេរដោយព្យាការីម៉ូសេ ។ គម្ពីរនេះប្រាប់នូវដំណើររឿងពីដើមដំបូងជាច្រើន ដូចជាការបង្កបង្កើតផែនដី, ការដាក់សត្វ និងមនុស្សឲ្យនៅលើផែនដី, ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា, វិវរណៈអំពីដំណឹងល្អចំពោះលោកអ័ដាម, ដើមកំណើតនៃពូជអំបូរ និងជាតិទាំងឡាយ, កំណើតភាសាទាំងឡាយនៅក្រុងបាបិល, និងដើមកំណើតនៃគ្រួសារលោកអ័ប្រាហាំ រហូតដល់ទៅការតាំងនៃវង្សអ៊ីស្រាអែល ។ តំណែងយ៉ូសែបជាអ្នកជួយជីវិតដល់ពួកអ៊ីស្រាអែលក៏បានបញ្ជាក់ឲ្យដឹងនៅក្នុងគម្ពីរលោកុប្បត្តិ ។

វិវរណៈនៅថ្ងៃចុងក្រោយបញ្ជាក់ ហើយបំភ្លឺពីដំណើររឿងក្នុងគម្ពីរលោកុប្បត្តិ (១ នីហ្វៃ ៥; អេធើរ ១; ម៉ូសេ ១–៨; អ័ប្រា. ១–៥) ។

នៅក្នុងគម្ពីរលោកុប្បត្តិ ជំពូកទី ១–៤ រៀបរាប់ពីការបង្កបង្កើតពិភពលោក និងការបង្កបង្កើនគ្រួសារលោកអ័ដាម ។ ជំពូកទី ៥–១០ កត់ពីប្រវត្តិលោកណូអេ ។ ជំពូកទី ១១–២០ ប្រាប់ពីអ័ប្រាហាំ និងគ្រួសារលោក រហូតដល់សម័យអ៊ីសាក ។ ជំពូកទី ២១–៣៥ រៀបរាប់ពីគ្រួសារអ៊ីសាក ។ ជំពូកទី ៣៦ ប្រាប់ពីអេសាវ និងគ្រួសារលោក ។ ជំពូកទី ៣៧–៥០ ប្រាប់ពីគ្រួសារយ៉ាកុប និងដំណើររឿងលក់យ៉ូសែបទៅស្រុកអេស៊ីព្ទ ហើយនិងតំណែងលោក ក្នុងការជួយសង្គ្រោះវង្សអ៊ីស្រាអែល ។

**លោភ** *សូមមើលផង* ច្រណែន

ដូចដែលប្រើក្នុងគម្ពីរ លោភ គឺច្រណែនអ្នកណាម្នាក់ ឬប្រាថ្នាចង់បានអ្វីមួយយ៉ាងខ្លាំង ។

កុំឲ្យលោភចង់បានអ្វីឲ្យសោះ, **និក្ខ**. ២០:១៧ (ចោទិ. ៥:២១; ម៉ូសាយ ១៣:២៤; គ. និង ស. ១៩:២៥) ។ អ្នកណាដែលស្អប់សេចក្តី លោភ នោះនឹងបានចំរើនអាយុយឺនយូរវិញ, **សុភា**. ២៨:១៦ ។ គេលោភចង់បានស្រែចំការ ក៏ដណ្តើមយកបាន, **មិកា** ២:២ ។ ចូរប្រយ័ត្ន ហើយខំចៀសពីសេចក្តីលោភចេញ, **លូកា** ១២:១៥ ។ ក្រិត្យវិន័យបានថា « កុំឲ្យលោភឲ្យសោះ » **រ៉ូម** ៧:៧ ។ នៅជាន់ ក្រោយបង្អស់ មនុស្សនឹងទៅជាមនុស្សលោភ, ២ ធីម៉ូ. ៣:១–២ ។ នៅពេលឡាបាន ដែលបានឃើញទ្រព្យរបស់យើង ទើបលោកកើត ក្តីលោភលន់ចង់បាន, **១ នីហ្វៃ** ៣:២៥ ។ ចូរកុំលោភទ្រព្យសម្បត្តិរបស់ខ្លួនឡើយ, **គ. និង ស.** ១៩:២៦ ។ ចូរឈប់មានចិត្តលោភ, **គ. និង ស.** ៨៨:១២៣ ។ ចូរកុំលោភចង់បានអ្វីដែលជារបស់ផងបងប្អូនអ្នកឡើយ, **គ. និង ស.** ១៣៦:២០ ។

**លោហិត** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, បូជា, ព្រះយេស៊ូវគ្រីស្ទ

ត្រូវបានចាត់ទុកដោយពួកសាសន៍អ៊ីស្រាអែលពីបុរាណ និងវប្បធម៌សព្វថ្ងៃជាច្រើនថា ជាគោលជីវិត ឬជាថាមពលដ៏សំខាន់នៃសាច់ ឈាមទាំងអស់ ។ នៅសម័យព្រះគម្ពីរសញ្ញាចាស់ ព្រះអម្ចាស់ទ្រង់បានហាមពួកអ៊ីស្រាអែលមិនឲ្យបរិភោគឈាមជាអាហារឡើយ (លេវី. ៣:១៧; ៧:២៦–២៧; ១៧:១០–១៤) ។

អំណាចដ៏ធួននៃយញ្ញបូជា គឺនៅក្នុងឈាម ពីព្រោះឈាមត្រូវបានចាត់ទុកថា ជារបស់សំខាន់ដល់ជីវិត ។ ការបូជាសត្វនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជានិមិត្តរូបអំពីការបូជាដ៏ធំ ដែលបានធ្វើដោយព្រះយេស៊ូវគ្រីស្ទក្រោយមក (លេវី. ១៧:១១; ម៉ូសេ ៥:៥–៧) ។ ព្រះលោហិតដ៏ធួននៃព្រះយេស៊ូវគ្រីស្ទសំអាតពួកអ្នកដែលប្រែចិត្តពីអំពើបាប (១ យ៉ូហាន ១:៧) ។

ញើសទ្រង់ក៏ត្រឡប់ដូចជាតំណក់ឈាមដ៏ធំៗ, **លូកា** ២២:៤៥ ។ យើងរាល់គ្នាបានញែកជាបរិសុទ្ធ ដោយសារការច្រួចព្រះលោហិត នៃព្រះយេស៊ូវគ្រីស្ទ, **ហេព្រើរ** ១០:១–២២ ។ ព្រះលោហិតចេញមកពីគ្រប់រន្ធញើស, **ម៉ូសាយ** ៣:៧ (គ. និង ស. ១៩:១៨) ។ ព្រះលោហិតរបស់ព្រះអម្ចាស់ ត្រូវបានច្រួចដើម្បីការផ្តាច់បាបទាំងឡាយ, **គ. និង ស.** ២៧:២ ។ ព្រះយេស៊ូវបាននាំមកនូវដង្វាយធួនដ៏ល្អ ឥតខ្ចោះ តាមរយៈការច្រួចព្រះលោហិតរបស់ព្រះអង្គ, **គ. និង ស.** ៧៦:៦៩ ។ ដោយសារព្រះលោហិត នោះអ្នករាល់គ្នាត្រូវបានញែក ចេញជាបរិសុទ្ធ, **ម៉ូសេ** ៦:៦០ ។

**លំដាប់នៃសិរីល្អ***សូមមើលផង* សិរីល្អនៃទេវស្ថាន, សិរីល្អនៃទេឡេស្ទាល; សិរីល្អនៃសេឡេស្ទាល

ជានគរទាំងឡាយនៅស្ថានសួគ៌ ។ នៅគ្រាសេចក្តីជំនុំជំរះចុងក្រោយបង្អស់ មនុស្សគ្រប់រូបនឹងត្រូវចាត់ឲ្យទៅទីលំនៅមួយដ៏នៅអស់កល្បជានិច្ច ក្នុងនគរនៃសិរីល្អណាមួយ លើកលែងតែអស់អ្នកណាដែលជាពួកកូនអន្តរធាន ។

ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា៖ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានវិមានជាច្រើន, **យ៉ូហាន** ១៤:២ (អេធើរ ១២:៣២) ។ ព្រះអាទិត្យនោះមានរស្មីម្យ៉ាងទៅ ព្រះច័ន្ទក៏មានរស្មីម្យ៉ាងទៅ ហើយផ្កាយក៏មានរស្មីម្យ៉ាងទៅ, **១ កូរិន**. ១៥:៤០–៤១ ។ ប៉ុលបាន ត្រូវលើកឡើងទៅស្ថានសួគ៌នៅជាន់ទីបី, **២ កូរិន**. ១២:២ ។ មានកន្លែងមួយដែលគ្មានសិរីល្អ ហើយមានការដាក់ទោសដ៏អស់កល្ប អស់កាលជានិច្ច, **គ. និង ស.** ៧៦:៣០–៣៨, ៤៣–៤៥ ។ មានលំដាប់សិរីល្អបីយ៉ាង, **គ. និង ស.** ៧៦:៥០–១១៣; ៨៨:២០–៣២ ។

**លំដាប់ពេល**

លំដាប់ពេលតទៅ ឬបញ្ជីព្រឹត្តិការណ៍ មិនមែនជាបញ្ជីទូលំទូលាយ ហើយគ្រាន់តែសំរាប់ឲ្យអ្នកអានយល់ពីលំដាប់នៃព្រឹត្តិការណ៍ទាំង ឡាយ នៅសម័យព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមនប៉ុណ្ណោះ៖

*ព្រឹត្តិការណ៍ទាំងឡាយនៅសម័យពួកអយ្យកោបុរាណ៖*(ដោយមានការពិបាកក្នុងការកំណត់ថ្ងៃដ៏ពិតប្រាកដនៃព្រឹត្តិការណ៍ទាំងឡាយ នៅក្នុងភាគនេះ ម្ល៉ោះហើយថ្ងៃខែមិនបានប្រាប់ឡើយ) ។

ម.គ.ស. (ឬ ម.យ.ទ. — មុនយុគទូទៅ)

៤០០០ អ័ដាមធ្លាក់ ។

ហេណុកធ្វើការងារបំរើ ។

ណូអេធ្វើការងារបំរើ; ទឹកជន់លិចផែនដី ។

ប៉មនៃក្រុងបាបិលបានសង់ឡើង; ពួកសាសន៍យ៉ារេឌបានធ្វើដំណើរទៅកាន់ដែនដីសន្យា ។

មិលគីស្សាដែកធ្វើការងារបំរើ ។

ណូអេស្លាប់ ។

អាប៊្រាម (អ័ប្រាហាំ) កើត ។

អ៊ីសាកកើត ។

យ៉ាកុបកើត ។

យ៉ូសែបកើត ។

យ៉ូសែបត្រូវបានលក់ទៅស្រុកអេស៊ីព្ទ ។

យ៉ូសែបទៅគាល់ផារ៉ោន ។

យ៉ាកុប (អ៊ីស្រាអែល) និងគ្រួសារលោកបានចុះទៅស្រុកអេស៊ីព្ទ ។

យ៉ាកុប (អ៊ីស្រាអែល) ស្លាប់ ។

យ៉ូសែបស្លាប់ ។

ម៉ូសេកើត ។

ម៉ូសេនាំកូនចៅអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ (និក្ខមនំ) ។

ម៉ូសេប្រែរូប ។

យ៉ូស្វេស្លាប់ ។

ក្រោយពីយ៉ូស្វេស្លាប់ទៅ នោះសម័យពួកចៅហ្វាយបានចាប់ផ្ដើមឡើង អុធ្នាលត្រូវជាចៅហ្វាយទី ១ ហើយសាំយូអែល ជាចៅហ្វាយចុងក្រោយបង្អស់; លំដាប់ និងថ្ងៃខែនៃព្រឹត្តិការណ៍តទៅនោះមិនទៀងទាត់ទេ ។

សូលត្រូវបានចាក់ប្រេងតាំងឲ្យធ្វើជាស្ដេច ។

---

*ព្រឹត្តិការណ៍ទាំងឡាយនៃសហនគរអ៊ីស្រាអែល៖*

១០៩៥ រាជ្យសូលចាប់ផ្ដើម ។

១០៦៣ ដាវីឌត្រូវបានចាក់ប្រេងតាំងឲ្យធ្វើជាស្ដេចដោយសាំយូអែល ។

១០៥៥ ដាវីឌធ្វើស្ដេចនៅក្រុងហេប្រុន ។

១០៤៧ ដាវីឌធ្វើស្ដេចនៅក្រុងយេរូសាឡិម; ណាថាន់ និងកាឌ់បានព្យាករ ។

១០១៥ សាឡូម៉ូនកើតជាស្ដេចលើអ៊ីស្រាអែលទាំងមូល ។

៩៩១ ធ្វើវិហាររួច ។

៩៧៥ សាឡូម៉ូនសុគត; ពូជ ១០ អំបូរនៅខាងជើង បានបះបោរទាស់នឹងរេហូបោម ជាបុត្រទ្រង់ ហើយអ៊ីស្រាអែលក៏បែក ។

*ព្រឹត្តិការណ៍ទាំងឡាយនៃអ៊ីស្រាអែល៖*

៩៧៥ យេរ៉ូបោមជាស្តេចអ៊ីស្រាអែល ។
៨៧៥ អ័ហាប់គ្រងរាជ្យពីក្រុងសាម៉ារី លើស្រុកអ៊ីស្រាអែលខាងជើង; អេលីយ៉ាបានព្យាករ ។
៨៥១ អេលីសេបានសម្តែងអព្ភូតហេតុដ៏ធំ ។
៧៩២ អេម៉ុសបានព្យាករ ។
៧៩០ យ៉ូណាស និងហូសេបានព្យាករ ។
៧២១ នគរខាងជើងត្រូវបំផ្លាញចោល; ពូជ ១០ អំបូរត្រូវបានចាប់យកជាឈ្លើយ; មីកាបានព្យាករ ។

*ព្រឹត្តិការណ៍ទាំងឡាយនៃយូដា៖*

៩៤៩ ស៊ីសាក ជាស្តេចស្រុកអេស៊ីព្ទ, បានប្លន់ក្រុងយេរូសាឡិម ។
៧៤០ អេសាយចាប់ផ្តើមព្យាករ ។ (រ៉ូមត្រូវបានកសាងឡើង; ណាបូណាសារ ជាស្តេចក្រុងបាប៊ីឡូន នៅឆ្នាំ ៧៤៧; ទិគ្លាត-ពីលេសើរទី ៣ ជាស្តេចស្រុកអាសស៊ើរ ពីឆ្នាំ ៧៤៧ ទៅ ៧៣៤) ។
៧២៨ ហេសេគា ជាស្តេចស្រុកយូដា ។ (សាលម៉ានេសើរទី ៤ ជាស្តេចអាសស៊ើរ) ។
៦៤២ ណាហ៊ុមបានព្យាករ ។
៦២៨ យេរេមា និងសេផានាបានព្យាករ ។
៦០៩ អូបាឌាបានព្យាករ; ដានីយ៉ែលត្រូវគេចាប់យកជាឈ្លើយទៅក្រុងបាប៊ីឡូន ។ (ក្រុងនីនីវេបានរលំនៅឆ្នាំ ៦០៦; នេប៊ូក្នេសា ជាស្តេចក្រុងបាប៊ីឡូន ពីឆ្នាំ ៦០៤ ទៅ ៥៦១) ។
៥៩៨ អេសេគាលបានព្យាករនៅក្រុងបាប៊ីឡូន; ហាបាគុកបានព្យាករ; សេដេគា ជាស្តេចយូដា ។
៥៨៧ នេប៊ូក្នេសាចាប់យកក្រុងយេរូសាឡិម ។

*ព្រឹត្តិការណ៍ទាំងឡាយក្នុងព្រះគម្ពីរមរមន៖*

៦០០ លីហៃចេញពីក្រុងយេរូសាឡិម ។
៥៨៨ មូលេកចេញពីក្រុងយេរូសាឡិម ឆ្ពោះទៅកាន់ដែនដីសន្យា ។
៥៨៨ ពួកសាសន៍នីហ្វៃបែកចេញពីពួកសាសន៍លេមិន (រវាងឆ្នាំ ៥៨៨ និង ៥៧០ ម.គ.ស.) ។

---

*ព្រឹត្តិការណ៍ទាំងឡាយក្នុងប្រវត្តិនៃពួកសាសន៍យូដា៖*

៥៣៧ ស៊ីរូសចេញក្រឹត្យថាសាសន៍យូដាអាចត្រឡប់ទៅក្រុងយេរូសាឡិម ពីក្រុងបាប៊ីឡូនវិញ ។
៥២០ ហាកាយ និងសាការីបានព្យាករ ។
៤៨៦ នាងអេសធើររស់នៅ ។
៤៥៨ អែសរ៉ាបានត្រូវបញ្ជាឲ្យរៀបចំសារឡើងវិញ ។
៤៤៤ នេហេមាត្រូវគេតាំងឲ្យធ្វើជាអ្នកអភិបាលលើស្រុកយូដា ។
៤៣២ ម៉ាឡាគីបានព្យាករ ។

*ព្រឹត្តិការណ៍ទាំងឡាយក្នុងព្រះគម្ពីរមរមន៖*

៤០០ យ៉ារ៉ុមទទួលផ្ទាំង ។
៣៦០ អោមណៃទទួលផ្ទាំង ។

*ព្រឹត្តការណ៍ទាំងឡាយក្នុងប្រវត្តិនៃពួកសាសន៍យូដា៖*

៣៣២ អ័លេក្សានត្រុសដ៏ឧត្តម ច្បាំងយកស្រុកស៊ីរី និងស្រុកអេស៊ីព្ទ ។
៣២៣ អ័លេក្សានត្រុសសុគត ។
២៧៧ សេពទូអាជិន្ត ជាការបកប្រែគម្ពីរយូដាទៅភាសាក្រេក បានចាប់ផ្ដើម ។
១៦៧ ម៉ាតាធាស ជាពួកម៉ាកាប៊ី បានបះបោរទាស់នឹងស្រុកស៊ីរី ។
១៦៦ យូដាស ម៉ាកាបេស បានក្លាយជាមេដឹកនាំពួកសាសន៍យូដា ។
១៦៥ វិហារបានត្រូវសំអាត ហើយបានធ្វើបុណ្យឆ្លងម្ដងទៀត; បុណ្យហានុកាបានចាប់ផ្ដើម ។
១៦១ យូដាស ម៉ាកាបេសស្លាប់ ។ ៦៣ប៉មពេច្បាំងដណ្ដើមយកក្រុងយេរូសាឡិម ហើយការត្រួតត្រានៃពួកម៉ាកាប៊ី បានចប់នៅស្រុកអ៊ីស្រាអែល ។

៥១ ព្រះនាងក្លេអូប៉ាត្រាសោយរាជ្យ ។
៤១ ហេរ៉ូឌ និងផាសែល ត្រូវបានលើកឲ្យធ្វើជាស្ដេចអនុរាជលើស្រុកយូដា ។
៣៧ ហេរ៉ូឌកើតជាមេដឹកនាំនៅក្រុងយេរូសាឡិម ។
៣១ ចម្បាំងអាកទិមបានច្បាំង; អូគូស្ទជារាជាធិរាជនៃរ៉ូម ពីឆ្នាំ ៣១ ម.គ.ស.ទៅ គ.ស. ១៤ ។
៣០ ព្រះនាងក្លេអូប៉ាត្រាសុគត ។
១៧ ហេរ៉ូឌសាងព្រះវិហារឡើងវិញ ។

*ព្រឹត្តិការណ៍ទាំងឡាយក្នុងព្រះគម្ពីរមរមន៖*

១៤៨ អ័ប៊ីណាឌៃត្រូវគេធ្វើទុក្ករកម្ម; អាលម៉ាបានតាំងសាសនាចក្រឡើងនៅចំណោមពួកសាសន៍នីហ្វៃឡើងវិញ ។
១២៤ បេនយ៉ាមីនបានថ្លែងលើកក្រោយបង្អស់ទៅកាន់ពួកសាសន៍នីហ្វៃ ។
១០០ អាលម៉ា ជាកូន និងបុត្រារបស់ស្ដេចម៉ូសាយ បានចាប់ផ្ដើមកិច្ចការរបស់គេ ។
៩១ រជ្ជកាលនៃពួកចៅក្រមបានចាប់ផ្ដើមនៅចំណោមពួកសាសន៍នីហ្វៃ ។

៥ សាំយូអែល ជាសាសន៍លេមិន បានព្យាករអំពីកំណើតព្រះគ្រីស្ទ ។

---

*ព្រឹត្តិការណ៍ទាំងឡាយក្នុងប្រវត្តិនៃពួកគ្រីស្ទាន៖*

គ.ស. (ឬ យ.ទ.– យុគទូទៅ)
កំណើតនៃព្រះយេស៊ូវគ្រីស្ទ ។
៣០ ការងារបំរើរបស់ព្រះគ្រីស្ទចាប់ផ្ដើម ។
៣៣ ព្រះគ្រីស្ទត្រូវគេឆ្កាង ។

៣៥ ប៉ុលប្រែចិត្តជឿ ។
៤៥ ប៉ុលធ្វើដំណើរទៅផ្សាយមុនដំបូង ។
៥៨ ប៉ុលត្រូវគេបញ្ជូនទៅរ៉ូម ។
៦១ ប្រវត្តិអំពីកិច្ចការនៃពួកសាវកចប់ ។

*ព្រឹត្តិការណ៍ទាំងឡាយក្នុងព្រះគម្ពីរមរមន៖*

គ.ស. ឬ យ.ទ.

៣៣ ឬ
៣៤ ព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញបានបង្ហាញអង្គទ្រង់នៅទ្វីបអាមេរិក ។

*ព្រឹត្តិការណ៍ទាំងឡាយក្នុងប្រវត្តិនៃពួកគ្រីស្ទាន៖*

៦២ រ៉ូមត្រូវឆេះ; ពួកគ្រីស្ទានត្រូវគេបៀតបៀន នៅក្រោមនេរ៉ូ ។

៧០ ពួកគ្រីស្ទានទៅពួននៅឯពេឡា; ក្រុងយេរូសាឡិមត្រូវគេព័ទ្ធ ហើយចាប់យក ។

៩៥ ពួកគ្រីស្ទានត្រូវពួកដូមីតបៀតបៀន ។

*ព្រឹត្តិការណ៍ទាំងឡាយក្នុងព្រះគម្ពីរមរមន៖*

៣៨៥ សាសន៍នីហ្វៃបានត្រូវបំផ្លាញចោល ។

៤២១ មរ៉ូណៃបានលាក់ផ្ទាំងទុក ។

**ល្បួង, សេចក្ដីល្បួង** *សូមមើលផង* កាន់ខ្ជាប់, សិទ្ធិជ្រើសរើស; អារក្ស

ការសាកល្បួងមើលពីសម្ថភាពរបស់មនុស្ស ចំពោះការជ្រើសរើសយក អំពើល្អ ជាជាងយកអំពើអាក្រក់; ជាការល្បួងលោមឲ្យធ្វើអំពើបាប ហើយដើរតាម សាតាំង ជាជាងព្រះ ។

សូមកុំនាំយើងខ្ញុំទៅក្នុងសេចក្ដីល្បួងឡើយ តែសូមប្រោសឲ្យយើងខ្ញុំ រួចពីសេចក្ដីអាក្រក់វិញ, **ម៉ាថាយ** ៦:១៣ (៣ នីហ្វៃ ១៣:១២) ។ ព្រះទ្រង់មិនឲ្យកើតមានសេចក្ដីល្បួង ហួសកម្លាំងអ្នករាល់គ្នាឡើយ, **១ កូរិន.** ១០:១៣ ។ ព្រះគ្រីស្ទបានត្រូវសេចក្ដីល្បួង ដូចជាយើង រាល់គ្នាដែរ, **ហេព្រើរ** ៤:១៤–១៥ ។ មានពរហើយ មនុស្សណាដែល ស៊ូទ្រាំនឹងសេចក្ដីល្បួង, **យ៉ាកុប** (ព.ស.ថ.) ១:១២–១៤ ។ សេចក្ដីល្បួងទាំងឡាយរបស់មារសត្រូវ ពុំអាចឈ្នះលើអស់អ្នកណា ដែលស្ដាប់តាមព្រះបន្ទូលនៃព្រះបានឡើយ, **១ នីហ្វៃ** ១៥:២៤ (ហេលេ. ៥:១២) ។ មនុស្សពុំអាចប្រព្រឹត្តអ្វីដោយខ្លួនឯងទេ លើកលែងតែមានអ្វី មកល្បួងខាងនេះមួយ ឬខាងនោះមួយ, **២ នីហ្វៃ** ២:១១–១៦ ។ ចូរចាំយាម ហើយអធិស្ឋានជានិច្ច ដើម្បីកុំឲ្យអ្នកត្រូវល្បួងហួសកម្លាំងដែល អ្នកអាចទ្រាំបាន, **អាលម៉ា** ១៣:២៨ ។ ចូរបង្រៀនពួកគេឲ្យទប់ទល់នឹង គ្រប់ការល្បួងនៃអារក្ស ដោយសេចក្ដីជំនឿរបស់គេ ជឿដល់ព្រះ អម្ចាស់យេស៊ូវគ្រីស្ទ, **អាលម៉ា** ៣៧:៣៣ ។ ចូរអធិស្ឋានជានិច្ច ខ្លាច ក្រែងអ្នកធ្លាក់ទៅក្នុងសេចក្ដីល្បួង, **៣ នីហ្វៃ** ១៨:១៥, ១៨ (គ. និង ស. ២០:៣៣; ៣១:១២; ៦១:៣៩) ។ ចូរប្រយ័ត្នអំពីសេចក្ដីឆ្មើងឆ្មៃ ខ្លាចក្រែងអ្នកធ្លាក់ទៅក្នុងសេចក្ដីល្បួង, **គ. និង ស.** ២៣:១ ។ លោកអ័ដាមបានក្លាយទៅជា នៅក្រោមបំណងនៃអារក្ស ពីព្រោះលោកបាន បណ្ដោយទៅតាមសេចក្ដីល្បួង, **គ. និង ស.** ២៩:៣៩–៤០ ។ ខ្ញុំត្រូវបានទុកឲ្យប្រទះការ ល្បួងគ្រប់បែបយ៉ាង, **យ.ស. — ប្រវត្តិ** ១:២៨ ។

**ល្អឥតខ្ចោះ**

ដែលបានទៅជាគ្រប់ ពេញ និងពេញលេញ; សុចរិតទាំងស្រុង ។ ល្អឥតខ្ចោះក៏អាចមានន័យថា គ្មានបាប ឬអំពើអាក្រក់សោះឡើយ ។ មានតែព្រះគ្រីស្ទមួយអង្គគត់ ដែលបានល្អឥតខ្ចោះទាំងស្រុង ។ ពួកអ្នក ដើរតាមដ៏ពិតរបស់ព្រះគ្រីស្ទ អាចក្លាយទៅជាល្អឥតខ្ចោះបាន តាមរយៈ ព្រះគុណ និងដង្វាយធួនរបស់ទ្រង់ ។

សូមឲ្យចិត្តឯងរាល់គ្នាបានគ្រប់លក្ខណ៍ចំពោះព្រះអម្ចាស់, **១ ពង្សាវ.** ៨:៦១ ។ ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ដូចជាព្រះ វរបិតា នៃអ្នក ដែលគង់នៅស្ថានសួគ៌, **ម៉ាថាយ** ៥:៤៨ (៣ នីហ្វៃ ១២:៤៨) ។ បើអ្នកណាមិនបានជំពប់ដោយពាក្យសំដី នោះជា មនុស្សគ្រប់លក្ខណ៍ ហើយ, **យ៉ាកុប** (ព.ស.ថ.) ៣:២ ។ សេចក្ដីជំនឿ គឺពុំមែនជាការចេះ ដឹងដ៏ឥតខ្ចោះ នូវអ្វីទាំងឡាយនោះឡើយ, **អាលម៉ា** ៣២:២១, ២៦ ។ ដង្វាយធួនត្រូវបានធ្វើឡើង ដើម្បីឲ្យព្រះទ្រង់បានទៅជាល្អឥតខ្ចោះ, **អាលម៉ា** ៤២:១៥ ។ មរ៉ូណៃ គឺជាបុរសម្នាក់ដែលប្រកបដោយ យោបល់ដ៏ឥតខ្ចោះ, **អាលម៉ា** ៤៨:១១–១៣, ១៧–១៨ ។ ព្រះវិញ្ញាណ នៃព្រះគ្រីស្ទ នោះត្រូវបាន ប្រទានដល់មនុស្សគ្រប់រូប ដើម្បីឲ្យវិនិច្ឆ័យ ដោយដឹងដោយការចេះដឹងដ៏ឥតខ្ចោះ ថាអ្វីមួយមកពីព្រះ ឬមក ពីអារក្ស, **មរ៉ូណៃ** ៧:១៥–១៧ ។ សូមមកឯព្រះគ្រីស្ទ ហើយឲ្យ បានល្អឥតខ្ចោះនៅក្នុងទ្រង់ចុះ, **មរ៉ូណៃ** ១០:៣២ ។ ចូរស៊ូនៅក្នុងសេចក្ដីអត់ធន់ចុះ រហូតដល់អ្នករាល់គ្នាបានល្អឥតខ្ចោះ, **គ. និង ស.** ៦៧:១៣ ។ ពួកគេនេះហើយ ជាមនុស្សសុចរិតដែលបានធ្វើឲ្យល្អឥតខ្ចោះ តាមរយៈ ព្រះយេស៊ូវ, **គ. និង ស.** ៧៦:៦៩ ។ តំណែងទាំងឡាយក្នុងសាសនាចក្រ គឺសំរាប់ការធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះ, **គ. និង ស.** ១២៤:១៤៣ (អេភេ. ៤:១១–១៣) ។ ពួកមនុស្សនៅរស់ពុំអាច បានល្អឥតខ្ចោះ ដោយគ្មានមនុស្សស្លាប់របស់គេឡើយ, **គ. និង ស.** ១២៨:១៥, ១៨ ។ ណូអេជាមនុស្សសុចរិត ហើយល្អឥតខ្ចោះម្នាក់ នៅក្នុងតំណវង្សគាត់; **ម៉ូសេ** ៨:២៧ ។

**វង្សអ៊ីស្រាអែល** *សូមមើល* អ៊ីស្រាអែល

**វាយផ្ចាល, ការវាយផ្ចាល** *សូមមើលផង* សេចក្ដីទំនាស់

ជាការតម្រង់ ឬការប្រៀនប្រដៅដោយឡែក ឬជាក្រុម ដើម្បីជួយពួក គេឲ្យបានល្អឡើង ឬឲ្យត្រឡប់ទៅជាខ្លាំងពូកែឡើង ។

កុំមើលងាយសេចក្ដីវាយផ្ចាលរបស់ព្រះ ដ៏មានព្រះចេស្ដាបំផុតឡើយ, **យ៉ូប ៥:១៧** (សុភា. ៣:១១) ។ ឱព្រះអម្ចាស់អើយ មានពរ ហើយ មនុស្សណាដែលទ្រង់វាយផ្ចាល, **ទំនុក.** ៩៤:១២ ។ គ្រប់ទាំងបទគម្ពីរ បានប្រគល់ឲ្យមានការរំឭកឲ្យដឹងខ្លួន ឲ្យមានការប្រដៅ តម្រង់, **២ ធីម៉ូ** ៣:១៦ ។ ព្រះអម្ចាស់ទ្រង់វាយផ្ចាលដល់អ្នកណាដែលទ្រង់ស្រឡាញ់, **ហេព្រើរ** ១២:៥–១១ ។ ព្រះអម្ចាស់ទ្រង់យល់ ឃើញថាសមនឹង ប្រដៅរាស្ត្រទ្រង់, **ម៉ូសាយ** ២៣:២១–២២ ។ លើកលែងតែព្រះ

អម្ចាស់ ទ្រង់វាយផ្ចាលរាស្ត្រទ្រង់ នោះពួកគេនឹងមិន នឹកឃើញទ្រង់ឡើយ, **ហេលេ.** ១២:៣ ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលនឹងបងប្រុសរបស់យ៉ារេឌ ហើយបានវាយផ្ចាលបន្ទោស លោក, **អេធើរ** ២:១៤ ។ ពួកគេអាចបានទទួលការវាយផ្ចាល ដើម្បីឲ្យពួកគេអាចបានប្រែចិត្ត, **គ. និង ស.** ១:២៧ ។ អ្នកណាដែល យើងស្រឡាញ់ នោះយើងវាយផ្ចាល ដើម្បីឲ្យអំពើបាបទាំងឡាយរបស់ពួកគេ អាចបានអត់ទោស, **គ. និង ស.** ៩៥:១ ។ អស់អ្នកណា ដែលមិនព្រមទ្រាំទ្រក្នុងសេចក្តីវាយផ្ចាល នោះមិនអាចញែកចេញជាបរិសុទ្ធបានឡើយ, **គ. និង ស.** ១០១:២–៥ ។ រាស្ត្រយើងត្រូវ តែបានវាយផ្ចាល រហូតដល់ពួកគេចេះគោរពតាម, **គ. និង ស.** ១០៥:៦ ។ អ្នកណាដែលមិនទ្រាំការវាយផ្ចាល នោះមិនសំណំនឹងនគរ របស់យើងឡើយ, **គ. និង ស.** ១៣៦:៣១ ។

**វិញ្ញាណ** *សូមមើលផង* ដំណើររស់ឡើងវិញ; ព្រលឹង, មនុស្ស, មនុស្សលោក; សេចក្តីស្លាប់ខាងវិញ្ញាណសាច់ឈាម

ជាផ្នែកនៃរូបដែលមានជីវិតរស់នៅ តាំងពីមុនកំណើតមក ដែលអាស្រ័យនៅក្នុងរូបកាយខាងសាច់ឈាម កាលនៅលើផែនដី ហើយនឹងមានតទៅទៀត បន្ទាប់ពីសេចក្តីស្លាប់ ទៅជារូបផ្សេង រហូតដល់ដំណើររស់ឡើងវិញ ។ គ្រប់របស់របរដែលមានជីវិត — មនុស្សលោក សត្វ និងតិណជាតិ — គឺជាវិញ្ញាណមុនមានរបស់ទាំងនោះរស់នៅលើផែនដី (លោកុ. ២:៤–៥; ម៉ូសេ ៣:៤–៧) ។ រូបកាយខាងវិញ្ញាណ មើលទៅដូចជារូបកាយខាងសាច់ឈាម (១ នីហ្វៃ ១១:១១; អេធើរ ៣:១៥–១៦; គ. និង ស. ៧៧:២; គ. និង ស. ១២៩) ។ វិញ្ញាណគឺជារូបធាតុ ប៉ុន្តែគឺជារបស់ហ្មត់ ឬសុទ្ធសាធជាងវត្ថុធាតុ ឬរូបធាតុមនុស្សទៅទៀត (គ. និង ស. ១៣១:៧) ។

មនុស្សគ្រប់រូប គឺពិតជាបុត្រា ឬបុត្រីរបស់ព្រះ ដោយបានកើតជាវិញ្ញាណពីមាតាបិតាសួគ៌ មុនដែលបានកើតមកពីឪពុកម្តាយ នៅលើផែនដី (ហេព្រើរ ១២:៩) ។ ជននិមួយៗដែលនៅលើផែនដី មានរូបកាយខាងវិញ្ញាណ ដែលមិនចេះស្លាប់ ព្រមទាំងមានរូបកាយ ជាសាច់ និងឆ្អឹងផង ។ ជួនកាល ព្រះគម្ពីរអធិប្បាយប្រាប់ថា វិញ្ញាណនិងរូបកាយខាងសាច់ឈាម រួមគ្នាទៅជាព្រលឹង (លោកុ. ២:៧; គ. និង ស. ៨៨:១៥; ម៉ូសេ ៣:៧, ៩, ១៩; អ័ប្រា. ៥:៧) ។ វិញ្ញាណអាចរស់នៅ ដោយពុំចាំបាច់រូបកាយខាងសាច់ឈាមបាន ប៉ុន្តែឯ រូបកាយខាងសាច់ឈាមវិញ ពុំអាចរស់នៅ ដោយគ្មានវិញ្ញាណឡើយ (យ៉ាកុប ២:២៦) ។ សេចក្តីស្លាប់ខាងសាច់ឈាម គឺជាការ បែកវិញ្ញាណចេញពីរូបកាយ ។ នៅក្នុងដំណើររស់ឡើងវិញ វិញ្ញាណត្រូវបានចូលរួមនឹងរូបកាយសាច់ និងឆ្អឹងដដែលដែលមានពីដើម តែមានការខុសគ្នាពីរយ៉ាង គឺ វិញ្ញាណ និងរូបកាយនឹងមិនបែកចេញពីគ្នាទៀតទេ ហើយរូបកាយខាងសាច់ឈាម នឹងទៅជាមិនអាច ស្លាប់ ហើយនឹងបានល្អឥតខ្ចោះ (អាលម៉ា ១១:៤៥; គ. និង ស. ១៣៨:១៦–១៧) ។

ខ្មោចគ្មានសាច់ ឬឆ្អឹង ដូចជាឃើញខ្ញុំនេះទេ, **លូកា** ២៤:៣៩ ។ ព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់ នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ, **រ៉ូម** ៨:១៦ ។ ចូរដំកើងព្រះនៅក្នុងរូបកាយ ហើយក្នុងវិញ្ញាណនៃអ្នករាល់គ្នា, **១ កូរិន.** ៦:២០ ។ រូបរាងនេះ គឺជារូបរាងរបស់វិញ្ញាណយើង, **អេធើរ** ៣:១៦ ។ មនុស្សជាវិញ្ញាណ, **គ. និង ស.** ៩៣:៣៣ ។ ព្រះគ្រីស្ទទ្រង់បានធ្វើការងារបំរើដល់ពួកវិញ្ញាណ ដ៏សុចរិតនៅស្ថានបរមសុខ, **គ. និង ស.** ១៣៨:២៨–៣០ (១ ពេត្រុស. ៣:១៨–១៩) ។ អ្នករាល់គ្នាបានកើតមកក្នុងលោកិយ ដោយ សារទឹក និងឈាម និងវិញ្ញាណ, **ម៉ូសេ** ៦:៥៩ ។ ទ្រង់បានឈរក្នុងចំណោមអស់អ្នកដែលជាវិញ្ញាណ, **អ័ប្រា.** ៣:២៣ ។

*អារក្សអសោចិ៍* ព្រះយេស៊ូវទ្រង់បណ្តេញអារក្សអសោចិ៍ឲ្យចេញជាច្រើន, **ម៉ាកុស** ១:២៧; ៣៤, ៣៩ ។ ម្នាល អារក្សអសោចិ៍ ចូរថយចេញពីមនុស្សនេះទៅ, **ម៉ាកុស** ៥:២–១៣ ។ អារក្សអសោចិ៍បង្រៀនមនុស្សថា គេពុំត្រូវអធិស្ឋានទេ, **២ នីហ្វៃ** ៣២:៨ ។ ដោយនូវព្រះនាមនៃព្រះយេស៊ូវ នោះលោកបានបណ្តេញពួកអារក្សអសោចិ៍ឲ្យចេញ, ៣ នីហ្វៃ ៧:១៩ ។ មានវិញ្ញាណក្លែងក្លាយ ជាច្រើនបានចេញទៅបោកបញ្ឆោតមនុស្សលោក, **គ. និង ស.** ៥០:២; ៣១–៣២ ។ យ៉ូសែប ស៊្មីធបានពន្យល់ប្រាប់ពីកូនសោបីយ៉ាង សំរាប់ឲ្យស្គាល់ថា ជាវិញ្ញាណមកពីព្រះ ឬមកពីអារក្ស, **គ. និង ស.** ១២៩ ។

**វិតនី, នូវល ខេ**

ជាអ្នកដឹកនាំដំបូងម្នាក់នៃសាសនាចក្រ ។ នូវល ខេ វិតនី គឺជាប៊ីស្សពនៅទីក្រុងខឺតឡង់ រដ្ឋអូហៃអូ (សហរដ្ឋ) ហើយក្រោយមក បានបំរើធ្វើជាប៊ីស្សពដ៏ជាអធិបតីនៃសាសនាចក្រ (គ. និង ស. ៧២:១–៨; ១០៤; ១១៧) ។

**វិតមើរ, ដាវីឌ**

ជាអ្នកដឹកនាំដំបូងម្នាក់នៃសាសនាចក្រ ដែលសាងឡើងវិញ ហើយជាសាក្សីម្នាក់ក្នុងពួកសាក្សីបីនាក់ ចំពោះកំណើតដ៏ឧត្តម និងសេចក្តី ពិតប្រាកដនៃព្រះគម្ពីរមរមន (គ. និង ស. ១៤, ១៧–១៨) ។ ព្រះអម្ចាស់ទ្រង់បានប្រទានការបង្គាប់ដល់លោកផ្ទាល់ នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា ១៤ និង ៣០:១–៤ ។

**វិតមើរ, យ៉ូហាន**

ជាអ្នកដឹកនាំដំបូងម្នាក់នៃសាសនាចក្រ ដែលសាងឡើងវិញ ហើយជាសាក្សីម្នាក់ក្នុងពួកសាក្សីប្រាំបីនាក់ ចំពោះព្រះគម្ពីរមរមន ។ សូម មើល « ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់ » នៅក្នុងទំព័របុព្វកថានៃព្រះគម្ពីរមរមន ។ លោកក៏បានហៅឲ្យផ្សាយដំណឹងល្អ (គ. និង ស. ៣០:៩–១១) ។

**វិតមើរ, ពេត្រុស ផុញ្ញ័រ**

ជាអ្នកដឹកនាំដំបូងម្នាក់នៃសាសនាចក្រ ដែលសាងឡើងវិញ ហើយជាសាក្សីម្នាក់ ក្នុងពួកសាក្សីប្រាំបីនាក់ ចំពោះព្រះគម្ពីរមរមន ។ សូម

មើល « ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់ » នៅក្នុងទំព័របុព្វកថានៃព្រះគម្ពីរមរមន ។ ព្រះអម្ចាស់ទ្រង់បានប្រទានការបង្គាប់ដល់ លោកផ្ទាល់ នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ១៦ និង ៣០:៥–៨ ។

**វិលលាម្ស, ហ្វ្រេឌើរិក ជី**

ជាអ្នកដឹកនាំដំបូងម្នាក់នៃសាសនាចក្រដែលបានសាងឡើងវិញ ។ គាត់បានបំរើធ្វើជាអ្នកប្រឹក្សាម្នាក់ នៅក្នុងគណៈ ប្រធាននៃ បព្វជិតភាពជាន់ខ្ពស់មួយរយៈ (គ. និង ស. ៨១; ៩០:៦, ១៩; ១០២:៣) ។

**វិវរណៈ**: *សូមមើលផង* ការនិមិត្ត; ការព្យាករណ៍, ការបំផុសគំនិត, បំផុសគំនិត; ពន្លឺ; ពន្លឺនៃព្រះគ្រីស្ទ; ព្រះបន្ទូលនៃព្រះ, ព្រះវិញ្ញាណបរិសុទ្ធ; ព្យាករ; សម្លេង; សុបិ្ត, សុបិន

ជាទំនាក់ទំនងពីព្រះមកដល់កូនចៅរបស់ទ្រង់នៅលើផែនដី ។ វិវរណៈអាចបានមកតាមរយៈពន្លឺនៃព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ តាមមាគ៌ាខាងការបំផុសគំនិត ការនិមិត្ត សុបិ្ត ឬការមកជួបរបស់ពួកទេវតា ។ វិវរណៈផ្ដល់នូវការដឹកនាំ ដែលអាចនាំពួកស្មោះត្រង់ ទោងសេចក្ដីសង្គ្រោះដ៏អស់កល្បជានិច្ច នៅក្នុងនគរសេឡេស្ទាល ។

ព្រះអម្ចាស់ទ្រង់បើកសម្ដែងកិច្ចការរបស់ទ្រង់ ដល់ពួកព្យាការីរបស់ទ្រង់ ហើយបញ្ជាក់ប្រាប់ដល់ពួកអ្នកដែលជឿថា វិវរណៈទាំងឡាយដែលបានប្រទានដល់ពួកព្យាការីនោះសុទ្ធតែពិត (អេម៉ុស ៣:៧) ។ តាមរយៈវិវរណៈ នោះព្រះអម្ចាស់ផ្ដល់នូវការដឹកនាំផ្សេងគ្នា សំរាប់ជននីមួយៗ ដែលស្វែងរកវិវរណៈ ហើយដែលមានសេចក្ដីជំនឿជឿ, ប្រែចិត្ត ហើយគោរពតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ យ៉ូសែបស្ម៊ីធមានប្រសាសន៍ថា « ព្រះវិញ្ញាណបរិសុទ្ធ ជាព្រះដ៏បើកសំដែង » ហើយថា « គ្មានមនុស្សណាអាចទទួលព្រះវិញ្ញាណបរិសុទ្ធ ដែលពុំបានទទួលវិវរណៈទាំងឡាយនេះឡើយ » ។

នៅក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ គណៈប្រធានទីមួយ និងក្រុមសាវក១២នាក់ គឺជាពួកព្យាការី ពួកអ្នកមើលឆុត និងពួកអ្នកទទួលវិវរណៈសំរាប់សាសនាចក្រ និងសំរាប់ពិភពលោក ។ ប្រធាននៃសាសនាចក្រ គឺជាបុរសម្នាក់គត់ ដែលព្រះអម្ចាស់ទ្រង់អនុញ្ញាតឲ្យទទួលវិវរណៈសំរាប់សាសនាចក្រ (គ. និង ស. ២៨:២–៧) ។ ជននីមួយៗអាចទទួលវិវរណៈផ្ទាល់ខ្លួន សំរាប់ប្រយោជន៍ដល់ខ្លួន ឯងបាន ។

មនុស្សរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋនៃព្រះអម្ចាស់, **ចោទិ.** ៨:៣ (ម៉ាថាយ ៤:៤; គ. និង ស. ៩៨:១១) ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូល ដោយនូវសម្លេងតូចរហៀងៗ, **១ ពង្សាវ.** ១៩:១២ ។ គ្រាណាដែលឥតមានការបើកសំដែង នោះ បណ្ដាជនវិនាស, **សុភា.** ២៩:១៨ ។ ពិតប្រាកដជាព្រះអម្ចាស់ទ្រង់នឹងមិនធ្វើអ្វីដូច្នោះឡើយ លើកតែទ្រង់សម្ដែងឲ្យពួកហោរា ជាអ្នក បំរើទ្រង់ ឃើញគំនិតលាក់កំបាំងរបស់ទ្រង់ផង, **អេម៉ុស** ៣:៧ ។ ស៊ីម៉ូន កូនយ៉ូណាសអើយ អ្នកមានពរ ត្បិតមិនមែនជាសាច់ឈាម ដែលបានសម្ដែងឲ្យអ្នកស្គាល់ទេ គឺព្រះវរបិតានៃខ្ញុំវិញ, **ម៉ាថាយ** ១៦:១៥–១៩ ។ ព្រះវិញ្ញាណទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ ទាំងសេចក្ដីពិត ហើយនឹងសម្ដែងឲ្យអ្នករាល់គ្នាដឹងការដែលត្រូវមក, **យ៉ូហាន** ១៦:១៣ ។ បើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញាមានតែ សូមដល់ព្រះ, **យ៉ាកុប** (ព.ស.ថ.) ១:៥ ។ ការណ៍ទាំងអស់នឹងត្រូវបានបើកសម្ដែងប្រាប់, **២ នីហ្វៃ** ២៧:១១ ។ យើងនឹងប្រទានដល់កូនចៅមនុស្សមួយបន្ទាត់ម្ដងៗ, **២ នីហ្វៃ** ២៨:៣០ ។ គ្មានអ្វីជាអាថ៌កំបាំងដែលនឹងពុំសម្ដែងឲ្យឃើញទេ, **២ នីហ្វៃ** ៣០:១៧ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញដល់អ្នក នូវគ្រប់អ្វីទាំងអស់, **២ នីហ្វៃ** ៣២:៥ ។ គ្មានមនុស្សណាម្នាក់ ស្គាល់ផ្លូវរបស់ព្រះទេ លើកលែង តែបានបង្ហាញដល់អ្នកនោះ, **យ៉ាកុប** ៤:៨ ។ អាលម៉ាបានតមអាហារ ហើយអធិស្ឋាន ដើម្បីឲ្យបានវិវរណៈ, **អាលម៉ា** ៥:៤៦ ។ ការណ៍ ទាំងឡាយដែលពុំដែលបានបើកសម្ដែងប្រាប់ នោះនឹងបានបើកសម្ដែងប្រាប់ដល់ពួកស្មោះត្រង់, **អាលម៉ា** ២៦:២២ ។ អ្នកណាដែល បដិសេធវិវរណៈ នោះមិនស្គាល់នូវដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទេ ហើយក៏មិនយល់នូវបទគម្ពីរដែរ, **មរមន** ៩:៧–៨ ។ អ្នករាល់គ្នា មិនទាន់បានទទួលសាក្សីទេ ទាល់តែនៅពេលក្រោយការសាកល្បងនៃសេចក្ដីជំនឿរបស់អ្នកសិន, **អេធើរ** ១២:៦ ។ ពាក្យរបស់យើង នឹងបានសំរេចទាំងអស់, **គ. និង ស.** ១:៣៨ ។ តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នក អំពីការណ៍នោះទេឬអី ?, **គ. និង ស.** ៦:២២–២៣ ។ យើងនឹងប្រាប់អ្នកនៅក្នុងគំនិតរបស់អ្នក និងនៅក្នុងចិត្តរបស់អ្នក, **គ. និង ស.** ៨:២–៣ ។ បើសិនជាត្រឹម ត្រូវ នោះយើងនឹងបណ្ដាលឲ្យទ្រូងរបស់អ្នកខ្វល់ខ្វាញ់ខាងក្នុង, **គ. និង ស.** ៩:៨ ។ ចូរកុំបដិសេធវិញ្ញាណនៃវិវរណៈឡើយ, **គ. និង ស.** ១១:២៥ ។ អស់អ្នកណាដែលសូម នោះនឹងបានទទួលវិវរណៈថែមទៅលើវិវរណៈ, **គ. និង ស.** ៤២:៦១ ។ អ្វីក៏ដោយដែលពួកគេ នឹងនិយាយ កាលណាបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាសម្លេងនៃព្រះអម្ចាស់, **គ. និង ស.** ៦៨:៤ ។ ព្រះទ្រង់នឹង ប្រទានដំរិះដល់អ្នក, **គ. និង ស.** ១២១:២៦ ។ យ៉ូសែប ស្ម៊ីធ បានឃើញព្រះវរបិតា និងព្រះរាជបុត្រា, **យ.ស. — ប្រវត្តិ** ១:១៧ ។ យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ ដែលទ្រង់បានបើកសម្ដែងមក ហើយនឹងបើកសម្ដែង, **ម. នៃ ស.** ១:៧, ៩ ។

**វិវរណៈរបស់យ៉ូហាន** *សូមមើលផង* កូនប្រុសរបស់សេបេដេ, យ៉ូហាន, អ័ប៉ូកាលិព្ស

ជាគម្ពីរចុងក្រោយបង្អស់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលមាននូវវិវរណៈដែលបានប្រទានដល់យ៉ូហានជាសាវក ។ លោកត្រូវបាន អនុញ្ញាតឲ្យមើលឃើញប្រវត្តិនៃពិភពលោក ជាពិសេស អំពីថ្ងៃចុងក្រោយបង្អស់ (វិវរ. ១:១–២; ១ នីហ្វៃ ១៤:១៨–២៧; គ. និង ស. ៧៧) ។ វិវរណៈរបស់យ៉ូហានក៏បានស្គាល់ថា អ័ប៉ូកាលិព្ស ។

យ៉ូហានបានទទួលវិវរណៈនេះ នៅថ្ងៃរបស់ព្រះអម្ចាស់ នៅឯកោះប៉ាត់ម៉ុស (វិវរ. ១:៩–១០) គឺចេញពីឆ្នេរសមុទ្រអាស៊ី មិនឆ្ងាយពីស្រុកអេភេសូរប៉ុន្មានទេ ។ រីឯថ្ងៃពិតប្រាកដអំពីវិវរណៈនេះ នោះមិនដឹងប្រាកដទេ ។

សំគាល់ទាំងឡាយ ដើម្បីឲ្យបានយល់គម្ពីរនេះ នោះមាននៅក្នុង ១ នីហ្វៃ ១៤:១៨–២៧ និង គ. និង ស. ៧៧ (អេធើរ ៤:១៥–១៦) ។

ជំពូកទី ១–៣ គឺជាបុព្វកថាដល់គម្ពីរនេះ និងសំបុត្រទាំងឡាយ

ទៅសាសនាចក្រទាំងប្រាំពីរនៅស្រុកអាស៊ី ។ យ៉ូហានបានសរសេរសំបុត្រទាំងឡាយទៅជួយពួកបរិសុទ្ធដោះស្រាយបញ្ហាខ្លះៗ ។ ជំពូកទី ៤–៥ កត់អំពីការនិមិត្តទាំងឡាយ ដែលយ៉ូហានបានទទួល ដែលបង្ហាញនូវឫទ្ធានុភាព និងឯព្រះចេស្ដាដ៏សុចរិតនៃព្រះ និងព្រះគ្រីស្ទ ។ នៅក្នុងជំពូកទី ៦–៩, ១១ យ៉ូហានបានកត់ថាបានឃើញគម្ពីរមួយ ដែលបិទដោយត្រាប្រាំពីរ រីឯត្រានីមួយៗទុកជាតំណាងមួយពាន់ឆ្នាំនៃប្រវត្តិសាស្ត្រនៃពិភពលោក ។ ជំពូកទាំងនេះ ទាក់ទងជាសំខាន់នឹងព្រឹត្តិការណ៍ទាំងឡាយ ដែលមាននៅក្នុងត្រាទីប្រាំពីរ (សូមមើល វិវរ. ៨–៩, ១១:១–១៥) ។ ជំពូកទី ១០ អធិប្បាយប្រាប់អំពីគម្ពីរដែល យ៉ូហានបានបរិភោគ ។ គម្ពីរនោះគឺជាតំណាងអំពីបេសកកម្មខាងមុខ ដែលលោកនឹងធ្វើ ។ ជំពូកទី ១២ កត់នូវការនិមិត្ត អំពីការអាក្រក់ដែលបានចាប់ផ្ដើម នៅលើស្ថានសួគ៌ កាលអារក្សសាតាំងបានបះបោរ ហើយត្រូវបានបោះចោល ។ សង្គ្រាមដែលបាន ចាប់ផ្ដើមនៅទីនោះ ក៏នៅតែច្បាំងនៅលើផែនដីតទៅទៀត ។ នៅក្នុងជំពូកទី ១៣, ១៧–១៩ យ៉ូហានបានអធិប្បាយប្រាប់អំពីនគរ ដ៏ទុច្ចរិតទាំងឡាយនៅលើផែនដី ដែលបានកាន់កាប់ដោយអារក្សសាតាំង ហើយបានកត់នូវទំនាយអំពីនគរទាំងនោះ ព្រមទាំងការ បំផ្លិចបំផ្លាញចុងក្រោយបង្អស់នៃអំពើអាក្រក់ ។ ជំពូកទី ១៤–១៦ អធិប្បាយប្រាប់អំពីសេចក្ដីសុចរិតនៃពួកបរិសុទ្ធ ដែលនៅកណ្ដាល អំពើអាក្រក់មុនពេលព្រះគ្រីស្ទទ្រង់យាងមកជាលើកទីពីរ ។ ជំពូកទី ២០–២២ អធិប្បាយប្រាប់អំពីសហស្សវត្ស, អំពីទីក្រុង យេរូសាឡិមថ្មីដ៏ល្អ, និងអំពីព្រឹត្តិការណ៍ចុងក្រោយបង្អស់នៃប្រវត្តិរបស់ផែនដី ។

**រូឌម្រុព្វ, វិលហ្វ៊ឌ** *សូមមើលផង* សេចក្ដីថ្លែងជាផ្លូវការ — ទី១, សេចក្ដីប្រកាស

ជាប្រធានទីបួននៃសាសនាចក្រ បន្ទាប់ពីដំណឹងល្អបានសាងឡើងវិញដោយព្យាការីយ៉ូសែប ស្ម៊ីធ ។ លោកកើតនៅឆ្នាំ ១៨០៧ ហើយស្លាប់នៅឆ្នាំ ១៨៩៨ ។

ត្រូវបានហៅឲ្យបំពេញតំណែង នៅក្នុងក្រុមប្រឹក្សានៃពួក ១២ នាក់, **គ. និង ស.** ១១៨:៦ ។ បាននៅក្នុងចំណោមពួកវិញ្ញាណជំរើសៗឯទៀត ដែលបានរក្សាទុក ឲ្យមកនៅពេលពេញកំណត់, **គ. និង ស.** ១៣៨:៥៣ ។ បានទទួលវិវរណៈ ឲ្យបញ្ឈប់ការរៀបការប្រពន្ធ ច្រើននៅក្នុងសាសនាចក្រ, **គ. និង ស.** សេចក្ដីប្រកាសជាផ្លូវការ– ទី ១ ។

**វាំងនន**

ជាពាក្យមួយ ដែលប្រើនៅក្នុងព្រះគម្ពីរ ដើម្បីឲ្យន័យថា (១) ជាវនាំងខ័ណ្ឌទីកន្លែង នៅក្នុងរោងឧបោសថ ឬនៅក្នុងព្រះវិហារ, (២) ជានិមិត្តរូបមួយ អំពីការញែកចេញពីគ្នា រវាងព្រះនឹងមនុស្ស, (៣) ជាស្បៃពាក់ដោយមនុស្ស ដើម្បីគ្របមុខ ឬគ្របក្បាល, ឬ(៤) ជាសេចក្ដីភ្លេចភ្លាំង ដែលព្រះបណ្ដាលឲ្យមានឡើង ដើម្បីបំបិទកុំឲ្យមនុស្សនៅចាំអំពីការរស់នៅមុនផែនដី ។

វាំងនននោះយាំងទីបរិសុទ្ធ ពីទីបរិសុទ្ធបំផុត, **និក្ខ.** ២៦:៣៣ ។ វាំងនននៃព្រះវិហារ ក៏រហែកជាពីរភាគ ក្នុងកាលគេឆ្កាងព្រះគ្រីស្ទ, **ម៉ាថាយ** ២៧:៥១ (ម៉ាកុស ១៥:៣៨; លូកា ២៣:៤៥) ។ ឥឡូវនេះ យើងមើលឃើញបែបស្រអាប់ ដូចជាដោយសារកញ្ចក់ តែនៅវេលានោះ នឹងឃើញមុខទល់នឹងមុខ, **១ កូរិន.** ១៣:១២ ។ ស្បៃខ្មៅនៃការឥតជំនឿបានលាត់ចេញពីគំនិតទ្រង់, **អាលម៉ា** ១៩:៦ ។ ពុំអាចត្រូវបិទបាំងបងប្រុសរបស់យ៉ារេឌមិនឲ្យឃើញ នៅខាងក្នុងវាំងននបានឡើយ, **អេធើរ** ៣:១៩ (អេធើរ ១២:១៩) ។ វាំងនននឹង ត្រូវរហែក ហើយអ្នកនឹងបានឃើញយើង, **គ. និង ស.** ៦៧:១០ (គ. និង ស. ៣៨:៨) ។ វាំងននគ្របព្រះវិហារបរិសុទ្ធរបស់យើងនឹងត្រូវ បានបើកឡើង, **គ. និង ស.** ១០១:២៣ ។ ស្បៃត្រូវបានបើកពីគំនិតរបស់ពួកយើង, **គ. និង ស.** ១១០:១ ។ វាំងនននៃសេចក្ដីងងឹតនឹង គ្របដណ្ដប់លើផែនដី, **ម៉ូសេ** ៧:៦១ ។

**សក្ដិសម, ភាពសក្ដិសម** *សូមមើលផង* សុចរិត, សេចក្ដីសុចរិត

ដើម្បីឲ្យបានខ្លួនសុចរិត ហើយដើម្បីឲ្យបានឈរដោយត្រឹមត្រូវ នៅចំពោះព្រះនេត្រនៃព្រះ និងចំពោះពួកអ្នកដឹកនាំ ដែលបានរើស តាំងរបស់ទ្រង់ ។

អ្នកណាដែលមិនយកឈើឆ្កាងរបស់ខ្លួន អ្នកនោះមិនគួរនឹងខ្ញុំឡើយ, **ម៉ាថាយ** ១០:៣៨ ។ អ្នកដែលធ្វើការ នោះគួរនឹងបានឈ្នួល, **លូកា** ១០:៧ (គ. និង ស. ៣១:៥) ។ ចូរមើលឲ្យឃើញថា អ្នករាល់គ្នាធ្វើការគ្រប់យ៉ាង ក្នុងភាពសក្ដិសម, **មរមន** ៩:២៩ ។ ពួកគេ ពុំបានទទួលបុណ្យជ្រមុជទឹកឡើយ លើកលែងតែពួកគេប្រកបដោយភាពសក្ដិសម, **មរ៉ូណៃ** ៦:១ ។ អ្នកណាដែលខ្ជិលច្រអូសមិនត្រូវ បានរាប់ថាសមនឹងឈរឡើយ, **គ. និង ស.** ១០៧:១០០ ។ អ្នកណាដែលមិនទ្រាំការវាយផ្ចាល នោះមិនសមនឹងនគររបស់យើងឡើយ, **គ. និង ស.** ១៣៦:៣១ ។ បព្វជិតភាពត្រូវបានពន្យារដល់សមាជិកប្រុសៗគ្រប់រូបណាដែលសក្ដិសម, **គ. និង ស.** សេចក្ដីប្រកាស ជាផ្លូវការ — ទី ២ ។

**សង្ឃ, បព្វជិតភាពមិលគីស្សាដែក** *សូមមើលផង* បព្វជិតភាពមិលគីស្សាដែក, សង្ឃជាន់ខ្ពស់

ជាជនម្នាក់ដែលធ្វើពិធីខាងសាសនា ជំនួសអ្នកផ្សេង ហើយធ្វើដល់ព្រះ ។ នៅក្នុងព្រះគម្ពីរ ពួកសង្ឃ គឺសំដៅទៅលើពួកសង្ឃជាន់ ខ្ពស់តាមរបៀបនៃមិលគីស្សាដែក (អាលម៉ា ១៣:២) ។ អស់អ្នកណាដែលទទួលភាពពោរពេញនៃសិរីល្អរបស់ព្រះ បន្ទាប់ពីដំណើររស់ឡើងវិញ នោះនឹងក្លាយទៅជាសង្ឃ និងស្ដេចទាំងឡាយ នៅស្ថានសេឡេស្ទាល ។

មិលគីស្សាដែកជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត, **លោកុ.** ១៤:១៨ ។ ឯងជាសង្ឃ នៅអស់កល្បជានិច្ច តាមរបៀបលោកមិលគីស្សាដែក, **ទំនុក.** ១១០:៤ (ហេព្រើរ ៥:៦; ៧:១៧, ២១) ។ ព្រះគ្រីស្ទ ទ្រង់បានតាំងយើងរាល់គ្នាឡើងជាស្ដេច និងជាសង្ឃថ្វាយព្រះ ហើយនិងព្រះវរបិតានៃទ្រង់, **វិវរ.** ១:៦ (៥:១០; ២០:៦) ។ ចូរចាំថា ព្រះអម្ចាស់ទ្រង់បានតែងតាំងពួកសង្ឃទាំងឡាយឡើង តាមរបៀបបរិសុទ្ធ របស់

ទ្រង់, **អាលម៉ា** ១៣:១–២០ ។ អស់អ្នកណាដែលចេញមក ក្នុងដំណើររស់ឡើងវិញនៃមនុស្សសុចរិត គឺជាពួកសង្ឃ និងពួកស្ដេច, **គ. និង ស.** ៧៦:៥០, ៥៥–៦០ ។

**សង្ឃ, បព្វជិតភាពអើរ៉ុន** *សូមមើលផង* បងប្រុសរបស់ម៉ូសេ; បព្វជិតភាពអើរ៉ុន; សង្ឃជាន់ខ្ពស់, អើរ៉ុន

ជាតំណែងមួយក្នុងបព្វជិតភាពអើរ៉ុន ។ កាលពីសម័យបុរាណ ជាតំណែងដ៏ខ្ពស់បំផុត ក្នុងបព្វជិតភាពលេវី នោះបានកាន់ដោយលោកអើរ៉ុន និងពូជពង្សលោកតែប៉ុណ្ណោះ ។ កាលព្រះគ្រីស្ទបានបំពេញក្រិត្យវិន័យលោកម៉ូសេ នោះបំរាមនេះក៏ត្រូវបានដកចេញ ។

ភារកិច្ចទាំងឡាយរបស់សង្ឃ នៅក្នុងសាសនាចក្រដែលបានសាងឡើងវិញត្រូវបានរៀបរាប់ប្រាប់, **គ. និង ស.** ២០:៤៦–៥២ ។

**សង្ឃជាន់ខ្ពស់** *សូមមើលផង* បព្វជិតភាពមិលគីស្សាដែក, បព្វជិតភាពអើរ៉ុន

ជាតំណែងមួយក្នុងបព្វជិតភាព ។ បទគម្ពីរស្ដីអំពី « សង្ឃជាន់ខ្ពស់ » មានន័យពីរយ៉ាង គឺៈ ជាតំណែងក្នុងបព្វជិតភាពមិលគីស្សាដែក និង (២) នៅក្រោមក្រិត្យវិន័យលោកម៉ូសេ គឺជាអ្នកត្រួតត្រាលើបព្វជិតភាពអើរ៉ុន ។

ន័យទីមួយ ស្ដីអំពីព្រះយេស៊ូវគ្រីស្ទជាសម្ដេចសង្ឃដ៏ធំ ។ លោកអ័ដាម និងពួកអយ្យកោទាំងអស់ក៏ជាសង្ឃជាន់ខ្ពស់ដែរ ។ សព្វថ្ងៃ នេះ ពួកសង្ឃត្រួតត្រាបីនាក់ រួមធ្វើជាគណៈប្រធាននៃសាសនាចក្រ ហើយត្រួតត្រាលើអស់ទាំងពួកអ្នកកាន់បព្វជិតភាព និងលើសមាជិក ក្នុងសាសនាចក្រ ។ មានបុរសដែលសក្ដិសមថែមទៀត ត្រូវបានតែងតាំងឡើងជាពួកសង្ឃជាន់ខ្ពស់ តាមដែលសមនៅក្នុង សាសនាចក្រសព្វថ្ងៃនេះ ។ ពួកសង្ឃជាន់ខ្ពស់អាចបានហៅ, ញែកចេញ, ហើយតែងតាំងជាពួកប៊ីស្សព (គ. និង ស. ៦៨:១៩; ១០៧:៦៩–៧១) ។

ក្នុងន័យទីពីរ ក្រោមក្រិត្យវិន័យលោកម៉ូសេ អ្នកត្រួតត្រាលើបព្វជិតភាពអើរ៉ុនហៅថា ជាសង្ឃជាន់ខ្ពស់ ។ តំណែងនេះគឺបានមក តាមពូជ ហើយផ្ដល់ដល់កូនច្បងក្នុងគ្រួសារអើរ៉ុន គឺអើរ៉ុនជាសង្ឃជាន់ខ្ពស់ទីមួយ តាមរបៀបអើរ៉ុន (និក្ខ. ២៨; ២៩; លេវី. ៨; គ. និង ស. ៨៤: ១៨) ។

មិលគីស្សាដែកជាសង្ឃនៃព្រះដ៏ខ្ពស់បំផុត, **លោកុ.** ១៤:១៨ (អាលម៉ា ១៣:១៤) ។ ពួកសង្ឃជាន់ខ្ពស់ត្រូវបានហៅ ហើយរៀបចំឡើងតាំងពីកំណើតលោកិយមក **អាលម៉ា** ១៨:១–១០ ។ ពួកសង្ឃជាន់ខ្ពស់ចាត់ចែងការណ៍ខាងវិញ្ញាណ, **គ. និង ស.** ១០៧:១០, ១២, ១៧ ។

**សង្គ្រាម** *សូមមើលផង* សេចក្ដីសុខសាន្ត

ជាចំបាំង ឬការប្រយុទ្ធដោយប្រើអាវុធ; ជាការតតាំងនឹងសស្ត្រាវុធ ។ ព្រះអម្ចាស់ទ្រង់អនុម័តឲ្យមានសង្គ្រាម ទុកជាមាគ៌ាចុងក្រោយ បង្អស់សំរាប់ឲ្យពួកបរិសុទ្ធរបស់ទ្រង់ ការពារក្រុមគ្រួសារ ទ្រព្យសម្បត្តិ សិទ្ធិ ឯកសិទ្ធិ និងសេរីភាពរបស់ពួកគេប៉ុណ្ណោះ (អាលម៉ា ៤៣:៩, ៤៥–៤៧) ។

ម៉ូរ៉ូណៃបានខិតខំព្យាយាមដើម្បីការពារប្រជាជនរបស់លោក សិទ្ធិរបស់លោក ដែនដីរបស់លោក និងសាសនារបស់លោក, **អាលម៉ា** ៤៨:១០–១៧ ។ យ៉ូសែប ស៊្មីធបានទទួលវិវរណៈ និងការព្យាករណ៍ពីសង្គ្រាម, **គ. និង ស.** ៨៧ ។ ចូរលះបង់សង្គ្រាម ហើយប្រកាសប្រាប់ពីសេចក្ដីសុខសាន្តវិញ, **គ. និង ស.** ៩៨:១៦, ៣៤–៤៦ ។ យើងខ្ញុំជឿថា មនុស្សលោកត្រូវបានរាប់ថាសុចរិត ក្នុងការការពារខ្លួន មិត្តភក្ដិ និងទ្រព្យសម្បត្តិ និងរដ្ឋាភិបាលរបស់គេ, **គ. និង ស.** ១៣៤:១១ ។ យើងខ្ញុំជឿក្នុងការគោរពប្រតិបត្តិ និងការគាំទ្រច្បាប់, **ម. នៃ ស.** ១:១២ ។

**សង្គ្រាមនៅស្ថានសួគ៌** *សូមមើលផង* ក្រុមប្រឹក្សានៅលើស្ថានសួគ៌; ជីវិតមុនផែនដី

ជាចំបាំង ដែលបានច្បាំងនៅជីវិតមុនផែនដី ក្នុងចំណោមពួកកូនចៅវិញ្ញាណរបស់ព្រះ ។

សាតាំងត្រូវបានបោះចេញពីស្ថានសួគ៌ ហើយចោលទៅឯផែនដី, **វិវរ.** ១២:៤, ៧–៩ ។ អារក្ស និងមួយភាគបីនៃពួកពលស្ថានសួគ៌ ត្រូវបានទំលាក់ចុះ, **គ. និង ស.** ២៩:៣៦–៣៧ ។ លូស៊ីហ្វើរបានបះបោរទាស់នឹងព្រះរាជបុត្រាបង្កើតតែមួយ, **គ. និង ស.** ៧៦:២៥–២៦ ។ សាតាំងស្វែងរកកិត្តិយសនៃព្រះវរបិតា ហើយចង់បំផ្លាញសិទ្ធិជ្រើសរើសរបស់មនុស្ស, **ម៉ូសេ** ៤:១–៤ (អេសាយ ១៤:១២–១៥; អ័ប្រា. ៣:២៧–២៨) ។ អស់អ្នកដែលបានដើរទៅតាមព្រះនោះបានរក្សាសណ្ឋានទីមួយរបស់ខ្លួន បានមកឯផែនដី ហើយបានទទួល រូបកាយ, **អ័ប្រា.** ៣:២៦ ។

**សញ្ញា** *សូមមើល* ព្រះគម្ពីរសញ្ញាចាស់, ព្រះគម្ពីរសញ្ញាថ្មី

**សណ្ដាប់**

ជាជំនឿ និងការប្រព្រឹត្តិទាំងឡាយ ដែលបានបន្តមកពីតំណមួយ ទៅតំណមួយទៀត (២ ថែស្ស. ២:១៥) ។ នៅក្នុងព្រះគម្ពីរ ព្រះអម្ចាស់ទ្រង់ហាមពួកសុចរិតជាញឹកញាប់ ឲ្យចៀសវាងពីសណ្ដាប់អាក្រក់ទាំងឡាយរបស់មនុស្សលោក (លេវី. ១៨:៣០; ម៉ាកុស ៧:៦–៨; ម៉ូសាយ ១:៥; គ. និង ស. ៩៣:៣៩–៤០) ។

**សណ្ឋានទីពីរ** *សូមមើល* ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់

**សប្បាយរីករាយ, សេចក្ដីសប្បាយរីករាយ***សូមមើល* សេចក្ដីអំណរ

**សប្ដិ, សុបិន***សូមមើលផង* វិវរណៈ

ជាមាគ៌ាមួយដែលព្រះទ្រង់បើកសម្ដែងព្រះហឫទ័យរបស់ទ្រង់ប្រាប់ដល់ម

នុស្សប្រុសស្រីនៅលើផែនដី ។ ប៉ុន្តែគ្រប់ទាំងសុបិនមិនមែនជា វិវរណៈទេ ។ សុបិនដែលបំផុសគំនិត គឺជាផលនៃសេចក្ដីជំនឿ ។

គាត់យល់សប្ដិឃើញថាមានជណ្ដើរមួយទល់នឹងផ្ទៃមេឃ, **លោកុ.** ២៨:១២ ។ យ៉ូសែបបានយល់សប្ដិ, **លោកុ.** ៣៧:៥ ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលនឹងអ្នកនោះក្នុងសុបិន, **ជនគ.** ១២:៦ ។ ស្ដេចនេប៊ូក្នេសាបានសុបិននិមិត្ត, **ដានី.** ២:១–៣ ។ ពួកចាស់ៗនឹងយល់ សប្ដិ, **យ៉ូអែល** ២:២៨ (កិច្ចការ ២:១៧) ។ ទេវតានៃព្រះអម្ចាស់លេចមកឯគាត់ក្នុងសុបិន, **ម៉ាថាយ** ១:២០ (ម៉ាថាយ ២:១៩) ។ លីហៃបានសរសេរសេចក្ដីជាច្រើនទុកដែលលោកបានឃើញក្នុងសុបិន **១ នីហ្វៃ** ១:១៦ ។ លីហៃបានយល់សប្ដិ, **១ នីហ្វៃ** ៨ ។

**សម្បថ** *សូមមើលផង* សម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព, សេចក្ដីសញ្ញា

ដូចដែលប្រើនៅក្នុងព្រះគម្ពីរ ជាទូទៅ គឺជាសេចក្ដីសញ្ញា ឬជាសេចក្ដីសន្យាដ៏ពិសិដ្ឋមួយ ។ ប៉ុន្តែមនុស្សអាក្រក់ ព្រមទាំងអារក្ស សាតាំង និងពួកទេវតាវា ក៏ស្បថដើម្បីសំរេចនូវបំណងអាក្រក់របស់វាដែរ ។ នៅសម័យព្រះគម្ពីរសញ្ញាចាស់ សម្បថ គឺជាការទទួល ស្គាល់ ប៉ុន្តែព្រះយេស៊ូវទ្រង់បានបង្រៀនថា មនុស្សមិនត្រូវស្បថនឹងព្រះនាមនៃព្រះ ឬនឹងអ្វីៗដែលទ្រង់បានបង្កើតមកឡើយ (ម៉ាថាយ ៥:៣៣–៣៧) ។

អញនឹងសំរេចតាមសេចក្ដីសម្បថ ដែលអញបានស្បថនឹងអ័ប្រាហាំ, **លោកុ.** ២៦:៣ ។ បើបុរសណាស្បថភ្ជាប់ខ្លួនដោយសម្បថណា មួយ អ្នកនោះមិនត្រូវក្បត់ពាក្យខ្លួនឡើយ, **ជនគ.** ៣០:២ ។ គេបានចូលក្នុងសម្បថដើម្បីនឹងកាន់តាមក្រិត្យវិន័យរបស់ព្រះ, **នេហ.** ១០:២៩ ។ អ្នករាល់គ្នាត្រូវធ្វើឲ្យសំរេចតាមគ្រប់ទាំងសេចក្ដី ដែលស្បថនឹងព្រះអម្ចាស់, **ម៉ាថាយ** ៥:៣៣ (សាស្ដា ៥:១–២; ៣ នីហ្វៃ ១២:៣៣) ។ ព្រះទ្រង់ស្បថសម្បថថា ពួកស្មោះត្រង់នឹងត្រូវបានសង្គ្រោះ, **ហេព្រើរ** ៦:១៣–១៨ ។ កាលសូរាំបានស្បថ នោះសេចក្ដី ខ្លាចទាំងប៉ុន្មានរបស់យើងក៏បាត់ទៅ, **១ នីហ្វៃ** ៤:៣៧ ។ ប្រជាជនអាំម៉ូនបានស្បថថាពួកគេនឹងមិនកំចាយឈាមទៀតឡើយ, **អាលម៉ា** ៥៣:១១ ។ ពួកសាសន៍នីហ្វៃដែលទុច្ចរិតបានធ្វើសម្បថ និងសេចក្ដីសញ្ញាសម្ងាត់ជាមួយនឹងអារក្សសាតាំង, **ហេលេ.** ៦:២១–៣០ ។ មនុស្សលោកបានជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈសម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព, **គ. និង ស.** ៨៤:៣៣–៤២ ។ គ្រប់ទាំងសេចក្ដីសញ្ញា កិច្ចសន្យា សំបុត្រធានា កាតព្វកិច្ច និងសម្បថ ដែលមិនបានភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធ នៃសេចក្ដីសន្យា នោះនឹងចប់នៅពេលមនុស្សស្លាប់ទៅ, **គ. និង ស.** ១៣២:៧ ។

**សម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព** *សូមមើលផង* បព្វជិតភាព, សម្បថ; សេចក្ដីសញ្ញា

សម្បថ គឺជាការស្បថបញ្ជាក់ថា ពិត ហើយស្មោះត្រង់ចំពោះសេចក្ដីសន្យាទាំងឡាយរបស់មនុស្សម្នាក់ ។ សេចក្ដីសញ្ញា គឺជាសេចក្ដី សន្យាមួយដ៏ម៉ឺងម៉ាត់រវាងប័ក្សពីរក្រុម ។ បព្វជិតភាពអើរ៉ុន ត្រូវបានទទួលដោយសេចក្ដីសញ្ញាប៉ុណ្ណោះ ។ អ្នកកាន់បព្វជិតភាព មិលគីស្សាដែកទទួលបព្វជិតភាពបានដោយសម្បថសម្ងាត់ ព្រមទាំងដោយសេចក្ដីសញ្ញា ។ កាលណាពួកអ្នកកាន់បព្វជិតភាពមានចិត្ត ស្មោះត្រង់ ហើយដំកើងការងារបំរើរបស់គេ ដូចដែលព្រះទ្រង់បង្គាប់ នោះទ្រង់ប្រទានពរដល់ពួកគេ ។ អស់អ្នកណាដែលមានចិត្ត ស្មោះត្រង់ ដរាបដល់ចុងបំផុត ហើយធ្វើនូវគ្រប់ការណ៍ទាំងអស់ដែលទ្រង់ឲ្យគេធ្វើ នោះនឹងបានទទួលនូវគ្រប់ទាំងអ្វីៗ ដែលព្រះវរបិតា ទ្រង់មាន (គ. និង ស. ៨៤:៣៣–៣៩) ។

ព្រះអម្ចាស់ ទ្រង់បានធ្វើសេចក្ដីសញ្ញាជាមួយនឹងអ័ប្រាហាំ ហើយអ័ប្រាហាំក៏គោរពធ្វើតាម, **លោកុ.** ១៥:១៨; ១៧:១; ២២:១៦–១៨ ។ ពួកសង្ឃនៅសម័យអេសេគាល មិនបានឲ្យចំណីដល់ហ្វូងចៀម, **អេសេ.** ៣៤:២–៣ ។ ពួកសង្ឃនៅសម័យម៉ាឡាគីបានបង្ខូចសេចក្ដី សញ្ញា, **ម៉ាឡាគី** ១–២ ។

**សម្លាប់** *សូមមើល* ការដាក់ទោសដល់ជីវិត; ឃាតកម្ម

**សមុទ្រក្រហម** *សូមមើលផង* ម៉ូសេ

ជាផ្ទៃទឹកនៅរវាងប្រទេសអេស៊ីព្ទ និងប្រទេសអារ៉ាប់ ។ ឯឈូងសមុទ្រខាងជើងទាំងពីរនោះធ្វើជាឆ្នេរសមុទ្រនៃជ្រោយស៊ីណាយ ។ ព្រះអម្ចាស់ទ្រង់បានញែកទឹកសមុទ្រក្រហមឲ្យចេញពីគ្នាយ៉ាងអស្ចារ្យ ដើម្បីឲ្យពួកសាសន៍អ៊ីស្រាអែល ដែលនៅក្រោមការដឹកនាំ របស់លោកម៉ូសេ អាចបានឆ្លងកាត់តាមដីគោក (និក្ខ. ១៤:១៣–៣១; ហេព្រើរ ១១:២៩) ។ ការញែកទឹកសមុទ្រឲ្យចេញពីគ្នាដោយ លោកម៉ូសេនោះត្រូវបានបញ្ជាក់នៅក្នុងវិវរណៈថ្ងៃចុងក្រោយ (១ នីហ្វៃ ៤:២; ហេព្រើរ ៨:១១; គ. និង ស. ៨:៣; ម៉ូសេ ១:២៥) ។

**សមុទ្រស្លាប់**

ជាសមុទ្រអំបិលនៅចុងខាងត្បូងប្រេកភ្នំយ័រដាន់ ។ ក៏ស្គាល់ថាជាសមុទ្រអំបិលដែរ ។ មានផ្ទៃប្រមាណ ៣៩៥ ម. ក្រោមទន្លេមេឌីតេរាន ។ ទីក្រុងសូដុំម កូម៉ូរ៉ា សូអារ ឬបេឡា នៅក្បែរឆ្នេរសមុទ្រស្លាប់ (លោកុ. ១៤:២–៣) ។

ក្នុងការសំរេចពាក្យព្យាករណ៍ ហើយជាទីសំគាល់មួយ អំពីការយាងមកលើកទីពីរ របស់ព្រះអង្គសង្គ្រោះ នោះទឹកក្នុងសមុទ្រស្លាប់នឹងបានជា ហើយជីវិតនឹងលូតលាស់ឡើងនៅទីនោះ (អេសេ. ៤៧:៨–៩) ។

**សម្លេង** *សូមមើលផង* វិវរណៈ

ដូចដែលបានប្រើនៅក្នុងព្រះគម្ពីរ ជួនកាល គឺជាសារដែលឮសូរ ដែលបានពោលដោយព្រះអម្ចាស់ ឬដោយទូតទាំងឡាយរបស់ទ្រង់ ។ សម្លេងនៃព្រះវិញ្ញាណអាចទៅជាមិនឮក៏បាន ហើយអាចចូលទៅក្នុងចិត្ត ឬក្នុងគំនិតតែម្ដងក៏បាន ។

លោកអ័ដាម និងនាងអេវ៉ា បានឮសម្លេងព្រះអម្ចាស់ដ៏ជាព្រះ, **លោកុ.** ៣:៨ (ម៉ូសេ ៤:១៤) ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅ អេលីយ៉ា ដោយនូវសម្លេងតូចរហៀងៗ, **១ ពង្សាវ.** ១៩:១១–១៣ ។ ពួកមនុស្សសុចរិតស្តាប់តាមសម្លេងនៃអ្នកគង្វាលល្អ, **យ៉ូហាន** ១០:១–១៦ ។ អស់អ្នកណាដែលកើតពីសេចក្តីពិត នោះក៏ឮសម្លេងខ្ញុំ, **យ៉ូហាន** ១៨:៣៧ ។ ខ្ញុំបានគោរពតាមសម្លេងនៃព្រះវិញ្ញាណ, **១ នីហ្វៃ** ៤:៦–១៨ ។ ស្រាប់តែមានសម្លេងបន្លឺមកខ្ញុំថា៖ អេណុស បាបរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ, **អេណុស** ១:៥ ។ គឺជាសម្លេងរហៀងៗ នៃភាពស្រទន់ឥតខ្ចោះ ហើយបានចាក់ទំលុះចូលទៅដល់ទាំងព្រលឹង, **ហេលេ.** ៥:២៩–៣៣ (៣ នីហ្វៃ ១១:៣–៧) ។ ទោះជាដោយសម្លេងរបស់យើងផ្ទាល់ ឬក៏ដោយសម្លេងនៃពួកអ្នកបំរើរបស់យើងក្តី គឺដូចគ្នាដែរ, **គ. និង ស.** ១:៣៨ ។ អ្វីក៏ដោយដែលពួកគេនឹងនិយាយកាលណាបណ្តាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាសម្លេងនៃព្រះអម្ចាស់, **គ. និង ស.** ៦៨:២–៤ ។ មនុស្សគ្រប់រូបដែលគោរពតាមសម្លេងរបស់យើង នោះនឹងបានឃើញព្រះភ័ក្ត្ររបស់យើង ហើយស្គាល់ថាយើងជាព្រះ, **គ. និង ស.** ៩៣:១ ។

**សហសមាគម** *សូមមើលផង* ក្រិត្យវិន័យនៃការថ្វាយ, ថ្វាយ

ជាអង្គការមួយ ដែលពួកបរិសុទ្ធក្នុងសាសនាចក្រដែលបានសាងឡើងវិញនៅសម័យដើម បានព្យាយាមកាន់តាមក្រិត្យវិន័យនៃការថ្វាយ ។ បុគ្គលទាំងឡាយបានចូលរួមគ្នានូវទីកន្លែង របស់របរ និងកម្រៃទាំងឡាយ ហើយទទួលនូវរបស់ទាំងនេះ ស្របតាមសេចក្តីត្រូវការ និងសេចក្តីខ្វះខាតរបស់ខ្លួន (គ. និង ស. ៥១:៣; ៧៨;១–១៥; ១០៤) ។

រីឯអ្វីៗរបស់អ្នកខាងសាច់ឈាម នោះអ្នកត្រូវបានស្មើគ្នា, **គ. និង ស.** ៧០:១៤ ។ ពួកបរិសុទ្ធបានត្រូវឲ្យរៀបចំ ដើម្បីឲ្យបានស្មើគ្នា នូវអ្វីៗទាំងអស់, **គ. និង ស.** ៧៨:៣–១ (គ. និង ស. ៨២:១៧–២០) ។ ព្រះអម្ចាស់ទ្រង់បានប្រទានដល់សហសមាគម នូវវិវរណៈ និង ព្រះបញ្ញត្តិមួយ, **គ. និង ស.** ៩២:១ ។ យ៉ូហាន ចនសុន គួរតែធ្វើជាសមាជិកនៃសហសមាគម, **គ. និង ស.** ៩៦:៦–៩ ។ ព្រះអម្ចាស់ទ្រង់ បានប្រទានការបង្គាប់ទូទៅ សំរាប់ការចាត់ចែងសហសមាគម, **គ. និង ស.** ១០៤ ។ រាស្ត្រយើងមិនបានសាមគ្គីគ្នា តាមការរួបរួមគ្នាដែលតម្រូវដោយក្រិត្យវិន័យនៃនគរសេឡេស្ទាលឡើយ, **គ. និង ស.** ១០៥:១–១៣ ។

**សហស្សវត្ស** *សូមមើលផង* ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ, ស្ថាននរក

ជារយៈពេលមួយពាន់ឆ្នាំនៅក្នុងសេចក្តីសុខសាន្ត ដែលនឹងចាប់ផ្តើមនៅពេលព្រះគ្រីស្ទយាងមកសោយរាជ្យនៅលើផែនដីវិញ ដោយព្រះអង្គទ្រង់ផ្ទាល់ (ម. នៃ ស. ១:១០) ។

មនុស្សនឹងមិនលើកដាវ ក៏មិនហាត់រៀនធ្វើសង្គ្រាមទៀតឡើយ, **អេសាយ** ២:៤ (២ នីហ្វៃ ១២:៤; មីកា ៤:៣) ។ ស្រុកដែលត្រូវ ចោលស្ងាត់ បានត្រឡប់ដូចជាសួនច្បារអេដែនវិញ, **អេសេ.** ៣៦:៣៥ ។ គេនឹងនៅហើយសោយរាជ្យជាមួយនឹងព្រះគ្រីស្ទនៅ មួយពាន់ឆ្នាំ, **វិវ.** ២០:៤ ។ ដោយសារអំពើសុចរិត នោះអារក្សសាតាំងគ្មានអំណាចសោះ, **១ នីហ្វៃ** ២២:២៦ ។ យើងនឹងស្ថិត នៅក្នុងសេចក្តីសុចរិតនៅលើផែនដីអស់មួយពាន់ឆ្នាំ **គ. និង ស.** ២៩:១១ ។ ក្នុងរយៈកាលមួយពាន់ឆ្នាំបានចប់ទៅ យើងនឹងប្រណី ដល់ផែនដីតែមួយរដូវតូចប៉ុណ្ណោះ, **គ. និង ស.** ២៩:២២ ។ សហស្សវត្សរ៍ដ៏ធំនឹងមកដល់, **គ. និង ស.** ៤៣:៣០ ។ កូនចៅនៃពួក សុចរិតនឹងធំឡើងដោយគ្មានបាប, **គ. និង ស.** ៤៥:៥៨ ។ កូនក្មេងនឹងត្រូវធំឡើង រហូតដល់វាទៅជាមនុស្សពេញវ័យ; មនុស្សនឹងត្រូវផ្លាស់ប្រែក្នុងមួយប៉ប្រិចភ្នែក, **គ. និង ស.** ៦៣:៥១ ។ នៅដើមប្រាំពីរពាន់ឆ្នាំ នោះព្រះអម្ចាស់ទ្រង់នឹងញែកផែនដីចេញជាបរិសុទ្ធ, **គ. និង ស.** ៧៧:១២ ។ ពួកគេពុំរស់ទៀតឡើយ រហូតដល់ចប់រយៈពេលមួយពាន់ឆ្នាំ, **គ. និង ស.** ៨៨:១០១ ។ សាតាំងនឹងត្រូវចង អស់រយៈពេលមួយពាន់ឆ្នាំ, **គ. និង ស.** ៨៨:១១០ ។ សហស្សវត្សរ៍ត្រូវបានរៀបរាប់ប្រាប់, **គ. និង ស.** ១០១:២៣–៣៤ ។ អស់រយៈ ពេលមួយពាន់ឆ្នាំ នោះផែនដីនឹងបានសំរាក, **ម៉ូសេ** ៧:៦៤ ។

**សរសើរដំកើង** *សូមមើល* ការថ្លែងអំណរគុណ, ដ៏អរគុណ, សិរីល្អ; អរគុណ

**សាការី**

ជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានព្យាករនៅរវាងឆ្នាំ ៥២០ ម.គ.ស. ។ លោកបានរស់នៅសម័យព្យាការី ហាកាយ (អែសរ៉ា ៥:១; ៦:១៤) ។

*គម្ពីរសាការី៖* គម្ពីរនេះត្រូវបានទុកជាទីសំគាល់ចំពោះពាក្យព្យាករណ៍អំពីការងារបំរើរបស់ព្រះគ្រីស្ទ នៅលើផែនដី និងអំពីការ យាងមកលើកទីពីររបស់ទ្រង់ (សាការី ៩:៩; ១១:១២–១៣; ១២:១០; ១៣:៦) ។ ជំពូកទី ១–៨ មាននូវប្រជុំការនិមិត្តទាំងឡាយ អំពីអនាគតនៃរាស្ត្ររបស់ព្រះ ។ ជំពូកទី ៩–១៤ មាននូវការនិមិត្តទាំងឡាយ អំពីព្រះមែស៊ី អំពីថ្ងៃចុងក្រោយបង្អស់ អំពីការប្រមូល ពួកអ៊ីស្រាអែល អំពីសង្គ្រាមចុងក្រោយបង្អស់ និងអំពីការយាងមកលើកទីពីរ ។

**សាការី** *សូមមើលផង* យ៉ូហាន-បាទិស្ទ, អេលីសាបិត

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាឪពុករបស់យ៉ូហាន-បាទិស្ទ ។ សាការីបានកាន់មុខងារជាសង្ឃ ហើយបានធ្វើការនៅក្នុងព្រះវិហារ ។

ទេវតាកាព្រីយ៉ែលបានសន្យានឹងសាការី ហើយនឹងអេលីសាបិត ជាប្រពន្ធលោកថា នឹងបានកូនប្រុសមួយ, **លូកា** ១:៥–២៥ (គ. និង ស. ២៧:៧) ។ អណ្តាតលោកក៏រលាស់បាន, **លូកា** ១:៥៩–៧៩ ។ សាការីត្រូវគេសម្លាប់នៅកណ្តាលព្រះវិហារនឹងអាសនា, **ម៉ាថាយ** ២៣:៣៥ (លូកា ១១:៥១) ។

**សាក្សី** *សូមមើលផង* ទីបន្ទាល់

ជាសេចក្តីថ្លែង ឬភស្តុតាងឯទៀត ដែលថាអ្វីមួយគឺពិត; ជាទីបន្ទាល់ ។ សាក្សីក៏អាចជាមនុស្សណាម្នាក់ ដែលថ្លែងការ ឬភស្តុតាង ដែលពឹងផ្អែកទៅលើជំនិះផ្ទាល់ខ្លួន; គឺជាអ្នកណាម្នាក់ ដែលធ្វើទីបន្ទាល់ ។

កុំឲ្យធ្វើបន្ទាល់ក្លែង, **និក្ខ.** ២០:១៦ ។ ដំណឹងល្អនឹងបានប្រកាសប្រាប់ទូទៅគ្រប់ក្នុងលោកិយ ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍, **ម៉ាថាយ** ២៤:១៤ (យ.ស. — ម៉ាថាយ ១:៣១) ។ អ្នករាល់គ្នានឹងធ្វើទីបន្ទាល់ពីខ្ញុំ, **កិច្ចការ** ១:៨ ។ ព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើង, **រ៉ូម** ៨:១៦ (១ យ៉ូហាន ៥:៦) ។ អ្នករាល់គ្នាព្រមឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល, **ម៉ូសាយ** ១៨:៨–៩ ។ យើងរាល់គ្នាទទួលទានបុណ្យរំឭក ដើម្បីធ្វើទីបន្ទាល់ដល់ព្រះវរបិតាថា យើងរាល់គ្នានឹងកាន់តាមព្រះបញ្ញត្តិទាំងឡាយ ហើយចងចាំដល់ ព្រះយេស៊ូវជានិច្ច, ៣ នីហ្វៃ ១៨:១០–១១ (ម៉ូរ៉ូណៃ ៤, ៥; គ. និង ស. ២០:៧៧–៧៩) ។ អ្នកពុំទទួលសាក្សីឡើយ រហូតដល់ពេលក្រោយពីការពិសោធន៍នៃសេចក្តីជំនឿរបស់អ្នកសិន, **អេធើរ** ១២:៦ ។ ច្បាប់នៃពួកសាក្សីៈ ដោយមាត់នៃសាក្សីពីរ ឬបីនាក់ នោះគ្រប់ ព្រះបន្ទូលនឹងត្រូវបានតាំងឡើង **គ. និង ស.** ៦:២៨ (ចោទិ. ១៧:៦; ម៉ាថាយ ១៨:១៦; ២ កូរិន. ១៣:១; អេធើរ ៥:៤; គ. និង ស. ១២៨:៣) ។ យើងបានតែងតាំងអ្នក ឲ្យធ្វើជាពួកសាវក និងជាពួកសាក្សីពិសេសអំពីព្រះនាមរបស់យើង, **គ. និង ស.** ២៧:១២ (គ. និង ស. ១០៧:២៣) ។ ពួក៧០នាក់ត្រូវបានហៅឲ្យផ្សាយដំណឹងល្អ ហើយឲ្យធ្វើជាពួកសាក្សីពិសេស ដល់ពួកសាសន៍ដទៃ និងនៅ ពេញសព្វក្នុងពិភពលោក, **គ. និង ស.** ១០៧:២៥ ។ ចូរឲ្យមានបញ្ជីកត់ទុក ហើយចូរឲ្យគាត់ធ្វើសាក្សីអំពីបុណ្យជ្រមុជទឹកទាំងឡាយ របស់អ្នក, **គ. និង ស.** ១២៧:៦ (គ. និង ស. ១២៨:២–៤) ។

**សាដ្រាក់** *សូមមើលផង* ដានីយ៉ែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ សាដ្រាក់ មែសាក់ និងអ័បេឌ-នេគោ គឺជាកំឡោះបីនាក់នៃសាសន៍អ៊ីស្រាអែល ជាមួយនឹងដានីយ៉ែល ដែលត្រូវបានចាប់យកទៅឯវាំងនៃនេប៊ូក្នេសា ជាស្តេចស្រុកបាប៊ីឡូន ។ ឈ្មោះរបស់សាដ្រាក់ក្នុងភាសាហេព្រើរ គឺ ហាណានា ។ កំឡោះបួននាក់មិនព្រមធ្វើឲ្យខ្លួនស្មោកគ្រោក ដោយបរិភោគសាច់ និងស្រាទំពាំងបាយជូររបស់ស្តេចឡើយ (ដានី. ១) ។ សាដ្រាក់ មែសាក់ និងអ័បេឌ-នេគោ ត្រូវស្តេចបោះទៅក្នុងគុកភ្លើង តែបានព្រះរាជបុត្រានៃព្រះបានជួយរក្សាជីវិតទុក (ដានី. ៣) ។

**សាច់** *សូមមើលផង* ខាងរូបកាយ; ដែលរមែងស្លាប់, ភាពដែលរមែងស្លាប់; មនុស្សខាងសាច់ឈាម, រូបកាយ

*សាច់* មានន័យច្រើនយ៉ាង គឺៈ (១) ជាលិកាទន់ ដែលរួមធ្វើជារូបកាយមនុស្សលោក សត្វ សត្វស្លាប ឬត្រី; (២) ជាភាពដែលរមែងស្លាប់; ឬ (៣) ជាស្ថានភាពមនុស្សខាងសាច់ឈាម ។

*ជាលិកា រូបកាយ៖* សត្វទាំងប៉ុន្មាននឹងបានជាអាហារសំរាប់អ្នក, **លោកុ.** ៩:៣ ។ សត្វទាំងប៉ុន្មានមិនត្រូវសម្លាប់ដោយឥតបង់ឡើយ, **ក.យ.ស., លោកុ.** ៩:១០–១១ (គ. និង ស. ៤៩:២១) ។ សត្វជើងបួន និងសត្វស្លាប គឺសំរាប់ឲ្យមនុស្សយកមកបរិភោគ និងសំរាប់ប្រើ ប្រាស់ជាសំលៀកបំពាក់, **គ. និង ស.** ៤៩:១៨–១៩ (គ. និង ស. ៥៩:១៦–២០) ។ ពួកយើងរាល់គ្នាគួរបរិភោគសាច់ដោយសំចៃ, **គ. និង ស.** ៨៩:១២–១៥ ។

*ភាពដែលរមែងស្លាប់៖* ព្រះយេស៊ូវ គឺជាព្រះរាជបុត្រាបង្កើតតែមួយ នៃព្រះវរបិតាក្នុងភាពដែលរមែងស្លាប់, **យ៉ូហាន** ១:១៤ (ម៉ូសាយ ១៥:១–៣) ។ អ័ដាមបានក្លាយទៅជាសាច់ទីមួយ, **ម៉ូសេ** ៣:៧ ។

*ស្ថានភាពមនុស្សខាងសាច់ឈាម៖* ត្រូវបណ្តាសាហើយ អ្នកណាដែលយកសាច់ឈាមជាដៃរបស់ខ្លួន, **យេរេ.** ១៧:៥ ។ វិញ្ញាណប្រុងស្រេចមែន តែសាច់ឈាមខ្សោយទេ, **ម៉ាកុស** ១៤:៣៨ ។ សេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម នោះមិនកើតមកពីព្រះ វរបិតាទេ, **១ យ៉ូហាន** ២:១៦ ។ នីហ្វៃមានទុក្ខព្រួយ ព្រោះតែសាច់ឈាម និងអំពើទុច្ចរិតរបស់លោក, **២ នីហ្វៃ** ៤:១៧–១៨, ៣៤ ។ ចូរកុំស្រុះស្រួលនឹងអារក្ស ហើយនិងសាច់ឈាមឡើយ, **២ នីហ្វៃ** ១០:២៤ ។

**សាតាំង** *សូមមើល* អារក្ស

**សានហេទ្រិន** *សូមមើលផង* ពួកសាសន៍យូដា

ជាព្រឹទ្ធសភាសាសន៍យូដា ហើយជាតុលាការដ៏ខ្ពស់របស់សាសន៍យូដា ផ្នែកខាងរដ្ឋការ និងខាងសាសនា ។ ក្រុមជំនុំសានហេទ្រិន មានសមាជិក ៧១ នាក់ ដែលជំរើសចេញពីចំណោមពួកសង្ឃជាន់ខ្ពស់ ពួកអាចារ្យ និងពួកអែលឌើរ ។ នៅក្នុងព្រះគម្ពីរ ជួនកាល គេហៅ ក្រុមជំនុំនេះថា ក្រុមប្រឹក្សា (ម៉ាថាយ ២៦:៥៩; ម៉ាកុស ១៤:៥៥; កិច្ចការ ៥:៣៤) ។

**សាប់យូល៉ូន** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់យ៉ាកុប និងនាងលេអា (លោកុ. ៣០:១៩–២០) ។

*ពូជអំបូររបស់សាប់យូល៉ូន៖* យ៉ាកុបបានប្រទានពរដល់ពូជអំបូររបស់សាប់យូល៉ូន (លោកុ. ៤៩:១៣) ។ ពូជអំបូររបស់សាប់យូល៉ូន បានរួមដៃនឹងដេបូរ៉ា និងបារ៉ាក ក្នុងចំបាំងទាស់នឹងពួកខ្មាំងសត្រូវនៃពួកអ៊ីស្រាអែល (ពួកចៅ. ៤:៤–៦, ១០) ។ ពួកគេបានរួមដៃនឹង គេឌាន ក្នុងចំបាំងនឹងពួកសាសន៍ម៉ាឌាន (ពួកចៅ. ៦:៣៣–៣៥) ។

**សាម៉ារី** *សូមមើលផង* ពួកសាសន៍សាម៉ារី

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជារាជធានី នៃនគរអ៊ីស្រាអែលខាងជើង (១ ពង្សាវ. ១៦:២៣–២៤) ។ មកពីមានទីតាំងទាហានដ៏ មាំមួនមួយនៅលើភ្នំ ទើបពួកសាសន៍អាសស៊ើរពុំអាចរឹបយកបានឡើយ រហូតដល់

មានចំពាំងរយៈពេលបីឆ្នាំក្រោយមក (២ពង្សាវ. ១៧:៥–៦) ។ ហេរ៉ូឌបានតាំងទីក្រុងនេះឡើងវិញ ហើយហៅថា សេបាស្ទី ។ នៅសម័យព្រះគម្ពីរសញ្ញាថ្មី ក្រុងសាម៉ារី គឺជាឈ្មោះឃុំ ទាំងមូលនៃស្រុកភីលីស្ទីន នៅខាងលិចយ័រដាន់ ។

**សារ៉ាយ** *សូមមើលផង* លីហៃ, ឪពុករបស់នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន គឺជាប្រពន្ធរបស់លីហៃ (១ នីហ្វៃ ៥:១–៨; ៨:១៤–១៦; ១៨:១៩) ហើយជាម្ដាយរបស់លេមិន លេមយួល សាំ នីហ្វៃ យ៉ាកុប យ៉ូសែប និងកូនស្រីទាំងឡាយ (១ នីហ្វៃ ២:៥; ២ នីហ្វៃ ៥:៦) ។

**សារ៉ាហិមឡា** *សូមមើលផង* មូលេក, អាំម៉ូន

នៅក្នុងព្រះគម្ពីរមរមន សារ៉ាហិមឡាគឺសំដៅដល់ (១) ជាបុរសម្នាក់ដែលបាននាំក្រុមរបស់មូលេក (២) ជាទីក្រុងមួយ ដែលបានដាក់តាមឈ្មោះរបស់លោក (៣) ដែនដីសារ៉ាហិមឡា ឬ(៤) ជាបណ្ដាជនដែលដើរតាមលោក ។

សារ៉ាហិមឡាក៏រីករាយជាខ្លាំង ដែលព្រះអម្ចាស់ទ្រង់បានបញ្ជូនពួកសាសន៍នីហ្វៃមក, **អោមណៃ** ១:១៤ ។ សារ៉ាហិមឡាបានប្រាប់អំពីពង្សាវតាររបស់ពួកអយ្យកោ, **អោមណៃ** ១:១៨ ។ អាំម៉ូនជាពូជពង្សពីសារ៉ាហិមឡា, **ម៉ូសាយ** ៧:៣, ១៣ ។ សាសនាចក្រត្រូវបានតាំងឡើង នៅក្នុងទីក្រុងសារ៉ាហិមឡា, **អាលម៉ា** ៥:២ ។ ដោយសារពួកសុចរិត នោះពួកទុច្ចរិតត្រូវបានសង្គ្រោះ នៅសារ៉ាហិមឡា, **ហេលេ.** ១៣:១២ ។ ទីក្រុងសារ៉ាហិមឡាត្រូវបានឆេះ កាលព្រះគ្រីស្ទទ្រង់សុគត, ៣ នីហ្វៃ ៨:៨, ២៤ ។

**សាលានៃពួកព្យាការី** *សូមមើលផង* យ៉ូសែប ជុញ៉ូរ, ស្ម៊ីធ

នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ (សហរដ្ឋ) នៅរដូវរងាក្នុងឆ្នាំ ១៨៣២–១៨៣៣ នោះព្រះអម្ចាស់ទ្រង់បានបញ្ជាយ៉ូសែប ស្ម៊ីធឲ្យរៀបចំធ្វើសាលាមួយ ប្រយោជន៍នឹងបង្ហាត់ពួកបងប្អូនប្រុសៗ អំពីអ្វីៗទាំងអស់ដែលទាក់ទងទៅនឹងដំណឹងល្អ និងនគរព្រះ ។ ចេញពី សាលានេះ មានពួកអ្នកដឹកនាំដំបូងជាច្រើននៃសាសនាចក្រ ។ សាលាមួយទៀតនៃពួកព្យាការី ឬនៃពួកអែលឌើរ នោះបានចាត់ចែង ដោយប៉ាលី ភី ប្រាត្ត នៅឃុំចាកសុន រដ្ឋមិសសួរី (គ. និង ស. ៩៧:១–៦) ។ មានសាលាប្រហែលគ្នានឹងសាលាទាំងនេះ បានបើក ក្រោយពីពួកបរិសុទ្ធបានផ្លាស់ទីលំនៅទៅទៅភូមិភាគខាងលិច ប៉ុន្តែមិនយូរប៉ុន្មានសាលាទាំងនោះក៏បិទទ្វារចោលទៅ ។ សព្វថ្ងៃនេះ ការបង្រៀនដំណឹងល្អ គឺធ្វើនៅឯផ្ទះ នៅឯក្រុមទាំងឡាយនៃបព្វជិតភាព និងនៅឯអង្គការផ្សេងៗទៀត និងតាមរយៈសាលាទាំងឡាយ និងសិក្ខាសាលា និងថ្នាក់ទាំងឡាយនៃវិជ្ជាស្ថាន នៅក្នុងសាសនាចក្រ ។

ចូរញែកខ្លួនជាបរិសុទ្ធ ហើយបង្រៀនគ្នាទៅវិញទៅមក នូវគោលលទ្ធិនៃនគរ, **គ. និង ស.** ៨៨:៧៤–៨០ ។ ចូរអ្នករាល់គ្នាព្យាយាម ស្វែងរក ហើយបង្រៀនគ្នាទៅវិញទៅមក, **គ. និង ស.** ៨៨:១១៨–១២២ ។ របៀបសាលារបស់ពួកព្យាការីត្រូវបានតាំងឡើង, **គ. និង ស.** ៨៨:១២៧–១៤១ ។ គណៈប្រធានទីមួយកាន់កូនសោទាំងឡាយនៃសាលានៃពួកព្យាការី, **គ. និង ស.** ៩០:៦–៧ ។

**សាលាប្រជុំ** *សូមមើលផង* ពួកសាសន៍យូដា

ជាកន្លែងប្រជុំមួយ ទុកប្រើសំរាប់ការងារខាងសាសនា ។ នៅសម័យព្រះគម្ពីរសញ្ញាថ្មី គ្រឿងសង្ហារឹម មានលក្ខណៈសាមញ្ញ គឺមានហឹបដាក់រមូរក្រិត្យវិន័យ និងការនិពន្ធពិសិដ្ឋទាំងឡាយ មានតុសំរាប់អាន និងកន្លែងអង្គុយសំរាប់ពួកអ្នកថ្វាយបង្គំ ។

ក្រុមអែលឌើរប្រចាំតំបន់ ត្រូវមើលគន់សាលាប្រជុំនីមួយៗ ។ ពួកគេសំរេចចិត្តថាតើនរណាគួរចូល និងនរណាមិនគួរចូល (យ៉ូហាន ៩:២២; ១២;៤២) ។ មេចាត់ការសំខាន់បំផុត គឺជាមេសាលាប្រជុំ (លូកា ១៣:១៤; ម៉ាកុស ៥:២២) ។ តាមធម្មតា លោកជា អាចារ្យដែលថែរក្សាអាគារ ហើយចាត់ចែងកិច្ចការទាំងឡាយ ។ អ្នកចូលរួមម្នាក់បានធ្វើកិច្ចការនៃបព្វជិត (លូកា ៤:២០) ។

មានសាលាប្រជុំមួយ នៅគ្រប់ក្រុង ដែលមានពួកសាសន៍យូដាអាស្រ័យនៅ នៅស្រុកគីលីស្ទី ព្រមទាំងនៅកន្លែងឯទៀត ។ នេះគឺជា ជំនួយដ៏ធំមួយ ក្នុងការផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ពីព្រោះពួកអ្នកផ្សាយសាសនាមុនដំបូង នៃសាសនាចក្រ អាចនិយាយនៅ ក្នុងសាលាប្រជុំទៅ (កិច្ចការ ១៣:៥, ១៤; ១៤:១; ១៧:១, ១០; ១៨:៤) ។ របៀបផ្សាយបែបនេះ មាននៅក្នុងចំណោមពួកអ្នក ផ្សាយសាសនា នៅក្នុងព្រះគម្ពីរមរមន (អាលម៉ា ១៦:១៣; ២១:៤–៥; ៣២:១), ព្រមទាំងនៅក្នុងចំណោមពួកអ្នកផ្សាយសាសនា មុនៗ នៅក្នុងសម័យកាន់កាប់ត្រួតត្រានេះដែរ (គ. និង ស. ៦៦:៧; ៦៨:១) ។

**សាវក** *សូមមើលផង* សិស្ស; វិវរណៈ

ក្នុងភាសាក្រេក សាវក មានន័យថា « អ្នកដែលចាត់ឲ្យចេញទៅ » ។ គឺជាឈ្មោះដែលព្រះយេស៊ូវបានដាក់ឲ្យពួក ១២ នាក់ ដែល ទ្រង់បានរើស ហើយបានតែងតាំងឲ្យធ្វើជាសិស្សដ៏ជិតស្និទ្ធបំផុតរបស់ទ្រង់ ហើយជាអ្នកជំនួយទ្រង់ នៅគ្រាទ្រង់គង់នៅលើផែនដី (លូកា ៦:១៣; យ៉ូហាន ១៥:១៦) ។ ទ្រង់បានចាត់ពួកគេឲ្យចេញទៅធ្វើជាតំណាងទ្រង់ ហើយបំរើជំនួសទ្រង់ ក្រោយពីទ្រង់បានយាងឡើង ទៅលើស្ថានសួគ៌ ។ តាំងពីបុរាណមក និងនៅក្នុងក្រុមសាវក ១២ នាក់ ក្នុងសាសនាចក្រដែលបានសាងឡើងវិញ នៅសព្វថ្ងៃនេះ សាវក គឺជាសាក្សីពិសេសមួយនៃព្រះយេស៊ូវគ្រីស្ទ ចំពោះពិភពលោកទូទៅ ដើម្បីធ្វើបន្ទាល់អំពីទេវភាពរបស់ទ្រង់ និងអំពីដំណើរដែល ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ (កិច្ចការ ១:២២; គ. និង ស. ១០៧:២៣) ។

សាសនាចក្ររបស់ព្រះគ្រីស្ទត្រូវបានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកព្យាការី, **អេភេ.** ២:២០; ៤:១១ ។ លីហៃ និងនីហ្វៃ បានឃើញពួកសាវក ១២ នាក់ ដើរតាមព្រះយេស៊ូវ, **១ នីហ្វៃ** ១:១០; ១១:៣៤ ។ ពួកសាវកត្រូវជំនុំជំរះវង្សអ៊ីស្រាអែល, **មរមន** ៣:១៨ ។

អស់អ្នកណាដែលលែងស្តាប់តាមពាក្យសំដីនៃពួកព្យាការី និងពួកសាវក នោះនឹងត្រូវកាត់ចេញ, **គ. និង ស.** ១:១៤ (៣ នីហ្វៃ ១២:១) ។ ការងារ និងបេសកកម្មរបស់ពួក ១២ នាក់ ត្រូវបានបើកសម្តែងប្រាប់, **គ. និង ស.** ១៨:២៦–៣៦ ។ យ៉ូសែប ស៊្មីធ ត្រូវបានតែងតាំងជាសាវក, **គ. និង ស.** ២០:២; ២១:១ ។ ពួកសាវកជាពួកសាក្សីពិសេសអំពីព្រះនាមនៃព្រះគ្រីស្ទ ហើយកាន់កូនសោ ទាំងឡាយខាងការងារបំរើ, **គ. និង ស.** ២៧:១២ (គ. និង ស. ១១២:៣០–៣២) ។ ពួកសាវក ១២ នាក់ធ្វើជាក្រុមមួយ ដោយមាន សិទ្ធិអំណាចស្មើគ្នានឹងប្រធានទីមួយ, **គ. និង ស.** ១០៧:២៣–២៤ ។ ពួក ១២ នាក់គឺជាក្រុមប្រឹក្សាត្រួតត្រាជាន់ខ្ពស់ដែលធ្វើដំណើរ, **គ. និង ស.** ១០៧:៣៣ ។ ពួកសាវកកាន់កូនសោទាំងឡាយខាងកិច្ចការផ្សាយសាសនា, **គ. និង ស.** ១០៧:៣៥ ។ ភារកិច្ចខ្លះរបស់ ពួកសាវកត្រូវបានរៀបរាប់ប្រាប់, **គ. និង ស.** ១០៧:៥៨ ។ យើងប្រាប់ដល់គ្រប់ពួក ១២ នាក់ថា៖ ចូរដើរតាមយើង ហើយឲ្យចំណីដល់ ចៀមយើងចុះ, **គ. និង ស.** ១១២:១៤–១៥ ។ យើងខ្ញុំជឿពួកសាវក, **ម. នៃ ស.** ១:៦ ។

*ការជ្រើសរើសពួកសាវក៖* ពួកសាវកត្រូវបានរើសដោយព្រះអម្ចាស់ (យ៉ូហាន ៦:៧០; ១៥:១៦) ។

ព្រះយេស៊ូវទ្រង់បានរើសពួកសាវក ១២ នាក់ ពីពួកសិស្សរបស់ទ្រង់, **លូកា** ៦:១៣–១៦ ។ ម៉ាត់ធាសត្រូវបានរើសឲ្យធ្វើជាសាវក, **កិច្ចការ** ១:២១–២៦ ។ អូលីវើរ ខៅឌើរី និងដាវីឌ វិតមើរត្រូវបានបញ្ជាឲ្យស្វែងរកពួក ១២ នាក់, **គ. និង ស.** ១៨:៣៧–៣៩ ។

**សាសនាចក្រ, ដ៏ធំ ហើយគួរខ្ពើមឆ្អើម** *សូមមើល* អារក្ស — សាសនាចក្រនៃអារក្ស

**សាសនាចក្រ, នាមនៃ** *សូមមើលផង* ពួកមរមន, សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ; សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

នៅក្នុងព្រះគម្ពីរមរមន កាលព្រះយេស៊ូវគ្រីស្ទ ទ្រង់យាងមកជួបពួកសាសន៍នីហ្វៃដែលសុចរិត មិនយូរប៉ុន្មានបន្ទាប់ពីដំណើររស់ឡើង វិញរបស់ទ្រង់ នោះទ្រង់មានព្រះបន្ទូលថា សាសនាចក្ររបស់ព្រះអង្គ គួរតែមាននាមព្រះអង្គ (៣ នីហ្វៃ ២៧:៣–៨) ។ នៅសម័យ ទំនើបនេះ ព្រះអម្ចាស់ទ្រង់បានបើកសម្តែងប្រាប់នាមនៃសាសនាចក្រថា « សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ » (គ. និង ស. ១១៥:៤) ។

**សាសនាចក្រដ៏គួរខ្ពើមឆ្អើម** *សូមមើល* អារក្ស-សាសនាចក្ររបស់អារក្ស

**សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើម** *សូមមើល* អារក្ស — សាសនាចក្រនៃអារក្ស

**សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ** *សូមមើលផង* ការសាងឡើងវិញនៃដំណឹងល្អ; ទីសំគាល់នៃ; នគរព្រះ ឬ នគរស្ថានសួគ៌; នាមនៃ; សាសនាចក្រ, សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ; សាសនាចក្រពិត, អ្នកបរិសុទ្ធ

ជាអង្គការមួយរបស់ពួកអ្នកជឿ ដែលបានទទួលយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទដាក់លើខ្លួន ដោយសារបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។ ដើម្បីឲ្យបានទៅជាសាសនាចក្រពិត នោះត្រូវទៅជាសាសនាចក្ររបស់ព្រះអម្ចាស់; ត្រូវមានសិទ្ធិអំណាច សេចក្តីបង្រៀន ក្រិត្យវិន័យ ពិធីបរិសុទ្ធទាំងឡាយ និងព្រះនាមរបស់ទ្រង់; ហើយត្រូវត្រួតត្រាតាមរយៈពួកអ្នកតំណាង ដែលទ្រង់បានតាំងឡើង ។

ព្រះអម្ចាស់ទ្រង់ក៏បន្ថែមមនុស្សរាល់តែថ្ងៃទៅក្នុងសាសនាចក្រថែមទៀត, **កិច្ចការ** ២:៤៧ ។ យើងដែលមានគ្នាច្រើន ក៏ជារូបកាយតែ មួយក្នុងព្រះគ្រីស្ទ, **រ៉ូម** ១២:៥ ។ ដោយសារព្រះវិញ្ញាណតែមួយ នោះយើងបានទទួលបុណ្យជ្រមុជទឹកចូលក្នុងរូបកាយតែមួយ, **១ កូរិន.** ១២:១៣ ។ សាសនាចក្របានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកព្យាការី, **អេភេ.** ២:១៩–២០ ។ ពួកសាវក និងពួក ព្យាការីជាអ្នកសំខាន់ចំពោះសាសនាចក្រ, **អេភេ.** ៤:១១–១៦ ។ ព្រះគ្រីស្ទជាសិរសានៃសាសនាចក្រ, **អេភេ.** ៥:២៣ ។ ទោះជាមាន សាសនាចក្រច្រើនក៏ដោយ គង់តែពួកគេទាំងអស់ជាសាសនាចក្រតែមួយដែរ, **ម៉ូសាយ** ២៥:១៩–២២ ។ សាសនាចក្របានត្រូវសំអាត ហើយចាត់ឲ្យមានរបៀបរៀបរយ, **អាលម៉ា** ៦:១–៦ ។ សាសនាចក្ររបស់ព្រះគ្រីស្ទត្រូវតែហៅតាមព្រះនាមទ្រង់, ៣ នីហ្វៃ ២៧:៨ ។ សាសនាបានរួមប្រជុំគ្នាជាញឹកញាប់ ដើម្បីតមអាហារ អធិស្ឋាន ហើយពិគ្រោះគ្នា, **មរ៉ូណៃ** ៦:៥ ។ គឺជាសាសនាចក្រតែមួយដែលពិត ហើយសកម្ម, **គ. និង ស.** ១:៣០ ។ សាសនាចក្រនៃព្រះគ្រីស្ទបានសាងឡើងនៅថ្ងៃចុងក្រោយបង្អស់, **គ. និង ស.** ២០:១ ។ ព្រះអម្ចាស់ទ្រង់ ហៅពួកអ្នកបំរើទ្រង់ឲ្យស្ថាបនាសាសនាចក្ររបស់ទ្រង់ឡើង, **គ. និង ស.** ៣៩:១៣ ។ ត្បិតសាសនាចក្ររបស់យើង នឹងត្រូវបានហៅថាដូច្នោះហើយ នៅថ្ងៃចុងក្រោយបង្អស់, **គ. និង ស.** ១១៥:៤ ។

**សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ** *សូមមើលផង* ការសាងឡើងវិញនៃដំណឹងល្អ, ទីសំគាល់នៃ; នាមនៃ; សាសនាចក្រ, សាសនាចក្រនៃព្រះយេស៊ូវ គ្រីស្ទ; សាសនាចក្រពិត

ជាឈ្មោះដែលឲ្យដល់សាសនាចក្រនៃព្រះគ្រីស្ទ នៅថ្ងៃចុងក្រោយ ដើម្បីញែកចេញពីសាសនាចក្រនៅក្នុងការកាន់កាប់ត្រួតត្រា ផ្សេងៗទៀត, (គ. និង .ស. ១១៥:៣–៤) ។

ព្រះអម្ចាស់ទ្រង់នឹងចាក់ដំរិះមកលើក្បាលនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.** ១២១:៣៣ ។ យ៉ូសែប ស៊្មីធ ជាព្យាការី និងអ្នក មើលឆុតនៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.**

១២៧:១២ ។ ថ្ងៃដ៏ធំនៃព្រះអម្ចាស់នៅជិត ដែលបង្អើយ ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.** ១២៨:២១, ២៤ ។ យ៉ូសែប ស្ម៊ីធ បានជួយប្រមូលពួកបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.** ១៣៥:៣ ។ ក្រុមទាំងឡាយនៃពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវរៀបចំធ្វើដំណើរទៅភូមិភាគខាងលិចនៃសហរដ្ឋ, **គ. និង ស.** ១៣៦:២ ។ ក្រិត្យវិន័យទាំងឡាយអំពីអាពាហ៍ពិពាហ៍ត្រូវបានបញ្ជាក់ប្រាប់ដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ, **គ. និង ស.** សេចក្ដីប្រកាសទី ១ —— បព្វជិតភាពត្រូវបានប្រគល់ដល់សមាជិកប្រុសៗណាដែលសិក្ដិសម នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ, **គ. និង ស.** សេចក្ដីប្រកាសទី ២ —— ដំណើររឿងអំពីការនិមិត្តទីមួយ ត្រូវបានប្រាប់ដល់គ្រប់ទាំងពួកបរិសុទ្ធថ្ងៃចុងក្រោយ, **យ.ស. —— ប្រវត្តិ** ១:១ ។

**សាសនាចក្រពិត, ទីសំគាល់នៃ** *សូមមើលផង* ទីសំគាល់, សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ; សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ

គោលលទ្ធិ និងកិច្ចការទាំងឡាយ នៃសាសនាចក្រមួយ ដែលបង្ហាញថា ព្រះទ្រង់បានយល់ព្រម ហើយជាមធ្យោបាយមួយ ដែលព្រះអម្ចាស់ទ្រង់តាំងឡើង ដើម្បីឲ្យកូនចៅទ្រង់មានព្រះពរដ៏ពោរពេញរបស់ព្រះអង្គ ។ ទីសំគាល់ខ្លះនៃសាសនាចក្រពិតមានដូចតទៅនេះ៖

*យោបល់ច្បាស់លាស់អំពីក្រុមព្រះ៖* ព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចជារូបព្រះអង្គទ្រង់, **លោកុ.** ១:២៦–២៧ ។ ព្រះអម្ចាស់ទ្រង់មាន បន្ទូលប្រទល់មុខនឹងម៉ូសេ, **និក្ខ.** ៣៣:១១ ។ ជីវិតដ៏នៅអស់កល្បជានិច្ច គឺឲ្យបានស្គាល់ព្រះដ៏ជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ, **យ៉ូហាន** ១៧:៣ ។ ព្រះវរបិតា និងព្រះរាជបុត្រា មានព្រះកាយជាសាច់ និងឆ្អឹង, **គ. និង ស.** ១៣០:២២–២៣ ។ ព្រះវរបិតា និងព្រះ រាជបុត្រាបានលេចមកឲ្យយ៉ូសែប ស្ម៊ីធឃើញ, **យ.ស. —— ប្រវត្តិ** ១:១៥–២០ ។ យើងខ្ញុំជឿដល់ព្រះ គឺព្រះវរបិតាដ៏គង់នៅអស់កល្ប ជានិច្ច, **ម. នៃ ស.** ១:១ ។

*គោលការណ៍ និងពិធីបរិសុទ្ធទី១៖* លើកលែងតែមនុស្សម្នាក់បានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ, **យ៉ូហាន** ៣:៣–៥ ។ ចូរអ្នក រាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ, **កិច្ចការ** ២:៣៨ ។ រួចគេក៏ដាក់ដៃលើគេ ហើយគេបានទទួលព្រះវិញ្ញាណបរិសុទ្ធ, **កិច្ចការ** ៨:១៤–១៧ ។ ត្រឡប់ទៅជាកូនចៅព្រះ ដោយសារសេចក្ដីជំនឿដល់ព្រះ យេស៊ូវគ្រីស្ទ, **កាឡាទី** ៣:២៦–២៧ ។ ចូរអ្នកប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមនៃព្រះរាជបុត្រា ដ៏ជាទីសំឡាញ់ របស់យើងចុះ, **២ នីហ្វៃ** ៣១:១១–២១ ។ ពួកអ្នកដែលជឿ បានទទួលបុណ្យជ្រមុជទឹក ហើយទទួលយកព្រះវិញ្ញាណបរិសុទ្ធ ដោយ សារការដាក់ដៃលើ, **គ. និង ស.** ៧៦:៥០–៥៣ ។ ត្រូវការឲ្យមានបព្វជិតភាពត្រឹមត្រូវដើម្បីធ្វើបុណ្យជ្រមុជទឹក និងប្រទានអំណោយ ទានជាព្រះវិញ្ញាណបរិសុទ្ធ, **យ.ស. —— ប្រវត្តិ** ១:៧០–៧២ ។ គោលការណ៍ និងពិធីបរិសុទ្ធទីមួយ នៃដំណឹងល្អបានត្រូវអធិប្បាយប្រាប់, **ម. នៃ ស.** ១:៤ ។

*វិវរណៈ៖* គ្រាណាដែលឥតមានការបើកសម្ដែង នោះបណ្ដាជនវមែងលែងទប់ចិត្ត, **សុភា.** ២៩:១៨ ។ ព្រះអម្ចាស់ទ្រង់សម្ដែងឲ្យ ពួកព្យាការីរបស់ទ្រង់ឃើញគំនិតលាក់កំបាំងរបស់ទ្រង់, **អេម៉ុស** ៣:៧ ។ ពួកជំនុំបានតាំងនៅលើថ្មដានៃវិវរណៈ, **ម៉ាថាយ** ១៦:១៧–១៨ (គ. និង ស. ៣៣:១៣) ។ វេទនាដល់ជនណា ដែលនឹងថាព្រះអម្ចាស់ទ្រង់ឈប់ធ្វើការដោយ វិវរណៈហើយ, ៣ នីហ្វៃ ២៩:៦ ។ វិវរណៈ និងបញ្ញត្តិទាំងឡាយមានមកតាមរយៈអ្នកដែលបានតាំងឡើងប៉ុណ្ណោះ, **គ. និង ស.** ៤៣:២–៧ ។ យើងខ្ញុំជឿចំពោះការណ៍ ទាំងអស់ ដែលទ្រង់បានបើកសម្ដែងមក, **ម. នៃ ស.** ១:៩ ។

*ពួកព្យាការី៖* សាសនាចក្របានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកព្យាការី, **អេភេ.** ២:១៩–២០ ។ ពួកសាវក និងពួក ព្យាការីជាអ្នកសំខាន់ចំពោះសាសនាចក្រ, **អេភេ.** ៤:១១–១៦ ។ យ៉ូសែប ស្ម៊ីធ បានត្រូវហៅឲ្យធ្វើជាអ្នកមើលឆុត ជាព្យាការី ហើយជា សាវក, **គ. និង ស.** ២១:១–៣ ។ ពួកយើងខ្ញុំជឿពួកព្យាការី, **ម. នៃ ស.** ១:៦ ។

*សិទ្ធិអំណាច៖* ព្រះយេស៊ូវទ្រង់បានប្រទានឲ្យពួកសិស្សទ្រង់ មានអំណាច និងសិទ្ធិអំណាច, **លូកា** ៩:១–២ (យ៉ូហាន ១៥:១៦) ។ នីហ្វៃ ជាកូនប្រុសរបស់ហេលេមិន មានសិទ្ធិអំណាចដ៏ធំអំពីព្រះ, **ហេលេ.** ១១:១៨ (៣ នីហ្វៃ ៧:១៧) ។ ព្យាការីត្រូវទទួលបញ្ញត្តិទាំង ឡាយ សំរាប់សាសនាចក្រ, **គ. និង ស.** ២១:៤–៥ ។ គ្មានអ្នកណាមួយអាចផ្សាយដំណឹងល្អ ឬស្ថាបនាសាសនាចក្រឡើងបានឡើយ លើកលែងតែអ្នកនោះបានតែងតាំងឡើង, **គ. និង ស.** ៤២:១១ ។ ពួកអែលឌើរត្រូវផ្សាយដំណឹងល្អ ដោយធ្វើការដោយនូវសិទ្ធិ អំណាច, **គ. និង ស.** ៦៨:៨ ។ អ្នកណាក៏ដោយដែលផ្សាយ ឬធ្វើការងារបំរើជំនួសព្រះ នោះត្រូវតែបានហៅពីព្រះ ដោយអស់អ្នក ណាដែលមានសិទ្ធិអំណាច, **ម. នៃ ស.** ១:៥ ។

*ព្រះគម្ពីរបន្ថែមទៀតនឹងមាននៅថ្ងៃមុខ៖* បន្ទះឈើនៃយូដានឹងរួមជាមួយនឹងបន្ទះឈើនៃយ៉ូសែប, **អេសេ.** ៣៧:១៥–២០ ។ ការចេញមកនៃព្រះគម្ពីរនៅថ្ងៃចុងក្រោយបានត្រូវប្រាប់ទុកជាមុន, **១ នីហ្វៃ** ១៣:៣៨–៤១ ។ យើងខ្ញុំជឿថា ទ្រង់នឹងបើកសម្ដែងនូវការណ៍ដ៏ធំ និងសំខាន់ៗជាច្រើន, **ម. នៃ ស.** ១:៩ ។

*ការកសាងនៃសាសនាចក្រ៖* សាសនាចក្របានស្អាងឡើង លើជើងជញ្ជាំងនៃពួកសាវក និងពួកព្យាការី, **អេភេ.** ២:១៩–២០ ។ ពួកសាវក និងពួកព្យាការីជាអ្នកសំខាន់ចំពោះសាសនាចក្រ, **អេភេ.** ៤:១១–១៦ ។ ព្រះគ្រីស្ទ ជាសិរសារនៃសាសនាចក្រ, **អេភេ.** ៥:២៣ ។ សាសនាចក្ររបស់ព្រះគ្រីស្ទត្រូវតែហៅតាមព្រះនាមទ្រង់, ៣ នីហ្វៃ ២៧:៨ ។ យើងខ្ញុំជឿចំពោះការរៀបចំដូចគ្នា ដូចដែលមាននៅក្នុងសាសនាចក្រពីអតីតកាល, **ម. នៃ ស.** ១:៦ ។

*កិច្ចការខាងការផ្សាយសាសនា៖* ដូច្នេះ ចូរទៅបង្រៀនគ្រប់ទាំងសាសន៍, **ម៉ាថាយ** ២៨:១៩–២០ ។ ពួក ៧០ នាក់ ក៏បានត្រូវ ហៅឲ្យទៅផ្សាយដំណឹងល្អ, **លូកា** ១០:១ ។ ពួកគេចង់ឲ្យសេចក្ដីសង្គ្រោះបានប្រកាសដល់សត្វលោកគ្រប់រូប, **ម៉ូសាយ** ២៨:៣ ។ ពួកអែលឌើរ

ត្រូវចេញទៅផ្សាយដំណឹងល្អពីរនាក់ៗ, **គ. និង ស.** ៤២:៦ ។ ដំណឹងល្អត្រូវបានផ្សាយដល់សត្វលោកគ្រប់រូប, **គ. និង ស.** ៥៨:៦៤ ។

*អំណោយទានទាំងឡាយខាងវិញ្ញាណ៖* គេក៏តាំងនិយាយភាសាផ្សេងៗ, **កិច្ចការ** ២:៤ ។ ពួកអែលឌើរត្រូវប្រោស ឲ្យមនុស្សឈឺ បានជា, **យ៉ាកុប** ៥:១៤ ។ កុំបដិសេធអំណោយទាននៃព្រះឡើយ, **មរ៉ូណៃ** ១០:៨ ។ អំណោយទានទាំងឡាយខាងវិញ្ញាណត្រូវបាន រាយប្រាប់, **គ. និង ស.** ៤៦:១៣–២៦ (១ កូរិន. ១២:១–១១; មរ៉ូណៃ ១០:៩–១៨) ។

*ព្រះវិហារ៖* យើងនឹងតាំងសេចក្ដីសញ្ញា ព្រមទាំងដាក់ទីបរិសុទ្ធរបស់យើង នៅកណ្ដាលគេឲ្យនៅអស់កល្បជានិច្ច, **អេសេ.** ៣៧:២៦–២៧ ។ ព្រះអម្ចាស់ទ្រង់នឹងលោតែមកដល់ព្រះវិហាររបស់ទ្រង់ភ្លាម, **ម៉ាឡាគី** ៣:១ ។ នីហ្វៃបានសង់ព្រះវិហារមួយ, **២ នីហ្វៃ** ៥:១៦ ។ ពួកបរិសុទ្ធត្រូវបានបន្ទោសផ្ទាល ដោយមិនបានសង់ព្រះដំណាក់នៃព្រះអម្ចាស់, **គ. និង ស.** ៩៥ (គ. និង ស. ៨៨:១១៩) ។ រាស្ត្ររបស់ ព្រះអម្ចាស់សង់ព្រះវិហារសំរាប់ប្រព្រឹត្តពិធីបរិសុទ្ធទាំងឡាយរហូត, **គ. និង ស.** ១២៤:៣៧–៤៤ ។ ការសង់ព្រះវិហារ និងការប្រព្រឹត្ត ពិធីបរិសុទ្ធជាផ្នែកនៃកិច្ចការដ៏ធំនៅថ្ងៃចុងក្រោយ, **គ. និង ស.** ១៣៨:៥៣–៥៤ ។

## សាស្ដា

ជាគម្ពីរមួយក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមាននូវការជញ្ជឹងគិត អំពីបញ្ហាដ៏ជ្រាលជ្រៅខ្លះៗនៃជីវិត ។

អ្នកនិពន្ធគម្ពីរ គឺជាគ្រូប្រដៅ សរសេរក្នុងគម្ពីរភាគច្រើនអំពីគំនិតយោបល់នៃអស់អ្នកដែលគ្មានការយល់ដឹងខាងដំណឹងល្អ ។ លោក សរសេរតាមមនោសញ្ចេតនាមនុស្សលោក — គឺថា អស់អ្នក « នៅក្រោមថ្ងៃ » (សាស្ដា ១:៩) ។ ក្នុងគម្ពីរ មានភាគជាច្រើនដែល មើលទៅដូចមិនល្អ ហើយស្រពាប់ស្រពោន (សាស្ដា ៩:៥, ១០) ។ នេះគឺមិនមែនជាភាពដែលព្រះអម្ចាស់ ទ្រង់ចង់ឲ្យយើងមើលទៅជីវិតទេ ប៉ុន្តែផ្ទុយទៅវិញ គឺជាភាពដែលគ្រូប្រដៅបានពិនិត្យឃើញ នូវអ្វីៗដែលបង្ហាញដល់មនុស្សអ័ព្ភអួរនៅលើផែនដី ។ ផ្នែកសំខាន់បំផុតខាងវិញ្ញាណនៅក្នុងគម្ពីរ គឺនៅជំពូកទី ១១ និង ១២ ជាកន្លែងដែលអ្នកសរសេរបានបញ្ចប់ថា សេចក្ដីដែលមានតម្លៃដ៏វែងឆ្ងាយ គឺជាការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

**សាឡិម** *សូមមើលផង* មិលគីស្សាដែក, យេរូសាឡិម

ជាទីក្រុងមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមិលគីស្សាដែកបានគ្រប់គ្រង ។ ទីក្រុងនេះប្រហែលស្ថិតនៅចំកន្លែងក្រុងយេរូសាឡិម សព្វថ្ងៃនេះ ។ ឈ្មោះថា « សាឡិម » នេះស្រដៀងនឹងពាក្យហេព្រើរ ដែលមានន័យថា « សុខសាន្ត » ។

មិលគីស្សាដែក ជាស្ដេចក្រុងសាឡិម ក៏បាននាំយកនំបុ័ង និងស្រាទំពាំងបាយជូរមក, **លោកុ.** ១៤:១៨ ។ លោកមិលគីស្សាដែក ស្ដេចក្រុងសាឡិម ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត, **ហេព្រើរ** ៧:១–២ ។ មិលគីស្សាដែក គឺជាស្ដេចលើដែនដីសាឡិម, **អាលម៉ា** ១៣:១៧–១៨ ។

**សាឡូម៉ូន** *សូមមើលផង* ដាវីឌ, នាងបាតសេបា

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាបុត្ររបស់ដាវីឌ និងនាងបាតសេបា (២ សាំយូ. ១២:២៤) ។ សាឡូម៉ូនបានក្លាយជាស្ដេចអ៊ីស្រាអែលមួយគ្រា ។

ដាវីឌបានឲ្យសាឡូម៉ូនធ្វើជាស្ដេច, **១ ពង្សាវ.** ១:១១–៥៣ ។ ដាវីឌបានដាក់ក្រិត្យឲ្យសាឡូម៉ូន ដើរតាមផ្លូវនៃព្រះអម្ចាស់, **១ ពង្សាវ.** ២:១–៩ ។ ព្រះអម្ចាស់ទ្រង់បានសន្យានឹងប្រទានឲ្យលោក មានចិត្តប្រកបដោយប្រាជ្ញាវាងវៃ, **១ ពង្សាវ.** ៣:៥–១៥ ។ បានកាត់ក្ដីរវាង ម្ដាយពីរនាក់ ហើយបានស្គាល់ម្ដាយពិតនៃកូននោះ, **១ ពង្សាវ.** ៣:១៦–២៨ ។ បាននិពន្ធពាក្យសុភាសិត និងទំនុកចំរៀងទាំងឡាយ, **១ ពង្សាវ.** ៤:៣២ ។ បានសង់ព្រះវិហារ, **១ ពង្សាវ.** ៦; ៧:១៣–៥១ ។ បានធ្វើបុណ្យឆ្លងព្រះវិហារ, **១ ពង្សាវ.** ៨ ។ មហាក្សត្រីស្រុក សេបា បានយាងមករកទ្រង់, **១ ពង្សាវ.** ១០:១–១៣ ។ សាឡូម៉ូនបានអភិសេកយកភរិយាក្រៅពីសាសន៍អ៊ីស្រាអែល ហើយភរិយា ទ្រង់ទាំងប៉ុន្មានបានបង្វែរព្រះទ័យទ្រង់ឲ្យថ្វាយបង្គំព្រះក្លែងក្លាយ, **១ ពង្សាវ.** ១១:១–៨ ។ ព្រះអម្ចាស់ទ្រង់ក៏កើតមានសេចក្ដីខ្ញាល់នឹង សាឡូម៉ូន, **១ ពង្សាវ.** ១១:៩–១៣ ។ បានសុគត, **១ ពង្សាវ.** ១១:៤៣ ។ ដាវីឌបានព្យាករអំពីការរុងរឿងនៃរាជ្យសាឡូម៉ូន, **ទំនុក.** ៧២ ។ សាឡូម៉ូនមានភរិយា និងស្នំជាច្រើន ប៉ុន្តែពួកភរិយាខ្លះ នោះព្រះអម្ចាស់ទ្រង់មិនបានរាប់ទេ, **គ. និង ស.** ១៣២:៣៨ (យ៉ាកុប ២:២៤) ។

**សិស្ស***សូមមើលផង* ការប្រែចិត្តជឿ, នឹម, ប្រែចិត្តជឿ; ពួកគ្រីស្ទាន; សាវ័ក

ជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ដែលរស់នៅតាមការបង្រៀនរបស់ព្រះគ្រីស្ទ (គ. និង ស. ៤១:៥) ។ ពាក្យថា សិស្ស ត្រូវបានយកមកពណ៌នាអំពីពួកសាវ័ក ១២ នាក់ ដែលព្រះគ្រីស្ទបានហៅ កាលទ្រង់គង់នៅលើផែនដី (ម៉ាថាយ ១០:១–៤) ។ ពាក្យថា សិស្ស ក៏ត្រូវបានយកមកពណ៌នាអំពីពួកបុរស ១២ នាក់ ដែលព្រះយេស៊ូវទ្រង់បានរើសឲ្យដឹកនាំសាសនាចក្ររបស់ទ្រង់ នៅក្នុងចំណោមពួក សាសន៍នីហ្វៃ និងសាសន៍លេមិន (៣ នីហ្វៃ ១៩:៤) ។

ចូរបិទត្រាបញ្ញត្តិច្បាប់នៅក្នុងពួកសិស្សរបស់យើងចុះ, **អេសាយ** ៨:១៦ ។ បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្ស ខ្ញុំមែន, **យ៉ូហាន** ៨:៣១ ។ មរមនជាសិស្សនៃព្រះយេស៊ូវគ្រីស្ទ, ៣ នីហ្វៃ ៥:១២–១៣ ។ អ្នករាល់គ្នាជាសិស្សយើង, ៣ នីហ្វៃ ១៥:១២ ។ សិស្សបីនាក់នឹងមិនបានភ្លក់សេចក្ដីស្លាប់ឡើយ, ៣ នីហ្វៃ ២៨:៤–១០ ។ សម្លេងនៃការព្រមាននឹងត្រូវប្រាប់ដោយមាត់នៃ ពួកសិស្សទាំងឡាយរបស់យើង, **គ. និង ស.** ១:៤ ។ ពួកសិស្សរបស់យើងនឹងឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ, **គ. និង ស.** ៤៥:៣២ ។ អស់អ្នកណាដែលមិននឹកចាំពីមនុស្សទាល់ក្រ និងមនុស្សកំសត់ទុគិត និងពីមនុស្សឈឺ និងមនុស្សមានទុក្ខវេទនា នោះឈ្មោះថាមិនមែន ជាសិស្សរបស់យើងឡើយ, **គ. និង ស.** ៥២:៤០ ។ អស់អ្នកណាដែលមិនព្រមប្តូរជីវិតរបស់ខ្លួន នោះពុំមែនជាសិស្សរបស់យើងទេ, **គ. និង ស.** ១០៣:២៧–២៨ ។

**សិទ្ធិកូនច្បង** *សូមមើលផង* កូនច្បង, សេចក្តីសញ្ញា

ជាសិទ្ធិទទួលមរតក ចំពោះកូនប្រុសច្បង ។ តាមន័យទូទៅ សិទ្ធិកូនច្បង មានរួមទាំងសិទ្ធិណាមួយ ឬសិទ្ធិទាំងអស់ក្នុងការទទួលមរតក ដែលផ្ទេរទៅឲ្យជនណាមួយ ដែលកើតក្នុងគ្រួសារ និងវប្បធម៌ ។

សូមឲ្យបងផ្ទេរអំណាចមរតករបស់បងច្បងមកឲ្យខ្ញុំសិន, **លោកុ.** ២៥:២៩–៣៤ (លោកុ. ២៧:៣៦) ។ បងច្បងក៏អង្គុយតាមបងច្បង, **លោកុ.** ៤៣:៣៣ ។ លោកដាក់អេប្រាអិមមុនម៉ាន៉ាសេ, **លោកុ.** ៤៨:១៤–២០ (យេរេ. ៣១:៩) ។ អំណាចនៃបងច្បងទៅជារបស់ផងយ៉ូសែប, **១ របា.** ៥:២ ។ អេសាវបានលក់ច្បាប់បងច្បង, **ហេព្រើរ** ១២:១៦ ។ អ្នករាល់គ្នាជាអ្នកគ្រងមរតកពេញច្បាប់, **គ. និង ស.** ៨៦:៩ ។ ស៊ីយ៉ូនមានសិទ្ធិកាន់បព្វជិតភាពតាមវង្សត្រកូល, **គ. និង ស.** ១១៣:៨ (អ័ប្រា. ២:៩–១១) ។

**សិទ្ធិជ្រើសរើស** *សូមមើលផង* ការទទួលខុសត្រូវ; ចេះទទួលការខុសត្រូវ, ទទួលការខុសត្រូវ, សេរី, សេរីភាព

ជាសមត្ថភាព និងឯកសិទ្ធិដែលព្រះទ្រង់ប្រទានដល់មនុស្ស ដើម្បីជ្រើសរើស ហើយដើម្បីប្រព្រឹត្តដោយខ្លួនឯង ។

អ្នកនឹងបរិភោគផ្លែឈើទាំងអស់បានតាមចិត្ត, **លោកុ.** ២:១៦ ។ មនុស្សពុំអាចប្រព្រឹត្តអ្វីៗដោយខ្លួនឯងបានទេ លើកលែងតែមានអ្វី មកល្បួងគេ, **២ នីហ្វៃ** ២:១៥–១៦ ។ មនុស្សលោកមានសិទ្ធិនឹងរើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច ឬក៏ការឃុំឃាំង និងការស្លាប់, **២ នីហ្វៃ** ២:២៧ ។ អ្នករាល់គ្នាមានសេរីភាព; អ្នកត្រូវបានអនុញ្ញាតឲ្យធ្វើអ្វីៗដើម្បីខ្លួនឯង, **ហេលេ.** ១៤:៣០ ។ វាបាន បំបែរមួយភាគបីនៃពួកពលបរិវារស្ថានសួគ៌ចេញ ពីព្រោះតែសិទ្ធិជ្រើសរើសរបស់ពួកគេ, **គ. និង ស.** ២៩:៣៦ ។ ជាការចាំបាច់ណាស់ ថា អារក្សគួរល្បួងកូនចៅមនុស្ស បើពុំនោះសោតទេ ពួកគេពុំអាចធ្វើជាភ្នាក់ងារចំពោះខ្លួនបានឡើយ, **គ. និង ស.** ២៩:៣៩ ។ ចូរបណ្តោយឲ្យមនុស្សរាល់គ្នារើសសំរាប់ខ្លួនចុះ, **គ. និង ស.** ៣៧:៤ ។ មនុស្សគ្រប់រូបអាចប្រព្រឹត្តតាមសិទ្ធិជ្រើសរើសខាងសីលធម៌ ដែលយើងបានប្រទានដល់គេ, **គ. និង ស.** ១០១:៧៨ ។ សាតាំងបានខំរកបំផ្លាញសិទ្ធិជ្រើសរើសរបស់មនុស្ស, **ម៉ូសេ** ៤:៣ ។ ព្រះអម្ចាស់ទ្រង់បានប្រទានសិទ្ធិជ្រើសរើសដល់មនុស្ស, **ម៉ូសេ** ៧:៣២ ។

**សិទ្ធិជ្រើសរើសដោយសេរី** *សូមមើល* សិទ្ធិជ្រើសរើស

**សិទ្ធិអំណាច** *សូមមើលផង* ការហៅ; កូនសោទាំងឡាយនៃបព្វជិតភាព; តែងតាំង, បព្វជិតភាព, បានហៅពីព្រះ, ពិធីតែងតាំង; ហៅ, អំណាច

ជាការអនុញ្ញាតដល់មនុស្សនៅលើផែនដី ដែលបានហៅ ឬតែងតាំងឲ្យធ្វើកិច្ចការសំរាប់ ហើយជំនួសព្រះដ៏ជាព្រះវរបិតា ឬក៏ព្រះ យេស៊ូវគ្រីស្ទ ក្នុងការប្រព្រឹត្តកិច្ចការរបស់ព្រះ ។

យើងបានចាត់អ្នកមក, **និក្ខ.** ៣:១២–១៥ ។ អ្នកត្រូវនិយាយគ្រប់សេចក្តីដែលយើងបង្គាប់, **និក្ខ.** ៧:២ ។ ទ្រង់ក៏ប្រទានឲ្យពួកសិស្ស ១២ នាក់មានអំណាច, **ម៉ាថាយ** ១០:១ ។ មិនមែនអ្នករាល់គ្នាបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលបានរើសអ្នកវិញ ទាំងតាំងអ្នករាល់គ្នា, **យ៉ូហាន** ១៥:១៦ ។ នីហ្វៃ និងលីហៃបានផ្សាយដោយសិទ្ធិអំណាចដ៏ខ្លាំង, **ហេលេ.** ៥:១៨ ។ នីហ្វៃ ជាកូនប្រុសរបស់ហេលេមិន ជាមនុស្សម្នាក់ របស់ព្រះ មានអានុភាព និងសិទ្ធិអំណាចដ៏ធំពីព្រះ, **ហេលេ.** ១១:១៨ (៣ នីហ្វៃ ៧:១៧) ។ ព្រះយេស៊ូវទ្រង់បានប្រទានអានុភាព និង សិទ្ធិអំណាចទៅពួកសាសន៍នីហ្វៃ ១២ នាក់, ៣ នីហ្វៃ ១២:១–២ ។ យ៉ូសែប ស្ម៊ីធត្រូវបានហៅដោយព្រះ ហើយបានតែងតាំង, **គ. និង ស.** ២០:២ ។ គ្មានអ្នកណាមួយនឹងផ្សាយដំណឹងល្អរបស់យើង ឬស្ថាបនាសាសនាចក្ររបស់យើងឡើងឡើយ លើកលែងតែអ្នកនោះ បានតែងតាំងឡើង ហើយបានស្គាល់ដោយសាសនាចក្រ ថាអ្នកនោះមានសិទ្ធិអំណាច, **គ. និង ស.** ៤២:១១ ។ ពួកអែលឌើរត្រូវ ផ្សាយដំណឹងល្អ ដោយធ្វើការដោយនូវសិទ្ធិអំណាច, **គ. និង ស.** ៦៨:៨ ។ បព្វជិតភាពមិលគីស្សាដែកមានសិទ្ធិអំណាច ដើម្បីចាត់ ចែងការណ៍ទាំងឡាយខាងវិញ្ញាណ, **គ. និង ស.** ១០៧:៨, ១៨–១៩ ។ អ្វីក៏ដោយដែលបានសំរេចដោយសិទ្ធិអំណាចពីព្រះ ការណ៍នោះក្លាយទៅជា ក្រិត្យវិន័យ, **គ. និង ស.** ១២៨:៩ ។ មនុស្សណាមួយដែលផ្សាយ ឬចាត់ចែងជំនួសព្រះ នោះត្រូវតែបានហៅពីព្រះ ដោយអស់អ្នកណា ដែលមានសិទ្ធិអំណាច, **ម. នៃ ស.** ១:៥ ។

**សិម** *សូមមើលផង* ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសដ៏សុចរិតម្នាក់របស់លោកណូអេ ហើយតាមទំនៀមទំលាប់មក គឺជាដូនតានៃប្រជាជនសិម ឬប្រជាជនសេម ព្រមទាំងពួកអារាប់ ពួកហេព្រើរ ពួកបាប៊ីឡូន ពួកស៊ីរី ពួកភីនីស៊ី និងពួកអាសសើរ (លោកុ. ៥:២៩–៣២; ៦:១០; ៧:១៣; ៩:២៦; ១០:២១–៣២; ម៉ូសេ ៨:១២) ។ នៅក្នុងវិវរណៈថ្ងៃចុងក្រោយ គេនិយាយដល់ សិម ថាជា «សម្តេចសង្ឃដ៏ធំ» (គ. និង ស. ១៣៨:៤១) ។

**សិរីល្អ** *សូមមើលផង* ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ; សេចក្តីពិត, លំដាប់សិរីល្អ

នៅក្នុងគម្ពីរ សិរីល្អគឺតែងតែនិយាយពីពន្លឺ និងសេចក្តីពិតនៃព្រះ ។ ក៏អាចនិយាយពីការសរសើរ ឬការឲ្យកិត្តិយស និងចំពោះករណីខ្លះនិយាយពីជីវិតដ៏នៅអស់កល្បជានិច្ច ឬក៏ពីសិរីល្អនៃព្រះ ។

បរិសុទ្ធ គឺព្រះអម្ចាស់នៃពួកពលបរិវារ ផែនដីទាំងមូលមានពេញដោយសិរីល្អនៃទ្រង់, **អេសាយ** ៦:៣ (២ នីហ្វៃ ១៦:៣) ។ យើងរាល់គ្នាកំពុងតែផ្លាស់ប្រែទៅឲ្យដូចជារូបឆ្លុះ ពីសិរីល្អទៅដល់សិរីល្អ, **២ កូរិន.** ៣:១៨ ។ ទ្រង់នឹងប្រោសខ្ញុំឲ្យទៅរស់នៅជាមួយនឹងទ្រង់ក្នុង សិរីល្អ, **អាលម៉ា** ៣៦:២៨ ។ សិរីល្អទាំងឡាយដែលបានទទួលក្នុងដំណើររស់ឡើងវិញ នោះខុសពីគ្នាស្របតាមសេចក្តីសុចរិត, **គ. និង ស.**

៧៦:៥០–១១៩ ។ សិរីល្អនៃព្រះ គឺជាបញ្ញា, **គ. និង ស.** ៩៣:៣៦ ។ សិរីល្អនៃព្រះ គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់ កល្បជានិច្ច ដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។ ខ្ញុំបានឃើញតួអង្គពីរ ដែលមានរស្មី និងសិរីរុងរឿងដែលពុំអាចពណ៌នាបានឡើយ, **យ.ស. — ប្រវត្តិ** ១:១៧ ។

**សិរីល្អនៃទេរេសទ្រាល** *សូមមើលផង* លំដាប់នៃសិរីល្អ

ជាលំដាប់ទីពីរ ក្នុងលំដាប់សិរីល្អទាំងបី ដែលមនុស្សនឹងអាស្រ័យនៅ បន្ទាប់ពីការជំនុំជំរះចុងក្រោយបង្អស់ ។

ប៉ុលបានឃើញសិរីល្អនៃទេរេសទ្រាល ប្រៀបដូចជារស្មីនៃព្រះច័ន្ទ, **១ កូរិន.** ១៥:៤០–៤១ ។ យ៉ូសែប ស៊្មីធ និងស៊ីឌនី រិកដុនបានឃើញសិរីល្អនៃទេរេសទ្រាល, **គ. និង ស.** ៧៦:៧១–៨០ ។ សិរីល្អនៃទេរេសទ្រាលហួសលើសសិរីល្អនៃទេឡេស្ទាលទៅទៀត, **គ. និង ស.** ៧៦:៩១ ។ អ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរទេរេសទ្រាលបាន នោះពុំអាចនៅជាប់ក្នុងសិរីល្អនៃទេរេសទ្រាល បានឡើយ, **គ. និង ស.** ៨៨:២៣; ៣០, ៣៨ ។

**សិរីល្អនៃទេឡេស្ទាល** *សូមមើលផង* លំដាប់នៃសិរីល្អ

ជាលំដាប់ទាបបំផុត ក្នុងលំដាប់សិរីល្អទាំងបី ដែលមនុស្សនឹងអាស្រ័យនៅ បន្ទាប់ពីការជំនុំជំរះចុងក្រោយបង្អស់ ។

ប៉ុលបានឃើញរស្មីនៃផ្កាយទាំងឡាយ, **១ កូរិន.** ១៥:៤០–៤១ ។ យ៉ូសែប ស៊្មីធ និងស៊ីឌនី រិកដុន បានឃើញសិរីល្អនៃទេឡេស្ទាល, **គ. និង ស.** ៧៦:៨១–៩០ ។ បណ្ដាជនដែលអាស្រ័យនៅពិភពទេឡេស្ទាល នោះមានជាច្រើនដ៏ឥតគណនា ដូចជាតារាទាំងឡាយ, **គ. និង ស.** ៧៦:១០៩–១២ ។ អ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរទេឡេស្ទាលបាន នោះពុំអាចនៅជាប់ក្នុងសិរីល្អ នៃទេឡេស្ទាលបានឡើយ, **គ. និង ស.** ៨៨:២៤, ៣១, ៣៨ ។

**សិរីល្អនៃសេឡេស្ទាល** *សូមមើលផង* ជីវិតដ៏នៅអស់កល្បជានិច្ច; ភាពដំកើងឡើង, លំដាប់នៃសិរីល្អ

ជាលំដាប់ដ៏ខ្ពស់បំផុតមួយ ក្នុងលំដាប់សិរីល្អទាំងបី ដែលជននីមួយៗអាចបាន បន្ទាប់ពីជីវិតនេះទៅ ។ នៅទីនេះ ពួកសុចរិតនឹងនៅក្នុង វត្តមាននៃព្រះ ដ៏ជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។

មានសិរីល្អនៃសេឡេស្ទាលមួយ, **១ កូរិន.** ១៥:៤០ (គ. និង ស. ៧៦:៩៦) ។ ប៉ុលបានត្រូវលើកឡើងទៅស្ថានសួគ៌ នៅជាន់ទីបី, **២ កូរិន.** ១២:២ ។ សិរីល្អនៃសេឡេស្ទាលបានត្រូវបង្ហាញឲ្យឃើញនៅក្នុងការនិមិត្ត, **គ. និង ស.** ៧៦:៥០–៧០ ។ បើពួកបរិសុទ្ធប្រាថ្នា ចង់បានមួយកន្លែង នៅក្នុងពិភពសេឡេស្ទាល នោះពួកគេត្រូវរៀបចំខ្លួន, **គ. និង ស.** ៧៨:៧ ។ អ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យ វិន័យនៃនគរសេឡេស្ទាលបានទេ នោះពុំអាចនៅជាប់ក្នុងសិរីល្អនៃសេឡេស្ទាលបានឡើយ, **គ. និង ស.** ៨៨:១៥–២២ ។ នៅក្នុង សិរីល្អនៃសេឡេស្ទាល នោះមានស្ថានសួគ៌ ឬលំដាប់បី; លក្ខខ័ណ្ឌបានចែងទុកសំរាប់ឲ្យបានលំដាប់ដ៏ខ្ពស់បំផុត, **គ. និង ស.** ១៣១:១–២ ។ ពួកកូនក្មេងដែលបានស្លាប់មុនគ្រប់អាយុទទួលខុសត្រូវ នោះត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល, **គ. និង ស.** ១៣៧:១០ ។

**ស៊ិបឡុន** *សូមមើលផង* កូនប្រុសរបស់អាលម៉ា, អាលម៉ា

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសរបស់អាលម៉ា ជាកូន ។ ស៊ិបឡុនបានបង្រៀនដំណឹងល្អដល់ពួកសាសន៍សូរាំ ហើយត្រូវគេ បៀតបៀនមកពីសេចក្ដីសុចរិតរបស់លោក ។ ព្រះអម្ចាស់ ទ្រង់បានដោះលែងលោកឲ្យរួចពីសេចក្ដីបៀតបៀនដែលលោកមាន ពីព្រោះមកពីសេចក្ដីស្មោះត្រង់ និងសេចក្ដីអត់ធ្មត់របស់លោក (អាលម៉ា ៣៨) ។ ស៊ិបឡុនក៏បានថែរក្សាបញ្ជីទាំងឡាយនៃពួកនីហ្វៃ បានមួយគ្រាដែរ (អាលម៉ា ៦៣:១–២, ១១–១៣) ។

**ស៊ិស** *សូមមើលផង* ពួកសាសន៍យ៉ារេឌ

ជាមេទ័ពសាសន៍យ៉ារេឌម្នាក់ នៅក្នុងព្រះគម្ពីរមរមន ។ លោកត្រូវស្លាប់នៅទីបញ្ចប់នៃចំបាំងដ៏ធំមួយ ដែលបំផ្លាញសាសន៍យ៉ារេឌ ទាំងមូល (អេធើរ ១៤:១៧–១៥:៣១) ។

**ស៊ីណុក**

ជាព្យាការីនៃពួកអ៊ីស្រាអែលម្នាក់ នៅសម័យព្រះគម្ពីរសញ្ញាចាស់ តែបានពោលដល់នៅក្នុងព្រះគម្ពីរមរមនប៉ុណ្ណោះ ។

បានព្យាករអំពីព្រះគ្រីស្ទត្រូវសុគត, **១ នីហ្វៃ** ១៩:១០ ។ បាននិយាយអំពីព្រះរាជបុត្រានៃព្រះ, **អាលម៉ា** ៣៣:១៥ (អាលម៉ា ៣៤:៧) ។ ជាទុក្ករបុគ្គលចំពោះសេចក្ដីពិត, **អាលម៉ា** ៣៣:១៧ ។ បានព្យាករអំពីការយាងមកនៃព្រះមែស៊ី, **ហេលេ.** ៨:២០ ។

**ស៊ីណូស**

ជាព្យាការីនៃពួកអ៊ីស្រាអែលម្នាក់ នៅសម័យព្រះគម្ពីរសញ្ញាចាស់ ដែលមានពាក្យព្យាករណ៍អំពីបេសកកម្មរបស់ព្រះគ្រីស្ទ ដែលមាន នៅក្នុងព្រះគម្ពីរមរមនប៉ុណ្ណោះ ។

បានព្យាករអំពីការបញ្ចុះសពព្រះគ្រីស្ទ និងថ្ងៃងងឹតបីថ្ងៃ, **១ នីហ្វៃ** ១៩:១០, ១២ ។ បានទាយអំពីការប្រមូលពួកអ៊ីស្រាអែល, **១ នីហ្វៃ** ១៩:១៦ ។ យ៉ាកុបបានស្រង់យកពាក្យប្រៀបប្រដូចរបស់ស៊ីណូស អំពីដើមអូលីវស្រុក និងដើមអូលីវព្រៃ, **យ៉ាកុប** ៥ ។ យ៉ាកុបបានអធិប្បាយប្រាប់ពីពាក្យប្រៀបធៀបរបស់ស៊ីណូស, **យ៉ាកុប** ៦:១–១០ ។ បានបង្រៀនអំពីការអធិស្ឋាន និងការថ្វាយបង្គំ, **អាលម៉ា** ៣៣:៣–១១ ។ បានបង្រៀនថា សេចក្ដីប្រោសលោះមានឡើង តាមរយៈព្រះរាជបុត្រា, **អាលម៉ា** ៣៤:៧ ។ ត្រូវគេប្រហារ ដោយ ព្រោះសេចក្ដីបន្ទាល់ដ៏អង់អាចរបស់លោក, **ហេលេ.** ៨:១៩ ។ បាននិយាយប្រាប់អំពីការសាងវិញនៃពួកសាសន៍លេមិន, **ហេលេ.** ១៥:១១ ។ បានធ្វើបន្ទាល់អំពីសេចក្ដីបំផ្លិចបំផ្លាញ កាលព្រះគ្រីស្ទសុគត, ៣ នីហ្វៃ ១០:១៥–១៦ ។

### ស៊ីនិព

នៅក្នុងព្រះគម្ពីរមរមន ជាបុរសម្នាក់ ដែលបាននាំមនុស្សមួយក្រុមវិលទៅឯដែនដីនីហ្វៃវិញ; លោកបានក្លាយទៅជាស្ដេចរបស់ពួកគេ ហើយបានដឹកនាំគេដោយសុចរិត (ម៉ូសាយ ៩–១០) ។

**ស៊ីម្មាន** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសទីពីររបស់យ៉ាកុប និងនាងលេអា ជាប្រពន្ធរបស់លោក (លោកុ. ២៩:៣៣; ៣៥:២៣; និក្ខ.១:២) ។ លោកបានចូលរួមដៃនឹងលេវី ក្នុងការប្រហារវង្គាលពួកសាសន៍ស៊ីគែម (លោកុ. ៣៤:២៥–៣១) ។ ការព្យាករណ៍របស់ យ៉ាកុប អំពីស៊ីម្មាន នោះមាននៅក្នុងគម្ពីរលោកុប្បត្តិ ៤៩:៥–៧ ។

*ពូជអំបូររបស់ស៊ីម្មាន៖* ពូជពង្សស៊ីម្មានតែងតែរស់នៅជាមួយនឹងពូជអំបូររបស់យូដា ហើយនៅតាមព្រំដែននគរយូដា (យ៉ូស្វេ ១៩:១–៩; ១ របារ. ៤:២៤–៣៣) ។ ពូជអំបូររបស់ស៊ីម្មានបានចូលរួមដៃនឹងពួកយូដា ទៅច្បាំងនឹងពួកសាសន៍កាណាន (ពួកចៅ. ១:៣, ១៧) ។ ក្រោយមក ពួកគេក៏បានចូលរួមនឹងកងទ័ពដាវីឌ (១ របា. ១២:២៥) ។

**ស៊ីម៉ូន-ពេត្រុស** *សូមមើល* ពេត្រុស

**ស៊ីម៉ូន សាសន៍កាណាន**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសាវកម្នាក់ ក្នុងពួកសាវកដើម១២នាក់របស់ព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ១០:២–៤) ។

**ស៊ីយ៉ូន** *សូមមើលផង* ហេណុក; យេរូសាឡិមថ្មី

ជាពួកអ្នកមានចិត្តបរិសុទ្ធ (គ. និង ស. ៩៧:២១) ។ ស៊ីយ៉ូនក៏មានន័យថា ជាកន្លែងមួយ ដែលពួកអ្នកមានចិត្តបរិសុទ្ធអាស្រ័យនៅ ។ ជាទីក្រុងមួយ ដែលហេណុក និងរាស្ត្រលោកបានសាង ហើយក្រោយមកត្រូវបានលើកយកទៅលើស្ថានសួគ៌ ដោយសារសេចក្ដី សុចរិត នោះត្រូវបានជាឲ្យឈ្មោះថា ស៊ីយ៉ូន (គ. និង ស. ៣៨:៤; ម៉ូសេ ៧:១៨–២១; ៦៩) ។ នៅថ្ងៃចុងក្រោយ នោះមានទីក្រុងមួយ ឈ្មោះថា ស៊ីយ៉ូន ដែលនឹងបានសាងនៅក្បែរឃុំចាកសុន រដ្ឋមិសសួរី (សហរដ្ឋ) ជាកន្លែងដែលពូជអំបូរអ៊ីស្រាអែលនឹងជួបជុំគ្នា (គ. និង ស. ១០៣:១១–២២; ១៣៣:១៨) ។ ពួកបរិសុទ្ធត្រូវបានទូន្មានឲ្យសាងស៊ីយ៉ូនឡើង នៅគ្រប់ទិសទីក្នុងពិភពលោក ដែលពួកគេ អាស្រ័យនៅ ។

ក្រុងដាវីឌ គឺបានហៅថាក្រុងស៊ីយ៉ូន, **១ពង្សាវ.** ៨:១ ។ ក្រិត្យវិន័យនឹងចេញពីក្រុងស៊ីយ៉ូនទៅ, **អេសាយ** ២:២–៣ (មីកា ៤:២; ២ នីហ្វៃ ១២:២–៣) ។ ព្រះប្រោសលោះនឹងយាងមកឯក្រុងស៊ីយ៉ូន, **អេសាយ** ៥៩:២០ ។ អញនឹងយកឯងរាល់គ្នា ម្នាក់ពីក្រុងមួយ ហើយពីរនាក់ពីពូជអំបូរមួយ នាំត្រឡប់ទៅឯក្រុងស៊ីយ៉ូនវិញ, **យេរេ.** ៣:១៤ ។ នៅភ្នំស៊ីយ៉ូន ហើយនៅក្រុងយេរូសាឡិម នោះមាន សេចក្ដីសង្គ្រោះ, **យ៉ូអែល** ២:៣២ (អូបា. ១:១៧) ។ មានពរហើយ ដល់អស់អ្នកណាដែលព្យាយាមនាំមកក្រុងស៊ីយ៉ូនរបស់យើង, **១ នីហ្វៃ** ១៣:៣៧ ។ ពួកកូនស្រីក្រុងស៊ីយ៉ូន ជាមនុស្សមានឫកខ្ពស់, **២ នីហ្វៃ** ១៣:១៦ (អេសាយ ៣:១៦) ។ វេទនាដល់អ្នកណា ដែល នៅក្រុងស៊ីយ៉ូនដោយស្រួល, **២ នីហ្វៃ** ២៨:១៩–២៥ ។ ចូរស្វែងរក ដើម្បីនាំមក ហើយតាំងឡើងនូវគតិនៃក្រុងស៊ីយ៉ូនចុះ, **គ. និង ស.** ៦:៦ (គ. និង ស. ១១:៦) ។ អ្នកនោះហើយដែលយើងបានបំភ្លឺឲ្យកំរើកគតិនៃស៊ីយ៉ូនដោយអំណាចដ៏ធំ ដើម្បីសេចក្ដីល្អ, **គ. និង ស.** ២១:៧ ។ ក្រុងយេរូសាឡិមថ្មីនឹងត្រូវបានហៅថា ក្រុងស៊ីយ៉ូន, **គ. និង ស.** ៤៥:៦៦–៦៧ ។ ទីក្រុងអិនឌីប៉ែនដែនស៍ រដ្ឋមិសសួរី គឺជា កន្លែងសំរាប់ទីក្រុងស៊ីយ៉ូន, **គ. និង ស.** ៥៧:១–៣ ។ ការវាយនឹងនៅលើពួកកូនចៅនៃក្រុងស៊ីយ៉ូនដរាបដល់ពួកគេប្រែចិត្ត, **គ. និង ស.** ៨៤:៥៨ ។ ព្រះអម្ចាស់ទ្រង់បានហៅរាស្ត្រទ្រង់ថា « ស៊ីយ៉ូន » ពីព្រោះពួកគេមានចិត្តតែមួយ និងគំនិតតែមួយ, **ម៉ូសេ** ៧:១៨–១៩ ។ ក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នឹងត្រូវបានស្ថាបនានៅលើទ្វីបអាមេរិក, **ម. នៃ ស.** ១:១០ ។

### ស៊ីរូស

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាស្ដេចស្រុកពើស៊ី ដែលបានសំរេចនូវពាក្យព្យាកររបស់លោកអេសាយ (២ របា. ៣៦:២២–២៣; អេសាយ ៤៤:២៨; ៤៥:១) ។ ដោយអនុញ្ញាតឲ្យពួកសាសន៍យូដាត្រឡប់ទៅក្រុងយេរូសាឡិម ដើម្បីទៅសង់ព្រះវិហារឡើងវិញ ហេតុនោះហើយ ទើបបានបញ្ចប់នូវការចាប់ឃុំឃាំងនៃពួកបាប៊ីឡូនភាគខ្លះ ។ ពាក្យព្យាកររបស់លោកអេសាយ បានចែងទុកប្រហែល ជា ១៨០ ឆ្នាំមុនកិច្ចការដែលស្ដេចបានធ្វើ ។

### ស៊ីអែសរ៉ុម

នៅក្នុងព្រះគម្ពីរមរមន ជាមេធាវីម្នាក់ នៅក្រុងអាំម៉ូណៃហា ។ អាលម៉ា និងអាមូលេកបានយល់ដោយព្រះវិញ្ញាណថា ស៊ីអែសរ៉ុម បានកុហក ។ ក្រោយមក លោកបានប្រែចិត្តជឿតាមដំណឹងល្អនៃព្រះគ្រីស្ទ (អាលម៉ា ១១:២១–៤៦; ១៥:១–១២) ។

**សុខុមាលភាព** *សូមមើល* ទ្រព្យសម្បត្តិ

**សុខុមាលភាព** *សូមមើលផង* ការដាក់ទាន; ការបំរើ, ដង្វាយ; តម,
តំណម; ទាន, មនុស្សក្រីក្រ

ជាដំណើរ និងមាគ៌ាទាំងឡាយ សំរាប់ថែទាំនូវសេចក្ដីត្រូវការរបស់មនុស្សខាងវិញ្ញាណ និងខាងសាច់ឈាម ។

ចូរលាដៃដល់បងប្អូន និងពួកអ្នកទាល់ក្រ ហើយនិងពួកកំសត់ទុគត នៅក្នុងស្រុកឯងចុះ, **ចោទិ.** ១៥:១១ ។ អ្នកណាដែលចែកចាយ ឲ្យដល់ពួកទាល់ក្រ អ្នកនោះនឹងមិនខ្វះខាតឡើយ, **សុភា.** ២៨:២៧ ។ តើមិនមែនជាការតមអត់ ដែលអញពេញចិត្តទេឬអី ? គឺដើម្បីឲ្យ ឯង

ចែកអាហារដល់អ្នកដែលឃ្លាន ហើយនាំមនុស្សក្រមកឯផ្ទះឯង, **អេសាយ** ៥៨:៦–៧ ។ យើងបានឃ្លាន ហើយអ្នករាល់គ្នាបានឲ្យ បរិភោគ យើងជាអ្នកដទៃ ហើយអ្នករាល់គ្នាបានទទួលយើង កាលណាអ្នករាល់បានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូន យើង នោះឈ្មោះថាបានធ្វើដល់យើងដែរ, **ម៉ាថាយ** ២៥:៣៥–៤០ ។ ចូរចែករំលែកទ្រព្យរបស់ខ្លួន ដល់ជនណាដែលត្រូវការ, **ម៉ូសាយ** ៤:១៦–២៦ ។ ពួកគេបានចែករំលែកគ្នាទៅវិញទៅមក ព្រមទាំងខាងសាច់ឈាម និងខាងវិញ្ញាណ តាមសេចក្ដីខ្វះខាត និងសេចក្ដីត្រូវការរបស់ពួកគេ, **ម៉ូសាយ** ១៨:២៩ ។ ពួកគេត្រូវបានបញ្ជា ឲ្យរួមគ្នាតមអាហារ ហើយអធិស្ឋាន ដើម្បីសុខុមាលភាព ដល់អស់អ្នកណា ដែលពុំស្គាល់ព្រះ, **អាលម៉ា** ៦:៦ ។ ចូរអធិស្ឋាន ដើម្បីសុខុមាលភាពរបស់អ្នក និងដើម្បីសុខុមាលភាពដល់ជនទាំងឡាយដែលនៅជុំវិញអ្នកផង, **អាលម៉ា** ៣៤:២៧–២៨ ។ ពួកគេមានវត្ថុសព្វសារពើ នៅមូលព្រមគ្នា, **៤ នីហ្វៃ** ១:៣ ។ ចូរនឹកដល់ មនុស្សទាល់ក្រ, **គ. និង ស.** ៤២:៣០–៣១ ។ ចូរទៅសួរសុខទុក្ខដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌ត, **គ. និង ស.** ៤៤:៦ ។ ចូរនឹកចាំក្នុងគ្រប់ការណ៍ទាំងអស់ពីមនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌ត, **គ. និង ស.** ៥២:៤០ ។ វេទនាដល់អ្នកដែលមាន ដែល មិនឲ្យទ្រព្យសម្បត្តិរបស់ខ្លួនដល់មនុស្សទាល់ក្រ ហើយវេទនាដល់អ្នកដែលទាល់ក្រ ដែលមិនចេះឆ្អែត ដែលមានចិត្តលោភលន់ ហើយ មិនព្រមធ្វើការ, **គ. និង ស.** ៥៦:១៦–១៧ ។ នៅក្រុងស៊ីយ៉ូន នោះគ្មានមនុស្សក្រីក្រនៅក្នុងចំណោមពួកគេឡើយ, **ម៉ូសេ** ៧:១៨ ។

**សុចរិត, សេចក្ដីសុចរិត** *សូមមើលផង* ដើរ, ដើរជាមួយនឹងព្រះ; ព្រះបញ្ញត្តិទាំងឡាយនៃព្រះ; ភាពសក្ដិសម, សក្ដិសម, សេចក្ដីស្មោះ; សេចក្ដីឥតសុចរិត; ឥតសុចរិត

គឺប្រកបដោយយុត្តិធម៌ បរិសុទ្ធ គុណធម៌ ស្មោះត្រង់; ប្រកបដោយការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ; ប្រកបដោយការជៀសវាងពីអំពើបាប ។

ព្រះអម្ចាស់ទ្រង់នឹងប្រទានពរដល់មនុស្សសុចរិត, **ទំនុក.** ៥:១២ ។ ព្រះនេត្រព្រះអម្ចាស់ទតទៅចំពោះមនុស្សសុចរិត, **ទំនុក.** ៣៤:១៥, ១៧ (១ ពេត្រុស ៣:១២) ។ កាលណាមនុស្សសុចរិតមានអំណាចឡើង នោះជនទាំងឡាយរមែងមានចិត្តរីករាយ, **សុភា.**២៩:២ (គ. និង ស. ៩៨:៩–១០) ។ មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្ដីសុចរិត, **ម៉ាថាយ** ៥:៦ (៣ នីហ្វៃ១២:៦) ។ ចូរស្វែងរក នគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន, **ម៉ាថាយ** ៦:៣៣ ។ ពួកសុចរិតនឹងចូលទៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ច, **ម៉ាថាយ** ២៥:៤៦ ។ សេចក្ដីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់, **យ៉ាកុប** (ព.ស.ថ.) ៥:១៦ ។ អ្នកណាដែលជាមនុស្សសុចរិត អ្នក នោះសព្វព្រះហឫទ័យនៃព្រះ, **១ នីហ្វៃ** ១៧:៣៥ ។ ទ្រង់នឹងទំនុកបំរុងពួកសុចរិតទុក; ពួកគេមិនត្រូវភ័យខ្លាចឡើយ, **១ នីហ្វៃ** ២២:១៧, ២២ ។ សាតាំងគ្មានអំណាចសោះ ដោយសារអំពើសុចរិតនៃរាស្ត្ររបស់ព្រះអម្ចាស់, **១ នីហ្វៃ** ២២:២៦ ។ បើគ្មានសេចក្ដី សុចរិត នោះក៏គ្មានសុភមង្គលដែរ, **២ នីហ្វៃ** ២:១៣ ។ ពួកសុចរិតនឹងគ្រងនគរនៃព្រះទុកជាមរតក, **២ នីហ្វៃ** ៩:១៨ ។ ពួកសុចរិតមិន ដែលខ្លាចដល់ពាក្យនៃសេចក្ដីពិតឡើយ, **២ នីហ្វៃ** ៩:៤០ ។ មនុស្សលោកទាំងអស់ត្រូវតែផ្លាស់ប្ដូរទៅរកស្ថានភាពនៃសេចក្ដីសុចរិត, **ម៉ូសាយ** ២៧:២៥–២៦ ។ ឈ្មោះនៃជនសុចរិតនឹងបានកត់នៅក្នុងសៀវភៅជីវិត, **អាលម៉ា** ៥:៥៨ ។ អ្នករាល់គ្នាបានស្វែងរក សុភមង្គល ដោយធ្វើអំពើទុច្ចរិត ដែលជាការផ្ទុយទៅនឹងធម្មជាតិនៃសេចក្ដីសុចរិត, **ហេលេ.** ១៣:៣៨ ។ បទចំរៀងនៃពួកសុចរិត គឺជាបទអធិស្ឋានដល់យើង, **គ. និង ស.** ២៥:១២ ។ ចូរឈរ ដោយពាក់សេចក្ដីសុចរិតទុកជាប្រដាប់ពាំងដើមទ្រូង, **គ. និង ស.** ២៧:១៦ (អេភេ. ៦:១៤) ។ សេចក្ដីស្លាប់នៃពួកសុចរិតនឹងបានទៅជាសេចក្ដីផ្អែមល្ហែមដល់ពួកគេ, **គ. និង ស.** ៤២:៤៦ ។ ពួកសុចរិត នឹងត្រូវបានប្រមូលគ្នាមកពីចំណោមសាសន៍ទាំងអស់, **គ. និង ស.** ៤៥:៧១ ។ មនុស្សលោកនឹងនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន តាមបំណងចិត្តរបស់ខ្លួន, **គ. និង ស.** ៥៨:២៧ ។ អ្នកណាដែលប្រព្រឹត្តកិច្ចការទាំងឡាយនៃសេចក្ដីសុចរិត នោះនឹងបានទទួលសេចក្ដីសុខ សាន្តនៅលោកិយនេះ និងជីវិតដ៏នៅអស់កល្បជានិច្ច នៅបរលោកនាយ, **គ. និង ស.** ៥៩:២៣ ។ នៅគ្រាយាងមកលើកទីពីរ នោះនឹងមានការបំបែកពួកសុចរិត និងពួកទុច្ចរិត, **គ. និង ស.** ៦៣:៥៤ ។ អំណាចនៃស្ថានសួគ៌អាចត្រួតត្រាបានដោយគោលការណ៍ នៃសេចក្ដីសុចរិតតែប៉ុណ្ណោះ, **គ. និង ស.** ១២១:៣៦ ។ នៅក្នុងចំណោមពួកសុចរិត នោះមានសេចក្ដីសុខសាន្ត, **គ. និង ស.** ១៣៨:២២ ។ ប្រជារាស្ត្រនៃក្រុងស៊ីយ៉ូនបានរស់នៅក្នុងសេចក្ដីសុចរិត, **ម៉ូសេ** ៧:១៨ ។ លោកអ័ប្រាហាំជាអ្នកដើរតាមសេចក្ដី សុចរិត, **អ័ប្រា.** ១:២ ។

**សុទ្ធ, សុទ្ធសាធ, ជ្រះថ្លា, បរិសុទ្ធ, ភាពសុទ្ធសាធ** *សូមមើលផង* ការញែកចេញជាបរិសុទ្ធ, ស្អាត និងឥតស្អាត

គឺជ្រះស្រលះពីអំពើបាប ឬពីទោស; គ្មានទោសឡើយ ។ ជននីមួយៗក្លាយទៅជាមនុស្សល្អបរិសុទ្ធ នៅពេលណាគំនិត និងចរិយា របស់ខ្លួនបានស្អាតស្អំគ្រប់បែបយ៉ាង ។ ជនណាដែលបានប្រព្រឹត្តអំពើបាប នោះអាចក្លាយទៅជាមនុស្សល្អបរិសុទ្ធបាន តាមរយៈ សេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ គឺដោយការប្រែចិត្ត និងការទទួលពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ ។

អ្នកណាដែលមានដៃស្អាត និងចិត្តបរិសុទ្ធ នោះនឹងបានទទួលពរពីព្រះអម្ចាស់, **ទំនុក.** ២៤:៣–៥ ។ ចូរញែកខ្លួនចេញជាស្អាតចុះ ឱពួកអ្នកដែលលើកយកគ្រឿងនៃព្រះអម្ចាស់, **អេសាយ** ៥២:១១ (គ. និង ស. ១៣៣:៤–៥) ។ មានពរដល់អ្នកដែលមានចិត្តបរិសុទ្ធ, **ម៉ាថាយ** ៥:៨ (៣ នីហ្វៃ ១២:៨) ។ សេចក្ដីណាដែលបរិសុទ្ធ ចូរពិចារណាពីសេចក្ដីទាំងនេះចុះ, **ភីលីព** ៤:៨ (ម. នៃ ស. ១:១៣) ។ អ្នកដែលមានចិត្តបរិសុទ្ធទាំងអស់គ្នាអើយ ចូរងើបក្បាលឡើង ហើយទទួលព្រះបន្ទូលដ៏ផ្អែមល្ហែមនៃព្រះចុះ, **យ៉ាកុប** ៣:២–៣ ។ តើអ្នករាល់គ្នាអាចសម្លឹងមើលទៅព្រះនៅថ្ងៃនោះ ដោយចិត្តបរិសុទ្ធ និងបាតដៃ

ស្អាតឬ ? **អាលម៉ា** ៥:១៩ ។ ដោយបានជ្រះថ្លា ហើយគ្មានប្រឡាក់នៅចំពោះព្រះ ពួកគេពុំអាចសម្លឹងមើលអំពើបាបទៀតឡើយ លើកលែងតែមើលដោយស្អប់ខ្ពើមប៉ុណ្ណោះ, **អាលម៉ា** ១៣:១២ ។ សូមឲ្យបានបរិសុទ្ធ ដូចជាព្រះគ្រីស្ទទ្រង់បរិសុទ្ធ, **ម៉ូរ៉ូណៃ** ៧:៤៨ (មរមន ៩:៦) ។ ព្រះគ្រីស្ទនឹងរក្សាដល់ព្រះអង្គទ្រង់ នូវរាស្ត្រដ៏បរិសុទ្ធ, **គ. និង ស.** ៤៣:១៤ ។ ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យកសាងដំណាក់មួយ នៅក្រុងស៊ីយ៉ូន ដើម្បីឲ្យពួកអ្នកដែលមាន ចិត្តបរិសុទ្ធបានឃើញព្រះ, **គ. និង ស.** ៩៧:១០–១៧ ។ នេះហើយជាស៊ីយ៉ូន — ជាអ្នកដែលមានចិត្តបរិសុទ្ធ, **គ. និង ស.** ៩៧:២១ ។

**សុភាសិត**

ជាពាក្យពេចន៍ ឬពាក្យទូន្មានខាងសិលធម៌ខ្លីៗ ។

*គម្ពីរសុភាសិត៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមាននូវពាក្យប្រៀបប្រដូច, ពាក្យចាស់ចែង, និងពាក្យកំណាព្យជា ច្រើន ឯពាក្យខ្លះបានសរសេរដោយហ្លួងសាឡូម៉ូន ។ គម្ពីរសុភាសិតត្រូវបានស្រង់ជាញឹកញាប់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

ជំពូកទី ១–៩ មាននូវការពន្យល់អំពីប្រាជ្ញាពិត ។ ជំពូកទី ១០–២៤ មាននូវការប្រមូលនៃពាក្យដែលចាស់ចែង អំពីការខុសត្រូវនៃរបៀបរស់នៅ ។ ជំពូកទី ២៥–២៩ មាននូវសុភាសិតនៃហ្លួងសាឡូម៉ូន ដែលពួកបុរសនៃហ្លួងហេសេគា ជាស្ដេចយូដា បានកត់ទុក ។ ជំពូកទី ៣០–៣១ សង្ខេបការរៀបរាប់អំពីស្រីបរិសុទ្ធ ។

**សុល, អ្នកស្រុកតើសុស** *សូមមើល* ប៉ុល

**សូដុំម** *សូមមើលផង* កូម៉ូរ៉ា

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាទីក្រុងដ៏ទុច្ចរិតមួយ ដែលព្រះអម្ចាស់ទ្រង់បានបំផ្លាញចោល (លោកុ. ១៩:១២–២៩) ។

**សូម** *សូមមើលផង* ការអធិស្ឋាន

គឺដើម្បីទូល សួរ ឬសូមដល់ព្រះនូវសំណូមពរដ៏វិសេសណាមួយ ។

ចូរសូម នោះតែងនឹងឲ្យមកអ្នក, **ម៉ាថាយ** ៧:៧ ។ បើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ, **យ៉ាកុប (ព.ស.ថ.)** ១:៥ (យ.ស. — ប្រវត្តិ ១:៧–២០) ។ ចូរសូមដល់យើង ដោយសេចក្ដីជំនឿ, **១ នីហ្វៃ** ១៥:១១ ។ បើអ្នកមិនយល់ពាក្យទាំងនេះទេ គឺមកពីអ្នកមិនសូម, **២ នីហ្វៃ** ៣២:៤ ។ សូមដោយចិត្តស្មោះ, **ម៉ូសាយ** ៤:១០ ។ ព្រះទ្រង់ប្រទានដល់អ្នក នូវអ្វីដែលអ្នកសូមដែលត្រឹមត្រូវ នៅក្នុងសេចក្ដីជំនឿ, **ម៉ូសាយ** ៤:២១ ។ ឲ្យសូមដល់ព្រះ បើសិនជាការណ៍ទាំងនេះមិនពិត, **ម៉ូរ៉ូណៃ** ១០:៤ ។ ពួកគេស្រឡាញ់ សេចក្ដីងងឹត ជាជាងពន្លឺ; ហេតុដូច្នេះហើយ ពួកគេពុំសូមអ្វីពីយើងឡើយ, **គ. និង ស.** ១០:២១ ។ អ្នករាល់គ្នាត្រូវបានបញ្ជានូវគ្រប់ ទាំងអស់ឲ្យសូមដល់ព្រះ, **គ. និង ស.** ៤៦:៧ ។

**សូរ៉ាំ, ពួកសាសន៍សូរ៉ាំ**

នៅក្នុងព្រះគម្ពីរមរមន គឺជាបាវបំរើរបស់ឡាបាន់ ដែលបានចូលរួមនឹងនីហ្វៃ និងលីហៃ ដើម្បីមកឯដែនដីសន្យា (១ នីហ្វៃ ៤:៣១–៣៨) ។ ដោយសារសេចក្ដីស្មោះត្រង់របស់សូរ៉ាំ នោះលីហៃបានប្រទានពរដល់គាត់ ជាមួយនឹងពួកកូនប្រុសទាំងឡាយរបស់លីហៃ (២ នីហ្វៃ ១:៣០–៣២) ។ ពូជពង្សរបស់គាត់បានហៅថាជា ពួកសាសន៍សូរ៉ាំ (យ៉ាកុប ១:១៣) ។

**សូរ៉ូបាបិល**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ កាលស៊ីរូសអនុញ្ញាតឲ្យពួកសាសន៍យូដាវិលទៅតំលីស្ទីនវិញ នោះសូរ៉ូបាបិលត្រូវបានតាំងឡើងឲ្យធ្វើជាចៅហ្វាយខេត្ត ឬជាតំណាងរាស្ត្រលើវង្សានុវង្សរបស់ពួកយូដា ។ ឈ្មោះលោកក្នុងភាសាពើស៊ី គឺ សេបោសារ (អែសរ៉ា ១:៨) ។ លោកបានរួមដៃក្នុងការកសាងព្រះវិហារ នៅក្រុងយេរូសាឡិមឡើងវិញ (អែសរ៉ា ៣:២, ៨; ៥:២) ។

**សូល, ស្ដេចនៃអ៊ីស្រាអែល**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាស្ដេចនៃអ៊ីស្រាអែលមុនដំបូង មុនប្រទេសត្រូវបែកបាក់ពីគ្នា ។ ទោះជាទ្រង់សុចរិត កាលនៅដើមរាជ្យទ្រង់ក៏ដោយ គង់តែទ្រង់បានក្លាយទៅជាពោរពេញដោយសេចក្ដីឆ្មើងឆ្មៃ ហើយមិនបានគោរពដល់ព្រះឡើយ (១ សាំយូ. ៩–៣១) ។

**សួនច្បារអេដែន** *សូមមើល* អេដែន

**សួនច្បារគែតសេម៉ានី** *សូមមើល* គែតសេម៉ានី

**សៀវភៅជីវិត** *សូមមើលផង* សៀវភៅរំឭក

តាមន័យមួយ សៀវភៅជីវិត គឺជាការសរុបនូវគំនិត និងកិច្ចការរបស់ជនម្នាក់ៗ— គឺជាបញ្ជីអំពីជីវិតរបស់គេ ។ ក៏ប៉ុន្តែគម្ពីរបាន ចែងថា មានបញ្ជីនៅស្ថានសួគ៌មួយច្បាប់ ដែលបានរក្សាទុកសំរាប់ពួកមនុស្សស្មោះត្រង់ គឺមានទាំងឈ្មោះគេ និងដំណើររឿងអំពីការ ប្រព្រឹត្តដ៏សុចរិតទាំងឡាយរបស់គេផង ។

ព្រះអម្ចាស់ទ្រង់នឹងលុបឈ្មោះមនុស្សបាបចេញពីបញ្ជីទ្រង់, **និក្ខ.** ៣២:៣៣ ។ អ្នកណាដែលឈ្នះ ឈ្មោះអ្នកនោះនឹងមិនត្រូវលុបចេញពីសៀវភៅជីវិតឡើយ, **វិវរ.** ៣:៥ ។ សៀវភៅមួយទៀតបានបើកឡើង គឺជាសៀវភៅជីវិត, **វិវរ.** ២០:១២ (គ. និង ស. ១២៨:៦–៧) ។ ឈ្មោះនៃជនសុចរិតនឹងបានកត់នៅក្នុងសៀវភៅជីវិត, **អាលម៉ា** ៥:៥៨ ។ ពាក្យអធិស្ឋានទាំងឡាយរបស់អ្នកត្រូវបានកត់ទុកនៅក្នុង សៀវភៅនាមនៃពួកអ្នក ដែលបានញែកចេញជាបរិសុទ្ធ, **គ. និង ស.** ៨៨:២ ។

**សៀវភៅរំឭក** *សូមមើលផង* ពង្សាវតារ, សៀវភៅជីវិត

ជាសៀវភៅមួយ ដែលលោកអ័ដាមបានចាប់ផ្ដើម ដែលកត់ពីកិច្ចការ

ទាំងឡាយនៃពូជពង្សរបស់លោកទុក; ក៏ជាបញ្ជីស្រដៀងគ្នាដែល បាន រក្សាទុក ដោយពួកព្យាការី និងសមាជិកស្មោះត្រង់ ចាប់ពីពេលនោះ មក ។ លោកអ័ដាម និងកូនចៅលោកបានកត់សៀវភៅរំឭក មួយទុក ដែលពួកគេបានសរសេរដោយវិញ្ញាណសណ្ឋិត និងសៀវភៅនៃជំណរ មួយ ដែលមានពង្សាវលី (ម៉ូសេ ៦:៥, ៨) ។ បញ្ជី បែបនេះអាចជា កត្តាមួយ ក្នុងការកំណត់សេចក្ដីជំនុំជំរះចុងក្រោយបង្អស់របស់យើង ។

សៀវភៅរំឭកបានកត់ទុក, **ម៉ាឡាគី** ៣:១៦–១៨ (៣ នីហ្វៃ ២៤:១៣–២៦)។ ពួកគេទាំងអស់គ្នាណាដែលពុំបានសរសេរទុក នៅ ក្នុងសៀវភៅរំឭក នោះនឹងពុំរកឃើញកេរ្តិ៍មរតក នៅថ្ងៃនោះ ឡើយ, **គ. និង ស.** ៨៥:៩ ។ មនុស្សស្លាប់ត្រូវជំនុំជំរះ តាមសៀវភៅ ទាំងឡាយ ដែលមានបញ្ជីនូវអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន, **គ. និង ស.** ១២៨:៧ ។ ចូរយើងថ្វាយនូវបញ្ជីមួយ ដែលមានបញ្ជីនៃពួក អ្នកស្លាប់ របស់យើង, **គ. និង ស.** ១២៨:២៤ ។ សៀវភៅរំឭកមួយត្រូវបាន កត់ទុក, **ម៉ូសេ** ៦:៥–៨ ។ យើងមានសៀវភៅរំឭកមួយ, **ម៉ូសេ** ៦:៤៦ ។ លោកអ័ប្រាហាំបានខ្នះខ្នែងសរសេរបញ្ជី សំរាប់ពូជពង្ស លោក, **អ័ប្រា.** ១:៣១ ។

**សេចក្ដីកុហក** *សូមមើលផង* ការនិយាយអាក្រក់; ការបោក, ចិត្តទៀងត្រង់, ទៀងត្រង់, បញ្ឆោត, សេចក្ដីបញ្ឆោត

ជាការនិយាយក្លែងក្លាយ ឬមិនពិត សំរាប់គោលបំណងខាងសេចក្ដី បញ្ឆោត ។

មិនត្រូវឲ្យឯងរាល់គ្នាលួច ឬប្រព្រឹត្តឆបោក ឬកុហកគ្នាឡើយ, **លេវី.** ១៩:១១ ។ ទូលបង្គំស្អប់ខ្ពើមសេចក្ដីកុហក, **ទំនុក.** ១១៩:១៦៣ ។ បបូរមាត់ដែលពោលពាក្យកុហក ជាទីស្អប់ខ្ពើមដល់ព្រះអម្ចាស់, **សុភា.** ១២:២២ ។ គេជារាស្ត្រអញ ដែលមិនព្រមប្រព្រឹត្តកុហក, **អេសាយ** ៦៣:៨ ។ អារក្សជាអ្នកកុហក ហើយជាឪពុកនៃសេចក្ដីកុហក, **យ៉ូហាន** ៨:៤៤ (២ នីហ្វៃ ២:១៨; អេធើរ ៨:២៥; ម៉ូសេ ៤:៤) ។ អ្នកមិនមែន កុហកដល់មនុស្សទេ តែគឺកុហកដល់ព្រះវិញ, **កិច្ចការ** ៥:៤ (អាលម៉ា១២:៣) ។ បើអ្នកណាថាខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់ បងប្អូនវិញ អ្នកនោះជាអ្នកកុហក, **១ យ៉ូហាន** ៤:២០ ។ គ្រប់ទាំង មនុស្សកុហក គេនឹងមានចំណែក នៅក្នុងសេចក្ដីស្លាប់ ទីពីរ, **វិវ.** ២១:៨ (គ. និង ស. ៦៣:១៧) ។ វេទនាដល់អ្នកកុហក ព្រោះតែអ្នក នោះនឹងត្រូវបោះចោលទៅក្នុងស្ថាននរក, **២ នីហ្វៃ** ៩:៣៤ ។ មនុស្ស ជាច្រើននឹងបង្រៀនលទ្ធិក្លែងក្លាយថា៖ និយាយកុហកបន្តិចបន្តួច នោះ គ្មានខុសអ្វីទេ, **២ នីហ្វៃ** ២៨:៨–៩ (គ. និង ស. ១០:២៥) ។ ឬក៏អ្នករាល់គ្នារមិលមើលខ្លួនឯងថា អ្នករាល់គ្នាអាចកុហកដល់ព្រះ អម្ចាស់ ? **អាលម៉ា** ៥:១៧ ។ ទ្រង់ជាព្រះនៃ សេចក្ដីពិត ហើយពុំអាច កុហកឡើយ, **អេធើរ** ៣:១២ (ជនគ. ២៣:១៩; ១ សាំយូ. ១៥:២៩; ទីតុស ១:២; ហេព្រើរ ៦:១៨; អេណុស ១:៦) ។ អ្នកណាដែលកុហក ហើយមិនប្រែចិត្ត នោះនឹងត្រូវបណ្ដេញចេញ, **គ. និង ស.** ៤២:២១ ។ ពួកមនុស្សកុហកគ្រងសិរីល្អខាង ទេឡេស្ទាលទុកជាមរតក, **គ. និង ស.** ៧៦:៨១, ១០៣–១០៦ ។ យើងខ្ញុំជឿលើការប្រព្រឹត្តដោយទៀងត្រង់, **ម. នៃ ស.** ១:១៣ ។

**សេចក្ដីកោតខ្លាច** *សូមមើលផង* ការកោតក្រែង, ដ៏ក្លាហាន; សេចក្ដីក្លាហាន, សេចក្ដីជំនឿ

*សេចក្ដីកោតខ្លាច* អាចមានន័យពីរយ៉ាងគឺ៖ (១) ខ្លាចព្រះ គឺមានចិត្ត គោរពកោតក្រែង និងស្ញប់ស្ញែងដល់ទ្រង់ ហើយគោរពតាម បញ្ញត្តិ ទាំងឡាយរបស់ទ្រង់ (២) ខ្លាចមនុស្ស, ការគ្រោះថ្នាក់ខាង សាច់ឈាម, ការឈឺ, និងអំពើអាក្រក់ គឺភ័យខ្លាចនូវរបស់របៀបនេះ ហើយញញើតរបស់ទាំងនោះជាខ្លាំង ។

*សេចក្ដីកោតខ្លាចដល់ព្រះ៖* ប្រាកដជាគ្មានសេចក្ដីកោតខ្លាចដល់ព្រះ នៅទីនេះទេ, **លោកុ.** ២០:១១ ។ ត្រូវឲ្យកោតខ្លាចដល់ ព្រះអម្ចាស់ ជាព្រះនៃអ្នក, **ចោទិ.** ៦:១៣ (យ៉ូស្វេ ២៤:១៤; ១ សាំយូ. ១២:២៤)។ ចូរគោរពដល់ព្រះអម្ចាស់ ដោយកោតខ្លាច, **ទំនុក.** ២:១១ ។ សេចក្ដី កោតខ្លាចដល់ព្រះអម្ចាស់ នោះជាដើមចមនៃប្រាជ្ញា, **ទំនុក.** ១១១:១០ ។ ចូរកោតខ្លាចដល់ព្រះអម្ចាស់វិញ ហើយចៀសចេញពីសេចក្ដីអាក្រក់ទៅ, **សុភា.** ៣:៧ ។ ពួកអ្នកដែលកោតខ្លាចដល់ព្រះនឹងមានសេចក្ដីសុខស្រួល, **សាស្ដា** ៨:១២ ។ ចូរបង្ហើយសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នា ដោយ កោតខ្លាច ហើយញាប់ញ័រចុះ, **ភីលីព** ២:១២ ។ ចូរកោតខ្លាចដល់ ព្រះ ហើយ សរសើរសិរីល្អរបស់ទ្រង់ចុះ, **វិវ.** ១៤:៧ (គ. និង ស. ៨៨:១០៤) ។ ពួកព្យាការីបានបំផុសដាស់ប្រជាជនជានិច្ច ដើម្បីធ្វើឲ្យ គេកោត ខ្លាចដល់ព្រះអម្ចាស់, **អេណុស** ១:២៣ ។ អាលម៉ា និងពួក បុត្រារបស់ម៉ូសាយបានដួលទៅលើដី ព្រោះការកោតខ្លាចចំពោះព្រះ បានធ្លាក់មកលើពួកគេ, **អាលម៉ា** ៣៦:៧ ។ ចូរបង្ហើយសេចក្ដីសង្គ្រោះ របស់អ្នករាល់គ្នា ដោយមានការកោតខ្លាច និងញាប់ញ័រចុះ, **មរមន** ៩:២៧ ។ ពួកអ្នកដែលមិនកោតខ្លាចដល់យើង នោះយើងនឹងរំខាន ហើយបណ្ដាលឲ្យញ័ររន្ធត់, **គ. និង ស.** ១០:៥៦ ។ អ្នកណាដែល កោតខ្លាចដល់យើង នោះនឹងទន្ទឹងចាំដល់ទីសំគាល់ទាំងឡាយ ពីការ យាងមកនៃកូនមនុស្ស, **គ. និង ស.** ៤៥:៣៩ ។

*សេចក្ដីកោតខ្លាចដល់មនុស្ស៖* កុំឲ្យខ្លាចអ្វីឡើយ ត្បិតយើងនៅជាមួយ អ្នកហើយ, **លោកុ.** ២៦:២៤ (អេសាយ ៤១:១០) ។ ព្រះអម្ចាស់ គង់នៅខាងយើងរាល់គ្នា កុំឲ្យខ្លាចគេឡើយ, **ជនគ.** ១៤:៩ ។ កុំ ខ្លាចអ្វីឡើយ ត្បិតពួកដែលនៅខាងយើង មានគ្នាច្រើន ជាង, **២ ពង្សាវ.** ៦:១៦ ។ ទូលបង្គំនឹងមិនខ្លាចឡើយ តើសាច់ឈាមនឹងអាចធ្វើអ្វីដល់ ទូលបង្គំបាន, **ទំនុក.** ៥៦:៤ ។ កុំឲ្យខ្លាចសេចក្ដី ត្មះតិះដៀលរបស់ មនុស្សឡើយ, **អេសាយ** ៥១:៧ (២ នីហ្វៃ ៨:៧) ។ ព្រះទ្រង់មិនបាន ប្រទានឲ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាច ឡើយ,២ ធីម៉ូ. ១:៧ ។ សេចក្ដីស្រឡាញ់ដែលពេញខ្នាត នោះបណ្ដេញសេចក្ដីភ័យខ្លាចចេញ, **១ យ៉ូហាន** ៤:១៨ (ម៉ូរ៉ូណៃ ៨:១៦) ។ ពួកកូនប្រុសរបស់ហេលេមិន មិនខ្លាចសេចក្ដីស្លាប់ឡើយ, **អាលម៉ា** ៥៦:៤៦–៤៨ ។ ទ្រូងនៃពួក ទុច្ចរិតពោរពេញទៅដោយសេចក្ដីភិត ភ័យចំពោះសេចក្ដីស្លាប់, **មរមន** ៦:៧ ។ ចូរកុំខ្លាចនូវអ្វីដែលមនុស្សអាចប្រព្រឹត្តឡើយ, **ម៉ូរ៉ូណៃ** ៨:១៦ ។

អ្នករាល់គ្នាមិនត្រូវខ្លាច មនុស្សជាងព្រះឡើយ, **គ. និង ស.** ៣:៧ (គ. និង ស. ៣០:១, ១១; ១២២:៩) ។ ចូរកុំខ្លាចនឹងធ្វើអំពើល្អឡើយ, **គ. និង ស.** ៦:៣៣ ។ អស់អ្នក ណាដែលនៅក្នុងសាសនាចក្ររបស់យើង មិនត្រូវខ្លាចឡើយ, **គ. និង ស.** ១០:៥៥ ។ បើសិនជាអ្នករាល់គ្នាបានប្រុងប្រៀបទុក ជាស្រេច នោះអ្នករាល់គ្នានឹងមិនត្រូវខ្លាចឡើយ, **គ. និង ស.** ៣៨:៣០ ។ ចូរកំចាត់ខ្លួនចេញពីសេចក្ដីខ្លាច, **គ. និង ស.** ៦៧:១០ ។ ចូរសង្ឃឹមឡើង ហើយចូរកុំខ្លាចឡើយ ត្បិតយើងជាព្រះអម្ចាស់ គង់នៅជាមួយនឹងអ្នក, **គ. និង ស.** ៦៨:៦ ។ ចូរកុំខ្លាចពួកខ្មាំងសត្រូវ របស់អ្នកឡើយ, **គ. និង ស.** ១៣៦:១៧ ។

**សេចក្ដីក្បត់សាសនា** *សូមមើលផង* ការបះបោរ;
ការសាងឡើងវិញនៃដំណឹងល្អ

ជាការបែរចេញពីសេចក្ដីពិតដោយបុគ្គលនីមួយៗ ដោយសាសនាចក្រ ឬដោយសាសន៍ទាំងស្រុង ។

*សេចក្ដីក្បត់សាសនាទូទៅ៖* ពួកអ៊ីស្រាអែលត្រូវការពារចិត្តខ្លួនពីការបែរចេញពីព្រះអម្ចាស់, **ចោទិ.** ២៩:១៨ ។ គ្រាណាដែលឥត មានការបើកសម្ដែង នោះបណ្ដាជនរមែងលែងទប់ចិត្ត, **សុភា.** ២៩:១៨ ។ គេបានផ្ដាច់សេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ចចេញ, **អេសាយ** ២៤:៥ ។ ខ្យល់បក់ប៉ះនឹងផ្ទះនោះ ផ្ទះនោះក៏រលំទៅ, **ម៉ាថាយ** ៧:២៧ ។ ខ្ញុំឆ្ងល់ណាស់ ពីដំណើរដែលអ្នករាល់គ្នាបាន ផ្លាស់ប្រែចេញទៅតាមដំណឹងល្អផ្សេងទៀតនោះជាឆាប់ម្ល៉េះ, **កាឡាទី** ១:៦ ។ ពួកគេបានចាប់ផ្ដើមតាមផ្លូវល្អ តែបានវង្វេងនៅក្នុង អ័ព្ទ, **១ នីហ្វៃ** ៨:២៣ (១ នីហ្វៃ ១២:១៧) ។ ក្រោយពីពួកគេបានភ្លក់ផ្លែឈើនោះហើយ នោះពួកគេបានធ្លាក់ចូលផ្លូវហាមឃាត់, **១ នីហ្វៃ** ៨:២៨ ។ សេចក្ដីក្បត់សាសនារបស់ពួកសាសន៍នីហ្វៃ បានបណ្ដាលឲ្យមានថ្មជំពប់មួយ ដល់ពួកអ្នកដែលមិនជឿ, **អាលម៉ា** ៤:៦–១២ ។ សមាជិកជាច្រើនក្នុងសាសនាចក្របានក្លាយទៅជាឆ្មើងឆ្មៃ ហើយបានបៀតបៀនសមាជិកផ្សេងៗទៀត, **ហេលេ.** ៣:៣៣–៣៤ (ហេលេ. ៤:១១–១៣; ៥:២–៣) ។ នៅពេលដែលព្រះអម្ចាស់ទ្រង់ធ្វើឲ្យប្រជារាស្ត្រទ្រង់ចំរុងចំរើន ជួននោះហើយដែលពួកគេធ្វើចិត្ត រឹងរូស ហើយបំភ្លេចទ្រង់, **ហេលេ.** ១២:២; ១៣:៣៨ ។ ពួកសាសន៍នីហ្វៃបានធ្វើចិត្តរឹងរូស ហើយបានធ្លាក់ទៅក្រោមអំណាចអារក្ស សាតាំង, **៣ នីហ្វៃ** ២:១–៣ ។ មរ៉ូណៃបានព្យាករអំពីសេចក្ដីក្បត់សាសនានៅគ្រាក្រោយបង្អស់, **មរមន** ៨:២៨, ៣១–៤១ ។ សេចក្ដី ក្បត់សាសនានឹងកើតឡើង មុនការយាងមកលើកទីពីរ, **គ. និង ស.** ១:១៣–១៦ ។

*សេចក្ដីក្បត់សាសនានៃសាសនាចក្រគ្រីស្ទានដើម៖* ប្រជាជននេះចូលមកជិតយើង ដោយបបូរមាត់របស់គេ, **អេសាយ** ២៩:១០, ១៣ ។ សេចក្ដីងងឹតនឹងគ្របលើផែនដី, **អេសាយ** ៦០:២ ។ ព្រះអម្ចាស់ទ្រង់នឹងចាត់អំណត់មក គឺជាអំណត់ខាងឯការឮព្រះបន្ទូលនៃព្រះ អម្ចាស់, **អេម៉ុស** ៨:១១ ។ នឹងមានព្រះគ្រីស្ទក្លែងក្លាយ ហើយព្យាការីក្លែងកើតឡើង, **ម៉ាថាយ** ២៤:២៤ ។ នឹងមានឆ្កែព្រៃដ៏សាហាវ ចូលមកក្នុងពួកអ្នករាល់គ្នា, **កិច្ចការ** ២០:២៩ ។ ខ្ញុំឆ្ងល់ណាស់ពីដំណើរដែលអ្នករាល់គ្នាបានផ្លាស់ប្រែពីទ្រង់ជាឆាប់ម្ល៉េះ, **កាឡាទី** ១:៦ ។ នឹងមានសេចក្ដីក្បត់សាសនាមកជាមុនការយាងមកលើកទីពីរ, ២ ថែស្ស. ២:៣ ។ មនុស្សខ្លះនិយាយបង្ខូចសេចក្ដីពិត, **២ ធីម៉ូ.** ២:១៨ ។ មនុស្សខ្លះមានឫកពាជាអ្នកគោរពប្រតិបត្តិដល់ព្រះ ប៉ុន្តែមិនព្រមទទួលស្គាល់ព្រះចេស្ដាទេ, **២ ធីម៉ូ.** ៣:៥ ។ នឹងមានគ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវទេ, **២ ធីម៉ូ.** ៤:៣–៤ ។ នឹងមានព្យាការីក្លែងក្លាយ ហើយនិងគ្រូក្លែងក្លាយក្នុងបណ្ដា ជន, **២ ពេត្រុស** ២:១ ។ មានមនុស្សខ្លះលួចចូល មិនព្រមទទួលព្រះអម្ចាស់ ដែលទ្រង់ជាម្ចាស់តែមួយផងទេ, **យូដាស** ១:៤ ។ មនុស្ស ខ្លះហៅថាខ្លួនជា សាវក តែមិនមែនជាសាវកទេ, **វិវរ.** ២:២ ។ នីហ្វៃបានមើលឃើញការបង្កើតឡើងនៃសាសនាចក្រដ៏ធំ ហើយគួរ ខ្ពើមឆ្អើម, **១ នីហ្វៃ** ១៣:២៦ ។ ពួកសាសន៍ដទៃបានជំពប់ ហើយបានតាំងសាសនាចក្រជាច្រើន, **២ នីហ្វៃ** ២៦:២០ ។ ពួកគេបាន វង្វេងចេញពីក្រិត្យក្រមរបស់យើង ហើយបានបំបាក់សេចក្ដីសញ្ញារបស់យើង ដែលនៅអស់កល្បជានិច្ច, **គ. និង ស.** ១:១៥ ។ សេចក្ដី ងងឹតគ្របដណ្ដប់លើផែនដី ហើយសេចក្ដីងងឹតដ៏ធំគ្របលើគំនិតនៃប្រជាជន, **គ. និង ស.** ១១២:២៣ ។ យ៉ូសែបត្រូវបានប្រាប់ថាសាសនាចក្រទាំងឡាយសុទ្ធតែខុសទាំងអស់គ្នា; ឯចិត្តរបស់ពួកគេនៅឆ្ងាយពីព្រះ, **យ.ស. — ប្រវត្តិ** ១:១៩ ។

**សេចក្ដីក្លាហាន, ដ៏ក្លាហាន** *សូមមើលផង* កោតខ្លាច, សេចក្ដីជំនឿ

គឺមិនខ្លាច ជាពិសេស ក្នុងការធ្វើនូវអ្វីដែលត្រឹមត្រូវ ។

ចូរមានកំឡាំង ហើយចិត្តក្លាហានឡើង, **ចោទិ.** ៣១:៦ (យ៉ូស្វេ ១:៦–៧) ។ ចូរសំរេចចិត្តក្លាហាននឹងកាន់ ហើយប្រព្រឹត្តតាមគ្រប់ទាំងសេចក្ដីដែលបានកត់ទុក, **យ៉ូស្វេ** ២៣:៦ ។ ព្រះទ្រង់មិនបានប្រទានឲ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ,២ ធីម៉ូ. ១:៧ ។ ចិត្តគាត់ក៏ចាប់ផ្ដើមមានសេចក្ដីក្លាហានឡើង កាលគាត់បានឮ **អាលម៉ា** ១៥:៤ (អាលម៉ា ៦២:១) ។ ពួកកូនប្រុសរបស់ហេលេមិន សុទ្ធតែមានចិត្តក្លាហានអង់អាចជាអតិបរមា, **អាលម៉ា** ៥៣:២០–២១ ។ ខ្ញុំមិនដែលបានឃើញសេចក្ដីក្លាហានដ៏ធំយ៉ាងនេះទេ, **អាលម៉ា** ៥៦:៤៥ ។ បងប្អូនអើយ ចូរមានចិត្តក្លាហានចុះ ហើយចូរទៅ ចូរទៅ ទៅរកជ័យជំនះ, **គ. និង ស.** ១២៨:២២ ។

**សេចក្ដីក្រោធ** *សូមមើល* សេចក្ដីខ្ញាល់

**សេចក្ដីខ្មាំង** *សូមមើលផង* ប្រណែន; ស្រឡាញ់; សេចក្ដីសងសឹក

នៅក្នុងគម្ពីរ គឺជាសេចក្ដីជំទាស់ សេចក្ដីប្រឆាំង និងសេចក្ដីស្អប់ ។

យើងនឹងដាក់សេចក្ដីខ្មាំងនឹងគ្នារវាងអ្នកនិងស្ត្រី, **លោកុ.** ៣:១៥ (ម៉ូសេ ៤:២១) ។ គំនិតខាងសាច់ឈាមជាសេចក្ដីខ្មាំងទាស់នឹងព្រះ, **រ៉ូម** ៨:៧ ។ មិត្តសំឡាញ់នឹងលោកិយ ជាខ្មាំងសត្រូវនឹងព្រះ, **យ៉ាកុប** (ព.ស.ថ.) ៤:៤ ។ នៅថ្ងៃនោះ សេចក្ដីខ្មាំងនឹងឈប់មាននៅ ចំពោះព្រះភ័ក្ត្ររបស់យើង, **គ. និង ស.** ១០១:២៦ ។

**សេចក្ដីងងឹតខាងក្រៅ** *សូមមើល* ស្ថាននរក

**សេចក្ដីងងឹតខាងក្រៅ***សូមមើល* ពួកកូនអន្តរធាន, ស្ថាននរក;
សេចក្ដីស្លាប់ខាងវិញ្ញាណ; អារក្ស

**សេចក្ដីងងឹតខាងវិញ្ញាណ***សូមមើលផង* ទុច្ចរិត, អំពើទុច្ចរិត

ជាអំពើទុច្ចរិត ឬការល្ងង់ខ្លៅអំពីការណ៍ខាងវិញ្ញាណ

វេទនាដល់ពួកអ្នកដែលយកសេចក្ដីងងឹតជាពន្លឺ, **អេសាយ** ៥:២០ (២ នីហ្វៃ ១៥:២០) ។ សេចក្ដីងងឹតនឹងគ្របលើផែនដី ហើយសេចក្ដីសូន្យសុងនឹងគ្របលើអស់ទាំងជនជាតិ, **អេសាយ** ៦០:២ ។ ព្រះយេស៊ូវនឹងបំភ្លឺដល់ពួកអ្នកដែលអង្គុយក្នុងសេចក្ដីងងឹត, **លូកា** ១:៧៩ ។ ពន្លឺក៏ភ្លឺមកក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតយល់មិនដល់ពន្លឺទេ, **យ៉ូហាន** ១:៥ (គ. និង ស. ៤៥:៧) ។ ចូរដោះចោលអស់ទាំងការ របស់សេចក្ដីងងឹតចេញ ហើយពាក់គ្រឿងការពាររបស់ពន្លឺវិញ, **រ៉ូម** ១៣:១២ ។ ចូរកុំឲ្យប្រកបក្នុងការឥតផលប្រយោជន៍របស់សេចក្ដី ងងឹតឡើយ, **អេភេ.** ៥:៨–១១ ។ គឺមកពីអ្នកមិនសូម នោះអ្នករាល់គ្នាមិនអាចនាំទៅងពន្លឺទេ តែត្រូវវិនាសនៅក្នុងសេចក្ដីងងឹតវិញ, **២ នីហ្វៃ** ៣២:៤ ។ សាតាំងផ្សាយនូវកិច្ចការទាំងឡាយនៃសេចក្ដីងងឹត, **ហេលេ.** ៦:២៨–៣១ ។ អំណាចនៃសេចក្ដីងងឹតមានជ័យជំនះ នៅលើផែនដី, **គ. និង ស.** ៣៨:៨, ១១–១២ ។ ពិភពលោកទាំងមូលថ្ងូរនៅក្រោមសេចក្ដីងងឹត និងអំពើបាប, **គ. និង ស.** ៨៤:៤៩–៥៤ ។ បើសិនជាភ្នែករបស់អ្នកស្មោះស្ម័គ្រទាំងស្រុង ទៅចំពោះសិរីល្អរបស់យើង នោះនឹងពុំមានសេចក្ដីងងឹតនៅក្នុងអ្នក ឡើយ, **គ. និង ស.** ៨៨:៦៧ ។ កិច្ចការទាំងឡាយនៃសេចក្ដីងងឹតបានចាប់ផ្ដើមមានជ័យជំនះ ក្នុងចំណោមពួកកូនប្រុសនៃមនុស្ស, **ម៉ូសេ** ៥:៥៥ ។

**សេចក្ដីឆ្មើងឆ្មៃ** *សូមមើលផង* ការឥតប្រយោជន៍;
ចិត្តសុភាពរាបសា; ទ្រព្យសម្បត្តិ; បន្ទាបខ្លួន, ប្រាក់;
សេចក្ដីប្រកបដោយលោកិយ, ឥតប្រយោជន៍

ជាការខ្វះខាត ឬអវត្តមានខាងចិត្តសុភាពរាបសា ឬខាងចិត្តទន់ភ្លន់ ។ សេចក្ដីឆ្មើងឆ្មៃញែកមនុស្សចេញឲ្យទាស់នឹងអ្នកដទៃ ហើយនឹងព្រះ ។ មនុស្សឆ្មើងឆ្មៃលើកខ្លួនលើអស់អ្នកទាំង ឡាយដែលនៅជុំវិញខ្លួន ហើយដើរតាមចំណង់ចិត្តរបស់ខ្លួន ជាជាងតាមព្រះ ហឫទ័យនៃព្រះ ។ ជាទូទៅ ការបញ្ឆោត ការច្រណែន ការធ្វើចិត្តរឹងរូស និងការអួតក្រអឺតក៏ជាភាពនៃមនុស្សឆ្មើងឆ្មៃ ។

ចូរប្រយ័ត្ន កុំឲ្យភ្លេចព្រះអម្ចាស់ ក្រែងចិត្តឯងបានអួតអាង, **ចោទិ.** ៨:១១–១៤ ។ ការលើកខ្លួន និងការប្រកាន់ខ្លួន នោះអញស្អប់, **សុភា.** ៨:១៣ (សុភា. ៦:១៦–១៧) ។ សេចក្ដីឆ្មើងឆ្មៃនាំមុខសេចក្ដីហិនវិនាស, **សុភា.** ១៦:១៨ ។ ថ្ងៃរបស់ព្រះអម្ចាស់នឹងមកលើពួកមានឫកខ្ពស់, **អេសាយ** ២:១១–១២ (២ នីហ្វៃ ១២:១១–១២) ។ សេចក្ដីអំនួតនៅក្នុងចិត្តឯង បានបញ្ឆោតឯងហើយ, **អូបា.** ១:៣ ។ អស់ពួកឆ្មើង ឆ្មៃនឹងដូចជាជញ្ជ្រាំង, **ម៉ាឡាគី** ៤:១ (១ នីហ្វៃ ២២:១៥; ៣ នីហ្វៃ ២៥:១; គ. និង ស. ២៩:៩) ។ អ្នកណាដែលដំកើង ខ្លួននោះនឹងត្រូវបន្ទាបចុះ, **ម៉ាថាយ** ២៣:១២ (គ. និង ស. ១០១:៤២) ។ ព្រះទ្រង់តតាំងនឹងមនុស្សអួតអាង, **១ ពេត្រុស** ៥:៥ ។ អាគារដ៏ធំ ហើយទូលាយ គឺជាសេចក្ដីឆ្មើងឆ្មៃនៃមនុស្សលោក, **១ នីហ្វៃ** ១១:៣៦ (១ នីហ្វៃ ១២:១៨) ។ កាលណាគេបានរៀនសូត្រ នោះគេស្មានថាខ្លួនឆ្លាតវៃ, **២ នីហ្វៃ** ៩:២៨–២៩ ។ អ្នកលើកខ្លួនឡើង ក្នុងការឆ្មើងឆ្មៃនៃចិត្តរបស់អ្នក, **យ៉ាកុប** ២:១៣, ១៦ (អាលម៉ា ៤:៨–១២) ។ តើអ្នករាល់គ្នា បានលះបង់ចោលនូវការឆ្មើងឆ្មៃរបស់អ្នកហើយឬ ? **អាលម៉ា** ៥:២៨ ។ ការឆ្មើងឆ្មៃដ៏ធំហួស ប្រមាណបានចូលទៅក្នុងចិត្តរបស់ប្រជាជន, **ហេលេ.** ៣:៣៣–៣៦ ។ ម្ដេចក៏កូនចៅមនុស្សឆាប់ដំកើងខ្លួនក្នុងសេចក្ដីឆ្មើងឆ្មៃដល់ម្ល៉េះហ្ន៎, **ហេលេ.** ១២:៤–៥ ។ សេចក្ដីឆ្មើងឆ្មៃនៃប្រជាជាតិនេះ បានបញ្ជាក់ឲ្យឃើញនូវសេចក្ដីបំផ្លិចបំផ្លាញដល់ពួកគេ, **ម៉ូរ៉ូណៃ** ៨:២៧ ។ ចូរប្រយ័ត្នពីសេចក្ដីឆ្មើងឆ្មៃ ក្រែងអ្នក រាល់គ្នាក្លាយទៅដូចជាពួកសាសន៍នីហ្វៃ, **គ. និង ស.** ៣៨:៣៩ ។ ចូរឈប់ពីសេចក្ដីឆ្មើងឆ្មៃ និងគំនិតផ្ដេសផ្ដាសរបស់អ្នក, **គ. និង ស.** ៨៨:១២១ ។

**សេចក្ដីជាប់ទោស***សូមមើលផង* ពួកកូនអន្តរធាន, ស្ថាននរក;
សេចក្ដីស្លាប់ខាងវិញ្ញាណ; អារក្ស

ជាស្ថានភាពនៃការបញ្ឈប់នូវការជឿនលឿនរបស់មនុស្ស ហើយបដិសេធនូវផ្លូវដែលទៅរកវត្តមាននៃព្រះ និងសិរីល្អរបស់ទ្រង់ ។ សេចក្ដីជាប់ទោសមាននៅតាមលំដាប់ច្រើនបែប ។ មនុស្សទាំងអស់ដែលមិនបានទទួលភាពពោរពេញនៃភាពថ្កើងថ្កានឡើងខាងសេឡេស្ទាល នោះនឹងត្រូវកំរិតការជឿនលឿន និងសិទ្ធិទៅតាមលំដាប់ខ្លះៗ ហើយពួកគេនឹងជាប់ទោសចំពោះស្ថានភាពនោះ ។

វេទនាដល់អ្នករាល់គ្នា ជាមនុស្សកំពុតអើយ ! អ្នករាល់គ្នានឹងត្រូវទោសធ្ងន់ជាងទៅទៀត, **ម៉ាថាយ** ២៣:១៤ ។ អ្នកណាដែល ពោលពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ នោះនឹងត្រូវទោសនៅអស់កល្បជានិច្ច, **ម៉ាកុស** ៣:២៩ ។ ពួកអ្នកដែលបានប្រព្រឹត្តអាក្រក់នឹងរស់ឡើងឲ្យជាប់មានទោស, **យ៉ូហាន** ៥:២៩ (៣ នីហ្វៃ ២៦:៥) ។ អ្នកណាដែលបរិភោគបែបមិនគួរសម អ្នកនោះឈ្មោះថា បរិភោគជាសេចក្ដីជំនុំជំរះដល់ខ្លួនវិញ, **១ កូរិន.** ១១:២៩ (៣ នីហ្វៃ ១៨:២៨–២៩) ។ អ្នកណាដែលមិនប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុតទេ អ្នកនោះនឹងត្រូវជាប់ទោស, **២ នីហ្វៃ** ៩:២៤ (ម៉ាកុស ១៦:១៦; អេធើរ ៤:១៨; គ. និង ស. ៦៨:៩; ៨៤:៧៤) ។ ពួកទុច្ចរិតនៅជាមួយព្រះនឹងវេទនាជាងនៅជាមួយពួកព្រលឹងដែលជាប់ទោសនៅស្ថាននរក, **មរមន** ៩:៤ ។ អ្នកណាដែលមិនប្រព្រឹត្តអ្វីសោះឡើយ ទាល់តែអ្នកនោះត្រូវបានបញ្ជា អ្នកនោះឈ្មោះថា ជាប់ទោសហើយ, **គ. និង ស.** ៥៨:២៩ ។ អ្នកណាដែលទទួលនូវភាពពោរពេញនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច នោះត្រូវនៅជាប់នឹងក្រិត្យវិន័យ បើពុំនោះសោតទេ អ្នកនោះនឹងជាប់ទោស, **គ. និង ស.** ១៣២:៦ ។

**សេចក្ដីជំនឿ** *សូមមើលផង* ជំនឿ, ជឿ; ទុកចិត្ត, ព្រះយេស៊ូវគ្រីស្ទ; សេចក្ដីសង្ឃឹម

ជាសេចក្ដីទុកចិត្តលើអ្វីមួយ ឬលើអ្នកណាម្នាក់ ។ ដូចជាយកមកប្រើជាច្រើនលើកច្រើនដងនៅក្នុងគម្ពីរ សេចក្ដីជំនឿ គឺជាសេចក្ដីទុកចិត្ត និងទីទុកចិត្តដល់ព្រះយេស៊ូវគ្រីស្ទ ដែលនាំជនណាម្នាក់ឲ្យគោរពតាមទ្រង់ ។ សេចក្ដីជំនឿត្រូវតែពឹងពាក់ដល់ព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យបាននាំជនណាម្នាក់ទៅរកសេចក្ដីសង្គ្រោះ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយក៏ត្រូវមានសេចក្ដីជំនឿជឿដល់ព្រះដ៏ជាព្រះវរបិតា ព្រះវិញ្ញាណបរិសុទ្ធ អំណាចនៃបព្វជិតភាព និងដល់សណ្ដានសំខាន់ៗនៃដំណឹងល្អដែលបានសាងឡើងវិញ ។

សេចក្ដីជំនឿមានរួមទាំងសេចក្ដីសង្ឃឹមចំពោះអ្វីៗ ដែលមើលមិនឃើញ ប៉ុន្តែពិត (ហេព្រើរ ១១:១; អាលម៉ា ៣២:២១; អេធើរ ១២:៦) ។ សេចក្ដីជំនឿកើតឡើងដោយសារការឮដំណឹងល្អ ដែលបានបង្រៀនដោយពួកអ្នកធ្វើការដែលមានសិទ្ធិអំណាច ដែលបាន ចាត់មកពីព្រះ (រ៉ូម ១០:១៤–១៧) ។ អព្ភូតហេតុមិនធ្វើឲ្យមានសេចក្ដីជំនឿទេ ប៉ុន្តែសេចក្ដីជំនឿដ៏ធំ គឺមានឡើងដោយសារការគោរពតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទវិញ ។ ម្យ៉ាងទៀត សេចក្ដីជំនឿមានមកដោយសារសេចក្ដីសុចរិត (អាលម៉ា ៣២:៤០–៤៣; អេធើរ ១២:៤, ៦, ១២; គ. និង ស. ៦៣:៩–១២) ។

សេចក្ដីជំនឿពិត នាំមកនូវអព្ភូតហេតុ ការនិមិត្ត ការយល់សប្ដិ ការធ្វើឲ្យជា និងគ្រប់ទាំងអំណោយទានពីព្រះ ដែលទ្រង់ប្រទានដល់ពួកបរិសុទ្ធរបស់ទ្រង់ ។ ដោយសារសេចក្ដីជំនឿ នោះមនុស្សអាចបានទទួលនូវការផ្ដាច់បាប ហើយតទៅ ក៏អាចបាននៅក្នុងវត្តមាននៃព្រះ ។ ការខ្វះសេចក្ដីជំនឿ នាំឲ្យមនុស្សអស់សង្ឃឹម គឺមានឡើងដោយសារអំពើទុច្ចរិត (ម៉ូរ៉ូណៃ ១០:២២) ។

មនុស្សសុចរិតនឹងរស់នៅ ដោយសារសេចក្ដីជំនឿ, **ហាបា.** ២:៤ ។ សេចក្ដីជំនឿរបស់នាងបានជួយសង្គ្រោះនាងហើយ, **ម៉ាថាយ** ៩:២២ (ម៉ាកុស ៥:៣៤; លូកា ៧:៥០) ។ ចូរឲ្យបានដូចសេចក្ដីជំនឿរបស់អ្នកចុះ, **ម៉ាថាយ** ៩:២៩ ។ បើអ្នករាល់គ្នាមានសេចក្ដីជំនឿ ដូចគ្រាប់ពូជមួយយ៉ាងល្អិត នោះនឹងគ្មានការអ្វី ដែលអ្នករាល់គ្នាធ្វើមិនកើតនោះទេ, **ម៉ាថាយ** ១៧:២០ (លូកា ១៧:៦) ។ ខ្ញុំបាន អធិស្ឋានឲ្យអ្នក ដើម្បីមិនឲ្យសេចក្ដីជំនឿរបស់អ្នកវិនាសបាត់ឡើយ, **លូកា** ២២:៣២ ។ សេចក្ដីជំនឿជឿដល់ព្រះនាមព្រះគ្រីស្ទ បានធ្វើឲ្យមនុស្សនេះមានកម្លាំងឡើង, **កិច្ចការ** ៣:១៦ ។ សេចក្ដីជំនឿកើតឡើង ដោយសារការឮព្រះបន្ទូលនៃព្រះ, **រ៉ូម** ១០:១៧ ។ បើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះសេចក្ដីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ, **១ កូរិន.** ១៥:១៤ ។ សេចក្ដីជំនឿប្រព្រឹត្តិដោយ សេចក្ដីស្រឡាញ់, **កាឡាទី** ៥:៦ ។ ដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ, **អេភេ.** ២:៨ (២ នីហ្វៃ ២៥:២៣) ។ ចូរយកសេចក្ដីជំនឿទុកជាខែល, **អេភេ.** ៦:១៦ (គ. និង ស. ២៧:១៧) ។ ខ្ញុំបានតស៊ូប្រណាំងជាស្រេច ខ្ញុំបានរក្សា សេចក្ដីជំនឿទៅហើយ,២ ធីម៉ូ. ៤:៧ ។ សេចក្ដីជំនឿ គឺជារបស់នឹងបានដូចសង្ឃឹម, **ហេព្រើរ** ១១:១ ។ ឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ, **ហេព្រើរ** ១១:៦ ។ សេចក្ដីជំនឿ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់នៅតែឯង, **យ៉ាកុប** (ព.ស.ថ.) ២:១៧–១៨, ២២ ។ ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗ ដែលព្រះអម្ចាស់ ទ្រង់បានបញ្ជា, **១ នីហ្វៃ** ៣:៧ ។ ព្រះអម្ចាស់ ទ្រង់អាចធ្វើនូវអ្វីៗគ្រប់យ៉ាង ដើម្បីកូនចៅមនុស្ស ប្រសិនបើគេអនុវត្តសេចក្ដីជំនឿជឿដល់ទ្រង់, **១ នីហ្វៃ** ៧:១២ ។ ទ្រនិចនៅក្នុង លីអាហូណា ដើរតាមសេចក្ដីជំនឿ, **១ នីហ្វៃ** ១៦:២៨ ។ ប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមទ្រង់ ដោយមាន សេចក្ដីជំនឿដ៏ឥតខ្ចោះ ជឿដល់ព្រះបរិសុទ្ធតែមួយ, **២ នីហ្វៃ** ៩:២៣ ។ ព្រះគ្រីស្ទសម្ដែងអព្ភូតហេតុដ៏ធំៗក្នុងចំណោមកូនចៅមនុស្ស តាមសេចក្ដីជំនឿរបស់គេ, **២ នីហ្វៃ** ២៦:១៣ (អេធើរ ១២:១២; ម៉ូរ៉ូណៃ ៧:២៧–២៩, ៣៤–៣៨) ។ អំពើបាបនៃអេណុសត្រូវបាន អត់ទោសហើយ ពីព្រោះតែសេចក្ដីជំនឿរបស់គាត់ដែលជឿដល់ព្រះគ្រីស្ទ, **អេណុស** ១:៣–៨ ។ សេចក្ដីសង្គ្រោះនឹងពុំមានដល់នរណាឡើយ លើកលែងតែដោយសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ, **ម៉ូសាយ** ៣:១២ ។ ចិត្តត្រូវបានផ្លាស់ប្ដូរដោយសេចក្ដីជំនឿ ជឿដល់ព្រះនាមព្រះអង្គ, **ម៉ូសាយ** ៥:៧ ។ ពាក្យអធិស្ឋានរបស់អ្នកបំរើទាំងឡាយរបស់ព្រះ ត្រូវបានទទួលចម្លើយតាមសេចក្ដីជំនឿ របស់គេ, **ម៉ូសាយ** ២៧:១៤ ។ សូមចំរើនកម្លាំងដល់យើងខ្ញុំផង តាមសេចក្ដីជំនឿរបស់យើងខ្ញុំ ទៅលើព្រះគ្រីស្ទ, **អាលម៉ា** ១៤:២៦ ។ ចូរអំពាវនាវដល់ព្រះនាមព្រះ ដោយនូវសេចក្ដីជំនឿចុះ, **អាលម៉ា** ២២:១៦ ។ សេចក្ដីជំនឿ គឺមិនមែនជាការចេះដឹងដ៏ឥតខ្ចោះ នូវអ្វីៗ ទាំងឡាយនោះទេ, **អាលម៉ា** ៣២:២១ (អេធើរ ១២:៦) ។ កាលពាក្យនេះចាប់ផ្ដើម រីកឡើង ចូរថែទាំវា ដោយសេចក្ដីជំនឿរបស់ អ្នកចុះ, **អាលម៉ា** ៣៣:២៣ (អាលម៉ា ៣២:២៨) ។ ការរក្សាជីវិតគេទុក គឺផ្ទុកទៅ លើព្រះចេស្ដាដ៏អស្ចារ្យនៃព្រះ ពីព្រោះតែសេចក្ដី ជំនឿរបស់គេដ៏ខ្លាំង, **អាលម៉ា** ៥៧:២៥–២៧ ។ មនុស្សជាច្រើនណាដែលនឹងសម្លឹង មើលទៅឯព្រះរាជបុត្រានៃព្រះ ដោយមានសេចក្ដី ជំនឿ អ្នកនោះនឹងអាចបានរស់, **ហេលេ.** ៨:១៥ ។ យើងឃើញថាសេចក្ដីជំនឿ របស់អ្នករាល់គ្នាល្មមគ្រប់គ្រាន់ ដើម្បីឲ្យយើងប្រោស ឲ្យអ្នកជាហើយ, ៣ នីហ្វៃ ១៧:៨ ។ សេចក្ដីជំនឿ គឺជាអ្វីដែលសង្ឃឹមចង់បាន ហើយមើលមិនឃើញ, **អេធើរ** ១២:៦ ។ អស់អ្នកទាំងឡាយណាដែលសម្ដែងអព្ភូតហេតុទាំងប៉ុន្មាន គឺបានសម្ដែងឡើងដោយសារ សេចក្ដីជំនឿ, **អេធើរ** ១២:១២–១៨ ។ បើគេមានសេចក្ដីជំនឿជឿដល់យើង នោះយើងនឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះគេវិញ, **អេធើរ** ១២:២៧–២៨, ៣៧ ។ មរមនបានបង្រៀនអំពីសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស, **ម៉ូរ៉ូណៃ** ៧ ។ អ្វីៗក៏ដោយ ដែលអ្នកសូមពីព្រះវរបិតា ដោយ នូវឈ្មោះយើង ដែលជាការល្អ ដោយនូវសេចក្ដីជំនឿជឿថា អ្នកនឹងបានទទួល មើលចុះ នោះនឹងបានប្រទានឲ្យអ្នក, **ម៉ូរ៉ូណៃ** ៧:២៦ ។ ពួកអ្នកដែលមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ អ្នកទាំងនោះនឹងតោងទៅនឹង អ្វីដែលល្អគ្រប់យ៉ាង, **ម៉ូរ៉ូណៃ** ៧:២៨ ។ បើសិនជាអ្នក រាល់គ្នាសូមដោយមានសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ នោះទ្រង់នឹងសម្ដែងសេចក្ដីពិត, **ម៉ូរ៉ូណៃ** ១០:៤ ។ បើគ្មានសេចក្ដីជំនឿ

នោះអ្នក ពុំអាចធ្វើអ្វីបានទេ ហេតុដូច្នេះហើយ ចូរសូមដោយនូវសេចក្ដីជំនឿ, **គ. និង ស.** ៨:១០ ។ នឹងត្រូវបាន អនុញ្ញាតដល់ពួកគេ ស្របតាមសេចក្ដីជំនឿរបស់គេ ក្នុងការអធិស្ឋានរបស់ពួកគេទាំងប៉ុន្មាននោះ, **គ. និង ស.** ១០:៤៧, ៥២ ។ មនុស្សទាំងអស់ត្រូវកាន់ខ្ជាប់នៅក្នុងសេចក្ដីជំនឿជឿដល់ព្រះនាមទ្រង់ ដរាបដល់ចុងបំផុត, **គ. និង ស.** ២០:២៥, ២៩ ។ ការរាប់ជាសុចរិត តាមរយៈព្រះគុណនៃព្រះអម្ចាស់ នោះគឺយុត្តិធម៌ និងត្រឹមត្រូវ, **គ. និង ស.** ២០:៣០ ។ ព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នកដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ, **គ. និង ស.** ៤២:១៤ ។ សេចក្ដីជំនឿពុំមែនមានឡើង ដោយសារទីសំគាល់ទាំងឡាយឡើយ ប៉ុន្តែទីសំគាល់ទាំងឡាយមកតាម ក្រោយអស់អ្នកដែលជឿវិញ, **គ. និង ស.** ៦៣:៩–១២ ។ ឪពុកម្ដាយត្រូវបង្រៀនកូន ចៅអំពីសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ, **គ. និង ស.** ៦៨:២៥ ។ ចូរស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និងដោយសារសេចក្ដីជំនឿផង, **គ. និង ស.** ៨៨:១១៨ ។ សេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺជាគោលការណ៍ទីមួយនៃដំណឹងល្អ, **ម. នៃ ស.** ១:៤ ។

**សេចក្ដីជំនុំជំរះចុងក្រោយបំផុត** *សូមមើលផង* ការដាក់ទោស; ជំនុំជំរះ, ដាក់ទោស, ព្រះយេស៊ូវគ្រីស្ទ — ចៅក្រម; សេចក្ដីជំនុំជំរះ

ជាសេចក្ដីជំនុំជំរះចុងក្រោយបង្អស់ ដែលនឹងកើតឡើង បន្ទាប់ពីដំណើររស់ឡើងវិញ ។ ព្រះ គឺតាមរយៈព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងជំនុំជំរះជននីមួយៗ ដើម្បីសំរេចនូវសិរីល្អដ៏នៅអស់កល្បជានិច្ចណាមួយដែលជននោះនឹងបានទទួល ។ សេចក្ដីជំនុំជំរះនេះនឹងផ្អែក ទៅលើការគោរពតាមបញ្ញត្តិទាំងឡាយរបស់ព្រះ ព្រមទាំងការទទួលនូវដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

ព្រះវរបិតា ទ្រង់បានប្រគល់ការជំនុំជំរះទាំងអស់ដល់ព្រះរាជបុត្រា, **យ៉ូហាន** ៥:២២ ។ យើងរាល់គ្នានឹងត្រូវឈរនៅមុខទីជំនុំជំរះ របស់ព្រះគ្រីស្ទ, **រ៉ូម** ១៤:១០ ។ ពួកមនុស្សស្លាប់ត្រូវជំនុំជំរះ ពីសេចក្ដីដែលកត់ទុកទាំងនោះ, **វិវ.** ២០:១២ (គ. និង ស. ១២៨:៦–៧) ។ អ្វីៗទាំងអស់ ដែលអ្នកធ្វើ នោះអ្នកត្រូវបញ្ជូនមកជំនុំជំរះ, **១ នីហ្វៃ** ១០:២០ ។ ពួកសាវក១២នាក់ និងពួកសិស្សសាសន៍នីហ្វៃ១២ នាក់នឹងជំនុំជំរះពួកអ៊ីស្រាអែល, **១ នីហ្វៃ** ១២:៩ (គ. និង ស. ២៩:១២) ។ មនុស្សទាំងអស់ត្រូវបង្ហាញខ្លួនចំពោះវេទិកាជំនុំជំរះនៃ ព្រះដ៏បរិសុទ្ធ, **២ នីហ្វៃ** ៩:១៥ ។ ចូរប្រុងប្រៀបព្រលឹងរបស់អ្នករាល់គ្នា ចាំថ្ងៃដ៏រុងរឿងនោះ, **២ នីហ្វៃ** ៩:៤៦ ។ តើអ្នករាល់គ្នាអាចរមិលមើលខ្លួននៅចំពោះទីជំនុំជំរះនៃព្រះឬ, **អាលម៉ា** ៥:១៧–២៥ ។ ព្រះយេស៊ូវគ្រីស្ទនឹងឈរជំនុំជំរះមនុស្សលោក, ៣ នីហ្វៃ ២៧:១៦ ។ ព្រះអម្ចាស់ ទ្រង់នឹងយាងចុះមកដោយសេចក្ដីបណ្ដាសា ដើម្បីជំនុំជំរះពួកមនុស្សអាក្រក់, **គ. និង ស.** ១៣៣:២ ។

**សេចក្ដីទុកចិត្ត** *សូមមើលផង* ជំនឿ, ជឿ; ទុកចិត្ត, សេចក្ដីជំនឿ

គឺមានការអះអាង ជំនឿ ទុកចិត្ត ឬក៏សេចក្ដីជំនឿដល់អ្វីមួយ ជាពិសេសដល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ ។

ស៊ូពឹងជ្រកនៅព្រះអម្ចាស់ ជាជាងទុកចិត្តនឹងមនុស្ស, **ទំនុក.** ១១៨:៨ ។ ព្រះអម្ចាស់ទ្រង់នឹងបានជាទីទុកចិត្តដល់អ្នក, **សុភា.** ៣:២៦ ។ ក្នុងកាលព្រះគ្រីស្ទនឹងលេចមក នោះយើងនឹងអាចមានចិត្តក្លាហាន, **១ យ៉ូហាន** ២:២៨ ។ ពួកសាសន៍នីហ្វៃដែលទុច្ចរិត គ្មានសេចក្ដី ទុកចិត្តពីកូនចៅគេឡើយ, **យ៉ាកុប** ២:៣៥ ។ ខណៈនោះ អ្នកនឹងមានចិត្តក្លាហានឡើង នៅចំពោះវត្តមាននៃព្រះ, **គ. និង ស.** ១២១: ៤៥ ។

**សេចក្ដីទំនាស់** *សូមមើលផង* កាន់ខ្ជាប់; ការវាយផ្ចាល; បៀតបៀន, ល្បួង, វាយផ្ចាល, សេចក្ដីបៀតបៀន; សេចក្ដីល្បួង

តាមរយៈសេចក្ដីទំនាស់ — ការសាកល្បង, បញ្ហា, និងការខ្វល់ខ្វាយ — នោះមនុស្សអាចមានការពិសោធន៍ជាច្រើនដែលនាំទៅរក ការដុះដាលខាងវិញ្ញាណ និងការចំរើនដ៏អស់កល្បជានិច្ចដោយសារការបែរទៅរកព្រះអម្ចាស់ ។

ព្រះអង្គទ្រង់ផ្ទាល់ជួយសង្គ្រោះអ្នក ឲ្យរួចពីគ្រប់ទាំងសេចក្ដីទំនាស់ និងសេចក្ដីវេទនារបស់អ្នក, **១ សាំយូ.** ១០:១៩ ។ គេបានអំពាវនាវដល់ព្រះអម្ចាស់ ដោយសេចក្ដីវេទនារបស់គេ, **ទំនុក.** ១០៧:៦, ១៣, ១៩, ២៨ ។ ទោះបីព្រះអម្ចាស់ទ្រង់ឲ្យអ្នករាល់គ្នាស៊ីសេចក្ដី ទំនាស់ទុកជាអាហារ គង់តែពួកគ្រូរបស់អ្នកមិនត្រូវលាក់អ្នកទៀត, **អេសាយ** ៣០:២០–២១ ។ ជាការចាំបាច់ ត្រូវតែមានការផ្ទុយ ចំពោះរឿងសព្វសារពើ, **២ នីហ្វៃ** ២:១១ ។ បើសិនជាពួកគេពុំដែលមានការល្វីងជូរចត់សោះឡើយ នោះពួកគេក៏ពុំអាចស្គាល់ការ ផ្អែមល្ហែមដែរ, **គ. និង ស.** ២៩:៣៩ ។ សេចក្ដីទំនាស់ និងសេចក្ដីទុក្ខលំបាករបស់អ្នក នោះគ្រាន់តែមួយភ្លែតប៉ុណ្ណោះទេ, **គ. និង ស.** ១២១:៧–៨ ។ គ្រប់ការណ៍ទាំងនេះ នឹងផ្ដល់ការពិសោធន៍ដល់អ្នក ហើយនឹងទៅជាការល្អដល់អ្នកទៅវិញ, **គ. និង ស.** ១២២:៥–៨ ។ ពួកគេភ្លក់នូវសេចក្ដីល្វីងជូរចត់ ប្រយោជន៍ឲ្យពួកគេអាចចេះឲ្យតម្លៃដល់របស់ល្អ, **ម៉ូសេ** ៦:៥៥ ។

**សេចក្ដីប្រកបដោយលោកិយ** *សូមមើលផង* ការឥតប្រយោជន៍, ទ្រព្យសម្បត្តិ; ប្រាក់; សេចក្ដីឆ្មើងឆ្មៃ; ឥតប្រយោជន៍

ជាសេចក្ដីប៉ងប្រាថ្នា និងសេចក្ដីខិតខំដ៏ឥតសុចរិត ដើម្បីទ្រព្យសម្បត្តិ និងរបស់របរខាងសាច់ឈាម ដោយលះបង់ចោលនូវអ្វីៗ ដែលជាវិញ្ញាណ ។

ត្បិតបើមនុស្សណានឹងបានលោកិយទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ? **ម៉ាថាយ** ១៦:២៦ ។ ពួកគេ បានភ្ជាប់ចិត្តគេទៅលើរបស់របរដ៏ឥតប្រយោជន៍នៃលោកិយ, **អាលម៉ា** ៤:៨ (អាលម៉ា ៣១:២៧) ។ ត្រូវទុកចោលរបស់ទាំងឡាយនៃពិភពលោកនេះ, **គ. និង ស.** ២៥:១០ ។ ចិត្តរបស់មនុស្សត្រូវបានភ្ជាប់ជាខ្លាំងទៅលើអ្វីៗទាំងឡាយនៃលោកនេះ, **គ. និង ស.** ១២១:៣៥ ។

**សេចក្ដីប្រកប, រាប់អាន** *សូមមើលផង* ការរួបរួមតែមួយ, សេចក្ដីស្រឡាញ់

ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ សេចក្ដីប្រកបមានរួមនូវការផ្ដល់មិត្តភាព ការបំរើ ការលើកដំកើង និងការចំរើនកម្លាំងដល់អ្នកផ្សេងៗ ទៀត ។

ចូរស្រឡាញ់អ្នកជិតខាងដូចខ្លួន, **លេវី.** ១៩:១៨ (ម៉ាថាយ ១៩:១៩; គ. និង ស. ៥៩:៦) ។ កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចំរើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង, **លូកា** ២២:៣២ ។ អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ បើអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ ដល់គ្នាទៅវិញទៅមក, **យ៉ូហាន** ១៣:៣៥ ។ ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង, **យ៉ូហាន** ២១:១៥–១៧ ។ គេបានអធិស្ឋានឲ្យយើង ទទួលយកនូវសេចក្ដីប្រកប ក្នុងការងារសំរាប់ពួកបរិសុទ្ធ, **២ កូរិន.** ៨:១–៥ ។ សេចក្ដីប្រកបយើងខ្ញុំនោះ គឺប្រកបនឹងព្រះវរបិតា ហើយ និងព្រះរាជបុត្រារបស់ទ្រង់, **១ យ៉ូហាន** ១:៣ ។ ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនបានរាប់គ្នាទៅវិញទៅមក, **ហេលេ.** ៦:៣ ។ ចូរបណ្ដោយឲ្យមនុស្សគ្រប់រូប គោរពបងប្អូនខ្លួន ដូចជាខ្លួនឯងផ្ទាល់, **គ. និង ស.** ៣៨:២៤–២៥ ។ បើសិនជាអ្នករាល់គ្នាមិនរួមគ្នា តែមួយទេ ឈ្មោះថាអ្នករាល់គ្នាពុំមែនជារបស់ផងយើងឡើយ, **គ. និង ស.** ៣៨:២៧ ។ ខ្ញុំទទួលរាប់អានអ្នក ដើម្បីធ្វើជាមិត្ត និងជា បងប្អូនអ្នក, **គ. និង ស.** ៨៨:១៣៣ ។

**សេចក្ដីប្រកាស** *សូមមើលផង* រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន វិលហ្វូឌ, វូឌរ្រុគ, អាពាហ៍ពិពាហ៍

ជាសេចក្ដីថ្លែងជាផ្លូវការ ដោយប្រធានវិលហ្វូឌ វូឌរ្រុគ នៅឆ្នាំ ១៨៩០ ដែលថ្លែងយ៉ាងច្បាស់ថា សាសនាចក្រ និងសមាជិក ទាំងឡាយត្រូវចុះចូលតាមច្បាប់នៃប្រទេស ហើយឈប់ចូលអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើនទៀតហើយ (គ. និង ស., ប្រកាសទី១) ។ ប្រធាន វូឌរ្រុគ បានចេញសេចក្ដីប្រកាស បន្ទាប់ពីបានទទួលការនិមិត្ត និងវិវរណៈពីព្រះ ។

**សេចក្ដីប្រកាសតាមផ្លូវការទី ១** *សូមមើលផង* រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍ខាង ប្រពន្ធច្រើន; សេចក្ដីប្រកាស; វិលហ្វូឌ វូឌរ្រុគ្វ, អាពាហ៍ពិពាហ៍

បានបោះពុម្ពនៅក្នុងទំព័រចុងក្រោយនៃគោលលទ្ធិ និងសេចក្ដីសញ្ញា ភាគដំបូងនៃសេចក្ដីប្រកាសតាមផ្លូវការទី ១ គឺស្គាល់ថាជាសេចក្ដីប្រកាស ដែរ ។ បានចេញដោយប្រធានវិលហ្វូឌ វូឌរ្រុគ្វ ហើយបានជូនដល់សមាជិកនៃសាសនាចក្រ នៅសន្និសីទ ថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៨៩០ ។ ចាប់ផ្ដើមពីឆ្នាំ ១៨៦២ និងសំរាប់រយៈពេល ២៥ ឆ្នាំបន្ដមក មានច្បាប់ជាច្រើនដែលធ្វើឲ្យអាពាហ៍ពិពាហ៍ ខាងប្រពន្ធច្រើនទៅជាខុសច្បាប់នៅសហរដ្ឋ ។ ព្រះអម្ចាស់ ទ្រង់បានបង្ហាញដល់វិលហ្វូឌ វូឌរ្រុគ្វ ក្នុងការនិមិត្ត និងក្នុងវិវរណៈ នូវអ្វីៗ ដែលនឹងកើតឡើងបើសិនជាពួកបរិសុទ្ធមិនឈប់ប្រព្រឹត្តនូវអាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន ។ សេចក្ដីប្រកាសបានថ្លែងប្រាប់ ដោយត្រឹម ត្រូវថា អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើននោះឈប់ប្រព្រឹត្តទៀតហើយ ។

**សេចក្ដីប្រកាសតាមផ្លូវការទី ២** *សូមមើលផង* គិមបុល, បព្វជិតភាព, ស្ពែនសើរ ដ័បបុលយូ

ជាការថ្លែងខាងគោលលទ្ធិ ទាក់ទងទៅនឹងអ្នក ដែលអាចកាន់បព្វជិតភាពនៃព្រះបាន ឥឡូវនេះ បានបោះពុម្ពនៅលើទំព័រចុង ក្រោយនៃគោលលទ្ធិ និងសេចក្ដីសញ្ញា ។ នៅដើមខែមិថុនា ឆ្នាំ ១៩៧៨ នោះព្រះអម្ចាស់ទ្រង់បានបង្ហាញដល់ប្រធាន ស្ពែនសើរ ដ័បបុលយូ គិមបុលថា បព្វជិតភាពគួរតែបានប្រទានដល់គ្រប់ទាំងសមាជិកប្រុសៗដែលសក្ដិសម នៅក្នុងសាសនាចក្រ ។ ការនេះ ធ្វើឲ្យបព្វជិតភាព និងព្រះពរខាងព្រះវិហារមានដល់សមាជិកដែលសក្ដិសមទាំងអស់ ដោយឥតគិតដល់សាសន៍ ឬសម្បុរស្បែកឡើយ ។ នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៧៨ សេចក្ដីប្រកាសនេះបានជូននៅសន្និសីទទូទៅនៃសាសនា ហើយបានទទួលជាឯកច្ឆន្ទ ។

**សេចក្ដីប្រឆាំង** *សូមមើល* សេចក្ដីទំនាស់

**សេចក្ដីប្រោសលោះ, ផែនការ** *សូមមើល* ផែនការនៃសេចក្ដីប្រោសលោះ

**សេចក្ដីពិត** *សូមមើលផង* ដំរិះ; ពន្លឺ, ពន្លឺនៃព្រះគ្រីស្ទ, បញ្ញា, បញ្ញាទាំងឡាយ

ជាដំរិះអំពីអ្វីៗដូចដែលមាននៅឥឡូវ និងដូចមានពីមុនមក ហើយនិងដូចដែលនឹងមាននៅខាងមុខ (គ. និង ស. ៩៣:២៤) ។ សេចក្ដីពិតក៏និយាយដល់ពន្លឺ និងវិវរណៈ ដែលមកពីស្ថានសួគ៌ ។

សេចក្ដីពិតត្រង់ពន្លកចេញពីដីមក, **ទំនុក.** ៨៥:១១ (ម៉ូសេ ៧:៦២) ។ អ្នករាល់គ្នានឹងស្គាល់សេចក្ដីពិត ហើយសេចក្ដីពិតនោះនឹង ប្រោសឲ្យអ្នករាល់គ្នាបានរួច, **យ៉ូហាន** ៨:៣២ ។ ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត, **យ៉ូហាន** ១៤:៦ ។ បើសិនជាយើងថា យើង គ្មានបាបសោះ នោះសេចក្ដីពិតមិនស្ថិតនៅក្នុងយើងទេ, **១ យ៉ូហាន** ១:៨ ។ អ្នកណាដែលមានទោស រាប់សេចក្ដីពិតទុកជាការពិបាក, **១ នីហ្វៃ** ១៦:២ ។ ពួកសុចរិតស្រឡាញ់សេចក្ដីពិត, **២ នីហ្វៃ** ៩:៤០ ។ ព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលតែការពិត ហើយមិនកុហកឡើយ, **យ៉ាកុប** ៤:១៣ ។ ព្រះអង្គជាព្រះនៃសេចក្ដីពិត ហើយពុំអាចកុហកឡើយ, **អេធើរ** ៣:១២ ។ ដោយសារព្រះចេស្ដានៃព្រះ វិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្ដីពិតនៃការណ៍គ្រប់យ៉ាង, **មរ៉ូណៃ** ១០:៥ ។ សេចក្ដីពិតជាប់នៅរៀងដរាបតទៅ, **គ. និង ស.** ១:៣៩ ។ អ្នកត្រូវបានបំភ្លឺដោយព្រះវិញ្ញាណនៃសេចក្ដីពិត, **គ. និង ស.** ៦:១៥ ។ ព្រះគម្ពីរមរមនមានសេចក្ដីពិត និងព្រះបន្ទូលនៃព្រះ, **គ. និង ស.** ១៩:២៦ ។ ព្រះដ៏ជាជំនួយត្រូវបានចាត់ឲ្យចេញទៅបង្រៀនពីសេចក្ដីពិត, **គ. និង ស.** ៥០:១៤ ។ អ្នកណា ដែលទទួលព្រះបន្ទូល ដោយសារព្រះវិញ្ញាណនៃ

សេចក្ដីពិត នោះទទួលព្រះបន្ទូល ដូចជាបានផ្សាយដោយព្រះវិញ្ញាណនៃសេចក្ដីពិត, **គ. និង ស.** ៥០:១៧–២២ ។ ចូរប្រកាសប្រាប់សេចក្ដីពិតតាមវិវរណៈដែលយើងបានប្រទានដល់អ្នកចុះ, **គ. និង ស.** ៧៥:៣–៤ ។ អ្វីៗក៏ដោយដែលជាសេចក្ដីពិត គឺជាពន្លឺ, **គ. និង ស.** ៨៤:៤៥ ។ ពន្លឺនៃព្រះគ្រីស្ទ គឺជាពន្លឺនៃសេចក្ដីពិត, **គ. និង ស.** ៨៨:៦–៧, ៤០ ។ ព្រះវិញ្ញាណរបស់យើងគឺជាសេចក្ដីពិត, **គ. និង ស.** ៨៨:៦៦ ។ បញ្ញា ឬពន្លឺនៃសេចក្ដីពិត ក៏ពុំបានបង្កើតឡើយ, **គ. និង ស.** ៩៣:២៩ ។ សិរីល្អនៃព្រះ គឺជាបញ្ញា ឬក៏ពន្លឺ និងសេចក្ដីពិត, **គ. និង ស.** ៩៣:៣៦ ។ យើងបានបញ្ជាដល់អ្នក ឲ្យចិញ្ចឹមកូនចៅរបស់ខ្លួន នៅក្នុងពន្លឺ និងសេចក្ដីពិត, **គ. និង ស.** ៩៣:៤០ ។ ព្រះរាជបុត្រាបង្កើតតែមួយរបស់យើងពោរពេញទៅដោយព្រះគុណ និងសេចក្ដីពិត, **ម៉ូសេ** ១:៦ ។

**សេចក្ដីមើលងាយ** *សូមមើលផង* ការប្រមាថព្រះ, ប្រមាថព្រះ

ជាការមិនគោរព ឬការបង្អាប់ដល់អ្វីៗដែលពិសិដ្ឋ; ជាពិសេស គឺការមិនគោរពកោតក្រែងដល់ព្រះនាមនៃព្រះ ។

កុំឲ្យចេញព្រះនាមរបស់ព្រះអម្ចាស់ ជាព្រះនៃឯងជាអសារឥតការឡើយ, **និក្ខ.** ២០:៧ (២ នីហ្វៃ ២៦:៣២; ម៉ូសាយ ១៣:១៥; គ. និង ស. ១៣៦:២១) ។ ហេតុអ្វីបានជាយើងបង្អាប់ដល់សេចក្ដីសញ្ញារបស់ពួកអយ្យកោយើង ? **ម៉ាឡាគី** ២:១០ ។ អស់ទាំងហេតុនៃ ពាក្យឥតប្រយោជន៍ ដែលគេបាននិយាយនឹងបានរាប់នៅក្នុងការជំនុំជំរះ, **ម៉ាថាយ** ១២:៣៤–៣៧ ។ មានទាំងពាក្យសរសើរ និងពាក្យប្រទេចផ្ដាសាចេញមកពីមាត់តែមួយ មិនគួរគប្បីឲ្យមានដូច្នោះឡើយ, **យ៉ាកុប** (ព.ស.ថ.) ៣:១០ ។ ពាក្យសំដីរបស់យើង នឹងកាត់ទោសយើង, **អាលម៉ា** ១២:១៤ (ម៉ូសាយ ៤:៣០) ។ ចូរឲ្យមនុស្សលោកទាំងអស់ប្រុងប្រយ័ត្ន អំពីរបៀបពួកគេយកព្រះនាមរបស់ យើងមកប្រើក្នុងបបូរមាត់របស់ពួកគេ, **គ. និង ស.** ៦៣:៦១–៦២ ។

**សេចក្ដីយុត្តិធម៌** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, មានចិត្តមេត្តាករុណា, សេចក្ដីមេត្តាករុណា

ជាលទ្ធផលនៃព្រះពរដ៏ប្រពៃ ចំពោះគំនិត និងកិច្ចការសុចរិត ហើយជាការដាក់ទោសចំពោះអំពើបាប ដែលមិនបានប្រែចិត្ត ។ សេចក្ដី យុត្តិធម៌ជាក្រិត្យវិន័យដ៏នៅអស់កល្បជានិច្ច ដែលតម្រូវឲ្យពិន័យទោស នៅពេលណាដែលបានបំពានក្រិត្យវិន័យនៃព្រះ (អាលម៉ា ៤២:១៣–២៤) ។ មនុស្សមានបាបត្រូវរងទោស បើសិនជាអ្នកនោះមិនប្រែចិត្តទេ (ម៉ូសេ ២:៣៨–៣៩; គ. និង ស. ១៩:១៧) ។ បើសិនជាអ្នកនោះប្រែចិត្ត នោះព្រះអង្គសង្គ្រោះរងទោស តាមរយៈដង្វាយធួន ដោយហៅរកសេចក្ដីមេត្តាករុណា (អាលម៉ា ៣៤:១៦) ។

ព្រលឹងណាដែលធ្វើបាប នោះនឹងត្រូវស្លាប់, **អេសេ.** ១៨:៤ ។ តើព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកប្រព្រឹត្តដូចម្ដេច បើមិនមែនឲ្យប្រព្រឹត្តដោយសុចរិត ? **មីកា** ៦:៨ ។ ព្រះយេស៊ូវទ្រង់នឹងមានព្រះហឫទ័យសុចរិត ហើយនឹងអត់ទោសបាបឲ្យយើង, **១ យ៉ូហាន** ១:៩ ។ សេចក្ដីយុត្តិធម៌នៃព្រះបានបំបែកពួកទុច្ចរិតចេញពីពួកសុចរិត, **១ នីហ្វៃ** ១៥:៣០ ។ ដង្វាយធួននឹងបំពេញសេចក្ដីត្រូវការនៃសេចក្ដីយុត្តិធម៌របស់ទ្រង់, **២ នីហ្វៃ** ៩:២៦ ។ មនុស្សលោកទាំងអស់ត្រូវធ្លាក់ ហើយគេនៅក្នុងកណ្ដាប់ដៃនៃសេចក្ដីយុត្តិធម៌, **អាលម៉ា** ៤២:១៤ ។ ដង្វាយធួនធ្វើឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្ដីយុត្តិធម៌, **អាលម៉ា** ៤២:១៥ ។ តើកូនយល់ថា សេចក្ដីមេត្តា ករុណាអាចកោងសេចក្ដីយុត្តិធម៌ឬ ? **អាលម៉ា** ៤២:២៥ ។ សេចក្ដីយុត្តិធម៌នៃព្រះព្យួរនៅពីលើអ្នកលើកលែងតែអ្នកប្រែចិត្ត, **អាលម៉ា** ៥៤:៦ ។ សេចក្ដីយុត្តិធម៌ និងសេចក្ដីជំនុំជំរះត្រូវជាទោសដែលភ្ជាប់ទៅនឹងក្រិត្យវិន័យរបស់យើង, **គ. និង ស.** ៨២:៤ ។ សេចក្ដីយុត្តិធម៌បន្តដំណើររបស់ខ្លួន ហើយទទួលស្គាល់អ្វីដែលជារបស់ផងខ្លួន, **គ. និង ស.** ៨៨:៤០ ។ គ្មាននរណាត្រូវបានលើកលែងពីសេចក្ដីយុត្តិធម៌ និងក្រិត្យវិន័យទាំងឡាយនៃព្រះឡើយ, **គ. និង ស.** ១០៧:៨៤ ។

**សេចក្ដីរួបរួមគ្នា (ការសមសន្ធា)** *សូមមើល* បុណ្យរំលង

**សេចក្ដីសង្ឃឹម** *សូមមើលផង* សេចក្ដីជំនឿ

ជាការទន្ទឹងចាំដោយអស់ពីចិត្តនូវព្រះពរទាំងឡាយដែលបានសន្យាទុកចំពោះសេចក្ដីសុចរិត ។ បទគម្ពីរតែងតែស្ដី អំពីសេចក្ដីសង្ឃឹម ទុកជាការរង់ចាំជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ។

មានពរហើយ អ្នកណាដែលទុកចិត្តនឹងព្រះអម្ចាស់, **យេរេ.** ១៧:៧ ។ ព្រះអម្ចាស់ទ្រង់នឹងធ្វើជាទីពំនាក់ដល់រាស្ត្រទ្រង់, **យ៉ូអែល** ៣:១៦ ។ យើងបានសេចក្ដីសង្ឃឹម ដោយសេចក្ដីអន់ធន់ និងដោយសារបទគម្ពីរ, **រ៉ូម** ១៥:៤ ។ ព្រះទ្រង់បានបង្កើតយើងឡើងជាថ្មី ដើម្បីឲ្យ យើងរាល់គ្នាបានសេចក្ដីសង្ឃឹមដ៏រស់ ដោយសារព្រះគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ, **១ ពេត្រុស** ១:៣ ។ អស់អ្នកណាដែលមាន សេចក្ដីសង្ឃឹម នោះក៏តែងជំរះសំអាតចិត្តខ្លួន, **១ យ៉ូហាន** ៣:២–៣ ។ អ្នករាល់គ្នាត្រូវតែឈានទៅមុខ ដោយមានការភ្លឺថ្លានៃសេចក្ដី សង្ឃឹមដ៏ឥតខ្ចោះ, **២ នីហ្វៃ** ៣១:២០ ។ ចូរមើលឲ្យឃើញថា អ្នករាល់គ្នាមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស, **អាលម៉ា** ៧:២៤ (១ កូរិន. ១៣:១៣; ម៉ូរ៉ូណៃ ១០:២០) ។ ខ្ញុំមានបំណងចង់ឲ្យអ្នករាល់គ្នាស្ដាប់តាមពាក្យខ្ញុំ ដោយមានសេចក្ដីសង្ឃឹម មួយថា អ្នកនឹងបានទទួលជីវិតដ៏នៅអស់កល្បជានិច្ច, **អាលម៉ា** ១៣:២៧–២៩ ។ បើអ្នកមានសេចក្ដីជំនឿ នោះអ្នកសង្ឃឹមទៅលើអ្វីៗ ដែលមើលមិនឃើញ ហើយដែលពិត, **អាលម៉ា** ៣២:២១ (ហេព្រើរ ១១:១) ។ សេចក្ដីសង្ឃឹមមានមកពីសេចក្ដីជំនឿ ហើយធ្វើជាយុថ្កានៃព្រលឹង, **អេធើរ** ១២:៤ (ហេព្រើរ ៦:១៧–១៩) ។ មនុស្សត្រូវមានសេចក្ដីសង្ឃឹម បើពុំនោះទេគេពុំអាចទទួលមរតកបានឡើយ, **អេធើរ** ១២:៣២ ។ មរមនបាននិយាយអំពីសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស, **ម៉ូរ៉ូណៃ** ៧:១ ។ អ្នករាល់គ្នា នឹងមានសេចក្ដីសង្ឃឹម តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យបានប្រោសឲ្យមានដល់ជីវិតដ៏នៅអស់កល្បជានិច្ច,

**ម៉ូរ៉ូណៃ** ៧:៤០–៤៣ ។ ព្រះវិញ្ញាណបរិសុទ្ធបំពេញអ្នកដោយសេចក្ដីសង្ឃឹម, **ម៉ូរ៉ូណៃ** ៨:២៦ (រ៉ូម ១៥:១៣) ។ ពួកគេបានលាចាកពីជីវិតលោកទៅ ដោយមានសេចក្ដីសង្ឃឹមដ៏មុតមាំ អំពីដំណើររស់ឡើងវិញដ៏រុងរឿង, **គ. និង ស.** ១៣៨:១៤ ។

**សេចក្ដីសង្គ្រោះ** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, បានប្រោសលោះ, ប្រោសលោះ, ផែនការនៃសេចក្ដីប្រោសលោះ; ព្រះគុណ; ព្រះយេស៊ូវគ្រីស្ទ; ភាពថ្កើងថ្កានឡើង; សេចក្ដីប្រោសលោះ, សេចក្ដីស្លាប់ខាងសាច់ឈាម; សេចក្ដីស្លាប់ខាងវិញ្ញាណ

ដើម្បីឲ្យបានរួចផុតពីសេចក្ដីស្លាប់ខាងសាច់ឈាម ព្រមទាំងពីសេចក្ដីស្លាប់ខាងវិញ្ញាណផង ។ មនុស្សគ្រប់រូបនឹងបានរួចផុតពីសេចក្ដី ស្លាប់ខាងសាច់ឈាម ដោយសារព្រះគុណនៃព្រះ តាមរយៈការសុគត និងដំណើររស់ឡើងវិញ នៃព្រះយេស៊ូវគ្រីស្ទ ។ ជនម្នាក់ៗ ក៏នឹង បានរួចផុតពីសេចក្ដីស្លាប់ខាងវិញ្ញាណដែរ ដោយសារព្រះគុណនៃព្រះ តាមរយៈសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ។ សេចក្ដីជំនឿ នេះត្រូវបានបើកសម្ដែងនៅក្នុងជីវិត ដែលគោរពតាមក្រិត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ និងការបំរើដល់ព្រះគ្រីស្ទ ។

ព្រះអម្ចាស់ទ្រង់ជាពន្លឺ ហើយជាសេចក្ដីសង្គ្រោះរបស់ខ្ញុំ, **ទំនុក.** ២៧:១ ។ គឺទ្រង់តែមួយព្រះអង្គ ដែលជាថ្មដា ហើយជាសេចក្ដី សង្គ្រោះនៃខ្ញុំ, **ទំនុក.** ៦២:២ ។ ដំណឹងល្អ គឺជាព្រះចេស្ដានៃព្រះ សំរាប់សេចក្ដីសង្គ្រោះ, **រ៉ូម** ១:១៦ (គ. និង ស. ៦៨:៤) ។ ចូរបង្ហើយសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នា ដោយកោតខ្លាចចុះ, **ភីលីព** ២:១២ ។ ព្រះទ្រង់បានរើសអ្នករាល់គ្នា ដើម្បីឲ្យបានសង្គ្រោះ ដោយការញែកចេញជាបរិសុទ្ធ, ២ ថែស្ស. ២:១៣ ។ សេចក្ដីសង្គ្រោះនឹងបានដោយឥតគិតថ្លៃ, **២ នីហ្វៃ** ២:៤ ។ គ្មានអំណោយ ទានណាប្រសើរជាងអំណោយទាននៃសេចក្ដីសង្គ្រោះឡើយ, **គ. និង ស.** ៦:១៣ ។ ព្រះយេស៊ូវគ្រីស្ទ ជាព្រះនាមតែមួយគត់ ដែលនឹងមានសេចក្ដី សង្គ្រោះមក, **ម៉ូសេ** ៦:៥២ (កិច្ចការ ៤:១០–១២) ។ យើងខ្ញុំជឿថា តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះមនុស្សលោកទាំងអស់អាច បានសង្គ្រោះ, **ម. នៃ ស.** ១:៣ ។

*សេចក្ដីសង្គ្រោះដល់កូនក្មេង៖* បើសិនជាមិនផ្លាស់គំនិត ហើយត្រឡប់ដូចជាកូនតូចនេះ នោះនឹងចូលទៅក្នុងនគរស្ថានសួគ៌ពុំបាន ឡើយ, **ម៉ាថាយ** ១៨:៣ ។ កូនក្មេងតូចៗ ក៏មានជីវិតដ៏នៅអស់កល្បជានិច្ចដែរ, **ម៉ូសាយ** ១៥:២៥ ។ បុណ្យជ្រមុជទឹកឲ្យទារក ជាអំពើ ដ៏គួរខ្ពើមឆ្អើម ហើយកូនក្មេងតូចៗ មានជីវិតរស់នៅក្នុងព្រះគ្រីស្ទ ពីព្រោះតែដង្វាយធួន, **ម៉ូរ៉ូណៃ** ៨:៨២៤ ។ កូនក្មេងតូចៗ ត្រូវបាន ប្រោសលោះតាមរយៈព្រះរាជបុត្រាបង្កើតតែមួយ; សាតាំងមិនអាចល្បួងវាបានឡើយ, **គ. និង ស.** ២៩:៤៦–៤៧ ។ កូនក្មេងត្រូវបានទទួលការបង្រៀនអំពីដំណឹងល្អ ហើយទទួលបុណ្យជ្រមុជទឹក កាលមានអាយុ ៨ ឆ្នាំ, **គ. និង ស.** ៦៨:២៥–២៨ ។ កូនក្មេងតូចៗត្រូវបានញែកចេញជាបរិសុទ្ធ តាមរយៈព្រះយេស៊ូវគ្រីស្ទ, **គ. និង ស.** ៧៤:៧ ។ មនុស្សបានត្រឡប់ទៅក្នុងស្ថានភាពទារកវិញ គឺឥតមាន ទោស, **គ. និង ស.** ៩៣:៣៨ ។ កូនក្មេងទាំងអស់ ដែលបានស្លាប់មុនគ្រប់អាយុទទួលខុសត្រូវ នោះត្រូវបានសង្គ្រោះនៅក្នុងនគរសេឡេស្ទាល, **គ. និង ស.** ១៣៧:១០ ។ កូនក្មេងនៅសុទ្ធសាធ ចាប់តាំងពីកំណើតលោកិយមកម្ល៉េះ, **ម៉ូសេ** ៦:៥៤ ។

**សេចក្ដីសង្គ្រោះ, ផែនការ** *សូមមើល* ផែនការនៃសេចក្ដីប្រោសលោះ

**សេចក្ដីសង្គ្រោះដល់កូនក្មេង** *សូមមើល* កូនក្មេង, ពួកកូនក្មេង; សេចក្ដីសង្គ្រោះ — សេចក្ដីសង្គ្រោះដល់កូនក្មេង

**សេចក្ដីសង្គ្រោះសំរាប់មនុស្សស្លាប់** *សូមមើលផង* ផែនការនៃសេចក្ដីប្រោសលោះ; ពង្សាវតារ; សេចក្ដីសង្គ្រោះ, សៀវភៅរំឭក

ជាឱកាសសំរាប់អស់អ្នកណា ដែលបានស្លាប់ទៅហើយ ដោយពុំបានទទួលពិធីសង្គ្រោះទាំងឡាយនៃដំណឹងល្អ ដើម្បីឲ្យបានពិធីទាំងនេះ ធ្វើជំនួសពួកគេនៅក្នុងព្រះវិហារ ដោយសមាជិកនៃសាសនាចក្រដែលសក្ដិសម ហើយមានជីវិតរស់នៅ ។ មនុស្សស្លាប់ត្រូវបាន ទទួលការបង្រៀនពីដំណឹងល្អ នៅស្ថានវិញ្ញាណ ហើយអាចទទួលពិធីបរិសុទ្ធទាំងឡាយ ដែលបានធ្វើជំនួសពួកគេនៅលោកនេះ ។

សមាជិកដែលស្មោះត្រង់នៅក្នុងសាសនាចក្រស្រាវជ្រាវ ហើយរៀបចំប្រវត្តិគ្រួសារ ដើម្បីរកឈ្មោះ និងថ្ងៃកំណើតរបស់ដូនតា ដើម្បី នឹងអាចធ្វើពិធីសង្គ្រោះជំនួសពួកគេ ។

ប្រាប់ដល់ពួកអ្នកដែលជាប់ចំណងថា ចូរចេញទៅ, **អេសាយ** ៤៩:៩ (អេសាយ ២៤:២២; ១ នីហ្វៃ ២១:៩) ។ ចូរប្រកាសប្រាប់ពី សេចក្ដីប្រោសលោះដល់ពួកឈ្លើយ, **អេសាយ** ៦១:១ (លូកា ៤:១៨) ។ លោកនឹងបង្វែចិត្តពួកឪពុកមកឯកូន, **ម៉ាឡាគី** ៤:៥–៦ (៣ នីហ្វៃ ២៥:៥–៦; គ. និង ស. ១១០:១៣–១៦) ។ មនុស្សស្លាប់នឹងឮសម្លេងព្រះរាជបុត្រានៃព្រះ, **យ៉ូហាន** ៥:២៥ ។ ហេតុអ្វីបានជាគេ ធ្វើបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់, **១ កូរិន.** ១៥:២៩ ។ ព្រះគ្រីស្ទ ទ្រង់បានយាងទៅប្រដៅដល់ពួកវិញ្ញាណ ដែលជាប់ឃុំ, **១ ពេត្រុស** ៣:១៨–២០ ។ ហេតុនេះហើយ បានជាផ្សាយដំណឹងល្អដល់មនុស្ស ដែលស្លាប់ហើយដែរ, **១ ពេត្រុស** ៤:៦ ។ ព្រះរាជបុត្រាក៏បានយាងទៅជួបពួកវិញ្ញាណដែលជាប់ឃុំ, **គ. និង ស.** ៧៦:៧៣ ។ ខណៈនោះ សេចក្ដីប្រោសលោះនឹងមានឡើងដល់អស់ អ្នកណា ដែលបានទទួលចំណែករបស់ខ្លួន នៅក្នុងគុកនោះ, **គ. និង ស.** ៨៨:៩៩ ។ អាងសំរាប់បុណ្យជ្រមុជទឹក នោះពុំមាននៅលើ ផែនដីដែលពួកបរិសុទ្ធរបស់យើងអាចធ្វើបុណ្យជ្រមុជទឹកជំនួសពួកអ្នកស្លាប់នោះទេ, **គ. និង ស.** ១២៤:២៩ ។ មនុស្សទាំងអស់ដែល បានស្លាប់ទៅជាអ្នកដែលនឹងទទួលដំណឹងល្អ នោះនឹងទៅជាពួកអ្នកគ្រងនគរសេឡេស្ទាលទុកជាមរតក, **គ. និង ស.** ១៣៧:៧–១០ ។ ព្រះរាជបុត្រា នៃព្រះបានលេចមកប្រកាសប្រាប់ពីការ

ដោះលែង ដល់ពួកជាប់ឃុំឃាំងទាំងឡាយ ដែលមានចិត្តស្មោះត្រង់, **គ. និង ស.** ១៣៨:១៨ ។ វិញ្ញាណជាច្រើនដែលនៅក្នុងគុកក៏ចេញមក, **ម៉ូសេ** ៧:៥៧ ។

**សេចក្ដីសញ្ញា** *សូមមើលផង* សម្បថ និងសេចក្ដីសញ្ញានៃបព្វជិតភាព សេចក្ដីសម្បថ; សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច; សេចក្ដីសញ្ញាអ័ប្រាហាំ

ជាកិច្ចព្រមព្រៀងមួយរវាងព្រះនិងមនុស្ស ប៉ុន្តែទាំងសងខាងមិនប្រព្រឹត្តក្នុងភាពស្មើគ្នានៅក្នុងកិច្ចព្រមព្រៀងនេះឡើយ ។ ព្រះទ្រង់ផ្ដល់ នូវលក្ខខណ្ឌសំរាប់សេចក្ដីសញ្ញា ហើយមនុស្សយល់ព្រមធ្វើនូវអ្វីៗដែលទ្រង់បញ្ជាឲ្យគេធ្វើ ។ រួចព្រះទ្រង់សន្យាដល់មនុស្សនូវព្រះពរនានាចំពោះការគោរពរបស់គេ ។

គោលការណ៍ និងពិធីបរិសុទ្ធបានត្រូវទទួលដោយសេចក្ដីសញ្ញា ។ សមាជិកក្នុងសាសនាចក្រណាដែលធ្វើសេចក្ដីសញ្ញាបែបនេះ គឺសន្យាថានឹងគោរពតាម៖ ជាឧទាហរណ៍ សមាជិកធ្វើសេចក្ដីសញ្ញានឹងព្រះអម្ចាស់ នៅគ្រាបុណ្យជ្រមុជទឹក ហើយធ្វើសេចក្ដីសញ្ញា ទាំងនោះម្ដងទៀត ដោយសារការទទួលទានបុណ្យរំឭក ។ គេធ្វើសេចក្ដីសញ្ញាថែមទៀតនៅក្នុងព្រះវិហារ ។ រាស្ត្រនៃព្រះអម្ចាស់ ជារាស្ត្រក្នុងសេចក្ដីសញ្ញា ហើយបានព្រះពរយ៉ាងធំ នៅពេលពួកគេកាន់តាមសេចក្ដីសញ្ញារបស់គេ ដែលបានធ្វើនឹងព្រះអម្ចាស់ ។

យើងនឹងតាំងសេចក្ដីសញ្ញាយើងចំពោះអ្នក, **លោកុ.** ៦:១៨ ។ ចូរកាន់តាមសេចក្ដីសញ្ញារបស់យើង នោះអ្នករាល់គ្នានឹងបានជាច់ជា របស់ផងយើង, **និក្ខ.** ១៩:៥ ។ កុំឲ្យតាំងសេចក្ដីសញ្ញានឹងគេ ឬនឹងព្រះរបស់គេឡើយ, **និក្ខ.** ២៣:៣២ ។ ចូរកាន់ថ្ងៃឈប់សំរាកទុក ជាសេចក្ដីសញ្ញានៅអស់កល្បជានិច្ច, **និក្ខ.** ៣១:១៦ ។ យើងនឹងមិនក្បត់សេចក្ដីសញ្ញារបស់យើងចំពោះអ្នករាល់គ្នាទេ, **ចៅហ្វាយ** ២:១ ។ ពួកអ្នកបរិសុទ្ធរបស់យើងបានតាំងសញ្ញានឹងយើង ដោយថ្វាយយញ្ញបូជា, **ទំនុក.** ៥០:៥ (គ. និង ស. ៩៧:៨) ។ ចូរនឹកចាំពី សេចក្ដីសញ្ញាបរិសុទ្ធរបស់ទ្រង់, **លូកា** ១:៧២ (គ. និង ស. ៩០:២៤) ។ ព្រះចេស្ដានៃព្រះយាងចុះមកសណ្ឋិតលើរាស្ត្រដែលនៅក្នុង សេចក្ដីសញ្ញារបស់ព្រះអម្ចាស់, **១ នីហ្វៃ** ១៤:១៤ ។ សេចក្ដីសញ្ញាដែលបានធ្វើចំពោះអ័ប្រាហាំនឹងបានសំរេចនៅថ្ងៃចុងក្រោយ, **១ នីហ្វៃ** ១៥:១៨ (៣ នីហ្វៃ ១៦:៥, ១១–១២; ២១:៧; មរមន ៩:៣៧) ។ រាស្ត្ររបស់ស្ដេចបេនយ៉ាមីនយល់ព្រមចូលក្នុងសេចក្ដីសញ្ញានឹងព្រះ ដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់, **ម៉ូសាយ** ៥:៥ ។ បុណ្យជ្រមុជទឹកជាទីបន្ទាល់ថា មនុស្សបានចូលក្នុងសេចក្ដីសញ្ញា មួយនឹងព្រះ ដើម្បីធ្វើតាមព្រះហឫទ័យរបស់ទ្រង់, **ម៉ូសាយ** ១៨:១៣ ។ អ្នករាល់គ្នាជាកូនចៅដែលនៅក្នុងសេចក្ដីសញ្ញា, ៣ នីហ្វៃ ២០:២៥–២៦ ។ ពួកទេវតាសំរេច ហើយធ្វើកិច្ចការនៃសេចក្ដីសញ្ញានៃព្រះវរបិតា, **មរ៉ូណៃ** ៧:៣១ ។ ការប្រួចលោហិតនៃព្រះគ្រីស្ទ គឺជាសេចក្ដីសញ្ញា, **មរ៉ូណៃ** ១០:៣៣ ។ អស់អ្នកណាដែលនៅក្នុងសាសនាចក្រនៃព្រះគ្រីស្ទ នោះត្រូវគោរពកាន់តាមអស់ទាំងសេចក្ដីសញ្ញា, **គ. និង ស.** ៤២:៧៨ ។ មានពរហើយ ដល់អស់អ្នកណាដែលបានកាន់តាមសេចក្ដីសញ្ញា, **គ. និង ស.** ៥៤:៦ ។ អ្នកណាដែលបណ្ដាច់ចំណងនោះ នឹងត្រូវបាត់បង់តំណែង និងជំហរនៅក្នុងសាសនាចក្រ, **គ. និង ស.** ៧៨:១១–១២ ។ អស់អ្នកទាំងនោះដែលទទួលបព្វជិតភាព ឈ្មោះថាទទួលសម្បថ និងសេចក្ដីសញ្ញានេះ, **គ. និង ស.** ៨៤:៣៩–៤០ ។ យល់ព្រមគោរពតាម សេចក្ដីសញ្ញារបស់ខ្លួន ដោយការបូជា, **គ. និង ស.** ៩៧:៨ ។ សេចក្ដីសញ្ញានៃអាពាហ៍ពិពាហ៍អាចនៅអស់កល្បជានិច្ច, **គ. និង ស.** ១៣២ ។ នេះត្រូវជាសេចក្ដីសញ្ញារបស់យើង ថាយើងនឹងដើរតាមរបៀបទាំងអស់, **គ. និង ស.** ១៣៦:៤ ។

**សេចក្ដីសញ្ញាដ៏អស់កល្បជានិច្ច***សូមមើល* សេចក្ដីសញ្ញា; សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច

**សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច** *សូមមើលផង* សេចក្ដីសញ្ញា

ជាភាពពោរពេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ (គ. និង ស. ៦៦:២) ។ គឺថ្មីរាល់ពេល ដែលបានបើកសម្ដែងជាថ្មីទៀត បន្ទាប់ពីគ្រាក្បត់សាសនា ។នៅអស់កល្បអស់កាលជានិច្ច មានន័យថា ជាសេចក្ដីសញ្ញារបស់ព្រះ ហើយបានទទួលនៅគ្រប់គ្រា កាន់កាប់ត្រួតត្រានៃដំណឹងល្អ ដែលប្រជាជនយល់ព្រមទទួលយក ។ សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ចត្រូវបានបើកសម្ដែងម្ដងទៀតដល់មនុស្សនៅលើផែនដី ដោយព្រះយេស៊ូវគ្រីស្ទ តាមរយៈព្យាការីយ៉ូសែប ស៊្មីធ ។ គឺមានពិធីបរិសុទ្ធដ៏ពិសិដ្ឋទាំងឡាយ ដែលចាត់ចែងដោយសិទ្ធិអំណាចនៃបព្វជិតភាព — ដូចជាបុណ្យជ្រមុជទឹក និងអាពាហ៍ពិពាហ៍ក្នុងព្រះវិហារ — ដែលមានសំរាប់សេចក្ដីសង្គ្រោះ, អមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស ។ កាលណាមនុស្សទទួលដំណឹងល្អ ហើយសន្យាថានឹងកាន់តាម ព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះព្រះទ្រង់ធ្វើសេចក្ដីសញ្ញាថានឹងប្រទានដល់គេ នូវព្រះពរទាំងឡាយនៃសេចក្ដីសញ្ញាថ្មី ហើយអស់ កល្បជានិច្ចរបស់ទ្រង់ ។

អញនឹងតាំងសេចក្ដីសញ្ញាអញ រវាងអញនឹងឯង, **លោកុ.** ១៧:៧ ។ លោកនឹងមានសេចក្ដីសញ្ញានៃការងារជាសង្ឃនៅជាដរាបតទៅ, **ជនគ.** ២៥:១៣ ។ មនុស្សបានធ្វើខុសនឹងច្បាប់ទាំងប៉ុន្មាន ហើយផ្ដាច់សេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ចចេញ; **អេសាយ** ២៤:៥ (គ. និង ស. ១:១៥) ។ អញនឹងតាំងសេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ចនឹងឯងរាល់គ្នា, **អេសាយ** ៥៥:៣ (យេរេ. ៣២:៤០) ។ គឺនឹង ទៅជាសេចក្ដីសញ្ញាដ៏នៅអស់កល្បជានិច្ច, **អេសេ.** ៣៧:២៦ ។ ព្រះអម្ចាស់ទ្រង់បានតាំងសេចក្ដីសញ្ញាថ្មី ហើយឯសេចក្ដីសញ្ញាចាស់ បានកន្លងផុតទៅ, **ហេព្រើរ** ៨:១៣ ។ ព្រះយេស៊ូវទ្រង់ជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មី, **ហេព្រើរ** ១២:២៤ (គ. និង ស. ៧៦:៦៩) ។ នេះជាសេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច, **គ. និង ស.** ២២:១ ។ យើងបញ្ជូនសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចរបស់យើង ឲ្យមកឯ ពិភពលោក, **គ. និង ស.** ៤៥:៩ (គ. និង ស. ៤៩:៩) ។ ព្រះអម្ចាស់ទ្រង់បានបញ្ជូនភាពពោរពេញនៃដំណឹងល្អរបស់ទ្រង់ គឺជាសេចក្ដីសញ្ញា

ដ៏អស់កល្បជានិច្ចរបស់ទ្រង់, **គ. និង ស.** ៦៦:២ (គ. និង ស. ១៣៣:៥៧) ។ ដើម្បីឲ្យបានលំដាប់ខ្ពស់បំផុតនៅក្នុងនគរសេឡេស្ទាល នោះមនុស្សត្រូវចូលក្នុងសេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ចខាងអាពាហ៍ពិពាហ៍, **គ. និង ស.** ១៣១:១–២ ។ សេចក្ដីសញ្ញាថ្មី ហើយអស់កល្បជានិច្ច នោះត្រូវបានបង្កើតឡើងសំរាប់ភាពពោរពេញនៃសិរីល្អរបស់ព្រះអម្ចាស់, **គ. និង ស.** ១៣២:៦, ១៩ ។

**សេចក្ដីសញ្ញាអ័ប្រាហាំ** *សូមមើលផង* ការកាត់ស្បែក; សេចក្ដីសញ្ញា អ័ប្រាហាំ

អ័ប្រាហាំបានទទួលដំណឹងល្អ ហើយបានទទួលការតែងតាំងចំពោះបព្វជិតភាពជាន់ខ្ពស់ (គ. និង ស. ៨៤:១៤; អ័ប្រា. ២:១១) ហើយលោកបានចូលក្នុងអាពាហ៍ពិពាហ៍ខាងសេឡេស្ទាល ដែលជាសេចក្ដីសញ្ញាខាងភាពថ្កើងថ្កាន (គ. និង ស. ១៣១:១–៤; ១៣២:១៩, ២៩) ។ អ័ប្រាហាំបានទទួលសេចក្ដីសន្យាថា គ្រប់អស់ទាំងពរនៃសេចក្ដីសញ្ញាទាំងឡាយនេះនឹងត្រូវបានប្រទានដល់ពូជពង្សរបស់លោក ខាងសាច់ឈាម (គ. និង ស. ១៣២:២៩–៣១; អ័ប្រា. ២:៦–១១) ។ សេចក្ដីសញ្ញា និងសេចក្ដីសន្យាទាំងនេះរួមគ្នាទៅ ហៅថាសេចក្ដីសញ្ញាអ័ប្រាហាំ ។ ការសាងឡើងវិញនៃសេចក្ដីសញ្ញានេះ គឺជាការសាងឡើងវិញនៃដំណឹងល្អ នៅគ្រាក្រោយបង្អស់ ព្រោះ តាមរយៈសេចក្ដីសញ្ញានេះ នោះគ្រប់ទាំងសាសន៍នៅលើផែនដីនឹងបានពរ (កាឡាទី ៣:៨–៩, ២៩; គ. និង ស. ១១០:១២; ១២៤:៥៨; អ័ប្រា. ២:១០–១១) ។

**សេចក្ដីសប្បុរស** *សូមមើលផង* ការបំរើ; សុខុមាលភាព, សេចក្ដីស្រឡាញ់; សេចក្ដីអាណិត

ជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាតនៃព្រះគ្រីស្ទ (ម៉ូរ៉ូណៃ ៧:៤៧); ជាសេចក្ដីស្រឡាញ់ដែលព្រះគ្រីស្ទមានដល់កូនចៅមនុស្ស ហើយកូនចៅ មនុស្សគួរតែមានចំពោះគ្នាទៅវិញទៅមក (២ នីហ្វៃ ២៦:៣០; ៣៣:៧–៩; អេធើរ ១២:៣៣–៣៤); ជាសេចក្ដីស្រឡាញ់ដ៏ខ្ពស់ឧត្តុង ឧត្ដម ខ្លាំងបំផុត គឺមិនមែនគ្រាន់តែសេចក្ដីស្រឡាញ់ជាមិត្តនោះទេ ។

ចំណេះធ្វើឲ្យចិត្តប៉ោងឡើង តែសេចក្ដីស្រឡាញ់ស្អាងចិត្តឡើងវិញ, **១ កូរិន.** ៨:១ ។ សេចក្ដីសប្បុរស គឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធ នោះខ្ពស់ជាងគ្រប់អ្វីៗទាំងអស់, **១ កូរិន.** ១៣ ។ ចុងបំផុតនៃបញ្ញត្តិគឺជាសេចក្ដីសប្បុរស ដែលកើតពីចិត្តស្អាត, ១ ធីម៉ូ. ១:៥ ។ ឲ្យសេចក្ដីរាប់អានគ្នា បានសេចក្ដីសប្បុរសថែមទៀត, **២ ពេត្រុស** ១:៧ ។ ព្រះអម្ចាស់ទ្រង់បញ្ជាថា មនុស្សទាំងអស់ត្រូវមានសេចក្ដី សប្បុរស, **២ នីហ្វៃ** ២៦:៣០ (ម៉ូរ៉ូណៃ ៧:៤៤–៤៧) ។ ចូរមើលថា តើអ្នកមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស, **អាលម៉ា** ៧:២៤ ។ សេចក្ដីស្រឡាញ់ដែលព្រះអម្ចាស់ទ្រង់មានចំពោះមនុស្សលោកគឺជាសេចក្ដីសប្បុរស, **អេធើរ** ១២:៣៣–៣៤ ។ បើគ្មានសេចក្ដីសប្បុរសទេ នោះមនុស្សលោកមិនអាចគ្រងទីកន្លែងដែលបានរៀបចំទុកនៅក្នុងវិមានទាំងឡាយរបស់ព្រះវរបិតា ទុកជាមរតកបានឡើយ, **អេធើរ** ១២:៣៤ (ម៉ូរ៉ូណៃ ១០:២០–២១) ។ ម៉ូរ៉ូណៃបានសរសេរពាក្យពេចន៍របស់មរមន អំពីសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស, **ម៉ូរ៉ូណៃ** ៧ ។ សេចក្ដីសប្បុរសធ្វើឲ្យមនុស្សលោកសមនឹងកិច្ចការរបស់ព្រះអម្ចាស់, **គ. និង ស.** ៤:៥–៦ (គ. និង ស. ១២:៨) ។ ចូរបំពាក់ខ្លួនដោយចំណងនៃសេចក្ដីសប្បុរស, **គ. និង ស.** ៨៨:១២៥ ។ សូមឲ្យចិត្តអ្នកពេញទៅដោយសេចក្ដីសប្បុរស, **គ. និង ស.** ១២១:៤៥ ។

**សេចក្ដីសុខសាន្ត** *សូមមើលផង* សហស្សវត្ស; អ្នកផ្សះផ្សា; សេចក្ដីសំរាក

នៅក្នុងព្រះគម្ពីរ សេចក្ដីសុខសាន្តអាចមានន័យដល់សេរីភាពពីការប្រយុទ្ធ និងពីការច្របូកច្របល់ ឬក៏សេចក្ដីស្ងប់ស្ងាត់ និងសេចក្ដី កំសាន្តខាងក្នុង ដែលកើតឡើងមកពីព្រះវិញ្ញាណ ដែលព្រះទ្រង់ប្រទានដល់ពួកបរិសុទ្ធដ៏ស្មោះត្រង់របស់ទ្រង់ ។

*សេរីភាពពីការប្រយុទ្ធ និងការច្របូកច្របល់៖* ទ្រង់បណ្ដាលឲ្យការសង្គ្រាមស្ងប់រំងាប់, **ទំនុក.** ៤៦:៩ ។ គេនឹងមិនហាត់រៀនធ្វើសឹកសង្គ្រាមទៀតដែរ, **អេសាយ** ២:៤ ។ ចូរឲ្យខំនៅជាមេត្រីនឹងមនុស្សទាំងអស់ចុះ កុំឲ្យសងសឹកឡើយ, **រ៉ូម** ១២:១៨–២១ ។ មានសេចក្ដីសុខសាន្តនៅតែមានតទៅនៅលើផែនដី, **៤ នីហ្វៃ** ១:៤, ១៥–២០ ។ ចូរលះបង់សង្គ្រាម ហើយប្រកាសប្រាប់ពីសេចក្ដីសុខ សាន្តវិញ, **គ. និង ស.** ៩៨:១៦ ។ ចូរលើកទង់ជ័យនៃសន្តិភាព, **គ. និង ស.** ១០៥:៣៩ ។

*សេចក្ដីសុខសាន្តមកពីព្រះដល់ពួកអ្នកដែលស្ដាប់តាម៖* ព្រះអង្គសង្គ្រោះនឹងត្រូវថ្វាយព្រះនាមថា ជាម្ចាស់នៃមេត្រីភាព, **អេសាយ** ៩:៦ ។ គ្មានសេចក្ដីសុខសោះ ដល់ពួកមនុស្សដែលប្រព្រឹត្តអាក្រក់, **អេសាយ** ៤៨:២២ ។ មានពួកពលបរិវារកកកុញពីស្ថានសួគ៌ ពោលសរសើរដល់ព្រះថា សួស្ដីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដី, **លូកា** ២:១៣–១៤ ។ ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា, **យ៉ូហាន** ១៤:២៧ ។ សេចក្ដីសុខសាន្តរបស់ព្រះហួសលើសពីអស់ទាំងគំនិត, **ភីលីព** ៤:៧ ។ រាស្ត្រនៃ ស្ដេចបេនយ៉ាមីនបានទទួលសេចក្ដីសុខសាន្តក្នុងសតិសម្បជញ្ញៈ, **ម៉ូសាយ** ៤:៣ ។ ល្អណាស់ហ្ន៎ គឺជើងនៃអ្នកដែលដើរលើភ្នំ ជាអ្នក ដែលផ្សាយសេចក្ដីសុខសាន្ត, **ម៉ូសាយ** ១៥:១៤–១៨ (អេសាយ ៥២:៧) ។ អាលម៉ាបានអំពាវនាវដល់ព្រះអម្ចាស់ ហើយបានទទួល សេចក្ដីសុខសាន្ត, **អាលម៉ា** ៣៨:៨ ។ ពួកវិញ្ញាណនៃមនុស្សសុចរិតត្រូវបានទទួលចូលក្នុងស្ថានភាពសុខសាន្ត, **អាលម៉ា** ៤០:១២ ។ តើយើងពុំបាននិយាយដោយភាពសុខសាន្តដល់គំនិតរបស់អ្នក អំពីការណ៍នោះទេឬអី ?, **គ. និង ស.** ៦:២៣ ។ ចូរដើរក្នុងភាពស្លូត បូតនៃព្រះវិញ្ញាណរបស់យើង នោះអ្នកនឹងបានសេចក្ដីសុខសាន្តនៅក្នុងយើង, **គ. និង ស.** ១៩:២៣ ។ អ្នកណាដែលប្រព្រឹត្តកិច្ចការទាំងឡាយដោយសេចក្ដីសុចរិត នោះនឹងបានទទួលសេចក្ដីសុខសាន្ត, **គ. និង ស.** ៥៩:២៣ ។ ចូរបំពាក់ខ្លួនដោយចំណងនៃសេចក្ដីសប្បុរស ដែលជាចំណងនៃសេច

ក្ដីល្អឥតខ្ចោះ និងសេចក្ដីសុខសាន្ត, **គ. និង ស.** ៨៨:១២៥ ។ បុត្រយើងអើយ ចូរមានសេចក្ដីសុខសាន្តដល់ព្រលឹងបុត្រចុះ, **គ. និង ស.** ១២១:៧ ។ ដោយឃើញថាមានសេចក្ដីសុខសាន្តដ៏ធំជាង ទើបខ្ញុំស្វែងរកព្រះពរទាំងឡាយ ខាងពួកអយ្យកោ, **អ័ប្រា.** ១:២ ។

**សេចក្ដីសុខស្រួល***សូមមើល* ពាក្យសំដីនៃព្រាផ្ការាងវៃ

**សេចក្ដីសំរាក** *សូមមើលផង* ថ្ងៃឈប់សំរាក, សេចក្ដីសុខសាន្ត

សេចក្ដីអរសប្បាយរីករាយ ចំពោះសេចក្ដីសុខសាន្ត និងសេរីភាព ចេញពីការព្រួយបារម្ភ និងការជ្រួលច្របល់ ។ ព្រះអម្ចាស់ទ្រង់ បានសន្យាថានឹងប្រទាននូវសេចក្ដីសំរាកបែបនេះដល់ពួកអ្នកដែលដើរតាមទ្រង់ដោយស្មោះត្រង់នៅក្នុងជីវិតនេះ ។ ទ្រង់ក៏បានរៀប ចំទីកន្លែងមួយទុកសំរាប់ជាទីសំរាកដល់ពួកគេនៅជីវិតខាងមុខ ។

វិញ្ញាណអញនឹងទៅជាមួយនឹងឯង ហើយអញនឹងឲ្យឯងបានសំរាក, **និក្ខ.** ៣៣:១៤ ។ អស់អ្នកដែលផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹង ឲ្យអ្នករាល់គ្នាឈប់សំរាក, **ម៉ាថាយ** ១១:២៨–២៩ ។ ពួកយើងរាល់គ្នាបានធ្វើការ ដើម្បីឲ្យពួកគេអាចបានចូលទៅក្នុងទីសំរាករបស់ទ្រង់, **យ៉ាកុប** ១:៧ (ហេព្រើរ ៤:១–១១) ។ អស់អ្នកណាដែលប្រែចិត្ត អ្នកនោះនឹងបានចូលទៅក្នុងសេចក្ដីសំរាករបស់យើង, **អាលម៉ា** ១២:៣៤ ។ មានមនុស្សជាច្រើនដែលបានធ្វើឲ្យបានបរិសុទ្ធ ហើយបានចូលទៅក្នុងសេចក្ដីសំរាកនៃព្រះអម្ចាស់, **អាលម៉ា** ១៣:១២–១៦ ។ ស្ថានបរមសុខគឺជាស្ថានភាពឈប់សំរាក, **អាលម៉ា** ៤០:១២ (អាលម៉ា ៦០:១៣) ។ គ្មានអ្នកណាអាចចូលទៅក្នុង ទីសំរាក របស់ទ្រង់បានទេ លើកលែងតែអ្នកនោះដែលបានលាងសំលៀកបំពាក់របស់ខ្លួន ដោយនូវលោហិតរបស់យើង, ៣ នីហ្វៃ ២៧:១៩ ។ ចូរផ្សាយប្រាប់ពីការប្រែចិត្តដល់ប្រជាជននេះ ដើម្បីឲ្យអ្នកអាចសំរាកជាមួយពួកគេ នៅក្នុងនគរនៃព្រះវរបិតារបស់យើង, **គ. និង ស.** ១៥:៦ (គ. និង ស. ១៦:៦) ។ អស់អ្នកណាដែលស្លាប់ទៅនឹងបានសំរាកពីការងាររបស់ខ្លួន, **គ. និង ស.** ៥៩:២ (វិវ. ១៤:១៣) ។ សេចក្ដីសំរាករបស់ទ្រង់ គឺជាភាពពោរពេញនៃសិរីល្អរបស់ទ្រង់, **គ. និង ស.** ៨៤:២៤ ។

**សេចក្ដីស្រឡាញ់** *សូមមើលផង* សេចក្ដីខ្លាំង, សេចក្ដីសប្បុរស; អាណិត

ជាភក្ដីភាព និងការគាប់ចិត្តជាខ្លាំង ។ សេចក្ដីស្រឡាញ់ដល់ព្រះ មានរួមទាំងភក្ដីភាព ការសរសើរ ការកោតក្រែង ការទន់ភ្លន់ សេចក្ដីមេត្តាករុណា ការអត់ឱនទោស ការអាណិត គុណ ការបំរើ អំណរគុណ ការប្រណីមេត្តា ។ ដំរាប់ដ៏ធំបំផុតអំពីសេចក្ដី ស្រឡាញ់ ដែលព្រះមានដល់ពួកកូនចៅទ្រង់ គឺមាននៅក្នុងដង្វាយធួនដ៏និរន្តនៃព្រះយេស៊ូវគ្រីស្ទ ។

ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចជាខ្លួនឯង, **លេវី.** ១៩:១៨ (ម៉ាថាយ ៥:៤៣–៤៤; ម៉ាថាយ ២២:៣៧–៤០; រ៉ូម ១៣:៩; កាឡាទី ៥:១៤; យ៉ាកុប ២:៨; ម៉ូសាយ ២៣:១៥; គ. និង ស. ៥៩:៦) ។ ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត, **ចោទិ.** ៦:៥ (ម៉ូរ៉ូណៃ ១០:៣២; គ. និង ស. ៥៩:៥) ព្រះអម្ចាស់ ជាព្រះនៃឯង ទ្រង់គ្រាន់តែល្បងឯងមើល ឲ្យដឹងជាឯងរាល់គ្នាស្រឡាញ់ដល់ ព្រះអម្ចាស់ ជាព្រះនៃឯង, **ចោទិ.** ១៣:៣ ។ អ្នកណាដែលព្រះអម្ចាស់ទ្រង់ស្រឡាញ់ នោះទ្រង់ក៏ស្ដីប្រដៅផង, **សុភា.** ៣:១២ ។ មិត្តសំឡាញ់រមែង ស្រឡាញ់គ្នានៅគ្រប់វេលា, **សុភា.** ១៧:១៧ ។ ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទាន ព្រះរាជបុត្រាទ្រង់តែ១, **យ៉ូហាន** ៣:១៦ (គ. និង ស. ១៣៨:៣) ។ ចូរស្រឡាញ់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់ គ្នាដែរ, **យ៉ូហាន** ១៣:៣៤ (យ៉ូហាន ១៥:១២, ១៧; ម៉ូសេ ៧:៣៣) ។ បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ, **យ៉ូហាន** ១៤:១៥ (គ. និង ស. ៤២:២៩) ។ គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិត ជំនួសពួក សំឡាញ់របស់ខ្លួននោះទេ, **យ៉ូហាន** ១៥:១៣ ។ ពេត្រុសអើយ តើអ្នកស្រឡាញ់ខ្ញុំជាជាងរបស់ទាំងនេះឬអី ? ចូរឲ្យចំណីដល់ហ្វូង ចៀមខ្ញុំស៊ីផង, **យ៉ូហាន** ២១:១៥–១៧ ។ គ្មានអ្វីនឹងពង្រាត់យើងចេញពីសេចក្ដីស្រឡាញ់របស់ព្រះ ដែលនៅក្នុងព្រះគ្រីស្ទបានឡើយ, **រ៉ូម** ៨:៣៥–៣៩ ។ ភ្នែកមិនដែលឃើញសេចក្ដីដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់, **១ កូរិន.** ២:៩ ។ ត្រូវឲ្យ បំរើគ្នាទៅវិញទៅមក ដោយសេចក្ដី ស្រឡាញ់វិញ, **កាឡាទី** ៥:១៣ ។ បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន, **អេភេ.** ៥:២៥ (កូល៉ុស ៣:១៩) ។ កុំឲ្យស្រឡាញ់ លោកិយ ឡើយ, **១ យ៉ូហាន** ២:១៥ ។ ព្រះទ្រង់ជាសេចក្ដីស្រឡាញ់, **១ យ៉ូហាន** ៤:៨ ។ យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បាន ស្រឡាញ់យើងជាមុន, **១ យ៉ូហាន** ៤:១៩ ។ ព្រះគ្រីស្ទទ្រង់បានរងទុក្ខ ពីព្រោះតែសេចក្ដីមេត្តាករុណាដ៏ប្រកបដោយសេចក្ដីស្រឡាញ់ របស់ទ្រង់ចំពោះមនុស្សលោក, **១ នីហ្វៃ** ១៩:៩ ។ ចូរឈានទៅមុខ ដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប, **២ នីហ្វៃ** ៣១:២០ ។ អ្នករាល់គ្នានឹងបង្រៀនពួកកូនចៅអ្នកឲ្យស្រឡាញ់ ហើយបំរើគ្នាទៅវិញទៅមក, **ម៉ូសាយ** ៤:១៥ ។ បើអ្នករាល់គ្នា ចាប់អារម្មណ៍ចង់ច្រៀងចំរៀងនៃសេចក្ដីស្រឡាញ់ដែលប្រោសលោះ តើអ្នករាល់គ្នាចាប់អារម្មណ៍យ៉ាងណោ ឥឡូវនេះ ? **អាលម៉ា** ៥:២៦ ។ សូមឲ្យអ្នកបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ចូរឲ្យអត់ធ្មត់ ពោរពេញដោយសេចក្ដីស្រឡាញ់, **អាលម៉ា** ១៣:២៨ ។ ចូរទប់អស់ទាំងតណ្ហារបស់កូន ដើម្បីឲ្យកូនអាចបានពោរពេញទៅដោយសេចក្ដីស្រឡាញ់, **អាលម៉ា** ៣៨:១២ ។ គ្មានការទាស់ទែងគ្នា ពីព្រោះតែសេចក្ដីស្រឡាញ់នៃព្រះ ដែលបានស្ថិតនៅក្នុងចិត្តរបស់ មនុស្ស, **៤ នីហ្វៃ** ១:១៥ ។ អ្វីក៏ដោយដែលអញ្ជើញឲ្យ ស្រឡាញ់ព្រះ គឺបំផុសគំនិតមកពីព្រះ, **ម៉ូរ៉ូណៃ** ៧:១៣–១៦ ។ សេចក្ដីសប្បុរស គឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ, **ម៉ូរ៉ូណៃ** ៧:៤៧ ។ សេចក្ដីស្រឡាញ់ដ៏ឥតខ្ចោះ បណ្ដេញការភ័យខ្លាចចេញអស់, **ម៉ូរ៉ូណៃ** ៨:១៦ (១ យ៉ូហាន ៤:១៨) ។ សេចក្ដីស្រឡាញ់ ធ្វើឲ្យមនុស្ស សមនឹងកិច្ចការរបស់ព្រះ, **គ. និង ស.** ៤:៥ (គ. និង ស. ១២:៨) ។ ការញែកជាបរិសុទ្ធនោះមានដល់អស់អ្នកណាដែលស្រឡាញ់ ហើយបំរើ

ព្រះ, **គ. និង ស.** ២០:៣១ ។ បើសិនជាអ្នកស្រឡាញ់យើង ចូរបំរើយើង ហើយកាន់តាមបញ្ញត្តិទាំងអស់របស់ យើងចុះ, **គ. និង ស.** ៤២:២៩ (យ៉ូហាន ១៤:១៥) ។ ចូរបង្ហាញនូវសេចក្ដី ស្រឡាញ់ដ៏ច្រើនឡើង ចំពោះអ្នកនោះដែលអ្នកបានស្ដី បន្ទោសចុះ, **គ. និង ស.** ១២១:៤៣ ។ មនុស្សលោកបានស្រឡាញ់អារក្សសាតាំងជាងព្រះ, **ម៉ូសេ** ៥:១៣, ១៨, ២៨ ។

**សេចក្ដីស្លាប់ខាងវិញ្ញាណ***សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; ពួកកូនអន្ដរធាន, ស្ថាននរក; សេចក្ដីជាប់ទោស; សេចក្ដីសង្គ្រោះ; អារក្ស

ជាការបែកចេញពីព្រះ និងពីឥទ្ធិពលទ្រង់ ។ ស្លាប់ចំពោះអ្វីៗខាងសេចក្ដីសុចរិត ។ លូស៊ីហ្វើរ និងពួកពលបរិវារស្ថានសួគ៌១ភាគ៣ បានរងទុក្ខសេចក្ដីស្លាប់ខាងវិញ្ញាណ កាលពួកគេត្រូវបានបណ្ដេញចេញពីស្ថានសួគ៌ (គ. និង ស. ២៩:៣៦–៣៧) ។

សេចក្ដីស្លាប់ខាងវិញ្ញាណត្រូវបាននាំមកក្នុងលោកិយ ដោយសារការធ្លាក់នៃលោកអ័ដាម (ម៉ូសេ ៦:៤៨) ។ ពួកមនុស្សដែលមានគំនិត ពាក្យសំដី និងកិច្ចការអាក្រក់នោះទៅជាស្លាប់ខាងវិញ្ញាណ កាលនៅរស់នៅលើផែនដីនៅឡើយ (១ ធីម៉ូ. ៥:៦) ។ តាមដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងដោយសារការគោរពតាមគោលការណ៍ និងពិធីបរិសុទ្ធនៃដំណឹងល្អ នោះមនុស្សប្រុសស្រីអាចត្រឡប់ទៅជា ជ្រះស្អាតពីអំពើបាប ហើយឈ្នះលើសេចក្ដីស្លាប់ខាងវិញ្ញាណ ។

សេចក្ដីស្លាប់ខាងវិញ្ញាណក៏មានឡើងផងដែរ បន្ទាប់ពីសេចក្ដីស្លាប់នៃរូបកាយខាងសាច់ឈាម ។ មនុស្សដែលបានរស់ឡើងវិញ ព្រមទាំង អារក្ស និងពួកទេវតាវា នឹងត្រូវបានទទួលការជំនុំជំរះ ។ ទាំងពួកអ្នកដែលបានរស់ឡើងវិញ និងអារក្ស ហើយនិងពួកទេវតា វានឹងត្រូវបានទទួលការជំនុំជំរះ ។ អស់អ្នកណាដែលបះបោរទាស់នឹងពន្លឺ និងសេចក្ដីពិតនៃដំណឹងល្អដោយអស់ពីចិត្ត អ្នកនោះនឹងរង ទុក្ខសេចក្ដីស្លាប់ខាងវិញ្ញាណ ។ សេចក្ដីស្លាប់នេះតែងតែបានហៅថា ជាសេចក្ដីស្លាប់ទីពីរ (អាលម៉ា ១២:១៦; ហេលេ. ១៤:១៦–១៩; គ. និង ស. ៧៦:៣៦–៣៨) ។

ពួកអ្នកដែលធ្វើអាក្រក់នឹងត្រូវកាត់ចេញ, **ទំនុក.** ៣៧:៩ ។ គំនិតខាងសាច់ឈាម នោះជាសេចក្ដីស្លាប់, **រ៉ូម** ៨:៦ (២ នីហ្វៃ ៩:៣៩) ។ អំពើសំរើបពន្លិចមនុស្សទៅក្នុងសេចក្ដីហិនវិនាស និងសេចក្ដីអន្ដរធាន, ១ ធីម៉ូ. ៦:៩ ។ អំពើបាបបង្កើតជាសេចក្ដីស្លាប់, **យ៉ាកុប** (ព.ស.ថ.) ១:១៥ ។ អ្នកណាដែលឈ្នះ នោះសេចក្ដីស្លាប់ទីពីរនឹងមិនធ្វើទុក្ខដល់អ្នកនោះបានឡើយ, **វិវ.** ២:១១ ។ សេចក្ដីស្លាប់ទីពីរគ្មានអំណាចលើអ្នកទាំងនោះឡើយ, **វិវ.** ២០:៦, ១២–១៤ ។ ពួកទុច្ចរិតនឹងមានចំណែក នៅក្នុងបឹងដែលឆេះជាភ្លើង និងស្ពាន់ធ័រ គឺជាសេចក្ដីស្លាប់ទីពីរ, **វិវ.** ២១:៨ (គ. និង ស. ៦៣:១៧–១៨) ។ មនុស្សទាំងឡាយមានសិទ្ធិនឹងរើសយកឥស្សរភាព និងជីវិតដ៏នៅ អស់កល្បជានិច្ច ឬក៏រើសយកការជាប់ឃុំឃាំង និងសេចក្ដីស្លាប់, **២ នីហ្វៃ** ២:២៧ (២ នីហ្វៃ ១០:២៣; អាលម៉ា ២៩:៥; ហេលេ. ១៤:៣០–៣១) ។ ព្រះទ្រង់បានរៀបចំផ្លូវសំរាប់ឲ្យដោះខ្លួនចេញពីសេចក្ដីស្លាប់ និងស្ថាននរក, **២ នីហ្វៃ** ៩:១០ ។ ចូរដោះខ្លួនពី ការឈឺចាប់នៃស្ថាននរក ដើម្បីកុំឲ្យខ្លួនអ្នករាល់គ្នារងទុក្ខសេចក្ដីស្លាប់ទីពីរ, **យ៉ាកុប** ៣:១១ ។ មនុស្សខាងសាច់ឈាមជាសត្រូវដល់ ព្រះ, **ម៉ូសាយ** ៣:១៩ ។ សូមឲ្យព្រះអម្ចាស់ទ្រង់ប្រទានដល់អ្នកនូវការប្រែចិត្ត ដើម្បីកុំឲ្យអ្នករងទុក្ខសេចក្ដីស្លាប់ទីពីរ, **អាលម៉ា** ១៣:៣០ ។ អាលម៉ាត្រូវបានលោមព័ទ្ធទៅដោយច្រវាក់ដ៏នៃអស់កល្បជានិច្ចនៃសេចក្ដីស្លាប់, **អាលម៉ា** ៣៦:១៨ ។ ពួកមនុស្សទុច្ចរិតស្លាប់ ចំពោះអ្វីៗ ដែលទាក់ទងទៅនឹងសេចក្ដីសុចរិត, **អាលម៉ា** ៤០:២៦ (អាលម៉ា ១២:១៦) ។ ការធ្លាក់ត្រូវបាននាំមកលើមនុស្សលោកទាំងអស់ នូវសេចក្ដីស្លាប់ខាងវិញ្ញាណ, **អាលម៉ា** ៤២:៩ (ហេលេ. ១៤:១៦–១៨) ។ កាលលោកអ័ដាមធ្លាក់ នោះលោកបានក្លាយទៅ ជាស្លាប់ខាងវិញ្ញាណ, **គ. និង ស.** ២៩:៤០–៤១, ៤៤ ។

**សេចក្ដីស្លាប់ខាងសាច់ឈាម***សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា ដែលរមែងស្លាប់, ដំណើររស់ឡើងវិញ; ភាពដែលមែងស្លាប់; សេចក្ដីសង្គ្រោះ

ជាការបំបែករូបកាយចេញពីវិញ្ញាណ ។ ការធ្លាក់ផ្ដល់មកនូវភាពដែលរមែងស្លាប់ និងសេចក្ដីស្លាប់លើផែនដី (២ នីហ្វៃ ២:២២; ម៉ូសេ ៦:៤៨) ។ ដង្វាយធួននៃ ព្រះយេស៊ូវគ្រីស្ទឈ្នះ លើសេចក្ដីស្លាប់ ដើម្បីឲ្យមនុស្សរាល់គ្នាបានរស់ឡើងវិញ (១ កូរិន. ១៥:២១–២៣) ។ ដំណើររស់ឡើងវិញ ជាអំណោយទានមួយដោយសេរី សំរាប់មនុស្សគ្រប់រូប សូម្បីតែពួកគេបានធ្វើអំពើល្អ ឬអាក្រក់នៅក្នុងជីវិតនេះ ក៏ដោយ (អាលម៉ា ១១:៤២–៤៤) ។ មនុស្សម្នាក់ៗ រងទុក្ខតែសេចក្ដីស្លាប់ខាងសាច់ឈាមតែមួយប៉ុណ្ណោះ ព្រោះកាលយើងរស់ឡើង វិញ នោះរូបកាយរបស់យើងមិន អាចស្លាប់ទៅទៀតឡើយ (អាលម៉ា ១១:៤៥) ។

គ្រប់ទាំងសាច់នឹងត្រូវវិនាសទៅទាំងអស់ ហើយមនុស្សនឹងត្រូវត្រឡប់ទៅជាធូលីដីវិញ, **យ៉ូប** ៣៤:១៥ ។ ការស្លាប់របស់ពួកអ្នកបរិសុទ្ធនៃព្រះអម្ចាស់ ជាការវិសេសដល់ព្រះនេត្រទ្រង់, **ទំនុក.** ១១៦:១៥ ។ ធូលីត្រឡប់ជាដីដូចដើមវិញ និងវិញ្ញាណត្រឡប់ទៅឯព្រះ, **សាស្ដា** ១២:៧ ។ សេចក្ដីស្លាប់បានមកដោយសារមនុស្ស, **១ កូរិន.** ១៥:២១ ។ ព្រះអង្គសង្គ្រោះកាន់កូនសោនៃស្ថាននរក និងសេចក្ដីស្លាប់, **វិវ.** ១:១៨ ។ នឹងគ្មានសេចក្ដីស្លាប់ ឬសេចក្ដីសោកសង្រេងទៀតឡើយ, **វិវ.** ២១:៤ ។ សេចក្ដីស្លាប់បានមកដល់ មនុស្សលោកគ្រប់រូប, **២ នីហ្វៃ** ៩:៦, ១១ (អាលម៉ា ១២:២៤) ។ ពួកគេមិនមើលសេចក្ដីស្លាប់ ទុកជាការតក់ស្លុតសោះឡើយ, **អាលម៉ា** ២៧:២៨ ។ អាលម៉ាអធិប្បាយប្រាប់អំពីស្ថានភាពនៃព្រលឹង រវាងសេចក្ដីស្លាប់ និងដំណើររស់ឡើងវិញ, **អាលម៉ា** ៤០:១១ ។ អស់អ្នកណាដែលស្លាប់ក្នុងយើងនោះនឹងមិនត្រូវភ្លក់សេចក្ដីស្លាប់ឡើយ, **គ. និង ស.** ៤២:៤៦ ។ អស់អ្នកណាដែលពុំបានកំណត់ឲ្យ ស្លាប់ នោះនឹងត្រូវបានជាស្បើយហើយ, **គ. និង ស.** ៤២:៤៨ ។ យើងនឹងល្បងលអ្នកនូវគ្រប់ការណ៍ទាំងអស់ គឺរហូតដល់ស្លាប់, **គ. និង ស.** ៩៨:១៤ ។ អ្នកក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ, **ម៉ូសេ** ៤:២៥ ។ អ័ដាមបានធ្លាក់ ហើយដោយសារការធ្លាក់របស់គាត់ ទើបមាន សេចក្ដីស្លាប់, **ម៉ូសេ** ៦:៤៨ ។

**សេចក្ដីស្លាប់ទីពីរ** *សូមមើល* សេចក្ដីស្លាប់ខាងវិញ្ញាណ

**សេចក្ដីស្មោះ** *សូមមើលផង* ទៀងត្រង់, សុចរិត, សេចក្ដីទៀងត្រង់; សេចក្ដីសុចរិត

ជាសេចក្ដីសុចរិត ទៀងត្រង់ និងស្មោះត្រង់ ។

ខ្ញុំមិនព្រមលះចោលសំដីដែលថាខ្ញុំត្រឹមត្រូវឡើយ ដរាបដល់ខ្ញុំស្លាប់, **យ៉ូប** ២៧:៥ ។ មនុស្សសុចរិត គេដើរតាមផ្លូវទៀងត្រង់របស់ខ្លួន, **សុភា.** ២០:៧ ។ ពួកគេជាមនុស្សស្មោះត្រង់គ្រប់ពេលវេលា នៅក្នុងកិច្ចការណាក៏ដោយ ដែលពួកគេទទួលបន្ទុក, **អាលម៉ា** ៥៣:២០ ។ ព្រះអម្ចាស់ទ្រង់ស្រឡាញ់ហៃរុម ស្ម៊ិធ មកពីសេចក្ដីស្មោះនៃចិត្តរបស់គាត់, **គ. និង ស.** ១២៤:១៥ ។

**សេចក្ដីអត់ធន់** *សូមមើលផង* កាន់ខ្ជាប់; ភាពស្លូតបូត, ស្លូតបូត

ជាការអត់ទ្រាំដោយស្ងប់ស្ងាត់; ជាការស៊ូទ្រាំសេចក្ដីទុក្ខវេទនា សេចក្ដីត្មះតិះដៀល ឬសេចក្ដីរបួសខូចខាត ដោយឥតត្អូញត្អែរ ឬសងសឹកឡើយ ។

ចូរស្ងៀមនៅចំពោះព្រះអម្ចាស់ ហើយរង់ចាំទ្រង់ដោយអត់ធន់ចុះ, **ទំនុក.** ៣៧:៧–៨ ។ អ្នកណាដែលមិនឆាប់ខឹង នោះឯងជាអ្នកប្រកបដោយយោបល់ច្រើន, **សុភា.** ១៤:២៩ ។ អ្នករាល់គ្នានឹងបានជីវិតគង់នៅវិញ ដោយមានចិត្តខ្ជាប់ខ្ជួន, **លូកា** ២១:១៩ ។ យើងបានសេចក្ដីសង្ឃឹម ដោយសេចក្ដីអត់ធន់ និងសេចក្ដីកំសាន្តចិត្ត ដោយសារបទព្រះគម្ពីរ, **រ៉ូម** ១៥:៤ ។ ចូរត្រាប់តាមពួកអ្នក ដែលគេងបាន សេចក្ដីសន្យាទុកជាមរដក ដោយចិត្តជឿ ហើយអត់ធន់វិញ, **ហេព្រើរ** ៦:១២–១៥ ។ ចូរទុកឲ្យសេចក្ដីខ្ជាប់ខ្ជួននោះ បានធ្វើការឲ្យ សំរេចពេញលេញចុះ ដើម្បីឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ, **យ៉ាកុប** (ព.ស.ថ.) ១:២–៤ ។ អ្នករាល់គ្នា បានឮនិយាយពីសេចក្ដីអត់ធន់របស់លោកយ៉ូប, **យ៉ាកុប** (ព.ស.ថ.) ៥:១១ ។ ពួកគេបានធ្វើតាមព្រះហឫទ័យនៃព្រះអម្ចាស់ ដោយការ រីករាយ និងដោយការអត់ធន់, **ម៉ូសាយ** ២៤:១៥ ។ កូនបានរងនូវការណ៍អស់ទាំងនេះដោយសេចក្ដីអត់ធន់ ពីព្រោះព្រះអម្ចាស់ទ្រង់ គង់នៅមួយនឹងកូន, **អាលម៉ា** ៣៨:៤–៥ ។ ចូរស៊ូនៅក្នុងសេចក្ដីអត់ធន់ចុះ រហូតដល់អ្នករាល់គ្នាបានល្អឥតខ្ចោះ **គ. និង ស.** ៦៧:១៣ ។

**សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ**

សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ គឺជាសេចក្ដីពិតខាងវិញ្ញាណ ដែលបានដឹងដោយសារវិវរណៈប៉ុណ្ណោះ ។ ព្រះទ្រង់បើកសម្ដែង សេចក្ដីអាថិកំបាំងទាំងឡាយរបស់ទ្រង់ដល់អស់អ្នកណា ដែលគោរពតាមដំណឹងល្អ ។ សេចក្ដីអាថិកំបាំងខ្លះៗរបស់ព្រះនឹងត្រូវបានបើក សម្ដែងនៅពេលខាងមុខ ។

គឺបានប្រទានមកអ្នករាល់គ្នា ឲ្យបានស្គាល់ការអាថិកំបាំងរបស់នគរស្ថានសួគ៌, **ម៉ាថាយ** ១៣:១១ ។ បើខ្ញុំស្គាល់អស់ទាំងសេចក្ដីអាថិកំបាំង តែគ្មានសេចក្ដីសប្បុរស នោះខ្ញុំមិនជាអ្វីទេ, **១ កូរិន.** ១៣:២ ។ នីហ្វៃមានចំណេះវិជ្ជាដ៏ជ្រាលជ្រៅអំពីសេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ, **១ នីហ្វៃ** ១:១ ។ គឺបានប្រទានដល់មនុស្សជាច្រើន ឲ្យបានស្គាល់សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ, **អាលម៉ា** ១២:៩ ។ ចំពោះមនុស្សខ្លះនឹងបានប្រទានឲ្យស្គាល់សេចក្ដីអាថិកំបាំងទាំងឡាយនៃព្រះ, **អាលម៉ា** ២៦:២២ ។ សេចក្ដីអាថិកំបាំងទាំងនេះ មិនទាន់ បានធ្វើឲ្យឪពុកបានស្គាល់គ្រប់យ៉ាងនៅឡើយទេ, **អាលម៉ា** ៣៧:១១ ។ មានការអាថិកំបាំងជាច្រើន ដែលគ្មាននរណាស្គាល់ឡើយ ក្រៅពីព្រះប៉ុណ្ណោះ, **អាលម៉ា** ៤០:៣ ។ សេចក្ដីអាថិកំបាំងនៃភាពជាព្រះ នោះមហិមាណាស់ហ្ន៎, **គ. និង ស.** ១៩:១០ ។ បើសិនជាអ្នក សូម នោះអ្នកនឹងបានទទួលវិវរណៈ ហើយនឹងបានស្គាល់សេចក្ដីអាថិកំបាំងទាំងឡាយនៃនគរ, **គ. និង ស.** ៤២:៦១, ៦៥ (១ កូរិន. ២:៧, ១១–១៤) ។ អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះនឹងត្រូវបានប្រទាននូវសេចក្ដីអាថិកំបាំងទាំងឡាយនៃនគរ, **គ. និង ស.** ៦៣:២៣ ។ ចំពោះពួកគេ នោះយើងនឹងបើកសម្ដែងអស់ទាំងសេចក្ដីអាថិកំបាំង, **គ. និង ស.** ៧៦:៧ ។ បព្វជិតភាពដ៏ធំជាង កាន់កូន សោនៃសេចក្ដីអាថិកំបាំងទាំងឡាយ, **គ. និង ស.** ៨៤:១៩ ។ ក្នុងកាលព្រះអម្ចាស់នឹងយាងមក នោះព្រះអង្គនឹងបើកសម្ដែង របស់របរដែលអាថិកំបាំង ដែលគ្មានមនុស្សណាស្គាល់, **គ. និង ស.** ១០១:៣២–៣៣ ។ បព្វជិតភាពមិលគីស្សាដែក គឺដើម្បីមាន ឯកសិទ្ធិក្នុងការទទួលសេចក្ដីអាថិកំបាំងទាំងឡាយនៃនគរ, **គ. និង ស.** ១០៧:១៩ ។

**សេចក្ដីអំណរ** *សូមមើលផង* ការគោរពតាម, គោរពតាម, ដែលគោរពតាម

ជាស្ថានភាពខាងសុភមង្គលដ៏ប្រសើរ ដែលមានមកពីការរស់នៅដោយសុចរិត ។ បំណងនៃជីវិតនេះ គឺសំរាប់ឲ្យមនុស្សទាំងអស់មាន សេចក្ដីអំណរ (២ នីហ្វៃ ២:២២–២៥) ។ សេចក្ដីអំណរដ៏ពោរពេញនឹងមានមក ដោយសារព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ (យ៉ូហាន ១៥:១១; គ. និង ស. ៩៣:៣៣–៣៤; ១០១:៣៦) ។

មនុស្សរាបសានឹងមានសេចក្ដីអំណរចំរើនឡើងក្នុងព្រះអម្ចាស់, **អេសាយ** ២៩:១៩ (២ នីហ្វៃ ២៧:៣០) ។ ខ្ញុំមកប្រាប់ដំណឹងល្អដល់ អ្នករាល់គ្នាពីសេចក្ដីអំណរយ៉ាងអស្ចារ្យ, **លូកា** ២:១០ ។ ឥតមានអ្នកណាដកយកសេចក្ដីអំណរនោះ ចេញពីអ្នករាល់គ្នាបានឡើយ, **យ៉ូហាន** ១៦:២២ ។ ឯផលផ្លែនៃព្រះវិញ្ញាណ នោះគឺសេចក្ដីស្រឡាញ់ អំណរ អរ មេត្រីភាព, **កាឡាទី** ៥:២២ ។ ផ្លែឈើនោះបានធ្វើ ឲ្យព្រលឹងឪពុកពោរពេញទៅដោយសេចក្ដីអំណរជាអតិបរមា, **១ នីហ្វៃ** ៨:១២ ។ មានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្ដី អំណរ, **២ នីហ្វៃ** ២:២៥ ។ សេចក្ដីអំណរនៃមនុស្សសុចរិតនឹងឯងបានពោរពេញរហូតតទៅ, **២ នីហ្វៃ** ៩:១៨ ។ គេអាចរស់នៅជា មួយនឹងព្រះ ក្នុងស្ថានភាពនៃសុភមង្គលដ៏មិនចេះចប់, **ម៉ូសាយ** ២:៤១ ។ យើងនឹងបោះបង់ចោលនូវអ្វីៗ ដែលយើងមានទាំងអស់ ដើម្បីយើងអាចបានទទួលសេចក្ដីអំណរដ៏ធំនេះ, **អាលម៉ា** ២២:១៥ ។ ក្រែងខ្ញុំអាចបានទៅជាឧបករណ៍មួយនៅក្នុងព្រះហស្តនៃព្រះ ដើម្បីនាំព្រលឹងមនុស្សខ្លះទៅកាន់ការប្រែចិត្ត ហើយនេះគឺសេចក្ដីអំណររបស់ខ្ញុំ, **អាលម៉ា** ២៩:៩ ។ ឱសេចក្ដីអំណរ

និងរស្មីដ៏អស្ចារ្យ ដែលឪពុកបានឃើញ, **អាលម៉ា** ៣៦:២០ ។ ព្រះវិញ្ញាណរបស់យើងនឹងបំពេញព្រលឹងរបស់អ្នកដោយសេចក្ដីអំណរ, **គ. និង ស.** ១១:១៣ ។ តើអ្នកនឹងមានសេចក្ដីអំណរដ៏មហិមាជាមួយអ្នកនោះ នៅក្នុងនគរនៃព្រះវរបិតារបស់យើងយ៉ាងណាទៅ, **គ. និង ស.** ១៨:១៥–១៦ ។ នៅក្នុងពិភពលោកនេះ សេចក្ដីអំណររបស់អ្នកពុំបានពោរពេញទេ ប៉ុន្តែនៅក្នុងយើង ទើបសេចក្ដីអំណររបស់អ្នកបានពោរពេញ, **គ. និង ស.** ១០១:៣៦ ។ នៅក្នុងជីវិតនេះ ខ្ញុំនឹងមានសេចក្ដីអំណរ, **ម៉ូសេ** ៥:១០–១១ ។

**សេចក្ដីអំណួត** *សូមមើល* សេចក្ដីឆ្មើងឆ្មៃ

**សេដេគា** *សូមមើលផង* មូលេក

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាស្ដេចចុងក្រោយបង្អស់នៃយូដា (២ ពង្សាវ. ២៤:១៧–២០; ២៥:២–៧) ។ សេដេគាបានដាក់គុកព្យាការីយេរេមា (យេរេ. ៣២:១–៥) ហើយយេរេមាបានព្យាករអំពីការជាប់ឃុំឃាំងរបស់សេដេគា (យេរេ. ៣៤:២–៨, ២១) ។ លីហៃ និងគ្រួសាររបស់លោកបានរស់នៅក្នុងក្រុងយេរូសាឡិម ក្នុងឆ្នាំទី ១ នៃរាជ្យសេដេគា (១ នីហ្វៃ ១:៤) ។ ពួកបុត្រារបស់ សេដេគាត្រូវគេប្រហារទាំងអស់ នៅសល់តែមួយគត់ ។ មូលេកជាបុត្រទ្រង់ បានរត់រួចទៅអឌ្ឍគោលខាងលិច (យេរេ. ៥២:១០; អេមណៃ ១:១៥; ហេលេ. ៨:២១) ។

**សេត** *សូមមើលផង* អ័ដាម

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសដ៏សុចរិតម្នាក់របស់លោកអ័ដាម និងនាងអេវ៉ា ។

សេតជាមនុស្សដ៏ល្អឥតខ្ចោះ ហើយរូបភាពគាត់ គឺជារូបភាពរបស់ឪពុករបស់គាត់បេះបិទ, **គ. និង ស.** ១០៧:៤២–៤៣ (លោកុ. ៥:៣) ។ សេតបាននៅក្នុងចំណោមពួកខ្លាំងពូកែ នៅស្ថានវិញ្ញាណ, **គ. និង ស.** ១៣៨:៤០ ។ ព្រះទ្រង់បានសម្ដែងអង្គទ្រង់ឲ្យសេតឃើញ, **ម៉ូសេ** ៦:១–៣; ៨–១៤ ។

**សេផានា**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានរស់នៅរជ្ជកាលយ៉ូសៀស (៦៣៩–៦០៨ ម.គ.ស.) ។

*គម្ពីរសេផានា៖* ជំពូកទី ១ និយាយអំពីថ្ងៃមួយដែលនឹងមកដល់ ដែលនឹងបានពោរពេញទៅដោយសេចក្ដីខ្ញាល់ និងទុក្ខកង្វល់ ។ ជំពូកទី ២ ទូន្មានឲ្យបណ្ដាជនអ៊ីស្រាអែល ស្វែងរកសេចក្ដីសុចរិត និងភាពស្លូតបូត ។ ជំពូកទី ៣ ប្រាប់អំពីការយាងមកលើកទីពីរ នៅពេលសាសន៍ទាំងអស់នឹងប្រមូលគ្នាទៅច្បាំង ។ ប៉ុន្តែព្រះអម្ចាស់នឹងសោយរាជ្យ នៅកណ្ដាលពួកគេ ។

**សេផូរ៉ា** *សូមមើលផង* ម៉ូសេ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាប្រពន្ធរបស់លោកម៉ូសេ ហើយជាកូនស្រីរបស់យេត្រូ (និក្ខ. ២:២១; ១៨:២) ។

**សេរី, សេរីភាព** *សូមមើលផង* ការជាប់ឃុំឃាំង; សិទ្ធិជ្រើសរើស; ឥស្សរភាព

ជាអំណាច ឬសិទ្ធិដើម្បីរើសតាមចិត្ត ដោយអត់ការបង្ខិតបង្ខំ ។ ស្ដីតាមគម្ពីរ មនុស្សណាដែលប្រែចិត្ត ហើយគោរពតាមព្រះហឫទ័យ ព្រះនោះបានផុតពីសេវកភាពនៃអំពើបាប តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ (ម៉ូសាយ ៥:៨) ។

សេចក្ដីពិតនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច, **យ៉ូហាន** ៨:៣២ ។ ពួកអ្នកណាដែលបានរួចផុតពីអំពើបាបនឹងបានទទួលជីវិតដ៏នៅអស់ កល្បជានិច្ច, **រ៉ូម** ៦:១៩–២៣ ។ មេកមួយដ៏សុចរិតដល់វង្សអ៊ីស្រាអែលនឹងត្រូវបាននាំចេញពីការជាប់ឃុំឃាំងទៅរកការរួចផុត, **២ នីហ្វៃ** ៣:៥ ។ ពួកគេអំពាវនាវដល់ព្រះអម្ចាស់ សូមឲ្យគេមានសេរីភាព, **អាលម៉ា** ៤៣:៤៨–៥០ ។ ម៉ូរ៉ូណៃមានសេចក្ដីអំណរក្នុង សេរីភាពនៃប្រទេសលោក, **អាលម៉ា** ៤៨:១១ ។ ព្រះវិញ្ញាណនៃព្រះ គឺជានិស្ស័យនៃសេរីភាព, **អាលម៉ា** ៦១:១៥ ។ ចូរដើរតាម យើងចុះ ហើយអ្នកនឹងបានទៅជាមនុស្សសេរី, **គ. និង ស.** ៣៨:២២ ។

**សេរេម** *សូមមើលផង* អ្នកទទឹងនឹងព្រះគ្រីស្ទ

ជាបុរសម្នាក់ នៅក្នុងព្រះគម្ពីរមរមន ដែលមិនទទួលស្គាល់ព្រះគ្រីស្ទ ហើយទាមទាររកទីសំគាល់ (យ៉ាកុប ៧:១–២០) ។

**សេសារ**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជានាមឲ្យដល់រាជាធិរាជខ្លះនៃរ៉ូម ។ គឺបានយកមកប្រើក្នុងគម្ពីរ ជានិមិត្តរូបអំពីរដ្ឋាភិបាល ឬអំណាចខាងលោកិយ ។

ចូរថ្វាយរបស់សេសារ ទៅសេសារទៅ, **ម៉ាថាយ** ២២:២១ (ម៉ាកុស ១២:១៧; លូកា ២០:២៥; គ. និង ស. ៦៣:២៦) ។

**សំបុត្ររបស់ប៉ុល** *សូមមើលផង* ឈ្មោះសំបុត្រនីមួយៗ, ប៉ុល

គម្ពីរ១៤ច្បាប់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពីដើមគឺជាសំបុត្រដែលបានសរសេរដោយសាវកប៉ុល ដល់សមាជិកក្នុងសាសនាចក្រ ។ គម្ពីរទាំងនេះអាចញែកចេញជាបួនក្រុម ដែលមានដូចតទៅនេះ គឺ៖

*ថែស្សាឡូនីចទី ១ និងទី ២ (ឆ្នាំ ៥០–៥១ គ.ស.)*

ប៉ុលបានសរសេរសំបុត្រដល់ពួកថែស្សាឡូនីចពីកូរិនថូស នៅគ្រាលោកធ្វើបេសកកម្មលើកទីពីរ ។ កិច្ចការរបស់លោកនៅស្រុកថែស្សាឡូនីច បានអធិប្បាយប្រាប់នៅក្នុងគម្ពីរកិច្ចការ ជំពូកទី ១៧ ។ លោកចង់វិលទៅស្រុកថែស្សាឡូនីចវិញ ប៉ុន្តែលោកមិនអាច ទៅបាន (១ ថែស្ស. ២:១៨) ។ ហេតុដូច្នោះហើយ ទើបលោកបានចាត់ធី

ម៉ូថេឲ្យទៅកំសាន្តពួកប្រែចិត្តជឿ ហើយឲ្យវិលមកប្រាប់ លោកវិញ អំពីអ្វីៗដែលពួកគេធ្វើ ។ សំបុត្រទី ១ គឺជាផលនៃសេចក្ដីអំណរគុណអំពីការវិលមកវិញនៃធីម៉ូថេ ។ សំបុត្រទី ២ បាន សរសេរនៅពេលបន្ទាប់ពីនោះភ្លាម ។

*កូរិនថូសទី ១ និងទី ២, កាឡាទី, រ៉ូម (ឆ្នាំ ៥៥–៥៧ គ.ស.)*

ប៉ុលបានសរសេរសំបុត្រដល់ពួកកូរិនថូស នៅគ្រាលោកធ្វើបេសកកម្មលើកទីបី ដើម្បីឆ្លើយនូវសំណួរទាំងឡាយ ហើយសំរួល ការមិនស្រុះស្រួលគ្នា នៅក្នុងចំណោមពួកបរិសុទ្ធ នៅស្រុកកូរិនថូស ។

សំបុត្រដល់ពួកកាឡាទីប្រហែលជាបានសរសេរដល់សាសនាចក្រ*ជាច្រើន*ក្រុមនៅស្រុកកាឡាទីទាំងមូល ។ សមាជិកខ្លះនៅក្នុង សាសនាចក្របានលះបងចោលដំណឹងល្អ ហើយយល់ស្របតាមក្រិត្យវិន័យនៃសាសន៍យូដា ។ នៅក្នុងសំបុត្រនេះ ប៉ុលបានពន្យល់ប្រាប់អំពីគោលបំណងនៃក្រិត្យវិន័យលោកម៉ូសេ និងតម្លៃនៃសាសនាខាងវិញ្ញាណ ។

ប៉ុលបានសរសេរសំបុត្រដល់ពួករ៉ូមពីក្រុងកូរិនថូស ដោយចង់រៀបចំពួកបរិសុទ្ធសាសន៍រ៉ូម ដែលលោកបានសង្ឃឹមថានឹងបានទៅជួប ពួកគេ ។ សំបុត្រនេះក៏បញ្ជាក់ម្ដងទៀតអំពីដំណឹងល្អ ដែលកំពុងតែមានទំនាស់គ្នាដោយពួកសាសន៍យូដា ដែលបានប្រែចិត្តជឿតាម សាសនាគ្រីស្ទាន ។

*ភីលីព, កូល៉ុស, អេភេសូរ, ភីលេម៉ូន, ហេព្រើរ (ឆ្នាំ ៦០–៦២ គ.ស.)*

ប៉ុលបានសរសេរសំបុត្រទាំងនេះ កាលលោកជាប់គុកមុនដំបូងនៅក្រុងរ៉ូម ។

ប៉ុលបានសរសេរសំបុត្រដល់ពួកភីលីព គោលសំខាន់ គឺដើម្បីបង្ហាញនូវអំណរគុណ និងសេចក្ដីគាប់ចិត្តចំពោះពួកបរិសុទ្ធនៅក្រុងភីលីព ហើយដើម្បីលួងលោមពីព្រោះការខកចិត្តដែលលោកត្រូវជាប់គុកយ៉ាងយូរ ។

ប៉ុលបានសរសេរសំបុត្រដល់ពួកកូល៉ុស មកពីដំណឹងថា ពួកបរិសុទ្ធនៅកូល៉ុស កំពុងតែធ្លាក់ទៅក្នុងកំហុសដ៏ធ្ងន់មួយ ។ គេបានជឿថា ការល្អឥតខ្ចោះកើតឡើង ដោយសារការគោរពតាមពិធីបរិសុទ្ធខាងក្រៅ តែមួយជាជាងការសាងចរិយាឲ្យបានដូចព្រះគ្រីស្ទវិញ ។

សំបុត្រដល់ពួកអេភេសូរ គឺមានសារៈសំខាន់ដ៏ធំ ព្រោះសំបុត្រនេះ មាននូវការបង្រៀនទាំងឡាយរបស់ប៉ុល អំពីសាសនាចក្រនៃព្រះ គ្រីស្ទ ។

សំបុត្រដល់ភីលេម៉ូន គឺជាសំបុត្រផ្ទាល់ខ្លួន អំពីអូនេសុីម ជាបាវបំរើ ដែលបានប្លន់ភីលេម៉ូន ជាចៅហ្វាយរបស់ខ្លួន ហើយរត់ទៅក្រុងរ៉ូម ។ ប៉ុលបានចាត់ឲ្យអូនេសុីមវិលទៅរកចៅហ្វាយវិញ ព្រមទាំងសំបុត្រអង្វរឲ្យលោកអត់ទោសឲ្យអូនេសុីមផង ។

ប៉ុលបានសរសេរសំបុត្រដល់ពួកហេព្រើរ ដល់សមាជិកសាសន៍យូដានៅក្នុងសាសនាចក្រ ដើម្បីបញ្ចុះបញ្ចូលពួកគេថា ក្រិត្យវិន័យលោកម៉ូសេនោះបានត្រូវសំរេចក្នុងព្រះគ្រីស្ទ ហើយថា ក្រិត្យវិន័យខាងដំណឹងល្អនៃព្រះគ្រីស្ទបានមកជំនួសហើយ ។

*ធីម៉ូថេទី ១ និងទី ២, ទីតុស (ឆ្នាំ ៦៤–៦៥ គ. ស.)*

ប៉ុលបានសរសេរសំបុត្រទាំងនេះ បន្ទាប់ពីលោកបានចេញពីគុកនៅក្រុងរ៉ូម លើកទីមួយ ។

ប៉ុលបានធ្វើដំណើរទៅអេភេសូរ ជាទីដែលលោកទុកធីម៉ូថេឲ្យបញ្ឈប់ការជុះនៃការស្មានខ្លះ ដោយសង្ឃឹមថានឹងបានវិលមកវិញនៅពេលក្រោយ ។ លោកបានសរសេរសំបុត្រទី ១ ទៅធីម៉ូថេ ប្រហែលជាចេញពីក្រុងម៉ាសេដូ ដើម្បីទូន្មាន ហើយលើកទឹកចិត្តធីម៉ូថេ ក្នុងការសំរេចកិច្ចការលោក ។

ប៉ុលបានសរសេរសំបុត្រទៅទីតុស នៅគ្រាលោកបានរួចពីគុក ។ លោកប្រហែលជាបានទៅកោះក្រេត ជាទីដែលទីតុសធ្វើ ការបំរើ ។ គោលសំខាន់នៃសំបុត្រនេះទាក់ទងទៅនឹងការរស់នៅដោយសុចរិត និងការអប់រំនៅក្នុងសាសនាចក្រ ។

ប៉ុលបានសរសេរសំបុត្រទី ២ ទៅធីម៉ូថេ កាលលោកជាប់គុកលើកទីពីរ មុនទុក្ករកម្មរបស់លោកបន្តិច ។ សំបុត្រនេះមាននូវពាក្យសំដីចុងក្រោយបង្អស់របស់ប៉ុល ហើយបង្ហាញនូវការក្លាហាន និងការទុកចិត្តដ៏អស្ចារ្យ នៅពេលលោកប្រឈមមុខនឹងសេចក្ដីស្លាប់ ។

**សំរេកស្រើប** *សូមមើលផង* កាមរាគ, ខាងកាមរាគ

គឺមានសេចក្ដីប៉ងប្រាថ្នាជាខ្លាំង ចំពោះអ្វីមួយ ដោយមិនគួរសម ។

កុំឲ្យឯងមានតណ្ហាខ្ជូលខ្មាញ់ចំពោះរូបឆោមឆាយរបស់គេឡើយ, **សុភា.** ៦:២៥ ។ អស់អ្នកណាដែលក្រឡេកឃើញស្ត្រី ហើយមានដំរេកសំរើបចង់បាន នោះបានប្រព្រឹត្តសេចក្ដីកំផិតហើយ, **ម៉ាថាយ** ៥:២៨ (៣ នីហ្វៃ ១២:២៨) ។ ពួកប្រុសៗមានសេចក្ដីសំរើបរោលរាលដល់គ្នាទៅវិញទៅមក, **រ៉ូម** ១:២៧ ។ គេនឹងហៅគ្រូកាន់តែច្រើនឡើងមកបង្រៀនឲ្យត្រូវចិត្តគេ,២ ធីម៉ូ. ៤:៣–៤ ។ ឡាបាន់បាន ឃើញទ្រព្យរបស់យើង ហើយកើតក្ដីលោភលន់ចង់បាន, **១ នីហ្វៃ** ៣:២៥ ។ ចូរកុំទៅតាមសេចក្ដីសំរើបនៃភ្នែករបស់ខ្លួនទៀតឡើយ, **អាលម៉ា** ៣៩:៣–៤, ៩ ។ អ្នកណាដែលក្រឡេកឃើញស្ត្រី ហើយមានដំរេកសំរើបចង់បាន នោះនឹងបោះបង់ចោលសេចក្ដីជំនឿ, **គ. និង ស.** ៤២:២៣ ។ ចូរឈប់ពីសេចក្ដីប៉ងប្រាថ្នាដ៏ស្រើបស្រាលទាំងអស់របស់អ្នកចុះ, **គ. និង ស.** ៨៨:១២១ ។

**សាំ** *សូមមើលផង* លីហៃ, ឪពុករបស់នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន គឺជាកូនប្រុសទីបីរបស់លីហៃ (១ នីហ្វៃ ២:៥) ។ លោកជាមនុស្សត្រង់ ហើយបរិសុទ្ធម្នាក់ ដែលបានសំរេចចិត្តនឹងដើរតាមព្រះអម្ចាស់ (១ នីហ្វៃ ២:១៧; ២ នីហ្វៃ ៥:៥–៦; អាលម៉ា ៣:៦) ។

**សាំយូអែល, ព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់**

ជាកូនប្រុសរបស់អែលកាណា និងនាងហាណា; សាំយូអែលបានកើតមក ជាចម្លើយរបស់ម្ដាយលោកដែលបានអធិស្ឋានសូម (១ សាំយូ. ១) ។ កាលលោកនៅវ័យក្មេង លោកនៅក្រោមការថែទាំនៃលោកអេលី ដែលជាសង្ឃជាន់ខ្ពស់ម្នាក់ ធ្វើការនៅឯទី ឧបោសថនៅឯស៊ីឡូរ (១ សាំយូ. ២:១១; ៣:១) ។ ព្រះអម្ចាស់ទ្រង់បានហៅសាំយូអែលឲ្យធ្វើជាព្យាការី តាំងពីលោកនៅវ័យក្មេង ម្ល៉េះ (១ សាំយូ. ៣) ។

ក្រោយពីអេលីបានស្លាប់ទៅ សាំយូអែលបានក្លាយទៅជាព្យាការី ហើយជាចៅហ្វាយនៃពួកអ៊ីស្រាអែលដ៏មហិមាម្នាក់ ព្រមទាំងបានថែងឡើងវិញនូវក្រិត្យវិន័យ ច្បាប់ និងការថ្វាយបង្គំដ៏ទៀងទាត់ខាងសាសនា នៅក្នុងស្រុក (១ សាំយូ. ៤:១៥–១៨; ៧:៣–១៧) ។

១ សាំយូ. ២៨:៥–២០ មាននូវដំណើររឿង អំពីការខាបយកសាំយូអែលពីស្លាប់មកវិញ ដោយស្ត្រីខាបខ្មោចនៅឯអេន-ដោរ តាមសំណូមពររបស់ស្តេចសូល ។ ដំណើររឿងនេះពុំអាចចាត់ទុកថាជាការនិមិត្ត មកពីព្រះបានឡើយ ពីព្រោះស្រីខាបខ្មោច ឬអ្នកហៅ ខ្មោចណាម្នាក់ ក៏ពុំអាចមានឥទ្ធិពលឲ្យព្យាការីលេចមកតាមសំណូមពររបស់គេបានឡើយ (១ សាំយូ. ២៨:២០; ៣១:១–៤) ។

*គម្ពីរសាំយូអែលទី ១ និងទី ២៖* នៅក្នុងព្រះគម្ពីរប៊ីបខ្លះ គម្ពីរសាំយូអែលទី ១ និងទី ២ គឺជាគម្ពីរតែមួយទេ ។ រីឯនៅក្នុងព្រះគម្ពីរផ្សេងទៀត គឺជាគម្ពីរពីរក្បាល ។ គម្ពីរនេះរៀបរាប់អំពីរយៈកាលប្រមាណ ១៣០ ឆ្នាំ គឺពីកំណើតរបស់សាំយូអែល រហូតដល់ពេល មុនស្តេចដាវីឌសុគតបន្តិច ។

*គម្ពីរសាំយូអែលទី ១៖* ជំពូកទី ១–៤ រៀបរាប់ថា ព្រះអម្ចាស់ទ្រង់បានដាក់បណ្តាសា ហើយធ្វើទោសដល់គ្រួសាររបស់អេលី ហើយហៅសាំយូអែល ឲ្យធ្វើជាសង្ឃជាន់ខ្ពស់ ហើយឲ្យធ្វើជាចៅហ្វាយ ។ ជំពូកទី ៤–៦ ប្រាប់អំពីហឹបនៃសេចក្តីសញ្ញាដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃនៃពួកសាសន៍ភីលីស្ទីន ។ ជំពូកទី ៧–៨ កត់នូវពាក្យបំរាមរបស់សាំយូអែល អំពីការមានព្រះក្លែងក្លាយ និងស្តេចអាក្រក់ ។ ជំពូកទី ៩–១៥ រៀបរាប់អំពីការអភិសេកសូល ឲ្យធ្វើជាស្តេច និងអំពីរាជ្យទ្រង់ ។ ជំពូកទី ១៦–៣១ ប្រាប់អំពីប្រវត្តិដាវីឌ និងអំពីរបៀបដែលទ្រង់បានអំណាចមក — សាំយូអែលបានចាក់ប្រេងលាបដាវីឌជាអ្នកដែលបានប្រហារកូលីយ៉ាត ។ សូលក៏ស្អប់ដាវីឌ ប៉ុន្តែដាវីឌ មិនព្រមសម្លាប់សូលឡើយ ទោះបីលោកមានឱកាសនឹងសម្លាប់ក្តី ។

*គម្ពីរសាំយូអែលទី ២៖* គម្ពីរនេះមាននូវសេចក្តីរាយការណ៍អំពីរាជ្យរបស់ដាវីឌ ជាស្តេចស្រុកយូដា ហើយចុងក្រោយបង្អស់ជាស្តេចស្រុកអ៊ីស្រាអែលទាំងមូល ។ ជំពូកទី ១–៤ បង្ហាញនូវការប្រយុទ្ធយ៉ាងយូរអង្វែងរវាងពួកអ្នកដើរតាមដាវីឌ នឹងពួកអ្នក ដើរតាមសូល បន្ទាប់ពីដាវីឌត្រូវបានអភិសេកឲ្យធ្វើជាស្តេច ដោយពួកស្រុកយូដា ។ ជំពូកទី ៥–១០ បង្ហាញថា ដាវីឌបានក្លាយ ទៅជាមានអំណាចជាខ្លាំង លើដែនដីជាច្រើន ។ ជំពូកទី ១១–២១ បង្ហាញនូវការចុះអន់ថយនៃអំណាចខាងវិញ្ញាណរបស់ដាវីឌ មកពីអំពើបាបទាំងឡាយរបស់ទ្រង់ និងមកពីការបះបោររវាងវង្សាទ្រង់ ។ ជំពូកទី ២២–២៤ អធិប្បាយប្រាប់អំពីការព្យាយាម ដែល ដាវីឌខំប្រឹងប្រែងដើម្បីឲ្យបានស្រុះស្រួលនឹងព្រះអម្ចាស់ ។

## សាំយូអែល, សាសន៍លេមិន

ជាព្យាការីសាសន៍លេមិនម្នាក់ នៅក្នុងព្រះគម្ពីរមរមន ដែលព្រះអម្ចាស់ទ្រង់បានចាត់ឲ្យទៅបង្រៀន ហើយព្រមានពួកសាសន៍នីហ្វៃ មុនកំណើតព្រះអម្ចាស់បន្តិច ។ សាំយូអែលបានព្យាករអំពីទីសំគាល់ទាំងឡាយ ដែលទាក់ទងទៅនឹងកំណើត និងការសុគតនៃ ព្រះយេស៊ូវគ្រីស្ទ និងអំពីសេចក្តីបំផ្លិចបំផ្លាញដល់ពួកសាសន៍នីហ្វៃ (ហេលេ. ១៣–១៦) ។

## សាំសុន

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជា « ចៅហ្វាយ » ទី ១២ នៃពួកអ៊ីស្រាអែល ។ គេបានស្គាល់លោកមកពីកម្លាំងដ៏មាំមួន ដែលលោកមាន ប៉ុន្តែលោកពុំមានប្រាជ្ញា ខាងសីលធម៌ និងខាងសកម្មភាពឡើយ (ពួកចៅ. ១៣:២៤–១៦:៣១) ។

**ស្ថានឃុំព្រលឹង** *សូមមើល* ស្ថាននរក

**ស្ថាននរក** *សូមមើលផង* ពួកកូនអន្តរធាន, សេចក្តីដាប់ទោស; សេចក្តីស្លាប់ខាងវិញ្ញាណ; អារក្ស

វិវរណៈនៅថ្ងៃចុងក្រោយស្តីអំពីស្ថាននរកយ៉ាងតិចពីរបែប ។ ទី ១ គឺជាទីបណ្តោះអាសន្ននៅស្ថានវិញ្ញាណ សំរាប់ពួកអ្នកដែលមិន បានគោរពតាម កាលរស់នៅលើផែនដី ។ បើស្តីតាមបែបនេះ ស្ថាននរកមានទីបញ្ចប់ ។ ពួកវិញ្ញាណនៅទីនោះនឹងបានរៀនពី ដំណឹងល្អ ហើយជួនកាល បន្ទាប់ពីការប្រែចិត្តរបស់គេ នោះគេនឹងបានរស់ឡើងវិញ ទៅរកលំដាប់នៃសិរីល្អ ដែលគេសមនឹងបាន ។ អស់អ្នកណា ដែលមិនប្រែចិត្ត ប៉ុន្តែមិនមែនជាពួកកូនអន្តរធានទេ នោះនឹងនៅក្នុងស្ថាននរករហូតក្នុងសហស្សវត្សរ៍ ។ បន្ទាប់ពីការ រងទុក្ខអស់រាប់ពាន់ឆ្នាំ នោះពួកគេនឹងបានរស់ឡើងវិញ ទៅរកសិរីល្អខាងទេវស្ថាល (គ. និង ស. ៧៦:៨១–៨៦; ៨៨:១០០–១០១) ។

ទី ២ គឺជាកន្លែងដ៏អចិន្ត្រៃយដល់អស់អ្នកណា ដែលមិនត្រូវបានប្រោសលោះ ដោយសារដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ បើស្តីតាមបែបនេះ ស្ថាននរក គឺជាទីអចិន្ត្រៃយ ។ គឺជាទីសំរាប់ពួកអ្នកដែលឃើញថានៅជាប់ក្នុង « *ភាពស្មោកគ្រោកដដែល* » (គ. និង ស. ៨៨:៣៥, ១០២) ។ ទីនេះ គឺជាកន្លែងដែលអារក្សសាតាំង ពួកទេវតាវា និងពួកកូនអន្តរធាន — គឺអស់អ្នកណាដែលមិនទទួលស្គាល់ព្រះរាជបុត្រា បន្ទាប់ពីព្រះវរបិតាបានបើកសម្តែងទ្រង់ឲ្យស្គាល់ — នឹងអាស្រ័យនៅអស់កល្បជានិច្ច (គ. និង ស. ៧៦:៤៣–៤៦) ។

ជួនកាល គម្ពីរស្តីអំពីស្ថាននរកថា ជាសេចក្តីងងឹតខាងក្រៅ ។

ព្រលឹងនៃស្តេចដាវីឌនឹងមិនត្រូវទុកឲ្យនៅក្នុងស្ថានឃុំព្រលឹងឡើយ, **ទំនុក.** ១៦:១០ (ទំនុក. ៨៦:១៣) ។ ចូរធ្លាក់ទៅនរក នៅក្នុងភ្លើង ដែលពន្លត់មិនបាន, **ម៉ាកុស** ៩:៤៣ (ម៉ូសាយ ២:៣៨) ។ អ្នកមាននៅក្នុងស្ថានឃុំព្រលឹងបានងើបភ្នែកឡើង ដោយរងទុក្ខ, **លូកា** ១៦:២២–២៣ (គ. និង ស. ១០៤:១៨) ។ សេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ប្រគល់មនុស្សស្លាប់មកវិញ, **វិវ.** ២០:១៣ ។ មានកន្លែងមួយរៀបចំទុក មែនហើយ គឺជាស្ថាននរកដ៏គួរឲ្យស្ញប់ស្ញែង, **១ នីហ្វៃ** ១៥:៣៥ ។ ចំណង់របស់សាច់ឈាមបណ្តាលឲ្យ វិញ្ញាណអារក្សមានអំណាច ដើម្បីនាំយើងចុះទៅស្ថាននរក, **២ នីហ្វៃ** ២:២៩ ។ ព្រះគ្រីស្ទ

បានរៀបចំផ្លូវសំរាប់ការរំដោះយើងចេញពី សេចក្ដីស្លាប់ និងស្ថាននរក, **២ នីហ្វៃ** ៩:១០–១២ ។ អស់អ្នកណាដែលនៅតែស្មោកគ្រោកដដែល នឹងទៅឯទីរងទុក្ខវេទនាដ៏អស់ កល្បជានិច្ច, **២ នីហ្វៃ** ៩:១៦ ។ អារក្ស បានបញ្ឆោតព្រលឹងគេ ហើយដឹកនាំគេដោយប្រុងប្រយ័ត្នចុះទៅស្ថាននរក, **២ នីហ្វៃ** ២៨:២១ ។ ព្រះយេស៊ូវទ្រង់បានប្រោសលោះព្រលឹង ខ្ញុំចេញពីស្ថាននរក, **២ នីហ្វៃ** ៣៣:៦ ។ ចូររំដោះ ខ្លួនពីការឈឺចាប់នៃស្ថាននរកចុះ, **យ៉ាកុប** ៣:១១ ។ នឹងត្រូវអារក្ស ចាប់ឃុំឃាំង ហើយដឹកនាំតាមអំពើចិត្តរបស់វាទៅកាន់សេចក្ដី បំផ្លិចបំផ្លាញ គឺជាច្រវាក់នៃស្ថាននរក, **អាលម៉ា** ១២:១១ ។ ពួកទុច្ចរិត នឹងត្រូវបោះចោលទៅភាពងងឹតខាងក្រៅ រហូតដល់គ្រារស់ឡើងវិញ របស់គេ, **អាលម៉ា** ៤០:១៣–១៤ ។ ពួកស្មោកគ្រោកនៅជាមួយព្រះ នឹងវេទនាដាងនៅស្ថាននរក, **មរមន** ៩:៤ ។ ទោសដែលចេញពីព្រះ ហស្តរបស់យើងទៅ គឺជាទោស ដ៏មិនចេះចប់មិនចេះហើយ, **គ. និង ស.** ១៩:១០–១២ ។ ស្ថាននរក គឺជាកន្លែងមួយដែលបានរៀបចំទុក សំរាប់អារក្ស និងពួកទេវតា របស់វា, **គ. និង ស.** ២៩:៣៧–៣៨ ។ អស់អ្នកណាដែលទទួលស្គាល់ព្រះ នោះនឹងបានរួចពីសេចក្ដីស្លាប់ និង ពីច្រវាក់ ទាំងឡាយនៃស្ថាននរក, **គ. និង ស.** ១៣៨:២៣ ។

**ស្ថានបរមសុខ** *សូមមើលផង* ស្ថានសួគ៌

ជាផ្នែកនៃស្ថានឃុំព្រលឹង ដែលពួកវិញ្ញាណសុចរិត ដែលបាន លាចាកពីជីវិតនេះទៅអាស្រ័យនៅ រង់ចាំដំណើររស់ឡើងវិញ នៃរូបកាយ ។ គឺជាស្ថានភាពនៃសុភមង្គល និងសេចក្ដីសុខសាន្ត ។

*ស្ថានបរមសុខ* ក៏បានប្រើនៅក្នុងព្រះគម្ពីរ ដើម្បីឲ្យន័យដល់ពិភពនៃ ពួកវិញ្ញាណ (លូកា ២៣:៤៣), ជានគរសេឡេស្ទាល (២ កូរិន. ១២:៤), និងជាស្ថានភាពដ៏រុងរឿងនៃគ្រាសហស្សវត្សរ៍របស់ផែនដី (ម. នៃ ស. ១:១០) ។

ឯអ្នកណាដែលឈ្នះ នោះអញនឹងឲ្យបរិភោគផ្លែរបស់ដើមជីវិត ដែល នៅស្ថានបរមសុខរបស់ព្រះ, **វិវរ.** ២:៧ ។ ស្ថានបរមសុខនៃព្រះ ក៏ត្រូវ ប្រគល់វិញ្ញាណនៃពួកសុចរិត, **២ នីហ្វៃ** ៩:១៣ ។ វិញ្ញាណនៃមនុស្ស សុចរិតនឹងបានទទួលស្ថានភាពនៃសុភមង្គល ដែលហៅថា ស្ថាន បរមសុខ, **អាលម៉ា** ៤០:១១–១២ ។ ពួកសិស្សនៃព្រះយេស៊ូវទាំងអស់ បានទៅឯស្ថានបរមសុខនៃព្រះ លើកលែងតែពួកបីនាក់, **៤ នីហ្វៃ** ១:១៤ ។ មិនយូរប៉ុន្មានទេ ខ្ញុំនឹងទៅសំរាកនៅឯស្ថានបរមសុខនៃព្រះ, **ម៉ូរ៉ូណៃ** ១០:៣៤ ។ ព្រះគ្រីស្ទទ្រង់បានធ្វើការងារបំរើ ដល់ពួកវិញ្ញាណ សុចរិត នៅឯស្ថានបរមសុខ, **គ. និង ស.** ១៣៨ ។

**ស្ថានវិញ្ញាណ** *សូមមើល* ជីវិតមុនផែនដី, ស្ថាននរក; ស្ថានបរមសុខ

**ស្ថានសួគ៌** *សូមមើលផង* សិរីល្អខាងសេឡេស្ទាល; នគរព្រះ ឬនគរស្ថានសួគ៌; ស្ថានបរមសុខ

ពាក្យថា *ស្ថានសួគ៌* មានន័យពីរយ៉ាងនៅក្នុងបទគម្ពីរ ។ ទី ១ គឺជាកន្លែង ដែលព្រះទ្រង់គង់នៅ ហើយជាទីលំនៅនៃពួកបរិសុទ្ធ នៅអនាគត (លោកុ. ២៨:១២; ទំនុក. ១១:៤; ម៉ាថាយ ៦:៩) ។ ទី ២ គឺជាលំហនៅជុំវិញ ផែនដី (លោកុ. ១:១, ១៧; និក្ខ. ២៤:១០) ។ ស្ថានសួគ៌ គឺច្បាស់ជា មិនមែនជាស្ថានបរមសុខទេ គឺជាកន្លែងបណ្ដោះអាសន្ន សំរាប់វិញ្ញាណ នៃពួកស្មោះត្រង់ ដែលបានរស់នៅ ហើយស្លាប់នៅលើផែនដីនេះ ។ ព្រះយេស៊ូវទ្រង់បានយាងទៅឯ*ស្ថានបរមសុខ*បន្ទាប់ពីទ្រង់បានសុគតនៅ លើឈើឆ្កាង ប៉ុន្តែដល់ថ្ងៃ ទីបី នោះទ្រង់បានប្រាប់នាងម៉ារាថា ទ្រង់មិន ទាន់បានយាងទៅឯព្រះវរបិតានៅឡើយទេ (លូកា ២៣:៣៩–៤៤; យ៉ូហាន ២០:១៧; គ. និង ស. ១៣៨:១១–៣៧) ។

ទូលបង្គំពិចារណាមើលផ្ទៃមេឃ ជាការដែលព្រះហស្តទ្រង់បានធ្វើ, **ទំនុក.** ៨:៣ ។ ផ្ទៃមេឃបានកើតមកដោយសារព្រះបន្ទូល ព្រះអម្ចាស់, **ទំនុក.** ៣៣:៦ ។ ឱលូស៊ីហ្វើរអើយ ឯងបានធ្លាក់ចុះមកពីលើមេឃហើយ ! **អេសាយ** ១៤:១២ (២ នីហ្វៃ ២៤:១២) ។ ផ្ទៃមេឃនឹង ត្រូវមូរឡើង ដូចជារមូរសៀវភៅ, **អេសាយ** ៣៤:៤ ។ យើងនឹងបង្កើតផ្ទៃមេឃថ្មី ហើយនិងផែនដីថ្មី, **អេសាយ** ៦៥:១៧ ។ ព្រះទ្រង់នឹងបើកទ្វារ ស្ថានសួគ៌, **ម៉ាឡាគី** ៣:១០ ។ ឱព្រះវរបិតានៃយើងខ្ញុំ ដែល គង់នៅស្ថានសួគ៌អើយ សូមឲ្យព្រះនាមទ្រង់បាន បរិសុទ្ធ, **ម៉ាថាយ** ៦:៩ (៣ នីហ្វៃ ១៣:៩) ។ ប៉ុលបានត្រូវលើកឡើងទៅស្ថានសួគ៌ នៅជាន់ទីបី, **២ កូរិន.** ១២:២ ។ នៅស្ថានសួគ៌ បានស្ងាត់ច្រៀប, **វិវរ.** ៨:១ (គ. និង ស. ៨៨:៩៥–៩៨) ។ បើពួកគេរក្សាការស្មោះត្រង់ ដរាប ដល់ចុងបំផុត នោះគេនឹងត្រូវបាន ទទួលឲ្យចូលទៅស្ថានសួគ៌, **ម៉ូសាយ** ២:៤១ ។ អ្នករាល់គ្នាអាចបានធ្វើជាកូនចៅនៃព្រះវរបិតា ដែល គង់នៅស្ថានសួគ៌, ៣ នីហ្វៃ ១២:៤៥ ។ យើងនឹងយាងមកលើពពក នៅលើមេឃ, **គ. និង ស.** ៤៥:១៦ ។ លោកអេលីយ៉ាត្រូវបានយក ទៅស្ថានសួគ៌ ដោយមិន បានភ្លក់សេចក្ដីស្លាប់ឡើយ, **គ. និង ស.** ១១០:១៣ ។ សិទ្ធិទាំងឡាយនៃបព្វជិតភាព គឺជាប់ជាមួយនឹងអំណាច ទាំងឡាយនៃស្ថានសួគ៌, **គ. និង ស.** ១២១:៣៦ ។ នៅស្ថានសួគ៌ មានគួពីរយ៉ាង, **គ. និង ស.** ១២៩:១ ។ ក្រុងស៊ីយ៉ូនត្រូវបានយក ទៅលើស្ថានសួគ៌, **ម៉ូសេ** ៧:២៣ ។

**ស្ទេផាន**

ស្ទេផានជាទុក្ករបុគ្គលម្នាក់ ដើម្បីព្រះអង្គសង្គ្រោះ និងសាសនាចក្រ របស់ទ្រង់ នៅសម័យព្រះគម្ពីរសញ្ញាថ្មី ។ ការផ្សាយរបស់លោក បាន ធ្វើជាស្រមោល ហើយប្រហែលជាបានផ្ដល់ឥទ្ធិពលដល់កិច្ចការដ៏ធំរបស់ ប៉ុល ដែលមានវត្តមានក្នុងកាលស្ទេផានបានដោះសារខ្លួន នៅចំពោះក្រុម ជំនុំសានហេទ្រិន (កិច្ចការ ៨:១; ២២:២០) ។

ស្ទេផានជាពួកមនុស្ស ៧ នាក់ ដែលបានតែងតាំងឲ្យជួយពួកសាវក ១២ នាក់, **កិច្ចការ** ៦:១–៨ ។ ស្ទេផានបានធ្វើការអស្ចារ្យ និង ទីសំគាល់យ៉ាងធំ, **កិច្ចការ** ៦:៨ ។ ស្ទេផានបានជជែកនឹងពួកសាសន៍ យូដា, **កិច្ចការ** ៦:៩–១០ ។ ក្ដីទោសក៏មានឡើងទាស់នឹង លោក ហើយលោកក៏ត្រូវគេកាត់ក្ដី នៅចំពោះក្រុមជំនុំសានហេទ្រិន, **កិច្ចការ** ៦:១១–១៥ ។ ស្ទេផានបានរាយការដោះស្រាយខ្លួន, **កិច្ចការ** ៧:២–៥៣ ។ ដោយបានពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ នោះ

លោកបានឃើញព្រះវរបិតា និងព្រះរាជបុត្រា នៅក្នុងការ និមិត្ត, **កិច្ចការ** ៧:៥៥–៥៦ ។ ស្ទេផានត្រូវគេធ្វើទុក្ករកម្ម មកពីទីបន្ទាល់របស់លោក, **កិច្ចការ** ៧:៥៤–៦០ ។

**ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ** *សូមមើលផង* ការនិមិត្តទីមួយ; ការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.); ការសាងឡើងវិញនៃដំណឹងល្អ, គោលលទ្ធិ និងសេចក្ដីសញ្ញា; ព្រះគម្ពីរមរមន; មុក្ដាដ៏មានតម្លៃមហិមា

ជាព្យាការីម្នាក់ ដែលបានជ្រើសរើស ឲ្យសាងសាសនាចក្រពិត នៃព្រះយេស៊ូវគ្រីស្ទ នៅលើផែនដីវិញ ។ យ៉ូសែប ស្ម៊ីធ បានកើត នៅរដ្ឋវើរម៉ុន្ត សហរដ្ឋអាមេរិក ហើយបានរស់នៅពីឆ្នាំ ១៨០៥ ទោឆ្នាំ ១៨៤៤ ។

នៅឆ្នាំ ១៨២០ ព្រះដ៏ជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ បានលេចមកឯយ៉ូសែប ហើយលោកបានដឹងថា គ្មានសាសនាណាមួយ នៅលើផែនដីជាសាសនាចក្រពិតឡើយ (យ.ស. — ប្រវត្តិ ១:១–២០) ។ បន្ទាប់មក ម៉ូរ៉ូណៃ ជាទេវតា ក៏បានមករកលោក ហើយ បានបើកសម្ដែងប្រាប់កន្លែងលាក់ផ្ទាំងមាសទាំងឡាយ ដែលមានបញ្ជីប្រវត្តិនៃប្រជាជនពីសម័យបុរាណ នៅលើទ្វីបអាមេរិក (យ.ស. — ប្រវត្តិ ១:២៩–៥៤) ។

យ៉ូសែបបានបកប្រែផ្ទាំងមាសទាំងឡាយនោះ ហើយបានបោះពុម្ពចេញជា ព្រះគម្ពីរមរមន នៅឆ្នាំ ១៨៣០ (យ.ស. — ប្រវត្តិ ១:៦៦, ៦៧; ៧៥) ។ នៅឆ្នាំ ១៨២៩ លោកបានទទួលអំណាចនៃបព្វជិតភាពពីយ៉ូហាន-បាទីស្ទ និងពីពេត្រុស យ៉ាកុប និងយ៉ូហាន (គ. និង ស. ១៣; ២៧:១២; ១២៨:២០; យ.ស. — ប្រវត្តិ ១:៦៨–៧០) ។

ដូចដែលបានដឹកនាំដោយព្រះ នៅថ្ងៃទី ៦ មេសា ១៨៣០ យ៉ូសែប និងពួកអ្នកឯទៀតក៏បានរៀបចំសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ ដែលបានសាងឡើងវិញ (គ. និង ស. ២០:១–៤) ។ នៅក្រោមការដឹកនាំរបស់យ៉ូសែប សាសនាចក្របានលូតលាស់ នៅប្រទេស កាណាដា ប្រទេសអង់គ្លេស និងនៅភូមិភាគខាងកើតនៃសហរដ្ឋ ជាពិសេស គឺនៅរដ្ឋអូហៃអូ រដ្ឋមិសសួរី និងរដ្ឋអិលលីណោយ ។ មានសេចក្ដីបៀតបៀនដ៏ធ្ងន់ជាប់តាមយ៉ូសែប និងពួកបរិសុទ្ធ មិនថាជាពួកគេនៅទីណាក្ដី ។ នៅថ្ងៃទី ២៧ មិថុនា ១៨៤៤ យ៉ូសែប និងហៃរុមជាបងប្រុសរបស់លោក ត្រូវគេធ្វើទុក្ករកម្ម នៅទីក្រុងកាតធេចរដ្ឋអិលលីណោយ សហរដ្ឋអាមេរិក ។

យ៉ូសែប កូនប្រុសរបស់យ៉ាកុប ក៏បានព្យាករអំពីយ៉ូសែប ស្ម៊ីធ, **២ នីហ្វៃ** ៣:៦–១៥ ។ ពីព្រោះមកពីទ្រង់ជ្រាបនូវគ្រោះដែលនឹងមានមក នោះព្រះអម្ចាស់ទ្រង់បានហៅយ៉ូសែប ស្ម៊ីធ ជាអ្នកបំរើរបស់ទ្រង់, **គ. និង ស.** ១:១៧ (គ. និង ស. ១៩:១៣) ។ យ៉ូសែប ស្ម៊ីធត្រូវ បានតែងតាំងជាសាវកនៃព្រះយេស៊ូវគ្រីស្ទ ហើយជាអែលឌើរទីមួយនៃសាសនាចក្រនេះ, **គ. និង ស.** ២០:២ ។ យ៉ូសែបត្រូវបានតែង តាំងឲ្យធ្វើសាវក ដោយពេត្រុស យ៉ាកុប និងយ៉ូហាន, **គ. និង ស.** ២៧:១២ ។ យ៉ូសែប និងស៊ិឌនី រិកដុនបានធ្វើបន្ទាល់ថា ពួកគេបាន ឃើញព្រះរាជបុត្រាបង្កើតតែមួយ នៃព្រះវរបិតា, **គ. និង ស.** ៧៦:២៣ ។ យ៉ូសែប ស្ម៊ីធជាមួយអូលីវើរ ខៅឌើរី បានឃើញព្រះអម្ចាស់ នៅក្នុងការនិមិត្ត, **គ. និង ស.** ១១០:១–៤ ។ ព្រះអម្ចាស់ទ្រង់បានហៅយ៉ូសែប ឲ្យធ្វើជាអែលឌើរពិនិត្យត្រួតត្រា ជាអ្នកបកប្រែ ជាអ្នក ទទួលវិវរណៈ ជាអ្នកមើលឆុត និងជាព្យាការី, **គ. និង ស.** ១២៤:១២៥ ។ យ៉ូសែប ស្ម៊ីធ បានសំរេចច្រើនជាងគេសំរាប់សេចក្ដី សង្គ្រោះដល់មនុស្សលោក ជាងមនុស្សផ្សេងៗទៀត លើកលែងតែព្រះយេស៊ូវប៉ុណ្ណោះ, **គ. និង ស.** ១៣៥:៣ ។

*ព្រះគម្ពីរដែលព្យាការីយ៉ូសែប ស្ម៊ីធបាននាំចេញមក៖* យ៉ូសែបបានបកប្រែភាគទាំងឡាយនៃផ្ទាំងមាស ដែលទេវតាម៉ូរ៉ូណៃបាន ប្រគល់ដល់លោក រីឯការបកប្រែនេះ ក៏បានបោះពុម្ពនៅឆ្នាំ ១៨៣០ ចេញជា ព្រះគម្ពីរមរមន ។ លោកក៏បានទទួលវិវរណៈជាច្រើន ពីព្រះអម្ចាស់ ដែលរាយនូវគោលលទ្ធិសំខាន់ៗ និងការរៀបចំសាសនាចក្រ ។ វិវរណៈទាំងនេះភាគច្រើន ត្រូវបានប្រមូលទុកដែល ឥឡូវនេះស្គាល់ថា គោលលទ្ធិ និងសេចក្ដីសញ្ញា ។ លោកក៏បាននាំចេញមកនូវ មុក្ដាដ៏មានតម្លៃមហិមា គឺជាការបកប្រែដែលបាន បំផុសគំនិត ចេញពីការសរសេរទាំងឡាយនៃលោកម៉ូសេខ្លះ លោកអ័ប្រាហាំខ្លះ និងពីម៉ាថាយខ្លះ ព្រមទាំងការសង្ខេបចេញពីប្រវត្តិ និងទីបន្ទាល់របស់លោកផ្ទាល់ ព្រមទាំងមាត្រា ១៣ ប្រការ អំពីគោលលទ្ធិ និងជំនឿ ដែលសាសនាចក្រជឿ ។

**ស្ម៊ីធ, យ៉ូសែប ស៊ីញ្ញ័រ** *សូមមើលផង* លូស៊ី ម៉ាក, ស្ម៊ីធ, យ៉ូសែប ជុញ្ញ័រ; ស្ម៊ីធ

ជាឪពុករបស់ព្យាការីយ៉ូសែប ស្ម៊ីធ ។ លោកកើតនៅថ្ងៃទី ១២ កក្កដា ១៧៧១ ។ លោកបានរៀបការយកលូស៊ី ម៉ាក ហើយគេទាំង ពីរមានកូន ៩ នាក់ (យ.ស. — ប្រវត្តិ ១:៤ ។ យ៉ូសែបបានក្លាយទៅជាអ្នកជឿយ៉ាងស្មោះត្រង់ ចំពោះការសាងឡើងវិញ នៅថ្ងៃចុង ក្រោយ ហើយជាអយ្យកោទីមួយក្នុងសាសនាចក្រ ។ លោកបានស្លាប់នៅថ្ងៃទី ១៤ កញ្ញា ១៨៤០ ។

ព្រះទ្រង់បានបើកសម្ដែងការបង្គាប់ទាំងឡាយដល់លោក តាមរយៈយ៉ូសែប ជាកូនប្រុសរបស់លោក, **គ. និង ស.** ៤; ២៣:៥ ។ ចូរឲ្យអ្នកបំរើដ៏ចំណាស់របស់យើង នៅជាមួយគ្រួសាររបស់លោក, **គ. និង ស.** ៩០:២០ ។ យ៉ូសែប ជាអ្នកបំរើដ៏ចំណាស់របស់យើង អង្គុយជាមួយលោកអ័ប្រាហាំ នៅខាងស្ដាំដៃរបស់លោក, **គ. និង ស.** ១២៤:១៩ ។ យ៉ូសែប ស្ម៊ីធ ជុញ្ញ័របានឃើញឪពុករបស់លោក នៅក្នុងការនិមិត្តអំពីនគរសេឡេស្ទាល, **គ. និង ស.** ១៣៧:៥ ។ ទេវតាបានបង្គាប់ឲ្យយ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ប្រាប់ឪពុកលោកអំពីការនិមិត្ត ដែលលោកបានទទួល, **យ.ស. — ប្រវត្តិ** ១:៤៩–៥០ ។

**ស្ម៊ីធ, យ៉ូសែប អែហ្វ**

ជាប្រធានទីប្រាំមួយ នៃសាសនាចក្រ ។ លោក គឺជាកូនប្រុសតែមួយរបស់ហៃរុម និងម៉ារា ហ្វៀលឌិង ស្ម៊ីធ ។ លោកកើតនៅថ្ងៃទី ១៣ វិច្ឆិកា ១៨៣៨ ហើយស្លាប់នៅថ្ងៃទី ១៩ វិច្ឆិកា ១៩១៨ ។

យ៉ូសែប អែហ្វ ស្ម៊ីធបានទទួលការនិមិត្តមួយ អំពីសេចក្ដីប្រោសលោះដល់មនុស្សស្លាប់, **គ. និង ស.** ១៣៨ ។

**ស្មិធ, លូស៊ី ម៉ាក** *សូមមើលផង* យ៉ូសែប ស៊ីញ៉ែរ, ស្មិធ, យ៉ូសែប ជុញ៉ែរ; ស្មិធ

ជាម្ដាយរបស់ព្យាការីយ៉ូសែប ស្មិធ ហើយជាប្រពន្ធរបស់យ៉ូសែប ស្មិធ ស៊ីញ៉ែរ (យ.ស. — ប្រវត្តិ ១:៤, ៧, ២០) ។ នាងកើតនៅថ្ងៃទី ៨ កក្កដា ១៧៧៦ ហើយស្លាប់ នៅថ្ងៃទី ៥ ឧសភា ១៨៥៦ ។

យ៉ូសែបបានឃើញម្ដាយរបស់លោក នៅក្នុងការនិមិត្តអំពីនគរសេឡេស្ទាល, **គ. និង ស.** ១៣៧:៥ ។

**ស្មិធ, សាំយូអែល អេច** *សូមមើលផង* យ៉ូសែប ជុញ៉ែរ ស្មិធ

ជាប្អូនប្រុសរបស់ព្យាការីយ៉ូសែប ស្មិធ (យ.ស. — ប្រវត្តិ ១:៤) ។ សាំយូអែលកើតនៅឆ្នាំ ១៨០៨ ហើយស្លាប់នៅឆ្នាំ ១៨៤៤ ។ លោកគឺជាសាក្សីម្នាក់ នៅក្នុងក្រុមពួកសាក្សីប្រាំបីនាក់ អំពីព្រះគម្ពីរមរមន ហើយបានធ្វើជាអ្នកផ្សាយសាសនាមុនដំបូង សំរាប់សាសនាចក្រដែលសាងឡើងវិញ (គ. និង ស. ២៣:៤; ៥២:៣០; ៦១:៣៣–៣៥; ៦៦:៧–៨; ៧៥:១៣) ។

**ស្មិធ, ហៃរុម** *សូមមើលផង* យ៉ូសែប ជុញ៉ែរ, ស្មិធ

ជាបងប្រុស ហើយជាសហការីដ៏ស្មោះត្រង់ម្នាក់របស់យ៉ូសែប ស្មិធ ។ ហៃរុមកើតនៅថ្ងៃទី ៩ កុម្ភៈ ១៨០០ ។ លោកបានបំរើជាអ្នក ជំនួយដល់យ៉ូសែប នៅក្នុងគណៈប្រធាននៃសាសនាចក្រ ហើយក៏ធ្វើជាអយ្យកោទីពីរនៃសាសនាចក្រ ។ នៅថ្ងៃទី ២៧ មិថុនា ១៨៤៤ លោកបានក្លាយទៅជាទុក្ករបុគ្គលជាមួយនឹងយ៉ូសែប នៅក្នុងគុកកាតធេច ។

ព្រះទ្រង់បានបើកសម្ដែងការបង្គាប់ទាំងឡាយដល់ហៃរុម តាមរយៈយ៉ូសែប ជាប្អូនប្រុសរបស់លោក, **គ. និង ស.** ១១; ២៣:៣ ។ មាន ពរហើយ ហៃរុម ស្មិធ ជាអ្នកបំរើរបស់យើង មកពីសេចក្ដីស្មោះនៃចិត្តរបស់គាត់, **គ. និង ស.** ១២៤:១៥ ។ ហៃរុមត្រូវបានបញ្ជាឲ្យ ទទួលតំណែងជាអយ្យកោក្នុងសាសនាចក្រ, **គ. និង ស.** ១២៤:៩១–៩៦, ១២៤ ។ យ៉ូសែប និងហៃរុម ត្រូវគេធ្វើទុក្ករកម្ម នៅក្នុងគុក កាតធេច, **គ. និង ស.** ១៣៥ ។ ហៃរុម និងពួកវិញ្ញាណជំរើសឯទៀត ត្រូវបានរក្សាទុកឲ្យមក នៅពេលពេញកំណត់, **គ. និង ស.** ១៣៨:៥៣ ។

**ស្មិធ, អិមម៉ា ហេល** *សូមមើលផង* យ៉ូសែប ជុញ៉ែរ, ស្មិធ

ជាប្រពន្ធរបស់ព្យាការីយ៉ូសែប ស្មិធ ។ ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យនាងអិមម៉ាជ្រើសរើសទំនុកសរសើរដំកើងទាំងឡាយសំរាប់ សាសនាចក្រ ។ នាងក៏បានបំរើជាប្រធានទីមួយនៃសមាគមស្ត្រី ។

វិវរណៈត្រូវបានប្រទានដល់នាងអិមម៉ា ស្មិធ អំពីព្រះហឫទ័យនៃព្រះអម្ចាស់, **គ. និង ស.** ២៥ ។ ព្រះអម្ចាស់ទ្រង់បានទូន្មានដល់អិមម៉ា ស្មិធ អំពីអាពាហ៍ពិពាហ៍, **គ. និង ស.** ១៣២:៥១–៥៦ ។

**ស្មៀន, អាចារ្យ**

ព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីប្រើប្រាស់ពាក្យនេះខុសពីគ្នាបន្តិចៈ (១) នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ភារៈកិច្ចសំខាន់របស់ស្មៀន គឺកត់ចម្លងព្រះគម្ពីរ (យេរេ. ៨:៨) ។ (២) គេច្រើនពោលដល់ពួកអាចារ្យនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយជួនកាល គេហៅថាជា ពួកអ្នកប្រាជ្ញច្បាប់ ។ ពួកគេបានចែងច្បាប់ឡើងតាមរបៀប ហើយអនុវត្តច្បាប់តាមកាលៈទេសៈនៃសម័យគេ (ម៉ាថាយ ១៣:៥២; ម៉ាកុស ២:១៦–១៧; ១១:១៧–១៨; លូកា ១១:៤៤–៥៣; ២០:៤៦–៤៧) ។

**ស្មោកគ្រោក, សេចក្ដីស្មោកគ្រោក** *សូមមើលផង* ទុច្ចរិត, បាប; មនុស្សទមិលល្មើស; ស្អាត និងឥតស្អាត; សេចក្ដីឥតសុចរិត; អំពើទុច្ចរិត, ឥតសុចរិត

ជាភាពឥតស្អាតខាងវិញ្ញាណ ពីព្រោះតែការមិនគោរពដល់ព្រះដោយចេតនា ។

ព្រះអម្ចាស់ទ្រង់នឹងលាងជំរះគ្រឿងលាមករបស់ពួកកូនស្រីៗក្រុងស៊ីយ៉ូនចេញ, **អេសាយ** ៤:៤ (២ នីហ្វៃ ១៤:៤) ។ នគរនៃព្រះមិនស្មោកគ្រោកទេ, **១ នីហ្វៃ** ១៥:៣៤ (អាលម៉ា ៧:២១) ។ ពួកអ្នកដែលស្មោកគ្រោក ក៏នៅតែស្មោកគ្រោកដដែល, **២ នីហ្វៃ** ៩:១៦ (មរមន ៩:១៤) ។ តើអ្នករាល់គ្នានឹងចាប់អារម្មណ៍យ៉ាងណាដែរ បើអ្នកឈរនៅខាងមុខវេទិកានៃព្រះ ដោយមានសំលៀកបំពាក់ ប្រឡាក់ដោយសេចក្ដីស្មោកគ្រោក ? **អាលម៉ា** ៥:២២ ។ ពួកគេត្រូវតែជាប់នៅក្នុងភាពស្មោកគ្រោកដដែល, **គ. និង ស.** ៨៨:៣៥ ។ តើដល់ពេលណាខ្ញុំនឹងបានសំរាក ហើយបានសំអាតឲ្យជ្រះពីអំពើស្មោកគ្រោក ? **ម៉ូសេ** ៧:៤៨ ។

**ស្រងែ**

ជាស្មៅ ឬល្អិតពុល ដែលមានរូបរាងដូចជាស្រូវសាលី ។ គេមិនអាចស្គាល់ថា ជាស្រងែ ឬជាស្រូវសាលីបានទេ ដរាបដល់ធំពេញ លេញ (ម៉ាថាយ ១៣:២៤–៣០; គ. និង ស. ៨៦:១–៧) ។

**ស្រីមេម៉ាយ** *សូមមើលផង* សុខុមាលភាព

ស្រីដែលប្ដីបានស្លាប់ទៅ ហើយមិនទាន់រៀបការជាថ្មី ។

កូនកំព្រា និងស្រីមេម៉ាយ គេនឹងមកបរិភោគ, **ចោទិ.** ១៤:២៩ ។ ស្រីមេម៉ាយក្រនេះ បានថ្វាយរបស់ទាំងអស់ ដែលនាងមាន, **ម៉ាកុស** ១២:៤១–៤៤ ។ ចូរទៅសួរពួកកំព្រា និងពួកមេម៉ាយ ក្នុងកាលដែលគេមានសេចក្ដីវេទនា, **យ៉ាកុប** (ព.ស.ថ.) ១:២៧ ។ ព្រះអម្ចាស់ ទ្រង់នឹងធ្វើសាក្សីយ៉ាងរហ័ស ទាស់នឹងពួកដែលសង្កត់សង្កិនស្រីមេម៉ាយ, ៣ នីហ្វៃ ២៤:៥ (សាការី ៧:១០) ។ ពួកស្រីមេម៉ាយ និងកូន កំព្រានឹងត្រូវបានផ្គត់ផ្គង់, **គ. និង ស.** ៨៣:៦ (គ. និង ស. ១៣៦:៨) ។

**ស្ត្រី, ពួកស្ត្រី** *សូមមើលផង* មនុស្ស, មនុស្សលោក

ជាស្ត្រីដែលមានវ័យចាស់ ជាបុត្រីនៃព្រះ ។ ពាក្យថា*ស្ត្រី* ជួនកាលប្រើនៅក្នុងព្រះគម្ពីរ ទុកជានាមខាងការគោរព (យ៉ូហាន ១៩:២៦; អាលម៉ា ១៩:១០) ។

ព្រះទ្រង់បានបង្កើតមនុស្សជាប្រុស ជាស្រី, **លោកុ.** ១:២៧ (ម៉ូសេ ២:២៧; ៦:៩; អ័ប្រា. ៤:២៧) ។ ស្ត្រីគ្រប់លក្ខណ៍ មានតម្លៃជាជាងត្បូងទទឹមទៅទៀត, **សុភា.** ៣១:១០–៣១ ។ ស្ត្រីជាសិរីល្អដល់បុរស, **១ កូរិន.** ១១:៧ ។ នៅក្នុងព្រះអម្ចាស់ នោះបុរសមិនមែនជាឥតពឹងអាស្រ័យដល់ស្ត្រីឡើយ ហើយស្ត្រីក៏មិនមែនជាឥតពឹងអាស្រ័យដល់បុរសដែរ, **១ កូរិន.** ១១:១១ ។ ពួកស្ត្រីៗគួរតែងខ្លួនតាមបែបគួរសម, **១ ធីម៉ូ.** ២:៩–១០ ។ យើងជាព្រះអម្ចាស់ដ៏ជាព្រះសព្វព្រះហឫទ័យនឹងព្រហ្មចារីភាពនៃស្ត្រី, **យ៉ាកុប** ២:២៨ ។ បាបរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ ហើយអ្នកជាស្ត្រីរើសតាំង, **គ. និង ស.** ២៥ ។ ពួកស្ត្រីមានសិទ្ធិពឹងពាក់ទៅលើស្វាមីរបស់ខ្លួនសំរាប់ការចិញ្ចឹមជីវិត, **គ. និង ស.** ៨៣:២ ។

**ស្រែ, វាល***សូមមើលផង* ចំការទំពាំងបាយជូរនៃព្រះអម្ចាស់; ពិភពលោក

នៅក្នុងគម្ពីរ គឺជាដីវាលធំសំរាប់ធ្វើស្រែចំការ ឬសំរាប់វាលស្មៅ ។ ស្រែយកមកធ្វើជានិមិត្តរូបអំពីពិភពលោក និងប្រជាជនទាំងឡាយ ដែលអាស្រ័យនៅទីនោះ ។

ស្រែ គឺជាតួលោកិយ, **ម៉ាថាយ** ១៣:៣៨ ។ នគរស្ថានសួគ៌ក៏ប្រៀបដូចជាកំណប់កប់ទុកក្នុងចំការ, **ម៉ាថាយ** ១៣:៤៤ ។ ខ្ញុំបាន ឃើញវាលដ៏ធំ ហើយទូលាយមួយ, **១ នីហ្វៃ** ៨:៩, ២០ ។ ចំការទុំហើយ, **អាលម៉ា** ២៦:៥ ។ ស្រែសសំព្រុះល្មមច្រូតហើយ, **គ. និង ស.** ៤:៤ (គ. និង ស. ៦:៣; ១១:៣; ១២:៣; ១៤:៣; ៣១:៤; ៣៣:៣, ៧) ។ ស្រែ គឺជាពិភពលោក, **គ. និង ស.** ៨៦:១–២ ។ យើងនឹង ប្រៀបធៀបនគរទាំងនេះ ទៅនឹងបុរសម្នាក់ដែលមានស្រែ, **គ. និង ស.** ៨៨:៥១ ។

**ស្លូតបូត, ភាពស្លូតបូត** *សូមមើលផង* ចិត្តសុភាពរាបសា; ចិត្តសង្រេង; បន្ទាបខ្លួន, សេចក្តីអត់ធន់

ជាអ្នកកោតខ្លាចដល់ព្រះ, អ្នកមានចិត្តសុចរិត, អ្នកមានចិត្តសុភាពរាបសា, អ្នកចង់រៀន, និងចេះអត់ធន់ចំពោះការរងទុក្ខ ។ មនុស្សស្លូតបូតព្រមដើរតាមការបង្រៀនទាំងឡាយនៃដំណឹងល្អ ។

ម៉ូសេជាមនុស្សស្លូតភាពណាស់, **ជនគ.** ១២:៣ ។ មនុស្សរាបសាគេនឹងបានផែនដីជាមរតក, **ទំនុក.** ៣៧:១១ (ម៉ាថាយ ៥:៥; ៣ នីហ្វៃ ១២:៥; គ. និង ស. ៨៨:១៧) ។ អស់អ្នករាបសាចូរស្វែងរកព្រះអម្ចាស់ ចូរស្វែងរកសេចក្តីសុចរិតចូរស្វែងរកសេចក្តីសុភាពចុះ, **សេផា.** ២:៣ (១ ធីម៉ូ. ៦:១១) ។ ចូររៀនអំពីខ្ញុំ ត្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព, **ម៉ាថាយ** ១១:២៩ ។ សេចក្តីសុភាព គឺជាផលផ្លែនៃ ព្រះវិញ្ញាណ, **កាឡាទី** ៥:២២–២៣ ។ អ្នកបំរើនៃព្រះអម្ចាស់ត្រូវមានចិត្តសុភាពរាបសា ប្រសប់ក្នុងការបង្រៀន មានចិត្តអត់ធ្មត់ ត្រូវប្រដៅដំរង់មនុស្សដែលទទឹងទទែង, ២ ធីម៉ូ. ២:២៤–២៥ ។ វិញ្ញាណសំឡូត ហើយរម្យទម នោះជាសេចក្តីដែលមានតម្លៃវិសេស នៅចំពោះព្រះ, **១ ពេត្រុស** ៣:៤ ។ ចូរលះបង់ចោលនូវមនុស្សខាងសាច់ឈាម ហើយក្លាយទៅជាមនុស្សស្លូតចុះ, **ម៉ូសាយ** ៣:១៩ (អាលម៉ា ១៣:២៧–២៨) ។ ព្រះទ្រង់បានបញ្ជាហេលេមិនឲ្យបង្រៀនប្រជាជនឲ្យមានចិត្តស្លូតបូត, **អាលម៉ា** ៣៧:៣៣ ។ ព្រះគុណ នៃព្រះអម្ចាស់ គឺមានគ្រប់គ្រាន់សំរាប់អ្នកស្លូតត្រង់, **អេធើរ** ១២:២៦ ។ អ្នករាល់គ្នាមានសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ ដោយសារតែ ភាពស្លូតបូតរបស់អ្នក, **ម៉ូរ៉ូណៃ** ៧:៣៩ ។ ពុំមានអ្នកណាបានទោជាទីគាប់ចំពោះព្រះឡើយ លើកលែងតែជនស្លូតបូត និងសុភាព ប៉ុណ្ណោះ, **ម៉ូរ៉ូណៃ** ៧:៤៤ ។ ការផ្តាច់បាបនាំមកនូវការស្លូតបូត ហើយដោយសារការស្លូតបូត ទើបមានការពិនិត្យពិច័យនៃព្រះវិញ្ញាណ បរិសុទ្ធ, **ម៉ូរ៉ូណៃ** ៨:២៦ ។ ចូរដើរក្នុងភាពស្លូតបូតនៃព្រះវិញ្ញាណរបស់យើង, **គ. និង ស.** ១៩:២៣ ។ ចូរត្រួតត្រាផ្ទះសំបែងរបស់អ្នក ដោយភាពស្លូតបូត, **គ. និង ស.** ៣១:៩ ។ អំណាច និងឥទ្ធិពលនៃបព្វជិតភាព គឺអាចកាន់កាប់បាន ដោយការទន់ភ្លន់ និងការស្លូតបូត, **គ. និង ស.** ១២១:៤១ ។

**ស្អប់, ការស្អប់** *សូមមើលផង* សេចក្តីខ្ញាំង; សេចក្តីស្រឡាញ់; សេចក្តីសងសឹក

ស្អប់ គឺជាការមិនចូលចិត្តដ៏ខ្លាំង ដល់នរណាម្នាក់ ឬដល់អ្វីមួយ ។

យើងជាព្រះ ទំលាក់សេចក្តីទុច្ចរិតរបស់ឪពុកទៅលើកូនចៅរបស់ពួកគេដែលស្អប់យើង, **និក្ខ.** ២០:៥ ។ មានប្រាំមួយមុខដែល ព្រះអម្ចាស់ទ្រង់ស្អប់, **សុភា.** ៦:១៦ ។ មនុស្សល្ងីល្ងើ គេមើលងាយ ម្តាយខ្លួន, **សុភា.** ១៥:២០ ។ ទ្រង់ត្រូវមនុស្សមើលងាយ ហើយបោះបង់ចោល, **អេសាយ** ៥៣:៣ ។ ត្រូវប្រព្រឹត្តល្អនឹងអ្នកណាដែល ស្អប់អ្នករាល់គ្នា, **ម៉ាថាយ** ៥:៤៤ ។ ត្បិតអ្នកនោះនឹង ស្អប់មួយ ហើយស្រឡាញ់មួយ ឬស្មោះត្រង់នឹងមួយ ហើយមើលងាយមួយ, **ម៉ាថាយ** ៦:២៤ ។ អ្នករាល់គ្នានឹងត្រូវមនុស្សទាំងអស់ស្អប់ ដោយព្រោះខ្ញុំ, **ម៉ាថាយ** ១០:២២ ។ អ្នកណាដែលប្រព្រឹត្តអាក្រក់ នោះ តែងស្អប់ដល់ពន្លឺ, **យ៉ូហាន** ៣:២០ ។ កុំឲ្យអ្នកណាមើល ងាយអ្នក ដោយព្រោះនៅក្មេងនោះឡើយ, **១ ធីម៉ូ.** ៤:១២ ។ មកពីគេមាន គេមើលងាយមនុស្សក្រីក្រ, **២ នីហ្វៃ** ៩:៣០ ។ ចូរកុំមើល ងាយដល់វិវរណៈនៃព្រះឡើយ, **យ៉ាកុប** ៤:៨ ។ ពួកគេមានសម្អប់ដ៏យូរ អង្វែងទាស់នឹងយើង, **យ៉ាកុប** ៧:២៤ ។ មនុស្សលោកចាត់ ដំបូន្មានទាំងឡាយនៃព្រះទុកជាគ្មានតម្លៃ ហើយមើលងាយព្រះបន្ទូលទាំង ឡាយរបស់ទ្រង់, **គ. និង ស.** ៣:៧ ។ ខ្ញុំត្រូវគេស្អប់ ហើយបៀតបៀន មកពីខ្ញុំថាបានឃើញការនិមិត្ត, **យ.ស. — ប្រវត្តិ** ១:២៥ ។

**ស្អប់ខ្ពើម***សូមមើល* ការស្អប់, ស្អប់

**ស្អាត និងឥតស្អាត** *សូមមើលផង* ក្រិត្យវិន័យលោកម៉ូសេ; បរិសុទ្ធ, សេចក្តីបរិសុទ្ធ, សេចក្តីស្មោកគ្រោក; ស្មោកគ្រោក

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះអម្ចាស់ទ្រង់បង្ហាញដល់ម៉ូសេ និងពួកសាសន៍អ៊ីស្រាអែលពីបុរាណថា មានអាហារខ្លះដែលចាត់ទុក ថាស្អាត ឬម្យ៉ាងទៀត គួរសមឲ្យបរិភោគ ។ ការវែកញែកដែលពួកសាសន៍អ៊ីស្រាអែលបានធ្វើរវាងអាហារស្អាត និងឥតស្អាត នោះមាន

ផលដ៏ធំចំពោះសាសនា និងជីវិតក្នុងសង្គមរបស់ពួកគេ ។ មានសត្វ សត្វស្លាប និងត្រីខ្លះ ដែលរាប់ទុកថាស្អាត ហើយគួរ បរិភោគបាន ឯសត្វឯទៀតដែលឥតស្អាត នោះត្រូវហាមមិនឲ្យបរិភោគឡើយ (លេវី. ១១; ចោទិ. ១៤:៣–២០) ។ មនុស្សខ្លះដែល មានជម្ងឺក៏រាប់ថាឥតស្អាតដែរ ។

និយាយតាមខាងវិញ្ញាណវិញ ដើម្បីឲ្យបានស្អាត គឺឲ្យផុតពីអំពើបាបនិងការប្រាថ្នាខាងអំពើបាប ។ បើតាមន័យនេះ ពាក្យថាស្អាតត្រូវបានយកមកប្រើសំរាប់ពណ៌នាប្រាប់ពីមនុស្សណាមានគុណសម្បត្តិ ហើយមានចិត្តបរិសុទ្ធ (ទំនុក. ២៤:៤) ។ រាស្ត្រក្នុងសេចក្ដីសញ្ញា របស់ព្រះតែងតែមានសេចក្ដីបង្គាប់ដ៏វិសេសវិសេសរហូត ដើម្បីឲ្យបានស្អាត (៣ នីហ្វៃ ២០:៤១; គ. និង ស. ៣៨:៤២; ១៣៣:៥) ។

អ្នកដែលមានដៃស្អាត និងចិត្តបរិសុទ្ធ អ្នកនោះនឹងឡើងទៅឯភ្នំនៃព្រះអម្ចាស់, **ទំនុក.** ២៤:៣–៥ ។ ចូរកុំរាប់អ្នកណាថាមិនស្អាត ឬមិនបរិសុទ្ធឡើយ, **កិច្ចការ** ១០:១១–២៨ ។ តើអ្នករាល់គ្នាអាចសម្លឹងមើលទៅព្រះនៅក្នុងថ្ងៃនោះ ដោយមានចិត្តបរិសុទ្ធ ហើយបាតដៃ ស្អាតឬ ?, **អាលម៉ា** ៥:១៩ ។ ព្រះអម្ចាស់ទ្រង់នឹងវាយផ្ចាលក្រុងស៊ីយ៉ូន ទាល់តែនាងបានស្អាតស្អំ, **គ. និង ស.** ៩០:៣៦ ។ ចូរអ្នករាល់គ្នា ដែលកាន់ប្រដាប់ទាំងឡាយ នៃព្រះអម្ចាស់បានជ្រះស្អាតចុះ, **គ. និង ស.** ១៣៣:៤–៥, ១៤ (អេសាយ ៥២:១១) ។

### ហត្ថ

ជាមាត្រាប្រវែងធម្មតានៅចំណោមពួកហេព្រើរ — ពីដើមគឺចម្ងាយពីកែងដៃទៅចុងម្រាម ។

### ហាកាយ

ជាព្យាការីម្នាក់ក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានព្យាករនៅប្រមាណឆ្នាំ ៥២០ ម.គ.ស. នៅក្រុងយេរូសាឡិម គឺបន្ទាប់ពីបណ្ដាជននៃ សាសន៍យូដា បានវិលពីនិរទេស ពីក្រុងបាប៊ីឡូនមកវិញ (អែសរ៉ា ៥:១; ៦:១៤) ។ លោកបានប្រាប់អំពីការសង់ព្រះវិហារនៃ ព្រះអម្ចាស់នៅក្រុងយេរូសាឡិមឡើងវិញ ហើយបានបន្ទោសប្រជាជន ពីព្រោះធ្វើមិនទាន់រួច ។ លោកក៏បានសរសេរអំពីព្រះវិហារ នៅសហស្សវត្សរ៍ និងរាជ្យនៃព្រះអង្គសង្គ្រោះ ។

*គម្ពីរហាកាយ៖* ជំពូកទី ១ ព្រះអម្ចាស់ទ្រង់បន្ទោសប្រជាជន ចំពោះការរស់នៅក្នុងផ្ទះរបស់ខ្លួនដែលបានធ្វើរួច នៅពេលព្រះវិហារ នៅមិនទាន់សង់ ។ ជំពូកទី ២ កត់អំពីពាក្យព្យាករណ៍របស់ហាកាយថា ព្រះអម្ចាស់ទ្រង់នឹងប្រទានសេចក្ដីសុខសាន្តនៅក្នុងព្រះវិហារ របស់ទ្រង់ ។

### ហាគុត

ជាអ្នកសង់សំពៅសាសន៍នីហ្វៃម្នាក់ នៅក្នុងព្រះគម្ពីរមរមន (អាលម៉ា ៦៣:៥–៧) ។

### ហាបាគុក

ជាព្យាការីម្នាក់ក្នុងព្រះគម្ពីរសញ្ញាចាស់ នៅស្រុកយូដា ដែលបានប្រាប់អំពីអំពើបាបនៃបណ្ដាជន ប្រហែលជានៅក្នុងរាជ្យនៃ ស្ដេចយេហូយ៉ាគីន (ឆ្នាំ ៦០០ ម.គ.ស.) ។

*គម្ពីរហាបាគុក៖* ជំពូកទី ១ គឺជាការពិភាក្សារវាងព្រះអម្ចាស់នឹងព្យាការីទ្រង់ គឺដូចជាការពិភាក្សានៅក្នុងគម្ពីរយេរេមា ១២ និង គ. និង ស. ១២១ ។ ហាបាគុកមានចិត្តខ្វល់ខ្វាយ ដែលពួកទុច្ចរិតចេះតែចំរើនឡើង ។ នៅជំពូកទី ២ ព្រះអម្ចាស់ទ្រង់ទូន្មានឲ្យហាបាគុក មានចិត្តអត់ធ្មត់ — មនុស្សសុចរិតត្រូវចេះរស់នៅដោយសេចក្ដីជំនឿ ។ ជំពូកទី ៣ កត់ពាក្យអធិស្ឋានរបស់ហាបាគុក ដែលលោកបាន ជំរាបដល់សេចក្ដីយុត្តិធម៌របស់ព្រះ ។

### ហារិស, ម៉ាទិន *សូមមើលផង* ពួកសាក្សីអំពីព្រះគម្ពីរមរមន

ជាសាក្សីម្នាក់ក្នុងចំណោមពួកសាក្សីបីនាក់ ចំពោះដើមកំណើត និងសេចក្ដីពិតប្រាកដអំពីព្រះគម្ពីរមរមន ។ លោកបានជួយប្រាក់ដល់យ៉ូសែប ស៊្មីធ និងសាសនាចក្រ ។ ព្រះអម្ចាស់ទ្រង់បានប្រាប់ឲ្យម៉ាទិន ហារិសលក់ដីធ្លីរបស់លោក ហើយឲ្យប្រាក់ ដើម្បីបង់ថ្លៃបោះ ពុម្ពព្រះគម្ពីរមរមន (គ. និង ស. ១៩:២៦–២៧, ៣៤–៣៥); ឲ្យធ្វើជាគំរូដល់សាសនាចក្រ (គ. និង ស. ៥៨:៣៥); ហើយឲ្យជួយ បង់ថ្លៃការបង្រៀនសាសនា (គ. និង ស. ១០៤:២៦) ។

ម៉ាទិស ហារិសត្រូវបានកាត់ចេញពីសាសនាចក្រ ប៉ុន្តែក្រោយមកបានត្រឡប់ជាសមាជិកពេញទីវិញ ។ នៅចុងជីវិតរបស់លោក នោះលោកបានធ្វើបន្ទាល់ថា លោកបានឃើញទេវតាម៉ូរ៉ូណៃ និងផ្ទាំងមាសទាំងឡាយ ដែលយ៉ូសែប ស៊្មីធ បានបកប្រែទៅជា ព្រះគម្ពីរមរមន ។

### ហិមណៃ *សូមមើលផង* ម៉ូសាយ, បុត្ររបស់បេនយ៉ាមីន; ម៉ូសាយ, ពួកបុត្ររបស់ទ្រង់

នៅក្នុងព្រះគម្ពីរមរមន គឺជាបុត្ររបស់ស្ដេចម៉ូសាយ ។ ហិមណៃបានទៅជាមួយបងប្អូនប្រុសៗ របស់លោក ដើម្បីទៅផ្សាយសាសនា ដល់ពួកសាសន៍លេមិន (ម៉ូសាយ ២៧:៨–១១, ៣៤–៣៧; ២៨:១–៩) ។

### ហឹបនៃសេចក្ដីសញ្ញា *សូមមើលផង* រោងឧបោសថ

ក៏ស្គាល់ថា ហឹបនៃព្រះយេហូវ៉ា និងហឹបនៃទីបន្ទាល់ដែរ, ហឹបនៃសេចក្ដីសញ្ញាគឺជាទូមួយមានរាងវែង ឬជាប្រអប់ធ្វើពីឈើ ដែល ស្រោបដោយមាស ។ ហឹបនេះ គឺជានិមិត្តរូបខាងសាសនាដ៏យូរ និងដ៏ពិសិដ្ឋបំផុតរបស់ពួកសាសន៍អ៊ីស្រាអែល ។ ទីសន្ដោសប្រោស ដែលនៅជុំវិញ ត្រូវបានចាត់ទុកថា ជាទីដំណាក់នៃព្រះយេហូវ៉ា (និក្ខ. ២៥:២២) ។ កាលបានធ្វើរោងឧបោសថរួចហើយ ក៏បានដាក់ ហឹបនៅក្នុងទីបរិសុទ្ធបំផុត គឺជាកន្លែងបរិសុទ្ធបំផុតនៅក្នុងរោង (១ ពង្សាវ. ៨:១–៨) ។

ម៉ូសេបានធ្វើហឹបតាមបញ្ញត្តិនៃព្រះ, **និក្ខ.** ២៥ ។ ពួកកូនចៅលេវីត្រូវបានបញ្ជាឲ្យថែរក្សាហឹប, **ជនគ.** ៣:១៥, ៣១ ។ ហឹបនៃសេចក្ដី សញ្ញាក៏ទៅ

មុខគេ, **ជនគ.** ១០:៣៣ ។ ចូរយកគម្ពីរក្រិត្យវិន័យនេះ ទៅដាក់ក្នុងហឹបនៃសេចក្ដីសញ្ញា, **ចោទិ.** ៣១:២៤–២៦ ។ ទឹក យ័រដាន់ត្រូវកាត់ផ្ដាច់ខាងមុខហឹបនៃសេចក្ដីសញ្ញា, **យ៉ូស្វេ** ៣:១៣–១៧; ៤:១–៧ ។ ពួកសង្ឃយកហឹបនៃសេចក្ដីសញ្ញាទៅច្បាំងយក ក្រុងយេរីខូរ, **យ៉ូស្វេ** ៦:៦–២០ ។ ពួកភីលីស្ទីនចាប់យកហឹបនៃព្រះ, **១ សាំយូ.** ៥ ។ ព្រះអម្ចាស់ទ្រង់ប្រទានពរដល់ផ្ទះរបស់ អូបិឌ-អេដំម មកពីហឹបនៃព្រះ, **២ សាំយូ.** ៦:១១–១២ ។ អ៊ុសាត្រូវព្រះអម្ចាស់ទ្រង់ប្រហារបង់ កាលគាត់ខំទប់ហឹបទាំងមិនស្ដាប់, **១ របា.** ១៣:៩–១២ (គ. និង ស. ៨៥:៨) ។ ចូរស្អាងទីបរិសុទ្ធផងព្រះអម្ចាស់ជាព្រះ ដើម្បីនឹងនាំហឹបនៃសេចក្ដីសញ្ញា, **១ របា.** ២២:១៩ ។ របស់នៅក្នុងហឹបនៃសេចក្ដីសញ្ញាត្រូវបានរៀបរាប់ប្រាប់, **ហេព្រើរ** ៩:៤ ។

**ហូសាណា**

ជាពាក្យពីភាសាហេព្រើរ ដែលមានន័យថា « សូមជួយសង្គ្រោះយើងខ្ញុំ » ហើយដែលត្រូវប្រើក្នុងការសរសើរ និងការអំពាវនាវ ។

នៅបុណ្យបារាំ ដែលបានធ្វើឡើងចំពោះការដែលព្រះអម្ចាស់បានដោះលែងសាសន៍អ៊ីស្រាអែល ទៅកាន់ដែនដីសន្យា នោះមនុស្សស្រែកហោពាក្យពីគម្ពីរទំនុកដំកើង ១១៨ ហើយបក់ធាងចាក ។ នៅដំណើរដែលព្រះអម្ចាស់យាងចូលក្រុងយេរូសាឡិមដោយ ជោគជ័យ នោះហ្វូងមនុស្សស្រែកថា « ហូសាណា » ហើយក្រាលធាងចាកថ្វាយឲ្យព្រះយេស៊ូវជិះលាលើ ដោយបែបនេះបង្ហាញ នូវយោបល់គេថា ព្រះយេស៊ូវ គឺជាព្រះអម្ចាស់ដដែល ដែលបានរំដោះសាសន៍អ៊ីស្រាអែលកាលពីសម័យបុរាណ, (ទំនុក. ១១៨:២៥–២៦; ម៉ាថាយ ២១:៩, ១៥; ម៉ាកុស ១១:៩–១០; យ៉ូហាន ១២:១៣) ។ មនុស្សទាំងនេះស្គាល់ថា ព្រះគ្រីស្ទ គឺជាព្រះមែស៊ី ដែលទន្ទឹងចាំជាយូរយារ ។ ពាក្យ*ហូសាណា* បានក្លាយទៅជាបុណ្យអំពីព្រះមែស៊ីនៅគ្រប់យុគ (១ នីហ្វៃ ១១:៦; ៣ នីហ្វៃ ១១:១៤–១៧) ។ ការស្រែកហូសាណា បានរួបរួមចូលក្នុងការឆ្លងព្រះវិហារខឺតឡង់ (សហរដ្ឋ) (គ. និង ស. ១០៩:៧៩) ហើយឥឡូវ នេះ ទុកជាផ្នែកមួយក្នុងការឆ្លងព្រះវិហារទំនើបថ្មី ។

**ហូសេ**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានព្យាករនៅនគរអ៊ីស្រាអែលខាងជើង នៅចុងរាជ្យនៃស្ដេចយេរូបោមទីពីរ ។ លោកបានរស់នៅសម័យប្រទេសចុះអន់ថយ និងហិនហោច មកពីអំពើបាបនៃសាសន៍អ៊ីស្រាអែល ។

*គម្ពីរហូសេ៖* ផ្ទៃរឿងដ៏សំខាន់នៅក្នុងគម្ពីរ គឺសេចក្ដីស្រឡាញ់ដែលព្រះទ្រង់មានចំពោះរាស្ត្រទ្រង់ ។ ការវាយផ្ចាលទាំងអស់ របស់ទ្រង់ គឺធ្វើដោយសេចក្ដីស្រឡាញ់ ហើយការសាងអ៊ីស្រាអែលឡើងវិញនឹងកើតឡើង ដោយព្រោះសេចក្ដីស្រឡាញ់របស់ទ្រង់ (ហូសេ ២:១៩; ១៤:៤) ។ ផ្ទុយទៅវិញ ហូសេបង្ហាញការក្បត់ និងការមិនស្មោះត្រង់របស់សាសន៍អ៊ីស្រាអែល ។ ក៏ប៉ុន្តែព្រះទ្រង់ នៅតែទន្ទឹងដល់ការប្រោសលោះនៃអ៊ីស្រាអែលចុងក្រោយបង្អស់ (ហូសេ ១១:១២–១៤:៩) ។

**ហេណុក** *សូមមើលផង* ស៊ីយ៉ូន

ជាព្យាការីម្នាក់ ដែលបានដឹកនាំបណ្ដាជននៅទីក្រុងស៊ីយ៉ូន ។ ការងារបំរើរបស់លោក នោះត្រូវបានអធិប្បាយប្រាប់នៅក្នុងព្រះគម្ពីរ សញ្ញាចាស់ព្រមទាំងនៅក្នុងមុក្ដាដ៏មានតម្លៃមហិមា ។ លោកជាអយ្យកោទី ៧ បន្ទាប់ពីលោកអ័ដាមមក ។ លោកជាកូនប្រុសរបស់ យ៉ារេឌ ហើយជាឪពុករបស់មធូសាឡា (លោកុ. ៥:១៨–២៤; លូកា ៣:៣៧) ។

ហេណុកជាបុរសដ៏សំខាន់ម្នាក់ ហើយមានការងារបំរើដ៏សំខាន់ៗច្រើនជាងដំណើររឿងដ៏ខ្លីអំពីលោកដែលព្រះគម្ពីរប៊ីបពោលដល់ ។ ព្រះគម្ពីរប៊ីបថ្លែងប្រាប់ថា លោកត្រូវបានប្រែរូប (ហេព្រើរ ១១:៥) ប៉ុន្តែមិនបានរៀបរាប់ប្រាប់អំពីការបង្រៀនរបស់លោកទេ ។ យូដាស ១:១៤ មានពាក្យស្រង់អំពីការព្យាករណ៍ដែលលោកបានទាយ ។ វិវរណៈនៅថ្ងៃចុងក្រោយអធិប្បាយប្រាប់អំពីហេណុកច្រើន ថែមទៀត ជាពិសេសអំពីការប្រកាសរបស់លោក អំពីទីក្រុងលោកដែលហៅថា ស៊ីយ៉ូន អំពីការនិមិត្តទាំងឡាយរបស់លោក និងអំពី ការព្យាករណ៍ទាំងឡាយរបស់លោក (គ. និង ស. ១០៧:៤៨–៥៧; ម៉ូសេ ៦–៧) ។ ក្រុងស៊ីយ៉ូនត្រូវបានយកទៅលើស្ថានសួគ៌ ពីព្រោះ តែសេចក្ដីសុចរិតនៃពួកអ្នកដែលនៅទីនោះ (ម៉ូសេ ៧:៦៩) ។

ព្រះទ្រង់បានបង្ហាញព្រះអង្គទ្រង់ដល់ហេណុក, **ម៉ូសេ** ៦:២៦–៣៧ ។ ហេណុកបានបង្រៀនអំពីដំណឹងល្អ, **ម៉ូសេ** ៦:៣៧–៦៨ ។ ហេណុកបានបង្រៀនប្រជាជន ហើយបានតាំងក្រុងស៊ីយ៉ូន, **ម៉ូសេ** ៧:១–២១ ។ ហេណុកបានឃើញពេលអនាគត ពីការយាង មកលើកទីពីរនៃព្រះគ្រីស្ទ, **ម៉ូសេ** ៧:២៣–៦៨ ។

**ហេព្រើរ** *សូមមើលផង* អ៊ីស្រាអែល

ជាភាសាសេមិត ដែលនិយាយដោយពួកកូនចៅនៃអ៊ីស្រាអែល ។

ភាសាហេព្រើរត្រូវបាននិយាយដោយពួកសាសន៍អ៊ីស្រាអែល រហូតដល់គេវិលមកពីការឃុំឃាំងនៃពួកបាប៊ីឡូនវិញ គឺនៅសម័យដែលភាសាអើរ៉ាមក្លាយទៅជាភាសានិយាយទូទៅរាល់ថ្ងៃ ។ នៅសម័យព្រះយេស៊ូវ ភាសាហេព្រើរ គឺជាភាសានៃពួកអ្នករៀនសូត្រ ភាសាច្បាប់ និងភាសាខាងសាសនា ។

**ហេព្រើរ, សំបុត្រដល់ពួក** *សូមមើលផង* ប៉ុល; សំបុត្ររបស់ប៉ុល

ជាគម្ពីរមួយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ប៉ុលបានសរសេរសំបុត្រនេះដល់សមាជិកក្នុងសាសនាចក្រដែលជាសាសន៍យូដា ដើម្បីបញ្ចុះបញ្ចូលគេថា សារៈសំខាន់នៃក្រិត្យវិន័យលោកម៉ូសេ នោះត្រូវបានសំរេចក្នុងព្រះគ្រីស្ទហើយ ហើយថា ក្រិត្យវិន័យខាងដំណឹងល្អនៃ ព្រះគ្រីស្ទដែលខ្ពស់ជាង នោះត្រូវបានយកមកជួសវិញ ។ កាលប៉ុលបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ នៅចុងបេសកកម្មទីបី (ប្រមាណជាឆ្នាំ ៦០ គ.ស.) នោះលោកបានឃើញថា សមាជិកក្នុងសាសនាចក្រដែលជាសាសន៍យូដាជាច្រើន នៅតែគោរពតាម ក្រិត្យវិន័យលោកម៉ូសេនៅឡើយ (កិច្ចការ ២១:២០) ។ នោះគឺយ៉ាងតិច ១០ ឆ្នាំក្រោយពីសន្និសីទនៃសាសនាចក្រនៅក្រុង យេរូសាឡិម ដែលបាន

ចាត់ថា ពិធីបរិសុទ្ធនៃក្រិត្យវិន័យលោកម៉ូសេខ្លះ ទុកជាមិនចាំបាច់សំរាប់សេចក្ដីសង្គ្រោះដល់ពួកគ្រីស្ទាន ដែលជាសាសន៍ដទៃឡើយ ។ តាមមើលទៅ បន្ទាប់ពីនោះភ្លាម ប៉ុលក៏សរសេរទៅពួកហេព្រើរ ដើម្បីបង្ហាញគេ ដោយគម្ពីររបស់គេ និងដោយហេតុសមរម្យថា មូលហេតុដែលគេមិនគួរប្រព្រឹត្តតាមក្រិត្យវិន័យលោកម៉ូសេតទៅទៀតនោះ ។

ជំពូកទី ១ និងទី ២ ពន្យល់ប្រាប់ថាព្រះយេស៊ូវទ្រង់ធំជាងពួកទេវតា ។ ជំពូកទី ៣–៧ ប្រៀបធៀបព្រះយេស៊ូវទៅនឹងលោកម៉ូសេ ហើយទៅនឹងក្រិត្យវិន័យលោកម៉ូសេ ហើយធ្វើបន្ទាល់ថា ទ្រង់ធំជាងលោកម៉ូសេ និងក្រិត្យវិន័យលោកម៉ូសេ ។ ក៏បង្រៀនថា បព្វជិតភាពមិលគីស្សាដែក ធំជាងបព្វជិតភាពអើរ៉ុន ។ ជំពូកទី ៨–៩ អធិប្បាយប្រាប់ថា ពិធីបរិសុទ្ធម៉ូសេបានរៀបចំប្រជាជន សំរាប់ ការបង្រៀនរបស់ព្រះគ្រីស្ទ ហើយពីរបៀបដែលព្រះគ្រីស្ទជាអ្នកកណ្ដាលចំពោះសេចក្ដីសញ្ញាថ្មី (អាលម៉ា ៣៧:៣៨–៤៥; គ. និង ស. ៨៤:២១–២៤) ។ ជំពូកទី ១០ ជាការទូន្មានឲ្យមានចិត្តឧស្សាហ៍ ហើយមានចិត្តស្មោះត្រង់ ។ ជំពូកទី ១១ ជាសេចក្ដីថ្លែងអំពីសេចក្ដីជំនឿ ។ ជំពូកទី ១២ ផ្ដល់នូវសេចក្ដីទូន្មាន និងសេចក្ដីសួរសុខទុក្ខ ។ ជំពូកទី ១៣ ពិគ្រោះអំពីស្ថានភាពនៃអាពាហ៍ពិពាហ៍ដ៏មាន កិត្តិយស និងការសំខាន់ ខាងការគោរពតាម ។

**ហេរ៉ូឌ**

ជាវង្សានៃពួកអ្នកត្រួតត្រានៅខេត្តយូដា នៅជិតសម័យព្រះយេស៊ូវគ្រីស្ទ ។ ពួកគេជាតួសំខាន់ៗ ក្នុងហេតុការណ៍ជាច្រើនក្នុង ព្រះគម្ពីរសញ្ញាថ្មី ។ សូមមើលគំនូរខាងក្រោមនេះ៖




**ហេរ៉ូឌាស**

ជាអនុជារបស់ហេរ៉ូឌ អ័គ្រីប៉ា នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ព្រះនាងបានរៀបមង្គលការជាមួយនឹងហេរ៉ូឌ ភីលីព ជាឪពុកមារបស់ខ្លួន ហើយក៏មានបុត្រីមួយគឺ ព្រះនាងសាឡូមេ ។ ព្រះនាង និងព្រះនាងសាឡូមេបានផ្សំគំនិតគ្នា ដើម្បីកាត់ក្បាលយ៉ូហាន-បាទីស្ទ (ម៉ាថាយ ១៤:៣–១១) ។

**ហេលេមិន, បុត្ររបស់បេនយ៉ាមីន** *សូមមើលផង*

បិតារបស់ម៉ូសាយ, បេនយ៉ាមីន

នៅក្នុងព្រះគម្ពីរមរមន ជាបុត្ររបស់ស្ដេចបេនយ៉ាមីនម្នាក់ ក្នុងចំណោមបុត្រាបីនាក់ (ម៉ូសាយ ១:២–៨) ។

**ហេលេមិន, ពួកកូនប្រុសរបស់លោក** *សូមមើលផង*

អាន់តៃ-នីហ្វៃ-លីហៃ; ហេលេមិន, កូនប្រុសរបស់អាលម៉ា

នៅក្នុងព្រះគម្ពីរមរមន ជាពួកកូនប្រុសនៃសាសន៍លេមិន ដែលបានប្រែចិត្ត ដែលស្គាល់ថាជាពួកសាសន៍អាំម៉ូន ដែលបានធ្វើទាហាន នៅក្រោមការដឹកនាំរបស់ហេលេមិន (អាលម៉ា ៥៣:១៦–២២) ។

ហេលេមិន ចាត់ពួកគេទុកជាត្រឹមត្រូវ ហើយបានហៅថាជាកូនលោក,

**អាលម៉ា** ៥៦:១០ ។ ម្ដាយពួកគេបានបង្រៀនពួកគេ កុំឲ្យ សង្ស័យពីអំណាចដែលព្រះអម្ចាស់អាចជួយពួកគេឡើយ, **អាលម៉ា** ៥៦:៤៧ ។ ពួកគេបានឈ្នះពួកសាសន៍លេមិន ហើយត្រូវបានរក្សា ជីវិតទុក ដោយសារសេចក្ដីជំនឿរបស់គេ សូម្បីតែមួយក៏មិនត្រូវស្លាប់ផង, **អាលម៉ា** ៥៦:៥២–៥៤, ៥៦; ៥៧:២៦ ។

**ហេលេមិន, កូនប្រុសរបស់ហេលេមិន**

ជាព្យាការី ហើយជាអ្នកកត់បញ្ជីម្នាក់ នៅក្នុងព្រះគម្ពីរមរមន ដែលបានបង្រៀនប្រជាជននៃសាសន៍នីហ្វៃ ។ លោកជាចៅរបស់ អាលម៉ា ដែលត្រូវជាកូន ហើយជាឪពុករបស់នីហ្វៃ ដែលបានទទួលអំណាចលើអស់ទាំងវត្ថុធាតុ (ហេលេ. ៥–១០) ។ ហេលេមិន និងនីហ្វៃ ជាកូនប្រុសរបស់លោក បានសរសេរគម្ពីរហេលេមិន ។

*គម្ពីរហេលេមិន៖* ជំពូកទី ១–២ អធិប្បាយប្រាប់អំពីគ្រាបញ្ហាដ៏ធំខាងរដ្ឋាភិបាល ។ ជំពូកទី ៣–៤ កត់ថា ហេលេមិន និងម៉ូរីណៃហា ជាមេទ័ពនៃកងទ័ពនីហ្វៃ បានទទួលសេចក្ដីសុខសាន្តមួយគ្រា នៅទីបញ្ចប់ ។ ប៉ុន្តែទោះជាមានការដឹកនាំដោយពួកបុរសល្អទាំងនេះ ក៏ដោយ គង់តែប្រជាជននៅតែទុច្ចរិតថែមទៀត ។ នៅជំពូកទី ៥–៦ នីហ្វៃបានលះបង់ចោលវេទិកាជំនុំជំរះ ដូចជាជីតាអាលម៉ាបានធ្វើ ដើម្បីទៅបង្រៀនប្រជាជន ។ នៅគ្រាមួយ ប្រជាជនបានប្រែចិត្ត ។ ប៉ុន្តែនៅជំពូកទី ៦–១២ សាសន៍នីហ្វៃបានក្លាយទៅជាទុច្ចរិត ។ ជំពូកចុងក្រោយបង្អស់គឺទី ១៣–១៦ មានហេតុរឿងដ៏អស្ចារ្យមួយ អំពីព្យាការីម្នាក់ ហៅថា សាំយូអែល សាសន៍លេមិន ដែលបាន ប្រាប់ទុកជាមុន អំពីកំណើត និងការឆ្កាងព្រះអង្គសង្គ្រោះ ហើយនិងទីសំគាល់ដែលនឹងដៅអំពីហេតុការណ៍ទាំងនោះ ។

**ហេលេមិន, កូនប្រុសរបស់អាលម៉ា** *សូមមើលផង*

កូនប្រុសរបស់អាលម៉ា; ពួកកូនប្រុសរបស់លោក, ហេលេមិន, អាន់តៃ-នីហ្វៃ-លីហៃ; អាលម៉ា

នៅក្នុងព្រះគម្ពីរមរមន ជាកូនប្រុសច្បងរបស់អាលម៉ា ដែលជាកូនប្រុសរបស់អាលម៉ា (អាលម៉ា ៣១:៧) ។ ហេលេមិន ជាព្យាការី ហើយជាមេទ័ពម្នាក់ ។

អាលម៉ាបានប្រគល់ដល់ហេលេមិន ជាកូនប្រុសលោក នូវបញ្ជីទាំងឡាយអំពីប្រជាជនលោក និងផ្ទាំងទាំងឡាយអំពីពួកសាសន៍យ៉ារេឌ, **អាលម៉ា** ៣៧:១–២, ២១ ។ អាលម៉ាបានបង្គាប់ហេលេមិន ឲ្យសរសេរប្រវត្តិអំពីប្រជាជនលោកបន្តទៀត, **អាលម៉ា** ៤៥–៦២ ។ ហេលេមិន បានតាំងសាសនាចក្រឡើងវិញ, **អាលម៉ា** ៤៥:២២–២៣ ។ ពួកទាហានកំឡោះសាសន៍អាំម៉ូននពីរពាន់នាក់បានប្រាថ្នាចង់ ឲ្យហេលេមិន ធ្វើជាមេដឹកនាំគេ, **អាលម៉ា** ៥៣:១៩, ២២ ។ ហេលេមិន និងកូនកំឡោះសាសន៍អាំម៉ូនរបស់លោក បានច្បាំងនឹងពួក សាសន៍លេមិន ហើយត្រូវបានរក្សាជីវិតទុក ដោយសារសេចក្ដីជំនឿ, **អាលម៉ា** ៥៧:១៩–២៧ ។

**ហេសេគា**

ជាស្ដេចដ៏សុចរិតម្នាក់នៃសាសន៍យូដា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ទ្រង់បានសោយរាជ្យអស់រយៈពេល ២៩ ឆ្នាំ គឺនៅសម័យ អេសាយ ជាព្យាការីនៅស្រុកយូដា (២ ពង្សាវ. ១៨–២០; ២ របា. ២៩–៣២; អេសាយ ៣៦–៣៩) ។ អេសាយបានជួយទ្រង់ក្នុងការ កែតម្រង់ ទាំងខាងសាសនា និងខាងរដ្ឋាភិបាល ។ ទ្រង់បានបង្ក្រាបការថ្វាយបង្គំរូបព្រះ ហើយបានបង្កើតពិធីបរិសុទ្ធខាងវិហារ ឡើងវិញ ។ ហេសេគាមានជន្មាយុ ១៥ ឆ្នាំទៀត តាមរយៈការអធិស្ឋាន និងសេចក្ដីជំនឿ (២ ពង្សាវ. ២០:១–៧) ។ គ្រាដំបូងនៃ រជ្ជកាលរបស់ទ្រង់ខ្លះបានលូតលាស់ ប៉ុន្តែការបះបោររបស់ទ្រង់ទាស់នឹងស្ដេចនៃស្រុកអាសស៊ើរ (២ ពង្សាវ. ១៨:៧) បានផ្ដល់នូវការ លុកលុយពីសាសន៍អាសស៊ើរពីរដង៖ ទីមួយ បានអធិប្បាយប្រាប់នៅក្នុងគម្ពីរអេសាយ ១០:២៤–៣២, រីឯទីពីរ នៅក្នុង ២ ពង្សាវ. ១៨:១៣–១៩:៧ ។ នៅក្នុងការលុកលុយទីពីរ នោះក្រុងយេរូសាឡិមត្រូវបានសង្គ្រោះ ដោយទេវតានៃព្រះអម្ចាស់ (២ ពង្សាវ. ១៩:៣៥) ។

**ហៃឌឹ, អូរសុន**

ជាសមាជិកម្នាក់ក្នុងក្រុមទីមួយនៃសាវក ១២ នាក់ ដែលបានហៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ (គ. និង ស. ៦៨:១–៣; ៧៥:១៣; ១០២:៣; ១២៤:១២៨–១២៩) ។ លោកបានធ្វើបេសកកម្មជាច្រើនដង សំរាប់សាសនាចក្រ ព្រមទាំងធ្វើពិធីឆ្លងដែនដីបរិសុទ្ធ នៅឆ្នាំ ១៨៤១ សំរាប់ការវិលមកវិញរបស់ប្រជាជននៃសាសន៍យូដា ។

**ហៅ, បានហៅពីព្រះ, ការហៅ** *សូមមើលផង*

ការកាន់កាប់ត្រួតត្រា, ជំរើស (គ. ឬ ន.); ដែលបានរើស (កិ.); តែងតាំង, បានរើស, ពិធីតែងតាំង; រើស, សិទ្ធិអំណាច; អ្នកកាន់កាប់ត្រួតត្រា

កាលបានហៅពីព្រះ គឺដើម្បីទទួលតំណែង ឬការអញ្ជើញពីទ្រង់ ឬពីពួកអ្នកដឹកនាំក្នុងសាសនាចក្ររបស់ទ្រង់ ដែលមានអំណាច ត្រឹមត្រូវ ដើម្បីឲ្យបំរើទ្រង់តាមមាគ៌ាណាមួយ ។

លោកបានដាក់ដៃលើលោក ហើយប្រគល់សេចក្ដីបង្គាប់ដល់លោក, **ជនគ.** ២៧:២៣ ។ យើងបានតាំងអ្នកឡើងជាព្យាការី, **យេរេ.** ១:៥ ។ ខ្ញុំបានរើសអ្នករាល់គ្នា ទាំងតាំងអ្នករាល់គ្នា, **យ៉ូហាន**១៥:១៦ ។ ប៉ុលបានត្រូវហៅឲ្យធ្វើជាសាវក, **រ៉ូម** ១:១ ។ គ្មានអ្នក ណាលើកខ្លួនដល់ងារដ៏ប្រសើរនោះឡើយ មានតែអ្នកដែលព្រះទ្រង់ហៅប៉ុណ្ណោះ, **ហេព្រើរ** ៥:៤ ។ ព្រះយេស៊ូវបានត្រូវហៅពីព្រះ តាមរបៀបលោកមិលគីស្សាដែក, **ហេព្រើរ** ៥:១០ ។ ខ្ញុំត្រូវបានហៅឲ្យផ្សាយព្រះបន្ទូលនៃព្រះ តាមវិញ្ញាណនៃវិវរណៈ និងការ ព្យាករណ៍, **អាលម៉ា** ៨:២៤ ។ ពួកសង្ឃត្រូវបានហៅ ហើយរៀបចំ ចាប់តាំងពីកំណើតលោកិយមក, **អាលម៉ា** ១៣:៣ ។ បើសិនជា អ្នករាល់គ្នាមានបំណងចង់បំរើព្រះ នោះអ្នករាល់គ្នាបានហៅឲ្យធ្វើកិច្ចការនោះហើយ, **គ. និង ស.** ៤:៣ ។ ចូរឈរឲ្យមាំមួនក្នុងកិច្ចការ ដែលយើងបានហៅឲ្យអ្នកធ្វើ, **គ. និង ស.**

៩:១៤ ។ អ្នកមិនត្រូវសន្និដ្ឋានថា អ្នកត្រូវបានហៅឲ្យទៅផ្សាយ លុះត្រាអ្នកត្រូវបានហៅ សិន, **គ. និង ស.** ១១:១៥ ។ ពួកអែលឌើរត្រូវបានហៅមក ដើម្បីបណ្ដាលឲ្យមានការប្រមូល នៃពួកអ្នកដែលបានរើសតាំង, **គ. និង ស.** ២៩:៧ ។ គ្មានអ្នកណាមួយនឹងទៅផ្សាយដំណឹងល្អរបស់យើង ឬស្ថាបនាសាសនាចក្ររបស់យើងឡើងឡើយ លើកលែងតែអ្នកនោះ បានតែងតាំងឡើង, **គ. និង ស.** ៤២:១១ ។ មានមនុស្សជាច្រើនដែលត្រូវបានហៅ ប៉ុន្តែមានមនុស្សតែបន្តិចទេដែលត្រូវបានរើស, **គ. និង ស.** ១២១:៣៤ ។ មនុស្សត្រូវតែបានហៅពីព្រះ, **ម. នៃ ស.** ១:៥ ។

**ហាំ** *សូមមើលផង* ណូអេ, អយ្យកោនៅក្នុងព្រះគម្ពីរប៊ីប

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសទីបីរបស់ណូអេ (លោកុ. ៥:៣២; ៦:១០; ម៉ូសេ ៨:១២, ២៧) ។

ណូអេ កូនប្រុសៗលោក និងគ្រួសារពួកគេបានចូលទៅក្នុងទូកធំ, **លោកុ.** ៧:១៣ ។ កាណានជាកូនប្រុសរបស់ហាំ បានត្រូវបណ្ដាសា, **លោកុ.** ៩:១៨–២៥ ។ រដ្ឋាភិបាលរបស់ហាំ គឺជារដ្ឋាភិបាលខាងអយ្យកោ ហើយបានទទួលពរចំពោះអ្វីៗខាងផែនដី និងប្រាជ្ញា ប៉ុន្តែមិនខាងបព្វជិតភាពទេ, **អ័ប្រា.** ១:២១–២៧ ។ ប្រពន្ធរបស់ហាំ គឺនាងអេស៊ីព្ទុស ដែលជាពូជពង្សរបស់កាអ៊ីន ហើយកូនចៅរបស់នាងអេស៊ីព្ទុស ដែលជាកូនស្រីរបស់គេ បានអាស្រ័យនៅស្រុកអេស៊ីព្ទ, **អ័ប្រា.** ១:២៣, ២៥ (ទំនុក. ១០៥:២៣; ១០៦:២១–២២) ។

**ហ្វាយែត, រដ្ឋនូវយ៉ោក (សហរដ្ឋអាមេរិក)**

ជាកន្លែងដែលមានស្រែរបស់ពេត្រុស វិតមើរ ស៊ីញ័រ ។ គឺជាកន្លែងដែលវិវរណៈជាច្រើនត្រូវបានប្រទានដល់ព្យាការី យ៉ូសែប ស្ម៊ីធ ជុញ៉ រ ។ ទីនេះហើយ ដែលសាសនាចក្របានរៀបចំឡើង នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៨៣០ ហើយបានឮសម្លេងនៃព្រះអម្ចាស់ (គ. និង ស. ១២៨:២០) ។

**ហ្វែប្ស, វិលលាម ដ័បបុលយូ**

ជាសមាជិក ហើយជាអ្នកដឹកនាំម្នាក់នៅក្នុងសាសនាចក្រមុនដំបូង បន្ទាប់ពីបានសាងឡើងវិញនៅឆ្នាំ ១៨៣០ ។ ព្រះអម្ចាស់ទ្រង់ បានហៅវិលលាម ហ្វែប្ស ឲ្យធ្វើជាអ្នកបោះពុម្ពសំរាប់សាសនាចក្រ (គ. និង ស. ៥៧:១១; ៥៨:៤០; ៧០:១) ។

**ឡុត** *សូមមើលផង* អ័ប្រាហាំ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់ហារ៉ាន ហើយជាក្មួយរបស់អ័ប្រាហាំ (លោកុ. ១១:២៧, ៣១; អ័ប្រា. ២:៤) ។ ហារ៉ានស្លាប់ ពីព្រោះមកពីមានអំណត់អត់នៅក្រុងអឺរ (អ័ប្រា. ២:១) ។ ឡុតបានចេញពីក្រុងអឺរទៅជាមួយនឹងអ័ប្រាហាំ និងនាង សារ៉ា ហើយបានធ្វើដំណើរជាមួយនឹងពួកគេទៅស្រុកកាណាន (លោកុ. ១២:៤–៥) ។ ឡុតបានសំរេចចិត្តនឹងអាស្រ័យនៅក្រុងសូដុំម ។ ព្រះអម្ចាស់ ទ្រង់បានចាត់សារទូតឲ្យទៅប្រាប់ឡុតឲ្យរត់ចេញពីក្រុងសូដុំម មុននឹងព្រះអម្ចាស់ទ្រង់បំផ្លាញទីក្រុងនោះចោល ពីព្រោះ មកពីអំពើអាក្រក់នៃប្រជាជន (លោកុ. ១៣:៨–១៣; ១៩:១, ១៣, ១៥); ប៉ុន្តែប្រពន្ធឡុតបានងាកបែរទៅមើលការបំផ្លាញ ហើយបាន ក្លាយទៅជាបង្គោលអំបិលទៅ (លោកុ. ១៩:២៦) ។ ព្រះគម្ពីរសញ្ញាថ្មីមាននូវសេចក្ដីយោងអំពីឡុត (លូកា ១៧:២៩; ២ ពេត្រុស ២:៦–៧) ។ ជីវិតលោកបន្ទាប់ពីបានបែកចេញពីអ័ប្រាហាំ ត្រូវបានរៀបរាប់ប្រាប់នៅក្នុងគម្ពីរលោកុប្បត្តិ ១៣ ១៤ និង ១៩ ។

**ឡាបាន់, អ្នករក្សាផ្ទាំងលង្ហិន** *សូមមើលផង* ផ្ទាំងលង្ហិន

នៅក្នុងព្រះគម្ពីរមរមន គឺជាបុរសម្នាក់ ដែលបានរក្សាផ្ទាំងលង្ហិននៅក្រុងយេរូសាឡិម នៅសម័យគ្រួសារលីហៃ ។ ឡាបាន់បានប្លន់ ហើយខំរកសម្លាប់នីហ្វៃ និងពួកបងប្អូនរបស់លោក (១ នីហ្វៃ ៣:១–២៧) ។ ព្រះវិញ្ញាណបាននាំនីហ្វៃឲ្យប្រហារឡាបាន់ ដើម្បីយក ផ្ទាំងទាំងឡាយ (១ នីហ្វៃ ៤:១–២៦) ។

**ឡាបាន់, បងប្រុសរបស់នាងរេបិកា** *សូមមើលផង* នាងរេបិកា

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាបងប្រុសរបស់នាងរេបិកា ហើយជាឪពុករបស់នាងលេអា និងនាងរ៉ាជែល ដែលជាប្រពន្ធទាំងពីរ របស់យ៉ាកុប (លោកុ. ២៤:២៩–៦០; ២៧:៤៣–៤៤; ២៨:១–៥; ២៩:៤–២៩; ៣០:២៥–៤២; ៣១:១–៥៥) ។

**ឡាម៉ូណៃ***សូមមើលផង* អាំម៉ូន, បុត្ររបស់ម៉ូសាយ

នៅក្នុងព្រះគម្ពីរមរមន គឺជាស្ដេចលេមិន ដែលបានប្រែចិត្តជឿ ដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ និងដោយការបំផុសគំនិតពីការងារ និងការបង្រៀនទាំងឡាយរបស់អាំម៉ូន (អាលម៉ា ១៧–១៩) ។

**ឡាសារ** *សូមមើលផង* នាងម៉ាថា; នាងម៉ារា ពីភូមិបេថានី

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាប្អូនប្រុសរបស់នាងម៉ាថា និងនាងម៉ារា ។ ព្រះយេស៊ូវទ្រង់បានប្រោសគាត់ឲ្យរស់ពីស្លាប់ (យ៉ូហាន ១១:១–៤៤; ១២:១–២, ៩–១១) ។ នេះមិនមែនជាឡាសារ ដែលជាអ្នកសុំទានគេ នៅក្នុងបទប្រៀបប្រដូច ដែលព្រះយេស៊ូវទ្រង់បាន បង្រៀននោះទេ (លូកា ១៦:១៩–៣១) ។

**អ័គ្រីប៉ា** *សូមមើលផង* ប៉ុល

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាបុត្ររបស់ហេរ៉ូឌ អ័គ្រីប៉ា ទី១ ហើយជាព្រះជេដ្ឋារបស់ព្រះនាងបេរេនីស និងព្រះនាងទ្រូស៊ីល ។ ទ្រង់ជាស្ដេចស្រុកកាលស៊ីស គឺនៅក្នុងល្បាណូល ។ ទ្រង់បានស្ដាប់សាវកប៉ុល ហើយជិតបានបញ្ចុះបញ្ចូលឲ្យចូលធ្វើជាអ្នកគ្រីស្ទាន (កិច្ចការ ២៥–២៦; យ.ស. — ប្រវត្តិ ១:២៤) ។

**អ័ដាម***សូមមើលផង* ការធ្លាក់នៃលោកអ័ដាម និងនាងអេវ៉ា; នាងអេវ៉ា; មហាទេវតា; មីកែល, អ័ដាម-អុនដៃ-អាម៉ាន; អេដែន

ជាមនុស្សទី១ ដែលបានបង្កើតមកនៅលើផែនដី ។

លោកអ័ដាមជាឪពុក និងជាអយ្យកោនៃមនុស្សលោកនៅលើផែនដី ។ ការរំលងរបស់លោកនៅក្នុងសួនច្បារអេដែន (លោកុ. ៣; គ. និង ស. ២៩:៤០–៤២; ម៉ូសេ ៤) បានបណ្ដាលឲ្យលោក « ធ្លាក់ » ហើយក្លាយទៅជាមនុស្សលោក ដែលជាជំហានមួយដ៏ចាំបាច់ សំរាប់ឲ្យមនុស្សលោកជឿនលឿននៅលើផែនដី (២ នីហ្វៃ ២:១៤–២៩; អាលម៉ា ១២:២១–២៦) ។ ហេតុដូច្នេះហើយ លោកអ័ដាម និងនាងអេវ៉ាគួរតែបានទទួលកិត្តិយស ចំពោះតួនាទីរបស់ពួកគេ ក្នុងការធ្វើឲ្យយើងរាល់គ្នាមានលទ្ធភាពក្នុងការចំរើនឡើង ដ៏អស់កល្បជានិច្ច ។ លោកអ័ដាមគឺជាអ្នកពីចាស់បុរាណ ហើយក៏ស្គាល់ថា មីកែល ដែរ (ដានី. ៧; គ. និង ស. ២៧:១១; ១០៧:៥៣–៥៤; ១១៦; ១៣៨:៣៨) ។ លោកជាមហាទេវតា ហើយនឹងយាងមកឯផែនដីម្ដងទៀត ជាអយ្យកោនៃគ្រួសារមនុស្សលោក ដើម្បីប្រុងប្រៀបទទួលការយាងមកលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (គ. និង ស. ២៩:២៦) ។

ព្រះទ្រង់បានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់, **លោកុ.** ១:២៦–២៨ (ម៉ូសេ ២:២៦–២៨; អ័ប្រា. ៤:២៦–២៨) ។ ព្រះទ្រង់បានប្រទានឲ្យ មនុស្សមានអំណាចលើគ្រប់ទាំងអស់ ហើយបានបញ្ជាគេឲ្យបង្កើតកូនឲ្យចំរើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដី, **លោកុ.** ១:២៨–៣១; (ម៉ូសេ ២:២៨–៣១; អ័ប្រា. ៤:២៨–៣១) ។ ព្រះទ្រង់បានដាក់លោកអ័ដាម និងនាងអេវ៉ាឲ្យនៅក្នុងសួនច្បារអេដែន ហើយបានហាមឃាត់ពួកគេមិនឲ្យបរិភោគផ្លែហាមឃាត់, **លោកុ.** ២:៧–៩, ១៥–១៧ (ម៉ូសេ ៣:៧–៩, ១៥–១៧; អ័ប្រា. ៥:៧–១៣) ។ លោកអ័ដាមបានឲ្យឈ្មោះដល់គ្រប់អស់ទាំងសត្វដែលមានជីវិត, **លោកុ.** ២:១៩–២០ (ម៉ូសេ ៣:១៩–២០; អ័ប្រា. ៥:២០–២១) ។ លោកអ័ដាម និងនាងអេវ៉ាបានរៀបការគ្នាដោយព្រះ, **លោកុ.** ២:១៨–២៥ (ម៉ូសេ ៣:១៨–២៥; អ័ប្រា. ៥:១៤–២១) ។ លោកអ័ដាម និងនាងអេវ៉ាត្រូវអារក្សសាតាំងល្បួង បានបរិភោគផ្លែនៃដើមដឹងខុសត្រូវ ហើយត្រូវបានដេញចេញពីសួនច្បារអេដែន, **លោកុ.** ៣ (ម៉ូសេ ៤) ។ លោកអ័ដាមមានអាយុ ៩៣០ ឆ្នាំ កាលលោកទទួលមរណភាព, **លោកុ.** ៥:៥; (ម៉ូសេ ៦:១២) ។ លោកអ័ដាម គឺជាមនុស្សទី១, **គ. និង ស.** ៨៤:១៦ ។ មុនលោកស្លាប់ទៅ នោះលោកបានហៅពូជពង្សរបស់លោកដែលសុចរិតនៅឯអ័ដាម-អុនឌៃ-អាម៉ាន ហើយបានប្រទានពរដល់ពួកគេ, **គ. និង ស.** ១០៧:៥៣–៥៧ ។ លោកអ័ដាមបានថ្វាយយញ្ញបូជា, **ម៉ូសេ** ៥:៤–៨ ។ លោកអ័ដាមបានទទួលបុណ្យជ្រមុជទឹក បានទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយបានទទួលការតែងតាំងចំពោះបព្វជិតភាព, **ម៉ូសេ** ៦:៥១–៦៨ ។

**អ័ដាម-អុនឌៃ-អាម៉ាន** *សូមមើលផង* អ័ដាម

ជាកន្លែងដែលលោកអ័ដាមបានប្រទានពរដល់ពូជពង្សរបស់លោកដែលសុចរិត បីឆ្នាំមុនលោកស្លាប់ទៅ (គ. និង ស. ១០៧:៥៣–៥៦) ហើយជាកន្លែងដែលលោកនឹងមក មុនការយាងមកលើកទីពីរ (គ. និង ស. ១១៦) ។

**អ័ប្រាហាំ** *សូមមើលផង* សេចក្ដីសញ្ញាអ័ប្រាហាំ

ជាកូនប្រុសរបស់ថេរ៉ា កើតនៅអើរ ស្រុកខាល់ដេ (លោកុ. ១១:២៦, ៣១; ១៧:៥) ។ ជាព្យាការីនៃព្រះអម្ចាស់ ដែលព្រះអម្ចាស់ទ្រង់ បានធ្វើសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ច ជាមួយនឹងលោក តាមរយៈសេចក្ដីសញ្ញាទាំងនេះ នោះអស់ទាំងសាសន៍នៅលើផែនដីនឹងបានពរ ។ អ័ប្រាហាំមានឈ្មោះដើមថា អាប់រ៉ាម ។

បានទៅនៅឯហារ៉ាន ជាទីដែលថេរ៉ាស្លាប់, **លោកុ.** ១១:៣១–៣២ (អ័ប្រា. ២:១–៥) ។ ត្រូវបានហៅដោយព្រះ ឲ្យធ្វើដំណើរទៅឯកាណាន ហើយទទួលសេចក្ដីសញ្ញាពីព្រះ, **លោកុ.** ១២:១–៨ (អ័ប្រា. ២:៤, ១៥–១៧) ។ បានធ្វើដំណើរទៅស្រុកអេស៊ីព្ទ, **លោកុ.** ១២:៩–២០ (អ័ប្រា. ២:២១–២៥) ។ បានទៅនៅឯហេប្រុន, **លោកុ.** ១៣:១៨ ។ បានជួយរំដោះឡុត, **លោកុ.** ១៤:១–១៦ ។ បានជួប នឹងមិលគីស្សាដែក, **លោកុ.** ១៤:១៨–២០ ។ នាងហាការបង្កើតបានកូនប្រុសមួយជូនលោកឈ្មោះ អ៊ីសម៉ាអែល, **លោកុ.** ១៦:១៥–១៦ ។ ឈ្មោះលោកបានដូរទៅជា អ័ប្រាហាំ, **លោកុ.** ១៧:៥ ។ ព្រះអម្ចាស់ទ្រង់បានមានបន្ទូលប្រាប់អ័ប្រាហាំ និងនាងសារ៉ាថា ពួកគេនឹងបានកូនប្រុសមួយ, **លោកុ.** ១៧:១៥–២២; ១៨:១–១៤ ។ នាងសារ៉ាបង្កើតបានកូនប្រុសមួយជូនលោកឈ្មោះ អ៊ីសាក, **លោកុ.** ២១:២–៣ ។ ត្រូវបានបញ្ជាឲ្យយកអ៊ីសាកធ្វើជាយញ្ញបូជា, **លោកុ.** ២២:១–១៨ ។ នាងសារ៉ាស្លាប់ ហើយត្រូវបានបញ្ចុះ, **លោកុ.** ២៣:១–២, ១៩ ។ អ័ប្រាហាំស្លាប់ ហើយត្រូវបានបញ្ចុះ, **លោកុ.** ២៥:៨–១០ ។ ការដែលអ័ប្រាហាំស្ម័គ្រចិត្តបូជាអ៊ីសាក នោះគឺជានិមិត្តរូបអំពីព្រះ និងព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់, **យ៉ាកុប** ៤:៥ ។ បានថ្វាយដង្វាយ១ភាគ១០ដល់មិលគីស្សាដែក, **អាលម៉ា** ១៣:១៥ ។ បានឃើញ ហើយបានធ្វើទីបន្ទាល់ទុកជាមុន អំពីការយាងរបស់ព្រះគ្រីស្ទ, **ហេលេ.** ៨:១៦–១៧ ។ បានទទួលបព្វជិតភាពពីមិលគីស្សាដែក, **គ. និង ស.** ៨៤:១៤ ។ ពួកស្មោះទ្រង់ក្លាយទៅជាពូជនៃអ័ប្រាហាំ, **គ. និង ស.** ៨៤:៣៣–៣៤ (កាឡាទី ៣:២៧–២៩) ។ បាន ទទួលគ្រប់ទាំងអស់ ដោយវិវរណៈ, **គ. និង ស.** ១៣២:២៩ ។ បានទទួលភាពថ្កើងថ្កានរបស់លោក, **គ. និង ស.** ១៣២:២៩ ។ បានស្វែងរកពរនៃពួកអយ្យកោ និងការតែងតាំងចំពោះបព្វជិតភាព, **អ័ប្រា.** ១:១–៤ ។ ត្រូវបៀតបៀនដោយពួកសង្ឃក្លែងក្លាយនៅស្រុកខាល់ដេ, **អ័ប្រា.** ១:៥–១៥ ។ ត្រូវបានព្រះអម្ចាស់សង្គ្រោះ, **អ័ប្រា.** ១:១៦–២០ ។ បានរៀនអំពីព្រះអាទិត្យ ព្រះច័ន្ទ និងតារា ទាំងឡាយ, **អ័ប្រា.** ៣:១–១៤ ។ បានរៀនអំពីជីវិតមុនផែនដី និងអំពីការបង្កបង្កើត, **អ័ប្រា.** ៣:២២–២៨ ។

*គម្ពីរអ័ប្រាហាំ*-បញ្ជីបុរាណដែលបានសរសេរដោយលោកអ័ប្រាហាំ ដែលបានមកជារបស់ផងសាសនាចក្រ ក្នុងឆ្នាំ ១៨៣៥ ។ បញ្ជីទាំងនេះ និងរក្តិតសពខ្លះៗ បានរកឃើញនៅក្នុងរូងនៃពួកសាសន៍អេស៊ីព្ទ ដោយលោក អាន់តូនីយ៉ូ ឡេប្ល៉ូឡូ ដែលបានឲ្យរបស់ ទាំងនេះទៅលោក មីកែល ច័ន្ទឡេរ ។ លោកច័ន្ទឡេរបានតាំងពិពណ៌របស់ទាំងនេះនៅសហរដ្ឋ ក្នុងឆ្នាំ ១៨៣៥ ។ មិត្តភក្ដិរបស់ យ៉ូសែប ស្ម៊ីធខ្លះបានទិញរបស់ទាំងនោះពីលោកច័ន្ទឡេរ ហើយបានយករបស់ទាំងនោះទៅឲ្យព្យាការី ដែលលោកបានបកប្រែ ។ ឥឡូវនេះមានឃើញភាគខ្លះៗពីបញ្ជីទាំងឡាយនោះនៅក្នុង មុក្ដាដ៏មានតម្លៃមហិមា ។

ជំពូកទី ១ កត់ត្រានូវការពិសោធន៍ទាំងឡាយរបស់អ័ប្រាហាំនៅអ៊ើរ ស្រុកខាល់ដេ ជាទីដែលពួកសង្ឃទុច្ចរិតបានខំរកបូជាលោក ។ ជំពូកទី ២ ប្រាប់អំពីដំណើររបស់លោកទៅស្រុកកាណាន ។ ព្រះអម្ចាស់ទ្រង់បានលេចមកឯលោក ហើយបានធ្វើសេចក្ដីសញ្ញាជាមួយនឹងលោក ។ ជំពូកទី ៣ កត់ត្រាថា លោកបានមើលឃើញសាកលលោក ហើយបានយល់ពីទំនាក់ទំនងរវាងភពទាំងឡាយនៅលើមេឃ ។ ជំពូកទី ៤–៥ ជាដំណើររឿងមួយទៀតស្ដីអំពីការបង្កបង្កើត ។

*ពូជរបស់អ័ប្រាហាំ* - ជាប្រជាជនណាដែលទទួលសេចក្ដីសន្យា និងសេចក្ដីសញ្ញាទាំងឡាយ ដែលព្រះទ្រង់បានធ្វើដល់លោកអ័ប្រាហាំ ដោយការគោរពតាមក្រិត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ មនុស្សប្រុសស្រីអាចទទួលពរទាំង ឡាយនេះបាន បើសិនជាពួកគេជាពូជពង្សរបស់អ័ប្រាហាំពិត ឬក៏បានរាប់ចូលក្នុងត្រកូលរបស់លោក ដោយការឱបក្រសោបយក ដំណឹងល្អ និងដោយការទទួលបុណ្យជ្រមុជទឹក (កាឡាទី ៣:២៦–២៩; ៤:១–៧; គ. និង ស. ៨៤:៣៣–៣៤; ១០៣:១៧; ១៣២:៣០–៣២; អ័ប្រា. ២:៩–១១) ។ ពូជពង្សរបស់អ័ប្រាហាំពិត អាចបាត់បង់ពរទាំងប៉ុន្មាននោះទៅវិញ មកពីការមិនគោរពតាម (រ៉ូម ៤:១៣; ៩:៦–៨) ។

**អ័ប៊ីណាដៃ** *សូមមើលផង* ធ្វើទុក្ករកម្ម, ទុក្ករកម្ម

ជាព្យាការីសាសន៍នីហ្វៃម្នាក់ នៅក្នុងព្រះគម្ពីរមរមន ។

បានព្យាករថាព្រះអម្ចាស់ទ្រង់នឹងធ្វើទោសដល់ប្រជារាស្ត្រនៃស្ដេចណូអេ ដែលទុច្ចរិតលើកលែងតែពួកគេប្រែចិត្ត, **ម៉ូសាយ** ១១:២០–២៥ ។ ត្រូវជាប់គុកដោយសារបានព្យាករអំពីសេចក្ដីបំផ្លិចបំផ្លាញដល់ស្ដេចណូអេ និងប្រជារាស្ត្ររបស់ទ្រង់, **ម៉ូសាយ** ១២:១–១៧ ។ បានបង្រៀនពួកសង្ឃទុច្ចរិតរបស់ស្ដេចណូអេ អំពីក្រិត្យវិន័យលោកម៉ូសេ និងអំពីព្រះគ្រីស្ទ, **ម៉ូសាយ** ១២–១៦ ។ អាលម៉ាដែលជាឪពុក បានជឿ ហើយបានសរសេរពាក្យសំដីលោកទុក, **ម៉ូសាយ** ១៧:២–៤ ។ ត្រូវស្ដេចណូអេបញ្ជាឲ្យដុតដល់ស្លាប់, **ម៉ូសាយ** ១៧:២០ ។

**អ័ប៉ូកាលីព្ស** *សូមមើលផង* វិវរណៈរបស់យ៉ូហាន

គម្ពីរវិវរណៈ ជាគម្ពីរចុងក្រោយបង្អស់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី; ក៏អាចមានន័យដល់វិវរណៈណាក៏ដោយដែលពិសេស; ចេញពី ភាសាក្រេក ដែលមានន័យថា « វិវរណៈ » ឬ « បើកសម្ដែង » ។

**អ័ប៉ូគ្រីផា** *សូមមើលផង* បទព្រះគម្ពីរ, ព្រះគម្ពីរប៊ីប

ជាគម្ពីរពិសិដ្ឋទាំងឡាយរបស់សាសន៍យូដា ដែលពុំបានរួមបញ្ចូលក្នុងព្រះគម្ពីរប៊ីបរបស់ពួកហេព្រើរទេ ប៉ុន្តែបានបង្រួមទុកនៅក្នុងព្រះ គម្ពីរប៊ីបរបស់សាសនាចក្រគ្រីស្ទានខ្លះៗ ។ គម្ពីរទាំងនេះតែងតែមានសារៈសំខាន់ ក្នុងការភ្ជាប់ព្រះគម្ពីរសញ្ញាចាស់ ទៅនឹងព្រះគម្ពីរសញ្ញាថ្មី ហើយនៅក្នុងសាសនាចក្រយើង គេចាត់ថាជាគម្ពីរគួរអានដែលមានប្រយោជន៍ ។

អ័ប៉ូគ្រីផាភាគច្រើនបានបកប្រែត្រឹមត្រូវ ប៉ុន្តែមានពាក្យបញ្ចូលដែលមិនត្រឹមត្រូវ, **គ. និង ស.** ៩១:១–៣ ។ អ័ប៉ូគ្រីផាអាចមាន ប្រយោជន៍ដល់អស់អ្នកណាដែលព្រះវិញ្ញាណបានបំភ្លឺ, **គ. និង ស.** ៩១:៤–៦ ។

**អ័បេឌ-នេកោ** *សូមមើលផង* ដានីយ៉ែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ គឺជាកំឡោះបីនាក់នៃសាសន៍អ៊ីស្រាអែល ជាមួយនឹងដានីយ៉ែល ដែលត្រូវបានចាប់យកទៅឯវាំងនៃនេប៊ូក្នេសា ជាស្ដេចស្រុកបាប៊ីឡូន ។ ឈ្មោះរបស់អ័បេឌ-នេកោក្នុងភាសាហេព្រើរគឺ អ័សារា ។ កំឡោះបួននាក់មិនព្រមធ្វើឲ្យខ្លួនស្មោកគ្រោក ដោយបរិភោគសាច់ និងស្រាទំពាំងបាយជូររបស់ស្ដេចឡើយ (ដានី. ១) ។ សាដ្រាក់ មែសាក់ និងអ័បេឌ-នេកោ ត្រូវស្ដេចបោះទៅក្នុងគុកភ្លើង តែបានព្រះរាជបុត្រានៃព្រះបានជួយរក្សាជីវិតទុក (ដានី. ៣) ។

**អ័ហាប់** *សូមមើលផង* នាងយេសិបិល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាស្ដេចដ៏ទុច្ចរិតបំផុត ហើយមានអំណាចម្នាក់នៅស្រុកអ៊ីស្រាអែលខាងជើង ។ ទ្រង់បានអភិសេកនឹងនាងយេសិបិល ជាបុត្រីនៃស្ដេចស្រុកស៊ីដូន គឺតាមនាងនេះហើយ ទើបមានការថ្វាយបង្គំព្រះបាល និងព្រះអាសថារ៉ូត នៅស្រុក អ៊ីស្រាអែល (១ពង្សាវ. ១៦:២៩០–៣៣; ២ពង្សាវ. ៣:២) ហើយបានព្យាយាមកំចាត់ពួកព្យាការី និងការថ្វាយបង្គំព្រះយេហូវ៉ាចេញ (១ ពង្សាវ. ១៨:១៣) ។

បានសោយរាជ្យលើពួកអ៊ីស្រាអែល ពីស្រុកសាម៉ារី បាន ២២ ឆ្នាំ, **១ ពង្សាវ.** ១៦:២៩ (១ ពង្សាវ. ១៦–០២២) ។ បានប្រព្រឹត្តលាមកអាក្រក់នៅព្រះនេត្រព្រះអម្ចាស់ លើសជាងអស់អ្នកណាដែលនៅមុនទ្រង់ទៅទៀត, **១ ពង្សាវ.** ១៦:៣០ ។ ត្រូវប្រហារនៅក្នុងចម្បាំង, **១ ពង្សាវ.** ២២:២៩–០៤០ ។

**អណ្ដាត** *សូមមើលផង* អំណោយទានខាងភាសា

ជានិមិត្តរូបមួយអំពីសំដី ។ ពួកបរិសុទ្ធត្រូវទប់អណ្ដាតខ្លួន នោះមានន័យថាពួកគេត្រូវទប់មាត់ខ្លួន ។ *អណ្ដាត* ក៏មានន័យថា ភាសា និងមនុស្សទាំងឡាយ ។ នៅទីបញ្ចប់ គ្រប់ទាំងជង្គង់នឹងលុតចុះ ហើយគ្រប់ទាំងអណ្ដាតនឹងទទួលស្គាល់ដល់ព្រះ (អេសាយ ៤៥:២៣; រ៉ូម ១៤:១១) ។

ត្រូវឲ្យរក្សាអណ្ដាតខ្លួន ឲ្យរួចពីសេចក្ដីអាក្រក់, **ទំនុក.** ៣៤:១៣ (១ ពេត្រុស. ៣:១០) ។ អ្នកណាដែលរក្សាមាត់ និងអណ្ដាតខ្លួន នោះក៏រក្សាព្រលឹងខ្លួន ឲ្យរួចពីទុក្ខព្រួយដែរ, **សុភា.** ២១:២៣ ។ បើអ្នកណាមិនចេះទប់អណ្ដាតខ្លួន នោះសាសនារបស់អ្នកនេះ ជាឥតប្រយោជន៍ទទេ, **យ៉ាកុប** (ព.ស.ថ.) ១:២៦ ។ បើអ្នកណាមិនបានជំពប់ដោយពាក្យសំដី នោះជាមនុស្សគ្រប់លក្ខណ៍ហើយ, **យ៉ាកុប** (ព.ស.ថ.) ៣:១–០១៣ ។ ដំណឹងល្អនឹងបានថ្លែងប្រាប់ដល់គ្រប់អស់ទាំងសាសន៍គ្រប់ពូជអំបូរ គ្រប់ភាសា ហើយគ្រប់ទាំងមនុស្ស, **វិវ.** ១៤:៦–៧

(២ នីហ្វៃ ២៦:១៣; ម៉ូសាយ ៣:១៣, ២០; គ. និង ស. ៨៨:១០៣; ១១២:១) ។ ព្រះអម្ចាស់ទ្រង់បាន អនុញ្ញាតឲ្យដល់អស់ទាំងសាសន៍ គឺដោយសាសន៍ និងដោយភាសាគេផ្ទាល់ ឲ្យបង្រៀនព្រះបន្ទូលរបស់ទ្រង់, **អាលម៉ា** ២៩:៨ ។ ផ្ទាំងទាំងនេះនឹងបានចេញ ទៅគ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន, **អាលម៉ា** ៣៧:៤ ។ ចូរឲ្យបាន ព្រះបន្ទូលរបស់យើងជាមុនសិន ចុះហើយខណៈនោះ អណ្ដាតរបស់អ្នកនឹងបានធូរ, **គ. និង ស.** ១១:២១ ។ មនុស្សគ្រប់រូបនឹងបានឮ ភាពពោរពេញនៃដំណឹងល្អ ដោយនូវអណ្ដាតរបស់ខ្លួន, **គ. និង ស.** ៩០:១១ ។

**អត់ទោស, អភ័យទោស***សូមមើលផង* ការឆ្លើយសារភាព; ការផ្ដាច់បាប; ការប្រែចិត្ត ឆ្លើយសារភាព, ដង្វាយធួន; ធ្វើឲ្យធួន, ប្រែចិត្ត

ដូចដែលប្រើនៅក្នុងគម្ពីរ ដើម្បីអត់ទោស តាមធម្មតា មានន័យមួយក្នុងពីរយ៉ាង គឺៈ (១) កាលព្រះទ្រង់អត់ទោសឲ្យមនុស្ស នោះទ្រង់លុប ឬញែកទោសដែលដាប់ចេញពីអំពើបាប ។ តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ នោះការអត់ទោសដល់អំពើបាប គឺមានដល់មនុស្សទាំងអស់ណាដែលប្រែចិត្ត លើកលែងតែពួកអ្នកដែលមានទោសចំពោះការធ្វើឃាតកម្ម ឬក៏អំពើបាបដ៏អត់ឱនឲ្យមិនបាន ជំទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ ។ (២) ដូចជាមនុស្សអត់ទោសឲ្យគ្នាទៅវិញទៅមក គឺពួកគេរាប់អានគ្នាដោយសេចក្ដីស្រឡាញ់ដូចព្រះគ្រីស្ទ ហើយ គ្មានគំនុំចំពោះពួកអ្នកដែលបានទាស់នឹងខ្លួនឡើយ (ម៉ាថាយ ៥:៤៣–៤៥; ៦:១២–១៥; លូកា ១៧:៣–៤; ១ នីហ្វៃ ៧:១៩–២១ ។

ព្រះអម្ចាស់ទ្រង់យឺតនឹងខ្ញាល់ ក៏មានសេចក្ដីមេត្តាករុណាជាបរិបូរ ទ្រង់តែងអត់ទោសនៃសេចក្ដីទុច្ចរិត និងការរំលង, **ជនគ.** ១៤:១៨ ។ ទោះបើអំពើបាបរបស់អ្នកដូចជាពណ៌ក្រហមក៏ដោយ គង់តែនឹងបានសដូចហិមៈ, **អេសាយ** ១:១៨ ។ សូមអត់ទោសសេចក្ដីកំហុស របស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោសដល់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ, **ម៉ាថាយ** ៦:១២ (លូកា ១១:៤; ៣ នីហ្វៃ ១៣:១១) ។ កូនមនុស្សមានអំណាចនឹងអត់ទោសបាប, **ម៉ាថាយ** ៩:៦ (ម៉ាថាយ ១៨:៣៥; ម៉ាកុស ២:១០; លូកា ៥:២០–២៤) ។ បើបងប្អូនធ្វើបាប នឹងខ្ញុំ នោះត្រូវឲ្យខ្ញុំអត់ទោសឲ្យគេដល់ប៉ុន្មានដងទៅ ? **ម៉ាថាយ** ១៨:២១–២២ (គ. និង ស. ៩៨:៤០) ។ អ្នកណាដែលពោលពាក្យ ប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ នោះមិនដែលបានអត់ទោសឲ្យឡើយ, **ម៉ាកុស** ៣:២៩ (អាលម៉ា ៣៩:៦) ។ បើបងប្អូនធ្វើបាបនឹងអ្នក ហើយប្រែចិត្ត នោះត្រូវឲ្យអត់ទោសឲ្យគាត់ចុះ, **លូកា** ១៧:៣ ។ ព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ត្បិតគេមិនដឹងជា គេធ្វើអ្វីទេ, **លូកា** ២៣:៣៤ ។ ចូរអធិស្ឋានសូមការអភ័យទោសចុះ, **១ នីហ្វៃ** ៧:២១ ។ ចូរអនុវត្តព្រះលោហិតដ៏ធួននៃព្រះគ្រីស្ទ ដើម្បីឲ្យយើងអាចទទួលការអភ័យទោសដល់អំពើបាបរបស់យើង, **ម៉ូសាយ** ៤:២ ។ បើអ្នកនោះសារភាពនូវអំពើបាបរបស់ខ្លួន ចំពោះ អ្នក និងចំពោះយើង ហើយប្រែចិត្ត អ្នកនោះហើយ អ្នកត្រូវអត់ទោសឲ្យ, **ម៉ូសាយ** ២៦:២៩–៣១ ។ អ្នកណាដែលប្រែចិត្ត ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ នោះនឹងបានអត់ទោស, **គ. និង ស.** ១:៣២ ។ ចូរលូកកណ្ដៀវរបស់អ្នក ហើយបាបទាំងឡាយ របស់អ្នក ត្រូវបានអត់ទោសឲ្យ, **គ. និង ស.** ៣១:៥ (គ. និង ស. ៣៤:៦១) ។ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ, **គ. និង ស.** ៥៨:៤២ ។ យើងនឹងអត់ទោស ដល់អ្នកណា ដែលយើងនឹងអត់ទោស ប៉ុន្តែឯអ្នកវិញ គឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់, **គ. និង ស.** ៦៤:១០ ។ ដរាបណាអ្នកអត់ទោសដល់គ្នាទៅវិញទៅមក ចំពោះការរំលងច្បាប់របស់ខ្លួន នោះសូម្បីតែយើងជាព្រះអម្ចាស់ក្ដី ក៏អត់ទោសឲ្យអ្នកដែរ, **គ. និង ស.** ៨២:១ ។ អ្នកណាដែលយើងស្រឡាញ់ នោះយើងវាយផ្ចាល ដើម្បីឲ្យអំពើបាបទាំងឡាយរបស់ពួកគេ អាចបានអត់ទោស, **គ. និង ស.** ៩៥:១ ។ យើងបានអភ័យទោសដល់អ្នក ចំពោះអំពើរំលងរបស់អ្នក, **ម៉ូសេ** ៦:៥៣ ។

**អនទ្រេ**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាប្អូនប្រុសរបស់ស៊ីម៉ូន-ពេត្រុស ហើយជាសាវកម្នាក់ក្នុងពួក១២នាក់ ដែលព្រះយេស៊ូវទ្រង់បានហៅ កាល ទ្រង់គង់នៅលើផែនដី (ម៉ាថាយ ៤:១៨–១៩; ម៉ាកុស ១:១៦–១៨, ២៩) ។

**អន្ទរធាន***សូមមើល* ពួកកូនអន្ទរធាន

**អព្ភូតហេតុ** *សូមមើលផង* ទីសំគាល់, សេចក្ដីជំនឿ

ជាហេតុការណ៍ដ៏អស្ចារ្យមួយដែលកើតឡើង ដោយព្រះចេស្ដានៃព្រះ ។ អព្ភូតហេតុជាកត្តាដ៏សំខាន់មួយ នៅក្នុងកិច្ចការនៃព្រះយេស៊ូវគ្រីស្ទ ។ គឺព្រមទាំងមានការប្រោសឲ្យជា ប្រោសឲ្យមនុស្សស្លាប់មានជីវិតរស់ឡើងវិញ និងដំណើររស់ឡើងវិញ ។ អព្ភូតហេតុ ជាផ្នែកមួយក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សេចក្ដីជំនឿ គឺជាការចាំបាច់ ដើម្បីឲ្យមានអព្ភូតហេតុបានសម្ដែងឡើង (ម៉ាកុស ៦:៥–៦; មរមន ៩:១០–២០; អេធើរ ១២:១២) ។

កាលណាផារ៉ោននិយាយមកឯងថា ចូរឯងសម្ដែងបាដិហារិយ៍មកមើល, **និក្ខ.** ៧:៩ ។ គ្មានអ្នកណាអាចនឹងធ្វើការឫទ្ធិបារមី ដោយនូវឈ្មោះខ្ញុំ រួចនិយាយអាក្រក់ពីខ្ញុំឡើយ, **ម៉ាកុស** ៩:៣៩ ។ ភូមិកាណា គឺជាទីកន្លែងដែលព្រះយេស៊ូវបានធ្វើទីសំគាល់មុនដំបូង, **យ៉ូហាន** ២:១១ ។ យើងជាព្រះនៃអព្ភូតហេតុទាំងឡាយ, **២ នីហ្វៃ** ២៧:២៣ ។ ព្រះចេស្ដានៃព្រះសម្ដែងអព្ភូតហេតុ, **អាលម៉ា** ២៣:៦ ។ ព្រះគ្រីស្ទអាចសម្ដែងអព្ភូតហេតុដ៏ធំផង ដល់ពួកអ្នកដែលនៅឯទ្វីបអាមេរិក ពីព្រោះគេមានសេចក្ដីជំនឿដ៏ធំ, ៣ នីហ្វៃ ១៩:៣៥ ។ ព្រះទ្រង់ពុំទាន់ឈប់ទោជាព្រះនៃអព្ភូតហេតុដែរ, **មរមន** ៩:១៥ ។ ចូរកុំសូមអព្ភូតហេតុឡើយ លើកលែងតែព្រះអម្ចាស់នឹងបញ្ជាដល់អ្នក, **គ. និង ស.** ២៤:១៣–១៤ ។ ដល់មនុស្សខ្លះ ត្រូវបានប្រទានឲ្យអាចសម្ដែងអព្ភូតហេតុទាំងឡាយ, **គ. និង ស.** ៤៦:២១ (ម៉ូរ៉ូណៃ ១០:១២) ។

**អយ្យកោ, ខាងអយ្យកោ** *សូមមើលផង* គ្រូផ្សាយដំណឹងល្អ; បព្វជិតភាពមិលគីស្សាដែក; ពរនៃអយ្យកោ, ឪពុកខាងសាច់ឈាម

ព្រះគម្ពីរស្ដីអំពីអយ្យកោពីរយ៉ាងគឺៈ (១) ជាតំណែងមួយក្នុងបព្វជិតភាពមិលគីស្សាដែក ជួនកាលហៅថា គ្រូផ្សាយដំណឹងល្អ; (២) ជាឪពុកទាំងឡាយនៃគ្រួសារ ។ ពួកអយ្យកោដែលបានតែងតាំងឡើង ឲ្យពរដ៏ពិសេសទាំងឡាយ ដល់សមាជិកដែលសក្ដិសម នៅក្នុងសាសនាចក្រ ។

*ពួកអយ្យកោដែលបានតែងតាំង៖* ទ្រង់បានប្រទានឲ្យអ្នកខ្លះធ្វើជាព្យាការី និងអ្នកខ្លះជាគ្រូផ្សាយដំណឹងល្អ **អេភេ.** ៤:១១ (ម. នៃ ស. ១:៦) ។ គឺជាភារកិច្ចរបស់ពួក១២នាក់ ឲ្យតែងតាំងពួកអ្នកធ្វើការងារបំរើខាងការផ្សាយដំណឹងល្អ, **គ. និង ស.** ១០៧:៣៩ ។ ហៃរុម អាចយកតំណែងខាងបព្វជិតភាព និងខាងអយ្យកោ, **គ. និង ស.** ១២៤:៩១–៩២, ១២៤; ១៣៥:១ ។

*ពួកឪពុក៖* យ៉ាកុបបានប្រទានពរឲ្យពួកកូនៗលោក និងពូជពង្សគេ, **លោកុ.** ៤៩:១១–២៨ ។ ខ្ញុំប្រាប់ដល់អ្នករាល់គ្នាយ៉ាងច្បាស់ ពីហ្លួងដាវីឌ ជាអយ្យកោ, **កិច្ចការ** ២:២៩ ។ លីហៃបានទូន្មាន ហើយបានប្រទានពរដល់ពូជពង្សលោក, **២ នីហ្វៃ** ៤:៣–១១ ។ ខ្ញុំបានក្លាយទៅជាអ្នកគ្រងមរតកដ៏ត្រឹមត្រូវ ដោយកាន់នូវសិទ្ធិដែលជារបស់ផងពួកអយ្យកោ, **អ័ប្រា.** ១:២–៤ ។

**អមតៈ, អមតភាព** *សូមមើលផង* ដង្វាយធួន; ដំណើររស់ឡើងវិញ; ធ្វើឲ្យធួន, ព្រះយេស៊ូវគ្រីស្ទ; ភាពរមែងស្លាប់; រមែងស្លាប់, សេចក្ដីសង្គ្រោះ

ជាសភាពខាងការរស់នៅរហូត នៅក្នុងស្ថានភាពដែលបានរស់ឡើងវិញ គឺមិននៅក្រោមសេចក្ដីស្លាប់ខាងសាច់ឈាមឡើយ ។

ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ, **ម៉ាកុស** ១៦:៦ ។ គ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ, **១ កូរិន.** ១៥:២២ ។ សេចក្ដីស្លាប់បានត្រូវលេបទៅ កាលរូបកាយដែលតែងតែស្លាប់ បានប្រដាប់ដោយសេចក្ដីមិនចេះស្លាប់, **១ កូរិន.** ១៥:៥៣–៥៤ ។ ព្រះគ្រីស្ទបានបំផ្លាញសេចក្ដីស្លាប់ ហើយបានយកសេចក្ដីមិនចេះស្លាប់មក, ២ ធីម៉ូ. ១:១០ ។ អមតភាព គឺជាការប្រគល់វិញ្ញាណទៅឯរូបកាយវិញ, **២ នីហ្វៃ** ៩:១៣ ។ វិញ្ញាណដែលបានរួមជាមួយនឹងរូបកាយ នោះក្លាយទៅជាអមតៈ គឺមិនស្លាប់ទៀតឡើយ, **អាលម៉ា** ១១:៤៥ ។ ពួកស្មោះត្រង់នឹងបានពាក់មកុដ ដោយអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច, **គ. និង ស.** ៧៥:៥ ។ ផែនដីនឹងបាន ញែកចេញជាបរិសុទ្ធ ប្រកបដោយអមតភាព, **គ. និង ស.** ៧៧:១ (គ. និង ស. ១៣០:៩) ។ កិច្ចការ និងសិរីល្អរបស់ព្រះ គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស, **ម៉ូសេ** ១:៣៩ ។

**អាណ** *សូមមើលផង* កៃផា

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ជាបុរសម្នាក់ដែលមានអានុភាពដ៏ធំ នៅក្នុងក្រុមជំនុំសានហេដ្រិន ។ កាលគេចាប់ព្រះយេស៊ូវ នោះទ្រង់ត្រូវគេនាំទៅជួបលោកជាដំបូង (យ៉ូហាន ១៨:១៣); លោកក៏បាននាំមុខគេ ក្នុងការវិនិច្ឆ័យពួកសាវក (កិច្ចការ ៤:៣–៦) ។

**អាណាចក្ររ៉ូម** *សូមមើលផង* រ៉ូម

ជាអាណាចក្ររ៉ូមពីសម័យបុរាណ ។ នៅសម័យពួកសាវក អាណាចក្ររ៉ូម គឺជារាជាណាចក្រដ៏ធំមួយ នៅក្នុងពិភពលោក ។ អាណាចក្រនេះមានរួមនូវអ្វីៗទាំងអស់ រវាងទន្លេអឺប្រាត ទន្លេដានូប ទន្លេរ៉ាញ សមុទ្រអាត្លង់ទិច និងទីរហោស្ថានសាហារ៉ា ។ ស្រុកភីលីស្ទីនក្លាយទៅជារដ្ឋចំណុះ ក្នុងឆ្នាំ ៦៣ ម.គ.ស. កាល ប៉ុមពាស យកក្រុងយេរូសាឡិម ។ ទោះជាពួកសាសន៍រ៉ូមអនុញ្ញាតឲ្យពួកសាសន៍យូដាមានសិទ្ធិជាច្រើនក៏ដោយ គង់តែពួកសាសន៍យូដាស្អប់ការគ្រប់គ្រងរបស់ពួករ៉ូម៉ាំង ហើយក៏មានការបះបោរជាញឹក ញាប់ដែរ ។

ប៉ុល ជាជនជាតិរ៉ូម បានប្រើភាសាក្រេក ដែលជាភាសានិយាយទូទៅក្នុងរាជាណាចក្រ ដើម្បីផ្សាយដំណឹងល្អពាសពេញរាជាណាចក្រ ។

ចូរថ្វាយរបស់សេសារ ទៅសេសារទៅ, **ម៉ាថាយ** ២២:១៧–២២ ។ ប៉ុលបានតវ៉ាសិទ្ធិលោកជាជាតិរ៉ូម, **កិច្ចការ** ១៦:៣៧–៣៩ (កិច្ចការ ២២:២៥–២៩) ។

**អាណិត** *សូមមើលផង* មានចិត្តមេត្តាករុណា, សេចក្ដីមេត្តាករុណា, សេចក្ដីសប្បុរស; សេចក្ដីស្រឡាញ់

នៅក្នុងគម្ពីរ សេចក្ដីអាណិតមានន័យចំៗថា « រងទុក្ខជាមួយ » ។ ក៏មានន័យថា ដើម្បីសម្ដែងនូវការអាណិតអាសូរ និងសេចក្ដីមេត្តាករុណាដល់អ្នកដទៃ ។

ព្រះអម្ចាស់ទ្រង់ហៅរាស្ត្រទ្រង់ឲ្យសម្ដែងសេចក្ដីអាណិតមេត្តា, **សាការី** ៧:៨–១០ ។ ព្រះយេស៊ូវទ្រង់មានព្រះហឫទ័យក្ដួលអាណិត, **ម៉ាថាយ** ៩:៣៦ (ម៉ាថាយ ២០:៣៤; ម៉ាកុស ១:៤១; លូកា ៧:១៣) ។ មានសាសន៍សាម៉ារីម្នាក់ មានចិត្តក្ដួលអាណិតដល់គាត់, **លូកា** ១០:៣៣ ។ ចូរមានចិត្តអាណិតអាសូរដល់គ្នាទៅវិញទៅមក, **១ ពេត្រុស** ៣:៨ ។ ព្រះគ្រីស្ទក៏ពោរពេញទៅដោយចិត្តប្រោសប្រណីដល់កូនចៅមនុស្ស, **ម៉ូសាយ** ១៥:៩ ។ ចិត្តយើងពោរពេញទៅដោយសេចក្ដីអាណិតមេត្តាដល់អ្នករាល់គ្នា, ៣ នីហ្វៃ ១៧:៦ ។ យ៉ូសែប ស្ម៊ីធបានអធិស្ឋានសូមសេចក្ដីអាណិតមេត្តាពីព្រះអម្ចាស់, **គ. និង ស.** ១២១:៣–៥ ។

**អាទិទេព** *សូមមើល* ក្រុមព្រះ, ព្រះ

**អាន្នានាសពីក្រុងដាម៉ាស** *សូមមើលផង* ប៉ុល

ជាសិស្សគ្រីស្ទានម្នាក់ពីក្រុងដាម៉ាស ដែលបានធ្វើបុណ្យជ្រមុជទឹកឲ្យប៉ុល (កិច្ចការ ៩:១០–១៨; ២២:១២) ។

**អាន់តៃ-នីហ្វៃ-លីហៃ** *សូមមើលផង* បុត្ររបស់ម៉ូសាយ; ពួកកូនប្រុសរបស់លោក; ពួកបុត្រារបស់ទ្រង់, ម៉ូសាយ, ហេលេមិន, អាំម៉ូន

នៅក្នុងព្រះគម្ពីរមរមន ជាឈ្មោះដែលបានឲ្យដល់ពួកសាសន៍លេមិន ដែលបានប្រែចិត្តជឿ ដោយសារពួកបុត្រារបស់ម៉ូសាយ ។ ក្រោយពីពួកគេបានប្រែចិត្តជឿ នោះប្រជាជនទាំងនេះ ដែលហៅថា ប្រជាជនអាំម៉ូន គេមានចិត្តស្មោះត្រង់រហូតដល់អស់មួយជីវិតរបស់ពួកគេ (អាលម៉ា ២៣:៤–៧, ១៦–១៧; ២៧:២០–២៧) ។

ពួកគេបានយកឈ្មោះថា ពួកអាន់តៃ-នីហ្វៃ-លីហៃ, **អាលម៉ា** ២៣:១៦–១៧; ២៤:១ ។ ពួកគេមិនព្រមកំចាយឈាមឡើយ ហើយបានកប់សស្ត្រាវុធរបស់គេចោល, **អាលម៉ា** ២៤:៦–១៩ ។ ពួកកូនប្រុសរបស់គេបានរៀបចំទៅធ្វើសង្គ្រាម ហើយបានរើសហេលេមិនឲ្យធ្វើជាមេដឹកនាំរបស់គេ, **អាលម៉ា** ៥៣:១៦–១៩; ៥៦–៥៨ (ពួកកូនប្រុសទាំងនេះក៏បានហៅថា កងទ័ពកំឡោះ ២,០០០ នាក់) ។

**អាន្នានាសពីក្រុងយេរូសាឡិម**

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោក និងប្រពន្ធលោក គឺនាងសាភីរ៉ា បានកុហកដល់ព្រះអម្ចាស់ ដោយដកប្រាក់មួយភាគទុក ដែលខ្លួនបានថ្វាយដល់ព្រះអម្ចាស់ ។ កាលពេត្រុសស្តីបន្ទោស នោះពួកគេទាំងពីរនាក់ដួលទៅលើដី ហើយស្លាប់ទៅ (កិច្ចការ ៥:១–១១) ។

**អាប់រ៉ាម** *សូមមើល* អ័ប្រាហាំ

**អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ** *សូមមើល* រៀបអាពាហ៍ពិពាហ៍, អាពាហ៍ពិពាហ៍

**អាពាហ៍ពិពាហ៍, រៀបអាពាហ៍ពិពាហ៍** *សូមមើលផង* ការលះលែងគ្នា; គ្រួសារ

ជាសេចក្តីសញ្ញា ឬជាកិច្ចសន្យាតាមច្បាប់ រវាងបុរស និងស្ត្រី ដែលធ្វើឲ្យពួកគេទៅជាប្តីប្រពន្ធ ។ ព្រះទ្រង់បានតែងតាំងអាពាហ៍ពិពាហ៍ (គ. និង ស. ៤៩:១៥) ។

មនុស្សនេះនៅតែម្នាក់ឯង នោះមិនស្រួលទេ, **លោកុ.** ២:១៨ (ម៉ូសេ ៣:១៨) ។ មនុស្សប្រុសនឹងនៅជាប់នឹងប្រពន្ធខ្លួន ហើយគេនឹងត្រឡប់ជាសាច់តែមួយសទ្ធ, **លោកុ.** ២:២៤ (ម៉ាថាយ ១៩:៥; អ័ប្រា. ៥:១៨) ។ កុំឲ្យអ្នកណាពង្រាត់មនុស្ស ដែលព្រះទ្រង់បានផ្សំផ្គុំគ្នា ឡើយ, **ម៉ាថាយ** ១៩:៦ (ម៉ាកុស ១០:៩) ។ នៅគ្រាជាន់ក្រោយបង្អស់ អ្នកខ្លះនឹងលាចេញពីសេចក្តីជំនឿ គឺហាមប្រាមមិនឲ្យយកប្តី ប្រពន្ធ, ១ ធីម៉ូ. ៤:១–៣ ។ ការវិវាហមង្គលជាការប្រសើរ, **ហេព្រើរ** ១៣:៤ ។ ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យពួកកូនប្រុសរបស់លីហៃ យកពួកកូនស្រីរបស់អ៊ីសម៉ាអែលធ្វើជាប្រពន្ធ, **១ នីហ្វៃ** ៧:១, ៥ (១ នីហ្វៃ ១៦:៧–៨) ។ ព្រះទ្រង់បានបង្កើតអ័ដាម និងនាងអេវ៉ា ឲ្យធ្វើជាប្តីប្រពន្ធ, **ម៉ូសេ** ៣:៧, ១៨, ២១–២៥ ។

*សេចក្តីសញ្ញាថ្មី ហើយអស់កល្បជានិច្ចខាងអាពាហ៍ពិពាហ៍៖* អាពាហ៍ពិពាហ៍ដែលបានផ្សំផ្គុំ នៅក្រោមក្រិត្យវិន័យនៃ ដំណឹងល្អ និងនៅក្រោមបព្វជិតភាពដ៏បរិសុទ្ធ គឺបានផ្សំផ្គុំចំពោះជីវិតនៅលើលោកិយ និងចំពោះភាពអស់កល្បជានិច្ច ។ ម្ល៉ោះហើយ មនុស្សប្រុសស្រីដ៏សក្តិសមណាដែលបានភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ក្នុងអាពាហ៍ពិពាហ៍ នោះអាចបាននៅជាប្តីប្រពន្ធដ៏អស់កល្បជានិច្ច ។

ព្រះយេស៊ូវបានបង្រៀនអំពីក្រិត្យវិន័យនៃអាពាហ៍ពិពាហ៍, **លូកា** ២០:២៧–៣៦ ។ នៅក្នុងព្រះអម្ចាស់ នោះបុរសមិនមែនជាឥតពឹងអាស្រ័យដល់ស្ត្រីឡើយ, **១ កូរិន.** ១១:១១ ។ ប្តី និងប្រពន្ធជាអ្នកគ្រងព្រះគុណនៃជីវិត ទុកជាមរតកជាមួយគ្នា, **១ ពេត្រុស** ៣:៧ ។ អ្វីក៏ដោយដែលអ្នកនឹងភ្ជាប់នៅលើផែនដី ក៏នឹងត្រូវបានភ្ជាប់នៅលើស្ថានសួគ៌ដែរ, **ហេលេ.** ១០:៧ (ម៉ាថាយ ១៦:១៩) ។ ដើម្បីឲ្យបានលំដាប់ខ្ពស់បំផុត នោះមនុស្សត្រូវចូលក្នុងសេចក្តីសញ្ញាថ្មី ហើយអស់កល្បជានិច្ច ខាងអាពាហ៍ពិពាហ៍, **គ. និង ស.** ១៣១:១–៤ ។ បើសិនជាបុរសណាមួយពុំមែនរៀបការប្រពន្ធដោយយើងទេ នោះសេចក្តីសញ្ញា និងអាពាហ៍ពិពាហ៍របស់ពួកគេគ្មានប្រសិទ្ធិភាព ឡើយ កាលណាពួកគេស្លាប់ទៅ, **គ. និង ស.** ១៣២:១៥ ។ បើសិនជាបុរសណាមួយរៀបការប្រពន្ធដោយព្រះ បន្ទូលយើង និងដោយសេចក្តីសញ្ញាថ្មី ហើយអស់កល្បជានិច្ច នោះសេចក្តីសញ្ញានឹងបានភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យា ហើយនឹងមានប្រសិទ្ធិភាពពេញលេញ កាលពួកគេចាកចេញពីលោកិយទៅ, **គ. និង ស.** ១៣២:១៩ ។

*អាពាហ៍ពិពាហ៍រវាងសេចក្តីជំនឿ៖* ជាអាពាហ៍ពិពាហ៍រវាងមនុស្សប្រុសនឹងស្រីដែលមានជំនឿ និងការប្រព្រឹត្តខាងសាសនាខុសពីគ្នា ។

ឯងនឹងមិនយកប្រពន្ធឲ្យកូនអញ ពីពួកកូនស្រីសាសន៍កាណានឡើយ, **លោកុ.** ២៤:៣ ។ បើកាលណាយ៉ាកុបយកប្រពន្ធ ក្នុងពួកកូនស្រីសាសន៍ហេត នោះតើឲ្យខ្ញុំនៅរស់ធ្វើអ្វីទៀត ? **លោកុ.** ២៧:៤៦ (លោកុ. ២៨:១–២) ។ ពួកអ៊ីស្រាអែលមិនត្រូវនឹងរៀបការជាមួយនឹងសាសន៍កាណានឡើយ, **ចោទិ.** ៧:៣–៤ ។ ពួកអ៊ីស្រាអែលបានរៀបការជាមួយនឹងពួកសាសន៍កាណាន បានថ្វាយបង្គំព្រះក្លែងក្លាយ ហើយបានត្រូវបណ្តាសា, **ពួកចៅ.** ៣:១–៨ ។ ភរិយាទាំងឡាយនៃហ្លួងសាឡាម៉ូន បានបំបែរចិត្តទ្រង់ឲ្យទៅថ្វាយបង្គំពួកព្រះក្លែង ក្លាយ, **១ ពង្សាវ.** ១១:១–៦ ។ យើងមិនឲ្យកូនស្រីយើងទៅសាសន៍ទាំងប៉ុន្មានដែលនៅក្នុងស្រុក ឬយកកូនស្រីរបស់គេមកឲ្យកូនប្រុស យើងឡើយ, **នេហេ.** ១០:៣០ ។ កុំឲ្យទឹមនឹមស្រៀក ជានឹមមួយនឹងមនុស្សមិនជឿឡើយ, **២ កូរិន.** ៦:១៤ ។ ព្រះអម្ចាស់បានគូសចំណាំ ទៅលើពួកសាសន៍លេមិន ដើម្បីកុំឲ្យពួកសាសន៍នីហ្វៃ ទៅលាយឡំ ហើយជឿតាមសណ្តាប់ដែលមិនត្រូវនោះឡើយ, **អាលម៉ា** ៣:៦–១០ ។ បើសិនជាបុរសណាមួយពុំមែនរៀបការប្រពន្ធ ដោយយើងទេ នោះសេចក្តីសញ្ញា និងអាពាហ៍ពិពាហ៍របស់ពួកគេគ្មានប្រសិទ្ធិភាពឡើយ កាលណាពួកគេស្លាប់ទៅ, **គ. និង ស.** ១៣២:១៥ ។ ពួកកូនប្រុសនៃមនុស្សបានយកប្រពន្ធ តាមតែចិត្តគេរើស, **ម៉ូសេ** ៨:១៣–១៥ ។

*អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន៖* ជាអាពាហ៍ពិពាហ៍របស់បុរសយក

ប្រពន្ធដែលនៅរស់ពីរ ឬច្រើននាក់ ។ តាមច្បាប់បុរសត្រូវមានប្រពន្ធតែមួយគត់ លើកលែងតែព្រះអម្ចាស់ ទ្រង់បញ្ជាដោយវិវរណៈប៉ុណ្ណោះ (យ៉ាកុប ២:២៧–៣០) ។ ដោយវិវរណៈ អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើនត្រូវបានប្រព្រឹត្ត នៅសម័យព្រះគម្ពីរសញ្ញាចាស់ និងនៅសម័យដំបូងនៃសាសនាចក្រដែលបានសាងឡើងវិញ នៅក្រោមការដឹកនាំរបស់ព្យាការី ដែលកាន់កូនសោនៃបព្វជិតភាព (គ. និង ស. ១៣២:៣៤–៤០, ៤៥) ។ គ្មានការប្រព្រឹត្តនៅក្នុងសាសនាចក្រទៀតឡើយ (គ. និង ស., សេចក្ដីប្រកាស ទី ១); សព្វថ្ងៃនេះ មានប្រពន្ធច្រើនជាងម្នាក់ នោះមិនសមនឹងធ្វើជាសមាជិក ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយឡើយ ។

នាងសារ៉ាយបានឲ្យនាងហាការទៅធ្វើជាប្រពន្ធរបស់អាប់រ៉ាម, **លោកុ.** ១៦:១–១១ ។ យ៉ាកុបបានទទួលយកនាងលេអា និងនាង រ៉ាជែល ហើយនិងបាវស្រីៗរបស់គេ ធ្វើជាប្រពន្ធ, **លោកុ.** ២៩:២១–២៨ (លោកុ. ៣០:៤, ៩, ២៦) ។ បើមនុស្សប្រុសយកប្រពន្ធ មួយទៀត នោះមិនត្រូវបន្ថយរបស់ទ្រព្យនៃប្រពន្ធដើមឡើយ, **និក្ខ.** ២១:១០ ។ ដាវីឌ និងភរិយាទាំងពីរបានឡើងទៅឯហេប្រុន, **២ សាំយូ.** ២:១–២ ។ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុបបានប្រព្រឹត្តតាមការណ៍ដែលពួកគេត្រូវបានបញ្ជាឲ្យប្រព្រឹត្ត ក្នុងការទទួលយកប្រពន្ធច្រើន, **គ. និង ស.** ១៣២:៣៧ ។ ដាវីឌ និងសាឡូម៉ូនមិនបានប្រព្រឹត្តអំពើបាបណាមួយឡើយ លើកលែងតែការណ៍ទាំងនោះ ដែលគេពុំបានទទួលមកពីព្រះអម្ចាស់ប៉ុណ្ណោះ, **គ. និង ស.** ១៣២:៣៨–៣៩ ។

**អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន** *សូមមើល*
រៀបអាពាហ៍ពិពាហ៍ — អាពាហ៍ពិពាហ៍ខាងប្រពន្ធច្រើន, អាពាហ៍ពិពាហ៍

**អាម៉ាលីកាយ**

នៅក្នុងព្រះគម្ពីរមរមន ជាអ្នកក្បត់ជាតិសាសន៍នីហ្វៃម្នាក់ ដែលបានអំណាចនៅក្នុងចំណោមពួកសាសន៍លេមិន ហើយបាននាំពួកគេ មកទាស់នឹងពួកសាសន៍នីហ្វៃ (អាលម៉ា ៤៦–៥១) ។

**អាម៉ុស**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានព្យាករពីឆ្នាំ ៧៩២ ទៅ ៧៤០ ម.គ.ស. នៅក្នុងរាជ្យអូសៀស ជាស្ដេចយូដា និងយេរ៉ូបោម ជាស្ដេចអ៊ីស្រាអែល ។

*គម្ពីរអេម៉ុស*៖ ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ មានពាក្យព្យាករណ៍របស់អេម៉ុសជាច្រើន ដែលព្រមានសាសន៍អ៊ីស្រាអែល និងសាសន៍នៅជិតខាង ឲ្យបែរទៅរកសេចក្ដីសុចរិតវិញ ។

ជំពូកទី ១–៥ ហៅសាសន៍អ៊ីស្រាអែល និងសាសន៍នៅជិតខាងឲ្យប្រែចិត្ត ។ ជំពូកទី ៣ ពន្យល់ប្រាប់ថា ព្រះអម្ចាស់ទ្រង់បើកសម្ដែងសេចក្ដីអាថ៌កំបាំងទាំងឡាយ ដល់ពួកព្យាការី ហើយថា មកពីការរំលងនោះសាសន៍អ៊ីស្រាអែលនឹងត្រូវបំផ្លាញចោល ដោយមារសត្រូវ ។ ជំពូកទី ៦–៨ ព្យាករប្រាប់អំពីការរលំនៃសាសន៍អ៊ីស្រាអែល ជាច្រើនឆ្នាំមុនការលុកលុយយកដោយពួកអាសស៊ើរ ។ ជំពូកទី ៩ ព្យាករប្រាប់ថា សាសន៍អ៊ីស្រាអែលនឹងត្រូវបានសាងឡើងវិញនៅដែនដីខ្លួន ។

**អាមូលេក** *សូមមើលផង* កូនប្រុសរបស់អាលម៉ា, អាលម៉ា

នៅក្នុងព្រះគម្ពីរមរមន ជាគូកនផ្សាយសាសនានឹងអាលម៉ា ជាកូនប្រុសរបស់អាលម៉ា ។

ត្រូវបានជួបដោយទេវតាមួយ, **អាលម៉ា** ៨:២០; ១០:៧ ។ បានទទួលអាលម៉ាចូលផ្ទះលោក, **អាលម៉ា** ៨:២១–២៧ ។ បានផ្សាយដោយអំណាចដល់ប្រជាជននៃអាំម៉ូណៃហា, **អាលម៉ា** ៨:២៩–៣២; ១០:១–១១ ។ ជាពូជពង្សពីនីហ្វៃ លីហៃ និងម៉ាន៉ាសេ, **អាលម៉ា** ១០:២–៣ ។ បានធ្វើបន្ទាល់ពីសេចក្ដីពិត, **អាលម៉ា** ១០:៤–១១ ។ បានហៅប្រជាជនឲ្យប្រែចិត្ត តែត្រូវបដិសេធ, **អាលម៉ា** ១០: ១២–៣២ ។ បានតមាត់នឹងស៊ីអែសរ៉ុម, **អាលម៉ា** ១១:២០–៤០ ។ បានបង្រៀនអំពីដំណើររស់ឡើងវិញ សេចក្ដីជំនុំជំរះ និងសេចក្ដីសាងឡើងវិញ, **អាលម៉ា** ១១:៤១–៤៥ ។ ចង់បញ្ឈប់ការកាប់សម្លាប់ពួកអ្នកជឿ, **អាលម៉ា** ១៤:៩–១០ ។ ត្រូវជាប់គុកជាមួយអាលម៉ា, **អាលម៉ា** ១៤:១៤–២៣ ។ បានរួចពីគុកដោយសារសេចក្ដីជំនឿ, **អាលម៉ា** ១៤:២៤–២៩ ។ បានធ្វើបន្ទាល់ពីដង្វាយធួន សេចក្ដីមេត្តាករុណា និងសេចក្ដីយុត្តិធម៌, **អាលម៉ា** ៣៤:៨–១៦ ។ បានបង្រៀនអំពីការអធិស្ឋាន, **អាលម៉ា** ៣៤:១៧–២៨ ។ បានលើកទឹកចិត្តប្រជាជន កុំឲ្យបង្អង់ការប្រែចិត្តឡើយ, **អាលម៉ា** ៣៤:៣០–៤១ ។ សេចក្ដីជំនឿរបស់អាលម៉ា និងអាំមូលេកបានបណ្ដាលឲ្យជញ្ជាំងគុករលំ, **អេធើរ** ១២:១៣ ។

**អាម៉ែន***សូមមើលផង* ការអធិស្ឋាន

មានន័យថា « សូមឲ្យបានដូច្នោះ » ឬក៏ « ដូច្នោះមែន » ។ *អាម៉ែន* ជាពាក្យពោល ដើម្បីបង្ហាញនូវការទទួលយក និងការយល់ព្រមដ៏អស់ពីចិត្ត និងដ៏ឧឡារិក (ចោទិ. ២៧:១៤–២៦) ឬក៏បង្ហាញសេចក្ដីពិត (១ ពង្សាវ. ១:៣៦) ។ សព្វថ្ងៃនេះ នៅពេលបញ្ចប់ការអធិស្ឋាន ទីបន្ទាល់ និងការនិយាយ នោះពួកអ្នកដែលបានឮពាក្យអធិស្ឋាន ឬពាក្យថ្លែង គេអាចពោលពាក្យ*អាម៉ែន* ឲ្យឮដើម្បីបញ្ជាក់នូវការយល់ព្រម និងការទទួលស្គាល់ ។

នៅសម័យព្រះគម្ពីរសញ្ញាចាស់ ជនណាមួយអាចថា*អាម៉ែន* នៅពេលស្បថ (១ របា. ១៦:៧, ៣៥–៣៦; នេហេ. ៥:១៣; ៨:២–៦) ។ ព្រះគ្រីស្ទត្រូវបានថ្វាយព្រះនាមថា « ព្រះដ៏ជា អាម៉ែន ជាស្មរបន្ទាល់ស្មោះត្រង់ ហើយពិតប្រាកដ » (វិវរ. ៣:១៤) ។ *អាម៉ែន* ក៏យក មកប្រើជាទីសំគាល់អំពីសេចក្ដីសញ្ញា នៅក្នុងសាលានៃពួកព្យាការី (គ. និង ស. ៨៨:១៣៣–១៣៥) ។

**អាយុដែលចេះទទួលការខុសត្រូវ** *សូមមើល* ការទទួលខុសត្រូវ;
កូនក្មេង, ចេះទទួលការខុសត្រូវ, ទទួលការខុសត្រូវ,
បុណ្យជ្រមុជទឹក, ធ្វើបុណ្យជ្រមុជទឹក —
មិនមែនសំរាប់ទារកទេ; បុណ្យជ្រមុជទឹកឲ្យទារក, ពួកកូនក្មេង

**អារក្ស** *សូមមើលផង* ពួកកូនអន្ធការ; ពួកទទឹងនឹងព្រះគ្រីស្ទ; មេបំផ្លាញ; លូស៊ីហ្វើរ; វិញ្ញាណ — វិញ្ញាណអារក្សអសោចិ៍, ស្ថាននរក

ជាសាតាំង ។ អារក្សជាខ្មាំងសត្រូវនៃសេចក្ដីសុចរិត និងនៃអស់អ្នកណាដែលស្វែងរកដើម្បីប្រព្រឹត្តិតាមព្រះហឫទ័យនៃព្រះ ។ វាជា បុត្រវិញ្ញាណដ៏ពិតរបស់ព្រះហើយនៅគ្រាមួយជាទេវតាដ៏មានសិទ្ធិអំណាច នៅវត្តមាននៃព្រះ (អេសាយ ១៤:១២; ២ នីហ្វៃ ២:១៧) ។ ប៉ុន្តែវាបានបះបោរកាលនៅជីវិតមុនផែនដី ហើយបានបបួល១ភាគ៣នៃកូនចៅវិញ្ញាណរបស់ព្រះវរបិតា ឲ្យបះបោរជាមួយវា (គ. និង ស. ២៩:៣៦; ម៉ូសេ ៤:១–៤; អ័ប្រា. ៣:២៧–២៨) ។ ពួកវាត្រូវបានដេញចេញពីស្ថានសួគ៌ ហើយបដិសេធមិនឲ្យមានឱកាសនឹងបានរូបកាយខាងសាច់ឈាម ហើយស្គាល់នូវជីវិតមនុស្សលោកឡើយ ហើយនឹងមានទោសដ៏នៅអស់កល្បជានិច្ច ។ ចាប់តាំងពីគ្រា ដែលសាតាំងត្រូវបានបណ្ដេញចេញពីស្ថានសួគ៌មក នោះវាបានខំបញ្ឆោតអស់ទាំងមនុស្សប្រុសស្រី ហើយដឹកនាំពួកគេឲ្យចេញពីកិច្ចការរបស់ព្រះជានិច្ច — ដើម្បីធ្វើឲ្យអស់ទាំងមនុស្សលោកមានទុក្ខវេទនាដូចវា (វិវរ. ១២:៩; ២ នីហ្វៃ ២:២៧; ៩:៨–៩) ។

ព្រះយេស៊ូវទ្រង់បន្ទោសដល់អារក្ស, **ម៉ាថាយ** ១៧:១៨ ។ ភ្លើងដែលឆេះអស់កល្បជានិច្ច បានរៀបចំទុកសំរាប់អារក្ស ហើយនិងពួកទេវតារបស់វា, **ម៉ាថាយ** ២៥:៤១ ។ ចូរតស៊ូនឹងអារក្ស នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ, **យ៉ាកុប** (ព.ស.ថ.) ៤:៧ ។ ពួកទុច្ចរិត នឹងត្រូវធ្លាក់ទៅក្នុងការជាប់ឃុំឃាំងនៃអារក្ស, **១ នីហ្វៃ** ១៤:៧ ។ អារក្សជាបិតានៃអស់ទាំងសេចក្ដីកុហក, **២ នីហ្វៃ** ២:១៨ (ម៉ូសេ ៤:៤) ។ អារក្សព្យាយាមធ្វើឲ្យមនុស្សទាំងអស់អាចមានទុក្ខវេទនាដូចខ្លួនវា, **២ នីហ្វៃ** ២:២៧ ។ បើសាច់ឈាមមិនអាចក្រោកឡើងទៀតទេ នោះវិញ្ញាណរបស់យើងនឹងក្លាយទៅជានៅក្នុងអំណាចនៃអារក្ស, **២ នីហ្វៃ** ៩:៨–៩ ។ អារក្សនឹងញាំញី បង្ក្រាបឲ្យសុខ ហើយបញ្ឆោត, **២ នីហ្វៃ** ២៨:២០–២៣ ។ ហើយអ្វីដែលអាក្រក់ គឺមកពីអារក្សវិញ, **អោមណៃ** ១:២៧ (អាលម៉ា ៥:៤០; មរ៉ូណៃ ៧:១២, ១៧) ។ សូមប្រយ័ត្នប្រយែងចុះ ក្រែងមានការទាស់ទែងគ្នាកើតឡើង ក្នុងចំណោមអ្នករាល់គ្នា ហើយក្រែងអ្នករាល់គ្នាគោរពតាមវិញ្ញាណអារក្សអសោចិ៍, **ម៉ូសាយ** ២:៣២ ។ បើសិនជាអ្នករាល់គ្នាមិនមែនជាចៀមរបស់អ្នកគង្វាលល្អទេ នោះអារក្សជាអ្នកគង្វាលរបស់អ្នកហើយ, **អាលម៉ា** ៥:៣៨–៣៩ ។ អារក្សនឹងមិនគាំទ្រដល់កូនចៅរបស់វាទេ, **អាលម៉ា** ៣០:៦០ ។ ចូរអធិស្ឋានជានិច្ច ដើម្បីកុំឲ្យអ្នកអាចត្រូវដឹកនាំដោយសេចក្ដីល្បួងនៃអារក្ស, **អាលម៉ា** ៣៤:៣៩ (៣ នីហ្វៃ ១៨:១៥, ១៨) ។ ចូរសង់គ្រឹះនៅលើព្រះដ៏ប្រោសលោះ ដើម្បីកុំឲ្យខ្យល់ដ៏ខ្លាំងក្លារបស់អារក្ស មានអំណាចមកលើកូនឡើយ, **ហេលេ.** ៥:១២ ។ អារក្សជាអ្នកនិពន្ធនៃអស់ទាំងអំពើបាប, **ហេលេ.** ៦:២៦–៣១ ។ អារក្សបានខំរក ដើម្បីដាក់ផែនការមួយដ៏ប្រកបដោយកលល្បិច, **គ. និង ស.** ១០:១២ ។ ជាការចាំបាច់ណាស់ថា អារក្សគួរល្បួងកូនចៅមនុស្ស បើពុំនោះសោតទេ ពួកគេពុំអាចធ្វើជាភ្នាក់ងារចំពោះខ្លួនបានឡើយ, **គ. និង ស.** ២៩:៣៩ ។ លោកអ័ដាមបានក្លាយទៅជានៅក្រោមបំណងនៃអារក្ស ពីព្រោះលោកបានបណ្ដោយទៅតាមសេចក្ដីល្បួង, **គ. និង ស.** ២៩:៤០ ។ ពួកកូនអន្ធការនឹងសោយរាជ្យជាមួយនឹងអារក្ស ព្រមទាំងពួកទេវតារបស់វា នៅក្នុងភាពដ៏អស់កល្បជានិច្ច, **គ. និង ស.** ៧៦:៣៣, ៤៤ ។ សាតាំងនឹងត្រូវចងអស់រយៈពេលមួយពាន់ឆ្នាំ, **គ. និង ស.** ៨៨:១១០ (វិវរ. ២០:២) ។ អាកំណាចយកពន្លឺ និងសេចក្ដីពិតចេញ, **គ. និង ស.** ៩៣:៣៩ ។ អារក្សសាតាំងពុំបានរក្សាសណ្ឋានទីមួយរបស់ខ្លួនឡើយ, **អ័ប្រា.** ៣:២៨ ។

*សាសនាចក្រនៃអារក្ស៖* ជាអង្គការអាក្រក់ និងខាងលោកិយទាំងប៉ុន្មាននៅលើផែនដី ដែលបង្ខូចដំណឹងល្អដ៏បរិសុទ្ធ និងដ៏ល្អឥតខ្ចោះ ហើយតតាំងទាស់នឹងកូនចៀមនៃព្រះ ។

អារក្សបានបង្កើតសាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើម, **១ នីហ្វៃ** ១៣:៦ (១ នីហ្វៃ ១៤:៩) ។ មានសាសនាចក្រតែពីរប៉ុណ្ណោះ មួយគឺសាសនាចក្រនៃកូនចៀមនៃព្រះ រីឯមួយទៀត គឺសាសនាចក្រនៃអារក្ស, **១ នីហ្វៃ** ១៤:១០ (អាលម៉ា ៥:៣៩) ។ ចូរកុំប្រឆាំង នឹងសាសនាចក្រណាឡើយ លើកលែងតែសាសនាចក្រនៃអារក្ស, **គ. និង ស.** ១៨:២០ ។ សាសនាចក្រដ៏ធំ ហើយគួរខ្ពើមឆ្អើម នឹងរលំចុះ, **គ. និង ស.** ២៩:២១ ។

**អាលផា និងអូមេកា** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

អាលផាជាអក្សរទី១ ក្នុងព្យញ្ជនៈក្រេក; អូមេកាជាអក្សរចុងក្រោយបង្អស់ ។ ពាក្យនេះក៏ជាព្រះនាមថ្វាយដល់ព្រះយេស៊ូវគ្រីស្ទ ហើយបានយកមកប្រើទុកជានិមិត្តរូប ដើម្បីបង្ហាញថា ព្រះគ្រីស្ទ គឺជាដើម ហើយជាចុងក្នុងការបង្កបង្កើត (វិវរ. ១:៨; គ. និង ស. ១៩:១) ។

**អាលម៉ា, កូនប្រុសរបស់អាលម៉ា** *សូមមើលផង* ពួកបុត្រារបស់ទ្រង់, ម៉ូសាយ, អាមូលេក; អាលម៉ាជាឪពុក

នៅក្នុងព្រះគម្ពីរមរមន ជាមេចៅក្រមទី១ ហើយជាព្យាការីលើសាសន៍នីហ្វៃ ។ កាលលោកនៅវ័យក្មេង លោកបានព្យាយាមរកបំផ្លាញសាសនាចក្រចោល (ម៉ូសាយ ២៧:៨–១០) ។ ប៉ុន្តែមានទេវតាមួយបានលេចមកឲ្យលោកឃើញ ហើយលោកបានប្រែចិត្តជឿ តាមដំណឹងល្អ (ម៉ូសាយ ២៧:៨–២៤; អាលម៉ា ៣៦:៦–២៧) ។ ក្រោយមកលោកបានលាចេញពីតំណែងជាមេចៅក្រម ដើម្បីទៅ បង្រៀនប្រជាជន (អាលម៉ា ៤:១១–២០) ។

*គម្ពីរអាលម៉ា៖* ជាគម្ពីរមួយដោយឡែកនៅក្នុងព្រះគម្ពីរមរមន ដែលមានរួមនូវសេចក្ដីសង្ខេបពីបញ្ជីរបស់ព្យាការីអាលម៉ាទាំងពីរ កូនប្រុសរបស់អាលម៉ា និងកូនប្រុសរបស់ហេលេមិន ។ ហេតុការណ៍ទាំងឡាយដែលពោលដល់នៅក្នុងគម្ពីរនោះបានកើតឡើង ប្រហែលជាឆ្នាំ ៩១ ទៅ ៥២ មុនគ្រីស្ទសករាជ (ម.គ.ស.) ។ គម្ពីរនេះមាន ៦៣ ជំពូក ។ ជំពូកទី ១–៤ អធិប្បាយប្រាប់ពីការបះបោរ នៃពួកអ្នកដែលដើរតាមនីហូរ និងអាំលិសៃ ទាស់នឹងពួកសាសន៍នីហ្វៃ ។ សង្គ្រាមទាំងឡាយ

ដែលបានកើតឡើងនោះ ក្លាយទៅជាសង្គ្រាមដ៏ប្រកបដោយការបំផ្លិចបំផ្លាញយ៉ាងធំបំផុតនៅពេលនោះ ក្នុងប្រវត្តិសាស្ត្រនៃពួកសាសន៍នីហ្វៃ ។ ជំពូកទី ៥–១៦ មានដំណើររឿងពីការផ្សាយសាសនាមុនដំបូងរបស់អាលម៉ា ព្រមទាំងសេចក្ដីបង្រៀនរបស់លោក អំពីអ្នកគង្វាលល្អ (អាលម៉ា ៥) និងការផ្សាយសាសនាជាមួយអាមូលេកនៅទីក្រុងអាំម៉ូណៃហា ។ ជំពូកទី ១៧–២៧ មាននូវបញ្ជីអំពីពួកបុត្រារបស់ម៉ូសាយ និងការងារបំរើរបស់ពួកគេ នៅក្នុងចំណោមពួកសាសន៍លេមិន ។ ជំពូកទី ២៨–៤៤ មាននូវសេចក្ដីបង្រៀនរបស់អាលម៉ា ដែលសំខាន់ៗបំផុត ។ នៅក្នុងជំពូកទី ៣២ អាលម៉ាបានប្រៀបធៀបព្រះបន្ទូលទៅនឹងគ្រាប់ពូជ; នៅក្នុងជំពូកទី ៣៦ លោករៀបរាប់អំពីការប្រែចិត្តលោកប្រាប់ ហេលេមិន ជាកូនប្រុសរបស់លោក ។ ជំពូកទី ៣៩–៤២ កត់អំពីពាក្យទូន្មានរបស់លោកដល់កូនប្រុសរបស់លោក គឺកូរីអានតុន ដែលបានសេពគប់ក្នុងអំពើរំលងខាងកាមគុណ; សេចក្ដីបង្រៀនដ៏សំខាន់នេះពន្យល់ប្រាប់អំពីសេចក្ដីយុត្តិធម៌ សេចក្ដីមេត្តាករុណា ដំណើររស់ឡើងវិញ និងអំពីដង្វាយធួន ។ ជំពូកទី ៤៥–៦៣ អធិប្បាយប្រាប់អំពីសង្គ្រាមទាំងឡាយនៃពួកសាសន៍នីហ្វៃនៅពេលនោះ និងអំពីការបម្លាស់ទីលំនៅ នៅក្រោមការដឹកនាំរបស់ហាកូត ។ ពួកអ្នកដឹកនាំដ៏ឆ្នើមៗ ដូចជាមេទ័ពម៉ូរ៉ូណៃ ទីអានគុម និងលីហៃ បានជួយថែរក្សាពួកសាសន៍នីហ្វៃទុកឲ្យបានគង់វង់ ដោយសារសកម្មភាពដ៏ក្លាហាន និងទាន់ពេលរបស់ពួកគេ ។

**អាលម៉ាជាឪពុក**

ជាព្យាការីសាសន៍នីហ្វៃម្នាក់ នៅក្នុងព្រះគម្ពីរមរមន ជាអ្នកដែលបានរៀបចំសាសនាចក្រឡើង នៅសម័យស្ដេចណូអេដ៏ទុច្ចរិត ។

ជាសង្ឃរបស់ស្ដេចណូអេដ៏ទុច្ចរិតម្នាក់ ហើយជាពូជពង្សរបស់នីហ្វៃ, **ម៉ូសាយ** ១៧:១–២ ។ ក្រោយពីបានស្ដាប់ ហើយជឿតាម អ័ប៊ីណាដៃនោះលោកត្រូវស្ដេចបណ្ដេញចេញ ។ លោកបានរត់គៀសខ្លួនទៅពួនហើយបានសរសេរពាក្យសំដីរបស់អ័ប៊ីណាដៃទុក, **ម៉ូសាយ** ១៧:៣–៤ ។ បានប្រែចិត្ត ហើយបានបង្រៀននូវពាក្យសំដីរបស់អ័ប៊ីណាដៃ, **ម៉ូសាយ** ១៨:១ ។ បានធ្វើបុណ្យជ្រមុជទឹកនៅ ទឹកមរមន, **ម៉ូសាយ** ១៨:១២–១៦ ។ បានរៀបចំសាសនាចក្រឡើង, **ម៉ូសាយ** ១៨:១៧–២៩ ។ បានមកដល់ក្រុងសារ៉ាហិមឡាជា មួយនឹងប្រជាជនរបស់លោក, **ម៉ូសាយ** ២៤:២៥ ។ ត្រូវបានប្រគល់អំណាចលើសាសនាចក្រ, **ម៉ូសាយ** ២៦:៨ ។ បានជំនុំជំរះ ហើយ បានដឹកនាំសាសនាចក្រ, **ម៉ូសាយ** ២៦:៣៤–៣៩ ។ បានប្រគល់តំណែងជាសង្ឃជាន់ខ្ពស់ដល់កូនប្រុសរបស់លោក, **អាលម៉ា** ៤:៤ (ម៉ូសាយ ២៩:៤២; អាលម៉ា ៥:៣) ។

**អាសនា** *សូមមើលផង* យញ្ញបូជា

ជាសំណង់មួយដែលយកមកប្រើសំរាប់ថ្វាយយញ្ញបូជា ដង្វាយទាំងឡាយ និងសំរាប់ថ្វាយបង្គំ ។

ណូអេបានស្អាងអាសនាមួយថ្វាយព្រះអម្ចាស់ ហើយបានថ្វាយដង្វាយដុត, **លោកុ.** ៨:២០ ។ អាប់រ៉ាមបានស្អាងអាសនាមួយថ្វាយ ព្រះអម្ចាស់, **លោកុ.** ១២:៧–៨ ។ អ័ប្រាហាំបានចងអ៊ីសាក ជាកូន នៅលើអាសនា, **លោកុ.** ២២:៩ (លោកុ. ២២:១–១៣) ។ យ៉ាកុប បានស្អាងអាសនាមួយនៅទីនោះ ហើយបានហៅទីនោះថា អែល-បេត-អែល, **លោកុ.** ៣៥:៦–៧ ។ អេលីយ៉ាបានស្អាងអាសនាមួយ ហើយបានប្រកួតនឹងពួកសង្ឃនៃព្រះបាល, **១ ពង្សាវ.** ១៨:១៧–៤០ ។ បើកាលណាអ្នកនាំយកដង្វាយរបស់អ្នកមកដល់អាសនា ចូរទៅរកជានឹងបងប្អូនជាមុនសិន, **ម៉ាថាយ** ៥:២៣–២៤ ។ នោះនៅក្រោមអាសនា ខ្ញុំក៏ឃើញមានអស់ទាំងព្រលឹងរបស់មនុស្ស ដែលគេបានសម្លាប់ដោយព្រោះតែព្រះបន្ទូលនៃព្រះ, **វិវរ.** ៦:៩ (គ. និង ស. ១៣៥:៧) ។ លីហៃបានសាងអាសនាមួយពីថ្ម ហើយបានថ្លែងអំណរគុណដល់ព្រះអម្ចាស់, **១ នីហ្វៃ** ២:៧ ។ អ័ប្រាហាំត្រូវបានជួយឲ្យរួចផុតពីស្លាប់នៅលើអាសនានៃព្រះអែលកេណា, **អ័ប្រា.** ១:៨–២០ ។

**អាសស៊ើរ**

ជារាជាណាចក្របុរាណមួយ ជាមួយនឹងបាប៊ីឡូន ដែលជាគូប្រជែងគ្នា ដែលត្រួតត្រាលើរដ្ឋនៃប្រទេសស៊ីរី និងភីលីស្ទីនភាគច្រើន នៅសម័យព្រះគម្ពីរសញ្ញាចាស់ទូទៅ ។ ថ្វីបើពួកសាសន៍ស៊ីរីជាមហាអំណាចចាប់តាំងពីពាក់កណ្ដាលសតវត្សទី ១២ ម.គ.ស. ទៅដល់ចុងសតវត្សទី ៧ ម.គ.ស. ក៏ដោយ គង់តែពួកគេពុំអាចស្ថាបនាជំហរនយោបាយមួយដ៏មានស្ថិរភាពបានដែរ ។ ពួកគេគ្រប់គ្រង ដោយភេរវកម្ម កំទេចពួកខ្មាំងសត្រូវរបស់ខ្លួនដោយភ្លើង និងដាវ ឬធ្វើឲ្យគេទន់ខ្សោយដោយនិរទេសប្រជាជនភាគច្រើន ទៅកាន់កន្លែងដទៃនៅក្នុងរាជាណាចក្ររបស់គេ ។ ប្រជារាស្ត្រទាំងនោះពុំដែលឈប់ធ្វើជាសត្រូវរបស់គេឡើយ ហើយដំណើររបស់រាជាណាចក្រទាំងមូល ត្រូវបានកត់ចំណាំដោយការបះបោរឥតឈប់ឈរ ។ (សូមមើល ២ ពង្សាវ. ១៨–១៩; ២ របា. ៣២; អេសាយ ៧:១៧–២០; ១០; ១៩; ៣៧) ។

**អាហារចុងក្រោយបង្អស់** *សូមមើលផង* បុណ្យរំលង; បុណ្យរំឭក

ស្របតាមព្រះគម្ពីរសញ្ញាថ្មី គឺជាអាហារចុងក្រោយបង្អស់ ដែលព្រះយេស៊ូវទ្រង់បានសោយ មុនគេចាប់ ហើយឆ្កាងទ្រង់ (លូកា ២២:១៤–១៨) ។ ព្រះអង្គ និងពួកសាវករបស់ទ្រង់១២នាក់ បានទទួលទានអាហារនេះ នៅបុណ្យរំលង (ម៉ាថាយ ២៦:១៧–៣០; ម៉ាកុស ១៤:១២–១៨; លូកា ២២:៧–១៣) ។

ព្រះអង្គសង្គ្រោះបានប្រទានពរដល់នំប៉ុង និងស្រាទំពាំងបាយជូរ ហើយបានប្រទានដល់ពួកសាវក, **ម៉ាថាយ** ២៦:២៦–២៩ (ម៉ាកុស ១៤:២២–២៥; លូកា ២២:៧–២០) ។ ព្រះយេស៊ូវទ្រង់បានលាងជើងពួកសាវក, **យ៉ូហាន** ១៣ ។ ត្រូវបានប្រាប់ថា យូដាស ជាអ្នកក្បត់ព្រះយេស៊ូវ, **យ៉ូហាន** ១៣:២១–២៦ (ម៉ាថាយ ២៦:២០–២៥) ។

**អាហារនៃព្រះអម្ចាស់** *សូមមើល* បុណ្យរំឭក

**អ៊ីសម៉ាអែល, កូនរបស់អ័ប្រាហាំ** *សូមមើលផង* នាងហាការ, អ័ប្រាហាំ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាកូនប្រុសរបស់អ័ប្រាហាំ និងនាងហាការ ដែលជាបាវបំរើស្រីសាសន៍អេស៊ីព្ទរបស់នាងសារ៉ា (លោកុ. ១៦:១១–១៦) ។ ព្រះអម្ចាស់ទ្រង់បានសន្យាដល់អ័ប្រាហាំព្រមទាំងនាងហាការថា អ៊ីសម៉ាអែលនឹងក្លាយទៅជាឪពុកនៃសាសន៍ដ៏ធំមួយ (លោកុ. ២១:៨–២១) ។

សេចក្ដីសញ្ញាបានទៅតាមអ៊ីសាក ជាជាងទៅតាមអ៊ីសម៉ាអែល, **លោកុ.** ១៧:១៩–២១ (កាឡាទី ៤:២២–៥:១) ។ ព្រះទ្រង់បានប្រទាន ពរដល់អ៊ីសម៉ាអែលថា លោកនឹងកើតបានកូនជាច្រើន, **លោកុ.** ១៧:២០ ។ អ៊ីសម៉ាអែលជួយកប់សពលោកអ័ប្រាហាំ, **លោកុ.** ២៥:៨–៩ ។ កូនប្រុស ១២ នាក់របស់អ៊ីសម៉ាអែលត្រូវបានប្រាប់ឈ្មោះ, **លោកុ.** ២៥:១២–១៦ ។ អ៊ីសម៉ាអែលបានស្លាប់, **លោកុ.** ២៥:១៧–១៨ ។ អេសាវបានយកកូនស្រីរបស់អ៊ីសម៉ាអែល គឺនាងម៉ាហាឡាត់ ធ្វើជាប្រពន្ធ, **លោកុ.** ២៨:៩ ។

**អ៊ីសម៉ាអែល, ឪពុកក្មេករបស់នីហ្វៃ** *សូមមើលផង* លីហៃ, ឪពុករបស់នីហ្វៃ

នៅក្នុងព្រះគម្ពីរមរមន ជាបុរសម្នាក់ជាមួយនឹងគ្រួសារគាត់ បានមកចូលរួមនឹងគ្រួសារលីហៃ ក្នុងដំណើររបស់ពួកគេទៅកាន់ដែនដី សន្យា ។

នីហ្វៃ និងបងប្អូនប្រុសលោកបានវិលទៅក្រុងយេរូសាឡិមវិញ ហើយបានបបួលអ៊ីសម៉ាអែល និងគ្រួសារលោក ឲ្យទៅជាមួយនឹងលីហៃ និងគ្រួសារលោក ទៅកាន់ដែនដីសន្យា, **១ នីហ្វៃ** ៧:២–៥ ។ គ្រួសារទាំងពីរបានរៀបការនឹងគ្នា, **១ នីហ្វៃ** ១៦:៧ ។ អ៊ីសម៉ាអែល បានស្លាប់នៅក្នុងទីរហោស្ថាន, **១ នីហ្វៃ** ១៦:៣៤ ។

**អ៊ីសាខារ** *សូមមើលផង* កូនរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

ជាកូនប្រុសរបស់យ៉ាកុប និងនាងលេអា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (លោកុ. ៣០:១៧–១៨; ៣៥:២៣; ៤៦:១៣) ។ ពូជពង្សលោកកើតជាអំបូរមួយក្នុងពូជអ៊ីស្រាអែលទាំង១២អំបូរ ។

*ពូជអំបូរអ៊ីសាខារ៖* ការប្រទានពររបស់យ៉ាកុបដល់អ៊ីសាខារមាននៅក្នុងគម្ពីរលោកុ. ៤៩:១៤–១៥ ។ ក្រោយពីបានចូលមករស់នៅក្នុងស្រុកកាណាន នោះពូជអំបូរនេះបានទទួលស្រុកភិលីស្ទីនដ៏មានដីជាតិល្អបំផុត គឺមានព្រមទាំងទីវាលអេសទ្រាឡុន ។ ក្នុងព្រំដែនរបស់ពួកអ៊ីសាខារ មានទីកន្លែងសំខាន់ៗជាច្រើន នៅក្នុងប្រវត្តិនៃសាសន៍យូដា ជាឧទាហរណ៍ គើមែល មេគីដោ ដូថាន់ គិលបោ យេសរាល តាបោរ និងណាសារ៉ែត (យ៉ូស្វេ ១៩:១៧–២៣) ។

**អ៊ីសាក** *សូមមើលផង* អ័ប្រាហាំ

ជាអយ្យកោម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ កំណើតលោកពីរលោកអ័ប្រាហាំ និងនាងសារ៉ា កាលគេមានអាយុចាស់ទៅហើយនោះ គឺជាអព្ភូតហេតុមួយ (លោកុ. ១៥:៤–៦; ១៧:១៥–២១; ២១:១–៨) ។ ការដែលលោកអ័ប្រាហាំស្ម័គ្រចិត្តបូជាអ៊ីសាក គឺជានិមិត្តរូបអំពីព្រះ និងព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ (យ៉ាកុប ៤:៥) ។ អ៊ីសាក គឺជាអ្នកគ្រងមរតក ចំពោះសេចក្ដីសន្យាទាំងឡាយ នៃសេចក្ដីសញ្ញាអ័ប្រាហាំ (លោកុ. ២១:៩–១២; ១ នីហ្វៃ ១៧:៤០; គ. និង ស. ២៧:១០) ។

អ៊ីសាកបានកើតមក, **លោកុ.** ២១:១–៧ ។ ត្រូវបានយកទៅធ្វើយញ្ញបូជានៅលើភ្នំម៉ូរីយ៉ា, **លោកុ.** ២២:១–១៩ (**គ. និង ស.** ១០១:៤) ។ បានរៀបការ, **លោកុ.** ២៤ ។ មានការទាក់ទងជាមួយនឹងកូនៗលោក, **លោកុ.** ២៧:១–២៨:៩ ។ បានទទួលភាពថ្កើងថ្កានឡើងជាមួយនឹងលោកអ័ប្រាហាំ និងយ៉ាកុប, **គ. និង ស.** ១៣២:៣៧ (ម៉ាថាយ ៨:១១) ។

**អ៊ីសាយ** *សូមមើលផង* ដាវីឌ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាឪពុករបស់ដាវីឌ ហើយជាដូនតារបស់ព្រះគ្រីស្ទ និងស្ដេចទាំងអស់នៅស្រុកយូដា ។

កូនប្រុសរបស់នាងរស់ គឺអូបិឌ ដែលជាឪពុករបស់អ៊ីសាយ, **នាងរស់** ៤:១៧, ២២ ។ ដូនតារបស់អ៊ីសាយរាប់ចាប់តាំងពីយូដា, **១ របា.** ២:៥–១២ (ម៉ាថាយ ១:៥–៦) ។

**អ៊ីស្រាអែល** *សូមមើលផង* ការយកមកចិញ្ចឹមជាកូន; កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ័ប្រាហាំ— ពូជនៃអ័ប្រាហាំ

ព្រះអម្ចាស់ទ្រង់បានឲ្យឈ្មោះអ៊ីស្រាអែល ទៅយ៉ាកុប ដែលជាកូនប្រុសរបស់អ៊ីសាក ហើយជាចៅរបស់អ័ប្រាហាំ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ (លោកុ. ៣២:២៨; ៣៥:១០) ។ ឈ្មោះថា អ៊ីស្រាអែល អាចនិយាយដល់យ៉ាកុបផ្ទាល់ ពូជពង្សលោក ឬក៏នគរដែលពួកពូជពង្សលោក បានអាស្រ័យនៅសម័យព្រះគម្ពីរសញ្ញាចាស់ (២ សាំយូ. ១:២៤; ២៣:៣) ។ ក្រោយពីលោកម៉ូសេ បាននាំពួកកូនចៅអ៊ីស្រាអែលចេញពីការឃុំឃាំងរបស់សាសន៍អេស៊ីព្ទ (និក្ខ. ៣–១៤) នោះពួកគេត្រូវបានគ្រប់គ្រងដោយពួកចៅហ្វាយ អស់ជាង ៣០០ ឆ្នាំ ។ ចាប់ផ្ដើមនឹងស្ដេចសូល នោះស្ដេចទាំងឡាយបានគ្រប់គ្រងលើអ៊ីស្រាអែលទាំងមូល រហូតដល់មរណភាពរបស់ស្ដេច សាឡូម៉ូន កាលពូជទាំង ១០ អំបូរបានបះបោរចេញពីស្ដេចរេហូបោម ដើម្បីទៅរៀបចំបង្កើតប្រទេសផ្សេង ។ ក្រោយពីនគរអ៊ីស្រា អែលបានបែកចែក នោះពូជអំបូរខាងជើង ជាភាគធំជាង បានយកឈ្មោះអ៊ីស្រាអែល រីឯនគរខាងត្បូងបានហៅថា យូដា ។ សព្វថ្ងៃនេះ ស្រុកកាណានក៏បានហៅថា អ៊ីស្រាអែល ។ តាមសេចក្ដីម្យ៉ាងទៀត អ៊ីស្រាអែល មានន័យថា អ្នកជឿតាមព្រះគ្រីស្ទពិត (រ៉ូម ១០:១; ១១:៧; កាឡាទី ៦:១៦; អេភេ. ២:១២) ។

*ពូជអ៊ីស្រាអែលទាំង១២អំបូរ៖* យ៉ាកុបជាចៅរបស់លោកអ័ប្រាហាំ ដែលបានដូរឈ្មោះទៅជាអ៊ីស្រាអែល មានកូនប្រុស ១២ នាក់ ។ ពូជពង្សពួកគេត្រូវបានស្គាល់ថា ពូជអ៊ីស្រាអែល ១២ អំបូរ ឬក៏កូនចៅរបស់

អ៊ីស្រាអែល ។ នេះគឺជាពូជទាំង ១២ អំបូរ៖ រូបេន ស៊ីម្មាន លេវី យូដា អ៊ីសាខារ សាប់យូល៉ូន (ពួកកូនប្រុសរបស់យ៉ាកុបជាមួយនឹងនាងលេអា); ដាន់ និង ណែបថាលី (ពួកកូនប្រុស របស់យ៉ាកុបជាមួយនឹងនាងប៊ីលហា); កាឌ់ និង អេស៊ើរ (ពួកកូនប្រុសរបស់យ៉ាកុបជាមួយនឹងនាងស៊ីលផា); យ៉ូសែប និង បេនយ៉ាមីន (ពួកកូនប្រុសរបស់យ៉ាកុបជាមួយនឹងនាងរ៉ាជែល) (លោកុ. ២៩:៣២–៣០:២៤; ៣៥:១៦–១៨) ។

យ៉ាកុបបានប្រទានពរឲ្យអ្នកដឹកនាំពូជអំបូរនីមួយៗ មុនលោកស្លាប់ទៅ (លោកុ. ៤៩:១–២៨) ។ ចំពោះពត៌មានបន្ថែមទៀត សូមមើលតាមឈ្មោះកូនរបស់យ៉ាកុបនីមួយៗ ។

រូបេន ជាកូនប្រុសច្បងរបស់យ៉ាកុប និងប្រពន្ធទីមួយ គឺនាងលេអា បានបាត់បង់សិទ្ធិកូនច្បង និងកេរ្តិ៍មរតកពីរភាគ មកពីអំពើកាមគុណ (លោកុ. ៤៩:៣–៤) ។ សិទ្ធិកូនច្បងក៏បានទៅយ៉ូសែប ជាកូនច្បងរបស់នាងរ៉ាជែល ជាប្រពន្ធទីពីររបស់យ៉ាកុប (១ របា. ៥:១–២) ។ រីឯលេវី ជាពូជអំបូរដែលព្រះអម្ចាស់ទ្រង់បានរើសឲ្យបំរើជាអ្នកចាត់ចែងបព្វជិតភាពរបស់ទ្រង់ នោះពុំបានទទួលកេរ្តិ៍មរតកអ្វីឡើយ ពីព្រោះពីការងារដ៏វិសេស ដើម្បីជួយផ្គត់ផ្គង់ដល់គ្រប់ពូជអំបូរទាំងអស់ ។ ហេតុនេះហើយ ទើបបណ្ដោយឲ្យកេរ្តិ៍មរតករបស់យ៉ូសែប ពីរផ្នែក ដើម្បីចែកគ្នានឹងកូនប្រុសពីរនាក់របស់យ៉ូសែប គឺអេប្រាអិម និងម៉ាន៉ាសេ (១ របា. ៥:១; យេរេ. ៣១:៩) ដែលរាប់ជាអំបូរ ផ្សេងទៀតរបស់អ៊ីស្រាអែល (ក.យ.ស., លោកុ. ៤៨:៥–៦) ។

សមាជិកនៃពូជអំបូរយូដាត្រូវបានទៅជាពួកអ្នកគ្រប់គ្រង រហូតដល់ព្រះមែស៊ីយាងមក (លោកុ. ៤៩:១០; ក.យ.ស., លោកុ. ៥០:២៤) ។ នៅថ្ងៃចុងក្រោយបង្អស់ ពូជអំបូរអេប្រាអិមនឹងមានឱកាសផ្សាយដំណឹងអំពីការសាងឡើងវិញនៃដំណឹងល្អ ទៅដល់មនុស្សលោក និងអំពីការប្រមូលពួកសាសន៍អ៊ីស្រាអែល ដែលបានខ្ចាត់ខ្ចាយ (ចោទិ. ៣៣:១៣–១៧) ។ ពេលវេលានឹងមកដល់ តាមរយៈដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នោះអេប្រាអិមនឹងមានមុខងារដឹកនាំ ក្នុងការរួបរួមពូជអំបូរនៃអ៊ីស្រាអែល (អេសាយ ១១:១២–១៣; គ. និង ស. ១៣៣:២៦–៣៤) ។

*ការខ្ចាត់ខ្ចាយនៃពួកសាសន៍អ៊ីស្រាអែល៖* ព្រះអម្ចាស់ទ្រង់បានកំចាត់កំចាយ ហើយធ្វើទុក្ខដល់ពូជអ៊ីស្រាអែលទាំង ១២ អំបូរ ពីព្រោះតែអំពើឥតសុចរិត និងការបះបោររបស់ពួកគេ ។ ក៏ប៉ុន្តែ ព្រះអម្ចាស់ទ្រង់ក៏ប្រើការខ្ចាត់ខ្ចាយនៃរាស្ត្រដ៏រើសរបស់ទ្រង់ ក្នុងចំណោម សាសន៍ទាំងឡាយក្នុងលោកិយ ដើម្បីប្រទានពរដល់សាសន៍ទាំងនោះ ។

យើងនឹងកំចាត់កំចាយអ្នករាល់គ្នានៅចំណោមពួកឥតសាសនា, **លេវី.** ២៦:៣៣ ។ ព្រះអម្ចាស់ទ្រង់នឹងកំចាត់កំចាយអ្នកឲ្យទៅនៅក្នុងគ្រប់ទាំងសាសន៍, **ចោទិ.** ២៨:២៥, ៣៧, ៦៤ ។ យើងនឹងប្រគល់គេទៅឲ្យត្រូវសាត់អណ្ដែតនៅកណ្ដាល អស់ទាំងសាសន៍នៅផែនដី, **យេរេ.** ២៩:១៨–១៩ ។ យើងនឹងរែងពួកវង្សអ៊ីស្រាអែលនៅកណ្ដាលអស់ទាំងសាសន៍, **អេម៉ុស** ៩:៩ (សាការី ១០:៩) ។ ព្រះយេស៊ូវត្រូវបានចាត់ឲ្យទៅឯពួកកូនចៀម ដែលបាត់បង់របស់ពូជពង្សសាសន៍អ៊ីស្រាអែល, **ម៉ាថាយ** ១៥:២៤ ។ ខ្ញុំក៏មានចៀមឯទៀត ដែលមិនមែននៅក្នុងក្រោលនេះ, **យ៉ូហាន** ១០:១៦ ។ ពួកសាសន៍អ៊ីស្រាអែលនឹងត្រូវខ្ចាត់ខ្ចាយពាសពេញលើផ្ទៃផែនដី, **១ នីហ្វៃ** ២២:៣–៨ ។ យ៉ាកុបអធិប្បាយពាក្យប្រៀបធៀបរបស់ស៊ីណូសអំពីដើមអូលីវស្រុក និងដើមអូលីវព្រៃ, **យ៉ាកុប** ៥–៦ ។ កិច្ចការ របស់ព្រះវរបិតានឹងចាប់ផ្ដើមនៅចំណោមពួកពូជអំបូរដែលបែកខ្ញែក, ៣ នីហ្វៃ ២១:២៦ ។

*ការប្រមូលនៃសាសន៍អ៊ីស្រាអែល៖* វង្សអ៊ីស្រាអែលនឹងត្រូវបានប្រមូលនៅថ្ងៃចុងក្រោយបង្អស់ គឺមុនការយាងមកនៃព្រះគ្រីស្ទ (ម. នៃ ស. ១:១០) ។ ព្រះអម្ចាស់ទ្រង់ប្រមូលពួកអ៊ីស្រាអែល ជារាស្ត្ររបស់ទ្រង់កាលណាគេទទួលស្គាល់ទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

ទ្រង់នឹងលើកទង់ជ័យ ហើយពួកគេនឹងមក, **អេសាយ** ៥:២៦ ។ យើងនឹងទទួលអ្នកមកវិញ ដោយសេចក្ដីមេត្តាជាខ្លាំង, **អេសាយ** ៥៤:៧ ។ ពួកអ៊ីស្រាអែល និងពួកយូដា នឹងត្រូវបានត្រឡប់ទៅស្រុកគេវិញ, **យេរេ.** ៣០:៣ ។ ព្រះអម្ចាស់ទ្រង់នឹងប្រមូលវង្សអ៊ីស្រា អែល មកពីគ្រប់សាសន៍ដែលគេបានខ្ចាត់ខ្ចាយទៅនោះ, **អេសេ.** ២៨:២៥ ។ នៅការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញ កំណត់បានមកដល់ នោះទ្រង់នឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ, **អេភេ.** ១:១០ ។ ក្រោយពីពួកអ៊ីស្រាអែលបានខ្ចាត់ខ្ចាយទៅ នោះ ពួកគេនឹងបានប្រមូលមកវិញ, **១ នីហ្វៃ** ១៥:១២–១៧ ។ ព្រះអម្ចាស់ទ្រង់នឹងប្រមូលប្រជារាស្ត្រទាំងអស់ដែលជាវង្សអ៊ីស្រាអែល, **១ នីហ្វៃ** ១៩:១៦ (៣ នីហ្វៃ ១៦:៥) ។ ពួកគេនឹងត្រូវបានចេញមកពីសេចក្ដីងងឹត ហើយនឹងស្គាល់ថា ព្រះអម្ចាស់ជាព្រះអង្គសង្គ្រោះ របស់គេ, **១ នីហ្វៃ** ២២:១២ ។ ព្រះទ្រង់ប្រមូល ហើយរាប់កូនចៅរបស់ទ្រង់, **១ នីហ្វៃ** ២២:២៥ ។ សាសន៍ទាំងឡាយនៃពួក សាសន៍ដទៃ គេនឹងនាំពួកអ៊ីស្រាអែលទៅឯដែនដីកេរ្តិ៍អាកររបស់ពួកគេវិញ, **២ នីហ្វៃ** ១០:៨ (៣ នីហ្វៃ ១៦:៤) ។ រាស្ត្ររបស់យើង និងពាក្យរបស់យើងនឹងត្រូវបានប្រមូលមកតែមួយ, **២ នីហ្វៃ** ២៩:១៣–១៤ ។ ពួកអែលឌើរបានត្រូវហៅឲ្យទៅប្រមូលពួកអ្នករើសតាំង, **គ. និង ស.** ២៩:៧ (គ. និង ស. ៣៩:១១) ។ យើងនឹងប្រមូលពួកអ្នករើសតាំងរបស់យើង, **គ. និង ស.** ៣៣:៦ ។ ចូរប្រមូលគ្នាមក ដើម្បីឲ្យយើងអាចប្រទានក្រិត្យវិន័យយើងដល់អ្នករាល់គ្នា ហើយដើម្បីអ្នកអាចបានទទួលអំណោយទាន, **គ. និង ស.** ៣៨:៣១–៣៣ ។ យើងនឹងប្រមូលរាស្ត្រយើងមកវិញ ដែលត្រូវជាវង្សអ៊ីស្រាអែល, **គ. និង ស.** ៣៩:១១ ។ ពួកបរិសុទ្ធនឹងចេញមក, **គ. និង ស.** ៤៥:៤៦ ។ លោកម៉ូសេបានប្រគល់នូវកូនសោទាំងឡាយនៃការប្រមូល, **គ. និង ស.** ១១០:១១ ។ សេចក្ដីសុចរិត និងសេចក្ដីពិតនឹងបោស ផែនដី ហើយប្រមូលពួកអ្នកដ៏រើសរបស់ព្រះអម្ចាស់, **ម៉ូសេ** ៧:៦២ ។ ការប្រមូលប្រៀបធៀបទៅនឹងឥន្ទ្រីប្រជុំគ្នាជុំវិញសត្វស្លាប់, **យ.ស. — ម៉ាថាយ** ១:២៧ ។

*ពូជអ៊ីស្រាអែលទាំង១០អំបូរដែលបាត់៖* ពូជអ៊ីស្រាអែលទាំង ១០ អំបូរបានធ្វើជានគរអ៊ីស្រាអែលខាងជើង ហើយត្រូវបានចាប់យកជាឈ្លើយទៅស្រុកអាសស៊ើរ នៅឆ្នាំ ៧២១ ម.គ.ស. ។

នៅសម័យនោះ គេបានទោង « ស្រុកខាងជើងទាំងឡាយ » ហើយក៏ក្លាយទៅបាត់ដំណឹងពីអ្នកផ្សេងៗ ។ នៅគ្រាចុងក្រោយបង្អស់ នោះពួកគេនឹងវិលមកវិញ ។

យើងនឹងបង្គាប់ដល់ទិសខាងជើងថា ចូរប្រគល់គេមក, **អេសាយ** ៤៣:៦ ។ ពួកនេះនឹងមកពីទិសខាងជើង, **អេសាយ** ៤៩:១២ (១ នីហ្វៃ ២១:១២) ។ ពួកយូដា និងពួកអ៊ីស្រាអែលនឹងចេញពីស្រុកខាងជើងជាមួយគ្នា, **យេរេ.** ៣:១៨ ។ ដូចជាព្រះអម្ចាស់មានព្រះជន្មរស់ ដែលទ្រង់បាននាំពួកកូនចៅអ៊ីស្រាអែល ឡើងរួចពីស្រុកខាងជើងមក, **យេរេ.** ១៦:១៤–១៦ ។ អញនឹងនាំគេមកពីស្រុកខាងជើង, **យេរេ.** ៣១:៨ ។ ពួកសាសន៍នីហ្វៃ និងពួកសាសន៍យូដានឹងបានពាក្យនៃពូជអ៊ីស្រាអែលដែលបាត់ទៅទាំងប៉ុន្មាន, **២ នីហ្វៃ** ២៩:១២–១៣ ។ យើងនឹងបង្ហាញខ្លួនដល់ពូជអ៊ីស្រាអែលដែលបាត់ទៅទាំងប៉ុន្មាន, ៣ នីហ្វៃ ១៧:៤ ។ នៅពេលដំណឹងល្អបានផ្សាយដល់ពួកសំណល់នៃវង្សអ៊ីស្រាអែល នោះពូជអំបូរដែលបាត់នឹងត្រូវបានប្រមូលមកផ្ទះ គឺមកឯដែនដីនៃកេរ្ដិ៍អាកររបស់ពួកគេវិញ, ៣ នីហ្វៃ ២១:២៦–២៩ ។ លោកម៉ូសេបានប្រគល់នូវកូនសោទាំងឡាយ នៃការប្រមូលសាសន៍អ៊ីស្រាអែល ដល់យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី, **គ. និង ស.** ១១០:១១ ។ ពួកអ្នកដែលនៅស្រុកទាំងឡាយនៅទិសខាងជើង នឹងត្រូវបាននឹកចាំនៅចំពោះ ព្រះអម្ចាស់, **គ. និង ស.** ១៣៣:២៦–៣២ ។ យើងខ្ញុំជឿចំពោះការប្រមូលដ៏ពិតប្រាកដនៃសាសន៍អ៊ីស្រាអែល, **ម. នៃ ស.** ១:១០ ។

**អូបាឌា**

ជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានទាយទុកជាមុនអំពីការធ្លាក់វេទនានៃស្រុកអេដុំម ។ លោកប្រហែលជាបានព្យាករនៅសម័យរាជ្យយ៉ូរ៉ាម (ឆ្នាំ ៨៤៣–៨៤៤ ម.គ.ស.) ឬនៅសម័យកាលលុកលុយយកស្រុកដោយពួកសាសន៍បាប៊ីឡូន នៅឆ្នាំ ៥៨៦ ម.គ.ស. ។

*គម្ពីរអូបាឌា៖* ជាគម្ពីរមួយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ គឺមានជំពូកតែមួយគត់ ។ នៅក្នុងគម្ពីរនេះ អូបាឌាបានសរសេរអំពីការរលំនៃសាសន៍អេដំម ហើយបានព្យាករថា ពួកអ្នកសង្គ្រោះនឹងឈរនៅលើភ្នំស៊ីយ៉ូន ។

**អូបិឌ** *សូមមើលផង* នាងរស់, បូអូស

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់បូអូស និងនាងរស់ ហើយឪពុករបស់អ៊ីសាយ ដែលក្លាយទៅបិតានៃស្ដេចដាវីឌ (នាងរស់ ៤:១៣–១៧, ២១–២២) ។

**អូមេកា** *សូមមើល* ព្រះយេស៊ូវគ្រីស្ទ, អាលផា និងអូមេកា

**អើម៉ាគេដូន** *សូមមើលផង* កុក; ម៉ាកុក; ការយាងមកលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ

ឈ្មោះថា*អើម៉ាគេដូន* គឺមកពីពាក្យហេព្រើរ*ហារមេគីដូន* ដែលមានន័យថា « ភ្នំមេគីដូន » ។ ច្រកភ្នំមេគីដូន នៅខាងលិចវាល អេសដ្រាឡូន គឺ ៥០ ម៉ៃ (៨០ គ.ម.) ខាងជើងក្រុងយេរូសាឡិម ហើយជាកន្លែងមួយដែលមានកើតចម្បាំងដ៏សំខាន់ៗជាច្រើន នៅសម័យព្រះគម្ពីរសញ្ញាចាស់ ។ ចម្បាំងដ៏ធំ និងចុងក្រោយបង្អស់នឹងកើតឡើងនៅជិតពេលនៃការយាងមកលើកទីពីរ នៃព្រះអម្ចាស់ គឺហៅថាចម្បាំងអើម៉ាគេដូន ព្រោះវានឹងចាប់ផ្ដើមឡើងនៅកន្លែងដដែលនោះ (មើល អេសេ. ៣៩:១១; សាការី ១២–១៤, ជាពិសេស ១២:១១; វិវរ. ១៦:១៤–២១) ។

**អើរ**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ក្រុងអើរនៅស្រុកខាល់ដេ គឺជាភូមិកំណើតរបស់អាប់រ៉ាម (លោកុ. ១១:២៧–២៨, ៣១; ១៥:៧; នេហេ. ៩:៧; អ័ប្រា. ២:១, ៤) ។

**អើរ៉ុន, បងប្រុសរបស់ម៉ូសេ** *សូមមើលផង* បព្វជិតភាពអើរ៉ុន; ម៉ូសេ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់អាំរ៉ាម និងយ៉ូកិបិតពីពូជអំបូររបស់លេវី (និក្ខ. ៦:១៦–២០); ជាបងប្រុសរបស់ម៉ូសេ (និក្ខ. ៧:៧) ។

ត្រូវបានតែងតាំងឡើងដោយព្រះអម្ចាស់ ឲ្យជួយម៉ូសេក្នុងការនាំកូនចៅអ៊ីស្រាអែល ចេញពីស្រុកអេស៊ីព្ទ ហើយឲ្យធ្វើជាអ្នកនិយាយជំនួសលោក, **និក្ខ.** ៤:១០–១៦, ២៧–៣១; ៥:១–១២:៥១ ។ នៅលើភ្នំស៊ីណាយម៉ូសេបានទទួលសេចក្ដីដឹកនាំទាំងឡាយអំពីតំណែងរបស់អើរ៉ុន និងកូនប្រុសរបស់គាត់បួននាក់ ឲ្យកាន់បព្វជិតភាពអើរ៉ុន, **និក្ខ.** ២៨:១–៤ ។ បានធ្វើកូនគោមាស តាមសំណូមពររបស់ប្រជាជន, **និក្ខ.** ៣២:១–៦, ២១, ២៤, ៣៥ ។ បានទទួលមរណភាពនៅលើភ្នំហោរ អាយុ ១២៣ ឆ្នាំ, **ជនគ.** ២០:២២–២៩ (ជនគ. ៣៣:៣៨–៣៩) ។ ព្រះអម្ចាស់ទ្រង់បានបញ្ជាក់បព្វជិតភាពមកលើអើរ៉ុន ព្រមទាំងទៅលើពូជរបស់គាត់ផង, **គ. និង ស.** ៨៤:១៨, ២៦–២៧, ៣០ ។ អស់អ្នកណាដែលដំកើងតំណែងខាងបព្វជិតភាព នោះក្លាយទៅជាកូនប្រុសរបស់ម៉ូសេ និងអើរ៉ុន, **គ. និង ស.** ៨៤:៣៣–៣៤ ។ ព្រះអម្ចាស់ទ្រង់នឹងរាប់ថាសុចរិត នូវកិច្ចការដ៏សុចរិតទាំងឡាយនៃអស់អ្នកណា ដែលបានហៅដោយព្រះវរបិតា ដូចជាអើរ៉ុនដែរ, **គ. និង ស.** ១៣២:៥៩ ។

**អើរ៉ុន, បុត្ររបស់ម៉ូសាយ** *សូមមើលផង* ម៉ូសាយ, បុត្ររបស់បេនយ៉ាមីន; ម៉ូសាយ, បុត្រាទាំងឡាយរបស់ទ្រង់

នៅក្នុងព្រះគម្ពីរមរមន គឺជាបុត្ររបស់ស្ដេចម៉ូសាយ ។ អើរ៉ុនបំរើធ្វើជាសាសនទូតម្នាក់ ដែលប្រកបដោយចិត្តខំប្រឹងប្រែង ក្នុងការជួយមនុស្សជាច្រើនឲ្យប្រែចិត្តជឿដល់ព្រះគ្រីស្ទ ។

ជាអ្នកដែលមិនជឿម្នាក់ ដែលខំស្វែងរកបំផ្លាញសាសនាចក្រ, **ម៉ូសាយ** ២៧:៨–១០, ៣៤ ។ មានទេវតាមួយបានលេចមកឲ្យលោក និងពួកគូកនលោកឃើញ, **ម៉ូសាយ** ២៧:១១ ។ បានប្រែចិត្ត ហើយបានចាប់ផ្ដើមបង្រៀនព្រះបន្ទូលនៃព្រះ, **ម៉ូសាយ** ២៧:៣២–២៨:៨ ។ បានប្រកែកមិនព្រមធ្វើជាស្ដេច ហើយផ្ទុយទៅវិញ បានទោងដែនដីនៃពួក

សាសន៍លេមិន ដើម្បីផ្សាយព្រះបន្ទូលនៃព្រះ, **អាលម៉ា** ១៧:៦–៩ ។ បានតមអាហារ ហើយអធិស្ឋានសូមការណែនាំ, **អាលម៉ា** ១៧:៨–១១ ។ បានបង្រៀនបិតារបស់ស្ដេចឡាម៉ូណៃ, **អាលម៉ា** ២២:១–២៦ ។ បានទៅផ្សាយដល់ពួកសាសន៍សូរាំ, **អាលម៉ា** ៣១:៦–៧ ។

**អេដែន** *សូមមើលផង* នាងអេវ៉ា, អ័ដាម;

ជាទីលំនៅរបស់ឪពុកម្ដាយមនុស្សដំបូងរបស់យើង គឺលោកអ័ដាម និងនាងអេវ៉ា (លោកុ. ២:៨–៣:២៤; ៤:១៦; ២ នីហ្វៃ ២:១៩–២៥; ម៉ូសេ ៣, ៤; អ័ប្រា. ៥) ដែលបានហៅជាសួនច្បារ គឺនៅទិសខាងកើតស្រុកអេដែន ។ លោកអ័ដាម និងនាងអេវ៉ាត្រូវបានបណ្ដេញចេញពីអេដែន បន្ទាប់ពីបានបរិភោគផ្លែឈើហាមឃាត់ ហើយបានក្លាយទៅជាមនុស្ស (ម៉ូសេ ៤:២៩) ។ វិវរណៈនៅថ្ងៃចុងក្រោយ បញ្ជាក់នូវដំណើររឿងក្នុងព្រះគម្ពីរ អំពីសួនច្បារអេដែន ។ គឺពតិមានបន្ថែមដ៏សំខាន់ថា សួនច្បារបានស្ថិតនៅលើទីដែលឥឡូវនេះ ស្គាល់ថា ជាទ្វីបអាមេរិកខាងជើង (គ. និង ស. ១១៦; ១១៧:៨) ។

**អេណុស, កូនប្រុសរបស់យ៉ាកុប**

ជាព្យាការីសាសន៍នីហ្វៃ ហើយជាអ្នកកត់បញ្ជីម្នាក់ នៅក្នុងព្រះគម្ពីរមរមន ដែលបានអធិស្ឋានសូម ហើយបានទទួលការផ្ដាច់បាបរបស់លោក ដោយសារសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ (អេណុស ១:១–៨) ។ ព្រះអម្ចាស់ទ្រង់បានធ្វើសេចក្ដីសញ្ញានឹងអេណុសថា នឹងនាំព្រះគម្ពីរមរមនចេញមកឲ្យពួកសាសន៍លេមិន (អេណុស ១:១៥–១៧) ។

*គម្ពីរអេណុស៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរមរមន ដែលប្រាប់អំពីពាក្យអធិស្ឋានរបស់អេណុស ដល់ព្រះអម្ចាស់ សូមការអត់ទោសផ្ទាល់ខ្លួន ហើយជំនួសប្រជារាស្ត្រលោក និងជំនួសអ្នកផ្សេងៗទៀត ។ ព្រះអម្ចាស់ទ្រង់បានសន្យានឹងលោកថា ព្រះគម្ពីរមរមននឹងត្រូវបានរក្សាទុក ហើយនឹងធ្វើឲ្យមានដល់ពួកសាសន៍លេមិននៅថ្ងៃក្រោយ ។ ទោះជាគម្ពីរមានតែមួយជំពូកក៏ដោយ គង់តែបានកត់នូវរឿងដ៏អស្ចារ្យ អំពីបុរសម្នាក់ដែលបានស្វែងរកព្រះរបស់លោក ដោយការអធិស្ឋាន បានរស់នៅដោយគោរពតាមបញ្ញត្តិទាំងឡាយរបស់ព្រះ ហើយមុនលោកស្លាប់ទៅ នោះលោកមានសេចក្ដីអំណរចំពោះការចេះដឹងរបស់លោកអំពីព្រះដ៏ប្រោសលោះ ។

**អេធើរ** *សូមមើលផង* ពួកសាសន៍យ៉ារេឌ

ជាព្យាការីសាសន៍យ៉ារេឌចុងក្រោយបង្អស់ម្នាក់ នៅក្នុងព្រះគម្ពីរមរមន (អេធើរ ១២:១–២) ។

*គម្ពីរអេធើរ៖* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរមរមន ដែលមានភាគទាំងឡាយអំពីបញ្ជីរបស់ពួកសាសន៍យ៉ារេឌ ។ ពួកសាសន៍យ៉ារេឌ ជាក្រុមមនុស្សដែលបាននៅលើអឌ្ឍគោលខាងលិចជាច្រើនសតវត្សមុនប្រជាជនលីហៃ ។ គម្ពីរអេធើរបានដកស្រង់ចេញពីផ្ទាំង ២៤ សន្លឹក ដែលប្រជាជនលិមហៃបានរកឃើញ (ម៉ូសាយ ៨:៨–៩) ។

ជំពូកទី ១–២ ប្រាប់អំពីពួកសាសន៍យ៉ារេឌបានចេញពីផ្ទះគេនៅសម័យប៉មបាបិល ហើយបានចាប់ផ្ដើមដំណើរគេទៅកន្លែង ដែលឥឡូវនេះស្គាល់ថា ទ្វីបអាមេរិក ។ ជំពូកទី ៣–៦ ពន្យល់ប្រាប់ថា បងប្រុសយ៉ារេឌបានឃើញព្រះអង្គសង្គ្រោះមុនជីវិតនៅលើផែនដី ហើយថាពួកសាសន៍យ៉ារេឌបានធ្វើដំណើរដោយកេត្រាប្រាំបីក្ដោង ។ ជំពូកទី ៧–១១ បន្តប្រាប់ពីប្រវត្តិនៃសេចក្ដីទុច្ចរិត ដែលមានទូទៅក្នុងប្រវត្តិនៃពួកសាសន៍យ៉ារេឌជាច្រើន ។ មរ៉ូណៃ ជាអ្នកពិនិត្យបញ្ជីអេធើរបន្ទាប់មក បានសរសេរក្នុងជំពូកទី ១២–១៣ អំពីការអស្ចារ្យទាំងឡាយ ដែលបានកើតឡើងដោយសេចក្ដីជំនឿ និងអំពីព្រះគ្រីស្ទ និងអំពីក្រុងយេរូសាឡិមថ្មី ដែលនឹងមក ។ ជំពូកទី ១៤–១៥ ប្រាប់អំពីពួកសាសន៍យ៉ារេឌ បានក្លាយទៅជាសាសន៍ខ្លាំងពូកែមួយ ប៉ុន្តែបានត្រូវបំផ្លាញចោលដោយសារសង្គ្រាមគ្នាឯង មកពីសេចក្ដីទុច្ចរិត ។

**អេប្រាអិម** *សូមមើលផង* កូនប្រុសរបស់យ៉ាកុប; ព្រះគម្ពីរមរមន; ម៉ាន៉ាសេ, យ៉ូសែប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសទីពីរ របស់យ៉ូសែប និងនាងអាសនេត (លោកុ. ៤១:៥០–៥២; ៤៦:២០) ។ ខុសពីទំនៀមទំលាប់ធម្មតា អេប្រាអិមបានទទួលពរខាងសិទ្ធិកូនច្បង ជំនួសម៉ាន៉ាសេ ដែលជាកូនប្រុសច្បង (លោកុ. ៤៨:១៧–២០) ។ អេប្រាអិមកើតជាឪពុក នៃពូជអំបូររបស់អេប្រាអិម ។

*ពូជអំបូររបស់អេប្រាអិម៖* អេប្រាអិមត្រូវបានទទួលសិទ្ធិកូនច្បង នៅស្រុកអ៊ីស្រាអែល (១ របា. ៥:១–២; យេរេ. ៣១:៩) ។ នៅថ្ងៃចុងក្រោយបង្អស់ នោះកម្មសិទ្ធ និងភារកិច្ចរបស់ពួកគេ គឺកាន់បព្វជិតភាព, នាំសារអំពីដំណឹងល្អដែលបានសាងឡើងវិញទៅដល់ពិភព លោក, ហើយលើកទង់ ដើម្បីប្រមូលសាសន៍អ៊ីស្រាអែលដែលខ្ចាត់ខ្ចាយ (អេសាយ ១១:១២–១៣; ២ នីហ្វៃ ២១:១២–១៣) ។ ពួកកូនចៅអេប្រាអិមនឹងបំពាក់សិរីល្អជាមកុដឲ្យពួកអ្នកមកពីស្រុកខាងជើងទាំងឡាយ ដែលនឹងត្រឡប់មកវិញ នៅថ្ងៃចុងក្រោយបង្អស់ (គ. និង ស. ១៣៣:២៦–៣៤) ។

*បន្ទះឈើនៃអេប្រាអិម ឬយ៉ូសែប៖* ជាបញ្ជីនៃក្រុមមួយចេញពីពូជអំបូររបស់អេប្រាអិម ដែលបាននាំចេញពីក្រុងយេរូសាឡិមទៅអាមេរិក នៅប្រហែល ៦០០ មុន គ.ស. ។ បញ្ជីនៃក្រុមនេះហៅថា បន្ទះឈើនៃអេប្រាអិម ឬយ៉ូសែប ឬក៏ព្រះគម្ពីរមរមន ។ បន្ទះឈើនេះ និងបន្ទះឈើនៃយូដា (ព្រះគម្ពីរប៊ីប) ផ្ដល់ទីបន្ទាល់អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ អំពីដំណើររស់ឡើងវិញ និងអំពីកិច្ចការដ៏ឧត្ដមរបស់ទ្រង់ នៅក្នុងចំណោមចំណែកទាំងពីរនេះក្នុងវង្សអ៊ីស្រាអែល ។

មែកនៃអេប្រាអិមនឹងត្រូវកាត់ចេញ ហើយនឹងសរសេរសក្ខីបទមួយទៀតអំពីព្រះគ្រីស្ទ, **ក.យ.ស.**, លោកុ. ៥០:២៤–២៦, ៣០–៣១ ។ បន្ទះឈើនៃយូដា និងបន្ទះឈើនៃយ៉ូសែបនឹងបានទៅជាបន្ទះមួយ, **អេសេ.** ៣៧:១៥–១៩ ។ ការសរសេរនៃយូដា និងការសរសេរនៃយ៉ូសែបនឹងដុះរួមគ្នា, **២ នីហ្វៃ** ៣:១២ ។ ព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលទៅសាសន៍ជាច្រើន, **២ នីហ្វៃ** ២៩ ។ កូនសោទាំងឡាយ នៃបញ្ជីពីបន្ទះឈើនៃអេប្រាអិមត្រូវបានប្រគល់ឲ្យទៅមរ៉ូណៃ, **គ. និង ស.** ២៧:៥ ។

**អេបិល**_សូមមើលផង_ កាអ៊ីន, អ័ដាម

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជាកូនប្រុសរបស់លោកអ័ដាម និងនាងអេវ៉ា ។

បានថ្វាយដល់ព្រះនូវយញ្ញបូជាដែលល្អប្រសើរជាងបងប្រុសលោក គឺកាអ៊ីន, **លោកុ.** ៤:៤–៥ (ហេព្រើរ ១១:៤; ម៉ូសេ ៥:១៦–២១) ។ ត្រូវកាអ៊ីនសម្លាប់, **លោកុ.** ៤:៨ (ម៉ូសេ ៥:៣២) ។ បានទទួលបព្វជិតភាពពីអ័ដាម, **គ. និង ស.** ៨៤:១៦ ។ អារក្សសាតាំងបានរួម គំនិតនឹងកាអ៊ីន ដើម្បីសម្លាប់អេបិល, **ម៉ូសេ** ៥:២៨–៣១ (ហេលេ. ៦:២៧) ។

**អេប្រុន**

ជាទីក្រុងបុរាណមួយនៅស្រុកយូដា នៅ ៣២ គ.ម ខាងត្បូងក្រុងយេរូសាឡិម ។ ជាកន្លែងកប់លោកអ័ប្រាហាំ និងគ្រួសារលោក (លោកុ. ៤៩:២៩–៣២) ។ ជារាជធានីរបស់ស្តេចដាវីឌ នៅគ្រាដំបូងនៃរាជ្យទ្រង់ (២ សាំយូ. ៥:៣–៥) ។

**អេភេសូរ, សំបុត្រដល់ពួក**_សូមមើលផង_ ប៉ុល; សំបុត្ររបស់ប៉ុល

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាសំបុត្រមួយដែលបានសរសេរដោយសាវកប៉ុល ទៅដល់ពួកបរិសុទ្ធ នៅឯអេភេសូរ ។ សំបុត្រគឺមានសារៈសំខាន់ដ៏ធំ ព្រោះមានការបង្រៀនរបស់ប៉ុល អំពីសាសនាចក្រនៃព្រះគ្រីស្ទ ។

ជំពូកទី ១ មានការសួរសុខទុក្ខធម្មតា ។ ជំពូកទី ២–៣ ពន្យល់ប្រាប់ពីការប្រែប្រួលដែលកើតឡើងដល់ប្រជាជន កាលគេក្លាយទៅជា សមាជិកនៃសាសនាចក្រ — ពួកគេក្លាយទៅជាជាតិតែមួយនឹងពួកបរិសុទ្ធ ដោយមានពួកសាសន៍ដទៃ និងសាសន៍យូដារួបរួមគ្នាក្នុងសាសនាចក្រតែមួយ ។ ជំពូកទី ៤–៦ ពន្យល់ប្រាប់ពីតំណែងរបស់ពួកសាវក និងពួកព្យាការី សេចក្តីត្រូវការឲ្យបានសមាគ្គីគ្នា និងសេចក្តីត្រូវការពាក់គ្រឿងការពារនៃព្រះទាំងមូល ។

**អេម៉ាញូអែល** _សូមមើលផង_ ព្រះយេស៊ូវគ្រីស្ទ

ជាព្រះនាមមួយថ្វាយដល់ព្រះយេស៊ូវគ្រីស្ទ ។ គឺមកពីពាក្យក្នុងភាសាហេព្រើរ ដែលមានន័យថា « ព្រះអង្គទ្រង់គង់នៅជាមួយនឹងយើង ខ្ញុំ » ។

អេម៉ាញូអែល គឺជានាមមួយ ទុកជាទីសំគាល់អំពីការរំដោះរបស់ព្រះ (អេសាយ ៧:១៤) សេចក្តីយោងរបស់អេសាយអំពីអេម៉ាញូអែលគឺបានបញ្ជាក់យ៉ាងច្បាស់ដោយលោកម៉ាថាយ ទុកជាពាក្យព្យាករណ៍អំពីកំណើតរបស់ព្រះយេស៊ូវ មកក្នុងជីវិតខាងសាច់ឈាម (ម៉ាថាយ ១:១៨–២៥) ។ នាមនេះក៏មាននៅក្នុងគម្ពីរថ្ងៃចុងក្រោយ (២ នីហ្វៃ ១៧:១៤; ២ នីហ្វៃ ១៨:៨; គ. និង ស. ១២៨:២២) ។

**អេលី**_សូមមើលផង_ ព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់, សាំយូអែល

ជាសង្ឃជាន់ខ្ពស់ ហើយជាចៅហ្វាយម្នាក់ ក្នុងព្រះគម្ពីរសញ្ញាចាស់ ក្នុងកាលព្រះអម្ចាស់ទ្រង់បានហៅសាំយូអែលឲ្យធ្វើជាព្យាការី (១ សាំយូ. ៣) ។ ព្រះអម្ចាស់ទ្រង់បន្ទោសលោក ដោយសារការប្រណីដល់អំពើទុច្ចរិតរបស់កូនៗលោក (១ សាំយូ. ២:២២–៣៦; ៣:១៣) ។

**អេលីយ៉ា**_សូមមើលផង_ ការភ្ជាប់, ភ្ជាប់, សេចក្តីសង្គ្រោះ; អេលីយ៉ាស

ជាព្យាការីម្នាក់ ក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានវិលមកវិញនៅថ្ងៃចុងក្រោយ ដើម្បីប្រគល់កូនសោទាំងឡាយ នៃអំណាចខាងការភ្ជាប់ទៅលើ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។ នៅជំនាន់លោកអេលីយ៉ាបានបង្រៀននៅនគរអ៊ីស្រាអែលខាងជើង (១ ពង្សាវ. ១៧–២ ពង្សាវ. ២) ។ លោកមានសេចក្តីជំនឿជឿដល់ព្រះអម្ចាស់ជាខ្លាំង ហើយបានសំគាល់ចំពោះអព្ភូតហេតុជាច្រើន ។ លោក ហាមមិនឲ្យភ្លៀងអស់រយៈពេលបីឆ្នាំកន្លះ ។ លោកបានប្រោសក្មេងប្រុសម្នាក់ឲ្យរស់ពីស្លាប់ ហើយបានហៅឲ្យភ្លើងចុះមកពីលើមេឃ (១ ពង្សាវ. ១៧–១៨) ។ ប្រជាជនយូដានៅតែរង់ចាំឲ្យអេលីយ៉ាវិលមកវិញ ដូចដែលម៉ាឡាគីបានព្យាករថាលោកនឹងមក (ម៉ាឡាគី ៤:៥) ។ លោកជាភ្ញៀវដែលត្រូវអញ្ជើញទៅបុណ្យរំលងនៃសាសន៍យូដាជាដរាប ដែលមានទ្វារបើកចំហ និងទីអង្គុយទំនេររង់ចាំ លោកជានិច្ច ។

ព្យាការី យ៉ូសែប ស្ម៊ីធ មានប្រសាសន៍ថា អេលីយ៉ាបានកាន់អំណាចខាងការភ្ជាប់នៃបព្វជិតភាពមិលគីស្សាដែក ហើយជាព្យាការីចុងក្រោយបង្អស់ ដែលបានកាន់កូនសោនោះ មុនជំនាន់ព្រះយេស៊ូវគ្រីស្ទ ។ លោកបានលេចមកលើភ្នំប្រែរូប ជាមួយនឹងម៉ូសេ ហើយបានប្រគល់កូនសោទាំងឡាយនៃបព្វជិតភាពទៅលើពេត្រុស យ៉ាកុប និងយ៉ូហាន (ម៉ាថាយ ១៧:៣) ។ លោកបានលេចមក ម្តងទៀត ជាមួយនឹងម៉ូសេ និងអ្នកផ្សេងៗទៀត នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៨៣៦ គឺនៅក្នុងព្រះវិហារខឺតឡង់ រដ្ឋអូហៃអូ ហើយបាន ប្រគល់កូនសោដដែលដល់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី (គ. និង ស. ១១០:១៣–១៦) ។ ការទាំងនេះ គឺជាការរៀបចំថ្វាយ ការយាងមកលើកទីពីរនៃព្រះអម្ចាស់ ដូចដែលបានពោលដល់ក្នុងគម្ពីរម៉ាឡាគី ៤:៥–៦ ។

អំណាចអេលីយ៉ា គឺជាអំណាចខាងការភ្ជាប់នៃបព្វជិតភាព ដែលថាអ្វីៗនៅលើផែនដីបានចង ឬស្រាយ នោះត្រូវបានចង ឬស្រាយនៅលើស្ថានសួគ៌ដែរ (គ. និង ស. ១២៨:៨–១៨) ។ ពួកអ្នកបំរើដ៏ជំរើសរបស់ព្រះអម្ចាស់នៅលើផែនដីសព្វថ្ងៃនេះ មានអំណាចខាងការភ្ជាប់ ហើយប្រព្រឹត្តពិធីសង្គ្រោះនៃដំណឹងល្អ សំរាប់មនុស្សនៅរស់ និងមនុស្សស្លាប់ (គ. និង ស. ១២៨:៨) ។

បានបិទផ្ទៃមេឃ ហើយត្រូវបានចិញ្ចឹមដោយក្អែក, **១ ពង្សាវ.** ១៧:១–៧ ។ បានបង្គាប់ម្សៅរបស់ស្រីមេម៉ាយកុំឲ្យខាប់ និងដបប្រេង រលោះឡើយ, **១ ពង្សាវ.** ១៧:៨–១៦ ។ បានប្រោសកូនប្រុសរបស់ស្រីមេម៉ាយឲ្យរស់ពីស្លាប់, **១ ពង្សាវ.** ១៧:១៧–២៤ ។ បានឈ្នះពួកសង្ឃនៃព្រះបាល, **១ ពង្សាវ.** ១៨:២១–៣៩ ។ សម្លេងតូចរហៀងៗនិយាយទៅលោក, **១ ពង្សាវ.** ១៩:១១–១២ ។ បានឡើងទៅលើស្ថានសួគ៌លើរថសេះភ្លើង, **២ ពង្សាវ.** ២:១១ ។ ម៉ាឡាគីបានព្យាករអំពីការត្រឡប់

មកវិញនៅថ្ងៃចុងក្រោយ, **ម៉ាឡាគី** ៤:៥–៦ (៣ នីហ្វៃ ២៥:៥) ។ បានលេចមកនៅក្នុងព្រះវិហារខឺតឡង់ រដ្ឋអូហៃអូ ក្នុងឆ្នាំ១៨៣៦, **គ. និង ស.** ១១០:១៣–១៦ ។

**អេលីយ៉ាស***សូមមើលផង* អេលីយ៉ា

មានការប្រើជាច្រើនចំពោះឈ្មោះ ឬតំណែងអេលីយ៉ាស នៅក្នុងគម្ពីរ គឺៈ

*អេលីយ៉ាៈ* អេលីយ៉ាស ជាពាក្យ (ក្រេក) អេលីយ៉ា ជាពាក្យ (ហេព្រើរ) នៅព្រះគម្ពីរសញ្ញាថ្មី ដូចជាក្នុងគម្ពីរម៉ាថាយ ១៧:៣–៤, លូកា ៤:២៥–២៦ និងយ៉ាកុប ៥:១៧ ។ តាមបទទាំងនេះ អេលីយ៉ាស គឺជាព្យាការីអេលីយ៉ា ពីបុរាណ ដែលមានសេចក្តីបង្រៀនកត់នៅក្នុងពង្សាវតារក្សត្រទី ១ និងទី ២ ។

*អ្នកមកមុនៈ* អេលីយ៉ាស ក៏ជាតំណែងសំរាប់អ្នកណាដែលជាអ្នកមកមុន។ ឧទាហរណ៍ យ៉ូហាន-បាទីស្ទគឺជាអេលីយ៉ាសមួយ ពីព្រោះលោកបានត្រូវចាត់ឲ្យមករៀបចំផ្លូវថ្វាយព្រះយេស៊ូវ (ម៉ាថាយ ១៧:១២–១៣) ។

*អ្នកសាងឡើងវិញៈ* តំណែងជាអេលីយ៉ាស ក៏បានដាក់ឲ្យអ្នកណាដែលមានបេសកកម្មពិសេស ដើម្បីសំរេច ដូចជាយ៉ូហាន ជាអ្នកទទួលវិវរណៈ (គ. និង ស. ៧៧:១៤) និងកាព្រីយ៉ែល (លូកា ១:១១–២០; គ. និង ស. ២៧:៦–៧; ១១០:១២) ។

*បុរសម្នាក់នៅក្នុងការកាន់កាប់ត្រួតត្រារបស់អ័ប្រាហាំៈ* ជាព្យាការីម្នាក់ហៅថា អេសាយ៉ាស ឬ អេលីយ៉ា ដែលច្បាស់ជាបានរស់នៅសម័យអ័ប្រាហាំ (គ. និង ស. ៨៤:១១–១៣; ១១០:១២) ។

**អេលីសេ**

ជាព្យាការីម្នាក់ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ នៅនគរអ៊ីស្រាអែលខាងជើង ហើយជាអ្នកប្រឹក្សានៃស្តេចជាច្រើននៅស្រុកនោះ ។

អេលីសេមានចិត្តរាបសា ហើយគួរឲ្យស្រឡាញ់ គឺពុំមានសេចក្តីឧស្សាហ៍ដ៏ឆួលក្តៅដូចជាលោកអេលីយ៉ាដែលជាចៅហ្វាយលោកមាននោះឡើយ ។ អព្ភូតហេតុសំខាន់ៗរបស់លោក (២ ពង្សាវ. ២–៥; ៨) ធ្វើបន្ទាល់ថាលោកច្បាស់ជាបានទទួលអំណាចពីអេលីយ៉ា កាលលោកជួសអេលីយ៉ាធ្វើជាព្យាការី (២ ពង្សាវ. ២:៩–១២) ។ ឧទាហរណ៍ លោកបានធ្វើឲ្យទឹកល្វីងទៅជាល្អ បានញែកទឹកនៃទន្លេយ័រដាន់ បានបន្ថែមប្រេងជូនស្រីមេម៉ាយ បានប្រោសក្មេងប្រុសពីស្លាប់ បានធ្វើឲ្យមនុស្សឃ្លង់ជា បានធ្វើឲ្យពូថៅដែកអណ្តែត ហើយបានធ្វើឲ្យពួកស៊ីរីខ្វាក់ (២ ពង្សាវ. ២–៦) ។ ការបង្រៀនរបស់លោកគង់នៅយូរជាង ៥០ ឆ្នាំ នៅរាជ្យយ៉ូរ៉ាម យេហ៊ូវ យ៉ូអាហាស និងយ៉ូអាស ។

បានទទួលស្បៃពីអេលីយ៉ា, **២ ពង្សាវ.** ២:១៣ ។ បានបន្ថែមប្រេងរបស់ស្រីមេម៉ាយ, **២ ពង្សាវ.** ៤:១–៧ ។ បានប្រោសកូនប្រុសរបស់ស្រីស្រុកស៊ូណែមឲ្យរស់ពីស្លាប់, **២ ពង្សាវ.** ៤:១៨–៣៧ ។ បានធ្វើឲ្យណាម៉ាន់ ជាសាសន៍ស៊ីរីបានជា, **២ ពង្សាវ.** ៥:១–១៤ ។ បានធ្វើឲ្យពួក ទាហានសាសន៍ស៊ីរីខ្វាក់ ហើយភ្នែកអ្នកបំរើបានបើក, **២ ពង្សាវ.** ៦:៨–២៣ ។

**អេសា**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាស្តេចទីបីនៃយូដា ។ ព្រះគម្ពីរចែងថា « ទ្រង់មានព្រះទ័យស្មោះត្រង់ដល់ព្រះអម្ចាស់ រហូតដល់អស់ព្រះជន្ម » (១ ពង្សាវ. ១៥:១៤) ។ នៅក្នុងរាជ្យទ្រង់ នោះទ្រង់បានបង្កើតកងទ័ពឲ្យមានប្រសិទ្ធិភាព, បានបោះចោលនឹមរបស់ ពួកអេធីយ៉ូពី, បានដករូបព្រះក្លែងក្លាយចេញ ហើយបានអញ្ជើញប្រជាជនឲ្យធ្វើសេចក្តីសញ្ញាមួយ ដើម្បីស្វែងរកព្រះយេហូវ៉ា (១ ពង្សាវ. ១៥–១៦; ២ របា. ១៤–១៦) ។ ក៏ប៉ុន្តែកាលដែលទ្រង់មានជម្ងឺនៅព្រះបាទា នោះទ្រង់ពុំបានស្វែងរកជំនួយពីព្រះអម្ចាស់ឡើយ ហើយក៏សុគតទៅ (១ ពង្សាវ. ១៥:២៣–២៤; ២ របា. ១៦:១២–១៣) ។

**អេសាយ**

ជាព្យាការីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានព្យាករពីឆ្នាំ ៧៤០–៧០១ ម.គ.ស. ។ ជានាយប្រឹក្សានៃស្តេចហេសេគា នោះអេសាយមានឥទ្ធិពលយ៉ាងខ្លាំង ទាំងខាងសាសនា និងខាងរដ្ឋាភិបាល ។

ព្រះយេស៊ូវទ្រង់តែងតែស្រង់ពាក្យអេសាយជាងព្យាការីណាៗទាំងអស់ ។ ពាក្យអេសាយក៏តែងតែបានស្រង់ដោយពេត្រុស យ៉ូហាន និងប៉ុលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ព្រះគម្ពីរមរមន និងគោលលទ្ធិ និងសេចក្តីសញ្ញា មានពាក្យស្រង់ពីអេសាយច្រើនជាងពីព្យាការី ណាៗទាំងអស់ ហើយផ្តល់នូវជំនួយ ក្នុងការបកស្រាយពាក្យអេសាយ ។ នីហ្វៃបានបង្រៀនប្រជាជនលោកចេញពីការសរសេររបស់អេសាយ (២ នីហ្វៃ ១២–២៤; អេសាយ ២–១៤) ។ ព្រះអម្ចាស់ទ្រង់បានប្រាប់ពួកសាសន៍នីហ្វៃថា « ពាក្យរបស់អេសាយ ជាពាក្យដ៏មហិមា » ហើយថា គ្រប់សេចក្តីទាំងអស់ដែលអេសាយបានព្យាករនោះនឹងបានសំរេច (៣ នីហ្វៃ ២៣:១–៣) ។

*គម្ពីរអេសាយៈ* ជាគម្ពីរមួយនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ពាក្យព្យាករណ៍របស់អេសាយជាច្រើនទាក់ទងទៅនឹងការយាងមកនៃព្រះដ៏ប្រោសលោះ ព្រមទាំងការបង្រៀនរបស់ទ្រង់នៅលើផែនដី (អេសាយ ៩:៦) ហើយជាព្រះមហាក្សត្រដ៏ធំមួយនៅថ្ងៃចុងក្រោយ បង្អស់ (អេសាយ ៦៣) ។ លោកក៏បានព្យាករជាច្រើនអំពីអនាគតនៃអ៊ីស្រាអែល ។

ជំពូកទី ១ គឺជាអារម្ភបទចំពោះគម្ពីរទាំងមូល ។ អេសាយ ៧:១៤; ៩:៦–៧; ១១:១–៥; ៥៣:១–១២; និង ៦១:១–៣ រៀបរាប់ទុកជាមុនអំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។ ជំពូកទី ២, ១១, ១២ និង ៣៥ ទាក់ទងទៅនឹងព្រឹត្តិការណ៍នៅថ្ងៃចុងក្រោយ កាលដំណឹងល្អបានសាងឡើងវិញ, អំពីអ៊ីស្រាអែលនឹងត្រូវបានជួបជុំ, និងអំពីផែនដីហួតហែងនឹងត្រូវបានផ្កាឡើងដូចជាកុលាប ។ ជំពូកទី ២៩ មាននូវពាក្យព្យាករណ៍អំពីការចេញមកនៃព្រះគម្ពីរមរមន (២ នីហ្វៃ ២៧) ។ ជំពូកទី ៤០–៤៦ ប្រកាសប្រាប់អំពីឥទ្ធិឫទ្ធិខ្ពង់ខ្ពស់នៃ ព្រះយេហូវ៉ាទុកជាព្រះដ៏ពិត លើសរូបព្រះទាំងឡាយនៃពួកអ្នកថ្វាយបង្គំព្រះផ្សេងៗ ។

ជំពូកដែលនៅសល់ទាំងប៉ុន្មាន គឺ ៤៧–៦៦ ទាក់ទងទៅនឹងព្រឹត្តិការណ៍អំពីការសាងឡើងវិញ នៃសាសន៍អ៊ីស្រាអែលនៅគ្រាចុងក្រោយបង្អស់ និងការតាំងក្រុងស៊ីយ៉ូនឡើង ដោយមានព្រះអម្ចាស់ ទ្រង់គង់នៅចំណោមរាស្ត្ររបស់ទ្រង់ ។

**អេសាវ** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីសាក

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសច្បងរបស់អ៊ីសាក និងនាងរេបិកា ហើយជាបងភ្លោះរបស់យ៉ាកុប ។ បងប្អូនទាំងពីរនាក់មិនត្រូវគ្នា តាំងពីកើតមក (លោកុ. ២៥:១៩–២៦) ។ ពូជពង្សអេសាវ គឺជាសាសន៍អេដំម ហើយពូជពង្សយ៉ាកុប គឺជាសាសន៍អ៊ីស្រាអែល បានត្រឡប់ទៅសាសន៍ទាស់នឹងគ្នា (លោកុ. ២៥:២៣) ។

អេសាវបានលក់សិទ្ធិកូនច្បងរបស់ខ្លួនទៅឲ្យយ៉ាកុប, **លោកុ.** ២៥:៣៣ (ហេព្រើរ ១២:១៦–១៧) ។ អេសាវយកប្រពន្ធសាសន៍ហេត ដែលនាំឲ្យឪពុកម្ដាយខ្លួនពិបាកចិត្ត, **លោកុ.** ២៦:៣៤–៣៥ ។ យ៉ាកុប និងអេសាវបានស្រុះស្រួលនឹងគ្នា, **លោកុ.** ៣៣ ។

## អេស៊ីព្ទ

ជាស្រុកនៅទិសឦសាន្ត ទ្វីបអាហ្វ្រិក ។ ភាគច្រើននៅស្រុកអេស៊ីព្ទ គឺជាទីគតដីជាតិ ហើយស្ងប់ស្ងាត់សូន្យ ។ បណ្ដាជនភាគច្រើន អាស្រ័យនៅតាមច្រកវាលណាល ដែលលាតសន្ធឹងប្រមាណ ៨៩០ គ.ម. ។

ស្រុកអេស៊ីព្ទពីបុរាណមានដីជាតិ ហើយល្បួតលាស់ ។ កិច្ចការខាងសាធារណៈដ៏សំខាន់ៗបានសង់ឡើង ព្រមទាំងទំនប់ទឹក ទីក្រុងដ៏មាំមួនៗ សំរាប់ការពារ និងវិមានរាជា ជាពិសេស គឺផ្នូរសាជីជ្រុង និងវិហារទាំងឡាយ ដែលនៅក្នុងចំណោមការ អស្ចារ្យក្នុងលោកនៅឡើយ ។ នៅគ្រាមួយ រដ្ឋាភិបាលអេស៊ីព្ទ គឺជាការធ្វើតាមរបៀបអយ្យកោនៃបព្វជិតភាព (អ័ប្រា. ១:២១–២៧) ។

អ័ប្រាហាំ និងយ៉ូសែបបានត្រូវនាំទៅឯស្រុកអេស៊ីព្ទ ដើម្បីជួយសង្គ្រោះគ្រួសារគេពីអំណត់អត់, **លោកុ.** ១២:១០ (លោកុ. ៣៧:២៨) ។ យ៉ូសែបត្រូវបានលក់ទៅឯស្រុកអេស៊ីព្ទ, **លោកុ.** ៤៥:៤–៥ (១ នីហ្វៃ ៥:១៤–១៥) ។ យ៉ាកុបត្រូវបាននាំទៅឯស្រុកអេស៊ីព្ទ, **លោកុ.** ៤៦:១–៧ ។ ម៉ូសេបាននាំកូនចៅសាសន៍អ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ, **និក្ខ.** ៣:៧–១០; ១៣:១៤ (ហេព្រើរ ១១:២៧; ១ នីហ្វៃ ១៧:៤០; ម៉ូសេ ១:២៥–២៦) ។ ស្រុកអេស៊ីព្ទជានិមិត្តរូបនៃអំពើអាក្រក់, **អេសេ.** ២៩:១៤–១៥ (ហូសេ ៩:៣–៧; អ័ប្រា. ១:៦, ៨, ១១–១២, ២៣) ។ ទេវតាមួយបានប្រាប់យ៉ូសែប ឲ្យភៀសខ្លួនចេញជាមួយនាងម៉ារា និងព្រះយេស៊ូវ ទៅឯស្រុកអេស៊ីព្ទ, **ម៉ាថាយ** ២:១៣ (ហូសេ ១១:១) ។

## អេស៊ីព្ទុស

ជាឈ្មោះប្រពន្ធ និងកូនស្រីរបស់ហាំ ជាកូនប្រុសរបស់ណូអេ ។ ក្នុងភាសាខាល់ដេ ឈ្មោះនេះមានន័យថា អេស៊ីព្ទ ឬជាអ្វីដែល ត្រូវហាមឃាត់ (អ័ប្រា. ១:២៣–២៥) ។

## អេសេគាល

ជាព្យាការីម្នាក់ ដែលបានសរសេរគម្ពីរអេសេគាលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ លោកជាសង្ឃពីត្រកូលសាដុក ហើយជាឈ្លើយម្នាក់ ដែលបានចាប់យកទៅដោយស្ដេចនេប៊ូក្នេសា ។ លោកបានរស់នៅជាមួយនឹងពួកសាសន៍យូដា ដែលនិរទេសនៅក្រុងបាប៊ីឡូន ហើយបានព្យាករអស់រយៈពេលប្រមាណជា ២២ ឆ្នាំ គឺពីឆ្នាំ ៥៩២ ទៅ ៥៧០ ម.គ.ស. ។

*គម្ពីរអេសេគាល៖* គម្ពីរអេសេគាលអាចចែកចេញជាបួនភាគ ។ ជំពូកទី ១–៣ ប្រាប់អំពីការនិមិត្តអំពីព្រះ និងការហៅអេសេគាល ឲ្យបំរើ; ជំពូក ទី ៤–២៤ ស្ដីអំពីសេចក្ដីជំនុំជំរះដល់ក្រុងយេរូសាឡិម និងមកពីហេតុអ្វីបានជាត្រូវជំនុំជំរះ; ជំពូកទី ២៥–៣២ ប្រកាសពី សេចក្ដីជំនុំជំរះដល់សាសន៍ទាំងឡាយ; និងជំពូកទី ៣៣–៤៨ កត់នូវការនិមិត្តអំពីអ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។

**អេស៊ើរ** *សូមមើលផង* កូនប្រុសរបស់អ៊ីសាក, យ៉ាកុប, អ៊ីស្រាអែល

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាកូនប្រុសរបស់យ៉ាកុប និងនាងស៊ីលជាបាវស្រីនាងលេអា (លោកុ. ៣០:១២–១៣) ។

*ពូជអំបូររបស់អេស៊ើរ៖* យ៉ាកុបបានឲ្យពរដល់អេស៊ើរ (លោកុ. ៤៩:២០) ហើយលោកម៉ូសេបានឲ្យពរដល់ពួកពូជពង្សអេស៊ើរ (ចោទិ. ៣៣:១, ២៤–២៩) ។ ពួកពូជពង្សទាំងនេះត្រូវបានហៅថា « មនុស្សខ្លាំងពូកែ ហើយមានចិត្តក្លាហាន » (១ របា. ៧:៤០) ។

**អេឡូហិម** *សូមមើល* ក្រុមព្រះ, ព្រះ,
ព្រះវរបិតាដែលគង់នៅស្ថានសួគ៌

**អែលឌើរ** *សូមមើលផង* បព្វជិតភាព, បព្វជិតភាពមិលគីស្សាដែក

ពាក្យ *អែលឌើរ* ត្រូវយកមកប្រើច្រើនបែបនៅក្នុងព្រះគម្ពីរប៊ីប ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យនេះតែងតែសំដៅទៅលើ ពួកចាស់ទុំ នៅក្នុងពូជអំបូរ តាមធម្មតា គឺជាអ្នកដែលផ្ទុកនូវកិច្ចការខាងរដ្ឋាភិបាល (លោកុ. ៥០:៧; យ៉ូស្វេ ២០:៤; នាងរស់ ៤:២; ម៉ាថាយ ១៥:២) ។ វ័យ និងការពិសោធន៍របស់គេ ធ្វើឲ្យពាក្យទូន្មានគេមានតម្លៃ ។ មុខងាររបស់គេមិនចាំបាច់ជាការហៅខាង បព្វជិតភាពនោះទេ ។

ក៏មានពួកអែលឌើរដែលបានតែងតាំងឡើងខាងបព្វជិតភាពមិលគីស្សាដែកនៅសម័យព្រះគម្ពីរសញ្ញាចាស់ដែរ (និក្ខ. ២៤:៩–១១) ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពួកអែលឌើរបានត្រូវពោលដល់ថា ជាតំណែងបព្វជិតភាពមួយក្នុងសាសនាចក្រ (យ៉ាកុប ៥:១៤–១៥) ។ នៅចំណោមពួកសាសន៍នីហ្វៃក៏មានពួកអែលឌើរដែលបានតែងតាំងឡើងខាងបព្វជិតភាព (អាលម៉ា ៤:៧, ១៦; ម៉ូរ៉ូណៃ ៣:១) ។ នៅក្នុងការកាន់កាប់ត្រួតត្រានេះ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី គឺជាអែលឌើរមុនដំបូង ដែលបានតែងតាំងឡើង (គ. និង ស. ២០:២–៣) ។

ឥឡូវនេះ អែលឌើរ គឺជាតំណែងប្រគល់ដល់ពួកអ្នកកាន់បព្វជិតភាព

មិលគីស្សាដែកគ្រប់រូប ។ ឧទាហរណ៍ អ្នកផ្សាយសាសនាបុរស ត្រូវហៅថា អែលឌើរ ។ ហើយសាវកក៏ជាអែលឌើរម្នាក់ ហើយជាការសមរម្យក្នុងការហៅពួកក្រុម ១២ នាក់ ឬពួកក្រុម ៧០ នាក់តាមតំណែងនេះ (គ. និង ស. ២០:៣៨; ១ ពេត្រុស ៥:១) ។ កាតព្វកិច្ចនៃពួកអែលឌើរដែលបានតែងតាំងឡើងក្នុងសាសនាចក្រសព្វថ្ងៃនេះ ត្រូវបានរៀបរាប់ប្រាប់ក្នុងវិវរណៈនៅថ្ងៃចុងក្រោយ (គ. និង ស. ២០:៣៨–៤៥; ៤២:៤៤; ៤៦:២; ១០៧:១២) ។

ម៉ូសេបានកត់ជូនដល់ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន, **ចោទិ.** ៣១:៩ ។ បាណាបាសបានផ្ញើជំនួយទៅដល់ពួកចាស់ទុំ ក្នុងសាសនាចក្រ, **កិច្ចការ** ១១:៣០ ។ ពួកចាស់ទុំត្រូវបានតែងតាំងឡើង ក្នុងគ្រប់ទាំងសាសនាចក្រ, **កិច្ចការ** ១៤:២៣ (ទីតុស ១:៥) ។ ចូរហៅពួកចាស់ទុំឲ្យមកអធិស្ឋានឲ្យពួកអ្នកឈឺ, **យ៉ាកុប** (ព.ស.ថ.) ៥:១៤ ។ ពួកអែលឌើរត្រូវបានតែងតាំងឡើង ដោយការដាក់ ដៃលើ, **អាលម៉ា** ៦:១ ។ ពួកអែលឌើរត្រូវឲ្យពរដល់ពួកកូនក្មេង, **គ. និង ស.** ២០:៧០ ។ ពួកអែលឌើរត្រូវចាត់ចែងការប្រជុំ ដោយ ព្រះវិញ្ញាណបរិសុទ្ធ, **គ. និង ស.** ៤៦:២ ។ ពួកអែលឌើរត្រូវរាយការពីដំណើររឿងអំពីការកាន់កាប់ត្រួតត្រារបស់ខ្លួន, **គ. និង ស.** ៧២:៥ ។ ពួកអែលឌើរត្រូវទៅប្រកាសដំណឹងល្អដល់សាសន៍ទាំងឡាយ, **គ. និង ស.** ១៣៣:៨ ។

**អែសរ៉ា**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺជាសង្ឃ ហើយជាអាចារ្យ ដែលបាននាំពួកសាសន៍យូដាខ្លះទៅក្រុងយេរូសាឡិមពីការជាប់ឃុំឃាំង ដោយពួកបាប៊ីឡូន (អែសរ៉ា ៧–១០: នេហេ. ៨, ១២) ។ នៅឆ្នាំ ៤៥៨ ម.គ.ស. នោះលោកបានទទួលការអនុញ្ញាតពី អើថាសើកសេសជាស្តេចស្រុកពើស៊ី ដើម្បីនាំពួកសាសន៍យូដាដែលនិរទេសណា ដែលចង់ទៅឯក្រុងយេរូសាឡិមវិញ (អែសរ៉ា ៧:១២–២៦) ។

សម័យមុនអែសរ៉ា នោះពួកសង្ឃមានអំណាចស្ទើរតែទាំងស្រុង ក្នុងការអានក្បួនគម្ពីរ ដែលបានកត់ទុក ដែលហៅ « ក្រិត្យវិន័យ » ។ អែសរ៉ាបានជួយធ្វើឲ្យមានគម្ពីរដល់ពួកសាសន៍យូដារាល់គ្នា ។ ការបើកអាន « គម្ពីរក្រិត្យវិន័យ » បានត្រឡប់ទៅជាបណ្តូលនៃជីវិតជាតិយូដា ។ មើលទៅការបង្រៀន ដ៏សំខាន់បំផុតរបស់អែសរ៉ា គឺមកពីគំរូអំពីការរៀបចំចិត្ត ដើម្បីស្វែងរកក្រិត្យវិន័យនៃព្រះអម្ចាស់ ដើម្បីគោរពតាម ហើយដើម្បីបង្រៀនដល់អ្នកឯទៀត (អែសរ៉ា ៧:១០) ។

*គម្ពីរអែសរ៉ា៖* ជំពូកទី ១–៦ អធិប្បាយ ប្រាប់អំពីហេតុការណ៍ដែលបានកើតឡើងពី ៦០ ទៅ ៨០ ឆ្នាំមុនអែសរ៉ាបានមកនៅក្រុងយេរូសាឡិម —— ក្រិត្យនៃស្តេចស៊ីរូសនៅឆ្នាំ ៥៣៧ ម.គ.ស. និងការវិលមកវិញនៃពួកសាសន៍យូដា នៅក្រោមសូរ៉ូបាបិល ។ ជំពូកទី ៧–១០ បង្ហាញប្រាប់អំពីរបៀបអែសរ៉ាទៅក្រុងយេរូសាឡិម ។ លោកព្រមទាំងពួកក្រុមលោក បានតមអាហារ ហើយអធិស្ឋាន សូមសេចក្តីការពារ ។ នៅក្រុងយេរូសាឡិម ពួកគេបានឃើញប្រជាជនយូដាជាច្រើន ដែលបានទៅក្រុងយេរូសាឡិមពេលមុនៗ នៅក្រោមសូរ៉ូបាបិល ហើយបានរៀបការជាមួយពួកស្ត្រី ក្រៅសេចក្តីសញ្ញា ហើយដោយហេតុនេះហើយ ទើបបានធ្វើឲ្យខ្លួនស្មោកគ្រោក ។ អែសរ៉ាបានអធិស្ឋានឲ្យគេ ហើយបានដាក់គេនៅក្រោមសេចក្តីសញ្ញាដើម្បីឲ្យលែងលះប្រពន្ធទាំងនោះចេញ ។ ប្រវត្តិរបស់អែសរ៉ាបន្ទាប់មកមាននៅក្នុងគម្ពីរនេហេមា ។

**អោមណើរ** *សូមមើលផង* ម៉ូសាយ, បុត្ររបស់បេនយ៉ាមីន; ម៉ូសាយ, ពួកបុត្រារបស់ទ្រង់

នៅក្នុងព្រះគម្ពីរមរមន គឺជាបុត្ររបស់ស្តេចម៉ូសាយ ។ អោមណើរបានទៅផ្សាយដំណឹងល្អដល់ពួកសាសន៍លេមិនជាមួយនឹងបងប្អូនលោក (ម៉ូសាយ ២៧:៨–១១, ៣៤–៣៧; ២៨:១–៩) ។

**អោមណៃ**

ជាអ្នកកត់បញ្ជីសាសន៍នីហ្វៃម្នាក់ នៅក្នុងព្រះគម្ពីរមរមន ដែលបានសរសេរ ប្រមាណជានៅឆ្នាំ ៣៦១ ម.គ.ស. (យ៉ារ៉ុម ១:១៥; អោមណៃ ១:១–៣) ។

*គម្ពីរអោមណៃ៖* ជាគម្ពីរដែលបានបកប្រែចេញពីផ្ទាំងនីហ្វៃតូច នៅក្នុងព្រះគម្ពីរមរមន ។ គម្ពីរនេះមានតែមួយជំពូកគត់ ដែលមាន នូវដំណើររឿងអំពីសង្គ្រាមទាំងប៉ុន្មាន នៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ។ អោមណៃបានសរសេរតែប៊ីខគត់ ដំបូងក្នុងគម្ពីរនេះ ។ បន្ទាប់មក ផ្ទាំងទាំងឡាយក៏បានប្រគល់បន្តគ្នាទៅ អ័ម៉ារ៉ុន គេមីស អ័ប៊ីណាដុមហើយទីបំផុត គឺអាម៉ាលេគៃ ។ អាម៉ាលេគៃបានប្រគល់ផ្ទាំងទាំងប៉ុន្មានទៅស្តេចបេនយ៉ាមីន ជាស្តេចក្រុងសារ៉ាហិមឡា ។

**អំណរគុណ** *សូមមើល* ការថ្លែងអំណរគុណ, ដ៏អរគុណ, អរគុណ

**អំណាច** *សូមមើលផង* បព្វជិតភាព, សិទ្ធិអំណាច

លទ្ធភាពដែលអាចធ្វើអ្វីមួយ ។ មានអំណាចលើអ្នកណា ឬអ្វីមួយ គឺមានសិទ្ធិអាចត្រួតត្រា ឬបញ្ជាជន ឬអ្វីមួយ ។ នៅក្នុងព្រះគម្ពីរ អំណាច តែងតែទាក់ទងទៅនឹងព្រះចេស្តានៃព្រះ ឬចេស្តានៃស្ថានសួគ៌ ។ គឺតែងតែទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិអំណាចនៃបព្វជិតភាព ដែលអនុញ្ញាត ឬមានសិទ្ធិដើម្បីធ្វើជំនួសព្រះ ។

គ្មិតមកពីហេតុនេះហើយ បានជាអញទុកឯងឲ្យរស់នៅ ដើម្បីនឹងបង្ហាញឫទ្ធិបារមីតាមឯង, **និក្ខ.** ៩:១៦ ។ ព្រះទ្រង់ជាកម្លាំង និងជាអំណាចរបស់ខ្ញុំ, **២ សាំយូ.** ២២:៣៣ ។ កាលណាឯងមានកម្លាំងដៃអាចធ្វើគុណឲ្យអ្នកនោះកុំឲ្យបង្ខាំងទុកឡើយ, **សុភា.** ៣:២៧ ។ ពិតមែនហើយខ្ញុំមានពេញជាព្រះចេស្តា ដោយសារព្រះវិញ្ញាណនៃព្រះអម្ចាស់, **មីកា** ៣:៨ ។ គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង, **ម៉ាថាយ** ២៨:១៨ ។ គេក៏នឹកប្លែកពីសេចក្តីដែលទ្រង់បង្រៀនណាស់ ពីព្រោះទ្រង់មានបន្ទូលដោយអំណាច, **លូកា** ៤:៣២ ។ ចូរអ្នករាល់គ្នានៅតែក្នុងទីក្រុងដរាបដល់ព្រះចេស្តាពីស្ថានលើ បានមកគ្របដណ្តប់លើអ្នករាល់គ្នា,

**លូកា** ២៤:៤៩ ។ អស់អ្នកណាដែលទទួលទ្រង់ អ្នកនោះហើយ ដែលទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ, **យ៉ូហាន** ១:១២ (គ. និង ស. ១១:៣០) ។ កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្ដា, **កិច្ចការ** ១:៨ ។ គ្មានអំណាចណាទេ លើកលែងតែមកពីព្រះ, **រ៉ូម** ១៣:១ ។ អ្នករាល់គ្នាត្រូវព្រះចេស្ដានៃព្រះកំពុងតែថែរក្សា ដោយសារសេចក្ដីជំនឿ សំរាប់ឲ្យបានសេចក្ដីសង្គ្រោះ, **១ ពេត្រុស** ១:៣–៥ ។ ខ្ញុំបានពោរពេញទៅដោយព្រះចេស្ដានៃព្រះ, **១ នីហ្វៃ** ១៧:៤៨ ។ គឺបានសម្ដែងឲ្យខ្ញុំដឹង ដោយសារព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ, **យ៉ាកុប** ៧:១២ ។ មនុស្សម្នាក់អាចមានអំណាចដ៏ធំ ដែលបានប្រ ទានមកពីព្រះ, **ម៉ូសាយ** ៨:១៦ ។ គេបានបង្រៀនដោយអានុភាព និងសិទ្ធិអំណាចពីព្រះ, **អាលម៉ា** ១៧:២–៣ ។ នីហ្វៃបានធ្វើការងារបំរើដោយអានុភាព និងដោយសិទ្ធិអំណាចដ៏ធំ, ៣ នីហ្វៃ ៧:១៥–២០ (៣ នីហ្វៃ ១១:១៩–២២) ។ ទោះជា មនុស្សអាចមានអំណាច អាចធ្វើកិច្ចការដ៏អស្ចារ្យជាច្រើនបានក៏ដោយ តែបើគេអួតអាងដោយកម្លាំងរបស់ខ្លួន អ្នកនោះត្រូវតែធ្លាក់ចុះ, **គ. និង ស.** ៣:៤ ។ អំណាចដើម្បីធ្វើអំពើល្អ គឺមាននៅក្នុងខ្លួនមនុស្សម្នាក់ៗ, **គ. និង ស.** ៥៨:២៧–២៨ ។ នៅក្នុងពិធីបរិសុទ្ធទាំង ឡាយ នៃបព្វជិតភាពមិគីស្សាដែក នោះអំណាចនៃព្រះត្រូវបានសម្ដែងឲ្យឃើញ, **គ. និង ស.** ៨៤:១៩–២២ ។ សិទ្ធិទាំងឡាយនៃ បព្វជិតភាព គឺជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌, **គ. និង ស.** ១២១:៣៤–៤៦ ។ យើងនឹងដឹកអ្នកដោយដៃយើង ហើយព្រះចេស្ដារបស់យើងនឹងស្ថិតនៅលើអ្នក, **អ័ប្រា.** ១:១៨ ។

**អំណោយទាន***សូមមើលផង* អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ; អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ

ព្រះទ្រង់ប្រទានដល់មនុស្សនូវព្រះពរ និងអំណោយទានជាច្រើន ។

មានអំណោយទានខាងវិញ្ញាណជាច្រើន, **១ កូរិន.** ១២:៤–១០ ។ ចូរសង្វាតឲ្យបានអំណោយទានយ៉ាងវិសេសទៅចុះ, **១ កូរិន.** ១២:៣១ ។ អស់ទាំងអំណោយទានដ៏ល្អឥតខ្ចោះ គឺមកពីព្រះ, **យ៉ាកុប** (ព.ស.ថ.) ១:១៧ ។ ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ គឺជា អំណោយទានពីព្រះ, **១ នីហ្វៃ** ១០:១៧ ។ ពួកអ្នកដែលនិយាយថា ឥតមានអំណោយទានទេ អ្នកនោះពុំស្គាល់នូវដំណឹងល្អនៃព្រះ គ្រីស្ទទេ, **មរមន** ៩:៧–៨ ។ គ្រប់ទាំងអំណោយទានណាដែលល្អ គឺមកពីព្រះគ្រីស្ទ, **មរ៉ូណៃ** ១០:៨–១៨ ។ ជីវិតដ៏នៅ អស់កល្បជានិច្ច គឺជាអំណោយទានដ៏មហិមាបំផុតនូវគ្រប់អំណោយទានទាំងឡាយនៃព្រះ, **គ. និង ស.** ១៤:៧ (១ នីហ្វៃ ១៥:៣៦) ។ អំណោយទាន ទាំងឡាយត្រូវបានប្រទានដល់អស់អ្នកណាដែលស្រឡាញ់ព្រះអម្ចាស់, **គ. និង ស.** ៤៦:៨–១១ ។ មនុស្សទាំងអស់ពុំបានគ្រប់អំណោយ ទាន ដែលបានប្រទានដល់ពួកគេឡើយ, **គ. និង ស.** ៤៦:១១–២៩ ។

**អំណោយទានខាងភាសា** *សូមមើលផង* អណ្ដាត, អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ

ជាអំណោយទានមួយ ពីព្រះវិញ្ញាណបរិសុទ្ធ ដែលបណ្ដាលឲ្យបុគ្គលទាំងឡាយចេះនិយាយ យល់ ឬបកប្រែភាសាទាំងឡាយ ដែលមិនធ្លាប់ស្គាល់ ។ យើងខ្ញុំជឿដល់អំណោយទានខាងភាសា (ម. នៃ ស. ១:៧) ។

គេបានពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធទាំងអស់ ក៏តាំងនិយាយភាសាផ្សេងៗ, **កិច្ចការ** ២:៤ ។ អ្នកណាដែលនិយាយភាសាដទៃ នោះមិនមែននិយាយនឹងមនុស្ស គឺទូលនឹងព្រះវិញ, **១ កូរិន.** ១៤:១–៥, ២៧–២៨ ។ ភាសាទាំងឡាយ នោះសំរាប់ជាទីសំគាល់ដល់ ពួកអ្នកដែលមិនជឿ, **១ កូរិន.** ១៤:២២–២៨ ។ បន្ទាប់មក ក៏មានបុណ្យជ្រមុជ ដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបន្ទាប់មកអ្នករាល់គ្នាអាចនិយាយដោយភាសានៃពួកទេវតា, **២ នីហ្វៃ** ៣១:១៣–១៤ ។ អាម៉ាលេគៃបានទូន្មានដល់មនុស្សទាំងអស់ ឲ្យជឿដល់អំណោយទានខាងការនិយាយភាសាផ្សេងៗ, **អោមណៃ** ១:២៥ ។ ត្រូវបានប្រទានដល់មនុស្សខ្លះ ឲ្យចេះនិយាយភាសា ដទៃផ្សេងៗ ហើយដល់ម្នាក់ទៀត ឲ្យចេះបកប្រែភាសាដទៃ, **គ. និង ស.** ៤៦:២៤–២៥ (១ កូរិន. ១២:១០; មរ៉ូណៃ ១០:៨, ១៥–១៦) ។ សូមឲ្យអំណោយទានខាងភាសាបានចាក់មក, **គ. និង ស.** ១០៩:៣៦ ។

**អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ***សូមមើលផង* ក្រុមព្រះ; ព្រះ, ព្រះវិញ្ញាណបរិសុទ្ធ, អំណោយទាន; អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ

គឺជាសិទ្ធិនៃសមាជិកគ្រប់រូបដ៏សក្ដិសម ដែលបានទទួលបុណ្យជ្រមុជទឹកចូលសាសនាចក្រ ដើម្បីឲ្យបានឥទ្ធិពលពីព្រះវិញ្ញាណបរិសុទ្ធជានិច្ច ។ បន្ទាប់ពីបុណ្យជ្រមុជទឹកនៃជនណាមួយចូលសាសនាចក្រដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទហើយ អ្នកនោះនឹងទទួលបានអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយការដាក់ដៃលើ ដោយអ្នកដែលមានសិទ្ធិអំណាចត្រឹមត្រូវ (កិច្ចការ ៨:១២–២៥; មរ៉ូណៃ ២:១–៣; គ. និង ស. ៣៩:២៣) ។ ការទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ នោះតែងតែបានពោលដល់ថា ជាបុណ្យជ្រមុជដោយភ្លើង (ម៉ាថាយ ៣:១១; គ. និង ស. ១៩:៣១) ។

មនុស្សទាំងឡាយបានត្រូវបញ្ជាឲ្យប្រែចិត្ត ទទួលបុណ្យជមុជទឹក ហើយទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ, **កិច្ចការ** ២:៣៨ ។ ពេត្រុស និងយ៉ូហានបានប្រទានអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយការដាក់ដៃលើ, **កិច្ចការ** ៨:១៤–២២ ។ ព្រះវិញ្ញាណបរិសុទ្ធត្រូវបានប្រទានឲ្យ ដោយការដាក់ដៃលើ, **កិច្ចការ** ១៩:២–៦ ។ ការផ្ដាច់បាបគឺកើតឡើងដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ, **២ នីហ្វៃ** ៣១:១៧ ។ យើងខ្ញុំជឿដល់ការដាក់ដៃលើ សំរាប់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ, **ម. នៃ ស.** ១:៤ ។

**អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ** *សូមមើលផង* អំណោយទាន

ជាព្រះពរទាំងឡាយខាងវិញ្ញាណដ៏វិសេស ដែលបានប្រទានដោយព្រះអម្ចាស់ ដល់បុគ្គលណាដែលសក្ដិសម សំរាប់ប្រយោជន៍ផ្ទាល់ខ្លួន និងសំរាប់ឲ្យពួកគេប្រើក្នុងការប្រទានពរឲ្យអ្នកផ្សេងៗ ។ ចំពោះការ

អធិប្បាយប្រាប់អំពីអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ សូមសិក្សា គោលលទ្ធិ និងសេចក្ដីសញ្ញា ៤៦:១១–៣៣; ១ កូរិន. ១២:១–១២; ម៉ូរ៉ូណៃ ១០:៨–១៨ ។

ចូរសង្វាតឲ្យបានអំណោយទានយ៉ាងវិសេសទោចុះ, **១ កូរិន.** ១២:៣១ (១ កូរិន. ១៤:១) ។ ពួកសាសន៍នីហ្វៃបានទទួលអំណោយទាននៃព្រះវិញ្ញាណជាច្រើន, **អាលម៉ា** ៩:២១ ។ វេទនានឹងមានដល់ជនណាដែលថា ព្រះអម្ចាស់ឈប់ធ្វើការដោយអំណោយទាន ឬដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ, ៣ នីហ្វៃ ២៩:៦ ។ ព្រះទ្រង់ប្រទានអំណោយទានដល់ពួកស្មោះត្រង់, **មរមន** ៩:៧ ។ អំណោយទានកើតឡើង ដោយសារព្រះវិញ្ញាណនៃព្រះគ្រីស្ទ, **ម៉ូរ៉ូណៃ** ១០:១៧ ។ មានអំណោយទានជាច្រើន ហើយមនុស្សរាល់គ្នា ត្រូវបានប្រទានអំណោយទានមួយ ដោយព្រះវិញ្ញាណនៃព្រះ, **គ. និង ស.** ៤៦:១១ ។ ពួកអ្នកដឹកនាំសាសនាចក្រត្រូវបានប្រទាន អំណាច ឲ្យចេះសង្កេតស្គាល់អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ, **គ. និង ស.** ៤៦:២៧ ។ ប្រធាននៃសាសនាចក្រមានគ្រប់ អំណោយទានទាំងអស់នៃព្រះ, **គ. និង ស.** ១០៧:៩២ ។

**អំណោយទានពិសិដ្ឋ** *សូមមើលផង* ជំណាក់នៃព្រះអម្ចាស់, ព្រះវិហារ

តាមន័យធម្មតា គឺជាអំណោយទានខាងអំណាចពីព្រះ ។ សមាជិកសក្តិសមទាំងឡាយនៅក្នុងសាសនាចក្រអាចទទួលអំណោយទានខាងអំណាច ដោយពិធីបរិសុទ្ធ នៅក្នុងព្រះវិហារ ដែលប្រគល់ដល់ពួកគេនូវការបង្គាប់ និងសេចក្ដីសញ្ញានៃបព្វជិតភាពបរិសុទ្ធ ដែលពួកគេត្រូវការ ដើម្បីទទួលភាពថ្កើងថ្កានឡើង ។ អំណោយទានពិសិដ្ឋមានរួមនូវការបង្គាប់អំពីផែនការនៃសេចក្ដីសង្គ្រោះ ។

នៅទីនោះ អ្នកនឹងត្រូវបានទទួលអំណោយទានដោយព្រះចេស្ដាមកពីស្ថានលើ, **គ. និង ស.** ៣៨:៣២, ៣៨ (លូកា ២៤:៤៩: គ.ស. ៤៣:១៦) ។ គប្បីកសាងគេហដ្ឋានមួយ គឺនៅក្នុងគេហដ្ឋាននោះហើយដែលយើងគ្រោងនឹងប្រទានអំណោយទានដល់អស់អ្នកណា ដែលយើងបានរើស, **គ. និង ស.** ៩៥:៨ ។ យើងបានរៀបចំអំណោយទានពិសិដ្ឋ និងព្រះពរដ៏មហិមាមួយទុក, **គ. និង ស.** ១០៥:១២, ១៨, ៣៣ ។ មនុស្សជាច្រើននឹងបានអរសប្បាយរីករាយ ដោយព្រោះតែអំណោយទានពិសិដ្ឋ ដែលពួកអ្នកបំរើរបស់យើងបានទទួល, **គ. និង ស.** ១១០:៩ ។ សិរីល្អ កិត្តិយស និងអំណោយទានពិសិដ្ឋត្រូវបានតែងតាំងឡើង ដោយពិធីនៃជំណាក់ដ៏បរិសុទ្ធរបស់យើង, **គ. និង ស.** ១២៤:៣៩ ។ អស់អ្នកណាដែលត្រូវបានហៅពីព្រះវរបិតាយើង ដូចជាលោកអើរ៉ុន នោះបានទទួលកូនសោទាំងឡាយ នៃបព្វជិតភាព, **គ. និង ស.** ១៣២:៥៩ ។

**អំបិល**

កាលពីបុរាណ មនុស្សបានប្រើអំបិល ទុកជារបស់ដ៏សំខាន់មួយសំរាប់ការពារអាហារកុំឲ្យខូច ។ គេចាត់ថា អំបិលជារបស់មួយដ៏សំខាន់សំរាប់ជីវិត ។

ប្រពន្ធរបស់ឡុតក្លាយទៅជាបង្គោលអំបិល, **លោកុ.** ១៩:២៦ ។ អ្នករាល់គ្នា ជាអំបិលនៃផែនដី, **ម៉ាថាយ** ៥:១៣ (លូកា ១៤:៣៤; ៣ នីហ្វៃ ១២:១៣) ។ រាស្ត្រនៃសេចក្ដីសញ្ញារបស់ព្រះអម្ចាស់ ត្រូវបានរាប់ដូចជាអំបិលនៃផែនដី, **គ. និង ស.** ១០១:៣៩–៤០ ។ បើសិនជាពួកបរិសុទ្ធមិនធ្វើជាអ្នកសង្គ្រោះនៃមនុស្សលោកទេ នោះពួកគេទៅដូចជាអំបិលដែលបាត់ជាតិប្រៃ, **គ. និង ស.** ១០៣:៩–១០ ។

**អំពើកាមគុណ** *សូមមើល* កាមរាគ, ខាងកាមរាគ, ទុច្ចរិត, ព្រហ្មចារីភាព; អំពើកាមរាគ; អំពើទុច្ចរិត

**អំពើកាមរាគខុសច្បាប់** *សូមមើលផង* កាមរាគ, ខាងកាមរាគ, អំពើកំផិត, អំពើសហាយស្មន់

ជាការស្ម័គ្រចិត្តក្នុងការចូលរួមក្នុងការកំផិត, ការសហាយស្មន់, ការប្រតិព័ទ្ធភេទដូចគ្នា, ការប្រតិព័ទ្ធស្រីនឹងស្រី, ការប្រតិព័ទ្ធនឹង ញាតិខ្លួន ឬក៏ការប្រតិព័ទ្ធផ្សេងៗទៀត ដែលមិនបរិសុទ្ធ ខុសពីធម្មជាតិ ឬមិនសមរម្យ ។

ចូរយើងបំផឹកស្រាឪពុកយើង ហើយទៅដេកជាមួយនឹងគាត់, **លោកុ.** ១៩:៣០–៣៦ ។ រូបេនក៏បានទៅរួមដំណេកនឹងប៊ិលហា ជាប្រពន្ធចុងរបស់ឪពុកខ្លួន, **លោកុ.** ៣៥:២២ (លោកុ. ៤៩:៤; ១ របា. ៥:១) ។ ការប្រតិព័ទ្ធភេទដូចគ្នា ហើយនិងការរួមដំណេក ឯទៀតដ៏ខុសឆ្គង នោះជាអំពើគួរខ្ពើមឆ្អើម, **លេវី.** ១៨:២២–២៣ ។ បើមនុស្សប្រុសណាមួយ ចាប់បង្ខំស្ត្រីឲ្យដេកជាមួយនឹងខ្លួន នោះត្រូវតែមនុស្សប្រុសនោះទេ ដែលមានទោស, **ចោទិ.** ២២:២៥–២៧ ។ អ្នកណាដែលក្រឡេកឃើញស្ត្រី ហើយមានដំរេកសំរើប ចង់បាន នោះបានប្រព្រឹត្តសេចក្ដីកំផិតនឹងនាងនោះ នៅក្នុងចិត្តខ្លួនហើយ, **ម៉ាថាយ** ៥:២៨ (នីហ្វៃ ១២:២៨) ។ ការសហាយស្មន់ ស្មោកគ្រោក សំរើបសំរាល គឺជាការថ្វាយបង្គំរូបព្រះ, **កូល៉ុស** ៣:៥ ។ នៅជាន់ក្រោយបង្អស់ មនុស្សនឹងមិនស្រឡាញ់តាមធម្មតា មនុស្ស, **២ ធីម៉ូ.** ៣:១–៣ ។ បាបខាងអំពើកាមរាគ គឺជាអំពើគួរខ្ពើមឆ្អើម, **អាលម៉ា** ៣៩:៣–៥ ។

**អំពើកំផិត** *សូមមើលផង* កាមរាគ; ការប្រតិព័ទ្ធភេទដូចគ្នា; ខាងកាមរាគ, ព្រហ្មចារីភាព; អំពើកាមរាគ, អំពើសហាយស្មន់

ជាការសេពគប់ខាងផ្លូវកាមគុណដែលខុសច្បាប់ រវាងមនុស្សប្រុសស្រី ។ ទោះជាអំពើកំផិត តាមធម្មតា មានន័យដល់ការរួមសង្វាស រវាងមនុស្សដែលរៀបការហើយ ជាមួយនឹងអ្នកផ្សេងទៀតដែលមិនមែនជាប្ដីប្រពន្ធខ្លួនក្ដី គង់តែនៅក្នុងគម្ពីរអាចមានន័យដល់មនុស្ស ដែលមិនរៀបការផងដែរ ។

ជួនកាល អំពើកំផិតត្រូវបានយកមកប្រើជានិមិត្តរូបអំពីការក្បត់សាសនានៃសាសន៍ណាមួយ ឬក៏ប្រជាជនទាំងមូលណាបែរចេញពីផ្លូវទាំងឡាយនៃព្រះអម្ចាស់ (ជនគ. ២៥:១–៣; អេសេ. ១៦:១៥–៥៩, យេរេ. ៣:៦–១០; ហូសេ ៤) ។

យ៉ូសែបមិនព្រមប្រព្រឹត្តអំពើទុច្ចរិតដ៏ធំនេះ និងអំពើបាបទាស់នឹងព្រះឡើយ, **លោកុ.** ៣៩:៧–១២ ។ កុំឲ្យផិតគ្នាឲ្យសោះ, **និក្ខ.** ២០:១៤ ។ អស់អ្នកណាដែលក្រឡេកឃើញស្ត្រី ហើយមានដំរេកសំរើបចង់បាន នោះឈ្មោះថា បានប្រព្រឹត្តសេចក្ដីកំផិតនឹងនាងនោះ នៅក្នុង ចិត្តខ្លួនហើយ, **ម៉ាថាយ** ៥:២៨ ។ គ្មានពួកមនុស្សកំផិត ឬពួកសហាយស្មន់ណាដែលបានគ្រងនគរព្រះទុកជាមរតកឡើយ, **១ កូរិន.** ៦:៩–១០ ។ ព្រះទ្រង់នឹងជំនុំជំរះមនុស្សកំផិត និងមនុស្សសហាយស្មន់គ្នា, **ហេព្រើរ** ១៣:៤ ។ អំពើកំផិត គឺជាអំពើគួរខ្ពើមឆ្អើមបំផុត ជាងអំពើបាបទាំងអស់ ក្រៅពីការខ្ចាយឈាមជនឥតទោស ឬការបដិសេធព្រះវិញ្ញាណបរិសុទ្ធ, **អាលម៉ា** ៣៩:៣–៥ ។ អ្នកណាដែល ផិតគ្នា ហើយមិនប្រែចិត្តទេ នោះនឹងត្រូវបណ្ដេញចេញ, **គ. និង ស.** ៤២:២៣–២៦ ។ បើសិនជាអ្នកណាមួយប្រព្រឹត្តអំពើកំផិត នៅក្នុងចិត្តរបស់ខ្លួន នោះនឹងមិនមានព្រះវិញ្ញាណឡើយ, **គ. និង ស.** ៦៣:១៤–១៦ ។

**អំពើបាបដ៏អត់ឱនមិនបាន** *សូមមើលផង* ការប្រមាថព្រះ; ឃាតកម្ម; ប្រមាថព្រះ, ពួកកូនអន្តរធាន, ព្រះវិញ្ញាណបរិសុទ្ធ

ជាអំពើបាបខាងការបដិសេធព្រះវិញ្ញាណបរិសុទ្ធ គឺជាអំពើបាប ដែលពុំអាចអត់ទោសឲ្យបានឡើយ ។

ពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធ នោះមិនដែលបានអត់ទោសដល់មនុស្សឡើយ, **ម៉ាថាយ** ១២:៣១–៣២ (ម៉ាកុស ៣:២៩; លូកា ១២:១០) ។ ពួកអ្នកដែលបានចំណែកនៃព្រះវិញ្ញាណបរិសុទ្ធរួចហើយ នោះគ្មានផ្លូវណានឹងនាំឲ្យគេប្រែចិត្តម្ដងទៀតទេ, **ហេព្រើរ** ៦:៤–៦ ។ ក្រោយដែលយើងបានទទួលស្គាល់សេចក្ដីពិតហើយ បើយើងធ្វើបាបស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណា សំរាប់នឹងលោះបាបទៀតទេ, **ហេព្រើរ** ១០:២៦ ។ បើកូនបដិសេធព្រះវិញ្ញាណបរិសុទ្ធ ហើយកូនដឹងថា កូនបានបដិសេធទ្រង់ នេះគឺជាអំពើបាបមួយដែលអត់ឱនមិនបានឡើយ, **អាលម៉ា** ៣៩:៥–៦ (យ៉ាកុប ៧:១៩) ។ ពួកគេពុំមានការអភ័យទោសទេ ដោយបានបដិសេធ ព្រះរាជបុត្រាបង្កើតតែមួយ ដោយបានឆ្កាងព្រះអង្គខាងឯខ្លួនគេ, **គ. និង ស.** ៧៦:៣០–៣៥ ។ ការពោលពាក្យប្រមាថទាស់នឹង ព្រះវិញ្ញាណបរិសុទ្ធ នោះនឹងអត់ទោសឲ្យពុំបានទេ ដែលជាការកំចាយឈាមដែលគ្មានទោស បន្ទាប់ពីអ្នករាល់គ្នាបានទទួលសេចក្ដីសញ្ញាថ្មី និងដ៏អស់កល្បជានិច្ចរបស់យើង, **គ. និង ស.** ១៣២:២៦–២៧ ។

**អំពើសហាយស្មន់** *សូមមើលផង* កាមរាគ, ខាងកាមរាគ, ព្រហ្មចារីភាព; អំពើកំផិត

ជាការរួមដំណេកដោយខុសច្បាប់ រវាងមនុស្សពីរនាក់ដែលមិនបានរៀបការនឹងគ្នា ។ នៅក្នុងគម្ពីរ ជួនកាល យកមកប្រើជាតំណាងអំពីសេចក្ដីក្បត់សាសនា ។

សូមកុំបង្ខំខ្ញុំឡើយ ត្បិតអំពើយ៉ាងនេះ មិនគួរធ្វើឡើយ, **២ សាំយូ.** ១៣:១២ ។ ចូរចៀសវាងពីសេចក្ដីកំផិត, **កិច្ចការ** ១៥:២០ ។ រូបកាយមិនមែនសំរាប់ការកំផិតទេ គឺសំរាប់តែព្រះអម្ចាស់វិញ, **១ កូរិន.** ៦:១៣–១៨ ។ ដើម្បីកុំឲ្យមានសេចក្ដីកំផិត នោះចូរឲ្យគ្រប់គ្នា មានប្រពន្ធជារបស់ផងខ្លួនវិញ, **១ កូរិន.** ៧:២–៣ ។ នេះគឺជាព្រះហឫទ័យរបស់ព្រះ គឺថាអ្នករាល់គ្នាគួរតែចៀសពីសេចក្ដីកំផិតចេញ, **១ ថែស្ស.** ៤:៣ ។ យ៉ាកុបបានព្រមានប្រជាជននីហ្វៃឲ្យទាស់នឹងសេចក្ដីកំផិត, **យ៉ាកុប** ៣:១២ ។ អ្នករាល់គ្នាកំពុងតែទុំ ព្រោះអំពើ ឃាតកម្មទាំងឡាយ និងអំពើកំផិតរបស់អ្នក សំរាប់ការបំផ្លិចបំផ្លាញ, **ហេលេ.** ៨:២៦ ។ ពួកអ្នកកំផិតទាំងប៉ុន្មានត្រូវតែប្រែចិត្ត ដើម្បីនឹង ចូលរួមនឹងសាសនាចក្រ, **គ. និង ស.** ៤២:៧៤–៧៨ ។

**អាំម៉ូន, ជាពូជពង្សសារ៉ាហិមឡា** *សូមមើលផង* លិមហៃ

នៅក្នុងព្រះគម្ពីរមរមន ជាបុរសខ្លាំងពូកែម្នាក់ ដែលបាននាំបេសកកម្មមួយពីក្រុងសារ៉ាហិមឡា ទៅដែនដីនីហ្វៃ-លីហៃ (ម៉ូសាយ ៧:១–១៦) ។ លោកត្រូវបានបង្ហាញបញ្ជីបុរាណមួយ ហើយបានពន្យល់ប្រាប់អំពីអ្នកមើលឆុត (ម៉ូសាយ ៨:៥–១៨) ។ ក្រោយមក លោកបានជួយរំដោះស្ដេចលិមហៃ និងរាស្ត្រទ្រង់ឲ្យរួចពីពួកសាសន៍លេមិន ហើយនាំពួកគេវិលមកក្រុងសារ៉ាហិមឡាវិញ (ម៉ូសាយ ២២) ។

**អាំម៉ូន, បុត្ររបស់ម៉ូសាយ** *សូមមើលផង* ម៉ូសាយ, បុត្ររបស់បេនយ៉ាមីន; ម៉ូសាយ, ពួកបុត្រារបស់ទ្រង់, អាន់តៃ-នីហ្វៃ-លីហៃ

នៅក្នុងព្រះគម្ពីរមរមន ជាបុត្ររបស់ស្ដេចម៉ូសាយម្នាក់ ។ អាំម៉ូនបានធ្វើការបំរើជាអ្នកផ្សាយសាសនាម្នាក់ ដោយសារការខិតខំព្យាយាមរបស់លោក បានជួយឲ្យមនុស្សជាច្រើនប្រែចិត្តជឿដល់ព្រះគ្រីស្ទ ។

ជាអ្នកមិនជឿម្នាក់ ដែលស្វែងរកកំទេចសាសនាចក្រចោល, **ម៉ូសាយ** ២៧:៨–១០, ៣៤ ។ មានទេវតាមួយបានលេចខ្លួនដល់លោក និងពួកគូកនរបស់លោក, **ម៉ូសាយ** ២៧:១១ ។ បានប្រែចិត្ត ហើយចាប់ផ្សាយព្រះបន្ទូលនៃព្រះ, **ម៉ូសាយ** ២៧:៣២–២៨:៨ ។ បានប្រកែកមិនព្រមធ្វើជាស្ដេច ហើយផ្ទុយទៅវិញ បានទៅដែនដីនៃពួកសាសន៍លេមិន ដើម្បីទៅផ្សាយព្រះបន្ទូលនៃព្រះ, **អាលម៉ា** ១៧:៦–៩ ។ បានតមអាហារ ហើយបានអធិស្ឋានសូមការណែនាំ, **អាលម៉ា** ១៧:៨–១១ ។ ត្រូវគេចងនាំទៅគាល់ស្ដេចឡាម៉ូណៃ, **អាលម៉ា** ១៧:២០–២១ ។ បានជួយសង្គ្រោះហ្វូងចៀមរបស់ស្ដេចឡាម៉ូណៃ, **អាលម៉ា** ១៧:២៦–៣៩ ។ បានផ្សាយសាសនាដល់ស្ដេចឡាម៉ូណៃ, **អាលម៉ា** ១៨:១–១៩:១៣ ។ បានថ្លែងអំណរគុណដល់ព្រះ ហើយបានពោរពេញទៅដោយសេចក្ដីអំណរ, **អាលម៉ា** ១៩:១៤ ។ ពួកអ្នក ដែលលោកបានជួយឲ្យប្រែចិត្តជឿ គេមិនដែលបាត់បង់ចេញឡើយ, **អាលម៉ា** ២៣:៦ ។ បានអរីករាយដោយបានធ្វើជាគ្រឿង ឧបករណ៍ នៅក្នុងព្រះហស្តនៃព្រះ ចំពោះការនាំមនុស្សរាប់ពាន់មករកសេចក្ដីពិត, **អាលម៉ា** ២៦:១–៨ (អាលម៉ា ២៦:១–៣៧) ។ បាននាំប្រជាជន អាន់តៃ-នីហ្វៃ-លីហៃ ទៅរកទីសុខសាន្ត, **អាលម៉ា** ២៧ ។ មានសេចក្ដីអំណរជាខ្លាំង ចំពោះការជួបបងប្អូនរបស់លោក, **អាលម៉ា** ២៧:១៦–១៨ ។

**អាំលិសៃ, សាសន៍អាំលិសៃ**

ជាបុរសម្នាក់នៅក្នុងព្រះគម្ពីរមរមន ដែលបាននាំសាសន៍នីហ្វៃមួយក្រុម ដែលមានសេចក្តីប្រាថ្នាចង់បានស្តេច នៅក្នុងរជ្ជកាលនៃពួកចៅក្រម ។ ពួកសាសន៍នីហ្វៃនេះ បានហៅថា ពួកសាសន៍អាំលិសៃ បានចេញមុខបះបោរទាស់នឹងព្រះ ម្ល៉ោះហើយ ពួកគេត្រូវ បណ្តាសា (អាលម៉ា ២–៣) ។

**អ្នកគង្វាល** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ, អ្នកគង្វាលល្អ

បើនិយាយតាមនិមិត្តរូបទៅ គឺជាអ្នកដែលថែរក្សាកូនចៅនៃព្រះអម្ចាស់ ។

ព្រះអម្ចាស់ ទ្រង់ជាអ្នកគង្វាលខ្ញុំ, **ទំនុក.** ២៣:១ ។ ពួកអ្នកគង្វាលគួរតែឲ្យចំណីដល់ហ្វូងចៀម, **អេសេ.** ៣៤:២–៣ ។

**អ្នកគង្វាលល្អ** *សូមមើលផង* ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទជាអ្នកគង្វាលល្អ ។ ស្តីតាមនិមិត្តរូប ពួកអ្នកដើរតាមទ្រង់ គឺទុកដូចជាចៀម ដែលព្រះយេស៊ូវទ្រង់ឃ្វាល ។

ព្រះអម្ចាស់ ទ្រង់ជាអ្នកគង្វាលខ្ញុំ, **ទំនុក.** ២៣:១ ។ ទ្រង់នឹងឃ្វាលហ្វូងរបស់ទ្រង់ ដូចជាអ្នកគង្វាល, **អេសាយ** ៤០:១១ ។ នោះយើង នឹងថែមើលចៀមរបស់យើង, **អេសេ.** ៣៤:១២ ។ ខ្ញុំជាអ្នកគង្វាលល្អ, **យ៉ូហាន** ១០:១៤–១៥ ។ ព្រះយេស៊ូវជាអ្នកគង្វាលដ៏ធំនៃ ហ្វូងចៀម, **ហេព្រើរ** ១៣:២០ ។ ទ្រង់បានរាប់ចំនួនចៀមរបស់ទ្រង់ ឯពួកវាក៏ស្គាល់ទ្រង់, **១ នីហ្វៃ** ២២:២៥ ។ អ្នកគង្វាលល្អនឹង ស្រែកហៅអ្នក ដោយព្រះនាមទ្រង់ គឺជាព្រះគ្រីស្ទ, **អាលម៉ា** ៥:៣៨, ៦០ ។ នឹងមានក្រោលតែមួយ និងអ្នកគង្វាលតែមួយ, ៣ នីហ្វៃ ១៥:២១ (យ៉ូហាន ១០:១៦) ។

**អ្នកគ្រងមរតក**

ជាជនដែលត្រូវបានគ្រងអំណោយទានខាងសាច់ឈាម ឬខាងវិញ្ញាណទុកជាមរតក ។ នៅក្នុងគម្ពីរ ពួកអ្នកសុចរិតត្រូវបានសន្យាថា គេនឹងក្លាយទៅជាអ្នកគ្រងរបស់ទាំងអស់ដែលព្រះទ្រង់មាន ទុកជាមរតក ។

អ័ប្រាហាំបានប្រាថ្នាចង់បានអ្នកគ្រងមរតក, **លោកុ.** ១៥:២–៥ ។ អ័ប្រាហាំបានកើតទៅជាអ្នកគ្រងលោកិយជាមរដក ដោយសារសេចក្តីសុចរិតនៃសេចក្តីជំនឿ, **រ៉ូម** ៤:១៣ ។ យើងជាកូនចៅព្រះ ហើយបើជាកូនចៅ នោះជាអ្នកគ្រងមរតក គឺជាអ្នកគ្រងមរតកនៃព្រះ ហើយជាអ្នកគ្រងមរតកជាមួយនឹងព្រះគ្រីស្ទ, **រ៉ូម** ៨:១៦–១៧ (គ. និង ស. ៨៤:៣៨) ។ អ្នកជាកូន គឺជាអ្នកគ្រងមរតកនៃព្រះ ដោយសារព្រះគ្រីស្ទ, **កាឡាទី** ៤:៧ ។ ព្រះទ្រង់បានតម្រូវព្រះរាជបុត្រារបស់ទ្រង់ឲ្យធ្វើជាអ្នកគ្រងរបស់ទាំងអស់ ទុកជាមរតក, **ហេព្រើរ** ១:២ ។ អស់អ្នកណាដែលទន្ទឹងចាំការផ្តាច់បាបរបស់គេ គឺជាអ្នកគ្រងនគរព្រះទុកជាមរតក, **ម៉ូសាយ** ១៥:១១ ។ ប្រជាជនក្លាយទៅជា កូនចៅនៃព្រះគ្រីស្ទ និងជាអ្នកគ្រងនគរព្រះទុកជាមរតក, **៤ នីហ្វៃ** ១:១៧ ។ អស់អ្នកណាដែលស្លាប់ទៅ ដោយគ្មានការចេះដឹងអំពី ដំណឹងល្អ នោះអាចទៅជាអ្នកគ្រងនគរសេឡេស្ទាលទុកជាមរតក, **គ. និង ស.** ១៣៧:៧–៨ ។ ពួកមនុស្សស្លាប់ណាដែលប្រែចិត្ត នោះជាអ្នកគ្រងសេចក្តីសង្គ្រោះទុកជាមរតក, **គ. និង ស.** ១៣៨:៥៩ ។ អ័ប្រាហាំបានក្លាយទៅជាអ្នកគ្រងមរតកដ៏ត្រឹមត្រូវ ដោយសារសេចក្តីសុចរិតរបស់លោក, **អ័ប្រា.** ១:២ ។

**អ្នកពីចាស់បុរាណ** *សូមមើល* អ័ដាម

**អ្នកទទឹងនឹងព្រះគ្រីស្ទ** *សូមមើលផង* អារក្ស

អ្នកណា ឬក៏អ្វីមួយដែលក្លែងក្លាយផែនការនៃសេចក្តីសង្គ្រោះនៃដំណឹងល្អដ៏ពិត ហើយដែលប្រឆាំងនឹងព្រះគ្រីស្ទដោយបើកមុខ ឬដោយ សម្ងាត់ ។ យ៉ូហានជាអ្នកទទួលវិវរណៈ លោកបានអធិប្បាយប្រាប់ពីពួកទទឹងនឹងព្រះគ្រីស្ទថាជាពួកបញ្ឆោត (១ យ៉ូហាន ២:១៨–២២; ៤:៣–៦; ២ យ៉ូហាន ១:៧) ។ អ្នកទទឹងនឹងព្រះគ្រីស្ទដ៏ធំបំផុតគឺ លូស៊ីហ្វើរ តែវាមានអ្នកជំនួយជាច្រើន គឺព្រមទាំងពួកវិញ្ញាណ និងមនុស្សផង ។

កូនអន្តរធានជំទាស់ ហើយដំកើងខ្លួនខ្ពស់លើអ្វីៗទាំងអស់ ដែលហៅថាព្រះ, ២ ថែស្ស. ២:១–១២ ។ វាបញ្ឆោតពួកមនុស្សនៅលើ ផែនដី ដោយសារអព្ភូតហេតុ, **វិវរ.** ១៣:១៣–១៧ ។ សេរេមមិនព្រមទទួលស្គាល់ព្រះគ្រីស្ទ ហើយបានបញ្ឆោតមនុស្សជាច្រើន, **យ៉ាកុប** ៧:១–២៣ ។ នីហូរបានបង្រៀនគោលលទ្ធិក្លែងក្លាយ បានតាំងសាសនាចក្រមួយ ហើយបានបង្កបង្កើតឧបាយកលផ្នែកសង្ឃ, **អាលម៉ា** ១:២–១៦ ។ កូរិហូរមើលងាយដល់ព្រះគ្រីស្ទ ដង្វាយធួន និងវិញ្ញាណខាងការព្យាករណ៍, **អាលម៉ា** ៣០:៦–៦០ ។

**អ្នកបរិសុទ្ធ** *សូមមើលផង* ពួកគ្រីស្ទាន; សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ; សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ

ជាសមាជិកដ៏ស្មោះត្រង់ម្នាក់ ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។

ចូរប្រមូលពួកអ្នកបរិសុទ្ធរបស់អញ ឲ្យមកឯអញ, **ទំនុក.** ៥០:៥ ។ សុលគាត់បានធ្វើអំពើអាក្រក់ដល់ពួកបរិសុទ្ធ នៅក្រុងយេរូសាឡិម, **កិច្ចការ** ៩:១–២១ ។ ពេត្រុសក៏ចុះទៅឯពួកបរិសុទ្ធ នៅភូមិលីដាដែរ, **កិច្ចការ** ៩:៣២ ។ សូមឲ្យអ្នក ដែលបានហៅមកធ្វើជាពួក បរិសុទ្ធនៅក្រុងរ៉ូមបានប្រកបដោយនូវព្រះគុណ និងសេចក្តីសុខសាន្តចុះ, **រ៉ូម** ១:៧ ។ អ្នករាល់គ្នាជាជាតិតែមួយនឹងពួកបរិសុទ្ធ, **អេភេ.** ២:១៩–២១ ។ ខ្ញុំបានឃើញសាសនាចក្រនៃកូនចៀម គឺជាពួកបរិសុទ្ធនៃព្រះ, **១ នីហ្វៃ** ១៤:១២ ។ មនុស្សខាងសាច់ឈាមជាសត្រូវដល់ព្រះ លើកលែងតែអ្នកនោះក្លាយទៅជាអ្នកបរិសុទ្ធ ដោយសារដង្វាយធួននៃព្រះគ្រីស្ទ, **ម៉ូសាយ** ៣:១៩ ។ យើង ដែលជាព្រះ អម្ចាស់បានប្រទានពរដល់ដីសំរាប់ជាការប្រើប្រាស់ដល់ពួកបរិសុទ្ធរបស់យើង, **គ. និង ស.** ៦១:១៧ ។ សាតាំងបានធ្វើសង្គ្រាមជាមួយនឹងពួកបរិសុទ្ធនៃព្រះ, **គ. និង ស.** ៧៦:២៨–២៩ ។ ចូរធ្វើការដោយមានចិត្តព្យាយាម ដើម្បីរៀបចំពួកបរិសុទ្ធសំរាប់សេចក្តីជំនុំជំរះ ដែលនឹងមកដល់, **គ. និង ស.** ៨៨:៨៤–៨៥ ។ ពួកបរិសុទ្ធគួរតែចំលែកនូវទ្រព្យរបស់ខ្លួន ដល់មនុស្សទាល់ក្រ និងមនុស្សកំសត់ទុគ៌ត, **គ. និង ស.** ១០៥:៣ ។ តំណែងទាំងឡាយខាងលើនេះ យើងបានប្រទានសំរាប់កិច្ចការខាងការងារបំរើ និងការ

ធ្វើឲ្យពួកបរិសុទ្ធរបស់ យើងបានល្អឥតខ្ចោះ, **គ. និង ស.** ១២៤:១៤៣ (អេភេ. ៤:១២) ។

**អ្នកផ្សះផ្សា** *សូមមើលផង* សេចក្ដីសុខសាន្ត

ជាអ្នកដែលនាំឲ្យមាន ឬផ្សាយសេចក្ដីសុខសាន្ត (ម៉ាថាយ ៥:៩; ៣ នីហ្វៃ ១២:៩) ។ អ្នកផ្សះផ្សាក៏អាចជាជនដែលប្រកាសដំណឹងល្អដែរ (ម៉ូសាយ ១៥:១១–១៨) ។

**អ្នកមើលឆុត** *សូមមើលផង* ព្យាការី; យូរីម និងធូមីម

ជាអ្នកដែលមានសិទ្ធិអំណាចពីព្រះ ដើម្បីមើលឃើញនូវអ្វីៗ ដែលព្រះទ្រង់បានលាក់ពីពិភពលោក ដោយភ្នែកខាងវិញ្ញាណ (ម៉ូសេ ៦:៣៥–៣៨) ។ អ្នកនោះ គឺជាអ្នកទទួលវិវរណៈ ហើយជាព្យាការី (ម៉ូសាយ ៨:១៣–១៦) ។ នៅក្នុងព្រះគម្ពីរមរមន អាំម៉ូនបាន បង្រៀនថា មានតែអ្នកមើលឆុតតែមួយគត់ ដែលអាចប្រើវត្ថុបកប្រែដ៏វិសេសនោះបាន ឬក៏ យូរីម និងធូមីម (ម៉ូសាយ ៨:១៣; ២៨:១៦) ។ អ្នកមើលឆុត ដឹងនូវការណ៍ដែលកន្លងផុតមកហើយ បច្ចុប្បន្ននេះ និងអានាគតកាល ។ កាលពីបុរាណ គេតែងតែហៅ ព្យាការីថា អ្នកមើលឆុត (១ សាំយូ. ៩:៩; ២ សាំយូ. ២៤:១១) ។

យ៉ូសែប ស្ម៊ីធ គឺជាអ្នកមើលឆុតដ៏មហិមាម្នាក់នៅថ្ងៃចុងក្រោយ (គ. និង ស. ២១:១; ១៣៥:៣) ។ ថែមទៅទៀត គណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួក១២ នាក់ គឺត្រូវបានគាំទ្រឲ្យធ្វើជាពួកព្យាការី ជាពួកអ្នកមើលឆុត និងជាពួកអ្នកទទួលវិវរណៈ ។

នេះគឺជាជនជាតិរឹងចចេស ដែលប្រាប់ដល់ពួកមើលឆុតថា កុំមើលឡើយ ហើយដល់ពួកហោរាថា កុំឲ្យទាយឡើយ, **អេសាយ** ៣០:៩–១០ ។ យើងនឹងបង្កើតអ្នកមើលឆុតដ៏ជំរើសម្នាក់ឡើង ចេញពីផលនៃពោះយើង, **២ នីហ្វៃ** ៣:៦–១៥ ។ នេះហើយជាប្រាជ្ញា; មែនហើយ គឺត្រូវធ្វើជាអ្នកមើលឆុត ជាអ្នកទទួលវិវរណៈ ជាអ្នកបកប្រែ ហើយជាព្យាការី, **គ. និង ស.** ១០៧:៩២ ។ ព្រះអម្ចាស់ទ្រង់ បានតាំងហៃរុម ស្ម៊ីធឲ្យធ្វើជាព្យាការី និងជាអ្នកមើលឆុត និងជាអ្នកទទួលវិវរណៈ ចំពោះសាសនាចក្រ, **គ. និង ស.** ១២៤:៩១–៩៤ ។

**អ្នកយកពន្ធ** *សូមមើលផង* អាណាចក្ររ៉ូម៉ាំង

នៅរ៉ូមពីសម័យបុរាណ ជាអ្នកទារពន្ធជំនួសរដ្ឋាភិបាល ។ ជាទូទៅ ពួកអ្នកយកពន្ធត្រូវពួកសាសន៍យូដាស្អប់ ។ ពួកអ្នកយកពន្ធខ្លះឆាប់ទទួលយកដំណឹងល្អ (ម៉ាថាយ ៩:៩–១០; លូកា ១៩:២–៨) ។

**អ្នកសង្រ្គោះ** *សូមមើលផង* ដង្វាយធួន; ធ្វើឲ្យធួន, ព្រះយេស៊ូវគ្រីស្ទ

ជាអ្នកអង្វរជំនួស ឬជាអ្នកនាំសម្រុះសម្រួល ។ ព្រះយេស៊ូវគ្រីស្ទជាអ្នកសង្រ្គោះនៅកណ្ដាលព្រះ និងមនុស្ស ។ ដង្វាយធួនទ្រង់ បានធ្វើឲ្យមានផ្លូវមួយ សំរាប់ឲ្យមនុស្សប្រែចិត្តចេញពីអំពើបាបទាំងឡាយរបស់ពួកគេ ហើយក្លាយទៅជាធួននឹងព្រះ ។

គ្មានអ្នកណាទោះឡើងព្រះវរបិតាបានឡើយ លើកលែងតែដោយសារព្រះយេស៊ូវគ្រីស្ទ, **យ៉ូហាន** ១៤:៦ ។ មានអ្នកសង្រ្គោះតែមួយគត់ នៅកណ្ដាលព្រះនឹងមនុស្ស, ១ ធីម៉ូ. ២:៥ ។ ព្រះគ្រីស្ទជាអ្នកកណ្ដាលរបស់សេចក្ដីសញ្ញាមួយដ៏ប្រសើរជាង, **ហេព្រើរ** ៨:៦ (ហេព្រើរ ៩:១៥; ១២:២៤; គ. និង ស. ១០៧:១៩) ។ ព្រះមែស៊ីដ៏បរិសុទ្ធនឹងអង្វរជំនួសគ្រប់កូនចៅមនុស្ស, **២ នីហ្វៃ** ២:៩ (អេសាយ ៥៣:១២; ម៉ូសាយ ១៤:១២) ។ កូនគួរតែសម្លឹងទៅព្រះ ជាអ្នកសង្រ្គោះដ៏ធំ, **២ នីហ្វៃ** ២:២៧–២៨ ។ ពួកយើងត្រូវបានធ្វើឲ្យល្អឥតខ្ចោះ តាមរយៈព្រះយេស៊ូវដ៏ជាអ្នកសង្រ្គោះនៃសេចក្ដីសញ្ញាថ្មី, **គ. និង ស.** ៧៦:៦៩ ។

**អ្នកកាន់កាប់ត្រួតត្រា, ការកាន់កាប់ត្រួតត្រា** *សូមមើលផង* ការហៅ, បានហៅពីព្រះ, ហៅ

ជាជនម្នាក់ ដែលកាន់កាប់កិច្ចការ ឬរបស់របរនៃមនុស្សដទៃ ។ អ្វីៗដែលអ្នកកាន់កាប់ត្រួតត្រាថែរក្សា គឺហៅថា ការកាន់កាប់ត្រួតត្រា ។ អ្វីៗទាំងអស់នៅលើផែនដី គឺជារបស់ផងព្រះអម្ចាស់ យើងរាល់គ្នា គឺជាអ្នកកាន់កាប់ត្រួតត្រារបស់ទ្រង់ ។ យើងរាល់គ្នាកាន់ ការខុសត្រូវចំពោះព្រះអម្ចាស់ ប៉ុន្តែយើងរាល់គ្នាអាចរាយការណ៍អំពីការកាន់កាប់ត្រួតត្រារបស់យើង ទៅពួកអ្នកតំណាងព្រះដែល មានសិទ្ធិអំណាច ។ នៅពេលយើងរាល់គ្នាទទួលការហៅឲ្យបំរើពីព្រះ ឬពីពួកអ្នកបំរើដែលមានសិទ្ធិអំណាចពីព្រះ ការកាន់កាប់ត្រួត ត្រា នោះអាចមានរួមទាំងកិច្ចការខាងវិញ្ញាណ និងខាងសាច់ឈាមផង (គ. និង ស. ២៩:៣៤) ។

ឯងមានចិត្តស្មោះនឹងត្រួតលើរបស់បន្តិច នោះអញនឹងតាំងឲ្យឯងត្រួតលើរបស់ជាច្រើនទៅទៀត, **ម៉ាថាយ** ២៥:១៤–២៣ ។ អស់អ្នកណាដែលគេប្រគល់ទុកជាច្រើនឲ្យ នោះនឹងត្រូវទារជាច្រើនពីអ្នកនោះវិញ, **លូកា** ១២:៤៨ (គ. និង ស. ៨២:៣) ។ ព្រះយេស៊ូវទ្រង់ បានប្រាប់នូវពាក្យប្រៀបប្រដូចអំពីអ្នកកាន់កាប់ត្រួតត្រាដែលមិនយុត្តិធម៌, **លូកា** ១៦:១–៨ ។ អស់អ្នកណាដែលឃើញថាជាអ្នកកាន់កាប់ ត្រួតត្រាដោយស្មោះត្រង់ នោះនឹងត្រូវបានចូលទៅក្នុងសេចក្ដីអំណរនៃព្រះអម្ចាស់របស់ខ្លួន **គ. និង ស.** ៥១:១៩ ។ ជនគ្រប់រូបត្រូវឲ្យ ដំណើររឿងអំពីការកាន់កាប់ត្រួតត្រារបស់ខ្លួន, **គ. និង ស.** ៧២:៣–៥ ។ អ្នកណាដែលជាអ្នកកាន់កាប់ត្រួតត្រាដ៏ស្មោះត្រង់ ហើយ ឈ្លាសវៃ នោះនឹងគ្រងគ្រប់របស់ទាំងអស់ទុកជាមរតក, **គ. និង ស.** ៧៨:២២ ។ ព្រះអម្ចាស់ត្រូវរាប់មនុស្សគ្រប់រូបឲ្យទទួលការខុសត្រូវ ជានាយគម្រូតការលើព្រះពរទាំងឡាយខាងផែនដី, **គ. និង ស.** ១០៤:១១–១៧ (គ. និង ស. ៤២:៣២) ។ ត្រូវខំព្យាយាម ប្រយោជន៍ឲ្យអ្នកអាចបានទៅជាអ្នកកាន់កាប់ត្រួតត្រាដ៏ឈ្លាសវៃ, **គ. និង ស.** ១៣៦:២៧ ។

**ឥន្ទធនូ** *សូមមើលផង* ទឹកជំនន់នៅសម័យណូអេ; ទូកធំ; ណូអេ, អយ្យកោក្នុងព្រះគម្ពីរប៊ីប

ជាសញ្ញា ឬទីសំគាល់មួយអំពីសេចក្ដីសញ្ញានៃព្រះជាមួយនឹងណូអេ (លោកុ. ៩:១៣–១៧) ។ ក.យ.ស., លោកុ. ៩:២១–២៥ ពន្យល់ប្រាប់ថា សេចក្ដីសញ្ញាមានរួមទាំងសេចក្ដីសន្យាទាំងឡាយដែល

ថាផែនដីនឹងមិនត្រូវលិចដោយទឹកជំនន់ទៀតឡើយ ថាក្រុងស៊ីយ៉ូននៃហេណុកនឹងវិលមកវិញ, ហើយថាព្រះអម្ចាស់ទ្រង់នឹងយាងមកគង់នៅលើផែនដីម្ដងទៀត ។

**ឥតបរិសុទ្ធ** *សូមមើល* ពួកទមិលល្មើស, អំពើដ៏ឥតបរិសុទ្ធ

**ឥតប្រយោជន៍, ការឥតប្រយោជន៍** *សូមមើលផង* សេចក្ដីឆ្មើងឆ្មៃ; សេចក្ដីប្រកបដោយលោកិយ

ជាសេចក្ដីភូតភរ ឬសេចក្ដីបញ្ឆោត; ជាសេចក្ដីឆ្មើងឆ្មៃ ។ ឥតប្រយោជន៍ និងការឥតប្រយោជន៍ ក៏អាចមានន័យថា អសារឥតការ ឬឥតតម្លៃ ។

អ្នកណាដែលមិនបណ្ដោយឲ្យព្រលឹងខ្លួន ទៅតាមសេចក្ដីភូតភរ នោះនឹងឈរនៅក្នុងទីបរិសុទ្ធរបស់ព្រះអម្ចាស់, **ទំនុក.** ២៤:៣–៤ ។ កាលណាអធិស្ឋាន នោះកុំឲ្យពោលពាក្យឥតប្រយោជន៍ដដែលៗ, **ម៉ាថាយ** ៦:៧ ។ អាគារដ៏ធំ ហើយទូលាយ គឺជាគំនិតដ៏ឥតប្រយោជន៍ និងជាសេចក្ដីឆ្មើងឆ្មៃ, **១ នីហ្វៃ** ១២:១៨ ។ តើអ្នករាល់គ្នានៅតែផ្ចង់ផ្ចួងចិត្តទៅលើតែវត្ថុដ៏ឥតប្រយោជន៍នៃលោកឬ ? **អាលម៉ា** ៥:៥៣ ។ ចូរកុំស្វែងរកវត្ថុដែលឥតប្រយោជន៍នៃលោកនេះឡើយ ត្បិតអ្នកពុំអាចយកវាទៅជាមួយបានទេ, **អាលម៉ា** ៣៩:១៤ ។ ការអសារឥតការ និងការឥតជំនឿនេះហើយ ដែលបាននាំសាសនាចក្រ ឲ្យនៅក្រោមការដាក់ទោស, **គ. និង ស.** ៨៤:៥៤–៥៥ ។ នៅពេលយើងខំស្វែងរកផ្លូវដើម្បីបំពេញសេចក្ដីប៉ងប្រាថ្នាដ៏ឥតប្រយោជន៍របស់យើង នោះស្ថានសួគ៌ដកខ្លួនចេញ, **គ. និង ស.** ១២១:៣៧ ។

**ឥតសុចរិត, សេចក្ដីដ៏ឥតសុចរិត** *សូមមើលផង* ទុច្ចរិត, ពួកទមិលល្មើស, សុចរិត, សេចក្ដីសុចរិត; សេចក្ដីស្មោកគ្រោក; ស្មោកគ្រោក, អំពើបាប; អំពើដ៏ឥតបរិសុទ្ធ; អំពើទុច្ចរិត

ទុច្ចរិត និងឥតយុត្តិធម៌; មនុស្សដែលមិនស្រឡាញ់ព្រះ ឬអ្វីៗដែលជារបស់ផងព្រះ ហើយជាអ្នកដែលមិនគាំទ្រគតិរបស់ទ្រង់ ។

ពួកមនុស្សទុច្ចរិតនឹងមិនដែលបានគ្រងនគរព្រះទុកជាមរតកទេ, **១ កូរិន.** ៦:៩–១០ ។ អស់មនុស្សណា ដែលពេញចិត្តនឹងសេចក្ដីទុច្ចរិត នោះបានជាប់មានទោសហើយ, ២ ថែស្ស. ២:១២ ។ ព្រះយេស៊ូវគ្រីស្ទអាចសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង, **១ យ៉ូហាន** ១:៩ ។ ស្ដេចដែលឥតសុចរិតម្នាក់បង្ខូចផ្លូវទាំងឡាយនៃសេចក្ដីសុចរិតទាំងអស់, **ម៉ូសាយ** ២៩:២៣ ។ មូលដ្ឋាននៃការបំផ្លិចបំផ្លាញ គឺបានសាងឡើងដោយអំពើដ៏ឥតសុចរិតរបស់ពួកមេធាវី និងពួកចៅក្រម, **អាលម៉ា** ១០:២៧ ។ យើងចាត់អ្នករាល់គ្នាឲ្យចេញទៅស្ដីបន្ទោសមនុស្សលោកពីអំពើដ៏ឥតសុចរិតទាំងឡាយ, **គ. និង ស.** ៨៤:៨៧ ។ ព្រលឹងត្រូវតែបានញែកជាបរិសុទ្ធ ពីគ្រប់អំពើដ៏ឥត សុចរិតទាំងអស់, **គ. និង ស.** ៨៨:១៧–១៨ ។ និស្ស័យនៃមនុស្សស្ទើរគ្រប់រូប គឺដើម្បីចាប់ផ្ដើមអនុវត្តអំណាចគ្រប់គ្រងដោយឥតសុចរិត, **គ. និង ស.** ១២១:៣៩ ។

**ឥតស្អាត** *សូមមើល* ស្អាត និងឥតស្អាត

**ឥស្សរភាព** *សូមមើលផង* ការឃុំឃាំង; សិទ្ធិជ្រើសរើស; សេរី, សេរីភាព

ជាស្ថានភាព ឬលក្ខខ័ណ្ឌខាងការអាចប្រព្រឹត្ត និងខាងការគិតតាមចិត្ត ។ ការគោរពតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ធ្វើឲ្យមនុស្សរួចផុតពីចំណងនៃអំពើបាបខាងវិញ្ញាណ (យ៉ូហាន ៨:៣១–៣៦) ។

ទូលបង្គំនឹងដើរទៅដោយសេរីភាព ត្បិតទូលបង្គំបានស្វែងរកអស់ទាំងបញ្ញត្តិនៃទ្រង់, **ទំនុក.** ១១៩:៤៥ ។ កន្លែងណាដែលមានព្រះ វិញ្ញាណនៃព្រះអម្ចាស់ នោះក៏មានសេរីភាពដែរ, **២ កូរិន.** ៣:១៧ ។ ចូរឈរឲ្យមាំមួន ក្នុងសេរីភាព ដែលព្រះគ្រីស្ទបានប្រោសយើង ឲ្យរួច, **កាឡាទី** ៥:១ (គ. និង ស. ៨៨:៨៦) ។ មនុស្សទាំងឡាយមានសិទ្ធិនឹងរើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច, **២ នីហ្វៃ** ២:២៧ ។ ដែនដីនេះនឹងត្រូវទៅជាដែនដីនៃឥស្សរភាព, **២ នីហ្វៃ** ១០:១១ ។ មរ៉ូណៃបានដោតទង់ឥស្សរភាពឡើងនៅក្នុង ចំណោមពួកសាសន៍នីហ្វៃ, **អាលម៉ា** ៤៦:៣៦ ។ ព្រះអម្ចាស់ និងពួកអ្នកបំរើទ្រង់ប្រកាសប្រាប់ពីឥស្សរភាពដល់ពួកវិញ្ញាណដែលជាប់ឃុំ ឃាំង, **គ. និង ស.** ១៣៨:១៨, ៣១, ៤២ ។

**ឧបាយកល** *សូមមើលផង* ការបោក, បញ្ឆោត, សេចក្ដីបញ្ឆោត

នៅក្នុងគម្ពីរ ឧបាយកល គឺជាឧបាយកិច្ចដែលបោកបញ្ឆោត ។

មានពរហើយ មនុស្សណាដែលគ្មានកលឧបាយនៅក្នុងចិត្តសោះ **ទំនុក.** ៣២:២ (ទំនុក. ៣៤:១៣; ១ ពេត្រុស ២:១) ។ ណាថាណែលជាសាសន៍អ៊ីស្រាអែល ដែលឥតមានចិត្តឧបាយ, **យ៉ូហាន** ១:៤៧ (គ. និង ស. ៤១:៩–១១) ។ ការចេះដឹងពេញទី នឹងពង្រីកព្រលឹងឲ្យធំទូលំទូលាយ ដោយឥតមានឧបាយកលឡើយ, **គ. និង ស.** ១២១:៤២ ។

**ឧបាយកលផ្ទែកសង្ឃ**

ជាពួកមនុស្សដែលផ្សាយ ហើយលើកខ្លួនធ្វើជាពន្លឺដល់ពិភពលោក ដើម្បីឲ្យគេអាចបានកម្រៃ និងការសរសើរពីពិភពលោក; ពួកគេពុំស្វែងរកសុខុមាលភាពនៃស៊ីយ៉ូនឡើយ (២ នីហ្វៃ ២៦:២៩) ។

ចូរឲ្យចំណីដល់ហ្វូងចៀមរបស់ព្រះ គឺមិនមែនដោយចង់បានកម្រៃឡើយ, **១ ពេត្រុស** ៥:២ ។ សាសនាចក្រដែលបានតាំងឡើងដើម្បីរកកម្រៃត្រូវរលំចុះ, **១ នីហ្វៃ** ២២:២៣ (មរមន ៨:៣២–៤១) ។ ដោយសារឧបាយកលផ្ទែកសង្ឃ និងអំពើទុច្ចរិត នោះព្រះយេស៊ូវនឹងត្រូវគេឆ្កាង, **២ នីហ្វៃ** ១០:៥ ។ បើយកឧបាយកលផ្ទែកសង្ឃមកប្រើនៅចំណោមប្រជាជននេះ ការណ៍នោះនឹងបញ្ជាក់នូវការបំផ្លិចបំផ្លាញរបស់គេទាំងស្រុងហើយ, **អាលម៉ា** ១:១២ ។ ពួកមនុស្សដទៃនឹងបានពោរពេញទៅដោយឧបាយកផ្ទែកសង្ឃ គ្រប់បែបយ៉ាង, ៣ នីហ្វៃ ១៦:១០ ។

**ឪពុកខាងសាច់ឈាម** *សូមមើលផង* ខាងអយ្យកោ; គ្រួសារ; ពរនៃអយ្យកោ, មាតាបិតា; អយ្យកោ

ជាឈ្មោះដ៏ពិសិដ្ឋមួយឲ្យដល់បុរស ដែលបានបង្កើត ឬក៏យកកូនមកចិញ្ចឹមតាមច្បាប់ ។

ចូរគោរពប្រតិបត្តិដល់ឪពុកម្ដាយ, **និក្ខ.** ២០:១២ (ចោទិ. ៥:១៦; ម៉ាថាយ ១៩:១៩; ម៉ូសាយ ១៣:២០) ។ ឪពុកនឹងស្ដីប្រដៅកូនដែលជាទីគាប់ចិត្តរបស់ខ្លួន, **សុភា.** ៣:១២ ។ ឪពុករាល់គ្នាអើយ ចូរកុំចាក់រុកកូនរបស់ខ្លួនឲ្យខឹងឡើយ, **អេភេ** ៦:១–៤ ។ ខ្ញុំបានទទួលការបង្រៀនខ្លះៗនូវចំណេះវិជ្ជាទាំងអស់របស់ឪពុកខ្ញុំ, **១ នីហ្វៃ** ១:១ ។ ឪពុកខ្ញុំជាមនុស្សសុចរិត — ព្រោះលោកបានបង្រៀនខ្ញុំ, **អេណុស** ១:១ ។ អាលម៉ាអធិស្ឋានឲ្យកូនប្រុសលោក, **ម៉ូសាយ** ២៧:១៤ ។ អាលម៉ាបានឲ្យបញ្ញត្តទាំងឡាយដល់កូនៗលោក, **អាលម៉ា** ៣៦–៤២ ។ ហេលេមិនដាក់ឈ្មោះឲ្យកូនៗលោកតាមដូនតារបស់ពួកគេ, **ហេលេ.** ៥:៥–១២ ។ មរមនបានគិតដល់កូន លោកជានិច្ចក្នុងការអធិស្ឋានរបស់លោក, **មរ៉ូណៃ** ៨:២–៣ ។ របស់ដ៏ធំៗអាចតម្រូវពីដៃនៃពួកឪពុក, **គ. និង ស.** ២៩:៤៨ ។ មនុស្សគ្រប់រូបតម្រូវឲ្យផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួនផ្ទាល់, **គ. និង ស.** ៧៥:២៨ ។ លោកបញ្ជាខ្ញុំឲ្យទៅរកឪពុកខ្ញុំ, **យ.ស.** — ប្រវត្តិ ១:៤៩ ។

# បទជំរើសនានាចេញពីការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស៊្មីធ

តទៅនេះ គឺជាភាគជំរើសទាំងឡាយ ចេញពីការបកប្រែព្រះគម្ពីរប៊ីបច្បាប់ស្ដេចយេម្ស ដោយយ៉ូសែប ស៊្មីធ (ក.យ.ស.) ។ ព្រះអម្ចាស់ ទ្រង់បានបំផុសគំនិតដល់យ៉ូសែប ស៊្មីធ ឲ្យសាងឡើងវិញ នូវសេចក្ដីពិតទាំងឡាយ ចំពោះឯកសារនៅក្នុងព្រះគម្ពីរប៊ីប ដែលបានបាត់បង់ ឬបានប្រែប្រួល ចាប់តាំងពីបានសរសេរពាក្យពេចន៍នោះលើកដំបូងមក ។ សេចក្ដីពិតទាំងឡាយដែលបានសាងឡើងវិញនេះ បាន បញ្ជាក់នូវគោលលទ្ធិ ហើយបានពន្យល់បទគម្ពីរឲ្យបានច្បាស់លាស់ឡើង ។ វគ្គទាំងឡាយដែលបានជ្រើសរើសឡើងសំរាប់សេចក្ដី ណែនាំដល់បទព្រះគម្ពីរ នឹងអាចជួយឲ្យអ្នកយល់បទព្រះគម្ពីរកាន់តែច្បាស់លាស់ឡើង ទោះជាបានបកប្រែចូលភាសាណាក្ដី ។

ពីព្រោះព្រះអម្ចាស់ទ្រង់បានបើកសម្ដែងប្រាប់ដល់យ៉ូសែប អំពីសេចក្ដីពិតខ្លះៗ ដែលពួកអ្នកនិពន្ធដើមបានកត់ទុកនៅគ្រាមួយ នោះការបកប្រែដោយយ៉ូសែប ស៊្មីធ មិនដូចការបកប្រែព្រះគម្ពីរប៊ីបឯទៀតនៅក្នុងពិភពលោកឡើយ ។ តាមន័យនេះ ពាក្យថា *ការបកប្រែ* គឺបានយកមកប្រើក្នុងបែបដ៏ទំលំទូលាយមួយ ហើយខុសពីធម្មតា ព្រោះការប្រែដោយយ៉ូសែប គឺជាវិវរណៈ ជាជាងការបកប្រែចំ ពីភាសាមួយទៅភាសាមួយទៀត ។ សំរាប់ពត៌មានបន្ថែមទៀត សូមមើល «ការបកប្រែដោយយ៉ូសែប ស៊្មីធ (ក.យ.ស.)» នៅក្នុង បញ្ជីរាយមុខប្រធានតាមលំដាប់អក្ខរក្រម នៅក្នុងសេចក្ដីណែនាំដល់បទព្រះគម្ពីរ ។

ការពន្យល់ដែលមានដូចតទៅនេះ បង្ហាញនូវបទជ្រើសរើសជាឧទាហរណ៍ ចេញពី ក.យ.ស. ៖

---

ាយយ៉ូសែបស៊្មីធ ។
សេចក្ដីយោងនៅក្នុងអក្សរធំនេះ
គឺជាវគ្គដែលយ៉ូសែប ស៊្មីធ ធ្វើកា
របកប្រែពីព្រះគម្ពីរប៊ីបច្បាប់ស្ដេចយេម្ស ។
ពីព្រោះការបកប្រែ របស់លោកបានសាង
ពាក្យពេចន៍ឡើងវិញ
ដល់ឯកសារនៅក្នុងព្រះគម្ពីរប៊ីប
នោះខទាំងឡាយប្រហែលខុសពីគម្ពី
រដែលអ្នកប្រើ ។

**ក.យ.ស., ម៉ាថាយ ៤:១, ៥–៦, ៨–៩**

(ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៤:១, ៥–៦, ៨–៩; ការប្រែប្រួលដូចគ្នា ត្រូវបានធ្វើនៅក្នុងគម្ពីរ លូកា ៤:២, ៥–១១)

នៅក្នុងវង់ក្រចក
គឺជាសេចក្ដីយោងនៅក្នុងព្រះ
គម្ពីររបស់អ្នក
ដែលអ្នកត្រូវប្រៀបធៀបនឹងការបកប្រែដេ

*(ព្រះយេស៊ូវទ្រង់ត្រូវបាននាំទៅដោយព្រះវិញ្ញាណ ពុំមែនដោយអារក្សសាតាំងទេ) ។*

សេចក្ដីថ្លែងនេះ
ពន្យល់ប្រាប់ពីប្រភេទគោលលទ្ធិ
ដែលយ៉ូសែប ស៊្មីធ
បានបញ្ជាក់ប្រាប់ឲ្យបានច្បាស់លាស់
នៅក្នុងការបកប្រែរបស់ លោក ។

១ គ្រានោះ ព្រះយេស៊ូវត្រូវបាននាំទៅដោយព្រះវិញ្ញាណ ទៅឯទីរហោស្ថាន ដើម្បីទៅជួបព្រះ ។

៥ គ្រានោះ ព្រះយេស៊ូវត្រូវបាននាំឡើងទៅឯក្រុងបរិសុទ្ធ ហើយព្រះវិញ្ញាណបានដាក់ទ្រង់លើកំពូលព្រះវិហារបរិសុទ្ធ ។

៦ គ្រានោះ អារក្សបានមករកទ្រង់ ហើយទូលថា បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរទំលាក់ខ្លួនទៅក្រោមចុះ ត្បិតមានសេចក្ដីចែងទុកមកថា «ទ្រង់នឹងបង្គាប់ពួកទេវតានៃទ្រង់ ពីដំណើរអ្នក ហើយពួកទេវតានឹងទ្រអ្នកដោយដៃ ក្រែងលោជើងអ្នកទង្គិចនឹងថ្ម» ។

៨ ហើយមួយទៀត ព្រះយេស៊ូវទ្រង់បានគង់នៅក្នុងព្រះវិញ្ញាណ ហើយព្រះវិញ្ញាណបាននាំទ្រង់ឡើងទៅលើកំពូលភ្នំយ៉ាងខ្ពស់ ហើយបានបង្ហាញអស់ទាំងនគរក្នុងលោកិយ និងសិរីល្អរបស់នគរទាំងនោះថ្វាយទ្រង់ទត ។

៩ ហើយអារក្សបានមករកទ្រង់ទៀត ហើយទូលថា គ្រប់របស់ទាំងនេះ ខ្ញុំនឹងឲ្យដល់អ្នក បើសិនជាអ្នកក្រាបថ្វាយបង្គំខ្ញុំ ។

នេះគឺជាឯកសារ ដែលយ៉ូសែប
ស៊្មីធបានបកប្រែ ។

## ក.យ.ស., លោកុប្បត្តិ ៩:១០–១៥

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ៩:៣–៩)

*(មនុស្សនឹងត្រូវទទួលការខុសត្រូវ ចំពោះឃាតកម្ម និងចំពោះការបង្ហិនជីវិតសត្វដែរ)* ។

១០ ប៉ុន្តែ រីឯឈាមនៃគ្រប់សាច់ទាំងអស់ ដែលយើងបានប្រទានដល់អ្នក សំរាប់ធ្វើជាអាហារនោះ នឹងត្រូវខ្ចាយទៅលើដី ដែលឲ្យ ជីវិតដល់សាច់ ហើយរីឯឈាមនោះ អ្នកមិនត្រូវបរិភោគឡើយ ។

១១ ហើយជាប្រាកដមែន មិនត្រូវកំចាយឈាមឲ្យសោះ លើកលែងតែសំរាប់ធ្វើជាអាហារ ដើម្បីរក្សាជីវិតរបស់អ្នកប៉ុណ្ណោះ; ហើយឈាមនៃសត្វគ្រប់មុខ នោះយើងនឹងតម្រូវពីដៃរបស់អ្នក ។

១២ ហើយអស់អ្នកណាដែលកំចាយឈាមរបស់មនុស្ស គឺដោយមនុស្សនោះហើយដែលឈាមរបស់គេត្រូវខ្ចាយ ត្បិតមនុស្ស មិនត្រូវកំចាយឈាមរបស់មនុស្សឲ្យសោះ ។

១៣ ត្បិតមានព្រះបញ្ញត្តិមួយដែលយើងប្រទានមកថា បងប្អូនរបស់មនុស្សគ្រប់រូបត្រូវរក្សាជីវិតនៃមនុស្សទុក ត្បិតដូចជារូបអង្គយើង នេះហើយដែលយើងបានបង្កើតមនុស្សមក ។

១៤ យើងមានព្រះបញ្ញត្តិមួយដែលយើងប្រទានដល់អ្នកថា ចូរអ្នករាល់គ្នាបង្កើតកូនឲ្យចំរើនជាច្រើនឡើង ចូរឲ្យមានជាបរិបូរនៅលើ ផែនដី ហើយឲ្យបានសាយគ្រាយនៅផែនដីចុះ ។

១៥ ហើយព្រះទ្រង់បានមានព្រះបន្ទូលទៅណូអេ និងពួកកូនប្រុសរបស់គាត់ដែលនៅជាមួយនឹងគាត់ថា ហើយមើលចុះ យើងនឹងតាំង សេចក្ដីសញ្ញារបស់យើងនឹងអ្នក ដែលយើងបានធ្វើចំពោះអយ្យកោរបស់អ្នក គឺហេណុក ស្ដីអំពីពូជរបស់អ្នកបន្ដបន្ទាប់ពីអ្នកមក ។

## ក.យ.ស., លោកុប្បត្តិ ៩:២១–២៥

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ៩:១៦–១៧)

*(ឥន្ទធនូត្រូវបានដាក់នៅលើផ្ទៃមេឃ ទុកជាទីរឭកអំពីសេចក្ដីសញ្ញារបស់ព្រះដល់ហេណុក និងដល់ណូអេ ។ នៅថ្ងៃចុងក្រោយបង្អស់ ជំនុំទូទៅនៃសាសនាចក្រនៃកូនច្បង [ស៊ីយ៉ូននៃព្រះអម្ចាស់នៅសម័យហេណុក; សូមមើលគម្ពីរ ម៉ូសេ ៧] នឹងចូលរួមនឹងពួកសុចរិត នៅលើផែនដី)* ។

២១ ហើយធ្នូនឹងត្រូវបានដាក់នៅនាពពក ហើយយើងនឹងមើលឃើញធ្នូ ដើម្បីឲ្យយើងអាចនឹកចាំពីសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ច ដែលយើងបានធ្វើចំពោះអយ្យកោរបស់អ្នក គឺហេណុក; គឺថា កាលណាមនុស្សលោកកាន់តាមព្រះបញ្ញត្តិទាំងអស់របស់យើង នោះស៊ីយ៉ូននឹងបានមកលើផែនដីម្ដងទៀត គឺទីក្រុងហេណុក ដែលយើងបានលើកឡើងមកឯយើងនោះ ។

២២ ហើយនេះគឺជាសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចរបស់យើងថា កាលណាពូជពង្សរបស់អ្នកឱបក្រសោបយកសេចក្ដីពិត ហើយសម្លឹងមើលទៅលើ គ្រានោះ ស៊ីយ៉ូននឹងសម្លឹងមើលមកក្រោម ហើយអស់ទាំងផ្ទៃមេឃនឹងញ័រដោយសប្បាយរីករាយ ហើយផែនដី នឹងញ័ររន្ធត់ដោយសេចក្ដីអំណរ

២៣ ហើយជំនុំទូទៅនៃសាសនាចក្រនៃកូនច្បងនឹងចុះមកស្ថានសួគ៌ ហើយគ្រងផែនដី ហើយនឹងមានទីលំនៅ រហូតដល់ចុងបំផុតមកដល់ ។ ហើយនេះគឺជាសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចរបស់យើង ដែលយើងបានធ្វើជាមួយនឹងអយ្យកោរបស់អ្នក គឺហេណុក ។

២៤ ហើយធ្នូនឹងនៅនាពពក ហើយយើងនឹងតាំងសេចក្ដីសញ្ញារបស់យើងចំពោះអ្នក ដែលយើងបានធ្វើរវាងយើងនឹងអ្នក ដើម្បីអស់ទាំងជីវិតនៃសាច់គ្រប់ពូជ ដែលនឹងមាននៅលើផែនដី ។

២៥ ហើយព្រះទ្រង់បានមានព្រះបន្ទូលទៅណូអេថា នេះគឺជាទីសំគាល់នៃសេចក្ដីសញ្ញាដែលយើងបានតាំងរវាងយើងនឹងអ្នក ដើម្បីសាច់គ្រប់ពូជ ដែលនឹងមាននៅលើផែនដី ។

## ក.យ.ស., លោកុប្បត្តិ ១៤:២៥–៤០

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ១៤)

*(ការងារបំរើដ៏មហិមារបស់មិលគីស្សាដែកត្រូវបានប្រាប់ អានុភាព និងព្រះពរទាំងឡាយនៃបព្វជិតភាពមិលគីស្សាដែកត្រូវបាន អធិប្បាយប្រាប់)* ។

២៥ ហើយមិលគីស្សាដែកបានបន្លឺសម្លេងរបស់លោក ហើយបានប្រទានពរដល់អាប់រ៉ាម ។

២៦ ឥឡូវនេះ មិលគីស្សាដែក គឺជាបុរសនៃសេចក្ដីជំនឿ ដែលបាននាំមកនូវសេចក្ដីសុចរិត; ហើយកាលនៅវ័យក្មេង លោកបាន កោតខ្លាចដល់ព្រះ ហើយបានបិទមាត់សិង្ហ ហើយបានពន្លត់អំណាចភ្លើង ។

២៧ ដូច្នេះហើយ ដោយបានទទួលការអនុមតិពីព្រះ ទើបលោកត្រូវបានតែងតាំងជាសង្ឃជាន់ខ្ពស់ តាមរបៀបនៃសេចក្ដីសញ្ញា ដែល ព្រះទ្រង់បានធ្វើជាមួយនឹងហេណុក ។

២៨ បព្វជិតភាពនោះគឺតាមរបៀបនៃព្រះរាជបុត្រានៃព្រះ របៀបនោះពុំបានមកដោយមនុស្ស ឬដោយបំណងនៃចិត្តមនុស្សទេ ឬដោយឪពុក ឬម្ដាយ ឬដោយការផ្ដើមនៃថ្ងៃ ឬទីបញ្ចប់នៃឆ្នាំឡើយ ប៉ុន្តែដោយសារព្រះវិញ ។

២៩ ហើយបព្វជិតភាពត្រូវបានប្រគល់ដល់មនុស្សលោក ដោយសារការហៅដោយសម្លេងរបស់ទ្រង់ផ្ទាល់ ស្របតាមព្រះហឫទ័យ របស់ទ្រង់ផ្ទាល់ ដល់អស់អ្នកណាដែលជឿដល់ព្រះនាមរបស់ទ្រង់ ។

៣០ ត្បិតព្រះទ្រង់បានស្បថនឹងហេណុក និងពូជលោក ដោយសេចក្ដីសម្បថដោយព្រះអង្គទ្រង់ ថាមនុស្សគ្រប់រូបត្រូវបានតែងតាំង តាមរបៀប និងការហៅ នោះគប្បីមានអំណាច ដោយសារសេចក្ដីជំនឿ ដើម្បីបំបាក់ភ្នំទាំងឡាយ ដើម្បីញែកទឹកសមុទ្រ ដើម្បីធ្វើ ឲ្យទឹករីងស្ងួត ដើម្បីបំបែរដំណើរទឹកចេញពីផ្លូវវា ។

៣១ ដើម្បីទប់ទល់ពួកពលទ័ពនៃសាសន៍ទាំងឡាយ ដើម្បីចែកផែនដី ដើម្បីបំបាក់ចំណងគ្រប់មុខដើម្បីឈរនៅក្នុងវត្តមាននៃព្រះ ដើម្បីធ្វើគ្រប់អ្វីៗទាំងអស់ ស្របតាមព្រះហឫទ័យរបស់ទ្រង់ ស្របតាមព្រះបញ្ញត្តិរបស់ទ្រង់ ដើម្បីមានអំណាចលើក្សត្របុរី និងអំណាច ទាំងឡាយ; ហើយនេះគឺដោយសារព្រះហឫទ័យនៃព្រះរាជបុត្រានៃព្រះដែលមានតាំងពីមុនកំណើតលោកិយមកម្ល៉េះ ។

៣២ ហើយមនុស្សលោក ដោយមានសេចក្ដីជំនឿនេះ បានឡើងមក

ដល់របៀបនេះ ដែលជារបៀបនៃព្រះ ទើបបានផ្លាស់ប្រែរូប ហើយត្រូវបាននាំឡើងទៅលើស្ថានសួគ៌ ។
៣៣ ហើយឥឡូវនេះ មិលគីស្សាដែក គឺជាសង្ឃជាន់ខ្ពស់តាមរបៀបនេះ ហេតុដូច្នេះហើយ ទើបលោកបានសេចក្ដីសុខសាន្ត នៅក្រុងសាឡិម ហើយត្រូវបានហៅថា ស្ដេចនៃសេចក្ដីសុខសាន្ត ។
៣៤ ហើយប្រជារាស្ត្រលោកបាននាំមកនូវសេចក្ដីសុចរិត ហើយបានទទួលស្ថានសួគ៌ ហើយស្វែងរកទីក្រុងហេណុក ដែលបានលើកឡើងយកទៅ ដោយបានបំបែកទីក្រុងនោះចេញពីផែនដី ទុកចំពោះថ្ងៃចុងក្រោយ ឬចំពោះចុងបំផុតផែនដី ។
៣៥ ហើយបានមានព្រះបន្ទូល ហើយស្បថដោយសម្បថមួយថា ផ្ទៃមេឃ និងផែនដីនឹងត្រូវបានមករួមគ្នា ហើយពួកកូននៃព្រះនឹងត្រូវបានសាកល្បងហាក់ដូចជាដោយភ្លើង ។
៣៦ ហើយមិលគីស្សាដែកនេះហើយ ដោយបានតាំងសេចក្ដីសុចរិត ទើបបានហៅថា ស្ដេចពីស្ថានសួគ៌ ដោយប្រជារាស្ត្ររបស់លោក ឬម្យ៉ាងទៀតថា ស្ដេចនៃសេចក្ដីសុខសាន្ត ។
៣៧ ហើយលោកបានបន្លឺសម្លេងរបស់លោក ហើយលោកបានប្រទានពរដល់អាប់រ៉ាម ដោយព្រោះមិលគីស្សាដែកជាសង្ឃជាន់ខ្ពស់ ហើយជាអ្នករក្សាឃ្លាំងនៃព្រះ;
៣៨ លោកនេះហើយដែលព្រះទ្រង់បានតាំងឲ្យទទួលដង្វាយ ១ភាគ១០ ដើម្បីមនុស្សទាល់ក្រ ។
៣៩ ហេតុដូច្នោះហើយ ទើបអាប់រ៉ាមបានថ្វាយដល់លោក នូវដង្វាយ១ភាគ១០ ចំពោះអ្វីៗទាំងអស់ដែលលោកមាន ចំពោះទ្រព្យសម្បត្តិទាំងអស់ដែលលោកមាន ដែលព្រះទ្រង់បានប្រទានដល់លោកលើសជាងដែលលោកត្រូវការ ។
៤០ ហើយហេតុការណ៍បានកើតឡើងថា ព្រះទ្រង់បានប្រទានដល់អាប់រ៉ាម ហើយបានប្រទានដល់លោក នូវទ្រព្យសម្បត្តិទាំងឡាយ និងកិត្តិយស និងដែនដីទាំងឡាយ ដើម្បីទុកជាកេរ្ដិ៍អាករដ៏អស់កល្បជានិច្ច; ស្របតាមសេចក្ដីសញ្ញាដែលលោកបានធ្វើ និងស្របតាម ព្រះពរទាំងឡាយ ដែលមិលគីស្សាដែកបានប្រទានដល់លោក ។

**ក.យ.ស., លោកុប្បត្តិ ១៥:៩–១២**

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ១៥:១–៦)

*(អ័ប្រាហាំបានឃើញព្រះរាជបុត្រានៃព្រះក្នុងការនិមិត្ត ហើយបានដឹងអំពីដំណើររស់ឡើងវិញ) ។*

៩ ហើយអាប់រ៉ាមបានទូលថា ឱព្រះអម្ចាស់ដ៏ជាព្រះអើយ សូមព្រះអង្គប្រទានដល់ទូលបង្គំ នូវដែនដីនេះ ទុកសំរាប់ជាកេរ្ដិ៍អាករដ៏អស់កល្បជានិច្ចផងចុះ ?
១០ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា ទោះជាអ្នកស្លាប់ក៏ដោយ ចុះតើយើងមិនអាចប្រទានដែនដីនេះដល់អ្នកទេឬអី ?
១១ ហើយបើសិនជាអ្នកស្លាប់ទៅ ក៏អ្នកនឹងត្រូវបានដែនដីនោះដែរ ត្បិតថ្ងៃនឹងមកដល់ ដែលកូនមនុស្សនឹងមានជីវិតរស់នៅ ប៉ុន្តែតើ លោកនឹងរស់នៅម្ដេចបាន បើសិនជាលោកមិនបានស្លាប់ទៅ ? លោកត្រូវតែបានប្រោសឲ្យមានជីវិតជាមុនសិន ។
១២ ហើយហេតុការណ៍បានកើតឡើងថា អាប់រ៉ាមបានទន្ទឹងចាំ ហើយបានមើលឃើញជំនាន់នៃកូនមនុស្ស ហើយបានអររីករាយ ហើយព្រលឹងលោកបានសំរាក ហើយលោកបានជឿដល់ព្រះអម្ចាស់ ហើយព្រះអម្ចាស់បានរាប់ជំនឿនោះ ទុកជាសេចក្ដីសុចរិតចំពោះ លោក ។

**ក.យ.ស., លោកុប្បត្តិ ១៧:៣–៧, ១១–១២**

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ១៧:៣–១២)

*(ព្រះទ្រង់បានតាំងសេចក្ដីសញ្ញាមួយ អំពីការកាត់ស្បែក ជាមួយនឹងអ័ប្រាហាំ ។ ពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹក និងអាយុដែលកូនក្មេង ត្រូវទទួលខុសត្រូវនោះត្រូវបានបើកសម្ដែងប្រាប់ដល់អ័ប្រាហាំ) ។*

៣ ហើយហេតុការណ៍បានកើតឡើងថា អាប់រ៉ាមបានក្រាបផ្កាប់មុខលោក ហើយបានអំពាវនាវដល់ព្រះនាមនៃព្រះអម្ចាស់ ។
៤ ហើយព្រះទ្រង់បានមានព្រះបន្ទូលជាមួយនឹងលោកថា រាស្ត្រយើងបានបែរចេញពីសិក្ខាបទទាំងឡាយរបស់យើង ហើយពុំបានកាន់តាមក្រិត្យក្រមរបស់យើង ដែលយើងបានប្រទានដល់ពួកអយ្យកោរបស់ពួកគេនោះទេ
៥ ហើយពួកគេពុំបានគោរពតាមការចាក់ប្រេង និងការបង្កប់ឬបុណ្យជ្រមុជទឹករបស់យើង ដែលយើងបានបញ្ជាដល់ពួកគេឡើយ;
៦ ប៉ុន្តែបានបែរចេញពីព្រះបញ្ញត្តិ ហើយបានទទួលខុសត្រូវចំពោះខ្លួនគេ នូវការលាងកូនក្មេង និងការប្រោះឈាម;
៧ ហើយបានថា ឈាមនៃអេបិលដែលសុចរិតត្រូវបានខ្ចាយជំនួសអំពើបាបទាំងឡាយ ហើយពុំបានដឹងពីផ្លូវណាដែលពួកគេទទួលខុសត្រូវនៅចំពោះយើងឡើយ ។
១១ ហើយយើងនឹងតាំងសេចក្ដីសញ្ញាមួយ អំពីការកាត់ស្បែក ជាមួយនឹងអ្នក ហើយនេះនឹងទៅជាសេចក្ដីសញ្ញារបស់យើងរវាងយើងនឹងអ្នក និងពូជរបស់អ្នក បន្ដពីអ្នករៀងទៅ តាមតំណរបស់ពួកគេ; ប្រយោជន៍ឲ្យអ្នកអាចបានស្គាល់ជារៀងរាបថា កូនក្មេងមិនត្រូវទទួលខុសត្រូវនៅចំពោះយើងឡើយ រហូតដល់ពួកគេមានអាយុប្រាំបីឆ្នាំ ។
១២ ហើយអ្នកត្រូវគោរពដើម្បីកាន់តាមគ្រប់សេចក្ដីសញ្ញាទាំងអស់របស់យើង ដែលយើងបានធ្វើសេចក្ដីសញ្ញាជាមួយនឹងពួក អយ្យកោរបស់ពួកអ្នក; ហើយអ្នកត្រូវកាន់តាមព្រះបញ្ញត្តិទាំងឡាយ ដែលយើងបានប្រទានដល់អ្នក ដោយព្រះឱស្ឋរបស់យើងផ្ទាល់ ហើយយើងនឹងទៅជាព្រះដល់អ្នក និងពូជរបស់អ្នក បន្ដពីអ្នករៀងទៅ ។

**ក.យ.ស., លោកុប្បត្តិ ១៧:២៣**

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ១៧:១៧)

*(អ័ប្រាហាំបានត្រេកអរ កាលបានប្រាប់ពីកំណើតរបស់អ៊ីសាកទុកជាមុន) ។*

២៣ ខណៈនោះ អ័ប្រាហាំក៏ក្រាបផ្កាប់មុខលោក ហើយត្រេកអរ ហើយបានគិតក្នុងចិត្តលោកថា នឹងមានកូនកើតដល់មនុស្ស ដែលមានអាយុ១០០ឆ្នាំ ហើយសារ៉ាដែលអាយុ៩០ឆ្នាំនឹងបង្កើតកូននោះ ។

**ក.យ.ស., លោកុប្បត្តិ ១៩:៩–១៥**

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ១៩:៥–១០)

*(ឡុតបានទប់ទល់នឹងអំពើទុច្ចរិតនៃក្រុងសូដុំម) ។*

៩ ហើយពួកគេបាននិយាយទៅគាត់ថា ចូរថយចេញ ។ ហើយពួកគេបានខឹងនឹងគាត់ ។

១០ ហើយពួកគេបាននិយាយនឹងគ្នាថា បុរសម្នាក់នេះបានចូលមកស្នាក់នៅក្នុងចំណោមពួកយើង ហើយឥឡូវនេះ គាត់ចង់តាំងខ្លួនធ្វើជាចៅក្រមម្នាក់ ឥឡូវនេះ យើងនឹងធ្វើគាត់ ឲ្យអាក្រក់ជាងបុរសពីរនាក់នោះទៅទៀត ។

១១ ហេតុដូច្នោះហើយ ទើបពួកគេបាននិយាយទៅបុរសនោះថា យើងនឹងយកបុរសពីរនាក់នោះ និងពួកកូនស្រីរបស់អ្នកផង; ហើយយើងនឹងប្រព្រឹត្តនឹងពួកគេ តាមដែលយើងឃើញថាល្អ ។

១២ ឥឡូវ ការណ៍នេះ គឺស្របតាមអំពើទុច្ចរិតនៃក្រុងសូដុំម ។

១៣ ហើយឡុតបាននិយាយថា ឥឡូវនេះ មើលចុះ ខ្ញុំមានកូនស្រីពីរនាក់ មិនទាន់ដែលស្គាល់ប្រុសណាទេ; ខ្ញុំសូមអង្វរនឹងបងប្អូនរបស់ខ្ញុំ សូមកុំឲ្យខ្ញុំនាំបុរសពីរនាក់នោះចេញមករកអ្នក; ហើយសូមអ្នករាល់គ្នាកុំធ្វើអ្វីដល់មនុស្សពីរនាក់នោះ តាមដែលភ្នែកអ្នក ឃើញថាល្អនោះឡើយ ។

១៤ ត្បិតព្រះទ្រង់នឹងមិនរាប់អ្នកបំរើរបស់ទ្រង់ជាសុចរិត ក្នុងការណ៍នេះឡើយ; ហេតុដូច្នោះហើយ ខ្ញុំសូមអង្វរនឹងបងប្អូនរបស់ខ្ញុំ នៅលើកនេះគត់ សូមអ្នករាល់គ្នាកុំធ្វើអ្វីដល់មនុស្សពីរនាក់នោះឡើយ ដើម្បីឲ្យពួកគេមានសេចក្ដីសុខនៅក្នុងផ្ទះរបស់ខ្ញុំ; ពីព្រោះ លោកបានចូលមកស្នាក់នៅក្រោមម្លប់នៃដំបូលផ្ទះខ្ញុំហើយ ។

១៥ ហើយពួកគេបានខឹងនឹងឡុត ហើយបានចូលទៅជិតចង់ទំលាយទ្វារ ប៉ុន្តែពួកទេវតានៃព្រះ ដែលជាមនុស្សបរិសុទ្ធ ក៏បានលូកដៃរបស់ពួកគេ ហើយចាប់ទាញឡុតចូលមកក្នុងផ្ទះមករកពួកគេវិញ រួចបិទទ្វារជិត ។

**ក.យ.ស., លោកុប្បត្តិ ៤៨:៥–១១**

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ៤៨:៥–៦)

*(ពូជរបស់យ៉ូសែបនឹងទៅជាពួកអ្នកដឹកនាំ ក្នុងការប្រមូលសាសន៍អ៊ីស្រាអែល នៅថ្ងៃចុងក្រោយ) ។*

៥ ហើយឥឡូវនេះ កូនប្រុសរបស់កូនទាំងពីរនាក់ គឺអេប្រាអិម និងម៉ាន៉ាសេ ដែលកើតដល់កូននៅស្រុកអេស៊ីព្ទ គ្រាមុនដែលឪពុក មកឯកូននៅស្រុកអេស៊ីព្ទ មើលចុះ ពួកគេជារបស់ផងឪពុក ហើយព្រះនៃពួកអយ្យកោរបស់កូននឹងប្រទានពរដល់ពួកគេ គឺដូចជារូបេន និងស៊ីម្មានដែរ ពួកគេក៏នឹងបានព្រះពរ ព្រោះពួកគេជារបស់ផងឪពុកដែរ ហេតុដូច្នោះហើយ ទើបពួកគេនឹងត្រូវបានហៅតាមឈ្មោះ របស់ឪពុក ។ (ហេតុដូច្នេះហើយ ទើបពួកគេត្រូវបានហៅថា សាសន៍អ៊ីស្រាអែល) ។

៦ ហើយពូជរបស់កូន ដែលកូនបង្កើតបានក្រោយពីពួកគេតទៅទៀត នោះនឹងបានជារបស់ផងកូន ហើយនឹងត្រូវបានហៅតាមឈ្មោះ នៃពួកបងប្រុសរបស់ពួកគេ ក្នុងចំណែកកេរ្តិ៍អាកររបស់ពួកគេ នៅក្នុងពូជអំបូរទាំងឡាយ ហេតុដូច្នេះហើយ ពួកគេត្រូវបានហៅថា ពូជអំបូររបស់ម៉ាន៉ាសេ និងពូជអំបូររបស់អេប្រាអិម។

៧ ហើយយ៉ាកុបបាននិយាយទៅយ៉ូសែបថា កាលព្រះនៃពួកអយ្យកោរបស់ឪពុកបានលេចមកឯឪពុកនៅភូមិលូស នៅស្រុកកាណាន ទ្រង់បានស្បថនឹងឪពុកថា ទ្រង់នឹងប្រទានដល់ឪពុក និងដល់ពូជរបស់ឪពុកនូវដែនដីមួយទុកជាកេរ្តិ៍អាករដ៏អស់កល្បជានិច្ច ។

៨ ហេតុដូច្នេះហើយ ឱកូនប្រុសរបស់ឪពុកអើយ ទ្រង់បានប្រទានដល់ឪពុក ក្នុងការចិញ្ចឹមកូនឲ្យធំឡើងធ្វើអ្នកបំរើដល់ឪពុក ក្នុងការជួយសង្គ្រោះគ្រួសារឪពុកឲ្យរួចពីសេចក្ដីស្លាប់

៩ ក្នុងការរំដោះប្រជាជនរបស់ឪពុក គឺពួកបងប្អូនរបស់កូនឲ្យរួចផុតពីអំណត់អត់ ដែលមានដ៏ធ្ងន់ធ្ងរនៅលើដែនដី ហេតុដូច្នោះហើយ ព្រះនៃពួកអយ្យកោរបស់កូននឹងប្រទានដល់កូន និងដល់ផលនៃពោះរបស់កូន ប្រយោជន៍ឲ្យពួកគេបានពរលើសជាងបងប្អូន របស់កូន និងលើសជាងគ្រួសារនៃឪពុករបស់កូនទៅទៀត

១០ ព្រោះកូនបានជោគជ័យ ហើយគ្រួសារនៃឪពុករបស់កូនបានក្រាបចុះចំពោះកូន ដូចដែលបានបង្ហាញដល់កូន មុនកូនត្រូវបានលក់ទៅស្រុកអេស៊ីព្ទ ដោយដៃនៃពួកបងប្រុសរបស់កូន; ហេតុដូច្នោះហើយ ទើបពួកបងប្រុសរបស់កូនត្រូវក្រាបចុះចំពោះកូន ពីតំណមួយ ទៅតំណមួយ គឺចំពោះផលនៃពោះរបស់កូនជារៀងរហូតទៅ

១១ ត្បិតកូននឹងទៅជាពន្លឺដល់ប្រជាជនរបស់កូន ដើម្បីដោះលែងពួកគេ នៅថ្ងៃជាប់ឃុំឃាំងរបស់ពួកគេ ឲ្យរួចផុតពីសេវកភាព ហើយដើម្បីផ្តល់សេចក្តីសង្គ្រោះដល់ពួកគេ កាលពួកគេបានជួបជុំគ្នា ដោយក្រាបនៅក្រោមអំពើបាប ។

**ក.យ.ស., លោកុប្បត្តិ ៥០:២៤–៣៨**

(ចូរប្រៀបធៀបនឹងគម្ពីរលោកុប្បត្តិ ៥០:២៤–២៦;
សូមមើលផង ២ នីហ្វៃ ៣)

*(ម៉ូសេ អើរ៉ុន និងយ៉ូសែប ស្ម៊ីធ ត្រូវបានប្រាប់ឈ្មោះទាំងអស់គ្នានៅក្នុងការព្យាករណ៍នេះដែលយ៉ូសែបមានកាលនៅស្រុកអេស៊ីព្ទ ។ យ៉ូសែបក៏បានព្យាករថា ព្រះគម្ពីរមរមននឹងក្លាយទៅជាគូកននឹងបញ្ជីរបស់យូដា) ។*

២៤ ហើយយ៉ូសែបបាននិយាយទៅបងប្អូនប្រុសរបស់លោកថា ខ្ញុំហៀបនឹងស្លាប់ហើយ ហើយនឹងទៅរកពួកអយ្យកោរបស់ខ្ញុំ ហើយខ្ញុំនឹងចុះទៅក្នុងផ្នូររបស់ខ្ញុំដោយសេចក្ដីអំណរ ។ ព្រះនៃឪពុករបស់ខ្ញុំ គឺយ៉ាកុប នឹងគង់នៅជាមួយអ្នក ដើម្បីដោះលែងអ្នក ឲ្យរួចពីផុតពីសេចក្តីទុក្ខវេទនា នៅថ្ងៃនៃសេវកភាពរបស់អ្នក ព្រោះព្រះអម្ចាស់ទ្រង់បានយាងមកជួបនឹងខ្ញុំ ហើយខ្ញុំបានទទួលសេចក្ដី សន្យាពីព្រះអម្ចាស់ថា ចេញពីផលនៃពោះរបស់ខ្ញុំ នោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងបង្កើតមែកមួយដ៏សុចរិតចេញពីពោះរបស់ខ្ញុំ និងព្យាការីម្នាក់ចំពោះអ្នក ដែលឪពុករបស់ខ្ញុំ គឺយ៉ាកុប បានឲ្យឈ្មោះថា សាសន៍អ៊ីស្រាអែល (ពុំមែនព្រះមែស៊ី ដែលហៅថា ស៊ីឡូរនោះទេ) ហើយព្យាការីនេះនឹងដោះលែងប្រជាជនរបស់ខ្ញុំ ឲ្យរួចផុតពីស្រុកអេស៊ីព្ទ នៅថ្ងៃនៃសេវកភាពរបស់អ្នក ។

២៥ ហើយហេតុការណ៍នឹងកើតឡើងថា ពួកគេនឹងត្រូវខ្ចាត់ខ្ចាយម្តងទៀត ហើយមែកមួយនឹងត្រូវកាត់ចេញ ហើយនឹងត្រូវបាននាំទៅស្រុកឆ្ងាយ ទោះជាយ៉ាងណាក៏ដោយ គង់តែពួកគេនឹងត្រូវបាននឹកចាំ នៅក្នុងសេចក្តីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ដែរ កាលព្រះមែស៊ី ទ្រង់នឹងយាងមក ត្បិតទ្រង់នឹងបានសម្តែងព្រះអង្គទ្រង់ដល់ពួកគេនៅគ្រាចុងក្រោយ ដោយវិញ្ញាណនៃព្រះចេស្តា ហើយនឹងនាំ ពួកគេចេញពីទីងងឹតទៅឯពន្លឺ ចេញពីទីកំបាំងងងឹត ហើយចេញពីការជាប់ឃុំឃាំង ទៅឯសេរីភាព ។

២៦ ព្រះអម្ចាស់ដ៏ជាព្រះរបស់ខ្ញុំ ទ្រង់នឹងបង្កើតអ្នកមើលឆុតម្នាក់ឡើង ដែលនឹងទៅជាអ្នកមើលឆុតម្នាក់ដ៏ជំរើស ចំពោះផលនៃ ពោះរបស់ខ្ញុំ ។

២៧ ព្រះអម្ចាស់ដ៏ជាព្រះនៃពួកអយ្យកោរបស់ខ្ញុំ ទ្រង់មានព្រះបន្ទូលមកខ្ញុំដូច្នេះថា អ្នកមើលឆុតម្នាក់ដ៏ជំរើសនឹងត្រូវបានបង្កើតឡើង ចេញពីផលនៃពោះអ្នក ហើយអ្នកនោះនឹងត្រូវបានដំកើងខ្ពស់ នៅក្នុងចំណោមផលនៃពោះអ្នក ហើយយើងនឹងប្រទានបញ្ញត្តិដល់អ្នក នោះថាគាត់ត្រូវធ្វើកិច្ចការមួយ ដើម្បីផលនៃពោះអ្នក ជាបងប្អូនរបស់គាត់ ។

២៨ ហើយគាត់នឹងនាំពួកគេឲ្យស្គាល់ពីសេចក្តីសញ្ញាទាំងឡាយដែលយើងបានធ្វើជាមួយនឹងពួកអយ្យកោរបស់អ្នក ហើយគាត់នឹង ធ្វើនូវកិច្ចការណាក៏ដោយដែលយើងបញ្ជាដល់គាត់ ។

២៩ ហើយយើងនឹងធ្វើឲ្យអ្នកនោះទៅជាធំ នៅចំពោះភ្នែកយើង ត្បិតគាត់នឹងធ្វើការរបស់យើង ហើយគាត់នឹងបានជាធំដូចអ្នកនោះ ដែលយើងបានប្រាប់ថា យើងនឹងបង្កើតឡើងសំរាប់អ្នក ឱវង្សអ៊ីស្រាអែលអើយ ដើម្បីដោះលែងរាស្ត្រយើង ចេញពីស្រុកអេស៊ីព្ទ ត្បិត យើងនឹងបង្កើតអ្នកមើលឆុតម្នាក់ឡើង ដើម្បីដោះលែងរាស្ត្រយើងចេញពីស្រុកអេស៊ីព្ទ ហើយអ្នកនោះនឹងត្រូវបានហៅថា ម៉ូសេ ។ ហើយដោយនូវឈ្មោះនេះ ទើបគាត់នឹងដឹងថា គាត់ចេញមកពីវង្សរបស់អ្នក ត្បិតគាត់នឹងត្រូវបានចិញ្ចឹមដោយបុត្រីរបស់ស្តេច ហើយ នឹងត្រូវបានហៅថាជាបុត្ររបស់ព្រះនាង ។

៣០ ហើយមួយទៀត យើងនឹងបង្កើតអ្នកមើលឆុតម្នាក់ចេញពីផលនៃពោះអ្នកហើយយើងនឹងឲ្យអ្នកនោះមានអំណាចនឹងនាំពាក្យរបស់យើងដល់ពូជនៃពោះអ្នក ហើយព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលថា ប៉ុន្តែមិនគ្រាន់តែនាំពាក្យយើងប៉ុណ្ណោះទេ គឺព្រមទាំង បញ្ជាក់ពាក្យទាំងនោះដល់គេផង ដែលនឹងត្រូវបានផ្សាយជាមុនក្នុងចំណោមពួកគេ នៅគ្រាចុងក្រោយបង្អស់

៣១ ហេតុដូច្នោះហើយ ផលនៃពោះអ្នកនឹងសរសេរទុក ហើយផលនៃពោះយូដានឹងសរសេរទុក ហើយអ្វីដែលផលនៃពោះអ្នក នឹងសរសេរ ព្រមទាំងអ្វីដែលផលនៃពោះយូដានឹងសរសេរ នោះនឹងបានប្រមូលទៅជាមួយគ្នា ដើម្បីបំភាន់នូវគោលលទ្ធិក្លែងក្លាយ ទាំងឡាយ ហើយបង្ក្រាបការទាស់ទែងគ្នាទាំងប៉ុន្មាន ហើយបង្កើតឲ្យមានសេចក្តីសុខសាន្ត នៅក្នុងចំណោមផលនៃពោះអ្នក ហើយ នាំពួកគេឲ្យស្គាល់ពួកអយ្យកោរបស់គេ នៅគ្រាចុងក្រោយ ហើយព្រមទាំងឲ្យស្គាល់សេចក្តីសញ្ញាទាំងឡាយរបស់យើង ព្រះអម្ចាស់ ទ្រង់មានព្រះបន្ទូលថាដូច្នោះ ។

៣២ ហើយចេញពីភាពទន់ខ្សោយ អ្នកនោះនឹងត្រូវបានធ្វើឲ្យមាំមួននៅក្នុងថ្ងៃដែលកិច្ចការរបស់យើងនឹងចេញទៅ ក្នុងចំណោមរាស្ត្ររបស់យើងទាំងអស់ ដើម្បីសាងពួកគេឡើងវិញ ដែលជាវង្សអ៊ីស្រាអែល នៅគ្រាចុងក្រោយបង្អស់ ។

៣៣ ហើយយើងនឹងប្រទានពរដល់អ្នកមើលឆុតនោះ ហើយអ្នកណាដែលស្វែងរកបំផ្លាញអ្នកនោះ នឹងត្រូវបានខ្មាស ព្រោះសេចក្តីសញ្ញានេះយើងបានប្រទានដល់អ្នក ព្រោះយើងនឹងនឹកចាំដល់អ្នក ពីតំណមួយទៅតំណមួយ ហើយឈ្មោះលោកនឹងត្រូវបានហៅថា យ៉ូសែប ហើយនឹងត្រូវបានដាក់តាមឈ្មោះរបស់ឪពុកលោក ហើយលោកនឹងបានដូចជាអ្នក ត្បិតការណ៍ដែលព្រះអម្ចាស់ទ្រង់នឹងធ្វើ ឡើងដោយស្នាដៃលោក នោះនឹងនាំប្រជាជនខ្ញុំទៅកាន់សេចក្តីសង្គ្រោះ ។

៣៤ ហើយព្រះអម្ចាស់ទ្រង់បានស្បថនឹងយ៉ូសែបថា ទ្រង់នឹងថែរក្សាពូជគាត់រហូត ដោយមានព្រះបន្ទូលថា យើងនឹងបង្កើតម៉ូសេឡើង ហើយរំពាត់នឹងនៅក្នុងដៃរបស់អ្នកនោះ ហើយអ្នកនោះនឹងប្រមូលរាស្ត្ររបស់យើង ហើយគាត់នឹងនាំពួកគេដូចជាហ្វូងចៀមមួយ ហើយគាត់នឹងវាយទឹកនៃសមុទ្រក្រហម ដោយរំពាត់របស់គាត់ ។

៣៥ ហើយគាត់នឹងមានសេចក្តីជំនុំជំរះ ហើយនឹងសរសេរព្រះបន្ទូលនៃព្រះ ។ ហើយគាត់នឹងមិនចេះនិយាយពាក្យច្រើនទេ ត្បិតយើងនឹងសរសេរក្រិតវិន័យរបស់យើងដល់គាត់ ដោយម្រាមដៃយើងផ្ទាល់ ។ ហើយយើងនឹងបង្កើតអ្នកនិយាយជំនួសម្នាក់ ដល់គាត់ ហើយឈ្មោះអ្នកនោះនឹងត្រូវបានហៅថា អើរ៉ុន ។

៣៦ ហើយការណ៍នោះក៏នឹងត្រូវបានសំរេចដល់អ្នកនៅគ្រាចុងក្រោយបង្អស់ដែរ ដូចដែលយើងបានស្បថមកហើយ ។ ហេតុដូច្នេះហើយ យ៉ូសែបបាននិយាយទៅបងប្អូនលោកថា ព្រះទ្រង់ប្រាកដជានឹងយាងមកជួបអ្នក ហើយនាំអ្នកចេញពីដែនដីនេះ ទៅកាន់ដែនដីដែលទ្រង់បានស្បថថានឹងឲ្យដល់អ័ប្រាហាំ និងដល់អ៊ីសាក និងដល់យ៉ាកុប ។

៣៧ ហើយយ៉ូសែបបានបញ្ជាក់ការណ៍ជាច្រើនដល់បងប្អូនលោក ហើយក៏ឲ្យពួកកូនចៅអ៊ីស្រាអែលស្បថ ដោយនិយាយទៅពួកគេថា ព្រះទ្រង់ប្រាកដជានឹងយាងមកជួបអ្នក ហើយអ្នករាល់គ្នាត្រូវយកឆ្អឹងខ្ញុំចេញពីនេះឡើងទៅជាមួយផង ។

៣៨ ម្ល៉ោះហើយ យ៉ូសែបក៏ស្លាប់ទៅ កាលគាត់មានអាយុ១១០ឆ្នាំ ហើយពួកគេបានដាក់បារទសពគាត់ រួចពួកគេបានដាក់សពគាត់ ចុះក្នុងមឈូសនៅស្រុកអេស៊ីព្ទ ហើយសពគាត់ត្រូវបានរក្សាទុកពីការបញ្ចុះដោយពួកកូនចៅអ៊ីស្រាអែល ប្រយោជន៍ឲ្យសពគាត់អាច បានសែងឡើងទៅ ហើយបញ្ចុះនៅក្នុងផ្នូរជាមួយឪពុកគាត់ ។ ហើយពួកគេបាននឹកចាំដល់សម្បថដែលពួកគេបានស្បថដល់គាត់យ៉ាង ដូច្នោះហើយ ។

**ក.យ.ស., និក្ខមនំ ៤:២១** (ចូរប្រៀបធៀបនឹងគម្ពីរនិក្ខមនំ ៤:២១; ៧:៣, ១៣; ៩:១២; ១០:១, ២០, ២៧; ១១:១០; ១៤:៤, ៨, ១៧; ចោទិយកថា ២:៣០)

*(ព្រះអម្ចាស់ទ្រង់ពុំមានការខុសត្រូវចំពោះចិត្តរឹងទទឹងរបស់ផារ៉ោនឡើយ ។ សូមមើលផង ក.យ.ស. និក្ខមនំ ៧:៣, ១៣; ៩:១២; ១០:១, ២០, ២៧; ១១:១០; ១៤:៤, ៨, ១៧; សេចក្តីយោងនីមួយៗ កាលបានបកប្រែត្រឹមត្រូវ នោះបង្ហាញឲ្យឃើញថា ផារ៉ោនបានធ្វើចិត្តរឹងទទឹងដោយខ្លួនឯង) ។*

២១ ហើយព្រះអម្ចាស់បានមានព្រះបន្ទូលនឹងម៉ូសេថា កាលណាអ្នកត្រឡប់ទៅដល់ស្រុកអេស៊ីព្ទហើយ នោះចូរអ្នកកុំខាននឹងធ្វើអស់ទាំងការអស្ចារ្យ ដែលយើងបានដាក់នៅដៃអ្នក ចំពោះមុខផារ៉ោនឡើយ ហើយយើងនឹងធ្វើឲ្យអ្នកបានលូតលាស់ ប៉ុន្តែផារ៉ោន នឹងធ្វើចិត្តរឹងទទឹង ហើយទ្រង់នឹងមិនបើកឲ្យបណ្ដាជនចេញទៅទេ ។

**ក.យ.ស., និក្ខមនំ ១៨:១** (ចូរប្រៀបធៀបនឹងគម្ពីរនិក្ខមនំ ១៨:១)

*(យេត្រូគឺជាសង្ឃជាន់ខ្ពស់)* ។

១ កាលយេត្រូ ជាសង្ឃជាន់ខ្ពស់នៅស្រុកម៉ាឌាន ដែលជាឪពុកក្មេកម៉ូសេ បានឮពីអស់ទាំងការដែលព្រះទ្រង់បានប្រោសដល់ម៉ូសេ និងពួកអ៊ីស្រាអែលជារាស្ត្រទ្រង់ ហើយដែលព្រះអម្ចាស់ទ្រង់បាននាំគេចេញពីស្រុកអេស៊ីព្ទមក

**ក.យ.ស., និក្ខមនំ ២២:១៨** (ចូរប្រៀបធៀបនឹងគម្ពីរនិក្ខមនំ ២២:១៨)

*(ពួកឃាតករនឹងមិនត្រូវនៅរស់ឡើយ)* ។

១៨ អ្នកមិនត្រូវទុកឲ្យអ្នកឃាតករនៅរស់ឡើយ ។

**ក.យ.ស., និក្ខមនំ ៣៣:២០, ២៣** (ចូរប្រៀបធៀបនឹងគម្ពីរនិក្ខមនំ ៣៣:២០, ២៣)

*(គ្មានមនុស្សមានបាបណាអាចមើលឃើញព្រះភ័ក្ត្ររបស់ព្រះ ហើយនៅរស់ឡើយ)* ។

២០ ហើយទ្រង់មានព្រះបន្ទូលនឹងម៉ូសេថា អ្នកពុំអាចមើលមុខយើងនៅពេលនេះបានឡើយ ក្រែងលោសេចក្ដីខ្ញាល់របស់យើង ឆួលឡើងទាស់នឹងអ្នក ហើយយើងបំផ្លាញអ្នក ព្រមទាំងប្រជាជនរបស់អ្នកចោល ត្បិតគ្មានមនុស្សណាម្នាក់ក្នុងចំណោមពួកគេ ដែលនឹងអាចមើលយើងនៅពេលនេះ ហើយនៅរស់បានឡើយ ត្បិតពួកគេជាមនុស្សមានបាបដ៏ក្រៃលែង ។ ហើយគ្មានមនុស្ស មានបាបណាម្នាក់នៅពេលណាមួយក្ដី ហើយនឹងពុំដែលមានមនុស្សមានបាបណាម្នាក់នៅពេលណាមួយ ដែលនឹងមើលមុខយើង ហើយនៅ រស់ឡើយ ។
២៣ ហើយយើងនឹងដកដៃយើងចេញ ហើយអ្នកនឹងបានឃើញយើងពីខាងខ្នងវិញ ប៉ុន្តែនឹងឥតឃើញមុខយើងឡើយ ដូចជាកាលពីពេលមុន ត្បិតយើងខ្ញាល់នឹងរាស្ត្ររបស់យើង គឺពួកអ៊ីស្រាអែល ។

**ក.យ.ស., និក្ខមនំ ៣៤:១–២, ១៤** (ចូរប្រៀបធៀបនឹងគម្ពីរនិក្ខមនំ ៣៤:១–២, ១៤; គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៤:២១–២៦) ។

*(បន្ទះថ្មលើកទីពីរដែលបានប្រទានដល់លោកម៉ូសេនោះមានក្រិត្យវិន័យទាបជាងបន្ទះថ្មលើកទីមួយ)* ។

១ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលនឹងម៉ូសេថា ចូរអ្នកដាប់បន្ទះថ្មពីរផ្ទាំងឲ្យដូចជាបន្ទះថ្មពីរពីមុន ហើយយើងនឹងចារិកចុះនូវ ពាក្យទាំងឡាយនៃក្រិត្យវិន័យ ដូចបានកត់នៅបន្ទះថ្មពីមុននោះ ដែលអ្នកបានបំបែកហើយ ប៉ុន្តែវានឹងមិនបានដូចពីដើមទេ ព្រោះយើង នឹងដកបព្វជិតភាពចេញពីចំណោមពួកគេ ហេតុដូច្នេះហើយ របៀបដ៏បរិសុទ្ធរបស់យើង និងក្រិត្យក្រមទាំងឡាយនៃរបៀបនោះនឹងពុំ ទៅពីមុខគេឡើយ ព្រោះវត្តមានរបស់យើងនឹងពុំទៅនៅកណ្ដាលពួកគេឡើយ ក្រែងលោយើងបំផ្លាញពួកគេចោល ។
២ ប៉ុន្តែយើងនឹងឲ្យក្រិត្យវិន័យដល់ពួកគេ ដូចកាលលើកមុន ប៉ុន្តែក្រិត្យវិន័យនោះនឹងស្របទៅតាមក្រិត្យវិន័យនៃបញ្ញត្តិខាងរូបកាយ វិញ ត្បិតយើងបានស្បថ ដោយសេចក្ដីក្រោធរបស់យើងថា ពួកគេនឹងពុំដែលចូលមកក្នុងវត្តមានរបស់យើង មកក្នុងសេចក្ដីសំរាក របស់យើងនៅថ្ងៃនៃការរសាត់ព្រាត់របស់ពួកគេឡើយ ។ ហេតុដូច្នេះហើយ ចូរធ្វើតាមអ្វីដែលយើងបានបញ្ជាដល់អ្នកចុះ ហើយចូរ រៀបចំជាស្រេចឲ្យទាន់ពេលព្រលឹម រួចឡើងមកឯលើភ្នំស៊ីណាយនៅពេលព្រឹក ហើយឈរនៅចំពោះយើងនៅលើកំពូលភ្នំ ។

*(ព្រះយេហូវ៉ា គឺជាព្រះនាមមួយ ដែលប្រជាជននៅក្នុងព្រះគម្ពីរសញ្ញាចាស់ ស្គាល់ថាជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ)* ។
១៤ ត្បិតមិនត្រូវឲ្យអ្នកវាល់គ្នាក្រាបថ្វាយបង្គំដល់ព្រះឯណាទៀតឡើយ ពីព្រោះព្រះអម្ចាស់ ដែលព្រះនាមជាព្រះយេហូវ៉ា គឺជាព្រះដ៏ ប្រច័ណ្ឌ ។

**ក.យ.ស., ចោទិយកថា ១០:២** (ចូរប្រៀបធៀបនឹងគម្ពីរចោទិយកថា ១០:២)

*(នៅលើបន្ទះថ្មលើកទីមួយ ព្រះទ្រង់បានបើកសម្ដែងប្រាប់នូវសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចនៃបព្វជិតភាពបរិសុទ្ធ)* ។

២ ហើយយើងនឹងកត់ចុះនៅបន្ទះថ្មទាំងពីរនោះ នូវពាក្យទាំងឡាយដែលនៅលើបន្ទះថ្មលើកដំបូង ដែលអ្នកបានបំបែកហើយ លើកលែងតែពាក្យទាំងឡាយនៃសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ចនៃបព្វជិតភាពបរិសុទ្ធ ហើយអ្នកត្រូវដាក់បន្ទះថ្មទាំងនោះទៅក្នុងហឹប ។

**ក.យ.ស., ១ សាំយូអែល ១៦:១៤–១៦, ២៣** (ចូរប្រៀបធៀបនឹងគម្ពីរ ១ សាំយូអែល ១៦:១៤–១៦, ២៣; ការប្រែប្រួលដូចគ្នា ត្រូវបានធ្វើដល់គម្ពីរ ១ សាំយូអែល ១៨:១០ និង ១៩:៩)

*(វិញ្ញាណអាក្រក់ដែលបានមកសណ្ឋិតលើសូលនោះពុំមែនមកពីព្រះអម្ចាស់ទេ)* ។

១៤ ប៉ុន្តែព្រះវិញ្ញាណនៃព្រះអម្ចាស់បានដកថយចេញពីសូលទៅ ហើយវិញ្ញាណអាក្រក់មួយដែលពុំមែនមកពីព្រះអម្ចាស់ ក៏មកបំភ័យទ្រង់ ។
១៥ ហើយពួកមហាតលិករបស់សូលទូលដល់ទ្រង់ថា មើលចុះ ឥឡូវនេះ មានវិញ្ញាណអាក្រក់មួយដែលពុំមែនមកពីព្រះអម្ចាស់ បានមកបំភ័យទ្រង់ហើយ ។
១៦ ឥឡូវនេះ សូមឲ្យព្រះអម្ចាស់នៃយើងខ្ញុំ បង្គាប់ដល់ពួកអ្នកបំរើរបស់ព្រះករុណា ដែលនៅចំពោះព្រះករុណានេះ ឲ្យរកមនុស្សម្នាក់

ដែលប្រសប់ចាប់ស៊ីងមក ហើយហេតុការណ៍នឹងកើតឡើងថា កាលណាវិញ្ញាណអាក្រក់មួយ ដែលពុំមែនមកពីព្រះអម្ចាស់ បានមកសណ្ឋិតលើព្រះករុណា នោះគេនឹងចាប់លេងឡើង ហើយព្រះករុណានឹងបានស្រួល ។

២៣ ហើយហេតុការណ៍បានកើតឡើងថា កាលណាវិញ្ញាណអាក្រក់ ដែលពុំមែនមកពីព្រះអម្ចាស់ បានមកសណ្ឋិតលើសូល នោះដាវីឌក៏យកស៊ីងមកចាប់លេងថ្វាយ រួចសូលទ្រង់បានធូរ ហើយស្រួលឡើងវិញ ហើយវិញ្ញាណអាក្រក់ក៏ថយចេញពីទ្រង់ទៅ ។

**ក.យ.ស., ២ សាំយូអែល ១២:១៣** (ចូរប្រៀបធៀបនឹងគម្ពីរ ២ សាំយូអែល ១២:១៣)

*(អំពើបាបដ៏ធ្ងន់ធ្ងររបស់ដាវីឌនោះពុំត្រូវបានលើកទោសដោយព្រះឡើយ)* ។

១៣ ហើយដាវីឌបានមានបន្ទូលទៅណាថាន់ថា យើងបានធ្វើបាបនឹងព្រះអម្ចាស់ ។ ហើយណាថាន់ក៏ទូលទៅដាវីឌថា ព្រះអម្ចាស់ ទ្រង់ក៏មិនបានលើកទោសដល់អំពើបាបរបស់ទ្រង់ដែរ ប្រយោជន៍កុំឲ្យទ្រង់ត្រូវសុគត ។

**ក.យ.ស., ២ របាក្សត្រ ១៨:២២** (ចូរប្រៀបធៀបនឹងគម្ពីរ ២ របាក្សត្រ ១៨:២២)

*(ព្រះអម្ចាស់ទ្រង់ពុំដាក់វិញ្ញាណភូតកុហកនៅក្នុងមាត់នៃពួកព្យាការីឡើយ)* ។

២២ ដូច្នេះ មើលចុះ ឥឡូវនេះ ព្រះអម្ចាស់ទ្រង់បានឃើញវិញ្ញាណភូតកុហកនៅក្នុងមាត់នៃពួកព្យាការីរបស់ព្រះករុណាទាំងនេះ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទាស់នឹងព្រះករុណា ។

**ក.យ.ស., ទំនុកដំកើង ១៤:១–៧**
(ចូរប្រៀបធៀបនឹងគម្ពីរទំនុកដំកើង ១៤:១–៧)

*(អ្នកនិពន្ធទំនុកដំកើងបានអរសប្បាយនៅថ្ងៃនៃការសាងឡើងវិញ)* ។

១ មនុស្សល្ងង់ខ្លៅតែងគិតក្នុងចិត្តថា គ្មានមនុស្សណាម្នាក់បានឃើញព្រះឡើយ ។ ពីព្រោះទ្រង់ពុំដែលបង្ហាញខ្លួនដល់យើងឡើយ ហេតុដូច្នេះហើយ គ្មានព្រះទេ ។ មើលចុះ ពួកគេសុទ្ធតែពុករលួយ ពួកគេបានប្រព្រឹត្តកិច្ចការទាំងឡាយដែលគួរខ្ពើមឆ្អើម ហើយឥត មានពួកគេណាម្នាក់ ដែលប្រព្រឹត្តល្អសោះ ។

២ ព្រោះព្រះអម្ចាស់ទ្រង់បានទតមើលពីលើស្ថានសួគ៌ ចំពោះកូនចៅមនុស្ស ហើយដោយសម្លេងរបស់ទ្រង់ នោះទ្រង់បានមានព្រះបន្ទូលទៅអ្នកបំរើរបស់ទ្រង់ថា ចូរអ្នករាល់គ្នាស្វែងរកក្នុងចំណោមកូនចៅមនុស្ស ដើម្បីឲ្យបានឃើញថា មានអ្នកណាខ្លះដែលយល់ ពីព្រះឬទេ ។ ហើយអ្នកនោះក៏បើកមាត់របស់ខ្លួនទៅរកព្រះអម្ចាស់ ហើយទូលថា មើលចុះ មនុស្សទាំងអស់នេះហើយ ដែលថាខ្លួនជា របស់ផងព្រះអង្គ ។

៣ ព្រះអម្ចាស់ទ្រង់ក៏មានព្រះបន្ទូលឆ្លើយតបថា ពួកគេបានវង្វេងចេញទាំងអស់ ពួកគេទាំងអស់គ្នាបានក្លាយទៅជាស្មោកគ្រោក អ្នកក៏អាចមើលឃើញហើយថា គ្មានអ្នកណាម្នាក់ដែលប្រព្រឹត្តល្អឡើយ សូម្បីតែម្នាក់ក៏គ្មានផង ។

៤ អ្នកទាំងអស់ដែលពួកគេមានសំរាប់ធ្វើជាគ្រូបង្រៀន នោះសុទ្ធតែជាពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត ហើយពុំមានការចេះដឹងនៅ ក្នុងពួកគេឡើយ ។ ពួកគេនេះហើយជាពួកអ្នកដែលស៊ីរាស្ត្ររបស់យើង ។ ពួកគេបរិភោគអាហារ ហើយមិនដែលអំពាវនាវដល់ព្រះ អម្ចាស់ឡើយ ។

៥ ពួកគេមានសេចក្ដីភិតភ័យជាខ្លាំង ត្បិតព្រះទ្រង់គង់នៅនឹងតំណមនុស្សសុចរិត ។ ទ្រង់ជាទីប្រឹក្សាដល់មនុស្សក្រីក្រ ពីព្រោះ ពួកគេមានសេចក្ដីខ្មាសដល់ពួកទុច្ចរិត ហើយភៀសខ្លួនទៅរកព្រះអម្ចាស់ សូមទីពឹងជ្រកខ្លួន ។

៦ ពួកគេមានសេចក្ដីខ្មាសដល់ការទូន្មាននៃមនុស្សក្រីក្រ ពីព្រោះព្រះអម្ចាស់ ទ្រង់ជាទីពឹងជ្រករបស់អ្នកនោះ ។

៧ ឱបើសិនជាស៊ីយ៉ូនបានចេញមកស្ថានសួគ៌ នោះជាសេចក្ដីសង្គ្រោះនៃសាសន៍អ៊ីស្រាអែល ។ ឱព្រះអម្ចាស់អើយ តើពេលណា ព្រះអង្គនឹងតាំងស៊ីយ៉ូន ? ក្នុងកាលព្រះអម្ចាស់ទ្រង់នាំពួកអ្នកជាប់ឃុំឃាំងនៃរាស្ត្រទ្រង់មកវិញ នោះយ៉ាកុបនឹងអរសប្បាយ អ៊ីស្រាអែលនឹងរីករាយសាទរ ។

**ក.យ.ស., ទំនុកដំកើង ២៤:៧–១០**
(ចូរប្រៀបធៀបនឹងគម្ពីរទំនុកដំកើង ២៤)

*(ទំនុកដំកើងនេះសរសើរដំកើងដល់ការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ)* ។

៧ ចូរងើបក្បាលឡើង ឱអ្នករាល់គ្នាដែលជាតំណទាំងឡាយនៃយ៉ាកុបអើយ; ហើយចូរអ្នករាល់គ្នាងើបឡើង; ហើយព្រះអម្ចាស់ដ៏មានព្រះចេស្ដា និងឥទ្ធិឫទ្ធិ; ព្រះអម្ចាស់ដ៏មានឥទ្ធិឫទ្ធិក្នុងចំបាំង ដែលជាស្ដេចដ៏មានសិរីល្អ ទ្រង់នឹងតាំងអ្នកឡើងជារៀងដរាប ។

៨ ហើយទ្រង់នឹងបូរផ្ទៃមេឃចេញ ហើយនឹងយាងចុះមកប្រោសលោះរាស្ត្រទ្រង់ ដើម្បីធ្វើឲ្យអ្នកទៅជាឈ្មោះមួយដ៏អស់កល្បជានិច្ច; ដើម្បីតាំងអ្នកនៅលើថ្មដាដ៏អស់កល្បជានិច្ច ។

៩ ចូរងើបក្បាលឡើង ឱអ្នករាល់គ្នាដែលជាតំណទាំងឡាយនៃយ៉ាកុបអើយ ចូរងើបក្បាលឡើង អ្នករាល់គ្នាដែលជាតំណទាំងឡាយ ដ៏អស់កល្បជានិច្ចអើយ ហើយព្រះអម្ចាស់នៃពួកពលបរិវារ ទ្រង់ជាស្ដេចលើអស់ទាំងស្ដេច

១០ គឺជាស្ដេចដ៏មានសិរីល្អ ទ្រង់នឹងយាងចុះមករកអ្នក; ហើយនឹងប្រោសលោះរាស្ត្រទ្រង់ ហើយនឹងតាំងពួកគេនៅក្នុងសេចក្ដីសុចរិត ។ សេឡា ។

**ក.យ.ស., ទំនុកដំកើង ១០៩:៤** (ចូរប្រៀបធៀបនឹងគម្ពីរទំនុកដំកើង ១០៩:៤)

*(យើងរាល់គ្នាត្រូវអធិស្ឋានឲ្យពួកមារសត្រូវរបស់យើង)* ។

៤ ហើយទោះជាទូលបង្គំមានសេចក្តីស្រឡាញ់ក៏ដោយ គង់តែពួកគេ
ជាពួកមារសត្រូវរបស់ខ្ញុំដែរ ប៉ុន្តែទូលបង្គំនឹងនៅតែអធិស្ឋានឲ្យ ពួកគេ
ជារៀងដរាប ។

**ក.យ.ស., អេសាយ ៤២:១៩–២៣**
(ចូរប្រៀបធៀបនឹងគម្ពីរអេសាយ ៤២:១៩–២២)

*(ព្រះអម្ចាស់ទ្រង់នឹងចាត់អ្នកបំរើរបស់ទ្រង់ឲ្យទៅឯអស់អ្នកណាដែលខ្វាក់)* ។

១៩ ត្បិតយើងនឹងចាត់អ្នកបំរើរបស់យើងឲ្យទៅឯអ្នកណាដែលខ្វាក់;
មែនហើយ ជាសារទូតដើម្បីទៅបើកភ្នែកអ្នកខ្វាក់ ហើយបើក
ត្រចៀកអ្នកថ្លង់
២០ ហើយពួកគេនឹងត្រូវបានធ្វើឲ្យបានល្អឥតខ្ចោះ ទោះជាគេមានការ
កង្វាក់ក៏ដោយ បើសិនជាពួកគេនឹងប្រុងស្តាប់តាមសារទូត ដែលជាអ្នក
បំរើរបស់ព្រះអម្ចាស់នោះ ។
២១ អ្នកជាមនុស្សដែលឃើញការណ៍ជាច្រើនយ៉ាង ប៉ុន្តែអ្នកមិន
ពិចារណាទេ ដែលបើកត្រចៀកចំហស្តាប់ ប៉ុន្តែអ្នកស្តាប់មិនឮសោះ ។
២២ ព្រះអម្ចាស់ទ្រង់មិនសព្វព្រះហឫទ័យនឹងមនុស្សបែបនេះឡើយ
ប៉ុន្តែដោយយល់ដល់សេចក្តីសុចរិតរបស់ទ្រង់ នោះទ្រង់នឹងលើក ដំកើង
ក្រឹត្យវិន័យ ហើយធ្វើឲ្យមានកិត្តិសព្ទ ។
២៣ អ្នកជាមនុស្សដែលត្រូវគេប្លន់ ហើយរឹបជាន់យក ពួកខ្មាំង
សត្រូវរបស់អ្នក គឺពួកគេទាំងអស់គ្នា បានដាក់អន្ទាក់អ្នកជាប់នៅក្នុង រូង
ហើយពួកគេបានលាក់អ្នកទុកនៅក្នុងគុកទាំងឡាយ ពួកគេត្រូវបានយក
ទៅជារំពា ហើយឥតមានអ្នកណាដោះឲ្យរួច ហើយសំរាប់ ជារឹប
ហើយឥតមានអ្នកណាថា ចូរប្រគល់ទៅឲ្យគេវិញនោះឡើយ ។

**ក.យ.ស., យេរេមា ២៦:១៣** (ចូរប្រៀបធៀបនឹងគម្ពីរយេរេមា
២៦:១៣)

*(ព្រះអម្ចាស់ទ្រង់មិនប្រែព្រះហឫទ័យទេ មនុស្សលោកទេតើដែលប្រែចិត្ត)* ។

១៣ ហេតុដូច្នេះហើយ ចូរកែផ្លូវទាំងឡាយរបស់អ្នក និងការ
ប្រព្រឹត្តទាំងឡាយរបស់អ្នក ហើយចូរគោរពតាមសម្លេងនៃព្រះអម្ចាស់នៃ
ព្រះរបស់អ្នក ហើយប្រែចិត្តចុះ នោះព្រះអម្ចាស់ទ្រង់នឹងបំបែរសេច
ក្តីអាក្រក់ ដែលទ្រង់បានប្រកាសទាស់នឹងអ្នកចេញ ។

**ក.យ.ស., អេម៉ុស ៧:៣** (ចូរប្រៀបធៀបនឹងគម្ពីរអេម៉ុស ៧:៣)

*(ព្រះអម្ចាស់ទ្រង់មិនប្រែព្រះហឫទ័យទេ មនុស្សលោកទេតើដែលប្រែចិត្ត)* ។

៣ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលអំពីពួកយ៉ាកុបថា ពួក
យ៉ាកុបត្រូវប្រែចិត្តពីព្រោះតែដំណើរនេះ ហេតុដូច្នេះហើយ យើងនឹង
មិនបំផ្លាញពួកគេចោលអស់រលីងឡើយ ព្រះអម្ចាស់ទ្រង់បានមានព្រះ
បន្ទូលថាដូច្នោះ ។

**ក.យ.ស., ម៉ាថាយ ៣:២៤–២៦**
(ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ២:២៣)

*(យុវវ័យ និងកុមារភាពរបស់ព្រះយេស៊ូវត្រូវបានអធិប្បាយប្រាប់)*

២៤ ហើយហេតុការណ៍បានកើតឡើងថា ព្រះយេស៊ូវទ្រង់បាន
ធំពេញវ័យឡើងជាមួយនឹងប្អូនៗរបស់ទ្រង់ ហើយបានចំរើនកម្លាំង ជា
ខ្លាំងឡើង ហើយបានទន្ទឹងដល់ព្រះអម្ចាស់ ចាំពេលនៃការងារបំរើរបស់
ទ្រង់មកដល់ ។
២៥ ហើយទ្រង់បានបំរើ នៅក្រោមព្រះវរបិតារបស់ទ្រង់ ហើយទ្រង់ពុំ
មានព្រះបន្ទូលដូចមនុស្សដទៃឡើយ ហើយទ្រង់ក៏ពុំត្រូវបង្រៀនឡើយ
ត្បិតទ្រង់មិនត្រូវការឲ្យមនុស្សណាម្នាក់បង្រៀនទ្រង់ឡើយ ។
២៦ ហើយជាច្រើនឆ្នាំក្រោយមក វេលានៃការងារបំរើរបស់
ទ្រង់ក៏មកដល់ ។

**ក.យ.ស., ម៉ាថាយ ៣:៤៣–៤៦**
(ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៣:១៥–១៧)

*(ព្រះយេស៊ូវទ្រង់បានទទួលបុណ្យជ្រមុជទឹកពីយ៉ូហាន
ដោយការពន្លិច)* ។

៤៣ ហើយព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលតបទៅគាត់ថា ចូរឲ្យខ្ញុំ
បានទទួលបុណ្យជ្រមុជទឹកពីអ្នកចុះ ត្បិតគួរឲ្យយើងបំពេញនូវគ្រប់សេចក្តី
សុចរិត ។ រួចគាត់ក៏ព្រមធ្វើថ្វាយទ្រង់ ។
៤៤ ហើយយ៉ូហានបានចុះទៅក្នុងទឹក ហើយបានធ្វើបុណ្យ
ជ្រមុជទឹកថ្វាយទ្រង់ ។
៤៥ ហើយកាលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹកហើយ នោះទ្រង់
យាងឡើងពីទឹកភ្លាម ហើយយ៉ូហានបានឃើញ ហើយមើលន៏
ផ្ទៃមេឃក៏បើកចំហដល់គាត់ ហើយគាត់បានឃើញព្រះវិញ្ញាណនៃព្រះ
យាងចុះមកដូចជាសត្វព្រាប ហើយសណ្ឋិតលើព្រះយេស៊ូវ ។
៤៦ ហើយមើលន៏ គាត់បានឮសម្លេងចេញពីស្ថានសួគ៌ថា នេះជាកូន
ស្ងួនភ្ងារបស់យើង ជាទីពេញចិត្តយើងណាស់ ។ ចូរស្តាប់តាម ទ្រង់ចុះ ។

**ក.យ.ស., ម៉ាថាយ ៤:១, ៥–៦, ៨–៩**
(ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៤:១, ៥–៦, ៨–៩;
ការកែសម្រួលដូចគ្នា ត្រូវបានធ្វើនៅក្នុងគម្ពីរ លូកា ៤:២,
៥–១១)

*(ព្រះយេស៊ូវទ្រង់ត្រូវបាននាំទៅដោយព្រះវិញ្ញាណ ពុំមែនដោយអារក្សទេ)* ។

១ គ្រានោះព្រះយេស៊ូវត្រូវបាននាំទៅដោយព្រះវិញ្ញាណ ទៅ
ឯទីរហោស្ថាន ដើម្បីទៅជួបព្រះ ។
៥ គ្រានោះ ព្រះយេស៊ូវត្រូវបាននាំឡើងទៅឯក្រុងបរិសុទ្ធ ហើយ
ព្រះវិញ្ញាណបានដាក់ទ្រង់លើកំពូលព្រះវិហារបរិសុទ្ធ ។
៦ គ្រានោះ អារក្សបានមករកទ្រង់ ហើយទូលថា បើអ្នកជាព្រះរាជ
បុត្រានៃព្រះមែន ចូរទំលាក់ខ្លួនទៅក្រោមចុះ ត្បិតមានសេចក្តីចែង

ទុកមកថា «ទ្រង់នឹងបង្គាប់ពួកទេវតានៃទ្រង់ ពីដំណើរអ្នក ហើយពួកទេវតានឹងទ្រអ្នកដោយដៃ ក្រែងលោជើងអ្នកទង្គិចនឹងថ្ម» ។
៨ ហើយមួយទៀត ព្រះយេស៊ូវទ្រង់បានគង់នៅក្នុងព្រះវិញ្ញាណ ហើយព្រះវិញ្ញាណបាននាំទ្រង់ឡើងទៅលើកំពូលភ្នំយ៉ាងខ្ពស់ ហើយបានបង្ហាញអស់ទាំងនគរក្នុងលោកិយ និងសិរីល្អរបស់នគរទាំងនោះថ្វាយទ្រង់ទត ។
៩ ហើយអារក្សបានមករកទ្រង់ទៀត ហើយទូលថា គ្រប់របស់ទាំងនេះខ្ញុំនឹងឲ្យដល់អ្នក បើសិនជាអ្នកក្រាបថ្វាយបង្គំខ្ញុំ ។

**ក.យ.ស., ម៉ាថាយ ៤:១១** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៤:១១)

*(ព្រះយេស៊ូវបានចាត់ឲ្យពួកទេវតាទៅធ្វើការងារបំរើយ៉ូហាន-បានទីស្ទ)* ។

១១ ហើយឥឡូវនេះ ព្រះយេស៊ូវបានដឹងថា យ៉ូហានត្រូវគេដាក់គុក នោះទ្រង់ក៏ចាត់ឲ្យពួកទេវតាទៅ ហើយមើលចុះ ពួកទេវតា ក៏មកហើយធ្វើការងារបំរើគាត់ ។

**ក.យ.ស., ម៉ាថាយ ៤:១៨** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៤:១៩)

*(ពួកព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់បាននិយាយអំពីព្រះយេស៊ូវ)* ។

១៨ ហើយទ្រង់បានមានព្រះបន្ទូលទៅពួកគេថា ខ្ញុំនេះហើយដែលបានចែងទុកដោយពួកព្យាការី ចូរមកតាមខ្ញុំ ហើយខ្ញុំនឹងតាំងអ្នក ឲ្យជាអ្នកនេសាទមនុស្សវិញ ។

**ក.យ.ស., ម៉ាថាយ ៤:២២** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៤:២៣)

*(ព្រះយេស៊ូវបានប្រោសបណ្ដាជនឲ្យជាក្នុងចំណោមពួកអ្នកដែលជឿដល់ព្រះនាមទ្រង់)* ។

២២ ហើយព្រះយេស៊ូវ ទ្រង់បានយាងគ្រប់សព្វក្នុងស្រុកកាលីឡេ បង្រៀនក្នុងសាលាប្រជុំទាំងឡាយរបស់ពួកគេ ហើយប្រកាស ដំណឹងល្អពីនគរ ព្រមទាំងប្រោសជម្ងឺគ្រប់មុខ និងអស់ទាំងជនជរាពិការឲ្យជាក្នុងចំណោមបណ្ដាជន ដែលជឿដល់ព្រះនាមទ្រង់ ។

**ក.យ.ស., ម៉ាថាយ ៦:១៤** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៦:១៣; ការកែសម្រួលដូចគ្នា ត្រូវបានធ្វើនៅក្នុងគម្ពីរលូកា ១១:៤)

*(ព្រះអម្ចាស់ទ្រង់ពុំដែលនាំយើងទៅក្នុងសេចក្ដីល្បួងឡើយ)* ។

១៤ ហើយសូមកុំឲ្យយើងត្រូវបាននាំទៅក្នុងសេចក្ដីល្បួងឡើយ ប៉ុន្តែសូមប្រោសឲ្យយើងខ្ញុំបានរួចពីសេចក្ដីអាក្រក់វិញ ។

**ក.យ.ស., ម៉ាថាយ ៦:២២** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៦:២២)

*(បើសិនជាភ្នែករបស់យើងស្មោះស្ម័គ្រទាំងស្រុង ទៅចំពោះសិរីល្អនៃព្រះ នោះរូបកាយយើងទាំងមូលនឹងបានពោរពេញទៅដោយពន្លឺ)* ។

២២ ពន្លឺរបស់រូបកាយ គឺជាភ្នែក បើសិនជាភ្នែករបស់អ្នកស្មោះស្ម័គ្រទាំងស្រុង ទៅចំពោះសិរីល្អនៃព្រះ នោះរូបកាយអ្នកទាំងមូលនឹងបានពោរពេញទៅដោយពន្លឺ ។

**ក.យ.ស., ម៉ាថាយ ៦:៣៨** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៦:៣៣)

*(យើងគួរស្វែងរកដើម្បីកសាងនគរព្រះជាមុនសិន)* ។

៣៨ ហេតុដូច្នោះហើយ ចូរកុំស្វែងរកអ្វីៗនៃលោកិយនេះឡើយ ប៉ុន្តែចូរអ្នកស្វែងរក ដើម្បីកសាងនគរព្រះ ហើយដើម្បីតាំងសេចក្ដី សុចរិតរបស់ទ្រង់ជាមុនសិន ទើបគ្រប់របស់ទាំងនេះនឹងត្រូវបានប្រទានដល់អ្នកថែមទៀត ។

**ក.យ.ស., ម៉ាថាយ ៧:១–២** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៧:១–២)

*(ចូរកុំថ្កោលទោសដោយមិនសុចរិតឡើយ)* ។

១ ឥឡូវ នេះគឺជាព្រះបន្ទូលទាំងឡាយដែលព្រះយេស៊ូវ ទ្រង់បានបង្រៀនពួកសិស្សទ្រង់ថា ពួកគេគួរប្រាប់ដល់បណ្ដាជន ។
២ ចូរកុំថ្កោលទោសដោយមិនសុចរិតឡើយ ដើម្បីកុំឲ្យអ្នករាល់គ្នាត្រូវគេថ្កោលទោសវិញ; ប៉ុន្តែចូរថ្កោលទោស ដោយការថ្កោស ទោសដ៏សុចរិតចុះ ។

**ក.យ.ស., ម៉ាថាយ ៧:៩–១១** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ៧:៦)

*(ចូរកុំប្រាប់សេចក្ដីអាថ៌កំបាំងទាំងឡាយដល់ពិភពលោកឡើយ)* ។

៩ ចូរអ្នករាល់គ្នាទៅក្នុងពិភពលោក ដោយនិយាយទៅកាន់មនុស្សទាំងអស់ថា ចូរប្រែចិត្តចុះ ត្បិតនគរស្ថានសួគ៌បានមកជិតដល់អ្នក ហើយ ។
១០ ហើយសេចក្ដីអាថ៌កំបាំងទាំងឡាយនៃនគរ នោះអ្នករាល់គ្នាត្រូវទុកក្នុងខ្លួនចុះ; ត្បិតវាមិនសមនឹងឲ្យរបស់បរិសុទ្ធដល់ឆ្កែ ឬអ្នក រាល់គ្នាត្រូវបោះកែវមុក្តាទាំងឡាយរបស់អ្នកដល់ជ្រូកឡើយ ក្រែងវាជាន់ឈ្លីនៅក្រោមជើងវា ។
១១ ត្បិតពិភពលោកពុំអាចទទួលនូវអ្វីដែលខ្លួនអ្នករាល់គ្នាផ្ទាល់ ពុំអាចនឹងទ្របាននោះឡើយ ហេតុដូច្នោះហើយ អ្នករាល់គ្នាមិនត្រូវឲ្យកែវមុក្តាទាំងឡាយរបស់អ្នកដល់ពួកគេឡើយ ក្រែងជាពួកគេបែរមកវិញ ហើយខ្វេះអ្នក ។

**ក.យ.ស., ម៉ាថាយ ៩:១៨–២១** (ឯកសារនេះត្រូវបានសាងឡើងវិញ ដោយព្យាការីយ៉ូសែប ស្ម៊ិធ ដែលបានបញ្ចូលនៅចន្លោះគម្ពីរ ម៉ាថាយ ៩:១៥ និងម៉ាថាយ ៩:១៦)

*(ព្រះយេស៊ូវ ទ្រង់មិនទទួលស្គាល់បុណ្យជ្រមុជទឹកនៃពួកផារិស៊ី ទ្រង់បានប្រទានក្រិត្យវិន័យនៃលោកម៉ូសេ)* ។

១៨ គ្រានោះ ពួកផារិស៊ីបានទូលនឹងទ្រង់ថា តើលោកនឹងមិនទទួលស្គាល់យើង ព្រមទាំងបុណ្យជ្រមុជទឹករបស់យើងទេឬអី ដោយឃើញថា យើងកាន់តាមក្រិត្យវិន័យទាំងមូល ?
១៩ ប៉ុន្តែព្រះយេស៊ូវ ទ្រង់បានមានព្រះបន្ទូលទៅពួកគេថា អ្នករាល់គ្នាពុំបានកាន់តាមក្រិត្យវិន័យទេ ។ បើសិនជាអ្នករាល់គ្នាបានកាន់ តាមក្រិត្យវិន័យមែន នោះអ្នករាល់គ្នាច្បាស់ជាបានទទួលខ្ញុំហើយ ត្បិតខ្ញុំនេះហើយដែលបានឲ្យក្រិត្យវិន័យនោះ ។
២០ ខ្ញុំមិនទទួលស្គាល់អ្នក ព្រមទាំងបុណ្យជ្រមុជទឹករបស់អ្នកទេ ពីព្រោះវាគ្មានប្រយោជន៍អ្វីដល់អ្នកឡើយ ។
២១ ត្បិតកាលរបស់ថ្មីបានមកដល់ នោះរបស់ចាស់នឹងត្រូវដកចេញ ។

**ក.យ.ស., ម៉ាថាយ ១៦:២៥–២៦** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ១៦:២៤)

*(អត្ថន័យនៃឃ្លាដែលថា «ផ្ទុកឈើឆ្កាងនៃព្រះយេស៊ូវ» នោះមានន័យថា បដិសេធនូវអំពើដ៏ឥតសុចរិត)* ។

២៥ គ្រានោះ ព្រះយេស៊ូវ ទ្រង់បានមានព្រះបន្ទូលទៅពួកសិស្សរបស់ទ្រង់ថា បើអ្នកណាចង់មកតាមខ្ញុំ នោះចូរឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ ។
២៦ ហើយឥឡូវនេះ បើសិនជាអ្នកណាចង់ផ្ទុកឈើឆ្កាងរបស់ខ្លួន នោះគឺត្រូវលះកាត់ចិត្តខ្លួនឯងចេញពីអស់ទាំងអំពើដ៏ឥតសុចរិត និងគ្រប់ទាំងសេចក្ដីសំរើបខាងលោកិយ ហើយកាន់តាមបញ្ញត្តិទាំងឡាយរបស់ខ្ញុំចុះ ។

**ក.យ.ស., ម៉ាថាយ ១៧:១០–១៤** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ១៧:១១–១៣)

*(លោកអេលីយ៉ាពីរនាក់នឹងត្រូវមក — ម្នាក់មកដើម្បីរៀបចំ រីឯម្នាក់ទៀតមកដើម្បីសាងឡើងវិញ)* ។

១០ ហើយព្រះយេស៊ូវ ទ្រង់បានមានព្រះបន្ទូលឆ្លើយតបទៅពួកគេថា លោកអេលីយ៉ាត្រូវមកមុនមែន ហើយនឹងសាងការណ៍ទាំងអស់ឡើងវិញ ដូចដែលពួកព្យាការីបានចែងទុក ។
១១ ហើយជាថ្មីទៀត ខ្ញុំប្រាប់អ្នករាល់គ្នាថា លោកអេលីយ៉ាបានមកហើយ ស្ដីអំពីអ្នកនោះដែលត្រូវបានចែងទុក មើលចុះ យើងនឹង ចាត់សារទូតរបស់យើងឲ្យទៅ ហើយអ្នកនោះនឹងរៀបចំផ្លូវចាំយើង ហើយពួកគេពុំបានស្គាល់លោកទេ ហើយបានប្រព្រឹត្តនឹងលោក តាមតែចិត្តគេ ។
១២ កូនមនុស្សក៏នឹងត្រូវរងទុក្ខដោយសារពួកគេដូច្នោះដែរ ។
១៣ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា តើនរណាជាលោកអេលីយ៉ា ? មើលចុះ នេះគឺជាលោកអេលីយ៉ា ដែលខ្ញុំចាត់ឲ្យមករៀបចំផ្លូវចាំខ្ញុំ ។
១៤ គ្រានោះ ពួកសិស្សបានយល់ថា ទ្រង់បានមានព្រះបន្ទូលទៅពួកគេ អំពីយ៉ូហាន-បាទិស្ទ ព្រមទាំងអំពីម្នាក់ទៀតដែលត្រូវមក ហើយសាងឡើងវិញនូវគ្រប់អ្វីៗទាំងអស់ ដូចដែលបានចែងទុកដោយពួកព្យាការី ។

**ក.យ.ស., ម៉ាថាយ ១៨:១១** (សូមមើលគម្ពីរម៉ាថាយ ១៨:១១; សូមមើលផងនូវគម្ពីរម៉ូរ៉ូណៃ ៨)

*(ពួកកូនក្មេងតូចៗមិនត្រូវការប្រែចិត្តទេ)* ។

១១ ត្បិតកូនមនុស្សបានមក ដើម្បីនឹងជួយសង្គ្រោះអ្នកណាដែលបាត់បង់ ហើយដើម្បីនឹងហៅមនុស្សមានបាប ឲ្យប្រែចិត្ត ប៉ុន្តែពួកកូនក្មេងតូចៗមិនត្រូវការប្រែចិត្តទេ ហើយខ្ញុំនឹងជួយសង្គ្រោះពួកគេ ។

**ក.យ.ស., ម៉ាថាយ ១៩:១៣** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ១៩:១៣)

*(ពួកកូនក្មេងតូចៗនឹងបានសង្គ្រោះ)* ។

១៣ លំដាប់នោះ មានគេនាំពួកកូនក្មេងតូចៗមកឯទ្រង់ ដើម្បីឲ្យទ្រង់ដាក់ព្រះហស្តលើពួកគេ ហើយអធិស្ឋាន ។ ហើយពួកសិស្សបានបន្ទោសដល់គេ ដោយនិយាយថា មិនត្រូវការទេ ត្បិតព្រះយេស៊ូវ ទ្រង់បានមានព្រះបន្ទូលថា ពួកកូនក្មេងនឹងត្រូវបានសង្គ្រោះហើយ ។

**ក.យ.ស., ម៉ាថាយ ២១:៣៣** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ២១:៣២–៣៣)

*(មនុស្សត្រូវតែប្រែចិត្តមុនគេអាចជឿដល់ព្រះគ្រីស្ទ)* ។

៣៣ ត្បិតអ្នកណាដែលមិនជឿតាមយ៉ូហាន ដែលស្ដីអំពីខ្ញុំទេ នោះពុំអាចជឿដល់ខ្ញុំដែរ លើកលែងតែអ្នកនោះប្រែចិត្តជាមុនសិន ។

**ក.យ.ស., ម៉ាថាយ ២១:៤៧–៥៦** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ២១:៤៥–៤៦)

*(ព្រះយេស៊ូវទ្រង់បានប្រកាសប្រាប់ថា ទ្រង់ជាថ្មជ្រុងយ៉ាងឯក ។ ដំណឹងល្អត្រូវបានប្រទានដល់ពួកសាសន៍យូដា រួចទើបទៅដល់ ពួកសាសន៍ដទៃ ។ ពួកទុច្ចរិតនឹងត្រូវបំផ្លាញចោល កាលព្រះយេស៊ូវទ្រង់យាងមកវិញ)* ។

៤៧ ហើយកាលពួកសង្គ្រាជ និងពួកផារិស៊ីបានឮពាក្យប្រៀបប្រដូចទាំងឡាយរបស់ទ្រង់ហើយ នោះពួកគេដឹងថា ទ្រង់មានព្រះបន្ទូល អំពីពួកគេ ។
៤៨ ហើយពួកគេនិយាយគ្នាថា តើមនុស្សនេះគិតថា មានតែខ្លួនគាត់ម្នាក់ឬដែលអាចបំផ្លាញនគរដ៏ធំនេះបាន ? ហើយពួកគេក៏ខឹងនឹងទ្រង់ ។

៤៩ ប៉ុន្តែកាលពួកគេរកហេតុដើម្បីចាប់ទ្រង់ ពួកគេខ្លាចហ្វូងមនុស្ស ពីព្រោះពួកគេបានដឹងថា បណ្ដាជនរាប់ទ្រង់ទុកជាព្យាការីម្នាក់ ។

៥០ ហើយឥឡូវនេះ ពួកសិស្សរបស់ទ្រង់បានមករកទ្រង់ ហើយទ្រង់មានព្រះបន្ទូលនឹងពួកគេថា តើអ្នករាល់គ្នាឆ្ងល់អំពីពាក្យប្រៀប ប្រដូចដែលខ្ញុំបាននិយាយអំពីពួកគេឬអី ?

៥១ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំជាថ្ម ហើយពួកទុច្ចរិតទាំងនោះបានចោលខ្ញុំចេញ ។

៥២ ខ្ញុំជាថ្មជ្រុងយ៉ាងឯក ។ ពួកសាសន៍យូដាទាំងនេះនឹងធ្លាក់លើខ្ញុំ ហើយនឹងត្រូវបាក់បែក ។

៥៣ ហើយនគរព្រះនឹងត្រូវបានហូតចេញពីពួកគេ ហើយនឹងត្រូវបានប្រគល់ទៅឲ្យសាសន៍មួយ ដែលនឹងបង្កើតផលចេញពីនគរនោះ (មានន័យដល់ពួកសាសន៍ដទៃ) ។

៥៤ ហេតុដូច្នោះហើយ អ្នកណាដែលធ្លាក់លើថ្មនេះ វានឹងកិនអ្នកនោះទៅជាម្សៅ ។

៥៥ ហើយដូច្នេះ កាលណាព្រះអម្ចាស់នៃចំការយាងមក នោះទ្រង់នឹងបំផ្លាញពួកមនុស្សទុច្ចរិត និងអាក្រក់ទាំងនោះចោល ហើយនឹង ប្រគល់ចំការរបស់ទ្រង់ដល់អ្នកធ្វើការផ្សេងទៀត នៅជាន់ក្រោយបង្អស់ គឺដល់អ្នកណាដែលនឹងផ្ដល់ផលទាំងឡាយដល់ទ្រង់ តាមរដូវ ផ្លែទាំងឡាយ ។

៥៦ ហើយនៅគ្រានោះ ទើបពួកគេយល់អំពីពាក្យប្រៀបប្រដូច ដែលទ្រង់បានមានព្រះបន្ទូលដល់ពួកគេថា ពួកសាសន៍ដទៃក៏នឹងត្រូវបំផ្លាញចោលដែរ កាលព្រះអម្ចាស់ទ្រង់នឹងយាងចុះមកពីលើស្ថានសួគ៌ ដើម្បីមកសោយរាជ្យនៅក្នុងចំការរបស់ទ្រង់ ដែលជាផែនដី ព្រមទាំងបណ្ដាជននៅលើផែនដី ។

**ក.យ.ស., ម៉ាថាយ ២៣:៦** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ២៣:៩)

*(ព្រះដែលគង់នៅស្ថានសួគ៌ គឺជាព្រះដ៏បង្កបង្កើត)* ។

៦ ហើយចូរកុំហៅអ្នកណាជាព្រះដ៏បង្កបង្កើតនៅលើផែនដី ឬជាព្រះវរបិតាសួគ៌ឡើយ ត្បិតព្រះដ៏បង្កបង្កើត និងព្រះវរបិតាសួគ៌របស់អ្នកមានតែមួយប៉ុណ្ណោះ គឺជាព្រះទ្រង់ដែលគង់នៅស្ថានសួគ៌ ។

**ក.យ.ស., ម៉ាថាយ ២៦:២២, ២៤–២៥**
(ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ២៦:២៦–២៩; ក.យ.ស., ម៉ាកុស ១៤:២០–២៥)

*(ព្រះយេស៊ូវទ្រង់បានតាំងបុណ្យរំឭកឡើង)* ។

២២ ហើយគ្រាដែលគេកំពុងតែបរិភោគ នោះព្រះយេស៊ូវទ្រង់យកនំបុ័ង ហើយកាច់ រួចប្រទានពរដល់នំបុ័ងនោះ រួចហើយប្រទានទៅពួកសិស្សរបស់ទ្រង់ ហើយមានព្រះបន្ទូលថា ចូរយកបរិភោគចុះ នេះហើយជាការនឹកចាំដល់រូបកាយខ្ញុំ ដែលខ្ញុំចេញថ្លៃលោះអ្នក ។

២៤ ត្បិតនេះហើយជាការនឹកចាំដល់ឈាមខ្ញុំ នៃសេចក្ដីសញ្ញាថ្មីដែលបានច្រួចចេញ សំរាប់មនុស្សជាច្រើន ដែលនឹងជឿដល់ឈ្មោះ ខ្ញុំ សំរាប់ការផ្ដាច់បាបទាំងឡាយរបស់ពួកគេ ។

២៥ ហើយខ្ញុំឲ្យបញ្ញត្តិមួយដល់អ្នកថា អ្នករាល់គ្នាត្រូវធ្វើនូវអ្វីៗដែលអ្នករាល់គ្នាឃើញខ្ញុំធ្វើ ហើយចូរធ្វើទីបន្ទាល់អំពីខ្ញុំ រហូតដល់ចុងបំផុត ។

**ក.យ.ស., ម៉ាថាយ ២៧:៣–៦** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាថាយ ២៧:៣–៥; កិច្ចការ ១:១៨)

*(សេចក្ដីស្លាប់របស់យូដាសត្រូវបានរៀបរាប់ប្រាប់)* ។

៣ គ្រានោះ យូដាសដែលបានក្បត់ទ្រង់ កាលគាត់ឃើញថាទ្រង់ជាប់ទោសដូច្នោះ ក៏ប្រែចិត្ត ហើយយកប្រាក់៣០ទៅឲ្យដល់ពួកសង្គ្រាជ និងពួកចាស់ទុំវិញ ។

៤ ដោយនិយាយថា ខ្ញុំបានធ្វើបាប ដោយបានក្បត់ឈាមដែលឥតមានទោស ។

៥ ហើយពួកគេបាននិយាយទៅគាត់ថា តើនោះអំពល់អ្វីដល់យើង ? ចូរដោះស្រាយខ្លួនឯងចុះ អំពើបាបទាំងឡាយរបស់អ្នក ស្រេចលើអ្នកចុះ ។

៦ ហើយគាត់ក៏បោះប្រាក់ចោលទៅក្នុងព្រះវិហារបរិសុទ្ធ រួចចេញទៅ ហើយចងកខ្លួននៅលើដើមឈើ ។ ហើយស្រាប់តែគាត់ដួលក្ខាម ហើយពោះគាត់ធ្លាយចេញពោះវៀនទ្រុល រួចគាត់ក៏ស្លាប់ទៅ ។

**ក.យ.ស., ម៉ាកុស ៩:៣** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាកុស ៩:៤)

*(យ៉ូហាន-បាទិស្ទបាននៅលើភ្នំនៃការប្រែរូប)* ។

៣ ហើយលោកអេលីយ៉ាស ព្រមទាំងលោកម៉ូសេ បានលេចមកឲ្យពួកគេឃើញ ឬម្យ៉ាងទៀត យ៉ូហាន-បាទិស្ទ និងលោកម៉ូសេ ហើយពួកគេកំពុងតែទូលនឹងព្រះយេស៊ូវ ។

**ក.យ.ស., ម៉ាកុស ៩:៤០–៤៨** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាកុស ៩:៤៣–៤៨)

*(ការកាត់ដៃ ឬជើងដែលធ្វើឲ្យអ្នកទាស់ចិត្ត គឺត្រូវបានប្រៀបធៀបនឹងការកំចាត់ចោលនូវទំនាក់ទំនងទាំងឡាយ ដែលអាចនាំឲ្យខ្លួន វង្វេងចេញ ។*

៤០ ហេតុដូច្នេះហើយ បើដៃអ្នកធ្វើឲ្យអ្នកទាស់ចិត្ត នោះចូរកាត់វាចោលទៅ ឬក៏បើបងប្អូនអ្នកធ្វើឲ្យអ្នកទាស់ចិត្ត ហើយមិនសារភាព និងមិនបំភ្លេចចោលទេ អ្នកនោះនឹងត្រូវកាត់ចេញ ។ ស៊ូឲ្យអ្នកចូលទៅក្នុងជីវិតកំបុតដៃវិញ ជាជាងមានដៃទាំងពីរ ហើយធ្លាក់ទៅនរក ។

៤១ ត្បិតគ្រាន់បើហើយដែលអ្នកចូលទៅក្នុងជីវិត ដោយគ្មានបងប្អូនវិញ ជាជាងមានអ្នក និងបងប្អូនអ្នកត្រូវបោះចោលទៅនរក ទៅក្នុងភ្លើងដែលពន្លត់មិនបាន ជាកន្លែងដែលមានដង្កូវមិនដែលស្លាប់ ហើយភ្លើងមិនដែលរលត់ឡើយ ។

៤២ ហើយមួយទៀត បើជើងអ្នកធ្វើឲ្យអ្នកទាស់ចិត្ត នោះ

ចូរកាត់វាចោលទៅ ត្បិតអ្នកនោះជាគំរូដែលអ្នកដើរតាម បើសិនជាគេ
ក្លាយទៅជាអ្នករំលង អ្នកនោះនឹងត្រូវកាត់ចេញ ។
៤៣ ស៊ូឲ្យអ្នកចូលទៅជីវិតកំបុតជើងវិញ ជាជាងមានជើងទាំងពីរ
ហើយត្រូវបោះចោលទៅនរក ទៅក្នុងភ្លើងដែលពន្លត់មិនបាន ។
៤៤ ហេតុដូច្នេះហើយ ចូរឲ្យមនុស្សគ្រប់រូបឈរ ឬដួលដោយខ្លួនឯង
ហើយមិនមែនដោយសារអ្នកដទៃឡើយ ឬមិនមែនដោយសារ ការ
ទុកចិត្តដល់អ្នកដទៃទេ ។
៤៥ ចូរសូមដល់ព្រះវរបិតារបស់ខ្ញុំ ហើយវានឹងបានសំរេចនៅ
រំពេចនោះដែលអ្នករាល់គ្នាសូម បើសិនជាអ្នករាល់គ្នាសូម ដោយនូវ
សេចក្តីជំនឿ ជឿថាអ្នករាល់គ្នានឹងបានទទួល ។
៤៦ ហើយបើភ្នែកអ្នក ដែលមើលឲ្យអ្នក ជាអ្នកដែលត្រូវបានតាំងឲ្យ
មើលគន់លើអ្នក ដើម្បីបង្ហាញពន្លឺដល់អ្នក បើគេក្លាយទៅជា អ្នករំលង
ហើយធ្វើឲ្យអ្នកទាស់ចិត្ត នោះចូរខ្វេះអ្នកនោះចោលទៅ ។
៤៧ ស៊ូឲ្យអ្នកចូលក្នុងនគរព្រះមានភ្នែកតែមួយ ជាជាងមាន
ភ្នែកទាំងពីរ ហើយត្រូវបោះចោលទៅក្នុងភ្លើងនរកវិញ ។
៤៨ ត្បិតគ្រាន់បើហើយដែលខ្លួនអ្នកត្រូវបានសង្គ្រោះ ជាជាងត្រូវ
បោះចោលទៅនរកជាមួយនឹងបងប្អូនអ្នក ជាកន្លែងដែលមានដង្កូវ មិន
ដែលស្លាប់ ហើយជាកន្លែងដែលមានភ្លើងមិនដែលរលត់ឡើយ ។

**ក.យ.ស., ម៉ាកុស ១២:៣២** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាកុស ១២:២៧)

*(ព្រះទ្រង់មិនមែនជាព្រះនៃមនុស្សស្លាប់ទេ ពីព្រោះទ្រង់ប្រោសមនុស្សស្លាប់ពីផ្នូររបស់ពួកគេ) ។*

៣២ ហេតុដូច្នេះហើយ ទ្រង់មិនមែនជាព្រះនៃមនុស្សស្លាប់ទេ ប៉ុន្តែជា
ព្រះនៃមនុស្សរស់វិញ ត្បិតទ្រង់ប្រោសពួកគេឲ្យឡើងពីផ្នូររបស់ ពួកគេ
មក ។ អ្នករាល់គ្នាភាន់ច្រឡំខ្លាំងណាស់ ។

**ក.យ.ស., ម៉ាកុស ១៤:២០–២៥** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាកុស ១៤:២២–២៥; ក.យ.ស., ម៉ាថាយ ២៦:២២, ២៤–២៥)

*(ព្រះយេស៊ូវទ្រង់បានតាំងបុណ្យរំឭកឡើង) ។*

២០ ហើយកាលគេកំពុងតែបរិភោគ នោះព្រះយេស៊ូវទ្រង់យកនំបុ័ង
ហើយប្រទានពរដល់នំបុ័ងនោះ រួចកាច់ ហើយប្រទានទៅពួក គេ ហើយ
មានព្រះបន្ទូលថា ចូរយកបរិភោគចុះ ។
២១ មើលចុះ នេះគឺសំរាប់ឲ្យអ្នកធ្វើក្នុងការនឹកចាំដល់រូបកាយខ្ញុំ
ត្បិតដរាបណាអ្នករាល់គ្នាធ្វើការនេះដោយញឹកញាប់ នោះអ្នក រាល់
គ្នានឹងនឹកចាំដល់ពេលនេះ ដែលខ្ញុំកំពុងតែនៅជាមួយនឹងអ្នក ។
២២ ហើយទ្រង់ក៏យកពែង ហើយកាលទ្រង់បានអរព្រះគុណ
រួចហើយ នោះទ្រង់ប្រទានដល់ពួកគេ ហើយពួកគេបានផឹកពីពែងនោះ
ទាំងអស់គ្នា ។
២៣ ហើយទ្រង់បានមានព្រះបន្ទូលទៅពួកគេថា នេះហើយជាការ
នឹកចាំដល់ឈាមខ្ញុំ ដែលបានច្រួចចេញ សំរាប់មនុស្សជាច្រើន ហើយ
ជាសេចក្តីសញ្ញាថ្មី ដែលខ្ញុំឲ្យដល់អ្នក ត្បិតអ្នករាល់គ្នាត្រូវធ្វើទីបន្ទាល់
អំពីខ្ញុំប្រាប់ដល់មនុស្សលោកទាំងអស់ ។
២៤ ហើយដរាបណាអ្នករាល់គ្នាធ្វើពិធីនេះដោយញឹកញាប់ នោះ
អ្នករាល់គ្នានឹងនឹកចាំដល់ខ្ញុំ នៅពេលនេះដែលខ្ញុំនៅជាមួយនឹងអ្នក ហើយ
បានផឹកពីពែងនេះជាមួយនឹងអ្នក គឺជាពេលចុងក្រោយបង្អស់នៃការងា
របំរើរបស់ខ្ញុំ ។
២៥ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាត្រូវធ្វើទីបន្ទាល់
អំពីការណ៍នេះ ត្បិតខ្ញុំនឹងមិនផឹងពីផលផ្លែទំពាំងបាយជូរទៀតទេ ដរាប
ដល់ថ្ងៃនោះដែលខ្ញុំនឹងផឹកជាថ្មី នៅក្នុងនគរព្រះ ។

**ក.យ.ស., ម៉ាកុស ១៤:៣៦–៣៨**
(ចូរប្រៀបធៀបនឹងគម្ពីរម៉ាកុស ១៤:៣២–៣៤)

*(សូម្បីតែនៅឯសួនច្បារគែតសេម៉ានី ក៏មានពួក១២នាក់ខ្លះដែលមិនទាន់យល់ដោយច្បាស់លាស់ពីតួនាទីរបស់ព្រះយេស៊ូវ ថាជាព្រះ មែស៊ី) ។*

៣៦ ហើយពួកគេបានមកដល់កន្លែងមួយ ដែលហៅថា គែតសេម៉ានី
ដែលជាសួនច្បារ ហើយពួកសិស្សបានចាប់ផ្តើមមានចិត្តភាំង ជាខ្លាំង
ហើយតប់ប្រមល់ណាស់ ហើយចាប់ផ្តើមវែកញែកក្នុងចិត្តគេ ដោយ
គិតថា តើនេះជាព្រះមែស៊ីឬអី ។
៣៧ ហើយព្រះយេស៊ូវ ទ្រង់ជ្រាបចិត្តគេ ក៏មានព្រះបន្ទូលទៅពួក
សិស្សទ្រង់ថា ចូរអ្នករាល់គ្នាអង្គុយនៅទីនេះសិន ចាំខ្ញុំទៅអធិស្ឋាន ។
៣៨ ហើយទ្រង់ក៏យកពេត្រុស និងយ៉ាកុប និងយ៉ូហាន ហើយបន្ទោស
ពួកគេ ហើយមានព្រះបន្ទូលទៅពួកគេថា ព្រលឹងខ្ញុំព្រួយជាខ្លាំង
គឺសឹងតែនឹងស្លាប់ ចូរអ្នករាល់គ្នានៅទីនេះ ហើយចាំយាមចុះ ។

**ក.យ.ស., ម៉ាកុស ១៦:៣–៦** (ចូរប្រៀបធៀបនឹងគម្ពីរម៉ាកុស ១៦:៤–៧; ការកែសម្រួលដូចគ្នា ត្រូវបានធ្វើនៅក្នុងគម្ពីរម៉ាថាយ ២៨:២–៨; ចូរប្រៀបធៀបនឹងគម្ពីរលូកា ២៤:២–៤)

*(ទេវតាពីររូបបានសួស្តីដល់ពួកស្ត្រីនៅឯផ្នូរនៃព្រះអង្គសង្គ្រោះ)*

៣ ប៉ុន្តែកាលពួកគេងើបមើលទៅ នោះពួកគេបានឃើញថា ថ្មបាន
ប្រមៀលចេញហើយ (ត្បិតថ្មនោះធំណាស់) ហើយមានទេវតាពីរ
រូបអង្គុយនៅលើថ្ម ពាក់អាវស ហើយពួកស្ត្រីក៏មានសេចក្តីភ័យស្លុត ។
៤ ប៉ុន្តែពួកទេវតាក៏មានប្រសាសន៍ទៅពួកគេថា ចូរកុំភ័យឡើយ អ្នក
រាល់គ្នាមករកព្រះយេស៊ូវ ពីណាសារ៉ែត ដែលត្រូវឆ្កាង; ទ្រង់ មានព្រះ
ជន្មរស់ឡើងវិញហើយ ទ្រង់មិនគង់នៅទីនេះទេ មើលចុះ នេះជាកន្លែង
ដែលគេបានផ្តេកព្រះសពទ្រង់
៥ ហើយចូរអ្នករាល់គ្នាទៅប្រាប់ពួកសិស្សទ្រង់ ព្រមទាំងពេត្រុស
ផងថា ទ្រង់យាងទៅឯស្រុកកាលីឡេមុនអ្នករាល់គ្នាហើយ អ្នករាល់
គ្នានឹងឃើញទ្រង់នៅស្រុកនោះ ដូចជាទ្រង់បានប្រាប់ដល់អ្នក ។
៦ ហើយពួកគេ កាលកំពុងតែដើរចូលទៅផ្នូរ ក៏ឃើញកន្លែងដែល
គេបានផ្តេកព្រះសពព្រះយេស៊ូវ ។

**ក.យ.ស., លូកា ១:៨** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១:៨)

*(សាការី ជាឪពុករបស់យ៉ូហាន-បាទិស្ទ កំពុងតែធ្វើការងារទាំងឡាយនៃបព្វជិតភាព) ។*

៨ ហើយកាលលោកកំពុងតែធ្វើការងារនៃពួកសង្ឃនៅចំពោះព្រះ
តាមរបៀបនៃបព្វជិតភាពរបស់លោក ។

**ក.យ.ស., លូកា ២:៤៦** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ២:៤៦)

*(ពួកអាចារ្យនៅក្នុងព្រះវិហារបរិសុទ្ធកំពុងតែស្ដាប់ព្រះយេស៊ូវ ហើយសួរទ្រង់នូវសំនួរទាំងឡាយ) ។*

៤៦ ហើយហេតុការណ៍បានកើតឡើងថា លុះកន្លងក្រោយមកបីថ្ងៃ
នោះមាតាបិតាទ្រង់ឃើញទ្រង់គង់នៅក្នុងព្រះវិហារបរិសុទ្ធ អង្គុយនៅ
កណ្ដាលពួកអាចារ្យ ហើយពួកអាចារ្យកំពុងតែស្ដាប់ទ្រង់ ហើយ
សួរទ្រង់នូវសំនួរទាំងឡាយ ។

**ក.យ.ស., លូកា ៣:៤–១១** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ៣:៤–៦)

*(ព្រះគ្រីស្ទទ្រង់នឹងយាងមកបំពេញពាក្យព្យាករណ៍, លោះបាបទាំងឡាយ, នាំសេចក្ដីសង្គ្រោះមក, ហើយធ្វើជាពន្លឺ, ហើយទ្រង់នឹង យាងមកនៅថ្ងៃនៃព្រះចេស្ដា និងនៅពេលពេញកំណត់) ។*

៤ ដូចជាមានសេចក្ដីចែងទុកមកក្នុងគម្ពីរនៃព្យាការីអេសាយ
ហើយនេះគឺជាពាក្យទាំងឡាយ ដែលថា «សម្លេងមនុស្សម្នាក់ ដែល
កំពុងតែស្រែកនៅទីរហោស្ថានថា ចូររៀបចំផ្លូវទទួលព្រះអម្ចាស់ ហើយ
ចូរតម្រង់ផ្លូវតូចថ្វាយទ្រង់ចុះ» ។
៥ ត្បិតមើលចុះ ហើយមើលន៏ ទ្រង់នឹងយាងមក ដូចជាមានសេច
ក្ដីចែងទុកមកក្នុងគម្ពីរនៃពួកព្យាការី ដើម្បីនឹងលោះបាបទាំងឡាយ
នៃមនុស្សលោក ហើយដើម្បីនាំឲ្យមានសេចក្ដីសង្គ្រោះដល់ពួកសាសន៍
ដែលឥតសាសនា ដើម្បីប្រមូលអស់អ្នកណាដែលបានបាត់បង់ ដែលជា
អ្នកនៅក្នុងក្រោលចៀមនៃពួកអ៊ីស្រាអែល
៦ មែនហើយ គឺជាពួកអ្នកដែលត្រូវខ្ចាត់ខ្ចាយ និងត្រូវរងទុក្ខ ហើយ
ព្រមទាំងដើម្បីរៀបចំផ្លូវ ហើយធ្វើឲ្យអាចមានផ្លូវក្នុងការផ្សាយ
ដំណឹងល្អដល់ពួកសាសន៍ដទៃ
៧ ហើយដើម្បីធ្វើជាពន្លឺដល់អស់អ្នកណាដែលអង្គុយក្នុងសេចក្ដីងងឹត
គឺទៅដល់ចុងផែនដីបំផុត; ដើម្បីនាំឲ្យមានដំណើររស់ពីស្លាប់ ឡើងវិញ
ហើយដើម្បីយាងឡើងទៅស្ថានខ្ពស់ ដើម្បីទៅគង់នៅខាងស្ដាំព្រះ
ហស្តនៃព្រះវរបិតា
៨ ដរាបដល់ពេលពេញកំណត់ ហើយក្រិត្យវិន័យ និងទីបន្ទាល់នឹងត្រូវ
បានបិទត្រាទុក ហើយកូនសោទាំងឡាយនៃនគរនឹងត្រូវបាន ថ្វាយដល់
ព្រះវរបិតាវិញ
៩ ដើម្បីអនុវត្តសេចក្ដីយុត្តិធម៌ដល់មនុស្សទាំងអស់; ដើម្បីយាងចុះមក
ជំនុំជំរះលើមនុស្សទាំងអស់ ហើយដើម្បីបញ្ជាក់ដល់អស់ទាំង មនុស្ស
ទមិលល្មើស អំពីអំពើដ៏ឥតសុចរិតទាំងឡាយរបស់ពួកគេ ដែលពួកគេ
បានប្រព្រឹត្ត និងការណ៍ទាំងអស់ នៅថ្ងៃដែលទ្រង់នឹងយាង មក
១០ ត្បិតជាថ្ងៃនៃព្រះចេស្ដា មែនហើយ គ្រប់ទាំងច្រកភ្នំនឹងបាន
លុបឲ្យពេញ ហើយគ្រប់ទាំងភ្នំធំតូចនឹងត្រូវបន្ទាបទៅ ផ្លូវក្ងិកក្ងក់នឹង
ទៅជាត្រង់ ហើយផ្លូវរដិបរដុបនឹងបានរាបស្មើទៅវិញ
១១ ហើយអស់ទាំងសាច់ឈាមនឹងបានឃើញសេចក្ដីសង្គ្រោះ
របស់ព្រះ ។

**ក.យ.ស., លូកា ១១:៥៣** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១១:៥២)

*(ភាពពោរពេញនៃបទព្រះគម្ពីរ គឺជាកូនសោនៃចំណេះ) ។*

៥៣ វេទនាដល់អ្នករាល់គ្នា ពួកអ្នកប្រាជ្ញច្បាប់អើយ ! ត្បិតអ្នករាល់
គ្នាបានដកកូនសោនៃចំណេះចេញ ដែលជាភាពពោរពេញនៃបទ ព្រះ
គម្ពីរ ខ្លួនអ្នករាល់គ្នាមិនបានចូលទៅក្នុងនគរទេ ហើយអស់អ្នកណា
ដែលកំពុងតែរកចូល នោះអ្នករាល់គ្នាហាមឃាត់មិនឲ្យចូល ។

**ក.យ.ស., លូកា ១២:៩–១២** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១២:៩–១០)

*(ពាក្យប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធនឹងមិនត្រូវអត់ទោសឲ្យឡើយ) ។*

៩ ប៉ុន្តែអ្នកណាដែលមិនព្រមទទួលស្គាល់ខ្ញុំ នៅមុខមនុស្សលោក
នោះក៏នឹងមិនត្រូវទទួលស្គាល់នៅចំពោះមុខពួកទេវតានៃព្រះដែរ ។
១០ ឥឡូវនេះ ពួកសិស្សទ្រង់ដឹងថាទ្រង់មានព្រះបន្ទូលបែបនេះ
ពីព្រោះពួកគេបាននិយាយអាក្រក់ទាស់នឹងទ្រង់ នៅមុខមនុស្ស ព្រោះ
ពួកគេខ្លាចចំពោះការទទួលស្គាល់ទ្រង់នៅមុខមនុស្សលោក ។
១១ ហើយពួកគេបានពិគ្រោះគ្នាថា ទ្រង់ជ្រាបពីចិត្តពួកយើង ហើយ
ទ្រង់មានព្រះបន្ទូលអំពីការកាត់ទោសពួកយើង ហើយពួកយើងនឹង មិន
ត្រូវបានអត់ទោសឲ្យឡើយ ។ ប៉ុន្តែទ្រង់បានមានព្រះបន្ទូលឆ្លើយតបទៅ
ពួកគេ ហើយមានព្រះបន្ទូលទៅពួកគេថា
១២ អស់អ្នកណាដែលពោលពាក្យទាស់នឹងកូនមនុស្ស ហើយប្រែចិត្ត
នោះនឹងបានអត់ទោសឲ្យអ្នកនោះ ប៉ុន្តែចំពោះអ្នកណាដែល ប្រមាថ
ដល់ព្រះវិញ្ញាណបរិសុទ្ធវិញ នោះនឹងមិនបានអត់ទោសឲ្យអ្នកនោះឡើយ ។

**ក.យ.ស., លូកា ១២:៤១–៥៧** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១២:៣៨–៤៨)

*(យើងត្រូវបំរុងខ្លួនជាស្រេចរង់ចាំការយាងមកនៃព្រះអម្ចាស់) ។*

៤១ ត្បិតមើលចុះ លោកមកដល់ក្នុងយាមទីមួយនៅពេលយប់
ហើយលោកក៏នឹងមកដល់ក្នុងយាមទីពីរ ហើយម្ដងទៀត លោកនឹង
មកដល់ក្នុងយាមទីបី ។
៤២ ហើយខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា លោកបានមកដល់ហើយ
ដូចជាមានសេចក្ដីចែងទុកពីលោក ហើយម្ដងទៀត កាល លោកនឹង
មកដល់ក្នុងយាមទីពីរ ឬមកដល់ក្នុងយាមទីបី នោះមានពរហើយ ដល់

ពួកអ្នកបំរើទាំងនោះ ក្នុងកាលលោកមកដល់ ដែលលោកឃើញកំពុងតែចាំយាមដូច្នោះ ។

៤៣ ត្បិតចៅហ្វាយនៃពួកអ្នកបំរើទាំងនោះនឹងក្រវាត់ចង្កេះខ្លួនលោក ហើយនឹងឲ្យពួកគេអង្គុយចុះបរិភោគអាហារ ហើយនឹង ចេញមក ហើយបំរើពួកគេ ។

៤៤ ហើយឥឡូវនេះ ប្រាកដមែន ខ្ញុំប្រាប់សេចក្ដីទាំងនោះដល់អ្នករាល់គ្នា ប្រយោជន៍ឲ្យអ្នករាល់គ្នាអាចដឹងសេចក្ដីនេះថា ការយាង មកនៃព្រះអម្ចាស់ គឺដូចជាចោរមកក្នុងពេលយប់ ។

៤៥ ហើយគឺដូចជាមនុស្សម្នាក់ ដែលជាម្ចាស់ផ្ទះដែរ បើសិនជាគាត់មិនចាំយាមរបស់របរគាត់ទេ នោះចោរនឹងមក នៅវេលាដែល គាត់មិនគិត ហើយយករបស់របរគាត់ទៅ ហើយចែកគ្នានូវរបស់របរនោះ ។

៤៦ ហើយពួកគេនិយាយគ្នាថា បើសិនជាម្ចាស់ផ្ទះដ៏ល្អនោះដឹងថាចោរនឹងមកនៅវេលាថ្មើរម៉ោន នោះគាត់នឹងចាំយាម ហើយមិនទុកឲ្យផ្ទះត្រូវទំលុះចូល ហើយត្រូវបាត់បង់របស់របរគាត់ទេ ។

៤៧ ហើយទ្រង់បានមានព្រះបន្ទូលទៅពួកគេថា ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ដូច្នេះ ចូរអ្នករាល់គ្នាបំរុងខ្លួនជាស្រេចដែរ ត្បិតកូន មនុស្សនឹងមកនៅវេលាដែលអ្នករាល់គ្នាមិនគិត ។

៤៨ គ្រានោះ ពេត្រុសក៏ទូលទៅទ្រង់ថា ព្រះអម្ចាស់អើយ ទ្រង់មានព្រះបន្ទូលពាក្យប្រៀបប្រដូចនេះ ដល់ត្រឹមតែយើងខ្ញុំប៉ុណ្ណោះ ឬដល់មនុស្សគ្រប់គ្នាដែរ ?

៤៩ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលថា ខ្ញុំនិយាយដល់អស់អ្នកណាដែលចៅហ្វាយនឹងតាំងឲ្យធ្វើជាអ្នកត្រួតត្រាលើពួកផ្ទះ របស់លោក ដើម្បីនឹងបើកអាហារឲ្យកូនចៅលោកបរិភោគតាមត្រូវពេល ។

៥០ ហើយពួកគេទូលថា ចុះតើអ្នកណាជាអ្នកបំរើដែលមានចិត្តស្មោះត្រង់ ហើយឈ្លាសវៃនោះ ?

៥១ ហើយព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលទៅពួកគេថា គឺជាអ្នកបំរើនោះដែលចាំយាម ដើម្បីនឹងចែកអាហាររបស់ខ្លួនតាម ត្រូវពេល ។

៥២ មានពរហើយ ដល់អ្នកបំរើនោះ ដែលចៅហ្វាយឃើញកំពុងតែធ្វើដូច្នោះ ក្នុងកាលចៅហ្វាយមកដល់ ។

៥៣ ខ្ញុំប្រាប់អ្នករាល់គ្នាជាពិតថា លោកនឹងតាំងអ្នកនោះ ឲ្យធ្វើជាអ្នកត្រួតត្រាលើរបស់ទ្រព្យទាំងអស់ដែលលោកមាន ។

៥៤ ប៉ុន្តែអ្នកបំរើអាក្រក់ គឺជាអ្នកនោះដែលមិនឃើញថាចាំយាមឡើយ ។ ហើយបើមិនឃើញអ្នកបំរើនោះចាំយាមទេ អ្នកនោះនឹងគិតស្មានក្នុងចិត្តខ្លួនថា ចៅហ្វាយខ្ញុំក្រមក; ហើយក៏តាំងវាយពួកអ្នកបំរើប្រុសស្រី ហើយក៏តាំងស៊ីផឹក ហើយស្រវឹង ។

៥៥ ចៅហ្វាយនៃអ្នកបំរើនោះនឹងមកដល់ថ្ងៃដែលអ្នកនោះមិននៅចាំ និងនៅវេលាដែលគាត់មិនគិត ហើយនឹងកាត់អ្នកនោះ ហើយនឹងឲ្យអ្នកនោះមានចំណែកជាមួយនឹងពួកមនុស្សមិនជឿ ។

៥៦ ហើយអ្នកបំរើណាដែលស្គាល់ចិត្តចៅហ្វាយរបស់ខ្លួន ហើយមិនរៀបចំចាំចៅហ្វាយមក ឬធ្វើតាមចិត្តលោកសោះ នោះនឹងត្រូវរំពាត់ជាច្រើន ។

៥៧ ប៉ុន្តែអ្នកណាដែលមិនស្គាល់ចិត្តចៅហ្វាយរបស់ខ្លួន ហើយបានប្រព្រឹត្តគួរនឹងត្រូវរំពាត់ នោះនឹងត្រូវវាយតិចវិញ ។ ត្បិតចំពោះ អស់អ្នកណាដែលត្រូវបានប្រគល់ទុកជាច្រើនឲ្យ នោះនឹងត្រូវបានទារជាច្រើនពីអ្នកនោះវិញ ហើយចំពោះអស់ណាដែលព្រះអម្ចាស់ ទ្រង់ប្រទានឲ្យច្រើន នោះមនុស្សលោកនឹងទារជាច្រើនពីអ្នកនោះដែរ ។

**ក.យ.ស., លូកា ១៦:១៦–២៣** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១៦:១៦–១៨)

*(ព្រះយេស៊ូវទ្រង់បានផ្ដល់បរិបទសំរាប់ពាក្យប្រៀបប្រដូចអំពីបុរសមានទ្រព្យសម្បត្តិ និងឡាសារ)* ។

១៦ ហើយពួកគេបានទូលទៅទ្រង់ថា យើងមានក្រិត្យវិន័យ និងពាក្យព្យាករណ៍នៃពួកព្យាការី ប៉ុន្តែរីឯបុរសនេះ យើងនឹងមិនទទួលស្គាល់លោក ជាអ្នកត្រួតត្រារបស់យើងទេ ត្បិតលោកបានតាំងខ្លួនជាចៅក្រមលើយើង ។

១៧ គ្រានោះ ព្រះយេស៊ូវទ្រង់ក៏មានព្រះបន្ទូលទៅពួកគេថា ក្រិត្យវិន័យ និងពាក្យព្យាករណ៍នៃពួកព្យាការីធ្វើបន្ទាល់អំពីខ្ញុំ មែនហើយ ពាក្យព្យាករណ៍ទាំងអស់ដែលពួកព្យាការីបានចែងទុក រហូតមកដល់យ៉ូហាន គឺបានទាយអំពីជំនាន់នេះ ។

១៨ តាំងពីនោះមក នគរព្រះត្រូវបានផ្សាយប្រាប់ ហើយមនុស្សគ្រប់រូបកំពុងតែខំប្រឹងប្រែងចូលនគរនោះ ។

១៩ ហើយដែលផ្ទៃមេឃ និងផែនដីបាត់ទៅ នោះងាយជាជាងបាត់ក្បៀសមួយ ក្នុងក្រិត្យវិន័យទៅទៀត ។

២០ ហើយហេតុអ្វីក៏អ្នករាល់គ្នាបង្រៀនពីក្រិត្យវិន័យ ហើយមិនទទួលស្គាល់ពាក្យដែលបានចែងទុក; ហើយកាត់ទោសដល់អ្នកនោះ ដែលព្រះវរបិតាបានចាត់ឲ្យមកបំពេញក្រិត្យវិន័យ ដើម្បីឲ្យអ្នករាល់គ្នាបានប្រោសលោះ ?

២១ ឱពួកចោលម្សៀតអើយ ត្បិតអ្នកបានគិតក្នុងចិត្តថា ឥតមានព្រះឡើយ ។ ហើយអ្នករាល់គ្នាបង្ខូចផ្លូវដ៏ត្រឹមត្រូវ ហើយនគរ ស្ថានសួគ៌បានរងទុក្ខ មកពីការឃោរឃៅរបស់អ្នក; ហើយអ្នករាល់គ្នាបៀតបៀនមនុស្សស្លូតត្រង់ ហើយនៅក្នុងការឃោរឃៅរបស់ អ្នក នោះអ្នករាល់គ្នាស្វែងរកបំផ្លាញនគរចោល ហើយអ្នករាល់គ្នាខំប្រឹងចាប់កូនចៅនៃនគរ ។ វេទនាអ្នករាល់គ្នា ជាពួកមនុស្សកំផិត អើយ !

២២ ហើយពួកគេបានមើលងាយដល់ទ្រង់ទៀត ដោយខឹងពីពាក្យថាពួកគេជាមនុស្សកំផិត ។

២៣ ប៉ុន្តែទ្រង់មានព្រះបន្ទូលតទៅទៀតថា អស់អ្នកណាដែលលែងប្រពន្ធរបស់ខ្លួន ហើយរៀបការជាមួយនឹងអ្នកផ្សេងទៀត នោះឈ្មោះថាប្រព្រឹត្តអំពើកំផិត ហើយអស់អ្នកណាដែលរៀបការនឹងនាងដែលប្ដីនាងបានលែងនាងចោល នោះឈ្មោះថាប្រព្រឹត្តអំពើកំផិតដែរ ។ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ខ្ញុំនឹងប្រៀបធៀបអ្នកដូចជាបុរសមានទ្រព្យសម្បត្តិ ។

**ក.យ.ស., លូកា ១៧:២១** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១៧:២០–២១)

*(នគរព្រះបានមកដល់រួចស្រេចហើយ)* ។

២១ គ្មានអ្នកណានឹងថា មើល នៅទីនេះ ឬថា មើល នៅទីនោះ ! ត្បិតមើលចុះ នគរព្រះបានមកដល់អ្នករួចស្រេចហើយ ។

**ក.យ.ស., លូកា ១៧:៣៦–៤០** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១៧:៣៧)

*(ព្រះយេស៊ូវទ្រង់បានពន្យល់ប្រាប់ពីការប្រមូលពួកសុចរិត) ។*

៣៦ ហើយពួកគេបានឆ្លើយ ហើយទូលទៅទ្រង់ថា ព្រះអម្ចាស់អើយ តើពួកគេនឹងត្រូវយកទៅឯណា ?

៣៧ ហើយទ្រង់ក៏មានព្រះបន្ទូលទៅពួកគេថា នៅកន្លែងណាដែលរូបកាយប្រមូលគ្នា ឬម៉្យាងទៀត នៅកន្លែងណាដែលពួកបរិសុទ្ធប្រមូលគ្នា គឺកន្លែងនោះហើយដែលសត្វឥន្ទ្រីនឹងប្រមូលគ្នា ឬនៅកន្លែងនោះហើយដែលពួកនៅសល់ទាំងប៉ុន្មាននឹងត្រូវបានប្រមូលគ្នា ។

៣៨ នេះទ្រង់បានមានព្រះបន្ទូលអំពីការប្រមូលពួកបរិសុទ្ធរបស់ទ្រង់ និងអំពីពួកទេវតាដែលចុះមក ហើយប្រមូលពួកអ្នកនៅសល់ ទាំងប៉ុន្មានចំពោះពួកគេ ម្នាក់ពីដំណេក ម្នាក់ទៀតពីកន្លែងកិនម្សៅ ហើយម្នាក់ទៀតពីចំការ គឺពីកន្លែងនានាដែលទ្រង់សព្វ ព្រះហឫទ័យ ។

៣៩ ត្បិតប្រាកដជានឹងមានផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលមានសុទ្ធតែសេចក្ដីសុចរិត ។

៤០ ហើយនឹងគ្មានអ្វីដែលមិនស្អាតឡើយ; ត្បិតផែនដីនឹងក្លាយទៅជាចាស់ ដូចជាសំលៀកបំពាក់ ដោយកាន់តែធំឡើងក្នុងសេចក្ដីពុករលួយ ហេតុដូច្នោះហើយ វានឹងបាត់ទៅ ហើយកំណល់កល់ជើងនឹងនៅតែបានញែកជាបរិសុទ្ធ ដោយបានស្អាតបាតពីអស់ទាំង អំពើបាប ។

**ក.យ.ស., លូកា ១៨:២៧** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ១៨:២៧)

*(ការទុកចិត្តលើទ្រព្យសម្បត្តិបង្ការជនណាមួយមិនឲ្យចូលនគរព្រះបាន) ។*

២៧ ហើយទ្រង់មានព្រះបន្ទូលទៅពួកគេថា មនុស្សណាដែលទុកចិត្តទៅលើទ្រព្យសម្បត្តិនោះពិបាកនឹងចូលទៅក្នុងនគរព្រះ ប៉ុន្តែ អ្នកណាដែលលះបង់ចោលនូវអ្វីៗដែលជារបស់របរនៃលោកិយនេះ អ្នកនោះអាចចូលបានដោយសារព្រះ ។

**ក.យ.ស., លូកា ២១:២៤–២៦** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ២១:២៤–២៦)

*(ព្រះយេស៊ូវទ្រង់បានពន្យល់ប្រាប់ពីទីសំគាល់ទាំងឡាយនៃការយាងមករបស់ទ្រង់) ។*

២៤ ឥឡូវនេះ នេះហើយជាការណ៍ដែលទ្រង់មានព្រះបន្ទូលដល់ពួកគេ ស្ដីអំពីសេចក្ដីបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម ។ ហើយគ្រានោះពួកសិស្សទ្រង់បានទូលសួរទ្រង់ថា លោកគ្រូ សូមប្រាប់យើងខ្ញុំអំពីការយាងមករបស់ព្រះអង្គផងចុះ ?

២៥ ហើយទ្រង់ក៏មានព្រះបន្ទូលឆ្លើយតបទៅពួកគេថា នៅគំណកាលណោះដែលពួកសាសន៍ដទៃនឹងបានពោរពេញ នោះនឹងមានទីសំគាល់ទាំងឡាយនៅក្នុងព្រះអាទិត្យ និងក្នុងព្រះច័ន្ទ និងក្នុងតារាទាំងឡាយ ហើយនៅលើផែនដីនឹងមានសេចក្ដីលំបាកដល់សាសន៍ទាំងឡាយ ដោយសេចក្ដីទ័លគំនិត ដូចជាសមុទ្រ និងទឹករលក ។ ផែនដីក៏នឹងត្រូវមានចលាចល និងទឹកទាំងឡាយនៃទីជំរៅផង

២៦ មនុស្សនឹងស្រយុតចិត្តដោយភ័យ ហើយដោយទន្ទឹងចាំការណ៍ដែលត្រូវមកលើផែនដី ។ ត្បិតអំណាចទាំងឡាយនៃស្ថានសួគ៌ នឹងត្រូវកក្រើករំពើក ។

**ក.យ.ស., លូកា ២១:៣២** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ២១:៣២)

*(គ្រប់ទាំងអស់នឹងបានបំពេញ កាលណាពេលវេលានៃពួកសាសន៍ដទៃបានពោរពេញ) ។*

៣២ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា មនុស្សតំណនេះ គឺជាតំណកាលដែលពួកសាសន៍ដទៃនឹងបានពោរពេញ នោះនឹងមិនត្រូវបាន កន្លងហួសបាត់ទៅឡើយ ទាល់តែគ្រប់ការណ៍ទាំងអស់បានពោរពេញ ។

**ក.យ.ស., លូកា ២៣:៣៥** (ចូរប្រៀបធៀបនឹងគម្ពីរលូកា ២៣:៣៤)

*(ព្រះយេស៊ូវទ្រង់បានសូមក្ដីអភ័យទោសដល់ពួកទាហានសាសន៍រ៉ូមដែលឆ្កាងទ្រង់) ។*

៣៥ គ្រានោះ ព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលថា ឱព្រះវរបិតាអើយ សូមអត់ទោសដល់ពួកគេផង ត្បិតពួកគេមិនដឹងជាគេធ្វើអ្វីទេ ។ (មានន័យដល់ពួកទាហានដែលឆ្កាងទ្រង់) ហើយពួកគេបានចែកព្រះពស្ត្រទ្រង់ ហើយចាប់ឆ្នោត ។

**ក.យ.ស., យ៉ូហាន ១:១–៣៤** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ូហាន ១:១–៣៤)

*(ដំណឹងល្អនៃព្រះយេស៊ូវត្រូវបានផ្សាយចាប់តាំងពីដើមដំបូងមក ។ មានអេលីយ៉ាសម្នាក់ [យ៉ូហាន-បាទីស្ទ] ដែលត្រូវរៀបចំផ្លូវថ្វាយព្រះគ្រីស្ទ ហើយមានអេលីយ៉ាសម្នាក់ទៀត [ព្រះគ្រីស្ទ] ដែលត្រូវសាងគ្រប់អ្វីទាំងអស់ឡើងវិញ) ។*

១ កាលដើមដំបូងនោះដំណឹងល្អត្រូវបានផ្សាយតាមរយៈព្រះរាជបុត្រា ។ ហើយដំណឹងល្អគឺជាព្រះបន្ទូល ហើយព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះរាជបុត្រា ហើយព្រះរាជបុត្រាបានគង់នៅជាមួយនឹងព្រះ ហើយព្រះរាជបុត្រានោះហើយជាព្រះ ។

២ ព្រះរាជបុត្រាបានគង់នៅជាមួយនឹងព្រះ តាំងពីដើមដំបូងមក ។

៣ គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីមួយកើតមក ក្រៅពីទ្រង់ឡើយ ។

៤ នៅក្នុងទ្រង់មានដំណឹងល្អ ហើយដំណឹងល្អគឺជាជីវិត ហើយជីវិតនោះគឺជាពន្លឺនៃមនុស្សលោក

៥ ហើយពន្លឺនោះក៏ភ្លឺមកក្នុងពិភពលោក ហើយពិភពលោកយល់មិនដល់ពន្លឺទេ ។

៦ មានមនុស្សម្នាក់ដែលត្រូវបានចាត់មកពីព្រះ ដែលមានឈ្មោះថា យ៉ូហាន ។

៧ អ្នកនោះបានមកក្នុពិភពលោកជាសាក្សី ដើម្បីនឹងធ្វើទីបន្ទាល់ពីពន្លឺ ដើម្បីនឹងធ្វើទីបន្ទាល់ពីដំណឹងល្អតាមរយៈព្រះរាជបុត្រា ដល់មនុស្សទាំងអស់ ប្រយោជន៍ឲ្យមនុស្សលោកបានជឿដោយសារគាត់ ។

៨ គាត់មិនមែនបានពន្លឺនោះទេ ប៉ុន្តែបានមកដើម្បីធ្វើទីបន្ទាល់ពីពន្លឺនោះវិញ

៩ ដែលជាពន្លឺដ៏ពិត ដែលបំភ្លឺដល់មនុស្សគ្រប់រូប ដែលកើតមកក្នុងលោកិយ ។

១០ គឺជាព្រះរាជបុត្រានៃព្រះ ។ ទ្រង់នេះហើយដែលបានគង់នៅក្នុងលោកិយ ហើយលោកិយក៏កើតមកដោយសារទ្រង់ ហើយលោកិយមិនស្គាល់ទ្រង់ទេ ។

១១ ទ្រង់បានយាងមករករាស្ត្រទ្រង់ ហើយរាស្ត្រទ្រង់មិនបានទទួលទ្រង់សោះ ។

១២ ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកនោះហើយ ដែលទ្រង់បានប្រទានអំណាច ឲ្យក្លាយទៅជាកូនព្រះ គឺដល់អស់អ្នកណាដែលជឿដល់ព្រះនាមទ្រង់ប៉ុណ្ណោះ ។

១៣ ទ្រង់មិនបានកើតមកពីឈាម ឬតាមសេចក្តីប៉ងប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ ប៉ុន្តែកើតមកពីព្រះវិញ ។

១៤ ហើយព្រះបន្ទូលដដែលនោះត្រូវបានធ្វើទៅជាសាច់ឈាម ហើយបានស្នាក់នៅក្នុងចំណោមយើងរាល់គ្នា ហើយយើងរាល់គ្នា បានឃើញសិរីល្អរបស់ទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា ពោរពេញទៅដោយព្រះគុណ និងសេចក្តីពិត ។

១៥ យ៉ូហានបានធ្វើទីបន្ទាល់ពីទ្រង់ ហើយបន្លឺឧទានឡើងថា នេះហើយជាព្រះអង្គដែលខ្ញុំបានប្រាប់ថា ព្រះអង្គដែលយាងមកក្រោយខ្ញុំ នោះត្រូវបានត្រឡប់ជាមុនខ្ញុំវិញ ត្បិតទ្រង់គង់នៅមុនខ្ញុំ ។

១៦ ត្បិតកាលដើមដំបូងមានព្រះបន្ទូល គឺជាព្រះរាជបុត្រា ដែលត្រូវបានធ្វើទៅជាសាច់ឈាមហើយត្រូវបានចាត់ឲ្យមករកយើងរាល់ គ្នា ដោយសារព្រះហឫទ័យនៃព្រះវរបិតា ។ ហើយអស់អ្នកណាជឿដល់ព្រះនាមទ្រង់ នោះនឹងបានទទួលភាពពោរពេញរបស់ទ្រង់ ។ ហើយយើងទាំងអស់គ្នាបានទទួលភាពពោរពេញរបស់ទ្រង់ គឺជាអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះគុណរបស់ទ្រង់ ។

១៧ ត្បិតក្រិត្យវិន័យត្រូវបានប្រទានមក តាមរយៈលោកម៉ូសេ ប៉ុន្តែជីវិត និងសេចក្តីពិត នោះបានមកតាមរយៈព្រះយេស៊ូវគ្រីស្ទវិញ ។

១៨ ត្បិតក្រិត្យវិន័យគឺតាមបញ្ញត្តិខាងរូបកាយ ចំពោះការចាត់ចែងខាងសេចក្តីស្លាប់ ប៉ុន្តែដំណឹងល្អគឺតាមអំណាចនៃជីវិតដ៏មិន ចេះចប់មិនចេះហើយ តាមរយៈព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាបង្កើតតែមួយ ដែលគង់នៅក្នុងឱរានៃព្រះវរបិតា ។

១៩ គ្មានអ្នកណាដែលឃើញព្រះក្នុងពេលណាមួយឡើយ លើកលែងតែអ្នកនោះបានធ្វើទីបន្ទាល់ពីព្រះរាជបុត្រាប៉ុណ្ណោះ ត្បិតលើក លែងតែតាមរយៈព្រះអង្គ នោះគ្មានអ្នកណាអាចបានសង្គ្រោះឡើយ ។

២០ ហើយនេះគឺជាទីបន្ទាល់របស់យ៉ូហាន កាលពួកសាសន៍យូដាចាត់ពួកសង្ឃ និងពួកលេវីពីក្រុងយេរូសាឡិម ឲ្យមកសួរគាត់ថា តើលោកជាអ្នកណា ?

២១ ហើយគាត់បានប្រាប់ ហើយមិនបដិសេធថា គាត់មិនមែនជាលោកអេលីយ៉ាសឡើយ ប៉ុន្តែបានប្រាប់ថា គាត់មិនមែនជាព្រះគ្រីស្ទទេ ។

២២ ហើយពួកគេបានសួរគាត់ថា ចុះតើលោកជាលោកអេលីយ៉ាសឬអី ? ហើយគាត់បានឆ្លើយថា ខ្ញុំមិនមែនជាលោកអេលីយ៉ាស នោះដែលនឹងសាងឡើងវិញនូវអ្វីៗទាំងអស់ទេ ។ ហើយពួកគេបានសួរគាត់ថា តើលោកជាព្យាការីនោះឬអី ? ហើយគាត់បាន ឆ្លើយថា មិនមែនទេ ។

២៣ គ្រានោះ ពួកគេបាននិយាយទៅគាត់ថា តើលោកជាអ្នកណា ? ដើម្បីឲ្យយើងរាល់គ្នាបាននាំពាក្យទៅជំរាបដល់លោក ដែលចាត់ឲ្យយើងខ្ញុំមកផង ។ តើលោកនឹងប្រសាសន៍ពីខ្លួនលោកដូចម្តេច ?

២៤ គាត់ក៏ប្រាប់ថា ខ្ញុំជាសម្លេងនៃមនុស្សម្នាក់ ដែលកំពុងតែបន្លឺឡើងនៅទីរហោស្ថានថា ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់ ដូចជាព្យាការីអេសាយបានទាយទុក ។

២៥ ហើយពួកអ្នកដែលបានចាត់មកនោះ គឺជាពួកផារិស៊ី ។

២៦ ហើយពួកគេក៏សួរគាត់ ហើយបាននិយាយទៅគាត់ថា ចុះហេតុអ្វីបានជាលោកធ្វើបុណ្យជ្រមុជទឹក បើសិនជាលោកមិនមែន ជាព្រះគ្រីស្ទ ឬជាលោកអេលីយ៉ាសដែលនឹងសាងឡើងវិញនូវអ្វីទាំងអស់ ឬជាព្យាការីនោះ ?

២៧ យ៉ូហានក៏ឆ្លើយដល់ពួកគេថា ខ្ញុំធ្វើបុណ្យជ្រមុជដោយទឹក ប៉ុន្តែនៅក្នុងចំណោមអ្នករាល់គ្នា នោះមានព្រះមួយអង្គ ដែលអ្នក រាល់គ្នាមិនស្គាល់

២៨ គឺព្រះអង្គនោះហើយដែលខ្ញុំធ្វើទីបន្ទាល់ ។ ទ្រង់ជាព្យាការីនោះ គឺលោកអេលីយ៉ាស ដែលយាងមកក្រោយខ្ញុំ គឺត្រូវត្រឡប់ ជាមុនខ្ញុំវិញ រីឯខ្សែស្បែកជើងទ្រង់នោះខ្ញុំមិនគួរនឹងស្រាយ ឬតំណែងទ្រង់នោះខ្ញុំមិនអាចបំពេញបានឡើយ ត្បិតទ្រង់នឹងធ្វើបុណ្យជ្រមុជ ពុំមែនដោយទឹកទេ ប៉ុន្តែដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធវិញ ។

២៩ លុះស្អែកឡើង យ៉ូហានបានឃើញព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងមកឯគាត់ ហើយក៏ពោលថា នុះន៏ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក !

៣០ ហើយយ៉ូហានបានធ្វើទីបន្ទាល់ពីទ្រង់ដល់ប្រជាជនថា គឺពីព្រះអង្គនេះហើយដែលខ្ញុំបានប្រាប់ថា ក្រោយខ្ញុំមានព្រះមួយអង្គដែលយាង ដែលបានត្រឡប់ជាមុនខ្ញុំ ត្បិតទ្រង់គង់នៅមុនខ្ញុំ ហើយខ្ញុំស្គាល់ទ្រង់ ហើយដឹងថាទ្រង់នឹងត្រូវបានសម្តែងឲ្យពួកអ៊ីស្រាអែលស្គាល់ ហេតុដូច្នេះហើយ ទើបខ្ញុំមកធ្វើបុណ្យជ្រមុជដោយទឹក ។

៣១ ហើយយ៉ូហានបានធ្វើទីបន្ទាល់ថា កាលទ្រង់បានទទួលបុណ្យជ្រមុជទឹកពីខ្ញុំ នោះខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះមកពីស្ថានសួគ៌មានរូបដូចជាព្រាប ហើយមកសណ្ឋិតលើទ្រង់ ។

៣២ ហើយខ្ញុំបានស្គាល់ទ្រង់ ត្បិតទ្រង់ជាព្រះអង្គដែលបានចាត់ខ្ញុំឲ្យមកធ្វើបុណ្យជ្រមុជដោយទឹក ទ្រង់មានព្រះបន្ទូលមកខ្ញុំថា ដែលអ្នក

ឃើញព្រះវិញ្ញាណយាងចុះមកសណ្ឋិតលើអ្នកណា ហើយគង់នៅលើអ្នកនោះ គឺអ្នកនោះហើយ ដែលធ្វើបុណ្យជ្រមុជដោយ ព្រះវិញ្ញាណបរិសុទ្ធ ។
៣៣ ហើយខ្ញុំបានឃើញមែន ហើយក៏ធ្វើទីបន្ទាល់ថា នេះហើយជាព្រះរាជបុត្រានៃព្រះ ។
៣៤ ការណ៍ទាំងនេះត្រូវបានសំរេចនៅភូមិបេថាបារ៉ា នៅត្រើយទន្លេយ័រដាន់ ជាកន្លែងដែលយ៉ូហានកំពុងតែធ្វើបុណ្យជ្រមុជទឹក ។

**ក.យ.ស., យ៉ូហាន ១:៤២** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ូហាន ១:៤២)

*(កេផាស មានន័យថា «អ្នកមើលឆុត» ឬ «ថ្ម» ) ។*

៤២ ហើយគាត់ក៏នាំបងទៅឯព្រះយេស៊ូវ ។ ហើយកាលព្រះយេស៊ូវទ្រង់បានទតមើលគាត់ ទ្រង់មានព្រះបន្ទូលថា អ្នកឈ្មោះស៊ីម៉ូន ជាកូនរបស់យ៉ូណាស អ្នកនឹងត្រូវហៅថា កេផាស គឺប្រែថា អ្នកមើលឆុត ឬថ្ម ។ ហើយពួកគេជាអ្នកនេសាទ ។ ហើយពួកគេបានលះ ចោលទាំងអស់ ហើយទៅតាមព្រះយេស៊ូវភ្លាម ។

**ក.យ.ស., យ៉ូហាន ៤:១–៤** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ូហាន ៤:១–២)

*(ព្រះយេស៊ូវបានធ្វើបុណ្យជ្រមុជទឹក) ។*

១ ហេតុដូច្នេះហើយ កាលពួកផារិស៊ីបានឮថាព្រះយេស៊ូវបានសិស្ស ហើយក៏ធ្វើបុណ្យជ្រមុជទឹកឲ្យ ជាច្រើនលើសជាងយ៉ូហានទៅ ទៀត,
២ ពួកគេក៏ខិតខំព្យាយាមរកមធ្យោបាយទាំងឡាយ ដើម្បីគេអាចសម្លាប់ទ្រង់ចោល ត្បិតមានមនុស្សជាច្រើនបានទទួលយ៉ូហានថាជាព្យាការី ប៉ុន្តែពួកគេមិនជឿដល់ព្រះយេស៊ូវទេ ។
៣ ឥឡូវនេះ ព្រះអម្ចាស់ទ្រង់ជ្រាបពីការណ៍នេះ ទោះជាព្រះអង្គទ្រង់ពុំបានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សជាច្រើន ដូចជាពួកសិស្សទ្រង់ ក្តី
៤ ត្បិតទ្រង់ទ្រាំឲ្យពួកគេធ្វើជាដំរាប់ គឺរាប់អានគ្នាទៅវិញទៅមក ។

**ក.យ.ស., យ៉ូហាន ៤:២៦** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ូហាន ៤:២៤)

*(ព្រះទ្រង់បានសន្យានឹងប្រទានព្រះវិញ្ញាណរបស់ទ្រង់ដល់ពួកអ្នកដែលជឿពិត) ។*

២៦ ត្បិតដល់មនុស្សបែបនេះហើយដែលព្រះទ្រង់បានសន្យានឹងប្រទានព្រះវិញ្ញាណរបស់ទ្រង់ឲ្យ ។ ហើយពួកអ្នកណាដែលថ្វាយបង្គំ ទ្រង់នោះត្រូវថ្វាយបង្គំដោយវិញ្ញាណ និងដោយសេចក្តីពិត ។

**ក.យ.ស., យ៉ូហាន ១៣:៨–១០** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ូហាន ១៣:៨–១០)

*(ព្រះយេស៊ូវទ្រង់លាងជើងពួកសាវក) ។*

៨ ពេត្រុសក៏ទូលទ្រង់ថា ទ្រង់មិនត្រូវលាងជើងឲ្យទូលបង្គំសោះឡើយ ។ ព្រះយេស៊ូវក៏មានព្រះបន្ទូលឆ្លើយថា បើខ្ញុំមិនលាងឲ្យអ្នក នោះអ្នកគ្មានចំណែកជាមួយនឹងខ្ញុំទេ ។
៩ ស៊ីម៉ូន-ពេត្រុសក៏ទូលទ្រង់ថា ឱព្រះអម្ចាស់អើយ បើដូច្នោះ សូមកុំលាងត្រឹមតែជើងទូលបង្គំប៉ុណ្ណោះឡើយ គឺសូមលាងដល់ទាំងដៃទូលបង្គំ និងក្បាលទូលបង្គំផងចុះ ។
១០ ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលទៅគាត់ថា អ្នកណាដែលបានលាងដៃរបស់ខ្លួន និងក្បាលរបស់ខ្លួន នោះត្រូវការលាងជើងរបស់ខ្លួនតែប៉ុណ្ណោះ ប៉ុន្តែត្រូវឲ្យបានស្អាតទាំងអស់ ហើយអ្នករាល់គ្នាក៏បានស្អាត ប៉ុន្តែមិនមែនទាំងអស់ទេ ។ ឥឡូវនេះគឺជាទំនៀម ទំលាប់នៃពួកសាសន៍យូដា នៅក្រោមក្រិត្យវិន័យរបស់ពួកគេ ហេតុដូច្នោះហើយទើបព្រះយេស៊ូវបានធ្វើការណ៍នេះ ដើម្បីឲ្យក្រិត្យ វិន័យអាចបានបំពេញ ។

**ក.យ.ស., យ៉ូហាន ១៤:៣០** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ូហាន ១៤:៣០)

*(ស្តេចនៃសេចក្តីងងឹត ឬសាតាំង គឺជាចៅហ្វាយរបស់លោកិយនេះ) ។*

៣០ ពីនេះទៅមុខ ខ្ញុំមិនបាននិយាយនឹងអ្នករាល់គ្នាប៉ុន្មានទៀតទេ ត្បិតស្តេចនៃសេចក្តីងងឹត ដែលជាចៅហ្វាយរបស់លោកិយនេះ ជិតមកដល់ហើយ ប៉ុន្តែគ្មានអំណាចលើខ្ញុំទេ ប៉ុន្តែវាមានអំណាចលើអ្នករាល់គ្នា ។

**ក.យ.ស., កិច្ចការ ៩:៧** (ចូរប្រៀបធៀបនឹងគម្ពីរកិច្ចការ ៩:៧; ២២:៩)

*(ពួកអ្នកដែលនៅជាមួយនឹងប៉ុល កាលគាត់បានប្រែចិត្តជឿ ក៏បានឃើញពន្លឺ ប៉ុន្តែពួកគេមិនបានឮសម្លេង ឬឃើញព្រះអម្ចាស់ទេ) ។*

៧ ហើយពួកអ្នកដែលកំពុងតែធ្វើដំណើរជាមួយនឹងគាត់ ក៏បានឃើញពន្លឺនោះដែរ ហើយមានសេចក្តីភ័យខ្លាច ប៉ុន្តែពួកគេមិនបានឮសម្លេងនៃព្រះអង្គដែលមានព្រះបន្ទូលជាមួយនឹងគាត់ឡើយ ។

**ក.យ.ស., រ៉ូម ៤:១៦** (ចូរប្រៀបធៀបនឹងគម្ពីររ៉ូម ៤:១៦)

*(ទាំងសេចក្តីជំនឿ និងកិច្ចការទាំងឡាយ តាមរយៈព្រះគុណ គឺជាការចាំបាច់សំរាប់សេចក្តីសង្គ្រោះ) ។*

១៦ ហេតុដូច្នេះហើយ អ្នករាល់គ្នាត្រូវបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿ និងកិច្ចការទាំងឡាយ តាមរយៈព្រះគុណ ប្រយោជន៍ឲ្យសេចក្តីសន្យាបានខ្ជាប់ខ្ជួន ដល់ពូជទាំងអស់ មិនមែនត្រឹមតែពូជដែលអាងក្រិត្យវិន័យប៉ុណ្ណោះទេ គឺដល់ទាំងពូជដែល អាងសេចក្តីជំនឿរបស់អ័ប្រាហាំ ដែលជាអយ្យកោនៃយើងរាល់គ្នាថែមទៀតផង ។

**ក.យ.ស., រ៉ូម ៧:៥–២៧** (ចូរប្រៀបធៀបនឹងគម្ពីររ៉ូម ៧:៥–២៥)

*(ព្រះគ្រីស្ទមានព្រះចេស្តា ដើម្បីនឹងប្រែប្រួលព្រលឹងមនុស្សលោក) ។*

៥ ត្បិតកាលយើងនៅខាងសាច់ឈាមនៅឡើយ នោះសេចក្ដីរំជួលរបស់អំពើបាប ដែលកើតដោយនូវក្រិត្យវិន័យ បានបណ្ដាលឲ្យអស់ទាំងអវយវៈ ក្នុងរូបកាយរបស់យើងរាល់គ្នា បង្កើតផលដល់សេចក្ដីស្លាប់ ។

៦ តែឥឡូវនេះ យើងត្រូវបានរួចពីក្រិត្យវិន័យហើយ ដោយបានស្លាប់ក្នុងសេចក្ដីដែលឃុំឃាំងយើងទុក ដោយបានស្លាប់ចំពោះ ក្រិត្យវិន័យ ប្រយោជន៍ឲ្យយើងបានគោរពប្រតិបត្តិ ដោយវិញ្ញាណដែលបានកែជាថ្មីវិញ ហើយមិនមែនតាមតែន័យពាក្យពីបុរាណនោះ ទៀតឡើយ ។

៧ ដូច្នេះ យើងនឹងថាដូចម្ដេច ? តើក្រិត្យវិន័យជាតួបាបឬអី ? ទេ មិនមែនឡើយ ខ្ញុំមិនបានទាំងស្គាល់បាបផង លើកលែងតែដោយ សារក្រិត្យវិន័យចេញ ត្បិតខ្ញុំមិនបានស្គាល់សេចក្ដីលោភផង លើកលែងតែដោយសារក្រិត្យវិន័យបានថែងថា «កុំឲ្យលោភ» ។

៨ តែកាលអំពើបាបបានឱកាស ដោយសារបញ្ញត្តិ នោះក៏បង្កើតគ្រប់ទាំងសេចក្ដីលោភនៅក្នុងខ្លួនខ្ញុំវិញ ។ ត្បិតក្រៅពីក្រិត្យវិន័យ អំពើបាបបានស្លាប់សូន្យ ។

៩ ត្បិតគ្រាមួយ ខ្ញុំបានរស់នៅ ដោយគ្មានការរំលងក្រិត្យវន័យ ប៉ុន្តែកាលព្រះបញ្ញត្តិនៃព្រះគ្រីស្ទបានកើតមក នោះបាបក៏រស់ឡើង ហើយឯខ្ញុំក៏ត្រូវ ស្លាប់វិញ ។

១០ ហើយកាលខ្ញុំមិនបានជឿតាមព្រះបញ្ញត្តិនៃព្រះគ្រីស្ទ ដែលបានកើតមក ដែលសំរាប់ឲ្យមានជីវិត នោះខ្ញុំឃើញថា វាបានដាក់ទោសខ្ញុំដល់ស្លាប់ ។

១១ ត្បិតបាបបានឱកាស ដោយមិនទទួលស្គាល់ព្រះបញ្ញត្តិ ហើយបានបញ្ឆោតខ្ញុំ ហើយដោយសារអំពើបាប នោះខ្ញុំត្រូវបានប្រហារបង់ ។

១២ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំឃើញថា ក្រិត្យវិន័យជាបរិសុទ្ធ ហើយសេចក្ដីបញ្ញត្តិក៏បរិសុទ្ធ សុចរិត ហើយល្អដែរ ។

១៣ ដូច្នេះ ចុះសេចក្ដីល្អនេះ បានប្រែទៅជាឲ្យខ្ញុំស្លាប់ឬអី ? ទេ មិនមែនឡើយ គឺជាបាបវិញទេតើ ដើម្បីឲ្យវាបានសម្ដែងចេញមកថា ជាបាបមែន ដោយសារអ្វីដែលជាសេចក្ដីល្អ ដោយបង្កើតសេចក្ដីស្លាប់នៅក្នុងខ្លួនខ្ញុំ ប្រយោជន៍ឲ្យបាប ដោយសារព្រះបញ្ញត្តិ បានក្លាយ ទៅជាធ្ងន់ក្រៃលែង ។

១៤ ត្បិតយើងដឹងថា ក្រិត្យវិន័យត្រូវខាងវិញ្ញាណ តែកាលខ្ញុំនៅក្រោមអំណាចក្រិត្យវិន័យ នោះខ្ញុំនៅខាងរូបកាយ ដោយត្រូវបានលក់ទៅក្រោមអំណាចអំពើបាប ។

១៥ តែឥឡូវនេះ ខ្ញុំនៅខាងវិញ្ញាណវិញ ត្បិតអ្វីដែលខ្ញុំត្រូវបានបញ្ជាឲ្យប្រព្រឹត្ត នោះខ្ញុំក៏ប្រព្រឹត្ត ហើយអ្វីដែលខ្ញុំត្រូវបានបញ្ជាមិនឲ្យអនុម័ត នោះខ្ញុំក៏មិនអនុម័ត ។

១៦ ត្បិតអ្វីដែលខ្ញុំដឹងថាមិនត្រូវ នោះខ្ញុំក៏នឹងមិនប្រព្រឹត្តដែរ ត្បិតអ្វីដែលជាអំពើបាប នោះខ្ញុំស្អប់ ។

១៧ គ្រានោះ បើសិនជាខ្ញុំមិនប្រព្រឹត្តការដែលខ្ញុំមិនត្រូវបានអនុម័ត នោះខ្ញុំយល់ព្រមថាក្រិត្យវិន័យល្អមែន ។

១៨ ដូច្នេះ មិនមែនខ្ញុំទៀតទេ ដែលប្រព្រឹត្តអំពើបាប ប៉ុន្តែខ្ញុំខំរកដើម្បីពង្រាបអំពើបាបនោះ ដែលនៅក្នុងខ្លួនខ្ញុំវិញ ។

១៩ ត្បិតខ្ញុំដឹងថា នៅក្នុងខ្លួនខ្ញុំ គឺក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ ព្រោះខ្ញុំមានចិត្តចង់ធ្វើល្អជានិច្ច ប៉ុន្តែ ដើម្បីប្រព្រឹត្តអ្វីដែលល្អ នោះខ្ញុំរកមិនកើតសោះ គឺដោយនូវព្រះគ្រីស្ទប៉ុណ្ណោះ ។

២០ ត្បិតការល្អដែលខ្ញុំចង់ធ្វើ កាលនៅក្រោមអំណាចក្រិត្យវិន័យ នោះខ្ញុំមិនឃើញថាជាល្អទេ ហេតុដូច្នេះហើយ ខ្ញុំមិនបានធ្វើការ នោះទេ ។

២១ ប៉ុន្តែការអាក្រក់ដែលខ្ញុំមិនចង់ធ្វើ នៅក្រោមអំណាចក្រិត្យវិន័យ នោះខ្ញុំឃើញថាជាល្អវិញ ការនោះហើយដែលខ្ញុំធ្វើ ។

២២ ឥឡូវនេះ បើខ្ញុំប្រព្រឹត្តការនោះ តាមរយៈជំនួយពីព្រះគ្រីស្ទ នោះខ្ញុំមិនចង់ធ្វើនៅក្រោមអំណាចក្រិត្យវិន័យទេ ខ្ញុំមិនបាននៅក្រោមអំណាចក្រិត្យវិន័យឡើយ ហើយវាមិនមែនខ្ញុំទៀតទេ ដែលខំរកធ្វើខុស ប៉ុន្តែដើម្បីពង្រាបអំពើបាប ដែលនៅក្នុងខ្លួនខ្ញុំទេតើ ។

២៣ យ៉ាងនោះ ខ្ញុំឃើញថានៅក្រោមអំណាចក្រិត្យវិន័យ គឺកាលខ្ញុំចង់ប្រព្រឹត្តសេចក្ដីល្អ នោះសេចក្ដីអាក្រក់ជាប់នៅនឹងខ្ញុំជានិច្ច ត្បិតខ្ញុំត្រេកអរចំពោះក្រិត្យវិន័យនៃព្រះ តាមប៉ែកខាងក្នុងមនុស្ស ។

២៤ ហើយឥឡូវនេះ ខ្ញុំឃើញមានក្រិត្យវិន័យមួយទៀត គឺជាព្រះបញ្ញត្តិនៃព្រះគ្រីស្ទ ហើយក្រិត្យវិន័យនោះក៏នៅជាប់ក្នុងគំនិតរបស់ខ្ញុំ ។

២៥ ប៉ុន្តែអស់ទាំងអវយវៈរបស់រូបកាយខ្ញុំ កំពុងតែធ្វើសង្គ្រាមនឹងក្រិត្យវិន័យនៃគំនិតរបស់ខ្ញុំ ហើយទាំងចាប់នាំខ្ញុំទៅជាប់ឃុំឃាំង ចំពោះក្រិត្យវិន័យខាងអំពើបាប ដែលនៅក្នុងអវយវៈរបស់ខ្ញុំទាំងប៉ុន្មានផង ។

២៦ ហើយបើខ្ញុំមិនពង្រាបអំពើបាប ដែលនៅក្នុងខ្លួនខ្ញុំទេ ប៉ុន្តែជាមួយនឹងសាច់ឈាម បំរើក្រិត្យវិន័យនៃអំពើបាបវិញ; ឱរូបខ្ញុំអើយ វេទនាអ្វីម្ល៉េះ ! តើអ្នកណានឹងជួយខ្ញុំឲ្យរួច ពីតួសេចក្ដីស្លាប់នេះទៅបាន ?

២៧ ខ្ញុំសូមអរព្រះគុណដល់ព្រះ តាមរយៈព្រះយេស៊ូវគ្រីស្ទ ដូច្នេះ គឺដោយសារគំនិត នោះខ្លួនខ្ញុំគោរពប្រតិបត្តិតាមក្រិត្យវិន័យនៃព្រះ ។

**ក.យ.ស., រ៉ូម ៨:៨** (ចូរប្រៀបធៀបនឹងគម្ពីររ៉ូម ៨:៨)

*(អស់អ្នកណាដែលដើរតាមផ្លូវទាំងឡាយខាងសាច់ឈាម នោះពុំអាចនឹងគាប់ព្រះហឫទ័យដល់ព្រះបានឡើយ)* ។

៨ ដូច្នេះ ពួកអ្នកណាដែលស្របតាមសាច់ឈាម នោះពុំអាចនឹងគាប់ព្រះហឫទ័យដល់ព្រះបានឡើយ ។

**ក.យ.ស., ១ កូរិនថូស ៧:១–២, ៥, ២៦, ២៩–៣៣**
(ចូរប្រៀបធៀបនឹងគម្ពីរ ១ កូរិនថូស ៧:១–២, ៥, ២៦, ២៩–៣៣)

*(ប៉ុលបានឆ្លើយសំណួរទាំងឡាយ អំពីអាពាហ៍ពិពាហ៍នៃពួកអ្នកដែលទៅធ្វើបេសកកម្ម)* ។

១ ឥឡូវនេះ ស្ដីអំពីសេចក្ដីដែលអ្នករាល់គ្នាបានសរសេរមកសួរខ្ញុំថា គឺជាការល្អដែលបុរសមិនប៉ះពាល់នឹងស្ត្រី ។

២ ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំនិយាយថា ដើម្បីឲ្យបានចៀសវាងពីការសហាយស្មន់ នោះចូរឲ្យបុរសគ្រប់រូបមានប្រពន្ធរបស់ខ្លួន ហើយចូរឲ្យស្ត្រីគ្រប់រូបមានប្ដីរបស់ខ្លួន ។

៥ ចូរអ្នករាល់គ្នាកុំបែកចេញពីគ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុងមួយពេល ដើម្បីឲ្យបានទំនេរនឹងតមអាហារ ហើយអធិស្ឋាន ហើយវិលមកនៅជាមួយគ្នាវិញ ដើម្បីកុំឲ្យអារក្សសាតាំងមកល្បួងអ្នក ដោយព្រោះអ្នកមិនចេះអត់ទ្រាំ ។

២៦ ដូច្នេះ ខ្ញុំស្មានជាការនេះបានល្អ ដោយព្រោះគ្រាលំបាកនេះ សំរាប់ឲ្យមនុស្សនៅតែដដែលវិញ ដើម្បីឲ្យគេអាចបានធ្វើការល្អលើសលែងទៅទៀត ។

២៩ ប៉ុន្តែខ្ញុំនិយាយទៅកាន់អ្នក ដែលត្រូវបានហៅឲ្យធ្វើការងារបំរើ ។ បងប្អូនអើយ ខ្ញុំប្រាប់សេចក្ដីនេះថា ពេលវេលាដែលនៅ សល់ គឺខ្លីណាស់ ដែលអ្នករាល់គ្នានឹងត្រូវបានចាត់ឲ្យទៅធ្វើការងារបំរើ ។ សូម្បីតែពួកអ្នកដែលមានប្រពន្ធ ក៏នឹងទៅដូចជាពួកអ្នក គ្មានប្រពន្ធដែរ ព្រោះអ្នករាល់គ្នាត្រូវបានហៅ ហើយជ្រើសរើសឲ្យធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។

៣០ ហើយហេតុការណ៍នៃពួកអ្នកដែលយំក៏នឹងទៅជាដូច្នោះដែរ គឺហាក់ដូចជាមិនបានយំ ហើយពួកអ្នកដែលអរសប្បាយ ក៏ហាក់ដូចជាពួកគេមិនបានអរសប្បាយដែរ ហើយពួកអ្នកដែលទិញ ក៏ហាក់ដូចជាគេគ្មានអ្វីសោះ

៣១ ហើយពួកអ្នកដែលប្រើប្រាស់លោកិយនេះ ដូចជាមិនប្រើប្រាស់លោកិយទេ ត្បិតគំរូនៃលោកិយនេះកំពុងកន្លងទៅ ។

៣២ ប៉ុន្តែបងប្អូនអើយ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដំកើងការហៅរបស់អ្នក ។ ខ្ញុំចង់ឲ្យអ្នករាល់គ្នាបានរួចពីសេចក្ដីកង្វល់ ។ ត្បិតអ្នកណា ដែលមិនបានរៀបការ នោះតែងតែរវល់នឹងការរបស់ព្រះអម្ចាស់ ដែលគេនឹងធ្វើដូចម្ដេចឲ្យទ្រង់សព្វព្រះហឫទ័យ ហេតុដូច្នេះហើយ ទើបគេមានការជោគជ័យ ។

៣៣ ប៉ុន្តែឯអ្នកណាដែលបានរៀបការ នោះតែងតែរវល់នឹងការនៅលោកិយនេះវិញ ដែលនឹងធ្វើដូចម្ដេចឲ្យបានគាប់ចិត្តដល់ប្រពន្ធខ្លួន ហេតុដូច្នេះហើយ ទើបមានការខុសពីគ្នា ត្បិតអ្នកនោះត្រូវបានរារាំង ។

**ក.យ.ស., ១ កូរិនថូស ១៥:៤០** (ចូរប្រៀបធៀបនឹងគម្ពីរ ១ កូរិនថូស ១៥:៤០)

*(មានសិរីល្អបីលំដាប់នៅក្នុងដំណើររស់ឡើងវិញ) ។*

៤០ ក៏មានរូបកាយទាំងឡាយខាងសេឡេស្ទាល និងរូបកាយទាំងឡាយខាងទេរេសទ្រាល និងរូបកាយទាំងឡាយខាងទេឡេស្ទាល ប៉ុន្តែសិរីល្អរបស់សេឡេស្ទាល នោះមួយ និងរបស់ទេរេសទ្រាល នោះមួយផ្សេងទៀត និងរបស់ទេឡេស្ទាល នោះមួយផ្សេងទៀត ។

**ក.យ.ស., ២ កូរិនថូស ៥:១៦** (ចូរប្រៀបធៀបនឹងគម្ពីរ ២ កូរិនថូស ៥:១៦)

*(ប៉ុលបានទូន្មានមិនឲ្យពួកបរិសុទ្ធរស់នៅតាមរបៀបខាងឯសាច់ឈាមទេ) ។*

១៦ ហេតុដូច្នេះហើយ ពីនេះទៅមុខ យើងខ្ញុំមិនរស់នៅតាមខាងឯសាច់ឈាមទៀតទេ មែនហើយ ទោះបើគ្រាមួយយើងបានរស់ នៅតាមខាងឯសាច់ឈាម ក៏យើងខ្ញុំបានស្គាល់ព្រះគ្រីស្ទដែរ គង់តែឥឡូវនេះ គឺពីនេះទៅមុខ យើងខ្ញុំមិនរស់នៅតាមខាងឯសាច់ ឈាមទៀតឡើយ ។

**ក.យ.ស., កាឡាទី ៣:១៩–២០** (ចូរប្រៀបធៀបនឹងគម្ពីរកាឡាទី ៣:១៩–២០)

*(ព្រះគ្រីស្ទជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មី ។ ក្រិត្យវិន័យនៃលោកម៉ូសេ [សេចក្ដីសញ្ញាចាស់] និងដំណឹងល្អដ៏អស់កល្បជានិច្ច [សេចក្ដីសញ្ញាថ្មី] ត្រូវបានប្រៀបធៀបនឹងគ្នា) ។*

១៩ ហេតុដូច្នោះ គឺខណៈនោះ ទើបក្រិត្យវិន័យត្រូវបានបន្ថែមបញ្ចូល ដោយព្រោះសេចក្ដីរំលងច្បាប់ ទាល់តែពូជបានកើតឡើង ដែលបានធ្វើសេចក្ដីសន្យា នៅក្នុងក្រិត្យវិន័យដែលបានប្រទានដល់លោកម៉ូសេ ជាអ្នកដែលបានតែងតាំងឡើង ដោយដៃរបស់ពួក ទេវតា ដើម្បីឲ្យធ្វើជាអ្នកកណ្ដាលម្នាក់នៃសេចក្ដីសញ្ញាទីមួយ (ក្រិត្យវិន័យ) ។

២០ ឥឡូវ អ្នកកណ្ដាលនេះពុំមែនជាអ្នកកណ្ដាលនៃសេចក្ដីសញ្ញាថ្មីទេ; ប៉ុន្តែមានអ្នកកណ្ដាលម្នាក់នៃសេចក្ដីសញ្ញាថ្មី ដែលជាព្រះគ្រីស្ទ ដូចដែលបានចែងទុកនៅក្នុងក្រិត្យវិន័យ ស្ដីអំពីសេចក្ដីសន្យាដែលបានធ្វើដល់លោកអ័ប្រាហាំ និងពូជរបស់លោក ។ ឥឡូវនេះ ព្រះគ្រីស្ទគឺជាអ្នកកណ្ដាលនៃជីវិត ត្បិតនេះហើយជាសេចក្ដីសន្យាដែលព្រះទ្រង់បានធ្វើនឹងលោកអ័ប្រាហាំ ។

**ក.យ.ស., អេភេសូរ ៤:២៦** (ចូរប្រៀបធៀបនឹងគម្ពីរ អេភេសូរ ៤:២៦)

*(កំហឹងដែលមិនសុចរិតគឺជាអំពើបាប) ។*

២៦ តើអ្នករាល់គ្នាអាចខឹង ហើយមិនធ្វើបាបបានឬ ? ចូរកុំឲ្យសេចក្ដីកំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ ។

**ក.យ.ស., ១ ថែស្សាឡូនីច ៤:១៥** (ចូរប្រៀបធៀបនឹងគម្ពីរ ១ ថែស្សាឡូនីច ៤:១៥)

*(ពួកមនុស្សសុចរិតដែលនៅរស់កាលព្រះអម្ចាស់យាងមក នឹងពុំមានប្រៀបលើពួកសុចរិតដែលស្លាប់ឡើយ) ។*

១៥ ត្បិតយើងខ្ញុំប្រាប់មកអ្នករាល់គ្នា តាមព្រះបន្ទូលនៃព្រះអម្ចាស់ដូច្នេះថា ពួកអ្នកដែលរស់នៅ កាលព្រះអម្ចាស់យាងមក នោះនឹងមិនទៅមុនពួកអ្នក ដែលបាននៅជាប់ដរាបដល់ព្រះអម្ចាស់យាងមក គឺជាពួកដែលបានដេកលក់ទៅហើយនោះទេ ។

**ក.យ.ស., ២ ថែស្សាឡូនីច ២:២–៣, ៧–៩** (ចូរប្រៀបធៀបនឹងគម្ពីរ ២ ថែស្សាឡូនីច ២:២–៩)

*(ប៉ុលបានព្យាករអំពីការក្បត់សាសនាមុនព្រះអម្ចាស់ទ្រង់យាងមកវិញ) ។*

២ ដើម្បីកុំឲ្យអ្នករាល់គ្នាឆាប់មានគំនិតរវើរវាយ ឬចប់ព្រួយដោយ

សារសំបុត្រណាឡើយ លើកលែងតែអ្នករាល់គ្នាបានទទួលសំបុត្រពីយើងខ្ញុំ; ឬដោយសារវិញ្ញាណណា ឬពាក្យសំដីណា ដែលថាថ្ងៃនៃព្រះគ្រីស្ទជិតដល់ហើយនោះឡើយ ។
៣ ចូរកុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ត្បិតនឹងមានសេចក្ដីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះនឹងត្រូវបានបើកសម្ដែងឲ្យស្គាល់ គឺជាកូនអន្តរធាន
៧ ត្បិតសេចក្ដីអាថ៌កំបាំងរបស់អំពើទុច្ចរិត កំពុងតែបណ្ដាលឡើងហើយ ហើយអ្នកនោះហើយដែលបណ្ដាលឡើងនៅពេលនេះ ហើយ ព្រះគ្រីស្ទទ្រាំឲ្យអ្នកនោះបណ្ដាលឡើង ដរាបដល់ពេលនោះបានពោរពេញ ដែលអ្នកនោះនឹងត្រូវបានដកចេញទៅ ។
៨ ហើយខណៈនោះ ទើបអាទុច្ចរិតនោះ នឹងត្រូវបានបើកសម្ដែងឲ្យស្គាល់ ដែលព្រះអម្ចាស់ទ្រង់នឹងបំផ្លាញ ដោយវិញ្ញាណនៃ ព្រះឱស្ឋរបស់ទ្រង់ ហើយនឹងធ្វើឲ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក ។
៩ មែនហើយ ព្រះអម្ចាស់ គឺជាព្រះយេស៊ូវ ដែលនឹងមិនយាងមកដរាបដល់មានសេចក្ដីក្បត់សាសនាជាមុន ដោយសារការធ្វើការ របស់អារក្សសាតាំង ដោយអស់ទាំងអំណាច និងទីសំគាល់ទាំងឡាយ និងការអស្ចារ្យដ៏កំភូតទាំងឡាយ

**ក.យ.ស., ១ ធីម៉ូថេ ២:៤** (ចូរប្រៀបធៀបនឹងគម្ពីរ ១ ធីម៉ូថេ ២:៤)

*(ព្រះគ្រីស្ទ គឺជាព្រះរាជបុត្រាបង្កើតតែមួយ ហើយជាអ្នកកណ្ដាល) ។*

៤ នោះទ្រង់សព្វព្រះហឫទ័យ ឲ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឲ្យបានស្គាល់សេចក្ដិពិត ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះ ហើយដែលបានតែងតាំងឡើងឲ្យធ្វើជាអ្នកកណ្ដាលមួយ រវាងព្រះនឹងមនុស្ស ដែលជាព្រះមួយអង្គ ហើយមានព្រះចេស្ដាលើមនុស្សទាំងអស់ ។

**ក.យ.ស., ១ ធីម៉ូថេ ៦:១៥–១៦** (ចូរប្រៀបធៀបនឹងគម្ពីរ ១ ធីម៉ូថេ ៦:១៥–១៦)

*(អស់អ្នកណាដែលមានពន្លឺនៃអមតភាពនៅក្នុងខ្លួន នោះអាចមើលឃើញព្រះយេស៊ូវ) ។*

១៥ នោះព្រះនឹងសម្ដែងឲ្យឃើញទ្រង់ ក្នុងវេលាកំណត់ គឺជាស្ដេចចក្រតែមួយអង្គដ៏មានពរ ជាស្ដេចលើអស់ទាំងស្ដេច ហើយជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ សូមឲ្យទ្រង់បានល្បីព្រះនាម និងព្រះចេស្ដានៅអស់កល្បជានិច្ច
១៦ នោះគ្មានមនុស្សណាដែលឃើញទ្រង់ ឬអាចមើលទ្រង់ឃើញ ដែលគ្មានមនុស្សណាអាចចូលជិតបានឡើយ គឺមានតែអ្នក ដែលមានពន្លឺនិងសេចក្ដីសង្ឃឹមដល់អមតភាពប៉ុណ្ណោះ ដែលគង់នៅក្នុងអ្នកនោះ ។

**ក.យ.ស., ហេព្រើរ ១:៦–៧** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ១:៦–៧)

*(ពួកទេវតាគឺជាវិញ្ញាណដែលធ្វើការងារបំរើ) ។*

៦ ហើយម្ដងទៀត កាលទ្រង់ឲ្យព្រះរាជបុត្រាបង្កើតតែមួយមកក្នុងលោកិយ នោះទ្រង់មានព្រះបន្ទូលថា ហើយចូរឲ្យអស់ទាំងទេវតានៃព្រះថ្វាយបង្គំទ្រង់ ជាអ្នកដែលធ្វើឲ្យពួកអ្នកធ្វើការងារបំរើទ្រង់ទៅដូចជាអណ្ដាតភ្លើងចុះ ។
៧ ហើយអំពីពួកទេវតា នោះទ្រង់មានព្រះបន្ទូលថា ពួកទេវតាគឺជាវិញ្ញាណដែលធ្វើការងារបំរើ ។

**ក.យ.ស., ហេព្រើរ ៤:៣** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ៤:៣)

*(កិច្ចការទាំងឡាយនៃព្រះត្រូវបានរៀបចំទុក តាំងពីកំណើតលោកិយមក) ។*

៣ ត្បិតយើងរាល់គ្នាដែលជឿក៏ចូលក្នុងសេចក្ដីសំរាក ដូចដែលទ្រង់មានព្រះបន្ទូលថា ដូចដែលយើងបានស្បថទាំងកំហឹងថា បើសិន ជាពួកគេរាល់គ្នាធ្វើចិត្តរឹងរូស នោះពួកគេមិនត្រូវចូល ទៅក្នុងសេចក្ដីសំរាករបស់យើងសោះឡើយ គឺយើងបានស្បថថា បើសិនជាពួក គេមិនធ្វើចិត្តរឹងរូសទេ នោះពួកគេនឹងបានចូលទៅក្នុងសេចក្ដីសំរាករបស់យើង; ទោះបើកិច្ចការទាំងឡាយនៃព្រះត្រូវបានរៀបចំទុក (ឬបានសំរេច) តាំងពីកំណើតលោកិយមកក៏ដោយ ។

**ក.យ.ស., ហេព្រើរ ៥:៧–៨**

*(សំគាល់មួយនៅក្នុងឯកសារនៃ ក.យ.ស. ថ្លែងថា ខ៧ និងខ៨ និយាយសំដៅទៅលោកមិលគីស្សាដែក ហើយមិនមែនព្រះគ្រីស្ទទេ ។ បើពុំនោះសោតទេ ឯកសារនៅក្នុងព្រះគម្ពីរច្បាប់ស្ដេចយ៉េម្ស និង ក.យ.ស. គឺដូចគ្នា) ។*

**ក.យ.ស., ហេព្រើរ ៦:១, ៣** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ៦:១, ៣)

*(គោលការណ៍ទាំងឡាយនៃព្រះគ្រីស្ទនាំទៅរកភាពដ៏ល្អឥតខ្ចោះ) ។*

១ ដូច្នេះ ដោយពុំបែរចេញពីគោលការណ៍ទាំងឡាយនៃគោលលទ្ធិរបស់ព្រះគ្រីស្ទ នោះចូរយើងជឿនទៅមុខ ទៅរកភាពដ៏ល្អឥត ខ្ចោះ ដោយមិនត្រូវតាំងឡើងវិញនូវសេចក្ដីដើមនៃសេចក្ដីប្រែចិត្តចេញពីការស្លាប់ និងសេចក្ដីជំនឿដល់ព្រះ ។
៣ ហើយយើងរាល់គ្នានឹងជឿនទៅមុខ ទៅរកភាពដ៏ល្អឥតខ្ចោះ បើសិនជាព្រះទ្រង់អនុញ្ញាតឲ្យ ។

**ក.យ.ស., ហេព្រើរ ៧:៣** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ៧:៣)

*(បព្វជិតភាពដ៏បរិសុទ្ធតាមរបៀបនៃព្រះរាជបុត្រានៃព្រះ គឺគ្មានមាតា ឬបិតាទេ ហើយគ្មានថ្ងៃចាប់ផ្ដើម ឬថ្ងៃបញ្ចប់ដែរ) ។*

៣ ត្បិតលោកមិលគីស្សាដែកត្រូវបានតែងតាំងឡើងឲ្យធ្វើជាសង្ឃតាមរបៀបនៃព្រះរាជបុត្រានៃព្រះ ជារបៀបដែលគ្មានមាតា ឬបិតាគ្មានពង្សាវតារទេ ក៏គ្មានថ្ងៃចាប់ផ្ដើម ឬទីបញ្ចប់នៃជីវិតដែរ ។ ហើយ

អស់អ្នកណាដែលត្រូវបានតែងតាំងឡើង ចំពោះ បព្វជិតភាពនេះ ក៏ត្រូវបានធ្វើឲ្យមានភាពដូចជាព្រះរាជបុត្រានៃព្រះ នៅជាសង្ឃជារៀងដរាបតទៅ ។

**ក.យ.ស., ហេព្រើរ ៧:២៥–២៦** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ៧:២៦–២៧)

*(តួនាទីរបស់ព្រះគ្រីស្ទជាអ្នកកណ្ដាលត្រូវបានពន្យល់ប្រាប់)* ។

២៥ ត្បិតគួរឲ្យមានសម្ដេចសង្ឃយ៉ាងនោះ សំរាប់យើង ដែលទ្រង់បរិសុទ្ធ ឥតពុតមាយា ឥតសៅហ្មង ដែលបានញែកចេញពី មនុស្សបាប ហើយត្រូវបានធ្វើជាអ្នកត្រួតត្រាលើស្ថានសួគ៌

២៦ ហើយពុំមែនដូចជាពួកសម្ដេចសង្ឃទាំងនោះ ដែលនឹងថ្វាយយញ្ញបូជាជារៀងរាល់ថ្ងៃ ដែលថ្វាយដោយព្រោះបាបខ្លួនជាមុនដំបូង រួចមកដោយព្រោះបាបរបស់ជនទាំងឡាយ ត្បិតទ្រង់មិនចាំបាច់នឹងថ្វាយយញ្ញបូជាដោយព្រោះបាបរបស់ទ្រង់នោះទេ ព្រោះទ្រង់ មិនស្គាល់បាបឡើយ ប៉ុន្តែដោយព្រោះបាបរបស់ជនទាំងឡាយវិញ ។ ហើយទ្រង់បានថ្វាយយញ្ញបូជានេះមួយដងជាសំរេច គឺក្នុងកាល ដែលទ្រង់ថ្វាយព្រះអង្គទ្រង់នោះឯង ។

**ក.យ.ស., ហេព្រើរ ១១:១** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ១១:១)

*(សេចក្ដីជំនឿគឺជាចិត្តដែលដឹងជាប្រាកដថានឹងបានដូចសង្ឃឹម)* ។

១ ឥឡូវនេះ សេចក្ដីជំនឿ គឺជាចិត្តដែលដឹងថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការណ៍ដែលមើលមិនឃើញ ។

**ក.យ.ស., ហេព្រើរ ១១:៣៥** (ចូរប្រៀបធៀបនឹងគម្ពីរហេព្រើរ ១១:៣៥)

*(ពួកអ្នកស្មោះត្រង់ណាដែលត្រូវគេធ្វើទុក្ខវេទនា ដោយព្រោះព្រះគ្រីស្ទនោះបានខណរស់ឡើងវិញទីមួយ)* ។

៣៥ ពួកស្រីៗបានទទួលមនុស្សស្លាប់របស់ខ្លួនមក ដោយរស់ពីស្លាប់ឡើងវិញ ហើយអ្នកខ្លះត្រូវគេធ្វើទុក្ខវេទនា ឥតទទួលការ ប្រោសលោះឲ្យរួចឡើយ ដើម្បីឲ្យពួកគេបានទទួលខណៈរស់ឡើងវិញទីមួយ

**ក.យ.ស., យ៉ាកុប ១:២** (ចូរប្រៀបធៀបនឹងគម្ពីរយ៉ាកុប ១:២)

*(សេចក្ដីទុក្ខវេទនាទាំងឡាយ គឺពុំមែនជាសេចក្ដីល្បួងទេ ដែលជួយញែកយើងរាល់គ្នាឲ្យបរិសុទ្ធ)* ។

២ បងប្អូនអើយ ចូររាប់ជាសេចក្ដីអំណរសព្វគ្រប់ចុះ កាលណាអ្នករាល់គ្នាធ្លាក់ទៅក្នុងសេចក្ដីទុក្ខវេទនាដ៏ច្រើន

**ក.យ.ស., យ៉ាកុប ២:១** (ចូរប្រៀបធៀបនឹងគម្ពីរ យ៉ាកុប ២:១)

*(ពួកសមាជិកមិនត្រូវរាប់ថាមនុស្សម្នាក់ខ្ពស់ជាងមនុស្សផ្សេងឡើយ)* ។

១ បងប្អូនអើយ អ្នករាល់គ្នាមិនអាចមានសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង គឺជាព្រះអម្ចាស់នៃសិរីល្អ ហើយ ក៏រើសមុខអ្នកណាបានឡើយ ។

**ក.យ.ស., ១ ពេត្រុស ៣:២០** (ចូរប្រៀបធៀបនឹងគម្ពីរ ១ ពេត្រុស ៣:២០)

*(វិញ្ញាណខ្លះដែលជាប់ឃុំនោះសុទ្ធតែឥតសុចរិតនៅជំនាន់លោកណូអេ)* ។

២០ មនុស្សខ្លះគឺជាពួកដែលមិនគោរពតាមនៅជំនាន់លោកណូអេ កាលដែលសេចក្ដីអត់ធ្មត់របស់ព្រះ បានរង់ចាំ កាលទូកធំកំពុងតែ ធ្វើ ហើយនៅក្នុងទូកនោះមានមនុស្សតែបន្តិច គឺប្រាំបីនាក់ប៉ុណ្ណោះ ដែលបានរួចដោយសារទឹក ។

**ក.យ.ស., ១ ពេត្រុស ៤:៦** (ចូរប្រៀបធៀបនឹងគម្ពីរ ១ ពេត្រុស ៤:៦)

*(ដំណឹងល្អត្រូវបានផ្សាយដល់ពួកអ្នកដែលស្លាប់ទៅហើយ)* ។

៦ ដោយហេតុនេះហើយ ទើបដំណឹងល្អត្រូវបានផ្សាយដល់ពួកអ្នកដែលស្លាប់ទៅហើយ ដើម្បីឲ្យពួកគេត្រូវជាប់ជំនុំជំរះតាមបែប មនុស្សខាងសាច់ឈាម ប៉ុន្តែបានរស់ខាងវិញ្ញាណ តាមព្រះហឫទ័យនៃព្រះវិញ ។

**ក.យ.ស., ១ ពេត្រុស ៤:៨** (ចូរប្រៀបធៀបនឹងគម្ពីរ ១ ពេត្រុស ៤:៨)

*(សេចក្ដីសប្បុរសបង្ការយើងរាល់គ្នាពីការធ្វើបាប)* ។

៨ ហើយមុនដំបូងបង្អស់ ត្រូវមានសេចក្ដីសប្បុរសនៅក្នុងចំណោមអ្នករាល់គ្នា; ត្បិតសេចក្ដីសប្បុរសបង្ការអំពើបាបជាអនេកអនន្ត ។

**ក.យ.ស., ១ យ៉ូហាន ២:១** (ចូរប្រៀបធៀបនឹងគម្ពីរ ១ យ៉ូហាន ២:១)

*(ព្រះគ្រីស្ទនឹងទៅជាព្រះដ៏គាំទ្ររបស់យើង ដែលគង់នៅចំពោះព្រះវរបិតា បើសិនជាយើងប្រែចិត្ត)* ។

១ កូនតូចៗរាល់គ្នាអើយ ដែលខ្ញុំសរសេរសេចក្ដីទាំងនេះផ្ញើមក នោះដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត តែបើសិនជាអ្នកណាធ្វើបាប ហើយប្រែចិត្ត នោះយើងមានព្រះដ៏គាំទ្រមួយអង្គ ដែលគង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត

**ក.យ.ស., ១ យ៉ូហាន ៣:៩** (ចូរប្រៀបធៀបនឹងគម្ពីរ ១ យ៉ូហាន ៣:៩)

*(អស់អ្នកណាដែលកើតពីព្រះ នោះមិននៅក្នុងអំពើបាបទៀតទេ)* ។

៩ អស់អ្នកណាដែលកើតពីព្រះ នោះមិននៅក្នុងអំពើបាបទៀតទេ ត្បិតព្រះវិញ្ញាណនៃព្រះគង់នៅក្នុងអ្នកនោះ ហើយអ្នកនោះមិនអាចនៅក្នុងអំពើបាបទៀតទេ ពីព្រោះអ្នកនោះបានកើតពីព្រះមក ដោយបានទទួលព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសន្យានោះ ។

**ក.យ.ស., ១ យ៉ូហាន ៤:១២** (ចូរប្រៀបធៀបនឹងគម្ពីរ ១ យ៉ូហាន ៤:១២)

*(មានតែអ្នកណាដែលជឿដល់ព្រះប៉ុណ្ណោះ ដែលអាចមើលទ្រង់ឃើញ) ។*

១២ គ្មានអ្នកណាដែលឃើញព្រះនៅពេលណាមួយឡើយ លើកលែងតែពួកអ្នកដែលជឿប៉ុណ្ណោះ ។ បើសិនជាយើង ស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ បានពេញខ្នាតក្នុងយើងដែរ ។

**ក.យ.ស., វិវរណៈ ១:១–៤** (ចូរប្រៀបធៀបនឹងគម្ពីរវិវរណៈ ១:១–៤)

*(យ៉ូហានបានទទួលវិវរណៈពីព្រះយេស៊ូវគ្រីស្ទ ហើយបានប្រគល់វិវរណៈនោះទៅឲ្យពួកអ្នកដឹកនាំ ដែលនៅលើសាសនាចក្រទាំងប្រាំពីរនៅស្រុកអាស៊ី) ។*

១ នេះជាវិវរណៈរបស់យ៉ូហាន ជាអ្នកបំរើព្រះ ដែលបានប្រទានដល់គាត់ពីព្រះយេស៊ូវគ្រីស្ទ ដើម្បីបង្ហាញដល់ពួកអ្នកបំរើរបស់ទ្រង់ ពីការណ៍ទាំងឡាយ ដែលបន្តិចទៀតត្រូវកើតមានមក ដែលទ្រង់បានចាត់ ហើយបានសំដែងឲ្យឃើញ ដោយទេវតារបស់ទ្រង់ ដល់អ្នក បំរើរបស់ទ្រង់ គឺយ៉ូហាន ។
២ គាត់បានធ្វើទីបន្ទាល់ពីព្រះបន្ទូលនៃព្រះ និងពីសេចក្ដីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ និងពីគ្រប់ទាំងសេចក្ដីដែលគាត់បានឃើញ ។
៣ មានពរហើយ អ្នកណាដែលមើល និងអស់អ្នកណាដែលស្ដាប់ ហើយយល់នូវពាក្យទាំងឡាយនៃការព្យាករណ៍នេះ ហើយប្រព្រឹត្ត តាមសេចក្ដីទាំងប៉ុន្មាន ដែលកត់ទុកនេះដែរ ត្បិតឯពេលវេលានៃការយាងមករបស់ព្រះអម្ចាស់ នោះជិតដល់ហើយ ។
៤ ឥឡូវនេះគឺជាសេចក្ដីបន្ទាល់របស់យ៉ូហាន ទៅដល់ពួកអ្នកបំរើប្រាំពីរនាក់ ដែលនៅលើសាសនាចក្រទាំងប្រាំពីរ នៅ ស្រុកអាស៊ី ។ សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្ដីសុខសាន្ត អំពីទ្រង់ដ៏គង់នៅ ក៏គង់នៅតាំងតែពីដើម ហើយ ត្រូវយាងមកទៀត ទ្រង់បានចាត់ទេវតារបស់ទ្រង់ដែលនៅចំពោះបល្ល័ង្កទ្រង់ ដើម្បីឲ្យទៅធ្វើទីបន្ទាល់ដល់អស់អ្នកណា ដែលជាពួកអ្នក បំរើប្រាំពីរនាក់ ដែលនៅលើសាសនាចក្រទាំងប្រាំពីរ ។

**ក.យ.ស., វិវរណៈ ២:២២** (ចូរប្រៀបធៀបនឹងគម្ពីរវិវរណៈ ២:២២)

*(ពួកទុច្ចរិតនឹងត្រូវបោះទៅក្នុងស្ថាននរក) ។*

២២ មើលចុះ យើងនឹងបោះនាងទៅក្នុងស្ថាននរក ហើយបោះពួកអ្នកដែលប្រព្រឹត្តសេចក្ដីកំផិតជាមួយនឹងនាង ឲ្យទៅក្នុងសេចក្ដី វេទនាជាខ្លាំង លើកលែងតែគេប្រែចិត្តលះបង់ការទាំងឡាយដែលគេប្រព្រឹត្តនោះចេញ ។

**ក.យ.ស., វិវរណៈ ៥:៦** (ចូរប្រៀបធៀបនឹងគម្ពីរវិវរណៈ ៥:៦)

*(ពួកអ្នកបំរើរបស់ព្រះទាំង១២នាក់ត្រូវបានចាត់ឲ្យទៅពេញលើផែនដី) ។*

៦ ហើយខ្ញុំក្រឡេកទៅឃើញ ហើយមើលន៏ នៅកណ្ដាលបល្ល័ង្ក និងតួមានជីវិតទាំងបួន និងនៅកណ្ដាលពួកអែលឌើរ នោះមាន កូនចៀមមួយឈរ ហាក់ដូចជាបានប្រហារហើយ ដោយមានទាំងស្នែង១២ និងភ្នែក១២ ដែលជាពួកអ្នកបំរើរបស់ព្រះទាំង១២នាក់ ដែលត្រូវបានចាត់ឲ្យទៅពេញលើផែនដី ។

**ក.យ.ស., វិវរណៈ ១២:១–១៧** (ចូរប្រៀបធៀបនឹងគម្ពីរវិវរណៈ ១២:១–១៧; គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៧)

*(ស្ត្រី [សាសនាចក្រ], កូន [នគរព្រះ], ដំបងដែក [ព្រះបន្ទូលនៃព្រះ], នាគ [អារក្សសាតាំង], និងមីកែល ត្រូវបានពន្យល់ប្រាប់ ។ សង្គ្រាមនៅលើស្ថានសួគ៌ត្រូវបានបន្តនៅលើផែនដី) ។*

១ ហើយមានទីសំគាល់មួយយ៉ាងធំ នៅលើស្ថានសួគ៌ គឺដែលមានរូបរាងដូចជាអ្វីៗនៅលើផែនដី មានស្ត្រីម្នាក់ប្រដាប់ខ្លួនដោយ ព្រះអាទិត្យ ហើយមានព្រះច័ន្ទនៅក្រោមជើងនាង ហើយនៅលើក្បាលនាងនោះមានមកុដធ្វើពីផ្កាយ១២ ។
២ ហើយស្ត្រីនោះមានគភ៌ ក៏ស្រែកដោយរៀបនឹងសំរាលចេញ ទាំងឈឺចាប់នឹងបង្កើតកូនមក ។
៣ ហើយនាងបង្កើតមានកូនប្រុសមួយ ដែលត្រូវគ្រប់គ្រាលើអស់ទាំងសាសន៍ ដោយដំបងដែក ហើយកូននាងត្រូវបាននាំឡើងទៅឯព្រះ និងបល្ល័ង្ករបស់ទ្រង់ ។
៤ ហើយក៏ឃើញមានទីសំគាល់មួយទៀត នៅស្ថានសួគ៌; ហើយមើលចុះ មាននាគដ៏ធំមួយមានសម្បុរក្រហម ដែលមានក្បាល៧ និងស្នែង១០ ហើយមានមកុដ៧នៅលើក្បាលវា ។ ហើយកន្ទុយវាក៏ទាញផ្កាយនៅលើមេឃ១ភាគក្នុង៣ ហើយក្រវាត់ចោលទៅលើផែនដី ។ ហើយនាគនោះក៏ស្ថិតនៅត្រង់មុខស្ត្រី ដែលរៀបនឹងសំរាលកូននោះ ដើម្បីនឹងលេបកូននាង ក្នុងកាលដែលសំរាល ចេញមក ។
៥ ហើយស្ត្រីនោះក៏រត់ទៅឯទីរហោស្ថាន នៅទីនោះនាងមានកន្លែងមួយដែលត្រូវបានរៀបចំទុកដោយព្រះ ដើម្បីឲ្យពួកគេចិញ្ចឹមនាងនៅទីនោះ អស់រយៈ ១២៦០ ឆ្នាំ ។
៦ ហើយមានសង្គ្រាមនៅលើស្ថានសួគ៌ មីកែល និងពួកទេវតារបស់លោកច្បាំងនឹងនាគ; ហើយនាគ និងពួកទេវតារបស់វាក៏ច្បាំង នឹងមីកែលដែរ
៧ ហើយនាគមិនបានឈ្នះលើមីកែលទេ ឬលើកូន ឬលើស្ត្រីដែលជាសាសនាចក្រនៃព្រះ ដែលត្រូវបានរួចផុតពីការឈឺចាប់របស់នាង ហើយដែលបាននាំនគរនៃព្រះរបស់យើង និងព្រះគ្រីស្ទរបស់ទ្រង់ចេញមក ។

៨ ក៏មិនឃើញមានកន្លែងណានៅលើស្ថានសួគ៌ សំរាប់នាគដ៏ធំនោះ ដែលត្រូវបានបោះទំលាក់ទៅ ឯពស់ពីចាស់បុរាណនោះត្រូវ បាន ហៅថា អារក្ស ហើយក៏ត្រូវបានហៅថា សាតាំងផង ដែលបាន បញ្ឆោតលោកិយទាំងមូល វាត្រូវបានបោះទំលាក់ទៅផែនដី ព្រម ទាំងពួកទេវតារបស់វាក៏ត្រូវបានបោះទំលាក់ទៅជាមួយវាដែរ ។

៩ ហើយខ្ញុំបានឮសម្លេងមួយយ៉ាងខ្លាំង នៅលើស្ថានសួគ៌ថា ឥឡូវនេះ សេចក្ដីសង្គ្រោះ និងព្រះចេស្ដា និងនគរនៃព្រះរបស់យើង រាល់គ្នា ហើយអំណាចនៃព្រះគ្រីស្ទរបស់ទ្រង់ បានមកដល់ហើយ

១០ ត្បិតអានោះដែលចោទប្រកាន់ពីពួកបងប្អូនយើងរាល់គ្នា នោះ ត្រូវបានបោះទំលាក់ទៅហើយ ដែលចេះតែចោទពីគេ នៅចំពោះ ព្រះ ទាំងយប់ទាំងថ្ងៃ ។

១១ ត្បិតគេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយ សារពាក្យនៃសេចក្ដីបន្ទាល់របស់គេ ព្រោះគេពុំបានស្រឡាញ់ ជីវិត របស់ខ្លួនឡើយ តែបានកាន់សេចក្ដីបន្ទាល់នោះដរាបដល់ស្លាប់ ។ ដោយហេតុនោះ ឱស្ថានសួគ៌ និងពួកអ្នកដែលនៅស្ថាន នោះអើយ ចូរអរសប្បាយឡើង ។

១២ ហើយបន្ទាប់ពីការណ៍ទាំងនេះ នោះខ្ញុំបានឮសម្លេងមួយទៀតថា វេទនាដល់បណ្ដាជនដែលនៅលើផែនដី មែនហើយ និងដល់ពួកអ្នក ដែលនៅលើកោះទាំងឡាយក្នុងសមុទ្រផង! ពីព្រោះអារក្សបានចុះមក ឯអ្នករាល់គ្នា ដោយមានសេចក្ដីឃោរឃៅ ជាខ្លាំង ដោយវាដឹងថា វាមានតែពេលវេលាដ៏ខ្លីប៉ុណ្ណោះ ។

១៣ ត្បិតកាលនាគឃើញថា វាត្រូវបោះទំលាក់ទៅផែនដីហើយ នោះវាក៏ធ្វើទុក្ខដល់ស្ត្រីដែលសំរាលកូនប្រុសនោះ ។

១៤ ដូច្នេះហើយ ស្ត្រីនោះត្រូវបានប្រទានឲ្យមានស្លាបពីរ ដូចជា ស្លាបនៃសត្វឥន្ទ្រីដ៏ធំ ដើម្បីឲ្យនាងបានហើរទៅនៅកន្លែងរបស់នាង នៅទីរហោស្ថាន ជាកន្លែងដែលនាងនឹងត្រូវបានចិញ្ចឹមអស់មួយខួប ពីរខួប ហើយកន្លះខួបផង ឲ្យឃ្លាតពីមុខសត្វនាគនោះចេញ ។

១៥ រួចពស់វាព្រួសទឹកចេញពីមាត់វាដូចជាទន្លេ ឲ្យហូរ ទៅតាមស្ត្រីនោះ ដើម្បីនឹងបន្សាត់នាងឲ្យបាត់តាមទន្លេនោះទៅ ។

១៦ ហើយផែនដីបានជួយស្ត្រីនោះ ហើយផែនដីបានហារមាត់ ហើយលេបទឹក ដែលនាគព្រួសចេញពីមាត់វាទៅបាត់ ។

១៧ ដូច្នេះហើយ នាគក៏ខឹងនឹងស្ត្រីនោះ ហើយចេញទៅធ្វើសង្គ្រាម នឹងសំណល់ពូជនាងទាំងប៉ុន្មាន ជាពួកអ្នកដែលកាន់តាមព្រះ បញ្ញត្តិទាំង ឡាយនៃព្រះ ហើយដែលមានសេចក្ដីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ។

**ក.យ.ស., វិវរណៈ ១៩:១៥, ២១** (ចូរប្រៀបធៀបនឹងគម្ពីរវិវរណៈ ១៩:១៥, ២១)

*(ព្រះទ្រង់ប្រើព្រះបន្ទូលនៃព្រះគ្រីស្ទ ដើម្បីវាយសាសន៍ទាំងឡាយ)* ។

១៥ ហើយចេញពីព្រះឱស្ឋទ្រង់ គឺជាព្រះបន្ទូលនៃព្រះ ហើយដោយ ព្រះបន្ទូលនោះ ទ្រង់នឹងវាយសាសន៍ទាំងឡាយ ហើយទ្រង់នឹង ត្រួត ត្រាលើពួកគេ ដោយព្រះបន្ទូលចេញពីព្រះឱស្ឋទ្រង់ ហើយទ្រង់ក៏ជាន់ក្នុង ធុងឃ្នាបនៃស្រាទំពាំងបាយជូរ ក្នុងសេចក្ដីឃោរឃៅ និងសេចក្ដី ខ្ញាល់នៃព្រះដ៏មហិទ្ធិឫទ្ធិ ។

២១ ហើយពួកដែលនៅសល់ ក៏ត្រូវប្រហារបង់ ដោយព្រះបន្ទូល របស់ព្រះអង្គ ដែលគង់លើសេះ ជាព្រះបន្ទូលដែលចេញពីព្រះឱស្ឋ ទ្រង់ មក នោះអស់ទាំងសត្វស្លាបបានឆ្អែត ដោយសាច់នៃពួកទាំងនោះ ។

# ប្រវត្តិសាសនាចក្រតាមលំដាប់ពេលកើតឡើង, ផែនទី, និងរូបថតទាំងឡាយ

**ឆ្នាំ ១៨០៥ ខែធ្នូ ថ្ងៃទី ២៣**

យ៉ូសែប ស្ម៊ីធ (១៨០៥–៤៤) បានកើតពីយ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ និងនាងលូស៊ី ម៉ាក់ស្ម៊ីធ នៅភូមិសារ៉ុន រដ្ឋវើរម៉ង់ (សូមមើល យ.ស. — ប្រវត្តិ ១:៣) ។

**ឆ្នាំ ១៨២០ ដើមនិទាឃរដូវ**

ព្យាការីយ៉ូសែប ស្ម៊ីធបានឃើញការនិមិត្តទីមួយ នៅក្នុងព្រៃឈើមួយ នៅភូមិប៉ាលម៉ៃរ៉ា និងភូមិម៉ានឆែសស្ទើរ រដ្ឋនូវយ៉ោក នៅក្បែរផ្ទះ លោក (សូមមើល យ.ស. — ប្រវត្តិ ១:១៥–១៧) ។

**ឆ្នាំ ១៨២៣ ខែកញ្ញា ថ្ងៃទី ២១–២២**

យ៉ូសែប ស្ម៊ីធត្រូវបានទេវតាម៉រ៉ូណៃមកជួប ហើយត្រូវបានប្រាប់ពីបញ្ជីនៃព្រះគម្ពីរមរមន ។ យ៉ូសែបបានឃើញផ្ទាំងមាសទាំងឡាយ ដែលបានកប់ទុក នៅក្បែរភ្នំមួយ (ភ្នំគូម៉ូរ៉ា) (សូមមើល យ.ស. — ប្រវត្តិ ១:២៧–៥៤)។

**ឆ្នាំ ១៨២៧ ខែកញ្ញា ថ្ងៃទី ២២**

យ៉ូសែប ស្ម៊ីធបានផ្ទាំងមាសទាំងឡាយពីម៉រ៉ូណៃ នៅភ្នំគូម៉ូរ៉ា (សូមមើល យ.ស. — ប្រវត្តិ ១:៥៩) ។

**ឆ្នាំ ១៨២៩ ខែឧសភា ថ្ងៃទី ១៥**

យ៉ូហាន-បាទីស្ទបានប្រគល់បព្វជិតភាពអើរ៉ុនដល់យ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី នៅភូមិហារម៉ូនី រដ្ឋផែនសិលវេញ៉ា (សូមមើល គ. និង ស. ១៣; យ.ស. — ប្រវត្តិ ១:៧១–៧២) ។

**ឆ្នាំ ១៨២៩ ខែឧសភា**

យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរីបានទទួលបព្វជិតភាពមិលគីស្សាដែក ពីពេត្រុស យ៉ាកុប និងយ៉ូហាន នៅក្បែរទន្លេសុសគ្វីហាណា រវាងភូមិហារម៉ូនី រដ្ឋផែនសិលវេញ៉ា នឹងភូមិខូលស្វិល រដ្ឋនូវយ៉ោក (សូមមើល គ. និង ស. ១២៨:២០) ។

**ឆ្នាំ ១៨២៩ ខែមិថុនា**

ការបកប្រែព្រះគម្ពីរមរមនត្រូវបានសំរេច ។ ពួកសាក្សីបីនាក់ និងពួកសាក្សីប្រាំបីនាក់ត្រូវបានបង្ហាញឲ្យឃើញផ្ទាំងមាស (សូមមើល ២ នីហ្វៃ ១១:៣; ២៧:១២–១៣; គ. និង ស. ១៧) ។

**ឆ្នាំ ១៨៣០ ខែមីនា ថ្ងៃទី ២៦**

មានព្រះគម្ពីរមរមនដែលបានបោះពុម្ពលើកទីមួយ នៅភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក

**ឆ្នាំ ១៨៣០ ខែមេសា ថ្ងៃទី ៦**

សាសនាចក្រត្រូវបានរៀបចំឡើង នៅភូមិហ្វាយែត្ត រដ្ឋនូវយ៉ោក ។

**ឆ្នាំ ១៨៣០ ខែកញ្ញា-តុលា**

ពួកសាសនទូតមុនដំបូងត្រូវបានហៅឲ្យទៅផ្សាយសាសនាដល់ពួកសាសន៍លេមិន (ពួកអាមេរិកាំងដើម) (សូមមើល គ. និង ស. ២៨; ៣០; ៣២) ។

**ឆ្នាំ ១៨៣០ ខែធ្នូ-មករា ឆ្នាំ ១៨៣១**

ពួកបរិសុទ្ធត្រូវបានបញ្ជាឲ្យទៅជួបជុំគ្នានៅរដ្ឋអូហៃអូ (សូមមើល គ. និង ស. ៣៧; ៣៨:៣១–៣២) ។

**ឆ្នាំ ១៨៣១ ខែកក្កដា ថ្ងៃទី ២០**

កន្លែងសំរាប់ទីក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិមថ្មី) នៅក្រុងអិនឌីប៉ែនដែន្ស រដ្ឋមិសសួរី ត្រូវបានបើកសម្ដែងប្រាប់ដល់ព្យាការីយ៉ូសែប ស្ម៊ីធ (សូមមើល គ. និង ស. ៥៧; ម. នៃ ស. ១:១០) ។

**ឆ្នាំ ១៨៣៣ ខែមីនា ថ្ងៃទី ១៨**

ស៊ីឌនី រិកដុន និងហ្វ្រេឌើរិក ជី វិលលាម្ស ត្រូវបានញែកចេញជាទីប្រឹក្សា នៅក្នុងគណៈ ប្រធាននៃសាសនាចក្រ (សូមមើល គ. និង ស. ៨១ ចំណងជើង) ហើយត្រូវបានប្រគល់នូវកូនសោទាំងឡាយនៃនគរចុងក្រោយបង្អស់នេះ (សូមមើល គ. និង ស. ៩០ ចំណងជើង; ខទី៦0 ។

**ឆ្នាំ ១៨៣៣ ខែវិច្ឆិកា ថ្ងៃទី ៧**

ពួកបរិសុទ្ធបានចាប់ផ្ដើមភៀសខ្លួនចេញពីហ្វូងមនុស្សកំណាច នៅឃុំចាកសុន រដ្ឋមិសសួរី រត់ឆ្លងកាត់ទន្លេមិសសួរី ហើយចូលទៅឃុំឃ្លេ ។

**ឆ្នាំ ១៨៣៤ ខែឧសភា ថ្ងៃទី ៥**

ប្រធានយ៉ូសែប ស្ម៊ីធបានចេញពីក្រុងខឺតឡង់ រដ្ឋអូហៃអូ សំដៅតាមរដ្ឋមិសសួរី ធ្វើជាអ្នកដឹកនាំជុំរុំស៊ីយ៉ូន ដើម្បីទៅរំដោះពួកបរិសុទ្ធដែលត្រូវគេចចេញពីឃុំចាកសុន ។

**ឆ្នាំ ១៨៣៥ ខែកុម្ភៈ ថ្ងៃទី ១៤**

ក្រុមពួកសាវក ១២ នាក់ ត្រូវបានរៀបចំឡើងនៅក្រុងខឺតឡង់ រដ្ឋអូហៃអូ (សូមមើល គ. និង ស. ១០៧:២៣–២៤) ។

**ឆ្នាំ ១៨៣៥ ខែកុម្ភៈ ថ្ងៃទី ២៨**

ការរៀបចំក្រុមទីមួយនៃពួក ៧០ នាក់ ត្រូវបានចាប់ផ្ដើមឡើង នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ។

**ឆ្នាំ ១៨៣៥ ខែសីហា ថ្ងៃទី ១៧**

គោលលទ្ធិ និងសេចក្ដីសញ្ញាត្រូវបានទទួលស្គាល់ថាជាគម្ពីរបមាណីយនៃសាសនាចក្រនៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ។

**ឆ្នាំ ១៨៣៦ ខែមីនា ថ្ងៃទី ២៧**

ព្រះវិហារខឺតឡង់ត្រូវបានធ្វើពិធីឆ្លង (សមមើល គ. និង ស. ១០៩) ។

**ឆ្នាំ ១៨៣៦ ខែមេសា ថ្ងៃទី ៣**

ព្រះយេស៊ូវគ្រីស្ទបានលេចមកឯយ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី នៅក្នុងព្រះវិហារខឺតឡង់ ។ លោកម៉ូសេ លោកអេលីយ៉ាស និងលោកអេលីយ៉ាបានលេចមក ហើយបានប្រគល់កូនសោទាំងឡាយនៃបព្វជិតភាព (សូមមើល គ. និង ស. ១១០) ។

**ឆ្នាំ ១៨៣៧ ខែកក្កដា ថ្ងៃទី ១៩**

ហ៊ីប៊ើរ ស៊ី គិមបុល និងជនប្រាំមួយនាក់ទៀតបានទៅដល់ក្រុងលីវើរភូល ប្រទេសអង់គ្លេស ធ្វើបេសកកម្មឆ្លងសមុទ្រលើកមុនដំបូងនៃសាសនាចក្រ ។

**ឆ្នាំ ១៨៣៨ ខែមេសា ថ្ងៃទី ២៦**

ឈ្មោះនៃសាសនាចក្រត្រូវបានបញ្ជាក់ប្រាប់តាមរយៈវិវរណៈ (សូមមើល គ. និង ស. ១១៥:៤) ។

**ឆ្នាំ ១៨៣៨ ខែធ្នូ ថ្ងៃទី ១**

ព្យាការីយ៉ូសែប ស្ម៊ីធ និងពួកអ្នកផ្សេងទៀតត្រូវគេដាក់គុក នៅក្នុងគុកលីប៊ើទី ក្រុងលីប៊ើទី ឃុំឃ្លេ រដ្ឋមិសសួរី (សូមមើល គ. និង ស. ១២១–១២៣) ។

**ឆ្នាំ ១៨៤០ ខែសីហា ថ្ងៃទី ១៥**

បុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ត្រូវបានប្រកាសប្រាប់ទូទៅ ដោយព្យាការីយ៉ូសែប ស្ម៊ីធ ។

**ឆ្នាំ ១៨៤១ ខែតុលា ថ្ងៃទី ២៤**
អែលឌើរ អ៊ួសុន ហៃឌ បានធ្វើពិធីឆ្លងដែនដីបរិសុទ្ធ សំរាប់ការវិលមកវិញនៃកូនចៅរបស់លោកអ័ប្រាហាំ (សូមមើល គ. និង ស. ៦៨:១–៣; ១២៤:១២៨–១២៩) ។

**ឆ្នាំ ១៨៤២ ខែមីនា ថ្ងៃទី ១៧**
សមាគមសង្គ្រោះសំរាប់ពួកស្ត្រីត្រូវបានរៀបចំឡើង នៅក្រុងណៅវូ រដ្ឋអិលលីណោយ ។

**ឆ្នាំ ១៨៤២ ខែឧសភា ថ្ងៃទី ៤**
អំណោយទានពិសិដ្ឋលើកទីមួយនៃព្រះវិហារត្រូវបានប្រទានឲ្យ ។

**ឆ្នាំ ១៨៤៤ ខែមិថុនា ថ្ងៃទី ២៧**
យ៉ូសែប ស្ម៊ីធ និងហៃរុម ស្ម៊ីធ ត្រូវគេធ្វើទុក្ករកម្មនៅក្នុងគុកកាតធេច (សូមមើល គ. និង ស. ១៣៥) ។

**ឆ្នាំ ១៨៤៦ ខែកុម្ភៈ ថ្ងៃទី ៤**
ពួកបរិសុទ្ធពីក្រុងណៅវូបានចាប់ផ្ដើមឆ្លងកាត់ទន្លេមិស៊ីស៊ីបពី ដើម្បីផ្លាស់ទៅនៅភូមិភាគខាងលិច ។ ពួកបរិសុទ្ធខ្លះពីភូមិភាគខាងកើតបាន ជិះសំពៅព្រុគ្លិន ពីរដ្ឋនូវយ៉ោកទៅរដ្ឋកាលីហ្វ័រញ៉ា ។

**ឆ្នាំ ១៨៤៦ ខែកក្កដា ថ្ងៃទី ១៦**
កងវរសេនាតូចមរមនត្រូវបានប្រមូលចូលធ្វើទាហាននៃសហរដ្ឋ នៅរដ្ឋអៃអូវ៉ា ។

**ឆ្នាំ ១៨៤៧ ខែមេសា**
ក្រុមត្រួសត្រាយរបស់ប្រធានព្រិកហាំ យ៉ង់បានចេញពី វិនទើរ ខ្វទើរ ធ្វើដំណើរទៅភូមិភាគខាងលិច (សូមមើល គ. និង ស. ១៣៦) ។

**ឆ្នាំ ១៨៤៧ ខែកក្កដា ថ្ងៃទី ២៤**
ប្រធានព្រិកហាំ យ៉ង់ បានចូលក្នុងច្រកភ្នំសលត៍លេក ។

**ឆ្នាំ ១៨៤៧ ខែធ្នូ ថ្ងៃទី ២៧**
នៅសន្និសីទរបស់សាសនចក្រ គេបានគាំទ្រប្រធានព្រិកហាំ យ៉ង់, អែលឌើរហ៊ីប៊ើរ ស៊ី គិមបុល, និងអែលឌើរវិលឡឺឌ រិចិត្ស ឲ្យធ្វើជាគណៈប្រ ធានទីមួយ ។

**ឆ្នាំ ១៨៤៨ ខែឧសភា–មិថុនា**
សត្វកណ្ដូបនៅច្រកភ្នំសលត៍លេកបានធ្វើឲ្យដំណាំខូចខាតអស់រលីង ។ ស្រែចំការត្រូវរួចផុតពីការបំផ្លិចបំផ្លាញ ដោយសារសត្វកុកស៊ីសត្វ កណ្ដូប ។

**ឆ្នាំ ១៨៤៩ ខែធ្នូ ថ្ងៃទី ៩**
សាលាថ្ងៃអាទិត្យត្រូវបានរៀបចំឡើង ដោយរិចឹត បាឡានតាញ ។

**ឆ្នាំ ១៨៥០ ខែមិថុនា ថ្ងៃទី ១៥**
*Deseret News* បានចាប់ផ្ដើមបោះពុម្ពនៅទីក្រុងសលត៍លេក ។

**ឆ្នាំ ១៨៥៦ ខែតុលា**
ក្រុមរទេះអូសរបស់វិលលី និងម៉ាទិន ត្រូវជាប់ព្យុះទឹកកកដើមឆ្នាំ ។ ត្រូវបានរកឃើញដោយក្រុមសង្គ្រោះពីច្រកភ្នំសលត៍លេក ។

**ឆ្នាំ ១៨៦៧ ខែធ្នូ ថ្ងៃទី ៨**
សមាគមសង្គ្រោះត្រូវបានរៀបចំឡើងវិញនៅក្រោមការដឹកនាំនៃប្រធានព្រិកហាំ យ៉ង់ ។

**ឆ្នាំ ១៨៦៩ ខែវិច្ឆិកា ថ្ងៃទី ២៨**
សមាគមនៃយុវនារីខាងការបន្ថយបន្ទុះត្រូវបានរៀបចំឡើង ដែលជាសមាគមមុនដំបូងនៃកម្មវិធីយុវនារី ។

**ឆ្នាំ ១៨៧៥ ខែមិថុនា ថ្ងៃទី ១០**
សមាគមនៃយុវជនខាងការចំរើនអញ្ញមញ្ញត្រូវបានរៀបចំឡើង ដែលជាសមាគមមុនដំបូងនៃកម្មវិធីយុវជន ។

**ឆ្នាំ ១៨៧៧ ខែមេសា ថ្ងៃទី ៦**
ព្រះវិហារសេនជ៍ចត្រូវបានធ្វើពិធីឆ្លង ។ ប្រធានព្រិកហាំ យ៉ង់បានទទួលវិវរណៈ ដើម្បីរៀបចំបព្វជិតភាព និងស្តេកទាំងឡាយនៃក្រុងស៊ីយ៉ូន ឲ្យមានរបៀបរៀបរយ ។

**ឆ្នាំ ១៨៧៨ ខែសីហា ថ្ងៃទី ២៥**
អូរេលា ស្ពែនសើរ រ៉ជើរ្ស បានធ្វើការប្រជុំបឋមសិក្សាមុនដំបូងបង្អស់ នៅភូមិហាមីងតោន រដ្ឋយូថាហ៍ ។

**ឆ្នាំ ១៨៨០ ខែតុលា ថ្ងៃទី ១០**
យ៉ូហាន ថេល័រ ត្រូវបានគាំទ្រឲ្យធ្វើជាប្រធាននៃសាសនចក្រ ។ មុក្ដាដ៏មានតម្លៃមហិមាត្រូវបានទទួលស្គាល់ជាគម្ពីរបមាណិយ ។

**ឆ្នាំ ១៨៨៣ ខែមេសា ថ្ងៃទី ១៤**
វិវរណៈដល់ប្រធានយ៉ូហាន ថេល័រ អំពីការរៀបចំពួក ៧០ នាក់ ។

**ឆ្នាំ ១៨៨៩ ខែមេសា ថ្ងៃទី ៧**
វិលហ្វូឌ វូឌរ្រុហ្វ ត្រូវបានគាំទ្រឲ្យធ្វើជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៨៩០ ខែតុលា ថ្ងៃទី ៦**
«សេចក្ដីប្រកាស» ត្រូវបានគាំទ្រទទួលស្គាល់នៅឯសន្និសីទទូទៅ ដោយប្រកាសប្រាប់អំពីការបញ្ចប់នូវការប្រព្រឹត្តខាងអាពាហ៍ពិពាហ៍យក ប្រពន្ធច្រើន (សូមមើល សេចក្ដីប្រកាស — ១) ។

**ឆ្នាំ ១៨៩៣ ខែមេសា ថ្ងៃទី ៦**
ប្រធានវិលហ្វូឌ វូឌរ្រុហ្វ បានធ្វើពិធីឆ្លងព្រះវិហារសលត៍លេក ដែលបានធ្វើអស់រយៈពេល ៤០ ឆ្នាំ ។

**ឆ្នាំ ១៨៩៨ ខែកញ្ញា ថ្ងៃទី ១៣**
ឡូរិនសូ ស្នូវ បានក្លាយទៅជាប្រធាននៃសាសនចក្រ ។

**ឆ្នាំ ១៨៩៩ ខែឧសភា ថ្ងៃទី ១៧**
ប្រធានឡូរិនសូ ស្នូវ បានទទួលវិវរណៈនៅក្រុងសត្ត ជ្ជច ដែលដាស់តឿនឲ្យលោកបញ្ជាក់ប្រាប់ពីដង្វាយ១ភាគ១០ (សូមមើល គ. និង ស. ១១៩) ។

**ឆ្នាំ ១៩០១ ខែតុលា ថ្ងៃទី ១៧**
យ៉ូសែប អែហ្វ ស្ម៊ីធ បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩១៨ ខែតុលា ថ្ងៃទី ៣**
ប្រធានយ៉ូសែប អែហ្វ ស្ម៊ីធ បានទទួលការនិមិត្តមួយ អំពីសេចក្ដីប្រោសលោះនៃមនុស្សស្លាប់ (សូមមើល គ. និង ស. ១៣៨) ។

**ឆ្នាំ ១៩១៨ ខែវិច្ឆិកា ថ្ងៃទី ២៣**
ហ៊ីប៊ើរ ជេ ក្រាន្ត បានក្លាយទៅជាប្រធាននៃសាសនចក្រ ។

**ឆ្នាំ ១៩៣៦ ខែមេសា**
កម្មវិធីខាងសន្តិសុខនៃសាសនាចក្រត្រូវបានតាំងឡើង ដើម្បីជួយមនុស្សទាល់ក្រ នៅគ្រាសេដ្ឋកិច្ចធ្លាក់ចុះដុនដាបដ៏មហិមា; កម្មវិធីនេះបាន ក្លាយទៅជាកម្មវិធីសង្គ្រោះនៃសាសនាចក្រ ។ កម្មវិធីនេះបានកើតឡើងពីវិវរណៈមួយដែលបានទទួលដោយប្រធានហ៊ីប៊ើរ ជី ក្រាន្តមកហើយ ។

**ឆ្នាំ ១៩៤១ ខែមេសា ថ្ងៃទី ៦**

ពួកអ្នកជំនួយដល់ពួក ១២ នាក់ ត្រូវបានហៅ ។

**ឆ្នាំ ១៩៤៥ ខែឧសភា ថ្ងៃទី ២១**

ជួច អាលបឺត ស្ម៊ីធ បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៥១ ខែមេសា ថ្ងៃទី ៩**

ដាវីឌ អូ ម៉ុកខេ ត្រូវបានគាំទ្រឲ្យធ្វើជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៦១ ខែកញ្ញា ថ្ងៃទី ៣០**

អែលឌើរ ហារ៉ូល ប៊ី លី នៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយ បានប្រកាសប្រាប់ថា កម្មវិធីទាំងអស់នៃសាសនាចក្រត្រូវធ្វើឲ្យទាក់ទង នឹងគ្នា តាមរយៈបព្វជិតភាព ដើម្បីចំរើនកម្លាំងដល់គ្រួសារ និងដល់បុគ្គលម្នាក់ៗ ។

**ឆ្នាំ ១៩៦៤ ខែតុលា**

ការប្រព្រឹត្តនូវរាត្រីគ្រួសារត្រូវបានបញ្ជាក់ឡើងវិញ។

**ឆ្នាំ ១៩៧០ ខែមករា ថ្ងៃទី២៣**

យ៉ូសែប ហ្វៀលឌីង ស្ម៊ីធ បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៧១ ខែមករា**

ទស្សនាវដ្ដីថ្មីនៃសាសនាចក្រ — *Ensign, New Era,* និង *Friends* — បានចាប់ផ្ដើមបោះពុម្ពផ្សាយ ។

**ឆ្នាំ ១៩៧២ ខែកក្កដា ថ្ងៃទី ៧**

ហារ៉ូល ប៊ី លី បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៧៣ ខែធ្នូ ថ្ងៃទី ៣០**

ស្ពែនស៊ើរ ដបុលយូ គិមបុល បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៧៥ ខែតុលា ថ្ងៃទី ៣**

ប្រធានស្ពែនស៊ើរ ដបុលយូ គិលបុល បានប្រកាសប្រាប់ពីការរៀបចំឡើងវិញនូវក្រុមទីមួយនៃពួក ៧០ នាក់ ។

**ឆ្នាំ ១៩៧៦ ខែមេសា ថ្ងៃទី ៣**

មាននិវរណៈពីរដែលបានបញ្ចូលក្នុង មុក្ដាដ៏មានតម្លៃមហិមា ។ នៅឆ្នាំ ១៩៨១ វិវរណៈទាំងនោះត្រូវបានដកចេញ ហើយក្លាយទៅជា គ. និង ស. ទី ១៣៧ និង ១៣៨ ។

**ឆ្នាំ ១៩៧៨ ខែកញ្ញា ថ្ងៃទី ៣០**

វិវរណៈត្រូវបានគាំទ្រដោយសាសនាចក្រ អនុម័តឲ្យសមាជិកប្រុសៗដែលសក្ដិសមគ្រប់រូបអាចកាន់បព្វជិតភាព ដោយមិនគិតដល់សញ្ជាតិ ឬសម្បុរឡើយ (សូមមើល សេចក្ដីប្រកាស— ១) ។

**ឆ្នាំ ១៩៧៩ ខែសីហា**

ព្រះគម្ពីរប៊ីបច្បាប់ស្ដេចយ៉េម្សនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលមានជំនួយខាងការសិក្សានោះបានបោះពុម្ពផ្សាយ ។

**ឆ្នាំ ១៩៨១ ខែកញ្ញា**

ច្បាប់ថ្មីនៃ ព្រះគម្ពីរមរមន, គោលលទ្ធិ និងសេចក្ដីសញ្ញា, មុក្ដាដ៏មានតម្លៃមហិមា ត្រូវបានបោះពុម្ពផ្សាយចេញជាភាសាអង់គ្លេស ។

**ឆ្នាំ ១៩៨៤ ខែមិថុនា**

ពួកប្រធានប្រចាំតំបន់ត្រូវបានតែងតាំងឡើងដោយបានហៅសមាជិកពីពួក ៧០ នាក់ ។

**ឆ្នាំ ១៩៨៥ ខែវិច្ឆិកា ថ្ងៃទី ១០**

អែសរ៉ា តាហ្វ បិនសុន បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៨៩ ខែមេសា ថ្ងៃទី ១**

ក្រុមទីពីរ នៃក្រុម ៧០ នាក់ត្រូវបានរៀបចំឡើងវិញ ។

**ឆ្នាំ ១៩៩៤ ខែមិថុនា ថ្ងៃទី ៥**

ហាវើឌ ដបុលយូ ហ័នទើរ បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៩៥ ខែមីនា ថ្ងៃទី ១២**

គួរដុន ប៊ី ហ៊ីងគ្លី បានក្លាយទៅជាប្រធាននៃសាសនាចក្រ ។

**ឆ្នាំ ១៩៩៥ ខែមេសា ថ្ងៃទី ១**

តំណែងនៃពួកតំណាងប្រចាំតំបន់លែងមានតទៅទៀត។ ការប្រកាសប្រាប់ពីតំណែងខាងការដឹកនាំថ្មី ឈ្មោះ អាជ្ញាធរប្រចាំ តំបន់ ។

**ឆ្នាំ ១៩៩៥ ខែកញ្ញា ថ្ងៃទី ២៣**

ក្រុមគ្រួសារៈ សេចក្ដីប្រកាសដល់ពិភពលោក ដោយគណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃក្រុមសាវក ១២ នាក់ ត្រូវបានបោះពុម្ពផ្សាយ ។

**ឆ្នាំ ១៩៩៧ ខែមេសា ថ្ងៃទី ៥**

អាជ្ញាធរប្រចាំតំបន់ត្រូវបានតែងតាំងឡើងជាក្រុម ៧០ នាក់ ។ ក្រុមទីបី ទីបួន ទីប្រាំ នៃក្រុម ៧០ នាក់ ត្រូវបានប្រកាសប្រាប់ ថានឹងមាន ។

**ឆ្នាំ ១៩៩៧ ខែតុលា ថ្ងៃទី ៤**

ប្រធានហ៊ីងគ្លី បានប្រកាសប្រាប់ពីការស្ថាបនាព្រះវិហារតូចៗ ។

**ឆ្នាំ ១៩៩៧ ខែវិច្ឆិកា**

សមាជិកនៃសាសនាចក្រមានចំនួនដល់ ១០ លាននាក់ ។

**ឆ្នាំ ១៩៩៨ ខែមេសា**

ប្រធានហ៊ីងគ្លីបានប្រកាសប្រាប់ពីគោលបំណងចង់បើកព្រះវិហារ ១០០ ខ្នង នៅឆ្នាំ ២០០០ ។

រូបថតនៃទីកន្លែងសំខាន់ៗអំពីប្រវត្តិសាសនាចក្រទាំងនេះ ពណ៌នាប្រាប់ពីដែនដីទាំងឡាយ ដែលពួកបរិសុទ្ធថ្ងៃចុងក្រោយពីដើមដំបូងបានដើរលើ, កន្លែងដែលពួកព្យាការីទំនើបបានរស់នៅ ហើយបានបង្រៀន, និងកន្លែងដែលមានព្រឹត្តិការណ៍ខាងបទគម្ពីរជាច្រើនបានកើតឡើង ។ ដើម្បីជួយអ្នកប្រើប្រាស់រូបថតទាំងឡាយឲ្យកាន់តែប្រសើរឡើង ក្នុងការសិក្សារបស់អ្នក នោះរូបថតនីមួយៗមានពាក្យពណ៌នាប្រាប់ដ៏ខ្លីៗ ។ លេខប្រាប់អំពីពាក្យពណ៌នា និងចំណងជើងនោះត្រូវគ្នានឹងរូបថត ដោយមានលេខ និងចំណងជើងដូចគ្នា ។ ឃ្លាទីមួយបន្ទាប់ពីចំណង ជើងនៃពាក្យពណ៌នានោះពន្យល់ប្រាប់ពីបរិយាកាសនៃរូបថត ព្រមទាំងការសំខាន់ៗដើម្បីរកមើល ហើយតែងតែប្រាប់ថារូបថតនោះបែរ ទៅទិសខាងណាផង ។ រួចហើយ ព្រឹត្តិការណ៍សំខាន់ៗខាងបទគម្ពីរក៏បានរាយប្រាប់ ព្រមទាំងមានសេចក្ដីយោងទាំងឡាយខាងបទគម្ពីរ ដែលអ្នកអាចបើកមើលថែមទៀត អំពីព្រឹត្តិការណ៍ទាំងនោះ ។

**១. ព្រៃពិសិដ្ឋ**

ព្រៃពិសិដ្ឋនៅភូមិប៉ាលម៉ៃរ៉ា និងម៉ានឆែសស្ទើរ រដ្ឋនូវយ៉ោក ។ ព្រៃឈើនេះនៅទិសខាងលិចផ្ទះឈើតូចរបស់គ្រួសារស្ម៊ីធ នៅឆ្នាំ ១៨២០ ។

*ព្រឹត្តិការណ៍សំខាន់ ៖* ការលេចមកនៃព្រះដ៏ជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ដល់ព្យាការីយ៉ូសែប ស្ម៊ីធ បានកើតឡើងនៅក្នុងព្រៃនេះ (យ. ស. — ប្រវត្តិ ១:១៤–២០) ។

**២. ភ្នំគូម៉ូរ៉ា និងតំបន់ម៉ានឆែសស្ទើរ-ប៉ាលម៉ៃរ៉ា**

មើលទៅខាងជើង រូបថតនេះបង្ហាញភ្នំគូម៉ូរ៉ា នៅភូមិម៉ានឆែសស្ទើរ រដ្ឋនូវយ៉ោក ។ ភ្នំនោះឃើញនៅជ្រុងក្រោមដៃខាងស្ដាំរូបថត ហើយសន្ធឹងទៅហួសជាងពាក់កណ្ដាលរូបថត ។ វិមានពណ៌សឃើញនៅលើកំពូលភ្នំជ្រុងខាងជើង គឺជារូបទេវតាមរ៉ូណៃ និងការចេញ មកនៃព្រះគម្ពីរមរមន ។ ភ្នំគូម៉ូរ៉ាមានចម្ងាយប្រាំគីឡូម៉ែត្រនៅទិសខាងកើតជ្រុងខាងជើងនៃព្រៃពិសិដ្ឋ ។ នៅជិតខាងលើរូបថត គឺជាភូមិ ប៉ាលម៉ៃរ៉ាមានចម្ងាយប្រាំមួយគីឡូម៉ែត្រកន្លះ ។ ស្រែរបស់គ្រួសារស្ម៊ីធ និងព្រៃពិសិដ្ឋនៅជ្រុងលើខាងឆ្វេងរូបថត ។

ព្រឹត្តិការណ៍សំខាន់ៗ ៖ គ្រួសាររបស់ព្យាការីយ៉ូសែប ស្ម៊ីធបានរស់នៅក្នុងតំបន់នេះ កាលបានទទួលការនិមិត្តទីមួយ (យ.ស. — ប្រវត្តិ ១:៣) ។ នៅឆ្នាំ ៤២១ គ.ស. មរ៉ូណៃបានកប់ផ្ទាំងមាសនៅលើភ្នំគូម៉ូរ៉ា ដែលមានពីប្រវត្តិដ៏ពិសិដ្ឋអំពីប្រជាជនរបស់លោក (ព. នៃ ម. ១:១–១១; មរមន ៦:៦; មរ៉ូណៃ ១០:១–២) ។ មរ៉ូណៃដដែលនេះបានប្រាប់យ៉ូសែប ស្ម៊ីធពីកន្លែងដើម្បីទៅរកផ្ទាំងទាំងឡាយ — គឺទៅទិសខាងជើងកំពូលភ្នំ នៅខាងលិច ជិតកំពូល ។ មរ៉ូណៃបានប្រគល់ផ្ទាំងទាំងនោះដល់លោក នៅឆ្នាំ ១៨២៧ (គ. និង ស. ២៧:៥;យ.ស. — ប្រវត្តិ ១:៣៣, ៥១៥៤, ៥៩)។

**៣. ផ្ទះឈើរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉ែរ**

ជាផ្ទះធ្វើដូចផ្ទះរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉ែរ គឺបានសង់នៅកន្លែងផ្ទះឈើដើម នៅជិតភូមិប៉ាលម៉ៃរ៉ា រដ្ឋនូវយ៉ោក ។ គ្រួសារស្ម៊ីធបានកាត់ ឈើសង់ផ្ទះមួយជាន់កន្លះ មិនយូរប៉ុន្មានបន្ទាប់ពីគេបានមកដល់ភូមិប៉ាលម៉ៃរ៉ា ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ព្យាការីយ៉ូសែប ស្ម៊ីធ បានសិក្សាព្រះគម្ពីប៊ីបនៅក្នុងផ្ទះនេះ កាលលោកបានខិតខំចង់ដឹងថា សាសនាចក្រមួយណា ត្រូវ (យ.ស. — ប្រវត្តិ ១:១១–១៣) ។ មរ៉ូណៃបានលេចមកឯយ៉ូសែប ហើយបានប្រាប់លោកពីផ្ទាំងទាំងឡាយនៃព្រះគម្ពីរមរមន (យ.ស. — ប្រវត្តិ ១:១–៤៧)

**៤. គ្រានឌិនក្រុមហ៊ុនបោះពុម្ព និងរោងពុម្ព**

រោងពុម្ពដែលបានធ្វើឡើងវិញតាមប្រវត្តិនៃអាគាររបស់ អែកបឺត ប៊ី គ្រានឌិន គឺជាកន្លែងដែលបានបោះពុម្ពផ្សាយព្រះគម្ពីរមរមនច្បាប់ទីមួយ នៅឆ្នាំ ១៨៣០ ។ ម៉ាទិន ហារិសបានយកស្រែទៅកក់ ហើយលក់ភាគខ្លះ ដើម្បីបង់ថ្លៃបោះពុម្ពព្រះគម្ពីរមរមន ៥ ពាន់ក្បាល ។ ចាប់ ផ្ដើមបោះពុម្ពនៅខែសីហា ឆ្នាំ ១៨២៩ ហើយបានរួចនៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ ១៩៣០ ។

*ព្រឹត្តិការណ៍សំខាន់ ៖* ម៉ាទិន ហារិស ត្រូវបានបញ្ជាឲ្យរំលែកទ្រព្យសម្បត្តិរបស់គាត់ដោយចិត្តចេតនា ដើម្បីបង់ថ្លៃបោះពុម្ពព្រះគម្ពីរមរមន (គ. និង ស. ១៩:២៦–៣៥) ។

**៥. កទន្លេសុសគ្វីហាណា**

រូបថតនេះបង្ហាញទន្លេសុសគ្វីហាណា នៅភូមិហារម៉ូនី រដ្ឋផែនសិលវេញ៉ា ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* យ៉ូសែប ស្ម៊ីធ កាលមុនដំបូងបានមកឯភូមិហារម៉ូនី នៅឆ្នាំ ១៨២៥ ដើម្បីរកការធ្វើ ។ លោក និងឪពុកលោក បានស្នាក់នៅជិតនេះ នៅឯផ្ទះរបស់អ៊ីសាច ហេល ជាកន្លែងដែលយ៉ូសែបបានជួបនាងអិមម៉ា ហេល ដែលនឹងទៅជាប្រពន្ធលោកពេល ខាងមុខ (យ.ស. — ប្រវត្តិ ១:៥៦–៥៧) ។ យ៉ូសែប និងនាងអិមម៉ាបានរៀបការនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ១៨២៧ ។ ព្យាការីបាន ទទួលផ្ទាំងមាសទាំងឡាយ នៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩២៧ នៅភូមិម៉ានឆែសស្ទើរ រដ្ឋនូវយ៉ោក ហើយមិនយូរប៉ុន្មានបន្ទាប់មក លោកបានផ្លាស់ទីលំនៅជាមួយនាងអិមម៉ា ទៅនៅភូមិហារម៉ូនី ជាកន្លែងដែលលោកបានចាប់ផ្ដើមបកប្រែផ្ទាំងទាំងឡាយ នៅក្នុងផ្ទះដ៏តូច របស់គេ នៅក្បែរទន្លេ ។ កាលកំពុងតែបកប្រែព្រះគម្ពីរមរមន យ៉ូសែប និងអូលីវើរ ខៅឌើរី ចង់ដឹងថែមទៀតអំពីបុណ្យជ្រមុជទឹក ហើយ បានដើរទៅឯទន្លេ ដើម្បីទៅអធិស្ឋានដល់ព្រះអម្ចាស់អំពីបុណ្យនោះ ។ តាមចម្លើយដល់ការអធិស្ឋាននេះ យ៉ូហាន-បាទីស្ទបានលេចមក នៅថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៨២៩ (យ.ស. — ប្រវត្តិ ១:៦៦; គ. និង ស. ១៣) ។ លោកបានប្រគល់បព្វជិតភាពអើរ៉ុនដល់យូសែប និងអូលីវើរ ។ ខណៈនោះ ពួកគេក៏ចុះទៅក្នុងទន្លេ ហើយបានធ្វើបុណ្យជ្រមុជទឹកឲ្យគ្នាទៅវិញទៅមក សំរាប់ការផ្ដាច់បាប ។ ខណៈនោះ យ៉ូសែប និងអូលីវើរ ត្រូវបានដឹកនាំដោយយ៉ូហាន-បាទីស្ទ ឲ្យតែងតាំងគ្នាទៅវិញទៅមក ចំពោះបព្វជិតភាពអើរ៉ុន ។ មិនយូរប៉ុន្មានក្រោយមក ពេត្រុស យ៉ាកុប និងយ៉ូហានបានលេចមកនៅលើច្រាំងទន្លេនេះ ហើយបានប្រគល់ដល់យ៉ូសែប

និង អូលីវើរ នូវបព្វជិតភាព មិលគីស្សាដែក (គ. និង ស. ២៧:១២–១៣; ១២៨:២០) ។

### ៦. ផ្ទះឈើរបស់ពេត្រុស វិតមើរ ស៊ីញ៉័រ

ផ្ទះឈើដែលបានសង់ឡើងវិញរបស់ពេត្រុស វិតមើរ ស៊ីញ៉័រ គឺបានសង់នៅលើកន្លែងដែលមានគ្រឹះផ្ទះដើម នៅភូមិហ្វាយែត្ត រដ្ឋនូវយ៉ោក ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* យ៉ូសែប ស្ម៊ីធ បានបង្ហើយការបកប្រែព្រះគម្ពីរមរមននៅទីនេះ នៅចុងខែមិថុនា ឆ្នាំ ១៨២៩ ។ នៅក្នុងព្រៃក្បែរ ផ្ទះនេះ ពួកសាក្សីបីនាក់បានឃើញទេវតាម៉ូរ៉ូណៃ ព្រមទាំងផ្ទាំងមាស ។ ឥឡូវនេះ សេចក្ដីបន្ទាល់របស់ពួកគេត្រូវបានបោះពុម្ពនៅគ្រប់ ច្បាប់នៃព្រះគម្ពីរមរមន ។ នៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ ប្រហែលជាមានមនុស្ស ៦០ នាក់ដែលបានជួបជុំគ្នានៅផ្ទះរបស់ពេត្រុស វិតមើរ ដើម្បីធ្វើសាក្សីអំពីការរៀបចំតាមផ្លូវការ នូវសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ ការប្រជុំ និងសន្និសីទលើកដំបូងៗនៃសាសនាចក្រ ដែលទើបបានរៀបចំឡើង ក៏បានធ្វើនៅទីនេះ ។ មានវិវរណៈ ២០ នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញា ដែលបានទទួលនៅឯផ្ទះរបស់ ពេត្រុស វិតមើរ ។

### ៧. ហាងរបស់នូវល ខេ វិតនី និងក្រុមហ៊ុន

ហាងនេះមានតួនាទីដ៏សំខាន់នៅក្នុងប្រវត្តិសាសនាចក្រ នៅក្រុងខឺតឡង់ ។ យ៉ូសែប និងនាងអិមម៉ា បានរស់នៅទីនេះអស់រយៈពេលមួយ ដ៏ខ្លី ។ ហាងនេះបានក្លាយទៅជាទីបញ្ជាការនៃសាសនាចក្រ នៅឆ្នាំ ១៨៣២ ។ វិវរណៈជាច្រើនដែលសំខាន់ៗគឺបានទទួលនៅទីនេះ ។ សាលានៃពួកព្យាការីត្រូវបានបង្រៀននៅក្នុងហាងនេះ ពីថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៨៣៣ រហូតដល់ពេលមួយ នៅខែមេសា ឆ្នាំ ១៨៣៣ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ព្យាការីយ៉ូសែបបានទទួលវិវរណៈអំពី ពាក្យសំដីនៃប្រាជ្ញាវាងវៃ (គ. និង ស. ៨៩) ។ លោកបានធ្វើការបកប្រែ ព្រះគម្ពីរប៊ីបភាគច្រើននៅទីនេះ ។

### ៨. ផ្ទះរបស់យ៉ូហាន ចនសុន

ផ្ទះរបស់យ៉ូហាន និងនាងអាលីស ចនសុន គឺនៅភូមិហៃរាំ រដ្ឋអូហៃអូ ។ បន្ទប់នេះគឺនៅជាន់ទីពីរ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ព្យាការីយ៉ូសែប ស្ម៊ីធ និងនាងអិមម៉ា ជាប្រពន្ធលោក បានរស់នៅឯផ្ទះនេះ ។ យ៉ូសែប និងស៊ីឌនី រិកដុនបានទទួលការនិមិត្តមួយដ៏អស្ចារ្យអំពីលំដាប់ទាំងឡាយនៃសិរីល្អ នៅចំពោះវត្តមាននៃមនុស្សដទៃជាច្រើន នៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ១៨៣២ (គ. និង ស. ៧៦) ។ ព្យាការីយ៉ូសែបក៏បានធ្វើការបកប្រែព្រះគម្ពីរប៊ីបដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.) នៅឯផ្ទះនេះដែរ ។ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ១៨៣២ កាលយ៉ូសែប និងនាងអិមម៉ាកំពុងតែនៅទីនេះ នោះស្រាប់តែមានហ្វូងមនុស្សកំណាចដែលបានក្បត់សាសនា និងពួកអ្នកទទឹងនឹងពួកមរមន បានវាយយ៉ូសែប និងស៊ីឌនី ជាធ្ងន់ ហើយលាបប្រេង និងស្លាប ។

### ៩. ព្រះវិហារខឺតឡង់

ព្រះវិហារខឺតឡង់នៅក្រុងខឺតឡង់ រដ្ឋអូហៃអូ ។

ព្រឹត្តិការណ៍សំខាន់ៗ ៖ ព្រះវិហារខឺតឡង់ គឺជាព្រះវិហារទីមួយ ដែលបានសង់ឡើងនៅគ្រាត្រួតត្រាកាន់កាប់នេះ (គ. និង ស. ៨៨:១១៩, ៩៥) ។

*នៅក្នុងព្រះវិហារនេះ* យ៉ូសែប ស្ម៊ីធបានឃើញការនិមិត្តមួយអំពីនគរសេឡេស្ទាល (គ. និង ស. ១៣៧) ។ ព្រះវិហារនេះត្រូវបានធ្វើពិធីឆ្លងនៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ ១៨៣៦ (គ. និង ស. ១០៩) ។ នៅថ្ងៃទី ៣ ខែមេសា ឆ្នាំ ១៨៣៦ ព្រះ អម្ចាស់ទ្រង់បានលេចមក ហើយបានទទួលព្រះវិហារនេះទុកជាកន្លែងមួយ ដែលទ្រង់នឹងបើកសម្ដែងប្រាប់ពីព្រះបន្ទូលរបស់ទ្រង់ដល់រាស្ត្រទ្រង់ (គ. និង ស. ១១០:១–១០) ។ បន្ទាប់ពីការលេចមក នោះយ៉ូសែប ស្ម៊ីធ និងអូលីវើរ ខៅឌើរី បានជួបនឹងលោកម៉ូសេ លោកអេលីយ៉ាស និងលោកអេលីយ៉ា ហើយពួកគេទាំងអស់គ្នាបានប្រគល់ឲ្យគេនូវកូនសោទាំងឡាយនៃបព្វជិតភាព និងពតិមានសំខាន់ៗ (គ. និង ស. ១១០:១១–១៦) ។ ព្រះវិហារនេះបានតាំងឡើងសំរាប់បំរើពួកបរិសុទ្ធ អស់រយៈពេលពីរឆ្នាំមុនពួកគេភៀសខ្លួនចេញពីក្រុងខឺតឡង់ទៅ ដោយសារសេចក្ដីបៀតបៀន ។

### ១០. ច្រកភ្នំអ័ដាមអុនដៃអាម៉ាន

មើលទៅទិសខាងកើតលើច្រកភ្នំអ័ដាម-អុនដៃ-អាម៉ាន នោះឃើញមានច្រកភ្នំដ៏ស្ងប់ស្ងាត់ ហើយល្អមួយ ដែលនៅក្នុងរដ្ឋមិសសួរី នៅទិសខាងជើងជ្រុងខាងលិច នៅជិតភូមិកាឡាទិន ។

ព្រឹត្តិការណ៍សំខាន់ៗ ៖ បីឆ្នាំមុនលោកអ័ដាមស្លាប់ នោះលោកបានហៅពូជពង្សដែលសុចរិតរបស់លោកឲ្យមកក្នុងច្រកភ្នំនេះ ហើយបាន ប្រទានពរចុងក្រោយបង្អស់របស់លោកទៅលើពួកគេ (គ. និង ស. ១០៧:៥៣–៥៦) ។ នៅឆ្នាំ ១៨៣៨ អ័ដាម-អុនដៃ-អាម៉ាន គឺជាទីតាំងនៅនៃពួកបរិសុទ្ធថ្ងៃចុងក្រោយរវាង ៥០០ ទៅ ១០០០ នាក់ ។ ពួកបរិសុទ្ធបានទុកទីនេះចោល កាលពួកគេត្រូវគេបណ្ដេញចេញពី រដ្ឋមិសសួរី ។ មុនការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ ដោយសិរីល្អ នោះលោកអ័ដាម និងពូជពង្សដ៏សុចរិតរបស់លោកនឹងជួបជុំគ្នា ទៀត នៅក្នុងច្រកភ្នំនេះ ដើម្បីទៅជួបព្រះអង្គសង្គ្រោះ (ដានី. ៧:៩–១០, ១៣–១៤; គ. និង ស. ១០៧:៥៣–៥៧; ១១៦:១) ។

### ១១. កន្លែងសំរាប់ព្រះវិហារហ្វារវែស្ទ

ទីតាំងនៅហ្វារវែស្ទ រដ្ឋមិសសួរី បានក្លាយទៅជាទីលំនៅដល់ពួកបរិសុទ្ធ ៣ ទៅ ៥ ពាន់ នាក់ ដែលបានស្វែងរកទីជំរក ឲ្យរួចផុតពីការបៀតបៀននៅឃុំចាកសុន និងឃុំក្លៃ ។ នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៨៣៨ ព្យាការីយ៉ូសែប ស្ម៊ីធ និងពួកអ្នកដឹកនាំផ្សេងៗទៀត នៅក្នុងសាសនាចក្រត្រូវគេចាប់ ហើយបន្ទាប់ពីបានឡើងតុលាការ នោះត្រូវជាប់គុកនៅក្នុងគុកលិបឺទី ។ នៅរដូវរងានៃឆ្នាំ ១៨៣៨–៣៩ ពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវគេបណ្ដេញចេញពីភូមិហ្វារវែស្ទ និងកន្លែងផ្សេងៗទៀតនៅរដ្ឋមិសសួរី ហើយក៏ផ្លាស់ទៅនៅរដ្ឋ អិលលីណោយ ។

ព្រឹត្តិការណ៍សំខាន់ៗ ៖ ជាកន្លែងសំរាប់ព្រះវិហារមួយ ដែលបានធ្វើពិធីឆ្លង ហើយបានដាក់ជ្រុងថ្ម ។ មាននិវរណៈព្រាំពីរដែលបានបោះពុម្ព ផ្សាយនៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា គឺបានទទួលនៅទីនេះ (កណ្ឌទី ១១៣–១១៥; ១១៧–១២០) ។ យ៉ូសែប អែហ្វ ស្ម៊ីធ ជាប្រធានទីប្រាំមួយនៃសាសនាចក្រ បានកើតនៅថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ១៨៣៨ នៅភូមិហ្វារវែស្ទ ។ ភូមិហ្វារវែស្ទត្រូវបានតាំងជាទីបញ្ជាការនៃសាសនាចក្រក្នុងពេលដ៏ខ្លី នៅក្រោមការដឹកនាំនៃព្យាការីយ៉ូសែប ស្ម៊ីធ ។

## ១២. គុកលិបឺទី

ជាគុកតូចមួយនៅក្រុងលិបឺទី រដ្ឋមិសសួរី ។ យ៉ូសែប ស្ម៊ីធ និងពួកបងប្អូនប្រុសៗប្រាំនាក់ទៀតត្រូវគេចាប់ដាក់គុកនៅខាងក្នុងជញ្ជាំង ដ៏ក្រាស់ដល់ទៅ ១.២ ម៉ែត្រ ពីថ្ងៃទី ១ ខែធ្នូ ១៨៣៨ ទៅដល់ថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣៩ ។ (ស៊ីឌនី រិកដុន ត្រូវបានលែងនៅចុង ខែកុម្ភៈ) ។ ពួកគេបានជាប់នៅក្នុងបន្ទប់ខាងក្រោមឬ

*ព្រឹត្តិការណ៍សំខាន់ ៖* ព្យាការីយ៉ូសែប ដោយបានអង្វរជំនួសពួកបរិសុទ្ធថ្ងៃចុងក្រោយរាប់ពាន់នាក់ ដែលត្រូវគេបណ្តេញចេញពីរដ្ឋមិសសួរី លោកបានទទួលចម្លើយតបដល់ការអធិស្ឋានរបស់លោក ដែលលោកបានចុះក្នុងសំបុត្រមួយទៅដល់ពួកបរិសុទ្ធដែលត្រូវភៀសខ្លួន (គ. និង ស. ១២១–១២៣) ។

## ១៣. វិមាននៅក្រុងណៅវូ

យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ និងគ្រួសារលោកបានចូលនៅក្នុងវិមាននៅក្រុងណៅវូ នៅខែសីហា ឆ្នាំ ១៨៤៣ ។ ក្រោយមក ក៏បានតឈៀង មួយនៅឈៀងខាងកើតអាគារ ធ្វើ ២២ បន្ទប់ ។ ចាប់ផ្តើមនៅខែមករា ឆ្នាំ ១៨៤៤ អេបេនេសេ រ៉ូបិនសុន បានកាន់កាប់ផ្ទះនោះទៅជា ផ្ទះសំណាក់ ហើយព្យាការីបានទុកប្រាំមួយបន្ទប់សំរាប់គ្រួសារលោក ។ ផ្ទះនោះបានតាំងទុកជាកន្លែងជួបជុំគ្នា នៃសង្គមមនុស្សនៅក្រុង ណៅវូ ។ ពួកអ្នកថ្លៃថ្នូរដ៏សំខាន់ៗត្រូវបានទទួលភៀវនៅទីនេះដោយព្យាការី ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ ព្យាការីយ៉ូសែប និងហៃរុម ជាបងប្រុសរបស់លោកត្រូវគេបាញ់ស្លាប់ នៅក្នុងគុកកាតធេច រដ្ឋអិលលីណោយ ហើយសពរបស់ពួកគេត្រូវបានយកមកផ្ទះនេះ ដើម្បីផ្តេកក្នុងមឈូសមុនធ្វើបុណ្យខ្មោច ។ សពពួក គេត្រូវបានកប់នៅផ្នូរខ្មោចតូចមួយរបស់គ្រួសារ នៅម្ខាងផ្លូវថ្មល់មេន នៅខាងលិចផ្ទះឈើចាស់ដែលយ៉ូសែបធ្លាប់នៅ កាលលោក ទើបមកដល់ក្រុងណៅវូមុនដំបូង ។ នាងអិមម៉ា ស្ម៊ីធបានរស់នៅក្នុងវិមានរហូតដល់ឆ្នាំ ១៨៧១ ។ គ្រានោះ នាងបានចូលទៅផ្ទះ សំណាក់ណៅវូ ជាកន្លែងដែលនាងស្លាប់នៅឆ្នាំ ១៨៧៩ ។

## ១៤. ហាងឥដ្ឋក្រហមរបស់ព្យាការីយ៉ូសែប ស្ម៊ីធ

ហាង និងការិយាល័យរបស់យ៉ូសែប ស្ម៊ីធ ដែលបានធ្វើវិញនេះ គឺនៅក្រុងណៅវូ រដ្ឋអិលលីណោយ ។ ហាងនេះគឺជាអាគារមួយដ៏សំខាន់បំផុតនៃសាសនាចក្រ នៅសម័យក្រុងណៅវូ ។ ទីនេះមិនគ្រាន់តែជាហាងទេ តែជាកន្លែងជួបជុំគ្នានៃការងារទាំងឡាយខាងសង្គម ខាង សេដ្ឋកិច្ច ខាងនយោបាយ និងខាងសាសនា ។ យ៉ូសែប ស្ម៊ីធមានការិយាល័យនៅបន្ទប់នៅជាន់ទីពីរ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* មុនធ្វើព្រះវិហាររួច បន្ទប់ខាងលើហាងនេះត្រូវបានប្រើប្រាស់ជាបន្ទប់នៃពិធីបរិសុទ្ធ ជាកន្លែងដែលបានប្រទាន អំណោយទានពិសិដ្ឋមុនដំបូង ។ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ១៨៤២ ព្យាការីយ៉ូសែប បានរៀបចំពួកស្ត្រីនៅក្នុងសាសនាចក្រធ្វើជា សមាគមសង្គ្រោះ ។

## ១៥. ព្រះវិហារណៅវូ

គំរូតូចអំពីព្រះវិហារណៅវូនេះ គឺនៅលើកន្លែងនៃព្រះវិហារដើម ។ ព្រះវិហារនេះត្រូវបានសង់ឡើងពីថ្មកំបោរប្រផេះដែលមាននៅទីនោះ ។ អាគារនេះមានបណ្តោយ ៣៩ ម. ហើយទទឹង ២៧ ម. ។ កំពូលខ្ពស់ពីដី ៤៨ ម. ។ សមាជិកនៃសាសនាចក្របានធ្វើការបូជាដ៏ធំ ដើម្បីសង់ព្រះវិហារដ៏ល្អនេះ ចាប់ផ្តើមធ្វើនៅឆ្នាំ ១៨៤១ ។ មនុស្សខ្លះបានធ្វើការសង់អាគារនេះអស់រាប់ខែ; អ្នកខ្លះទៀតបានបូជាប្រាក់ កាសរបស់ខ្លួន ។ ទោះជាមិនទាន់ធ្វើព្រះវិហាររួចផង ក៏គង់តែព្រះវិហារនោះពេញទៅដោយសមាជិកទាំងឡាយ ដែលបានមកដើម្បីទទួល ពិធីបរិសុទ្ធនៅខែមុនៗដែលពួកគេត្រូវភៀសខ្លួនទៅភូមិភាគខាងលិចដែរ ។ កាលពួកបរិសុទ្ធជាច្រើនបានចេញពីក្រុងណៅវូនៅដើមរដូវ ផ្ការីក នៃឆ្នាំ ១៨៤៦ ដោយសារការគំរាមកំហែងពីហ្វូងមនុស្សកំណាច ក៏នៅមានមនុស្សវិសេសដែលបាននៅដើម្បីធ្វើព្រះវិហារឲ្យរួច ។ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៨៤៦ អែលឌើរ អ្គសុន ហៃឌ និងវិលហ្វូល វូឌរុព្វ ហើយប្រហែលជាមានមនុស្ស ២០ នាក់ទៀត ដែល បានធ្វើពិធីឆ្លងដំណាក់នៃព្រះអម្ចាស់នេះ ។ ព្រះវិហារនេះត្រូវបានទុកចោលនៅខែកញ្ញា កាលពួកបរិសុទ្ធនៃសាសនាចក្រដែលនៅសល់ ទាំងប៉ុន្មានត្រូវគេបណ្តេញចេញពីក្រុងណៅវូ; គ្រានោះ ហ្វូងមនុស្សកំណាចបានបន្ថោកបន្ទាប ហើយបានបង្ខូចសំណង់ដ៏ពិសិដ្ឋនោះចោល ។ ព្រះវិហារក៏ត្រូវភ្លើងឆេះនៅខែតុលា ឆ្នាំ ១៨៤៨ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* សន្និសីទទូទៅត្រូវបានធ្វើនៅក្នុងបន្ទប់ជំនុំក្នុងព្រះវិហារ នៅថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៨៤៥ ។ កិច្ចការខាងពិធី បរិសុទ្ធបានចាប់ផ្តើមធ្វើនៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៨៤៥ ហើយបានធ្វើតមករហូតដល់ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៨៤៦ ។ មានពួកបរិសុទ្ធជាង ៥,៥០០ នាក់ដែលបានទទួលអំណោយទានពិសិដ្ឋ និងបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់ និងការភ្ជាប់ទាំងឡាយត្រូវបានធ្វើនៅទីនោះ ។

## ១៦. គុកកាតធេច

ជាគុកមួយនៅភូមិកាតធេច រដ្ឋអិលលីណោយ

ព្រឹត្តិការណ៍សំខាន់ៗ ៖ យ៉ូសែប ស្ម៊ីធ និងបងប្រុសលោក គឺហៃរុម បានជិះទេះទៅភូមិកាតធេច នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៨៤៤ ។ ពួកគេត្រូវគេចាប់ដាក់ក្នុងគុកនេះ នៅថ្ងៃទី ២៥ ខែមិថុនា ដោយការចោទក្លែងក្លាយថាក្បត់ជាតិ ។ នៅថ្ងៃទី ២៧ ខែមិថុនា មានហ្វូង មនុស្សកំណាចលាបមុខខ្មៅ

បានសំរុកចូលគុក ។ យ៉ូសែប និងហៃរុមទាំងពីរនាក់ត្រូវគេបាញ់ស្លាប់ ហើយ យ៉ូហាន ថេល័រត្រូវរបួស ជាច្រើនកន្លែង ។ ជាការអស្ចារ្យណាស់ដែល វិលឡឺឌ រិចឆ្សិ មិនត្រូវបានរបួសសោះឡើយ ។ ក្រោយមក យ៉ូហាន ថេល័រ បានសរសេរ បទរំឭកដែលប្រកបដោយការបំផុសគំនិត ដែលឥឡូវនេះ មាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣៥ ។

**១៧. ការនិក្ខមនំទៅភូមិភាគខាងលិច**

ការចាប់ផ្ដើមចាកចេញពីក្រុងណៅវូ រដ្ឋអិលលីណោយ ត្រូវបានគ្រៀម ទុកសំរាប់ខែមីនា-មេសា ប៉ុន្តែដោយសារតែការគំរាមកំហែងពីហ្វូងមនុស្ស កំណាច ម្ល៉ោះហើយ បានជាប្រធានព្រិកហាំ យ៉ង់ បានដឹកនាំថា ពួកបរិសុទ្ធ ត្រូវចាប់ផ្ដើមធ្វើដំណើរឆ្លងទន្លេមិស៊ីស៊ីបពី នៅថ្ងៃទី ៤ ខែកុម្ភៈ ១៨៤៦ ។ ប្រធានយ៉ង់បាននៅដើម្បីប្រារព្ធអំណោយទានពិសិដ្ឋដល់ពួកបរិសុទ្ធ ហើយ មិនបានចេញពីក្រុងណៅវូទេ ទាល់តែដល់ ពាក់កណ្ដាលខែកុម្ភៈ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* មុនយ៉ូសែប ស្មីធស្លាប់ លោកបានព្យាករថា «ពួក អ្នករាល់គ្នាខ្លះនឹងនៅរស់ ដើម្បីទៅជួយតាំងទីលំនៅ ហើយ ស្ថាបនាទីក្រុង ទាំងឡាយ ហើយនឹងឃើញពួកបរិសុទ្ធក្លាយទៅជាប្រជាជនដ៏ខ្លាំងក្លា នៅកណ្ដាលភ្នំរ៉ុកគី» ។ មានពួកបរិសុទ្ធជិតទៅ ១២,០០០ នាក់ ដែលបាន ចាកចេញពីក្រុងណៅវូ ពីខែកុម្ភៈទៅខែកញ្ញា ឆ្នាំ ១៨៤៦ ។ បន្ទាប់ពីពួក បរិសុទ្ធបានចេញពី វិនទើរ ខ្វទើរ និង កន្លែងក្រោយៗទៀត ពួកគេបាន រៀបចំគ្នាតាមក្រុម ១០ នាក់, ក្រុម ៥០ នាក់, និងក្រុម ១០០ នាក់ ដែល មានមេរៀងៗខ្លួន (គ. និង ស. ១៣៦:៣) ។ នៅខែកញ្ញា ឆ្នាំ ១៨៤៦ មានហ្វូងមនុស្សកំណាចប្រមាណ ៨០០ នាក់ មានទាំងកាំភ្លើងធំប្រាំ មួយដើមផង បានចូលហ៊ុំយក ក្រុងណៅវូ ។ បន្ទាប់ពីបានច្បាំងអស់បួនប្រាំថ្ងៃ ក្រោយមក នោះពួកបរិសុទ្ធដែលនៅសល់ទាំងប៉ុន្មានត្រូវបានបង្ខំឲ្យចុះចាញ់ ដើម្បីទុកជីវិត ឲ្យរស់ ហើយមានឱកាសនឹងឆ្លងទន្លេទៅ ។ មានមនុស្ស ប្រុសស្រី និងកូនក្មេងប្រាំទៅប្រាំមួយរយនាក់ ដែលបានឆ្លងទន្លេ ហើយបាន បោះជំរុំ នៅម្ខាងច្រាំង ។ ប្រធានព្រិកហាំ យ៉ង់ បានចាត់រទេះជំនួយដោយ ស្បៀងអាហារ ឲ្យទៅជួយយក «ពួកបរិសុទ្ធក្រីក្រ» ទាំងនេះចេញមក ។

**១៨. ព្រះវិហារសលត៍លេក**

មិនយូរថ្ងៃប៉ុន្មានបន្ទាប់ពីក្រុមត្រួសត្រាយនៃពួកបរិសុទ្ធបានចូលច្រកភ្នំសលត៍ លេក ប្រធានព្រិកហាំ យ៉ង់ បានដោតដីនឹងឈើច្រត់លោក ហើយ ប្រកាសថា ៖ «នៅទីនេះហើយដែលយើងនឹងសង់ព្រះវិហារនៃព្រះ របស់យើង» ។ ពិធីជីកដីត្រូវបានប្រារព្ធឡើងនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ១៨៥៣ ។ នៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៩៥៣ ពិធីដាក់ច្រុងថ្មត្រូវបាន ប្រារព្ធឡើង ។ ព្រះវិហារត្រូវបានធ្វើរួច ហើយធ្វើ ពិធីឆ្លង ៤០ ឆ្នាំក្រោយមក នៅថ្ងៃទី ៦ ខែមេសា ១៨៩៣ ។ គណៈប្រធានទីមួយ និងក្រុមសាវក ១២ នាក់ ជួបជុំគ្នានៅទីនេះរាល់ អាទិត្យ ដើម្បីពិភាក្សា ហើយសូមការដឹកនាំពី ព្រះអម្ចាស់ នូវការចាត់ចែង នឹងការកសាងនគរព្រះ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ព្រះអម្ចាស់ទ្រង់បានប្រទានដល់ពួកប្រធាន នៃសាសនាចក្រ និងពួកអ្នកមានសិទ្ធិអំណាចផ្សេងៗទៀត នូវការហូរហៀ នៃវិញ្ញាណខាងវិវរណៈនៅទីនេះ ដូចជាសេចក្ដីប្រកាសតាមផ្លូវការ — ទី២ ។ ឆាប់ៗនេះ គណៈប្រធានទីមួយ និងក្រុមប្រឹក្សានៃពួកសាវក ១២ នាក់ បានអនុម័តដោយឯកច្ឆន្ទឲ្យបោះពុម្ពផ្សាយ «ក្រុមគ្រួសារ ៖ សេច ក្ដីប្រកាសដល់ពិភពលោក» ។ ពិធីបរិសុទ្ធទាំងឡាយនៅ ក្នុងព្រះវិហារ ដែលបានធ្វើសំរាប់មនុស្សនៅរស់ ព្រមទាំងមនុស្សស្លាប់ នោះបានប្រទានពរ ដល់មនុស្សរាប់លាននាក់ ។

អ័ដាម-អុនដៃ-អាម៉ាន, រដ្ឋមិសសួរី, ៥:ឃ៣

ទ្វីបអាហ្វ្រិក, ៧:ង២

អាបានី, រដ្ឋនូវយ៉ោក, ១:គ៣

អាមហើស្ត, រដ្ឋអូហៃអូ, ៣:គ៤

ទ្វីបអ័ន្តអាទិច, ៧:ង៤

ទន្លេអរខ័នសរ, ៦:ឃ៣

ផ្លូវអារមីងតោន ស្គូលហោស, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ឃ៣

រោងផេះ, ក្រុងខឺតឡង់, ៤:ខ៣

ទ្វីបអាស៊ី, ៧:ច២

មហាសមុទ្រអាត្លង់ទិច, ១:ឃ៤, ៦:ជ២

ទ្វីបអូស្ត្រាលី, ៧:ឆ៣

ធនាគារ, ក្រុងខឺតឡង់, ៤:ខ៤

កន្លែងធ្វើបុណ្យជ្រមុជទឹក, ក្រុងខឺតឡង់, ៤:ខ២

បូស្តុន, រដ្ឋម៉ាស្សាជូសសែត្ស, ១:ឃ៣

រោងឥដ្ឋ, ក្រុងខឺតឡង់, ៤:ក២

បាហ្វាឡូ, រដ្ឋនូវយ៉ោក, ៣:ង២

រដ្ឋកាលីហ្វ័រញ៉ា, ៦:ក៣

ផ្លូវលំកាលីហ្វ័រញ៉ា, ៦:ខ២

ប្រទេសកាណាដា, ១:គ១, ៣:គ៣, ៣:ឃ២, ៦:ច១

ទន្លេកាណាដា, ៦:ឃ៣

ផ្លូវកាណានដៃគ្វា, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:គ៣

កាតធេច, រដ្ឋអិលលីណោយ, ៥:ឆ២

ផ្នូរខ្មោច, ក្រុងខឺតឡង់, ៤:ខ៣

ទ្វីបអាមេរិកកណ្ដាល, ៧:ខ២

ទន្លេច័ក្រិន, ដៃខាងកើត, ក្រុងខឺតឡង់, ៤:ខ១

ទន្លេចារីតោន, រដ្ឋមិសសួរី, ៥:ង២

ផ្លូវឈិល្លីខូថេ, ក្រុងខឺតឡង់, ៤:ខ៤

ឃ្លីបឡង់, រដ្ឋអូហៃអូ, ៣:គ៤

ខូលស្វិល, រដ្ឋនូវយ៉ោក, ១:ខ៣, ៣:ជ៣

រដ្ឋខុនណែកទីកាត់, ១:គ៣

ទន្លេខុនណែកទីកាត់, ១:ឃ១

ខោនសិល ប្លើព្ស (ខានស៊្វល), រដ្ឋអៃអូវ៉ា, ៥:គ១, ៦:ង២

ផ្លូវខៅឌើរី, ក្រុងខឺតឡង់, ៤:ក៣

ទំនប់ទឹក, ក្រុងខឺតឡង់, ៤:ខ២

ទន្លេដេលឡាវ៉ារ, ១:ខ៤

ដៃវិត្ត, រដ្ឋមិសសួរី, ៥:ង៣

ព្រែកអេរី, រដ្ឋនូវយ៉ោក, ២:ខ២, ៣:ច១

ទ្វីបអឺរ៉ុប, ៧:ង១

ហ្វាវវែស្ត, រដ្ឋមិសសួរី, ៥:ឃ៣, ៦:ង២

ភូមិហ្វាមមីងតោន, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ក៤

ហ្វាយ៉េត្ត, រដ្ឋនូវយ៉ោក, ១:ក៣, ៣:ឆ២, ៦:ឆ១

បឹងហ្វិងគឺ, រដ្ឋនូវយ៉ោក, ១:ក៣, ៣:ឆ២

ទន្លេហ្វិស៊ីង, រដ្ឋមិសសួរី, ៥:ឃ៣

បន្ទាយព្រិចដើរ, ៦:គ២

បន្ទាយហល, ៦:ខ១

បន្ទាយឡារ៉ាមី, ៦:គ២

បន្ទាយលៃវិនវឺត, ៥:ឃ៤, ៦:ង២

ផ្លូវហ្វក្ស, នៅប៉ាលម៉ៃរ៉ា, ១:ក៣

ហ្វ្រិដម, រដ្ឋនូវយ៉ោក, ៣:ច២

កាលឡាទិន, រដ្ឋមិសសួរី, ៥:ឃ៣

កាដែន ក្រូវ, រដ្ឋអៃអូវ៉ា, ៥:ឃ២

ទន្លេហ៊ីឡា, ៦:ខ៤

គិលសុម, រដ្ឋនូវហាំស៊ើរ, ១:ឃ២

ទន្លេក្រាន្ត, រដ្ឋមិសសួរី, ៥:ឃ២

ក្រានឌិន អ៊ី ប៊ី, រោងពុម្ព, ភូមិប៉ាលម៉ៃរ៉ា, ២:គ២

បឹងក្រេតសលត៍លេក, ៦:ខ២

រោងកិនស្រូវរបស់គ្រិស្ត, ក្រុងខឺតឡង់, ៤:ខ២

ហារម៉ូនី, រដ្ឋផែនស៊ិលវេញ៉ា, ១:ខ៣, ៣:ជ៣

ស្រែរបស់ហារិស ម៉ាទិន, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ខ១

ផ្ទះរបស់ហារិស ម៉ាទិន, ក្រុងខឺតឡង់, ៤:ឃ៤

អូហាថាវៃ, នៅតំបន់ប៉ាលម៉ៃរ៉ា, ២;ខ២, ២:ឃ៤

ហោនស្វិល, រដ្ឋមិសសួរី, ៥:ឃ៣

ភ្នំគូម៉ូរ៉ា, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:គ៤

ហៃរ៉ាំ, រដ្ឋអូហៃអូ, ៣:គ៤

ទន្លេហើឌសុន, រដ្ឋនូវយ៉ោក, ១:គ៣

រដ្ឋអិលលីណោយ, ៥:ឆ៣, ៦:ច២

អ៊ិនឌីប៉ែនដែន្ស, រដ្ឋមិសសួរី, ៥:ឃ៤, ៦:ង២

មហាសមុទ្រឥណ្ឌា, ៧:ច៣

ទឹកដីរបស់ពួកអាមេរិកាំងដើម, ៥:ខ២, ៦:គ១, ៦:ឃ៣

រដ្ឋអ៊ិនឌីអានណា, ៦:ច២

រដ្ឋអៃអូវ៉ា, ៥:ង១, ៦:ង២

ឃុំចាកសុន, រដ្ឋមិសសួរី, ៥:ឃ៤

ផ្ទះសំណាក់របស់ចនសុន យ៉ូហាន, ក្រុងខឺតឡង់, ៤:ខ២

ផ្លូវយ៉ូសែប, ក្រុងខឺតឡង់, ៤:ក៤

ខឺតឡង់, រដ្ឋអូហៃអូ, ៣:គ៣, ៦:ច២

ព្រះវិហារខឺតឡង់, ៤:ខ៤

ផ្ទះរបស់ណែត យ៉ូសែប ស៊ុញ៉រ, ភូមិខូលស្វិល, រដ្ឋនូវយ៉ោក, ៣:ជ៣

ផ្ទះរបស់ណែត វិនសុន, ក្រុងខឺតឡង់, ៤:ក៤

បឹងអេរី, ៣:គ៣

បឹងហ៊្យូរ៉ុន, ៣:គ១

បឹងអុនតារីយ៉ូ, ១:ក២, ៣:ច១

ល្បាណូន, រដ្ឋនូវហាំស៊ើរ, ១:ឃ២

លិបឺទី, រដ្ឋមិសសួរី, ៥:ឃ៤, ៦:ង២

ឡូ អង់កិឡែស, ៦:ក៣

ភូមិម៉ាសេដុន, នៅក្នុងតំបន់ប៉ាលម៉ៃរ៉ា, ២:ក១

រដ្ឋមេន, ១:ឃ២

ភូមិម៉ានចេសស្ទើរ, រដ្ឋនូវយ៉ោក, ១:ក៣, ២:ឃ៣, ៣:ច២

ផ្លូវម៉ាកែល, ក្រុងខឺតឡង់, ៤:ក២

រដ្ឋម៉ាស្សាជូសសែត្ស, ១:គ៣

ម៉កអិលវេនស្បិន, រដ្ឋមិសសួរី, ៥:ង៣

មែនដុន, រដ្ឋនូវយ៉ោក, ៣:ច២

ប្រទេសម៉ិកស៊ិក, ៦:ខ៣

ស្ថានទូត សាន លូវី រេយ, ៦:ក៤

ទន្លេមិស៊ីស៊ីពី, ៥:ឆ៣

រដ្ឋមិសសួរី, ៥:ច៣, ៦:ង៣

ទន្លេមិសសួរី, ៥:គ២, ៥:ច៤

មនត្រូស, រដ្ឋអៃអូវ៉ា, ៥:ច២

ស្រែរបស់មូលី អ៊ីសាក, ក្រុងខឺតឡង់, ៤:ឃ១

ភ្នំភិស្កា, រដ្ឋអៃអូវ៉ា, ៥:ឃ១

ណៅវូ, រដ្ឋអិលលីណោយ, ៥:ច២, ៦:ង២

រដ្ឋនូវហាំស៊ើរ, ១:ឃ២

រដ្ឋនូវជើរស៊ី, ១:ខ៤

រដ្ឋនូវយ៉ោក, ១:ខ៣, ៣:ច៣, ៦:ឆ១

ទីក្រុងនូវយ៉ោក, ១:គ៤, ៦:ឆ១

ទ្វីបអាមេរិកខាងជើង, ៧:ខ២

មហាសមុទ្រអាត្លង់ទិចខាងជើង, ៧:ឃ២

មហាសមុទ្រប៉ាស៊ីហ្វិកខាងជើង, ៧:ក២, ៧:ជ២

ទន្លេផ្លាត្តខាងជើង, ៦:គ២

ណូវិច, រដ្ឋវើរម៉ង់, ១:ឃ២

រដ្ឋអូហៃអូ, ៣:ខ៤, ៦:ច២

ឃុំអុនតារីយ៉ូ, រដ្ឋនូវយ៉ោក, ២:ក៣, ២:គ៣

អូវេញ, រដ្ឋអូហៃអូ, ៣:គ៤

ទឹកដីអូរីកុន, ៦:ក១

មហាសមុទ្រប៉ាស៊ីហ្វិក, ៦:ក១, ៧:ក៣
ស្រុកប៉ាលម៉ៃរ៉ា, រដ្ឋនូវយ៉ោក, ១:ក៣, ២:ឃ១, ៣:ច២
ភូមិប៉ាលម៉ៃរ៉ា, រដ្ឋនូវយ៉ោក, ២:គ២
ទន្លេភេកូស, ៦:គ៤
រដ្ឋផែនសិលវេញ៉ា, ១:ខ៣, ៣:ង៣, ៦:ឆ២
ផែរីស្បឺក, រដ្ឋនូវយ៉ោក, ៣:ង២
ភីឡាដិលភា, រដ្ឋផែនសិលវេញ៉ា, ១:ខ៤, ៦:ឆ២
ទន្លេផ្លាត្ត, ៥:ខ១
ផ្ទះរបស់ប្រាត ប៉ាលី ភី, ក្រុងខឺតឡង់, ៤:ក៣ការិយាល័យបោះពុម្ព, ក្រុងខឺតឡង់, ៤:ខ៤
ភេប្ល៉ូ, ៦:គ៣
ឃ្វិនស៊ី, រដ្ឋអិលលីណោយ, ៥:ច២, ៦:ង២
រេមុស, រដ្ឋអិលលីណោយ, ៥:ឆ២
រ៉េឌ ប្រិក, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ឃ២
រដ្ឋរ៉ូឌ អៃឡង់, ១:ឃ៣
រិចម៉ិន្ត, រដ្ឋមិសសួរី, ៥:ឃ៤
ផ្ទះរបស់រិកដុន ស៊ីឌនី, ក្រុងខឺតឡង់, ៤:ខ៤
ទន្លេរីអូក្រាន្ត, ៦:គ៤
រ៉ូឆែសស្ទើរ, រដ្ឋនូវយ៉ោក, ៣:ច១
សាក្រាម៉ង់តូ, ៦:ក២
ព្រៃពិសិដ្ឋ, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ខ៣
សាឡិម, រដ្ឋម៉ាស្សាជូសសែត្ស, ១:ឃ៣
ទីក្រុងសលត៍លេក, ៦:ខ២
សាន ប៊ឺនណាឌីណូ, ៦:ខ៣
សាន ឌីអេកូ, ៦:ក៤
សាន ហ្វ្រានស៊ិស្កូ, ៦:ក២
សានតាហ្វេ, ៦:គ៣
រោងអារឈើ, ក្រុងខឺតឡង់, ៤:ខ២
សាលារៀន, ក្រុងខឺតឡង់, ៤:ខ៣
សារ៉ុន, រដ្ឋវើរម៉ង់, ១:គ២
ស្វល ប្រិក, រដ្ឋមិសសួរី, ៥:ឃ៣
ផ្នូរខ្មោចរបស់ស្ម៊ីធ អាលវិន, ភូមិប៉ាលម៉ៃរ៉ា, ២:គ២
ផ្ទះរបស់ស្ម៊ីធ ហៃរុម, ក្រុងខឺតឡង់, ៤:ខ៤
ហាងលក់ដូររបស់ស្ម៊ីធ យ៉ូសែប ជុញ្ញ័រ, ក្រុងខឺតឡង់, ៤:ខ៣
ផ្ទះរបស់ស្ម៊ីធ យ៉ូសែប ជុញ្ញ័រ, ៣:ជ៣, ៤:ខ៣
ស្រែរបស់ស្ម៊ីធ យ៉ូសែប ស៊ីញ៉័រ, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ខ៣
ផ្ទះក្តាររបស់ស្ម៊ីធ យ៉ូសែប ស៊ីញ៉័រ, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ខ៣
ផ្ទះឈើរបស់ស្ម៊ីធ យ៉ូសែប ស៊ីញ៉័រ, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ខ៣
ទន្លេស្នេក, ៦:ខ១
ទ្វីបអាមេរិកខាងត្បូង, ៧:គ៣
មហាសមុទ្រអាត្លង់ទិចខាងត្បូង, ៧:ឃ៤
បេនប្រិចខាងត្បូង, រដ្ឋនូវយ៉ោក, ៣:ជ៣
បមហាសមុទ្រប៉ាស៊ីហ្វិកខាងត្បូង, ៧:ក៤
ទន្លេផ្លាត្តខាងត្បូង, ៦:គ២
ស្ព្រិងហ្វៀល, រដ្ឋអិលលីណោយ, ៥:ជ២
សន្ត លូវីស, រដ្ឋមិសសួរី, ៥:ជ៤
ផ្លូវស្តាបហ្វ៊ីឌ, នៅតំបន់ប៉ាលម៉ៃរ៉ា, ២:ជ៤
ទន្លេសុសគ្វីហាណា, រដ្ឋផែនសិលវេញ៉ា, ១:ក៤, ៣:ឆ៣
រោងស្បែក, ក្រុងខឺតឡង់, ៤:ខ២
ថមសុន, រដ្ឋអូហៃអូ, ៣:ឃ៣
ថបស្មៀល, រដ្ឋម៉ាស្សាជូសសែត្ស, ១:ឃ៣
ខេត្តតូរ៉ុនតូ, ប្រទេសកាណាដា, ៣:ង១
ធុកសុន, ៦:ខ៤
ថើនប្រិច, រដ្ឋវើរម៉ង់, ១:គ២
រដ្ឋវើរម៉ង់, ១:គ២
វ៉ាស៊ីងតោន, ឌី ស៊ី, ៦:ឆ២
ឃុំវេញ, រដ្ឋនូវយ៉ោក, ២:ក៣, ២:គ២
វៃទិងហាំ, រដ្ឋវើរម៉ង់, ១:គ៣
ផ្ទះរបស់វិតនី នូវល ខេ, ក្រុងខឺតឡង់, ៤:ខ២
ហាងរបស់វិតនី នូវល ខេ, ក្រុងខឺតឡង់, ៤:ខ២
ផ្លូវវិតនី, ក្រុងខឺតឡង់, ៤:ក៣
វិនទើរ ខ្វទើរ, ទឹកដីរបស់អាមេរិកាំងដើម, ៥:ខ១, ៦:ង២

ផែនទីដែលមានដូចតទៅនេះ អាចជួយឲ្យអ្នកកាន់តែយល់អំពីប្រវត្តិសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ និងអំពីព្រះ គម្ពីរដែលបានបើកសម្ដែងតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ និងពួកអ្នកតពីលោកមក ។ ដោយស្គាល់នូវភូមិសាស្ត្រនៃដែនដីដែលបានពោលដល់នៅព្រះគម្ពីរទាំងឡាយ នោះអ្នកអាចយល់អំពីព្រឹត្តិការណ៍ក្នុងគម្ពីរកាន់ប្រសើរឡើង ។


១. សហរដ្ឋប៉ែកឦសាន

២. ប៉ាលម៉ៃរ៉ា-ម៉ានចែសស្ទើរ, ១៨២០–៣១

៣. តំបន់នៅរដ្ឋនូវយ៉ោក, រដ្ឋផែនសិលវេញ៉ា, និងរដ្ឋអូហៃអូ នៅសហរដ្ឋ

៤. ខឺតឡង់, រដ្ឋអូហៃអូ, ១៨៣០–៣៨

៥. តំបន់នៅរដ្ឋមិសសួរី, រដ្ឋអិលលីណោយ, និងរដ្ឋអៃអូវ៉ា នៅសហរដ្ឋ

៦. ដំណើរនៃសាសនាចក្រទៅទិសខាងលិច

៧. ផែនទីនៃពិភពលោក


លិបិក្រមតាមលំដាប់អក្ខរក្រមនៃឈ្មោះកន្លែងទាំងឡាយ អាចជួយឲ្យអ្នករកឃើញកន្លែងនៅលើផែនទី ។ ពីក្រោយឈ្មោះនីមួយៗ មានលេខផែនទី និងក្រឡាតារាងដែលមានលេខនិងអក្សរ ។ ជាឧទាហរណ៍ កន្លែងនៃបន្ទាយហាល គឺ ៦:ខ១; នេះមានន័យថា ផែនទី ទី៦ នៅក្រឡា ខ១ ។ អ្នកអាចរកឃើញក្រឡាណាមួយនៅលើផែនទី ដោយមើលតាមលេខដែលនៅខាងលើ និងនៅចំហៀងផែនទីនោះ ។ ឈ្មោះផ្សេងទៀតនៃកន្លែងទាំងឡាយ គឺកត់ទុកនៅក្នុងវង់ក្រចក; ជាឧទាហរណ៍ ខោនសិលប្លើព្យ (ខានស្វិល) ។

តទៅនេះគឺជាសំគាល់ដើម្បីយល់ពីសញ្ញា និងតួអក្សរទាំងឡាយ ដែលបានយកមកប្រើប្រាស់នៅលើផែនទីទាំងប៉ុន្មាន ។ ថែមទៀត ផែនទី នីមួយៗអាចមានសំគាល់ផ្សេងៗ ដែលមានពាក្យពន្យល់ប្រាប់ពីសញ្ញាថែមទៀត ដែលមាននៅលើផែនទីនោះ ។

| | |
|---|---|
| • ចំណុចក្រហម | គឺជាទីក្រុង ឬភូមិចំណុចទោងឈ្មោះទីក្រុង ឬទីកន្លែង ។ |
| *មហាសមុទ្រអាត្លង់ទិច* | អក្សរបែបនេះគឺបានយកមកប្រើប្រាស់ដើម្បីប្រាប់ពីកន្លែងទាំងឡាយខាងភូមិសាស្ត្រ ដូចជា មហាសមុទ្រ សមុទ្រ បឹង ទន្លេ ភ្នំ ប្រកភ្នំ ទីរហោស្ថាន និងកោះទាំងឡាយ ។ |
| ប៉ាលម៉ៃរ៉ា | អក្សរបែបនេះគឺបានយកមកប្រើប្រាស់សំរាប់ទីក្រុង និងភូមិទាំងអស់ ។ |
| **នូវយ៉ោក** | អក្សរបែបនេះគឺបានយកមកប្រើប្រាស់សំរាប់ប៉ែកខាងនយោបាយ ដូចជា ភូមិភាគ និងរដ្ឋ និងទឹកដីទាំងឡាយនៃសហរដ្ឋ ។ |
| **កាណាដា** | អក្សរបែបនេះគឺបានយកមកប្រើប្រាស់សំរាប់ប៉ែកខាងនយោបាយធំៗ ដូចជាសាសន៍ ប្រទេស និងទ្វីបទាំងឡាយ ។ |




១. **ថបស្មៀល** ជាទីកំណើតរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ កើតនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ១៧៧១ ។

២. **គិលសុម** នាងលូស៊ី ម៉ាក បានកើតនៅទីនេះ ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៧៧៥ ។

៣. **ថើនប្រ៊ិច** យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ និងនាងលូស៊ី ម៉ាក បានរៀបការនៅទីនេះ ថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៧៩៦ ។

៤. **វ៉ៃទិងហាំ** ជាទីកំណើតរបស់ព្រិកហាំ យ៉ង់ កើតនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៨០១ ។

៥. **ហារម៉ូនី** នាងអិមម៉ា ហេល បានកើតនៅស្រុកហារម៉ូនី នៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ១៨០៤ ។

៦. **សារ៉ុន** យ៉ូសែប ស្ម៊ីធ ជុញ៉័រ បានកើតនៅទីនេះ ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៨០៥ (សូមមើល យ.ស. — ប្រវត្តិ ១:៣) ។

៧. **ល្បាណុន** គ្រួសារលោកស្ម៊ីធបានរស់នៅស្រុកល្បាណុន ពីឆ្នាំ ១៨១១ ទៅ ១៨១៣ នៅពេលនោះហើយដែលយ៉ូសែប ស្ម៊ីធបានទទួលការវះកាត់ជើង ។

៨. **ណូវិច** គ្រួសារលោកស្ម៊ីធបានរស់នៅទីនេះ ពីឆ្នាំ ១៨១៤ ទៅ ១៨១៦ មុនផ្លាស់ទៅនៅភូមិប៉ាលម៉ៃរ៉ា ។

៩. **ប៉ាលម៉ៃរ៉ា** គ្រួសារលោកស្ម៊ីធបានផ្លាស់មកនៅទីនេះ ឆ្នាំ ១៨១៦ (សូមមើល យ.ស. — ប្រវត្តិ ១:៣) ។

# ប៉ាលម៉ៃរ៉ា-ម៉ានឆែសស្ទើរ, ១៨២០–៣១

**ផែនទី ទី២**




១. **ផ្ទះឈើរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ** ទេវតាម៉ូរ៉ូណៃបានលេចមកឯយ៉ូសែប ស្ម៊ីធ នៅបន្ទប់ខាងលើនៃផ្ទះនេះ នៅថ្ងៃទី ២១–២២ ខែ កញ្ញា ឆ្នាំ ១៨២៣ (សូមមើល យ.ស. — ប្រវត្តិ ១:២៩–៤៧) ។

២. **ស្រែរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ** ស្រែនេះដែលមានទំហំ ៤.៧ ហិកតារ គឺបានធ្វើដោយគ្រួសារស្ម៊ីធ ពីឆ្នាំ ១៨២០ ទៅ ១៨២៩ ។

៣. **ព្រៃពិសិដ្ឋ** ការនិមិត្តទីមួយរបស់យ៉ូសែប ស្ម៊ីធ ជុញ៉័រ បានកើតឡើងនៅក្នុងព្រៃនេះ នៅដើមនិទាឃរដូវនៃឆ្នាំ ១៨២០ (សូមមើល យ.ស. — ប្រវត្តិ ១:១១–២០) ។

៤. **ផ្ទះក្ដាររបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ** ផ្ទះនេះបានចាប់ផ្ដើមសង់នៅឆ្នាំ ១៨២២ ដោយអាលវិន ស្ម៊ីធ ហើយគ្រួសារស្ម៊ីធបាននៅទីនេះ ពីឆ្នាំ ១៨២៥ ទៅ ១៨២៩ ។

៥. **ភ្នំគូម៉ូរ៉ា** នៅទីនេះហើយដែលទេវតាម៉ូរ៉ូណៃបានប្រគល់ដល់ព្យាការីយ៉ូសែប ស្ម៊ីធ នូវផ្ទាំងមាស នៅថ្ងៃទី ២២ ខែកញ្ញា ១៨២៧ (សូមមើល យ.ស. — ប្រវត្តិ ១:៥០–៥៤, ៥៩) ។

៦. **ស្រែរបស់ម៉ាទិន ហារិស** ស្រែនេះត្រូវបានកក់ ហើយលក់ភាគខ្លះ ដើម្បីបង់ថ្លៃបោះពុម្ពព្រះគម្ពីរមរមន ។

៧. **រោងពុម្ពរបស់អ៊ី ប៊ី ក្រានឌិន** ៥ ពាន់ក្បាលនៃព្រះគម្ពីរមរមនបានបោះពុម្ពនៅទីនេះ ឆ្នាំ ១៨២៩–៣០ ។

៨. **ស្ទូហាថាវៃ** នៅស្ទូនេះហើយជាទីដែលសាសនាចក្របានធ្វើបុណ្យជ្រមុជទឹកលើកដំបូង ។

# ផែនទី ទី៣

## តំបន់នៅរដ្ឋញូវយ៉ោក, រដ្ឋផែនស៊ីលវេញ៉ា, និងរដ្ឋអូហៃអូ នៅក្នុងសហរដ្ឋ




១. **បេនប្រិចខាងត្បូង** យ៉ូសែប ស្ម៊ីធ និង នាងអិមម៉ា ហេល បានរៀបការនៅទីនេះ នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ ១៨២៧ (សូមមើល យ.ស. — ប្រវត្តិ ១:៥៧) ។

២. **ខូលស៊្វិល** សាខាទីមួយនៃសាសនាចក្រត្រូវបានរៀបចំឡើង នៅផ្ទះរបស់យ៉ូសែប ណែត ស៊ីញ៉ូរ នៅស្រុកខូលស៊្វិល នៅឆ្នាំ ១៨៣០ ។

៣. **ផ្ទះរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉ូរ នៅភូមិហារម៉ូនី** ការបកប្រែព្រះគម្ពីរមរមនភាគច្រើនត្រូវបានសំរេចនៅទីនេះ ។ នៅលើច្រាំងទន្លេ សុសគ្វីហាណា បព្វជិតភាពត្រូវបានតាំងឡើងវិញ នៅឆ្នាំ ១៨២៩ (សូមមើល គ. និង ស. ១៣; ១២៨:២០; យ.ស. — ប្រវត្តិ ១:៧១–៧២) ។

៤. **ហ្វាយ៉ែត្ត** ពួកសាក្សីបីនាក់បានឃើញផ្ទាំងមាស និងទេវតាម៉ូរ៉ូណៃ (គ. និង ស. ១៧) ។ ការបកប្រែព្រះគម្ពីរមរមនត្រូវបានសំរេច នៅទីនេះ នៅខែមិថុនា ឆ្នាំ ១៨២៩ ។ សាសនាចក្រត្រូវបានរៀបចំឡើងនៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ (សូមមើល គ. និង ស. ២០; ២១) ។

៥. **មែនដុន** ផ្ទះដើមរបស់ព្រិកហាំ យ៉ង់ និងហ៊ីប៊ើ ស៊ី គិមបុល ។

៦. **ខឺតឡង់** ពួកអ្នកផ្សាយសាសនាដែលបានចាត់ឲ្យទៅផ្សាយដល់ពួកលេមិន គេបានឈប់នៅទីនេះ នៅឆ្នាំ ១៨៣០ ហើយបាន ធ្វើបុណ្យជ្រមុជទឹកឲ្យស៊ីឌនី រិកដុន និងពួកអ្នកផ្សេងទៀត នៅក្នុងតំបន់ខឺតឡង់ ។ នេះជាទីបញ្ជាការនៃសាសនាចក្រ ពីឆ្នាំ ១៨៣១ ទៅ ១៨៣៨ ។ ព្រះវិហារទីមួយនៃគ្រាកាន់កាប់ត្រួតត្រានេះ ត្រូវបានសង់នៅក្រុងខឺតឡង់ ហើយបានធ្វើបុណ្យឆ្លងនៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ ១៨៣៦ (សូមមើល គ. និង ស. ១០៩) ។

៧. **ព្រែកអេរី** សាខាបីនៃសាសនាចក្រនៅក្រុងញូវយ៉ោក បានធ្វើដំណើរតាមព្រែកអេរី និងបឹងអេរី ទៅក្រុងខឺតឡង់ រដ្ឋអូហៃអូ នៅខែមេសា និងខែឧសភា ឆ្នាំ ១៨៣១ ។

៨. **ហៃរ៉ាំ** យ៉ូសែប និងនាងអិមម៉ាបាននៅទីនេះ ពីខែកញ្ញា ឆ្នាំ ១៨៣១ ទៅខែកញ្ញា ១៨៣២ ។ យ៉ូសែប និងស៊ីឌនី រិកដុន បានធ្វើការបកប្រែព្រះគម្ពីរប៊ីប (ក.យ.ស.) ។ មានវិវរណៈជាច្រើនដែលបានទទួលនៅទីនេះ ៖ គ. និង ស. ១, ៦៥, ៦៧, ៦៨, ៦៩, ៧៣, ៧៤, ៧៦, ៧៩, ៨០, ៨១, ៩៩, ១៣៣ ។

៩. **អាមហើស្ត** យ៉ូសែប ស្ម៊ីធ ត្រូវបានគាំទ្រឲ្យធ្វើជាប្រធាននៃបព្វជិតភាពដ៏ខ្ពស់ នៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៨៣២ (សូមមើល គ. និង ស. ៧៥) ។

១០. **តូរ៉ុនតូ** ផ្ទះរបស់យ៉ូហាន ថេល័រ ជាប្រធានទីបីនៃសាសនាចក្រ និងនាងម៉ារា ហ្វៀលឌិង ស្ម៊ីធ ដែលជាប្រពន្ធរបស់ហៃរុម ស្ម៊ីធ ។

# ខឺតឡង់, រដ្ឋអូហៃអូ, ១៨៣០–៣៨

**ផែនទី ទី៤**




១. **ផ្ទះរបស់នូវល ខេ វិតនី** យ៉ូសែប និងនាងអិមម៉ា បាននៅទីនេះជាច្រើនអាទិត្យ បន្ទាប់ពីគេបានមកដល់ក្រុងខឺតឡង់ថ្មីៗ នៅឆ្នាំ ១៨៣១ ។

២. **ស្រែរបស់អ៊ីសាក មូលី** យ៉ូសែប និងនាងអិមម៉ា ស្ម៊ីធ បាននៅទីនេះ ពីខែមីនា រហូតដល់ខែកញ្ញា ឆ្នាំ ១៨៣១ ។ ពួកសង្ឃជាន់ ខ្ពស់ត្រូវបានតែងតាំងនៅទីនេះជាលើកដំបូង ។ យ៉ូសែបបានធ្វើការបកប្រែដោយយ៉ូសែប ស្ម៊ីធ (ក.យ.ស.) ។

៣. **ហាងរបស់នូវល ខេ វិតនី** គណៈប្រធានទីមួយនៃសាសនាចក្រត្រូវបានទទួលកូនសោទាំងឡាយនៃនគរនៅទីនេះ ។ សាលានៃពួក ព្យាការីបានជួបគ្នានៅទីនេះជាលើកដំបូង ។ ក.យ.ស. កំពុងតែនឹងធ្វើចប់នៅទីនេះ នៅឆ្នាំ ១៨៣៣ ។ យ៉ូសែប និងនាងអិមម៉ាបាននៅ ទីនេះ ពីឆ្នាំ ១៨៣២ ទៅ ១៨៣៣ ។ យ៉ូសែបបានទទួលវិវរណៈជាច្រើននៅទីនេះ ។

៤. **ផ្ទះសំណាក់របស់យ៉ូហាន ចនសុន** យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ ត្រូវបានហៅឲ្យធ្វើជាលោកអយ្យកោទីមួយនៃសាសនាចក្រនៅទីនេះ នៅឆ្នាំ ១៨៣៣ ។ ផ្ទះសំណាក់នេះមានរោងបោះពុម្ពទីមួយនៅក្រុងខឺតឡង់ ។ *The Evening and the Morning Star* ត្រូវបានបោះពុម្ពនៅទីនេះ បន្ទាប់ពីការបំផ្លាញរោងពុម្ពនៅឃុំចាកសុន រដ្ឋមិសសួរី ។ ពួកសាវក ១២ នាក់ បានចេញពីទីនេះ នៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៨៣៥ សំរាប់បេសកកម្មទីមួយរបស់ពួកគេ ។

៥. **ផ្ទះរបស់យ៉ូសែប ស្ម៊ីធ ជុញ៉រ** យ៉ូសែប និង នាងអិមម៉ាបាននៅទីនេះ ពីឆ្នាំ ១៨៣៤ ទៅ ១៨៣៧ ។ ការបកប្រែគម្ពីរអ័ប្រាហាំបាន ចាប់ផ្ដើមឡើង ។

៦. **រោងបោះពុម្ព** *ការបង្រៀនអំពីសេចក្ដីជំនឿ* ត្រូវបានធ្វើនៅទីក្នុងអាគារនេះ ។ ពួកសាវក ១២ នាក់ និងក្រុមទីមួយនៃក្រុម ៧០ នាក់ ត្រូវបានហៅ ហើយតែងតាំងនៅទីនេះ ។ គោលលទ្ធិ និងសេចក្ដីសញ្ញា (ច្បាប់ទីមួយ), ព្រះគម្ពីរមរមន (ច្បាប់ទីពីរ), *The Evening and the Morning Star, Latter Day Saints' Messenger and Advocate,* និងច្បាប់ទីមួយនៃ *Elders' Journal* ត្រូវបានបោះពុម្ពនៅទីនេះ ។

៧. **ព្រះវិហារខឺតឡង់** ព្រះវិហារនេះ គឺជាព្រះវិហារទីមួយនៅគ្រាកាន់កាប់ត្រួតត្រានេះ ។ ព្រះយេស៊ូវគ្រីស្ទបានលេចមក ហើយបាន ទទួលព្រះវិហារនេះ ។ លោកម៉ូសេ លោកអេលីយ៉ាស និងលោកអេលីយ៉ា បានលេចមក ហើយបានតាំងឡើងវិញនូវកូនសោខ្លះៗនៃ បព្វជិតភាព (សូមមើល គ. និង ស. ១១០) ។ សាលានៃពួកព្យាការីក៏បានជួបជុំគ្នានៅទីនេះដែរ ។ វិវរណៈទាំងឡាយដែលបានទទួល នៅទីនេះគឺ៖ គ. និង ស. ១០៩, ១១០, ១៣៧ ។

**ខឺតឡង់ (មិនប្រាប់កន្លែងច្បាស់ទេ)** នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៨៣៥ គោលលទ្ធិ និងសេចក្ដីសញ្ញា ត្រូវបានទទួលស្គាល់ជាព្រះគម្ពីរ ។ វិវរណៈទាំងឡាយដែលបានទទួលនៅក្រុងខឺតឡង់គឺ៖ គ. និង ស. ៤១–៥០, ៥២–៥៦, ៦៣–៦៤, ១០២–១០៤, ១០៦–១១០, ១៣៤, និង ១៣៧ ។ កណ្ឌទី ១០៤ ចែកទីកន្លែងទាំងឡាយទុកជាការកាន់កាប់ត្រួតត្រា ដល់ពួកសាមាជិកក្នុងសាសនាចក្រ ដែលចូល រួមក្នុងសហសមាគម (សូមមើលខ ១៩–៤៦) ។

# ផែនទី ទី៥

## តំបន់នៅរដ្ឋមិសសួរី, រដ្ឋអិលលីណោយ, និងរដ្ឋអៃអូវ៉ា នៅក្នុងសហរដ្ឋ




១. **អិនឌីប៉ែនដែន្ស** សំគាល់ទុកជាកន្លែងជួបជុំគ្នានៃស៊ីយ៉ូន (សូមមើល គ. និង ស. ៥៧:៣) ។ កន្លែងសំរាប់សង់ព្រះវិហារត្រូវបានធ្វើ ពិធីឆ្លងនៅ ថ្ងៃទី ៣ ខែសីហា ឆ្នាំ ១៨៣១ ។ ពួកបរិសុទ្ធត្រូវគេបណ្តេញចេញពីទីនេះ នៅឆ្នាំ ១៨៣៣ ។

២. **ទន្លេហ្វ៊ិស៊ីង** យ៉ូសែប ស៊្មីធ និងជំរុំស៊ីយ៉ូនបានធ្វើដំណើរពីក្រុងខឺតឡង់ រដ្ឋអូហៃអូ ទៅរដ្ឋមិសសួរី នៅឆ្នាំ ១៨៣៤ ដើម្បីទៅតាំង ពួកបរិសុទ្ធនៅឃុំចាកសុន ដល់ដីធ្លីរបស់គេវិញ ។ គ. និង ស. ១០៥ ត្រូវបានបើកសម្តែងប្រាប់នៅលើច្រាំងទន្លេនេះ ។

៣. **ហ្វារវែស្ទ** នេះគឺជាទីលំនៅដ៏ធំបំផុតរបស់ពួកមរមននៅរដ្ឋមិសសួរី ។ កន្លែងមួយសំរាប់សង់ព្រះវិហារត្រូវបានធ្វើពិធីឆ្លងនៅ កន្លែងនេះ (សូមមើល គ. និង ស. ៧៨:១៥; ១០៧:៥៣–៥៧; ១១៦) ។

៤. **អ័ដាម-អុនដៃ-អាម៉ាន** ព្រះអម្ចាស់ទ្រង់បានប្រាប់ថាកន្លែងនេះដែលនៅក្នុងរដ្ឋមិសសួរីប៉ែកខាងលើ គឺជាកន្លែងនៅពេលខាងមុខ សំរាប់ជួបជុំគ្នា ក្នុងកាលព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងយាងមកជួបនឹងលោកអ័ដាម និងពួកពង្សដ៏សុចរិតរបស់លោក (សូមមើល គ. និង ស. ៧៨:១៥; ១០៧:៥៣–៥៧; ១១៦) ។

៥. **គុកលិប៊ីទី** យ៉ូសែប ស៊្មីធ និងពួកអ្នកផ្សេងៗទៀតត្រូវបានចោទក្លែងក្លាយ ហើយជាប់គុកនៅទីនេះ ពីខែធ្នូ ឆ្នាំ ១៨៣៨ ទៅដល់ខែ មេសា ឆ្នាំ ១៨៣៩ ។ នៅកណ្តាលពេលដ៏ប្រកបដោយការខ្វល់ខ្វាយដល់សាសនាចក្រ នោះយ៉ូសែបបានបួងសួងដល់ព្រះអម្ចាស់ សូម ការដឹកនាំ ហើយក៏បានទទួល គ. និង ស. ១២១–១២៣ ។

៦. **ណោវូ** នៅឯទន្លេមីស៊ីស៊ីពពី កន្លែងនេះគឺជាកន្លែងជួបជុំគ្នាសំរាប់ពួកបរិសុទ្ធ ពីឆ្នាំ ១៨៣៩ ទៅ ១៨៤៦ ។ នៅទីនេះមានព្រះ វិហារមួយបានសង់ឡើង ហើយពិធីបរិសុទ្ធទាំងឡាយ ដូចជាបុណ្យជ្រមុជទឹកជំនួសមនុស្សស្លាប់, អំណោយទានពិសិដ្ឋ, និងការភ្ជាប់ គ្រួសារ បានចាប់ផ្តើមឡើង ។ នៅទីនេះហើយដែលសមាគមសង្គ្រោះបានរៀបចំឡើង នៅឆ្នាំ ១៨៤២ ។ វិវរណៈទាំងឡាយដែលបានទទួលគឺៈ គ. និង ស. ១២៤–១២៩ ។

៧. **កាតធេច** នៅទីនេះហើយដែលយ៉ូសែប ស៊្មីធ និងបងប្រុសលោក គឺហៃរុម ត្រូវគេធ្វើទុក្ខកម្ម នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ (សូមមើល គ. និង ស. ១៣៥) ។

៨. **វិនទើរ ខ្វទើរ** ជាទីបញ្ជាការសំរាប់ឲ្យពួកបរិសុទ្ធស្នាក់នៅ (១៨៤៦–៤៨) កាលធ្វើដំណើរទៅប្រកភ្នំសលត៍លេក ។ ជំរុំអ៊ីស្រាអែលត្រូវបានរៀបចំឡើង សំរាប់ការធ្វើដំណើរទៅភូមិភាគខាងលិច (គ. និង ស. ១៣៦) ។

៩. **ខោនសិល ប្លើព្យ (ខានស្វិល)** គណៈប្រធានទីមួយត្រូវបានគាំទ្រនៅទីនេះ នៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ១៨៤៧ ដោយមានព្រិកហាំ យ៉ង់ ធ្វើជាប្រធាន ។

# ដំណើរនៃសាសនាចក្រទៅទិសខាងលិច




១. **ហ្វាយ៉ែត្ត** ព្យាការីយ៉ូសែប ស្ម៊ីធ បានចេញពីភូមិហ្វាយ៉ែត្តទៅក្រុងខឺតឡង់ រដ្ឋអូហៃអូ នៅខែមករា ឆ្នាំ ១៨៣១ ។ សាខាទាំងបី ដែលនៅរដ្ឋនូវយ៉ោកក៏ទៅតាមនៅខែមេសា និងខែឧសភា ឆ្នាំ ១៨៣១ នៅក្រោមបញ្ជារបស់ព្រះអម្ចាស់ដែលឲ្យទៅជួបជុំគ្នា (សូមមើល គ. និង ស. ៣៧; ៣៨) ។

២. **ខឺតឡង់** ជាទីបញ្ជាការនៃសាសនាចក្រពីថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ១៨៣១ ទៅថ្ងៃទី ១២ ខែមករា ឆ្នាំ ១៨៣៨ កាលព្យាការីផ្លាស់ ទៅភូមិហ្វារវែស្ត រដ្ឋមិសសួរី ។

៣. **អ៊ិនឌីប៉ែនដែន្ស** ព្រះអម្ចាស់បានប្រាប់ថា អ៊ិនឌីប៉ែនដែន្ស (នៅឃុំចាកសុន, រដ្ឋមិសសួរី) គឺជាទីជួបជុំគ្នានៃស៊ីយ៉ូន នៅខែកក្កដា ឆ្នាំ ១៨៣១ (សូមមើល គ. និង ស. ៥៧:៣) ។ ហ្វូងមនុស្សកំណាចបានបង្ខំឲ្យពួកបរិសុទ្ធចេញពីឃុំចាកសុន នៅខែវិច្ឆិកា ឆ្នាំ ១៩៣៣ ។

៤. **លិប៊ើទី** ពួកបរិសុទ្ធពីឃុំចាកសុនបានជួបជុំគ្នានៅឃុំឃ្លៃ ពីឆ្នាំ ១៨៣៣ ទៅ ១៨៣៦ កាលពួកគេតម្រូវឲ្យចេញទៀត ។ ព្យាការី យ៉ូសែប ស្ម៊ីធ និងពួកឯអ្នកផ្សេងទៀតត្រូវជាប់គុកនៅទីនេះ ។

៥. **ហ្វារវែស្ត** ទីជំរកត្រូវបានតាំងឡើងនៅទីនេះ សំរាប់ពួកបរិសុទ្ធនៅឆ្នាំ ១៨៣៦–៣៨ ។ ជាទីបញ្ជាការនៃសាសនាចក្រនៅឆ្នាំ ១៨៣៨ ។ នៅឆ្នាំ ១៨៣៨–៣៩ ពួកបរិសុទ្ធត្រូវបានបង្ខំឲ្យភៀសខ្លួនរត់ទៅរដ្ឋអិលលីណោយ ។

៦. **ណៅវូ** ជាទីបញ្ជាការនៃសាសនាចក្រនៅឆ្នាំ ១៨៣៩–៤៦ ។ ក្រោយពីទុក្ករកម្មនៃព្យាការី និងបងប្រុសរបស់លោក ពួកបរិសុទ្ធ បានផ្លាស់ទៅនោងភូមិភាគខាងលិច ។

៧. **ខោនសិល ប្លើព្យ** ពួកអ្នកត្រួសត្រាយបានមកដល់ទីនេះនៅខែមិថុនា ឆ្នាំ ១៨៤៦ ។ សមាជិកពីកងវរសេនាតូចមរមនបានចេញ ដំណើរនៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៨៤៦ នៅក្រោមការដឹកនាំរបស់យេម្ស អាលលិន ។

៨. **វិនទើរ ខ្វទើរ** ជាទីបញ្ជាការនៃសាសនាចក្រនៅឆ្នាំ ១៨៤៦–៤៨ ។ ក្រុមទៅមុនគេ ដែលនៅក្រោមការដឹកនាំរបស់ប្រធាន ព្រិកហាំ យ៉ង់ បានចេញដំណើរទៅភូមិភាគខាងលិច នៅខែមេសា ឆ្នាំ ១៨៤៧ ។

៩. **បន្ទាយលៀវិនវឺត** កងវរសេនាតូចមរមនត្រូវបានប្រដាប់ខ្លួននៅទីនេះ មុននឹងចេញទៅភូមិភាគខាងលិចនៅខែសីហា ឆ្នាំ ១៨៤៦ ។

១០. **សាន តាហ្វេ** ភីលីព យុក បានបញ្ជាកងវរសេនាតូចមរមន កាលពួកគេចេញដំណើរពីទីនេះទៅនៅថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៨៤៦ ។

១១. **ភេបូ** មានកងទាហានឈឺបីកងដែលបានបញ្ជាឲ្យទៅឯភូមិភេបូ ដើម្បីទៅសំរាក ជាទីដែលពួកគេបានស្នាក់នៅរដូវរងារនៃឆ្នាំ ១៨៤៦–៤៧ ។

១២. **សានឌីអេកូ** កងវរសេនាតូចមរមនបានធ្វើដំណើរ ៣,២០០ គ.ម. ចប់នៅទីនេះ នៅថ្ងៃទី ២៩ខែមករា ឆ្នាំ ១៨៤៧ ។

១៣. **ឡូ អង់កិឡែស** កងវរសេនាតូចមរមនត្រូវបានឲ្យចេញនៅទីនេះ នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ១៨៤៧ ។

១៤. **សាក្រាម៉ង់តូ** សមាជិកពីកងវរសេនាតូចខ្លះដែលបានឲ្យចេញ គេបានធ្វើការនៅទីនេះ និងនៅឯរោងកិនស្រូវរបស់សើតទើរ នៅឯទន្លេអាមេរិកាំងខាងកើតបន្តិច ជាទីដែលពួកគេបានជួយរកឃើញមាស ។

១៥. **ទីក្រុងសលត៍លេក** ព្រិកហាំ យ៉ង់ បានមកដល់ច្រកភ្នំសលត៍លេក នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ១៨៤៧ ។

## ផែនទី ទី៧


មហាសមុទ្រប៉ាស៊ីហ្វិកខាងជើង
អាស៊ី
អឺរ៉ុប
អាហ្វ្រិក
អូស្ត្រាលី
មហាសមុទ្រឥណ្ឌា
មហាសមុទ្រអាត្លង់ទិចខាងជើង
មហាសមុទ្រអាត្លង់ទិចខាងត្បូង
អាមេរិកខាងជើង
អាមេរិកកណ្ដាល
អាមេរិកខាងត្បូង
មហាសមុទ្រប៉ាស៊ីហ្វិក
មហាសមុទ្រប៉ាស៊ីហ្វិកខាងត្បូង
អង់តាក់ទិក
ជ
ក
ខ
គ
ឃ
ង
ច
ឆ
ជ
១
២
៣
៤



**១. ព្រៃពិសិដ្ឋ** នៅក្នុងព្រៃក្បែរផ្ទះលោកនេះហើយដែលព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលការនិមិត្តទីមួយ ។



**២. តំបន់នៃភ្នំគូម៉ូរ៉ា និងម៉ានឆែសស្ទើរ-ប៉ាលម៉ៃរ៉ា** ទេវតាមរ៉ូណៃបាននាំយ៉ូសែប ស្ម៊ីធ ឲ្យរកឃើញផ្ទាំងមានទាំងឡាយ ដែលលោកបាន កប់ទុកនៅឯភ្នំនេះ (ភ្នំឃើញនៅចំកណ្ដាលប៉ែកខាងលើ) ។



**៣. ផ្ទះឈើរបស់យ៉ូសែប ស្ម៊ីធ ស៊ីញ៉័រ** នេះជាផ្ទះដែលបានធ្វើឲ្យដូចផ្ទះ ដែលគ្រួសារស្ម៊ីធបានរស់នៅគ្រាមួយ ។



**៤. គ្រានឌិនក្រុមហ៊ុនបោះពុម្ព និងរោងពុម្ព** ការបោះពុម្ពព្រះគម្ពីរមរមនលើកទីមួយ គឺបានធ្វើនៅទីនេះ ។



**៥. ទន្លេសុសគ្វីហាណា** បព្វជិតភាពអើរ៉ុន និងបព្វជិតភាពមិលគីស្សាដែកត្រូវបានតាំងឡើងវិញ នៅលើច្រាំងទន្លេនេះ (សូមមើល គ. និង ស. ១៣; ១២៨:២០) ។



**៦. ផ្ទះឈើរបស់ពេត្រុស វិតមើរ ស៊ីញ៉័រ** ផ្ទះដែលធ្វើឲ្យដូចផ្ទះនេះត្រូវបានសង់នៅកន្លែងដែលសាសនាចក្របានរៀបចំឡើង នៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៨៣០ ។




**៧. ហាងរបស់នូវល ខេ វិតនី និងក្រុមហ៊ុន** វិវរណៈដែលបានក្លាយទៅជា ពាក្យសំដីនៃប្រាជ្ញាវាងវៃ (សូមមើល គ. និង ស. ៨៩) គឺបានទទួលនៅទីនេះ ហើយព្រមទាំងវិវរណៈផ្សេងៗទៀត ។



**៨. ផ្ទះរបស់យ៉ូហាន ចនសុន** កាលនៅផ្ទះនេះ ហើយធ្វើការបកប្រែព្រះគម្ពីរប៊ីប នោះព្យាការីយ៉ូសែប ស្ម៊ីធ និងស៊ីឌនី រិកដុន បានទទួល វិវរណៈមួយ ដែលឥឡូវនេះកត់នៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៦ ហើយព្រមទាំងវិវរណៈផ្សេងៗទៀត ។



**៩. ព្រះវិហារខឺតឡង់** ជាព្រះវិហារដែលបានសង់លើកដំបូងបង្អស់នៅគ្រាកាន់កាប់ត្រួតត្រានេះ នៅឆ្នាំ ១៨៣៦ ។ នៅក្នុងព្រះ វិហារនេះ ព្រះយេស៊ូវគ្រីស្ទ លោកម៉ូសេ លោកអេលីយ៉ាស លោកអេលីយ៉ា បានលេចមក ហើយបានតាំងឡើងវិញនូវកូនសោទាំងឡាយ នៃបព្វជិតភាព (សូមមើល គ. និង ស. ១១០) ។



**១០. ច្រកភ្នំនៃអ័ដាម-អុនដៃ-អាម៉ាន** នៅទីនេះហើយដែលលោកអ័ដាម និងពូជពង្សរបស់លោកដ៏សុចរិតបានជួបគ្នា (សូមមើល គ. និង ស. ១០៧:៥៣–៥៧) ។ លោកអ័ដាម ពួកព្យាការីផ្សេងៗទៀត និងពួកបរិសុទ្ធដែលស្មោះត្រង់នៅគ្រប់សម័យនឹងទៅជួបព្រះអង្គ សង្គ្រោះនៅទីនេះ មុនការយាងមកលើកទីពីររបស់ទ្រង់ ។



**១១. កន្លែងសំរាប់ព្រះវិហារហ្វារវែស្ត** នៅឆ្នាំ ១៨៣៨ ព្រះអម្ចាស់ទ្រង់បានបញ្ជាឲ្យពួកបរិសុទ្ធសង់ព្រះវិហារមួយនៅទីនេះ (សូមមើល គ. និង ស. ១១៥:៧–៨) ។ ការបៀតបៀនពីហ្វូងមនុស្សកំណាចបានបង្ការពួកគេមិនឲ្យធ្វើបានឡើយ ។



**១២. គុកលិបឺទី** កាលត្រូវគេចោទក្លែងក្លាយ ហើយជាប់គុកនៅទីនេះ ព្យាការីយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយដែលឥឡូវនេះ កត់នៅក្នុង គោលលទ្ធិ និង សេចក្ដីសញ្ញា ១២១–១២៣ ។



**១៣. វិមាននៅក្រុងណេវូ** ជាផ្ទះសំរាប់គ្រួសាររបស់យ៉ូសែបស្មីធចាប់ផ្ដើមនៅឆ្នាំ១៨៤៣។ នៅសម័យដំបូង នៃ សាសនាចក្រទីនេះគឺជាទីជួបជុំគ្នាខាងការរស់នៅក្នុងចំណោមពួកបរិសុទ្ធ ។



**១៤. ហាងឥដ្ឋក្រហមរបស់ព្យាការីយ៉ូសែប ស្ម៊ីធ** នៅក្នុងអាគារនេះហើយដែលសមាគមសង្គ្រោះបានរៀបចំឡើង នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ១៨៤២ ។



**១៥. ព្រះវិហារណៅវូ** រូបគំរូនេះបង្ហាញពីលំអនៃសំណង់នោះ មុនត្រូវឆេះនៅឆ្នាំ ១៨៤៨ ។



**១៦. គុកកាតធេច** នៅទីនេះហើយដែលព្យាការីយ៉ូសែប ស្ម៊ីធ និងហៃរុម ជាបងប្រុសលោក ត្រូវគេធ្វើទុក្ករកម្ម នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៨៤៤ (សូមមើល គ. និង ស. ១៣៥) ។



**១៧. ការធ្វើនិក្ខមនំទៅភូមិភាគខាងលិច** នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ១៨៤៦ រទេះលើកទីមួយបានឆ្លងកាត់ទន្លេមិសិស៊ីពី ដើម្បីចាប់ផ្ដើម ដំណើរក្នុងប្រវត្តិសាស្ត្រទៅភូមិភាគខាងលិច ។



១៨. ព្រះវិហារសលត៍លេក ច្រកភ្នំសលត៍លេកនេះ គឺជាទីសំគាល់មួយដែលបានសង់អស់ ៤០ ឆ្នាំ ។

# ផែនទី
# និងរូបថតទាំងឡាយពីព្រះគម្ពីរ

រូបថតនៃទីកន្លែងដ៏សំខាន់ៗទាំងនេះជាតួយ៉ាងអំពីដែនដីទាំងឡាយដែលព្រះយេស៊ូវបានយាង ជាទីដែលពួកព្យាការីបាននៅ ហើយបាន បង្រៀន និងជាទីដែលព្រឹត្តិការណ៍ជាច្រើនក្នុងព្រះគម្ពីរបានកើតឡើង ។ ដើម្បីជួយអ្នកប្រើប្រាស់រូបថតទាំងឡាយឲ្យកាន់តែប្រសើរឡើង ក្នុងការសិក្សារបស់អ្នក រូបថតនីមួយៗមានពាក្យពណ៌នាប្រាប់ដ៏ខ្លីៗ ។ លេខប្រាប់អំពីពាក្យពណ៌នា និងចំណងជើងនោះត្រូវគ្នានឹងរូបថត ដោយមានលេខ និងចំណងជើងដូចគ្នា ។ ឃ្លាទីមួយបន្ទាប់ពីចំណងជើងនៃពាក្យពណ៌នានោះពន្យល់ប្រាប់ពីបរិយាកាសនៃរូបថត ព្រមទាំង ការសំខាន់ៗ ដើម្បីរកមើល ហើយតែងតែប្រាប់ថារូបថតនោះបែរទៅទិសខាងណាផង ។ រួចហើយព្រឹត្តិការណ៍សំខាន់ៗខាងបទគម្ពីរ ក៏បាននាយប្រាប់ ព្រមទាំងមានសេចក្ដីយោងទាំងឡាយខាងបទគម្ពីរ ដែលអ្នកអាចបើកមើលថែមទៀត អំពីព្រឹត្តិការណ៍ទាំងនោះ ។

**១. ទន្លេនីល និងស្រុកអេស៊ីព្ទ**

មានរុក្ខជាតិដុះនៅតាមច្រាំងទន្លេនីល ។ នៅត្រើយនោះ មានទីធ្លាដែលជាទីរហោស្ថានដែលរាលស្ទើតែពាសពេញស្រុកអេស៊ីព្ទ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ជាដែនដីដែលបានរកឃើញដោយនាងអេស៊ីព្ទុស (អ័ប្រា. ១:២៣–២៥) ។ លោកអ័ប្រាហាំបានទៅស្រុកអេស៊ីព្ទ (លោកុ. ១២:១០–២០; អ័ប្រា. ២:២១–២៥) ។ យ៉ូសែបត្រូវបានលក់យកទៅស្រុកអេស៊ីព្ទ បានក្លាយទៅជាអ្នកត្រួតត្រាម្នាក់ ហើយបាន ជួយសង្គ្រោះគ្រួសាររបស់លោកឲ្យរួចផុតពីអំណត់អត់ (លោកុ. ៣៧; ៣៩–៤៦) ។ ពូជពង្សរបស់យ៉ូសែបបានរស់នៅស្រុកអេស៊ីព្ទ (លោកុ. ៤៧; និក្ខ. ១; ១២:៤០) ។ បុត្រីរបស់ផារ៉ោនបានឃើញទារកម៉ូសេនៅក្នុងទន្លេ ហើយបានយកលោកមកចិញ្ចឹម (និក្ខ. ២:១–១០) ។ លោកម៉ូសេបាននាំពួកសាសន៍អ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទ (និក្ខ. ៣–១៤) ។ នាងម៉ារា យ៉ូសែប និងព្រះយេស៊ូវបានទៅ នៅស្រុកអេស៊ីព្ទអស់មួយរយៈ ដើម្បីចេញឲ្យផុតពីស្ដេចហេរ៉ូឌ (ម៉ាថាយ ២;១៣–១៥, ១៩–២១) ។ នៅថ្ងៃចុងក្រោយបង្អស់ ពួកអេស៊ីព្ទនឹងស្គាល់ព្រះអម្ចាស់ ហើយព្រះអម្ចាស់នឹងប្រទានពរដល់ស្រុកអេស៊ីព្ទ (អេសាយ ១៩:២០–២៥) ។ (សូមមើល សេចក្ដីណែនាំដល់បទព្រះ គម្ពីរ, «អេស៊ីព្ទ») ។

**២. ភ្នំស៊ីណាយ (ហូរេប) និងទីរហោស្ថានស៊ីណាយ**

ភ្នំដ៏សំខាន់ទាំងឡាយ គឺជាកំពូលភ្នំយេបិលម៉ូសា (ភ្នំម៉ូសេ) ។ មានទីកន្លែងជាច្រើនដែលអាចទៅជាភ្នំស៊ីណាយ ។ កន្លែងដែលគេឯង ទទួលស្គាល់ គឺជាភ្នំយេបិលម៉ូសា ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ព្រះទ្រង់បានលេចមកឯលោកម៉ូសេ ហើយបានប្រទានដល់លោកនូវព្រះបញ្ញត្តិ ១០ប្រការ (និក្ខ. ១៩–២០) ។ លោកម៉ូសេ លោកអើរ៉ុន ព្រមទាំងកូនប្រុសរបស់អើរ៉ុនពីរនាក់ និងពួកចាស់ទុំ ៧០ នាក់ បានឃើញ ហើយបានទូលជាមួយនឹងព្រះ (និក្ខ. ២៤:៩–១២) ។ ព្រះទ្រង់បានប្រទានដល់លោកម៉ូសេ នូវការបង្គាប់ទាំងឡាយ ដើម្បីសង់រោងឧបោសថ (និក្ខ. ២៥–២៨; ៣០–៣១) ។ ពួកសាសន៍អ៊ីស្រាអែលបានថ្វាយបង្គំរូបកូនគោមាស ដែលពួកគេបានបបួលឲ្យលោកអើរ៉ុនធ្វើ (និក្ខ. ៣២:១–៨) ។ លោក អេលីយ៉ាបានរត់គៀសខ្លួនទៅដែនដីនេះ ចេញពីច្រកភ្នំយេសរាល ជាទីកន្លែងដែលក្សត្រីយេសិ៍បិលបានគង់នៅ (១ ពង្សាវ. ១៩:១–១៨) ។ ទីនេះក៏ជាកន្លែងដែលលោកអេលីយ៉ាបានទូលជាមួយនឹងព្រះ (១ ពង្សាវ. ១៩:៨–១៩) ។

**៣. ទីរហោស្ថាននៅខេត្តយូដា និងសមុទ្រស្លាប់**

មើលទៅទិសខាងត្បូងឆៀងខាងកើត គឺជាទីរហោស្ថាននៅខេត្តយូដា ។ ដែលឃើញនៅខាងក្រោយ គឺជាសមុទ្រស្លាប់ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ទីរហោស្ថាននៅខេត្តយូដា គឺជាទីជំរកដ៏សំខាន់មួយនៅច្រើនសម័យនៃប្រវត្តិសាស្ត្រដើម ។ ដាវីឌបានពួនពី ស្ដេចសូល (១ សាំ. ២៦:១–៣) ។ ព្រះយេស៊ូវបានតមអាហារអស់ ៤០ ថ្ងៃ ៤០ យប់ (ម៉ាថាយ ៤:១–១១; ម៉ាកុស ១:១២–១៣) ។ ព្រះយេស៊ូវបានយាងតាមផ្លូវពីក្រុងយេរូសាឡិម ទៅក្រុងយេរីខូរ កាត់ទីរហោស្ថាននៅខេត្តយូដា ទុកជាបរិយាកាសសំរាប់ពាក្យប្រៀប ប្រដូចអំពីសាសន៍សាម៉ារីដែលល្អ ពីព្រោះពួកអ្នកធ្វើដំណើរតែឯង ងាយមានគ្រោះថ្នាក់នៅទីនោះ (លូកា ១០:២៥–៣៧) ។ (សូមមើល សេចក្ដីណែនាំដល់បទព្រះគម្ពីរ, «សមុទ្រស្លាប់») ។

**៤. កាដេស-បារនេ**

នេះជារូបភាពមើលពីទិសខាងជើងឆៀងខាងកើត នូវច្រកភ្នំនៃទីរហោស្ថានដ៏ធំ (ក៏ហៅថា ប្រឡាយគោក) ដែលមានកាដេស-បារនេ ។ ស្ទឹងដែលហូរមកទីនេះនៅរដូវវស្សា ធ្វើឲ្យទីនេះទៅជាមានទឹកជោកជាំ ហើយមានផ្លែផ្កាដ៏បរិបូរ នៅក្នុងទីរហោស្ថានស៊ិន ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នេះប្រហែលកន្លែងដែលលោកម៉ូសេបានចាត់មនុស្ស ១២ នាក់ឲ្យទៅស៊ើបការមើលស្រុកកាណាន (ជនគ. ១៣:១៧–៣០) ។ ទីនេះទុកជាជំរុំសំរាប់ពួកសាសន៍អ៊ីស្រាអែលនៅវវាង ៣៨ ឆ្នាំ ក្នុងកំឡុងពេល ៤០ ឆ្នាំដែលពួកគេដើរវសាត់ព្រាត់ នៅក្នុងទីរហោស្ថាន (ចោទិ. ២:១៤) ។ នាងម៉ារាមបានស្លាប់ ហើយបានកប់នៅទីនេះ (ជនគ. ២០:១) ។ មានព្រឹត្តិការណ៍អំពីការបះបោររបស់កូរេ, ការរអ៊ូរទាំនៃប្រជាជន, និងដំបងរបស់អើរ៉ុនពកឡើង (ជនគ. ១៦–១៧) ។ នៅក្បែរទីនេះ លោកម៉ូសេបានវាយថ្ម ហើយក៏មានទឹកហូរចេញមក (ជនគ. ២០:៧–១១) ។

**៥. ផ្នូរទាំងឡាយនៃពួកអយ្យកោ**

គឺជាសំណង់មួយដ៏ល្បីល្បាញបំផុតនៅដែនដីបរិសុទ្ធ ។ គឺបានសង់នៅហេប្រុន ដោយស្ដេចហេរ៉ូឌ ពីលើកន្លែងចាស់បុរាណ នៅក្នុងរូងភ្នំ ម៉ាក់ពេឡា ដែលបានទិញដោយលោកអ័ប្រាហាំ ទុកជាកន្លែងកប់ខ្មោចគ្រួសារ (លោកុ. ២៣) ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ជាកន្លែងកប់ខ្មោចនាងសារ៉ា (លោកុ. ២៣) និងលោកអ័ប្រាហាំ (លោកុ. ២៥:៩) ។ សពលោកអ៊ីសាក នាងរេបិកា និងនាងលេអា ក៏បានកប់នៅទីនេះដែរ (លោកុ. ៤៩:៣០–៣១) ។ សពយ៉ូសែបក៏បាននាំពីស្រុកអេស៊ីព្ទ មកស្រុកកាណាន ហើយបានកប់នៅក្នុងរូងភ្នំ (លោកុ. ៥០) ។

### ៦. ស្រុកភ្នំនៅយូដា

ស្រុកភ្នំនៅយូដា គឺបណ្តោយ ៥៦ គ.ម និងទទឹង ២៧ គ.ម. ។

*ព្រឹត្តិការណ៍សំខាន់ៗ* ៖ ព្រះអម្ចាស់បានសន្យាថានឹងឲ្យដែនដីនេះដល់លោកអ័ប្រាហាំ និងពូជលោក (លោកុ. ១៣;១៤–១៨; ១៧:៨) ។ សពនាងសារ៉ា និងលោកអ័ប្រាហាំត្រូវបានកប់នៅក្នុងរូងភ្នំម៉ាក់ពេឡានៅហេប្រុន (លោកុ. ២៣:១៩; ២៥:៩) ។ ហ្លួងដាវីឌបានវាយយកក្រុងយេរូសាឡិមពីពួកសាសន៍យេប៊ូស (២ សាំ. ៥:៤–៩) ។ មានព្រឹត្តិការណ៍ថែមទៀតពីព្រះគម្ពីរសញ្ញាចាស់ដែលបានកត់ទុកថា បានកើតឡើងនៅលើភ្នំទាំងនេះ ជាងនៅកន្លែងផ្សេងៗទៀត ។

### ៧. បេថ្លេហិម

រូបថតនេះបង្ហាញភ្នំរេជិបរដុប និងវាលស្មៅរបស់ពួកអ្នកគង្វាលសត្វចៀមនៅខាងមុខ ដោយមានទីក្រុងយេរូសាឡិមទំនើបនៅខាងក្រោយ ។

*ព្រឹត្តិការណ៍សំខាន់ៗ* ៖ សពនាងរ៉ាជែលត្រូវបានកប់នៅក្បែរទីនេះ (លោកុ. ៣៥:១៦–២០) ។ នាងរស់ និងបូអូសបានរស់នៅទីនេះ (នាងរស់ ១:១៩–២:៤) ។ ស្តេចដាវីឌត្រូវបានប្រសូត ហើយចាក់ប្រេងតាំងជាស្តេចនៅទីនេះ (១ សាំ. ១៦:១–១៣) ។ ព្រះអម្ចាស់ ទ្រង់បានប្រសូតនៅទីនេះ ហើយពួកអ្នកគង្វាលសត្វចៀម និងពួកអ្នកប្រាជ្ញបានថ្វាយបង្គំទ្រង់ (ម៉ាថាយ ២:១–១១; លូកា ២:៤–១៦) ។ (សូមមើល សេចក្តីណែនាំដល់បទព្រះគម្ពីរ, «បេថ្លេហិម») ។

### ៨. យេរូសាឡិម

មើលទៅខាងជើង ៖ នៅចំកណ្តាលរូបថត មានចេតិយនៃពួកមូស្លាមដែលមានដោមលាបមាស ហៅថា ដោមធ្វើពីថ្ម ។ ពួកសាសន៍យូដាបានថ្វាយបង្គំពីបុរាណនៅក្នុងព្រះវិហារទាំងឡាយដែលមានទីនេះ ។ កំផែងដែលនៅក្បែរដោមធ្វើពីថ្មនោះព័ទ្ធជុំវិញទីក្រុងយេរូសាឡិមចាស់ ។ នៅខាងស្តាំកំផែង គឺជាច្រកភ្នំកេដ្រុន ។ នៅស្តាំដៃឆ្ងាយ គឺជាភ្នំដើមអូលីវ ។ ទៅខាងជើង ត្រើយដោមធ្វើពីថ្ម គឺប្រហែលជាទីគាល់កូថា ឬកាល់វ៉ារី ។

*ព្រឹត្តិការណ៍សំខាន់ៗ* ៖ ក្រុងយេរូសាឡិមត្រូវបានហៅថា ក្រុងសាឡិមពីបុរាណ (ទំនុក. ៧៦:២) ។ លោកអ័ប្រាហាំបានថ្វាយដង្វាយ១ភាគ១០ ដល់លោកមិលគីស្សាដែក (លោកុ. ១៤:១៨–២០) ។ លោកអ័ប្រាហាំបានយកអ៊ីសាកមកធ្វើយញ្ញបូជា (លោកុ. ២២:២–១៤) ។ ស្តេចដាវីឌបានវាយយកក្រុងយេរូសាឡិមពីពួកសាសន៍យេប៊ូស (២ សាំ. ៥:៤–៩) ។ ស្តេចសាឡូម៉ូនបានសង់ព្រះវិហារមួយ (១ ពង្សាវ. ៦–៧) ។ លីហៃបានចេញពីទីនេះ ដើម្បីទៅឯដែនដីសន្យា (១ នីហ្វៃ ១:៤; ២) ។ ព្រះអម្ចាស់ទ្រង់បានធ្វើការងារបំរើ, បានធ្វើឲ្យធួននឹងបាបទាំងឡាយរបស់យើង, ហើយមានព្រះជន្មរស់ឡើងវិញ (ម៉ាថាយ ២១–២៩) ។ ដូចដែលព្រះអម្ចាស់បានព្យាករ ទុកថា ក្រុងយេរូសាឡិមនឹងត្រូវបំផ្លាញចោលនៅពេលឆាប់ៗបន្ទាប់ពីការសុគតរបស់ទ្រង់ ។ យ.ស. — ម៉ាថាយ ១:៣–២០) ។ ក្រុងយេរូសាឡិមនឹងត្រូវគេវាយយកនៅថ្ងៃចុងក្រោយបង្អស់ (អេសេ. ៣៨–៣៩; យ៉ូអែល ២–៣; វិវរ. ១១; ១៦) ។ ព្រះអម្ចាស់ទ្រង់នឹងលេចមកឯទីនេះ មុនការយាងមកលើកទីពីរបន្តិច (សាការី ១២–១៤; គ. និង ស. ៤៥:៤៨–៥៣) ។ (សូមមើល សេចក្តីណែនាំដល់បទព្រះគម្ពីរ, «សាឡិម») ។

### ៩. ព្រះវិហារហេរ៉ូឌ

រូបថតនេះគឺជារូបគំរូពីព្រះវិហារហេរ៉ូឌ ដូចដែលគេស្មាននៅឆ្នាំ ៦៧ គ.ស. ។ កំផែងដែលព័ទ្ធជុំវិញបរិវេណព្រះវិហារនោះមានទីបរិសុទ្ធ ដូចជាបរិសុទ្ធលើអស់ទាំងបរិសុទ្ធ, ទីបរិសុទ្ធ, និងទីលានបី ។

*ព្រឹត្តិការណ៍សំខាន់ៗ* ៖ យ៉ូសែប និងនាងម៉ារាបានយកទារកយេស៊ូវទៅថ្វាយនៅព្រះវិហារ (លូកា ២:២២–៣៨) ។ ព្រះអម្ចាស់ទ្រង់បានបង្រៀននៅក្នុងព្រះវិហារ កាលមានព្រះជន្មាយុ ១២ ជន្ម (លូកា ២:៤១–៤៦) ។ ព្រះអម្ចាស់បានដេញពួកអ្នកដូរប្រាក់ចេញពីព្រះវិហារ (ម៉ាថាយ ២១:១២–១៣) ហើយបានព្យាករប្រាប់អំពីការបំផ្លិចបំផ្លាញនៃព្រះវិហារ (ម៉ាថាយ ២៤:១–២) ។ ព្រះវិហារ នៅអនាគតកាលនឹងត្រូវបានសង់នៅក្រុងយេរូសាឡិម (អេសេ. ៤០–៤៨; សាការី ៨:៧–៩) ។ (សូមមើល សេចក្តីណែនាំដល់បទ ព្រះគម្ពីរ, «ព្រះវិហារ, ដំណាក់នៃព្រះអម្ចាស់») ។

### ១០. ជណ្តើរទៅកាន់ព្រះវិហារ

ទីធ្លាព្រះវិហារចែកចេញជាទីលាន ហើយទីលានខាងក្រៅនៅទាបជាងគេបង្អស់ ។ ពួកអ្នកមកថ្វាយបង្គំបានចូលតាមទ្វារនានា មានទាំងទ្វារទាំងនោះដែលនាំទៅជាន់លើ គឺពីជណ្តើរទៅកាន់ទីលានខាងក្រៅរួចហើយ ចូលទៅទីលានខាងក្នុង ។ មានមនុស្សរាប់លាននាក់បានឡើងជណ្តើរទាំងនេះតាមតំណពេលតមក មានទាំងព្រះរាជបុត្រានៃព្រះផង ។ កាលកងទ័ពទីតុសបំផ្លាញព្រះវិហារចោល នៅឆ្នាំ ៧០ គ.ស. នោះជណ្តើរត្រូវបានលុបទៅដោយសំរាម ។ គេបានជីកឃើញជណ្តើរកាលគេជីកភាគនៃទីក្រុងយេរូសាឡិមចាស់ ។

*ព្រឹត្តិការណ៍សំខាន់* ៖ លោកអេសេគាលបានឃើញការនិមិត្តមួយ អំពីទំហំនិងរាងព្រះវិហារនៅអនាគតកាល (អេសេ. ៤០) ។ (សូមមើល សេចក្តីណែនាំដល់បទព្រះគម្ពីរ, «ព្រះវិហារ, ដំណាក់នៃព្រះអម្ចាស់») ។

### ១១. ភ្នំដើមអូលីវ, ឱឌ្យាន អ្លសុន ហៃឌ

រូបនេះមើលទៅទិសខាងត្បូងឆៀងខាងកើតពីឱឌ្យាន អ្លសុន ហៃឌ ដែលនៅលើភ្នំដើមអូលីវ ឆ្ពោះទៅក្រុងយេរូសាឡិម ។ នៅជំរាលខាងលិចភ្នំដើមអូលីវ គឺជាសួនច្បារគែតសេម៉ានី ។ នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៨៤១ អែលឌើរអ្លសុន ហៃឌ បានដើរឡើងភ្នំដើមអូលីវ ហើយបានថ្វាយពាក្យអធិស្ឋានក្នុងតំណែងជាព្យាការី ដើម្បីការវិលមកវិញនៃកូនចៅរបស់អ័ប្រាហាំ និងការសង់ព្រះវិហារ ។

*ព្រឹត្តិការណ៍សំខាន់ៗ*៖ពួករ៉ូមបានបំផ្លាញក្រុងយេរូសាឡិម នៅឆ្នាំ ៧០ គ.ស. ដូចដែលបានប្រាប់ទុកជាមុនដោយព្រះអង្គសង្គ្រោះ (សូមមើល យ.ស. — ម៉ាថាយ ១:២៣) ។ ព្រះអង្គសង្គ្រោះនឹងឈរលើភ្នំដើមអូលីវទៀតមុនការលេចមករបស់ទ្រង់ដល់អស់ទាំងមនុស្សលោក ។ (សូមមើល សាការី ១៤:៣–៥; គ. និង ស. ៤៥:៤៨–៥៣; ១៣៣:១៩–២០; សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ, «ភ្នំដើមអូលីវ») ។

### ១២. សួនច្បារគែតសេម៉ានី

រូបថតនៃដើមអូលីវចាស់នេះបានថតនៅកន្លែងបុរាណនៃសួនច្បារគែតសេម៉ានី ។ ព្រះអង្គសង្គ្រោះបានអធិស្ឋាននៅជិតកន្លែងនេះ ក្រោយពីចេញពីបន្ទប់ខាងលើ នៅយប់ដែលទ្រង់ត្រូវគេក្បត់ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នៅទីនេះហើយដែលព្រះយេស៊ូវគ្រីស្ទបានចាប់ផ្តើមរងទុក្ខជំនួសអំពើបាបទាំងឡាយនៃមនុស្សលោក (ម៉ាថាយ ២៦:៣៦–៤៤; ម៉ាកុស ១៤:៣២–៤១; គ. និង ស. ១៩:១៦–១៩) ។ បន្ទាប់ពីទ្រង់បានអធិស្ឋាន នោះទ្រង់ត្រូវយូដាស-អ៊ីស្ការីយុតក្បត់ ហើយពួកសិស្សរបស់ទ្រង់បានលះបង់ទ្រង់ បន្ទាប់ពីគេចាប់ទ្រង់នៅក្នុងសួនច្បារ (ម៉ាកុស ១៤:៥០) ។ (សូមមើល សេចក្តីណែនាំ ដល់បទគម្ពីរ, «គែតសេម៉ានី») ។

### ១៣. គាល់កូថា

ថ្មនេះមើលទៅដូចជារលាក្បាល ហើយនៅក្រៅទ្វារក្រុងយេរូសាឡិមចេញទៅក្រុងដាម៉ាស ។ នេះប្រហែលជាកន្លែងដែលព្រះយេស៊ូវគ្រីស្ទត្រូវគេឆ្កាង ។

*ព្រឹត្តិការណ៍សំខាន់ ៖* បន្ទាប់ពីព្រះយេស៊ូវត្រូវគេវាយ ហើយចំអកឡកឡឺយ នោះទ្រង់ត្រូវគេនាំទៅ «កន្លែងមួយហៅថា គាល់កូថា ... ជាកន្លែងរលាក្បាល» គឺជាទីដែលទ្រង់ត្រូវគេឆ្កាង (ម៉ាថាយ ២៧:២៦–៣៥; យ៉ូហាន ១៩:១៧–១៨) ។ (សូមមើល សេចក្តីណែនាំ ដល់បទគម្ពីរ, «គាល់កូថា») ។

### ១៤. សួនច្បារផ្នូរ

នេះគឺជាកន្លែងបុរាណនៃទីបញ្ចុះព្រះសពព្រះអង្គសង្គ្រោះ ។ ពួកព្យាការីទំនើបជាច្រើនមានអារម្មណ៍ថា ព្រះសពនៃព្រះអង្គសង្គ្រោះត្រូវ បានបញ្ចុះនៅក្នុងសួនច្បារផ្នូរនេះ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* បន្ទាប់ពីព្រះអង្គសង្គ្រោះបានសុគតនៅលើឈើឆ្កាង នោះព្រះសពរបស់ទ្រង់ត្រូវបានបញ្ចុះក្នុងផ្នូរធ្វើពីថ្ម (ម៉ាថាយ ២៧:៥៧–៦០) ។ នៅថ្ងៃទីបី មានស្ត្រីប្អូនប្រាំនាក់បានទៅឯផ្នូរ ហើយមិនឃើញព្រះសពព្រះអង្គសង្គ្រោះនៅទីនោះទេ (ម៉ាថាយ ២៨:១; យ៉ូហាន ២០:១–២) ។ ពួកសាវកពេត្រុស និងយ៉ូហានបានទៅឯផ្នូរ ហើយក៏មិនឃើញព្រះសពព្រះអង្គសង្គ្រោះនៅទីនោះដែរ (យ៉ូហាន ២០:២–៩) ។ ព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ទ្រង់បានលេចមកឲ្យនាងម៉ារាពីស្រុកម៉ាក់ដាឡាឃើញ (យ៉ូហាន ២០:១១–១៨) ។

### ១៥. យេរីខូរ

រូបថតនេះបង្ហាញរុក្ខជាតិដែលមាននៅក្រុងយេរីខូរសព្វថ្ងៃនេះ ។ កាលពីបុរាណ យេរីខូរគឺជាទីក្រុងមួយដែលមានកំផែងព័ទ្ធជុំវិញ នៅក្នុងច្រកភ្នំនៃទន្លេយ័រដាន់ គឺនៅ ២៥២ ម. ក្រោមផ្ទៃសមុទ្រ ។ យេរីខូរគឺជាកន្លែងដែលមានដីជាតិខាងដំណាំ ដែលមានដើមគ្រោត និងដើមក្រូចល្ងតលាស់ជាបរិបូរ ។ នៅខាងក្រោយ គឺជាភ្នំនៃការប្រែរូបពីបុរាណ (ម៉ាថាយ ៤:១–១១) ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នៅក្បែរទីនេះហើយដែលយ៉ូស្វេ និងពួកកូនចៅអ៊ីស្រាអែលបានឆ្លងទន្លេយ័រដាន់មុនដំបូង ចូលទៅឯដែនដីសន្យា (យ៉ូស្វេ ២:១–៣; ៣:១៤–១៦) ។ ព្រះអម្ចាស់ទ្រង់បានបណ្តាលឲ្យកំផែងរលំដោយអព្ភូតហេតុ នៅមុខកងទ័ពអ៊ីស្រាអែល (យ៉ូស្វេ ៦; សូមមើលផង ហេព្រើរ ១១:៣០) ។ យ៉ូស្វេបានដាក់បណ្តាសាដល់ទីក្រុង (យ៉ូស្វេ ៦:២៦), ដែលបានសំរេច (១ ពង្សាវ. ១៦:៣៤) ។ លោកអេលីសេបានប្រោសទឹកយេរីខូរ (២ ពងមាវ.២:១៨–២២) ។ ព្រះអង្គសង្គ្រោះបានយាងកាត់ទីនេះ កាលទ្រង់យាងទៅក្រុងយេរូសាឡិមលើកក្រោយបង្អស់, បានប្រោសបារទីមេ ជាមនុស្សខ្វាក់, ហើយបានស្នាក់នៅជាមួយសាខេ ជាអ្នកយកពន្ធ (ម៉ាកុស ១០:៤៦–៥២; លូកា ១៨:៣៥–៤៣; ១៩:១–១០) ។ ផ្លូវទៅក្រុងយេរីខូរ ពីក្រុងយេរូសាឡិមគឺបានយកមកប្រើក្នុងពាក្យប្រៀបប្រដូច អំពីសាសន៍សាម៉ារីដែលល្អម្នាក់ (លូកា ១០:៣០–៣៧) ។

### ១៦. ស៊ីឡូរ

នៅក្នុងរូបពីទិសខាងលិចនេះ ឃើញសំណង់បែកបាក់នៃទីក្រុងពីបុរាណនៅខាងឆ្វេងប៉ែកកណ្តាល ។ សំណង់ដែលបែកបាក់ទាំងនេះគឺនៅ ភ្នំតូចមួយដែលព័ទ្ធជុំវិញដោយភ្នំកូនខ្ពស់ៗ ។

*ប្រឹត្តិការណ៍សំខាន់ៗ៖* ពួកពូជអំបូរអ៊ីស្រាអែលបានប្រជុំគ្នា ហើយបានទទួលទីកន្លែងរបស់ខ្លួន (យ៉ូស្វេ ១៨–២២) ។ រោងឧបោសថ និងហឹបនៃសេចក្តីសញ្ញាត្រូវបានដំឡើងនៅទីនេះ ហើយមានតមកជាច្រើនសតវត្ស (យ៉ូស្វេ ១៨:១) ។ នៅទីនេះហើយដែលនាង ហាណាបានអធិស្ឋាន ហើយបានថ្វាយកូនប្រុសរបស់នាងឲ្យទៅធ្វើការបំរើព្រះអម្ចាស់ (១ សាំ. ១) ។ ពួកសាសន៍អ៊ីស្រាអែលបានយក ហឹបពីក្រុងស៊ីឡូរ ហើយត្រូវចាញ់ពួកសាសន៍ភីលីស្ទីន រួចហើយត្រូវពួកភីលីស្ទីនរឹបយកហឹបទៅ (១ សាំ. ៤:១–១១) ។

### ១៧. ភ្នំគេរីស៊ីម និងភ្នំអេបាល

មើលទៅទិសខាងលិចៈ នៅខាងឆ្វេង គឺជាភ្នំគេរីស៊ីម ហើយនៅខាងស្តាំ គឺជាភ្នំអេបាល ។ រូបថតនេះ គឺជាភូមិណាប្លុសនៅសព្វថ្ងៃនេះ ។ ទីក្រុងស៊ីគែមពីបុរាណ គឺនៅក្នុងច្រកភ្នំរវាងភ្នំទាំងពីរនេះ (គឺនៅខាងស្តាំរូបថត) ។

*ព្រឹត្តិការណ៍សំខាន់ៗ៖* លោកអ័ប្រាហាំបានបោះជំរុំនៅស្រុកស៊ីគែម (លោកុ. ១២:៦–៧) ។ យ៉ាកុបក៏បានបោះជំរុំនៅទីនេះដែរ ហើយបានទិញដីមួយកន្លែង (លោកុ. ៣៣:១៨–២០) ។ ភ្នំគេរីស៊ីម គឺជាភ្នំមានពរ រីឯភ្នំអេបាលគឺជាភ្នំត្រូវបណ្តាសា (ចោទិ. ២៧–២៨) ។ នៅភ្នំអេបាល យ៉ូស្វេបានដំឡើងរីមានមួយដែលមានក្រិត្យវិន័យលោកម៉ូសេ រួចហើយក៏អានក្រិត្យវិន័យឲ្យពួកសាសន៍អ៊ីស្រាអែល ស្តាប់ (យ៉ូស្វេ ៨:៣០–៣៥) ។ ឆ្អឹងសពរបស់យ៉ូសែបត្រូវបានកប់នៅស្រុកស៊ីគែម (យ៉ូស្វេ ២៤:៣២) ។

### ១៨. ដូថាន់ នៅស្រុកសាម៉ារី

ភូមិភាគដែលនៅក្នុងដែនដីបរិសុទ្ធនេះ គឺមានទៅដោយជួរ និងច្រកភ្នំទាំងឡាយ ។ វាជាទីដែលមានវាលស្មៅល្អ ។ កាលពួកសាសន៍អ៊ីស្រាអែលមកតាំងទីនៅ ភូមិភាគនេះត្រូវបានប្រគល់ដល់ម៉ាន៉ាសេ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នៅក្នុងច្រកភ្នំដូថាន់នេះហើយដែលយ៉ូសែបត្រូវបានលក់ទៅស្រុកអេស៊ីព្ទ (លោកុ. ៣៧:១២–២៨) ។ អូបាឌា បានជួយសង្គ្រោះពួកព្យាការី ១០០ នាក់ ដោយបានលាក់ពួកគេទុកនៅក្នុងរអាងថ្ម កាលនាងយេសិបិលខំរកសម្លាប់ពួកព្យាការីនៃពួកអ៊ីស្រាអែលចោល (១ ពង្សាវ. ១៨:១៣) ។ កងទ័ពនៃពួកស៊ីរីបានហ៊ុំលោកអេលីយ៉ា និងបាវបំរើលោក ជាអ្នកដែលព្រះអម្ចាស់បានជួយសង្គ្រោះដោយអព្ភូតហេតុ (២ ពង្សាវ. ៦:១៣–២៣) ។

## ១៩. សេសារា និងវាលទំនាបសារ៉ុន ទៅ កើមែល

មើលទៅទិសខាងជើង គឺកំពង់សេសារាពីបុរាណ ។ ហើយក៏មើលទៅខាងលើរូបថត គឺជាជួរភ្នំកើមែល ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* លោកអេលីយ៉ាបានតទល់នឹងពួកព្យាការីក្លែងក្លាយនៃព្រះបាលនៅលើភ្នំកើមែល (១ ពង្សាវ. ១៨) ។ វា ម៉ារីស (ផ្លូវសមុទ្រ) ជាផ្លូវដ៏សំខាន់មួយនៅសម័យបុរាណ គឺសន្ធឹងទៅខាងជើងក្រុងសេសារា ។ បន្ទាប់ពីបានទទួលការនិមិត្តដ៏ជាក់ស្តែង មួយ កាលនៅក្រុងយ៉ុបប៉េ នោះពេត្រុសបានចាប់ផ្តើមការងារបំរើនៅក្នុងចំណោមពួកសាសន៍ដទៃ ដោយបានបង្រៀនមេគ្រប់គ្រងលើកងទ័ពរ៉ូមម្នាក់ ឈ្មោះ កូនេលាស នៅក្រុងសេសារា (កិច្ចការ ១០) ។ ភីលីពបានផ្សាយដំណឹងល្អ ហើយបាននៅទីនេះ ហើយមានកូនក្រមុំបួននាក់ដែល ចេះព្យាករ (កិច្ចការ ៨:៤០; ២១:៨–៩) ។ ប៉ុលបានជាប់គុកនៅទីក្រុងនេះពីរឆ្នាំ (កិច្ចការ ២៣–២៦) ។ លោកបានផ្សាយដំណឹងល្អ ដល់ភេលីច, ភេស្ទុស, និងស្តេចហេរ៉ូឌ អ័គ្រីប៉ា ទី២ ដែលមានបន្ទូលថា៖ «បន្តិចទៀត ឯងនឹងនាំឲ្យយើងត្រឡប់ជាអ្នកគ្រីស្ទានដែរ» (កិច្ចការ ២៦:២៨) ។

## ២០. យ៉ុបប៉េ

មើលទៅខាងជើងឆៀងខាងលិច គឺជាទីក្រុងយ៉ុបប៉េ ដែលនៅឯកំពង់ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* យ៉ូណាសបានទៅក្រុងយ៉ុបប៉េ ដោយចុះសំពៅទៅក្រុងតើស៊ីស (យ៉ូណាស ១:១–៣) ។ ក្រុងយ៉ុបប៉េគឺជា កំពង់សាឡូម៉ូន ហើយក្រោយមក សូរ៉ូបាបិលបានប្រើជាផ្លូវនាំឈើតាត្រៅពីព្រៃល្បាណូន ដើម្បីទៅសង់ព្រះវិហារទាំងឡាយរបស់ពួកគេ (២ របា. ២:១៦; អែសរ៉ា ៣:៧) ។ នៅទីនេះហើយដែលពេត្រុសបានប្រោសនាងតេប៊ីថា ហើយនាងក៏ស្គាល់ថា នាងដោរកាស ឲ្យរស់ពីស្លាប់ឡើងវិញ (កិច្ចការ ៩:៣៦–៤៣) ។ ពេត្រុសក៏បានឃើញការនិមិត្តអំពីសត្វដែលស្អាត និងមិនស្អាតដែលបើកសម្តែងដល់ លោកនូវសេចក្តីត្រូវការឲ្យចាប់ផ្តើមការងារបំរើនៅក្នុងចំណោមពួកសាសន៍ដទៃ (កិច្ចការ ១០) ។ អ្លុសុន ហៃឌ បានមកទីនេះ ដើម្បីធ្វើពិធីឆ្លងដែនដីបរិសុទ្ធ នៅឆ្នាំ ១៨៤១ ។

## ២១. ច្រកភ្នំយេសរាល

មើលទៅខាងលិច ពីលើកំពូលភ្នំតាបោរ ទៅឯច្រកភ្នំយេសរាល ។ ទោះបីជាគេតែងតែគិតថាច្រកភ្នំយេសារាល ជាច្រកភ្នំមួយដ៏ធំក្តី គង់តែតាមពិតច្រកភ្នំនេះគឺជាច្រកភ្នំជាច្រើន ដែលភ្ជាប់វាលទំនាបអាកូនឹងច្រកភ្នំយ័រដាន់ នឹងភូមិភាគនៃសមុទ្រកាលីឡេ ។ ជាឧទាហរណ៍ ច្រកភ្នំមេគីដោ គឺនៅភាគខាងលិចច្រកភ្នំនេះ ។ ច្រកភ្នំយេសរាល គឺជាផ្លូវដ៏ធំមួយដែលកាត់ដែនដីបរិសុទ្ធ នៅរវាង សមុទ្រមេឌីទែរ៉ាណេ ទៅខាងលិច នឹងច្រកភ្នំយ័រដាន់ទៅខាងកើត ។

*ចព្រឹត្តិការណ៍សំខាន់ៗ ៖* ផ្លូវថ្នល់ធំដែលភ្ជាប់ស្រុកអេស៊ីព្ទនឹងមេសូប៉ូតាមា គឺកាត់ច្រកភ្នំនេះ ហើយមានចំបាំងជាច្រើនដែលបានច្បាំងនៅ ទីនេះ (ចៅហ្វាយ ១:២២–២៧; ៥:១៩; ២ ពង្សាវ. ២៣:២៩–៣០) ។ ការតយុទ្ធចុងក្រោយបង្អស់នៅក្នុងដែនដីនេះ គឺចាប់ផ្តើមនឹង ចំបាំងអើម៉ាគេដូនដែលនឹងច្បាំងក្រោយបន្តិចពីការយាងមកលើកទីពីររបស់ព្រះអង្គសង្គ្រោះ; ចំបាំងនេះបានឈ្មោះមកពី ហារ ម៉ាគេដោ ឬភ្នំម៉ាគេដោ (អេសេ.៣៨; យ៉ូអែល ៣:៩–១៤; សាការី ១៤:២–៥; វិវរ. ១៦:១៤–១៦) ។

## ២២. ភ្នំតាបោរ

មើលទៅខាងជើងឆៀងខាងលិច ។ វាលទំនាបដែលនៅជុំវិញភ្នំតាបោរ គឺជាច្រកភ្នំយេសរាល ហើយក៏ស្គាល់ថា វាលអែស្ត្រាឡុន ។ ភូមិណាសារ៉ែតនៅលើភ្នំខាងត្រើយភ្នំតាបោរ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នាងដេបូរ៉ា និងបារ៉ាក បានប្រមូលពលទ័ពនៃព្រះអម្ចាស់ ទៅទាស់នឹងយ៉ាប៊ីន ជាស្តេចនៃក្រុងហាសោរ (ចៅហ្វាយ ៤:៤–១៦) ។ ភ្នំតាបោរ គឺជាកន្លែងបុរាណនៃការប្រែរូបរបស់ព្រះអង្គសង្គ្រោះ (ម៉ាថាយ ១៧:១–៩); ភ្នំមួយទៀតគឺ ភ្នំហ៊ើម៉ូន ។ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ, «ការប្រែរូប» ។

## ២៣. សមុទ្រកាលីឡេ និងភ្នំបទដូនពរ

មើលទៅខាងត្បូងឆៀងខាងលិច ទៅលើជ្រុងខាងជើងឆៀងខាងលិចសមុទ្រកាលីឡេ គឺជាបឹងទឹកសាប ។ ទិបេរាស គឺនៅឯឆ្នេរសមុទ្រ ខាងឆ្ងាយ និងនៅខាងឆ្វេងរូបថតដ៏ឆ្ងាយ ។ ភ្នំដែលនៅចំកណ្តាលខាងក្រោយ គឺជាកន្លែងបុរាណនៃភ្នំបទដូនពរ ។ កាពើណិម គឺនៅខាងឆ្វេង ចេញពីរូបថត ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ព្រះអង្គសង្គ្រោះទ្រង់បានចំណាយពេលជាច្រើននៃការងារបំរើរបស់ទ្រង់នៅលើផែនដី នៅក្នុងភូមិភាគនេះ ។ នៅទីនេះហើយដែលទ្រង់បានហៅ ហើយតែងតាំងពួកសាវក ១២ នាក់ (ម៉ាថាយ ៤:១៨–២២; ១០:១–៤; ម៉ាកុស ១:១៦–២០; ២:១៣–១៤; ៣:៧; ១៣–១៩; លូកា ៥:១–១១), បានបង្រៀនបទង្រៀននៅលើភ្នំ (ម៉ាថាយ ៥–៧), ហើយបានបង្រៀនដោយ ពាក្យប្រៀបប្រដូចទាំងឡាយ (ម៉ាថាយ ១៣:១–៥២; ម៉ាកុស ៤:១–៣៤) ។ អព្ភូតហេតុទាំងឡាយដែលទ្រង់បានសម្តែង គឺមានដូចតទៅនេះ ៖ ទ្រង់បានប្រោសមនុស្សឃ្លង់ (ម៉ាថាយ ៨:១–៤); បានធ្វើឲ្យព្យុះស្ងប់ (ម៉ាថាយ ៨:២៣–២៧); បានបណ្តេញកបអារក្ស អសោចិ៍ឲ្យចេញពីកំឡោះម្នាក់ រួចហើយ ពួកអារក្សអសោចិ៍បានទៅចូលសត្វជ្រូក ដែលរត់ធ្លាក់ទៅក្នុងសមុទ្រ (ម៉ាកុស ៥:១–១៥); បានប្រោសកូនស្រីរបស់យ៉ៃរ៉ុសឲ្យបានរស់ពីស្លាប់ឡើងវិញ (ម៉ាថាយ ៩:១៨–១៩, ២៣–២៦; ម៉ាកុស ៥:២២–២៤, ៣៥–៤៣); បានឲ្យអាហារដល់មនុស្ស ៥ពាន់នាក់ និង ៤ពាន់នាក់ (ម៉ាថាយ ១៤:១៤–២១; ១៥:៣២–៣៨); បានបញ្ជាពួកសិស្សរបស់ទ្រង់ឲ្យ ទំលាក់អួនរបស់ពួកគេ ដែលធ្វើឲ្យពួកគេបានត្រីជាច្រើន (លូកា ៥:១–៦); បានប្រោសមនុស្សជាច្រើន (ម៉ាថាយ ១៥:២៩–៣១; ម៉ាកុស ៣:៧–១២); ហើយបានលេចមក បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ដើម្បីមកបង្រៀនពួកសិស្សរបស់ទ្រង់ (ម៉ាកុស ១៤:២៧–២៨; ១៦:៧; យ៉ូហាន ២១:១–២៣) ។

## ២៤. កាពើណិម

កាពើណិមនៅខាងឆ្នេរសមុទ្រកាលីឡេជ្រុងខាងជើង គឺទីកណ្តាលនៃការងារបំរើរបស់ព្រះយេស៊ូវនៅស្រុកកាលីឡេ (ម៉ាថាយ ៩:១–២; ម៉ាកុស ២:១–៥) ។ ជាកន្លែងលក់ដូរ និងកន្លែងនេសាទដ៏សំខាន់ និងដ៏ជោគជ័យមួយ ជាទីលំនៅរបស់ពួកសាសន៍ដទៃ ព្រមទាំង ពួកសាសន៍យូដា ។ នៅសតវត្សទីមួយ ប្រហែលជាមានប្រជាជនមិនលើសពីមួយពាន់នាក់ទេ ។ កាពើណិមនៅចំផ្លូវលក់ដូរដ៏សំខាន់ៗ ដោយមានដីល្អដែលមានជីជាតិនៅជុំវិញផង ។ ពួកទាហានសាសន៍រ៉ូមបានសង់កន្លែ

ឯងូតទឹក និងឃ្លាំងសំរាប់ដាក់របស់របរនៅទីនេះ ដែល ផ្តល់នូវសំណង់សាធារណៈដែលមាំមួន ទៅនឹងសំណង់ខាងសង្គមដែលបានរៀបចំឡើង ។ ទោះបីមានអព្ភូតហេតុជាច្រើនដែលសម្តែងនៅទីនេះក្តី គង់តែប្រជាជនតែងតែបដិសេធការងារបំរើរបស់ព្រះអង្គសង្គ្រោះដែរ ។ ហេតុដូច្នេះហើយទើបព្រះយេស៊ូវដាក់បណ្តាសាដល់ ទីក្រុង (ម៉ាថាយ ១១:២០, ២៣–២៤) ។ តាមរយៈពេលតមក ក្រុងកាពើណិមក៏បានបែកបាក់ ហើយនៅស្ងាត់ស្ងៀមឈឹងដោយ គ្មានមនុស្សនៅ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* កាពើណិមត្រូវបានស្គាល់ថាជា «ទីក្រុង» របស់ព្រះអង្គសង្គ្រោះផ្ទាល់ (ម៉ាថាយ ៩:១–២; ម៉ាកុស ២:១–៥) ។ ទ្រង់បានសម្តែងអព្ភូតហេតុជាច្រើននៅកន្លែងនេះ ។ ជាឧទាហរណ៍ ទ្រង់បានប្រោសមនុស្សជាច្រើន (ម៉ាកុស ១:៣២–៣៤), ព្រមទាំង ប្រោសបាវបំរើរបស់មេទ័ពម្នាក់ផង (លូកា ៧:១–១០), បានប្រោសម្តាយក្មេករបស់ពេត្រុស (ម៉ាកុស ១:២១, ២៩–៣១), ប្រោសមនុស្ស ស្លាប់ដៃស្លាប់ជើងម្នាក់ដែលគេសំរូតគ្រែចុះពីដំបូលផ្ទះមក (ម៉ាកុស ២:១–១២), ប្រោសមនុស្សម្នាក់មានដៃស្វិត (ម៉ាថាយ ១២:៩–១៣) ។ នៅទីនេះហើយដែលព្រះយេស៊ូវទ្រង់បានបណ្តេញអារក្សអសោចិ៍ជាច្រើនឲ្យចេញ (ម៉ាកុស ១:២១–២៨, ៣២–៣៤), បាន ប្រោសកូនស្រីរបស់យ៉ៃរ៉ុសឲ្យមានជីវិតរស់ពីស្លាប់ឡើងវិញ (ម៉ាកុស ៥:២២–២៤, ៣៥–៤៣), ហើយបានប្រទាននូវបទបង្រៀនអំពីនំបុ័ង ជីវិត នៅក្នុងសាលាប្រជុំនៅក្រុងកាពើណិម (យ៉ូហាន ៦:២៤–៥៩) ។ ព្រះអង្គសង្គ្រោះបានបង្គាប់ពេត្រុសឲ្យស្ទូចត្រីពីសមុទ្រកាលីឡេ បើកមាត់វា ហើយយកប្រាក់ទៅបង់ពន្ធ (ម៉ាថាយ ១៧:២៤–២៧) ។

## ២៥. ទន្លេយ័រដាន់

ទន្លេយ័រដាន់ចាប់ផ្តើមនៅខាងជើងសមុទ្រកាលីឡេ ហូរចូលសមុទ្រ រួចហើយ ហូរទៅខាងត្បូង ចូលក្នុងសមុទ្រស្លាប់ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ឡុតបានរើសយកវាលទំនាបទាំងឡាយនៅយ័រដាន់សំរាប់ខ្លួន (លោកុ. ១៣:១០–១១) ។ យ៉ូស្វេបានញែកទឹកចេញ ដែលបណ្តោយឲ្យពួកអ៊ីស្រាអែលឆ្លងកាត់ទៅឯដែនដីសន្យា (យ៉ូស្វេ ៣:១៣–១៧; ៤:១–៩, ២០–២៤) ។ អេលីយ៉ា និងអេលីសេក៏បានញែកទឹក (២ ពង្សាវ. ២:៥–៨, ១២–១៤) ។ ណាម៉ាន់ត្រូវបានជាពីរោគឃ្លង់ (២ពង្សាវ. ៥:១–១៥) ។ យ៉ូហាន-បាទិស្ទបានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សជាច្រើន ព្រមទាំងព្រះអង្គសង្គ្រោះផង (ម៉ាថាយ ៣:១–៦, ១៣–១៦) ។ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ, «ទន្លេយ័រដាន់») ។

## ២៦. សេសារា ភីលីព

ជ្រោះនេះគឺនៅឯជើងភ្នំហើរម៉ូន ។ វាជាក្បាលទឹកនៃទន្លេយ័រដាន់ ។ ស្តេចហេរ៉ូឌ ភីលីព ដែលគ្រប់គ្រងទីនោះ ទ្រង់បានស្ថាបនាទីក្រុងមួយដើម្បីដំកើងកិត្តិយសដល់សេសារ (ជារាជាធិរាជរបស់ទ្រង់) និងដល់រូបអង្គទ្រង់; កាលពីដើម គេហៅទីក្រុងនោះថា ប៉ានាស ហើយឥឡូវនេះគេហៅថា បានាស ឬសេសារា ភីលីព ។

*ព្រឹត្តិការណ៍សំខាន់ ៖* ព្រះអង្គសង្គ្រោះទ្រង់បានជួបនឹងពួកសិស្សរបស់ទ្រង់នៅក្រុងសេសារា ភីលីព ។ នៅទីនេះហើយដែលពេត្រុសបានប្រកាសថាព្រះអង្គសង្គ្រោះជា «ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់» ។ ខណៈនោះ ព្រះអង្គសង្គ្រោះបានសន្យាថានឹង ប្រទានដល់ពេត្រុសនូវ «កូនសោទាំងឡាយនៃនគរស្ថានសួគ៌» (ម៉ាថាយ ១៦:១៣–២០) ។

## ២៧. ណាសារ៉ែត

រូបនៃទីក្រុងណាសារ៉ែតទំនើបនេះមើលទៅខាងត្បូង ។ ណាសារ៉ែតគឺជាភូមិតូចមួយ នៅសម័យព្រះគម្ពីរប៊ីប ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* នីហ្វៃបានឃើញក្នុងការនិមិត្ត នូវព្រះមាតារបស់ព្រះអង្គសង្គ្រោះ នៅភូមិណាសារ៉ែត (១ នីហ្វៃ ១១:១៣–២២) ។ ទេវតាកាព្រីយ៉ែលបានប្រាប់នាងម៉ារាថា នាងនឹងបានបុត្រាមួយជាព្រះអង្គសង្គ្រោះ (លូកា ១:២៦–៣៥) ។ កាព្រីយ៉ែលបានប្រាប់ឲ្យយ៉ូសែបយកនាងម៉ារាធ្វើជាប្រពន្ធ ហើយឲ្យដាក់ឈ្មោះបុត្រនាងថា យេស៊ូវ (ម៉ាថាយ ១:១៨–២៥) ។ ព្រះយេស៊ូវបានមាន វ័យធំនៅភូមិណាសារ៉ែត (ម៉ាថាយ ២:១៩–២៣; លូកា ២:៤–៤០; ៤:១៦) ។ ទ្រង់បានផ្សាយដំណឹងល្អ ហើយបានប្រាប់គេថា ទ្រង់ ជាព្រះមែស៊ី (លូកា ៤:១៦–២១), ប៉ុន្តែប្រជាជននៅភូមិណាសារ៉ែតបានបដិសេធទ្រង់ (ម៉ាថាយ ១៣:៥៤–៥៨; លូកា ៤:២២–៣០) ។

## ២៨. ដាន់

ទីក្រុងបុរាណនេះគេបានហៅថា លេសែម (យ៉ូស្វេ ១៩:៤៧) ឬ ឡាអ៊ីស (ចៅហ្វាយ ១៨:៧, ១៤) កាលពីមុនពួកអ៊ីស្រាអែលច្បាំង យកដែនដី ។ មានជ្រោះទាំងឡាយនៅកន្លែងនេះ ព្រមទាំងជ្រោះសេសារា ភីលីព ដែលជាក្បាលទឹកដ៏សំខាន់ៗនៃទន្លេយ័រដាន់ ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* លោកអ័ប្រាហាំបានជួយសង្គ្រោះឡុត (លោកុ. ១៤:១៣–១៦) ។ ពូជអំបូររបស់ដាន់បានយកកន្លែងនេះបាន ហើយបានឲ្យឈ្មោះថា ដាន់ (យ៉ូស្វេ ១៩:៤៧–៤៨) ។ ស្តេចយេរ៉ូបោមបានដំឡើងកូនគោមាស ជាបុព្វហេតុដែលធ្វើឲ្យពូជទាំង ១០ អំបូរដែលនៅខាងជើងត្រូវវិនាស (១ ពង្សាវ. ១២:២៦–៣៣) ។ ក្រុងដាន់ គឺជាទីក្រុងនៃអ៊ីស្រាអែល ដែលនៅខាងជើងបំផុត — ម្ល៉ោះហើយ បទគម្ពីរសំដៅទៅដែនដីនៃអ៊ីស្រាអែលថា «ចាប់តាំងពីក្រុងបៀរ-សេបា រហូតដល់ក្រុងដាន់» (២ របា. ៣០:៥; បៀរ-សេបា គឺជាទីក្រុង ដែលនៅទិសខាងត្បូងបំផុត) ។ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ, «ដាន់») ។

## ២៩. អាថែន

រូបថតនេះបង្ហាញនូវសំណង់បាក់បែកនៃប៉ារថេណុន នៅក្រុងអាថែន ។ ក្រុងអាថែន គឺជារាជធានី អ័ត្តិកា នៅប្រទេសក្រេកពីបុរាណ ហើយនៅសម័យព្រះគម្ពីរសញ្ញាថ្មី គឺជាទីក្រុងនៅក្នុងខេត្តអាខៃ នៅប្រទេសរ៉ូម ។ ក្រុងនេះត្រូវបានឲ្យឈ្មោះនោះ ដើម្បីឲ្យកិត្តិយសដល់ ព្រះនៃពួកក្រេកនាមអាថែណា ។ ដល់សម័យព្រះគម្ពីរសញ្ញាថ្មី ក្រុងអាថែនបានបាត់បង់នូវអានុភាព និងសិរីល្អពីដើមច្រើនណាស់ទៅ ហើយ ប៉ុន្តែនៅតែមានរូបចម្លាក់ និងវិមាននៃអាទិទេព និងទេពធិតាជាច្រើន ព្រមទាំងមាន «ព្រះដ៏ពុំស្គាល់» (កិច្ចការ ១៧:២៣) ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* សាវកប៉ុលបានទៅឯទីក្រុងនេះ ហើយបានផ្សាយដំណឹងល្អនៅឯភ្នំអើរីយ៉ូស នៅក្បែរប៉ាថេណុន (កិច្ចការ ១៧:១៥–៣៤) ។ ពួកអ្នកផ្សាយសាសនាត្រូវបានចាត់ពីក្រុងអាថែន ឲ្យទៅបែកផ្សេងៗទៀតនៅប្រទេសក្រេក (១ ថែស្សា. ៣:១–២) ។

### ៣០. កូរិនថូស

ជាក្រុងដ៏ធំមួយនៅខេត្តអាខៃ នៃប្រទេសរ៉ូម ។ ក្រុងនេះនៅប្ចូរដីដែលភ្ជាប់ពេឡូប៉ូនេស៊ូរទៅនឹងដែនដីក្រេក ដែលធ្វើជាកំពង់មួយ នៅខាងកើត និងនៅខាងលិច ។ ក្រុងកូរិនថូស គឺជាទីក្រុងកំពង់មួយដែលស្តុកស្តំ ហើយមានឥទ្ធិពល ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* ប៉ុលបាននៅក្រុងកូរិនថូសមួយឆ្នាំកន្លះ ហើយបានតាំងសាសនាចក្រនៅទីនោះ (កិច្ចការ ១៨:១–១៨) ។ ប៉ុលបានសរសេរសំបុត្រជាច្រើនទៅសមាជិកនៃសាសនាចក្រនៅក្រុងកូរិនថូស មានសំបុត្រពីរច្បាប់ដែលឥឡូវនេះ មាននៅក្នុងព្រះគម្ពីរសញ្ញាថ្មី (កូរិនថូស ទី ១ និង ទី ២) ។

### ៣១. អេភេសូរ

ជាសំណង់បាក់បែកនៃរោងល្ខោនរបស់ពួកក្រេក នៅក្រុងអេភេសូរ ជាកន្លែងដែលសាវកប៉ុលបានផ្សាយដំណឹងល្អ ។ នៅសម័យព្រះ គម្ពីរសញ្ញាថ្មី ក្រុងអេភេសូរ គឺជាក្រុងដ៏ល្បីល្បាញមួយពេញពិភពលោក ដែលស្គាល់អំពីព្រះវិហារដ៏ធំ ដែលបានសង់ឡើង ដើម្បីផ្តល់ កិត្តិយសដល់ព្រះឌីអាន នៃពួករ៉ូម ។ ឥឡូវនេះ បែកបាក់ទៅហើយ តែគ្រាមួយ ក្រុងអេភេសូរគឺជារដ្ឋធានីនៃខេត្តអាស៊ី នៅប្រទេសរ៉ូម ហើយជាមជ្ឈមណ្ឌលដ៏ធំមួយ ។ ជាងប្រាក់ទាំងឡាយនៅទីក្រុងនោះ មានរបររកស៊ីដ៏ល្អតលាស់ ដោយលក់រូបព្រះឌីអាន ។

*ព្រឹត្តិការណ៍សំខាន់ៗ ៖* សាវកប៉ុលបានទៅជួបពួកអេភេសូរ នៅចុងដំណើរទីពីរដែលលោកទៅធ្វើបេសកកម្ម (កិច្ចការ ១៨:១៨–១៩) ។ នៅដំណើរទីបី លោកបានស្នាក់នៅទីក្រុងនេះអស់រយៈពេលពីរឆ្នាំ ។ លោកត្រូវគេបង្ខំឲ្យចេញ ដោយមកពីមានការបះបោរ ដែលពួកជាងប្រាក់បានបង្កឡើង ព្រោះគេអស់របររកស៊ី នៅពេលប៉ុលបានបង្រៀនជំទាស់នឹងការថ្វាយបង្គំព្រះឌីអាន ដែលជាព្រះក្លែងក្លាយ (កិច្ចការ ១៩:១, ១០, ២៣–៤១; ២០:១) ។ រោងល្ខោននៅអេភេសូរ គឺជារោងដ៏ធំបំផុតមួយ ដែលពួកក្រេកបានសង់ឡើង ហើយជាកន្លែងដែលពួកគូកនរបស់ប៉ុលបានប្រឈមមុខនឹងហ្វូងមនុស្សកំណាច (កិច្ចការ ១៩:២៩–៣១) ។ ប៉ុលបានសរសេរសំបុត្រមួយច្បាប់ដល់ ពួកសមាជិកនៃសាសនាចក្រនៅក្រុងអេភេសូរ កាលលោកជាប់ឃុំឃាំងនៅក្រុងរ៉ូម ។ មានសាខាមួយនៅក្នុងចំណោមប្រាំពីរសាខានៃ សាសនាចក្រនៅខេត្តអាស៊ី ដែលគម្ពីរវិវរណៈបានស្តីដល់ គឺនៅក្រុងអេភេសូរ (វិវរ. ១:១០–១១; ២:១) ។

### ៣២. កោះប៉ាត់ម៉ុស

ជាកោះមួយនៅលើសមុទ្រអេជាន ដែលគេបានបំបរបង់យ៉ូហានទៅ (វិវរ. ១:៩) ។ តាមប្រពៃណី លោកបានធ្វើការនៅទីនោះ ដីកថ្មពាល ។

*ព្រឹត្តិការណ៍សំខាន់ ៖* យ៉ូហានបានឃើញការនិមិត្តដ៏ធំមួយ ដែលហៅថាអ័ប៉ូកាលិព្យ (គម្ពីរវិវរណៈ) ។ ព្រះអម្ចាស់ទ្រង់បានប្រាប់លោក ឲ្យផ្ញើគម្ពីរនេះទៅឲ្យសាសនាចក្រទាំងប្រាំពីរដែលនៅខេត្តអាស៊ី (វិវរ. ១:១១) ។

ផែនទីដែលមានដូចតទៅនេះ អាចជួយឲ្យអ្នកកាន់តែយល់អំពីបទគម្ពីរកាន់តែប្រសើរឡើង ។ ដោយស្គាល់ពីភូមិសាស្ត្រនៃដែនដីទាំងឡាយដែលបានពោលដល់នៅក្នុងគម្ពីរ នោះអ្នកអាចយល់អំពីព្រឹត្តិការណ៍ទាំងឡាយក្នុងព្រះគម្ពីរកាន់តែប្រសើរឡើង ។


១. ផែនទីខាងភូមិសាស្ត្របរិយមនៃដែនដីបរិសុទ្ធ
២. ការនិក្ខមនំរបស់ពួកអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ហើយចូលទៅស្រុកកាណាន
៣. ការបែកខ្ញែកនៃពូជទាំង១២អំបូរ
៤. អាណាចក្ររបស់ដាវីឌ និងសាឡូម៉ូន
៥. អាណាចក្រអាសស៊ើរ
៦. អាណាចក្របាប៊ីឡូនថ្មី (នេប៊ូក្នេសា) និងនគរអេស៊ីព្ទ
៧. អាណាចក្រពើស៊ី
៨. អាណាចក្ររ៉ូម៉ាំង
៩. ពិភពលោកនៅសម័យព្រះគម្ពីរសញ្ញាចាស់
១០. ស្រុកកាណាននៅសម័យព្រះគម្ពីរសញ្ញាចាស់
១១. ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរសញ្ញាថ្មី
១២. យេរូសាឡិមនៅសម័យព្រះគម្ពីរសញ្ញាថ្មី
១៣. ដំណើរទាំងឡាយដែលសាវកប៉ុលទៅផ្សាយសាសនា
១៤. កំពស់ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរប៊ីប


លិបិក្រមតាមលំដាប់អក្ខរក្រមនៃឈ្មោះកន្លែងទាំងឡាយ អាចជួយឲ្យអ្នករកឃើញកន្លែងនៅលើផែនទី ។ ពីក្រោយឈ្មោះនីមួយៗ មានលេខផែនទី និងក្រឡាតារាងដែលមានលេខនិងអក្សរ ។ ជាឧទាហរណ៍ កន្លែងសំរាប់ រ៉ាបាត (អាំម៉ាន) នៅលើផែនទី លេខ១ គឺ ១:ឃ៥; នេះមានន័យថា ផែនទី ទី១ នៅក្រឡា ឃ៥ ។ អ្នកអាចរកឃើញក្រឡាណាមួយនៅលើផែនទី ដោយមើលតាមលេខ ដែលនៅខាងលើ និងនៅចំហៀងផែនទីនោះ ។ ឈ្មោះផ្សេងទៀតនៃកន្លែងទាំងឡាយ គឺកត់ទុកនៅក្នុងវង់ក្រចក; ជាឧទាហរណ៍ រ៉ាបាត (អាំម៉ាន) ។ បច្ឆុនសញ្ញា (?) នៅពីក្រោយឈ្មោះ នោះសំគាល់ថាកន្លែងនៅលើផែនទីគឺជាការៈស្មាន ព្រោះមិនដឹងទៀងទាត់ទេ ។

តទៅនេះគឺជាការសំគាល់ដើម្បីយល់ពីសញ្ញា និងតួអក្សរទាំងឡាយ ដែលបានយកមកប្រើប្រាស់នៅលើផែនទីទាំងប៉ុន្មាន ។ ថែមទៀត ផែនទី នីមួយៗ អាចមានសំគាល់ផ្សេងៗ ដែលមានពាក្យពន្យល់ប្រាប់ពីសញ្ញាថែមទៀត ដែលមាននៅលើផែនទីនោះ ។

● ចំណុចក្រហម គឺជាទីក្រុង ឬភូមិ ។ ជួនកាល មានខ្សែបន្ទាត់តូចពីចំណុចទៅឯឈ្មោះទីក្រុង ឬទីកន្លែង ។

▲ ត្រីកោណតូចគឺជាសំគាល់ពីភ្នំ ។

*សមុទ្រស្លាប់* — អក្សរបែបនេះគឺបានយកមកប្រើប្រាស់ ដើម្បីប្រាប់ពីកន្លែងទាំងឡាយខាងភូមិសាស្ត្រ ដូចជាមហាសមុទ្រ សមុទ្រ បឹង ទន្លេ ភ្នំ ច្រកភ្នំ ទីរហោស្ថាន និងកោះទាំងឡាយ ។

យេរូសាឡិម — អក្សរបែបនេះគឺបានយកមកប្រើប្រាស់ សំរាប់ទីក្រុង និងភូមិទាំងអស់ (និងសំរាប់កន្លែងទាំងឡាយដែលបានរៀបរាប់ ប្រាប់ដោយក្បោះក្បាយ នៅលើផែនទីពីទីក្រុងយេរូសាឡិម) ។

**ម៉ូអាប់** — អក្សរបែបនេះគឺបានយកមកប្រើប្រាស់ សំរាប់ប៉ែកខាងនយោបាយ ដូចជាភូមិភាគ និងរដ្ឋ និងទឹកដីទាំងឡាយនៃសហរដ្ឋ ។

**យូដា** — អក្សរបែបនេះគឺបានយកមកប្រើប្រាស់ សំរាប់ប៉ែកខាងនយោបាយធំៗ ដូចជាសាសន៍ ប្រទេស និងទ្វីបទាំងឡាយ ។

ផែនទីជាគំរូ

**ផែនទីសំរាប់ណែនាំ**



អាបាណា, ទន្លេ, ១:ឃ១
អាប៊ីលេន, ភូមិភាគ, ១១:ឃ១
អាកាឌ (អាខាឌ), ភូមិភាគ, ៩:ឆ២
អាកូរ, (អ័កូរ, តូលេមេ), ១:ខ៣, ៣:ក៣, ៤:គ៣, ១០:ខ២, ១១:ខ៣
អាខៃ, ខេត្តនៅប្រទេសរ៉ូម, ៨:គ២, ១៣:ឃ២
អ័ទ្រា, សមុទ្រនៃ(អ័ទ្រា), ៨:ខ២
អេណូន, ១១:គ៤
អៃយ, ២:ឃ១, ១០:ខ៥
អៃយ៉ាឡូន, ១:ខ៥, ១០:ខ៥, ១១:ខ៥
អាខាឌ (អាកាឌ), ភូមិភាគ, ៩:ឆ២
អ័លេក្សានទ្រា, ៨:គ៣, ១៣:ច៤
អាម៉ាលេក, ភូមិភាគ, ៤:គ៦
អាំម៉ាន (រ៉ាបាត), ១:ឃ៥, ១០:ឃ៥, ១៤:ឃ២
អាំម៉ូន, ភូមិភាគ, ១:ឃ៦, ៣:ខ៥, ៤:ឃ៤, ១០:ឃ៦
អាន់ទីយ៉ូក, នៅប្រទេសពីស៊ីឌា, ១៣:ច២
អាន់ទីយ៉ូក, នៅប្រទេសស៊ីរី, ៨:គ៣, ១៣:ជ២
បន្ទាយអនតូនា, នៅក្រុងយេរូសាឡិម, ១២:គ៣
អាប់ភាស, ផ្សារ, ១៣:ខ១
អាខ្វាបា, ឈូងសមុទ្រ, ២:ឃ៤
អារ៉ាបា (ច្រកភ្នំរីព្ត), ១:ខ៨, ២:ឃ២, ៤:គ៧, ១០:គ៨
អារ៉ាប់, ៥:គ៣, ៨:ឃ៤
ទីរហោស្ថានអារ៉ាប់, ៩:ច៣
សមុទ្រអារ៉ាប់, ៦:ឃ៤
អើរ៉ាត, ២:ឃ១, ៣:ក៥, ៤:គ៥
សមុទ្រអើរ៉ាល, ៥:ឃ១, ៦:ឃ១, ៧:គ២
អារ៉ាម-ដាម៉ាស, ភូមិភាគ, ៤:ឃ២
អារ៉ារ៉ាត, ភ្នំ, ៩:ច១
អើកោប, ភូមិភាគ, ៤:ឃ៣
អើរីម៉ាថេ, ១១:ខ៥
អើណូន, ១:គ៧, ២:ឃ១, ៣:ខ៥, ៤:ឃ៥, ១០:គ៧, ១១:គ៧
អាសកាឡូន (អាសកេឡូន), ១១:ក៦
អាសដូឌ (អាសូត), ១:ក៦, ៣:ក៥, ៤:គ៥, ១០:ក៦
អេសើរ, ពូជអំបូរ, ៣:ក៣

អាសកេឡូន (អាសកាឡូន), ១:ក៦, ៣:ក៥, ៤:គ៥, ១០:ក៦, ១១:ក៦
អាស៊ី, ខេត្តនៅប្រទេសរ៉ូម, ៨:គ២, ១៣:ច២
អាសស៊ើរ, ៥:គ៣, ៩:ច២
អាសស៊ើរ, ៩:ច២
អាណាចក្រអាសស៊ើរ, ៥:គ៣
អាថែន, ៦:ក២, ៧:ក២, ៨:គ២, ១៣:ឃ២
អាសូត, ១១:ក៦

បាបិល (ស៊ីណើរ), ៩:ឆ៣
បាប៊ីឡូន, ៥:គ៣, ៦:គ៣, ៧:ខ៣, ៩:ច៣
បាប៊ីឡូនា, ភូមិភាគ, ៩:ច៣
អាណាចក្របាប៊ីឡូន, ថ្មី, ៦:គ៣
បាសាន, ភូមិភាគ, ១:ក៣, ១០:គ២
បៀរ-សេបា, ១:ខ៧, ២:គ១, ៣:ក៥, ៤:គ៦, ៩:ឃ៤, ១០:ខ៧, ១១:ខ៨
បេនយ៉ាមីន, ពូជអំបូរ, ៣:ក៥
បេរា, ១៣:ឃ១
បេសោរ, ទន្លេ, ១:ក៧, ១០:ក៧, ១១:ក៨
បេថាបារ៉ា, ១១:គ៦
បេថានី, ១១:ខ៦
បេថានី, ផ្លូវទៅ, ១២:ឃ៥
បេតអែល (លូស), ៣:ក៥, ៤:គ៥, ១០:ខ៥, ១១:ខ៦
បេថែសដា, ស្រះ, នៅក្រុងយេរូសាឡិម, ១២:គ៣
បេថ្លេហិម, ១:ខ៦, ៣:ក៥, ៤:គ៥, ១០:ខ៦, ១១:ខ៦
បេថ្លេហិម, ផ្លូវទៅ, ១២:ក៧
បេតផាសេ, ១១:ខ៦
បេតសៃដា, ១១:គ៣
បេត-សាន, ៣:ខ៤, ៤:ឃ៤, ១០:គ៤
បេសេថា, ១២:ខ២
ប៊ីធូនា, ភូមិភាគ, ១៣:ច១
សមុទ្រខ្មៅ, ៥:ខ១, ៦:ខ១, ៧:ក២, ៨:គ២, ៩:ខ១, ១៣:ច១
បូសរ៉ា, ៣:ខ៦, ៤:ឃ៦
ព្រិតាននា, ភូមិភាគ, ៨:ក១

សេសារា, ១១:ខ៤, ១៣:ជ៣
សេសារា ភីលីព, ១១:គ២
កៃផា, ផ្ទះរបស់, នៅក្រុងយេរូសាឡិម, ១២:ខ៦
កាណា, ១១:គ៣
កាណាន, ភូមិភាគម ២:គ១, ៩:ឃ៣
កាពើណិម, ១១:គ៣
កាប់ថោរ (ក្រេត), កោះ, ៩:ក៣
កាប៉ាដូគា, ភូមិភាគ, ១៣:ជ២
កើកេមីស, ៥:ខ២, ៦:ខ២, ៩:ឃ២
កើមែល, ភ្នំ, ១:ខ៣, ៣:ក៣, ៤:គ៣, ១០:ខ៣, ១១:ខ៣
កាតធេច, ៨:ខ៣
សមុទ្រកាស្ពាន, ៥:គ១, ៦:គ១, ៧:ខ២, ៨:ឃ២, ៩:ឆ១
កៅកាស, ៥:គ១, ៨:ឃ២, ៩:ច១
គេនេសារ៉ែត, សមុទ្រ, ១:គ៣, ៣:ខ៣, ៤:ឃ៣, ៩:ឃ៣, ១០:គ៣, ១១:គ៣
ឃីយ៉ូស, កោះ, ១៣:ង២
ខូរ៉ាស៊ីន, ១១:គ៣
ស៊ីលីស៊ី, ភូមិភាគ, ១៣:ឆ២
គ្នីដុស, ១៣:ង២
កូរិនថូស, ១៣:ឃ២
ក្រេត (កាប់ថោរ), កោះ, ៨:គ៣, ៩:ក៣, ១៣:ឃ៣
គីប្រុស (គីទីម), កោះ, ៨:គ៣, ៩:គ៣, ១៣:ឆ៣
គីរេន, ១៣:ឃ៣

ដាស៊ី, ភូមិភាគ, ៨:គ២
ដាម៉ាស, ១:ឃ១, ៣:ខ២, ៤:ឃ២, ៩:ឃ៣, ១០:ឃ១, ១១:ឃ១, ១៣:ជ៣
ដាន់ (ឡាអ៊ីស), ៣:ខ៣, ៤:ឃ៣, ១០:គ២
ដាន់, ពូជអំបូរ, ៣:ខ៣, ៣:ក៥
សមុទ្រស្លាប់ (សមុទ្រប្រៃ), ១:គ៦, ២:ឃ១, ៣:ខ៥, ៤:ឃ៤, ៩:ឃ៤, ១០:គ៦, ១១:គ៧, ១:ក៧
សមុទ្រស្លាប់ (ខាងក្រោម), ១៤:គ៣
សមុទ្រស្លាប់ (នៅស្មើ), ១៤:ក៧, ១៤:គ៣
សមុទ្រស្លាប់, ផ្លូវទៅ, ១២:គ៨
ដេកាប៉ូល, ភូមិភាគ, ១១:គ៤
ឌើរបេ, ១៣:ឆ២

ឌីបូន, ២:ឃ១
ដុបកា, ២:គ៤
ដោរ, ៣:ក៤, ៤:គ៤
ដូថាន់, ១០:ខ៤
ឌូរ៉ា, វាលទំនាប, ៩:ច២

សមុទ្រខាងកើត (ខាងក្រោម), ៥:គ៤, ៦:គ៤
ទីរហោស្ថានខាងកើត, ២:ឃ៣
អេបាល, ភ្នំ, ១:ខ៤, ៣:ក៤, ៤:គ៤, ១០:ខ៤, ១១:ខ៥, ១៤:ខ៦
អេដំម, ភូមិភាគ, ១:គ៨, ២:ឃ២, ៣:ខ៦, ៤:ឃ៧, ១០:គ៨
អេស៊ីព្ទ, នគរ, ៦:ក៣
អេស៊ីព្ទ, ភូមិភាគ, ២:ក៣, ៥:ខ៤, ៧:ក៤, ៨:គ៤, ៩:គ៤, ១៣:ច៤
អេស៊ីព្ទ, ទន្លេ, ២:គ២
អេក្រុន, ១:ខ៦, ១០:ក៦
អេឡា, ១:ក៦, ១០:ខ៦, ១១:ខ៦
អេឡាំ, ភូមិភាគ, ៥:គ៣, ៦:គ៣, ៧:គ៣, ៩:ជ៣
អេលីម, ២:គ៣
អេម៉ោស, ១១:ខ៦
អេម៉ោស, ផ្លូវទៅ, ១២:ក៤
អេនដោរ, ១០:គ៣
អេន-គេឌី, ៤:ឃ៥, ១០:គ៧
ជ្រោះអេន-រ៉ូគែល, ១២:គ៧
អេភេសូរ, ៨:គ២, ១៣:ង២
អេប្រាអិម, ពូជអំបូរ, ៣:ក៤
អេស្ត្រាឡុន, ច្រកភ្នំ, ១:ខ៣, ១០:ខ៣
អេថាម, ទីរហោស្ថាន, ២:ខ៣
អឺប្រាត, ទន្លេ, ៥:ខ៣, ៦:គ៣, ៨:ឃ៣, ៩:ង២
អេស៊ាន-គេប៊ើរ, ២:ឃ៣, ៣:ក៨, ៤:គ៨, ៩:ឃ៤

ហ្វៀរ ហេវ៉ែន្ស, កំពង់, ១៣:ឯ៣
ទ្វាររូបត្រី, នៅក្រុងយេរូសាឡិម, ១២:ខ៣

កាឌ, ពូជអំបូរ, ៣:ខ៤
កាដារ៉ា, ១១:គ៤
កាឡាទី, ភូមិភាគ, ១៣:ឆ១
កាលីឡេ, ខាងក្រោម, ភូមិភាគ, ១:គ៣
កាលីឡេ, ភូមិភាគ, ១១:គ២
កាលីឡេ, សមុទ្រ (គេនេសារ៉ែត), ១:គ៣, ៣;ខ៣, ៤:ឃ៣, ៩:ឃ៣, ១០:គ៣, ១១:គ៣
កាលីឡេ, ខាងលើ, ភូមិភាគ, ១:គ២
សួនច្បារផ្នូរ, នៅក្រុងយេរូសាឡិម, ១២:ខ៣
ទ្វារស្អាតស្អំ, ១២:ឃ៤
កាត់, ៣;ក៥, ៤:គ៥, ១០:ក៦
កាត់-ហេភើរ, ១០:ខ៣
គោល, ភូមិភាគ, ៨:ក១
កាសា, ១:ក៦, ២:គ១, ៣:ក៥, ៤:គ៥, ១០:ក៧, ១១:ក៧, ១៣:ជ៤
គេរ៉ារ, ១០:ក៧
គេរ៉ារ, ទន្លេ, ១:ក៧, ១០:ក៧, ១១:ក៧
គេរីស៊ីម, ភ្នំ, ១:ខ៥, ៣:ក៤, ៤:គ៤, ១០:ខ៥, ១១:ខ៥, ១៤:ខ៦
យេមេនា, ភូមិភាគ, ៨:ខ១
គេសើរ, ភូមិភាគ, ៤:ឃ៣
គែតសេម៉ានី, សួនច្បារ, នៅក្រុងយេរូសាឡិម, ១២:ឃ៤
គេសើរ, ៤:គ៥
គីបៀរ, ៤:គ៥
គីបៀន, ១០:ខ៥
ជ្រោះគីហុន, នៅក្រុងយេរូសាឡិម, ១២:ឃ៦
គីលបោ, ភ្នំ, ១:គ៤, ៣:ខ៤, ១០:គ៤, ១១:គ៤, ១៤:គ៦
កាឡាត, ភូមិភាគ, ១:គ៤, ១០:គ៤
គីលកាល, ១:គ៥, ២:ឃ១, ៤:ឃ៥
គាល់កូថា, នៅក្រុងយេរូសាឡិម, ១២:ខ៣
កូម៉ូរ៉ា, តំបន់នៃសូដុំម និង, ១០:គ៨
កូសែន, ភូមិភាគ, ២:ក២, ៩:គ៤
សមុទ្រធំ (មេឌីទេរេនាន, ខាងលើ), ១:ក៤, ២:ខ១, ៣:ក៤, ៤:គ៤, ៥:ក៣, ៦:ក៣, ៧:ក៣, ៩:ខ៣, ១០:ក៥, ១១:ក៦, ១៣:ឃ៣, ១៤:ក២, ១៤:ក៦
ក្រេក, ៧:ក២

ហារ៉ាន (ប៉ាដាន់-អើរ៉ាម), ៩:ង២
វាំងហាសម៉ូនាន, នៅក្រុងយេរូសាឡិម, ១២:គ៥
ហាសោរ, ៣:ខ៣, ៤:ឃ៣, ១០:គ២,
ហេប្រុន, ១:ខ៦, ២:ឃ១, ៣:ក៥, ៤:គ៥, ១០:ខ៧, ១១:ខ៧
ហេប្រុន, ផ្លូវទៅ, ១២:ក៧
ហេលីអុបប៉ូល (អូន), ២:គ៣
ហើរម៉ូន, ភ្នំ, ១:គ១, ៣:ខ២, ៤:ឃ២, ១០:គ១, ១១:ឃ១, ១៤:ឃ៥
វាំងស្តេចហេរ៉ូឌ, នៅក្រុងយេរូសាឡិម, ១២:ខ៥
ហែសបុន, ៤:ឃ៥
ប្រឡាយហេសេគា, នៅក្រុងយេរូសាឡិម, ១២:គ៦
ហ៊ីនណំម, ច្រកភ្នំ, នៅក្រុងយេរូសាឡិម, ១២:ខ៧
ហ៊ីសប៉ានា, ភូមិភាគ, ៨:ក២
ហេត, ប្រជាជន, ៩:ឃ២
ហេវី, ប្រជាជន, ៣:ខ២
ហោរ, ភ្នំ, ២:ឃ២
ហូរេប, ភ្នំស៊ីណាយ), ២:គ៤, ៩:ឃ៤
ហោរី, ប្រជាជន, ៩:ង២
ហោម៉ា, ២:ឃ១, ៤:គ៦
ហ៊ូឡេ (ទឹកមេរ៉ុម), បឹង, ១០:គ២, ១៤:គ៦
ច្រកភ្នំហ៊ូឡេ, ១:គ២, ១១:គ២

អ៊ីខូនាម, ១៣:ឆ២
អេដំម, ភូមិភាគ, ១:ខ៧, ១០:ខ៧, ១១:ខ៧
ទន្លេឥណ្ឌុស, ៧:ឃ៤
អ៊ីស្រាអែល, ស្រះ, នៅក្រុងយេរូសាឡិម, ១២:គ៤
អ៊ីស្រាអែល, ភូមិភាគ, ៤:គ៤
អ៊ីសាខារ, ពូជអំបូរ, ៣:ខ៤
អ៊ីតាលី, ខេត្តនៅប្រទេសរ៉ូម,

យ៉ាបុក, ទន្លេ, ១:គ៥, ៣:ខ៤, ៤:ឃ៤, ១០:គ៥, ១១:គ៥
យ៉ាបេស-កាឡាត, ៣:ខ៤
យេរីខូរ, ១:គ៥, ២:ឃ១, ៣:ខ៥, ៤:ឃ៥, ១០:គ៦, ១៤:ក៧, ១៤:គ៣
យេរីខូរ, ផ្លូវទៅ, ១២:ឃ៥
យេរូសាឡិម (សាឡិម), ១:ខ៦, ២:ឃ១, ៣:ក៥, ៤:គ៥, ៥:ខ៣, ៦:ខ៣, ៧:ក៣, ៨:គ៣, ៩:ឃ៣, ១០:ខ៦, ១១:ខ៦, ១៣:ជ៣, ១៤:ខ២, ១៤:ខ៦

យេរូសាឡិម, ទីក្រុងប៉ែកខាងក្រោម, ១២:គ៦
យេរូសាឡិម, ទីក្រុងប៉ែកខាងលើ, ១២:គ៦
យេសរាល, ៤:ឃ៤, ១០:ខ៤
យេសរាល (អែស្ត្រាឡូន), ច្រកភ្នំ, ១:ខ៣, ១០:ខ៣
យ៉ុបប៉េ, ១:ក៥, ៣;ក៤, ៤:គ៤, ១០:ក៥, ១១:ក៥, ១៣:ជ៣
យ៉ុបប៉េ, ផ្លូវទៅ, ១២:ក៤
ទន្លេយ័រដាន់, ១:គ៥, ២:ឃ១, ៣:ខ៤, ៤:ឃ៤, ១០:គ៥, ១១:គ៥
យូដា, ភូមិភាគ, ៥:ខ៣, ១០:ខ៧
យូដា, ពូជអំបូរ, ៣:ក៥
យូដា, ភូមិភាគ, ១:ខ៦, ១១:ខ៧
យូដា, ទីរហោស្ថាននៅ, ១:ខ៧, ១១:ខ៧
ស្រុកភ្នំនៅយូដា, ១៤:ខ២

កាដេស-បារនា, ២:គ២, ៣:ក៦, ៤:គ៦
ច្រកភ្នំកេដ្រុន, នៅក្រុងយេរូសាឡិម, ១២:ឃ៦
គេរ-ហារេសេត, ១០:គ៧
គីសុន, ទន្លេ, ១:ខ៣, ១០:ខ៣, ១១:ខ៣
គីទីម (គីប្រុស), កោះ, ៩:គ៣

ឡាគីស, ១:ក៦, ៣:ក៥, ៤:គ៥, ១០:ក៦
ឡាអ៊ីស (ដាន់), ១០:គ២
ឡៅឌីសេ, ១៣:ង២
ភ្នំល្បាណូន, ១:គ១, ១០:គ១, ១១:គ១
លិព្យា (ពូត), ៨:ខ៣, ១៣:គ៤
ទីរហោស្ថានលិព្យា, ៩:ខ៤
លីតានី, ទន្លេ, ១:គ១, ១០:គ១, ១១:គ២
សមុទ្រខាងក្រោម (សមុទ្រខាងកើត, ឈូងសមុទ្រពើស៊ី), ៥:គ៤, ៦:គ៤, ៧:ខ៤, ៨:ឃ៣, ៩:ជ៣
លូស (បេតអែល), ១០:ខ៥
លូកា, ភូមិភាគ, ១៣:ច២
លូឌ, ភូមិភាគ, ១៣:ង២
លីស្ត្រា, ១៣:ឆ២

ម៉ាសេដូន, ភូមិភាគ, ៧:ក២, ៨:គ២, ១៣:ឃ១
ម៉ាខារ, ១១:គ៧
ម៉ាក់ដាឡា, ១១:គ៣
ម៉ាហាណាអិម, ១០:គ៤
ម៉ាលតា, កោះ, ១៣:ខ៣
ម៉ាន៉ាសេ, ពូជអំបូរ, ៣:ក៤, ៣:ខ៣
ម៉ារ៉ា, ២:ខ៣
មារ អ៊ីនទើណុម (សមុទ្រធំ, សមុទ្រមេឌីទែរ៉េនាន, សមុទ្រខាងលើ), ៨:ខ៣
មេឌីបា, ៤:ឃ៥
អាណាចក្រមេឌី, ៦:ឃ៣
សមុទ្រមេឌីទែរ៉េនាន (សមុទ្រធំ, សមុទ្រខាងលើ), ១:ក៥, ២:ខ១, ៣:ក៤, ៤:គ៤, ៥:ក៣, ៦:ក៣, ៧:ក៣, ៨:ខ៣, ៩:ខ៣, ១០:ក៥, ១១:ក៦, ១៣:ឃ៣, ១៤:ក២, ១៤:ក៦
សមុទ្រមេឌីទែរ៉េនាន, កំពស់នៃ, ១៤:ក២, ១៤:ក៦
មេគីដោ, ១:ខ៣, ៣:ក៤, ៤:គ៤, ៦:ខ៣, ៩:ឃ៣, ១០:ខ៣
មេលីតា (ម៉ាលតា), កោះ, ១៣:ខ៣
មេមភីស (ណូព), ២:ក៣, ៥:ខ៣, ៦:ខ៣, ៧:ក៣, ៨:គ៣
មេសូប៉ូតាមា, ៨:ឃ៣, ៩:ង២
ម៉ាឌាន, ភូមិភាគ, ២:ឃ៤, ៩:ឃ៤
មីលេត, ១៣:ង២
ម៉ូអាប់, វាលទំនាប, ១:គ៦, ១១:គ៦
ម៉ូអាប់, ភូមិភាគ, ១:គ៧, ២:ឃ១, ៣:ខ៦, ៤:ឃ៦, ១០:គ៧
ម៉ូរេស, ភ្នំ, ១:គ៣, ១០:ខ៣
ម៉ូរីយ៉ា, ភ្នំ, ១៤:ខ៦
មីសេនេ, ៥:ក២
មីរ៉ា, ១៣:ច២
មីស៊ា, ភូមិភាគ, ១៣:ង២

ណាបាធា, ភូមិភាគ, ១១:គ៨
ណាអ៊ីន, ១១:គ៤
ណែបថាលី, ពូជអំបូរ, ៣:ខ៣
ណាសារ៉ែត, ១:ខ៣, ១១:ខ៣
នេបូរ, ភ្នំ, ១:គ៦, ២:ឃ១, ៣:ខ៥, ៤:ឃ៥, ១០:គ៦, ១១:គ៦
នេកែវ, ភូមិភាគ, ១:ក៨, ១០:ក៨
ណៃល, ទន្លេ, ២:ក៣, ៥:ខ៤, ៦:ខ៤, ៧:ក៤, ៨:គ៤, ៩:គ៤
ដីសណ្ដរណៃល, ២:ក២, ៩:គ៤
នីនីវេ, ៥:គ២, ៩:ច២
ណូព (មេមភីស), ២:ក៣

ដើមអូលីវ, ភ្នំ, ១:ខ៦, ១០:ខ៦, ១១:ខ៦, ១២:ឃ៤, ១៤:ខ៦
អូន (ហេលីអុបប៉ូល), ២:ក៣, ៩:គ៤

ប៉ាដាន់-អើរ៉ាម (ហារ៉ាន), ៩:ង២
ប៉ាភីលា, ភូមិភាគ, ១៣:ង២
ប៉ាផុស, ១៣:ឆ៣
ប៉ារ៉ាន, ទីរហោស្ថាន, ២:គ៣
អាណាចក្រប៉ារធី, ៨:ឃ៣
ប៉ាត់ម៉ូស, កោះ, ១៣:ង២
ពេណូអែល, ១០:គ៤
ពើរា, ១១:គ៥
ពើកា, ១៣:ច២
ពើកាមុម, ១៣:ង២
ពើស៊ី, ៥:ឃ៤, ៦:ឃ៤
ឈូងសមុទ្រពើស៊ី, (សមុទ្រខាងក្រោម), ៩:ជ៣
ផារប៉ារ, ទន្លេ, ១:ឃ១, ១០:ឃ១, ១១:ឃ២
ភីឡាដិលតា, ១១:ឃ៦
ភីលីព, ១៣:ឃ១
ភីលីស្ទា, វាលទំនាប, ១:ក៦, ១០:ក៦
ភីលីស្ទា, ភូមិភាគ, ៤:គ៥
ភីលីស្ទីន, ប្រជាជន, ២:គ២
ភីណីស៊ី, ភូមិភាគ, ១:គ១, ៤:ឃ២, ៩:ឃ៣, ១០:ខ១, ១១:ខ២, ១៣:ជ៣
ព្រីគា, ភូមិភាគ, ១៣:ង២
ពីហាហ៊ីរ៉ុថ, ២:ខ៣
ពីស៊ីឌា, ភូមិភាគ, ១៣:ង២
ពីថំ, ២:ខ២
ប៉ុនតុស, ភូមិភាគ, ១៣:ឆ១
តូលេមេ (អ័កូរ, អាកូរ), ១:ខ៣, ១១:ខ៣, ១៣:ជ៣
ពូទីយ៉ូលី, ១៣:ខ១

រ៉ាបាត (អាំម៉ាន), ១:ឃ៥, ៣:ខ៥, ១០:ឃ៥, ១៤:ឃ២
រ៉ាមសេស (តានីស), ២:ខ២

រ៉ាម៉ូត-កាឡាត, ៣:ខ៤, ៤:ឃ៤
សមុទ្រក្រហម, ២:ឃ៤, ៥:ខ៤, ៦:ខ៤, ៧:ខ៤, ៨:គ៤, ៩:ឃ៤
រេផិឌីម, ២:គ៤
រូបេន, ពូជអំបូរ, ៣:ខ៥
រេគាម, ១៣:ខ២
រ៉ូដូស, កោះ, ៩:ខ៣, ១៣:ង៣
រ៉ូម, ៨:ខ២, ១៣:ក១
រាជបាំងសាច, ក្រុងយេរូសាឡិម, ១២:គ៥

សាឡាមីន, ១៣:ឆ៣
សាឡិម (យេរូសាឡិម), ៩:ឃ៣
សាលិម, ១១:គ៤
សមុទ្រប្រៃ (សមុទ្រស្លាប់), ១:គ៦, ២:ឃ១, ៣:ខ៥, ៤:ឃ៥, ៩:ឃ៤
សាម៉ារី, ១:ខ៤, ៥:ខ៣, ១០:ខ៤, ១១:ខ៥, ១៣:ជ៣
សាម៉ារី, ភូមិភាគ, ១:ខ៤, ១០:ខ៤, ១១:ខ៤
សាម៉ារី, ផ្លូវទៅ, ១២:១
សាម៉ូត្រាស, កោះ, ១៣:ង១
សារិបតា, ១១:ខ១
សារម៉ាទី, ភូមិភាគ, ៨:គ១
ស្រះនាគ, នៅក្រុងយេរូសាឡិម, ១២:ក៦
សារ៉ុន, វាលទំនាប, ១:ខ៤, ១០:ខ៤, ១១:ខ៥
ស៊ីគែម, ៣:ក៤, ៤:គ៤, ១០:ខ៤
ទ្វារចៀម, នៅក្រុងយេរូសាឡិម, ១២:គ៤
សេភេឡា, ១:ខ៦, ១០:ខ៦, ១៤:ខ២
ស៊ីឡូរ, ៣:ក៤, ៤:ឃ៤, ១០:ខ៥
ស៊ីណើរ (បាប៊ិល), ៩:ឆ៣
សេអ៊ីរ, ទីរហោស្ថាន, ២:ខ២
ស៊ូសាន (ស៊ូសា), ៦:គ៣, ៧:ខ៣, ៩:ឆ៣

ស៊ីដូន, ១:គ១, ៣:ក២, ៤:ឃ២, ៩:ឃ៣, ១០:គ១, ១១:គ១, ១៣:ជ៣
ស៊ីឡោម, ស្រះ, នៅក្រុងយេរូសាឡិម, ១២:គ៧
ស៊ីម្មាន, ពូជអំបូរ, ៣:ក៦
បាប, ទីរហោស្ថាន, ២:គ៤
ស៊ីណាយ, ភ្នំ (ហូរេប), ២:គ៤, ៩:ឃ៤
ជ្រោយស៊ីណាយ, ២:គ៣
ទីរហោស្ថានស៊ីណាយ, ២:គ៤
ស្មឺន៉ា, ១៣:ង២
សូដុំម និង កូម៉ូរ៉ា, តំបន់, ១០:គ៨
បាំងសាចសាឡូម៉ូន, នៅក្រុងយេរូសាឡិម, ១២:ឃ៤
សូរេក, ទន្លេ, ១:ខ៦, ១០:ខ៦, ១១:ខ៦
ស្ពើរតា, ៦:ក២, ៧:ក២
សុកកុត, នៅប្រទេសអ៊ីស្រាអែល, ៣:ខ៤, ៤:ឃ៤
សុកកុត, នៅប្រទេសអេស៊ីព្ទ, ២:ខ២
ស៊ូអែស, ឈូងសមុទ្រ, ២:ខ៣
ស៊ូសា (ស៊ូសាន), ៦:គ៣, ៧:ខ៣, ៩:ឆ៣
ទ្វារស៊ូសា, នៅក្រុងយេរូសាឡិម, ១២:ឃ៤
ស៊ូខារ, ១១:ខ៥
ស៊ីរ៉ាគូស, ១៣:ខ២
ស៊ីរី, ភូមិភាគម ៦:ខ៣, ៨:គ៣, ៩:ឃ៣, ១១:គ២, ១៣:ជ៣

តាបោរ, ភ្នំ, ១:គ៣, ៣:ខ៤, ៤:ឃ៤, ១០:គ៣, ១១:គ៣, ១៤:គ៦
តានីស (រ៉ាមសេស), ២:ខ២
តើសុស, ១៣:ឆ២
ថេកោ, ១០:ខ៦
ព្រះវិហារ, នៅក្រុងយេរូសាឡិម, ១២:គ៤
ព្រះវិហារ, កំពូល, នៅក្រុងយេរូសាឡិម, ១២:ឃ៥
ព្រះវិហារ, ជណ្តើរទៅ, នៅក្រុងយេរូសាឡិម, ១២:ឃ៥
ថេប, ៥:ខ៤, ៦:ខ៤, ៧:ក៤, ៨:គ៤
ថែស្សាឡូនិច, ៨:គ២, ១៣:ឃ១
ផ្ទះសំណាក់បីខ្នង, ១៣:ខ១
ទីបេរាស, ១១:គ៣
ទីគ្រីស, ទន្លេ, ៥:គ២, ៦:គ២, ៨:ឃ៣, ៩:ឆ៣
ស្រះប៉ម, នៅក្រុងយេរូសាឡិម, ១២:ខ៥
នាយយ័រដាន់, ខ្ពង់រាបខាងកើត, ១៤:ឃ២
ទ្រអាស, ៦:ក២, ៧:ក២, ១៣:ង២
ត្រោយ, ៩:ខ២
ទីរ៉ុស, ១:ខ២, ៣:ក៣, ៤:គ៣, ៩:ឃ៣, ១០:ខ១, ១១:ខ២, ១៣:ជ៣

សមុទ្រខាងលើ (ធំ, មេឌីទេរេនាន), ៧:ក៣, ៩:ខ៣
បន្ទប់ខាងលើ, នៅក្រុងយេរូសាឡិម, ១២:ខ៦
អ៊ើរ, ៥:គ៣, ៩:ង២, ៩:ឆ៣
អ៊ើរ៉ាទុ, ភូមិភាគ, ៩:ង១

ទ្វារទឹក, នៅក្រុងយេរូសាឡិម, ១២:គ៧
ទឹកម៉េរ៉ុម (បឹងហ៊ូឡេ), ១០:គ២
ជំរុំនៅទីរហោស្ថាន, ២:គ៤

យេរមុក, ទន្លេ, ១:គ៣, ១០:គ៣, ១១:គ៣

សាប់យូល៉ូន, ពូជអំបូរ, ៣:ក៣
សេរេត, ទន្លេ, ១:គ៨, ២:ឃ២, ៣:ខ៦, ៤:ឃ៦, ១០:គ៨, ១១:គ៨
ស៊ីកឡាក់, ៤:គ៥
ស៊ីន, ទីរហោស្ថាន, ២:គ២
ស៊ីយ៉ូន, ភ្នំ, ១៤:ខ៦




## ផែនទីទាំងឡាយដែលទាក់ទងទៅនឹងព្រះគម្ពីរប៊ីប

ផែនទីដែលមានដូចតទៅនេះ គឺបានផ្ដល់ដើម្បីជួយក្នុងការសិក្សាព្រះគម្ពីរ ហើយបានរៀបចំឡើងដើម្បីជួយខាងការបង្រៀនទាំងឡាយ ដែលមាននៅក្នុងថ្នាក់បង្រៀនទាំងឡាយនៅក្នុងសាសនាចក្រ ។

ការរាយផែនទីខាងលើនេះ គឺចំអុលប្រាប់ពីផែនទីនីមួយៗ ដែលមានលេខរៀងតតាមក្រោម ។ ផែនទីទាំងនេះគឺជាផែនទីអំពីភូមិភាគធំៗ ព្រមទាំងអំពីកន្លែងតូចតាចស្របតាមភូមិសាស្ត្រ ។

**ផែនទី ទី១** ផែនទីខាងភូមិសាស្ត្របរិយាយ អំពីដែនដីបរិសុទ្ធ

**ផែនទី ទី២** ការនិក្ខមនំរបស់ពួកអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ និងការចូលស្រុកកាណាន

**ផែនទី ទី៣** ការញែកពូជទាំង ១២ អំបូរ

**ផែនទី ទី៤** អានាចក្ររបស់ដាវីឌ និងសាឡូម៉ូន

**ផែនទី ទី៥** អាណាចក្រស៊ីរី

**ផែនទី ទី៦** អាណាចក្របាប៊ីឡូនថ្មី (នេប៊ូក្នេសារ) និងនគរអេស៊ីព្ទ

**ផែនទី ទី៧** អាណាចក្រពើស៊ី

**ផែនទី ទី៨** អាណាចក្ររ៉ូម

**ផែនទី ទី៩** ពិភពលោកនៅសម័យព្រះគម្ពីរសញ្ញាចាស់

**ផែនទី ទី១០** ស្រុកកាណាននៅសម័យព្រះគម្ពីរសញ្ញាចាស់

**ផែនទី ទី១១** ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរសញ្ញាថ្មី

**ផែនទី ទី១២** ក្រុងយេរូសាឡិមនៅសម័យព្រះយេស៊ូវ

**ផែនទី ទី១៣** ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា

**ផែនទី ទី១៤** កំពស់នៃដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរប៊ីប

ផែនទីខាងភូមិសាស្ត្របរិយមនៃដែនដីបរិសុទ្ធ

**ផែនទី ទី១**



# ការនិក្ខមនំរបស់ពួកអ៊ីស្រាអែលពីស្រុកអេស៊ីព្ទ ហើយចូលទៅស្រុកកាណាន

**ផែនទី ទី២**




១. **រ៉ាមសេស** ពួកអ៊ីស្រាអែលត្រូវបានបណ្តេញចេញពីស្រុកអេស៊ីព្ទ (និក្ខ. ១២; ជនគ. ៣៣:៥) ។

២. **សុកកុត** បន្ទាប់ពីពួកហេព្រើរបានចេញពីទីជំរុំទីមួយនេះ ព្រះអម្ចាស់ទ្រង់បានយាងមកជួបពួកគេក្នុងពពកនៅពេលថ្ងៃ ហើយក្នុង បង្គោលភ្លើងនៅពេលយប់ (និក្ខ. ១៣:២០–២២) ។

៣. **ពីហាហ៊ីរ៉ុថ** ពួកអ៊ីស្រាអែលបានឆ្លងសមុទ្រក្រហម (និក្ខ. ១៤; ជនគ. ៣៣:៨) ។

៤. **ម៉ារ៉ា** ព្រះអម្ចាស់ទ្រង់បានធ្វើឲ្យទឹកម៉ារ៉ាទៅជាសាប (និក្ខ. ១៥:២៣–២៦) ។

៥. **អេលីម** ពួកអ៊ីស្រាអែលបានបោះជំរុំនៅក្បែរក្បាលទឹក ១២ (និក្ខ. ១៥:២៧) ។

៦. **ទីរហោស្ថានបាប** ព្រះអម្ចាស់ទ្រង់បានចាត់ឲ្យមាននំម៉ាន៉ា និងសត្វក្រួច ដើម្បីឲ្យអាហារដល់ពួកអ៊ីស្រាអែល (និក្ខ. ១៦) ។

៧. **រេផិឌីម** ពួកអ៊ីស្រាអែលបានច្បាំងជាមួយនឹងពួកអាម៉ាលេក (និក្ខ. ១៧:៨–១៦) ។

៨. **ភ្នំស៊ីណាយ (ភ្នំហូរែប ឬ ភ្នំយេមិល មូសា)** ព្រះអម្ចាស់ទ្រង់បានបើកសម្តែងប្រាប់នូវព្រះបញ្ញត្តិ ១០ ប្រការ (និក្ខ. ១៩–២០) ។

៩. **ទីរហោស្ថានស៊ីណាយ** ពួកអ៊ីស្រាអែលបានសង់រោងឧបោសថ (និក្ខ. ២៥–៣០) ។

១០. **ជំរុំនៅទីរហោស្ថាន** ពួកចាស់ទុំ ៧០នាក់ត្រូវបានហៅឲ្យជួយលោកម៉ូសេត្រួតត្រាប្រជាជន (ជនគ. ១១:១៦–១៧) ។

១១. **អេស៊ាន-គេប៊ើរ** ពួកអ៊ីស្រាអែលបានឆ្លងកាត់ដែនដីអេសាវ និងដែនដីអាំម៉ូនដោយក្តីសុខសាន្ត (ចោទិ. ២) ។

១២. **កាដេស-បារនា** លោកម៉ូសេបានចាត់ពួកស៊ើបការឲ្យទៅឯដែនដីសន្យា; ពួកអ៊ីស្រាអែលបានបះបោរ ហើយមិនបានចូលដែនដី នោះទេ; កាដេសបានទៅជាជំរុំដ៏សំខាន់មួយរបស់ពួកអ៊ីស្រាអែល អស់ជាច្រើនឆ្នាំ (និក្ខ. ១៣:១–៣, ១៧–៣៣; ១៤; ៣២:៨; ចោទិ. ២:១៤) ។

១៣. **ទីរហោស្ថានខាងកើត** ពួកអ៊ីស្រាអែលបានចៀសវាងការតយុទ្ធជាមួយនឹងពួកអេដំម និងពួកម៉ូអាប់ (ជនគ. ២០:១៤–២១; ២២–២៤) ។

១៤. **ទន្លេអើណូន** ពួកអ៊ីស្រាអែលបានបំផ្លាញពួកអាម៉ូរី ដែលបានតតាំងនឹងពួកគេ (ចោទិ. ២:២៤–៣៧) ។

១៥. **ភ្នំនេបូរ** លោកម៉ូសេបានសម្លឹងមើលដែនដីសន្យា (ចោទិ. ៣៤:១–៤) ។ លោកម៉ូសេបានប្រគល់នូវការបង្រៀនចុងក្រោយរបស់លោក (ចោទិ. ១–៣២) ។

១៦. **វាលទំនាបម៉ូអាប់** ព្រះអម្ចាស់ទ្រង់បានប្រាប់ពួកអ៊ីស្រាអែលឲ្យចែកដី ហើយបំបែកបណ្តាជន (ជនគ. ៣៣:៥០–៥៦) ។

១៧. **ទន្លេយ័រដាន់** ពួកអ៊ីស្រាអែលបានឆ្លងទន្លេយ័រដាន់នៅលើដីគោក ។ នៅក្បែរគីលកាល មានថ្មពីបាតទន្លេយ័រដាន់ដែលបានតំរាប ទុកជាអនុស្សាវរីយ៍អំពីការញែកទឹកទន្លេយ័រដាន់ (យ៉ូស្វេ ៣–៥:១) ។

១៨. **យេរីខូរ** កូនចៅអ៊ីស្រាអែលបានចាប់យក ហើយបំផ្លាញទីក្រុង (យ៉ូស្វេ ៦) ។

# ការបែកខ្ញែកនៃពូជទាំង១២អំបូរ
# ការបែកខ្ញែកនៃពូជទាំង១២អំបូរ; អាណាចក្ររបស់ដាវីឌ និងសាឡូម៉ូន

ផែនទី ទី៣ និងទី៤



# អាណាចក្រអាសស៊ើរ

**ផែនទី ទី៥**

ប្រមាណជាឆ្នាំ ៧២១ ម.គ.ស. (២ ពង្សាវតាក្សត្រ ១៧:១–៦)




# អាណាចក្របាប៊ីឡូនថ្មី (នេប៊ូក្នេសា) និងនគរអេស៊ីព្ទ

**ផែនទី ទី៦**

ប្រមាណជាឆ្នាំ ៦០០–៥៨៦ ម.គ.ស. (២ ពង្សាវតារក្សត្រ ២៤–២៥)



# អាណាចក្រពើស៊ី

**ផែនទី ទី៧**




# អាណាចក្ររ៉ូម៉ាំង

**ផែនទី ទី៨**



ផែនទី ទី៩



សមុទ្រកាសព្យែន
ភ្នំអារ៉ារ៉ាត
អាសស៊ើរ
នីនីវេ
មេសូប៉ូតាមា
បាប៊ីឡូន
អេឡាំ
ទន្លេទីក្រីស
ទន្លេអឺប្រាត
ស៊ីរី
កាណាន
អេស៊ីព្ទ
ទន្លេនីល
គីឡូម៉ែត្រ
0 ១០០ ២០០ ៣០០ ៤០០

១. **ភ្នំអារ៉ារ៉ាត** ជាកន្លែងបុរាណដែលលោកណូអេបានកៀងទូកធំ (លោកុ. ៨:៤) ។ កន្លែងមែនទែននោះគ្មាននរណាស្គាល់ទេ ។

២. **អ៊ើរ** ជាទីលំនៅទីមួយរបស់លោកអ័ប្រាហាំ ជាកន្លែងដែលលោកជិតកើតទោមនុស្ស សំរាប់ធ្វើយញ្ញបូជា, បានឃើញទេវតានៃព្រះ យេហូវ៉ា, ហើយបានទទួលយូរីម និងធូមីម (លោកុ. ១១:២៨–១២:១; អ័ប្រា. ១; ៣;១) ។ (ក៏សំគាល់ដែលថា កន្លែងមួយទៀត សំរាប់ អ៊ើរ គឺនៅមេសូប៉ូតាមាខាងជើង) ។

៣. **បាប៊ីឡូន, បាប៊ិល (ស៊ីណើរ)** លើកដំបូង ត្រូវបានមកនៅដោយគូស ជាកូនប្រុសរបស់ហាំ និងដោយនិមរ៉ូឌ ។ ជាកន្លែងដើមនៃពួក សាសន៍យ៉ារេឌ នៅសម័យប៉មនៃបាប៊ិល នោងវាលទំនាបស៊ីណើរ ។ ក្រោយមក ជាទីក្រុងខេត្តបាប៊ីឡូន ហើយជាទីលំនៅរបស់ស្ដេចនៃ ពួកបាប៊ីឡូន ព្រមទាំងស្ដេចនេប្វូក្នេសារ ដែលបានចាប់ពួកសាសន៍យូដាជាច្រើនធ្វើជាឈ្លើយ យកទៅទីក្រុងនេះ បន្ទាប់ពីការបំផ្លិចបំផ្លាញក្រុងយេរូសាឡិម (៥៨៧ ម.គ.ស.) ។ ពួកសាសន៍យូដាជាប់នៅជាឈ្លើយ នៅក្រុងបាប៊ីឡូនអស់រយៈ ៧០ ឆ្នាំ រហូតដល់សម័យស្ដេច ស៊ីរូស ដែលបានអនុញ្ញាតឲ្យពួកសាសន៍យូដាវិលទៅក្រុងយេរូសាឡិមវិញ ដើម្បីសង់ព្រះវិហារ ។ ដានីយ៉ែល ជាព្យាការី ក៏បាន អាស្រ័យនៅទីនេះ នៅក្រោមស្ដេចនេប្វូក្នេសារ, ស្ដេចបេលសាសារ, និងស្ដេចដារីយុស ទី១ (លោកុ. ១១:១–៩; ២ ពង្សាវ. ២៤–២៥; យេរេ. ២៧:១–២៩:១០; អេសេ. ១:១; ដានី. ១–១២; អោមណៃ ១:២២; អេធើរ ១:៣៣–៤៣) ។

៤. **ស៊ូសាន (ស៊ូសា)** ជារាជធានីនៃអានាចក្រពើស៊ី នៅក្រោមរដ្ឋកាលរបស់ស្ដេចដារីយុស ទី១ (ដារីយុសដ៏មហិមា), ស្ដេចសើកសេស (អ័ហាស្វេរុស), និងស្ដេចអើថាសើកសេស ។ ជាទីលំនៅរបស់ព្រះនាងអេសធើរ គឺសេចក្ដីក្លាហាន និងសេចក្ដី ជំនឿរបស់ព្រះនាងនេះហើយ ដែលបានជួយសង្គ្រោះពួកសាសន៍យូដា ។ ដានីយ៉ែល និងនេហេមា ក្រោយមក បានបំរើនៅទីនេះ (នេហេ. ១:១; ២:១; នាងអេសធើរ ១:១; ដានី. ៨:២) ។

៥. **វាលទំនាបឌូរ៉ា** សាឌ្រាក់, មែសាក់, និងអ័បេឌ-នេកោ ត្រូវបានបោះទៅក្នុងឡភ្លើង នៅពេលពួកគេមិនព្រមថ្វាយបង្គំរូបព្រះធ្វើពី មាស ដែលបានធ្វើដោយស្ដេចនេប្វូក្នេសារ; ព្រះរាជបុត្រានៃព្រះបានរក្សាជីវិតពួកគេទុក ហើយពួកគេបានចេញមកពីឡភ្លើងដោយគ្មាន គ្រោះថ្នាក់អ្វីឡើយ (ដានី. ៣) ។

៦. **អាសស៊ើរ** ក្រុងអាសស៊ើរ គឺជារាជធានីទីមួយរបស់ស្រុកអាសស៊ើរ ក្រោយមកគឺក្រុងនីនីវេ ។ សាលម៉ានេស៊ើរ ទី១ និងសើកូន ទី២ ជាអ្នកគ្រប់គ្រងរបស់ពួកអាសស៊ើរ បានច្បាំងយកនគរអ៊ីស្រាអែលខាងជើង ហើយបានចាប់យកកុលទាំង ១០ អំបូរ ទៅជាឈ្លើយ នៅឆ្នាំ ៧២១ ម.គ.ស. (២ ពង្សាវ. ១៤–១៥, ១៧–១៩) ។ ស្រុកអាសស៊ើរគឺជាខ្មាំងដល់ស្រុកយូដា រហូតដល់ឆ្នាំ ៦១២ ម.គ.ស. កាលស្រុកអាសស៊ើរត្រូវបានច្បាំងយកដោយស្រុកបាប៊ីឡូន ។

៧. **នីនីវេ** ជារាជធានីនៃស្រុកអាសស៊ើរ ។ ស្រុកអាសស៊ើរបានទៅច្បាំងនឹងដែនដីយូដា រវាងរាជ្យនៃស្ដេចហេសេគា និងការងារបំរើ របស់ព្យាការីអេសាយ ។ ក្រុងយេរូសាឡិម ជារាជធានីនៃស្រុកយូដា នោះត្រូវបានរួចផុតនៅពេលទេវតាបានវាយពួកទាហារអាសស៊ើរ ស្លាប់អស់ ១៨៥,០០០ នាក់ (២ ពង្សាវ. ១៩:៣២–៣៧) ។ ព្រះអម្ចាស់ទ្រង់បានប្រាប់ព្យាការីយ៉ូណាសឲ្យទៅហៅប្រជាជននៅទីក្រុងឲ្យប្រែចិត្ត (យ៉ូណាស ១:២; ៣:១–៤) ។

៨. **ហារ៉ាន** លោកអ័ប្រាហាំបានស្នាក់នៅទីនេះអស់មួយរយៈ មុនធ្វើដំណើរទៅស្រុកកាណាន ។ ឪពុក និងបងប្រុសរបស់លោក អ័ប្រាហាំបាននៅទីនេះ ។ នាងរេបិកា (ម្ដាយរបស់អ៊ីសាក), និងនាងរ៉ាជែល, នាងលេអា, នាងប៊ីលហា និងនាងស៊ីលផា (ជា ប្រពន្ធទាំងឡាយរបស់យ៉ាកុប), ពួកគេបានមកពីតំបន់នេះ (លោកុ. ១១:៣១–៣២; ២៤:១០; ២៩:៤–៦; អ័ប្រា. ២:៤–៥) ។

៩. **កើកេមិស** ជាវ៉ោននេខូវបានចាញ់ស្ដេចនេប្វូក្នេសារនៅទីនេះ កាលដែលបញ្ចប់នូវអំណាចនៃពួកអេស៊ីព្ទនៅស្រុកកាណាន (២ របា. ៣៥:២០–៣៦:៦) ។

១០. **ស៊ីដូន** ទីក្រុងនេះបានស្ថាបនាដោយស៊ីដូន ដែលជាចៅរបស់ហាំ ហើយជាទីក្រុងនៃពួកកាណានមួយដែលនៅជើងបង្អស់ (លោកុ. ១០:១៥–២០) ។ ជាទីលំនៅនៃព្រះនាងយេសិបិល ជាអ្នកដែលបាននាំឲ្យមានការថ្វាយបង្គំដល់ព្រះបាលនៅស្រុកអ៊ីស្រាអែល (១ ពង្សាវ. ១៦:៣០–៣៣) ។

១១. **ទីរុស** នេះជាទីក្រុងនៅតាមកំពង់ និងខាងទំនិញទិញដូរមួយនៅសុកស៊ីរី ។ ស្ដេចហ៊ីរ៉ាមពីក្រុងទីរុសបានបញ្ជូនឈើតាត្រៅ និងមាស និងពួកអ្នកធ្វើការ ឲ្យទៅជួយស្ដេចសាឡូម៉ូនសង់ព្រះវិហាររបស់ទ្រង់ (១ ពង្សាវ. ៥:១–១០, ១៨, ៩:១១) ។

១២. **ដាម៉ាស** លោកអ័ប្រាហាំបានជួយសង្គ្រោះឡុតនៅជិតទីនេះ ។ ដាម៉ាសជាទីក្រុងធំមួយនៅស្រុកស៊ីរី ។ នៅក្នុងរាជ្យស្ដេច ដាវីឌ ពួកអ៊ីស្រាអែលបានច្បាំងយកទីក្រុងនេះ ។ លោកអេលីយ៉ាបានចាក់ប្រេងលាបហាសាអែលឲ្យធ្វើជាស្ដេចលើដាម៉ាស (លោកុ. ១៤:១៤–១៥; ២ សាំយូ. ៨:៥–៦; ១ ពង្សាវ. ១៩:១៥) ។

១៣. **កាណាន** លោកអ័ប្រាហាំ និងកូនចៅរបស់លោកត្រូវព្រះអម្ចាស់ប្រទានដែនដីនេះឲ្យទុកជាកេរ្តិ៍អាករដ៏អស់កល្បជានិច្ច (លោកុ. ១៧:៨) ។

១៤. **ភ្នំស៊ីណាយ (ហូរេប)** ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលជាមួយនឹងលោកម៉ូសេចេញពីគុម្ពបន្លាដែលឆេះ (និក្ខ. ៣:១–២) ។ លោកម៉ូសេបានទទួលក្រិត្យវិន័យ និងព្រះបញ្ញត្តិ ១០ ប្រការ (និក្ខ. ១៩–២០) ។ ព្រះអម្ចាស់ទ្រង់បានមានព្រះបន្ទូលជាមួយនឹងលោក អេលីយ៉ា ដោយសម្លេងតូចរហៀងៗ (១ ពង្សាវ. ១៩:៨–១២) ។

១៥. **អេស៊ាន-គេប៊ើរ** ស្ដេចសាឡូម៉ូនបានធ្វើ «នាវាមួយក្រុម» នៅត្រង់អេស៊ាន-គេប៊ើរ (១ ពង្សាវ. ៩:២៦) ។ ប្រហែលជា នៅកំពង់នេះហើយដែលមហាក្សត្រិយ៍ស្រុកសេបាបានចុះសំពៅមករកទ្រង់ បន្ទាប់ពីបានឮកិត្តិនាមរបស់សាឡូម៉ូន (១ ពង្សាវ. ១០:១–១៣) ។

១៦. **អេស៊ីព្ទ** លោកអ័ប្រាហាំបានធ្វើដំណើរមកទីនេះ ពីព្រោះតែសេចក្ដីអំណត់អត់ដ៏ធំមួយនៅស្រុកអ៊ើរ (អ័ប្រា. ២:១, ២១) ។ ព្រះអម្ចាស់ទ្រង់បានប្រាប់អ័ប្រាហាំឲ្យបង្រៀនពួកអេស៊ីព្ទ នូវអ្វីៗដែលទ្រង់បានបើកសម្ដែងដល់លោក (អ័ប្រា. ៣:១៥) ។ ពួកបងប្រុសរបស់យ៉ូសែបបានលក់លោកជាទាសករ (លោកុ. ៣៧:២៨) ។ យ៉ូសែបបានក្លាយទៅជាអ្នកត្រួតត្រានៅផ្ទះរបស់ប៉ូទីផារនៅទីនេះ ។ លោកត្រូវគេចាប់ដាក់គុក ។ លោកបានបកស្រាយសប្តិដូនផារ៉ោន ហើយបានទទួលតំណែងដែលមានសិទ្ធិអំណាចនៅស្រុកអេស៊ីព្ទ ។ យ៉ូសែប និងពួកបងប្អូនរបស់លោកបានជួបជុំគ្នា ។ យ៉ាកុប និងក្រុមគ្រួសាររបស់លោកបានផ្លាស់មកនៅទីនេះ (លោកុ. ៣៩–៤៦) ។ ពួកកូនចៅអ៊ីស្រាអែលបានរស់នៅត្រង់កូសែន កាលពួកគេស្នាក់នៅស្រុកអេស៊ីព្ទ (លោកុ. ៤៧:៦) ។

ពួកអ៊ីស្រាអែលបានកើនចំនួនជាច្រើន «ក៏បានទៅជាស្តុកស្តម្ភឡើងសន្ធឹក»; គ្រានោះពួកគេត្រូវពួកអេស៊ីព្ទដាក់ក្នុងសេវកភាព (និក្ខ. ១:៧–១៤) ។ ក្រោយពីមានគ្រោះជាច្រើនកើតឡើង ទើបផារ៉ោនអនុញ្ញាតឲ្យពួកអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទទៅ (និក្ខ. ១២:៣១–៤១) ។ លោកយេរេមាត្រូវបានចាប់យកទៅស្រុកអេស៊ីព្ទ (យេរេ. ៤៣:៤–៧) ។

១៧. **កាប់ថោរ (ក្រេត)** ជាដែនដីបុរាណរបស់ពួកមីណូរ ។

១. **ដាន់ (ឡាអ៊ីស)** ស្ដេចយេរ៉ូបោមបានដំឡើងកូនគោមាស ដើម្បីឲ្យប្រជាជននៅនគរខាងជើងថ្វាយបង្គំ (១ ពង្សាវ. ១២:២៦–៣៣) ។ ដាន់គឺជាទីព្រំដែនខាងជើងបង្អស់នៃនគរអ៊ីស្រាអែលពីបុរាណ ។

២. **ភ្នំកើមែល** លោកអេលីយ៉ាបានប្រកួតប្រជែងនឹងពួកសង្ឃនៃព្រះ ហើយបានបើកមេឃឲ្យភ្លៀង (១ ពង្សាវ. ១៨:១៧–៤០) ។

៣. **មេគីដោ** ជាកន្លែងមួយដែលមានចំបាំងជាច្រើន (ចៅហ្វាយ ៤:១៣–១៦; ៥:១៩; ២ របា. ៣៥:២០–២៣; ២ ពង្សាវ. ២៣:២៩) ។ ស្ដេចសាឡូម៉ូនបានកេណ្ឌមនុស្សឲ្យមកសង់ក្រុងមេគីដោឡើង (១ ពង្សាវ. ៩:១៥) ។ ស្ដេចយ៉ូសៀសពីស្រុកយូដា ត្រូវរបួសជាខ្លាំង នៅក្នុងចំបាំងតតាំងនឹងផារ៉ោននេខូរពីស្រុកអេស៊ីព្ទ (២ ពង្សាវ. ២៣:២៩–៣០) ។ នៅការយាងមកលើកទីពីរ នៃព្រះអម្ចាស់ នោះនឹង មានការតយុទ្ធចុងក្រោយបង្អស់កើតឡើងនៅក្នុងច្រកភ្នំយេសរាល ដែលជាចំណែកចំបាំងអើម៉ាគេដូន (យ៉ូអែល ៣:១៤; វិវ. ១៦:១៦; ១៩:១១–២១) ។ រីឯឈ្មោះថា អើម៉ាគេដូន គឺជាពាក្យក្រេកបកប្រែមកពីពាក្យហេព្រើរ Har Megiddon ឬក៏ភ្នំមេគីដូន ។

៤. **យេសរាល** ឈ្មោះទីក្រុងដែលនៅក្នុងច្រកភ្នំដ៏ធំ ហើយដែលមានដីជាតិបំផុតនៅអ៊ីស្រាអែល ដែលមានឈ្មោះដូចគ្នា ។ ពួកស្ដេចនៅ នគរខាងជើងបានសង់វាំងនៅទីនេះ (២ សាំយូ. ២:៨–៩; ១ ពង្សាវ. ២១:១–២) ។ ព្រះនាងយេសិបិលដ៏ទុច្ចរិត បានគង់នៅទីនេះ ហើយបានសុគតនៅទីនេះដែរ (១ ពង្សាវ. ២១; ២ ពង្សាវ. ៩:៣០) ។

៥. **បេត-សាន** ពួកអ៊ីស្រាអែលបានប្រឈមមុខនឹងពួកកាណាននៅទីនេះ (យ៉ូស្វេ ១៧:១២–១៦) ។ សពរបស់ស្ដេចសូលនោះ គេបានបោះភ្ជាប់នឹងកំផែងទីក្រុងនេះ (១ សាំយូ. ៣១:១០–១៣) ។

៦. **ដូថាន់** យ៉ូសែបត្រូវបានលក់ជាទាសករដោយពួកបងប្រុសរបស់លោក (លោកុ. ៣៧:១៧, ២៨; ៤៥:៤) ។ លោកអេលីសេបាន ឃើញការនិមិត្តមួយ អំពីភ្នំពោរពេញទៅដោយសេះ និងរាជរថ (២ ពង្សាវ. ៦:១២–១៧)។

៧. **សាម៉ារី** ជារាជធានីនៃនគរខាងជើង (១ ពង្សាវ. ១៦:២៤–២៩) ។ ស្ដេចអ័ហាប់បានសង់ព្រះវិហារមួយថ្វាយព្រះបាល (១ ពង្សាវ. ១៦:៣២–៣៣) ។ លោកអេលីយ៉ា និងអេលីសេបានធ្វើការងារបំរើនៅទីនេះ (១ ពង្សាវ. ១៨:២; ២ ពង្សាវ. ៦:១៩–២០) ។ ពួកអាសស៊ើរច្បាំងបានទីក្រុង ហើយបញ្ចប់នូវការចាប់ពួជទាំង ១០ អំបូរ (២ ពង្សាវ. ១៨:៩–១០)។

៨. **ស៊ីគែម** លោកអ័ប្រាហាំបានសង់អាសនាមួយនៅទីនេះ (លោកុ. ១២:៦–៧) ។ យ៉ាកុបបាននៅជិតនេះ ។ ស៊ីម្មាន និងលេវីបានសម្លាប់ពួកប្រុសទាំងអស់នៅទីក្រុងនេះ (លោកុ. ៣៤:២៥) ។ យ៉ូស្វេបានលើកទឹកចិត្តឲ្យ «ចូររើស...នៅថ្ងៃនេះចុះ» ដើម្បីបំរើព្រះ កាលមកដល់ក្រុងស៊ីគែម (យ៉ូស្វេ ២៤:១៥) ។ នៅទីនេះហើយដែលស្ដេចយេរ៉ូបោមបានតាំងរាជធានីនៃនគរខាងជើង (១ ពង្សាវ. ១២) ។

៩. **ភ្នំអេបាល និងភ្នំកេរិស៊ីម** យ៉ូស្វេបានបំបែកពួកអ៊ីស្រាអែលនៅត្រង់ភ្នំពីរនេះ — ព្រះពរទាំងឡាយពីក្រិត្យវិន័យត្រូវបានប្រកាសប្រាប់ ពីលើភ្នំកេរិស៊ីម ក្នុងកាលប្រាប់ពីបណ្ដាសាពីលើភ្នំអេបាល (យ៉ូស្វេ ៨:៣៣) ។ ក្រោយមក ពួកសាម៉ារីបានសង់ព្រះវិហារមួយនៅ កេរិស៊ីម (២ ពង្សាវ. ១៧:៣២–៣៣) ។

១០. **ពេញូអែល (ពេនីអែល)** នៅទីនេះហើយដែលយ៉ាកុបបានចំបាប់នឹងសារទូតពីព្រះអម្ចាស់អស់មួយយប់ (លោកុ. ៣២:២៤–៣២) ។ គេឌានបានបំផ្លាញបន្ទាយរបស់ពួកម៉ាឌានចោល (ចៅហ្វាយ ៨:៥, ៨–៩) ។

១១. **យ៉ុបប៉េ** យ៉ូណាសបានចុះទូកពីទីនេះទៅតើស៊ីស ដើម្បីចៀសវាងឲ្យផុតពីបេសកកម្មទៅក្រុងនីនីវេ (យ៉ូណាស ១:១–៣) ។

១២. **ស៊ីឡូរ** នៅសម័យពួកចៅហ្វាយ រាជធានីរបស់អ៊ីស្រាអែល និងរោងឧបោសថបាននៅទីនេះ (១ សាំយូ. ៤:៣–៤) ។

១៣. **បេត-អែល (លូស)** នៅទីនេះហើយដែលលោកអ័ប្រាហាំបានបែកចេញពីឡុត (លោកុ. ១៣:១–១១) ហើយបានឃើញការ និមិត្តមួយ (លោកុ. ១៣; អ័ប្រា. ២:១៩–២០) ។ យ៉ាកុបបានឃើញការនិមិត្តមួយអំពីជណ្ដើរទៅស្ថានសួគ៌ (លោកុ. ២៨:១០–២២) ។ រោងឧបោសថបាននៅទីនៅគ្រាមួយ (ចៅហ្វាយ ២០:២៦–២៨) ។ ស្ដេចយេរ៉ូបោមបានដំឡើងកូនគោមាស ដើម្បីឲ្យប្រជាជននៅ នគរខាងជើងថ្វាយបង្គំ (១ ពង្សាវ. ១២:២៦–៣៣) ។

១៤. **គេឌាន** ប្រជាជនហេវីពីក្រុងនេះបានបញ្ឆោតយ៉ូស្វេឲ្យចូលក្នុងការសំបថ (យ៉ូស្វេ ៩) ។ ថ្ងៃនៅនឹងនរកាលយ៉ូស្វេឈ្នះចំបាំង (យ៉ូស្វេ ១០:២–១៣) ។ នេះគឺជាទីបណ្ដោះអាសន្ននៃរោងឧបោសថ (១ របា. ១៦:៣៩) ។

១៥. **កាសា, អាសដូឌ, អាសកេឡុន, អេក្រុន, កាត់ (ទីក្រុងទាំងប្រាំរបស់ពួកភីលីស្ទីន)** ពីទីក្រុងទាំងនេះហើយដែលពួកភីលីស្ទីនបាន ធ្វើសង្គ្រាមជាមួយនឹងពួកអ៊ីស្រាអែល ។

១៦. **បេតថ្លេហិម** សពនាងរ៉ាជែលត្រូវបានបក់នៅជិតទីនេះ (លោកុ. ៣៥:១៩) ។ នាងរស់ និងបូអូសបាននៅទីនេះ (នាងរស់ ១:១–២; ២:១, ៤) ។ ទីនេះត្រូវបានហៅថា ក្រុងរបស់ហ្លួងដាវីឌ (លូកា ២:៤) ។

១៧. **ហេប្រុន** លោកអ័ប្រាហាំ (លោកុ. ១៣:១៨), អ៊ីសាក, យ៉ាកុប (លោកុ. ៣៥:២៧), ដាវីឌ (២ សាំយូ. ២:១–៤), និង អាប់សាឡំម (២ សាំយូ. ១៥:១០) បាននៅទីនេះ ។ នេះគឺជារាជធានីទីមួយនៃស្រុកយូដា នៅក្រោមស្ដេចដាវីឌ (២ សាំយូ. ២:១១) ។ ហើយគេជឿថាទីនេះហើយដែលគេបានកប់សពអ័ប្រាហាំ, នាងសារ៉ា, អ៊ីសាក, នាងរេបិកា, យ៉ាកុប, និង នាងលេអា នៅក្នុងរូងថ្ម ម៉ាក់ពេឡា (លោកុ. ២៣:១៧–២០; ៤៩:៣១, ៣៣) ។

១៨. **អេន-គេឌី** ដាវីឌបានពួនពីសូល ហើយបានប្រណីជីវិតដល់សូល (១ សាំយូ. ២៣:២៩; ២៤:១–២២) ។

១៩. **កេរ៉ារ** លោកអ័ប្រាហាំ និងអ៊ីសាកបាននៅទីនេះមួយគ្រា (លោកុ. ២០–២២; ២៦) ។

២០. **បៀរ-សេបា** លោកអ័ប្រាហាំបានជីកអណ្ដូងមួយនៅទីនេះ ហើយបានធ្វើសេចក្ដីសញ្ញាជាមួយនឹងអ័ប៊ីម្មាឡិច (លោកុ. ២១:៣១) ។ អ៊ីសាកបានឃើញព្រះអម្ចាស់ (លោកុ. ២៦:១៧, ២៣–២៤) ហើយយ៉ាកុបបាននៅទីនេះ (លោកុ. ៣៥:១០; ៤៦:១) ។

២១. **សូដុំម និងកូម៉ូរ៉ា** ឡុតបានសុខចិត្តនៅក្រុងសូដុំម (លោកុ. ១៣:១១–១២; ១៤:១២) ។ ព្រះទ្រង់បានបំផ្លាញក្រុងសូដុំម និងក្រុងកូម៉ូរ៉ាចោល ពីព្រោះតែសេចក្ដីទុច្ចរិត (លោកុ. ១៩:២៤–២៦) ។ ក្រោយមក ព្រះយេស៊ូវទ្រង់បានយកទីក្រុងទាំងនេះមកធ្វើ ជានិមិត្តរូបអំពីសេចក្ដីទុច្ចរិត (ម៉ាថាយ ១០:១៥) ។


ក
ខ
គ
ឃ
១
២
៣
៤
៥
៦
៧
៨
ស៊ីដូន
ទន្លេលីតានី
ដាម៉ាស
ភ្នំហ៊ើរម៉ូន
ផារប៉ារ
លីតានី
ទីរ៉ុស
ភេនីស៊ី
ដាន់
១ (ឡាអ៊ីស)
បឹងហ៊ូឡេ
(ទឹកមេរ៉ុម)
ហាសោរ
បាសាន
អាកូរ
សមុទ្រគេនេសារ៉ែត
(សមុទ្រកាលីឡេ)
គីសុន
ភ្នំកើមែល
២
ច្រកភ្នំយេសរាល
(ម៉េគីដ្ដូ)
កាត់-ហេភើរ
ភ្នំតាបោរ
អេនដោរ
យ៉ារមុក
មេគីដោ
៣
៤
ភ្នំម៉ូរេស
៥
យេសរាល
បេត-សាន
ភ្នំគីលបោ
កាឡាត
ដូថាន់
៦
សាម៉ារី
វាលទំនាបសារ៉ុន
៧
សាម៉ារី
ភ្នំអេបាល
ស៊ីគែម
៩
៨
ភ្នំកេរិស៊ីម
១០
ពេណូអែល
មាហានាអិម
យ៉ាបុក
សមុទ្រធំ (សមុទ្រមេឌីទែរ៉ាណេ)
១១
យ៉ុបប៉េ
អៃយ៉ាឡូន
ស៊ីឡូរ
១២
បេតអែល
(លូស)
១៣
អៃយ
១៤
គីបៀន
យេរីខូ
ទន្លេយ័រដាន់
រ៉ាបាត (អាំម៉ាន)
អាំម៉ូន
សូរ៉េក
១៥
អេក្រុន
១៥
អាសដូឌ
១៥
កាត់
យេរូសាឡិម
ភ្នំដើមអូលីវ
សេភេឡា
បេថ្លេហិម
១៦
ភ្នំនេបូ
អាសកេឡូន
១៥
អេឡា
វាលទំនាបភីលីស្ទីន
ថេកោ
សមុទ្រស្លាប់
កាសា
១៥
ឡាគីស
យូដា
ហេប្រូន
១៧
អេន-កេឌី
១៨
អើណូន
កេរ៉ារ
១៩
កេរ៉ារ
ម៉ូអាប់
២០
បៀរ-សេបា
បេសោរ
គៀរ-ហារេសេត
ជ
អេដំម
២១
តំបន់នៃក្រុងសូដុំម និងកូម៉ូរ៉ា
នេកេវ
សេរេត
អារ៉ាបា
អេដំម
គីឡូម៉ែត្រ
០
២០
៤០
៦០

១. **ទីរ៉ុស និងស៊ីដូន** ព្រះយេស៊ូវទ្រង់បានប្រៀបធៀបក្រុងខូរ៉ាស៊ីន និងក្រុងបេតសៃដា ទៅនឹងក្រុងទីរ៉ុស និងក្រុងស៊ីដូន (ម៉ាថាយ ១១:២–២២) ។ ទ្រង់បានប្រោសកូនស្រីរបស់ស្ត្រីពិសាសន៍ដទៃម្នាក់ (ម៉ាថាយ ១៥:២១–២៨) ។

២. **ភ្នំនៃការប្រែរូប** ព្រះយេស៊ូវទ្រង់បានប្រែរូបនៅចំពោះពេត្រុស, យ៉ាកុប, និងយ៉ូហាន ហើយពួកគេបានទទួលកូនសោទាំងឡាយនៃ នគរ (ម៉ាថាយ ១៧:១–១៣) ។ (មនុស្សខ្លះជឿជាក់ថា ភ្នំនៃការប្រែរូប គឺជាភ្នំហើរម៉ូន; មនុស្សខ្លះទៀតជឿជាក់ថាជាភ្នំតាបោរវិញ) ។

៣. **សេសារា ភីលីព** ពេត្រុសបានធ្វើបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយជាកូនសោទាំងឡាយនៃនគរដែលបានសន្យាទុក (ម៉ាថាយ ១៦:១៣–២០) ។ ព្រះយេស៊ូវទ្រង់បានប្រាប់ទុកជាមុន អំពីការសុគត និងដំណើររស់ឡើងវិញរបស់ទ្រង់ផ្ទាល់ (ម៉ាថាយ ១៦:២១–២៨) ។

៤. **ភូមិភាគកាលីឡេ** ព្រះយេស៊ូវទ្រង់បានចំណាយព្រះជន្មាយុ និងការងារបំរើរបស់ទ្រង់នៅស្រុកកាលីឡេ (ម៉ាថាយ ៤:២៣–២៥) ។ នៅទីនេះហើយដែលទ្រង់បានប្រទានការបង្រៀននៅលើភ្នំ (ម៉ាថាយ ៥–៧); បានប្រោសមនុស្សឃ្លង់ (ម៉ាថាយ ៨:១–៤); ហើយបាន រើស, តែងតាំង, និងចាត់ពួកសាវក ១២ នាក់ឲ្យទៅបង្រៀន មានតែយូដាស-អ៊ីស្ការីយុតទេដែលមិនមែនមកពីស្រុកកាលីឡេ (ម៉ាកុស ៣:១៣–១៩) ។ នៅស្រុកកាលីឡេនេះហើយដែលព្រះគ្រីស្ទ កាលមានព្រះជន្មរស់ឡើងវិញនោះទ្រង់បានលេចមកឲ្យពួកសាវកឃើញ (ម៉ាថាយ ២៨:១៦–២០) ។

៥. **សមុទ្រកាលីឡេ ក្រោយមកហៅថា សមុទ្រទីបេរាស** ព្រះយេស៊ូវទ្រង់បានបង្រៀនចេញពីទូករបស់ពេត្រុស (លូកា ៥:១–៣) ហើយបានហៅពេត្រុស, អនទ្រេ, យ៉ាកុប, និងយ៉ូហានឲ្យធ្វើជាពួកអ្នកនេសាទមនុស្ស (ម៉ាថាយ ៤:១៨–២២; លូកា ៥:១–១១) ។ ទ្រង់ក៏បានសម្ងប់ព្យុះ (លូកា ៨:២២–២៥), បានបង្រៀននូវពាក្យប្រៀបប្រដូចចេញពីទូក (ម៉ាថាយ ១៣), ហើយបានយាងលើទឹកសមុទ្រ (ម៉ាថាយ ១៤:២២–៣២), ហើយលេចមកឲ្យពួកសិស្សរបស់ទ្រង់ឃើញ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ (យ៉ូហាន ២១) ។

៦. **បេតសៃដា** ពេត្រុស, អនទ្រេ, និងភីលីពបានកើតនៅក្រុងបេតសៃដា (យ៉ូហាន ១:៤៤) ។ ព្រះយេស៊ូវទ្រង់បានចេញទៅជាមួយ នឹងពួកសាវកដោយឡែក នៅជិតក្រុងបេតសៃដា ។ ហ្វូងមនុស្សបានដើរតាមទ្រង់ ហើយទ្រង់បានប្រទានអាហារដល់មនុស្ស ៥ ពាន់នាក់ (លូកា ៩:១០–១៧; យ៉ូហាន ៦:១–១៤) ។ នៅទីនេះហើយដែលព្រះយេស៊ូវទ្រង់បានប្រោសមនុស្សខ្វាក់ម្នាក់ (ម៉ាកុស ៨:២២–២៦) ។

៧. **កាពើណិម** នេះជាស្រុករបស់ពេត្រុស (ម៉ាថាយ ៨:៥, ១៤) ។ នៅកាពើណិមនេះហើយដែលម៉ាថាយបានហៅថាជា «ក្រុងផ្ទាល់» របស់ព្រះយេស៊ូវ នោះព្រះយេស៊ូវទ្រង់បានប្រោសមនុស្សស្លាប់ដៃស្លាប់ជើង (ម៉ាថាយ ៩:១–៧; ម៉ាកុស ២:១–១២), បានប្រោសបាវបំរើរបស់មេទ័ពម្នាក់, បានប្រោសម្តាយក្មេករបស់ពេត្រុស (ម៉ាថាយ ៨:៥–១៥), បានហៅម៉ាថាយឲ្យធ្វើជាសាវកម្នាក់ របស់ទ្រង់ (ម៉ាថាយ ៩:៩), បានបើកភ្នែកមនុស្សខ្វាក់ឲ្យមើលឃើញ បានបណ្តេញអារក្សចេញ (ម៉ាថាយ ៩:២៧–៣៣), បានប្រោសមនុស្សម្នាក់ ដែលមានដៃស្វិតនៅថ្ងៃឈប់សំរាក (ម៉ាថាយ ១២:៩–១៣), បានប្រទានបទបង្រៀនអំពីនំបុ័ងជីវិត (យ៉ូហាន ៦:២២–៦៥), ហើយបានយល់ព្រមបង់ពន្ធ ដោយប្រាប់ពេត្រុសឲ្យទៅយកប្រាក់ពីមាត់ត្រី (ម៉ាថាយ ១៧:២៤–២៧) ។

៨. **ម៉ាក់ដាឡា** នេះជាស្រុករបស់នាងម៉ារាពីស្រុកម៉ាក់ដាឡា (ម៉ាកុស ១៦:៩) ។ ព្រះយេស៊ូវទ្រង់បានមកទីនេះ ក្រោយពីបានប្រទាន អាហារដល់មនុស្ស ៤ ពាន់នាក់ (ម៉ាថាយ ១៥:៣២–៣៩), ហើយពួកផារិស៊ី និងពួកសាឌូស៊ីបានសូមឲ្យទ្រង់បង្ហាញទីសំគាល់ពី ស្ថានសួគ៌ (ម៉ាថាយ ១៦:១–៤) ។

៩. **កាណា** ព្រះយេស៊ូវទ្រង់បានធ្វើឲ្យទឹកក្លាយទៅជាស្រាទំពាំងបាយជូរ (យ៉ូហាន ២:១–១១) ហើយបានប្រោសកូនប្រុសរបស់នាម៉ឺន ម្នាក់នៅកាពើណិម (យ៉ូហាន ៤:៤៦–៥៤) ។ កាណាគឺជាស្រុករបស់ណាថាណែល (យ៉ូហាន ២១:២) ។

១០. **ណាសារ៉ែត** ទេវតាបានមកជួប ហើយប្រាប់នាងម៉ារា និងយ៉ូសែបនៅភូមិណាសារ៉ែត (ម៉ាថាយ ១:១៨–២៥; លូកា ១:២៦–៣៨; ២:៤–៥) ។ កាលបានវិលមកពីស្រុកអេស៊ីព្ទវិញ នោះព្រះយេស៊ូវបានចំណាយកុមារ័យ និងយុវវ័យនៅទីនេះ (ម៉ាថាយ ២;១៩–២៣; លូកា ២:៥១–៥២), បានប្រកាសប្រាប់ថា ទ្រង់ជាព្រះមែស៊ី ហើយរាស្ត្ររបស់ទ្រង់បានបដិសេធថាមិនស្គាល់ទ្រង់ (លូកា ៤:១៤–៣២) ។

១១. **យេរីខូរ** ព្រះយេស៊ូវទ្រង់បានប្រទានពន្លឺដល់មនុស្សខ្វាក់ (លូកា ១៨:៣៥–៤៣) ។ ទ្រង់ក៏បានសោយជាមួយនឹងសាខេ «ជាមេលើពួកអ្នកយកពន្ធ» (លូកា ១៩:១–១០) ។

១២. **បេថាបារ៉ា** យ៉ូហាន-បាទីស្ទបានធ្វើបន្ទាល់ថាលោកគឺជា «សម្លេងដែលបន្លឺឡើងនៅទីរហោស្ថាន» (យ៉ូហាន ១:១៩–២៨) ។ យ៉ូហានបានធ្វើបុណ្យជ្រមុជទឹកថ្វាយព្រះយេស៊ូវ នៅក្នុងទន្លេយ័រដាន់ ហើយបានធ្វើបន្ទាល់ថា ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ (យ៉ូហាន ១:២៨–៣៤) ។

១៣. **ទីរហោស្ថាននៅយូដា**
យ៉ូហាន-បាទីស្ទបានផ្សាយសាសនានៅឯទីរហោស្ថាននេះ (ម៉ាថាយ ៣:១–៤) ជាទីដែលព្រះយេស៊ូវ បានតមអាហារអស់ ៤០ ថ្ងៃ ហើយត្រូវបានល្បួង (ម៉ាថាយ ៤:១–១១) ។

១៤. **អេម៉ោស** ព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ ទ្រង់បានយាងតាមផ្លូវទៅភូមិអេម៉ោស ជាមួយនឹងសិស្សរបស់ទ្រង់ពីរនាក់ (លូកា ២៤:១៣–៣២) ។

១៥. **បេតផាសេ** ពួកសិស្សពីរនាក់បានបញ្ជិះព្រះយេស៊ូវលើកូនលា ក្នុងកាលទ្រង់យាងចូលក្រុងយេរូសាឡិមដោយជោគជ័យ (ម៉ាថាយ ២១:១–១១) ។

១៦. **បេថានី** នេះហើយជាស្រុករបស់នាងម៉ារា, នាងម៉ាថា និងឡាសារ (យ៉ូហាន ១១:១) ។ នាងម៉ារាបានស្តាប់ព្រះបន្ទូលរបស់ ព្រះយេស៊ូវ ហើយព្រះយេស៊ូវបានមានព្រះបន្ទូលទៅនាងម៉ាថាឲ្យរើស «ចំណែកយ៉ាងល្អ» (លូកា ១០:៣៨–៤២); ព្រះយេស៊ូវបាន ប្រោសឡាសារឲ្យរស់ពីស្លាប់ឡើងវិញ (យ៉ូហាន ១១:១–៤៤) ហើយនាងម៉ារាបានលាបព្រះបាទារបស់ព្រះយេស៊ូវនឹងប្រេង (ម៉ាថាយ ២៦:៦–១៣; យ៉ូហាន ១២:១–៨) ។

១៧. **បេថ្លេហិម** ព្រះយេស៊ូវបានប្រសូតមក ហើយបានផ្តេកនៅលើស្នូក (លូកា ២:១–៧) ពួកទេវតាបានទៅប្រាប់ពួកអ្នកគង្វាលសត្វ ចៀមអំពីកំណើតរបស់ព្រះយេស៊ូវ (លូកា ២:៨–២០) ពួកអ្នកប្រាជ្ញត្រូវបាននាំផ្លូវដោយផ្កាយមួយ ទៅរកព្រះយេស៊ូវ (ម៉ាថាយ ២:១–១២) ហើយស្តេចហេរ៉ូឌបានសម្លាប់កូនក្មេងចោល (ម៉ាថាយ ២:១៦–១៨) ។



ក
ខ
គ
ឃ
សំគាល់នៃផែនទី ទី១១
ព្រំដែននយោបាយ
ស៊ីដូន
សារិបតា
ភ្នំល្បាណូន
អាប៊ីលេន
ដាម៉ាស
ភ្នំហ៊ើរម៉ូន
ស៊ីរី
លីតានី
ផារប៉ារ
ទីរ៉ុស
ភីនីស៊ី
សេសារា
ភីលីព
ច្រកភ្នំហ៊ូឡេ
កាលីឡេ
តូលេមេ
(អាកូរ)
ខូរ៉ាស៊ីន
បេតសៃដា
កាពើណិម
ម៉ាក់ដាឡា
សមុទ្រកាលីឡេ
(គេនេសារ៉ែត)
កាណា
ទីបេរាស
ភ្នំកើមែល
ណាសារ៉ែត
ភ្នំតាបោរ
យ៉ើរមូក
កាដារ៉ា
ណាអ៊ីន
សមុទ្រធំ (សមុទ្រមេឌីទែរ៉ាណេ)
សេសារា
ភ្នំគីលបោ
ដេកាប៉ូល
សាលិម ?
អេណូន
សាម៉ារី
វាលទំនាបសារ៉ុន
សាម៉ារី
ភ្នំអេបាល
ស៊ីខារ
ភ្នំកេរិស៊ីម
យ៉ាបុក
យ៉ុបប៉េ
ពេរា
អើរីម៉ាថេ?
អៃយ៉ាឡូន
បេតអែល
ភីឡាដិលភា
យេរីខូរ
អាសូត
អេម៉ោស
យេរូសាឡិម
ភ្នំដើមអូលីវ
បេថាបារ៉ា
វាលទំនាបម៉ូអាប់
បេតផាសេ
បេថានី
ភ្នំនេបូរ
អាសកាឡូន
បេថ្លេហិម
អេឡា
យូដា
កាសា
ហេប្រុន
ម៉ាខារ
អើណូន
សមុទ្រស្លាប់
អេដំម
បេរេវ
ទីរហោស្ថានយូដា
បៀរ-សេបា
ណាបាធា
សេរេត
ជ
គីឡូម៉ែត្រ
០
២០
៤០
៦០
១
២
៣
៤
៥
៦
៧
៨

១. **គាល់កូថា** ប្រហែលជាកន្លែងដែលគេភ្ជាប់ព្រះយេស៊ូវ (ម៉ាថាយ ២៧:៣៣–៣៧) ។

២. **សួនច្បារផ្នូរ** ព្រះសពព្រះយេស៊ូវត្រូវបានបញ្ចុះ (យ៉ូហាន ១៩:៣៨–៤២) ។ ព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ ទ្រង់បានលេចមកឲ្យនាងម៉ារាឃើញនៅក្នុងសួនច្បារផ្នូរ (យ៉ូហាន ២០:១–១៧) ។

៣. **បន្ទាយអនតូនា** ព្រះយេស៊ូវត្រូវគេចោទ, ដាក់ទោស, មើលងាយ, ហើយវាយនៅទីនេះ (យ៉ូហាន ១៨:២៨–១៩:១៦) ។ ប៉ុល ត្រូវគេចាប់ ហើយបានប្រាប់ពីដំណើរដែលលោកប្រែចិត្ត (កិច្ចការ ២១:៣១–២២:២១)។

៤. **ស្រះបេថេសដា** ព្រះយេស៊ូវទ្រង់បានប្រោសមនុស្សពិការម្នាក់ នៅថ្ងៃឈប់សំរាក (យ៉ូហាន ៥:២–៩) ។

៥. **ព្រះវិហារ** កាព្រីយ៉ែលបានសន្យានឹងសាការីថា នាងអេលីសាបិតនឹងមានគតិបានកូនប្រុសមួយ (លូកា ១:៥–២៥) ។ វាំងននៃ ព្រះវិហារត្រូវបានរហែកក្នុងកាលព្រះអង្គសង្គ្រោះទ្រង់សុគត (ម៉ាថាយ ២៧:៥១) ។

៦. **បាំងសាចសាឡូម៉ូន** ព្រះយេស៊ូវទ្រង់បានប្រកាសប្រាប់ថា ទ្រង់ជាព្រះរាជបុត្រានៃព្រះ ។ ពួកសាសន៍យូដាបានខិតខំចោលថ្ម សម្លាប់ទ្រង់ (យ៉ូហាន ១០:២២–៣៩) ។ ពេត្រុសបានផ្សាយពីការប្រែចិត្ត បន្ទាប់ពីបានប្រោសមនុស្សខ្វិនម្នាក់ (កិច្ចការ ៣:១១–២៦) ។

៧. **ទ្វារស្អាតស្អំ** ពេត្រុស និងយ៉ូហានបានប្រោសមនុស្សខ្វិនម្នាក់ (កិច្ចការ ៣:១–១០) ។

៨. **កំពូលព្រះវិហារ** ព្រះយេស៊ូវត្រូវអារក្សសាតាំងល្បួង (ម៉ាថាយ ៤:៥–៧) ។ (មានទីបុរាណពីរកន្លែងអំពីព្រឹត្តិការណ៍នេះ) ។

៩. **ភ្នំបរិសុទ្ធ** (មិនស្គាល់ទីកន្លែងទៀងទាត់ទេ)

*ក.* តាមពាក្យបុរាណថា ទីនេះហើយដែលលោកអ័ប្រាហាំបានសង់អាសនាមួយ ដើម្បីយកអ៊ីសាកធ្វើជាយញ្ញបូជា (លោកុ. ២២:៩–១៤) ។

*ខ.* ហ្លួងសាឡូម៉ូនបានសង់ព្រះវិហារ (១ ពង្សាវ. ៦:១–១០; ២ របា. ៣:១)។

*គ.* ពួកបាប៊ីឡូនបានបំផ្លាញព្រះវិហារចោល នៅឆ្នាំ៥៨៧ ម.គ.ស. (២ ពង្សាវ. ២៥:៨–៩) ។

*ឃ.* ហ្លួងស៊្រូបាបិលបានសង់ព្រះវិហារឡើងវិញ នៅឆ្នាំ ៥១៥ ម.គ.ស. (អែសរ៉ា ៣:៨–១០; ៥:២; ៦:១៤–១៦) ។

*ង.* ស្តេចហេរ៉ូឌបានពង្រីកទីលាន ហើយបានសង់ព្រះវិហារឡើងវិញ ចាប់ផ្តើមនៅឆ្នាំ ១៧ ម.គ.ស. ។ ព្រះយេស៊ូវត្រូវយកមកថ្វាយ នៅទីនេះកាលពីទារក (លូកា ២:២២–៣៩) ។

*ច.* កាលទ្រង់មានព្រះជន្មាយុ ១២ ឆ្នាំ នោះទ្រង់បានបង្រៀននៅក្នុងព្រះវិហារ (លូកា ២:៤១–៥០) ។

*ឆ.* ព្រះយេស៊ូវទ្រង់សំអាតព្រះវិហារ (ម៉ាថាយ ២១:១២–១៦; យ៉ូហាន ២:១៣–១៧) ។

*ជ.* ព្រះយេស៊ូវបានបង្រៀននៅក្នុងព្រះវិហារជាច្រើនដង (ម៉ាថាយ ២១:២៣–២៣:៣៩; យ៉ូហាន ៧:១៤–៨:៥៩) ។

*ឈ.* ពួករ៉ូមនៅក្រោមទីតុសបានបំផ្លាញព្រះវិហារចោល នៅឆ្នាំ ៧០ គ.ស. ។

១០. **សួនច្បារគែតសេម៉ានី** ព្រះយេស៊ូវទ្រង់បានរងទុក្ខ, ត្រូវគេក្បត់ ហើយត្រូវគេចាប់ (ម៉ាថាយ ២៦:៣៦–៤៦; លូកា ២២:៣៩–៥៤) ។

១១. **ភ្នំដើមអូលីវ**

*ក.* ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលប្រាប់ទុកមុនអំពីការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម និងព្រះវិហារ ។ ទ្រង់ក៏មានព្រះបន្ទូលអំពីការយាង មកលើកទីពីរ (ម៉ាថាយ ២៤:៣–២៥:៤៦; សូមមើលផង យ.ស.— ម៉ាថាយ) ។

*ខ.* ពីទីនេះហើយដែលព្រះយេស៊ូវបានយាងឡើងទៅលើស្ថានសួគ៌ (កិច្ចការ ១:៩–១២) ។

*គ.* នៅខែតុលា ថ្ងៃទី ២៤ ឆ្នាំ ១៨៤១ អែលឌើរអ៊ួរសុន ហៃឌ បានធ្វើពិធីឆ្លងដែនដីបរិសុទ្ធ ទុកសំរាប់ការវិលមកវិញនៃកូនចៅលោក អ័ប្រាហាំ ។

១២. **ជ្រោះគីហុន** សាឡូម៉ូនត្រូវបានលាបប្រេងឲ្យធ្វើជាស្តេច (១ ពង្សាវ. ១:៣៨–៣៩) ។ ស្តេចហេសេគាបានជីកប្រឡាយ ដើម្បីបង្ហូរទឹកពីក្បាលទឹកនេះចូលទៅទីក្រុង (២ របា. ៣២:៣០) ។

១៣. **ទ្វារទឹក** អែសរ៉ាបានអាន ហើយបកស្រាយក្រិត្យវិន័យលោកម៉ូសេឲ្យប្រជាជនស្តាប់ (នេហេ. ៨:១–៨) ។

១៤. **ច្រកភ្នំហ៊ីនណំម** ព្រះម៉ូឡុកដែលក្លែងក្លាយត្រូវបានបង្គំ ដោយយកកូនប្រុសកូនស្រីធ្វើយញ្ញបូជា (២ ពង្សាវ. ២៣:១០; ២ របា. ២៨:៣) ។

១៥. **ផ្ទះរបស់កៃផា** ព្រះយេស៊ូវត្រូវគេយកទៅគាល់កៃផា (ម៉ាថាយ ២៦:៥៧–៦៨) ។ ពេត្រុសបានបដិសេធថាលោកមិនស្គាល់ ព្រះយេស៊ូវទេ (ម៉ាថាយ ២៦:៦៩–៧៥) ។

១៦. **បន្ទប់ខាងលើ** ជាកន្លែងពីបុរាណដែលព្រះយេស៊ូវទ្រង់សោយអាហារនៃបុណ្យរំលង ហើយបានតាំងសាក្រាម៉ង់ឡើង (ម៉ាថាយ ២៦:២០–៣០) ។ ទ្រង់បានលាងជើងពួក ១២ នាក់ (យ៉ូហាន ១៣:៤–១៧) ហើយបានបង្រៀនពួកគេ (យ៉ូហាន ១៣:១៨–១៧:២៦) ។

១៧. **វាំងស្តេចហេរ៉ូឌ** ព្រះគ្រីស្ទត្រូវគេនាំទៅគាល់ស្តេចហេរ៉ូឌ ប្រហែលជានៅទីនេះ (លូកា ២៣:៧–១១) ។

១៨. **យេរូសាឡិម** (មិនស្គាល់ទីកន្លែងទៀតទាត់ទេ)

*ក.* មិលគីស្សាដែកបានសោយរាជ្យជាស្តេចនៃក្រុងសាឡិម (លោកុ. ១៤:១៨) ។

*ខ.* ស្តេចដាវីឌបានវាយយកទីក្រុងពីពួកយេប៊ូស (២ សាំយូ. ៥:៧; ១ របា. ១១:៤–៧) ។

*គ.* ទីក្រុងត្រូវបានបំផ្លាញដោយពួកបាប៊ីឡូន ប្រមាណជាឆ្នាំ ៥៨៧ ម.គ.ស. (២ ពង្សាវ. ២៥:១–១១) ។

*ឃ.* ព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតពេញមនុស្សជាច្រើន នៅបុណ្យថ្ងៃ ៥០ (កិច្ចការ ២:១–៤) ។

*ង.* ពេត្រុស និងយ៉ូហានត្រូវគេចាប់ ហើយនាំមកចំពោះក្រុមជំនុំ (កិច្ចការ ៤:១–២៣) ។

*ច.* អាន៉ានាស និងសាភីរ៉ា បានកុហកដល់ព្រះអម្ចាស់ ហើយស្លាប់ (កិច្ចការ ៥:១–១០) ។

*ឆ.* ពេត្រុស និងយ៉ូហានត្រូវគេចាប់ ប៉ុន្តែទេវតាបានជួយដោះលែងពួកគេឲ្យរួចពីគុក (កិច្ចការ ៥:១៧–២០) ។

*ជ.* ពួកសាវកបានរើសមនុស្សប្រាំពីរនាក់ឲ្យជួយពួកគេ (កិច្ចការ ៦:១–៦)។

*ឈ.* ទីបន្ទាល់របស់ស្តេផានដល់ពួកយូដាត្រូវបានបដិសេធ ហើយលោកត្រូវគេចោលថ្មស្លាប់ (កិច្ចការ ៦:៨–៧:៦០) ។

*ញ.* យ៉ាកុបត្រូវគេធ្វើទុក្ករកម្ម (កិច្ចការ ១២:១–២) ។

*ដ.* ទេវតាបានដោះលែងពេត្រុសឲ្យរួចពីគុក (កិច្ចការ ១២:៥–១១) ។

*ឋ.* ពួកសាវកបានសំរេចចិត្តអំពីការកាត់ស្បែក (កិច្ចការ ១៥:៥–២៩) ។

*ឌ.* ពួករ៉ូមនៅក្រោមទីតុសបានបំផ្លាញទីក្រុងចោល នៅឆ្នាំ ៧០ គ.ស. ។


ក
ខ
គ
ឃ
សំគាល់នៃផែនទី ទី១២
ទីក្រុងនៅសម័យព្រះយេស៊ូវ
កំផែងនៅតំបន់ពេលក្រោយមក
ផ្លូវទៅស្រុកសាម៉ារី
បេសេថា
(ទីក្រុងថ្មី)
គាល់កូថា
១
២ សួនច្បារផ្នូរ
ស្រះបេថែសដា
៤
ទ្វារត្រី
បន្ទាយអាន់តូនា
៣
ស្រះអ៊ីស្រាអែល
ទ្វារស៊ូសា
៦
ទ្វារចៀម
ព្រះវិហារ
៥
៧
១០
១១
ស្ពាន
ស្រះប៉ម
៩
៨
រាជរោងសាច
កំពូលព្រះវិហារ
ជណ្ដើរទៅព្រះវិហារ
វាំងហាសម៉ូនាន
ផ្លូវទៅក្រុងអេម៉ោស និងយ៉ុបប៉េ
១៧
វាំងស្ដេចហេរ៉ូឌ
១៧
បំពង់ទឹក
បំពង់ទឹក
ទីក្រុងនៅប៉ែកខាងលើ
ស្រះនាគ
ផ្ទះរបស់កៃផា
១៥
បន្ទប់ខាងលើ
១៦
ទីក្រុងនៅប៉ែកខាងក្រោម
ជ្រោះគីហុន
១២
ប្រឡាយរបស់ហេសេគា
ទ្វារទឹក
ស្រះស៊ីឡោម
១៣
ជ្រលងភ្នំហ៊ីនណោម
១៤
ជ្រោះអេន-រ៉ូគែល
ផ្លូវទៅក្រុងបេថ្លេហិម និងហេប្រុន
ផ្លូវទៅសមុទ្រស្លាប់
ម៉ែត្រ
០ ១០០ ២០០ ៣០០ ៤០០
១
២
៣
៤
៥
៦
៧
៨

# ដំណើរទាំងឡាយដែលសាវកប៉ុលទៅផ្សាយសាសនា

ផែនទី ទី១៣



១. **កាសា** ភីលីពបានផ្សាយពីព្រះយេស៊ូវ ហើយបានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សកំរៀវម្នាក់ សាសន៍អេធីយ៉ូពី តាមផ្លូវទៅក្រុងកាសា (កិច្ចការ ៨:២៦–៣៩) ។

២. **យេរូសាឡិម**-សូមមើលផែនទី លេខ ១២ សំរាប់ព្រឹត្តិការណ៍ទាំងឡាយនៅក្រុងយេរូសាឡិម ។

៣. **យ៉ុបប៉េ** ពេត្រុសបានឃើញការនិមិត្តមួយថា ព្រះទ្រង់បានអនុញ្ញាតឲ្យពួកសាសន៍ដទៃបានអំណោយទានខាងការប្រែចិត្ត (កិច្ចការ ១០; ១១:៥–១៨) ។ ពេត្រុសបានប្រោសនាងតេប៊ីថាឲ្យរស់ពីស្លាប់ឡើងវិញ (កិច្ចការ ៩:៣៦–៤២) ។

៤. **សាម៉ារី** ភីលីពបានធ្វើការងារបំរើនៅស្រុកសាម៉ារី (កិច្ចការ ៨:៥–១៣) ហើយក្រោយមក ពេត្រុស និងយ៉ូហានបានបង្រៀន នៅទីនេះ (កិច្ចការ ៨:១៤–២៥) ។ បន្ទាប់ពីពួកគេបានប្រទានអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ នោះស៊ីម៉ូន ជាគ្រូអាបធ្មប់ បានខំរកទិញអំណោយទាននេះពីពួកគេ (កិច្ចការ ៨:៩–២៤) ។

៥. **សេសារា** នៅទីនេះហើយដែលបន្ទាប់ពីទេវតាបានធ្វើការងារបំរើដល់មេទ័ពម្នាក់ ឈ្មោះកូនេលាស នោះពេត្រុសបានអនុញ្ញាតឲ្យ លោកទទួលបុណ្យជ្រមុជទឹក (កិច្ចការ ១០) ។ នៅទីនេះហើយដែលប៉ុលបានដោះសាខ្លួននៅចំពោះស្តេចអ័គ្រីប៉ា (កិច្ចការ ២៥–២៦; សូមមើលផង យ.ស.— ប្រវត្តិ ១:២៤–២៥) ។

៦. **ដាម៉ាស** ព្រះយេស៊ូវទ្រង់បានលេចមកឲ្យសុលឃើញ (កិច្ចការ ៩:១–៧) ។ បន្ទាប់ពីលោកអាន្នានាសបានធ្វើឲ្យសុលមើលឃើញ វិញ នោះសុលបានទទួលបុណ្យជ្រមុជទឹក ហើយបានចាប់ផ្តើមការងារបំរើរបស់លោក (កិច្ចការ ៩:១០–២៧) ។

៧. **អាន់ទីយ៉ូក (នៅស៊ីរី)** នៅទីនេះហើយដែលពួកសិស្សត្រូវបានហៅថាជាពួកគ្រីស្ទាន លើកទីមួយ (កិច្ចការ ១១:២៦) ។ អ័ក្កាបុស បានព្យាករអំពីអំណត់អត់ (កិច្ចការ ១១:២៧–២៨) ។ ការបែកបាក់ដ៏ធំមួយបានកើតឡើងនៅអាន់ទីយ៉ូក អំពីការកាត់ស្បែក (កិច្ចការ ១៤:២៦–២៨; ១៥:១–៩) ។ នៅអាន់ទីយ៉ូក ប៉ុលបានចាប់ផ្តើមបេសកកម្មរបស់លោក ជាមួយនឹងស៊ីឡាស, បាណាបាស, និងយូដាស-បាសាបាស (កិច្ចការ ១៥:២២, ៣០, ៣៥) ។

៨. **តើសុស** ជាស្រុករបស់ប៉ុល; ប៉ុលត្រូវបានចាត់ឲ្យមកទីនេះ ដើម្បីរក្សាជីវិតទុក (កិច្ចការ ៩:២៩–៣០) ។

៩. **គីប្រុស** បន្ទាប់ពីបានទទួលការបៀតបៀន ពួកបរិសុទ្ធខ្លះបានភៀសខ្លួនទៅនៅកោះនេះ (កិច្ចការ ១១:១៩) ។ ប៉ុលបានធ្វើដំណើរ កាត់កោះគីប្រុស កាលលោកធ្វើដំណើរទៅផ្សាយសាសនាលើកទីមួយ (កិច្ចការ ១៣:៤–៥) ដូចជាបាណាបាស និងម៉ាកុសបានធ្វើនៅពេលក្រោយ (កិច្ចការ ១៣:៦–១១) ។

១០. **ប៉ាផុស** ប៉ុលបានដាក់បណ្តាសាដល់គ្រូអាបធ្មប់ម្នាក់នៅទីនេះ (កិច្ចការ ១៣:៦–១១) ។

១១. **ឌើបេ** ប៉ុល និងបាណាបាសបានផ្សាយដំណឹងល្អនៅទីក្រុងនេះ (កិច្ចការ ១៤:៦–៧, ២០–២១) ។

១២. **លីស្ត្រា** កាលប៉ុលបានប្រោសមនុស្សមានជើងពិការម្នាក់ នោះលោក និងបាណាបាសត្រូវគេបានហៅថាជាព្រះ ។ ប៉ុលត្រូវគេ ចោលថ្ម ហើយគិតថាលោកស្លាប់ ប៉ុន្តែបានមានសារតិឡើងវិញ ហើយបានផ្សាយដំណឹងល្អតទៅទៀត (កិច្ចការ ១៤:៦–១២) ។ ជាស្រុករបស់ធីម៉ូថេ (កិច្ចការ ១៦:១–៣) ។

១៣. **អ៊ីកូនាម** នៅបេសកកម្មលើកទីមួយរបស់ពួកគេ នោះប៉ុល និងបាណាបាសបានផ្សាយដំណឹងល្អនៅទីនេះ ហើយត្រូវបានគំរាម កំហែងថានឹងចោលថ្ម (កិច្ចការ ១៣:៥១–១៤:៧) ។

១៤. **ឡៅឌីសេ និងកូល៉ុស** ក្រុងឡៅឌីសេគឺជាសាខាមួយនៃសាសនាចក្រ ដែលប៉ុលបានទៅជួប ហើយបានទទួលសំបុត្រ (កូល៉ុស ៤:១៦) ។ ក៏ជាទីក្រុងមួយក្នុងទីក្រុងប្រាំពីរដែលបានរាយឈ្មោះប្រាប់នៅក្នុងគម្ពីរវិវរណៈ (ទីក្រុងឯទៀតគឺៈ ក្រុងអេភេសូរ ក្រុងស្មឺរណា ក្រុង ពើកាម៉ុស ក្រុងធាទេរ៉ា ក្រុងសើដេស និងក្រុងភីឡាដិលភា; សូមមើលគម្ពីរវិវរណៈ ១:១១) ។ ក្រុងកូល៉ុសនៅខាងកើតក្រុងឡៅឌីសេ ១៨ គ.ម. ។ ប៉ុលបានសរសេរទៅពួកបរិសុទ្ធដែលនៅទីនោះ ។

១៥. **អាន់ទីយ៉ូក (នៅពិស៊ីឌា)** នៅបេសកកម្មលើកទីមួយរបស់ពួកគេ នោះប៉ុល និងបាណាបាសបានបង្រៀនពួកសាសន៍យូដាថា ព្រះគ្រីស្ទបានកើតមកពីព្រះវង្សហ្លួងដាវីឌ ។ ប៉ុលបានប្រគល់ដំណឹងល្អដល់ពួកអ៊ីស្រាអែល រួចហើយដល់ពួកសាសន៍ដទៃ ។ ប៉ុល និងបាណាបាសត្រូវគេបៀតបៀន ហើយត្រូវគេបណ្តេញចេញ (កិច្ចការ ១៣;១៤–៥០) ។

១៦. **មីលេត** កាលលោកមកធ្វើបេសកកម្មលើកទីបី នោះប៉ុលបានព្រមានពួកអែលឌើរនៃសាសនាចក្រអំពី «ឆ្កែព្រៃដ៏សាហាវ» ដែលនឹងចូលមកក្នុងហ្វូងចៀម (កិច្ចការ ២០:២៩–៣១) ។

១៧ **ប៉ាត់ម៉ុស យ៉ូហានត្រូវជាប់គុកនៅកោះនេះ** កាលលោកបានឃើញការនិមិត្តទាំងឡាយដែលឥឡូវនេះមាននៅក្នុងគម្ពីរវិវរណៈ (វិវ. ១:៩) ។

១៨. **អេភេសូរ** អ័ប៉ុឡូសបានផ្សាយដំណឹងល្អនៅទីនេះដោយមានអំណាច (កិច្ចការ ១៨:២៤–២៨) ។ កាលមកធ្វើបេសកកម្ម លើកទីបី នោះប៉ុលបានបង្រៀននៅក្រុងអេភេសូរអស់ពីរឆ្នាំ ដោយប្រែចិត្តមនុស្សជាច្រើន (កិច្ចការ ១៩:១០, ១៨) ។ នៅទីនេះហើយ ដែលលោកបានប្រទានអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយការដាក់ដៃលើ (កិច្ចការ ១៩:១–៧) ហើយបានសម្តែងអព្ភូតហេតុ ជាច្រើន ព្រមទាំងបណ្តេញអារក្សអសោចិ៍ចេញផង (កិច្ចការ ១៩:៨–២១) ។ នៅទីនេះហើយដែលពួកអ្នកថ្វាយបង្គំព្រះឌីអានបានបះ បោរទាស់នឹងប៉ុល (កិច្ចការ ១៩:២២–៤១) ។ ផ្នែកនៃគម្ពីរវិវរណៈ គឺស្តីដល់សាសនាចក្រនៅក្រុងអេភេសូរ (វិវ. ១:១១) ។

១៩. **ទ្រូអាស** កាលប៉ុលមកទីនេះក្នុងដំណើរមកផ្សាយសាសនាលើកទីពីរ នោះលោកបានឃើញការនិមិត្តអំពីមនុស្សម្នាក់ នៅស្រុក ម៉ាសេដូន អង្វរសូមជំនួយ (កិច្ចការ ១៦:៩–១២) ។ កាលលោកមកធ្វើបេសកកម្មលើកទីបីនៅទីនេះ នោះប៉ុលបានប្រោសអើទីកុសឲ្យរស់ពីស្លាប់ឡើងវិញ (កិច្ចការ ២០:៦–១២) ។

២០. **ភីលីព** ប៉ុល, ស៊ីឡាស, និងធីម៉ូថេបានប្រែចិត្តស្ត្រីម្នាក់ ឈ្មោះលីឌា, បានបណ្តេញអារក្សអសោចិ៍មួយចេញ ហើយត្រូវគេវាយ (កិច្ចការ ១៦:១១–២៣) ។ ពួកគេបានទទួលជំនួយដ៏ឧត្តមឲ្យរួចពីគុក (កិច្ចការ ១៦:២៣–២៦) ។

២១. **អាថែន** កាលប៉ុលទៅធ្វើបេសកកម្មលើកទីពីរនៅក្រុងអាថែន នោះលោកបានផ្សាយនៅភ្នំអើរ៉េយ៉ូសអំពី «ព្រះដ៏ពុំស្គាល់» (កិច្ចការ ១៧:២២–៣៤) ។

២២. **កូរិនថូស** ប៉ុលបានទៅឯកូរិនថូស កាលទៅធ្វើបេសកកម្មលើកទីពីរ ដែលលោកបានស្នាក់នៅជាមួយនឹងអ័គីឡា និងនាងព្រីស៊ីល ។ លោកបានផ្សាយដំណឹងល្អនៅទីនេះ ហើយបានធ្វើបុណ្យជ្រមុជទឹកឲ្យមនុស្សជាច្រើន (កិច្ចការ ១៨:១–១៨) ។ ចេញពីក្រុងកូរិនថូស នោះប៉ុលបានសរសេរសំបុត្រទៅពួករ៉ូម ។

២៣. **ថែស្សាឡូនិច** ប៉ុលបានផ្សាយដំណឹងល្អនៅទីនេះ នៅដំណើរទៅធ្វើបេសកកម្មលើកទីពីររបស់លោក ។ ក្រុមផ្សាយសាសនា ជាមួយលោកបានចេញពីក្រុងបេរា បន្ទាប់ពីពួកសាសន៍យូដាបានរកធ្វើទុក្ខដល់ពួកគេ (កិច្ចការ ១៧:១–១០) ។

២៤. **បេរា** ប៉ុល, ស៊ីឡាស, និងធីម៉ូថេ បានឃើញមនុស្សដែលមានចិត្តល្អដើម្បីបង្រៀន នៅដំណើរទៅធ្វើបេសកកម្មលើកទីពីររបស់ លោក ។ ពួកសាសន៍យូដានៅក្រុងថែស្សាឡូនិចបានដើរតាម ហើយបៀតបៀនពួកគេ (កិច្ចការ ១៧:១០–១៣) ។

២៥. **ម៉ាសេដូន** ប៉ុលបានបង្រៀននៅទីនេះ នៅដំណើរទៅធ្វើបេសកម្មលើកទីពីរ និងលើកទីបីរបស់លោក (កិច្ចការ ១៦:៩–៤០; ១៩:២១) ។ ប៉ុលបានសរសើរដល់ចិត្តសប្បុរសរបស់ពួកបរិសុទ្ធនៅក្រុងម៉ាសេដូន ដែលបានជូនដល់លោក និងដល់ពួកបរិសុទ្ធដែលក្រីក្រនៅក្រុងយេរូសាឡិម (រ៉ូម ១៥:២៦; ២ កូរិន. ៨:១–៥; ១១:៩) ។

២៦. **មេលីត** សំពៅដែលប៉ុលជិះបានបែកបាក់នៅកោះនេះ តាមផ្លូវលោកទៅក្រុងរ៉ូម (កិច្ចការ ២៦:៣២; ២៧:១, ៤១–៤៤) ។ លោកគ្មានគ្រោះថ្នាក់អ្វីទេពីពស់ចឹក ហើយបានប្រោសមនុស្សជាច្រើនដែលឈឺនៅកោះមេលីត (កិច្ចការ ២៨:១–៩) ។

២៧. **រ៉ូម** ប៉ុលបានផ្សាយដំណឹងល្អនៅទីនេះអស់ពីរឆ្នាំ កាលគ្មានសិទ្ធចេញទៅណាមកណា (កិច្ចការ ២៨:១៦–៣១) ។ លោកក៏ បានសរសេរសំបុត្រ ឬលិខិតពីរក្បាលទៅពួកអេភេសូរ ពួកភីលីព និងពួកកូល៉ុស និងទៅធីម៉ូថេ និងភីលេម៉ូន កាលជាប់គុកនៅក្រុងរ៉ូម ។ ពេត្រុសបានសរសេរសំបុត្រទីមួយរបស់លោកពី «បាប៊ីឡូន» ប្រហែលជាពីក្រុងរ៉ូម គឺក្រោយពីការបៀតបៀនរបស់នេរ៉ូដល់ពួកគ្រីស្ទាន នៅឆ្នាំ ៦៤ គ.ស. ។ គេជឿថាទោះជាពេត្រុស និងប៉ុលត្រូវគេធ្វើទុក្ខកម្មនៅទីនេះ ។

# កំពស់ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរប៊ីប






*សភាពខ្ពស់ទាបត្រូវបានពង្រីកឡើង ដើម្បីបង្ហាញឲ្យឃើញជាក់ច្បាស់នូវកំពស់ខុសគ្នា



**១. ទន្លេណៃល និងស្រុកអេស៊ីព្ទ** ដូចជាកន្លែងនេះហើយដែលម្ដាយរបស់លោកម៉ូសេបានលាក់កូនប្រុសរបស់នាង ។ បុត្រីរបស់ផារ៉ោន បានឃើញលោក ហើយបានចិញ្ចឹមលោកនៅក្នុងវាំងស្ដេចអេស៊ីព្ទ ។



**២. ភ្នំស៊ីណាយ (ហូរែប) និងទីរហោស្ថានស៊ីណាយ** តាមព្រះបញ្ញត្តិនោះលោកម៉ូសេបាននាំពួកសាសន៍អ៊ីស្រាអែលមកភ្នំនេះ ដើម្បី ទទួលក្រិត្យវិន័យរបស់ព្រះ ។ រូបថតនេះបង្ហាញកន្លែងបុរាណនៃភ្នំស៊ីណាយ ។



**៣. ទីរហោស្ថាននៅខេត្តយូដា និងសមុទ្រស្លាប់** ព្រះអង្គសង្គ្រោះទ្រង់បានយាងទៅទីរហោស្ថាន ដើម្បីទៅទូលជាមួយព្រះវរបិតា របស់ទ្រង់ ។



**៤. កាដេស-បារនេ** កន្លែងនេះដែលស្គាល់ថា កាដេស-បារនេ ប្រហែលជាកន្លែងដែលពួកអ៊ីស្រាអែលបោះជំរុំ កាលពួកគេនៅក្នុងទី រហោស្ថានអស់ ៤០ ឆ្នាំ ។



៥. **ផ្នូរទាំងឡាយនៃពួកអយ្យកោ** សំណង់នេះដែលនៅឯហេប្រុន គេថាបានសង់លើផ្នូរខ្មោចរបស់លោកអ័ប្រាហាំ, អ៊ីសាក, និងយ៉ាកុប ។



៦. **ស្រុកភ្នំនៅយូដា** ទេសភាពរដិបរដុបបែបនេះហើយដែលគ្របដណ្ដប់ដែនដីបរិសុទ្ធភាគច្រើន នៅទិសខាងត្បូង និងខាងកើតក្រុង យេរូសាឡិម ។



៧. **បេថ្លេហិម** នៅទីក្រុងនេះហើយដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទបានប្រសូតមក ។



៨. **យេរូសាឡិម** — ទីក្រុងនេះគិតថាបរិសុទ្ធដល់សាសនាបី សាសនាគ្រីស្ទាន សាសនាយូដា សាសនាអ៊ីស្លាម ។



៩. **ព្រះវិហារហេរ៉ូឌ** រូបគំរូនេះគិតថាដូចព្រះវិហារពីបុរាណពិត គិតតាមទំហំ ។



១០. **ជណ្ដើរទៅកាន់ព្រះវិហារ** ជាជណ្ដើរទៅកាន់ព្រះវិហារហេរ៉ូឌ ជណ្ដើរទាំងនេះត្រូវបានជីកឃើញដោយពួកបុរាណវត្ថុវិទូ ។



**១១. ភ្នំដើមអូលីវ, ឱឡាន អ្លសុន ហៃឌ** នៅក្បែរទីនេះ នៅឆ្នាំ ១៨៤១ អែលឌើរអ្លសុន ហៃឌ បានធ្វើពិធីឆ្លងដែនដីបរិសុទ្ធ សំរាប់ការវិលមកវិញ នៃកូនចៅលោកអ័ប្រាហាំ ។



**១២. សួនច្បារគែតសេម៉ានី** ដើមអូលីវពីបុរាណប្រហែលជាតមកពីដើមទាំងនោះដែលមាននៅក្នុងសួនច្បារ កាលព្រះអង្គសង្គ្រោះទ្រង់ អធិស្ឋាន ហើយស្រក់ញើសដូចជាឈាម នៅពេលទ្រង់ចាប់ធ្វើដង្វាយធួន ។



១៣. **គាល់កូថា** តាមពាក្យបុរាណដ៏សំខាន់ថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទត្រូវគេឆ្កាងនៅក្បែរទីនេះ ។



១៤. **សួនច្បារផ្នូរ** ពួកព្យាការីទំនើបជាច្រើនមានអារម្មណ៍ថា នៅទីនេះហើយដែលគេបញ្ចុះព្រះសពព្រះអង្គសង្គ្រោះ នៅក្នុងរូងផ្នូររបស់ យ៉ូសែបពីស្រុកអើរីម៉ាថេ បន្ទាប់ពីការឆ្កាង ។



១៥. **យេរីខូរ** នេះគឺជាទីក្រុងទីមួយដែលយ៉ូស្វេវាយបាន (សូមមើលគម្ពីរ យ៉ូស្វេ ៦:២–២០); ក្រុងយេរីខូរគឺជាទីក្រុងមួយដ៏ចាស់ បុរាណបំផុត ។



១៦. **ស៊ីឡូរ** រោងឧបោសថដែលដាក់ហឹបនៃសេចក្តីសញ្ញា ត្រូវបានតំឡើងនៅទីនេះ ហើយនៅទីនេះតមកអស់ជាច្រើនសតវត្ស ។



**១៧. ភ្នំកេរីស៊ីម និងភ្នំអេបាល** ភ្នំទាំងពីរនេះមើលទៅលើទីក្រុងស៊ីគែម ជាកន្លែងដែលគេកប់ឆ្អឹងយ៉ូសែប (សូមមើលគម្ពីរយ៉ូស្វេ ២៤:៣២) ។



**១៨. ដូថាន់ នៅស្រុកសាម៉ារី** នៅច្រកភ្នំដ៏មានជីជាតិនេះហើយដែលពួកបងប្រុសរបស់យ៉ូសែបបានមកឃ្វាលចៀម កាលពួកគេលក់ ប្អូនប្រុសទៅពួកអ្នកជំនួញសាសន៍ម៉ាឌាន និងសាសន៍អ៊ីស្មាអែល ។



**១៩. សេសារា និងវាលទំនាបសារ៉ុន ទៅ គើមែល** ប៉ុលបានផ្សាយដំណឹងល្អដល់ស្តេចអ័គ្រីប៉ានៅទីក្រុងនេះ (សូមមើលគម្ពីរកិច្ចការ ២៦) ។



**២០. យ៉ុបប៉េ** នៅទីនេះហើយដែលពេត្រុសបានឃើញការនិមិត្តមួយ បង្គាប់ឲ្យលោកយកដំណឹងល្អទៅពួកសាសន៍ដទៃ (សូមមើលគម្ពីរ កិច្ចការ ១០) ។



**២១. ច្រកភ្នំយេសរាល** សាសន៍ទាំងអស់នឹងជួបជុំគ្នានៅទីនេះ ក្នុងចំបាំងនៃអើម៉ាគេដូន (សូមមើលគម្ពីរ សាការី ១១–១៤; វិវរ. ១៦:១៤–២១) ។



**២២. ភ្នំតាបោរ** នៅកំពូលទីនេះគឺជាកន្លែងបុរាណដែលព្រះគ្រីស្ទប្រែរូបនៅចំពោះសាវកពេត្រុស យ៉ាកុប និងយ៉ូហាន (សូមមើលគម្ពីរ ម៉ាថាយ ១៧:១–៩) ។



**២៣. សមុទ្រកាលីឡេ និងភ្នំបទជូនពរ** នៅលើភ្នំនេះគឺជាកន្លែងបុរាណដែលព្រះអង្គសង្គ្រោះបង្រៀននៅលើភ្នំ ។



**២៤. កាពើណិម** មានសំណង់បាក់បែកបន្តិចបន្តួចទេដែលសំគាល់ប្រាប់ពីកន្លែងនៃទីក្រុង ដែលព្រះអង្គសង្គ្រោះបានសម្តែងអព្ភូតហេតុ របស់ទ្រង់ជាច្រើន ។



២៥. **ទន្លេយ័រដាន់** រូបថតនេះបានថតនៅក្បែរព្រែកពីសមុទ្រកាលីឡេ ។



២៦. **សេសារា ភីលីព** ព្រះយេស៊ូវគ្រីស្ទបានសន្យានឹងប្រទានដល់ពេត្រុស នូវកូនសោទាំងឡាយនៃនគរ ប្រហែលនៅក្បែរកន្លែងនេះ (សូមមើលគម្ពីរ ម៉ាថាយ ១៦:១៩) ។



**២៧. ណាសារ៉ែត** ព្រះយេស៊ូវមានវ័យធំនៅភូមិនេះ ។



**២៨. ដាន់** ទីក្រុងមួយនៅសម័យព្រះគម្ពីរសញ្ញាចាស់បានសង់នៅទីនេះ ដែលជាព្រំដែនខាងជើងបំផុតនៃស្រុកអ៊ីស្រាអែល ។



២៩. **អាថែន** រូបថតនេះជា ប៉ាថេណូន ដែលនៅភ្នំអើរីយ៉ូស ជាកន្លែងដែលប៉ុលបានផ្សាយសាសនាអំពី «ព្រះដ៏ពុំស្គាល់» (សូម មើលគម្ពីរ កិច្ចការ ១៧:១៥–៣៤) ។



៣០. **កូរិនថូស** ប៉ុលបានសរសេរសំបុត្រទៅពួករ៉ូមពីក្រុងនេះ ។



**៣១. អេភេសូរ** នៅទីនេះហើយដែលប៉ុលបានផ្សាយសាសនាទាស់នឹងការថ្វាយបង្គំរូបព្រះ ហើយបានធ្វើឲ្យពួកជាងប្រាក់ខឹង ជាពួកអ្នក ដែលមានរបររកស៊ីដោយលក់រូបព្រះឌីអាន (សូមមើលគម្ពីរកិច្ចការ ១៩:២៤–៤១) ។



**៣២. កោះប៉ាត់ម៉ុស** លក្ខណៈភូមិសាស្ត្រនៃដីទាំងអស់នេះ គឺជាផ្នែកនៃកោះមេឌីទេរ៉ាណេ ដែលគេបានបំបរបង់យ៉ូហាន ជាអ្នកទទួល វិវរណៈ (សូមមើលគម្ពីរវិវរណៈ ១:៩) ។

CAMBODIAN

4 02347 44258 9

34744 258